គាថាធម្មបទ ១ ភាគចប់

(បិដកភាគ ៥២ មានគាថា ៤២៣ និង ទ្រឹង ៣០២)



ទ្រៀបទ្រៀងដោយខ្ញុំព្រះករុណា

គេជធរោ ឈាឫ ក៉ាន

ឫត្តព្រះគុន្ធកុដិ

ព.ស. ២៥៧០

គ.ស. ២០២៦

អាសយដ្ឋាន: ភូមិរំចេក ៣ សង្កាត់រតន: ក្រុងបាត់ដំបង ខេត្តបាត់ដំបង

<u>អារម្ភកថា</u>

សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋៈ (គាថាធម្មបទ)

(មានគាថា ៤២៣ និង រឿង ៣០២ នៅក្នុងគាថាធម្មបទនេះ)

ខ្ញុំព្រះករុណា **តេជធរោ ឈាវ រ៉ាឆាន (Chheav Rachhan)** គង់នៅវត្តព្រះគន្ធកុដិ ភូមិ រំចេក ៣ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។ ដោយសង្កេតឃើញថា គាថាធម្មបទ នេះ មានរឿងរ៉ាវច្រើន អ្នកបោះពុម្ពបានចែកជាភាគតូចៗ ហើយច្រើនក្បាល ដូច្នេះ ខ្ញុំព្រះ ករុណាអាត្មាភាព ចង់សម្រួលអោយនៅសល់តែ ១ ក្បាល មានចំនួន ៣៥៦៥ ទំព័រ ជាសំណុំ PDF ។ ទោះបីច្រើនទំព័រក៏មែនពិត តែទំហំជា PDF អាចបើកមើលបាន ។ សៀវភៅគាថាធម្ម បទនេះ គឺបោះពុម្ពដោយសមាគមធម្មទាន អរិយវង្ស យង់ សុជាត មានធម្មាចារ្យ **អ៊ឹម រ៉ៃយ៉ា** ជា ប្រធានរួចរាល់ហើយក្នុងគេហទំព័រ ៥000 ឆ្នាំ មានចំនួន ៤ ក្បាល ដូច្នេះ អាត្មាភាពយកទាំង ៤ ក្បាលមករួមបញ្ចូលគ្នាជា ១ ក្បាល ។ ក្នុងនោះផងដែរ អាត្មាភាព បានលុបទំព័រក្នុងសៀវភៅ ទាំង ៤ ក្បាល មកដាក់សរុបក្នុងសៀវភៅ ១ ក្បាល ដាក់តាមលំដាប់សូត្រ និងទំព័រដោយ ស្វាយប្រវត្តិ (Auto) ។ ម្យ៉ាងទៀត ទំព័រច្រើន ប្រសិនបើមិនប្រើទំព័រ Auto (ស្វាយប្រវត្តិ)ទេ និង ពិបាកស្វែងរកទំព័រ ដូច្នេះបានជាប្រើទំព័រស្វាយប្រវត្តិ ដោយគ្រាន់តែបើក PDF ហើយ ចុចទៅ លើពាក្យថា Research រួចហើយចុចទៅលើទំព័រណាដែលចង់បាន ឧទាហរណ៍ថា ចង់មើល រឿងនាងវិសាខានៅទំព័រ ១000 គ្រាន់តែសរសេរនៅក្នុងកន្លែង Research (ស្វែងរកទំព័រ) វា នឹងទៅដល់ទំព័រនោះមួយរំពេច ដោយមិនចាំបាច់ទាញទៅរកមួយទំព័រៗ នោះឡើយ ។ មួយ ទៀត សូមបញ្ជាក់ថា សៀវភៅទាំង ៤ ក្បាលនេះ ដែលបានដាក់បញ្ចូលគ្នាមិនមានការកែតម្រូវ អត្ថបទខាងក្នុងឡើយ គឺយកទាំងស្រុងពីសៀវភៅសមាគម។

អ្នកមានឧបការគុណរៀបរៀងសៀវភៅនេះឡើង ដោយសមាគមធម្មទាន អរិយវង្ស យង់ សុជាត រួមមាន៖

១-លោកគ្រូធម្មាចារ្យ **អ៊ឹម រ៉ៃយ៉ា** ជាប្រធាន

២-ខ្ញុំព្រះករុណាអាត្មាភាព **ឈាវ រ៉ាឆាន** ជាអនុប្រធាន

៣-លោកគ្រូ **ឡាន សុខុម** ជាលេខា ហើយជាអ្នកមានឧបការៈច្រើនក្នុងការរៀបរៀងសៀវភៅនេះឡើង ដែលបានចំណាយពេលជិត ៣០ ឆ្នាំ មួយអន្លើដោយសមាជិកការងារក្នុងសមាគមទាំងអស់ ។

ជាលទ្ធផលដែលសមាគមបានរៀបរៀងឡើង គឺ អដ្ឋកថាបិដក ១១០ ក្បាល និងសៀវភៅជាច្រើនទៀត ដែលបានបោះពុម្ពក្នុងគេហទំព័រ ៥០០០ ឆ្នាំ ។ ជាចុងក្រោយដោយអំណាចការខិតខំប្រឹងប្រែងក្នុងការរៀបចំសៀវភៅនេះឡើង ទាំងបោះពុម្ពជាលក្ខណៈផ្ទាល់ខ្លួន និងក្នុងសមាគម សូមជូនបុណ្យដល់អស់លោកជាសប្បុរសទាំងឡាយ ប្រាថ្នានូវសម្បត្តិណា សូមឱ្យបានសម្រេចនូវសម្បត្តិនោះ ទាំងពេលបច្ចុប្បន្ន និងអនាគត កុំបីក្លាយទៅជាប្រការៈដទៃឡើយ សូមអនុមោទនា!!! ។

ខ្ញុំព្រះករុណា តេជធរោ ឈាវ រ៉ាឆាន ជាសិស្សថ្នាក់បណ្ឌិត

(Chheav Rachhan a PhD Student)



ស្វែងរកទំព័រដោយស្វ័យប្រវត្តិ (Auto) លើកុំព្យូទ័រ



ស្វែងរកទំព័រដោយស្វាយប្រវត្តិ (Auto) លើទូរស័ព្ទ



សុត្តន្តបិដក គាថាធម្មបទ

សុត្តន្តបិដកភាគ ៥២
សន្ទីកប្រាប់មាតិកា

មាតិកា ..... **លេខទំព័រ**

ខុទ្ទកបាឋ: សរណាគមន៍ ៣២
ពាក្យប្រារព្ធ ៣៣
ពណ៌នាត្រៃសរណៈ ៣៩
ខុទ្ទកបាឋ:សិក្ខាបទ ១០ ..... ៥៧
អដ្ឋកថាសិក្ខាបទ ១០ ..... ៥៨
ទ្វត្តឹសាការៈ (អាការៈ ៣២) ៨៩
អដ្ឋកថាទ្វត្តឹសាការ ៨៩
ខុទ្ទកបាឋ: សាមណេរបញ្ហា ១៥៣
អដ្ឋកថាកុមារបញ្ហា ១៥៤
ខុទ្ទកបាឋ: មង្គលសូត្រ ១៨០
អដ្ឋកថាមង្គលសូត្រ ១៨៣
ខុទ្ទកបាឋ: រតនសូត្រ ៣០៦
អដ្ឋកថារតនសូត្រ ៣១០
ខុទ្ទកបាឋ: តិរោកុដ្ដកណ្ឌ ៣៨៥
អដ្ឋកថាពិរោកុដ្ដកណ្ឌ ៣៨៦
ខុទ្ទកបាឋ: និធិកណ្ឌ ៤១៧
អដ្ឋកថានិធិកណ្ឌ ៤១៩
ខុទ្ទកបាឋ: ករណីយមេត្តសូត្រ ៤៥០
អដ្ឋកថា ករណីយមេត្តសូត្រ ៤៥២

យមកវគ្គទី ១ .....**៤៩០**

រឿងព្រះចក្ខុបាលត្ថេរ ៤៩៦
រឿងមដ្ឋកុណ្ឌលី ៥២៦
រឿងព្រះតិស្សត្ថេរ ៥៤២
រឿងនាងកាឡីយក្ខិនី ៥៥៣
រឿងភិក្ខុក្រុងកោសម្ពី ៥៦៣
រឿងចុល្លកាល និងមហាកាល ៥៨០
រឿងទេវទត្តភិក្ខុ ៥៩៣
រឿងសញ្ជ័យ ៦០១
រឿងព្រះនន្ទត្ថេរ ៦៤១
រឿងនាយចុន្ទសូករិក: ៦៥៦
រឿងធម្មិកឧបាសក ៦៦១
រឿងភិក្ខុទេវទត្ត ៦៦៦
រឿងនាងសុមនាទេវី ៦៨៩
រឿងភិក្ខុជាសម្លាញ់នឹងគ្នាពីរនាក់ ៦៩៣

អប្បមាទវគ្គទី ២ .....**៧០២**

រឿងព្រះនាងសាមាវតី ៧០៤
រឿងកុម្ភឃោសក: ៧៩៦
រឿងចូឡបន្ថកត្ថេរ ៨០៧
រឿងពាលក្ខត្តឫក្ស ៨២៧

រឿងព្រះមហាកស្សបត្ថេរ ៨៣១
រឿងភិក្ខុ ២ អង្គជាសម្លាញ់នឹងគ្នា ៨៣៤
រឿងសក្កទេវរាជ ៨៣៨
រឿងអញ្ញតរភិក្ខុ ៨៦០
រឿងព្រះតិស្សត្ថេរអ្នកមានប្រក្រតីនៅក្នុងនិគម ៨៦២

ចិត្តវគ្គទី ៣ .....៨៦៨

រឿងមេឃិយត្ថេរ ៨៧០
រឿងអញ្ញត្រភិក្ខុ ៨៧៤
រឿងឧក្កណ្ឋិតភិក្ខុ ៨៨៧
រឿងក្មួយរបស់ព្រះសង្ឃរក្ខិតត្ថេរ ៨៩១
រឿងព្រះចិត្តហត្ថត្ថេរ ៨៩៧
រឿងភិក្ខុប្រារព្ធវិបស្សនា ៩០៧
រឿងបូតិគត្តិស្សត្ថេរ ៩១៤
រឿងនន្ទគោបាលក: ៩១៩
រឿងសោរេយ្យត្ថេរ ៩២៣

បុប្ផវគ្គទី ៤ .....៩៣៣

រឿងភិក្ខុ ៥០០ ដែលខ្វល់ខ្វាយក្នុងបឋវីកថា ៩៣៦
រឿងព្រះថេរចម្រើនមរិចិកម្មដ្ឋាន ៩៣៩
រឿងព្រះបាទវិឌូឌភ: ៩៤២
រឿងនាងបតិបូជិកា ៩៧៣

រឿងកោសិយសេដ្ឋី ៩៧៨
រឿងបាដិកាជីវក ៩៨៩
រឿងឆត្តបាណិឧបាសក ៩៩៤
រឿងនាងវិសាខា ១០០០
រឿងបញ្ហារបស់ព្រះអានន្ទត្ថេរ ១០៤៤
រឿងប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរ ១០៤៨
រឿងព្រះគោធិកត្ថេរ ១០៥៦
រឿងគរហាទិន្ន ១០៦១

ភាគទី ៥ .....១០៧៦

រឿងអញ្ញាត្របុរស ១០៧៩
រឿងសទ្ធិវិហារិករបស់ព្រះមហាកស្សបត្ថេរ ១១០២
រឿងអានន្ទសេដ្ឋី ១១១០
រឿងគណ្ឋិភេទកចោរ ១១១៥
រឿងព្រះឧទាយិត្ថេរ ១១១៨
រឿងភិក្ខុអ្នកក្រុងបាវា ១១២០
រឿងសុប្បពុទ្ធកុដ្ឋិ ១១២២
រឿងអ្នកស្រែ ១១២៦
រឿងសុមនមាលាការ ១១៣១
រឿងឧប្បលវណ្ណាថេរី ១១៣៩
រឿងជម្ពុកាជីវក ១១៤៤
រឿងអហិប្រេត ១១៥៨
រឿងសដ្ឋិកូដប្រេត ១១៦៥

រឿងព្រះសុធម្មត្ថេរ ១១៧១
រឿងព្រះវនវាសីតិស្សត្ថេរ ១១៨៥

បណ្ឌិតវគ្គទី ៦ .....**១២១០**

រឿងព្រះរាធត្ថេរ ១២១៣
រឿងអស្សជិភិក្ខុ និងបុនព្វសុក: ១២១៩
រឿងព្រះឆន្នត្ថេរ ១២២២
រឿងព្រះមហាកប្បិនត្ថេរ ១២២៤
រឿងបណ្ឌិតសាមណេរ ១២៤៣
រឿងព្រះលកុណ្ឌកភទ្ទិយត្ថេរ ១២៦៦
រឿងមាតារបស់នាងកាណា ១២៦៨
រឿងភិក្ខុ ៥០០ រូប ១២៧៥
រឿងព្រះថេរៈតាំងនៅក្នុងធម៌ ១២៧៨
រឿងការស្តាប់ធម៌ ១២៨១
រឿងអាគន្តុកភិក្ខុ ១២៨៤

អរហន្តវគ្គទី ៧ .....**១២៨៨**

រឿងពេទ្យជីវក ១២៩០
រឿងព្រះមហាកស្សបត្ថេរ ១២៩៤
រឿងព្រះវេឡុដ្ឋសីសត្ថេរ ១២៩៩
រឿងព្រះអនុរុទ្ធត្ថេរ ១៣០២
រឿងមហាកច្ចាយនត្ថេរ ១៣០៦

រឿងព្រះសារីបុត្តត្ថេរ ១៣០៩
រឿងព្រះតិស្សត្ថេរអ្នកក្រុងកោសម្ពី ១៣១៤
រឿងព្រះសារីបុត្តត្ថេរ (ដទៃទៀត) ១៣១៩
រឿងព្រះខទិរវនិយរេវតត្ថេរ ១៣២២
រឿងអញ្ញតរិត្ថី ១៣៣៦

សហស្សវគ្គទី ៨ .....១៣៣៩

រឿងតម្ពទាឋិកចោរឃាតក ១៣៤២
រឿងព្រះទារុចីរិយត្ថេរ ១៣៤៩
រឿងព្រះនាងកុណ្ឌលកេសីថេរី ១៣៥៨
រឿងអនត្ថបុច្ឆកព្រាហ្មណ៍ ១៣៦៩
រឿងព្រាហ្មណ៍ជាអរិរបស់ព្រះសារីបុត្តត្ថេរ ១៣៧២
រឿងព្រាហ្មណ៍ជាក្មួយរបស់ព្រះសារីបុត្តត្ថេរ ១៣៧៥
រឿងព្រាហ្មណ៍ជាសម្លាញ់របស់ព្រះសារីបុត្តត្ថេរ ១៣៧៧
រឿងអាយុវឌ្ឍនកុមារ ១៣៧៩
រឿងសង្កិច្ចសាមណេរ ១៣៨៥
រឿងព្រះខានុកោណ្ឌញ្ញត្ថេរ ១៣៩៩
រឿងព្រះសប្បទាសត្ថេរ ១៤០២
រឿងនាងបដាចារា ១៤០៧
រឿងកិសាគោតមី ១៤១៧
រឿងពហុបុត្តិកាថេរី ១៤២៣

បាបវគ្គទី ៩ .....**១៤២៧**

រឿងព្រាហ្មណ៍ឈ្មោះចូឡេកសាដក ១៤៣០
រឿងព្រះសេយ្យសកត្ថេរ ១៤៣៦
រឿងនាងលាជទេវធីតា ១៤៣៧
រឿងអនាថបិណ្ឌិកសេដ្ឋី ១៤៤២
រឿងភិក្ខុមិនទុកដាក់បរិក្ខារ ១៤៤៩
រឿងសេដ្ឋីឈ្មោះពិឡាលបទក: ១៤៥២
រឿងមហាធនពាណិជ ១៤៥៧
រឿងកុក្កុដមិត្ត ១៤៦១
រឿងព្រានសុខនឈ្មោះកោក: ១៤៧០
រឿងព្រះតិស្សត្ថេរកុលបក:របស់ជាងកែវ ១៤៧៤
រឿងជន ៣ ពួក ១៤៧៨
រឿងព្រះបាទសុប្បពុទ្ធសក្យ: ១៤៨៥

ទណ្ឌវគ្គទី ១០ .....**១៤៩០**

រឿងឆព្វគ្គិយភិក្ខុ ១៤៩៣
រឿងឆព្វគ្គិយភិក្ខុ (ដទៃទៀត) ១៤៩៥
រឿងកុមារច្រើននាក់ ១៤៩៧
រឿងព្រះកោណ្ឌធានត្ថេរ ១៤៩៩
រឿងឧបោសថកម្ម ១៥០៨
រឿងអជគរប្រេត ១៥១០
រឿងព្រះមហាមោគ្គល្លានត្ថេរ ១៥១៦

រឿងភិក្ខុមានភណ្ឌៈច្រើន ១៥២៤
រឿងសន្តតិមហាមាត្យ ១៥៣៣
រឿងព្រះបិលោតិកត្ថេរ ១៥៤០
រឿងសុខសាមណេរ ១៥៤៤

ឆរាឆត្តទី ១១ .....**១៥៦១**

រឿងស្រីសម្លាញ់របស់នាងវិសាខា ១៥៦៣
រឿងនាងសិរិមា ១៥៦៨
រឿងនាងឧត្តរាថេរី ១៥៧៥
រឿងព្រះអធិមានិកភិក្ខុ ១៥៧៧
រឿងនាងរូបនន្ទាថេរី ១៥៧៩
រឿងព្រះនាងមល្លិកាទេវី ១៥៨៦
រឿងព្រះលាទ្ធុទាយិត្ថេរ ១៥៩១
រឿងបឋមពោធិកាល ១៥៩៧
រឿងសេដ្ឋីបុត្រមានទ្រព្យច្រើន ១៦០០

អដ្ឋឆត្តទី ១២ .....**១៦០៦**

រឿងពោធិរាជកុមារ ១៦០៨
រឿងព្រះឧបនន្ទសក្យបុត្រ ១៦១៥
រឿងព្រះបធានិកតិស្សត្ថេរ ១៦២០
រឿងមាតាព្រះកុមារកស្សបត្ថេរ ១៦២៣
រឿងឧបាសកឈ្មោះមហាកាល ១៦២៩

រឿងទេវទត្តភិក្ខុ (ដទៃទៀត) ១៦៣៣
រឿងទេវទត្តបំបែកសង្ឃ ១៦៣៦
រឿងព្រះកាលត្ថេរ ១៦៣៨
រឿងឧបាសកឈ្មោះចុល្លកាល ១៦៤០
រឿងព្រះអត្តទត្ថត្ថេរ ១៦៤៣

ឈោកវគ្គទី ១៣ .....**១៦៤៦**

រឿងភិក្ខុកំលោះ ១៦៤៨
រឿងព្រះបាទសុទ្ធោទន: ១៦៥១
រឿងភិក្ខុចម្រើនវិបស្សនា.....១៦៥៥
រឿងអភយរាជកុមារ ១៦៥៧
រឿងព្រះសម្មជ្ជនត្ថេរ ១៦៥៩
រឿងអង្គុលីមាលត្ថេរ ១៦៦២
រឿងកូនស្រីជាងតម្បាញ ១៦៦៤
រឿងភិក្ខុ ៣០ រូប ១៦៧២
រឿងចិញ្ចមាណវិកា ១៦៧៤
រឿងអសទិសទាន ១៦៨១
រឿងកាឡ:កូនរបស់អនាថបិណ្ឌិកសេដ្ឋី ១៦៨៩

ពុទ្ធវគ្គទី ១៤ .....**១៦៩៤**

រឿងមារធីតា ១៦៩៧
រឿងយមកប្បាដិហារ្យ ១៧០៦

រឿងឯរកបត្តនាគរាជ ១៧៤៣
រឿងបញ្ហារបស់ព្រះអានន្ទត្ថេរ ១៧៥០
រឿងភិក្ខុមិនត្រេកអរ ១៧៥៥
រឿងអគ្គិទត្តបុរោហិត ១៧៥៩
រឿងបញ្ហារបស់ព្រះអានន្ទ ១៧៦៩
រឿងសម្ពហុលភិក្ខុ ១៧៧១
រឿងព្រះចេតិយមាសរបស់ព្រះកស្សបទសពល ១៧៧៣

សុខវគ្គទី ១៥ .....**១៧៧៨**

រឿងរម្ងាប់ជម្លោះនៃពួកញាតិ ១៧៨០
រឿងមារ ១៧៨៥
រឿងបរាជ័យរបស់ព្រះបាទកោសល ១៧៨៧
រឿងស្រីក្នុងត្រកូលណាមួយ ១៧៨៩
រឿងឧបាសកម្នាក់ ១៧៩១
រឿងព្រះបាទបសេនទិកោសល ១៧៩៥
រឿងព្រះតិស្សត្ថេរ ១៧៩៩
រឿងសក្កទេវរាជ ១៨០១

ឥយវគ្គទី ១៦ .....**១៨០៧**

រឿងបព្វជិត ៣ រូប ១៨០៩
រឿងកុដុម្ពិកម្នាក់ ១៨១៤
រឿងនាងវិសាខាឧបាសិកា ១៨១៨

រឿងស្តេចលិច្ឆវី ១៨២០
រឿងអនិត្ថិគន្ធកុមារ ១៨២២
រឿងព្រាហ្មណ៍ម្នាក់ ១៨២៦
រឿងកុមារ ៥០០ .....១៨២៩
រឿងព្រះអនាគាមិត្ថេរ ១៨៣៣
រឿងនន្ទិយឧបាសក ១៨៣៦

កោធវគ្គទី ១៧ .....**១៨៤១**

រឿងព្រះនាងរោហិណី ១៨៤៣
រឿងភិក្ខុមួយរូប ១៨៤៩
រឿងឧត្តរាឧបាសិកា ១៨៥២
រឿងបញ្ហារបស់ព្រះមហាគ្គល្លាន ១៨៦៥
រឿងបញ្ហាដែលភិក្ខុទូលសួរ ១៨៦៨
រឿងបុណ្ណាសី ១៨៧៤
រឿងអតុលឧបាសក ១៨៧៩
រឿងឆព្វិយភិក្ខុ (ដទៃទៀត) ១៨៨៤

មលវគ្គទី ១៨ .....**១៨៨៧**

រឿងកូនរបស់គោឃាតក: ១៨៩១
រឿងព្រាហ្មណ៍ម្នាក់ ១៨៩៩
រឿងព្រះតិស្សត្ថេរ (ដទៃទៀត) ១៩០១
រឿងព្រះលោឡុទាយិត្ថេរ ១៩០៦

រឿងកុលបុត្រម្នាក់ ១៩១០
រឿងភិក្ខុឈ្មោះចូឡសារី ១៩១៤
រឿងឧបាសក ៥ នាក់ ១៩១៩
រឿងភិក្ខុកំលោះឈ្មោះតិស្សៈ ១៩២២
រឿងឧបាសក ៥ នាក់ ១៩២៦
រឿង មេណ្ឌកសេដ្ឋី ១៩៣១
រឿងព្រះឧជ្ឈានសញ្ញិត្ថេរ ១៩៤៥
រឿងសុភទ្ទបរិព្វាជក ១៩៤៦

ឆម្មជ្ឈភគ្គទី ១៩ .....១៩៥0

រឿងមហាមាត្យអ្នកវិនិច្ឆ័យក្តី ១៩៥៣
រឿងឆព្វគ្គិយភិក្ខុ ១៩៥៦
រឿងព្រះឯកុទានត្ថេរ ១៩៥៨
រឿងព្រះលកុណ្ឌកភទ្ទិយត្ថេរ ១៩៦១
រឿងភិក្ខុច្រើនរូប ១៩៦៤
រឿងភិក្ខុឈ្មោះហត្ថកៈ ១៩៦៦
រឿងព្រាហ្មណ៍ម្នាក់ ១៩៦៨
រឿងតិរ្ថិយ ១៩៧0
រឿងព្រានសន្ធូចឈ្មោះ អរិយៈ ១៩៧៤
រឿងភិក្ខុច្រើនរូប ១៩៧៦

មគ្គភគ្គទី ២0 .....១៩៧៩

រឿងភិក្ខុ ៥០០ រូប ១៩៨២
រឿងភិក្ខុ ៥០០ ផ្សេងទៀត ១៩៨៧
រឿងបធានកម្មិកតិស្សត្ថេរ ១៩៩០
រឿងសូករប្រេត ១៩៩៤
រឿងព្រះបោថិលត្ថេរ ២០០១
រឿងព្រះថេរចាស់ ២០០៦
រឿងសទ្ធិវិហារិករបស់ព្រះសារីបុត្តត្ថេរ ២០១០
រឿងឈ្មួញមានទ្រព្យច្រើន ២០១៥
រឿងនាងកិសាគោតមី ២០១៨
រឿងនាងបដាចារ ២០២០

បកិណ្ណកវគ្គទី ២១ .....**២០២៣**

រឿងបុព្វកម្មរបស់ព្រះសាស្តា ២០២៦
រឿងកុមារិកាបរិភោគពងមាន់ ២០៤១
រឿងភិក្ខុអ្នកនគរភទ្ទិយៈ ២០៤៣
រឿងលកុណ្ឌកភទ្ទិយត្ថេរ ២០៤៧
រឿងទារុសាកដិកៈ ២០៥១
រឿងភិក្ខុវជ្ជីបុត្រ ២០៥៨
រឿងចិត្តគហបតី ២០៦២
រឿងចូឡសុភទ្ទា ២០៦៤
រឿងព្រះថេរឈ្មោះឯកវិហារី ២០៧២

ឆិរយវគ្គទី ២២ .....**២០៧៤**

រឿងនាងបរិព្វាជិកាឈ្មោះសុន្ទរី ២០៧៧
រឿងសត្វដែលត្រូវទុក្ខបៀតបៀន ២០៨២
រឿងភិក្ខុនៅត្រង់ឆ្នេរស្ទឹងឈ្មោះវគ្គុមុទា ២០៨៤
រឿងសេដ្ឋីបុត្រឈ្មោះខេមក: ២០៨៦
រឿងភិក្ខុប្រដៅក្រ ២០៨៩
រឿងស្រីឆ្នាស ២០៩២
រឿងអាគន្តុកភិក្ខុ ២០៩៤
រឿងនិគ្គណ្ឋ ២០៩៧
រឿងសាវ័កតិរ្ថិយ ២១០០

ឆគតិភគ្គទី ២៣ .....២១០៤

រឿងរបស់ព្រះសាស្តា ២១០៧
រឿងភិក្ខុធ្លាប់ជាហត្ថាចារ្យ ២១១២
រឿងកូនរបស់ព្រាហ្មណ៍ចាស់ជរា ២១១៤
រឿងព្រះបាទបសេនទិកោសល ២១២២
រឿងសានុសមណេរ ២១២៥
រឿងដំរីឈ្មោះបាវេរក: ២១៣២
រឿងសម្ពហុលភិក្ខុ ២១៣៥
រឿងមារ ២១៤០

តណ្ហាភគ្គទី ២៤ .....២១៤៦

រឿងកបិលមច្ឆៈ ២១៥១
រឿងជ្រូកញី ២១៦១
រឿងវិព្ភន្តកភិក្ខុ ២១៧០
រឿងពន្ធនាគារ ២១៧៣
រឿងព្រះនាងខេមា ២១៧៨
រឿងឧគ្គសេនសេដ្ឋីបុត្រ ២១៨១
រឿងចូឡធនុគ្គហបណ្ឌិត ២១៩០
រឿងមារ (ដទៃទៀត).....២១៩៦
រឿងឧបកាជីវក ២២០០
រឿងសក្កទេវរាជ ២២០២
រឿងអបុត្តកសេដ្ឋី ២២០៨
រឿងអង្កុរទេវបុត្រ ២២១៣

អិក្ខវគ្គទី ២៥ .....**២២១៦**

រឿងភិក្ខុ ៥ រូប ២២២០
រឿងភិក្ខុសម្លាប់ហង្ស ២២២៥
រឿងកោកាលិកភិក្ខុ ២២៣១
រឿងព្រះធម្មារាមត្ថេរ ២២៣៤
រឿងភិក្ខុណាមួយ ២២៣៧
រឿងបញ្ចង្គទាយកព្រាហ្មណ៍ ២២៤១
រឿងសម្ពហុលភិក្ខុ ២២៤៦
រឿងភិក្ខុ ៥០០ រូប ២២៦២
រឿងព្រះសន្តកាយត្ថេរ ២២៦៣

រឿងព្រះនង្គកូដត្ថេរ ២២៦៦
រឿងព្រះវក្កលិត្ថេរ ២២៧០
រឿងសុមនសាមណេរ.....២២៧៣

ព្រហ្មណវគ្គទី ២៦ .....**២២៩៣**

រឿងព្រាហ្មណ៍មានសេចក្តីជ្រះថ្លាច្រើន ២៣០២
រឿងភិក្ខុច្រើនរូប ២៣០៥
រឿងមារ (ដទៃទៀត) ២៣០៦
រឿងព្រាហ្មណ៍ម្នាក់ ២៣០៨
រឿងព្រះអានន្ទត្ថេរ ២៣០៩
រឿងបព្វជិតមួយរូប ២៣១២
រឿងព្រះសារីបុត្តត្ថេរ ២៣១៤
រឿងព្រះនាងមហាបជាបតីគោតមី ២៣១៩
រឿងព្រះសារីបុត្តត្ថេរ ២៣២១
រឿងជដិលព្រាហ្មណ៍ ២៣២៣
រឿងកុហកព្រាហ្មណ៍ ២៣២៤
រឿងកិសាគោតមី ២៣២៩
រឿងព្រាហ្មណ៍ម្នាក់ ២៣៣១
រឿងឧគ្គសេន ២៣៣៣
រឿងព្រាហ្មណ៍ពីរនាក់ ២៣៣៤
រឿងអក្កោសកភារទ្វាជព្រាហ្មណ៍ ២៣៣៦
រឿងព្រះសារីបុត្តត្ថេរ ២៣៤០
រឿងឧប្បលវណ្ណាថេរី ២៣៤២

រឿងព្រាហ្មណ៍ម្នាក់ ២៣៤៤
រឿងខេមាភិក្ខុនី ២៣៤៥
រឿងព្រះតិស្សត្ថេរអ្នកនៅក្នុងញកភ្នំ ២៣៤៧
រឿងភិក្ខុមួយរូប ២៣៥៣
រឿងសាមណេរ ២៣៥៦
រឿងព្រះមហាបន្ថកត្ថេរ ២៣៦២
រឿងព្រះបិលិន្ទវច្ឆត្ថេរ ២៣៦៤
រឿងភិក្ខុមួយរូប ២៣៦៦
រឿងព្រះសារីបុត្តត្ថេរ ២៣៦៨
រឿងព្រះមហាមោគ្គល្លានត្ថេរ ២៣៧០
រឿងព្រះរេវតត្ថេរ ២៣៧២
រឿងព្រះចន្ទាភត្ថេរ ២៣៧៤
រឿងព្រះសីវលិត្ថេរ ២៣៨០
រឿងព្រះសុន្ទរសមុទ្ទត្ថេរ ២៣៨៣
រឿងព្រះជោតិកត្ថេរ ២៣៩០
រឿងភិក្ខុធ្លាប់ជាអ្នករបាំងមួយរូប ២៤២១
រឿងភិក្ខុធ្លាប់ជាអ្នករបាំងមួយរូបទៀត ២៤២៣
រឿងព្រះវង្គីសត្ថេរ ២៤២៤
រឿងព្រះនាងធម្មទិន្នាថេរី ២៤២៩
រឿងព្រះអង្គុលីមាលត្ថេរ ២៤៣២
រឿងទេវហិតព្រាហ្មណ៍ ២៤៣៤

ពោធិវគ្គទី ១ (អដ្ឋកថាឈ្មោះបរមត្ថទីបនី) ២៤៤១

បឋមពោធិសូត្រ ២៤៤១
អដ្ឋកថាបឋមពោធិសូត្រ ២៤៥០
ទុតិយពោធិសូត្រ ២៥៣៣
អដ្ឋកថាទុតិយពោធិសូត្រ ២៥៣៥
តតិយពោធិសូត្រ ២៥៣៩
អដ្ឋកថាតតិយពោធិសូត្រ ២៥៤១
ហាំហាំកសូត្រ ២៥៤៦
អដ្ឋកថាហាំហាំកសូត្រ ២៥៤៧
ថេរសូត្រ ២៥៥៥
អដ្ឋកថាថេរសូត្រ ២៥៥៦
មហាកស្សបសូត្រ ២៥៦៣
អដ្ឋកថាមហាកស្សបសូត្រ ២៥៦៤
បាវាសូត្រ ២៥៧៣
អដ្ឋកថាបាវាសូត្រ ២៥៧៤
សង្គាមជិសូត្រ ២៥៨៥
អដ្ឋកថាសង្គាមជិសូត្រ ២៥៨៧
ជដិលសូត្រ ២៥៩៣
អដ្ឋកថាជដិលសូត្រ ២៥៩៤
ពាហិយសូត្រ ២៦០០
អដ្ឋកថាពាហិយសូត្រ ២៦០៦

មុច្ចលិន្ទវគ្គទី ២ .....២៦៤៦

មុច្ចលិន្ទសូត្រ ២៦៤៦
អដ្ឋកថាមុច្ចលិន្ទសូត្រ ២៦៤៨
រាជសូត្រ ២៦៥២
អដ្ឋកថារាជសូត្រ ២៦៥៤
ទណ្ឌសូត្រ ២៦៦៧
អដ្ឋកថាទណ្ឌសូត្រ ២៦៦៨
សក្ការសូត្រ ២៦៧២
អដ្ឋកថាសក្ការសូត្រ ២៦៧៤
ឧបាសកសូត្រ ២៦៨០
អដ្ឋកថាឧបាសកសូត្រ ២៦៨១
គព្ភិនីសូត្រ ២៦៨៥
អដ្ឋកថាគព្ភិនីសូត្រ ២៦៨៨
ឯកបុត្តសូត្រ ២៦៩២
អដ្ឋកថាឯកបុត្តសូត្រ ២៦៩៣
សុប្បវាសាសូត្រ ២៦៩៨
អដ្ឋកថាសុប្បវាសាសូត្រ ២៧០៥
វិសាខាសូត្រ ២៧៧៣
អដ្ឋកថាវិសាខាសូត្រ ២៧៧៤
កាឡិគោភទ្ទិយសូត្រ ២៧៨០
អដ្ឋកថាកាឡិគោភទ្ទិយសូត្រ ២៧៨៤

ឆឡភគ្គទី ៣ .....**២៧៩២**

កម្មសូត្រ ២៧៩២
អដ្ឋកថាកម្មសូត្រ ២៧៩៣
នន្ទសូត្រ ២៧៩៨
អដ្ឋកថានន្ទសូត្រ ២៨០៥
យសោជសូត្រ ២៨២៥
អដ្ឋកថាយសោជសូត្រ ២៨៣២
សារិបុត្តសូត្រ ២៨៤៩
អដ្ឋកថាសារិបុត្តសូត្រ ២៨៥០
កោលិតសូត្រ ២៨៥៣
អដ្ឋកថាកោលិតសូត្រ ២៨៥៤
បិលិន្ទវច្ឆសូត្រ ២៨៥៩
អដ្ឋកថាបិលិន្ទវច្ឆសូត្រ ២៨៦១
មហាកស្សបសូត្រ ២៨៦៧
អដ្ឋកថាមហាកស្សបសូត្រ ២៨៦៩
បិណ្ឌបាតសូត្រ ២៨៨១
អដ្ឋកថាបិណ្ឌបាតសូត្រ ២៨៨៥
សិប្បសូត្រ ២៨៨៩
អដ្ឋកថាសិប្បសូត្រ ២៨៩២
លោកសូត្រ ២៨៩៧
អដ្ឋកថាលោកសូត្រ ២៨៩៩

មេឃិយវគ្គទី ៤ .....២៩១៩

មេឃិយសូត្រ ២៩១៩
អដ្ឋកថាមេឃិយសូត្រ ២៩២៧
ឧទ្ទតសូត្រ ២៩៦៧
អដ្ឋកថាឧទ្ទតសូត្រ ២៩៦៨
គោបាលសូត្រ ២៩៧៣
អដ្ឋកថាគោបាលសូត្រ ២៩៧៦
ជុណ្ហសូត្រ ២៩៨២
អដ្ឋកថាជុណ្ហសូត្រ ២៩៨៥
នាគសូត្រ ២៩៩២
អដ្ឋកថានាគសូត្រ ២៩៩៥
បិណ្ឌោលភារទ្វាជសូត្រ ៣០០២
អដ្ឋកថាបិណ្ឌោលភារទ្វាជសូត្រ ៣០០៤
សារិបុត្តសូត្រ ៣០១០
អដ្ឋកថាសារិបុត្តសូត្រ ៣០១១
សុន្ទរីសូត្រ ៣០១៣
អដ្ឋកថាសុន្ទរីសូត្រ ៣០១៩
ឧបសេនវង្គន្តបុត្តសូត្រ ៣០៣៧
អដ្ឋកថាឧបសេនវង្គន្តបុត្តសូត្រ ៣០៣៨
សារិបុត្តសូត្រ ៣០៤៦
អដ្ឋកថាសារិបុត្តសូត្រ ៣០៤៧

ឧទ្ទានសោណត្ថេរវត្ថុទី ៥ .....៣០៥១

រាជសូត្រ ៣០៥១
អដ្ឋកថារាជសូត្រ ៣០៥៣
អប្បាយុកាសូត្រ ៣០៥៧
អដ្ឋកថាអប្បាយុកាសូត្រ ៣០៥៩
សុប្បពុទ្ធកុដ្ឋិសូត្រ ៣០៦៥
អដ្ឋកថាសុប្បពុទ្ធកុដ្ឋិសូត្រ ៣០៧០
កុមារកសូត្រ ៣០៩៨
អដ្ឋកថាកុមារកសូត្រ ៣១០០
ឧបោសថសូត្រ ៣១០២
អដ្ឋកថាឧបោសថសូត្រ ៣១១៥
សោណសូត្រ ៣១៣៥
អដ្ឋកថាសោណសូត្រ ៣១៤៣
កង្ខារេវតសូត្រ ៣១៥៨
អដ្ឋកថាកង្ខារេវតសូត្រ ៣១៥៩
អានន្ទសូត្រ ៣១៦២
អដ្ឋកថាអានន្ទសូត្រ ៣១៦៣
សទ្ធាយមានសូត្រ ៣១៦៧
អដ្ឋកថាសទ្ធាយមានសូត្រ ៣១៦៨
ចូឡបន្ថកសូត្រ ៣១៧០
អដ្ឋកថាចូឡបន្ថកសូត្រ ៣១៧១

ឧទានជច្ចន្ធវគ្គទី៦ .....៣១៧៦

អាយុសមឱសជ្ជនសូត្រ ៣១៧៦
អដ្ឋកថាអាយុសមឱសជ្ជនសូត្រ ៣១៨៥
បដិសល្លានសូត្រ ៣២០០
អដ្ឋកថាបដិសល្លានសូត្រ ៣២០៥
អាហុសូត្រ ៣២១៣
អដ្ឋកថាអាហុសូត្រ ៣២១៤
បឋមកិរសូត្រ ៣២២០
អដ្ឋកថាបឋមកិរសូត្រ ៣២២៧
ទុតិយកិរសូត្រ ៣២៣៨
អដ្ឋកថាទុតិយកិរសូត្រ ៣២៤២
តិត្តសូត្រ ៣២៤៦
អដ្ឋកថាតិត្តសូត្រ ៣២៥២
សុភូតិសូត្រ ៣២៥៦
អដ្ឋកថាសុភូតិសូត្រ ៣២៥៧
គណិកាសូត្រ ៣២៦០
អដ្ឋកថាគណិកាសូត្រ ៣២៦២
ឧបាតិសូត្រ ៣២៧០
អដ្ឋកថាឧបាតិសូត្រ ៣២៧១
ឧបបជ្ជន្តិសូត្រ ៣២៧៦
អដ្ឋកថាឧបបជ្ជន្តិសូត្រ ៣២៧៩

ឧទ្ទានចូឡវគ្គនី ៧ .....៣២៨៤

(បឋម) ភទ្ទិយសូត្រ ៣២៨៤
អដ្ឋកថាបឋមភទ្ទិយសូត្រ ៣២៨៥
ទុតិយភទ្ទិយសូត្រ ៣២៩០
អដ្ឋកថាទុតិយភទ្ទិយសូត្រ ៣២៩១
បឋមកាមសូត្រ ៣២៩៤
អដ្ឋកថាបឋមកាមសូត្រ ៣២៩៥
ទុតិយកាមសូត្រ ៣២៩៨
អដ្ឋកថាទុតិយកាមសូត្រ ៣២៩៩
លកុណ្ឌកភទ្ទិយសូត្រ ៣៣០២
អដ្ឋកថាលកុណ្ឌកភទ្ទិយសូត្រ ៣៣០៤
តណ្ហក្ខយសូត្រ ៣៣០៩
អដ្ឋកថាតណ្ហក្ខយសូត្រ ៣៣១០
បបញ្ចក្ខយសូត្រ ៣៣១៣
អដ្ឋកថាបបញ្ចក្ខយសូត្រ ៣៣១៤
មហាកច្ចានសូត្រ ៣៣១៧
អដ្ឋកថាមហាកច្ចានសូត្រ ៣៣១៨
ឧទបានសូត្រ ៣៣២៤
អដ្ឋកថាឧទបានសូត្រ ៣៣២៦
ឧទេនសូត្រ ៣៣៣៦
អដ្ឋកថាឧទេនសូត្រ ៣៣៣៨

បាដលិគ្គាមិយវគ្គទី ៨ .....៣៣៤៦

បឋមនិព្វានសូត្រ ៣៣៤៦
អដ្ឋកថាបឋមនិព្វានសូត្រ ៣៣៤៧
ទុតិយនិព្វានសូត្រ ៣៣៥៦
អដ្ឋកថាទុតិយនិព្វានសូត្រ ៣៣៥៧
តតិយនិព្វានសូត្រ ៣៣៦០
អដ្ឋកថាតតិយនិព្វានសូត្រ ៣៣៦១
ចតុត្ថនិព្វានសូត្រ ៣៣៦៦
អដ្ឋកថាចតុត្ថនិព្វានសូត្រ ៣៣៦៧
ចុន្ទសូត្រ ៣៣៧០
អដ្ឋកថាចុន្ទសូត្រ ៣៣៧៨
បាដលិគាមិយសូត្រ ៣៣៩៣
អដ្ឋកថាបាដលិគាមិយសូត្រ ៣៤០៣
ទ្វិធាបថសូត្រ ៣៤៣១
អដ្ឋកថាទ្វិធាបថសូត្រ ៣៤៣៣
វិសាខាសូត្រ ៣៤៣៨
អដ្ឋកថាវិសាខាសូត្រ ៣៤៤២
បឋមទព្វសូត្រ ៣៤៤៨
អង្គកថាបឋមទព្វសូត្រ ៣៤៥០
ទុតិយទព្វសូត្រ ៣៤៥៧
អង្គកថាទុតិយទព្វសូត្រ ៣៤៥៩

ព្រះ

សុត្តន្តបិដក

និង

បរមត្ថជោតិកា អដ្ឋកថា

សេចក្តីប្រែជាភាសាខ្មែរ

ខុទ្ទកនិកាយ

ខុទ្ទកបាឋ ធម្មបទគាថា ឰទាន

បឋមភាគ

ឆាលីប្រែ ៥២



ជោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣

សុត្តន្តបិដក

ខុទ្ទកនិកាយ ខុទ្ទកបាឋៈ

សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ

ខុទ្ទកបាឋ

សរណាគមន៍

[១] *ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីរឭក ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីរឭក ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីរឭក ។ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីរឭក ជាគម្រប់ពីរជង់ផង ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីរឭក ជាគម្រប់ពីរជង់ផង ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីរឭក ជាគម្រប់ពីរជង់ផង ។ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីរឭក ជាគម្រប់បីជង់ផង ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីរឭក ជាគម្រប់បីជង់ផង ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីរឭក ជាគម្រប់បីជង់ផង ។*

សរណាគមន៍ ចប់

អដ្ឋកថា

ខុទ្ទកនិកាយ

ឈ្មោះ បរមត្ថជោតិកា

ខុទ្ទកចាឯ:

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ពាក្យច្រារព្ធ

និទ្ទេសនេះ ខ្ញុំសូមដល់ព្រះពុទ្ធជាសរណ: សូមដល់ព្រះធម៌ជាសរណ: សូមដល់ព្រះសង្ឃជាសរណ: ។ សូម្បីវារ:ទី ២ ទី ៣ ក៏ដូចគ្នា ។ ជានិទ្ទេស អធិប្បាយអំពីការដល់ព្រះរតនត្រ័យ ជាគោលខាងដើមនៃគម្ពីរខុទ្ទបាឯ: ។

ឥឡូវនេះ ដើម្បីបើកផ្ទារ ចែក ធ្វើឲ្យងាយនូវអត្ថនៃបាលីនោះ ខ្ញុំនឹងពោលអធិប្បាយសេចក្តីនេះ ដោយអដ្ឋកថាខុទ្ទកបាឯ: ឈ្មោះថា បរមត្ថជោតិកា ដោយពាក្យថា ខ្ញុំសូមនមស្ការព្រះរតនត្រ័យ ដែលខត្តមជាងវត្ថុទាំងឡាយ ដែលគួរនមស្ការហើយ និងធ្វើកិច្ចពណ៌នានៃខុទ្ទកបាឯ: ។ កិច្ចពណ៌នានេះ ខ្ញុំ ជាអ្នកដឹងក្នុងសាសនាតិចតួច ធ្វើបានលំបាកក្រៃលែង ព្រោះខុទ្ទកបាឯ: មានអត្ថជ្រាលជ្រៅក៏ពិត តែព្រោះហេតុដែលការវិនិច្ឆ័យរបស់បុព្វាចារ្យមានជានិច្ច ដល់ថ្ងៃនេះ មួយអន្ទើដោយនវង្គសត្ថុសាសន: ក៏នៅតាំងនៅ ដូចក្នុងកាលមុន ដូច្នោះ ខ្ញុំអាស្រ័យនវង្គសត្ថុសាសន: និងការវិនិច្ឆ័យរបស់បុព្វាចារ្យ

នេះ ទើបប្រាថ្នានឹងពណ៌នាសេចក្តី ដោយការគោរពយ៉ាងក្រៃលែងក្នុងព្រះសទ្ធម្ម មិនមែនបំណងលើកខ្លួន សង្កត់សង្កិនលោកឡើយ សូមលោកទាំងឡាយ តាំងចិត្តស្តាប់នូវកិច្ចពណ៌នាសេចក្តីនេះហោង ។

ការកំណត់ខុទ្ទកបាឋៈ

ខ្ញុំបានពោលក្នុងពាក្យប្រារព្ធនោះថា នឹងធ្វើកិច្ចពណ៌នាសេចក្តីនៃខុទ្ទក-បាឋៈខ្លះ ។ ខ្ញុំចាំបាច់កំណត់ខុទ្ទកបាឋៈទាំងឡាយជាមុនហើយ ទើបនឹងធ្វើកិច្ចពណ៌នាអត្ថឯក្រោយ ឯកទេសចំណែកនីមួយៗ របស់ខុទ្ទកនិកាយ ឈ្មោះថា **ខុទ្ទក។** *ឯកទេសចំណែកនីមួយៗ របស់និកាយទាំង ៥ ឈ្មោះថា* **ខុទ្ទកនិកាយ** *ពោលដោយធម៌ និងដោយអត្ថ គម្ពីរទាំងនេះមាន ៥ និកាយ គឺទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ និងខុទ្ទកនិកាយ ឈ្មោះថា* **និកាយ ៥ ។**

បណ្តានិកាយទាំង ៥ នោះ ព្រះសូត្រ ៣៤ មានព្រហ្មជាលសូត្រជាដើម ឈ្មោះថា **ទីឃនិកាយ** *ដូចលោកពោលថា និកាយដែលរួបរួមព្រះសូត្រ ៣៤ ចែកជាវគ្គមាន៣ ឈ្មោះថា* **ទីឃនិកាយ។** *អនុលោមទី១ ព្រះសូត្រ១៥២ មានមូលបរិយាយសូត្រជាដើម ឈ្មោះថា* **មជ្ឈិមនិកាយ។** *ព្រះសូត្រ ៧៧៦២ សូត្រ មានឱឃតរណសូត្រជាដើម ឈ្មោះថា* **សំយុត្តនិកាយ។** *ព្រះសូត្រ ៩៥៥៧ មានចិត្តបរិយោទានសូត្រជាដើម ឈ្មោះថា* **អង្គុត្តរនិកាយ។**

ខុទ្ទកបាឋៈ ធម្មបទ ឧទាន ឥតិវុត្តក: សុត្តនិបាត វិមានវត្ថុ បេតវត្ថុ

ថេរគាថា ថេរីគាថា ជាតក និទ្ទេស បដិសម្ភិទាមគ្គ អបទាន ពុទ្ធវង្ស ចរិយា-បិដក ពុទ្ធវចនៈ វៀរវិនយបិដក និងអភិធម្មបិដក ឬនិកាយ ៤ ឈ្មោះថា **ខុទ្ទកនិកាយ** ។

ហេតុអ្វី ទើបនិកាយនេះ លោកហៅថា **ខុទ្ទកនិកាយ** *ហេតុជាទីប្រមូលមក ជាទីលំនៅនៃពួកធម៌តូចៗ ជាច្រើន ។ ពិតហើយ ការរួមគ្នា លោកហៅថា* **និកាយ** *ពោលដោយសាសនា និងដោយលោក ក្នុងសេចក្តីនេះ មានសាធកជាដើមយ៉ាងនេះ គឺម្នាលភិក្ខុទាំងឡាយ ពួកសត្វតិរច្ឆាននេះ ដ៏វិចិត្រយ៉ាងណា ចិត្តណាដែលវិចិត្រយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញ សូម្បីនូវពួកធម៌មួយ ដទៃអំពីចិត្តនោះឡើយ ។ ពួកក្សត្រ ព្រាហ្មណ៍ ពួកក្សត្រចិក្ខល្លិកា ។ ឯកទេសចំណែកមួយរបស់ខុទ្ទកនិកាយនោះ មានដូច្នេះ ពួកធម៌តូចៗ ដែលទាក់ទងក្នុងព្រះសុត្តន្តបិដកទាំងនេះ សំដៅយកទីដែលបើកផ្លូវ ចែក ធ្វើឲ្យងាយដោយអត្ថ ខុទ្ទកបាឋៈ ៩ ប្រភេទ គឺ សរណសិក្ខាបទ ទុតិយសាការ កុមារប្បញ្ហា (សាមណេរប្បញ្ហា) មង្គលសូត្រ រតនសូត្រ តិរោកុដ្ឋសូត្រ និធិកណ្ឌសូត្រ និងមេត្តសូត្រ ជាចំណែកខាងដើមនៃពួកធម៌ទាំងនោះ ដោយអាចារ្យខាងក្រោយមក លើកឡើងប្រុប់បង្រៀន មិនជាពាក្យដែលព្រះមានព្រះភាគត្រាស់ ។ ពិតហើយ គាថាទាំងនេះ ព្រះមានមានព្រះភាគត្រាស់ថា*

អនេកជាតិសង្សារំ សន្ធាវិស្សំ អនិព្ពិសំ
គហាការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ។

គហការកំ និដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

កាលតថាគតមិនទាន់បានជួបប្រទះ (ពោធិញ្ញាណវេលាតែ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្តីកើត ជាទុក្ខរឿយៗ ។

នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ (របស់តថាគត) ទៀត មិនបានឡើយ ឆ្អឹងជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ជាគ្រឿងក្សយតណ្ហាទាំងឡាយហើយ ។

ឈ្មោះថា ជាបឋមពុទ្ធវចនៈទាំងអស់ ព្រោះជាព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ ដែលឈ្មោះថា បឋមពុទ្ធតម្រាស់នោះ ក៏ព្រោះត្រាស់ដោយព្រះមនស មិនមែនទ្រង់បន្ទឹព្រះវាចាត្រាស់ឡើយ ចំណែកព្រះគាថានេះថា

យទា ហវេ ចាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ ខយំ បជ្ជយានំ អវេទីតិ ។

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាម ញុាំងកិលេសឲ្យក្តៅ អ្នកជុតបង់នូវកិលេស ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួង របស់ព្រាហ្មណ៍នោះ រមែងអស់ទៅ ក្នុងកាលនោះ ព្រោះដឹងច្បាស់នូវធម៌ ព្រមទាំងហេតុ ។

ឈ្មោះថា ជាបឋមពុទ្ធតម្រាស់ ព្រោះជាព្រះតម្រាស់ដែលព្រះមានព្រះភាគទ្រង់បន្ទឺព្រះវាចាត្រាស់ ។ ព្រោះដូច្នោះ ខុទ្ទកបាឋៈ ៩ ប្រភេទនេះ ឈ្មោះថា ជាគោលខាងដើមនៃពួកធម៌តូចៗ ទាំងនេះ យើងនឹងផ្តើមពណ៌នាសេចក្តីនៃខុទ្ទកបាឋៈនោះ តាំងអំពីនេះជាដើមទៅ ។

និទានសោធនៈ

[១] *វាចានេះថា* **ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ** *ជាពាក្យខាងដើមនៃពាក្យផ្តើមនោះ ខ្ញុំសូមពណ៌នាអត្ថនៃពាក្យផ្តើមនោះ ដូច្នេះថា ត្រៃសរណៈ អ្នកណាពោល ពោលក្នុងទីណា ពោលក្នុងកាលណា ពោលព្រោះហេតុអ្វី ។ ម្យ៉ាងទៀត ដែលមិនបានត្រាស់ខាងដើម ព្រោះហេតុអ្វី ទើបក្នុងទីនេះពោលថា ត្រាស់ជាប្រការដំបូង ចាំបាច់ត្រូវជម្រះពាក្យផ្តើមខាងដើម បន្ទាប់អំពីនេះទៅ ក្នុងពាក្យផ្តើម ក៏នឹងចង្អុលបង្ហាញរឿងព្រះពុទ្ធ រឿងការដល់សរណៈ និងរឿងបុគ្គលដែលដល់សរណៈ និងសម្តែងការជាប់ ការមិនជាប់នៃសរណគមន៍ ទាំងផល ទាំងសរណៈដែលគួរដល់ក្នុងសរណៈ ២ មាន* **ធម្មំ សរណំ** *ជាដើម ក៏ស្គាល់*

ហើយថា មានន័យយ៉ាងនេះ និងអធិប្បាយហេតុក្នុងការកំណត់ដោយលំដាប់ និងប្រកាសត្រៃសរណៈនោះ ដោយឧបមាទាំងឡាយ ។

បណ្តាគាថាទាំងនោះ គាថាដំបូង មានប្រស្នា ៥ ប្រការ គឺត្រៃសរណៈបុគ្គលណាពោល ១ ពោលក្នុងទីណា ១ ពោលអំពីពេលណា ១ ពោលព្រោះហេតុអ្វី ១ ព្រះតថាគតមិនបានត្រាស់មកអំពីមុន ព្រោះហេតុអ្វី ទើបក្នុងទីនេះបានត្រាស់ជាដំបូង ។

និងវិសជ្ជនាប្រស្នាទាំង ៥ នោះថា ប្រស្នាថា អ្នកណាពោល ឆ្លើយថា ព្រះមានព្រះភាគត្រាស់ មិនមែនសាវក មិនមែនឥសីទាំងឡាយ មិនមែនទេវតាពោល ។

ប្រស្នាថា ពោលទីណា វិសជ្ជនាថា ត្រង់ឥសិបតនមិគទាយវន ក្រុងពារាណសី ។

ប្រស្នាថា ពោលអំពីពេលណា ឆ្លើយថា កាលព្រះយសសម្រេចអរហត្តមួយអន្ទើដោយសម្ងាញ់ទាំងឡាយ កាលព្រះអរហន្ត ៦១ ធ្វើការសម្តែងធម៌ក្នុងលោក ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន ។

បញ្ហាថា ពោលព្រោះហេតុអ្វី ឆ្លើយថា ដើម្បីបព្វជ្ជា និងដើម្បីឧបសម្បទាដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុលបុត្រនោះ ភិក្ខុគប្បីកោរសក់ និងពុកមាត់ឲ្យជាដំបូង ហើយឲ្យស្លៀកសំពត់កាសាយៈទាំង-ឡាយ រួចឲ្យពាក់ចីវរឆៀងស្មាម្ខាងឲ្យថ្វាយបង្គំបាទាភិក្ខុទាំងឡាយ ហើយឲ្យអង្គុយច្រហោង ផ្គងអញ្ជលីឡើង រួចប្រាប់ថា អ្នកចូរពោលពាក្យយ៉ាងនេះថា

ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីរឭក ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីរឭក ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីរឭក ។

ប្រស្នាថា ព្រោះហេតុអ្វី ទើបក្នុងទីនេះ ត្រាស់ជាដំបូង វិសជ្ជនាថា ព្រោះទេវតា និងមនុស្សនាំគ្នាចូលកាន់សាសនា ជាឧបាសកខ្លះ ជាបព្វជិតខ្លះ ដោយផ្លូវនេះ ដូច្នោះ ទើបគួរដឹងថា នវង្គសត្ថុសាសនៈនេះ បុព្វាចារ្យទាំង-ទ្បាយបង្រួបបង្រួមក្នុងបិដកទាំង ៣ លើកឡើងកាន់ការប្រៀនប្រដៅ ទើបពោលថា ត្រាស់ជាដំបូងក្នុងខុទ្ទកបាឋៈនេះ ព្រោះជាផ្លូវចូលកាន់សាសនា ។

ពណ៌នា ត្រៃសរណៈ

អំពីពុទ្ធៈដោយអត្ថ

*ឥទ្បូវនេះ ពាក្យណាខ្ញុំពោលថា នឹងចង្អុលបង្ហាញរឿងព្រះពុទ្ធ រឿងការដល់សរណៈ និងរឿងបុគ្គលដល់សរណៈ ក្នុងពាក្យនោះ សត្វពិសេសឈ្មោះថា **ពុទ្ធ** ព្រោះបញ្ញត្តអាស្រ័យខន្ធសន្តានដែលត្រូវអប់រំ ដោយការសម្រេចអនុត្តរវិមោក្ខដែលជានិមិត្តនៃព្រះញាណឯណា ដែលរាវរំងមិនបាន ឬព្រោះបញ្ញត្តអាស្រ័យការត្រាស់ដឹងឯងក្រៃលែងនូវសច្ចៈ ដែលជាបទដ្ឋាននៃព្រះសព្វញ្ញុតញ្ញាណ ដូចដែលលោកពោលថា*

ព្រះមានព្រះភាគអង្គណា ទ្រង់កើតឯង មិនមានអាចារ្យ ត្រាស់ដឹងសច្ចៈទាំងឡាយ ដោយព្រះអង្គឯង ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮមកក្នុងកាលមុន ព្រះអង្គទ្រង់ដល់នូវភាពជាសព្វញ្ញូ ក្នុងសច្ចៈទាំងនោះផង ទ្រង់

ដល់នូវភាពជាអ្នកស្ងាត់ ក្នុងពលៈទាំងឡាយផង ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **ពុទ្ធ** *។ ការចង្អុលបង្ហាញរឿងព្រះពុទ្ធដោយអត្ថប៉ុណ្ណេះសិន ។*

អំពី ពុទ្ធៈ ដោយព្យញ្ជនៈ

បើពោលដោយព្យញ្ជនៈគប្បីជ្រាបដោយនយជាដើមយ៉ាងនេះថា ឈ្មោះថា **ពុទ្ធ** *ព្រោះទ្រង់ជាបុគ្គលត្រាស់ដឹង ឈ្មោះថា* **ពុទ្ធ** *ព្រោះទ្រង់ជាអ្នកជាស់ឲ្យក្រាក់ សមដូចលោកពោលថា*

សំណួរត្រង់ពាក្យថា **ពុទ្ធ** *ចុះឈ្មោះថា* **ពុទ្ធ** *ដោយអត្ថដូចម្តេច ។ ឈ្មោះថា* **ព្រះពុទ្ធ** *ព្រោះហេតុទ្រង់ត្រាស់ដឹងសច្ចៈទាំងឡាយ ។ ឈ្មោះថា* **ពុទ្ធ** *ព្រោះហេតុទ្រង់ញុំាងពពួកសត្វឲ្យត្រាស់ដឹង ។ ឈ្មោះថា* **ពុទ្ធ** *ព្រោះព្រះអង្គដឹងធម៌ទាំងពួង ។ ឈ្មោះថា* **ពុទ្ធ** *ព្រោះព្រះអង្គឃើញធម៌ទាំងពួង ។ ឈ្មោះថា* **ពុទ្ធ** *ព្រោះព្រះអង្គដឹងច្បាស់ ។ ឈ្មោះថា* **ពុទ្ធ** *ព្រោះព្រះអង្គរីកហើយ ។ ឈ្មោះថា* **ពុទ្ធ** *ព្រោះគេពោលថា ព្រះអង្គមានអាសវៈអស់ហើយ ។ ឈ្មោះថា* **ពុទ្ធ** *ព្រោះគេពោលថា ព្រះអង្គមានឧបធិក្កិលេសដកហើយ ។ ឈ្មោះថា* **ពុទ្ធ** *ព្រោះហេតុទ្រង់ ច្រាសចាកភាគៈ ដោយចំណែកមួយ ។ ឈ្មោះថា* **ពុទ្ធ** *ព្រោះហេតុទ្រង់ច្រាសចាកទោសៈ ដោយចំណែកមួយ ។ ឈ្មោះថា* **ពុទ្ធ** *ព្រោះហេតុទ្រង់ច្រាសចាកមោហៈ ដោយចំណែកមួយ ។ ឈ្មោះថា* **ពុទ្ធ** *ព្រោះហេតុទ្រង់មានកិលេសចេញហើយដោយចំណែកមួយ ។ ឈ្មោះថា* **ពុទ្ធ** *ព្រោះហេតុទ្រង់ទៅហើយកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ។ ឈ្មោះថា* **ពុទ្ធ** *ព្រោះហេតុទ្រង់ជាបុគ្គលឯក ត្រាស់*

ជីឯចំពោះសម្មាសម្ពោធិញ្ញាណ មិនមានគុណជាតជនៃក្រៃលែងជាង ។ ឈ្មោះ ថា **ពុទ្ធ** *ព្រោះទ្រង់កម្ចាត់បង់សេចក្តីល្ងង់ ព្រោះការបាននូវប្រាជ្ញា ។ ព្រះនាម* **ពុទ្ធ** *នុ៎ះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុស ថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនពួកមិត្ត និងអមាត្យថ្វាយ មិនមែន ពួកញាតិ និងសាលោហិតថ្វាយ មិនមែនពួកសមណព្រាហ្មណ៍ថ្វាយ មិន មែនពួកទេវតាថ្វាយទេ ព្រះនាមថា* **ពុទ្ធ** *នុ៎ះ របស់ព្រះពុទ្ធទាំងឡាយមាន ព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតនៃវិមោក្ខប្បញ្ញត្តិថា* **ពុទ្ធ** *នេះ កើតព្រោះ ការត្រាស់ជីឯ ព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់ ពោធិព្រឹក្ស ហេតុនោះ (លោកពោលថា) **ពុទ្ធ** ។*

ក្នុងបទថា **ពុទ្ធ** *នុ៎ះ ឈ្មោះថា* **ពុទ្ធ** *ព្រោះអត្ថថា ត្រាស់ជីឯសច្ចៈ ទាំងឡាយ ដូចបុគ្គលដែលចុះមកក្នុងលោក ក៏ហៅថា អ្នកចុះមក(អវតារ) ឈ្មោះថា* **ពុទ្ធ** *ព្រោះអត្ថថា ទ្រង់ជាស់ពួកសត្វឲ្រាក់ ដូចខ្យល់ដែលធ្វើស្វឹក ឈើឲ្យស្ងួត ក៏ហៅថា ស្វឹកឈើស្ងួត ។ ពាក្យថា ព្រោះព្រះអង្គជីឯធម៌ ទាំងពួង លោកអធិប្បាយថា ឈ្មោះថា* **ពុទ្ធ** *ព្រោះការជីឯដែលអាចជីឯ បានគ្រប់យ៉ាង ។ ពាក្យថា ព្រោះព្រះអង្គឃើញធម៌ទាំងពួង លោកអធិប្បាយ ថា ឈ្មោះថា* **ពុទ្ធ** *ព្រោះការជីឯដែលអាចជីឯធម៌បានគ្រប់យ៉ាង ។ ពាក្យថា ព្រោះព្រះអង្គជីឯច្បាស់ លោកអធិប្បាយថា ឈ្មោះថា* **ពុទ្ធ** *ព្រោះត្រាស់ជីឯ ឯង មិនមែនអ្នកជនៃធ្វើឲ្យត្រាស់ជីឯ ។ ពាក្យថា ព្រោះព្រះអង្គរីកហើយ លោកអធិប្បាយថា ឈ្មោះថា* **ពុទ្ធ** *ព្រោះទ្រង់រីក ព្រោះរីកដោយព្រះគុណ*

ច្រើនប្រការ ដូចផ្កាឈូកវែក ។ ដោយពាក្យថា ព្រោះគេពោលថា ព្រះអង្គ មានអាសវៈអស់ហើយជាដើម លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធ** *ព្រោះទ្រង់ភ្ញាក់ហើយ ព្រោះអស់កិលេស ដូចការដេកលក់គ្រប់យ៉ាង ដូចបុរសភ្ញាក់ ព្រោះអស់ការដេកលក់ ព្រោះទ្រង់លះធម៌ ដែលធ្វើការរួញរានៃចិត្ត បាន ។ លោកពោលថា ព្រោះហេតុទ្រង់ទៅហើយកាន់ផ្លូវ ជាទីទៅនៃបុគ្គលម្នាក់ឯង ដូច្នេះ ក៏ដើម្បីសម្តែងថា ព្រះមានព្រះភាគ លោកហៅថា* **ពុទ្ធ** *ព្រោះទ្រង់យាងតាមឯកាយនមគ្គ ដូចបុរសដើរផ្លូវ គេក៏ហៅថា អ្នកដើរទៅ ព្រោះបរិយាយនៃអត្ថថា ទៅកាន់ផ្លូវត្រាស់ដឹង ។ ពាក្យថា ព្រោះហេតុទ្រង់ជាបុគ្គលឯក ត្រាស់ដឹងចំពោះសម្មាសម្ពោធិញ្ញាណ មិនមានគុណជាតជនៃក្រៃលែងជាង លោកអធិប្បាយថា ឈ្មោះថា* **ពុទ្ធ** *មិនមែន ព្រោះត្រាស់ដឹងដោយអ្នកជនៃ ដែលពិត ឈ្មោះថា* **ពុទ្ធ** *ព្រោះត្រាស់ដឹងក្រៃលែងនូវសម្មាសម្ពោធិដ៏កំពូល ដោយព្រះអង្គឯងប៉ុណ្ណោះ ។ ពាក្យថា ព្រោះទ្រង់កម្ចាត់បង់សេចក្តីល្ងង់ ព្រោះការបាននូវប្រាជ្ញា ជាពាក្យសម្តែងបរិយាយថា* **ពុទ្ធិ ពុទ្ធុំ ពោធោ** *។ ក្នុងពាក្យនោះ គប្បីជ្រាបអត្ថដែលអាចធ្វើ* **ពុទ្ធ** *សព្ទ របស់បទទាំងអស់ឲ្យសម្រេចសេចក្តី ដោយន័យយ៉ាងនេះថា លោកអធិប្បាយដើម្បីឲ្យដឹងថា* **ពុទ្ធ** *ព្រោះទ្រង់ប្រកបដោយព្រះគុណ គឺ* **ពុទ្ធិ** *ដូចគេតែងហៅថា សំពត់ខៀវ សំពត់ក្រហម ព្រោះប្រកបដោយពណ៌ខៀវ ពណ៌ក្រហម បន្ទាប់អំពីនោះ ពាក្យថា ព្រះនាមថា* **ពុទ្ធ** *នុ៎ះ ជាដើម លោកពោលក៏ដើម្បីឲ្យដឹងថា បញ្ញត្តនេះប្រព្រឹត្តទៅតាមអត្ថ គឺន័យសេចក្តី ។ ការ*

ចង្អុលអំពីពុទ្ធដោយព្យញ្ជនៈមានដូចពោលមកនេះ ។

អំពីការដល់សរណាគមន៍

និងរឿងបុគ្គលដែលចូលដល់សរណាគមន៍

ឥឡូវនេះ នឹងចង្អុលបង្ហាញក្នុងរឿងការដល់សរណាគមន៍ជាដើម ដូចតទៅនេះ ព្រះរតនត្រ័យ ឈ្មោះថា **សរណៈ** *ព្រោះកម្ចាត់ អធិប្បាយថា សង្កត់សង្កិន ទម្លាយ នាំចេញ រម្ងាប់ភ័យ គឺសេចក្តីខ្លាច ការតក់ស្លុត ទុក្ខ ទុគ្គតិ ការសៅហ្មង ដោយការដល់សរណៈនោះឯងរបស់មនុស្សទាំងឡាយ ដែលដល់សរណាគមន៍ ។ ម្យ៉ាងទៀត ព្រះពុទ្ធ ឈ្មោះថា* **សរណៈ** *ព្រោះកម្ចាត់ភ័យរបស់សត្វទាំងឡាយ ដោយការឲ្យចូលដល់វត្ថុដែលជាប្រយោជន៍ និងនាំចេញចាកវត្ថុដែលមិនជាប្រយោជន៍ ។ ព្រះធម៌ ឈ្មោះថា* **សរណៈ** *ព្រោះឲ្យសត្វឆ្ងាយកន្លារ គឺភព និងឲ្យនូវការស្រឡះនៃចិត្ត ។ ព្រះសង្ឃ ឈ្មោះថា* **សរណៈ** *ព្រោះធ្វើសក្ការៈ សូម្បីតិចតួច ឲ្យត្រឡប់បាននូវផលដ៏បរិបូណ៌ ព្រោះដូច្នោះ ទើបរតនត្រ័យនោះ ឈ្មោះថា* **សរណៈ** *ដោយបរិយាយដូចពោលមកនេះ ។*

ចិត្តប្បាទដែលការជ្រះថ្លា ក្នុងព្រះរតនត្រ័យនេះ និងការគោរពក្នុងព្រះ-រតនត្រ័យនោះ កម្ចាត់ ទម្លាយនូវកិលេសបាន ប្រព្រឹត្តទៅដោយអាការ គឺការមានព្រះរតនត្រ័យនោះជាខាងមុខ ឬមិនមានអ្នកដទៃជាបច្ច័យ ឈ្មោះថា **សរណាគមន៍។** *សត្វដែលដល់ព្រមដោយចិត្តប្បាទនោះ រមែងដល់ព្រះរតន-ត្រ័យនោះជាសរណៈ អធិប្បាយថា រមែងចូលដល់ព្រះរតនត្រ័យ ដោយ*

ចិត្តប្បាទ ដែលមានប្រការដូចពោលហើយយ៉ាងនេះថា **ឯស មេ សរណំ ឯស មេ បរាយណំ** *នេះជាសរណៈរបស់ខ្ញុំ នេះជាទីទៅខាងមុខរបស់ខ្ញុំ ។ បុគ្គលកាលចូលដល់ រមែងចូលដល់ដោយវិធីសមាទាន ដូចនាយពាណិជ្ជ ២ នាក់ ឈ្មោះតបុស្សៈ និងភល្លិកៈជាដើមថា* **ឯតេ មយំ ភន្តេ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ឧបាសកេ នោ ភគវា ធារេតុ** *បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំង ២ សូមដល់នូវព្រះមានព្រះភាគ និងព្រះធម៌ជាសរណៈ សូមព្រះមានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គទាំង ២ ថាជាឧបាសក ដូច្នេះក៏បាន ។*

ចូលដល់ដោយវិធីយល់ព្រមធ្វើជាសិស្ស ដូចព្រះមហាកស្សបៈ[1] ជាដើមថា **សត្ថា មេ ភន្តេ ភគវា សាវកោហមស្មិ** *បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក ដូច្នេះក៏បាន ។*

ចូលដល់ដោយវិធីបង្អោនខ្លួន ទៅក្នុងព្រះរតនត្រ័យនោះ ដូចព្រហ្មាយុ-ព្រាហ្មណ៍ជាដើម តាមបាលីថា **ឯវំ វុត្តេ ព្រហ្មាយុ ព្រាហ្មណោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស... ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សាតិ** *កាលបើឧត្តរមាណពពោលយ៉ាងនេះហើយ ព្រហ្មាយុព្រាហ្មណ៍ក៏ក្រោកអំពីអាសនៈ ធ្វើទូវសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ចំពោះត្រង់ទីដែលព្រះមាន-*

១- កស្សបៈ ក្នុងទីនេះ បានដល់ឧរុវេលកស្សបៈ

ព្រះភាគគង់ បន្ទូនូវឧទានវាចាអស់វារៈ ៣ ដងថា សូមថ្វាយបង្គំ ព្រះមាន-ព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ... សូមថ្វាយបង្គំ ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ដូច្នេះក៏បាន ។

ចូលដល់ដោយវិធីប្រគល់ខ្លួន ដូចយោគីបុគ្គលដែលខ្វល់ខ្វាយក្នុងកម្ម-ដ្ឋានក៏បាន ។

ចូលដល់ដោយវិសយ និងដោយកិច្ចច្រើនវិធី ដូចជាដោយវិធីកម្ចាត់ឧបក្កិលេសដោយការដល់សរណាគមន៍ ដូចព្រះអរិយបុគ្គលទាំងឡាយក៏បាន ។ អំពីការដល់សរណាគមន៍ និងរឿងបុគ្គលដែលចូលដល់សរណា-គមន៍ដូច ពោលមកនេះ ។

អំពីសរណៈជាថ៎ មិនជាថ៎ និងផលរបស់សរណាគមន៍

ឥឡូវនេះ នឹងសម្តែងសរណាគមន៍ជាថ៎ជាដើម ដែលខ្ញុំពោលថា នឹងសម្តែងសរណាគមន៍ជាថ៎ និងមិនជាថ៎ មួយអន្ទើដោយផល និងសរណៈដែលគួរដល់ ដូចតទៅនេះថា ការជាថ៎សរណាគមន៍របស់បុគ្គលដែលដល់សរណា-គមន៍យ៉ាងនេះ មាន ២ យ៉ាង គឺមានទោស និងមិនមានទោស ការជាថ៎សរណាគមន៍ព្រោះការស្លាប់ ឈ្មោះថា មិនមានទោស ការជាថ៎សរណាគមន៍ព្រោះងាកទៅរាប់អានសាសនាដទៃ និងប្រព្រឹត្តខុសក្នុងព្រះសាស្តា ឈ្មោះថាមានទោស ។ ការជាថ៎ទាំង ២ នោះ រមែងមានដល់ពួកបុថុជ្ជនប៉ុណ្ណោះ សរណៈនៃបុថុជ្ជនទាំងនោះ រមែងឈ្មោះថា សៅហ្មង ព្រោះប្រព្រឹត្តទៅដោយ

ការមិនដឹង ការសង្ស័យ និងការដឹងខុស ព្រោះប្រព្រឹត្តមិនអើពើជាដើមក្នុងព្រះពុទ្ធគុណទាំងឡាយ ឯព្រះអរិយបុគ្គល មិនមានសរណៈជាច់ទៅឡើយ ឯការសៅហ្មងនៃសរណៈក៏មិនមាន ដូចដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ឧទ្ទិសខ្ជួនចំពោះគ្រូជទៃ ដោយហេតុឯណា ហេតុនោះ មិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ គឺថា ហេតុនុ៎ះមិនដែលមានឡើយ ។ ឯពួកបុថុជ្ជនមិនទាន់ជាច់សរណៈដរាបណា ដរាបនោះ ក៏នៅឈ្មោះថា ជាអ្នកមានសរណៈមិនជាច់ ការជាច់សរណៈនៃបុថុជ្ជនទាំងនោះ រមែងមានទោស មានការសៅហ្មង និងឲ្យផលមិនគួរប្រាថ្នា ការជាច់សរណៈដែលមិនមានទោស ក៏មិនមានផល ព្រោះមិនមានវិបាក ។ ឯការមិនជាច់សរណៈ ពោលដោយផល ក៏រមែងឲ្យផលដែលគួរប្រាថ្នាតែម្យ៉ាង ដូចព្រះតម្រាស់ថា

ពួកជនណាមួយ បានដល់នូវព្រះពុទ្ធ ជាទីពឹងទីរឭកហើយ ពួកជននោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញពពួកនៃទេវតាមិនខាន ដូច្នេះ ។

ក្នុងសេចក្តីនោះ គប្បីជ្រាបអធិប្បាយនៃគាថាយ៉ាងនេះថា ជនពួកណាជាល់នូវសរណៈ ដោយការកាត់ឧបក្កិលេសបានដោយសរណគមន៍ ជនពួកនោះ នឹងមិនទៅអបាយ ។ ឯជនក្រៅអំពីនោះ នឹងមិនទៅអបាយ ក៏ដោយការដល់សរណៈ ។

សម្តែងសរណៈជាច់មិនជាច់ និងផលមានប្រមាណប៉ុណ្ណេះ ។

អំពីសរណៈដែលគួរដល់

ក្នុងការសម្តែងសរណៈដែលគួរដល់ បុគ្គលអ្នកចោទសួរ ពោលថា ក្នុងពាក្យថា ខ្ញុំដល់ព្រះពុទ្ធជាសរណៈ បុគ្គលណាដល់ព្រះពុទ្ធជាសរណៈ បុគ្គលនោះ នឹងគប្បីដល់ព្រះពុទ្ធ ឬសរណៈទាំង ២ ពាក្យ ការពោលតែពាក្យ ១ ក៏ឥតប្រយោជន៍ ព្រោះហេតុអ្វី ព្រោះមានតែកិរិយា គឺការដល់ មិនមានកម្ម ២ សេចក្តីពិត អ្នកគិតខាងអក្ខរសាស្ត្រ មិនបំណងកម្ម ២ ក្នុងសេចក្តីនេះ ដូចក្នុងពាក្យថា **អដំ គាមំ ឧតិ** ជាដើមដូច្នោះ ។

បើបុគ្គលអ្នកសួរពោលថា ការពោលពាក្យទាំង ២ មានតែប្រយោជន៍តែម្យ៉ាង ដូចក្នុងពាក្យថា **គច្ឆតោ បុព្វំ និសំ គច្ឆតិ បច្ឆិមំ និសំ** អ្នកគិតអក្ខរសាស្ត្រមិនបំណងយកយ៉ាងនោះទេ ព្រោះលោកមិនបំណងយកថា ព្រះពុទ្ធ និងសរណៈជាតួហេតុស្មើៗ គ្នា សេចក្តីពិត កាលបំណងថា ព្រះពុទ្ធ និងសរណៈទាំងនោះ ជាតួហេតុស្មើៗ គ្នាហើយ បុគ្គលមានចិត្តអាក់អន់ ចូលគាល់ព្រះពុទ្ធ ក៏នឹងគប្បីឈ្មោះថា ដល់នូវព្រះពុទ្ធ ដល់នូវសរណៈ សរណៈនោះធ្វើឲ្យផ្សេងទៅថា ព្រះពុទ្ធ ។ បុគ្គលនោះក៏ឈ្មោះថា ដល់នូវសរណៈទាំងអស់ ។

បើអ្នកសួរពោលថា លោកបំណងយកកាពដែលព្រះពុទ្ធ និងសរណៈជាតួហេតុស្មើៗ គ្នា ព្រោះបាលីថា **ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ** សរណៈនោះឯងក្សេម ផុតភ័យ សរណៈនោះឧត្តម មិនបំណងដូច្នោះទេ ព្រោះក្នុងបទគាថានោះ មានតែព្រះពុទ្ធជាសរណៈ សេចក្តីពិត ក្នុងបទគាថានោះ លោកបំណងដល់កាពដែលព្រះពុទ្ធ និងសរណៈជាតួហេតុស្មើៗ គ្នា

យ៉ាងនេះថា សរណៈក្សេមផង ឧត្តមផង ព្រោះពិចារណាដល់ព្រះរតនត្រ័យ មានព្រះពុទ្ធជាដើមនោះ ក្នុងភាពជាសរណៈ ដែលរាប់បានថា កម្ចាត់ភ័យ ដល់បុគ្គលដែលដល់សរណគមន៍បានពិត ឯក្នុងបាលីបទេសជនៃ កាលមានការសម្ពន្ធដោយបុគ្គលដល់សរណគមន៍ លោកក៏មិនបំណងភាពដែលព្រះពុទ្ធ និងសរណៈ ជាតួហេតុស្មើៗ គ្នា ព្រោះមិនសម្រេចជាសរណគមន៍ ដូច្នោះ ទើបពាក្យនេះ សាធកមិនបាន ។

បើអ្នកសួរពោលថា គួរសំដៅយកភាពដែលព្រះពុទ្ធ និងសរណៈ ជាតួហេតុស្មើៗ គ្នា ព្រោះសម្រេចជាសរណគមន៍ កាលមានការសម្ពន្ធដោយបុគ្គលដែលដល់សរណគមន៍បាន ក្នុងបាលីនេះថា **ឯតំ សរណមាគម្ម សព្ព-ទុក្ខា បមុច្ចតិ** *បុគ្គលអាស្រ័យសរណៈនោះ រមែងរួចផុតចាកទុក្ខទាំងពួង ដូច្នេះ មិនមែនដូច្នោះទេ ព្រោះជាប់ជំពាក់ដោយទោស ដែលពោលមកមុនហើយ ។ សេចក្តីពិត ក្នុងសេចក្តីនោះ គប្បីជាប់ជំពាក់ដោយទោសដែលពោលអំពីមុនថា កាលព្រះពុទ្ធ និងសរណៈជាតួហេតុស្មើៗ គ្នា បុគ្គលមានចិត្តអាក់អន់ អាស្រ័យសរណៈ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ក៏គប្បីរួចផុតចាកទុក្ខបានទាំងអស់ទៅហើយ តែមិនជាប់ជំពាក់ដោយទោសក៏មិនមែនដូច្នោះ ទើបពាក្យនោះលើកមកសាធកមិនបាន ។ គប្បីជ្រាបអធិប្បាយក្នុងសេចក្តីនោះយ៉ាងនេះថា សត្វទាំងឡាយកាលនឹងរួចផុតដោយអានុភាពរបស់ព្រះមានព្រះភាគ ដែលជាកល្យាណមិត្ត លោកក៏ពោលថា អាស្រ័យកល្យាណមិត្ត ទើបរួចផុតបាន ដូចក្នុងបាលីថា*

ម្នាលអានន្ទ សត្វទាំងឡាយ មានជាតិជាធម្មតា រមែងរួចចាកជាតិ ក៏ព្រោះអាស្រ័យនឹងតថាគតជាមិត្តល្អ យ៉ាងណា ក្នុងទីនេះ បុគ្គល កាលរួចផុតដោយអានុភាពនៃសរណៈ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ លោកក៏ពោលថា បុគ្គលអាស្រ័យសរណៈនេះ រមែងរួចផុតចាកទុក្ខទាំងពួង ដូច្នេះក៏យ៉ាងនោះ ។

ភាពដែលព្រះពុទ្ធជាគមនីយក៏មិនត្រូវ ភាពដែលសរណៈជាគមនីយក៏មិនត្រូវ ភាពដែលព្រះពុទ្ធ និងសរណៈទាំង ២ ជាគមនីយក៏មិនត្រូវ ដោយប្រការទាំងពួងយ៉ាងនេះ គមនីយរបស់បុគ្គលដល់នូវសរណគមន៍ ដែលលោកអធិប្បាយថា ខ្ញុំដល់វត្ថុដែលគប្បីប្រាថ្នា គួរពោលដល់ បន្ទាប់អំពីនោះ ក៏គួរពោលយុត្តិ គឺប្រការដែលត្រូវក្នុងរឿងនេះ ដូច្នោះ ខ្ញុំនឹងពោលយុត្តិដូចតទៅនេះថា

ក្នុងយុត្តិនោះ ព្រះពុទ្ធប៉ុណ្ណោះជាគមនីយ តែដើម្បីសម្តែងអាការ គឺការដល់ពាក្យពោលដល់សរណៈនោះ មានពាក្យថា ខ្ញុំដល់ព្រះពុទ្ធ ជាសរណៈ ព្រះពុទ្ធអង្គនោះជាសរណៈរបស់ខ្ញុំ ព្រះពុទ្ធអង្គនោះជាបាយណៈរបស់ខ្ញុំ ជាអ្នកកម្ចាត់ទុក្ខ ជាបុគ្គលទ្រទ្រង់នូវប្រយោជន៍ ខ្ញុំដល់ ខ្ញុំគប់រក ខ្ញុំសេព ខ្ញុំចូលជិតព្រះពុទ្ធអង្គនោះ ដោយបំណងដូចពោលមកនេះ ឬពោលថា ខ្ញុំដឹងយ៉ាងនេះ ពិតហើយ គតិជាប្រយោជន៍របស់ធាតុពួកណា សូម្បីការដឹង ក៏ជាប្រយោជន៍របស់ធាតុទាំងនោះ ។

បើអ្នកសួរ ពោលថា សេចក្តីនោះ មិនត្រូវ ព្រោះមិនប្រកប **៥តិ** *សព្ទ

ពាក្យចោទនោះក៏មិនត្រឹមត្រូវ យុត្តិដែលត្រឹមត្រូវក្នុងរឿងនោះគប្បីមានដូច្នេះ ថា បើសេចក្តីក្នុងរឿងនោះគប្បីមានយ៉ាងនេះសោត បន្ទាប់អំពីនោះ ក៏គប្បីត្រូវប្រកប **៧តិ** *សព្ទ ដូចក្នុងប្រយោគទាំងឡាយជាដើមថា* **អនិច្ចំ រូបំ អនិច្ចំ រូបន្តិ យថាភូតំ បជានាតិ** *រមែងដឹងច្បាស់នូវរូបដែលមិនទៀង តាមសេចក្តីពិតថា រូបមិនទៀង ដូច្នេះ។ តែ* **៧តិ** *សព្ទ លោកមិនប្រកបទ្បើយ ព្រោះដូច្នោះ ទើបការចោទសួរនោះមិនត្រឹមត្រូវ ព្រោះហេតុអ្វី ព្រោះអត្ថនៃ* **៧តិ** *សព្ទ មាននៅក្នុងខ្លួននោះហើយ អត្ថនៃ* **៧តិ** *សព្ទក្នុងទីនេះ ក៏មានព្រម ដូចក្នុងប្រយោគទាំងឡាយជាដើមយ៉ាងនេះថា* **យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ** *បុគ្គលណាជល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាសរណៈ ដូច្នេះ តែមិនមែនត្រូវប្រកប* **៧តិ** *ក្នុងទីគ្រប់អន្លើ ព្រោះមានការនៅព្រមក្នុងខ្លួនហើយ បណ្ឌិតគប្បីជ្រាបអត្ថនៃ* **៧តិ** *សព្ទ សូម្បីមិនបានប្រកប ដូចប្រកបក្នុងទីនោះ ទាំងក្នុងទីដទៃដែលមានកំណើតយ៉ាងនេះ ព្រោះដូច្នោះ ទើប* **៧តិ** *សព្ទ មិនមានទោស។ បើអ្នកសួរ ពោលថា ពាក្យណាដែលអ្នកពោលថា ដើម្បីសម្តែងអាការ គឺជល់ ទើបត្រូវពោលប្រារព្ធសរណៈ ដូច្នេះ ពាក្យនោះក៏មិនត្រឹមត្រូវ ព្រោះសរណៈប៉ុណ្ណោះ ជាគមនីយ គឺវត្ថុដែលគួរដល់ បានក្នុងបាលីជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបព្វជ្ជា ... ដោយត្រៃសរណាគមន៍ទាំងឡាយនេះ ដូច្នេះ ពាក្យដែលខ្ញុំពោលនោះ មិនមែនមិនត្រឹមត្រូវ ព្រោះហេតុអ្វី ព្រោះពាក្យនោះមានការនៅព្រមក្នុងខ្លួន។ សេចក្តីពិត អត្ថនៃ* **៧តិ** *សព្ទនោះ ក៏មាន*

ព្រមក្នុងពាក្យទាំងនោះឯង ព្រោះមិនប្រកប **៨តិ** *សព្ទ ដូចពាក្យមុន ក៏គប្បីឃើញដូចប្រកប* **៨តិ** *សព្ទ ក្រៅអំពីនេះ ក៏គប្បីជាប់ជំពាក់ដោយទោស ដែលពោលមក អំពីមុននោះឯង ព្រោះដូច្នោះ គប្បីកាន់យកតាមដែលលោកប្រៀនប្រដៅប៉ុណ្ណោះ ។*

សម្តែងវត្ថុដែលគួរដល់ ដូចពោលមកដូច្នេះ

អំពីសរណៈ គឺព្រះធម៌ និងព្រះសង្ឃ

ឥឡូវនេះ នឹងពោលអធិប្បាយតទៅ ក្នុងពាក្យដែលខ្ញុំពោលទុកថា ក្នុងសរណៈទាំង ២ មាន **ធម្មំ សរណំ** *ជាដើម ក៏ដឹងហើយថា មានន័យនេះដូចគ្នា ។ ន័យនៃការពណ៌នាអត្ថនេះ ខ្ញុំពោលក្នុងពាក្យនេះថា* **ពុទ្ធំ សរណំ គច្ឆាមិ** *ក៏គប្បីជ្រាបន័យនៃការពណ៌នាសេចក្តីនោះ ក្នុង ២ បទនេះថា* **ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ ។** *ពិតហើយ ក្នុងសេចក្តីនោះ ពោលដោយអត្ថ និងព្យញ្ជនៈរបស់ព្រះធម៌ និងព្រះសង្ឃ ក៏មានត្រឹមតែការចង្អុលបង្ហាញប៉ុណ្ណោះ ដែលមិនដូចគ្នាក្រៅអំពីនោះក៏ដូចគ្នា ដូចដែលពោលមកហើយនោះឯង ព្រោះនឹងពោលអធិប្បាយចំពោះទីដែលមិនដូចគ្នា ក្នុងព្រះធម៌ និងព្រះសង្ឃនេះ ដូច្នេះ អាចារ្យមួយពួកពោលថា មគ្គ ផល និព្វាន ឈ្មោះថា ព្រះធម៌ ។ ឧន្តិ ការពេញចិត្ត ឬមតិរបស់ពួកយើងថា មគ្គ និងវិរាគៈប៉ុណ្ណោះ ឈ្មោះថា ព្រះធម៌ក្នុងអត្ថនេះ ព្រោះទ្រទ្រង់បុគ្គលចម្រើនមគ្គផល និងដែលធ្វើឲ្យជាក់ច្បាស់ព្រះនិព្វានហើយ ដោយមិនឲ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ និងធ្វើឲ្យស្រឡះចិត្តយ៉ាងក្រៃលែង សូមលើកយកអគ្គប្បសាទ-*

សូត្រនោះឯងជាសាធក សមដូចព្រះមានព្រះភាគត្រាស់ក្នុងអគ្គប្បសាទសូត្រ នោះយ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ ពួកសង្ខតធម៌ ធម៌ដែលបច្ច័យតាក់តែងទាំងប៉ុន្មាន មគ្គប្រកបដោយអង្គ ៨ ជ័ប្រសើរ ប្រាកដជាប្រសើរជាង ពួកសង្ខតធម៌ទាំងនោះ ។

ក្រុមរបស់បុគ្គលទាំងឡាយ ដែលដល់ព្រមដោយអរិយមគ្គ ៤ យ៉ាង និងដែលមានខន្ធសន្តានអប់រំក្រៃលែង ដោយសាមញ្ញផល ៤ ឈ្មោះថា ព្រះសង្ឃ ព្រោះរួមគ្នាដោយការរួមទិដ្ឋិ និងសីល សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកយល់សេចក្តីនោះដូចម្តេច ធម៌ទាំងឡាយដែលតថាគតត្រាស់ដឹងហើយ សម្តែងហើយ ដល់អ្នកទាំងឡាយ ដូចជាសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ម្នាលអានន្ទ អ្នកដែលឃើញភិក្ខុពីររូបមានវាទៈផ្សេងគ្នា ក្នុងធម៌ទាំងឡាយនេះដែរឬ ។

ពិតហើយ ព្រះសង្ឃដោយបរមត្ថ ដែលបុគ្គលគប្បីដល់ជាសរណៈ ក្នុងព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ថា ព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគ ជាអាហុនេយ្យបុគ្គល ជាបាហុនេយ្យបុគ្គល ជាទក្ខិណេយ្យបុគ្គល ជាអញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ សរ-ណគមន៍របស់បុគ្គលដែលដល់នូវសរណៈនោះ រមែងមិនជាច់ មិនសៅហ្មង

ដោយការធ្វើការថ្វាយបង្គំជាដើមក្នុងភិក្ខុសង្ឃ ឬភិក្ខុនីសង្ឃពួកជទៃ ឬសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ឬសម្មតិសង្ឃ មានសង្ឃចតុវគ្គជាដើម ឬក្នុងបុគ្គលណាមួយ ដែលបួសឧទ្ទិសចំពោះព្រះមានព្រះភាគ ការផ្សែងគ្នាក្នុងសង្ឃសរណៈ ដែលមានប្រមាណប៉ុណ្ណេះ ចំណែកវិធី គឺការជាប់ និងមិនជាប់ជាដើមនៃសរណាគមន៍នេះ និងទី ២ ក្រៅអំពីដែលពោលហើយ គប្បីជ្រាបតាមន័យដែលពោលមកអំពីមុនហើយ កិច្ចពណ៌នាសេចក្តីក្នុងសរណៈ ២ ថា **ធម្មំ សរណំ** *ជាដើម ដែលធ្លាប់ដឹងមកហើយ ក៏នយនេះដូចគ្នា ។*

អំពីសរណៈ គឺព្រះធម៌ និងព្រះសង្ឃមានប្រមាណប៉ុណ្ណេះ

អធិប្បាយ ហេតុក្នុងការកំណត់តាមលំដាប់

ក្នុងពាក្យនេះថា នឹងអធិប្បាយហេតុក្នុងការកំណត់តាមលំដាប់ ឥឡូវនេះ នឹងអធិប្បាយហេតុ ក្នុងការកំណត់តាមលំដាប់ យ៉ាងនេះថា ក្នុងពាក្យដល់សរណៈទាំង ៣ នោះ លោកប្រកាសព្រះពុទ្ធជាលំដាប់ដំបូង ព្រោះជាបុគ្គលប្រសើរជាងសត្វទាំងពួង ប្រកាសព្រះធម៌លំដាប់បន្ទាប់មក ព្រោះជាដែនកើតនៃព្រះពុទ្ធទាំងនោះ និងព្រោះជាធម៌ដែលព្រះពុទ្ធអង្គនោះ ទ្រង់នាំចេញទូន្មានហើយ ប្រកាសព្រះសង្ឃក្នុងលំដាប់ចុងក្រោយ ព្រោះជាបុគ្គលទ្រទ្រង់ទុកនូវព្រះធម៌នោះ និងព្រោះសេពព្រះសទ្ធម្ម ម្យ៉ាងទៀត លោកប្រកាសព្រះពុទ្ធជាលំដាប់ដំបូង ព្រោះទ្រង់ប្រកបសត្វទាំងពួងទុកក្នុងហិតប្រយោជន៍ ប្រកាសព្រះធម៌ក្នុងលំដាប់បន្ទាប់ ព្រោះជាដែនកើតនៃព្រះពុទ្ធនោះ និងព្រោះជាធម្មហិតាយ គឺធម៌ដែលជាប្រយោជន៍ដល់សត្វទាំងពួង ប្រកាសព្រះសង្ឃ

ក្នុងលំដាប់ចុងក្រោយ ព្រោះព្រះសង្ឃ ជាអ្នកបដិបត្តិដើម្បីសម្រេចហិត-ប្រយោជន៍ និងមានហិតប្រយោជន៍ដែលសម្រេចហើយ កំណត់ដោយភាព ជាសរណៈ ។

ប្រកាសដោយឧបមា

ឥឡូវនេះ នឹងពោលអធិប្បាយពាក្យដែលនឹងប្រកាសព្រះសរណត្រ័យ ដោយឧបមាទាំងឡាយ ក្នុងពាក្យនោះ ព្រះពុទ្ធប្រៀបដូចព្រះចន្ទពេញវង់ ព្រះធម៌ប្រៀបដូចក្រុមនៃរស្មីរបស់ព្រះចន្ទ ព្រះសង្ឃប្រៀបដូចទ្វីបលោក ដែលស្កប់ស្កល់ដោយរស្មីរបស់ព្រះចន្ទពេញវង់ ដែលធ្វើឲ្យកើតឡើង ។ ព្រះពុទ្ធប្រៀបដូចព្រះអាទិត្យជះពន្លឺស្រទន់ ព្រះធម៌ដូចពោល ប្រៀបដូចសំណាញ់នៃរស្មីរបស់ព្រះអាទិត្យនោះ ព្រះសង្ឃប្រៀបដូចទ្វីបលោក ដែលព្រះអាទិត្យនោះកម្ចាត់ងងឹតហើយ ។ ព្រះពុទ្ធប្រៀបដូចអ្នកជុតព្រៃ ព្រះធម៌ជាគ្រឿងជុតព្រៃ គឺកិលេស ប្រៀបដូចភ្លើងជុតព្រៃ ព្រះសង្ឃដែលជាបុញ្ញក្ខេត្ត ព្រោះជុតកិលេសបានហើយ ប្រៀបដូចភូមិភាគដែលជាខេត្ត ព្រោះជុតព្រៃអស់ហើយ ព្រះពុទ្ធប្រៀបដូចភ្លៀងធំ ព្រះធម៌ប្រៀបដូចទឹកភ្លៀង ព្រះសង្ឃអ្នករម្ងាប់ធូលី គឺកិលេស ប្រៀបដូចជនបទដែលរម្ងាប់លម្អងធូលី ព្រោះភ្លៀងធ្លាក់ ។ ព្រះពុទ្ធប្រៀបដូចសារថី ព្រះធម៌ប្រៀបដូចឧបាយក្នុងការទូន្មានសេះអាជានេយ្យ ព្រះសង្ឃប្រៀបដូចហ្វូងសេះអាជានេយ្យ ដែលទូន្មានល្អហើយ ។ ព្រះពុទ្ធ ប្រៀបដូចសល្យវេជ្ជ គឺពេទ្យវះ ព្រោះទ្រង់ជកព្រួញ គឺទិដ្ឋិបានអស់ ព្រះធម៌ ប្រៀបដូចឧបាយដែលជកព្រួញចេញបាន ព្រះសង្ឃ ជាអ្នកជកព្រួញ

គឺទិដ្ឋិចេញហើយ ប្រៀបដូចជនដែលត្រូវដកព្រួញចេញហើយ ។ ម្យ៉ាងទៀត ព្រះពុទ្ធប្រៀបដូចចក្ខុវេជ្ជ ព្រោះទ្រង់បកក្លាសមោហៈចេញបានហើយ ព្រះធម៌ ប្រៀបដូចឱជាយជាគ្រឿងបកក្លាសរបស់ភ្នែក ព្រះសង្ឃ ជាអ្នកមានក្លាសបកចេញហើយ ជាអ្នកមានភ្នែក គឺញាណដ៏ស្រស់ថ្លា ប្រៀបដូចជនដែលបកភ្នែកហើយ មានភ្នែកស្រស់ថ្លា ។ ម្យ៉ាងទៀត ព្រះពុទ្ធប្រៀបដូចពេទ្យដ៏ឈ្លាស ព្រោះទ្រង់អាចកម្ចាត់ព្យាធិ គឺកិលេស ព្រមទាំងអនុស័យចេញបាន ព្រះធម៌ ប្រៀបដូចកេសជ្ជៈ ដែលទ្រង់ផ្សំត្រឹមត្រូវហើយ ព្រះសង្ឃមានព្យាធិ គឺកិលេស និងអនុស័យរម្ងាប់ហើយ ប្រៀបដូចពួកជនដែលព្យាធិរម្ងាប់ហើយ ព្រោះការដាក់ថ្នាំ ។

ម្យ៉ាងទៀត ព្រះពុទ្ធ ប្រៀបដូចអ្នកចង្អុលផ្លូវ ព្រះធម៌ ប្រៀបដូចផ្លូវល្អ ឬផ្លូវដែលផុតភ័យ ព្រះសង្ឃ ប្រៀបដូចអ្នកដំណើរដល់ទីដែលផុតភ័យ ព្រះពុទ្ធ ប្រៀបដូចនាយទូកដែលល្អ ព្រះធម៌ ប្រៀបដូចទូក ព្រះសង្ឃប្រៀបដូចអ្នកដំណើរដល់ត្រើយ ។ ព្រះពុទ្ធ ប្រៀបដូចព្រៃហិមពាន្ត ព្រះធម៌ប្រៀបដូចឱសថ ដែលកើតក្នុងព្រៃហិមពាន្តនោះ ព្រះសង្ឃ ប្រៀបដូចបុគ្គលមិនមានរោគ ព្រោះប្រើថ្នាំ ។ ព្រះពុទ្ធ ប្រៀបដូចអ្នកឲ្យទ្រព្យ ព្រះធម៌ប្រៀបដូចទ្រព្យ ព្រះសង្ឃ អ្នកបានអរិយទ្រព្យមកដោយប្រពៃ ប្រៀបដូចជនដែលបានទ្រព្យតាមបំណង ។ ព្រះពុទ្ធ ប្រៀបដូចអ្នកចង្អុលកំណប់ទ្រព្យ ព្រះធម៌ប្រៀបដូចកំណប់ទ្រព្យ ព្រះសង្ឃ ប្រៀបដូចជនដែលបានកំណប់ទ្រព្យ ។

ម្យ៉ាងទៀត ព្រះពុទ្ធជាវីរបុរស ប្រៀបដូចអ្នកឲ្យនូវការមិនមានភ័យ ព្រះ

ធម៌ ប្រៀបដូចមិនមានភ័យ ព្រះសង្ឃ អ្នកកន្ទងបង់នូវភ័យគ្រប់យ៉ាង ប្រៀប ដូចជនដែលដល់នូវការមិនមានភ័យ ។ ព្រះពុទ្ធ ប្រៀបដូចអ្នកលួងលោម ព្រះធម៌ ប្រៀបដូចការលួងលោម ព្រះសង្ឃ ប្រៀបដូចបុគ្គលដែលបានធូរ ស្បើយ ព្រោះការលួងលោម ។ ព្រះពុទ្ធ ប្រៀបដូចមិត្តល្អ ព្រះធម៌ ប្រៀប ដូចពាក្យប្រៀនប្រដៅ ដែលជាហិតប្រយោជន៍ ព្រះសង្ឃ ប្រៀបដូចអ្នកជួប នូវប្រយោជន៍ខ្លួន ព្រោះប្រកបហិតប្រយោជន៍ ។ ព្រះពុទ្ធ ប្រៀបដូចអណ្តូង កើតទ្រព្យ ព្រះធម៌ ប្រៀបដូចទ្រព្យដែលជាសារៈ ព្រះសង្ឃ ប្រៀបដូចជន ដែលប្រើទ្រព្យជាសារៈ ។ ព្រះពុទ្ធ ប្រៀបដូចអ្នកស្រពស្រង់ព្រះកុមារ ព្រះ ធម៌ ប្រៀបដូចទឹកដែលស្រពស្រង់លើព្រះសិរសា ព្រះសង្ឃជាអ្នកស្រព ស្រង់ល្អហើយដោយទឹក គឺព្រះសទ្ធម្ម ប្រៀបដូចពួកព្រះរាជកុមារដែលស្រង់ ល្អហើយ ។ ព្រះពុទ្ធ ប្រៀបដូចជាងអ្នកធ្វើគ្រឿងអលង្ការ ព្រះធម៌ ប្រៀប ដូចគ្រឿងអលង្ការ ព្រះសង្ឃដែលប្រដាប់ដោយព្រះសទ្ធម្ម ប្រៀបដូចពួកព្រះ រាជឱរសដែលប្រដាប់ហើយ ។ ព្រះពុទ្ធ ប្រៀបដូចដើមចន្ទន៍ ព្រះធម៌ ប្រៀប ដូចក្លិនដែលកើតអំពីដើមចន្ទន៍នោះ ព្រះសង្ឃ រម្ងាប់ការក្តៅក្រហាយបានឥត សេសសល់ ព្រោះឧបភោគ គឺប្រើប្រាស់ព្រះសទ្ធម្ម ប្រៀបដូចជនដែល រម្ងាប់ការក្តៅ ព្រោះប្រើលម្អិតខ្លឹមចន្ទន៍ ។ ព្រះពុទ្ធ ប្រៀបដូចបិតាប្រគល់ មត៌កដោយធម៌ ព្រះធម៌ ប្រៀបដូចមត៌ក ព្រះសង្ឃអ្នកបន្តមត៌ក គឺព្រះសទ្ធម្ម ប្រៀបដូចពួកបុត្រដែលបន្តមត៌ក ។ ព្រះពុទ្ធ ប្រៀបដូចផ្កាបទុមដែលរីក ព្រះ ធម៌ ប្រៀបដូចទឹកដមដែលកើតអំពីផ្កាបទុមដែលរីកនោះ ព្រះសង្ឃ ប្រៀប

ដូចពួកភមរដែលស្រូបទឹមដមនោះ ។ គប្បីប្រកាសត្រៃសរណៈនោះ ដោយ ឧបមាទាំងឡាយ ដូចពោលមកនេះចុះ ។

មាតិកានៃកថាពណិនាសេចក្តីដែលលើកឡើងតាំងទុកខាងដើម ដោយ ៤ គាថាថា ត្រៃសរណៈអ្នកណាពោល ពោលក្នុងទីណា ពោលកាលណា ពោលព្រោះហេតុអ្វីជាដើម ក៏ឈ្មោះថា ប្រកាសហើយ ដោយអត្ថ ដោយកថា មានប្រមាណប៉ុណ្ណេះឯង ។

កថាពណិនា ត្រៃសរណៈ ចប់

សុត្តន្តបិដក

ទុជ្ជកចាម៖ សិក្ខាបទ ៧០

[២] ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការសម្ចាប់សត្ត ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការកាន់យក នូវវត្ថុដែលគេមិនបានឲ្យ ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការប្រព្រឹត្តនូវធម៌មិនប្រសើរ ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការពោលនូវពាក្យកុហក ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរ

ចាកការបរិភោគនូវភោជនាហារក្នុងកាលខុស ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការរាំ ច្រៀង ប្រគំ និងការមើលល្បែងផ្សេងៗ ដែលជាសត្រូវដល់កុសលធម៌ ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការទ្រទ្រង់ការប្រដាប់ និងការតាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រង គ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកសេនាសនៈដ៏ខ្ពស់ (ហួសប្រមាណ) និងសេនាសនៈដ៏ប្រសើរ ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការកាន់យកនូវមាស និងប្រាក់ ។

សិក្ខាបទ ១០ ចប់

អដ្ឋកថា

ពណ៌នាសិក្ខាបទ

[២] *កាលសម្តែងការចូលកាន់ព្រះសាសនា ដោយការដល់សរណគមន៍យ៉ាងនេះហើយ ដើម្បីពណ៌នាបាឋៈដែលពោលអំពីសិក្ខាបទ ដែលតាំងជានិក្ខេបបទ ដើម្បីសម្តែងសិក្ខាបទទាំងឡាយ ដែលឧបាសក ឬបព្វជិតអ្នកចូលមកកាន់ព្រះសាសនា គប្បីសិក្សាជាលំដាប់ដំបូង ឥឡូវនេះ ខ្ញុំនឹងពោលមាតិកាដូចតទៅនេះ*

សិក្ខាបទទាំងនេះ បុគ្គលណាពោល ពោលទីណា ពោលអំពីពេលណា ពោលព្រោះហេតុអ្វី ចាំបាច់កំណត់ពោលធ្វើន័យនោះ ដោយការប្លែកនៃសិក្ខាបទទូទៅ ចាំបាច់កំណត់ពោលដែលជាបកតិវជ្ជផង និងបណ្ណត្តិវជ្ជផង ធ្វើនូវការចង្អុលបង្ហាញន័យទូទៅគ្រប់សិក្ខាបទ ដោយព្យញ្ជនៈ និងអត្ថរបស់បទទាំងឡាយ ។

តែក្នុងសិក្ខាបទ ៥ ខាងដើម គប្បីជ្រាបវិនិច្ឆ័យដោយប្រការសការប្លែកគ្នានៃសិក្ខាបទទូទៅ ដោយភាពតែមួយ និងភាពផ្សេងគ្នាជាដើម តាំងអំពីបាណាតិបាតជាដើមទៅ ដោយអារម្មណ៍ ការសមាទាន និងការជាប់ ដោយការមានទោសច្រើន ដោយប្រយោគ អង្គ និងសមុដ្ឋាន ដោយវេទនា មូល និងកម្ម ដោយការវៀរ និងដោយផល ។

យុត្តិ គឺការត្រឹមត្រូវអំពីកិច្ចពណ៌នាសិក្ខាបទ ៥ ខាងដើម គប្បីនាំមកប្រើក្នុង ៥ សិក្ខាបទក្រោយ គប្បីពោលសិក្ខាបទមួយប្រការៗ គប្បីជ្រាបថាសិក្ខាបទមានដោយអាក្រក់ជាដើមផងដែរ ។

ក្នុងមាតិកា ១០ នោះ សិក្ខាបទ មានបាណាតិបាតាវេរមណីជាដើមនោះ ព្រះមានព្រះភាគមួយអង្គគ្រាស់ មិនមែនសាវ័ក ។ ពិតហើយ ព្រះមានព្រះភាគទ្រង់ចេញអំពីក្រុងកបិលពស្តុដល់ក្រុងសាវត្ថី ទ្រង់ឲ្យវាហុលបព្វជ្ជាហើយ ក្នុងវត្តជេតពនអារាមរបស់អនាថបិណ្ឌិក នាក្រុងសាវត្ថី គ្រាស់សិក្ខាបទ ១០ នោះ ដើម្បីកំណត់សិក្ខាបទសម្រាប់សាមណេរទាំងឡាយ សមដូចលោកពោលពាក្យនេះថា

លំដាប់អំពីនោះមក ព្រះដ៏មានបុណ្យទ្រង់គង់ក្នុងក្រុងកបិលវត្ថុ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់យាងសំដៅទៅកាន់ចារិកឯក្រុងសាវត្ថី ទ្រង់ត្រាច់ទៅកាន់ចារិកដោយលំដាប់ៗ ហើយ ទ្រង់បានទៅដល់ក្រុងសាវត្ថីនោះ ។ តាមតំណាលក្នុងនិទានថា ព្រះដ៏មានបុណ្យទ្រង់គង់ក្នុងជេតវនារាមរបស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។បេ។ គ្រាតពីនោះមក សាមណេរទាំងឡាយបានត្រិះរិះសេចក្តីនេះនឹងគ្នាថា សិក្ខាបទរបស់យើងទាំងឡាយមានប៉ុន្មានហ្ន៎ មា៉ងទៀត យើងទាំងឡាយ គួរសិក្សាក្នុងវិនយដូចម្តេចខ្លះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសិក្ខាបទទាំងឡាយ ១០ ដល់សាមណេរទាំងឡាយ មា៉ងទៀត អនុញ្ញាតឲ្យសាមណេរទាំងឡាយ សិក្សាក្នុងសិក្ខាបទទាំងឡាយ ១០ នោះ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ១ ។បេ។ ចេតនាជាហេតុវៀរចាកកិរិយាទទួលកាន់យកនូវមាស និងប្រាក់ ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសិក្ខាបទទាំង ១០ នេះដល់សាមណេរទាំងឡាយ មា៉ងទៀត អនុញ្ញាតឲ្យពួកសាមណេរសិក្សាក្នុងសិក្ខាបទទាំងឡាយ ១០ នេះ ដូច្នេះ ។

សិក្ខាបទទាំង ១០ នោះ គប្បីជ្រាបថា លោកលើកឡើងប្រៀនប្រដៅដោយគន្លងព្រះសូត្រថា **សមាធាយ សិក្ខតិ សិក្ខាបទេសុ** *សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ និងដោយគន្លងបាឋៈ ដែលលោកបានសម្តែងក្នុងសរណាគមន៍យ៉ាងនេះថា* **ចាណាតិចាតា វេរមណីសិក្ខាបទំ សមាធិយាមិ**

ខ្ញុំសមាទានសិក្ខាបទ គឺចេតនាវៀរចាកសម្លាប់សត្វជាដើម គប្បីជ្រាបន័យដែលថា សិក្ខាបទទាំងនេះ អ្នកណាពោល ពោលទីណា ពោលអំពីពេលណា ពោលព្រោះហេតុអ្វី នឹងពោលន័យនេះប៉ុណ្ណោះសិន ។

ការប្រែកគ្នានៃសិក្ខាបទ

បណ្តាសិក្ខាបទទាំងនោះ សិក្ខាបទទី ៤-៥ ពីរសិក្ខាបទខាងដើម ទូទៅដល់ឧបាសកផង សាមណេរផង ព្រោះជានិច្ចសីល តែបើពោលដោយឧបោសថ សីលរបស់ពួកឧបាសក វៀរសិក្ខាបទក្រោយបង្អស់ ព្រោះសិក្ខាបទទី ៧-៨ រួមចូលគ្នាតែមួយ សិក្ខាបទទាំងអស់ ក៏ទូទៅដល់សាមណេរទាំងឡាយ ចំណែកសិក្ខាបទក្រោយជាពិសេស សម្រាប់តែសាមណេរប៉ុណ្ណោះ គប្បីជ្រាបកំណត់ដោយការប្រែកគ្នានៃសិក្ខាបទទូទៅ ដូចពោលមក ដូច្នេះ គប្បីកំណត់បកតិវជ្ជៈ និងបណ្ណត្តិវជ្ជៈយ៉ាងនេះ គឺបណ្តាសិក្ខាបទទាំងនោះ សិក្ខាបទ ៥ ខាងដើម កំណត់ដោយចេតនា វៀរចាកបកតិវជ្ជៈរបស់បាណាតិបាតជាដើម ព្រោះមានកុសលចិត្តជាសមុដ្ឋាន ដោយចំណែកមួយ សិក្ខាបទក្រៅអំពីនោះ កំណត់ដោយចេតនា វៀរចាកបណ្ណត្តិវជ្ជៈ ។

ចង្អុលបង្ហាញបទទូទៅ

ព្រោះហេតុដែលបណ្តាបទទាំងនោះ បទថា **វេរមណី សិក្ខាបទំ សមាទិយាមិ** ជាបទទូទៅទាំងអស់ ដូច្នោះ គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនោះទូទៅ ទាំងដោយព្យញ្ជនៈ ទាំងដោយអត្ថដូចតទៅនេះ

ក្នុងបទទាំងនោះ គប្បីជ្រាបដោយព្យញ្ជនៈមុន ឈ្មោះថា **វេរមណី** *ព្រោះវៀរចាកពៀរ អធិប្បាយថា លះបង់ បន្ទោបង់នូវពៀរ គឺធ្វើឲ្យអស់ឲ្យដល់នូវការមិនមាន ។ ម្យ៉ាងទៀត បុគ្គលរមែងវៀរចាកពៀរដោយចេតនានោះ ហេតុនោះ ចេតនានោះ ឈ្មោះថា* **វេរមណី** *ព្រោះយក* **វិ** *អក្ខរៈជា* **វេ** *អក្ខរៈ ។ ដោយហេតុនោះឯង ទើបក្នុងពាក្យនេះ ពុទ្ធបរិស័ទសូត្រជា ២ យ៉ាងថា* **វេរមណីសិក្ខាបទំ** *ឬ* **វិរមណីសិក្ខាបទំ** *។ ឈ្មោះថា* **សិក្ខា** *ព្រោះបុគ្គលគប្បីសិក្សា ឈ្មោះថា* **បទ** *ព្រោះជាគ្រឿងដល់បទនៃសិក្ខា ។ បទនៃសិក្ខា ឈ្មោះថា* **សិក្ខាបទ** *អធិប្បាយថា ឧបាយជាគ្រឿងដល់សិក្ខា ។ ម្យ៉ាងទៀត លោកអធិប្បាយថា ជាមូល ជាទីអាស្រ័យ ជាទីតាំង ។ សិក្ខាបទ គឺចេតនាជាគ្រឿងវៀរ ឈ្មោះថា* **វេរមណីសិក្ខាបទ** *ឬ* **វិរមណីសិក្ខាបទ** *តាមន័យទី ២ ។ ខ្ញុំកាន់យកដោយប្រពៃ ឈ្មោះថា* **សមាទិយាមិ** *លោកអធិប្បាយថា ខ្ញុំកាន់យកដោយបំណងមិនកន្ទងល្មើស ព្រោះជាបុគ្គលធ្វើសិក្ខាបទមិនឲ្យជាកំណាត់ មិនឲ្យដាច់ មិនឲ្យពព្រុសពពាល ។*

តែកាលពោលដោយអត្ថ បទថា **វេរមណី** *បានដល់ វិរតិ ប្រកបដោយចិត្តដែលជាកាមាវចរកុសល ។ វិរតិរបស់បុគ្គលដែលវៀរចាកបាណាតិបាត លោកពោលទុកក្នុងវិភង្គ ដោយន័យជាដើមយ៉ាងនេះថា ចេតនាវៀរចេតនាហាមឃាត់ វៀរផ្តាច់ វៀរបង់ មិនធ្វើ មិនប្រព្រឹត្ត មិនកន្ទង មិនកន្ទងល្មើសព្រំដែន ការទាញស្ថានដោយអរិយមគ្គ ឈ្មោះថា* **សេតុ** *អំពីបាណាតិបាត ក្នុងសម័យនោះឯណា ។ ធម្មតាវេរមណីនោះ ជាលោកុត្តរមានក៏ពិត*

តែក្នុងទីនេះ ក៏គួរជាវេរមណីដែលប្រព្រឹត្តទៅដោយការសមាទាន ព្រោះបុគ្គលសមាទានពោលថា **សមាទិយាមិ** ព្រោះដូច្នោះ ទើបវេរមណីជាលោកុត្តរនោះ មិនមាន ខ្ញុំពោលថា វិរតិ ប្រកបដោយចិត្តដែលជាកាមាវចរកុសល ។

បទថា **សិក្ខា** បានដល់ សិក្ខា ៣ គឺអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា តែក្នុងទីនេះ សីល គឺសម្បត្តវិរតិ វិបស្សនាជាចំណែកលោកិយ រូបជ្ឈាន និងអរូបជ្ឈាន និងអរិយមគ្គ លោកចំណងថា សិក្ខា ក្នុងបទថា **សិក្ខា** នេះ ដូចលោកពោលថា

ធម៌ទាំងឡាយដូចម្តេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ច្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ មានរូបជាអារម្មណ៍ក្តី ។បេ។ ក្នុងសម័យនោះ ការប៉ះពាល់ ក៏កើតមាន ។បេ។ ការមិនរាយមាយ ក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា **សិក្ខា** ។

ធម៌ទាំងឡាយដូចម្តេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា បុគ្គលចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ។បេ។ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ។បេ។ ចូលកាន់បញ្ចមជ្ឈាន ។បេ។ ការមិនរាយមាយក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា **សិក្ខា** ។

ធម៌ទាំងឡាយដូចម្តេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា បុគ្គលចម្រើនមគ្គ ដើម្បីកើតក្នុងអរូបភព ។បេ។ ចូលកាន់នេវសញ្ញានាសញ្ញា-

យតនជ្ឈាន ។បេ។ ការមិនរាយមាយក៏កើតមាន ធម៌ទាំង៦ប្បាយនេះ ឈ្មោះ ថា **សិក្ខា** ។

ធម៌ទាំង៦ប្បាយដូចម្តេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា បុគ្គល ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ។បេ។ ការមិនរាយមាយក៏កើតមាន ធម៌ទាំង៦ប្បាយនេះ ឈ្មោះថា **សិក្ខា** ។

បទ គឺឧបាយជាគ្រឿងដល់ ម្យ៉ាងទៀត ជាមូល ជាទីអាស្រ័យ ជា ទីតាំងនៃសិក្ខាណាមួយ បណ្តាសិក្ខាទាំងនោះ ហេតុនោះ ទើបឈ្មោះថា សិក្ខាបទ សមដូចលោកពោលដូច្នេះថា ម្នាលភិក្ខុទាំង៦ប្បាយ ភិក្ខុអាស្រ័យ សីល តាំងស៊ប់នៅក្នុងសីល កាលចម្រើនទូវពោជ្ឈង្គៈ ... យ៉ាងនេះជាដើម ។ គប្បីធ្វើការចង្អុលបង្ហាញដោយព្យញ្ជនៈ ដោយអត្ថ ដោយសាធារណៈ ដោយបទ ក្នុងបទទាំងនេះ ដោយប្រការដូច្នេះ ។

ការពណ៌នាសិក្ខាបទ ៥ ខាងដើម

ពាក្យណាដែលខ្ញុំពោលថា ក្នុងសិក្ខាបទ ៥ ខាងដើម ចាំបាច់ចង្អុល បង្ហាញ ដោយប្រការសភាវៈប្លែកគ្នា ។បេ។ គប្បីជ្រាបវិនិច្ឆ័យ ។បេ។ ក្នុងពាក្យ នោះ ឥឡូវនេះ ខ្ញុំនឹងចង្អុលបង្ហាញដូច្នេះ ជាបឋមក្នុងពាក្យថា **ចាណាតិ-ចាតោ** *នេះ បទថា* **ចាណោ** *បានដល់ ការបន្តនៃខន្ធដែលទាក់ទងដោយ ជីវិតិន្ទ្រិយ ។ ន័យម្យ៉ាងទៀត បានដល់ សត្វដែលបណ្ឌិតអាស្រ័យការបន្ត នៃខន្ធនោះបញ្ញត្ត ។ វធកចេតនា គឺចេតនាគិតនឹងសម្លាប់របស់បុគ្គលដែល មានសេចក្តីសម្គាល់ក្នុងសត្វមានជីវិតនោះ ថាជាសត្វមានជីវិត ជាសមុដ្ឋាននៃ*

សេចក្តីព្យាយាមដែលនឹងកាត់ជីវិតិន្ទ្រិយរបស់សត្វមានជីវិតនោះ ប្រព្រឹត្តទៅតាមកាយទ្វារ និងវចីទ្វារ ទ្វារណាមួយ ឈ្មោះថា **ចាណាតិចាត ។**

ក្នុងពាក្យថា **អនិដ្ឋាឆានំ** *នេះ បទថា* **អនិដ្ឋំ** *បានដល់ ទ្រព្យដែលមានម្ចាស់ហួងហែង ដែលម្ចាស់ទ្រព្យខ្ជួនឯង កាលធ្វើតាមត្រូវការក៏មិនត្រូវទោស មិនត្រូវពាក្យតិះដៀល ចេយ្យចេតនារបស់បុគ្គល ដែលមានការសម្គាល់ក្នុងទ្រព្យដែលមានម្ចាស់រក្សាថា ជាទ្រព្យរបស់ម្ចាស់ទ្រព្យហួងហែង ជាសមុដ្ឋាននៃសេចក្តីព្យាយាមនឹងលួចទ្រព្យនោះ ប្រព្រឹត្តទៅផ្លូវកាយទ្វារ និងវចីទ្វារ ទ្វារណានីមួយនោះឯង ឈ្មោះថា* **អនិដ្ឋាឆាន ។**

បទថា **អព្រហ្មចរិយំ** *បានដល់ ការប្រព្រឹត្តមិនប្រសើរ ចេតនាជាហេតុល្មើសនូវហាន: គឺការសេពអសទ្ធម្ម ប្រព្រឹត្តទៅផ្លូវកាយទ្វារ ដោយការសេពមេថុន ឈ្មោះថា* **អព្រហ្មចរិយ: ។**

ក្នុងពាក្យថា **មុសាវាឆោ** *នេះ បទថា* **មុសា** *បានដល់ វចីបយោគ ឬកាយបយោគ ដែលធ្វើប្រយោជន៍របស់បុគ្គលដែលប្រាថ្នាឲ្យឃ្លាតសេចក្តីពិតជាខាងមុខ មិច្ឆាចេតនា ចេតនាដែលគិតនឹងពោលខុស ធ្វើខុសរបស់បុគ្គលនោះ ដោយបំណងនឹងឲ្យអ្នកជនៃយល់ខុស ជាសមុដ្ឋាននៃកាយបយោគ និងវចីបយោគដែលធ្វើអ្នកជនៃឲ្យយល់ខុស ប្រព្រឹត្តទៅផ្លូវកាយទ្វារ និងវចីទ្វារ ទ្វារណាមួយ ឈ្មោះថា* **មុសាវាឆ ។**

ក្នុងពាក្យថា **សុរាមេរយមជ្ជប្បមាឆដ្ឋានំ** *នេះ បទថា* **សុរា** *បានដល់ សុរា ៥ យ៉ាង គឺសុរាធ្វើដោយមេរ្យា សុរាធ្វើដោយនំ សុរាធ្វើដោយថ្នាយ*

សុរាធ្វើអំពីពូជនៃសុរា និងសុរាធ្វើដោយគ្រឿងផ្សំផ្សេងៗ ។

មេរ័យក៏មាន ៥ យ៉ាង គឺមេរ័យដែលធ្វើដោយផ្កា មេរ័យដែលធ្វើដោយផ្លែឈើ មេរ័យដែលធ្វើដោយទឹកអំពៅ មេរ័យដែលធ្វើដោយផ្កាស្រគំ មេរ័យដែលផ្សំដោយគ្រឿងផ្សំ ។ បទថា **មទ្ធំ** *បានដល់ ទាំង ២ នោះឯង ឈ្មោះថា* **មជ្ជ** *ព្រោះអត្ថថា ជាទីតាំងនៃសេចក្តីស្រវឹង ឬវត្ថុដទៃណា ទោះជាអ្វីក៏ដោយ ដែលជាទីតាំងនៃសេចក្តីស្រវឹង បុគ្គលស្រវឹង ប្រមាទដោយវត្ថុណាដែលផឹកហើយ វត្ថុនេះក៏ហៅថា* **មជ្ជ។** *បទថា* **បទដ្ឋានំ** *បានដល់ ចេតនាដែលបរិភោគមជ្ជៈនោះ លោកហៅថា* **បមាទដ្ឋានំ** *ព្រោះជាហេតុនៃការស្រវឹងដោយការប្រមាទ ចេតនាបរិភោគមជ្ជៈ គឺសុរា និងមេរ័យ ប្រព្រឹត្តទៅផ្លូវកាយទ្វារ ដោយបំណងនឹងបរិភោគ គប្បីជ្រាបថា សុរាមេរ័យ ជាទីតាំងនៃសេចក្តីប្រមាទដោយប្រការណា គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទាំងនោះមុនរាប់តាំងអំពីបាណាតិបាតជាដើមទៅ ដោយប្រការដូច្នេះ ។*

វិនិច្ឆ័យសិក្ខាបទដូចគ្នា និងផ្សេងគ្នាជាដើម

ក្នុងពាក្យថា ដូចគ្នានិងផ្សេងគ្នាជាដើម ដោយសិក្ខាបទតែម្យ៉ាងដូចគ្នាតែផ្សេងគ្នាជាដើមនេះ អ្នកចោទសួរពោលថា បាណាតិបាត ឬសិក្ខាបទដែលមានអទិន្នាទានជាដើមតែមួយដូចគ្នា ព្រោះបុគ្គលដែលគប្បីសម្ងាប់ ត្រូវសម្ងាប់ ប្រយោគ និងចេតនាជាដើមតែមួយដូចគ្នា ឬផ្សេងគ្នា ព្រោះមានបុគ្គលដែលត្រូវសម្ងាប់ជាដើមផ្សេងគ្នា ឬមិនមែនទាំង ២ យ៉ាង ក៏ព្រោះហេតុអ្វី ទើបអ្នកចោទសួរពោលពាក្យនេះ បើសិក្ខាបទតែមួយដូចគ្នា ព្រោះបុគ្គលដែល

ត្រូវសម្លាប់ជាដើម ជាមនុស្សតែម្នាក់សោត កាលបើដូច្នោះ កាលណា បុគ្គលសម្លាប់ច្រើននាក់ សម្លាប់មនុស្សដែលត្រូវសម្លាប់តែម្នាក់ ឬបុគ្គល អ្នកសម្លាប់តែម្នាក់ សម្លាប់មនុស្សដែលត្រូវសម្លាប់ច្រើននាក់ មនុស្សដែល គប្បីត្រូវសម្លាប់ច្រើននាក់ ក៏នឹងត្រូវសម្លាប់ដោយប្រយោគមួយ មាន សាហត្ថិកប្បយោគជាដើម ឬចេតនាតែម្យ៉ាង ក៏នឹងញុំាងប្រយោគរបស់បុគ្គល ដែលចូលទៅកាត់ជីវិតន្ទ្រិយរបស់បុគ្គល ដែលត្រូវសម្លាប់ច្រើននាក់ឲ្យតាំង ខ្បើង កាលនោះ ចាណាតិបាតក៏គប្បីមានតែមួយ តែបើសិក្ខាបទផ្សេងគ្នា ព្រោះអ្នកដែលត្រូវសម្លាប់ជាដើមផ្សេងគ្នាសោត កាលបើដូច្នោះ កាលណា អ្នកសម្លាប់តែម្នាក់ បើធ្វើប្រយោគមួយ ដើម្បីមនុស្សម្នាក់ ក៏រមែងសម្លាប់ បុគ្គលដែលត្រូវសម្លាប់ច្រើននាក់ ឬអ្នកសម្លាប់ច្រើននាក់ កាលធ្វើច្រើន ប្រយោគ ដើម្បីមនុស្សច្រើននាក់ មានទេវទត្ត យញ្ញទត្ត និងសោមទត្ត ជាដើម ក៏រមែងសម្លាប់បានចំពោះទេវទត្ត យញ្ញទត្ត ឬសោមទត្តម្នាក់ ប៉ុណ្ណោះ ឬបុគ្គលដែលគប្បីត្រូវសម្លាប់តែម្នាក់ ត្រូវអ្នកសម្លាប់ សម្លាប់ ដោយច្រើនប្រយោគ មានសហត្ថិកប្បយោគជាដើម ចេតនាច្រើនក៏នឹងញុំាង ប្រយោគរបស់បុគ្គល ដែលចូលទៅកាត់ជីវិតន្ទ្រិយរបស់បុគ្គលដែលត្រូវ សម្លាប់ម្នាក់ប៉ុណ្ណោះ ឲ្យតាំងខ្បើង ។ កាលនោះ ចាណាតិបាតក៏គប្បីមាន ច្រើនយ៉ាង សូម្បីពាក្យទាំង ២ នោះ ក៏មិនត្រឹមត្រូវ ។ សិក្ខាបទនឹងឈ្មោះ ថា តែមួយដូចគ្នា ព្រោះបុគ្គលដែលត្រូវសម្លាប់ជាដើមនោះ មានតែម្នាក់ក៏ មិនមែនសិក្ខាបទ ឈ្មោះថា ផ្សេងគ្នា ព្រោះបុគ្គលដែលត្រូវសម្លាប់ជាដើម

នោះផ្សេងគ្នាក៏មិនមែន សេចក្តីពិត សិក្ខាបទតែមួយ និងផ្សេងគ្នា ក៏ដោយ ហេតុដទៃ ពាក្យនោះ គប្បីប្រើជល់បាណាតិបាត សិក្ខាបទក្រៅអំពីនោះ ក៏គប្បីប្រើយ៉ាងនោះ ។

ខ្ញុំនឹងលើកសេចក្តីនេះទៀងដូចតទៅនេះថា ដំបូង បាណាតិបាតនោះ ឈ្មោះថា តែមួយ ព្រោះបុគ្គលដែលគប្បីត្រូវសម្លាប់ និងអ្នកសម្លាប់ជាដើម តែមួយដូចគ្នា ឈ្មោះថា ផ្សេងគ្នា ព្រោះបុគ្គលដែលត្រូវសម្លាប់ជាដើមផ្សេងគ្នាក៏មិនមែន ដោយពិតនោះ បាណាតិបាត ឈ្មោះថា តែមួយដូចគ្នា ព្រោះបុគ្គលដែលត្រូវសម្លាប់ និងអ្នកសម្លាប់ជាដើមតែមួយដូចគ្នា ដោយចាត់ជាគូៗ គ្នា ។ ទាំងឈ្មោះថា តែមួយដូចគ្នា ព្រោះបុគ្គលដែលត្រូវសម្លាប់ និងអ្នកសម្លាប់ជាដើមទាំង ២ នោះ តែមួយដូចគ្នា ដោយចាត់ជាគូៗ គ្នា ឬឈ្មោះថា ផ្សេងគ្នា ព្រោះបុគ្គលដែលគប្បីត្រូវសម្លាប់ និងអ្នកសម្លាប់ជាដើមនោះ ជាមនុស្សម្នាក់ទៀត ក្រៅអំពីមនុស្សទាំង ២ នាក់នោះ ។

ពិតហើយ កាលមនុស្សអ្នកសម្លាប់ច្រើននាក់ សូម្បីសម្លាប់មនុស្សដែលត្រូវសម្លាប់ច្រើននាក់ ដោយប្រយោគច្រើនប្រយោគ មានសារក្ខបបយោគ មានការជីកស្រះជាដើម ឬដោយប្រយោគមួយ មានឱបាតខណនបយោគ គឺការជីកអណ្តូងជាដើម ក៏ជាបាណាតិបាត កាលបុគ្គលអ្នកសម្លាប់តែម្នាក់ សម្លាប់បុគ្គលដែលត្រូវសម្លាប់ច្រើននាក់ ដោយប្រយោគមួយ ឬច្រើនប្រយោគ ដោយចេតនាមួយ ដែលញុំងប្រយោគនោះឲ្យតាំងឡើង ឬដោយច្រើនប្រយោគ ក៏ជាបាណាតិបាតច្រើនបាណាតិបាត ម្យ៉ាងទៀត កាលបុគ្គលអ្នកសម្លាប់ច្រើន

សូម្បីត្រូវសម្លាប់បុគ្គលដែលត្រូវសម្លាប់តែម្នាក់ ដោយប្រយោគច្រើន តាមដែលពោលហើយ ឬដោយប្រយោគមួយ ក៏ជាបាណាតិបាតច្រើន ក្នុងសិក្ខាបទ មានអទិន្នាទានជាដើម ក៏មាននយ័ដូច្នេះ គប្បីជ្រាបវិនិច្ឆ័យដោយភាពជាសិក្ខាបទតែមួយដូចគ្នា និងដូចគ្នា និងផ្សេងគ្នាជាដើម ដោយប្រការដូចពោលមកដូច្នេះ ។

បើពោលដោយអារម្មណ៍ ក្នុងសេចក្តីនេះ បាណាតិបាត មានជីវិតិន្ទ្រិយជាអារម្មណ៍ អទិន្នាទាន អព្រហ្មចរិយៈ និងសុរាមេរយមជ្ជប្បមាទដ្ឋាន មានសង្ខារ គឺបណ្តារូបធម៌ មានរូបាយតនៈជាដើមណាមួយជាអារម្មណ៍ មុសាវាទ មានសត្វជាអារម្មណ៍ ព្រោះប្រារព្ធបុគ្គលនឹងពោលមុសាប្រព្រឹត្តទៅ អាចារ្យពួកខ្លះពោលថា សូម្បីអព្រហ្មចរិយៈក៏មានសត្វជាអារម្មណ៍ ម្យ៉ាងទៀត អទិន្នាទាន មានសត្វជាអារម្មណ៍ ក្នុងកាលដែលសត្វជាបុគ្គល ដែលគប្បីត្រូវលួចទៅ ប្រការមួយទៀត អទិន្នាទាន មានសត្វជាអារម្មណ៍ ក៏ដោយអំណាចសង្ខារ មិនមែនដោយអំណាចព្រះបញ្ញត្ត ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយអារម្មណ៍ ដូចពោលមកដូច្នេះ ។

កាលពោលដោយសមាទាន សិក្ខាបទទាំងនេះ មានបាណាតិបាតាវេរ-មណីសិក្ខាបទជាដើម សាមណេរសមាទានក្នុងសម្នាក់ភិក្ខុប៉ុណ្ណោះ ទើបឈ្មោះថា សមាទាន ចំណែកឧបាសក សមាទានឯងក្តី សមាទានក្នុងសម្នាក់របស់អ្នកដទៃក្តី ក៏ឈ្មោះថា សមាទានហើយ សមាទានរួមគ្នាក្តី (រួមសិក្ខាបទចូលគ្នា) សមាទានបែកគ្នាក្តី (សមាទានរាយសិក្ខាបទមួយៗ) ក៏ឈ្មោះថា

សមាទានហើយ តែផ្សេងគ្នាដូចម្តេច បុគ្គលសមាទានរួមគ្នា ក៏មានវិរតិ ១ មានចេតនា ១ ប៉ុណ្ណោះ តែប្រាកដជា វិរតិ និងចេតនាទាំងនោះ មានដល់ ៥ ដោយអំណាចកិច្ច ។ ឯបុគ្គលដែលសមាទានបែកគ្នា គប្បីជ្រាបថា មាន វិរតិ ៥ ចេតនា ៥ ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយការសមាទាន ដោយប្រការដូច្នេះ ។

បើពោលដោយការជាប់ ក្នុងសេចក្តីនេះ សម្រាប់សាមណេរទាំងឡាយ កាលសិក្ខាបទមួយជាប់ គ្រប់សិក្ខាបទក៏ជាប់ ព្រោះសិក្ខាបទទាំងនោះជា ហានៈ ជាទីតាំងនៃបាវាជិករបស់សាមណេរទាំងនោះ ដោយសិក្ខាបទដែល សាមណេរកន្ទងល្មើសនោះឯង មានកម្មជាប់តាមមក ។

តែសម្រាប់គ្រហស្ថ កាលសីលមួយជាប់ ក៏ជាប់មួយប៉ុណ្ណោះ ព្រោះ សីលរបស់គ្រហស្ថមានអង្គ ៥ រមែងនឹងបរិបូណ៌ទៀត ដោយការសមាទាន សីលប៉ុណ្ណោះ ។ តែអាចារ្យមួយពួកទៀតពោលថា បណ្តាសីលដែលគ្រហស្ថ សមាទាន ជាសិក្ខាបទមួយៗ កាលសីលណាមួយជាប់ ក៏ជាប់មួយប៉ុណ្ណោះ តែបណ្តាសីលដែលគ្រហស្ថសមាទានរួមគ្នាយ៉ាងនេះថា **បញ្ចង្គសមង្គាគតំ សីលំ សមាទិយាមិ** *ខ្ញុំសូមសមាទានសីល ដែលប្រកបដោយអង្គ ៥ ដូច្នេះ កាលសីលណាមួយជាប់ សីលដ៏សេស ក៏ជាប់ទាំងអស់ ។ ព្រោះហេតុអ្វី ព្រោះសីលដែលសមាទានមិនជាប់ ដ្បិតសីលដែលគ្រហស្ថកន្ទងល្មើស នោះឯង ក៏មានចំណងកម្ម ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយការជាប់ ដោយប្រការដូច្នេះ ។*

កាលពោលដោយទោសច្រើន បណ្តាសត្វមានជីវិត រៀរចាកគុណ មានសត្វតិរច្ឆានជាដើម ជាណាតិជាត ឈ្មោះថា មានទោសតិច ក៏ព្រោះសត្វមានខ្លួនតូច ឈ្មោះថា មានទោសច្រើន ក៏ព្រោះថា សត្វមានខ្លួនធំ ។ ព្រោះហេតុអ្វី ព្រោះប្រយោគធំ គឺសេចក្តីព្យាយាមច្រើន ទោះបីមានបយោគស្មើគ្នា ឈ្មោះថា មានទោសច្រើន ព្រោះវត្ថុធំ ចំណែកបណ្តាសត្វមានជីវិត ដែលមានគុណ មានមនុស្សជាដើម ជាណាតិជាត ឈ្មោះថា មានទោសតិច ក៏ព្រោះមនុស្សមានគុណតិច ឈ្មោះថា មានទោសច្រើន ក៏ព្រោះមនុស្សមានគុណច្រើន តែបើមានខ្លួន និងគុណស្មើគ្នា ក៏គប្បីជ្រាបថា មានទោសតិច ព្រោះកិលេស និងសេចក្តីព្យាយាមទន់ខ្សោយ និងមានទោសច្រើន ព្រោះកិលេស និងសេចក្តីព្យាយាមខ្លាំងក្លា ក្នុងសិក្ខាបទដ៏សេស ក៏មានន័យដូច្នេះ ។ ម៉្យាងទៀត ក្នុងសេចក្តីនេះ សុរាមេរយមជ្ជប្បមាទដ្ឋានប៉ុណ្ណោះ ឈ្មោះថា មានទោសច្រើន ជាណាតិជាតជាដើម មិនមែនមានទោសច្រើនឡើយ ព្រោះអ្វី ព្រោះធ្វើអន្តរាយដល់អរិយធម៌ ព្រោះធ្វើមនុស្សដែលកើតមកជាមនុស្ស ឲ្យក្លាយជាមនុស្សឆ្កួត ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយការមានទោសច្រើន ដោយប្រការដូច្នេះ ។

កាលពោលដោយបយោគ ក្នុងសេចក្តីនេះ ជាណាតិជាត មានប្រយោគ ៦ គឺសាហត្ថិកប្បយោគ អាណត្តិកប្បយោគ និស្សគ្គិយប្បយោគ ថាវ-រប្បយោគ វិជ្ជាមយប្បយោគ ឥទ្ធិមយប្បយោគ ។

បណ្តាបយោគទាំងនោះ ការប្រហារដោយកាយ ឬរបស់ដែលជាប់នឹង

កាយ ឈ្មោះថា សាហត្ថិកប្បយោគៗ នោះ ចែកជា ២ គឺសាហត្ថិកប្បយោគ ដោយចំពោះ និងសាហត្ថិកប្បយោគដោយមិនចំពោះ ។ ក្នុងសាហត្ថិកប្បយោគ ទាំង ២ នោះ សាហត្ថិកប្បយោគដោយចំពោះ បុគ្គលរមែងពាក់ព័ន្ធដោយ កម្ម ព្រោះការស្លាប់របស់មនុស្សដែលទៅចំពោះប្រហារប៉ុណ្ណោះ ។ ក្នុង សាហត្ថិកប្បយោគមិនចំពោះយ៉ាងនេះថា បុគ្គលណាម្នាក់ក៏ដោយ ចូរស្លាប់ ដូច្នេះ បុគ្គលរមែងជាប់ដោយកម្ម ព្រោះការស្លាប់របស់បុគ្គលណាម្នាក់ ព្រោះ ការប្រហារជាបច្ច័យ ។ ម្យ៉ាងទៀត ដោយសាហត្ថិកប្បយោគទាំង ២ បុគ្គល គ្រាន់តែត្រូវប្រហារស្លាប់ ឬស្លាប់ដោយរោគនោះខាងក្រោយ បុគ្គលក៏រមែង ជល់នូវកម្មពន្ធ ខណៈដែលបុគ្គលត្រូវប្រហារប៉ុណ្ណោះ តែបើបុគ្គលប្រហារ ដោយបំណងនឹងឲ្យគេស្លាប់ តែគេមិនស្លាប់ដោយការប្រហារនោះ បែរជាគិត ប្រហារបុគ្គលនោះទៀត បើក្នុងពេលក្រោយ គេស្លាប់ដោយការប្រហារ ដំបូងនោះ បុគ្គលក៏រមែងត្រូវកម្មពន្ធក្នុងវេលានោះប៉ុណ្ណោះ បើសត្វនោះស្លាប់ ដោយការប្រហារលើកទី ២ ក៏មិនជាបាណាតិបាត បើបុគ្គលនោះស្លាប់ដោយ សាហត្ថិកប្បយោគទាំង ២ បុគ្គលក៏ត្រូវកម្មពន្ធ ដោយការប្រហារដំបូងប៉ុណ្ណោះ បើបុគ្គលមិនស្លាប់ ដោយសាហត្ថិកប្បយោគទាំង ២ ក៏មិនជាបាណាតិបាត ឡើយ ក្នុងប្រការដែលមនុស្សច្រើននាក់ប្រហារមនុស្សម្នាក់ ក៏នយនេះ ក្នុង សេចក្តីនោះ កម្មពន្ធ រមែងមានដល់បុគ្គលដែលប្រហារបុគ្គលនោះស្លាប់ ប៉ុណ្ណោះ ។

ការតាំងចិត្តប្រើឲ្យគេធ្វើ ឈ្មោះថា អាណត្ថិកប្បយោគ ក្នុងអាណត្តិ-

កប្បយោគនោះ ក៏គប្បីជ្រាបកម្មពន្ធ ដោយនយដែលបានពោលក្នុងសាហត្ថិកប្បយោគនោះឯង ក្នុងអាណត្តិកប្បយោគនោះ គប្បីជ្រាបថា មានកំណត់ ៦ យ៉ាង ។

អាណត្តិកប្បយោគ កំណត់ ៦ យ៉ាង គឺវត្ថុ ១ កាល ១ ឱកាស ១ អាវុធ ១ ឥរិយាបថ ១ កិរិយាវិសេស ១ ។ ក្នុងការកំណត់ ៦ នោះ សត្វមានជីវិត គប្បីចាំទុកថាជាវត្ថុ ។ ពេលព្រឹក ល្ងាច និងពេលនៅជាកំលោះ ក្រមុំ ពេលជាមនុស្សធំជាដើម គប្បីចាំទុកថាកាល ។ គាម និគម ព្រៃ ច្រក ឬផ្លូវបំបែក ដូចពោលមកនេះជាដើម គប្បីចាំទុកថា ឱកាស ។ អាវុធ គឺជាវ ធ្នូ ឬលំពែង ការឈរ ឬការអង្គុយ របស់អ្នកដែលត្រូវសម្ងាប់ និងអ្នកសម្ងាប់ ដូចពោលមកនេះជាដើម គប្បីចាំទុកថាជាឥរិយាបថ ។ ការចាក់ច្នៃ ការកាត់ ការធ្វើឲ្យជាប់ ឬការបោចសក់ ដូចពោលមកជាដើម គប្បីចាំទុកថា កិរិយាវិសេស ។ បើបុគ្គលត្រូវគេប្រើឲ្យសម្ងាប់បុគ្គលណា ធ្វើវត្ថុឲ្យឃ្លៀងឃ្លាត គឺសម្ងាប់ខុសបុគ្គល សម្ងាប់អ្នកដទៃក្រៅអំពីបុគ្គលនោះសោត អ្នកប្រើក៏មិនត្រូវកម្មពន្ធ បើបុគ្គលនោះមិនធ្វើវត្ថុឲ្យឃ្លៀងឃ្លាត សម្ងាប់មិនខុសបុគ្គល ជនទាំង ២ ក៏ត្រូវកម្មពន្ធ គឺអ្នកប្រើត្រូវក្នុងខណៈប្រើ អ្នកដែលត្រូវប្រើត្រូវក្នុងខណៈសម្ងាប់ ក្នុងការកំណត់ដទៃៗ មានកាលជាដើម ក៏មាននយដូច្នេះ ។

ការលែងគ្រឿងប្រហារដោយកាយ ឬរបស់ដែលជាប់ដោយកាយ ដើម្បីធ្វើឲ្យស្លាប់ ឈ្មោះថា និស្សគ្គិយប្បយោគ ។ និស្សគ្គិយប្បយោគនោះក៏ចែក

ជា ២ ដូចគ្នា គឺនិស្សគ្គិយប្បយោគដោយចំពោះ និងមិនចំពោះ ក្នុងសេចក្តីនេះ កម្មពន្ធ គប្បីជ្រាបតាមន័យដែលពោលមកហើយខាងដើមនោះឯង ។

ការជីកអណ្តូង ការដាក់ភ្លើងចម្រូង ការប្រកបថ្នាំពិស និងគន្ធីរយន្តជាដើម ដើម្បីធ្វើឲ្យសត្វស្លាប់ ឈ្មោះថា ថាវរប្បយោគ ថាវរប្បយោគនោះ ចែកជា ២ គឺថាវរប្បយោគចំពោះ និងមិនចំពោះ ។ ក្នុងសេចក្តីនេះ កម្មពន្ធគប្បីជ្រាបតាមន័យដែលពោលមកហើយខាងដើម តែការប្លែកគ្នា មានដូច្នេះ កាលអ្នកជីកដំឡូង ធ្វើអណ្តូងជាដើមក្បែរៗ ឬធ្វើអណ្តូងទទេក្តី របស់មនុស្សដទៃៗ បើបុគ្គលនោះស្លាប់ ព្រោះអណ្តូងនោះជាបច្ច័យ កម្មពន្ធក៏មានដល់អ្នកជីកដំឡូង ។ ម្យ៉ាងទៀត កាលមនុស្សទាំងនោះ ឬអ្នកដទៃលុបអណ្តូងនោះចោល ធ្វើផ្ទៃដីឲ្យរាប ឬបុគ្គលចោសធូលី កោយធូលីទៅ ឬអ្នកជីកដំឡូង ជីកដំឡូងធ្វើរណ្តៅ ឬកាលភ្លៀងធ្លាក់ បែកភក់ មនុស្សចុះទៅជាប់ស្លាប់ក្នុងភក់នោះ កម្មពន្ធមានដល់អ្នកជីកដំឡូងនោះឯង បើមនុស្សដែលបានដំឡូង ឬអ្នកដទៃធ្វើរណ្តៅនោះឲ្យទូលាយ ឬជ្រៅជាងមុន បុគ្គលចុះទៅស្លាប់ព្រោះរណ្តៅធំ ឬជ្រៅនោះ កម្មពន្ធក៏មានដល់មនុស្សទាំង ២ ហេតុទាំង-ទ្បាយ រមែងប្រៀបធៀបគ្នាបាននឹងការជីកដំឡូង យ៉ាងណា កាលមនុស្សលុបរណ្តៅឲ្យរាបក្នុងទីនោះ មនុស្សក៏ផុតចាកការធ្លាក់រណ្តៅ ក៏ដូច្នោះ ។

ក្នុងថាវរប្បយោគ មានការដាក់ភ្លើងចម្រូងជាដើម ក៏យ៉ាងនោះដូចគ្នា កម្មពន្ធតាមហេតុដែលកើត ក៏គប្បីជ្រាប ជរាបណាថាវរប្បយោគនោះនៅប្រព្រឹត្តទៅ ។

ការវាយវិជ្ជាអាគមដែលធ្វើឲ្យស្លាប់ ឈ្មោះថា វិជ្ជាមយប្បយោគ ។

ការធ្វើឫទ្ធិផ្សេងៗ ដែលកើតអំពីវិបាកកម្ម ដើម្បីធ្វើឲ្យបុគ្គលនោះស្លាប់ ដូចប្រើអាវុធ គឺចង្កឹមជាដើម ទាំងយចង្កឹមជាដើម ឈ្មោះថា ឥទ្ធិមយប្ប-យោគ ។ ឯអទិន្នាទាន ក៏មានប្រយោគ គឺសាហត្ថិកប្បយោគ និងអាណត្តិ-កប្បយោគជាដើម ដែលប្រព្រឹត្តទៅដោយអំណាចថេយ្យាវហារ បរសេយ្ហា-វហារ បដិច្ឆន្នាវហារ បរិកប្បាវហារ និងកុសាវហារ ប្រភេទនៃបយោគទាំង-នោះ ក៏គប្បីជ្រាបដោយទំនងដែលពោលមកហើយនោះឯង សិក្ខាបទទាំង ៣ មានអព្រហ្មចរិយៈជាដើម ក៏បានចំពោះនូវសាហត្ថិកប្បយោគតែម្យ៉ាង ក្នុង-សេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយបយោគ ដោយប្រការដូចពោលមក ដូច្នេះ ។

បើពោលដោយអង្គ ក្នុងសេចក្តីនេះ បាណាតិបាតមានអង្គ ៥ គឺបាណ-សត្វមានជីវិត ១ បាណសញ្ញី សម្គាល់ថាមានជីវិត ១ វធកចិត្តំ ចិត្តគិតនឹង-សម្លាប់ ១ វាយមតិ ព្យាយាមនឹងសម្លាប់ ១ តេនមរណតិ សត្វស្លាប់ដោយ-ព្យាយាមនោះ ។

អទិន្នាទានក៏មានអង្គ ៥ ដូចគ្នា គឺបរបរិគ្គហិតំ របស់មានម្ចាស់រក្សា ១ បរបរិគ្គហិតសញ្ញី សម្គាល់ថា របស់មានម្ចាស់ហួងហែង ១ ថេយ្យចិត្តំ មាន-ចិត្តគិតនឹងលួច ១ វាយមតិ ព្យាយាមនឹងលួច ១ តេន អាទាតព្ពំ អាទានំ-គច្ឆតិ លួចបានមកដោយការព្យាយាមនោះ ១ ។

ចំណែកអព្រហ្មចរិយៈមានអង្គ ៤ គឺអជ្ឈាចរិយវត្ថុ វត្ថុដែលគប្បីកន្ទង-

ល្មើស ១ សេវនចិត្តំ ចិត្តគិតនឹងសេព ១ បយោគំ សមាបជ្ជតិ ព្យាយាម នឹងចូលដល់ ១ សាទិយតិ ត្រេកអរ ១ ។

មុសាវាទមានអង្គ ៤ ដូចគ្នា គឺមុសា រឿងកុហក ១ វិសំវាទនចិត្តំ ចិត្ត គិតនឹងពោលកុហក ១ វាយាមោ ព្យាយាមកើតអំពីចិត្តនោះ ១ បរវិសំ-វាទនំ និយាយកុហកចំពោះបុគ្គលដទៃ និងអ្នកដទៃដឹងរឿងកុហក ១ ។

សុរាមេរយមជ្ជប្បមាទដ្ឋាន ក៏មានអង្គ ៤ គឺ សុរាទីនំ អញ្ញតរំ របស់ស្រវឹង មានសុរាជាដើមណាមួយ ១ មទនីយបាតុកម្យតាចិត្តំ ចិត្តគិតចង់ផឹក ១ តជ្ជំ វាយាមំ អាបជ្ជតិ ការព្យាយាមកើតអំពីចិត្តនោះ ១ បីតេ ច បវិស្សតិ ផឹកចូលទៅក្នុងបំពង់ក ១ ។ ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយអង្គ ដោយប្រការដូចពោលមក ដូច្នេះ ។

បើពោលដោយសមុដ្ឋាន ក្នុងសេចក្តីនេះ បាណាតិបាត អទិន្នាទាន និងមុសាវាទ មានសមុដ្ឋាន ៣ គឺកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ។ អព្រហ្មចរិយៈមានសមុដ្ឋាន ១ គឺកាយចិត្ត ។ សុរាមេរយមជ្ជប្ប-មាទដ្ឋាន មានសមុដ្ឋាន ២ គឺកាយ ១ ចិត្ត ១ ក្នុងសេចក្តីនេះ គប្បីជ្រាប វិនិច្ឆ័យដោយសមុដ្ឋាន ដោយប្រការដូចពោលមក ដូច្នេះ ។

បើពោលដោយវេទនា ក្នុងសេចក្តីនេះ បាណាតិបាត ប្រកបដោយទុក្ខ-វេទនា អទិន្នាទាន ប្រកបដោយវេទនា ៣ ណាមួយ មុសាវាទក៏ដូចគ្នា សិក្ខា-បទ ២ ទៀត ប្រកបដោយសុខវេទនា និងអទុក្ខមសុខវេទនា ក្នុងសេចក្តី នេះ គប្បីជ្រាបវិនិច្ឆ័យដោយវេទនា ដោយប្រការដូចពោលមក ដូច្នេះ ។

បើពោលដោយមូល ក្នុងសេចក្តីនេះ បាណាតិបាត មានទោសៈ និង មោហៈជាមូល អទិន្នាទាន និងមុសាវាទ មានលោភៈ និងមោហៈជាមូល ក៏មាន មានទោសៈ និងមោហៈជាមូលក៏មាន ។ សិក្ខាបទ ២ ទៀត ក្រៅ អំពីនេះ មានលោភៈ និងមោហៈជាមូល ក្នុងសេចក្តីនេះ គប្បីជ្រាប វិនិច្ឆ័យដោយមូល ដោយប្រការដូចពោលមក ដូច្នេះ ។

បើពោលដោយកម្ម ក្នុងសេចក្តីនេះ បាណាតិបាត អទិន្នាទាន និង អព្រហ្មចរិយៈ ជាកាយកម្ម និងជាកម្មបថ មុសាវាទជាវចីកម្មតែម្យ៉ាង ដែលកាច់បំបាក់នូវប្រយោជន៍ ក៏ជាកម្មបថ មុសាវាទក្រៅអំពីនេះ ជាកម្ម តែម្យ៉ាង សុរាមេរយមជ្ជប្បមាទដ្ឋាន ជាកាយកម្មតែម្យ៉ាង ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយកម្មដូចពោលមក ដូច្នេះ ។

បើពោលដោយវិរតិ ក្នុងសេចក្តីនេះ អ្នកចោទសួរពោលថា បុគ្គលកាល វៀរបាណាតិបាតជាដើម វៀរអំពីណា ។ នឹងពោលចង្អុលបង្ហាញ ដូច្នេះ ជា បឋម បុគ្គលកាលវៀរ ដោយសមាទានវិរតិ រមែងវៀរចាកអកុសលកម្ម មាន បាណាតិបាតជាដើមរបស់ខ្លួនឯង ឬរបស់អ្នកដទៃ ។ សួរថា ប្រារព្ធអ្វី ។ ឆ្លើយថា ប្រារព្ធអកុសលកម្មដែលវៀរនោះឯង កាលវៀរដោយសម្បត្តវិរតិ រមែងវៀរចាកអកុសលកម្មដូចពោលហើយនោះឯង សួរថា ប្រារព្ធអ្វី ឆ្លើយ ថា ប្រារព្ធអារម្មណ៍នៃអកុសលកម្ម មានបាណាតិបាតជាដើម ដែលពោល ហើយ ។ តែអាចារ្យពួកខ្លះពោលថា បុគ្គលប្រារព្ធសង្ខារទាំងឡាយ ដែល រាប់បានថា ទឹកស្រវឹង គឺសុរា និងមេរ័យ ទើបវៀរចាកទីតាំងនៃសេចក្តី

ប្រមាទ គឺការធើ្វកសុភ និងមេរ័យ ។ បុគ្គលប្រារព្ធបណ្តាសត្វ និងសង្ខារ ចំពោះដែលខ្លួនគប្បីលួច និងគប្បីបំផ្លាញ ទើបវៀរចាកអទិន្នាទាន និង មុសាវាទ ។ ប្រារព្ធសត្វតែម្យ៉ាង ទើបវៀរចាកបាណាតិបាត និងអព្រហ្ម-ចរិយៈ ។ អាចារ្យក្រៅអំពីនោះ មានការឃើញយ៉ាងនេះថា កាលបើដូច្នោះ បុគ្គលកាលគិតយ៉ាងណាមួយ ក៏ធ្វើយ៉ាងណាមួយ លះវត្តុណា ក៏មិនជឹងវត្តុ នោះ ដូច្នេះ កាលមិនត្រូវការយ៉ាងនោះ ទើបពោលថា បុគ្គលលះវត្តុណា ក៏ ប្រារព្ធវត្តុនោះ គឺអកុសលកម្ម មានបាណាតិបាតជាដើមរបស់ខ្លួននោះឯង ទើប វៀរ ។ ពាក្យនោះមិនត្រឹមត្រូវ ព្រោះហេតុអ្វី ព្រោះវត្តុនោះ មិនមានអារម្មណ៍ បច្ចុប្បន្ន និងមិនមានអារម្មណ៍ខាងក្រៅ ។ ពិតហើយ ក្នុងបាលីវិភង្គនៃសិក្ខា-បទទាំងឡាយ លោកសួរថា សិក្ខាបទទាំង ៥ ជាកុសលប៉ុន្មាន ។បេ។ ជា អរណៈប៉ុន្មាន ហើយក្នុងការឆ្លើយបញ្ហាដែលប្រព្រឹត្តទៅយ៉ាងនេះថា កុសល ទាំងឡាយ ប្រកបដោយសុខវេទនាក៏មាន ទើបពោលដល់ភាពជាធម៌ មាន អារម្មណ៍ជាបច្ចុប្បន្ន និងអារម្មណ៍ខាងក្រៅយ៉ាងនេះថា មានអារម្មណ៍ជាបច្ចុ-ប្បន្ន មានអារម្មណ៍ខាងក្រៅ ពាក្យនោះរមែងមិនត្រឹមត្រូវសម្រាប់បុគ្គលដែល ប្រារព្ធអកុសលធម៌ មានបាណាតិបាតជាដើមរបស់ខ្លួន ។ ក្នុងពាក្យថា បុគ្គល គិតម្យ៉ាង ធ្វើម្យ៉ាង នឹងលះវត្តុណា ក៏មិនជឹងវត្តុនោះ សូមពោលចង្អុលបង្ហាញ ដូច្នេះ បុគ្គលកំពុងបដិបត្តិ ដោយធ្វើកិច្ចឲ្យសម្រេច ប្រាថ្នានឹងពោលថា គិត ម្យ៉ាង ធ្វើម្យ៉ាង ឬលះវត្តុណា មិនជឹងវត្តុនោះ ដូច្នេះ រមែងមិនបាន ដូច លោកពោលថា

អារភិត្វាន អមតំ ជហាន្តោ សព្វទាបកេ

ឯឌ្ឍសប្បនញ្ជេត្ត ភវេ មគ្គត្ថោរិយបុគ្គលោ។

ព្រះអរិយបុគ្គលតាំងនៅក្នុងមគ្គ ប្រកបអមតធម៌ ក៏លះ

បាបធម៌បានទាំងអស់ ជាឧទាហរណ៍ក្នុងសេចក្តីនេះ ។

គប្បីជ្រាបវិនិច្ឆ័យដោយវិតិ ដោយប្រការដូចពោលមក ដូច្នេះ ។

បើពោលដោយផល បាបធម៌ មានបាណាតិបាតជាដើម ទាំងអស់នេះ រមែងឲ្យកើតផល គឺទុគ្គតិ និងឲ្យកើតវិបាកដែលមិនគួរជ្រាប្តា មិនគួរចង់បាន មិនគួរពេញចិត្តក្នុងសុគតិផង ឲ្យកើតផល មានការមិនក្លៀវក្លាជាដើម ក្នុងចំណែកខាងមុខ និងបច្ចុប្បន្ន ។ ម្យ៉ាងទៀត ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយផល តាមន័យជាដើមយ៉ាងនេះថា វិបាករបស់បាណាតិបាតយ៉ាងស្រាលបំផុត កាលកើតជាមនុស្ស ក៏ធ្វើឲ្យជាអ្នកមានអាយុខ្លី ។

ប្រការមួយទៀត ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយសមុដ្ឋាន វេទនា មូល កម្ម និងផលរបស់ចេតនា វៀរចាកបាណាតិបាតជាដើម ក្នុងចេតនាវៀរនោះឲ្យយល់ដូច្នេះ ។ វេរមណីទាំងអស់នេះ តាំងឡើងដោយសមុដ្ឋាន ៤ គឺកាយ កាយចិត្ត វាចាចិត្ត កាយវាចាចិត្ត ។ ទាំងអស់នោះឯង ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន មានអលោភៈ អទោសៈជាមូលក៏មាន មានអលោភៈ អទោសៈ អមោហៈជាមូលក៏មាន ក្នុងសេចក្តីនេះ វេរមណីទាំង ៤ ជាកាយកម្ម មុសាវាទាវេរមណី ជាវចីកម្ម តែក៏តាំងឡើងអំពីចិត្ត ក្នុងខណៈមគ្គចិត្ត វេរមណីទាំងពួងក៏ជាមនោកម្ម ។

ចាណាតិថាតា វេរមណី *មានផលជាដើមយ៉ាងនេះ គឺមានអវយវៈតូចធំបរិបូណ៌ មានសម្បត្តិ គឺកាពខ្ពង់ខ្ពស់ មានសម្បត្តិ គឺកាពវាងវៃ មានជើងតាំងនៅរាបស្មើ ការស្អាត ស្រស់បស់ ល្អ ក្លាហាន មានកម្លាំងច្រើន មានវាចាពីរោះ ជាទីស្រឡាញ់របស់សត្វលោក ការមានវាចាមិនមានទោស ការមានបរិស័ទមិនបែកគ្នា ការមានសេចក្តីអង់អាច ការមានរូបមិនខ្វះខាត ភាពជាបុគ្គលមិនស្លាប់ព្រោះសត្រូវ ភាពជាបុគ្គលមានបរិវារច្រើន ភាពជាបុគ្គលមានរូបស្អាត ភាពជាបុគ្គលមានទ្រង់ទ្រាយល្អ ការមានរោគតិច ការមិនសោកស្តាយ ការមិនព្រាត់ប្រាសចាកសត្វ និងសង្វាជាទីពេញចិត្ត និងការមានអាយុវែង ។*

អនិច្ឆាធានា វេរមណី *មានផលជាដើមយ៉ាងនេះ គឺមានទ្រព្យច្រើន មានទ្រព្យ គឺធញ្ញជាតិច្រើន ស្តុកស្តម្ភដោយកោគៈ ការកើតកោគទ្រព្យដែលមិនទាន់កើត កោគទ្រព្យដែលកើតហើយ នៅជាថាវរៈ បានកោគទ្រព្យតាមប្រាថ្នាយ៉ាងធាប់រហ័ស មានកោគទ្រព្យមិនត្រូវភ័យអន្តរាយ គឺភ័យអំពីព្រះរាជា ចោរ ទឹក ភ្លើង ទាយាទដែលមិនស្រឡាញ់គ្នា បានទ្រព្យដែលមិនជាសាធារណៈ បានលោកុត្តរទ្រព្យ មិនស្គាល់ការមិនមាន និងរស់នៅជាសុខ ។*

អព្រហ្មចរិយា វេរមណី *មានផលជាដើមយ៉ាងនេះ គឺការមិនមានសត្រូវ ការជាទីស្រឡាញ់របស់បុគ្គលគ្រប់រូប ការបានបាយទឹក សំពត់ ទីដេកជាដើម ការដេកជាសប្បាយ ការក្រោកសប្បាយ ការផុតភ័យក្នុងអបាយ ការមិនកើតជាស្រី ឬកើតជាមនុស្សមិនមានកេទ ការមិនក្រោធ ការធ្វើដោយគោរព*

ភាពជាទីស្រឡាញ់នៃស្ត្រី និងបុរស មានឥន្ទ្រិយបរិបូណិ មានលក្ខណៈ បរិបូណិ មិនមានសេចក្តីសង្ស័យ ជាអ្នកខ្ងល់ខ្ងាយតិច នៅជាសុខ មិនមានភ័យអំពីទីណា មិនមានការព្រាត់ប្រាសចាកសត្ង និងសង្ខារជាទីស្រឡាញ់ ។

មុសាវាធា វេរមណី មានផលយ៉ាងនេះ គឺមានឥន្ទ្រិយផូរផង់ ជាអ្នកមានវាចាពីរោះ ជាអ្នកមានធ្មេញរាបស្មើស្អាត ជាអ្នកមិនធាត់ពេក ជាអ្នកមិនស្គម ជាអ្នកមិនទាបពេក ជាអ្នកមិនខ្ពស់ពេក ជាអ្នកមានសម្ផស្ស សប្បាយ មាត់មានក្ងិនដូចផ្តាខប្បល អ្នកនៅក្រោមបង្គាប់ ស្តាប់ឪវាទល្អ មានវាចាដែលអ្នកដទៃជឿបាន មានអណ្តាតទន់ក្រហម ដូចផ្តាកោមុទ និងខប្បល ការមិនរាយមាយ ការមិនអណ្តែតអណ្តូងជាដើម ។

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី មានផលយ៉ាងនេះ គឺប្តេជ្ញាបានធាប់រហ័សក្នុងករណីយកិច្ចទាំងពួង ទាំងអតីត អនាគត និងបច្ចុប្បន្ន ការមានសតិគ្រប់កាល មិនជាមនុស្សធ្ពួត ជាអ្នកមានញាណ មិនខ្ជិលច្រអូស មិនល្ងង់ មិន-គ មិនស្រវឹង មិនប្រមាទ មិនវង្វេង មិនភ័យខ្ងាច មិនប្រណាំងវាសនា មិនសង្ស័យ មិនងឿងឆ្ងល់ ភាពជាអ្នកពោលពិត ភាពជាអ្នកពោលតែវាចា មិនស៊ិកសៀត មិនគ្រោតគ្រាត មិនឥតប្រយោជន៍ ជាអ្នកមិនខ្ជិលច្រអូស ទាំងពេលយប់ និងពេលថ្ងៃ ជាអ្នកមានកតញ្ញូ ជាអ្នកមានកតវេទី ជាអ្នកមិនកំណាញ់ ជាអ្នកលះបង់ ជាអ្នកមានសីល ជាមនុស្សទៀងត្រង់ ជាអ្នកមិនក្រោធ ជាអ្នកមានហិរិ ជាអ្នកមានឧត្តប្បៈ ជាអ្នកមានសម្មាទិដ្ឋិ ជាអ្នកមានបញ្ញាច្រើន ជាអ្នកមានការដឹង ជាបណ្ឌិត ជាអ្នកឈ្ងាសក្នុងវត្ថុដែលជា

ប្រយោជន៍ និងមិនជាប្រយោជន៍ជាដើម ។ ក្នុងសេចក្តីនេះ គប្បីជ្រាប វិនិច្ឆ័យដោយសមុដ្ឋាន វេទនា មូល កម្ម និងផល ដោយប្រការដូចពោល មក ដូច្នេះ ។

ពណ៌នាសិក្ខាបទ ៥ ខាងក្រោយ

ពាក្យដែលខ្ញុំពោលថា យុត្តិអំពីពាក្យពណ៌នា ៥ សិក្ខាបទដើមនោះ គួរនាំមកប្រើក្នុង ៥ សិក្ខាបទក្រោយ គួរពោលជាសិក្ខាបទមួយៗ និងគួរជ្រាបថា សិក្ខាបទមានយ៉ាងអាក្រក់ជាដើមផង ឥឡូវនេះ នឹងពណ៌នាដូចតទៅនេះ ។ ពាក្យណា ក្នុងកិច្ចពណ៌នា ៥ សិក្ខាបទដើម រមែងយុត្តិ ពាក្យនោះ រមែងគួរដល់ការពណ៌នានោះ មកប្រកបក្នុង ៥ សិក្ខាបទខាងក្រោយ ។ ក្នុងសេចក្តីនេះ ប្រកបសេចក្តីដូច្នេះថា បើពោលដោយអារម្មណ៍ ក្នុងសិក្ខាបទមុនៗ សុរាមេរយមជ្ជប្បមាទដ្ឋាន មានសង្វារ មានរូបាយតនៈណាមួយជាដើម ជាអារម្មណ៍ យ៉ាងណា ក្នុងទីនេះ វិកាលភោជនក៏ដូច្នោះ គប្បីជ្រាបសេចក្តីផ្សេងគ្នានៃអារម្មណ៍របស់សិក្ខាបទក្រោយ គ្រប់សិក្ខាបទដោយនយនេះ ។

តែបើពោលដោយសមាទាន ៥ សិក្ខាបទខាងដើម ដែលសាមណេរ ឬឧបាសកសមាទាន រមែងឈ្មោះថា សមាទានហើយ យ៉ាងណា ៥ សិក្ខាបទក្រោយនេះ ក៏ដូច្នោះ ។ បើពោលដោយអង្គ ការផ្សេងគ្នារបស់អង្គនៃសិក្ខាបទ ៥ ខាងដើម មានបាណាតិបាតជាដើម បានពោលហើយក្នុងទីនោះ យ៉ាងណា ក្នុងទីនេះ ក៏ដូច្នោះ ។

វិកាលភោជន មានអង្គ ៤ គឺវិកាល ១ របស់ជាយាវកាលិក ១ ការ

បរិភោគ ១ ភាពមិនជាមនុស្សឆ្កួត ១ ។ គប្បីជ្រាបការផ្សេងគ្នានៃអង្គរបស់សិក្ខាបទក្រៅអំពីនោះដោយទំនងនេះ ។

ម្យ៉ាងទៀត បើពោលដោយសមុដ្ឋាន ក្នុងទីនោះ សុភមេរយមជ្ឈប្បមាទដ្ឋានមានសមុដ្ឋាន ២ គឺកាយ ១ កាយចិត្ត ១ យ៉ាងណា ក្នុងទីនេះ វិកាលកោជន ក៏ដូច្នោះ គប្បីជ្រាបសមុដ្ឋានរបស់សិក្ខាបទ គ្រប់សិក្ខាបទដោយនយដូច្នេះ ។

ម្យ៉ាងទៀត បើពោលដោយវេទនា ក្នុងទីនេះ អទិន្នាទាន ប្រកបដោយវេទនា ៣ យ៉ាងណាមួយ យ៉ាងណា ក្នុងទីនេះ វិកាលកោជន ក៏យ៉ាងនោះ គប្បីជ្រាបការប្រកបព្រម ដោយវេទនារបស់សិក្ខាបទ គ្រប់សិក្ខាបទ ដោយនយនេះ ។

ម្យ៉ាងទៀត ក្នុងទីនោះ អព្រហ្មចរិយៈ មានលោកៈ និងមោហៈជាមូល យ៉ាងណា សូម្បីក្នុងទីនេះ វិកាលកោជន និងសិក្ខាបទ ២ ទៀត ក៏ដូច្នោះ គប្បីជ្រាបការផ្សេងគ្នានៃមូលរបស់សិក្ខាបទ គ្រប់សិក្ខាបទដោយនយនេះ ។

ម្យ៉ាងទៀត ក្នុងទីនោះ បាណាតិបាតជាដើម ជាកាយកម្ម យ៉ាងណា សូម្បីក្នុងទីនេះ វិកាលកោជនជាដើមក៏ដូច្នោះ ។

ម្យ៉ាងទៀត **ជាតរូបរជតប្បដិគ្គហាន** *ជាកាយកម្មក៏មាន ជាវចីកម្មក៏មាន ដោយបរិយាយនៃការប្រព្រឹត្តទៅ និងការកើតតាមកាយទ្វារជាដើម មិនមែនកម្មបថ ។*

ម្យ៉ាងទៀត បើពោលដោយវិរតិ ក្នុងទីនោះ បុគ្គលកាលវៀរ រមែងវៀរ

ចាកអកុសល មានបាណាតិបាតជាដើមរបស់ខ្លួន ឬរបស់អ្នកដទៃ យ៉ាងណា ក្នុងទីនេះ ក៏រមែងវៀរចាកអកុសល មានវិកាលភោជនជាដើម ក៏ដូច្នោះ ។

ម្យ៉ាងទៀត បើពោលដោយភាពជាកុសល ក៏តែមួយដូចគ្នា ។ ក្នុង ៥ វេរមណីខាងដើម មាន ៤ សមុដ្ឋាន គឺកាយ ១ កាយចិត្ត ១ វាចាចិត្ត ១ និងកាយវាចាចិត្ត ១ គ្រប់វេរមណីប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន មានអលោភៈ អទោសៈជាមូលក៏មាន មានអលោភៈ អទោសៈ អមោហៈជាមូលក៏មាន និងគ្រប់វេរមណី ឲ្យកើតផលដែលគួរជ្រាបថ្លា មានប្រការផ្សេងៗ យ៉ាងណា ក្នុងទីនេះ ក៏ដូច្នោះ ទើបខ្ញុំពោលថា

យុត្តិអំពីកិច្ចពណ៌នា ៥ សិក្ខាបទខាងដើមនោះ គួរនាំមកប្រើក្នុង ៥ សិក្ខាបទក្រោយ គួរពោលសិក្ខាបទជាលំដាប់ៗ គួរជ្រាបថា សិក្ខាបទមានយ៉ាងអាក្រក់ជាដើមផងដែរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង ៥ សិក្ខាបទខាងក្រោយនោះ ។ ពាក្យថា **វិកាលភោជនំ** *បានដល់ ការបរិភោគអាហារកន្លងកាលវេលាអំពីថ្ងៃត្រង់ ។ ពិតហើយ ការបរិភោគអាហារ បើកន្លងកាលថ្ងៃត្រង់នោះ គឺការបរិភោគអាហារកន្លងកាល ដែលទ្រង់អនុញ្ញាត ព្រោះដូច្នោះ ទើបលោកហៅថា វិកាលភោជន ចេតនាវៀរចាកការបរិភោគអាហារក្នុងវេលាវិកាលនោះ។ ក្នុងពាក្យថា* **នច្ចគីតវាទិតវិសូកទស្សនំ** *នេះ ការរាំណាមួយ ឈ្មោះថា* **នច្ច** *ការច្រៀងណាមួយ ឈ្មោះថា* **គីត** *ការប្រគំណាមួយ ឈ្មោះថា* **វាទិត ។** *ការមើលវត្ថុជាសត្រូវ ព្រោះទម្លាយធម៌ចំណែកកុសល ដោយជាបច្ច័យ ធ្វើ*

ឲ្យកើតកិលេស ឈ្មោះថា **វិសូកទស្សន** *ឬការមើល ការឃើញដែលជាសត្រូវ ក៏ឈ្មោះថា* **វិសូកទស្សន** *។ ការរាំផង ការច្រៀងផង ការប្រគំផង ការមើលវត្ថុដែលជាសត្រូវផង ឈ្មោះថា* **នច្ចគីតវាទិតវិសូកទស្សន** *។ វិសូកទស្សនៈក្នុងទីនេះ គប្បីកាន់យកតាមន័យ ដែលត្រាស់ក្នុងព្រហ្មជាល-សូត្រ ។ ពិតហើយ ក្នុងព្រហ្មជាលសូត្រនោះ ព្រះមានព្រះភាគត្រាស់ថា*

ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយៗ នូវការស្តាប់ និងការមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ មានសភាពយ៉ាងនេះ ។ ឯល្បែងដែលជាសត្រូវដល់កុសលធម៌នោះ តើដូចម្តេចខ្លះ ។ គឺល្បែងរាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ មហោស្រពខ្លះ ចម្បាំងស្តេចការតៈ និងព្រះរាមជាដើមខ្លះ គងខ្លះ រគាំងខ្លះ ស្គរមានជ្រុង ៤ ខ្លះ រូបគំនូរខ្លះ ល្បែងដុំដែកខ្លះ ល្បែងវាវខ្លះ ល្បែងលាងឆ្នែងខ្លះ ជីវជល់គ្នាខ្លះ សេះប្រខាំគ្នាខ្លះ ក្របីជល់គ្នាខ្លះ គោជល់គ្នាខ្លះ ពពែជល់គ្នាខ្លះ កែះជល់គ្នាខ្លះ មាន់ជល់គ្នាខ្លះ ចាបជល់គ្នាខ្លះ ល្បែងគុនដំបងខ្លះ ប្រដាល់ខ្លះ ចំបាប់ខ្លះ ទីសម្រាប់ច្បាំងគ្នាខ្លះ ទីសម្រាប់រៀបពលខ្លះ លំនៅកងទ័ពខ្លះ ទីមើលសេនាប្រកបដោយអង្គ ៤ ខ្លះ ។ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកកិរិយាស្តាប់ និងការមើលល្បែង ដែលជាសត្រូវដល់កុសលធម៌ មានសភាពដូច្នេះឯង ។

ម្យ៉ាងទៀត ការរាំ ការច្រៀង និងការប្រគំតាមដែលពោលមកហើយ

ប៉ុណ្ណោះដែលជាសត្រូវ ឈ្មោះថា **នច្ចគីតវាធិតវុសូក** ការមើល ការរាំ ការច្រៀង ការប្រគំ ដែលជាសត្រូវទាំងនោះ ឈ្មោះថា **នច្ចគីតវាធិត-វិសូកទស្សន** ចេតនាវៀរចាកការរាំ ការច្រៀង និងប្រគំដែលជាសត្រូវនោះ កាលគួរនឹងពោលថា **ទស្សនសវនា** សូម្បីការស្តាប់ លោកក៏ហៅថាទស្សន: ដូចគ្នា ។ ការយល់ឃើញ សូម្បីមិនមែនប្រព្រឹត្តទៅតាមចក្ខុទ្វារ លោកក៏ហៅថា ទស្សន: ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **សោ ច ហោតិ មិច្ឆាទិដ្ឋិកោ វិបរីតទស្សនោ** បុគ្គលនោះ រមែងជាមិច្ឆាទិដ្ឋិ មានការឃើញ ខុស មានទស្សន:វិបរិត ។ ឯការកន្ងងល្មើសក្នុងសិក្ខាបទនេះ រមែងមានដល់បុគ្គលចូលទៅមើល ព្រោះចង់មើលប៉ុណ្ណោះ ឯបុគ្គលដើរទៅជួប ឬ ឃើញចំពោះ (អារម្មណ៍) ដែលមកប្រាកដ ក្នុងឧកាសដែលឈរ អង្គុយ ដេក ក៏មានតែការសៅហ្មង មិនមែនកន្ងងល្មើស ។ ក្នុងសិក្ខាបទនេះ ការច្រៀងដែលអាស្រ័យធម៌ ក៏មិនគួរ តែធម៌ដែលអាស្រ័យការច្រៀង គប្បីជ្រាបថា សមគួរ ។

ផ្តាជាដើម គប្បីប្រកបដោយការទ្រទ្រង់ តាមសមគួរក្នុងសិក្ខាបទនោះ ។ ពាក្យថា **មាលា** បានដល់ ផ្តាប្រភេទណាមួយ ។ ពាក្យថា **វិលេបន** បានដល់ របស់ណាមួយ ដែលគេបុកផ្សំដើម្បីលាប ក្រៅអំពីនោះ គ្រឿងក្រអូបមានលម្អិត និងផ្សែងអប់ជាដើមគ្រប់យ៉ាង ឈ្មោះថា គ្រឿងក្រអូប ។ គ្រឿងក្រអូបគ្រប់យ៉ាង ប្រើតាក់តែង ប្រដាប់ មិនគួរ តែប្រើជាថ្នាំ គួរ ។ គ្រឿងក្រអូបដែលគេនាំមកដើម្បីបូជា សម្រាប់បុគ្គលដែលទទួលទុក រមែង

មិនគួរ ដោយបរិយាយណាមួយឡើយ ។ ទីដេកលើសង្ឃាត លោកហៅថា **ឧច្ចាសយនំ** *ទីដេកជាអកប្បិយ និងគ្រឿងកម្រាលដែលជាអកប្បិយ លោកហៅថា* **មហាសយនំ** *ទីដេកទាំង ២ យ៉ាងនោះ សម្រាប់បុគ្គលដែលទទួលវ៉ែងមិនគួរ ទោះក្នុងបរិយាយណាមួយក៏ដោយ ។*

បទថា **ជាតរូប** *បានដល់ មាស ។ បទថា* **រជត** *បានដល់ កហាបណៈ គឺរបស់ណាមួយ មានមាសកលោហៈ មាសកឈើ និងមាសកជ័រជាដើមដែលគេចាយវាយក្នុងប្រទេសនោះៗ ។ មាស និងប្រាក់ទាំង ២ នោះ ឈ្មោះថា* **ជាតរូបរជត ។** *ការទទួលយកមាស និងប្រាក់នោះ ឈ្មោះថា* **បដិគ្គហា** *គឺការទទួល ។ ការទទួលនោះ វ៉ែងមិនគួរ ទោះបរិយាយណាក៏ដោយ ។ គប្បីជ្រាបសិក្ខាបទនីមួយៗ ដូចពោលមកដូច្នេះ ។*

ទាំង ១០ សិក្ខាបទនេះ បុគ្គលសមាទានដោយឆន្ទៈ ឬវីរិយៈ ចិត្ត វិមង្សាដែលថោកថយ ឈ្មោះថា **ហីន ។** *ដោយឆន្ទៈ វីរិយៈ ចិត្ត និងវិមង្សាជាកណ្តាល ឈ្មោះថា* **មជ្ឈិម ។** *ដោយឆន្ទៈ វីរិយៈ ចិត្ត វិមង្សា យ៉ាងប្រណីត ឈ្មោះថា* **បណីត ។** *ម្យ៉ាងទៀត សិក្ខាបទ ១០ នេះ សៅហ្មងដោយតណ្ហា ទិដ្ឋិ និងមានះ ឈ្មោះថា យ៉ាងអាក្រក់ ។ ដែលមិនសៅហ្មង ឈ្មោះថា កណ្តាល ។ ដែលបញ្ញាឧបត្ថម្ភក្នុងសិក្ខាបទនោះៗ ឈ្មោះថា យ៉ាងល្អ ។ ម្យ៉ាងទៀត សិក្ខាបទទាំងនេះ ដែលសមាទានដោយកុសលចិត្តជាញាណវិប្បយុត្ត ឈ្មោះថា យ៉ាងអាក្រក់ ។ ដែលសមាទានដោយកុសល-*

ចិត្ត ជាញាណសម្បយុត្ត ជាសសង្ខារិក ឈ្មោះថា ជាកណ្ហាល ។ ដែល សមាទានដោយកុសលចិត្តជាញាណសម្បយុត្ត អសង្ខារិក ឈ្មោះថា យ៉ាង ល្អ ។ គប្បីជ្រាបសិក្ខាបទ មានយ៉ាងអាក្រក់ជាដើម ដូចពោលមកដូច្នេះ ។

មាតិកាឯណា ខ្ញុំលើកឡើងជាបទតាំងទុក ដើម្បីពណ៌នាបាឋៈនៃសិក្ខាបទ ដោយ ៦ គាថា មានពាក្យថា សិក្ខាបទនេះ បុគ្គលណាពោល ពោលទីណា ពោលក្នុងកាលណា ពោលព្រោះហេតុអ្វីជាដើម មាតិកានោះខ្ញុំប្រកាសដោយ អត្ថ ដោយពាក្យមានប្រមាណប៉ុណ្ណេះឯង ។

អធិប្បាយសិក្ខាបទ ចប់

សុត្តន្តបិដក

ខុទ្ទកនិកាយ: អាការ ៣២

[៣] ក្នុងកាយនេះ មានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង ទាច បេះដូង ថ្លើម ពោះវៀន ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បារ ទឹករំអិល ទឹកមូត្រ ខួរក្នុងក្បាល ។

អាការ ៣២ ចប់

អដ្ឋកថា

ទុត្តិសាការ

សម្ពន្ធនៃបទ

[៣] *កម្មដ្ឋាន គឺកាយគតាសតិនេះ ដែលពួកតិរ្ថិយទាំងពួង មិនធ្លាប់ឲ្យប្រព្រឹត្តទៅហើយ ក្រៅពុទ្ធកាល ដើម្បីការបរិសុទ្ធនៃអាសយញ្ញាណ និង ដើម្បីចិត្តការនារបស់កុលបុត្រដែលមានបយោគដ៏បរិសុទ្ធ ដោយសិក្ខាបទ ១០ យ៉ាងនេះ ជាអ្នកតាំងនៅក្នុងសីល ព្រះមានព្រះភាគទ្រង់សរសើរដោយ អាការដ៏ច្រើន ក្នុងព្រះសូត្រនោះ យ៉ាងនេះថា*

ម្នាលភិក្ខុទាំងឡាយ ធម៌មួយយ៉ាងដែលបុគ្គលបានចម្រើនហើយ បាន សន្សំរឿយៗ ហើយ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសង្វេគច្រើន តែងប្រ-ព្រឹត្តទៅ ដើម្បីសេចក្តីចម្រើនច្រើន តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីក្សេមចាក យោគៈច្រើន តែងប្រព្រឹត្តទៅ ដើម្បីបាននូវសតិ និងសម្បជញ្ញៈ តែងប្រ-ព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ តែងប្រព្រឹត្តទៅ ដើម្បីនៅជាសុខ ក្នុង បច្ចុប្បន្ន តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា វិមុត្តិ និងផល ។ ធម៌មួយយ៉ាង គឺអ្វី ។ គឺកាយគតាសតិ ។

ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាមិនបរិភោគនូវកាយគតាសតិ ពួកភិក្ខុ នោះឈ្មោះថា មិនបរិភោគនូវព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា បរិភោគនូវកាយគតាសតិ ពួកភិក្ខុនោះ ទើបឈ្មោះថា បរិភោគនូវព្រះនិព្វាន ។

ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាមិនបរិភោគ ព្រះ និព្វានក៏ឈ្មោះថា ពួកភិក្ខុទាំងនោះ មិនបរិភោគដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាបរិភោគហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុ នោះបរិភោគដែរ ។

ម្នាលភិក្ខុទាំងឡាយ កាយគតាសតិរបស់ពួកភិក្ខុណាសាបសូន្យហើយ ព្រះនិព្វានរបស់ពួកភិក្ខុនោះ ក៏ឈ្មោះថា សាបសូន្យដែរ ។ ម្នាលភិក្ខុទាំង-ឡាយ កាយគតាសតិរបស់ពួកភិក្ខុណាមិនសាបសូន្យ ព្រះនិព្វានរបស់ពួក ភិក្ខុនោះ ក៏ឈ្មោះថា មិនសាបសូន្យដែរ ។

ដូច្នេះហើយ ទ្រង់សម្តែងជាបព្វៈ ១៤ គឺអានាបានបព្វៈ ឥរិយាបថបព្វៈ

ចតុសម្បជញ្ញបព្វៈ បដិកូលមនសិការបព្វៈ ធាតុមនសិការបព្វៈ នវសីវថិកាបព្វៈ មាន ៩ បព្វៈ ដោយន័យថា

ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលបុគ្គលបានចម្រើន ដូចម្តេច បានធ្វើឲ្យរឿយៗ ដូចម្តេច ទើបមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ... ដូច្នេះជាដើម ។

ឥឡូវនេះ និទ្ទេសនៃការចម្រើនកាយគតាសតិកម្មដ្ឋាននោះ មកដល់តាមលំដាប់ហើយ ក្នុងនិទ្ទេសនោះ ខ្ញុំពោលជាវិបស្សនា ៣ បព្វៈ គឺឥរិយាបថបព្វៈ ចតុសម្បជញ្ញបព្វៈ ធាតុមនសិការបព្វៈ ពោលនវសីវថិកាបព្វៈ ជាអាទីនវាបុនស្សនាក្នុងវិបស្សនាញ្ញាណ ឯសមាធិភាវនាក្នុងខុទ្ទមាតិកអសុភជាដើម ក្នុងនិទ្ទេសនោះ ដែលគប្បីប្រាថ្នា ខ្ញុំក៏ប្រកាសពិស្តារហើយ ក្នុងអសុភភាវនានិទ្ទេស គម្ពីរវិសុទ្ធិមគ្គទាំងអស់ ។ ២ បព្វៈនេះ គឺអានាបានបព្វៈ និងបដិកូលមនសិការបព្វៈ ក៏ពោលជាសមាធិហើយ ក្នុងនិទ្ទេសនោះ ក្នុង ២ បព្វៈនោះ អានាបានបព្វៈ ជាកម្មដ្ឋានមួយផ្នែកដោយពិត ដោយជាអានាបានសតិ ឯកម្មដ្ឋាន គឺទុតិសាការនោះ ជាបរិយាយនៃភាវនាចំណែកមួយរបស់កាយគតាសតិ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងសង្គ្រោះខ្លួរក្នុងក្បាល ដោយខ្លួរក្នុងឆ្អឹង ក្នុងបាលីបទេសនោះៗ យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញច្បាស់ នូវកាយនេះឯង ខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះ

មក ដែលមានស្បែកបិទបាំងជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការ ផ្សេងៗ ដូច្នេះថា ក្នុងកាយនេះ មានសក់ រោម ។បេ។ ទឹកមូត្រ ដូច្នេះ ។ ខ្ញុំផ្តើមហើយ កម្មដ្ឋាន គឺទុត្តិសាការនោះ និងពណ៌នាសេចក្តីដូចតទៅនេះ

បណ្តាបទទាំងនោះ បទថា **អត្ថិ** *ប្រែថា មាន ។ បទថា* **ឥមស្មឹ** *សេចក្តីថា ដែលពោលតាំងអំពីបាតជើងឡើងទៅ អំពីចុងសក់ចុះមក មានស្បែកស្រោបដោយជុំវិញ ពេញទៅដោយរបស់មិនស្អាត មានប្រការផ្សេងៗ ។ បទថា* **កាយេ** *បានដល់ ក្នុងសរីរៈ ។ ពិតហើយ សរីរៈ ហៅថា កាយ ព្រោះសន្សំរបស់មិនស្អាត ឬព្រោះជាទីចម្រើនដុះដាលនៃសក់ជាដើម ដែលគួរខ្ពើម និងរបស់រោគរាប់រយ មានរោគក្អែកជាដើម ។ បទថា* **កេសា ។បេ។ មុត្តំ** *គឺអាការ ៣២ មានសក់ជាដើមនេះ ក្នុងទុត្តិសាការនេះ គប្បីជ្រាបការសម្ពន្ធសេចក្តីយ៉ាងនេះថា សក់នៅក្នុងកាយនេះ រោមមាននៅក្នុងកាយនេះជាដើម ។ ឈ្មោះថា ត្រាស់នូវអ្វី ដោយទុត្តិសាការកម្មដ្ឋាននោះ ជាការត្រាស់ថា បុគ្គលណាម្នាក់ កាលពិចារណាដោយអាការគ្រប់យ៉ាង ក្នុងកលេវរកាយប្រមាណមួយព្យាមនេះ គឺប្រមាណប៉ុណ្ណេះ ខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក ពាសដោយស្បែកជុំវិញ តែងមិនឃើញអ្វីមួយ ទោះជាកែវមុក្តា កែវមណី កែវពិទូរ្យ ក្រស្នា ចន្ទន៍ ស្បូវ ភ្ញាំង កប៊ូរ ឬលម្អិតជាដើម សូម្បីទំហំតូចមួយ ថាស្អាត ដោយពិត រមែង*

ឃើញកាយ មានសក់ រោមជាដើម ដែលមានក្លិនស្អុយ គួរខ្ពើមយ៉ាងក្រៃលែង មិនមានសិរីដែលគួរមើលឡើយ មានប្រការផ្សេងៗ ថាមិនស្អាតតែម្យ៉ាង ។

ពណ៌នាដោយការសម្ពន្ធនៃបទ

ក្នុងទុត្តីសាការកម្មដ្ឋាននេះប៉ុណ្ណោះសិន

អសុភភាវនា

គប្បីជ្រាបការពណ៌នាទុត្តីសាការកម្មដ្ឋាននោះ ជាអសុភភាវនា ដូចតទៅ

ជាបឋម កុលបុត្រដែលផ្តើមបំពេញកម្មដ្ឋាន ជាអ្នកតាំងនៅក្នុងសីល មានបាណាតិបាតវេរមណីសិក្ខាបទជាដើមយ៉ាងនេះហើយ មានប្រយោគដែលបរិសុទ្ធ បំណងប្រកបរឿយៗ នូវអនុយោគ គឺការបំពេញកម្មដ្ឋានចំណែកទុត្តីសាការ ដើម្បីសម្រេចការបរិសុទ្ធនៃអាសយញ្ញាណ កុលបុត្រនោះ រមែងមានបលិពោធ ១០ ប្រការ គឺកង្វល់ដោយលំនៅ ១ ដោយត្រកូល ១ ដោយលាភ ១ ដោយគណៈ ១ ដោយការងារ ១ ដោយការដើរផ្លូវ ១ ដោយញាតិ ១ ដោយការរៀនគម្ពីរ ១ ដោយរោគ ១ ដោយឥទ្ធិឫទ្ធិ ឬដោយការកង្វល់ដោយកិត្តិយស ១ កាលបើដូច្នោះ កុលបុត្រនេះ ក៏ត្រូវកាត់កង្វល់ទាំង ១០ នោះចេញ ដោយវិធីយ៉ាងនេះ គឺដោយការលះនូវការជាប់ជំពាក់ក្នុងអាវាស ត្រកូល លាភ គណៈ ញាតិ និងកិត្តិយសចោល ដោយការមិនខ្វល់ខ្វាយក្នុងការងារ ការដើរផ្លូវ និងការរៀនគម្ពីរ ដោយការព្យាបាលរោគ កាលបើដូច្នោះ កុលបុត្រនេះ កាត់បលិពោធបានហើយ មិនកាត់ការត្រេកអរក្រៃលែងក្នុងនេក្ខម្ម: កំណត់ការបដិបត្តិ ជុសខាត់ រហូតដល់ខាងចុង មិន

លះបង់អាចារ តាមព្រះវិន័យសូម្បីតិចតួច ក៏គប្បីចូលទៅរកអាចារ្យអ្នកឲ្យកម្មដ្ឋាន ដែលជាបុគ្គលប្រកបដោយអាគម គឺបរិយត្តិ អធិគម គឺបដិវេធ ឬប្រកបដោយគុណឯណាមួយ អំពីអាគម និងអធិគមនោះ ដោយវិធីដែលសមគួរដល់ព្រះវិន័យ និងគប្បីជ្រាប់បំណងរបស់ខ្លួនដល់អាចារ្យនោះ ដែលខ្លួនធ្វើឲ្យលោកមានចិត្តត្រេកអរ ដោយបវត្តសម្បទា ។ អាចារ្យនោះ គប្បីជ៏ងការផ្សេងគ្នានៃនិមិត្ត ដែលអាស្រ័យចរិយា និងអធិមុត្តិរបស់កុលបុត្រនោះ បើកម្មដ្ឋាននោះ ជារបស់សមគួរ កាលបើដូច្នោះ កុលបុត្រនោះ បំណងនឹងនៅក្នុងវិហារដែលខ្លួននៅសោត បន្ទាប់អំពីនោះ ក៏គប្បីឲ្យកម្មដ្ឋានដោយសង្ខេប បើកុលបុត្រនោះ បំណងនៅក្នុងវិហារដទៃ ក៏គប្បីជ្រាប់កម្មដ្ឋានពិស្តារ ព្រមទាំងប្រការដែលគួរធ្វើមុន ដោយជ្រាប់ប្រការដែលគួរលះ និងប្រការដែលគួរកំណត់ជ៏ងជាដើម ព្រមទាំងប្រភេទចរិត ដោយជ្រាប់កម្មដ្ឋានដែលសមគួរដល់រាគចរិតជាដើម កុលបុត្រនោះ កាលរៀនកម្មដ្ឋាន ព្រមទាំងប្រការដែលគួរធ្វើមុន មួយអន្ទើដោយប្រភេទនោះហើយ លាអាចារ្យរៀរសេនាសនៈ ១៨ ប្រភេទដែលគួររៀរដូច្នេះ គឺ

អាវាសធំ អាវាសថ្មី (អាវាសដែលធ្វើមិនទាន់ហើយ) អាវាសចាស់ (អាវាសដែលទ្រុឌទ្រោម) អាវាសជិតផ្លូវ អាវាសក្បែរត្រពាំងទឹក អាវាសដែលមានស្មៅឈើ អាវាសមានផ្កាឈើ អាវាសមានផ្លែឈើ អាវាសដែលបុគ្គលទាំងឡាយប្រាថ្នា (អាវាសដែលមនុស្សចូលចិត្តមក) អាវាសជិតនគរ អាវាសជិតព្រៃឧស អាវាសជិតស្រែចម្ការ អាវាសដែលមានអារម្មណ៍

ជាសត្រូវ អាវាសក្បែរកំពង់ទឹក អាវាសជាប់ព្រំដែន អាវាសត្រង់ចន្លោះព្រំដែន អាវាសដែលជាអសប្បាយ អាវាសដែលមិនបានកល្យាណមិត្ត បណ្ឌិតស្គាល់ទី ១៨ ប្រការនេះ ដូច្នេះហើយ គប្បីវៀរឲ្យឆ្ងាយ ដូចអ្នកដើរផ្លូវវៀរផ្លូវដែលមានភ័យចំពោះមុខ ដូច្នោះ ។ ហើយចូលទៅកាន់សេនាសនៈដែលប្រកបដោយអង្គ ៥ ដែលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា

> *ម្នាលភិក្ខុទាំងឡាយ ចុះសេនាសនៈប្រកបដោយអង្គ ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេនាសនៈក្នុងលោកនេះ មិនឆ្ងាយពេក មិនជិតពេក ល្មមទៅមកស្រួល មិនកុះករដោយមនុស្សក្នុងវេលាថ្ងៃ មិនសូវមានសំឡេង មិនសូវគឹកកង៉ក្នុងរាត្រី មិនសូវមានសម្ផស្សដោយរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំ ១ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ កើតទ្បើងដល់ភិក្ខុដែលនៅក្នុងសេនាសនៈនោះដោយមិនលំបាក ១ ពួកភិក្ខុជាថេរៈដែលនៅក្នុងសេនាសនៈនោះ ជាពហុស្សូត ចេះចាំនូវនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិនយ ទ្រទ្រង់មាតិកា ១ ភិក្ខុចូលទៅរកភិក្ខុជាថេរៈទាំងនោះម្តងៗ ហើយសួរប្រឹក្សាថា បពិត្រលោកដ៏ចម្រើន រឿងនេះ តើដូចម្តេច សេចក្តីអធិប្បាយនៃរឿងនេះ តើដូចម្តេច*

១ លោកដ៏មានអាយុទាំងនោះ រមែងពន្យល់រឿង ដែលមិនទាន់ច្បាស់លាស់ផង ធ្វើឲ្យងាយនូវរឿង ដែលជ្រៅផង បន្ទោបង់នូវសេចក្តីសង្ស័យក្នុងធម៌ ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីសង្ស័យច្រើន ប្រការផង ១ ។ ម្នាលភិក្ខុទាំងឡាយ សេនាសនៈ ប្រកបដោយអង្គ ៥ យ៉ាងនេះឯង ។

ដូច្នេះហើយ ធ្វើកិច្ចគ្រប់យ៉ាងឲ្យសម្រេចហើយ ពិចារណាទោសក្នុងកាមទាំងឡាយ និងអានិសង្សក្នុងនេក្ខម្មៈ ធ្វើចិត្តឲ្យជ្រះថ្លា ដោយការរឭកដល់ព្រះរតនត្រ័យ ដោយភាវៈដែលព្រះសម្ពុទ្ធត្រាស់ដឹងល្អហើយ ដោយភាវៈដែលព្រះធម៌ ជាធម៌ល្អ និងដោយភាវៈដែលព្រះសង្ឃជាអ្នកបដិបត្តិល្អហើយ មិនលះឧគ្គហកោសល ៧ យ៉ាង ដែលលោកពោលយ៉ាងនេះថា

អ្នកប្រាជ្ញ ជាអ្នកឈ្លាសក្នុងឧបាយ ៧ គឺដោយវាចា ដោយចិត្ត ដោយវណ្ណៈ ដោយសណ្ឋាន ដោយទិស ដោយឱកាស និងដោយបរិច្ឆេទ និងមនសិការ-កោសល ១០ យ៉ាង ដែលលោកពោលទុកយ៉ាងនេះ គឺដោយលំដាប់ ដោយមិនលឿនពេក មិនយឺតពេក ដោយការពារសេចក្តីរាយមាយ ដោយកន្ទងបញ្ញត្ត ដោយរំលងលំដាប់ ដោយអប្បនា និងសូត្រ ៣ ទើប គួរផ្តើមចម្រើនទុត្តិសាការ ពិតហើយ ការចម្រើន

ទុត្តីសាការដោយអាការគ្រប់យ៉ាង រមែងសម្រេចដល់អ្នកផ្តើម ដូចពោលមកនេះ មិនមែនសម្រេចដោយប្រការដទៃទេ ។

ក្នុងការចម្រើនទុត្តីសាការនោះ ភិក្ខុទទួលតចបញ្ចកកម្មដ្ឋានមុនខាងដើម ពោលដោយព្រះត្រៃបិដក កាលតចបញ្ចកកម្មដ្ឋានស្ទាត់ជំនាញហើយ ដោយអនុលោមតាមន័យថា **កេសា លោមា** *ជាដើម ស្ទាត់ជំនាញហើយដោយបដិលោម តាមន័យថា* **តចោ ទន្តា** *ជាដើម គប្បីចម្រើនកន្ទះខែ ដោយវាចា ដើម្បីកាត់បង់នូវវិតក្កដែលរាយមាយទៅខាងក្រៅ ដោយអនុលោមនិងបដិលោមតាមន័យទាំង ២ នោះឯង ដើម្បីឲ្យស្ទាត់ក្នុងបាលី និងផ្លូវចិត្ត ដើម្បី កំណត់សភាវៈនៃចំណែកវាងកាយជាអារម្មណ៍ ពិតហើយ ការចម្រើនផ្លូវវាចា នូវតចបញ្ចកកម្មដ្ឋាននោះ កាត់បង់នូវការរាយមាយទៅខាងក្រៅបានហើយ រមែងជាបច្ចយដល់ការចម្រើនផ្លូវវាចា ព្រោះស្ទាត់ក្នុងបាលីហើយ ការចម្រើនផ្លូវចិត្ត រមែងជាបច្ចយដល់ការកំណត់ពណ៌នៃអសុភ និងលក្ខណៈចំណែកណាមួយ កាលបើដូច្នោះ ដោយន័យនោះ ក៏គប្បីចម្រើនវក្កបញ្ចក-កម្មដ្ឋាន គឺពួកធម៌ ៥ មានវក្កំជាគម្រប់ ៥ អស់កន្ទះខែ បន្ទាប់អំពីនោះ សឹមចម្រើនតចបញ្ចកកម្មដ្ឋាន និងវក្កបញ្ចកកម្មដ្ឋានទាំង ២ នោះអស់កន្ទះខែ បន្ទាប់អំពីនោះ សឹមចម្រើនបដ្ឋាសបញ្ចកកម្មដ្ឋានកន្ទះខែទៀត បន្ទាប់អំពីនោះ ក៏ចម្រើនទាំង ៣ បញ្ចក: នេះប្រមាណកន្ទះខែ កាលបើដូច្នោះ ក៏គប្បីបន្ថែមមត្តលុទ្ធំដែលមិនបានត្រាស់ទុកខាងចុង ក្នុង ៣ ពួកនេះ ដើម្បីចម្រើន*

រួមគ្នា ជាមួយអាការនៃបឋវីធាតុទាំងឡាយ ហើយចម្រើនមត្តលុង្គំកន្ទះខែ បន្ទាប់អំពីនោះ ក៏ចម្រើនបញ្ចកៈ និងចតុក្កៈកន្ទះខែ មេទធក្កៈកន្ទះខែ បន្ទាប់អំពីនោះ ក៏ចម្រើនបញ្ចកៈ និងចតុក្កៈរួមគ្នាជាមួយមេទធក្កៈកន្ទះខែ មុត្តធក្កៈកន្ទះខែ បន្ទាប់អំពីនោះ ក៏ចម្រើនទ្វត្តឹសាការទាំងអស់កន្ទះខែ គប្បីចម្រើនកំណត់ដោយវណ្ណៈ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ ចំនួន ៦ ខែ ដូចពោលមក ដូច្នេះ ។ សេចក្តីនេះ លោកពោលសំដៅដល់បុគ្គលដែលមានបញ្ញាថ្នាក់កណ្តាល ឯបុគ្គលដែលមានបញ្ញាទន់ខ្សោយគប្បីចម្រើន ជរាបដល់អស់ជីវិត បុគ្គលមានបញ្ញាមុតស្រួច ការចម្រើនរមែងសម្រេចបានក្នុងកាលមិនយូរឡើយ ។

កេសា

ក្នុងសេចក្តីនេះ អ្នកចោទសួរពោលថា កិកុអ្នកចម្រើនកម្មដ្ឋាននេះ កំណត់ទ្វត្តឹសាការនេះដោយវណ្ណៈជាដើមដូចម្តេច សេចក្តីពិត កិកុអ្នកផ្តើមកម្មដ្ឋាន កាលចម្រើនទ្វត្តឹសាការ ដោយចែកជាតចបញ្ចកកម្មដ្ឋានជាដើម ដោយនយថា មាននៅក្នុងកាយនេះ សក់ ដូច្នេះជាដើម រមែងកំណត់សក់ជារបស់ដូចដែលកិកុនេះឃើញហើយពីមុន ដោយវណ្ណៈថា មានពណ៌ខ្មៅ កំណត់សក់ដែលមានរមូរវែង ដោយសណ្ឋានថា ដូចដងជញ្ជីង តែព្រោះហេតុក្នុងកាយនេះ ចាប់ពីពោះឡើងទៅលើ ហៅថា ទិសខាងលើ ទាបជាងពោះមកក្រោម ហៅថា ទិសខាងក្រោម ដូច្នោះ ទើបកំណត់ដោយទិសថា កើតក្នុងទិសខាងលើនៃកាយនេះ កំណត់ដោយឱកាសថា កើតត្រង់ស្បែក

ក្បាល ជុំវិញត្រចៀក និងជង-ក កំណត់សក់នោះថា សក់មិនដឹងថា អញកើតត្រង់ស្បែកក្បាល សូម្បីស្បែកក្បាល ក៏មិនដឹងថា សក់កើតត្រង់អញ ប្រៀបដូចស្មៅកុណ្ឌៈដែលកើតលើកំពូលដំបូក មិនដឹងថាអញកើតលើកំពូលដំបូក សូម្បីកំពូលដំបូក ក៏មិនដឹងថា ស្មៅកុណ្ឌៈកើតលើអញ ដូច្នោះ កំណត់ថា ពិតហើយ សក់ទាំងនេះ វៀរចាកការគិត និងការពិចារណាជាធម៌ មិនមានចេតនា ជាអព្យាកតៈ សោះសូន្យទទេ បដិកូលដោយកិន គួរខ្ពើមរអើមក្រៃលែង មិនមែនសត្វ មិនមែនបុគ្គល កាលពោលដោយបរិច្ឆេទការកាត់ផ្តាច់ មាន ២ យ៉ាង គឺកាត់ផ្តាច់ដោយសកាគ និងកាត់ផ្តាច់ដោយវិសភាគ ក្នុងបរិច្ឆេទ ២ យ៉ាងនោះ កំណត់ដោយការផ្តាច់ ដោយសកាគយ៉ាងនេះថា សក់ត្រូវកាត់ផ្តាច់ខាងក្រោមត្រឹមផ្ទៃស្បែកដែលតាំងនៅ និងដោយគល់របស់ខ្លួនដែលចូលទៅក្នុងស្បែកនោះ ប្រមាណមួយចុងគ្រាប់ស្រូវតាំងនៅខាងលើ កាត់ផ្តាច់ដោយអាកាស ទទឹងដោយសក់ផងគ្នា និងកំណត់ដោយការកាត់ផ្តាច់ ដោយវិសភាគយ៉ាងនេះថា សក់មិនមែនអាការ ៣១ ដ៏សេស អាការ ៣១ ដ៏សេស ក៏មិនមែនសក់ កំណត់សក់ដោយវណ្ណៈជាដើម ក៏មានប្រការដូចពោលមកយ៉ាងនេះ ។

លោមា

ក្នុងអាការ ៣១ ដ៏សេស ការកំណត់រោមដែលកិកូនេះធ្លាប់ឃើញហើយដោយវណ្ណៈ ដោយច្រើនមានពណ៌ខៀវ ដោយសណ្ឋាន មានសណ្ឋានដូចជង្ហ ឬមានសណ្ឋានដូចជក់ត្នោត-ង កំណត់ដោយទិសទាំង ២ កំណត់ដោយ

ឱកាសថា កើតត្រង់ស្បែកនៃសរីរៈដ៏សេស វៀរបាតដៃ-ជើង ។

ក្នុងអាការ ៣០ ដ៏សេសនោះ កំណត់ថា រោមមិនដឹងថា អញកើតត្រង់ស្បែកនៃសរីរៈ សូម្បីស្បែកនៃសរីរៈក៏មិនដឹងថា រោមកើតត្រង់អញ ប្រៀបដូចស្មៅទព្ទៈដែលកើតត្រង់ស្រុកចាស់ រមែងមិនដឹងថា អញកើតត្រង់ស្រុកចាស់ សូម្បីស្រុកចាស់ក៏មិនដឹងថា ស្មៅទព្ទៈកើតត្រង់អញ ដូច្នោះ ដ្បិតថា រោមទាំងនោះ វៀរការគិត និងការពិចារណា ជាធម៌មិនមានចេតនា ជាអព្យាកតៈ សោះសូន្យទទេ បដិកូលដោយកិនស្អុយ គួរខ្ពើមរអើមក្រៃលែង មិនមែនសត្វ មិនមែនបុគ្គល កំណត់ដោយបរិច្ឆេទថា រោមខាងក្រោមខណ្ឌដោយផ្ទៃស្បែកដែលតាំងនៅ និងគល់របស់ខ្លួនដែលចូលទៅក្នុងស្បែកនោះ ប្រមាណមួយខ្លួនចៃតាំងនៅ រោមខាងលើខណ្ឌដោយអាកាស ខាងទទឹងខណ្ឌដោយរោមផងគ្នា នេះជាការកំណត់រោមទាំងនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង កំណត់រោមដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

ឧទ្ទា

បន្ទាប់អំពីនេះទៅ ក៏កំណត់ថា បុគ្គលមានក្រចកគ្រប់គ្រាន់ក៏មាន ២០ ក្រចកទាំងអស់នោះ ដោយពណ៌ មានពណ៌ស ក្នុងឱកាសដែលផុតអំពីសាច់ មានពណ៌ក្រហមក្នុងឱកាសដែលជាប់សាច់ ដោយសណ្ឋាន មានសណ្ឋានដូចឱកាសដែលតាំងនៅ ដោយច្រើនមានសណ្ឋានដូចគ្រាប់ស្រគំ ឬមានសណ្ឋានដូចស្រកាត្រី ។ ដោយទិស តាំងនៅក្នុងទិសទាំង ២ ដោយឱកាស តាំងនៅ

ខាងចុងម្រាម ។

ក្នុងក្រចកនោះ កំណត់ថា ក្រចកវមែងមិនដឹងថា អញតាំងនៅខាងចុងម្រាម សូម្បីម្រាមក៏មិនដឹងថា ក្រចកតាំងនៅត្រង់ចុងរបស់អញ ប្រៀបដូចគ្រាប់ស្រគំដែលពួកក្មេងអ្នកស្រុកដោតត្រង់ចុងកំណាត់ឈើ មិនដឹងថា អញត្រូវដោតត្រង់ចុងកំណាត់ឈើ សូម្បីចុងកំណាត់ឈើក៏មិនដឹងថា គ្រាប់ស្រគំត្រូវដោតត្រង់អញ ដូច្នោះ ដ្បិតថា ក្រចកទាំងនោះ រៀរចាកការគិត និងការពិចារណា ជាធម៌មិនមានចេតនា ។បេ។ មិនមែនបុគ្គល កំណត់ដោយបរិច្ឆេទថា ក្រចកខាងក្រោមត្រូវខណ្ឌដោយសាច់ម្រាមត្រង់គល់ ឬដោយទីដែលតាំងនៅត្រង់គល់នោះ ខាងលើខណ្ឌដោយឧកាសត្រង់ចុង ដោយស្បែកចុងសងខាងនៃម្រាមទាំងសងខាង នេះជាការកំណត់ក្រចកទាំងនោះ ដោយសភាគ ឯការកំណត់វិសភាគក៏ដូចគ្នានឹងសក់នោះឯង កំណត់ក្រចកដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

ឧន្ទា

បន្តអំពីនោះទៅ ក៏កំណត់ថា បុគ្គលមានធ្មេញគ្រប់បរិបូណិ ក៏មាន ៣២ ធ្មេញទាំងអស់នោះ ដោយពណិ ក៏មានពណិស ដោយសណ្ឋាន ធ្មេញរបស់បុគ្គលដែលមានធ្មេញរាបស្មើ និងប្រាកដដូចផ្ទៃសង្ខដែលគេកាត់ និងដូចផ្កាពណិសក្រពុំដែលតម្រៀប ធ្មេញរបស់បុគ្គលដែលមិនរាបស្មើ មានសណ្ឋានផ្សេងៗ គ្នា ដូចលំដាប់តាំងលើអាសនៈសាលាចាស់ ។ ក្នុងចុងជួរធ្មេញសងខាងនៃធ្មេញទាំងនោះ ៨ ធ្មេញ ខាងក្រោមពីរ ខាងលើពីរ មានចុង ៤

មានគល់ ៤ មានសណ្ឋានដូចអាសន្ទិវែង ។ ៨ ធ្មេញ ដែលតាំងនៅតាម លំដាប់នោះ ក្នុងធ្មេញទាំងនោះ មានចុង ៣ មានឬស ៣ មានសណ្ឋានដូច មើមក្រចាប់ ៤ ធ្មេញ ខាងក្រោម ១ ខាងលើ ១ តាមលំដាប់នោះ ក្នុង ធ្មេញទាំងនោះ មានចុង ២ មានឬស ២ មានសណ្ឋានដូចចន្ទល់រទេះ ធ្មេញ ចន្ទូមមាន ៤ តាំងនៅតាមលំដាប់ ក្នុងធ្មេញទាំងនោះ ខាងក្រោម ១ ខាង លើ១ មានចុង ១ មានឬស ១ មានសណ្ឋានដូចផ្តាម្ចិះក្រពុំ បន្ទាប់អំពីនោះ ៨ ធ្មេញ ខាងក្រោម ៤ ខាងលើ ៤ ត្រង់កណ្តាលជួរធ្មេញទាំងសងខាង មាន ចុង ១ មានឬស ១ មានសណ្ឋានដូចគ្រាប់ឃ្ងោក ដោយទិស កើតក្នុងទិស ខាងលើ ។ ដោយឧកាស ធ្មេញលើ តាំងនៅក្នុងធ្អឹងថ្ពាមលើ មានចុងចុះ ក្រោម ធ្មេញក្រោមតាំងនៅក្នុងធ្អឹងថ្ពាមក្រោម មានចុងឡើងលើ ។

ក្នុងធ្មេញនោះ ក៏កំណត់ថា ធ្មេញមិនដឹងថា អញតាំងនៅក្នុងធ្អឹងថ្ពាម ខាងក្រោម តាំងនៅក្នុងធ្អឹងថ្ពាមខាងលើ ធ្អឹងថ្ពាមក្រោម ក៏មិនដឹងថា ធ្មេញ តាំងនៅក្នុងអញ ធ្អឹងថ្ពាមលើក៏មិនដឹងថា ធ្មេញតាំងនៅក្នុងអញ ប្រៀបដូច សសរដែលបុរសកសាងតាំងឡើងក្នុងផ្ទៃថ្មខាងក្រោម ស៊ីកចូលក្នុងផ្ទៃថ្មខាង លើ រមែងមិនដឹងថា អញត្រូវគេតាំងទុកក្នុងផ្ទៃថ្មខាងក្រោម ត្រូវស៊ីកចូលក្នុង ផ្ទៃថ្មខាងលើ ផ្ទៃថ្មខាងក្រោមក៏មិនដឹងថា សសរត្រូវគេតាំងទុកក្នុងអញ ផ្ទៃ ថ្មខាងលើក៏មិនដឹងថា សសរត្រូវគេស៊ីកចូលក្នុងអញ ដូច្នោះ ។ ជ្បិតថា ធ្មេញទាំងនោះ រៀរចាកការគិត និងការពិចារណាជាធម្មតា ។បេ។ មិនមែន បុគ្គលកំណត់ដោយបរិច្ចេទថា ធ្មេញក្រោម ខណ្ឌដោយរណ្តៅធ្អឹងថ្ពាម ស៊ីក

ចូលក្នុងឆ្នើងថ្លាមតាំងនៅ និងដោយឫសរបស់ខ្លួន ធ្វេញលើខណ្ឌដោយអាកាស ទទឹងកំណត់ដោយធ្វេញផងគ្នា នេះជាការកំណត់ធ្វេញទាំងនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ធ្វេញដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

តថោ

បន្ទាប់អំពីនេះទៅ វត្ថុដែលបិទបាំងគំនរសាកសពផ្សេងៗ ខាងក្នុងសរីរៈ ឈ្មោះថា ស្បែក ។ ស្បែកមានពណ៌ស ស្បែកនោះប្រាកដដូចមានពណ៌ផ្សេងៗ មានពណ៌ខ្មៅ ពណ៌សជាដើម ព្រោះត្រូវជ្រលក់ដោយគ្រឿងជ្រលក់ស្បែក ដូច្នោះ ក៏សនោះឯង ដោយពណ៌ដែលជាសភាគគ្នា ។ ការដែលស្បែកនោះមានពណ៌ស ប្រាកដដោយស្បែកដែលត្រូវភ្លើងរលាក និងត្រូវប្រហារដោយគ្រឿងប្រហារជាដើម ។ កំណត់ដោយសណ្ឋាន ដោយសង្ខេបថា មានសណ្ឋានដូចអាវ ដោយពិស្តារថា មានសណ្ឋានផ្សេងៗ ។ ពិតហើយ ស្បែកម្រាមជើងមានសណ្ឋានដូចសម្បុកជង្កវនាង ស្បែកខ្នងជើង មានសណ្ឋានដូចស្រោមជើងដែលគេខូចប់ ស្បែកស្មង មានសណ្ឋានដូចស្លឹកត្នោតដែលគេខូចបាយ ស្បែកជើង មានសណ្ឋានដូចថង់វែង ដែលគេច្រកអង្ករពេញ ស្បែកត្រគាក មានសណ្ឋានដូចសំពត់តម្រង់ទឹក ដែលមានទឹកពេញ ស្បែកខ្នងមានសណ្ឋានដូចបន្ទះស្បែកស្រោបខែល ស្បែកពោះមានសណ្ឋានដូចស្បែកដែលគេជាស់ស្នូកពិណ ។ ស្បែកទ្រូងមានសណ្ឋាន ៤ ជ្រុង ស្បែកជើមដៃទាំង ២ មានសណ្ឋានដូចស្បែកដែលគេរុំធ្នូ ស្បែកខ្នងដៃ មានសណ្ឋានដូចស្រោមកាំបិត-

កោរ ឬមានសណ្ឋានដូចស្រោមស្មិត ស្បែកម្រាមដៃមានសណ្ឋានដូចស្រោមសោ ស្បែកកមានសណ្ឋានដូចអាវមានក ស្បែកមុខមានសណ្ឋានដូចសម្បុកជង្វៃ មានប្រហោងតូចធំ ស្បែកក្បាលមានសណ្ឋានដូចស្មៅកបាត្រ ។

ព្រះយោគាវចរ កំណត់ស្បែកជាអារម្មណ៍ បញ្ជូនចិត្តចូលទៅរវាងស្បែកនិងសាច់ តាំងអំពីបបូរមាត់លើ កំណត់ស្បែកមុខជាលំដាប់ដំបូង បន្ទាប់អំពីនោះ កំណត់ស្បែកក្បាល ស្បែកកខាងក្រៅ បន្ទាប់អំពីនោះ គប្បីកំណត់ស្បែកដៃស្តាំ ដោយអនុលោម និងបដិលោម លំដាប់តមក គប្បីកំណត់ស្បែកដៃឆ្វេង ស្បែកខ្នង ស្បែកត្រគាក បន្ទាប់អំពីនោះ កំណត់ស្បែកខ្នងជើងស្តាំ ដោយអនុលោម និងបដិលោម ស្បែកខ្នងជើងឆ្វេង ស្បែកតម្រងបស្សាវៈ ស្បែកពោះតូច ស្បែកបេះដូង ស្បែកកផ្នែកខាងក្នុង បន្ទាប់អំពីនោះ ស្បែកចង្កាក្រោម ស្បែកបបូរមាត់ក្រោម កំណត់យ៉ាងនេះទៀត រហូតដល់បបូរមាត់លើ ។ កំណត់ដោយទិសថា កើតក្នុងទិសទាំង ២ កំណត់ដោយឱកាសថា រុំព័ទ្ធពេញសរីរៈតាំងនៅ ។

ក្នុងស្បែកនោះ ព្រះយោគាវចរកំណត់ថា ស្បែកមិនដឹងថា អញស្រោបសរីរៈដែលប្រកបដោយមហាភូតរូបទាំង ៤ នេះ សូម្បីសរីរៈ ដែលប្រកបដោយមហាភូតរូបទាំង ៤ នេះ ក៏មិនដឹងថា អញត្រូវបានស្បែកស្រោប ប្រៀបដូចហិប ដែលពាសដោយស្បែកស្រស់ៗ រមែងមិនដឹងថា អញស្រោបហិប ហិបក៏មិនដឹងថា អញត្រូវស្បែកស្រស់ស្រោប ដូច្នោះ ។ ព្រោះថា ស្បែកទាំងនោះ វៀរចាកការគិត និងការពិចារណាជាធម្មតា ។បេ។ មិនមែនបុគ្គល ។

លោកពោលលម្អិតថា

អាលូចម្មបដិច្ចន្នោ នវទ្វារោ មហាវណោ
សមន្តតោ បគ្ឃរតិ អសុចិបូតិគន្ធិយោ ។

រាងកាយនេះ ស្រោបដោយស្បែកស្រស់ មានទ្វារ ៩ មានមុខដំបៅច្រើន មិនស្អាត មានក្លិនស្អុយ រមែងហូរចេញដោយជុំវិញ ។

កំណត់ដោយបរិច្ចេទថា ស្បែកខាងក្រោមខណ្ឌដោយសាច់ ឬដែលតាំងនៅត្រង់សាច់នោះ ខាងលើខណ្ឌដោយសម្បុរថ្ងៃ នេះជាការកំណត់ស្បែកនោះដោយសភាគ ការកំណត់ដោយវិសភាគក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ ស្បែកដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះឯង ។

មំសំ

បន្ទាប់អំពីនោះទៅ ក៏កំណត់សាច់ដែលមាន ៩០០ ដុំ ក្នុងសរីរៈ ដោយវណ្ណៈថា មានពណិក្រហមដូចផ្ការចារ ដោយសណ្ឋាន មានសណ្ឋានផ្សេងៗគ្នា ពិតហើយ សាច់កំភូនជើងនៃសរីរៈនោះ មានសណ្ឋានដូចបាយដែលខ្ចប់ដោយស្លឹកត្នោត អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចផ្ការកេតក្រពុំ មិនទាន់រីកដូច្នេះក៏មាន សាច់ជើងមានសណ្ឋានដូចត្បាល់បាយ-អ សាច់ត្រគាកមានសណ្ឋានដូចឈើសម្រាប់គោះបន្ទរ សាច់ខ្នងមានសណ្ឋានដូចបន្ទះស្ពរត្នោត សាច់ធ្មឹងជំនីរទាំងសងខាងមានសណ្ឋានដូចដី ដែលគេបូកស្ពើងៗ ក្នុងទីដែលគេធ្វើជង្រុកដែលត្បាញដោយឫស្សី សាច់ដោះមានសណ្ឋានដូចជុំដីដែល

សើមដែលគេធ្វើឲ្យមូល ហើយបោះទៅ សាច់ដៃទាំងសងខាង មានសណ្ឋានដូចកណ្តុរធំដែលគេកាត់កន្ទុយ កាត់ក្បាល ពន្ធាត់ស្បែកតាំងទុក ។ អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចចង្កោមសាច់ ដូច្នេះក៏មាន សាច់ថ្ពាល់មានសណ្ឋានដូចគ្រាប់ថ្ងាន់ដែលគេជាក់ត្រង់ថ្ពាល់ អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចកង្កែប ដូច្នេះក៏មាន សាច់អណ្តាតមានសណ្ឋានដូចត្របកឈូក សាច់ច្រមុះមានសណ្ឋានដូចទូដាក់សៀវភៅដែលគេផ្តាប់ សាច់ប្រឡង់ក្អែកមានសណ្ឋានដូចផ្លែល្វាទុំពាក់កណ្តាល សាច់ក្បាលមានសណ្ឋានដូចប្រេងដែលលាបខ្លះស្តើងៗ សម្រាប់អប់បាត្រ ព្រះយោគាវចរកំណត់សាច់ជាអារម្មណ៍ គប្បីកំណត់ចំណែកគ្រោតគ្រោតទាំងនេះឯងដោយសណ្ឋាន ដ្បិតថាព្រះយោគាវចរកំណត់យ៉ាងនេះ សាច់ដែលល្អិតក៏ទីងប្រាកដដល់ញាណ កំណត់ដោយទិស សាច់កើតក្នុងទិសទាំង ២ ។ កំណត់ដោយឱកាស សាច់បូកលាបតាមឆ្អឹង ៣០០ កំណាត់ ដែលជាគ្រោងតាំងនៅ ។

ក្នុងសាច់នោះ ក៏កំណត់ថា សាច់ ៩០០ ដុំ រមែងមិនដឹងថា អញបូកលាបឆ្អឹង ៣០០ កំណាត់ សូម្បីឆ្អឹង ៣០០ កំណាត់ក៏មិនដឹងថា អញត្រូវសាច់ ៩០០ ដុំបូកលាប ប្រៀបដូចជញ្ជាំងផ្ទះដែលត្រូវបូកលាបដោយដី គ្រោតគ្រោតដី គ្រោតគ្រោតរមែងមិនដឹងថា អញបូកលាបជញ្ជាំងផ្ទះ សូម្បីជញ្ជាំងផ្ទះក៏មិនដឹងថា អញត្រូវដីបូកលាប ដ្បិតថា សាច់ទាំងនោះ វៀរចាកការគិត និងការពិចារណាជាធម្មតា ។បេ។ មិនមែនបុគ្គល លោកពោលដោយពិស្តារថា

បរមត្ថជោតិកា អដ្ឋកថា កថាពណិនាត្រៃសរណៈ

នវបេសិសតា មំសា អនុលិត្តា កលេវរំ
នានាកិមិកុលាកិណ្ណំ មិឌ្ឍត្តានំវ ឫតិកំ។

សាច់ ៩០០ ដុំ ឫកលាបកលេវរកាយ ដែលពពាក់ពពូន ដោយហ្វូងដង្កូវប្រភេទផ្សេងៗ មានក្លិនស្អុយ ដូចលាមក ។

កំណត់ដោយបរិច្ចេទថា សាច់ខាងក្រោម ខណ្ឌដោយធ្មឹង ឬទីតាំងនៅនៃធ្មឹងនោះ សាច់ខាងលើខណ្ឌដោយស្បែក សាច់ខាងទទឹងខណ្ឌដោយសាច់គ្នាឯង នេះជាការកំណត់អត្ថនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង កំណត់អត្ថដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

ឆ្លារុ

បន្ទាប់អំពីនេះទៅ នឹងកំណត់សរសៃ ៩០០ ក្នុងសរីរៈ ដោយវណ្ណៈ មានពណិស ។ អាចារ្យពួកខ្លះពោលថា មានពណិដូចទឹកឃ្មុំ ។ ដោយសណ្ឋានមានសណ្ឋានផ្សេងៗ ពិតហើយ បណ្តាសរសៃ ៩០០ នោះ សរសៃធំៗ មានសណ្ឋានដូចផ្តាកនូលៈក្រពុំ សរសៃតូចមានសណ្ឋានដូចខ្សែអន្ទាក់ដែលគេដាក់ជ្រូក សរសៃដែលតូចជាងនោះ ក៏មានសណ្ឋានដូចវល្លិផោម ដែលតូចជាងនោះទៅទៀត មានសណ្ឋានដូចខ្សែពិណធំ របស់អ្នកសីហឡ ដែលតូចជាងនោះទៅទៀត មានសណ្ឋានដូចអំបោះដែលមានសរសៃធំ សរសៃត្រង់ខ្នងដៃខ្នងជើង មានសណ្ឋានដូចជើងបក្សី សរសៃក្បាលមានសណ្ឋានដូច

សំពត់ស្តើងៗ ដែលគ្របលើក្បាលរបស់ក្មេងអ្នកស្រុក សរសៃខ្លងមាន សណ្ឋានដូចសំណាញ់ចាប់ត្រីដែលសើមដោយទឹក ហើយចេញហាលថ្ងៃ សរសៃដែលទៅតាមអវយវៈតូចធំនោះៗ ក្នុងសរីរៈនេះមានសណ្ឋានដូចអាវ សំណាញ់ ដែលពាក់ត្រង់សរីរៈ ដោយទិស សរសៃកើតក្នុងទិសទាំង ២ ។ បណ្តាសរសៃទាំងនោះ សរសៃធំ ឈ្មោះថា **កណ្ឌរ** *មាន ៥ ចងតាំងអំពី គុម្ភត្រចៀកខាងស្តាំមកខាងមុខ និងខាងក្រោយដល់ខាងឆ្វេង ចងតាំងអំពី សៀតផ្តាខាងឆ្វេងមកខាងមុខ និងខាងក្រោយដល់ខាងស្តាំ ចងតាំងអំពី កញ្ចឹងក ខាងស្តាំមកខាងមុខ និងខាងក្រោយដល់ខាងឆ្វេង ចងតាំងអំពី កញ្ចឹងកខាងឆ្វេងមកខាងមុខ និងខាងក្រោយ ដល់ខាងស្តាំ ចងដៃខាងស្តាំ មកខាងមុខ ៥ ខាងក្រោយ ៥ រួមជាសរសៃធំ ១០ ដែលឈ្មោះថា* **កណ្ឌរៈ** *ជា ១០ ចាក់ស្រែះពេញខ្លួន ។ ដៃខាងឆ្វេង ជើងខាងស្តាំ និងជើងខាងឆ្វេង ក៏ដូចគ្នាយ៉ាងនោះ ។ រួមសេចក្តីថា សរសៃធំ ៦០ ដូចពោលមកទាំងនេះ កំណត់ថា ជាគ្រឿងជួយទ្រទ្រង់សរីរៈ ជួយកំណត់សរីរៈក៏មាន កំណត់ដោយឱកាស សរសៃចងឆ្អឹងខាងក្នុងឆ្អឹងជាមួយនឹងស្បែក និងឆ្អឹងជាប់នឹងសាច់ តាំងនៅពេញសរីរៈ ។*

ក្នុងសរសៃនោះ កំណត់ថា សរសៃរមែងមិនដឹងថា ឆ្អឹង ៣០០ កំណាត់ ត្រូវអញ្ចងសូម្បីឆ្អឹង ៣០០ កំណាត់ ក៏មិនដឹងថា អញត្រូវសរសៃចង ប្រៀបដូចឈើរៀចៗ ត្រូវវល្ចិចងលាម វល្ចិរមែងមិនដឹងថា ឈើកោងត្រូវ អញចងសូម្បីឈើកោងក៏មិនដឹងថា អញត្រូវវល្ចិចង ដូច្នោះ ។ ដ្បិតថា

សរសៃទាំងនោះ វៀរចាកការគិត និងពិចារណាជាធម្មតា ។បេ។ មិនមែនបុគ្គល ។ លោកពោលសរុបថា

នវុត្ថារុសតា ហោន្តិ ព្យាមមត្តេ កលេវរេ
ពទ្ធន្តិ អត្តសង្ខ្លាដំ អគារមិវ វល្លិយោ ។

សរសៃ ៩០០ រមែងចងគ្រោងឆ្អឹងក្នុងសរីរៈ
ប្រមាណមួយព្យាម ដូចវល្លិចងផ្ទះ ដូច្នោះ ។

កំណត់ដោយបរិច្ឆេទថា សរសៃខាងក្រោម ខណ្ឌដោយឆ្អឹង ៣០០ កំណាត់ ឬទីតាំងនៅនៃឆ្អឹងនោះ សរសៃខាងលើខណ្ឌដោយស្បែក និងសាច់ ខាងទទឹងខណ្ឌដោយសរសៃគ្នាឯង នេះជាការកំណត់សរសៃទាំងនោះដោយសភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង កំណត់សរសៃដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

អដ្ឋិ

បន្ទាប់អំពីនេះទៅ ក៏កំណត់ដោយវណ្ណៈថា ឆ្អឹងមានប្រភេទដែលលោកពោលដោយនយជាដើមយ៉ាងនេះថា ព្រោះលោកកាន់យកឆ្អឹងធ្មេញ ៣២ ចែកទុកដោយឡែក ឆ្អឹងដ៏សេសក្នុងសរីរៈ គឺឆ្អឹងដៃ ៦៤ ឆ្អឹងជើង ៦៤ ឆ្អឹងខ្ទីដែលជាប់សាច់ ៦៤ ឆ្អឹងកែងជើង ២ ឆ្អឹងកជើងម្ខាង ២ ឆ្អឹងស្មុង ២ ឆ្អឹងក្បាលជង្គង់ ១ ឆ្អឹងក្លៅ ១ ឆ្អឹងចង្កេះ ២ ឆ្អឹងទ្រនង់ខ្នង ១៨ ឆ្អឹងជំនីរ ២៤ ឆ្អឹងទ្រូង ១៤ ឆ្អឹងជិតបេះដូង ១ ឆ្អឹងជងកាំបិត ២ ឆ្អឹងស្មាបប្រចៀវ ២ ឆ្អឹងដើមដៃ ២ ឆ្អឹងចុងដើមដៃ (ទ្វេអគ្គពាហាគ្គនិ) ២ ឆ្អឹងក ៧ ឆ្អឹងចង្កា ២

ធ្មឹងច្រមុះ ១ ធ្មឹងក្នែក ២ ធ្មឹងត្រចៀក ២ ធ្មឹងថ្ងាស ១ ធ្មឹងបង្ហើយ ១ ធ្មឹងលលាដ៍ក្បាល ៩ ធ្មឹងទាំងអស់នោះឯងមានពណិស ។

កំណត់ដោយសណ្ឋានថា ធ្មឹងមានសណ្ឋានផ្សេងៗ គ្នា ។ ពិតហើយ បណ្តាធ្មឹងទាំងនោះ ធ្មឹងចុងម្រាមជើង មានសណ្ឋានដូចគ្រាប់ល្ងៀង បន្ទាប់អំពីនោះ ធ្មឹងថ្នាំងកណ្តាលរបស់ម្រាមជើងមានសណ្ឋានដូចគ្រាប់ខ្នុរដែលមិនពេញ ធ្មឹងថ្នាំងខាងគល់មានសណ្ឋានដូចស្ពរតូច អាចារ្យមួយពួកពោលថា មានសណ្ឋានដូចអង្កាំកន្ទុយក្ងោកក៏មាន ធ្មឹងខ្នងជើងមានសណ្ឋានដូចគំនរប្រសដើមកន្ទល:ដែលគេជំ ធ្មឹងកែងជើងមានសណ្ឋានដូចកំពីងត្នោតដែលមានគ្រាប់ ១ ធ្មឹង-កជើងមានសណ្ឋានដូចផ្ងែអង្គញ់ចងផ្ទោបគ្នា ធ្មឹងស្មងតូចមានសណ្ឋានដូចដងធ្នូ ធ្មឹងស្មងធំមានសណ្ឋានដូចសរសៃស្ងួត ព្រោះស្រេកឃ្ងាន ធ្មឹងស្មងដែលស៊ីកចូលក្នុង-កជើង មានសណ្ឋានដូចពន្ធកដើមល្មើ ដែលបកសម្បកចេញ ធ្មឹងស្មងដែលតាំងនៅក្នុងធ្មឹងជង្គង់ មានសណ្ឋានដូចស្ពរសម្ភោរ ធ្មឹងក្បាលជង្គង់មានសណ្ឋានដូចពពុះទឹក ដែលកាត់មួយចំហៀង ធ្មឹងភ្ងៅមានសណ្ឋានដូចដងកាំបិត និងដងពូថៅដែលចាំងច្បាលៗ ធ្មឹងភ្ងៅដែលតាំងនៅក្នុងធ្មឹងចង្កេះមានសណ្ឋានដូចដងស្នប់របស់ជាងមាស ។ ឧកាសដែលធ្មឹងភ្ងៅតាំងនៅក្នុងធ្មឹងចង្កេះនោះ មានសណ្ឋានដូចផ្ងែបុសនាគកាត់ខាងចុង ធ្មឹងចង្កេះមាន ២ ក៏ជាប់គ្នាតែមួយ មានសណ្ឋានដូចចង្ក្រានដែលនាយស្ងួនធ្នាំងធ្ងើ អាចារ្យពួកខ្ងះពោលថា មានសណ្ឋានដូចខ្នើយរបស់តាបសដូច្នេះក៏មាន ។ ធ្មឹងត្រគាកមានសណ្ឋានដូចសំណកពស់ដែលគេផ្តាប់ ធ្មឹងទ្រនង់ខ្នង ១៨ មាន

ប្រហោងតូច-ធំ ក្នុងទី ៧-៨ កន្លែង ខាងក្នុងមានសណ្ឋានដូចសំពត់ជួតក្បាល ដែលជាក់ត្រួតៗ គ្នា ខាងក្រៅមានសណ្ឋានដូចបំពង់មូល ឆ្អឹងទ្រនង់ខ្នងទាំងនោះមានបន្ទា ២-៣ ពក ដូចធ្មេញរណា ។ បណ្តាឆ្អឹងជំនីរ ២៤ ចំណែកដែលបរិបូណ៌ មានសណ្ឋានដូចកណ្តៀវអ្នកសីហឡ ដែលបរិបូណ៌ ចំណែកដែលមិនបរិបូណ៌មានសណ្ឋានដូចកណ្តៀវអ្នកសីហឡ ដែលមិនបរិបូណ៌ អាចារ្យមួយពួកពោលថា ទាំងអស់នោះឯង មានសណ្ឋានដូចស្វាបទាំង ២ របស់មាន់សំឡីដែលជាប់ចេញ ដូច្នេះក៏មាន ឆ្អឹងដើមទ្រូង ១៤ កំណាត់មានសណ្ឋានដូចបន្ទះឈើ ដូចបន្ទះត្រែស្នែងចាស់ៗ ឆ្អឹងបេះដូងមានសណ្ឋានដូចបន្ទះវែក ឆ្អឹងជង្គាំបិត មានសណ្ឋានដូចកាំបិតលោហៈតូចៗ បណ្តាឆ្អឹងជង្គាំបិតទាំងនោះ ឆ្អឹងខាងក្រោមមានសណ្ឋានដូចអង្ឃចន្ទ ឆ្អឹងស្វាបប្រចៀវមានសណ្ឋានដូចមុខពូថៅ អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចចបអ្នកសីឡហៈ ដែលកាត់ពាក់កណ្តាល ដូច្នោះក៏មាន ឆ្អឹងដើមដៃមានសណ្ឋានដូចជង្គកញ្ចក់ អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចជង្គាំបិតធំដូច្នោះក៏មាន ឆ្អឹងចុងដើមដៃ មានសណ្ឋានដូចឫសត្នោតគូ ឆ្អឹងកដៃ មានសណ្ឋានដូចសំពត់ជួតក្បាល ដែលគេជាក់ភ្ជាប់រួមគ្នា ឆ្អឹងខ្នងដៃមានសណ្ឋានដូចគំនរឫសកន្ទូលដែលគេដំ ឆ្អឹងគល់នៃម្រាមដៃមានសណ្ឋានដូចស្គរតូច ឆ្អឹងថ្ពាំងកណ្តាល មានសណ្ឋានដូចគ្រាប់ខ្នុរដែលមិនបរិបូណ៌ ឆ្អឹងម្រាមខាងចុងមានសណ្ឋានដូចគ្រាប់ល្ង្វឹង ឆ្អឹងក ៧ មានសណ្ឋានដូចទំពាំងដែលគេចោះជាក់តម្រៀបគ្នា ឆ្អឹងចង្កាខាងក្រោម មានសណ្ឋានដូចខ្សែចងញញួរនៃជាងមាស

ឆ្នើងចង្កាខាងលើ មានសណ្ឋានដូចឈើជម្រះ ៧ ឯឆ្នើងប្រឡង់ក្អែក និងក្តោងច្រមុះ មានសណ្ឋានដូចផ្លែត្នោតខ្ចីដែលមិនទាន់មានសាច់ ឆ្នើងថ្ងាស មានសណ្ឋានដូចសម្បកស័ង្ខបែកដែលគេជាក់ផ្តាប់ ឆ្នើងត្រចៀក មានសណ្ឋានដូចស្រោមកាំបិតកោរបស់ជាងកោរកាត់ បណ្តាឆ្នើងថ្ងាស និងឆ្នើងគុម្ពត្រចៀកឆ្នើងក្នុងឱកាសដែលជាប់គ្នា ជាបន្ទះខាងលើ មានសណ្ឋានដូចចម្រៀកសំពត់ចាស់ដែលបិតឆ្នាំង ដែលពេញដោយទឹក ឆ្នើងបង្ហើយមានសណ្ឋានដូចត្រឡោកជូង ដែលគេកាត់ទទឹងពីខាងមុខ ឆ្នើងក្បាលមានសណ្ឋានដូចសម្បកឃ្លោកចាស់ដែលជាក់គេព្បួរ ។ ដោយទិសឆ្នើងទាំងឡាយ កើតក្នុងទិសទាំង ២ ។

ដោយឱកាសឆ្នើងទាំងឡាយ តាំងនៅពេញសរីរៈ មិនមានរៀរ តែដោយពិសេស ឆ្នើងក្បាលតាំងនៅលើឆ្នើង-ក ឆ្នើង-កតាំងនៅលើឆ្នើងទ្រនង់ខ្នង ឆ្នើងទ្រនង់ខ្នងតាំងនៅលើឆ្នើងចង្កេះ ឆ្នើងចង្កេះតាំងនៅលើឆ្នើងក្លៅ ឆ្នើងក្លៅតាំងនៅលើឆ្នើងជង្គង់ ឆ្នើងជង្គង់តាំងនៅលើឆ្នើងស្មង ឆ្នើងស្មងតាំងនៅលើឆ្នើង-កជើង ឆ្នើង-កជើងតាំងនៅលើឆ្នើងខ្នងជើង ឆ្នើងខ្នងជើងក៏លើកឆ្នើង-កជើងឡើងតាំងទុក ឆ្នើង-កជើងក៏ទ្រឆ្នើងស្មង ។បេ។ ឆ្នើង-កក៏ទ្រឆ្នើងក្បាលតាំងឡើង គប្បីជ្រាបឆ្នើងចំណែកដ៏សេស ដោយទំនងដូចពោលមក ដូច្នេះ ។

ក្នុងឆ្នើងនោះ កំណត់ថា ឆ្នើងក្បាល រមែងមិនដឹងថា អញតាំងនៅលើឆ្នើង-ក ។បេ។ ឆ្នើង-កជើងរមែងមិនដឹងថា អញតាំងនៅលើឆ្នើងខ្នងជើង សូម្បីឆ្នើងខ្នងជើងក៏មិនដឹងថា អញលើកឆ្នើង-កជើងឡើងតាំងទុក ប្រៀបដូចបណ្តា

ទព្ធសម្ភារៈមានឥដ្ឋ និងបន្ទង់ ឥដ្ឋជាដើមខាងលើរមែងមិនដឹងថា អញតាំងនៅលើឥដ្ឋជាដើមខាងក្រោម ឥដ្ឋជាដើមត្រង់កណ្តាលក៏មិនដឹងថា អញលើកឥដ្ឋជាដើមខាងលើតាំងទុក ដូច្នោះ ដ្បិតថា ឆ្អឹងទាំងនោះ រៀរការគិត និងការពិចារណាជាធម្មតា ។បេ។ មិនមែនបុគ្គល ។ ឆ្អឹង ៣០០ កំណាត់ដែលជាគ្រោងសរីរៈទាំងនេះ ដែលសរសៃ ៩០០ និងសាច់ ៩០០ ដុំ ចង និងបូកលាប ស្បែកស្រោបឲ្យជាប់គ្នាតែមួយ បូកលាបដោយជ័រស្អិតទៅតាមបសាទទទួលរស ៧០០០ មានតំណក់ញើស ត្រងដោយរណ្តៅរោម ៩៩០០០ មានត្រកូលជន្ទូវ ៨០ ត្រកូល រាប់បានថាជាកាយតែម្យ៉ាង ដែលព្រះយោគាវចរ កាលពិចារណាដោយសភាវៈពិត រមែងមិនឃើញវត្ថុណាមួយដែលគួរចូលទៅប្រកាន់ តែនឹងឃើញសរីរៈនៃឆ្អឹងតែម្យ៉ាងដែលចងរឹតដោយសរសៃដេរជាសដោយសាកសពផ្សេងៗ កាលឃើញហើយ រមែងចូលជល់ភាពជាឱរសរបស់ព្រះទសពល ដូចព្រះតម្រាស់ថា

បដិចាដិយត្តីនិ ឋិតានិ កោដិយា
អនេកសន្ធិយមិតោ ន កេហិចិ
ពធ្ធោ នហារូហិ ជរាយ ចោធិតោ
អចេតនោ កដ្ឋកលិង្ឌូបមោ ។

ឆ្អឹងទាំងឡាយ តាំងចុងរៀងគ្នាក្នុងទី-តជាច្រើនអំពីកាយនេះ ដែលវត្ថុណាមួយ មិនបានចងទុក កាយនេះ សរសៃទាំងឡាយចងទុក ដែលជរាជាស់តឿនហើយ មិនមានចេតនា ឧបមាដូចអង្គត់ឧស ។

កុណបំ កុណបេ ជាតំ អសុចិអសុចិម្ហិ ច
បូតិកាយម្ហិ បូតីនិ ឧត្តនេ ចាបិ ឧត្តនុំ
គេឧនធម្មេហិ វយធម្មំ អដ្ឋិបុដេ អដ្ឋិបុដោ
និញត្តោ បូតិកាយម្ហិ តម្ហិ ច វិនេថច្ចនុំ
ហោស្សថ បុត្តា ឧសពលស្សាតិ ច ។

សាកសពកើតក្នុងសាកសព របស់ស្អុយកើតក្នុងរបស់
មិនស្អាត របស់មានក្លិនមិនល្អ កើតក្នុងរបស់មានក្លិន
មិនល្អ របស់ប៉ែកធ្លាយ កើតក្នុងរបស់ដែលប្រែប្រួល
ទៅ គំនរធ្មឹងកើតក្នុងគំនរធ្មឹង របស់ស្អុយកើតក្នុងកាយ
ស្អុយ អ្នកទាំងឡាយ ចូរកម្ចាត់បង់នូវការពេញចិត្តក្នុង
កាយស្អុយនេះចេញ ទើបឈ្មោះថា ជាបុត្ររបស់
តថាគតទសពល ។

ដោយបរិច្ចេទ ក៏កំណត់ថា ខាងក្នុងធ្មឹងខណ្ឌដោយខួរក្នុងធ្មឹង ខាងក្រៅ
ខណ្ឌដោយសាច់ ត្រង់ចុង និងគល់ខណ្ឌដោយធ្មឹងជាមួយគ្នា នេះជាការកំណត់
ធ្មឹងទាំងនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះ
ឯង ។ កំណត់ធ្មឹងដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

អដ្ឋិមិញ្ជំ

តអំពីនេះទៅ នឹងកំណត់ខួរក្នុងធ្មឹង ដែលនៅខាងក្នុងធ្មឹងទាំងឡាយ មាន
ប្រភេទតាមដែលពោលហើយក្នុងសរីរ: ដោយពណ៌ មានពណ៌ស ដោយ

សណ្ឋាន ដូចឧកាសរបស់ខ្ជូន គឺខ្ទរក្នុងធ្មឹងដែលនៅក្នុងធ្មឹងទាំងឡាយ ដែលមានទំហំធំ មានសណ្ឋានដូចពន្ធកផ្តៅធំ ដែលគេស៊ីកក្នុងបំពង់ប្រស្សី និងដើមបបុស ដែលមានទំហំធំ ខ្ទរក្នុងធ្មឹងដែលនៅក្នុងធ្មឹងតូចៗ មានសណ្ឋានដូចពន្ធកផ្តៅ ដែលមានដើមតូច ដែលគេស៊ីកក្នុងបំពង់ប្រស្សី និងដើមបបុសខ្នាតតូច ដោយទិស កើតក្នុងទិសទាំង ២ ដោយឧកាស តាំងនៅក្នុងធ្មឹងទាំងឡាយ ។

ខ្ទរក្នុងធ្មឹងទាំងនោះ ក៏កំណត់ថា ខ្ទរក្នុងធ្មឹងរមែងមិនដឹងថា អញនៅខាងក្នុងធ្មឹង សូម្បីធ្មឹងក៏មិនដឹងថា ខ្ទរក្នុងធ្មឹងនៅខាងក្នុងអញ ប្រៀបដូចទឹកដោះជូរ និងទឹកអំពៅនៅខាងក្នុងបំពង់ប្រស្សី ឬដើមបបុស ដូច្នោះ រមែងមិនដឹងថា អញនៅខាងក្នុងប្រស្សី ឬដើមបបុសជាដើម សូម្បីប្រស្សី និងបបុសជាដើមក៏មិនដឹងថា ទឹកដោះជូរ និងទឹកអំពៅនៅខាងក្នុងអញ ដូច្នោះ ពិតហើយធម៌ទាំងនេះ រៀរការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ចេទ ខ្ទរក្នុងធ្មឹងខណ្ឌដោយផ្ទៃខាងក្នុងធ្មឹងទាំងឡាយ និងដោយចំណែកនៃខ្ទរក្នុងធ្មឹង នេះជាការកំណត់ខ្ទរក្នុងធ្មឹងនោះដោយសភាគ ឯការកំណត់ដោយវិសភាគដូចគ្នានឹងសក់នោះឯង ។ កំណត់ខ្ទរក្នុងធ្មឹង ដោយវណ្ណៈជាដើមមានប្រការដូចពោលមក ដូច្នេះ ។

វក្ពុំ

បន្តពីនេះទៅ នឹងកំណត់វក្ក: គឺទាច ដែលមាន ២ ជុំក្នុងសរីរ: ដោយពណិ មានពណិក្រហមខ្ចីដូចគ្រាប់រលួសផ្អុង ដោយសណ្ឋាន មានសណ្ឋាន

ដូចផ្ទៃអង្គញ្ជាំដោតអំបោះរបស់ក្មេងអ្នកស្រុក អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចស្វាយពីរផ្ទៃដែលមានទងតែមួយ ដូច្នេះក៏មាន ដោយឱកាស ទាចនោះ ត្រូវសរសៃគ្រោតគ្រោត ដែលចេញមកអំពីប្រជុំក មានគល់តែមួយធ្លាក់មកបន្តិច ហើយបែកចេញជា ២ ចំណែក ចងរួបរឹតទុក ហើយព័ទ្ធសាច់បេះដូងតាំងនៅ ។

ក្នុងទាចនោះ ក៏កំណត់ថា ទាចមិនដឹងថា អញត្រូវសរសៃគ្រោតគ្រោតចង សូម្បីសរសៃគ្រោតគ្រោតក៏មិនដឹងថា អញចងទាច ប្រៀបដូចស្វាយ ២ ផ្ទៃជាប់ទងតែមួយ រមែងមិនដឹងថា អញត្រូវទងចង សូម្បីទង ក៏មិនដឹងថា អញចងស្វាយ ២ ផ្ទៃ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ រៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ដោយបរិច្ឆេទកំណត់ថា ទាច ខណ្ឌដោយចំណែកនៃទាច នេះជាការកំណត់ទាចនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង កំណត់ដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

ហាទយំ

បន្ទាប់អំពីនេះទៅ ក៏កំណត់ថា ហទយៈខាងក្នុងសរីរៈ ដោយពណ៌ មានពណ៌ក្រហម ដូចត្របកឈូកក្រហម ដោយសណ្ឋាន មានសណ្ឋាន ដូចផ្កាឈូកក្រពុំបកត្របកក្រៅចេញហើយ ជាក់សំយុង ។ បេះដូងនោះ ខាងក្នុងដូចផ្ទៃបុសនាគ កាត់កំពូលខាងលើ ខាងក្រៅរលីង ខាងក្នុងក៏ដូចខាងក្នុងនៃផ្ទៃនោងព្រៃ ។ បេះដូងរបស់អ្នកមានបញ្ញាច្រើន រីកបន្តិច របស់អ្នក

មានបញ្ញាខ្សោយក្រពុំតែម្យ៉ាង មនោធាតុ និងមនោវិញ្ញាណធាតុ អាស្រ័យរូបណាប្រព្រឹត្តទៅ លះបង់រូបនោះចេញទៅហើយ ។ ឈាមតាំងនៅខាងក្នុងប្រមាណកន្លះទូកដៃ ខាងក្នុងបេះដូង ពោល គឺដុំសាច់ ចំណែកដ៏សេសឈាមនោះ របស់បុគ្គលរាគចរិត មានពណ៌ក្រហម របស់បុគ្គលទោសចរិត ពណ៌ខ្មៅ របស់បុគ្គលមោហចរិត មានពណ៌ដូចទឹកលាងសាច់ របស់បុគ្គលវិតក្កចរិត មានពណ៌ដូចទឹកពពាយជ្រូង របស់បុគ្គលសទ្ធាចរិត មានពណ៌ដូចផ្កាកណិការ របស់បុគ្គលបញ្ញាចរិតថ្លា មិនល្អក់កករ ប្រាកដដូចជាពន្លឺនៃកែវមណីដោយកំណើត ដែលជម្រះហើយ ។ ដោយទិស កើតក្នុងទិសខាងលើ ដោយឱកាស តាំងនៅកណ្តាលដោះទាំង ២ ខាង ក្នុងសរីរៈ ។

ក្នុងបេះដូងនោះ កំណត់ថា បេះដូងមិនដឹងថា អញតាំងនៅពាក់កណ្តាលដោះទាំង ២ សូម្បីដោះក៏មិនដឹងថា បេះដូងតាំងនៅត្រង់ពាក់កណ្តាលអញ ប្រៀបដូចគន្លឹះតាំងនៅកណ្តាលសន្ទះបង្ហួច និងសន្ទះទ្វារទាំង ២ រមែងមិនដឹងថា អញតាំងនៅត្រង់កណ្តាលសន្ទះបង្ហួច និងទ្វារទាំង ២ សូម្បីសន្ទះបង្ហួច និងទ្វារ ក៏មិនដឹងថា គន្លឹះតាំងនៅកណ្តាលអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនោះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា បេះដូងខ្ពស់ដោយចំណែកនៃបេះដូង នេះជាការកំណត់បេះដូងនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង កំណត់បេះដូងដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

យកនំ

បន្តអំពីនេះទៅ ក៏កំណត់ថា សាច់ ២ បន្ទះ ដែលហៅថា ថ្លើមខាងក្នុង សរីរៈ ដោយវណ្ណៈ មានពណ៌ក្រហម ដូចពណ៌ត្របកខាងក្រៅ នៃឈូកក្រហម ដោយសណ្ឋាន មានគល់ ១ ចុងបែកជា ២ មានសណ្ឋាន ដូចផ្កាឈូសផ្កង ។ ថ្លើមរបស់បុគ្គលអ្នកមានបញ្ញាទន់ខ្សោយ ឆែកខាងចុងតែ ១ ហើយធំ របស់អ្នកមានបញ្ញាច្រើន មានឆែក ២-៣ តែតូច ដោយទិសកើតក្នុងទិសខាងលើ ដោយឱកាស អាស្រ័យឆ្អឹងជំនីរខាងស្តាំ តាំងនៅខាងក្រោមកន្សោមដោះទាំង ២ ។

ក្នុងថ្លើមនោះ កំណត់ថា ថ្លើមរមែងមិនដឹងថា អញអាស្រ័យឆ្អឹងជំនីរខាងស្តាំតាំងនៅ សូម្បីកន្សោមដោះទាំង ២ និងឆ្អឹងជំនីរខាងស្តាំ ក៏មិនដឹងថា ថ្លើមអាស្រ័យអញតាំងនៅ ប្រៀបដូចដុំសាច់ដែលព្យួរត្រង់ចំហៀងនៃឆ្នាំង រមែងមិនដឹងថា អញព្យួរត្រង់ចំហៀងនៃឆ្នាំង សូម្បីឆ្នាំងក៏មិនដឹងថា ដុំសាច់ព្យួរក្នុងទីរបស់អញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ រៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ខណ្ឌដោយចំណែកនៃថ្លើមជាមួយគ្នា នេះជាការកំណត់ថ្លើមដោយសភាគ ឯកំណត់ដោយវិសភាគ ដូចគ្នានឹងសក់នោះឯង ។ កំណត់ថ្លើមដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

កិលោមកំ

បន្ទាប់អំពីនេះទៅ ក៏កំណត់ថា ដោយពណ៌ភាវ មាន ២ យ៉ាង គឺភាវប្រភេទបិទ និងភាវប្រភេទមិនបិទ មានពណ៌ដូចសំពត់ទុកូលចាស់ ដោយ

សណ្ឋាន មានសណ្ឋានដូចឱកាសរបស់ខ្លួន ដោយទិស កើតក្នុងទិសទាំង ២ ដោយឱកាស វាវប្រកេទបិទព័ទ្ធបេះដូង និងទាចតាំងនៅ វាវប្រកេទមិនបិទ ហ៊ុមសាច់ក្រោមស្បែកពេញសរីរៈតាំងនៅ ។

ក្នុងវាវនោះ កំណត់ថា វាវរមែងមិនដឹងថា អញស្រោបបេះដូង និងទាច និងស្រោបសាច់ខាងក្រោមស្បែកពេញសរីរៈ សូម្បីបេះដូងក្តី ទាចក្តី សាច់ទូទៅក្នុងសរីរៈក្តី ក៏មិនដឹងថា អញត្រូវវាវស្រោបឡើយ ប្រៀបដូចសាច់ដែលត្រូវសំពត់ទុកូលខ្ចប់ សំពត់ទុកូលក៏មិនដឹងថា អញខ្ចប់សាច់ សាច់ក៏មិនដឹងថា អញត្រូវសំពត់ទុកូលស្រោប ដូច្នោះ ។ ដ្បិតថា ធម៌ទាំងនេះ រៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា វាវខាងក្រោមខណ្ឌដោយសាច់ ខាងលើខណ្ឌដោយស្បែក ខាងទទឹងខណ្ឌដោយចំណែកនៃវាវ នេះជាការកំណត់វាវនោះ ដោយសភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់វាវដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

បិហាកំ

បន្តអំពីនេះទៅ ក៏កំណត់ថា ដោយពណ៌ ក្រពះខាងក្នុងសរីរៈមានពណ៌ខៀវ មានពណ៌ដូចផ្កាកន្ទីក្រៀម ។ ដោយសណ្ឋាន ដោយច្រើនមានសណ្ឋានដូចអណ្តាតគោខ្មៅ មិនជាប់គ្នាប្រមាណ ៧ ធ្នាប់ ។ ដោយទិស កើតក្នុងទិសខាងលើ ដោយឱកាសតាំងនៅខាងឆ្វេងបេះដូង អាស្រ័យខាងលើផ្នែពោះ កាលចេញមកខាងក្រៅ ព្រោះត្រូវប្រហារ ដោយគ្រឿងប្រហារ

សត្វក៏នឹងអស់ជីវិត ។

ក្នុងក្រពះនោះ ក៏កំណត់ថា ក្រពះមិនដឹងថា អញអាស្រ័យចំណែកខាងលើរបស់ផ្ទៃពោះ ចំណែកខាងលើរបស់ផ្ទៃពោះក៏មិនដឹងថា ក្រពះអាស្រ័យអញតាំងនៅ ប្រៀបដូចដុំលាមកគោ អាស្រ័យចំណែកខាងលើពោះតាំងនៅ រមែងមិនដឹងថា អញអាស្រ័យចំណែកខាងលើនៃពោះតាំងនៅ សូម្បីចំណែកខាងលើរបស់ពោះក៏មិនដឹងថា ដុំគោមើយអាស្រ័យអញតាំងនៅ ដូច្នោះ ដ្បិតថា ធម៌ទាំងនោះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ក្រពះខណ្ឌដោយចំណែកនៃក្រពះ នេះជាការកំណត់ក្រពះនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ក្រពះដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

បច្ឆាសំ

តអំពីនេះទៅ ក៏កំណត់ថា ដោយពណ៌ សួតជាប្រភេទដុំសាច់ ៣២ ដុំ ខាងក្នុងសរីរៈ ពណ៌ក្រហម ដូចផ្លែល្វាស្រគាល ដោយសណ្ឋាន មានសណ្ឋានដូចនំដែលកាត់មិនស្មើ អាចារ្យមួយពួកពោលថា មានសណ្ឋានដូចគំនរឥដ្ឋដែលគេកធ្វើកំពែងដូច្នេះក៏មាន ។ សួតមិនមានរស មិនមានឱជៈ ដូចគ្នានឹងចំបើងដែលសត្វទំពាហើយ ព្រោះត្រូវប៉ះខូចដោយភ្លើងធាតុដែលកើតអំពីកម្ម ផ្សព្វផ្សាយទ្បើង ព្រោះមិនមានអាហារដែលទំពាស៊ី និងផឹក ។ ដោយទិសកើតក្នុងទិសខាងលើ ដោយឱកាស តាំងខាងលើ សំយុងគ្របបេះដូង និងថ្លើមត្រង់ចន្លោះដោះទាំង ២ ។

ក្នុងសូត្រនោះ ក៏កំណត់ថា សូត្រមិនដឹងថា អញតាំងនៅសំយុងរវាងកន្សោមដោះទាំង ២ ខាងក្នុងសរីរៈ សូម្បីកន្សោមដោះទាំង ២ ក្នុងសរីរៈក៏មិនដឹងថា សូត្រសំយុងខាងក្នុងអញ ប្រៀបដូចសម្បុកសត្វដែលសំយុងនៅខាងក្នុងជង្រុកចាស់ រមែងមិនដឹងថា អញសំយុងនៅខាងក្នុងជង្រុកចាស់ ទោះជង្រុកចាស់ក៏មិនដឹងថា សម្បុកសត្វសំយុងនៅខាងក្នុងអញ ដូច្នោះ ដ្បិតថាធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល នេះជាការកំណត់សូត្រនោះដោយសភាគ ឯការកំណត់ដោយវិសភាគក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់សូត្រដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

អដ្ឋំ

អំពីនេះទៅ ក៏កំណត់ថា ដោយពណ៌ ពោះវៀនធំ មាន ២១ ផ្នត់ ពោះវៀនធំរបស់បុរសប្រមាណ ៣២ ហត្ថ របស់ស្ត្រីប្រមាណ ២៨ ហត្ថ មានពណ៌ស ដូចពណ៌នៃស្ករត្នោត និងជាយ-អ ដោយសណ្ឋាន មានសណ្ឋានដូចពស់ដែលគេកាត់ក្បាល ឆ្វាយរង្វិលជាក់ក្នុងស្នូកឈាម ។ ដោយទិស កើតក្នុងទិសទាំង ២ ដោយឱកាស តាំងនៅខាងក្នុងសរីរៈដែលមានបំពង់ក និងផ្លូវចេញនៃកំរីសជាទីបំផុត ព្រោះខាងលើជាប់ត្រង់បំពង់ក និងខាងក្រោម ជាប់ត្រង់ទ្វារធំ ។

ក្នុងពោះវៀនធំទាំងនោះ ក៏កំណត់ថា ពោះវៀនធំ រមែងមិនដឹងថា អាត្មាអញតាំងនៅខាងក្នុងសរីរៈ សូម្បីសរីរៈក៏មិនដឹងថា ពោះវៀនធំតាំងនៅក្នុង

អញ ប្រៀបដូចខ្ចីនពស់ដែលគេកាត់ក្បាលដាក់ក្នុងស្នូកឈាម រមែងមិនដឹងថា អញតាំងនៅក្នុងស្នូកឈាម សូម្បីស្នូកឈាមក៏មិនដឹងថា សរីរៈពស់ដែលមានក្បាលជាប់ តាំងនៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទក៏កំណត់ថា ពោះវៀនធំខណ្ឌដោយចំណែកនៃពោះវៀនធំ ។ នេះជាការកំណត់ពោះវៀនធំដោយសកាគ ចំណែកការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។

អន្តគុណាំ

បន្ទាប់អំពីនោះទៅ ក៏កំណត់ថា ដោយវណ្ណៈ ពោះវៀនតូច នៅក្នុងចន្លោះពោះវៀនធំក្នុងសរីរៈ ពណ៌សដូចឫសចង្កឹលណី ដោយសណ្ឋាន មានសណ្ឋានដូចឫសចង្កឹលណីនោះឯង ។ អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចទឹកនោមគោ ដូច្នេះក៏មាន ដោយទិស កើតក្នុងទិសទាំង ២ ដោយឱកាស ចងខាងចុងមាត់រង្វេលពោះវៀនធំរួមគ្នា ដូចបន្ទះក្តារយន្តដែលចងខ្សែ ក្នុងកាលដែលមនុស្សធ្វើចប និងពូថៅជាដើម ទាញយន្តតាំងនៅ រវាងផ្នត់ពោះវៀនធំ ២១ ផ្នត់ ដូចខ្សែដែលគេចងចង្វាយខ្សែជួតជើង តាំងនៅក្នុងរវាងខ្សែជួតជើងប៉ុណ្ណោះ ។

ក្នុងពោះវៀនតូចនោះ ក៏កំណត់ថា ពោះវៀនតូចរមែងមិនដឹងថា អញចងពោះវៀនធំ ខាងក្នុងពោះវៀនធំ ២១ ផ្នត់ ពោះវៀនធំក៏មិនដឹងថា ពោះវៀនតូចចងអញ ប្រៀបដូចខ្សែតូចចងចង្វាយខ្សែធំជួតជើង រមែងមិនដឹងថា អញចងចង្វាយខ្សែជួតជើង សូម្បីខ្សែជួតជើងក៏មិនដឹងថា ខ្សែតូចចងអញ

ដូច្នោះ ។ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា ពោះវៀនតូចខាងក្នុងដោយចំណែកនៃពោះវៀនតូច នេះជាការកំណត់ពោះវៀនតូចនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ពោះវៀនតូចដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

ឧទរិយំ

បន្តអំពីនោះទៅ ក៏កំណត់ថា អាហារថ្មី ដោយពណ៌ មានពណ៌ដូចអាហារដែលលេបចូលទៅ ដោយសណ្ឋាន មានសណ្ឋានដូចអង្កាវដែលចងធូរៗ ក្នុងសំពត់តម្រងទឹក ដោយទិស កើតក្នុងទិសខាងលើ ។ ដោយឱកាស តាំងនៅក្នុងពោះ ធម្មតាពោះ ជាផ្ទៃនៃពោះវៀនធំ ដូចខ្សែដែលកើតឯង ត្រង់កណ្តាលសំពត់សើម ដែលត្រូវច្របាច់ទាំងសងខាង ខាងក្រៅមានសភាពរលីង ខាងក្នុងប្រឡាក់ប្រឡូសដោយគំនរសាច់ស្មោកគ្រោក ដូចសំពត់ជូតរដូវ ដែលប្រឡាក់ប្រឡូស អាចារ្យពួកខ្លះពោលថា ដូចផ្នែកខាងក្នុងរបស់ផ្លែខ្នុរសម្ល ដូច្នេះក៏មាន ។ ក្នុងពោះនោះ មានត្រកូលដង្កូវ ៣២ ត្រកូល យ៉ាងនេះ គឺត្រកូលតក្កោលកៈ មានទំហំប៉ុនផ្លែក្រវាញ កណ្ហុប្បាទកៈ មានទំហំប៉ុនជន្ធេន តាលហិរកៈ មានទំហំប៉ុនជក់ស្ពោតជាដើម ដេរជាសប្រវាឡើងគ្នា នៅអាស្រ័យជាប្រចាំ កាលណាមិនមានអាហារ ទឹក និងថ្នាយជាដើម ក៏វារចុះ វារឡើង ស្រែកយំទ្រហឹង ហើយជញ្ជក់សាច់បេះដូង ក្នុងកាលមនុស្សបរិភោគអាហារ មានថ្នាយ និងទឹកចូលទៅ ក៏អើតក សុះសា

ជណ្តើមអាហារ ២-៣ ដែលលេបទៅគ្រាដំបូង ផ្ទៃពោះក៏ក្លាយជាផុះសម្រាប់កើតជាបង្គន់ ជារោងព្យាបាល និងជាព្រៃខ្មោចរបស់ដង្កូវទាំងនោះ ជាទីប្រៀបដូចក្នុងសរទរដូវ តំណក់ភ្លៀងគ្រោតគ្រោតធ្លាក់ចុះមកក្នុងអណ្តូងស្មោកគ្រោក ជិតទ្វារស្រុកពួកមនុស្សចណ្ឌាល សាកសពផ្សេងៗ មានបស្សាវៈ ឧច្ចារៈ កំណាត់ស្បែក ឆ្អឹង សរសៃ ទឹកមាត់ ទឹកសំបោរ និងឈាមជាដើម ត្រូវទឹកនាំមកបញ្ចូលគ្នាជាមួយភក់ និងទឹក ក៏មានដង្កូវត្រកូលតូច-ធំកើតឯងកន្លងទៅ ២-៣ ថ្ងៃ ក៏ក្តៅដោយកម្តៅថ្ងៃ ក៏បែកជាពពុះ ផុសឡើងខាងលើ មានពណ៌ខៀវចាស់ មិនគួរចូលទៅក្បែរ ឬសម្លឹងមើល មិនចាំបាច់ពោលដល់ការហិត ឬភ្លក់ យ៉ាងណា ទឹក និងបាយជាដើម មានប្រការផ្សេងៗ ក៏ដូច្នោះដូចគ្នា ។ កាលអង្រែ គឺធ្មេញ បុកល្អិតហើយ កាលដៃ គឺអណ្តាតត្រឡប់ទៅមកហើយ ប្រឡាក់ប្រឡូសដោយទឹកមាត់ ជ្រាសចាកការដល់ព្រមដោយពណ៌ ក្លិន រសជាដើម យ៉ាងណា ដូចកម្អួតឆ្កែក្នុងស្នូកបាយឆ្កែច្របល់គ្នាដោយទឹកប្រមាត់ ទឹកស្លេស្ម ជុតដោយកម្លាំងភ្លើងធាតុក្នុងពោះ និងកម្តៅ មានដង្កូវត្រកូលតូច-ធំ ពពាក់ពពូនខាងលើ ក្លាយជាគំនរសំរាមមានក្លិនស្អុយ គួរខ្ពើមរអើមក្រៃលែង ។ ដែលស្តាប់ហើយ ធ្វើមិនឲ្យចង់ផឹកទឹក បរិភោគបាយជាដើម កុំចាំបាច់ពោលដល់ការសម្លឹងមើលដោយចក្ខុគឺបញ្ញាឡើយ ដែលជាទីទឹក និងបាយជាដើមធ្លាក់ទៅហើយ នឹងបែងជា ៥ ចំណែក គឺ ១ ចំណែកសត្វក្នុងពោះស៊ី ១ ចំណែកភ្លើងជុតភោល ១ ចំណែកក្លាយជាបស្សាវៈ ១ ចំណែកក្លាយជាឧច្ចារៈ ១ ចំណែកក្លាយជាឱជៈ

ទំនុកបម្រុងឈាម និងសាច់ ។

ក្នុងអាហារថ្មីនោះ ក៏កំណត់ថា អាហារថ្មី រមែងមិនដឹងថា អញនៅក្នុងពោះ ដែលមានក្លិនស្អុយគួរខ្ពើមក្រៃលែងនេះ សូម្បីពោះក៏មិនដឹងថា អាហារថ្មីនៅក្នុងអញ ប្រៀបដូចកម្អួតឆ្អែដែលនៅក្នុងស្នូក សូម្បីស្នូកក៏មិនដឹងថា កម្អួតឆ្អែ នៅក្នុងអញ ដូច្នោះ ដូ្បតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ដឹងថា អាហារថ្មីខណ្ឌដោយចំណែកអាហារថ្មី នេះជាការកំណត់អាហារថ្មីនោះដោយសកាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់អាហារថ្មីដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

ការីសំ

តអំពីនេះទៅ ក៏កំណត់ថា អាហារចាស់ខាងក្នុងសរីរៈ ដោយច្រើន ដោយពណ៌ក៏ដូចអាហារដែលលេបចូលទៅ ដោយសណ្ឋាន ក៏មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសខាងក្រោម ដោយឱកាស តាំងនៅក្នុងទីដែលអាហាររលាយ ហើយនៅអាស្រ័យ ធម្មតាប្រទេសដែលអាហាររលួសហើយនៅអាស្រ័យ ក៏ជាបទេសដូចខាងក្នុងបំពង់ឫស្សី និងបបុស កម្ពស់ប្រមាណ ៨ ធ្នាប់ នៅខាងចុងពោះវៀនធំ រាងពោះតូច និងឆ្អឹងទ្រនង់ខ្នងខាងក្រោម ប្រៀបដូចទឹកភ្លៀងធ្លាក់ត្រង់ទីខាងលើ ហូរចុះទៅទីខាងក្រោមពេញហើយ ដក់នៅ យ៉ាងណា ទឹក និងបាយជាដើមណាមួយ ដែលធ្លាក់ចូលក្នុងលំនៅរបស់អាហារថ្មី កាលភ្លើងធាតុជុតឲ្យឆ្អិន បែកជាពពុះតូច-ធំ

ក្លាយជារបស់ល្អិតដូចមេរ្យា ព្រោះភ្លើងជាតុធ្វើឲ្យល្អិត ហើយក៏ហូរទៅតាមបំពង់ពោះវៀនធំ ប្រជ្រៀតគ្នា តាំងនៅ ដូចជីពណ៌លឿងដែលគេញាត់ក្នុងបំពង់ឫស្សី និងដើមបបុស ក៏ដូច្នោះដូចគ្នា ។

ក្នុងអាហារចាស់នោះ ក៏កំណត់ថា អាហារចាស់រមែងមិនដឹងថា អញនៅក្នុងលំនៅរបស់អាហារ ដែលរលាយហើយ សូម្បីលំនៅរបស់អាហារ ដែលរលាយហើយ ក៏មិនដឹងថា អាហារចាស់នៅក្នុងអញ ប្រៀបដូចជីឥដ្ឋ ដែលគេច្របាច់ញាត់ក្នុងបំពង់ឫស្សី និងដើមបបុស រមែងមិនដឹងថា អញនៅក្នុងបំពង់ឫស្សី និងដើមបបុស សូម្បីបំពង់ឫស្សី និងដើមបបុស ក៏មិនដឹងថា ជីឥដ្ឋនៅក្នុងអញ ដូច្នោះ ដឿតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា អាហារចាស់ ១ណ្ហដោយចំណែកនៃអាហារចាស់ នេះជាការកំណត់អាហារចាស់នោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់អាហារចាស់ដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

មត្តលុង្គំ

បន្ទាប់អំពីនេះទៅ ក៏កំណត់ដោយពណ៌ថា ខួរក្នុងលលាដ៍ក្បាល ក្នុងសរីរៈមានពណ៌សដូចផ្សិត ។ អាចារ្យពួកខ្លះពោលថា មានពណ៌ដូចទឹកដោះស្រស់ ដូច្នេះក៏មាន ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ដោយទិសកើតក្នុងទិសខាងលើ ។ ដោយឱកាសជាប្រភេទជុំខួរ ៤ ជុំ ដែលអាស្រ័យស្នាមសរសៃ ៤០០ ខាងក្នុងលលាដ៍ក្បាល រួមគ្នាតាំងនៅដូចជុំមេរ្យា ៤ ជុំ

ដែលគេរួមគ្នាតាំងទុក ។

លលាដ៍ក្បាលនោះកំណត់ថា ខួរក្នុងក្បាល រមែងមិនដឹងថា អញនៅក្នុងលលាដ៍ក្បាល លលាដ៍ក្បាលក៏មិនដឹងថា ខួរក្នុងក្បាលនៅក្នុងអញ ប្រៀបដូចដុំម្សៅដែលគេដាក់ក្នុងសម្បកឃ្លោកចាស់ ឬទឹកដោះក្តៅ រមែងមិនដឹងថា អញនៅក្នុងសម្បកឃ្លោកចាស់ សូម្បីសម្បកឃ្លោកចាស់ ក៏មិនដឹងថា ដុំម្សៅ ឬទឹកដោះក្តៅនៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ រៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ខួរក្នុងក្បាល ខណ្ឌដោយចំណែកនៃខួរក្នុងក្បាល នេះជាការកំណត់ខួរក្នុងក្បាលនោះដោយសកាគ ឯការកំណត់ដោយវិសភាគ ដូចគ្នានឹងសក់នោះឯង ។ កំណត់ខួរក្នុងក្បាលដោយពណ៌ជាដើម មានប្រការដូចពោលមកដូច្នេះ ។

បិត្តំ

បន្តអំពីនេះទៅ កំណត់ថា ប្រមាត់មាន ២ ប្រភេទ គឺប្រមាត់ក្នុងស្រោម និងប្រមាត់ក្រៅស្រោម មានពណ៌ដូចប្រេងស្រគំខាប់ អាចារ្យពួកខ្លះពោលថា ប្រមាត់ក្រៅស្រោម មានពណ៌ដូចផ្កាពិកុលក្រៀមដូច្នេះក៏មាន មានសណ្ឋានដូចឱកាស ដោយទិស កើតក្នុងទិសទាំង ២ ដោយឱកាស ប្រមាត់ក្រៅស្រោម រៀរទីរបស់សក់ រោម ក្រចក ធ្មេញ ដែលផុតចាកសាច់ និងស្បែកដែលរឹង ឬក្រិន ប្រមាត់ជ្រួតពេញសរីរៈដ៏សេស ដូចតំណក់ប្រេង ផ្សាយទៅលើទឹក កាលប្រមាត់កម្រើកហើយ ក្អែកក៏ទៅជាលឿង វិលមុខ ញ័រខ្លួន

និងកើតរមាស់ ។ ប្រមាត់ក្នុងស្រោមតាំងនៅក្នុងស្រោមប្រមាត់ ដូចផ្លែនោងព្រៃធំ អាស្រ័យសាច់បេះដូង តាំងនៅក្នុងចន្លោះបេះដូង និងសួត កាលកម្រើកហើយ សត្វទាំងឡាយនឹងទៅជាឆ្គួត មានចិត្តវិបល្លាស លះបង់នូវហិរិនិងឱត្តប្បៈ ធ្វើការដែលមិនគួរធ្វើ ពោលពាក្យដែលមិនគួរពោល គិតវត្ថុដែលមិនគួរគិត ។

ក្នុងប្រមាត់នោះ ក៏កំណត់ថា ប្រមាត់ឥតស្រោម រមែងមិនដឹងថា អញជ្រួតជ្រាបពេញសរីរៈ សូម្បីសរីរៈក៏មិនដឹងថា ប្រមាត់ក្រៅស្រោមជ្រួតជ្រាបក្នុងអញ ប្រៀបដូចប្រេងជ្រួតជ្រាបក្នុងទឹក រមែងមិនដឹងថា អញជ្រួតជ្រាបក្នុងទឹក សូម្បីទឹកក៏មិនដឹងថា ប្រេងជ្រួតជ្រាបក្នុងអញ ដូច្នោះ ប្រមាត់ក្នុងស្រោម រមែងមិនដឹងថា អញនៅក្នុងស្រោម សូម្បីស្រោមក៏មិនដឹងថា ប្រមាត់នៅក្នុងអញ ប្រៀបដូចទឹកភ្លៀងដែលនៅក្នុងកន្សោមនោងព្រៃ រមែងមិនដឹងថា អញនៅក្នុងកន្សោមនោងព្រៃ សូម្បីកន្សោមនោងព្រៃ ក៏មិនដឹងថា ទឹកភ្លៀងនៅក្នុងអញ ដូច្នោះ ។ ជ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទក៏កំណត់ថា ប្រមាត់ខណ្ឌដោយចំណែកនៃប្រមាត់ នេះជាការកំណត់ប្រមាត់នោះដោយសភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ប្រមាត់ដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

សេម្ហំ

បន្តអំពីនេះទៅ នឹងពោលអំពីសេម្ហៈ ដោយពណ៌ ស្លេស្មមានប្រមាណ

មួយបាត្រ[1] ខាងក្នុងសរីរៈ មានពណ៌ស ដូចពណ៌ក្នុងទឹកផ្លែល្វា ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ដោយទិស កើតក្នុងទិសខាងលើ ដោយឱកាស តាំងនៅក្នុងពោះ ក្នុងកាលលេបអាហារ មានទឹក និងភោជនជាដើម កាលទឹក និងភោជនជាដើមធ្លាក់ចុះ ក៏បែកចេញជា ២ ចំណែក ហើយបិទបាំងវិញ បើមានតិច ផ្ទៃពោះនឹងមានក្ងិនដូចសាកសព គួរខ្ពើមរអើមក្រៃលែង ដូចបបូសដែលទុំ ដូចពងមាន់ស្អុយ ប្រៀបដូចចកក្នុងទឹក កាលកំណាត់ឈើ ឬអំបែងធ្លាក់ចុះ ក៏ជាច់ចេញជា ២ ចំណែក ហើយត្រឡប់មកបិទបាំងផ្ទៃទឹកទៀត ដូច្នោះ កើក្តី ស្ងាបក្តី នឹងមានក្ងិនស្អុយដូចសាកសព ស្អុយដោយក្ងិនដែលផ្សាយឡើងក្នុងពោះនោះ បុគ្គលនោះក៏ត្រូវគេដេញគំហកថា ចេញទៅឯង ជះក្ងិនស្អុយ ហើយកាលសេម្ហៈចម្រើនច្រើនឡើង ក៏ជួយរម្ងាប់ក្ងិនស្អុយតាំងនៅខាងក្នុងផ្ទៃពោះនោះឯង ដូចបន្ទុះក្តារដែលបិទបង្គន់ ។

ក្នុងសេម្ហៈនោះ ក៏កំណត់ថា សេម្ហៈរមែងមិនដឹងថា អញនៅក្នុងផ្ទៃពោះ សូម្បីផ្ទៃពោះក៏មិនដឹងថា សេម្ហៈនៅក្នុងអញ ប្រៀបដូចដុំពពុះនៅលើអណ្តូងស្មោកគ្រោក រមែងមិនដឹងថា អញនៅក្នុងអណ្តូងស្មោកគ្រោក សូម្បីអណ្តូងស្មោកគ្រោកក៏មិនដឹងថា ដុំពពុះនៅក្នុងអញ ដូច្នោះ ជ្បិតថា ធម៌ទាំងនេះវៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា សេម្ហៈខណ្ឌដោយចំណែកនៃសេម្ហៈ ។ នេះជាការកំណត់សេម្ហៈនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់សេម្ហៈដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

១- ឯកបត្ត ក្នុងទីខ្លះ លោកប្រែថា មួយកម្សៀ

បុព្វោ

បន្ទាប់ពីនេះទៅ ក៏កំណត់បុព្វោថា ដោយពណ៌ ខ្លុះមានពណ៌ដូចស្លឹកឈើទុំ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ដោយទិស កើតក្នុងទិសទាំង ២ ដោយឱកាស ធម្មតាឱកាសរបស់ទិសតាំងនៅជាប្រចាំមិនមាន និងតាំងនៅក្នុងតំណែងសរីរៈដែលខ្លុះសន្សំ តាំងនៅ កាលត្រូវជង្គត់ បន្ទា ឬអណ្តាតភ្លើងជាដើមក្តី ប៉ះខូបហើយ ក៏រងឈាម ឬកើតបូស ឬពកជាដើម ។ ក្នុងខ្លុះនោះក៏កំណត់ថា ខ្លុះរមែងមិនដឹងថា អញតាំងនៅក្នុងតំណែងដែលត្រូវជង្គត់ និងបន្ទាជាដើមប៉ះខូប ឬក្នុងតំណែងដែលកើតបូស និងពកជាដើមក្នុងទីនោះៗ នៃសរីរៈ សូម្បីតំណែងនៃសរីរៈក៏មិនដឹងថា ខ្លុះនៅក្នុងអញប្រៀបដូចជ័រឈើដែលហូរចេញ តាំងនៅក្នុងទីដែលត្រូវមុខពូថៅជាដើមចំពោះក្នុងទីនោះៗ នៃដើមឈើ រមែងមិនដឹងថា អញតាំងនៅក្នុងទីដែលត្រូវចំពោះរបស់ដើមឈើ សូម្បីទីដែលត្រូវចំពោះរបស់ដើមឈើ ក៏មិនដឹងថា ជ័រឈើតាំងនៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ខ្លុះខណ្ឌដោយចំណែកនៃខ្លុះ នេះជាការកំណត់ខ្លុះនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ខ្លុះដោយវណ្ណៈជាដើមមានប្រការដូចពោលមក ដូច្នេះ ។

លោហិតំ

បន្តបន្ទាប់អំពីនេះទៅ នឹងពោលអំពីលោហិត ឈាមមាន ២ យ៉ាង គឺ ឈាមខាប់ និងឈាមរាវ នឹងកំណត់ឈាមខាប់មុន ដោយពណ៌ មានពណ៌

ដូចទឹកលក្ខ្មាប់ ឈាមរាវមានពណ៌ដូចទឹកលក្ខ្មាថ្លា ។ ដោយសណ្ឋានឈាមគ្រប់យ៉ាងមានសណ្ឋានដូចឱកាសរបស់ខ្លួន ដោយទិស ឈាមខាប់កើតក្នុងទិសខាងលើ ឈាមរាវកើតក្នុងទិសទាំង ២ ដោយឱកាសឈាមរាវផ្សព្វផ្សាយទៅពេញសរីរៈគ្រប់ចំណែករបស់សត្វរស់ រឿរតែទីដែលសក់ រោម ក្រចក និងធ្មេញដែលផុតចាកសាច់ និងស្បែកដែលក្រិន និងស្ងួតប៉ុណ្ណោះ ឈាមខាប់ធ្វើចំណែកខ្លះនៃថ្លើមឲ្យពេញលេញ ហើយធ្វើតំណក់ឈាមឲ្យស្រក់ចុះម្តងបន្តិចៗ លើក្រពះ បេះដូង ថ្លើម និងសួត ប្រមាណពេញមួយទូកដៃ ។ ធ្វើក្រពះ បេះដូង ថ្លើម និងសួតឲ្យសើម កាលមិនធ្វើក្រពះ និងបេះដូងជាដើមឲ្យសើម សត្វទាំងឡាយក៏ស្រេកទឹក ។

ក្នុងឈាមក៏កំណត់ថា ឈាមរមែងមិនដឹងថា អញធ្វើក្រពះ និងបេះដូងជាដើមឲ្យសើម តាំងនៅចំណែកខាងក្រោមនៃថ្លើម សូម្បីត្រង់ចំណែករបស់ថ្លើម ក្រពះ និងបេះដូងជាដើម ក៏មិនដឹងថា ឈាមតាំងនៅក្នុងអញ ឬធ្វើអញឲ្យសើម តាំងនៅ ប្រៀបដូចទឹកដែលនៅក្នុងកាជនៈចាស់ៗ ធ្វើដុំដីជាដើមខាងក្រោមឲ្យសើម រមែងមិនដឹងថា អញតាំងនៅក្នុងកាជនៈចាស់ៗ ធ្វើដុំដីជាដើមខាងក្រោមឲ្យសើម សូម្បីកាជនៈចាស់ៗ ឬដុំដីជាដើមខាងក្រោម ក៏មិនដឹងថា ទឹកតាំងនៅក្នុងអញ ឬធ្វើអញឲ្យសើម តាំងនៅ ដូច្នោះ ដ្បិតថាធម៌ទាំងនេះ រឿរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ឈាមខាងក្នុងដោយចំណែកនៃឈាម ។ នេះជាការកំណត់ឈាមនោះ ដោយសភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹង

សក់នោះឯង ។ កំណត់ឈាមដោយពណ៌ជាដើម មានប្រការដូចពោលមកដូច្នេះ ។

សេនោ

បន្តអំពីនេះទៅ ក៏កំណត់សេនោថា ញើសក្នុងសរីរៈ ដោយពណ៌ មានពណ៌ដូចទឹកល្ងថ្លា ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ដោយទិសកើតក្នុងទិសទាំង ២ ដោយឱកាស ធម្មតាញើស ហូរចេញជានិច្ចក៏មិនមែនតែញើសមានសព្វកាល ឬក្នុងកាលណាសរីរៈក្តៅ ព្រោះពន្លឺថ្ងៃ និងរដូវប្រែប្រួលជាដើម ពេលនោះ ញើសនឹងហូរចេញគ្រប់រន្ធសក់ និងរន្ធរោមដូចទឹកក្នុងក្រអៅឈូក និងទង់ឈូកដែលកាត់មិនរាបស្មើលើកឡើងផុតទឹកដូច្នោះ ទើបព្រះយោគាវចរកំណត់ញើសនោះ ដោយសណ្ឋាន ដោយរន្ធសក់ និងរណ្តៅរោមទាំងនោះ បុព្វាចារ្យទាំងឡាយពោលថា ដែលព្រះយោគាវចរកំណត់យកញើសជាអារម្មណ៍ គប្បីមនសិការដាក់ចិត្តក្នុងញើស ដោយភាពដែលញើសធ្វើរន្ធសក់ និងរណ្តៅរោមឲ្យពេញ ហើយតាំងនៅ ។

ក្នុងញើសនោះកំណត់ថា ញើសរមែងមិនដឹងថា អញហូរចេញអំពីរន្ធសក់ និងរណ្តៅរោម សូម្បីរន្ធសក់ និងរណ្តៅរោម ក៏មិនដឹងថា ញើសហូរចេញអំពីអញ ប្រៀបដូចទឹកដែលហូរចេញអំពីក្រអៅ និងទង់ឈូក រមែងមិនដឹងថា អញហូរចេញអំពីក្រអៅឈូក និងទង់ឈូក សូម្បីក្រអៅឈូក និងទង់ឈូក ក៏មិនដឹងថា ទឹកហូរចេញអំពីអញ ដូច្នោះ ជ្បឹតថា ធម៌ទាំងនេះវៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ

កំណត់ថា ញើសខណ្ឌដោយចំណែកនៃញើស នេះជាការកំណត់ញើសនោះ ដោយសកាគ ។ ឯការកំណត់ដោយវិសកាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ញើសដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

មេទោ

បន្ទាប់អំពីនេះទៅ ក៏កំណត់មេទោ ដោយវណ្ណថា ខ្លាញ់ខាប់នៅក្នុងចន្លោះស្បែក និងសាច់ក្នុងសរីរៈ ដោយពណ៌ មានពណ៌ដូចរមៀតដែលពុស ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ពិតហើយ សម្រាប់បុគ្គលដែលមានខ្លួនធាត់ មានសេចក្តីសុខ ខ្លាញ់ខាប់ដែលផ្សាយទៅក្នុងចន្លោះស្បែក និងសាច់ មានសណ្ឋានដូចសំពត់សម្បកឈើចាស់ជ្រលក់រមៀត សម្រាប់បុគ្គលដែលមានខ្លួនស្គម ខ្លាញ់ខាប់ អាស្រ័យសាច់កំភួនជើង សាច់ក្លៅ សាច់អាស្រ័យឆ្អឹងខ្នង សាច់ខ្នង និងសាច់ផ្ទៃពោះប្រជុំគ្នា មានសណ្ឋានដូចសំពត់សម្បកឈើចាស់ជ្រលក់រមៀត ដែលគេប្រមូល ។ ដោយទិសកើតក្នុងទិសទាំង ២ ដោយឱកាស ខ្លាញ់ខាប់ សម្រាប់បុគ្គលធាត់ ផ្សាយទូទៅពេញសរីរៈ សម្រាប់បុគ្គលស្គម អាស្រ័យសាច់កំភួនជើងជាដើម គឺខ្លាញ់ស្អិត មិនមែនសង្គ្រោះដើម្បីជាខួរក្នុងឆ្អឹង មិនមែនដើម្បីជាប្រេងក្នុងពំនូតបាយ មិនមែនដើម្បីធ្វើជាប្រេងប្រទីប ព្រោះជារបស់គួរខ្ពើមរអើមក្រៃលែង ។

ក្នុងខ្លាញ់ខាប់នោះកំណត់ថា ខ្លាញ់ខាប់រមែងមិនដឹងថា អញអាស្រ័យពេញសរីរៈ ឬសាច់ដែលរឹងជាដើមតាំងនៅ សូម្បីសរីរៈទាំងមូល ឬសាច់

ដែលរឹងជាដើម ក៏មិនដឹងថា ខ្លាញ់ខាប់អាស្រ័យអញតាំងនៅ ប្រៀបដូចសំពត់សម្បកឈើចាស់ជ្រលក់រមៀត ដែលគេជាក់ផ្អែកគំនរសោច់ រមែងមិនដឹងថា អញគេជាក់ផ្អែកគំនរសោច់ សូម្បីគំនរសោច់ក៏មិនដឹងថា សំពត់សម្បកឈើចាស់ជ្រលក់រមៀត ជាក់ផ្អែកអញ ដូច្នោះ ។ ដ្បិតថា ធម៌ទាំងនេះវៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ខ្លាញ់ខាប់ខាងក្រោមខណ្ឌដោយសាច់ ខាងលើខណ្ឌដោយស្បែក ជុំវិញខណ្ឌដោយចំណែកនៃខ្លាញ់ខាប់ នេះជាការកំណត់ខ្លាញ់ខាប់នោះដោយសភាគ ឯការកំណត់ដោយវិសភាគ ដូចគ្នានឹងសក់នោះឯង ។ កំណត់ខ្លាញ់ខាប់ដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

អស្សុ

លំដាប់អំពីនេះទៅ ក៏កំណត់ថា ដោយវណ្ណៈ ទឹកភ្នែកមានពណ៌ដូចប្រេងល្ងថ្លា ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសខាងលើ ដោយឱកាស តាំងនៅក្នុងប្រឡង់ភ្នែក ។ ទឹកភ្នែកនោះ មិនមែនជក់នៅក្នុងប្រឡង់ភ្នែកគ្រប់កាល ដូចប្រមាត់ក្នុងស្រោមនោះឡើយ សេចក្តីនេះដូចម្តេច កាលណាសត្វទាំងឡាយកើតសោមនស្ស ក៏សើចសប្បាយ កើតទោមនស្សក៏ទ្រហោយំ ឬបរិភោគអាហារហឺរក៏ដូចគ្នា កាលណាភ្នែកទាំង ២ នៃសត្វទាំងនោះត្រូវផ្សែង ឬលម្អងធូលី និងកម្ទេចជាដើមប៉ះខ្ទប់ កាលនោះទឹកភ្នែកកើតឡើងព្រោះសោមនស្ស ទោមនស្ស និងអាហារក្តៅជាដើម ក៏នៅជក់ ហៀរចេញពេញប្រឡង់ភ្នែក បុព្វាចារ្យទាំងឡាយពោលថា ព្រះ

យោគាវចរកំណត់យកទឹកភ្នែកជាអារម្មណ៍ គប្បីមនសិការដាក់ចិត្តក្នុងទឹកភ្នែកដែលកំពុងជក់ពេញប្រឡង់ភ្នែកនោះឯង ។

ក្នុងទឹកភ្នែកនោះកំណត់ថា ទឹកភ្នែករមែងមិនដឹងថា អញជក់នៅក្នុងប្រឡង់ភ្នែក ប្រឡង់ភ្នែកមិនដឹងថា ទឹកភ្នែកជក់នៅក្នុងអញ ប្រៀបដូចទឹកដែលជក់នៅក្នុងប្រឡង់ផ្លែត្នោត ដែលកាត់ខាងចុង រមែងមិនដឹងថា អញជក់នៅក្នុងប្រឡង់ផ្លែត្នោតដែលកាត់ចុង សូម្បីប្រឡង់ផ្លែត្នោតដែលកាត់ចុង ក៏មិនដឹងថា ទឹកជក់នៅក្នុងអញ ដូច្នោះ ជ្បិតថា ធម៌ទាំងនេះវៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ទឹកភ្នែកខណ្ឌដោយចំណែកនៃទឹកភ្នែក នេះជាការកំណត់ទឹកភ្នែកនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹកភ្នែកដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

វសា

តអំពីនោះទៅ ក៏កំណត់ខ្លាញ់រាវដោយពណ៌ថា ខ្លាញ់រាវ គឺខ្លាញ់ដែលរលាយ នៅក្នុងសរីរៈ មានពណ៌ដូចប្រេងដែលស្រោចក្នុងចាយក្តាំង ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស តាំងនៅត្រង់បាតដៃ ខ្នងដៃ បាតជើង ខ្នងជើង ក្តោងច្រមុះ ថ្ងាស និងចង្ការ តែខ្លាញ់រាវនោះ មិនមែនរលាយ តាំងនៅក្នុងឱកាសទាំងនោះគ្រប់កាលឡើយ ។ សេចក្តីនេះដូចម្តេច ។ កាលណាបទេសទាំងនោះក្តៅ ព្រោះកម្តៅភ្លើង ឬកម្តៅថ្ងៃ រដូវ និងធាតុដែលផ្សំគ្នា កាលនោះ

ខ្ញាញ់រាវក៏រលាយ ជ្រួតជ្រាបទៅក្នុងបទេសទាំងនោះ ដូចទឹកសន្សើមក្នុងអណ្តូងទឹកដែលមានទឹកថ្លា ។ ក្នុងខ្ញាញ់រាវ កំណត់ថា ខ្ញាញ់រាវ រមែងមិនដឹងថា អញជ្រាបសើមនៅតាមបាតដៃជាដើម សូម្បីបាតដៃជាដើមក៏មិនដឹងថា ខ្ញាញ់រាវជ្រាបអញ ដូចទឹកសន្សើមដែលជ្រាបក្នុងអណ្តូងទឹក រមែងមិនដឹងថា អញជ្រាបក្នុងអណ្តូងទឹក សូម្បីអណ្តូងទឹកក៏មិនដឹងថា ទឹកសន្សើមជ្រាបអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះវៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ខ្ញាញ់រាវណ្ហដោយចំណែកនៃខ្ញាញ់រាវ នេះជាការកំណត់ខ្ញាញ់រាវនោះដោយសភាគ ឯការកំណត់ដោយវិសភាគក៏ដូចគ្នានឹងសក់នោះឯង កំណត់ខ្ញាញ់រាវជាដើម មានប្រការដូចពោលមកដូច្នេះ ។

ខេឡា

បន្តអំពីនេះទៅ ក៏កំណត់ខេឡាដោយពណ៌ថា ទឹកមាត់ខាងក្នុងមាត់ក្នុងសរីរៈ ពណ៌សដូចពពុះទឹក ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចពពុះទឹកសមុទ្រដូច្នេះក៏មាន ដោយទិស កើតក្នុងទិសខាងលើ ដោយឱកាស ហូរចុះអំពីថ្ពាល់ទាំងសងខាង តាំងនៅត្រង់អណ្តាត តែទឹកមាត់នោះ មិនមែនសន្សំតាំងនៅត្រង់ថ្ពាល់នោះគ្រប់កាលទេ្បីយ សេចក្តីនេះដូចម្តេច ។ កាលណា សត្វទាំងឡាយឃើញ ឬនឹកដល់អាហារ ដូច្នោះ ឬជាក់របស់ក្តៅ របស់ដែលមានរសល្វីង ហឺរ ប្រៃ និងជូរណាមួយក្នុងមាត់ និងកាលណាបេះដូងរបស់សត្វទាំងនោះមិនសប្បាយ ឬ

កើតការស្រេកឃ្លានឡើងក្នុងកាលខ្លះ កាលនោះ ទឹកមាត់នឹងហូរអំពីថ្ពាល់ទាំងសងខាងតាំងនៅត្រង់អណ្តាត តែត្រង់ចុងអណ្តាតទឹកមាត់នោះស្ងើង ត្រង់គល់អណ្តាតក្រាស អំបុកក្តី អង្កក្តី របស់ទំពាជនៃៗ ណាមួយ ដែលជាក់ចូលក្នុងមាត់ ដែលមិនទាន់រលាយទៅ ដូចទឹកក្នុងអណ្តូងដែលជីកលើខ្សាច់ មាត់ស្ងើង កាលនោះទឹកមាត់ នឹងអាចធ្វើរបស់ទំពាឲ្យសើម ។

ក្នុងទឹកមាត់នោះ កំណត់ថា ទឹកមាត់រមែងមិនដឹងថា អញហូរចេញអំពីថ្ពាល់ទាំង ២ តាំងនៅត្រង់អណ្តាត សូម្បីអណ្តាតក៏មិនដឹងថា ទឹកមាត់ហូរចេញអំពីថ្ពាល់ទាំង ២ តាំងនៅលើអញ ប្រៀបដូចទឹកដែលតាំងនៅក្នុងអណ្តូងដែលគេជីកលើឆ្នេរខ្សាច់ មាត់ស្ងើង រមែងមិនដឹងថា អញតាំងនៅត្រង់អណ្តូង សូម្បីអណ្តូងក៏មិនដឹងថា ទឹកតាំងនៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះវៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ទឹកមាត់ខណ្ឌដោយចំណែកនៃទឹកមាត់ នេះជាការកំណត់ទឹកមាត់នោះដោយសកាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹកមាត់ដោយពណ៌ជាដើម មានប្រការដូចពោលមកដូច្នេះ ។

សិង្ឃាណិកា

បន្តអំពីនេះទៅ ក៏កំណត់សិង្ឃាណិកាដោយពណ៌ថា ទឹកសម្បាវមានពណ៌ដូចរំអិលត្នោតខ្ចី ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចពន្លកផ្តៅ ដែលគេជាក់ជាប់តគ្នា ចូលទៅ

ក្នុងវន្ទច្រមុះ ដូច្នេះក៏មាន ដោយទិសកើតក្នុងទិសខាងលើ ដោយឱកាស ជក់នៅពេញច្រមុះ តែទឹកសម្បារនោះ មិនមែនសន្សំជក់នៅក្នុងវន្ទច្រមុះនោះ គ្រប់កាលឡើយ សេចក្តីនេះដូចម្តេច ។ បុរសខ្ចប់ទឹកដោះជូរក្នុងស្បែកឈូក យកបន្ទាចោះស្បែកឈូកខាងក្រោម ពេលនោះ ដុំទឹកដោះជូរក៏នឹងហូរចេញ អំពីប្រហោងនោះ ធ្លាក់ចុះទៅខាងក្រៅ យ៉ាងណា កាលណាសត្វទាំងឡាយ យំ ឬកើតជាតុកម្រើកដោយអាហារ និងរដូវដែលមិនត្រូវគ្នា កាលនោះ ខួរក្នុងក្បាលក៏ក្លាយជាស្លេស្មហូរចេញ អំពីខាងក្នុងក្បាល ធ្លាក់តាមពិតាន ជក់នៅពេញច្រមុះដូច្នោះដូចគ្នា ។

ក្នុងទឹកសម្បារនេះ កំណត់ថា ទឹកសម្បារមិនដឹងថា អញជក់នៅក្នុងវន្ទច្រមុះ សូម្បីវន្ទច្រមុះក៏មិនដឹងថា ទឹកសម្បារជក់នៅក្នុងអញ ប្រៀបដូចទធិដែលគេជាក់ក្នុងសម្បកខ្វង រមែងមិនដឹងថា អញនៅក្នុងសម្បកខ្វង ទោះសម្បកខ្វងក៏មិនដឹងថា ទឹកដោះជូរនៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ ប្រាសចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ទឹកសម្បារខណ្ឌដោយចំណែកនៃទឹកសម្បារ នេះជាការកំណត់ទឹកសម្បារនោះដោយសភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ទឹកសម្បារដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

លសិកា

លំដាប់អំពីនេះទៅ ក៏កំណត់ថា សាកសពដែលរអិលជាប្រចៀង ខាងក្នុង

ទី-តនៃសរីរៈខាងក្នុងសរីរៈ ឈ្មោះថា ទឹកអំអិល ។ ដោយពណ៌ ទឹកអំអិលនោះមានពណ៌ដូចជវកណិការ ដោយសណ្ឋានមានសណ្ឋានដូចអាកាសដែលតាំងនៅ ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាសឲ្យសម្រេចកិច្ច គឺធ្វើកិច្ចផ្សើមត្រង់ទី-តនៃឆ្អឹងទាំងឡាយ តាំងនៅខាងក្នុងទី-ត ១៨០ កន្លែង ។ ក្នុងទឹកអំអិលនោះ បុគ្គលណាមានទឹកអំអិលតិច បុគ្គលនោះក្រោកឡើង អង្គុយចុះ ឈានទៅមុខ ឈានថយក្រោយ បត់ដៃ លាដៃ ឆ្អឹងទាំងឡាយក៏នឹងលាន់ប្រសៗ ដើរទៅក៏ដូចធ្វើសំឡេងផ្ចាត់ម្រាមដៃ ធ្វើដំណើរទៅឆ្ងាយបានត្រឹមតែ ១ យោជន៍ ២ យោជន៍ វាយោធាតុក៏កម្រើក កាយក៏លំបាក ឯទឹកអំអិលនៃបុគ្គលណាមានច្រើន ឆ្អឹងទាំងឡាយរបស់បុគ្គលនោះ ក៏មិនលាន់ប្រសៗ ក្នុងខណៈក្រោកឡើង និងអង្គុយចុះជាដើម ធ្វើដំណើរបានយូរ វាយោធាតុក៏មិនកម្រើក កាយក៏មិនលំបាក ។

ក្នុងទឹកអំអិលនោះ កំណត់ថា ទឹកអំអិលរមែងមិនដឹងថា អញផ្សើមត្រង់ទី-ត ១៨០ កន្លែង សូម្បីទី-ត ១៨០ កន្លែងក៏មិនដឹងថា ទឹកអំអិលផ្សើមអញ ប្រៀបដូចប្រេងបន្តក់ភ្លៅវេជ រមែងមិនដឹងថា អញផ្សើមភ្លៅវេជ ភ្លៅវេជក៏មិនដឹងថា ប្រេងផ្សើមអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ រៀវចាកការគិតនិងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ទឹកអំអិលខណ្ឌដោយចំណែកនៃទឹកអំអិលនោះ ដោយសភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ទឹកអំអិលដោយវណ្ណៈជាដើមមានប្រការដូចពោលមក ដូច្នេះ ។

ឫត្តំ

បន្តបន្ទាប់អំពីនេះទៅ កំណត់ទឹកមូត្រដោយពណ៌ថា ទឹកមូត្រក្នុងសរីរៈ ដោយវណ្ណៈ មានពណ៌ដូចទឹកល្បុងសណ្តែកវាជមាស ដោយសណ្ឋាន មានសណ្ឋានដូចទឹកដែលនៅក្នុងក្អមទឹកដែលពេញ ដែលគេជាក់ផ្តាប់មាត់ ។ ដោយទិស កើតក្នុងទិស ខាងក្រោម ដោយឱកាស តាំងនៅក្នុងជ្រោកនោម ។ ជ្រោកនោម លោកហៅថា តម្រងបស្សាវៈ ដែលប្រៀបដូចទឹកស្មោកគ្រោក រមែងចូលទៅក្នុងធ្នាំង ដែលមិនមានមាត់ ដែលគេព្យួរនៅក្នុងអណ្តូង ស្មោកគ្រោក ផ្លូវចូលទៅរបស់ទឹកស្មោកគ្រោកនោះមិនជ្រាកជ យ៉ាងណា ទឹកមូត្រចូលទៅក្នុងសរីរៈ តែផ្លូវចូលទៅរបស់ទឹកមូត្រនោះ មិនជ្រាកជ ផ្លូវចេញប៉ុណ្ណោះជ្រាកជ ។

ក្នុងទឹកមូត្រនោះកំណត់ថា ទឹកមូត្រនោះមិនដឹងថា អញតាំងនៅក្នុងតម្រងបស្សាវៈ តម្រងបស្សាវៈក៏មិនដឹងថា ទឹកមូត្រតាំងនៅក្នុងអញ ប្រៀបដូចទឹកស្មោកគ្រោកក្នុងធ្នាំងដែលមិនមានមាត់ ដែលគេជាក់ក្នុងអណ្តូងស្មោកគ្រោក រមែងមិនដឹងថា អញនៅក្នុងធ្នាំងដែលមិនមានមាត់ សូម្បីធ្នាំងក៏មិនដឹងថា ទឹកស្មោកគ្រោកតាំងនៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ រៀវចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ទឹកមូត្រខណ្ឌដោយតម្រងបស្សាវៈ និងដោយចំណែកនៃទឹកមូត្រ នេះជាការកំណត់ទឹកមូត្រនោះដោយសភាគ ។ ឯការកំណត់ដោយវិសភាគក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ទឹកមូត្រដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។ ព្រះយោគាវចរកំណត់ទុត្តិសាការនេះ ដោយវណ្ណៈជាដើម

ដោយប្រការដូច្នេះ ។

ព្រោះអាស្រ័យការប្រកបរឿយៗ នូវភាវនា ការចម្រើនទុត្តិសាការនោះៗ ទុត្តិសាការ មានសក់ជាដើម ក៏រមែងស្ងាត់ជំនាញ ប្រាកដច្បាស់ក្នុងកោដ្ឋាស ដែលជាចំណែកៗ ដល់ព្រះយោគាវចរនោះ ដែលកំណត់ទុត្តិសាការនេះ ដោយវណ្ណៈជាដើម ដោយប្រការដូច្នេះ ។ តាំងអំពីនេះទៅ កាលបុរសមានភ្នែក ពិនិត្យមើលកម្រងផ្កានៃផ្កាទាំងឡាយ ដែលមាន ៣២ ពណ៌ ដែលជោត ដោយអំបោះតែមួយ ផ្កាគ្រប់ផ្កា រមែងប្រាកដមិនមុន មិនក្រោយ យ៉ាងណា កាលព្រះយោគាវចរ ពិនិត្យពិចារណាកាយនេះដោយសតិថា ក្នុងកាយនេះ មានសក់ជាដើម ធម៌ទាំងអស់នោះ រមែងប្រាកដមិនមុន មិនក្រោយដូច្នោះដូចគ្នា សតិដែលតាំងឡើងក្នុងសក់ទាំងឡាយដែលនឹកដល់ រមែងប្រព្រឹត្តទៅ រហូតដល់ទឹកមូត្រ តាំងអំពីនោះទៅ មនុស្ស និងសត្វតិរច្ឆានជាដើម ដែលដើរទៅមក និងលះអាការផស្សៈ ប្រាកដច្បាស់តែគំនរនៃកោដ្ឋាសជាចំណែកៗ ប៉ុណ្ណោះ ដល់ព្រះយោគាវចរនោះ ទឹក និងភោជនជាដើមដែលសត្វទាំងនោះលេបចូលទៅ ដូចទម្លាក់ទៅក្នុងគំនរកោដ្ឋាស ។

ក្នុងសេចក្តីនេះ អ្នកចោទសួរពោលថា បើដូច្នោះ ព្រះយោគាវចរនេះ គប្បីធ្វើអ្វី បន្ទាប់អំពីនោះទៅ ។ ការចង្អុលបង្ហាញដូច្នេះ និមិត្តទាំងនោះឯង ដែលព្រះយោគាវចរគប្បីសេព គប្បីចម្រើន គប្បីធ្វើឲ្យច្រើន គប្បីកំណត់ដោយល្អ សួរថា ព្រះយោគាវចរនេះ សេព ចម្រើននិមិត្តនោះ ធ្វើឲ្យច្រើន កំណត់ឲ្យជាការកំណត់ ដោយល្អដូចម្តេច ។ ឆ្លើយថា ព្រះយោគាវចរនេះ

សេពនិមិត្តត្រង់ទុត្តីសាការ មានសក់ជាដើមប្រាកដ ជាកោដ្ឋាសចំណែកនោះៗ រមែងចង គប់រក ចូលទៅអង្គុយជិតដោយសតិ ឲ្យចិត្តទាញយកនូវបន្ទប់ គឺសតិ ឬធ្វើសតិដែលបានក្នុងនិមិត្តនោះឲ្យជុះដាល លោកហៅថា ចម្រើននិមិត្តនោះ ។ ពាក្យថា ធ្វើឲ្យច្រើន បានដល់ ធ្វើនិមិត្តនោះរឿយៗ ឲ្យប្រកបដោយសតិដែលវិតក្ក និងវិចារៈប៉ះខ្ទប់ហើយ ។ ពាក្យថា កំណត់ឲ្យជាការកំណត់ដោយល្អ បានដល់ និមិត្តដែលកំណត់ដោយល្អ មិនវិនាសទៅទៀត ដោយប្រការណា ព្រះយោគាវចររមែងកំណត់ចូលទៅទទួល ចូលទៅចងនិមិត្តនោះដោយសតិ ដោយប្រការនោះ ។

ម្យ៉ាងទៀត មនសិការកោសល ការឈ្វាសក្នុងមនសិការឯណា ដែលពោលអំពីមុន ១០ ប្រការយ៉ាងនេះ គឺដោយលំដាប់ ១ ដោយមិនរហ័សពេក ១ ដោយមិនយឺតពេក ១ ដោយការពារការរាយមាយ ១ ដោយកន្លងបញ្ញត្ត ១ ដោយរំលងលំដាប់ ១ ដោយលក្ខណៈ ១ សូត្រទាំងបី ១ ។ មនសិការកោសលនោះ គប្បីជ្រាបថា ព្រះយោគាវចរមនសិការដោយលំដាប់ ឈ្មោះថា សេព ។ មនសិការដោយមិនលឿនពេក ដោយមិនយឺតពេក ឈ្មោះថា ចម្រើន មនសិការដោយការពារការរាយមាយ ឈ្មោះថា ធ្វើឲ្យច្រើន មនសិការដោយកន្លងបញ្ញត្តិជាដើម ឈ្មោះថា កំណត់ឲ្យជាការកំណត់ដោយល្អ ។

ក្នុងសេចក្តីនេះ អ្នកចោទសួរថា ព្រះយោគាវចរនេះ មនសិការធម៌ទាំងនេះ ដោយមនសិការកោសល មានដោយលំដាប់ជាដើមដូចម្តេច ។ សូម

ពោលចង្អុលបង្ហាញ ដូច្នេះ សេចក្តីពិត ព្រះយោគាវចរនេះ កាលមនសិការសក់ហើយ បន្ទាប់អំពីនោះក៏មនសិការរោម មិនមនសិការក្រចក ។ ក្នុងអាការ គ្រប់យ៉ាងក៏មានន័យ ដូច្នេះ ព្រោះហេតុអ្វី ព្រោះថា ព្រះយោគាវចរកាលមនសិការខុសលំដាប់ ចិត្តក៏លំបាក ធ្លាក់ចុះទៅអំពីទុត្តីសាការភាវនាចម្រើនភាវនាមិនសម្រេច ព្រោះមិនបាននូវអស្សាទ គឺសេចក្តីត្រេកអរ ដែលគួរបានដោយភាវនាសម្បត្តិ ប្រៀបដូចបុរសមិនឈ្វាស ឡើងជណ្តើរ ៣២ កាំ ខុសលំដាប់ ក៏លំបាកកាយ រមែងធ្លាក់ចុះ ឡើងជណ្តើរមិនសម្រេច ដូច្នោះ ។

ម្យ៉ាងទៀត ព្រះយោគាវចរសូម្បីមនសិការដោយលំដាប់ ក៏មិនមនសិការរហ័សពេកថា កេសា លោមា ។ ព្រោះថា ព្រះយោគាវចរកាលមនសិការរហ័សពេក ក៏មិនអាចកំណត់ពណ៌ និងសណ្ឋានជាដើម ដែលផុតចាកទុត្តីសាការ បន្ទាប់អំពីនោះ ក៏មិនឈ្វាសក្នុងទុត្តីសាការ និងកម្មដ្ឋានដែលវិនាសទៅ ប្រៀបដូចបុរសកំពុងដើរផ្លូវធ្វាយ មិនអាចកំណត់ផ្លូវរាបស្មើ ផ្លូវមិនរាបស្មើ ដើមឈើ ដង្គត់ រណ្តៅ ផ្លូវបែកជា ២ ជាដើម ដែលផុតទៅអំពីផ្លូវ តអំពីនោះ ក៏មិនឈ្វាសក្នុងផ្លូវ ការដើរផ្លូវធ្វាយក៏នឹងអស់ទៅ ដូច្នោះ ។

ម្យ៉ាងទៀត ព្រះយោគាវចរ មនសិការដោយមិនរហ័សពេក យ៉ាងណាក៏មនសិការដោយមិនយឺតពេក ដូច្នោះ ព្រោះថា ព្រះយោគាវចរកាលមនសិការយឺតពេក ក៏មិនដល់នូវការសម្រេចទុត្តីសាការភាវនា តែនឹកដល់នូវសេចក្តីលំបាកដោយកាមវិតក្កជាដើមក្នុងចន្លោះ ព្រោះភាវនាជាច់ ប្រៀបដូចបុរសដើរ

ផ្លូវឆ្ងាយ ទើសទាក់នឹងដើមឈើ ភ្នំ និងអូរជាដើមក្នុងរវាងផ្លូវ ក៏មិនដល់ទីដែលខ្លួនប្រាថ្នា តែនឹងដល់នូវសេចក្តីលំបាកដោយសីហៈ និងខ្លាជាដើម ក្នុងរវាងផ្លូវនោះឯង ដូច្នោះ ។

ម្យ៉ាងទៀត ព្រះយោគាវចរសូម្បីមនសិការដោយមិនយឺតពេក ក៏មនសិការដោយការពារនូវសេចក្តីរាយមាយ ព្រះយោគាវចរមែងមនសិការដោយប្រការដែលមិនរាយមាយ ព្រោះការងារជនៃទៗ មាននវកម្មជាដើម ព្រះយោគាវចរដែលមានចិត្តរាយមាយទៅខាងក្រៅ មានការត្រិះរិះនៃចិត្ត មិនតាំងមាំក្នុងទ្វត្តឹ-សាការ មានសក់ជាដើម ក៏មិនដល់នូវការសម្រេចនៃការងារ នឹងដល់នូវសេចក្តីលំបាកក្នុងរវាងផ្លូវនោះឯង ដូចសម្ងាញ់របស់ព្រះពោធិសត្វ ដល់នូវសេចក្តីលំបាក ក្នុងការធ្វើដំណើរទៅកាន់នគរតក្កសិលា ឯព្រះយោគាវចរដែលមានចិត្តមិនរាយមាយ មានការត្រិះរិះនៃចិត្តតាំងមាំក្នុងទ្វត្តឹសាការ មានសក់ជាដើម ក៏ដល់នូវការសម្រេចនៃការងារ ដូចព្រះពោធិសត្វ ដល់នូវសេចក្តីសម្រេចនៃរាជសម្បត្តិក្នុងនគរតក្កសិលា ។ ធម៌ទាំងនោះ រមែងប្រាកដដោយអសុក ដោយពណ៌ ឬដោយភាពទេ ដោយអំណាចជារមី ចរិយា និងការបង្អោនចិត្តដើម្បីដល់ព្រះយោគាវចរនោះ ដែលមនសិការដោយការពារការរាយមាយដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះយោគាវចរមនសិការធម៌ទាំងនោះដោយកន្ធងបញ្ចត្ត ។ ពាក្យថា ដោយកន្ធងបញ្ចត្ត បានដល់ មនសិការកន្ធងនូវភោហារជាដើមយ៉ាងនេះថា កេសា លោមា ដោយជាអសុកជាដើម តាមដែលប្រាកដហើយ ។

មនសិការដូចម្តេច ប្រៀបដូចមនុស្សទាំង២ប្លាយដែលចូលទៅអាស្រ័យក្នុងព្រៃធ្វើគ្រឿងសម្គាល់ ដោយកាច់បំបាក់មែកឈើជាដើម ដើម្បីចំណាំទីដែលមានទឹក ព្រោះជាទឹកដីដែលមិនធ្លាប់ស្គាល់ ទៅតាមសញ្ញានោះ រមែងបរិភោគនូវទឹកបាន ។ តែកាលណាថ្នឹកក្នុងភូមិភាគហើយ ចោះបង់ការជាក់ចិត្តក្នុងគ្រឿងចំណាំនោះ ទៅកាន់ទីដែលមានទឹក បរិភោគទឹកបាន យ៉ាងណាមិញ ព្រះយោគាវចរនេះក៏ដូច្នោះដូចគ្នា មនសិការធម៌ទាំងនោះ ដោយវោហារនោះៗ មានកេសា លោមាជាដើមហើយ កាលធម៌ទាំងនោះប្រាកដជាច្បាស់ ដោយអារម្មណ៍ មានអសុភជាដើមឯណានីមួយ ក៏កន្ទងនូវវោហារនោះមនសិការដោយអារម្មណ៍ មានអសុភជាដើមនោះឯង ។

ក្នុងសេចក្តីនោះ បុគ្គលអ្នកសួរពោលថា ធម៌ទាំងនោះប្រាកដដោយភាពជាអសុភជាដើមដល់ព្រះយោគាវចរនោះដូចម្តេច ដោយវណ្ណៈដូចម្តេច ដោយភាពជារបស់ទេដូចម្តេច ។ ម្យ៉ាងទៀត ព្រះយោគាវចរនោះ មនសិការធម៌ទាំងនេះដោយអសុភដូចម្តេច ដោយវណ្ណៈដូចម្តេច ឬដោយភាពទេដូចម្តេច ជាបឋម សក់ទាំង២ប្លាយរមែងប្រាកដដល់ព្រះយោគាវចរនោះ ដោយអសុភជា ៥ ចំណែក គឺពណ៌ សណ្ឋាន ក្លិន ទីអាស្រ័យ និងឱកាស តាំងនៅព្រះយោគាវចរនេះក៏មនសិការធម៌ទាំងនេះ ជា ៥ ចំណែកនោះឯង ដោយអសុភ ។ សេចក្តីនេះដូចម្តេច ធម្មតាសក់ទាំងនេះ ដោយពណ៌មិនស្អាតជារបស់បដិកូល គួរខ្ពើមក្រៃលែង ។ ពិតហើយ មនុស្ស២ទាំង២ប្លាយឃើញសម្បកឈើ ឬអំបោះ ដែលមានពណ៌ដូចសក់ ដែលធ្លាក់ទៅក្នុងទឹក និង

បាយ ក្នុងពេលថ្ងៃ រមែងចោល ឬខ្ចីមទឹក និងបាយ សូម្បីជារបស់ពេញចិត្ត ដោយសម្គាល់ថា សក់ ។ សូម្បីដោយសណ្ឋានក៏មិនស្អាត ពិតហើយ មនុស្សទាំងឡាយប៉ះសម្បកឈើ ឬសរសៃអំពៅដែលមានសណ្ឋានដូចសក់ ដែលធ្លាក់ចូលទៅក្នុងទឹក ឬបាយក្នុងពេលយប់ រមែងចោល ឬខ្ចីមបាយ សូម្បីជារបស់ពេញចិត្ត ដោយសម្គាល់ថា សក់ ។ សូម្បីដោយក្លិនក៏មិនស្អាត ពិតហើយ សក់ទាំងឡាយដែលរៀរការតាក់តែង មានលាបប្រេងដោតផ្កា អប់ផ្សែងជាដើម ក្លិនគួរឆ្អៀសក្រៃលែង បុគ្គលហិតក្លិនសក់ដែលពោះចូលក្នុងភ្លើង ត្រូវបិទច្រមុះ បែរមុខចេញ ដោយទីលំនៅក៏មិនស្អាត ពិតហើយ សក់ទាំងនោះសន្សំហើយ ក៏ចម្រើនបរិបូណ៌ ដោយការហូរមកកកផ្តុំគ្នានៃប្រមាត់ ស្លេស្ម ខ្ទុះ និងឈាម ដូចដើមម្រះព្រៅជាដើមក្នុងគំនរសំរាម ដោយការហូរមក ប្រមូលផ្តុំនៃវត្តស្មោកគ្រោក របស់មនុស្សច្រើនប្រភេទ ។ សូម្បីដោយឱកាសក៏មិនស្អាត ។ ពិតហើយ សក់ទាំងនោះកើតក្នុងស្បែកទន់ ដែលគ្របក្បាលរបស់មនុស្សទាំងឡាយ ខាងលើកំពូលនៃគំនរសាកសព ៣១ មានរោមជាដើម គួរខ្ពើមរអើមក្រៃលែង ដូចដើមម្រះព្រៅជាដើមក្នុងគំនរសំរាម ។ ក្នុងសាកសព ៣១ មានរោមជាដើម ក៏នយដូច្នេះ ។ ព្រះយោគាវចរមនសិការធម៌ទាំងនេះ ដែលជ្រាកដដោយអសុភ ដោយភាពជារបស់មិនស្អាតយ៉ាងនេះជាបឋម ។

បើធម៌ទាំងនេះ ជ្រាកដដល់ព្រះយោគាវចរនោះ ដោយពណ៌ជាដើមនោះ សក់ទាំងឡាយក៏ជ្រាកដជានីលកសិណ ។ រោម ក្មេញ ក៏យ៉ាងនោះ រមែង

ប្រាកដដោយជាឱទាតកសិណ ។ ក្នុងទុត្តីសាការគ្រប់យ៉ាង ក៏មានន័យដូច្នេះ ។ ព្រះយោគាវចរនោះ រមែងមនសិការធម៌ទាំងនេះ ដោយជាកសិណនោះៗ ឯង ។ ធម៌ដែលប្រាកដដោយវណ្ណៈយ៉ាងនេះ ព្រះយោគាវចរក៏មនសិការដោយវណ្ណៈ បើធម៌ទាំងនោះប្រាកដដល់ព្រះយោគាវចរនោះ ដោយភាពជារបស់ទេ កាលបើដូច្នោះ សក់ទាំងឡាយរមែងប្រាកដ ជាអាការប្រជុំដោយវិនិព្ភោគរូប ដែលមានឱជៈជាគម្រប់ ៨ ដោយការកំណត់ បំបែកចេញពីក្រុម ។ រោមជាដើមក៏ប្រាកដដល់ព្រះយោគាវចរ ដូចកាលសក់ប្រាកដ ។ ព្រះយោគាវចរនោះ រមែងមនសិការធម៌ទាំងនេះយ៉ាងនោះដូចគ្នា ធម៌ដែលប្រាកដដោយភាពជារបស់ទេយ៉ាងនេះ ក៏មនសិការដោយភាពជារបស់ទេ ។

ព្រះយោគាវចរនេះ មនសិការយ៉ាងនេះ ឈ្មោះថា មនសិការធម៌ទាំងនោះដោយលំដាប់ ។ ពាក្យថា ដោយរំលងលំដាប់ អធិប្បាយថា ព្រះយោគាវចររំលងសក់ដែលប្រាកដជាអសុភជាដើមណាមួយ ហើយមនសិការរោម ជាអ្នកសម្ងឹងកណ្តាលក្នុងសក់ទាំងឡាយ ហើយមនសិការរោមទាំង-ឡាយ កាលមនសិការក្នុងរោមទាំងឡាយ ក៏ឈ្មោះថា រំលងសក់ ប្រៀបដូចឈ្លឹងសម្ងឹងជាកណ្តាលត្រង់បទេស ដែលខ្ជួនចាប់ដោយកន្ទុយ រំលងបទេសជនៃតាមមាត់ កាលទាមបទេសនោះ ក៏ឈ្មោះថា រំលងបទេសក្រៅអំពីនេះ ដូច្នោះ ។ ក្នុងទុត្តីសាការគ្រប់យ៉ាង ក៏មានន័យដូច្នេះ ។ ធម៌ទាំងនោះ កាលប្រាកដដល់ព្រះយោគាវចរនោះ ដែលមនសិការដោយរំលងលំដាប់យ៉ាងនេះ រមែងប្រាកដមិនសេសសល់ឡើយ ថែមទាំងប្រាកដច្បាស់

ជាងទៀតផង ។

កាលបើដូច្នោះ ធម៌ពួកណាប្រាកដដោយភាពជារបស់មិនស្អាត ដល់ព្រះយោគាវចរណា ទាំងប្រាកដថា ប្រាកដច្បាស់ជាង ប្រៀបដូចស្វាដែលត្រូវព្រានដេញ លោតទៅក្នុងដើមត្នោត ៣២ ដើម មិនឈប់សូម្បីត្រឹមតែ ១ ដើម លោតទៅ កាលណាត្រឡប់ ក៏ហត់នឿយ កាលនោះ ទើបឈប់អាស្រ័យត្នោតដែលស្អាត ដែលបិទបាំងដោយស្លឹកត្នោតក្រាស់ដើមណាមួយ ប៉ុណ្ណោះ យ៉ាងណា ស្វា គឺចិត្តរបស់ព្រះយោគាវចរនោះ ក៏ដូច្នោះដូចគ្នា ដែលព្រះយោគាវចរនោះដេញទៅក្នុងកាយនេះ ដែលមានកោដ្ឋាស ៣២ គឺចំណែក មិនឈប់ សូម្បីតែចំណែកមួយ លោតទៅ កាលណាត្រឡប់ ព្រោះមិនមានសេចក្តីប្រាថ្នាក្នុងការសំដុះទៅកាន់អារម្មណ៍ដ៏ច្រើនក៏ហត់នឿយ កាលនោះ ធម៌ណារបស់ព្រះយោគាវចរនោះស្ងាត់ជំនាញ ឬព្រោះសមដល់ចរិតជាងគេ ក្នុងចំណែក ៣២ មានសក់ជាដើម ឬជាអ្នកបានបំពេញបារមីមុនក្នុងធម៌ណា ក៏អាស្រ័យធម៌នោះ ឈប់ដោយឧបចារសមាធិ កាលបើដូច្នោះ ព្រះយោគាវចរធ្វើនិមិត្តទាំងនោះឯងឲ្យដល់វិតក្ក រហូតដល់វិតក្កទល់ទ្រៀយៗ ក៏ធ្វើបឋមជ្ឈានឲ្យកើតឡើងតាមលំដាប់ តាំងនៅក្នុងបឋមជ្ឈានោះហើយ ផ្តើមវិបស្សនារមែងសម្រេចអរិយភូមិបាន ។

ម្យ៉ាងទៀត ធម៌ទាំងនោះ រមែងប្រាកដដោយវណ្ណៈដល់ព្រះយោគាវចរណា ប្រៀបដូចស្វាត្រូវព្រានដេញទៅក្នុងព្រៃត្នោត ៣២ ដើម មិនឈប់ក្នុងដើមណាមួយ កាលណាត្រឡប់ក៏នឿយហត់ កាលនោះ ទើបឈប់អាស្រ័យ

ដើមត្នោតដែលស្អាត ដែលគ្របដណ្តប់ដោយស្លឹកត្នោតក្រាស់ណាមួយប៉ុណ្ណោះ យ៉ាងណា ស្មា គឺចិត្តរបស់ព្រះយោគាវចរនោះ ក៏ដូច្នោះ កាលព្រះយោគាវចរនោះឯង ដេញជាប់តាមទៅ ក្នុងកាយនេះ ដែលមានអាការ ៣២ មិនឈប់ក្នុងចំណែកណាមួយ លោតទៅ កាលណាត្រឡប់ ព្រោះមិនមានសេចក្តីជ្រាបថ្នា សុះទៅក្នុងអារម្មណ៍ដ៏ច្រើន ក៏នឿយហត់ កាលនោះ ធម៌ណារបស់ព្រះយោគាវចរនោះ ស្ទាត់ជំនាញហើយ ឬសមគួរដល់ចរិតថា ក្នុងអាការ ៣២ មានសក់ជាដើម ឬជាអ្នកបំពេញបារមីមកអំពីមុន ក្នុងធម៌ណា ក៏អាស្រ័យធម៌នោះ ឈប់នៅក្នុងឧបចារសមាធិ កាលបើដូច្នោះ ព្រះយោគាវចរធ្វើនិមិត្តនោះឯងឲ្យដល់វិតក្ក ត្រូវវិតក្កទល់ទ្រើយៗ ក៏ធ្វើឲ្យកើតរូបាវចរជ្ឈានទាំង ៥ ដោយនីលកសិណ ឬដោយបីតកសិណតាមលំដាប់ និងតាំងនៅក្នុងរូបាវចរជ្ឈាននោះណាមួយ ផ្តើមចម្រើនវិបស្សនា ក៏សម្រេចអរិយភូមិបាន ។

ម្យ៉ាងទៀត ធម៌ទាំងនោះ ប្រាកដដោយភាពជារបស់ទទេ ដល់ព្រះយោគាវចរណា ព្រះយោគាវចរនោះមែងមនសិការដោយលក្ខណៈ កាលមនសិការដោយលក្ខណៈ រមែងសម្រេចឧបចារជ្ឈាន ដោយកំណត់ធាតុ ៤ ក្នុងធម៌ទាំងនោះ កាលបើដូច្នោះ កាលមនសិការ ក៏មនសិការធម៌ទាំងនោះ ដោយសូត្រទាំង ៣ គឺមិនទៀង ជាទុក្ខ ជាអនត្តា ។ នេះជាវិបស្សនានយរបស់ព្រះយោគាវចរនោះ ។ ព្រះយោគាវចរផ្តើមចម្រើនវិបស្សនានេះ និងបដិបត្តិ ទៅតាមលំដាប់ ក៏រមែងសម្រេចអរិយភូមិ ដូច្នេះ ។

ពាក្យណាខ្ញុំពោលថា ព្រះយោគាវចរនេះ មនសិការធម៌ទាំងនេះដូចម្តេច ពាក្យនោះ ខ្ញុំព្យាករហើយ ដោយកថាមានប្រមាណប៉ុណ្ណេះ ។ ម្យ៉ាងទៀត ពាក្យណាខ្ញុំពោលថា គប្បីជ្រាបការពណ៌នាបាឋៈនោះយ៉ាងនេះ ដោយការនាសេចក្តីនៃពាក្យនោះ ឈ្មោះថា ខ្ញុំប្រកាសហើយ ដូច្នេះ ។

បកិណ្ណកនយ

ឥឡូវនេះ គប្បីជ្រាបបកិណ្ណកនយនេះ ដើម្បីការពិនិត្យ និងការឈ្វាសក្នុងទុត្តិសាការនេះថា

និមិត្តោ លក្ខណាតោ ធាតុតោ សុញ្ញតោបិ ច
ខន្ធាធិតោ ច វិញ្ញេយ្យា ទុត្តិសាការនិច្ឆយោ ។

គប្បីជ្រាបវិនិច្ឆ័យទុត្តិសាការដោយនិមិត្ត លក្ខណៈ ធាតុ ការពិនិត្យ និងដោយខន្ធជាដើម ។

បណ្តាបកិណ្ណកៈនោះ ពាក្យថា ដោយនិមិត្ត សេចក្តីថា ទុត្តិសាការនេះមានប្រការដូចពោលមកហើយនេះ មាននិមិត្ត ១៦០ ដែលព្រះយោគាវចរអាចកំណត់ទុត្តិសាការបានដោយកោដ្ឋាសដែលជាចំណែកៗ គឺសក់មាននិមិត្ត ៥ គឺពណ៌ សណ្ឋាន ទ្រង់ទ្រាយ ទិស ឱកាស (ទីកើត) និងបរិច្ឆេទក្នុងរោមជាដើម ក៏មានន័យដូច្នេះ ។

ពាក្យថា ដោយលក្ខណៈ សេចក្តីថា ក្នុងទុត្តិសាការមានលក្ខណៈ ១២៨ ដែលព្រះយោគាវចរអាចធ្វើមនសិការទុត្តិសាការបានដោយលក្ខណៈ គឺសក់មានលក្ខណៈ ៤ គឺលក្ខណៈរឹង ជ្រួតជ្រាប ក្តៅ និងបក់ផាត់ ក្នុងរោមជាដើម

ក៏មានន័យដូច្នេះ ។

ពាក្យថា ដោយធាតុ សេចក្តីថា ក្នុងទ្វត្តឹសាការធាតុទាំងឡាយ ដែលព្រះមានព្រះភាគត្រាស់ក្នុងបាលីនេះថា **ចតុធាតុរោ ភិក្ខវេ អយំ បុរិស-បុគ្គលោ** *ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះ មានធាតុ ៤ ដូច្នេះ ។ ធាតុមាន ១២៨ ដែលព្រះយោគាវចរអាចកំណត់ទ្វត្តឹសាការបានដោយធាតុ ២ ក្នុងសក់មានធាតុ ៤ គឺចំណែកដែលរឹង ជាបឋវីធាតុ ចំណែកដែលជ្រួតជ្រាបជាអាបោធាតុ ចំណែកដែលក្តៅ ជាតេជោធាតុ ចំណែកដែលកម្រើក ជាវាយោធាតុ ក្នុងរោមជាដើមក៏យ៉ាងនេះ ។*

ពាក្យថា ដោយភាពទេ សេចក្តីថា ក្នុងទ្វត្តឹសាការ មានសុញ្ញតា ១២៨ ដែលព្រះយោគាវចរអាចពិចារណាឃើញទ្វត្តឹសការដោយភាពទេ គឺក្នុងសក់មានសុញ្ញតា ៤ គឺបឋវីធាតុ ទទេចាកអាបោធាតុជាដើម អាបោធាតុជាដើមក៏យ៉ាងនោះ ទទេចាកបឋវីធាតុជាដើម ក្នុងរោមជាដើមក៏យ៉ាងនេះ ។

ពាក្យថា ដោយខន្ធជាដើម សេចក្តីថា ក្នុងទ្វត្តឹសាការ មានសក់ជាដើម លោកសង្គ្រោះដោយខន្ធជាដើម គប្បីជ្រាបវិនិច្ឆ័យដោយន័យជាដើមយ៉ាងនេះថា សក់ទាំងឡាយមានខន្ធប៉ុន្មាន មានអាយតនៈប៉ុន្មាន មានធាតុប៉ុន្មាន មានសច្ចៈប៉ុន្មាន មានសតិប្បដ្ឋានប៉ុន្មាន ។ កាយរមែងជ្រុកជដូចគំនរសំរាម និងឈើចាស់ ព្រះយោគាវចរនោះពិចារណាយ៉ាងនេះ តាមដែលលោកពោលថា

ឧត្តិ សត្តោ ឧរោ ចោសោ បុគ្គលោ ឆ្ងបលព្ភតិ
សុញ្ញភូតោ អយំ កាយោ តិណាកដ្ឋសមូបមោ។

មិនមានសត្វ នរៈ បុរស មិនមែនបុគ្គល កាយនេះ
មានសភាពទេ ប្រៀបដូចស្មៅ និងឈើ ។

ម្យ៉ាងទៀត ការត្រេកអរណា ដែលមិនមែនរបស់មនុស្ស ដែលលោក
ពោលយ៉ាងនេះថា

សុញ្ញាគារំ បវិត្តស្ស សន្តចិត្តស្ស តាទិនោ
អាមានុសី រតី ហោតិ សម្មា ធម្មំ វិបស្សតោ ។

សេចក្តីត្រេកអរ ដែលមិនមែនជារបស់មនុស្ស រមែងមាន
ដល់ភិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នក
ឃើញធម៌ដោយប្រពៃ ។

សេចក្តីត្រេកអរនោះនៅមិនឆ្ងាយឡើយ ។ បន្ទាប់អំពីនោះ អមតៈ គឺ
បីតិ និងបាមោជ្ជណា ដែលសម្រេចមកអំពីវិបស្សនា ដែលព្រះមានព្រះភាគ
ត្រាស់យ៉ាងនេះថា

យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្ពយំ
លភតិ បីតិបាមោជ្ជំ អមតំ តំ វិជានតំ ។

ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធ
ទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះ
រមែងបានបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ
ឈ្មោះថា ជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌
ទាំងឡាយ ។

ព្រះយោគាវចរ កាលសោយបីតិ និងបាមោជ្ជ ដែលជាអមតៈនោះ មិនយូរទ្បើយ នឹងធ្វើឲ្យជាក់ច្បាស់នូវអមតៈ គឺព្រះនិព្វាន ដែលមិនចាស់ មិនស្លាប់ ដែលអរិយជនសេពហើយ ដូច្នេះ ។

ទុត្តីសាការ ចប់

សុត្តន្តបិដក

ខុទ្ទកចារ: សាមណេរបញ្ហា

[៤] ធម្មជាតឈ្មោះតែ ១ គឺអ្វី គឺសត្វទាំងអស់ តាំងនៅដោយអាហារ ។ ធម្មជាតឈ្មោះតែ ២ គឺអ្វី គឺនាម និងរូប ។ ធម្មជាតឈ្មោះតែ ៣ គឺអ្វី គឺវេទនា ៣ ។ ធម្មជាតឈ្មោះតែ ៤ គឺអ្វី គឺអរិយសច្ច ៤ ។ ធម្មជាតឈ្មោះតែ ៥ គឺអ្វី គឺឧបាទានក្ខន្ធ ៥ ។ ធម្មជាតឈ្មោះតែ ៦ គឺអ្វី គឺអាយតនៈខាងក្នុង ៦ ។ ធម្មជាតឈ្មោះតែ ៧ គឺអ្វី គឺពោជ្ឈង្គ ៧ ។ ធម្មជាតឈ្មោះតែ ៨ គឺអ្វី គឺអរិយមគ្គប្រកបដោយអង្គ ៨ ។ ធម្មជាតឈ្មោះតែ ៩ គឺអ្វី គឺសត្តាវាស ៩ ។ ធម្មជាតឈ្មោះតែ ១០ គឺអ្វី គឺបុគ្គលដែលហៅថា ព្រះអរហន្តប្រកបដោយអង្គ ១០ ។

សាមណេរប្បញ្ហា ចប់

អដ្ឋកថា

កុមារប្បញ្ហា

[៤] ឥឡូវនេះ ដល់លំដាប់ពណ៌នាសេចក្តីរបស់កុមារប្បញ្ហាជាដើម យ៉ាងនេះថា អ្វីឈ្មោះថា ១ ខ្ញុំនឹងពោលអត្ថុប្បត្តិហេតុនៃកុមារប្បញ្ហាទាំងនោះ និងប្រយោជន៍នៃការដាក់បទតាំងទុកក្នុងទីនេះ ហើយពណ៌នាសេចក្តី និងអត្ថុប្បត្តិហេតុនៃកុមារប្បញ្ហាទាំងនោះ ។ ឈ្មោះថា **សោចាកៈ** ជាព្រះមហាសាវ័ករបស់ព្រះមានព្រះភាគ ។ ព្រះសោចាកៈនោះ សម្រេចជាព្រះអរហន្ត តាំងពីអាយុបាន ៧ ឆ្នាំអំពីកំណើត ។ ព្រះមានព្រះភាគ មានព្រះពុទ្ធបំណងនឹងទ្រង់អនុញ្ញាតឧបសម្បទា ដោយការព្យាករណ៍បញ្ហាដល់លោក ទ្រង់ឃើញថា លោកអាចព្យាករបញ្ហាទាំងឡាយ ដែលទ្រង់បំណងហើយ ទើបត្រាស់សួរបញ្ហាដោយនយជាដើមយ៉ាងនេះថា អ្វីឈ្មោះថា ១ ។ លោកក៏ព្យាករ និងធ្វើចិត្តរបស់ព្រះមានព្រះភាគ ឲ្យទ្រង់ត្រេកអរដោយការព្យាករណ៍នោះ ។ នុ៎ះឯងបានជាឧបសម្បទារបស់ព្រះសោចាកៈនោះ ។

នេះជាហេតុកើតរឿងរបស់សាមណេរប្បញ្ហាទាំងនោះ ។

ប្រយោជន៍នៃការតាំងបទ

ព្រោះហេតុដែលប្រកាសចិត្តការវនា ដោយវត្ថុជាដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដោយសរណគមន៍ ប្រកាសសីលការវនា ដោយសិក្ខាបទ និងប្រកាសកាយការវនា ដោយទុត្តិ៍សាការ ដូច្នោះ ឥឡូវនេះ ទើបការព្យាករបញ្ហាទាំងនេះ ជាប្រធានបទក្នុងទីនេះ ដើម្បីសម្តែងមុខ គឺបញ្ញាការវនាដោយ

ប្រការផ្សេងៗ ឬព្រោះហេតុដែលសមាធិ មានសីលជាបទដ្ឋាន និងបញ្ញា មានសមាធិជាបទដ្ឋាន ដូចព្រះមានព្រះភាគត្រាស់ថា **សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ** *នរជនមានបញ្ញាជាគ្រឿងរក្សាខ្លួន តាំងនៅក្នុងសីល ចម្រើនទូវចិត្ត និងបញ្ញា ... ដូច្នេះ ទើបគួរជ្រាបថា កាលខ្ញុំសម្តែងសីលដោយសិក្ខាបទទាំងឡាយ និងសមាធិដែលមានសីលនោះជាគោចរ ដោយទុត្តីសាការហើយ ទើបដាក់បញ្ហាព្យាករជាប្រធានក្នុងទីនេះ ដើម្បីសម្តែងប្រភេទនៃបញ្ញា ដែលជាគ្រឿងពិនិត្យពិចារណាធម៌ផ្សេងៗ សម្រាប់បុគ្គល ដែលមានចិត្តតាំងមាំហើយ ។*

នេះជាប្រយោជន៍នៃការដាក់បញ្ហាទាំងនោះជាប្រធានបទក្នុងទីនេះ ។

អ្វីឈ្មោះថា ១

ឥឡូវនេះ និងពណ៌នាអត្ថនៃបញ្ហាទាំងនោះ ភិក្ខុកាលនឿយណាយដោយប្រពៃក្នុងធម៌ឯណាមួយ រមែងធ្វើទីបំផុតទុក្ខបានដោយលំដាប់ ។ ម្យ៉ាងទៀត ព្រះសោបាកៈនេះ នឿយណាយក្នុងធម៌ណាមួយ ដែលធ្វើទីបំផុតទុក្ខហើយ ព្រះមានព្រះភាគ ទ្រង់សំដៅដល់ធម៌នោះ ទើបត្រាស់សួរបញ្ហាថា អ្វីឈ្មោះថា ១ ព្រះថេរៈទូលស្នងជាបុគ្គលាធិដ្ឋានថា សត្វទាំងពួងតាំងនៅបានដោយអាហារ ។ ក្នុងសេចក្តីនេះ ព្រះសូត្រទាំងឡាយយ៉ាងនេះថា **កតមា ច ភិក្ខវេ សម្មាសតិ ៤ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ** *ម្នាលភិក្ខុទាំងឡាយ សម្មាសតិ តើដូចម្តេច ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណាឃើញកាយក្នុងកាយ ដូច្នេះ ជាគ្រឿងសាធកក្នុងការកើតយុត្តិ ដោយការឆ្លើយ*

យ៉ាងនេះ ។ ក្នុងពាក្យនេះ សត្វទាំងពួង លោកពោលថា តាំងនៅបានដោយអាហារណា អាហារនោះ ឬភាពដែលសត្វទាំងនោះតាំងនៅបានដោយអាហារ គប្បីជ្រាបថា ព្រះថេរៈត្រូវគ្រាស់សួរថា អ្វីឈ្មោះថា ១ ទូលចង្អុលបង្ហាញហើយ ។ ពិតហើយ ក្នុងសេចក្តីនោះ ព្រះមានព្រះភាគទ្រង់បំណងថា ឈ្មោះថា ១ ក្នុងទីនេះ តែមិនបានគ្រាស់ដើម្បីឲ្យដឹងថា ឈ្មោះថា ១ ដទៃក្នុងព្រះសាសនា ឬក្នុងលោកមិនមាន ។ សេចក្តីពិត ព្រះមានព្រះភាគគ្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ គ្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌មួយ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ គ្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌មួយនេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ ដូច្នេះ ពាក្យនុ៎ះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនោះ ។

ក្នុងពាក្យថា **អាហារដ្ឋិតិកា** *នេះ ព្រះថេរៈកាន់យកបច្ច័យ ដោយ* **អាហារ** *សព្ទ ហៅសត្វទាំងពួងដែលតាំងនៅបានដោយបច្ច័យថា តាំងនៅ*

បានដោយអាហារ ដូចបច្ច័យ លោកហៅថា អាហារ ក្នុងប្រយោគជាដើម យ៉ាងនេះ សុភនិមិត្តរមែងមាន ការធ្វើទុកក្នុងចិត្តខុសទំនងនឹងការធ្វើឲ្យ ក្រាស់ក្រែលក្នុងសុភនិមិត្តនោះ នេះជាអាហារដែលញុំាងកាមច្ឆន្ទៈមិនទាន់ កើតឡើង ឲ្យកើតឡើង ... ដូច្នេះ តែកាលលោកពោលសំដៅយកអាហារ ៤ ក៏ពោលថា តាំងនៅបានដោយអាហារដូច្នេះ ។

*ពាក្យថា **សព្វេ** ក៏គួរមិនពាល់ត្រូវ ដូចក្នុងប្រយោគជាដើមថា ពួកទេវតាជាអសញ្ញសត្វ មិនមានហេតុ មិនមានអាហារ មិនមានផស្សៈ មិនមានវេទនា ... ។*

ក្នុងសេចក្តីនោះ មានពាក្យគប្បីចង្អុលបង្ហាញដូច្នេះថា កាលត្រូវពោលយ៉ាងនេះ ការដែលខន្ធទាំងឡាយ តាំងនៅបានដោយបច្ច័យ ក៏ត្រឹមត្រូវពិត ព្រោះបាលីថា ពួកធម៌ប្រកបដោយបច្ច័យ តើដូចម្តេច ។ ខន្ធ ៥ គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ... ដូច្នេះ តែភាពដែលសត្វទាំងឡាយ តាំងនៅបានដោយបច្ច័យ ពាក្យនេះ ប្រហែលជាមិនត្រឹមត្រូវពិតនោះឯង សេចក្តីនេះ មិនគួរឃើញយ៉ាងនេះ ។ ព្រោះហេតុអ្វី ។ ព្រោះពោលបង្រួបបង្រួមសម្រេចដល់ខន្ធក្នុងសត្វទាំងឡាយ ។ ពិតហើយ លោកពោលបង្រួបបង្រួមសម្រេចក្នុងសត្វទាំងឡាយហើយ ព្រោះអ្វី ។ ព្រោះលោកអាស្រ័យខន្ធប្បញ្ញត្តិ ។ សេចក្តីនេះដូចម្តេច ដូចឧបចារនៃស្រុកក្នុងផ្ទះ ឧបមាដូចកាលផ្ទះ ១-២ ខ្នង ឬ ៣ ខ្នងនៃស្រុក ត្រូវភ្លើងឆេះ ក៏ពោលសរុបសម្រេចដល់ស្រុកក្នុងផ្ទះយ៉ាងនេះថា ស្រុកត្រូវភ្លើងឆេះ ព្រោះអាស្រ័យផ្ទះ

ច្រើនខ្នងបញ្ចូត្ត យ៉ាងណា គប្បីជ្រាបថា ពោលរួមសេចក្តីសម្រេចដល់ថា សត្វទាំងឡាយ តាំងនៅបានដោយអាហារ ក្នុងសត្វទាំងឡាយ ដែលតាំងនៅបានដោយអាហារ ព្រោះអត្ថថា ជាបច្ចយក្នុងខន្ធទាំងឡាយដូច្នោះដូចគ្នា ។ តែបើពោលដោយបរមត្ថ គប្បីជ្រាបថា កាលខន្ធទាំងឡាយ កើត ចាស់ និង ស្លាប់ ព្រះមានព្រះភាគកាលត្រាស់ថា ម្នាលភិក្ខុ អ្នកកើត ចាស់ និងស្លាប់ គ្រប់ខណៈ ដូច្នេះ ។ ឈ្មោះថា ទ្រង់សម្តែងថា ត្រាស់សរុបសេចក្តីសម្រេច ដល់ខន្ធក្នុងសត្វទាំងនោះ កាលណា សត្វទាំងពួង តាំងនៅបានដោយអាហារ ដែលហៅថា បច្ចយឯណា អាហារនោះ ឬកាពដែលសត្វតាំងនៅបានដោយ អាហារ គប្បីជ្រាបថា មាន ១ ព្រោះថា អាហារ ឬការដែលសត្វតាំងនៅ បានដោយអាហារ រមែងជាហានៈ ទីតាំងនៃនិព្វិទា ព្រោះជាហេតុនៃអនិច្ចតា ។ កាលនោះ ភិក្ខុនឿយណាយ ព្រោះឃើញអនិច្ចតាក្នុងសង្ខារទាំងឡាយដែល គេសម្គាល់ថា សត្វទាំងពួងនោះ រមែងជាអ្នកធ្វើទីបំផុតទុក្ខជាលំដាប់ រមែង សម្រេចបរមត្ថវិសុទ្ធិ ដូចដែលត្រាស់ថា

សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំង ពួង មិនទៀង ដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ដូច្នេះ ។

ក្នុងបញ្ហាដំបូងនេះ មានបាឋៈ ២ យ៉ាងថា **ឯកំ ឆាម កឹ** *និង* **កិហា ។**

ក្នុងបាឋៈទាំង ២ នោះ បាឋៈអ្នកសីហឡថា **កិមហ** ជ្បិតថា អ្នកសីហឡទាំងនោះជំនួសដោយការពោលថា **កឹ** ក៏ពោលថា **កិមហ** ។ អាចារ្យអ្នកសីហឡពួកខ្លះពោលថា ពាក្យថា **មហ** ជានិបាត បាឋៈរបស់ពួកអ្នកកាន់លទ្ធិខាងថេរវាទក៏យ៉ាងនេះដូចគ្នា ។ តែបាឋៈទាំង ២ មានសេចក្តីតែមួយ ។ គាប់ចិត្តយ៉ាងណា ក៏គប្បីសូត្រ គប្បីពោលយ៉ាងនោះ ។ ឧបមាដូចទីខ្លះពោលថា **ឧទ្ធំ** និងទីខ្លះក៏ពោលថា **ឧក្កំ** ក្នុងបាលីទាំងឡាយយ៉ាងនេះថា **សុខេន ឆុដ្ឋោ អជ ភ ា ឧខេន ឧក្កំ នោមនស្សំ បដិសំវេទេតិ** យ៉ាងណា ទីខ្លះក៏ថា **ឃកំ** ទីខ្លះក៏ថា **ឃកកំ** ក៏ដូច្នោះ តែក្នុងទីនេះ មានបាឋៈនេះតែម្យ៉ាងថា **ឃកំ ឆាម** ។

អ្វីឈ្មោះថា ២

ព្រះសាស្តា ទ្រង់មានព្រះហឫទ័យដែលព្រះថេរៈធ្វើឲ្យត្រេកអរ ដោយការព្យាករណ៍នេះយ៉ាងនេះហើយ ទើបត្រាស់សួរបញ្ហាក្រៃលែងទៀត ដូចន័យជំបូងថា អ្វីឈ្មោះថា ២ ព្រះថេរៈពោលដំណែលថា **នេ** ទូលតបដោយទេសនាជាបុគ្គលាធិដ្ឋានថា គឺនាម និងរូប ។ បណ្តានាម និងរូបនោះ រឿងដែលមិនមែនរូបទាំងអស់ លោកហៅថា នាម ព្រោះបង្អោនមុខកាន់អារម្មណ៍តែម្យ៉ាង ព្រោះជាហេតុបង្អោនចិត្តទៅតែម្យ៉ាង ។ តែក្នុងទីនេះ លោកបំណងយកធម៌ដែលមានអាសវៈប៉ុណ្ណោះ ព្រោះជាហេតុនៃនិព្វិទា គឺការនឿយណាយ ឯមហាភូតរូប ៤ និងរូបទាំងអស់ដែលអាស្រ័យមហាភូតរូបនោះ ប្រព្រឹត្តទៅលោកហៅថា រូប ព្រោះអត្ថថា បែកធ្លាយ រូបនោះ ក្នុងទីនេះ លោកបំណង

យកទាំងអស់ តែព្រះថេរៈពោលក្នុងទីនេះថា ឈ្មោះថា ២ គឺនាម និងរូប ក៏ដោយបំណងនេះឯង មិនមែនពោលព្រោះមិនមានធម៌ ២ យ៉ាងដទៃ ដូច ដែលត្រាស់ថា

> *ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនៀយណាយដោយ ប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ន បាន ។ ធម៌ ២ គឺអ្វី ។ គឺនាម ១ រូប ១ ។ ម្នាលភិក្ខុ ទាំងឡាយ កាលបើភិក្ខុនៀយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ញា ២ ឧទ្ទេស ២ វេយ្យា- ករណ៍ ២ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។*

ក្នុងបញ្ញានេះ គប្បីជ្រាបថា ភិក្ខុលះអត្តទិដ្ឋិ គឺការឃើញថាខ្លួនបាន ដោយ ការឃើញត្រឹមតែនាមរូប ហើយកាលនៀយណាយដោយមុខ គឺការពិចារណា ឃើញអនត្តា រមែងជាអ្នកធ្វើទីបំផុតទុក្ខបាន រមែងសម្រេចបរមត្ថវិសុទ្ធបាន ដូចព្រះតម្រាស់ថា

> **សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ**
> **អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**
>
> *កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា ធម៌ទាំង ពួង មិនមែនជារបស់ខ្លួនដូច្នេះ កាលណោះ រមែងនៀយ*

ណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ដូច្នេះ ។

អ្វីឈ្មោះថា ៣

ឥឡូវនេះ ព្រះសាស្តា មានចិត្តដែលព្រះថេរៈធ្វើឲ្យត្រេកអរ ដោយការ ព្យាករណ៍បញ្ហានេះហើយ ទើបត្រាស់សួរបញ្ហាក្រៃលែងឡើង ដូចន័យមុនថា អ្វីឈ្មោះថា ៣ ។ ព្រះថេរៈពោលជំដែលថា **តីណិ** *ដើម្បីសម្តែងសង្ខ្យាដែល សមគួរដល់លិង្គ គឺរបស់សព្វនៃការដែលគប្បីព្យាករទៀត ទើបទូលស្នងថា* **តិស្សោ វេទនា** *។ ម្យ៉ាងទៀត ព្រះថេរៈគិតថា អញនឹងត្រឡប់ ពាក្យថា* **តីណិ** *របស់វេទនាដែលព្រះមានព្រះភាគត្រាស់ថា* **តិស្សោ វេទនា** *កាល សម្តែង ទើបទូលស្នងដូច្នេះ ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងសេចក្តីនេះដូចពោល មក ដូច្នេះ ជ្បិតថា ទេសនារបស់ពួកលោកដែលសម្រេចនូវទេសនាវិលាស ព្រោះការបែកធ្លាយនៃបដិសម្ភិទា មានកថាមុខជាច្រើន តែអាចារ្យពួកខ្លះ ពោលថា បទថា* **តីណិ** *នេះជាបទលើស ។ តែព្រះថេរៈពោលក្នុងទីនេះថា* **តិស្សោ វេទនា** *គឺវេទនា ៣ តាមន័យមុននោះឯង មិនមែនពោលព្រោះមិន មានធម៌ ៣ ដទៃ ដូចព្រះតម្រាស់ថា*

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនៀយណាយដោយ ប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ន បាន ។ ធម៌ ៣ គឺអ្វីខ្លះ ។ គឺវេទនាទាំង ៣ ។ ម្នាលភិក្ខុ ទាំងឡាយ កាលបើភិក្ខុនៀយណាយដោយប្រពៃ ។បេ។

រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ចា ៣ ខនេ្ធស ៣ វេយ្យាករណ៍ ៣ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។

ក្នុងបញ្ហានេះ គប្បីជ្រាបថា ភិក្ខុលះសុខសញ្ញា ដោយការឃើញវេទនាទាំង ៣ ជាទុក្ខ ហើយនឿយណាយដោយមុខ គឺការពិចារណាឃើញទុក្ខតាមគន្ថង្គព្រះសូត្រ ដែលត្រាស់ថា វេទនាឯណាមួយ វេទនាទាំងនោះ តថាគតពោលថាជាទុក្ខ ឬតាមគន្ថង្គភាពជាទុក្ខ ព្រោះទុក្ខជាទុក្ខ ព្រោះប្រែប្រួល និងជាទុក្ខព្រោះបច្ច័យតាក់តែងយ៉ាងនេះថា

យោ សុខំ ទុក្ខតោ ទក្ខិ ទុក្ខមទុក្ខិ សល្លតោ
អទុក្ខមសុខំ សន្តំ អទុក្ខិ នំ អនិច្ចតោ ។

ភិក្ខុណា បានឃើញសុខវេទនាថាជាទុក្ខ បានឃើញទុក្ខវេទនាថាជាព្រួញ បានឃើញអទុក្ខមសុខវេទនាជាទីស្ងប់នោះ ថាជារបស់មិនទៀង ... ដូច្នេះ ។

រមែងជាបុគ្គលធ្វើទីបំផុតទុក្ខបាន រមែងសម្រេចបរមត្ថវិសុទ្ធិបាន ដូចព្រះតម្រាស់ថា

សព្ពេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ
អថ និព្ពិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលឃើញដោយប្រាជ្ញាថា សង្ខារទាំង

ពួង នាំមកនូវសេចក្តីទុក្ខដូច្នេះ កាលណោះ រមែងនឿយ
ណាយក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ដូច្នេះ ។

អ្វីឈ្មោះថា ៤

ព្រះសាស្តា ជាបុគ្គលមានព្រះហឫទ័យដែលព្រះថេរៈធ្វើឲ្យត្រេកអរ ដោយការព្យាករណ៍នេះ ដូច្នេះហើយ ទើបត្រាស់សួរបញ្ហាក្រៃលែងទៀត ដូចនយមុនៗ ថា អ្វីឈ្មោះថា ៤ ក្នុងបញ្ហានេះ ក្នុងចំណែកព្យាករបញ្ហានេះ កន្លែងខ្លះ លោកបំណងយកអាហារ ៤ តាមនយមុនៗ ដូចព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៤ គឺអ្វី ។ គឺអាហារទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។

កន្លែងខ្លះ ភិក្ខុមានចិត្តអប់រំហើយ ក្នុងគុណធម៌ទាំងឡាយណា រមែងជាអ្នកធ្វើទីបំផុតទុក្ខបាន ដោយលំដាប់ គុណធម៌ទាំងនោះ គឺសតិប្បដ្ឋាន ៤ ដូចជង្គលាភិក្ខុនីពោលថា

ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រ-

យោជន៍ដោយប្រពៃ ក្នុងធម៌ ៤ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៤ គឺអ្វី ។ គឺសតិប្បដ្ឋាន ៤ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។

តែក្នុងទីនេះ ការកាត់ភវតណ្ហាមាន ព្រោះត្រាស់ដឹងតាម និងចាក់ធ្លុះអរិយសច្ចទាំង ៤ ណា ព្រោះហេតុដែលអរិយសច្ច ៤ នោះ លោកបំណងយកហើយ ឬព្រោះហេតុដែលបញ្ហាកម្ម ដែលលោកព្យាករដោយបរិយាយនេះ ជាការព្យាករណ៍ល្អហើយទាំងអស់ ដូច្នោះ ព្រះថេរៈពោលដដែលថា **ចត្តារិ** ទើបទូលតបថា **អរិយសច្চានិ** ។ ក្នុងពាក្យនោះ សព្ទថា **ចត្តារិ** ជាការកំណត់ដោយចំនួន ។ បទថា **អរិយសច្চានិ** បានដល់ សច្ចៈដែលជាអរិយៈ អធិប្បាយថា មិនខុស មិនឃ្លៀងឃ្លាត ដូចព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះជារបស់ពិត មិនប្រែប្រួល មិនភ្លាយទៅជារបស់ដទៃឡើយ ព្រោះហេតុនោះ បានជាតថាគត ហៅថា អរិយសច្ច ។

ម្យ៉ាងទៀត ព្រោះលោកអធិប្បាយថា ព្រោះជាសច្ចៈដែលមនុស្សលោក

និងទេវលោកគប្បីប្រព្រឹត្តទៅ គប្បីសម្រេច ។ ព្រោះប្រព្រឹត្តទៅក្នុងផ្លូវចម្រើន ដែលគេយល់ថា ឋានៈដែលគួរព្យាយាមខ្លះ ព្រោះមិនប្រព្រឹត្តទៅក្នុងផ្លូវដែលមិនចម្រើនខ្លះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធសាវ័កទាំងឡាយ ដែលតែងដឹងថាជាព្រះអរិយៈ ព្រោះប្រកបដោយអរិយធម៌ គឺពោធិបក្ខិយធម៌ ៣៧ ប្រការ រមែងចាក់ផ្ដុំអរិយសច្ចទាំងនេះ ព្រោះហេតុនោះ ទើបលោកហៅថា អរិយសច្ច ដូចព្រះតម្រាស់ថា

> ម្នាលភិក្ខុទាំងឡាយ អរិយសច្ចមាន ៤ ។បេ។ អរិយសច្ចទាំង ៤ នេះ ព្រះអរិយៈទាំងឡាយ រមែងចាក់ផ្ដុំនូវអរិយសច្ចៈទាំង ៤ នេះ ព្រោះហេតុនោះ ទើបហៅថា អរិយសច្ច ដូច្នេះ ។

ម៉្យាងទៀត ឈ្មោះថា អរិយសច្ច ព្រោះជាសច្ចៈនៃព្រះមានព្រះភាគដែលជាអរិយៈ ដូចព្រះតម្រាស់ថា

> ព្រះតថាគតជាអរិយបុគ្គល ក្នុងលោក ព្រមទាំងទេវលោក ។បេ។ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ព្រោះហេតុនោះ (សច្ចៈ ៤ ដែលតថាគតសម្តែងហើយ) ហៅថា អរិយសច្ច ។

ម៉្យាងទៀត ឈ្មោះថា អរិយសច្ច ព្រោះធ្វើឲ្យសម្រេចនូវភាពជាអរិយៈ ព្រោះអរិយសច្ចទាំងនោះ ទ្រង់ដឹងក្រៃលែងដោយព្រះអង្គឯងហើយ ដូចព្រះតម្រាស់ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដែលមានឈ្មោះថា អរហំសម្មាសម្ពុទ្ធ ព្រោះតថាគត បានត្រាស់ដឹងនូវ អរិយសច្ច ៤ នេះ តាមសេចក្តីពិត ។

អត្ថនៃបទរបស់អរិយសច្ចទាំងនោះ មានដូច្នេះ ការកាត់ផ្តាច់នូវភវតណ្ហា រមែងមាន ព្រោះការត្រាស់ដឹងតាម និងការចាក់ធ្លុះអរិយសច្ចទាំងឡាយនេះ ដូចព្រះតម្រាស់ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ចនេះ តថាគតក្តី អ្នកទាំងឡាយក្តី បានត្រាស់ដឹងហើយ បានចាក់ធ្លុះហើយ ។បេ។ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច តថាគតក្តី អ្នកទាំងឡាយក្តី បានត្រាស់ដឹងហើយ បានចាក់ធ្លុះហើយ ។ ភវតណ្ហាជាធម្មជាតនាំសត្វ ឲ្យចូលទៅកាន់ភព បានផ្តាច់ផ្តិលអស់ហើយ ភពថ្មីទៀត ក្នុងកាលឥឡូវនេះ មិនមានឡើយ ។

អ្វីឈ្មោះថា ៥

ព្រះសាស្តា មានព្រះហឫទ័យដែលព្រះថេរៈធ្វើឲ្យត្រេកអរ ដោយការព្យាករណ៍បញ្ហានេះហើយ ទើបត្រាស់សួរបញ្ហាក្រៃលែងឡើង តាមន័យមុនៗ ថា អ្វីឈ្មោះថា ៥ ព្រះថេរៈពោលពាក្យជដែលថា **បញ្ច** *ទើបទូលតបថា ឧបាទានក្ខន្ធ ។ ក្នុងពាក្យទាំងនោះ ពាក្យថា* **បញ្ច** *ជាការកំណត់ចំនួន ។ ខន្ធទាំងឡាយ ដែលត្រូវឧបាទានឲ្យកើតមក ឬដែលធ្វើឧបាទានឲ្យកើត ឈ្មោះ*

ថា ឧបាទានក្ខន្ធ ៥ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណណាមួយ មាន អាសវៈ ដែលភិក្ខុគប្បីកាន់យក ពាក្យនេះ ជាឈ្មោះនៃឧបាទានក្ខន្ធទាំងនោះ ក្នុងទីនេះ ព្រះថេរៈពោលថា ឧបាទានក្ខន្ធ ៥ តាមន័យមុននោះឯង មិនមែន ព្រោះមិនមានធម៌ ៥ យ៉ាងដទៃ ដូចព្រះតម្រាស់ថា

> *ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនៀយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៥ គឺអ្វីខ្លះ ។ គឺឧបាទានក្ខន្ធទាំង ៥ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនៀយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ចា ៥ ខន្ធេស ៥ វេយ្យាករណ៍ ៥ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះដូច្នេះ ។*

ក្នុងបញ្ហានេះ ភិក្ខុកាលពិចារណាដោយការកើត ការរលត់ជាអារម្មណ៍ បាននូវអមតៈ ដោយវិបស្សនាហើយ រមែងធ្វើឲ្យជាក់ច្បាស់នូវអមតៈ គឺព្រះនិព្វានដោយលំដាប់ ដូចព្រះតម្រាស់ថា

យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ
លភតិ បីតិបាមោជ្ជំ អមតំ តំវិជានតំ ។

ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធ ទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះ

រមែងបានបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។

អ្វីឈ្មោះថា ៦

ព្រះសាស្តា ជាបុគ្គលមានព្រះហឫទ័យ ដែលព្រះថេរៈធ្វើឲ្យត្រេកអរ ដោយការព្យាករណ៍នេះយ៉ាងនេះហើយ ទើបត្រាស់សួរបញ្ហាឲ្យក្រៃលែង តាមន័យមុនថា អ្វីឈ្មោះថា ៦ ។ ព្រះថេរៈពោលពាក្យជំដែលថា ឆ ទើបទូលតបថា អាយតនៈខាងក្នុង ។ ក្នុងពាក្យទាំងនោះ ពាក្យថា ឆ ជាការកំណត់ចំនួន ។ អាយតនៈទាំងឡាយដែលប្រកបខាងក្នុង ឬធ្វើខ្លួនឲ្យជាទីអាស្រ័យប្រព្រឹត្តទៅ ឈ្មោះថា **អជ្ឈត្តិក** *។ ឈ្មោះថា* **អាយតន** *ព្រោះបន្ត ឬព្រោះសាងនូវសេចក្តីចម្រើន ឬព្រោះនាំសង្សារទុក្ខមកអស់កាលយូរ ពាក្យនេះជាឈ្មោះរបស់ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ មនៈ ។ ក្នុងទីនេះ ព្រះថេរៈពោលថា អាយតនៈខាងក្នុង ៦ តាមន័យមុន មិនមែនពោលព្រោះមិនមានធម៌ ៦ ដទៃ ។ ដូចព្រះតម្រាស់ត្រាស់ថា*

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៦ គឺអ្វី ។ គឺអាយតនៈខាងក្នុងទាំង ៦ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគត

ពោលថា បញ្ហា ៦ ឧទ្ទេស ៦ វេយ្យាករណ៍ ៦ ដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។

ក្នុងបញ្ហានេះ ភិក្ខុពិចារណាអាយតនៈខាងក្នុង ៦ ដោយភាពជារបស់ទទេ តាមព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ស្រុកស្ងាត់នុ៎ះ ជាឈ្មោះនៃអាយតនៈខាងក្នុងទាំង ៦ ដូច្នេះ ដោយភាពជារបស់ទទេ និងដោយភាពជារបស់បញ្ឆោត ព្រោះតាំងនៅយូរមិនបាន ដូចពពុះទឹក និងថ្លៃបណ្តើរកូន ដូច្នោះ ក៏នឿយណាយ ធ្វើទីបំផុតទុក្ខដោយលំដាប់ រមែងចូលដល់ទីដែលមច្ចុរាជមើលមិនឃើញ ដូចព្រះតម្រាស់ថា

យថា បុព្ពុឡកំ បស្សេ យថា បស្សេ មរីចិកំ
ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។

បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញព្រេញថ្លៃយ៉ាងណា ស្តេចមច្ចុ មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ ។

អ្វីឈ្មោះថា ៧

ព្រះសាស្តា ជាបុគ្គលមានព្រះហឫទ័យ ដែលព្រះថេរៈធ្វើឲ្យត្រេកអរដោយការព្យាករណ៍បញ្ហានេះហើយ ទើបត្រាស់សួរបញ្ហាឲ្យក្រៃលែងតាមន័យមុនថា អ្វីឈ្មោះថា ៧ ។ វិញ្ញាណដ្ឋិតិ ៧ ព្រះថេរៈពោលការព្យាករណ៍បញ្ហាធំក៏ពិត តែភិក្ខុមានចិត្តអប់រំល្អហើយ ក្នុងធម៌ពួកណា រមែងជាអ្នកធ្វើ

ទីបំផុតទុក្ខបាន ព្រះថេរៈកាលសម្តែងធម៌ទាំងនោះ ទើបទូលស្នងថា ពោជ្ឈង្គ ៧ ។ ម្យ៉ាងទៀត សេចក្តីនេះ ព្រះមានព្រះភាគទ្រង់អនុមតិហើយ ដូចដែលត្រាស់ថា

ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនីជាអ្នកប្រាជ្ញ ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនី ជាមនុស្ស មានប្រាជ្ញាច្រើនមែន ម្នាលគហបតីទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ ចូលមករកតថាគត ហើយសួរនូវសេចក្តីនុ៎ះ តថាគតក៏ដោះស្រាយសេចក្តីនោះយ៉ាងនោះ ដូចជាកជង្គលាភិក្ខុនីដែលដោះស្រាយដែរ ។

ជង្គលាភិក្ខុនីនោះព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៧ គឺអ្វី ។ គឺពោជ្ឈង្គទាំង ៧ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ញា ៧ ឧទ្ទេស ៧ វេយ្យាករណ៍ ៧ ដូច្នេះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។

សេចក្តីនេះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់អនុមតិហើយ ដោយប្រការដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **សត្ត** *ជាការកំណត់ចំនួនជាប់ខាត មិនខ្វះមិនលើស ។ ពាក្យថា* **ពោជ្ឈង្គ** *នេះ ជាឈ្មោះរបស់ធម៌ មានសតិជាដើម ។*

អត្ថនៃបទក្នុងពោជ្ឈង្គ ៧ នេះ មានដូច្នេះ ឈ្មោះថា **ពោធិ** *ព្រោះវិគ្គហៈថា អរិយសាវ័ករមែងត្រាស់ដឹងដោយធម្មសាមគ្គី ពោល គឺសតិ ធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខា ដែលជាបដិបក្ខចំពោះឧបទ្ទវជាច្រើន មានការរួញរា ការរាយមាយ ការបញ្ឈប់ព្យាយាម ការព្យាយាមកាមសុខល្លិកានុយោគ អត្តកិលមថានុយោគ និងការប្រកាន់ដោយខុសច្បទិដ្ឋិ និងសស្សតទិដ្ឋិជាដើមដែលកើតឡើងក្នុងខណៈនៃមគ្គចិត្ត ឯលោកិយ និងលោកុត្តរនោះ លោកអធិប្បាយថា ក្រៅកឡើងអំពីការដេកលក់ គឺសន្តានដែលមានកិលេស ឬចាក់ធ្លុះអរិយសច្ច ៤ ឬធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះឯង ដូចដែលលោកពោលថា ទ្រង់ចម្រើនពោជ្ឈង្គ ៧ ត្រាស់ដឹងក្រៃលែងឯង នូវអនុត្តរសម្មាសម្ពោធិ ។*

ម្យ៉ាងទៀត សូម្បីព្រះអរិយសាវ័ក ក៏ឈ្មោះថា **ពោធិ** *ព្រោះវិគ្គហៈថា ត្រាស់ដឹងដោយធម្មសាមគ្គីនេះ មានប្រការតាមដែលពោលមកហើយ។ ដូច្នោះទើបឈ្មោះថា* **ពោជ្ឈង្គ** *។ ព្រោះជាអង្គ គឺចំណែកនៃពោធិ ពោល គឺធម្មសាមគ្គីនោះ ដូចអង្គនៃឈាន និងអង្គនៃមគ្គ ម្យ៉ាងទៀត ឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃអរិយសាវ័ក ដែលបានកោហាវថា* **ពោធិ** *នោះ ដូចអង្គ គឺចំណែកនៃកងទ័ព និងអង្គ គឺចំណែកនៃរថជាដើម ដូច្នោះ ។*

មួយប្រការទៀត គប្បីជ្រាបថា ពោជ្ឈង្គនៃពោជ្ឈង្គទាំងឡាយ ដោយវិធីដែលលោកពោលក្នុងគម្ពីរបដិសម្ភិទាយ៉ាងនេះថា

សំណួរត្រង់ពាក្យថា ពោជ្ឈង្គ តើពោជ្ឈង្គដោយអត្ថថាដូចម្តេច ។ ឈ្មោះ

ថា ពោជ្ឈង្គ ព្រោះហេតុប្រព្រឹត្តទៅព្រមក្នុងការត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គព្រោះហេតុត្រាស់ដឹងតាម ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងចំពោះ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងព្រម[1] *ព្រះយោគាវចរកាលចម្រើន ធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ នេះ យ៉ាងនេះ មិនយូរឡើយ នឹងជាបុគ្គលបាននូវគុណា មានការនឿយណាយ ដោយចំណែកមួយជាដើម ដោយហេតុនោះ ទើបត្រាស់ថា រមែងជាអ្នកធ្វើទីបំផុតទុក្ខបានក្នុងបច្ចុប្បន្ន សមដូចព្រះមានព្រះភាគត្រាស់ថា*

> *ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ រមែងប្រព្រឹត្តទៅដើម្បីនឿយណាយដោយពិត ដើម្បីប្រាសចាកពាគៈ ដើម្បីរម្ងាប់ ដើម្បីចូលទៅជិតរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។*

អ្វីឈ្មោះថា ៨

ព្រះសាស្តា ជាបុគ្គលមានចិត្តដែលព្រះថេរៈធ្វើឲ្យត្រេកអរ ដោយការព្យាករបញ្ហា ដូច្នេះហើយ ទើបត្រាស់សួរបញ្ហាក្រៃលែងឡើងថា អ្វីឈ្មោះថា ៨ ព្រះថេរៈពោលលោកធម៌ ៨ ដោយការព្យាករណ៍ច្រើនបញ្ហាក៏ពិត តែភិក្ខុមានចិត្តអប់រំល្អហើយ ក្នុងធម៌ពួកណា រមែងជាអ្នកធ្វើទីបំផុតទុក្ខបាន ព្រះថេរៈកាលសម្តែងធម៌ទាំងនោះ មិនបានពោលថា អង្គនៃអរិយមគ្គ ៨ ព្រោះ

១- សេចក្តីពិស្តារមានក្នុងបិដកលេខ ៣១ ទំព័រ ៦៤ ។

ធម្មតាមគ្គដែលផុតចាកអង្គ ៨ មិនមាន តែមគ្គមានត្រឹមអង្គ ៨ ប៉ុណ្ណោះ ដូច្នោះ កាលនឹងសម្រេចសេចក្តីនោះ ទើបទូលឆ្លើយដោយវិលាសនៃទេសនា ថា អរិយមគ្គមានអង្គ ៨ អត្ថ និងទេសនានយនេះ ព្រះមានព្រះភាគ ទ្រង់អនុមតិហើយទាំងអស់ ដូចព្រះតម្រាស់ថា

ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនីជាអ្នកប្រាជ្ញ ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនី ជាមនុស្សមានប្រាជ្ញាច្រើនមែន ម្នាលគហបតីទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ ចូលមករកតថាគត ហើយសួរនូវសេចក្តីនុ៎ះ តថាគតក៏ដោះស្រាយសេចក្តីនោះយ៉ាងនោះ ដូចជាកជង្គលាភិក្ខុនី ដែលដោះស្រាយដែរ ។ ព្រះនាងកជង្គលាភិក្ខុនីនោះ ព្យាករទុកយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៨ គឺអ្វី ។ គឺអដ្ឋង្គិកមគ្គដ៏ប្រសើរទាំង ៨ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ ដូច្នេះ ពាក្យនុ៎ះ ព្រះមានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។

អត្ថ និងទេសនានយ័នេះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់អនុមតិ ហើយ ដោយប្រការដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អរិយោ** *ប្រែថា ដែលបុគ្គលត្រូវការព្រះ-និព្វានគប្បីសម្រេច ។ ម្យ៉ាងទៀត មគ្គ គប្បីជ្រាបថា អរិយៈ ព្រោះប្រព្រឹត្ត ទៅឆ្ងាយចាកកិលេសទាំងឡាយ ព្រោះធ្វើឲ្យជាព្រះអរិយៈ និងព្រោះបាន អរិយផល ។ អង្គនៃមគ្គនោះមាន ៨ ព្រោះហេតុនោះ ទើបមគ្គនោះ ឈ្មោះ ថា មានអង្គ ៨ មគ្គនេះ គប្បីជ្រាបថា គ្រាន់តែជាអង្គប៉ុណ្ណោះ ព្រោះមគ្គមាន សភាពដែលបុគ្គលមិនគប្បីបាន ដោយចែកចេញជាអង្គ ដូចកងទ័ពមានអង្គ ៤ និងតន្ត្រីមានអង្គ ៥ ។ បុគ្គលរមែងស្វែងរកព្រះនិព្វានដោយផ្លូវនេះ ឬ ស្វែងរកឯង ឬសម្រាប់កិលេស ហេតុនោះ ទើបផ្លូវនេះ ឈ្មោះថា មគ្គ ។*

ភិក្ខុកាលចម្រើនមគ្គ មានប្រភេទ ៨ និងមានអង្គ ៨ នេះ យ៉ាងនេះ រមែងទម្លាយអវិជ្ជា ធ្វើវិជ្ជាឲ្យកើត ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយហេតុ នោះ ទើបលោកពោលថា ជាអ្នកធ្វើទីបំផុតទុក្ខបានក្នុងបច្ចុប្បន្ន សមដូចព្រះ តម្រាស់ត្រាស់យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ ចុងគ្រាប់ស្រូវឬយក្តី ចុងគ្រាប់ស្រូវដំណើបក្តី ដែលបុគ្គលរៀបចំត្រូវទំនង គឺធ្វើឲ្យមានចុងឡើងលើ បុគ្គលសង្កត់ដោយដៃ ឬជាន់ដោយជើង នឹងមុតដៃ ឬជើង នឹងធ្វើឈាមឲ្យផុលឡើងបាន ហេតុ នេះ ទើបមាន រឿងនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចុងគ្រាប់ ស្រូវបុគ្គលរៀបចំត្រូវទំនង ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្ត

តម្កល់ត្រូវនឹងទម្ងាយអវិជ្ជា នឹងធ្វើវិជ្ជាឲ្យកើតឡើង នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ហេតុនេះទើបមាន ។

អ្វីឈ្មោះថា ៩

ព្រះសាស្តា ជាបុគ្គលមានព្រះហឫទ័យ ដែលព្រះថេរៈធ្វើឲ្យត្រេកអរដោយការព្យាករណ៍បញ្ហានេះ ទើបត្រាស់សួរបញ្ហាក្រៃលែងឡើងថា អ្វីឈ្មោះថា ៩ ។ ព្រះថេរៈពោលត្រួតថា **ឆវ** ទើបទូលឆ្លើយថា **សត្តាវាស** ។

ក្នុងពាក្យនោះ ពាក្យថា **ឆវ** ជាការកំណត់ចំនួន ពាក្យថា **សត្ត** បានដល់ សត្វមានជីវិតដែលលោកបញ្ញត្តអាស្រ័យខន្ធ ដែលទាក់ទងក្នុងជីវិតិន្ទ្រិយ ។ ពាក្យថា **អាវាស** បានដល់ ឈ្មោះថា **អាវាស** ព្រោះជាទីអាស្រ័យ ។ ទីអាស្រ័យរបស់សត្វទាំងឡាយ ឈ្មោះថា **សត្តាវាស** ឈ្មោះថា ជាគន្ធងនៃទេសនា តែបើពោលដោយអត្ថ ពាក្យនេះជាឈ្មោះរបស់សត្វ ៩ ប្រភេទ ដូចលោកពោលថា

> ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្សទេវតាពួកខ្លះ និងវិនិបាតិកៈពួកខ្លះ នេះជាសត្តាវាសទី ១ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់ព្រហ្មលោក ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជាសត្តាវាសទី ២ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា

ដូចពួកទេវតាក្នុងជាន់អាភស្សរៈ នេះជាសត្តាវាសទី ៣ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់សុភកិណ្ហៈ នេះជាសត្តាវាសទី ៤ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វឥតសញ្ញា មិនដឹងច្បាស់ (នូវអារម្មណ៍) ដូចពួកទេវតាជាអសញ្ញិសត្វ នេះជាសត្តាវាសទី ៥ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វចូលកាន់អាកាសានញ្ចាយតនជ្ឈាន ។បេ។ នេះជាសត្តាវាសទី ៦ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈានដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ។បេ។ នេះជាសត្តាវាសទី ៧ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈានដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ។បេ។ នេះជាសត្តាវាសទី ៨ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈានដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។បេ។ នេះជាសត្តាវាសទី ៩ ។

ក្នុងទីនេះ ព្រះថេរៈពោលថា សត្តាវាស ៩ តាមន័យមុនៗ នោះឯង មិនមែនពោលព្រោះមិនមានធម៌ ៩ ដទៃ ដូចព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៩ គឺអ្វី ។ គឺសត្តាវាសទាំង ៩ ។ ម្នាលភិក្ខុទាំងឡាយកាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ៩ ខរទូស ៩ វេយ្យាករណ៍ ៩ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះដូច្នេះ ។

ក្នុងបញ្ហានេះ ភិក្ខុលះការយើញថា ទៀង ស្អាត សុខជាដើម ដោយញាតប្បវិញ្ញា ក្នុងសត្តាវាស ៩ ព្រោះបាលីថា ធម៌ ៩ គួរកំណត់ដឹង គឺ សត្តាវាស ៩ នឿយណាយដោយការយើញត្រឹមតែជាគំនរសង្ខារសុទ្ធៗ ជ្រុសចាកតម្រេក ដោយការយើញអនិច្ចលក្ខណៈ ដោយតីរណប្បវិញ្ញា រួចផុតដោយការយើញទុក្ខលក្ខណៈ យើញទីបំផុតដោយប្រពៃ ដោយការយើញអនត្តលក្ខណៈ ត្រាស់ដឹងនូវភាពជាធម៌ប្រពៃ ដោយបហានប្បវិញ្ញា រមែងជាបុគ្គលធ្វើទីបំផុតទុក្ខបាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ យើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៩ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុង

បច្ចុប្បន្នបាន ។ ធម៌ ៩ គឺអ្វី ។ គឺសត្តាវាសទាំង ៩ ដូច្នេះ ។

អ្វីឈ្មោះថា ១០

ព្រះសាស្តា ជាបុគ្គលមានព្រះហឫទ័យដែលព្រះថេរៈធ្វើឲ្យត្រេកអរ ដោយព្យាករនេះយ៉ាងនេះ ទើបត្រាស់សួរបញ្ហាក្រៃលែងឡើងទៀតថា អ្វីឈ្មោះថា ១០ ។ ក្នុងបញ្ហានេះ ព្រះមានព្រះភាគត្រាស់អកុសលកម្មបថ ១០ ក្នុងការព្យាករណ៍ទាំងឡាយ ក្រៅអំពីការព្យាករណ៍បញ្ហានេះ ដូចព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ទាំង ១០ គឺអ្វី ។ គឺអកុសលកម្មបថទាំង ៩ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ១០ ខុទ្ទេស ១០ វេយ្យាករណ៍ ១០ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។

ពិតហើយ ទោះជាយ៉ាងនោះ ក្នុងទីនេះ ព្រោះហេតុដែលព្រះថេរៈ មិននាំខ្លួនឯងចូលទៅ បំណងនឹងព្យាករនូវអរហត្ត ឬព្រោះហេតុដែលបញ្ហាកម្ម ដែលព្រះថេរៈព្យាករដោយបរិយាយនេះ ជាការព្យាករណ៍ល្អហើយ ដូច្នោះ

បុគ្គលដែលប្រកបដោយអង្គ ១០ ពួកណា លោកហៅថា ព្រះអរហន្ត ព្រះថេរៈ កាលសម្តែងការសម្រេចអង្គទាំង ១០ នោះ ទើបទូលដោយទេសនាជាបុគ្គលាធិដ្ឋានថា បុគ្គលដែលប្រកបដោយអង្គ ១០ លោកហៅថា ព្រះអរហន្ត ព្រោះក្នុងសេចក្តីនេះ បុគ្គលដែលប្រកបដោយអង្គ ១០ ពួកណា លោកហៅថា ព្រះអរហន្ត គប្បីជ្រាបថា អង្គទាំង ១០ នោះ ព្រះថេរៈត្រូវព្រះសាស្តាត្រាស់សួរថា អ្វីឈ្មោះថា ១០ ទើបទូលស្នងព្រះពុទ្ធដីកា ។ អង្គទាំង ១០ នោះ គប្បីជ្រាបដោយនយដែលត្រាស់ក្នុងសូត្រទាំងឡាយជាដើមយ៉ាងនេះថា

> *បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ត្រាស់ថា អសេក្ខៈ អសេក្ខៈ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាអសេក្ខៈ តើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រកបដោយសម្មាទិដ្ឋិ ជាអសេក្ខៈ ប្រកបដោយសម្មាសង្កប្បៈ ជាអសេក្ខៈ ប្រកបដោយសម្មាវាចា ជាអសេក្ខៈ ប្រកបដោយសម្មាកម្មន្តៈ ជាអសេក្ខៈ ប្រកបដោយសម្មាអាជីវៈ ជាអសេក្ខៈ ប្រកបដោយសម្មាវាយាមៈ ជាអសេក្ខៈ ប្រកបដោយសម្មាសតិ ជាអសេក្ខៈ ប្រកបដោយសម្មាសមាធិ ជាអសេក្ខៈ ប្រកបដោយសម្មាញាណ ជាអសេក្ខៈ ប្រកបដោយសម្មាវិមុត្តិ ជាអសេក្ខៈ ។ ម្នាលភិក្ខុ (ភិក្ខុ) ជាអសេក្ខៈយ៉ាង*

នេះឯង ។

អដ្ឋកថាខុទ្ទកបាឋៈ

កុមារបញ្ហា ចប់

សុត្តន្តបិដក

ខុទ្ទកបាឋៈ មង្គលសូត្រ

[៥] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ទេវតា ១ អង្គ កាលរាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ លុះទេវតានោះ ឋិតនៅក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមាន ព្រះភាគដោយគាថា ។*

[៦] *ទេវតា និងមនុស្សទាំងឡាយជាច្រើន ប្រាថ្នារកសួស្តី បានគិតរកមង្គលទាំងឡាយ សូមព្រះអង្គសម្តែងប្រាប់នូវមង្គលដ៏ឧត្តម ។ (ព្រះមានព្រះភាគទ្រង់ត្រាស់ថា) ការមិនសេពគប់ពាលជនទាំងឡាយ ១ ការសេពគប់បណ្ឌិតជនទាំងឡាយ ១ ការបូជាចំពោះ*

បុគ្គលដែលគួរបូជាទាំងឡាយ ១ នេះជាមង្គលដ៏ឧត្តម ។ ការនៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១ ការតម្កល់ខ្លួនប្រពៃ ១ នេះជាមង្គលដ៏ឧត្តម ។ ភាវៈនៃបុគ្គលបានស្តាប់ បានរៀនច្រើន ១ សិល្បៈ គឺសេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់អ្នកបួស និងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាប្រពៃ ១ វាចាដែលបុគ្គលពោលល្អ ១ នេះជាមង្គលដ៏ឧត្តម ។ ការបម្រើមាតាបិតា ១ សេចក្តីសង្គ្រោះដល់បុត្ត និងភរិយា ១ ការងារទាំងឡាយដែលមិនច្របូកច្របល់ ១ នេះជាមង្គលដ៏ឧត្តម ។ ការបរិច្ចាគទាន ១ ការប្រព្រឹត្តធម៌ ១ សេចក្តីសង្គ្រោះញាតិទាំងឡាយ ១ ការងារទាំងឡាយដែលមិនមានទោស ១ នេះជាមង្គលដ៏ឧត្តម ។ ការមិនត្រេកអរក្នុងបាប និងការវៀរចាកបាប ១ សេចក្តីសង្រួមចាកការផឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទ ក្នុងធម៌ទាំង-ឡាយ ១ នេះជាមង្គលដ៏ឧត្តម ។ សេចក្តីគោរព ១ សេចក្តីឱនលំទោន ១ សេចក្តីត្រេកអរតាមមានតាមបាន ១ ភាពជាអ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយ ១ ការស្តាប់នូវធម៌តាមកាល ១ នេះជាមង្គលដ៏ឧត្តម ។

សេចក្តីអត់ធន់ ១ ការៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ ការជួបប្រទះនូវសមណៈទាំងឡាយ ១ ការសន្ទនាទៅវិញ ទៅមកនូវធម៌តាមកាល ១ នេះជាមង្គលដ៏ឧត្តម ។ សេចក្តីព្យាយាមដុតនូវបាបធម៌ ១ ការប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ១ ការឃើញនូវអរិយសច្ចទាំងឡាយ ១ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ១ នេះជាមង្គលដ៏ឧត្តម ។ ចិត្តនៃបុគ្គលណាដែលលោក-ធម៌ទាំងឡាយ ពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ ការមិនមានសេចក្តីសោក ១ ធូលី គឺរាគៈទៅប្រាសហើយ ១ ចិត្តក្សេមក្សាន្ត ១ នេះជាមង្គលដ៏ឧត្តម ។ ទេវតា និងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្តី ក្នុងទីទាំងពួង នេះជាមង្គលដ៏ឧត្តមរបស់ទេវតា និងមនុស្សទាំងឡាយនោះ ។

មង្គលសូត្រ ចប់

អដ្ឋកថា

មង្គលសូត្រ

ប្រយោជន៍នៃនិក្ខេបបទ

[៥-៦] *ឥឡូវនេះ ដល់លំដាប់ពណ៌នានៃមង្គលសូត្រ ដែលលើកឡើងជានិក្ខេបបទ បន្តលំដាប់អំពីកុមារប្បញ្ហា ។ ក្នុងទីនេះ ខ្ញុំនឹងពោលប្រយោជន៍នៃនិក្ខេបបទហើយ ទើបនឹងពណ៌នាអត្ថនៃមង្គលសូត្រនោះ ។ សេចក្តីនេះដូចម្តេច សេចក្តីពិត ព្រះសូត្រនេះ ព្រះមានព្រះភាគ មិនបានត្រាស់តាមលំដាប់ តែខ្ញុំពោលដើម្បីសម្តែងថា ការរាប់អានព្រះសាសនាដោយការដល់សរណៈ និងនយតាមប្រភេទសីល សមាធិ បញ្ញា ទ្រង់សម្តែងដោយសិក្ខាបទ ទុតិយសាការ និងកុមារប្បញ្ហានេះ ទាំងអស់នោះក៏ជាមង្គលយ៉ាងក្រៃលែង ព្រោះបុគ្គលត្រូវការមង្គល ចាំបាច់ធ្វើព្យាយាមក្រៃលែងក្នុងមង្គលនោះៗ ឯង ។ ឯការរាប់អានព្រះសាសនាជាដើមនោះ ជាមង្គលនោះ បណ្ឌិតគប្បីជ្រាបតាមគន្ថង ព្រះសូត្រនេះ ។*

នេះជាប្រយោជន៍នៃនិក្ខេបបទ ក្នុងមង្គលសូត្រនោះ ។

បឋមមហាសង្គាយនា

ដើម្បីពណ៌នាអត្ថនៃមង្គលសូត្រនោះ ដែលលើកជានិក្ខេបបទយ៉ាងនេះ មានមាតិកា ដូច្នេះ ។

ខ្ញុំពោលវិធីយ៉ាងនេះថា ពាក្យនេះបុគ្គលណាពោល ពោលក្នុងកាលណា ពោលព្រោះហេតុអ្វី កាលនឹងពណ៌នាសេចក្តីនៃបាឋៈ មាន ៧ ជាដើម

ក៏និងពោលសមុដ្ឋានដែលកើតមង្គល កំណត់មង្គលនោះហើយ និងចង្អុលបង្ហាញនូវមង្គលនៃមង្គលសូត្រនោះ ។

ក្នុងមាតិកានោះ កន្ទះគាថាដំបូងថា **វុត្តំ យេន យថា យស្មា ឯតំ វត្វា ឥមំ វិធិំ** *លោកពោលសំដៅដល់ពាក្យ គឺ* **ឯវម្មេ សុតំ ។បេ។ ភគវន្តំ គាថាយ អជ្ឈភាសិ ។** *ពិតហើយ ព្រះសូត្រនេះ លោកពោលដោយស្តាប់បន្តៗ គ្នាមក ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាសយម្ភូ គឺត្រាស់ដឹងឯង មិនមានអាចារ្យ ព្រោះដូច្នោះ ពាក្យនេះ ទើបមិនមែនជាព្រះតម្រាស់របស់ព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ ព្រោះហេតុដែលមានពាក្យពោលថា ពាក្យនេះអ្នកណាពោល ពោលកាលណា និងពោលព្រោះហេតុអ្វី ដូច្នោះ ទើបសូមពោលចង្អុលបង្ហាញ ។ ដូច្នេះ ពាក្យនេះ ព្រះអានន្ទពោល និងពោលក្នុងកាលធ្វើមហាសង្គាយនាលើកទី ១ ។*

សេចក្តីពិត ការធ្វើមហាសង្គាយនាលើកទី ១ នេះ គួរជ្រាបមកតាំងអំពីដើម ដើម្បីភាពឈ្វាសវៃក្នុងនិទានវចនៈ គឺពាក្យខាងដើមនៃព្រះសូត្រទាំងពួង ដូចតទៅនេះ

កាលព្រះមានព្រះភាគ ជានាថនៃលោក ទ្រង់បំពេញពុទ្ធកិច្ច តាំងអំពីទ្រង់ប្រកាសធម្មចក្រ រហូតដល់ទ្រង់ជ្រោសសុភទ្ទបរិព្វាជក ហើយទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងកាលទៀបភ្លឺ ថ្ងៃវិសាខបុណ្ណមី ចន្ទោះដើមសាលព្រឹក្សទាំងគូ ក្នុងសាលវនឧទ្យាន ដែលជាទីឈប់សម្រាករបស់មល្លក្សត្រ ជិតក្រុងកុសិនារា ព្រះមហាកស្សបដែលជាសង្ឃត្តេររបស់

ភិក្ខុប្រមាណ ៧ សែនរូប ដែលប្រជុំគ្នាក្នុងថ្ងៃចែកព្រះបរមសារីរិកធាតុរបស់ព្រះមានព្រះភាគ មករឭកដល់ពាក្យរបស់សុភទ្ទវុឌ្ឍបព្វជិតពោលក្នុងកាលព្រះមានព្រះភាគបរិនិព្វានបាន ៧ ថ្ងៃថា

អាវុសោទាំងឡាយ ណ្ហើយ អ្នកទាំងឡាយ កុំសោកសៅ កុំខ្សឹកខ្សួលឡើយ ពួកយើងនឹងបានរួចស្រឡះហើយ ព្រោះថា ពួកយើង មហាសមណៈនោះ តែងបៀតបៀនថា អំពើនេះគួរ ដល់អ្នក អំពើនេះមិនគួរ ដល់អ្នក ឥឡូវនេះ ពួកយើងនឹងប្រាថ្នាធ្វើនូវអំពើណា នឹងធ្វើនូវអំពើនោះ មិនប្រាថ្នាធ្វើនូវអំពើណា នឹងមិនធ្វើអំពើនោះបាន ដូច្នេះ ។

លោកត្រិះរិះថា ពួកភិក្ខុអាក្រក់យល់ថា ជាវចនា គឺធម្មវិន័យ មានសាស្តាកន្លងទៅហើយ បានចូលរួមជាបក្ខពួក ក៏នាំគ្នាញ៉ាំញីព្រះសទ្ធម្ម ឲ្យអន្តរធានទៅ ក្នុងកាលមិនយូរឡើយ សេចក្តីនេះ រមែងប្រព្រឹត្តទៅបានដរាបណា ធម្មវិន័យនៅតាំងនៅដរាបនោះ ជាវចនៈ គឺធម្មវិន័យ ក៏ឈ្មោះថាមិនមានសាស្តានិព្វានទៅហើយឡើយ សមដូចព្រះមានព្រះភាគទ្រាស់ថា

ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណឹះឥតអំពីតថាគតទៅ ធម៌ និងវិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ ដូច្នេះ ។

កុំដូច្នោះឡើយ យើងនឹងនាំគ្នាធ្វើសង្គាយនាធម្មវិន័យ ដោយវិធីដែល

ព្រះសាសនានេះគប្បីតាំងនៅយូរអង្វែង ។

ម្យ៉ាងទៀត ខ្ញុំកស្សប ដែលព្រះមានព្រះភាគ ទ្រង់អនុគ្រោះដោយសាធារណបរិភោគក្នុងចីវរត្រាស់ថា

*កស្សប អ្នកនឹងទ្រទ្រង់សំពត់បង្សុកូល ដែលធ្វើដោយផ្ទៃរបស់តថាគត ដែលតថាគតប្រើប្រាស់ ស្លៀកដណ្តប់ហើយឬ ដូច្នេះហើយ ទ្រង់អនុគ្រោះដោយអសាធារណបរិភោគក្នុងចីវរ និងដោយការទ្រង់លើកតម្កើង ប្រៀបធៀបព្រះអង្គក្នុងឧត្តរិមនុស្សធម្ម មានអនុបុព្វវិហារ ៩ និងអភិញ្ញា ៦ ជាប្រភេទ ដោយន័យជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាជរាបណា ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក វិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះជរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកកស្សបប្រាថ្នាជរាបណា ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក វិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះជរាបនោះដែរ ដូច្នេះ ភាពជាអ្នកមិនមានបំណុលជំទែងមួយ នឹងមានដល់អាត្មាអញនោះបាន ព្រះមានព្រះភាគទ្រង់ជ្រាបអាត្មាអញថា កស្សបនេះ នឹងជាអ្នកបន្តវង្សព្រះសទ្ធម្មរបស់តថាគត ដូច្នេះហើយ ទើបទ្រង់អនុគ្រោះដោយអសាធារណានុគ្រោះនេះ ដូចព្រះរាជាទ្រង់ជ្រាបព្រះឱរសដែលនឹងបន្តវង្សរបស់ព្រះអង្គ ហើយទ្រង់អនុគ្រោះដោយទ្រង់ប្រគល់គ្រឿងក្រោះនិងឥស្សរិយយសរបស់ព្រះអង្គដូច្នោះ មិនមែនឬ ដូច្នេះ ទើបញុំាងសេចក្តី

ឧស្សាហ៍ឲ្យកើតដល់ភិក្ខុទាំងឡាយ ដើម្បីប្រារព្ធសង្គាយនាព្រះធម៌ ព្រះវិនយ ដូចដែលព្រះអានន្ទពោលថា

គ្រានោះឯង ព្រះមហាកស្សប ពោលនឹងភិក្ខុទាំងឡាយថា

លំដាប់នោះ ព្រះមហាកស្សបដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា អាវុសោទាំងឡាយ សម័យមួយ ខ្ញុំគិតថា នឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងបាវានេះ រួចហើយនឹងទៅកាន់ក្រុងកុសិនារា ហើយក៏ដើរទៅតាមផ្លូវឆ្ងាយជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួន ៥០០ រូប ដូច្នេះ ។

សុភទ្ទកណ្ឌគួរពោលឲ្យពិស្តារទាំងអស់ បន្ទាប់អំពីនោះ ព្រះមហាកស្សបពោលថា

ម្នាលអាវុសោទាំងឡាយ ណ្ហើយចុះ យើងរាល់គ្នាសង្គាយនាធម្មៈ និងវិនយ តំណាទៅមុខ អកុសលធម្មៈមុខជានឹងរុងរឿងឡើង កុសលធម្មៈមុខជានឹងសាបសូន្យទៅ សការៈមិនមែនជាវិនយ មុខជានឹងរុងរឿងឡើង វិនយមុខជានឹងសាបសូន្យទៅ តំណាទៅមុខ ពួកបុគ្គលជាអធម្មវាទី នឹងមានកម្លាំងឡើង ពួកបុគ្គលជាធម្មវាទី នឹងថយកម្លាំងចុះ ពួកបុគ្គលជាអវិនយវាទី នឹងមានកម្លាំងឡើង ពួកបុគ្គលជាវិនយវាទី នឹងថយកម្លាំងចុះ ដូច្នេះ ។

កិក្ខុទាំងឡាយពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់ជ្រើសរើសកិក្ខុទាំងឡាយចុះ ។ ព្រះថេរៈវៀរកិក្ខុដែលជាបុថុជ្ជន សោតាបន្ន សកទាគាមី អនាគាមី និងព្រះខីណាស្រពសុក្ខវិបស្សកៈ ដែលទ្រទ្រង់ព្រះបរិយត្តិ គឺនវង្គសត្ថុសាសនៈទាំងអស់ ច្រើនរយ ច្រើនពាន់រូប ចម្រាញ់យកចំពោះកិក្ខុដែលជាព្រះអរហន្តប្រកេទតេវិជ្ជោជាដើម ដែលទ្រទ្រង់ព្រះបរិយត្តិគឺព្រះត្រៃបិដកទាំងអស់ សម្រេចបដិសម្ភិទា មានអានុភាពធំក្រៃលែងដោយច្រើន ដែលព្រះមានព្រះភាគ ទ្រង់តែងតាំងក្នុងភាពជាឯតទគ្គៈ ដែលព្រះ-សង្គីតិកាចារ្យបំណងពោលថា គ្រានោះឯង ព្រះមហាកស្សបជ្រើសរើសព្រះអរហន្ត ៥០០ រូប ខ្វះ ១ ដូច្នេះ ។

សួរថា ហេតុអ្វី ទើបព្រះថេរៈឲ្យខ្វះមួយរូប ។ ឆ្លើយថា ដើម្បីទុកឱកាសដល់ព្រះអានន្ទត្ថេរ ព្រោះថា រួមព្រះអានន្ទផង វៀរព្រះអានន្ទផង ក៏មិនអាចធ្វើសង្គាយនាបាន ដ្បិតថា ព្រះអានន្ទជាព្រះសេក្ខៈ នៅមានកិច្ចធ្វើនៅឡើយដូច្នោះ ទើបមិនអាចរួមបាន ។ តែព្រោះនវង្គសត្ថុសាសនៈ មានសុតៈ និងគេយ្យៈជាដើមណាមួយ ដែលព្រះទសពលទ្រង់សម្តែងហើយ ឈ្មោះថាព្រះអានន្ទមិនបានទទួលចំពោះព្រះភក្ត្រៈបស់ព្រះមានព្រះភាគ មិនមាន ដូច្នោះទើបមិនអាចវៀរបាន ។ បើព្រះអានន្ទជាសេក្ខៈ ក៏គួរ ព្រះថេរៈគប្បីជ្រើសរើសព្រោះជាអ្នកមានឧបការៈច្រើនចំពោះការសង្គាយនាធម៌ តែព្រោះហេតុអ្វី ទើបព្រះថេរៈមិនជ្រើសរើស ព្រោះចៀសវាងពាក្យតិះដៀល ។ សេចក្តីពិត ព្រះថេរៈមានការស្និទ្ធស្នាលពន់ពេកក្នុងព្រះអានន្ទ ។ ពិតហើយ សូម្បីព្រះអានន្ទ

មានសីសៈស្លាវហើយ ព្រះថេរៈក៏នៅទូន្មានលោក ដោយវាទៈថា កុមារ ដូចពាក្យថា កុមារម្នាក់នេះ មិនស្គាល់ប្រមាណសោះឡើយ ម្យ៉ាងទៀត ព្រះ អានន្ទនេះកើតក្នុងសក្យត្រកូល ជាព្រះអនុជរបស់ព្រះតថាគត ជាឱរសរបស់ ព្រះបិតុលា ។ ក្នុងការជ្រើសរើសព្រះអានន្ទ ភិក្ខុទាំងឡាយនឹងសម្គាល់ថា លោកលម្អៀងព្រោះស្រឡាញ់ គប្បីតិះដៀលថា ព្រះថេរៈ វៀរពួកភិក្ខុដែល ដល់នូវអសេក្ខប្បដិសម្ភិទាចេញ ទៅជ្រើសរើសព្រះអានន្ទ ដែលសម្រេច សេក្ខប្បដិសម្ភិទា ។ ព្រះថេរៈ កាលចៀសវាងនូវពាក្យតិះដៀលនោះ គិតថា វៀរព្រះអានន្ទចេញ ក៏មិនអាចធ្វើសង្គាយនាបាន អញនឹងជ្រើសរើស លុះ ណាតែភិក្ខុទាំងឡាយអនុមតិប៉ុណ្ណោះ ដូច្នេះ ទើបមិនជ្រើសរើសឯង ។

គ្រានោះ ភិក្ខុទាំងឡាយនាំគ្នាសំណូមពរព្រះថេរៈ ដើម្បីជ្រើសរើសព្រះ អានន្ទ ដូចព្រះអានន្ទពោលថា

ភិក្ខុទាំងឡាយ បានជ្រាប់ព្រះមហាកស្សបយ៉ាងនេះថា
បពិត្រព្រះករុណាដ៏ចម្រើន ព្រះអានន្ទមានអាយុនេះ
នៅជាសេក្ខបុគ្គលពិតមែន តែលោកមិនអាចនឹងលុះ
ដោយឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិទេ
ធម៌ក្តី វិន័យក្តី ព្រះអានន្ទនេះ បានសិក្សារៀនសូត្រក្នុង
សម្នាក់ព្រះមានព្រះភាគជាច្រើន បពិត្រព្រះករុណាដ៏
ចម្រើន បើដូច្នោះ សូមព្រះថេរៈជ្រើងរើសយកព្រះ
អានន្ទមានអាយុផង ដូច្នេះ ។

ទើបព្រះថេរៈមានចំនួន ៥០០ រូប រួមទាំងព្រះអានន្ទដែលព្រះថេរៈជ្រើសរើស ដោយអនុមតិរបស់ភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។

លំដាប់នោះ ភិក្ខុដែលជាថេរៈទាំងឡាយប្រឹក្សាគ្នាថា យើងនឹងជួយគ្នាធ្វើសង្គាយនាធម៌ និងវិនយ ទីណាហ្ន៎ បានសម្រេចថា ធ្វើក្នុងក្រុងរាជគ្រឹះដែលមានគោចរ និងអាហារច្រើន មានសេនាសនៈច្រើន បើដូច្នោះ យើងនៅចាំវស្សា នាំគ្នាសង្គាយនាក្នុងក្រុងរាជគ្រឹះ ភិក្ខុដែលមិនបានជ្រើសរើសមិនគប្បីនៅចាំវស្សាក្នុងក្រុងរាជគ្រឹះ ហេតុអ្វី ទើបភិក្ខុដែលជាថេរៈបានសម្រេចដូច្នោះ ព្រោះលោកត្រិះរិះថា ការធ្វើសង្គាយនានេះ ជាថាវរកម្មរបស់យើង បុគ្គលដែលជាវិសភាគ គប្បីចូលមកក្នុងចំណោមសង្ឃ ហើយរើថាវរកម្មនោះចេញ ។ គ្រានោះ ទើបព្រះមហាកស្សបប្រកាសដោយញត្តិទុតិយកម្ម ។ ពាក្យប្រកាសនោះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងសង្គីតិក្ខន្ធកៈនោះឯង ។

គ្រានោះ រាប់តាំងអំពីព្រះតថាគតបរិនិព្វាន កាលការលេងសាធុកីឡាកន្លងទៅ ៧ ថ្ងៃ ការបូជាព្រះធាតុកន្លងទៅ ៧ ថ្ងៃទៀត ព្រះមហាកស្សបជ័ងថា ក្នុងកាលកន្លងទៅកន្លះខែហើយ នៅសល់មួយខែកន្លះ ក៏ដល់តិថីចូលវស្សា ទើបពោលថា អាវុសោទាំងឡាយ យើងនឹងនាំគ្នាទៅក្រុងរាជគ្រឹះ ក៏នាំពួកភិក្ខុពាក់កណ្តាលធ្វើដំណើរបែកទៅផ្លូវមួយ សូម្បីព្រះអនុរុទ្ធក៏នាំពួកភិក្ខុពាក់កណ្តាលបែកទៅផ្លូវមួយ ។ ឯព្រះអានន្ទត្ថេរកាន់បាត្រ និងចីវររបស់ព្រះមានព្រះភាគដែលពួកភិក្ខុចោមរោម បំណងនឹងទៅក្រុងសាវត្ថី ហើយ

សឹមទៅក្រុងរាជគ្រឹះ ក៏បែកផ្លូវ ធ្វើដំណើរទៅកាន់ក្រុងសាវត្ថី ។ ក្នុងទីដែលព្រះអានន្ទត្ថេរទៅដល់ ក៏មានសំឡេងឲ្យឹកឲ្យូល យំរៀបរាប់ថា បពិត្រលោកម្ចាស់ឈ្មោះអានន្ទ លោកម្ចាស់ទុកព្រះសាស្តានៅឯណា មកហើយ ។ លុះព្រះថេរៈដល់ក្រុងសាវត្ថីតាមលំដាប់ ក៏មានសំឡេងយំសោកដ៏ធំ ដូចក្នុងគ្រាដែលព្រះមានព្រះភាគទ្រង់បរិនិព្វាន ។

បានញ្ចថា សម័យនោះ ព្រះអានន្ទត្រូវលួងលោមមហាជននោះ ដោយធម្មីកថាដែលប្រកបដោយការមិនទៀងជាដើម ហើយទើបចូលទៅកាន់វត្តជេតពនវិហារ បើកទ្វារព្រះគន្ធកុដិ ដែលព្រះទសពលប្រថាប់ ហើយលើកគ្រែចេញ បោសសម្អាតព្រះគន្ធកុដិ ចោលសំរាម គឺផ្ការក្រៀម នាំគ្រែចូលទៅតម្រៀបទុកដូចមុន បានធ្វើវត្តបដិបត្តិគ្រប់យ៉ាងដែលគួរធ្វើ ដូចក្នុងកាលព្រះមានព្រះភាគគង់ព្រះជន្មនៅ ។

ព្រះថេរៈសង្កត់ចិត្ត ឆាន់ថ្នាំបញ្ចុះលាយដោយទឹកដោះក្នុងថ្ងៃទី ២ ដើម្បីធ្វើកាយដែលមានភាពធ្ងន់ឲ្យស្រាល ព្រោះតាំងអំពីព្រះមានព្រះភាគ ទ្រង់បរិនិព្វាន ត្រូវឈរច្រើន អង្គុយច្រើន ទើបអង្គុយតែក្នុងវិហារប៉ុណ្ណោះ ដែលលោកអាងដល់ ទើបពោលនឹងបុរសដែលសុភមាណពប្រើទៅ ដូច្នេះថា

ម្នាលមាណព កាលនេះមិន គួរ (ទៅទេ) ដ្បិតថ្ងៃនេះ
យើងបានផឹកថ្នាំខ្ងះទៅហើយ បើដូច្នោះ ចាំយើងពិចា-
រណានូវកាល និងសម័យសិនហើយ សឹមទៅក្នុងថ្ងៃ
ស្អែក ដូច្នេះ ។

ថ្ងៃទី ២ ព្រះថេរៈមានព្រះចេតកត្តេរជាបច្ឆាសមណៈ ត្រូវសុភមាណព សួរបញ្ហា ហើយបាននពោលសូត្រទី ១០ ឈ្មោះសុភសូត្រក្នុងទីឃនិកាយ ។ គ្រានោះ ព្រះថេរៈឲ្យសុភមាណពជួយជួសជុលវត្តដែលបាក់បែក ក្នុងជេត-ពនវិហារ កាលទៀបនឹងចូលវស្សា ទើបទៅកាន់ក្រុងរាជគ្រឹះ ។ ព្រះមហា-កស្សបត្តេរ និងព្រះអនុរុទ្ធត្តេរក៏យ៉ាងនោះ នាំពួកភិក្ខុទាំងអស់ទៅកាន់ក្រុង រាជគ្រឹះដូចគ្នា ។

សម័យនោះ ក្នុងក្រុងរាជគ្រឹះមានវត្តធំៗ ១៨ កន្លែង វត្តទាំងអស់មាន សំរាម ដែលគេចោលចាត់រាត់រាយពេញទាំងអស់ ព្រោះក្នុងកាលព្រះមាន ព្រះភាគបរិនិព្វាន ភិក្ខុទាំងឡាយកាន់ជាត្រចីវរបស់ខ្លួន ចោះបង់វត្ត និង បរិវេណ និមន្តទៅអស់ កាលនោះ ព្រះថេរៈទាំងឡាយគិតគ្នាថា យើងនឹង នាំគ្នាជួសជុលវិហារដែលទ្រុឌទ្រោម មួយវែងដំបូងនៃវស្សា ដើម្បីបូជាព្រះ ពុទ្ធតម្រាស់ និងដោះពាក្យតិះដៀលរបស់ពួកតិរ្ថិយ ដ្បិតថា ពួកតិរ្ថិយនាំគ្នា តិះដៀលថា ពួកសាវ័ករបស់ព្រះគោតម កាលសាស្តានៅមានជីវិត ក៏នាំគ្នា ទំនុកបម្រុង លុះព្រះសាស្តាបរិនិព្វានហើយ ក៏នាំគ្នាចោះបង់ទៅ ។ លោក អធិប្បាយថា ព្រះថេរៈទាំងឡាយគិតគ្នាដូច្នោះ ដើម្បីដោះពាក្យតិះដៀល របស់ពួកតិរ្ថិយទាំងនោះ ។ សមដូចលោកពោលថា

គ្រានោះ ភិក្ខុទាំងឡាយជាថេរៈ មានសេចក្តីត្រិះរិះដូច្នេះ
ថា ម្នាលអាវុសោ បដិសង្ខរណកម្ម គឺការជួសជុល
សេនាសនៈ ដែលបែកបាក់ធ្លុះធ្លាយ ព្រះមានព្រះភាគ

ទ្រង់សរសើរហើយ ម្នាលអាវុសោ បើដូច្នោះ គួរតែយើងរាល់គ្នាជួសជុលសេនាសនៈ ដែលបែកបាក់ធ្លុះធ្លាយ អស់ខែមួយដំបូងសិន ដល់មកខែកណ្តាល យើងនឹងប្រជុំគ្នាធ្វើសង្គាយនានូវធម៌ និងវិន័យ ដូច្នេះ ។

ថ្ងៃទី ២ ព្រះថេរៈទាំងនោះ នាំគ្នាទៅឈរក្បែរទ្វារព្រះរាជនិវេសន៍ ព្រះបាទអជាតសត្រូវ ទ្រង់យាងមកថ្វាយបង្គំ ហើយបវារណាថា បពិត្រលោកម្ចាស់ ញោមអាចជួយអ្វីបានខ្លះ លោកម្ចាស់ទាំងឡាយត្រូវការអ្វី ។ ព្រះថេរៈទាំងឡាយថ្វាយព្រះពរសុំហត្ថកម្ម ដើម្បីធ្វើការជួសជុលវត្តធំៗ ១៨ កន្លែង ព្រះរាជាទ្រង់ទទួលថា សាធុ ហើយព្រះរាជទានមនុស្ស ដែលជាជាងមានថ្វីដៃ ។ ព្រះថេរៈទាំងឡាយឲ្យជួសជុលវិហារអស់ក្នុងមួយខែដំបូង បន្ទាប់មក ទើបក្រាបទូលព្រះរាជាថា សូមថ្វាយព្រះពរ ការជួសជុលវិហារស្រេចហើយ ឥឡូវនេះ ពួកអាត្មានឹងនាំគ្នាធ្វើសង្គាយនាធម៌ និងវិនយ ។ ព្រះរាជាមានព្រះតម្រាស់ថា សាធុ សូមលោកម្ចាស់ ធ្វើដោយសប្បាយចិត្តចុះ អាណាចក្រសូមជាធុរៈរបស់ញោម ឯធម្មចក្រ ជាធុរៈរបស់លោកម្ចាស់ ហើយសូមជ្រាបមកចុះ តើឲ្យញោមជួយអ្វី ។ ព្រះថេរៈទាំងឡាយថ្វាយព្រះពរថា សូមមហារាជឲ្យសាងទីប្រជុំ សម្រាប់ភិក្ខុទាំងឡាយ ដែលជួយគ្នាធ្វើសង្គាយនាធម៌ ។ ត្រាស់សួរថា នឹងធ្វើត្រង់ណាលោកម្ចាស់ ។ ព្រះថេរៈជ្រាបថា ធ្វើក្បែរទ្វារគុហាសត្តបណ្ណ ក្បែរភ្នំវេភារៈ ទើបសមគួរមហាបពិត្រ ។ ព្រះបាទអជាតសត្តុទូលថា សាធុ ហើយឲ្យសាងមណ្ឌបធំ មាន

ជញ្ជាំងសសរ និងជណ្តើរ រៀបចំយ៉ាងល្អ វិចិត្រដោយផ្កា និងក្បាលច្រើនប្រភេទ ដូចវេស្សកម្មទេវបុត្រនិម្មិត មណ្ឌបធំនោះ មានពិតានមាស លម្អដោយកម្រងផ្កាច្រើនប្រភេទ ដែលជាក់សំយុង នៅត្រង់ផែនដី ក៏ពង្រាបឲ្យស្មើល្អ ។ លម្អដោយផ្កាបូជាច្រើនប្រភេទ ប្រៀបដូចផ្លូវដើរដែលប្រជាប់ដោយកម្រាលកែវមណីរ័តន៍ វិចិត្រដូចវិមានព្រហ្ម ឲ្យក្រាលអាសនៈដែលជាកប្បិយ ៥០០ ដែលមានតម្លៃកាត់ថ្លៃមិនបាន ក្នុងមហាមណ្ឌបនោះ សម្រាប់ភិក្ខុ ៥០០ រូប ឲ្យក្រាលអាសនៈព្រះថេរៈ បែរមុខទៅទិសខាងជើង បែរខ្នងទៅទិសខាងត្បូង ឲ្យក្រាលធម្មាសនៈដែលអង្គុយសម្តែងធម៌ ដែលគួរជាអាសនៈសម្រាប់ព្រះមានព្រះភាគ ត្រង់កណ្តាលមណ្ឌប បែរមុខទៅទិសខាងកើត ជាក់ផ្ទៃដែលមានជង្រចនាអំពីភ្នក់លើធម្មាសនៈនោះ ហើយផ្តៀងដល់ភិក្ខុសង្ឃឲ្យជ្រាបថា កិច្ចកម្មសម្រេចហើយ ។

ភិក្ខុទាំងឡាយ ពោលនឹងព្រះអានន្ទថា អាវុសោអានន្ទ ស្អែកនេះ ជាថ្ងៃប្រជុំសង្ឃ ខ្ញុំជាសេក្ខៈ មានកិច្ចដែលត្រូវធ្វើ ដោយហេតុនោះ ទើបអ្នកមិនគួរទៅប្រជុំ ចូរអ្នកកុំប្រមាទ ។ គ្រានោះ ព្រះអានន្ទត្រិះរិះថា ស្អែកនេះ ជាថ្ងៃប្រជុំ ការដែលអញជាសេក្ខៈទៅប្រជុំ មិនសមគួរឡើយ ដូច្នេះ ទើបព្យាយាមដោយកាយគតាសតិអស់រាត្រីជ័យ ក្នុងកាលទៀបភ្លឺ ទើបចុះអំពីទីចង្រ្កម ចូលទៅកាន់វិហារ ពិចារណាដល់កាយ បំណងនឹងសិងសម្រាក ។ ជើងទាំង ២ ផុតផែនដី សីសៈមិនទាន់ដល់ខ្នើយ ក្នុងចន្លោះនោះ ចិត្តក៏មិនប្រកាន់មាំ រួចផុតចាកអាសវៈទាំងឡាយ ។

ពិតហើយ ព្រះអានន្ទនេះ ព្យាយាមខាងក្រៅដោយការចង្រ្តម មិនអាចធ្វើគុណវិសេសឲ្យកើតបាន ទើបត្រិះរិះថា ព្រះមានព្រះភាគបានត្រាស់នឹងអញមិនមែនឬថា អានន្ទ អ្នកមានបុណ្យធ្វើទុកហើយ ចូរប្រកបព្យាយាមរឿយៗ អ្នកនឹងជាបុគ្គលមិនមានអាសវៈបានដោយឆាប់រួសរាន់ ធម្មតា ព្រះសម្ពុទ្ធទាំងឡាយត្រាស់មិនដែលខុស អាត្មាអញប្រារព្ធព្យាយាមពេក ដោយហេតុនោះ ទើបចិត្តប្រព្រឹត្តទៅក្នុងការរាយមាយ ណ្ហើយចុះ អញនឹងប្រកបព្យាយាមតែល្មមប្រមាណ ទើបចុះអំពីទីចង្រ្តម ឈរក្នុងទីលាងជើងៗ ហើយក៏ចូលវិហារ អង្គុយលើគ្រែ គិតនឹងសម្រាកបន្តិច ក៏ទម្រេតកាយលើគ្រែជើងទាំង ២ ផុតដី ក្បាលមិនទាន់ដល់ខ្នើយ ក្នុងចន្លោះនោះ ចិត្តមិនប្រកាន់មាំ ក៏ផុតចាកអាសវៈទាំងឡាយ ។ អរហត្តរបស់ព្រះថេរៈរៀរចាកឥរិយាបថទាំង ៤ ដោយហេតុនោះ កាលសួរថា ក្នុងព្រះសាសនានេះ ភិក្ខុអង្គណាមិនអង្គុយ មិនដេក មិនឈរ មិនដើរ សម្រេចអរហត្ត ក៏គួរធ្វើយថាគឺព្រះអានន្ទត្ថេរ ។

ក្នុងថ្ងៃទី ២ ភិក្ខុជាថេរៈទាំងឡាយឆាន់ភត្តាហារ ទុកជាក់ជាត្រចីវរហើយក៏ប្រជុំគ្នាក្នុងធម្មសភា ឯព្រះអានន្ទត្ថេរបំណងនឹងឲ្យសង្ឃដឹងការសម្រេចអរហត្តរបស់ខ្លួន ទើបមិនទៅព្រមជាមួយភិក្ខុទាំងឡាយៗ កាលអង្គុយលើអាសនៈដែលសមគួរវៀងៗ ខ្លួន ក៏អង្គុយវៀរអាសនៈរបស់ព្រះអានន្ទត្ថេរក្នុងពេលនោះ កាលព្រះថេរៈពួកខ្លះសួរថា នុ៎ះអាសនៈរបស់អ្នកណា ក៏មានសំឡេងឆ្លើយថា របស់ព្រះអានន្ទ សួរថា ព្រះអានន្ទទៅណា សម័យនោះ

ព្រះថេរៈត្រិះរិះថា ឥឡូវនេះ ជាកាលដែលអាត្មាអញគួរទៅ ។ ដូច្នេះ កាលសម្តែងអានុភាពរបស់ខ្លួន ទើបមុជចុះក្នុងផែនដី បង្ហាញខ្លួនលើអាសនៈនោះឯង អាចារ្យពួកខ្លះពោលថា មកតាមអាកាសក៏មាន ។

កាលព្រះអានន្ទអង្គុយស្រេចបាច់ ទើបព្រះមហាកស្សបត្ថេរប្រឹក្សានឹងភិក្ខុទាំងឡាយថា អាវុសោទាំងឡាយ យើងនឹងសង្គាយនាអ្វីមុន តើធម៌ ឬ វិនัយ ។

ភិក្ខុទាំងឡាយក្រាបថា បពិត្រមហាកស្សប ធម្មតាវិនัយជាអាយុរបស់សាសនា បើវិនัយតាំងនៅ សាសនាក៏ឈ្មោះថា តាំងនៅដែរ ព្រោះដូច្នោះ យើងនឹងសង្គាយនាវិនัយមុន ។ ព្រះថេរៈសួរថា ប្រគល់ឲ្យជាធុរៈដល់នរណា សង្គាយនាវិនัយហ្ន៎ ភិក្ខុទាំងឡាយក្រាបថា គឺព្រះឧបាលី ។ ព្រះថេរៈសួរជំទាស់ថា ព្រះអានន្ទមិនអាចឬ ភិក្ខុទាំងឡាយក្រាបថា មិនមែនមិនអាចទេ តែព្រះសម្មាសម្ពុទ្ធកាលគង់ព្រះជន្មនៅ អាស្រ័យការរៀនបរិយត្តិរបស់លោក ទើបទ្រង់ស្តាបនាព្រះឧបាលី ទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកទ្រទ្រង់វិនัយ ស្រេចនឹងឧបាលី ដូច្នេះ ព្រោះដូច្នោះ យើងនឹងសួរព្រះឧបាលិត្ថេរសង្គាយនាវិនัយ ។ បន្ទាប់អំពីនោះ ទើបព្រះថេរៈសន្ទុតដោយខ្លួនឯង ដើម្បីសួរវិនัយ ឯព្រះឧបាលិត្ថេរក៏សន្ទុតខ្លួន ដើម្បីឆ្លើយវិនัយក្នុងសេចក្តីនោះ មានបាលីដូច្នេះថា គ្រានោះ ព្រះមហាកស្សបត្ថេរផ្តៀងសង្ឃថា

សុណាតុ មេ អាវុសោ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ ឧបាលឹ វិនិយំ បុច្ឆេយ្យំ *អ្នកដ៏មានអាយុទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ បើ*

សង្ឃតិកម្មនេះ មានកាលសមគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរវិនយ នឹង ឧបាលី ។ សូម្បីព្រះឧបាលីក៏ផ្តៀងសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អាយស្មតា មហាកស្សបេន វិនយំ បុដ្ឋោ វិសជ្ជេយ្យំ *បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃតិកម្មនេះ មានកាលសមគួរដល់សង្ឃហើយ លោកម្ចាស់កស្សបត្រូវសួរព្រះវិនយចំពោះខ្ញុំ ខ្ញុំក៏ត្រូវដោះស្រាយក្នុងកាលឥឡូវនេះ ។*

ឯព្រះឧបាលីកាលសន្មតខ្លួន ដោយខ្លួនឯងយ៉ាងនេះហើយ ក៏ក្រោកចាកអាសនៈ ដណ្តប់ចីវរ ថ្វាយបង្គំភិក្ខុដែលជាថេរៈ ហើយអង្គុយលើធម្មាសនៈ ចាប់ផ្តើតក្តុក បន្ទាប់អំពីនោះ ទើបព្រះមហាកស្សបត្ថេរសួរវិនយទាំងអស់តាំងអំពីបឋមបារាជិកជាដើមទៅ ជាមួយនឹងព្រះឧបាលិត្ថេរ ។ ព្រះឧបាលិត្ថេរ ក៏ឆ្លើយ ភិក្ខុទាំងអស់ ៥០០ រូប ក៏សូធ្យព្រមៗ គ្នា តាំងអំពីបឋមបារាជិកសិក្ខាបទ ព្រមទាំងនិទានទៅ សូម្បីសិក្ខាបទក្រៅអំពីនោះ ក៏សូធ្យទាំងអស់ ព្រោះហេតុនោះ គប្បីកាន់យករឿងទាំងអស់តាមអដ្ឋកថាព្រះវិនយ ។ ព្រះឧបាលិត្ថេរកាលសង្គាយនាព្រះវិនយបិដកទាំងមូល ព្រមទាំងឧភតោវិភង្គ មួយអន្ទើដោយគម្ពីរខន្ធកៈ និងបរិវារ ដោយន័យនេះហើយ ក៏ជាក់ផ្តើតក្តុក ចុះអំពីធម្មាសនៈ ថ្វាយបង្គំភិក្ខុចាស់ ហើយអង្គុយលើអាសនៈ ដែលសមគួរដល់ខ្លួន ។

ឯព្រះមហាកស្សបត្ថេរកាលសង្គាយនាវិនយ ហើយបំណងនឹងសង្គាយនាព្រះធម៌ ទើបសួរភិក្ខុទាំងឡាយថា អ្នកទាំងឡាយ កាលនឹងសង្គាយនាធម៌

នឹងប្រគល់ធុរៈដល់អ្នកណា កិក្ខុទាំងឡាយប្រាប់ថា ជាធុរៈដល់ព្រះអានន្ទ គ្រានោះ ទើបព្រះមហាកស្សបផ្តៀងសង្ឃថា

សុណាតុ មេ អាវុសោ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អានន្ទំ ធម្មំ បុច្ឆេយ្យំ *បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្គីតិកម្ម មានកាលគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរនូវធម៌ចំពោះអានន្ទដ៏មានអាយុ ។ គ្រានោះ ព្រះអានន្ទក៏ផ្តៀងសង្ឃថា*

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អាយស្មតា មហាកស្សបេន ធម្មំ បុដ្ឋោ វិសជ្ជេយ្យំ *បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្គីតិកម្មមានកាលគួរដល់សង្ឃហើយ លោកម្ចាស់មហាកស្សបនឹងសួរធម៌ចំពោះខ្ញុំ ខ្ញុំគប្បីឆ្លើយក្នុងកាលឥឡូវនេះ ដូច្នេះ ។*

គ្រានោះ ព្រះអានន្ទក្រោកចាកអាសនៈ ដណ្តប់ចីវរឆៀងស្មាម្ខាង ថ្វាយបង្គំកិក្ខុចាស់ ហើយក៏អង្គុយលើធម្មាសនៈ កាន់ផ្ងើតភ្លុក ។ លំដាប់នោះ ព្រះមហាកស្សបត្តេរសួរធម៌ដល់ព្រះអានន្ទថា អានន្ទ ព្រហ្មជាលសូត្រ ព្រះមានព្រះភាគត្រាស់ក្នុងទីណា ។ ឆ្លើយថា ត្រាស់ក្នុងដំណាក់ ក្នុងព្រះរាជ-ឧទ្យាន ឈ្មោះអម្ពលដ្ឋិកា ដែលនៅចន្លោះក្រុងរាជគ្រឹះ និងស្រុកនាលន្ទ ។ សួរថា ទ្រង់ប្រារព្ធអ្នកណា ។ ឆ្លើយថា ទ្រង់ប្រារព្ធសុប្បិយបរិព្វាជក និងព្រហ្មទត្តមាណព ។ គ្រានោះ ព្រះមហាកស្សបសួរព្រះអានន្ទដល់និទានៃព្រហ្មជាលសូត្រ សួរដល់បុគ្គល ។ សួរថា អានន្ទ សាមញ្ញផលសូត្រ ទ្រង់ត្រាស់ក្នុងទីណា ។ ឆ្លើយថា ត្រង់ចម្ការស្វាយរបស់ពេទ្យជីវក ក្រុង

រាជគ្រឹះ ។ សួរថា ត្រាស់ជាមួយអ្នកណា ។ ឆ្លើយថា ជាមួយព្រះបាទ អជាតសត្តុវេទេហីបុត្រ ។ លំដាប់នោះ ទើបព្រះមហាកស្សបសួរព្រះអានន្ទ ដល់និទាននៃសាមញ្ញផលសូត្រផង សួរដល់បុគ្គលផង ។ ព្រះមហាកស្សប សួរទាំង ៥ និកាយ ដោយឧបាយនេះឯង ។ ព្រះអានន្ទត្រូវសួរហើយ សួរទៀត ក៏ឆ្លើយបានទាំងអស់ បឋមមហាសង្គីតិជំបូងនេះ ព្រះថេរៈ ៥០០ រូបនាំគ្នាធ្វើ ។ ដូចដែលលោកពោលថា

សតេហិ បញ្ចហិ កតា តេន បញ្ចសតានិ ច

ថេរេហេវ កតត្តា ច ថេរិកាតិ បវុច្ចតិ ។

បឋមសង្គីតិ កាលធ្វើសង្គាយនាធំគ្រាជំបូង ដែលព្រះថេរៈ ៥០០ រូបនាំគ្នាធ្វើ ដោយហេតុនោះ ទើបលោកហៅថា **បញ្ចសតា** *និងព្រោះភិក្ខុទាំងនោះ សុទ្ធតែជាព្រះថេរៈទាំងអស់ ទើបហៅថា* **ថេរិកា** *គឺលទ្ធិថេរវាទ ។*

កាលបឋមមហាសង្គីតិនេះកំពុងប្រព្រឹត្តទៅ កាលព្រះអានន្ទ ដែលព្រះមហាកស្សប កាលសួរគម្ពីរទីឃនិកាយ និងគម្ពីរមជ្ឈិមនិកាយជាដើមអស់ហើយ កាលនឹងសួរគម្ពីរខុទ្ទកនិកាយតាមលំដាប់ ក្នុងចុងពាក្យដែលលោកសួរជាដើមយ៉ាងនេះថា អាវុសោ អានន្ទ មង្គលសូត្រ ព្រះមានព្រះភាគទ្រង់ត្រាស់ក្នុងទីណា ដូច្នេះ ទើបសួរដល់និទានក្នុងពាក្យនេះថា សួរទាំងនិទាន សួរទាំងបុគ្គល ។ ព្រះអានន្ទបំណងនឹងពោលនិទាននោះឲ្យពិស្តារថា ត្រាស់ដូចម្តេច អ្នកណាស្តាប់មក ស្តាប់ក្នុងកាលណា និងអ្នកណាពោល ពោលទីណា ពោលដល់អ្នកណា នឹងពោលសេចក្តីនោះឲ្យអស់ កាលនឹងសម្តែង

សេចក្តីនោះថា ត្រាស់យ៉ាងនេះ ខ្ញុំស្តាប់មក ស្តាប់មកសម័យមួយ ព្រះមានព្រះភាគត្រាស់ ត្រាស់ត្រង់ក្រុងសាវត្ថី ត្រាស់ដល់ទេវតា ដូច្នេះ ទើបពោលថា **ឯវម្មេ សុតំ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។បេ។ ភគវន្តំ គាថាយ អជ្ឈភាសិ ។** *ពាក្យនេះព្រះអានន្ទពោលយ៉ាងនេះ ។ ឯពាក្យនោះ គប្បីជ្រាបថា លោកពោលក្នុងកាលធ្វើបឋមមហាសង្គីតិ ។*

ឥឡូវនេះ និងអធិប្បាយក្នុងសេចក្តីនេះថា ត្រាស់ព្រោះហេតុអ្វី ។ ព្រោះហេតុដែលព្រះមហាកស្សបសួរដល់និទាន ដូច្នោះ ទើបលោកពោលនិទាននោះឲ្យពិស្តារតាំងអំពីដើម ម្យ៉ាងទៀត ព្រោះទេវតាខ្លះឃើញព្រះអានន្ទអង្គុយលើធម្មាសនៈ ចោមរោមដោយគណៈដែលជំនាញ ទើបកើតចិត្តគិតថា ព្រះអានន្ទនេះ ជាវេទេហមុនី សូម្បីដោយប្រក្រតី រាប់ត្រឹមតែនៅក្នុងសក្យត្រកូល ជាទាយាទរបស់ព្រះមានព្រះភាគ តែព្រះមានព្រះភាគទ្រង់សរសើរទុកក្នុងតំណែងឯតទគ្គៈដល់ទៅ ៥ ស្ថាន ជាអ្នកប្រកបដោយអច្ឆរិយអព្ភូតធម៌ ៤ ប្រការ ជាទីស្រឡាញ់ពេញចិត្តរបស់បរិស័ទ ៤ ឥឡូវនេះ ប្រហែលជាទាយាទដោយធម៌របស់ព្រះមានព្រះភាគ កើតជាពុទ្ធៈ ។

ដូច្នោះ ព្រះអានន្ទដឹងទៅ ដល់ការត្រិះរិះផ្លូវចិត្តរបស់ទេវតាទាំងនោះដោយចិត្តរបស់ខ្លួន អត់ធន់នឹងការសរសើរគុណដែលមិនមានពិតនោះមិនបាន ដើម្បីសម្តែងភាវៈដែលខ្លួនត្រឹមតែជាសាវក ទើបពោលថា **ឯវម្មេ សុតំ ឯកំ សមយំ ភគវា ។បេ។ អជ្ឈភាសិ ។** *ក្នុងចន្លោះនេះ ព្រះអរហន្ត ៥០០*

រូប និងទេវតាច្រើនពាន់ ក៏សរសើរព្រះអានន្ទថា សាធុ សាធុ មហាប្រឹថពី ក៏កម្រើកញាប់ញ័រ ភ្ជៀងផ្ការាច្រើនប្រភេទក៏រោយចុះមកអំពីអាកាស ការអស្ចារ្យ ដទៃក៏ប្រាកដច្រើន ទេវតាជាច្រើនកើតនូវសេចក្តីសង្វេគថា ពាក្យណា ខ្ញុំ ស្តាប់មកចំពោះព្រះភក្ត្រារបស់ព្រះមានព្រះភាគ ពាក្យនោះ សូម្បីហេតុ-ការណ៍កន្ជងផុតខ្សែភ្នែកមកហើយ ក៏មកកើតបាន ។ ពាក្យនេះ ព្រះអានន្ទ ពោលក្នុងកាលធ្វើបឋមមហាសង្គីតិ គប្បីជ្រាបថា លោកពោលព្រោះហេតុ នេះ ដោយប្រការដូច្នេះ ។ ដោយកិច្ចពណ៌នាមក មានប្រមាណប៉ុណ្ណេះ ក៏ ឈ្មោះថា ប្រកាសអត្ថកន្ជះគាថានេះថា **រុត្តំ យេន យធា យស្មា ចេតំ រត្វា ឥមំ វិធឹ** ពោលវិធីនេះថា បុគ្គលណាពោល ពោលក្នុងកាលណា ពោល ព្រោះហេតុអ្វី ។

ពណ៌នាចាឋៈថា ឯវំ ជាដើម

ដើម្បីប្រកាសភាពដែលរូបរឹតដោយមាតិកាជាដើមយ៉ាងនេះថា **ឯវមិច្ចា-ធិចាជស្ស អត្ថំ នានប្បការតោ** សេចក្តីនៃបាឋៈថា **ឯវំ** ជាដើម ដោយ ប្រការផ្សេងៗ ឥឡូវនេះ សូមអធិប្បាយដូច្នេះ សព្ទថា **ឯវំ** នេះ គប្បី យើញថា

ប្រើក្នុងអត្ថទាំងឡាយ មានអត្ថជាដើមថា ឧបមា គឺប្រៀបធៀប ឧបទេស គឺណែនាំ សម្បហំសនៈ គឺលើកសរសើរ គរហណៈ គឺតិះដៀល វចនសម្បដិគ្គហណៈ គឺទទួលពាក្យ អាការ គឺអាការ និទស្សនៈ គឺឧទា-ហរណ៍ និងអវធារណៈ គឺរារាំងសេចក្តីដទៃ ។

ពិតហើយ **ឯវំ** *សព្ទនេះ ប្រើក្នុងការប្រៀបធៀប ដូចក្នុងប្រយោគជាដើមថា* **ឯវំ ជាតេន មច្ចេន កត្តព្ពំ កុសលំ ពហុំ** *កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើនយ៉ាងនោះ ដូច្នេះ ។*

ប្រើក្នុងអត្ថថា ណែនាំ ដូចក្នុងប្រយោគជាដើមថា **ឯវន្តេ អភិក្កមិតព្ពំ ឯវំ បដិក្កមិតព្ពំ** *អ្នកត្រូវឈានដើរទៅមុខយ៉ាងនេះ អ្នកត្រូវថយក្រោយយ៉ាងនេះ ដូច្នេះ ។*

ប្រើក្នុងអត្ថថា លើកសរសើរ ដូចក្នុងប្រយោគជាដើមថា **ឯវមេតំ ភគវា ឯវមេតំ សុគត** *បពិត្រព្រះដ៏មានព្រះភាគ ហេតុនុ៎ះ យ៉ាងនេះហើយ បពិត្រព្រះសុគត ហេតុនុ៎ះ យ៉ាងនេះហើយ ដូច្នេះ ។*

ប្រើក្នុងអត្ថថា តិះដៀល ដូចក្នុងប្រយោគជាដើមថា **ឯវមេវ បនាយំ វសលី យស្មឹ វា តស្មឹ វា តស្ស មុណ្ឌកស្ស វណ្ណំ ភាសតិ** *មេចង្រៃនេះធ្លាប់តែអីចឹងៗ ហ៊ានពោលសរសើរសមណៈត្រង់ឱលក្នុងទីផ្តេសផ្តាស ដូច្នេះ ។*

ប្រើក្នុងអត្ថថា ទទួលពាក្យ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ** *ភិក្ខុទទួលពាក្យនៃព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ដូច្នេះ ។*

ប្រើក្នុងអត្ថថា អាការ ដូចក្នុងប្រយោគជាដើមថា **ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ** *ខ្ញុំបានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយក៏យ៉ាងនោះដែរ ដូច្នេះ ។*

ប្រើក្នុងអត្ថថា ឧទាហរណ៍ ដូចក្នុងប្រយោគជាដើមថា **ឯវំ ភទ្ទំ មាណវក**

យេន សមណោ អានន្ទោ ។បេ។ អនុកម្បំ ឧបាទាយ *ម្នាលមាណព ឯងចូរមកនេះ ឯងចូរទៅរកព្រះសមណៈឈ្មោះអានន្ទ លុះចូលទៅជល់ហើយ ចូរសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន មានកម្លាំងនៅជាសុខសប្បាយ និងព្រះសមណៈ ឈ្មោះអានន្ទ តាមពាក្យរបស់អញថា សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ ផ្តាំឲ្យសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន និងកម្លាំង និងអាការនៅជាសុខសប្បាយ ចំពោះព្រះអានន្ទដ៏ចម្រើន រួចហើយឯងចូរនិមន្តថា សូមលោកម្ចាស់អានន្ទ អាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តមកកាន់ទីលំនៅរបស់សុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ឲ្យទាន ដូច្នេះ ។*

ប្រើក្នុងអត្ថថា ភាវាំងសេចក្តីដទៃ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **តំ កិំ មញ្ញថ កាលាមា ។បេ។ ឯវំ នោ ឯត្ថ ហោតិ** *ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្តេច ធម៌នេះជាកុសល ឬជាអកុសល ។ ជាអកុសល ព្រះអង្គ ។ ជាធម៌ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ ។ ជាធម៌ប្រកបដោយទោស ព្រះអង្គ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬអ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ព្រះអង្គ ។ ធម៌ទាំងនេះដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ឬមិនប្រព្រឹត្តទៅទេ ឬក៏ក្នុងដំណើរនោះ ដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះ ដែលបុគ្គលសមាទានបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ*

យើងខ្ញុំក៏យល់ក្នុងដំណើរនោះដូច្នោះដែរ ដូច្នេះ ។

តែក្នុងទីនេះ **ឃរំ** *សព្ទ គប្បីឃើញថា ប្រើក្នុងអត្ថ គឺអាការ ឧទាហរណ៍ និងរាងសេចក្តីដទៃ ។*

ក្នុងអត្ថទាំង ៣ នោះ ព្រះថេរៈសម្តែងអត្ថនេះ ដោយ **ឃរំ** *សព្ទ ដែលមានអត្ថជាអាការថា ព្រះតម្រាស់របស់ព្រះមានព្រះភាគអង្គនោះ ល្អិតដោយនយផ្សេងៗ ដែលកើតឡើង ដោយច្រើនអធ្យាស្រ័យសម្បុរដោយអត្ថ និងព្យញ្ជនៈ មានបាដិហារ្យផ្សេងៗ ជ្រាលជ្រៅដោយធម៌ អត្ថ ទេសនា និងបដិវេធ មកប៉ះខ្ញុំបាទសោតៈ ល្មមសមគួរដល់កាសាវៀងៗ ខ្លួនរបស់សព្វសត្វទាំងឡាយ អ្នកណាអាចដឹងបាន ដោយប្រការទាំងពួង តែខ្ញុំសូម្បីប្រើកម្លាំងទាំងអស់ឲ្យកើតការចង់ស្តាប់ បានស្តាប់មកយ៉ាងនេះ គឺខ្ញុំក៏បានស្តាប់មកហើយ ដោយអាការណាមួយ ។*

ដោយ **ឃរំ** *សព្ទ ដែលមានអត្ថជាឧទាហរណ៍ ព្រះថេរៈកាលដោះខ្លួនថា ខ្ញុំមិនមែនព្រះសយម្ភូ ព្រះសូត្រនេះ ខ្ញុំមិនបានធ្វើឲ្យជាក់ច្បាស់ ទើបសម្តែងព្រះសូត្រទាំងមូល ដែលគួរពោលក្នុងឥឡូវនេះថា* **ឃវម្មេ សុតំ** *គឺខ្ញុំបានស្តាប់មកយ៉ាងនេះ ។*

ដោយ **ឃរំ** *សព្ទ ដែលមានសព្ទជា រាងសេចក្តីដទៃ ព្រះថេរៈកាលសម្តែងកម្លាំង គឺការចង់ចាំរបស់ខ្លួន ដែលគួរដល់ការៈ ដែលព្រះមានព្រះភាគទ្រង់សរសើរយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អានន្ទ ជាកំពូលសាវ័ករបស់តថាគតដែលជាពហុស្សូត មានគតិ មានសតិ មានធិតិ ពុទ្ធុប្បដ្ឋាក ដូច្នេះ*

រមែងឲ្យកើតនូវការចង់ស្តាប់ដល់សត្វទាំងឡាយ ដ្បិតថា ខ្ញុំស្តាប់មកហើយ យ៉ាងនេះ ពាក្យនោះ មិនខ្វះ មិនលើស ទោះជាដោយអត្ថ ឬព្យញ្ជនៈ បណ្ឌិតគប្បីឃើញយ៉ាងនេះប៉ុណ្ណោះ មិនគប្បីឃើញដទៃឡើយ ។

អធិប្បាយសព្ទថា មេ

មានអត្ថ ៣ យ៉ាង ។ ពិតហើយ **មេ** *សព្ទ មានអត្ថថា* **មយា** *ដែលខ្ញុំ ដូចក្នុងប្រយោគជាដើមថា* **គាថាភិគីតម្មេអភោជនេយ្យំ** *ភោជនដែលតថាគតពោលហើយដោយគាថា (ច្រៀង) ជាវត្ថុមិនគួរដល់ការបរិភោគទេ ។*

មានអត្ថថា **មយ្ហំ** *គឺដល់ខ្ញុំ ដូចក្នុងប្រយោគជាដើមថា* **សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ** *បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ សូមអង្វរ សូមព្រះមានព្រះភាគសម្តែងធម៌ដោយសង្ខេបដល់ខ្ញុំ ។*

មានអត្ថថា **មម** *គឺរបស់ខ្ញុំ ដូចក្នុងប្រយោគជាដើមថា* **ធម្មធាយាទា មេ ភិក្ខវេ ភវថ** *ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកធម៌របស់តថាគត ជាមត៌កចុះ តែក្នុងទីនេះ* **មេ** *សព្ទ រមែងពាល់ត្រូវក្នុងអត្ថទាំង ២ គឺ* **មេ សុតំ** *ប្រែថា ដែលខ្ញុំស្តាប់មក និង* **មម សុតំ** *ការស្តាប់របស់ខ្ញុំ ។*

អធិប្បាយបទថា សុតំ

សុត *សព្ទនេះ មានឧបសគ្គ និងមិនមានឧបសគ្គ ផ្សេងគ្នាដោយច្រើនអត្ថ ដូចជាមានអត្ថថា ទៅ ជ្រាកដ តម្រេក សន្សំ ខ្វល់ខ្វាយ សំឡេងដែលជ្រាកដតាមសោតៈ និងជឿតាមសោតទ្វារជាដើម ។ ពិតហើយ* **សុត** *សព្ទនោះ មានអត្ថថា ទៅ ដូចក្នុងប្រយោគជាដើមថា* **សេឆាយ បសុតោ** *ទៅ*

ហើយដោយសេនា ។

មានអត្ថថា ជ្រុកជ ដូចក្នុងប្រយោគជាដើមថា **សុតធម្មស្ស បស្សតោ** *បុគ្គលមានធម៌ស្តាប់ហើយ បានឃើញច្បាស់ ។*

មានអត្ថថា តម្រេក ដូចក្នុងប្រយោគជាដើមថា **អវស្សុតា អវស្សុ-តស្ស** *(សុន្ទរីនន្ទាជាម្ចាស់) មានតម្រេក មិនគួរនឹងត្រេកអរឲ្យបុរស បុគ្គលដែលមានតម្រេក ... ដូច្នេះ ។*

មានអត្ថថា សន្សំ ដូចក្នុងប្រយោគជាដើមថា **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ** *បុណ្យ ឈ្មោះថា បានសន្សំ មិនមែនតិចឡើយ ។*

មានអត្ថថា ទ្រុល់ទ្រាយ ដូចក្នុងប្រយោគជាដើមថា **យេ ឈានបសុតា ធីរា** *អ្នកប្រាជ្ញពួកណា ជាអ្នកប្រកបរឿយៗ (ទ្រុល់ទ្រាយ) ក្នុងឈាន ។*

មានអត្ថថា សំឡែងដែលដឹងតាមត្រចៀក ដូចក្នុងប្រយោគជាដើមថា **ឯដ្ឋំ សុតំ មុតំ** *រូបដែលឃើញ សំឡែងដែលបានឮ អារម្មណ៍ដែលដឹង ។*

មានអត្ថថា ដឹងតាមសោតទ្វារ ដូចក្នុងប្រយោគជាដើមថា **សុតធរោ សុតសន្និចយោ** *(ភិក្ខុក្នុងសាសនានេះ) ជាអ្នកទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ។*

តែក្នុងទីនេះ សព្ទថា **សុត** *ព្រោះអត្ថថា ចូលទៅទ្រទ្រង់ ឬការទ្រទ្រង់ដោយវិថីវិញ្ញាណ មានសោតវិញ្ញាណជាប្រធាន ក្នុងពាក្យនោះ កាលណា* **មេ** *សព្ទ មានសេចក្តីថា* **មយា** *ប្រែថា ដែលខ្ញុំកាលនោះ ប្រកបសេចក្តីថា ដែលខ្ញុំស្តាប់មកហើយ គឺទ្រទ្រង់ចាំហើយដោយវិថីវិញ្ញាណ ដែលមាន*

សោតវិញ្ញាណជាប្រធានយ៉ាងនេះ ។ កាលណា **មេ** *សព្ទ មានសេចក្តីថា* **មម** *គឺរបស់ខ្ញុំ កាលនោះក៏ជ្រាកដសេចក្តីថា ការស្តាប់របស់ខ្ញុំ គឺការទ្រទ្រង់ចាំដោយវិថីវិញ្ញាណ ដែលមានសោតវិញ្ញាណជាប្រធាន ។*

បណ្តាបទទាំង ៣ នោះ ដូចពណ៌នាមកនេះ បទថា **ឃរំ** *ជាបទចង្អុលដល់កិច្ច គឺនាទីរបស់សោតវិញ្ញាណ ។ បទថា* **មយា** *គឺបទដែលសម្តែងដល់បុគ្គលដែលប្រកបសោតវិញ្ញាណដែលពោលហើយ ។ បទថា* **សុតំ** *ជាបទដែលចង្អុលដល់ការកាន់យកមិនខ្វះ មិនលើស និងមិនវិបរិត ព្រោះបដិ-សេធការៈ គឺការមិនបានស្តាប់ ។*

នយម្យ៉ាងទៀត បទថា **ឃរំ** *ជាបទសម្តែងដល់ការៈដែលចិត្ត មានចិត្តគិតនឹងស្តាប់ជាដើម ប្រព្រឹត្តទៅក្នុងអារម្មណ៍ដោយប្រការផ្សេងៗ ។ បទថា* **មេ** *ជាបទសម្តែងដល់ខ្លួន ។ បទថា* **សុតំ** *ជាបទសម្តែងដល់ធម៌ ។*

នយម្យ៉ាងទៀត បទថា **ឃរំ** *ជាបទចង្អុលបង្ហាញធម៌ដែលគួរចង្អុលបង្ហាញ ។ បទថា* **មេ** *ជាបទចង្អុលបង្ហាញតួបុគ្គល ។ បទថា* **សុតំ** *ជាបទចង្អុលបង្ហាញកិច្ចរបស់បុគ្គល ។*

នយម្យ៉ាងទៀត បទថា **ឃរំ** *អធិប្បាយដល់ប្រការផ្សេងៗ នៃវិថីចិត្តទាំងឡាយ ជាអាការប្បញ្ញត្តិ ។ សព្ទថា* **មេ** *អធិប្បាយដល់អ្នកធ្វើ ។ សព្ទថា* **សុតំ** *អធិប្បាយដល់វិសយ ។*

ម្យ៉ាងទៀត បទថា **ឃរំ** *អធិប្បាយដល់កិច្ចរបស់បុគ្គល ។ សព្ទថា* **សុតំ** *អធិប្បាយដល់កិច្ចរបស់វិញ្ញាណ ។ សព្ទថា* **មេ** *អធិប្បាយដល់បុគ្គល*

ដែលប្រកបដោយកិច្ចទាំង ២ ។

នយមួ៉ាងទៀត បទថា **ឃរំ** *សម្តែងដល់ការៈ ។ សព្ទថា* **មេ** *សម្តែងដល់បុគ្គល ។ សព្ទថា* **សុតំ** *សម្តែងដល់កិច្ចរបស់បុគ្គលនោះ ។*

ក្នុងពាក្យទាំងនោះ ពាក្យថា **ឃរំ** *និងពាក្យថា* **មេ** *ជាវិជ្ជមានប្បញ្ញត្តិ ព្រោះជាសច្ចិកត្ថបរមត្ថ ។ ពាក្យថា* **សុតំ** *ជាវិជ្ជមានប្បញ្ញត្តិ ។*

នយមួ៉ាងទៀត បទថា **ឃរំ** *និង* **មេ** *ឈ្មោះថា ឧបាទាប្បញ្ញត្តិ ព្រោះពោលអាស្រ័យអារម្មណ៍នោះៗ ។ ពាក្យថា* **សុតំ** *ឈ្មោះថា ឧបនិធាប្បញ្ញត្តិ ព្រោះពោលអាងអារម្មណ៍ មានអារម្មណ៍ដែលឃើញហើយជាដើម ។*

ក្នុងពាក្យទាំង ៣ នោះ ព្រះថេរៈសម្តែងមិនភ័ន្តច្រឡំ ដោយពាក្យថា **ឃរំ។** *ការមិនវង្វេងរឿងដែលស្តាប់មកដោយពាក្យថា* **សុតំ** *ម៉្យាងទៀត ព្រះថេរៈសម្តែងការជាក់ចិត្តដោយឧបាយ ដោយពាក្យថា* **ឃរំ** *ព្រោះមិនមានការចាក់ធ្លុះដោយប្រការផ្សេងៗ សម្រាប់បុគ្គលដែលជាក់ចិត្តដោយមិនមែនឧបាយ សម្តែងការមិនរាយមាយដោយពាក្យថា* **សុតំ** *ព្រោះមិនមានការស្តាប់ សម្រាប់បុគ្គលដែលមានចិត្តរាយមាយ ។ ពិតហើយ បុគ្គលដែលមានចិត្តរាយមាយ សូម្បីលោកពោលគ្រប់គ្រាន់គ្រប់យ៉ាង ក៏នឹងពោលថា ខ្ញុំមិនបានឮ សូមនិយាយម្តងទៀតចុះ ។ ក្នុងសេចក្តីនេះ បុគ្គលនឹងឲ្យសម្រេចការតាំងខ្លួនប្រពៃ និងភាពជាអ្នកធ្វើបុណ្យទុកមុន ក៏ដោយការជាក់ចិត្តដោយឧបាយ និងឲ្យសម្រេចការស្តាប់ធម៌របស់សប្បុរស និងការពឹងពាក់អាស្រ័យសប្បុរសដោយការមិនរាយមាយ ព្រះថេរៈសម្តែងការដល់ព្រម ដោយចក្រនៃធម៌ ២*

ចំណុចខាងក្រោយរបស់ខ្លួន ដោយអាការដ៏ល្អ ដោយបទថា **ឯវំ** នេះ ។ សម្តែងការដល់ព្រមដោយចក្រធម៌ ២ ខាងដើម ដោយសេចក្តីព្យាយាមស្តាប់ ដោយបទថា **សុតំ** ។ ម្យ៉ាងទៀត ព្រះថេរៈសម្តែងការបរិសុទ្ធនៃអធ្យាស្រ័យ និងបរិសុទ្ធនៃការព្យាយាមយ៉ាងនោះ គឺសម្តែងការឈ្វាសវៃក្នុងអធិគម ដោយការបរិសុទ្ធនៃអធ្យាស្រ័យផង សម្តែងការឈ្វាសក្នុងបរិយត្តិផង ដោយភាពបរិសុទ្ធនៃសេចក្តីព្យាយាម ។

ម្យ៉ាងទៀត ព្រះថេរៈសម្តែងការដល់ព្រមដោយអត្តប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទារបស់ខ្លួន ដោយពាក្យដែលសម្តែងបដិវេធ មានប្រការផ្សេងៗ ដោយពាក្យថា **ឯវំ** នេះ ។ សម្តែងការដល់ព្រម ដោយធម្មប្បដិ-សម្ភិទា និងនិរុត្តិប្បដិសម្ភិទា ដោយពាក្យដែលសម្តែងបដិវេធ មានដោយប្រការដែលគួរស្តាប់ ដោយពាក្យថា **សុតំ** នេះ ម្យ៉ាងទៀត ព្រះថេរៈកាលពោលពាក្យដែលសម្តែងដល់ការជាក់ចិត្តដោយឧបាយនេះ ក៏ប្រកាសឲ្យដឹងថា ធម៌ទាំងនេះ ខ្ញុំសម្លឹងដោយចិត្ត ហើយចាក់ធ្លុះដោយទិដ្ឋិ ដោយពាក្យថា **ឯវំ** ។ កាលពោលពាក្យដែលសម្តែងដល់ការព្យាយាមស្តាប់នេះ ក៏ប្រកាសឲ្យគេដឹងថា ធម៌ដ៏ច្រើន ខ្ញុំស្តាប់ហើយ ទ្រទ្រង់ចាំហើយ វត់មាត់ហើយ ដោយពាក្យថា **សុតំ** ។ ដើម្បីសម្តែងការបរិបូណ៌នៃអត្ថ និងព្យញ្ជនៈ ឲ្យកើតការអើពើដើម្បីស្តាប់ដោយពាក្យទាំង ២ នេះ ។

ម្យ៉ាងទៀត ព្រះអានន្ទ មិនតាំងធម៌ដែលព្រះតថាគតទ្រង់ប្រកាសហើយដើម្បីខ្លួន កន្ទងនូវភូមិរបស់អសប្បុរស កាលប្តេជ្ញាភាពជាសាវក ទើបឈាន

ចុះកាន់កូមិរបស់សប្បុរស ដោយពាក្យទាំងអស់ថា **ឯវំ មេ សុតំ** *នេះ ។ ម្យ៉ាងទៀត ព្រះថេរៈ ឈ្មោះថា លើកចិត្តចាកអស្សទ្ធម្ម តាំងចិត្តទុកក្នុងព្រះសទ្ធម្ម ។ ម្យ៉ាងទៀត កាលសម្តែងថា ព្រះតម្រាស់របស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ខ្ញុំស្តាប់មកហើយដោយយកចិត្តទុកជាក់ ឈ្មោះថា ដោះនូវខ្លួន មានព្រះសាស្តាជាបន្ទាល់ ជិតស្និទ្ធនឹងព្រះពុទ្ធតម្រាស់ តាំងបែបផែននៃធម៌ ។*

ម្យ៉ាងទៀត ព្រះថេរៈមិនព្រមទទួលពាក្យថា **ឯវំ មេ សុតំ** *ខ្លួនធ្វើឲ្យកើតឡើង កាលបើកនូវការស្តាប់មកមុនបុគ្គលណាទាំងអស់ ទើបគួរជ្រាបថា លោក ឈ្មោះថា ទម្លាយនូវការមិនជឿ ធ្វើឲ្យកើតសទ្ធាសម្បទា ការដល់ព្រមដោយការជឿក្នុងព្រះធម៌នេះ ដល់ពពួកទេវតា និងមនុស្សថា ព្រះតម្រាស់នេះ ខ្ញុំទទួលមកចំពោះព្រះភក្ត្រៈរបស់ព្រះមានព្រះភាគអង្គនោះ ដែលជាអ្នកភ្ញៀវក្នុងដោយចតុវេសារជ្ជញ្ញាណ ជាអ្នកទ្រទ្រង់នូវកម្លាំង ១០ តាំងនៅក្នុងតំណែងដ៏ឧត្តម ជាអ្នកបន្ទឺសីហនាទ ជាអ្នកទ្រទ្រង់នូវកំពូលរបស់សព្វសត្វ ទ្រង់ជាធំក្នុងធម៌ ទ្រង់ជាស្តេចនៃធម៌ ទ្រង់ជាអធិបតីនៃធម៌ ទ្រង់មានធម៌ជាទីពឹងអាស្រ័យ ទ្រង់បង្វិលនូវចក្រដ៏ប្រសើរ គឺសទ្ធម្ម ទ្រង់ជាព្រះសម្មាសម្ពុទ្ធត្រាស់ដឹងប្រពៃ ដោយព្រះអង្គឯង ក្នុងបទព្រះតម្រាស់នោះមិនគួរធ្វើសេចក្តីសង្ស័យអល់អែកក្នុងអត្ថ ឬធម៌ បទ ឬព្យញ្ជនៈឡើយ ក្នុងសេចក្តីនេះមានពាក្យពោលថា*

វិនាសយតិ អសទ្ធិយំ សទ្ធំ វឌ្ឍតិ សាសនេ

ឯវម្មេ សុតមិច្ចេវំ វាទំ គោតមសាវកោ។

ព្រះអានន្ទ សាវ័ករបស់ព្រះគោតម កាលពោលពាក្យថា **ឯវម្មេ សុតំ** *ឈ្មោះថា ទម្លាយអសទ្ធិយ គឺការមិនជឿ ដើម្បីបណ្តុះនូវសទ្ធាក្នុងសាសនា ។*

អធិប្បាយបទថា ឯកំ-សមយំ

សព្ទថា **ឯកំ** *សម្តែងការកំណត់ចំនួន សព្ទថា* **សមយំ** *សម្តែងកាលដែលកំណត់ ។ ពីរពាក្យថា* **ឯកំ សមយំ** *សម្តែងកាលមិនពិតប្រាកដ ។ ក្នុងពាក្យនោះ* **សមយ** *សព្ទ មានអត្ថថា ព្រមព្រៀង ខណៈ កាល ប្រជុំ ហេតុ លទ្ធិ បានចំពោះ លះបង់ និងចាក់ផ្លុះ ។*

ពិតហើយ **សមយ** *សព្ទនោះ មានអត្ថថា ព្រមព្រៀង ដូចក្នុងប្រយោគជាដើមថា* **អប្បេវ នាម ស្វេបិ ឧបសង្កមេយ្យាម កាលញ្ច សមយញ្ច ឧចាឧាយ** *បើដូច្នោះ ចាំយើងពិចារណានូវកាល និងសម័យ (កាលព្រមព្រៀង) សិនហើយ សឹមទៅក្នុងថ្ងៃស្អែក ។*

មានអត្ថថា ខណៈ ដូចក្នុងប្រយោគជាដើមថា **អយំ ភិក្ខវេ ឯកោ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ** *ម្នាលភិក្ខុទាំងឡាយ នេះជាខណៈ និងសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យតែមួយ ដូច្នេះ ។*

មានអត្ថថា កាល ដូចក្នុងប្រយោគជាដើមថា **ឧណ្ហសមយោ បរិឡាហសមយោ** *សម័យក្តៅ សម័យ (កាល) ស្រុះស្រាប់ ដូច្នេះ ។*

មានអត្ថថា ប្រជុំ ដូចក្នុងប្រយោគជាដើមថា **មហាសមយោ បវនស្មឹ** *ថ្ងៃនេះជាថ្ងៃប្រជុំធំ ក្នុងជង្រៃធំ ។*

មានអត្ថថា ហេតុ ដូចក្នុងប្រយោគជាដើមថា **សមយោបិ ខោ តេ ភទ្ទាលិ ។បេ។ សមយោ អប្បដិវិទ្ធោ អហោសិ ។** *ម្នាលភទ្ទាលិ អ្នកមិនបានដឹងហេតុថា ព្រះមានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី តែព្រះមានព្រះភាគ គង់ដឹងអាត្មាអញថា ភិក្ខុឈ្មោះភទ្ទាលិ មិនបានបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តាដូច្នេះឡើយ ម្នាលភទ្ទាលិ នេះឯងជា* **ហេតុ** *ដែលអ្នកមិនបានដឹង ។*

មានអត្ថថា លទ្ធិ ដូចក្នុងប្រយោគជាដើមថា **តេន ខោ បន សមយេន ឧគ្គាហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ សមយប្បវាទកេ តិណ្ឌុកាចីរេ ឯកសាលកេ មល្លិកាយ អារាមេ បដិវសតិ** *សម័យនោះឯង បរិព្វាជកឈ្មោះឧគ្គាហមានៈ ជាសមណមុណ្ឌិកាបុត្រ អាស្រ័យនៅក្នុងអារាមរបស់ព្រះនាងមល្លិកាទេវី ដែលមានសាលាមួយ មានជួរដើមទន្ទាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សាន្តរទិដ្ឋិ (លទ្ធិ) ។*

មានអត្ថថា បានចំពោះ ដូចក្នុងប្រយោគជាដើមថា

ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយកោ
អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ ។

បណ្ឌិត ជាអ្នកមិនប្រមាទ តែងបានចំពោះប្រយោជន៍ទាំងពីរ គឺ ប្រយោជន៍ណា ក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ណា ដែលមានក្នុងបរលោកក្តី ធីរជន ឈ្មោះថា បណ្ឌិត ព្រោះការបានចំពោះនូវប្រយោជន៍ទាំងពីរនោះ ។

មានអត្ថថា លះបង់ ដូចក្នុងប្រយោគជាដើមថា **សម្មា មានាភិ-សមយាអន្តមកាសិ ទុក្ខស្ស** *ធ្វើនូវទីបំផុតកងទុក្ខ ដោយហេតុដែលបាន លះបង់នូវមានះចោលដោយប្រពៃ ។*

មានអត្ថថា ចាក់ធ្លុះ ដូចក្នុងប្រយោគជាដើមថា **ទុក្ខស្ស បីឡនដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ អភិសមយដ្ឋោ** *ទុក្ខមានអត្ថថា បៀតបៀន មានបច្ចយតាក់តែង ធ្វើឲ្យក្តៅក្រហាយ ប្រែប្រួល និងគួរចាក់ធ្លុះ។*

តែក្នុងទីនេះ **សមយ** *សព្ទនេះ មានអត្ថថា កាល ។ ដោយហេតុនោះ ទើបព្រះថេរៈសម្តែងថា* **ឯកំ សមយំ** *សម័យមួយ បណ្តាសម័យទាំងឡាយ ដែលហៅថា កាលជាដើមថា ឆ្នាំ រដូវ ខែ កន្ទុះខែ យប់ ថ្ងៃ ព្រឹក ពេលថ្ងៃ ល្ងាច បឋមយាម មជ្ឈិមយាម បច្ឆិមយាម និងព្រលឹម ។*

លោកអធិប្បាយថា សម័យរបស់ព្រះមានព្រះភាគនេះ ដែលហៅថា កាល មានច្រើន ដែលប្រាកដក្រៃលែងក្នុងពួកទេវតា និងមនុស្សជាដើមយ៉ាងនេះ គឺសម័យទ្រង់ចូលកាន់ព្រះគភ៌ សម័យប្រសូត សម័យទ្រង់សង្វេគ សម័យទ្រង់ចេញបួស សម័យទ្រង់ធ្វើទុក្ករកិរិយា សម័យទ្រង់ឈ្នះមារ សម័យទ្រង់ត្រាស់ដឹង សម័យគង់ប្រថាប់ជាសុខក្នុងបច្ចុប្បន្ន សម័យទេសនា សម័យបរិនិព្វាន បណ្តាសម័យទាំងនោះ ព្រះថេរៈសម្តែងសម័យមួយ ពោល គឺ សម័យទេសនា ។

លោកអធិប្បាយថា បណ្តាសម័យទ្រង់ធ្វើកិច្ចដោយព្រះញាណ និងទ្រង់ធ្វើកិច្ចដោយព្រះករុណា (បានដល់) សម័យទ្រង់ធ្វើកិច្ចដោយព្រះករុណានេះ

បណ្តាសម័យទ្រង់បដិបត្តិ ដើម្បីជាប្រយោជន៍ចំពោះខ្លួន និងសម័យទ្រង់បដិបត្តិដើម្បីជាប្រយោជន៍ដល់អ្នកដទៃ (បានដល់) បណ្តាសម័យទ្រង់បដិបត្តិដើម្បីជាប្រយោជន៍ដល់អ្នកដទៃនេះ បណ្តាសម័យទ្រង់បដិបត្តិករណីយកិច្ចទាំង ២ ដល់បរិសទ្យ ដែលប្រជុំគ្នា (បានដល់) សម័យទ្រង់ពោលធម្មីកថានេះ បណ្តាសម័យទេសនា និងបដិបត្តិ (បានដល់) សម័យទេសនានេះ បណ្តាសម័យទាំងនោះ ព្រះថេរៈសម្តែងថា **ឯកំ សមយំ** *សម័យមួយ សំដៅយកសម័យណាមួយ ។*

ក្នុងសេចក្តីនេះ បុគ្គលអ្នកសួរពោលថា ព្រោះហេតុអ្វី ទើបក្នុងព្រះសូត្រលោកធ្វើនិទ្ទេសជាទុតិយាវិភត្តិ មិនធ្វើដូចក្នុងអភិធម្មដែលធ្វើនិទ្ទេសជាសត្តមីវិភត្តថា **យស្មឹ សមយេ កាមាវចរំ** *និងក្នុងសុត្តបទដទៃក្រៅអំពីអភិធម្មនេះថា* **យស្មឹ សមយេ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ** *និងដូចក្នុងវិនយដែលធ្វើនិទ្ទេស ជាតតិយាវិភត្តិថា* **តេន សមយេន ពុទ្ធោ ភគវា** *ការពោលចង្អុលបង្ហាញ ដូច្នេះ ព្រោះក្នុងអភិធម្ម និងវិនយនោះ* **សមយ** *សព្ទ មានអត្ថយ៉ាងនោះ ឯក្នុងព្រះសូត្រនេះ មានអត្ថដទៃ ។ សេចក្តីពិត បណ្តាបិដកទាំង ៣ នោះ ក្នុងអភិធម្មបិដក* **សមយ** *សព្ទ មានអត្ថថា កំណត់ការៈ ។ ពិតហើយ អធិករណៈ គឺ* **សមយ** *សព្ទ ដែលមានអត្ថថា កាល និងមានអត្ថថា ប្រជុំ និងការៈនៃធម៌ មានផស្សៈជាដើមនោះ កំណត់បានដោយការៈនៃសម័យ គឺខណៈ ការព្រមព្រៀង និងហេតុនៃធម៌ទាំងឡាយមានផស្សៈជាដើម ដែលពោលហើយក្នុងអភិធម្មបិដក និងសុត្តបទដទៃនោះ*

ព្រោះដូច្នោះ ទើបធ្វើនិទ្ទេសជាសត្តមីវិភត្តិ ក្នុងអភិធម្មបិដកនោះ ដើម្បីបញ្ជាក់អត្ថនោះ ។

ឯក្នុងព្រះវិនយបិដក **សមយ** *សព្ទ មានអត្ថថា ហេតុ មានអត្ថថា ករណៈ ។ ពិតហើយ សម័យទ្រង់បញ្ញត្តសិក្ខាបទនោះ សូម្បីព្រះថេរៈ មានព្រះសារីបុត្រជាដើម គង់ជីឯងបានដោយលំបាក ដោយសម័យនោះជាហេតុ និងជាករណៈ ។ ព្រះមានព្រះភាគ កាលទ្រង់បញ្ញត្តសិក្ខាបទទាំងឡាយ ទ្រង់ក៏សម្ដែងដល់ហេតុនៃការបញ្ញត្តិសិក្ខាបទ ទើបប្រថាប់នៅក្នុងទីនោះៗ ព្រោះដូច្នោះ ទើបលោកធ្វើនិទ្ទេសជាតតិយាវិភត្តិទុកក្នុងវិនយបិដក ដើម្បីផ្ទុះបញ្ចាំងសេចក្ដីនោះ ។ ឯក្នុងសេចក្ដីនេះ និងចាបៈនៃសុត្តន្តបិដក ដែលមានកំណើតជាទៃៗ* **សមយ** *សព្ទ មានអត្ថថា អច្ចន្តសំយោគ គឺទុតិយាវិភត្តិ ដែលប្រែថា រហូត ពិតហើយ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងសូត្រនេះ ឬសូត្រជាទៃអស់សម័យណា ក៏ប្រថាប់ដោយករុណាវិហារធម៌រហូតទៅ គឺរហូតសម័យនោះ ព្រោះដូច្នោះ ទើប* **សមយ** *សព្ទ គួរជ្រាបថា លោកធ្វើនិទ្ទេសជាទុតិយាវិភត្តិក្នុងសូត្រនេះ ដើម្បីផ្ទុះបញ្ចាំងសេចក្ដីនោះ ។ ក្នុងសេចក្ដីនេះ មានពាក្យពោលថា*

តំ តំ អត្ថមបេក្ខិត្វា ករុម្ភេន ករណេន ច

អញ្ញត្រ សមយោ វុត្តោ ឧបយោគេន សោ ឥធ។

លោកពិចារណាអត្ថនោះៗ ពោល **សមយ** *សព្ទ ក្នុងបិដកជាទៃដោយសត្តមីវិភត្តិ និងដោយតតិយាវិភត្តិ តែក្នុងសុត្តន្តបិដកនេះ* **សមយ** *សព្ទនោះ លោកពោលដោយទុតិយាវិភត្តិ ។*

អធិប្បាយបទថា ភគវា

ពាក្យថា **ភគវា** *នេះ ជាពាក្យហៅព្រះមានព្រះភាគអង្គនោះ ជាបុគ្គលវិសេសដោយគុណ ជាកំពូលនៃសត្វ ជាគ្រូ និងគួរគោរព ដូចលោកពោលថា*

ភគវាតិ វចនំ សេដ្ឋំ ភគវាតិ វចនមុត្តមំ
គរុគារវយុត្តោ សោ ភគវា តេន វុច្ចតិ ។

ពាក្យថា **ភគវា** *ជាពាក្យប្រសើរបំផុត*

ពាក្យថា **ភគវា** *ជាពាក្យឧត្តមបំផុត*

ព្រះអង្គទ្រង់ជាគ្រូ និងគួរដល់ការគោរព

ដោយហេតុនោះ ទើបបណ្ឌិត ហៅថា **ភគវា ។**

សេចក្តីពិត នាម គឺឈ្មោះមាន ៤ គឺ **អាវត្តិក** *ឈ្មោះតាមវិយ* **លិង្គិក** *ឈ្មោះតាមភេទ* **ឧមិត្តក** *ឈ្មោះតាមគុណ* **អធិច្ចសមុប្បន្ន** *ឈ្មោះដែលអណ្តែតៗ ។ ឈ្មោះថា* **អធិច្ចសមុប្បន្ននាម** *លោកអធិប្បាយថា ជានាមដែលតាំងតាមការគាប់ចិត្ត ។ នាមទាំង ៤ នោះ នាមជាដើមយ៉ាងនោះថា កូនគោ គោបង្វឹក គោបម្រើការ ឈ្មោះថា* **អាវត្តិកនាម ។** *នាមជាដើមយ៉ាងនេះថា បុគ្គលមានឈើច្រត់ គឺមនុស្សច្រាស់ បុគ្គលមានឆត្រ គឺព្រះរាជា សត្វមានសិរ គឺក្អែក សត្វមានប្រមោយ គឺដំរី ឈ្មោះថា* **លិង្គិកនាម ។** *នាមជាដើមយ៉ាងនេះថា អ្នកមានវិជ្ជា ៣ អ្នកមានអភិញ្ញា ៦ ឈ្មោះថា* **ឧមិត្តកនាម ។** *នាមជាដើមយ៉ាងនេះថា អ្នកចម្រើនដោយសីរ អ្នកចម្រើនដោយទ្រព្យ ប្រព្រឹត្តទៅមិនសម្ញឹងអត្ថនៃពាក្យ ឈ្មោះថា* **អធិច្ចសមុប្បន្ន-នាម ។** *ឯនាមថា* **ភគវា** *នេះ ជា* **ឧមិត្តកនាម** *ដោយព្រះគុណ មិនមែន*

ព្រះនាងមហាមាយាពុទ្ធមាតាជាក់ឲ្យ មិនមែនព្រះបាទសុទ្ធោទនមហារាជ ពុទ្ធបិតាជាក់ឲ្យ មិនមែនព្រះញាតិ ៨៤០០០ អង្គជាក់ឲ្យ មិនមែនទេវតាពិសេស មានសក្កទេវរាជ ស្តេចសន្តុសិតជាក់ឲ្យ ដូចព្រះសារីបុត្រពោលថា ព្រះនាម **ភគវា** *នុ៎ះ មិនមែនព្រះមាតាថ្វាយ ។បេ។ បញ្ញត្តិថា* **ភគវា** *នេះ កើតព្រោះការត្រាស់ដឹង ព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនោះ (លោកពោលថា) **ភគវា** ។ ដើម្បីប្រកាសគុណទាំងឡាយ ដែលជាគុណនេមិត្តកនាម ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលគាថានេះថា*

ភគី ភជី ភាគី វិភត្តវា ឥតិ
អកាសិ ភគ្គន្តិ គរូតិ ភាគ្យវា
ពហូហិ ញាយេហិ សុភាវិតត្តនោ
ភវន្តគោ សោ ភគវាតិ វុច្ចតិ ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា **ភគវា** *ព្រោះទ្រង់ជាអ្នកមានភគៈ គឺជោគ ព្រោះទ្រង់ជាអ្នកសេពទីស្ងាត់ ព្រោះទ្រង់ជាអ្នកមានភាគ គឺចំណែកដែលគួរបានទទួលចតុប្បច្ច័យ ឬចំណែកនៃធម៌ ព្រោះទ្រង់ជាអ្នកចែកនូវធម៌ ព្រោះទ្រង់បានកាច់បំបាក់នូវបាបធម៌ ព្រោះទ្រង់ជាគ្រូ ព្រោះទ្រង់មានភាគ្យ គឺបុណ្យ ព្រោះទ្រង់អប់រំព្រះអង្គល្អហើយ ដោយញាយធម៌ដ៏ច្រើន ព្រោះទ្រង់ដល់នូវទីបំផុតភព ។*

ភាពនៃព្រះគុណ បទថា **ភគវា** *នោះ គប្បីឃើញតាមន័យដែលបានពោលហើយ ក្នុងនិទ្ទេសជាដើមនោះឯង ។*

ម្យ៉ាងទៀត បរិយាយជនៃនៅមានទៀត ដូច្នេះថា

ភាគ្យវា ភគ្គវា យុត្តោ ភគេហិ ច វិភត្តវា

ភត្តវា វន្តគមនោ ភវេសុ ភគវា តតោ។

ព្រះដ៏មានបុណ្យ ទ្រង់កាច់បំបាក់កិលេស ទ្រង់ប្រកបដោយភគធម៌ ទ្រង់ចែកធម៌ ទ្រង់សេពនូវធម៌ ទ្រង់ខ្ជាក់កិលេស ដែលជាហេតុទៅកាន់ភពទាំងឡាយបានហើយ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា **ភគវា ។**

ក្នុងបទទាំងនោះ គប្បីជ្រាបថា លោកកាន់យកលក្ខណៈនៃនិរុត្តិសាស្ត្រយ៉ាងនេះថា ចុះអក្ខរៈថ្មី ផ្ទាស់អក្ខរៈជាដើម ឬកាន់យកលក្ខណៈ ការរួបរួមក្នុងសព្ទ មាន **បិសោទរ** *សព្ទជាដើម តាមន័យរបស់សព្ទសាស្ត្រ កាលគួរហៅថាព្រះ* **ភាគ្យវា** *ព្រោះទ្រង់មានភាគ្យ គឺបុណ្យបារមី មានទាន និងសីលជាដើមដ៏កំពូល ដែលឲ្យកើតសេចក្តីសុខ ទាំងលោកិយ និងលោកុត្តរ តែហៅក្លាយថា* **ភគវា ។** *ម្យ៉ាងទៀត ព្រោះហេតុដែលទ្រង់កាច់បំបាក់កិលេស ដែលធ្វើនូវសេចក្តីក្រវល់ក្រវាយរាប់សែនប្រភេទ គឺប្រភេទលោភៈ ទោសៈ មោហៈ ប្រភេទវិបរិតមនសិការ ប្រភេទអហិរិកៈ អនោត្តប្បៈ ប្រភេទកោធៈ ឧបនាហៈ ប្រភេទមក្ខៈ បឡាសៈ ប្រភេទឥស្សា មច្ឆរិយៈ ប្រភេទសាឋេយ្យៈ ប្រភេទថម្ភៈ សារម្ភៈ ប្រភេទមានៈ អតិមានៈ ប្រភេទ*

មទៈ បមាទៈ ប្រភេទតណ្ហា អវិជ្ជា ប្រភេទអកុសលមូល ៣ ទុច្ចរិត ៣ សង្កិលេស ៣ មលៈ ៣ វិសមៈ ៣ សញ្ញា ៣ វិតក្ក ៣ បបញ្ចធម៌ ៣ ប្រភេទវិបរិយេស ៤ អាសវៈ ៤ គន្ថៈ ៤ ឱឃៈ ៤ យោគៈ ៤ អគតិ ៤ តណ្ហុប្បាទ ៤ ចេតោខីលៈ ៥ វិនិពន្ធៈ ៥ នីវរណៈ ៥ អភិនន្ទៈ ៥ វិវាទ-មូល ៦ តណ្ហាកាយ ៦ អនុសយ ៧ មិច្ឆត្តៈ ៨ តណ្ហាមូលកៈ ៩ អកុ-សលកម្មបថ ១០ ទិដ្ឋិគតៈ ៦២ តណ្ហាវិបរិត ១០៨ ឬពោលដោយសង្ខេប មាវ ៥ គឺកិលេសមារ ខន្ធមារ អភិសង្ខារមារ មច្ចុមារ និងទេវបុត្តមារ ដូច្នោះ កាលគួរហៅថា **ភគ្គវា** *ក៏ហៅក្លាយថា* **ភគវា** *ព្រោះទ្រង់កាច់បំបាក់បង់ឧបទ្រវទាំងនោះបាន សេចក្តីនេះ លោកពោលថា*

ភគ្គរាគោ ភគ្គទោសោ ភគ្គមោហោ អនាសវោ

ភគ្គាស្ស បាបកា ធម្មា ភគវា តេន វុច្ចតិ ។

ទ្រង់កាច់បំបាក់នូវរាគៈ ទោសៈ មោហៈ មាន

អាសវៈ ទ្រង់កាច់បំបាក់នូវបាបធម៌បានហើយ

ដោយហេតុនោះ ទើបលោកហៅថា **ភគវា។**

ការដល់ព្រមនៃព្រះរូបកាយរបស់ព្រះអង្គ ដែលទ្រទ្រង់នូវបុញ្ញលក្ខណៈ រាប់រយ ឈ្មោះថា លោកសម្តែងដោយភាពដែលទ្រង់មាន **ភាគ្យ** *គឺបុណ្យ ការដល់ព្រមនៃព្រះធម្មកាយ ឈ្មោះថា លោកសម្តែងដោយភាពដែលទ្រង់កាច់បំបាក់ទោសៈបានហើយ ។ ភាពដែលសត្វលោក និងអ្នកជិតស្និទ្ធរាប់អានច្រើនក្តី ភាពជាបុគ្គលដែលគ្រហស្ថ និងបព្វជិតទាំងឡាយ ចូលមកគាល់*

ក្តី ភាពជាបុគ្គលអាចជួយកម្ចាត់ទុក្ខផ្លូវកាយ និងទុក្ខផ្លូវចិត្តដល់បុគ្គលដែលចូលមករកក្តី ភាពជាបុគ្គលធ្វើឧបការៈដោយអាមិសទាន និងធម្មទានក្តី ភាពជាអ្នកអាចក្នុងការប្រកបលោកិយសុខ និងលោកុត្តរសុខក្តី លោកសម្តែងដោយព្រះគុណ ២ យ៉ាងនោះ ។

ម្យ៉ាងទៀត ព្រោះ **ភគ** *សព្វក្នុងលោក ប្រព្រឹត្តទៅក្នុងធម៌ ៦ គឺ ឥស្សរិយៈ ធម្មៈ យស សិរី កាម បយត្ត ។ ព្រះមានព្រះភាគអង្គនោះទ្រង់មានឥស្សរិយភាពជាធំ ក្នុងចិត្តរបស់ព្រះអង្គឯងដ៏កំពូល ឬទ្រង់មានឥស្សរិយបរិបូណ៌ ដោយអាការគ្រប់យ៉ាង ដែលសន្មតថាជាលោកិយ មានអណិមា គឺធ្វើខ្លួនឲ្យតូច សង្ឃិមា គឺធ្វើខ្លួនឲ្យស្រាល ទ្រង់មានលោកុត្តរធម៌ក៏ដូចគ្នា ទ្រង់មានយសដ៏បរិសុទ្ធក្រៃលែង ដែលទ្រង់បានដោយព្រះគុណតាមសេចក្តីពិត ប្រាកដទូទៅក្នុងលោកទាំង ៣ ទ្រង់មានព្រះសិរីល្អ សព្វសព៌ាង្គ-កាយបរិបូណ៌ ដោយអាការគ្រប់យ៉ាង ទ្រង់អាចឲ្យទាក់ភ្នែក ទាក់ចិត្តដល់បុគ្គលខ្វល់ខ្វាយក្នុងការមើលព្រះរូបបាន ទ្រង់មានព្រះកាមដែលសំដៅដល់សេចក្តីសម្រេចនៃប្រយោជន៍ដែលទ្រង់បំណង ព្រោះប្រយោជន៍ណាមួយដែលទ្រង់បំណងហើយ ប្រាថ្នាហើយ ទោះជាប្រយោជន៍ខ្លួនក្តី ប្រយោជន៍អ្នកដទៃក្តី ប្រយោជន៍នោះៗ ក៏សម្រេច សមបំណងទាំងអស់ ហើយទ្រង់មានព្រះបរិយត្តិ ពោលគឺសម្មាវាយាមៈ ដែលជាហេតុកើតនូវភាពជាគ្រូរបស់សត្វលោកទាំងពួង ដូច្នោះ ទើបលោកហៅថា* **ភគវា** *ដោយអត្តនេះថា ទ្រង់មានភគធម៌ ព្រោះភាពដែលទ្រង់ប្រកបដោយភគធម៌ទាំងនេះ ។*

អធិប្បាយបទថា វិភត្តវា

ម្យ៉ាងទៀត ព្រោះព្រះមានព្រះភាគ ទ្រង់ជាវិភត្តវា លោកអធិប្បាយថា ទ្រង់ចែក បើកផ្សារ សម្តែង នូវធម៌ទាំងពួងដោយប្រភេទ មានកុសលជាដើម ឬនូវធម៌ មានកុសលធម៌ជាដើម ដោយប្រភេទ មានខន្ធ អាយតនៈ ធាតុ សច្ចៈ ឥន្ទ្រិយ និងបដិច្ចសមុប្បាទជាដើម ឬនូវទុក្ខអរិយសច្ច ដោយអត្ថ គឺ បីឡនៈ សង្ខតៈ សន្តាបៈ វិបរិណាមៈ នូវសមុទយអរិយសច្ច ដោយអត្ថ គឺ អាយូហនៈ និទាន សំយោគ បលិពោធ នូវនិរោធអរិយសច្ច ដោយអត្ថ គឺ និស្សរណៈ វិវេក អសង្ខតៈ អមតៈ នូវមគ្គអរិយសច្ច ដោយអត្ថ គឺ និយ្យានិក ហេតុ ទស្សនៈ អធិបតេយ្យ ដូច្នោះ កាលគួរនឹងហៅថា **វិភត្តវា** តែហៅក្លាយថា **ភគវា**។

អធិប្បាយបទថា ភត្តវា

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះមានព្រះភាគ ទ្រង់គប់រក ទ្រង់សេព ទ្រង់ធ្វើឲ្យច្រើន នូវធម៌ដែលជាទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ នូវ កាយវិវេក ចិត្តវិវេក និងឧបធិវិវេក នូវសុញ្ញវិមោក្ខ អប្បណិហិតវិមោក្ខ អនិមិត្តវិមោក្ខ និងនូវឧត្តរិមនុស្សធម៌ដែលជាលោកិយផង លោកុត្តរដទៃៗ ផង ដូច្នោះ កាលគួរហៅថា **ភត្តវា** តែក៏ហៅក្លាយថា **ភគវា**។

អធិប្បាយបទថា ភវេសុ វន្តគមន

ម្យ៉ាងទៀត ព្រោះការទៅ ពោល គឺតណ្ហាក្នុងភពទាំង ៣ ដែលទ្រង់ ខ្ជាក់ចោលហើយ ដូច្នោះ កាលគួរនឹងហៅថា **ភវេសុវន្តគមន** តែលោកកាន់

យក **ក** *អក្ខរៈ អំពី* **ភវ** *សព្ទ* **គ** *អក្ខរៈ អំពី* **គមន** *សព្ទ* **វ** *អក្ខរៈ អំពី* **វន្ត** *សព្ទ ហើយធ្វើឲ្យជាទីឃៈ ហៅថា* **ភគវា** *ដូចក្នុងផ្លូវលោក កាលគួរនឹងហៅពេញៗ ថា* **មេឃាឝស្ស ឲស្ស មាលា** *តែអ្នកប្រាជ្ញលោកកាន់យក* **មេ** *អំពី* **មេឃាឝស្ស** *កាន់យក* **ឲ** *អំពី* **ឲស្ស** *កាន់យក* **លា** *អំពី* **មាលា** *ក៏ហៅថា* **មេឲលា** *ដូច្នោះឯង ។*

ព្រះអានន្ទត្ថេរ កាលសម្តែងធម៌តាមដែលបានស្តាប់មក រៀនសូត្រមក ទើបប្រកាសព្រះសរីរធម៌របស់ព្រះមានព្រះភាគ ឲ្យជាក់ច្បាស់ ដោយពាក្យថា **ឯវម្មេ សុតំ** *ក្នុងព្រះសូត្រនេះ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ដោយប្រការដូច្នេះ ទើបព្រះថេរៈលួងលោមជនដែលមានចិត្តរាយមាយ ព្រោះមិនជួបព្រះមានព្រះភាគថា ជាវចនៈ គឺធម៌ និងវិនិយនេះ ឈ្មោះថា មានសាស្តាកន្លងហើយ ក៏មិនមែន ធម៌ និងវិនិយនេះ ជាសាស្តារបស់អ្នកទាំងឡាយ ។*

ពាក្យថា **ឯកំ សមយំ ភគវា** *ព្រះថេរៈកាលសម្តែងភាពដែលព្រះមានព្រះភាគ មិនមានក្នុងសម័យនោះ ឈ្មោះថា សម្តែងបរិនិព្វាននៃព្រះរូបកាយ ។ ដោយពាក្យនោះ ព្រះថេរៈរំមែងញ៉ាំងជនដែលស្រេវឹង មានស្រេវឹងក្នុងជីវិតជាដើមឲ្យសង្វេគ ហើយញ៉ាំងឧស្សាហ៍ក្នុងធម៌ឲ្យកើតដល់ជននោះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់សម្តែងអរិយធម៌នេះយ៉ាងនោះ ទ្រទ្រង់នូវកម្លាំង ១០ មានព្រះកាយដូចពេជ្រ ក៏គង់ស្តេចបរិនិព្វាន ក្នុងសេចក្តីនោះ បុគ្គលដទៃណា គប្បីឲ្យកើតការហួងហែងក្នុងជីវិតបាន ។*

ព្រះថេរៈកាលពោលថា **ឯវំ** *ឈ្មោះថា សម្តែងទេសនាសម្បត្តិ គឺការ*

ជល់ព្រមនៃទេសនា កាលពោលពាក្យថា **មេ សុតំ** *ឈ្មោះថា សម្តែងសាវក-សម្បត្តិ ។ កាលពោលពាក្យថា* **ឯកំ សមយំ** *ឈ្មោះថា សម្តែងកាល-សម្បត្តិ កាលពោលពាក្យថា* **ភគវា** *ឈ្មោះថា សម្តែងទេសកសម្បត្តិ គឺការជល់ព្រមនៃអ្នកសម្តែង ។*

អធិប្បាយបទថា សាវត្ថិយំ វិហរតិ

ពាក្យថា **សាវត្ថី** *ក្នុងពាក្យថា* **សាវត្ថិយំ វិហរតិ** *នេះ បានដល់ នគរដែលជាលំនៅប្រចាំរបស់ឥសី ឈ្មោះ* **សាវត្ថ:** *ដូចពាក្យថា* **កាកណ្ឌិ មាកណ្ឌិ** *ជូច្នោះ ទើបលោកហៅថា* **សាវត្ថី** *ជា* **ឥត្ថិលិង្គ** *សព្វ អ្នកប្រាជ្ញខាងអក្ខរ-សាស្ត្រពោលយ៉ាងនេះ ។ ឯអដ្ឋកថាចារ្យទាំងឡាយពោលថា គ្រឿងឧបភោគ បរិភោគសម្រាប់មនុស្ស មានសព្វយ៉ាងក្នុងនគរនោះ ហេតុនោះ ទើបនគរ នោះ ឈ្មោះថា* **សាវត្ថី** ។ *តែការប្រកបសព្វ កាលត្រូវសួរថា មានរបស់ប៉ុន្មាន ទើបអាស្រ័យពាក្យថា មានគ្រប់យ៉ាង ប្រកបថា* **សាវត្ថី** *មានរបស់គ្រប់យ៉ាង ។*

> *គ្រឿងឧបករណ៍មានព្រម ក្នុងក្រុងសាវត្ថីសព្វកាល ព្រោះ ជូច្នោះ សំដៅដល់របស់គ្រប់យ៉ាង ទើបហៅថា* **សាវត្ថី** ។
>
> *រាជធានីនៃដែនកោសល គួរជាទីត្រេកអរ គួរសរសើរ គួរ ចាប់ចិត្ត មិនស្ងាត់ចាកសំឡេង ១០ យ៉ាង ជល់ព្រម ដោយជ្រាយ និងទឹក ។*

ក្រុងសាវត្ថីរាជធានី ដល់នូវការចម្រើនបរិបូណ៌ មាំទាំ រុងរឿង គួរជាទីត្រេកអរនៃចិត្ត ដូចក្រុងអាឡកមន្ទា-ទេពធានីរបស់ពួកទេព្តា ដូច្នោះ ។

ទៀបក្រុងសាវត្ថីនោះ ពាក្យនេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ។

ពាក្យថា **វិហរតិ** *នេះ ជាពាក្យសម្តែងការដល់ព្រមដោយវិហារ បណ្តា ឥរិយាបថវិហារ ទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារបែបណានីមួយ ដោយមិនប្លែកគ្នា តែក្នុងព្រះសូត្រនេះ សម្តែងការប្រកបព្រម ដោយឥរិយាបថវិហារក្នុងបណ្តាឥរិយាបថ មានការឈរ ដើរ អង្គុយ ដេក ឥរិយាបថណានីមួយ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទ្រង់ប្រថាប់ឈរក្តី ទ្រង់យាងក្តី ប្រថាប់អង្គុយក្តី ផ្តំក្តី ក៏គប្បីជ្រាបថា* **វិហរតិ** *ទាំងអស់ ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះ ទ្រង់កាត់នូវសេចក្តីលំបាកនៃឥរិយាបថណាមួយ ដោយឥរិយាបថមួយទៀត ទ្រង់បរិហារអត្តភាពឲ្យប្រព្រឹត្តទៅមិនលំបាក ព្រោះដូច្នោះ ទើបហៅថា* **វិហរតិ** ។

អធិប្បាយបទថា ជេតវនេ

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ជេតវនេ** *នេះ ដូច្នេះ ។ ព្រះរាជកុមារព្រះនាមថា* **ជេត** *ព្រោះឈ្នះជនដែលជាសត្រូវរបស់ខ្លួន ឬថា* **ជេត** *ព្រោះប្រសូតក្នុងកាលព្រះរាជាទ្រង់ឈ្នះសត្រូវ ឬឈ្មោះថា* **ជេត** *ព្រោះព្រះរាជាទ្រង់ដាក់ឈ្មោះយ៉ាងនេះ ដល់ព្រះរាជកុមារ ព្រោះមានព្រះរាជបំណងឲ្យជាមង្គល ។ ដែលឈ្មោះថា* **វន** *ព្រោះឲ្យគប់រក អធិប្បាយថា ឲ្យធ្វើនូវការ*

ភក្តីដល់ខ្លួន ព្រោះការដល់ព្រមនៃខ្លួន គឺឲ្យកើតការស្រឡាញ់ក្នុងខ្លួន ។ ម្យ៉ាងទៀត ឈ្មោះថា **វន** *ព្រោះស្រែកហៅ អធិប្បាយថា ហាក់បីដូចហៅសត្វទាំងឡាយថា សូមមកប្រើប្រាស់ខ្ញុំចុះ ។* **វន** *របស់ជេតរាជកុមារ ឈ្មោះថា* **ជេតវន ។** *ពិតហើយ ជេតវននោះដែលព្រះរាជកុមារព្រះនាមថា* **ជេត** *ជាំហើយថែរក្សា ។ ជេតរាជកុមារនោះ ជាម្ចាស់របស់ជេតវននោះ ព្រោះដូច្នោះ ទើបហៅថា* **ជេតវន ។** *ក្នុងជេតវននោះ ។*

អធិប្បាយបទថា អនាថបិណ្ឌិកស្ស អារាមេ

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អនាថបិណ្ឌិកស្ស អារាមេ** *នេះ ដូច្នេះថា គហបតីនោះ ឈ្មោះសុទត្តៈ ដោយឪពុកម្តាយជាក់ឈ្មោះឲ្យ ។ ម្យ៉ាងទៀត លោកបានឲ្យជុំបាយជាទានដល់មនុស្សអនាថាជាប្រចាំ ព្រោះលោកជាអ្នកប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ និងព្រោះជាអ្នកដល់ព្រមដោយគុណមានករុណាជាដើម ព្រោះលោកជាអ្នកស្តុកស្តម្ភដោយសម្បត្តិ ដែលគួរប្រុងប្រៀបគ្រប់យ៉ាង ដោយហេតុនោះ ទើបបានឈ្មោះថា* **អនាថបិណ្ឌិក ។** *បទថា ដែលឈ្មោះថា* **អារាម** *ព្រោះជាទីដែលសត្វទាំងឡាយ ឬដោយចំពោះ គឺបព្វជិតទាំងឡាយនាំគ្នាមកត្រេកអរ អធិប្បាយថា បព្វជិតទាំងឡាយនាំគ្នាមកអំពីទីនោះៗ ត្រេកអរដោយមិនធុញទ្រាន់ ព្រោះជេតពននោះ ស្រស់ស្អាតដោយផ្កា ផ្លែឈើ ស្វឹកឈើខ្ចីជាដើម និងព្រោះដល់ព្រមដោយអង្គនៃសេនាសនៈ ៥ ប្រការ មានមិនឆ្ងាយពេក មិនជិតពេកជាដើម ។ មួយប្រការទៀត ឈ្មោះថា* **អារាម** *ព្រោះនាំបុគ្គលដែលទៅក្នុងទីនោះៗ មកខាង*

ក្នុងខ្លួន រួចត្រេកអរ ព្រោះសម្បត្តិដូចពោលមកហើយ ។ ពិតហើយ អារាម នោះ អនាថបិណ្ឌិកគហបតី ទិញអំពីព្រះហស្តរបស់ជេតរាជកុមារ ដោយ ប្រាក់ ១៨ កោដិ សាងសេនាសនៈអស់ ១៨ កោដិ ស្រេចហើយ ធ្វើវិហារ អស់ប្រាក់ ១៨ កោដិ វេរច្ចាយភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយ បរិច្ចាគប្រាក់ ៥៤ កោដិ យ៉ាងនេះ ព្រោះដូច្នោះ ទើបហៅថា អារាមរបស់ អនាថបិណ្ឌិក ។ ក្នុងអារាមរបស់អនាថបិណ្ឌិកនោះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ជេតវនេ** *ប្រើរួមជាម្ចាស់ដើម ពាក្យថា* **អនាថបិណ្ឌិកស្ស អារាមេ** *ប្រើរួមជាម្ចាស់ក្រោយ ។ មានពាក្យសួរថា ប្រើរួមជាវត្តជេតពន និងអារាមទាំងនោះ មានប្រយោជន៍អ្វី ។ សូមចង្អុល បង្ហាញដូច្នេះថា ពោលដោយអធិការមុន ប្រយោជន៍ គឺការធ្វើនូវការកំណត់ ធ្វើយនូវពាក្យដែលត្រាស់ក្នុងទីណាមួយ ជាការប្រកបបុគ្គលដែលត្រូវការ បុណ្យជាទៃៗ ក្នុងការដល់ (កាន់យក) ជាបែបផែនណាមួយ ។ ពិតហើយ ក្នុងប្រយោជន៍ ២ យ៉ាងនោះ ទ្រព្យ ១៨ កោដិដែលបានអំពីការលក់ដី ក្នុង ការសាងប្រាសាទ មានទ្វារ និងខ្ញោងទ្វារ ដើមឈើទាំងឡាយមានតម្លៃច្រើន កោដិ ជាបរិច្ចាគរបស់ជេតរាជកុមារ ។ ទ្រព្យ ៥៤ កោដិ ជាបរិច្ចាគរបស់ អនាថបិណ្ឌិកសេដ្ឋី ។ ដោយការប្រើរួមជាវត្តជេតពន និងអារាមនោះ ព្រះ អានន្ទកាលសម្តែងបុគ្គលដែលត្រូវការបុណ្យ រមែងធ្វើបុណ្យទាំងឡាយយ៉ាង នេះ ក៏រមែងប្រកបបុគ្គលដែលត្រូវការបុណ្យជាទៃៗ ក្នុងការកាន់យកជាបែប ផែនដោយប្រការណា ការប្រកបបុគ្គលដែលត្រូវការបុណ្យ ទុកក្នុងការកាន់*

យកជាបែបផែន ក៏គប្បីជ្រាបថា ជាប្រយោជន៍ក្នុងសេចក្តីនេះ ដោយប្រការនោះ ។

ក្នុងសេចក្តីនេះ អ្នកចោទសួរពោលថា បើព្រះមានព្រះភាគប្រថាប់នៅក្បែរក្រុងសាវត្ថីមុន ព្រះអានន្ទមិនគួរពោលថា ក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិក តែបើប្រថាប់នៅក្នុងវត្តជេតពននោះ ក៏មិនគួរពោលថា ជិតក្រុងសាវត្ថី ព្រោះថា ព្រះមានព្រះភាគមិនអាចប្រថាប់ក្នុងទីទាំង ២ កន្លែងក្នុងពេលតែមួយបានឡើយ ។ សូមចង្អុលបង្ហាញដូច្នេះថា ខ្ញុំពោលមកហើយមិនមែនឬថា ពាក្យថា **សាវត្ថិយំ** *ជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ព្រោះថា ប្រៀបដូចហ្វូងគោត្រាច់ទៅក្បែរស្ទឹងគង្គា និងយមុនាជាដើម គេក៏ហៅថា ត្រាច់ទៅជិតស្ទឹងគង្គា ត្រាច់ទៅជិតស្ទឹងយមុនា យ៉ាងណា ព្រះមានព្រះភាគកាលប្រថាប់នៅក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិក ជិតក្រុងសាវត្ថី ក៏គប្បីជ្រាបថា ប្រថាប់នៅក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិក ជិតក្រុងសាវត្ថី សូម្បីក្នុងព្រះសូត្រនេះ ក៏ដូច្នោះ ។ ពិតហើយ ពាក្យថា* **សាវត្ថី** *របស់ព្រះថេរៈ ក៏ដើម្បីសម្តែងគោចរគាម ពាក្យដ៏សេស សម្តែងទីនៅប្រចាំដែលសមគួរដល់បព្វជិត ។*

ក្នុងពាក្យទាំង ២ នោះ ព្រះថេរៈសម្តែងការអនុគ្រោះគ្រហស្ថរបស់ព្រះមានព្រះភាគ ដោយការប្រារព្ធក្រុងសាវត្ថី សម្តែងការអនុគ្រោះបព្វជិត ដោយការប្រារព្ធវត្តជេតពនជាដើម ។ ម្យ៉ាងទៀត សម្តែងការវៀរអត្តកិលមថានុយោគ ព្រោះកាន់យកបច្ចយ ដោយពាក្យដើមសម្តែងនូវឧបាយ វៀរកាម-

សុខល្ហិកានុយោគ ព្រោះលះវត្ថុកាមដោយពាក្យក្រោយ ។ ម្យ៉ាងទៀត សម្តែងសេចក្តីព្យាយាមក្នុងទេសនាដោយពាក្យដើម សម្តែងការបង្អោនទៅក្នុងវិវេកដោយពាក្យក្រោយ សម្តែងការចូលទៅដោយកុណា ដោយពាក្យដើម និង សម្តែងការចូលទៅដោយបញ្ញា ដោយពាក្យក្រោយ ។ សម្តែងភាពដែលព្រះមានព្រះភាគ ទ្រង់បង្អោនទៅក្នុងការឲ្យសម្រេចហិតសុខ ដល់សត្វទាំង-ឡាយ ដោយពាក្យដើម សម្តែងភាពដែលទ្រង់មិនជាប់នៅក្នុងការបំពេញហិតសុខដល់អ្នកដទៃ ដោយពាក្យក្រោយ ។ សម្តែងការនៅជាផាសុក ដែលទ្រង់លះសុខ ប្រកបដោយធម៌ជានិមិត្ត ដោយពាក្យដើម សម្តែងការនៅជាផាសុក ដែលមានការប្រកបរឿយៗ នូវឧត្តរិមនុស្សធម៌ជានិមិត្ត ដោយពាក្យក្រោយ ។ សម្តែងភាពដែលទ្រង់មានឧបការៈច្រើន ដល់មនុស្សទាំងឡាយ ដោយពាក្យដើម ។ សម្តែងភាពដែលទ្រង់មានឧបការៈច្រើន ដល់ទេវតាទាំង-ឡាយ ដោយពាក្យក្រោយ ។ សម្តែងភាពដែលព្រះមានព្រះភាគ ទ្រង់កើតឡើងក្នុងលោក ចម្រើនក្នុងលោក ដោយពាក្យដើម សម្តែងភាពដែលលោកប្រឡាក់ប្រឡូសព្រះអង្គមិនបាន ដោយពាក្យក្រោយ មានបែបដូចពោលមកនេះជាដើម ។

ពាក្យថា **អថ** *ប្រើក្នុងអត្ថថា មិនដាច់ខ្សែ សព្ទថា* **នោ** *ជានិបាត ប្រើក្នុងអត្ថថា សម្តែងរឿងដទៃៗ ដោយពាក្យ ២ នោះ ។ ព្រះថេរៈសម្តែងថា រឿងដទៃៗ នេះ កើតឡើងក្នុងព្រះវិហាររបស់ព្រះមានព្រះភាគមិនដាច់ ។ រឿងនោះ គឺអ្វី គឺរឿងទេវតាមួយអង្គជាដើម ។ សព្ទថា* **អញ្ញតរា** *ក្នុងពាក្យថា*

អញ្ញតរា ប្រែថា ទេវតាមួយអង្គនោះ សម្តែងការមិនពិតប្រាកដ ។ ពិតហើយ ទេវតានោះ មិនប្រាកដឈ្មោះ និងគោត្រ ព្រោះដូច្នោះ ទើបលោកពោលថា **អញ្ញតរា** ។ ទេវតា គឺទេវៈនោះឯង ពាក្យថា **អញ្ញតរា** នេះ សាធារណៈទូទៅដល់ស្ត្រី និងបុរស តែក្នុងទីនេះ បុរសប៉ុណ្ណោះ គឺទេវបុត្រ ។ ក្នុងពាក្យខ្លះ ទេវបុត្រ លោកពោលថា ទេវតា ដោយជាសាធារណនាម ។

អធិប្បាយ អភិក្កន្ត សព្ទ

ក្នុងពាក្យថា **អភិក្កន្តាយ រត្តិយា** នេះ **អភិក្កន្ត** សព្ទ ប្រើក្នុងអត្ថទាំងឡាយ គឺអស់ទៅ ល្អ ស្អាត ត្រេកអរក្រៃលែងជាដើម ។

ក្នុងអត្ថទាំងនោះ ប្រើក្នុងអត្ថថា អស់ទៅ ដូចក្នុងប្រយោគជាដើមថា

អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខុំ ចាតិមោក្ខំ ។

បពិត្រព្រះអង្គដ៏ចម្រើន វេលាវត្រីអស់ហើយ បឋមយាម កន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់សម្តែងបាតិមោក្ខ ដល់ភិក្ខុទាំងឡាយ ។

ប្រើក្នុងអត្ថថា ល្អ ដូចក្នុងប្រយោគជាដើមថា

អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច ។

បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះ ចាត់ថា ល្អ ជាងផង ប្រសើរជាងផង ។

ប្រើក្នុងអត្ថថា ស្អាត ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា

កោ មេ វន្ទតិ ចាគានិ ឥទ្ធិយា យសសា ជលំ
អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា។

អ្នកណាហ្ន៎ រុងរឿងដោយឫទ្ធិ និងយស មានសម្បុរ ល្អ (ស្អាត) ញុំាងទិសទាំងពួងឲ្យភ្លឺ មកថ្វាយបង្គំ ជាទានៃតថាគត ។

ប្រើក្នុងអត្ថថា ត្រេកអរក្រៃលែង ដូចក្នុងប្រយោគជាដើមថា

អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម *បពិត្រគោតម ជ័ចម្រើន ពីរោះណាស់ បពិត្រគោតមជ័ចម្រើន ពីរោះណាស់ ។*

ក្នុងព្រះសូត្រនេះ ប្រើក្នុងអត្ថថា អស់ទៅ អធិប្បាយថា បទថា **អភិក្កន្តាយ រត្តិយា** *ប្រែថា កាលរាត្រីអស់ទៅហើយ ។*

ក្នុងពាក្យថា **អភិក្កន្តវណ្ណា** *នេះ* **អភិក្កន្ត** *សព្ទ ក្នុងអត្ថថា ស្អាត ។* **វណ្ណ** *សព្ទ ប្រើក្នុងអត្ថថា ពណ៌សម្បុរ សរសើរ ពួកត្រកូល ហេតុ ទ្រង់ទ្រាយ ទំហំ រូបាយតន:ជាដើម ។*

ប្រើក្នុងអត្ថថា ពណ៌សម្បុរ ដូចក្នុងប្រយោគជាដើមថា **សុវណ្ណវណ្ណាសិ ភគវា** *បពិត្រព្រះអង្គជ័ចម្រើន ព្រះអង្គមានពណ៌សម្បុរដូចមាស ។*

ប្រើក្នុងអត្ថថា សរសើរ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **កនា**

សញ្ឃជ្ឋា បន តេ គហបតិ ឥមេ សមណស្ស គោតមស្ស វណ្ណា នៃ គហបតី ពាក្យសរសើរ (គុណ) ព្រះគោតមទាំងនេះ អ្នកចងក្រង ពីពេលណា ។

ប្រើក្នុងអត្ថថា ពួកត្រកូល ដូចក្នុងប្រយោគជាដើមថា **ចត្តារោ មេ ភោ គោតម វណ្ណា** បពិត្រព្រះគោតមដ៏ចម្រើន ត្រកូលទាំង ៤ នេះ ។

ប្រើក្នុងអត្ថថា ហេតុ ដូចក្នុងប្រយោគជាដើមថា **អថ កេន នុ វណ្ណេន គនូថេនោតិ វុចូតិ** កាលបើដូច្នេះ ព្រោះហេតុអ្វីហ្នឹ ទើបអ្នកពោលថា លួចក្ងិន ។

ប្រើក្នុងអត្ថថា ទ្រង់ទ្រាយ ដូចក្នុងប្រយោគជាដើមថា **មហន្តំ ហត្ថិ-រាជវណ្ណំ អភិនិម្មិនិត្វា** និម្មិតសណ្ឋានជាស្តេចដំរីធំ ។

ប្រើក្នុងអត្ថថា ទំហំ ដូចក្នុងប្រយោគជាដើមថា **តយោ បត្តស្ស វណ្ណា** បាត្រ ៣ ឌ្នាត ។

ប្រើក្នុងអត្ថថា រូបាយតន: ដូចក្នុងប្រយោគជាដើមថា **វណ្ណោ គន្ធោ រសោ ឱជា** រូប ក្ងិន រស ឱជា ។

វណ្ណ សព្ទ ក្នុងសូត្រនេះ គប្បីប្រើក្នុងអត្ថថា ពណិសម្បុរ ដោយហេតុ នោះ ទើបលោកអធិប្បាយថា បទថា **អភិក្ពន្ធវណ្ណា** ប្រែថា មានពណិ សម្បុរគួរស្រឡាញ់ ។

អធិប្បាយបទថា កេវលកប្បំ

កេវល សព្ទ ក្នុងបទថា **កេវលកប្បំ** នេះ មានអត្ថជាច្រើន ដូចជា

មានអត្ថថា មិនមានចំណែកសល់ ដោយច្រើន មិនលាយឡំ មិនច្រើនពេក មាំទាំ មិនជាប់ជំពាក់ ។

ពិតហើយ **កេវល** *សព្ទនោះ មានអត្ថថា មិនមានចំណែកសល់ ដូចក្នុងប្រយោគជាដើមថា* **កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ** *ទ្រង់ប្រកាសព្រហ្មចរិយៈដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ។*

មានអត្ថថា ដោយច្រើន ដូចក្នុងប្រយោគជាដើមថា **កេវលកប្បា ច អង្គមគធា បហូតំ ខាទនីយំ ភោជនីយំ អាទាយ អភិក្កមិតុកាមា ហោន្តិ** *ព្រោះថា ជនអ្នកនៅក្នុងដែនអង្គៈ និងមគធៈ ទាំងអស់គ្នា (ដោយច្រើន) ប្រាថ្នានឹងនាំយក ខាទនីយភោជនីយាហារមានប្រមាណច្រើន ចូលមកបូជា ។*

មានអត្ថថា មិនលាយឡំ ដូចក្នុងប្រយោគជាដើមថា **កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ** *សេចក្តីកើតឡើងនៃកងទុក្ខសុទ្ធៗ ទាំងអស់នេះ រមែងមានយ៉ាងនេះឯង ។*

មានអត្ថថា មិនច្រើនពេក ដូចក្នុងប្រយោគជាដើមថា **កេវលំ សទ្ធាមត្តកំ ឆ្ឌេន អយមាយស្មា** *ព្រោះអាស្រ័យនូវគុណធម៌ ត្រឹមតែសទ្ធាម្យ៉ាងដោយពិត ។*

មានអត្ថថា មាំទាំ ដូចក្នុងប្រយោគជាដើមថា **អាយស្មតោ ភន្តេ អនុរុទ្ធស្ស ពាហិយោ នាម សទ្ធិវិហារិកោ កេវលកប្បំ សង្ឃភេទាយ ឋិតោ** *បពិត្រព្រះអង្គដ៏ចម្រើន សទ្ធិវិហារិករបស់អនុរុទ្ធដ៏មានអាយុ ឈ្មោះ ភាហិយៈ នៅតែទទូចដើម្បីបំបែកសង្ឃ ឥតឈប់ឈរ ។*

មានអត្ថថា មិនជាប់ជំពាក់ ដូចក្នុងប្រយោគជាដើមថា **កេវលី វុសិតវា ឧត្តមបុរិសោតិ វុច្ចតិ** *ម្នាលភិក្ខុទាំងឡាយ (ភិក្ខុលះអង្គ ៥ ប្រកបដោយអង្គ ៥) ហៅថា ជាឧត្តមបុរស មានគុណគ្រប់គ្រាន់ (មិនជាប់ជំពាក់) ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះ ដូច្នេះ ។*

តែក្នុងសូត្រនេះ **កេវលៈ** *សព្ទនោះ លោកបំណងយកអត្ថថា មិនមានចំណែកសេសសល់ ។*

ចំណែក **កប្ប** *សព្ទ មានអត្ថច្រើន ដូចជា ការជឿមាំ វោហារ កាល បញ្ញត្តិ តាក់តែង វិកប្ប លេស និងដោយជុំវិញ ។*

ពិតហើយ **កប្ប** *សព្ទនោះ មានអត្ថថា ជឿមាំ ដូចក្នុងប្រយោគជាដើមថា* **ឯកប្បនីយមេតំ ភោគោ គោតមស្ស យថា តំ អរហាតោ សម្មាសម្ពុទ្ធស្ស** *ពាក្យរបស់ព្រះគោតមដ៏ច្រើន ដែលជាអរហន្តសម្មាសម្ពុទ្ធនេះ ជាពាក្យគួរជឿពិតហើយ ។*

មានអត្ថថា វោហារ ដូចក្នុងប្រយោគជាដើមថា **អនុជានាមិ ភិក្ខវេ បញ្ចហិ សមណាកប្បេហិ ផលំ បរិភុញ្ជិតុំ** *ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើ ដោយសមណកប្ប (វោហារ) ៥ យ៉ាង ។*

មានអត្ថថា កាល ដូចក្នុងប្រយោគជាដើមថា **យេន សុទំ និច្ចកប្បំ វិហារាមិ** *តថាគតនេះឯង តែងនៅអស់កាលជានិច្ច ។*

មានអត្ថថា បញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា **ឥច្ចាយស្មា កប្បោ**

កប្បមាណពជ៏មានអាយុទូលសួរថា ។

មានអត្ថថា តាក់តែង ដូចក្នុងប្រយោគជាដើមថា **អលង្ឆតោ មាល្យ-ធរោ សុវត្ថោ សុកុណ្ឌលី កប្បិតកេសមស្សុ** *អ្នកមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា ស្បៃកជណ្តប់ល្អ មានប្រដាប់ត្រចៀកល្អ មានសក់ និង ពុកចង្កាកាត់ចោលហើយ ។*

មានអត្ថថា គួរ ដូចក្នុងប្រយោគជាដើមថា **កប្បតិ ទុផ្ទុលកប្បោ** *កំណត់ដោយស្រមោល ព្រះអាទិត្យជ្រៅទៅ ប្រមាណពីរធ្នាប់ គួរ ។*

មានអត្ថថា លេស ដូចក្នុងប្រយោគជាដើមថា **អត្ថិ កប្បោ និប្បដ្ឋិតុំ** *បើដូច្នោះ អាត្មាអញដេកសិន ។*

មានអត្ថថា ដោយជុំវិញ ដូចក្នុងប្រយោគជាដើមថា **កោសលកប្បំ ជេតវនំ ឯការាសេត្វា** *ញុំាងវត្តជេតពនឲ្យភ្លឺស្វាងដោយជុំវិញ ។*

តែក្នុងសូត្រនេះ **កប្ប** *សព្ទនោះ លោកបំណងយកអត្ថថា ដោយជុំវិញ ដោយប្រការដែលក្នុងពាក្យថា* **កោសលកប្បំ ជេតវនំ** *នេះ គួរនឹងជ្រាបយ៉ាងនេះថា ញុំាងវស្សី ឲ្យភ្លឺពេញវត្តជេតពនដោយជុំវិញ មិនមានសេសសល់ឡើយ ។*

បទថា **ឯការាសេត្វា** *បានដល់ ផ្សាយដោយវស្សី អធិប្បាយថា វស្សីតែមួយ រុងរឿងតែម្យ៉ាង ដូចព្រះចន្ទ និងព្រះអាទិត្យ ។*

បទថា **យេន ភគវា តេនុបសង្កមិ** *ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ដោយប្រការដែលគប្បីឃើញអត្ថក្នុងពាក្យនេះយ៉ាងនេះថា ព្រះ*

មានព្រះភាគប្រថាប់នៅក្នុងទីណា ទេវបុត្រក៏ចូលទៅគាល់ក្នុងទីនោះ ឬគប្បីឃើញក្នុងពាក្យនេះយ៉ាងនេះថា ព្រះមានព្រះភាគ ដែលទេវតា និងមនុស្ស គប្បីចូលទៅគាល់ ដោយហេតុណា ទេវបុត្រក៏ចូលទៅគាល់ដោយហេតុនោះឯង ។ ព្រះមានព្រះភាគ ដែលទេវតា និងមនុស្សនាំគ្នាចូលទៅគាល់ ដោយហេតុណាមួយ ដោយបំណងនឹងសម្រេចគុណវិសេស មានប្រការផ្សេងៗ ដូចដើមឈើធំដែលចេញផ្លែជានិច្ច ដែលហ្វូងបក្សីនាំគ្នាចូលទៅ ដោយបំណងនឹងបរិភោគផ្លែឈើដែលមានរសឆ្ងាញ់ ដូច្នោះ ។ លោកអធិប្បាយថា បទថា **ឧបសង្កមិ** *ប្រែថា ទៅហើយ ។ បទថា* **ឧបសង្កមិត្វា** *ជាពាក្យពោលដល់ចុងក្រោយនៃការចូលទៅគាល់ ។ ម្យ៉ាងទៀត លោកអធិប្បាយថា ទេវតាទៅយ៉ាងនោះហើយ បន្ទាប់អំពីនោះ ក៏ទៅកាន់ទីបន្ទាប់អំពីអាសនៈពោល គឺទីជិតព្រះមានព្រះភាគ ។ បទថា* **ភគវន្តំ អភិវាទេត្វា** *បានដល់ថ្វាយបង្គំ នមស្ការព្រះមានព្រះភាគ ។*

សព្ទថា **ឯកមន្តំ** *ជាសព្ទនិទ្ទេស ធ្វើជាការនបុំសកលិង្គ លោកអធិប្បាយថា ឱកាសមួយ ចំណែកមួយ ។ ម្យ៉ាងទៀត ពាក្យនេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថសត្តមីវិភត្តិ ។ សព្ទថា* **អដ្ឋាសិ** *បដិសេធឥរិយាបថអង្គុយជាដើម អធិប្បាយថា សម្រេចការឈរ គឺបានឈរហើយ ។*

សួរថា ទេវតាទាំងនោះឈរដូចម្តេច ទើបឈ្មោះថា បានជាអ្នកឈរក្នុងចំណែកម្ខាង ។ ឆ្លើយថា បុរាណាចារ្យពោលថា

ន បច្ឆតោ ន បុរតោ ន ចាបិ អាសន្នទូរតោ

ន កច្ចេ នោបិ បដិវាតេ ន ចាបិ ឧណតុណ្ណតេ
ឥមេ ធោសេ វិវជ្ជេត្វា ឯកមន្តំ ឋិតា អហុ ។

មិនឈរខាងក្រោយ មិនឈរខាងមុខ មិនឈរជិត
មិនឈរឆ្វាយ មិនឈរក្នុងទីសើម មិនឈរលើខ្យល់
មិនឈរទីទាប និងទីខ្ពស់ ឈរវៀរទោសទាំងនេះ
ឈ្មោះថា ឈរក្នុងចំណែកម្ខាង ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ទើបទេវតាឈរតែម្យ៉ាង មិនអង្គុយ ។ ឆ្លើយថា ព្រោះទេវតាបំណងត្រឡប់ទៅវិញដោយរហ័ស ពិតហើយ ទេវតាទាំងឡាយ អាស្រ័យអំណាចប្រយោជន៍ណាមួយ ទើបមកកាន់មនុស្សលោក ដូចបុរស អ្នកស្អាតមកចូលបង្គន់ ។ ដោយប្រក្រតី មនុស្សលោករមែងជារបស់បដិកូល ព្រោះជារបស់ស្អុយសម្រាប់ទេវតាទាំងនោះ តាំងអំពី ១០០ យោជន៍ ទេវតាទាំងឡាយ មិនអភិរម្យក្នុងមនុស្សលោកនោះឡើយ ដោយហេតុនោះ ទើបទេវតាអង្គនោះមិនអង្គុយ ព្រោះបំណងធ្វើកិច្ចដែលមក ហើយប្រញាប់ត្រឡប់ទៅ ។ មនុស្សទាំងឡាយ រមែងអង្គុយដើម្បីបន្ទោបង់សេចក្តីលំបាកនៃឥរិយាបថ មានដើរជាដើម យ៉ាងណា ការលំបាកនោះ សម្រាប់ទេវតាមិនមាន ព្រោះដូច្នោះ ទើបទេវតាមិនអង្គុយ ។

ម្យ៉ាងទៀត ព្រះមហាសាវ័កពួកណា ឈរចោមរោមព្រះមានព្រះភាគ ព្រះមានព្រះភាគក៏ទ្រង់រាប់អានព្រះមហាសាវ័កទាំងនោះ គឺទ្រង់ប្រថាប់ឈរដែរ ព្រោះហេតុនោះ ទើបទេវតាមិនអង្គុយ ។

ម្យ៉ាងទៀត ទេវតាមិនអង្គុយ ក៏ព្រោះគោរពក្នុងព្រះមានព្រះភាគ ។ ពិតហើយ អាសនៈរមែងកើតជល់ទេវតាទាំងឡាយ ដែលបំណងនឹងអង្គុយ ទេវតាអង្គនេះមិនប្រាថ្នាអាសនៈទាំងនោះ មិនគិតសូម្បីតែអង្គុយ ទើបឈរក្នុងចំណែកម្ខាង ។

បទថា **ឯកមន្តំ ឋិតា ខោ សា ទេវតា** *សេចក្តីថា ទេវតាអង្គនោះឈរក្នុងទីសមគួរ នាចំណែកម្ខាង ដោយហេតុទាំងនេះយ៉ាងនេះហើយ ។ បទថា* **ភគវន្តំ គាថាយ អជ្ឈភាសិ** *សេចក្តីថា បានទូលព្រះមានព្រះភាគដោយពាក្យកម្រងកែវ ដែលកំណត់ដោយអក្ខរបទ ។ ពោលដូចម្តេច ពោលយ៉ាងនេះថា* **ពហូ ទេវា មនុស្សា ច ។បេ។ ព្រូហិ មង្គលមុត្តមំ ។**

មូលហេតុកើតមង្គលប្បញ្ហា

ក្នុងកិច្ចពណ៌នាមង្គលសូត្រនោះ ព្រោះហេតុដែលខ្ញុំតាំងមាតិកាថា កាលនឹងពណ៌នាសេចក្តីនៃបាឋៈ មាន **ឯវំ** *ជាដើម ដោយប្រការផ្សេងៗ និងពោលជល់សមុដ្ឋាន ដូច្នេះ ។ នេះជាឱកាសដែលនឹងពោលជល់សមុដ្ឋាននោះ ដូច្នោះ នឹងពោលជល់សមុដ្ឋាន មូលហេតុកើតមង្គលប្បញ្ហាជាមុន ហើយនឹងពណ៌នាអត្ថនៃបទគាថាទាំងនេះជាក្រោយ ។*

បានឮថា ក្នុងជម្ពូទ្វីប មហាជនប្រជុំគ្នាក្នុងទីនោះៗ ក្នុងទីនោះៗ ដូចជាក្បែរទ្វារក្រុង សភានៃស្ថានរាជការជាដើម ប្រគល់ទ្រព្យ មាស ប្រាក់ ឲ្យគេនិទានរឿងផ្សេងៗ ដូចជា រឿងនាំនាងសិតាមកជាដើម ។ រឿងនីមួយៗ ពោលអស់ ៤ ខែទើបចប់ ។ ក្នុងទីនោះៗ មួយថ្ងៃៗ រឿងមង្គលប្បញ្ហាកើត

ឡើងថា អ្វីហ្នឹងជាមង្គល វត្ថុដែលឃើញជាមង្គលឬ វត្ថុដែលបានឮជាមង្គលឬ រឿងដែលដឹងជាមង្គលឬ នរណាហ្នឹងស្គាល់មង្គល ដូច្នេះ ។

គ្រានោះ បុរសម្នាក់ ឈ្មោះទិដ្ឋមង្គលិក ជាអ្នករាប់អាន ជឿនូវការឃើញថាជាមង្គល ពោលថា ខ្ញុំស្គាល់មង្គល ។ វត្ថុដែលឃើញជាមង្គលក្នុងលោករូបដែលសន្មតគ្នាថា ជាមង្គលក្រៃលែង ឈ្មោះថា **ទិដ្ឋ** *។ រូបដូចម្តេច បុគ្គលខ្លះ ក្នុងលោកនេះ ក្រាក់អំពីព្រលឹម ឃើញសត្វត្រចៀកកាំក្តី ឃើញដើមញៀជំទង់ក្តី ឃើញស្រីមានគភ៌ក្តី ឃើញក្មេងជំទង់តាក់តែងប្រដាប់កាយ ទូលក្អមទឹកដែលពេញក្តី ឃើញត្រីស្ងិនក្រហមក្តី សេះអាជានេយ្យក្តី រថទឹមដោយសេះក្តី គោឈ្មោលក្តី គោញីក្តី គោក្រហមក្តី ឬថា ឃើញរូបជំទៃណាបែបនោះ ដែលសន្មតគ្នាថា ជាមង្គលក្រៃលែង រូបដែលឃើញនេះ ហៅថា* **ទិដ្ឋមង្គល** *។ បុគ្គលពួកខ្លះ ក៏រមែងទទួលពាក្យរបស់បុគ្គលនោះ ពួកខ្លះក៏មិនព្រមទទួល ពួកដែលមិនព្រមទទួល ក៏ជំទាស់នឹងបុគ្គលទាំងនោះ ។*

គ្រានោះ បុរសម្នាក់ ឈ្មោះសុតមង្គលិកក៏ពោលថា អ្នកអើយ ឈ្មោះថា ក្អែក រមែងឃើញរបស់ស្អាតខ្លះ របស់មិនស្អាតខ្លះ របស់ស្អាត និងមិនស្អាតខ្លះ របស់ពេញចិត្តខ្លះ របស់មិនពេញចិត្តខ្លះ បើរូបដែលបុគ្គលនោះឃើញគប្បីជាមង្គលសោត ក៏គប្បីជាមង្គលទាំងអស់ ព្រោះដូច្នោះ រូបដែលឃើញមិនជាមង្គលឡើយ សំឡេងដែលបានឮឯណោះទេតើ ជាមង្គល ។ សំឡេងដែលសន្មតថា ជាមង្គលក្រៃលែង ។ ឈ្មោះថា សុតៈ ដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ក្រោកឡើងអំពីព្រលឹម បានឮសំឡេងដូច្នេះថា ចម្រើនហើយ

ចម្រើនទៀត ពេញ ស ចិត្តល្អ សិរី ចម្រើនដោយសិរី ថ្លៃនេះឫក្សល្អ យាមល្អ ថ្ងៃល្អ មង្គលល្អ ឬសំឡេងដែលសន្មតថា មង្គលឯណានីមួយ ។ សំឡេងដែលបានឮនេះ ហៅថា **សុតមង្គល** *។ ជនពួកខ្លះក៏រមែងទទួលពាក្យរបស់គាត់ ជនពួកខ្លះក៏មិនព្រមទទួល ពួកដែលមិនព្រមទទួល ក៏ជំទាស់ ។*

គ្រានោះ បុរសម្នាក់ ឈ្មោះមុតមង្គលិក ពោលថា អ្នកអើយ តាមពិតនោះ ឈ្មោះថា ត្រចៀក រមែងបានឮសំឡេងល្អខ្លះ មិនល្អខ្លះ គាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះ បើសំឡេងដែលបុគ្គលនោះបានឮ ជាមង្គលសោត ក៏នឹងជាមង្គលទាំងអស់ទៅហើយ ព្រោះដូច្នោះ ទើបសំឡេងដែលបានឮ មិនជាមង្គលទៀយ តែវត្ថុដែលជីងហើយឯណោះទេតើ ជាមង្គល ក្ងិន រស និងផោដ្ឋព្វៈ វត្ថុដែលគប្បីពាល់ត្រូវ ឈ្មោះថា មុតៈ សេចក្តីនេះ ដូចម្តេច ។ បុគ្គលខ្លះ ក្រោកអំពីព្រលឹម ហិតក្ងិនផ្កា មានផ្កាឈូកជាដើម ទំពាឈើសូនខ្លះ ចាប់ពាល់ផែនដីខ្លះ ចាប់ពាល់សន្ធឹងពណ៌ខៀវខ្លះ អាចម៍គោស្រស់ខ្លះ អណ្តើកខ្លះ លូខ្លះ ផ្កាខ្លះ ផ្លែឈើខ្លះ លាបដោយដីសដោយប្រពៃខ្លះ ស្លៀកសំពត់សខ្លះ ជូតដោយសំពត់សខ្លះ ឬថា ហិតក្ងិន លិទ្ធរស ពាល់ត្រូវផោដ្ឋព្វៈ ដែលសន្មតថា ជាមង្គលក្រៃលែងជនៃណាមួយបែបនោះ វត្ថុដូចពោលមកនេះ ហៅថា **មុតមង្គល** *។ ពួកខ្លះ ក៏រមែងទទួលពាក្យរបស់គាត់ ពួកខ្លះ ក៏មិនព្រមទទួល ។*

ក្នុង ៣ ពួកនោះ ទិដ្ឋមង្គលិកបុរស មិនអាចធ្វើឲ្យសុតមង្គលិកបុរស និងមុតមង្គលិកបុរសយល់ព្រមបាន ទាំង ៣ ចំណែកនោះ ចំណែកនីមួយៗ

ក៏ធ្វើ ២ ចំណែកទៀត ឲ្យយល់ព្រមមិនបាន បណ្តាមនុស្សទាំងនោះ មនុស្ស ពួកណា ទទួលពាក្យរបស់ទិដ្ឋមង្គលិកបុរស ពួកនោះក៏ប្រកាន់ថា រូបដែល ឃើញហើយប៉ុណ្ណោះជាមង្គល ។ ពួកណាវិមែងទទួលពាក្យរបស់សុតមង្គលិក-កបុរស និងមុតមង្គលិកបុរស ពួកនោះក៏កាន់យកសំឡេងដែលបានឮប៉ុណ្ណោះ ជាមង្គល វត្តុដែលបានជីងប៉ុណ្ណោះជាមង្គល ។ រឿងមង្គលប្បញ្ហានេះ ប្រាកដ ពេញជម្ពូទ្វីប ដោយប្រការដូច្នេះ ។

គ្រានោះ មនុស្សពេញជម្ពូទ្វីប ប្រកាន់ជាពួកៗ នាំគ្នាគិតមង្គលទាំងឡាយ ថា អ្វីហ្ន៎ ជាមង្គល ។ អារក្ខទេវតានៃមនុស្សទាំងនោះ ស្តាប់រឿងនោះហើយ ក៏នាំគ្នាគិតមង្គលទាំងឡាយដូចគ្នា ។ ទាំងពួកភុម្មទេវតាជាសម្ងាញ់នៃទេវតា ទាំងនោះ ស្តាប់រឿងអំពីអារក្ខទេវតាទាំងនោះហើយ ក៏នាំគ្នាគិតមង្គលទាំង នោះដូចគ្នា ។ អាកាសដ្ឋកទេវតា ជាមិត្តរបស់ទេវតាទាំងនោះ ចាតុម្មហារាជិ-កទេវតាជាមិត្តរបស់អាកាសដ្ឋកទេវតាទាំងនោះ ដោយឧបាយនេះ ដរាបដល់ អកនិដ្ឋទេវតាជាមិត្តរបស់សុទស្សីទេវតា ស្តាប់រឿងអំពីសុទស្សីទេវតាទាំង នោះហើយ ក៏កាន់យកជាពួកៗ នាំគ្នាគិតមង្គលទាំងឡាយ ដោយឧបាយយ៉ាង នេះ ការគិតមង្គលបានកើតគ្រប់ទីកន្លែង រហូតដល់ម៉ឺនចក្រវាល ។ ការគិត មង្គលកើតឡើងហើយ សូម្បីវិនិច្ឆ័យថា នេះជាមង្គល នេះជាមង្គល តែក៏មិន ជាប់ស្រេច ទើបតាំងនៅអស់ ១២ ឆ្នាំ មនុស្សក្តី ទេវតាក្តី ព្រហ្មទាំងអស់ក្តី រៀរព្រះអរិយសាវក បែកគ្នាជា ៣ ពួក គឺទិដ្ឋមង្គលិក ១ ពួក សុតមង្គលិក ១ ពួក និងមុតមង្គលិក ១ ពួក សូម្បី ១ ពួកៗ ក៏មិនយល់ព្រមតាមការ

ពិតបានថា នេះប៉ុណ្ណោះ ជាមង្គល មង្គលកោលាហល គឺការជ្រួលច្របល់ រឿងមង្គលកើតឡើងហើយក្នុងលោក ។

*ឈ្មោះថា កោលាហលមាន ៥ គឺកប្បកោលាហល ១ ចក្កវត្តិកោលាហល ១ ពុទ្ធកោលាហល ១ មង្គលកោលាហល ១ មោនេយ្យកោលាហល ១ ។ បណ្តាកោលាហលទាំង ៥ នោះ ពួកទេវតាជាន់កាមាវចរ ឱនក្បាលរម្យាយសក់ ទ្រហោយំ យកដៃជូតទឹកភ្នែក ស្បៀកសំពត់ពណ៌ក្រហម ទ្រទ្រង់ភេទចម្លែកៗ ក្រៃលែង ត្រាច់ទៅក្នុងទឹកដីមនុស្ស ស្រែកប្រកាសថា កន្លងទៅមួយសែនឆ្នាំទៀត កប្បនឹងប្រាកដ លោកនេះនឹងវិនាស មហាសមុទ្រនឹងរីងស្ងួត មហាប្រឹថពីនេះ និងស្តេចភ្នំសិនេរុនឹងត្រូវភ្លើងឆេះ នឹងវិនាស លោកវិនាសនឹងមានដល់ព្រហ្មលោក ។ នែអ្នកនិទ្ទុក្ខ សូមអ្នកទាំងឡាយនាំគ្នាចម្រើនមេត្តាចុះ ចូរនាំគ្នាចម្រើនករុណា មុទិតា ឧបេក្ខាចុះ អ្នកនិទ្ទុក្ខ ចូរបម្រើមាតាបិតា ចូរកោតក្រែងបុគ្គលជាធំក្នុងត្រកូល ជាអ្នកក្សាក់រឭកចុះ កុំប្រមាទឡើយ នេះ ឈ្មោះថា **កប្បកោលាហល ។***

*ទេវតាជាន់កាមាវចរនោះឯង ត្រាច់ទៅក្នុងទឹកដីមនុស្ស ប្រកាសថា កន្លងទៅ ១០០ ឆ្នាំ ស្តេចចក្រពត្តិ នឹងកើតឡើងក្នុងលោក នេះ ឈ្មោះថា **ចក្កវត្តិកោលាហល ។** ឯទេវតាជាន់សុទ្ធាវាស ប្រជាប់ខ្លួនដោយអាភរណៈព្រហ្ម ជូតក្បាលដោយឆ្នួតព្រហ្ម កើតបីតិបាមោជ្ជ ពោលពុទ្ធគុណ ត្រាច់ទៅក្នុងទឹកដីមនុស្ស ប្រកាសថា កន្លងទៅ ១០០០ ឆ្នាំ ព្រះពុទ្ធនឹងកើតឡើងក្នុងលោក នេះ ឈ្មោះថា **ពុទ្ធកោលាហល ។***

ទេវតាជាន់សុទ្ធាវាសនោះឯង ដឹងចិត្តរបស់ពួកមនុស្ស ត្រាច់ទៅក្នុងទឹកជីមនុស្ស ប្រកាសថា កន្លងទៅ ១២ ឆ្នាំ ព្រះសម្មាសម្ពុទ្ធនឹងត្រាស់មង្គលនេះ ឈ្មោះថា **មង្គលកោលាហាល ។**

ទេវតាជាន់សុទ្ធាវាសនោះឯង ត្រាច់ទៅក្នុងទឹកជីមនុស្ស ប្រកាសថា កន្លងទៅ ៧ ឆ្នាំ ភិក្ខុមួយរូប សមាគមជាមួយនឹងព្រះមានព្រះភាគ នឹងទូលសួរមោនេយ្យប្បដិបទា នេះ ឈ្មោះថា **មោនេយ្យកោលាហាល ។** *បណ្តាកោលាហាលទាំង ៥ នេះ មង្គលកោលាហាលរបស់ទេវតា និងមនុស្សទាំងឡាយ កើតឡើងហើយក្នុងលោក ។*

គ្រានោះ កាលទេវតា និងមនុស្សទាំងឡាយ នាំគ្នាសម្រេចមិនទាន់បាននូវមង្គលទាំងឡាយ កន្លងទៅ ១២ ឆ្នាំ ទេវតាជាន់តាវត្តិង្សក៏ប្រជុំគ្នា នាំគ្នាគិតយ៉ាងនេះថា មេផ្ទះ ក៏ជាម្ចាស់របស់មនុស្សក្នុងផ្ទះ មេស្រុក ក៏ជាប្រធានរបស់មនុស្សដែលនៅក្នុងស្រុក ព្រះរាជាជាប្រធានរបស់មនុស្សទាំងឡាយ សក្កទេវរាជអង្គនេះ ក៏ជាបុគ្គលប្រសើរបំផុតរបស់ពួកយើង គឺជាអធិបតីនៃទេវលោកទាំង ២ គឺចាតុម្មហារាជិកា និងតាវត្តិង្ស ដោយបុញ្ញ តេជៈ ឥស្សរិយបញ្ញា ។ ហេតុនេះ យើងគប្បីនាំគ្នាទៅទូលសេចក្តីនោះនឹងសក្កទេវរាជ ស្តេចទេវតាចុះ ។ ទេវតាទាំងនោះ ក៏នាំគ្នាទៅកាន់សម្នាក់ទេវរាជ ថ្វាយបង្គំសក្កទេវរាជដែលមានព្រះសិរីរៈ មានសិរី ដោយអាការណៈប្រចាំព្រះអង្គដែលសមគួរដល់ខណៈនោះ មានពួកទេពអប្សរ ២៥០ កោដិ[1] ប្រថាប់លើ

១- ក្នុងទីខ្លះ ពាក្យថា អឌ្ឍតេយ្យកោដិ នេះ លោកប្រែថា ២ កោដិកន្លះ ។

បណ្ឌុកម្ពលសិលាអាសនៈដ៏ប្រសើរ ខាងក្រោមដើមបាវិច្ឆត្តកៈ ហើយឈរក្នុងទីសមគួរ នាចំណែកម្ខាង ទូលថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ សូមទ្រង់ប្រទានទូវព្រះវរោកាស សូមទ្រង់ជ្រាបចុះ ឥឡូវនេះ មង្គលប្បញ្ហាតាំងឡើងហើយ ជន ១ ពួកពោលថា រូបដែលឃើញជាមង្គល ១ ពួកពោលថា សំឡេងដែលបានឮជាមង្គល ១ ពួកពោលថា វត្ថុដែលដឹងហើយជាមង្គល បណ្តាអ្នកទាំងនោះ ពួកទូលបង្គំ និងពួកជនដទៃ មិនទាន់បានទូវភាពត្រឹមត្រូវ សូមទ្រង់ព្រះមេត្តាព្យាករតាមសេចក្តីពិតដល់ពួកទូលបង្គំផងចុះ ។ សក្កទេវរាជ ដោយប្រក្រតី ទ្រង់មានបញ្ញា ទើបត្រាស់ថា រឿងមង្គលនេះ កើតឡើងទីណាមុន ពួកទេវតាក្រោបទូលថា បពិត្រមហារាជ ពួកទូលបង្គំស្តាប់ពាក្យទេវតាចាតុម្មហារាជ បន្ទាប់អំពីនោះ ពួកទេវតាចាតុម្មហារាជ ស្តាប់ពាក្យរបស់ពួកអាកាសដ្ឋកទេវតា ពួកអាកាសដ្ឋកទេវតា ស្តាប់ពាក្យរបស់ពួកភុម្មទេវតា ពួកភុម្មទេវតាស្តាប់ពាក្យរបស់ទេវតាដែលរក្សាមនុស្ស ទេវតាដែលរក្សាមនុស្សពោលថា រឿងមង្គលកើតឡើងក្នុងមនុស្សលោក ។

លំដាប់នោះ សក្កទេវរាជត្រាស់សួរស្តេចទេវតាទាំងនោះថា ព្រះសម្ពុទ្ធប្រថាប់នៅទីណា ។ ទេវតាទាំងឡាយទូលថា ប្រថាប់នៅក្នុងមនុស្សលោក ព្រះឥន្ទ្រត្រាស់សួរថា បុគ្គលណាម្នាក់ បានទូលសួរព្រះមានព្រះភាគអង្គនោះហើយឬនៅ ពួកទេវតាទូលថា មិនមានទេ ព្រះអង្គ ។ ព្រះឥន្ទ្រត្រាស់ថា នែអ្នកនិទ្ទុក្ខ ហេតុអ្វីអ្នកទាំងឡាយបោះបង់គំនរភ្លើង ហើយមកសម្លាប់ក្នុងពន្ធីអំពិលអំពែក ហេតុអ្វី ទើបអ្នកទាំងឡាយរំលងព្រះមានព្រះភាគ ដែលទ្រង់

សម្តែងមង្គលមិនមានសេសសល់ មកសម្គាល់ខ្ញុំថា គួរសាកសួរ ណ្ហើយចុះ អ្នកនិទ្ទុក្ខទាំងឡាយ យើងនឹងសាកសួរព្រះមានព្រះភាគអង្គនោះ ពួកយើងនឹងបានការព្យាករណាប្បញ្ហាដ៏មានសិរីពិត ទើបមានទេវោង្ការ ប្រើទេវបុត្រមួយអង្គថា អ្នកចូរទៅទូលសួរព្រះមានព្រះភាគចុះ ។ ទេវបុត្រអង្គនោះ តាក់តែងគ្រឿងអលង្ការដ៏សមគួរដល់ខណៈ រុងរឿងដូចផ្ទេកបន្ទោរ មានពួកទេវតាចោមរោម ទៅកាន់វត្តជេតពនមហាវិហារ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរក្នុងទីសមគួរ នាចំណែកម្ខាង កាលសួរមង្គលប្បញ្ហា ទើបពោលជាគាថាថា **ពហូ ទេវា មនុស្សា ច** *ជាដើម ។*

នេះជាមូលហេតុនៃមង្គលប្បញ្ហា ។

អធិប្បាយបទថា ពហូ ទេវា

ឥឡូវនេះ នឹងពណ៌នាអត្ថនៃបទគាថា ។ សព្ទថា **ពហូ** *សម្តែងចំនួនមិនពិតប្រាកដ ព្រោះហេតុនោះ ទើបលោកអធិប្បាយថា ច្រើនរយ ច្រើនពាន់ ច្រើនសែន ។ ឈ្មោះថា* **ទេវ** *ព្រោះលេង អធិប្បាយថា លេងជាមួយកាមគុណ ៥ ឬរុងរឿងដោយសិរីរបស់ខ្លួន ។ ន័យម្យ៉ាងទៀត បទថា* **ទេវា** *បានដល់ ទេវៈទាំង ៣ គឺ* **សម្មតិទេវ ឧបបត្តិទេវ** *និង* **វិសុទ្ធិទេវ** *ដូចលោកពោលថា*

បទថា **ទេវា** *បានដល់ ទេវៈ ៣ គឺសម្មតិទេវៈ ១ ឧបបត្តិទេវៈ ១ និងវិសុទ្ធិទេវៈ ១ ។*

បណ្តាទេវៈទាំង ៣ នោះ ពួកព្រះរាជា ព្រះរាជកុមារ

និងព្រះទេពី លោកហៅថា សម្មុតិទេព ។ ពួកទេព ឋិតនៅក្នុងចាតុម្មហារាជិកាទ្បើងទៅ លោកហៅថា ឧបបត្តិទេព ។ ពួកព្រះអរហន្តខីណាស្រពជាសាវ័ករបស់ ព្រះតថាគត និងពួកខីណាស្រពដែលជាព្រះបច្ចេកពុទ្ធ លោកហៅថា វិសុទ្ធិទេព ។

ក្នុងទេវៈទាំង ៣ នោះ ក្នុងសូត្រនេះ លោកបំណងយកឧបបត្តិទេព ។ ឈ្មោះថា **មនុស្សា** *ព្រោះជាវង្សរបស់ព្រះបាទមនុ តែបុរាណពោលថា ឈ្មោះថា* **មនុស្ស** *ព្រោះជាអ្នកមានចិត្តខ្ពស់ ។ មនុស្សទាំងនោះមាន ៤ គឺអ្នកជម្ពូទ្បីប ១ អ្នកអមរគោយានទ្បីប ១ អ្នកឧត្តរកុរុទ្បីប ១ អ្នកបុព្វវិទេហទ្បីប ១ ។ ក្នុងសូត្រនេះ លោកបំណងយកអ្នកជម្ពូទ្បីប ឈ្មោះថា* **មង្គលានិ** *ព្រោះសត្វរុងរឿងដោយគុណទាំងនេះ អធិប្បាយថា សត្វដល់នូវការសម្រេច និងសេចក្តីចម្រើន ។*

បទថា **អចិន្តយុំ** *ប្រែថា គិតគ្នាហើយ ។ បទថា* **អាកង្ខមានា** *បានដល់ បំណង ប្រាថ្នា ត្រូវការ ។ បទថា* **សោត្ថានំ** *ប្រែថា សួស្តី លោកអធិប្បាយថា ភាពដែលធម៌ទាំងឡាយប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងចំណែកខាងមុខគ្រប់យ៉ាង ស្អាតល្អ ។ បទថា* **ព្រូហិ** *បានដល់ សម្តែង ប្រកាស ប្រាប់ បើកផ្លូវ ចែក ធ្វើឲ្យងាយ ។ បទថា* **មង្គលំ** *បានដល់ ហេតុនៃការសម្រេច ហេតុនៃសេចក្តីចម្រើន ហេតុនៃសម្បត្តិគ្រប់យ៉ាង ។ បទថា* **ឧត្តមំ** *បានដល់ វិសេសប្រសើរ នាំប្រយោជន៍ និងសេចក្តីសុខមកឲ្យដល់លោកទាំងពួង*

ដូចពោលមកនេះ ជាការពណ៌នាតាមលំដាប់បទនៃគាថាទាំងឡាយ ។

ឯសេចក្តីរួម មានដូច្នេះ ទេវបុត្រនោះឯង ឃើញទេវតាក្នុងម៉ឺនចក្រវាល ប្រជុំគ្នាក្នុងចក្រវាលនេះ ព្រោះចង់ស្តាប់មង្គលប្បញ្ហា នាំគ្នានិម្មិតអត្តភាពដ៏ល្អិត ១០ ខ្នះ ២០ ខ្នះ ៣០ ខ្នះ ៤០ ខ្នះ ៥០ ខ្នះ ៦០ ខ្នះ ៧០ ខ្នះ ៨០ ខ្នះ ។ ទំហំ ឱកាសចុងភេមទ្រាយ ១ ឈរជុំវិញព្រះមានព្រះភាគ ដែលប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរ បញ្ចេញព្រះរស្មី គ្របសង្កត់ទេវតា មារ ព្រហ្មទាំងអស់ ដោយព្រះសិរី និងព្រះតេជៈ ហើយទ្រង់ជ្រាបវិតក្កនៃចិត្តនៃពួកមនុស្សអ្នកជម្ពូទ្វីប ដែលមិនបានមកប្រជុំ ក្នុងសម័យនោះដោយចិត្តខ្លួនឯង ទើបពោលគាថា ដើម្បីដកនូវព្រួញ គឺសេចក្តីសង្ស័យរបស់ទេវតា និងមនុស្សទាំងពួងថា

ទេវតា និងមនុស្សទាំងឡាយជាច្រើន ប្រាថ្នារកសួស្តី
បានគិតរកមង្គលទាំងឡាយ សូមព្រះអង្គសម្តែងប្រាប់
នូវមង្គលដ៏ឧត្តម ។

បពិត្រព្រះមានព្រះភាគ ទ្រង់ជាអ្នកដែលខ្ញុំព្រះអង្គទូលសួរហើយ ដោយអនុមតិរបស់ទេវតាទាំងនោះ និងដោយអនុគ្រោះមនុស្សទាំងឡាយ មង្គលឯណា ដែលជាឧត្តមមង្គល ព្រោះនាំមកនូវប្រយោជន៍ និងសេចក្តីសុខដល់ខ្ញុំព្រះអង្គទាំងឡាយ សូមទ្រង់អាស្រ័យព្រះករុណាត្រាស់ប្រាប់មង្គលនោះដល់ខ្ញុំព្រះអង្គទាំងឡាយចុះ ។

អធិប្បាយបទថា អសេវនា ច

ព្រះមានព្រះភាគ ទ្រង់ស្តាប់ពាក្យទេវបុត្រនោះយ៉ាងនេះហើយ ទើបត្រាស់ព្រះគាថាថា **អសេវនា ច ពាលានំ** ជាដើម ។ ក្នុងព្រះគាថានោះ បទថា **អសេវនា** បានដល់ ការមិនគប់ មិនចូលទៅជិត ។

បទថា **ពាលានំ** សេចក្តីថា ឈ្មោះថា ពាល ព្រោះរស់នៅ ជកជង្ហើម បាន អធិប្បាយថា រស់នៅដោយត្រឹមតែជកជង្ហើមចេញ-ចូល មិនរស់នៅដោយការរស់នៅដោយបញ្ញា ។ នូវពាលទាំងនោះ ។

បទថា **បណ្ឌិតានំ** សេចក្តីថា ឈ្មោះថា បណ្ឌិត ព្រោះប្រព្រឹត្តទៅ អធិប្បាយថា ប្រព្រឹត្តទៅដោយគតិ គឺការដឹងក្នុងប្រយោជន៍ដែលជាបច្ចុប្បន្ន និងប្រយោជន៍ខាងមុខ ។ នូវបណ្ឌិតទាំងនោះ ។

បទថា **សេវនា** បានដល់ ការគប់រក ការចូលជិត ការមានបណ្ឌិតនោះជាសម្ងាញ់ មានបណ្ឌិតនោះជាមិត្រ ការដល់ព្រមដោយបណ្ឌិតនោះ ។

បទថា **បូជា** បានដល់ ធ្វើសក្ការៈ គោរពរាប់អាន ក្រាបថ្វាយបង្គំ ។

បទថា **បូជនីយានំ** ប្រែថា បុគ្គលគួរបូជា ។

បទថា **ឯតម្មង្គលមុត្តមំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ប្រមូលការមិនសេពគប់បុគ្គលពាល ១ ការគប់រកបណ្ឌិត ១ ការបូជាដល់បុគ្គលដែលគួរបូជា ១ ទើបត្រាស់ថា **ឯតម្មង្គលមុត្តមំ ។** លោកអធិប្បាយថា ពាក្យណាលោកសួរថា សូមត្រាស់ប្រាប់មង្គលដ៏ឧត្តមចុះ អ្នកចូរកាន់យកពាក្យនោះថា មង្គលដ៏ឧត្តមក្នុងសេចក្តីនោះមុន នេះជាពណ៌នាបទនៃគាថានោះ ។

ឯពណ៌នាអត្ថនៃបទនោះ គប្បីជ្រាបដូច្នេះ ព្រះមានព្រះភាគទ្រង់ស្តាប់

ពាក្យរបស់ទេវបុត្រនោះហើយ ទើបត្រាស់ព្រះគាថានេះថា **អសេវនា ច ពាលានំ** *ជាដើម ។*

ក្នុងគាថានោះ គាថាមាន ៤ គឺ **បុច្ឆិតគាថា អបុច្ឆិតគាថា សាធុ-សន្ធិកគាថា អនធុសន្ធិកគាថា ។**

បណ្តាគាថាទាំង ៤ នោះ គាថាដែលទ្រង់ត្រូវសួរហើយ ទើបត្រាស់ឈ្មោះថា **បុច្ឆិតគាថា** *ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា* **បុច្ឆាមិ តំ គោតម ភូរិបញ្ញ កថំករោ សាវកោ សាធុ ហោតិ** *បពិត្រព្រះគោតមទ្រង់មានព្រះបញ្ញាដូចផែនដី ខ្ញុំសូមក្រាបទូលសួរព្រះអង្គ (បុគ្គលដែលចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្តី ឬក៏ពួកឧបាសកមានផ្ទះក្តី) ប្រតិបត្តិដូចម្តេច ទើបហៅថា សាវកល្អ ។ និងដូចប្រយោគថា* **កថំ នុ តុំ មារិស ទិយមតារិ** *បពិត្រព្រះអង្គនិទ្ទុក្ខ ព្រះអង្គឆ្ងន់នូវអន្ទង់ ដោយហេតុដូចម្តេចហ្ន៎ ។*

គាថាដែលព្រះអង្គមិនត្រូវអ្នកដទៃសួរ ទ្រង់ត្រាស់ដោយព្រះអធ្យាស្រ័យរបស់ព្រះអង្គឯង ឈ្មោះថា **អបុច្ឆិតគាថា** *ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា* **យំ បរេ សុខតោ អាហុ តទរិយា អាហុ ទុក្ខតោ** *ពួកជនពាលជនៃពោលនូវវត្ថុកាមណា ថាជាសុខ ព្រះអរិយៈទាំងឡាយ ពោលនូវវត្ថុកាមនោះ ថាជាទុក្ខ ។ គាថាទាំងអស់របស់ព្រះពុទ្ធទាំងឡាយ ឈ្មោះថា* **សាធុ-សន្ធិកគាថា** *ព្រោះបាលីថា* **សនិទានានាហំ ភិក្ខវេ ធម្មំ ទេសេស្សាមិ** *ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងធម៌សមតាមហេតុ ដូច្នេះ ។ ដែលឈ្មោះថា* **អនធុសន្ធិកគាថា** *គាថាមិនមានហេតុ មិនមានក្នុងសាសនានេះ បណ្តាគាថា*

ទាំងនេះ ដូចពោលមកនេះ គាថានេះ ឈ្មោះថា **បុច្ឆិតគាថា** *ព្រោះជាគាថាដែលព្រះមានព្រះភាគត្រូវទេវបុត្រសួរហើយ ទើបត្រាស់តប ។ គាថានេះ ច្រាប់បុគ្គលដែលមិនគួរសេពគប់ ក្នុងបុគ្គលដែលគួរសេពគប់ និងមិនគួរសេពគប់ហើយ ទើបច្រាប់បុគ្គលដែលគួរសេពគប់ ប្រៀបដូចបុរសអ្នកឈ្វាសស្គាល់ផ្លូវផង ស្គាល់វត្តុដែលមិនមែនផ្លូវផង ត្រូវគេសួរដល់ផ្លូវ ទើបច្រាប់ផ្លូវដែលគួរវៀរជាមុនហើយ ក្រោយមក ទើបច្រាប់ផ្លូវដែលគួរកាន់យកថា ក្នុងទីត្រង់នោះ មានផ្លូវបែកជា ២ ក្នុងផ្លូវបែកជា ២ នោះ ពួកអ្នកចូរវៀរបង់នូវផ្លូវខាងឆ្វេង ហើយកាន់យកផ្លូវខាងស្តាំ ដូច្នោះ ។ ព្រះមានព្រះភាគ ទ្រង់ដូចបុរសអ្នកឈ្វាសក្នុងផ្លូវ ដែលត្រាស់ថា*

> *ម្នាលតិស្សៈ ពាក្យថា បុរសអ្នកឈ្វាសក្នុងផ្លូវនេះ ជាឈ្មោះរបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ពិតហើយ តថាគតអរហន្តសម្មាសម្ពុទ្ធនោះ ទ្រង់ជាអ្នកឈ្វាសក្នុងលោកនេះ ជាអ្នកឈ្វាសក្នុងលោកដទៃ ឈ្វាសក្នុងទឹកដីមច្ចុផង ឈ្វាសក្នុងទឹកដីមិនមែនជារបស់មច្ចុផង ទ្រង់ឈ្វាសក្នុងការជីងនូវអន្ទាក់នៃមារ និងមិនមែនអន្ទាក់នៃមារ ។*

ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលត្រាស់ច្រាប់ដល់បុគ្គលដែលមិនគួរសេពគប់ ទើបត្រាស់ថា ការមិនសេពគប់បុគ្គលពាល ការសេពគប់បណ្ឌិត សេចក្តីពិត បុគ្គលពាលទាំងឡាយមិនគួរសេពគប់ មិនគួរចូលជិត ដូចផ្លូវ

ដែលគួរវៀរ បន្ទាប់អំពីនោះ ក៏គួរសេពគប់ គួរចូលជិត តែបណ្ឌិតដូចជាផ្លូវដែលគួរកាន់យក ។ អ្នកចោទសួរ ពោលថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់មង្គល ត្រាស់ការមិនសេពគប់បុគ្គលពាល និងការសេពគប់បណ្ឌិតមុន សេចក្តីនេះ ចង្អុលបង្ហាញដូច្នេះថា ព្រោះពួកទេវតា និងមនុស្ស ប្រកាន់នូវការឃើញ ថាជាមង្គល ក្នុងវត្ថុដែលឃើញហើយជាដើម ដោយការសេពគប់បុគ្គលពាល ទាំងការសេពគប់បុគ្គលពាលនោះ ក៏មិនជាមង្គលដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់តិះដៀលការសមាគមជាមួយនឹងបុគ្គលដែលមិនមែនកល្យាណមិត្រ ដែលកាច់បំបាក់នូវប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ ហើយទ្រង់សរសើរការសមាគមជាមួយនឹងកល្យាណមិត្រ ដែលឲ្យសម្រេចប្រយោជន៍ក្នុងលោកទាំង ២ ទើបត្រាស់ការមិនសេពគប់បុគ្គលពាល និងការសេពគប់បណ្ឌិតមុន ដល់ទេវតា និងមនុស្សទាំងនោះ ។

សត្វទាំងឡាយគ្រប់ប្រភេទ ដែលប្រកបដោយអកុសលកម្មបថ មានបាណាតិបាតជាដើម ឈ្មោះថា ពាល ក្នុងចំនួនពាល និងបណ្ឌិតនោះ ។ ពាលទាំងនោះនឹងដឹងបានដោយអាការទាំង ៣ ដូចព្រះមានព្រះភាគត្រាស់នៅក្នុងព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយ ពាលលក្ខណៈ មាន ៣ ។ ម្យ៉ាងទៀត គ្រូទាំង ៦ មានបូរណកស្សបជាដើម និងសត្វដទៃៗ ទាំងនោះ គឺទេវទត្ត កោកាលិកៈ កដមោតិកៈ តិស្សខណ្ឌាទេវីបុត្រ សមុទ្ទទត្តៈ ចិញ្ចមាណវិកា ជាដើម និងបងប្រុសរបស់ទីឃវិទៈ ក្នុងអតីតកាល គប្បីជ្រាបថាជាពាល ។

ពាលទាំងនោះ រមែងញុំាងខ្លួនឯង និងអ្នកដទៃដែលធ្វើតាមពាក្យរបស់

ខ្ជនឲ្យវិនាស ដោយទិដ្ឋិគត: គឺការឃើញដែលខ្ជនកាន់យកមិនល្អ ដូចផ្ទះដែលត្រូវភ្លើងឆេះ ដូចបង់ប្រុសរបស់ទីឃវិទ: ធ្លាក់ចុះដេកផ្ងារ ដោយអត្តភាពប្រមាណ ៦០ យោជន៍ ឆេះនៅក្នុងមហានរកអស់ ៤ ពុទ្ធន្តរ និងដូចត្រកូល ៥០០ ដែលគាប់ចិត្តក្នុងទិដ្ឋិរបស់បង់ប្រុសនៃទីឃវិទ:នោះ ត្រកូលទាំងនោះនៅរួមជាសម្ងាញ់របស់បង់ប្រុសនៃទីឃវិទ:នោះឯង ឆេះក្នុងមហានរក ដូច្នោះ សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា

> *ម្នាលភិក្ខុទាំងឡាយ ភ្លើងតែងឆេះរាលអំពីផ្ទះបបុស ឬផ្ទះស្មៅ មកឆេះផ្ទះកំពូលទាំងឡាយ ដែលគេលាបទាំងខាងក្នុងទាំងខាងក្រៅ មិនមានខ្យល់ចូល មានសន្ទះទ្វារដ៏ជិតស្និទ្ធ មានបង្អួចបិទជិតបាន ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភ័យទាំងឡាយ ណាមួយកើតឡើង ភ័យទាំងអស់នោះ តែងកើតឡើងអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ឧបទ្រពទាំង-ឡាយ ណាមួយកើតឡើង ឧបទ្រពទាំងអស់នោះ តែងកើតឡើងអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ឧបសគ្គទាំង-ឡាយ ណាមួយកើតឡើង ឧបសគ្គទាំងអស់នោះ តែងកើតអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ក៏ដូច្នោះដែរ ។*

ម្យ៉ាងទៀត បុគ្គលពាលដូចត្រីស្អុយ បុគ្គលសេពគប់បុគ្គលពាលនោះដូចស្លឹកឈើដែលខ្ចប់ត្រីស្អុយ រមែងជួបនូវភាវ:ដែលវិញ្ញូជនបោះចោល និងរង្កៀស សមដូចព្រះមានព្រះភាគត្រាស់ថា

បូតិមច្ឆំ កុសគ្គេន យោ នរោ ឧបនេយ្ហតិ
កុសាបិ បូតី វាយន្តិ ឯវំ ពាលូបសេវនា ។

ជនណាខ្ចប់នូវត្រីស្អុយដោយចុងស្មៅក្តាំង សូម្បីស្មៅក្តាំង ក៏មានក្លិនស្អុយផ្សាយចេញ ការគប់រកនូវបុគ្គលពាល (របស់ជននោះ) ក៏យ៉ាងនោះដែរ ។

ម្យ៉ាងទៀត កាលសក្កទេវរាជប្រទានពរដល់អកិត្តិបណ្ឌិត ក៏ពោលយ៉ាងនេះថា

ពាលំ ន បស្សេ ន សុណេ ន ច ពាលេន សំវសេ
ពាលេនល្ហាបសល្ហាបំ ន កយិរា ន ច រោចយេ ។

បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា អាត្មាសូមកុំឲ្យជួបនឹងមនុស្សពាល សូមកុំឲ្យឮដំណឹងមនុស្សពាល សូមកុំឲ្យនៅរួមនឹងមនុស្សពាល សូមកុំឲ្យបានធ្វើ ទាំងកុំឲ្យពេញចិត្តនឹងការចរចាទៅមកនឹងមនុស្សពាល ។

សក្កទេវរាជត្រាស់សួរថា

កិន្នុ តេ អករំ ពាលោ វធ កស្សប ការណំ
កេន កស្សប ពាលស្ស ឧស្សុកំ នាភិកង្ខសិ ។

មនុស្សពាលបានធ្វើអ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោកមិនប្រាថ្នាជួបមនុស្សពាល ។

អកិត្តិបណ្ឌិតឆ្លើយថា

អនយំ ឆយតិ ទុម្មេធោ អធុរាយំ និយុញ្ជតិ
ទុន្នយោ សេយ្យសោ ហោតិ សម្មា វុត្តោ បកុប្បតិ
វិនយំ សោ ន ជានាតិ សាធុ តស្ស អទស្សនំ។

បុគ្គលពាល រមែងណែនាំនូវអំពើមិនគួរណែនាំ រមែងប្រកបក្នុងកិច្ចមិនមែនជាធុរៈ ការណែនាំទៅរកអាក្រក់ជាការប្រសើរ (របស់បុគ្គលពាលនោះ) បុគ្គលពាលបើទុកជាគេនិយាយត្រូវ ក៏នៅតែខឹង បុគ្គលពាលរមែងមិនដឹងច្បាប់អ្វីទេ ការមិនជួបប្រទះនឹងបុគ្គលពាលនោះជាការប្រពៃ ។

ព្រះមានព្រះភាគ កាលទ្រង់តិះដៀល ការសេពគប់បុគ្គលពាល ដោយអាការទាំងពួងយ៉ាងនេះ ទើបត្រាស់ថា ការមិនសេពគប់បុគ្គលពាល ជាមង្គល ឥឡូវនេះ កាលទ្រង់សរសើរ ការសេពគប់បណ្ឌិត ទើបត្រាស់ថា ការសេពគប់បណ្ឌិត ជាមង្គល ។

សត្វគ្រប់ប្រភេទ ដែលប្រកបដោយកុសលកម្មបថ ១០ មានចេតនាវៀរចាកបាណាតិបាតជាដើម ឈ្មោះថា បណ្ឌិត ។

ក្នុងពួកពាល និងបណ្ឌិតនោះ ។

បណ្ឌិតទាំងនោះ គប្បីដឹងបានដោយអាការ ៣ យ៉ាង ដូចព្រះមានព្រះភាគត្រាស់ក្នុងសូត្រថា ម្នាលភិក្ខុទាំងឡាយ បណ្ឌិតលក្ខណៈ គឺលក្ខណៈ

របស់បណ្ឌិតមាន ៣ ។ ម្យ៉ាងទៀត ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអសីតិ-មហាសាវក សាវកដទៃៗ របស់ព្រះតថាគត និងបណ្ឌិត មានសុនេត្តសាស្តា មហាគោវិន្ទសាស្តា វិធុរបណ្ឌិត សរភង្គតាបស ព្រះមហោសថ សុត្តសោម-បណ្ឌិត ព្រះបាទនិមិរាជ អយោឃរកុមារ និងអគិត្តិបណ្ឌិតជាដើម គប្បីជ្រាបថា ជាបណ្ឌិត ។

បណ្ឌិតទាំងនោះ ជាអ្នកអាចកម្ចាត់ភ័យឧបទ្រព និងឧបសគ្គបានគ្រប់យ៉ាង ដល់ពួកដែលធ្វើតាមពាក្យរបស់ខ្លួន ហាក់បីដូចការពារបានក្នុងវេលាមានភ័យ ហាក់បីដូចពន្លឺប្រទីបក្នុងពេលងងឹត ហាក់បីដូចបានបាយទឹកជាដើមក្នុងវេលាត្រូវទុក្ខ មានការស្រែកឃ្លានជាដើមគ្របសង្កត់ ។ ពិតហើយ អាស្រ័យតថាគត ពួកទេវតា និងមនុស្សរាប់មិនបាន ប្រមាណមិនអស់ នាំគ្នាសម្រេចធម៌ ជាទីអស់អាសវៈ តាំងនៅក្នុងព្រហ្មលោក តាំងនៅក្នុងទេវលោក កើតក្នុងសុគតិលោក ត្រកូល ៨០០០០ ត្រកូល ធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះសារីបុត្រ និងទំនុកបម្រុងព្រះថេរៈដោយបច្ច័យ ៤ ទៅកើតក្នុងស្ថានសួគ៌ ។ ត្រកូលទាំងឡាយធ្វើចិត្តឲ្យជ្រះថ្លាក្នុងមហាសាវកទាំងពួង រាប់តាំងអំពីព្រះមហា-មោគ្គល្លាន ព្រះមហាកស្សបជាដើម ក៏យ៉ាងនោះដូចគ្នា ។ សាវកទាំងឡាយរបស់សុនេត្តសាស្តា ពួកខ្លះកើតក្នុងព្រហ្មលោក ពួកខ្លះក៏កើតជាសម្ងាញ់របស់ពួកទេវតាជាន់បរនិម្មិតវសវត្តី ។បេ។ ពួកខ្លះបានជាសម្ងាញ់របស់គហបតីមហាសាល ។ ព្រះមានព្រះភាគ ក៏បានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មិនមានភ័យកើតអំពីបណ្ឌិត មិនមានឧបទ្រវអំពីបណ្ឌិត មិនមានឧបសគ្គអំពី

បណ្ឌិត ។

ម្យ៉ាងទៀត បណ្ឌិត ដូចរបស់ក្រអូប មានក្រស្នា និងផ្កាជាដើម បុគ្គលដែលសេពគប់បណ្ឌិត ក៏ដូចគ្នានឹងកញ្ចប់ស្មឹកឈើដែលខ្ចប់គ្រឿងក្រអូប មានក្រស្នា និងផ្កាជាដើម ដែលជួបនូវការៈ ដែលវិញ្ញូជនសរសើរ និងពេញចិត្ត ។ សូម្បីព្រះមានព្រះភាគក៏បានត្រាស់ដូច្នេះថា

តគរំវ បលាសេន យោ ឧរោ ឧបនយ្ហតិ

បត្តាបិ សុរភី វាយន្តិ ឯវំ ធីរូបសេវនា ។

ជនណា ខ្ចប់ខ្ចីមក្រស្នាដោយស្មឹកឈើ សូម្បីស្មឹកឈើក៏មានក្លិនក្រអូបផ្សាយចេញ ការគប់រកអ្នកប្រាជ្ញ (របស់ជននោះ) ក៏យ៉ាងនោះដែរ ។

ម្យ៉ាងទៀត កាលសក្កទេវរាជប្រទានពរដល់អកិត្តិបណ្ឌិត ក៏ពោលថា

ធីរំ បស្សេ សុណេ ធីរំ ធីរេន សហ សំវសេ

ធីរេនល្ហាបសល្ហាបំ តំ ការេ តញ្ហេ រោចយេ ។

បើព្រះអង្គ នឹងប្រទានពរដល់អាត្មា អាត្មាសូមឲ្យជួបប្រទះអ្នកប្រាជ្ញ សូមឲ្យស្តាប់អ្នកប្រាជ្ញ សូមឲ្យនៅរួមជាមួយនឹងអ្នកប្រាជ្ញ សូមឲ្យបានធ្វើ ទាំងសូមឲ្យបានចូលចិត្តនឹងការចរចាទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ ។

សក្កទេវរាជត្រាស់សួរថា

កិន្នុ តេ អការំ ធីរោ វជ្ជ កស្សប ការណំ

កេន កស្សប ជីវស្ស ឧស្សន្នំ អភិកង្ខសិ ។

អ្នកប្រាជ្ញបានធ្វើប្រយោជន៍អ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោកចង់ជួបប្រទះអ្នកប្រាជ្ញ ។

អតិត្តិបណ្ឌិតឆ្លើយថា

ឧយំ ឧយតិ មេធាវី អធុរាយំ ឧ យុញ្ជតិ
សុឧយោ សេយ្យសោ ហោតិ សម្មា វុត្តោ ឧ កុប្បតិ
វិឧយំ សោ បជានាតិ សាធុ តេន សមាគមោ ។

អ្នកប្រាជ្ញ រមែងណែនាំនូវហេតុដែលគួរដឹកនាំ រមែងមិនប្រកបក្នុងកិច្ចដែលមិនមែនជាធុរៈ ការដឹកនាំល្អ ជាការប្រសើរ (របស់អ្នកប្រាជ្ញនោះ) អ្នកប្រាជ្ញ បើគេនិយាយត្រូវហើយ រមែងមិនក្រោធ អ្នកប្រាជ្ញនោះ រមែងចេះដឹងច្បាប់ ការសេពគប់ជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃ ។

ព្រះមានព្រះភាគ កាលទ្រង់សរសើរការគប់រកបណ្ឌិត ដោយធម៌ទាំងពួងយ៉ាងនេះ ទើបត្រាស់ថា ការសេពគប់បណ្ឌិតជាមង្គល ។

ឥឡូវនេះ កាលទ្រង់សរសើរការបូជាបុគ្គល ដែលចូលដល់ភាពជាបុគ្គលគួរបូជាដោយលំដាប់ ដោយការមិនសេពគប់បុគ្គលពាល និងការសេពគប់បណ្ឌិតនោះ ទើបត្រាស់ថា **បូជា ច បូជនីយានំ មង្គលំ ។** *ព្រះមានព្រះភាគ ឈ្មោះថា* **បូជនីយ** *ព្រោះទ្រង់វៀរចាកទោសគ្រប់យ៉ាង និង*

ព្រោះទ្រង់ប្រកបដោយគុណគ្រប់យ៉ាង ហើយខាងក្រោយអំពីនោះ គឺព្រះបច្ចេកពុទ្ធ ព្រះអរិយសាវ័កទាំងឡាយ ឈ្មោះថា **បូជនីយ** *។ ពិតហើយ ការបូជាបូជនីយបុគ្គលទាំងនោះ សូម្បីតិចតួច ក៏ជាប្រយោជន៍ នាំមកនូវសេចក្តីសុខអស់កាលយូរ ។ ក្នុងសេចក្តីនេះ មានរឿងនាយសុមនមាលាការ និងនាងមល្លិកាជាដើម ជាគំរូ ។ ក្នុងរឿងទាំង ២ នោះ សូមពោលតែមួយរឿង គ្រាន់ជាគំរូ ។*

សេចក្តីថា ព្រឹកថ្ងៃមួយ ព្រះមានព្រះភាគទ្រង់ស្លៀកអន្តរវាសក ហើយកាន់បាត្រ និងចីវរ ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ខណៈនោះ នាយមាលាការ ឈ្មោះសុមនមាលាការកំពុងដើរកាន់ផ្កា សម្រាប់ព្រះបាទពិម្ពិសារជាកំពូលនៃអ្នកមគធៈ បានឃើញព្រះមានព្រះភាគយាងចូលដល់ក្រុង ផូរផង់គួរជ្រះថ្លា ប្រដាប់ដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០ ប្រការ រុងរឿងដោយពុទ្ធសិរី កាលឃើញហើយ ក៏គិតថា ព្រះរាជាទ្រង់ទទួលផ្កាហើយ ក៏គប្បីប្រទានទ្រព្យ ១០០ ឬ ១០០០ ន៎ុះគ្រាន់តែជាសេចក្តីសុខក្នុងលោកនេះប៉ុណ្ណោះ តែការបូជាព្រះមានព្រះភាគ រមែងមានផលប្រមាណមិនបាន រាប់មិនអស់ នាំប្រយោជន៍ និងសេចក្តីសុខមកឲ្យអស់កាលយូរ ។ ណ្ហើយចុះ អញនឹងបូជាព្រះមានព្រះភាគ ដោយផ្កាទាំងនេះដូច្នេះ គាត់មានចិត្តជ្រះថ្លា ចាប់ផ្កាមួយក្តាប់បាចទៅចំពោះព្រះភក្ត្រព្រះមានព្រះភាគ ។ ផ្កាទាំងឡាយទៅតាមអាកាស ប្រតិស្ថានជាពិតានផ្កា នៅលើព្រះមានព្រះភាគ ។ នាយមាលាការឃើញអានុភាពនោះ ក៏មានចិត្តជ្រះថ្លា

ក្រៃលែងឡើង ទើបបាចផ្កាមួយក្តាប់ទៀត សូម្បីផ្កាទាំងនោះ ក៏ទៅប្រតិស្ថានជាពិតានផ្កា ។ នាយមាលាការបាចផ្កា ៨ ក្តាប់យ៉ាងនេះ ផ្កាទាំងនោះ ក៏ទៅប្រតិស្ថានជាផ្ទះកំពូលដែលជាវិការនៃផ្កា ។

ព្រះមានព្រះភាគ ប្រថាប់នៅក្នុងផ្ទះកំពូល មហាជនក៏ប្រជុំគ្នា ។ ព្រះមានព្រះភាគទតឃើញនាយមាលាការ ក៏ទ្រង់ធ្វើការញញឹមឲ្យប្រាកដ ។ ព្រះអានន្ទក៏ទូលសួរដល់ហេតុដែលទ្រង់ញញឹមដោយគិតថា ព្រះសម្ពុទ្ធទាំងឡាយមិនមានហេតុ មិនមានបច្ច័យ ទ្រង់មិនញញឹមឲ្យប្រាកដឡើយ ។ ព្រះមានព្រះភាគត្រាស់ថា អានន្ទ នាយមាលាការនេះនឹងត្រាច់ទៅក្នុងទេវតា និងមនុស្សលោកអស់សែនកប្ប ដោយអានុភាពនៃការបូជានេះ ហើយក្នុងទីបំផុតក៏នឹងបានជាព្រះបច្ចេកពុទ្ធ នាមថា សុមនិស្សរៈ ។ មានព្រះតម្រាស់ចប់ក៏ត្រាស់ព្រះគាថានេះ ដើម្បីទ្រង់សម្តែងធម្មកថាថា

តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ ។

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ ឬដល់នូវសេចក្តីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អ ។

ចប់គាថា សត្វ ៨៤០០០ បានសម្រេចធម៌ ។ ការបូជាបូជនីយបុគ្គលទាំងនោះ សូម្បីតិចតួច គប្បីជ្រាបថា មានប្រយោជន៍ និងសេចក្តីសុខអស់កាលយូរ ដោយប្រការដូច្នេះ ។

ការបូជានោះ ជាអាមិសបូជា ទឹងពោលថ្វីក្នុងបដិបត្តិបូជា ព្រោះកុលបុត្រពួកណា បូជាព្រះមានព្រះភាគ ដោយទទួលសរណាគមន៍ និងសិក្ខាបទ ដោយការសមាទានអង្គឧបោសថ និងដោយគុណទាំងឡាយរបស់ខ្លួន មានបារិសុទ្ធិ-សីល ៤ ជាដើម អ្នកណាទឹងពណ៌នាផលនៃការបូជារបស់កុលបុត្រទាំងនោះបាន ដឹងតថា កុលបុត្រទាំងនោះ លោកពោលថា បូជាព្រះតថាគត ដោយការបូជាដ៏ឧត្តម ដូចព្រះមានព្រះភាគត្រាស់ថា

ម្នាលអានន្ទ បុគ្គលណាមួយ ទោះបីភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបា-សិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីគោរព ក្រែង ប្រព្រឹត្តតាមធម៌ បុគ្គលនោះ ឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ដោយគ្រឿងបូជាដ៏ឧត្តម ។

ការបូជាព្រះបច្ចេកពុទ្ធ និងអរិយសាវក នាំមកនូវប្រយោជន៍ និងសេចក្តីសុខ គប្បីជ្រាបតាមគន្ថនេះ ។

ម្យ៉ាងទៀត សម្រាប់គ្រហស្ថ គប្បីជ្រាបបូជនីយបុគ្គលក្នុងសេចក្តីនេះយ៉ាងនេះ គឺបុគ្គលចម្រើនបំផុត បងប្រុសក្តី បងស្រីក្តី ឈ្មោះថា បូជនីយ-បុគ្គលរបស់ប្អូន មាតាបិតា ជាបូជនីយបុគ្គលរបស់បុត្រ ប្តី ឪពុកក្មេក ម្តាយក្មេក ជាបូជនីយបុគ្គលរបស់ស្ត្រីទាំងឡាយ ដឹងតថា ការបូជាបូជនីយបុគ្គលទាំងនោះ ជាមង្គលទាំងអស់ ព្រោះរាប់ថា ជាកុសលធម៌ និងព្រោះជាហេតុចម្រើនអាយុជាដើម ព្រះមានព្រះភាគមានព្រះពុទ្ធតម្រាស់ដូច្នេះថា

សត្វទាំងនោះ ក៏ជាអ្នកគោរពមាតា គោរពបិតា

គោរពសមណៈ គោរពព្រាហ្មណ៍ និងជាអ្នក ប្រព្រឹត្តកោតក្រែង ត្រកូលរៀមច្បង ប្រព្រឹត្ត សមាទាន នូវកុសលធម៌នេះ ក៏បានចម្រើនអាយុ ចម្រើនពណ៌សម្បុរឡើងវិញ ដូច្នេះ ។

ឥឡូវនេះ ព្រោះខ្ញុំបានតាំងមាតិកាថា ពោលសមុដ្ឋានជាទីកើតមង្គល រួច កំណត់មង្គលនោះ និងចង្អុលបង្ហាញអត្ថនៃមង្គលនោះ ដូច្នោះ ទើបសូមចង្អុល បង្ហាញ ដូច្នេះ ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះ ៣ មង្គល គឺការ មិនសេពគប់បុគ្គលពាល ការសេពគប់បណ្ឌិត និងការបូជាបុគ្គលដែលគួរបូជា ដោយប្រការដូច្នេះ ។ ក្នុងមង្គលទាំង ៣ នោះ គប្បីជ្រាបការមិនសេពគប់ បុគ្គលពាល ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍របស់លោក ទាំង ២ ព្រោះការពារភ័យ មានភ័យកើតអំពីបុគ្គលពាលជាបច្ច័យជាដើម ការគប់រកបណ្ឌិត និងការបូជាបុគ្គលដែលគួរបូជា ឈ្មោះថា ជាមង្គល ព្រោះ ជាហេតុនៃព្រះនិព្វាន និងសុគតិ ដោយនយដែលពោលហើយ ក្នុងកិច្ច ពណ៌នាបន្ថែម នៃផលរបស់ការសេពគប់បណ្ឌិត និងការបូជាបុគ្គលដែលគួរ បូជានោះឯង ។ តែខ្ញុំមិនសម្តែងមាតិកា បន្ទាប់អំពីនេះទៅ នឹងកំណត់ប្រការ ដែលជាមង្គលទាំងនេះ ទើបចង្អុលបង្ហាញអត្ថដែលជាមាតិកានោះជាមង្គល ។

អធិប្បាយបទថា អសេវនា ច ពាលានំ ចប់

អធិប្បាយបទថា បដិរូបទេសវាសោ ច

ព្រះមានព្រះភាគ ត្រូវទេវបុត្រសូមនូវមង្គលតែម្យ៉ាងថា **ព្រូហិ មង្គល-មុត្តមំ** សូមទ្រង់ត្រាស់ប្រាប់មង្គលដ៏ឧត្តម តែត្រាស់ដល់ ៣ មង្គល ដោយ ១ គាថា ប្រៀបដូចបុរសចិត្តទូលាយ ត្រូវគេសូមតែបន្តិចក៏ឲ្យច្រើនក្រៃលែងជាងនោះ ហើយទ្រង់ត្រាស់មង្គលជាច្រើនទៀត ដោយគាថាទាំងឡាយថា **បដិរូបទេសវាសោ ច** ជាដើម ក៏ព្រោះទេវតាទាំងឡាយចង់ស្តាប់ ព្រោះមង្គលទាំងឡាយមាន និងព្រោះមង្គលណាមួយ អនុកូលដល់សត្វណាមួយ ទ្រង់មានព្រះពុទ្ធបំណងនឹងប្រកបសត្វនោះៗ ក្នុងមង្គលនោះ ។ បណ្តាគាថានោះៗ នឹងពោលក្នុងគាថាដំបូងមុន ។ បទថា **បដិរូបោ** ប្រែថា សមគួរ ។ ឱកាសជាទីនៅអាស្រ័យរបស់សត្វទាំងឡាយគ្រប់កន្លែង ទោះជាគាមក្តី និគមក្តី នគរក្តី ជនបទក្តី ឈ្មោះថា ទេសៈ ។ ការនៅអាស្រ័យក្នុងទេសៈនោះ ឈ្មោះថា **វាសៈ** ។ បទថា **បុព្ពេ** ប្រែថា អំពីមុន គឺក្នុងជាតិដែលកន្លងមកហើយ ។ ភាពជាអ្នកមានកុសលសន្សំហើយ ឈ្មោះថា ភាពជាអ្នកមានបុណ្យបានធ្វើហើយ ។ ចិត្ត ឬអត្តភាពទាំងមូល ឈ្មោះថា **អត្ត** ។ ការប្រកប គឺការតាំងសេចក្តីប្រាថ្នារបស់ខ្លួនប្រពៃ ។ លោកអធិប្បាយថា ការតាំងខ្លួនដោយប្រពៃ ឈ្មោះថា **សម្មាបណិធិ** ។ ពាក្យក្រៅអំពីនោះ មានន័យដូចពោលហើយនោះឯង នេះជាពណ៌នាបទ ក្នុងគាថាដំបូងនោះ ។

ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ ក្នុងបទេសណា បរិស័ទ ៤ នៅចាកនៅឡើយ នៅបំពេញបុញ្ញកិរិយាវត្ថុ មានទានជាដើមនៅឡើយទេ នវង្គ-សត្ថុសាសនៈនៅរុងរឿង បទេសនោះ ឈ្មោះថា **បដិរូបទេស** ការនៅ

អាស្រ័យក្នុងបដិរូបទេសនោះ ត្រាស់ថា ជាមង្គល ព្រោះជាបច្ច័យដល់ការធ្វើបុណ្យនៃសត្វទាំងឡាយ ក្នុងសេចក្តីនេះ មានអ្នកប្រមង់ដែលចូលទៅកាន់កោះ សីហឡជាដើម ជាគំរូ ។

នយម្យ៉ាងទៀត បទេសជាទីត្រាស់ដឹងព្រះពោធិញ្ញាណ បទេសដែលទ្រង់ប្រកាសធម្មចក្រ បទេស គឺគល់ស្វាយរបស់នាយគណ្ហៈ ដែលទ្រង់សម្តែងយមកប្បាដិហារ្យ ទម្លាយសេចក្តីស្រើងរបស់ពួកតិរ្ថិយទាំងពួង ត្រង់កណ្តាលបរិស័ទប្រមាណ ១២ យោជន៍ បទេសដែលទ្រង់ចុះអំពីទេវលោក ឬបទេសជាទៃដែលជាទីនៅប្រថាប់របស់ព្រះពុទ្ធ មានក្រុងសាវត្ថី ក្រុងរាជគ្រឹះជាដើម បទេសនោះ ឈ្មោះថា **បដិរូបទេស** *ការនៅអាស្រ័យក្នុងបដិរូបទេសនោះ ត្រាស់ថា ជាមង្គល ព្រោះជាបច្ច័យដល់ការបានអនុត្តរិយៈ ៦ នៃសត្វទាំង-ឡាយ ។*

ម្យ៉ាងទៀត ទិសបូព៌ តាំងអំពីជង្គលនិគម រហូតមកដល់មហាសាលា ខាងក្រៅជាបច្ចន្តិមជនបទ ខាងក្នុងចូលមកជាមជ្ឈិមជនបទ ។ ទិសអាគ្នេយ៍ តាំងអំពីសឹង្គសល្លវតីមក ខាងក្រៅជាបច្ចន្តិមជនបទ ខាងក្នុងជាមជ្ឈិមជនបទ ទិសទក្សិណ តាំងអំពីសេតកណ្ណិកនិគមចូលមក ខាងក្រៅជាបច្ចន្តិមជនបទ ខាងក្នុងជាមជ្ឈិមជនបទ ។ ទិសខាងលិច តាំងអំពីថូនស្រុករបស់ព្រាហ្មណ៍ចូលមក ខាងក្រៅជាបច្ចន្តិមជនបទ ខាងក្នុងជាមជ្ឈិមជនបទ ។ ទិសឧត្តរ តាំងអំពីភ្នំឧសីរធជៈចូលមក ខាងក្រៅជាបច្ចន្តិមជនបទ ខាងក្នុងជាមជ្ឈិម-ជនបទ ។ នេះជាមជ្ឈិមប្រទេស ដែលមានបណ្តាយ ៣០០ យោជន៍ ទទឹង

២៥០ យោជន៍ ដោយជុំវិញ ៩០០ ។ មជ្ឈិមប្រទេសនេះ ឈ្មោះថា **បដិរូបទេស។**

ស្តេចចក្រពត្តិទាំង៤ព្រាយ ដែលគ្រងឥស្សរិយាធិបតីនៃទ្វីបធំទាំង ៤ ទ្វីបតូច ២ ពាន់ រមែងកើតក្នុងបដិរូបទេសនោះ ព្រះមហាសាវ័កទាំង៤ព្រាយ មានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើមបំពេញបារមីមកមួយអសង្ខ្យៃ និងមួយសែនកប្ប ក៏កើតក្នុងបដិរូបទេសនោះ ព្រះបច្ចេកពុទ្ធទាំង៤ព្រាយ បំពេញបារមីមក ២ អសង្ខ្យៃ និងមួយសែនកប្ប កើតក្នុងបដិរូបទេសនោះ ព្រះសម្មាសម្ពុទ្ធទាំង៤ព្រាយ បំពេញបារមីមក ៤ អសង្ខ្យៃ និងមួយសែនកប្ប ខ្វះ ៨ អសង្ខ្យៃ និងមួយសែនកប្ប ខ្វះ ១៦ អសង្ខ្យៃ និងមួយសែនកប្ប ខ្វះ ក៏ទ្រង់កើតឡើងក្នុងបដិរូបទេសនោះ បណ្តាបុគ្គលទាំងនោះ សត្វទាំង៤ព្រាយទទួលឱកាសរបស់ស្តេចចក្រពត្តិ តាំងនៅក្នុងសីល ៥ ហើយក៏មានស្ថានសួគ៌ជាទីទៅខាងមុខ តាំងនៅក្នុងឱកាសរបស់ព្រះបច្ចេកពុទ្ធ ក៏ដូចគ្នា ។ ឯសត្វទាំង៤ព្រាយ តាំងនៅក្នុងឱកាសរបស់ព្រះពុទ្ធ សាវ័ករបស់ព្រះពុទ្ធ រមែងមានស្ថានសួគ៌ជាទីទៅខាងមុខ មានព្រះនិព្វានជាទីទៅខាងមុខ ព្រោះដូច្នោះ ការនៅក្នុងបដិរូបទេសនោះ ទើបត្រាស់ថា ជាមង្គល ព្រោះជាបច្ច័យនៃសម្បត្តិទាំងនេះ ។

ភាពជាអ្នកប្រារព្ធព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រព សន្សំកុសលក្នុងជាតិដែលកន្លងមក ឈ្មោះថា ភាពជាអ្នកធ្វើបុណ្យក្នុងកាលមុន ។ ភាពជាអ្នកធ្វើបុណ្យក្នុងកាលមុននោះ ក៏ជាមង្គល ។ ព្រោះហេតុអ្វី ព្រោះធ្វើ

អធិប្បាយថា ភាពជាអ្នកបានធ្វើបុណ្យក្នុងកាលមុន រមែងឲ្យសម្រេចអរហត្ត កាលចប់គាថា ៤ បទ ដែលសម្តែងចំពោះព្រះភក្ត្របស់ព្រះសម្ពុទ្ធ ព្រះ-បច្ចេកពុទ្ធ ឬដែលស្តាប់ចំពោះព្រះភក្ត្របស់ព្រះពុទ្ធ ឬសាវ័កបស់ព្រះពុទ្ធ ។ មនុស្សណាបានសាងបារមី មានកុសលមូលក្រាស់មកអំពីមុន មនុស្សនោះធ្វើ វិបស្សនាឲ្យកើតហើយ រមែងសម្រេចធម៌ដែលអស់អាសវៈ ដោយកុសល-មូលនោះឯង ដូចព្រះបាទមហាកប្បិន និងអគ្គមហេសី ដោយហេតុនោះ ទើប ព្រះមានព្រះភាគត្រាស់ថា ភាពជាអ្នកធ្វើបុណ្យក្នុងកាលមុន ជាមង្គល ។

បុគ្គលខ្លះ ក្នុងលោកនេះ រមែងធ្វើខ្លួនដែលទ្រុស្តសីល ឲ្យតាំងនៅក្នុង សីល ដែលមិនមានសទ្ធា ឲ្យតាំងនៅក្នុងសទ្ធាសម្បទា ខ្លួនដែលកំណាញ់ ឲ្យ តាំងនៅក្នុងចាគសម្បទា ការតាំងខ្លួនដូចពោល ឈ្មោះថា តាំងខ្លួនប្រពៃ ។ ការតម្កល់ខ្លួនប្រពៃនេះ ហៅថា **អត្តសម្មាបណិធិ** *។ អត្តសម្មាបណិធិនេះ ឯងជាមង្គល ព្រោះហេតុអ្វី ព្រោះជាហេតុលះបង់នូវពៀរ ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ន និងចំណែកខាងមុខ នឹងជួបនូវអានិសង្សច្រើនយ៉ាង ។*

ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះ ៣ មង្គល គឺការនៅក្នុងបដិ-រូបទេស ១ ភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន ១ និងការតម្កល់ខ្លួនប្រពៃ ១ ដោយប្រការដូច្នេះ ។ ភាពដែលមង្គលទាំងនោះជាមង្គល ក៏បានចង្អុល បង្ហាញក្នុងមង្គលទាំងអស់នោះហើយ ។

អធិប្បាយបទថា បដិរូបទេសវាសោ ច ចប់

អធិប្បាយ បទថា ពាហុសច្ចញ្ច

ឥឡូវនេះ ភាពជាពហូសូត ឈ្មោះថា **ពាហុសច្ច** ក្នុងបទនេះថា **ពាហុសច្ចញ្ច** ភាពឈ្វាសក្នុងការងារហត្ថកម្មគ្រប់យ៉ាង ឈ្មោះថា សិប្ប: ។ ការទូន្មានកាយ វាចា ចិត្ត ឈ្មោះថា **វិនយ ។** បទថា **សុសិក្ខិតោ** ប្រែថា ដែលសិក្សាដោយល្អហើយ ។ បទថា **សុភាសិតា** ប្រែថា ដែលគេពោលដោយល្អហើយ សព្ទថា **យា** សម្តែងការមិនពិតប្រាកដ ។ ពាក្យបន្ទឺខាងពាក្យសម្តី ឈ្មោះថា **វាចា ។** ពាក្យដ៏សេស មានន័យដូចពោលមកហើយទាំងអស់នោះឯង ។ នេះជាពណ៌នាបទក្នុងគាថាថា **ពាហុសច្ចញ្ច** នេះ ។

ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ ភាពជាអ្នកទ្រទ្រង់ទុកនូវសត្ថុ-សាសន:ដែលទ្រង់ពណ៌នា ដោយន័យជាដើមយ៉ាងនេះថា ជាអ្នកទ្រទ្រង់នូវសុត: សន្សំសុត: និងពាក្យថា ភិក្ខុរូបខ្ទះក្នុងធម្មវិន័យនេះ មានសុត:ច្រើនគឺសុត: គេយ្យ: វេយ្យាករណ:ជាដើម ឈ្មោះថា **ភាពជាពហូសូត ។** ភាពជាពហូសូតនោះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុលះអកុសល និងជួបនូវកុសល ព្រោះជាហេតុធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចតាមលំដាប់ សមដូចព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា

> ម្នាលភិក្ខុទាំងឡាយ អរិយសាវក មានការចេះដឹង ទុកជាអវត្ថុ រមែងលះបង់នូវអកុសល ចម្រើននូវកុសល លះបង់នូវអំពើដែលមានទោស ចម្រើននូវអំពើដែលមិនមានទោស រក្សាខ្លួនឲ្យបរិសុទ្ធ ក៏យ៉ាងនោះដែរដូច្នេះ ។
>
> ដូចព្រះតម្រាស់មួយទៀតថា

ទើបស្តាប់ធម៌ លុះស្តាប់ហើយ ទើបទ្រទ្រង់នូវធម៌ពិចារណានូវសេចក្តី នៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ កាលបើពិចារណានូវសេចក្តីហើយ ក៏ចូលចិត្តនូវធម៌ និងគំនិតកាលមានសេចក្តីចូលចិត្តនូវធម៌ និងគំនិតហើយ ក៏មានឆន្ទៈកើតឡើង លុះមានឆន្ទៈកើតឡើងហើយ ក៏ប្រឹងប្រែង លុះប្រឹងប្រែងហើយ ក៏ត្រិះរិះ លុះត្រិះរិះហើយ ក៏តម្កល់ (នូវសេចក្តីព្យាយាមដើម្បីមគ្គ) ជាអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចដោយនាម-កាយផង បានចាក់ធ្លុះ ឃើញច្បាស់នូវបរមត្ថសច្ចនោះដោយបញ្ញាផង ។

ម្យ៉ាងទៀត ពាហុសច្ចៈរបស់គ្រហស្ថឯណា មិនមានទោស នុ៎ះក៏គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំង ២ ។

សិប្បៈរបស់គ្រហស្ថ និងសិប្បៈរបស់បព្វជិត ឈ្មោះថា **សិប្បៈ** *។ បណ្តាសិប្បៈទាំង ២ នោះ កិច្ចកម្ម មានការងារជាងកែវមណី ជាងមាសជាដើម ដែលវៀរចាកការប្រទូស្តជីវិតសត្វជាដៃ វៀរចាកអកុសល ឈ្មោះថា* **អគារិកសិប្បៈ** *គឺសិប្បៈរបស់គ្រហស្ថ ។ អគារិកសិប្បៈនោះ ឈ្មោះថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍ក្នុងលោកនេះ ។*

ការធ្វើសមណបរិក្ខារ មានការបោក និងដេរចីវរជាដើម ដែលព្រះមានព្រះភាគសរសើរក្នុងទីនោះៗ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ កិច្ច

ទាំងឡាយណាមួយ ធំ ឬតូច របស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុជាអ្នកបុិនប្រសប់ មិនខ្វិលច្រអូស ក្នុងកិច្ចទាំងនោះ ។ និងដែលត្រាស់ថា ជានាថ-ករណធម៌ ឈ្មោះថា **អគារិកសិប្បៈ** *គឺសិប្បៈរបស់បព្វជិត ។ សិប្បៈរបស់បព្វជិតនោះ គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំង ២ ដល់ខ្លួនឯង និងដល់អ្នកដទៃ ។*

វិន័យរបស់គ្រហស្ថ និងវិន័យរបស់បព្វជិត ឈ្មោះថា **វិន័យ** *។ បណ្តាវិន័យទាំង ២ នោះ ការវៀរអកុសលកម្មបថ ១០ ឈ្មោះថា វិន័យរបស់គ្រហស្ថ ។ វិន័យរបស់គ្រហស្ថនោះ គ្រហស្ថសិក្សាល្អហើយក្នុងវិន័យនោះ ឈ្មោះថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍ និងសេចក្តីសុខក្នុងលោកទាំង ២ ដោយការមិនប៉ះពាល់នូវសង្កិលេស និងការកំណត់គុណគឺអាចារៈ ។*

ការមិនត្រូវអាបត្តិ ៧ កង ឈ្មោះថា វិន័យរបស់បព្វជិត ។ សូម្បីវិន័យរបស់បព្វជិតនោះ ដែលបព្វជិតសិក្សាល្អហើយ ដោយនយដែលពោលមកហើយ ឬថាវិសុទ្ធិសីល ៤ ឈ្មោះថា វិន័យរបស់បព្វជិត វិន័យរបស់បព្វជិតនោះ ដែលបព្វជិតសិក្សាល្អហើយ ដោយការសិក្សាដោយប្រការដែលតាំងនៅក្នុងចតុប្បារិសុទ្ធិសីលនោះហើយ សម្រេចនូវអរហត្តបាន គប្បីជ្រាបថា ជាមង្គល ព្រោះហេតុជួបនូវសុខ ទាំងលោកិយ ទាំងលោកុត្តរ ។

វាចាដែលវៀរចាកទោស មានមុសាវាទជាដើម ឈ្មោះថា **វាចាសុភាសិត** *ដូចដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយ*

អង្គ ៤ ជាវាចាសុភាសិត ឬវាចាដែលចរចាមិនផ្តេសផ្តាស ឈ្មោះថា វាចាសុភាសិត ដូចព្រះមានព្រះភាគត្រាស់ថា

សុភាសិតំ ឧត្តមមាហុ សន្តោ ធម្មំ ភណេ នាធម្មំ តំ ទុតិយំ
បិយំ ភណេ នាប្បិយំ តំ តតិយំ សច្ចំ ភណេ នាលិកន្តំ ចតុត្ថំ។

ពួកសប្បុរសបានពោលនូវវាចាជាសុភាសិតដ៏ឧត្តម (នោះជាទី ១) ពោលនូវវាចាជាធម៌ មិនពោលនូវវាចាមិនមែនជាធម៌ នោះជាទី ២ ពោលវាចាគួរស្រឡាញ់ មិនពោលវាចាដែលមិនគួរស្រឡាញ់ នោះជាទី ៣ ពោលពាក្យពិត មិនពោលពាក្យឡេះឡោះ នោះជាទី ៤ ។

វាចាសុភាសិតនេះ គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍ក្នុងលោកទាំង ២ តែព្រោះវាចាសុភាសិតនេះទាក់ទងក្នុងវិនយ ដូច្នោះ ទោះបីមិនសង្គ្រោះវាចាសុភាសិតនោះដោយវិនយសព្វ ក៏គប្បីជ្រាបថា ជាវិនយ ។ កាលបើដូច្នោះ វាចា មានការសម្តែងធម៌ដល់បុគ្គលជនៃជាដើម គប្បីជ្រាបថា ជាវាចាសុភាសិតក្នុងទីនេះ ។ សេចក្តីពិត វាចាសុភាសិត ត្រាស់ថា ជាមង្គល ក៏ព្រោះជាហេតុជួបនូវសុខក្នុងលោកទាំង ២ និងព្រះនិព្វានរបស់សត្វទាំងឡាយ ដូចការនៅក្នុងបដិរូបទេស ដូច្នោះ ។

សមដូចព្រះវង្គីសត្ថេរពោលថា

យំ ពុទ្ធោ ភាសតិ វាចំ ខេមំ និព្វានបត្តិយា
ទុក្ខស្សន្តកិរិយាយ សា វេ វាចានមុត្តមំ។

ព្រះពុទ្ធទ្រង់ត្រាស់នូវព្រះវាចាណា ជាគ្រឿងក្សេម ដើម្បីជល់នូវព្រះនិព្វាន ដើម្បីធ្វើនូវទីបំផុតនៃទុក្ខ វាចានោះឯង ឈ្មោះថា ជាវាចាដ៏ឧត្តម ។

ព្រះសម្ពុទ្ធត្រាស់មង្គលនៃគាថានេះ ៤ មង្គល គឺពាហុសច្ចៈ ១ សិប្បៈ ១ វិនយដែលសិក្សាល្អហើយ ១ និងវាចាសុភាសិត ១ ដោយប្រការដូច្នេះ ។ ការដែលមង្គលនោះជាមង្គល ក៏បានចង្អុលបង្ហាញក្នុងមង្គលនោះទាំងអស់ ។

អធិប្បាយបទថា ពាហុសច្ចញ្ច ជាដើម ចប់

អធិប្បាយបទថា មាតាបិតុប្បដ្ឋានំ

ឥឡូវនេះ នឹងពណ៌នាក្នុងគាថានេះថា **មាតាបិតុប្បដ្ឋានំ។** *មាតា និងបិតា ហេតុនោះ ឈ្មោះថា មាតា និងបិតា ។ បទថា* **ឧបដ្ឋានំ** *ប្រែថា ការទំនុកបម្រុង ។ កូនទាំងឡាយផង ភរិយាទាំងឡាយផង ឈ្មោះថា បុត្រ និងភរិយា ការសង្គ្រោះ ឈ្មោះថា សង្គហៈ ។ ការងារ គឺកិច្ចកម្ម ដែលតិះដៀលមិនបាន ឈ្មោះថា មិនច្របូកច្របល់ ។ ពាក្យដ៏សេស មានន័យដូចពោលហើយទាំងអស់នោះឯង នេះជាពណ៌នាបទ ។*

ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ស្ត្រីដែលញ៉ាំងបុត្រឲ្យកើត ឈ្មោះថា មាតា បិតាក៏ដូចគ្នា ។ ការធ្វើឧបការៈដោយការលាងជើង គក់ច្របាច់ជូសក្អែល ឆូតទឹកឲ្យ និងការជូនបច្ចុយ ៤ ឈ្មោះថា ទំនុកបម្រុង ។ ក្នុងការ

ទំនុកបម្រុងនោះ ព្រោះមាតាបិតាមានឧបការៈច្រើន ប្រាថ្នាប្រយោជន៍អនុគ្រោះ ដល់កូនទាំងឡាយ មាតាបិតាទាំងឡាយណា សម្ដែងឃើញកូនទាំងឡាយលេង នៅខាងក្រៅ ដើរមក មានខ្លួនប្រឡាក់ធូលី ក៏ជូតធូលីឲ្យ បើបក្បាលបបោស អង្អែល ស្រឡាញ់ អាណិត ។ កូនទាំងឡាយប្រើក្បាលទូលមាតាបិតា អស់ ១០០ ឆ្នាំ ក៏មិនអាចធ្វើបដិការៈសងនូវគុណរបស់មាតាបិតានោះបាន និងព្រោះ ហេតុដែលមាតាបិតានោះ ជាអ្នកទំនុកបម្រុង បង្ហាញលោកនេះ សន្ដតថា ជាព្រហ្ម សន្ដតថាជាបុព្វាចារ្យ ជួរច្បោះ ការទំនុកបម្រុងមាតាបិតានោះ រមែង នាំមកនូវការសរសើរក្នុងលោកនេះ ការលះលោកទៅហើយ ក៏នាំមកនូវ សេចក្ដីសុខក្នុងស្ថានសួគ៌ ដោយហេតុនោះ ទើបត្រាស់ថាជាមង្គល សមដូច ព្រះមានព្រះភាគត្រាស់ថា

> *មាតាបិតាទាំងឡាយ ដែលហៅថា ព្រហ្មក្ដី បុព្វាចារ្យក្ដី អាហុនេយ្យៈក្ដី (សុទ្ធតែ) ជាអ្នកអនុគ្រោះដល់ពួកសត្វ គឺកូន ។ ព្រោះហេតុនោះឯង អ្នកប្រាជ្ញ គួរនមស្ការ គួរធ្វើ សក្ការៈដល់មាតាបិតាទាំងនោះ ដោយបាយ ទឹក សំពត់ គ្រឿងដេក គ្រឿងអប់ គ្រឿងផ្ដួតទឹក និងទឹកសម្រាប់លាង ជើង ។ ព្រោះការដែលបានទំនុកបម្រុងមាតាបិតានោះហើយ បានជាអ្នកប្រាជ្ញទាំងឡាយ សរសើរនូវបុគ្គលនោះ ក្នុង លោកនេះឯង បុគ្គលនោះ លុះលះលោកនេះទៅហើយ រមែងរីករាយក្នុងឋានសួគ៌ ។*

នយម្យ៉ាងទៀត កិច្ចកម្ម ៥ យ៉ាង មានការចិញ្ចឹម ធ្វើកិច្ចរបស់លោក និងការតាំងវង្សត្រកូលជាដើម ឈ្មោះថា ការបម្រើ ។ ការបម្រើនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុនៃប្រយោជន៍ក្នុងបច្ចុប្បន្ន ៥ យ៉ាង មានការហាមមិនឲ្យធ្វើបាបជាដើម ។ សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា

ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត កូនត្រូវទំនុកបម្រុងដោយស្ថានទាំង ៥ យ៉ាង គឺកូនត្រូវតាំងចិត្តថា អាត្មាអញ មាតាបិតាបានចិញ្ចឹមរក្សាមកហើយ នឹងចិញ្ចឹមមាតាបិតាវិញ ១ នឹងជួយធ្វើការងាររបស់មាតាបិតា ១ ទាំងតម្កល់វង្សត្រកូល ១ ប្រតិបត្តិឲ្យជាអ្នកសមគួរទទួលទ្រព្យមត៌កបាន ១ មួយទៀត ឧទ្ទិសទក្ខិណាទានដល់មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ ១ ។

ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត កូនត្រូវទំនុកបម្រុងដោយស្ថានទាំង ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកូនដោយស្ថានទាំង ៥ យ៉ាងវិញ ដូច្នេះ គឺហាមឃាត់កូនចាកអំពើអាក្រក់ ១ ឲ្យកូនតម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ ១ ដណ្តឹងភរិយាស្វាមីសមគួរឲ្យ ១ ចែកទ្រព្យឲ្យកូនក្នុងសម័យគួរ ១ ។

ម្យ៉ាងទៀត បុគ្គលណាទំនុកបម្រុងមាតាបិតា ដោយឲ្យកើតការជ្រះថ្លាក្នុងវត្ថុ គឺរតនៈទាំង ៣ ដោយឲ្យដល់ព្រមដោយសីល ដោយឲ្យបព្វជ្ជា បុគ្គល

នេះជាកំពូលនៃបុគ្គល ដែលទំនុកបម្រុងមាតាបិតា ។ ការទំនុកបម្រុងមាតាបិតារបស់បុគ្គលនោះ ជាការតបស្នងសងឧបការគុណដែលមាតាបិតាធ្វើមកហើយ ត្រាស់ថាជាមង្គល ព្រោះជាបទដ្ឋាននៃប្រយោជន៍ទាំងឡាយ ក្នុងបច្ចុប្បន្នផង ក្នុងចំណែកខាងមុខផងដ៏ច្រើន ។

បុត្រក្តី ធីតាក្តី ដែលកើតអំពីខ្លួន រាប់ថា ជាបុត្រទាំងអស់ ក្នុងពាក្យថា **បុត្តទារស្ស** *នេះ ។ បទថា* **ទារា** *បានដល់ ភរិយា ២០ ពួក ពួកណាមួយ ។ បុត្រ និងភរិយា ឈ្មោះថា* **បុត្តទារ ។** *នូវបុត្រ និងភរិយានោះ ។ បទថា* **សង្គហោ** *បានដល់ ធ្វើការឧបការៈដោយការសរសើរជាដើម ។ ការឧបការៈនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុនៃប្រយោជន៍ក្នុងបច្ចុប្បន្ន មានភាពជាអ្នកចាត់ការងារល្អជាដើម ។ សេចក្តីពិត ព្រះមានព្រះភាគទ្រង់សង្គ្រោះបុត្រ និងភរិយា ដែលទ្រង់លើកឡើងសម្តែងថា ទិសខាងលិច គប្បីជ្រាបថា គឺបុត្រ និងភរិយាផងដែរ ។ ទើប* **ភរិយា** *សព្ទ ត្រាស់ដូច្នេះថា*

> *ម្នាលគហបតិបុត្ត ភរិយាជាទិសខាងលិច ស្វាមីត្រូវទំនុកបម្រុង ដោយស្ថានទាំងឡាយ ៥ យ៉ាង គឺដោយការរាប់អានជាភរិយាពេញទី ១ ដោយមិនមើលងាយ ១ ដោយមិនប្រព្រឹត្តក្បត់ចិត្ត ១ ដោយប្រគល់ឲ្យជាធំ (ក្នុងការផ្ទះ) ១ ដោយការឲ្យគ្រឿងតែងខ្លួន ១ ។ ម្នាលគហបតិបុត្ត ភរិយាជាទិសខាងលិច ដែលស្វាមីទំនុកបម្រុង ដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះស្វាមី*

ដោយស្ថានទាំងឡាយ ៥ យ៉ាងវិញ គឺចាត់ចែងការងារ
ដោយល្អ ១ សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ ១
មិនប្រព្រឹត្តក្បត់ចិត្ត ១ ថែទាំទ្រព្យដែលស្វាមីរកបានមក ១
ឈ្វាស មិនខ្ជិលច្រអូស ក្នុងកិច្ចសព្វគ្រប់ ១ ។

ម្យ៉ាងទៀត បទថា **សង្គហោ** បានដល់ ការសង្គ្រោះដោយទាន បិយ-
វាចា អត្ថចរិយា ។ សេចក្តីនេះដូចម្តេច ការឲ្យស្បៀងអាហារក្នុងថ្ងៃឧបាសថ
ការឲ្យលេងបុណ្យនក្ខត្តឬក្ស ធ្វើមង្គល ក្នុងថ្ងៃមង្គល ការទូន្មានប្រៀនប្រដៅ
ក្នុងប្រយោជន៍ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅក្នុង
លោកខាងមុខ ការសង្គ្រោះនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃ
ប្រយោជន៍ក្នុងបច្ចុប្បន្ន ព្រោះជាហេតុនៃប្រយោជន៍ខាងមុខ និងព្រោះជាហេតុ
នៃភាពជាបុគ្គល ដែលទេវតាទាំងឡាយនមស្ការ ដូចសក្កទេវរាជត្រាស់ថា

យេ គហដ្ឋា បុញ្ញករា សីលវន្តោ ឧចាសកា
ធម្មេន ធារំ ចោសេន្តិ តេ នមស្សាមិ មាតលិ ។

ពួកគ្រហស្ថណា ជាអ្នកធ្វើបុណ្យ ជាឧបាសកមានសីល
ចិញ្ចឹមកូន ប្រពន្ធ ដោយធម៌ ម្នាលមាតលិ ខ្ញុំក៏ថ្វាយ
បង្គំចំពោះពួកគ្រហស្ថនោះដែរ ។

ការងារទាំងឡាយ មានកសិកម្ម គោរក្ខកម្ម និងវាណិជ្ជកម្មជាដើម រៀរ
ចាកភាវៈច្របូកច្របល់ មានការកន្ងងកាល ការធ្វើមិនសមគួរ និងការធ្វើធូរ
ថយជាដើម ព្រោះជាអ្នកស្គាល់កាល ព្រោះជាអ្នកធ្វើសមគួរ ព្រោះជាអ្នកមិន

ខ្ជិលច្រអូស និងព្រោះមិនគួរវិនាស ព្រោះដល់ព្រមដោយការព្យាយាមប្រឹងប្រែង ឈ្មោះថា ការងារមិនច្របូកច្របល់ ។ ការងារមិនច្របូកច្របល់ទាំងនោះ ដែលបុគ្គលប្រកបបានយ៉ាងនេះ ព្រោះខ្លួន បុត្រ ភរិយា ឬទាសកម្មករ ដែលជាអ្នកឈ្វាស គ្រាស់ថា ជាមង្គល ព្រោះជាហេតុឲ្យបានទ្រព្យ ស្រូវ និងសេចក្តីចម្រើនក្នុងបច្ចុប្បន្ន ។ សមដូចព្រះមានព្រះភាគគ្រាស់ដូច្នេះថា

បុគ្គលមានការងារសមតាមកាល មានធុរៈ (មិនទម្លាក់ចោល) ជាអ្នកឥស្សិ រមែងបាននូវទ្រព្យ ។ និងពុទ្ធដីកាមួយកន្លែងទៀតថា

> *បុគ្គលដេកក្នុងវេលាថ្ងៃ ជាប្រក្រតី មិនក្រោកឡើងពីយប់ ជាប្រក្រតី ជាអ្នកស្រវឹងជានិច្ច ជាអ្នកលេងល្បែង មិនអាចនឹងគ្រប់គ្រងផ្ទះសម្បែងបាន ។ ប្រយោជន៍ទាំងឡាយ តែងកន្ងងហួសមនុស្សដែលលះបង់ចោលនូវការងារ ដោយពោលអាងថា វេលានេះ ត្រជាក់ណាស់ ក្តៅណាស់ ល្ងាចណាស់ ។ ជនណាមួយ ធ្វើនូវកិច្ចរបស់បុរស មិនអើពើនូវត្រជាក់ និងក្តៅ ក្រៃលែងជាងស្មៅ (ទៅទៀត) ជននោះ រមែងមិនសាបសូន្យចាកសេចក្តីសុខឡើយ ។*

និងមួយកន្លែងទៀតថា

> *កាលបុគ្គលសន្សំទ្រព្យ រមែងធ្វើទ្រព្យឲ្យជាគំនរ ដូចជាឃ្មុំដូច្នោះឯង ។ ភោគៈទាំងឡាយតែងដល់នូវការពូនជាគំនរដូចជាដំបូកដែលកណ្តៀរកពូនដូច្នោះឯង យ៉ាងនេះជាដើម ។*

ព្រះមានព្រះភាគ ត្រាស់មង្គលនៃគាថានេះ ៤ មង្គល គឺការបម្រើមាតា ១ បម្រើបិតា ១ ការសង្គ្រោះបុត្រភរិយា ១ និងការងារមិនច្របូកច្របល់ ១ ឬ ៥ មង្គល ព្រោះចែកការសង្គ្រោះបុត្រ និងភរិយាជា ២ ឬ ៣ មង្គល ព្រោះរួមការបម្រើមាតា និងបិតាចូលតែមួយ ។ ភាពដែលមង្គលទាំងនេះជាមង្គល បានចង្អុលបង្ហាញក្នុងមង្គលនោះៗ ហើយនោះឯង ។

អធិប្បាយបទថា មាតាបិតុប្បដ្ឋានំ ចប់

អធិប្បាយបទថា ទានញ្ច

ឥឡូវនេះ នឹងពណ៌នាក្នុងគាថានេះថា **ទានញ្ច** *។ ឈ្មោះថា* **ទាន** *ព្រោះគេឲ្យដោយវត្ថុនេះ លោកអធិប្បាយថា គេប្រគល់ទ្រព្យដែលមានរបស់ខ្លួនឲ្យដល់អ្នកដទៃ ។ ការប្រព្រឹត្តធម៌ ឬការប្រព្រឹត្តដែលមិនប្រាសចាកធម៌ ឈ្មោះថា* **ធម្មចរិយា** *។ ឈ្មោះថា* **ញាតិ** *ព្រោះបុគ្គលណាក៏ដឹងថា នេះជាគ្នារបស់យើង ។ ការមិនមានទោស ឈ្មោះថា* **អនវជ្ជ** *លោកអធិប្បាយថា បុគ្គលណាម្នាក់ និន្ទាមិនបាន តិះដៀលមិនបាន ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។ នេះជាពណ៌នាបទ ។*

ឯពណ៌នាអត្ថ គប្បីជ្រាបដូច្នេះ ចេតនាជាហេតុបរិច្ចាគវត្ថុ ១០ មានបាយជាដើម ដែលមានការដឹងល្អជាប្រធានចំពោះអ្នកដទៃ ឬការមិនមានលោភៈដែលប្រកបដោយចាគចេតនានោះ ឈ្មោះថា **ទាន** *។*

ពិតហើយ បុគ្គលរមែងប្រគល់វត្ថុនោះឲ្យដល់អ្នកដទៃ ដោយការមិនលោភ ។ ដោយហេតុនោះ ទើបខ្ញុំពោលថា ឈ្មោះថា **ទាន** *ព្រោះបុគ្គលឲ្យដោយវត្ថុនេះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុជួបនូវផលវិសេសដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅខាងមុខ មានភាពជាបុគ្គលដែលជនច្រើនស្រឡាញ់ និងពេញចិត្តជាដើម ។ ក្នុងរឿងទាននេះ គប្បីរឭកដល់សូត្រទាំងឡាយជាដើមយ៉ាងនេះថា ម្នាលសីហៈ ទាយកអ្នកម្ចាស់ទាន ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន ។*

ម្យ៉ាងទៀត ឈ្មោះថា **ទាន** *មាន ២ គឺអាមិសទាន និងធម្មទាន ក្នុងទានទាំង ២ នោះ អាមិសទានបានពោលមកហើយនោះឯង ។ ឯការសម្តែងធម៌ដែលព្រះសម្មាសម្ពុទ្ធប្រកាសហើយ ដែលនាំមកនូវការអស់ទុក្ខ និងសុខក្នុងលោកនេះ និងលោកខាងមុខ ព្រោះប្រោថ្នាឲ្យជាប្រយោជន៍ដល់អ្នកដទៃ ឈ្មោះថា* **ធម្មទាន** ។ *ម្យ៉ាងទៀត បណ្តាទានទាំង ២ នេះ ធម្មទាននេះតែម្យ៉ាង ជាកំពូលនៃទានទាំងពួង ដូចព្រះមានព្រះភាគត្រាស់ថា*

សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ
សព្វរតឹ ធម្មរតិ ជិនាតិ តណ្ហាក្ខយោ សព្វទុក្ខំ ជិនាតិ។

ធម្មទាន ឈ្នះអាមិសទានទាំងពួង ធម្មរស ឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ ឈ្នះសេចក្តីត្រេកអរទាំងពួង ការអស់តណ្ហា ឈ្នះទុក្ខទាំងពួង ។

ក្នុងព្រះសូត្រ និងគាថានោះ ដែលត្រាស់ភាពដែលអាមិសទានជាមង្គល

ប៉ុណ្ណោះ ចំណែកធម្មទានត្រាស់ថា ជាមង្គល ព្រោះជាបទដ្ឋាននៃគុណទាំង-ទ្វាយ មានភាពជាអ្នកជ្រាបនូវអត្ថជាដើម សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា

> *ម្នាលភិក្ខុទាំងឡាយ ភិក្ខុសម្តែងធម៌ដល់បុគ្គលដទៃ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សាដោយពិស្តារយ៉ាងណាៗ ភិក្ខុនោះ ក៏ដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផង ក្នុងធម៌នោះ យ៉ាងនោះៗ ដូច្នេះជាដើម ។*

ការប្រព្រឹត្តកុសលកម្មបថ ១០ ឈ្មោះថា **ធម្មចរិយា** *ដូចព្រះមានព្រះភាគត្រាស់យ៉ាងនេះជាដើមថា ម្នាលគហបតីទាំងឡាយ ការប្រព្រឹត្តធម៌ ការប្រព្រឹត្តស្មើមាន ៣ យ៉ាង ។ ការប្រព្រឹត្តធម៌នោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុចូលដល់ស្ថានសួគ៌ទេវលោក សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា*

> *ម្នាលគហបតិទាំងឡាយ ព្រោះសេចក្តីប្រព្រឹត្តស្មើ គឺប្រព្រឹត្តធម៌ ជាហេតុយ៉ាងនេះឯង បានជាពួកសត្វខ្លះ ក្នុងលោកនេះ ដល់បែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោកយ៉ាងនេះ ដូច្នេះ ។*

ជនដែលជាប់ខ្សែស្រឡាយខាងមាតា ឬបិតា រហូតដល់ ៧ ជួរ ឈ្មោះថា **ញាតិ** *។ ការសង្គ្រោះញាតិទាំងនោះ បុគ្គលដែលត្រូវវិនាសកោគៈ ត្រូវវិនាសដោយជំងឺគ្របសង្កត់ហើយ មករកខ្ជួនដោយអាហារ និងគ្រឿងស្បៀក*

ជណ្តប់ មានស្រូវជាដើមតាមកម្លាំង ត្រាស់ថា ជាមង្គល ព្រោះជាហេតុជួបនូវផលវិសេសដែលជាបច្ចុប្បន្ន មានការសរសើរជាដើម និងជាចំណែកខាងមុខ មានទៅសុគតិជាដើម ។ កិច្ចកម្មដែលជាសុចរិត ដោយកាយ វាចា ចិត្ត មានការសមាទានអង្គឧបោសថ ការធ្វើសេចក្តីខ្វល់ខ្វាយ ការដាំដើមឈើធ្វើសួន ដាំដើមឈើធ្វើព្រៃ និងសាងស្ពានជាដើម ឈ្មោះថា ការងារមិនមានទោស ។ ការងារមិនមានទោសទាំងនោះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុឲ្យជួបនូវប្រយោជន៍ និងសេចក្តីសុខច្រើនប្រការ ។ គប្បីរឭកដល់ព្រះសូត្រទាំងឡាយ មានសូត្រជាដើមយ៉ាងនេះថា

> *ម្នាលវិសាខា ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថ ប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកចាតុម្មហារាជិកទេវតា ដូច្នេះ ។*

ព្រះមានព្រះភាគ ត្រាស់មង្គលនៃគាថានោះ ៤ មង្គល គឺទាន ១ ធម្មចរិយា ១ ការសង្គ្រោះញាតិ ១ ការងារមិនមានទោស ១ ដោយប្រការដូច្នេះ ។ ភាពដែលមង្គលទាំងនោះជាមង្គល ក៏បានចង្អុលបង្ហាញហើយក្នុងមង្គលទាំងនោះឯង ។

អធិប្បាយបទថា ទានញ្ច ចបៈ

អធិប្បាយបទថា អារតី

ឥឡូវនេះ និងពណ៌នាក្នុងគាថាថា **អារតី វិរតី** នេះ ។ ឈ្មោះថា **អារមណា** ព្រោះលះបង់ ។ ឈ្មោះថា **វិរមណា** ព្រោះវៀរ ។ ម្យ៉ាងទៀត ចេតនា ឈ្មោះថា **វិរតិ** ព្រោះជាគ្រឿងដែលសត្វវៀរចាក ។ បទថា **ចាចា** បានដល់ ចាបអកុសល ។ ឈ្មោះថា **មជ្ជ** ព្រោះអត្ថថា ជាទីតាំងនៃសេចក្តីស្រវឹង ។ ការផឹកមជ្ជ: ឈ្មោះថា **មជ្ជចាន ។** សង្រួមចាកមជ្ជបាន:នោះ ។ ការសង្រួម ឈ្មោះថា **សំយម ។** ការមិនប្រមាទ ឈ្មោះថា **អប្បមាទ ។** បទថា **ធម្មេសុ** បានដល់ ក្នុងកុសលទាំងឡាយ ។ ពាក្យដ៏សេស មានន័យដូចពោលមកទាំងអស់ហើយនោះឯង នេះជាពណ៌នាបទ ។

ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ ការមិនត្រេកអរក្រៃលែងផ្ទូវចិត្តតែម្យ៉ាងរបស់បុគ្គលដែលឃើញទោសក្នុងបាប ឈ្មោះថា **អារតិ ។** ការវៀរចាកតាមកាយ វាចា ដោយកម្ម និងទ្វារ ឈ្មោះថា **វិរតិ ។**

ធម្មតាវិរតិនោះមាន ៣ គឺសម្បត្តវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទ-វិរតិ ១ ។ បណ្តាវិរតិទាំង ៣ នោះ វិរតិចេតនា វៀរចាកវត្ថុដែលជួបឯណារបស់កុលបុត្រ ក្នុងន័យជាដើមយ៉ាងនេះថា ការដែលអាត្មាអញសម្ងាប់សត្វ ឬលួចទ្រព្យជាដើមនេះ កាលនឹកដល់ជាតិ ត្រកូល ឬគោត្ររបស់ខ្ជួន ក៏មិនសមគួរដល់អាត្មាអញទ្បើយ វិរតិចេតនានេះ ឈ្មោះថា **សម្បត្តវិរតិ ។** កុល-បុត្តមិនធ្វើបាប មានបាណាតិបាតជាដើម តាំងអំពីប្រព្រឹត្តវិរតិឯណា វិរតិនោះ ប្រព្រឹត្តទៅដោយសមាទានសិក្ខាបទ ឈ្មោះថា **សមាទានវិរតិ ។** ពៀរនិងភ័យ ៥ របស់ព្រះអរិយសាវករម្ងាប់ទៅ តាំងអំពីប្រព្រឹត្តវិរតិណា វិរតិ

នោះ ប្រកបដោយអរិយមគ្គ ឈ្មោះថា **សម្មុច្ឆេឋវិរតិ ។** *ចាបអកុសលនោះ មាន ៤ យ៉ាង ពោល គឺកម្មក្លិសដែលព្រះមានព្រះភាគត្រាស់ពិស្តារ យ៉ាងនេះថា*

ម្នាលគហបតិបុត្ត ការធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង (សម្លាប់សត្វ) ជាកម្មក្លិសស ១ ការកាន់យកទ្រព្យដែលម្ចាស់គេមិនឲ្យ ជាកម្មក្លិសស ១ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាកម្មក្លិសស ១ ការនិយាយពាក្យកុហក ជាកម្មក្លិសស ១ កម្មក្លិសស ៤ ប្រការនេះដែលអរិយសាវ័កនោះ បានលះបង់ហើយ ដូច្នេះហើយ ទ្រង់សង្ខេបដោយគាថាយ៉ាងនេះថា

ចាណាតិចោតោ អទិន្នាទានំ មុសាវាទោ ច បវុច្ចតិ
បទារគមនញ្ចេវ ឆបសំសន្តិ បណ្ឌិតា ។

ការសម្លាប់សត្វ ១ លួចទ្រព្យគេ ១ និយាយកុហក ១ សេពកិរិយាបុគ្គលដទៃ ១ ហៅថា (កម្មក្លិសស) បណ្ឌិតទាំងឡាយ មិនសរសើរឡើយ ។

ការវៀរចាកចាបអកុសលនោះ ការវៀរទាំងអស់នេះ ត្រាស់ថាជាមង្គល ព្រោះជាហេតុជួបនូវផលវិសេសច្រើនប្រការ មានការលះភ័យ ពៀរដែលជាបច្ចុប្បន្ន និងប្រព្រឹត្តទៅខាងមុខជាដើម ។

ក្នុងសេចក្តីនេះ គប្បីរាប់ដល់ព្រះសូត្រទាំងឡាយ ដោយន័យជាដើមថា

ម្នាលគហបតិបុត្ត អរិយសាវក រៀរជាសមុច្ឆេទនូវបាណាតិបាត ។

និងពណ៌នានូវការសង្រួមក្នុងការផឹកទឹកស្រវឹង ពាក្យនេះជាឈ្មោះរបស់ចេតនា រៀរចាកទីតាំងនៃសេចក្តីប្រមាទ គឺការផឹកគ្រឿងស្រវឹង គឺសុរា និងមេរ័យ ដែលពោលអំពីមុនហើយ ។ ព្រោះហេតុដែលបុគ្គលផឹកទឹកស្រវឹងរមែងមិនដឹងអត្ថ មិនដឹងធម៌ រមែងធ្វើអន្តរាយដល់មាតា ធ្វើអន្តរាយដល់បិតា សូម្បីដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកបស់ព្រះតថាគត រមែងជួបនូវការតិះដៀលក្នុងភពបច្ចុប្បន្ន ជួបនូវទុគ្គតិក្នុងភពខាងមុខ និងជួបនូវភាពឆ្កួតក្នុងភពតៗ ទៅ ។ ឯការសង្រួមចាកការផឹកទឹកស្រវឹង រមែងសម្រេចការរម្ងាប់ទោសទាំងនោះ និងការដល់ព្រមដោយគុណដែលផុយគ្នានឹងទោសនោះដូច្នោះ ការសង្រួមក្នុងការផឹកទឹកស្រវឹងនេះ គប្បីជ្រាបថា ជាមង្គល ។

ការនៅមិនប្រាសចាកសតិ ក្នុងកុសលធម៌ទាំងឡាយ ដោយអត្ថ គប្បីជ្រាបដោយជាបដិបក្ខចំពោះសេចក្តីប្រមាទ ដែលលោកពោលក្នុងបាលីថា

> *ការធ្វើដោយមិនគោរព ការធ្វើមិនឲ្យរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តទម្រន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយៗ ការធ្វេសប្រហែសក្នុងការចម្រើននូវពួកធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែសមានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រមាទ ។*

ឈ្មោះថា ការមិនប្រមាទក្នុងកុសលធម៌ទាំងឡាយ ការមិនប្រមាទក្នុងកុសលធម៌នោះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុ ជួបនូវកុសលច្រើនប្រការ និងព្រោះជាហេតុសម្រេចអមតធម៌ ។ ក្នុងសេចក្តីនោះ គប្បីរឭកដល់ពាក្យទូន្មានរបស់ព្រះសាស្តាជាដើមយ៉ាងនេះថា បុគ្គលមិនប្រមាទ បុគ្គលមានសេចក្តីព្យាយាម និងពុទ្ធវចនៈមួយទៀតថា សេចក្តីមិនប្រមាទ ជាផ្លូវមិនស្លាប់ ដូច្នេះ ។

ព្រះមានព្រះភាគ ត្រាស់មង្គលនៃគាថានេះ ៣ មង្គល គឺការវៀរចាកបាប ១ ការសង្រួមចាកការផឹកទឹកស្រវឹង ១ ការមិនប្រមាទក្នុងកុសលធម៌ទាំងឡាយ ១ ដោយប្រការដូច្នេះ ។ ភាពដែលជាមង្គលទាំងនោះជាមង្គលក៏បានចង្អុលបង្ហាញហើយក្នុងមង្គលនោះទាំងអស់ ដូច្នេះ ។

អធិប្បាយបទថា អារតី ចប់

អធិប្បាយបទថា គារវោ ច

ឥទ្បូវនេះ នឹងពណ៌នាក្នុងគាថា **គារវោ ច** *ដូច្នេះ ។ បទថា* **គារវោ** *បានដល់ ភាពជាអ្នកធ្ងន់ ។ បទថា* **និវាតោ** *បានដល់ ភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួន ។ បទថា* **សន្តុដ្ឋិ** *ប្រែថា ការសន្តោស ។ ការដឹងឧបការគុណដែលលោកធ្វើទុក ឈ្មោះថា* **កតញ្ញុតា ។** *បទថា* **កាលេន** *ប្រែថា ខណៈ ឬសម័យ ។ ការស្តាប់ធម៌ ឈ្មោះថា* **ធម្មស្សវន ។** *ពាក្យដ៏សេស មាន*

ន័យដូចពោលមកហើយនោះឯង នេះជាពណ៌នាបទ ។

ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ សេចក្តីគោរព ការធ្វើសេចក្តីគោរព ភាពជាបុគ្គលមានសេចក្តីគោរពតាមសមគួរក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវ័ករបស់ព្រះតថាគត អាចារ្យ ឧបជ្ឈាយ៍ មាតាបិតា បងប្រុស បងស្រីជាដើម ជាបុគ្គលគួរប្រកបដោយសេចក្តីគោរព ឈ្មោះថា **គារវ។** *គារវៈនេះ ព្រោះហេតុដែលជាហេតុនៃការទៅសុគតិជាដើម ដូចព្រះតម្រាស់ថា*

ធ្វើសេចក្តីគោរព ដល់បុគ្គលដែលគួរគោរព រាប់អានបុគ្គលដែលគួររាប់អាន បូជាដល់បុគ្គលដែលគួរបូជា ព្រោះអំពើនោះដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។

និងដូចព្រះពុទ្ធតម្រាស់មួយទៀតយ៉ាងនេះថា

បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៧ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺសេចក្តីគោរពព្រះសាស្តា ១ ... ដូច្នេះជាដើម ទើបត្រាស់ថា ជាមង្គល ។

ភាពជាអ្នកមានចិត្តជាក់ទាប ភាពជាបុគ្គលមានការប្រព្រឹត្តមិនបំប៉ោងខ្លួន ឈ្មោះថា ការប្រព្រឹត្តបន្ទាបខ្លួន ។ បុគ្គលប្រកបដោយភាពជាអ្នកបន្ទាបខ្លួន ឯណា កម្ចាត់នូវមានះបាន កម្ចាត់នូវការរីងគ្នីងបាន ដូចសំពត់ជូតជើង ដូចគោឧសភជាក់ស្នែង និងដូចពស់ដកចង្កឹមហើយ រមែងជាអ្នកល្អិតល្អន់ទន់ភ្លន់ ស្រស់បស់ដោយសេចក្តីសុខ ភាពជាបុគ្គលបន្ទាបខ្លួននេះ ជា

និរាគ និរាគនេះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុបាននូវគុណ មានយស ជាដើម ។ ម្យ៉ាងទៀត ត្រាស់ថា ជាអ្នកបន្ទាបខ្លួន មិនរឹងត្អឹង បុគ្គលបែបនោះ រមែងបានយស ដូច្នេះជាដើម ។

ការសន្តោសដោយបច្ច័យតាមមានតាមបាន ឈ្មោះថា **សន្តុដ្ឋី** ។ *សន្តោសនោះមាន ១២ យ៉ាង គឺក្នុងចីវរ ៣ យ៉ាង គឺយថាលាភសន្តោស សន្តោសតាមដែលបាន យថាពលសន្តោស សន្តោសតាមកម្លាំង យថាសារុប្បសន្តោស សន្តោសតាមសមគួរ ក្នុងបិណ្ឌបាតជាដើមក៏យ៉ាងនេះ ។*

នឹងពណ៌នាប្រភេទនៃសន្តោសនោះ ដូច្នេះ ។ ភិក្ខុក្នុងធម្មវិន័យនេះ បានចីវរល្អក្តី មិនល្អក្តី ភិក្ខុនោះ ក៏ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរនោះប៉ុណ្ណោះ មិនប្រាថ្នាចីវរដទៃ កាលបានក៏មិនទទួលនេះ ឈ្មោះថា យថាលាភសន្តោសក្នុងចីវររបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុអាពាធ កាលដណ្តប់ចីវរធ្ងន់ រមែងមានខ្លួនកោងចុះ ឬលំបាក ទើបលោកប្តូរចីវរនោះជាមួយភិក្ខុដែលយល់ចិត្តគ្នា ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរនោះ ក៏ឈ្មោះថា សន្តោស នេះឈ្មោះថា យថាពលសន្តោសក្នុងចីវររបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត ជាអ្នកបានបច្ច័យដែលប្រណីត លោកបានចីវរ មានចីវរល្អជាដើមណាមួយ ដែលមានតម្លៃច្រើន គិតថា ចីវរនេះសមគួរដល់ព្រះថេរៈ ដែលជាអ្នកបួសយូរ និងភិក្ខុដែលជាពហុសូត ទើបប្រគេនដល់ភិក្ខុទាំងនោះ ខ្លួនឯងក៏ជ្រើសរើសយកសេសសំពត់អំពីគំនរសំរាម ឬចាកទីដទៃ

ណាមួយ ធ្វើសង្ឃាដីគ្រង ក៏នៅតែជាអ្នកសន្តោសនោះឯង នេះឈ្មោះថា **យថាសារុប្បសន្តោស** *ក្នុងចីវរបស់ភិក្ខុនោះ ។*

ម្យ៉ាងទៀត ភិក្ខុក្នុងធម្មវិនយនេះបានបិណ្ឌបាតសៅហ្មងក្តី ប្រណីតក្តី ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះ មិនបំណងបិណ្ឌបាតដទៃ ។ កាលបានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោស** *ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។*

ម្យ៉ាងទៀត ភិក្ខុអាពាធធាន់បិណ្ឌបាតសៅហ្មង រោគនឹងកម្រើកឡើងធ្ងន់ ទើបលោកប្រគេនបិណ្ឌបាតនោះដល់ភិក្ខុដែលគាប់ចិត្ត ធាន់សប្បិ ទឹកឃ្មុំ និង ទឹកដោះស្រស់ជាដើមអំពីដៃរបស់ភិក្ខុនោះ ធ្វើសមណធម៌ ក៏នៅតែជាអ្នក សន្តោស នេះជា **យថាពលសន្តោស** *ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។*

ភិក្ខុមួយរូបទៀត បានបិណ្ឌបាតដ៏ប្រណីត គិតថា បិណ្ឌបាតនេះ សម គួរដល់ព្រះថេរៈដែលជាអ្នកបួសយូរ សូម្បីដល់សព្រហ្មចារីដទៃ ដែលវៀរ បិណ្ឌបាតប្រណីតចេញ ក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅមិនបាន ទើបប្រគេន ដល់ភិក្ខុទាំងនោះ ខ្លួនឯងត្រាច់បិណ្ឌបាត ធាន់អាហារដែលលាយគ្នា ក៏នៅតែ ជាអ្នកសន្តោស នេះឈ្មោះថា **យថាសារុប្បសន្តោស** *ក្នុងបិណ្ឌបាតរបស់ភិក្ខុ នោះ ។*

ម្យ៉ាងទៀត សេនាសនៈមកដល់ភិក្ខុក្នុងធម្មវិនយនេះ លោកក៏សន្តោស ដោយសេនាសនៈនោះឯង ។ មិនព្រមទទួលសេនាសនៈដទៃដែលមកដល់ល្អ ជាង នេះឈ្មោះថា **យថាលាភសន្តោស** *ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។*

ម្យ៉ាងទៀត ភិក្ខុអាពាធនៅក្នុងសេនាសនៈដែលមិនត្រូវខ្យល់ រមែងទ្រុឌទ្រោមយ៉ាងក្រៃលែង ដោយរោគប្រមាត់ជាដើម ទើបលោកប្រគេនសេនាសនៈដល់ភិក្ខុដែលត្រូវគ្នា ហើយនៅក្នុងសេនាសនៈដែលត្រជាក់ មានខ្យល់ដែលដល់លំជាប់ភិក្ខុនោះ ធ្វើសមណធម៌ ក៏នៅឈ្មោះថា ជាអ្នកសន្តោសនេះឈ្មោះថា **យថាពលសន្តោស** *ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។*

ភិក្ខុមួយរូបទៀត មិនព្រមទទួលសេនាសនៈដែលល្អ ដែលមកដល់ គិតថា សេនាសនៈល្អ ជាទីតាំងនៃសេចក្តីប្រមាទ កាលភិក្ខុអង្គុយក្នុងសេនាសនៈនោះ ថីនមិទ្ធៈរមែងគ្របសង្កត់ កាលនិទ្រា ហើយក្រាក់ឡើងកាមវិតក្កៈរមែងផ្សាយឡើង ទើបលោកបដិសេធសេនាសនៈនោះៗ នៅតែក្នុងទីវាល គល់ឈើ និងកុដិដែលប្រក់ដោយស្មៅទីណានីមួយ ក៏នៅតែជាអ្នកសន្តោស នេះឈ្មោះថា **យថាសារុប្បសន្តោស** *ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។*

ម្យ៉ាងទៀត ភិក្ខុក្នុងធម្មវិនយនេះបានកេសជ្ជៈ មិនថា ផ្លែសម៉ ឬផ្លែកន្ធត ព្រៃ លោកក៏ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយកេសជ្ជៈនោះ ។ មិនប្រាថ្នាកេសជ្ជៈដទៃ មានសប្បិ ទឹកឃ្មុំ ទឹកអំពៅជាដើមដែលបានហើយ កាលបានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោស** *ក្នុងគិលានប្បច្ចយរបស់ភិក្ខុនោះ ។*

ម្យ៉ាងទៀត ភិក្ខុអាពាធត្រូវការប្រេង តែបានទឹកអំពៅ លោកក៏ប្រគេនទឹកអំពៅនោះដល់ភិក្ខុដែលគាប់ចិត្ត តែធ្វើថ្នាំដោយប្រេងអំពីដៃរបស់ភិក្ខុនោះ

ធ្វើសមណធម៌ ក៏នៅតែជាអ្នកសន្តោស នេះឈ្មោះថា **យថាពលសន្តោស** ក្នុងគិលានប្បច្ចយរបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត ដាក់សម៉ត្រាំទឹកមូត្រ ក្នុងភាជនៈមួយ ដាក់របស់មានរសឆ្ងាញ់ ៤ យ៉ាង ក្នុងភាជនៈមួយ កាលត្រូវភិក្ខុសព្រហ្មចារីប្រាប់ថា លោកម្ចាស់ត្រូវការរបស់ណា សូមកាន់យកចុះ បើអាពាធរបស់ភិក្ខុនោះរម្ងាប់ទៅដោយសម៉ត្រាំទឹកមូត្រ និងមធុរស គឺទាំង ២ យ៉ាងនោះណាមួយសោត កាលបើដូច្នោះ លោកគិតថា ធម្មតាសម៉ត្រាំដោយមូត្រ ព្រះពុទ្ធជាដើមទ្រង់សរសើរហើយ ហើយព្រះសម្ពុទ្ធត្រាស់ថា បព្វជ្ជាអាស្រ័យទឹកមូត្រជាភេសជ្ជៈ គប្បីធ្វើនូវឧស្សាហ៍ក្នុងមុត្តភេសជ្ជៈនោះ ដរាបដល់អស់ជីវិតបដិសេធវត្ថុ មានរសឆ្ងាញ់ជាភេសជ្ជៈ ធ្វើភេសជ្ជៈដោយសម៉ត្រាំដោយទឹកមូត្រ ក៏ជាអ្នកសន្តោសយ៉ាងក្រៃលែង នេះឈ្មោះថា **យថាសារុប្ប-សន្តោស** ក្នុងគិលានប្បច្ចយរបស់ភិក្ខុនោះ ។

សន្តោសទាំងអស់នោះ មានប្រភេទយ៉ាងនេះ ក៏ហៅថា **សន្ពុដ្ឋី** សន្ពុដ្ឋីនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុជួបនូវការលះបាបធម៌ទាំងឡាយ មានការប្រាថ្នាលើសចំណែក ការប្រាថ្នាច្រើន និងការប្រាថ្នាលាមកជាដើម ព្រោះជាហេតុនៃសុគតិ ព្រោះជាគ្រឿងអប់រំអរិយមគ្គ និងព្រោះជាហេតុនៃភាពជាអ្នកនៅបានសប្បាយក្នុងទិសទាំង ៤ ដូចព្រះមានព្រះភាគត្រាស់ថា

ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ

សន្តោស្សមានោ ឥតរីតរេន ។

បុគ្គលជាអ្នកនៅជាសុខ ក្នុងទិសទាំង ៤ មិនលំបាក

ត្រេកអរដោយបរិក្ខារ តាមមាន តាមបាន ... ។

ការស្គាល់ឧបការគុណដែលបុគ្គលណាម្នាក់ធ្វើមកហើយ ទោះច្រើន ឬតិច ដោយការរឭកដល់រឿយៗ ឈ្មោះថា **កតញ្ញូតា** *។ ម្យ៉ាងទៀត បុណ្យទាំងឡាយនោះឯង មានឧបការៈច្រើនដល់សត្វទាំងឡាយ ព្រោះការពារទុក្ខ មានទុក្ខក្នុងនរកជាដើមបាន ។ ដូច្នោះ ការរឭកដល់ឧបការៈនៃបុណ្យទាំង-នោះ គប្បីជ្រាបថា ជាកតញ្ញូតា ។ កតញ្ញូតា ទ្រង់ត្រាស់ថា ជាមង្គល ព្រោះជាហេតុជួបនូវផលវិសេស មានប្រការផ្សេងៗ មានភាពជាបុគ្គលដែលសប្បុរសសរសើរជាដើម ទាំងព្រះមានព្រះភាគក៏ត្រាស់ថា បុគ្គលជាបុព្វការី ១ បុគ្គលជាកតញ្ញូកតវេទី ១ បុគ្គល ២ ពួកនេះ រកបានដោយក្រក្នុងលោក ។*

ការស្តាប់ធម៌ ដើម្បីបន្ទោបង់នូវវិតក្ក ក្នុងកាលដែលចិត្តប្រកបដោយខន្ធៈ ឬចិត្តត្រូវវិតក្កទាំងឡាយ មានកាមវិតក្កជាដើមណាមួយគ្របសង្កត់ ឈ្មោះថា ការស្តាប់ធម៌តាមកាល ។ អាចារ្យពួកខ្លះពោលថា ការស្តាប់ធម៌រៀងរាល់ ៥ ថ្ងៃម្តង ឈ្មោះថា ស្តាប់ធម៌តាមកាល ដូចដែលលោកពោលថា ព្រះអនុរុទ្ធក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត យើងខ្ញុំព្រះអង្គតែងអង្គុយប្រជុំគ្នា ដោយធម្មីកថាពេញមួយយប់ រាល់ថ្ងៃទី ៥ ។

ម្យ៉ាងទៀត ក្នុងកាលណា ភិក្ខុចូលទៅរកកល្យាណមិត្តហើយ អាចស្តាប់ធម៌ បន្ទោបង់នូវសេចក្តីសង្ស័យរបស់ខ្លួនចេញបាន ការស្តាប់ធម៌ក្នុង

កាលនោះ ក៏គប្បីជ្រាបថា ការស្តាប់ធម៌តាមកាល ដូចព្រះមានព្រះភាគ ត្រាស់ថា បានចូលទៅសាកសួរពិគ្រោះនឹងគ្រូ ឬសព្រហ្មចារីបុគ្គលទាំងនោះ តាមកាលដ៏គួរ ... ។ ការស្តាប់ធម៌តាមកាលនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុជួបនូវផលវិសេសច្រើនប្រការ មានការលះនីវរណៈ បាននូវ អានិសង្ស ៤ នឹងសម្រេចធម៌ដែលជាទីអស់អាសវៈជាដើម សមដូចព្រះ មានព្រះភាគត្រាស់ដូច្នេះថា

> *ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវ័កធ្វើឲ្យ ជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ផ្ចង់ចិត្តទាំងអស់ ផ្អៀង សោតប្រសាទស្តាប់ធម៌ សម័យនោះ នីវរណធម៌ទាំង ៥ មិនមានដល់ភិក្ខុនោះឡើយ ។*

និងត្រាស់ថា

> *ម្នាលភិក្ខុទាំងឡាយ អានិសង្សទាំងឡាយ ៤ ប្រការ នៃធម៌ ដែលចូលទៅកាន់ត្រចៀករឿយៗ ជាធម៌ដែល បុគ្គលចាំស្ទាត់វត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ជ្រុះ ដោយទិដ្ឋិ គឺបញ្ញា រមែងកើតប្រាកដ ។*

និងត្រាស់ថា

> *ម្នាលភិក្ខុទាំងឡាយ កាល (នៃកុសលធម៌) ៤ យ៉ាងនេះ កាលបើបុគ្គលចម្រើនដោយប្រពៃ ឲ្យប្រព្រឹត្ត ទៅដោយប្រពៃ រមែងឲ្យដល់នូវការអស់ទៅនៃអាសវៈ*

ដោយលំដាប់ ។ កាល ៤ យ៉ាង តើដូចម្តេចខ្លះ ។

គឺការស្តាប់ធម៌តាមកាល ១ ... យ៉ាងនេះជាដើម ។

ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះ ៥ មង្គល គឺ សេចក្តីគោរព ១ ការបន្ទាបខ្លួន ១ សន្តោស ១ កតញ្ញុតា ១ និងការស្តាប់ធម៌តាមកាល ១ ដោយប្រការដូច្នេះ ។ ភាពដែលមង្គលទាំងនោះជាមង្គល ក៏បានចង្អុលបង្ហាញហើយ ក្នុងមង្គលទាំងនោះឯង ។

អធិប្បាយថា បទថា គារវោ ច ចប់

អធិប្បាយបទថា ខន្តិ ច

ឥទ្បូវនេះ នឹងពណ៌នាក្នុងគាថាថា **ខន្តិ ច** *នេះ ការអត់ធន់ ឈ្មោះថា* **ខន្តិ ។** *ឈ្មោះថា* **សុវច** *ព្រោះប្រដៅងាយ ព្រោះជាបុគ្គលកាន់យកចំណែកខាងស្តាំ ។ កម្មរបស់បុគ្គលប្រដៅងាយ ឈ្មោះថា* **សោវចស្ស ។** *ភាវៈនៃកម្មរបស់បុគ្គលប្រដៅងាយ ឈ្មោះថា* **សោវចស្សតា ។** *ឈ្មោះថា សមណៈ ព្រោះរម្ងាប់កិលេសទាំងឡាយបាន ។ បទថា* **ទស្សនំ** *បានដល់ ការសម្លឹងមើល ។ ការសន្ទនា ឈ្មោះថា* **ធម្មសាកច្ឆា ។** *ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។ នេះជាពណ៌នាបទ ។*

ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះថា **អធិវាសនខន្តិ** *ឈ្មោះថា ខន្តី កិក្ខុដែលប្រកបដោយខន្តីនោះហើយ រមែងមិនមានអាការខុសប្រក្រតី ជាអ្នក*

ហាក់ដូចមិនបានឮពាក្យជេរដោយអក្កោសវត្ថុ ១០ និងដូចមិនឃើញបុគ្គលដែលបៀតបៀន ដោយការសម្ងាប់ និងការចងជាដើម ដូចខន្តិវាទីតាបសដូច្នោះ ។ ដូចព្រះមានព្រះភាគត្រាស់ថា

អហុ អតីតមទ្ធានេ សមណោ ខន្តិទីបនោ
តំ ខន្តិយា យេវ ឋិតំ កាសិរាជា អឆេទយិ ។

សមណៈជាអ្នកសម្តែងនូវខន្តី មានហើយក្នុងអតីតកាល ព្រះបាទកាសី ទ្រង់ត្រាស់ឲ្យចោរឃាតកបុរសសម្ងាប់សមណៈនោះ អ្នកតាំងនៅក្នុងខន្តី ។

ឬរមែងជាក់ចិត្តថា បុគ្គលនោះធ្វើល្អហើយ ព្រោះមិនមានការត្រេកអរក្រៃលែងជាងនោះ ដូចព្រះបុណ្ណត្ថេរ ដូច្នោះ ដែលលោកក្រាបទូលថា

បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងជេរគំរាមខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះយ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ល្អណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះ មិនប្រហារអាត្មាអញដោយជាតដៃ ... ដូច្នេះ ។

កិក្ខុប្រកបដោយខន្តីនោះហើយ រមែងជាបុគ្គលដែលសូម្បីតែឥសីទាំងឡាយក៏សរសើរ ដូចសរភង្គឥសីពោលថា

កោធំ វធិត្វា ន កទាចិ សោចតិ មក្ខប្បហានំ

ឥសយោ វណ្ណយន្តិ សព្វេសំ វុត្តំ ជរុសំ ទមេថ ឯតំ
ទន្តឹ ឧត្តមមាហុ សន្តោ ។

បុគ្គលសម្ងាប់សេចក្តីក្រោធ រមែងមិនក្រៀមក្រំក្នុងកាល
ណាម្តងទ្បើយ ឥសីទាំងឡាយ រមែងសរសើរនូវការ
លះបង់នូវសេចក្តីលុបគុណគេ បុគ្គលគប្បីអត់ធន់ចំពោះ
ពាក្យអាក្រក់ ដែលបុគ្គលទាំងពួងពោលហើយ ពួក
សប្បុរសពោលនូវសេចក្តីអត់ធន់នុ៉ះ ថាជាគុណជាតិ
ដ៏ឧត្តម ។

រមែងជាបុគ្គលដែលទេវតាទាំងឡាយ គប្បីសរសើរ ដូចសក្កទេវរាជ
ត្រាស់ថា

យោ ហវេ ពលវា សន្តោ ទុព្វលស្ស តិតិក្ខតិ
តមាហុ បរមំ ទន្តឹ និច្ចំ ទមតិ ទុព្វលោ ។

ជនណាមានកម្ងាំង ជាអ្នកស្ងប់ ហើយអត់ឱនចំពោះ
បុគ្គលមានកម្ងាំងខ្សោយ បណ្ឌិតទាំងឡាយសរសើរ
ជននោះ ថាជាអ្នកមានសេចក្តីអត់ទ្រាំដ៏ក្រៃលែង ព្រោះ
ថា បុគ្គលមានកម្ងាំងថយ តែងអត់សង្កត់ជានិច្ច ។

រមែងជាបុគ្គលដែលព្រះពុទ្ធទាំងឡាយ គប្បីសរសើរ ដូចព្រះមានព្រះ
ភាគត្រាស់ថា

អក្ពោសំ វធពន្ធញ្ច អទុដ្ឋោ យោ តិតិក្ខតិ

ខន្ដីពលំ ពលានីកំ តមហំ ព្រូមិ ព្រាហ្មណំ។

បុគ្គលណា មិនប្រទូស្ដ អត់សង្កត់ពាក្យជេរផង ការបៀតបៀន និងការចងផងបាន ទើបតថាគត ហៅបុគ្គលដែលមានខន្ដិជាពល មានខន្ដិជារេហ៍ពល នោះឯង ថាជាព្រាហ្មណ៍ ។

ខន្ដីនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុជួបនូវគុណទាំងនោះ និងគុណដទៃៗ ដែលទ្រង់សរសើរក្នុងទីនេះ ។

កាលត្រូវសព្រហ្មចារី ប្រៀនប្រដៅក៏មិនដល់នូវការរាយមាយ និងអង្គុយស្ងៀម ឬគិតដល់គុណ និងទោស ជាក់នូវការអើពើ សេចក្ដីគោរព និងការមានចិត្ដជ្ជាក់ទៅ ជាទីទៅខាងមុខយ៉ាងក្រៃលែង ហើយបន្ទឹពាក្យថា **សាធុ** *ជូរច្នេះ ឈ្មោះថា* **សោវចស្សតា** *គឺការប្រដៅងាយ ។* **សោវចស្សតា** *នោះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុបានឱវាទ និងអនុសាសនីអំពីសម្នាក់សព្រហ្មចារីទាំងឡាយ និងព្រោះជាហេតុលះទោស និងសម្រេចនូវគុណ ។*

ការចូលទៅរកការទំនុកបម្រុង ការរឭក ការស្ដាប់ និងការឃើញអ្នកបួសទាំងឡាយ ដែលស្ងប់រម្ងាប់កិលេស ហើយអប់រំកាយ វាចា ចិត្ដ និងបញ្ញាហើយ ប្រកបដោយសេចក្ដីស្ងប់ដ៏ឧត្ដម ឈ្មោះថា ការឃើញសមណៈទាំងឡាយ ។ ការឃើញសមណៈទាំងឡាយ លោកពោលថា ទស្សនៈ ដោយទេសនាយ៉ាងទាប ។ ការឃើញសមណៈនោះ គប្បីជ្រាបថា ជាមង្គល ។ ព្រោះហេតុអ្វី ព្រោះមានឧបការៈច្រើន ពិតហើយ ព្រះមាន

ព្រះភាគត្រាស់ជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការជួបប្រទះ នូវភិក្ខុទាំងនោះថា មានឧបការៈច្រើន ព្រោះបុណ្យឯណា ដែលកុលបុត្រ អ្នកប្រាថ្នាប្រយោជន៍ ឃើញភិក្ខុទាំងឡាយដែលមានសីល មកដល់ទ្វារផ្ទះ បើទេយ្យធម៌មាន ក៏គប្បីរាប់អាន ដោយទេយ្យធម៌តាមកម្លាំង បើមិនមាន គប្បីថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន កាលការថ្វាយបង្គំដោយបញ្ចង្គប្រតិ-ស្ឋានមិនដល់ព្រម ក៏គប្បីផ្គងអញ្ជលីនមស្ការ បើនមស្ការមិនដល់ព្រម ក៏គប្បី មានចិត្តជ្រះថ្លា សម្លឹងមើលដោយចក្ខុជាទីស្រឡាញ់ ដោយបុណ្យ មានការ សម្លឹងមើលជាមូលយ៉ាងនេះ រោគ ឬទោស កន្ទុយថ្លែន ឬពក នឹងមិនមាន ក្នុងចក្ខុអស់ពាន់ជាតិ ចក្ខុទាំង ២ ក៏នឹងផូរផង់ មានសិរី មានពណ៌ ៥ ដូច បង្កងកែវមណីដែលបើកក្នុងវតនវិមាន បុគ្គលនោះ នឹងបានសម្បត្តិក្នុងទេវតា និងមនុស្សប្រមាណសែនកប្ប កាលកើតជាមនុស្ស ក៏ជាអ្នកមានបញ្ញា គប្បី សោយវិបាកសម្បត្តិបែបនេះ ដោយបុណ្យដែលសម្រេចមកអំពីការឃើញ សមណៈ ដែលបុគ្គលនោះ ប្រព្រឹត្តមកដោយប្រពៃ មិនគួរអស្ចារ្យឡើយ សូម្បីសត្វតិរច្ឆាន បណ្ឌិតទាំងឡាយ ក៏ពណ៌នាវិបាកសម្បត្តិ នៃការឃើញ សមណៈ ដោយត្រឹមតែធ្វើសទ្ធាឲ្យកើតហើយតែម្យ៉ាងយ៉ាងនេះ ក្នុងបាលី-បទេសណា បាលីបទេសនោះ មានដូច្នេះ

សត្វទីទុយ អាស្រ័យវេទិយកបព្ពត មកអស់កាលយូរ ទីទុយនេះសុខ ពិតហ្ន៎ ឃើញព្រះពុទ្ធដ៏ប្រសើរ ដែលក្រោកឡើងអំពីព្រលឹម ។ ទីទុយធ្វើចិត្ត ឲ្យជ្រះថ្លាក្នុងតថាគត និងភិក្ខុសង្ឃ ដែលជាអគ្គបុគ្គល មិនទៅទុគ្គតិអស់

សែនកប្ប ទីទុយនោះចុតិអំពីទេវលោក កាលកុសលកម្ម ជាស់តឿនហើយ នឹងបានជាព្រះបច្ចេកពុទ្ធ ជាអនន្តញ្ញាណ ប្រាកជនាមថា សោមនស្ស ដូច្នេះ ។

ក្នុងវេលាព្រលប់ ឬក្នុងវេលាទៀបភ្លឺ ភិក្ខុខាងព្រះសូត្រ ២ រូប រមែងសន្ទនាទូវព្រះសូត្រជល់គ្នានឹងគ្នា ភិក្ខុចំណែកខាងវិន័យ ក៏សន្ទនាព្រះវិន័យ ភិក្ខុខាងអភិធម្ម ក៏សន្ទនាខាងព្រះអភិធម្ម ភិក្ខុខាងជាតក ក៏សន្ទនាខាងជាតក ខាងអដ្ឋកថា ក៏សន្ទនាខាងអដ្ឋកថា ឬសន្ទនាគ្នាក្នុងកាលនោះៗ ដើម្បីជម្រះចិត្តដែលត្រូវសេចក្តីរាយមាយគ្របសង្កត់ និងការសង្រ្គយដឹកនាំទៅ ការសន្ទនាតាមកាលនេះ ឈ្មោះថា សន្ទនាធម៌តាមកាល ការសន្ទនាធម៌តាមកាលនោះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុនៃគុណទាំងឡាយ មានការឈ្វាសក្នុងអាគម គឺនិកាយទាំង ៥ ជាដើម ។

ព្រះមានព្រះភាគ ត្រាស់មង្គលនៃគាថានេះ ៤ មង្គល គឺការអត់ធន់ ១ ភាពជាអ្នកប្រដៅងាយ ១ ការឃើញសមណៈ ១ ការសន្ទនាធម៌តាមកាល ១ ដោយប្រការដូច្នេះ ។ ភាពដែលមង្គលទាំងនោះជាមង្គល បានចង្អុលបង្ហាញហើយ ក្នុងមង្គលទាំងអស់ហើយនោះឯង ។

អធិប្បាយថាបទថា ខន្តិ ច ចបៅ

អធិប្បាយបទថា តថោ ច

ឥឡូវនេះ នឹងពណ៌នាក្នុងគាថាថា **តថោ ច** *នេះ ។ ឈ្មោះថា* **តប**

ព្រោះដុតនូវបាបធម៌ ។ ការប្រព្រឹត្តដូចព្រហ្ម ឬការប្រព្រឹត្តរបស់ព្រហ្ម ឈ្មោះ
ថា **ព្រហ្មចរិយ** *លោកអធិប្បាយថា ការប្រព្រឹត្តដ៏ប្រសើរ ការឃើញអរិយ-*
សច្ចទាំង៤ឋាយ ឈ្មោះថា **អរិយសច្ចាន ទស្សនំ ។** *អាចារ្យពួកខ្លះពោលថា*
អរិយសច្ចានិ ទស្សនំ *ដូច្នេះក៏មាន ។ ឈ្មោះថា* **និព្វាន** *ព្រោះចេញចាក*
តណ្ហាជាគ្រឿងជោតក្រង ។ ការធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា **សច្ឆិកិរិយា ។**
ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ឈ្មោះថា **និព្វានសច្ឆិកិរិយា ។** *ពាក្យដ៏*
សេស មានន័យដូចពោលមកហើយនោះឯង ។ នេះជាពណ៌នាបទ ។

ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះថា ឥន្ទ្រិយសំវរៈ ឈ្មោះថា **តប**
ព្រោះដុតអកិរិយា និងទោមនស្សជាដើម ឬសេចក្តីព្យាយាម ឈ្មោះថា **តប**
ព្រោះដុតការខ្ជិលច្រអូស បុគ្គលប្រកបដោយតបៈទាំងនោះ លោកហៅថា
អាតាបី *តបៈនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុលះអកិរិយាជាដើម*
និងបានឈានជាដើម ។

ឈ្មោះថា **ព្រហ្មចរិយ** *ជាឈ្មោះនៃមេថុនវិរតិ សមណធម៌ សាសនា*
និងមគ្គ ។ ពិតហើយ មេថុនវិរតិ លោកហៅថា **ព្រហ្មចរិយ** *ដូចក្នុង*
ប្រយោគជាដើមថា **អព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ** *លះបង់*
អព្រហ្មចរិយៈហើយ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ។ សមណធម៌ ហៅ
ថា **ព្រហ្មចរិយ** *ដូចក្នុងប្រយោគជាដើមថា* **ភគវតិ នោ អាវុសោ ព្រហ្ម-**
ចរិយំ វុស្សតិ *ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុង*
សម្នាក់ព្រះមានព្រះភាគរបស់យើងដែរឬ ។

សាសនា ហៅថា **ព្រហ្មចរិយ** *ដូចក្នុងប្រយោគយ៉ាងនេះជាដើមថា* **ន តាវាហំ ចាបិម បរិនិព្វាយិស្សាមិ យាវ មេ ឥទំ ព្រហ្មចរិយំ ន ឥទ្ធញ្ចេវ ភវិស្សតិ ផីតញ្ច វិត្ថារិកំ ពហុជញ្ញំ** *ម្នាលមារមានចិត្តបាប ព្រហ្មចារ្យ របស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅ សព្វទិស គេមិនទាន់ដឹងច្រើនគ្នា ... ជរាបណា តថាគតនឹងមិនទាន់បរិនិព្វាន ជរាបនោះ ។*

មគ្គ ហៅថា **ព្រហ្មចរិយ** *ដូចក្នុងប្រយោគយ៉ាងនេះជាដើមថា* **អយមេវ ខោ ភិក្ខុ អរិយោ អដ្ឋង្គិកោ មគ្គោ ព្រហ្មចរិយំ សេយ្យថីទំ សម្មាទិដ្ឋិ** *ម្នាលភិក្ខុ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ហៅថា* **ព្រហ្មចរិយ** *។ មគ្គទាំង ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ... ។ តែក្នុងទីនេះ ព្រហ្មចរិយៈ គ្រប់យ៉ាងមិនមានសេសសល់ រមែងគួរ ព្រោះមគ្គ លោកសង្គ្រោះដោយ អរិយសច្ចានទស្សនៈខាងមុខហើយ ។ ព្រហ្មចរិយៈនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុជួបនូវផលវិសេសច្រើនប្រការ ខ្ពស់ឡើងៗ ។*

ការយើញមគ្គ ដោយត្រាស់ដឹងអរិយសច្ច ៤ ដែលពោលហើយ ក្នុងកុមារប្បញ្ហា ឈ្មោះថា **អរិយសច្ចានទស្សន ។** *អរិយសច្ចានទស្សនៈនោះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុកន្ទងបង់នូវទុក្ខក្នុងសង្សារវដ្ត ។*

អរហត្តផល លោកបំណងយកថា និព្វានក្នុងទីនេះ ។ ឈ្មោះថា **និព្វាន-សច្ឆិកិរិយា** *គឺធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ពិតហើយ អរហត្តផលនោះ លោកពោលថា និព្វាន ព្រោះចេញចាកតណ្ហា ដែលតែងហៅថា* **វាន** *ព្រោះ*

ដោតក្រងទុកក្នុងគតិ ៥ ។ ការដល់ ឬការពិចារណានិញ្ចាននោះ ហៅថា **សច្ឆិកិរិយា** តែការធ្វើឲ្យជាក់ច្បាស់នូវព្រះនិញ្ចានក្រៅពីនេះ សម្រេចបានដោយការឃើញអរិយសច្ច ៤ នោះឯង ដោយហេតុនោះ ការឃើញអរិយ-សច្ចនោះ ទើបលោកមិនបំណងយកក្នុងទីនេះ ។ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិញ្ចាននោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនាំមកនូវជាសុខ ក្នុងបច្ចុ-ប្បន្នជាដើម ដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះ ៤ មង្គល គឺតប: ១ ព្រហ្មចរិយ: ១ អរិយសច្ចានទស្សន: ១ និងនិញ្ចានសច្ឆិកិរិយា ១ ដោយប្រការដូច្នេះ ។ ការដែលមង្គលទាំងនោះ ជាមង្គល បានចង្អុលបង្ហាញ ក្នុងមង្គលទាំងនោះឯង ។

អធិប្បាយបទថា តទោ ច ចប់

អធិប្បាយបទថា ផុដ្ឋស្ស លោកធម្មេហិ

ឥឡូវនេះ នឹងពណ៌នាក្នុងគាថាថា **ផុដ្ឋស្ស លោកធម្មេហិ** នេះ ។ បទថា **ផុដ្ឋស្ស** បានដល់ ពាល់ត្រូវហើយ ប៉ះពាល់ហើយ ប្រសព្វហើយ ។ ធម៌ទាំងឡាយក្នុងលោក ឈ្មោះថា **លោកធម៌ ។** លោកអធិប្បាយថា ធម៌ទាំងឡាយនឹងមិនវិលត្រឡប់ដរាបណា លោកធម៌នៅប្រព្រឹត្តទៅដរាបនោះ ។ បទថា **ចិត្តំ** បានដល់ មនោ មានស: ។ បទថា **យស្ស** បានដល់ របស់ភិក្ខុថ្មី ភិក្ខុកណ្តាល ឬភិក្ខុជាថេរ: ។ បទថា **ន កម្បតិ** បានដល់

មិនញាប់ញ័រ មិនកម្រើក ។ បទថា **អសោកំ** *បានដល់ មិនមានសេចក្តីសោក ដកនូវសេចក្តីសោកចេញហើយ ។ បទថា* **វិរជំ** *បានដល់ ប្រាសចាកធូលី គឺកិលេស កម្ចាត់ធូលី គឺកិលេសហើយ ។ បទថា* **ខេមំ** *បានដល់ មិនមានភ័យ មិនមានឧបទ្រវ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។ នេះជាពណ៌នាបទ ។*

ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះថា ចិត្តនៃបុគ្គលណាដែលលោកធម៌ ៨ មានលាភ មិនមានលាភជាដើមពាល់ត្រូវគ្របសង្កត់ហើយ រមែងមិនញាប់ញ័រ មិនកម្រើក មិនរង្គោះ ឈ្មោះថា ចិត្តនៃបុគ្គលណាដែលលោកធម៌ប៉ះខ្ទប់ហើយមិនកម្រើក ចិត្តនោះនៃបុគ្គលនោះ គប្បីជ្រាបថាជាមង្គល ព្រោះនាំមកនូវភាពប្រសើរលើសលោក ដែលធម៌ណាមួយឲ្យកម្រើកមិនបាន ។

សួរថា ចិត្តនៃបុគ្គលណា ត្រូវលោកធម៌ទាំងនោះប៉ះខ្ទប់ហើយមិនកម្រើក ឆ្លើយថា ចិត្តនៃព្រះអរហន្តខីណាស្រព មិនមែនចិត្តរបស់បុគ្គលដទៃ ។ ពិតហើយ ព្រះមានព្រះភាគត្រាស់ដូច្នេះថា

សេលោ យថា ឯកឃនោ វាតេន ន សមីរតិ
ឯវំ រូបា រសា សទ្ទា គន្ធា ផស្សា ច កេវលា
ឥដ្ឋា ធម្មា អនិដ្ឋា ច ន បវេធេន្តិ តាទិនោ
ឋិតំ ចិត្តំ វិប្បមុត្តំ វយញ្ចស្សានុបស្សតិ ។

ថ្មដែលតាន់សុទ្ធ មិនបានរញ្ជួយដោយខ្យល់ យ៉ាងណាមិញ រូប សំឡេង ក្លិន រស ផស្សៈ និងធម្មារម្មណ៍ទាំងអស់

ដែលជាទីគាប់ចិត្តក្តី មិនជាទីគាប់ចិត្តក្តី ក៏ញុំាងចិត្តរបស់កិក្ខុជាតាទិបុគ្គលឲ្យញាប់ញ័រមិនបាន យ៉ាងនោះដែរ ចិត្តរបស់កិក្ខុនោះជាចិត្តឋិតនៅខ្ជាប់ខ្ជួន ជាចិត្តផុតស្រឡះចាកកិលេសហើយ លោកពិចារណាឮវសេចក្តីកើត និងសេចក្តីរលត់នៃចិត្តនោះ ។

ចិត្តរបស់ព្រះខីណាស្រពប៉ុណ្ណោះ ឈ្មោះថា **អសោក** *។ ពិតហើយ ចិត្តនៃព្រះខីណាស្រពប៉ុណ្ណោះ ឈ្មោះថា* **អសោក** *ព្រោះមិនមានការសោក ដែលលោកពោលដោយន័យជាដើមថា សេចក្តីស្តាយស្រណោះ សេចក្តីស្រងេះស្រងោច សេចក្តីសោយសោក សេចក្តីរីងស្ងួតក្នុងចិត្ត សេចក្តីក្រៀមក្រំក្នុងចិត្ត ។ អាចារ្យពួកខ្លះពោលដល់ព្រះនិព្វាន ពាក្យនោះ ភ្ជាប់សេចក្តីមិនបាន ជាមួយនឹងបទខាងដើម ចិត្តរបស់ព្រះខីណាស្រពប៉ុណ្ណោះ ឈ្មោះថា* **អសោក** *យ៉ាងណា ក៏ឈ្មោះថា* **វិរជ ទេម** *ដូច្នោះ ។ ពិតហើយ ចិត្តនៃព្រះខីណាស្រពនោះ ឈ្មោះថា* **វិរជ** *ព្រោះប្រាសចាកធូលី មានរាគៈ ទោសៈ មោហៈជាដើម និងឈ្មោះថា* **ទេម** *ព្រោះផុតចាកយោគៈទាំង ៤ ព្រោះថា ចិត្តទាំង ៣ យ៉ាងនោះ លោកកាន់យកហើយក្នុងខណៈចិត្តប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំងនោះ ដោយអាការនោះៗ គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវភាពជាបុគ្គលឧត្តុង្គឧត្តមលើសលោក មានភាពជាបុគ្គល ដែលមានខន្ធមិនប្រព្រឹត្តទៅហើយ និងព្រោះនាំមកនូវភាពជាអាហុនេយ្យបុគ្គលជាដើម ។*

ព្រះមានព្រះភាគ ត្រាស់មង្គលនៃគាថានេះ ៤ មង្គល គឺចិត្តដែលមិនញាប់ញ័រដោយលោកធម៌ប្រាំបី ១ ចិត្តមិនសោយសោក ១ ចិត្តប្រាសចាកលម្អងធូលី គឺកិលេស ១ ចិត្តក្សេម ១ ដោយប្រការដូច្នេះ ។ ភាពដែលមង្គលទាំងនេះ ជាមង្គល ក៏បានចង្អុលបង្ហាញហើយ ក្នុងមង្គលទាំងអស់នោះឯង ។

អធិប្បាបទថា ផុដ្ឋស្ស លោកធម្មេហិ ចប៌

អធិប្បាយបទថា ឯតាទិសានិ

ព្រះមានព្រះភាគ កាលត្រាស់មហាមង្គល ៣៨ ប្រការ ដោយគាថា ១០ មានពាក្យថា **អសេវនា ច ពាលានំ** *ការមិនសេពគប់បុគ្គលពាលជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសរសើរមង្គល ដែលទ្រង់ត្រាស់ទាំងនេះហើយ ទើបត្រាស់គាថាចុងក្រោយថា* **ឯតាទិសានិ កត្វាន** *ជាដើម ។*

ពណ៌នាអត្ថនៃគាថាចុងក្រោយនោះ ដូច្នេះថា បទថា **ឯតាទិសានិ** *ប្រែថា ដូច្នេះ ឬទាំងនេះ គឺមានការមិនសេពគប់បុគ្គលពាលជាដើម មានប្រការដែលខ្ញុំពោលមកហើយ ។ បទថា* **កត្វាន** *ប្រែថា ធ្វើ ។ សេចក្តីពិត ពាក្យនេះ មិនក្រៅអត្ថអំពីអត្ថថា* **កត្វាន កត្វា ករិត្វា** *គឺប្រែថា ធ្វើដូចគ្នា ។ បទថា* **សព្វត្ថមបរាជិតា** *សេចក្តីថា សត្វទាំងឡាយធ្វើមង្គលទាំងនេះដែលជាសត្រូវ ៤ ប្រភេទ គឺខន្ធមារ កិលេសមារ អភិសង្ខារមារ និងទេវ-*

បុត្តមារ សូម្បីតែមួយ ក៏ធ្វើឲ្យចាញ់មិនបាន ក្នុងទីទាំងពួង លោកអធិប្បាយ ថា ញ៉ាំងមារទាំង ៤ នោះ ឲ្យចាលចាញ់ដោយខ្លួនឯង ។ **ម** *អក្សរៈ ក្នុង ពាក្យថា* **សព្វត្ថមបរាជិតា** *នេះ គប្បីជ្រាបថា ត្រឹមតែធ្វើការតបទ ។*

បទថា **សព្វត្ថ សោត្ថឹ គច្ឆន្តិ** *សេចក្តីថា សត្វទាំងឡាយ ធ្វើមង្គល ដូចពោលមកនេះ ដែលមានទាំង ៤ ធ្វើឲ្យចាញ់មិនបានហើយ រមែងដល់នូវ សួស្តីក្នុងទីទាំងពួង គឺក្នុងលោកនេះ និងលោកខាងមុខ ទោះឈរក្តី ដើរក្តី អាសវៈពួកណា ដែលធ្វើនូវការចង្អៀតចង្អល់ និងក្តៅក្រហាយ គប្បីកើត ឡើង ព្រោះការសេពគប់បុគ្គលពាលជាដើម ព្រោះមិនមានអាសវៈ ទាំង នោះ ទើបដល់នូវសួស្តី លោកអធិប្បាយថា ជាបុគ្គលដែលឧបទ្រវមិនរារាំង ដែលឧបសគ្គមិនរារាំង ក្សេមទួលាយ មិនមានភ័យចំពោះមុខ ។ ឯនិគ្គហិត ក្នុងពាក្យថា* **សព្វត្ថ សោត្ថឹ គច្ឆន្តិ** *នេះ គប្បីជ្រាបថា ត្រាស់ដើម្បីងាយ ស្រួលដល់ការចងគាថា ទ្រង់បញ្ចប់ទេសនា ដោយបទនៃគាថាថា* **តំ តេសំ មង្គលមុត្តមំ** *។ ទ្រង់បញ្ចប់ដូចម្តេច ទ្រង់បញ្ចប់ថា ម្នាលទេវបុត្រ ព្រោះហេតុដែលជនធ្វើ មង្គលដូចពោលមកនេះ រមែងដល់នូវសួស្តី ក្នុងទី ទាំងពួងយ៉ាងនេះ ដូច្នោះ ទើបលោកកាន់យកថា មង្គលទាំង ៣៨ ប្រការ មានការមិនសេពគប់បុគ្គលពាលជាដើម ជាមង្គលឧត្តម ប្រសើរបំផុត ល្អ បំផុត សម្រាប់ជនទាំងនោះ ដែលធ្វើមង្គលដូចពោលមកនេះ ។*

ចុងក្រោយ ទេសនាដែលព្រះមានព្រះភាគទ្រង់បញ្ចប់យ៉ាងនេះ ទេវតា សែនកោដិសម្រេចអរហត្ត ទេវតាដែលសម្រេចសោតាបត្តិផល សកទាគា-

មិផល អនាគាមិផល រាប់ប្រមាណមិនបាន ។ គ្រានោះ ព្រឹកឡើង ព្រះដ៏មានព្រះភាគត្រាស់ហៅព្រះអានន្ទមក ត្រាស់ថា ម្នាលអានន្ទ កាលអំពីយប់មិញនេះ ទេវតាមួយរូប ចូលមកសួរមង្គលប្បញ្ហា កាលនោះ តថាគតបានពោលមង្គល ៣៨ ប្រការដល់ទេវតារូបនោះ ម្នាលអានន្ទ អ្នកចូររៀនមង្គលបរិយាយនេះ កាលរៀនហើយ ចូរបង្រៀនដល់ភិក្ខុទាំងឡាយ ព្រះថេរៈរៀនហើយ ក៏បង្រៀនដល់ភិក្ខុទាំងឡាយ ។ មង្គលសូត្រនេះ អាចារ្យនាំបន្តៗ គ្នាមក ប្រព្រឹត្តទៅដរាបដល់សព្វថ្ងៃនេះ គប្បីជ្រាបថា សាសនព្រហ្មចរិយៈនេះ ចម្រើនមាំទាំ ផ្សាយទៅ ជនទាំងឡាយដ៏ច្រើន ចេះដឹង ដរាបណាទេវតា និង មនុស្សប្រកាសល្អហើយ ។

ដើម្បីការឈ្លាសក្នុងការសន្សំការចេះដឹង ក្នុងមង្គលទាំងនេះឯង ឥឡូវនេះ និងប្រកបសេចក្តីតាំងអំពីដើម ដូច្នេះ ។

សត្វទាំងឡាយដែលប្រាថ្នាសុខក្នុងលោកនេះ និងលោកខាងមុខ និងលោកុត្តរសុខទាំងនេះ លះនូវការសេពគប់បុគ្គលពាល អាស្រ័យតែបណ្ឌិត បូជាបុគ្គលដែលគួរបូជា នៅក្នុងបដិរូបទេស និងភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុនជាសន្តឹង ក្នុងការបំពេញកុសល តាំងខ្លួនប្រពៃ មានអត្តភាពប្រដាប់ដោយពាហុសច្ចៈ សិប្បៈ និងវិនយ ពោលសុភាសិតដែលសមគួរដល់វិនយ មិនទាន់លះភេទគ្រហស្ថដរាបណា ក៏ជម្រះនូវមូលបំណុលចាស់ដោយទំនុកបម្រុងមាតាបិតា ប្រកបមូលបំណុលថ្មី ដោយការសង្គ្រោះបុត្រ និងភរិយា ដល់នូវការតាំងមាំដោយទ្រព្យ និងស្រូវ ដោយភាពជាបុគ្គលមាន

ការងារមិនច្របូកច្របល់ ទាញយកនូវសារៈនៃភោគៈ ដោយការឲ្យទាន និង សារៈនៃជីវិត ដោយការប្រព្រឹត្តធម៌ ធ្វើប្រយោជន៍ដល់ជនរបស់ខ្លួន ដោយ ការសង្គ្រោះញាតិ និងប្រយោជន៍ដល់ជនដទៃៗ ដោយការងារដែលមិនមាន ទោស រៀរការប្រទូស្តអ្នកដទៃ ដោយការរៀរចាកបាប រៀរចាកការប្រទូស្ត ខ្លួនឯង ដោយសង្រួមក្នុងការផឹកទឹកស្រវឹង ចម្រើនបុរេកុសល ដោយសេចក្តី មិនប្រមាទក្នុងធម៌ទាំងឡាយ លះភេទគ្រហស្ថ ដល់ភាពជាបុគ្គលចម្រើនបុរេ កុសល បើនៅក្នុងភាវៈជាបព្វជិត ក៏ញុំាងវត្តសម្បទាឲ្យសម្រេចដោយសេចក្តី គោរពក្នុងព្រះពុទ្ធ សាវ័ករបស់ព្រះពុទ្ធ និងឧបជ្ឈាយ៍ឃាចារ្យជាដើម និង ដោយការប្រព្រឹត្តបន្ទាបខ្លួន លះនូវការចង់បាននូវបច្ច័យ ដោយសន្តោស តាំងនៅក្នុងសប្បុរសភូមិ ដោយភាពជាកតញ្ញូ លះនូវភាពជាបុគ្គលមាន ចិត្តរញ្ជួរ ដោយការស្តាប់ធម៌ គ្រប់សង្កត់អន្តរាយគ្រប់យ៉ាង ដោយខន្តី ។ ធ្វើខ្លួនឲ្យមានទីពឹង ដោយភាពជាអ្នកប្រដៅងាយ មើលការប្រកបបដិបទា ដោយការឃើញសមណៈបានូបចង់នូវសេចក្តីសង្ស័យ ក្នុងធម៌ទាំងឡាយជាទី តាំងនៃសេចក្តីសង្ស័យ ដោយការសន្ទនាធម៌ ដល់នូវសីលវិសុទ្ធិ ដោយ តបៈ គឺឥន្ទ្រិយសំវរៈ ដល់នូវចិត្តវិសុទ្ធិ ដោយព្រហ្មចរិយៈ គឺសមណធម៌ និងញុំាងវិសុទ្ធិ ៤ ក្រៅអំពីនោះឲ្យដល់ព្រម ដល់នូវញាណទស្សនវិសុទ្ធិ ដែលជាបរិយាយនៃការឃើញអរិយសច្ច ដោយបដិបទានេះ ធ្វើឲ្យជាក់ ច្បាស់នូវព្រះនិព្វាន ដែលរាប់បានថា អរហត្តផល កាលធ្វើឲ្យជាក់ច្បាស់ ហើយ ជាអ្នកមានចិត្តមិនញាប់ញ័រដោយលោកធម៌ ៨ ដូចសិនេរុបព៌ត មិន

ញាប់ញ័រដោយខ្យល់ និងភ្លៀង រមែងជាអ្នកមិនសោយសោក ប្រាសចាកលម្អងកិលេស មានការក្សេម ទូលាយ រមែងជាបុគ្គលដែលសត្រូវណាម្នាក់ឲ្យចុះចាញ់មិនបាន ក្នុងទីទាំងពួងផង ដល់នូវសួស្តី ក្នុងទីគ្រប់អន្ទើផង ។ ដោយប្រការដូច្នេះ ទើបព្រះមានព្រះភាគត្រាស់ថា ទេវតា និងមនុស្សទាំង-ឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្តី ក្នុងទីទាំងពួង នេះជាមង្គលដ៏ឧត្តមរបស់ទេវតា និងមនុស្សទាំងឡាយនោះ ៗ

អធិប្បាយមង្គលសូត្រ ចប់

សុត្តន្តបិដក

ខុទ្ទកនិកាយ: រតនសូត្រ

[៧] ពួកភូតណា បិតនៅលើផែនដីក្តី ពួកភូតណា បិតនៅឰដ៏អាកាសក្តី ដែលមកជួបជុំក្នុងទីនេះ ពួកភូតទាំងអស់នោះ ចូរមានចិត្តល្អមួយទៀត ចូរស្តាប់នូវភាសិតដោយគោរព ព្រោះហេតុនោះ អ្នកទាំងឡាយជាភូតទាំងអស់ ចូរស្តាប់ (នូវព្រះបរិត្ត) ចូរធ្វើនូវមេត្តាចិត្តដល់ពពួកសត្វជាមនុស្សជាតិ មនុស្សទាំងឡាយណា តែងនាំមកនូវពលី ក្នុងពេលថ្ងៃ និងពេលយប់ ព្រោះហេតុនោះ សូមអ្នកទាំងឡាយ កុំប្រហែសធ្វេសរក្សានូវមនុស្សទាំងនោះ ។ ទ្រព្យណាមួយក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី រតនវត្ថុដ៏ឧត្តមណា ក្នុងឋានសួគ៌ក្តី ទ្រព្យ និងរតនវត្ថុទាំងនោះឯង ស្មើដោយព្រះតថាគតមិនមានឡើយ រតន: គឺព្រះពុទ្ធនេះឯង ជារតន: ដ៏ឧត្តម ដោយសច្ចៈនេះ សូមមានសិរីសួស្តី ។

ព្រះសក្យមុនី ទ្រង់មានព្រះហឫទ័យតម្កល់មាំ បានត្រាស់ដឹងហើយនូវព្រះធម៌ណា ជាទីក្សយទៅនៃកិលេស ជាទីប្រាសចាកវាគ: ជាធម៌មិនស្លាប់ ជាធម៌ឧត្តម រតន:នីមួយស្មើដោយព្រះធម៌នោះមិនមាន រតន: គឺព្រះធម៌នេះឯង ជារតន:ដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

ព្រះពុទ្ធជាបុគ្គលប្រសើរ ទ្រង់សរសើរនូវសមាធិណា ថាជាធម៌ដ៏ស្អាតបណ្ឌិតទាំងឡាយ ពោលហើយនូវសមាធិណា ថាជាធម៌ឲ្យផលដោយលំដាប់ សមាធិឯទៀតស្មើដោយសមាធិនោះមិនមានឡើយ រតន: គឺព្រះធម៌នេះឯង ជារតន:ដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

បុគ្គលទាំង៦ប្លាយណា ៨ ពួក ដែលពួកសប្បុរសសរសើរហើយ រាប់ជាគូមាន ៤ គូ បុគ្គលទាំង៦ប្លាយនោះ ជាសាវ័ករបស់ព្រះសុគត លោកគួរដល់ទក្ខិណាទាន ទានទាំង៦ប្លាយដែលបុគ្គលឲ្យហើយ ចំពោះទក្ខិណេយ្យ-បុគ្គលទាំង៦ប្លាយនោះ ជាទានមានផលច្រើន រតន: គឺព្រះសង្ឃនេះឯង ជារតន:ដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

អរិយបុគ្គលទាំង៦ប្លាយណា ក្នុងសាសនានៃព្រះសម្ពុទ្ធព្រះនាមគោតម ប្រកបត្រូវល្អហើយ មានចិត្តខ្ជាប់ខ្ជួន ឥតមានសេចក្តីប្រាថ្នាឡើយ អរិយ-បុគ្គលទាំង៦ប្លាយនោះ ដល់ហើយនូវអរហន្តផល សម្រេចហើយនូវព្រះនិព្វាន បាននូវការរលត់កិលេសដោយទេ (ឥតមានទិញដូរឡើយ) ហើយទទួលនូវផល រតន: គឺព្រះសង្ឃនេះឯង ជារតន:ដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

សសរគោល ដែលគេបោះភ្ជាប់នឹងផែនដី ជារបស់មិនកម្រើកញាប់ញ័រដោយខ្យល់ព្យុះ ដែលបក់មកអំពីទិសទាំង ៤ យ៉ាងណាមិញ អ្នកណាពិចារណាឃើញ នូវអរិយសច្ចទាំង៦ប្លាយ តថាគតហៅអ្នកនោះ ថាជាសប្បុរស (មិនញាប់ញ័រដោយលោកធម៌ទាំង៦ប្លាយ) ដូចសសរគោលដូច្នោះឯង រតន: គឺព្រះសង្ឃនេះឯង ជារតន:ដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

អរិយបុគ្គលទាំង៦ប្លាយណា ធ្វើឲ្យជាក់ច្បាស់នូវអរិយសច្ចទាំង៦ប្លាយ ដែលព្រះតថាគត ព្រះអង្គមានប្រាជ្ញាដ៏ជ្រាលជ្រៅ សម្តែងប្រពៃហើយ

អរិយបុគ្គលទាំងនោះ ទុកជាប្រមាទដ៏លើសលប់ក៏ដោយ អរិយបុគ្គលទាំងនោះ គង់មិនកាន់យកភពជាគម្រប់ ៨ គឺ មិនកើតទៀតហួសពី ៧ ជាតិឡើយ រតនៈ គឺ ព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

(សំយោជនក្លិសេស ៣ យ៉ាង គឺ) សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាស ណាមួយ ធម៌ទាំងឡាយ ៣ នោះ សោតាបន្នបុគ្គលនោះ បានលះបង់ហើយ ជាមួយនឹងទស្សនសម្បទា គឺសោតាបត្តិមគ្គ មួយទៀត សោតាបន្នបុគ្គល រួចស្រឡះចាកអបាយទាំង ៤ ផង មិនអាចធ្វើនូវអភិដ្ឋានទាំងឡាយ ៦ ផង រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសេចក្តីសួស្តី ។ ប្រសិនបើសោតាបន្នបុគ្គលនោះ ធ្វើនូវបាបកម្មដោយកាយវាចា ឬដោយចិត្តក៏ដោយ (ព្រោះសេចក្តីភ្លាំងភ្លាត់) សោតាបន្នបុគ្គលនោះ មិនដែលបិទបាំងនូវបាបកម្មនោះឡើយ ការៈនៃបុគ្គលមានផ្លូវនៃព្រះនិព្វានឃើញហើយ ជាបុគ្គលមិនដែលបិទបាំងបាបកម្ម ព្រះពុទ្ធទាំងឡាយ បានត្រាស់សម្តែងហើយ រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

គុម្ពឈើក្នុងព្រៃ មានត្រួយលូតលាស់ ក្នុងខាងដើមគិម្ហរដូវ គឺខែក្តៅយ៉ាងណាមិញ ព្រះពុទ្ធបានត្រាស់សម្តែងហើយ នូវធម៌ដ៏ប្រសើរ ជាធម៌អាចញុំាងសត្វទាំងឡាយ ឲ្យដល់នូវព្រះនិព្វាន ដើម្បីប្រយោជន៍ដ៏ឧត្តម ដូចជាគុម្ពឈើមានក្នុងព្រៃដូច្នោះឯង រតនៈ គឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម

ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរ ទ្រង់ជ្រាបនូវធម៌ដ៏ប្រសើរ ទ្រង់ប្រទាននូវធម៌ដ៏ប្រសើរ ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ ព្រះអង្គប្រសើរ ឥតមានអ្នកណាមួយស្មើ ទ្រង់ត្រាស់សម្តែងហើយ នូវធម៌ដ៏ប្រសើរ រតនៈ គឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

កម្មចាស់ (របស់អរិយបុគ្គលណា) អស់ហើយ កម្មថ្មី រមែងមិនកើតប្រាកដ អរិយបុគ្គលទាំងឡាយណា មានចិត្តនឿយណាយហើយក្នុងភពតទៅ អរិយបុគ្គលទាំងឡាយនោះ មានពូជអស់ហើយ មានឆន្ទៈ គឺសេចក្តីប៉ុនប៉ងក្នុងចិត្ត មិនជុះចម្រើនឡើង ជាអ្នកមានប្រាជ្ញា តែងរលត់ទៅ ដូចប្រទីបដែលរលត់ទៅនេះ រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ យើងទាំងឡាយសូមនមស្ការ នូវព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់មកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមមានសិរីសួស្តី ។

ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ យើងទាំងឡាយ សូមនមស្ការ នូវព្រះធម៌ដែលមកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមមានសិរីសួស្តី ។

ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅឰដ៏អាកាសក្តី

ដែលមកប្រជុំគ្នាក្នុងទីនេះ យើងទាំងឡាយសូមនមស្ការ នូវព្រះសង្ឃដែលមានមកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមមានសិរីសួស្តី ។

រតនសូត្រ ចប់

អដ្ឋកថា

រតនសូត្រ

ប្រយោជន៍នៃឯកុប្បបទ

[៧] *ឥឡូវនេះ ដល់លំដាប់ពណ៌នានៃរតនសូត្រ ដែលលើកឡើងក្នុងលំដាប់បន្ទាប់អំពីមង្គលសូត្រនោះ ដោយន័យជាដើមថា* **យានីធ ភូតានិ** *ខ្ញុំនឹងពោលប្រយោជន៍នៃការតាំងរតនសូត្រនោះ ក្នុងទីនេះ បន្ទាប់អំពីនោះ កាលសម្តែងការឈមចុះនូវអត្ថនៃសូត្រនេះ តាមនិទានវចនៈដ៏បរិសុទ្ធក្តី ដូចការចុះទឹកក្នុងស្ទឹង និងអូរជាដើម តាមកំពង់ទឹកដ៏បរិសុទ្ធក្តី ប្រកាសន័យនេះថា សូត្រនេះ បុគ្គលណាពោល ពោលក្នុងកាលណា ពោលទីណា ពោលព្រោះហេតុអ្វី ហើយទើបធ្វើនូវកិច្ចពណ៌នាសេចក្តីនៃរតនសូត្រនេះ ។*

ក្នុង ២ សូត្រនោះ ព្រោះព្រះមានព្រះភាគ ទ្រង់សម្តែងការរក្សាខ្លួនឯង និងការកម្ចាត់អាសវៈទាំងឡាយ ដែលមានការធ្វើមិនល្អ និងការធ្វើមិនល្អជាបច្ច័យដោយមង្គលសូត្រ ចំណែកសូត្រនេះ ឲ្យសម្រេចការរក្សាអ្នកដទៃ

និងការកម្ចាត់អាសវៈទាំងឡាយ ដែលមានអមនុស្សជាដើមជាបច្ច័យ ដូច្នោះ ទើបសូត្រនេះ ជាការតាំងទុកក្នុងលំដាប់ បន្ទាប់អំពីមង្គលសូត្រនោះឯង ។

ប្រយោជន៍នៃការតាំងរតនសូត្រ ក្នុងទីនេះមានប្រមាណប៉ុណ្ណេះសិន

រឿងក្រុងវេសាលី

ឥឡូវនេះ ក្នុងពាក្យថា **យេន វុត្តំ យទា យត្ត យស្មា ចេតំ** នេះ អ្នកចោទសួរពោលថា សូត្រនេះអ្នកណាពោល ពោលកាលណា ពោលទីណា ពោលព្រោះហេតុអ្វី នឹងចង្អុលបង្ហាញ ដូច្នេះថា សេចក្តីពិត សូត្រនេះ ព្រះមានព្រះភាគមួយអង្គត្រាស់ សាវ័កជាដើមមិនបានពោលឡើយ ។ សួរថា ត្រាស់ក្នុងកាលណា ឆ្លើយថា ត្រាស់កាលក្រុងវេសាលីត្រូវឧបទ្រវទាំងឡាយ មានទុព្ភិក្ខភ័យជាដើមចូលរាំង ព្រះមានព្រះភាគ កាលពួកស្តេចលិច្ឆវីទូលអារាធនា នាំទ្រង់មកអំពីក្រុងរាជគ្រឹះ កាលនោះ រតនសូត្រនោះ ទ្រង់ក៏ត្រាស់ដើម្បីបំបាត់ឧបទ្រពទាំងនោះក្នុងក្រុងវេសាលី ។ ការវិសជ្ជនាបញ្ហាទាំងនោះ មានប៉ុណ្ណេះសិន ។ ឯពិស្តារ បុរាណាចារ្យទាំងឡាយ ពណ៌នារាប់តាំងអំពីក្រុងវេសាលីជាដើមទៅ ។

បានឮមកថា អគ្គមហេសីរបស់ស្តេចក្រុងពារាណសីទ្រង់ព្រះគភ៌ ។ ព្រះនាងទ្រង់ជ្រាបហើយ ក៏បានក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះរាជាក៏ទ្រង់ព្រះរាជទានគ្រឿងបរិហារព្រះគភ៌ ។ ព្រះនាងបានទទួលបរិហារព្រះគភ៌

យ៉ាងល្អ ក៏យាងចូលកាន់មន្ទីរប្រសូត ក្នុងកាលព្រះគភិគ្រប់ខែ ។ ពួកសត្វ ដែលមានបុណ្យរមែងប្រសូតចាកគភិក្នុងពេលទៀបភ្លឺ ។ ក្នុងបណ្តាអ្នកមានបុណ្យទាំងនោះ អគ្គមហេសីនោះក៏ជាអ្នកមានបុណ្យមួយអង្គ ដោយហេតុនោះ ក្នុងពេលទៀបភ្លឺ ព្រះនាងក៏ប្រសូតជុំសាច់ដូចផ្តាច្បា ដែលមានត្របកក្រហម ដូចលក្ត បន្ទាប់អំពីនោះ ទេវីអង្គដទៃ ក៏ប្រសូតព្រះឌរសដូចរូបមាស អគ្គ-មហេសី ទ្រង់ប្រសូតជុំសាច់ ដូច្នោះ ព្រះនាងទ្រង់ព្រះតម្រិះថា សំឡេងតិះដៀលគប្បីកើតដល់អញ ក្នុងទីចំពោះមុខនៃព្រះរាជា ព្រះនាងខ្វាចការតិះដៀលនោះ ទើបបញ្ជាឲ្យដាក់ជុំសាច់នោះក្នុងភាជនៈមួយ យកភាជនៈមួយ ទៀតគ្រប ប្រថាប់ព្រះរាជត្រា ហើយឲ្យបណ្តែតទៅតាមក្រសែស្ទឹងគង្គា គ្រាន់តែភ្នាក់ងារទាំងឡាយបណ្តែតទៅ ទេវតាទាំងឡាយ ក៏រៀបចំធ្វើនូវការរក្សា យកជ័រមហាហិង្គុចារឹកផែនមាស ចងនៅត្រង់ភាជនៈនោះថា ព្រះរាជ-ឌរសព្រះរាជធីតារបស់អគ្គមហេសីនៃព្រះបាទក្រុងពារាណសី ។ បន្ទាប់អំពីនោះ ភាជនៈនោះមិនត្រូវបានភ័យ គឺរលកបៀតបៀន ក៏អណ្តែតទៅតាមក្រសែស្ទឹងគង្គា ។

សម័យនោះ តាបសមួយរូបអាស្រ័យត្រកូលអ្នកចិញ្ចឹមគោនៅប្របឆ្នេរស្ទឹងគង្គានោះ ។ ក្នុងពេលព្រឹក តាបសនោះក៏ចុះកាន់ស្ទឹងគង្គា ក្រឡេកឃើញភាជនៈអណ្តែតមក ក៏កាន់យកដោយបង្សុកូលសញ្ញា ដោយយល់ថា ជារបស់ដែលគេចោលហើយ ។ បន្ទាប់មក ក៏ឃើញបន្ទះមាសចារឹកអក្សរ និងត្រា ក៏ស្រាយចេញ ឃើញជុំសាច់នោះ លុះឃើញហើយ តាបសរូបនោះក៏គិតថា នេះប្រហែលជាសត្វដែលកើតក្នុងគភិ ដូច្នោះ ទើបមិនស្អុយរលួយ ក៏នាំជុំសាច់

ទៅកាន់ទីអាស្រ័យ ទុកក្នុងទីស្អាត រំលងទៅកន្ទុះខែ ជុំសាច់ក៏បែកចេញជា ២ ចម្រៀក តាបសឃើញហើយ ក៏ទុកយ៉ាងល្អ ។ បន្ទាប់អំពីនោះ រំលងទៅកន្ទុះខែទៀត ជុំសាច់នីមួយៗ ក៏ចេញពក ៥ ជាដៃ ជើង និងក្បាល តាបសក៏ផ្គុំតផ្គង់យ៉ាងល្អទៀត ។ បន្ទាប់អំពីនោះកន្ទុះខែទៀត ជុំសាច់ក៏ក្លាយជាទារកដូចរូបមាស មួយជុំទៀត ក៏ជាទារិកា តាបសកើតការស្រឡាញ់ដូចបុត្រក្នុងទារកទាំង ២ នោះ ទឹកដោះក៏កើតអំពីមេដៃរបស់តាបសនោះ ។ តាំងពីនោះមក តាបសបានទឹកដោះ និងអាហារមក ក៏បរិភោគអាហារ បន្តក់ទឹកដោះក្នុងមាត់ទារកទាំង ២ វត្តុណាមួយចូលទៅក្នុងផ្ទៃរបស់ទារកនោះ វត្តុទាំងអស់នោះ ក៏ហាក់ដូចជាចូលទៅក្នុងភាជនៈធ្វើដោយកែវមណី ។ ទារកទាំង ២ មិនមានពណ៌សម្បុរយ៉ាងនេះ ។ តែអាចារ្យពួកជទៃៗ ពោលថា ពណ៌សម្បុរទារកទាំង ២ នោះ ជាក់ដល់គ្នានិងគ្នា ដូចត្រូវអំបោះជោត ទើបទារកទាំងនោះប្រាកដឈ្មោះថា លិច្ឆវី ព្រោះមិនមានពណ៌សម្បុរ ឬព្រោះមានស្បែកថ្លា ដោយប្រការដូច្នេះ ។

តាបសចិញ្ចឹមទារក លុះថ្ងៃរះឡើង ក៏ចូលទៅកាន់ស្រុក ហើយស្វែងរកអាហារ ពេលរសៀលក៏ត្រឡប់ ។ អ្នកចិញ្ចឹមគោទាំងឡាយ ជីងដល់ការខ្វល់ខ្វាយនោះរបស់តាបសនោះ ក៏ពោលថា បពិត្រលោកម្ចាស់ ការចិញ្ចឹមទារក ជាបលិពោធរបស់អ្នកបួសទាំងឡាយ សូមលោកម្ចាស់ឲ្យនូវទារកដល់ពួកខ្ញុំចុះ ពួកខ្ញុំនឹងនាំគ្នាចិញ្ចឹម សូមលោកម្ចាស់ ធ្វើកិច្ចកម្មរបស់លោកម្ចាស់ចុះ ។ តាបសក៏ព្រមទទួល ។ ស្រែកឡើង ពួកអ្នកចិញ្ចឹមគោ ក៏នាំគ្នា

ធ្វើផ្ទះឲ្យរាបស្មើ ហើយរោយខ្សាច់ លើកទង់ មានតន្ត្រីបន្ទឺឡើង នាំគ្នាមកកាន់អាស្រមៗ តាបសពោលថា ទារកទាំង ២ មានបុណ្យច្រើន ពួកអ្នកចូរនាំគ្នាចិញ្ចឹមឲ្យចម្រើនវ័យ ដោយការមិនប្រមាទ ។ កាលឲ្យចម្រើនវ័យហើយ ចូរវៀបចំអាវាហ៍វិវាហ៍ដល់គ្នានិងគ្នា ឲ្យព្រះរាជាទ្រង់ត្រេកអរដោយបញ្ចកោរស ចូរជ្រើសរើសភូមិបទេស នាំគ្នាសាងព្រះនគរឡើង ចូរអភិសេកព្រះកុមារក្នុងទីនោះ ហើយប្រគល់ទារកឲ្យ ។ ពួកអ្នកចិញ្ចឹមគោទទួលពាក្យហើយ ក៏នាំទារកទៅចិញ្ចឹម ។

ទារកទាំង ២ ចម្រើនធំធាត់ ក៏លេងនូវការលេង ប្រើដៃខ្លះ ជើងខ្លះ វាយតប់កូនរបស់អ្នកចិញ្ចឹមគោជនៃៗ ក្នុងទីដែលឈ្លោះគ្នា កូនអ្នកចិញ្ចឹមគោទាំងនោះក៏ស្រែកយំ ត្រូវមាតាបិតាសួរថា ហេតុអ្វី ទើបយំ ក៏ប្រាប់ថា អាកូនអត់ឪអត់ម៉ែ ដែលតាបសចិញ្ចឹមទាំងនេះវាយខ្ញុំ ។ បន្ទាប់អំពីនោះ មាតាបិតារបស់ក្មេងទាំងនោះក៏ពោលថា ទារកទាំង ២ នេះ ចូលចិត្តគំរាមកំហែងដល់ក្មេងជនៃៗ ឲ្យក្តៅក្រហាយ ពួកយើងនឹងមិនសង្គ្រោះវា លះបង់វាចោល ។ បានឮថា តាំងអំពីកាលនោះមក ទើបទីនោះ ត្រូវហៅថា វជ្ជី ដែលមានទំហំ ៣០០ យោជន៍ ។ គ្រានោះ ពួកអ្នកចិញ្ចឹមគោធ្វើព្រះរាជាឲ្យត្រេកអរ ហើយជ្រើសរើសយកបទេសនោះ សាងព្រះនគរក្នុងបទេសនោះ ហើយអភិសេកព្រះរាជកុមារដែលព្រះជន្មបាន ១៦ ឆ្នាំ តែងតាំងជាព្រះរាជា បានធ្វើវិវាហ-មង្គលជាមួយទារិការបស់ព្រះអង្គ បានជាក់កតិកាថា នឹងមិននាំទារិកាមកអំពីខាងក្រៅ នឹងមិនឲ្យទារិកាអំពីទីនេះដល់បុគ្គលណាម្នាក់ឡើយ ។ ដោយ

ការនៅរួមគ្នាគ្រាដំបូងរបស់ព្រះកុមារាកុមារីនោះ ក៏កើតទារក ១ គូ ជាធីតាម្នាក់ ឱរសម្នាក់ ដោយអាការយ៉ាងនេះ ក៏កើតជាគូៗ ដល់នៅ ១៦ ដង ។ តាំងអំពីនោះ ទារកទាំងនោះ ចម្រើនវ័យដោយលំដាប់ ។ នគរនោះក៏មិនគ្រប់គ្រាន់ ដែលអាចធ្វើអាវាស ឧទ្យាន លំនៅ បរិវារ និងសម្បត្តិ ទើបព័ទ្ធរបង ៣ ជាន់ ចន្លោះមួយគាវុតមួយៗ ព្រោះនគរនោះ ត្រូវពង្រីកចេញរឿយៗ ទើបកើតឈ្មោះថា វេសាលីនេះឯង ។

រឿងក្រុងវេសាលី ចប់

ការឯិមន្តព្រះមានព្រះភាគ

ក្រុងវេសាលីនេះ កាលព្រះមានព្រះភាគ ទ្រង់កើតឡើង ក៏មាំទាំបរិបូណ៌ ព្រោះថា ក្រុងវេសាលីនោះ មានព្រះអង្គម្ចាស់រហូតដល់ ៧៧០៧ អង្គ ឃុវរាជ សេនាបតី និងភណ្ឌាគារិកក៏ដូចគ្នា ដូចលោកពោលថា

សម័យនោះឯង ក្រុងវេសាលីនោះ ចម្រើនមាំទាំ មានមនុស្សច្រើន មានមនុស្សកកកុញ មានអាហារកបានងាយ មានប្រាសាទ ៧៧០៧ ខ្នង មានផ្ទះកំពូល ៧៧០៧ ខ្នង មានអាវាម ៧៧០៧ អារាម មានស្រះបោក្ខរណី ៧៧០៧ ស្រះ ។

សម័យតមក ក្រុងវេសាលីនោះកើតទុព្ភិក្ខភ័យ ភ្លៀងរាំង ស្រូវសាលីក៏ងាប់អស់ អ្នកកម្សត់ក្រីក្រស្លាប់មុន គេចោលមនុស្សទាំងនោះទៅខាងក្រៅនគរ ។ ពួកអមនុស្សបានភ្ជិនមនុស្ស ក៏នាំគ្នាចូលកាន់ព្រះនគរ ។ បន្ទាប់

អំពីនោះ មនុស្សស្លាប់ក៏ច្រើនឡើង ។ ព្រោះភាពជាកូលនោះ អហិវាត-
កវោគក៏កើតជល់សត្វទាំងឡាយ ។ អ្នកក្រុងវេសាលីត្រូវភ័យ ៣ យ៉ាង គឺ
ទុព្ភិក្ខភ័យ អមនុស្សភ័យ និងរោគភ័យបៀតបៀន ក៏ចូលទៅគាល់ព្រះរាជា
ក្រាបទូលថា បពិត្រតេជៈ ភ័យ ៣ យ៉ាងកើតក្នុងនគរនេះហើយ តាំងអំពី
មុននេះ ៧ ជួរវាជត្រកូល មិនធ្លាប់កើតភ័យបែបនេះឡើយ ប្រហែលជាទ្រង់
មិនតាំងនៅក្នុងធម៌ ទើបឥឡូវនេះ ភ័យកើតឡើង ។ ព្រះរាជាទ្រង់ប្រជុំ
ស្តេចលិច្ឆវីគ្រប់អង្គ ក្នុងទីរាជការ ត្រាស់ថា សូមពិចារណាថយក្រោយ ក្នុង
ប្រការដែលពួកយើងមិនតាំងនៅក្នុងធម៌ចុះ ។ ស្តេចលិច្ឆវីទាំងនោះពិចារណា
ថយក្រោយជល់បវេណីគ្រប់យ៉ាង ក៏ទ្រង់មិនឃើញមានកំហុសឆ្គងណាមួយ
ក៏មិនឃើញទោសរបស់ព្រះរាជា ទើបនាំគ្នាគិតថា ភ័យរបស់យើងនេះ រម្ងាប់
បានដូចម្តេច ។ ក្នុងទីប្រជុំនោះ ស្តេចលិច្ឆវីពួកខ្លះអាងជល់សាស្តាទាំង ៦
ថា ទាល់តែសាស្តាទាំងនេះឈានជើងចុះប៉ុណ្ណោះ ភ័យក៏នឹងរម្ងាប់ទៅ ។ ពួក
ខ្លះត្រាស់ថា បានឮថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ព្រះមានព្រះភាគ
អង្គនោះ ទ្រង់សម្តែងធម៌ ដើម្បីជាប្រយោជន៍ជល់សត្វទាំងពួង ទ្រង់មានឫទ្ធិ
ច្រើន មានអានុភាពច្រើន ទាល់តែទ្រង់យាងព្រះបាទចុះប៉ុណ្ណោះ ភ័យគ្រប់
យ៉ាងក៏រម្ងាប់ទៅ ដោយហេតុនោះ ស្តេចលិច្ឆវីទាំងនោះ ទើបសប្បាយក្នុង
ព្រះហឫទ័យ ត្រាស់ថា ព្រះមានព្រះភាគអង្គនេះ ឥឡូវនេះ ទ្រង់ប្រថាប់នៅ
ទីណាហ្ន៎ ពួកយើងបញ្ជូនមនុស្សទៅយាង ទ្រង់នឹងមិនយាងមក ។ ស្តេច
លិច្ឆវីពួកខ្លះត្រាស់ថា ធម្មតាព្រះពុទ្ធ ទ្រង់ករុណាសត្វ ហេតុអ្វី ថាមិនយាង

មក ។ ព្រះមានព្រះភាគអង្គនោះ ឥឡូវនេះ ប្រថាប់នៅក្នុងក្រុងរាជគ្រឹះ ព្រះបាទពិម្ពិសារទ្រង់ឧបដ្ឋាក ក្រែងតែទ្រង់មិនឲ្យយាងមក ។ ពួកខ្លះគ្រាស់ថា បើដូច្នោះ យើងទូលព្រះបាទពិម្ពិសារឲ្យទ្រង់ជ្រាប ហើយយាងព្រះមានព្រះភាគមក ហើយទ្រង់ប្រគល់គ្រឿងបណ្ណាការជាច្រើន បញ្ជូនស្តេចលិច្ឆវី ២ អង្គ មួយអន្ទើដោយពលសេនាច្រើន ទៅកាន់រាជសម្នាក់នៃព្រះបាទពិម្ពិសារ ដោយគ្រាស់ថា សូមអ្នកទូលព្រះបាទពិម្ពិសារឲ្យទ្រង់យល់ ហើយយាងព្រះមានព្រះភាគមក ។ ស្តេចលិច្ឆវីទាំង ២ អង្គយាងទៅថ្វាយគ្រឿងបណ្ណាការដល់ព្រះបាទពិម្ពិសារ ហើយទូលឲ្យទ្រង់ជ្រាប រួចគ្រាស់ថា បពិត្រមហារាជ សូមទ្រង់មេត្តាបញ្ជូនព្រះមានព្រះភាគមកកាន់នគរបស់ទូលបង្គំផងចុះ ។ ព្រះរាជាទ្រង់មិនទទួល ដោយគ្រាស់ថា ពួកអ្នកចូរដើរខ្លួនឯង ។ ស្តេចលិច្ឆវីក៏ទូលថា សាធុ ហើយចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភ័យ ៣ យ៉ាង កើតឡើងក្នុងនគរបស់ខ្ញុំព្រះអង្គ បើទ្រង់គប្បីយាងទៅសោត សូស្តីគប្បីមានដល់ពួកខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ពិចារណាថា កាលគ្រាស់រតនសូត្រក្នុងក្រុងវេសាលី ការពារឭងផ្សាយទៅសែនកោដិចក្រវាល កាលសូត្រនេះចប់ សត្វ ៨៤០០០ ឭងគ្រាស់ដឹងធម៌ ហើយទើបទ្រង់ទទួលនិមន្ត គ្រានោះ ព្រះបាទពិម្ពិសារទ្រង់បានជំណឹងថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្ត ហើយទ្រង់ឲ្យឃោសនាទៅក្នុងព្រះនគរថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្ត យាងទៅក្រុងវេសាលី ហើយ ទ្រង់ចូលគាល់ព្រះមានព្រះភាគទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់

ទទួលនិមន្តយាងទៅក្រុងវេសាលីឬ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ ។ ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើជួច្នោះ សូមទ្រង់បង្អង់ ទម្រាំចាត់ចែងផ្លូវថ្វាយស្រេច ។

គ្រានោះ ព្រះបាទពិម្ពិសារ ទ្រង់ធ្វើផ្លែដើ ៥ យោជន៍ ចន្លោះក្រុងរាជគ្រឹះ និងសួឹងគង្គាឲ្យរាបស្មើហើយ បានក្រាបទូលព្រះមានព្រះភាគជាល់កាល ។ ព្រះមានព្រះភាគ មានភិក្ខុ ៥០០ រូបចោមរោម ហើយទ្រង់យាងទៅ ព្រះរាជាទ្រង់យកផ្កាដែលមាន ៥ ពណ៌ រោយត្រង់ផ្លូវ ៥ យោជន៍ត្រឹមក្បាលជង្ហឹង ឲ្យលើកទង់ជ្ងាលា ក្អមទឹក និងដើមចេកជាដើម ឲ្យបាំងស្វេតច្ឆត្រ ២ ជាន់ សម្រាប់ព្រះមានព្រះភាគ ឆត្រមួយជាន់សម្រាប់ភិក្ខុមួយរូបៗ ទ្រង់ធ្វើការបូជាដោយផ្កា និងគ្រឿងប្រអូបជាដើម ព្រមដោយរាជបរិវាររបស់ព្រះអង្គ ឲ្យព្រះមានព្រះភាគប្រថាប់នៅក្នុងវិហារមួយខ្នងៗ ថ្វាយមហាទាន ទ្រង់នាំព្រះមានព្រះភាគទៅកាន់ឆ្នេរសួឹងគង្គាអស់កាល ៥ ថ្ងៃ ក្នុងទីនោះ ទ្រង់តាក់តែងទូកដោយគ្រឿងប្រដាប់គ្រប់យ៉ាង ហើយទ្រង់បញ្ជូនដំណឹងទៅ ថ្វាយស្តេចលិច្ឆវីក្រុងវេសាលីថា ព្រះមានព្រះភាគទ្រង់យាងមកហើយ សូមស្តេចលិច្ឆវីគ្រប់អង្គតាក់តែងផ្លូវ ទទួលព្រះមានព្រះភាគចុះ ។ ស្តេចលិច្ឆវីទាំងនោះ ស្រុះស្រួលគ្នាថា នឹងធ្វើការបូជាទ្វេគុណ ធ្វើផ្លែដើ ៣ យោជន៍ ចន្លោះក្រុងវេសាលី និងសួឹងគង្គាឲ្យរាបស្មើ រៀបចំស្វេតច្ឆត្រ ៤ ជាន់ សម្រាប់ព្រះមានព្រះភាគ ២ ជាន់ សម្រាប់ភិក្ខុមួយរូបៗ ធ្វើការបូជា ទ្រង់យាងមករង់ចាំ ។

គ្រានោះ ព្រះបាទពិម្ពិសារទ្រង់ធ្វើទូក ២ គ្រឿង ហើយសាងមណ្ឌប

ប្រកាន់ជោយផ្កា ក្រាលពុទ្ធាសនៈ ធ្វើជោយរតនៈសុទ្ធក្នុងមណ្ឌបនោះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ប្រថាប់លើពុទ្ធាសនៈនោះ ។ សូម្បីភិក្ខុ ៥០០ រូប ក៏ទ្បើងទូកអង្គុយតាមសមគួរ ព្រះរាជា ទ្រង់ជូនដំណើរព្រះមានព្រះភាគ ចុះទឹកប្រមាណត្រឹមព្រះសូរង ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅរង់ចាំត្រង់ច្រាំងគង្គានេះឯង ទម្រាំទ្រង់យាងត្រឡប់មក ហើយទ្រង់ក៏យាងត្រឡប់ ។ ទេវតាខាងលើ រហូតដល់អកនិដ្ឋភព បាននាំគ្នាធ្វើការបូជា ។ នាគរាជទាំងឡាយ មានកម្ពលនាគ និងអស្សតរនាគជាដើម អាស្រ័យនៅបាតស្ទឹងគង្គា ក៏នាំគ្នាធ្វើការបូជា ដោយការបូជាធំយ៉ាងនេះ ព្រះមានព្រះភាគយាងទៅតាមស្ទឹងគង្គា អស់ចម្ងាយផ្លូវប្រមាណមួយយោជន៍ ក៏ចូលដល់ព្រំដែនរបស់ស្តេចលិច្ឆវី ក្រុងវេសាលី ។

បន្ទាប់អំពីនោះ ពួកស្តេចលិច្ឆវីក៏ធ្វើការបូជា ២ ដង លើសព្រះបាទពិម្ពិសារទ្រង់ធ្វើ ចេញទៅទទួលព្រះមានព្រះភាគដល់ក្នុងទឹក ប្រមាណត្រឹមព្រះសូរង ។ ខណៈនោះឯង មហាមេឃគ្របដណ្តប់ដោយភាពងងឹត ផ្គរបន្ទោរបង្ហាញខ្លួន ផ្គរលាន់គ្រហឹមក្នុងទិសទាំង ៤ ។ សម័យនោះ ព្រះសម្ពុទ្ធទ្រង់លើកព្រះបាទដំបូង ជាន់ត្រង់ឆ្នេរស្ទឹងគង្គា ភ្លៀងបោកខ្យាព័ន្ធក៏បាចសាចចុះមក ជនពួកណាត្រូវការសើម ជនទាំងនោះរមែងសើម ជនពួកណាមិនត្រូវការ ក៏មិនសើម ក្នុងទីគ្រប់កន្លែង មានទឹកហូរទៅត្រឹមក្បាលជង្គង់ ត្រឹមភ្លៅ ត្រឹមចង្កេះ ត្រឹម-ក សាកសពទាំងពួង ត្រូវទឹកបន្សាត់ទម្លាក់ចុះកាន់ស្ទឹងគង្គា ផ្ទៃដីក៏ស្អាតបរិសុទ្ធ ។

ពួកស្តេចលិច្ឆវីឲ្យព្រះមានព្រះភាគគង់ប្រថាប់ គ្រប់មួយយោជន៍ក្នុងផ្លូវ ថ្វាយមហាទាន ទ្រង់ធ្វើការបូជាទេគុណ អស់កាល ៣ ថ្ងៃ ទើបនាំព្រះមានព្រះភាគចូលកាន់ក្រុងវេសាលី ។ កាលព្រះមានព្រះភាគ យាងដល់ក្រុងវេសាលី សក្កទេវរាជដែលមានពួកទេវតាចោមរោមយាងមកដល់ ។ ព្រះមានព្រះភាគប្រថាប់ឈរក្បែរទ្វារព្រះនគរ ទ្រង់ហៅព្រះអានន្ទមកត្រាស់ថា ម្នាលអានន្ទ អ្នកចូររៀនរតនសូត្រនេះ កាន់គ្រឿងប្រកបពលិកម្ម ដើរទៅក្នុងចន្លោះកំពែង ៣ ជាន់នៃក្រុងវេសាលី ជាមួយពួកស្តេចលិច្ឆវីរាជកុមារ ធ្វើព្រះបរិត្តហើយបានត្រាស់រតនសូត្រ ។

ការវិសជ្ជនាបញ្ហាទាំងនេះថា ព្រះសូត្រនេះអ្នកណាពោល ពោលក្នុងកាលណា ពោលទីណា និងពោលព្រោះហេតុអ្វី បុរាណាចារ្យទាំងឡាយបានពណ៌នាពិស្តារ តាំងអំពីរឿងក្រុងវេសាលីជាដើម ដោយប្រការដូច្នេះ ។

ដូច្នោះ ក្នុងថ្ងៃដែលព្រះមានព្រះភាគ យាងដល់ក្រុងវេសាលីនោះឯង រតនសូត្រនេះ ព្រះមានព្រះភាគ ត្រាស់ក្បែរទ្វារក្រុងវេសាលី ដើម្បីកម្ចាត់ឧបទ្រពទាំងនោះ ព្រះអានន្ទក៏រៀនយក កាលពោលដើម្បីជាបរិត្ត ទើបយកបាត្រយស់ព្រះមានព្រះភាគមកជាក់ទឹក ដើរប្រសព្រំពេញព្រះនគរ គ្រាន់តែព្រះថេរៈពោលថា **យន្តិញ្ចិ** *ពួកអមនុស្សដែលអាស្រ័យគំនរសំរាម និងជញ្ជាំងផ្ទះជាដើម ដែលមិនទាន់គេចទៅក្នុងគ្រាដំបូង ក៏នាំគ្នាគេចទៅតាមទ្វារធំទាំង ៤ ទ្វារទាំងឡាយក៏មិនមានចន្លោះ អមនុស្សពួកខ្លះ កាលមិនមានទីទំនេរក្នុងទ្វារទាំងឡាយ ក៏ផ្ទោះកំពែងគេចទៅ ។ ពួកអមនុស្សនាំគ្នាទៅហើយ រោគនៃ*

ពួកមនុស្សទាំងឡាយក៏ស្ងប់ទៅ ពួកមនុស្សទាំងឡាយ ក៏នាំគ្នាមកបូជាព្រះ-ថេរៈដោយផ្កា និងគ្រឿងក្រអូបគ្រប់យ៉ាងជាដើម មហាជនយកគ្រឿងក្រអូបគ្រប់យ៉ាងលាបសណ្ឋាគារ គឺទីប្រជុំ កណ្តាលព្រះនគរ ធ្វើពិតានវិចិត្រដោយរតនៈ ប្រដាប់ដោយគ្រឿងអាភរណៈទាំងពួងបូជាពុទ្ធាសនៈ ក្នុងទីនោះហើយ នាំព្រះមានព្រះភាគយាងមក ។

ព្រះមានព្រះភាគ យាងចូលកាន់សណ្ឋាគារ គង់ប្រថាប់លើអាសនៈដែលគេបូជា ។ ភិក្ខុសង្ឃក្តី គណៈក្តី មនុស្សទាំងឡាយក្តី ក៏អង្គុយក្នុងអាសនៈដែលសមគួរ ។ សូម្បីសក្កទេវរាជស្តេចទេវតា ក៏ប្រថាប់គង់ក្បែរទេវបរិស័ទក្នុងទេវលោកទាំង ២ មួយអន្លើដោយទេវលោកដទៃៗ ផងដែរ សូម្បីព្រះអានន្ទត្ថេរ ក៏ត្រាច់ទៅពេញក្រុងវេសាលី ធ្វើការរក្សាហើយ ក៏មកជាមួយអ្នកក្រុងវេសាលី អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ក្នុងទីនោះ ព្រះមានព្រះភាគ ក៏បានត្រាស់រតនសូត្រនោះឯង ដល់មនុស្សទាំងអស់ ។

មាតិកាណា ខ្ញុំតាំងទុកថា ខ្ញុំនឹងប្រកាសន័យនេះថា រតនសូត្រនេះ បុគ្គលណាពោល ពោលកាលណា ពោលទីណា ពោលព្រោះហេតុអ្វី មាតិកានោះ ខ្ញុំពោលពិស្តារហើយ ដោយប្រការទាំងពួង ដោយពាក្យប្រមាណប៉ុណ្ណេះ ។

អធិប្បាយបទថា យានីធ

ឥឡូវនេះ នឹងផ្តើមពណ៌នាសេចក្តី ព្រោះខ្ញុំបានពោលថា នឹងពណ៌នាអត្ថនៃរតនសូត្រនោះ តែអាចារ្យមួយពួកទៀតពោលថា ព្រះមានព្រះភាគត្រាស់ ៥ គាថាខាងដើម ដែលសល់អំពីព្រះអានន្ទត្ថេរពោល តែទោះជាយ៉ាង

ណាក៏ដោយ ប្រយោជន៍អ្វីបស់យើង ដោយគាថាតិចតួច ដែលមិនទាន់បាន ពិនិត្យពិចារណានេះ ខ្ញុំនឹងពណ៌នាអត្ថនៃរតនសូត្រនេះ ដោយប្រការទាំងពួង ។

នឹងពណ៌នាគាថាដំបូង គឺ **យានីធ ភូតានិ** *ជាដើម ។ ក្នុងគាថាដំបូង នោះ បទថា* **យានិ** *បានដល់ បែបណា ទោះសត្តិតូច ឬសត្តិធំ ។ បទថា* **ឥធ** *ប្រែថា ក្នុងប្រទេសនេះ ព្រះមានព្រះភាគត្រាស់ដល់ទីដែលប្រជុំក្នុង ខណៈនោះ ។*

ក្នុងបទថា **ភូតានិ ភូត** *សព្ទ សំដៅដល់ មានពិត ដូចក្នុងប្រយោគ ជាដើមថា* **ភូតស្មឹ ចាចិត្តិយំ** *ភិក្ខុណាមួយ ប្រាប់ឧត្តរិមនុស្សធម្មដល់ អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយៈ ព្រោះឧត្តរិមនុស្សធម្មនោះ ភិក្ខុមាន ពិតមែន ។*

ប្រើក្នុងអត្ថថា **ខន្ធបញ្ចកៈ** *ដូចក្នុងប្រយោគជាដើមថា* **ភូតមិនធន្តិ ភិក្ខវេ សមនុបស្សថ** *ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញនូវ ខន្ធបញ្ចកៈនេះ ដែលកើតឡើងហើយឬទេ ។*

ប្រើក្នុងអត្ថថា រូប ៤ យ៉ាង មានបឋវីធាតុជាដើម ដូចក្នុងប្រយោគ ជាដើមថា **ចត្តារោ ខោ ភិក្ខុ មហាភូតា ហេតុ** *ម្នាលភិក្ខុ មហាភូតទាំង ៤ ជាហេតុ មហាភូតទាំង ៤ ជាបច្ច័យ ដូច្នេះជាដើម ។*

ប្រើក្នុងអត្ថថា ព្រះខីណាស្រព ដូចក្នុងប្រយោគជាដើមថា **យោ ច កាលឃសោ ភូតោ** *បុគ្គលណា ជាអ្នកទំពាស៊ីនូវពេលវេលា ដូច្នេះ ។*

ប្រើក្នុងអត្ថថា សត្វទាំងឡាយ ដូចក្នុងប្រយោគជាដើមថា **សព្វេ**

និក្ខិបិស្សន្តិ ភូតា លោកេ សមនុស្សយំ *សត្វទាំងឡាយនេះឯង តែងលះបង់រាងកាយក្នុងលោក ដូច្នេះ ។*

ប្រើក្នុងអត្ថថា ដើមឈើ ដូចក្នុងប្រយោគជាដើមថា **ភូតគាមថា-តព្យតាយ** *កិកុំធ្វើភូតគាម មានឈើ និងស្មៅជាដើមឲ្យវិនាស ត្រូវអាបត្តិបាចិត្តិយៈ ដូច្នេះ ។*

ប្រើក្នុងអត្ថថា ពួកសត្វខាងក្រោម ទេវតាជាន់ចាតុម្មហារាជ ដូចក្នុងប្រយោគជាដើមថា **សព្វេ និក្ខិបិស្សន្តិ ភូតា លោកេ សមនុស្សយំ** *សត្វទាំងឡាយនេះឯង តែងលះបង់រាងកាយក្នុងលោក ដូច្នេះ ។ តែ* **ភូត** *សព្ទក្នុងទីនេះ គប្បីជ្រាបថា ប្រើក្នុងអត្ថថា អមនុស្សដោយមិនផ្សេងគ្នា ។*

បទថា **សមាគតានិ** *ប្រែថា ប្រជុំហើយ ។ បទថា* **ភុម្មានិ** *បានដល់កើតឡើងត្រង់ដែនដី ។ សព្ទថា* **វា** *ប្រើក្នុងអត្ថថា មិនពិតប្រាកដ ។ ដ្បិតថា* **វា** *សព្ទនោះ ព្រះមានព្រះភាគទ្រង់ធ្វើវិកប្បថា* **យានីធ ភុម្មានិ វា ភូតានិ សមាគតានិ** *ហើយត្រាស់ថា* **យានិ វ អន្តលិក្ខេ** *ដើម្បីទ្រង់ធ្វើវិកប្បទី ២ ទៀត សេចក្តីថា សត្វទាំងឡាយណាដែលកើតហើយក្នុងអាកាស សត្វទាំងនោះមកប្រជុំគ្នាហើយក្នុងទីនេះ ។ ក្នុងសេចក្តីនេះ សត្វទាំងឡាយដែលកើតហើយ ឧប្បត្តិកហើយ តាំងអំពីទេវតាជាន់យាមា រហូតដល់អកនិដ្ឋ គប្បីជ្រាបថា កើតហើយក្នុងអាកាស ព្រោះជាសត្វកើតក្នុងវិមានដែលប្រាកដក្នុងអាកាស ។ សត្វទាំងឡាយខាងក្រោមអំពីនោះ រាប់តាំងអំពីស្តេចកុំសិនេរុ រហូតដល់ទេវតាដែលអាស្រ័យនៅក្នុងដើមឈើ និងវល្លិជាដើម និងពួក*

ដែលកើតហើយត្រង់ផែនដី សត្វទាំងនោះ គប្បីជ្រាបថា ជាសត្វដែលកើតត្រង់ផែនដី ព្រោះជាសត្វដែលកើតត្រង់ផែនដី និងត្រង់ដើមឈើ វល្លិ ភ្នំជាដើម ដែលទាក់ទងដោយផែនដី ។

ព្រះមានព្រះភាគ កាលទ្រង់កំណត់ពួកសត្វ មនុស្ស គ្រប់ពួក ដោយបទថា **កុម្ភានិ វា យានិ វ អន្តលិក្ខេ** *ទ្រង់សរុបមួយបទទៀត ទើបត្រាស់ថា* **សព្វេ ភូតា សុមនា ភវន្តុ** *។ បទថា* **សព្វេ** *បានដល់ មិនមានសេសសល់ ។ សព្ទថា* **ឯវ** *ចុះក្នុងអត្ថថា អវធារណៈ គឺហាមអត្ថដទៃ អធិប្បាយថា មិនវៀរសូម្បីតែមួយ ។ បទថា* **ភូតា** *បានដល់ ពួកអមនុស្ស បទថា* **សុមនា ភវន្តុ** *បានដល់ ចូរជាអ្នកកើតនូវបីតិសោមនស្ស ។ បទថា* **អថោបិ** *ជានិបាត ទាំង ២ ពាក្យ ចុះក្នុងអត្ថ គឺការកាន់យកនូវពាក្យដើម្បីប្រកបក្នុងកិច្ចដទៃ ។ បទថា* **សក្កច្ច សុណន្តុ ភាសិតំ** *បានដល់ ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត រួបរួមដោយចិត្តទាំងអស់ហើយ ចូរស្តាប់ទេសនារបស់តថាគត ដែលនាំមកនូវទិព្វសម្បត្តិ និងលោកុត្តរសុខ ។*

ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ប្រារព្ធពួកភូតដោយព្រះតម្រាស់ដែលមិនពិតប្រាកដថា **យានីធ ភូតានិ សមាគតានិ** *ហើយទើបកំណត់ជា ២ ចំណែកទៀតថា* **កុម្ភានិ វាយានិ វ អន្តលិក្ខេ** *បន្ទាប់អំពីនោះ ក៏ត្រាស់សរុបទៀតថា* **សព្វេ ភូតា** *ទ្រង់ប្រកបសត្វក្នុងអាសយសម្បត្តិ ដោយព្រះតម្រាស់ថា* **សុមនា ភវន្តុ** *ទ្រង់ប្រកបសត្វក្នុងប្រយោគសម្បត្តិ ដោយព្រះតម្រាស់ថា* **សក្កច្ច សុណន្តុ ភាសិតំ** *ទ្រង់ប្រកបសត្វក្នុងសម្បត្តិ គឺ*

យោនិសោមនសិការ និងក្នុងសម្បត្តិ គឺការយោសនាអំពីអ្នកជំនៃ ក៏ដូចគ្នា ទ្រង់ប្រកបសត្វក្នុងសម្បត្តិ គឺការតាំងខ្លួនប្រពៃ និងការចូលរកសប្បុរស និងក្នុងសម្បត្តិ គឺហេតុនៃសមាធិ និងបញ្ញា ក៏ដូចគ្នា ទើបទ្រង់បញ្ចប់ ព្រះគាថា ។

អធិប្បាយបទថា តស្មា ហិ

និងពោលគាថាទី ២ ថា **តស្មា ហិ** *ជាដើម ។ ក្នុងគាថានោះ បទថា* **តស្មា** *ជាពាក្យពោលហេតុ ។ បទថា* **ភុតា** *ជាពាក្យអញ្ជើញ ។ បទថា* **និសាមេថ** *បានដល់ ចូរស្តាប់ ។ បទថា* **សព្ពេ** *បានដល់ មិនមានសេសសល់ សេចក្តីនេះ លោកអធិប្បាយដូចម្តេច លោកអធិប្បាយថា ព្រោះហេតុអ្នក ទាំងឡាយលះទិព្វស្ថាន និងការដល់ព្រមនៃគ្រឿងឧបភោគបរិភោគ ក្នុងទិព្វ-ស្ថាននោះ មកប្រជុំក្នុងទីនេះ ដើម្បីស្តាប់ធម៌ មិនមែនដើម្បីមើលការរាំច្រៀង ជាដើមទេ្បីយ ដូច្នេះឯង ចូរអ្នកទាំងឡាយដែលជាភូត តាំងចិត្តស្តាប់ ។*

ម្យ៉ាងទៀត ដោយព្រះតម្រាស់ថា **សុមនា ភវន្តុ សក្កច្ច សុណន្តុ** *ព្រះ មានព្រះភាគទ្រង់ឃើញថា ភូតទាំងនោះ មានចិត្តល្អ ចង់ស្តាប់ដោយគោរព ទើបត្រាស់ថា ព្រោះអ្នកទាំងឡាយប្រកបដោយភាពជាអ្នកមានចិត្តល្អ ដោយ អត្តសម្មាបណិធិ យោនិសោមនសិការ និងអាសយសុទ្ធិ ដោយភាពជាអ្នក ប្រាថ្នានឹងស្តាប់ដោយគោរព និងដោយបយោគសុទ្ធិ ព្រោះជាបទដ្ឋាននៃការ ចូលរកសប្បុរស និងការយោសនាអំពីអ្នកជំនៃ ដូច្នេះឯង ចូរភូតទាំងឡាយ តាំងចិត្តស្តាប់ចុះ ។*

ម្យ៉ាងទៀត ពាក្យណា ត្រាស់ថា **ភាសិតំ** *ខាងចុងគាថាទី ១ ទ្រង់អាង ពាក្យនោះជាតួហេតុ ទើបត្រាស់ថា ព្រោះធម្មតាភាសិតរបស់តថាគត មាន ដោយកម្រៃក្រៃពេក ព្រោះខណៈដែលរៀរចាកអខណៈទាំងពួង ជាការក្រ និងមានអានិសង្សច្រើន ព្រោះបដិបត្តិដោយព្រះគុណ មានបញ្ញាគុណ និង ករុណាគុណជាដើម ខ្ញុំក៏បំណងនឹងពោលភាសិតនោះ ទើបពោលថា* **សុណាថ្ពុ ភាសិតំ** *ដូច្នោះឯង ចូរភូតទាំងឡាយតាំងចិត្តស្តាប់ចុះ ។ ព្រះតម្រាស់នេះ ទ្រង់អធិប្បាយដោយបទនៃគាថានេះ ។*

ព្រះមានព្រះភាគ កាលទ្រង់លើកហេតុយ៉ាងនេះ ទ្រង់ប្រកបភូតទាំង-ឡាយទុកក្នុងការតាំងចិត្ត ស្តាប់ភាសិតរបស់ព្រះអង្គ ទើបទ្រង់ផ្តើមត្រាស់ ភាសិតដែលគប្បីតាំងចិត្តស្តាប់ថា **មេត្តំ ករោថ មានុសិយា បជាយ ។** *ភាសិតនោះ មានអត្ថថា មហាជនដែលជាមនុស្សណា ត្រូវឧបទ្រវទាំង ៣ រារាំងហើយ ចូរអ្នកទាំងឡាយ ចូលទៅតាំងមេត្តាភាពជាមិត្រ ការមាន អធ្យាស្រ័យ ឲ្យនូវប្រយោជន៍ដល់មហាជនមនុស្សនោះចុះ ។ តែអាចារ្យពួក ខ្លះពោលថា* **មានុសិកំ** *ពាក្យនោះ មិនត្រឹមត្រូវ ព្រោះភូតដែលនៅត្រង់ផែន ដីមិនកើត ។ អាចារ្យពួកដទៃពណ៌នាអត្ថណា សូម្បីពណ៌នានោះ ក៏មិនត្រឹម ត្រូវ ។ ឯក្នុងទីនេះ មានអធិប្បាយថា ខ្ញុំមិនពោលដោយកម្លាំងនៃភាពជាធំ ថាជាពុទ្ធៈ ។ តែវត្តុណាជាប្រយោជន៍ដល់ពួកអ្នក និងដល់មហាជនមនុស្ស នេះ ខ្ញុំនឹងពោលវត្តុនោះថា* **មេត្តំ ករោថ មានុសិយា បជាយ** *ចូរពួកអ្នក ធ្វើមេត្តាដល់មហាជនដែលជាមនុស្សចុះ ។*

ម្យ៉ាងទៀត ក្នុងសេចក្តីនេះ មេត្តា គប្បីជ្រាបថា ជាប្រយោជន៍ដល់អ្នកធ្វើមេត្តាដោយព្រះសូត្រទាំងឡាយយ៉ាងនេះថា

បើបុគ្គលមានចិត្តមិនប្រទូស្តសត្វ សូម្បីតែសត្វមួយ ចម្រើនមេត្តា ជាបុគ្គលឈ្មោះសវៃ ដោយមេត្តានោះ មួយទៀត ព្រះអរិយៈ កាលអនុគ្រោះសត្វទាំងអស់ ដោយចិត្តហើយ ឈ្មោះថា ធ្វើបុណ្យច្រើន ជនទាំង-ឡាយណា ឈ្នះផែនដីដ៏ជេរជាសទៅដោយសត្វ ជនទាំងឡាយនោះ ជាធម្មិករាជ ប្រហែលដោយឥសី ហើយញុំាងការបូជា ឲ្យប្រព្រឹត្តទៅ (គឺទ្រង់ឈ្មោះសវៃ ក្នុងការទំនុកបម្រុងធញ្ញាហារ គឺស្រែស្រូវ ឲ្យសម្បូណ៌ ក្នុងព្រះរាជអាណាចក្រ ១ ទ្រង់ឈ្មោះសវៃ ក្នុងការសង្គ្រោះរាជបុរស ១ ទ្រង់ប្រកបឧបាយ ចងចិត្តមនុស្ស ឲ្យចូលចិត្ត ១ ទ្រង់មានព្រះបន្ទូល ផ្អែមល្ហែម ១ ជាហេតុឲ្យស្រុកទេសរាបទាប សាន្តត្រាណ គ្មានចោរទាល់តែមិនបាច់ដាក់គន្ធឹះ ចាក់សោទ្វារផ្ទះ ១) ការបូជាទាំងឡាយនោះ មិនដល់មួយចំណិតនៃបុគ្គលអ្នកចម្រើនមេត្តាចិត្ត ដែលចែកឲ្យជាចំណែក ១៦ៗ ដងឡើយ ដូច្នេះ ។ និងដោយអានិសង្ស ១១ ប្រការ ។

មេត្តា គប្បីជ្រាបថា ជាប្រយោជន៍ដល់សត្វទាំងឡាយដែលគេធ្វើមេត្តា

ដោយព្រះសូត្រជាដើមយ៉ាងនេះថា **ទេវតានុកម្បតោ ចោសោ សធា ភគ្គានិ បស្សតិ** *បុរសដែលទេវតាអនុគ្រោះហើយ តែងឃើញសេចក្តីចម្រើនសព្វកាល ។*

ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តា មានប្រយោជន៍ដល់បុគ្គលទាំង ២ ចំណែកយ៉ាងនេះ ទើបត្រាស់ថា **មេត្តំ ករោថ មានុសិយា បជាយ** *ដូច្នេះ កាលទ្រង់សម្តែងឧបការៈ ទើបត្រាស់ថា* **ឯវា ច រត្តោ ច ហរន្តិ យេ ពលឹ តស្មា ហិ នេ រក្ខថ អប្បមត្តា។** *មនុស្សទាំងឡាយណា តែងនាំមកនូវពលីក្នុងពេលថ្ងៃ និងពេលយប់ ព្រោះហេតុនោះ សូមអ្នកទាំង-ឡាយ កុំប្រហែសធ្វេស រក្សានូវមនុស្សទាំងនោះ ។*

ភាសិតនេះ មានអត្ថថា មនុស្សពួកណាសាងទេវតាដោយរូបគំនូរ និងធ្វាក់ដោយឈើជាដើម ហើយចូលទៅកាន់រុក្ខចេតិយជាដើម ធ្វើពលីកម្ម ក្នុងពេលថ្ងៃ និងពលីកម្មក្នុងពេលយប់ ក្នុងថ្ងៃខាងរនោចជាដើម ឧទ្ទិសទេវតាទាំងឡាយ ឬប្រគេនសលាកភត្តជាដើម ធ្វើពលីកម្មឧទ្ទិសដល់អារក្ខទេវតា រហូតដល់ការឲ្យនូវបត្តិទាន គឺចំណែកបុណ្យដល់ព្រហ្ម និងទេវតាទាំងឡាយ និងធ្វើពលីកម្មក្នុងពេលយប់ ដោយការលើកឆត្រ អុជប្រទីប ប្រដាប់នូវកម្រងផ្កា និងរៀបចំឲ្យមានការស្តាប់ធម៌មួយយប់ទល់ភ្លឺជាដើម មនុស្សទាំងនោះ ពួកអ្នកមិនគប្បីរក្សាដូចម្តេចបាន ។ ព្រោះហេតុដែលមនុស្សពួកណាធ្វើពលីកម្មឧទ្ទិសដល់អ្នកទាំងឡាយពេលថ្ងៃក្តី ពេលយប់ក្តី យ៉ាងនេះ ចូរពួកអ្នករក្សាមនុស្សទាំងឡាយនោះចុះ ។ អធិប្បាយថា ដូច្នោះ ពួកអ្នកចូរ

គ្រប់គ្រងរក្សាមនុស្សទាំងនោះ គឺបុគ្គលដែលមិនប្រមាទ ធ្វើនូវភាពជាបុគ្គលកតញ្ញូនោះទុកក្នុងចិត្ត រឭកដល់ជានិច្ច ចូរនាំវត្ថុដែលមិនជាប្រយោជន៍ដល់ពួកជនទាំងនោះចេញទៅ គប្បីនាំចូលមកតែវត្ថុជាប្រយោជន៍ ។

អធិប្បាយបទថា យទ្ធិញ្ចិ

ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា មនុស្សមានឧបការៈក្នុងទេវតាទាំងឡាយយ៉ាងនេះហើយ ទើបទ្រង់ផ្តើមប្រកបសច្ចវចនៈ ដោយនយថា **យទ្ធិញ្ចិ វិត្តំ** *ជួចេ្នះជាដើម ដើម្បីទ្រង់រម្ងាប់ឧបទ្ទវរបស់មនុស្សទាំងនោះ និងដើម្បីការស្តាប់ធម៌របស់ទេវតា និងមនុស្សទាំងឡាយ ដោយការប្រកាសគុណរបស់ព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម ក្នុងសច្ចវចនៈនោះ បទថា* **យទ្ធិញ្ចិ** *សេចក្តីថា លោកកាន់យកមិនសេសសល់ ដោយមិនកំណត់ គឺវត្ថុណាមួយដែលគួរធ្វើការផ្ងាស់ប្តូរបានក្នុងទីកន្លែងនោះៗ ។ បទថា* **វិត្តំ** *បានដល់ ទ្រព្យ ។ ពិតហើយ ទ្រព្យនោះ ឈ្មោះថា* **វិត្ត** *ព្រោះឲ្យកើតការត្រេកអរ ។ ទ្រង់សម្តែងមនុស្សលោក ដោយបទថា* **ឥធ វា** *ទ្រង់សម្តែងលោកដ៏សេសក្រៅអំពីមនុស្សនោះ ដោយបទថា* **ហុរំ វា ។** *ដោយ ២ បទនោះ គប្បីជ្រាបថា ស៊ីសេចក្តីដល់នាគ និងគ្រុឌជាដើមដ៏សេស រៀមនុស្ស និងទេវតាទាំងឡាយ ព្រោះកាលដែលកាន់យកលោកទាំងពួង រៀមនុស្សទាំងឡាយ ក៏បានត្រាស់ខាងមុខថា* **សគ្គេសុ វា ។**

ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តឯណាសម្រាប់មនុស្ស គឺជាទ្រព្យប្រើផ្ងាស់ប្តូរ និងដែលប្រើជាគ្រឿងប្រដាប់ គ្រឿងបរិភោគ និងគ្រឿងឧបភោគ មាន

មាស ប្រាក់ កែវមុក្តា កែវមណី កែវពិទូរ្យ កែវប្រវាល កែវទទឹម និងកែវមានមកិតជាដើម និងទ្រព្យជាគ្រឿងត្រេកអរនៃចិត្តឯណា សម្រាប់នាគ និងគ្រុឌជាដើមដែលកើតក្នុងភពទាំងឡាយ ដែលធំទូលាយច្រើនរយោជន៍ ក្នុងវិមានវតនៈ ក្នុងផ្ទៃដីដែលក្រាលដោយឥដ្ឋាច់ កែវមុក្តា និងកែវមណី ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ ក៏ជាការសម្តែងហើយ ដោយបទទាំង ២ នេះ ដោយប្រការដូច្នេះ ។

បទថា **សគ្គេសុ វា** *បានដល់ ទេវលោកដែលជាកាមាវចរ និងរូបាវចរទេវលោកទាំងនោះ ឈ្មោះថា* **សគ្គ** *គឺស្ថានសួគ៌ ព្រោះប្រព្រឹត្តទៅ គឺដល់បានដោយកម្មដ៏ស្អាត ។ ម្យ៉ាងទៀត ឈ្មោះថា* **សគ្គ** *ព្រោះមានអារម្មណ៍ល្អក្រៃលែង ។ បទថា* **យំ** *បានដល់ មានម្ចាស់របស់ ឬមិនមានម្ចាស់របស់ឯណា ។ បទថា* **រតនំ** *បានដល់ ឈ្មោះថា* **រតន** *ព្រោះនាំឲ្យកើត គឺចម្រើនទូវសេចក្តីត្រេកអរ ពាក្យថា* **រតន** *នេះ ជាឈ្មោះរបស់វត្ថុទាំងអស់ដែលធ្វើឲ្យស្អាត មានតម្លៃច្រើន ថ្លឹងថ្លែងមិនបាន ធ្វើបានលំបាក និងជារបស់បរិភោគ ប្រើប្រាស់របស់សត្វដែលមិនថោកថយ ដូចលោកពោលថា*

ចិត្តីកតំ មហគ្ឃញ្ច អតុលំ ទុល្លភទស្សនំ
អនោមសត្តបរិភោគំ រតនំ តេន វុច្ចតិ ។

របស់ដែលធ្វើឲ្យគេកោតក្រែង មានតម្លៃច្រើន ថ្លឹងមិនបាន ឃើញបានដោយលំបាក ជាគ្រឿងប្រើប្រាស់របស់សត្វដែលមិនថោកថយ ដោយហេតុនោះ ទើបហៅថា **រតនៈ** ។

បទថា **បណីតំ** *បានដល់ ប្រសើរបំផុត មិនតិច គួរត្រេកអរនៃចិត្ត រតនៈណាក្នុងសួគ៌ទាំងឡាយ តាំងអំពីវិមានសុធម្មសភា រៀយន្តប្រាសាទ ដែលជារតនៈ មានទំហំច្រើនរយយោជន៍ ជារបស់មានម្ចាស់ និងរតនៈណា ដែលទាក់ទងនៅក្នុងវិមានដែលទំនេរ ក្នុងស្ថានសួគ៌ទាំងឡាយ ដែលធ្វើអបាយ ប៉ុណ្ណោះឲ្យពេញ មិនមែនសម័យដែលព្រះពុទ្ធកើតឡើង មិនមានម្ចាស់ ឬ រតនៈជនៃណា ដែលអាស្រ័យនៅក្នុងផែនដី មហាសមុទ្រ និងភ្នំហិមពាន្តជា ដើមមិនមានម្ចាស់ រតនៈជនៃនោះ ក៏ឈ្មោះថា ទ្រង់សម្តែងហើយដោយបទ នៃគាថានេះ ដោយប្រការដូច្នេះ ។*

សព្ទថា **ន** *ក្នុងបាទគាថាថា* **ន នោ សមំ អត្ថិ តថាគតេន** *ចុះក្នុង ការបដិសេធ ។ សព្ទថា* **នោ** *ចុះក្នុងអត្ថហាមសេចក្តីជនៃ ។ បទថា* **សមំ** *បានដល់ ប្រៀបផៀប ។ បទថា* **អត្ថិ** *ប្រែថា មាន ។ បទថា* **តថាគតេន** *បានដល់ ដោយព្រះពុទ្ធ ។ លោកអធិប្បាយដូចម្តេច ។ លោកអធិប្បាយ ដូច្នេះ ទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត និងរតនៈនោះឯណា ដែលព្រះមាន ព្រះភាគទ្រង់ប្រកាសហើយ បណ្តាទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត និងរតនៈ នោះ រតនៈសូម្បីតែមួយ ដែលស្មើដោយពុទ្ធរតនៈ មិនមានឡើយ ពិតហើយ ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ ឈ្មោះថា* **រតន** *ព្រោះអត្ថថា ធ្វើឲ្យកើត នូវការកោតក្រែង ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ គឺអ្វី គឺចក្កវត្តន៍ និងមណីវត្តន៍របស់ស្តេចចក្រពត្តិ ដែលកើតឡើងហើយ មហាជននឹងធ្វើ សេចក្តីគោរពកោតក្រែងក្នុងទីជនៃ បុគ្គលណាកាន់យកផ្ការ និងគ្រឿងក្រអូប*

ជាដើម ហើយមិនទៅកាន់ស្ថានរបស់យក្ស ឬស្ថានរបស់ភូត ៨ ជនគ្រប់គ្នា នឹងធ្វើសេចក្តីគោរពកោតក្រែង បូជាចំពោះចក្កវត្តន៍ និងមណីវត្តន៍ប៉ុណ្ណោះ ប្រាថ្នាពរនោះៗ និងពរឯណានីមួយ ប្រាថ្នាហើយប្រាថ្នាទៀត ក៏សម្រេចផលបាន រតនៈនោះ ស្មើដោយពុទ្ធរតនៈ មិនមាន ។

បើទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ឈ្មោះថា **រតន** *ព្រោះអត្ថថា ធ្វើឲ្យកើតការគោរពកោតក្រែងព្រះតថាគតប៉ុណ្ណោះ ក៏ឈ្មោះថា* **រតន** *។ ពិតហើយ កាលព្រះតថាគត ទ្រង់កើតឡើងហើយ ទេវតា និងមនុស្សដែលមានសក្តិច្រើន គ្រប់ពួក គ្រប់ត្រកូល ទេវតា និងមនុស្សទាំងនោះ រមែងមិនធ្វើសេចក្តីគោរពកោតក្រែង ក្នុងរតនៈដទៃ រមែងមិនបូជារតនៈដទៃណាមួយ ។ ពិតហើយ សហម្បតីព្រហ្មក៏បូជាព្រះតថាគត ដោយកម្រងរតនៈប៉ុនក្តឹងព្រះ-សិនេរុ ។ ទេវតាដទៃ និងមនុស្សទាំងឡាយ មានព្រះបាទពិម្ពិសារ និងព្រះបាទកោសល និងអនាថបិណ្ឌិកជាដើម ក៏បូជាតាមកម្លាំង ព្រះបាទអសោក-មហារាជ លះបង់ព្រះរាជទ្រព្យ ៩៦ កោដិ សាងវិហារ ៨៤០០០ ពេញជម្ពូទ្វីប ឧទ្ទិសចំពោះព្រះមានព្រះភាគ សូម្បីព្រះអង្គទ្រង់បរិនិព្វានហើយ ។ និងពោលទៅថ្វីសម្រាប់បុគ្គលដែលគោរពកោតក្រែងដទៃនោះ ។ ម្យ៉ាងទៀត កាលព្រះពុទ្ធអង្គណាមួយដទៃបរិនិព្វានហើយ ធ្វើការកោតក្រែង ឧទ្ទិសទីប្រសូត ទីត្រាស់ដឹង ទីប្រកាសធម្មចក្រ និងទីបរិនិព្វាន ឬចេតិយ គឺព្រះបដិមា ក៏ប្រព្រឹត្តទៅដូចនឹងព្រះមានព្រះភាគ ។ រតនៈដែលស្មើដោយព្រះតថាគត ព្រោះអត្ថថា ធ្វើឲ្យកើតនូវការគោរពកោតក្រែង មិនមាន ដោយ*

ប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ ឈ្មោះថា **រតន** *ព្រោះអត្ថថា មានតម្លៃច្រើនក៏ដូចគ្នា ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ គឺអ្វី គឺសំពត់ដែនកាសី ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំពត់កាសិក ទោះចាស់ក៏មានពណ៌ល្អ មានសម្ផស្សក៏ស្រួល ទាំងមានតម្លៃក៏ច្រើន ។ ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ ស្មើដោយពុទ្ធរតន: មិនមាន រតន:ជាគ្រឿងត្រេកអរនៃចិត្ត ឈ្មោះថា* **រតន** *ព្រោះអត្ថថា មានតម្លៃច្រើន ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា* **រតន** *ពិតហើយ ព្រះតថាគតទ្រង់ទទួលបង្សុកូលចីវរបស់ជនពួកណា ទាននោះរបស់ជនទាំងនោះ រមែងមានផលច្រើន មានអានិសង្សច្រើន ដូច្នេះ ។ ព្រោះព្រះតថាគតនោះ មានតម្លៃច្រើន ។ ដោយពាក្យពោលដល់ប្រការដែលព្រះតថាគត ទ្រង់មានតម្លៃច្រើនយ៉ាងនេះ គប្បីជ្រាបបទនៃព្រះសូត្រដែលសាធកការមិនមានទោស ក្នុងសេចក្តីនេះ ដូច្នេះថា*

> *ប្រសិនបើតថាគតទទួលចីវរ បិណ្ឌបាត សេនាសន: និងគិលានប្បច្ចយភេសជ្ជបរិក្ខាររបស់ពួកជនណា ការទទួលនោះ រមែងមានផលច្រើន មានអានិសង្សច្រើនដល់ពួកជននោះ បានជាតថាគតពោលយ៉ាងនេះ ព្រោះតថាគតមានតម្លៃច្រើន ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានតម្លៃច្រើន យ៉ាងណាមិញ ម្នាលភិក្ខុ*

ទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។

រតនៈស្មើដោយតថាគត ព្រោះអត្ថថា មានតម្លៃច្រើន រមែងមិនមានដោយប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ ឈ្មោះថា **រតន** *ព្រោះអត្ថថា ប្លឹងមិនបាន ក៏ដូចគ្នា ។ ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ គឺអ្វី គឺចក្កវត្តន៍នៃស្តេចចក្រពត្តិ មានដុំជាកែវមណីឥន្ទនីល មានកាំជារតនៈ ៧ ពាន់កាំ មានខ្នងកង់ជាវិការនៃកែវប្រពាល មានទី-តជាមាសកើតឡើងរៀងរាល់ ១០ កាំទទួលខ្សាច់ហើយ ធ្វើសំឡេងដូចសំឡេងតន្ត្រី ដែលមានអង្គ ៥ ដែលអ្នកជំនាញប្រគំហើយ ផ្នែកសងខាងនៃដុំ មានមុខរាជសីហ៍ ២ ខាងក្នុងកង់រថមានប្រហោង មិនមានអ្នកធ្វើ ឬអ្នកឲ្យធ្វើ វន្ទនោះកើតឡើងអំពីឧតុ មានកម្មជាបច្ច័យ ដែលព្រះរាជាទ្រង់បំពេញចក្កពត្តិវត្ត ១០ ប្រការហើយ ថ្ងៃឧបោសថ ១៥ កើត ១៥ រោច ទ្រង់កក់សីសៈហើយ ទ្រង់រក្សាឧបោសថ ទ្រង់ឡើងលើមហាប្រាសាទ ទ្រង់ជម្រះសីល ប្រថាប់គង់ហើយ ទតឃើញចក្កវត្តន៍ប្រាកដឡើង ដូចព្រះចន្ទ និងព្រះអាទិត្យពេញវង់ ទ្រង់បានឮសំឡេងមកតាំងអំពីទី ១២ យោជន៍ ឃើញពណ៌មកតាំងអំពីទី ៣ យោជន៍ ដែលមហាជនសម្ងំឃើញ នាំគ្នាក្រាក់ផ្អើលថា ពន់ពេកថា ប្រហែលជាព្រះចន្ទ និងព្រះអាទិត្យជួងទី ២ កើតឡើងហើយ អណ្តែតមកខាងលើព្រះនគរ មិនខ្ពស់ពេក មិនទាបពេក តាមទិសខាងកើត ខាងក្នុងព្រះរាជនិវេសន៍ ហើយឈប់និងថ្កល់ ដូចជាក់ក្លៅ ក្នុងទីដែលមហាជនគួរបូជា ដោយគ្រឿងក្រអូប និងផ្កា

ជាដើម ។

ហត្ថិរ័តន៍ ជំរីកែវកើតឡើងតាមចក្ករ័តន៍នោះឯង គឺជំរីសសុទ្ធ ជើងក្រហម មានកម្ចាំងស្មើជំរី ៧ មានឫទ្ធិទៅក្នុងអាកាសបាន មកអំពីត្រកូលជំរីឈ្មោះឧបោសថក៏មាន មកអំពីត្រកូលឆទ្ទន្តក៏មាន បើមកអំពីត្រកូលឧបោសថ ក៏ជាជំរីច្បងគេទាំងអស់ បើមកអំពីត្រកូលឆទ្ទន្ត ក៏ជាជំរីប្អូនគេទាំងអស់ មានការសិក្សាហើយ ទូន្មានហើយ ជំរីនោះ នាំបរិស័ទប្រមាណ ១២ យោជន៍ ឆ្ងែលជម្ពូទ្វីប ទៅហើយត្រឡប់មកឯង មុនអាហារព្រឹកនោះឯង ។

អស្សតរ័តន៍ ក៏កើតតាមហត្ថិរ័តន៍នោះឯង គឺជាសេះសសុទ្ធ ជើងក្រហម ក្បាលដូចក្បាលក្អែក មានសក់ដូចស្មៅជំណេកទន្សាយ មកអំពីត្រកូលស្តេចសេះវលាហក ។ ក្នុងសេចក្តីនេះ ពាក្យដ៏សេស ដូចគ្នានឹងហត្ថិរ័តន៍នោះឯង ។

មណីរ័តន៍ ក៏កើតជាប់តាមអស្សតរ័តន៍នោះ មណីនោះ ជាកែវពិទូរ្យស្អាតដោយធម្មជាតិ ជាកែវមានជ្រុង ៨ ដែលគេឆ្នៃយ៉ាងល្អ ដោយបណ្តោយ ក៏ដូចគ្នានឹងជុំនៃចក្រ មកអំពីវេបុលបព៌ត មណីនោះ ពេលយប់ងងឹត ដែលប្រកបដោយអង្ត ៤ ជាក់លើកំពូលទង់របស់ព្រះរាជា ក៏ជះពន្លឺទៅរាប់យោជន៍ ពួកមនុស្សសម្គាល់ថាជាពេលថ្ងៃ ប្រកបការងារ មើលឃើញដោយហោចសូម្បីស្រមោច និងស្រមោចក្រហម ។

ឥត្ថីរ័តន៍ក៏កើតឡើងតាមមណីរ័តន៍នោះឯង គឺស្ត្រីដែលជាអគ្គមហេសីដោយប្រក្រតី ឬមកអំពីឧត្តរកុរុទ្វីប ឬមកអំពីត្រកូលមទ្ទរាជ រៀរចាកទោស

៦ មានការខ្ពស់ពេកជាដើម កន្ទងបង់នូវពណ៌របស់មនុស្ស តែមិនដល់វណ្ណៈទិព្វ សម្រាប់ព្រះរាជា នាងមានកាយក្តៅក្នុងកាលត្រជាក់ មានកាយត្រជាក់ក្នុងកាលក្តៅ មានសម្ផស្សជូចសំឡីដែលគេថ្ពេច ៧ ជង កិនចន្ទន៍ផ្សាយចេញអំពីព្រះកាយ កិនឧប្បលផ្សាយចេញអំពីមាត់ និងជាស្ត្រីប្រកបដោយគុណសម្បត្តិដ៏ចម្រើន មានការក្រាក់មុនជាដើម ។

គហបតិរ័តន៍ ក៏កើតជាប់តាមឥត្ថីរ័តន៍នោះឯង គឺសេដ្ឋីដែលធ្វើការងារដោយប្រក្រតីរបស់ព្រះរាជា តែកាលចក្កវត្តិន៍កើតឡើង ក៏ប្រាកដទិព្វចក្ខុ ឃើញនូវរណ្តៅទ្រព្យបានប្រមាណមួយយោជន៍ដោយជុំវិញ ទោះជារបស់មានម្ចាស់និងមិនមានម្ចាស់ ក៏ចូលគាល់ព្រះរាជា ទូលនូវបំណងថា បពិត្រទេវរាជ សូមទ្រង់ជាក់ព្រះរាជការកិច្ចចុះ ទូលបង្គំនឹងធ្វើកិច្ចដែលគួរធ្វើ ទាក់ទងនឹងទ្រព្យរបស់ព្រះអង្គដោយខ្លួនឯង ។

*បរិនាយករ័តន៍ ក៏កើតតាមគហបតិរ័តន៍នោះឯង ដោយប្រក្រតី គឺព្រះជេដ្ឋឱរសរបស់ព្រះរាជា កាលចក្កវត្តិន៍កើតឡើង ក៏ជាបុគ្គលប្រកបដោយបញ្ញាឈ្លាសវៃក្រៃលែង អាចកំណត់ដឹងចិត្តរបស់បរិស័ទប្រមាណ ១២ យោជន៍ដោយចិត្តរបស់ខ្លួន ហើយធ្វើនិគ្គហៈ គឺការដាក់ទោស និងបគ្គហៈ គឺការសរសើរ បរិនាយកនោះ ក៏ចូលគាល់ព្រះរាជាទូលនូវសេចក្តីប្រាថ្នាថា បពិត្រមហារាជ សូមទ្រង់ជាក់ព្រះរាជការៈចុះ ខ្ញុំព្រះអង្គនឹងបរិហារព្រះរាជការផែនដីរបស់ព្រះអង្គដោយខ្លួនឯង ។ ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តដទៃណាបែបនោះឈ្មោះថា **រតន** ព្រោះអត្ថថា ថ្លឹងមិនបាន ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តណា*

មិនអាចពិនិត្យពិចារណា វាយតម្លៃថា មានតម្លៃ ១០០ , ១០០០ ឬ ១ កោដិ ក្នុងទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ សូម្បីរតនៈណាមួយ ស្មើដោយពុទ្ធ-រតនៈ មិនមានឡើយ ។ បើទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ឈ្មោះថា **រតន** *ព្រោះអត្ថថា ថ្លឹងមិនបាន ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា* **រតន។** *ពិតហើយ ព្រះតថាគត បុគ្គលណាម្នាក់ ក៏មិនអាចពិចារណាដោយសីល ដោយសមាធិ ឬដោយបណ្ឌាបញ្ញាជាដើមណាមួយ ហើយកំណត់ថា ទ្រង់មានគុណប៉ុណ្ណោះ ទ្រង់ស្មើ ឬប្រៀបធៀបនឹងបុគ្គលនេះ រតនៈស្មើដោយព្រះតថាគត ព្រោះអត្ថថា ថ្លឹងមិនបាននោះ រតនៈនោះមិនមានឡើយ ដោយប្រការដូច្នេះ ។*

ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តណា ឈ្មោះថា **រតន** *ព្រោះអត្ថថា ឃើញបានលំបាក ក៏ដូចគ្នា ។ ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនេះ គឺភាពជារបស់ប្រាកដបានលំបាក បានដល់ ស្តេចចក្រពត្តិ និងរតនៈ ៧ ប្រការរបស់ស្តេចចក្រពត្តិនោះ រតនៈនោះ ស្មើដោយពុទ្ធរតនៈ មិនមាន ។ បើទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ឈ្មោះថា* **រតន** *ព្រោះអត្ថថា ឃើញបានលំបាកសោត ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា* **រតន** *ភាពជារតនៈរបស់ស្តេចចក្រពត្តិជាដើម និងឃើញបានលំបាកមកអំពីណា ពិតហើយ រតនៈទាំងនោះ រមែងកើតឡើងច្រើនក្នុងកប្ប ១ ប៉ុណ្ណោះ តែព្រោះទ្វីបលោកសូន្យចាកព្រះតថាគតរាប់អសង្ខ្យេយ្យកប្ប ដូច្នោះ ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា ឃើញបានលំបាកព្រោះកើតឡើងម្តងម្កាល ។ សមដូចព្រះមានព្រះភាគ ត្រាស់ក្នុងសម័យបរិនិព្វានដូច្នេះថា*

ម្នាលអានន្ទ ពួកទេវតាពោលទោសថា ពួកយើងមក អំពីចម្ងាយ ដើម្បីឃើញព្រះតថាគតៗ ជាព្រះអរហន្ត សម្មាសម្ពុទ្ធកើតឡើងក្នុងលោកមានម្តងៗ ក្នុងបច្ឆិម-យាម នៃរាត្រីថ្ងៃនេះឯង បរិនិព្វានទីងមានដល់ព្រះ តថាគត ក៏ភិក្ខុមានសក្តិធំនេះ មកឈរវាំងនៅចំព្រះ កត្រៃនៃព្រះមានព្រះភាគ ពួកយើងមិនបានឃើញព្រះ តថាគត ក្នុងបច្ឆិមកាលឡើយ ។

រតនៈស្មើដោយព្រះតថាគត ព្រោះអត្ថថា ឃើញបានដោយក្រ រមែង មិនមាន ដោយប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ បានឈ្មោះថា **រតនៈ** *ព្រោះអត្ថថា ជាគ្រឿងបរិភោគប្រើប្រាស់របស់សត្វ ដែលមិនថោកទាប ក៏ដូចគ្នា ។ ទ្រព្យ ជាគ្រឿងត្រេកអរនៃចិត្តនោះ គឺអ្វី គឺរតនៈជាដើមរបស់ស្តេចចក្រពត្តិ ។ ពិត ហើយ រតនៈនោះ មិនមែនកើតឡើងដើម្បីជាគ្រឿងបរិភោគ សូម្បីដោយការ យល់សប្តិរបស់បុរសថោកថយ បុគ្គលមានត្រកូលទាប ដូចជាមនុស្សចណ្ឌាល ជាងផែង ព្រាន ជាងរថ និងអ្នកចាក់សំរាមជាដើម ដែលមានទ្រព្យរាប់សែន កោដិក្តី នៅលើមហាប្រាសាទ ៧ ជាន់ក្តី តែជាគ្រឿងបរិភោគ របស់សត្វ ដែលមិនថោកថយ ព្រោះកើតដើម្បីជាគ្រឿងបរិភោគ របស់ព្រះមហាក្សត្រ ដែលជាឧភតោសុជាតិ បំពេញចក្កពត្តិវត្ត ១០ ប្រការបរិបូណ៌ រតនៈនោះ ស្មើដោយពុទ្ធរតនៈមិនមានឡើយ ។ បើទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ឈ្មោះ*

ថា **រតន** *ព្រោះអត្ថថា ជាគ្រឿងបរិភោគរបស់សត្វដែលមិនថោកថយសោត ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា* **រតន ។** *ពិតហើយ ព្រះតថាគតមិនមែនជាគ្រឿងបរិភោគ សូម្បីត្រឹមតែការយល់សប្តិរបស់គ្រូទាំង ៦ មានបូរណកស្សប ជាដើម ដែលសន្មតគ្នាថា ជាសត្វថោកថយ មិនដល់ព្រមដោយឧបនិស្ស័យ មានទស្សនវិបរិត និងរបស់សត្វដទៃបែបនោះ តែជាគ្រឿងបរិភោគរបស់ពួកបុគ្គលដែលដល់ព្រមដោយឧបនិស្ស័យ ជាអ្នកអាចសម្រេចអរហត្ត កាលចប់គាថា ៤ បទ បុគ្គលមានញាណទស្សនៈ ទម្លាយនូវកិលេស មានព្រះពាហិយ-ទារុចីរិយជាដើម និងរបស់ព្រះមហាសាវ័កទាំងឡាយដទៃៗ ដែលជាបុត្រនៃត្រកូលធំ ។ ពិតហើយ ពួកសត្វដែលមិនថោកថយទាំងនោះ កាលញុំងទស្សនានុត្តរិយៈ សវនានុត្តរិយៈ និងបារិចរិយានុត្តរិយៈជាដើមឲ្យសម្រេច ឈ្មោះថា បរិភោគប្រើប្រាស់ព្រះតថាគត ។ រតនៈដែលស្មើដោយព្រះតថាគត ព្រោះអត្ថថា ជាគ្រឿងបរិភោគរបស់សត្វ ដែលមិនថោកថយ មិនមានឡើយ ដោយប្រការដូច្នេះ ។*

ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ ដោយមិនវិសេស ឈ្មោះថា **រតន** *ព្រោះអត្ថថា ឲ្យកើតនូវការត្រេកអរ ។ ទ្រព្យ គឺគ្រឿងត្រេកអរនៃចិត្តនោះ គឺអ្វី គឺចក្កវត្តន៍របស់ស្តេចចក្រពត្តិ ពិតហើយ ស្តេចចក្រពត្តិទ្រង់ឃើញចក្ក-វត្តន៍នោះហើយ ក៏ទ្រង់សប្បាយព្រះហឫទ័យ ចក្កវត្តន៍នោះ នាំមកនូវការត្រេកអរដល់ព្រះរាជា ដោយប្រការដូច្នេះ ។*

ម្យ៉ាងទៀត ស្តេចចក្រពត្តិទ្រង់ចាប់ព្រះសុវណ្ណកិង្ខា ដោយព្រះហស្តឆ្វេង

ទ្រង់ប្រោះព្រំដោយព្រះហស្តស្តាំ មានព្រះរាជឱង្ការថា ចក្កវត្តន៍ចូរវិលទៅ ចក្កវត្តន៍ចូរមានជ័យជម្នះ ។ បន្ទាប់អំពីនោះ ចក្កវត្តន៍ក៏បន្លឺសំឡេងពីរោះ ដូចតន្ត្រីមានគ្រឿង ៥ ហោះទៅទិសខាងកើត ។ ស្តេចចក្រពត្តិទ្រង់លើកចតុរង្គសេនាដែលមានទទឹង ១២ យោជន៍ជាប់តាមទៅ ដោយអានុភាពចក្ក-វត្តន៍ មិនខ្ពស់ពេក មិនទាបពេក ឆ្ងាយអំពីផែនដី យ៉ាងទាបត្រឹមដើមឈើទាប យ៉ាងខ្ពស់ត្រឹមដើមឈើខ្ពស់ ទ្រង់ទទួលគ្រឿងបណ្ណាការអំពីដៃរបស់ពួកជនដែលកាន់បណ្ណាការ មានផ្កា ផ្លែឈើ និងពន្លកឈើក្នុងដើមឈើជាដើម ។

ឯព្រះរាជាដែលធ្លាប់ជាបដិបក្ខ មកគាល់ដោយសេចក្តីគោរព ឱនលំទោនយ៉ាងក្រៃលែងថា សូមទ្រង់យាងមកចុះ ព្រះមហារាជ ក៏ទ្រង់អនុ-សាសន៍ ទូន្មានដោយនយថា កុំសម្លាប់សត្វមានជីវិត ដូច្នេះជាដើម ទើបយាងទៅ ។ ក្នុងទីណាព្រះរាជាមានបំណងសោយ ឬបំណងនឹងផ្ទំពេលថ្ងៃក្នុងទីនោះ ចក្កវត្តន៍ក៏ចុះអំពីអាកាស ហើយឈប់ ដូចជាក់ក្លៅ ក្នុងទីដែលរាបស្មើ សមគួរដល់កិច្ចគ្រប់យ៉ាង មានកិច្ចដែលទាក់ទងដោយទឹកជាដើម កាលព្រះរាជាគិតយាងទៅទៀត ចក្កវត្តន៍ក៏បន្លឺសំឡេងដោយនយមុននោះឯង ទើបរសាត់ទៅ ។ ឯបរិស័ទទំហំ ១២ យោជន៍បានឮសំឡេងនោះ ក៏នាំគ្នាហោះទៅ ។ ចក្កវត្តន៍ចុះកាន់មហាសមុទ្រទិសខាងកើតដោយលំដាប់ កាលចក្កវត្តន៍នោះចុះកាន់សមុទ្រ ទឹកក៏រួញខ្លួនទៅប្រមាណមួយយោជន៍ឈប់ស្ងៀមដូចធ្វើការស្រឡាញ់រាប់អាន ។ មហាជនក៏រើសរតនៈទាំង ៧ តាមសេចក្តីត្រូវការ ព្រះរាជាទ្រង់ចាប់ឃ្លោកមាសទៀត ទ្រង់ប្រោះព្រំដោយទឹក ត្រាស់ថា

រាជកិច្ចរបស់ខ្ញុំប្រព្រឹត្តទៅ ហើយទ្រង់យាងត្រឡប់ ។ កងទ័ពនៅខាងមុខ ចក្កវត្តន៍ នៅខាងក្រោយ ព្រះរាជានៅកណ្តាល ។ ទឹកត្រឡប់មកវិញ ពេញត្រង់ទីដែលចក្កវត្តន៍ចុះនោះ ។ ចក្កវត្តន៍ទៅក្នុងសមុទ្រទិសទក្សិណ ទិសខាងបស្ចិម និងទិសឧត្តរ ដោយឧបាយនេះឯង ។

*ចក្កវត្តន៍វិលទៅ ៤ ទិសយ៉ាងនេះហើយ ក៏ឡើងកាន់អាកាសប្រមាណ ៣០០ យោជន៍ ព្រះរាជាទ្រង់ប្រថាប់ឈរលើចក្កវត្តន៍នោះ ទ្រង់ឈ្នះដោយអានុភាពចក្កវត្តន៍ ទ្រង់មើលចក្រវាលមួយ ដែលប្រជាប់ដោយទ្វីបធំ ៤ និងទ្វីបតូច ២០០០ ដូចសួនបុណ្ឌរីកដែលរីកល្អហើយយ៉ាងនេះ គឺបុព្វវិទេហទ្វីប ប្រជាប់ដោយទ្វីបតូច ៥០០ មានបរិមណ្ឌល ៧០០០ យោជន៍ ឧត្តរកុរុទ្វីប ក៏ដូចគ្នា មានបរិមណ្ឌល ៨០០០ យោជន៍ អាមរគោយានទ្វីប មានបរិមណ្ឌល ៧០០០ យោជន៍ដូចគ្នា និងជម្ពុទ្វីបមានបរិមណ្ឌល ១០០០០ យោជន៍ ។ ស្តេចចក្រពត្តិអង្គនោះ កំពុងពិនិត្យមើលយ៉ាងនេះ ទ្រង់ក៏ត្រេកអរក្រៃលែង ចក្កវត្តន៍នោះបានឲ្យកើតសេចក្តីត្រេកអរដល់ព្រះរាជា ដោយអាការយ៉ាងនេះ ។ ចក្កវត្តន៍នោះ មិនស្មើនឹងពុទ្ធវត្តន៍ឡើយ ។ បើឈ្មោះថា **រតន** ព្រោះអត្ថថាឲ្យកើតសេចក្តីត្រេកអរសោត ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា **រតន** ចក្កវត្តន៍តែម្យ៉ាង នឹងធ្វើអ្វីបាន ។*

ពិតហើយ ការត្រេកអរក្នុងចក្រពត្តិ ដែលខ្ជិនធ្វើឲ្យកើត រតនៈគ្រប់យ៉ាង មានចក្កវត្តន៍ជាដើម ក៏មិនទាន់រាប់ស្មើមួយចម្រៀកនៃចំណែកការត្រេកអរដែលជាទេព្យឯណា ព្រះតថាគតទ្រង់ធ្វើឲ្យកើតសេចក្តីត្រេកអរក្នុងបឋមជ្ឈាន

ការត្រេកអរក្នុងបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន និងបញ្ចមជ្ឈាន សេចក្តីត្រេកអរក្នុងអាកាសានញ្ចាយតនជ្ឈាន វិញ្ញាណញ្ចាយតនជ្ឈាន អាកិញ្ចញ្ញាយតនជ្ឈាន និងនេវសញ្ញានាសញ្ញាយតនជ្ឈាន សេចក្តីត្រេកអរក្នុងសោតាបត្តិមគ្គ សេចក្តីត្រេកអរក្នុងសោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ និងអរហត្តផល ដល់ទេវតា និងមនុស្ស រាប់មិនអស់ ដែលទទួលឱវាទរបស់ព្រះអង្គ ។ ក្រៃលែងជាង ប្រណីតជាងការត្រេកអរនោះ រតនៈ ស្មើដោយព្រះតថាគត ព្រោះអត្ថថា ឲ្យកើតនូវការត្រេកអរ មិនមាន ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ធម្មតារតនៈនេះមាន ២ យ៉ាង គឺ **សវិញ្ញាណការតន** *និង* **អវិញ្ញាណការតន** *។ បណ្តារតនៈទាំង ២ នោះ អវិញ្ញាណករតនៈ បានដល់ ចក្កវត្តន៍ និងមណីវត្តន៍ ឬរតនៈជនៃណា មានមាស និងប្រាក់ជាដើម ដែលទាក់ទងដោយអនិន្ទ្រិយ ។*

សវិញ្ញាណករតនៈ បានដល់ រតនៈ មានហត្ថិវត្តន៍ជាដើម មានបរិនាយកវត្តន៍ជាទីបំផុត ឬរតនៈជនៃណាបែបនោះ ដែលទាក់ទងដោយឥន្ទ្រិយ ។ កាលបើដូច្នោះ ក្នុងរតនៈទាំង ២ យ៉ាង សវិញ្ញាណករតនៈ ពោលថា ជារតនៈប្រសើរ ក្នុងសេចក្តីនេះ ។ ព្រោះហេតុអ្វី ព្រោះថា រតនៈ មានមាស ប្រាក់ កែវមណី កែវមុក្តាជាដើម ត្រូវនាំចូលទៅប្រើជាគ្រឿងអលង្ការនៃហត្ថិវត្តន៍ជាដើម ដែលជាសវិញ្ញាណករតនៈ ។

សវិញ្ញាណករតនៈមាន ២ យ៉ាង គឺរតនៈជាសត្វតិរច្ឆាន និងរតនៈជា

មនុស្ស ។ បណ្តាសវិញ្ញាណកវត្ថុ ២ យ៉ាងនោះ វត្ថុដែលជាមនុស្ស ពោលហើយថា ជាវត្ថុប្រសើរ ព្រោះហេតុអ្វី ព្រោះថា វត្ថុដែលជាសត្វ តិរច្ឆាន រមែងជាពាហនៈរបស់វត្ថុដែលជាមនុស្ស ។ មនុស្សវត្ថុមាន ២ យ៉ាង គឺឥត្ថីរតន៍ និងបុរិសរតន៍ ។ បណ្តាមនុស្សវត្ថុទាំង ២ យ៉ាងនោះ បុរិសរតន៍ ឈ្មោះថា របស់ប្រសើរ ។ ព្រោះហេតុអ្វី ព្រោះថា ឥត្ថីរតន៍ ជាបាទិចារិការបស់បុរិសរតន៍ ។ បុរិសវត្ថុក៏មាន ២ យ៉ាង គឺអគារិករតន៍ និងអនាគារិករតន៍ ។ បណ្តាបុរិសរតន៍ ២ យ៉ាងនោះ អនាគារិករតន៍ ជាវត្ថុប្រសើរ ព្រោះហេតុអ្វី ព្រោះថា ក្នុងអគារិករតន៍ ស្តេចចក្រពត្តិដ៏ប្រសើរ ក៏គង់ថ្វាយបង្គំអនាគារិករតន៍ដែលប្រកបដោយគុណ មានសីលជាដើម ដោយបញ្ចង្គប្រតិស្ឋាន ទំនុកបម្រុង អង្គុយជិត ជួបនូវសម្បត្តិដែលជាទិព្វ និងមនុស្ស សម្រេចនិព្វានសម្បត្តិក្នុងទីបំផុត ។

កាលបើដូច្នោះ សូម្បីអនាគារិករតន៍ក៏មាន ២ យ៉ាង គឺ **អរិយរតន** *និង* **បុថុជ្ជនរតន ។**

អរិយវត្ថុមាន ២ យ៉ាង គឺ **សេក្ខរតន** *និង* **អសេក្ខរតន ។**

អសេក្ខវត្ថុក៏មាន ២ យ៉ាង គឺ **សុក្ខវិបស្សករតន** *និង* **សមថ-យានិករតន ។**

សមថយានិករតន៍ក៏មាន ២ យ៉ាង គឺដែលសម្រេចសាវកបារមី និងដែលមិនសម្រេចសាវកបារមី ។ បណ្តាសមថយានិករតន៍ទាំង ២ យ៉ាងនោះ សមថយានិករតន៍ដែលសម្រេចសាវកបារមី ឈ្មោះថា ប្រសើរ ព្រោះ

ហេតុអ្វី ព្រោះថា មានគុណច្រើន ព្រះបច្ចេកពុទ្ធរតន៍ ឈ្មោះថា ជារតនៈប្រសើរជាងសាវកបារមីបត្តរតន៍ ។ ព្រោះហេតុអ្វី ព្រោះថា មានគុណច្រើន ។ សាវកច្រើនរយ ដូចជាព្រះសារីបុត្រ ព្រះមោគ្គល្លាន ក៏មិនដល់ចំណែកទី ១០០ នៃគុណទាំងឡាយរបស់ព្រះបច្ចេកពុទ្ធមួយអង្គ ។

សម្មាសម្ពុទ្ធរតន៍ ពោលថា ជារតនៈដ៏ប្រសើរជាងបច្ចេកពុទ្ធរតន៍ ព្រោះហេតុអ្វី ព្រោះថា មានគុណច្រើន ។ បើព្រះបច្ចេកពុទ្ធទាំងឡាយគង់ពត់ក្អែនជាប់ៗ គ្នា ពេញជម្ពូទ្វីប ក៏មិនស្មើនឹងមួយចម្រៀកនៃព្រះគុណទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធមួយអង្គ ។ សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលជាសត្វមិនមានជើងក្តី មានជើងពីរក្តី ។បេ។ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ច្រោកដជាប្រសើរ ជាងពួកសត្វទាំងនោះ ។ រតនៈដែលស្មើដោយព្រះតថាគតមិនមានឡើយ ដោយបរិយាយណាមួយ ដោយប្រការដូច្នេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ន ឧបោ សមំ អត្ថិ តថាគតេន** *ទ្រព្យ និងរតនវត្ថុទាំងនោះឯង ស្មើដោយព្រះតថាគតមិនមានឡើយ ។*

ព្រះមានព្រះភាគ កាលត្រាស់ភាពដែលពុទ្ធរតន៍ ដែលរតនៈដទៃៗ ប្រៀបធៀបមិនបានយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីរម្ងាប់ឧបទ្រវដែលកើតដល់សត្វទាំងនោះ ទ្រង់មិនអាស្រ័យជាតិ ទ្រង់មិនអាស្រ័យគោត្រ ទ្រង់មិនអាស្រ័យភាពជាកុលបុត្រ ទ្រង់មិនអាស្រ័យភាពជាអ្នកមានពណ៌សម្បុរស្អាតជាដើម បើទ្រង់អាស្រ័យភាពដែលពុទ្ធរតន៍ មិនមានអ្វីប្រៀបធៀបបានដោយ

គុណទាំងឡាយ មានសីលក្ខន្ធ និងសមាធិក្ខន្ធជាដើមក្នុងលោក ដែលមានអវីចីជាដើម មានកវគ្គព្រហ្មជាទីបំផុត ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥមម្បិ ពុទ្ធេ រតនំ បណីតំ ឯតេន សច្ចេន សុវត្ថិ ហោតុ** *រតនៈ គឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ដោយសច្ចៈនេះ សូមមានសិរីសួស្តី ដូច្នេះ ។*

សច្ចវចនៈនោះ មានសេចក្តីដូច្នេះថា ភាពដែលព្រះពុទ្ធមិនមានបុគ្គលប្រៀបបានដោយព្រះគុណទាំងឡាយនោះៗ និងទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ឬរតនៈគ្រប់យ៉ាង ដែលមានក្នុងលោកនេះ ឬលោកដទៃ ឬក្នុងស្ថានសួគ៌ទាំង-ឡាយ នេះឈ្មោះថា រតនៈដ៏ប្រណីតក្នុងព្រះពុទ្ធ បើសេចក្តីនេះជាសច្ចៈសោតកាលបើដូច្នោះ ដោយសច្ចៈនេះ សូមសួស្តីកើតមាន សូមវត្ថុដែលល្អទាំង-ឡាយមាន ការមិនមានរោគ ការប្រាសចាកឧបទ្រវ ចូរមានដល់សត្វទាំងនេះ ក្នុងសេចក្តីនេះ គប្បីជ្រាបថា បណីតវតន៍ បានដល់ ភាពជារតនៈប្រណីត គឺការៈដែលព្រះពុទ្ធជារតនៈប្រណីត ដូចភាពជាខ្លួន ឬព្រោះទាក់ទងនឹងខ្លួន ក្នុងប្រយោគជាដើមយ៉ាងនេះថា **ចក្ខុំ ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វា** *ម្នាលអានន្ទ ចក្ខុហ្នឹងឯងសូន្យចាកខ្លួន ឬចាកបរិក្ខាររបស់ខ្លួន ។ ពិតហើយ ក្រៅអំពីនេះ ចក្ខុក៏ជាការបដិសេធមិនបានថាជាខ្លួន ឬវត្ថុដែលទាក់ទងជាមួយនឹងខ្លួន ដូច្នោះ ។ ពិតហើយ ដោយប្រការក្រៅអំពីនេះ ព្រះពុទ្ធរមែងមិនសម្រេចជារតនៈ ដ្បិតថា មិនមានក្នុងវត្ថុណា វត្ថុនោះ ក៏មិនសម្រេចជារតនៈ ។ តែបើរតនៈទាក់ទងដោយវិធីណាមួយក៏ដោយ ដែលរាប់ថាជាប្រយោជន៍មាន បុគ្គលធ្វើសេចក្តីគោរពកោតក្រែងជាដើមមានក្នុង*

វត្តុណា ព្រោះវត្តុនោះ លោកសំដៅយកភាពជារតនៈ ទើបបញ្ញត្តថា **រតន** *ដូច្នោះ ទើបព្រះពុទ្ធសម្រេចថា ជារតនៈ ព្រោះរតនៈនោះមាន ។ ម្យ៉ាងទៀត បទថា* **ឥធម្បិ ពុទ្ធេ រតនំ បណីតំ** *គប្បីជ្រាបអត្ថយ៉ាងនេះថា ព្រះពុទ្ធជារតនៈ ដោយប្រការដូច្នេះ ។ លុះព្រះដ៏មានព្រះភាគត្រាស់ព្រះគាថា សួស្តី ក៏កើតដល់រាជត្រកូល ភ័យក៏រម្ងាប់ទៅ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នា ព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។*

ព្រះមានព្រះភាគ កាលត្រាស់វចនៈយ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្តើមត្រាស់បទថា **ខយំ វិរាគំ** *ជាដើម ។ ក្នុងពាក្យនោះ ព្រោះកិលេសទាំងឡាយ មានរាគៈជាដើមអស់ទៅ ព្រោះធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ឬព្រោះហេតុដែលព្រះនិព្វាននោះ លុះកិលេសទាំងនោះអស់ទៅ ដោយរលត់មិនកើត និងព្រោះហេតុដែលព្រះនិព្វាននោះ មិនប្រកបដោយកិលេស មានរាគៈជាដើម ដោយការជួប និងដោយអារម្មណ៍ ឬព្រោះកាលបុគ្គលធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះហើយ កិលេសទាំងឡាយ មានរាគៈជាដើម ក៏អស់ទៅដោយឥតសេសសល់ ប្រាសទៅ ត្រូវកម្ចាត់ទៅ ដូច្នោះ ទើបព្រះនិព្វាន លោកហៅថា* **ខយ** *ហៅថា* **វិរាគ** *តែព្រោះនិព្វាននោះ ការកើតមិនប្រាកដ ការវិនាសមិនប្រាកដ ភាពដែលចិត្តប្រែប្រួលមិនមាន ដូច្នោះ ទើបព្រះនិព្វាននោះ លោកពោលថា មិនកើត មិនចាស់ មិនស្លាប់ ហៅថា អមតៈ តែក្នុងទីនេះ លោកហៅថា ប្រណីត ព្រោះអត្ថថា ឧត្តម និងព្រោះអត្ថថា មិនឆ្អែត ។ បទថា* **យធជ្ឈគា** *បានដល់ សម្រេច ជួប បានធ្វើឲ្យ*

ជាក់ច្បាស់ដោយកម្លាំងញាណ របស់ខ្លួននូវព្រះនិព្វាននោះ ។ បទថា **សក្យ-មុនី** *បានដល់ ឈ្មោះថា* **សក្យ** *ព្រោះទ្រង់ជាឱរសរបស់សក្យត្រកូល ។ ឈ្មោះថា* **មុនី** *ព្រោះប្រកបដោយមោនេយ្យធម៌ មុនី គឺសក្យៈ ឈ្មោះថា* **សក្យមុនី** *។ បទថា* **សមាហិតោ** *បានដល់ ដែលមានចិត្តតាំងមាំហើយក្នុងសមាធិ ដែលជាអរិយមគ្គ ។ បទថា* **ន តេន ធម្មេន សមត្តិ កិញ្ចិ** *សេចក្តីថា ធម្មជាតណាមួយដែលស្មើដោយធម៌ ដែលព្រះសក្យមុនីទ្រង់សម្រេចហើយ មានឈ្មោះថា* **ឱយ** *ជាដើមនោះ មិនមាន ។ ព្រោះហេតុនោះ ក្នុងព្រះសូត្រដទៃ ព្រះមានព្រះភាគក៏ត្រាស់ជាដើមថា*

> *ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មាន ដែលជាសង្ខតធម៌ (ធម៌ដែលមានបច្ច័យប្រជុំតាក់តែង) ក្តី ជាអសង្ខតធម៌ (ធម៌ដែលមិនមានបច្ច័យប្រជុំតាក់តែង) ក្តី វិរាគៈ (ការប្រាសចាកតម្រេក) ដែលជាគ្រឿងញាំញីនូវសេចក្តីស្រវឹង នាំចេញនូវសេចក្តីស្រេកឃ្លាន ដកឡើងនូវសេចក្តីអាល័យ កាត់ផ្តាច់នូវវដ្តៈ អស់តណ្ហា ប្រាសចាកតម្រេក រលត់មិនសេសសល់ មិនមានតណ្ហានេះប្រាកដជាប្រសើរជាងធម៌ទាំងនោះ ។*

ព្រះមានព្រះភាគ កាលត្រាស់ភាពដែលព្រះនិព្វានធម៌ ដែលធម៌ដទៃណាមួយប្រៀបធៀបមិនបានយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីរម្ងាប់ឧបទ្រវដែលកើតដល់សត្វទាំងនោះ ទ្រង់អាស្រ័យភាពដែលរតនៈ គឺនិព្វានធម៌ មិន

មានធម៌ដទៃដូច ដោយគុណទាំងឡាយ គឺភាពជាធម៌ដែលអស់កិលេស ខ្ជាក់ចោលនូវកិលេស ជាអមតធម៌ និងជាបណីតធម៌ ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ ធម្មេ រតនំ បណីតំ ឯតេន សច្ចេន សុវត្ថិ ហោតុ** *រតនៈ គឺ ព្រះធម៌នេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលមកហើយ ក្នុងគាថាដើមនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាព្រមទទួលអាជ្ញានៃព្រះគាថានេះឯង ។*

អធិប្បាយបទថា យម្ពុទ្ធសេដ្ឋោ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ ដោយគុណនៃនិព្វានធម៌យ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្តើមត្រាស់ដោយព្រះគុណនៃមគ្គធម៌ថា **យម្ពុទ្ធសេដ្ឋោ** *ជាដើម ។ ក្នុងពាក្យនោះ ឈ្មោះថា* **ពុទ្ធ** *ដោយន័យជាដើមថា ត្រាស់ដឹងសច្ចៈទាំងឡាយ ។ ឈ្មោះថា* **សេដ្ឋ** *ព្រោះជាបុគ្គលឧត្តម និងគួរសរសើរ ឈ្មោះថា* **ពុទ្ធសេដ្ឋ** *ព្រោះជាអ្នកត្រាស់ដឹង ជាបុគ្គលឧត្តម និងគួរសរសើរ ម្យ៉ាងទៀត ឈ្មោះថា* **ពុទ្ធសេដ្ឋ** *ព្រោះជាបុគ្គលប្រសើរបំផុតក្នុងព្រះពុទ្ធទាំងឡាយ ដែលហៅថា* **អនុពុទ្ធ បច្ចេកពុទ្ធ** *និង* **សុតពុទ្ធ** *។ ព្រះពុទ្ធប្រសើរបំផុតអង្គនោះ ទ្រង់សរសើរ ទ្រង់លើកតម្កើង ប្រកាសសមាធិធម៌ណា ក្នុងបាលីទាំងនោះ ដោយន័យជាដើមថា មគ្គដែលប្រកបដោយអង្គ ៨ ដ៏ក្សេមក្សាន្តជាងមគ្គទាំងឡាយ សម្រាប់ដើរទៅកាន់ព្រះនិព្វាន ឈ្មោះអមតៈ និងដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវ*

សម្មាសមាធិ ដែលឥតទោស ព្រមទាំងបច្ចយ ព្រមទាំងបរិវារ ... ឈ្មោះថា **សុឌ្ឍិ** *បានដល់ ផូរផង់ក្រៃលែង ព្រោះធ្វើនូវការកាត់មន្ទិល គឺកិលេសបាន ជាសមុច្ឆេទ ។ បទថា* **សមាធិមានន្តរិកញ្ញមាហុ** *សេចក្តីថា បណ្ឌិតទាំង-ទ្បាយពោលដល់សមាធិឯណាថា អានន្តរិកសមាធិ គឺសមាធិកើតក្នុងលំដាប់ ព្រោះអោយផលពិតប្រាកដ ក្នុងលំដាប់នៃការបដិបត្តិរបស់ខ្លួន ។ ដរាបណា ហាមបង់នូវការកើតផលនៃអានន្តរិកសមាធិនោះ កាលសមាធិដែលជាតួមគ្គ កើតឡើងហើយ មិនមាន ដូចលោកពោលថា*

> *បុគ្គលនេះ ជាអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវ សោតាបត្តិផល ទុកជាវេលាភ្លើងឆេះកប្បទីងមាន បើ បុគ្គលនេះ មិនទាន់ធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដរាបណា ភ្លើងក៏មិនគប្បីឆេះកប្បដរាបនោះដែរដូច្នេះ ។*

បទថា **សមាធិនា តេន សមោ ន វិជ្ជតិ** *សេចក្តីថា រូបាវចរសមាធិ ឬ អរូបាវចរសមាធិឯណាមួយ ដែលស្មើដោយអានន្តរិកសមាធិដ៏ស្អាត ដែលព្រះ សម្ពុទ្ធដ៏ប្រសើរសរសើរហើយនោះ មិនមានឡើយ ព្រោះហេតុអ្វី ព្រោះសត្វ កើតក្នុងព្រហ្មលោកនោះៗ ព្រោះអប់រំសមាធិទាំងនោះហើយ ក៏នៅមានការ កើតក្នុងអបាយ មាននរកជាដើមទៀតបាន និងព្រោះព្រះអរិយបុគ្គលកាត់នូវ ការកើតគ្រប់យ៉ាងបានជាសមុច្ឆេទ ព្រោះអប់រំសមាធិ ដែលជាតួអរហត្តនេះ ហើយ ព្រោះហេតុនោះ ក្នុងសូត្រដទៃ ព្រះមានព្រះភាគក៏ត្រាស់ថា*

> *ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មាន ដែលជាសង្ខតធម៌*

មគ្គប្រកបដោយអង្គ ៨ ជ័ប្រសើរ គឺការឃើញត្រូវ ១ ។បេ។ តាំងចិត្តមាំត្រូវ ១ នេះ ប្រាកដជាប្រសើរជាងធម៌ទាំងនោះ ។

ព្រះមានព្រះភាគ កាលត្រាស់ភាពដែលអានន្តរិកសមាធិ ដែលសមាធិជាទៃៗ ប្រៀបផ្ទឹមមិនបានដូច្នេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យភាពដែលរតនៈគឺមគ្គធម៌ដែលមិនមានរតនៈដទៃស្មើ ដោយនយមុននោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ ពុទ្ធេ រតនំ បណីតំ ឯតេន សច្ចេន សុវត្ថិ ហោតុ** *រតនៈ គឺព្រះធម៌នេះឯងជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបដោយនយដែលពោលមកអំពីមុនហើយ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានោះឯង ។*

អធិប្បាយបទថា យេ បុគ្គលា

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈដោយគុណនៃមគ្គធម៌យ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្តើមត្រាស់ដោយសង្ឃគុណថា **យេ បុគ្គលា** *ជាដើម ។ ក្នុងពាក្យនោះ សព្ទថា* **យេ** *ជានិទ្ទេសមិនពិតប្រាកដ ។ បទថា* **បុគ្គលា** *បានដល់ សត្វទាំងឡាយ ។ សព្ទថា* **អដ្ឋ** *ជាការកំណត់ចំនួនសត្វទាំងនោះ ។ ពិតហើយ សត្វទាំងនោះមាន ៨ គឺអ្នកបដិបត្តិ (មគ្គ) ៤ និងអ្នកតាំងនៅក្នុងផល ៤ ។ បទថា* **សតំ បសដ្ឋា** *បានដល់ ដែលសប្បុរស គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវក ទេវតា និងមនុស្សជាទៃសរសើរ*

ហើយ ។ ព្រោះហេតុអ្វី ព្រោះប្រកបដោយគុណ មានសីលដែលកើតរួមគ្នា ជាដើម ។ សេចក្តីពិត គុណទាំងឡាយរបស់សប្បុរសទាំងនោះ មានសីល សមាធិជាដើមកើតរួមគ្នា ដូចពណ៌ និងក្លិន ជាដើមដែលកើតរួមគ្នារបស់ផ្កាចម្ប៉ា និងផ្កាពិកុលជាដើម ។ ដោយហេតុនោះ ទើបបុគ្គលទាំងនោះ ជាទីស្រឡាញ់ ជាទីពេញចិត្ត គួរសរសើរ របស់សប្បុរសទាំងឡាយ ដូចផ្កាទាំងឡាយដែលដល់ព្រមដោយពណ៌ និងក្លិនជាដើម ជាទីស្រឡាញ់ពេញចិត្ត គួរសរសើរនៃទេវតា និងមនុស្សទាំងឡាយ ទើបព្រះមានព្រះភាគត្រាស់ថា **យេ បុគ្គលា អដ្ឋ សតំ បសដ្ឋា។**

ម្យ៉ាងទៀត សព្ទថា **យេ** *ជានិទ្ទេសមិនពិតប្រាកដ ។ បទថា* **បុគ្គលា** *បានដល់ សត្វទាំងឡាយ ។ សព្ទថា* **អដ្ឋសតំ** *ជាការកំណត់ចំនួនសត្វទាំងនោះ ។ ពិតហើយ សត្វទាំងនោះ បានដល់ ព្រះសោតាបន្ន ៣ ពួក គឺឯក-ពីជី កោលំកោលៈ និងសត្តក្ខត្តុបរមៈ ព្រះសកទាគាមី ៣ ពួក ដែលសម្រេចផលក្នុងកាមភព រូបភព និងអរូបភព ។ ព្រះសោតាបន្ន និងព្រះសកទាគាមីទាំងនោះ មាន ២៤ ពួក ដោយបដិបទា ៤ ។ ព្រះអនាគាមីក្នុងទេវតាជាន់អវិហាមាន ៥ ពួក គឺអន្តរាបរិនិព្វាយី ឧបហច្চបរិនិព្វាយី សសង្ខារបរិ-និព្វាយី អសង្ខារបរិនិព្វាយី ឧទ្ធំសោតោអកនិដ្ឋគាមី ។ ព្រះអនាគាមីក្នុងទេវតាជាន់អតប្បា សុទស្សា សុទស្សី ក៏មានមួយជាន់ ៥ ពួកដូចគ្នា ។ ឯក្នុងអកនិដ្ឋកភពមាន ៤ រឿងឧទ្ធំសោតោ រួមជាព្រះអនាគាមី ២៤ ពួក ។ ព្រះអរហន្ត មាន ២ ពួក គឺសុក្ខវិបស្សកៈ និងសមថយានិក ។ ព្រះអរិយ-*

បុគ្គលតាំងនៅក្នុងមគ្គ មាន ៤ ពួក រួមជាព្រះអរិយបុគ្គល ៥៤ ពួក ។ ព្រះអរិយបុគ្គលទាំងនោះ គុណនឹងធុរៈ ២ គឺសទ្ធាធុរៈ និងបញ្ញាធុរៈ ជា ១០៨ ពួក ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

បទថា **ចត្តារិ ឋានានិ យុគានិ ហោន្តិ** *សេចក្តីថា បុគ្គលដែលទ្រង់លើកឧទ្ទេសដោយពិស្តារថា ព្រះអរិយបុគ្គលទាំងអស់មាន ៨ ពួកក្តី ១០៨ ពួកក្តី ដោយសង្ខេប បុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គ សោតាបត្តិផល ជា ១ គូយ៉ាងនេះ រហូតដល់ដែលតាំងនៅក្នុងអរហត្តមគ្គ ភិក្ខុដែលតាំងនៅក្នុងអរហត្តផល រួមជា ១ គូ សរុបទាំងអស់ ៤ គូ ។ សព្ទថា* **តេ** *ក្នុងបទថា* **តេ ឧក្កិដ្ឋោយ្យា** *ជាសព្ទនិទ្ទេស អធិប្បាយកំណត់ពិតប្រាកដនូវបទឧទ្ទេសដែលលើកទ្បើងមិនពិតប្រាកដ បុគ្គលដែលព្រះមានព្រះភាគត្រាស់ពិស្តារថា មាន ៨ ពួក ឬ ១០៨ ពួក ដោយសង្ខេបមាន ៤ គូ រមែងគួរដល់ទក្ខិណា ហេតុនោះ ទើបឈ្មោះថា* **ឧក្កិដ្ឋោយ្យ ។** *ទេយ្យធម៌ដែលបុគ្គលជឿកម្ម និងផលនៃកម្ម មិនពិចារណាដល់ថា ភិក្ខុរូបនេះនឹងធ្វើកិច្ចកម្មដែលជាគ្រូពេទ្យ ឬកិច្ចកម្មទទួលបម្រើនេះដល់អញ ដូច្នេះជាដើម ហើយប្រគេន ឈ្មោះថា* **ឧក្កិដ្ឋា ។** *បុគ្គលប្រកបដោយសីលគុណជាដើម និងបុគ្គលទាំងនេះដែលមានសភាពដូច្នោះ ឈ្មោះថា រមែងគួរដល់ទក្ខិណានោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **តេ ឧក្កិដ្ឋោយ្យា ។**

បទថា **សុគតស្ស សាវកា** *សេចក្តីថា ព្រះមានព្រះភាគ ឈ្មោះថា* **សុគត** *ព្រោះប្រកបដោយការយាងទៅល្អ ព្រោះយាងទៅកាន់ទីដែលល្អ ព្រោះ*

យាងទៅដោយល្អ និងព្រោះត្រាស់ល្អ ។ ជាសាវ័ករបស់ព្រះសុគតអង្គនោះ ។ លោកទាំងអស់នោះ ឈ្មោះថា សាវក ព្រោះស្តាប់ព្រះតម្រាស់ ។ បុគ្គលដទៃៗ គប្បីស្តាប់ក៏ពិត តែបុគ្គលនោះស្តាប់ហើយ ក៏មិនធ្វើកិច្ចដែលគួរធ្វើ ។ ឯសាវ័កទាំងនេះ ស្តាប់ហើយ ធ្វើកិច្ចដែលគួរធ្វើ គឺបដិបត្តិធម៌សមគួរដល់ធម៌ សម្រេចមគ្គផល ព្រោះហេតុនោះ ទើបលោកទាំងនេះត្រាស់ថា សាវក ។

បទថា **ឯតេសុ ទិន្នានិ មហាផលានិ** *សេចក្តីថា ទានទាំងឡាយសូម្បីតិចតួច ដែលប្រគេនក្នុងសាវ័ករបស់ព្រះតថាគតទាំងនេះ ឈ្មោះថា មានផលច្រើន ព្រោះជាទានដែលចូលដល់ទក្ខិណាវិសុទ្ធិខាងបដិគ្គាហក ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងសូត្រដទៃថា*

> *ម្នាលភិក្ខុទាំងឡាយ សង្ឃក្តី គណៈក្តី ទាំងប៉ុន្មាន សង្ឃជាសាវ័ក របស់ព្រះតថាគត ដែលចាត់ជាគូនៃបុរសមាន ៤ គូ ចាត់ជាបុរសបុគ្គល (រៀងគ្នា) មាន ៨ នេះប្រាកដជាប្រសើរជាង សង្ឃ និងគណៈទាំងនោះ ។*

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈ ដោយភិក្ខុដែលតាំងនៅក្នុងមគ្គ តាំងនៅក្នុងផលយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥមម្បិ សង្ឃេ រតនំ បណីតំ** *នេះ ក៏ជារតនៈដ៏ប្រណីតក្នុងសង្ឃ អត្តនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដូចពោលមកមុននោះឯង ។ ពួកអមនុស្សក្នុងសែនកោដិ នាំគ្នាទទួលពុទ្ធ-*

អាជ្ញានៃព្រះគាថានេះឯង ។

អធិប្បាយបទថា យេ សុប្បយុត្តា

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ ដោយគុណរបស់សង្ឃរតនៈ ដោយកិក្ខុដែលតាំងនៅក្នុងមគ្គ និងតាំងនៅក្នុងផលយ៉ាងនេះហើយ ឥឡូវនេះ ទើបផ្តើមត្រាស់ដោយគុណរបស់ព្រះខីណាសវបុគ្គលទាំងឡាយ ដែលសោយសុខក្នុងផលសមាបត្តិប៉ុណ្ណោះថា **យេ សុប្បយុត្តា** *ជាដើម ។ ក្នុងពាក្យនោះ ពាក្យថា* **យេ** *ជាពាក្យឧទ្ទេសមិនពិតប្រាកដ ។*

បទថា **សុប្បយុត្តា** *ប្រែថា ប្រកបល្អហើយ អធិប្បាយថា លះអនេសនា គឺការស្វែងរកមិនសមគួរច្រើនយ៉ាង ហើយអាស្រ័យការចិញ្ចឹមជីវិតដោយបរិសុទ្ធ ផ្តើមប្រកបខ្ជួនក្នុងវិបស្សនា ។ ម្យ៉ាងទៀត បទថា* **សុប្បយុត្តា** *បានដល់ ប្រកបដោយកាយបយោគ និងវចីបយោគ ដែលបរិសុទ្ធល្អ ។ ទ្រង់សម្តែងសីលក្ខន្ធរបស់ព្រះខីណាសវបុគ្គលទាំងនោះដោយបទថា* **សុប្បយុត្តា** *នោះ ។ បទថា* **មនសា ឧជ្ជុគេ** *បានដល់ ដោយចិត្តដែលត្រង់ អធិប្បាយថា ដោយចិត្តដែលប្រកបដោយសមាធិដែលមាំទាំ ។ ទ្រង់សម្តែងសមាធិក្ខន្ធនៃខីណាសវបុគ្គលទាំងនោះដោយបទថា* **មនសា ឧជ្ជុគេ** *នោះ ។ បទថា* **និក្កាមិនោ** *បានដល់ ជាអ្នកមិនអាល័យក្នុងកាយ និងជីវិត មានព្យាយាមចេញចាកកិលេសទាំងពួង ដែលបុគ្គលមានបញ្ញា គឺធុរៈធ្ងៃហើយ ដោយសេចក្តីព្យាយាម ។ ទ្រង់សម្តែងបញ្ញាក្ខន្ធដែលប្រកបដោយសេចក្តីព្យាយាមរបស់ព្រះខីណាសវបុគ្គលទាំងនោះ ដោយបទថា* **និក្កាមិនោ**

នោះ ។ បទថា **គោតមសាសនម្ហិ** *បានដល់ ក្នុងសាសនារបស់ព្រះតថាគត ព្រះនាមថាគោតម ដោយគោត្រនោះឯង ។ បទថា* **គោតមសាសនម្ហិ** *នោះ ទ្រង់សម្តែងថា ពួកបុគ្គលក្រៅសាសនានេះ ដែលធ្វើតបៈដើម្បីបានជាទេវតា មានប្រការផ្សេងៗ ក៏មិនមានសេចក្តីព្យាយាមចេញចាកកិលេសទាំងឡាយ ព្រោះមិនមានគុណ មានការប្រកបយ៉ាងល្អជាដើម ។ ពាក្យថា* **តេ** *ជាពាក្យអធិប្បាយឧទ្ទេសដែលតាំងទុកមុន ។ ក្នុងពាក្យថា* **បត្តិបត្តា** *នេះ គុណគួរសម្រេច ហេតុនោះ ទើបឈ្មោះថា* **បត្តិ** ***។*** *នូវបុគ្គលដែលសម្រេចហើយជាបុគ្គលក្សេម ផុតចាកយោគៈដោយឥតសេសសល់ ឈ្មោះថា* **បត្តញ្ញា** *នោះ ។ ពាក្យនេះ ជាឈ្មោះនៃអរហត្តផល ។ បុគ្គលសម្រេចគុណ ដែលគួរសម្រេចនោះ ហេតុនោះ ទើបឈ្មោះថា* **បត្តិបត្តា** ***។*** *បទថា* **អមតំ** *បានដល់ ព្រះនិព្វាន ។ បទថា* **វិគយ្ហ** *បានដល់ ចូលដល់ដោយអារម្មណ៍ ។ បទថា* **លទ្ធា** *ប្រែថា បានហើយ ។ បទថា* **មុធា** *បានដល់ ដោយមិនមានតម្លៃ គឺមិនធ្វើតម្លៃត្រឹមតែមួយកាកណិក ។ បទថា* **ឯកូតិំ** *បានដល់ ផល-សមាបត្តិដែលរម្ងាប់សេចក្តីក្រវល់ក្រវាយដោយអំណាចកិលេសហើយ ។ បទថា* **ភុញ្ជមានា** *បានដល់ សោយ ។ លោកអធិប្បាយដូចម្តេច ។ លោកអធិប្បាយថា ពួកជនណា ក្នុងសាសនា របស់ព្រះគោតមនេះ ឈ្មោះថាប្រកបល្អហើយ ព្រោះដល់ព្រមដោយសីល ឈ្មោះថា មានចិត្តធ្ងន់ ព្រោះដល់ព្រមដោយសមាធិ ឈ្មោះថា មិនមានសេចក្តីអាល័យ ព្រោះដល់ព្រមដោយបញ្ញា ជនទាំងនោះក៏ចូលដល់អមតៈ ដោយសម្មាបដិបត្តិនេះ ជាបុគ្គល*

បានទទេ សោយ នូវការរលត់ ដែលឃើញបានថាជាផលសមាបត្តិ ឈ្មោះថា ជាបុគ្គលសម្រេចគុណដែលគួរសម្រេច ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈ ដោយព្រះខីណាសវបុគ្គលដែលសោយផលសមាបត្តិយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ សង្ឃេ រតនំ បណីតំ** *នេះ ក៏ជារតនៈដ៏ប្រណីតក្នុងសង្ឃ សេចក្តីនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលអំពីមុនហើយ ពួកអមនុស្សក្នុងសែនកោដិចក្រវាលក៏នាំគ្នាព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។*

អធិប្បាយបទថា យថិន្ទខីលោ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំង ដោយខីណាសវបុគ្គលយ៉ាងនេះហើយ ទ្រង់ផ្តើមត្រាស់ដោយគុណនៃព្រះសោតាបន្នបុ៉ណ្ណោះថា **យថិន្ទខីលោ** *ជាដើម ។ ក្នុងពាក្យនោះ បទថា* **យថា** *ជាពាក្យឧបមា ។ ពាក្យថា* **ឥន្ទខីលោ** *នេះ ជាឈ្មោះរបស់សសរខ្ឿម ដែលគេបោះចូលដី ៨ ហត្ថ ឬ ១០ ហត្ថ ខាងក្នុងធរណីទ្វារ ដើម្បីការពារទ្វារព្រះនគរ ។ បទថា* **បថវី** *ប្រែថា ផែនដី ។ បទថា* **សិតោ** *បានដល់ចូលទៅអាស្រ័យខាងក្នុង ។ បទថា* **សិយា** *ប្រែថា គប្បីកើត ។ បទថា* **ចតុព្ភិ វាតេហិ** *ប្រែថា ដែលខ្យល់បក់មកអំពីទិសទាំង ៤ ។ បទថា* **អសម្បកម្បិយោ** *បានដល់ មិនអាចឲ្យញាប់ញ័រ គឺមិនអាចឲ្យកម្រើកបាន ។ បទថា* **តជ្ជបមំ** *ប្រែថា ដូច្នោះ ដូចគ្នា ។ បទថា* **សប្បុរិសំ** *បានដល់*

បុរសឧត្តម ។ បទថា **វទាមិ** *ប្រែថា ពោល ។ បទថា* **យោ អរិយសច្ចានិ អវេច្ច បស្សតិ** *ប្រែថា បុគ្គលណាពិចារណាឃើញអរិយសច្ច ៤ ដោយបញ្ញា ។ ក្នុងសេចក្តីនោះ អរិយសច្ចទាំងឡាយ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងកុមារប្បញ្ហា និងគម្ពីរវិសុទ្ធិមគ្គនោះឯង ។*

ឯសេចក្តីសង្ខេបក្នុងសេចក្តីនេះ មានដូច្នេះ ដូចសសរខឿន ដែលលិចចូលទៅក្នុងដីដ៏ជ្រៅ ខ្សាច់បក់មកអំពីទិសទាំង ៤ គប្បីឲ្យញាប់ញ័រមិនបានយ៉ាងណា សប្បុរសណា ឃើញអរិយសច្ច តថាគតពោលសប្បុរសនេះឧបមាដូច្នោះដូចគ្នា ព្រោះហេតុអ្វី ព្រោះសប្បុរសនោះ ជាបុគ្គលដែលខ្សាច់គឺវាទៈរបស់តិរ្ថិយទាំងពួងធ្វើឲ្យកម្រើកមិនបាន គឺបុគ្គលណាក៏មិនអាចឲ្យកម្រើក ឬឃ្លាតចាកទស្សនៈនោះបាន ដូចសសរខឿនដែលខ្សាច់បក់មកអំពីទិសទាំង ៤ ធ្វើឲ្យញាប់ញ័រមិនបាន ដូច្នោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងសូត្រដទៃថា

> *ម្នាលភិក្ខុទាំងឡាយ ដូចសសរដែកក្តី សសរគោលក្តី ដែលមានរណ្តៅដ៏ជ្រៅ គេជាំស៊ប់សួនល្អឥតមានកម្រើក ឥតមានញាប់ញ័រ បើទុកជាភ្លៀងលាយដោយខ្សាច់ដ៏ខ្លាំងមកអំពីទិសខាងកើត ក៏មិនធ្វើសសរនោះឲ្យកម្រើក មិនធ្វើឲ្យរញ្ជួយ មិនធ្វើឲ្យញាប់ញ័រ បើទុកជាខ្សាច់បក់មកអំពីទិសខាងលិចក្តី ។បេ។ អំពីខាងជើងក្តី ភ្លៀងដែលលាយដោយខ្សាច់ដ៏ខ្លាំងមកអំពីទិសខាងត្បូងក្តី ក៏មិនធ្វើ*

ឲ្យសសរនោះ កម្រើករញ្ជួយញាប់ញ័រឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះរណ្តៅជ្រៅ ព្រោះសសរគេជាំស៊ប់សួនល្អ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ឯណានីមួយ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរម្ងាប់ទុក្ខ សមណៈ ឬព្រាហ្មណ៍ទាំងនោះ មិនក្រេឡែកមើលមុខសមណៈ ឬព្រាហ្មណ៍ដទៃថា លោកដ៏ចម្រើននេះ កាលបើដឹង ក៏ដឹងដោយពិត កាលបើឃើញ ក៏ឃើញដោយពិត ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបានឃើញនូវអរិយសច្ច ៤ ដោយប្រពៃ ។

ព្រះមានព្រះភាគ កាលត្រាស់គុណនៃសង្ឃរតនៈ ដោយអំណាចព្រះសោតាបន្នដែលប្រចក្សដល់មនុស្សជាច្រើនយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥធម្បិ សង្ឃេ រតនំ បណីតំ** *នេះ ក៏ជារតនៈដ៏ប្រណីតក្នុងសង្ឃ ។ អត្ថនៃសច្ចវចនៈនោះគប្បីជ្រាបតាមន័យដែលពោលមកមុនហើយនោះឯង ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។*

អធិប្បាយបទថា យេ អរិយសង្ឃានិ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ ដែលមានសង្ឃរតនៈជាទីតាំង ដោយគុណរបស់ព្រះសោតាបន្ន ដោយមិនប្លែកគ្នាយ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្តើមត្រាស់ថា **យេ អរិយសង្ឃានិ** ជាដើម ដោយគុណរបស់ព្រះ-សោតាបន្នសត្តក្ខត្តុបរមៈ និងចូឡសោតាបន្នទាំងអស់ បណ្តាព្រះសោតាបន្ន ៣ ប្រភេទ គឺឯកពីជី កោលំកោលៈ សត្តក្ខត្តុបរមៈ ដូចព្រះតម្រាស់ថា

> បុគ្គលខ្លះ ក្នុងលោកនេះ ដល់នូវសោតៈ ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹង ប្រព្រឹត្តទៅខាងមុខ បុគ្គលនោះ កើតក្នុងភព ជារបស់មនុស្សតែម្តងទៀត ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះហៅថា បុគ្គលជាឯកពីជី ។
>
> បុគ្គលខ្លះ ក្នុងលោកនេះ ដល់នូវសោតៈ ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹង ប្រព្រឹត្តទៅខាងមុខ បុគ្គលនោះ សុះទៅ អន្ទោលទៅកាន់ត្រកូល ២ ឬ ៣ ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះហៅថា បុគ្គលជាកោលំកោល ។
>
> បុគ្គលខ្លះ ក្នុងលោកនេះ ដល់នូវសោតៈ ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹង ប្រព្រឹត្តទៅខាងមុខ បុគ្គលនោះ សុះទៅ អន្ទោលទៅក្នុង ទេវតា និងមនុស្សអស់វារៈ

៧ ជង ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះហៅថា បុគ្គល ជាសត្តក្ខត្តុបរមៈ[1] ។

ក្នុងពាក្យនោះ ពាក្យថា **យេ អរិយសច្ចានិ** *នេះ មានន័យដូចពោលមកហើយនោះឯង ។ បទថា* **វិភាវយន្តិ** *បានដល់ កម្ចាត់ងងឹត គឺកិលេសដែលបិទបាំងសច្ចៈហើយ ធ្វើឲ្យជាក់ច្បាស់ប្រាកដដល់ខ្លួនដោយពន្លឺនៃបញ្ញា ។ បទថា* **គម្ភីរបញ្ញេន** *បានដល់ ដែលព្រះមានព្រះភាគអ្នកមានបញ្ញា មានកម្លាំង ដែលបុគ្គលណាម្នាក់ មិនបានដោយញាណនៃលោកនេះ មួយអន្ទើដោយទេវលោក ដោយព្រះបញ្ញាមិនមានប្រមាណ លោកអធិប្បាយថា បុគ្គលដែលជាសព្វញ្ញូ ។*

បទថា **សុទេសិតានិ** *បានដល់ ទ្រង់សម្តែងដោយល្អ ដោយន័យនោះៗ មានសមាសន័យ អព្យាសន័យ សាកល្យន័យ វេកល្យន័យជាដើម ។ បទថា* **កិញ្ចាបិ តេ ហោន្តិ ភុសប្បមត្តា** *សេចក្តីថា បុគ្គលទាំងឡាយ ដែលអប់រំអរិយសច្ចហើយយ៉ាងនោះ អាស្រ័យហានៈនៃសេចក្តីប្រមាទ មានភាពជាទេវរាជ និងភាពជាស្តេចចក្រពត្តិជាដើម ជាអ្នកប្រមាទពេញបន្ទុកក៏ពិត តែនាមរូបណាគប្បីតាំងនៅ ព្រោះវិញ្ញាណដែលសោតាបត្តិមគ្គញ្ញាណតាក់តែងរលត់ទៅ ហើយកើតក្នុងសង្ឃារវដ្តដែលមិនមានទីបំផុតខាងដើម កើតតែ ៧ ភព ក៏មិនកាន់យកភពទី ៨ ព្រោះនាមរូបនោះរលត់ទៅ ព្រោះតាំងនៅមិនបាន*

១- បិដកខ្មែរ លោកសម្តែងសត្តក្ខត្តុបរមបុគ្គលនេះមុនហើយ ទើបសម្តែងកោលំកោល-បុគ្គល និងឯកពីជីបុគ្គលឯក្រោយ ។

តែក្នុងកពទី ៧ នោះឯង ក៏ទីងផ្តើមវិបស្សនា ហើយសម្រេចអរហត្ត ។

ព្រះមានព្រះភាគ កាលត្រាស់គុណសង្ឃរតន: ដោយព្រះសោតាបន្ន ដែលជាសត្តក្ខត្តុបរម:យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចន:ថា **ឥធម្បិ សង្ឃេ រតនំ បណីតំ** *នេះ ក៏ជារតន: ដ៏ប្រណីតក្នុងព្រះសង្ឃ អត្តនៃសច្ចវចន:នោះ គប្បីជ្រាបតាមន័យដែលពោលមកអំពីមុនហើយនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលព្រះពុទ្ធអាជ្ញានៃគាថានេះឯង ។*

អធិប្បាយ បទថា សហាវស្ស

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចន: មានសង្ឃរតន:ជាទីតាំង ដោយគុណ គឺការមិនកាន់យកកពទី ៨ របស់ព្រះសោតាបន្នសត្តក្ខត្តុបរមយ៉ាងនេះហើយ ឥឡូវនេះ ទីងផ្តើមត្រាស់ថា **សហាវស្ស** *ជាដើម ដោយគុណរបស់ព្រះសោតាបន្នសត្តក្ខត្តុបរម:នោះឯង សូម្បីដល់ ៧ កពដែលប្លែកពីបុគ្គលដទៃៗ ដែលមិនទាន់លះការកាន់យកកពបាន ។ ក្នុងពាក្យនោះ បទថា* **សហាវ** *ប្រែថា ព្រមជាមួយ ។ បទថា* **អស្ស** *បានដល់ បណ្តាព្រះសោតាបន្នដែលត្រាស់ថា ព្រះសោតាបន្នទាំងនោះ មិនកាន់យកកពទី ៨ កពណាមួយ ។ បទថា* **ទស្សនសម្បទាយ** *បានដល់ ដោយការដល់ព្រមនៃសោតាបត្តិមគ្គ ។ ពិតហើយ សោតាបត្តិមគ្គ ឃើញព្រះនិព្វានហើយ ទើបលោកហៅថា ទស្សន: ព្រោះឃើញព្រះនិព្វានមុនធម៌ទាំងពួង ដោយការដល់ព្រមនៃកិច្ចដែលគួរធ្វើ ។ ការប្រាកដនៃសោតាបត្តិមគ្គនោះក្នុងខ្លួន ឈ្មោះថា* **ទស្សនសម្បទា។** *មួយ*

អន្ទើដោយទស្សនសម្បទានោះឯង ។ សព្ទថា **សុ** *ក្នុងពាក្យថា* **តយស្សុ ធម្មា ៨ហិតា ភវន្តិ** *នេះ ជានិបាត ចុះក្នុងអត្ថថា គ្រាន់តែធ្វើបទឲ្យពេញ ដូចក្នុងប្រយោគជាដើមថា* **៨ំ សុ មេ សារិបុត្ត មហាវិកដភោ៨នស្មឹ ហោតិ** *ម្នាលសារីបុត្ត នេះឯងជាវត្តខាងកោជនយ៉ាងចម្លែកធំរបស់តថាគត ។ ក្នុងសេចក្តីនេះ មានអត្ថយ៉ាងនេះថា ព្រោះធម្មតាសំយោជន: ៣ ខាងក្រោម ឈ្មោះថា ព្រះសោតាបន្ន លះបានហើយ ឈ្មោះថា លះហើយ មួយអន្ទើ ដោយទស្សនសម្បទារបស់ព្រះសោតាបន្ននោះ ។*

ឥឡូវនេះ ដើម្បីទ្រង់សម្តែងធម៌ដែលព្រះសោតាបន្នលះបានហើយ ទើបត្រាស់ថា **សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច សីលព្វតំ វាបិ យ៨ន្តិ កេ៨ិ** *ក្នុងធម៌ ៣ យ៉ាងនោះ កាលកាយនៅមានទិដ្ឋិ មានវត្ថុ ២០ ក្នុងកាយដែលហៅថា ឧបាទានក្ខន្ធ ៥ ដែលមានឈ្មោះថា សក្កាយទិដ្ឋិ ឬថា កាលកាយនៅមានទិដ្ឋិ គឺការឃើញក្នុងកាយនោះ (ក៏មាន) ព្រោះហេតុនោះ ឈ្មោះថា សក្កាយទិដ្ឋិ អធិប្បាយថា ទិដ្ឋិដែលមាននៅក្នុងកាយ តាមដែលពោលមកហើយ ឬទិដ្ឋិ ការឃើញក្នុងកាយដែលមាននោះឯង ព្រោះហេតុនោះ ឈ្មោះថា សក្កាយទិដ្ឋិ អធិប្បាយថា ទិដ្ឋិក្នុងកាយតាមដែលពោលមកហើយ ដែលប្រព្រឹត្តទៅយ៉ាងនេះថា* **អត្តា** *ពោល គឺរូបជាដើម ។ ទិដ្ឋិទាំងពួងនោះ ឈ្មោះថា ព្រះសោតាបន្នលះទាំងអស់ហើយ ព្រោះលះសក្កាយទិដ្ឋិនោះបានហើយ ដ្បិតថា សក្កាយទិដ្ឋិនោះជាមូលរបស់ធម៌ គឺកិលេសទាំងនោះ បណ្ឌិតហៅថា* **វិចិកិច្ឆិត** *ព្រោះរម្ងាប់ព្យាធិ គឺកិលេសទាំងពួង ។* **បញ្ញា-**

ចិកិច្ឆិត *គឺបញ្ជោះស្រាយនោះទៅជ្រាសហើយចាកវត្ថុនេះ ឬវត្ថុនេះទៅជ្រាសហើយចាកបញ្ជាចិកិច្ឆិតនោះ ហេតុនោះ ទើបឈ្មោះថា* **វិចិកិច្ឆិត** ។ *ពាក្យនេះ ជាឈ្មោះនៃសេចក្តីសង្ស័យដែលមានវត្ថុ ៨ ដែលត្រាស់ដោយនយជាដើមថា សង្ស័យក្នុងព្រះសាស្តា ។ ការសង្ស័យទាំងអស់ ឈ្មោះថា លះបានហើយ ព្រោះលះវិចិកិច្ឆានោះបានហើយ ។ ពិតហើយ ការសង្ស័យនោះជាមូលនៃកិលេសទាំងនោះ ។ សីលផ្សេងៗ មានគោសីល កុក្កុរសីល និងវត្ត មានគោវត្ត និងកុក្កុរវត្តជាដើម ដែលមកក្នុងបាលីបទេសជាដើមយ៉ាងនេះថា សមណព្រាហ្មណ៍ខាងក្រៅព្រះសាសនានេះ ប្រកាន់នូវការបរិសុទ្ធដោយសីល បរិសុទ្ធដោយវត្ត ហៅថា* **សីលវត្ត** ។ *តបៈដើម្បីបានជាទេវតា មានការអាក្រាតកាយ មានក្បាលត្រងោលជាដើមគ្រប់យ៉ាង ក៏ឈ្មោះថា លះបានហើយ ព្រោះលះសីលវត្តនោះ ។ ពិតហើយ សីលវត្តនោះ ជាមូលរបស់តបៈនោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ខាងចុងគាថាទាំងអស់ថា* **យទត្ថិ កិញ្ចិ** *ដែលប្រែថា ឯណាមួយមាន ។ គប្បីជ្រាបថា បណ្តាសំយោជនៈខាងក្រោម ៣ នោះ សក្កាយទិដ្ឋិ លះបានក៏ដោយការដល់ព្រមដោយការឃើញទុក្ខ វិចិកិច្ឆា លះបានដោយការដល់ព្រមនៃការឃើញសមុទយៈ សីលព្វត លះបានដោយការដល់ព្រមនៃការឃើញមគ្គ និងការឃើញព្រះនិព្វាន ។*

អធិប្បាយបទថា ចតូហាបាយេហិ

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការលះកិលេសវដ្តរបស់ព្រះសោតា-

បន្ទនោះយ៉ាងនេះហើយ ឥឡូវនេះ កាលកិលេសវដ្តនោះមាន វិបាកវដ្តណា គប្បីមាន កាលទ្រង់សម្តែងការលះវិបាកវដ្តនោះ ព្រោះលះកិលេសវដ្តនោះបាន ទើបត្រាស់ថា **ចតូហាបាយេហិ ច វិប្បមុត្តោ** *ក្នុងពាក្យនោះ ឈ្មោះថាអបាយ មាន ៤ គឺនិរយៈ តិរច្ឆាន បិត្តិវិស័យ និងអសុរកាយ អធិប្បាយថា ព្រះសោតាបន្ននោះ សូម្បីសល់ ៧ ភព ក៏ផុតចាកអបាយទាំង ៤ នោះ ។*

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការលះវិបាកវដ្តរបស់ព្រះសោតាបន្ននោះយ៉ាងនេះហើយ ឥឡូវនេះ កម្មវដ្តណា ជាឫសគល់នៃវិបាកវដ្តនោះ កាលទ្រង់សម្តែងការលះកម្មវដ្តនោះ ទើបត្រាស់ថា **ឆ ឋានានិ អភព្វោ កាតុំ** *និងមិនគួរធ្វើអកិដ្ឋាន ៦ ។ ក្នុងពាក្យនោះ បទថា* **អភិឋានានិ** *បានដល់ហានៈដែលគ្រោតគ្រាត ។ ព្រះសោតាបន្ននោះ មិនគួរធ្វើអកិដ្ឋាននោះ ។ អកិដ្ឋានទាំងនោះ គប្បីជ្រាបថា ជាកម្ម គឺមាតុឃាត បិតុឃាត អរហន្តឃាត លោហិតុប្បាទ សង្ឃភេទ និងអញ្ញសត្ថារុទ្ទេស គឺរាប់អានសាស្តាដទៃ មានចូលតិរ្ថិយជាដើម ដែលព្រះមានព្រះភាគត្រាស់នៅក្នុងឯកនិបាត អង្គុត្តរ-និកាយ ដោយនយជាដើមថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គប្បីផ្តាច់បង់ជីវិតមាតា ដោយហេតុឯណា ហេតុនោះ មិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ ។ ពិតហើយ អរិយសាវ័កដែលដល់ព្រមដោយទិដ្ឋិ មិនគប្បីផ្តាច់ជីវិតសូម្បីតែស្រមោចខ្មៅ ស្រមោចក្រហមក៏ពិតតែអកិដ្ឋាន ៦ នោះ ព្រះមានព្រះភាគត្រាស់ ក៏ដើម្បីតិះដៀលភាវៈនៃបុថុជ្ជន ។ ពិតហើយ បុថុជ្ជនរមែងធ្វើអកិដ្ឋានដែលមានទោសច្រើនយ៉ាងនេះបាន ក៏ព្រោះ*

មិនដល់ព្រមដោយទិដ្ឋិ ឯព្រះសោតាបន្ន ដែលដល់ព្រមដោយទិដ្ឋិ មិនគួរធ្វើអកិជ្ជានទាំងនោះ ។ ឯការប្រើ **អភព្វ** *សព្ទ ក្នុងទីនេះ ក៏ដើម្បីសម្តែងថា ព្រះសោតាបន្នមិនធ្វើសូម្បីក្នុងភពជទៃ ។ សេចក្តីពិត ក្នុងភពជទៃ ព្រះសោតាបន្នសូម្បីមិនដឹងថា ខ្លួនជាអរិយសាវក ដោយធម្មតានោះ ក៏មិនធ្វើបាប ៦ យ៉ាងនោះ ឬធ្វើពៀរ ៥ មានបាណាតិបាតជាដើម ឬដល់នូវហាន: ៦ មួយ អន្ទើដោយការរាប់អានសាសនាជទៃ ដែលអាចារ្យពួកខ្លះសំដៅដល់ ហើយពោលថា* **ឆ ចាភិឋានានិ** *ដូច្នេះក៏មាន ព្រះអរិយសាវក និងក្មេងអ្នកស្រុកដែលចាប់ត្រីជាដើម ក៏ជាឧបមាក្នុងសេចក្តីនេះ ។*

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់អរិយសាវកដែលនៅមានភព ៧ ដែលជាសង្ឃរតន: ដោយគុណប្លែកពីបុគ្គលជទៃៗ ដែលលះការកាន់យកនូវភពមិនទាន់បាន យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចន:ថា **ឥមម្ហិ សង្ឃេ រតនំ បណីតំ** *នេះ ក៏ជារតន: ដ៏ប្រណីតក្នុងសង្ឃនោះ ។ អត្ថនៃសច្ចវចន:នោះ គប្បីជ្រាបដោយន័យដែលពោលមកអំពីមុនហើយនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។*

អធិប្បាយ បទថា កិញ្ចាបិ សោ

ព្រះមានព្រះភាគ កាលទ្រង់ត្រាស់សច្ចវចន: មានសង្ឃរតន:ជាដើមជាទីតាំង ដោយប្លែកពីបុគ្គលជទៃ ដែលមិនទាន់លះការកាន់យកភពបាននៃព្រះសោតាបន្ន សូម្បីសល់ ៧ ភព យ៉ាងនេះហើយ ឥឡូវនេះ ព្រះសោតា-

បន្ទដែលដល់ព្រមដោយទស្សនៈ មិនមែនមិនគួរធ្វើអភិដ្ឋាន ៦ យ៉ាងប៉ុណ្ណោះ ទេ សូម្បីបាបកម្មតិចតួចណាមួយ ក៏មិនគួរធ្វើដែរ ហើយបិទបាំងបាបកម្មនោះ ដូច្នោះ ទើបទ្រង់ផ្តើមត្រាស់ដោយគុណា គឺព្រះសោតាបន្នដែលដល់ព្រមដោយទស្សនៈ សូម្បីនៅដោយសេចក្តីប្រមាទ ក៏មិនមានការបិទបាំងកម្មដែលធ្វើមកហើយថា **កិញ្ចាបិ សោ កម្មំ ករោតិ ចាបកំ** *ប្រសិនបើសោតាបន្នបុគ្គលនោះ ធ្វើបាបកម្ម ... ដូច្នេះ ។*

ព្រះតម្រាស់នោះ មានអត្ថដូច្នេះ សូម្បីព្រះសោតាបន្ននោះដល់ព្រមដោយទស្សនៈ អាស្រ័យការនៅដោយសេចក្តីប្រមាទ មិនមានស្មារតី រៀរសិក្ខាបទដែលជាលោកវជ្ជ ដែលព្រះមានព្រះភាគ ទ្រង់សំដៅដល់ការតាំងចិត្តកន្ទងល្មើស ត្រាស់ថា សិក្ខាបទណា តថាគតបញ្ញត្តដល់សាវកទាំងឡាយ សាវកទាំងឡាយ រមែងមិនកន្ទងល្មើសសិក្ខាបទនោះរបស់តថាគត ព្រោះហេតុនៃជីវិត ដូច្នេះ រមែងធ្វើបាបកម្មដទៃ ផ្សេងកាយ ដែលព្រះពុទ្ធទ្រង់រង្កៀស ពោលគឺការកន្ទងល្មើសសិក្ខាបទដែលជាបណ្តាត្តិវជ្ជ មានកុដិការសិក្ខាបទ និងសហសេយ្យសិក្ខាបទជាដើមក្តី ធ្វើបាបកម្មផ្សេងៗថា មានបង្រៀនធម៌ដល់អនុបសម្បន្នដែលពោលព្រមគ្នាក្តី សម្តែងធម៌ដល់មាតុគ្រាមលើស ៥-៦ ម៉ាត់ក្តី ការពោលវាយមាយក្តី ពោលពាក្យគ្រោតគ្រាតជាដើមក្តី ឬធ្វើបាបកម្មផ្សេងចិត្ត មិនថា ក្នុងទីណា គឺការធ្វើឲ្យកើត លោភៈ ទោសៈ ការត្រេកអរក្នុងមាសជាដើម ការមិនពិចារណាក្នុងការបរិភោគចីវរជាដើមក្តី ព្រះសោតាបន្ននោះ ក៏មិនបិទបាំងបាបកម្មនោះ គឺព្រះសោតាបន្ននោះដឹងថា កម្មនេះមិន

សមគួរ មិនគួរធ្វើ មិនបិទបាំងបាបកម្មនោះសូម្បីតែមួយភ្លែត ក្នុងរំពេចនោះ ឯង ក៏ធ្វើឲ្យជាក់ច្បាស់ គឺបើកផ្សារក្នុងព្រះសាស្តា ឬក្នុងសព្រហ្មចារីដែលជាវិញ្ញូជន ហើយសម្តែងតាមធម៌ ឬវាំងប្រយ័ត្នក្នុងសិក្ខាបទដែលគួរសង្រួមយ៉ាងនេះថា ខ្ញុំនឹងមិនធ្វើទៀតឡើយ ។ ព្រោះហេតុអ្វី ព្រោះថា ព្រះមានព្រះភាគ ត្រាស់ដល់ភាពដែលព្រះសោតាបន្នដែលឃើញបទ គឺព្រះនិព្វាន ហើយ មិនគួរបិទបាំងបាបកម្ម អធិប្បាយថា ព្រះមានព្រះភាគត្រាស់ដល់ភាពដែលបុគ្គលអ្នកឃើញបទ គឺព្រះនិព្វាន ដែលដល់ព្រមដោយទស្សនៈដែលមិនគួរធ្វើបាបកម្មបែបនោះ ហើយបិទបាំងនូវបាបកម្មនោះ សេចក្តីនេះ ទ្រង់ត្រាស់ដូចម្តេច ទ្រង់ត្រាស់ថា

> ម្នាលភិក្ខុទាំងឡាយ ដូចជាកុមារក្មេង ជាកូនខ្ចីនៅដេកផ្ងារនៅឡើយ ប៉ះពាល់រងើកភ្លើងដោយដៃក្តី ដោយជើងក្តី ក៏ដកមកវិញជាប្រញាប់ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ធម្មតារបស់បុគ្គល ដែលប្រកបដោយទិដ្ឋិ គឺការចេញចាកអាបត្តិមានសភាពយ៉ាងណា ភិក្ខុក៏គង់ត្រូវអាបត្តិមានសភាពយ៉ាងនោះខ្លះដែរ តែថា ភិក្ខុនោះសម្តែង បើក ធ្វើឲ្យច្បាស់ឡើង នូវអាបត្តិនោះ ក្នុងសម្ងាក់សាស្តា ឬក្នុងពួកសព្រហ្មចារីបុគ្គល ជាអ្នកប្រាជ្ញដោយឆាប់រហ័ស លុះសម្តែង បើក ធ្វើឲ្យច្បាស់ឡើងហើយ ក៏ដល់នូវកិរិយាសង្រួមតទៅ យ៉ាងនោះដែរ ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈ ដោយគុណរបស់ព្រះសោតាបន្ន សូម្បីនៅដោយសេចក្តីប្រមាទ តែក៏ជាប់ព្រមដោយទស្សនៈមិនមានការបិទបាំងបាបកម្ម ដែលធ្វើហើយយ៉ាងនេះ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥធម្បិ សង្ឃេ រតនំ បណីតំ** *ដូច្នេះ ក៏ជារតនៈដ៏ប្រណីតក្នុងសង្ឃ ។ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមនัยដែលពោលមកអំពីមុនហើយនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាលក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។*

អធិប្បាយបទថា វនប្បគុម្ពេ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំងដោយប្រការនៃគុណទាំងនោះរបស់បុគ្គលទាំងឡាយ ទាក់ទងក្នុងព្រះសង្ឃយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យព្រះបរិយត្តិធម៌ ដែលព្រះមានព្រះភាគកាលទ្រង់សម្តែងគុណព្រះរតនត្រ័យ ដែលទ្រង់សម្តែងយ៉ាងសង្ខេបក្នុងទីនេះ និងទ្រង់សម្តែងពិស្តារក្នុងទីដទៃ ទើបទ្រង់ផ្តើមត្រាស់សច្ចវចនៈ មានព្រះពុទ្ធ-វចនៈជាទីតាំងទៀតថា **វនប្បគុម្ពេ យថា ផុស្សិតគ្គេ** *ក្នុងសច្ចវចនៈនោះ ក្រុមដើមឈើដែលកំណត់ទីតាំងនៅប្រចាំជិតៗ គ្នា ឈ្មោះថា* **វនៈ** *។ គុម្ពឈើដែលរីកចម្រើនដោយឫស ខ្លឹម ក្រមរ មែក និងស្លឹក ឈ្មោះថា* **បគុម្ពៈ** *។ គុម្ពឈើដែលរីកចម្រើនរបស់ព្រៃ ឬក្នុងព្រៃ ឈ្មោះថា* **វនប្បគុម្ពោ** *។ គុម្ពឈើដែលដុះដាលក្នុងព្រៃនោះ លោកហៅថា* **វនប្បគុម្ពេ** *កាលបើដូច្នោះ ក៏ហៅបានថា* **វនសណ្ឌ** *ប្រែថា ជង្ហឹព្រៃ ដូចក្នុងប្រយោគជាដើមថា* **អត្តិ សរិតក្ក**

សវិចារេ អត្ថិ អវិតក្កវិចារមត្តេ សុខេ ទុក្ខេ ជីវេ *ប្រកបដោយវិតក្កក៏មាន ប្រកបដោយវិចារៈក៏មាន មិនមានវិតក្ក មានវិចារៈក៏មាន សុខ ទុក្ខ ជីវៈដូច្នេះ ។ ពាក្យថា* **យថា** *ជាពាក្យឧបមា ។ ត្រួយរបស់គុម្ពឈើនោះ ត្រសុំត្រសាយហើយ ហេតុនោះ ទើបគុម្ពឈើនោះ ឈ្មោះថា មានត្រួយរីកហើយ ។ អធិប្បាយថា ផ្កាដែលកើតឯង ត្រង់មែកធំ-តូច ។ ផ្កានោះ លោកពោលថា មានត្រួយរីកហើយ តាមន័យដែលពោលមកអំពីមុនហើយនោះឯង ។ បទថា* **គិម្ហានមាសេ បឋមស្មឹ គិម្ហេ** *សេចក្តីថា ក្នុងខែ ១ នៃខែក្នុងគិម្ហរដូវ ៤ ខែ បើសួរថា ក្នុងខែណា ឆ្លើយថា ក្នុងខែខាងដើមនៃគិម្ហន្តរដូវ អធិប្បាយថា ក្នុងខែចេត្រ ។ ពិតហើយ ចិត្ត មាសានោះ លោកហៅថា ដើមគិម្ហន្តរដូវ និងហៅថា* **ពាលវសន្តានោ** *គឺវសន្តានរដូវយ៉ាងទន់ ។ ពាក្យក្រៅអំពីនោះ ប្រាកដច្បាស់ដោយអត្ថនៃបទហើយនោះឯង ។*

ឯការសរុបសេចក្តីក្នុងទីនេះ មានដូច្នេះថា គុម្ពឈើដែលដុះដាល លូតលាស់ ហៅថា គុម្ពឈើជំទង់ ត្រួយ មែក មានផ្ការីកស្គុសស្គាយ រមែងស្រស់ត្រកាលពន់ពេក ក្នុងព្រៃដែលក្រាស់ដោយដើមឈើច្រើនប្រភេទ ក្នុងពាល-វសន្តាន ដែលឈ្មោះថា ខែខាងដើមនៃគិម្ហរដូវ យ៉ាងណា ព្រះមានព្រះភាគទ្រង់មិនមែនសម្តែងព្រោះឃើញដល់លាភ មិនមែនទ្រង់សម្តែងព្រោះឃើញដល់សក្ការៈជាដើមឡើយ តែបើមានព្រះហឫទ័យដែលព្រះមហាករុណា ឲ្យទ្រង់មានឧស្សាហ៍តែម្យ៉ាង ទ្រង់បានសម្តែងព្រះបរិយត្តិធម៌ដ៏ប្រសើរ ដែលឈ្មោះថា មានឧបមាយ៉ាងនោះ ព្រោះស្រស់ត្រកាលក្រៃលែងដោយផ្កា គឺ

ប្រភេទនៃអត្តប្រើនប្រការ មានខន្ធ អាយតនៈជាដើមក៏មាន មានសតិប្បដ្ឋាន និងសម្មប្បធានជាដើមក៏មាន មានសីលក្ខន្ធ សមាធិក្ខន្ធជាដើមក៏មាន ឈ្មោះថា ឲ្យដល់នូវព្រះនិព្វាន ព្រោះសម្តែងមគ្គដែលឲ្យដល់ព្រះនិព្វាន ដើម្បីជាប្រយោជន៍ក្រៃលែងដល់សត្វទាំងឡាយដូច្នោះដូចគ្នា ។ ឯក្នុងពាក្យថា **បរមំ ហិតាយ** *លោកចុះនិគ្គហិតដើម្បីងាយស្រួលដល់ការចងគាថា ។ ឯអត្តមានដូច្នេះថា ទ្រង់បានសម្តែងដើម្បីជាប្រយោជន៍ក្រៃលែង គឺដើម្បីព្រះនិព្វាន ។*

ព្រះមានព្រះភាគ កាលត្រាស់ព្រះបរិយត្តិធម៌ ដែលដូចគុម្ពឈើដ៏ស្រស់ស្អាតក្នុងព្រៃ មានត្រួយ មែក ផ្កាវិកស្គុសស្គាយយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យព្រះបរិយត្តិធម៌នេះឯង ទើបទ្រង់ប្រកបសច្ចវចនៈ ដែលមានពុទ្ធវតនៈជាទីតាំងថា **ឥធម្បិ ពុទ្ធេ រតនំ បណីតំ** *នេះ ក៏ជាវតនៈដ៏ប្រសើរក្នុងព្រះសម្ពុទ្ធ ។ អត្តនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលអំពីមុនហើយនោះឯង ។ តែគប្បីប្រកបអត្តតែម្យ៉ាងយ៉ាងនេះថា គុណជាត ពោលគឺព្រះបរិយត្តិធម៌ មានប្រការតាមដែលពោលមកហើយនេះ ក៏ជាវតនៈដ៏ប្រណីតក្នុងព្រះសម្មាសម្ពុទ្ធ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលព្រះពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។*

អធិប្បាយបទថា វរោ វរញ្ញូ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ ដែលមានព្រះពុទ្ធវតនៈជាទីតាំងដោយបរិយត្តិធម៌យ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្តើមត្រាស់ដោយលោកុត្តរធម៌ថា **វរោ វរញ្ញូ** *។ ក្នុងពាក្យនោះ បទថា* **វរោ** *សេចក្តីថា ព្រះពុទ្ធ*

ទ្រង់មានអធ្យាស្រ័យបង្អោនចិត្តជឿ ដែលប្រណីត ប្រាថ្នាថា ឱហ្ន៎ ! សូម្បីអាត្មាអញ ក៏គប្បីមានសភាពដូច្នេះ ។ ឬព្រះពុទ្ធដ៏ប្រសើរឧត្តម ប្រសើរបំផុត ព្រោះប្រកបដោយព្រះគុណដ៏ប្រសើរ ។ បទថា **វរញ្ញូ** *បានដល់ ទ្រង់ជ័ងព្រះនិព្វាន ។ ពិតហើយ ព្រះនិព្វាន ឈ្មោះថា ប្រសើរ ព្រោះអត្ថថាឧត្តមជាងធម៌ទាំងពួង ។ ព្រះពុទ្ធអង្គនោះ ត្រាស់ជ័ងនូវព្រះនិព្វាននោះ ត្រង់មណ្ឌលពោធិព្រឹក្សដោយព្រះអង្គឯង ។ បទថា* **វរទោ** *សេចក្តីថា ប្រទានធម៌ដ៏ប្រសើរ ដែលជាចំណែកត្រាស់ជ័ង និងចំណែកដែលអប់រំបន្ទុំបារមីដល់សាវ័កទាំងឡាយ មានបព្វជិតគ្គិយ កទូវគ្គិយ និងជដិលជាដើមដល់ទេវតា និងមនុស្សជនៃ ។ បទថា* **វរាហរោ** *បានដល់ ដែលហៅថា* **វរាហរោ** *ព្រោះទ្រង់នាំមកនូវមគ្គដ៏ប្រសើរ ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះ ទ្រង់បំពេញបារមី ៣០ មកតាំងអំពីព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់នាំនូវបុរាណមគ្គដ៏ប្រសើរដែលព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គមុនៗ ទ្រង់ដើរមកហើយ ។ ដោយហេតុនោះ ទើបទ្រង់ត្រូវហៅថា* **វរាហរោ** *ដែលនាំមកនូវមគ្គដ៏ប្រសើរ ។*

ម្យ៉ាងទៀត ព្រះសម្ពុទ្ធ ឈ្មោះថា **វរោ** *គឺបុគ្គលប្រសើរ ព្រោះទ្រង់បាននូវព្រះសព្វញ្ញុតញ្ញាណ ឈ្មោះថា* **វរញ្ញូ** *គឺបុគ្គលជ័ងធម៌ដ៏ប្រសើរ ព្រោះទ្រង់ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ឈ្មោះថា* **វរទោ** *ព្រោះទ្រង់ប្រទានធម៌ដ៏ប្រសើរ ព្រោះទ្រង់ប្រទានវិមុត្តិសុខដល់សត្វទាំងឡាយ ឈ្មោះថា* **វរាហរោ** *គឺទ្រង់នាំមកនូវមគ្គដ៏ប្រសើរ ព្រោះទ្រង់នាំមកនូវបដិបទាដ៏ឧត្តម ឈ្មោះថា* **អនុត្តរោ** *ព្រោះមិនមានគុណណាមួយ ដែលក្រៃលែងជាងលោកុត្តរគុណ*

ទាំងនោះ ។

មានន័យដទៃទៀតថា ឈ្មោះថា **វរោ** *ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋាន-ធម៌ គឺឧបសមៈ ។ ឈ្មោះថា* **វរញ្ញូ** *ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋានធម៌ គឺបញ្ញាដឹងដោយជុំវិញ ។ ឈ្មោះថា* **វរទោ** *ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋាន-ធម៌ គឺចាគៈ ។ ឈ្មោះថា* **វរាហរោ** *ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋាន គឺសច្ចៈ ។ ទ្រង់នាំមកនូវមគ្គដ៏ប្រសើរ ។ ម្យ៉ាងទៀត ឈ្មោះថា* **វរោ** *ព្រោះទ្រង់អាស្រ័យបុណ្យ ។ ឈ្មោះថា* **វរញ្ញូ** *ក៏ព្រោះទ្រង់អាស្រ័យបុណ្យ ។ ឈ្មោះថា* **វរទោ** *ព្រោះទ្រង់ប្រគល់ឧបាយនៃបុណ្យនោះដល់បុគ្គលដែលត្រូវការជាព្រះពុទ្ធ ។ ឈ្មោះថា* **វរាហរោ** *ព្រោះទ្រង់នាំមកនូវឧបាយនៃបុណ្យនោះដល់បុគ្គលដែលត្រូវការជាព្រះបច្ចេកពុទ្ធ ។ ឈ្មោះថា* **អនុត្តរោ** *ព្រោះមិនមានបុគ្គលស្មើដូចក្នុងធម៌នោះៗ ឬព្រោះជាបុគ្គលមិនមានអាចារ្យ តែក៏បានជាអាចារ្យរបស់បុគ្គលដទៃៗ ដោយព្រះអង្គឯង ទ្រង់បានសម្តែងធម៌ដ៏ប្រសើរ ព្រោះទ្រង់សម្តែងធម៌ដ៏ប្រសើរ ដែលប្រកបដោយគុណ មានធម៌ដែលត្រាស់សម្តែងល្អហើយជាដើម ដើម្បីផលនោះដល់បុគ្គលត្រូវការជាសាវក ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។*

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់ទ្រង់ដោយលោកុត្តរធម៌ ៩ ប្រការយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥតិបិ ពុទ្ធោ** *ជាដើម អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលអំពីមុនហើយនោះឯង តែគប្បីប្រកបសេចក្តីតែមួយ*

យ៉ាងនេះថា ព្រះសម្ពុទ្ធអង្គនោះ បានត្រាស់ដឹងលោកុត្តរធម៌ដ៏ប្រសើរបានផង បានប្រទានលោកុត្តរធម៌បានផង ទ្រង់នាំមកនូវលោកុត្តរធម៌បានផង ទ្រង់សម្តែងលោកុត្តរធម៌បានផង នេះក៏ជារតនៈដ៏ប្រណីតក្នុងព្រះពុទ្ធ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានោះ ។

អធិប្បាយបទថា ខីណំ

ព្រះមានព្រះភាគ ទ្រង់អាស្រ័យបរិយត្តិធម៌ និងលោកុត្តរធម៌ហើយ ត្រាស់វចនៈ មានពុទ្ធរតនៈជាទីតាំង ដោយ ២ គាថា យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណ គឺការសម្រេចអនុបាទិសេសនិព្វានៃសាវ័កទាំងឡាយ ដែលបានស្តាប់បរិយត្តិធម៌នោះ និងបដិបត្តិតាមគន្ថៈដែលបានស្តាប់មកហើយ បានសម្រេចលោកុត្តរធម៌ទាំង ៩ ប្រការ ទើបទ្រង់ផ្តើមត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំងទៀតថា **ខីណំ បុរាណំ ។** *ក្នុងសច្ចវចនៈនោះ បទថា* **ខីណំ** *បានដល់ កាត់ផ្តាច់ ។ បទថា* **បុរាណំ** *ប្រែថា ចាស់ ។ បទថា* **នវំ** *បានដល់ ក្នុងឥឡូវនេះដែលកំពុងប្រព្រឹត្តទៅ គឺបច្ចុប្បន្ន ។ បទថា* **នត្ថិ សម្ភវំ** *បានដល់ ការប្រាកដមិនមាន ។ បទថា* **វិរត្តចិត្តា** *បានដល់ មានចិត្តប្រាសចាកភាគៈ ។ បទថា* **អាយតិកេ ភវស្មឹ** *បានដល់ ក្នុងភពថ្មី ក្នុងអនាគតកាល ។ បទថា* **តេ** *បានដល់ ភិក្ខុខីណាស្រពដែលអស់កម្មកពចាស់ មិនមានកម្មភពថ្មី និងមានចិត្តប្រាសចាកតម្រេកក្នុងភពតទៅ ។ បទថា* **ខីណ-ពីជា** *បានដល់ ជាអ្នកមានពូជដកហើយ ។ បទថា* **អវិរុឡ្ហិឆន្ទា** *បានដល់ ជាអ្នកវៀរចាកឆន្ទៈដែលដុះបាន ។ បទថា* **និព្វន្តិ** *បានដល់ អស់ទៅ ។ បទថា*

ធីរា បានដល់ បុគ្គលដល់ព្រមដោយបញ្ញា ឈ្មោះធិតិ ។ បទថា **យថា-យម្បឥធោ** ប្រែថា ដូចប្រទីបនេះ ។

លោកអធិប្បាយដូចម្តេច លោកអធិប្បាយថា កម្មនោះ នៃសត្វទាំង-ទ្បាយកើតហើយរលត់ទៅ ជាកម្មចាស់ ជាអតីតកាល រមែងមិនទាន់អស់ទៅ ព្រោះអាចនាំមកនូវបដិសន្ធិ ព្រោះលះសិនេហៈ គឺតណ្ហាមិនទាន់បាន កម្មចាស់នោះរបស់ព្រះខីណាស្រពទាំងទ្បាយណា ឈ្មោះថា អស់ទៅ ក៏ព្រោះមិនអាចឲ្យវិបាកតទៅ ដូចពូជដែលក្តៅងេះហើយ ព្រោះសិនេហៈ គឺតណ្ហា រលីងស្ងួតទៅដោយអរហត្តមគ្គ និងកម្មណារបស់ភិក្ខុខីណាស្រពពួកណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ដោយអំណាចពុទ្ធបូជាជាដើម ហៅថា កម្មថ្មី ។ កម្ម ថ្មីនោះរបស់ភិក្ខុខីណាស្រពណា ក៏បង្កនូវភពបាន ព្រោះមិនអាចឲ្យផលតទៅ ដូចផ្តានៃដើមឈើដែលមានឫសជាប់ហើយ ព្រោះលះតណ្ហាបាននោះឯង ។

ម្យ៉ាងទៀត ភិក្ខុខីណាស្រពពួកណា មានចិត្តនឿយណាយហើយ ក្នុង ភពតទៅ ព្រោះលះតណ្ហាបាននោះឯង ភិក្ខុខីណាស្រពទាំងនោះ ឈ្មោះថា មានពូជអស់ហើយ ព្រោះបដិសន្ធិវិញ្ញាណ ដែលលោកពោលហើយ ក្នុង ពាក្យនេះថា កម្ម គឺស្រែ វិញ្ញាណ គឺពូជ អស់ទៅ ព្រោះអស់កម្មនោះឯង ឆន្ទៈឯណានៃការកើត ពោល គឺភពថ្មី មានមកហើយអំពីកាលមុន ។ ភិក្ខុ ខីណាស្រពទាំងទ្បាយ ឈ្មោះថា មានឆន្ទៈមិនដុះ ព្រោះមិនកើតក្នុងពេល ចុតិដូចក្នុងកាលមុន ព្រោះឆន្ទៈនោះលះបានហើយ ព្រោះលះសមុទយៈនោះ ឯង ឈ្មោះថា អ្នកប្រាជ្ញ ព្រោះដល់ព្រមដោយធិតិប្បញ្ញា រមែងរលត់ទៅ ដូច

ប្រទីបដួងនេះរលត់ទៅ ដូច្នោះ ព្រោះចរមវិញ្ញាណរលត់ទៅ រមែងកន្ទងបង់នូវផ្លូវនៃបញ្ញត្តិជាដើមយ៉ាងនេះថា មានរូប ឬមិនមានរូបទៀត ។

បានឮថា បណ្តាប្រទីបច្រើនដួង ដែលគេដុតដើម្បីបូជាទេវតាប្រចាំក្រុង ក្នុងសម័យនោះ ប្រទីប ១ រលត់ទៅហើយ ព្រះមានព្រះភាគ កាលទ្រង់ចង្អុលបង្ហាញប្រទីបដួងនោះ ទើបត្រាស់ថា **យថាយម្បឌីចោ** *ដូចប្រទីបដួងនេះ ។*

ព្រះមានព្រះភាគ កាលត្រាស់គុណ គឺការសម្រេចអនុបាទិសេសនិព្វាន របស់ព្រះខីណាស្រព ដែលស្តាប់បរិយត្តិធម៌ ដែលត្រាស់ដោយ ២ គាថា មុននោះផង បដិបត្តិតាមគន្ថបរិយត្តិដែលស្តាប់ហើយផង សម្រេចលោកុត្តរ-ធម៌ទាំង ៩ ប្រការយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង កាលទ្រង់ប្រកបសច្ចវចនៈ មានសង្ឃរតនៈជាទីតាំង ទើបទ្រង់បញ្ចប់ទេសនា ថា **ឥធម្បិ សង្ឃេ** *ជាដើម អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមនយដែលពោលមកមុនហើយនោះឯង ។ តែគប្បីប្រកបសេចក្តីតែមួយ យ៉ាងនេះថា គុណជាត ពោល គឺព្រះនិព្វានរបស់ភិក្ខុខីណាស្រព ដោយប្រការតាមដែលពោលមកហើយ នេះក៏ជារតនៈដែលប្រណីតក្នុងសង្ឃ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។*

ចប់ទេសនា សួស្តីក៏មានដល់រាជត្រកូល ឧបទ្រព្យទាំងពួង ក៏រម្ងាប់ទៅ សត្វ ៨៤០០០ ក៏បានត្រាស់ដឹងធម៌ ។

អធិប្បាយគាថា ៣ មានយានីធជាដើម

គ្រានោះ សក្កទេវរាជទ្រង់ព្រះតម្រិះថា ព្រះមានព្រះភាគ ទ្រង់អាស្រ័យ

គុណព្រះរតនត្រ័យ ប្រកបសច្ចវចនៈ ទ្រង់ធ្វើសួស្តីដល់អ្នកនគរ ។ សូម្បីអញ ក៏គប្បីពោលពាក្យណានីមួយ អាស្រ័យគុណព្រះរតនត្រ័យ ដើម្បីសួស្តីដល់អ្នកនគរ ដូច្នេះហើយ ទើបត្រាស់ ៣ គាថាខាងចុងថា **យានីធ ភូតានិ** *ជាដើម ។ ក្នុង ៣ គាថានោះ ព្រោះហេតុដែលព្រះពុទ្ធ លោកហៅថា តថាគត ព្រោះយាងមក ដូចដែលមនុស្សទាំងឡាយ ត្រូវខ្វល់ខ្វាយ នាំគ្នាមកដើម្បីជាប្រយោជន៍ដល់សត្វលោក ព្រោះយាងទៅ ដូចដែលមនុស្សទាំងនោះគប្បីទៅ ព្រោះទ្រង់ជីងទូទៅ ដូចដែលមនុស្សទាំងនោះគប្បីជីងទូទៅ ព្រោះទ្រង់ជីងដូចដែលមនុស្សទាំងនោះគប្បីជីង ព្រោះទ្រង់ជួបនូវវត្ថុ ដែលមានយ៉ាងនោះ ម្យ៉ាងទៀត ព្រោះព្រះពុទ្ធអង្គនោះ ដែលទេវតា និងមនុស្សទាំងឡាយបូជា ដោយឥតសេសសល់ ដោយផ្កា និងគ្រឿងក្រអូបជាដើម ដែលកើតខាងក្រៅជាឧបករណ៍ និងដែលកើតក្នុងខ្លួន មានកិច្ចបដិបត្តិធម៌សមគួរដល់ធម៌ជាដើមដូច្នោះ ។ សក្កទេវរាជទ្រង់ប្រមូលទេវបរិស័ទ មួយអន្ទើនឹងព្រះអង្គ ហើយត្រាស់ថា* **តថាគតំ ទេវមនុស្សបូជិតំ ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ** *យើងខ្ញុំទាំងឡាយ សូមនមស្ការព្រះពុទ្ធ ដែលទេវតា និងមនុស្សបូជាហើយ សូមសួស្តីកើតមាន ។*

ម្យ៉ាងទៀត ព្រោះក្នុងព្រះធម៌ មគ្គធម៌ប្រព្រឹត្តទៅហើយ ដែលគប្បីប្រព្រឹត្តទៅ ដោយការដកនូវបក្ខពួកកិលេស ដោយកម្លាំងសមថៈ និងវិបស្សនា ដែលជាធម៌គូគ្នា សូម្បីនិព្វានធម៌ ដែលព្រះពុទ្ធជាដើម ទ្រង់សម្រេចហើយ ដូចដែលទ្រង់ត្រាស់ដឹង គឺចាក់ធ្លុះដោយបញ្ញា មួយអន្ទើ

ដែលនឹងកម្ចាត់ទុក្ខទាំងពួង ដូច្នោះ ទើបលោកហៅថា តថាគត ។ ម្យ៉ាងទៀត ព្រោះព្រះសង្ឃប្រព្រឹត្តទៅហើយ ដូចដែលលោកបដិបត្តិ ដើម្បីជាប្រយោជន៍ដល់ខ្លួន គប្បីប្រព្រឹត្តទៅដោយមគ្គនោះៗ ហេតុនោះ ទើបលោកហៅថា តថាគត ។ ដូច្នោះ សូម្បីក្នុង ២ គាថាដ៏សេស ទើបសក្កទេវរាជគ្រាស់ថា យើងខ្ញុំទាំងឡាយ សូមនមស្ការតថាគតធម៌ សូមសួស្តីកើតមាន យើងខ្ញុំសូមនមស្ការតថាគតសង្ឃ សូមសួស្តីកើតមាន ដូច្នេះ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

សក្កទេវរាជកាលគ្រាស់ ៣ គាថាយ៉ាងនេះហើយ ទ្រង់ធ្វើប្រទក្សិណព្រះមានព្រះភាគ ទ្រង់យាងត្រឡប់ទៅកាន់ទេវបុរី មួយអន្ទើដោយទេវបរិស័ទ ។ ចំណែកព្រះមានព្រះភាគ ទ្រង់សម្តែងរតនសូត្រនោះឯង ។ ក្នុងថ្ងៃទី ២ សត្វប្រមាណ ៨៤០០០ ក៏គ្រាស់ដឹងធម៌ ។ ទ្រង់សម្តែងយ៉ាងនេះដល់ថ្ងៃទី ៧ ។ ការគ្រាស់ដឹងធម៌ មានហើយយ៉ាងនោះឯង រាល់ៗ ថ្ងៃ ។ ព្រះមានព្រះភាគនៅប្រថាប់ក្នុងក្រុងវេសាលីកន្លះខែហើយ ទើបទ្រង់ប្រាប់ដល់ពួកស្តេចលិច្ឆវីថា នឹងត្រឡប់ បន្ទាប់អំពីនោះ ពួកស្តេចលិច្ឆវី ក៏នាំព្រះមានព្រះភាគចូលកាន់ប្រាំងសួឹងគង្គា ដោយសក្ការៈជាទ្វេគុណ ៣ ថ្ងៃទៀត ពួកស្តេចនាគដែលកើតនៅក្នុងសួឹងគង្គាគិតគ្នាថា ពួកមនុស្សធ្វើសក្ការៈ ដល់ព្រះតថាគត ពួកយើងនឹងមិននាំគ្នាធ្វើខ្លះឬ ទើបសាងផ្ទះច្រើនខ្នង ជាវិការនៃមាស ប្រាក់ និងកែវមណី ក្រាលបល្ល័ង្ក ធ្វើដោយមាស ប្រាក់ និងកែវមណី ធ្វើទឹកឲ្យត្រជាក់ដោយឈូក ៥ ពណ៌ ទូលអារាធនាព្រះមានព្រះភាគថា សូមទ្រង់

មេត្តាធ្វើនូវសេចក្តីអនុគ្រោះពួកខ្ញុំព្រះអង្គផងចុះ ។ ព្រះមានព្រះភាគ ទ្រង់ទទួលទ្រង់ឡើងកាន់ផ្ទះកែវ ឯភិក្ខុ ៥០០ ក៏ឡើងកាន់ទូកវៀងៗ ខ្លួន ។ ពួកស្តេចនាគនាំព្រះមានព្រះភាគ មួយអន្ទើដោយភិក្ខុសង្ឃ ចូលទៅកាន់នាគពិភព ។ បានឮថា ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ជាល់នាគបរិស័ទមួយយប់ទល់ភ្លឺ ថ្ងៃទី ២ ពួកស្តេចនាគនាំគ្នាថ្វាយមហាទាន ដោយរបស់ទំពា របស់ឆាន់ដែលជាទិព្វ ។ ព្រះមានព្រះភាគ ទ្រង់អនុមោទនាហើយ ទ្រង់ចេញអំពីនាគពិភព ។

ពួកកុម្ភទេវតានាំគ្នាគិតថា ពួកមនុស្ស និងនាគនាំគ្នាធ្វើសក្ការៈជាល់ព្រះតថាគត ពួកយើងមិនធ្វើខ្លះឬ ទើបនាំគ្នាលើកស្វែតច្ឆត្រធំតូច លើគុមឈើ ប្រគាបឈើ ដើមឈើ និងភ្នំ ។ ដោយឧបាយនោះឯង សក្ការៈវិសេសដ៏ធំក៏កើត ជារបជាល់ភពអកនិដ្ឋព្រហ្ម ។ សូម្បីព្រះបាទពិម្ពិសារ ក៏ទ្រង់បានធ្វើទេគុណ ជាងសក្ការៈដែលពួកស្តេចលិច្ឆវីធ្វើ កាលព្រះមានព្រះភាគយាងមកទ្រង់នាំព្រះមានព្រះភាគ ៥ ថ្ងៃ ទើបជាល់ក្រុងរាជគ្រឹះ ដោយន័យដូចពោលមកអំពីមុនហើយ ។

ព្រះមានព្រះភាគ យាងជាល់ក្រុងរាជគ្រឹះហើយ ខាងក្រោយអាហារ ពួកភិក្ខុដែលអង្គុយប្រជុំគ្នាក្នុងសាលាមួល ពោលក្នុងរវាងគ្នានិងគ្នាយ៉ាងនេះថា ឱ ! អានុភាពរបស់ព្រះមានព្រះភាគ ក្នុងទីភូមិភាគ ៨ យោជន៍ ទាំងត្រើយអាយ និងត្រើយនាយនៃស៊ីងគង្គា ត្រូវពង្រាបទីទំនាប និងទីទួលឲ្យរាបហើយដោយខ្សាច់ គ្របជណ្តប់ដោយផ្កាទាំងឡាយ ស៊ីងគង្គាប្រមាណមួយយោជន៍

ក៏ត្រូវគ្រែបដណ្តប់ដោយផ្ការ៉ូកពណ៌ផ្សេងៗ ឆត្រតូច-ធំត្រូវលើកឡើងដរាប ដល់អកនិដ្ឋព្រហ្ម ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបរឿងនោះហើយ ចេញអំពី ព្រះគន្ធកុដិ យាងទៅកាន់សាលាមូលដោយបាដិហារ្យ សមគួរដល់ខណៈនោះ គង់ប្រថាប់លើពុទ្ធាសនៈដ៏ប្រសើរ ដែលគេបានរៀបចំក្នុងសាលាមូលនោះ ។ កាលគង់ប្រថាប់ហើយ ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាល ភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នា និយាយរឿងអ្វី ភិក្ខុ ទាំងឡាយក្រាបទូលរឿងទាំងអស់នោះ ។ ព្រះមានព្រះភាគ ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បូជាវិសេសនេះ មិនបានកើតព្រោះពុទ្ធានុភាពរបស់ តថាគត ទាំងមិនមែនព្រោះអានុភាពរបស់នាគ ទេវតា និងព្រហ្មឡើយ ដោយពិត កើតព្រោះអានុភាពនៃការបរិច្ចាគបន្តិចបន្តួចទេតើ ។ ទើបភិក្ខុ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនដឹងការបរិច្ចាគតិចតួច នោះ សូមព្រះមានព្រះភាគ មេត្តាប្រាប់ពួកខ្ញុំព្រះអង្គ ដូចដែលពួកខ្ញុំព្រះអង្គ ដឹងការបរិច្ចាគតិចតួចនោះផងចុះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ រឿងធ្លាប់មានមកហើយ ក្នុងនគរតក្កសិលា មានព្រាហ្មណ៍ម្នាក់ ឈ្មោះសង្ខៈ គាត់មានកូនប្រុសម្នាក់ ឈ្មោះសុសិមមាណព ។ មាណពនោះ អាយុបាន ១៦ ឆ្នាំ ដោយវ័យ ថ្ងៃមួយ ចូលទៅរកបិតា ថ្វាយបង្គំហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង ។ បិតាសួរថា នែ សុសិមៈ អ្នកមានរឿង អ្វី សុសិមៈឆ្លើយថា ខ្ញុំចង់ទៅក្រុងពារាណសី រៀនសិប្បៈ ព្រាហ្មណ៍ពោលថា នែ សុសិមៈ បើដូច្នោះ ឪពុកមានសម្លាញ់ជាព្រាហ្មណ៍ឈ្មោះនោះ ចូរបា

ទៅរកអាចារ្យនោះរៀនសូត្រចុះ ហើយប្រគល់ទ្រព្យ ១០០០ កហាបណៈ ។ សុសិមមាណពនោះទទួលទ្រព្យហើយ ក៏សំពះមាតាបិតា ធ្វើដំណើរទៅក្រុងពារាណសីដោយលំដាប់ គាត់ចូលទៅរកអាចារ្យដោយវិធី ប្រកបដោយភាពទន់ភ្លន់ ថ្វាយបង្គំហើយ ប្រាប់ការងាររបស់ខ្លួន អាចារ្យដឹងថា ជាកូនរបស់សម្លាញ់ ក៏ទទួលមាណព បានធ្វើការទទួលយ៉ាងល្អគ្រប់យ៉ាង មាណពនោះប្រាសចាកការនឿយហត់ក្នុងការធ្វើដំណើរផ្លូវឆ្ងាយហើយ ក៏ជាក់កហាបណៈនោះ ទៀបបាតជើងអាចារ្យ សូមឱកាសរៀនសិប្បៈ ។ អាចារ្យក៏បើកឱកាសឲ្យរៀនសូត្រ មាណពរៀនបានរហ័ស និងបានច្រើនផង ព្រមទាំងទ្រទ្រង់នូវសិប្បៈដែលរៀនបានហើយ មិនឲ្យសាបសូន្យផង ដូចប្រែងថ្លាជាក់ក្នុងកាជនៈមាស គាត់រៀនសិប្បៈដែលគួររៀនអស់ ១២ ឆ្នាំ ឲ្យចប់សព្វគ្រប់ត្រឹម ២-៣ ខែប៉ុណ្ណោះ ។ មាណពស្វាធ្យាយតាំងអំពីខាងដើម និងកណ្តាលប៉ុណ្ណោះ មិនឃើញខាងចុង ទើបចូលទៅរកអាចារ្យសួរថា លោកអាចារ្យ ខ្ញុំឃើញតែខាងដើម និងកណ្តាលរបស់សិប្បៈនេះប៉ុណ្ណោះ មិនឃើញខាងចុងឡើយ អាចារ្យក៏ពោលថា ឯខ្ញុំក៏ឃើញយ៉ាងនោះដូចគ្នានោះឯង ។ ទើបមាណពសួរថា បពិត្រលោកអាចារ្យ បើដូច្នោះ អ្នកណាដឹងខាងចុងរបស់សិប្បៈនេះ ។ អាចារ្យពោលថា នែមា នៅឯព្រៃឥសិបតនៈ មានឥសីច្រើនអង្គ ឥសីទាំងនោះគង់នឹងដឹង ។ មាណពប្រាប់ថា បពិត្រលោកអាចារ្យ ខ្ញុំនឹងចូលទៅសួរឥសីទាំងនោះឯង ។ អាចារ្យក៏ប្រាប់ថា នែមា អ្នកចូរទៅសួរតាមសប្បាយចុះ ។ មាណពទៅកាន់ព្រៃឥសិបតនៈ ចូលទៅរកព្រះបច្ចេកពុទ្ធទាំងឡាយ

សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ជឿខាងចុងនៃសិប្បៈខ្លះដែរឬទេ ។ ព្រះបច្ចេកពុទ្ធពោលថា អើ អាត្មាជឿ ។ មាណពអារាធនាថា សូមឲ្យខ្ញុំសិក្សាខាងចុងសិប្បៈនោះផងចុះ ។ ព្រះបច្ចេកពុទ្ធពោលថា បើដូច្នោះ ចូរបួសចុះ បុគ្គលដែលមិនបួស សិក្សាមិនបានទេ ។ មាណពទទួលថា សាធុ សូមឲ្យខ្ញុំបួសចុះ ។ សូមលោកម្ចាស់ ធ្វើតែទីដែលលោកម្ចាស់ប្រាថ្នាហើយ ឲ្យខ្ញុំសិក្សាខាងចុងសិប្បៈ ក៏ជាការស្រេច ។ ព្រះបច្ចេកពុទ្ធទាំងនោះឲ្យមាណពបួសហើយ ក៏មិនអាចប្រកបមាណពក្នុងកម្មដ្ឋាន ឲ្យសិក្សាតែអភិ-សមាចារ ដោយនយជាដើមថា អ្នកគប្បីស្លៀកយ៉ាងនេះ គប្បីដណ្តប់យ៉ាងនេះ ។ មាណពសិក្សាក្នុងសិក្ខាបទនោះ តែព្រោះជាអ្នកដល់ព្រមដោយឧបនិស្សយ មិនយូរប៉ុន្មានក៏ត្រាស់ដឹងបច្ចេកពោធិញ្ញាណ ។ ព្រះបច្ចេកពុទ្ធ-សុសិមៈដល់នូវលោកយសដ៏ក្រៃលែង កុះករដោយបរិវារ ប្រាកដទូទៅក្នុងក្រុងពារាណសីថា ជាព្រះបច្ចេកពុទ្ធ តែមិនយូរប៉ុន្មាន លោកក៏បរិនិព្វានព្រោះបានធ្វើកម្មដែលជាហេតុឲ្យអាយុខ្លី ។ ព្រះបច្ចេកពុទ្ធទាំងឡាយ និងពួកមហាជន នាំគ្នាធ្វើឈាបនកិច្ចសរីរៈរបស់លោក រក្សាធាតុ សាងព្រះស្តូបក្បែរទ្វារព្រះនគរ ។

ឯសង្ខព្រាហ្មណ៍ គិតថា កូនរបស់អញទៅយូរហើយ មិនមានដំណឹងម្តងសោះឡើយ បំណងនឹងជួបកូន ទើបចេញអំពីតក្កសិលា ធ្វើដំណើរទៅតាមលំដាប់ ក៏ដល់ក្រុងពារាណសី ឃើញពួកមហាជនប្រជុំគ្នា គិតថា ក្នុងពួកជនជាច្រើន គង់មានម្នាក់ ដឹងដំណឹងកូនរបស់អញពិត ទើបចូលទៅត្រង់

ប្រជុំជន សួរថា មាណពឈ្មោះសុសិមៈមកក្នុងទីនេះ មានដែរឬទេ អ្នកធ្លាប់ឮដំណឹងរបស់សុសិមមាណពខ្លះដែរឬ ។ ជនទាំងនោះពោលថា អើព្រាហ្មណ៍ ពួកខ្ញុំដឹង លោករៀនចប់ត្រៃវេទក្នុងសម្នាក់ព្រាហ្មណ៍ ទានគរនេះហើយ បួសក្នុងសម្នាក់ព្រះបច្ចេកពុទ្ធទាំងឡាយ បានត្រាស់ជាព្រះបច្ចេកពុទ្ធ បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុហើយ នេះព្រះស្តូប ពួកយើងសាងឡើងសម្រាប់លោក ។ សង្ខព្រាហ្មណ៍យកដៃវាយផែនដី ទ្រហោយំ ទៅកាន់លានចេតិយនោះ ជកស្មៅហើយ យកសំពត់ដណ្តប់វេចខ្ជាប់ នាំទៅរោយត្រង់លានព្រះចេតិយរបស់ព្រះបច្ចេកពុទ្ធ យកទឹកក្នុងកុណ្ឌីប្រោះព្រំ ធ្វើការបូជាដោយផ្កាព្រៃ យកសំពត់ដណ្តប់លើកឡើង ធ្វើជាទង់ ចងធ្នូ គឺធ្នូរបស់ខ្លួនជាក់លើស្តូប ហើយត្រឡប់ទៅ ។

ព្រះមានព្រះភាគ កាលទ្រង់នាំអតីតនិទាននេះមកហើយ កាលទ្រង់បន្តអនុសន្ធិជាតកនោះជាមួយបច្ចុប្បន្ន ទើបត្រាស់ធម៌ដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកគប្បីមានការគិតថា អ្នកដទៃជាសង្ខព្រាហ្មណ៍ សម័យនោះពិត តែពួកអ្នកមិនគប្បីឃើញយ៉ាងនេះ សម័យនោះ តថាគតជាសង្ខ-ព្រាហ្មណ៍ តថាគតជកស្មៅត្រង់លានព្រះចេតិយ របស់សុសិមព្រះបច្ចេកពុទ្ធ ដោយផលកម្មរបស់តថាគតនោះ ទើបជនទាំងឡាយធ្វើផ្លូវ ៨ យោជន៍ ឲ្យប្រាសចាកជង្គត់ និងបន្ទា ធ្វើផ្ទៃដីឲ្យរាបស្មើស្អាត តថាគតរោយខ្ជាប់ត្រង់លានព្រះចេតិយព្រះសុសិមបច្ចេកពុទ្ធនោះ ដោយផលនៃកម្មរបស់តថាគតនោះ ទើបជនទាំងឡាយរោយខ្ជាប់ត្រង់ផ្លូវ ៨ យោជន៍ តថាគតបូជាត្រង់

ព្រះស្តូបនោះ ដោយផ្កាព្រៃ ដោយផលកម្មនៃតថាគតនោះ ទើបជនទាំងឡាយ ធ្វើកម្រាលផ្កាច្រើនប្រភេទ ទាំងលើគោក និងក្នុងទឹក ក្នុងផ្លូវ ៩ យោជន៍ តថាគតច្រោះព្រំផែនដីដោយទឹក ក្នុងកុណ្ឌីទឹកត្រង់ព្រះស្តូបនោះ ដោយផលនៃកម្មនោះ ទើបក្លៀងចោក្ខរពីរ្យធ្លាក់ត្រង់ក្រុងវេសាលី តថាគតលើកទង់ជ័យ និងឆត្រត្រង់ព្រះចេតិយនោះ ដោយផលនៃកម្មរបស់តថាគតនោះ ទើបជនទាំងឡាយលើកទង់ជ័យ និងឆត្រតូចធំ រហូតដល់អកនិដ្ឋភព ។ ម្នាលភិក្ខុទាំងឡាយ ការបូជាវិសេស មិនមែនកើតព្រោះពុទ្ធានុភាពរបស់តថាគតឡើយ មិនមែនព្រោះអានុភាពរបស់នាគ ទេវតា និងព្រហ្មឡើយ ដោយពិតនោះ កើតព្រោះអានុភាពរបស់ការបរិច្ចាគបន្តិចបន្តួចទេតើ ។ ចប់ធម្មកថា

បានត្រាស់ព្រះគាថានេះថា

មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ
ច ដេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ ។

បើបុគ្គលឃើញសុខធំទូលាយ ព្រោះលះសុខមានប្រមាណតិចចេញ អ្នកមានប្រាជ្ញា កាលឃើញច្បាស់សុខធំទូលាយ គប្បីលះសុខមានប្រមាណតិចចេញ ។

អធិប្បាយរតនសូត្រ

នៃ

អដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះបរមត្ថជោតិកា ចប់

ឧជ្ជកចាឯ: តិរោកុឌ្ឌកណ្ឌ

[៨] បើបុគ្គលយើញសុខធំទូលាយ ព្រោះលះសុខមានប្រមាណតិចចេញ អ្នកមានប្រាជ្ញា កាលយើញច្បាស់សុខធំទូលាយ គប្បីលះសុខមានប្រមាណតិចចេញ ។

ប្រេតទាំងឡាយ មកកាន់ផ្ទះនៃញាតិ ដោយគិតថា ជាផ្ទះរបស់ខ្លួន ហើយឈរនៅជិតខាងក្រៅជញ្ជាំងទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ ទាំងឡាយខ្លះ ជិតទ្វារក្រុង និងទ្វារផ្ទះទាំងឡាយខ្លះ ។ កាលបើបាយទឹក បង្អែម និងចំអាបមានគ្រប់គ្រាន់ ដែលពួកញាតិតាក់តែងទុកហើយ មិនមានញាតិណាមួយ នឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយជាបច្ចយ ។ ញាតិទាំងឡាយណា ជាអ្នកអនុគ្រោះ ញាតិទាំង-ឡាយនោះ រមែងឧទ្ទិសឲ្យនូវទឹក និងភោជនដ៏ម៉ត់ចត់ ដ៏ប្រសើរ ជារបស់គួរតាមកាល ដល់ញាតិទាំងឡាយ យ៉ាងនេះថា ទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ បានដល់នូវសេចក្តីសុខ ។ ចំណែកប្រេតជាញាតិ ជាអ្នកមកប្រជុំគ្នាទាំងនោះ មកជួបជុំគ្នាហើយ ក្នុងមន្ទីរឲ្យទាននោះ កាលបើបាយ និងទឹកមានល្មមគ្រាន់ ក៏អនុមោទនាដោយគោរពថា យើងទាំងឡាយបានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយណា សូមពួកញាតិរបស់យើងទាំងឡាយនោះ រស់នៅយឺនយូរ ការបូជាដែលញាតិទាំងឡាយធ្វើហើយ ដល់យើងទាំងឡាយក្តី ញាតិទាំងឡាយ ជាអ្នកឲ្យទានក្តី មិនមែនជាឥតផលឡើយ កសិកម្មក៏មិនមានក្នុងភូមិនៃប្រេតនោះ គោរក្ខកម្មក៏មិនមានក្នុងភូមិនៃប្រេតនោះ ពាណិជ្ជកម្មដែលជាហេតុបានសម្បត្តិបែបដូច្នោះ

ក៏មិនមាន ការលក់ទិញផ្ទាស់ប្តូរដោយប្រាក់ក៏មិនមាន បុគ្គលទាំងឡាយ ធ្វើកាលកិរិយាលះលោកនេះទៅហើយ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងប្រេតវិស័យនោះ ដោយផលទានដែលញាតិទាំងឡាយ ឧទ្ទិសឲ្យហើយអំពីលោកនេះ ។ ទឹកធ្លាក់ចុះលើទីទួល រមែងហូរទៅកាន់ទីទាបជាដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយ អំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ ។ ផ្លូវទឹកមានទន្លេ និងស្ទឹងជាដើមដ៏ពេញ រមែងញ៉ាំងសាគរឲ្យពេញប្រៀប ដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយ អំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។ បុគ្គលកាលរឭកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួន ក្នុងកាលមុនថា អ្នកនេះ បានឲ្យរបស់នេះដល់អញ អ្នកនេះ បានធ្វើគុណនេះដល់អញ ជនទាំងឡាយនោះជាញាតិមិត្តជាសម្លាញ់របស់អញ ដូច្នេះហើយ គួរឲ្យទក្ខិណាទានចំពោះប្រេតទាំងឡាយ ។ ការយំសោកសៅ និងការខ្សឹកខ្សួលដទៃណា មិនមានប្រយោជន៍ឡើយ ការយំជាដើមនោះ មិនសម្រេចប្រយោជន៍ដល់ប្រេតទាំងឡាយទេ ញាតិទាំងឡាយ រមែងឋិតនៅយ៉ាងនោះដដែល ឥតបានដឹង បានឮឡើយ ។ លុះតែទក្ខិណាទាននេះ ដែលបុគ្គលបានឲ្យហើយ តម្កល់ទុកប្រពៃហើយក្នុងសង្ឃ ទើបសម្រេចផលដោយរួសរាន់ ដើម្បីប្រយោជន៍ដល់ប្រេតនោះ អស់កាលជាអង្វែង ។ ញាតិធម៌នោះ ឈ្មោះថា មហាបពិត្រ បានសម្តែងជាបែបយ៉ាងហើយ ការបូជាដ៏ថ្លៃថ្លាចំពោះប្រេតទាំងឡាយ ឈ្មោះ

ថា បានធ្វើហើយផង កម្ចាំងកាយនៃភិក្ខុទាំងឡាយ ឈ្មោះថា បានបំពេញ ឲ្យហើយផង បុណ្យឈ្មោះថា បានសន្សំទុក មិនមែនតិចឡើយផង ។

តិរោកុដ្ដកណ្ឌ ចប់

អដ្ឋកថា

តិរោកុដ្ដ កណ្ឌ

ប្រយោជន៍នៃការតាំងបទព្រះសូត្រ

[៨] *ឥឡូវនេះ ដល់លំដាប់ពណ៌នាទុវតិរោកុដ្ដសូត្រ ដែលលើកឡើងចំពោះលំដាប់ បន្ទាប់អំពីរតនសូត្រ ដោយន័យជាដើមថា* **តិរោកុដ្ដេសុ តិដ្ឋន្តិ** *ជាដើម នឹងពោលប្រយោជន៍នៃការតាំងតិរោកុដ្ដសូត្រនេះ ក្នុងទីនេះហើយទើបពណ៌នាសេចក្តី ។*

ក្នុងសេចក្តីនោះ សេចក្តីពិត តិរោកុដ្ដសូត្រនេះ ព្រះមានព្រះភាគ ក៏មិនបានត្រាស់តាមលំដាប់នេះ តែក៏ទ្រង់សម្តែងកិច្ចបដិបត្តិកុសលកម្មនេះបានដោយប្រការផ្សេងៗ មុនព្រះសូត្រនេះ ព្រោះបុគ្គលប្រមាទក្នុងកិច្ចបដិបត្តិកុសលកម្មនោះ កាលកើតក្នុងឋានៈដែលសៅហ្មងជាងនរក និងកំណើតសត្វ

តិវច្ឆាន ក៏រមែងកើតក្នុងជំពូកប្រែតបែបនោះ ដូច្នោះ ទើបព្រះមានព្រះភាគ ត្រាស់រតនសូត្រ ដើម្បីសម្តែងថា បុគ្គលមិនគួរធ្វើសេចក្តីប្រមាទក្នុងកិច្ចបដិ-បត្តិកុសលកម្មនោះ និងដើម្បីរម្ងាប់ឧបទ្រវនៃក្រុងវេសាលី ដែលពួកភូតទាំង-ទ្បាយណា បៀតបៀនហើយ ឬត្រាស់ដើម្បីសម្តែងថា ក្នុងពួកភូតទាំងនោះ មានភូតពួកខ្លះ មានរូបរាងបែបនោះ គប្បីជ្រាបប្រយោជន៍នៃការតាំង តិរោកុឌ្ឌសូត្រនោះ ក្នុងទីនេះ ។

អនុមោទនាកថា

តែព្រោះតិរោកុឌ្ឌសូត្រ បុគ្គលណាប្រកាស ប្រកាសទីណា ប្រកាសក្នុងកាលណា ប្រកាសព្រោះហេតុអ្វី ពណ៌នាសេចក្តីនៃតិរោកុឌ្ឌសូត្រនោះ ការប្រកាសតិរោកុឌ្ឌសូត្រនោះអស់ហើយ កាលធ្វើតាមលំដាប់ ឈ្មោះថា ធ្វើល្អហើយ ដូច្នោះ ខ្ញុំនឹងពណ៌នាសេចក្តីនោះយ៉ាងនោះដូចគ្នា ។

ពាក្យថា **តិរោកុឌ្ឌសូត្រ** *នេះ បុគ្គលណាប្រកាស ប្រកាសទីណា ប្រកាសក្នុងកាលណា ប្រកាសព្រោះហេតុអ្វី សូមចង្អុលបង្ហាញថា តិរោកុឌ្ឌសូត្រ ព្រះមានព្រះភាគ ទ្រង់ប្រកាស តិរោកុឌ្ឌសូត្រនោះឯង ទ្រង់ប្រកាស ដើម្បីអនុមោទនាដល់ព្រះបាទមគធរដ្ឋក្នុងថ្ងៃស្អែក ដើម្បីធ្វើសេចក្តីនេះឲ្យជាក់ច្បាស់ គួរពោលរឿងពិស្តារ ក្នុងសេចក្តីនេះ ដូច្នេះ ។*

ក្នុងកប្បទី ៩២ បន្ទាប់អំពីកប្បនេះ មាននគរឈ្មោះកាសី ក្នុងនគរនោះ ព្រះរាជាឈ្មោះថា ជយសេន ព្រះទេវីរបស់ព្រះរាជានោះ ព្រះនាមថា សិរិមា ព្រះពោធិសត្វព្រះនាមថា ផុស្ស: កើតក្នុងព្រះគភ៌របស់ព្រះនាង ត្រាស់ដឹង

សម្មាសម្ពោធិញ្ញាណតាមលំដាប់ ព្រះរាជាជ័យសេនទ្រង់កើតការដឹងដល់ការកើតរបស់ព្រះអង្គថា ឱរសរបស់អញចេញបួស ទើបបានជាព្រះពុទ្ធ ព្រះពុទ្ធក៏ជារបស់អញ ព្រះធម៌ក៏ជារបស់អញ ព្រះសង្ឃក៏ជារបស់អញ ទ្រង់ឧបដ្ឋាកដោយព្រះអង្គគ្រប់កាល មិនព្រមប្រទានឱកាសដល់បុគ្គលដទៃៗឡើយ ។

បងប្អូនរបស់ព្រះមានព្រះភាគ មាតាដទៃ ៣ អង្គ នាំគ្នាត្រិះរិះថា ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់កើតឡើងដើម្បីជាប្រយោជន៍ដល់សត្វលោកទាំងពួង មិនមែនដើម្បីជាប្រយោជន៍ដល់បុគ្គលម្នាក់ប៉ុណ្ណោះឡើយ តែព្រះបិតារបស់អញ ទ្រង់មិនប្រទានឱកាសដល់អញ និងមនុស្សដទៃៗ សោះ អញនឹងបានឧបដ្ឋាកដូចម្តេចហ្ន៎ ។ ទើបព្រះរាជឱរសទាំងនោះ សម្រេចព្រះហឫទ័យថា យើងនឹងធ្វើឧបាយណាមួយ ។ ស្តេចទាំង ៣ អង្គឲ្យចៅហ្វាយស្រុកជាយដែនធ្វើហាក់បីដូចជាណ្តើមស្រុក ។ បន្ទាប់អំពីនោះ ព្រះរាជាទ្រង់ឮថាចៅហ្វាយស្រុកជាយដែនបះបោរ ទើបទ្រង់បញ្ជូនរាជឱរសទាំង ៣ អង្គចេញទៅបង្ក្រាប ។ ព្រះឱរសទាំងនោះបង្ក្រាបស្រេចហើយ ក៏យាងត្រឡប់មក ព្រះរាជាទ្រង់សប្បាយព្រះរាជហឫទ័យ ទ្រង់ព្រះរាជទានពរថា អ្នកប្រាថ្នារបស់ណាក៏ចូរទទួលរបស់នោះ ។ ព្រះរាជឱរសទាំង ៣ ក្រាបទូលថា ខ្ញុំព្រះអង្គប្រាថ្នាឧបដ្ឋាកព្រះមានព្រះភាគ ព្រះរាជាត្រាស់ថា រៀវពរនោះចេញ ទទួលពរដទៃចុះ ។ ព្រះរាជឱរសក្រាបទូលថា ពួកទូលបង្គំមិនប្រាថ្នាពរដទៃទេ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ អ្នកចូរកំណត់កាល មកហើយទទួលចុះ ។ ព្រះ

រាជាឱរសសូម ៧ ឆ្នាំ ព្រះរាជាទ្រង់មិនព្រះរាជទាន ទើបព្រះរាជឱរសទូលសូមបន្ថយចុះយ៉ាងនេះ គឺ ៦ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ ៧ ខែ ៦ ខែ ៥ ខែ ៤ ខែ រហូតដល់ ៣ ខែ ទើបព្រះរាជាថា បាន ។ ព្រះរាជឱរសទាំងនោះ បានទទួលព្រះរាជទានពរហើយ ក៏ទ្រង់ត្រេកអរក្រៃលែង ចូលគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គប្រាថ្នានឹងឧបដ្ឋាកទ្រង់អស់ត្រៃមាស សូមទ្រង់មេត្តាទទួលចាំវស្សាអស់ត្រៃមាសនេះ សម្រាប់ខ្ញុំព្រះអង្គផងចុះ ។ ព្រះមានព្រះភាគក៏ទ្រង់ទទួលដោយតុណ្ហីភាព ។ បន្ទាប់អំពីនោះ ព្រះរាជឱរសទាំង ៣ អង្គ ក៏បញ្ជូនហត្ថលេខា ចាត់ចែងដល់ភ្នាក់ងារអ្នករក្សាសួយក្នុងជនបទរបស់ព្រះអង្គថា ខ្ញុំនឹងឧបដ្ឋាកព្រះមានព្រះភាគអស់កាល ៣ ខែនេះ អ្នកចូររៀបចំគ្រឿងប្រកបការឧបដ្ឋាកព្រះមានព្រះភាគ ឲ្យព្រមគ្រប់ប្រការ តាំងអំពីសាងវិហារជាដើមទៅ ។ ម្ចាស់ភ្នាក់ងារអ្នករក្សាសួយនោះ រៀបចំចាត់ចែងគ្រប់យ៉ាងហើយ ក៏បញ្ជូនសំបុត្រឲ្យទ្រង់ជ្រាប ។ ព្រះរាជឱរសទាំងនោះ ក៏ស្លៀកដណ្តប់កាសាវពស្ត្រ ទ្រង់ឧបដ្ឋាកព្រះមានព្រះភាគដោយគោរព ដោយបុរសវេយ្យាវច្ចៈ ២៥០០ នាក់ នាំព្រះមានព្រះភាគទៅកាន់ជនបទ ថ្វាយព្រះវិហារឲ្យទ្រង់ចាំវស្សា ។

គហបតីបុត្រម្នាក់ ដែលជាភ្នាក់ងារក្សាឃ្លាំងរបស់ព្រះរាជឱរសទាំងនោះ មួយអន្ទើដោយភរិយា ជាអ្នកមានបសាទសទ្ធា ចូលទៅបដិបត្តិការថ្វាយទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធានដោយគោរព ។ ភ្នាក់ងារអ្នករក្សាសួយ

ក្នុងជនបទ នាំកូនគហបតីនោះ ឲ្យធ្វើការថ្វាយដោយគោរព មួយអន្ទើដោយបុរសអ្នកជនបទប្រមាណ ១១០០០ នាក់ ។ បណ្តាមនុស្សទាំងនោះ ជនពួកខ្លះ មានចិត្តត្រេកអរសប្បាយ និងមច្ឆរិយៈគ្របសង្កត់ ជនទាំងនោះក៏នាំគ្នាធ្វើអន្តរាយដល់ទាន ដោយសុីទេយ្យធម៌ខ្លួនឯងខ្លះ ឲ្យដល់កូនរបស់ខ្លួនខ្លះ និងយកភ្លើងដុតរោងទាន ។ កាលបវារណាចេញវស្សា ព្រះរាជឱរសទាំងឡាយ ក៏ទ្រង់ធ្វើសក្ការៈក្រៃលែងដល់ព្រះមានព្រះភាគ តាមព្រះមានព្រះភាគ ចូលទៅគាល់ព្រះរាជបិតា ។ ព្រះមានព្រះភាគ យាងទៅក្នុងទីនោះហើយ ក៏បរិនិព្វាន ។ ព្រះរាជា ព្រះឱរស ភ្នាក់ងារអ្នករក្សាសួយក្នុងជនបទ និងអ្នកភ្នាក់ងារ អ្នករក្សាឃ្លាំង ធ្វើកាលកិរិយាទៅតាមលំដាប់ កើតក្នុងស្ថានសួគ៌ មួយអន្ទើដោយបរិស័ទ និងបរិវារ ។ ពួកជនដែលមានចិត្តត្រេកអរសប្បាយ និងមច្ឆរិយៈគ្របសង្កត់ ក៏នាំគ្នាទៅកើតក្នុងនរកទាំងឡាយ ។ ជនទាំង ២ ពួកនោះ ចេញពីស្ថានសួគ៌ ចូលដល់ស្ថានសួគ៌ ចេញអំពីនរកទៅកើតនរក ដោយប្រការដូច្នេះ ។ កប្បកន្ទងទៅហើយ ៩២ កប្ប ។

តមក ក្នុងកទ្ទកប្បនេះ កាលព្រះពុទ្ធព្រះនាមថាកស្សប ជនដែលមានចិត្តត្រេកអរសប្បាយ និងមច្ឆរិយៈគ្របសង្កត់ទាំងនោះ ក៏កើតជាប្រេត ។ កាលនោះ មនុស្សទាំងឡាយថ្វាយទាន ឧទ្ទិសដើម្បីប្រយោជន៍ដល់ពួកប្រេតដែលជាញាតិរបស់ខ្លួនថា សូមទាននេះ មានដល់ពួកញាតិរបស់ខ្ញុំ ។ ប្រេតទាំងនោះក៏បានសម្បត្តិ ។ ខណៈនោះ ប្រេតទាំងនោះឃើញដូច្នោះ ក៏ចូលទៅគាល់ព្រះមានព្រះភាគកស្សបសម្មុទ្ធ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធ្វើម្តេចហ្ន៎ ទើប

ពួកខ្ញុំបានសម្បត្តិខ្លះ ។ ព្រះមានព្រះភាគត្រាស់ថា ឥឡូវនេះ ពួកអ្នកមិនទាន់បានទេ តែក្នុងអនាគត នឹងមានព្រះពុទ្ធព្រះនាមថាគោតម ក្នុងកាលរបស់ព្រះមានព្រះភាគអង្គនោះ នឹងមានព្រះរាជាព្រះនាមថាពិម្ពិសារ ទ្រង់ជាញាតិរបស់ពួកអ្នក រាប់អំពីនេះថយទៅ ៩២ កប្ប ទ្រង់នឹងថ្វាយទានដល់ព្រះពុទ្ធឧទ្ទិសចំណែកកុសលដល់ពួកអ្នក កាលនោះ ទើបពួកអ្នកបានបរិភោគ ។ បានឮថា កាលព្រះពុទ្ធមានព្រះតម្រាស់យ៉ាងនេះហើយ ព្រះពុទ្ធតម្រាស់នោះ បានប្រោកជដល់ប្រេតទាំងនោះ ហាក់បីដូចជាត្រាស់ថា ពួកអ្នកនឹងបានក្នុងថ្ងៃស្អែកនេះ ។

ពេលវេលាកន្លងទៅមួយពុទ្ធន្តរ ព្រះមានព្រះភាគនៃយើងក៏កើតឡើងក្នុងលោក ។ ព្រះរាជឱរសទាំង ៣ អង្គនោះ ក៏ចុតិអំពីទេវលោក មួយអន្ទើនឹងបុរស ២៥០០ នាក់ ជនទាំងនោះ បានកើតក្នុងត្រកូលព្រាហ្មណ៍ទាំងឡាយក្នុងដែនមគធៈ បួសជាឥសីដោយលំដាប់ បានជាជដិល ៣ នាក់បងប្អូន ក្នុងគយាសីសបទេស ។ ក្នាក់ងារក្សាសួយក្នុងជនបទ បានជាព្រះបាទពិម្ពិសារ បុត្រគហបតីដែលជាក្នាក់ងារក្សាឃ្លាំង បានជាសេដ្ឋីឈ្មោះវិសាខ ភរិយារបស់គាត់បានជាធីតារបស់សេដ្ឋីឈ្មោះធម្មទិន្នា បរិស័ទដ៏សេសកើតជាព្រះរាជបរិវាររបស់ព្រះបាទពិម្ពិសារទាំងអស់ ។ ព្រះមានព្រះភាគនៃយើងទ្រង់កើតឡើងក្នុងលោក កន្លងទៅ ៧ សប្តាហ៍ ក៏យាងមកកាន់ក្រុងពារាណសីដោយលំដាប់ ប្រកាសធម្មចក្រ ប្រោសបញ្ចវគ្គិយភិក្ខុជាដើមរឿយៗ ទៅ រហូតដល់ទូន្មានជដិលទាំង ៣ នាក់ ដែលមានបរិវារ ២៥០០ នាក់ ទើបយាងទៅកាន់ក្រុង

រាជគ្រឹះ ។ ក្នុងក្រុងរាជគ្រឹះនោះ ទ្រង់ប្រោសព្រះបាទពិម្ពិសារដែលយាងចូលទៅគាល់ក្នុងថ្ងៃនោះឯង ឲ្យតាំងនៅក្នុងសោតាបត្តិផល មួយអន្ទើដោយព្រាហ្មណ៍និងគហបតី អ្នកមគធ: ដកមួយម៉ឺននាក់ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្ត្ររបស់ព្រះបាទពិម្ពិសារ ដើម្បីសោយក្នុងថ្ងៃស្អែក ។ លុះថ្ងៃស្អែកឡើង កាលសក្កទេវរាជទ្រង់សរសើរដោយគាថាទាំងឡាយ យ៉ាងនេះជាដើមថា

ឧន្តោ ឧន្តេហិ សហ បុរាណជដិលេហិ ទិប្បមុត្តោ ទិប្បមុត្តេហិ សិង្គីនិក្ខសុវណ្ណោ រាជគហំ ចាទិសិ ភគវា ។

ព្រះដ៏មានព្រះភាគ ព្រះអង្គទូន្មានហើយ (នូវឥន្ទ្រិយ) មានព្រះហឬទ័យផុតស្រឡះហើយ (ចាកអាសវធម៌) ព្រះអង្គមានពណ៌ល្អដូចដុំមាស ឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្ទើដោយពួកបុរាណជដិល ដែលជាអ្នកទូន្មានហើយ (នូវឥន្ទ្រិយ) ដែរ ជាអ្នកមានចិត្តផុតស្រឡះហើយ (ចាកអាសវធម៌) ទ្រង់ចូលកាន់ក្រុងរាជគ្រឹះ ដូច្នេះ ។

ទ្រង់ទទួលមហាទាន ក្នុងព្រះរាជនិវេសន៍របស់ព្រះបាទពិម្ពិសារ ប្រេតទាំងនោះ ឈរចោមរោម ដោយទន្ទឹងថា ឥឡូវនេះ ព្រះរាជាទ្រង់នឹងឧទ្ទិសទានដល់ពួកយើង ឥឡូវនេះ ព្រះរាជាទ្រង់នឹងឧទ្ទិសទានដល់ពួកយើង ។ ឯព្រះបាទពិម្ពិសារ ថ្វាយទានហើយ ទ្រង់ព្រះតម្រិះថា ព្រះមានព្រះភាគ គប្បីប្រថាប់នៅក្នុងទីណាហ្នឹ ទ្រង់ព្រះតម្រិះដល់រឿងទីគង់នៅ របស់ព្រះមាន

ព្រះភាគប៉ុណ្ណោះ ទ្រង់មិនបានឧទ្ទិសទាននោះដល់បុគ្គលណាឡើយ ។

ប្រេតទាំងឡាយអស់សង្ឃឹម លុះពេលរាត្រី ទើបនាំគ្នាធ្វើសំឡេងប្លែកៗ ទ្រហឹងអឺងកង គួរតក់ស្លុតក្រៃលែងក្នុងព្រះរាជនិវេសន៍ ។ ព្រះរាជាទ្រង់ស្លុតព្រះរាជហឫទ័យភ័យខ្លាច លុះព្រឹកឡើង ក៏ក្រាបទូលដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮសំឡេងបែបនេះ ហេតុកេទអ្វីនឹងមានដល់ខ្ញុំព្រះអង្គឬហ្ន៎ ។ ព្រះមានព្រះភាគត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ សូមទ្រង់កុំខ្លាចឡើយ មិនមានវត្ថុអាក្រក់ណាមួយ កើតដល់មហាបពិត្រទេ តែបុរាណញាតិរបស់មហាបពិត្រ កើតជាប្រេតមាន ប្រេតទាំងនោះ ត្រាច់រង្គាត់អស់មួយពុទ្ធន្តរ ទន្ទឹងចំពោះមហាបពិត្រថា ទ្រង់នឹងថ្វាយទានដល់ព្រះពុទ្ធ ហើយឧទ្ទិសចំណែកបុណ្យដល់ពួកគេ កាលពីមុនមិញ មហាបពិត្រ មិនបានឧទ្ទិសចំណែកកុសលដល់ប្រេតទាំងនោះ ទើបពួកប្រេតនោះអស់សង្ឃឹម នាំគ្នាបន្ទឺសំឡេងចម្លែកៗ អឺងកង ដូច្នោះ ។

ព្រះបាទពិម្ពិសារក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ កាលខ្ញុំព្រះអង្គថ្វាយទាន ពួកប្រេតទាំងនោះ គួរបានដែរឬទេ ។ ព្រះមានព្រះភាគត្រាស់ថា បាន មហាបពិត្រ ។ ព្រះបាទពិម្ពិសារក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមព្រះមានព្រះភាគទ្រង់ទទួលនិមន្ត ហើយសោយក្នុងថ្ងៃស្អែកនេះផងចុះ ខ្ញុំព្រះអង្គនឹងឧទ្ទិសទានដល់ពួកប្រេតនោះ ។ ព្រះមានព្រះភាគទ្រង់ក៏ទទួល ។ ព្រះរាជាយាងចូលព្រះរាជនិវេសន៍ ចាត់ចែងមហាទាន ហើយឲ្យក្រាបទូលកត្តកាលដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ យាង

ចូលខាងក្នុងព្រះរាជនិវេសន៍ ប្រថាប់គង់លើពុទ្ធាសនៈដែលគេរៀបចំ មួយអន្ទើដោយភិក្ខុសង្ឃ ។

ប្រេតទាំងនោះ នាំគ្នាឈរខាងក្រៅជញ្ជាំងជាដើម ដោយទន្ទឹងថា ថ្ងៃនេះពួកយើងនឹងបានអ្វីខ្លះ ។ ព្រះមានព្រះភាគ ទ្រង់បានធ្វើដោយអាការដែលប្រេតទាំងនោះ ប្រាកដដល់ព្រះរាជាគ្រប់គ្នា ។

ព្រះរាជាថ្វាយទឹកទក្ខិណោទក ឧទ្ទិសថា សូមទាននេះ មានដល់ពួកញាតិរបស់ពួកខ្ញុំ ។ រំពេចនោះឯង ស្រះបោក្ខរណី ដេរដាសដោយផ្កាឈូក ក៏កើតដល់ប្រេតទាំងនោះ ប្រេតទាំងនោះក៏ងូត និងផឹកក្នុងស្រះបោក្ខរណីនោះ រម្ងាប់សេចក្តីក្រវល់ក្រវាយ សេចក្តីលំបាក និងសេចក្តីស្រេកឃ្លានបាន ហើយមានពណ៌សម្បុរដូចមាស ។

លំដាប់នោះ ព្រះរាជា ថ្វាយយាគូ របស់ទំពា របស់បរិភោគជាដើម ហើយទ្រង់ឧទ្ទិស ។ ក្នុងរំពេចនោះឯង បបរ របស់ទំពា និងរបស់បរិភោគដែលជាទិព្វ ក៏កើតដល់ប្រេតទាំងនោះ ។ ប្រេតទាំងនោះ ក៏នាំគ្នាបរិភោគរបស់ទិព្វទាំងនោះ មានឥន្ទ្រិយឆ្អែតស្កប់ស្កល់ ។

លំដាប់នោះ ព្រះរាជាថ្វាយសំពត់ និងសេនាសនៈជាដើម ទ្រង់ឧទ្ទិសឲ្យនូវគ្រឿងអលង្ការផ្សេងៗ មានសំពត់ទិព្វ យានទិព្វ ប្រាសាទទិព្វ កម្រាល និងទីដេកជាដើម ក៏កើតឡើងដល់ពួកប្រេតទាំងនោះ ។ សម្បត្តិរបស់ពួកប្រេតទាំងនោះ ប្រាកដគ្រប់យ៉ាងដោយប្រការណា ព្រះមានព្រះភាគ ក៏ទ្រង់អធិដ្ឋានឲ្យព្រះរាជាឃើញដោយប្រការនោះ ។ ព្រះរាជាទ្រង់ត្រេកអរក្រៃលែង ។ បន្ត

អំពីនោះ ព្រះមានព្រះភាគទ្រង់សោយស្រេចហើយ ទ្រង់ហាមភត្តហើយ បានត្រាស់ព្រះគាថាទាំងនេះថា **តិរោកុឌ្ដេសុ តិដ្ឋន្តិ** *ជាដើម ដើម្បីទ្រង់អនុមោទនាដល់ព្រះបាទមគធរដ្ឋ ។*

ដោយពាក្យមានប្រមាណប៉ុណ្ណេះ មាតិកានេះថា **យេន យត្ត យថា យស្មា តិរោកុឌ្ដំ បកាសិតំ បកាសយិត្វា តំ សព្វំ** *ក៏ជាការចែកហើយទាំងដោយសង្ខេប និងដោយពិស្តារ ។*

ឥឡូវនេះ នឹងពណ៌នាសេចក្តីនៃតិរោកុឌ្ដសូត្រនេះតាមលំដាប់ គឺ

អធិប្បាយគាថាទី ១

នឹងពណ៌នាក្នុងបឋមគាថាមុន ។ ចំណែកខាងក្រៅនៃជញ្ជាំងទាំងឡាយ ហៅថា **តិរោកុឌ្ដ ។** *ពាក្យថា* **តិដ្ឋន្តិ** *ជាពាក្យពោលដល់ឥរិយាបថឈរ ព្រោះហាមឥរិយាបថអង្គុយជាដើម ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ដល់ពួកប្រេត ដែលឈរត្រង់ចំណែកជនៃជញ្ជាំងក្នុងទីនេះថា* **តិរោកុឌ្ដេសុ តិដ្ឋន្តិ** *ឈរនៅត្រង់ខាងក្រៅជញ្ជាំង ដូចលោកពោលដល់បុគ្គលដែលសម្តែងឫទ្ធិផ្សេងៗ ដែលទៅក្នុងចំណែកជនៃកំពែង និងចំណែកជនៃក្តាំថា ទៅក្រៅកំពែង ក្រៅក្តាំ មិនទើសទាក់ ដូច្នោះ ។ ក្នុងពាក្យថា* **សន្ធិសិង្ឃាដកេសុ ច** *នោះ ផ្លូវដែលមានមុំ ៤ ឬត្រង់ទី-តនៃផ្ទះ និងទី-តនៃជញ្ជាំង និងមាត់បង្អួច លោកហៅថា* **សន្ធិ ។** *ផ្លូវបែកជា ៣ លោកហៅថា* **សិង្ឃាដក ។** *ព្រះមានព្រះភាគ ទ្រង់ធ្វើពាក្យនោះកន្លែងតែមួយ ភ្ជាប់ជាមួយពាក្យដើម ទើបត្រាស់ថា* **សន្ធិសិង្ឃាដកេសុ ច ។** *បទថា* **ទ្វារពាហាសុ**

តិដ្ឋន្តិ បានដល់ ឈរផ្អែកទ្វារព្រះនគរ និងទ្វារផ្ទះ ។ ផ្ទះញោតិអំពីមុនក្តី ផ្ទះរបស់ខ្លួនដែលធ្លាប់គ្រប់គ្រងក្តី ឈ្មោះថា ផ្ទះរបស់ខ្លួន ក្នុងពាក្យថា **អាគន្ត្វាន សកំ ឃរំ** នេះ ។ ព្រោះហេតុដែលប្រេតទាំងនោះ នាំគ្នាមកដោយសក-សញ្ញា គឺសម្គាល់ថាជាផ្ទះរបស់ខ្លួន ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ដល់ផ្ទះទាំង ២ នោះថា **អាគន្ត្វាន សកំ ឃរំ** ប្រែថា មកកាន់ផ្ទះរបស់ខ្លួន ។

អធិប្បាយគាថាទី ២

ព្រះមានព្រះភាគ កាលទ្រង់បង្ហាញដល់ព្រះរាជា នូវប្រេតជាច្រើនដែលនាំគ្នាមកកាន់ព្រះរាជនិវេសន៍ របស់ព្រះបាទពិម្ពិសារ ដែលជាផ្ទះញោតិក្នុងកាលមុន សូម្បីខ្លួនមិនធ្លាប់គ្រប់គ្រងមក ដោយសម្គាល់ថា ជាផ្ទះរបស់ខ្លួន ឈរនៅខាងក្រៅជញ្ជាំង ត្រង់ផ្លូវបែកជា ៤ ផ្លូវបែកជា ៣ និងត្រង់សន្ទះទ្វារ សោយផលនៃសេចក្តីច្រណែន និងសេចក្តីកំណាញ់ ពួកខ្លះមានពុកមាត់ និងសក់វែង មានមុខខ្មៅ មានអវយវៈតូចធំចងដោយចំណងធូរខ្លះ តឹងខ្លះ មានសក់កន្ទ្រើង ដូចដើមត្នោតត្រូវភ្លើងឆេះ ឈរបង្ហាញខ្លួនក្នុងទីនោះៗ ពួកខ្លះមានសរីរៈត្រូវភ្លើងឆេះខាងក្នុងពោះ អណ្តាតភ្លើងចេញតាមមាត់ ព្រោះការត្រជុសគ្នានៃឈើកួតភ្លើង គឺសេចក្តីស្រេកឃ្លានដុតរោល ពួកខ្លះ មិនបានផឹករសជ្រៃ ក្រៅអំពីរស គឺសេចក្តីស្រេកឃ្លាន ព្រោះសូម្បីបានផាយទឹក ក៏មិនអាចបរិភោគបានតាមត្រូវការ ព្រោះមានបំពង់កប៉ុនគូថម្ជុល និងមានពោះធំដូចភ្នំ ពួកខ្លះ មានសរីរៈមិនគួរមើល វិកល វិការ គួរឲ្យខ្ពាចពន់ពេក បានទឹកខ្ទុះ ទឹកឈាម ទឹករំអិលជាដើម ដែលហូរចេញអំពីបូសដែលបែកនៃ

គ្នានិងគ្នា ឬរបស់សត្វដទៃ លិទ្ធក្រែបដូចទឹកអម្រឹត ទើបត្រាស់ថា

ប្រែតទាំងឡាយ មកកាន់ផ្ទះនៃញាតិ ដោយគិតថាជា
ផ្ទះរបស់ខ្លួន ហើយឈរនៅជិតខាងក្រៅជញ្ជាំង
ទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវបែបជា ៣
ទាំងឡាយខ្លះ ជិតទ្វារក្រុង និងទ្វារផ្ទះទាំងឡាយខ្លះ ។

កាលទ្រង់សម្តែងភាពដែលកម្មរបស់ប្រែតទាំងនោះធ្វើមកហើយ ជាកម្ម ធ្ងន់ ទើបត្រាស់គាថាទី ២ ថា **បហូតេ អន្នបានម្ហិ** *ជាដើម ។*

បណ្តាបទទាំងនោះ បទថា **បហូតេ** *បានដល់ មិនតិច ។ លោកអធិប្បាយថា ច្រើន រហូតល្មមត្រូវការ ។ ផ្ទាស់ ៣ ជា* **ប** *ដូចក្នុងប្រយោគជាដើមថា* **បហុសន្តោ ឯ ភរតិ** *បុគ្គលមានច្រើនក៏មិនចិញ្ចឹម ។ តែអាចារ្យពួកខ្លះសូត្រថា* **បហូតេ** *ក៏មាន* **ពហូកេ** *ក៏មាន ។ បាឋៈទាំងនោះ ជាបាឋៈដែលសរសេរដោយការភ្លាត់ ។ បាយផង ទឹកផង ឈ្មោះថា បាយ និងទឹករបស់ទំពាផង របស់បរិភោគផង ឈ្មោះថា របស់ទំពា និងរបស់បរិភោគ ។ ព្រះមានព្រះភាគទ្រង់សម្តែងអាហារ ៤ យ៉ាង គឺរបស់ស៊ី របស់ផឹក របស់ទំពា និងរបស់លិទ្ធភ្ជក្សដោយបទនេះ ។ បទថា* **ឧបដ្ឋិតេ** *បានដល់ ចូលទៅតាំងទុក ។ លោកអធិប្បាយថា ចាត់ចែង តាក់តែង រួបរួម ។ បទថា* **ឯកោបិ តេសំ សរតិ សត្តានំ** *សេចក្តីថា កាលសត្វទាំងនោះកើតក្នុងបិត្តិវិស័យ បុគ្គលណាម្នាក់ ជាមាតាក្តី បុត្រក្តី ក៏មិនរឭកដល់ ។ ព្រោះហេតុអ្វី ព្រោះកម្មជាបច្ច័យ គឺព្រោះមច្ឆរិយកម្មដែលខ្លួនធ្វើមាន ដោយបដិសេធការ*

ទទួល និងការឲ្យជាដើមជាបច្ច័យ ព្រោះកម្មរបស់សត្វទាំងនោះ មិនឲ្យញាតិនីកឃើញ ។

អធិប្បាយគាថាទី ៣

ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា មិនមានញាតិណាមួយ ដែលល្មមរឭកដល់ ព្រោះកម្មដែលមានវិបាកជាទុក្ខក្តៅផ្សា ដែលសត្វទាំងនោះធ្វើ ទុកជាបច្ច័យដល់សត្វដែលជាប្រេតទាំងនោះ ដែលត្រាច់ទន្ទឹងចំពោះញាតិទាំង-ឡាយថា កាលបាយទឹកជាដើម មិនមែនតិច ដែលញាតិចូលទៅតាំងទុកក្នុងសង្ឃ គួរតែញាតិទាំងឡាយ គប្បីឲ្យអ្វីមួយ ឧទ្ទិសដល់ពួកយើងខ្ញុះ យ៉ាងនេះ ទើបត្រាស់ថា

កាលបើបាយទឹក បង្អែម និងចំអាបមានគ្រប់គ្រាន់ ដែលពួកញាតិតាក់តែងហើយ មិនមានញាតិណាមួយនឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយជាបច្ច័យ ។ កាលទ្រង់សរសើរភាពដែលព្រះរាជាថ្វាយឧទ្ទិសដល់ព្រះញាតិរបស់ព្រះរាជា ដែលកើតក្នុងបិត្តិវិស័យ ទើបត្រាស់ព្រះគាថាទី ២ ថា **ឯវំ ទទន្តិ ញាតីនំ** *ជាដើម ។*

បណ្តាបទទាំងនោះ បទថា **ឯវំ** *ជាពាក្យឧបមា ។ ពាក្យថា* **ឯវំ** *នោះសម្ពន្ធជា ២ នัយ គឺ*

ជនណា ជាអ្នកអាណិតអាសូរ ជនទាំងនោះ រមែងឲ្យបាយទឹកជាដើមដើម្បីញាតិទាំងឡាយ កាលញាតិណាមួយ រឭកមិនបាន ព្រោះកម្មរបស់សត្វទាំងនោះជាបច្ច័យយ៉ាងនេះ ១ ។ ថ្វាយព្រះពរមហាបពិត្រ ជនទាំងឡាយណា

ជាអ្នកអាណិតអាសូរ ជនទាំងនោះ រមែងឲ្យបាយទឹកដ៏ស្អាតប្រណីត ជាកប្បិយ គួរតាមកាល ដើម្បីញាតិទាំងឡាយ ដូចមហាបពិត្រថ្វាយទានដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **ទទន្តិ** *បានដល់ ឲ្យ ឧទ្ទិស ប្រគល់ឲ្យ ។ បទថា* **ញាតីនំ** *បានដល់ ជនដែលទាក់ទងខាងមាតា និងខាងបិតា ។ បទថា* **យេ** *បានដល់ ពួកណានីមួយ ជាបុត្រក្តី ធីតាក្តី បងប្អូនក្តី ។ បទថា* **ហោន្តិ** *ប្រែថា រមែងមាន ។ បទថា* **អនុកម្បកា** *បានដល់ បុគ្គលបំណងប្រយោជន៍ បុគ្គលស្វែងរកប្រយោជន៍ ។ បទថា* **សុចិ** *បានដល់ ឥតមន្ទិល គួរសរសើរ ត្រេកអរ កើតឡើងដោយធម៌ បានមកដោយធម៌ ។ បទថា* **បណីតំ** *បានដល់ ឧត្តម ប្រសើរបំផុត ។ បទថា* **កាលេន** *បានដល់ តាមកាល ដែលពួកប្រេតជាញាតិមកឈរខាងក្រៅជញ្ជាំងជាដើម ។ បទថា* **កប្បិយំ** *បានដល់ គួរ សមគួរ គួរបរិភោគរបស់ព្រះអរិយៈទាំងឡាយ ។ បទថា* **ចានភោជនំ** *បានដល់ ទឹកផង បាយផង ឈ្មោះថា* **ចានភោជនំ** ។ *ក្នុងទីនេះ លោកបំណងយកទេយ្យធម៌គ្រប់យ៉ាង ដោយលើកទឹក និងបាយឡើងជាប្រធាន ។*

អធិប្បាយគាថាទី ២ សម្ពន្ធនឹងគាថាទី ៣

ព្រះមានព្រះភាគ កាលទ្រង់សរសើរបាយ និងទឹក ដែលព្រះបាទមគធរាជទ្រង់ថ្វាយ ដើម្បីអនុគ្រោះដល់ពួកព្រះញាតិ ដែលជាប្រេតយ៉ាងនេះ ទើបត្រាស់ថា

ញាតិទាំងឡាយណា ជាអ្នកអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឲ្យនូវទឹក និងភោជនដ៏ហ្មត់ចត់ ដ៏ប្រសើរ ជារបស់គួរតាមកាល ដល់ញាតិទាំងឡាយ យ៉ាងនេះ ។ កាលទ្រង់សម្តែងប្រការដែលទានឲ្យហើយឈ្មោះថា ឲ្យដើម្បីញាតិទាំងនោះទៀត ទើបត្រាស់ពាក់កណ្តាលខាងដើមនៃគាថាទី ៤ ថា **ឥទំ ហោ ញាតីនំ ហោតុ** *ជាដើម គប្បីសម្ពន្ធអត្ថ និងកន្លះដើមគាថានៃគាថាទី ៣ ថា ញាតិទាំងឡាយណា ជាអ្នកអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឲ្យនូវទឹក និងភោជនដ៏ហ្មត់ចត់ ដ៏ប្រសើរ ជារបស់គួរតាមកាលដល់ញាតិទាំងឡាយ យ៉ាងនេះថា ទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ បានដល់នូវសេចក្តីសុខ ។ ដោយហេតុនោះ ដូចអាការដែលគប្បីឲ្យ ជាការធ្វើហើយ ដោយ* **ឯវំ** *សព្ទ ដែលមានអត្ថថា អាការ ក្នុងពាក្យថា ជនទាំងនោះ រមែងឲ្យដោយអាការយ៉ាងនេះថា សូមទាននេះឯង មានដល់ញាតិទាំងឡាយ មិនមែនដោយអាការដទៃ ។*

បណ្តាបទទាំងនោះ បទថា **ឥទំ** *ជាបទសម្តែងគំរូនៃទេយ្យធម៌ ។ បទថា* **ហោ** *ត្រឹមតែជានិបាតតែម្យ៉ាង មិនមែនឆដ្ឋីវិភត្តិ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា* **កច្ចិ បន ហោ អន្តរុន្ធា សមគ្គា សម្មោទមានា ។** *និងថា* **យេហិ ហោ អរិយា ។** *បទថា* **ញាតីនំ ហោតុ** *សេចក្តីថា ចូរមានដល់ញាតិទាំងឡាយ ដែលកើតក្នុងបិត្តិវិស័យ ។ បទថា* **សុខិតា ហោន្តុ ញាតយោ** *សេចក្តីថា សូមពួកញាតិដែលចូលដល់បិត្តិវិស័យទាំងនោះ ចូរជាអ្នកសោយផលទាននេះ មានសេចក្តីសុខចុះ ។*

អធិប្បាយចុងគាថាទី ៤ សម្ពន្ធនឹងដើមគាថាទី ៥

ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រការដែលទាន ដែលញាតិគប្បីឲ្យដល់ញាតិទាំងឡាយ ដែលចូលដល់បិត្តិវិស័យ ទើបត្រាស់ថា សូមទាននេះឯង មានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ បាននូវសេចក្តីសុខដូច្នេះ ព្រោះហេតុដែលព្រះមានព្រះភាគត្រាស់ថា សូមទាននេះឯង មានដល់ញាតិទាំងឡាយ កម្មដែលបុគ្គលណាមួយធ្វើហើយ រមែងមិនឲ្យផលដល់បុគ្គលម្នាក់ទៀត តែវត្ថុនោះដែលញាតិឲ្យឧទ្ទិសយ៉ាងនោះតែម្យ៉ាង រមែងជាបច្ច័យដល់កុសលកម្មនៃញាតិទាំងឡាយ ដូច្នោះ កាលទ្រង់សម្តែងប្រការដែលកុសលកម្ម ដែលឲ្យកើតផលក្លាមៗ ព្រោះវត្ថុនោះឯងទៀត ទើបត្រាស់ដល់កន្ទះគាថាក្រោយនៃគាថាទី ៤ ថា **តេ ច តត្ថ** និងកន្ទះគាថាខាងដើមនៃគាថាទី ៥ ថា **បហ្វតេ អន្នចានម្ហិ** ។

កន្ទះគាថាដើម និងកន្ទះគាថាក្រោយ នៃគាថាទាំងនោះ មានសេចក្តីថា លោកអធិប្បាយថា ប្រេតដែលជាញាតិទាំងនោះមកដោយជុំវិញ មកប្រជុំរួមគ្នា ក្នុងទីមួយកន្លែង ដែលញាតិឲ្យទាននោះ លោកអធិប្បាយថា ប្រេតទាំងនោះ មកដោយប្រពៃ មករួមគ្នា មកព្រមគ្នា ដើម្បីសេចក្តីត្រូវការយ៉ាងនេះថា ញាតិទាំងឡាយរបស់យើងនឹងឧទ្ទិសទាននេះ ដើម្បីជាប្រយោជន៍ដល់យើងទាំងឡាយ ។ បទថា **បហ្វតេ អន្នចានម្ហិ** សេចក្តីថា ក្នុងបាយទឹកដែលញាតិឲ្យឧទ្ទិសដើម្បីខ្លួនមានច្រើននោះ ។ បទថា **សក្កច្ចំ អនុមោទរេ** សេចក្តីថា ប្រេតទាំងនោះជឿមាំលើផលនៃកម្ម មិនលះបង់នូវការគោតក្រែង មានចិត្តមិនញាប់ញ័រ រមែងត្រេកអរអនុមោទនា កើតបីតិបាមោជ្ជថា ទាននេះ

ចូរមានផល ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងទាំងឡាយ ។

អធិប្បាយចុងគាថាទី ៥ ភ្ជាប់នឹងដើមគាថាទី ៦

ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រការដែលកុសលកម្ម ឲ្យផលកើតភ្លាមៗ ដល់ញាតិទាំងឡាយ ដែលចូលដល់បិត្តិវិសយយ៉ាងនេះ ទើបត្រាស់ថា

ចំណែកប្រេតជាញាតិ ជាអ្នកមកប្រជុំគ្នាទាំងនោះ មកជួបជុំគ្នា ហើយ ក្នុងមន្ទីរឲ្យទាននោះ កាលបើបាយ និងទឹកមានល្មមគ្រាន់ ក៏អនុមោទនាដោយគោរព ។

កាលទ្រង់សម្តែងអាការសរសើរ ច្រារឰញាតិទាំងឡាយរបស់ប្រេតទាំងនោះ ទើបសោយផលនៃកុសលកម្ម ដែលកើតព្រោះអាស្រ័យពួកញាតិទៀត ទើបត្រាស់កន្ទះគាថាក្រោយ នៃគាថាទី ៥ ថា **ចិរំ ជីវន្តុ** *និងកន្ទះគាថាដើមនៃគាថាទី ៦ ថា* **អម្ហាកញ្ច កតា បូជា ។**

កន្ទះគាថាក្រោយ និងកន្ទះគាថាដើម នៃគាថាទាំងនោះ មានសេចក្តីថា បទថា **ចិរំ ជីវន្តុ** *បានដល់ មានជីវិតនៅយូរ មានអាយុវែង ។ បទថា* **ញាតី** *ប្រែថា ញាតិទាំងឡាយរបស់ពួកយើង ។ បទថា* **យេសំ** **ហេតុ** *បានដល់ ព្រោះអាស្រ័យញាតិទាំងឡាយណា ព្រោះហេតុនៃញាតិពួកណា ។ បទថា* **លភាម្ហសេ** *ប្រែថា បាន ។ ពួកប្រេតពោលអាងសម្បត្តិដែលខ្លួនបានក្នុងខណៈនោះ ។*

ពិតហើយ ទក្ខិណា រមែងសម្រេចផល គឺកើតផលក្នុងខណៈនោះបានក៏ដោយអង្គ ៣ គឺដោយការអនុមោទនារបស់ប្រេតទាំងឡាយ ១ ដោយការ

ឧទ្ទិសរបស់ទាយកទាំងឡាយ ១ ដោយការដល់ព្រមនៃទក្ខិណេយ្យបុគ្គល ១ ។

បណ្តាអង្គទាំង ៣ នោះ ទាយកទាំងឡាយ ជាហេតុពិសេស ដោយហេតុនោះ ទើបប្រេតទាំងឡាយពោលថា **យេសំ ហេតុ លភាម្ហសេ** *ប្រែថា រមែងបាននូវព្រោះហេតុនៃញាតិពួកណា ។ បទថា* **អម្ហាកញ្ច កតា បុជា** *សេចក្តីថា និងញាតិទាំងឡាយដែលឧទ្ទិសទាននេះ យ៉ាងនេះថា សូមទាននេះ មានដល់ញាតិទាំងឡាយរបស់យើង ដូច្នេះ ឈ្មោះថា ធ្វើការបូជាពួកយើងហើយ ។ បទថា* **ទាយកា ច អនិប្ផលា** *សេចក្តីថា កម្មដែលសម្រេចមកអំពីការបរិច្ចាគ ដែលទាយកធ្វើហើយក្នុងសន្តានណា ទាយកទាំងឡាយឈ្មោះថា មិនឥតផល ក៏ព្រោះកម្មនោះឲ្យផលក្នុងសន្តាននោះប៉ុណ្ណោះ ។ ក្នុងសេចក្តីនេះ បុគ្គលអ្នកចោទសួរពោលថា ញាតិទាំងឡាយ ចូលដល់បិត្តិ-វិស័យបានប៉ុណ្ណោះឬ ឬថា សូម្បីបុគ្គលដទៃៗ ក៏បាន ។ សូមចង្អុលបង្ហាញដូច្នេះ ព្រះមានព្រះភាគត្រូវព្រាហ្មណ៍ឈ្មោះជាណុស្សោណិទូលសួរហើយ ក៏ទ្រង់ព្យាករសេចក្តីនេះដូច្នេះថា ក្នុងសេចក្តីនេះ តថាគតគប្បីពោលពាក្យណា ។ សមដូចព្រះសង្គីតិកាចារ្យពោលដូច្នេះថា*

> *បពិត្រព្រះគោតមដ៏ចម្រើន យើងជាព្រាហ្មណ៍ តែងឲ្យទាន តែងធ្វើអំពើ ដែលគេគប្បីធ្វើដោយសទ្ធា ហើយឧទ្ទិសថា ទាននេះ សូមឲ្យសម្រេចផល ដល់ប្រេតទាំងឡាយ ជាញាតិសាលោហិត ពួកប្រេតទាំងឡាយ ជាញាតិសា-លោហិត សូមបរិភោគនូវទាននេះ បពិត្រព្រះគោតមដ៏*

ចម្រើន ចុះទាននោះ នឹងសម្រេចផលដល់ប្រេតទាំងឡាយ ជាញាតិសាលោហិតដែរឬទេ ប្រេតទាំងឡាយ ជាញាតិ-សាលោហិតនោះ នឹងបរិភោគនូវទាននោះ បានដែរឬទេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ទាននេះ សម្រេចផលក្នុងទីគួរ មិនសម្រេចផលក្នុងទីមិនគួរ ។ បពិត្រព្រះគោតមដ៏ចម្រើន ទីដែលគួរ តើដូចម្តេច ទីដែលមិនគួរ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ពោល ពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្តីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតក្នុងនរក អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយកើតក្នុងនរក សត្វនរកនោះ តែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងនរកនោះ ដោយសារអាហារនោះ សត្វនរកនោះឋិតនៅក្នុងនរកនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ មានសេចក្តីយល់ខុស បុគ្គលនោះ លុះបែកធ្លាយ

រាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតនៃតិរច្ឆាន អាហារ
ណា ជាអាហារសម្រាប់សត្វទាំងឡាយ ដែលកើតក្នុង
កំណើតតិរច្ឆាន សត្វតិរច្ឆាននោះ ក៏ញុំាងអត្តភាពឲ្យប្រ-
ព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ សត្វតិរច្ឆាននោះ
ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍
ទាននោះមិនសម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា
ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ ចំណែក
ឯបុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណា-
តិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកមុសា-
វាទ វៀរស្រឡះចាកបិសុណវាចា វៀរស្រឡះចាកផរុស-
វាចា វៀរស្រឡះចាកសម្ផប្បលាប ជាអ្នកមិនមានអភិជ្ឈា
មិនមានចិត្តព្យាបាទ មានសេចក្តីយល់ត្រូវ បុគ្គលនោះ
លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងពួកមនុស្ស
អាហារណា ជាអាហារសម្រាប់ពួកមនុស្ស បុគ្គលនោះ ក៏
ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ
បុគ្គលនោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ
ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផល ដល់សត្វ
ដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថា ទីមិនគួរ ។
ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នក

វៀរស្រឡះចាកបាណាតិបាត ។បេ។ មានសេចក្តីយល់ត្រូវ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងពួកទេវតា អាហារណាជាអាហារសម្រាប់ពួកទេវតា ទេវតានោះ ក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ទេវតានោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ មានសេចក្តីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងបិត្តិវិស័យ អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយ ដែលកើតក្នុងបិត្តិវិស័យ ប្រេតនោះ ក៏ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ប្រេតនោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ឬក៏ពួកមិត្តអាមាត្យក្តី ជនជាញាតិសាលោហិតក្តី ឧទ្ទិសឲ្យនូវទានណា ដល់ប្រេតនោះ អំពីលោកនេះ ប្រេតនោះ ក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ប្រេតនោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ សម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯងហៅថាទីគួរ ។

ជានុស្សោណិព្រាហ្មណ៍ទូលសួរថា

បពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើប្រេត ជាញាតិ-សាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ តើអ្នកណា បរិភោគទាននោះ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា

អើព្រាហ្មណ៍ ពួកប្រេតដែលជាញាតិសាលោហិតដទៃទៀតរបស់គេ គង់ទៅកើតក្នុងទីនោះមិនខាន ប្រេតទាំងនោះឯង បរិភោគទាននោះ ។

ជានុស្សោណិព្រាហ្មណ៍ទូលសួរថា

បពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើប្រេតជាញាតិសាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ ទាំងពួកប្រេត ជាញាតិសាលោហិតដទៃទៀតរបស់គេ ក៏មិនបានទៅកើតក្នុងទីនោះដែរ តើអ្នកណា បរិភោគទាននោះ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា

អើ ព្រាហ្មណ៍ ទីណាដែលស្វាត់ចាកប្រេតទាំងឡាយ ជាញាតិសាលោហិត ដោយកាលជាយូរអង្វែងនេះ ទីនោះមិនមែនជាហេតុ មិនមែនជាឱកាស គឺថា មិនធ្លាប់មានឡើយ ម្នាលព្រាហ្មណ៍ មួយទៀត ធម្មតាអ្នកឲ្យទាន មិនមែនជាគ្មានផលទេ ។

អធិប្បាយ ចុងគាថាទី ៦ ភ្ជាប់នឹងដើមគាថាទី ៧

ព្រះមានព្រះភាគ កាលទ្រង់សរសើរព្រះរាជា ព្រោះអាស្រ័យសម្បត្តិរបស់ពួកព្រះញាតិក្នុងជាតិមុនរបស់ព្រះបាទមគធរដ្ឋ ដែលចូលដល់បិត្តិវិស័យ ទើបទ្រង់សម្តែងថា សូមថ្វាយព្រះពរ ព្រះញាតិរបស់មហាបពិត្រទាំងនោះ ត្រេកអរ នាំគ្នាសរសើរក្នុងទានសម្បទានេះ ទើបត្រាស់ថា

> យើងទាំងឡាយ បានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយណា សូមពួកញាតិរបស់យើងទាំងឡាយនោះ រស់នៅយឺនយូរ ការបូជាដែលញាតិទាំងឡាយ ធ្វើហើយ ដល់យើងទាំងឡាយក្តី ញាតិទាំងឡាយ ជាអ្នកឲ្យទានក្តី មិនមែនជាឥតផលទេ្បីយ ដូច្នេះ ។

កាលទ្រង់សម្តែងការមិនមានហេតុដែលឲ្យបានសម្បត្តិដទៃ មានកសិកម្ម និងគោរក្ខកម្មជាដើមរបស់ពួកប្រេត ដែលចូលដល់បិត្តិវិស័យទាំងនោះ និងភាពដែលពួកប្រេតទាំងនោះ ញុំាងជីវិតឲ្យប្រព្រឹត្តទៅដោយទាន ដែលញាតិឲ្យអំពីមនុស្សលោកនេះ ទើបត្រាស់កន្ទុះគាថាក្រោយនៃគាថាទី ៦ ថា **ន ហិ តត្ថ កសី អត្ថិ** និងគាថាទី ៧ នេះថា **វណិជ្ជា តាទិសី** ជាដើម ។

ក្នុងគាថានោះ ពណ៌នាសេចក្តីដូច្នេះ សូមថ្វាយព្រះពរ ក្នុងបិត្តិវិស័យនោះ មិនមានកសិកម្ម ដែលពួកប្រេតទាំងនោះនឹងអាស្រ័យហើយ បាននូវសម្បត្តិ ។ បទថា **គោរក្ខេត្ត ន វិជ្ជតិ** សេចក្តីថា មិនមែនមិនមានកសិកម្មតែម្យ៉ាងប៉ុណ្ណោះទេ ក្នុងបិត្តិវិស័យនោះ សូម្បីតែគោរក្ខកម្មក៏មិនមាន ដែលពួកប្រេតទាំងនោះអាស្រ័យហើយ បានសម្បត្តិ ។ បទថា **វណិជ្ជា តាទិសី**

ឧត្តិ សេចក្តីថា មិនមានការជួញដូរ ដែលជាហេតុឲ្យបានសម្បត្តិនៃពួកប្រេតទាំងនោះ ។ បទថា **ហិរញ្ញេន កយាកយំ** សេចក្តីថា ក្នុងបិត្តិវិស័យនោះ មិនមាន សូម្បីតែការជួញដូរដោយប្រាក់ ដែលជាហេតុឲ្យបានសម្បត្តិរបស់ពួកប្រេតទាំងនោះ ។

បទថា **ឥតោ ទិន្នេន យាបេន្តិ បេតា កាលកតា តហិំ** សេចក្តីថា តែពួកប្រេត រមែងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយទានដែលពួកញាតិ ឬពួកមិត្តសម្ងាញ់ឲ្យទៅអំពីមនុស្សលោកនេះតែម្យ៉ាង ។ បទថា **បេតា** បានដល់ ពួកសត្វដែលចូលដល់បិត្តិវិស័យ ។ បទថា **កាលកតា** បានដល់ ទៅតាមពេលស្លាប់របស់ខ្លួន ។ អធិប្បាយថា ធ្វើកាលកិរិយា ធ្វើមរណកាល ។ បទថា **តហិំ** បានដល់ បិត្តិវិស័យនោះ ។

អធិប្បាយគាថាទី ៨ និង៩

ព្រះមានព្រះភាគ កាលត្រាស់ថា បុគ្គលធ្វើកាលកិរិយាទៅហើយ តែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងបិត្តិវិស័យនោះ ដោយទានដែលពួកញាតិ មិត្តសម្ងាញ់ឲ្យហើយអំពីមនុស្សលោកនេះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ប្រកាសសេចក្តីនោះ ដោយឧបមាទាំងឡាយ ទើបត្រាស់ ២ គាថានេះថា **ឧន្នតេ ឧទកំ វុដ្ឋំ** ជាដើម ។

គាថានោះ មានសេចក្តីថា ទឹកដែលធ្លាក់ពីលើមេឃ ស្រក់ចុះលើទីទួលលើទីភូមិភាគដែលខ្ពស់ រមែងហូរចុះទៅកាន់ទីទាប គឺហូរទៅដល់ភូមិភាគដែលទាប យ៉ាងណា ទានដែលពួកញាតិ មិត្តសម្ងាញ់ឲ្យ អំពីមនុស្សលោក

នេះ រមែងសម្រេចផល អធិប្បាយថា កើតផល ប្រាកដផលដល់ពួកប្រេត ដូច្នោះដូចគ្នា ។ ពិតហើយ បេតលោក ឈ្មោះថា ហានៈ គឺទីតាំងនៃសេចក្តីសម្រេចផលនៃទាន ដូចជាទីទាប ជាហានៈដែលដក់ទឹកហូរមក ដូចព្រះតម្រាស់ត្រាស់ថា ម្នាលព្រាហ្មណ៍ ទាននោះ សម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯងហៅថា ទីគួរ ។ ឧបមាដូចទឹកដែលហូរអំពីជ្រោះ ញកភ្នំអូរធំ អូរតូច បឹង ស្ទឹងធំ រមែងធ្វើសាគរ គឺសមុទ្រឲ្យពេញ យ៉ាងណា ទានដែលញាតិមិត្ត សម្ថាញ់ ឲ្យទៅអំពីមនុស្សលោកនេះ រមែងសម្រេចផល ដល់ពួកប្រេត តាមន័យដែលពោលមកអំពីមុនហើយ ដូច្នោះ ។

អធិប្បាយគាថាទី ៧០

ព្រះមានព្រះភាគ កាលទ្រង់ប្រកាសសេចក្តីនេះថា បុគ្គលកាលធ្វើកាលកិរិយាទៅហើយ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងបិត្តិវិស័យ ដោយទានដែលញាតិមិត្តសម្ថាញ់ឲ្យទៅអំពីមនុស្សលោកនេះ ដូច្នេះហើយ កាលទ្រង់សម្តែងគាថា ព្រោះហេតុដែលពួកប្រេតទាំងនោះ ទន្ទឹងថា ពួកយើងនឹងបានអ្វីមួយអំពីមនុស្សលោកនេះ នាំគ្នាមកដល់ផ្ទះញាតិហើយ ក៏មិនអាចសូមថា សូមអ្នកទាំងឡាយឲ្យរបស់ឈ្មោះនេះដល់ពួកខ្ញុំចុះ ដូច្នោះ កុលបុត្រកាលរឭកដល់វត្តុដែលគួររឭកទាំងនេះ គប្បីឲ្យទក្ខិណា ដើម្បីពួកប្រេតទាំងនោះ ទើបត្រាស់គាថានេះថា **អទាសិ មេ** *ជាដើម ។*

គាថានោះ មានសេចក្តីថា កុលបុត្រកាលរឭកគ្រប់យ៉ាង យ៉ាងនេះថា អ្នកបានឲ្យទ្រព្យ ឬធញ្ញាហារនេះដល់អញ អ្នកបានព្យាយាមដោយខ្លួនឯង

បានធ្វើកិច្ចឈ្មោះនេះដល់អញ បុគ្គលនោះជាញាតិ ព្រោះទាក់ទងខាងមាតា ឬខាងបិតារបស់អញ បុគ្គលនោះជាមិត្ត ព្រោះអាចជួយស្រោចស្រង់ ដោយសេចក្តីស្រឡាញ់ ហើយបុគ្គលនោះ ជាសម្ងាញ់លេងជីជាមួយគ្នា របស់អញ ដូច្នេះ គប្បីឲ្យទក្ខិណា គប្បីបង្អោនទានឲ្យដល់បុគ្គលដែលស្លាប់ទៅហើយ ។

មានបាឋៈដទៃទៀតថា **បេតានំ ទក្ខិណា ទជ្ជា** ។ បាឋៈនោះមានអត្ថថា ឈ្មោះថា **ទជ្ជា** ព្រោះជារបស់ដែលគប្បីឲ្យ ។ របស់ដែលគប្បីឲ្យនោះ គឺអ្វី គឺទក្ខិណា ដើម្បីបុគ្គលដែលស្លាប់ទៅហើយ ដោយហេតុនោះ កុលបុត្រកាលរឭកដល់បុគ្គលនោះ អធិប្បាយថា កាលរឭកដល់កិច្ចដែលបុគ្គលនោះធ្វើមកអំពីមុន ដោយន័យថា បុគ្គលនោះបានឲ្យវត្ថុនោះដល់អញ ដូច្នេះជាដើម ។ ពាក្យនេះ គប្បីជ្រាបថា ជាបឋមាវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ ។

អធិប្បាយគាថាទី ១១

ព្រះមានព្រះភាគ កាលទ្រង់សម្តែងអនុស្សរណវត្ថុ ដែលជាហេតុក្នុងការប្រគល់ឲ្យនូវទក្ខិណាដើម្បីពួកប្រេតយ៉ាងនេះ ទើបត្រាស់ថា

បុគ្គលកាលរឭកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួន ក្នុងកាលមុនថា អ្នកនេះបានឲ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះដល់អញ ជនទាំងឡាយនោះ ជាញាតិមិត្ត ជាសម្ងាញ់របស់អញ ដូច្នេះហើយ គួរឲ្យទក្ខិណាទាន ចំពោះប្រេតទាំងឡាយ ។

កាលទ្រង់សម្តែងទៀតថា ជនទាំងឡាយណា មានការទ្រហោយំ និងការសោយសោកជាដើមជាខាងមុខ ព្រោះការស្លាប់របស់ញាតិតាំងនៅ ។ បុគ្គល

ដែលស្លាប់ទៅហើយ រមែងមិនឲ្យប្រយោជន៍ណាមួយដល់ជនទាំងនោះ ការទ្រហោយំ និងការសោយសោកជាដើមនៃជនទាំងនោះ មានតែធ្វើខ្លួនឲ្យក្តៅក្រហាយតែម្យ៉ាងប៉ុណ្ណោះ រមែងមិនញុំាងប្រយោជន៍ណាមួយឲ្យសម្រេចដល់បុគ្គលដែលស្លាប់ទៅហើយឡើយ ទើបត្រាស់គាថានេះថា **ន ហិ រុណ្ណំ វា** *ជាដើម ។*

បណ្តាបទទាំងនោះ បទថា **រុណ្ណំ** *បានដល់ ការកន្ទក់កន្ទេញ ការស្រក់ទឹកភ្នែក ការសម្តែងសេចក្តីលំបាកកាយដោយបទនេះ ។ បទថា* **សោកោ** *បានដល់ ការសុបសៅ ការសោកសង្រេង ។ ទ្រង់សម្តែងសេចក្តីលំបាកផ្លូវចិត្តដោយបទនេះ ។ បទថា* **យាវញ្ញា** *បានដល់ ឬក្រៅអំពីការយំសោកណា ។ បទថា* **បរិទេវនា** *បានដល់ ការយំរៀបរាប់ពណ៌នាដល់គុណដោយន័យថា ឱ ! កូនតែមួយជាទីស្រឡាញ់ ជាទីពេញចិត្ត កូននៅឯណាដូច្នេះជាដើម របស់បុគ្គលដែលត្រូវញាតិព្យសនៈពាល់ត្រូវហើយ ។ ទ្រង់សម្តែងការលំបាកវាចាដោយបទនេះ ។*

អធិប្បាយគាថាទី ១២

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការយំជាដើម មិនជាប្រយោជន៍ថាការយំដទៃទាំងអស់ មិនមានប្រយោជន៍ដល់អ្នកដែលស្លាប់ទៅហើយ ដែលពិតនោះ មានតែធ្វើខ្លួនឲ្យក្តៅក្រហាយតែម្យ៉ាងប៉ុណ្ណោះ ញាតិទាំងឡាយក៏គង់នៅយ៉ាងនោះ ដូច្នេះហើយ កាលទ្រង់សម្តែងកាពដែលទក្ខិណាដែលព្រះបាទមគធរាជទ្រង់ថ្វាយហើយ មានប្រយោជន៍ ទើបត្រាស់គាថានេះថា **អយញ្ច**

ខោ ឧក្កិណ្ណា *ជូច្នេះជាដើម ។*

គាថានោះ មានសេចក្តីថា សូមថ្វាយព្រះពរ ទក្ខិណានេះឯង មហាបពិត្រ ថ្វាយឧទ្ទិសដល់ពួកព្រះញាតិ របស់មហាបពិត្រក្នុងថ្ងៃនេះ ព្រោះហេតុដែល ព្រះសង្ឃជាស្រែបុណ្យដ៏កំពូលនៃលោក ជូច្នោះ ទក្ខិណានោះ គប្បីជាទក្ខិណា ដែលទ្រង់បានតម្កល់ល្អហើយក្នុងសង្ឃ ទើបសម្រេចផល លោកអធិប្បាយ ថា សម្រេចផល ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់បេតជន អស់ កាលយូរ ។ បទថា **ឧបកប្បតិ** *បានដល់ សម្រេចផលដោយហេតុ គឺសម្រេច ផលក្នុងខណៈភ្លាមៗ មិនយូរឡើយ ។ ដូចការដែលជាក់ច្បាស់ក្នុងវារៈពេចនោះ ក៏ត្រាស់ថា សេចក្តីនោះជាក់ច្បាស់ដល់តថាគតដោយហេតុ យ៉ាងណា ទក្ខិណា ដែលសម្រេចផលក្នុងវារៈពេចនោះ ក្នុងទីនេះ ក៏ត្រាស់ថា សម្រេចផលដោយ ហេតុ ជូច្នោះ ។ ហេតុណាត្រាស់ថា ម្នាលព្រាហ្មណ៍ ទាននោះ រមែង សម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថាទីគួរ ជូច្នេះ ។ ទក្ខិណាដែលសម្រេចផលក្នុងហេតុនោះដោយប្រការទ មានខុប្បិបាសិកប្រេត វន្តាសាប្រេត បរទត្តជីវីប្រេត និងនិជ្ឈាមតណ្ហិកប្រេតជាដើម ក៏ត្រាស់ថា រមែងសម្រេចផលដោយហេតុ ដូចឲ្យកហាបណៈក្នុងលោក គេក៏សន្មតថា បុគ្គលនោះឲ្យកហាបណៈ ជូច្នោះ ។ តែក្នុងអត្ថវិកប្បនេះ បទថា* **ឧបកប្បតិ** *បានដល់ ប្រាកដផល លោកអធិប្បាយថា កើតផល ។*

អធិប្បាយគាថាទី ១៣

ព្រះមានព្រះភាគ កាលទ្រង់សម្តែងទក្ខិណា ដែលព្រះរាជាថ្វាយហើយ

មានប្រយោជន៍យ៉ាងនេះ ទើបត្រាស់ថា

លុះតែទក្ខិណាទាននេះ ដែលបុគ្គលបានឲ្យហើយ តម្កល់ទុកប្រពៃហើយក្នុងសង្ឃ ទើបសម្រេចផលដោយរួសរាន់ ដើម្បីប្រយោជន៍ដល់ប្រេតនោះ អស់កាលជាអង្វែង ដូច្នេះ ។

ព្រោះញាតិធម៌ដែលព្រះរាជាទ្រង់ថ្វាយទក្ខិណានេះ ទ្រង់សម្តែងហើយ ដោយទ្រង់ធ្វើកិច្ចដែលពួកញាតិគួរធ្វើដល់ពួកញាតិ ទ្រង់ធ្វើឲ្យច្រោកដដល់ជនជាច្រើន ឬទ្រង់លើកជាគំរូថា ញាតិធម៌ អ្នកទាំងឡាយក៏គប្បីបំពេញដោយការធ្វើកិច្ចដែលពួកញាតិគប្បីធ្វើយ៉ាងនោះដូចគ្នា មិនគប្បីធ្វើខ្ជិនឲ្យក្តៅក្រហាយដោយការយំជាដើម ដែលឥតប្រយោជន៍ ការបូជាពួកប្រេត ដែលព្រះរាជាទ្រង់ញ៉ាំងពួកប្រេតទាំងនោះឲ្យជួបនូវទិព្វសម្បត្តិ ទ្រង់ធ្វើហើយយ៉ាងឱឡារឯកម្ងាំងរបស់កិកូទាំងឡាយ ដែលព្រះរាជាទ្រង់អង្គាសកិកូសង្ឃ មានព្រះសម្ពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹកជាដើម ឈ្មោះថាទ្រង់បន្តែមឲ្យហើយ ឯបុណ្យមិនមែនតិច ដែលព្រះរាជាទ្រង់ញ៉ាំងចាគចេតនាមានគុណ គឺសេចក្តីអនុគ្រោះជាដើម ដែលជាបរិវារឲ្យកើត ក៏ទ្រង់ជួបហើយដូច្នោះ កាលទ្រង់ញ៉ាំងព្រះរាជាឲ្យត្រេកអរដោយគុណតាមសេចក្តីពិតទាំងនេះទៀត ទើបទ្រង់បញ្ចប់ទេសនា ដោយព្រះគាថានេះថា

ញាតិធម៌នោះ ឈ្មោះថា មហាបពិត្រ បានសម្តែងជាបែបយ៉ាងហើយ ការបូជាដ៏ថ្លៃថ្លាចំពោះប្រេតទាំងឡាយ ឈ្មោះថា បានធ្វើហើយផង កម្ងាំងកាយនៃកិកូទាំងឡាយ ឈ្មោះ

ថា បានបំពេញឲ្យហើយផង បុណ្យ ឈ្មោះថា បានសន្សំទុក មិនមែនតិចឡើយផង ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ចង្អុលបង្ហាញព្រះរាជាដោយធម្មីកថា ដោយបទគាថានេះថា **សោ ញាតិធម្មោ ច អយំ និទស្សិតោ។** *សេចក្តីពិត ការសម្តែងញាតិធម៌នេះឯង ជាការចង្អុលបង្ហាញរឿយៗ ក្នុងសេចក្តីនេះ ។ ទ្រង់ទូន្មានដោយបទគាថានេះថា* **បេតានបូជា ច កតា ឧឡារា** *សេចក្តីពិត ការសរសើរថា* **ឧឡារា** *ក៏ជាការដឹកនាំដោយការបូជារឿយៗ ក្នុងសេចក្តីនេះ ទ្រង់ឲ្យអាចហ៊ាន ដោយបទគាថានេះថា* **ឥលញ្ច ភិក្ខូនម-ន្តុប្បទិន្នំ។** *សេចក្តីពិត ការបន្តែមកម្លាំងដល់ភិក្ខុទាំងឡាយ ក៏ជាទានយ៉ាងនេះមួយបែបក្នុងសេចក្តីនេះ ។ ពាក្យថា បានបំពេញនូវកម្លាំង ជាការជាំបណ្តុះ ឲ្យអាចហ៊ាន ដោយការបន្តែមនូវឧស្សាហ៍ដល់ព្រះរាជានោះ ។ ទ្រង់ឲ្យក្សៀវក្សា ដោយបទគាថានេះថា* **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ។** *សេចក្តីពិត ការសម្រេច ដល់ការជួបនូវបុណ្យនោះឯង គប្បីជ្រាបថា ជាការឲ្យកើតនូវសេចក្តីត្រេកអរ ដោយពណ៌នាគុណតាមសេចក្តីពិត ដល់ព្រះរាជានោះក្នុងសេចក្តីនេះ ។*

ចប់ទេសនា ការសម្រេចធម៌មានដល់សត្វ ៨៤០០០ ដែលសង្វេគ ព្រោះពណ៌នាទោសនៃការចូលដល់បិត្តិវិស័យ ហើយតាំងសេចក្តីព្យាយាមដោយឧបាយជ្រាជ្រា ។ ក្នុងថ្ងៃស្អែកឡើង ព្រះមានព្រះភាគ ក៏ទ្រង់សម្តែងតិរោកុដ្ដសូត្រនេះឯងដល់ទេវតា និងមនុស្សទាំងឡាយ ការត្រាស់ដឹងធម៌យ៉ាងនោះ

មានរហូត ៧ ថ្ងៃ ដោយប្រការដូច្នេះ ។

អដ្ឋកថា តិរោកុដ្ដសូត្រ

នៃ

អដ្ឋកថា តិរោកុដ្ដសូត្រ ចប់

សុត្តន្តបិដក

ខុទ្ទកនិកាយ ឯកកនិបាត

[៩] បុរសកប់កំណប់ទ្រព្យទុកក្នុងទីជ្រៅ ជាទីបំផុតនៃទឹក ដោយគិតថា កាលបើកិច្ចដែលត្រូវការកើតឡើងហើយ ទ្រព្យនេះនឹងបានជាប្រយោជន៍ដល់អាត្មាអញ ដែលត្រូវពួកមច្ចាមិត្តពោលបង្គាប់នឹងបានដោះខ្លួនចេញពីស្តេច ឬត្រូវចោរបៀតបៀន នឹងបានដោះខ្លួនចេញពីចោរ នឹងបានដោះបំណុល ឬក្នុងពេលទុរ្ភិក្ស ឬក៏ក្នុងកាលអន្តរាយទាំងឡាយ ធម្មតាកំណប់ដែលគេកប់ទុកក្នុងលោក ដើម្បីប្រយោជន៍នេះឯង ។ កំណប់ដែលបុគ្គលកប់ក្នុងទីជ្រៅ មានទីបំផុតទល់នឹងទឹក ដល់ម្ល៉ោះ កំណប់ទ្រព្យទាំងអស់នោះក៏មិនសម្រេចដល់បុគ្គលនោះសព្វកាលទេ ដ្បិតថា កំណប់ទ្រព្យរមែងឃ្លាតទៅចាកទីខ្លះ សេចក្តីចំណាំរបស់បុគ្គលនោះ រមែងវង្វេងទៅខ្លះ នាគទាំងឡាយរមែងនាំជញ្ជូនទៅខ្លះ ពុំនោះសោត ពួកយក្សនាំយកទ្រព្យនោះទៅខ្លះ អ្នកទទួលមត៌កដែលមិនជាទីស្រឡាញ់ រមែងគាស់យកនូវកំណប់ទ្រព្យនោះ កាលខ្លួនមិនបានឃើញខ្លះ ខ្លួនអស់បុណ្យទៅវេលាណា កំណប់ទ្រព្យទាំងអស់នោះ រមែងវិនាសបាត់បង់ទៅក្នុងវេលានោះ ។ កំណប់ទ្រព្យដែលស្ត្រីឬបុរសណា បានកប់ទុកល្អហើយ ដោយទាន សីល ដោយការសង្រួម និងដោយការទូន្មានខ្លួន ក្នុងចេតិយ ឬក្នុងសង្ឃ ឬក្នុងបុគ្គល ឬក្នុងពួកភ្ញៀវ ឬមួយក្នុងមាតា ក្នុងបិតា ឬថា ក្នុងបងប្រុស-ស្រីដែលជាច្បង កំណប់ទ្រព្យនោះ ចាត់ជាកំណប់ទ្រព្យដែលកប់ទុកប្រពៃហើយ នរណាៗ មិនគប្បីផ្តាច់

បាន ជាកំណាប់ទ្រព្យដែលជាប់តាមខ្លួនទៅ កាលភោគៈទាំងឡាយ ដែលខ្លួន ត្រូវលះបង់ហើយទៅ ខ្លួនរមែងកាន់យកនូវកំណាប់ទ្រព្យ គឺបុណ្យនុ៎ះទៅ កំណាប់ទ្រព្យ គឺបុណ្យ មិនទូទៅដល់ពួកជនដទៃ ជារបស់ដែលចោរលួចទៅ មិនបាន ។ កំណាប់ទ្រព្យ គឺបុណ្យណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញ គួរ ធ្វើនូវកំណាប់ទ្រព្យ គឺបុណ្យនោះ កំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ឲ្យនូវសេចក្តី ប្រាថ្នាគ្រប់យ៉ាង ដល់ទេវតា និងមនុស្សទាំងឡាយ ពួកទេវតា និងមនុស្ស ទាំងឡាយ ប្រាថ្នាណាស់នូវផលណាៗ ផលទាំងពួងនោះៗ រមែងបានដោយ កំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ ភាពជាអ្នកមានសម្បុរផូរផង់ មានសំឡេងពីរោះ ទ្រង់ទ្រាយល្អ រូបល្អ ជាអធិបតី មានយសបរិវារ ផលទាំងអស់ រមែងបាន ដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ ភាពជាស្តេចប្រទេសរាជ ឥស្សរិយយស សេចក្តីសុខរបស់ស្តេចចក្រពត្តិ ជាទីស្រឡាញ់ ភាពជាស្តេចនៃទេវតា ក្នុង ទេវនិកាយទាំងឡាយ ផលទាំងអស់ រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យ នុ៎ះ ។ សម្បត្តិជារបស់មនុស្សណាមួយ សេចក្តីត្រេកអរ ក្នុងទេវលោកណា មួយ សម្បត្តិ គឺព្រះនិព្វានណាមួយ សម្បត្តិទាំងអស់ រមែងបានដោយកំណាប់ ទ្រព្យ គឺបុណ្យនុ៎ះ ។ ភាពនៃបុគ្គលកាលអាស្រ័យមិត្តសម្បទា បើប្រកប សេចក្តីព្យាយាម ដោយឧបាយដែលត្រូវ ជាអ្នកស្ទាត់ក្នុងវិជ្ជា និងវិមុត្តិឥដ្ឋ-ផលទាំងអស់ បានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ បដិសម្ភិទា វិមោក្ខ សាវកបារមីញាណ បច្ចេកពោធិញាណ និងពុទ្ធភូមិណាៗ ឥដ្ឋផលទាំងអស់ រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ បុញ្ញសម្ភទានោះ ឲ្យសម្រេច

ប្រយោជន៍ដ៏ធំ ដោយប្រការដូច្នេះ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ជាធីរជន ទើបសរសើរនូវភាពនៃបុគ្គលជាអ្នកមានបុណ្យបានធ្វើហើយ ។

និធិកណ្ឌ ចប់

អដ្ឋកថា
និធិកណ្ឌ

ហេតុដែលតាំងព្រះសូត្រ

[៩] *និធិកណ្ឌសូត្រនេះ ខ្ញុំលើកឡើងដោយនយថា* **និធឺ និធេតិ បុរិសោ** *ជាដើម បន្ទាប់អំពីលំដាប់តិរោកុដ្ដសូត្រ ឥឡូវនេះ ខ្ញុំនឹងពោលនិក្ខេបបទ និងសម្តែងអត្ថុប្បត្តិហេតុនៃនិធិកណ្ឌសូត្រក្នុងទីនេះហើយ នឹងពណ៌នាសេចក្តីនៃនិធិកណ្ឌសូត្រនោះ ។*

បណ្តាហេតុទាំង ២ នោះ ក្នុងទីនេះ គប្បីជ្រាបហេតុតាំង (និក្ខេបបទ) នៃនិធិកណ្ឌសូត្រនេះសិន ។ ពិតហើយ និធិកណ្ឌសូត្រនេះ ព្រះមានព្រះភាគមិនបានត្រាស់តាមលំដាប់នេះ ព្រោះជាសូត្រគួគ្នានឹងតិរោកុដ្ដសូត្រ ព្រោះទាក់ទងដោយការអនុមោទនា ដូច្នោះ ទើបខ្ញុំលើកឡើងក្នុងទីនេះ ។ ឬថា គប្បីជ្រាបថា ខ្ញុំកាលសម្តែងវិបត្តិនៃពួកជនដែលប្រាសចាកបុណ្យ ដោយតិរោកុដ្ដសូត្រហើយ ទើបលើកនិធិកណ្ឌសូត្រនេះតាំងទុកក្នុងទីនេះ ក៏ដើម្បី

សម្តែងសម្បត្តិនៃពួកជន ដែលធ្វើបុណ្យទុកដោយសូត្រនេះ ។ និក្ខេបបទនៃនិធិកណ្ឌសូត្រនោះ ទុកក្នុងទីនេះប៉ុណ្ណោះ ។

អត្តុប្បត្តិហេតុ

និធិកណ្ឌសូត្រនេះ កើតឡើងដោយហេតុដូច្នេះថា បានឮថា ក្នុងក្រុងសាវត្ថី កុដុម្ពិកៈម្នាក់ ស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន តែបុគ្គលនោះ ជាអ្នកមានបសាទសទ្ធា មានចិត្តជ្រះថ្លាកមន្ទិល គឺសេចក្តីកំណាញ់នៅគ្រប់គ្រងផ្ទះ ។ ថ្ងៃមួយ គាត់ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន សម័យនោះ ព្រះរាជាមានព្រះបំណងត្រូវការទ្រព្យ ទើបបញ្ជូនរាជបុរសម្នាក់ ទៅក្នុងសម្នាក់របស់គាត់ ដោយព្រះរាជបញ្ជាថា អ្នកចូរទៅនាំកុដុម្ពិកៈឈ្មោះនេះមក ។ រាជបុរសនោះ ទៅនិយាយនឹងកុដុម្ពិកៈនោះថា នែគហបតី ព្រះរាជាអញ្ជើញអ្នក ។ កុដុម្ពិកៈមានចិត្តប្រកបដោយគុណ មានសទ្ធាជាដើម កំពុងអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទើបពោលថា នែរាជបុរស អ្នកទៅមុនចុះ ខ្ញុំទៅឯក្រោយ ខ្ញុំកំពុងកប់ទ្រព្យក្នុងខណៈនេះសិន ។ ព្រះមានព្រះភាគទ្រង់សោយស្រេច ទ្រង់ដកព្រះហស្តចេញអំពីបាត្រហើយ ។ ដើម្បីទ្រង់សម្តែងបុញ្ញសម្បទា ដោយនិធិបរមត្ថ បានត្រាស់ព្រះគាថាទាំងនេះថា **និធឹ និធេតិ បុរិសោ** *ជាដើម ដើម្បីអនុមោទនាដល់កុដុម្ពិកៈនោះ ។ និធិកណ្ឌសូត្រនេះ មានអត្តុប្បត្តិហេតុដូចពោលមកដូច្នេះ ។*

ខ្ញុំពោលនិក្ខេបបទ និងសម្តែងអត្តុប្បត្តិហេតុនៃនិធិកណ្ឌសូត្រទុកក្នុងទីនេះហើយ នឹងពណ៌នាអត្ថនៃនិធិកណ្ឌសូត្រនោះដូចតទៅនេះ

អធិប្បាយគាថាធី ១

បណ្តាបទទាំងនោះ បទថា **និធី និធេតិ បុរិសោ** សេចក្តីថា ឈ្មោះថា **និធិ** ព្រោះកប់ អធិប្បាយថា តាំងទុក រក្សាទុក ។ និធិនោះមាន ៤ គឺ ថាវរនិធិ ១ ជង្គមនិធិ ១ អង្គសមនិធិ ១ អនុគាមិកនិធិ ១ ។ បណ្តានិធិ ៤ នោះ ទ្រព្យដែលជាប់ផែនដីក្តី ទ្រព្យដែលតាំងនៅក្នុងអាកាសក្តី ប្រាក់ក្តី មាសក្តី ស្រែក្តី ដីកូមិក្តី ឬទ្រព្យបែបនោះដទៃណាមួយ ដែលមិនអាចកម្រើកដោយខ្លួនឯងបាន ឈ្មោះថា **ថាវរនិធិ** ។ ខ្ញុំស្រី ខ្ញុំប្រុស ដីរ គោ សេះ លា ពពែ ចៀម មាន់ ជ្រូក ឬទ្រព្យដែលមានសភាពបែបនោះដទៃណាមួយ ដែលប្រកបដោយការកម្រើកបានខ្លួនឯង ឈ្មោះថា **ជង្គម** កំណប់ទ្រព្យនេះ ឈ្មោះថា **ជង្គមនិធិ** ។ ពាហុសច្ចៈ ដែលជាប្រភពកើតការងារ ជាប្រភពកើតសិប្បៈ ជាទីតាំងនៃវិជ្ជាការ ឬពហុសច្ចៈដែលមានសភាពបែបនោះដទៃណាមួយ ដែលសិក្សាហើយសិក្សាទៀត ជំនាញជាប់ខ្លួន ប្រៀបដូចអវយវៈតូចធំ ឈ្មោះថា **អង្គសម** គឺទ្រព្យស្មើដោយអវយវៈ ទ្រព្យនេះ ឈ្មោះថា **អង្គសមនិធិ** ។ បុណ្យដែលសម្រេចដោយទាន ដែលសម្រេចដោយសីល ដែលសម្រេចដោយភាវនា បុណ្យដែលសម្រេចដោយការស្តាប់ធម៌ ដែលសម្រេចដោយការសម្តែងធម៌ ឬបុណ្យបែបនោះដទៃណាមួយ ដែលឲ្យផលគួរជាទីប្រាថ្នា ហាក់ដូចជាជាប់តាមទៅក្នុងទីនោះៗ ឈ្មោះថា **អនុគាមិក** គឺជាប់តាមទៅបាន ។ កំណប់ទ្រព្យនេះ ឈ្មោះថា **អនុគាមិកនិធិ** ។ ចំណែកក្នុងទីនេះ ទ្រង់បំណងយកថាវរនិធិ ។

បទថា **និធេតិ** បានដល់ តាំងទុក សន្សំទុក រក្សាទុក ។ បទថា **បុរិសោ**

បានដល់ មនុស្ស ។ បុរសក្តី ស្ត្រីក្តី ខ្ទើយក្តី រមែងកប់ទ្រព្យបានក៏ពិត តែក្នុងទីនេះ ទ្រង់ធ្វើទេសនា ដោយបុរសជាសំខាន់ តែដោយអត្ថ គប្បីឃើញថា ទ្រង់ប្រមូលមនុស្សទាំងនោះទុកក្នុងទីនេះ ។ បទថា **គម្ភីរេ ឧទកន្តិកេ** *សេចក្តីថា ដែលឈ្មោះថា* **គម្ភីរ** *ព្រោះអត្ថថា ឈមចុះបាន ឈ្មោះថា* **ឧទកន្តិក** *ព្រោះជាទីមានទឹកជាទីបំផុត ។ ទីជ្រៅតែមិនមានទឹកជាទីបំផុតក៏មាន ដូចគ្នានឹងអណ្តូងជម្រៅ ១០០ ជួរបុរស ក្នុងផែនដីត្រង់ទីទួល ។ ទីដែលមានទឹកជាទីបំផុត តែមិនជ្រៅក៏មាន ដូចជាអណ្តូងជម្រៅ ១-២ ហត្ថ ក្នុងទីដែលមានកក់ ។ ទីដែលជ្រៅផង មានទឹកជាបំផុតផងក៏មាន ដូចអណ្តូងដែលគេជីកក្នុងផែនដីត្រង់ទីទួល រហូតដល់ទឹកហូរមកក្នុងកាលនោះ ។ ពាក្យថា* **គម្ភីរេ ឧទកន្តិកេ** *នេះ គ្រាស់សំដៅដល់ទីជ្រៅដែលមានទឹកជាទីបំផុតនោះ ។*

បទថា **អត្តេ កិច្ចេ សមុប្បន្នេ** *សេចក្តីថា ឈ្មោះថា* **អត្ត** *ព្រោះមិនប្រាសចាកប្រយោជន៍ ។ លោកអធិប្បាយថា នាំមកនូវប្រយោជន៍ នាំមកនូវឧបការៈ ។ ឈ្មោះថា* **កិច្ច** *ព្រោះគួរធ្វើ ។ លោកអធិប្បាយថា ករណីណាមួយដែលកើតឡើងហើយនោះឯង ឈ្មោះថា* **សមុប្បន្ន** *។ លោកអធិប្បាយថា ដែលតាំងឡើងហើយ ដោយភាពជាកិច្ចដែលគួរធ្វើ ។ ពាក្យនេះ ជាការសម្តែងដល់ប្រយោជន៍នៃការកប់ទ្រព្យថា កាលកិច្ចដែលជាប្រយោជន៍នោះកើតឡើងហើយ កំណប់ទ្រព្យនឹងជាប្រយោជន៍ដល់យើង សេចក្តីពិត បុរសនោះកប់ទ្រព្យ ក៏ដើម្បីជាប្រយោជន៍យ៉ាងនេះថា កាលករណីណាមួយដែលនាំ*

មកនូវប្រយោជន៍កើតទ្បើង កំណប់ទ្រព្យនឹងជាប្រយោជន៍ដល់យើង នឹង មានដើម្បីសេចក្តីសម្រេចនៃកិច្ចរបស់យើងនោះ ។ សេចក្តីពិត ការសម្រេច នៃកិច្ចនោះឯង គប្បីជ្រាបថា ជាប្រយោជន៍របស់កំណប់ទ្រព្យនោះ កាលកិច្ច កើតទ្បើង ។

អធិប្បាយគាថាធី ២

ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រយោជន៍នៃការកប់ទ្រព្យយ៉ាងនេះ កាលទ្រង់សម្តែងបំណងនៃការជួបនូវប្រយោជន៍ ឥឡូវនេះ ដើម្បីទ្រង់សម្តែង នូវបំណងនៃការចៀសវាងនូវវត្ថុមិនជាប្រយោជន៍ ទើបត្រាស់ថា

> *នឹងបានដោះខ្លួនចេញពីស្តេច ឬត្រូវចោរបៀតបៀន នឹងបានដោះ ខ្លួនចេញពីចោរ នឹងបានដោះបំណុល ឬក្នុងពេលទុរ្ភិក្ស ឬក៏ក្នុង កាលអន្តរាយទាំងឡាយ ធម្មតាកំណប់ដែលគេកប់ទុកក្នុង លោក ដើម្បីប្រយោជន៍នេះឯង ។*

គាថានេះ គប្បីប្រកបសេចក្តីតាមកំណើតសត្វជាមួយបទថា **ភវិស្សតិ បមោក្ខាយ** *ដែលត្រាស់ក្នុងពាក្យនេះថា* **អត្ថាយ មេ ភវិស្សតិ** *និងព្រះតម្រាស់ថា* **ឥណាស្ស វា បមោក្ខាយ** *ទើបនឹងជ្រាបសេចក្តីបាន ក្នុងសេចក្តី នោះ ប្រកបសេចក្តីយ៉ាងនេះថា បុរសកប់កំណប់ទ្រព្យ មិនមែនដោយបំណង ថា ជាប្រយោជន៍ដល់អញតែម្យ៉ាងប៉ុណ្ណោះទេ សេចក្តីនេះ គឺអ្វីទៅវិញ គឺ បុរសកប់ទ្រព្យ ក៏ដោយបំណងថា នឹងជួយដោះអាត្មាអញឲ្យផុតចាកភាជកយ ដែលត្រូវពួកសត្រូវ ពួកបច្ចាមិត្តប្រទូស្ត ដោយន័យជាដើមយ៉ាងនេះថា អ្នក*

នេះជាចោរខ្លះ ជាប្រុសស្មន់ខ្លះ គេចនូវកាស៊ីខ្លះ ដូច្នេះជាដើម និងជួយដោះអាត្មាអញឲ្យផុតចាកចោរភ័យ ដែលត្រូវពួកចោរបៀតបៀនដោយការលួចទ្រព្យ ដោយរបៀបកាត់ជញ្ជាំងជាដើម ដោយការចាប់ជំរិតថា ឯងចូរឲ្យមាសប៉ុណ្ណេះៗ ជាដើម ម្នាស់បំណុលទារឲ្យអញសងបំណុល ក៏ជួយដោះអញឲ្យផុតចាកបំណុលខ្លះ ។ សម័យដែលកើតទុព្ភិក្ខភ័យ សម្លឹងវិនាសអាហារកបានដោយលំបាក ក្នុងសម័យនោះ និងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយទ្រព្យបន្តិចបន្តួច ធ្វើមិនបានងាយ កំណប់ទ្រព្យនោះ ក៏នឹងជួយបានក្នុងគ្រាទុព្ភិក្ខភ័យបែបនោះមកដល់ដូច្នេះខ្លះ និងជួយបានក្នុងគ្រាអន្តរាយដែលកើតអំពីអគ្គិភ័យ ឧទកភ័យ ទាយាទដែលមិនជាទីស្រឡាញ់ ដូច្នេះជាដើម ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រយោជន៍នៃការរក្សាទ្រព្យ ២ យ៉ាង ដោយ ២ គាថា គឺការប្រាថ្នាដែលនឹងជួបប្រយោជន៍ និងការប្រាថ្នាដែលនឹងគេចចេញអំពីវត្ថុដែលមិនមែនប្រយោជន៍យ៉ាងនេះហើយ ឥឡូវនេះ កាលត្រាស់ត្រួតនូវប្រយោជន៍ទាំង ២ ដល់កុដុម្ពិកៈនោះ ទើបត្រាស់ថា **ឯតទត្ថាយ លោកស្មឹ ឯឯ ឆាម ឯឯយ្យតិ** *ធម្មតាកំណប់ដែលគេកប់ក្នុងលោកដើម្បីជាប្រយោជន៍នេះឯង ។*

គាថានោះមានអត្ថថា ប្រយោជន៍នេះ គឺការជួបនូវប្រយោជន៍ និងការចៀសចេញអំពីវត្ថុដែលមិនជាប្រយោជន៍ ទ្រង់សម្តែងដោយន័យជាដើមយ៉ាងនេះថា នឹងជាប្រយោជន៍ដល់អញ និងដើម្បីដោះអាត្មាអញឲ្យផុតអំពីរាជភ័យ ។ ធម្មតាកំណប់ មានប្រាក់ មាសជាដើមណាមួយ គេកប់តម្កល់

ទុក រក្សាទុកក្នុងឱកាសលោកនេះ ក៏ដើម្បីជាប្រយោជន៍នោះ គឺដើម្បីធ្វើកិច្ច ទាំងនោះឲ្យសម្រេច ។

អធិប្បាយគាថាទី ៣

ឥទ្បូវនេះ ព្រោះកំណប់ទ្រព្យទាំងនោះ គេកប់ល្អហើយយ៉ាងនេះ តែងឲ្យសម្រេចប្រយោជន៍ ដែលបំណងដល់អ្នកមានបុណ្យប៉ុណ្ណោះ មិនសម្រេចប្រយោជន៍ដល់អ្នកដទៃ ដូច្នោះ កាលទ្រង់សម្តែងប្រយោជន៍ ទើបត្រាស់ថា

កំណប់ដែលបុគ្គលកប់ក្នុងទីជ្រៅ មានទីបំផុតទល់នឹងទឹក ដល់ម្ល៉ោះ កំណប់ទ្រព្យទាំងអស់នោះ ក៏មិនសម្រេច ដល់បុគ្គលនោះ សព្វកាលទេ ។

គាថានោះ មានអត្ថថា កំណប់ទ្រព្យនោះ គេកប់ល្អដល់ម្ល៉ោះ លោកអធិប្បាយថា សូម្បីកំណប់ទ្រព្យដែលគេកប់យ៉ាងល្អដល់ម្ល៉ោះ គេកប់ល្អដូចម្តេច គេកប់ក្នុងទីជ្រៅ មានទឹកជាទីបំផុត លោកអធិប្បាយថា ល្អដរាបស្មើនឹងការរាប់បានថា កប់ក្នុងទីជ្រៅ មានទឹកជាទីបំផុត ។ បទថា **ន សព្វោ សព្វទាយេវ តស្ស តំ ឧបកប្បតិ** *សេចក្តីថា កំណប់ទ្រព្យរមែងមិនសម្រេចប្រយោជន៍ មិនសម្រេចផលសព្វយ៉ាង លោកអធិប្បាយថា មិនអាចធ្វើកិច្ចតាមដែលពោលមកហើយ ដល់បុរសដែលកប់ទុកបានសព្វកាល សេចក្តីនេះដូចម្តេច គឺជួនកាល សម្រេចប្រយោជន៍ ជួនកាល មិនសម្រេចប្រយោជន៍ទេ ។ សព្ទថា* **តំ** *ក្នុងគាថានោះ គប្បីឃើញថា ជានិបាត ចុះក្នុងអត្ថបទបូរណៈ គឺធ្វើបទឲ្យពេញ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា* **យថា**

តំ អប្បមត្តស្ស អាតាបិនោ ។ *ជួនកាល លោកធ្វើលិង្គឲ្យផ្សេងគ្នា ដើម្បីគួរនឹងពោលថា* **សោ** *ក៏ពោលភ្ជាប់ថា* **តំ ។** *ពិតហើយ កាលពោលយ៉ាងនោះ សេចក្តីនោះ ក៏ដឹងបានស្រួល ។*

អធិប្បាយគាថាធី ៤-៥

ព្រះមានព្រះភាគ កាលត្រាស់ថា **ឯ សព្ពោ សព្ពធាយេវ តស្ស តំ ឧបកប្បតិ** *យ៉ាងនេះ ឥឡូវនេះ កាលទ្រង់សម្តែងហេតុដែលមិនសម្រេចប្រយោជន៍ទើបត្រាស់ថា*

ជ្បិតថា កំណប់ទ្រព្យរមែងឃ្លាតទៅចាកទីខ្លះ សេចក្តីចំណាំរបស់បុគ្គលនោះ រមែងវង្វេងទៅខ្លះ នាគទាំងឡាយរមែងនាំជញ្ជួនទៅខ្លះ ពុំនោះសោតពួកយក្សនាំយកទ្រព្យនោះទៅខ្លះ អ្នកទទួលមត៌កដែលមិនជាទីស្រឡាញ់រមែងគាស់យកនូវកំណប់ទ្រព្យនោះ កាលខ្លួនមិនបានឃើញខ្លះ ខ្លួនអស់បុណ្យទៅវេលាណា កំណប់ទ្រព្យទាំងអស់នោះ រមែងវិនាសបាត់បង់ទៅក្នុងវេលានោះ ។

គាថានេះមានអត្ថថា កំណប់ទ្រព្យនោះ ឃ្លាតចេញទៅអំពីទីដែលគេកប់ល្អហើយ គឺមិនមានចេតនា ក៏ទៅទីដទៃបាន ដោយអំណាចទ្រព្យអស់បុណ្យខ្លះ ។ ការចាំរបស់បុគ្គលនោះឃ្លៀងឃ្លាត គឺចាំមិនបាន ដល់ទីដែលកប់ទ្រព្យខ្លះ ពួកនាគដែលការអស់បុណ្យរបស់បុគ្គលនោះ ជាស់តឿនហើយ ប្តូរកន្លែងកប់ទ្រព្យនោះ យកទៅទីដទៃខ្លះ ពួកយក្ខលួចយកទៅតាមគាប់ចិត្តខ្លះ ពួកទាយាទដែលទទួលមត៌កមិនជាទីពេញចិត្ត ជីកផែនដីយកទ្រព្យនោះទៅ

ក្នុងកាលដែលបុគ្គលនោះមិនឃើញខ្លះ ។ កំណប់ទ្រព្យមិនសម្រេចប្រយោជន៍ដល់បុគ្គលនោះ ព្រោះមានការឃ្លាតចាកទីដើមទាំងនោះ ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់ហេតុដែលមិនសម្រេចប្រយោជន៍ ដែលលោកសន្ធត មានការធ្វើឲ្យឃ្លៀងឃ្លាតជាដើមយ៉ាងនេះហើយ ឥឡូវនេះ គ្រាទ្រង់សម្តែងហេតុ ដែលគេសន្ធតថា ការអស់បុណ្យណាមួយ ដែលជាមូលនៃហេតុទាំងនោះ ទើបត្រាស់ថា **យទា បុញ្ញក្ខយោ ហោតិ សព្វមេតំ វិនស្សតិ ។**

គាថានោះ មានសេចក្តីថា សម័យណា បុណ្យដែលកោគសម្បត្តិឲ្យសម្រេចអស់ទៅ ក៏ធ្វើវត្ថុដែលមិនមែនបុណ្យ ដែលប្រព្រឹត្តទៅដើម្បីការវិនាសនៃកោគសម្បត្តិ មានឱកាសតាំងនៅ សម័យនោះ ធនជាតិណា មានប្រាក់ និងមាសជាដើម ដែលបុគ្គលកប់ហើយ ធនជាតិទាំងអស់នោះក៏វិនាសអស់ទៅ ។

អធិប្បាយគាថាទី ៦

ព្រះមានព្រះភាគ កាលត្រាស់ដល់កំណប់ទ្រព្យ ដែលបុគ្គលកប់ហើយដោយបំណងនោះៗ តែក៏មិនសម្រេចប្រយោជន៍តាមដែលបំណងដល់លោកសន្ធត ក៏ត្រូវមានការវិនាសទៅជាធម្មតា ឥឡូវនេះ ដើម្បីទ្រង់សម្តែងបុញ្ញ-សម្បទាប៉ុណ្ណោះថា ជាកំណប់ទ្រព្យដោយបរមត្ថ កាលទ្រង់សម្តែងនិធិកណ្ឌ-សូត្រនេះ ដែលទ្រង់ផ្តើមដើម្បីអនុមោទនាដល់កុដុម្ពិកៈនោះ ទើបត្រាស់ថា

កំណប់ដែលស្ត្រី ឬបុរសណា បានកប់ទុកល្អហើយ ដោយ
ទាន សីល ដោយការសង្រួម ដោយការទូន្មានខ្លួន ។

បណ្តាបទទាំងនោះ បទថា **ទានំ** *គប្បីកាន់យកតាមន័យដែលពោលមកហើយក្នុងមង្គលថា* **ទានញ្ច ធម្មចរិយា** *នោះ ។ បទថា* **សីលំ** *បានដល់ ការមិនកន្លងល្មើសតាមផ្លូវកាយ និងវាចា គឺសីល ៥ សីល ៨ សីល ១០ និងបាតិមោក្ខសំវរសីលជាដើម ។ សីលត្រង់ប៉ាង លោកបំណងយកថា ជាសីលក្នុងទីនេះ ។ បទថា* **សញ្ញមោ** *បានដល់ ការសង្រួម អធិប្បាយថា ការហាមចិត្តទៅក្នុងអារម្មណ៍ផ្សេងៗ ពាក្យនេះជាឈ្មោះនៃសមាធិដែលបុគ្គលប្រកបហើយ លោកហៅថា ជាអ្នកសង្រួមដ៏ឧត្តម ក្នុងបាលីថា* **ហាត្ថសញ្ញតោ ចាឧសញ្ញតោ វាចាសញ្ញតោ សញ្ញតុត្តមោ** *ប្រែថា ជាអ្នកសង្រួមដៃ សង្រួមជើង សង្រួមវាចា ឈ្មោះថា ជាអ្នកសង្រួមដ៏ឧត្តម ។ អាចារ្យមួយពួកទៀតពោលថា ការសង្រួម លោកអធិប្បាយថា ការរវាំង ការប្រយ័ត្ន ពាក្យនេះជាឈ្មោះឥន្ទ្រិយសំវរៈ ។ ការទូន្មាន ឈ្មោះថា* **ឧម** *អធិប្បាយថា ការរម្ងាប់កិលេស ពាក្យនេះ ជាឈ្មោះនៃបញ្ញា ។ ពិតហើយ បញ្ញាក្នុងបាលីខ្លះ ហៅថា* **បញ្ញា** *ក្នុងប្រយោគជាដើមយ៉ាងនេះថា* **សុស្សូសំ លភតេ បញ្ញំ** *បុគ្គលស្តាប់ដោយល្អ រមែងបាននូវបញ្ញា ទីខ្លះ លោកហៅថា* **ធម្ម** *ក្នុងប្រយោគជាដើមយ៉ាងនេះថា* **សច្ចំ ធម្មោ ធិតិ ចាគោ** *ប្រែថា សច្ចៈ ធម្មៈ ធិតិ ចាគៈ ទីខ្លះ លោកហៅថា* **ឧម** *ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា* **យទិ សច្ចា ឧមា ចាគា ខន្តិយា ន វិជ្ជតិ** *បើធម៌ក្រៃលែងជាង សច្ចៈ ទមៈ ចាគៈ ខន្តី មិនមានសោត ។*

បណ្ឌិតស្គាល់ទានជាដើមយ៉ាងនេះហើយ គប្បីប្រមូលមក ហើយជ្រាប

អត្ថន្តូវគាថានេះយ៉ាងនេះថា កំណប់ទ្រព្យដែលសម្រេចដោយបុណ្យនៃបុគ្គលណា ជាស្ត្រីក្តី បុរសក្តី ទោះគេយកធម៌ទាំង ៤ នេះ គឺទាន សីល សញ្ញមៈ ទមៈ ដែលកប់ទុកល្អហើយ ដោយការធ្វើធម៌ទាំង ៤ មានទានជាដើមទាំងនោះ ទុកដោយល្អក្នុងចិត្តសន្តាន ឬក្នុងវត្ថុមានចេតិយជាដើម ដូចកំណប់ទ្រព្យ ដែលសម្រេចដោយធនជាតិ ក៏យកប្រាក់ មាស មុក្តា មណី កប់ដោយការជាក់ប្រាក់ មាសជាដើមនោះ ក្នុងទីតែមួយដូច្នេះ ។

អធិប្បាយគាថាទី ៧

ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពដែលបុញ្ញសម្បទាជាកំណប់ទ្រព្យ ដោយបរមត្ថ ដោយគាថានេះថា **យស្ស ធានេន** *ជាដើមយ៉ាងនេះហើយ គ្រាទ្រង់សម្តែងវត្ថុត្រង់រណ្តៅទ្រព្យ ដែលបុគ្គលស្តាប់ហើយ ឈ្មោះថា កប់យ៉ាងល្អ ទើបត្រាស់ថា*

ក្នុងចេតិយ គឺក្នុងសង្ឃ ឬក្នុងបុគ្គល ឬក្នុងពួកក្រៀវ ឬមួយ
ក្នុងមាតា ក្នុងបិតា ឬថា ក្នុងបងប្រុស-ស្រីដែលជាច្បង ។

ក្នុងគាថានោះ ឈ្មោះថា **ចេតិយ** *ព្រោះគួរធ្វើ លោកអធិប្បាយថា គួរបូជា ។ ឈ្មោះថា* **ចេតិយ** *ព្រោះវិចិត្រហើយ ។ ចេតិយនោះមាន ៣ យ៉ាង គឺបរិភោគចេតិយ ១ ឧទ្ទិស្សកចេតិយ ១ ធាតុកចេតិយ ១ ។*

បណ្តាចេតិយទាំង ៣ នោះ ពោធិព្រឹក្ស ឈ្មោះថា **បរិភោគចេតិយ** *ព្រះបដិមា ឈ្មោះថា* **ឧទ្ទិស្សកចេតិយ** *ព្រះស្តូប មានបន្ទប់បញ្ចុះព្រះធាតុ ឈ្មោះថា* **ធាតុកចេតិយ** ។

បទថា **សង្ឃោ** *បានដល់ បុគ្គលណាម្នាក់ ក្នុងពួកសង្ឃ មានព្រះពុទ្ធជាប្រធាន ។ បទថា* **បុគ្គលោ** *បានដល់ បុគ្គលណាម្នាក់ ក្នុងពួកគ្រហស្ថ និងបព្វជិតជាដើម ។ ឈ្មោះថា* **អតិដ្ឋិ** *គឺក្រៀវ ព្រោះបុគ្គលនោះមិនមានតិចី គឺមកថ្ងៃណាក៏បាន ពាក្យនេះជាឈ្មោះរបស់ក្រៀវ ដែលមកក្នុងខណៈនោះ ។ ពាក្យដ៏សេស ក៏មានន័យដែលពោលមកហើយនោះឯង ។*

បណ្ឌិតស្គាល់ចេតិយជាដើមយ៉ាងនេះហើយ ឥឡូវនេះ គប្បីជ្រាបអត្ថនៃគាថានេះយ៉ាងនេះ កំណប់ទ្រព្យនោះ ត្រាស់ថា ជាការកប់ល្អហើយ កំណប់ទ្រព្យនោះដែលគេកប់ទុកក្នុងវត្ថុទាំងនោះ រមែងឈ្មោះថា កប់ល្អហើយ ។ ព្រោះហេតុអ្វី ព្រោះអាចឲ្យនូវផលដែលគួរប្រាថ្នាបានអស់កាលយូរ ។ ពិតហើយ ជនទាំងឡាយ ថ្វាយក្នុងព្រះចេតិយសូម្បីតិចតួច រមែងជាបុគ្គលបានផល ដែលប្រាថ្នាអស់កាលយូរ ដូចព្រះតម្រាស់ថា

ឯកបុប្ផំ ឯត្ថាន អសីតិកប្បកោដិយោ
ទុគ្គតឹ នាភិជានាមិ បុប្ផទានស្សិទំ ផលំ ។

ខ្ញុំបានថ្វាយផ្កា ១ ទង ក៏មិនស្គាល់ទុគ្គតិ អស់ ៨០ កោដិនៃកប្ប នេះជាផលនៃការថ្វាយផ្កា ។

និងគាថាថា

មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ

បើបុគ្គលឃើញសុខធំទូលាយ ព្រោះលះសុខមានប្រមាណតិចចេញ ។

គប្បីជ្រាបការចែកផលទានក្នុងវត្ថុ មានព្រះសង្ឃជាដើម តាមន័យដែល

ពោលមកហើយ ក្នុងទក្ខិណាវិសុទ្ធិសូត្រ និងក្នុងវេលាមសូត្រជាដើម ដោយប្រការដូច្នោះ ។ ម្យ៉ាងទៀត ទ្រង់សម្តែងការប្រព្រឹត្តទៅ និងការចម្រើនផលនៃទាន ក្នុងវត្ថុ មានចេតិយជាដើមដោយប្រការណា ក៏គប្បីប្រារព្ធគុណនោះៗ ក្នុងទីទាំងពួងតាមការប្រកបហើយ ទើបជ្រាបការប្រព្រឹត្តទៅ និងការចម្រើនផលនៃសីល មានចារិតសីល វារិតសីល សញ្ញមៈ ពុទ្ធានុស្សតិ ទមៈ វិបស្សនា មនសិការ និងការពិចារណាវត្ថុនោះដោយប្រការនោះ ។

អធិប្បាយគាថាធី ៨

ព្រះមានព្រះភាគ កាលទ្រង់សម្តែងវត្ថុ មានចេតិយជាដើមនៃកំណប់ទ្រព្យដែលសម្រេចដោយបុណ្យ ដែលគេកប់ដោយទានជាដើម យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងការផ្សេងគ្នារបស់កំណប់ទ្រព្យនោះ ដែលគេកប់ក្នុងវត្ថុទាំងនោះ ចាកកំណប់ទ្រព្យ ដែលគេកប់ក្នុងទីជ្រៅ មានទឹកជាទីបំផុត ទើបត្រាស់ថា

> កំណប់ទ្រព្យនុ៎ះ ចាត់ជាកំណប់ទ្រព្យដែលកប់ទុកប្រពៃហើយ នរណាៗ មិនគប្បីផ្តាច់បាន ជាកំណប់ទ្រព្យដែលជាប់តាមខ្លួនទៅ កាលភោគៈទាំងឡាយ ដែលខ្លួនត្រូវលះបង់ហើយទៅ ខ្លួនរមែងកាន់យកនូវកំណប់ទ្រព្យ គឺបុណ្យនុ៎ះទៅ ។

ក្នុងគាថានោះ ព្រះមានព្រះភាគ ទ្រង់សម្តែងកំណប់ទ្រព្យដែលកប់ល្អហើយ ដោយទានជាដើមនោះ ដោយបទដើមថា កំណប់ទ្រព្យនុ៎ះ ចាត់ជាកំណប់ទ្រព្យដែលកប់ទុកប្រពៃហើយ ។ បទថា **អាដេយ្យោ** បានដល់ មនុស្ស

ដទៃៗ មិនអាចផ្ចាញ់ ហើយយកទៅបាន ។ បាឋៈថា **អជ្ឈេរ្យា** *ក៏មាន ។ អធិប្បាយថា ដែលបុគ្គលណាម្នាក់ មិនគប្បីឈ្នះ មិនគួរឈ្នះ គឺបុគ្គលត្រូវការប្រយោជន៍ និងសេចក្តីសុខ គួរកសាងឯង ។ ក្នុងបាឋៈនេះ ប្រកបសេចក្តីថា កំណប់ទ្រព្យនេះ បុគ្គលណាម្នាក់ផ្ចាញ់មិនបាន ដោយសម្តែងពាក្យសួរទៀតថា ព្រោះហេតុអ្វី ទើបសម្ពន្ធសេចក្តីថា ព្រោះហេតុដែលកំណប់ទ្រព្យដែលកប់ហើយ ជាប់ទៅមិនបាន ។ តែភាពដែលកំណប់ទ្រព្យដែលកប់ល្អហើយ ដោយប្រការក្រៅអំពីនេះ ជារបស់ដែលបុគ្គលណាម្នាក់ឈ្នះបានលោកគប្បីពោលហើយ តែលោកមិនបានពោល ។ ពិតហើយ កំណប់ទ្រព្យនោះដែលកប់ល្អហើយ ដែលបុគ្គលណាម្នាក់យកឈ្នះមិនបាន គឺមិនមានបុគ្គលណាម្នាក់យកឈ្នះបានឡើយ ។ កំណប់ទ្រព្យ ឈ្មោះថា អនុគាមិក ព្រោះជាប់តាមទៅបាន អធិប្បាយថា មិនលះបង់បុគ្គលសូម្បីកំពុងទៅបរិលោក ដោយការឲ្យផលក្នុងភពនោះៗ ។*

បានឮថា បទថា **បហាយ គមនីយេសុ ឯតំ អាទាយ គច្ឆតិ** *នេះមានសេចក្តីយ៉ាងនេះថា កាលមរណកាលជ្រាកដឡើង បណ្តាភោគៈទាំងឡាយដែលចាំបាច់លះទៅ បុគ្គលនោះក៏នាំទៅបាននូវកំណប់ទ្រព្យ គឺបុណ្យនេះ សេចក្តីនេះមិនត្រឹមត្រូវ ព្រោះហេតុអ្វី ព្រោះភោគៈទាំងឡាយទៅមិនបាន សេចក្តីពិតភោគៈនោះៗ ដែលមច្ចុ គឺអ្នកដែលត្រូវស្លាប់ គប្បីលះទៅប៉ុណ្ណោះ ទៅមិនបានឡើយ តែគតិវិសេសនោះៗ ទេតើ ចាំបាច់ត្រូវទៅ ។ ព្រោះបើគប្បីមានយ៉ាងនេះសោត ក៏គប្បីពោលបានថា បណ្តាគតិវិសេសទាំងឡាយ ដែលចាំ*

ជាច់លះកោគៈទាំងឡាយទៅ ដូច្នោះ ទើបគួរជ្រាបក្នុងសេចក្តីនោះយ៉ាងនេះ ថា កាលកោគៈទាំងឡាយ រង់ចាំតែលះបង់អ្នកដែលត្រូវស្លាប់ដោយប្រការ ជាដើមយ៉ាងនេះថា **និធិ វា ឋានា ចវតិ** កំណប់ទ្រព្យឃ្លាតទៅចាកទីខ្លះ មច្ចុៈ គឺអ្នកដែលត្រូវស្លាប់ ក៏នាំទៅបានចំពោះតែកំណប់ គឺបុណ្យ ដ្បិតថា កំណប់ទ្រព្យ គឺបុណ្យ មិនលះមច្ចុៈនោះ ព្រោះជាទ្រព្យជាប់តាមទៅបាន ។ ក្នុងគាថានោះ អ្នកចោទសួរពោលថា ក្នុងបទថា **គមនីយេសុ** នេះ គប្បីមានអត្ថថា **គន្តព្វេសុ** ក៏មិនមែន សេចក្តីថា **គច្ឆន្តេសុ** ពាក្យនោះ មិនគប្បីកាន់យកតែមួយចំណុច ។ ដូចក្នុងពាក្យថា **អរិយា ឯយ្យានិកា** នេះ មានសេចក្តីថា **ឯយ្យន្តា** មិនមែនមានសេចក្តីថា **ឯយ្យាតព្វា** យ៉ាងណា សូម្បីក្នុងទីនេះ ក៏មានសេចក្តីថា **គច្ឆន្តេសុ** មិនមែនមានសេចក្តីថា **គន្តព្វេសុ** ដូច្នោះ ។

ម្យ៉ាងទៀត ព្រោះហេតុដែលបុគ្គលទាំងនេះ បំណងនឹងឲ្យដល់បុគ្គលណា ក្នុងកាលនឹងស្លាប់ ក៏ចាប់ពាល់កោគៈឲ្យមិនបាន ដូច្នោះ កោគៈទាំងនោះ ដែលបុគ្គលនោះ ត្រូវលះទៅផ្លូវកាយមុន ខាងក្រោយ ទើបចាំបាច់ចេញទៅតាមផ្លូវចិត្តដែលអស់សង្ឃឹម លោកអធិប្បាយថា គប្បីកន្ទងទៅ ។ ព្រោះដូច្នោះ ទើបគួរយើញក្នុងសេចក្តីនេះយ៉ាងនេះថា បណ្តាកោគៈទាំងឡាយ ដែលចាំបាច់លះទៅផ្លូវកាយមុន ក្រោយមក ទើបលះទៅតាមផ្លូវចិត្ត ។ ក្នុងសេចក្តីខាងដើម សត្តមីវិភត្តិ ចុះក្នុងនិទ្ធារណៈថា បណ្តាកោគៈទាំងឡាយដែលចាំបាច់លះទៅ បុគ្គលនោះក៏នាំកោគៈ គឺបុញ្ញនិធិប៉ុណ្ណោះចេញអំពីកោគៈទាំងឡាយ

នាំទៅ ។ ក្នុងប្រការក្រោយ សត្តមីវិភត្តិ ចុះក្នុងការណៈ ដោយការៈថា ដោយការៈដែលកោគៈទាំងឡាយជាប់តាមទៅ ក៏រមែងកំណត់ការៈ គឺកំណប់ទ្រព្យនោះនាំទៅបានផង ។

អធិប្បាយគាថាទី ៩

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការផ្សងគ្នានៃបុញ្ញនិធិនេះចាកកំណប់ទ្រព្យដែលគេកប់ទុកក្នុងទីជ្រៅ មានទឹកជាទីបំផុត កាលទ្រង់ញុំាងឧស្សាហ៍ឲ្យកើតដល់ទេវតា និងមនុស្សទាំងឡាយ ក្នុងបុញ្ញនិធិនោះ ដោយពណ៌នាគុណបុញ្ញនិធិដែលទ្រង់សម្តែងដោយព្រះអង្គទៀត ដូចឈ្លួញអ្នកលក់ដ៏ឱឡារញុំាងឧស្សាហ៍ឲ្យកើតដល់អ្នកទិញ ដោយពណ៌នាគុណនៃទំនិញរបស់ខ្លួនដូច្នោះ ទើបត្រាស់ថា

> *កំណប់ទ្រព្យ គឺបុណ្យ មិនទូទៅដល់ពួកជនដទៃ ជារបស់ដែលចោរលួចទៅមិនបាន កំណប់ទ្រព្យ គឺបុណ្យណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញ គួរធ្វើនូវកំណប់ទ្រព្យ គឺបុណ្យនោះ ។*

បណ្តាបទទាំងនោះ បទថា **អសាធារណមញ្ញេសំ** *ប្រែថា មិនទូទៅដល់ជនដទៃ ។* **ម** *អក្ខរៈ ធ្វើបទសន្ធិ ដូចក្នុងប្រយោគជាដើមថា* **អទុក្ខម-សុខាយ វេទនាយ សម្បយុត្តា** *ប្រកបដោយវេទនាដែលមិនមែនទុក្ខ មិនមែនសុខ ។ និធិដែលចោរទាំងឡាយលួចទៅមិនបាន ឈ្មោះថា* **អចោរ-ហារណោ ។** *អធិប្បាយថា រមែងជានិធិដែលចោរទាំងឡាយនាំទៅមិនបាន ។ ឈ្មោះថា* **និធិ** *ព្រោះបុគ្គលនោះកប់ ។ ព្រះមានព្រះភាគ កាលទ្រង់ពណ៌នា*

គុណនៃបុញ្ញនិធិដោយ ២ បទខាងដើមយ៉ាងនេះហើយ បន្ទាប់អំពីនោះ ក៏ទ្រង់ញុាំងឧស្សាហ៍ឲ្យកើតក្នុងបុញ្ញនិធិនោះ ដោយបទក្រោយ ទើបត្រាស់ថា បុញ្ញនិធិឯណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញ គប្បីធ្វើបុញ្ញនិធិនោះ ។

គាថានោះមានសេចក្តីថា ព្រោះហេតុដែលធម្មតា បុញ្ញនិធិមិនសាធារណៈដល់ជនដទៃ និងជានិធិដែលចោរលួចទៅមិនបាន ។ តែមិនមែននិធិដែលមិនសាធារណៈ ហើយចោរលួចទៅមិនបានតែម្យ៉ាងប៉ុណ្ណោះទេ ពិតហើយ នៅជានិធិដែលត្រាស់យ៉ាងនេះថា និធិនោះ កប់ទុកល្អហើយ ដែលបុគ្គលណាម្នាក់ផ្ទាញ់មិនបាន ជាប់តាមខ្លួនទៅបាន ។ និធិណាជាប់តាមខ្លួនទៅបាន ព្រោះហេតុដែលនិធិនោះ ជាបុញ្ញនិធិតែម្យ៉ាង ដូច្នោះ អ្នកប្រាជ្ញ គឺបុគ្គលដែលដល់ព្រមដោយពុទ្ធិ គឺការដឹង ដល់ព្រមដោយធិតិ គឺបញ្ញា គប្បីធ្វើបុណ្យ បំពេញបុណ្យទាំងឡាយ ។

អធិប្បាយគាថាទី ៩

ព្រះមានព្រះភាគ កាលទ្រង់ញុាំងឧស្សាហ៍ឲ្យកើតដល់ទេវតា និងមនុស្សទាំងឡាយ ក្នុងបុញ្ញនិធិ ដោយពណ៌នាគុណយ៉ាងនេះហើយ ឥឡូវនេះ ជនទាំងឡាយណាឧស្សាហ៍ហើយ ធ្វើឧស្សាហ៍នោះឲ្យសម្រេចផល ដោយការធ្វើបុញ្ញនិធិ បុញ្ញនិធិរបស់ជនទាំងនោះ រមែងឲ្យផល កាលទ្រង់សម្តែងផលនោះដោយសង្ខេប ទើបត្រាស់ថា កំណប់ទ្រព្យ គឺបុណ្យនោះ ឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដល់ទេវតា និងមនុស្សទាំងឡាយ ។

ឥឡូវនេះ ព្រោះបុញ្ញនិធិទាក់ទងដោយសេចក្តីប្រាថ្នាជាគ្រឿងឲ្យនូវវត្ថុ

តាមសេចក្តីប្រាថ្នា ទើបវៀរសេចក្តីប្រាថ្នាចេញមិនបាន ដូចព្រះតម្រាស់ (ក្នុងមជ្ឈិមនិកាយសាលិយកសូត្រ) ថា

ម្នាលគហបតីទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រសិនបើប្រាថ្នាថា ឱហ្ន៎ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ទៅ សូមឲ្យអាត្មាអញបានទៅកើតជាមួយនឹងពួកខត្តិយមហាសាលដូច្នេះ ហេតុនុ៎ះឯង រមែងមាន បុគ្គលនោះ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ទៅ មុខជានឹងបានទៅកើតជាមួយនឹងពួកខត្តិយមហាសាល បានមែន ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះ ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ដោយពិត ។បេ។ ដ្បិតបុគ្គលនោះ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញារបស់ខ្លួន ចំពោះចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ បានមែន ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះ ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើដោយពិត ។

ពិតហើយ ព្រះមានព្រះមានភាគ ក៏ត្រាស់ (ក្នុងមជ្ឈិមនិកាយសំរូប-បត្តិសូត្រ) ថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកប្រកបដោយសទ្ធា ប្រកបដោយសីល ប្រកបដោយសុតៈ ប្រកបដោយ

ចាគៈ ប្រកបដោយបញ្ញា ។ កិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឯហ្ន៎ អាត្មាអញ លុះដល់រំលាងខន្ធ បន្ទាប់អំពីមរណៈទៅ សូមឲ្យទៅកើតជាមួយនឹងពួកខត្តិយមហាសាល ។ កិក្ខុនោះ តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះទុក ។ ធម៌ទាំង ៥ មានសទ្ធាជាដើមនោះ ឈ្មោះថា សង្ខារផង ឈ្មោះថា វិហារធម៌ផង ដែលកិក្ខុនោះចម្រើនហើយយ៉ាងនេះ ធ្វើឲ្យរឿយៗ ហើយយ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីកើតជាមួយនឹងខត្តិយមហាសាលនោះមែន ។

ព្រោះដូច្នោះ កាលទ្រង់សម្តែងបរិយាយនៃការសង្ឃឹមយ៉ាងនោះ ការប្រាថ្នាដែលមានអធិដ្ឋានភាវនា ដោយការតាំងចិត្តជាបរិក្ខារ ព្រោះក្នុងភាពដែលបុញ្ញនិធិនោះឲ្យផលដែលគួរប្រាថ្នាគ្រប់យ៉ាងនោះ ទើបត្រាស់ថា

ពួកទេវតា និងមនុស្សទាំងឡាយ ប្រាថ្នាណាស់នូវផលណាៗ ផលទាំងពួងនោះៗ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។

អធិប្បាយគាថាទី ១១

ឥឡូវនេះ ផលគ្រប់យ៉ាងដែលទេវតា និងមនុស្សរមែងបានដោយបុញ្ញនិធិនោះ កាលទ្រង់សម្តែងផលនោះ ជាបែបៗ ទើបត្រាស់គាថាយ៉ាងនេះថា

ភាពជាអ្នកមានសម្បុរផូរផង់ មានសំឡេងពីរោះជាដើម ។

បណ្តាគាថាទាំងនោះ នឹងវិនិច្ឆ័យក្នុងគាថាទី ១ សិន ការមានឆវីវណ្ណស្អាត មានពណ៌សម្បុរដូចមាស ឈ្មោះថា មានពណ៌សម្បុរល្អនោះ បុគ្គល

រមែងបានដោយបុញ្ញនិធិនោះ ។ ដូចព្រះតម្រាស់ដែលត្រាស់ (ក្នុងទីឃ-
និកាយលក្ខណសូត្រ) ថា

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិ ពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជា អ្នកមិនមានសេចក្តីក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ ចិត្ត សូម្បីជនច្រើននាក់ នាំគ្នាស្តីថាឲ្យ ក៏មិនឈឺចិត្ត មិនក្រោធ មិនចងកំហឹងទុក មិនតម្កល់ទុកនូវសេចក្តីក្រោធ ទាំងមិនបាន ធ្វើនូវសេចក្តីក្រោធ នូវការប្រទូស្ត និងសេចក្តីតូចចិត្តឲ្យ ប្រាកដឡើង (ដោយកាយវិការ ឬវចីវិការ) ឡើយ ព្រះ តថាគតជាអ្នកបានឲ្យនូវកម្រាល និងសំពត់ដណ្តប់មានសាច់ ល្អិត ទន់ល្មៃ គឺសំពត់ធ្វើពីសម្បកឈើ មានសាច់ម៉ដ្ត សំពត់ ធ្វើពីកប្បាសមានសាច់ម៉ដ្ត សំពត់ធ្វើពីសូត្រ មានសាច់ម៉ដ្ត សំពត់ធ្វើពីរោមសត្វ មានសាច់ម៉ដ្ត ។ ព្រះតថាគតនោះ ព្រោះ បានធ្វើសន្សំនូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកហានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាន នូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានពណ៌សម្បុរ (លឿង ក្អឹបំព្រង) ដូចជាសម្បុរនៃមាស និងមានស្បែកជិតស្និទ្ធ ល្អ ដូចជាមាស ។

កាពជាបុគ្គលមានសំឡេងដូចព្រហ្ម ជាអ្នកនិយាយសំឡេងដូចសត្វករវិក

ឈ្មោះថា ភាពជាអ្នកមានសំឡេងពីរោះ ព្រោះភាពជាអ្នកមានសំឡេងពីរោះ នោះ ដែលបុគ្គលរមែងបាន ក៏ដោយបុញ្ញនិធិនេះ ដូចព្រះតម្រាស់ត្រាស់ (ក្នុងលក្ខណសូត្រ) ថា

> *ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកលះបង់នូវផរុសវាចា វៀរស្រឡះហើយចាកផរុសវាចា ជាអ្នកនិយាយតែពាក្យដែលឥតទោស ពាក្យដែលជាសុខដល់ត្រចៀកគេ គួរឲ្យស្រឡាញ់ គួរឲ្យតាំងទុកក្នុងហឫទ័យ ជាសម្តីអ្នកក្រុង ទាំងជាទីស្រឡាញ់នៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកសាង នូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកហ៊ានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានអណ្តាតវែង ១ មានសូរសព្ទសំឡេងក្រាំងក្រអៅ ដូចជាសំឡេងព្រហ្ម កាលបើបញ្ចេញវាចាលាន់ឮពីរោះ ដូចជាសំឡេងសត្វករវិក ១ ។*

បទថា **សុសណ្ឋានា** *បានដល់ ការមានទ្រង់ទ្រាយល្អ លោកអធិប្បាយថា ការតាំងនៅនៃអវយវៈធំ-តូច ក្នុងការដែលគួរពេញ គួរមូល ដោយភាពជាអវយវៈដែលពេញ និងមូល ដូចព្រះតម្រាស់ត្រាស់ (ក្នុងលក្ខណសូត្រ) ថា*

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិ ពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវ សេចក្តីសុខ ប្រាថ្នាសេចក្តីក្សេមក្សាន្តចាកយោគៈ ដល់ពួកជន ច្រើនថា ធ្វើដូចម្តេចជនទាំងនេះ នឹងបានចម្រើនដោយសទ្ធា ចម្រើនដោយសីល ចម្រើនដោយសុតៈ ចម្រើនដោយវុឌ្ឍិ ចម្រើនដោយចាគៈ ចម្រើនដោយលោកិយធម៌ ចម្រើនដោយ ប្រាជ្ញា ចម្រើនដោយទ្រព្យ និងធញ្ញាហារ ចម្រើនដោយស្រែ និងចម្ការ ចម្រើនដោយសត្វជើង ២ និងសត្វជើង ៤ ចម្រើន ដោយកូន និងប្រពន្ធ ចម្រើនដោយពួកបុរសជាទាសៈ និង កម្មករ ចម្រើនដោយពួកញាតិ ចម្រើនដោយពួកមិត្ត ចម្រើន ដោយពួកផៅពង្ស ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំ កុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកហាន-សួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិ-សលក្ខណៈទាំង ៣ នេះ គឺ មានចំណែកកន្ទុះកាយខាងលើ ស្រដៀងនឹងចំណែកកន្ទុះកាយនៃរាជសីហ៍ ១ មានខ្នងពេញ ស្មើ ឥតមានចង្អូរផតខូងត្រង់កណ្តាល ១ មានកមូលសម ១ ។

បទនៃព្រះសូត្រទាំងឡាយ ដែលធ្វើឲ្យការបានសម្រេចនូវបុញ្ញនិធិនេះ សូម្បីក្នុងទីដទៃអំពីនេះ ក៏គប្បីនាំអំពីទីនោះៗ ពោលដោយន័យនេះ ។ តែ

ព្រោះខ្លាចពិស្តារ ទើបសម្តែងដោយសង្ខេប ឥឡូវនេះ ខ្ញុំនឹងពណ៌នាបទ ដ៏សេស ។

សរីរៈទាំងមូល គប្បីជ្រាបថា **រូប** *ក្នុងពាក្យថា* **សុរូបតា** *នេះ ។ ដូច ក្នុងប្រយោគជាដើមថា សភាពដែលអាកាសរុំព័ទ្ធ រមែងរាប់ថា រូបទាំង អស់ ។ ភាពដែលរូបនោះល្អ ឈ្មោះថា មានរូបស្អាត លោកអធិប្បាយថា មិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិនស ពេក ។ បទថា* **អាធិបច្ចំ** *បានដល់ ភាពជាធំ អធិប្បាយថា ភាពជា ចៅហ្វាយ ដោយភាពជាក្សត្រមហាសាលជាដើម ។ បទថា* **បរិវារោ** *បាន ដល់ សម្រាប់គ្រហស្ថ សម្បត្តិ គឺជនរបស់ខ្លួន និងជនដោយជុំវិញ សម្រាប់ បព្វជិត សម្បត្តិ គឺបរិស័ទ ។ ភាពជាធំ និងភាពមានបរិវារ ឈ្មោះថា ភាព ជាធំ និងមានបរិវារ បណ្តាឥដ្ឋផលទាំងនោះ គប្បីជ្រាបថា សម្បត្តិ គឺភោគៈ ត្រាស់ដោយភាពជាធំ សម្បត្តិ គឺជនរបស់ខ្លួន និងជនដោយជុំវិញ ត្រាស់ ដោយភាពមានបរិវារ ។ ដោយពាក្យថា* **សព្វមេតេន លព្ភតិ** *ព្រះមានព្រះ ភាគរមែងសម្តែងថា ពាក្យនោះបានត្រាស់ថា ទេវតា និងមនុស្សទាំងឡាយ ប្រាថ្នាផលណាមួយ ផលទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញ-និធិនេះ ក្នុងពាក្យនោះ ឥដ្ឋផល មានពណ៌សម្បុរល្អជាដើម ដែលត្រាស់ ចំណែកដំបូងមុននេះ គប្បីជ្រាបថា ផលទាំងអស់នោះ បុគ្គលបានដោយ បុញ្ញនិធិនេះ ។*

អធិប្បាយគាថាធី ៧២

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសម្បត្តិរបស់ទេវតា និងមនុស្សដែលទាបជាងសម្បត្តិ គឺកាពជាព្រះរាជា ដែលបុគ្គលគប្បីបានដោយបុញ្ញានុភាព ដោយគាថានេះយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងសម្បត្តិ គឺកាពជាព្រះរាជាទាំង ២ នោះ ទើបត្រាស់គាថានេះថា

កាពជាស្តេចបទេសរាជ ឥស្សរិយយស សេចក្តីសុខ
របស់ស្តេចចក្រពត្តិ ជាទីស្រឡាញ់ កាពជាស្តេចនៃ
ទេវតា ក្នុងទេពនិកាយទាំងឡាយ ផលទាំងអស់ រមែង
បានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។

បណ្តាបទទាំងនោះ បទថា **បទេសរជ្ជំ** បានដល់ កាពជាព្រះរាជានៃប្រទេស ក្នុងប្រទេសនីមួយៗ សូម្បីតែទ្វីបមួយ មិនសោយរាជ្យក្នុងទ្វីបទាំងអស់ ។ កាពជាព្រះរាជាដែលជាធំ ឈ្មោះថា **ឥស្សរិយ** ។ ទ្រង់សម្តែងកាពជាស្តេចចក្រពត្តិ ដោយបទនេះ ។ សុខរបស់ស្តេចចក្រពត្តិ ឈ្មោះថា **ចក្កវត្តិសុខ** ។ បទថា **បិយំ** បានដល់ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ។ ទ្រង់សម្តែងកាពជាស្តេចចក្រពត្តិ មានមហាសមុទ្រទាំង ៤ ជាព្រំប្រទល់ដោយបទនេះ ។ កាពជាព្រះរាជាក្នុងពួកទេវតា ឈ្មោះថា **ទេវរជ្ជំ** ។ ឈ្មោះថា ទ្រង់សម្តែងកាពជាព្រះរាជារបស់ទេវតានៃមនុស្សទាំង-ឡាយ មានស្តេចមន្ធាតុរាជជាដើម ដោយបទនេះ ។ ដោយបទថា **អបិ ឥច្ឆេសុ** នេះ ទ្រង់សម្តែងកាពជាព្រះរាជារបស់ទេវតានៃមនុស្សទាំងឡាយ ដែលកើតក្នុងទិព្វទាំងឡាយ ដែលហៅថា **ឥព្វ** ព្រោះមានក្នុងភពទិព្វ ដោយ

បទថា **សព្វមេតេន លព្ភតិ** ទ្រង់សម្តែងថា ក្នុងពាក្យដែលត្រាស់ថា **យំ យំ ឥច្ឆាភិបត្ថេន្តិ សព្វមេតេន លព្ភតិ** ឥដ្ឋផល មានភាពជាបទេសរាជ ដែលត្រាស់ជាចំណែកទី ២ នេះ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នេះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ ។

អធិប្បាយគាថាទី ១៣

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសម្បត្តិ គឺភាពជាព្រះរាជានៃទេវតា និងមនុស្ស ដែលបុគ្គលគប្បីបាន ដោយបុញ្ញានុភាព ដោយគាថាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ធ្វើសម្បត្តិ ដែលត្រាស់ដោយ ២ គាថាខាងមុខ ដោយសង្ខេប និងទ្រង់សម្តែងសម្បត្តិ គឺព្រះនិព្វាន ទើបត្រាស់គាថានេះថា

សម្បត្តិរបស់មនុស្សណាផង សេចក្តីត្រេកអរក្នុងទេវ-
លោកណាផង សម្បត្តិ គឺព្រះនិព្វានណាផង សម្បត្តិ
ទាំងអស់ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។

បណ្តាបទនៃគាថានោះ មានដូច្នេះ ឈ្មោះថា **មានុសី** ព្រោះជារបស់មនុស្សទាំងឡាយ **មានុសី** នោះឯង ឈ្មោះថា **មានុស្សិកា។** ការដល់ព្រម ឈ្មោះថា **សម្បត្តិ ។** លោកនៃទេវតាទាំងឡាយ ឈ្មោះថា **ទេវលោកេ ។** ក្នុងទេវលោកនោះ ។ បទថា **យា** ជាការកាន់យកមិនមានសេសសល់ឡើយ ។ ឈ្មោះថា **រតិ** ព្រោះត្រេកអរដោយសម្បត្តិដែលកើតខាងក្នុង ឬជាគ្រឿងឧបករណ៍ខាងក្រៅ ។ ពាក្យនេះ ជាឈ្មោះរបស់សុខ និងវត្ថុជាគ្រឿងឲ្យមានសុខ ។ ពាក្យថា **យា** ជាពាក្យសម្តែងដែលមិនពិតប្រាកដ ។

ច *សព្ទ មានសេចក្តីថា រួមគ្នានឹងសម្បត្តិទាំងពួង ។ ព្រះនិព្វាននោះឯង ឈ្មោះថា* **និព្វានសម្បត្តិ** ។

ពណ៌នាសេចក្តី មានដូច្នេះ ដោយបទថា **សុវណ្ណតា** *ជាដើម សម្បត្តិ និងសេចក្តីត្រេកអរនោះ ទើបត្រាស់ថា* **មានុស្សិកា ច សម្បត្តិ ទេវលោកេ ច យា រតិ** *សម្បត្តិរបស់មនុស្ស និងការត្រេកអរក្នុងទេវលោក ។ សម្បត្តិ និងការត្រេកអរទាំងអស់នោះ និងសម្បត្តិ គឺព្រះនិព្វាន ដែលបុគ្គលគប្បី សម្រេចដោយភាពជាព្រះអរិយបុគ្គល ដែលជាសទ្ធានុសារីបុគ្គលជាដើម ជាទៃៗ ឥដ្ឋផលដូចពោលមកនេះ ដែលត្រាស់ជាទី ៣ គប្បីជ្រាបថា ឥដ្ឋផល ទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ ។ ម្យ៉ាងទៀត សម្បត្តិ របស់មនុស្សឯណា ដែលមិនបានត្រាស់ទុកមុនដោយឥដ្ឋផល មានភាពជា អ្នកមានពណ៌សម្បុរល្អជាដើម និងដោយការចេះដឹង និងការឈ្វាសជាដើម ដែលលោកសម្តែងដោយន័យយ៉ាងនេះថា ជាអ្នកអង់អាច ជាអ្នកមានសតិ ការនៅប្រព្រឹត្តព្រហ្មចរិយៈ ក្នុងព្រះធម្មវិន័យនេះជាដើម ការត្រេកអរក្នុង ឈានជាដើម ក្នុងទេវលោកជាទៃណា និងនិព្វានសម្បត្តិតាមដែលពោល ហើយឯណា ឥដ្ឋផលដូចពោលមកនេះ ត្រាស់ជាចំណែកទី ៣ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ គប្បីជ្រាប ពណ៌នាក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។*

អធិប្បាយគាថាទី ១៤

ព្រះមានព្រះភាគ កាលទ្រង់សម្តែងនិព្វានសម្បត្តិដែលគប្បីបាន ដោយ

បុញ្ញានុភាព និងដែលគប្បីសម្រេចដោយភាពជាព្រះអរិយបុគ្គល មានសទ្ធានុសារីបុគ្គលជាដើមដោយគាថានេះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងនិព្វាននោះ និងឧបាយនៃនិព្វាននោះ ដោយភាពជាអ្នកជំនាញក្នុងវិជ្ជា ៣ និងឧកតោភាគវិមុត្តិ ទើបត្រាស់គាថានេះថា

> *ភាពនៃបុគ្គល កាលអាស្រ័យមិត្តសម្បទា បើប្រកបសេចក្តីព្យាយាមដោយឧបាយ ដែលត្រូវជាអ្នកស្ទាត់ក្នុងវិជ្ជា និងវិមុត្តិ ឥដ្ឋផលទាំងអស់ បានដោយកំណប់ទ្រព្យគឺបុណ្យនោះ ។*

ពណ៌នាបទនៃគាថានោះ មានដូច្នេះថា ឈ្មោះថា **សម្បទា** *ព្រោះជាគ្រឿងសម្រេចផល គឺដល់នូវសេចក្តីចម្រើននៃគុណសម្បទា គឺមិត្ត ឈ្មោះថា មិត្តសម្បទា ។ នូវមិត្តសម្បទានោះ ។ បទថា* **អាគម្ម** *ប្រែថា អាស្រ័យ ។ បទថា* **យោគិសោ** *បានដល់ ដោយឧបាយ ។ បទថា* **បយុញ្ជតោ** *បានដល់ ធ្វើនូវការប្រកបឧស្សាហ៍ ។ ឈ្មោះថា* **វិជ្ជា** *ព្រោះជាគ្រឿងជីងចាស់ ។ ឈ្មោះថា* **វិមុត្តិ** *ព្រោះជាគ្រឿងរួចផុត ឬរួចផុតឯង ។ វិជ្ជាផង វិមុត្តិផង ឈ្មោះថា វិជ្ជា និងវិមុត្តិ ។ ភាពជាអ្នកជំនាញក្នុងវិជ្ជា និងវិមុត្តិ ឈ្មោះថា* **វិជ្ជាវិមុត្តិវសីភាវោ** *។ ឯពណ៌នាសេចក្តី មានដូចតទៅនេះ*

ភាពដែលបុគ្គល អាស្រ័យមិត្តសម្បទា គឺអាស្រ័យព្រះសាស្តា ឬសព្រហ្មចារី ជាទីតាំងនៃសេចក្តីគោរពណាមួយ ទទួលឱវាទ និងអនុសាសនីអំពីលោកហើយ ប្រកបដោយយោនិសោមនសិការ ដោយកិច្ចបដិបត្តិតាម

ដែលលោកប្រៀនប្រដៅ ជាអ្នកជំនាញក្នុងវិជ្ជា ៣ មានបុព្វេនិវាសញ្ញាណជាដើម និងក្នុងវិមុត្តិ មានសមាបត្តិ ៨ និងព្រះនិព្វាន ដែលមកយ៉ាងនេះថា ក្នុងធម៌ទាំងនោះ វិមុត្តិ គឺអ្វី គឺការរួចផុតដ៏ក្រៃលែងនៃចិត្ត និងព្រះនិព្វាន ដោយអត្ថថា មិនយឺតយូរដោយប្រការនេះ ផលដែលត្រាស់ជាចំណែកទី ៤ នេះ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញ-និធិនេះ ។

អធិប្បាយគាថាធី ១៥

ព្រះមានព្រះភាគ កាលទ្រង់សម្តែងនិព្វានសម្បត្តិ ដែលបានដោយអានុភាពនៃបុណ្យដែលជាចំណែកនៃភាពជាអ្នកជំនាញក្នុងវិជ្ជា និងវិមុត្តិ ដែលពោលមកអំពីមុនហើយ គប្បីសម្រេចដោយអំណាចនៃវិជ្ជា ៣ និងឧភតោ-ភាគវិមុត្តិ ដោយគាថានេះ យ៉ាងនេះហើយ ឥឡូវនេះ ព្រោះលោកដល់នូវភាពជាបុគ្គលសម្រេចនូវភាពជាអ្នកជំនាញក្នុងវិជ្ជា និងវិមុត្តិ ជាអ្នកមានវិជ្ជា ៣ និងរួចផុតដោយចំណែក ២ លោកទាំងនោះ មិនមែនបាននូវសេចក្តីចម្រើននៃគុណ មានបដិសម្ភិទាជាដើមឡើយ តែការចម្រើននៃគុណ ដែលបុគ្គលរមែងបានដោយបុញ្ញសម្បទានោះ ដែលធ្វើហើយ ដោយប្រការនោះៗ ដោយជាបទដ្ឋាននៃវិមុត្តិនោះ ជួច្នោះ កាលទ្រង់សម្តែងសេចក្តីចម្រើននៃគុណានោះ ទើបត្រាស់គាថានេះថា

បដិសម្ភិទា វិមោក្ខ សាវកបារមីញ្ញាណ បច្ចេកពោធិញ្ញាណ
និងពុទ្ធភូមិណាៗ ឥដ្ឋផលទាំងអស់ រមែងបានដោយ

កំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។

ព្រោះថា បញ្ញានេះ ដល់នូវការបែកធ្លាយក្នុងធម៌ អត្ថ និរុត្តិ និងបដិ-ភាណ លោកហៅថា បដិសម្ភិទា វិមោក្ខ ៨ នេះ ដោយន័យថា បុគ្គលមានរូប រមែងឃើញរូបជាដើម ។ សាវកបារមីនេះ ដែលឲ្យសម្រេចសាវកសម្បត្តិ ដែលសាវកទាំងឡាយរបស់ព្រះមានព្រះភាគ គប្បីសម្រេច ។ ព្រះបច្ចេកពុទ្ធ ណា ដែលឲ្យសម្រេចភាពជាព្រះសយម្ភូ និងពុទ្ធភូមិណា ដែលឲ្យសម្រេចភាពជាអ្នកឧត្តមនៃសព្វសត្វ ឥដ្ឋផលដែលត្រាស់ជាចំណែកទី ៥ នេះ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ ដែលគេធ្វើហើយដោយប្រពៃ ។

អធិប្បាយគាថាទី ១២

ព្រះមានព្រះភាគ កាលទ្រង់សម្តែងផល ដែលត្រាស់ទុកថា ទេវតា និងមនុស្សទាំងឡាយ ប្រាថ្នាឥដ្ឋផលណាមួយ ឥដ្ឋផលទាំងអស់នោះ បុគ្គលរមែងបានដោយបុញ្ញនិធិនេះ ដោយគាថា ៥ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សរសើរបុញ្ញសម្បទា ដែលឃើញថា ជានិធិដែលឲ្យផលគួរប្រាថ្នាគ្រប់យ៉ាង ទើបទ្រង់បញ្ចប់ទេសនា ដោយគាថានេះថា

បុញ្ញសម្បទានេះ ឲ្យសម្រេចប្រយោជន៍ដ៏ធំ ដោយប្រការ
ដូច្នេះ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយជាធីរជន ទើប
សរសើរនូវភាពនៃបុគ្គលជាអ្នកមានបុណ្យធ្វើទុកហើយ ។

ពណ៌នាបទនៃគាថានោះ មានដូច្នេះថា បទថា **ឃវំ** *ជាពាក្យសម្តែងភាព*

ដែលកន្ទងហើយ ។ ឈ្មោះថា **មហាត្តិកា** *ព្រោះមានប្រយោជន៍ច្រើន លោកអធិប្បាយថា ប្រព្រឹត្តទៅដើម្បីប្រយោជន៍យ៉ាងធំ បាឋៈថា* **មហាទ្ធិកា** *ដូច្នេះក៏មាន ។ បទថា* **ឯសា** *ជាពាក្យឧទ្ទេស លើកបុញ្ញសម្បទា ដែលត្រាស់តាំងអំពីដើមបទនេះថា* **យស្ស ឆានេន សីលេន** *រហូតដល់បទថា* **កយិរាថ ធីរោ បុញ្ញានិ** *ដោយពាក្យឧទ្ទេសនោះ ។ សព្ទថា* **យឥធំ** *ជានិបាតចុះក្នុងអត្ថ ធ្វើឲ្យប្រជុំគ្នា ។ ដើម្បីទ្រង់អធិប្បាយបទឧទ្ទេស ដែលទ្រង់លើកថា* **ឯសា** *ទើបទ្រង់ធ្វើឲ្យប្រជុំគ្នាថា* **យា ឯសា** *ដោយនិបាតសព្ទថា* **យឥធំ** *នោះ ។ ការដល់ព្រមនៃបុណ្យទាំងឡាយ ឈ្មោះថា* **បុញ្ញសម្បទា ។** *បទថា* **តស្មា** *ជាពាក្យសម្តែងហេតុ ។ បទថា* **ធីរា** *បានដល់ អ្នកមានបញ្ញា ។ បទថា* **បសំសន្តិ** *ប្រែថា សរសើរ ។ បទថា* **បណ្ឌិតា** *បានដល់ ដែលដល់ព្រមដោយបញ្ញា ។ បទថា* **កតបុញ្ញតំ** *ប្រែថា ភាពជាអ្នកមានបុណ្យបានធ្វើហើយ ។*

ចំណែកឯពណ៌នាសេចក្តី មានដូច្នេះថា ព្រះដ៏មានព្រះភាគ កាលទ្រង់សរសើរបុញ្ញនិធិ គឺភាពជាអ្នកមានពណ៌សម្បុរល្អជាដើម មានពុទ្ធភូមិ ជាទីបំផុត ដែលល្មមបុគ្គលគប្បីសម្រេចបាន ដោយអានុភាពនៃបុញ្ញសម្បទាដូច្នេះហើយ ឥឡូវនេះ កាលទ្រង់សំដែងតាមសេចក្តីនោះឯង កាលទ្រង់លើកភាពដែលបុញ្ញសម្បទា តាមដែលពោលហើយ មានប្រយោជន៍ច្រើនដោយសេចក្តីនោះឯង ទើបត្រាស់ថា ការដែលបុញ្ញសម្បទា ដែលតថាគតសម្តែងដោយន័យថា **យស្ស ឆានេន សីលេន** *ដូច្នេះ ព្រោះហេតុនោះ ទើប*

បណ្ឌិតអ្នកមានបញ្ញា ដូចតថាគតសរសើរ ភាពជាអ្នកមានបុណ្យបានធ្វើ ហើយ ដែលមានអាការ និងវោការៈ គឺខន្ធច្រើន ដោយពាក្យដែលពោលក្នុងទីនេះ មានពាក្យថា កំណប់ទ្រព្យ គឺបុណ្យមិនទូទៅដល់ពួកជនដទៃ ជារបស់ដែលចោរលួចទៅមិនបានជាដើម និងដែលបានពោលថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំខ្លាចបុណ្យទៀយ ពាក្យថា បុណ្យនេះ ជាឈ្មោះនៃសេចក្តីសុខនោះឯង ដូច្នេះជាដើម ដោយគុណតាមសេចក្តីពិត ព្រោះមិនខ្វិលច្រអូសក្នុងការសម្តែងធម៌ ដែលនាំមកនូវប្រយោជន៍ និងសេចក្តីសុខដល់សត្វទាំងឡាយ មិនមែនសរសើរឲ្យចូលខាងបក្ខពួករបស់ខ្លួនទៀយ ។

លុះចប់ទេសនា ឧបាសកនោះ ក៏តាំងនៅក្នុងសោតាបត្តិផល មួយអន្លើ ដោយជនជាច្រើន ឯឧបាសកនោះ ក៏ចូលទៅគាល់ ព្រះបាទបសេនទិ-កោសល ក្រាបទូលសេចក្តីនោះ ។ ព្រះរាជាទ្រង់ត្រេកអរក្រៃលែង ទ្រង់សរសើរថា សាធុ គហបតី សាធុ គហបតី អ្នកកប់កំណប់ទ្រព្យ ដែលខ្ញុំនាំទៅមិនបាន ទ្រង់បានធ្វើការបូជាដ៏ច្រើនដល់ឧបាសកនោះឯង ៗ

អដ្ឋកថា និធិកណ្ឌសូត្រ ចប់

សុត្តន្តបិដក

ខុទ្ទកនិកាយ: ការណីយមេត្តសូត្រ

[១០] កិច្ចណា (ដែលព្រះអរិយៈ) បានត្រាស់ដឹងនូវបទដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន (បានធ្វើហើយ) កិច្ចនោះ កុលបុត្តអ្នកឈ្វាសក្នុងប្រយោជន៍គួរធ្វើ (កុលបុត្តនោះ) ជាអ្នកអាចហ៊ានផង ត្រង់ដោយកាយនិងវាចាផង ត្រង់ល្អដោយចិត្តផង គេប្រជៅងាយផង មានសភាពទន់ភ្លន់ផង មិនមានមានះដ៏ក្រៃលែងផង សន្តោសផង គេចិញ្ចឹមងាយផង មានកិច្ចធុរៈតិចផង ប្រព្រឹត្តស្រាលព្រម (មានបរិក្ខារតិច) ផង មានឥន្ទ្រិយស្រគត់ស្រគំផង មានប្រាជ្ញាចាស់ផង មិនឃ្មើសឃ្មងផង មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយផង វិញ្ញូជនទាំងឡាយ គួរតិះដៀលជនទាំងឡាយដទៃដោយកម្មណាមិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមកសូម្បីតិចតួច (ហើយគួរផ្សាយមេត្តាចិត្តចំពោះពពួកសត្វថា) សត្វទាំងឡាយទាំងពួងសូមឲ្យមានសេចក្តីសុខ ឲ្យមានសេចក្តីក្សេម ឲ្យមានខ្លួនដល់នូវសេចក្តីសុខចុះ សត្វមានជីវិតទាំងឡាយណាមួយ ឥតមានសេសសល់ ទោះសត្វមានសេចក្តីតក់ស្លុត គឺនៅមានតណ្ហាក្តី មាំមួន គឺឥតមានតណ្ហាក្តី សត្វទាំង-ឡាយណា មានកាយវែងក្តី ធំក្តី មានកាយយ៉ាងកណ្តាលក្តី ខ្លីក្តី មានកាយស្គម ឬធាត់ក្តី សត្វទាំងឡាយណា ដែលយើងឃើញហើយក្តី មិនឃើញហើយក្តី សត្វទាំងឡាយណា នៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ដែលកើតរួចមកហើយក្តី ដែលកំពុងស្វែងរកទីកើតក្តី សត្វទាំងអស់ (នោះ) ចូរមានខ្លួនជាសុខចុះ ។ សត្វដទៃមិនគួរកំហែងបៀតបៀននូវសត្វដទៃឡើយ មិនគួរ

មើលងាយគេតិចតួចក្នុងទីណាមួយឡើយ មិនគួរប្រាថ្នានូវសេចក្តីទុក្ខដល់គ្នា និងគ្នា ព្រោះសេចក្តីក្រេវក្រោធ និងសេចក្តីចង្អៀតចង្អល់ក្នុងចិត្តឡើយ ។ មាតាថ្នមរក្សាបុត្តដែលកើតអំពីខ្លួន ជាកូនតែមួយដោយអាយុ (ស្មើដោយជីវិត) យ៉ាងណាមិញ បុគ្គលគួរចម្រើនមេត្តាចិត្ត មិនមានប្រមាណចំពោះសត្វទាំងឡាយទាំងពួង យ៉ាងនោះឯង ។ បុគ្គលគួរចម្រើនមេត្តាចិត្ត មិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមានពៀរ មិនមានសត្រូវ ទៅក្នុងលោកទាំងអស់ គឺក្នុងទីខាងលើផង ខាងក្រោមផង ខាងទទឹង គឺត្រង់កណ្តាលផង ។ (បុគ្គលអ្នកចម្រើនមេត្តាចិត្តនោះ) ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកមានសេចក្តីងោកងក់ទៅប្រាស់ហើយ គឺជាអ្នកមិនដេកលក់អស់កាលត្រឹមណា គួរតម្កល់នូវសតិនោះ អស់កាលត្រឹមនោះ បណ្ឌិតទាំង-ឡាយ ពោលនូវកិរិយានុ៎ះថា ជាព្រហ្មវិហារក្នុងសាសនានេះ ។ (បុគ្គលដែលមានមេត្តាព្រហ្មវិហារ) មិនឆប់នឹងទិដ្ឋិ ជាអ្នកមានសីលប្រកបដោយទស្សនសម្បត្តិ គឺសោតាបត្តិមគ្គ (តទៅទៀត) បន្ទោបង់នូវសេចក្តីជាប់ជំពាក់ក្នុងកាមទាំងឡាយហើយ រមែងមិនមកកាន់ គព្ភសេយ្យាទៀតឡើយ ។

មេត្តសូត្រ ចប់

ខុទ្ទកបាឋៈ ចប់

អដ្ឋកថា

មេត្តសូត្រ

ប្រយោជន៍នៃការតាំងនិក្ខេបបទ

[១០] ឥឡូវនេះ ដល់លំដាប់ពណ៌នាអត្ថនៃមេត្តសូត្រ ដែលលើកឡើងក្នុងលំដាប់ បន្ទាប់អំពីនិធិកណ្ឌសូត្រ ។ ក្នុងទីនេះ ខ្ញុំនឹងពោលប្រយោជន៍នៃការតាំងមេត្តសូត្រនោះ ហើយបន្ទាប់អំពីនោះ គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនេះថា មេត្តសូត្រនោះ បុគ្គលណាពោល ពោលក្នុងកាលណា ពោលទីណា ពោលព្រោះហេតុដូចម្តេច ជម្រះនិទានហើយ ទើបនឹងពណ៌នាអត្ថនៃមេត្តសូត្រនោះ ។

ក្នុងមេត្តសូត្រនោះ ព្រោះទ្រង់ត្រាស់បុញ្ញសម្បទា មានទាន សីលជាដើម ដោយនិធិកណ្ឌសូត្រ ។ កាលបុគ្គលធ្វើមេត្តាក្នុងសត្វទាំងឡាយ បុញ្ញសម្បទានោះ រមែងមានផលច្រើន រហូតដល់អាចឲ្យសម្រេចពុទ្ធភូមិបាន ដូច្នោះ ទើបខ្ញុំលើកមេត្តសូត្រឡើងក្នុងទីនេះ ដើម្បីសម្តែងថា មេត្តសូត្រមានឧបការៈដល់បុញ្ញសម្បទានោះ ឬព្រោះហេតុដែលខ្ញុំ កាលសម្តែងកម្មដ្ឋានដែលអាចលះទោសៈ ដោយទុត្តិសាការសម្រាប់ជនទាំងឡាយ ដែលរាប់អានព្រះសាសនាដោយសរណៈ ហើយតាំងនៅក្នុងសីល ដោយសិក្ខាបទទាំងឡាយ នឹងអាចលះមោហៈដោយកុមារប្បញ្ហា ទើបសម្តែងថា ការប្រព្រឹត្តសរណៈជាដើមនោះជាមង្គល និងរក្សាខ្លួនឯងដោយមង្គលសូត្រ សម្តែងការរក្សាអ្នកដទៃ ដែលសមគួរដល់មង្គលនោះ ដោយរតនសូត្រ សម្តែងការឃើញកូតពួកខ្លះ ក្នុង

បណ្តាភូតទាំងឡាយដែលពោលមកក្នុងរតនសូត្រ និងការវិបត្តិនៃជន ដែលប្រមាទក្នុងបុញ្ញសម្បត្តិ ដូចដែលពោលហើយដោយតិរោកុឌ្ឌសូត្រ និងសម្តែងសម្បត្តិដែលជាបដិបក្ខចំពោះវិបត្តិដែលពោលក្នុងតិរោកុឌ្ឌសូត្រ ដោយនិធិ-កណ្ឌសូត្រ តែមិនទាន់បានសម្តែងកម្មដ្ឋាន ដែលអាចលះទោសៈ ដូច្នោះ ដើម្បីសម្តែងកម្មដ្ឋានដែលអាចលះទោសៈនោះ ទើបខ្ញុំលើកមេត្តសូត្រនេះ ឡើងក្នុងទីនេះ ។ កាលបើដូច្នោះ ទើបខុទ្ទកបាឋៈបរិបូណ៌ដោយល្អ ការពោលមកដូច្នេះ ជាប្រយោជន៍នៃការតាំងមេត្តសូត្រនោះក្នុងទីនេះ ។

អធិប្បាយនិទាន

ឥឡូវនេះ ខ្ញុំនឹងលើកមាតិកានេះឡើងថា គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនេះថា មេត្តសូត្រនេះ បុគ្គលណាពោល ពោលកាលណា ពោលទីណា និងពោលព្រោះហេតុអ្វី ខ្ញុំជម្រះនិទានហើយ នឹងពណ៌នាសេចក្តីនៃមេត្តសូត្រនោះ ដូច្នេះ ។

ក្នុងមាតិកានោះ គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនេះ និងការជម្រះនិទាន ដោយសង្ខេបយ៉ាងនេះមុនថា មេត្តសូត្រនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ សាវ័កជាដើមមិនបានពោល តែកាលណា ភិក្ខុទាំងឡាយត្រូវទេវតាទាំងឡាយបៀតបៀន ក្បែរភ្នំហិមពាន្ត ទើបនាំគ្នាមកគាល់ព្រះមានព្រះភាគកាលនោះ ទើបព្រះមានព្រះភាគត្រាស់មេត្តសូត្រនោះ ដើម្បីការពារ និងដើម្បីជាកម្មដ្ឋានសម្រាប់ភិក្ខុទាំងនោះ ។

ចំណែកដោយពិស្តារ គប្បីជ្រាបយ៉ាងនេះថា សម័យមួយ ក្នុងតិចីជិត

ចូលវស្សា ព្រះមានព្រះភាគ ប្រថាប់នៅក្នុងក្រុងសាវត្ថី ។ សម័យនោះ ភិក្ខុទាំងឡាយ មកអំពីនគរផ្សេងៗ ជាច្រើន ទទួលកម្មដ្ឋានក្នុងសម្នាក់ព្រះមានព្រះភាគហើយ បំណងនឹងចាំវស្សាក្នុងទីនោះៗ ទើបចូលគាល់ព្រះមានព្រះភាគ ។ បានឮថា សម័យនោះ ព្រះមានព្រះភាគ ត្រាស់កម្មដ្ឋានទាំង-ឡាយ ដែលសមគួរដល់ចរិត ៨៤០០០ ប្រភេទ ដោយនយយ៉ាងនេះ គឺ អសុភកម្មដ្ឋាន ១១ យ៉ាង គឺអសុភដែលមានវិញ្ញាណ និងមិនមានវិញ្ញាណ សម្រាប់បុគ្គលរាគចរិត កម្មដ្ឋាន មានមេត្តាកម្មដ្ឋានជាដើម ៤ យ៉ាង សម្រាប់បុគ្គលទោសចរិត កម្មដ្ឋាន មានមរណស្សតិកម្មដ្ឋានជាដើម សម្រាប់បុគ្គលមោហចរិត កម្មដ្ឋាន មានអានាបានស្សតិ និងបបវីកសិណជាដើម សម្រាប់បុគ្គលវិតក្កចរិត កម្មដ្ឋាន មានពុទ្ធានុស្សតិកម្មដ្ឋានជាដើម សម្រាប់បុគ្គលសទ្ធាចរិត កម្មដ្ឋាន មានចតុធាតុវវដ្ឋានកម្មដ្ឋានជាដើម សម្រាប់បុគ្គលពុទ្ធិចរិត ។

លំដាប់នោះ ភិក្ខុប្រមាណ ៥០០ រូប រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះមានព្រះភាគ កំពុងស្វែងរកសេនាសនៈ ដែលជាសប្បាយ និងគោចរគាម ធ្វើដំណើរទៅតាមលំដាប់ បានជួបភ្នំ មានផ្ទាំងថ្មពណ៌ខៀវចាស់ដូចកែវមណី ប្រដាប់ដោយដងព្រៃពណ៌ខៀវ មានម្លប់ត្រជាក់ មានផែនដីរាបស្មើ ក្រាលដោយខ្សាច់ ដូចបន្ទះប្រាក់ និងដូចសំណាញ់នៃកែវមុក្តា ព័ទ្ធដោយជលាល័យដ៏ស្អាតល្អ ជាប់គ្នានឹងព្រៃហិមពាន្ត ក្នុងបច្ចន្តបទេស ភិក្ខុទាំងនោះស្នាក់នៅមួយយប់ក្នុងទីនោះ កាលរាត្រីអស់ហើយ ធ្វើសរីរកិច្ច ក៏នាំគ្នាចូលទៅបិណ្ឌ-

ជាត ត្រង់ភូមិមួយកន្លែងជិតទីនោះឯង ភូមិនោះប្រកបដោយត្រកូលមួយពាន់ ដែលនៅអាស្រ័យកុះករក្នុងភូមិនោះ មនុស្សទាំងឡាយមានបសាទសទ្ធា ជនទាំងនោះឃើញភិក្ខុទាំងឡាយប៉ុណ្ណោះ ក៏កើតបីតិសោមនស្ស ព្រោះការឃើញបព្វជិតក្នុងបច្ចន្តបទេស រកបានដោយកម្រ និមន្តភិក្ខុទាំងនោះឲ្យឆាន់ហើយ ក៏អារាធនាថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់គង់នៅទីនេះអស់ត្រៃមាសចុះ ហើយនាំគ្នាសង់កុដិសម្រាប់ធ្វើសេចក្តីព្យាយាម ៥០០ ខ្នង រៀបចំគ្រឿងឧបករណ៍គ្រប់យ៉ាង មានគ្រែ តាំង ក្អមទឹកសម្រាប់ឆាន់ ទឹកប្រើប្រាស់ជាដើមក្នុងទីនោះ ។

ក្នុងថ្ងៃស្អែកឡើង ភិក្ខុទាំងឡាយ ចូលទៅបិណ្ឌបាតក្នុងតំបន់ដនៃ ក្នុងភូមិនោះ មនុស្សទាំងឡាយ ក៏ទំនុកបម្រុងយ៉ាងនោះដូចគ្នា អារាធនាឲ្យនៅចាំវស្សា ។ ភិក្ខុទាំងឡាយទទួលនិមន្ត ដោយអាងលេសថា បើមិនមានអន្តរាយទើបនាំគ្នាចូលទៅកាន់ដងព្រៃនោះ ជាអ្នកប្រារព្ធសេចក្តីព្យាយាមអស់យប់និងថ្ងៃ រាយជួងប្រាប់យាម ជាអ្នកច្រើនដោយយោនិសោមនសិការ ទើបចូលទៅអង្គុយត្រង់គល់ឈើ ។ រុក្ខទេវតាទាំងឡាយ ត្រូវតេជះរបស់ភិក្ខុអ្នកមានសីលកម្ចាត់ហើយ ក៏ចុះចាកវិមានរៀងៗ ខ្លួន នាំកូនៗ ត្រាច់ទៅរហាំ ប្រៀបដូចកាលព្រះរាជា ឬរាជអមាត្យទៅកាន់លំនៅរបស់អ្នកស្រុក កាន់យកឱកាសទំនេរក្នុងផ្ទះទាំងឡាយ របស់ពួកអ្នកស្រុកៗ ក៏ត្រូវចេញអំពីផ្ទះ ទៅកាន់ទីជនៃ បានត្រឹមតែសម្លឹងមើលក្បែរៗ ដោយបំណងថា កាលណាហ្ន៎ ទើបព្រះរាជាយាងទៅវិញ យ៉ាងណា ទេវតាទាំងឡាយ ត្រូវលះបង់វិមានរបស់ខ្លួន

រៀងៗ ខ្លួន បានត្រឹមតែសម្លឹងមើលជិតៗ ដោយបំណងថា កាលណាហ្ន៎ ទើប លោកទៅវិញ ក៏ដូច្នោះដូចគ្នា ។ បន្ទាប់អំពីនោះ ទេវតាទាំងឡាយក៏នាំគ្នា គិតយ៉ាងនេះថា កិក្ខុទាំងឡាយ ចូលវស្សាជំបូងហើយ នឹងនៅអស់ត្រៃមាស ដោយពិត ពួកយើងមិនអាចនាំកូននៅរោងការឆួយបានយូរឡើយ ណ្ហ៎ីយចុះ ពួកយើងនឹងបង្ហាញអារម្មណ៍ ដែលគួរខ្លាចដល់កិក្ខុទាំងឡាយ ។ ទើបទេវតា ទាំងនោះនិម្មិតរូបយក្ខដែលគួរខ្លាច ឈរនៅចំពោះមុខ ក្នុងពេលដែលកិក្ខុ ទាំងឡាយធ្វើសមណធម៌ នៅពេលរាត្រី និងធ្វើសំឡេងគួរខ្លាច ព្រោះឃើញ រូបទាំងនោះ និងបានឮសំឡេងនោះ ហទយៈរបស់កិក្ខុទាំងឡាយក៏កម្រើក កិក្ខុទាំងនោះមានពណ៌សម្បុរស្វេកស្វាំង និងកើតរោគស្គមលឿង ។ ដោយ ហេតុនោះ ទើបកិក្ខុទាំងនោះ មិនអាចធ្វើចិត្តឲ្យមានអារម្មណ៍តែមួយបាន កាលចិត្តមិនមានអារម្មណ៍តែ ១ កិតភ័យរឿយៗ ព្រោះសេចក្តីខ្លាច សតិ របស់ កិក្ខុទាំងនោះក៏ប្រាសទៅ បន្ទាប់អំពីនោះ អារម្មណ៍ដែលស្អុយ ក៏ជួប ដល់កិក្ខុទាំងនោះ ដែលប្រាសចាកសតិហើយ ខ្លួរក្បាលរបស់កិក្ខុទាំងនោះ ហាក់ដូចត្រូវក្អិនស្អុយនោះបៀតបៀន រោគឈឺក្បាលក៏កើតឡើងយ៉ាងធ្ងន់ ។ កិក្ខុទាំងនោះ ក៏មិនព្រមប្រាប់រឿងនោះដល់គ្នានិងគ្នា ។

ថ្ងៃមួយ កាលកិក្ខុគ្រប់រូបប្រជុំគ្នា ក្នុងពេលបម្រើព្រះសង្ឃត្ថេរ ។ ព្រះ សង្ឃត្ថេរសួរថា អាវុសោ កាលពួកលោកចូលទៅកាន់ជងព្រៃនេះ ២-៣ ថ្ងៃ ពណ៌សម្បុរបរិសុទ្ធផូរផង់ក្រៃពេក ឥន្ទ្រិយក៏ផូរផង់ តែឥឡូវនេះ ក្នុងទីនេះ ពួកលោកស្គាំងស្គម ពណ៌សម្បុរស្វេកស្វាំង កើតរោគស្គមលឿង ក្នុងទីនេះ

ពួកលោកមិនសប្បាយឬ ។

លំដាប់នោះ ភិក្ខុមួយរូបពោលថា បពិត្រលោកម្ចាស់ ពេលយប់ ខ្ញុំ
ឃើញ និងឮអារម្មណ៍ដែលគួរខ្លាចយ៉ាងនេះៗ ហិតតែក្លិនបែបនេះ ដោយហេតុ
នោះ ទើបចិត្តរបស់ខ្ញុំ មិនតាំងមាំជាសមាធិ ។ ភិក្ខុគ្រប់រូបក៏នាំគ្នាប្រាប់រឿង
នោះដោយឧបាយនេះដូចគ្នា ព្រះសង្ឃត្ថេរពោលថា អាវុសោ ព្រះមានព្រះភាគ
ទ្រង់បញ្ញត្តការចូលវស្សា ២ យ៉ាង សេនាសនៈនេះ មិនសប្បាយដល់ពួក
យើង មកចុះអាវុសោ ពួកយើងនាំគ្នាទៅគាល់ព្រះមានព្រះភាគ ទូលសួរដល់
សេនាសនៈដែលជាសប្បាយដទៃៗ ភិក្ខុទាំងនោះទទួលពាក្យព្រះថេរៈថា សាធុ
គ្រប់រូបក៏ទុកជាក់សេនាសនៈ កាន់ចាត្រ ចីវរ មិនប្រាប់ដល់បុគ្គលណាម្នាក់
ក្នុងត្រកូលទាំងឡាយ នាំគ្នាចារិកទៅកាន់ក្រុងសាវត្ថី ដល់ក្រុងសាវត្ថី
តាមលំដាប់ ហើយក៏នាំគ្នាចូលគាល់ព្រះមានព្រះភាគ ។

ព្រះមានព្រះភាគ ទ្រង់ឃើញភិក្ខុទាំងនោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំង-
ឡាយ តថាគតបញ្ញត្តសិក្ខាបទថា ភិក្ខុមិនគប្បីចារិកទៅខាងក្នុងវស្សា ហេតុ
អ្វី ទើបពួកអ្នកនាំគ្នាចារិក ។ ទើបភិក្ខុទាំងនោះ ក្រាបទូលរឿងទាំងអស់ដល់
ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់អាវជ្ជនៈក៏មិនឃើញសេនាសនៈ
ដែលជាសប្បាយដទៃសម្រាប់ភិក្ខុទាំងនោះ ពេញជម្ពូទ្វីប ដោយហោចសូម្បី
ត្រឹមតែតាំងដែលមានជើង ៤ ដូច្នោះ ទើបត្រាស់ប្រាប់ភិក្ខុទាំងនោះថា ម្នាល
ភិក្ខុទាំងឡាយ សេនាសនៈដែលជាសប្បាយដទៃ សម្រាប់ពួកអ្នកមិនមានទេ
ពួកអ្នកចូរនៅក្នុងទីនោះឯង នឹងសម្រេចធម៌ជាទីអស់អាសវៈ ទៅចុះភិក្ខុទាំង-

ទ្បាយ ពួកអ្នកទៅអាស្រ័យសេនាសនៈនោះជាមួយគ្នាចុះ តែបើពួកអ្នកប្រាថ្នាការមិនមានភ័យអំពីទេវតាទាំងទ្បាយ ក៏ចូរនាំគ្នារៀនព្រះបរិត្តនេះ ដ្បិតថាព្រះបរិត្តនេះ នឹងជាគ្រឿងការពារ និងជាកម្មដ្ឋានសម្រាប់ពួកអ្នក ដូច្នេះហើយទើបត្រាស់ព្រះសូត្រនេះ ។

តែអាចារ្យពួកជនៃទៀតពោលថា ព្រះមានព្រះភាគត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងទ្បាយ អ្នកចូរទៅចុះ ពួកអ្នកចូរទៅអាស្រ័យសេនាសនៈនោះឯង ជាមួយគ្នាចុះ ហើយទើបត្រាស់ថា ម្យ៉ាងទៀត ភិក្ខុនៅព្រៃ គួរស្គាល់បរិហារ ។ បរិហារដូចម្តេច បរិហារយ៉ាងនេះ គឺផ្សាយមេត្តា ២ ពេល គឺធ្វើពេលល្ងាច និងព្រឹក ធ្វើព្រះបរិត្ត ២ ពេល ចម្រើនអសុភ ២ ពេល ចម្រើនមរណស្សតិ ២ ពេល និងគិតដល់សង្វេគវត្ថុ ៨ គឺជាតិ ជរា ព្យាធិ មរណៈ អបាយទុក្ខបួន ២ ពេល ។

ម្យ៉ាងទៀត ជាតិ ជរា ព្យាធិ មរណៈ ៤ អបាយទុក្ខជាគម្រប់ ៥ អតីតវដ្តមូលទុក្ខ ១ អនាគតវដ្តមូលទុក្ខ ១ ទុក្ខព្រោះការស្វែងអាហារបច្ចុប្បន្នជាមូល ១ ។ ព្រះមានព្រះភាគ កាលទ្រង់ប្រាប់ការបរិហារយ៉ាងនេះហើយទើបត្រាស់ព្រះសូត្រនេះ ដើម្បីជាមេត្តា ដើម្បីជាព្រះបរិត្ត និងដើម្បីឈានដែលជាបាទនៃវិបស្សនាដល់ភិក្ខុទាំងនោះ ។ គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនេះថា **យេន វុត្តំ យត្ថ យត្ត យស្មា** *ចេ និងការជម្រះនិព្វាន ដោយប្រការដូច្នេះ ។*

មាតិកានោះ ខ្ញុំតាំងទុកថា **យេន វុត្តំ យត្ថ យត្ត យស្មា ចេតេស**

ធីបនា និធានំ សោធយិត្វា ។ មាតិកានោះ ខ្ញុំពោលពិស្តារហើយ ដោយ អាការទាំងពួង ដោយគាថាមានប្រមាណប៉ុណ្ណេះ ។

អធិប្បាយ គាថាធី ១

ឥឡូវនេះ នឹងផ្តើមពណ៌នាសេចក្តីនៃព្រះសូត្រនោះ ដែលធ្វើការជម្រះ និទានហើយយ៉ាងនេះ ខ្ញុំបានពោលថា នឹងពណ៌នាសេចក្តីនៃព្រះសូត្រនោះ ដូច្នេះ ។ ក្នុងគាថានោះ នឹងផ្តើមពណ៌នាបទនៃគាថានេះថា **ការណីយមត្ត-កុសលេន** ដូច្នេះជាមុនសិន ។ បទថា **ការណីយំ** ប្រែថា គប្បីធ្វើ អធិប្បាយ ថា គួរដល់ការធ្វើ ។ បដិបទា ឈ្មោះថា អត្ត ឬប្រយោជន៍ដល់ខ្លួនណាមួយ ប្រយោជន៍ទាំងអស់នោះ លោកហៅថា អត្ត ព្រោះមិនមានកិលេស ដូច សត្រូវ ឈ្មោះថា **ការណី** ព្រោះដែលបុគ្គលគប្បីចូលដល់ ។ បុគ្គលឈ្លាស ក្នុងប្រយោជន៍ ឈ្មោះថា **អត្តកុសល** លោកអធិប្បាយថា ជាបុគ្គលឈ្លាស ក្នុងប្រយោជន៍ ។ បទថា **យំ** ជាបឋមាវិភត្តិ សម្តែងការមិនពិតប្រាកដ ។ បទថា **តំ** ជាទុតិយាវិភត្តិ សម្តែងអត្តពិតប្រាកដ ។ ឬថា ពាក្យថា **យំ តំ** ទាំង ២ ជាបឋមាវិភត្តិ ។ ពាក្យថា **សន្តំ បទំ** ជាទុតិយាវិភត្តិ ។ បណ្តា ពាក្យទាំង ២ នោះ ឈ្មោះថា **សន្ត** ព្រោះជាលក្ខណៈ ដែលមានឈ្មោះថា **បទ** ព្រោះដែលបុគ្គលគប្បីដល់ ពាក្យនេះជាឈ្មោះនៃព្រះនិព្វាន ។ បទថា **អភិសមេច្ច** ប្រែថា សម្រេចហើយ ។ បុគ្គលណា រមែងអាច ហេតុនោះ បុគ្គលនោះ ឈ្មោះថា **សក្ក** គឺជាអ្នកអាច លោកអធិប្បាយថា ជាអ្នកអាច ជាអ្នកអាចហ៊ាន ។ បទថា **ឧជុ** បានដល់ ប្រកបដោយការត្រង់ ។ បុគ្គល

ណាត្រង់ដោយល្អ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **សុហុជ្ជ** *គឺអ្នកត្រង់ដោយល្អ ។ ការប្រដៅងាយមានក្នុងបុគ្គលនោះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា* **សុវចោ** *គឺជាអ្នកប្រដៅងាយ ។ បទថា* **អស្ស** *ប្រែថា គប្បីមាន គប្បីកើត ។ បទថា* **មុទុ** *បានដល់ ប្រកបដោយការទន់ភ្លន់ បុគ្គលណាមិនមានអតិមានៈ ហេតុនោះ បុគ្គលនោះ ឈ្មោះថា* **អនតិមានី** ។

ឯពណ៌នាក្នុងគាថាទី ១ មានដូច្នេះថា ។

និងវិនិច្ឆ័យក្នុងពាក្យថា **ការណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិ-សមេច្ច** *នេះមុន ។* **ការណី** *ក៏មាន* **អការណី** *ក៏មាន ។ ក្នុង ២ យ៉ាងនោះ ដោយសង្ខេប សិក្ខា ៣ ឈ្មោះថា* **ការណី** ។ *សីលវិបត្តិ ទិដ្ឋិវិបត្តិ អាចារវិបត្តិ អាជីវវិបត្តិ ដូចពោលមកយ៉ាងនេះជាដើម ឈ្មោះថា* **អការណី** *ម្យ៉ាងទៀត* **អត្ថកោសល** *ក៏មាន* **អនត្ថកោសល** *ក៏មាន ។ ក្នុង ២ យ៉ាងនោះ បុគ្គលណាបួសក្នុងសាសនានេះ មិនប្រកបខ្លួនដោយប្រពៃ ជាអ្នកមានសីលដាច់ អាស្រ័យអានេសនា គឺការស្វែងរកដែលមិនសមគួរ ២១ យ៉ាង ចិញ្ចឹមជីវិត គឺឲ្យឫស្សី ១ ឲ្យស្លឹកឈើ ១ ឲ្យផ្កា ១ ឲ្យផ្លែឈើ ១ ឲ្យឈើសូនរ ១ ឲ្យទឹកលុបមុខ ១ ឲ្យទឹកដុតធ្មេញ ១ ឲ្យលម្អិតលាបខ្លួន ១ ឲ្យដីដុសខ្លួន ១ និយាយបញ្ឆោត ១ និយាយលេងលាយមែន ១ ចិញ្ចឹមកូនឲ្យគេ ១ ទទួលបម្រើគ្រហស្ថ ១ ធ្វើខ្លួនជាគ្រូពេទ្យ ១ ធ្វើខ្លួនជាទូត ១ ទទួលបញ្ជូនដំណឹងគ្រហស្ថ ១ យកលាភទាក់លាភ ១ ដោះដូរ ១ ធ្វើគ្រូមើលផែនដី ១ ធ្វើគ្រូមើលឫក្ស ១ ជាគ្រូមើលលក្ខណៈ ១ ។ ប្រព្រឹត្តអគោចរ ៦ គឺ*

កន្ទែងស្រីពេស្យា ១ សម្ផាក់ស្រីមេម៉ាយ ១ សម្ផាក់ក្រមុំចាស់ ១ សម្ផាក់ខ្ទើយ ១ សម្ផាក់កិក្ខុនី ១ រោងសុភ ១ ។ ច្រឡូកច្រឡំដោយគ្រហស្ថ គឺ ព្រះរាជា អមាត្យ តិរ្ថិយ សាវកតិរ្ថិយ ដោយការច្រឡូកច្រឡំ ដែលមិនសមគួរ ។ សេពគប់បុគ្គលចូលត្រកូល ដែលមិនមានបសាទសទ្ធា មិនដូចជាអណ្តូងទឹក ជេរ និងបរិភាស ប្រាថ្នាតែវត្ថុដែលមិនជាប្រយោជន៍ មិនផាសុក មិនលែងនូវយោគៈ ដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា កុលបុត្តនេះ ឈ្មោះថា ឈ្វាសក្នុងវត្តមិនជាប្រយោជន៍ ។

ម្យ៉ាងទៀត បុគ្គលណាបួសក្នុងព្រះសាសនានេះ ប្រកបខ្ជួនដោយប្រពៃ លះអនេសនា ប្រាថ្នាតែការតាំងនៅក្នុងចតុប្បារិសុទ្ធិសីល បំពេញបាតិមោក្ខ-សំវរសីលដោយសទ្ធាជាសំខាន់ បំពេញឥន្ទ្រិយសំវរសីល ដោយសតិជាសំខាន់ បំពេញអាជីវបារិសុទ្ធិសីល ដោយសេចក្តីព្យាយាមជាសំខាន់ បំពេញការសេពបច្ច័យដោយបញ្ញាជាសំខាន់ បុគ្គលនេះ ឈ្មោះថា កុលបុត្តអ្នកឈ្វាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត បុគ្គលណា ជម្រះបាតិមោក្ខសំវរសីល ដោយជម្រះអាបត្តិ ៧ កង ជម្រះឥន្ទ្រិយសំវរសីល ដោយមិនឲ្យអភិជ្ឈាជាដើមកើតក្នុងអារម្មណ៍ដែលប៉ះពូបក់ក្នុងទ្វារ ៦ ជម្រះអាជីវបារិសុទ្ធិសីល ដោយវៀរអនេសនា និងសេពតែបច្ច័យដែលវិញ្ញូជនសរសើរ និងដែលព្រះពុទ្ធ សាវករបស់ព្រះពុទ្ធសរសើរ ជម្រះការសេពបច្ច័យ ដោយការពិចារណាបច្ច័យតាមដែលពោល និងជម្រះសម្បជញ្ញៈ ដោយការពិចារណាជាសាត្ថកសម្បជញ្ញៈជាដើម ក្នុង

ការផ្ចាស់ឥរិយាបថទាំង ៤ បុគ្គលនេះ ក៏ឈ្មោះថា កុលបុត្តអ្នកឈ្វាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត បុគ្គលណា សំពត់ស្មោកគ្រោក អាស្រ័យទឹកប្រៃ ក៏ធ្វើឲ្យស្អាតបាន កញ្ចក់អាស្រ័យផេះ ក៏ធ្វើឲ្យស្អាតបាន មាសអាស្រ័យការលត់ ក៏ធ្វើឲ្យបរិសុទ្ធបាន យ៉ាងណា សីលអាស្រ័យញាណ ក៏ផូរផង់បាន ដូច្នោះ ។ ហើយជម្រះដោយទឹក គឺញាណ ធ្វើសីលឲ្យបរិសុទ្ធបាន ប្រៀបដូចសត្វត្រជៀវវិចរក្សាទូវស៊ុត សត្វចាមរីរក្សាទូវរោមកន្ទុយ នារីមានកូនតែមួយរក្សាបុត្រតែម្នាក់ជាទីស្រឡាញ់ និងដូចបុរសមានភ្នែកម្ខាង រក្សាទូវភ្នែកម្ខាងនោះ យ៉ាងណា បុគ្គលមិនប្រមាទក៏រក្សាសីលក្ខន្ធរបស់ខ្លួនក៏ដូច្នោះ បុគ្គលនោះពិចារណាទាំងព្រឹក ទាំងល្ងាច ក៏មិនជួបនូវទោស មានប្រមាណតិចតួច បុគ្គលនេះ ក៏ឈ្មោះថា កុលបុត្តអ្នកឈ្វាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត បុគ្គលណាតាំងនៅក្នុងសីល ដែលមិនធ្វើនូវការក្តៅក្រហាយ រមែងផ្គងបដិបទាដែលជាគ្រឿងសង្កត់កិលេស ។ កាលផ្គងបដិបទានោះហើយ រមែងធ្វើបរិកម្មក្នុងកសិណ កាលធ្វើបរិកម្មក្នុងកសិណហើយ រមែងញុំងសមាបត្តិទាំងឡាយឲ្យកើត បុគ្គលនេះ ក៏ឈ្មោះថា កុលបុត្តអ្នកឈ្វាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត បុគ្គលណាចេញចាកសមាបត្តិ ពិចារណាសង្ខារទាំងឡាយ រមែងសម្រេចអរហត្ត បុគ្គលនេះជាកំពូលនៃអ្នកឈ្វាសក្នុងប្រយោជន៍ ជនទាំងនេះ ជាអ្នកឈ្វាសក្នុងប្រយោជន៍ដែលលោកសរសើរហើយ ដោយត្រឹម

តែតាំងនៅក្នុងសីល ដែលមិនធ្វើការក្តៅក្រហាយ ឬដោយត្រឹមតែផ្គងនូវបដិបទាជាគ្រឿងសង្កត់កិលេស ជនទាំងនោះ លោកបំណងថា កុលបុត្តអ្នកឈ្វាសក្នុងប្រយោជន៍ក្នុងអត្តនេះ ។ ភិក្ខុទាំងនោះក៏ដូច្នោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគទ្រង់សំដៅដល់ភិក្ខុទាំងនោះ ទើបត្រាស់ទេសនាជាបុគ្គលាធិដ្ឋានតែម្យ៉ាងថា **ករណីយមត្តកុសលេន** *ដូច្នេះ ។*

បន្ទាប់អំពីនោះ កាលភិក្ខុទាំងនោះកើតសេចក្តីសង្ស័យថា កិច្ចណាមួយដែលត្រូវធ្វើ ទើបព្រះមានព្រះភាគត្រាស់ថា **យន្តំ សន្តំ បទំ អភិសមេច្ច** *ពាក្យនេះ មានអធិប្បាយដូច្នេះថា ព្រះពុទ្ធ និងអនុពុទ្ធទាំងឡាយសរសើរកិច្ចដែលបុគ្គលបំណងនឹងសម្រេចសន្តិបទ ដោយការចាក់ធ្លុះ ហើយគប្បីធ្វើ ។ ក្នុងពាក្យនេះ គប្បីជ្រាបថា ពាក្យថា* **យំ** *ខ្ញុំបានពោលខាងដើមបទគាថានោះហើយ រមែងប្រព្រឹត្តទៅដោយអធិការថា* **ករណីយំ** *គឺ* **តំ សន្តំ បទំ អភិ-សមេច្ច ។** *តែព្រោះសេចក្តីនេះ មានបាឋៈដែលត្រូវបន្ថែមពាក្យដ៏សេស ដូច្នោះទើបខ្ញុំពោលថា* **វិហរិតុ កាមេន ។**

ម្យ៉ាងទៀត ក្នុងពាក្យនេះ គប្បីជ្រាបអធិប្បាយយ៉ាងនេះថា ពាក្យថា **សន្តំ បទំ អភិសមេច្ច** *រមែងប្រព្រឹត្តទៅដោយអធិការថា កិច្ចនោះ ដែលបុគ្គលបំណងដឹងបទ គឺព្រះនិព្វានថា* **សន្ត** *ដោយលោកិយប្បញ្ញា ដោយបានស្តាប់មកជាដើម និងសម្រេចបទ គឺព្រះនិព្វាននោះ គប្បីធ្វើ ។ ម្យ៉ាងទៀត កាលត្រាស់ថា* **ករណីយមត្តកុសលេន** *កាលភិក្ខុទាំងឡាយនាំគ្នាគិតថា ធ្វើអ្វី ទើបត្រាស់ថា* **យន្តំ សន្តំ បទំ អភិសមេច្ច ។** *ន័យនោះ គប្បីជ្រាបអធិប្បាយ*

យ៉ាងនេះ កិច្ចណាដែលបុគ្គលជឿនសន្តិបទ ដោយលោកិយប្បញ្ញាហើយ គប្បីធ្វើ គប្បីប្រកបកិច្ចនោះ ក៏គួរធ្វើលោកអធិប្បាយថា កិច្ចក៏គួរដល់ការធ្វើទាំងអស់ ។

សួរថា កិច្ចនោះ គឺអ្វី ។ ឆ្លើយថា កិច្ចអ្វីដទៃ គប្បីមាន ក្រៅអំពីឧបាយសម្រេចនិព្វានបទនោះ ។ កិច្ចនោះ ខ្ញុំពោលហើយដោយបទដើម ដែលសម្តែងសិក្ខា ៣ ព្រោះអត្ថថា គួរដល់ការធ្វើ សេចក្តីពិត ទោះបីយ៉ាងនោះក្តី ក្នុងកាលពណ៌នាអត្ថនៃពាក្យនោះ ខ្ញុំក៏បានពោលហើយថា **ការណី** *ក៏មាន* **អការណី** *ក៏មាន ។ ក្នុង ២ យ៉ាងនោះ ដោយសង្ខេប សិក្ខា ៣ ឈ្មោះថា* **ការណី ។** *តែព្រោះទ្រង់សម្តែងសង្ខេបពេក បណ្តាភិក្ខុទាំងនោះ ពួកខ្លះក៏មិនជឿង ។ បន្ទាប់អំពីនោះ ការត្រាស់កិច្ចដោយចំពោះយ៉ាងក្រៃលែង ដែលភិក្ខុនៅព្រៃគួរធ្វើឲ្យពិស្តារ ដើម្បីឲ្យពួកភិក្ខុដែលមិនជឿង បានជឿង ទើបត្រាស់កន្ទុះគាថានេះមុនថា* **សក្កោ ឧជ្ជុ ច សុហុជ្ជុ ច សុវចោ ចស្ស មុទុ អនតិមានី ។**

លោកអធិប្បាយដូចម្តេច លោកអធិប្បាយថា ភិក្ខុនៅព្រៃ បំណងនឹងសម្រេចសន្តិបទ ឬសម្រេចសន្តិបទនោះ ដោយលោកិយប្បញ្ញាហើយ បដិបត្តិដើម្បីសម្រេចសន្តិបទនោះ មិនអាល័យក្នុងកាយ និងជីវិត ដោយការប្រកបបធានិយង្គ ប្រការទី ២ និងទី ៤ គប្បីជាអ្នកអាចបដិបត្តិចាក់ធ្លុះនូវសច្ចៈ ករណីយកិច្ចដែលគួរធ្វើណាមួយ ទោះខ្ពស់ទាបនៃសព្រហ្មចារី ក្នុងការបវរកម្មកសិណ សមាទានវត្តជាដើម និងក្នុងការជួសជុលបាត្រ ចីវរជា

ដើមរបស់ខ្លួន ក៏គប្បីអាច គប្បីឧស្សាហ៍ មិនខ្ជិលច្រអូស អាចក្នុងករណីយ-កិច្ចទាំងនោះ និងក្នុងកិច្ចដទៃក៏ដូចគ្នា ។ កាលជាអ្នកអាច ក៏គប្បីជាអ្នកត្រង់ ដោយការប្រកបដោយបធានិយង្គប្រការទី ៣ កាលជាអ្នកត្រង់ ក៏គប្បីជាអ្នកត្រង់ដោយល្អ ដោយជាអ្នកត្រង់តែម្យ៉ាង ឬដោយជាអ្នកត្រង់ក្នុងកាលដែលនៅជាកំលោះ ដោយមិនដល់នូវសន្ដោស តែមិនរួញរារឿយៗ ជារាបដល់អស់ជីវិត ។ ឈ្មោះថា **ឧជុ** ព្រោះធ្វើដោយការមិនអួត ឈ្មោះថា **សុហុជ្ជ** ព្រោះមិនមានមាយា ឬថា ត្រង់ ព្រោះលះនូវការវៀចវេរដោយកាយ និងវាចា ឈ្មោះថា ត្រង់ល្អ ព្រោះលះនូវការវៀចផ្លូវចិត្ត ។ ឈ្មោះថា **ឧជុ** ព្រោះមិនអួតគុណដែលមាន ឈ្មោះថា **សុហុជ្ជ** ព្រោះមិនអត់សង្កត់ចំពោះលាភដែលកើតព្រោះគុណដែលមិនពិត ។ គប្បីឈ្មោះថា ជាអ្នកត្រង់ និងត្រង់ដោយល្អ ដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ដោយសិក្ខាទី ២ ទី ៣ ខាងដើម និងដោយបយោគសុទ្ធិ និងអាសយសុទ្ធិ ដោយប្រការដូច្នេះ ។

ភិក្ខុមិនមែនជាអ្នកត្រង់ និងត្រង់ល្អតែប៉ុណ្ណោះទេ ដែលពិត គប្បីជាអ្នកប្រដៅងាយទៀតផង ។ បុគ្គលណា ត្រូវលោកស្ដីប្រដៅ ពោលថា លោកមិនគួរធ្វើរឿងនេះ ក៏ពោលថា លោកម្ចាស់ឃើញអ្វី លោកម្ចាស់ឮអ្វី លោកម្ចាស់ជាអ្វីនឹងខ្ញុំ ជាឧបជ្ឈាយ៍ អាចារ្យ សម្លាញ់ធ្លាប់ជួបឬ ឬបៀតបៀនបុគ្គលនោះ ដោយការមិននិយាយតប ឬព្រមទទួលហើយ តែមិនធ្វើយ៉ាងនោះ បុគ្គលនោះ ឈ្មោះថា នៅឆ្ងាយអំពីការសម្រេចគុណវិសេស ។ ឯបុគ្គលណា ត្រូវលោកទូន្មាន ក៏ពោលថា សាធុ លោកម្ចាស់ លោកម្ចាស់

ពោលល្អហើយ ។ ឈ្មោះថា ទោសរបស់ខ្លួន ជារបស់ឃើញបានលំបាក លោកម្ចាស់ឃើញខ្ញុំយ៉ាងនេះ សូមអធ្យាស្រ័យស្តីប្រដៅទៀតចុះ ខ្ញុំនឹងទទួលឱវាទអំពីសម្ងាក់លោកម្ចាស់អស់កាលយូរ នឹងបដិបត្តិតាមលោកម្ចាស់ប្រៀនប្រដៅ បុគ្គលនោះឈ្មោះថា មិននៅឆ្ងាយពីការសម្រេចគុណវិសេស ព្រោះដូច្នោះ បុគ្គលទទួលពាក្យរបស់អ្នកដទៃ ហើយធ្វើយ៉ាងនេះ គប្បីឈ្មោះថា ជាអ្នកប្រដៅងាយ ។

ម្យ៉ាងទៀត បុគ្គលអ្នកប្រដៅងាយ យ៉ាងណា ក៏គប្បីជាអ្នកទន់ភ្លន់យ៉ាងនោះ ។ បទថា **មុទុ** *សេចក្តីថា ភិក្ខុត្រូវពួកគ្រហស្ថប្រើក្នុងភាពជាទូតបញ្ជូនដំណឹងជាដើម ក៏ជាអ្នកមិនធ្វើការទន់ភ្លន់ក្នុងកិច្ចនោះ ជាអ្នករឹងប៉ឹងនោះឯង គប្បីជាអ្នកទន់ភ្លន់ក្នុងវត្តបដិបត្តិ និងព្រហ្មចរិយៈទាំងមូល អត់ធន់ចំពោះការមិនចាំបាច់ទទួលបម្រើក្នុងកិច្ចនោះ ដូចមាសដែលជាងតាក់តែងដោយល្អ ។ ម្យ៉ាងទៀត បទថា* **មុទុ** *បានដល់ ជាអ្នកមិនមានមុខក្រៀមក្រំ ជាអ្នកមានមុខរីក ចរចាពាក្យដែលឲ្យកើតសុខ ទទួលភ្លៀវ ដូចបុគ្គលដែលចុះកាន់កំពង់ទឹក ដែលល្អដោយស្រួល មិនមែនជាអ្នកទន់ភ្លន់តែម្យ៉ាងទេ គប្បីជាបុគ្គលមិនមានអតិមានៈ មើលងាយអ្នកដទៃផងដែរ ។ មិនគប្បីពោលមើលងាយអ្នកដទៃ ដោយវត្ថុនៃការមើលងាយ មានជាតិ និងគោត្រជាដើម គប្បីមានចិត្តស្មើ ដូចក្មេងចណ្ឌាល ដូចព្រះសារីបុត្រ ដូច្នោះ ។*

អធិប្បាយគាថាទី ២

ព្រះមានព្រះភាគ កាលទ្រង់ត្រាស់ករណីយកិច្ច ដោយចំពោះយ៉ាង

ក្រៃលែងរបស់ភិក្ខុដែលនៅព្រៃ ដែលបំណងនឹងសម្រេចសន្តិបទ ឬបដិបត្តិដើម្បីសម្រេចសន្តិបទនោះយ៉ាងនេះហើយ មានព្រះពុទ្ធបំណងនឹងត្រាស់ក្រៃលែងឡើងជាងនោះទៀត ទើបត្រាស់គាថាទី ២ ថា **សន្តុស្សកោ ច** ជាដើម ក្នុងគាថាទី ២ នោះ ភិក្ខុ ឈ្មោះថា សន្តោស ព្រោះសន្តោសដោយសន្តោស ១២ យ៉ាង មានប្រភេទដែលពោលហើយ ក្នុងមង្គលសូត្រនេះថា **សន្តុដ្ឋី ច កតញ្ញុតា** នេះ ។ ម្យ៉ាងទៀត ភិក្ខុណាវៃងត្រេកអរហេតុនោះ ភិក្ខុនោះ ឈ្មោះថា **តុស្សកៃ** ប្រែថា អ្នកត្រេកអរ ភិក្ខុអ្នកត្រេកអរដោយរបស់ខ្លួនឯង ត្រេកអរដោយរបស់ដែលមាន ត្រេកអរដោយការស្មោះស្មើ ហេតុនោះ ទើបឈ្មោះថា **សន្តុស្សកៃ** គឺអ្នកសន្តោស ។ ក្នុងលក្ខណៈ ៣ យ៉ាងនោះ បច្ច័យ ៤ ដែលលោកលើកឡើងសម្តែងក្នុងវេនឧបសម្បទា យ៉ាងនេះថា **បិណ្ឌិយាលោបភោជនំនិស្សាយ** អាស្រ័យភោជន គឺដុំបាយដែលរកមកដោយកម្លាំងស្នងជាដើម ហើយខ្លួនក៏ទទួលហើយ ឈ្មោះថារបស់ខ្លួន ។ ភិក្ខុមិនសម្តែងអាការខុសប្រក្រតី ក្នុងវេលាទទួល និងវេលាបរិភោគ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបច្ច័យរបស់ខ្លួននោះ ល្អក្តី មិនល្អក្តី ដែលគេប្រគេនដោយគោរព និងមិនគោរពក្តី ហៅថា ជាអ្នកត្រេកអរដោយរបស់ខ្លួន ។

របស់ណាបានមកហើយ មានដល់ខ្លួន របស់នោះ ឈ្មោះថា មាន ភិក្ខុត្រេកអរដោយរបស់មាននោះឯង មិនប្រាថ្នារបស់ដទៃអំពីនោះ លះភាពជាបុគ្គលប្រាថ្នាច្រើន ហៅថា ត្រេកអរដោយរបស់ដែលមាន ។

ការលះត្រេកអរក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ឈ្មោះថា ប្រព្រឹត្តស្មើ កិក្ខុត្រេកអរក្នុងអារម្មណ៍ទាំងពួង ដោយអាការស្មើនោះ ឈ្មោះថា ត្រេកអរ ដោយអាការស្មើ ។

ឈ្មោះថា **សុភរ** *ព្រោះគេចិញ្ចឹមដោយងាយ ។ លោកអធិប្បាយថា បុគ្គលដែលគេចិញ្ចឹមងាយ ។ កិក្ខុណា កាលមនុស្សយកបាត្រដាក់ពេញដោយបាយ សាច់ជាដើមប្រគេន ហើយសម្តែងភាវៈមុខស្មើ អាក់អន់ចិត្ត ពោលថា ពួកអ្នកឲ្យអ្វី មើលងាយបិណ្ឌបាតចំពោះមុខបុគ្គលនោះ ឲ្យដល់សាមណេរ និងគ្រហស្ថជាដើម កិក្ខុនោះ ឈ្មោះថា* **ទុព្ភរ** *គឺបុគ្គលដែលគេចិញ្ចឹមលំបាក មនុស្សទាំងឡាយឃើញកិក្ខុនោះហើយ លះបង់អំពីចម្ងាយនោះឯង ដោយពោលថា កិក្ខុចិញ្ចឹមក្រ អ្នកណាក៏មិនអាចចិញ្ចឹមបាន ឯកិក្ខុណាបានរបស់សៅហ្មងក្តី ប្រណីតក្តីណាមួយ តិច ឬច្រើន មានចិត្តត្រេកអរ មានមុខផូរផង់ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ កិក្ខុនោះ ឈ្មោះថា* **សុភរ** *គឺអ្នកចិញ្ចឹមងាយ ។ មនុស្សទាំងឡាយឃើញកិក្ខុនោះ ជាអ្នកស្រេគត់ស្រេគំ ក៏ប្តេជ្ញាទទួលចិញ្ចឹមថា លោកម្ចាស់របស់យើងចិញ្ចឹមងាយ កិក្ខុបែបនេះ លោកបំណងថា ជា* **សុភរ** *គឺអ្នកចិញ្ចឹមងាយក្នុងទីនេះ ។*

កិច្ចរបស់កិក្ខុនោះតិច ហេតុនោះ កិក្ខុនោះ ឈ្មោះថា **អប្បកិច្ចៈ** *គឺអ្នកមានកិច្ចតិច មិនមែនខ្វល់ខ្វាយដោយកិច្ចច្រើន ដូចជា ត្រេកអរក្នុងការងារ ត្រេកអរក្នុងការនិយាយ ត្រេកអរក្នុងការច្រឡូកច្រឡំជាដើម ។ ម្យ៉ាងទៀត ជាអ្នកវៀរកិច្ច មានការកសាងលំនៅរបស់សង្ឃ និងបង្រៀនសាមណេរ ឬ*

ញោមវត្តជាដើម ពេញវិហារ ។ លោកអធិប្បាយថា ការកោរសក់ កាត់ក្រចក និងជុតជាត្រ ចោកចីវរជាដើមរបស់ខ្លួន ក្រៅអំពីកិច្ច គឺសមណធម៌។

ការប្រព្រឹត្តរបស់ភិក្ខុនោះស្រាល ហេតុនោះ ភិក្ខុនោះ ឈ្មោះថា **សល្ល-ហុកវុត្តិ** *គឺអ្នកមានការប្រព្រឹត្តស្រាល ។ ភិក្ខុមានបរិក្ខារច្រើនរូបខ្លះ វេលាធ្វើដំណើរ ក៏ឲ្យមហាជនកាន់ជាត្រ ចីវរ កម្រាល ប្រេង ទឹកអំពៅជាដើមជាច្រើន ទូលលើក្បាល កណ្តៀតជាដើម យ៉ាងណា ភិក្ខុណាមិនមានសភាពយ៉ាងនោះ រមែងជាអ្នកមានបរិក្ខារតិច រក្សាត្រឹមតែសមណបរិក្ខារ ៨ មានជាត្រ ចីវរជាដើមប៉ុណ្ណោះ កាលដើរផ្លូវ ក៏ធ្វើដំណើរទៅ ដូចបក្សីមានតែស្លាប ភិក្ខុបែបនោះ លោកចំណាងថា ជាអ្នកមានការប្រព្រឹត្តស្រាល ក្នុងទីនេះ ។ ឥន្ទ្រិយទាំងឡាយរបស់ភិក្ខុនោះស្ងប់ ហេតុនោះ ទើបភិក្ខុនោះ ឈ្មោះថា មានឥន្ទ្រិយស្រគត់ស្រគំ លោកអធិប្បាយថា ជាអ្នកមានឥន្ទ្រិយមិនរាយមាយដោយអំណាចរាគៈជាដើម ក្នុងឥដ្ឋារម្មណ៍ជាដើម ។ បទថា* **ឯបកោ** *បានដល់ដែលជាវិញ្ញូជន ជាអ្នកដឹងច្បាស់ មានបញ្ញា អធិប្បាយថា ជាអ្នកប្រកបដោយបញ្ញា គ្រឿងតាមរក្សាសីល ដោយបញ្ញាកំណត់បច្ច័យ ៤ មានចីវរជាដើម និងដោយបញ្ញាកំណត់ដឹងនូវសប្បាយ ៧ មានអាវាសសប្បាយជាដើម ។*

បុគ្គលមិនធ្នាំឆ្គង ហេតុនោះ ទើបឈ្មោះថា **អប្បគព្ភ** *គឺអ្នកមិនធ្នាំឆ្គង អធិប្បាយថា វៀរចាកការធ្នាំឆ្គងផ្លូវកាយ ៨ ហាន: ចាកការធ្នាំឆ្គងដោយវាចា ៤ ហាន: និងចាកការធ្នាំឆ្គងផ្លូវចិត្តច្រើនហាន: ។*

ការធ្វើមិនសមគួរផ្លូវកាយក្នុងសង្ឃ គណៈ បុគ្គល ភោងធាន់ ភោងភ្លើង កំពង់ទឹក ផ្លូវបិណ្ឌបាត និងការចូលកាន់ចន្លោះស្រុក ឈ្មោះថា ការធ្លាំធ្លងផ្លូវកាយ ៨ ស្ថាន គឺភិក្ខុបន្ថុះក្នុងសាសនានេះ អង្គុយត្រចោមក្បាលជង្គង់ ឬយកជើងជាក់លើជើងក្នុងកណ្តាលសង្ឃ ។ ក្នុងកណ្តាលគណៈ ក្នុងទីប្រជុំបរិសទ ៤ ក៏ដូចគ្នា ក្នុងបុគ្គលដែលចាស់ជាងក៏ដូចគ្នា ។ ឯក្នុងភោងធាន់ ភិក្ខុមិនឲ្យអាសនៈដល់បុគ្គលដែលចាស់ជាង ហាមអាសនៈដល់ភិក្ខុថ្មី ក្នុងភោងភ្លើងក៏ដូចគ្នា ។ ក្នុងភ្លើង ភិក្ខុមិនសូមឱកាសភិក្ខុចាស់ជាង ធ្វើការជុតភ្លើងជាដើម ។ ឯក្នុងកំពង់ទឹក លោកពោលពាក្យថា មិនត្រូវប្រកាន់ថា ភិក្ខុកំលោះ ឬភិក្ខុចាស់ គប្បីងូតបានតាមលំដាប់របស់អ្នកមកដល់ ភិក្ខុមិនកាន់យកពាក្យនោះ មកឯក្រោយ ក៏ចុះទឹក បៀតបៀនភិក្ខុចាស់ និងភិក្ខុថ្មី ។ ឯក្នុងផ្លូវបិណ្ឌបាត ភិក្ខុទៅខាងមុខ យកដៃប៉ះដៃភិក្ខុចាស់ ដើម្បីយកអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ និងអាហារដ៏ប្រសើរ ក្នុងការចូលទៅកាន់ចន្លោះស្រុក មានជាដើមយ៉ាងនេះថា ភិក្ខុចូលទៅមុនភិក្ខុចាស់ ធ្វើការលេងដោយកាយជាមួយនឹងភិក្ខុកំលោះ ។

ការបន្ទឹរាចាមិនសមគួរក្នុងសង្ឃ គណៈ បុគ្គល និងចន្លោះស្រុក ឈ្មោះថា ធ្លាំធ្លងដោយវាចា ៤ ស្ថាន យ៉ាងនេះថា ភិក្ខុបន្ថុះក្នុងសាសនានេះមិនសូមឱកាសក្នុងកណ្តាលសង្ឃ ពោលធម៌ ។ ក្នុងគណៈ ក្នុងបុគ្គលដែលចាស់ជាងដូចពោលខាងដើមក៏ដូចគ្នា ។ ក្នុងទីនោះ ភិក្ខុត្រូវមនុស្សទាំងឡាយសួរបញ្ហា មិនសូមឱកាសភិក្ខុដែលចាស់ជាង ក៏ឆ្លើយបញ្ហា ។ ឯក្នុងចន្លោះស្រុក

ភិក្ខុពោលជាដើមយ៉ាងនេះថា ក្នុងស្រុកឈ្មោះនោះ មានអ្វី បបរ ឬរបស់ទំពា ឬរបស់បរិភោគ លោកនឹងឲ្យអ្វីដល់ខ្ញុំ ថ្ងៃនេះ ខ្ញុំនឹងទំពា បរិភោគផឹកនូវអ្វី ។

មិនជល់នូវការល្មើសផ្លូវកាយវាចាក្នុងហាន:នោះ។ តែក៏មានវិតក្ក ដែលមិនសមគួរប្រការផ្សេងៗ មានកាមវិតក្កជាដើមផ្លូវចិត្ត ឈ្មោះថា ការធ្លាំធ្លែងផ្លូវចិត្តមានច្រើនហាន: ។

បទថា **កុលេសុ អនន្តគិទ្ធោ** សេចក្តីថា ភិក្ខុចូលទៅរកត្រកូលទាំងនោះ មិនគិតដោយការចង់បានបច្ច័យ ឬដោយការច្រឡូកច្រឡំ មិនសមគួរក្នុងត្រកូលទាំងនោះ លោកអធិប្បាយថា មិនសោយសោកជាមួយផង មិនត្រេកអរជាមួយផង មិនសុខ ដោយកាលត្រកូលទាំងនោះជួបនូវសុខ មិនទុក្ខ កាលត្រកូលទាំងនោះជួបនូវទុក្ខ កាលករណីយកិច្ចទាំងឡាយកើតឡើង ក៏មិនចូលប្រកបដោយខ្លួនឯង ។ ពាក្យណាថា **អស្ស** ដែលត្រាស់ក្នុងពាក្យនេះថា **សុវចោ អស្ស** នៃគាថានេះ ពាក្យនោះ គប្បីប្រកបចូលជាមួយបទទាំងអស់យ៉ាងនេះថា **សន្តុស្សកោ ច អស្ស សុភរោ ច អស្ស។**

អធិប្បាយគាថាទី ៣

ព្រះមានព្រះភាគ កាលត្រាស់ប្រាប់ករណីដែលក្រៃលែងជាងនោះ ដោយចំពោះក្រៃលែង ដល់ភិក្ខុអ្នកនៅព្រៃ ដែលបំណងនឹងសម្រេចសន្តិបទហើយ ឬបំណងនឹងបដិបត្តិ ដើម្បីសម្រេចសន្តិបទនោះយ៉ាងនេះហើយ ឥឡូវនេះ មានព្រះពុទ្ធបំណងនឹងត្រាស់ប្រាប់ករណី ទើបត្រាស់កន្ទុះគាថាថា **ន ច ពុទ្ធំ-**

សមាចរេ កិញ្ចិ យេនវិញ្ញូ បរេ ឧបវាទេយ្យុំ។

កន្លះគាថានោះ មានសេចក្តីដូច្នេះ កិក្ខុកាលធ្វើករណីនេះយ៉ាងនេះ ក៏មិនគប្បីប្រព្រឹត្តកាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត ដែលហៅថា **ខុទ្ទ** *គឺលាមក កាលមិនប្រព្រឹត្ត មិនមែនមិនប្រព្រឹត្តតែកម្មគ្រោតគ្រោតតែម្យ៉ាងឡើយ សូម្បីកម្មបន្តិចបន្តួចណាមួយ ក៏មិនប្រព្រឹត្ត លោកអធិប្បាយថា មិនប្រព្រឹត្តកម្មអាក្រក់ទាំងចំនួនតិច និងទំហំតូច ។*

បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងទោសដែលឃើញបានឯងក្នុងការប្រព្រឹត្តលាមកកម្មនោះថា **យេន វិញ្ញូ បរេ ឧបវាទេយ្យុំ។** *ក្នុងពាក្យនេះ ព្រោះបុគ្គលមិនមែនវិញ្ញូជនដទៃ មិនកាន់យកជាប្រមាណ ព្រោះវិញ្ញូជនទាំងនោះ នៅធ្វើកម្ម មិនមានទោស ឬមានទោស មានទោសតិច ឬទោសច្រើន ចំណែកវិញ្ញូជនទាំងឡាយប៉ុណ្ណោះ កាន់យកជាប្រមាណបាន ព្រោះថាវិញ្ញូជនទាំងនោះជ្រុថ្នាគ្រប់គ្រាន់ហើយ រមែងតិះដៀលបុគ្គលដែលគួរតិះដៀល សរសើរបុគ្គលដែលគួរសរសើរ ដូច្នោះ ទើបត្រាស់ថា* **វិញ្ញូ បរេ ។**

ព្រះមានព្រះភាគ កាលត្រាស់ឧបចារនៃកម្មដ្ឋាន មានករណី និងអករណី ដោយចំពោះយ៉ាងក្រៃលែង ដល់កិក្ខុអ្នកនៅព្រៃ ដែលបំណងនឹងសម្រេចសន្តិបទ ហើយនៅ ឬបំណងនឹងបដិបត្តិ ដើម្បីសម្រេចសន្តិបទនោះ និងដល់ពួកកិក្ខុដែលបំណងនឹងទទួលកម្មដ្ឋានគ្រប់រូប ដោយលើកកិក្ខុដែលនៅព្រៃជាសំខាន់ ដោយ ២ គាថាកន្លះយ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្តើមត្រាស់មេត្តាកថា ដោយនយថា **សុខិនោ វា ខេមិនោ ហោន្តុ** *ជាដើម ដើម្បីជាបរិត្ត*

កម្ចាត់ភ័យអំពីទេវតានោះ និងដើម្បីជាកម្មដ្ឋាន ដោយឈានជាបាទនៃវិបស្សនា ដល់ភិក្ខុទាំងនោះ ។

បណ្តាបទទាំងនោះ បទថា **សុខិនោ** បានដល់ ជាអ្នកដល់ព្រមដោយសុខ ។ បទថា **ខេមិនោ** ប្រែថា ជាអ្នកមានសេចក្តីក្សេម ។ លោកអធិប្បាយថា ជាបុគ្គលមិនមានភ័យ មិនមានឧបទ្រវ ។ បទថា **សព្វេ** បានដល់ មិនសេសសល់ឡើយ ។ បទថា **សត្តា** បានដល់ សត្វមានជីវិត ។ បទថា **សុខិតត្តា** បានដល់ បុគ្គលមានចិត្តដល់នូវសុខ ។ ក្នុងពាក្យនេះ គប្បីជ្រាបថា ឈ្មោះថា បុគ្គលមានសេចក្តីសុខ ដោយសុខផ្លូវកាយ ។ ឈ្មោះថា មានចិត្តដល់នូវសុខ ដោយសុខផ្លូវចិត្ត ។ ឈ្មោះថា មានការក្សេមដោយសុខទាំង ២ នោះ ឬដោយទៅប្រាសចាកភ័យ និងឧបទ្រវទាំងពួង ។ ហេតុអ្វី ទើបត្រាស់យ៉ាងនេះ ក៏ដើម្បីសម្តែងអាការនៃមេត្តាភាវនា ។ កាលបើដូច្នេះ ទើបគួរចម្រើនមេត្តាថា សូមសត្វទាំងពួងមានសេចក្តីសុខ ដូច្នេះ ឬថា ចូរមានសេចក្តីក្សេម ដូច្នេះ ឬថា ចូរជាបុគ្គលមានខ្លួនដល់នូវសុខ ដូច្នេះ ។

អធិប្បាយគាថាទី ៤

ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនាដោយសង្ខេប តាំងអំពីឧបចារៈដល់អប្បនាជាទីបំផុតយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងមេត្តាភាវនានោះដោយពិស្តារ ទើបត្រាស់ ២ គាថាថា **យេ កេចិ** ជាដើម ។ ម្យ៉ាងទៀត ព្រោះហេតុដែលចិត្តត្រូវសន្សំនៅក្នុងអារម្មណ៍ច្រើនៗ រមែងមិនបញ្ឈប់នៅក្នុងអារម្មណ៍ ១ ដោយខាងដើមប៉ុណ្ណោះ តែនឹងសុះជាប់តាម

ប្រភេទអារម្មណ៍ដោយលំដាប់ ដូច្នោះ ទើបត្រាស់ ២ គាថាថា **យេ កេចិ** *ជាដើម ដើម្បីចិត្តដែលសុះតាមទៅហើយ ឈប់នៅក្នុងអារម្មណ៍ដែលជាប្រភេទនៃទុកៈរបស់សត្វ និងតិកៈនៃសត្វ មានតសថាវរទុកៈជាដើម ។ ម្យ៉ាងទៀត ព្រោះហេតុដែលអារម្មណ៍ណានៃបុគ្គលណា ជាអារម្មណ៍ដែលប្រាកដច្បាស់ហើយ ចិត្តនៃបុគ្គលនោះ រមែងតាំងនៅជាសុខក្នុងអារម្មណ៍នោះ ដូច្នោះ អារម្មណ៍របស់ភិក្ខុរូបណា ក្នុងបណ្តាភិក្ខុទាំងនោះប្រាកដច្បាស់ហើយ ព្រះមានព្រះភាគ មានព្រះពុទ្ធបំណងនឹងឲ្យចិត្តរបស់ភិក្ខុរូបនោះ តាំងនៅក្នុងអារម្មណ៍នោះ ទើបត្រាស់ ២ គាថាថា* **យេ កេចិ** *ជាដើម ដែលសម្តែងការផ្សេងគ្នានៃអារម្មណ៍ជាទុកៈ និងតិកៈ មានតសថាវរទុកៈជាដើម ។*

សេចក្តីពិត ក្នុង ២ គាថានោះ ព្រះមានព្រះភាគទ្រង់សម្តែងទុកៈ គឺធម៌ពួក ២ នៃសត្វ ៤ ទុកៈ គឺតសថាវរទុកៈ គឺសត្វដែលតក់ស្លុត និងមាំទាំ ១ ទិដ្ឋាទិដ្ឋទុកៈ សត្វដែលឃើញហើយ និងសត្វដែលមិនទាន់ឃើញ ១ ទូរ-សន្តិកទុកៈ ពួកសត្វដែលនៅឆ្ងាយ និងនៅជិត ១ ភូតសម្ភវេសីទុកៈ សត្វដែលកើតហើយ និងស្វែងរកទីកើត ១ ។ ហើយទ្រង់សម្តែងតិកៈ ៣ តិកៈ គឺ ទីឃវស្សមជ្ឈិមតិកៈ សត្វដែលមានអត្តភាពវែង ខ្លី និងកណ្តាល ១ មហន្ត-ណុកមជ្ឈិមតិកៈ គឺសត្វដែលមានអត្តភាពធំ តូច និងកណ្តាល ១ ។ ថូលាណុកមជ្ឈិមតិកៈ គឺសត្វដែលមានអត្តភាពធាត់ ស្គម និងកណ្តាល ដោយមជ្ឈិមបទជាទីកើតប្រយោជន៍ក្នុង ៣ តិកៈ និងអនុកថូលបទ ជាទីកើតប្រយោជន៍ក្នុង ២ តិកៈ ដោយ ៦ បទ មានទីឃបទជាដើម ។ បណ្តា

បទទាំងនោះ បទថា **យេ កេចិ** ជាពាក្យសម្តែងថា មិនមានចំណែកសេសសល់ ។ ពួកសត្វដែលកើតហើយ គឺបាណ ឈ្មោះថា **ចាណាភូត** ម្យ៉ាងទៀត សត្វទាំងឡាយ រមែងដកដង្ហើម ហេតុនោះ ទើបឈ្មោះថា **ចាណា** ។ ទ្រង់កាន់យកបញ្ចវោរសត្វ ដែលទាក់ទងដោយអស្សាសបស្សាសៈ ដោយបទនេះ ។ សត្វទាំងឡាយរមែងកើត ហេតុនោះ ទើបឈ្មោះថា **ភូត** ។ ទ្រង់កាន់យកឯកវោការសត្វ និងចតុវោការសត្វ ដោយបទនេះ ។ បទថា **អត្ថិ** ប្រែថា មាន គឺមានព្រម ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសត្វទាំងពួង ដែលទ្រង់សង្គ្រោះដោយទុកៈ និងតិកៈរួមគ្នា ដោយពាក្យថា **យេ កេចិ ចាណាភូតត្ថិ** នេះយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សង្គ្រោះសត្វទាំងនោះ សម្តែងដោយទុកៈនេះថា **តសា វា ថាវរា វា អនវសេសា** ។

ក្នុងទុកៈនេះ សត្វទាំងឡាយ រមែងតក់ស្លុត ហេតុនោះ ទើបឈ្មោះថា **តសា** ពាក្យនេះ ជាឈ្មោះនៃសត្វទាំងឡាយ ដែលមានតណ្ហា និងមានភ័យ ។ សត្វទាំងឡាយរមែងមាំទាំ ហេតុនោះ ទើបឈ្មោះថា **ថាវរា** ពាក្យនេះ ជាឈ្មោះរបស់ព្រះអរហន្តទាំងឡាយ ដែលលះតណ្ហា និងភ័យបានហើយ ។ ចំណែកដែលសល់នៃសត្វទាំងនោះមិនមាន ហេតុនោះ ទើបឈ្មោះថា **អនវសេសា** លោកអធិប្បាយថា គ្រប់ខ្លួនសត្វ ។ ពាក្យណាត្រាស់ខាងចុងនៃគាថាទី ២ ពាក្យនោះ គប្បីភ្ជាប់គ្រប់ទុកៈ និងតិកៈ ។ បទថា **យេ កេចិ ចាណាភូតត្ថិ** សេចក្តីថា សត្វទាំងឡាយដែលតក់ស្លុតក្តី មាំទាំក្តី មិនមាន

សល់ សត្វទាំងអស់នោះ ចូរជាបុគ្គលមានខ្លួនដល់នូវសេចក្តីសុខ ពួកសត្វ ដែលកើតហើយក្តី ស្វែងរកទីកើតក្តី ត្រឹមណា សត្វទាំងអស់នេះ ត្រឹមនោះ ចូរជាអ្នកមានខ្លួនដល់នូវសុខចុះ ដោយប្រការដូច្នេះ ។

ឥឡូវនេះ បណ្តាបទទាំង ៦ មាន **ឥឃា វា** *ជាដើម ដែលសម្តែងតិក: ៣ ពួក មានទីឃវស្សមជ្ឈិមតិក:ជាដើម ។ បទថា* **ឥឃា** *បានដល់ សត្វ ដែលមានអត្តភាពវែង មាននាគ ត្រី ទន្សែងជាដើម ពិតហើយ អត្តភាពរបស់ នាគទាំងឡាយក្នុងមហាសមុទ្រ មានប្រវែងច្រើនរយព្យាម ។ អត្តភាពរបស់ ត្រី និងទន្សែងជាដើម មានច្រើនយោជន៍ ។ បទថា* **មហន្តា** *សត្វមានអត្ត-ភាពធំក្នុងទឹក មានត្រី និងអណ្តើក លើគោក មានស្តេចដំរីជាដើម ក្នុងចំនួន អមនុស្ស មានទានវៈ (យក្សព្រៃ) ជាដើម និងគ្រាស់ថា រាហូ ជាកំពូល នៃសត្វដែលមានអត្តភាពជាធំទាំងឡាយ ។ ពិតហើយ អត្តភាពរបស់រាហូនោះ កម្ពស់ ៤៨០០ យោជន៍ ដៃប្រវែង ១២០០ យោជន៍ ចន្លោះចិញ្ចើម ៥០ យោជន៍ ចន្លោះថ្នាំងដៃក៏ដូចគ្នា ជាតដៃមានទំហំ ២០០ យោជន៍ ។ បទថា* **មជ្ឈិមា** *បានដល់ អត្តភាពរបស់សេះ គោ ក្របី ជ្រូក ។ បទថា* **រស្សកា** *បានដល់ សត្វទាំងឡាយ មានខ្នាតខ្លី ត្រង់កណ្តាលវែង ត្រង់កណ្តាលធាត់ មានមនុស្សតឿជាដើម ក្នុងជាតិនោះៗ ។ បទថា* **អណុកា** *បានដល់ សត្វ ទាំងឡាយដែលមានអត្តភាពល្អិត ឬតូចជាដើម ដែលកើតក្នុងទឹកជាដើម មិន ជាអារម្មណ៍នៃមំសចក្ខុ ជាវិស័យរបស់ទិព្វចក្ខុ ។ ម្យ៉ាងទៀត សត្វទាំង-ឡាយណា ទាប ត្រង់កណ្តាលធំ ត្រង់កណ្តាលធាត់ សត្វទាំងនោះ គប្បី*

ជ្រាបថា តូច ។ បទថា **ថូលា** បានដល់ សត្វទាំងឡាយដែលមានអត្តភាពមូល មានត្រី អណ្តើក គ្រំ ខ្យងជាដើម ។

អធិប្បាយគាថាទី ៥

ព្រះមានព្រះភាគ ទ្រង់សម្តែងសត្វទាំងឡាយមិនសេសសល់ ដោយតិក: ៣ តិក: យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សង្គ្រោះសម្តែងដោយទុក: ៣ ទុក: ថា **ឯដ្ឋា វា យេ ច អនិដ្ឋា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ឯដ្ឋា** បានដល់ សត្វពួកណាធ្លាប់ឃើញដោយមកប្រាកដដល់ភ្នែករបស់ខ្លួន ។ បទថា **អនិដ្ឋា** បានដល់ សត្វទាំង-ឡាយណាតាំងនៅក្នុងសមុទ្រដទៃ ភ្នំដទៃ និងចក្រវាលដទៃជាដើម ។ តែព្រះមានព្រះភាគទ្រង់សម្តែងសត្វដែលនៅឆ្ងាយ និងមិនឆ្ងាយអត្តភាពរបស់ខ្លួនដោយទុក:នេះថា **យេ ច ទូរេ វសន្តិ អាទូរេ។** សត្វទាំងនោះ គប្បីជ្រាបថាជាសត្វមិនមានជើង និងជើង ២ ។ ពួកសត្វដែលនៅក្នុងកាយរបស់ខ្លួនហៅថា **អាទូរេ** គឺនៅមិនឆ្ងាយ សត្វដែលនៅក្រៅកាយ ហៅថា **ទូរេ** គឺនៅឆ្ងាយ ។ ម្យ៉ាងទៀត ពួកសត្វដែលនៅខាងក្នុងឧបចារៈ ហៅថា នៅមិនឆ្ងាយ ។ ដែលនៅក្រៅឧបចារៈ ហៅថា នៅឆ្ងាយ ។ ដែលនៅក្នុងព្រះវិហារតាមជនបទ ទ្វីប ចក្រវាល ហៅថា នៅមិនឆ្ងាយ ដែលនៅក្នុងចក្រវាលដទៃ ហៅថា នៅឆ្ងាយ ។ បទថា **ភូតា** បានដល់ កើតហើយ កើតឡើងហើយ ។ ព្រះខីណាស្រពពួកណា កើតហើយនោះឯង មិនរាប់ថា កើតទៀត ពាក្យនោះជាឈ្មោះនៃព្រះខីណាស្រពទាំងនោះ ។ សត្វទាំងឡាយណា ស្វែងរកទីកើត

ហេតុនោះ សត្វទាំងនោះ ឈ្មោះថា **សម្ភវេសី** ។ *ពាក្យនេះជាឈ្មោះរបស់ព្រះសេក្ខៈ និងបុថុជ្ជនទាំងឡាយ ដែលកំពុងស្វែងរកទីកើតក្នុងអនាគត ព្រោះភវសំយោជនៈនៅមាន ។ ម្យ៉ាងទៀត បណ្តាកំណើតទាំង ៤ សត្វដែលជាអណ្ឌជៈ និងជលាពុជៈ មិនទាន់ទម្លាយសម្បកស៊ុត និងស្បូនចេញមកជរាបណា ជរាបនោះក៏ឈ្មោះថា* **សម្ភវេសី** ។ *កាលទម្លាយសម្បកស៊ុត និងស្បូនចេញមកខាងក្រៅ ឈ្មោះថា* **ភូត** ។ *ពួកសត្វដែលជាសំសេទជៈ និងឱបបាតិកៈ ឈ្មោះថា* **សម្ភវេសី** *ក្នុងខណៈបឋមចិត្ត តាំងអំពីខណៈទុតិយចិត្តទៅ ឈ្មោះថា* **ភូត** ។ *ម្យ៉ាងទៀត សត្វទាំងឡាយកើតក្នុងឥរិយាបថណា មិនទាន់ប្តូរឥរិយាបថដទៃអំពីឥរិយាបថនោះជរាបណា ជរាបនោះ ឈ្មោះថា* **សម្ភវេសី** *ក្រៅអំពីនោះទៅ ឈ្មោះថា* **ភូត** ។

អធិប្បាយគាថាទី ៦

ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនាក្នុងសត្វទាំងឡាយដោយប្រាថ្នាតែឲ្យចូលដល់ប្រយោជន៍សុខរបស់ភិក្ខុទាំងនោះ ដោយប្រការផ្សេងៗដោយ ២ គាថាកន្លះថា **សុខិនោ វា** *ជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងមេត្តាភាវនានោះ សូម្បីដោយប្រាថ្នាឲ្យចេញទៅអំពីវត្តដែលមិនជាប្រយោជន៍ និងទុក្ខ ទើបត្រាស់ថា* **ន បរោ បរំ និកុព្ភេថ** ។ *នេះជាបាឋៈចាស់ តែបច្ចុប្បន្នសូត្រថា* **បរំ ហិ** *ដូច្នេះក៏មាន បាឋៈនេះមិនប្រពៃ ។*

បណ្តាបទទាំងនោះ បទថា **បរោ** *បានដល់ ជនដទៃ ។ បទថា* **ន និកុព្ភេថ** *បានដល់ មិនបោកបញ្ឆោត ។ បទថា* **នាតិមញ្ញេថ** *បានដល់ មិនសំខាន់ពេក*

គឺមិនមើលងាយ ។ បទថា **កត្តចិ** *បានដល់ ក្នុងឱកាសណាមួយ គឺក្នុងស្រុក ឬក្នុងគាមក្ខេត្ត កណ្តាលពួកញាតិ ឬកណ្តាលពួកបុគ្គល ដូច្នេះជាដើម ។ បទថា* **ឆំ** *ប្រែថា នុ៎ះ ។ បទថា* **កិញ្ចិ** *បានដល់ បុគ្គលណាម្នាក់ គឺក្សត្រ ឬព្រាហ្មណ៍ គ្រហស្ថ ឬបព្វជិតដែលដល់នូវសេចក្តីសុខ ឬដល់នូវសេចក្តីទុក្ខ ដូច្នេះជាដើម ។ បទថា* **ព្យារោសនា បដិឃសញ្ញោ** *បានដល់ ព្រោះការខឹងក្រោធ ដោយកាយវិការ និងវចីវិការ និងព្រោះថ្នាំងថ្នាក់ដោយមនោវិការ ។ ព្រោះកាលគួរនឹងត្រាស់ថា* **ព្យារោសនាយ បដិឃសញ្ញាយ** *តែក៏ត្រាស់ថា* **ព្យារោសនា បដិឃសញ្ញោ** *ដូចកាលគួរត្រាស់ថា* **សម្មទញ្ញាយ វិមុត្តា** *តែក៏ត្រាស់ថា* **សម្មទញ្ញោ វិមុត្តា** *និងដូចកាលគួរត្រាស់ថា* **អនុបុព្ពសិក្ខាយ អនុបុព្ពកិរិយាយ អនុបុព្ពបដិបទាយ** *តែក៏ត្រាស់ថា* **អនុបុព្ពសិក្ខា អនុបុព្ពកិរិយា អនុបុព្ពបដិបទា អញ្ញោរាធនា** *ដូច្នោះ ។ បទថា* **នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ** *សេចក្តីថា មិនគប្បីប្រាថ្នាទុក្ខដល់គ្នានិងគ្នា ។ លោកអធិប្បាយដូចម្តេច ។ លោកអធិប្បាយថា មិនមែនចម្រើនមេត្តាដោយមនសិការជាដើមថា ចូរសត្វទាំងឡាយមានសេចក្តីសុខ មានសេចក្តីក្សេមចុះ ដូច្នេះតែម៉្យាងទេ ដែលពិត គប្បីមនសិការយ៉ាងនេះថា ឱហ្ន៎ ! បុគ្គលដទៃ ទោះបុគ្គលណាក៏ដោយ មិនគប្បីគំរាមបុគ្គលដទៃណាម្នាក់ ដោយកិរិយាបន្ទំ មានការបោកបញ្ឆោតជាដើម មិនគប្បីមើលងាយបុគ្គលដទៃណាម្នាក់ ទោះជាទីកន្លែងណា ដោយមានវត្ថុ ៩ យ៉ាង មានជាតិជាដើម មិនគប្បីប្រាថ្នានូវទុក្ខដល់គ្នានិងគ្នា ព្រោះសេចក្តីក្រោធ ឬព្រោះការចង្អៀតចង្អល់ ដូច្នេះទៀតផង ។*

អធិប្បាយគាថាទី ៧

ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនា ដោយអត្ថ ដោយប្រាថ្នាឲ្យបុគ្គលនោះចេញទៅអំពីវត្ថុដែលមិនជាប្រយោជន៍ និងទុក្ខយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងមេត្តាភាវនានោះដោយឧបមា ទើបត្រាស់ថា **មាតា យថា និយំ បុត្តំ** ជាដើម ។

គាថានោះ មានសេចក្តីថា មាតាគប្បីអនុគ្រោះបុត្រក្នុងខ្លួន គឺបុត្រដែលកើតក្នុងខ្លួន កើតអំពីទ្រូង គប្បីថ្នាក់ថ្នមបុត្រនោះ ដែលមានតែម្នាក់ប៉ុណ្ណោះ ស្មើដោយជីវិត គឺហ៊ានលះបង់ជីវិតរបស់ខ្លួនដើម្បីរក្សាបុត្រនោះ ដើម្បីហាមទុក្ខដែលមកដល់បុត្រនោះ យ៉ាងណា ភិក្ខុគប្បីធ្វើមនសៈដែលប្រកបដោយមេត្តានេះឲ្យចម្រើន គឺឲ្យកើតរឿយៗ ឲ្យវឹកទៅ និងញុំងមេត្តាភាវនានោះឲ្យចម្រើន មិនមានប្រមាណ ដោយកាន់យកសត្វមិនមានប្រមាណជាអារម្មណ៍ ឬដោយផ្សាយទៅមិនសេសសល់ សូម្បីតែក្នុងសត្វមួយ ។

អធិប្បាយគាថាទី ៨

ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនា ដោយអាការទាំងពួងយ៉ាងនេះ ឥឡូវនេះ កាលទ្រង់សម្តែងការចម្រើនមេត្តាភាវនានោះ ទើបត្រាស់ថា **មេត្តញ្ច សព្វលោកស្មិំ** ជាដើម ។

ក្នុងគាថានោះ ឈ្មោះថា **មិត្ត** ព្រោះស្រឡាញ់ និងរក្សា អធិប្បាយថាជាប់ជំពាក់ ព្រោះមានអធ្យាស្រ័យប្រាថ្នាប្រយោជន៍ និងរក្សាឲ្យផុតចាកការមកដល់នៃវត្ថុដែលមិនជាប្រយោជន៍ ។ ភាពជាមិត្ត ឈ្មោះថា **មេត្តា** ។ បទថា **សព្វលោកស្មិំ** បានដល់ ក្នុងសត្វលោក មិនមានសេសសល់ ។ មាន

ក្នុងចិត្ត ហេតុនោះ ទើបឈ្មោះថា **មានស។** *ពាក្យថា* **មានសំ** *នោះ លោកពោលយ៉ាងនេះ ក៏ព្រោះប្រកបជាមួយចិត្ត ។ បទថា* **ភាវយេ** *ប្រែថា ឲ្យចម្រើន ។ ប្រមាណរបស់មានសៈនោះមិនមាន ហេតុនោះ ទើបឈ្មោះថា* **អបរិមាណា។** *លោកពោលយ៉ាងនេះ ក៏ព្រោះមេត្តាមានសត្វមិនមានប្រមាណជាអារម្មណ៍ ។ បទថា* **ឧទ្ធំ** *ប្រែថា ខាងលើ ទ្រង់កាន់យករូបកពដោយបទនោះ ។ បទថា* **អធោ** *ប្រែថា ខាងក្រោម ។ ទ្រង់កាន់យកកាមភពដោយបទនោះ ។ បទថា* **តិរិយំ** *បានដល់ ខាងទទឹង ។ ទ្រង់កាន់យករូបភពដោយបទនោះ ។ បទថា* **អសម្ពាធំ** *បានដល់ រៀរចាកការចង្អៀតចង្អល់ ។ លោកអធិប្បាយថា មានព្រំដែនបែកហើយ គឺមានសិរីភាព ។ សត្រូវ លោកហៅថា ព្រំដែន អធិប្បាយថា ទៅក្នុងទីដែលមិនមានព្រំដែននោះ ។ បទថា* **អវេរំ** *បានដល់ រៀរចាកពៀរ អធិប្បាយថា រៀរចាកការប្រកបដនៃចេតនាដែលញុំងពៀរក្នុងចន្លោះៗ ។ បទថា* **អសបត្តំ** *បានដល់ ប្រាសចាកសត្រូវ ។ ពិតហើយ បុគ្គលនៅដោយមេត្តា រមែងជាទីស្រឡាញ់របស់មនុស្ស ជាទីស្រឡាញ់របស់ពួកអមនុស្ស ។ សត្រូវណាម្នាក់ របស់បុគ្គលនោះ រមែងមិនមាន ។ ដោយហេតុនោះ មានសៈរបស់បុគ្គលនោះ ទើបលោកហៅថា* **អសបត្ត** *ព្រោះប្រាសចាកសត្រូវ ។ ពាក្យដែលថា សត្រូវៗ ជាពាក្យដោយបរិយាយពណ៌នាសេចក្តីតាមបទនេះមានប៉ុណ្ណេះ ចំណែកការសម្តែងភាពដែលបំណងក្នុងទីនេះ មានដូច្នេះ ។*

គប្បីចម្រើនពង្រីកមេត្តាដែលត្រាស់ថា **ឯវម្បិ សព្ពភូតេសុ មានសំ**

ភាវយេ អបរិមាណំ *ដូច្នេះ ផ្សាយមេត្តាដែលមាននៅក្នុងចិត្ត មិនមានប្រមាណ ឲ្យសម្រេចដល់នូវការចម្រើនដុះដាល បរិបូណ៌ក្នុងលោកទាំងពួង ។ ធ្វើដូចម្តេច គឺផ្សាយមេត្តាចិត្តនោះទៅ មិនសេសសល់ ទាំងខាងលើ ខាងក្រោម ខាងទទឹង ខាងលើ តាំងអំពីភវគ្គព្រហ្មចុះមក ខាងក្រោម តាំងអំពីអវីចីនរកឡើងមក ខាងទទឹងតាំងអំពីទិសដ៏សេស ឬខាងលើ ក៏បានដល់ អរូបធាតុ ខាងក្រោមក៏បានដល់ កាមធាតុ ខាងទទឹងក៏បានដល់ រូបធាតុ កាលចម្រើនមេត្តាយ៉ាងនេះ ធ្វើមិនឲ្យមានការចង្អៀតចង្អល់ ពៀរ និងសត្រូវ គប្បីចម្រើនមេត្តានោះ ដោយប្រការដែលមិនមានការចង្អៀតចង្អល់ មិនមានពៀរ និងមិនមានសត្រូវ ។ ឬថា មេត្តានោះដល់នូវសម្បទាការនា ជាគុណឈ្មោះថា មិនចង្អៀតចង្អល់ ព្រោះជាឱកាសលោកទាំងពួង គឺភូមិ ៣១ ជាគុណឈ្មោះថា មិនមានពៀរ ព្រោះកម្ចាត់អាឃាតរបស់ខ្លួន ក្នុងសត្វដទៃចោល ជាគុណឈ្មោះថា មិនមានសត្រូវ ព្រោះកម្ចាត់អាឃាតរបស់សត្វដទៃក្នុងខ្លួនចេញ ក៏គប្បីចម្រើន ពង្រីកមេត្តា ដែលមានក្នុងចិត្តនោះ ដែលមិនចង្អៀតចង្អល់ មិនមានពៀរ មិនមានសត្រូវ មិនមានប្រមាណក្នុងលោកទាំងពួង ដោយកំណត់ទិសទាំង ៣ គឺខាងលើ ខាងក្រោម និងខាងទទឹង ។*

អធិប្បាយគាថាទី ៩

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការចម្រើនមេត្តាភាវនាយ៉ាងនេះហើយ កាលទ្រង់សម្តែងការមិនមានឥរិយាបថពិតប្រាកដ នៃបុគ្គលប្រកបរឿយៗ នូវការចម្រើនមេត្តានោះ ទើបត្រាស់ថា **តិដ្ឋំ ចរំ ។បេ។ អធិដ្ឋេយ្យ** *ដូច្នេះ ។*

គាថានោះមានសេចក្តីថា បុគ្គលចម្រើនមេត្តា កាលចម្រើនមេត្តាមានក្នុងចិត្តយ៉ាងនេះ មិនចាំបាច់កំណត់ឥរិយាបថ ដូចក្នុងបាលីថា អង្គុយពត់ក្អែនតាំងកាយឲ្យត្រង់ កាលធ្វើការបន្ទោបង់នូវការនឿយហត់ ដោយឥរិយាបថណាមួយតាមសប្បាយ ទោះឈរ ឬដើរ អង្គុយ ឬដេក គង់ជាបុគ្គលប្រាសចាកការងងុយងោកងក់ជរាបណា ក៏គប្បីតាំងសតិក្នុងមេត្តាឈាននោះជរាបនោះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់សម្តែងការចម្រើនមេត្តាការនាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងភាពជាអ្នកជំនាញ ទើបត្រាស់ថា **តិដ្ឋំ ចរំ** *ជាដើម ។ ពិតហើយ បុគ្គលជំនាញហើយ គង់បំណងនឹងតាំងសតិក្នុងមេត្តាឈាន ដោយឥរិយាបថជរាបណា ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ក៏រមែងបាន ។ ម្យ៉ាងទៀត បុគ្គលជំនាញ ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ព្រោះហេតុនោះ ការឈរជាដើម រមែងមិនធ្វើអន្តរាយដល់បុគ្គលនោះ ។ ម្យ៉ាងទៀត បុគ្គលជំនាញ បំណងនឹងតាំងសតិមាំក្នុងមេត្តាឈាននេះជរាបណា ក៏គង់ជាបុគ្គលប្រាសចាកការងោកងុយ ទើបតាំងនូវសតិជរាបនោះ ។ ការយឺតយូរក្នុងមេត្តាឈាននោះនៃបុគ្គលនោះ រមែងមិនមាន ដោយហេតុនោះ ទើបត្រាស់ថា ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី គង់ជាអ្នកប្រាសចាកការងោកងុយជរាបណា ក៏គប្បីតាំងសតិជរាបនោះ ។*

គាថានោះ មានអធិប្បាយដូច្នេះថា បុគ្គលជំនាញគប្បីចម្រើនមេត្តា ដែលត្រាស់ថា **មេតញ្ច សព្វលោកស្មឹ មានសម្ភាវយេ** *ដោយប្រការដែលបុគ្គលជំនាញ មិនចាំបាច់ជ្រើសរើសដោយឥរិយាបថ បណ្តាឥរិយាបថ មាន*

ឈរជាដើម ឬដល់ឥរិយាបថ មានឈរជាដើម គង់បំណងនឹងតាំងសតិក្នុងមេត្តាឈាននោះជរាបណា ជាអ្នកប្រាសចាកការងឹុយងោកងក់ហើយ ក៏គប្បីតាំងសតិនោះជរាបនោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពជាអ្នកជំនាញក្នុងមេត្តាការនាយ៉ាងនេះ ទ្រង់ប្រកបមេត្តាក្នុងមេត្តាវិហារនោះថា **ឯតំ សតឹ អធិដ្ឋេយ្យ** *ដូច្នេះ ។ កាលទ្រង់សរសើរការនៅយ៉ាងនោះ ទើបត្រាស់ថា* **ព្រហ្មមេតំ វិហារំ ឥធមាហុ ។**

គាថានោះមានអត្ថថា ការនៅដោយមេត្តានេះ ទ្រង់សរសើរតាំងអំពីដើម តាំងអំពីព្រះពុទ្ធត្រាស់ថា **សុខិនោ វា ខេមិនោ វា ហោន្តុ** *ចូរជាអ្នកមានសេចក្តីសុខ ឬមានការក្សេម រហូតដល់ព្រះពុទ្ធត្រាស់ថា* **ឯតំ សតឹ អធិដ្ឋេយ្យ** *ប្រៃថា គប្បីតាំងនូវសតិនោះជរាបនោះ ។ អ្នកប្រាជ្ញទាំងឡាយពោលការនៅនោះថា* **ព្រហ្មវិហារ** *គឺការនៅដូចព្រហ្ម ពោលការនៅនោះថា* **សេដ្ឋវិហារ** *គឺការនៅដ៏ប្រសើរ ក្នុងព្រះសាសនា គឺក្នុងធម្មវិនយរបស់ព្រះ-អរិយៈនេះ ព្រោះមិនមានការនៅដូចទិព្វ នៅដូចព្រហ្ម នៅដូចព្រះអរិយៈ និងនៅដោយឥរិយាបថវិហារ និងការនៅដោយមេត្តានោះ ធ្វើប្រយោជន៍ដល់ខ្លួនផង ដល់អ្នកដទៃផង ។ ព្រោះការស្លាប់ជាប់តគ្នាមិនមានចន្លោះ ដូច្នោះ អ្នកចម្រើនមេត្តា ឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី មិនងឹុយងោកងក់ជរាបណា គប្បីតាំងនូវសតិនោះជរាបនោះ ។*

អធិប្បាយគាថាទី ៩០

ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនាប្រការផ្សេងៗ ដល់ភិក្ខុទាំងនោះយ៉ាងនេះហើយ ឥឡូវនេះ ព្រោះមេត្តាជិតចំពោះអត្តទិដ្ឋិ គឺការឃើញថាជាខ្លួន ព្រោះមានសត្វជាអារម្មណ៍ ដូច្នោះ កាលទ្រង់សម្តែងការសម្រេចអរិយភូមិ ធ្វើមេត្តាឈាននោះឯងឲ្យជាបាទដល់ភិក្ខុទាំងនោះ ដោយលើកការហាម ការប្រកាន់ទិដ្ឋិឡើងជាប្រធាន ទើបទ្រង់បញ្ចប់ទេសនាដោយគាថានេះថា **ទិដ្ឋិញ្ច អនុបគម្ម** ជាដើម ។

គាថានោះ មានសេចក្តីថា ការនៅដោយមេត្តាឈាននោះ ទ្រង់សរសើរថា **ព្រហ្មមេតំ វិហារំ ឥធមាហុ** អ្នកប្រាជ្ញទាំងឡាយពោលការនៅនោះថាជាព្រហ្មវិហារក្នុងធម្មវិនយនេះ បុគ្គលចម្រើនមេត្តា ចេញអំពីការនៅដោយមេត្តាឈាននោះហើយ កំណត់នាមធម៌ មានវិតក្ក វិចារៈជាដើមក្នុងទីនេះ និងរូបធម៌តាមគន្ថង្គការកំណត់នាមធម៌នោះជាដើម ហើយកំណត់អរូបធម៌ និងដោយការកំណត់នាមរូបនេះ ក៏មិនប្រកាន់ដោយទិដ្ឋិយ៉ាងនេះថា នេះគំនរសង្ខារដែលបរិសុទ្ធ បុគ្គលរមែងប្រកាន់មិនបានថា ជាសត្វក្នុងសង្ខារដូច្នេះ ជាអ្នកមានសីល ដោយលោកុត្តរសីលតាមលំដាប់ ដល់ព្រមដោយទស្សនៈដែលតែងហៅថា សម្មាទិដ្ឋិក្នុងសោតាបត្តិមគ្គ ដែលប្រកបដោយលោកុត្តរ-សីល បន្ទាប់អំពីនោះ ក៏នាំចេញ កម្ចាត់ រម្ងាប់នូវការវង្វេងក្នុងកាមទាំង-ឡាយ គឺកិលេសកាមដែលមិនទាន់លះបាន ដោយការធ្វើឲ្យស្រាលស្តើងដោយសកទាគាមិមគ្គ និងអនាគាមិមគ្គ និងដោយការលះមិនឲ្យសេសសល់ក៏មិនចូលដល់នូវការដេកក្នុងគភ៌ម្តាយទៀត គឺមិនចាំបាច់ដេកក្នុងគភ៌ទៀត

យ៉ាងពិតប្រាកដ បានដល់ កើតក្នុងពួកទេវតាជាន់សុទ្ធាវាសទាំងឡាយ សម្រេចអរហត្ត ហើយបរិនិព្វានក្នុងជាន់សុទ្ធាវាសនោះឯង ។

ព្រះមានព្រះភាគ កាលទ្រង់បញ្ចប់ទេសនាយ៉ាងនេះហើយ ត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកចូរទៅចុះ ពួកអ្នកចូរនៅក្នុងជង្ឃព្រៃនោះឯង ចូរវាយជួងក្នុងថ្ងៃធម្មសវនៈ ៨ ថ្ងៃ ក្នុង ១ ខែ ហើយចូរសូត្រនូវព្រះសូត្រនេះ ចូរធ្វើធម្មកថា ធម្មសន្ទនា អនុមោទនា ចូរសេព ចម្រើនធ្វើឲ្យច្រើននូវកម្មដ្ឋាននេះឯង ពួកអមនុស្សទាំងនោះ នឹងមិនបង្ហាញអារម្មណ៍ដែលគួរខ្លាចនោះ នឹងជាអ្នកបំណាងល្អ ប្រាថ្នាប្រយោជន៍ដល់ពួកអ្នកពិត ភិក្ខុទាំងនោះទទួលព្រះពុទ្ធតម្រាស់ហើយ ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំហើយ ធ្វើប្រទក្សិណទៅក្នុងជង្ឃព្រៃនោះ ហើយធ្វើតាមព្រះតម្រាស់គ្រប់ប្រការ ។ ទេវតាទាំងឡាយកើតបីតិសោមនស្សថា លោកម្ចាស់ទាំងឡាយបំណាងល្អ ប្រាថ្នានូវប្រយោជន៍ដល់ពួកយើង ។ ក៏នាំគ្នាបោសសេនាសនៈឯង ចាត់ចែងទឹកក្តៅ ប្របាច់ខ្នង ប្របាច់ជើង និងតាំងការពារក្សា ភិក្ខុទាំងនោះក៏នាំគ្នាចម្រើនមេត្តា ធ្វើមេត្តានោះឲ្យជាបាទ ផ្តើមវិបស្សនា ក៏សម្រេចអរហត្ត ជាអគ្គផលខាងក្នុងត្រៃមាសនោះឯងគ្រប់រូប បវារណាដោយវិសុទ្ធិបវារណា ក្នុងថ្ងៃមហាបវារណាចេញវស្សានោះឯង ។

ព្រះតថាគតជាម្ចាស់នៃធម៌ ទ្រង់ឈ្វាសក្នុងប្រយោជន៍ ត្រាស់ករណីយមេត្តសូត្រ ដែលមានប្រយោជន៍ ដោយប្រការដូច្នេះ ។

ភិក្ខុទាំងឡាយ ដែលមានបញ្ញាបរិបូណ៌ បានទទួលសេចក្តីសូម្បីនៃហទយៈ

យ៉ាងក្រៃលែង ក៏សម្រេចនូវសន្តិបទ ។

ព្រោះដូច្នោះឯង វិញ្ញូជនដែលប្រាថ្នានឹងសម្រេចសន្តិបទ ដែលជាអមតៈ ដែលគួរអស្ចារ្យ ដែលព្រះអរិយៈស្រឡាញ់រាប់អាន គប្បីធ្វើករណីដែលមានប្រយោជន៍ មានសីល សមាធិ បញ្ញា ដែលមិនមានមន្ទិល អស់កាលជានិច្ច កុំឲ្យជាប់ហោង ៗ

អដ្ឋកថាមេត្តសូត្រ

នៃ

អដ្ឋកថាខុទ្ទកនិកាយ ឈ្មោះបរមត្តជោតិកា ចប់

និគមគាថា

ដោយគាថាមានប្រមាណប៉ុណ្ណេះ ខ្ញុំបានពោលពាក្យណាថា ខ្ញុំសូមនមស្ការព្រះរតនត្រ័យដ៏ឧត្តម នៃវត្ថុដែលគួរថ្វាយបង្គំ ហើយនឹងសម្តែងអដ្ឋកថានៃខុទ្ទកបាឋៈណាមួយ ។

ក្នុងពាក្យនោះ ខ្ញុំចងអដ្ឋកថានៃខុទ្ទកបាឋៈ ៩ ប្រភេទ គឺសរណៈ ១ សិក្ខាបទ ១ ទុត្តីសាការ ១ កុមារបញ្ហា ១ មង្គលសូត្រ ១ រតនសូត្រ ១ តិរោកុដ្ឋសូត្រ ១ និធិកណ្ឌសូត្រ ១ និងមេត្តសូត្រ ១ ដោយហេតុនោះ ទើបខ្ញុំពោលពាក្យនេះថា

ខ្ញុំបំណងឲ្យព្រះសទ្ធម្មតាំងមាំ ទើបរចនាអដ្ឋកថានៃខុទ្ទកបាឋៈនេះ ជួបនូវកុសលឯណា ។

សូមមហាជន ធាប់រួសរាន់សម្រេចនូវសេចក្តីចម្រើនរុងរឿង បរិបូណ៌ក្នុងធម៌ដែលព្រះអរិយៈប្រកាសហើយ ព្រោះអានុភាពនៃកុសលនោះ ។

អដ្ឋកថានៃខុទ្ទកបាឋៈ ឈ្មោះបរមត្ថជោតិកានេះ រចនាដោយព្រះថេរៈដែលគ្រូទាំងឡាយឲ្យឈ្មោះថា ពុទ្ធឃោសៈ ជាអ្នកប្រជាប់ដោយគុណ គឺបរិសុទ្ធិ ការជឿ ការដឹង និងការព្យាយាម ដែលគុណសមុទយៈ គឺសីលាចារៈ អាជ្ជវៈ និងមទ្ទវៈជាដើម បណ្តាលហើយ ជាអ្នកអាចឈមចុះកាន់ព្រៃស្តុក គឺលទ្ធិខ្លួន និងលទ្ធិដទៃ ប្រកបដោយការឈ្លាសវៃ ដែលមានពន្លឺគឺអំណាចនៃញាណ ដែលមិនមានអ្វីរារាំង ក្នុងសត្ថុសាសនៈ មានព្រះត្រៃបិដក បរិយត្តិធម៌ ព្រមទាំងអដ្ឋកថា ជាមហាកវី ប្រកបដោយលម្អនៃវចនៈដ៏ពីរោះឧឡារ ដែលបន្ទឺបានស្រួលនូវសម្បត្តិ គឺករណៈ ឲ្យកើតហើយ ដោយ

មហាវេយ្យាករណ៍ ដែលមានវាទៈពាល់ត្រូវ បែកធ្លាយ មានវាទៈដ៏ប្រសើរ ជាអ្នកមានសេចក្តីបរិសុទ្ធ និងការដឹងដ៏បរិបូណ៌ ជាអលង្ការនៃវង្សរបស់ព្រះបរៈទាំងឡាយ ដែលនៅក្នុងមហាវិហារ ជាប្រទីបនៃបវេណីវង្ស ជាអ្នកមានការដឹងមាំទាំហើយ ក្នុងឧត្តរិមនុស្សធម៌ ដែលប្រជាប់ដោយគុណ មានអភិញ្ញា ៦ និងបដិសម្ភិទាជាដើម ។

តាវ ឥដ្ឋតុ លោកស្មឹ លោកឥដ្ឋរណោសិនំ
ឧសេ្សដ្ឋឹ កុលបុត្តានំ ឧយំ សីលាទិវិសុទ្ធិយា ។
យាវ ពុទ្ធោតិ នាមម្បិ សុទ្ធចិត្តស្ស តាទិនោ
លោកម្ហិ លោកជេដ្ឋស្ស បវត្តិ មហោសិនោ ។

គម្ពីរបរមត្ថជោតិកា ដែលសម្តែងន័យនៃវិសុទ្ធិ មានសីលវិសុទ្ធិជាដើម ដល់កុលបុត្រទាំងឡាយ ដែលស្វែងរកការចេញចាកលោក ចូរតាំងនៅជរាប ដែលឈ្មោះថា **ពុទ្ធ** របស់បុគ្គលដែលមានចិត្តបរិសុទ្ធ ជាតាទិបុគ្គល ចម្រើនបំផុតក្នុងលោក ជាអ្នកស្វែងរកគុណធំ ប្រព្រឹត្តទៅក្នុងលោកហោង ។

អដ្ឋកថាខុទ្ទកថាយ

នៃ

អដ្ឋកថាខុទ្ទកថាយ ឈ្មោះបរមត្ថជោតិកា ចប់

សុត្តន្តបិដក

ខុទ្ទកនិកាយ

សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ

ធម្មបទគាថា

យមកវគ្គទី ១

[១១] *ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមជានជើងគោដែលកំពុងអូសទៅ ។ ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី (នូវសុចរិត) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអនុ្ទលតាមប្រាណ ។*

អ្នកឯណោះ បានជេរអញ អ្នកឯណោះ បានវាយអញ អ្នកឯណោះ បានផ្តាញ់អញ អ្នកឯណោះ បានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នកណា ចងសេចក្តីក្រោធបែបនោះទុក (ដូច្នេះ) ពៀររបស់អ្នកនោះមិនរម្ងាប់ឡើយ ។

អ្នកឯណោះ បានជេរអញ អ្នកឯណោះ បានវាយអញ អ្នកឯណោះ បានផ្តាញ់អញ អ្នកឯណោះ បានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នក

ណា មិនចង់សេចក្តីក្រោធបែបនេះទុក (ដូច្នេះ) ពៀរបស់អ្នកនោះ ទើប រម្ងាប់បាន ។ ពិតមែន តាំងពីកាលណាមក ក្នុងលោកនេះ ពៀរទាំងឡាយ មិនរម្ងាប់ដោយពៀរឡើយ ពៀរទាំងឡាយតែងរម្ងាប់ ដោយមិនមានពៀរ នេះជាបវេណីធម៌ ។ ជនទាំងឡាយដទៃ (ក្រៅអំពីបណ្ឌិត) តែងមិនដឹងខ្លួនថា យើងទាំងឡាយនឹងវិនាសក្នុងកណ្តាលនៃពួកនេះដូច្នេះឡើយ ចំណែកជនទាំងឡាយណា ក្នុងពួកនេះ ដឹងខ្លួនថា យើងទាំងឡាយ នឹងវិនាសក្នុងកណ្តាលនៃពួកនេះ ដូច្នេះ ការឈ្លោះប្រកែកទាំងឡាយ រមែងរម្ងាប់អំពីជនទាំងឡាយនោះ ។

បុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយទាំង-ឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមធូរថយ កិលេសមារ រមែងគ្របសង្កត់បុគ្គលនោះឯង ដូចខ្យល់ដែលគ្របសង្កត់ដើមឈើទុព្វលដូច្នោះ ។ ឯបុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាមិនល្អ សង្រួមប្រពៃក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន មានសទ្ធា ប្រារព្ធព្យា-យាម កិលេសមារតែងគ្របសង្កត់បុគ្គលនោះមិនបាន ដូចខ្យល់គ្របសង្កត់ថ្មភ្នំតាន់មិនបានដូច្នោះ ។

អ្នកណា នៅមានទឹកចត់ គឺរាគាទិក្កិលេស (ក្នុងសន្តាន) ជាអ្នកបោះបង់ការទន្ទានន្ទូវឥន្ទ្រិយ និងសច្ចៈ ហើយស្លៀកដណ្តប់សំពត់កាសាវៈ អ្នកនោះ មិនគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈឡើយ ។ លុះតែអ្នកណា មានទឹកចត់ គឺរាគាទិក្កិលេស ខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំ

ក្នុងចតុប្បាសុទ្ធិសីល ប្រកបដោយការទូន្មាននូវឥន្ទ្រិយ និងសច្ចៈ អ្នកនោះឯង ទើបគួរនឹងស្លៀកជណ្តប់សំពត់កាសាវៈបាន ។

ជនទាំងឡាយ ដែលយល់ឃើញក្នុងធម៌មានខ្វីម ថាជាធម៌មិនមានខ្វីមផង ជាអ្នកមានតម្រិះខុសជាអារម្មណ៍ រមែងមិនបាននូវធម៌ដែលមានខ្វីមឡើយ ។ ជនទាំងឡាយ ដែលយល់ឃើញនូវធម៌មានខ្វីម ថាជាធម៌មានខ្វីមផង យល់ឃើញនូវធម៌គ្មានខ្វីម ថាជាធម៌គ្មានខ្វីមផង ជាអ្នកមានតម្រិះត្រូវជាអារម្មណ៍ រមែងបាននូវធម៌ដែលមានខ្វីម ។

ផ្ទះដែលប្រក់ខ្វីខ្ជាហើយ តំណក់ទឹកភ្លៀង រមែងលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុកហើយ រាគៈរមែងចាក់ជោតយ៉ាងនោះឯង ។

ផ្ទះដែលប្រក់ល្អហើយ តំណក់ទឹកភ្លៀង រមែងមិនលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ រាគៈរមែងមិនចាក់ជោតបានយ៉ាងនោះឯង ។ បុគ្គលអ្នកធ្វើបាប តែងសោកស្តាយក្នុងលោកទាំងពីរ គឺសោកស្តាយ ក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងសោកស្តាយ ក្តៅក្រហាយ ព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំង ២ គឺរីករាយក្នុងលោកនេះ ១ រីករាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។ បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយក្នុងលោកទាំង ២ គឺក្តៅក្រហាយក្នុងលោកនេះ ១ ក្តៅក្រហាយ

ក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងក្តៅក្រហាយដោយគិតឃើញថា បាប អញបានធ្វើហើយ លុះមរណកាលទៅកាន់ទុគ្គតិ ក៏រងើរតែក្តៅក្រហាយដ៏ក្រៃលែង ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរក្នុងលោកទាំង ២ គឺត្រេកអរក្នុងលោកនេះ ១ ត្រេកអរក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងត្រេកអរដោយគិតឃើញថា បុណ្យអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់សុគតិ ក៏រងើរតែត្រេកអរដ៏ក្រៃលែង ។

បើនរជនពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីច្រើន តែជាអ្នកប្រមាទ មិនធ្វើតាមពាក្យនោះ រមែងជាអ្នកមិនមានចំណែកសាមញ្ញផលឡើយ ដូចអ្នករក្សាគោ កាលរាប់គោប្រគល់ឲ្យអ្នកដទៃហើយ (ជាអ្នកមិនបានបរិភោគនូវបញ្ចគោរស) ដូច្នោះឯង ។ បើនរជនពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តនូវធម៌សមគួរដល់ធម៌ បានលះបង់រាគៈ ទោសៈ និងមោហៈ ជាអ្នកដឹងនូវធម៌ ដែលគួរកំណត់តាមហេតុ មានចិត្តដកផុតអំពីសេចក្តីសៅហ្មង មិនមានសេចក្តីប្រកាន់មាំក្នុងលោកនេះ និងលោកខាងមុខ នរជននោះ រមែងជាអ្នកបានចំណែកសាមញ្ញផល ។

យមកវគ្គទី ១ ចប់

ធម្មបទដ្ឋកថា

អដ្ឋកថា ខុទ្ទកនិកាយ គាថាធម្មបទ

យមកវគ្គ

បឋមវគ្គ

ខ្ញុំដែលព្រះកុមារកស្សបត្ថេរ ជាអ្នកទូន្មានខ្ជួនល្អហើយ ប្រព្រឹត្តស្មើដោយប្រក្រតី មានចិត្តមាំទាំ ប្រាថ្នានូវការតាំងមាំនៃព្រះសទ្ធម្ម បំណងថា អដ្ឋកថាដែលពណ៌នាអត្ថធម្មបទដ៏ល្អ ដែលព្រះសាស្តាទ្រង់ជាអ្នកឈ្វាស ក្នុងសភាវៈដែលជាធម៌ និងមិនមែនធម៌ មានបទ គឺព្រះសទ្ធម្មដល់ព្រមហើយ មានព្រះអធ្យាស្រ័យដ៏មានកម្លាំងនៃព្រះករុណា ឲ្យនូវឧស្សាហ៍ដោយល្អហើយ ទ្រង់អាស្រ័យហេតុនោះៗ សម្តែងហើយ ជាគ្រឿងចម្រើនបីតិ និងជាមោជ្ឈរបស់ទេវតា និងមនុស្សទាំងឡាយ ជាពាក្យដ៏សុខុម នាំបន្តគ្នាមកតាំងនៅហើយក្នុងតម្ពបណ្ណិទ្វីប ដោយភាសាអ្នកកោះ មិនទាន់ធ្វើអត្ថដល់ព្រមនៃប្រយោជន៍ឲ្យសម្រេចដល់សត្វទាំងឡាយដ៏សេសបាន ហេតុដូច្នោះ អដ្ឋកថានៃធម្មបទនោះ នឹងធ្វើប្រយោជន៍ឲ្យសម្រេចដល់លោកទាំងពួងបាន ដូច្នេះ អាភជនាដោយគោរពហើយ ទើបក្រាបនមស្ការព្រះបាទានៃព្រះសម្ពុទ្ធដ៏មានសិរី ទ្រង់សម្ងឹងឃើញទីបំផុតលោកបាន មានឫទ្ធិដ៏រុងរឿង ទ្រង់ញ៉ាំងប្រទីប គឺព្រះសទ្ធម្មឲ្យភ្លឺសន្ធោសន្ធៅ ក្នុងកាលដែលលោកងងឹត គឺមោហៈធំគ្របជណ្តប់

ហើយ បូជាព្រះសទ្ធម្មនៃព្រះសម្ពុទ្ធអង្គនោះ និងធ្វើអញ្ជលីដល់ព្រះសង្ឃ-សាវ័កព្រះសម្ពុទ្ធអង្គនោះ ហើយនឹងពោលអដ្ឋកថា ដែលពណ៌នាអត្ថនៃធម្មបទនោះ ដោយកាសាជនៃ ដោយអត្ថមិនឲ្យសេសសល់ លះកាសានោះ និងលំដាប់នៃពាក្យដែលដល់នូវការពិស្តារពន់ពេកចោល លើកទ្បើងកាន់កាសាដ៏ពីរោះ អធិប្បាយបទ ព្យញ្ជនៈនៃគាថាទាំងឡាយ ដែលលោកមិនទាន់បានអធិប្បាយហើយ ក្នុងអដ្ឋកថានោះ មិនឲ្យសេសសល់ នាំមកនូវបីតិ និងជាមោជ្ជនៃចិត្ត អាស្រ័យអត្ថ និងធម៌ដល់អ្នកជ្រាជ្រទាំងឡាយ ។

បទនមស្ការ ចប់

យមកវគ្គ

រឿង ព្រះចក្ខុបាលត្ថេរ

លំនាំដើម

មានបុច្ឆាថា ព្រះធម្មទេសនា ដែលមានពាក្យថា

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្ត ហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមជានជើងគោដែលកំពុងអូសទៅ ។

ដូច្នេះ តើព្រះគាថានេះ ព្រះសាស្តាទ្រង់ត្រាស់ ហើយក្នុងទីណា ។

ឆ្លើយថា ទ្រង់ត្រាស់ហើយក្នុងក្រុងសាវត្ថី ។

មានបុច្ឆាតទៅទៀតថា ទ្រង់ប្រារព្ធអ្នកណា ។

ឆ្លើយថា ទ្រង់ប្រារព្ធព្រះចក្ខុបាលត្ថេរ ។

បានឮមកថា ក្នុងក្រុងសាវត្ថី មានកុដុម្ពិកៈម្នាក់ ឈ្មោះមហាសុវណ្ណ ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានសម្បត្តិច្រើន តែមិនមានកូន ។ ថ្ងៃមួយ គាត់ចូលទៅកាន់កំពង់ទឹក ងូតស្រេចហើយត្រឡប់មក ឃើញដើមឈើធំ ដែលជាធំនៃឈើទាំងឡាយ ១ ដើម បរិបូរដោយមែកក្នុងរវាងផ្លូវ គិតថា ដើមឈើនេះនឹងមានទេវតាដែលមានសក្តិធំអាស្រ័យនៅ ដូច្នេះហើយ ទើបឲ្យគេជម្រះចំណែកខាងក្រោម នៃដើមឈើនោះឲ្យស្អាត ហើយឲ្យព័ទ្ធ

របង់ រោយទ្បាច់ លើកទង់ជ័យ និងទង់ជ្ងាលាឡើង តាក់តែងដើមឈើធំ នោះហើយ ធ្វើសេចក្តីប្រាថ្នា គឺបន់ស្រន់ថា ខ្ញុំបានបុត្រ ឬធីតាហើយ នឹងធ្វើ សក្ការៈធំដល់លោក ដូច្នេះហើយ ចៀសចេញទៅ ។

ក្នុងកាលបន្តមក ភរិយារបស់សេដ្ឋីក៏តាំងគភ៌ ។ គាត់ក៏ឲ្យធ្វើនូវពិធី បរិហារគភ៌ដល់នាង លុះកន្លងទៅ ១០ ខែ នាងប្រសូតកូនប្រុសម្នាក់ លោក សេដ្ឋីឲ្យឈ្មោះបុត្រនោះថា ជាលៈ ព្រោះទារកនោះ គាត់អាស្រ័យដើមឈើ ធំដែលខ្ជូនរក្សា ទើបបានហើយ ។

ក្នុងកាលជាចំណែកជនៃ លោកសេដ្ឋីបានកូនប្រុសម្នាក់ទៀត គាត់ឲ្យ ឈ្មោះថា ចុល្លជាលៈ ហើយឲ្យឈ្មោះកូនប្រុសច្បងថា មហាជាលៈ ។ កាលកុមារពីរនាក់នោះចម្រើនវ័យ មាតាបិតាគិតដល់ចំណងដោយគ្រឿងចង គឺការគ្រប់គ្រងគេហដ្ឋាន ។

ក្នុងកាលចំណែកជនៃ មាតាបិតាបានធ្វើកាលកិរិយាទៅ ។ ពួកញាតិ ក៏បើកសម្បត្តិទាំងអស់ ប្រគល់ឲ្យដល់សេដ្ឋីបុត្រទាំង ២ ។

ក្នុងសម័យនោះ ព្រះសាស្តាទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរ ឲ្យប្រព្រឹត្ត ទៅហើយ ទ្រង់យាងទៅដោយលំដាប់ ប្រថាប់នៅនាវត្តជេតពនមហាវិហារ ដែលសេដ្ឋីឈ្មោះអនាថបិណ្ឌិក បរិច្ចាគទ្រព្យ ៥៤ កោដិ សាងថ្វាយ ទ្រង់ ទូន្មានមហាជនឲ្យតាំងនៅក្នុងផ្លូវសួគ៌ និងក្នុងផ្លូវនិព្វាន ។

មែនពិត ព្រះតថាគតទ្រង់នៅចាំវស្សា ១ វស្សាប៉ុណ្ណោះ ក្នុងនិគ្រោធ-មហាវិហារ ដែលព្រះញាតិវង្សខាងព្រះមាតា ៨ ម៉ឺនត្រកូល និងខាងព្រះ

បិតា ៨ ម៉ឺនត្រកូល សរុបជា ១ សែន ៦ ម៉ឺនត្រកូលសាងថ្វាយ ទ្រង់នៅចាំវស្សានាវត្តជេតពនមហាវិហារ ដែលអនាថបិណ្ឌិកសេដ្ឋីសាងថ្វាយ ១៩ វស្សា ។ ទ្រង់ចាំវស្សាក្នុងបុព្វារាម ដែលនាងវិសាខាមហាឧបាសិកាបរិច្ចាគទ្រព្យ ២៧ កោដិ សាងថ្វាយចំនួន ៦ វស្សា ។ ទ្រង់អាស្រ័យត្រកូលទាំង ២ ដែលជាធំដោយគុណធម៌ ទ្រង់នៅចាំវស្សាអាស្រ័យក្រុងសាវត្ថី ជាគោចរគាមអស់ ២៥ វស្សា ដោយប្រការដូច្នេះ ។

អនាថបិណ្ឌិកសេដ្ឋីក្តី នាងវិសាខាមហាឧបាសិកាក្តី រមែងទៅកាន់ទីឧបដ្ឋាកព្រះតថាគត ១ ថ្ងៃ ពីរដងជាប្រចាំ ។ កាលទៅ មិនធ្លាប់មានដៃទទេ ដោយគិតក្រែងថា ភិក្ខុកំលោះ និងសាមណេរនឹងសម្ងីមើលដៃរបស់ខ្លួន ។ កាលទៅមុនពេលឆាន់អាហារ រមែងប្រើឲ្យមនុស្សកាន់ខាទនីយជាដើមទៅ បើទៅខាងក្រោយពេលឆាន់អាហារ ប្រើឲ្យមនុស្សកាន់កេសជ្ជៈ និងទឹកអដ្ឋបានទៅ ហើយក្នុងគេហដ្ឋាននៃជនទាំងពីរនោះ គេក្រាលអាសនៈទុកដើម្បីភិក្ខុមួយកន្លែង ២ ពាន់រូបជានិច្ចកាល ។ ភិក្ខុរូបណាប្រាថ្នាវត្ថុណា ទោះជាបាយទឹក ឬកេសជ្ជៈរបស់នោះក៏សម្រេចដល់ភិក្ខុរូបនោះ សមតាមប្រាថ្នា ។

ក្នុងជនទាំង ២ នោះ អនាថបិណ្ឌិកសេដ្ឋីមិនធ្លាប់ទូលសួរបញ្ហាចំពោះព្រះសាស្តា រហូតដល់ថ្ងៃមួយ ។ បានឮថា គាត់គិតថា ព្រះតថាគតជាព្រះពុទ្ធ ជាបុគ្គលល្អិតល្អន់ ជាកូរ្តល្អិតល្អន់ កាលទ្រង់សម្តែងធម៌ដល់អាត្មាអញដោយទ្រង់ព្រះតម្រិះថា ពួកគហបតីមានឧបការៈដល់តថាគតច្រើនដូច្នេះ ទ្រង់នឹងលំបាក ហើយមិនទូលសួរបញ្ហា ដោយសេចក្តីស្រឡាញ់ក្នុងព្រះ

សាស្តាដ៏ក្រៃលែង ។ ចំណែកព្រះសាស្តា លុះសេដ្ឋីអង្គុយហើយ ទ្រង់ពុទ្ធតម្រិះថា សេដ្ឋីនេះរក្សាតថាគតក្នុងទីមិនគួររក្សា ព្រោះថាតថាគតបានកាត់ក្បាលរបស់តថាគត ដែលប្រដាប់តាក់តែងហើយ ខ្ទេះនូវកែវភ្នែករបស់តថាគតចេញហើយ ពុះរះនូវសាច់បេះដូងរបស់តថាគតហើយ លះបង់កូនប្រពន្ធ ជាទីស្រឡាញ់ស្មើដោយជីវិតរបស់តថាគតហើយ បំពេញបារមី ៤ អសង្ខ្យេយ្យ និង ១ សែនកប្ប បំពេញហើយដើម្បីសម្តែងធម៌ដល់អ្នកដទៃប៉ុណ្ណោះ សេដ្ឋីនេះរក្សាតថាគតក្នុងទីដែលមិនគួររក្សា កាលទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ត្រាស់ព្រះធម្មទេសនា ១ កណ្ឌជានិចួ ។

គ្រានោះ ក្នុងក្រុងសាវត្ថីមានមនុស្សរស់នៅ ៧ កោដិ ក្នុងមនុស្សទាំងនោះ អ្នកបានស្តាប់ធម្មកថារបស់ព្រះសាស្តាហើយ កើតជាអរិយសាវ័កប្រមាណ ៥ កោដិ នូវជាបុថុជ្ជនប្រមាណ ២ កោដិ ក្នុងមនុស្សទាំងនោះ កិច្ចរបស់អរិយសាវ័កមានត្រឹម ២ យ៉ាងប៉ុណ្ណោះ គឺក្នុងកាលមុនពេលឆាន់អាហារ លោកថ្វាយទាន ក្នុងកាលខាងក្រោយអំពីពេលឆាន់អាហារហើយ លោកមានដៃកាន់គ្រឿងសក្ការបូជា មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ប្រើមនុស្សឲ្យកាន់ទេយ្យធម៌ មានសំពត់ ភេសជ្ជៈ និងទឹកបានជាដើម ទៅដើម្បីស្តាប់ធម៌ ។

ក្រោយមកថ្ងៃមួយ មហាបាលកុដុម្ពិកៈឃើញពួកអរិយសាវ័ក មានដៃកាន់គ្រឿងសក្ការបូជា មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ទៅកាន់វិហារ ទើបសួរថា មហាជននេះទៅណា កាលបានឮថា ទៅស្តាប់ធម៌ ក៏គិតថា

អញ្ជក៏នឹងទៅដែរ កាលទៅដល់ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយនៅខាងក្រោយប្រជុំជន ។

ធម្មតាព្រះពុទ្ធទាំងឡាយ កាលទ្រង់សម្តែងធម៌ ទតឃើញឧបនិស្សយនៃគុណ មានសរណៈ សីល និងបព្វជ្ជាជាដើមក្នុងកាលមុន ហើយទើបទ្រង់សម្តែងធម៌តាមអំណាចអធ្យាស្រ័យ ។

ហេតុនោះ ថ្ងៃនោះ ព្រះសាស្តាទតឃើញឧបនិស្សយរបស់មហាបាល-កុដុម្ពិកៈហើយ កាលទ្រង់សម្តែងធម៌ បានត្រាស់អនុបុព្វីកថា គឺទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា ទោស និងការសៅហ្មងនៃកាមទាំងឡាយ និងអានិសង្សក្នុងនេក្ខម្មៈ ។

មហាបាលកុដុម្ពិកៈបានស្តាប់ធម៌រួចហើយគិតថា បុត្ត និងធីតាក្តី ភោគ-សម្បត្តិក្តី រមែងមិនទៅតាមបុគ្គលដែលទៅកាន់បរលោក សូម្បីសរីរៈក៏ទៅមិនបាន ប្រយោជន៍អ្វីរបស់អញដោយការនៅគ្រប់គ្រងផ្ទះ អញនឹងបួស លុះទេសនាចប់ គាត់ក៏ចូលទៅគាល់ព្រះសាស្តាសូមបួស ។ ខណៈនោះ ព្រះសាស្តាត្រាស់សួរថា ញាតិណាមួយរបស់អ្នកដែលគួរលា មិនមានទេឬ គាត់ទូលថា បពិត្រព្រះអង្គ ប្អូនប្រុសរបស់ខ្ញុំព្រះអង្គមាន ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ ចូរអ្នកលាប្អូននោះជាមុន ។

គាត់ទទួលថា សាធុ ហើយថ្វាយបង្គំព្រះសាស្តា ទៅដល់ផ្ទះហៅប្អូនប្រុសមកប្រគល់ទ្រព្យសម្បត្តិឲ្យថា នែប្អូ សវិញ្ញាណកទ្រព្យក្តី អវិញ្ញាណកទ្រព្យក្តីណាមួយ ដែលមានក្នុងត្រកូលនេះ ទ្រព្យនោះ ចូរធ្លាក់ជាការៈរបស់ឯងទាំង

អស់ ឯងចូរថែរក្សាទ្រព្យនោះចុះ ។

ឬនប្រុសសួរថា នែបង ចុះបងវិញ ។ បងប្រុសឆ្លើយថា អញនឹងបួសក្នុងសម្នាក់របស់ព្រះសាស្តា ។ ឬនប្រុសពោលថា បងនិយាយអ្វី កាលមាតារបស់យើងស្លាប់ហើយ ខ្ញុំបានបងដូចជាមាតា កាលបិតាស្លាប់ហើយ ខ្ញុំបានបងដូចជាបិតា សម្បត្តិដ៏ច្រើនមាននៅក្នុងផ្ទះរបស់យើង យើងនៅគ្រប់គ្រងផ្ទះប៉ុណ្ណោះក៏អាចធ្វើបុណ្យបាន សូមបងកុំធ្វើយ៉ាងនោះឡើយ ។ បងប្រុសពោលថា នែបា អញបានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ព្រោះព្រះសាស្តាទ្រង់សម្តែងធម៌ មានគុណាពីរោះក្នុងខាងដើមផង កណ្តាលផង និងទីបំផុតផង លើកឡើងកាន់ត្រៃលក្ខណ៍ដ៏សុខុម ធម៌នោះ បុគ្គលណាមួយ មិនអាចបំពេញឲ្យបរិបូណ៌ក្នុងចំណែកផ្ទះបានឡើយ អញនឹងបួស ឬនប្រុសពោលថា អើ បងនៅកំលោះដោយពិត ចាំបួសក្នុងកាលបងចាស់ចុះ បងពោលថា នែបា ដៃនិងជើងរបស់មនុស្សចាស់របស់ខ្លួនក៏ថាមិនស្តាប់ មិនប្រព្រឹត្តទៅក្នុងអំណាចនឹងពោលទៅថ្វីដល់ញាតិទាំងឡាយ អញនឹងមិនធ្វើតាមពាក្យរបស់អ្នក អញនឹងបំពេញសមណធម៌ឲ្យបរិបូរណ៌ ។

ដៃ និងជើងរបស់បុគ្គលណា ទ្រុឌទ្រោមទៅព្រោះជរាថាមិនស្តាប់ បុគ្គលនោះមានកម្លាំង ដែលជរាកម្ចាត់ហើយ នឹងប្រព្រឹត្តធម៌បានដូចម្តេច គឺអញនឹងបួស ។

កាលឬនប្រុសកំពុងទ្រហោយំនោះឯង គាត់ចូលទៅកាន់សម្នាក់ព្រះសាស្តា ហើយទូលសូមបួស បានបព្វជ្ជាឧបសម្បទាហើយ នៅក្នុងសម្នាក់នៃអាចារ្យ

និងឧបជ្ឈាយ៍គ្រប់ ៥ វស្សាហើយ ចេញវស្សាបវារណាហើយ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយទូលសួរថា បពិត្រព្រះអង្គ ក្នុងព្រះសាសនានេះ មានធុរៈប៉ុន្មានយ៉ាង ។

ព្រះសាស្តាត្រាស់ឆ្លើយថា ម្នាលភិក្ខុ ធុរៈមាន ២ យ៉ាង គឺគន្ថធុរៈ និង វិបស្សនាធុរៈប៉ុណ្ណោះ មហាបាលភិក្ខុទូលសួរថា បពិត្រព្រះអង្គ គន្ថធុរៈដូចម្តេច វិបស្សនាធុរៈដូចម្តេច ។ ព្រះសាស្តាត្រាស់ថា ធុរៈ គឺការរៀនមួយនិកាយក្តី ពីរនិកាយក្តី ចប់ពុទ្ធវចនៈ គឺព្រះត្រៃបិដកក្តី តាមសមគួរដល់បញ្ញារបស់ខ្លួន ហើយទ្រទ្រង់ ពោល ប្រាប់នូវពុទ្ធវចនៈនោះ ឈ្មោះថា គន្ថធុរៈ ។ ចំណែកការផ្តើមនូវការអស់ និងការសូន្យក្នុងអត្តភាព ញុំាងវិបស្សនាឲ្យចម្រើនដោយអំណាចនៃការធ្វើឲ្យជាប់តគ្នា ហើយកាន់យកអរហត្តរបស់ភិក្ខុ ដែលមានការប្រព្រឹត្តស្ងាត់ជំនាញ ត្រេកអរក្រៃលែងហើយក្នុងសេនាសនៈដ៏ស្ងាត់ ឈ្មោះថា វិបស្សនាធុរៈ ។ មហាបាលភិក្ខុពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គបួសហើយក្នុងកាលខ្លួនចាស់ មិនអាចបំពេញគន្ថធុរៈឲ្យបរិបូណ៌បាន តែនឹងបំពេញវិបស្សនាធុរៈឲ្យបរិបូណ៌បាន សូមទ្រង់ត្រាស់ប្រាប់កម្មដ្ឋានដល់ខ្ញុំព្រះអង្គចុះ ។

លំដាប់នោះ ព្រះសាស្តាបានត្រាស់ប្រាប់កម្មដ្ឋាន រហូតដល់អរហត្តដល់មហាបាលភិក្ខុ លោកថ្វាយបង្គំព្រះសាស្តាហើយ ស្វែងរកភិក្ខុដែលទៅជាមួយខ្លួន បានភិក្ខុ ៦០ រូបហើយ ចេញព្រមគ្នាធ្វើដំណើរទៅជាមួយភិក្ខុទាំងនោះ អស់ចម្ងាយផ្លូវ ១២០ យោជន៍ ដល់តំបន់ជាយដែនមួយ មួយអន្ទឹ

ដោយអ្នកបួមដំណើរចូលទៅបិណ្ឌបាតក្នុងស្រុកនោះ ។

ពួកមនុស្សឃើញភិក្ខុទាំងឡាយដល់ព្រមដោយវត្ត មានចិត្តជ្រះថ្លា រៀបចំអាសនៈហើយ និមន្តឲ្យគង់ អង្គាសដោយអាហារដ៏ប្រណីតហើយ សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់នឹងទៅទីណា កាលលោកទាំងឡាយពោលថា ឧបាសក និងឧបាសិកាទាំងឡាយ អាត្មាទៅកាន់ទីដែលជាផាសុក ដូច្នេះហើយ ពួកមនុស្សដែលជាបណ្ឌិតដឹងថា លោកម្ចាស់ទាំងឡាយស្វែងរកសេនាសនៈចាំវស្សា ទើបអារាធនាថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ទាំងឡាយនៅក្នុងទីនេះអស់ត្រីមាស យើងខ្ញុំទាំងឡាយនឹងតាំងនៅក្នុងសរណៈ ហើយរក្សាសីល ។ ភិក្ខុទាំងឡាយក៏គិតឃើញថា យើងបានអាស្រ័យត្រកូលទាំងនេះនឹងធ្វើការចេញទៅអំពីភពបាន ដូច្នេះ ទើបទទួលនិមន្ត ។ ពួកមនុស្សទទួលប្តេជ្ញារបស់លោកទាំងឡាយហើយ បាននាំគ្នាបោសសម្អាត រៀបចំទីលំនៅក្នុងពេលយប់ និងទីលំនៅក្នុងពេលថ្ងៃ ហើយវេរប្រគេន ។ ភិក្ខុទាំងឡាយចូលទៅបិណ្ឌបាតក្នុងស្រុកនោះជាប្រចាំ ។ កាលនោះ ពេទ្យម្នាក់ចូលទៅរកភិក្ខុទាំងឡាយ បវារណាថា បពិត្រលោកម្ចាស់ ធម្មតាក្នុងទីលំនៅរបស់មនុស្សច្រើន រមែងមិនមានផាសុកខ្លះ បើការមិនផាសុកនោះកើតឡើងហើយ លោកម្ចាស់ទាំងឡាយគប្បីប្រាប់ដល់ខ្ញុំ ខ្ញុំនឹងធ្វើភេសជ្ជៈប្រគេន ។

ក្នុងថ្ងៃចាំវស្សា ព្រះថេរៈហៅភិក្ខុទាំងនោះមកព្រមគ្នា ហើយសួរថា អាវុសោទាំងឡាយ អ្នកទាំងឡាយនឹងឲ្យត្រីមាសនេះកន្លងទៅដោយឥរិយាបថប៉ុន្មាន ។ ភិក្ខុទាំងឡាយឆ្លើយថា នឹងឲ្យកន្លងទៅដោយឥរិយាបថគ្រប់ទាំង

៤ ព្រះថេរៈពោលថា អាវុសោទាំងឡាយ សេចក្តីនោះសមគួរឬ យើងទាំង-ឡាយគួរជាបុគ្គលមិនប្រមាទមិនមែនឬ ព្រោះយើងទាំងឡាយរៀនព្រះកម្ម-ដ្ឋានមកអំពីសម្នាក់របស់ព្រះសម្ពុទ្ធ ដែលទ្រង់គង់ព្រះជន្មនៅ ជម្មតាព្រះពុទ្ធ ទាំងឡាយដែលបុគ្គលអួតអាង មិនអាចឲ្យទ្រង់ត្រេកអរបាន ដ្បិតថា ព្រះពុទ្ធ ទាំងឡាយនោះ ដែលបុគ្គលមានអធ្យាស្រ័យល្អមួយពួកប៉ុណ្ណោះ គប្បីឲ្យទ្រង់ ត្រេកអរបាន ។ ឈ្មោះថា អបាយទាំង ៤ ដូចផ្ទះរបស់ខ្លួនឯងនៃបុគ្គលអ្នក ប្រមាទហើយ អ្នកទាំងឡាយ ចូរជាអ្នកមិនប្រមាទចុះ ភិក្ខុទាំងឡាយសួរថា ចុះលោកម្ចាស់វិញ ។ ព្រះថេរៈពោលថា អាវុសោទាំងឡាយ ខ្ញុំនឹងឲ្យត្រីមាស នេះកន្ទងទៅដោយឥរិយាបថ ៣ គឺមិនសណ្តូកខ្នង ភិក្ខុទាំងឡាយពោលថា សាធុ សូមលោកម្ចាស់មិនប្រមាទចុះ ។

កាលព្រះថេរៈមិនឈានចុះកាន់និទ្រា កាលមួយខែកន្ទងទៅហើយ រោគ ក្នុងភ្នែកក៏កើតឡើង ទឹកហូរចេញអំពីភ្នែកទាំងពីរ ដូចទឹកដែលហូរចេញអំពី ធ្នាំងដែលធ្លុះ ។ ព្រះថេរៈបំពេញសមណធម៌អស់រាត្រីទាំងមូល ហើយក្នុង ពេលអារុណរះ ចូលបន្ទប់គង់ហើយ ។ ក្នុងពេលភិក្ខាចារ ភិក្ខុទាំងឡាយទៅ កាន់សម្នាក់របស់ព្រះថេរៈប្រាប់ថា ពេលនេះ ជាពេលភិក្ខាចារលោកម្ចាស់ ។ ព្រះថេរៈឆ្លើយថា អាវុសោទាំងឡាយ បើយ៉ាងនោះលោកទាំងឡាយកាន់បាត្រ និងចីវរចុះ ដូច្នេះហើយ ឲ្យភិក្ខុទាំងឡាយកាន់បាត្រ និងចីវររបស់ខ្លួនចេញ ទៅហើយ ។

ភិក្ខុទាំងឡាយ ឃើញភ្នែកទាំងពីររបស់ព្រះថេរៈមានខ្ទុះ ទើបសួរថា

បពិត្រលោកម្ចាស់ នុ៎ះជាអ្វី ។ ព្រះថេរៈពោលថា អាវុសោទាំងឡាយ ខ្យល់ចាក់នូវក្អែករបស់ខ្ញុំ ។ ភិក្ខុទាំងឡាយពោលថា បពិត្រលោកម្ចាស់ គ្រូពេទ្យបវារណាយើងមិនមែនឬ យើងគួរប្រាប់ដល់គាត់ ព្រះថេរៈពោលថា សាធុ អាវុសោទាំងឡាយ ។

ទើបភិក្ខុទាំងឡាយ បានប្រាប់ដល់គ្រូពេទ្យ គាត់ចម្អិនប្រេងបញ្ជូនទៅប្រគេនហើយ ព្រះថេរៈដាក់តំណាក់ប្រេងក្នុងច្រមុះអង្គុយបន្តក់ហើយ ចូលទៅខាងក្នុងស្រុក ។

គ្រូពេទ្យឃើញ ក៏សាកសួរថា បពិត្រលោកម្ចាស់ បានឮថា ខ្យល់ចាក់ក្អែករបស់លោកម្ចាស់ឬ ។ ព្រះថេរៈពោលថា អើ ឧបាសក ។ គ្រូពេទ្យពោលថា បពិត្រលោកម្ចាស់ ខ្ញុំចម្អិនប្រេងហើយបញ្ជូនទៅប្រគេនលោកម្ចាស់បន្តក់តាមច្រមុះហើយឬ ។ ព្រះថេរៈពោលថា អើ ឧបាសក ។ គ្រូពេទ្យពោលថា ឥឡូវនេះ ជូចម្តេចទៅហើយលោកម្ចាស់ ។ ព្រះថេរៈពោលថា ខ្យល់នៅតែចាក់នោះឯង ឧបាសក ។

គ្រូពេទ្យឆ្ងល់ក្នុងចិត្តគិតថា អញបញ្ជូនប្រេងដើម្បីនឹងញាំងរោគឲ្យរម្ងាប់បាន ដោយការបន្តក់ត្រឹមតែម្តងប៉ុណ្ណោះ ទៅប្រគេនហើយ ហេតុអ្វីហ្ន៎ ទើបរោគមិនសះស្បើយ ទើបសាកសួរថា បពិត្រលោកម្ចាស់ ប្រេងនោះលោកម្ចាស់ គង់បន្តក់ ឬសឹងបន្តក់ ។ ព្រះថេរៈនៅស្ងៀម សូម្បីគ្រូពេទ្យសាកសួរ ក៏មិនពោល ។

គ្រូពេទ្យគិតថា អញនឹងទៅវិហារមើលទីលំនៅឯង ដូច្នេះហើយ ពោល

ថា បើយ៉ាងនោះសូមនិមន្តទៅចុះ ។ បញ្ជូនព្រះថេរៈហើយ ទៅកាន់វិហារ មើលទីលំនៅរបស់ព្រះថេរៈ ឃើញតែទីចង្រ្កម និងទីអង្គុយ មិនឃើញទីសិង ទើបសាកសួរថា បពិត្រលោកម្ចាស់ ប្រែងនោះលោកម្ចាស់អង្គុយបន្តក់ ឬ សិងបន្តក់ ។ ព្រះថេរៈក៏នៅស្ងៀម ។ គ្រូពេទ្យអង្វរហើយអង្វរទៀតថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំធ្វើយ៉ាងនោះ ធម្មតាសមណធម៌ បើ រាងកាយនៅប្រព្រឹត្តទៅ ក៏អាចធ្វើបាន សូមលោកម្ចាស់សិងបន្តក់ចុះ ។

ព្រះថេរៈឆ្លើយថា ទៅចុះអ្នក អាត្មានឹងប្រឹក្សាមើលហើយទើបដឹង ។ ក្នុង ទីនោះមិនមានញាតិសាលោហិតរបស់ព្រះថេរៈឡើយ តើលោកប្រឹក្សាជាមួយ អ្នកណា តែទោះជាយ៉ាងនោះលោកប្រឹក្សាជាមួយកាយថា នែបាលិតៈ អ្នក ចូរពោលមកមុន អ្នកនឹងឃើញដល់ចក្ខុ ឬនឹងឃើញដល់ព្រះពុទ្ធសាសនា ។ ក្នុងសង្សារវដ្តដែលមានទីបំផុត ដែលបុគ្គលដឹងមិនបាន ការគណនារាប់ខ្លួន របស់អ្នកដែលខ្វាក់ភ្នែកមិនបាន ។ ព្រះពុទ្ធទាំងឡាយកន្ទងទៅច្រើនរយ ច្រើន ពាន់អង្គហើយ ព្រះពុទ្ធទាំងនោះ ព្រះពុទ្ធសូម្បីមួយអង្គក៏កំណត់មិនបាន អ្នក បានចងចិត្តទុកឥឡូវនេះឯងថា នឹងមិនដេកអស់កាល ៣ ខែ ក្នុងរដូវក្តៅ នេះ ។ ហេតុនោះ ភ្នែករបស់អ្នកវិនាស ឬបែកក៏ដោយចុះ អ្នកចូរទ្រទ្រង់តែ ព្រះពុទ្ធសាសនាចុះ កុំឃើញដល់ចក្ខុឡើយ កាលទូន្មានភូតកាយ បាន ភាសិតគាថានេះថា

ចក្ខុដែលអ្នកប្រកាន់ថារបស់ខ្លួន វិនាសក៏វិនាសចុះ ត្រចៀក ក៏វិនាសទៅចុះ កាយក៏ដូចគ្នាយ៉ាងនោះចុះ វត្ថុទាំងអស់

អាស្រ័យកាយនេះ ក៏វិនាសទៅចុះ បាលិតៈ ហេតុអ្វី ទើបអ្នកប្រមាទ ។ ចក្ខុដែលអ្នកសម្គាល់ថារបស់ខ្លួន ទ្រុឌទ្រោមទៅចុះ ត្រចៀកក៏ទ្រុឌទ្រោមទៅចុះ កាយក៏ដូចគ្នាយ៉ាងនោះចុះ វត្ថុសព្វយ៉ាងអាស្រ័យកាយនេះ ក៏ចូរទ្រុឌទ្រោមទៅចុះ បាលិតៈ ហេតុអ្វី ទើបអ្នកប្រមាទ ។ ចក្ខុដែលអ្នកប្រកាន់ថារបស់ខ្លួន ចូរបែកទៅចុះ ត្រចៀកក៏បែកទៅចុះ រូបក៏ដូចគ្នាយ៉ាងនោះចុះ វត្ថុសព្វយ៉ាងអាស្រ័យកាយនេះ ក៏បែកទៅចុះ បាលិតៈ ហេតុអ្វី ទើបអ្នកប្រមាទ ។

កាលព្រះថេរៈឲ្យឱវាទដល់ខ្លួនឯងដោយ ៣ គាថាយ៉ាងនេះហើយ បានអង្គុយធ្វើនត្ថុកម្ម ហើយទើបចូលទៅស្រុកដើម្បីបិណ្ឌបាត គ្រូពេទ្យឃើញហើយ សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ធ្វើនត្ថុកម្មហើយឬ ។ ព្រះថេរៈពោលថា អើ ឧបាសក ។ គ្រូពេទ្យពោលថា តើអាការដូចម្តេចខ្លះ លោកម្ចាស់ ។ ព្រះថេរៈពោលថា នៅតែឈឺចាប់នោះឯងឧបាសក ។ គ្រូពេទ្យពោលថា លោកម្ចាស់អង្គុយបន្តក់ ឬសិងបន្តក់ ។ ព្រះថេរៈក៏នៅស្ងៀម ព្រះថេរៈសូម្បីគ្រូពេទ្យសួរហើយសួរទៀត ក៏មិនពោលអ្វីឡើយ ។ ខណៈនោះ គ្រូពេទ្យពោលជាមួយលោកថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនធ្វើសេចក្តីសប្បាយតាំងអំពីថ្ងៃនេះ សូមលោកម្ចាស់កុំបីពោលថា គ្រូពេទ្យឈ្មោះនោះចម្អិនប្រេងឲ្យអាត្មា ឯខ្ញុំក៏មិនពោលថា ខ្ញុំចម្អិនប្រេងប្រគេនលោកម្ចាស់ ។

ព្រះថេរៈត្រូវគ្រូពេទ្យបញ្ឈប់ហើយ ត្រឡប់ទៅកាន់វិហារត្រិះរិះថា អ្នក

សូម្បីគ្រូពេទ្យក៏ដកពាក្យហើយ អ្នកកុំបីលះឥរិយាបថនេះចោលឡើយ សមណៈ ហើយពោលទូន្មានខ្លួនដោយគាថាយ៉ាងនេះថា

ចាលិតៈ អ្នកត្រូវគ្រូពេទ្យបោះបង់ការព្យាបាលហើយ ទៀងចំពោះមច្ចុ-រាជ ហេតុអ្វី អ្នកនៅប្រមាទ ដូច្នេះហើយ បំពេញសមណធម៌ ។

លំដាប់នោះ លុះមជ្ឈិមឈាមកន្ទង់ហើយ ភ្នែកក្តី កិលេសក្តីរបស់លោក បែកព្រមគ្នាមិនមុនមិនក្រោយ លោកជាព្រះអរហន្តសុខវិបស្សកៈ ចូលទៅកាន់បន្ទប់គង់ហើយ ។

ក្នុងពេលភិក្ខាចារ ភិក្ខុទាំងឡាយទៅប្រាប់លោកថា បពិត្រលោកម្ចាស់ កាលនេះជាកាលភិក្ខាចារ ព្រះថេរៈពោលថា កាលឬ អាវុសោទាំងឡាយ ភិក្ខុទាំងឡាយពោលថា ពិតហើយលោកម្ចាស់ ព្រះថេរៈពោលថា បើដូច្នោះ អ្នកទាំងឡាយ ចូរទៅចុះ ភិក្ខុទាំងឡាយពោលថា ចុះលោកម្ចាស់វិញ ព្រះថេរៈពោលថា អាវុសោទាំងឡាយ ភ្នែករបស់ខ្ញុំវិនាសហើយ ។

ភិក្ខុទាំងឡាយមើលភ្នែករបស់ព្រះថេរៈហើយ មានភ្នែកពេញដោយទឹកភ្នែក លួងលោមព្រះថេរៈថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំគិតថ្វីឡើយ យើងខ្ញុំនឹងបដិបត្តិលោកម្ចាស់ ដូច្នេះហើយ ធ្វើវត្តដែលគួរធ្វើ ស្រេចហើយ ចូលទៅកាន់ស្រុក ។ ពួកមនុស្សមិនឃើញព្រះថេរៈ សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់របស់យើងខ្ញុំទៅឯណា បានឮដំណឹងនោះហើយ ក៏ផ្ញើបបរទៅប្រគេនមុនហើយ កាន់យកបិណ្ឌបាតទៅឯង ថ្វាយបង្គំព្រះថេរៈ ហើយទ្រហោយំបម្រះនៀលទៀបបាទរបស់ព្រះថេរៈ លួងលោមថា បពិត្រ

លោកម្ចាស់ យើងខ្ញុំទាំងឡាយនឹងទទួលបដិបត្តិ សូមលោកម្ចាស់កុំគិតថ្លៃឡើយ ហើយលាត្រឡប់ទៅ ។ តាំងអំពីនោះមក ជនទាំងនោះក៏បញ្ជូនបបរនិងផ្ការយ ទៅប្រគេនឯវិហារជានិច្ច ។

ចំណែកព្រះថេរៈ ក៏ពោលទូន្មានភិក្ខុ ៦០ រូប ក្រៅអំពីនេះជានិច្ច ។ ភិក្ខុទាំងឡាយតាំងនៅក្នុងឱវាទរបស់លោក លុះជិតថ្ងៃបវារណា ក៏សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាគ្រប់រូប ។

ភិក្ខុទាំងឡាយកាលចេញវស្សាហើយ ចង់គាល់ព្រះសាស្តា ទើបជ្រាប់ព្រះថេរៈថា យើងខ្ញុំចង់គាល់ព្រះសាស្តា ។

ព្រះថេរៈបានស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយហើយ គិតថា អាត្មាអញជាបុគ្គលទុព្វលភាព ហើយក្នុងរវាងផ្លូវព្រៃជ្រៅ ដែលអមនុស្សអាស្រ័យនៅក៏មាន បើអញទៅជាមួយភិក្ខុទាំងឡាយ លោកនឹងនាំគ្នាលំបាកមិនអាចបានសូម្បីភិក្ខា អញនឹងបញ្ជូនភិក្ខុទាំងនេះទៅមុន ។ លំដាប់នោះ ទើបលោកពោលនឹងភិក្ខុទាំងឡាយថា អាវុសោទាំងឡាយ ចូរអ្នកទាំងឡាយទៅមុនចុះ ភិក្ខុទាំងឡាយសួរថា ចុះលោកម្ចាស់វិញ ព្រះថេរៈពោលថា ខ្ញុំជាមនុស្សទុព្វលភាព ហើយក្នុងរវាងផ្លូវ ព្រៃជ្រៅដែលអមនុស្សអាស្រ័យនៅក៏មាន បើខ្ញុំទៅជាមួយអ្នកទាំងឡាយ អ្នកទាំងឡាយនឹងលំបាកទាំងអស់ អ្នកទាំង-ឡាយ ចូរទៅមុនចុះ ភិក្ខុទាំងឡាយពោលថា សូមលោកម្ចាស់កុំធ្វើយ៉ាងនេះឡើយ យើងខ្ញុំនឹងទៅជាមួយលោកម្ចាស់នោះឯង ព្រះថេរៈពោលថា អ្នកទាំងឡាយ កុំពេញចិត្តយ៉ាងនោះឡើយ បើយ៉ាងនោះការមិនមានសេចក្តី

សុខនីងមានដល់ខ្ញុំ ប្អូនប្រុសរបស់ខ្ញុំឃើញអ្នកទាំងឡាយហើយ គង់នីងសាក សួរ បើដូច្នោះ អ្នកទាំងឡាយ គប្បីប្រាប់ភាពដែលក្អែករបស់ខ្ញុំវិនាសហើយ ដល់គេ ប្អូនខ្ញុំគង់នីងបញ្ជូនអ្នកណាម្នាក់មកកាន់សម្នាក់របស់ខ្ញុំ ខ្ញុំនីងទៅជា មួយបុគ្គលនោះ អ្នកទាំងឡាយ ចូរថ្វាយបង្គំព្រះទសពល និងព្រះអសីតិ-មហាថេរៈតាមពាក្យរបស់ខ្ញុំ ដូច្នេះហើយ ក៏បញ្ជូនភិក្ខុទាំងនោះទៅ ។

ភិក្ខុទាំងឡាយសូមខមាទោសព្រះថេរៈហើយ ចូលទៅខាងក្នុងស្រុក ពួក មនុស្សនិមន្តឲ្យគង់ ថ្វាយភិក្ខាហើយសួរថា បពិត្រលោកម្ចាស់ មើល អាកប្បកិរិយារបស់លោកម្ចាស់ទាំងឡាយ ហាក់ដូចជាទៅណាហ្ន៎ ។

ភិក្ខុទាំងឡាយឆ្លើយថា អើ ឧបាសកទាំងឡាយ ពួកអាត្មាចង់គាល់ព្រះ សាស្តា ។ ពួកជនទាំងនោះអង្វរច្រើនលើកច្រើនសាហើយ ជ្រាបការពេញ ចិត្តក្នុងការដែលភិក្ខុទាំងឡាយចង់ទៅតែពីខាងបាន ទើបតាមជូនទៅ ហើយ យំរៀបរាប់ត្រឡប់មក ។

ចំណែកភិក្ខុទាំងឡាយ ទៅដល់វត្តជេតពនដោយលំដាប់ ថ្វាយបង្គំព្រះ សាស្តា និងព្រះមហាថេរៈទាំងឡាយតាមពាក្យរបស់ព្រះថេរៈហើយ លុះស្អែក ឡើងចូលទៅកាន់ផ្លូវដែលប្អូនប្រុសរបស់ព្រះថេរៈនៅ ដើម្បីបិណ្ឌបាត កុដុម្ពិកៈ ចាំភិក្ខុទាំងឡាយបាន និមន្តឲ្យគង់ធ្វើបដិសណ្ឋារៈ ហើយសួរថា ព្រះថេរៈ ដែលជាបងប្រុសរបស់ខ្ញុំនៅឯណា ។

លំដាប់នោះ ភិក្ខុទាំងឡាយប្រាប់ដំណឹងនោះដល់ចុល្លបាលហើយ ។ គាត់ទ្រហោយំ បម្រះនៀលទៀបជើងរបស់ភិក្ខុទាំងឡាយ សួរថា បពិត្រ

លោកម្ចាស់ ឥឡូវនេះ គួរធ្វើយ៉ាងណាល្អ ភិក្ខុទាំងឡាយពោលថា ព្រះថេរៈត្រូវការឲ្យបុគ្គលណាម្នាក់ទៅអំពីទីនេះ ក្នុងកាលទៅដល់ហើយ លោកនឹងមកជាមួយបុគ្គលនោះ ចុល្លបាលពោលថា បពិត្រលោកម្ចាស់ បុគ្គលនេះជាក្មួយរបស់ខ្ញុំឈ្មោះចូលិតៈ សូមលោកម្ចាស់ទាំងឡាយបញ្ជូនបុគ្គលនេះទៅចុះ ភិក្ខុទាំងឡាយពោលថា បញ្ជូនទៅយ៉ាងនេះមិនបាន អន្តរាយក្នុងផ្លូវមាន ត្រូវឲ្យបួសជាមុន ហើយបញ្ជូនទៅ ទើបគួរ ។ ចុល្លបាលពោលថា សូមលោកម្ចាស់ទាំងឡាយធ្វើយ៉ាងនោះហើយ បញ្ជូនទៅចុះ ។ គ្រានោះ ភិក្ខុទាំងឡាយឲ្យក្មួយនោះបួសហើយ បង្រៀនឲ្យសិក្សាវត្តបដិបត្តិ មានទទួលចីវរជាដើមអស់កន្លះខែហើយ ប្រាប់ផ្លូវហើយ បញ្ជូនទៅ ។

សាមណេរដល់ស្រុកនោះដោយលំដាប់ ឃើញបុរសដឹងក្តីម្នាក់ត្រង់ទ្វារស្រុក ទើបសួរថា វិហារព្រៃណាមួយអាស្រ័យស្រុកនេះមានឬ ជននោះឆ្លើយថា មានលោកម្ចាស់ សាមណេរសួរថា អ្នកណានៅក្នុងទីនោះ ជននោះពោលថា ព្រះថេរៈឈ្មោះចូលិតៈលោកម្ចាស់ សាមណេរពោលថា សូមអ្នកប្រាប់ផ្លូវដល់អាត្មាបន្តិចចុះ ជននោះពោលថា លោកម្ចាស់ត្រូវជាអ្វីនឹងលោក សាមណេរពោលថា អាត្មាជាក្មួយរបស់ព្រះថេរៈ ។

ខណៈនោះ អ្នកស្រុកនោះនាំសាមណេរទៅកាន់វិហារហើយ ។ លោកថ្វាយបង្គំព្រះថេរៈ ហើយធ្វើវត្តបដិបត្តិបម្រើព្រះថេរៈដោយល្អ អស់កន្លះខែហើយ ពិតថា បពិត្រលោកម្ចាស់ កុដុម្ពិកៈជាអ៊ំរបស់ខ្ញុំត្រូវការឲ្យលោកម្ចាស់ត្រឡប់ទៅ សូមលោកម្ចាស់ទៅជាមួយខ្ញុំចុះ ។

ព្រះថេរៈពោលថា បើយ៉ាងនោះ ចូរអ្នកចាប់ចុងឈើច្រត់របស់ខ្ញុំចុះ ។ សាមណេរចាប់ចុងឈើច្រត់ ចូលទៅខាងក្នុងស្រុកជាមួយព្រះថេរៈ ។ ពួកមនុស្សនិមន្តឲ្យគង់ហើយ សាកសួរថា បពិត្រលោកម្ចាស់មើលឫកហាក់ដូចជាចង់និមន្តទៅណាទេដឹង ព្រះថេរៈឆ្លើយថា អើ ឧបាសក និងឧបាសិកាទាំងឡាយ អាត្មានឹងទៅថ្វាយបង្គំព្រះសាស្តា ពួកមនុស្សទាំងនោះអង្វរដោយប្រការផ្សេងៗ កាលមិនបានដូចបំណង ក៏ជូនព្រះថេរៈទៅដល់ពាក់កណ្តាលផ្លូវហើយ នាំគ្នាទ្រហោយំ ត្រឡប់មក ។

សាមណេរនាំព្រះថេរៈដោយចុងឈើច្រត់ទៅ ដល់ស្រុកដែលព្រះថេរៈធ្លាប់អាស្រ័យឈ្មោះសង្កជ្ជៈ ក្នុងព្រៃរវាងផ្លូវ ។ សាមណេរបានឮសំឡេងស្រីម្នាក់ ដែលចេញអំពីស្រុកនោះហើយ ច្រៀងបណ្តើរ រកឧសបណ្តើរក្នុងព្រៃ កាន់យកនិមិត្តក្នុងសំឡេងហើយ ។

មែនពិត មិនមានសំឡេងដទៃឈ្មោះថាអាចផ្សាយទៅពេញសរីរៈរបស់បុរសទាំងឡាយ តាំងនៅដូចសំឡេងស្រីទ្បើយ ហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ (ក្នុងអង្គុត្តរនិកាយ ឯកនិបាត) ថា

> *ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសំឡេងដទៃសូម្បីតែសំឡេង ១ ដែលគ្របសង្កត់ចិត្តបុរសហើយឋិតនៅដូចសំឡេងស្ត្រីនេះសោះទ្បើយ ម្នាលភិក្ខុទាំងឡាយ សំឡេងស្ត្រី ទើបអាចគ្របសង្កត់ចិត្តបុរស ហើយឋិតនៅ ។*

សាមណេរកាន់យកនិមិត្តក្នុងសំឡេងនោះហើយ លែងចុងឈើច្រត់ចោល ហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បង្អង់ចាំសិនកិច្ចរបស់ខ្ញុំមាន ដូច្នេះហើយ ទៅកាន់សម្នាក់របស់ស្រីនោះ ។ នាងឃើញសាមណេរហើយ បានឈប់ស្ងៀម ។ សាមណេរដល់នូវសីលវិបត្តិជាមួយនាងហើយ ។ ព្រះថេរៈគិតថា អាត្មាអញបានឮសំឡេងច្រៀងឯណាមួយអម្បាញ់មិញនេះឯង ឯសំឡេងនោះ គង់ជាសំឡេងស្រី សូម្បីសាមណេរក៏ឃឺតយូរ សាមណេរនឹងដល់នូវសីលវិបត្តិដោយពិត ។ ចំណែកសាមណេរនោះធ្វើកិច្ចរបស់ខ្លួនស្រេចហើយមកដល់ ពោលថា បពិត្រលោកម្ចាស់ យើងទាំងឡាយ ទៅជាមួយគ្នាចុះ ។

ខណៈនោះ ព្រះថេរៈសួរថា នែសាមណេរ អ្នកក្លាយជាមនុស្សអាក្រក់ហើយមែនឬ សាមណេរក៏ស្ងៀមនៅ ព្រះថេរៈសួរដដែលក៏មិនពោលពាក្យណាមួយឡើយ ។

លំដាប់នោះ ព្រះថេរៈពោលនឹងសាមណេរថា ធុរៈដោយការដែលមនុស្សអាក្រក់ដូចអ្នកចាប់ចុងឈើច្រត់របស់ខ្ញុំមិនមាន ។ សាមណេរដល់នូវសេចក្តីសង្វេគហើយ ដោះនូវសំពត់កាសាវៈចេញហើយ ស្លៀកដណ្តប់តាមបែបគ្រហស្ថពោលថា បពិត្រលោកម្ចាស់ កាលមុនខ្ញុំជាសាមណេរ តែឥឡូវនេះខ្ញុំជាគ្រហស្ថហើយ ។ ម្យ៉ាងទៀត ខ្ញុំកាលបួសក៏មិនបានបួសដោយសទ្ធា បួសព្រោះខ្លាចចំពោះអន្តរាយក្នុងវាងផ្លូវ សូមលោកម្ចាស់ទៅជាមួយខ្ញុំចុះ ។

ព្រះថេរៈពោលថា នែអ្នកគ្រហស្ថអាក្រក់ក្តី សាមណេរអាក្រក់ក្តី ក៏អាក្រក់ដូចតែគ្នា អ្នកសូម្បីតាំងនៅក្នុងភាពជាសមណៈហើយ មិនអាចធ្វើគុណ

ត្រឹមតែសីលឲ្យបរិសុទ្ធ ទម្រាំជាគ្រហស្ថនឹងធ្វើកល្យាណកម្មអ្វីបាន ធុរៈដោយការដែលមនុស្សអាក្រក់ដូចអ្នក ចាប់ចុងឈើច្រត់របស់អាត្មាមិនមាន ។

នាយបាលិតៈឆ្លើយថា បពិត្រលោកម្ចាស់ ផ្លូវមានអមនុស្ស លោកម្ចាស់ក៏ខូចក្អែកនឹងនៅទីនេះបានដូចម្តេច ។

លំដាប់នោះ ព្រះថេរៈពោលថា នែអ្នក អ្នកកុំគិតយ៉ាងនេះឡើយ អាត្មាដេកស្ងាប់ក្នុងទីនេះក្តី ដេកបម្រះនទៀលក្នុងទីនេះក្តី ឈ្មោះថា ការទៅជាមួយអ្នក មិនមាន ។ ហើយបានពោលគាថានេះថា

> *ណ្ហើយចុះ ខ្ញុំជាអ្នកមានក្អែកខូចហើយ មកកាន់ផ្លូវកន្តារដេកក្តី នឹងមិនទៅព្រោះភាពជាសម្ងាញ់ក្នុងជនពាល រមែងមិនមាន ។ ណ្ហើយចុះ ខ្ញុំជាបុគ្គលមានចក្ខុវិនាសហើយ មកកាន់ផ្លូវកន្តារ ទោះស្ងាប់ក៏មិនទៅ ព្រោះភាពជាសម្ងាញ់ក្នុងជនពាល រមែងមិនមាន ។*

នាយបាលិតៈបានឮពាក្យនោះហើយ កើតនូវសេចក្តីសង្វេគគិតថា អញធ្វើកម្មដ៏ប្រព្រឹត្តទៅដោយរហ័ស មិនសមគួរហ្ន៎ ដូច្នេះហើយ ឱបដៃខ្សឹក-ខ្សួលរត់ចូលកាន់ព្រៃចៀសចេញទៅ ដោយប្រការនោះឯង ។

ដោយតេជៈនៃសីលរបស់ព្រះថេរៈ បណ្តាកម្ពលសីលាអាសនៈរបស់សក្កទេវរាជ បណ្តាយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្រាស់ ១៥ យោជន៍ មានពណ៌ដូចផ្កាជ័យព្រឹក មានប្រក្រតីទ្រុឌចុះក្នុងពេលប្រថាប់គង់ និងប៉ោងឡើងក្នុងពេលក្រោកឡើង សម្តែងអាការក្តៅហើយ ។

សក្កទេវរាជទ្រង់ព្រះតម្រិះថា នរណាហ្ន៎ ប្រាប់ឲ្យអាត្មាអញឃ្លាតចាកស្ថាន ដូច្នេះហើយ ទ្រង់សម្ងឹងចុះមក បានឃើញព្រះថេរៈដោយទិព្វចក្ខុ ។

ហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា

ស្តេចសហស្សនេត្រ ជាស្តេចនៃទេវតា បញ្ជូនទិព្វចក្ខុ ទ្រង់ជ្រាបថា ព្រះបាលត្ថេរអង្គនេះ តិះដៀលបុគ្គលអាក្រក់ ជម្រះគ្រឿងចិញ្ចឹមជីវិតឲ្យបរិសុទ្ធហើយ ស្តេចសហស្សនេត្រ ជាស្តេចនៃទេវតា បញ្ជូនទិព្វចក្ខុទ្រង់ជ្រាបថា ព្រះបាលត្ថេរអង្គនេះ ធ្ងន់ក្នុងធម៌ ត្រេកអរក្នុងសាសនាគង់នៅហើយ ។

ខណៈនោះ សក្កទេវរាជទ្រង់ព្រះតម្រិះថា បើអាត្មាអញមិនទៅកាន់សម្នាក់របស់លោកម្ចាស់ដែលជាអ្នកតិះដៀលបុគ្គលបាប ជាអ្នកធ្ងន់ក្នុងធម៌បែបនេះ ក្បាលរបស់អញគប្បីបែកជា ៧ ភាគ អញនឹងទៅកាន់សម្នាក់របស់លោក ។

ហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា

ស្តេចសហស្សនេត្រជាស្តេចនៃទេវតា ទ្រទ្រង់នូវសិរីរបស់ទេវរាជ ទ្រង់យាងមកក្នុងខណៈនោះហើយ ចូលទៅជិតព្រះចក្ខុបាលត្ថេរហើយ ។

កាលទ្រង់យាងចូលទៅជិតហើយ ទ្រង់បានធ្វើសំឡេងជើងក្នុងទីជិតព្រះថេរៈ ។ ខណៈនោះ ព្រះថេរៈសួរថា នេះជាអ្នកណាហ្ន៎ សក្កទេវរាជឆ្លើយថា ខ្ញុំជាអ្នកជំណើរលោកម្ចាស់ ព្រះថេរៈពោលថា អ្នកទៅណាឧបាសក សក្ក-

ទេវរាជពោលថា ទៅក្រុងសាវត្ថី ព្រះថេរៈពោលថា ទៅចុះអ្នក ព្រះឥន្ទ្រ ពោលថា ចុះលោកម្ចាស់វិញនិមន្តទៅណា ព្រះថេរៈពោលថា អាត្មាក៏ទៅក្នុងទីនោះដូចគ្នា ព្រះឥន្ទ្រពោលថា បើយ៉ាងនោះយើងទាំងឡាយទៅជាមួយគ្នាចុះ ព្រះថេរៈពោលថា អាត្មាជាមនុស្សទុព្វលភាព ការយឺតយូរនឹងមានដល់អ្នកដែលទៅជាមួយអាត្មា ។ ព្រះឥន្ទ្រពោលថា កិច្ចប្រញាប់ប្រញាល់របស់ខ្ញុំមិនមាន បើខ្ញុំទៅជាមួយលោកម្ចាស់នឹងបានទូវបុញ្ញកិរិយាវត្ថុ ១០ ណាមួយ បពិត្រលោកម្ចាស់ យើងទៅជាមួយគ្នាចុះ ។

ព្រះថេរៈគិតថា នេះប្រហែលជាសប្បុរស ទើបពោលថា បើយ៉ាងនោះចូរចាប់ចុងឈើច្រត់ចុះ ។

សក្កទេវរាជធ្វើយ៉ាងនោះហើយ បង្ហូរញើសដីឲ្យដល់វត្តជេតពនក្នុងពេលល្ងាច ។

ព្រះថេរៈបានស្តាប់សំឡេងប្រគំ មានសង្ខ និងស្គរតូចជាដើម ហើយសួរថា នុ៎ះជាសំឡេងទីណា ព្រះឥន្ទ្រពោលថា ក្នុងក្រុងសាវត្ថីលោកម្ចាស់ ព្រះថេរៈពោលថា ក្នុងកាលទៅអាត្មាទៅអស់កាលយូរ ព្រះឥន្ទ្រពោលថា ខ្ញុំស្គាល់ផ្លូវត្រង់លោកម្ចាស់ ។

ក្នុងខណៈនោះ ព្រះថេរៈកំណត់បានថា បុគ្គលនេះមិនមែនមនុស្ស ពិតជាទេវតា ព្រោះហេតុនោះ ទើបបុរាណាចារ្យពោលថា ។

ស្តេចសហស្សនេត្រ ជាស្តេចនៃទេវតា ទ្រទ្រង់នូវសិរីរបស់

ទេវរាជ បង្ហូរញើសនោះ ទ្រង់យាងមកដល់ក្រុងសាវត្ថីហើយ ។

ព្រះឥន្ទ្រនាំព្រះថេរៈទៅកាន់បណ្ណសាលា ដែលកុដុម្ពិកៈជាបុនធ្វើដើម្បីប្រយោជន៍ដល់ព្រះថេរៈនោះហើយ និមន្តឲ្យគង់លើបន្ទះក្តារ ហើយក្លែងខ្លួនជាសម្ងាញ់ ជាទីស្រឡាញ់ទៅកាន់សម្នាក់របស់ចុល្លបាលកុដុម្ពិកៈ ត្រាស់ហៅថា នែបាលៈសម្ងាញ់ បាលកុដុម្ពិកៈស្រែកសួរថា មានការអ្វីសម្ងាញ់ ឥន្ទ្រនិម្មិតពោលថា ឯងដឹងភាពដែលព្រះថេរៈមកហើយឬនៅ ចុល្លបាលពោលថា ខ្ញុំមិនទាន់ដឹងទេ ព្រះថេរៈមកហើយឬ ទេវរាជត្រាស់ថា អើសម្ងាញ់ខ្ញុំទៅវិហារឃើញព្រះថេរៈគង់ក្នុងបណ្ណសាលាដែលឯងធ្វើ មកហើយ អម្បាញ់មិញនេះឯង ដូច្នេះហើយ ទ្រង់ចៀសចេញទៅ ។

ចំណែកកុដុម្ពិកៈ ទៅដល់វិហារឃើញព្រះថេរៈហើយ ទ្រហោយំបម្រះនៀលទៀបបាទជើងពោលថា បពិត្រលោកម្ចាស់ ខ្ញុំឃើញហេតុនេះហើយទើបមិនព្រមឲ្យលោកម្ចាស់បួស ដូច្នេះជាដើមហើយ ធ្វើកុមារដែលជាទាសៈពីរនាក់ឲ្យជាអ្នកជា ឲ្យបួសក្នុងសម្នាក់របស់ព្រះថេរៈហើយ ប្រាប់ថា អ្នកទាំងឡាយ ចូរនាំរបស់ធាន់ មានបបរ និងបាយជាដើម មកអំពីខាងក្នុងផ្ទះឧបដ្ឋាកព្រះថេរៈចុះ ដូច្នេះហើយ ប្រគល់ឲ្យ ។ សាមណេរទាំងឡាយធ្វើវត្តបដិបត្តិ ឧបដ្ឋាកព្រះថេរៈហើយ ។

ថ្ងៃមួយ ក្នុងកាលជាខាងក្រោយ ភិក្ខុទាំងឡាយដែលនៅក្នុងទិសដទៃមកកាន់វត្តជេតពន ដោយបំណងគាល់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តា សួរសុខទុក្ខព្រះអសីតិមហាថេរៈហើយ ត្រាច់ចារិកក្នុងវិហារដល់លំនៅរបស់ព្រះចក្ខុបាលត្ថេរហើយ មានមុខឆ្ពោះទៅកាន់ទីនោះក្នុងពេលល្ងាច ដោយបំណង

ថា នឹងមើលទីនេះ ។

ក្នុងខណៈនោះ មហាមេឃតាំងឡើង ពួកលោកគិតថា ឥឡូវនេះ ល្ងាចណាស់ហើយ មេឃក៏តាំងឡើងហើយ អញនឹងមកមើលអំពីព្រឹក ដូច្នេះហើយ ត្រឡប់ទៅ ។ ភ្លៀងធ្លាក់ក្នុងបឋមយាម រាំងក្នុងមជ្ឈិមយាម ។ ព្រះថេរៈជាអ្នកធ្លាប់ប្រារព្ធសេចក្តីព្យាយាម និមន្តចង្រ្កមជានិច្ចកាល ហេតុនោះទើបចុះកាន់ទីចង្រ្កមហើយ ក្នុងបច្ឆិមយាម ។ ក្នុងកាលនោះ មេភ្លៀងជាច្រើន តាំងឡើងហើយលើផែនដីដែលភ្លៀងធ្លាក់ថ្មី ។ សត្វល្អិតទាំងនោះ កាលព្រះថេរៈចង្រ្កម ក៏ជល់នូវសេចក្តីវិបត្តិ គឺស្លាប់ដោយច្រើន ។

ពួកអន្តេវាសិក មិនទាន់ជ្រាបទីចង្រ្កមរបស់ព្រះថេរៈអំពីព្រលឹម ។ ឯពួកភិក្ខុក្រៅអំពីនេះ មកដោយបំណងថា នឹងមើលលំនៅរបស់ព្រះថេរៈ ឃើញសត្វល្អិតទាំងឡាយក្នុងទីចង្រ្កមហើយសួរថា លោកម្ចាស់អង្គណាចង្រ្កមក្នុងទីនេះ ។ ពួកអន្តេវាសិករបស់ព្រះថេរៈឆ្លើយថា ឧបជ្ឈាយ៍របស់ពួកខ្ញុំលោកម្ចាស់ ។ ភិក្ខុទាំងឡាយនោះតិះដៀលថា លោកទាំងឡាយចូរមើលកម្មរបស់សមណៈចុះ ក្នុងកាលមានភ្លៀក លោកដេកលក់មិនធ្វើអ្វី ក្នុងកាលមានចក្ខុពិការ ឥឡូវនេះ បែរជាចង្រ្កមធ្វើសត្វមានប្រមាណជល់ម៉្លេះឲ្យស្លាប់ហើយ លោកគិតថា នឹងធ្វើប្រយោជន៍ បែរជាធ្វើការគ្មានប្រយោជន៍ទៅវិញ ។

ភិក្ខុទាំងនោះ ទៅក្រាបទូលព្រះតថាគតហើយក្នុងខណៈនោះថា បពិត្រព្រះអង្គ ព្រះចក្ខុបាលត្តេរយកលេសថាចង្រ្កម ធ្វើសត្វមានជីវិតជាច្រើនឲ្យស្លាប់ហើយ ។

ព្រះសាស្តាត្រាស់សួរថា អ្នកទាំងឡាយឃើញលោកកំពុងធ្វើសត្វមានជីវិតជាច្រើនឲ្យស្លាប់ហើយឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ មិនបានឃើញទេ ។ ព្រះសាស្តាត្រាស់ថា អ្នកទាំងឡាយមិនឃើញលោក យ៉ាងណា ឯលោកក៏មិនឃើញសត្វមានជីវិតទាំងនោះដូច្នោះ ។ ម្នាលភិក្ខុទាំងឡាយ ចេតនាជាហេតុឲ្យស្លាប់របស់ព្រះខីណាស្រពទាំងឡាយមិនមាន ។ ភិក្ខុទាំង-ឡាយទូលសួរថា បពិត្រព្រះអង្គ កាលឧបនិស្ស័យនៃអរហត្តមាន ហេតុអ្វីទើបលោកក្លាយជាបុគ្គលមានចក្ខុងងឹតហើយ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រោះអំណាចកម្មដែលខ្លួនធ្វើទុកហើយ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ តើលោកបានធ្វើកម្មអ្វីមកហើយ ។

បុព្វកម្មរបស់ព្រះចក្ខុបាលត្ថេរ

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើយ៉ាងនោះ អ្នកទាំងឡាយចូរស្តាប់ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល ព្រះបាទពារាណសីគ្រងរាជ្យក្នុងក្រុងពារាណសី ។ គ្រូពេទ្យម្នាក់ត្រាច់ធ្វើវេជ្ជកម្មក្នុងស្រុក និងនិគម ឃើញស្ត្រីទុព្វលដោយចក្ខុម្នាក់ ទើបសួរថា ការមិនផាសុករបស់នាងដូចម្តេច ស្រីនោះឆ្លើយថា ខ្ញុំមិនឃើញដោយភ្នែក គ្រូពេទ្យពោលថា ខ្ញុំនឹងព្យាបាលឲ្យនាង ស្រីនោះពោលថា សូមព្យាបាលចុះ គ្រូពេទ្យពោលថា នាងនឹងឲ្យអ្វីដល់ខ្ញុំ ស្រីនោះពោលថា បើអ្នកអាចធ្វើភ្នែករបស់ខ្ញុំឲ្យដូចប្រក្រតីបាន ខ្ញុំ កូនប្រុស និងកូនស្រី នឹងព្រមធ្វើជាទាសីរបស់អ្នក គ្រូពេទ្យទទួលថា សាធុ ដូច្នេះហើយ ប្រកបថ្នាំឲ្យហើយ

ក្អែកក៏ជាដួចប្រក្រតី ដោយថ្នាំមួយដងប៉ុណ្ណោះ ។

ស្រីនោះគិតហើយថា អញបានប្តេជ្ញាដល់ពេទ្យនោះថា អាតា្មអញ មួយអន្ទើដោយកូនប្រុសកូនស្រី ព្រមធ្វើជាទាសីរបស់គាត់ គាត់ទឹងមិនហៅអញដោយវាចាពីរោះ អញទឹងបោកបញ្ឆោតគាត់ ពេលគ្រូពេទ្យមកហើយសួរថា អាការដួចម្តេចទៅហើយ នាងឆ្លើយថា ពីមុនក្អែករបស់ខ្ញុំឈឺតិចៗ ឥឡូវនេះ ឈឺខ្លាំងពន់ពេក ។ គ្រូពេទ្យគិតថា ស្រីនេះបំណងទឹងបោកអញ ហើយមិនឲ្យវត្ថុណាមួយ សេចក្តីត្រូវការរបស់អញដោយឈ្នួលដែលស្រីនេះឲ្យដល់អញមិនមាន អញទឹងធ្វើឲ្យស្រីនេះខ្វាក់ក្អែកឥឡូវនេះ ហើយទៅដល់ផ្ទះប្រាប់សេចក្តីនោះដល់ភរិយា នាងក៏នៅស្ងៀម ។ ពេទ្យនោះ ផ្សំថ្នាំមួយមុខទៀត ហើយទៅកាន់សម្នាក់ស្រីនោះ ប្រាប់ឲ្យបន្តក់ថា នែនាង ចូរនាងបន្តក់ថ្នាំនេះ ។ ក្អែកទាំងពីរបានរលត់ហើយ ដូចអណ្តាតភ្លើង ។ គ្រូពេទ្យនោះ បានមកកើតជាចក្ខុបាលភិក្ខុហើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កម្មដែលបុត្ររបស់តថាគតធ្វើហើយក្នុងកាលនោះ ជាប់តាមលោកអំពីខាងក្រោយ ។ មែនពិត ឈ្មោះថាបាបកម្មនេះ រមែងតាមបុគ្គលអ្នកធ្វើ ដូចកង់រទេះវិលតាមស្នាមជើងគោដែលនាំធុរៈទៅ ដូច្នោះ ។ កាលត្រាស់រឿងនេះហើយ ព្រះធម្មរាជាបានត្រាស់ព្រះគាថានេះបន្តអនុសន្ធិដួចប្រថាប់រាជសាសន៍ដោយត្រាស់ថា

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា

មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា

តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមជានជើងគោដែលកំពុងអូសទៅ ។

សេចក្តីអធិប្បាយ

ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ មានកាមាវចរចិត្តជាដើម ឈ្មោះថា មនោ ក្នុងព្រះគាថានេះ តែក្នុងបទនេះកាលនិយម ប៉ាន់ស្មាន់ កំណត់ចុះដោយអំណាចចិត្តដែលកើតឡើងដល់គ្រូពេទ្យនោះ ក្នុងគ្រានោះ រមែងបានចំពោះចិត្តដែលប្រព្រឹត្តទៅដោយទោមនស្ស ប្រកបដោយបដិឃៈតែម្យ៉ាង ។

បទថា **បុព្ពង្គមា** *គឺឈ្មោះថា មកតាមព្រមដោយចិត្តនោះ ដែលជាប្រធាន ទៅមុន ។*

បទថា **ធម្មា** *គឺឈ្មោះថា ធម៌ ៤ យ៉ាង ដោយអំណាចគុណធម៌ ទេសនាធម៌ បរិយត្តិធម៌ និងនិស្សត្តនិជ្ជីវធម៌ ។ ក្នុងធម៌ ៤ ប្រការនោះ* **ធម្ម** *សព្ទ ក្នុងពាក្យថា*

នហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ

អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតឹ ។

សភាវៈទាំងពីរ គឺកុសលធម៌ ១ អកុសលធម៌ ១ មិនមែន

មានផលស្មើគ្នាទេ អកុសលធម៌ នាំសត្វទៅកាន់នរក

កុសលធម៌ ញុាំងសត្វឲ្យដល់ នូវសុគតិ ។

ដូច្នេះ ឈ្មោះថា គុណធម៌ ។ **ធម្ម** *សព្ទ ក្នុងពាក្យថា* **ធម្មំ ភោ ភិក្ខវេ តេសិស្សាមិ អាទិកល្យាណំ** *ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ ដែលមានលម្អបទដើម ... ដល់អ្នកទាំងឡាយ ។ ដូច្នេះជាដើម ឈ្មោះថា ទេសនាធម៌ ។* **ធម្ម** *សព្ទ ក្នុងពាក្យថា* **ឥធ ភិក្ខុ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ** *ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ រៀនទូវធម៌ គឺសុត្តៈ គេយ្យៈ ។បេ។ ដូច្នេះជាដើម ឈ្មោះថា បរិយត្តិធម៌ ។* **ធម្ម** *សព្ទ ក្នុងពាក្យថា* **តស្មឹ ខោ បន សមយេ ធម្មា ហោន្តិ ខន្ធា ហោន្តិ** *ពួកធម៌កើតមានក្នុងសម័យនោះ ពួកខន្ធកើតមានក្នុងសម័យនោះ ។ ដូច្នេះជាដើម ឈ្មោះថា និស្សត្តធម៌ គឺធម៌មានសភាពមិនមែនសត្វ នយក្នុងបទថា និជ្ជីវធម៌ គឺធម៌មិនមែនជីវិត ក៏ដូចគ្នា ។ ក្នុងធម៌ ៤ ប្រការនោះ និស្សត្តធម៌ ឬនិជ្ជីវធម៌ ព្រះសាស្តាទ្រង់បំណងយកក្នុងទីនេះ ។ និស្សត្តធម៌ និងនិជ្ជីវធម៌នោះ ដោយអត្ថ បានដល់អរូបក្ខន្ធ ៣ គឺវេទនាក្ខន្ធ សញ្ញាក្ខន្ធ សង្ខារក្ខន្ធ ។ ព្រោះថា អរូបក្ខន្ធ ៣ ប្រការនោះ មានចិត្តជាប្រធាន ។*

មានពាក្យសួរថា ចិត្ត មានវត្ថុដូចគ្នា មានអារម្មណ៍តែមួយ កើតក្នុងខណៈតែមួយ ជាមួយធម៌ទាំងនោះ មិនមុនមិនក្រោយ តើជាប្រធានរបស់ធម៌ទាំងនោះបានដូចម្តេច ។

មានពាក្យឆ្លើយថា ចិត្ត បានឈ្មោះថា ជាប្រធាននៃធម៌ទាំងនោះ ដោយ

អត្ថថា ជាបច្ចយញ្ជាំងធម៌ឲ្យកើតឡើង ឧបមាដូចពួកចោរជាច្រើន ធ្វើចោរ-កម្ម មានប្អូនស្រុកជាដើមទាំងអស់នេះ កាលមានបុគ្គលសួរថា អ្នកណាជាមេរបស់ពួកវា អ្នកណាជាបច្ចយរបស់ពួកវា គឺអាស្រ័យអ្នកណា ទើបធ្វើកម្ម នោះបាន បុគ្គលនោះ ឈ្មោះទត្តៈក្តី មត្តៈក្តី គេហៅថា ជាមេរបស់ចោរ យ៉ាងណា ពាក្យឧបមេយ្យដែលជាគ្រឿងឲ្យអត្ថដល់ព្រមនេះ បណ្ឌិតគប្បីដឹងច្បាស់ ដូច្នោះ ។ ចិត្ត ឈ្មោះថា ជាប្រធាននៃធម៌ទាំងឡាយនោះ ដោយអត្ថថា ជាបច្ចយ ញ្ជាំងធម៌ឲ្យកើតឡើង ដូច្នេះ ហេតុនោះ ធម៌ទាំងឡាយនោះ ឈ្មោះថា មានចិត្តជាប្រធាន ។ ព្រោះកាលចិត្តមិនកើតឡើង ធម៌ទាំងនោះរមែងមិនអាចកើតឡើងបាន ។ ចំណែកចិត្ត ទោះចេតសិកធម៌ពួកខ្លះមិនកើតឡើង ក៏រមែងកើតឡើងបានពិត ។ ម្យ៉ាងទៀត ចិត្ត ឈ្មោះថាជាធំនៃធម៌ទាំងឡាយនោះ ដោយអំណាចជាអធិបតិ ហេតុនោះ ទើបធម៌ទាំងឡាយនោះ ឈ្មោះថា មានចិត្តជាធំ ។ ឧបមាដូចជនទាំងឡាយ មានចោរដែលជាមេជាដើមជាអធិបតិ បានឈ្មោះថា ជាធំនៃជនទាំងឡាយ មានចោរជាដើមយ៉ាងណា ចិត្តជាអធិបតិបាន ឈ្មោះថា ជាធំនៃធម៌ទាំងនោះ ដូច្នោះ ។ ហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា មានចិត្តជាធំ ។ ម្យ៉ាងទៀត វត្ថុទាំងឡាយនោះ។ សម្រេចហើយដោយវត្ថុ មានឈើជាដើម ក៏ឈ្មោះថា របស់សម្រេចហើយ ដោយឈើជាដើម យ៉ាងណា សូម្បីធម៌ទាំងឡាយនោះ បានឈ្មោះថា សម្រេចហើយដោយចិត្ត ព្រោះសម្រេចមកអំពីចិត្ត ដូច្នោះ ។

បទថា **បទុដ្ឋេន** *គឺដែលទោស មានអកិរិយាជាដើម ចូលមកប្រទូស្ត*

ហើយ ។ មែនពិត ចិត្តប្រក្រតី ឈ្មោះថា កវង្គចិត្ត កវង្គចិត្តនោះ មិនត្រូវ ទោសប្រទូស្តហើយ ។ ឧបមាដូចទឹកថ្លាសៅហ្មងហើយ ព្រោះពណ៌ទាំង-ទ្បាយ មានពណ៌ខៀវជាដើមចូលមក ក៏បែរជាទឹកមានពណ៌ខៀវជាដើម ឈ្មោះថា ជាទឹកថ្មីក៏មិនមែន ឈ្មោះថា ទឹកថ្លាដូចពីដើមនោះ ក៏មិនមែន យ៉ាងណា កវង្គចិត្តនោះ ដែលទោសមានអកិជ្ឈាជាដើម ចូលមកប្រទូស្ត ហើយ ឈ្មោះថា ជាចិត្តថ្មីក៏មិនមែន ឈ្មោះថា ជាកវង្គចិត្តដូចពីមុននោះ ក៏មិនមែន ដូច្នោះ ហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ទាំងទ្បាយ ចិត្តនេះផូរផង់ តែសៅហ្មងហើយ ព្រោះឧបក្កិលេសទាំងទ្បាយ ចូលមកហើយ ដូច្នេះ ។ បើបុគ្គលមានចិត្តប្រទូស្តហើយយ៉ាងនេះ ។

បាទព្រះគាថាថា **ភាសតិ វា ករោតិ វា** *គឺកាលបុគ្គលពោល រមែងពោលចំពោះតែវចីទុច្ចរិត ៤ យ៉ាង ។ កាលធ្វើ រមែងធ្វើចំពោះតែកាយទុច្ចរិត ៣ យ៉ាង កាលមិនពោល មិនធ្វើ ព្រោះភាពដែលខ្លួនជាបុគ្គលមានចិត្តដែលទោស មានអកិជ្ឈាជាដើមប្រទូស្តហើយនោះ រមែងធ្វើមនោទុច្ចរិត ៣ ឲ្យពេញ ។ អកុសលកម្មបថ ១០ របស់បុគ្គលនោះ រមែងដល់នូវការពេញដោយប្រការយ៉ាងនេះ ។*

បាទព្រះគាថាថា **តតោ នំ ទុក្ខមន្វេតិ** *សេចក្តីថា ទុក្ខរមែងតាមបុគ្គលនោះទៅ ព្រោះទុច្ចរិត ៣ យ៉ាងនោះ គឺទុក្ខដែលជាផលប្រព្រឹត្តទៅក្នុងកាយផង ប្រព្រឹត្តទៅក្នុងចិត្តផង ដោយបរិយាយនេះថា ទុក្ខ មានកាយជាទីតាំង ខ្លះ ទុក្ខ មានចិត្តក្រៅអំពីនេះជាទីតាំងខ្លះ រមែងទៅតាមអត្តភាពនោះ បុគ្គល*

ទៅក្នុងអបាយ ៤ ក្តី ក្នុងពួកមនុស្សក្តី ព្រោះអានុភាពនៃទុច្ចរិត ។

មានពាក្យសួរថា ទុក្ខរមែងជាប់តាមបុគ្គលនោះដូចអ្វី ។ មានពាក្យឆ្លើយថា ដូចកង់វិលទៅតាមស្នាមជើងរបស់គោដែលអូសរទេះទៅ អធិប្បាយថា ដូចកង់រទេះទៅតាមស្នាមជើងរបស់គោដែលគេទឹមត្រង់នឹម ហើយនាំនឹមទៅ ដូច្នោះ ទោះគោនោះអូសទៅមួយថ្ងៃក្តី ពីរថ្ងៃក្តី ដប់ថ្ងៃក្តី កន្ទុះខែក្តី រមែងមិនអាចឲ្យកង់រទេះវិលត្រឡប់ គឺមិនអាចលះបង់កង់ទៅបានដោយពិត កាលគោឈានជើងទៅខាងមុខ នឹមក៏ជាប់ករបស់គោ កាលគោថយក្រោយ កង់ក៏កកិតត្រង់សាច់ស្មង កង់បៀតបៀនដោយហេតុពីរប្រការនេះ វិលតាមស្នាមជើងរបស់គោទៅ យ៉ាងណា ទុក្ខប្រព្រឹត្តទៅខាងផ្លូវកាយផង ផ្លូវចិត្តផង ដែលមានទុច្ចរិតជាមូល រមែងជាប់តាមបុគ្គលដែលមានចិត្តប្រទូស្តហើយ ធ្វើទុច្ចរិត ៣ ប្រការឲ្យពេញ តាំងនៅក្នុងទីដែលបុគ្គលនោះទៅហើយ មាននរកជាដើម ដូច្នោះឯង ។

ក្នុងកាលចប់គាថា ភិក្ខុ ៣ ពាន់រូប បានសម្រេចអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយ ។ ទេសនាបានជាកថាមានប្រយោជន៍ មានផលដល់បរិស័ទដែលប្រជុំគ្នាហើយ ដូច្នេះឯង ॥

រឿង ចក្ខុបាលត្ថេរ ចប់

រឿង មជ្ឈកុណ្ឌលី

លំនាំដើម

ឯគាថាទី ២ មានពាក្យថា **មនោបុព្វំគមា** ជាដើម ព្រះមានព្រះភាគទ្រង់ប្រារព្ធមជ្ឈកុណ្ឌលីមាណព ភាសិតហើយ ក្នុងក្រុងសាវត្ថីនោះឯង ។

បានឮមកថា ក្នុងក្រុងសាវត្ថីមានព្រាហ្មណ៍ម្នាក់ ឈ្មោះអទិន្នបុព្វកៈ គាត់មិនធ្លាប់ឲ្យរបស់ណាមួយដល់បុគ្គលណាម្នាក់ឡើយ ព្រោះដូច្នោះ ប្រជុំជនទើបដាក់ឈ្មោះឲ្យគាត់ថា អទិន្នបុព្វកៈ ។ គាត់មានកូនប្រុសម្នាក់ជាទីស្រឡាញ់ពេញចិត្ត ។ ក្រោយមក គាត់ចង់ធ្វើគ្រឿងប្រដាប់ឲ្យកូន គិតថា បើអញជួលជាងមាស ក៏ត្រូវឲ្យថ្លៃឈ្នួល ដូច្នេះហើយ ទើបផែមាសធ្វើឲ្យជាកុណ្ឌលរលោងៗ ស្រេចហើយ បានឲ្យដល់កូនរបស់ខ្លួន ។ ព្រោះដូច្នោះ ទើបកូនរបស់គាត់ ប្រាកដឈ្មោះថា មជ្ឈកុណ្ឌលី ។

ក្នុងកាលកូននោះអាយុបាន ១៦ ឆ្នាំ ក៏កើតរោគលឿង ។ មាតាក្រឡេកមើលបុត្រហើយ ទើបពោលនឹងព្រាហ្មណ៍ជាប្តីថា នែព្រាហ្មណ៍ រោគកើតឡើងដល់កូនរបស់អ្នក សូមអ្នករកគ្រូពេទ្យមកព្យាបាលចុះ ។

ព្រាហ្មណ៍ឆ្លើយថា នែនាង បើខ្ញុំរកពេទ្យមក យើងនឹងត្រូវឲ្យថ្លៃព្យាបាលដល់គេ នាងប្រហែលមិនមើលកាលអស់ទ្រព្យរបស់យើងទេ ។

ព្រាហ្មណីសួរថា បើយ៉ាងនេះ អ្នកនឹងធ្វើដូចម្តេច ។ ព្រាហ្មណ៍ឆ្លើយថា ទ្រព្យរបស់យើងមិនខាតបង់ទៅបាន យ៉ាងណា យើងនឹងធ្វើយ៉ាងនោះ ។

ព្រាហ្មណ៍នោះទៅកាន់សម្នាក់គ្រូពេទ្យទាំងឡាយហើយ សួរថា ពួកអ្នកដាក់ថ្នាំប្រភេទណាដល់បុគ្គលដែលមានរោគប្រភេទនោះ ។

លំដាប់នោះ ពួកគ្រូពេទ្យក៏ច្រាប់ថ្នាំដែលស្វែងជាដើមដល់គាត់ គាត់ទៅយកឫសឈើជាដើមដែលពួកគ្រូពេទ្យច្រាប់នោះមកហើយ ធ្វើថ្នាំឲ្យដល់កូន ។ កាលព្រាហ្មណ៍ធ្វើយ៉ាងនោះឯង រោគក៏កម្រើកខ្លាំងឡើង រហូតដល់មិនមានអ្នកណាអាចព្យាបាលបាន ។ ព្រាហ្មណ៍ដឹងថា កូនទុព្វលភាពហើយ ទើបរកគ្រូពេទ្យម្នាក់មក គ្រូពេទ្យនោះមកពិនិត្យមើលហើយ ទើបពោលថា ខ្ញុំមានកិច្ចខ្លះ ដែលត្រូវធ្វើ អ្នកចូរកមនុស្សដទៃមកព្យាបាលចុះ ដូច្នេះហើយ មិនព្យាបាល លាព្រាហ្មណ៍ត្រឡប់ទៅ ។

ព្រាហ្មណ៍ដឹងកាលថា កូនជិតស្លាប់ហើយ គិតថាពួកជនដែលមកហើយដើម្បីប្រយោជន៍សួរសុខទុក្ខកូននេះ នឹងឃើញទ្រព្យសម្បត្តិក្នុងផ្ទះ អញនឹងយកកូនអញទៅខាងក្រៅ ដូច្នេះហើយ ទើបនាំយកកូនចេញមកឲ្យដេកត្រង់យ៉ាមុខខាងក្រៅ ។

ក្នុងពេលបច្ចូសសម័យថ្ងៃជិតរះ ព្រះមានព្រះភាគចេញអំពីមហាករុណាសមាបត្តិ ទ្រង់ប្រមើលមើលលោកដោយពុទ្ធចក្ខុ កាលទតឃើញពួកសត្វដែលជាផៅពង្សល្មមទ្រង់ទូន្មានបាន ដែលមានកុសលមូលក្រាស់ហើយ មានសេចក្តីជ្រះថ្លាបានធ្វើហើយ ក្នុងព្រះពុទ្ធទាំងឡាយ អំពីកាលមុន ទ្រង់បានផ្សាយសំណាញ់ គឺព្រះញាណទៅក្នុងមុខចក្រវាល ។ មជ្ឈកុណ្ឌលីមាណពជ្រាកដហើយក្នុងសំណាញ់ញាណនោះ ដោយអាការដែលដេកត្រង់យ៉ាមុខខាងក្រៅនោះ ។

ព្រះសាស្តាទ្រង់ទតឃើញហើយ ទ្រង់ជ្រាបថា ព្រាហ្មណ៍ដែលជាបិតា

នាំមដ្ឋកុណ្ឌលីចេញមកខាងក្រៅផ្ទះហើយ ឲ្យដេកក្នុងទីនោះ ទ្រង់ត្រិះរិះថា នឹងមានប្រយោជន៍ខ្លះឬហ្ន៎ ដោយបច្ច័យដែលតថាគតទៅក្នុងទីនោះ លុះទ្រង់ប្រមើលមើល ក៏បានឃើញហេតុនេះថា មាណពនេះនឹងធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគត ធ្វើកាលកិរិយាហើយ នឹងកើតក្នុងវិមានមាសកម្ពស់ ៣០ យោជន៍ ក្នុងស្ថានតាវត្តិង្សទេវលោក មានស្រីទេពអប្សរជាបរិវារ ១ ពាន់ ។ ចំណែកព្រាហ្មណ៍នឹងធ្វើឈាបនសរីរៈនោះ ទ្រហោយំក្នុងទីបច្ចា ។ ទេវបុត្រនឹងសម្លឹងមើលអត្តភាពខ្លួន ដែលមានកម្ពស់ប្រមាណ ៣ គាវុត តាក់តែងដោយគ្រឿងអលង្ការ ទម្ងន់ ៦០ រទេះ មានស្រីទេពអប្សរជាបរិវារ ១ ពាន់ គិតថា សិរីសម្បត្តិនេះ អញបានដោយកម្មអ្វីហ្ន៎ ដូច្នេះហើយ ក៏បានជ្រាបថា បានដោយចិត្តជ្រះថ្លាក្នុងតថាគត គិតថា បិតាមិនរកគ្រូពេទ្យមកព្យាបាលឲ្យអញ ព្រោះខ្ជាចទ្រព្យអស់ទៅ ឥឡូវនេះ ទៅកាន់ឈាបនដ្ឋានទ្រហោយំ អញនឹងធ្វើបិតាឲ្យដល់នូវអាការចម្លែកដូច្នេះ ដោយអាក់អន់ក្នុងបិតា ទើបកាឡាខ្លួនដូចមដ្ឋកុណ្ឌលីមាណព មកដេកយំក្នុងទីជិតឈាបនដ្ឋាននោះ ។ ពេលនោះព្រាហ្មណ៍នឹងសួរថា អ្នកជានរណា ទេវបុត្រនោះនឹងឆ្លើយថា ខ្ញុំជាមដ្ឋកុណ្ឌលីមាណពជាកូនរបស់អ្នក ព្រាហ្មណ៍ពោលថា អ្នកទៅកើតក្នុងទីណា ទេវបុត្រពោលថា ក្នុងតាវត្តិង្សពិភព ។ កាលព្រាហ្មណ៍សួរថា ព្រោះធ្វើកម្មដូចម្តេច ទេវបុត្រនឹងជ្រាប់ថា ខ្ញុំកើតព្រោះចិត្តជ្រះថ្លាក្នុងព្រះតថាគត ។ ព្រាហ្មណ៍នឹងសួរតថាគតថា ឈ្មោះថា ការធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះអង្គប៉ុណ្ណោះហើយ ទៅកើតក្នុងស្ថានសួគ៌មានឬ ពេលនោះ តថាគតនឹងជ្រាប់ព្រាហ្មណ៍នោះថា មិន

មានអ្នកណាអាចកំណត់ ដោយការរាប់បានថា មានប្រមាណប៉ុណ្ណេះរយ ប៉ុណ្ណោះពាន់ ឬប៉ុណ្ណោះសែនបានឡើយ ដូច្នេះហើយ នឹងភាសិតគាថាក្នុងធម្មបទ ។ ក្នុងកាលចប់គាថា ការត្រាស់ដឹងធម៌នឹងមានដល់សត្វប្រមាណ ៨ ម៉ឺន ៤ ពាន់ ។ មជ្ឈកុណ្ឌលីទេវបុត្រ នឹងបានជាព្រះសោតាបន្ន សូម្បីអទិន្នបុព្វកព្រាហ្មណ៍ក៏ដូចគ្នា ។ អាស្រ័យកុលបុត្រនេះ ការបូជាធម៌ដ៏ច្រើននឹងមានដោយប្រការដូច្នេះ លុះថ្ងៃស្អែកឡើង ទ្រង់ធ្វើកិច្ចបជិបត្តិព្រះសរីរៈស្រេចហើយ ដែលមហាភិក្ខុសង្ឃរោមរោមហើយ ទ្រង់យាងចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត យាងដល់ទ្វារផ្ទះរបស់ព្រាហ្មណ៍ដោយលំដាប់ ។

ក្នុងខណៈនោះ មជ្ឈកុណ្ឌលីមាណពកំពុងដេកបែរមុខទៅឯក្នុងផ្ទះ ។ ព្រះសាស្តាទ្រង់ជ្រាបថា មិនឃើញព្រះអង្គ ទើបទ្រង់បញ្ចេញព្រះរស្មីប្រមាណមួយព្យាម ។ មាណពគិតថា នេះពន្លឺអ្វីហ្ន៎ ទើបប្រែខ្លួនត្រឡប់មកឃើញព្រះសាស្តា ហើយគិតថា អញអាស្រ័យបិតាដែលជាបុគ្គលពាល ទើបមិនបានចូលទៅគាល់ព្រះពុទ្ធដែលមានសភាពបែបនេះ ហើយធ្វើសេចក្តីខ្ពស់ខ្ពាយដោយកាយក្តី ថ្វាយទានក្តី ស្តាប់ធម៌ក្តី ។ ឥឡូវនេះ សូម្បីតែដៃទាំងពីររបស់អញក៏លើកសំពះមិនបាន កិច្ចដែលគួរធ្វើដទៃមិនមាន ដូច្នេះហើយ បានធ្វើចិត្តប៉ុណ្ណោះឲ្យជ្រះថ្លា ។

ព្រះសាស្តាទ្រង់ព្រះតម្រិះរិះថា ដោយការដែលមាណពនេះ ធ្វើចិត្តឲ្យជ្រះថ្លាប្រមាណប៉ុណ្ណោះក៏ល្មម ហើយទ្រង់យាងចៀសចេញទៅ ។ កាលព្រះតថាគតជាត់អំពីក្រសែភ្នែកទៅ មាណពនោះក៏មានចិត្តជ្រះថ្លា ធ្វើកាល-

កិរិយាហើយ ហាក់ដូចជាដេកលក់ហើយក្រាក់ឡើង ទៅកើតក្នុងវិមានមាសកម្ពស់ ៣០ យោជន៍ ក្នុងទេវលោក ។

ចំណែកព្រាហ្មណ៍ ធ្វើឈាបនកិច្ចសរីរៈមាណពនោះហើយ មានតែការទ្រហោយំប្រព្រឹត្តខាងមុខ ក្នុងទីប៉ាឆាវាល់ៗ ថ្ងៃ យំបណ្តើរវៀបរាប់បណ្តើរថា កូនតែមួយរបស់ឪពុក កូននៅទីណា កូនតែមួយរបស់ឪពុក កូននៅទីណា ។

ទេវបុត្រសម្លឹងមើលសម្បត្តិរបស់ខ្លួនហើយ គិតថា សម្បត្តិនេះអញបានដោយកម្មអ្វីហ្ន៎ កាលពិចារណាក៏បានដឹងថា បានដោយចិត្តជ្រះថ្លាក្នុងព្រះសាស្តាដូច្នេះហើយ ទើបគិតតទៅថា ព្រាហ្មណ៍នេះ ក្នុងកាលអញមានជំងឺមិនបានរកគ្រូពេទ្យមកព្យាបាលឡើយ ឥឡូវនេះ បែរជាទៅព្រៃខ្មោចទ្រហោយំអញគួរធ្វើគាត់ឲ្យដល់នូវប្រការដ៏ចម្លែក ដូច្នេះហើយ ទើបកាឡាខ្លួនដូចមដ្ឋកុណ្ឌលីមាណពមកហើយ បានផ្គងដើមដៃទ្រហោយំក្នុងទីមិនឆ្ងាយអំពីទីប៉ាឆា ។

ព្រាហ្មណ៍ឃើញទេវនិមិត្តនោះហើយ ទើបគិតថា អញយំព្រោះសោយសោកដល់កូន ចុះមាណពនេះយំត្រូវការអ្វីហ្ន៎ អញនឹងសួរគេមើល ដូច្នេះហើយ កាលនឹងសួរ ទើបពោលគាថានេះថា

> *អ្នកមានខ្លួនប្រដាប់ហើយ មានកុណ្ឌលរលើង ទ្រទ្រង់នូវកម្រងផ្កា មានខ្លួនច្រោះព្រំដោយខ្លឹមចន្ទន៍ក្រហម ផ្គងដើមដៃកន្ទក់កន្ទេញក្នុងកណ្តាលព្រៃស្មសាន តើអ្នកដល់នូវសេចក្តីទុក្ខដូចម្តេច ។ មាណពពោលថា វង្វេច ជាវិការនៃមាស*

មានរស្មីភ្លឺផ្លេក កើតឡើងដល់ខ្ញុំ បើខ្ញុំមិនបាននូវគូនៃកង់
របស់រថនោះទេ ខ្ញុំនឹងលះបង់ជីវិត ព្រោះសេចក្តីទុក្ខនោះ ។
ពេលនោះ ព្រាហ្មណ៍បានពោលនឹងមាណពថា ម្នាលមាណព
ដ៏ចម្រើន អ្នកចូរប្រាប់ (នូវគូនៃកង់) មាស ឬកែវមណី
កែវទទឹម ឬប្រាក់ដល់ខ្ញុំៗ នឹងញ៉ាំងអ្នកឲ្យបាននូវគូនៃកង់
(នោះ) ។

មាណពនោះបានស្តាប់ពាក្យនោះ គិតថា ព្រាហ្មណ៍នេះ មិនធ្វើថ្នាំឲ្យ
ដល់កូន កាលឃើញអញមានរូបរាងដូចកូន ក៏ទ្រហោយំ ពោលថា ខ្ញុំនឹង
ធ្វើកង់រថ ដែលធ្វើដោយមាសជាដើមឲ្យ ណ្តើយចុះ អញនឹងក្លែងពោល
លែងដល់ព្រាហ្មណ៍នេះ ដូច្នេះហើយ ទើបពោលថា អ្នកធ្វើគូនៃកង់ឲ្យដល់ខ្ញុំ
ធំប៉ុនណា កាលព្រាហ្មណ៍នោះពោលថា អ្នកត្រូវការធំប៉ុនណា ទើបប្រាប់ថា

ខ្ញុំត្រូវការដោយព្រះចន្ទ និងព្រះអាទិត្យទាំងពីរវង់ ប្រាកដឮ
ដ៏អាកាស នុ៎ះរថរបស់ខ្ញុំ ជាវិការនៃមាស សមដោយព្រះ
អាទិត្យ និងព្រះចន្ទនោះ ជាគូនៃកង់ ។

លំដាប់នោះ ព្រាហ្មណ៍ ពោលថា

ម្នាលមាណព អ្នកណាប្រាថ្នា នូវរបស់ដែលមិនគួរប្រាថ្នា
អ្នកនោះចំជាល្ងង់មែន ខ្ញុំសម្គាល់ថា អ្នកនឹងស្លាប់ អ្នកពិតជា
មិនបានព្រះចន្ទ និងព្រះអាទិត្យឡើយ ។

លំដាប់នោះ ទើបមាណពពោលនឹងព្រាហ្មណ៍នោះថា បុគ្គលដែល

ទ្រហោយំ ចង់បាននូវវត្ថុដែលប្រាកដ ជាបុគ្គលល្ងង់ ឬបុគ្គលដែលទ្រហោយំ ចង់បានវត្ថុដែលមិនប្រាកដ ជាបុគ្គលល្ងង់ ដូច្នេះហើយ ទើបពោលគាថានេះថា

ការចរទៅ និងចរមក (នៃព្រះចន្ទ និងព្រះអាទិត្យទាំងពីរ) ក្តី វណ្ណធាតុ (ការទ្រទ្រង់នៃរស្មី) ក្តី រមែងប្រាកដក្នុងវិថីទាំងពីរ បុគ្គលអ្នកធ្វើមរណកាល ទៅកាន់លោកខាងមុខ រមែងមិនប្រាកដឡើយ បណ្តាយើងទាំងពីរ ជាអ្នកកំពុងកន្ទក់កន្ទេញក្នុងទីនេះ តើអ្នកណាល្ងង់ជាង ។

ព្រាហ្មណ៍ស្តាប់ពាក្យនោះហើយ កំណត់បានថា មាណពនេះនិយាយត្រូវ ទើបពោលថា

ម្នាលមាណព អ្នកនិយាយចំជាពិតមែនហើយ បណ្តាយើងទាំងពីរនាក់ ជាអ្នកកំពុងកន្ទក់កន្ទេញ ខ្ញុំឯងជាបុគ្គលល្ងង់ជាង (ព្រោះ) ខ្ញុំប្រាថ្នានូវកូនប្រុសដែលធ្វើមរណកាលទៅកាន់លោកខាងមុខហើយ ដូចជាទារកយំទារ នូវព្រះចន្ទដូច្នោះដែរ ។

ដូច្នេះហើយ ជាអ្នកប្រាសចាកសេចក្តីសោក ព្រោះពាក្យរបស់មាណពនោះ កាលធ្វើការសរសើរមាណព បានពោលគាថាទាំងនេះថា

អ្នកបានស្រោចស្រពនូវខ្ញុំ ដែលភ្លើង គឺសេចក្តីសោកកំពុងឆេះសព្វ ឲ្យស្ងប់រម្ងាប់ ញ៉ាំងសេចក្តីក្រវល់ក្រវាយទាំងពួង

ឲ្យរលត់បាន ដូចបុគ្គលយកទឹកស្រោចភ្លើង កំពុងឆេះនូវ
ឆ្នាំងខ្ញាញ់ អ្នកណាបានបន្ទោបង់នូវសេចក្តីសោក ព្រោះកូន
ចំពោះខ្ញុំដែលមានសោក កំពុងគ្របសង្កត់ អ្នកនោះ ឈ្មោះ
ថា បានដកនូវកូនសរ គឺសេចក្តីសោក ដែលអាស្រ័យនូវ
ហឫទ័យរបស់ខ្ញុំ ខ្ញុំនោះ ជាអ្នកមានកូនសរ គឺសេចក្តីសោក
ដកហើយ ខ្ញុំជាអ្នកមានចិត្តត្រជាក់ហើយ មានទុក្ខរលត់ហើយ
ម្នាលមាណព ខ្ញុំលែងសោកស្តាយ លែងយំទួញហើយ
ព្រោះបានស្តាប់នូវពាក្យរបស់អ្នក ។

ខណៈនោះព្រាហ្មណ៍ ក៏សួរថាអ្នកឈ្មោះអ្វី ទើបពោលថា

អ្នកជាទេវតាឬ ឬជាគន្ធព្វ ឬមួយជាព្រះឥន្ទ្រ បានបំពេញ
ទានក្នុងកាលមុន អ្នកជាអ្វី ជាកូនរបស់អ្នកណា យើងនឹង
ស្គាល់អ្នក ដូចម្តេចបាន ។

លំដាប់នោះ មាណពប្រាប់ដល់ព្រាហ្មណ៍ថា

អ្នកបានដុតកូនណា ដោយខ្លួនឯងក្នុងទីបូជាសព (ឈាប-
នដ្ឋាន) ហើយកន្ទក់កន្ទេញផង យំទួញផង កូននោះ គឺខ្ញុំ
ហ្នឹងឯង ធ្វើនូវកុសលកម្ម បានទៅកើតជាមួយនឹងពួកទេវតា
ជាន់តាវត្តិង្ស ។

ព្រាហ្មណ៍បានពោលថា

កាលអ្នកឲ្យទានតិច ឬច្រើនក្នុងផ្ទះ របស់ខ្លួនក្តី ឬក៏រក្សានូវ

ខបោសថកម្ម ប្រាកដដូច្នោះក្តី ខ្ញុំមិនបានឃើញអ្នកទៅកាន់ទេវលោក តើដោយបុណ្យអ្វី ។

មាណពបានពោលថា

ខ្ញុំជាអ្នកមានអាពាធ ឈឺធ្ងន់ ដល់នូវសេចក្តីទុក្ខ មានរូបក្តៅក្រហាយជានិច្ច ក្នុងផ្ទះរបស់ខ្លួន ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គមានធូលី គឺកិលេសទៅប្រាសហើយ មានសេចក្តីសង្ស័យឆ្ងងផុតហើយ មានជំណើរល្អ មានបញ្ញាមិនថយថោក ខ្ញុំនោះមានចិត្តរីករាយ ជ្រះថ្លា បានធ្វើអញ្ជលី ចំពោះព្រះតថាគតលុះខ្ញុំបានធ្វើកុសលកម្មនោះហើយ ក៏បានទៅកើតជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។

កាលមាណពនោះ កំពុងពោលទូន្មាននោះឯង សរីរៈទាំងមូលរបស់ព្រាហ្មណ៍ ក៏ពេញហើយដោយបីតិ ។ កាលគាត់ប្រកាស់នូវបីតិនោះ ទើបពោលថា

អើហ្នឹ អស្ចារ្យណាស់ ចម្លែកណាស់ ផលនៃអញ្ជលិកម្ម ដល់ម្ល៉ះតើ អើ ខ្ញុំក៏មានចិត្តរីករាយ មានចិត្តជ្រះថ្លាដែរ សូមដល់នូវព្រះពុទ្ធជាទីរឲក ក្នុងថ្ងៃនេះឯង ។

លំដាប់នោះ មាណពបានពោលទូន្មានថា

អ្នកចូរមានចិត្តជ្រះថ្លា ដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីរឲក ក្នុងថ្ងៃនេះចុះ អ្នកចូរសមាទាននូវ

សិក្ខាបទទាំង ៥ កុំឲ្យដាច់ កុំឲ្យធ្លុះធ្លាយដូច្នោះចុះ ចូរវៀរចាកការសម្លាប់សត្វយ៉ាងធាប់ផង ចូរវៀរបង់នូវការកាន់យកទ្រព្យដែលគេមិនបានឲ្យ ក្នុងលោកផង កុំផឹកនូវទឹកស្រវឹងផង កុំពោលនូវពាក្យកុហកផង ចូរជាអ្នកសន្តោស ដោយប្រពន្ធរបស់ខ្លួនផង ។

ព្រាហ្មណ៍ទទួលថា សាធុ ហើយបានពោលនូវគាថាទាំងនេះថា

បពិត្រអ្នកដែលគេគប្បីបូជា អ្នកប្រាថ្នានូវសេចក្តីចម្រើនដល់ខ្ញុំ បពិត្រទេវតា អ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នក អ្នកជាអាចារ្យរបស់ខ្ញុំ ខ្ញុំសូមដល់នូវព្រះពុទ្ធជាទីរឭកផង សូមដល់នូវព្រះធម៌ ជាទីរឭកផង សូមដល់នូវព្រះសង្ឃ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់ជន និងទេវតាជាទីរឭកផង ខ្ញុំវៀរចាកការសម្លាប់សត្វ យ៉ាងធាប់ផង វៀរបង់នូវការកាន់យកទ្រព្យ ដែលគេមិនបានឲ្យក្នុងលោកផង មិនផឹកទឹកស្រវឹងផង មិនពោលពាក្យកុហកផង សន្តោសដោយប្រពន្ធរបស់ខ្លួនផង ។

លំដាប់នោះ ទេវបុត្រពោលថា នែព្រាហ្មណ៍ ទ្រព្យក្នុងផ្ទះរបស់អ្នកមានច្រើន ចូរអ្នកទៅគាល់ព្រះសាស្តា ហើយថ្វាយទាន ចូរស្តាប់ធម៌ ចូរសួរនូវបញ្ហា ដូច្នេះហើយ ក៏អន្តរធានទៅក្នុងទីនោះឯង ។

ចំណែកព្រាហ្មណ៍ទៅផ្ទះហើយ ហៅព្រាហ្មណីមកពោលថា នែនាងដ៏

ចម្រើន ខ្ញុំនឹងនិមន្តព្រះសមណគោតម ហើយទូលសួរបញ្ហា ចូរនាងធ្វើសក្ការៈ ដូច្នេះហើយ ទៅកាន់វិហារ មិនថ្វាយបង្គំព្រះសាស្តា មិនធ្វើបដិសណ្ឋារៈ ឈរក្នុងទីម្ខាង ហើយក្រាបទូលថា បពិត្រព្រះគោតម សូមទ្រង់មួយអន្ទឹ ដោយភិក្ខុសង្ឃ ទទួលភត្តាហារនៃខ្ញុំ ដើម្បីសោយក្នុងថ្ងៃនេះ ។

ព្រះសាស្តាទ្រង់ទទួលហើយ ។ គាត់បានជ្រាបថា ព្រះសាស្តាទ្រង់ទទួលហើយ ទើបមកដោយរហ័ស ប្រើមនុស្សឲ្យរៀបចំខាទនីយភោជនីយាហារក្នុងផ្ទះរបស់ខ្លួន ។ ព្រះសាស្តា មានភិក្ខុសង្ឃចោមរោមហើយ យាងទៅកាន់ផ្ទះនៃព្រាហ្មណ៍នោះ ប្រថាប់គង់លើអាសនៈដែលគេតាក់តែង ។ ព្រាហ្មណ៍ អង្គាសហើយដោយគោរព ។

មហាជនប្រជុំគ្នា ។ បានឮថា កាលព្រះតថាគតដែលព្រាហ្មណ៍មិច្ឆាទិដ្ឋិនិមន្តហើយ ។ ពួកជនពីរពួកមកប្រជុំគ្នា គឺពួកជនដែលជាមិច្ឆាទិដ្ឋិប្រជុំគ្នាដោយតាំងចិត្តថា ថ្ងៃនេះ ពួកយើងនឹងឃ្លាំមើលព្រះសមណគោតមដែលត្រូវព្រាហ្មណ៍បៀតបៀន ដោយសួរបញ្ហា ។ ពួកជនដែលជាសម្មាទិដ្ឋិក៏ប្រជុំគ្នាដោយតាំងចិត្តថា ថ្ងៃនេះ ពួកយើងនឹងចាំមើលពុទ្ធវិស័យ និងពុទ្ធលីលា ។

លំដាប់នោះ ព្រាហ្មណ៍ចូលទៅគាល់ព្រះតថាគត ដែលទ្រង់ធ្វើភត្តកិច្ចស្រេចហើយ អង្គុយលើអាសនៈទាប បានទូលសួរបញ្ហាថា បពិត្រព្រះគោតម ឈ្មោះថាពួកជនដែលមិនបានថ្វាយទានដល់ព្រះអង្គ មិនបានបូជាព្រះអង្គ មិនបានស្តាប់ធម៌ មិនបានរក្សាឧបោសថ បានទៅកើតក្នុងឋានសួគ៌ដោយគ្រាន់តែមានចិត្តជ្រះថ្លាតែម្យ៉ាងប៉ុណ្ណោះមានឬ ។ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍

ហេតុអ្វី អ្នកសួរតថាគត ភាពដែលបុគ្គលធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគតហើយ កើតក្នុងឋានសួគ៌ ដែលមដ្ឋកុណ្ឌលីជាកូនរបស់អ្នក ប្រាប់ដល់អ្នកហើយមិនមែនឬ ព្រាហ្មណ៍ពោលថា ប្រាប់ក្នុងកាលណាព្រះគោតមដ៏ចម្រើន ព្រះសាស្តាត្រាស់ថា ថ្ងៃនេះ អ្នកទៅកាន់ឈាបនដ្ឋាន យំខ្សឹកខ្សួល ឃើញមាណពម្នាក់ផ្តងដើមដៃកន្ទក់កន្ទេញក្នុងទីមិនឆ្ងាយហើយសួរថា

អ្នកមានខ្លួនប្រជាប់ហើយមាន កុណ្ឌលរលីង ទ្រទ្រង់នូវ
កម្រងផ្កា មានខ្លួនប្រោះព្រំដោយខ្លឹម ចន្ទន៍ក្រហម ...
ដូច្នេះជាដើម មិនមែនឬ ។

កាលទ្រង់ប្រកាសពាក្យដែលជនទាំងពីរសន្ទនាគ្នាហើយ បានត្រាស់រឿងមដ្ឋកុណ្ឌលីទាំងអស់ ។ ព្រោះដូច្នេះឯង ទើបរឿងមដ្ឋកុណ្ឌលីនោះ បានឈ្មោះថា ជាពុទ្ធកាសិត ។ កាលព្រះសាស្តាត្រាស់រឿងមដ្ឋកុណ្ឌលីនោះហើយ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ មិនថា មានត្រឹមតែមួយរយ ឬពីររយ ដោយពិត ការដែលរាប់សត្វ ដែលធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគតហើយកើតក្នុងឋានសួគ៌ រមែងមិនមាន ។ មហាជនក៏កើតសេចក្តីសង្វេគហើយ ។

លំដាប់នោះ ព្រះសាស្តាទ្រង់ជ្រាបភាពដែលមហាជននោះមិនអស់សេចក្តីសង្ស័យ ទ្រង់បានអធិដ្ឋានថា មដ្ឋកុណ្ឌលីទេវបុត្រ ចូរមកមួយអន្ទឹងដោយវិមាននោះឯង ។ ទេវបុត្រមានអត្តភាពដែលប្រជាប់តាក់តែងហើយ ដោយគ្រឿងអភរណៈទិព្វ កម្ពស់ប្រមាណ ៣ គាវុតមកហើយ ចុះអំពីវិមានថ្វាយបង្គំព្រះសាស្តាហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាកាលត្រាស់សួរទេវបុត្រថា អ្នកធ្វើកម្មដូចម្តេច ទើបបាននូវសម្បត្តិនេះ បានត្រាស់ព្រះគាថាថា

ម្នាលទេវតា អ្នកមានសម្បុរដ៏រុងរឿង ញុំាងទិសទាំងពួង
ឲ្យភ្លឺ ដូចផ្កាយព្រឹក ... តថាគតសូមសួរអ្នក អ្នកកាលកើត
ជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច ។

ទេវបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សម្បត្តិនេះ ខ្ញុំព្រះអង្គ បានហើយ ព្រោះធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា សម្បត្តិ នេះ អ្នកបានហើយ ព្រោះធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគតឬ ទេវបុត្រពោលថា ព្រះកុរណា ព្រះអង្គ ។

មហាជនសម្ងំមើលទេវបុត្រហើយ បានប្រកាសសេចក្តីត្រេកអរថា នែ បា ពុទ្ធគុណគួរអស្ចារ្យពិតហ្ន៎ កូនរបស់អទិន្នបុព្វកព្រាហ្មណ៍ មិនបានធ្វើ បុណ្យណាមួយដទៃឡើយ ញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះសាស្តាហើយ បាន សម្បត្តិបែបនេះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់ដល់ជនទាំងនោះថា ក្នុងការធ្វើកម្មដែល ជាកុសល និងអកុសល ចិត្តជាប្រធាន ចិត្តជាធំ ។ ព្រោះថា កម្មដែលធ្វើ ដោយចិត្តដែលជ្រះថ្លាហើយ រមែងមិនលះបុគ្គលដែលទៅកាន់ទេវលោក មនុស្សលោក ដូចស្រមោល ដូច្នោះ ។ កាលត្រាស់រឿងនេះហើយ ព្រះ ធម្មរាជាបានត្រាស់ព្រះគាថានេះ បន្តអនុសន្ធិ ដូចប្រថាប់ព្រះរាជសាសន៍ ហើយ ដោយព្រះរាជលញ្ជកវថា

មនោបុព្ពង្គមា ធម្មា មនោសដ្ឋា មនោមយា

មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា

តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី (នូវសុចរិត) ព្រោះសុចរិតទាំងនោះ សុខ រមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអនុលតាមប្រាណ ។

សេចក្តីអធិប្បាយ

ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ហៅថា ចិត្ត ក្នុងព្រះគាថានោះក៏ពិត ដោយមិនប្លែកគ្នា តែកាលនិយម ប៉ាន់ស្មាន កំណត់ក្នុងបទនេះ រមែងបានដល់ចិត្តជាកាមាវចរកុសល ៨ ដួង កាលពោលដោយអំណាចវត្ថុ រមែងបានដល់ចិត្តដែលប្រកបដោយញាណ ប្រព្រឹត្តទៅមួយអន្ទើដោយសោមនស្ស អំពីកាមាវចរកុសលចិត្ត ៤ ដួងប៉ុណ្ណោះ ។

បទថា **បុព្ពង្គមា** *សេចក្តីថា ប្រកបជាមួយចិត្តដែលជាអ្នកទៅមុខនោះ ។ ខន្ធ ៣ មានវេទនាជាដើម ឈ្មោះថា ធម៌ ។ មែនហើយ ចិត្តជាប្រធានរបស់អរូបក្ខន្ធទាំង ៣ មានវេទនាក្ខន្ធជាដើម ដោយអត្ថ គឺជាបច្ច័យឲ្យកើតឡើង ហេតុនោះ ទើបខន្ធទាំង ៣ ប្រការនោះ ឈ្មោះថា មានចិត្តជាប្រធាន ឧបមាដូចកាលទាយកជាច្រើន កំពុងធ្វើបុណ្យ មានប្រគេនបាត្រ និងចីវរជាដើមដល់មហាភិក្ខុសង្ឃក្តី មានបូជាដ៏ក្រៃលែង និងស្តាប់ធម៌ អុជប្រទីប និង*

ធ្វើសក្ការៈដោយកម្រងផ្កាជាដើមក្តីជាមួយគ្នា កាលមានបុគ្គលពោលថា អ្នកណាជាប្រធាននៃទាយកទាំងនោះ ទាយកណាជាបច្ចយរបស់ពួកជនទាំងនោះ គឺពួកជនទាំងនោះ អាស្រ័យទាយកណា ទើបធ្វើបុណ្យទាំងនោះបាន ទាយកនោះ ឈ្មោះតិស្សៈក្តី ឈ្មោះបុស្សៈក្តី ប្រជុំជនរមែងហៅថា ជាប្រធានរបស់ពួកគេ យ៉ាងណា ពាក្យឧបមេយ្យដែលជាគ្រឿងឲ្យកើតអត្ថ គឺការដល់ព្រមនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនោះ ។ ចិត្ត ឈ្មោះថា ជាប្រធាននៃធម៌ទាំងនេះ ដោយអត្ថថា ជាបច្ចយឲ្យកើតឡើង ដោយប្រការដូច្នេះ ហេតុនោះ ទើបធម៌ទាំងនេះ ឈ្មោះថា មានចិត្តជាប្រធាន ។ ពិតហើយ ធម៌ទាំងនោះ កាលចិត្តមិនកើតឡើង រមែងមិនអាចកើតឡើងបាន ចំណែកចិត្ត កាលចេតសិកពួកខ្លះមិនកើតឡើង ក៏កើតឡើងបាន ។ ចិត្ត ឈ្មោះថា ជាធំជាងធម៌ទាំងនេះ ដោយអំណាចជាអធិបតី ព្រោះដូច្នោះ ទើបធម៌ទាំងនេះ ឈ្មោះថា មានចិត្តជាធំ ។ ម្យ៉ាងទៀត វត្ថុទាំងឡាយនោះៗ សម្រេចហើយដោយវត្ថុ មានមាសជាដើម ក៏ឈ្មោះថា សម្រេចហើយដោយមាសជាដើម យ៉ាងណា សូម្បីធម៌ទាំងឡាយនោះ ក៏បានឈ្មោះថា សម្រេចហើយដោយចិត្ត ព្រោះជារបស់សម្រេចមកអំពីចិត្ត ដូច្នោះ ។

បទថា **បសន្នេន** *សេចក្តីថា ផូរផង់ហើយ ដោយគុណទាំងឡាយ មានការមិនសម្ងឹង (ទោស) ជាដើម ។*

ពីរបទថា **ភាសតិ វា ករោតិ វា** *សេចក្តីថា បុគ្គលមានចិត្តបែបនេះ កាលនឹងពោល រមែងពោលតែវចីសុចរិត ៤ យ៉ាង កាលធ្វើ រមែងធ្វើតែ*

កាយសុចរិត ៣ យ៉ាង កាលមិនពោល កាលមិនធ្វើ រមែងធ្វើតែមនោ-សុចរិត ៣ យ៉ាងឲ្យពេញបរិបូណ៌ ព្រោះភាពដែលខ្លួនជាអ្នកមានចិត្តផូរផង់ ហើយដោយគុណទាំងឡាយ មានការមិនសម្លឹងជាដើមនោះ ។ កុសលកម្ម-បថ ១០ របស់បុគ្គលនោះ រមែងដល់នូវការបរិបូណ៌ ដោយប្រការយ៉ាងនេះ ។

ចាទព្រះគាថាថា **តតោ នំ សុខមន្វេតិ** *សេចក្តីថា សេចក្តីសុខ រមែងតាមបុគ្គលនោះទៅ ព្រោះសុចរិត ៣ យ៉ាងនោះ ។ កុសលទាំង ៣ ភូមិ ព្រះដ៏មានព្រះភាគទ្រង់បំណងយកហើយក្នុងទីនេះ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបអធិប្បាយថា សេចក្តីសុខដែលជាផល ដែលប្រព្រឹត្តទៅក្នុងកាយ និងប្រព្រឹត្តទៅក្នុងចិត្តដោយបរិយាយនេះថា សេចក្តីសុខមានកាយជាទីតាំងខ្លះ សេចក្តីសុខមានចិត្តជាទីតាំងខ្លះ រមែងតាមទៅ គឺរមែងមិនលះបុគ្គលនោះដែលកើតហើយក្នុងសុគតិភពក្តី តាំងនៅហើយក្នុងទីសោយសុខក្នុងសុគតិក្តី ព្រោះអានុភាពនៃសុចរិត ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ មានពាក្យសួរជ្រៀតចូលមកថា សេចក្តីនេះដូចអ្វី ឆ្លើយថា ដូចស្រមោលមានប្រក្រតីទៅតាមខ្លួន អធិប្បាយថា ធម្មតាស្រមោល ជារបស់ជាប់នឹងសរីរៈ កាលសរីរៈដើរ ស្រមោលក៏ដើរទៅ កាលសរីរៈឈប់ ស្រមោលក៏ឈប់ ។ កាលសរីរៈអង្គុយ ស្រមោលក៏អង្គុយ ។ មិនមានបុគ្គលណាអាចពោលជាមួយស្រមោលដោយពាក្យដែលល្អិតក្តី ដោយពាក្យដែលគ្រោតគ្រាតក្តីថា អ្នកចូរត្រឡប់ទៅឬដេញវាយហើយ ទើបឲ្យត្រឡប់បាននោះឡើយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះវាជារបស់ជាប់នឹងសរីរៈ យ៉ាងណា សេចក្តីសុខដែលប្រព្រឹត្ត*

ទៅក្នុងកាយ និងប្រព្រឹត្តទៅក្នុងចិត្ត មានសុខ ដោយកាមាវចរសុខជាដើម មានកុសលនៃកុសលកម្មបថ ១០ នេះ ដែលបុគ្គលប្រព្រឹត្តច្រើនហើយ និងប្រព្រឹត្តល្អហើយជាឫសគាល់ រមែងមិនលះបង់បុគ្គលនោះ ក្នុងទីដែលបុគ្គលនោះទៅហើយ ដូចស្រមោល អន្ទោលទៅតាមប្រាណ ដូច្នោះឯង ។

ក្នុងកាលចប់គាថា ការត្រាស់ដឹងធម៌មានហើយដល់សត្វ ៨ ម៉ឺន ៤ ពាន់ ។ មដ្ឋកុណ្ឌលីទេវបុត្រតាំងនៅហើយក្នុងសោតាបត្តិផល អទិន្នបុព្វកព្រាហ្មណ៍ក៏ដូចគ្នា ។ គាត់បានសាបព្រោះសម្បត្តិធំដល់ម្ល៉ោះ ក្នុងព្រះពុទ្ធសាសនាហើយ ដូច្នេះឯង ។

រឿង មដ្ឋកុណ្ឌលី ចប់

រឿង ព្រះតិស្សត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះតិស្សត្ថេរ បានត្រាស់ព្រះធម្មទេសនានេះថា **អកោច្ឆិ មំ អវធិ មំ** *ជាដើម ។*

បានឮមកថា ព្រះតិស្សត្ថេរនេះ ជាឱរសព្រះបិតុច្ឆាបស់ព្រះដ៏មានព្រះភាគ បួសក្នុងកាលឯចាស់ បរិភោគលាភសក្ការៈដែលកើតឡើងហើយ ក្នុងព្រះពុទ្ធសាសនា មានរាងកាយធាត់ល្អ មានចីវរស្អាតរៀបរយហើយដោយច្រើន អង្គុយក្នុងភេងធាន់កណ្តាលវិហារ ។ កិកូអាគន្តុកៈទាំងឡាយមកហើយ

ដើម្បីប្រយោជន៍ចូលគាល់ព្រះតថាគត ទៅកាន់សម្នាក់របស់លោក ដោយសម្គាល់ថា នេះជាមហាថេរៈ ដូច្នេះហើយ សួរដល់វត្ត សួរដល់កិច្ចដែលគួរធ្វើ មានច្របាច់ជើងជាដើម ព្រះតិស្សៈក៏គង់ស្ងៀមនៅ ។

លំដាប់នោះ កិកុកំលោះមួយអង្គសួរថា លោកម្ចាស់វស្សាប៉ុន្មានហើយ លោកឆ្លើយថា មិនទាន់មានវស្សាទេ ខ្ញុំបួសហើយ ក្នុងកាលជាមនុស្សចាស់ ទើបកិកុកំលោះពោលថា លោកម្ចាស់តាដ៏មានអាយុ ជាអ្នកប្រជៅក្រ លោកម្ចាស់មិនស្គាល់ប្រមាណខ្លួនឯង ឃើញមហាថេរៈមានប្រមាណប៉ុណ្ណេះហើយ មិនធ្វើវត្ត សូម្បីតែសាមីចិកម្ម កាលវត្តដែលព្រះថេរៈទាំងនេះសួរដោយអើពើ លោកម្ចាស់ក៏នៅស្ងៀម សូម្បីតែសេចក្តីរង្កៀស ក៏មិនមានដល់លោកម្ចាស់ដូច្នេះ ទើបលាដៃ ។ ព្រះតិស្សៈញ៉ាំងទុតិយមានៈឲ្យកើតឡើងហើយ សួរថា ពួកលោកមកកាន់សម្នាក់អ្នកណា កាលអាគន្តុកៈទាំងនោះឆ្លើយថា ខ្ញុំមកកាន់សម្នាក់របស់ព្រះសាស្តា ទើបពោលថា ពួកលោកសម្គាល់ខ្ញុំថា នេះជាអ្នកណា ខ្ញុំនឹងកាត់មូលរបស់ពួកលោកចេញឲ្យបាន ដូច្នេះហើយ ស្រែកយំដល់នូវសេចក្តីទុក្ខទោមនស្ស ទៅកាន់សម្នាក់របស់ព្រះសាស្តាហើយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរថា ម្នាលតិស្សៈ តើមានរឿងអ្វីហ្ន៎ ទើបអ្នកជាទុក្ខទោមនស្ស មានមុខជោកដោយទឹកភ្នែក ទ្រហោយំមកហើយ ។ ចំណែកកិកុទាំងនោះ គឺអាគន្តុកកិកុគិតថា កិកុនេះគង់មិនធ្វើកម្មល្អក់កករណាមួយឡើយ ដូច្នេះ ទើបទៅជាមួយព្រះតិស្សៈនោះឯង ថ្វាយបង្គំព្រះសាស្តាហើយ បានអង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ព្រះតិស្សៈនោះ កាល

ព្រះសាស្តាត្រាស់សួរហើយ បានក្រាបទូលថា បពិត្រព្រះអង្គ ភិក្ខុទាំងនេះ ជេរខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា អ្នកអង្គុយហើយក្នុងទីណា ព្រះតិស្សៈទូលថា ត្រង់ភោងធាន់កណ្តាលវិហារ ព្រះសាស្តាត្រាស់ថា ភិក្ខុទាំងនេះមក អ្នកបានឃើញដែរឬទេ ព្រះតិស្សៈឆ្លើយថា ឃើញព្រះអង្គ ព្រះសាស្តាត្រាស់ថា អ្នកបានក្រោកឡើងធ្វើការទទួលដែរឬ ព្រះតិស្សៈឆ្លើយថា មិនបានធ្វើទេ ព្រះអង្គ ព្រះសាស្តាត្រាស់ថា អ្នកបានសួរដោយអើពើ ដល់ការទទួលបរិក្ខារ របស់ភិក្ខុទាំងនោះដែរឬ ព្រះតិស្សៈតបថា ខ្ញុំព្រះអង្គមិនបានសួរដោយអើពើ ឡើយព្រះអង្គ ព្រះសាស្តាត្រាស់ថា អ្នកបានសួរដោយអើពើដើម្បីដល់ទូទំនៀម ឬទឹកផឹកដែរឬ ព្រះតិស្សៈតបថា ខ្ញុំព្រះអង្គមិនបានសួរដោយអើពើ ឡើយ ព្រះសាស្តាត្រាស់ថា អ្នកនាំអាសនៈមកហើយ ធ្វើការគក់ច្របាច់ជើង ឲ្យដែរឬ ព្រះតិស្សៈតបថា មិនបានធ្វើទេ ព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលតិស្សៈ វត្តទាំងពួងនោះ អ្នកគួរធ្វើដល់ភិក្ខុដែលជាថេរៈ ។ កាលដែល អ្នកមិនធ្វើវត្តទាំងពួងនោះ អង្គុយក្នុងកណ្តាលវិហារ មិនសមគួរ ទោសរបស់ អ្នកខ្លួនឯងមាន អ្នកចូរខមាទោសភិក្ខុទាំងឡាយនោះចុះ ព្រះតិស្សៈពោលថា បពិត្រព្រះអង្គ ភិក្ខុទាំងឡាយនេះ បានជេរខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គមិនសូមខមា-ទោសឡើយ ព្រះសាស្តាត្រាស់ថា ម្នាលតិស្សៈ អ្នកកុំធ្វើយ៉ាងនេះ ទោស របស់អ្នកមាន អ្នកចូរសូមខមាទោសភិក្ខុទាំងនោះចុះ ព្រះតិស្សៈពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនព្រមសូមទោសភិក្ខុទាំងនេះទេ ។

លំដាប់នោះ ព្រះសាស្តាកាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ

ព្រះតិស្សៈនេះ ជាបុគ្គលប្រដៅក្រ ដូច្នេះហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តិស្សៈនេះមិនមែនប្រដៅក្រតែក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តិស្សៈនេះក៏ជាបុគ្គលប្រដៅក្រដូចគ្នា កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ ជ្រាបលោកថា ជាបុគ្គលប្រដៅក្រតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ តើលោកបានធ្វើអ្វី ក្នុងអតីតកាល ដូច្នេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើយ៉ាងនោះ ចូរអ្នកទាំងឡាយស្តាប់ ដូច្នេះហើយ ទ្រង់បាននាំអតីតនិទានមក ។

បុព្វកម្មរបស់ព្រះតិស្សៈ

ក្នុងអតីតកាល កាលព្រះបាទពារាណសីសោយរាជសម្បត្តិ ក្នុងនគរពារាណសី តាបសឈ្មោះទេវិលៈនៅក្នុងហិមវន្តប្បទេស ៨ ខែ ប្រាថ្នាចូលទៅអាស្រ័យនគរ ៤ ខែ ដើម្បីបរិភោគរសប្រៃ និងរសជូរ ទើបមកអំពីហិមវន្តប្បទេស ជួបពួកអ្នកយាមទ្វារនគរ ទើបសួរថា ពួកបុព្វជិតដែលមកដល់នគរនេះហើយ ស្នាក់នៅក្នុងទីណា ពួកអ្នកយាមទាំងឡាយប្រាប់ថា ក្នុងរោងនាយស្មូនឆ្នាំង លោកម្ចាស់ ។ លោកទៅកាន់រោងនាយស្មូនឆ្នាំងហើយ ឈរត្រង់ទ្វារពោលថា បើអ្នកមិនយល់ទាស់ទេ អាត្មាសូមស្នាក់នៅក្នុងរោងត្រឹមមួយរាត្រី ។ ស្មូនឆ្នាំងពោលថា ពេលយប់ កិច្ចរបស់ខ្ញុំត្រង់រោងមិនមាន រោងនេះធំ និមន្តលោកម្ចាស់ស្នាក់នៅ តាមសប្បាយចុះ ដូច្នេះហើយប្រគល់រោងប្រគេន ។

កាលលោកចូលទៅអង្គុយហើយ ។ តាបសមួយរូបទៀត ឈ្មោះនារទៈ

មកអំពីហិមវន្តប្បទេស បានសូមស្នាក់នៅមួយវាត្រីជាមួយនាយស្មូនឆ្នាំង ។ នាយស្មូនឆ្នាំងគិតថា តាបសអង្គដែលមកមុនជាអ្នកប្រជៅក្រ ដូចគ្នានឹងតាបសអង្គនេះឬទេហ្ន៎ក៏មិនដឹង អញនឹងដោះខ្លួនចេញ ដូច្នេះហើយ ទើបពោលថា បើលោកម្ចាស់អង្គណាចូលទៅមុនពេញចិត្តសោត សូមលោកម្ចាស់ស្នាក់នៅតាមការពេញចិត្តរបស់តាបសអង្គមុនចុះ ។ នារទតាបសនោះ ចូលទៅរកទេវិលៈ ហើយពោលថា លោកអាចារ្យ បើលោកម្ចាស់មិនយល់ទាស់ទេ ខ្ញុំសូមស្នាក់នៅក្នុងវោងនេះមួយវាត្រីចុះ កាលលោកពោលថា វោងធំ សូមលោកម្ចាស់ចូលទៅចំណែកម្ខាងចុះ ដូច្នេះហើយ ទើបចូលអង្គុយក្នុងទីមួយកន្លែងទៀតនៃតាបសដែលចូលទៅមុន ។

តាបសទាំងពីរបួប ពោលប្រាស្រ័យនាំឲ្យរឭកដល់គ្នាហើយ ក្នុងកាលសិង នារទតាបសកំណត់ទីសិងនៃតាបស និងទ្វារហើយ ទើបសិង ចំណែកទេវិលតាបសនោះកាលនឹងសិង មិនសិងក្នុងទីរបស់ខ្លួន សិងទទឹងត្រង់ទ្វារ ។ នារទតាបសកាលចេញទៅក្នុងវាត្រី បានជាន់ត្រង់ជជារបស់លោក ។ កាលលោកពោលថា អ្នកណាជាន់ខ្ញុំ នារទតាបសពោលថា ខ្ញុំលោកអាចារ្យ ទេវិលៈពោលថា នែជដិលកោង អ្នកមកអំពីព្រៃហើយ ជាន់ត្រង់ជជារបស់ខ្ញុំ នារទតាបសពោលថា លោកអាចារ្យខ្ញុំមិនដឹងថា លោកអាចារ្យសិងទីនេះ សូមលោកអាចារ្យអត់ទោសដល់ខ្ញុំចុះ ។ កាលលោកកំពុងរអ៊ូនោះឯង ចេញទៅខាងក្រៅហើយ ។ ទេវិលតាបសគិតថា តាបសនេះ ចូលមកគប្បីជាន់អញ ដូច្នេះហើយ ទើបសិងបែរក្បាលទៅខាងចុងជើង ។

ចំណែកនារទតាបស កាលនឹងចូលទៅ គិតថា ពីមុនអញបានខុសម្តង ហើយ ក្នុងលោកអាចារ្យ ឥឡូវនេះអញនឹងចូលទៅខាងចុងជើងរបស់លោក ដូច្នេះហើយ កាលមក បានជាន់ត្រង់ករបស់លោក កាលលោកពោលថា នេះអ្នកណា ទើបពោលថា លោកអាចារ្យ គឺខ្ញុំ ។ កាលលោកពោលថា នែជដិលកោង ដំបូងអ្នកជាន់ត្រង់ជជារបស់ខ្ញុំហើយ ឥឡូវនេះ ជាន់ត្រង់ករបស់ខ្ញុំទៀត ខ្ញុំនឹងដាក់បណ្តាសាអ្នក នារទតាបសពោលថា លោកអាចារ្យ ទោសរបស់ខ្ញុំមិនមាន ខ្ញុំមិនដឹងថា លោកម្ចាស់សិងហើយយ៉ាងនេះ ខ្ញុំចូលមកដោយគិតថា ជំបូងកំហុសរបស់ខ្ញុំមាន ឥឡូវនេះ ខ្ញុំនឹងចូលទៅខាងចុងជើងដូច្នេះ សូមលោកម្ចាស់អត់ទោសដល់ខ្ញុំចុះ ទេវិលតាបសពោលថា នែជដិលកោង ខ្ញុំនឹងដាក់បណ្តាសាលោក នារទតាបសពោលថា លោកអាចារ្យ សូមលោកកុំធ្វើយ៉ាងនេះឡើយ ។

ទេវិលៈមិនអើពើនឹងពាក្យសម្តីរបស់នារទតាបសនោះឡើយ នៅតែចេះដាក់បណ្តាសានារទតាបសនោះដោយគាថាថា

ព្រះអាទិត្យ មានរស្មីរាប់ពាន់ មានតេជៈរាប់រយ មាន ប្រក្រតីកម្ចាត់នូវងងឹត លុះព្រះអាទិត្យរះឡើង មកក្នុង ពេលព្រឹក ក្បាលរបស់លោក ចូរបែកជា ៧ ភាគ ។

នារទតាបសពោលថា លោកអាចារ្យទោសរបស់ខ្ញុំមិនមាន កាលកំពុងពោលនោះឯង លោកម្ចាស់បានដាក់បណ្តាសាហើយ ទោសរបស់អ្នកណាមានក្បាលរបស់អ្នកនោះចូរបែកចុះ ក្បាលរបស់អ្នកមិនមានទោស កុំបីបែកឡើយ

ដូច្នេះហើយ បានជាក់បណ្តាសាដោយគាថាថា

ព្រះអាទិត្យ មានរស្មីរាប់ពាន់ មានតេជះរាប់រយ មាន
ប្រក្រតីកម្ចាត់នូវងងឹត លុះព្រះអាទិត្យរះឡើងក្នុងពេល
ព្រឹក ក្បាលរបស់លោក ចូរបែកជា ៧ ភាគចុះ ។

នារទតាបសនោះមានអានុភាពធំ អាចរឭកជាតិបាន ៨០ កប្ប គឺក្នុងអតីតកាល ៤០ កប្ប ក្នុងអនាគតកាល ៤០ កប្ប ។ ព្រោះហេតុនោះ លោកពិចារណាថា បណ្តាសានឹងធ្លាក់លើអ្នកណាហ្ន៎ដូច្នេះ កាលពិចារណាក៏ដឹងថា នឹងធ្លាក់ទៅលើលោកអាចារ្យ ។ អាស្រ័យសេចក្តីករុណាក្នុងទេវិលៈ ទើបបានឃាត់អារុណមិនឲ្យរះដោយកម្លាំងនៃឫទ្ធិ ។

អ្នកនគរកាលអារុណមិនរះ ក៏នាំគ្នាទៅកាន់ទ្វារព្រះរាជវាំង ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព កាលព្រះអង្គទ្រង់គ្រងរាជសម្បត្តិ អារុណមិនរះ សូមទ្រង់មេត្តាឲ្យអារុណរះ ដើម្បីទូលបង្គំទាំងឡាយចុះ ។

ព្រះរាជាទ្រង់ពិចារណាចរិយានុវត្ត មានកាយកម្មជាដើមរបស់ព្រះអង្គ ក៏មិនបានឃើញការដែលមិនសមគួរណាមួយ ទើបទ្រង់ព្រះតម្រិះថា ហេតុអ្វីហ្ន៎ដូច្នេះ ទ្រង់សង្ស័យថា ប្រហែលជាការវិវាទរបស់ពួកបុព្វជិត ដូច្នេះហើយ ទើបត្រាស់សួរថា ពួកបុព្វជិតក្នុងនគរនេះមានដែរឬទេ កាលមានបុគ្គលក្រាបទូលថា កាលពីល្ងាចមុ្ងលមិញនេះ មានពួកបុព្វជិតមកក្នុងរោងនាយស្នួនធ្នាំង ។ ព្រះរាជាមានរាជបុរសកាន់គប់ភ្លើងនាំទ្រង់ទៅក្នុងទីនោះ ក្នុងរំពេចនោះឯង ទ្រង់អភិវាទនារទតាបសហើយ ប្រថាប់ក្នុងទីសមគួរ នាចំណែកម្ខាង

ត្រាស់សួរថា

បពិត្រលោកម្ចាស់នារទៈ ការងារទាំងឡាយ របស់ពួកអ្នកជម្ពូទ្វីប រមែងប្រព្រឹត្តទៅមិនបាន ទ្វីបលោកកើតងងឹតហើយ ព្រោះហេតុអ្វី លោកម្ចាស់ដែលខ្ញុំសួរហើយ សូមប្រាប់ហេតុនោះដល់ខ្ញុំ ។

នារទតាបសពោលរឿងទាំងពួងថ្វាយហើយ ថ្វាយព្រះពរថា អាត្មាភាពដែលតាបសរូបនេះផ្តាសាហើយ ព្រោះហេតុនេះ កាលបើយ៉ាងនោះ ទើបអាត្មាភាពជាក់បណ្តាសាដែរថា ទោសរបស់ខ្ញុំមិនមាន ទោសរបស់បុគ្គលណាមាន បណ្តាសាចូរធ្លាក់លើបុគ្គលនោះឯង កាលផ្តាសាហើយ ទើបគិតថា បណ្តាសានឹងធ្លាក់លើអ្នកណាហ្ន៎ កាលពិចារណាទៅក៏ឃើញថា ក្នុងពេលព្រះអាទិត្យរះឡើង ក្បាលរបស់អាចារ្យនឹងបែកជា ៧ ភាគ ដូច្នេះហើយ អាស្រ័យសេចក្តីករុណាក្នុងលោក ទើបមិនឲ្យអារុណរះឡើង ។ ព្រះរាជាត្រាស់ថា ធ្វើយ៉ាងណាកុំឲ្យអន្តរាយមានដល់លោក នារទតាបសពោលថា បើលោកសូមខមាទោសនឹងអាត្មាភាព អន្តរាយនឹងមិនមាន ព្រះរាជាត្រាស់ថា បើយ៉ាងនោះសូមលោកម្ចាស់ខមាទោសចុះ ទេវិលតាបសពោលថា ជដិលនោះជាន់អាត្មាត្រង់ជជា និងក អាត្មាមិនព្រមសូមទោសជដិលកោងនោះឡើយ ។ ព្រះរាជាត្រាស់ថា សូមលោកម្ចាស់ខមាទោសចុះ កុំធ្វើយ៉ាងនេះឡើយ ។

ទេវិលតាបសទូលថា អាត្មាមិនព្រមសូមទោសឡើយ កាលព្រះរាជាត្រាស់ថា ក្បាលលោកម្ចាស់នឹងបែកជា ៧ ភាគ ដូច្នេះក៏នៅតែមិនព្រមសូម

ទោសនោះឯង ។

លំដាប់នោះ ព្រះរាជាត្រាស់ថា លោកម្ចាស់មិនព្រមសូមទោសតាមគាប់ចិត្តរបស់ខ្លួនឬ ដូច្នេះហើយ ច្រាប់ឲ្យរាជបុរសចាប់ទេវិលតាបសនោះត្រង់ដៃ ត្រង់ជើង ត្រង់ពោះ ត្រង់ក ឲ្យក្រាបទៀបបាទមូលរបស់នារទតាបស ។

នារទតាបសពោលថា លោកអាចារ្យ សូមលោកម្ចាស់ក្រោកឡើងចុះ ខ្ញុំព្រមអត់ទោសឲ្យលោកម្ចាស់ ដូច្នេះហើយ ថ្វាយព្រះពរថា បពិត្រមហារាជ តាបសនេះមិនខមាទោសអាត្មាដោយស្មគ្រចិត្តឡើយ មានស្រះមួយក្នុងទីមិនឆ្ងាយ សូមទ្រង់ឲ្យលោកឈរទូលជុំដីស្អិតលើក្បាល ត្រាំទឹកនៅក្នុងស្រះនោះ ត្រឹម-ក ។ ព្រះរាជាត្រាស់ឲ្យធ្វើយ៉ាងនោះហើយ ។ នារទតាបសហៅទេវិលតាបសមកថា លោកអាចារ្យកាលឫទ្ធិខ្ញុំរម្ងាយហើយ កាលពន្លឺព្រះអាទិត្យតាំងឡើង លោកម្ចាស់គប្បីមុជក្នុងទឹកហើយ ផុសឡើងក្នុងទីដទៃ ។ ដុំដីស្អិតលើក្បាលរបស់ទេវិលៈនោះ គ្រាន់តែរស្មីព្រះអាទិត្យពាល់ត្រូវប៉ុណ្ណោះក៏បែកជា ៧ ចម្រៀក ។ ទេវិលតាបសនោះបានជ្រមុជទៅកាន់ទីដទៃហើយ ។

ព្រះសាស្តាកាលទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាក្នុងកាលនោះបានជាអានន្ទ ទេវិលតាបសបានជាតិស្សៈ នារទតាបសបានជាតថាគតនេះឯង ។ សូម្បីក្នុងគ្រានោះ តិស្សៈនេះក៏ជាបុគ្គលប្រដៅក្រយ៉ាងនេះដូចគ្នាដូច្នេះហើយ ត្រាស់ឲ្យហៅតិស្សភិក្ខុមក ហើយត្រាស់ថា ម្នាលតិស្សៈ កាលភិក្ខុគិតថា អញត្រូវបុគ្គលនោះជេរហើយ ត្រូវបុគ្គលនោះប្រហារហើយ ត្រូវបុគ្គលនោះឈ្នះហើយ បុគ្គលនោះ បានលួចទ្រព្យ

របស់អញទៅហើយ ដូច្នេះ ឈ្មោះថា ពៀរមែងមិនរម្ងាប់បាន តែកាលកិកូមិនចូលទៅចង យ៉ាងនោះឯង ពៀរមែងរម្ងាប់បាន ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថា ដូច្នេះថា

អកោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។
អកោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។

អ្នកឯណោះ បានជេរអញ អ្នកឯណោះ បានវាយអញ អ្នកឯណោះ បានផ្តាញ់អញ អ្នកឯណោះ បានលួចយកទ្រព្យអញទៅហើយ បើអ្នកណាចងសេចក្តីក្រោធបែបនោះទុក (ដូច្នេះ) ពៀរបស់អ្នកនោះមិនរម្ងាប់ឡើយ ។

អ្នកឯណោះ បានជេរអញ អ្នកឯណោះ បានវាយអញ អ្នកឯណោះ បានផ្តាញ់អញ អ្នកឯណោះ បានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នកណាមិនចងសេចក្តីក្រោធបែបនោះទុក (ដូច្នេះ) ពៀរបស់អ្នកនោះ ទើបរម្ងាប់បាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អកោច្ឆិ** *គឺជេរហើយ ។ បទថា* **អវធិ** *គឺប្រហារហើយ ។ បទថា* **អជិនិ** *គឺបានឈ្នះអញដោយការអាងសាក្សីកោងខ្លះ*

ដោយការពោលផ្ដុំញ្ញផ្ដាល់ខ្លះ ដោយការធ្វើឲ្យក្រៃលែងជាងការធ្វើខ្លះ ។

បទថា **អហាសិ** *គឺបុគ្គលនោះបានលួចទ្រព្យ គឺបណ្ដាវត្ថុទាំងឡាយមានសំពត់ជាដើមណាមួយរបស់អញ ។*

ពីរបទថា **យេ ច តំ** *ជាដើម សេចក្ដីថា ជនពួកណាមួយ គឺទេវតាក្ដី មនុស្សក្ដី គ្រហស្ថក្ដី បព្វជិតក្ដី ចូលទៅចងសេចក្ដីក្រោធនោះ គឺមានវត្ថុជាដើមថា អ្នកឯណោះបានជេរអញ ដូចមនុស្សបុរសនេះ មួលទូកនេះដោយកូនកំព្រា និងដូចពួកអ្នកប្រម៉ាំងចងវត្ថុ មានត្រីស្អុយជាដើម ដោយវត្ថុ មានស្បូវភ្លាំងជាដើមរឿយៗ ។ ពៀរបស់ជននោះកើតឡើងហើយតែម្ដង រមែងមិនរម្ងាប់ គឺមិនស្ងប់បានឡើយ ។*

បានព្រះគាថាថា **យេ ច តំ នូបនយ្ហន្តិ** *សេចក្ដីថា ជនទាំងឡាយណាមិនចូលទៅចងសេចក្ដីក្រោធនោះ គឺមានពាក្យជេរជាដើមជាទីតាំង ដោយអំណាចការមិនរឭកដល់ និងការមិនធ្វើទុកក្នុងចិត្តខ្លះ ដោយអំណាចការពិចារណាឃើញកម្មយ៉ាងនេះថា បុគ្គលណាម្នាក់ដែលមិនមានទោស សូម្បីអ្នកគង់ជេរហើយក្នុងភពមុន គង់ប្រហារហើយក្នុងភពមុន គង់នឹងជួលសាក្សីកោងឈ្នះហើយក្នុងភពមុន ទ្រព្យណាមួយរបស់បុគ្គលណាម្នាក់ អ្នកគង់នឹងសង្កត់សង្កិនដណ្ដើមយកហើយក្នុងភពមុន ។ ព្រោះដូច្នោះ អ្នកសូម្បីជាបុគ្គលមិនមានទោស ទើបបានផលដែលមិនគួរប្រាថ្នា មានពាក្យជេរជាដើមដូច្នេះខ្លះ ពៀរបស់ជនទាំងនោះ សូម្បីកើតហើយ ព្រោះសេចក្ដីប្រមាទរមែងស្ងប់បានដោយការមិនចង សេចក្ដីក្រោធនេះ ដូចភ្លើងមិនមានកំញ្ជម*

កើតឡើងហើយ រលត់ទៅដូច្នេះឯង ។

ក្នុងកាលចប់ធម្មទេសនា ភិក្ខុមួយសែនរូបបានសម្រេចអរិយផលទាំង-ឡាយ មានសោតាបត្តិផលជាដើម ។ ព្រះធម្មទេសនាបានជាកថាមានប្រយោជន៍ដល់មហាជនហើយ ។ ព្រះតិស្សត្ថេរសូម្បីជាបុគ្គលប្រដៅក្រ ក៏ក្លាយជាបុគ្គលប្រដៅងាយហើយ ដូច្នេះឯង ។

រឿង ព្រះតិស្សត្ថេរ ចប់

រឿង នាងកាឡីយក្ខិនី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្រីអារម្នាក់ ត្រាស់ធម្មទេសនានេះថា **ន ហិ វេរេន វេរានិ** ជាដើម ។

បានញ្ញមកថា បុត្រកុដុម្ពិកៈម្នាក់ កាលបិតាធ្វើកាលកិរិយាហើយ ធ្វើការងារទាំងពួង ទាំងទីវាល ទាំងក្នុងស្រុកដោយខ្លួនឯង បដិបត្តិមាតា ។ បន្ទាប់មកមាតាបានប្រាប់ដល់បុត្រនោះថា នែបា ម៉ែនឹងនាំនាងកុមារិកាមកឲ្យឯង បុរសនោះពោលថា បពិត្រអ្នកម៉ែ សូមម៉ែកុំពោលយ៉ាងនេះឡើយ ខ្ញុំនឹងបដិបត្តិម៉ែដរាបដល់អស់ជីវិត ។ មាតាពោលថា នែបា អ្នកតែម្នាក់ឯងធ្វើការទាំងទីវាល និងក្នុងស្រុក ព្រោះហេតុនោះ ទើបម៉ែមិនមានការសប្បាយចិត្តឡើយ ម៉ែនឹងនាំកុមារិកាមកឲ្យឯង ។

បុរសនោះសូម្បីឃាត់ម្តាយច្រើនដងហើយ ក៏បាននៅស្ងៀម ។ មាតានោះចេញអំពីផ្ទះ ដើម្បីនឹងទៅកាន់ត្រកូលមួយ ។

លំដាប់នោះ បុត្រសួរមាតាថា អ្នកម៉ែទៅកាន់ត្រកូលណា ម្តាយតបថា ទៅកាន់ត្រកូលឈ្មោះនោះ ដូច្នេះហើយ ហាមការដែលទៅកាន់ត្រកូលនោះ ហើយប្រាប់ត្រកូលដែលខ្លួនពេញចិត្ត ។ មាតាបានទៅកាន់ត្រកូលនាងកុមារិកានោះហើយ កំណត់ថ្ងៃរៀបការ នាំកុមារិកាម្នាក់នោះមក បានធ្វើទុកក្នុងផ្ទះរបស់បុត្រ ។

កុមារិកានោះជាស្រីអារ ទើបមាតាពោលនឹងបុត្រថា នែបា អ្នកឲ្យម្តាយនាំកុមារិកាមកតាមគាប់ចិត្តរបស់ឯងហើយ ឥឡូវនេះ កុមារិកានោះជាស្រីអារ គ្មានកូន ធម្មតាត្រកូលដែលមិនមានបុត្រ រមែងអន្តរធានបវេណី រមែងមិនបន្តគ្នាទៅ ព្រោះដូច្នេះ ម៉ែនឹងនាំកុមារិកាជទៃមក សូម្បីកូននោះពោលឃាត់ថា សូមម៉ែកុំធ្វើដូច្នេះឡើយ ក៏ម្តាយនៅតែពោលយ៉ាងនោះរឿយៗ ។ ស្រីអារបានឮពាក្យនោះ ទើបគិតថា ធម្មតាកូនរមែងមិនអាចឃាត់ពាក្យមាតាបិតាបាន ឥឡូវនេះម៉ែក្មេកគិតនាំស្រីជទៃដែលមិនអារមកហើយ នឹងប្រើអញដូចជាទាសី បើយ៉ាងនោះអញនឹងនាំកុមារិកាម្នាក់មកដោយខ្លួនឯង ដូច្នេះហើយ ទើបទៅកាន់ត្រកូលមួយ សូមកុមារិកាដើម្បីប្រយោជន៍ដល់ប្តី ។ ត្រូវពួកជនក្នុងត្រកូលនោះឃាត់ថា នាងពោលអ្វីដូច្នោះ ដូច្នេះហើយ ទើបលួងលោមថា ខ្ញុំជាស្រីអារ ត្រកូលដែលមិនមានកូនរមែងវិនាស កូនស្រីរបស់អ្នក មានកូនហើយ នឹងបានជាម្ចាស់របស់សម្បត្តិ សូមលោកមេត្តាលើកកូន

នោះ ឲ្យដល់ប្តីរបស់ខ្ញុំចុះ ដូច្នេះហើយ ញុាំងត្រកូលនោះឲ្យព្រម ហើយនាំមកផ្ទះរបស់ប្តី ។

បន្ទាប់មកស្រីអារនោះ មានបរិវិតក្កថា បើស្រីនេះបានកូនប្រុស ឬកូនស្រីសោត វានឹងជាម្ចាស់សម្បត្តិតែម្នាក់ឯង អញគួរធ្វើនាងកុំឲ្យបានកូនទៀយ។

លំដាប់នោះ ទើបស្រីអារនោះពោលនឹងនាងនោះថា គភ៌តាំងទ្បើងក្នុងផ្ទៃរបស់នាងកាលណា សូមនាងប្រាប់ដល់ខ្ញុំក្នុងកាលនោះ នាងទទួលថា សាធុ កាលគភ៌តាំងហើយ បានប្រាប់ដល់ស្រីអារនោះ ។ ចំណែកស្រីអារនោះ បានឲ្យបបរ និងបាយដល់ស្រីនោះជានិច្ច ។ ក្រោយមកនាងបានឲ្យថ្នាំសម្រាប់រំលូតកូន លាយជាមួយអាហារដល់នាងនោះ គភ៌ក៏ធ្លាក់ ។ កាលគភ៌តាំងជាលើកទីពីរ នាងក៏បានប្រាប់ដល់ស្រីអារនោះ ស្រីអារនោះ ក៏បានធ្វើគភ៌ឲ្យធ្លាក់ដោយឧបាយយ៉ាងនោះឯង ជាលើកទីពីរ ។

លំដាប់នោះ ពួកស្រីដែលស្និទស្នាលគ្នាបានសួរស្រីនោះថា ស្រីរួមប្តីធ្វើអន្តរាយដល់នាងខ្លះដែរឬ នាងប្រាប់សេចក្តីនោះហើយ ត្រូវស្រីទាំងនោះពោលថា ស្រីអន្ធពាល ហេតុអ្វី ទើបនាងធ្វើយ៉ាងនោះ ស្រីអារនេះបានប្រកបថ្នាំសម្រាប់ធ្វើគភ៌ឲ្យធ្លាក់ដល់នាង ព្រោះខ្លាចនាងជាធំ ព្រោះដូច្នោះ ទើបគភ៌របស់នាងរលូត ។ នាងកុំធ្វើយ៉ាងនេះទៀត ។ ក្នុងលើកទីបី ទើបនាងមិនប្រាប់ ។ បន្ទាប់មក ស្រីអារឃើញពោះរបស់នាងនោះហើយ ទើបពោលថា ហេតុអ្វី ទើបនាងមិនប្រាប់ការមានគភ៌ដល់ខ្ញុំ កាលស្រីនោះពោលថា នាងនាំខ្ញុំមកហើយ ធ្វើគភ៌ខ្ញុំធ្លាក់ដល់ទៅពីរដង ខ្ញុំប្រាប់នាងធ្វើអ្វី ទើបគិតថា ឥឡូវ

នេះ អញវិនាសហើយ ឃ្លាំចាំមើលការប្រមាទរបស់កុមារិកានោះ កាលគភ៌ចាស់ទៃហើយ ទើបបានឱកាស បានប្រកបថ្នាំមិនឲ្យសម្រាលកូន ព្រោះគភ៌ចាស់ទើបដេកទទឹងទ្វារ ។ វេទនាដ៏ក្លាំងក្លាក៏កើតឡើង នាងក៏អស់ជីវិតទៅ ។

នាងតាំងសេចក្តីប្រាថ្នាថា អញត្រូវស្រីនេះឲ្យវិនាសហើយ ហាងនាំអញមក ធ្វើទារកឲ្យវិនាសដល់ទៅ ៣ នាក់ ឥឡូវនេះ ខ្លួនអញក៏វិនាស អញស្លាប់ពីអត្តភាពនេះ គប្បីកើតជាយក្ខិនីអាចទំពាស៊ីទារកបស់ហាងចុះ ដូច្នេះហើយ ស្លាប់ទៅកើតជាមេធ្នាក្នុងផ្ទះនោះឯង ។ ចំណែកស្វាមីចាប់ស្រីអារនោះ ហើយពោលថា ហាងបានធ្វើការកាត់ត្រកូលរបស់អញឲ្យដាច់សូន្យ ដូច្នេះហើយ វាយដោយអវយវៈទាំងឡាយ មានកែង និងជង្គង់ជាដើមឲ្យដាប ហើយ ស្រីអារនោះស្លាប់ព្រោះជំងឺនោះឯង ហើយកើតជាមេមាន់ក្នុងផ្ទះនោះដូចគ្នា ។

ចំណែរកាលមិនយូរ មេមាន់បានពងជាច្រើន ។ មេធ្នាមកស៊ីពងមាន់ទាំងនោះអស់ សូម្បីលើកទីពីរ លើកទីបី ធ្នាក៏ស៊ីដូចគ្នា ។ មេមាន់ធ្វើសេចក្តីប្រាថ្នាថា ហាងស៊ីពងរបស់អញអស់បីដងហើយ ឥឡូវនេះ ហាងក៏ចង់ស៊ីខ្លួនអញទៀតដូច្នេះ អញស្លាប់ពីអត្តភាពនេះហើយ គប្បីបានស៊ីហាង និងកូនរបស់ហាងដូច្នេះហើយ ។ ចុតិចាកអត្តភាពនោះ បានកើតជាមេខ្លាដំបង ។ ចំណែកមេធ្នា បានកើតជាមេម្រឹគ ។ ក្នុងកាលមេម្រឹគនោះកើតកូនហើយ មេខ្លាក៏បានមកស៊ីកូនទាំងឡាយដល់ទៅបីដង កាលដល់ពេលស្លាប់ មេម្រឹគធ្វើសេចក្តីប្រាថ្នាថា កូនរបស់អញមេខ្លានេះស៊ីអស់បីដងហើយ ឥឡូវនេះ វានឹង

ស៊ីខ្លួនអញផង ឥឡូវនេះ អញចុតិចាកអត្តភាពនេះហើយ គប្បីបានស៊ីកូនរបស់វាចុះ ដូច្នេះហើយ បានស្លាប់ទៅកើតជាយក្ខិនី ។ ចំណែកមេខ្លាចុតិអំពីអត្តភាពនោះហើយ កើតជាកុលធីតា ក្នុងក្រុងសាវត្ថី ។ នាងដល់នូវសេចក្តីចម្រើនហើយ បានទៅកាន់ត្រកូលប្តី ក្នុងស្រុកក្បែរទ្វារក្រុង ។ ចំណែរកាលតមក នាងបានប្រសូតកូនប្រុសម្នាក់ ។ នាងយក្ខិនីកាឡាខ្លួនជាស្រីសម្លាញ់ជាទីស្រឡាញ់របស់នាងមកហើយ សួរថា ស្រីសម្លាញ់របស់ខ្ញុំនៅទីណា ពួកអ្នកស្រុកបានប្រាប់ថា នាងប្រសូតបុត្រនូវខាងក្នុងបន្ទប់ ។ នាងយក្ខិនីស្តាប់ពាក្យនោះ ធ្វើជាពោលថា សម្លាញ់របស់ខ្ញុំប្រសូតកូនជាប្រុសឬជាស្រីហ្ន៎ ខ្ញុំនឹងមើលកូននោះ ដូច្នេះហើយ ចូលទៅធ្វើជាសម្លឹងមើលទាកចាប់ស៊ីហើយក៏ចេញទៅ ។ ក្នុងលើកទីពីរក៏បានស៊ីដូចគ្នា ។ ក្នុងលើកទីបី នាងកុលធីតាមានគកិចាស់ខែ ហៅប្តីមកហើយ ប្រាប់ថា នែអ្នក យក្ខិនីម្នាក់ស៊ីកូនរបស់ខ្ញុំអស់ពីរនាក់ហើយ ឥឡូវនេះ ខ្ញុំនឹងទៅកាន់ផ្ទះត្រកូលរបស់ខ្ញុំដើម្បីប្រសូតបុត្រ ដូច្នេះហើយ ទៅកាន់ផ្ទះនៃត្រកូលខ្លួន ប្រសូតបុត្រក្នុងទីនោះ ។ ក្នុងកាលនោះ យក្ខិនីនោះ ដល់នូវពេលបញ្ចូនទឹក ព្រោះថាយក្ខិនីទាំងឡាយ ត្រូវដងទឹកអំពីអនោតត្តស្រះ ទូលលើក្បាលមក ដើម្បីព្រះបាទវេស្សវណ តាមវារៈ ៤ ខែខ្លះ ៥ ខែខ្លះ ទើបផុតបាន ។ យក្ខិនីដទៃមានកាយហត់នឿយ ដល់នូវការអស់ជីវិតក៏មាន ។ ចំណែកយក្ខិនីនោះលុះផុតវេនដងទឹកហើយប៉ុណ្ណោះ ក៏ប្រញាប់ទៅកាន់ផ្ទះនោះ សួរថា សម្លាញ់របស់ខ្ញុំនៅឯណា ពួកអ្នកស្រុកប្រាប់ថា អ្នកនឹងជួបគេក្នុងទីណា ព្រោះយក្ខិនី

ម្នាក់ស៊ីកូនរបស់គេ ដែលប្រសូតក្នុងទីនេះ ព្រោះដូច្នេះ ទើបនាងទៅកាន់ផ្ទះ នៃត្រកូល ។ យក្ខិនីនោះគិតថា ទោះបីទៅក្នុងទីណាក៏ដោយ នឹងមិនផុតអំពី អញបានឡើយ ដូច្នេះហើយ ដោយកម្លាំងពៀរឲ្យឧស្សាហ៍ហើយ រត់បែរមុខ ទៅកាន់ក្រុង ។ ចំណែកនាងកុលធីតា ក្នុងថ្ងៃដាក់ឈ្មោះឲ្យទារកនោះ ងូតទឹក ដាក់ឈ្មោះ ហើយពោលនឹងប្តីថា នែអ្នក ឥឡូវនេះ យើងនាំគ្នាទៅកាន់ផ្ទះរបស់យើងចុះ ពបុត្រទៅជាមួយស្វាមីតាមផ្លូវកាត់ តម្រង់ទៅត្រង់កណ្តាលវិហារ ប្រគល់កូនឲ្យប្តីហើយ ចុះងូតទឹកក្នុងស្រះបោក្ខរណីក្បែរវិហារ ហើយឡើងមកទទួលយកកូន កាលប្តីកំពុងងូត ឈរឲ្យកូនជៅដោះ ឃើញយក្ខិនីមក ចាំបានហើយ ស្រែកដោយសំឡេងខ្លាំងថា នែអ្នកមកឲ្យធាប់ឡើង នេះយក្ខិនីនោះ ដូច្នេះហើយ មិនអាចឈរចាំរហូតប្តីនោះមកបាន ទើបរត់ត្រឡប់បែរមុខទៅកាន់វិហារហើយ ។

ក្នុងសម័យនោះ ព្រះសាស្តាទ្រង់សម្តែងធម៌ក្នុងកណ្តាលបរិស័ទ នាងកុលធីតានោះឲ្យកូនដេកទៀបខ្នងព្រះបាទរបស់ព្រះសុគត ហើយក្រាបទូលថា បុត្រនេះ ខ្ញុំម្ចាស់ថ្វាយដល់ទ្រង់ហើយ សូមទ្រង់ប្រទានជីវិតដល់កូនរបស់ខ្ញុំម្ចាស់ចុះ ។ សុមនទេវបុត្រដែលអាស្រ័យនៅត្រង់ខ្ងោងទ្វារ មិនអនុញ្ញាតឲ្យយក្ខិនីចូលទៅខាងក្នុង ។ ព្រះសាស្តាទ្រង់ត្រាស់ហៅព្រះអានន្ទត្ថេរមកហើយ ត្រាស់ថា ម្នាលអានន្ទ ចូរអ្នកទៅហៅយក្ខិនីនោះមក ព្រះអានន្ទទៅហៅយក្ខិនីនោះមកហើយ ។ នាងកុលធីតាក្រាបទូលថា បពិត្រព្រះអង្គ យក្ខិនីនេះមក ។ ព្រះសាស្តាត្រាស់ថា យក្ខិនីចូរមកចុះ នាងកុំយំថ្ងីឡើយ ដូច្នេះ

ហើយ បានត្រាស់នឹងយក្ខិនីដែលមកឈរហើយថា ហេតុអ្វី ទើបនាងធ្វើយ៉ាងនោះ បើពួកនាងមិនមកចំពោះមុខព្រះពុទ្ធ ដូចតថាគតហើយ ពៀរបស់ពួកនាង នឹងបានជាកម្មតាំងនៅអស់មួយកប្ប ដូចពៀរបស់ពស់ និងសត្វស្ការ របស់ខ្លាឃ្មុំ និងដើមពង្រ របស់ក្អែក និងសត្វមៀម ហេតុអ្វី ទើបពួកអ្នកធ្វើនូវពៀរវេរាឲ្យគ្នានៅវិញទៅមក ព្រោះពៀរម្ចាប់បានដោយការមិនមានពៀរ មិនមែនរម្ងាប់ដោយពៀរទ្បើយ ដូច្នេះហើយ បានត្រាស់គាថានេះថា

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ

អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

ពិតមែន តាំងពីកាលណា មកក្នុងលោកនេះ ពៀរទាំង-ទ្បាយ មិនរម្ងាប់ដោយពៀរទ្បើយ ពៀរទាំងទ្បាយ តែងរម្ងាប់ដោយមិនមានពៀរ នេះជាបវេណីធម៌ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ន ហិ វេរេន** *ជាដើម សេចក្តីថា ដូចបុគ្គលកាលលាងនូវបស់ប្រឡាក់ហើយ ដោយរបស់មិនស្អាត មានទឹកមាត់ ទឹកសម្បោរជាដើម ដោយរបស់មិនស្អាតទាំងនោះឯង រមែងមិនអាចធ្វើឲ្យបរិសុទ្ធ ជាត់ក្លិនស្អុយបាន ។ ដោយពិតនោះ បែរជាមិនបរិសុទ្ធ និងមានក្លិនស្អុយក្រៃលែងជាងមុនទៅទៀត យ៉ាងណា បុគ្គលកាលជេរតបបុគ្គលដែលជេរ ប្រហារតបជនដែលប្រហារ រមែងមិនអាចញុំាងពៀរឲ្យរម្ងាប់ដោយពៀរបានដោយពិត បុគ្គលឈ្មោះថា ធ្វើពៀរនោះឯងឲ្យក្រៃលែង ដូច្នោះនោះឯង ។*

ក្នុងកាលណាៗ ឈ្មោះថា ពៀរទាំងឡាយ រមែងមិនរម្ងាប់បានដោយពៀរទេឡើយ ។ ដោយពិត ឈ្មោះថា រមែងចម្រើនតែម្យ៉ាង ដោយប្រការដូច្នេះ ។

ពីរបទថា **អវេរេន ច សម្មន្តិ** *សេចក្តីថា ដូចរបស់មិនស្អាត មានទឹកមាត់ជាដើមនោះ ដែលបុគ្គលលាងដោយទឹកថ្លា រមែងបរិសុទ្ធបាន ទីដែលលាងនោះ រមែងជាទីបរិសុទ្ធ មិនមានក្លិនស្អុយ យ៉ាងណា ពៀរទាំងឡាយ រមែងរម្ងាប់ គឺរមែងស្ងប់ បានដល់ រមែងដល់នូវការមិនមានពៀរ ដោយទឹកគឺខន្តី និងមេត្តា ដោយការធ្វើទុកក្នុងចិត្តដោយឧបាយ ដោយការពិចារណាដូច្នោះនោះឯង ។*

បាទព្រះគាថាថា **ឯស ធម្មោ សនន្តនោ** *សេចក្តីថា ធម៌នេះ ដែលពាប់ថាការស្ងប់ពៀរដោយការមិនមានពៀរ ជាបុរាណធម៌ គឺជាមាគ៌ានៃព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពទាំងឡាយរាល់ៗ អង្គ យាងទៅហើយ ។*

ក្នុងកាលចប់គាថា យក្ខិនីនោះតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាបានជាប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាហើយ ។

ព្រះសាស្តា បានត្រាស់នឹងស្រីនោះថា នាងចូរឲ្យបុត្ររបស់នាងដល់យក្ខិនីចុះ នាងកុលធីតាពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គខ្លាច ព្រះសាស្តាត្រាស់ថា នាងកុំខ្លាចឡើយ ព្រោះអាស្រ័យយក្ខិនីនេះ អន្តរាយមិនមានដល់នាងឡើយ នាងបានឲ្យបុត្រដល់យក្ខិនីនោះហើយ យក្ខិនីនោះពទារកនោះឱបថើបហើយ ឲ្យដល់នាងវិញ ហើយទ្រហោយំ ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរយក្ខិនីនោះថា តើនាងកើតអ្វី យក្ខិនី

ក្រាបទូលថា បពិត្រព្រះអង្គ កាលមុនខ្ញុំម្ចាស់សម្រេចការចិញ្ចឹមជីវិត ដោយមិនជ្រើសរើស គង់មិនទាន់បានអាហារល្មមពេញពោះ ឥឡូវនេះ ខ្ញុំម្ចាស់ចិញ្ចឹមជីវិតបានដូចម្តេច ។

លំដាប់នោះ ព្រះសាស្តាត្រាស់លួងលោមយក្ខិនីនោះថា នាងកុំគិតខ្លាយ ដូច្នេះហើយ ត្រាស់នឹងស្រីនោះថា នាងចូរនាំយក្ខិនីទៅឲ្យនៅក្នុងផ្ទះរបស់ខ្លួន ហើយចូរបដិបត្តិដោយបបរ និងបាយយ៉ាងល្អ ។ ស្រីនោះនាំយក្ខិនីទៅហើយ ឲ្យស្នាក់នៅក្នុងរោងត្បាល់ក្តឿង បានបដិបត្តិដោយបបរ និងបាយយ៉ាងល្អហើយ ក្នុងកាលបុកស្រូវអង្រែប្រាកដដល់យក្ខិនីនោះ ដូចត្រូវក្បាល ។ ទើបហៅនាងកុលធីតាដែលជាសម្ងាញ់មកហើយ ពោលថា ខ្ញុំមិនអាចនៅក្នុងទីនេះបាន នាងចូរឲ្យខ្ញុំស្នាក់នៅក្នុងទីដទៃចុះ ស្រីសម្ងាញ់នោះឲ្យស្នាក់នៅក្នុងទីទាំងនេះ គឺក្នុងរោងអង្រែក្បែរពាងទឹក ក្បែរចង្រ្កាន ត្រង់សំយាបផ្ទះ ក្បែរគំនរសំរាម ក្បែរទ្វារស្រុក នាងក៏ពោលថា ក្នុងរោងអង្រែនេះ អង្រែរមែងប្រាកដដូចវាយក្បាលខ្ញុំ ត្រង់ក្បែរពាងទឹកនេះ ពួកក្មេងរមែងជាចទឹកដែលសល់ទៅ ។ ក្បែរចង្រ្កាននេះ ពួកឆ្កែរមែងមកដេក ត្រង់សំយាបផ្ទះ ពួកក្មេងរមែងធ្វើស្មោកគ្រោក ក្បែរគំនរសំរាមនេះ ជនទាំងឡាយរមែងចាកសំរាមក្បែរទ្វារស្រុកនេះ ពួកក្មេងអ្នកស្រុក រមែងលេងក្លាល់គ្នាដោយការគណនាដូច្នេះហើយ បានឃាត់ទីទាំងពួងនោះ ។

គ្រានោះ ទើបស្រីសម្ងាញ់ ឲ្យនាងយក្ខិនីនោះ ស្នាក់នៅត្រង់ទីស្ងាត់ខាងក្រៅស្រុកហើយ នាំកោជនមានបបរ និងបាយជាដើមយ៉ាងល្អ ទៅដើម្បីយក្ខិនី

នោះ ហើយបដិបត្តិក្នុងទីនោះ ។ យក្ខិនីនោះគិតយ៉ាងនេះថា ឥឡូវនេះ សម្លាញ់របស់អញមានឧបការៈច្រើនដល់អញ ណ្ហើយចុះ អញនឹងតបគុណណាមួយដូច្នេះហើយ បានប្រាប់ដល់ស្រីសម្លាញ់នោះថា ក្នុងឆ្នាំនេះ នឹងមានភ្លៀងល្អ នាងចូរធ្វើស្រូវក្នុងទីទួលចុះ ក្នុងឆ្នាំនេះ មានភ្លៀងរាំង នាងចូរធ្វើស្រូវត្រង់ទីទំនាបចុះ សំណាបដែលពួកជនដ៏សេសធ្វើហើយ រមែងខូចបង់ដោយទឹកច្រើនពេកខ្លះ ដោយទឹកតិចខ្លះ ចំណែកសំណាបរបស់នាងកុលធីតានោះ រមែងបរិបូណ៌ពន់ពេក ។

គ្រានោះ ពួកជនដ៏សេសទាំងនោះនាំគ្នាសួរនាងថា នែនាង សម្ងួតដែលនាងធ្វើហើយ មិនខូចខាតដោយទឹកច្រើនពេក រមែងមិនខូចខាតដោយទឹកតិចពេក នាងដឹងភ្លៀងល្អ និងភ្លៀងរាំងហើយ ទើបធ្វើការងារឬ ។ សេចក្តីនេះដូចម្តេចហ្ន៎ នាងប្រាប់ថា យក្ខិនីជាសម្លាញ់របស់ខ្ញុំប្រាប់ភាពដែលភ្លៀងល្អ និងភ្លៀងរាំងដល់ខ្ញុំ ខ្ញុំធ្វើស្រូវទាំងឡាយ ក្នុងទីទួល និងទីទំនាបតាមពាក្យរបស់យក្ខិនីនោះ ហេតុនោះ ទើបស្រូវរបស់ខ្ញុំសម្បូរល្អ ។ ពួកអ្នកមិនឃើញកោជនមានបបរ និងបាយជាដើម ដែលខ្ញុំនាំទៅអំពីផ្ទះជានិច្ចទេឬ របស់ទាំងនោះ ខ្ញុំនាំទៅឲ្យយក្ខិនីនោះ សូម្បីពួកអ្នកក៏ចូរនាំកោជន មានបបរ និងបាយជាដើមយ៉ាងល្អ ទៅឲ្យយក្ខិនីផងចុះ នាងនឹងមើលថែការងាររបស់ពួកអ្នកដែរ ។

គ្រានោះ ពួកអ្នកស្រុកទាំងអស់នាំគ្នាធ្វើសក្ការៈដល់យក្ខិនីនោះហើយ ។ ចាប់តាំងពីពេលនោះមក នាងមើលថែការងារទាំងឡាយរបស់ជនទាំងពួង ជាអ្នកបានទួរលាភដ៏ប្រសើរ មានបរិវារច្រើនហើយ ។

ក្នុងកាលតមក យក្ខិនីនោះរៀបចំសលាកភត្ត ៨ សម្រាប់ហើយ ។ សលាកភត្តនោះ ជនទាំងឡាយនៅតែប្រគេនរហូតដល់សព្វថ្ងៃនេះឯង ៕

រឿង នាងកាឡិយក្ខិនី ចប់

រឿង ភិក្ខុក្រែងកោសម្ពី

លំនាំដើម

ព្រះសាស្តា គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុក្រែងកោសម្ពី ត្រាស់ព្រះធម្មទេសនាថា **ឃរេ ច ន វិជាយន្តិ** *ជាដើម ។*

សេចក្តីពិស្តារថា ភិក្ខុពីររូប គឺព្រះវិនយធរមួយរូប ព្រះធម្មកថិកមួយរូប មានបរិវារមួយរូប ៥០០ បាននៅក្នុងឃោសិតារាម ក្បែរក្រុងកោសម្ពី ។ ថ្ងៃមួយ ក្នុងភិក្ខុពីររូបនោះ ធម្មកថិកទៅបង្គន់ហើយ រៀរទឹកជម្រះដ៏សេសទុកក្នុងភាជន៍ ត្រង់អាងទឹកហើយ ចេញមក ។ ក្រោយមក ព្រះវិនយធរចូលទៅត្រង់អាងទឹកនោះ ឃើញទឹកនោះ ចេញមកសួរព្រះធម្មកថិកថា អាវុសោ លោកបន្សល់ទឹកទុកឬ ព្រះធម្មធរពោលថា ករុណាលោកម្ចាស់ ព្រះវិនយធរពោលថា លោកមិនដឹងថា អាបត្តិ ព្រោះការបន្សល់ទឹកនេះឬ ព្រះធម្មធរពោលថា ខ្ញុំព្រះករុណាមិនដឹង ព្រះវិនយធរពោលថា មិនដឹង ក៏ហីទៅចុះ អាវុសោ តែជាអាបត្តិក្នុងសេចក្តីនេះ ព្រះធម្មធរពោលថា បើយ៉ាងនោះ ខ្ញុំ

នឹងសម្តែងអាបត្តិនោះចេញ ។ ព្រះវិនយធរពោលថា អាវុសោ បើសេចក្តីនោះ លោកមិនក្តែងព្រោះមិនមានស្មារតី អាបត្តិមិនមាន ។

ព្រះធម្មកថិកនោះ បានជាបុគ្គលមានការឃើញអាបត្តិនោះ ថាមិនមែនអាបត្តិ ។ ចំណែកព្រះវិនយធរបានប្រាប់ដល់ពួកនិស្សិតរបស់ខ្លួនថា ព្រះធម្មកថិករូបនេះ សូម្បីត្រូវអាបត្តិក៏មិនដឹង ពួកនិស្សិតព្រះវិនយធរនោះ ឃើញពួកនិស្សិតរបស់ព្រះធម្មកថិកនោះហើយ បានពោលថា ឧបជ្ឈាយ៍របស់ពួកលោកសូម្បីត្រូវអាបត្តិហើយ ក៏មិនដឹងថា ត្រូវអាបត្តិ ។ ពួកកូនសិស្សរបស់ព្រះធម្មកថិកនោះ ទៅប្រាប់ដល់ឧបជ្ឈាយ៍របស់ខ្លួនហើយ ។ ព្រះធម្មកថិកនោះពោលយ៉ាងនេះថា ព្រះវិនយធររូបនេះកាលមុនពោលថា មិនជាអាបត្តិឥឡូវនេះ ពោលថាជាអាបត្តិ ព្រះវិនយធរនោះពោលមុសា ពួកកូនសិស្សរបស់ព្រះធម្មកថិកទៅពោលថា ឧបជ្ឈាយ៍របស់ពួកលោកពោលមុសា ពួកនិស្សិតរបស់ព្រះវិនយធរ និងព្រះធម្មកថិកនោះ ធ្វើទុវជម្ចោះដល់គ្នា និងគ្នាឲ្យចម្រើនហើយ ដោយប្រការយ៉ាងនេះ ។

ក្រោយមក ព្រះវិនយធរបានឱកាសហើយ ទើបបានធ្វើឧក្ខេបនីយកម្មដល់ព្រះធម្មកថិក ព្រោះទោសដែលមិនឃើញអាបត្តិ ។ ចាប់តាំងពីកាលនោះ សូម្បីពួកឧបដ្ឋាក ដែលប្រគេនបច្ច័យដល់ភិក្ខុពីររូបនោះ ក៏បែកគ្នាជាពីរចំណែក ពួកភិក្ខុនីដែលទទួលឱវាទក្តី ពួកអារក្ខទេវតាក្តីរបស់ភិក្ខុពីររូបនោះ ពួកអាកាសទេវតាដែលជាសម្ងាញ់ស្និទស្នាលរបស់ពួកអារក្ខទេវតាទាំងនោះក្តី ពួកបុថុជ្ជនទាំងឡាយក្តី ក៏បែកគ្នាជាពីរចំណែក រហូតដល់ព្រហ្មលោក ក៏កោលាហលកង

រំពងដោយសំឡេងតែមួយ រហូតដល់អកនិដ្ឋភព ។

គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះតថាគត ក្រាបទូលការដែលពួកភិក្ខុលើកវត្ត ប្រកាន់ថា ព្រះធម្មកថិករូបនេះ សង្ឃលើកវត្តហើយ ដោយកម្មដែលប្រកបដោយធម៌ពិត កាលដែលពួកភិក្ខុប្រព្រឹត្តតាមព្រះធម្មកថិក ដែលសង្ឃលើកវត្តហើយ ប្រកាន់ថា ព្រះឧបជ្ឈាយ៍របស់ពួកយើង សង្ឃលើកវត្តហើយ ដោយកម្មដែលមិនប្រកបដោយធម៌ ។ ការដែលពួកភិក្ខុប្រព្រឹត្តតាមព្រះធម្មកថិក បុគ្គលដែលសង្ឃលើកវត្តទាំងនោះ សូម្បីពួកភិក្ខុដែលលើកវត្តឃាត់ហើយ ក៏នៅតែចចេសតាមចោមរោមព្រះធម្មកថិកនោះ ។ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ជូនឱវាទទៅថា ភិក្ខុទាំងឡាយ ចូរព្រមព្រៀងគ្នា អស់វារៈពីរដងហើយ ទ្រង់បានឮថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងឡាយមិនប្រុងប្រាព្រមព្រៀងគ្នាឡើយ លើកទីបី ទ្រង់ឮថា ភិក្ខុសង្ឃបែកគ្នាហើយ ភិក្ខុសង្ឃបែកគ្នាហើយ ដូច្នេះ ទើបទ្រង់ទៅកាន់សម្នាក់របស់ភិក្ខុទាំងឡាយ ហើយត្រាស់ទោសក្នុងការលើកវត្តរបស់ពួកភិក្ខុដែលលើកវត្ត និងទោសក្នុងការមិនឃើញអាបត្តិរបស់ពួកភិក្ខុក្រៅអំពីនេះហើយ ទ្រង់អនុញ្ញាតសង្ឃកម្មទាំងឡាយ មានឧបោសថជាដើម ក្នុងសីមាតែមួយ ត្រង់យោសិតារាមនោះឯង ដល់ភិក្ខុទាំងឡាយទៀត ហើយទ្រង់បញ្ញត្តិវត្តក្នុងភោជនសាលាថា ម្នាលភិក្ខុទាំងឡាយ គប្បីអង្គុយក្នុងជួរមានអាសនៈមួយៗ ក្នុងចន្លោះៗ ដូច្នេះជាដើម ដល់ភិក្ខុទាំងឡាយដែលកើតការប្រេះឆា ក្នុងទីទាំងឡាយ មានភោជនសាលាជាដើម ហើយទ្រង់បានឮថា សូម្បីឥឡូវនេះ ភិក្ខុទាំងឡាយ ក៏នៅតែប្រេះឆា

និងគ្នា ទើបទ្រង់ទៅកាន់យោសិតារាមនោះ ហើយត្រាស់ឃាត់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំបីធ្វើការប្រេះឆាគ្នា ឡើយ ដូច្នេះជាដើមហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ការប្រេះឆា ការឈ្លោះប្រកែក ប្រណាំង ប្រជែង និងការវិវាទនោះ ធ្វើនូវសេចក្តីវិនាសមកឲ្យមែនពិត សូម្បីសត្វ ប្រចៀចអាស្រ័យការឈ្លោះគ្នា គង់អាចធ្វើស្តេចជីវិឲ្យដល់នូវការអស់ជីវិត ដូច្នេះហើយ ទ្រង់ត្រាស់លដុកិកជាតក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរព្រមព្រៀងគ្នាចុះ កុំវិវាទគ្នាឡើយ ព្រោះថា សូម្បីសត្វចាបទាំង-ឡាយ អាស្រ័យការវិវាទគ្នា ដល់នូវការអស់ជីវិត ដូច្នេះហើយ ទ្រង់ត្រាស់វដ្តកជាតក ។

ទោះបីយ៉ាងនេះ ពួកភិក្ខុនោះក៏មិនស្តាប់ព្រះវាចា កាលភិក្ខុជាធម្មវាទីរូបណាមួយមិនពេញចិត្តឲ្យព្រះតថាគតទ្រង់លំបាក ក៏ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ដែលជាម្ចាស់នៃធម៌ ទ្រង់បង្អង់សិន បពិត្រព្រះអង្គ សូមព្រះដ៏មានព្រះភាគ ទ្រង់មានសេចក្តីខ្វល់ខ្វាយតិច ប្រកបព្យាយាមក្នុងធម៌ជាគ្រឿងនៅជាសុខក្នុងទិដ្ឋធម៌ចុះ ពួកខ្ញុំព្រះអង្គនឹងប្រាកដ ព្រោះការប្រេះឆា ការទាស់ទែង ការប្រកួតប្រជែង និងការវិវាទនោះឯង ព្រះដ៏មានព្រះភាគត្រាស់និទានដល់ភាពដែលព្រះបាទទីឃីតិកោសលរាជ ត្រូវព្រះបាទព្រហ្មទត្ត រឹបជាន់យកទ្រព្យសម្បត្តិ កៃង៉ភេទមិនឲ្យអ្នកណាស្គាល់ ស្តេចនៅក្នុងក្រុងពារាណសី ត្រូវចាប់ផ្តាច់ព្រះជន្មហើយ និងការដែលព្រះបាទព្រហ្មទត្ត និងទីឃាវុកុមារនោះ ព្រមព្រៀងគ្នា ចាប់តាំងពីកាលទីឃាវុកុមារ លើកព្រះជន្មរបស់ព្រះអង្គថ្វាយ

ថា ម្នាលភិក្ខុទាំងឡាយ រឿងនេះធ្លាប់មានមកហើយក្នុងក្រុងពារាណសី មានព្រះបាទក្រុងកាសីមួយអង្គ ព្រះនាមថាព្រហ្មទត្តដូច្នេះជាដើម ។ សូម្បីត្រាស់ទូន្មានថា ម្នាលភិក្ខុទាំងឡាយ ការអត់សង្កត់ និងការស្ងប់ស្ងៀមបែបនោះ គង់មានហើយដល់ព្រះរាជាទាំងនោះ ដែលមានដំបងកាន់ហើយ មានសស្ត្រាកាន់ហើយ ការដែលអ្នកទាំងឡាយបួសហើយក្នុងធម្មវិនយ ដែលពោលប្រពៃហើយយ៉ាងនេះ គួរជាអ្នកអត់ធ្មត់ ជាអ្នកស្ងប់ស្ងៀម គប្បីស្អាតក្នុងធម្ម-វិនយនេះឯង ដូច្នេះហើយ ក៏មិនអាចឲ្យភិក្ខុទាំងឡាយព្រមព្រៀងគ្នាបាន ។

ព្រះដ៏មានព្រះភាគ ទ្រង់រអាព្រះហឫទ័យព្រោះការនៅរង្គៀសនោះ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ តថាគតនៅរង្គៀសជាទុក្ខ ភិក្ខុទាំងនេះមិនធ្វើតាមពាក្យរបស់តថាគត បើដូច្នោះ តថាគតគប្បីចៀសចេញចាកគណៈនៅម្នាក់ឯងដូច្នេះហើយ ទ្រង់យាងចូលបាតក្នុងក្រុងកោសម្ពី មិនត្រាស់ប្រាប់ភិក្ខុសង្ឃ ទ្រង់កាន់បាតចីវររបស់ទ្រង់ យាងទៅពាលកលោណកាវាមតែមួយព្រះអង្គឯង ត្រាស់ឯកចារិកវត្តជល់ព្រះភគុ ត្រង់ពាលកលោណកាវាមនោះហើយ ត្រាស់អានិសង្សនៃសាមគ្គីរសជល់កុលបុត្រ ៣ រូប ក្នុងមិគទាយវន ឈ្មោះបាចីន-វំសៈ ហើយយាងទៅកាន់ព្រៃបាលិលេយ្យកៈ ។ បានឮមកថា គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់អាស្រ័យព្រៃបាលិលេយ្យកៈ ទ្រង់ចាំវស្សាត្រង់គល់សាល-ព្រឹក្សធំ ក្នុងជង្ឃព្រៃភ្ជិតវន ដែលជិរីបាលិលេយ្យកៈឧបដ្ឋាក នៅជាសុខ ។

ចំណែកពួកឧបាសក ដែលនៅក្នុងក្រុងកោសម្ពីឯណោះ ទៅកាន់វិហារមិនឃើញព្រះសាស្តា ទើបសួរថា បពិត្រលោកម្ចាស់ ព្រះសាស្តាយាងទៅទី

ណា ភិក្ខុទាំងនោះពោលថា ទ្រង់ទៅកាន់ព្រៃបាលិលេយ្យកៈហើយ ឧបាសក សួរថា ព្រោះហេតុអ្វី ភិក្ខុទាំងឡាយប្រាប់ថា ទ្រង់ព្យាយាមធ្វើពួកអាត្មាឲ្យ ព្រមព្រៀងគ្នា តែពួកអាត្មាមិនបានជាអ្នកព្រមព្រៀងគ្នាឡើយ ឧបាសកពោល ថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយ បួសក្នុងសម្នាក់របស់ព្រះ សាស្តាហើយ សូម្បីទ្រង់ធ្វើសាមគ្គី ក៏មិនបានជាអ្នកសាមគ្គីគ្នាហើយឬ ភិក្ខុ ទាំងឡាយពោលថា អើ យ៉ាងនោះឯង ពួកមនុស្សគិតថា ពួកភិក្ខុនេះ បួស ក្នុងសម្នាក់របស់ព្រះសាស្តាហើយ សូម្បីទ្រង់ធ្វើសាមគ្គីក៏មិនសាមគ្គីគ្នា ពួក យើងមិនបានឃើញព្រះសាស្តា ព្រោះអាស្រ័យភិក្ខុទាំងឡាយនេះ ពួកយើង មិនថ្វាយអាសនៈ និងមិនធ្វើសាមីចិកម្ម មានការថ្វាយបង្គំជាដើមដល់ភិក្ខុទាំង-ឡាយនេះ ។ ចាប់តាំងពីកាលនោះមក ក៏មិនធ្វើសូម្បីត្រឹមតែសាមីចិកម្មដល់ ភិក្ខុទាំងនោះ ។ ភិក្ខុទាំងឡាយស្គមស្គាំងព្រោះមានអាហារតិច ក្នុងកាលពីរ បីថ្ងៃប៉ុណ្ណោះក៏ជាបុគ្គលត្រង់ សម្តែងទោសដែលប្រព្រឹត្តកន្ទងដល់គ្នានិងគ្នា សូមខមាទោសដល់គ្នានិងគ្នាហើយ ពោលថា នែឧបាសកទាំងឡាយ ពួក អាត្មាព្រមព្រៀងគ្នាហើយ ពួកអ្នកចូរឲ្យពួកអាត្មាដូចកាលមុនចុះ ។ ឧបាសក ទាំងឡាយពោលថា លោកម្ចាស់ទាំងឡាយ ទូលសូមខមាទោសព្រះសាស្តា ហើយឬ ភិក្ខុទាំងឡាយប្រាប់ថា មិនទាន់បានខមាទោសទេ ឧបាសកទាំង-ឡាយពោលថា បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយ ទូលសូមខមាទោស នឹងព្រះសាស្តាចុះ ចំណែកពួកខ្ញុំ និងពួកលោកម្ចាស់ នឹងជាគ្នាដូចកាលមុន ក្នុងកាលពួកលោកម្ចាស់សូមខមាទោសព្រះសាស្តាហើយ ។

ភិក្ខុទាំងឡាយមិនអាចទៅកាន់សម្នាក់របស់ព្រះសាស្តា ព្រោះខាងក្នុងវស្សា ញ៉ាំងខាងក្នុងវស្សានោះឲ្យកន្ងទៅដោយសេចក្តីលំបាក ។

ចំណែកព្រះសាស្តាដែលជំរីនោះឧបដ្ឋាក ប្រថាប់នៅជាសុខហើយ ចំណែកជំរីរនោះលះហ្ងូងចូលទៅកាន់ដងព្រៃនោះ ដើម្បីការនៅជាសុខ ព្រះធម្មសង្គាហកាចារ្យពោលដូចម្តេច ព្រះធម្មសង្គាហកាចារ្យពោលថា (គ្រានោះ សេចក្តីត្រិះរិះមានដល់ស្តេចជំរីនោះថា) អញត្រូវរុកកូនដោយពួកជំរីញី ជំរីស្ទាវ និងកូនជំរី ទំពាស៊ីស្មៅដែលគេកាត់ចុងហើយ និងចាំស៊ីមែកឈើដែលបាក់ធ្លាក់ចុះ ហើយអញផឹកទឹកដែលល្អក់ កាលអញចុះកាន់កំពង់ហើយ ពួកជំរីញីក៏ដើរជ្រៀតបៀតទៅ បើដូច្នោះ អញនឹងចេញអំពីហ្ងូងម្នាក់ឯង ។ គ្រានោះ ឯង ស្តេចជំរីនោះ ចៀសចេញអំពីហ្ងូវ ចូលទៅក្នុងព្រៃបាលិលេយ្យកៈ ដែលជាព្រៃរក្ខិតវន ត្រង់មណ្ឌលដើមសាលព្រឹក្សធំ ដែលព្រះដ៏មានព្រះភាគទ្រង់គង់ហើយ កាលចូលទៅហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ សម្ងឹងមើលមិនឃើញវត្ថុណាមួយ ទើបជាន់ត្រង់គល់សាលព្រឹក្សធំដោយជើង ឈូសឲ្យរាបស្មើ កាន់មែកឈើដោយប្រមោយបាស ។ តាំងអំពីនោះមក ស្តេចជំរីនោះចាប់ក្អមដោយប្រមោយ ដងទឹកធាន់ នាំមកតម្កល់ទុក កាលទ្រង់បំណងដោយទឹកក្តៅ ក៏រៀបចំទឹកក្តៅថ្វាយ ។ ស្តេចជំរីនោះ រៀបចំទឹកក្តៅបានដូចម្តេច ស្តេចជំរីនោះកួតឈើងាប់ដោយប្រមោយ ឲ្យភ្ងើងកើតឡើងដាក់អុសឲ្យធេះឡើង យកថ្មដាក់ក្នុងគំនរភ្ងើងនោះហើយ ធ្តឹះដុំថ្មនោះទៅដោយកំណាត់ឈើ ប្រមៀលចុះទៅក្នុងត្រពាំងតូច ដែលខ្ជូនចំណាំ លំដាប់

នោះ លូកប្រមោយចូលទៅក្នុង ដីឆ៖ថា ទឹកក្តៅហើយ ទើបថ្វាយបង្គំព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា ម្នាលបាលិលេយ្យកៈ ទឹកអ្នកជាំហើយឬដូច្នេះហើយ ទ្រង់យាងទៅស្រង់ក្នុងទីនោះ ។ ក្នុងកាលនោះ ស្តេចដ៏វីរនោះ នាំផ្លែឈើជាច្រើនមកថ្វាយដល់ព្រះសាស្តា កាលព្រះសាស្តាទ្រង់ចូលស្រុកដើម្បីបិណ្ឌបាត ស្តេចដ៏វីរនោះកាន់បាត្រ និងចីវរទុកលើពោង ដើរតាមព្រះសាស្តាទៅ ។ ព្រះសាស្តាយាងដល់ស្រុកហើយច្រាបថា ម្នាលបាលិលេយ្យកៈ ចាប់អំពីនេះទៅ អ្នកមិនអាចទៅបានឡើយ អ្នកចូរយកបាត្រ និងចីវរបស់តថាគតមក ដូច្នេះហើយ ឲ្យស្តេចដ៏វីរនោះយកបាត្រ និងចីវរ មកថ្វាយហើយ ទ្រង់ចូលស្រុកដើម្បីបិណ្ឌបាត ចំណែកស្តេចដ៏វីរនោះឈរក្នុងទីនោះឯង ទម្រាំព្រះសាស្តាទ្រង់យាងមក ក្នុងពេលព្រះសាស្តាទ្រង់យាងមក ធ្វើការទទួលហើយ កាន់បាត្រ និងចីវរដោយនយមុន ទៅដាក់ចុះក្នុងទីប្រថាប់ហើយ ថ្វាយនូវការបក់ដោយមែកឈើ សម្តែងវត្ត ។ ក្នុងរាត្រី ស្តេចដ៏វីរនោះកាន់កំណាត់ឈើធំដោយប្រមោយ ត្រាច់ទៅក្នុងចន្លោះៗ នៃដងព្រៃ ទម្រាំអារុណរះឡើង ដើម្បីការពារអន្តរាយដែលមានអំពីសត្វសាហាវ ដោយតាំងចិត្តថា អញនឹងរក្សាព្រះសាស្តា ។ បានឮថា ដងព្រៃនោះ ឈ្មោះថា រក្ខិតវនសណ្ឌៈ តាំងអំពីកាលនោះមក ។ កាលអរុណរះហើយ ស្តេចដ៏វីរនោះ ធ្វើវត្តទាំងពួងដោយឧបាយនោះឯង ផ្តើមតាំងអំពីការថ្វាយទឹកលុបព្រះភក្ត្រ ។

ក្នុងកាលនោះ ពានរមួយឃើញដ៏វីរនោះក្រោកឡើងហើយ ធ្វើអភិសមាចារិកវត្តដល់ព្រះតថាគតហើយគិតថា អញនឹងធ្វើអ្វីមួយថ្វាយហ្ន៎ ហើយត្រាច់

ទៅ ថ្ងៃមួយ យើញសម្បុកយ្ចុំប្រាសចាកមេត្រង់មែកឈើ កាច់មែកឈើហើយ នាំសម្បុកយ្ចុំព្រមទាំងមែកឈើ ទៅកាន់សម្នាក់ព្រះសាស្តា បានកាច់ស្ងឹកចេកទ្រថ្ងាយ ។ ព្រះសាស្តាទ្រង់ទទួលហើយ ។ ពានរកំពុងសម្ងឹងមើលដោយគិតថា ព្រះសាស្តាទ្រង់ឆាន់ឬអត់ហ្នឹ យើញព្រះសាស្តាទ្រង់ទទួលហើយ គង់ធ្វើព្រងើយ គិតថា ហេតុអ្វីហ្នឹ ទើបចាប់មែកឈើប្រែឡើង ប្រែចុះ ពិចារណាមើល យើញកូនយ្ចុំតូចៗ ហើយ ទើបនាំកូនយ្ចុំនោះចេញសន្សឹមៗ ហើយប្រគេនជាថ្មី ។ ព្រះសាស្តាទ្រង់សោយហើយ ។ ពានរនោះមានចិត្តត្រេកអរ បានចាប់មែកឈើនោះៗ ឈរសម្រាក ក្នុងកាលនោះ មែកឈើដែលពានរនោះចាប់ក្តី មែកឈើដែលពានរនោះឈរហើយក្តី បាក់ហើយ ។ ពានរនោះធ្លាក់ចុះចំជង្គត់ឈើមួយ មានខ្លួនត្រូវជង្គត់ទម្លុះហើយ មានចិត្តជ្រះថ្លាធ្វើកាលកិរិយាហើយ កើតក្នុងវិមានមាសកម្ពស់ ៣០ យោជន៍ ក្នុងស្ថានតាវត្តិង្ស មានស្រីទេពអប្សរមួយពាន់ជាបរិវារ ។

កាលដែលព្រះតថាគត ដែលជំរីឧបដ្ឋាកប្រថាប់នៅក្នុងជងព្រៃរក្ខិតវននោះ បានប្រាកដពេញផ្ទៃជម្ពូទ្វីប ។ ត្រកូលធំៗ គឺអនាថបិណ្ឌិកសេដ្ឋី និងនាងវិសាខាមហាឧបាសិកាជាដើម បានបញ្ជូនជំណឹងអំពីនគរសាវត្ថី ទៅដល់ព្រះអានន្ទត្ថេរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បង្ហាញព្រះសាស្តាដល់ពួកខ្ញុំ ។ ចំណែកភិក្ខុ ៥០០ រូបដែលនៅក្នុងទិសចាំវស្សាហើយ ចូលទៅរកព្រះអានន្ទត្ថេរ ស្នើថា អាវុសោអានន្ទ ធម្មីកថាក្នុងទីចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ យើងខ្ញុំខានស្តាប់មកយូរហើយ អាវុសោអានន្ទ យើងខ្ញុំ

គប្បីបានស្តាប់ធម្មីកថា ក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ។ ព្រះថេរៈ នាំភិក្ខុនោះទៅក្នុងទីនោះ ហើយគិតថា ការចូលទៅកាន់សម្នាក់ព្រះតថាគត ដែលទ្រង់នៅមួយព្រះអង្គឯងអស់ត្រីមាស មួយអន្ទើដោយភិក្ខុមានប្រមាណ ប៉ុណ្ណេះ មិនគួរឡើយ ដូច្នេះហើយ ទើបបញ្ឈប់ភិក្ខុនោះខាងក្រៅហើយ ចូល ទៅគាល់ព្រះសាស្តាមួយអង្គឯងប៉ុណ្ណោះ ។ ស្តេចដ៏វីបាលិលេយ្យកៈឃើញ ព្រះអានន្ទត្ថេរនោះហើយ កាន់មែកឈើសុំទៅ ព្រះសាស្តាទតឃើញហើយ ត្រាស់ថា ចៀសចេញទៅបាលិលេយ្យកៈ កុំឃាត់លោកឡើយ ភិក្ខុនោះជា ឧបដ្ឋាក ។ ស្តេចដ៏វីបាលិលេយ្យកៈនោះ ទម្លាក់កំណាត់ឈើក្នុងទីនោះឯង ហើយបានអើពើដល់ការទទួលបាត្រ និងចីវរ ។ ព្រះថេរៈមិនបានឲ្យឡើយ ។ ស្តេចដ៏វីបានគិតថា បើភិក្ខុរូបនេះ មានវត្តបានរៀនហើយ លោកគង់នឹងមិន ដាក់បរិក្ខារបស់ខ្លួនលើផ្ទាំងថ្ម ដែលជាទីប្រថាប់របស់ព្រះសាស្តាឡើយ ។ ព្រះថេរៈដាក់បាត្រ និងចីវរ ត្រង់ផែនដីហើយ ។

ពិតហើយ ជនដែលដល់ព្រមហើយដោយវត្ត រមែងមិនដាក់បរិក្ខារបស់ ខ្លួនលើទីគង់ ឬលើទីសិងរបស់គ្រូ ។ ដ៏វីនោះឃើញអាការនោះ មានចិត្តជ្រះថ្លា ហើយ ។ ព្រះថេរៈអភិវាទព្រះសាស្តាហើយ គង់ក្នុងទីសមគួរ នាចំណែក ម្ខាង ។ ព្រះសាស្តាត្រាស់សួរថា ម្នាលអានន្ទ អ្នកមកម្នាក់ឯងប៉ុណ្ណោះឬ ។ ទ្រង់ស្តាប់ភាពដែលព្រះថេរៈមកហើយជាមួយភិក្ខុ ៥០០ ទើបត្រាស់ថា ភិក្ខុ ទាំងនោះនៅឯណា ព្រះថេរៈទូលថា ខ្ញុំព្រះអង្គមិនជ្រាបទឹកព្រះហឫទ័យរបស់ ព្រះអង្គ ទើបបញ្ឈប់ពួកលោកនៅខាងក្រៅ ហើយមកតែឯង ។ ព្រះសាស្តា

ត្រាស់ថា ចូរអ្នកហៅភិក្ខុទាំងឡាយមកចុះ ព្រះថេរៈបានធ្វើតាមព្រះតម្រាស់ហើយ ។ ភិក្ខុទាំងនោះមកថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយភិក្ខុទាំងឡាយហើយ កាលភិក្ខុទាំងនោះទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ជាព្រះសម្ពុទ្ធដ៏សុខុម ជាក្សត្រដ៏សុខុម ទ្រង់ឈរ និងទ្រង់ប្រថាប់គង់មួយព្រះអង្គឯង អស់ត្រីមាសធ្វើកិច្ចដែលធ្វើបានដោយលំបាក អ្នកធ្វើវត្ត និងបដិវត្តក្តី អ្នកថ្វាយទឹកលុបព្រះភក្ត្រក្តី ប្រហែលមិនមានឡើយ ។ ព្រះសព្វញ្ញូត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កិច្ចទាំងពួងរបស់តថាគត គឺស្តេចដ៏វិបុលិលេយ្យកៈធ្វើហើយ បុគ្គលដែលបានសម្ងាញ់បែបនេះនៅជាមួយគ្នាគួរហើយ បើមិនបានសម្ងាញ់បែបនេះ កាលត្រាច់ទៅម្នាក់ឯងប៉ុណ្ណោះប្រសើរជាង ដូច្នេះហើយ ទ្រង់ភាសិតគាថា ៣ គាថា ក្នុងនាគវគ្គទាំងនេះថា

> បើបុគ្គលបានសម្ងាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងនៅ ញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតី គ្របសង្កត់សេចក្តីអន្តរាយទាំងពួង ហើយត្រាច់ទៅជាមួយនឹងសម្ងាញ់នោះឯង ។ បើស្វែងរកមិនបានសម្ងាញ់ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿង ញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែឯកឯងវិញ ដូចព្រះរាជាលះបង់រដ្ឋ

ដែលទ្រង់ឈ្នះហើយ ស្តេចទៅតែឯកអង្គ ពុំនោះសោត ដូច ជីរឈ្មោះមាតង្គៈ ដែលលះហ្វូងគ្រាច់ទៅតែឯក ឯង ក្នុងព្រៃ ជូច្នោះដែរ ។

កាលគ្រាច់ទៅ របស់បុគ្គលឯកឯង ជាគុណជាតិប្រសើរផុត

(ព្រោះថា) សហាយតាគុណ រមែងមិនមាន ក្នុងជនពាល ទ្បើយ បុគ្គលនោះ គប្បីជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ គ្រាច់ ទៅតែម្នាក់ឯងផង មិនគប្បីធ្វើអំពើបាបទាំងឡាយផង ដូចជីរ ឈ្មោះមាតង្គៈ ជាសត្វមិនមានសេចក្តីខ្វល់ខ្វាយ លះបង់ហ្វូង គ្រាច់ទៅតែឯកឯងក្នុងព្រៃ ជូច្នោះដែរ ។

ក្នុងកាលចប់គាថា កិកូទាំង ៥០០ រូប តាំងនៅក្នុងអរហត្តហើយ ។ ព្រះ អានន្ទត្ថេរ ក្រាបទូលដំណឹងដែលត្រកូលធំៗ មានអនាថបិណ្ឌិកសេដ្ឋីជាដើម បញ្ជូនមកហើយក្រាបទូលថា បពិត្រព្រះអង្គ អរិយសាវ័ក ៥ កោដិ មាន អនាថបិណ្ឌិកសេដ្ឋីជាប្រធាន ទន្ទឹងការយាងមករបស់ព្រះអង្គ ។ ព្រះសាស្តា ត្រាស់ថា បើយ៉ាងនោះ អ្នកចូលទទួលបាត្រ និងចីវរ ជូច្នេះហើយ ឲ្យព្រះ ថេរៈទទួលបាត្រ និងចីវរហើយ យាងចេញទៅ ។ ស្តេចជីរបានទៅឈរវាំង ផ្លូវ ។ កិកូទាំងឡាយឃើញជូច្នោះ ទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះ អង្គ ស្តេចជីរធ្វើអ្វី ព្រះសាស្តាត្រាស់ថា ម្នាលកិកូទាំងឡាយ ជីរបំណងនឹង ប្រគេនភិក្ខាជល់អ្នកទាំងឡាយ ជីរនេះបានធ្វើឧបការៈដល់តថាគត អស់រាត្រី ជ័យ្យរ ការញុំាងចិត្តរបស់ជីរនេះឲ្យអាក់អន់មិនគួរ ម្នាលកិកូទាំងឡាយ អ្នក

ទាំងឡាយចូរត្រឡប់ចុះ ។ ព្រះសាស្តាទ្រង់នាំភិក្ខុទាំងឡាយត្រឡប់ហើយ ។

ចំណែកជីរចូលទៅកាន់ដងព្រៃហើយ ប្រមូលផ្លែឈើផ្សេងៗ មានផ្លែខ្នុរ និងផ្លែចេកជាដើមមក ធ្វើឲ្យជាគំនរ ក្នុងថ្ងៃស្អែកឡើង បានប្រគេនដល់ភិក្ខុទាំងឡាយ ។ ភិក្ខុ ៥០០ រូប មិនអាចឆាន់ផ្លែឈើទាំងឡាយឲ្យអស់បានឡើយ ។ ក្នុងកាលចប់ភត្តកិច្ច ព្រះសាស្តាទ្រង់កាន់បាត្រ និងចីវរយាងចេញទៅហើយ ។ ស្តេចជីរទៅតាមក្នុងចន្លោះៗ នៃភិក្ខុទាំងឡាយ ឈរខាំងព្រះភក្ត្រព្រះសាស្តា ។ ភិក្ខុទាំងឡាយឃើញដូច្នោះ ទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ជីរនេះគិតធ្វើអ្វី ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ជីរនេះបញ្ជូនពួកអ្នកទៅហើយ តែបបួលតថាគតឲ្យត្រឡប់ ភិក្ខុទាំងឡាយទូលថា យ៉ាងនោះឬព្រះអង្គ ព្រះសាស្តាត្រាស់ថា អើ យ៉ាងនោះឯង ភិក្ខុទាំងឡាយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងជីរនោះថា ម្នាលបាលិលេយ្យកៈ នេះការទៅមិនត្រឡប់របស់តថាគត ឈានក្តី វិបស្សនាក្តី មគ្គ និងផលក្តី រមែងមិនមានដល់អ្នកដោយអត្តភាពនេះ អ្នកចូរឈប់ចុះ ។ ស្តេចជីរបានស្តាប់ព្រះតម្រាស់នោះហើយ បានស៊កប្រមោយចូលក្នុងមាត់ ទ្រហោយំ ដើរតាមទៅអំពីខាងក្រោយ ។ ស្តេចជីរនោះបើយាងព្រះសាស្តាឲ្យត្រឡប់បាន គប្បីបដិបត្តិដោយអាការយ៉ាងនោះ ដរាបដល់អស់ជីវិត ចំណែកព្រះសាស្តាយាងដល់ព្រំដែននៃស្រុកហើយត្រាស់ថា ម្នាលបាលិលេយ្យកៈ ចាប់តាំងអំពីនេះទៅ មិនមែនជាទឹកដីរបស់អ្នក ជាទឹកដីរបស់មនុស្សទាំងឡាយ ។ មានអន្តរាយ

បៀតបៀនដោយជុំវិញ អ្នកចូរឈប់បង្អង់ចុះ ដីរនោះឈរយំក្នុងទីនោះ កាល ព្រះសាស្តាបាត់អំពីគន្ធង់ចក្ខុទៅ ក៏បែកទ្រូងស្លាប់ ធ្វើកាលកិរិយាហើយ កើត ក្នុងកណ្តាលស្រីទេពអប្សរមួយពាន់ ក្នុងវិមានមាស កម្ពស់ ៣០ យោជន៍ ក្នុងតាវត្តិង្សពិភព ព្រោះសេចក្តីជ្រះថ្លាក្នុងព្រះសាស្តា មានឈ្មោះថាបាលិ-លេយ្យកទេវបុត្រ ។ ចំណែកព្រះសាស្តា យាងដល់វត្តជេតពនហើយដោយ លំដាប់ ។

ភិក្ខុក្រុងកោសម្ពីបានដំណឹងថា ព្រះសាស្តាយាងដល់ក្រុងសាវត្ថីហើយ បានទៅក្នុងទីនោះ ដើម្បីទូលសូមខមាទោសចំពោះព្រះសាស្តា ។ ព្រះបាទ កោសលទ្រង់បានដំណឹងថា ភិក្ខុក្រុងកោសម្ពីដែលជាអ្នកបង្កការប្រេះឆាទាំង នោះនិមន្តមក ទើបចូលទៅគាល់ព្រះសាស្តាទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គ មិនព្រមឲ្យភិក្ខុទាំងនោះ ចូលមកកាន់ដែនដីរបស់ទូលបង្គំឡើយ ព្រះសាស្តា ត្រាស់តបថា បពិត្រមហារាជ ភិក្ខុទាំងនោះជាអ្នកមានសីល តែមិនកាន់យក ពាក្យរបស់តថាគត ព្រោះវិវាទគ្នានឹងគ្នាប៉ុណ្ណោះ ឥឡូវនេះ ភិក្ខុទាំងឡាយ នោះ មកដើម្បីសូមខមាទោសនឹងតថាគត ។ បពិត្រមហារាជ សូមឲ្យភិក្ខុ ទាំងឡាយនោះមកចុះ ។

ចំណែកអនាថបិណ្ឌិកសេដ្ឋីទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនព្រមឲ្យ ភិក្ខុទាំងនោះចូលមកក្នុងវិហារនេះឡើយ ដូច្នេះហើយ ត្រូវព្រះសាស្តាយាត់ ជូចគ្នា បានស្ងៀមហើយ ។ កាលភិក្ខុទាំងនោះដល់ក្រុងសាវត្ថីដោយលំដាប់ ហើយ ព្រះដ៏មានព្រះភាគត្រាស់ឲ្យប្រទានសេនាសនៈនាចំណែកម្ខាង ធ្វើឲ្យ

ជាទីស្ងាត់ដល់ភិក្ខុទាំងឡាយ ។ ភិក្ខុពួកជទៃមិនគង់ មិនឈរជាមួយភិក្ខុទាំងនោះ ។

ពួកជនដែលមកហើយ ទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុទាំងឡាយណាជាអ្នកក្រុងកោសម្ពី ដែលជាអ្នកបង្កនូវការប្រែធាទាំងនោះ ព្រះសាស្តាទ្រង់បង្ហាញថា នុ៎ះគឺពួកភិក្ខុទាំងនោះ ។ ភិក្ខុអ្នកក្រុងកោសម្ពីទាំងនោះ ត្រូវពួកជនដែលមកហើយ ចង្អុលដោយម្រាមដៃថា បានឮថា នុ៎ះពួកភិក្ខុក្រុងកោសម្ពី ដែលជាអ្នកបង្កនូវជម្លោះទាំងនោះ បានឮថា នុ៎ះពួកភិក្ខុក្រុងកោសម្ពី ដែលបង្កជម្លោះនោះដូច្នេះ មិនអាចធើបមុខរួច ព្រោះសេចក្តីខ្វាស ជាអ្នកឱនកចុះ ក្រាបទៀបបាទមូលនៃព្រះដ៏មានព្រះភាគ ទូលសូមខមាទោសព្រះដ៏មានព្រះភាគហើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយធ្វើកម្មធ្ងន់ហើយឈ្មោះថា អ្នកទាំងឡាយ បួសហើយក្នុងសម្នាក់របស់ព្រះសម្ពុទ្ធ ដូចតថាគតនេះ កាលតថាគតធ្វើនូវសាមគ្គី មិនធ្វើតាមពាក្យតថាគត ចំណែកបណ្ឌិតក្នុងកាលមុន ស្តាប់ឱវាទរបស់មាតា និងបិតា ដែលត្រូវប្រហារជីវិត កាលមាតាបិតានោះត្រូវផ្តាច់ជីវិត ក៏មិនកន្ធងឱវាទនោះ ខាងក្រោយបានគ្រងរាជសម្បត្តិក្នុងដែនពីរ ដូច្នេះហើយ ទ្រង់ត្រាស់ទីឃាវុកុមារជាតកទៀត ដូចមុននោះឯង ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារសូម្បីកាលព្រះជនក និងព្រះជននី ត្រូវប្រហារជីវិតយ៉ាងនោះ ក៏មិនឈានកន្ធងឱវាទរបស់ព្រះជនក និងព្រះជននីទាំងនោះឡើយ ក្រោយមកបានធីតារបស់ព្រះបាទព្រហ្មទត្ត គ្រងរាជ-

សម្បត្តិក្នុងដែនកាសី និងដែនកោសលទាំងពីរហើយ ចំណែកអ្នកទាំងឡាយ មិនធ្វើតាមពាក្យរបស់តថាគត ធ្វើកម្មធ្ងន់ហើយ ដូច្នេះហើយ ត្រាស់គាថានេះថា

ឃរេ ច ន វិជានន្តិ មយមេត្ត យមាម្ហសេ
យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។

ជនទាំងឡាយដទៃ (ក្រៅអំពីបណ្ឌិត) តែងមិនដឹងខ្លួនថា យើងទាំង ឡាយនឹងវិនាសក្នុងកណ្តាលនៃពួកនេះដូច្នេះឡើយ ចំណែកជនទាំងឡាយណា ក្នុងពួកនេះ ដឹងខ្លួនថា យើងទាំង-ឡាយ នឹងវិនាសកណ្តាលនៃពួកនេះ ដូច្នេះ ការឈ្លោះប្រកែក ទាំងឡាយ រមែងរម្ងាប់អំពីជនទាំងឡាយនោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឃរេ** *ជាដើម សេចក្តីថា ពួកជនដែលធ្វើការប្រែធា វៀរបណ្ឌិតទាំងនោះចេញ គឺពួកដទៃក្រៅពីបណ្ឌិតនោះ ឈ្មោះថា ជនពួកដទៃ ជនពួកដទៃនោះធ្វើនូវការវឹកវរក្នុងជំនុំសង្ឃនោះ រមែងមិនដឹងខ្លួនថា យើងទាំងឡាយរមែងលំបាក គឺបែកខ្ញែក វិនាស បានដល់ ទៅកាន់ទីជិត គឺ សម្ងាត់មច្ចុជានិច្ច ។*

បានព្រះគាថាថា **យេ ច តត្ថ វិជានន្តិ** *សេចក្តីថា ជនទាំងឡាយណា ដែលជាបណ្ឌិតក្នុងក្រុមនោះរមែងដឹងខ្លួនថាយើងទាំងឡាយទៅកាន់ទីជិតមច្ចុ។*

បានព្រះគាថាថា **តតោ សម្មន្តិ មេធគា** *សេចក្តីថា ជនទាំងនោះដឹងយ៉ាងនេះឯង ញុំាងយោនិសោមនសិការឲ្យកើតឡើងហើយ រមែងបដិបត្តិ*

ដើម្បីស្ងប់នូវការប្រកួតប្រកាន់ គឺការទាស់ទែងគ្នា ។ កាលបើដូច្នោះ ការប្រកួតប្រកាន់ទាំងនោះ រមែងស្ងប់ព្រោះបដិបត្តិរបស់បណ្ឌិតទាំងនោះ ។

ម្យ៉ាងទៀត គប្បីជ្រាបអធិប្បាយក្នុងព្រះគាថានេះយ៉ាងនេះថា ពាក្យថា **ឃរេ** ជាដើម សេចក្តីថា ជនទាំងឡាយ សូម្បីតថាគតពោលទូន្មានថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំធ្វើនូវការបែកបាក់គ្នាដូច្នេះជាដើម ក្នុងកាលមុន ក៏មិនរាប់អានព្រោះមិនទទួលឱវាទរបស់តថាគត ឈ្មោះថា ជនពួកដទៃ ។ ជនពួកដទៃនោះ រមែងមិនដឹងខ្លួនថា យើងទាំងឡាយប្រកាន់ខុសដោយអំណាចអគតិ មានឆន្ទៈជាដើម រមែងដល់នូវការលំបាក បានដល់ព្យាយាមដើម្បីសេចក្តីចម្រើននៃហេតុដែលធ្វើនូវសេចក្តីវិនាស មានការប្រះធាជាដើមក្នុងកណ្តាលសង្ឃនេះ ។ តែឥឡូវនេះ បុរសដែលជាបណ្ឌិតទាំងឡាយណា ក្នុងរវាងនៃអ្នកទាំងឡាយនោះ ពិចារណាដឹងច្បាស់ថា កាលមុន យើងទាំងឡាយកំពុងព្យាយាមដោយអំណាចអគតិ មានឆន្ទៈជាដើម បដិបត្តិដោយមិនប្រពៃហើយការប្រកួតប្រកាន់ ក៏រាប់ថាជាជម្ងោះក្នុងឥឡូវនេះ ទាំងនេះ រមែងស្ងប់ចាកសម្នាក់បណ្ឌិតទាំងឡាយនោះ គឺព្រោះអាស្រ័យបុរសដែលជាបណ្ឌិតទាំងនោះ ដោយប្រការដូច្នេះ ។

ក្នុងវេលាចប់គាថា ភិក្ខុដែលប្រជុំគ្នាបានតាំងនៅក្នុងអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

រឿងភិក្ខុក្រុងកោសម្ពី ចប់

រឿង ចុល្លកាល និងមហាកាល

លំនាំដើម

ព្រះសាស្តា កាលទ្រង់ចូលទៅអាស្រ័យសេតព្យនគរ ប្រថាប់នៅក្នុងព្រៃធ្នង់ ទ្រង់ប្រារព្ធចុល្លកាល និងមហាកាល ត្រាស់ព្រះធម្មទេសនានេះថា **សុភានុបស្សីន វិហារន្តំ** ជាដើម ។

សេចក្តីពិស្តារថា កុដុម្ពិក:អ្នកសេតព្យនគរ ៣ នាក់បងប្អូន គឺចុល្លកាល ១ មជ្ឈិមកាល ១ មហាកាល ១ ។ បណ្តាបងប្អូន ៣ នាក់នោះ បងប្រុសធំ និងប្អូនប្រុសពៅ ត្រាច់ទៅក្នុងទិសទាំងឡាយ នាំរបស់របរមកដោយរទេះ ៥០០ មជ្ឈិមកាលលក់របស់ដែលបងប្អូនទាំងពីរនាំមក ។

តមកសម័យនោះ បងប្អូនទាំងពីរនោះផុតវត្តផ្សេងៗ ដោយរទេះ ៥០០ ទៅកាន់ក្រុងសាវត្ថី ដោះរទេះទាំងឡាយត្រង់ចន្លោះក្រុងសាវត្ថី និងវត្តជេតពន។

ក្នុងបងប្អូនពីរនាក់នោះ មហាកាលឃើញអរិយសាវ័កអ្នកក្រុងសាវត្ថីទាំងឡាយ មានដៃកាន់កម្រងផ្កា និងគ្រឿងក្រអូបជាដើម ទៅស្តាប់ធម៌នាពេលល្ងាច ទើបសួរថា ជនទាំងនេះទៅណា ។ បានស្តាប់ពាក្យនោះហើយ គិតថា សូម្បីអញក៏ទៅ ហៅប្អូនប្រុសមកហើយប្រាប់ថា នែបា អ្នកចូរជាបុគ្គលមិនប្រមាទក្នុងរទេះទាំងឡាយ ។ ចំណែកខ្ញុំនឹងទៅស្តាប់ធម៌ ដូច្នេះហើយ ទៅថ្វាយបង្គំព្រះសាស្តា អង្គុយត្រង់ទីបំផុតនៃបរិស័ទ ។

ថ្ងៃនោះ ព្រះសាស្តា កាលនឹងត្រាស់អនុបុព្វីកថាតាមអធ្យាស្រ័យរបស់មហាកាលនោះ ទើបត្រាស់ទោស ការបោកទាប និងការសៅហ្មង នៃកាមទាំងឡាយ ដោយបរិយាយដ៏ច្រើន ដោយអំណាចនៃសូត្រ មានទុក្ខក្ខន្ធសូត្រ

ជាដើម ។ មហាកាលបានស្តាប់ព្រះធម្មទេសនានោះហើយ គិតថា មនុស្ស យើង ត្រូវលះវត្ថុទាំងពួងទៅ កោគៈ និងញាតិទាំងឡាយ រមែងមិនជាប់ តាមបុគ្គលដែលទៅកាន់បរលោកឡើយ អញត្រូវការអ្វីដោយការគ្រប់គ្រងផ្ទះ អញនឹងបួស កាលមហាជនថ្វាយបង្គំ ហើយចៀសចេញទៅ ទូលសូមបព្វជ្ជានឹងព្រះសាស្តា កាលព្រះសាស្តាត្រាស់ថា បុគ្គលដែលអ្នកគួរលាណា ម្នាក់មិនមានទេឬ មហាកាលពោលថា ប្អូនប្រុសខ្ញុំព្រះអង្គមាន កាលទ្រង់ត្រាស់ថា បើដូច្នោះ អ្នកចូរលាគេចុះ ។ មហាកាលទទួលថា សាធុ ព្រះអង្គ ត្រឡប់មកប្រាប់ប្អូនប្រុសដូច្នេះថា នែបា អ្នកចូរគ្រប់គ្រងសម្បត្តិទាំងអស់ នេះចុះ ចុល្លកាលសួរថា ចុះបងវិញ មហាកាលប្រាប់ថា បងនឹងបួសក្នុងសម្នាក់របស់ព្រះសាស្តា ។ ចុល្លកាលអង្វរបងប្រុសនោះដោយប្រការផ្សេងៗ ក៏មិនអាចឲ្យត្រឡប់បាន ទើបពោលថា សាធុ បង សូមបងធ្វើតាមអធ្យាស្រ័យចុះ មហាកាលទៅបួសក្នុងសម្នាក់របស់ព្រះសាស្តាហើយ ។ ចំណែកចុល្លកាល ក៏បួសដោយតាំងចិត្តថា អញនឹងបបួលបងប្រុសសឹក ។

ក្នុងកាលតមក មហាកាលបានឧបសម្បទាហើយ ចូលទៅគាល់ព្រះសាស្តា ទូលសួរដល់ធុរៈក្នុងព្រះសាសនា ។ កាលព្រះសាស្តាត្រាស់ប្រាប់ធុរៈ ២ យ៉ាងហើយ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចបំពេញគន្ថធុរៈបាន ព្រោះខ្ញុំព្រះអង្គបួសកាលឯចាស់ តែនឹងបំពេញវិបស្សនាធុរៈឲ្យបរិបូណ៌ ទូលឲ្យព្រះអង្គត្រាស់ប្រាប់សោសានិកធុតង្គ រហូតដល់ព្រះអរហត្ត កាលកន្លងបឋមយាម កាលជនដេកលក់អស់គ្រប់គ្នាហើយ ទៅកាន់ព្រៃខ្មោច

វេលាទៀបភ្លឺ កាលជនទាំងអស់មិនទាន់ភ្ញាក់ ត្រឡប់មកកាន់វិហារវិញ ។

គ្រានោះ ស្រីអ្នករកស៊ីរៀបចំបុណ្យខ្មោចម្នាក់ឈ្មោះកាឡី ជាអ្នកយាមព្រៃខ្មោច ឃើញទីឈរទីអង្គុយ ទីចង្ក្រមរបស់ព្រះថេរៈហើយ គិតថា អ្នកណាហ្ន៎ មកក្នុងទីនេះ អញនឹងឃ្លាំចាប់ខ្លួន កាលមិនអាចចាប់បាន ថ្ងៃមួយទើបអុជប្រទីបត្រង់ខ្លួម ក្បែរព្រៃខ្មោច នាំកូនប្រុសស្រីទៅពួនក្នុងចំណែកម្ខាង ឃើញព្រះថេរៈនិមន្តមកក្នុងមជ្ឈិមយាម ទើបទៅថ្វាយបង្គំហើយពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ស្នាក់នៅក្នុងទីរបស់ពួកខ្ញុំឬ ព្រះថេរៈតបថា អើ ឧបាសិកា ស្រីនោះពោលថា បពិត្រលោកម្ចាស់ធម្មតាអ្នកនៅព្រៃខ្មោចទាំងឡាយ រឿនរបៀបរបបសិន ទើបគួរ ។

ព្រះថេរៈមិនពោលថា អាត្មានឹងប្រព្រឹត្តក្នុងរបៀបដែលនាងប្រាប់ហើយយ៉ាងណា បែរជាពោលថា ធ្វើយ៉ាងណាទើបគួរឧបាសិកា ស្រីនោះពោលថា បពិត្រលោកម្ចាស់ ធម្មតាអ្នកនៅក្នុងព្រៃខ្មោចទាំងឡាយ គួរប្រាប់ភាពដែលខ្លួននៅក្នុងព្រៃខ្មោច ដល់អ្នកយាមព្រៃខ្មោច ដល់ព្រះមហាថេរៈក្នុងវិហារ ដល់ម្ចាស់ស្រុក ។ ព្រះថេរៈពោលថា ព្រោះហេតុអ្វី ស្រីនោះពោលថា ព្រោះពួកចោរធ្វើកម្មហើយ ត្រូវពួកម្ចាស់ទ្រព្យដេញតាមស្នាមជើងទៅ ក៏ចោលកញ្ចប់កណ្ហៈក្នុងព្រៃ ហើយលបចៀសចេញទៅ ។ កាលបើដូច្នោះ ពួកមនុស្សក៏នឹងចោមរោមធ្វើអន្តរាយដល់បុគ្គលដែលនៅក្នុងព្រៃខ្មោច តែបើបានប្រាប់ដល់ម្ចាស់ស្រុកនោះហើយ ម្ចាស់ស្រុកទាំងនោះ រមែងជួយការពារអន្តរាយបាន ដោយពោលធានាថា ពួកអ្នកចូរប្រាប់ភាពដែលលោកម្ចាស់

អង្គនេះ នៅក្នុងទីនេះ អស់កាលប្រមាណប៉ុណ្ណេះ លោកម្ចាស់រូបនេះ មិនមែនចោរទេ ព្រោះដូច្នោះ គួរប្រាប់ដល់ម្ចាស់ស្រុកទាំងនោះ ។

ព្រះថេរៈពោលថា កិច្ចដទៃណាមួយដែលអាត្មាគួរធ្វើមានទៀតដែរឬទេ ស្រីនោះពោលថា បពិត្រលោកម្ចាស់ ធម្មតាអ្នកនៅក្នុងព្រៃខ្មោចត្រូវរៀវត្តុទាំងឡាយ មានត្រី សាច់ មេរ៉ា ល្ង និងទឹកអំពៅជាដើមចេញ មិនគួរសិងនៅពេលថ្ងៃ មិនជាអ្នកខ្ជិលច្រអូស គួរប្រារព្ធព្យាយាម ភាពជាអ្នកមិនអួតអាង មិនមានមាយា ជាអ្នកមានអធ្យាស្រ័យស្អាត ពេលល្ងាច ជនត្រឡប់អស់ហើយ គប្បីមកអំពីវិហារ ពេលព្រឹក កាលពួកជនមិនទាន់ក្រោកឡើង គប្បីទៅវិហារ ។ បពិត្រលោកម្ចាស់ បើលោកម្ចាស់នៅក្នុងទីនេះ ដោយអាការយ៉ាងនេះសោត នឹងអាចញុំាងកិច្ចនៃបព្វជិតឲ្យដល់ទីបំផុតបាន បើពួកជននាំសពមកចោល ខ្ញុំនឹងលើកឡើងកាន់ផ្ទះកំពូល ដែលពាសដោយសំពត់កម្ពល ធ្វើសក្ការៈដោយវត្តុទាំងឡាយ មានគ្រឿងក្រអូប និងកម្រងផ្កាជាដើមហើយ នឹងធ្វើការដាក់សព បើលោកម្ចាស់មិនអាចញុំាងកិច្ចនៃបព្វជិតឲ្យដល់ទីបំផុតបានសោត ខ្ញុំនឹងលើកឡើងកាន់ជើងថ្ករ ហើយដុតភ្លើង យកតម្ពក់ទាញសពមកខាងក្រៅ ពុះដោយពូថៅ ច្រៀកជាចម្រៀកតូចធំ ហើយដាក់ក្នុងភ្លើង បង្ហាញដល់លោកម្ចាស់ហើយ ទើបដុត ។

ពេលនោះ ព្រះថេរៈប្រាប់នាងកាឡីនោះថា ល្អហើយនាង បើនាងឃើញរូបារម្មណ៍ណាមួយហើយ ចូរប្រាប់ដល់អាត្មា ។ នាងកាឡីទទួលថា កុណា លោកម្ចាស់ ។ ព្រះថេរៈធ្វើសមណធម៌ក្នុងព្រៃខ្មោចតាមអធ្យាស្រ័យរបស់

ខ្លួន ។ ចំណែកព្រះចុល្លកាលត្ថេរ ជួនក្រោក ជួនអង្គុយ នឹកដល់ឃរាវាស គិតដល់បុត្រ និងភរិយា គិតថា បងប្រុសរបស់អញនេះ ធ្វើកម្មធ្ងន់ហ្ន៎ ។

លំដាប់នោះ កុលធីតាម្នាក់ធ្វើកាលកិរិយាក្នុងពេលល្ងាច ដែលមិនទាន់ក្រៀមស្វូត ស្គមស្គាំងព្រោះព្យាធិកម្រើកឡើងក្នុងមួយរំពេចប៉ុណ្ណោះ ពួកញាតិសែងសពកុលធីតានោះ ទៅកាន់ព្រៃខ្មោចក្នុងពេលល្ងាច មួយអន្ទើដោយគ្រឿងដុតផ្សែងៗ មានអុស និងប្រេងជាដើម ឲ្យថ្លៃឈ្នួលដល់ស្រីអ្នកយាមព្រៃខ្មោច ដោយពាក្យថា ចូរនាងរៀបចំបូជាសពនេះ ដូច្នេះហើយ ប្រគល់សពឲ្យហើយ ចៀសចេញទៅ ។ នាងដោះសំពត់របស់នាងកុលធីតានោះចេញហើយ ឃើញសរីរៈស្អាប់ភ្លាមៗ នោះនៅប្រណីត មានពណ៌ដូចមាស ទើបគិតថា អារម្មណ៍នេះ គួរបង្ហាញដល់លោកម្ចាស់ ហើយទៅថ្វាយបង្គំព្រះថេរៈពោលថា បពិត្រលោកម្ចាស់ អារម្មណ៍បែបនេះមាន សូមលោកម្ចាស់ទៅពិចារណាចុះ ។

ព្រះថេរៈទទួលថា សាធុ ដូច្នេះហើយ ទៅឲ្យបើកសំពត់ដណ្តប់ចេញហើយ ពិចារណាតាំងអំពីចុងជើងដល់ចុងសក់ហើយ ពោលថា រូបនេះប្រណីតពន់ពេក មានពណ៌ដូចមាស នាងគប្បីដាក់រូបនោះក្នុងភ្លើង ក្នុងកាលដែលរូបនោះត្រូវអណ្តាតភ្លើងធំរលាកហើយ សឹមប្រាប់ដល់អាត្មា ដូច្នេះហើយទៅកាន់លំនៅរបស់ខ្លួននោះឯង គង់ហើយ ។ នាងធ្វើយ៉ាងនោះហើយ ទើបប្រាប់ដល់ព្រះថេរៈ។ ក៏ទៅពិចារណាក្នុងទីដែលត្រូវអណ្តាតភ្លើងប៉ះខ្លប់ហើយ ពណ៌នៃសរីរៈបានដូចជាមេគោពពាល ។ ជើងទាំងពីរក្រញាង សំយុងចុះ ដៃ

ទាំងពីរក្តាប់ចូល ថ្ងាស់មានស្បែករបកហើយ ។

ព្រះថេរៈពិចារណាថា សរីរៈនេះ ធម្មជាតិធ្វើឲ្យមិនអផ្សុកដល់បុគ្គលដែលសម្លឹងមើលក្នុងឥឡូវនេះឯង អម្បាញ់មិញនោះឯង តែឥឡូវនេះ បែរជាដល់នូវការអស់ទៅ ដល់នូវការវិនាសទៅហើយ ។ ត្រឡប់ទៅកាន់ទីសម្រាកពេលយប់ អង្គុយពិចារណាដល់ការអស់ទៅ និងការសូន្យទៅ ពោលគាថាថា

សង្ខារធម៌ទាំងឡាយ មិនទៀងមែនពិត មានកិរិយាកើតឡើង និងវិនាសទៅវិញជាធម្មតា រមែងកើតឡើងហើយ រលត់ទៅវិញ លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយ ទើបបាននូវសេចក្តីសុខគ្រប់យ៉ាង ។

ចម្រើនវិបស្សនាបានសម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយ ។ កាលលោកសម្រេចអរហត្តហើយ ព្រះសាស្តាមានភិក្ខុសង្ឃចោមរោម ទ្រង់យាងចារិកទៅកាន់សេតព្យនគរហើយ ស្តេចចូលកាន់ព្រៃផ្ចង់ ។ ភរិយារបស់ព្រះចុល្លកាលបានឮថា ព្រះសាស្តាយាងមកដល់ហើយ គិតថាពួកយើង នឹងនាំគ្នាចាប់ប្តីរបស់ពួកយើង ដូច្នេះហើយ បញ្ជូនមនុស្សទៅអារាធនាព្រះសាស្តា ។

ក្នុងទីដែលព្រះពុទ្ធទាំងឡាយ ទ្រង់នឹងស្និទ្ធស្នាល គួរភិក្ខុមួយរូបដែលប្រាប់ការក្រាលអាសនៈ ត្រូវនាំមុខទៅមុន ។ អាសនៈសម្រាប់ព្រះពុទ្ធទាំងឡាយ គប្បីក្រាលត្រង់កណ្តាល អាសនៈសម្រាប់ព្រះសារីបុត្តត្ថេរ គប្បីឲ្យ

ក្រោលខាងស្តាំ អាសនៈសម្រាប់ព្រះមហាមោគ្គល្លានត្ថេរ គប្បីឲ្យក្រោលខាងឆ្វេងនៃអាសនៈរបស់ព្រះសម្ពុទ្ធ អាសនៈសម្រាប់កិក្ខុសង្ឃ គប្បីឲ្យក្រោលទាំងសងខាងបន្ទាប់អំពីនោះទៅ ។ ព្រោះដូច្នោះ ព្រះមហាកាលត្ថេរសម្រាកនៅក្នុងទីជាំងចីវរ បញ្ជូនព្រះចុល្លកាលទៅថា ចូរលោកទៅមុន ប្រាប់ដល់ការក្រោលអាសនៈ ។

ពួកជនក្នុងផ្ទះធ្វើការស្និទ្ធស្នាលនឹងលោក ចាប់តាំងពីកាលដែលពួកគេឃើញលោកក្រោលអាសនៈទាប ក្នុងទីបំផុតនៃព្រះសង្ឃត្ថេរ ក្រោលអាសនៈខ្ពស់ក្នុងទីបំផុតរបស់ព្រះសង្ឃនវក ។ ព្រះចុល្លកាលនេះជ្រាប់ថា ពួកនាងចូរធ្វើយ៉ាងនោះ ចូរក្រោលអាសនៈខ្ពស់ក្នុងទីខ្ពស់ ចូរក្រោលអាសនៈទាបក្នុងទីទាប ។

ពួកស្រីធ្វើហាក់ដូចមិនបានឮនូវពាក្យរបស់លោក ចោមរោមគ្នាថា លោកម្ចាស់និមន្តទៅណា កិច្ចឲ្យក្រោលអាសនៈមិនសមគួរដល់លោកម្ចាស់ឬ លោកម្ចាស់លាអ្នកណាបួស អ្នកណាព្រមឲ្យលោកម្ចាស់បួស លោកម្ចាស់មកក្នុងទីនេះធ្វើអ្វី ដូច្នេះហើយ នាំគ្នាទាញស្បង់ និងចីវរចេញហើយ ឲ្យស្លៀកសំពត់ស ពាក់នូវឈ្នួតផ្កាលើក្បាល ហើយបញ្ជូនទៅដោយពាក្យថា អ្នកចូរទៅនាំព្រះសាស្តាមក ពួកខ្ញុំនឹងក្រោលអាសនៈ ។

ចុល្លកាលតាំងនៅក្នុងភាវៈនៃកិក្ខុអស់កាលមិនយូរ មិនទាន់បានវស្សាក៏សឹក ទើបមិនខ្មាស ព្រោះដូច្នោះ ទើបគាត់អស់សេចក្តីរង្កៀសដោយកិរិយាអាការនោះ ទៅថ្វាយបង្គំព្រះសាស្តាហើយ នាំកិក្ខុសង្ឃមានព្រះពុទ្ធជា

ប្រធានមក ។

ក្នុងកាលស្រេចកត្តកិច្ចរបស់កិកុសង្ឃ ពួកភរិយារបស់ព្រះមហាកាល គិតគ្នាថា ស្រីពួកនេះ ចោមរោមចាប់ប្តីរបស់ខ្លួនបាន ពួកយើងក៏នឹងចាប់ប្តីរបស់ពួកយើងដែរ ទើបឲ្យនិមន្តព្រះសាស្តាដើម្បីប្រយោជន៍ដល់ការសោយក្នុងថ្ងៃស្អែក ។

ក្នុងកាលនោះ កិកុជទៃបានទៅប្រាប់ឲ្យក្រាលអាសនៈ ស្រីទាំងនោះមិនបានឱកាសក្នុងខណៈនោះ អារាធនាកិកុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យគង់ហើយបានថ្វាយកិក្ខា ។ ចុល្លកាលមានភរិយាពីរនាក់ មជ្ឈិមកាលមានភរិយា ៤ នាក់ មហាកាលមាន ៨ នាក់ ចំណែកកិកុទាំងឡាយប្រាថ្នាធ្វើកិច្ច បានអង្គុយធ្វើភត្តកិច្ចហើយ ពួកដែលប្រាថ្នាទៅខាងក្រៅ ក៏បានក្រោកទៅហើយ ចំណែកព្រះសាស្តាប្រថាប់គង់ធ្វើភត្តកិច្ច ក្នុងកាលស្រេចភត្តកិច្ចរបស់ព្រះអង្គ ស្រីទាំងនោះទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហាកាលធ្វើអនុមោទនាដល់ពួកខ្ញុំម្ចាស់ហើយ សឹមទៅ សូមទ្រង់យាងទៅមុនចុះ ។

ព្រះសាស្តាត្រាស់ថា សាធុ បានយាងទៅមុនហើយ ។ កាលដល់ទ្វារស្រុក កិកុសង្ឃក៏លើកទោសថា ហេតុអ្វីទើបព្រះសាស្តាទ្រង់ធ្វើបែបនេះ ព្រះអង្គទ្រង់ជ្រាបហើយធ្វើ ឬមិនជ្រាបហើយធ្វើហ្ន៎ មួយទៀមិញអន្តរាយនៃបព្វជ្ជាកើតឡើងដល់ចុល្លកាលព្រោះទៅមុនគេ ថ្ងៃនេះ អន្តរាយមិនមាន ព្រោះកិកុជទៃទៅមុន ឥឡូវនេះ ព្រះសាស្តាត្រាស់ឲ្យព្រះមហាកាលឈប់បង្អង់ ហើយទ្រង់យាងមក កិកុអ្នកមានសីលដល់ព្រមហើយដោយអាចារ ស្រីទាំងនោះ នឹង

ធ្វើអន្តរាយនៃបព្វជ្ជាដល់ព្រះមហាកាលនោះបានឬហ្ន៎ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់កិកូទាំងនោះហើយ ទ្រង់ត្រឡប់មកប្រថាប់ឈរ ត្រាស់សួរថា ម្នាលកិកូទាំងឡាយ ពួកអ្នកពោលអ្វី កិកូទាំងនោះទូលសេចក្តីនោះហើយ ព្រះសាស្តាត្រាស់ថា ម្នាលកិកូទាំងឡាយ ពួកអ្នកសម្គាល់មហាកាលដូចចុល្លកាលឬ កិកូទាំងឡាយទូលថា យ៉ាងនោះឯង ព្រះអង្គ ព្រោះចុល្លកាលនោះមានភរិយាពីរនាក់ ចំណែកព្រះមហាកាលនេះមានភរិយាដល់ទៅ ៨ នាក់ លោកត្រូវភរិយាទាំង ៨ ចោមរោមចាប់ហើយនឹងធ្វើអ្វីបាន ។

ព្រះសាស្តាត្រាស់ថា ម្នាលកិកូទាំងឡាយ ពួកអ្នកកុំពោលយ៉ាងនោះឡើយ ។ ចុល្លកាលក្រោកឡើង ក្រោកឡើងព្រមហើយ ច្រើនទៅដោយអារម្មណ៍ថាស្អាត ដូចគ្នានឹងដើមឈើដែលមានកម្ទាំងទុព្វល តាំងនៅត្រង់មាត់ជ្រោះងាយនឹងដាច់ ចំណែកមហាកាលបុត្រតថាគត តាមឃើញអារម្មណ៍ថាមិនស្អាត ជាអ្នកមិនញាប់ញ័រឡើយ ដូចថ្មភ្នំតាន់ ដូច្នេះហើយ បានភាសិតគាថាទាំងនេះថា

សុភានុបស្សឺ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ
ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ
តំ វេ បសហតី មារោ វាតោ រុក្ខំ ទុព្ពលំ
អសុភានុបស្សឺ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ
ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារាធវីរិយំ

តំ វ ឆប្បសហាតី មរោ វាតោ សេលំវ បព្ភតំ ។

បុគ្គលដែលឃើញ នូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយទាំង៦ឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមធូរថយ កិលេសមារ រមែងគ្របសង្កត់បុគ្គលនោះឯង ដូចខ្យល់ដែលគ្របសង្កត់ដើមឈើទុព្វល ដូច្នោះ ។ ឯបុគ្គលដែលឃើញ នូវអារម្មណ៍ថាមិនល្អ សង្រួមប្រពៃក្នុងឥន្ទ្រិយទាំង៦ឡាយ ដឹងប្រមាណក្នុងភោជន មានសទ្ធា ប្រារព្ធព្យាយាម កិលេសមារ តែងគ្របសង្កត់បុគ្គលនោះមិនបាន ដូចខ្យល់គ្របសង្កត់ថ្មភ្នំតាន់មិនបាន ដូច្នោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សុភានុបស្សិំ** *បានដល់ បុគ្គលតាមឃើញអារម្មណ៍ថាស្អាត អធិប្បាយថា បុគ្គលបណ្តែតបណ្តោយចិត្តទៅក្នុងអារម្មណ៍ដែលគួរជ្រាថ្នា បុគ្គលណាកាលកាន់យកដោយនិមិត្ត ដោយអនុព្យញ្ជនៈ រមែងកាន់យកថា ក្រចកទាំងឡាយស្អាត កាន់យកថា ម្រាមដៃទាំងឡាយស្អាត កាន់យកថា ដៃទាំងពីរ ជើងទាំងពីរ ដើមដៃទាំងពីរ ស្មាទាំងពីរ ចង្កេះ ពោះ សុជន់ទាំងពីរ ក បបូរមាត់ ធ្មេញទាំងឡាយ មាត់ ច្រមុះ ភ្នែកទាំងគូ ត្រចៀកទាំងគូ ចិញ្ចើមទាំងគូ ថ្ងាស សក់ទាំងឡាយស្អាត ។ កាន់យកថា សក់ រោម ក្រចក ធ្មេញ ស្បែក ស្អាត ឬកាន់យកថា សម្បុរល្អ ទ្រង់ទ្រាយល្អ បុគ្គលនេះ ឈ្មោះថា តាមឃើញអារម្មណ៍ថាស្អាត បុគ្គលនោះ គឺជាអ្នក*

តាមឃើញនូវអារម្មណ៍ថាស្អាត យ៉ាងនោះ ។

បទថា **ឥន្ទ្រិយេសុ** *បានដល់ ក្នុងឥន្ទ្រិយទាំង ៦ មានចក្ខុជាដើម ។*

បទថា **អសំវុតំ** *បានដល់ ដែលមិនរក្សាទ្វារទាំងឡាយ មានចក្ខុទ្វារជាដើម ។*

បទថា **អមត្តញ្ញុំ** *សេចក្តីថា ឈ្មោះថា បុគ្គលមិនស្គាល់ប្រមាណក្នុងភោជន ព្រោះមិនស្គាល់ប្រមាណនេះ គឺប្រមាណក្នុងការស្វែងរក ប្រមាណក្នុងការទទួល ប្រមាណក្នុងការបរិភោគ ។ ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកមិនស្គាល់ប្រមាណ ព្រោះមិនស្គាល់ប្រមាណទាំងនេះ គឺប្រមាណក្នុងការពិចារណា ប្រមាណក្នុងការលះ គឺមិនដឹងថា ភោជននេះ ប្រកបដោយធម៌ នេះមិនប្រកបដោយធម៌ ។ បទថា* **កុសីតំ** *សេចក្តីថា ឈ្មោះថា អ្នកខ្ជិលច្រអូស ព្រោះជាអ្នកប្រព្រឹត្តទៅក្នុងអំណាចរបស់កាមវិតក្ក ព្យាបាទវិតក្ក និងវិហឹង្សាវិតក្ក ។*

បទថា **ហីនវីរិយំ** *សេចក្តីថា ជាអ្នកមិនមានសេចក្តីព្យាយាម គឺវៀរចាកការធ្វើសេចក្តីព្យាយាមក្នុងឥរិយាបថទាំង ៤ ។*

បទថា **បសហតិ** *ប្រែថា រមែងគ្របសង្កត់ គឺញាំញី ។*

បានព្រះគាថាថា **វាតោ រុក្ខំ ឧព្ភវំ** *សេចក្តីថា ដូចខ្យល់ដែលមានកម្លាំងខ្លាំង កួចនូវដើមឈើដែលមានកម្លាំងខ្សោយ ដែលដុះត្រង់មាត់ជ្រោះឲ្យដាច់ អធិប្បាយថា ខ្យល់នោះញាំងចំណែកផ្សេងៗ មានផ្កា ផ្លែ ស្លឹកនិងជាដើមនៃដើមឈើនោះឲ្យជ្រុះខ្លះ កាច់បំបាក់មែកតូចខ្លះ កាច់មែកធំខ្លះ ដក*

នូវដើមឈើនោះ ព្រមទាំងឫស ធ្វើឲ្យឫសឡើងលើ មែកចុះក្រោម យ៉ាងណា មារ គឺកិលេសដែលកើតខាងក្នុង រមែងកួចបុគ្គលដែលឃើញបែបនោះ បានដូច្នោះដូចគ្នា គឺកិលេសមារ រមែងធ្វើឲ្យត្រូវអាបត្តិតូចៗ ដូចខ្សល់មានកម្លាំងខ្លាំង បក់ចំណែកផ្សេងៗ មានផ្កា ផ្លែ ស្វ៊ែកខ្វីជាដើមនៃដើមឈើដែលមិនរឹងមាំឲ្យជ្រុះចុះខ្លះ ធ្វើឲ្យត្រូវអាបត្តិមានឧស្សគ្គិយៈជាដើម ដូចខ្សល់មានកម្លាំងខ្លាំង កាច់បំបាក់មែកឈើតូចៗ ខ្លះ ធ្វើឲ្យត្រូវអាបត្តិសង្ឃាទិសេស ១៣ ដូចខ្សល់មានកម្លាំងកាច់បំបាក់នូវមែកធំខ្លះ ធ្វើឲ្យត្រូវអាបត្តិបារាជិក នាំចេញចាកសាសនាដែលព្រះដ៏មានព្រះភាគត្រាស់ល្អហើយ ឲ្យដល់នូវភាពជាគ្រហស្ថក្នុងរយៈពេលពីរបីថ្ងៃប៉ុណ្ណោះ ដូចខ្សល់មានកម្លាំងខ្លាំងដកដើមឈើធ្វើឲ្យរលំមានឫសឡើងលើ មានមែកចុះក្រោមខ្លះ ។ កិលេសមារ រមែងញាំងបុគ្គលបែបនោះ ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ។

បទថា **អសុភានុបស្សី** *សេចក្តីថា ជាអ្នកឃើញអារម្មណ៍មិនល្អ ១០ យ៉ាងណាមួយថាមិនស្អាត គឺប្រកបក្នុងមនសិការ ដោយភាពជារបស់បដិកូល បានឃើញសក់ទាំងឡាយ ថាជារបស់មិនស្អាត ឃើញរោម ក្រចក ធ្មេញ ស្បែក ពណ៌សម្បុរ ទ្រង់ទ្រាយដោយភាពមិនស្អាត ។*

បទថា **ឥន្ទ្រិយេសុ** *បានដល់ ក្នុងឥន្ទ្រិយ ៦ ។ បទថា* **សុសំវុតំ** *បានដល់ ដែលវៀរចាកការកាន់យក មានកាន់យកដោយនិមិត្តជាដើម គឺជាអ្នកមានទ្វារបិទហើយ ។*

បទថា **មតញ្ញុំ** *សេចក្តីថា បុគ្គលស្គាល់ប្រមាណក្នុងភោជន ដោយផ្លូវ*

គ្នាក្នុងភាពជាបុគ្គលមិនស្គាល់ប្រមាណ ។

បទថា **សទ្ធំ** *សេចក្តីថា ជាអ្នកប្រកបដោយលោកិយសទ្ធា មានការជឿកម្ម និងផលជាលក្ខណៈមួយ និងប្រកបដោយលោកុត្តរសទ្ធា ពោល គឺការជ្រះថ្លាដែលមិនញាប់ញ័រក្នុងវត្ថុ ៣ យ៉ាងមួយ ។*

បទថា **អារាធវីរិយំ** *បានដល់ ជាអ្នកផ្គងព្យាយាម គឺជាអ្នកមានសេចក្តីព្យាយាមពេញលេញ ។*

បទថា **តំ វ** *បានដល់ បុគ្គលនោះ គឺឃើញបែបនោះ អធិប្បាយថា ខ្យល់ដែលមានកម្លាំងខ្លាយបក់ស្រាលៗ រមែងមិនអាចឲ្យសិលាតាន់ញាប់ញ័របានយ៉ាងណា កិលេសមារដែលមានកម្លាំងខ្លាយ សូម្បីកើតឡើងខាងក្នុង រមែងកួចបុគ្គលនោះមិនបាន គឺមិនអាចឲ្យញាប់ញ័រកម្រើករំពើកឃ្លាតចាកទីបាន ដូច្នោះ ។*

ពួកស្រីទាំងនោះឯង ដែលជាភរិយាចាស់របស់មហាកាលនោះ ចោមរោមព្រះថេរៈហើយ ពោលពាក្យជាដើមថា លោកម្ចាស់លាអ្នកណាបួសឥឡូវនេះ លោកម្ចាស់ទៅជាគ្រហស្ថឬមិនទៅ ដូច្នេះហើយ បានជាអ្នកប្រាថ្នានឹងដោះសំពត់កាសាវពស្ត្រទាំងឡាយរបស់ព្រះថេរៈចេញ ។

ព្រះថេរៈកំណត់អាការរបស់ស្រីទាំងនោះបានហើយ ក្រោកចាកអាសនៈដែលអង្គុយ ហើយហោះទៅដោយឫទ្ធិ ទម្លាយហោជាងផ្ទះកំពូល ទៅតាមអាកាស កាលព្រះសាស្តាត្រាស់ព្រះគាថាចប់ សរសើរព្រះសរីរៈរបស់ព្រះសាស្តា ដែលមានពណ៌ដូចមាស ចុះមកថ្វាយបង្គំព្រះយុគលបាទរបស់

ព្រះតថាគតហើយ ។

ក្នុងកាលចប់គាថា ភិក្ខុដែលប្រជុំគ្នា តាំងនៅក្នុងអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ចុល្លកាល និងមហាកាល ចប់

រឿង ទេវទត្តភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបានសំពត់កាសាវពស្ត្រ ដែលបុគ្គលនាំមកអំពីដែនគន្ធារៈរបស់ទេវទត្តភិក្ខុ ក្នុងក្រុងរាជគ្រឹះ ត្រាស់ព្រះធម្មទេសនានេះថា **អនិក្កសាវោ** *ជាដើម ។*

សេចក្តីពិស្តារថា សម័យមួយ អគ្គសាវ័កទាំងពីរ នាំបរិវារបស់ខ្លួនមួយអង្គ ៥០០ ទៅទូលលាព្រះសាស្តាហើយ បានទៅអំពីវត្តជេតពន កាន់ក្រុងរាជគ្រឹះ ។

អ្នកក្រុងរាជគ្រឹះរួមគ្នាមួយពួក ២ នាក់ខ្លះ ៣ នាក់ខ្លះ ច្រើននាក់ខ្លះ បានប្រគេនអាគន្តុកទាន ។ សម័យថ្ងៃមួយ ព្រះសារីបុត្រកាលធ្វើអនុមោទនាសម្តែងធម៌យ៉ាងនេះថា ឧបាសកឧបាសិកាទាំងឡាយ ទាយកមួយពួកថ្វាយទានដោយខ្លួនឯង តែមិនបបួលអ្នកដទៃ ទាយកនោះ រមែងបានភោគសម្បត្តិក្នុងទីដែលខ្លួនកើតហើយ តែមិនបានបរិវារសម្បត្តិ បុគ្គលមួយពួក បបួល

អ្នកជនៃតែខ្លួនឯងមិនថ្វាយ បុគ្គលនោះ រមែងបានបរិវារសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ តែជាអ្នកមិនមានភោគសម្បត្តិ បុគ្គលមួយពួកខ្លួនឯង ក៏មិនបានថ្វាយ អ្នកជនៃក៏មិនបបួល បុគ្គលនោះ រមែងមិនបានវត្ថុសូម្បីត្រឹមតែបាយចុងអង្គរល្មមចម្អែតផ្ទៃ រមែងជាមនុស្សអនាថា មិនមានបច្ចុយ ក្នុងទីដែលខ្លួនកើតហើយ ជនមួយពួកខ្លួនឯងក៏ថ្វាយផង បបួលអ្នកជនៃផង បុគ្គលនោះ រមែងបានទាំងភោគសម្បត្តិ ទាំងបរិវារសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ អស់រយអត្តភាពខ្លះ ពាន់អត្តភាពខ្លះ សែនអត្តភាពខ្លះ ។

បុរសបណ្ឌិតម្នាក់ ស្តាប់ធម្មទេសនានោះហើយ គិតថា ព្រះធម្មទេសនាអស្ចារ្យពន់ពេក លោកម្ចាស់សារីបុត្រពោលហេតុនៃសេចក្តីសុខ អញធ្វើកម្មញ៉ាំងសម្បត្តិទាំងពីរនេះឲ្យសម្រេច រមែងសមគួរ ដូច្នេះហើយ ទើបនិមន្តព្រះថេរៈថា បពិត្រលោកម្ចាស់ សូមអ្នកនេះសូមនិមន្តលោកម្ចាស់ទាំងឡាយទទួលកិច្ចារបស់ខ្ញុំចុះ ព្រះថេរៈសួរថា អ្នកត្រូវការភិក្ខុប៉ុន្មាន ឧបាសកសួរថា ភិក្ខុដែលជាបរិវារបស់លោកម្ចាស់មានប៉ុន្មាន ព្រះថេរៈពោលថា មានប្រមាណមួយពាន់រូប ឧបាសកពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ មួយអន្ទើដោយភិក្ខុទាំងអស់ទទួលកិច្ចារបស់ខ្ញុំ ។ ព្រះថេរៈទទួលហើយ ។

ឧបាសកត្រាច់ទៅក្នុងផ្លូវនៃព្រះនគរ បបួលដោយពាក្យថា អ្នកម៉ែ លោកឪពុកទាំងឡាយ ខ្ញុំនិមន្តភិក្ខុមួយពាន់រូប អ្នកទាំងឡាយនឹងអាចប្រគេនភិក្ខាមានចំនួនប៉ុណា អ្នកទាំងឡាយ នឹងអាចប្រគេនភិក្ខាដល់ភិក្ខុមានចំនួនប៉ុណា ។

ពួកមនុស្សពោលដោយល្មមសមគួរដល់កម្លាំងរៀងៗ ខ្លួនថា ពួកខ្ញុំនឹងប្រគេនដល់ភិក្ខុ ១០ រូប ពួកខ្ញុំ ២០ រូប ពួកខ្ញុំ ១០០ រូប ។

ឧបាសកពោលថា បើដូច្នោះ យើងទាំងឡាយនឹងចម្អិនរួមគ្នាក្នុងទីមួយកន្លែង សូមអ្នករាល់គ្នាប្រមូលវត្ថុផ្សេងៗ មានប្រេង ល្ង អង្ករ សប្បិ ទឹកអំពៅជាដើម ដូច្នេះហើយ ឲ្យទុកជាក់ក្នុងទីមួយកន្លែង ។

ពេលនោះ កុដុម្ពិក:ម្នាក់ឲ្យសំពត់កាសាវៈ ដែលនាំមកអំពីដែនគន្ធារៈ ដែលមានតម្លៃ ១ សែនដល់ឧបាសកនោះហើយ ប្រាប់ថា បើទានវដ្ត: (ទេយ្យ-ធម៌) របស់អ្នកមិនទាន់គ្រប់គ្រាន់សោត អ្នកគប្បីចំណាយសំពត់នេះ ឲ្យគ្រប់ចំណែកដែលខ្វះខាត បើទានវដ្ត:របស់អ្នកគ្រប់គ្រាន់សោត អ្នកគប្បីប្រគេនសំពត់នេះដល់ភិក្ខុអង្គណាដែលអ្នកប្រាថ្នា ។ ក្នុងកាលនោះ ទានវដ្ត:គ្រប់យ៉ាងរបស់ឧបាសកនោះគ្រប់គ្រាន់ហើយ វត្ថុណាមួយឈ្មោះថា ខ្វះខាតមិនមាន ទើបឧបាសកនោះសួរមនុស្សទាំងឡាយថា សំពត់កាសាវពស្ត្រដែលមានតម្លៃកាត់ថ្លៃមិនបាននេះ ដែលកុដុម្ពិក:ម្នាក់ពោលយ៉ាងនេះ ហើយប្រគល់ឲ្យ ។ ទានវដ្ត:របស់ពួកយើង ក៏មានគ្រប់គ្រាន់ហើយ យើងទាំង-ឡាយនឹងប្រគេនសំពត់កាសាវៈនេះ ដល់ភិក្ខុអង្គណាហ្ន៎ ។

មនុស្សពួកខ្លះពោលថា គួរប្រគេនដល់ព្រះសារីបុត្តត្ថេរ ពួកខ្លះពោលថា ព្រះថេរៈជាច្រើនមកក្នុងវេលាស្រូវទុំ ហើយក៏ទៅ ទេវទត្តភិក្ខុជាសម្ងាញ់ក្នុងការមង្គល និងអវមង្គលទាំងឡាយរបស់ពួកយើង តាំងនៅជានិច្ច ដូចក្អមទឹក ពួកយើងនឹងប្រគេនសំពត់នោះដល់លោក កាលវាចាប្រព្រឹត្តទៅច្រើនផ្លូវ

យ៉ាងនោះ ពួកដែលពោលថា ប្រគេនដល់ទេវទត្តភិក្ខុ មានចំនួនច្រើនជាង កាលបើយ៉ាងនោះ ទើបពួកគេប្រគេនសំពត់កាសាវពស្ត្រនោះ ដល់ទេវទត្តភិក្ខុ ។

ទេវទត្តកាន់សំពត់នោះហើយ ដេរ ជ្រលក់ ស្បៃកដណ្តប់ត្រាច់ទៅ ។ ពួកមនុស្សឃើញលោកហើយ ទើបពោលថាសំពត់នេះ មិនសមគួរដល់ទេវទត្តភិក្ខុសោះ គួរដល់ព្រះសារីបុត្តត្ថេរ ។ ទេវទត្តភិក្ខុដណ្តប់សំពត់ដែលមិនសមគួរដល់ខ្លួន ត្រាច់ទៅហ្ន៎ ។

ខណៈនោះ ភិក្ខុដែលនៅក្នុងទិសដទៃមួយរូប ចេញអំពីនគរពារាណសីទៅកាន់នគរសាវត្ថី ថ្វាយបង្គំព្រះសាស្តា ជាបុគ្គលដែលព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈ ត្រាស់សួរដល់ការនៅជាផាសុខ របស់អគ្គសាវកទាំងពីរហើយ ទើបក្រាបទូលរឿងទាំងអស់នោះ តាំងពីដើមដល់ចប់ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទេវទត្តនោះទ្រទ្រង់សំពត់ដែលមិនសមគួរដល់ខ្លួនក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុន ក៏ទ្រទ្រង់ហើយដូចគ្នា ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តទ្រង់សោយរាជសម្បត្តិ ក្នុងនគរពារាណសី ។ នាយព្រានជីវអ្នកនគរពារាណសីម្នាក់ ផ្តួលជីវហើយ នាំភ្លុកស្បែក ពោះវៀនធំ និងសាច់មកហើយ លក់ដូរចិញ្ចឹមជីវិត ។ គ្រានោះ ជីវទាំងឡាយមួយពាន់ ដើរវកស៊ីក្នុងព្រៃមួយ ជួបព្រះបច្ចេកពុទ្ធច្រើនអង្គ ចាប់តាំងអំពីកាលនោះ កាលទៅរមែងក្រាបចុះដោយជើងទាំងពីរ ហើយថ្វាយបង្គំ

ក្នុងកាលដែលទៅ និងមក ហើយទើបឆ្ងងទៅ ។ ថ្ងៃមួយ ព្រានដីរឃើញកិរិយានោះហើយ គិតថា អញសម្ងាប់ដីរទាំងនេះបានដោយលំបាក ក្នុងកាលទៅ និងមក ដីរទាំងនេះរមែងថ្ងាយបង្គំព្រះបច្ចេកពុទ្ធទាំងឡាយ ដីរទាំងនេះឃើញអ្វីហ្ន៎ ទើបថ្ងាយបង្គំ ។ កំណត់បានថា ឃើញសំពត់កាសាវពស្ត្រដូច្នេះហើយ ត្រិះរិះថា ឥឡូវនេះ អញនឹងបានសំពត់កាសាវពស្ត្រ រមែងគួរ ។ កាលព្រះបច្ចេកពុទ្ធមួយរូប ចុះទៅកាន់ជាតស្រះស្រង់ទឹក ដាក់សំពត់កាសាវៈទាំងឡាយត្រង់មាត់ច្រាំង ទើបលួចចីវរទៅ ចាប់លំពែងអង្គុយទូរនៅត្រង់មាត់ផ្លូវ ដែលដីរទាំងនោះទៅមក ។ ពួកដីរឃើញព្រានហើយ ទើបថ្ងាយបង្គំដោយសម្គាល់ថា ព្រះបច្ចេកពុទ្ធ ហើយក៏ឆ្ងងទៅ នាយព្រានដីរនោះយកលំពែងពួយដីរដែលទៅខាងក្រោយគេបង្អស់ឲ្យងាប់ហើយ កាន់យកចំណែកផ្សេងៗ មានភ្លុកជាដើម កប់ចំណែកដែលសល់ក្នុងផែនដី ហើយទៅ ។

ក្នុងកាលតមក ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតដីរ បានជាមេហ្វូង ជាប្រធាន ។ ក្នុងកាលនោះ ព្រានដីរនោះក៏នៅតែធ្វើយ៉ាងនោះ ។ ព្រះមហាបុរសជ្រាបការអស់នៃបរិស័ទរបស់ខ្លួន ទើបសួរថា ដីរទាំងនេះទៅណា ទើបរលស់អស់ កាលពួកដីរទាំងនោះឆ្លើយថា ខ្ញុំមិនដឹងទេ ព្រះពោធិសត្វក៏គិតថា ដីរទាំងឡាយទៅណាក៏មិនជ្រាបអញ ឬក៏មិនទៅណាអន្តរាយពិតជាមានទីកសង្ស័យថា អន្តរាយគប្បីមានអំពីសម្នាក់នៃបុរស ដែលអង្គុយទូរសំពត់កាសាវៈក្នុងទីមួយ ។ ដើម្បីចាប់បុរសនោះ ទើបបញ្ជូនដីរទាំងអស់ឲ្យដើរទៅមុន ចំណែកខ្លួនដើរមកឯក្រោយ នាយព្រានដីរនោះ កាលដីរដ៏សេសថ្ងាយ

បន្តំហើយដើរទៅ ឃើញព្រះមហាបុរសកំពុងដើរមក ទើបមូរចីវរ ពួយ លំពែងទៅ ។

ព្រះមហាបុរសគ្រប់គ្រងសតិដើរមក ថយក្រោយទៅគេចលំពែងហើយ ពេលនោះ ទើបស្ទុះចូលទៅដើម្បីចាប់នាយព្រាននោះ ដោយសម្គាល់ថាបុគ្គល នេះឲ្យជំរីរបស់អញវិនាសហើយ នាយព្រានជំរីនេះ ពួនកំបាំងដើមឈើមួយ ដើម ពេលនោះ ព្រះមហាបុរសយកប្រមោយចាប់ព្រាន ព្រមទាំងដើមឈើ បំណងថា នឹងចាប់សង្កត់ចុះត្រង់ផែនដី ឃើញសំពត់កាសាវ:ដែលព្រាននាំ មកបង្ហាញ ទើបឈប់បង្អង់ដោយគិតឃើញថា បើអញប្រទូស្តក្នុងបុរសនេះ សោត ឈ្មោះថា ការខ្មាសក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រព ច្រើនពាន់អង្គ ឈ្មោះថា អញទម្លាយហើយ ។ ហើយបែរជាសួរថា ញាតិ របស់យើងប្រមាណប៉ុណ្ណេះ អ្នកឯងឲ្យវិនាសហើយឬ ។

នាយព្រានជំរីសារភាពថា ពិតហើយ ព្រះមហាបុរសពោលថា ព្រោះ ហេតុអ្វី ទើបអ្នកធ្វើកម្មគ្រោតគ្រាតយ៉ាងនេះ អ្នកដណ្តប់សំពត់មិនគួរដល់ខ្លួន សមគួរដល់អ្នកប្រាសចាករាគ:ទាំងឡាយ កាលធ្វើកម្មដ៏លាមកបែបនេះ ឈ្មោះ ថា ធ្វើកម្មធ្ងន់ កាលពោលយ៉ាងនោះហើយ ដើម្បីសង្កត់សង្កិនឲ្យក្រៃលែង ឡើង ទើបពោលគាថា

> អ្នកណា នៅមានទឹកចត់ គឺរាគាទិក្កិលេស (ក្នុងសន្តាន)
> ជាអ្នកបោះបង់ការទូន្មាននូវឥន្ទ្រិយ និងសច្ចៈហើយ ស្លៀក
> ដណ្តប់សំពត់កាសាវ: អ្នកនោះ មិនគួរនឹងស្លៀកដណ្តប់

សំពត់កាសាវៈឡើយ ។ លុះតែអ្នកណា មានទឹកចត់ គឺ រាគាទិក្កិលេសខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់ មាំក្នុងចតុប្បារិសុទ្ធិសីល ប្រកបដោយការទូន្មាននូវឥន្ទ្រិយ និងសច្ចៈ អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្តប់សំពត់ កាសាវៈបាន ។ ដូច្នេះហើយ ពោលថា អ្នកធ្វើកម្មមិន សមគួរ ហើយដោះលែងទៅ ។

ព្រះសាស្តាកាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រោនជ័រក្នុងកាលនោះ បានជាទេវទត្តក្នុងកាលឥឡូវនេះ ជ័រជ័ប្រសើរដែល សង្កត់សង្កិននាយព្រោននោះ គឺតថាគតនេះឯង ដូច្នេះ ត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ទ្រទ្រង់ សំពត់មិនសមគួរដល់ខ្លួនដូចគ្នា ដូច្នេះហើយ បានភាសិតព្រះគាថាទាំងនេះថា

អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហេស្សតិ
អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ
យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ
ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ ។

អ្នកណា នៅមានទឹកចត់ គឺរាគាទិក្កិលេស (ក្នុងសន្តាន) ជាអ្នកបោះបង់ការទូន្មាននូវឥន្ទ្រិយ និងសច្ចៈ ហើយស្លៀក ដណ្តប់សំពត់កាសាវៈ អ្នកនោះ មិនគួរនឹងស្លៀកដណ្តប់ សំពត់កាសាវៈឡើយ ។ លុះតែអ្នកណា មានទឹកចត់ គឺ

រាគាទិក្លិសេសខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំ ក្នុងចតុប្បារិសុទ្ធសីល ប្រកបដោយការទូន្មាននូវឥន្ទ្រិយ និង សច្ចៈ អ្នកនោះឯង ទើបគួរនឹងស្បៀកជណ្តប់សំពត់កាសាវៈ បាន ។ សេចក្តីនេះ បណ្ឌិតគប្បីសម្តែងដោយឆន្ទជាតកដូច្នេះ ។

អធិប្បាយសេចក្តី

បណ្តាបទទាំងនោះ បទថា **អនិក្កសាវោ** *សេចក្តីថា បុគ្គលឈ្មោះថាមានកិលេសដូចទឹកចត់ ព្រោះកិលេសដូចទឹកចត់ទាំងឡាយ មានកាមរាគៈជាដើម ។*

បទថា **បរិទហោសុត្ថ** *សេចក្តីថា នឹងប្រើប្រាស់ដោយអំណាចនៃការស្បៀកជណ្តប់ និងការក្រាល ។ ព្រះបាលីថា* **បរិទហិស្សតិ** *ក៏មាន ។*

បាទព្រះគាថាថា **អបេតោ ទមសច្ចេន** *សេចក្តីថា ប្រាសចាក អធិប្បាយថា ប្រាសទៅអំពីការទូន្មានឥន្ទ្រិយ និងវចីសច្ចៈ ដែលជាចំណែកបរមត្ថសច្ចៈ ។*

បទថា **ន សោ** *ជាដើម សេចក្តីថា បុគ្គលនោះ គឺបុគ្គលបែបនោះរមែងមិនគួរស្បៀកជណ្តប់សំពត់កាសាវៈឡើយ ។*

បទថា **វន្តកសាវស្ស** *សេចក្តីថា គប្បីជាអ្នកមានកិលេសដូចទឹកចត់ដែលខ្ជាក់ហើយ គឺមានកិលេសដូចទឹកចត់ដែលចោលហើយ បានដល់ មានកិលេសដូចទឹកចត់លះហើយដោយមគ្គ ៤ ។*

បទថា **សីលេសុ** *បានដល់ ក្នុងបរិសុទ្ធសីល ៤ ។ បទថា* **សុសមាហិតោ** *បានដល់ បុគ្គលតាំងមាំល្អ គឺតាំងនៅដោយល្អ ។*

បទថា **ឧបេតោ** *សេចក្តីថា ប្រកបដោយការទូន្មានឥន្ទ្រិយ និងវចីសច្ចៈ មានប្រការដូចពោលហើយ ។*

បទថា **ស វេ** *ជាដើម សេចក្តីថា បុគ្គលនោះ គឺបែបនោះ រមែងគួរស្បៃកជណ្តប់សំពត់កាសាវពស្ត្រនោះ ។*

ក្នុងកាលចប់គាថា ភិក្ខុដែលនៅក្នុងទិសផ្សេងនោះ បានជាព្រះសោតាបន្ន ជនដទៃមានចំនួនច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាបានសម្រេចប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

រឿង ទោវចត្តភិក្ខុ ចប់

រឿង សញ្ជ័យ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការមិនមករបស់សញ្ជ័យបរិព្វាជក ដែលអគ្គសាវ័កទាំងពីរក្រាបទូលហើយ ត្រាស់ព្រះធម្ម-ទេសនានេះថា **អសារេ សារមតិនោ** *ជាដើម ។ អនុបុព្វីកថាក្នុងរឿងសញ្ជ័យនោះដូចតទៅនេះ*

សេចក្តីពិស្តារថា ក្នុងទីបំផុត ៤ អសង្ខ្យេយ្យ និងមួយសែនកប្បអំពីកប្បនេះទៅ ព្រះសាស្តានៃយើងទាំងឡាយ ជាកូនរបស់ព្រាហ្មណ៍ ឈ្មោះថាសុមេធ ក្នុងអមរវតីនគរ ដល់នូវការសម្រេចសិប្បៈគ្រប់យ៉ាង ដោយ

កាល ធ្វើកាលកិរិយាទៅនៃមាតា និងបិតា ទ្រង់បរិច្ចាគទ្រព្យច្រើនកោដិ បួស ជាឥសីក្នុងហិមវន្តប្បទេស ធ្វើឈាន និងអភិញ្ញាឲ្យកើតហើយ ទៅដោយ អាកាស ឃើញមនុស្សធ្វើផ្លូវ ដើម្បីប្រយោជន៍ដល់ការយាងអំពីសុទស្សន-វិហារ ចូលកាន់ទៅអមរវតីនគរនៃព្រះទសពល ព្រះនាមថាទីបង្ករ ខ្លួនឯង ក៏កាន់យកមួយចំណែក កាលចំណែកនោះមិនទាន់សម្រេច ដេកក្រាបធ្វើខ្លួន ឲ្យជាស្ពាន ក្រាលស្បែកខ្លាលើកក់ ដើម្បីព្រះសាស្តាដែលយាងមកហើយ ដោយបំណងថា សូមព្រះសាស្តា មួយអន្ទើដោយសង្ឃសាវក មិនចាំបាច់ ជាន់កក់ សូមទ្រង់ជាន់អញយាងទៅចុះ ។ លុះព្រះសាស្តាទតឃើញ ក៏ទ្រង់ ព្យាករថា សត្វនេះជាពុទ្ធង្គារ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ក្នុងទី បំផុត ៤ អសង្ខ្យៃ និងមួយសែនកប្ប ក្នុងអនាគត ។ ក្នុងសម័យតមក ព្រះសាស្តាអង្គនោះ ក៏ទទួលព្យាករក្នុងសម្នាក់ព្រះពុទ្ធ ២៣ អង្គ ដែលទ្រង់ កើតឡើង បំភ្លឺលោកឲ្យភ្លឺ គឺ ព្រះកោឌញ្ញៈ ១ ព្រះសុមង្គលៈ ១ ព្រះ សុមនៈ ១ ព្រះរេវតៈ ១ ព្រះសោភិតៈ ព្រះអនោមទស្សី ១ ព្រះបទុមៈ ១ ព្រះនារទៈ ១ ព្រះបទុមុត្តរៈ ១ ព្រះសុមេធៈ ១ ព្រះសុជាតៈ ១ ព្រះ បិយទស្សី ១ ព្រះអដ្ឋទស្សី ១ ព្រះធម្មទស្សី ១ ព្រះសិទ្ធត្ថៈ ១ ព្រះតិស្សៈ ១ ព្រះផុស្សៈ ១ ព្រះវិបស្សី ១ ព្រះសិខី ១ ព្រះវេស្សភូ ១ ព្រះកកុសន្ធៈ ១ ព្រះកោនាគមនៈ ១ ព្រះកស្សបៈ ១ ទ្រង់បំពេញបារមី ៣០ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ តាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរ ឲ្យមហាទានដែលធ្វើផែនដីឲ្យកម្រើក ៧ ដង ទ្រង់បរិច្ចាគព្រះរាជឱរស និង

ព្រះជាយាក្នុងទីបំផុតព្រះជន្មាយុ ក៏ទ្រង់កើតឡើងក្នុងតុសិតបុរី តាំងនៅក្នុងតុសិតបុរីនោះជរាបអស់ព្រះជន្មាយុ កាលទេវតាក្នុងម៉ឺនចក្រវាលប្រជុំគ្នាអារាធនាថា

បពិត្រមហាវីរៈ កាលនេះ ជាកាលរបស់ព្រះអង្គ សូមទ្រង់កើតឡើងក្នុងព្រះគភ៌នៃព្រះមាតា ត្រាស់ដឹងអមតបទ ញុំាងលោកនេះ ព្រមទាំងទេវលោកឲ្យឆ្លង ។

ទ្រង់ជ្រើសរើសនូវឋានៈធំៗ ដែលគួរជ្រើសរើស ៥ ទ្រង់ចុតិអំពីតុសិតបុរីនោះហើយ ទ្រង់បដិសន្ធិក្នុងសក្យរាជត្រកូល ដែលព្រះញាតិបម្រើដោយមហាសម្បត្តិក្នុងសក្យត្រកូលនោះ ។ ទ្រង់ដល់នូវការចម្រើនវ័យដោយលំដាប់ សោយសិរីរាជសម្បត្តិ ក្នុងប្រាសាទទាំងបីដែលសមគួរដល់រដូវទាំងបី ដូចសិរីសម្បត្តិក្នុងទេវលោក ។

ក្នុងសម័យដែលទ្រង់យាងទៅដើម្បីប្រពាតឧទ្យាន ទ្រង់ឃើញទេវទូត ៣ គឺមនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់ដោយលំដាប់ ទ្រង់កើតនូវសេចក្តីសង្វេគ យាងត្រឡប់ហើយ ក្នុងថ្ងៃទី ៤ ទ្រង់ឃើញបព្វជិត ញុំាងនូវការពេញព្រះហឫទ័យក្នុងការបំពេញបព្វជ្ជាឲ្យកើតឡើងថា ការបួសជាការល្អហ្ន៎ ។ ទ្រង់ទៅកាន់ឧទ្យាន ញុំាងថ្ងៃឲ្យអស់ទៅក្នុងឧទ្យាននោះ ប្រថាប់គង់ត្រង់ឆ្នេរស្រះពោក្ខរណីជាមង្គល ដែលវិស្សកម្មទេវបុត្រ កាឡាឦនជាខ្នាន់ព្រះកេសនិម្មិតតាក់តែងថ្វាយ ទ្រង់បានឮដំណឹងប្រសូតរបស់រាហុលកុមារ ទ្រង់ជ្រាបដល់សេចក្តីស្នេហាក្នុងឱរសមានកម្លាំង ទ្រង់ត្រិះរិះថា អញនឹងកាត់ចំណងនេះ រហូតដល់ចងអញមិនបាននោះឯង ។ ពេលល្ងាច ទ្រង់ចូលទៅ

កាន់ព្រះនគរ ទ្រង់ស្តាប់គាថានេះ ដែលព្រះរាជធីតារបស់ព្រះបិតុលា ឈ្មោះ កិសាគោតមីភាសិតថា

ព្រះរាជកុមារនេះ ជាព្រះរាជឱរសនៃមាតាណា មាតានោះ រលត់ដោយពិត ជាឱរសនៃបិតាណា បិតានោះ រលត់ដោយពិត ជាព្រះស្វាមីរបស់នារីណា នារីនោះ រលត់ គឺត្រជាក់ចិត្តដោយពិត ។

ទ្រង់ព្រះតម្រិះថា អាត្មាអញដែលព្រះនាងកិសាគោតមីនេះឲ្យបានឮនិព្ទុតបទហើយ ទើបដោះកែវមុក្តាហារអំពីព្រះសូរង បញ្ជូនទៅឲ្យដល់ព្រះនាង ហើយស្តេចចូលទៅកាន់លំនៅរបស់ព្រះអង្គ ប្រថាប់គង់លើព្រះទែនបន្ទំដ៏មានសិរី ទតឃើញប្រការដែលប្លែករបស់ពួកស្រីរបាំ ដែលនិទ្រាហើយមានព្រះហឫទ័យនឿយណាយ ទើបជាស់ឆន្នៈអមាត្យឲ្យក្រោកឡើង ឲ្យនាំសេះកណ្ឋកៈមក ។ ទ្រង់ឡើងសេះកណ្ឋកៈ មានឆន្នៈអមាត្យជាសម្ងាញ់ដែលទេវតាក្នុងម៉ឺនចក្រវាលហែហមហើយ ទ្រង់ចេញមហាភិនេស្ក្រមណ៍ ទ្រង់ព្រះផ្នួសត្រង់ឆ្នេរស៊ីងអនោមានទី ។ ទ្រង់យាងដល់ក្រុងរាជគ្រឹះដោយលំដាប់ ទ្រង់យាងចិណ្ឌបាតក្នុងក្រុងរាជគ្រឹះនោះ ប្រថាប់គង់ត្រង់ញកក្តំបណ្ឌវៈ ដែលស្តេចផែនដី នគរមគធៈអាចធនាដោយរាជសម្បត្តិ ទ្រង់បដិសេធពាក្យអាចធនានោះ ទ្រង់ទទួលប្តេជ្ញាអំពីព្រះបាទមគធៈដើម្បីប្រយោជន៍ដល់ការបានសម្រេចសព្វញ្ញុតញ្ញាណហើយ ទ្រង់នឹងមកកាន់ដែនរបស់ព្រះអង្គមុនគេ ។ ទ្រង់ចូលទៅរកអាឡារតាបស និងឧទកតាបស ទ្រង់មិនពេញព្រះហឫទ័យ

ក្នុងគុណវិសេស ដែលទ្រង់បានសម្រេចក្នុងសម្នាក់របស់តាបសនោះ ទ្រង់តាំងមហាបធានអស់ ៦ ឆ្នាំ ។

ក្នុងថ្ងៃវិសាខបុណ្ណមីពេលព្រឹក ទ្រង់សោយបាយាសដែលនាងសុជាតាថ្វាយ ហើយទ្រង់បណ្តែតថាសមាសក្នុងស្ទឹងនេរញ្ជរា ឲ្យចំណែកនៃថ្ងៃកន្ងងទៅដោយសមាបត្តិផ្សេងៗ ក្នុងដងព្រៃមហាវន្តត្រង់ឆ្នេរស្ទឹងនេរញ្ជរានោះ ពេលល្ងាច ទ្រង់ទទួលស្មៅ ដែលសោត្ថិយព្រាហ្មណ៍ថ្វាយ មានព្រះគុណដែលស្តេចកាលនាគសរសើរហើយ ទ្រង់យាងទៅកាន់មណ្ឌលពោធិព្រឹក្ស ធ្វើប្តេជ្ញាថា អាត្មាអញនឹងមិនទម្ងាយក្នែនេះ អស់កាលដែលចិត្តរបស់អាត្មាអញ មិនរួចផុតចាកអាសវៈទាំងឡាយ ដោយការមិនចូលទៅប្រកាន់មាំ ប្រថាប់គង់បែរព្រះភក្ត្រទៅកាន់ទិសបូព៌ កាលព្រះអាទិត្យមិនទាន់អស្តង្គត ទ្រង់កម្ចាត់មារ និងពលបាន ទ្រង់សម្រេចបុព្វេនិវាសញ្ញាណក្នុងបឋមយាម ទ្រង់សម្រេចចុតូបបាតញ្ញាណក្នុងមជ្ឈិមយាម ទ្រង់ឈានចុះក្នុងបច្ចយាការ ក្នុងទីបំផុតនៃបច្ឆិមយាម ក្នុងអរុណរះឡើង ទ្រង់ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណ ដែលប្រដាប់ដោយគុណគ្រប់យ៉ាង មានព្រះទសពលញ្ញាណ និងចតុវេសារជ្ជញ្ញាណជាដើម ទ្រង់ញ្ចាំងកាលឲ្យកន្ងងទៅត្រង់មណ្ឌលពោធិព្រឹក្ស អស់ ៧ សប្តាហ៍ ក្នុងសប្តាហ៍ទី ៨ ប្រថាប់គង់ត្រង់គល់អជ្ជបាលនិគ្រោធ ទ្រង់ដល់នូវភាពជាអ្នកខ្ងល់ខ្ងាយតិច ដោយពិចារណាឃើញថា ជាធម៌មានសភាពជ្រាលជ្រៅ ដែលសហម្បតីព្រហ្ម មានមហាព្រហ្មមួយម៉ឺនជាបរិវារ អារាធនាឲ្យសម្តែងធម៌ ទ្រង់ពិចារណាមើលលោកដោយពុទ្ធចក្ខុហើយ ទ្រង់ទទួល

ពាក្យអារាធនារបស់ព្រហ្ម ទ្រង់ពិចារណាថា អាត្មាអញគប្បីសម្តែងធម៌ដល់នរណាមុនគេហ្ន៎ ។ ទ្រង់ជ្រាបថា អាឡារតាបស និងឧទកតាបសធ្វើកាលកិរិយាហើយ ទ្រង់នឹកដល់ឧបការៈច្រើនរបស់បញ្ចវគ្គិយភិក្ខុ ទ្រង់ក្រោកអំពីអាសនៈទៅកាន់កាសីបុរី ក្នុងវាងផ្លូវ បានសន្ទនាជាមួយឧបកាជីវក ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ទ្រង់ដល់លំនៅរបស់បញ្ចវគ្គិយ ក្នុងព្រៃឥសិបតនមិគទាយវន ទ្រង់ញុំាងបញ្ចវគ្គិយទាំងនោះ ដែលហៅទ្រង់ដោយពាក្យដែលមិនសមគួរឲ្យក្រាក់ខ្ជួនហើយ កាលនឹងញុំាងព្រហ្ម ១៨ កោដិ មានព្រះអញ្ញាកោណ្ឌញ្ញៈជាប្រធាន ឲ្យផឹកនូវអមតៈ ទើបទ្រង់សម្តែងធម្មចក្រ ទ្រង់មានធម្មចក្រដ៏បវរឲ្យប្រព្រឹត្តទៅហើយ ក្នុងតិថីទី ៥ នៃបក្ខ ទ្រង់ញុំាងភិក្ខុទាំងអស់នោះឲ្យតាំងនៅក្នុងអរហត្ត ក្នុងថ្ងៃជាមួយគ្នានោះឯង ។ ទ្រង់ឃើញឧបនិស្ស័យសម្បត្តិរបស់យសកុលបុត្រហើយ ត្រាស់ហៅយសកុលបុត្រ ដែលនៀយណាយ លះផ្ទះចេញមកទាំងកណ្តាលយប់ថា ម្នាលយស អ្នកចូរមកនេះចុះ ធ្វើយសកុលបុត្រឲ្យសម្រេចសោតបត្តិផលទាំងយប់នោះឯង ក្នុងថ្ងៃរះឡើងឲ្យសម្រេចអរហត្ត ។ ទ្រង់ញុំាងសម្ងាញ់របស់យស ៥៤ នាក់ជនៃទៀត ឲ្យបព្វជ្ជាដោយឯហិភិក្ខុឧបសម្បទាហើយ ឲ្យបានសម្រេចអរហត្ត ។

កាលព្រះអរហន្តកើតឡើងក្នុងលោក ៦១ អង្គ ដោយប្រការយ៉ាងនេះហើយ ព្រះសាស្តាទ្រង់នៅចាំវស្សាបវារណាហើយ ទ្រង់បញ្ជូនភិក្ខុ ៦០ រូបទៅក្នុងទិសទាំងឡាយដោយព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរត្រាច់ចារិកទៅចុះ ដូច្នេះជាដើម ។ ចំណែកទ្រង់ទៅកាន់ឧរុវេលាបទេស

ក្នុងរវាងផ្លូវទ្រង់បានទូន្មានភទ្រវគ្គិយកុមារ ៣០ រូបក្នុងព្រៃកប្បាស ។ បណ្តាភទ្រវគ្គិយកុមារ ៣០ រូបនោះ បុគ្គលដែលទាបជាងគេបង្អស់ ជាព្រះសោតាបន្ន ខ្ពស់ជាងគេបង្អស់ ជាព្រះអនាគាមី ។ ទ្រង់ឲ្យភទ្រវគ្គិយទាំងអស់នោះបព្វជ្ជាដោយឯហិភិក្ខុដូចគ្នាហើយ ទ្រង់បញ្ជូនទៅក្នុងទិសទាំងឡាយ ចំណែកព្រះអង្គទ្រង់ទៅកាន់ឧរុវេលាបទេស ទ្រង់សម្តែងបាដិហារ្យ ៣៥០០ ទូន្មានជដិល ៣ នាក់បងប្អូន ដែលមានជដិលមួយពាន់នាក់ជាបរិវារ មានឧរុវេលកស្សបៈជាដើម ឲ្យបព្វជ្ជាដោយឯហិភិក្ខុភាវៈដូចគ្នាហើយ ឲ្យប្រជុំគ្នាត្រង់គយាសីសប្បទេស ឲ្យតាំងនៅក្នុងអរហត្ត ដោយអាទិត្តបរិយាយទេសនា ចោមរោមដោយព្រះអរហន្តមួយពាន់អង្គ យាងទៅកាន់ឧទ្យានលដ្ឋិវន ជិតនគររាជគ្រឹះ ដោយទ្រង់ព្រះតម្រិះថា នឹងដោះប្តេជ្ញាដែលថ្វាយដល់ព្រះបាទពិម្ពិសារ ត្រាស់ព្រះធម្មកថាជ័ពីរោះដល់ព្រះរាជា ។ ព្រះរាជាទ្រង់ឮថា ព្រះសាស្តាយាងមកហើយ ទ្រង់មកគាល់ មួយអន្ទើដោយព្រាហ្មណ៍ និងគហបតី ១២ ម៉ឺននាក់ ញុំាងព្រះរាជា និងព្រាហ្មណ៍ មួយអន្ទើដោយគហបតី ១១ ម៉ឺននាក់ ឲ្យតាំងនៅក្នុងសោតាបត្តិផល ១ ម៉ឺនទៀត ឲ្យតាំងនៅក្នុងសរណៈ ៣ ។ ស្អែកឡើង មានព្រះគុណដែលសក្កទេវរាជកាឡាខ្លួនជាមាណពសរសៅរហើយ ទ្រង់ចូលទៅកាន់នគររាជគ្រឹះ ទ្រង់ធ្វើភត្តកិច្ចក្នុងព្រះរាជនិវេសន៍ ទ្រង់ទទួលវេឡុវនារាម ប្រថាប់នៅក្នុងវេឡុវនារាមនោះឯង ។ សារីបុត្រ និងមោគ្គល្លាន ចូលទៅគាល់ទ្រង់ក្នុងវេឡុវនារាមនោះ ។

អនុបុព្វីកថាក្នុងរឿងព្រះសារីបុត្រ និងព្រះមោគ្គល្លាននោះ មានដូចតទៅ

សេចក្តីពិស្តារថា កាលព្រះពុទ្ធទ្រង់មិនទាន់កើតឡើងនោះឯង មានស្រុកព្រាហ្មណ៍ពីរតំបន់ គឺឧបតិស្សគ្រាម ១ កោលិតគ្រាម ១ ក្នុងទីមិនឆ្ងាយអំពីក្រុងរាជគ្រឹះ ។ ក្នុងពីរតំបន់នោះ ក្នុងថ្ងៃដែលនាងព្រាហ្មណីឈ្មោះសារីក្នុងឧបតិស្សគ្រាមតាំងគភ៌នោះឯង នាងព្រាហ្មណីឈ្មោះមោគ្គល្លី ក្នុងកោលិត-គ្រាម ក៏តាំងគភ៌ដែរ ។ បានឮថា ត្រកូលទាំងពីរនោះ បានជាសម្ងាញ់ជាប់ទាក់ទងគ្នាតមកដល់ទៅ ៧ ជួរត្រកូលនោះឯង ។ ព្រាហ្មណ៍ជាប្តីបានឲ្យពិធីបរិហារគភ៌ដល់ព្រាហ្មណីទាំងពីរនោះ ក្នុងថ្ងៃតែមួយដូចគ្នា ។ ដោយកាលកន្លងទៅ ១០ ខែ ព្រាហ្មណីទាំងពីរនោះក៏ប្រសូតបុត្រ ។ ក្នុងថ្ងៃដាក់ឈ្មោះពួកញាតិដាក់ឈ្មោះកូនរបស់សារីព្រាហ្មណីថា ឧបតិស្សៈ ព្រោះជាកូនរបស់ត្រកូលមេស្រុកក្នុងតំបន់ឧបតិស្សគ្រាម ។តាំងឈ្មោះកូនរបស់មោគ្គល្លីព្រាហ្មណីថា កោលិតៈ ព្រោះជាកូនរបស់ត្រកូលមេស្រុក ក្នុងតំបន់កោលិតគ្រាមនេះ ។ ក្នុងទាំងពីរនោះ ដល់នូវការចម្រើនហើយ បានដល់នូវការសម្រេចនៃសិប្បៈគ្រប់យ៉ាង ក្នុងពេលទៅកាន់ស្តឹង ឬឧទ្យាន ដើម្បីប្រយោជន៍ក្នុងការលេងឧបតិស្សមាណពមានគ្រែស្នែង ៥០០ ជាគ្រឿងហែហម កោលិតមាណពទីមរថដោយសេះអាជានេយ្យ ៥០០ ជាគ្រឿងហែហម ជនទាំងពីរ មានមាណពជាបរិវារម្នាក់ ៥០០ ។ ក្នុងក្រុងរាជគ្រឹះ មានមហោស្រពលើកំពូលភ្នំរាល់ៗ ឆ្នាំ ។ ពួកញាតិបានលើកគ្រែត្រួតគ្នាដើម្បីកុមារទាំងពីរនោះក្នុងទីជាមួយគ្នានោះឯង ។ កុមារទាំងពីរ ក៏អង្គុយមើលមហោស្រពរួមគ្នា រមែងសើចក្នុងហានៈដែលគួរសើច រមែងដល់នូវសេចក្តីសង្វេគ ក្នុងហានៈដែល

គួរសង្វេគ រមែងឲ្យរង្វាន់ក្នុងហាន:ដែលគួរឲ្យរង្វាន់ ។ ថ្ងៃមួយ កាលកុមារទាំងពីរនោះមើលមហោស្រពដោយទំនងនេះ ការសើចក្នុងហាន:ដែលគួរសើច ឬការសង្វេគក្នុងហាន:ដែលគួរសង្វេគ ឬការឲ្យរង្វាន់ក្នុងហាន:ដែលគួរឲ្យ មិនមានហើយដូចក្នុងថ្ងៃមុនៗ ព្រោះញាណជល់នូវការចាស់ក្លាដោយជុំវិញហើយ ។ ជនទាំងពីរគិតគ្នាយ៉ាងនេះថា នឹងមានប្រយោជន៍អ្វី ដែលគួរមើលក្នុងការនេះ ជនទាំងអស់នេះ កាលមិនទាន់ជល់មួយរយឆ្នាំ ក៏នឹងជល់នូវភាពជាសភាវៈមិនមានបញ្ញត្តិ យើងទាំងពីរគួរស្វែងរកធម៌ជាគ្រឿងរួចផុតយ៉ាងឯក ដូច្នេះហើយ កាន់យកជាអារម្មណ៍ អង្គុយហើយ ។ លំដាប់នោះ កោលិត:ពោលនឹងឧបតិស្ស:ថា នែឧបតិស្ស:សម្លាញ់ ហេតុអ្វី ទើបអ្នកមិនសើចសប្បាយដូចក្នុងថ្ងៃដទៃៗ ថ្ងៃនេះ អ្នកមានចិត្តមិនរីករាយ អ្នកកំណត់អ្វីបានឬ ឧបតិស្ស:ពោលថា កោលិត:សម្លាញ់ ខ្ញុំអង្គុយគិតដល់ហេតុនេះថា ក្នុងការមើលមនុស្សទាំងនេះ មិនមានសារៈ ការមើលនេះ មិនមានប្រយោជន៍ អញគួរស្វែងរកមោគ្គធម៌ដើម្បីខ្លួន ចុះអ្នកវិញ ព្រោះហេតុ អ្វីទើបមិនរីករាយ សូម្បីកោលិត:នោះក៏ប្រាប់យ៉ាងនោះដូចគ្នា ។ លំដាប់នោះ ឧបតិស្ស:ជ្រាបភាពដែលកោលិត:នោះមានអធ្យាស្រ័យដូចគ្នានឹងខ្លួនហើយ ទើបពោលថា នែសម្លាញ់ យើងទាំងពីរគិតគ្នាល្អហើយ យើងគួរស្វែងរកមោគ្គធម៌ ធម្មតាអ្នកស្វែងរក ត្រូវបានបព្វជ្ជាបែបណាមួយ ទើបគួរ យើងទាំងពីរនឹងបួសក្នុងសម្នាក់អ្នកណាហ្ន៎ ។

សម័យនោះឯង សញ្ជ័យបរិព្វាជក អាស្រ័យនៅក្នុងក្រុងរាជគ្រឹះជាមួយ

បរិព្វាជកបរិសទ្យ៉ាងច្រើន ។ សារីបុត្រ និងមោគ្គល្លានទាំងពីរនោះ ជាក់កតិកាគ្នាថា យើងនឹងបួសក្នុងសម្នាក់សញ្ជ័យនោះ ។ ហើយបញ្ជូនមាណព ៥០០ ទៅដោយពាក្យថា អ្នកទាំងឡាយ ចូរយកក្រែស្នែង និងរថទៅចុះមួយអន្ទើដោយមាណព ៥០០ បួសហើយក្នុងសម្នាក់របស់សញ្ជ័យ ។ តាំងអំពីជនទាំងពីរបួសហើយ សញ្ជ័យក៏បាននូវភាពប្រសើរដោយលាភ យសយ៉ាងហូរហៀរ ។ ជនទាំងពីររៀនចប់លទ្ធិសម័យរបស់សញ្ជ័យ ដោយត្រឹមតែពីបីថ្ងៃប៉ុណ្ណោះ ទើបសួរថា លោកអាចារ្យ លទ្ធិដែលលោកដឹងមានត្រឹមប៉ុណ្ណោះ ឬមានក្រៃលែងជាងនេះ កាលសញ្ជ័យឆ្លើយថា មានត្រឹមប៉ុណ្ណោះឯង អ្នកទាំងពីរចេះចប់ហើយ ។ ទើបជនទាំងពីរគិតគ្នាថា បើដូច្នេះ ការនៅប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់របស់លោក ក៏មិនមានប្រយោជន៍ យើងទាំងពីរចេញមកដើម្បីស្វែងរកមោគ្គធម៌ ។ មោគ្គធម៌នោះ យើងមិនអាចឲ្យកើតឡើងបានក្នុងសម្នាក់របស់លោកអាចារ្យនេះ ជម្ពូទ្វីបធំណាស់ យើងត្រាច់ទៅកាន់គាមនិគម ជនបទ និងរាជធានី គង់នឹងបានអាចារ្យដែលសម្តែងមោគ្គធម៌ត្រឹមតែម្នាក់ពិត ។ តាំងអំពីនោះ បុគ្គលណាម្នាក់ពោលក្នុងទីណាមួយថា សមណព្រាហ្មណ៍ដែលជាបណ្ឌិតមាន ជនទាំងពីរមែងទៅធ្វើសាកច្ឆាក្នុងទីនោះៗ បញ្ហាដែលជនទាំងពីរសួរទៅ អាចារ្យដទៃមិនអាចឆ្លើយបាន តែជនទាំងពីរអាចស្រាយប្រស្នារបស់អាចារ្យទាំងនោះបាន ។ ជនទាំងពីរ ស៊ើបរកពេញជម្ពូទ្វីបយ៉ាងនេះហើយ ត្រឡប់មកកាន់លំនៅរបស់ខ្លួន ធ្វើកតិកាគ្នាថា កោលិតៈសម្លាញ់ បណ្តាយើងពីរនាក់ អ្នកណាបានសម្រេចអមតធម៌មុន អ្នក

នោះ ចូរច្រាប់ដល់គ្នានិងគ្នា ។

កាលជនទាំងពីរធ្វើកតិកាគ្នាយ៉ាងនោះ ព្រះសាស្តាយាងដល់ក្រុងរាជគ្រឹះ ដោយលំដាប់ដូចពោលហើយ ទ្រង់ទទួលវេឡុវនហើយ ប្រថាប់នៅក្នុងវេឡុ-វននោះ ។ ក្នុងកាលនោះ ព្រះអស្សជិត្ថេរក្នុងចំនួនបញ្ចវគ្គិយ រវាងព្រះអរហន្ត ៦១ អង្គ ដែលព្រះសាស្តាទ្រង់បញ្ជូនទៅដើម្បីប្រកាសគុណព្រះរតនត្រ័យ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរចារិកទៅដើម្បីប្រយោជន៍ដល់ជនច្រើនចុះ ។ ត្រឡប់មកកាន់ក្រុងរាជគ្រឹះហើយ ក្នុងស្អែកឡើង លោកកាន់បាត្រ និងចីវរទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាតអំពីព្រលឹម ។

សម័យនោះ ឧបតិស្សបរិព្វាជកធ្វើកត្តកិច្ចអំពីព្រលឹមហើយ ទៅកាន់អារាមរបស់បរិព្វាជកជួបព្រះថេរៈ ទើបគិតថា អ្នកបួសបែបនេះអញមិនធ្លាប់ជួបឡើយ ភិក្ខុរូបនេះគង់ជាបុគ្គលម្នាក់ បណ្តាបុគ្គលដែលជាព្រះអរហន្ត ឬជាអ្នកសម្រេចអរហត្តមគ្គក្នុងលោក ធ្វើម្តេចហ្ន៎ អញគប្បីចូលទៅរកភិក្ខុនេះ ហើយសួរថា លោកដ៏មានអាយុ លោកម្ចាស់បួសឧទ្ទិសចំពោះអ្នកណា អ្នកណាជាសាស្តារបស់លោកម្ចាស់ លោកម្ចាស់គាប់ចិត្តក្នុងធម៌របស់អ្នកណា ។

ពេលនោះ បរិវិតក្កនេះមានដល់គាត់ថា កាលនេះ មិនមែនកាលគួរសួរបញ្ហានឹងភិក្ខុនេះ ភិក្ខុនេះកំពុងចូលទៅកាន់ចន្លោះស្រុកត្រាច់បិណ្ឌបាត បើដូច្នោះ អញនឹងស្វែងរកមោគ្គធម៌ដែលបុគ្គលត្រូវការដឹងហើយ គួរដើរតាមភិក្ខុនេះ ទៅអំពីខាងក្រោយ ។ គាត់ឃើញព្រះថេរៈបានបិណ្ឌបាតហើយ ទៅកាន់ឱកាសណាមួយ ហើយជ្រាបសេចក្តីដែលព្រះថេរៈនោះបំណងនឹងគង់

ទើបរៀបតាំងរបស់បរិក្ខារជកសម្រាប់ខ្លួនប្រគេន ។ ក្នុងពេលដែលលោកឆាន់ស្រេចហើយ ក៏ប្រគេនទឹកក្នុងកុណ្ឌីរបស់ខ្លួនដល់ព្រះថេរៈ កាលធ្វើអាចរិយ-វត្តយ៉ាងនោះហើយ ទើបធ្វើបដិសណ្ឋារៈ ទាក់ចិត្តជាមួយព្រះថេរៈដែលឆាន់ស្រេចហើយ សាកសួរយ៉ាងនេះថា បពិត្រលោកម្ចាស់ ឥន្ទ្រិយរបស់លោកម្ចាស់ផូរផង់ពេក ពណ៌សម្បុរបរិសុទ្ធ លោកម្ចាស់បួសឧទ្ទិសចំពោះអ្នកណា អ្នកណាជាគ្រូរបស់លោកម្ចាស់ លោកម្ចាស់គាប់ចិត្តក្នុងធម៌របស់អ្នកណា ។

ព្រះថេរៈគិតថា ធម្មតាបរិក្ខារជកទាំងនេះ រមែងជាបដិបក្ខចំពោះសាសនា អញនឹងសម្តែងជម្រៅក្នុងព្រះសាសនាដល់បរិក្ខារជកនេះ កាលសម្តែងទូវភាពដែលខ្លួនបួសថ្មី ទើបពោលថា អាវុសោ ខ្ញុំជាអ្នកបួសថ្មី បួសហើយមិនយូរ ទើបតែមកកាន់ធម្មវិន័យនេះ ខ្ញុំមិនអាចសម្តែងធម៌ដោយពិស្តារទេ ។ បរិក្ខារជកជ្រាប់ថា ខ្ញុំឈ្មោះឧបតិស្សៈ សូមលោកម្ចាស់ពោលតាមសមត្ថភាពចុះ តិចក្តី ច្រើនក្តី សេចក្តីនោះ ជាការៈរបស់ខ្ញុំ ដើម្បីចាក់ធ្លុះដោយនយមួយរយនយមួយពាន់ ដូច្នេះហើយ សាកសួរថា

> *ទោះតិចក្តី ច្រើនក្តី សូមលោកម្ចាស់ពោលមកចុះ ចូរជ្រាប់ដល់ខ្ញុំតែអត្ថប៉ុណ្ណោះ ខ្ញុំត្រូវការអត្ថ មិនចាំបាច់ធ្វើព្យញ្ជនៈឲ្យច្រើនឡើយ ។ កាលគាត់ជ្រាប់យ៉ាងនោះហើយ ទើបព្រះថេរៈពោលគាថាថា ធម៌ទាំងឡាយណា មានហេតុជាដែនកើត ព្រះតថាគតត្រាស់ហេតុនៃធម៌នោះ និងហេតុនៃការរលត់នៃធម៌ទាំងនោះ ព្រះមហាសមណៈមានប្រក្រតីត្រាស់យ៉ាងនេះ ។*

បរិព្វាជកស្តាប់ត្រឹមពីរបទខាងដើមប៉ុណ្ណោះ ក៏តាំងនៅក្នុងសោតាបត្តិផល ដល់ព្រមដោយយន័យមួយពាន់ ។ ព្រះថេរៈញុំាងពីរបទក្រៅអំពីនេះឲ្យចប់ ក្នុងពេលឧបតិស្សៈជាព្រះសោតាបន្ន ។ គាត់ជាព្រះសោតបន្នហើយ កាលគុណវិសេសជាន់ខ្ពស់មិនទាន់ប្រព្រឹត្តទៅក៏ជំទាស់ថា ហេតុក្នុងវត្ថុនេះនឹងមាន ទើបសាកសួរព្រះថេរៈថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនចាំបាច់ពង្រីកព្រះធម្មទេសនាឲ្យក្រៃលែងឡើងឡើយ សេចក្តីប៉ុណ្ណោះក៏ល្មមគ្រប់គ្រាន់ ព្រះសាស្តារបស់ពួកយើងប្រថាប់នៅឯណា ។ ព្រះថេរៈឆ្លើយថា ទ្រង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ។ ឧបតិស្សៈសួរថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់និមន្តទៅមុនចុះ ខ្ញុំមានសម្លាញ់ម្នាក់ទៀត ហើយខ្ញុំទាំងពីរបានធ្វើកតិកាដល់គ្នានិងគ្នាថា អ្នកណាសម្រេចអមតៈមុន អ្នកនោះចូរប្រាប់ដល់គ្នានិងគ្នា ខ្ញុំដោះប្តេជ្ញានោះហើយ នឹងនាំសម្លាញ់នោះទៅកាន់សម្នាក់របស់ព្រះសាស្តា តាមដែលលោកម្ចាស់ទៅហើយនោះឯង ដូច្នេះហើយ ក្រាបទៀបបាទាទាំងពីររបស់ព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន ធ្វើប្រទក្សិណ ៣ ជុំ បញ្ជូនព្រះថេរៈទៅហើយ បានបែរមុខទៅកាន់អាវាសរបស់បរិព្វាជកហើយ ។ កោលិតបរិព្វាជកឃើញឧបតិស្សៈមកអំពីចម្ងាយ គិតថា ថ្ងៃនេះ ទឹកមុខសម្លាញ់របស់អញមិនដូចក្នុងថ្ងៃដទៃៗ គេគង់បានសម្រេចអមតៈដោយពិត ទើបសួរដល់ការសម្រេចអមតៈ ។ ឧបតិស្សបរិព្វាជកនោះក៏ទទួលថា អើ អាវុសោ អមតៈខ្ញុំបានសម្រេចហើយ បានភាសិតគាថានោះឯងដល់កោលិតបរិព្វាជកនោះ ។

ក្នុងកាលចប់គាថា កោលិតៈតាំងនៅក្នុងសោតាបត្តិផលហើយ ទើប

ពោលថា សម្ងាញ់ព្រះសាស្តារបស់ពួកយើងប្រថាប់នៅឯណា ឧបតិស្សៈពោលថា ប្រថាប់នៅវត្តវេឡុវ័ន ដំណឹងនេះព្រះអស្សជិត្ថេរអាចារ្យរបស់យើងជ្រាប់ហើយ កោលិតៈពោលថា នែសម្ងាញ់ បើដូច្នោះយើងទៅគាល់ព្រះសាស្តាចុះ ។

ធម្មតាព្រះសារីបុត្តត្ថេរនេះ រមែងជាអ្នកបូជាអាចារ្យសព្វកាល ព្រោះដូច្នោះ ទើបពោលនឹងកោលិតៈយ៉ាងនេះថា នែសម្ងាញ់ យើងនឹងជ្រាប់អមតៈដែលយើងទាំងពីរបាន ដល់សញ្ជ័យបរិព្វាជកដែលជាអាចារ្យរបស់យើងផង លោកជីងក៏នឹងចាក់ផ្ទុះ បើមិនចាក់ផ្ទុះ ជឿពួកយើងហើយនឹងទៅកាន់សម្នាក់របស់ព្រះសាស្តា ស្តាប់ធម្មទេសនារបស់ពុទ្ធបុគ្គលទាំងឡាយហើយ នឹងធ្វើនូវការចាក់ផ្ទុះនូវមគ្គ និងផល ។

លំដាប់នោះ ជនទាំងពីរក៏បានទៅកាន់សម្នាក់របស់សញ្ជ័យ ។ សញ្ជ័យគ្រាន់តែឃើញទើបសួរថា បាទាំងពីរ ពួកបាបានអ្នកណាបង្ហាញផ្លូវអមតៈហើយឬ ទើបសម្ងាញ់ទាំងពីរជ្រាប់ថា បានហើយលោកអាចារ្យ ព្រះពុទ្ធទ្រង់កើតឡើងហើយក្នុងលោក ព្រះធម៌កើតឡើងហើយ ព្រះសង្ឃកើតឡើងហើយ លោកអាចារ្យប្រព្រឹត្តធម៌ទេឥតសារៈ សូមលោកអាចារ្យមកចុះយើងទាំងឡាយនឹងទៅកាន់សម្នាក់ព្រះសាស្តា ។ សញ្ជ័យពោលថា អ្នកទាំងពីរទៅចុះ ខ្ញុំមិនអាចទេ សម្ងាញ់ទាំងពីរសួរថា ព្រោះហេតុអ្វី សញ្ជ័យជ្រាប់ថា ខ្ញុំជាអាចារ្យរបស់មហាជនហើយ ការនៅជាអន្តេវាសិករបស់ខ្ញុំនោះ ដូចគ្នានឹងការកម្រើកនៃទឹកក្នុងពាង ខ្ញុំមិនអាចនៅជាអន្តេវាសិកបាន សម្ងាញ់ទាំងពីរពោលថា កុំធ្វើយ៉ាងនោះឡើយលោកអាចារ្យ សញ្ជ័យពោលថា ណ្ហើយចុះ

ជា ជានាំគ្នាទៅចុះ ខ្ញុំមិនអាចទេ ៗ ញ៉ាំងពីរពោលថា លោកអាចារ្យ តាំងអំពីកាលព្រះពុទ្ធកើតឡើងក្នុងលោក មហាជនមានគ្រឿងក្រអូប កម្រងផ្កាជាដើមក្នុងដៃទៅបូជាព្រះអង្គប៉ុណ្ណោះ ឯខ្ញុំទាំងពីរក៏នឹងទៅក្នុងទីនោះដូចគ្នា លោកអាចារ្យនឹងធ្វើដូចម្តេច ។ សញ្ជ័យពោលថា ជាទាំងទ្វេ ក្នុងលោកនេះ អ្នកល្ងង់មានច្រើន ឬអ្នកឆ្លាតមានច្រើន សម្ចាញ់ទាំងពីរពោលថា អ្នកល្ងង់មានច្រើនលោកអាចារ្យ ឯអ្នកឈ្លាសមានត្រឹមតិចតួច សញ្ជ័យពោលថា ជាទាំងពីរ បើដូច្នោះ ពួកជនដែលឈ្លាសវៃ នឹងទៅកាន់សម្នាក់ព្រះគោតម ពួកជនល្ងង់ខ្លៅនឹងមកកាន់សម្នាក់ខ្ញុំ ជាទៅចុះ ខ្ញុំមិនទៅទេ ។

ទើបសម្ចាញ់ទាំងពីរនោះពោលថា លោកអាចារ្យ លោកនឹងជ្រុកជឯង ។ ដូច្នេះហើយ ចៀសចេញទៅ កាលសម្ចាញ់ទាំងពីរនោះកំពុងទៅ បរិស័ទរបស់សញ្ជ័យបែកគ្នាហើយ ខណៈនោះអាចមបានជាទីទេ ។ សញ្ជ័យនោះ ឃើញអាចមទទេហើយ ក៏ក្អួតឈាមក្តៅៗ ។ ក្នុងបរិព្វាជក ៥០០ នាក់ ដែលទៅជាមួយសម្ចាញ់ទាំងពីរនោះ បរិស័ទរបស់សញ្ជ័យ ២៥០ នាក់ ត្រឡប់ហើយ ។ សម្ចាញ់ទាំងពីរទៅកាន់វត្តវេឡុវ័ន មួយអន្ទើដោយបរិព្វាជក ២៥០ ដែលជាអន្តេវាសិករបស់ខ្លួន ។

ព្រះសាស្តាប្រថាប់គង់សម្តែងធម៌ ក្នុងកណ្តាលបរិស័ទ ៤ ទតឃើញបរិព្វាជកទាំងនោះអំពីចម្ងាយ ត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម្ចាញ់ពីរនាក់នោះកំពុងមក គឺកោលិតៈ និងឧបតិស្សៈ ជនទាំងពីរនោះ ជាគូសាវ័កដ៏កំពូលរបស់តថាគត ។ សម្ចាញ់ទាំងពីរនោះ

ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងចំណែកម្ខាង ជនទាំងពីរបានក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា ខ្ញុំព្រះអង្គគប្បីបាននូវបព្វជ្ជា គប្បីបាននូវឧបសម្បទាក្នុងសម្នាក់របស់ព្រះដ៏មានព្រះភាគផងចុះ ព្រះដ៏មានព្រះភាគត្រាស់ថា អ្នកទាំងឡាយចូរជាភិក្ខុចុះ ធម៌តថាគតពោលល្អហើយ ចូរប្រព្រឹត្តព្រហ្មចរិយៈដើម្បីធ្វើទីបំផុតនៃទុក្ខដោយប្រពៃចុះ ។ ជនទាំងអស់ បានជាបុគ្គលទ្រទ្រង់បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ហាក់បីដូចព្រះថេរៈមានវស្សា ១០០ ។

គ្រានោះ ព្រះសាស្តាទ្រង់ពង្រីកព្រះធម្មទេសនា ដោយអំណាចចរិយាដល់បរិស័ទរបស់សម្ងាញ់ទាំងពីរ រៀរអគ្គសាវ័កទាំងពីរចេញ ជនដ៏សេសសម្រេចអរហត្តហើយ ឯកិច្ចដោយមគ្គខាងលើរបស់អគ្គសាវ័កទាំងពីរ មិនបានសម្រេចឡើយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសាវ័កបារមីញាណ ជារបស់ធំ ។

ក្នុងថ្ងៃទីពីរ បន្ទាប់អំពីបួសហើយ ព្រះមហាមោគ្គល្លានចូលទៅអាស្រ័យស្រុកកាឡវាលៈ ក្នុងដែនមគធៈ កាលបីនមិទ្ធៈគ្របសង្កត់ ព្រះសាស្តាទ្រង់ធ្វើឲ្យសង្វេគហើយ បន្ទោបង់បីនមិទ្ធៈបាន កំពុងស្តាប់ធាតុកម្មដ្ឋាន ដែលព្រះតថាគតប្រទានហើយ ញុំាងកិច្ចក្នុងមគ្គ ៣ ខាងលើឲ្យសម្រេច ដល់ទីបំផុតសាវ័កបារមីញាណហើយ ។

ចំណែកព្រះសារីបុត្រកន្ទងទៅបានកន្ទះខែអំពីថ្ងៃបួស ចូលទៅអាស្រ័យក្រុងរាជគ្រឹះនោះហើយ នៅក្នុងវិហារសូករខាតាជាមួយព្រះសាស្តា កាលព្រះ

សាស្តា ទ្រង់សម្តែងវេទនាបរិគ្គហសូត្រដល់ទីឃនខបរិព្វាជក ដែលជាក្មួយរបស់ខ្លួន បញ្ជូនញាណទៅតាមក្រសែនៃព្រះសូត្រ ក៏ដល់នូវទីបំផុតនៃសាវកបារមីញាណ ដូចបុគ្គលដែលបរិភោគភត្តដែលគេឲ្យដល់អ្នកដទៃ ។

មានពាក្យសួរថា ព្រះសារីបុត្រជាអ្នកមានបញ្ញាច្រើនមិនមែនឬ បើដូច្នោះ ហេតុអ្វី ទើបសម្រេចសាវកបារមីញាណក្រោយព្រះមហាមោគ្គល្លាន ឆ្លើយថា ព្រោះមានបរិកម្មច្រើន ឧបមាដូចមនុស្សក្រីក្រ បំណងនឹងទៅទីណាមួយ ក៏ចេញទៅដោយរហ័ស ចំណែកព្រះរាជាត្រូវមានការប្រុងប្រៀបច្រើន មានការត្រៀមដំរី ព្រះរាជពាហន:ជាដើម ទើបសមគួរ យ៉ាងណា ឧបមេយ្យនេះ គប្បីជ្រាបយ៉ាងនោះ ។

ក្នុងរសៀលថ្ងៃនោះឯង ព្រះសាស្តាទ្រង់ប្រជុំសាវក ក្នុងវត្តវេឡុវន ប្រទានតំណែងជាអគ្គសាវកដល់ព្រះថេរៈទាំងពីរហើយ ទ្រង់សម្តែងជាតិមោក្ខ ។ ពួកភិក្ខុលើកទោសពោលថា ព្រះសាស្តាប្រទានតំណែងដល់ភិក្ខុទាំងឡាយ ដោយយល់មុខ កាលទ្រង់ប្រទានតំណែងអគ្គសាវក គួរប្រទានដល់បញ្ចវគ្គិយភិក្ខុដែលបួសមុន បើមិនឃើញបញ្ចវគ្គិយទាំងនោះ ក៏គួរប្រទានដល់ភិក្ខុ ៥៥ រូប មានព្រះយសត្ថេរជាប្រធាន បើមិនសម្លឹងមើលភិក្ខុទាំងនោះ ក៏គួរប្រទានដល់ភទ្ទវគ្គិយ បើមិនសម្លឹងមើលដល់ភទ្ទវគ្គិយៈទាំងនោះ ក៏គួរប្រទានដល់ភិក្ខុ ៣ នាក់បងប្អូន មានព្រះឧរុវេលកស្សបៈជាដើម តែព្រះសាស្តាទ្រង់រំលងភិក្ខុទាំងនោះ មានប្រមាណត្រឹមណោះ កាលប្រទានតំណែងអគ្គសាវក ក៏ទ្រង់យល់មុខប្រទានដល់អ្នកបួសក្រោយគេបង្អស់ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសន្ទនាគ្នាអំពីរឿងអ្វី កាលភិក្ខុទាំងឡាយទូលថា រឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនឲ្យតំណែងដោយយល់មុខ ដល់ពួកភិក្ខុឡើយ តែតថាគតឲ្យតំណែងដែលបុគ្គលម្នាក់ៗ ប្រាថ្នាហើយនោះឯង ដល់ភិក្ខុទាំងនោះ ឯអញ្ញាកោណ្ឌញ្ញៈកាលថ្វាយទាន ទាក់ទងដោយស្រូវដ៏ប្រសើរ ៩ ដងក្នុងកាលស្រូវមួយរដូវក៏មិនបានប្រាថ្នាតំណែងអគ្គសាវកឡើយ តែបានប្រាថ្នាដើម្បីចាក់ធ្លុះអរហត្ត ដែលជាធម៌ដ៏ប្រសើរមុនសាវកទាំងឡាយ ហើយថ្វាយទាន ។ ភិក្ខុទាំងឡាយទូលសួរថា ថ្វាយក្នុងកាលណាព្រះអង្គ ។ ព្រះសាស្តាទ្រង់សាកសួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនឹងស្តាប់ឬ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងស្តាប់ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រាប់អំពីកទ្ទុកប្បនេះទៅ ៩១ កប្ប ព្រះមានព្រះភាគព្រះនាមវិបស្សី ទ្រង់កើតឡើងហើយក្នុងលោក ក្នុងកាលនោះ កុដុម្ពិកៈពីរនាក់បងប្អូន គឺមហាកាល និងចុល្លកាល បានព្រោះស្រូវសាលីច្រើន ថ្ងៃមួយ ចុល្លកាលទៅស្រែឃើញស្រូវល្អ ហែកជង្ហើមស្រូវសាលីមួយដើមហើយភ្ងក្សមើល ។ មានរសឆ្ងាញ់ល្អ គាត់ប្រាថ្នានឹងថ្វាយគព្ភសាលីទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ទើបចូលទៅរកបងប្រុស ហើយពោលថា ខ្ញុំនឹងហែកស្រូវផើមចម្អិនឲ្យជារបស់គួរដល់ព្រះពុទ្ធទាំងឡាយ ហើយថ្វាយទាន បងប្រុសពោលថា ឯងនិយាយអ្វី ការហែកស្រូវសាលីកំពុងផើមធ្វើទាន មិនធ្លាប់មានឡើយក្នុងអតីតៈ នឹងមិនមានក្នុងអនាគត ឯងកុំធ្វើ

ស្រែវសាលីឲ្យវិនាសទ្បើយ ចុល្លកាលអង្ករៀយៗ ដដែលៗ កាលនោះ ទើប
បងប្រុសពោលថា បើដូច្នោះ យើងត្រូវបែងស្រែជាពីរចំណែក ហើយកុំប៉ះពាល់
ចំណែករបស់យើង ចូរធ្វើចំណែកដែលឯងច្រូថ្នា ក្នុងស្រែដែលជាចំណែក
របស់ឯងចុះ ។ ចុល្លកាលទទួលថា សាធុ ហើយចែកស្រែគ្នា បានសូមកម្ចាង
មនុស្សជាច្រើន ហែកដង្ហើមស្រែវសាលីកិនជាទឹកដោះ ចម្អិនដោយសប្បិ ទឹក
ឃ្មុំ និងស្ករផែនថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ក្នុងកាលស្រេច
ភត្តកិច្ចក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទានដ៏ប្រសើររបស់ខ្ញុំព្រះអង្គនេះ
សូមប្រព្រឹត្តទៅដើម្បីការត្រាស់ដឹងធម៌ដ៏ប្រសើរ មុនសាវកទាំងពួង ។ ព្រះ
សាស្តាត្រាស់ថា ការច្រូថ្នារបស់អ្នកចូរសម្រេចយ៉ាងនោះចុះ ហើយទ្រង់ធ្វើ
អនុមោទនា ។ គាត់ទៅស្រែពិនិត្យមើល ឃើញស្រែកកកុញដោយកួរស្រូវ
សាលីដូចគេចងជាបាច់ៗ ក្នុងស្រែទាំងមូល បាននូវបីតិ ៥ យ៉ាង ហើយ
គិតថា ជាលាភរបស់អញហ្ន៎ លុះដល់ស្រូវល្មមធ្វើអំបុក បានថ្វាយទានដ៏
ប្រសើរដោយអំបុក ។ បានថ្វាយទានដែលទាក់ទងដោយស្រូវដ៏ប្រសើរ មួយ
អន្ទើដោយអ្នកស្រុកទាំងឡាយ មុនច្រូតបានថ្វាយទានដ៏ប្រសើរក្នុងកាលច្រូត
ក្នុងកាលធ្វើចំណងបានថ្វាយទានដ៏ប្រសើរក្នុងកាលធ្វើចំណង ក្នុងគ្រាបោក
បែនជាដើម ក៏បានថ្វាយទានដ៏ប្រសើរក្នុងកាលបោកបែន ក្នុងកាលស្រូវមក
ដល់លាន ... ប្រសើរដល់ក្នុងជង្រុក បានថ្វាយទានដ៏ប្រសើរ ៩ ដង ក្នុង
ស្រែមួយរដូវ ដោយប្រការយ៉ាងនេះ ។ ទីដែលច្រូតកាត់យកហើយ បាន
ពេញដូចដើមរាល់ៗ ដង ។ ស្រូវបានដុះជាលបរិបូណ៌ឡើងយ៉ាងក្រៃលែង

ឈ្មោះថា ធម៌រមែងរក្សាបុគ្គលរក្សាធម៌ សមដូចព្រះមានព្រះភាគត្រាស់ថា

ធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលសន្សំល្អហើយ រមែងនាំមកនូវសេចក្តីសុខ នេះជាអានិសង្សក្នុងធម៌ដែលបុគ្គលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។

អញ្ញាកោណ្ឌញ្ញៈ ប្រាថ្នាដើម្បីត្រាស់ដឹងធម៌ដ៏ប្រសើរមុនគេ ទើបបានថ្វាយទានដ៏ប្រសើរ ៩ ដង ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធ ព្រះនាមថាវិបស្សី ដោយប្រការយ៉ាងនេះឯង ។[1]

ម្យ៉ាងទៀត ក្នុងកាលនៃព្រះពុទ្ធព្រះនាមថាបទុមុត្តរៈ ក្នុងហង្សវតីនគរ ក្នុងទីបំផុតមួយសែនកប្បអំពីនេះទៅ អញ្ញាកោណ្ឌញ្ញៈថ្វាយមហាទានអស់ ៧ ថ្ងៃហើយ ក្រាបទៀបបាទមូលរបស់ព្រះដ៏មានព្រះភាគអង្គនោះ តាំងសេចក្តីប្រាថ្នាដើម្បីត្រាស់ដឹងធម៌ដ៏ប្រសើរមុនគេដូចគ្នា ។ តថាគតបានឲ្យផលដែលអញ្ញាកោណ្ឌញ្ញៈនេះប្រាថ្នាហើយនោះឯង ដោយប្រការដូច្នេះ ។ មិនមែនឲ្យដោយយល់មុខឡើយ ។

ភិក្ខុទាំងឡាយទូលសួរថា ជន ៥៥ នាក់ មានយសកុលបុត្រជាប្រធាន ធ្វើកម្មអ្វី ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ជន ៥៥ នោះ ប្រាថ្នាអរហត្ត ក្នុងសម្នាក់ព្រះពុទ្ធមួយអង្គ ធ្វើកុសលកម្មច្រើនហើយ ខាងក្រោយ កាលព្រះពុទ្ធមិនទាន់កើតឡើង ជាសម្ងាញ់នឹងគ្នា ធ្វើបុណ្យរួមជាពួកតែមួយ ជាអ្នក

១- ក្នុងទីខ្លះថា មហាកាល ជាអ្នកធ្វើទាននេះ ។

ចាត់ចែងបុណ្យសពជនឥតទីពឹង ។ ថ្ងៃមួយ ជនទាំងនោះ ជួបស្រីស្ងាប់ម្នាក់ ស្រុះស្រួលថានឹងជុត ទើបនាំទៅកាន់ឈាបនដ្ឋាន ក្នុងជនទាំងនោះ ផ្អាកក្នុងព្រៃខ្មោច ៥ នាក់ ដោយប្រាប់ថា ពួកអ្នកចូរជុត ឯមនុស្សដ៏សេស ចូលទៅក្នុងស្រុក ។ បុរសម្នាក់យកឈើសូលចាក់សពនោះ ត្រឡប់ទៅ ត្រឡប់មក បានអសុកសញ្ញាហើយ ។ គាត់សម្តែងដល់សម្ងាញ់ ៤ នាក់ក្រៅអំពីនេះថា អ្នកដ៏ចម្រើន អ្នកចូរមើលសពនេះមានស្បែករបកហើយ ក្នុងទីនោះៗ ដូចគោពពាលមិនស្អាត ស្អុយ គួរខ្ពើមរអើម ។ ជនទាំង ៤ នោះក៏បានអសុក-សញ្ញាក្នុងសពនោះ ។ ជនទាំង ៥ ចូលទៅកាន់ស្រុកប្រាប់ដល់សម្ងាញ់ដ៏សេស ចំណែកបុរសនោះបានទៅកាន់ផ្ទះ ប្រាប់ដល់មាតាបិតា និងភរិយា ។ ជនទាំងអស់នោះក៏ចម្រើនអសុកសញ្ញាហើយ នេះជាបុព្វកម្មរបស់មនុស្ស ៥៥ នាក់ មានយសកុលបុត្រជាប្រធាននោះ ។ ព្រោះហេតុនេះឯង ការសម្គាល់ក្នុងផ្ទះដែលដេរដាស់ដោយស្ត្រី ហាក់ដូចព្រៃខ្មោច ទើបកើតដល់យសកុល-បុត្រ ។ ដោយឧនិស្ស័យសម្បត្តិនោះ ទើបការសម្រេចគុណវិសេសកើតឡើងដល់ជនទាំងអស់ ។ ជនទាំងនេះ បានទទួលផលដែលខ្លួនប្រាថ្នាហើយដូចគ្នា ដោយប្រការយ៉ាងនេះ មិនមែនតថាគតឲ្យដោយយល់មុខឡើយ ។

ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គ ភទ្ទវគ្គិយដែលជាសម្ងាញ់នឹងគ្នាបានធ្វើកម្មអ្វី ។

ម្នាលភិក្ខុទាំងឡាយ ពួកភទ្ទវគ្គិយនោះក៏ប្រាថ្នាអរហត្តក្នុងសម្នាក់ព្រះពុទ្ធក្នុងកាលមុន ហើយធ្វើបុណ្យ ។ ក្រោយមក កាលព្រះពុទ្ធមិនទាន់កើតឡើង

ជាអ្នកលេង ៣០ នាក់ ស្តាប់តុណ្ហិលោវាទហើយ បានវក្ខាសីល ៥ អស់ ៦ ម៉ឺនឆ្នាំ កន្លះគ្គិយទាំងនេះក៏បានផលដែលខ្លួនប្រាថ្នាហើយដូចគ្នា ដោយប្រការយ៉ាងនេះ មិនមែនតថាគតឲ្យដោយយល់មុខដល់កិក្ខុទាំងឡាយនោះទេ្បីយ ។

កិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គ កស្សបៈ ៣ នាក់បងប្អូនមានឧរុវេលកស្សបៈជាដើម ធ្វើកម្មអ្វីដែរ ។

ព្រះសាស្តាត្រាស់ថា ជនទាំងនោះប្រាថ្នាអរហត្តដូចគ្នា ធ្វើបុណ្យហើយ ។ ក្នុង ៩២ កប្បរាប់អំពីនេះទៅ ព្រះពុទ្ធ ២ អង្គ គឺព្រះតិស្សៈ ១ ព្រះផុស្សៈ ១ ទ្រង់កើតទ្បើងហើយ ។ រាជាព្រះនាមមហិទ្ធៈ បានជាព្រះបិតារបស់ព្រះពុទ្ធទ្រង់ព្រះនាមផុស្សៈ កាលទ្រង់សម្រេចសម្ពោធិហើយ ព្រះឱរសពៅរបស់ព្រះរាជាបានជាព្រះអគ្គសាវក កូនបុរោហិតបានជាទុតិយសាវក ។ ព្រះរាជាបានយាងទៅកាន់សម្នាក់ព្រះសាស្តា ទ្រង់ទតមើលជនទាំងនោះថា រាជឱរសច្បងរបស់អញជាព្រះពុទ្ធ រាជឱរសពៅជាអគ្គសាវក បុត្របុរោហិតជាទុតិយសាវក ទ្រង់បន្ទឺព្រះឧទាន ៣ ដងថា ព្រះពុទ្ធជារបស់ខ្ញុំ ព្រះធម៌ជារបស់ខ្ញុំ ព្រះសង្ឃជារបស់ខ្ញុំ ខ្ញុំសូមនមស្ការដល់ព្រះដ៏មានព្រះភាគដែលជាអរហន្តទ្រង់ត្រាស់ដឹងប្រពៃដោយព្រះអង្គឯងនោះ ដូច្នេះហើយ ក្រាបទៀបបាទមូលរបស់ព្រះសាស្តា ទ្រង់ទទួលប្តេជ្ញាថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គហាក់ដូចជាអង្គុយដេកលក់ក្នុងទីបំផុតអាយុប្រមាណ ៩ ម៉ឺនឆ្នាំ សូមទ្រង់កុំយាងទៅកាន់ផ្ទះរបស់ជនជនៃ សូមទ្រង់ទទួលបច្ច័យ ៤ របស់ខ្ញុំព្រះអង្គអស់កាលដែលខ្ញុំព្រះអង្គនៅមានជីវិត ដូច្នេះហើយ ទ្រង់ធ្វើពុទ្ធឧបដ្ឋាក ជា

ប្រចាំ ។ ម្យ៉ាងទៀត ព្រះរាជាទ្រង់មានព្រះរាជឱរស ៣ ព្រះអង្គទៀត ។ បណ្តាឱរស ៣ អង្គនោះ ព្រះរាជឱរសច្បងមានអ្នកចម្បាំងជាបរិវារ ៥០០ ព្រះរាជឱរសកណ្តាលមាន ៣០០ ព្រះរាជឱរសពៅមាន ២០០ ព្រះរាជឱរសទាំង ៣ អង្គនោះទូលសូមឱកាសនឹងព្រះបិតាថា សូមប្បីទូលបង្គំទាំងឡាយ ក៏នឹងនិមន្តព្រះជេដ្ឋាសោយដែរ សូមប្បីទូលអង្វរវើយៗ ក៏មិនបាន ។ កាលបច្ចន្តជនបទបះបោរហើយ ត្រូវបញ្ជូនទៅដើម្បីប្រយោជន៍នឹងរម្ងាប់បច្ចន្តជនបទនោះ លុះបង្ក្រាបបច្ចន្តជនបទបានរាបទាបហើយ មកកាន់សម្នាក់ព្រះរាជបិតា ។ គ្រានោះ ព្រះបិតាទ្រង់ឱបព្រះឱរសទាំង ៣ នោះហើយ ថើបត្រង់សីសៈត្រាស់ថា បាទាំងឡាយបិតាឲ្យពរដល់បុត្រ ។ ឱរសទាំង ៣ នោះទូលថា សាធុ ព្រះអង្គ ។ ធ្វើពរឲ្យជាការកាន់យកហើយ ដោយកាលកន្លងទៅពីរបីថ្ងៃ ព្រះបិតាត្រាស់ទៀតថា នែបាទាំងឡាយ ពួកបាចូរទទួលពរចុះ ។ រាជបុត្រទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ការបំណងដោយវត្ថុណាមួយដទៃរបស់ទូលបង្គំមិនមាន ឥឡូវនេះ ទូលបង្គំនឹងនិមន្តព្រះជេដ្ឋាសោយ សូមទ្រង់ព្រះរាជទានពរនេះដល់ទូលបង្គំចុះ ព្រះរាជាត្រាស់ថា នែបា យើងឲ្យមិនបានទេ ព្រះរាជឱរសទូលថា បើមិនព្រះរាជទានជានិច្ច សូមទ្រង់ព្រះរាជទានត្រឹម ៧ ឆ្នាំ ព្រះរាជាត្រាស់ថា មិនបានទេបា ព្រះរាជឱរសទូលថា បើដូច្នេះ សូមព្រះរាជទានត្រឹម ៦ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ ៧ ខែ ៦ ខែ ៥ ខែ ៤ ខែ ព្រះរាជាត្រាស់ថា មិនបានទេបា ព្រះរាជឱរសទូលថា ណ្ហើយចុះ សូមទ្រង់ព្រះរាជទានត្រឹមតែ ៣ ខែដល់ខ្ញុំព្រះអង្គទាំងឡាយ ម្នាក់

មួយខែៗ ចុះ ព្រះរាជាពោលថា សាធុ បើដូច្នោះ បាចូរនិមន្តឲ្យទ្រង់សោយ បាន ៣ ខែ ។

នាយឃ្លាំងរបស់ព្រះរាជបុត្រទាំង ៣ នោះ មានម្នាក់ នាយស្មៀន ក៏ម្នាក់ដូចគ្នា ។ ព្រះរាជបុត្រទាំង ៣ អង្គនោះ មានបុរស ១២ ម៉ឺនជាបរិវារ ។ ព្រះរាជឱរសទាំង ៣ ឲ្យហៅបរិវារទាំងនោះមកហើយ ត្រាស់ថា យើងទាំង ៣ នឹងទទួលសីល ១០ ជណ្តប់សំពត់កាសាវពស្ត្រពីរជាន់ នៅរួមជាមួយព្រះសាស្តាអស់ ៣ ខែនេះ ពួកអ្នកគប្បីទទួលតម្លៃមានប្រមាណប៉ុណ្ណេះ ញុំាងរបស់ទំពា និងរបស់បរិភោគគ្រប់យ៉ាងឲ្យប្រព្រឹត្តទៅដល់កិក្ខុ ៩ ម៉ឺនរូប និងអ្នកចម្បាំងរបស់យើងមួយពាន់នាក់ ព្រោះបន្ទាប់អំពីនេះទៅ ពួកយើងមិនបានពោលពាក្យណាមួយទៀយ ។

ព្រះរាជឱរសទាំង ៣ នោះ នាំបុរសបរិវារមួយពាន់សមាទានសីល ១០ ជណ្តប់សំពត់កាសាវពស្ត្រ នៅតែក្នុងវិហារ ។ នាយឃ្លាំង និងនាយស្មៀន បានរួមគ្នាបើកស្បៀងតាមវារៈៗ អំពីឃ្លាំងទាំងឡាយរបស់បងប្អូនទាំង ៣ ថ្វាយទាន ។

កូនរបស់ពួកកម្មករស្រែកយំត្រូវការបបរ និងភត្តជាដើម កម្មកទាំងនោះ កាលកិក្ខុសង្ឃមិនទាន់មក ក៏ឲ្យវត្ថុមានបបរ និងភត្តជាដើមដល់កូនទាំងនោះ ។ ក្នុងពេលដែលកិក្ខុសង្ឃឆាន់ស្រេចហើយ មិនធ្លាប់មានរបស់អ្វីសល់ទៀយ ។

ក្នុងកាលបន្ទាប់មក ពួកកម្មកទាំងនោះពោលអាងថា ខ្ញុំឲ្យដល់កូនដូច្នេះ

ហើយ ទទួលទៅបរិភោគឯង ។ ឃើញអាហារដែលពេញចិត្ត ក៏មិនអាចអត់ធ្មត់បាន ពួកជនទាំងនោះមានប្រមាណ ៨៤០០០ នាក់ ពួកគេបរិភោគអាហារដែលថ្វាយសង្ឃហើយ ក្រោយអំពីបែកកាយ បានទៅកើតក្នុងចិត្តវិស័យហើយ ។

ចំណែកព្រះឱរសបីនាក់បងប្អូន មួយអន្លើដោយបុរសមួយពាន់ ធ្វើកាលកិរិយាហើយ កើតក្នុងទេវលោក អន្លើអំពីទេវលោក កាន់ទេវលោក ញុំងកាលឲ្យអស់ទៅ ៩២ កប្ប រាជឱរសបីនាក់បងប្អូននោះ ប្រាថ្នាអរហត្តធ្វើកល្យាណកម្មក្នុងកាលនោះ ដោយប្រការយ៉ាងនេះ ។ ជដិលបីនាក់បងប្អូននោះបានទទួលផលដែលខ្លួនប្រាថ្នាហើយដូចគ្នា តថាគតមិនមែនឲ្យដោយយល់មុខឡើយ ។

ចំណែកស្មៀនរបស់ឱរសទាំងបីអង្គនោះ ក្នុងកាលនោះបានជាព្រះបាទពិម្ពិសារ នាយឃ្លាំងបានជាវិសាខឧបាសក ។ កម្មការបស់ជនទាំងបីនោះកើតហើយក្នុងពួកប្រេតក្នុងកាលនោះ អន្លើលទៅមកដោយអំណាចនៃទុគ្គតិ និងសុគតិ ក្នុងកប្បនេះ កើតក្នុងបេតលោកនោះឯង អស់ ៤ ពុទ្ធន្តរ ។

ប្រេតទាំងនោះចូលគាល់ព្រះដ៏មានព្រះភាគ ព្រះនាមកកុសន្ធៈ ដែលទ្រទ្រង់ព្រះជន្មាយុបាន ៤ ម៉ឺនឆ្នាំ ទ្រង់កើតឡើងមុនព្រះពុទ្ធគ្រប់អង្គ ក្នុងកប្បនេះទូលថា សូមទ្រង់មេត្តាប្រាប់កាលដែលបានអាហារដល់ខ្ញុំព្រះអង្គទាំងឡាយ ។

ព្រះដ៏មានព្រះភាគត្រាស់ថា អ្នកមិនបានអាហារក្នុងកាលរបស់តថាគត តែខាងក្រោយ កាលផែនដីដុះឡើងប្រមាណមួយយោជន៍ ព្រះពុទ្ធព្រះនាមកោនា-

គមនៈនឹងកើតឡើង ។ ពួកអ្នកគប្បីទូលសួរព្រះអង្គចុះ ។

ប្រែតទាំងនោះ ញុាំងកាលមានប្រមាណប៉ុណ្ណោះឲ្យអស់ទៅហើយ កាលព្រះពុទ្ធព្រះនាមកោនាគមនៈកើតឡើងហើយ ទើបបានទូលសួរទ្រង់ សូម្បីព្រះពុទ្ធអង្គនោះក៏ត្រាស់ថា ពួកអ្នកមិនបានអាហារក្នុងកាលរបស់តថាគត តែខាងក្រោយ កាលមហាប្រឹថពីដុះឡើងបានមួយយោជន៍ ព្រះពុទ្ធព្រះនាមកស្សបៈកើតឡើង ពួកអ្នកគប្បីទូលសួរព្រះអង្គចុះ ។

ប្រែតទាំងនោះញុាំងកាលមានប្រមាណប៉ុណ្ណោះ ឲ្យអស់ទៅហើយ កាលព្រះពុទ្ធព្រះនាមកស្សបៈកើតឡើងហើយ ទើបទូលសួរព្រះអង្គ សូម្បីព្រះពុទ្ធអង្គនោះក៏ត្រាស់ថា ពួកអ្នកមិនបានអាហារក្នុងកាលរបស់តថាគតឡើយ តែក្នុងកាលខាងក្រោយ មហាប្រឹថពីដុះឡើងប្រមាណមួយយោជន៍ ព្រះពុទ្ធព្រះនាមគោតមទ្រង់កើតឡើង ក្នុងកាលនោះញាតិរបស់ពួកអ្នក បានជាព្រះរាជាព្រះនាមពិម្ពិសារ ស្តេចពិម្ពិសារនោះថ្វាយទានដល់ព្រះសាស្តាហើយ ទឹងឲ្យចំណែកកុសលទានដល់ពួកអ្នក ពួកអ្នកនឹងបានអាហារក្នុងគ្រានោះ ។ មួយពុទ្ធន្តរបានប្រាកដដល់ប្រែតទាំងនោះ ដូចក្នុងថ្ងៃស្អែក ។

ប្រែតទាំងនោះកាលព្រះតថាគតកើតឡើងហើយ កាលព្រះបាទពិម្ពិសារថ្វាយទានក្នុងថ្ងៃទីមួយ ប្រែតបន្ទឹសំឡែងគួរខ្លាចបង្ហាញខ្លួនដល់ព្រះរាជា ក្នុងចំណែកនៃរាត្រីហើយ ។ ស្អែកឡើង ព្រះរាជាយាងមកកាន់វេឡុវ័ន ក្រាបទូលរឿងនោះ ដល់ព្រះតថាគត ។

ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ក្នុងទីបំផុត ៩២ កប្បអំពីកប្ប

នេះទៅ ក្នុងកាលនៃព្រះពុទ្ធព្រះនាមផុស្សៈ ពួកប្រេតនោះ ជាព្រះញាតិរបស់ព្រះអង្គ បរិភោគអាហារដែលគេថ្វាយភិក្ខុសង្ឃ កើតក្នុងបេតលោកហើយ អន្ទោលទៅ បានទូលសួរព្រះពុទ្ធទាំងឡាយដែលកើតឡើងហើយ មានព្រះពុទ្ធកកុសន្ធៈជាដើម ដែលព្រះពុទ្ធទាំងនោះ ត្រាស់ប្រាប់ពាក្យនេះៗ ហើយ ទន្ទឹងចំពោះទានរបស់ព្រះអង្គ អស់កាលមានប្រមាណប៉ុណ្ណោះ ។ មរ្យិលមិញនេះ កាលទ្រង់ថ្វាយទានហើយ មិនបានទទួលចំណែកបុណ្យ ទើបបានធ្វើយ៉ាងនោះ ។ ព្រះរាជាទូលសួរថា បពិត្រព្រះអង្គ បើខ្ញុំព្រះអង្គថ្វាយទានក្នុងឥឡូវនេះ ប្រេតទាំងនោះនឹងបានទទួលឬ ។

ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ នឹងបាន ។ ព្រះរាជាទ្រង់និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ថ្វាយមហាទានក្នុងថ្ងៃស្អែក ហើយបានព្រះរាជទានចំណែកបុណ្យថា បពិត្រព្រះអង្គដ៏ចម្រើន សូមបាយទឹកដែលជាទិព្វ សម្រេចដល់ពួកប្រេតទាំងនោះ អំពីមហាទាននេះ ។ បាយទឹកដែលជាទិព្វ កើតហើយដល់ប្រេតទាំងនោះដូច្នោះឯង ។ ស្អែកឡើង ប្រេតទាំងនោះអាក្រាតកាយ បង្ហាញខ្លួនហើយ ។ ព្រះរាជាទូលថា ថ្ងៃនេះ ពួកប្រេតអាក្រាតកាយបង្ហាញខ្លួនដល់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ព្រោះទ្រង់មិនបានថ្វាយសំពត់ ។

ស្អែកឡើង ទើបព្រះរាជាថ្វាយចីវរទាំងឡាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ ទ្រង់ឲ្យចំណែកបុណ្យថា សូមសំពត់ជាទិព្វទាំងឡាយសម្រេចដល់ប្រេតទាំងនោះ អំពីចីវរទាននេះចុះ ។ ក្នុងខណៈនោះឯង សំពត់ទិព្វកើត

ទ្បើងដល់ប្រេតទាំងនោះហើយ ។ ប្រេតទាំងនោះលះអត្តភាពរបស់ប្រេតតាំង
នៅដោយអត្តភាពដែលជាទិព្វហើយ ។ ព្រះសាស្តាកាលទ្រង់ធ្វើអនុមោទនា
ទ្រង់បានធ្វើអនុមោទនាដោយតិរោកុឌ្ឌសូត្រថា **តិរោកុឌ្ឌេសុ តិដ្ឋន្តិ** *ជាដើម ។*
ក្នុងទីបំផុតអនុមោទនា ធម្មាភិសមយមានដល់សត្វ ៨៤០០០ ហើយ ។ ព្រះ
សាស្តាកាលត្រាស់រឿងនៃជដិល ៣ នាក់បងប្អូនហើយ ទ្រង់នាំព្រះធម្ម-
ទេសនានេះមកហើយ ដោយប្រការដូច្នេះ ។

ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គ អគ្គសាវ័កទាំងពីរបានធ្វើកម្ម
អ្វី ។ ព្រះសាស្តាត្រាស់ថា អគ្គសាវ័កទាំងពីរធ្វើសេចក្តីប្រាថ្នា ដើម្បីជាអគ្គ-
សាវ័ក ។ ពិតហើយ ក្នុងទីបំផុត ១ អសង្ខ្យៃ និង ១ សែនកប្ប រាប់
អំពីកប្បនេះទៅ សារីបុត្រកើតក្នុងត្រកូលព្រាហ្មណមហាសាល មានឈ្មោះ
ថា សរទមាណព ។ មោគ្គល្លានកើតក្នុងត្រកូលគហបតិមហាសាល មាន
ឈ្មោះថា សិរិវឌ្ឍកុដុម្ពិកមាណព ។ មាណពទាំងពីរនោះបានជាសម្លាញ់
លេងដ៏រួមគ្នា ។ សរទមាណពដោយអនិច្ចកម្មទៅនៃបិតា បានគ្រប់គ្រងទ្រព្យ
ដ៏ច្រើន ដែលជាមត៌ករបស់ត្រកូល ។ ថ្ងៃមួយ នៅក្នុងទីកំបាំងគិតថា អញ
រមែងដឹងអត្តភាពក្នុងលោកនេះប៉ុណ្ណោះ មិនដឹងអត្តភាពក្នុងលោកខាងមុខ
ទ្បើយ ធម្មតាការស្លាប់របស់សត្វដែលកើតហើយទាំងឡាយ ជារបស់ទៀង
អញគួរបួសជាបព្វជិតបែបណាមួយ ធ្វើការស្វែងរកមោក្ខធម៌ ។

សរទមាណពនោះ ចូលទៅរកសម្លាញ់ហើយពោលថា សិរិវឌ្ឍសម្លាញ់
ខ្ញុំនឹងបួស ហើយស្វែងរកមោក្ខធម៌ អ្នកនឹងបួសជាមួយខ្ញុំឬ ។ សិរិវឌ្ឍតបថា

ខ្ញុំមិនអាចបួសបានទេ អ្នកបួសម្នាក់ឯងចុះ ។ សារទមាណពនោះ គិតថា ធម្មតាអ្នកទៅបរលោក នាំសម្ងាញ់ ឬញាតិមិត្តទៅមិនបានឡើយ កម្មដែលខ្លួនធ្វើហើយ ជារបស់ខ្លួនឯង ។ បន្ទាប់អំពីនោះ ទើបសារទមាណពឲ្យបើកឃ្លាំងកែវចេញ ឲ្យមហាទានដល់មនុស្សកំព្រា អ្នកដើរផ្លូវ វនិព្វក និងយាចកទាំងឡាយ ចូលទៅកាន់ជើងភ្នំ បួសជាឥសីហើយ ។ ជនទាំងឡាយបួសតាមសារទៈនោះដោយអាការយ៉ាងនេះ គឺម្នាក់ ពីរនាក់ បីនាក់ រហូតមានជដិលប្រមាណ ៧ ម៉ឺន ៤ ពាន់នាក់ ។ ជដិលទាំងនោះញុំាងអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតហើយ ប្រាប់កសិណបរិកម្មដល់ជដិលទាំងនោះ ។ សូម្បីជដិលទាំងនោះ ក៏ញុំាងអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើងហើយ ។

ដោយសម័យនោះ ព្រះពុទ្ធទ្រង់ព្រះនាមអនោមទស្សី ទ្រង់កើតឡើងហើយក្នុងលោក ក្នុងនគរឈ្មោះចន្ទវតី ព្រះរាជាព្រះនាមយសវន្ត ជាព្រះបិតា ព្រះទេវីព្រះនាមយសោធរាជាព្រះមាតា ដើមអង្រ្គងជាទីត្រាស់ដឹង អគ្គសាវ័កទាំងពីរ ឈ្មោះនិសភៈ ១ ឈ្មោះអនោមៈ ១ ឧបដ្ឋាកឈ្មោះវរុណ អគ្គសាវិកាទាំងពីរ ព្រះនាមសុនន្ទា ១ សុមនា ១ ព្រះជន្មាយុមានមួយសែនឆ្នាំ ព្រះសរីរៈកម្ពស់ ៥៨ ហត្ថ ព្រះរស្មីនៃព្រះសរីរៈផ្សាយទៅ ១២ យោជន៍ ភិក្ខុមួយសែនជាបរិវារ ។ ថ្ងៃមួយ ក្នុងពេលទៀបភ្លឺ ព្រះពុទ្ធព្រះនាមថាអនោមទស្សីនោះ ទ្រង់ចេញអំពីមហាករុណាសមាបត្តិ ទ្រង់ពិចារណាមើលសត្វលោក ទតឃើញសារទតាបសហើយ ទ្រង់ព្រះតម្រិះថា ព្រោះតថាគតទៅកាន់សម្នាក់សារទតាបស ក្នុងថ្ងៃនោះជាបច្ច័យ ព្រះធម្មទេសនានឹងមានគុណ

ធំ សរទតាបសនេះ នឹងប្រាថ្នាតំណែងអគ្គសាវក សិរីវឌ្ឍកុដុម្ពិកៈដែលជាសម្ងាញ់តាបសនោះ នឹងប្រាថ្នាតំណែងអគ្គសាវកទីពីរ ក្នុងកាលចប់ទេសនាជជិល ១ ម៉ឺន ៤ ពាន់បរិវារតាបសនោះ នឹងសម្រេចអរហត្ត តថាគតគួរទៅក្នុងទីនោះ ។ ដូច្នេះហើយ ទ្រង់កាន់បាត្រ និងចីវរបស់ព្រះអង្គមិនត្រាស់ហៅបុគ្គលដទៃ ឃាងទៅមួយព្រះអង្គឯង ដូចស្តេចរាជសី កាលអន្តេវាសិកទាំងឡាយរបស់សរទតាបសទៅហើយ ដើម្បីបេះផ្លែឈើ ទ្រង់អធិដ្ឋានថា ចូរសរទតាបស ជ្រាបនូវភាពដែលតថាគតជាព្រះពុទ្ធ កាលសរទតាបសឃើញនោះឯង ទ្រង់ចុះអំពីអាកាស ប្រថាប់លើផែនដីហើយ ។

សរទតាបសឃើញពុទ្ធានុភាព និងការសម្រេចនៃព្រះសរីរៈ ពិនិត្យនូវមន្តសម្រាប់ទាយព្រះលក្ខណៈ ក៏ជ្រាបបានថា បុគ្គលដែលប្រកបដោយលក្ខណៈទាំងនេះ បើនៅគ្រប់គ្រងផ្ទះ រមែងបានជាស្តេចចក្រពត្តិ បើចេញបួស រមែងបានជាព្រះសព្វញ្ញុពុទ្ធ មានកិលេសដំបូលបើកហើយក្នុងលោក ។ បុរសនេះជាព្រះពុទ្ធដោយឥតសង្ស័យ ទើបធ្វើការទទួល ថ្វាយបង្គំដោយបញ្ចង្គប្បតិស្ឋាន បានរៀបចំអាសនៈថ្វាយហើយ ។ ព្រះដ៏មានព្រះភាគ គង់ប្រថាប់លើអាសនៈដែលរៀបចំ សរទតាបសកាន់យកអាសនៈដែលសមគួរដល់ខ្លួនហើយ អង្គុយក្នុងចំណែកម្ខាង ។ ក្នុងសម័យនោះ ជជិល ៨៤០០០ កាន់ផ្លែឈើទាំងឡាយប្រណីតៗ មានឱជៈល្អមកដល់សម្នាក់អាចារ្យហើយ ក្រឡេកមើលអាសនៈដែលព្រះពុទ្ធប្រថាប់ និងអាចារ្យអង្គុយហើយ ទើបពោលថា បពិត្រលោកអាចារ្យ ពួកខ្ញុំត្រាច់ទៅដោយយល់ថា ក្នុងលោកនេះ

បុគ្គលជាធំជាងលោកអាចារ្យ មិនមាន បុរសនេះ ប្រហែលជាធំជាងលោកអាចារ្យហ្ន៎ ។

សារទតាបសឆ្លើយថា នែបាទាំងឡាយ ពួកបានិយាយអ្វី ពួកបាជ្រាបថ្នាធ្វើភ្នំសិនេរុដែលមានកម្ពស់ ៦៨ សែនយោជន៍ ឲ្យស្មើនឹងគ្រាប់ស្ពៃឬ នែបាពួកបាកុំធ្វើការប្រៀបធៀបខ្ញុំ នឹងព្រះសព្វញ្ញុពុទ្ធឡើយ ។

គ្រានោះ តាបសទាំងនោះគិតថា បើបុរសនេះ ជាបុគ្គលតូចតាចសោតលោកអាចារ្យរបស់យើងគង់មិនទាញវត្តុបែបនេះមកឧបមា បុរសនេះ ធំប៉ុនណាហ្ន៎ ដូច្នេះហើយ តាបសទាំងអស់ក្រាបទៀបព្រះបាទទាំងទ្វេ ថ្វាយបង្គំដោយសិរសាហើយ ។ គ្រានោះ អាចារ្យពោលនឹងតាបសទាំងនោះថា បាទាំងឡាយ ទេយ្យធម៌ដែលសមគួរដល់ព្រះពុទ្ធទាំងឡាយរបស់យើងមិនមានព្រះសាស្តាក៏យាងមកក្នុងទីនេះ ក្នុងពេលកិក្ខាចារ ពួកយើងនឹងថ្វាយទេយ្យ-ធម៌តាមកាល តាមកម្លាំង ពួកអ្នកចូរនាំផ្លែឈើប្រណីតដែលមានមក ដូច្នេះកាលបាននាំមកហើយ លាងដៃទាំងពីរហើយ ជាក់ក្នុងបាត្ររបស់ព្រះតថាគតដោយខ្លួនឯង កាលព្រះសាស្តាទ្រង់ទទួលផលាផល ទេវតាទាំងឡាយក៏ជាក់ឱជៈដែលជាទិព្វចូល។ តាបសនោះបានត្រងទឹកថ្វាយដោយខ្លួនឯងនោះឯង ។

បន្ទាប់មក កាលព្រះសាស្តាប្រថាប់គង់ធ្វើភត្តកិច្ចហើយ តាបសនោះហៅអន្តេវាសិកទាំងអស់មកហើយ អង្គុយពោលសាវាណីយកថា ក្នុងទីជិតព្រះសាស្តា ។ ព្រះសាស្តាត្រិះរិះថា ចូរអគ្គសាវកទាំងពីរមក ព្រមដោយភិក្ខុសង្ឃចុះ ។ អគ្គសាវកទាំងពីរនោះ ជ្រាបព្រះតម្រិះរបស់ព្រះសាស្តាហើយ

មានព្រះខីណាស្រពមួយសែនរូបជាបរិវារ មកថ្វាយបង្គំព្រះសាស្តាហើយ បាន ឈរក្នុងចំណែកម្ខាង ។

លំដាប់នោះ សារទតាបសហៅអន្តេវាសិកទាំងឡាយមកហើយ ពោលថា បាទាំងឡាយ សូម្បីអាសនៈដែលព្រះពុទ្ធប្រថាប់គង់ក៏ទាប អាសនៈសម្រាប់ សមណៈមួយសែនក៏មិនមាន ពួកអ្នកគួរធ្វើពុទ្ធសក្ការៈឲ្យឱឡារក្នុងថ្ងៃនេះ ចូរ នាំផ្តាទាំងឡាយដែលដល់ព្រមដោយពណ៌ និងក្លិន មកអំពីជើងភ្នំចុះ ។ ពេល ដែលនិយាយហាក់ដូចជាយឺតយូរ តែវិស័យរបស់ឫទ្ធិបុគ្គលមិនគួរគិត ព្រោះ ដូច្នោះ ដោយកាលត្រឹមតែមួយសម្ពុះប៉ុណ្ណោះ តាបសទាំងនោះនាំផ្តាទាំង- ឡាយ ដែលដល់ព្រមដោយពណ៌ និងក្លិនមកហើយ តាក់តែងអាសនៈផ្តា សម្រាប់ព្រះពុទ្ធ ប្រមាណបានមួយយោជន៍ សម្រាប់អគ្គសាវ័កទាំងពីរ ប្រមាណ ៣ គាវុត សម្រាប់ភិក្ខុដ៏សេស មានប្រមាណផ្សេងៗ គ្នា គឺមាន ប្រមាណកន្លះយោជន៍ជាដើម សម្រាប់ភិក្ខុថ្មីក្នុងសង្ឃ មានប្រមាណមួយ ឧសភៈ (២៥ ព្យាម) បុគ្គលណាម្នាក់មិនគប្បីគិតថា ក្នុងអាស្រមបទមួយ កន្លែង អាចតាក់តែងអាសនៈធំ មានប្រមាណត្រឹមនោះបានដូចម្តេច ព្រោះថា នេះជាវិស័យនៃឫទ្ធិ កាលតាក់តែងអាសនៈស្រេចហើយយ៉ាងនោះ សារទ- តាបសឈរផ្គងអញ្ជលីចំពោះព្រះភក្ត្របស់ព្រះតថាគតហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ឡើងគាន់អាសនៈផ្តានេះ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះអង្គ អស់កាលជ័យូរ ព្រោះហេតុនោះ ទើប បុរាណាចារ្យពោលថា

សរទតាបសយកផ្កាផ្សេងៗ និងគ្រឿងក្រអូបរួមចូលគ្នា តុបតែងដោយអាសនៈផ្កាហើយ បានក្រាបទូលពាក្យនេះថា បពិត្រព្រះវីរៈ អាសនៈដែលខ្ញុំព្រះអង្គតាក់តែងហើយនេះ សមគួរដល់ព្រះអង្គ ទ្រង់កាលញុំាងចិត្តខ្ញុំព្រះអង្គឲ្យជ្រះថ្លា សូមទ្រង់ប្រថាប់គង់លើអាសនៈផ្កា ព្រះសម្ពុទ្ធទ្រង់បានញុំាងចិត្តខ្ញុំព្រះអង្គ ឲ្យជ្រះថ្លាហើយ ញុំាងលោកនេះ ព្រមទាំងទេវលោកឲ្យត្រេកអរហើយ ទើបប្រថាប់គង់លើអាសនៈផ្កា អស់ ៧ យប់ ៧ ថ្ងៃ ។

កាលព្រះសាស្តាប្រថាប់គង់ហើយយ៉ាងនោះ អគ្គសាវ័កទាំងពីរ និងភិក្ខុដ៏សេស ក៏គង់ហើយលើអាសនៈដែលដល់លំដាប់ខ្លួន ។ សរទតាបសបានកាន់ឆត្រផ្កាធំ ឈរចាំងលើសិរីសោភារបស់ព្រះតថាគត ព្រះសាស្តាទ្រង់អធិដ្ឋានថា ចូរសក្ការៈរបស់ជដិលនេះមានផលធំ ដូច្នេះហើយ ទ្រង់ចូលនិរោធ-សមាបត្តិ ។ អគ្គសាវ័កទាំងពីរក្តីភិក្ខុដ៏សេសក្តី ជ្រាបថា ព្រះសាស្តាទ្រង់ចូលសមាបត្តិហើយ ក៏ចូលសមាបត្តិ កាលព្រះតថាគតប្រថាប់គង់ចូលនិរោធ-សមាបត្តិ អស់ ៧ ថ្ងៃ ពួកអន្តេវាសិក កាលដល់ពេលត្រាច់ទៅរកភិក្ខាចរិកោគមូលផលាផលក្នុងព្រៃហើយ ឈរផ្គងអញ្ជលីដល់ព្រះពុទ្ធទាំងឡាយអស់កាលដ៏សេស ។ ចំណែកសរទតាបស មិនទៅកាន់ទីភិក្ខាចារ ចាំងឆត្រផ្កានោះឯង ឲ្យកាលកន្លងទៅដោយបីតិ និងសុខអស់ ៧ ថ្ងៃ ។ ព្រះសាស្តាទ្រង់ចេញអំពីនិរោធហើយ ត្រាស់ហៅអគ្គសាវ័កឈ្មោះនិសភត្ថេរ ដែលគង់ខាងស្តាំ ដោយព្រះតម្រាស់ថា ម្នាលនិសភៈ អ្នកចូរធ្វើអនុមោទនា

អាសនៈផ្តាជល់តាបសទាំង៦ឡាយ ដែលធ្វើសក្ការៈ ព្រះថេរៈមានចិត្តត្រេកអរ ហាក់ដូចមេទ័ពធំ ជួបនូវលាភធំអំពីសម្នាក់របស់ស្តេចចក្រពត្តិ តាំងនៅក្នុងសាវកបារមីញ្ញាណ ផ្តើមអនុមោទនាអាសនៈផ្តាហើយ ។ ក្នុងទីបំផុតនៃទេសនារបស់ព្រះនិសភត្ថេរនោះ ព្រះសាស្តាត្រាស់ហៅទុតិយសាវក ដោយព្រះតម្រាស់ថា ម្នាលភិក្ខុ អ្នកក៏ចូរសម្តែងធម៌ ។ ព្រះអនោមត្ថេរពិចារណាព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ពោលធម៌ហើយដោយអគ្គសាវកទេសនា ការត្រាស់ដឹងមិនមានដល់តាបសសូម្បីមួយរូប ។

គ្រានោះ ព្រះសាស្តាតាំងនៅក្នុងពុទ្ធវិស័យមិនមានប្រមាណ ទ្រង់ផ្តើមធម្មទេសនាហើយ ក្នុងកាលចប់ទេសនា ជដិល ៧ ម៉ឺន ៤ ពាន់ រៀរសរទ-តាបសចេញ សម្រេចអរហត្តហើយ ។ ព្រះសាស្តាទ្រង់លាព្រះហស្តត្រាស់ថា អ្នកទាំង៦ឡាយចូរមកជាភិក្ខុចុះ រំពេចនោះឯង សក់ និងពុកមាត់របស់ជដិលទាំងនោះ បានអន្តរធានទៅហើយ បរិក្ខារ ៨ បានដណ្តប់កាយហើយនោះឯង ។

មានពាក្យសួរជ្រៀតចូលមកថា ព្រោះហេតុអ្វី ទើបសរទតាបសមិនបានសម្រេចអរហត្ត ឆ្លើយថា ព្រោះមានចិត្តរាយមាយ ។ បានឮថា តាំងអំពីកាលសរទតាបសនោះ ផ្តើមស្តាប់ធម្មទេសនារបស់ព្រះអគ្គសាវក ដែលគង់លើអាសនៈទីពីរនៃព្រះសម្ពុទ្ធ តាំងនៅក្នុងសាវកបារមីញ្ញាណ សម្តែងធម៌ កើតការគិតឡើងថា ឱហ្ន៎ សូម្បីអញគប្បីបានទទួលធុរៈដែលសាវកូរបនេះបានទទួលក្នុងសាសនារបស់ព្រះពុទ្ធ ដែលទ្រង់កើតឡើងក្នុងអនាគត ដោយ

បរិវិតក្កនោះ ទើបសរទតាបសនោះ មិនអាចធ្វើការចាក់ធ្លុះនូវមគ្គផលបាន ។ លោកឈរថ្វាយបង្គំព្រះតថាគតហើយ ក្នុងទីចំពោះព្រះភក្ត្រ ក្រាបទូលថា បពិត្រព្រះអង្គ ភិក្ខុដែលគង់លើអាសនៈក្នុងលំដាប់នៃទ្រង់ជាអ្វី ក្នុងសាសនារបស់ព្រះអង្គ ។

ព្រះសាស្តាត្រាស់ថា ភិក្ខុដែលញុំាងធម្មចក្រដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅតាម ជាអ្នកដល់នូវទីបំផុតនៃសាវកបារមីញាណ ចាក់ធ្លុះនូវបញ្ញា ១៦ យ៉ាង តាំងនៅ បុគ្គលនេះ ឈ្មោះថា ជាអគ្គសាវ័កក្នុងសាសនារបស់តថាគត ។ សរទៈបានធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ ដោយផលនៃសក្ការៈដែលខ្ញុំព្រះអង្គបាំងធត្រផ្តាធ្វើហើយ អស់ ៧ ថ្ងៃនេះ ខ្ញុំព្រះអង្គមិនបានប្រាថ្នាភាពជាសក្កៈ ឬភាពជាព្រហ្មដទៃឡើយ តែខ្ញុំព្រះអង្គសូមបានជាអគ្គសាវ័កបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគត ដូចព្រះនិសភៈអង្គនេះ ។

ព្រះសាស្តាទ្រង់បញ្ជូនអនាគតំសញ្ញាណទៅ ពិចារណាថា ការប្រាថ្នារបស់បុរសនេះនឹងសម្រេចឬហ្ន៎ ទ្រង់បានឃើញថា កន្លងមួយអសង្ខ្យៃ និងមួយសែនកប្បហើយ នឹងបានសម្រេច កាលទ្រង់ឃើញហើយ ទើបត្រាស់នឹងតាបសថា សេចក្តីប្រាថ្នារបស់អ្នកមិនឥតប្រយោជន៍ទេឡើយ ក្នុងអនាគត កន្លងទៅមួយអសង្ខ្យៃ និងមួយសែនកប្ប ព្រះពុទ្ធព្រះនាមថា គោតម ទ្រង់កើតឡើងក្នុងលោក ព្រះមាតារបស់ទ្រង់ព្រះនាមមហាមាយាទេវី ព្រះបិតាព្រះនាមសុទ្ធោទនមហារាជ ព្រះឱរសព្រះនាមរាហុល ឧបដ្ឋាក

មាននាមថាអានន្ទ ទុតិយសាវ័កមាននាមថាមោគ្គល្លាន ចំណែកអគ្គសាវ័ក របស់ព្រះអង្គនាមថាធម្មសេនាបតីសារីបុត្រ កាលទ្រង់ព្យាករតាបសយ៉ាង នោះហើយ ត្រាស់ធម្មកថា មានកិរ្យាចោមរោមហោះទៅហើយ ។

ចំណែកសរទតាបស ទៅកាន់សម្នាក់ព្រះថេរៈដែលជាអន្តេវាសិក ហើយ បញ្ជូនដំណឹងទៅដល់សិរិវឌ្ឍកុដុម្ពិកៈជាសម្លាញ់ថា បពិត្រលោកម្ចាស់ សូម លោកម្ចាស់ទាំងឡាយ ប្រាប់ដល់សម្លាញ់របស់ខ្ញុំថា សរទតាបសដែលជា សម្លាញ់របស់អ្នក បានប្រាថ្នាតំណែងព្រះអគ្គសាវ័ក ក្នុងសាសនារបស់ព្រះពុទ្ធ ព្រះនាមថាគោតម ដែលទ្រង់នឹងកើតឡើងក្នុងអនាគត ទៀបបាទមូលរបស់ ព្រះពុទ្ធព្រះនាមអនោមទស្សីហើយ ចូរអ្នកប្រាថ្នាតំណែងទុតិយអគ្គសាវ័ក ចុះ ។ កាលពោលយ៉ាងនោះហើយ បានទៅក្នុងចំណែកម្ខាងមុនព្រះថេរៈ ទាំងឡាយ បានឈរត្រង់មាត់ទ្វាររបស់សិរិវឌ្ឍហើយ ។ សិរិវឌ្ឍពោលថា យូរហើយហ្ន៎ លោកម្ចាស់របស់ខ្ញុំទើបមក ដូច្នេះហើយ និមន្តឲ្យគង់លើ អាសនៈ ខ្លួនអង្គុយលើអាសនៈទាបជាង ហើយសាកសួរថា ហេតុអ្វី អន្តេ-វាសិកបរិស័ទលោកម្ចាស់បាត់អស់ទៅ សរទតាបសពោលថា យ៉ាងនោះឯង សម្លាញ់ ព្រះសម្ពុទ្ធអនោមទស្សី ទ្រង់មកកាន់អាស្រមរបស់យើងទាំងឡាយ ពួកខ្ញុំធ្វើសក្ការៈដល់ព្រះអង្គតាមកម្លាំងរបស់ខ្លួន ព្រះសាស្តាទ្រង់សម្តែងធម៌ ប្រោសពួកយើងគ្រប់គ្នា ក្នុងកាលចប់ទេសនា រៀវតែខ្ញុំចេញ ជនដ៏សេស សម្រេចអរហត្ត ហើយបួស ។ ខ្ញុំឃើញព្រះនិសភត្ថេរ អគ្គសាវ័ករបស់ព្រះ សាស្តា ទើបប្រាថ្នាតំណែងអគ្គសាវ័កក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមគោតម

ដែលទ្រង់នឹងកើតឡើងក្នុងអនាគត ឯអ្នកក៏ចូរប្រាថ្នាតំណែងទុតិយសាវ័កក្នុងសាសនារបស់ព្រះអង្គចុះ ។

សិរិវឌ្ឍពោលថា ខ្ញុំមិនមានការស្និទ្ធស្នាលនឹងព្រះសម្ពុទ្ធទ្បើយ សារទតាបសពោលថា រឿងទូលព្រះសម្ពុទ្ធជាការៈរបស់ខ្ញុំឯង អ្នកចូររៀបចំសក្ការៈធំចុះ ។

សិរិវឌ្ឍស្តាប់ពាក្យរបស់តាបសនោះហើយ បានធ្វើទីប្រមាណ ៨ ករីសៈ (មួយករីសៈ ១២៥ ហត្ថ) ដោយមាត្រាវង្វាស់ត្រង់ទ្វារផ្ទះរបស់ខ្លួន ឲ្យមានផែនដីស្មើហើយ កៀរខ្សាច់ រោយផ្កា មានលាជជាគម្រប់ ៥ ធ្វើមណ្ឌបប្រក់ដោយផ្កាឧប្បលខៀវ តាក់តែងពុទ្ធាសនៈ រៀបចំអាសនៈដល់ភិក្ខុដ៏សេស រៀបចំសក្ការៈ និងគ្រឿងទទួលដ៏ច្រើនហើយ បានឲ្យសញ្ញាដល់សារទតាបសដើម្បីប្រយោជន៍និមន្តព្រះពុទ្ធទាំងឡាយ ។

ព្រះតាបសបាននាំភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទៅត្រង់លំនៅរបស់សិរិវឌ្ឍកុដុម្ពិកៈនោះហើយ ។ ចំណែកសិរិវឌ្ឍកុដុម្ពិកៈ ធ្វើការទទួលបាត្រអំពីព្រះហស្តរបស់ព្រះតថាគត និមន្តឲ្យចូលទៅកាន់មណ្ឌប ថ្វាយទឹកទក្ខិណោទកដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អង្គុយលើអាសនៈដែលតាក់តែង អង្គាសដោយកោជនដ៏ប្រណីត ក្នុងពេលស្រេចភត្តកិច្ច និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន គ្រងសំពត់ដែលមានតម្លៃច្រើន ហើយក្រាបទូលថា បពិត្រព្រះអង្គ ការផ្ចងផ្តើមនេះ មិនបានប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់តំណែងមានប្រមាណតូចតាចទ្បើយ សូមទ្រង់ធ្វើសេចក្តីអនុគ្រោះដោយទំនង

នេះឯង អស់កាល ៧ ថ្ងៃចុះ ។

ព្រះសាស្តាទ្រង់ទទួលហើយ ។ គាត់ញ្ចាំងមហាទានឲ្យប្រព្រឹត្តទៅដោយ ទំនងនោះឯងរហូត ៧ ថ្ងៃ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ឈរផ្គងនូវ អញ្ជលីក្រាបទូលថា បពិត្រព្រះអង្គ សរទតាបសសម្ងាញ់របស់ខ្ញុំព្រះអង្គប្រាថ្នា ថា ខ្ញុំគប្បីជាអគ្គសាវករបស់ព្រះសាស្តាអង្គណា ខ្ញុំព្រះអង្គគប្បីជាទុតិយសាវក របស់ព្រះសាស្តាអង្គនោះដូចគ្នា ។ ព្រះសាស្តាទ្រង់ពិចារណាដល់អនាគតកាល ទ្រង់ឃើញភាវ: គឺកាលសម្រេចនៃសេចក្តីប្រាថ្នារបស់បុគ្គលនោះ ទើបទ្រង់ ព្យាករថា កន្ងងអំពីនេះទៅមួយអសង្ខេយ្យ និងមួយសែនកប្ប អ្នកក៏នឹងបាន ជាទុតិយសាវករបស់ព្រះពុទ្ធព្រះនាមគោតម ។

សិរិវឌ្ឍ ស្តាប់ព្យាការរបស់ព្រះសម្ពុទ្ធហើយ ជាអ្នកត្រេកអររីករាយ ហើយ ព្រះសាស្តាទ្រង់ធ្វើភត្តានុមោទនាហើយ ព្រមទាំងបរិវារយាងទៅកាន់ វិហារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីប្រាថ្នាដែលបុត្ររបស់តថាគត ប្រាថ្នាហើយក្នុងកាលនោះ ។ អគ្គសាវកទាំងពីរនោះបានតំណែងតាមដែលខ្ជូន ប្រាថ្នានោះឯង តថាគតមិនមែនឲ្យដោយយល់មុខឡើយ ។

កាលព្រះសាស្តាត្រាស់ព្រះពុទ្ធវចន:យ៉ាងនោះឯង អគ្គសាវកទាំងពីរ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ទូលរឿងដែលជាបច្ចុប្បន្នទាំងអស់ថា បពិត្រព្រះ អង្គដ៏ចម្រើន ខ្ញុំព្រះអង្គកាលនៅជាអ្នកគ្រប់គ្រងផ្ទះ ទៅមើលមហោស្រពលើ កំពូលភ្នំដូច្នេះជាដើម រហូតដល់ការសម្រេចសោតាបត្តិផល អំពីសម្នាក់ព្រះ អស្សជិត្ថេរ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងពីរ

នោះទៅកាន់សម្នាក់របស់អាចារ្យសញ្ជ័យ បំណងនឹងនាំលោកឲ្យមកកាន់បាទមូលរបស់ព្រះអង្គ ប្រាប់ថាលទ្ធិរបស់លោកមិនមានសារៈ ហើយពោលអានិសង្សក្នុងការមកទីនេះ អាចារ្យសញ្ជ័យឆ្លើយថា ឥឡូវនេះ ឈ្មោះថា ការនៅជាអន្តេវាសិករបស់ខ្ញុំ ហាក់ដូចជាការដល់នូវភាពកម្រើកនៃទឹកក្នុងត្រពាំង ខ្ញុំមិនអាចនៅជាអន្តេវាសិកបាន កាលខ្ញុំព្រះអង្គប្រាប់ថា លោកអាចារ្យ ពេលនេះ មហាជនមានដៃកាន់វត្ថុ មានគ្រឿងក្រអូប និងផ្កាកម្រងជាដើម ទៅបូជាចំពោះព្រះសាស្តា លោកនឹងធ្វើដូចម្តេច គាត់ឆ្លើយថា ក្នុងលោកនេះ អ្នកឈ្លាសវៃច្រើន ឬអ្នកល្ងង់ខ្លៅច្រើន កាលខ្ញុំព្រះអង្គឆ្លើយថា អ្នកល្ងង់ខ្លៅច្រើន គាត់ក៏ពោលថា បើដូច្នោះ ពួកអ្នកឈ្លាសវៃ នឹងទៅកាន់សម្នាក់ព្រះគោតម ពួកអ្នកល្ងង់ខ្លៅនឹងមកកាន់សម្នាក់របស់ខ្ញុំ អ្នកទាំងពីរទៅចុះ មិនប្រាថ្នានឹងមក ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សញ្ជ័យកាន់យករបស់ដែលមិនមានសារៈ ថាមានសារៈ និងរបស់ដែលមានសារៈ ថាមិនមានសារៈ ព្រោះភាពដែលខ្លួនជាមិច្ឆាទិដ្ឋិ ។ ចំណែកអ្នកទាំងពីរជីងវត្ថុជាសារៈដោយភាពជាសារៈ និងវត្ថុដែលមិនជាសារៈ ដោយភាពមិនជាសារៈ លះវត្ថុដែលមិនមានសារៈចេញ កាន់យកតែវត្ថុដែលជាសារៈប៉ុណ្ណោះ ព្រោះភាពដែលខ្លួនជាបណ្ឌិត ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថានេះថា

អសារេ សារមតិនោ សារេ ចាសារទស្សិនោ
តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា ។

សារញ្ច សារតោ ញត្វា អសារញ្ច អសារតោ

តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា ។

ជនទាំងឡាយ ដែលយល់ឃើញក្នុងធម៌មានខ្វឹម ថាជាធម៌មិនមានខ្វឹមផង ជាអ្នកតម្រិះខុសជាអារម្មណ៍ រមែងមិនបាននូវធម៌ដែលមានខ្វឹមឡើយ ។ ជនទាំងឡាយ ដែលយល់ឃើញនូវធម៌មានខ្វឹម ថាជាធម៌មានខ្វឹមផង យល់ឃើញនូវធម៌គ្មានខ្វឹម ថាជាធម៌គ្មានខ្វឹមផង ជាអ្នកមានតម្រិះត្រូវជាអារម្មណ៍ រមែងបាននូវធម៌ដែលមានខ្វឹម ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **អសារេ សារមតិនោ** *សេចក្តីថា សការៈនេះ គឺបច្ច័យ ៤ មិច្ឆាទិដ្ឋិមានវត្ថុ ១០ ធម្មទេសនាដែលជាឧបនិស្សយនៃមិច្ឆាទិដ្ឋិនោះ ឈ្មោះថា ជាធម៌មិនមានខ្វឹម បុគ្គលមានប្រក្រតីឃើញក្នុងធម៌ ដែលមិនមានខ្វឹមនោះ ថាជាខ្វឹម ។*

បាទព្រះគាថាថា **សារេ ចាសារទស្សិនោ** *សេចក្តីថា សការៈ គឺសម្មាទិដ្ឋិមានវត្ថុ ១០ ធម្មទេសនាដែលជាឧបនិស្សយនៃសម្មាទិដ្ឋិនោះ ឈ្មោះថាជាខ្វឹម បុគ្គលមានប្រក្រតីឃើញក្នុងធម៌ដែលជាខ្វឹមនោះថា នេះជាខ្វឹម ។*

ពីរបទថា **តេ សារំ** *ជាដើម សេចក្តីថា ជនទាំងនោះ គឺបុគ្គលដែលកាន់យកមិច្ឆាទិដ្ឋិនោះតាំងនៅជាអ្នកមានសេចក្តីត្រិះរិះជាគោចរ ដោយអំណាចនៃវិតក្កទាំងឡាយ មានកាមវិតក្កជាដើម រមែងមិនសម្រេចសីលសារៈ*

សមាធិសារៈ បញ្ញាសារៈ វិមុត្តិសារៈ វិមុត្តិញ្ញាណទស្សនសារៈ និងនិព្វាន ដែលជាបរមត្ថសារៈ ។

បទថា **សារញ្ច** *សេចក្តីថា ជឹងនូវសារៈ មានសីលសារៈជាដើមនោះ ឯងថា នេះឈ្មោះថាសារៈ និងជឹងធម៌ដែលមិនជាសារៈ មានប្រការដូចពោលហើយថា នេះមិនជាសារៈ ។*

ពីរបទថា **តេ សារំ** *ជាដើម សេចក្តីថា ជនទាំងនោះ គឺបណ្ឌិតដែលប្រកាន់សម្មាទស្សនៈយ៉ាងនោះតាំងនៅ ជាអ្នកមានតម្រិះត្រូវជាគោចរ ដោយអំណាចការត្រិះរិះទាំងឡាយ មានការត្រិះរិះចេញចាកកាមជាដើម រមែងសម្រេចធម៌ដែលជាសារៈ មានប្រការដូចពោលហើយនោះ ។*

ក្នុងកាលចប់គាថា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ទេសនាបានជាប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ៗ

រឿង សញ្ជ័យ ចប់

រឿង ព្រះឧទុម្ពរត្ថេរ

លំនាំដើម

ព្រះសាស្តា គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះឧទុម្ពរត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យថា អគារំ ទុច្ឆន្នំ** *ជាដើម ។*

សេចក្តីពិស្តារថា ព្រះសាស្តាទ្រង់មានបវារណាធម្មចក្រឲ្យប្រព្រឹត្តទៅហើយ យាងទៅកាន់ក្រុងរាជគ្រឹះ ប្រថាប់នៅក្នុងវត្តវេឡុវ័ន ។ បណ្តាទូត ១០ នាក់ មានបរិវារម្នាក់ ១ ពាន់ ដែលព្រះបាទសុទ្ធោទនមហារាជ ទ្រង់បញ្ជូនទៅ ដោយត្រាស់ថា អ្នកទាំងឡាយចូរនាំព្រះអយ្យបុត្រមកឲ្យខ្ញុំចុះ ព្រះកាឡុទាយត្ថេរទៅក្រោយគេបង្អស់ សម្រេចអរហត្តហើយ ជ្រាបកាលដែលទ្រង់មកហើយ ពណ៌នាផ្សះដោយគាថា ៦០ គាថា នាំព្រះសាស្តាដែលមានព្រះខីណាស្រព ២ ម៉ឺនចោមរោមហើយ ទៅកាន់កបិលវត្ថុបុរី ទ្រង់ធ្វើភ្លៀងបោក្ខរពស្សៈ ឲ្យជាអត្ថុប្បត្តិហេតុហើយ ត្រាស់មហាវេស្សន្តរជាតកក្នុងសមាគមព្រះញាតិ ស្អែកឡើង ទ្រង់ចូលទៅបិណ្ឌបាត ប្រោសព្រះបិតាឲ្យតាំងនៅក្នុងសោតាបត្តិផល ដោយព្រះគាថាថា **ឧដ្ឋិត្តេ ឧបប្បមជ្ជេយ្យ** *ជាដើម ។ ប្រោសព្រះនាងមហាបជាបតិគោតមីឲ្យតាំងនៅក្នុងសោតាបត្តិផល និងប្រោសព្រះរាជាឲ្យតាំងនៅក្នុងសកទាគាមិផល ដោយព្រះគាថាថា* **ធម្មញ្ចរេ សុចរិតំ** *ជាដើម ។ ក្នុងកាលស្រេចភត្តកិច្ច ទ្រង់អាស្រ័យពណ៌នាព្រះគុណរបស់រាហុលមាតា ត្រាស់ចន្ទកិន្នរីជាតក ក្នុងថ្ងៃទី ៣ បន្ទាប់អំពីថ្ងៃនោះ កាលវិវាហមង្គលដែលយាងព្រះមានព្រះភាគចូលផ្ទះ អភិសេករបស់នន្ទកុមារប្រព្រឹត្តទៅ ។ ទ្រង់ចូលទៅបិណ្ឌបាត ប្រទានបាត្រក្នុងព្រះហស្តរបស់នន្ទកុមារ ត្រាស់មង្គល ស្តេចក្រោកអំពីអាសនៈហើយចៀសចេញទៅ ទ្រង់មិនបានទទួលបាត្រអំពីព្រះហស្តរបស់នន្ទកុមារឡើយ ។*

ចំណែកនន្ទកុមារនោះ ដោយការគោរពក្នុងព្រះសាស្តា ទើបមិនអាច

ទូលថា សូមទ្រង់ទទួលបាត្រវិញចុះ តែគិតយ៉ាងនេះថា ព្រះសាស្តាទ្រង់នឹងទទួលបាត្រត្រង់ក្បាលជណ្តើរ ។ ក្នុងទីនោះព្រះសាស្តាក៏ទ្រង់មិនបានទទួល ។ នន្ទកុមារក៏គិតថា ទ្រង់គង់នឹងទទួលត្រង់មាត់ជណ្តើរ ។ ក្នុងទីនោះព្រះសាស្តាក៏មិនទទួល ។ នន្ទកុមារក៏គិតថា ទ្រង់នឹងទទួលត្រង់ព្រះលានរាជវាំង ក្នុងទីនោះព្រះសាស្តាក៏ទ្រង់មិនទទួល ។ ព្រះកុមារប្រុងថ្វាយយាងត្រឡប់ យាងទៅដោយការមិនពេញព្រះហឫទ័យ ដោយការគោរពក្នុងព្រះតថាគត ទើបមិនអាចទូលថា សូមទ្រង់ទទួលបាត្រចុះ ទ្រង់យាងគិតថា ព្រះអង្គនឹងទទួលក្នុងទីនេះ ព្រះអង្គនឹងទទួលក្នុងទីនេះ ក្នុងខណៈនោះ ស្រីពួកជវៃឃើញអាការនោះហើយ ទើបប្រាប់ដល់នាងជនបទកល្យាណីថា បពិត្រព្រះនាង ព្រះដ៏មានព្រះភាគទ្រង់នាំនន្ទកុមារទៅហើយ គង់នឹងពង្រាត់នន្ទកុមារអំពីព្រះនាង ។

ចំណែកនាងជនបទកល្យាណីនោះ បានឮពាក្យនោះហើយ មានតំណក់ទឹកកំពុងហូរនោះឯង មានសក់ដែលបួងបានមួយចំហៀង ប្រញាប់ទៅទូលថា បពិត្រអយ្យបុត្រ សូមព្រះអង្គប្រញាប់យាងត្រឡប់ ពាក្យរបស់នាងនោះហាក់បីដូចជាក់ទៅតាំងនៅក្នុងហទយៈរបស់នន្ទកុមារ ព្រះសាស្តាទ្រង់នៅតែមិនទទួលបាត្រអំពីដៃរបស់នន្ទកុមារនោះ ទ្រង់នាំនន្ទកុមារនោះទៅកាន់វិហារហើយត្រាស់ថា នន្ទ អ្នកចង់បួសឬទេ នន្ទកុមារនោះ ដោយការគោរពក្នុងព្រះពុទ្ធ ទើបមិនទូលថា ខ្ញុំព្រះអង្គមិនបួសទេ តែទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងបួស ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរឲ្យនន្ទបួសចុះ ។

ព្រះសាស្តាយាងទៅកាន់ក្រុងកបិលវត្ថុបុរីក្នុងថ្ងៃទី ៣ ទ្រង់ញុាំងនន្ទកុមារ ឲ្យបួសហើយ ក្នុងថ្ងៃទី ៧ ព្រះមាតារបស់ព្រះរាហុលតាក់តែងព្រះរាជកុមារ ហើយ បញ្ជូនទៅកាន់សម្នាក់ព្រះដ៏មានព្រះភាគ ដោយព្រះសារនីយ៍ថា នែបាចូរបាមើលសមណៈដែលមានសមណៈ ២ ម៉ឺនចោមរោម ទ្រង់មានពណ៌សម្បុរដូចមាស មានវណ្ណៈនៃព្រះរូបដូចព្រហ្មនោះ សមណៈនោះជាបិតារបស់បា កំណប់ទ្រព្យធំមានហើយ ក្នុងកាលដែលព្រះបិតារបស់បានោះប្រសូត ។ តាំងអំពីកាលទ្រង់ចេញបួស មាតាមិនធ្លាប់ឃើញឡើយ បាចូរទៅទូលសូមមត៌កជាមួយទ្រង់ថា បពិត្រព្រះបិតា ខ្ញុំជាកុមារ លុះអភិសេកហើយនឹងបានជាស្តេចចក្រពត្តិ ខ្ញុំត្រូវការដោយទ្រព្យ សូមព្រះបិតាព្រះរាជទានទ្រព្យដល់ខ្ញុំ ព្រោះបុត្រ រមែងជាម្ចាស់របស់សម្បត្តិនៃបិតា ។ ព្រះរាជកុមារយាងទៅកាន់សម្នាក់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំហើយ ក៏បាននូវសេចក្តីស្រឡាញ់ក្នុងបិតាត្រេកអរហើយ ទូលថា បពិត្រសមណៈ ម្ចប់របស់ព្រះអង្គ ត្រជាក់ សុខណាស់ បានឈរពោលពាក្យជាទៃដ៏ច្រើន ដែលសមគួរដល់ខ្លួន ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើភត្តកិច្ចហើយ ទ្រង់អនុមោទនាហើយ ស្តេចក្រោកចាកអាសនៈ ចៀសចេញទៅ សូម្បីព្រះកុមារក៏ទូលសូមថា បពិត្រសមណៈ សូមទ្រង់ប្រទានមត៌កដល់ខ្ញុំចុះ បពិត្រសមណៈ សូមទ្រង់ប្រទានមត៌កដល់ខ្ញុំចុះ ដូច្នេះហើយ ក៏យាងតាមព្រះដ៏មានព្រះភាគទៅ ។ ព្រះដ៏មានព្រះភាគ ក៏មិនឲ្យព្រះរាជកុមារត្រឡប់ ។ ចំណែកបរិជនក៏មិនអាចយាងព្រះរាជកុមារ ដែលយាងទៅតាមព្រះដ៏មានព្រះភាគឲ្យត្រឡប់បាន ព្រះរាជកុមារនោះ បានយាង

ទៅដល់អាវាមនោះឯង ជាមួយព្រះដ៏មានព្រះភាគ ដោយប្រការដូច្នេះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះថា កុមារនេះចង់បានទ្រព្យ ដែលជាសម្បត្តិរបស់បិតា ទ្រព្យនោះទៅតាមវណ្ណៈ មានការចង្អៀតចង្អល់ ណ្តើយចុះ តថាគតនឹងឲ្យអរិយទ្រព្យ ៧ ប្រការ ដែលតថាគតបានចំពោះ ត្រង់មណ្ឌលពោធិព្រឹក្សដល់កុមារនេះ នឹងធ្វើកុមារនេះឲ្យជាម្ចាស់មត៌ក ដែលជាលោកុត្តរ ។

គ្រានោះឯង ព្រះដ៏មានព្រះភាគត្រាស់ឲ្យហៅព្រះសារីបុត្រមកហើយ ត្រាស់ថា ម្នាលសារីបុត្រ បើដូច្នោះ អ្នកចូរឲ្យរាហុលកុមារបួសចុះ ព្រះថេរៈ ឲ្យកុមារនោះឲ្យបួសហើយ ។ កាលព្រះកុមារបួសហើយ ទុក្ខមានប្រមាណ ជាទម្ងន់កើតឡើងដល់ព្រះរាជា ព្រោះទ្រង់បានឮដំណឹងនោះ ។

ព្រះរាជាទ្រង់មិនអាចសង្កត់នូវសេចក្តីទុក្ខនោះបាន យាងទៅកាន់សម្នាក់ ព្រះដ៏មានព្រះភាគ ទូលហើយ សូមប្រទានពរថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គ សូមប្រទានព្រះវរោកាស លោកម្ចាស់ទាំងឡាយ មិនគប្បីញុំាងបុត្រដែល មាតាបិតាមិនអនុញ្ញាតឲ្យបួសឡើយ ។

ព្រះដ៏មានព្រះភាគ ប្រទានពរនោះដល់ព្រះរាជាហើយ ស្អែកឡើងសោយ ព្រះក្រយាហារព្រឹក ក្នុងព្រះរាជនិវេសន៍ហើយ កាលព្រះរាជាប្រថាប់នៅក្នុង ចំណែកម្ខាង ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងពេលដែលព្រះអង្គទ្រង់ធ្វើ ទុក្ករកិរិយា ទេវតាមួយអង្គចូលមករកខ្ញុំព្រះអង្គប្រាប់ថា ព្រះរាជឱរសរបស់ ព្រះអង្គសោយទិវង្គតហើយ ខ្ញុំព្រះអង្គមិនជឿពាក្យរបស់ទេវតានោះ ទើប

ជំទាស់ទេវតានោះថា បុត្រារបស់ខ្ញុំ បើមិនទាន់សម្រេចពោធិញ្ញាណ មិនធ្វើកាលកិរិយាឡើយ ដូច្នេះហើយ ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ឥឡូវនេះ ព្រះអង្គនឹងជឿបានដូចម្តេច សូម្បីក្នុងកាលមុន កាលបុរសម្នាក់ បង្ហាញឆ្នឹងដល់ទ្រង់ ទូលថា កូនរបស់ព្រះអង្គសោយទិវង្គតហើយ ក៏ទ្រង់មិនជឿបានត្រាស់មហាធម្មបាលជាតក ព្រោះអត្តុប្បត្តិហេតុនេះឯង ។ ក្នុងកាលចប់គាថា ព្រះរាជាតាំងនៅក្នុងអនាគាមិផល ។

ព្រះដ៏មានព្រះភាគ ត្រាស់ព្រះបិតាឲ្យតាំងនៅក្នុងផល ៣ ដោយប្រការដូច្នេះហើយ មានភិក្ខុសង្ឃចោមរោម យាងត្រឡប់ទៅកាន់ក្រុងរាជគ្រឹះទៀតបន្ទាប់អំពីនោះ ទ្រង់ទទួលប្តេជ្ញាជាមួយអនាថបិណ្ឌិកសេដ្ឋី ដើម្បីប្រយោជន៍ដល់ការយាងមកក្រុងសាវត្ថី កាលវត្តជេតពនមហាវិហារធ្វើស្រេចហើយ ទ្រង់យាងទៅចាំវស្សាក្នុងវត្តជេតពនមហាវិហារនោះ ។

កាលព្រះសាស្តា ប្រថាប់នៅក្នុងវត្តជេតពនយ៉ាងនេះឯង ព្រះនន្ទូអផ្សុកហើយ ទើបប្រាប់សេចក្តីនោះ ដល់ភិក្ខុទាំងឡាយថា អាវុសោ ខ្ញុំមិនត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចរិយៈ មិនអាចបន្តព្រហ្មចរិយៈទៅបាន ខ្ញុំនឹងពោលលាសិក្ខាហើយសឹក ។ ព្រះដ៏មានព្រះភាគ ទ្រង់ស្តាប់ការប្រព្រឹត្តទៅនោះហើយ ត្រាស់ឲ្យហៅព្រះនន្ទូមកគាល់ហើយត្រាស់ថា ម្នាលនន្ទូ បានឮថា អ្នកប្រាប់ដល់ភិក្ខុច្រើនរូបយ៉ាងនេះថា អាវុសោ ខ្ញុំមិនត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចរិយៈ មិនអាចបន្តព្រហ្មចរិយៈទៅបាន ខ្ញុំនឹងពោលលាសិក្ខាហើយសឹកពិតឬ ។ ព្រះនន្ទូទូលថា បពិត្រព្រះអង្គ ពិតយ៉ាងនោះហើយ ព្រះដ៏មានព្រះភាគត្រាស់ថា

ម្នាលនន្ទ អ្នកមិនត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចរិយៈ មិនអាចបន្តព្រហ្ម-
ចរិយៈទៅបាន នឹងពោលលាសិក្ខាសឹកទៅដើម្បីហេតុអ្វី ព្រះនន្ទពោលថា
បពិត្រព្រះអង្គ កាលខ្ញុំព្រះអង្គចេញចាកផ្ទះ នាងជនបទកល្យាណីសាកិយៈ
មានសក់មូរបានពាក់កណ្តាល បានផ្តាំពាក្យនេះនឹងខ្ញុំព្រះអង្គថា បពិត្រអយ្យ-
បុត្រ សូមអយ្យបុត្រប្រញាប់យាងមក បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនោះឯងរឭក
ដល់ពាក្យនោះ ទើបមិនត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចរិយៈ មិនអាចបន្ត
ព្រហ្មចរិយៈទៅបាន នឹងពោលលាសិក្ខា សឹកទៅ ។

គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ចាប់ព្រះនន្ទត្រង់ដើមដៃហើយ នាំ
ទៅកាន់តាវត្តិង្សទេវលោកដោយឫទ្ធិ ក្នុងរវាងផ្លូវ ទ្រង់បង្ហាញស្វាញី
មួយដែលមានត្រចៀក ច្រមុះ កន្ទុយជាច់អស់ អង្គុយត្រោមក្បាលជង្គង់
លើដង្គត់ឈើ ដែលភ្លើងឆេះ ត្រង់ស្រែដែលភ្លើងឆេះមួយកន្លែង ហើយទ្រង់
បង្ហាញស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាប ដែលមកកាន់ទី
បម្រើរបស់សក្កទេវរាជ ក្នុងតាវត្តិង្សពិភព ។

កាលទ្រង់បង្ហាញហើយ ត្រាស់យ៉ាងនេះថា ម្នាលនន្ទ អ្នកសម្គាល់
សេចក្តីនេះដូចម្តេច ចំណែកមួយណាមានរូបស្អាតជាង គួរមើលជាង គួរ
ជ្រះថ្លាជាង នាងជនបទកល្យាណីសាកិយៈ ឬស្រីទេពអប្សរ ៥០០ ដែលមាន
ជើងដូចជើងព្រាបនេះ ។ នន្ទបានស្តាប់ព្រះពុទ្ធតម្រាស់នោះហើយ ទូលថា
បពិត្រព្រះអង្គដ៏ចម្រើន ស្វាញីមានត្រចៀក ច្រមុះ និងកន្ទុយកំបុតនោះយ៉ាង
ណា បពិត្រព្រះអង្គដ៏ចម្រើន នាងជនបទកល្យាណីសាកិយៈក៏ដូចគ្នាដូច្នោះ

ព្រោះការប្រៀបធៀបគ្នា នាងរមែងមិនដល់នូវការរាប់ខ្លះ មិនដល់នូវមួយចម្រៀកខ្លះ មិនដល់ចំណែកមួយខ្លះនៃស្រីទេពអប្សរ ៥០០ នេះដោយពិត ស្រីទេពអប្សរ ៥០០ នេះឯងមានរូបស្អាតជាង គួរមើលជាង និងគួរជ្រះថ្លាជាង ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនន្ទ ចូរអ្នកត្រេកអរ ម្នាលនន្ទ ចូរអ្នកត្រេកអរ តថាគតនឹងជាទីជានារបស់អ្នក ដើម្បីបានចំពោះស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាប ព្រះនន្ទទូលថា បពិត្រព្រះអង្គ បើទ្រង់ជានាជាល់ខ្ញុំព្រះអង្គដើម្បីបានចំពោះនូវទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាបសោត បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងត្រេកអរក្នុងព្រហ្មចរិយៈ ។

គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់នាំនន្ទទៅបាត់អំពីទីនោះ ទៅប្រាកដក្នុងវត្តជេតពនវិញ ។

ភិក្ខុទាំងឡាយបានស្តាប់ហើយថា ព្រះនន្ទជាព្រះកាតារបស់ព្រះដ៏មានព្រះភាគ ឱរសរបស់ព្រះមាតុច្ឆា ប្រព្រឹត្តព្រហ្មចរិយៈ ព្រោះស្រីទេពអប្សរទាំងឡាយ បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់ជាអ្នកជានារបស់ព្រះនន្ទនោះ ដើម្បីបានចំពោះស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាប ។

គ្រានោះឯង ពួកភិក្ខុដែលជាសម្ភាញ់របស់ព្រះនន្ទ ហៅព្រះនន្ទដោយវាទៈថា ជាអ្នកស៊ីឈ្នួលខ្លះ ដោយវាទៈថា ជាបុគ្គលដែលព្រះដ៏មានព្រះភាគទ្រង់ជានាខ្លះថា បានឮថា ព្រះនន្ទជាកូនឈ្នួល បានឮថា ព្រះនន្ទ ព្រះសាស្តាទ្រង់ជានា ព្រះនន្ទប្រព្រឹត្តព្រហ្មចរិយៈ ព្រោះហេតុនៃស្រីទេពអប្សរ ៥០០

បានឮថា ព្រះដ៏មានព្រះភាគទ្រង់ជាបុគ្គលធានារបស់លោក ដើម្បីបានចំពោះនូវស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាប ។

គ្រានោះឯង ព្រះនន្ទមានការខ្មាសអៀន រង្កៀសដោយវាទៈថា ជាអ្នកស៊ីឈ្នួលខ្លះ ជាអ្នកដែលព្រះសាស្តាកក់ឲ្យខ្លះ របស់ពួកភិក្ខុទាំងឡាយ ជាបុគ្គលម្នាក់ឯងចៀសចេញទៅហើយ ជាអ្នកមិនប្រមាទ មានព្យាយាម មានខ្លួនបញ្ជូនទៅ ។ ចំណែរកាលមិនយូរឡើយ បានធ្វើឲ្យជាក់ច្បាស់នូវទីបំផុតនៃអគ្គព្រហ្មចរិយៈ ដែលកុលបុត្រអ្នកចេញចាកផ្ទះទាំងឡាយ បួសមិនមានផ្ទះដោយប្រពៃ ត្រូវការដោយការដឹងក្រៃលែងឯង សម្រេចហើយក្នុងទិដ្ឋធម៌ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញបាននៅចប់ហើយ កិច្ចដែលគួរធ្វើ អាត្មាអញធ្វើស្រេចហើយ កិច្ចដទៃដើម្បីភាពយ៉ាងនេះមិនមាន ។ ឈ្មោះថា ព្រះនន្ទបានជាព្រះអរហន្តមួយអង្គ ក្នុងបណ្តាព្រះអរហន្តទាំងឡាយ ។

គ្រានោះ ទេវតាមួយអង្គញ៉ាំងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ក្នុងចំណែកនៃរាត្រីហើយ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គ ព្រះនន្ទជាព្រះកាតារបស់ព្រះអង្គ ជាឱរសរបស់ម្ចាស់មីង ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ជាអ្នកមិនមានអាសវៈព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយការដឹងក្រៃលែងនេះឯង សម្រេចហើយក្នុងទិដ្ឋធម៌ ។ ញាណបានកើតឡើងដល់ព្រះដ៏មានព្រះភាគដូចគ្នាថា នន្ទធ្វើឲ្យជាក់ច្បាស់នូវចេតោ-វិមុត្តិ បញ្ញាវិមុត្តិ ជាអ្នកមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយការដឹងក្រៃលែងឯង សម្រេចហើយក្នុងទិដ្ឋធម៌ ព្រះនន្ទនោះ ដោយ

កន្ទងទៅនៃរាត្រីនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំហើយ បានក្រាបទូលពាក្យនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់ជាអ្នកធានារបស់ខ្ញុំព្រះអង្គ ដើម្បីបានចំពោះនូវស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាប ដោយការធានាណា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គដោះព្រះដ៏មានព្រះភាគអំពីការធានានោះ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនន្ទ សូម្បីតថាគតក៏កំណត់ចិត្តអ្នកដោយចិត្តរបស់តថាគត ដឹងហើយថា នន្ទធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយការដឹងក្រៃលែងឯង សម្រេចហើយក្នុងទិដ្ឋធម៌ សូម្បីទេវតាក៏ប្រាប់សេចក្តីនេះដល់តថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនន្ទធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ជាអ្នកមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយការដឹងក្រៃលែងឯង សម្រេចហើយក្នុងទិដ្ឋធម៌ ។ ម្នាលនន្ទ កាលណាចិត្តរបស់អ្នក ផុតហើយចាកអាសវៈទាំង-ឡាយ ព្រោះមានការមិនប្រកាន់មាំ កាលនោះ តថាគតក៏ផុតចាកការធានានោះ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ជ្រាបសេចក្តីនេះហើយ ទ្រង់បន្ទឺឧទាននេះក្នុងពេលនោះថា

ភិក្ខុណា បានឆ្លងកន់ គឺកាម បានញាំញីបង្វា គឺកាម
ភិក្ខុនោះ បានដល់នូវការអស់មោហៈ រមែងមិនញាប់ញ័រ
ព្រោះសុខ និងទុក្ខឡើយ ។

សម័យថ្ងៃមួយ ភិក្ខុទាំងឡាយសួរព្រះនន្ទថា អាវុសោនន្ទ កាលមុន

លោកម្ចាស់ពោលថា ខ្ញុំអផ្សុកហើយ ឥឡូវនេះ ចិត្តរបស់លោកម្ចាស់ជួចម្តេច ព្រះនន្ទូឆ្លើយថា អាវុសោ ការជាប់ជំពាក់ក្នុងភាពជាគ្រហស្ថរបស់ខ្ញុំមិនមាន ។ ពួកភិក្ខុបានស្តាប់ពាក្យនោះហើយ ពោលថា លោកម្ចាស់នន្ទូពោលមិនពិត រមែងព្យាករអរហត្តផលក្នុងថ្ងៃដែលកន្លងមកហើយថា ខ្ញុំជាអ្នកអផ្សុកហើយ តែឥឡូវនេះពោលថា ការជាប់ជំពាក់ក្នុងភាពជាគ្រហស្ថរបស់ខ្ញុំមិនមាន ដូច្នេះហើយ ក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃមុនអត្តភាពរបស់នន្ទូជួចគ្នានឹងផ្ទះដែលគេប្រក់មិនល្អ តែឥឡូវនេះជួចផ្ទះដែលគេប្រក់ល្អហើយ ព្រោះថា នន្ទូនេះតាំងអំពីកាលដែលខ្លួនឃើញស្រីទេពអប្សរហើយ ព្យាយាមដើម្បីសម្រេចទីបំផុតនៃកិច្ចរបស់បព្វជិត បានសម្រេចកិច្ចនោះហើយ ទ្រង់បានភាសិតព្រះគាថានេះថា

យថា អគារំ ទុច្ឆន្នំ វុដ្ឋី សមតិវិជ្ឈតិ
ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។
យថា អគារំ សុឆន្នំ វុដ្ឋី ន សមតិវិជ្ឈតិ
ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។

ផ្ទះដែលប្រក់ខ្វិខ្វាហើយ តំណក់ទឹកភ្លៀងរមែងលិចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុកហើយ រាគៈរមែងចាក់ជោតយ៉ាងនោះឯង ។ ផ្ទះដែលប្រក់ល្អហើយ តំណក់ទឹកភ្លៀងមិនលិចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ រាគៈរមែងមិនចាក់ជោតបាន យ៉ាងនោះឯង ។

បណ្តាបទទាំងនោះ បទថា **អគារំ** *គឺនូវផ្ទះប្រភេទណាមួយ ។*

បទថា **ទុច្ឆន្នំ** *គឺដែលប្រក់រង្វើលៗ មានប្រហោងតូចប្រហោងធំ ។*

បទថា **សមតិវិជ្ឈតិ** *គឺគ្រាប់ភ្លៀងរមែងលិចស្រោចបាន ។*

បទថា **អភាវិតំ** *ជាដើម សេចក្តីថា រាគៈរមែងចាក់ជោតចិត្ត ដែលឈ្មោះថា មិនបានអប់រំ ព្រោះជាធម្មជាតឆ្ងាយអំពីភាវនា ប្រៀបដូចភ្លៀងលិចស្រោចផ្ទះនោះបាន ដូច្នោះ មិនមែនតែរាគៈតែម្យ៉ាងប៉ុណ្ណោះទេ កិលេសទាំងពួង មានទោសៈ មោហៈ និងមានះជាដើម ក៏ចាក់ទម្លុះចិត្តបែបនោះដូចគ្នា ។*

បទថា **សុភាវិតំ** *បានដល់ ដែលអប់រំល្អហើយ ដោយសមថភាវនា និងវិបស្សនាភាវនា កិលេសទាំងឡាយ មានរាគៈជាដើម រមែងមិនអាចចាក់ជោតចិត្តបែបនោះបាន ដូចភ្លៀងមិនអាចលិចស្រោចផ្ទះដែលប្រក់ល្អហើយបាន ដូច្នោះ ។*

ក្នុងកាលចប់គាថា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ទេសនាបានសម្រេចប្រយោជន៍ដល់មហាជនហើយ ។

សម័យតមក ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោ ឈ្មោះថា ព្រះពុទ្ធទាំងឡាយជាអច្ឆរិយបុគ្គល ។ ព្រះនន្ទ ឈ្មោះថា អាស្រ័យនាងជនបទកល្យាណីអផ្សុកហើយ ព្រះសាស្តាទ្រង់ធ្វើពួកនាងទេពអប្សរ ឲ្យជាអាមិសដឹកនាំបានហើយ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំង-ទ្បាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំង

នោះក្រាបទូលថា ដោយកថាឈ្មោះនេះ ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ ក្នុងកាលមុន នន្ទនេះ តថាគតបានបញ្ឆោតដោយមាតុគ្រាមទូន្មានហើយដូចគ្នា ដូច្នេះហើយ កាលភិក្ខុនោះទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិក្នុងក្រុងពារាណសី មានឈ្មួញអ្នកក្រុងពារាណសីម្នាក់ឈ្មោះកប្បកៈ ។ លាវបស់ឈ្មួញនាំការៈបានមួយកុម្ភៈ លានោះដើរទៅបានមួយថ្ងៃ ៧ យោជន៍ ។ គ្រាមួយ ឈ្មួញនោះទៅកាន់នគរតក្កសិលា នាំការៈទៅដោយលា លែងលាឲ្យត្រាច់ទៅទម្រាំលក់ទ្រព្យរបស់អស់ ។ គ្រានោះ លាវបស់ឈ្មួញនោះត្រាច់ទៅលើខ្នងប្រឡាយ ជួបលាញីមួយ ទើបចូលទៅរក លាញីកាលធ្វើបដិសណ្ឋារៈជាមួយលាឈ្មោលនោះ ទើបពោលថា អ្នកមកអំពីណា លាឈ្មោលឆ្លើយថា ខ្ញុំមកពីនគរពារាណសី លាញីពោលថា អ្នកមកដោយកម្មអ្វី លាឈ្មោលឆ្លើយថា ដោយកម្មរបស់ឈ្មួញ លាញីពោលថា អ្នកនាំការៈទៅបានប៉ុន្មាន លាឈ្មោលឆ្លើយថា ប្រមាណមួយកុម្ភៈ លាញីពោលថា កាលនាំការៈប្រមាណប៉ុណ្ណោះទៅក្នុងទីប៉ុន្មានយោជន៍ លាឈ្មោលឆ្លើយថា បាន ៧ យោជន៍ លាញីពោលថា ក្នុងទីដែលអ្នកទៅហើយ លាញីណាមួយធ្វើការគក់ច្របាច់ជើងឬបម្រើអ្នក មានដែរឬ លាឈ្មោលឆ្លើយថា មិនមានឡើយ លាញីពោលថា បើដូច្នោះ អ្នកប្រហែលជាបានទទួលសេចក្តីទុក្ខច្រើន ។

ពិតហើយ ឈ្មោះថា កម្មមានការគក់ជើងជាដើម សម្រាប់សត្វតិរច្ឆាន

ទាំងឡាយ រមែងមិនមានដោយពិត តែលាញីពោលពាក្យបែបនោះ ដើម្បីអាស្រ័យដល់កាមសំយោជនៈ ។ លានោះ អផ្សុកដោយពាក្យរបស់លាញីនោះហើយ ។

ចំណែកកប្បកពាណិជ្ជលក់ភណ្ឌៈអស់ហើយ ទៅកាន់ទីដែលលាស្នាក់នៅ ពោលថា នែបា អ្នកចូរមកចុះ យើងនឹងទៅ លាឈ្មោលនោះឆ្លើយថា ចូរលោកទៅចុះ ខ្ញុំមិនទាន់ទៅទ្បើយ លំដាប់នោះ នាយកប្បកៈអង្វរលានោះហើយអង្វរទៀត គិតថា អញនឹងញុំាងលានោះ ដែលមិនប្រុងប្នាទៅឲ្យខ្លាចហើយ នឹងនាំទៅ ដូច្នេះហើយ ពោលនូវគាថានេះថា

ខ្ញុំនឹងធ្វើជន្ធញមានមុខស្រួច ប្រវែង ១៦ ធ្នាប់ដល់អ្នក ហើយចាក់ទម្លុះកាយរបស់អ្នក នែលា ឯងចូរដឹងយ៉ាងនេះ លាបានស្តាប់ពាក្យនោះហើយឆ្លើយថា កាលបើដូច្នោះ ខ្ញុំនឹងដឹងកិច្ចដែលគួរធ្វើដល់អ្នកដែរ ដូច្នេះហើយពោលគាថានេះថា

> *បើអ្នកធ្វើជន្ធញមានមុខស្រួចប្រវែង ១៦ ធ្នាប់ដល់ខ្ញុំ ខ្ញុំនឹងសង្កត់ខាងមុខ លើកខាងក្រោយទ្បើងហើយ ធ្វើភណ្ឌៈរបស់អ្នកឲ្យធ្លាក់ទៅ នែកប្បកៈ អ្នកចូរដឹងយ៉ាងនេះ ។*

ឈ្លួញបានស្តាប់ពាក្យនោះ ទើបត្រិះរិះថា ដោយហេតុអ្វីហ្ន៎ ទើបលានេះពោលយ៉ាងនេះដាក់អញ ដូច្នេះហើយ កាលក្រឡេកមើលឆ្វេង-ស្តាំ ឃើញលាញីនោះហើយ គិតថា លានេះ គង់ត្រូវលាញីនេះឲ្យសិក្សាហើយយ៉ាងនេះ អញត្រូវបញ្ឆោតលានេះ ដោយមាតុគ្រាមថា ខ្ញុំនឹងនាំលាមានរូប

យ៉ាងនេះមកឲ្យអ្នក ហើយនឹងនាំទៅ ដូច្នេះហើយ ទើបពោលគាថានេះថា

ខ្ញុំនឹងនាំលាក្រមុំមានជើងបួន មានមុខដូចសង្ខ មានកាយសព្វអន្ទើស្អាត មកជាភរិយាអ្នក នែលា អ្នកចូរដឹងយ៉ាងនេះ ។ លាបានស្តាប់ពាក្យនោះមានចិត្តត្រេកអរ ពោលគាថានេះថា

អ្នកនឹងនាំលាញីក្រមុំមានជើងបួន មានមុខដូចសង្ខ មានសរីរៈស្អាត មកជាប្រពន្ធរបស់ខ្ញុំ នែកប្បកៈ អ្នកចូរដឹងយ៉ាងនេះ ខ្ញុំនឹងទៅឲ្យរហ័ស រហូត ១៤ យោជន៍ ។

ពេលនោះ ទើបនាយកប្បក:ពោលនឹងលានោះថា បើដូច្នោះ អ្នកចូរមកចុះ ដូច្នេះហើយ បានដឹកទៅកាន់ទីរបស់ខ្លួន ។ លានោះ ដោយកាលកន្លង ទៅ ២-៣ ថ្ងៃទើបពោលនឹងនាយកប្បក:ថា អ្នកបានពោលនឹងខ្ញុំថា នឹងនាំភរិយាមកឲ្យខ្ញុំ ដូច្នេះ មិនមែនឬ នាយកប្បក:ឆ្លើយថា អើ ខ្ញុំពោលហើយ ខ្ញុំនឹងមិនទម្លាយពាក្យរបស់ខ្លួន នឹងនាំភរិយាមកឲ្យអ្នក តែខ្ញុំឲ្យអាហារដល់អ្នកមួយចំណែក អាហារនោះចូរគ្រប់គ្រាន់ដល់អ្នក ដែលមានខ្លួនជាគម្រប់ពីរ ឬមិនគ្រប់គ្រាន់ក្តី អ្នកគប្បីដឹងខ្លួនឯងចុះ សូម្បីកូនទាំងឡាយអាស្រ័យសង្វាសរបស់អ្នកទាំងពីរក៏នឹងកើតឡើង អាហារនោះ ចូរគ្រប់គ្រាន់ដល់អ្នកនិងកូនជាច្រើននោះ ឬមិនគ្រប់ក្តី អ្នកគប្បីដឹងឯងចុះ ។ លាកាលនាយកប្បក:នោះ ពោលយ៉ាងនោះ បានជាអ្នកអស់សេចក្តីប្រាថ្នាហើយ ។

ព្រះសាស្តា កាលនាំព្រះធម្មទេសនានេះមកហើយ ទ្រង់ញុំាងជាតកឲ្យចប់ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាញីក្នុងកាលនោះ បានជា

នាងជនបទកល្យាណី លោឈ្មោលបានជានន្ទ ចំណែកឈ្មួញ បានជាតថាគត នេះឯង ។ ក្នុងកាលមុន នន្ទនេះ តថាគតក៏បានបញ្ឆោតដោយមាតុគ្រាមទុន្ទាន ហើយ ដោយប្រការយ៉ាងនេះ ។

រឿង ព្រះនន្ទត្ថេរ ចប់

រឿង នាយចុន្ទសូករិកៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបុរស ឈ្មោះចុន្ទ-សូករិកៈ ត្រាស់ធម្មទេសនានេះថា **៨ឆ សោចតិ បេច្ច សោចតិ** *ជាដើម ។*

បានឮថា នាយចុន្ទសូករិកៈនោះ សម្លាប់ជ្រូកទាំងឡាយបរិភោគខ្លះ លក់ដូរខ្លះ ចិញ្ចឹមជីវិតអស់ ៥៥ ឆ្នាំ ។ ក្នុងពេលស្រូវថ្លៃ គាត់យករនេះជីកស្រូវទៅកាន់ជនបទ ដូរកូនជ្រូកស្រុកដោយស្រូវប្រមាណមួយនាឡិ ឬពីរនាឡិ ដាក់ពេញរនេះហើយត្រឡប់មក ព័ទ្ធទីមួយកន្លែងដូចក្រោល ខាងក្រោយលំនៅ ហើយដាំបន្លែក្នុងទីនោះឯង ដើម្បីកូនជ្រូកទាំងនោះ ។ កាលកូនជ្រូកទាំងនោះ ស៊ីបន្លែផ្សេងៗ ខ្លះ សរីរវិលជ្រះ គឺលាមកខ្លះ ក៏ធំចម្រើនឡើង ។ គាត់ប្រាថ្នាសម្លាប់ជ្រូកណាក៏ចងជ្រូកនោះឲ្យណែន ក្នុងទីដែលសម្លាប់ ហើយវាយដោយជំបងបួនជ្រុង ដើម្បីឲ្យសាច់ជ្រូកប៉ោងធំឡើង ដឹងថា សាច់ប៉ោងក្រាស់ហើយ ក៏ខ្ចាស់មាត់ដោយឈើទៅក្នុងចន្ទោះធ្មេញ ច្រកទឹកក្តៅដែលក្តៅខ្លាំង ចូលទៅ

ក្នុងមាត់ដោយនាឡិលោហៈ ។ ទឹកក្តៅនោះចូលទៅក្នុងពោះ ក៏ហូរចេញមកដោយចំណែកខាងក្រោម គឺតាមទ្វារធំ ករីសៈតូចមួយ នៅមានជរាបណារមែងជាទឹកល្អក់ជរាបនោះ កាលពោះស្អាតហើយ ទើបចេញទឹកថ្លាមិនល្អក់ពេលនោះ ទើបគាត់ស្រោចទឹកក្តៅដែលសល់លើស្បែកជ្រូកនោះ ទឹកនោះក៏បកយកស្បែកខ្មៅចេញទៅ បន្ទាប់អំពីនោះ ទើបរោលរោមដោយគប់ស្មៅហើយកាត់ក្បាលដោយដាវដ៏មុត ត្រង់ឈាមដែលហូរចេញដោយភាជន៍ លាបសាច់ដោយឈាមហើយ អាំងអង្គុយបរិភោគក្នុងកណ្តាលបុត្រ និងភរិយាលក់ចំណែកដែលសល់ ។ គាត់ចិញ្ចឹមជីវិតដោយទំនងនេះឯង អស់កាលកន្ទងទៅ ៥៥ ឆ្នាំ ។ កាលព្រះតថាគតប្រថាប់នៅក្នុងធុរវិហារ ការបូជាដោយផ្កាត្រឹមតែមួយក្តាប់ក្តី ការថ្វាយភិក្ខាត្រឹមតែមួយវែកក្តី ឈ្មោះថា បុណ្យជនៃតិចតួចក្តី មិនមានហើយ ត្រឹមមួយថ្ងៃ ។

គ្រានោះ រោគកើតឡើងក្នុងសរីរៈរបស់គាត់ ការក្តៅក្រហាយអំពីអវីចីមហានរកជ្រោកជជល់គាត់ទាំងរស់នោះឯង ។

ឈ្មោះថា កម្តៅក្នុងអវីចី រមែងជាកម្តៅដែលអាចទម្លាយភ្នែករបស់បុគ្គលដែលឈរមើលក្នុងទីប្រមាណ ១០០ យោជន៍បាន សមដូចពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ដូច្នេះថា មានភ្លើងធេះច្រាលរន្ទាល ផ្សាយទៅបានមួយរយយោជន៍ជុំវិញ តាំងនៅសព្វៗ កាល ។

ព្រោះហេតុដែលកម្តៅក្នុងអវីចីនោះ មានប្រមាណក្រៃលែងជាងកម្តៅរបស់ភ្លើងដោយប្រក្រតី ទើបព្រះនាគសេនត្ថេរពោលឧបមានេះថា បពិត្រ

មហារាជ ដុំថ្មប្រមាណប៉ុនផ្ទះកំពូលដែលបុគ្គលទម្លាក់ទៅក្នុងភ្លើងនរក រមែងជល់នូវការរលាយបាន ដោយខណៈមួយ យ៉ាងណា ចំណែកសត្វដែលកើតក្នុងនរកនោះ ប្រៀបដូចនៅក្នុងគភ៌មាតា ទីងរលួយទៅ ព្រោះកម្លាំងនៃកម្មដូច្នោះ ក៏មិនមែន ។

កាលការក្តៅក្រហាយនោះ ប្រាកដជល់នាយចុន្ទសូករិកៈនោះហើយ អាការដែលសមគួរជល់កម្មក៏កើតឡើង គាត់ស្រែកសំឡេងដូចជ្រូក រារជើង ៤ ទៅក្នុងផ្ទះនោះឯង ទៅកាន់ទិសខាងកើតខ្លះ ទៅកាន់ទិសខាងលិចខ្លះ ។

លំដាប់នោះ ពួកមនុស្សក្នុងផ្ទះចាប់គាត់ ហើយបិទមាត់ ធម្មតាផលនៃកម្ម បុគ្គលណាម្នាក់មិនអាចនឹងហាមបាន គាត់នៅត្រាច់ស្រែកទៅខាងនោះខ្លះ ខាងនេះខ្លះ មនុស្សក្នុងផ្ទះ ៧ ខ្នងដោយជុំវិញ មិនបានដេកលក់ ម្យ៉ាងទៀត មនុស្សក្នុងផ្ទះទាំងអស់ កាលមិនអាចហាមការចេញទៅខាងក្រៅរបស់គាត់ ដែលត្រូវមរណភ័យគំរាមហើយបាន ទើបបិទទ្វារផ្ទះ រក្សានៅក្នុងផ្ទះដោយប្រការដែលគាត់នៅខាងក្នុង មិនអាចត្រាច់ទៅខាងក្រៅបាន ។

នាយចុន្ទសូករិកៈ ត្រាច់ស្រែកទៅខាងនោះខ្លះ ខាងនេះខ្លះ ខាងក្នុងផ្ទះនោះឯង ដោយកម្តៅក្នុងនរក គាត់ត្រាច់ទៅយ៉ាងនោះអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៨ ធ្វើកាលកិរិយាហើយ ទៅកើតក្នុងអវីចីមហានរក ។ អវីចីមហានរកអ្នកប្រាជ្ញ គប្បីពណ៌នាតាមនេរយិកសូត្រ ។

ភិក្ខុនិមន្តទៅតាមទ្វារផ្ទះរបស់គាត់ បានឮសំឡេងនោះហើយ ជាអ្នកមានសេចក្តីសម្គាល់ថាសំឡេងជ្រូក ទៅកាន់វិហារ អង្គុយក្នុងសម្នាក់ព្រះសាស្តា

ហើយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលសូករៈទាំងឡាយ ដែលនាយចុន្ទសូករិកៈបិទទ្វារផ្ទះសម្ងាប់ ថ្ងៃនេះជាថ្ងៃទី ៧ មង្គលកិរិយាណា មួយប្រហែលនឹងមានក្នុងផ្ទះរបស់គាត់ ។ បពិត្រព្រះអង្គដ៏ចម្រើន មេត្តាចិត្ត ឬសេចក្តីករុណាណាមួយរបស់គាត់ ដែលសម្ងាប់ជ្រូកទាំងឡាយមានប្រមាណ ប៉ុណ្ណោះ រមែងមិនមាន សត្វដែលកាចសាហាវបែបនេះ ខ្ញុំព្រះអង្គទាំងឡាយ មិនធ្លាប់ឃើញឡើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គាត់មិនមែនសម្ងាប់ជ្រូកអស់ ៧ ថ្ងៃនេះឡើយ ផលដែលសមគួរដោយកម្មកើតឡើងហើយដល់បុគ្គលនោះ ការក្តៅក្រហាយក្នុងអវីចីមហានរក ជ្រាកដជាដល់គាត់ទាំងរស់នោះឯង ដោយការក្តៅក្រហាយនោះ គាត់ស្រែកដូចជ្រូក ត្រាច់ទៅខាងក្នុងនិវេសន៍អស់ ៧ ថ្ងៃ ថ្ងៃនេះធ្វើកាលកិរិយាទៅកើតក្នុងអវីចី ។ កាលភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ កាលគាត់សោយសោកយ៉ាងនេះ ក្នុងលោកនេះហើយ នឹងទៅកើតក្នុងឋានៈដែលជាទីសោយសោកដូច្នេះទៀតឬ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ឈ្មោះថា បុគ្គលប្រមាទហើយ ជាគ្រហស្ថក្តី បព្វជិតក្តី រមែងសោយសោកក្នុងលោកទាំងពីរពិត ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ឥធ សោចតិ បេច្ច សោចតិ ទុព្ភយត្ត សោចតិ
សោ សោចតិ សោ វិហញ្ញតិ ទិស្វា កម្មកិលិដ្ឋមត្តនោ ។

បុគ្គលអ្នកធ្វើបាប តែងសោកស្តាយក្នុងលោកទាំងពីរ គឺសោក

ស្តាយក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែង
សោកស្តាយក្តៅក្រហាយ ព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ចាបការី** *ជាដើម សេចក្តីថា បុគ្គលធ្វើបាប មានប្រការផ្សេងៗ រមែងសោកស្តាយក្នុងលោកនេះ ក្នុងសម័យជិតស្លាប់ ដោយចំណែកមួយពិត ដោយគិតថា កម្មល្អអញមិនបានធ្វើហ្ន៎ កម្មអាក្រក់ អញបានធ្វើហើយ នេះជាការសោកស្តាយព្រោះកម្មរបស់បុគ្គលនោះ កាលបុគ្គលនោះសោយផល ស្លាប់ទៅហើយ រមែងសោកស្តាយ នេះជាការសោកស្តាយ ព្រោះវិបាកក្នុងលោកខាងមុខរបស់បុគ្គលនោះ បុគ្គលនោះ រមែងសោកស្តាយ ក្នុងលោកទាំងពីរយ៉ាងនេះឯង ដោយហេតុនោះឯង នាយចុន្ទ-សូករិកៈនោះ ឈ្មោះថា សោកស្តាយទាំងរស់នោះឯង ។*

បាទព្រះគាថាថា **ឯិស្សា កម្មកិលិដ្ឋមត្តនោ** *សេចក្តីថា បុគ្គលនោះ ឃើញកម្មសៅហ្មងរបស់ខ្លួនហើយ តែងសោកស្តាយ រវើរវាយមានប្រការផ្សេងៗ ឈ្មោះថា រមែងក្តៅក្រហាយ គឺរមែងលំបាក ។*

ក្នុងកាលចប់ទេសនា ភិក្ខុជ័ច្រើន បានជាព្រះសោតាបន្នជាដើម ហើយទេសនាមានប្រយោជន៍ ដល់មហាជនហើយ ដូច្នេះឯង ॥

រឿង នាយចុន្ទសូករិកៈ ចប់

រឿង ធម្មិកឧបាសក

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រោរព្ធធម្មិកឧបាសក ត្រាស់ធម្មទេសនានេះថា **ឥធ មោទតិ បេច្ច មោទតិ** ជាដើម ។

បានឮថា ក្នុងនគរសាវត្ថី មានឧបាសកអ្នកបដិបត្តិធម៌ប្រមាណ ៥០០ នាក់ បណ្តាឧបាសកទាំងនោះ ម្នាក់ៗ មានឧបាសក ៥០០ ជាបរិវារ ។ ឧបាសក ដែលជាប្រធាននៃឧបាសកទាំងនោះ មានកូនប្រុស ៧ នាក់ កូនស្រី ៧ នាក់ ។ បណ្តាកូនប្រុស និងកូនស្រីទាំងនោះ ម្នាក់ៗ មានសលាកយាគូ សលាកភត្ត បក្ខិកភត្ត សង្ឃភត្ត ឧបោសថិកភត្ត អាគន្តុកភត្ត វេស្សាវាសិក-ភត្ត មួយមុខមួយសម្រាប់ ។ ជនទាំងនោះ បានជាបុគ្គលឈ្មោះថា អនុ-ជាតបុត្រទាំងអស់នោះឯង សលាកយាគូជាដើមមួយសម្រាប់ គឺរបស់កូន ១៤ នាក់ របស់ភរិយាមួយ របស់ឧបាសកមួយ រមែងប្រព្រឹត្តទៅ ដោយប្រការដូច្នេះ ។ គាត់ មួយអន្លើដោយបុត្រ និងភរិយា បានជាអ្នកមានសីល មានកល្យាណធម៌ មានការត្រេកអរក្នុងការឲ្យទាន ដោយប្រការដូច្នេះ ។ ចំណែរកាលតមក រោគកើតឡើងដល់ឧបាសក អាយុសង្ខារអស់ទៅ ដោយជុំវិញហើយ ។

គាត់ប្រាថ្នានឹងស្តាប់ធម៌ ទើបបញ្ជូនមនុស្សទៅកាន់សម្នាក់ព្រះសាស្តា ដោយក្រាបទូលថា សូមទ្រង់បញ្ជូនភិក្ខុ ៨ រូប ឬ ១៦ រូប ដល់ខ្ញុំព្រះអង្គ ។

ព្រះសាស្តាទ្រង់បញ្ជូនភិក្ខុទាំងឡាយទៅ ភិក្ខុទាំងនោះទៅហើយ អង្គុយ

លើអាសនៈ ដែលគេតាក់តែងជុំវិញគ្រែរបស់គាត់ កាលគាត់ពោលថា បពិត្រលោកម្ចាស់ ការឃើញលោកម្ចាស់ទាំងឡាយ របស់ខ្ញុំបានដោយលំបាក ខ្ញុំជាបុគ្គលទុព្វលភាព សូមលោកម្ចាស់ទាំងឡាយ ស្វាធ្យាយព្រះសូត្រមួយ ប្រោសខ្ញុំចុះ ។

ទើបភិក្ខុទាំងឡាយសួរថា អ្នកបំណងនឹងស្តាប់សូត្រណា កាលគាត់ប្រាប់ថា សតិប្បដ្ឋានសូត្រដែលព្រះពុទ្ធគ្រប់អង្គទ្រង់មិនលះបង់ ។ ទើបផ្តើមសូធ្យព្រះសូត្រថា **ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា** *ជាដើម ។*

ខណៈនោះ រថ ៦ គ្រឿង ប្រដាប់ដោយអលង្ការគ្រប់យ៉ាង ទឹមដោយសេះសិន្ធពមួយពាន់ ទំហំប្រមាណ ១៥០ យោជន៍ មកអំពីទេវលោក ៦ ជាន់ ។ ទេវតាឈរនៅលើរថទាំងនោះ អញ្ជើញថា ខ្ញុំនឹងនាំទៅកាន់ទេវលោករបស់ខ្ញុំ ខ្ញុំនឹងនាំទៅកាន់ទេវលោករបស់ខ្ញុំ អ្នកដ៏ចម្រើន ចូរកើតក្នុងទីនេះ ដើម្បីការត្រេកអរក្នុងទេវលោករបស់ខ្ញុំ ដូចបុគ្គលទម្លាយនូវភាជន៍ដី ហើយកាន់យកភាជន៍មាស ។

ឧបាសកមិនប្រាថ្នាឲ្យអន្តរាយដល់ការស្តាប់ធម៌ ទើបពោលថា អ្នកទាំងឡាយ ចូរបង្អង់សិន អ្នកទាំងឡាយ ចូរបង្អង់សិន ។

ភិក្ខុឈប់ស្ងៀមព្រោះយល់ថា ឧបាសកនិយាយជាមួយពួកលោក គ្រានោះ កូនប្រុស និងកូនស្រីរបស់គាត់គិតថា ឪពុករបស់ពួកយើង ក្នុងកាលមុន ជាអ្នកមិនឆ្អែតដោយការស្តាប់ធម៌ តែឥឡូវនេះ ឲ្យនិមន្តភិក្ខុមកធ្វើការ

ស្វាធ្យាយហើយ ហាមឃាត់ដោយខ្លួនឯង ឈ្មោះថា សត្វដែលមិនខ្លាចចំពោះមរណៈ មិនមានហ្ន៎ ដូច្នេះហើយ ទើបទ្រហោយំ ពួកភិក្ខុប្រឹក្សាគ្នាថា ឥឡូវនេះ មិនជាឱកាសហើយ ទើបក្រោកចាកអាសនៈចៀសចេញទៅ ឧបាសកញ៉ាំងកាលបន្តិចឲ្យកន្លងទៅហើយ ក៏បានទូវស្សារតី សួរកូនទាំងឡាយថា ព្រោះហេតុអ្វី ទើបពួកអ្នកយំសោក ទើបពួកកូនជ្រាប់ថា ពុកឲ្យនិមន្តភិក្ខុមកហើយស្តាប់ធម៌ បែរជាហាមឃាត់ដោយខ្លួនឯង កាលបើដូច្នោះ ទើបពួកខ្ញុំគិតថា ឈ្មោះថា សត្វមិនខ្លាចចំពោះមរណៈមិនមាន ដូច្នេះ ទើបយំសោក ។ ឧបាសកសួរថា ចុះលោកម្ចាស់ទាំងឡាយនិមន្តទៅឯណា កូនទាំងឡាយឆ្លើយថា បពិត្រលោកឪពុក ពួកលោកម្ចាស់ទាំងឡាយនិយាយគ្នាថា មិនជាឱកាស ក្រោកចាកអាសនៈ ចៀសចេញទៅហើយ ។ ឧបាសកពោលថា ឪពុកមិនបានពោលជាមួយលោកម្ចាស់ទាំងឡាយឡើយ កូនសួរថា បើដូច្នោះ លោកឪពុកនិយាយជាមួយអ្នកណា ។ ឧបាសកពោលថា ទេវតាតាក់តែងរថ ៦ គ្រឿង នាំមកអំពីទេវលោក ៦ ជាន់ ឈប់នៅក្នុងអាកាស បន្ទឺសំឡេងថា ចូរអ្នកត្រេកអរក្នុងទេវលោករបស់ខ្ញុំ ចូរអ្នកត្រេកអរក្នុងទេវលោករបស់ខ្ញុំ ឪពុកនិយាយជាមួយទេវតាទាំងនោះទេតើ ។ កូនពោលថា បពិត្រលោកឪពុក តើរថនៅឯណា ពួកខ្ញុំមើលមិនឃើញឡើយ ឧបាសកពោលថា តើកម្រងផ្កាដែលជោតជាកម្រងដើម្បីពុក មានដែរឬទេ កូនពោលថា មាន ឧបាសកពោលថា ទេវលោកជាន់ណាគួរ ជាទីត្រេកអរ កូនពោលថា តុសិតពិភព ជាទីប្រថាប់នៅរបស់ព្រះពោធិសត្វគ្រប់អង្គ របស់ព្រះពុទ្ធ-

មាតា និងរបស់ព្រះពុទ្ធបិតា ជាទីត្រេកអរ ។

ឧបាសកពោលថា បើដូច្នោះ ពួកអ្នកចូរបន្ទឺសំឡេងថា សូមកម្រងផ្កាជាប់ត្រង់រថដែលមកអំពីស្ថានតុសិត ដូច្នេះហើយ ចោះកម្រងផ្កាទៅចុះ ។

កូនទាំងនោះ បានចោះទៅហើយ កម្រងផ្កានោះ បានទៅត្រង់ចន្ទោលសំយុងចុះក្នុងអាកាស ។ មហាជនឃើញតែកម្រងផ្កានោះមិនឃើញរថឡើយ ។ ឧបាសកពោលថា អ្នកទាំងឡាយឃើញកម្រងផ្កានោះទេ កាលបុត្រឆ្លើយថា ឃើញ ទើបពោលថា កម្រងផ្កានោះជាប់ត្រង់រថដែលមកអំពីតុសិត ឪពុកនឹងទៅកាន់ស្ថានតុសិត ពួកអ្នកកុំត្រិះរិះថ្ងីឡើយ ពួកអ្នកមានសេចក្តីជ្រាបថ្លាកើតក្នុងសម្លាក់ឪពុក ក៏ចូរធ្វើបុណ្យទាំងឡាយ តាមទំនងដែលឪពុកធ្វើហើយចុះ ដូច្នេះហើយ ធ្វើកាលកិរិយាតាំងនៅលើរថដែលមកអំពីស្ថានតុសិត ។ អត្តភាពរបស់គាត់ កម្ពស់ប្រមាណ ៣ គាវុត ប្រដាប់ដោយអលង្ការទម្ងន់ ៦០ រនេះ កើតក្នុងវិមានប្រមាណ ២៥ យោជន៍ជ្រោកជហើយ ។

ព្រះសាស្តាត្រាស់សួរភិក្ខុទាំងនោះ ដែលមកដល់វិហារហើយ ដោយលំដាប់ថា ម្នាលភិក្ខុទាំងឡាយ ឧបាសកបានស្តាប់ធម្មទេសនាហើយឬ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ស្តាប់ហើយ តែឧបាសកបានឃាត់ក្នុងចន្ទោះនោះឯងថា សូមអ្នកឈប់បង្អង់សិន លំដាប់នោះ បុត្រ និងធីតារបស់ឧបាសកនោះកន្ទក់កន្ទេញហើយ ពួកខ្ញុំព្រះអង្គប្រឹក្សាគ្នាថា ឥឡូវនេះមិនជាឱកាស ទើបក្រោកចាកអាសនៈចេញមក ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបាសកនោះមិនពោលជាមួយអ្នកឡើយ តែទេវតាតាក់តែងរថ ៦ គ្រឿងនាំមកអំពីទេវលោក ៦ ជាន់ អញ្ជើញឧបាសកនោះហើយ គាត់មិនជ្រាបថានឹងធ្វើអន្តរាយដល់ការសម្តែងធម៌ ទើបពោលនឹងទេវតាទាំងនោះ ភិក្ខុទាំងឡាយទូលថា យ៉ាងនោះឬព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ភិក្ខុទាំងឡាយក្រាបទូលថា ឥឡូវនេះ តើគាត់កើតហើយក្នុងទីណា ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ ក្នុងស្ថានតុសិត ភិក្ខុទាំងឡាយសួរថា បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកនោះ ត្រេកអរក្នុងកណ្តាលជុំនំញាតិក្នុងលោកនេះហើយ កើតក្នុងស្ថានដែលជាទីត្រេកអរនោះទៀតឬ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ព្រោះបុគ្គលមិនប្រមាទហើយទាំងឡាយ ជាគ្រហស្ថក្តី ជាបព្វជិតក្តី រមែងត្រេកអរក្នុងទីទាំងពួងនោះឯង ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ឥធ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ
សោ មោទតិ សោ បមោទតិ ទិស្វា កម្មវិសុទ្ធិមត្តនោ ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំងពីរគឺរីករាយក្នុងលោកនេះ ១ រីករាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កតបុញ្ញោ** *ជាដើម សេចក្តីថា បុគ្គលធ្វើ*

កុសលមានប្រការផ្សេងៗ រមែងត្រេកអរដោយការត្រេកអរ ព្រោះកម្មក្នុងលោកនេះថា កម្មអាក្រក់អញមិនបានធ្វើឡើយ កម្មល្អ អញធ្វើហើយហ្ន៎ ។ លុះលោកនេះទៅហើយ រមែងត្រេកអរដោយការត្រេកអរព្រោះវិបាក ឈ្មោះថា រមែងត្រេកអរក្នុងលោកទាំងពីរយ៉ាងនេះ ។

បទថា **កម្មវិសុទ្ធឹ** *ជាដើម សេចក្តីថា ធម្មិកឧបាសកឃើញកម្មដែលបរិសុទ្ធ គឺការដល់ព្រមនៃបុញ្ញកម្មរបស់ខ្លួនហើយ មុនធ្វើកាលកិរិយា រមែងត្រេកអរក្នុងលោកនេះ ធ្វើកាលកិរិយាហើយ ឥឡូវនេះ ក៏រមែងត្រេកអរ គឺត្រេកអរក្រៃលែងក្នុងលោកខាងមុខ ។*

ក្នុងកាលចប់គាថា ជនទាំងឡាយដ៏ច្រើនបានជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម ។ ព្រះធម្មទេសនា មានប្រយោជន៍ដល់មហាជនជួបច្នេះឯង ។

រឿង ធម្មិកឧបាសក ចប់

រឿង ភិក្ខុទេវទត្ត

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធទេវទត្តភិក្ខុ ត្រាស់ធម្មទេសនានេះថា **ឥធ តប្បតិ បេច្ច តប្បតិ** *ជាដើម ។*

រឿងទេវទត្តភិក្ខុ ព្រះសាស្តាត្រាស់ជាតកទាំងអស់ ដែលទ្រង់ប្រារព្ធ

ទេវទត្តឲ្យពិស្តារហើយ តាំងអំពីពេលបួសរហូតដល់ផែនដីស្រូប ឯសេចក្តីសង្ខេបក្នុងរឿងទេវទត្តកិក្ខុនេះ ដូចតទៅនេះ

កាលព្រះសាស្តាទ្រង់អាស្រ័យនិគម ឈ្មោះអនុបិយនៃមលក្សត្រ ប្រថាប់នៅក្នុងអនុបិយអម្ពវនោះឯង ។ ក្នុងថ្ងៃទទួលព្រះលក្ខណៈនៃព្រះតថាគតនោះឯង ត្រកូលព្រះញាតិ ៨ ម៉ឺន ប្រគាល់ព្រះឱរស ៨ ម៉ឺនឲ្យដោយពាក្យថា សុទ្ធត្តកុមារ ទោះជាព្រះរាជាក៏ដោយ ជាព្រះពុទ្ធក៏ដោយ នឹងមានស្តេចជាបរិវារត្រាច់ទៅ កាលព្រះឱរសទាំងនោះបួសហើយដោយច្រើន ពួកព្រះញាតិឃើញសក្យៈ ៦ អង្គ គឺភទ្ទិយៈ អនុរុទ្ធ អានន្ទ ភគុ កិម្ពិលៈ ទេវទត្ត មិនទាន់បានបួសទើបសន្ទនាគ្នាថា ពួកយើងគង់ឲ្យកូនរបស់ខ្លួនបួស បានសក្យៈទាំង ៦ នេះប្រហែលមិនមែនព្រះញាតិទេដឹង ព្រោះដូច្នោះទើបមិនបានបួស ។

គ្រានោះ មហានាមសក្យៈចូលទៅរកអនុរុទ្ធត្រាស់ថា នែបា បុគ្គលចេញចាកត្រកូលបួសក្នុងត្រកូលរបស់យើងមិនមាន ឬនបួស ឬបងនឹងបួស ។ អនុរុទ្ធកុមារនោះជាស្តេចសុខុមាលជាតិ មានភោគៈសម្បូរ សូម្បីពាក្យថាមិនមាន ទ្រង់ក៏មិនធ្លាប់ឮ ។ ពិតហើយ ថ្ងៃមួយ កាលក្សត្រ ៦ អង្គនោះទ្រង់លេងកីឡាជោះឡូ អនុរុទ្ធទ្រង់ចាញ់ដោយនំហើយ បញ្ជូនមនុស្សទៅដើម្បីត្រៀវការនំ គ្រានោះ ព្រះមាតារបស់លោក ទ្រង់បញ្ជូននំទៅ ក្សត្រទាំងឡាយសោយហើយទាំគ្នាលេងទៀត អនុរុទ្ធនោះឯងជាអ្នកចាញ់រហូតទៅ ចំណែកព្រះមាតា កាលទ្រង់បញ្ជូនមនុស្សទៅក៏បញ្ជូននំទៅអស់បីដង ក្នុងវារៈទី ៤ បញ្ជូនទៅថា នំមិនមាន ព្រះកុមារទ្រង់សម្គាល់ថា នំនេះប្រហែល

ជានំប្រភេទណាមួយ ព្រោះមិនធ្លាប់បានឮពាក្យថា មិនមាន ទើបទ្រង់បញ្ជូនមនុស្សទៅថា ចូរនាំនំមិនមាននោះមកចុះ ។

ចំណែកព្រះមាតារបស់លោក កាលមនុស្សទូលថា បពិត្រព្រះនាង បានឮថា ព្រះនាងទ្រង់ប្រទាននំមិនមាន ។ ទើបព្រះនាងព្រះតម្រិះរិះថា កូនរបស់អញមិនធ្លាប់បានឮពាក្យថាមិនមាន តែអញនឹងឲ្យដឹងសេចក្តីនោះដោយឧបាយនេះ ទើបទ្រង់គ្រប់ថាសមាសទទេដោយថាសមាសដទៃ ហើយបញ្ជូនទៅ ។

ពួកទេវតាដែលរក្សាព្រះនគរគិតថា អនុរុទ្ធសក្យៈបានថ្វាយកត្តជាចំណែកខ្លួន ដល់ព្រះបច្ចេកពុទ្ធឈ្មោះឧបរិដ្ឋៈ ក្នុងកាលដែលខ្លួននៅជាអន្ធការៈ ទ្រង់ធ្វើសេចក្តីប្រាថ្នាថា ព្រះអង្គកុំបីឮពាក្យថាមិនមាន កុំដឹងទីដែលកើតនៃភោជន បើស្តេចអនុរុទ្ធនេះទ្រង់ឃើញថាសទទេសោត ពួកយើងក៏មិនបាន ចូរទៅកាន់ទេវសមាគមផង ក្បាលរបស់ពួកយើងនឹងបែក ៧ ភាគផង ពេលនោះ ទើបធ្វើថាសមាសនោះឲ្យពេញដោយនំទិព្វ កាលថាសនោះ គ្រាន់តែអ្នកបម្រើជាក់ចុះត្រង់ទីសម្រាប់លេង ហើយបើកទ្វើង ភ្លិនក៏ផ្សាយទូទៅពេញព្រះនគរ ជុំនំគ្រាន់តែក្បត្រទាំង ៦ ជាក់ចូរទៅក្នុងព្រះឱស្ឋប៉ុណ្ណោះ ក៏ផ្សាយទៅ ពេញបសាទដែលទទួលរសទាំង ៧ ពាន់ ។

ព្រះកុមារនោះទ្រង់ព្រះតម្រិះថា អាត្មាអញប្រហែលមិនជាទីស្រឡាញ់របស់ព្រះមាតា ទើបព្រះមាតាទ្រង់មិនចម្អិននំឈ្មោះនំមិនមាននេះឲ្យដល់អញអស់កាលមានប្រមាណប៉ុណ្ណោះ ។ តាំងអំពីនេះទៅ អញមិនបរិភោគនំដទៃទៀយ ដូច្នេះហើយ យាងទៅកាន់ដំណាក់ ទូលសួរព្រះមាតាថា បពិត្រព្រះ

មាតា ទូលបង្គំជាទីស្រឡាញ់របស់មាតា ឬមិនជាទីស្រឡាញ់ ព្រះមាតាពោលថា នែបា បាជាទីស្រឡាញ់ក្រៃលែងរបស់មាតា ដូចក្អែករបស់បុគ្គលមានតែម្ខាង និងដូចហទយៈរបស់មាតាដូច្នោះ ព្រះអនុរុទ្ធពោលថា បើដូច្នោះ ហេតុអ្វី ទើបព្រះមាតា ទ្រង់មិនចម្អិននំមិនមានឲ្យដល់ទូលបង្គំ អស់កាលមានប្រមាណប៉ុណ្ណោះ ។

ព្រះនាងសួរក្មេងស្និទ្ធស្នាលថា នំណាមួយមាននៅក្នុងថាសឬ អ្នកបម្រើពោលថា បពិត្រព្រះនាង ថាសពេញទៅដោយនំ ឈ្មោះថានំបែបនេះទូលបង្គំក៏មិនធ្លាប់ឃើញដែរ ។ ព្រះនាងទ្រង់ព្រះតម្រិះថា កូនរបស់អញជាអ្នកមានបុណ្យ មានអភិនីហារបានធ្វើហើយ ទេវតាទាំងឡាយជាក់នំឲ្យពេញថាសបញ្ជូនទៅហើយ ។ លំដាប់នោះ ទើបព្រះអនុរុទ្ធទូលនឹងព្រះមាតាថា បពិត្រព្រះមាតា តាំងអំពីនេះទៅទូលបង្គំមិនសោយនំជនៃ សូមព្រះមាតាចម្អិនតែនំមិនមានតែម្យ៉ាង ។ តាំងអំពីនោះមក សូម្បីព្រះនាងកាលព្រះកុមារនោះទូលថា ទូលបង្គំត្រូវការសោយនំ ព្រះនាងក៏គ្រប់ថាសទទេនោះឯង ដោយថាសជនៃ បញ្ជូនទៅឲ្យព្រះកុមារនោះ ទេវតាទាំងឡាយបញ្ជូននំទិព្វថ្វាយព្រះកុមារនោះអស់កាលដែលលោកនៅជាឃរាវាស ។

ព្រះកុមារនោះ កាលទ្រង់មិនជ្រាបសូម្បីត្រឹមតែពាក្យ មានប្រមាណប៉ុណ្ណោះ ទ្រង់នឹងជ្រាបដល់ការបួសបានដូចម្តេច ព្រោះដូច្នោះ ទើបកុមារទូលសួរព្រះភាតាថា ការបួសនេះដូចម្តេច កាលស្តេចមហានាមត្រាស់ថា អ្នកបួសត្រូវកោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាវពស្ត្រ ត្រូវដេក

លើកម្រាលដែលធ្វើដោយឈើ ឬលើគ្រែដែលត្បាញដោយផ្តៅ គ្រាច់បិណ្ឌបាត នេះឈ្មោះថា ការបួស ។ ទើបទូលថា ព្រះជេដ្ឋា ខ្ញុំជាសុខុមាលជាតិ ខ្ញុំមិនអាចបួសបានទេ ។ ព្រះបាទមហានាមត្រាស់ថា នែបា បើដូច្នោះ ចូរបារៀនន្ហូរកិច្ចដែលជាឃរាវាសចុះ ។ ក្នុងយើងទាំងពីរ បើម្នាក់មិនបួស មិនគួរ ។

ខណៈនោះ អនុរុទ្ធកុមារសួរបងថា ឈ្មោះថា ការងារនេះដូចម្តេច កុលបុត្រដែលមិនដឹងសូម្បីតែទីកើតនៃកត្ត នឹងស្គាល់ការងារបានដូចម្តេច ។

ថ្ងៃមួយ ការសន្ធនាកើតឡើងដល់ក្សត្រ ៣ អង្គថា ឈ្មោះថា កត្ត កើតឡើងក្នុងទីណា កិម្ពិលកុមារប្រាប់ថា កើតឡើងក្នុងជង្រុក គ្រានោះ ភទ្ទិយ-កុមារជំទាស់កិម្ពិលកុមារនោះថា ព្រះអង្គមិនជ្រាបទីកើតនៃកត្ត ឈ្មោះថា កត្ត រមែងកើងឡើងត្រង់ឆ្នាំងបាយ អនុរុទ្ធជំទាស់ថា ទោះបីអ្នកទាំងពីរ ក៏ន្ហូរមិនដឹង ធម្មតា កត្ត រមែងកើតក្នុងថាសមាស ប្រមាណមួយហត្ថក្តាប់ ។

បានឮថា ក្សត្រ ៣ អង្គនោះ ថ្ងៃមួយ កិម្ពិលកុមារទ្រង់យើញគេជញ្ជូនស្រូវចុះអំពីជង្រុក ក៏យល់ថាស្រូវទាំងនេះកើតឡើងហើយក្នុងជង្រុកនោះឯង ។

ចំណែកភទ្ទិយកុមារ ថ្ងៃមួយ ទ្រង់យើញគេដួសកត្តចេញអំពីឆ្នាំងបាយ ក៏យល់ថា កត្តកើតឡើងក្នុងឆ្នាំងបាយនោះឯង ។

ចំណែកអនុរុទ្ធកុមារ មិនធ្លាប់យើញសូម្បីមនុស្សបុកអង្ករ ដាំបាយ ឬដួសបាយ ទ្រង់យើញតែបាយដែលគេដួសហើយតម្កល់ទុកចំពោះមុខប៉ុណ្ណោះ ទើបទ្រង់យល់ថា កត្តកើតក្នុងថាសក្នុងពេលដែលត្រូវការបរិភោគ ។ ស្តេចទាំង ៣ អង្គនោះ ទ្រង់មិនជ្រាបសូម្បីទីកើតនៃកត្ត ដោយប្រការយ៉ាងនេះ

ព្រោះដូច្នោះ ទើបព្រះអនុរុទ្ធទូលសួរថា ឈ្មោះថា ការងារនេះដូចម្តេច កាលទ្រង់បានស្តាប់កិច្ចការដែលយរាវាសគប្បីធ្វើប្រចាំឆ្នាំ មានខាងដើមត្រូវភ្លូវស្រែ ។ ទើបសួរថា កាលណាទីបំផុតនៃការងារទាំងឡាយនឹងប្រាកដ ។ កាលណាទើបទូលបង្គំមានសេចក្តីខ្វល់ខ្វាយតិច ប្រើប្រាស់កោគៈបាន ។ កាលព្រះបាទមហានាមត្រាស់ប្រាប់ការមិនមានទីបំផុតនៃការងារទាំងឡាយហើយ ទូលថា បើយ៉ាងនោះ ម្ចាស់បងនោះឯងជាអ្នកគ្រប់គ្រងយរាវាសចុះ ទូលបង្គំមិនត្រូវការដោយយរាវាសនោះទេ្លយ ដូច្នេះហើយ ចូលគាល់ព្រះមាតាក្រាបទូលថា បពិត្រព្រះមាតា សូមព្រះមាតាអនុញ្ញាតដល់ទូលបង្គំចុះ ទូលបង្គំនឹងបួស កាលព្រះនាងទ្រង់ឃាត់អស់វារៈពីរដង ត្រាស់ថា បើកទិយកុមារជាសម្លាញ់របស់បុត្របួសសោត ចូរកូនបួសជាមួយទ្រង់ចុះ ទើបចូលទៅរកព្រះកទិយៈនោះទូលថា នែសម្លាញ់ ការបួសរបស់ខ្ញុំជាប់ទាក់ទងជាមួយទ្រង់ ដូច្នេះហើយបានញ៉ាំងកទិយៈនោះឲ្យយល់ព្រមដោយប្រការផ្សេងៗ ក្នុងថ្ងៃទី ៧ ទ្រង់ទទួលបួជ្ជាដើម្បីប្រយោជន៍នឹងបួសជាមួយព្រះអង្គ ។

បន្ទាប់អំពីនោះ ក្សត្រទាំង ៦ អង្គ គឺកទិយសក្យរាជ អនុរុទ្ធ អានន្ទ ភគុ កិម្ពិលៈ និងទេវទត្ត មានឧបាលីដែលជាភូសាមាលាជាគម្រប់ ៧ ទ្រង់សោយមហាសម្បត្តិអស់ ៧ ថ្ងៃ ដូចទេវតាសោយទិព្វសម្បត្តិ ហើយយាងចេញដោយចតុរង្គសេនា ហាក់ដូចយាងទៅប្រពាតឧទ្យាន ដល់ដែនក្សត្រអង្គជទៃហើយ ទ្រង់បញ្ជូនកងទ័ពទាំងអស់ឲ្យត្រឡប់ដោយព្រះរាជអាជ្ញា ទ្រង់យាងចូលកាន់ដែនក្សត្រអង្គជទៃ ។ ក្នុងជន ៧ នាក់នោះ ក្សត្រ ៦ អង្គ

ទ្រង់ ដោះអករណៈរៀងៗ ខ្លួន ធ្វើជាបង្វេចហើយប្រាប់ថា នែឧបាលី ចូរអ្នក ត្រឡប់ទៅចុះ ទ្រព្យប៉ុណ្ណេះល្មមចិញ្ចឹមជីវិតរបស់អ្នក ដូច្នេះហើយ ប្រទានដល់ ឧបាលី ។ ឧបាលីយំបម្រះនទៀលទៀបបាទារបស់ក្សត្រ ៦ អង្គនោះ កាល មិនអាចកន្ធង់អាជ្ញារបស់ស្តេចទាំងនោះ ទើបក្រោកឡើងកាន់បង្វេចនោះ ត្រឡប់ទៅ ។ ក្នុងកាលនៃជនទាំងនោះកើតជាពីរពួក ព្រៃ ហាក់ដូចជាដល់ នូវការទ្រហោយំ ផែនដី ហាក់ដូចជាដល់នូវការញាប់ញ័រ ។ ចំណែកឧបាលី ភូសាមាលា ទៅបានបន្តិច ក៏ត្រឡប់គិតយ៉ាងនេះថា ស្តេចសក្យៈ កាច ណាស់ គប្បីសម្លាប់អញចង់ ដោយយល់ថារាជកុមារទាំងឡាយត្រូវអញ ផ្តាច់ព្រះជន្មហើយ ដូច្នេះក៏ថាបាន ធម្មតាសក្យកុមារទាំងនេះ ទ្រង់លះ សម្បត្តិបែបនេះ ចោលអករណៈដែលមានតម្លៃ កាត់ថ្លៃមិនបានទាំងនេះដូច ដុំទឹកមាត់ ហើយបួស នឹងពោលថ្វីដល់អញ កាលគិតដូច្នេះហើយ ទើប ស្រាយបង្វេចចេញ យកអករណៈទាំងនោះព្យួរលើដើមឈើហើយ ពោល ថា អ្នកណាត្រូវការ ចូរកាន់យកចុះ ដូច្នេះហើយ ទៅកាន់សម្នាក់របស់ សក្យកុមារទាំងនោះ សក្យកុមារទាំងនោះត្រាស់សួរថា ព្រោះហេតុអ្វី ទើប អ្នកត្រឡប់មក ក៏ក្រាបទូលសេចក្តីនោះហើយ ។

គ្រានោះ សក្យកុមារទាំងនោះ ទ្រង់នាំគ្នាចូលទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំ ព្រះអង្គទាំងឡាយឈ្មោះថាជាសក្យៈ មានការប្រកាន់ខ្លួនប្រចាំសន្តាន ។ បុគ្គល នេះជាអ្នកបម្រើរបស់ខ្ញុំព្រះអង្គអស់រាត្រីយូរ សូមទ្រង់ឲ្យបុគ្គលនេះបួសមុន

ខ្ញុំព្រះអង្គទាំងឡាយនឹងធ្វើសាមីចិកម្ម មានការអភិវាទជាដើមដល់បុគ្គលនេះ ការប្រកាន់ខ្លួនរបស់ខ្ញុំព្រះអង្គ នឹងសាបរលាបទៅដោយអាការយ៉ាងនេះ ។ ដូច្នេះហើយ ឲ្យឧបាលីនោះបួសមុន ឯខ្លួនបួសខាងក្រោយ ។ បណ្តាសក្យៈ ៦ អង្គនោះ ព្រះភទ្ទិយៈបានជាព្រះអរហន្តតេវិជ្ជោ ក្នុងវេលាវស្សានោះឯង ។ ឯព្រះអនុរុទ្ធជាអ្នកមានទិព្វចក្ខុ ក្រោយមកទ្រង់ស្តាប់មហាបុរិសវិតក្កសូត្រ បានសម្រេចអរហត្តហើយ ព្រះអានន្ទតាំងនៅក្នុងសោតាបត្តិផលហើយ ។ ព្រះភគុត្តេរ និងព្រះកិម្ពិលត្តេរ ក្នុងកាលខាងក្រោយមក ចម្រើនវិបស្សនាសម្រេចអរហត្ត ទេវទត្តកិក្ខុបានសម្រេចឫទ្ធិដែលជារបស់បុថុជ្ជន ។

ក្នុងកាលបន្ទាប់មក កាលព្រះសាស្តាប្រថាប់នៅក្នុងក្រុងកោសម្ពី លាភនិងសក្ការៈជាច្រើន កើតឡើងដល់ព្រះតថាគត មួយអន្ទើដោយសង្ឃសាវក មនុស្សទាំងឡាយក្នុងក្រុងកោសម្ពីនោះ មានដៃកាន់សំពត់ និងកេសជ្ជៈជាដើម ចូលទៅកាន់វិហារហើយ សួរគ្នាថា ព្រះសាស្តាប្រថាប់នៅក្នុងទីណាហ្ន៎ ព្រះសារីបុត្តត្តេរនៅក្នុងទីណាហ្ន៎ ព្រះមហាមោគ្គល្លានត្តេរនៅទីណាហ្ន៎ ព្រះមហាកស្សបត្តេរនៅទីណាហ្ន៎ ព្រះភទ្ទិយត្តេរនៅទីណាហ្ន៎ ព្រះអនុរុទ្ធត្តេរនៅទីណាហ្ន៎ ព្រះអានន្ទត្តេរនៅទីណាហ្ន៎ ព្រះភគុត្តេរនៅទីណាហ្ន៎ ព្រះកិម្ពិលត្តេរនៅទីណាហ្ន៎ ដូច្នេះហើយ ដើរមើលទីគង់នៃអសីតិមហាសាវក ឈ្មោះថា បុគ្គលសួរថា ទេវទត្តគង់ ឬឈរទីណាហ្ន៎ដូច្នេះ មិនមាន ទើបទេវទត្តគិតថា អញបួសជាមួយសក្យរាជទាំងនោះដូចគ្នា សក្យៈទាំងនោះជាខត្តិយបព្វជិត សូម្បីអាត្មាអញក៏ជាខត្តិយបព្វជិត ពួកមនុស្សក៏មានដៃកាន់លាភសក្ការៈ ស្វែងរក

លោកទាំងនោះ អ្នកហារមាត់សួរដល់ឈ្មោះរបស់អញ មិនមាន អញនឹងសេពគប់ជាមួយអ្នកណាហ្ន៎ គប្បីញុំាងអ្នកណាឲ្យជ្រះថ្លា ហើយញុំាងលាភ-សក្ការៈឲ្យកើតដល់អញបាន ។

ពេលនោះ ការសម្រេចចិត្តនេះមានដល់លោកថា ព្រះបាទពិម្ពិសារមួយអន្ទើដោយបរិវារ ១១ ម៉ឺន ទ្រង់តាំងនៅក្នុងសោតាបត្តិផលហើយ ដោយការឃើញគ្រាដំបូងនោះឯង អញមិនអាចសេពគប់ជាមួយព្រះរាជានោះបាន សូម្បីព្រះបាទកោសល អញក៏មិនអាចសេពគប់បាន ឯអជាតសត្តុកុមារព្រះឱរសរបស់ព្រះរាជានេះឯង នៅមិនទាន់ដឹងគុណ និងទោសរបស់បុគ្គលណា អញសេពគប់ជាមួយកុមារនោះ ។ ទេវទត្តនោះ ចេញអំពីក្រុងកោសម្ពីទៅកាន់ក្រុងរាជគ្រឹះ និមិត្តភេទជាកុមារតូច រុំអសិរពិស ៤ ត្រង់ដៃ និងជើងទាំង ៤ ពស់ ១ ទៀតរុំត្រង់ក ពស់ ១ ទៀត ធ្វើជាឈ្នួតក្បាល ពស់មួយទៀត ធ្វើជាខ្សែសង្វារ ចុះពីលើអាកាស ដោយសង្វារពស់នេះ អង្គុយលើភ្លៅរបស់អជាតសត្តុកុមារ កាលកុមារនោះ ទ្រង់ខ្ចាចហើយ ត្រាស់ថា អ្នកជានរណា ទើបថ្វាយព្រះពរថា អាត្មា គឺទេវទត្ត ដើម្បីបន្ទោបង់នូវការខ្ចាចរបស់ព្រះរាជកុមារ ទើបត្រឡប់អត្តភាពនោះជាភិក្ខុ ទ្រទ្រង់សង្ឃាដីបាត្រ និងចីវរឈរនៅចំពោះព្រះភក្ត្រ ញុំាងរាជកុមារនោះឲ្យជ្រះថ្លា ញុំាងលាភ និងសក្ការៈឲ្យកើតហើយ ។

ទេវទត្តភិក្ខុនោះ កាលលាភ និងសក្ការៈគ្របសង្កត់ហើយ ញុំាងការគិតដ៏លាមកឲ្យកើតឡើងថា អញនឹងគ្រប់គ្រងភិក្ខុសង្ឃជួច្នេះហើយ ក៏សាបសូន្យ

ចាកឫទ្ធិដំណាលគ្នានឹងចិត្តប្បាទនោះឯង ហើយថ្វាយបង្គំព្រះសាស្តា ដែលកំពុងសម្តែងធម៌ដល់បរិស័ទ មួយអន្លើដោយព្រះរាជាក្នុងវត្តវេឡុវនវិហារ ក្រោកចាកអាសនៈហើយ ផ្គងអញ្ជលីក្រាបទូលថា បពិត្រព្រះអង្គ ពេលនេះ ទ្រង់ចាស់ជរាហើយ សូមទ្រង់ខ្វល់ខ្វាយតិច ប្រកបរឿយៗ នូវវិហារធម៌ដែលជាទីសប្បាយក្នុងទិដ្ឋធម៌ចុះ ខ្ញុំព្រះអង្គនឹងគ្រប់គ្រងភិក្ខុសង្ឃ សូមទ្រង់ប្រគល់ភិក្ខុសង្ឃដល់ខ្ញុំព្រះអង្គចុះ ដូច្នេះហើយ ត្រូវព្រះសាស្តាសង្កត់សង្កិនដោយខេឡាសិកវាទ ទ្រង់ឃាត់ហើយ មិនពេញចិត្ត បានចង្អាយាតនេះ ក្នុងព្រះតថាគតជាគ្រាដំបូង ហើយចៀសចេញទៅ ។

គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់ឲ្យធ្វើបកាសនីយកម្ម ក្នុងក្រុងរាជគ្រឹះជល់ទេវទត្តហើយ ។ លោកគិតថា ឥឡូវនេះ អញត្រូវព្រះសមណគោតមកម្ចាត់ហើយ ឥឡូវនេះ អញនឹងធ្វើសេចក្តីវិនាសដល់ព្រះសមណគោតមនេះដូច្នេះហើយ ទើបទៅគាល់ព្រះបាទអជាតសត្តុកុមារទូលថា បពិត្រព្រះរាជកុមារ កាលមុនមនុស្សទាំងឡាយមានអាយុវែង ឥឡូវនេះអាយុខ្លី ការដែលទ្រង់គប្បីទិវង្គតតាំងអំពីក្មេង នុ៎ះជាហានៈមាននៅ បើដូច្នោះ សូមទ្រង់សម្រេចទោសព្រះបិតាជាព្រះរាជាចុះ អាត្មាសម្រេចទោសព្រះដ៏មានព្រះភាគ ហើយធ្វើជាព្រះពុទ្ធ កាលព្រះកុមារតាំងនៅក្នុងរាជសម្បត្តិហើយ បានតែងតាំងបុរសទាំង-ឡាយ ដើម្បីសម្លាប់ព្រះតថាគត កាលបុរសទាំងនោះសម្រេចសោតាបត្តិផលត្រឡប់ទៅហើយ ទើបឡើងភ្នំគិជ្ឈកូដឯង ប្រមៀលថ្មដោយបំណងថា អញខ្លួនឯងនឹងផ្តាច់ជីវិតព្រះសមណគោតម បានធ្វើកម្ម គឺលោហិតឲ្យពុះពងឡើង

កាលមិនអាចសម្ងាប់ដោយឧបាយនេះ ទើបឲ្យលែងដំរីនាឡាគិរីទៅទៀត កាលដំរីនោះកំពុងដើរមក ព្រះអានន្ទត្ថេរលះបង់ជីវិតរបស់ខ្លួន ថ្វាយព្រះសាស្តា បានឈរពាំងខាងមុនហើយ ។

ព្រះសាស្តាទ្រង់ទូន្មានដំរីហើយ ទ្រង់ចេញអំពីនគរមកកាន់វិហារ សោយមហាទាន ដែលពួកឧបាសកច្រើនពាន់នាំមកហើយ ទ្រង់សម្តែងអនុបុព្វីកថា ប្រោសអ្នកក្រុងរាជគ្រឹះ ១៨ កោដិ ដែលប្រជុំគ្នាក្នុងថ្ងៃនោះ ធម្មាភិសមយកើតមានដល់សត្វប្រមាណ ៨៤០០០ ។

ព្រះដ៏មានព្រះភាគ ទ្រង់ស្តាប់កថាពណ៌នាគុណរបស់ព្រះថេរៈថា ឱ ! ព្រះអានន្ទមានគុណច្រើន កាលស្តេចដំរីបែបនោះមក បានលះបង់ជីវិតរបស់ខ្លួន ឈរពាំងមុខព្រះសាស្តា ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អានន្ទនេះក៏លះបង់ជីវិតដើម្បីប្រយោជន៍ដល់តថាគតហើយដូចគ្នា កាលភិក្ខុទាំងឡាយទូលអាយាចនាហើយ ទើបត្រាស់ចុល្លហង្សជាតក មហាហង្សជាតក និងកក្កដជាតក ។

កម្មរបស់ទេវទត្ត ព្រោះញុំាងព្រះបាទអជាតសត្តុកុមារ ឲ្យសម្រេចទោសព្រះរាជាក្តី រៀបចំនាយខ្នាន់ធ្នូក្តី ព្រោះប្រមៀលថ្មក្តី មិនបានប្រាកដដូចព្រោះលែងដំរីនាឡាគិរីឡើយ ។ គ្រានោះឯង មហាជនបានចោទគ្នាឡើងថា សូម្បីព្រះរាជាក៏ទេវទត្តនោះឯងជាអ្នកឲ្យសម្រេចទោស នាយខ្នាន់ធ្នូក៏ទេវទត្តនោះឯងរៀបចំឡើង ដុំថ្មក៏ទេវទត្តជាអ្នកប្រមៀលដូចគ្នា ឥឡូវនេះលោកក៏បានលែងដំរីនាឡាគិរី ព្រះរាជាទ្រង់សេពគប់បុគ្គលណាមកបែបនេះហ្ន៎ ព្រះរាជាទ្រង់ឮ

ពាក្យរបស់មហាជនហើយ ទើបឲ្យនាំកត្ត ៥០០ សម្រាប់មក មិនបានយោង ទៅឧបដ្ឋាកទេវទត្តនោះទៀតឡើយ សូម្បីអ្នកនគរមិនបានប្រគេនវត្ថុត្រឹមតែ កិក្ខាដល់លោកដែលចូលទៅកាន់ត្រកូល ។

ទេវទត្តនោះសាបសូន្យចាកលាភ និងសក្ការៈហើយ បំណងនឹងចិញ្ចឹម ជីវិតដោយការបោកបញ្ឆោត ទើបចូលទៅគាល់ព្រះសាស្តា ទូលសូមវត្ថុ ៥ ប្រការ ត្រូវព្រះដ៏មានព្រះភាគទ្រង់ហាមថា ម្នាលទេវទត្ត អ្នកកុំធ្វើដូច្នោះឡើយ បុគ្គលណាប្រាថ្នា បុគ្គលនោះក៏ចូលជាអ្នកនៅព្រៃចុះ ដូច្នេះហើយ ទូលថា នែអាវុសោទាំងឡាយ ពាក្យសម្តីរបស់អ្នកណាស្អាត របស់ព្រះតថាគត ឬ របស់ខ្ញុំ ខ្ញុំនឹងពោលដោយអំណាចបដិបទាយ៉ាងនេះក្រិដ្ឋយ៉ាងនេះថា បពិត្រ ព្រះអង្គ ខ្ញុំព្រះអង្គសូមព្រះរាជទានព្រះវរោកាស សូមកិក្ខុទាំងឡាយជាអ្នក នៅព្រៃ ត្រាច់បិណ្ឌបាត ទ្រទ្រង់សំពត់បង្សុកូល នៅដោយគល់ឈើ មិន គប្បីឆាន់ត្រី និងសាច់ដរាបដល់អស់ជីវិត ហើយពោលថា បុគ្គលណាប្រាថ្នា ផុតចាកទុក្ខ បុគ្គលនោះ ចូរមកជាមួយខ្ញុំ ដូច្នេះហើយ ចៀសចេញទៅ កិក្ខុ ពួកខ្លះជាអ្នកបួសថ្មី មានការចេះដឹងតិច បានស្តាប់ពាក្យរបស់ទេវទត្តនោះ ហើយ បបួលគ្នាថា ព្រះទេវទត្តនិយាយត្រូវ ពួកយើងនឹងទៅជាមួយទេវទត្ត នោះ ដូច្នេះហើយ បានសេពគប់ជាមួយលោក ។

ទេវទត្តនោះញុំាងជនដែលជ្រះថ្លាក្នុងរបស់សៅហ្មងឲ្យឃល់ ដោយវត្ថុ ៥ ប្រការនោះ មួយអន្ទើដោយកិក្ខុ ៥០០ រូប ឲ្យត្រាច់សូម្បីបច្ច័យក្នុងត្រកូល ទាំងឡាយមកបរិភោគ ព្យាយាមដើម្បីបំបែកសង្ឃហើយ ។ ទេវទត្តកាល

ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលទេវទត្ត បានឮថា អ្នកព្យាយាមដើម្បីបំបែកសង្ឃ ដើម្បីទម្លាយចក្កពិតឬ ទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនេះពិតហើយ សូម្បីទ្រង់ប្រទានឱវាទ ដោយព្រះពុទ្ធវចនៈជាដើមថា ម្នាលទេវទត្ត ការបំបែកសង្ឃមានទោសធ្ងន់ ក៏មិនបានកាន់យកព្រះវាចារបស់ព្រះសាស្តាឡើយ ហើយចៀសចេញទៅ ជួបព្រះអានន្ទដែលកំពុងត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ទើបពោលថា អាវុសោអានន្ទ តាំងអំពីថ្ងៃនេះជាដើមទៅ ខ្ញុំនឹងធ្វើឧបោសថ ធ្វើសង្ឃកម្មវៀរចាកព្រះដ៏មានព្រះភាគ វៀរចាកភិក្ខុសង្ឃ ។

ព្រះថេរៈក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ព្រះសាស្តាទ្រង់ជ្រាបសេចក្តីនោះហើយ កើតធម្មសង្វេគ ទ្រង់បវិតក្កថា ទេវទត្តធ្វើកម្មជាហេតុឲ្យខ្លួនឆេះក្នុងអវីចី ដែលទាក់ទងដល់សេចក្តីវិនាសដល់សត្វលោក និងទេវលោក ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អំពើល្អ មនុស្សសប្បុរស ធ្វើបានដោយងាយ
អំពើល្អ មនុស្សបាប ធ្វើបានដោយក្រ ។

ទ្រង់បន្ទឺព្រះឧទានទៀតថា

អំពើបាប មនុស្សបាប ធ្វើបានដោយងាយ អំពើ
បាប ព្រះអរិយៈទាំងឡាយ ធ្វើបានដោយក្រ ។

គ្រានោះឯង ទេវទត្តអង្គុយក្នុងចំណែកម្ខាង មួយអន្ទើដោយបរិស័ទរបស់ខ្លួនក្នុងថ្ងៃឧបោសថ ពោលថា វត្ថុ ៥ ប្រការនេះ គាប់ចិត្តដល់បុគ្គលណា បុគ្គលនោះចូរចាប់ស្វាក កាលភិក្ខុវជ្ជីបុត្រ ៥០០ រូប ជាអ្នកបួសថ្មី

មិនស្គាល់ធម៌វិន័យ ដែលព្រះដ៏មានព្រះភាគទ្រង់ធ្វើ ចាប់ស្វាកហើយ បានទម្លាយសង្ឃ នាំភិក្ខុទាំងនោះ ទៅកាន់គយាសីសប្បទេស ។

ព្រះសាស្តា ទ្រង់ឮដំណឹងដែលទេវទត្តនោះទៅហើយក្នុងទីនោះ ទើបបញ្ជូនអគ្គសាវ័កទាំងពីរទៅ ដើម្បីប្រយោជន៍ដល់ការនាំភិក្ខុទាំងនោះមកវិញ អគ្គសាវ័កទាំងពីរនោះទៅក្នុងទីនោះហើយ ទូន្មានដោយអនុសាសនី ទាក់ទងក្នុងអាទេសនាបាដិហារ្យ និងអនុសាសនីដែលទាក់ទងក្នុងឥទ្ធិប្បាដិហារ្យ ញុំាងភិក្ខុទាំងនោះ ឲ្យផឹកអមតធម៌ហើយ នាំមកតាមអាកាស ។

ចំណែកកោកាលិកភិក្ខុពោលថា អាវុសោទេវទត្តក្រោកឡើង សារីបុត្រ និងមោគ្គល្លាននាំភិក្ខុទាំងនោះទៅអស់ហើយ ខ្ញុំជ្រាបលោកហើយ មិនមែនឬថា អាវុសោ លោកកុំទុកចិត្តសារីបុត្រ និងមោគ្គល្លាន ព្រោះសារីបុត្រ និងមោគ្គល្លាន មានការជ្រុថ្នាលាមក លុះនៅក្នុងអំណាចសេចក្តីជ្រុថ្នាលាមកដូច្នេះហើយ យកក្បាលជង្គង់ឡកត្រង់ដើមទ្រូង ។ ឈាមក្តៅៗ បានខ្ទុរចេញតាមមាត់ទេវទត្តក្នុងទីនោះឯង ។

ចំណែកពួកភិក្ខុឃើញព្រះសារីបុត្រ មានភិក្ខុសង្ឃចោមរោមមកតាមអាកាសហើយ ក្រាបទូលថា បពិត្រព្រះអង្គ ព្រះសារីបុត្តត្ថេរក្នុងកាលទៅមានពីរូបប៉ុណ្ណោះ ឥឡូវនេះ មានបរិវារមក រុងរឿងពិតហ្ន៎ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលទេវទត្តកើតក្នុងកំណើតតិរច្ឆាន បុត្ររបស់តថាគតមកកាន់សម្នាក់តថាគត ក៏រមែងរុងរឿងដូចគ្នា ដូច្នេះហើយ ត្រាស់ជាតកនេះថា

សេចក្តីចម្រើន តែងមានដល់ពួកជនអ្នកមានសីល អ្នកប្រព្រឹត្ត
បដិសណ្ឋារៈ នាងចូរមើលម្រឹគឈ្មោះលក្ខណៈ កំពុងដើរ
មក ដែលពួកញាតិហែហមហើយ នាងឃើញម្រឹគឈ្មោះ
កាឡៈនេះ ដែលសាបសូន្យចាកពួកញាតិ (កំពុងដើរមក)
ឬទេ ដូច្នេះជាដើម ។

កាលពួកភិក្ខុក្រាបទូលទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ទេវទត្ត ឲ្យអគ្គសាវ័កពីរអង្គ គង់សង្ឃខាងហើយ ពោលថា ខ្ញុំនឹងសម្តែងធម៌ដោយ ពុទ្ធលីលា ធ្វើកិរិយាតាមព្រះអង្គហើយ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ មិនមែនតែឥឡូវប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តនេះ ក៏ធ្វើតាមលីលារបស់តថាគត តែមិនអាច ដូច្នេះហើយ ត្រាស់នូវចរកាក-ជាតកថា[1]

ប្រពន្ធក្អែកគោកសួរថា

នែក្អែកទឹកឈ្មោះវីរកៈ អ្នកឃើញសត្វស្វាបដែលពោល
ពាក្យពីរោះ មានផ្ងួតកដូចជាផ្ងួតកនៃក្ងោក ជាក្អែកគោក
ឈ្មោះសវិដ្ឋកៈ ជាប្តីរបស់ខ្ញុំដែរឬ ។

ក្អែកទឹកពោធិសត្វពោលថា

ក្អែកសវិដ្ឋកៈ កាលធ្វើតាមសត្វស្វាបអ្នកត្រាច់ទៅក្នុងទឹក
និងលើគោក បានបរិភោគត្រីស្រស់ជានិច្ចនោះ ត្រូវសាវាយ

១- បិដកខ្មែរ ជាវីរកជាតក ។

ព័ន្ធព័ន្ធស្ងាប់ទៅហើយ ដូច្នេះជាដើម ។

សូម្បីថ្ងៃដទៃៗ ទៀត ទ្រង់ប្រារព្ធកថាដូច្នោះដូចគ្នា ត្រាស់ជាតកទាំង-ឡាយជាដើមយ៉ាងនេះថា

ខទិរវនិយបក្សីពោលថា

ឱហ្ន៎ ត្រសេះនេះ កាលចោះនូវឈើក្នុងព្រៃទាំងឡាយ បានហើរទៅក្នុងពួកឈើមិនមានខ្វឹម ជាចំណែកនៃឈើស្វួតក្នុង កាលជាខាងក្រោយមកត្រសេះ (នេះ) បានហើរ មកទម្លាយ អំបែងក្បាល (របស់ខ្លួន) និងដើមសង្កែជាឈើមានខ្វឹមអំពីកំណើត ។

កេសរសីហាពោធិសត្វពោលថា ខ្វរក្បាលរបស់អ្នកធ្លាយចេញផង លលាដ៍ក្បាលរបស់អ្នកបែកធ្លាយផង ឆ្នឹងជីនីរទាំងអស់ របស់អ្នក ជីរបំបាក់ហើយផង ក្នុងថ្ងៃនេះ អ្នកនៅរុងរឿងអ្វីទៀត ។

ទ្រង់ប្រារព្ធកថាថា ទេវទត្តជាបុគ្គលអកតញ្ញូ ទើបត្រាស់ជាតកទាំងឡាយជាដើមទៀតថា

សត្វត្រសេះពោលថា កម្លាំងណារបស់យើងមានហើយ យើងធ្វើកិច្ចដល់អ្នកតាមកម្លាំងនោះ បពិត្រមិគរាជ ខ្ញុំសូមក្រាបថ្វាយបង្គំអ្នក យើងត្រូវបានសាច់បន្ទិចបន្តួចខ្លះ ។

រាជសីហ៍ឆ្លើយតបថា អ្នកឯងចូលទៅតាមចន្លោះនៃធ្មេញ របស់ខ្ញុំដែលជាអ្នកស៊ី (សាច់) និងឈាម ធ្វើនូវអំពើអាក្រក់ទាំង-ឡាយជានិច្ច រស់នៅ ដោយសាច់ណា សាច់នោះមានច្រើន ។

ទ្រង់ប្រារព្ធការខ្វល់ខ្វាយដើម្បីសម្ងាប់ព្រះអង្គ របស់ទេវទត្តកិក្ខុនោះ ទៀត ត្រាស់ជាតកទាំងឡាយជាដើមថា

ប្រើសពោធិសត្វពោលថា ម្នាលដើមចំបក់ អ្នកជម្រុះផ្លែមក ដោយហេតុណា ហេតុនុ៎ះ អញជាប្រើសបានដឹងហើយ អញនឹងទៅកាន់ដើមចំបក់ឯទៀត ផ្លែរបស់អ្នកអញមិនពេញចិត្តទេ ។

កាលកថានៅប្រព្រឹត្តទៅទៀតថា ទេវទត្តវិនាសចាកផលពីរប្រការ គឺ ចាកលាភ និងសក្ការៈ ១ ចាកសមញ្ញផល ១ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីកាលមុនទេវទត្តក៏វិនាសហើយដូចគ្នា ដូច្នេះហើយ ត្រាស់ជាតកទាំងឡាយជាដើមថា

រុក្ខទេវតាពោធិសត្វពោលថា ក្អែកទាំងឡាយបែកធ្លាយហើយ សំពត់ជាត់ហើយ ការឈ្លោះក៏មានក្នុងផ្ទះនៃស្ត្រីជាសម្ងាញ់ ការងារទាំងឡាយខូចទាំងសងខាង គឺក្នុងទឹកផង លើគោកផង ។

ព្រះសាស្តាកាលប្រថាប់នៅក្រុងរាជគ្រឹះ ទ្រង់ប្រារព្ធទេវទត្តត្រាស់ជាតកជាច្រើនដោយប្រការយ៉ាងនេះហើយ ទ្រង់ចេញអំពីក្រុងរាជគ្រឹះ ទៅកាន់ក្រុងសាវត្ថី ប្រថាប់នៅក្នុងជេតពនមហាវិហារ ។

ចំណែកទេវទត្ត មានជំងឺអស់ ៩ ខែ ក្នុងកាលចុងក្រោយ ប្រាថ្នានឹងគាល់ព្រះសាស្តា ទើបប្រាប់សាវ័កវបស់ខ្លួនថា ខ្ញុំនឹងគាល់ព្រះសាស្តា អ្នកទាំងឡាយ ចូរបង្ហាញព្រះសាស្តានោះដល់ខ្ញុំចុះ កាលសាវ័កទាំងនោះឆ្លើយថា លោកម្ចាស់ក្នុងកាលដែលអាចប្រព្រឹត្តជាបុគ្គលមានពៀរ ជាមួយព្រះសាស្តា

យើងខ្ញុំមិនអាចនាំលោកម្ចាស់ ទៅក្នុងទីដែលព្រះសាស្តាគង់នៅបានឡើយ ទើបពោលថា អ្នកទាំងឡាយ កុំធ្វើឲ្យខ្ញុំវិនាសឡើយ ខ្ញុំធ្វើអាឃាតក្នុងព្រះសាស្តា តែសម្រាប់ព្រះសាស្តា មិនមានការអាឃាតក្នុងខ្ញុំ សូម្បីមានប្រមាណប៉ុនចុងសក់ឡើយ ពិតហើយ ព្រះដ៏មានព្រះភាគអង្គនោះ

ទ្រង់មានព្រះហឫទ័យស្មើ ក្នុងបុគ្គលទូទៅ គឺក្នុងនាយខ្នាន់ធ្នូ ក្នុងទេវទត្ត ក្នុងអង្គុលីមាលចោរ ក្នុងជីវធន្ធបាល និងក្នុងព្រះរាហុល ។

ព្រោះដូច្នោះ ទើបទេវទត្តអង្វរហើយអង្វរទៀតថា សូមអ្នកទាំងឡាយបង្ហាញព្រះដ៏មានព្រះភាគដល់ខ្ញុំ ។ ពេលនោះ សាវ័កទាំងនោះ នាំទេវទត្តនោះចេញទៅដោយគ្រែតូច ភិក្ខុទាំងឡាយ បានដំណឹងអំពីការមក របស់ទេវទត្តនោះ ទើបក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ បានឮថា ទេវទត្តមកដើម្បីប្រយោជន៍គាល់ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តនោះមិនបានឃើញតថាគតដោយអត្តភាពនោះ បានឮថា ទេវទត្តរមែងមិនបានឃើញព្រះពុទ្ធអង្គទៀត ចាប់តាំងអំពីកាលដែលសូមវត្ថុ ៥ ប្រការ សេចក្តីនេះរមែងជាធម្មតា ពួកភិក្ខុក្រាបទូលថា ទេវទត្តមកដល់ទីនោះ និងទីនោះហើយ ព្រះសាស្តាត្រាស់ថា ទេវទត្តចូរធ្វើវត្តដែលខ្លួនប្រាថ្នាចុះ តែទោះជាយ៉ាងណា ក៏ទេវទត្តមិនបានឃើញតថាគត ភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ ទេវទត្តមកដល់ទីប្រមាណមួយប្រយោជន៍អំពីទីនេះហើយ ហើយទូលបន្តៗ ទៀតថា មកដល់កន្លះយោជន៍ហើយ មួយគាវុតហើយ មកដល់ជិតស្រះបោក្ខរណីហើយ ព្រះសាស្តាត្រាស់ថា សូម្បីទេវទត្តចូលមកខាងក្នុងវត្ត

ជេតពន ក៏មិនបានឃើញតថាគតពិត ។

ពួកសាវ័កនាំទេវទត្តមក ដាក់គ្រែត្រង់ច្រាំងស្រះបោក្ខរណីជិតវត្តជេតពន ហើយក៏ចុះទៅដើម្បីងូតទឹកក្នុងស្រះបោក្ខរណី សូម្បីទេវទត្តក្រោកអំពីគ្រែ ហើយអង្គុយដាក់ជើងទាំងពីលើផែនដី ជើងទាំងពីរនោះក៏លិចចុះក្នុងផែនដី លោកលិចចុះហើយដោយលំដាប់ត្រឹមកជើង ត្រឹមជង្គង់ ត្រឹមចង្កេះ ត្រឹមដោះ រហូតត្រឹម-ក ក្នុងកាលដែលឆ្អឹងចង្កាប៉ះផែនដី បានពោលគាថានេះថា

ឥមេហិ អដ្ឋិហិ តមត្តបុគ្គលំ ទេវាតិទេវំ ឆរទម្មសារថឹ
សមន្តចក្ខុំ សតបុញ្ញលក្ខណំ ចាណេហិ ពុទ្ធំ សរណំ គតោស្មីតិ ។

ខ្ញុំសូមដល់ព្រះពុទ្ធ ជាបុគ្គលដ៏ប្រសើរ ជាទេវតានៃទេវតា ជាសារថីនៃបុគ្គលដែលគួរទូន្មាន មានព្រះចក្ខុឃើញដោយជុំវិញ ទ្រទ្រង់នូវបុញ្ញលក្ខណៈរាប់រយ ថាជាទីពឹងដោយឆ្អឹងទាំងឡាយ និងឲ្យល់ដង្ហើមនេះ ដូច្នេះ ។

បានឣថា ព្រះតថាគតទ្រង់ឃើញឋានៈនេះ ទើបឲ្យទេវទត្តបួស បើទេវទត្តនោះមិនបានបួសសោត ជាគ្រហស្ថនឹងធ្វើកម្មដ៏ធ្ងន់ មិនអាចធ្វើបច្ចុយនៃភពតទៅ កាលបួសហើយ ទោះធ្វើកម្មធ្ងន់ក៏ពិត ក៏អាចធ្វើបច្ចុយនៃភពតទៅបាន ព្រោះដូច្នោះ ទើបព្រះសាស្តាឲ្យទេវទត្តបួសហើយ ។

ពិតហើយ ទេវទត្តនោះ នឹងបានជាព្រះបច្ចេកពុទ្ធ ព្រះនាមអដ្ឋិស្សរៈ ក្នុងទីបំផុតនៃមួយសែនកប្បអំពីកប្បនេះ ទេវទត្តនោះ លិចក្នុងដីទៅហើយ កើតក្នុងអវីចី លោកជាអ្នកកម្រើកមិនបាន ត្រូវភ្ជីងធេះព្រោះជាអ្នកខុសក្នុង

ព្រះពុទ្ធដែលមិនញាប់ញ័រ សរីរៈរបស់លោកកម្ពស់ប្រមាណមួយរយយោជន៍ កើតក្នុងរណ្តៅអវីចីដែលមានប្រមាណ ៣០០ យោជន៍ ក្បាលស៊កចូលទៅក្នុងផែនដីដែក ខាងលើដល់គុម្ពត្រចៀក ជើងទាំងពីរលិចក្នុងផែនដីដែក ខាងក្រោមត្រឹមកជើង ដែកស្រួចមានប្រមាណប៉ុនដើមត្នោតធំ ចេញអំពីជញ្ជាំងខាងក្រោយ ចាក់ទម្លុះខ្នងធ្លុះទៅខាងមុខ ជោតជាប់នឹងជញ្ជាំងខាងមុខ ដែកស្រួចមួយទៀត ចេញអំពីជញ្ជាំងខាងស្តាំ ទម្លុះឆ្អឹងជំនីរស្តាំធ្លុះទៅឆ្អឹងជំនីរឆ្វេង ជោតជាប់ជញ្ជាំងខាងឆ្វេង ដែកស្រួចមួយទៀត ចេញអំពីជញ្ជាំងខាងលើទម្លុះក្បាល ធ្លុះចេញទៅខាងក្រោម ជោតជាប់នឹងផែនដីដែក ទេវទត្តនោះជាអ្នកកម្រើកមិនបាន ត្រូវក្លឹងឆេះក្នុងអវីចីនោះ ដោយប្រការយ៉ាងនេះ ។

ភិក្ខុទាំងឡាយសន្ទនាគ្នាថា ទេវទត្តដល់នូវឋានៈមានប្រមាណប៉ុណ្ណោះ មិនទាន់បានគាល់ព្រះសាស្តា ត្រូវលិចចុះកាន់ផែនដីហើយ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តប្រព្រឹត្តខុសក្នុងតថាគតរហូតលិចចុះក្នុងដីក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន ក្នុងកាលមុនទេវទត្តក៏លិចចុះហើយដូចគ្នា ដើម្បីទ្រង់សម្តែងភាពដែលបុរសវង្វេងផ្លូវ ត្រូវព្រះអង្គលួងលោមហើយ លើកឡើងដាក់លើខ្នងរបស់ខ្លួន នាំដល់ទីក្សេមហើយ បែរជាកាត់ភ្លុកទាំងឡាយអស់ ៣ ដងយ៉ាងនេះ គឺត្រង់ចុង ត្រង់កណ្តាល ត្រង់គល់ ក្នុងវារៈទីបីកាលដើរផុតគន្លងចក្ខុនៃមហាបុរសហើយ ក៏លិចចុះក្នុងផែនដីក្នុងកាលដែលទ្រង់ជាស្តេចជីរ ទើបត្រាស់ជាតកនេះជាដើមថា

រុក្ខទេវតាពោលថា ប្រសិនបើគេឲ្យផែនដីទាំងមូល ដល់បុរស

អកតញ្ញូ ជាអ្នកឃើញទោសជានិច្ច ក៏មិនគប្បីញុំាងបុរសអកតញ្ញូ នោះ ឲ្យត្រេកអរបានឡើយ ។

កាលកថាតាំងឡើងហើយដូច្នោះឯង ទៀត ទើបត្រាស់ខន្តិវាទិជាតកដើម្បី សម្តែងភាពដែលទេវទត្តនោះ កាលនៅជាព្រះបាទកលាបុ ប្រព្រឹត្តខុសក្នុង ព្រះអង្គដែលជាខន្តិវាទីតាបស ហើយលិចចុះកាន់ផែនដី និងចុល្លធម្មបាល-ជាតក ដើម្បីទ្រង់សម្តែងភាពដែលទេវទត្តនោះ កាលជាព្រះបាទមហាបតាបៈ ប្រព្រឹត្តខុសក្នុងព្រះអង្គជាចុល្លធម្មបាល ហើយលិចចុះក្នុងផែនដី កាលទេវទត្ត ធរណីស្រូបហើយ មហាជនត្រេកអរ លើកទង់ជ័យ ទង់ជ្ងាលា និងដើមចេក តម្កល់ក្អមទឹកពេញហើយ ប្រគំមហោស្រពធំ ដោយប្រការឮថា ជាលាភ របស់ពួកយើងហ្ន៎ ។ ពួកភិក្ខុក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ព្រះ ដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលទេវទត្តស្លាប់ហើយ មហាជន ត្រេកអរមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ក្នុងកាលមុន ក៏ត្រេកអរ ហើយដូចគ្នា ។ ដើម្បីសម្តែងភាពដែលមហាជនត្រេកអរក្នុងកាលព្រះរាជា ព្រះនាមបិង្គលៈ ក្នុងនគរពារាណសី ដែលជាស្តេចកាចយោរយៅ មិនជាទី ស្រឡាញ់របស់ជនទូទៅសោយទិវង្គតហើយ ទើបត្រាស់បិង្គលជាតកនេះថា

ព្រះពោធិសត្វពោលថា ជនទាំងអស់ត្រូវស្តេចបិង្គលៈបៀតបៀន ហើយ កាលស្តេចនោះ សោយទិវង្គតហើយ ជនទាំងឡាយរមែង បាននូវសេចក្តីត្រេកអរ ម្នាលទ្វារបាល ស្តេចអកណ្ហនេត្រ ជាទី ស្រឡាញ់របស់អ្នកឬ ព្រោះហេតុអ្វី បានជាអ្នកយំ ។

ទ្វារបាលបុរសពោលថា ស្តេចអកណ្ហនេត្រ មិនមែនជាទីស្រឡាញ់របស់ខ្ញុំទេ ខ្ញុំខ្លាចស្តេចនោះត្រឡប់មកវិញ (ព្រោះស្តេចនោះ) ទៅអំពីមនុស្សលោកនេះ គប្បីបៀតបៀនទូវមច្ចុរាជ មច្ចុរាជនោះក្រែងត្រូវស្តេចបិង្គលៈបៀតបៀនហើយ គប្បីនាំមកទុកក្នុងមនុស្ស-លោកនេះវិញ ។

ភិក្ខុទាំងឡាយទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះទេវទត្តកើតហើយក្នុងទីណា ព្រះសាស្តាត្រាស់ថា ក្នុងអវីចីមហានរក ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទេវទត្តប្រព្រឹត្តក្តៅក្រហាយក្នុងលោកនេះហើយ ទៅកើតក្នុងទីដែលក្តៅក្រហាយនោះទៀតឬ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ជនទាំងឡាយជាបព្វជិតក្តី ជាគ្រហស្ថក្តី មានប្រក្រតីនៅដោយសេចក្តីប្រមាទ រមែងក្តៅក្រហាយក្នុងលោកទាំងពីរនោះឯង ដូច្នេះហើយ ត្រាស់គាថានេះថា

ឥធ តប្បតិ បេច្ច តប្បតិ ចាបការី ឧភយត្ថ តប្បតិ
ចាបំ មេ កតន្តិ តប្បតិ អយ្យោ តប្បតិ ទុគ្គតឹ គតោ ។

បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺក្តៅក្រហាយ ក្នុងលោកនេះ ១ ក្តៅក្រហាយ ក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងក្តៅក្រហាយដោយគិតឃើញថា បាបអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់ទុគ្គតិ ក៏រងរឹតតែក្តៅក្រហាយដ៏ក្រៃលែង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ឥធ តប្បតិ** សេចក្តីថា រមែងក្តៅក្រហាយក្នុងលោកនេះ ដោយហេតុត្រឹមតែទោមនស្ស ដោយការក្តៅក្រហាយព្រោះកម្ម ។

បទថា **បេច្ច** សេចក្តីថា ចំណែកក្នុងលោកខាងមុខ រមែងក្តៅក្រហាយព្រោះទុក្ខក្នុងអបាយដ៏ខ្លាំងក្លាក្រៃលែង ដោយការក្តៅក្រហាយព្រោះវិបាក ។

បទថា **បាបការី** សេចក្តីថា អ្នកធ្វើបាបមានប្រការផ្សេងៗ ។

បទថា **ឧភយត្ថ** សេចក្តីថា ឈ្មោះថា រមែងក្តៅក្រហាយក្នុងលោកទាំងពីរ ដោយការក្តៅក្រហាយ មានប្រការដូចពោលហើយ ។

ពីរបទថា **បាបំ មេ** សេចក្តីថា អ្នកមានប្រក្រតីធ្វើបាបនោះ កាលក្តៅក្រហាយដោយការក្តៅក្រហាយព្រោះកម្ម ឈ្មោះថា រមែងក្តៅក្រហាយដោយគិតថា កម្មអាក្រក់អញធ្វើហើយ នោះជាការក្តៅក្រហាយមានប្រមាណតិចតួច តែកាលក្តៅក្រហាយដោយការក្តៅក្រហាយព្រោះវិបាក ឈ្មោះថាទៅកាន់ទុគ្គតិ រមែងក្តៅក្រហាយក្រៃលែងឡើង គឺរមែងក្តៅក្រហាយពន់ពេកដោយការក្តៅក្រហាយដ៏ទារុណក្រៃលែង ។

ក្នុងកាលចប់គាថា មហាជនបានជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើមហើយ ទេសនាបានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ॥

រឿងនេវឧត្ត ចប់

រឿង នាងសុមនាទេវី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងសុមនាទេវី ត្រាស់ព្រះធម្មទេសនានេះថា **ឥធ នន្ទតិ បេច្ច នន្ទតិ** ជាដើម ។

សេចក្តីពិស្តារថា ភិក្ខុ ២ ពាន់រូប តែងធាន់ក្នុងផ្ទះរបស់អនាថបិណ្ឌិក-សេដ្ឋី ក្នុងក្រុងសាវត្ថីរាល់ថ្ងៃ ក្នុងផ្ទះរបស់នាងវិសាខាមហាឧបាសិកា ក៏ដូចគ្នា ។ បុគ្គលណាម្នាក់ក្នុងក្រុងសាវត្ថី ជាអ្នកបំណងនឹងថ្វាយទាន បុគ្គលនោះៗ ត្រូវបានឱកាសរបស់ជនទាំងពីរនោះមុនហើយ ទើបធ្វើបាន ។

សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះបុគ្គលជនៃៗ សួរថា អនាថ-បិណ្ឌិកសេដ្ឋី ឬនាងវិសាខាមកកាន់ភោងទានរបស់អ្នកហើយឬ កាលជននោះឆ្លើយថា មិនបានមក រមែងតិះដៀល ទោះបីបុគ្គលនោះលះទ្រព្យរាប់សែនហើយធ្វើ ក៏អ្នកស្រុកនៅតែពោលថា នេះឈ្មោះថា ទានអ្វី ព្រោះលោកទាំងពីរនោះ រមែងជីងការគាប់ចិត្តរបស់ភិក្ខុសង្ឃ និងកិច្ចដែលសមគួរដល់ភិក្ខុសង្ឃ ។ កាលលោកទាំងពីរនោះ នៅក្នុងទីនោះ ពួកភិក្ខុរមែងធាន់បានតាមពេញចិត្តនោះឯង ព្រោះដូច្នោះបុគ្គលគ្រប់គ្នា បំណងនឹងថ្វាយទាន ទើបអញ្ជើញជនទាំងពីរនោះទៅ ។ ជនទាំងពីរនោះរមែងមិនបានអង្គាសភិក្ខុទាំងឡាយក្នុងផ្ទះរបស់ខ្លួនដោយហេតុនេះ ព្រោះហេតុនោះ នាងវិសាខា កាលពិចារណាថា នរណាហ្ន៎នឹងតាំងនៅក្នុងកិច្ចរបស់អញ អង្គាសភិក្ខុសង្ឃ ឃើញចៅស្រីហើយទើបតាំងទុកក្នុងនាទីរបស់ខ្លួន នាងអង្គាសភិក្ខុសង្ឃក្នុងផ្ទះរបស់នាងវិសាខានោះ ។

សូម្បីអនាថបិណ្ឌិកសេដ្ឋី ក៏តាំងកូនស្រីច្បងឈ្មោះមហាសុភទ្ទា ។ នាង មហាសុភទ្ទានោះ ធ្វើការទ្រលំទ្វាយជល់កិក្ខុទាំងឡាយ និងស្តាប់ធម៌បានជា ព្រះសោតាបន្នហើយ ទៅកាន់ត្រកូលស្វាមី ។

បន្ទាប់អំពីនោះ អនាថបិណ្ឌិកក៏តាំងនាងចូឡសុភទ្ទាជំនួស ។ សូម្បី នាងចូឡសុភទ្ទានោះ ក៏ធ្វើយ៉ាងនោះដូចគ្នា ជាព្រះសោតាបន្នហើយ ក៏ទៅ កាន់ត្រកូលនៃស្វាមី ។ លំដាប់នោះ ទើបអនាថបិណ្ឌិកតាំងធីតាពៅឈ្មោះ សុមនាទេវីជំនួស ។

នាងសុមនាទេវីនោះ ស្តាប់ធម៌ហើយសម្រេចសកទាគាមិផល ទាំងនៅ ជាកុមារិកានោះឯង រសាប់រសល់ដោយការមិនផាសុកបៃបនោះ កាត់អាហារ មានបំណងនឹងឃើញបិតា ទើបឲ្យអញ្ជើញមក ។ លោកសេដ្ឋី លុះបានឮ ដំណឹងរបស់កូនស្រីក្នុងរោងទានមួយកន្លែង ក៏មករកហើយនិយាយថា នែ សុមនា នាងកើតអ្វីឬ នាងសុមនាឆ្លើយថា មិនជាការថ្លៃទេបួនប្រុស បិតាសួរ ថា នាងរវើរវាយហើយឬ សុមនាឆ្លើយថា មិនរវើរវាយទេបួនប្រុស បិតា ពោលថា នាងខ្លាចឬ ធីតាឆ្លើយថា មិនខ្លាចទេបួនប្រុស លុះនាងសុមនាទេវី ពោលបានប៉ុណ្ណោះ ក៏ធ្វើកាលកិរិយាហើយ ។

លោកសេដ្ឋីនោះ សូម្បីជាព្រះសោតាបន្ន ក៏មិនអាចអត់សង្កត់សេចក្តី សោកដែលកើតក្នុងធីតាបាន ធ្វើការបូជាសពធីតាស្រេចហើយ ទ្រហោយំ ទៅកាន់សម្នាក់ព្រះសាស្តា កាលព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលគហបតី ហេតុអ្វីទើបអ្នកជាទុក្ខទោមនស្ស មានមុខជោកដោយទឹកភ្នែកមកហើយ ទើប

ក្រាបទូលថា បពិត្រព្រះអង្គ នាងសុមនាទេវីកូនស្រីរបស់ខ្ញុំព្រះអង្គ ធ្វើកាល-កិរិយាហើយ ។ ព្រះសាស្តាត្រាស់ថា បើដូច្នោះ ហេតុអ្វីទើបអ្នកសោយសោក សេចក្តីស្លាប់រមែងប្រព្រឹត្តទៅដោយចំណែកមួយ ដល់សព្វសត្វមិនមែនឬ ។ អនាថបិណ្ឌិកឆ្លើយថា បពិត្រព្រះអង្គ សេចក្តីនោះខ្ញុំព្រះអង្គជ្រាបហើយ តែ ធីតារបស់ខ្ញុំព្រះអង្គដល់ព្រមដោយហិរិ និងឱត្តប្បៈបែបនេះ ក្នុងវេលាទៀប ស្លាប់ នាងមិនអាចគ្រប់គ្រងសតិបានឡើយ រវើរវាយស្លាប់ទៅហើយ ដោយ ហេតុនោះ ទោមនស្សមិនមែនតិច កើតដល់ខ្ញុំព្រះអង្គ ។ ព្រះសាស្តាត្រាស់ ថា ម្នាលគហបតី នាងនិយាយអ្វីខ្លះ ។ អនាថបិណ្ឌិកសេដ្ឋីពោលថា បពិត្រ ព្រះអង្គ ខ្ញុំព្រះអង្គហៅនាងថា នាងកើតអ្វីឬ ពេលនោះនាងក៏ពោលនឹងខ្ញុំព្រះ អង្គថា មិនជាការថ្វីឡើយបុនប្រុស បន្ទាប់អំពីនោះ កាលខ្ញុំព្រះអង្គពោលថា នាងរវើរវាយឬ ក៏ឆ្លើយថា មិនរវើរវាយទេបុនប្រុស កាលខ្ញុំព្រះអង្គសួរថា នាងខ្លាចឬ ក៏ឆ្លើយថា មិនខ្លាចទេបុនប្រុស លុះពោលបានត្រឹមណេះ ក៏ ធ្វើកាលកិរិយាហើយ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់នឹងសេដ្ឋីនោះថា ម្នាលគហបតី កូនស្រីរបស់អ្នកមិនមែនរវើរវាយឡើយ ។ អនាថបិណ្ឌិកសេដ្ឋីពោលថា ហេតុ អ្វីទើបនាងពោលយ៉ាងនោះ ។ ព្រះសាស្តាត្រាស់ថា ព្រោះអ្នកជាបុនប្រុស របស់នាងពិត ។ ម្នាលគហបតី កូនស្រីរបស់អ្នកជាធំជាងអ្នកដោយមគ្គ និង ផល ព្រោះអ្នកត្រឹមតែជាសោតាបន្ន ចំណែកធីតារបស់អ្នក ជាសកទាគាមី ព្រោះនាងជាធំដោយមគ្គ និងផល ទើបនាងពោលយ៉ាងនោះ ។ អនាថបិណ្ឌិក-

សេដ្ឋីពោលថា យ៉ាងនោះឬព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលគហបតី យ៉ាងនោះឯង ។ អនាថបិណ្ឌិកសេដ្ឋីពោលថា ពេលនេះ នាងកើតក្នុងទីណា ព្រះអង្គ ។ កាលព្រះសាស្តាត្រាស់ថា ម្នាលគហបតី ក្នុងស្ថានតុសិត ទើប លោកសេដ្ឋីទូលថា កូនស្រីរបស់ខ្ញុំព្រះអង្គត្រេកអរក្នុងពួកញាតិ ក្នុងលោក នេះ សូម្បីទៅអំពីលោកនេះហើយ កើតក្នុងទីដែលត្រេកអរដូចគ្នាឬ ។ គ្រា នោះ ព្រះសាស្តាត្រាស់ទីឆសេដ្ឋីនោះថា ម្នាលគហបតី ធម្មតាបុគ្គលមិន ប្រមាទ ជាគ្រហស្តក្តី ជាបព្វជិតក្តី រមែងត្រេកអរក្នុងលោកនេះ និងលោក ខាងមុខពិត ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ឥធ នន្ទតិ បេច្ច នន្ទតិ កតបុញ្ញោ ឧភយត្ថ នន្ទតិ
បុញ្ញំ មេ កតន្តិ នន្ទតិ ភិយ្យោ នន្ទតិ សុគតឹ គតោ ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរក្នុងលោកទាំងពីរ គឺត្រេកអរ ក្នុងលោកនេះ ១ ត្រេកអរក្នុងលោកខាងមុខ ១ បុគ្គលនោះរមែង ត្រេកអរដោយគិតឃើញថា បុណ្យអញបានធ្វើហើយ លុះធ្វើ មរណកាលទៅកាន់សុគតិ ក៏រីងរឹតតែត្រេកអរជ៏ក្រៃលែង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឥធ** *សេចក្តីថា រមែងត្រេកអរក្នុងលោកនេះ ដោយការត្រេកអរព្រោះកម្ម ។*

បទថា **បេច្ច** *សេចក្តីថា រមែងត្រេកអរក្នុងលោកខាងមុខ ដោយការ ត្រេកអរព្រោះវិបាក ។*

បទថា **កតបុញ្ញោ** គឺធ្វើបុណ្យ មានប្រការផ្សេងៗ ។

បទថា **ឧភយត្ត** សេចក្តីថា រមែងត្រេកអរក្នុងលោកនេះ ដោយគិតថា កុសលអញធ្វើហើយ បាបអញមិនបានធ្វើ កាលសោយវិបាក ឈ្មោះថា រមែងត្រេកអរក្នុងលោកខាងមុខ ។

ពីរបទថា **បុញ្ញំ មេ** សេចក្តីថា កាលត្រេកអរក្នុងលោកនេះ ឈ្មោះថា រមែងត្រេកអរ ព្រោះអាស្រ័យការត្រេកអរព្រោះកម្ម ដោយហេតុត្រឹម សោមនស្សប៉ុណ្ណោះថា បុណ្យអញធ្វើហើយ ។

បទថា **ភិយ្យោ** ជាដើម សេចក្តីថា បុគ្គលនោះទៅកាន់សុគតិហើយ កាលសោយទិព្វសម្បត្តិអស់ ៥៧ កោដិ ៦០ សែនឆ្នាំខ្ទះ ឈ្មោះថា ត្រេកអរយ៉ាងក្រៃលែងក្នុងតុសិតបុរី ដោយការត្រេកអរ ព្រោះវិបាក ។

ក្នុងកាលចប់គាថា ជនជាច្រើនបានជាអរិយបុគ្គល មានសោតាបន្ន ជាដើម ហើយព្រះធម្មទេសនាបានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

រឿង នាងសុមនាទេវី ចប់

រឿង ភិក្ខុជាសម្ចាញ់នឹងគ្នាពីរនាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុពីររូបដែលជាសម្ចាញ់នឹងគ្នា ត្រាស់ព្រះធម្មទេសនានេះថា **ពហុម្ឈិ ចេ ហសិតំ**

ភាសមានោ ដូច្នេះជាដើម ។

សេចក្តីពិស្តារថា កុលបុត្រពីរនាក់ដែលជាអ្នកក្រុងសាវត្ថី ជាសម្លាញ់នឹងគ្នាទៅកាន់វិហារ ស្តាប់ធម្មទេសនារបស់ព្រះសាស្តា ហើយលះកាមទាំង-ទ្បាយ ថ្វាយជីវិតក្នុងព្រះសាសនារបស់ព្រះសាស្តា បួសហើយនៅក្នុងសម្នាក់អាចារ្យ និងឧបជ្ឈាយ៍គ្រប់ ៥ ឆ្នាំហើយ ចូលទៅគាល់ព្រះសាស្តាទូលសួរដល់ធុរៈក្នុងសាសនា បានស្តាប់វិបស្សនាធុរៈ និងគន្ថធុរៈដោយពិស្តារហើយ ១ រូបក្រាបទូលមុនថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបួសហើយ ក្នុងកាលឯចាស់ មិនអាចបំពេញធុរៈបាន តែបំពេញវិបស្សនាធុរៈបាន ដូច្នេះហើយ ទូលឲ្យព្រះសាស្តាត្រាស់ប្រាប់វិបស្សនារហូតដល់អរហត្ត ហើយព្យាយាមសម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងទ្បាយ ។

ចំណែកសម្លាញ់មួយអង្គទៀតគិតថា អញនឹងបំពេញគន្ថធុរៈ ដូច្នេះហើយរៀនព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកដោយលំដាប់ ពោលធម៌សូត្រសរភញ្ញក្នុងទីដែលខ្លួនទៅហើយ ប្រាប់ធម៌ដល់ភិក្ខុ ៥០០ បានជាអាចារ្យរបស់មហាគណៈ ១៨ គណៈ ។

ភិក្ខុទាំងទ្បាយ រៀនព្រះកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ទៅកាន់លំនៅរបស់ព្រះថេរៈក្រៅអំពីនេះ គឺព្រះថេរៈដែលបំពេញវិបស្សនា តាំងនៅក្នុងឱវាទរបស់លោក សម្រេចអរហត្តហើយ នមស្ការព្រះថេរៈ ប្រាប់ថាយើងខ្ញុំប្រុថ្នានឹងគាល់ព្រះសាស្តា ។

ព្រះថេរៈពោលថា នែអាវុសោ អ្នកទាំងទ្បាយចូរទៅចុះ ចូរថ្វាយបង្គំ

ព្រះសាស្តា នមស្ការព្រះមហាថេរៈទាំង ៨០ រូប តាមពាក្យរបស់ខ្ញុំ ចូរជ្រាប់សម្ងាញ់របស់ខ្ញុំថា លោកអាចារ្យរបស់យើងខ្ញុំនមស្ការលោកម្ចាស់ ដូច្នេះហើយបញ្ជូនទៅ ។ ភិក្ខុទាំងនោះទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្តា នមស្ការព្រះអសីតិមហាថេរៈហើយ ទៅកាន់សម្នាក់ព្រះគន្ធកុត្តេរជ្រាប់ថា បពិត្រលោកម្ចាស់ លោកអាចារ្យរបស់ពួកខ្ញុំនមស្ការដល់លោកម្ចាស់ កាលព្រះថេរៈសួរថា លោកអាចារ្យរបស់ពួកអ្នកនោះជាអ្នកណា ភិក្ខុទាំងនោះជ្រាប់ថា ជាសម្ងាញ់របស់លោកម្ចាស់ ។

កាលព្រះថេរៈបញ្ជូនដំណឹងសួរសុខទុក្ខនេះរឿយៗ ភិក្ខុនោះអត់ធន់បានអស់កាលតិចតួច ក្រោយមកមិនអាចអត់ធន់បាន កាលពួកអាគន្តុកភិក្ខុជ្រាប់ថា លោកអាចារ្យរបស់ពួកខ្ញុំនមស្ការលោកម្ចាស់ ដូច្នេះហើយ ទើបពោលថា អាចារ្យរបស់ពួកអ្នកជាអ្នកណា ភិក្ខុទាំងឡាយជ្រាប់ថា ជាសម្ងាញ់របស់លោកម្ចាស់ ទើបពោលថា នេះអ្វីហ្ន៎ ដែលពួកអ្នករៀនក្នុងសម្នាក់របស់ភិក្ខុនោះ បណ្តានិកាយ មានទីឃនិកាយជាដើម និកាយណាមួយ លោកចេះឬ បណ្តាបិដក ៣ បិដកណាមួយ លោកចេះឬ ពួកអ្នកបានហើយឬ ដូច្នេះហើយ គិតថា សម្ងាញ់របស់អញរមែងមិនចេះសូម្បីគាថា ប្រកបដោយបទ ៤ សមាទានបង្សុកូលក្នុងព្រៃ តាំងអំពីបួសហើយ គង់បានអន្តេវាសិកច្រើនហ្ន៎ ក្នុងកាលដែលលោកមក អញគួរសួរបញ្ហាល្បងមើល ។

សម័យក្រោយមក ព្រះថេរៈវិបស្សកៈ បានមកគាល់ព្រះសាស្តា ទុកជាក់ជាត្រ និងចីវរក្នុងសម្នាក់ព្រះថេរៈជាសម្ងាញ់ហើយ ទៅថ្វាយបង្គំព្រះ

សាស្តា និងនមស្ការព្រះអសីតិ និងមហាថេរៈហើយ ក៏ត្រឡប់មកលំនៅ របស់ព្រះថេរៈដែលជាសម្ងាញ់ លំជាប់នោះ ព្រះគន្ធិកត្តេរឲ្យភិក្ខុទាំងឡាយ ធ្វើវត្តដល់លោក ហើយកាន់យកអាសនៈសមគួរប៉ុណ្ណោះ អង្គុយហើយ ដោយតាំងចិត្តថា នឹងសួរប្រស្នា ។

ខណៈនោះ ព្រះសាស្តាទ្រង់ជ្រាបថា គន្ធិកភិក្ខុនេះគប្បីបៀតបៀនបុត្រ តថាគត ដែលមានសភាពបែបនេះ ហើយកើតក្នុងនរក ដោយទ្រង់ករុណា ទ្រង់ធ្វើហាក់ដូចចារិកទៅក្នុងវិហារ យាងដល់ទីដែលភិក្ខុទាំងពីរគង់ហើយ ប្រថាប់គង់លើពុទ្ធាសនៈដែលគេរៀបចំ ។ ពិតហើយ ភិក្ខុទាំងឡាយកាល អង្គុយក្នុងទីនោះៗ រៀបចំអាសនៈសម្រាប់ព្រះពុទ្ធមុនហើយទើបគង់ ។ ព្រោះ ហេតុនោះ ទើបព្រះសាស្តាប្រថាប់គង់លើអាសនៈដែលព្រះគន្ធិកភិក្ខុនោះ រៀបចំដោយប្រក្រតីនោះឯង ។ កាលប្រថាប់គង់ហើយ ទើបត្រាស់សួរបញ្ហា ក្នុងបឋមជ្ឈានដល់ព្រះគន្ធិកភិក្ខុ កាលលោកទូលតបមិនបាន ទើបត្រាស់សួរ បញ្ហាក្នុងរូបសមាបត្តិ និងអរូបសមាបត្តិទាំង ៨ តាំងអំពីទុតិយជ្ឈានជាដើម ទៅ ព្រះគន្ធិកត្តេរក៏មិនអាចឆ្លើយបាន សូម្បីត្រឹមតែមួយប្រស្នា ។ ព្រះ វិបស្សកត្តេរទូលតបបញ្ហានោះបានទាំងអស់ ។

ពេលនោះ ព្រះសាស្តាត្រាស់សួរបញ្ហាក្នុងសោតាបត្តិមគ្គ ព្រះគន្ធិកត្តេរ ក៏មិនអាចទូលឆ្លើយបាន បន្ទាប់អំពីនោះ ទើបត្រាស់សួរព្រះខីណាស្រព ព្រះ ថេរៈក៏ឆ្លើយបាន ។

ព្រះសាស្តាទ្រង់សរសើរថា សាធុ សាធុ ហើយត្រាស់សួរបញ្ហាក្នុងមគ្គ

ដ៏សេសទាំងឡាយដោយលំដាប់ ព្រះគន្ធិកត្ថេរក៏មិនអាចទូលឆ្លើយបញ្ហាបានសូម្បីត្រឹមតែមួយ ចំណែកព្រះខីណាស្រពឆ្លើយបញ្ហាដែលគ្រាស់សួរហើយបានទាំងអស់ ។ ព្រះសាស្តាបានប្រទានសាធុការដល់ព្រះខីណាស្រពនោះក្នុងហានៈទាំង ៤ ។ ទេវតាទាំងឡាយ តាំងអំពីភុម្មទេវតា រហូតដល់ព្រហ្មលោកនាគក្តី គ្រុឌក្តី បានស្តាប់សាធុការនោះហើយ ក៏បានឲ្យសាធុការ ។

ពួកអន្តេវាសិក និងសទ្ធិវិហារិករបស់ព្រះគន្ធិកត្ថេរ បានស្តាប់សាធុការនោះហើយ ទើបពោលទោសព្រះសាស្តាថា ព្រះសាស្តាទ្រង់ធ្វើកម្មអ្វីដូច្នេះ ទ្រង់បានប្រទានសាធុការដល់ព្រះមហល្លកត្ថេរ ដែលមិនចេះដឹងអ្វីសោះក្នុងហានៈទាំង ៤ ចំណែកលោកអាចារ្យរបស់ពួកយើង ដែលទ្រទ្រង់នូវព្រះបរិយត្តិធម៌បានទាំងអស់ ជាប្រធាននៃភិក្ខុប្រមាណ ៥០០ រូប ព្រះអង្គមិនបានធ្វើ សូម្បីត្រឹមតែការសរសើរ ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលអ្វី កាលភិក្ខុទាំងនោះក្រាបទូលសេចក្តីនោះហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាចារ្យរបស់ពួកអ្នក ដូចអ្នករក្សាគោទាំងឡាយ ដើម្បីថ្លៃឈ្នួលក្នុងសាសនារបស់តថាគត ចំណែកបុត្ររបស់តថាគត ដូចម្ចាស់បរិភោគបញ្ចូគោរសតាមគាប់ចិត្ត ដូច្នេះហើយ បានភាសិតព្រះគាថាទាំងឡាយថា

ពហុម្បិ ចេ សហិតំ ភាសមានោ ន តក្ករោ ហោតិ នរោ បមត្តោ
គោគោវ គារោ គណយំ បរេសំ ន ភាគវា សាមញ្ញស្ស ហោតិ

អប្បម្បិ ចេ សហិតំ ភាសមានោ ធម្មស្ស ហោតិ អនុធម្មចារី
រាគញ្ច ទោសញ្ច បហាយ មោហំ សម្មប្បជានោ សុវិមុត្តចិត្តោ
អនុបាទិយានោ ឥធ វា ហុរំ វា សភាគវា សាមញ្ញស្ស ហោតិ ។

បើនរជនពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីច្រើន តែជាអ្នកប្រមាទ មិនធ្វើតាមពាក្យនោះ រមែងជាអ្នកមិនមានចំណែកសាមញ្ញ-ផលឡើយ ដូចអ្នករក្សាគោ កាលរាប់គោប្រគល់ឲ្យអ្នកដទៃហើយ (ជាអ្នកមិនបានបរិភោគនូវបញ្ចគោរស) ជួញ្ជោះឯង ។ បើនរជនពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តនូវធម៌សមគួរដល់ធម៌ បានលះបង់រាគៈ ទោសៈ និងមោហៈ ជាអ្នកដឹងនូវធម៌ដែលគួរកំណត់តាមហេតុ មានចិត្តដកផុតអំពីសេចក្តីសៅហ្មង មិនមានសេចក្តីប្រកាន់មាំក្នុងលោកនេះ និងលោកខាងមុខ នរជននោះ រមែងជាអ្នកបាននូវចំណែកសាមញ្ញផល ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សហិតំ** *នេះ ជាឈ្មោះនៃព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក នរជនចូលទៅរកអាចារ្យទាំងឡាយ រៀននូវពុទ្ធវចនៈនោះហើយពោល គឺច្រាប់ បានដល់ សម្តែងនូវព្រះពុទ្ធវចនៈ សូម្បីច្រើនដល់ជនដទៃ តែជាបុគ្គលដែលមិនធ្វើកិច្ច ដែលការកបុគ្គលស្តាប់ធម៌នោះហើយ គប្បីធ្វើ គឺមិនញុំាងការធ្វើទុកក្នុងចិត្តឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម សូម្បីត្រឹមតែមួយខណៈមាន់ទន្ទេះស្លាប នរជននោះ*

រមែងជាបុគ្គលមានចំណែកនៃផល ត្រឹមតែការធ្វើវត្ត បដិវត្តអំពីសម្នាក់នៃអន្តេវាសិកទាំងឡាយតែម្យ៉ាង តែមិនជាបុគ្គលមានចំណែកនៃគុណរបស់សមណៈទេ្បីយ ដូចអ្នកឃ្វាលគោ រក្សាគោទាំងឡាយដើម្បីថ្លៃឈ្នួលប្រចាំថ្ងៃ ទទួលទៅអំពីព្រឹក វេលាល្ងាចរាប់ប្រគល់ឲ្យដល់ម្ចាស់ទាំងឡាយ ហើយទទួលយកត្រឹមតែថ្លៃឈ្នួលប្រចាំថ្ងៃ តែមិនបានបរិភោគបញ្ចោរសតាមគាប់ចិត្តដូច្នោះឯង ។

ម្ចាស់គោពួកខ្លះ រមែងបរិភោគបញ្ចោរសនៃគោទាំងឡាយ ដែលនាយគោបាលប្រគល់ឲ្យហើយ យ៉ាងណា ការកបុគ្គលទាំងឡាយ ស្តាប់ធម៌ដែលនរជននោះពោលហើយ បដិបត្តិតាមនរជននោះប្រៀនប្រដៅហើយ ក៏ដូច្នោះ ពួកខ្លះសម្រេចបឋមជ្ឈានជាដើម ពួកខ្លះចម្រើនវិបស្សនាហើយ សម្រេចមគ្គផល រាប់ថាជាចំណែកនៃគុណរបស់សមណៈ ដូចម្ចាស់គោទាំងឡាយ រមែងជាអ្នកមានចំណែកនៃគោរស ដូច្នោះ ។ ព្រះសាស្តាត្រាស់គាថាទី ១ ដោយអំណាចនៃភិក្ខុសម្បូរដោយសីល ជាអ្នកមានសុតៈច្រើន តែមានប្រក្រតីនៅដោយការប្រមាទ មិនប្រព្រឹត្តហើយក្នុងយោនិសោមនសិការ ដោយអំណាចនៃត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម មិនមែនត្រាស់ដោយអំណាចនៃភិក្ខុទុស្តសីលទេ្បីយ ដោយប្រការដូច្នេះ ។

ចំណែកគាថាទី ២ ទ្រង់ត្រាស់ដោយអំណាចនៃការកបុគ្គល ដែលមានសុតៈតិច តែធ្វើកម្មក្នុងយោនិសោមនសិការ ។

ក្នុងបទទាំងនោះ បទថា **អប្បម្បិ** ចេ សេចក្តីថា តិច គឺសូម្បីត្រឹមមួយ

វគ្គ ឬក៏ពីរវគ្គ ។

បានព្រះគាថាថា **ធម្មស្ស ហោតិ អនុធម្មចារី** *ជាដើម សេចក្តីថា នរជនដឹងអត្ថ ដឹងធម៌ហើយ ប្រព្រឹត្តធម៌សមគួរដល់លោកុត្តរធម៌ ៩ គឺប្រភេទនៃធម៌ មានបារិសុទ្ធិសីល ៤ ធុតង្គគុណ និងអសុភកម្មដ្ឋានជាដើម ក៏រាប់ថាជាបដិបត្តិនៃចំណែកខាងដើម រមែងជាបុគ្គលឈ្មោះថា មានប្រក្រតីប្រព្រឹត្តធម៌សមគួរ គឺសង្ឃឹមបាននូវការចាក់ផ្លុះថា អាត្មាអញនឹងចាក់ផ្លុះក្នុងថ្ងៃនេះ អាត្មាអញនឹងចាក់ផ្លុះក្នុងថ្ងៃនេះ នោះឯងឈ្មោះថា រមែងប្រព្រឹត្ត ។ នរជននោះលះរាគៈ ទោសៈ និងមោហៈដោយសម្មាបដិបទានេះហើយ កំណត់ដឹងធម៌ដែលគួរកំណត់ដឹងដោយប្រពៃ ដោយហេតុ ដោយនយ មានចិត្តរួចផុតល្អហើយ ដោយអំណាចនៃតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិ-វិមុត្តិ និងនិស្សរណវិមុត្តិ ។ អស់នូវការប្រកាន់មាំក្នុងលោកនេះ ឬក្នុងលោកដទៃ គឺមិនចូលទៅប្រកាន់ខន្ធ អាយតនៈ និងធាតុទាំងឡាយដែលទាក់ទងក្នុងលោកនេះ និងលោកដទៃ ឬដែលជាខាងក្នុង និងខាងក្រៅដោយ ឧបាទាន ៤ ឈ្មោះថា ជាមហាខីណាស្រព រមែងជាអ្នកមានចំណែកនៃគុណរបស់សមណៈ គឺផលដែលមកហើយដោយអំណាចនៃគុណរបស់សមណៈ ពោលគឺមគ្គ និងគុណរបស់សមណៈ គឺគំនរនៃអសេក្ខធម៌ ៥ (គឺសីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញ្ញាណទស្សនក្ខន្ធ) ។*

ព្រះសាស្តាទ្រង់រួបរួមកំពូលនៃទេសនា ដោយអរហត្ត ដូចមេជាងកាន់យកកំពូលនៃផ្ទះ ដោយកំពូលកែវ ដូច្នោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានជាអរិយបុគ្គល មានសោតាបន្ន ជាដើម ។ ទេសនាមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

រឿងភិក្ខុជាសម្ងាញ់ឆឹងគ្នាពីរនាក់ ចប់

យមកវគ្គទី ១ ចប់

សុត្តន្តបិដក

ធម្មបទគាថា អប្បមាទវគ្គទី ២

[១២] សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថា មិនស្លាប់ ជនទាំងឡាយ ដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិតបានជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា (ទើបស្ថិតនៅ) ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរ ក្នុងធម៌ជាគោចរ នៃអរិយបុគ្គលទាំងឡាយ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងប៉ះពាល់នូវព្រះនិព្វាន ជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាតដ៏ប្រសើរបំផុត ។ យសតែងចម្រើនកុះករ ដល់បុគ្គលអ្នកមានសេចក្តីប្រឹងប្រែង មានស្មារតី មានការងារស្អាត (ឥតទោស) ជាអ្នកពិចារណារួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌ មិនមានសេចក្តីប្រមាទ ។ អ្នកប្រាជ្ញគប្បីសាងកោះ គឺអរហត្តផល ជាកោះដែលជំនន់ គឺកិលេសជន់ពន្ធិចមិនបាន ដោយសេចក្តីប្រឹងប្រែងផង ដោយសេចក្តីមិនប្រមាទផង ដោយការសង្រួមក្នុងចតុប្បារិសុទ្ធិសីលផង ដោយការទូន្មានឥន្ទ្រិយផង ។ ពួកជនពាលអប្បឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញរមែងរក្សាទុកនូវសេចក្តីមិនប្រមាទ ដូចទ្រព្យយ៉ាងប្រសើរ ។ អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗ នូវសេចក្តីប្រមាទ ចូរកុំប្រកបរឿយៗ នូវសេចក្តីរីករាយ

ត្រេកអរក្នុងកាមទ្បើយ ដ្បិតបុគ្គលអ្នកមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបានសេចក្តីសុខដ៏ទូលាយ ។

កាលណាបណ្ឌិត បន្ទោបង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ កាលនោះ លោកនឹងទ្បើងកាន់ប្រាសាទ គឺបញ្ញា ជាបុគ្គលមិនសោក រមែងឃើញពួកសត្វដែលមានសោក ធីរជនតែងឃើញពួកជនពាល ដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើលពួកជនដែលស្ថិតនៅលើផែនដីជុំវិញ ។

បណ្ឌិតមានប្រាជ្ញាមោះមុត កាលពួកបុគ្គលកំពុងប្រមាទ លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោកភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែបនោះ ដូចសេះល្បើនដែលទៅចោលនូវសេះ មានកម្លាំងទន់ទាប ជុំវិញ ។

មឃមាណព ដល់នូវភាពជាបុគ្គលប្រសើរបំផុត ជាងទេវតាទាំង-ទ្បាយ ព្រោះតែសេចក្តីមិនប្រមាទ អ្នកប្រាជ្ញទាំងឡាយតែងសរសើរនូវសេចក្តីមិនប្រមាទ តុះតិះដៀលនូវសេចក្តីប្រមាទ សព្វៗ កាល ។ ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទ តែងដុតចោលសំយោជនៈ ទាំងតូចទាំងធំ ដូចភ្លើងឆេះ (វាលនូវកម្ទេចទាំងតូចទាំងធំ) ជុំវិញ ។

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យ ក្នុងសេចក្តីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ ឈ្មោះថា ស្ថិតនៅក្នុងទី

ជិតនៃព្រះនិព្វាន ។

អប្បមាទវគ្គទី ២ ចប់

អដ្ឋកថា

អប្បមាទវគ្គ

រឿង ព្រះនាងសាមាវតី

លំនាំដើម

ព្រះសាស្តា កាលអាស្រ័យក្រុងកោសម្ពី ប្រថាប់នៅនាឃោសិតារាម ទ្រង់ប្រារព្ធមរណៈរបស់ស្រី ៥០០ មានព្រះនាងសាមាវតីជាប្រធាន និងនៃញាតិ ៥០០ របស់នាងមាគន្ទិយានោះ ដែលមាននាងមាគន្ទិយាជាប្រធាន ទើបត្រាស់ព្រះធម្មទេសនានេះថា **អប្បមាទោ អមតំ បទំ** *ជាដើម ក្នុងរឿងនោះ មានអនុបុព្វីកថាដូចតទៅនេះ*

ក្នុងកាលកន្លងមកហើយ ព្រះរាជាពីរអង្គ គឺព្រះរាជាដែនអល្លកប្បៈ ទ្រង់ព្រះនាមអល្លកប្បៈ ក្នុងដែនវេដ្ឋទីបកៈ ព្រះនាមវេដ្ឋទីបកៈ ជាសម្ងាញ់និងគ្នាតាំងអំពីកំលោះ ទ្រង់សិក្សាសិប្បៈ ក្នុងសម្នាក់អាចារ្យតែមួយ ដោយព្រះរាជបិតាសោយទិវង្គតទៅរៀងៗ ខ្លួន បានលើកស្វេតឆត្រឡើងហើយ

គ្រងរាជ្យជាព្រះរាជាក្នុងជែន ក្នុងមួយជែនប្រមាណ ១០ យោជន៍ ។ ព្រះរាជាពីរអង្គនោះ យាងមកប្រជុំគ្នាសព្វកាលតាមកាល ទ្រង់ឈរ ទ្រង់អង្គុយ ទ្រង់ផ្ដួរមគ្នា ទតមហាជនដែលកើត និងស្លាប់ ទ្រង់ប្រឹក្សាគ្នាថា ឈ្មោះថាបុគ្គល តាមគ្នាទៅកាន់បរលោកមិនមាន ដោយទីបំផុត សូម្បីសរីរៈរបស់ខ្លួនក៏យកទៅមិនបាន ត្រូវលះវត្ថុទាំងពួងទៅ ប្រយោជន៍អ្វីដោយការនៅគ្រប់គ្រងផ្ទះរបស់យើង យើងនឹងបួស ដូច្នេះហើយ ទ្រង់ប្រគល់រាជសម្បត្តិឲ្យដល់ព្រះរាជឱរស និងអគ្គមហេសី ចេញបួសជាឥសី នៅក្នុងហិមវន្ត-ប្បទេស ទ្រង់ប្រឹក្សាគ្នាថា ពួកយើងមិនអាចរស់នៅ ទើបលះរាជសម្បត្តិចេញបួស ក៏មិនមែន ពួកយើងកាលនៅក្នុងទីតែមួយ ក៏ដូចអ្នកមិនបានបួសនោះឯង ព្រោះដូច្នោះ យើងនឹងបែកគ្នា អ្នកចូរនៅត្រង់ភ្នំនោះ ខ្ញុំនឹងនៅត្រង់ភ្នំនេះ តែជួបគ្នាក្នុងថ្ងៃឧបោសថ រាល់កន្លះខែ កាលនោះតាបសទាំងពីរនោះកើតសេចក្ដីត្រិះរិះឡើងយ៉ាងនេះថា កាលបើដូច្នេះ ការច្រឡូកច្រឡំដោយគណៈនឹងមានដល់យើងទាំងឡាយ អ្នកគប្បីដុតភ្លើងឲ្យឆេះឡើងត្រង់ភ្នំរបស់អ្នក ខ្ញុំក៏អុជភ្លើងឲ្យឆេះឡើងត្រង់ភ្នំរបស់ខ្ញុំ ដោយគ្រឿងសញ្ញានោះ យើងទាំងឡាយនឹងដឹងភាពដែលនៅមានជីវិត តាបសទាំងពីរនោះធ្វើយ៉ាងនោះហើយ ។

ក្នុងកាលដទៃ វេដ្ឋទីបកតាបសធ្វើកាលកិរិយា កើតជាទេវតាដែលមានសក្កិធំបន្ទាប់អំពីនោះ កាលដល់កន្លះខែ អល្លកប្បតាបសកាលមិនឃើញភ្លើងក៏ជ្រាបបានថា សម្ងាញ់របស់អញធ្វើកាលកិរិយាហើយ ។ សូម្បីវេដ្ឋទីបក

តាបស ក្រេឡកមើលទិព្វសិរីរបស់ខ្លួនក្នុងខណៈដែលកើត ពិចារណាដល់កម្ម ឃើញកិរិយាដែលខ្លួនធ្វើតាំងអំពីចេញបួសហើយ គិតថា ឥឡូវនេះអញនឹងទៅសួរសុខទុក្ខសម្លាញ់របស់អញ ។ ក្នុងខណៈនោះ ទើបលះអត្តភាពនោះហើយ ធ្វើហាក់ដូចមនុស្សវ័យឆ្វេងផ្លូវ ទៅកាន់សម្នាក់របស់អល្លកប្បតាបសនោះ ថ្វាយបង្គំហើយ បានឈរនៅក្នុងទីសមគួរ នាចំណែកម្ខាង ។ លំដាប់នោះ អល្លកប្បតាបសនោះសួរបុរសនោះថា អ្នកមកអំពីណា ។ បុរសនោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំជាមនុស្សវ័យឆ្វេងផ្លូវ ដើរមកអំពីទីឆ្ងាយពន់ពេក ចុះលោកម្ចាស់តែមួយរូបប៉ុណ្ណោះនៅក្នុងទីនេះឬ ឬមានអ្នកណាជាទៃខ្លះដែរទេ ។ តាបសពោលថា មានសម្លាញ់របស់ខ្ញុំម្នាក់ដែរ បុរសនោះសួរថា ចុះគាត់នៅឯណា ។ តាបសពោលថា គេនៅត្រង់ភ្នំនោះ តែថ្ងៃឧបោសថ គេមិនដុតភ្លើងឲ្យឆេះសោះ គេប្រហែលជាស្លាប់ហើយដោយពិត បុរសនោះឆ្លើយថា យ៉ាងនោះឬ លោកម្ចាស់ ។ តាបសពោលថា អើអ្នកយ៉ាងនោះឯង ។ បុរសនោះពោលថា ខ្ញុំគឺតាបសនោះលោកម្ចាស់ តាបសពោលថា ចុះអ្នកកើតក្នុងទីណា ។ បុរសនោះប្រាប់ថា ខ្ញុំកើតជាទេវតាមានសក្តិធំក្នុងទេវលោក មកនេះដោយបំណងថានឹងសួរសុខទុក្ខលោកម្ចាស់ តើលោកម្ចាស់នៅក្នុងទីនេះហេតុអាក្រក់ណាមួយ មានខ្លះដែរឬ ។ តាបសពោលថា អើ អាវុសោ ខ្ញុំលំបាកព្រោះជីវ ។ បុរសនោះពោលថា បពិត្រលោកម្ចាស់ ជីវធ្វើអ្វីដល់លោកម្ចាស់ ។ តាបសពោលថា ជីវបន្ទោបង់លាមកក្នុងទីដែលបោស យកជើងឈូសជីឲ្យហុយឡើង ខ្ញុំចាំជញ្ជូនអាចម៍ជីវចោល ចាំកៀរជីឲ្យស្មើ ក៏

រមែងលំបាក ។ បុរសនោះពោលថា តើលោកម្ចាស់ប្រាថ្នាមិនឲ្យដីរទាំងនោះមកដែរឬទេ តាបសពោលថា អើអាវុសោ ។ បុរសនោះពោលថា បើដូច្នោះខ្ញុំនឹងធ្វើមិនឲ្យដីរទាំងនោះមក ។ បានប្រគេនពិនសម្រាប់ឲ្យដីរស្រឡាញ់ និងបង្រៀនមន្តសម្រាប់ឲ្យដីរស្រឡាញ់ដល់តាបសហើយ កាលនឹងឲ្យ បានចង្អុលបង្ហាញខ្សែពិន ៣ ខ្សែ ឲ្យរៀនមន្ត ៣ បទ ហើយប្រាប់ថា កាលដេញខ្សែពិននេះ រាយមន្តបទនេះហើយ ដីរមិនអាចបែរក្រោយក្រឡេកមើល រមែងគេចទៅ កាលដេញពិនខ្សែនេះ រាយមន្តបទនេះហើយ ដីរនឹងបែរមើលក្រោយបណ្តើរ គេចទៅបណ្តើរ កាលដេញពិនខ្សែនេះ រាយមន្តបទនេះហើយ ដីរមេហ្វូងរមែងបង្អោនខ្លួនចូលមក ហើយពោលថា វត្ថុណាដែលលោកម្ចាស់គាប់ចិត្ត លោកម្ចាស់គប្បីធ្វើវត្ថុនោះចុះ ថ្វាយបង្គំតាបសហើយ ក៏ចៀសចេញទៅ ។

តាបសរាយមន្តសម្រាប់ដេញដីរ ផ្តាត់ខ្សែពិនសម្រាប់ដេញដីរ ញុំាងដីរឲ្យគេចទៅហើយ ។

ក្នុងសម័យនោះ ក្នុងក្រុងកោសម្ពី មានព្រះរាជាព្រះនាមបរន្តបៈ ។ ថ្ងៃមួយ ព្រះបាទបរន្តបៈគង់អាងកម្តៅថ្ងៃត្រង់ទីវាល ជាមួយព្រះរាជទេវី ដែលទ្រទ្រង់គភ៌ ព្រះរាជទេវីទ្រទ្រង់ដណ្តប់សំពត់កម្ពលក្រហម ដែលមានតម្លៃមួយសែន ដែលជាព្រះភូសារបស់ព្រះរាជា ព្រះនាងគង់ប្រាស្រ័យជាមួយព្រះរាជាដោះព្រះទម្រង់ដែលមានតម្លៃមួយសែន អំពីព្រះអង្គុលីរបស់ព្រះរាជា មកពាក់ក្នុងដៃរបស់ព្រះនាង ។

ក្នុងសម័យនោះ បក្សីហត្ថីលិង្គហើរមកតាមអាកាស ឃើញព្រះរាជទេវី ទើបសម្លុបស្ងាប ចោះពួយចុះដោយសម្គាល់ថាជាដុំសាច់ ព្រះរាជាទ្រង់កិតភ័យដោយសន្ធឹកបស់បក្សីនោះ ទើបទ្រង់ក្រោកចូលទៅខាងក្នុងព្រះរាជនិវេសន៍ ព្រះរាជទេវីមិនអាចទៅដោយរហ័សបាន ព្រោះទ្រង់គភ៌ចាស់ខែ និងព្រោះជាអ្នកមានជាតិនៃអ្នកមានជាតិជាអ្នកខ្លាច ។ គ្រានោះ ទើបបក្សីនោះធាបព្រះនាងនោះឲ្យគង់ក្នុងក្រចក ហើរទៅកាន់អាកាសហើយ ។ បានឮថា បក្សីទាំងនោះមានកម្លាំងស្មើនឹងជីរ ៥ ព្រោះដូច្នោះ ទើបនាំចំណីទៅតាមអាកាស ទំក្នុងទីដែលពេញចិត្តហើយ រមែងទំពាស៊ីនូវមំសៈ ។ ព្រះនាងកាលបក្សីនោះនាំទៅ ព្រះនាងភ័យខ្លាចចំពោះមរណភ័យ ទើបត្រិះរិះថា បើអញស្រែក ធម្មតាសំឡេងមនុស្សជាទីភ័យខ្លាចសម្រាប់សត្វតិរច្ឆាន សត្វនេះស្តាប់សំឡេងនេះហើយ និងទម្លាក់អញចោល កាលបើដូច្នោះ អញនឹងដល់នូវការអស់ជីវិតព្រមទាំងកូនក្នុងផ្ទៃ តែកាលសត្វនេះទំក្នុងទីណាហើយ ចាប់ផ្តើមស៊ីអញក្នុងទីនោះ អញនឹងស្រែក ហើយដេញឲ្យសត្វនេះគេចទៅ ព្រះនាងអត់ធ្មត់ទប់បាន ព្រោះភាពជាបណ្ឌិត ។ ក្នុងកាលនោះ ត្រង់ហោមវន្តប្បទេស មានដើមជ្រៃធំមួយ ចម្រើនឡើងបន្តិចម្តងៗ ហើយតាំងនៅដោយអាការដូចមណ្ឌប ។ បក្សីនោះនាំចំណី មានម្រឹគជាដើមទៅហើយ រមែងទំពាស៊ីត្រង់ដើមជ្រៃនោះ ព្រោះដូច្នោះ សត្វហត្ថីលិង្គនោះ នាំព្រះរាជទេវីទៅត្រង់ដើមជ្រៃនោះឯង ដាក់ក្នុងរវាងប្រគាបឈើ សម្លឹងមើលផ្លូវដែលខ្លួនហើរមកហើយ បានឮថា ការសម្លឹងមើលផ្លូវដែលហើរមកហើយ ជាធម្មតារបស់សត្វទាំងនោះ ក្នុងខណៈ

នោះ ព្រះទេវីព្រះតម្រិះថា ឥឡូវនេះ គួរបង្អើលបក្សីនេះឲ្យហើរទៅ ទើប ព្រះនាងលើកព្រះហស្តទាំងពីរឡើង ទះផង ស្រែកផង បក្សីនោះក៏ហើរទៅ ហើយ ។ គ្រានោះ ជាពេលព្រះអាទិត្យអស្តង្គត ខ្យល់កម្មជវាតបានតាំង ឡើងហើយក្នុងព្រះគភ៌របស់ព្រះទេវីនោះ មហាមេឃក៏គ្រហឹមគ្រប់ទិស ឈ្មោះ ថាការដេកលក់មិនមាន អស់រាត្រីហួតភ្លឺដល់ព្រះទេវីដែលតាំងនៅក្នុងសេចក្តី សុខ មិនបានសូម្បីត្រឹមតែពាក្យថា កុំខ្លាចឡើយព្រះនាង កាលសេចក្តីទុក្ខ គ្របសង្កត់ហើយ កាលរាត្រីអស់ហើយ ការស្រឡះអំពីវិលាហកក្តី ការរះ ឡើងនៃអរុណក្តី ការប្រសូតិនៃសត្វដែលនៅក្នុងគភ៌របស់ព្រះនាងក្តី មាន ហើយ ក្នុងខណៈតែមួយ ។ ព្រះនាងបានជាក់ឈ្មោះព្រះរាជឱរសថា ខរទេន ព្រោះកាន់យករជូវពពក និងរជូវអរុណរះប្រសូតហើយ ។

លំនៅរបស់អល្លកប្បតាបស ក៏នៅមិនឆ្ងាយអំពីទីនោះ ។ ដោយប្រក្រតី ក្នុងថ្ងៃមានភ្លៀង តាបសនោះរមែងមិនទៅព្រៃដើម្បីប្រយោជន៍ដល់ផលាផល ព្រោះចាញ់រងា ទៅកាន់គល់ឈើនោះ រើសឆ្អឹងម្រីគដែលបក្សីស៊ីហើយ ស្ងោរ ឲ្យមានរសហើយក៏បរិភោគ ព្រោះដូច្នោះក្នុងថ្ងៃនោះ តាបសក៏គិតថា នឹងរើស ឆ្អឹង ទើបទៅត្រង់គល់ឈើនោះ ហើយស្វែងរកឆ្អឹងត្រង់គល់ឈើ បានឮសំឡេង ទាវកខាងលើ ទើបឆ្ងៀងមើល ឃើញព្រះទេវី ទើបសួរថា នាងជាអ្នកណា ព្រះទេវីឆ្លើយថា ខ្ញុំជាស្រីមនុស្ស ។ តាបសសួរថា នាងមកបានដូចម្តេច កាលនាងពោលថា សត្វហត្ថីលិង្គនាំខ្ញុំមក ទើបពោលថា នាងចូរចុះមក ។ ព្រះទេវីពោលថា ខ្ញុំខ្លាចមកអំពីកំណើត តាបសពោលថា នាងជានរណា

ព្រះទេវីពោលថា ខ្ញុំជាម្ចាស់ក្សត្រីយ៍ តាបសពោលថា សូម្បីខ្ញុំក៏ជាស្តេចដូចគ្នា ព្រះទេវីពោលថា បើដូច្នោះ សូមអ្នកបង្ហាញនូវមាយាក្សត្រ តាបសនោះក៏បង្ហាញហើយ ព្រះទេវីពោលថា បើដូច្នោះ សូមលោកម្ចាស់ឡើងមក នាំកូនតូចរបស់ខ្ញុំចុះ ។ ព្រះតាបសនោះធ្វើផ្លូវឡើងដោយចំណែកម្ខាង ឡើងទៅហើយ ទទួលទាវក កាលព្រះទេវីពោលថា កុំយកដៃពាល់ខ្ញុំ ក៏មិនពាល់ព្រះនាង បីទាវកចុះមក សូម្បីព្រះរាជទេវីក៏ចុះហើយ ។ គ្រានោះ តាបសនាំនាងទៅកាន់អាស្រមបទ មិនធ្វើសីលភេទឡើយ ទំនុកបម្រុងហើយដោយសេចក្តីអនុគ្រោះ នាំទឹកឃ្មុំដែលមិនមានមេមក នាំស្រូវសាលីដែលកើតឯងមក បានស្វាជាបបរឲ្យហើយ ។ កាលតាបសនោះកំពុងទំនុកបម្រុងយ៉ាងនោះ ក្នុងកាលដទៃ ទើបព្រះទេវីគិតថា អញមិនស្គាល់ផ្លូវមកតាមណាឡើយ សូម្បីត្រឹមតែការស្និទ្ធស្នាលរបស់អញនឹងតាបសនេះក៏មិនមាន បើតាបសនេះបោះបង់អញចោល អញទៅណាហ្ន៎ យើងទាំងពីរនាក់ក៏នឹងស្លាប់ ក្នុងទីនេះឯង គួរធ្វើឧបាយណាមួយទម្លាយសីលរបស់តាបសរូបនេះ ធ្វើដោយអាការដែលតាបសរូបនេះ មិនបោះបង់អញទៅបាន ។ ពេលនោះ ទើបព្រះរាជទេវីលួងលោមតាបស ដោយការបង្ហាញសំពត់ស្បៃក សំពត់ជណ្តប់ឲ្យរបូត ឲ្យដល់នូវការវិនាសនៃសីលហើយ តាំងអំពីថ្ងៃនោះ ជនទាំងពីរ ក៏នៅស្និទ្ធស្នាលនឹងគ្នាហើយ ។

ក្នុងថ្ងៃមួយ តាបសសង្កេតមើលការប្រកបនៃផ្កាយនក្ខត្តឫក្ស ឃើញភាពសៅហ្មងនៃផ្កាយនក្ខត្តឫក្សរបស់ព្រះបាទបវរន្តបៈ ទើបត្រាស់ថា នែនាង

ដ៏ចម្រើន ព្រះបាទបវន្តបៈក្នុងក្រុងកោសម្ពី សោយទិវង្គតហើយ ។

ព្រះរាជទេវីត្រាស់ថា ព្រោះហេតុអ្វី ទើបលោកម្ចាស់ត្រាស់យ៉ាងនេះ លោកម្ចាស់មានការអាឃាតជាមួយព្រះបាទបវន្តបៈនោះឬ តាបសពោលថា នែនាង ខ្ញុំមិនមានសេចក្តីអាឃាតជាមួយទ្រង់ឡើយ ខ្ញុំឃើញការសៅហ្មងរបស់ផ្កាយនក្ខត្តឫក្សរបស់ព្រះបាទបវន្តបៈ ទើបពោលយ៉ាងនេះ ។ ព្រះរាជទេវីទ្រង់កន្សែងហើយ ។ គ្រានោះ ទើបតាបសត្រាស់សួរព្រះទេវីនោះថា ព្រោះហេតុអ្វី ទើបនាងយំ កាលព្រះទេវីត្រាស់ប្រាប់ភាពដែលព្រះបាទបវន្តបៈនោះជាព្រះស្វាមីរបស់ព្រះនាងហើយ ទើបតាបសត្រាស់ថា នែនាង នាងកុំយំឡើយ ធម្មតាសត្វកើតហើយ រមែងស្លាប់ពិត ។ ព្រះទេវីត្រាស់ថា ខ្ញុំជ្រាបលោកម្ចាស់តាបសពោលថា បើដូច្នេះ ហេតុអ្វី ទើបនាងយំ ព្រះទេវីពោលថា កូនរបស់ខ្ញុំជាបុគ្គលគួរដល់រាជសម្បត្តិ ដែលជារបស់ត្រកូល បើកូននេះនៅក្នុងក្រុងនោះ គេនឹងឲ្យលើកស្វេតឆត្រឡើង ឥឡូវនេះ បុត្រនេះជាបុគ្គលវិនាសធំហើយ ដោយសេចក្តីសោកយ៉ាងនេះ ទើបខ្ញុំយំ ។ តាបសពោលថា ណ្ហើយចុះ នាងកុំគិតថ្វីឡើយ បើប្រាថ្នារាជសម្បត្តិឲ្យបុត្រ ខ្ញុំនឹងធ្វើអាការឲ្យកុមារនេះបានរាជសម្បត្តិតាមប្រាថ្នា ។

គ្រានោះ តាបសបានឲ្យពិន និងមន្តញ៉ាំងដីរឲ្យស្រឡាញ់ដល់បុត្ររបស់នាងហើយ ។ ក្នុងកាលនោះ ដីរច្រើនសែនមកស្នាក់នៅត្រង់គល់ជ្រៃសាខានោះ លំជាប់នោះ ទើបតាបសត្រាស់នឹងកុមារនោះថា កាលដីរទាំងឡាយមិនទាន់មកដល់នោះឯង ចូរអ្នកឡើងដើមឈើ កាលដីរទាំងឡាយមកដល់ហើយ

ចូរវាយមន្តបទនេះ ដេញពិនខ្សែនេះ ដីរទាំងអស់មិនអាចបែរមើលក្រោយ គេចទៅ ពេលនោះ អ្នកគប្បីចុះមក កុមារនោះធ្វើតាមនោះហើយ ត្រឡប់មកប្រាប់ការប្រព្រឹត្តទៅហើយ ។ ដល់ថ្ងៃទី ២ ទើបតាបសប្រាប់កុមារនោះថា ក្នុងថ្ងៃនេះ ចូរអ្នករាយមន្តបទនេះ ដេញពិនខ្សែនេះ ដីរត្រឡប់មើលក្រោយបណ្តើរ រត់ទៅបណ្តើរ ក្នុងកាលនោះ កុមារក៏ទ្រង់ធ្វើតាមនោះហើយ ត្រឡប់មកប្រាប់ការប្រព្រឹត្តទៅនោះ ។ គ្រានោះ តាបសហៅមាតារបស់កុមារនោះមកហើយ ប្រាប់ថា នែនាង ចូរនាងឲ្យរាជសាសន៍ដល់បុត្ររបស់នាង បុត្រនេះទៅអំពីទីនេះឯង នឹងបានជាស្តេចផែនដី ។ ព្រះរាជទេវីគ្រាស់ហៅព្រះរាជឱរសមកហើយ ត្រាស់ថា កូនជារាជបុត្ររបស់ព្រះបាទបរន្តបៈ ក្នុងក្រុងកោសម្ពី សត្វហត្ថីលិង្គនាំយើងមក ទាំងដែលមានគតិ ដូច្នេះហើយ ត្រាស់ប្រាប់ឈ្មោះសេនាបតីជាដើម ត្រាស់ថា កាលជនទាំងនោះមិនជឿ បុត្រគប្បីយកសំពត់កម្ពលដែលជាព្រះភូសាជណ្តប់ និងព្រះទម្រង់ដែលជាគ្រឿងប្រដាប់របស់ព្រះបិតានេះ បង្ហាញចុះ ដូច្នេះ ទើបបញ្ជូនទៅហើយ ។

ទើបព្រះកុមារសួរតាបសថា ឥឡូវនេះ ខ្ញុំនឹងធ្វើដូចម្តេច តាបសពោលថា អ្នកចូរអង្គុយខាងក្រោមដើមឈើ រាយមន្តបទនេះ ដេញពិនខ្សែនេះ ដីរមេហ្វូងនឹងបង្អោនខ្នងចូលមករកអ្នក អ្នកគប្បីអង្គុយលើខ្នងរបស់ដីរ ហើយចូរទៅដណ្តើមយករាជសម្បត្តិ ។

ព្រះរាជកុមារនោះ ថ្វាយបង្គំតាបស និងមាតាហើយ ទ្រង់ធ្វើតាមនោះ ហើយអង្គុយលើខ្នងដីរដែលចូលមកហើយ ។ រួបប្រាប់ដីរថា ខ្ញុំជាបុត្ររបស់

ព្រះបាទបវន្តបៈ ក្នុងក្រុងកោសម្ពី ចូរអ្នកដណ្តើមយករាជសម្បត្តិ ដែលជារបស់បិតាឲ្យដល់ខ្ញុំចុះ ។ ជីវមេហ្វូងស្តាប់ពាក្យនោះហើយ ទើបស្រែកដោយសំឡេងជីវថា ជីវទាំងឡាយចូរមកប្រជុំគ្នាឲ្យបានច្រើនពាន់ ។ ជីវច្រើនពាន់មកប្រជុំគ្នាហើយ ក៏ប្រាប់ទៀតថា ជីវចាស់ៗ ចូរថយចេញទៅ ជីវចាស់ៗនាំគ្នាថយទៅហើយ ជីវនោះក៏ស្រែកទៀតថា ជីវតូចៗ ចូរត្រឡប់ទៅ ។ ជីវទាំងនោះក៏នាំគ្នាត្រឡប់ហើយ ។ ព្រះរាជកុមារនោះ កាលជីវចម្បាំងទាំងឡាយនាំគ្នាចោមរោមហើយ ដល់ស្រុកជាយដែនហើយ ប្រកាសថា ខ្ញុំជារាជបុត្រស្តេចផែនដី អ្នកដែលប្រាថ្នាសម្បត្តិ ចូរមកជាមួយយើង តាំងអំពីនោះទៅក៏ទ្រង់ធ្វើការប្រមូលមនុស្សទៅព័ទ្ធព្រះនគរហើយ បញ្ជូនព្រះរាជសាសន៍ទៅថា តើឲ្យយើងច្បាំង ឬឲ្យរាជសម្បត្តិ ។ អ្នកក្រុងទាំងឡាយពោលថា យើងមិនឲ្យទាំងពីរយ៉ាង ពិតហើយ ព្រះរាជទេវីរបស់យើងមានគភ៌ចាស់ ត្រូវសត្វហត្ថីលិង្គនាំទៅហើយ យើងទាំងឡាយមិនដឹងថា ព្រះនាងនៅមានព្រះជន្ម ឬក៏មិនមានហើយ ដរាបណាដែលពួកយើងមិនជ្រាបរឿងរាវរបស់ព្រះនាង យើងនឹងមិនឲ្យទាំងការច្បាំង និងរាជសម្បត្តិ ។ បានឮថា កាពជាស្តេចផែនដីដោយពូជពង្ស មានហើយក្នុងកាលនោះ លំដាប់នោះ ទើបព្រះរាជ-កុមារត្រាស់ថា យើងជាបុត្ររបស់ព្រះនាង ហើយអាងដល់សេនាបតីជាដើមកាលជនទាំងនោះមិនជឿយ៉ាងនោះ ទើបបង្ហាញសំពត់កម្ពល និងព្រះទម្រង់ ។ ពួកអ្នកនគរចាំសំពត់កម្ពលក្រហម និងព្រះទម្រង់នោះបាន អស់សន្ទេះសង្ស័យ ទើបបើកទ្វារ អភិសេកកុមារនោះក្នុងរាជសម្បត្តិហើយ ។

នេះជារឿងនៃការកើតឡើងរបស់ព្រះបាទឧទេនជាបឋម ។

កាលទុព្ភិក្ខភ័យកើតហើយក្នុងដែនអល្លកប្បៈ បុរសម្នាក់ឈ្មោះកោតុ-ហលិកៈ មិនអាចរស់នៅបាន ទើបនាំភរិយាដែលមានកូនខ្ចីឈ្មោះកាឡីរៀបចំស្បៀងចេញទៅហើយ ដោយបំណងថា នឹងទៅរកស៊ីឯក្រុងកោសម្ពី អាចារ្យពួកខ្លះពោលថា ប្តីប្រពន្ធនោះចេញទៅហើយ ក្នុងកាលមហាជនកំពុងស្លាប់ដោយអហិវាតរោគក៏មាន ។ ប្តីប្រពន្ធពីរនាក់នោះ ធ្វើដំណើរទៅ កាលស្បៀងអស់ហើយ កាលសេចក្តីឃ្លានគ្របសង្កត់ហើយ មិនអាចនាំកុមារទៅបានកាលនោះ ទើបប្តីពោលនឹងភរិយាថា នែនាង បើយើងនៅមានជីវិតក៏នឹងបានកូនទៀត គេចោលកូនហើយក៏ទៅ ។ ធម្មតាថា ទឹកចិត្តរបស់មាតាទន់ភ្លន់ព្រោះដូច្នោះ ទើបពោលថា ខ្ញុំមិនអាចចោលកូនទាំងដែលនៅមានជីវិតបានទេ ។ ប្តីពោលថា បើដូច្នោះ យើងគិតធ្វើដូចម្តេច ភរិយាពោលថា យើងបួរគ្នានាំទៅ ។ មាតាលើកកូនឡើង ដូចកម្រងផ្កាក្នុងភារៈរបស់ខ្លួន ផ្អិបត្រង់ទ្រូងបីទៅហើយក៏ឲ្យដល់ឪពុក ។ វេទនាមានកម្លាំងជាងការស្រេកឃ្លានកើតដល់បុរសជាប្តីនោះ ក្នុងទីដែលគាត់ទទួលកូននោះហើយដាក់ចុះ ក៏ពោលនឹងភរិយានោះ ដដែលហើយដដែលទៀតថា នែនាង បើយើងនៅមានជីវិត យើងនឹងបានកូនទៀត យើងចោលកូននេះចុះ ។ ភរិយាក៏ឃាត់ជាច្រើនដង ហើយក៏នៅស្ងៀម ។ កុមារត្រូវផ្ងាស់ប្តូរតាមភារៈ ទៀយហាត់ទន់ខ្សោយ ដេកលក់ក្នុងដៃរបស់ឪពុក ។ បុរសជាប្តីដឹងថា កូនប្រុសដេកលក់ ទើបបណ្តោយឲ្យម្តាយដើរទៅមុន ហើយយកកុមារនោះ ផ្តេកលើកម្រាលស្មៅឈើ ក្រោម

ដើមឈើមួយកន្លែង ហើយដើរទៅ ។ មាតាក្រឡេកមើលមិនឃើញកូន ទើបសួរថា នែអ្នក កូនយើងទៅណា ប្តីពោលថា ខ្ញុំឲ្យវាដេកក្រោមគុម្ពឈើមួយកន្លែង ភរិយាពោលថា នែអ្នក អ្នកកុំញ៉ាំងខ្ញុំឲ្យវិនាសឡើយ ខ្ញុំរៀបកូនហើយមិនអាចរស់នៅបានទេ សូមអ្នកនាំកូនខ្ញុំមកចុះ គក់ទ្រែងយំរៀបរាប់ហើយ ។ គ្រានោះ ទើបបុរសជាប្តីត្រឡប់ទៅយកកុមារនោះមក កូននោះក៏ស្លាប់ហើយក្នុងរវាងផ្លូវ ។ នាយកោតុហលិក: ចោលកូនក្នុងហាន:មានប្រមាណប៉ុណ្ណេះ ទើបត្រូវគេចោះចោលអស់ ៧ ជង ក្នុងអន្តរភព ដោយផលនៃកម្មនោះ ដោយប្រការដូច្នេះ ។ ឈ្មោះថា ជាបកម្មនេះ បុគ្គលមិនគួរមើលងាយថា មានប្រមាណតិចឡើយ ស្វាមីភរិយាពីរនាក់នោះ ធ្វើដំណើរទៅដល់ត្រកូលរបស់អ្នកចិញ្ចឹមគោមួយកន្លែងហើយ ។

ក្នុងថ្ងៃនោះ មានការធ្វើពិធីដល់មេគោទឹកដោះរបស់នាយគោបាល ក្នុងផ្ទះរបស់នាយគោបាល ព្រះបច្ចេកពុទ្ធមួយរូបឆាន់ជានិច្ច ។ នាយគោបាលនោះ និមន្តព្រះបច្ចេកពុទ្ធឆាន់ស្រេចហើយ ទើបបានធ្វើការមង្គល ។ ជាយាសគេរៀបចំជាច្រើន នាយគោបាលឃើញប្តីប្រពន្ធពីរនាក់នោះមក ទើបសួរថា អ្នកមកអំពីណា ដឹងរឿងនោះហើយ ជាកុលបុត្រមានចិត្តទន់ភ្លន់ ទើបធ្វើសេចក្តីសង្រ្គោះក្នុងជនទាំងពីរនោះ ឲ្យជាយាស និងសប្បិដ៏ច្រើន ។

ភរិយាពោលនឹងស្វាមីថា នែអ្នក បើអ្នកមានជីវិត ខ្ញុំក៏ឈ្មោះថា មានជីវិត អ្នកស្រែកឃ្លានមកអស់កាលយូរ ចូរបរិភោគតាមសេចក្តីត្រូវការ ដូច្នេះហើយ ទើបដាក់ជាយាសខាងមុខ មួយអន្ទើដោយសប្បិ ខ្លួនឯងបរិភោគសប្បិ

ភវតែបន្តិចប៉ុណ្ណោះ ចំណែកនាយកោតុហលិកៈបរិភោគច្រើនពេក មិនអាច អស់ចំណង់ក្នុងអាហារបាន ព្រោះខ្ជូនស្រែកឃ្លានមក ៧-៨ ថ្ងៃហើយ ។ នាយ គោបាលកាលឲ្យបាយាសដល់ប្តីប្រពន្ធពីរនាក់នោះហើយ ទើបខ្ជូនឯង ផ្តើម បរិភោគ ។ នាយកោតុហលិកៈ អង្គុយមើលបុរសនោះហើយ ឃើញបាយាស ដែលនាយគោបាលពូតឲ្យដល់ឆ្កែញី ដែលដេកហើយក្រោមតាំង គិតថា ឆ្កែ ញីនេះមានបុណ្យ ទើបបានកោជនបែបនេះជានិច្ច ។ លុះដល់កណ្តាលយប់ នាយកោតុហលិកៈនោះ មិនអាចញុំាងបាយាសនោះឲ្យរលួយបាន ទើបធ្វើ កាលកិរិយា ទៅកើតក្នុងផ្ទៃឆ្កែញីនោះ ។ គ្រានោះ ភរិយារបស់គាត់ធ្វើសរីរ-កិច្ចហើយ ក៏ធ្វើការស៊ីឈ្នួលក្នុងផ្ទះនោះឯង បានអង្គរមួយនាឡិ ចម្អិនហើយ ជាក់ជាត្រព្រះបច្ចេកពុទ្ធ ហើយពោលថា បពិត្រលោកម្ចាស់ ដោយកុសល-កម្មនេះ ខ្ញុំព្រះអង្គសូមដល់នូវភាពជាទាសៈរបស់លោកម្ចាស់ចុះ ដូច្នេះហើយ ទើបគិតថា អាត្មាអញគួរនៅក្នុងទីនេះឯង លោកម្ចាស់រមែងមកក្នុងទីនេះ ជានិច្ច ទេយ្យធម៌ ទោះមាន ឬមិនមានក៏ដោយចុះ អញនឹងថ្វាយបង្គំ ធ្វើនូវ សេចក្តីខ្វល់ខ្វាយ ញុំាងចិត្តឲ្យជ្រះថ្លារាល់ថ្ងៃ នឹងជួបនូវបុណ្យច្រើន គិតដូច្នេះ ហើយ ទើបនាងធ្វើការស៊ីឈ្នួលនៅក្នុងផ្ទះនោះឯង ។

ក្នុងខែទី ៦ ឬទី ៧ ឆ្កែនោះឯងក៏កើតកូនមកតែមួយ ទើបនាយគោបាល ឲ្យនាំយកទឹកដោះរបស់មេគោមួយ ឲ្យដល់កូនឆ្កែនោះ ។ មិនយូរប៉ុន្មាន កូន ឆ្កែនោះក៏ធំធាត់ ។ គ្រានោះ ព្រះបច្ចេកពុទ្ធកាលធាន់ រមែងឲ្យដុំបាយដល់កូន ឆ្កែនោះមួយដុំជានិច្ច អាស្រ័យដុំបាយ ទើបឆ្កែនោះមានសេចក្តីស្រឡាញ់ក្នុង

ព្រះបច្ចេកពុទ្ធ ។ នាយគោបាលរមែងទៅកាន់ទីបម្រើរបស់ព្រះបច្ចេកពុទ្ធ មួយ ថ្ងៃពីរដងជានិច្ច ។ នាយគោបាលនោះកាលដើរទៅ ក៏យកដំបងវាយគុម្ពឈើ និងដីក្នុងទីដែលមានសត្វកាច ត្រង់រវាងផ្លូវ ហើយបន្លឺសំឡេងថា សុសុ ៣ ដង ញុំាងសត្វសាហាវឲ្យគេចទៅហើយ ឯឆ្កែក៏ទៅជាមួយនាយគោបាលនោះ ។ ថ្ងៃមួយ នាយគោបាលនោះ ពោលនឹងព្រះបច្ចេកពុទ្ធថា បពិត្រលោកម្ចាស់ កាលណាខ្ញុំមិនមានឱកាសទំនេរ កាលនោះខ្ញុំនឹងបញ្ជូនឆ្កែនេះមក សូមលោកម្ចាស់មកដោយសញ្ញានៃឆ្កែនេះ ដែលខ្ញុំបញ្ជូនមកហើយ ។ តាំងអំពីនោះមក ក្នុងថ្ងៃដែលមិនមានឱកាស នាយគោបាលនោះ ក៏បញ្ជូនឆ្កែទៅដោយពាក្យថា នែឆ្កែ ចូរបាទៅនាំព្រះបច្ចេកពុទ្ធមក ដោយពាក្យប្រើត្រឹមតែម្តងប៉ុណ្ណោះ ឆ្កែនោះក៏រត់ទៅដល់ទីដែលម្ចាស់វាយគុម្ពឈើ និងផែនដី ក៏ព្រុសបីដង ដឹងថាសត្វកាចគេចទៅហើយ ដោយសំឡេងនោះ ទៅដល់លំនៅរបស់ព្រះបច្ចេក-ពុទ្ធដែលធ្វើសរីរកិច្ចអំពីព្រលឹម ចូលទៅកាន់បណ្ណសាលាគង់ហើយ ។ ឆ្កែដល់ទ្វារបណ្ណសាលា ទើបព្រុស ៣ ដង ឲ្យព្រះបច្ចេកពុទ្ធដឹងថា ខ្លួនមកហើយ ក៏ដេកក្រាបនៅត្រង់ចំណែកម្ខាង កាលព្រះបច្ចេកពុទ្ធកំណត់កាលចេញទៅហើយ ឆ្កែនោះក៏ដើរព្រុសទៅខាងមុខនោះឯង ។ ព្រះបច្ចេកពុទ្ធកាលសាកល្បងឆ្កែនោះ ទើបនិមន្តទៅផ្លូវដទៃ ពេលនោះ ទើបឆ្កែនោះ ឈរព្រុសរាំងខាងមុខព្រះបច្ចេកពុទ្ធនោះ ហើយនាំលោកត្រឡប់មកកាន់ផ្លូវក្រៅអំពីនេះ ។ សម័យថ្ងៃមួយ ព្រះបច្ចេកពុទ្ធកាលសាកល្បងឆ្កែនោះ ទើបនិមន្តទៅកាន់ផ្លូវដទៃ សូម្បីឆ្កែនោះឈរាំងឃាត់នៅខាងមុខក៏មិនត្រឡប់ យកជើង

ធ្លឹះធ្លែនោះហើយនិមន្តទៅ ធ្លែដឹងថា ព្រះបច្ចេកពុទ្ធមិនត្រឡប់ ទើបទៅខាំ ជាយស្បង់ទាញមក នាំលោកមកកាន់ផ្ទូវក្រៅអំពីនេះ ។ ធ្លែនោះ បានញ្ចាំង សេចក្តីស្រឡាញ់ដ៏មានកម្ទាំង ឲ្យកើតឡើងហើយ ក្នុងព្រះបច្ចេកពុទ្ធនោះ ដោយប្រការយ៉ាងនេះ ។

ក្នុងកាលដទៃ ចីវររបស់ព្រះបច្ចេកពុទ្ធចាស់ហើយ កាលនោះ ទើបនាយ គោបាលប្រគេនចីវរសម្រាប់ធ្វើចីវរដល់លោក ទើបព្រះបច្ចេកពុទ្ធពោលនឹង នាយគោបាលនោះថា នែអ្នក ឈ្មោះថា ការធ្វើចីវរ បុគ្គលម្នាក់ឯងធ្វើបាន លំបាក ។ អាត្មាទៅកាន់ទីដែលសប្បាយហើយនឹងធ្វើ ។ នាយគោបាលពោល ថា បពិត្រលោកម្ចាស់ សូមនិមន្តលោកម្ចាស់ធ្វើទីនេះចុះ ព្រះបច្ចេកពុទ្ធពោល ថា នែអ្នក អាត្មាមិនអាចធ្វើក្នុងទីនេះបានទេ ។ នាយគោបាលពោលថា បពិត្រ លោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់កុំទៅខាងក្រៅយូរពេក ។ ធ្លែបាន ឈរស្តាប់ពាក្យរបស់ជនទាំងពីរនោះដូចគ្នា ។ ព្រះបច្ចេកពុទ្ធពោលនឹងនាយ គោបាលនោះថា ចូរឈប់ទីនេះចុះឧបាសក ។ ឲ្យនាយគោបាលត្រឡប់ ហើយ ហោះឡើងទៅកាន់អាកាស មានមុខធ្ពោះទៅកាន់ភ្នំគន្ធមាទន៍ ចៀស ចេញទៅហើយ ។ ធ្លែសម្ទឹងមើលព្រះបច្ចេកពុទ្ធដែលរសាត់ទៅក្នុងអាកាស ឈរព្រុសហើយ កាលព្រះបច្ចេកពុទ្ធនោះផុតពីគន្ធងចក្ខុ ហទយ:ក៏បែក ស្ទាប់ទៅ ។

ឈ្មោះថា សត្វតិរច្ឆានទាំងឡាយ ជាសត្វមានជាតិស្មោះត្រង់ មិនវៀច វេរ ចំណែកមនុស្សចិត្តគិតផ្សេង មាត់និយាយផ្សេង ព្រោះហេតុនោះឯង

ទើបនាយបេស្សៈជាកូនរបស់ហ្មដីវី ពោលថា

បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សមានចិត្តសាំញុំ បពិត្រ ព្រះអង្គដ៏ចម្រើន ពួកសត្វចិញ្ចឹម មានចិត្តងាយយល់ ។

ឆ្អែនោះធ្វើកាលកិរិយាហើយ ទៅកើតក្នុងស្ថានតាវត្តិង្ស មានស្រីទេពអប្សរមួយពាន់ចោមរោម បានសោយនូវសម្បត្តិធំ ព្រោះជាសត្វស្មោះត្រង់ មិនវៀចវេរ ដោយប្រការដូច្នេះ ។

កាលទេវបុត្រនោះខ្សឹបត្រង់ត្រចៀករបស់បុគ្គលណាមួយ សំឡេងរមែងលាន់ឮទៅឆ្ងាយ រហូត ១៦ យោជន៍ ចំណែកសំឡេងពោលដោយប្រក្រតី រមែងឮពេញទេវនគរទាំងមូល ដែលមានប្រមាណមួយម៉ឺនយោជន៍ ព្រោះហេតុនោះឯង ទើបទេវបុត្រនោះមានឈ្មោះថា យោសកទេវបុត្រ ។ នេះជាអានិសង្ស ជាផលនៃការព្រុសដោយសេចក្តីស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធ ។ យោសកទេវបុត្រនោះ តាំងនៅក្នុងទេវនគរនោះ មិនយូរក៏ចុតិហើយ ។

ពិតហើយ ទេវបុត្រទាំងឡាយរមែងឃ្លាតចាកទេវលោកដោយហេតុ ៤ យ៉ាង គឺដោយអស់អាយុ ១ ដោយអស់បុណ្យ ១ ដោយការអត់អាហារ ១ ដោយសេចក្តីក្រោធ ១ ។

ក្នុងហេតុ ៤ យ៉ាងនោះ ទេវបុត្រអង្គណាធ្វើបុញ្ញកម្មច្រើន ទេវបុត្រអង្គនោះ កើតក្នុងទេវលោកតាំងនៅដរាបដល់អស់អាយុ ហើយក៏កើតក្នុងទេវលោកជាន់ខ្ពស់បន្តបន្ទាប់ ទៅ យ៉ាងនេះឈ្មោះថា ចុតិដោយការអស់អាយុ ។ ទេវបុត្រអង្គណាធ្វើបុណ្យតិច ទេវបុត្រអង្គនោះអស់ទៅក្នុងចន្លោះដូចធុញ្ញជាតិ

ដែលបុគ្គលជាក់ក្នុងជង្រុកធំ ត្រឹមតែ ៤-៥ នាឡិដូច្នោះ ។ ទេវបុត្រនោះរមែងធ្វើកាលកិរិយាក្នុងរវាងនោះឯង យ៉ាងនេះឈ្មោះថា រមែងចុតិដោយការអស់បុណ្យ ។ ទេវបុត្រអង្គខ្លះជាអ្នកបរិភោគកាមគុណ មិនបរិភោគអាហារព្រោះភ្លេចស្មារតី មានកាយទន់ខ្សោយក៏ធ្វើកាលកិរិយា យ៉ាងនេះឈ្មោះថា រមែងចុតិដោយការអត់អាហារ ។ ទេវបុត្រអង្គខ្លះ មិនអត់ធន់ក្នុងសម្បត្តិអ្នកដទៃអាក់អន់ហើយ ទើបកាលកិរិយា យ៉ាងនេះឈ្មោះថាចុតិដោយសេចក្តីក្រោធ ។

ឃោសកទេវបុត្រនេះ រវល់តែបរិភោគកាមគុណ ភ្លេចស្មារតី ទើបចុតិដោយការអត់អាហារ ។ កាលចុតិស្រេចហើយ បដិសន្ធិក្នុងផ្ទៃនៃស្រីនគរសោកិនី ក្នុងក្រុងកោសម្ពី ។ ក្នុងថ្ងៃប្រសូតនាងសួរទាសីថា កូនយើងប្រុសឬស្រី កាលនាងទាសីឆ្លើយថា កូនប្រុសអ្នកនាង ទើបប្រាប់ឲ្យនាងទាសីយកទៅចោលដោយពាក្យថា ចូរនាងយកទារកនេះដាក់ក្នុងចង្អេរ ហើយយកទៅចោលត្រង់គំនរសំរាម ។ ពិតហើយ ស្រីនគរសោកិនីទាំងឡាយ រមែងចិញ្ចឹមកូនស្រី មិនចិញ្ចឹមកូនប្រុស ព្រោះពូជពង្សរបស់ពួកនាងបន្តទៅបានក៏ដោយកូនស្រី ។ ក្អែកខ្លះ ឆ្កែខ្លះ នាំគ្នាចោមរោមកុមារនោះ ។ ដោយផលនៃការព្រុស ដែលកើតអំពីសេចក្តីស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធ សត្វសូម្បីតែមួយក៏មិនអាចចូលជិតបាន ។ ក្នុងខណៈនោះ បុរសម្នាក់ចេញទៅខាងក្រៅស្រុក ឃើញការចោមរោមរបស់ក្អែក និងឆ្កែនោះ គិតថា នុ៎ះមានហេតុអ្វីហ្ន៎ ទើបដើរទៅទីនោះ ឃើញទារក ក៏កើតសេចក្តីស្រឡាញ់ដូចកូន ទើបនាំទៅកាន់ផ្ទះដោយត្រេកអរថា អញបានកូនប្រុសហើយ ។

ក្នុងកាលនោះ សេដ្ឋីអ្នកក្រុងកោសម្ពីទៅកាន់រាជត្រកូល ជួបបុរោហិតដើរមកអំពីព្រះរាជវាំង ទើបសួរថា លោកអាចារ្យ ថ្ងៃនេះលោកបានពិនិត្យមើលការប្រកបរបស់ផ្កាយនក្ខត្តឫក្ស ដែលជាគ្រោះល្អ គ្រោះអាក្រក់ហើយឬ បុរោហិតឆ្លើយថា នែលោកសេដ្ឋី កិច្ចដទៃរបស់ពួកយើងមិនមាន សេដ្ឋីពោលថា នឹងមានអ្វីកើតឡើងដល់ជនបទឬ បុរោហិតពោលថា ហេតុដទៃមិនមាន តែក្មេងដែលកើតក្នុងថ្ងៃនេះ នឹងបានជាសេដ្ឋីដ៏ប្រសើរក្នុងក្រុងនេះ ។

គ្រានោះ ភរិយារបស់សេដ្ឋីមានគភ៌ចាស់ ព្រោះដូច្នោះ ទើបសេដ្ឋីនោះបញ្ជូនអ្នកបម្រើទៅកាន់ផ្ទះយ៉ាងរហ័ស ដោយពាក្យថា អ្នកចូរទៅ ហើយចូរដឹងភរិយារបស់ខ្ញុំថា តើប្រសូតបុត្រហើយឬនៅ លុះជ្រាបថាមិនទាន់ប្រសូតចូលគាល់ព្រះរាជាស្រេចហើយ ប្រញាប់ត្រឡប់ទៅផ្ទះ ហៅស្រីបម្រើឈ្មោះកាឡីមកហើយ ឲ្យទ្រព្យមួយពាន់ពោលថា ចូរនាងទៅពិនិត្យមើលក្នុងក្រុងនេះ ឲ្យទ្រព្យមួយពាន់នាំក្មេងដែលកើតក្នុងថ្ងៃនេះមក ។ នាងកាឡីនោះ កាលពិនិត្យមើលទៅដល់ផ្ទះនោះ ឃើញកុមារហើយ ទើបសួរស្រីមេផ្ទះថា កុមារនេះកើតក្នុងកាលណា កាលស្រីនោះឆ្លើយថា កើតថ្ងៃនេះ ទើបពោលថា ចូរឲ្យក្មេងនេះដល់ខ្ញុំ ទើបប្រមូលតម្លៃតាំងអំពីមួយកហាបណៈជាដើម រហូតដល់ឲ្យទ្រព្យមួយពាន់ ហើយនាំក្មេងនោះទៅបង្ហាញដល់សេដ្ឋី ។ សេដ្ឋីគិតថា បើកូនរបស់ខ្ញុំកើតមកជាស្រី អ្នកចូរឲ្យកុមារនេះ រួមជាមួយកូនស្រីរបស់យើងនោះ ហើយធ្វើគេឲ្យជាម្ចាស់នៃតំណែងសេដ្ឋី បើកូនរបស់យើងកើតមកជាកូនប្រុស យើងនឹងសម្ងាប់វាចោល ដូច្នេះហើយ ទើបទទួលក្មេងនោះទុកក្នុង

ផ្ទះ ។ ក្នុងកាលតមក ភរិយារបស់សេដ្ឋីនោះប្រសូតបុត្រប្រុស ដោយកន្លង ទៅ ២-៣ ថ្ងៃ ទើបសេដ្ឋីគិតថា បើមិនមានក្មេងនេះ កូនប្រុសរបស់អញក៏ នឹងបានតំណែងសេដ្ឋី ។ ឥឡូវនេះ អញគួរតែសម្លាប់វាចោល ដូច្នេះហើយ ទើបហៅនាងកាឡីមក ពោលថា ហង់ចូរទៅក្នុងកាលដែលពួកគោចេញអំពី ក្រោល ហង់ចូរដាក់ក្មេងនេះឲ្យដេកទទឹង ត្រង់កណ្តាលទ្វារក្រោល មេគោ ទាំងឡាយនឹងជាន់វាស្លាប់ តែចូរដឹងថា មេគោជាន់ឬមិនជាន់ហើយសឹមមក ។ នាងកាឡីនោះទៅហើយ លុះនាយគោបាលបើកទ្វារក្រោលប៉ុណ្ណោះ ក៏យក ក្មេងនោះឲ្យដេកតាមនោះ គឺដូចសេដ្ឋីបញ្ជា ។ គោឧសភៈមួយក្បាលជាមេ ហ្វូង ចេញខាងក្រោយគោទាំងពួងក្នុងកាលដទៃ តែក្នុងថ្ងៃនោះ ចេញមកមុន គោដទៃទាំងអស់ បានឈរក្រុងទារកក្នុងរវាងជើងទាំងបួន ។ មេគោច្រើនរយ ក៏នាំគ្នាប្រច្រៀតសងខាងគោឧសភៈចេញទៅ ។ សូម្បីនាយគោបាលក៏គិត ថា គោឧសភៈនេះ កាលមុន ចេញក្រោយគោទាំងអស់ តែថ្ងៃនេះចេញមក មុនគេ ហើយឈរស្ទៀមត្រង់ទ្វារក្រោល តើមានហេតុអ្វីហ្ន៎ ទើបដើរទៅ កាលឃើញទារកដេកនៅក្រោមពោះគោនោះ ក៏បាននូវសេចក្តីស្រឡាញ់ដូច កូន ទើបនាំទៅផ្ទះ ដោយគិតថា អញបានកូនប្រុសហើយ ។ នាងកាឡីទៅ ហើយ ត្រូវសេដ្ឋីសួរ ទើបប្រាប់រឿងនោះ សេដ្ឋីពោលថា ហង់ចូរទៅ ចូរឲ្យ ទ្រព្យគេមួយពាន់ ហើយនាំក្មេងនោះមក ដូច្នេះហើយ ឲ្យទ្រព្យមួយពាន់ បាននាំត្រឡប់មកឲ្យជាប្ដីទៀត ។

គ្រានោះ សេដ្ឋីពោលនឹងនាងកាឡីថា នែកាឡី ក្នុងក្រុងនេះមានពួករនេះ

៥០០ ក្រោកទៀងអំពីព្រលឹម រមែងទៅលក់ដូរ នាងចូរយកក្មេងនេះ ទៅឲ្យដេកត្រង់ផ្លូវរទេះ ពួកគោនឹងជាន់ ឬកង់រទេះនឹងកិនវា លុះដឹងរឿងរបស់វាហើយ សឹមត្រឡប់មក ។ នាងកាឡីនោះ នាំក្មេងនោះទៅហើយ ឲ្យដេកត្រង់ផ្លូវរទេះ ក្នុងកាលនោះ ប្រជានក្រុមរទេះបានទៅខាងមុខ ។ គ្រានោះ ពួកគោរបស់គាត់ដល់ទីនោះហើយ នាំគ្នាទម្លាក់នឹមចោល សូម្បីគាត់លើកទៀងហើយ ដេញទៅច្រើនដង ក៏មិនដើរទៅខាងមុខ ។ កាលគាត់ព្យាយាមជាមួយគោទាំងពីរនោះយ៉ាងនេះឯង អរុណក៏រះទៀង ។ ទើបគាត់គិតថា គោទាំងពីរនាំគ្នាធ្វើហេតុនេះព្រោះអ្វី ទើបពិនិត្យមើលផ្លូវ ឃើញទារកហើយក៏គិតថា កម្មរបស់អញធ្ងន់ហ្ន៎ មានសេចក្តីត្រេកអរថា អញបានកូនប្រុសហើយ ទើបនាំក្មេងនោះទៅកាន់ផ្ទះ ។ នាងកាឡីទៅហើយ កាលសេដ្ឋីសួរ ទើបប្រាប់ការប្រព្រឹត្តទៅនោះ កាលសេដ្ឋីប្រាប់ថា ហាងចូរទៅឲ្យទ្រព្យមួយពាន់ ហើយចូរនាំក្មេងនោះត្រឡប់មក ដូច្នេះហើយ បានធ្វើតាមនោះ ។

កាលនោះ សេដ្ឋីពោលនឹងនាងកាឡីនោះថា ឥឡូវនេះ ហាងចូរនាំវាទៅកាន់ព្រៃខ្មោច ហើយឲ្យដេកក្នុងចន្លោះគុម្ពឈើ វានឹងត្រូវសត្វ មានឆ្កែព្រៃជាដើមខាំ ឬត្រូវអមនុស្សប្រហារឲ្យស្លាប់ក្នុងទីនោះ ហាងដឹងថា វាស្លាប់ហើយឬមិនទាន់ស្លាប់សឹមត្រឡប់មក ។ នាងកាឡីនោះ នាំក្មេងនោះទៅឲ្យដេកក្នុងព្រៃខ្មោចហើយ បានឈរនៅក្នុងទីមួយកន្លែង ។ ឆ្កែខ្លះ ក្អែកខ្លះ អមនុស្សខ្លះ មិនអាចចូលជិតក្មេងនោះបាន ។ មានពាក្យសួរជ្រៀតចូលមកថា មាតាបិតា និងបណ្តាបងប្អូនជាដើម បុគ្គលណាម្នាក់ ឈ្មោះថា រក្សាក្មេងនោះ មិន

មានមិនមែនឬ អ្នកណារក្សាក្មេងនោះ ឆ្លើយថា កម្មគ្រាន់តែការព្រុសប៉ុណ្ណោះ ដែលក្មេងឲ្យប្រព្រឹត្តទៅហើយ ដោយការស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធ ក្នុងកាលកើតជាឆ្កែ ជាអ្នករក្សាក្មេង ។ គ្រានោះ នាយអជបាលម្នាក់ គៀងមេពពែទាំងឡាយមួយសែនក្បាលទៅរកស៊ី ដើរទៅក្បែរព្រៃខ្មោចនោះ ។ មេពពែមួយស៊ីស្លឹកឈើជាដើម ចូលទៅកាន់គុម្ពឈើ ឃើញទារកហើយ ទើបលុតជង្គង់ឲ្យទឹកដោះដល់ទារក ។ សូម្បីនាយអជបាលធ្វើសំឡេងថា ហេ ហេ ក៏មិនចេញទៅទៀយ បុរសនោះគិតថា នឹងយករំពត់វាយវាឲ្យចេញ ទើបចូលទៅកាន់គុម្ពឈើ ឃើញមេពពែលុតជង្គង់ឲ្យទារកតូចជៅដោះ ក៏បានទួរសេចក្តីស្រឡាញ់ក្នុងទារកដូចកូន ទើបនាំទារកនោះទៅដោយគិតថា អញបានកូនប្រុសហើយ នាងកាឡីឃើញហេតុនោះហើយ ទើបទៅ ត្រូវសេដ្ឋីសួរហើយ ទើបប្រាប់ការប្រព្រឹត្តទៅនោះ ដែលសេដ្ឋីពោលថា ហាងចូរទៅឲ្យទ្រព្យមួយពាន់ ហើយនាំវាត្រឡប់មកទៀត នាងកាឡីបានធ្វើតាមហើយ ។

គ្រានោះ សេដ្ឋីពោលនឹងនាងទាសីនោះថា នែកាឡី ហាងចូរយកក្មេងនេះទៅចឹងភ្នំដែលជាទីទម្លាក់ចោរ ចូរបោះវាទៅក្នុងជ្រោះ វាប៉ះនឹងបាតជ្រោះ នឹងដាច់ជាកំណាត់តូចធំ ធ្លាក់ចុះត្រង់ផែនដី ហាងដឹងថា វាស្លាប់ហើយ ឬមិនស្លាប់សឹមត្រឡប់មក នាងកាឡីនោះ នាំក្មេងនោះទៅទីនោះហើយ ឈរនៅលើកំពូលភ្នំ បោះទម្លាក់ទៅហើយ ។ គុម្ពឫស្សីធំអាស្រ័យបាតជ្រោះនោះឯង ចម្រើនក្នុងបាតជ្រោះនោះឯង វល្លិ៍ទំពាំងបាយជូរមានស្លឹកក្រាស់បានចាក់ស្រែះលើគុម្ពឫស្សីនោះ ទារកកាលធ្លាក់ ក៏ធ្លាក់លើវល្លិ៍នោះ ដូចគេដាក់លើសំពត់

រោមសត្វក្នុងថ្ងៃនោះ មេជាងផែងត្រូវការដោយឫស្សី ចូលទៅជាមួយកូនប្រុស ផ្តើមកាប់គុម្ពឫស្សីនោះ កាលដើមឫស្សីរង្គើទារកក៏យំឡើង ។ ទើបពោលថា ដូចសំឡេងក្មេង ទើបឡើងទៅតាមផ្លូវមួយ ឃើញទារកនោះ មានចិត្តត្រេកអរ ទើបនាំទៅដោយគិតថា អញបានកូនប្រុសហើយ ។ នាងកាឡីទៅកាន់សម្នាក់របស់សេដ្ឋី ត្រូវសេដ្ឋីនោះសួរហើយ ទើបប្រាប់រឿងនោះ កាលសេដ្ឋីពោលថា ហាងចូរទៅ ឲ្យទ្រព្យគេមួយពាន់ ហើយនាំវាមក នាងបានធ្វើយ៉ាងនោះហើយ ។

កាលសេដ្ឋីធ្វើកម្មនោះៗ ទារកចម្រើនធំធាត់ហើយ ។ ទារកនោះមានឈ្មោះថា យោសកៈ ។ យោសកកុមារនោះប្រាកជដល់សេដ្ឋីដូចបន្ទាក្នុងភ្នែក សេដ្ឋីមិនអាចសម្លឹងមើលដោយត្រង់ៗ បាន ។ គ្រានោះ សេដ្ឋីត្រិះរិះរកឧបាយសម្លាប់យោសកកុមារនោះ ទើបទៅកាន់សម្នាក់របស់នាយស្មូនឆ្នាំង ដែលជាសម្លាញ់របស់ខ្លួន ហើយសួរថា ក្នុងកាលណា ទើបអ្នកដុត-ឡ ។ កាលបុរសនោះឆ្លើយថា ស្អែកនេះ ទើបពោលថា បើដូច្នោះ អ្នកចូរយកទ្រព្យមួយពាន់នេះ ហើយចូរធ្វើការងារឲ្យខ្ញុំមួយ ស្មូនឆ្នាំងពោលថា ការងារអ្វី ។ សេដ្ឋីពោលថា ខ្ញុំមានកូនជាតិអាក្រក់ម្នាក់ ខ្ញុំនឹងបញ្ជូនវាមកកាន់សម្នាក់របស់អ្នក បើដូច្នោះ អ្នកចូរឲ្យវាចូលកាន់បន្ទប់ យកកាំបិតដែលមុតកាត់ឲ្យជាកំណាត់តូចធំ ដាក់ក្នុងថ្លាង ហើយដុតក្នុង-ឡ ទ្រព្យមួយពាន់នេះជារង្វាន់សម្រាប់អ្នក ។ ក្នុងកាលក្រោយ ខ្ញុំនឹងធ្វើវត្ថុដែលគួរធ្វើជល់អ្នកឲ្យក្រៃលែងឡើង ។ ស្មូនឆ្នាំងពោលថា បានលោកម្ចាស់ ។

ស្អែកឡើង សេដ្ឋីហៅយោសកកុមារមកហើយពោលថា នែបា ម្សិលមិញនេះ អញប្រាប់ការងារដល់នាយស្នួនឆ្នាំងម្យ៉ាង ឯងចូរមក ហើយចូរទៅកាន់សម្នាក់របស់គាត់ ពោលយ៉ាងនេះថា បានឮថា អ្នកចូរញ៉ាំងការងារដែលឪពុករបស់ខ្ញុំប្រាប់កាលពីម្សិលមិញនេះឲ្យសម្រេចចុះ ដូច្នេះហើយ បានបញ្ជូនទៅហើយ ។ យោសកៈនោះទទួលថា បាទ បានទៅហើយ ។ ឯកូនប្រុសរបស់សេដ្ឋី កំពុងលេងកូនឃ្លីជាមួយពួកក្មេង កាលយោសកកុមារនោះដើរទៅក្នុងទីនោះ ទើបហៅយោសកៈនោះហើយសួរថា បងទៅណា កាលនាយយោសកៈពោលថា យកដំណឹងរបស់លោកឪពុកទៅកាន់សម្នាក់របស់នាយស្នួនឆ្នាំង ទើបពោលថា ខ្ញុំនឹងទៅក្នុងទីនោះ ក្មេងទាំងនេះឈ្នះខ្ញុំច្រើនពិន្ទុហើយ សូម្បីបងឈ្នះយកពិន្ទុសងឲ្យខ្ញុំវិញ យោសកកុមារពោលថា បងខ្ជាចលោកឪពុក ។ កូនសេដ្ឋីប្រាប់ថា សូមបងកុំខ្ជាចឡើយ ខ្ញុំនឹងនាំដំណឹងនោះទៅឯង ពួកក្មេងច្រើននាក់ឈ្នះខ្ញុំហើយ សូមបងឈ្នះយកពិន្ទុឲ្យខ្ញុំ ទម្រាំខ្ញុំត្រឡប់មក ។ បានឮថា យោសកៈជាអ្នកឈ្លាសក្នុងការលេងឃ្លី ព្រោះដូច្នោះ ទើបកូនប្រុសរបស់សេដ្ឋី បានទាក់ទាញយោសកៈនោះយ៉ាងនោះ ។

ចំណែកយោសកៈនោះពោលនឹងកូនសេដ្ឋីនោះថា បើដូច្នោះ ចូរឯងទៅប្រាប់នាយស្នួនឆ្នាំងថា បានឮថា កាលពីម្សិលមិញនេះ ឪពុករបស់ខ្ញុំប្រាប់ឲ្យអ្នកធ្វើការងារមួយ សូមអ្នកញ៉ាំងការងារនោះឲ្យសម្រេចចុះ ដូច្នេះហើយបញ្ជូនកូនសេដ្ឋីនោះទៅហើយ ។ កូនប្រុសរបស់សេដ្ឋីនោះ ទៅកាន់សម្នាក់របស់នាយស្នួនឆ្នាំងនោះ បានពោលតាមពាក្យនោះ ។ គ្រានោះ នាយស្នួន

ឆ្នាំងបានសម្លាប់កូនប្រុសសេដ្ឋីនោះ តាមពាក្យសេដ្ឋីប្រាប់នោះឯង ហើយចោះទៅក្នុង-ឮ ។

ចំណែកយោសកកុមារលេងអស់ភាគនៃថ្ងៃ លុះល្ងាចក៏ត្រឡប់ទៅផ្ទះសេដ្ឋីឃើញហើយ ទើបសួរថា នែបា ឯងមិនបានទៅឬ ក៏ប្រាប់ដល់ហេតុដែលខ្លួនមិនទៅ និងហេតុដែលប្អូនប្រុសទៅឲ្យជ្រាប ។ សេដ្ឋីស្តាប់ពាក្យនោះហើយ ទើបស្រែកយំពោលថា កុំសម្លាប់ឡើយ ហាក់បីដូចមានឈាមពុះក្នុងសរីរៈទាំងមូល ផ្គងដើមដៃកន្ទក់កន្ទេញថា ស្នូនឆ្នាំងជ័ចម្រើន កុំឲ្យខ្ញុំវិនាសឡើយ កុំឲ្យខ្ញុំវិនាសឡើយ ដូច្នេះ បានទៅកាន់សម្នាក់របស់នាយស្នូនឆ្នាំងនោះហើយ ។

នាយស្នូនឆ្នាំងឃើញសេដ្ឋីនោះមកដោយអាការយ៉ាងនោះ ទើបពោលថា នែលោកម្ចាស់ លោកម្ចាស់កុំធ្វើសំឡេងខ្លាំងឡើយ ការងាររបស់លោកម្ចាស់សម្រេចហើយ ។ សេដ្ឋីនោះត្រូវសេចក្តីសោកប្រៀបដូចភ្នំសង្កត់ហើយសោយទោមនស្ស មានប្រមាណមិនមែនតិច ដូចបុគ្គលមានចិត្តប្រទូស្តចំពោះបុគ្គលដែលមិនប្រទូស្ត ដូច្នោះ ។

ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា

> បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១

អាពាធជាទម្ងន់ ១ ក្រឡុកចិត្ត (ឆ្កួត) ១ រីបជាន់អំពីស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់ពួកញាតិរលីង ១ ពុកផុយកោគសម្បត្តិទាំងឡាយ ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ ១ បុគ្គលមិនមានអាជ្ញានោះ លុះបែកធ្លាយរាងកាយរមែងទៅកើតក្នុងនរក ។

ទោះបីដូច្នោះ សេដ្ឋីក៏មិនអាចសម្លឹងមើលនាយយោសកៈនោះត្រង់ៗ បានត្រិះរិះរកឧបាយថា ធ្វើម្តេចហ្ន៎ ទើបសម្លាប់វាបាន ក៏ឃើញឧបាយថា អញនឹងបញ្ជូនវាទៅកាន់សម្នាក់របស់នាយស្មៀន អ្នកទារពន្ធក្នុង ១០០ ស្រុករបស់អញឲ្យវាស្លាប់ ដូច្នោះហើយ ទើបសរសេរលិខិតទៅដល់មនុស្សនាយស្មៀននោះថា ជននេះជាកូនដែលមានជាតិអាក្រក់របស់ខ្ញុំ ចូរអ្នកសម្លាប់វាហើយបោះទៅក្នុងរណ្តៅលាមក កាលធ្វើការងារយ៉ាងនេះស្រេចហើយ ខ្ញុំនឹងដឹងវត្តដែលតបស្នងដល់អ្នកក្នុងកាលខាងក្រោយ ដូច្នេះហើយ ទើបពោលថា នែបាយោសកៈ អ្នកហូតព័ន្ធរបស់ឪពុកមាននៅត្រង់ស្រុកសួយ ១០០ ស្រុក អ្នកចូរនាំយកសំបុត្រនេះទៅឲ្យជននោះ ដូច្នេះ ទើបយកសំបុត្រចងត្រង់ជាយសំពត់របស់យោសកកុមារ ។

នាយយោសកៈនោះ មិនចេះអក្ខរសម័យឡើយ ព្រោះតាំងពីកុមារ សេដ្ឋីគិតសម្លាប់គេរហូត តែមិនអាចសម្លាប់បាន តើនឹងឲ្យគេសិក្សាអក្សរដូចម្តេចបាន ។ នាយយោសកៈនោះ ចងសំបុត្រសម្លាប់ខ្លួនឯងត្រង់ជាយសំពត់ដោយប្រការដូច្នេះ កាលនឹងចេញដំណើរ ទើបពោលថា បពិត្រលោកឪពុក

ខ្ញុំមិនមានស្បៀងសម្រាប់ដើរផ្លូវ ។ សេដ្ឋីពោលថា ឯងមិនចាំបាច់មានកិច្ច
កង្វល់ដោយស្បៀងដើរផ្លូវទេ្បីយ ក្នុងស្រុកឈ្មោះនោះ ក្នុងរវាងផ្លូវ សេដ្ឋី
ជាសម្លាញ់របស់អញមាន ឯងចូរទៅបរិភោគអាហារព្រឹកត្រង់ផ្ទះរបស់គេ
ហើយសឹមចេញដំណើរទៅ ។

យោសក:នោះទទួលថា បាទ ថ្វាយបង្គំបិតាហើយ ចេញដំណើរទៅ
ដល់ស្រុកនោះ សួរកផ្ទះសេដ្ឋី ជួបនឹងភរិយារបស់សេដ្ឋី កាលនាងពោល
ថា អ្នកមកពីណា ទើបឆ្លើយថា ខ្ញុំមកពីក្នុងក្រុង ភរិយាសេដ្ឋីពោលថា អ្នក
ជាកូនរបស់អ្នកណា យោសក:ពោលថា បពិត្រអ្នកម៉ែ ខ្ញុំជាកូនរបស់សេដ្ឋី
ដែលជាសម្លាញ់របស់អ្នកម៉ែ ភរិយាសេដ្ឋីពោលថា ឯងឈ្មោះយោសក:ឬ
យោសក:ឆ្លើយថា បាទ អ្នកម៉ែ ។

ព្រមគ្នានឹងការបានឃើញប៉ុណ្ណោះ សេចក្តីស្រឡាញ់ដូចកូនក្នុងយោសក:
នោះ កើតឡើងដល់នាងហើយ ។

សេដ្ឋីមានកូនក្រមុំម្នាក់ នាងមានអាយុ ១៥-១៦ ឆ្នាំ រូបរាងស្រស់
ស្អាតគួរជ្រះថ្លា សេដ្ឋីឲ្យស្រីបម្រើម្នាក់ដើម្បីរក្សានាងហើយ ឲ្យនៅក្នុងបន្ទប់
ដ៏មានសិរី ត្រង់ជាន់ខាងលើនៃប្រាសាទ ៧ ជាន់ ។ ក្នុងខណៈនោះ កូនក្រមុំ
សេដ្ឋីបានប្រើឲ្យស្រីបម្រើទៅផ្សារ ។ គ្រានោះ ភរិយាសេដ្ឋីឃើញទាសីនោះ
ហើយ សួរថា តើនាងទៅណា កាលនាងឆ្លើយថា បពិត្រអ្នកស្រី ខ្ញុំទៅ
ដោយកិច្ចបម្រើរបស់ធីតានៃអ្នកស្រី ទើបពោលថា ចូរនាងមកខាងណោះសិន
រៀរការបម្រើនោះ ចូររៀបចំគ្រែ លាងជើង លាបប្រេង ក្រាលទីដេកឲ្យកូន

របស់យើង សឹមធ្វើការបម្រើឯក្រោយ ។ នាងបានធ្វើតាមពាក្យប្រាប់ហើយ ។ គ្រានោះ កូនស្រីរបស់សេដ្ឋីបានសម្លុតស្រីបម្រើនោះដែលមកយឺត ។ ពេលនោះ ស្រីបម្រើនោះប្រាប់ថា បពិត្រអ្នកនាង កុំអាលខឹងខ្ញុំឡើយ កូនសេដ្ឋីឈ្មោះយោសក:មកហើយ ខ្ញុំធ្វើវត្តនេះ វត្តនេះដល់គាត់ហើយ ទើបទៅផ្សារហើយមក ។ គ្រាន់តែបានស្តាប់ពាក្យថា យោសក:ជាកូនសេដ្ឋីនោះ សេចក្តីស្រឡាញ់ជ្រាបចូលតាំងអំពីស្បែក រហូតដល់ខួរក្នុងឆ្អឹង តាំងឡើងដល់កូនស្រីសេដ្ឋីហើយ ។

ពិតហើយ កូនស្រីសេដ្ឋីនោះ ជាភរិយារបស់នាយយោសក:នោះ ក្នុងកាលនៅជានាយកោតុហលិក: បានប្រគេនបាយ ១ នាឡិដល់ព្រះបច្ចេកពុទ្ធ ដោយអានុភាពនៃផលទាននោះ ទើបនាងមកកើតក្នុងត្រកូលសេដ្ឋីនោះ ។ សេចក្តីស្រឡាញ់ក្នុងកាលមុន បានលិចលង់ គ្របជាប់កូនស្រីសេដ្ឋីនោះ ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា

> *សេចក្តីស្រឡាញ់នោះ រមែងកើតដោយហេតុពីរយ៉ាង គឺដោយធ្លាប់នៅរួមគ្នាក្នុងកាលមុន ១ ដោយការទំនុកបម្រុងគ្នាក្នុងបច្ចុប្បន្ននេះ ១ ដូចជាឧប្បលដែលដុះក្នុងទឹក ដោយហេតុ ២ យ៉ាង គឺទឹក ១ ភក់ ១ ដូច្នេះ ។*

ពេលនោះ ទើបសួរស្រីបម្រើនោះថា ឥឡូវនេះ បុរសនោះនៅឯណា ។ ស្រីបម្រើពោលថា គាត់ដេកលក់ក្នុងជំណោក ។ ធីតាសេដ្ឋីពោលថា ក្នុងដៃរបស់គាត់មានអ្វីខ្លះឬ ស្រីបម្រើពោលថា មានសំបុត្រត្រង់ជាយសំពត់ ។

ទើបកូនស្រីសេដ្ឋីនោះគិតថា នុ៎ះជាសំបុត្រអ្វីហ្ន៎ កាលនាយយោសក: កំពុងដេកលក់ កាលមាតាបិតាមិនឃើញ ព្រោះវេលាបញ្ជូនចិត្តទៅក្នុងរឿងដទៃ ចុះទៅកាន់សម្នាក់ហើយ ស្រាយយកសំបុត្រនោះ ចូលទៅកាន់បន្ទប់របស់ខ្លួន បិទទ្វារបើកបង្ហួចអានសំបុត្រ ព្រោះនាងឈ្លាសក្នុងអក្ខរសម័យ ហើយគិតថា ឱមនុស្សល្ងង់ខ្លៅ ចងសំបុត្រសម្រាប់សម្លាប់ត្រង់ជាយសំពត់ ហើយក៏គ្រាច់ទៅ បើអញមិនឃើញសំបុត្រហើយ គង់មិនមានជីវិត ដូច្នេះហើយ ទើបហែកសំបុត្រនោះចោល សរសេរសំបុត្រមួយច្បាប់ទៀត តាមពាក្យរបស់សេដ្ឋីថា កូនប្រុសរបស់ខ្ញុំនេះ ឈ្មោះយោសក: ចូរនាំគ្រឿងបណ្ណាការមកអំពីស្រុកទាំង ១០០ ធ្វើមង្គលជាមួយកូនស្រីសេដ្ឋីក្នុងជនបទនេះ ហើយធ្វើផ្ទះពីរជាន់ត្រង់កណ្តាលស្រុកជាលំនៅរបស់ខ្លួន ធ្វើការរក្សាឲ្យរឹងមាំដោយរបង គឺកំពែង និងរបង គឺបុរសហើយ ចូរបញ្ជូនដំណឹងមកឲ្យខ្ញុំថា ការនេះ ការនេះ ខ្ញុំធ្វើស្រេចហើយ កាលកម្មយ៉ាងនេះអ្នកធ្វើហើយ ខ្ញុំនឹងដឹងវត្តដែលគួរធ្វើដល់អ្នកក្នុងកាលខាងក្រោយ ។ លុះសរសេរស្រេចហើយ ទើបនាងរួសរាន់ ចុះទៅចងត្រង់ជាយសំពត់របស់នាយយោសក:នោះវិញ ។

យោសក:នោះ ដេកលក់ពេញមួយថ្ងៃ ក្រោកឡើងបរិភោគហើយ ក៏ចៀសចេញទៅ ក្នុងថ្ងៃស្អែកឡើង ទៅកាន់ស្រុកនោះអំពីព្រលឹម ក្រឡេកឃើញនាយស្មៀនធ្វើកិច្ចក្នុងផ្ទះនោះឯង ។នាយស្មៀននោះឃើញនាយយោសក:នោះហើយ ទើបសួរថា មានការអ្វីឬ នាយយោសក:នោះពោលថា លោកឪពុករបស់ខ្ញុំបញ្ជូនសំបុត្រមកដល់លោក ទើបស្មៀនសួរថា សំបុត្រដើម្បី

កិច្ចអ្វី ចូរបាប្រាប់មកចុះ ទទួលសំបុត្រហើយអាន ក៏មានការពេញចិត្ត ទើប ពោលនឹងគហបតីទាំងឡាយថា នែអ្នកទាំងឡាយ សូមអ្នកទាំងឡាយមើល ការស្រឡាញ់ក្នុងខ្ញុំរបស់ចៅហ្វាយយើងចុះ លោកសេដ្ឋីបញ្ជូនកូនមកកាន់ សម្នាក់ខ្ញុំ ដោយប្រាប់ថា ចូរធ្វើមង្គលដល់កូនប្រុសច្បងរបស់ខ្ញុំ ពួកអ្នកចូរ ប្រញាប់យកឈើជាដើមមកឲ្យរហ័ស ដូច្នេះហើយ ឲ្យសង់ផ្ទះមានប្រការ ដូចពោលហើយ ត្រង់កណ្តាលស្រុក ឲ្យនាំបណ្តាការមកអំពីស្រុក ១០០ នាំ កូនស្រីរបស់សេដ្ឋីក្នុងជនបទ មកធ្វើមង្គលហើយ ទើបបញ្ជូនដំណឹងទៅដល់ សេដ្ឋីថា ការនេះ ការនេះ ខ្ញុំធ្វើស្រេចហើយ ។

ព្រោះបានស្តាប់ដំណឹងនោះ ទោមនស្សជ័ធំកើតឡើងដល់សេដ្ឋីហើយ ថា អញឲ្យធ្វើវត្តណា វត្តនោះមិនសម្រេច វត្តណាមិនឲ្យធ្វើ វត្តនោះក៏បែរ ជាសម្រេច ការសោយសោកនោះ ផ្សំគ្នានឹងការសោយសោកដល់បុត្ររួម ចូលគ្នាតែមួយ ញាំងការក្តៅក្រហាយក្នុងពោះឲ្យកើតឡើង ឲ្យកើតរោគអតិ-សារៈហើយ គឺរោគចុះឈាមហើយ ។ កូនក្រមុំរបស់សេដ្ឋីប្រាប់ពួកមនុស្ស ថា បើអ្នកណាមួយមកអំពីសម្នាក់របស់សេដ្ឋី អ្នកមិនប្រាប់ដល់ខ្ញុំហើយ កុំ ប្រាប់ដល់សេដ្ឋីបុត្រមុនឡើយ សូម្បីសេដ្ឋីសោតក៏គិតថា ឥឡូវនេះ អញមិន ធ្វើបុត្រអាក្រក់នោះ ឲ្យជាម្ចាស់ទ្រព្យសម្បត្តិរបស់អញឡើយ ដូច្នេះហើយ ទើបប្រាប់នាយស្មៀនម្នាក់ថា នែអ៊ំ ខ្ញុំប្រាថ្នានឹងជួបកូនរបស់ខ្ញុំ ចូរអ៊ំបញ្ជូន អ្នកបម្រើម្នាក់ទៅហៅកូនរបស់ខ្ញុំមក បុរសនោះទទួលថា បាទ ឲ្យសំបុត្រ ហើយ បញ្ជូនមនុស្សម្នាក់ទៅ ។ ចំណែកកូនស្រីរបស់សេដ្ឋី ដឹងថាបុរសនោះ

មកឈរត្រង់ទ្វារ ឲ្យហៅមកហើយសួរថា នែបា តើបាមានការអ្វី អ្នកបម្រើពោលថា លោកសេដ្ឋីមានជំងឺត្រូវការជួបកូនប្រុស ទើបឲ្យហៅ ។ សេដ្ឋីធីតាពោលថា នែបា សេដ្ឋីនោះនៅមានកម្លាំង ឬថមថយកម្លាំងហើយ អ្នកបម្រើពោលថា នៅមានកម្លាំងនៅឡើយ នៅបរិភោគអាហារបាន ។

កូនស្រីសេដ្ឋីនោះ មិនឲ្យបុត្រសេដ្ឋីដឹងនោះឡើយ ឲ្យទីលំនៅនឹងស្បៀងសម្រាប់ដើរផ្លូវដល់បុរសនោះហើយពោលថា គាត់នឹងទៅបានក្នុងកាលដែលខ្ញុំបញ្ជូនទៅ ចូរស្នាក់នៅសិនចុះ ។

មហាសេដ្ឋីបានពោលនឹងនាយស្បៀនទៀតថា នែអ៊ំ អ្នកមិនទាន់បានបញ្ជូនសំបុត្រទៅកាន់សម្នាក់របស់កូនខ្ញុំទេឬ ។

នាយស្បៀនពោលថា បពិត្រលោកម្ចាស់ ខ្ញុំបញ្ជូនមនុស្សទៅហើយ តែមិនទាន់មក សេដ្ឋីពោលថា បើដូច្នោះ ចូរអ្នកបញ្ជូនមនុស្សទៅទៀត ។ នាយស្បៀននោះបញ្ជូនទៅហើយ ។

កូនស្រីរបស់សេដ្ឋី បដិបត្តិក្នុងបុរសនោះយ៉ាងនោះដូចគ្នា ក្នុងកាលនោះរោគរបស់សេដ្ឋីធ្ងន់ហើយ កាជន:មួយចូល កាជន:មួយចេញ ។

ទើបសេដ្ឋីសួរនាយស្បៀនទៀតថា នែអ៊ំ អ្នកមិនទាន់បានបញ្ជូនសំបុត្រទៅកាន់សម្នាក់កូនរបស់ខ្ញុំទេឬ ។ នាយស្បៀនពោលថា បពិត្រលោកម្ចាស់ ខ្ញុំបញ្ជូនទៅហើយ តែមនុស្សដែលទៅមិនទាន់ត្រឡប់ ។ សេដ្ឋីពោលថា បើដូច្នោះ ចូរអ្នកបញ្ជូនមនុស្សទៅទៀត ។

នាយស្បៀននោះ បញ្ជូនទៅហើយ ត្រូវកូនស្រីសេដ្ឋីសួរអំពីបវត្តិហេតុ

នោះ ដល់បុរសដែលមកក្នុងវារៈទីបីហើយ បុរសនោះប្រាប់ថា បពិត្រអ្នកនាង សេដ្ឋីឈឺធ្ងន់ដាច់អាហារហើយ មានការស្លាប់ជាទីទៅខាងមុខ ភាជនៈមួយចេញ ភាជនៈមួយចូល ។ កូនស្រីសេដ្ឋីគិតថា ឥឡូវនេះ ជាកាលដែលសេដ្ឋីបុត្រគួរទៅបាន ទើបប្រាប់ដល់សេដ្ឋីបុត្រថា បានឮថា ឪពុករបស់លោកមានជំងឺ ។ កាលសេដ្ឋីបុត្រពោលថា នែនាង នាងនិយាយអ្វី ទើបពោលថា ការមិនសុខមានដល់ឪពុករបស់លោក ឃោសកៈពោលថា ឥឡូវនេះ ខ្ញុំគួរធ្វើដូចម្តេច សេដ្ឋីធីតាពោលថា លោក យើងនឹងកាន់គ្រឿងបណ្ណាការអំពីស្រុកសួយ ១០០ ស្រុក ទៅសួរសុខទុក្ខលោក ។ ឃោសកៈនោះទទួលថា ពិតហើយ ទើបឲ្យមនុស្សនាំគ្រឿងបណ្ណាការមក យកវរទេះដឹកចៀសចេញទៅ ។

គ្រានោះ កូនស្រីរបស់សេដ្ឋីនោះ និយាយនឹងឃោសកៈនោះថា ឪពុករបស់លោកថយកម្លាំង បើយើងកាន់គ្រឿងបណ្ណាការ មានប្រមាណប៉ុណ្ណេះទៅ នឹងជាការយឺតយូរ សូមលោកឲ្យបញ្ជូនបណ្ណាការនេះត្រឡប់ចុះ ដូច្នេះហើយ ទើបបញ្ជូនបណ្ណាការទាំងអស់នោះ ទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួន ហើយពោលទៀតថា នែលោក លោកគប្បីឈរខាងចុងជើងនៃបិតារបស់លោក ខ្ញុំនឹងឈរខាងក្បាល ។ កាលចូលទៅកាន់ផ្ទះនោះហើយ នាងក៏ប្រាប់ពួកមនុស្សរបស់ខ្លួនថា ពួកអ្នកចូរកាន់យកការពារទាំងខាងមុខផ្ទះ ទាំងខាងក្រោយផ្ទះ ។ ក្នុងកាលដែលជនទាំងពីរចូលទៅ សេដ្ឋីបុត្របានឈរហើយខាងចុងជើងបិតា ចំណែកភរិយា បានឈរខាងក្បាល ។

ក្នុងខណៈនោះ សេដ្ឋីដេកផ្អារហើយ ចំណែកនាយស្មៀន កាលច្រចាប់

ជើងរបស់សេដ្ឋីនោះ ទើបពោលថា បពិត្រលោកម្ចាស់ កូនប្រុសរបស់លោកម្ចាស់មកហើយ ។ សេដ្ឋីពោលថា គេនៅឯណា នាយស្មៀនប្រាប់ថា គេឈរត្រង់ចុងជើង ។

គ្រានោះ សេដ្ឋីឃើញកូនប្រុសនោះហើយ ទើបហៅនាយស្មៀនមក ហើយសួរថា ក្នុងផ្ទះរបស់ខ្ញុំមានទ្រព្យប៉ុន្មាន កាលនាយស្មៀនប្រាប់ថា មាន ៤០ កោដិប៉ុណ្ណោះ តែគ្រឿងឧបភោគបរិភោគ ស្រុក ស្រែ សត្វជើង ២ ជើង ៤ យាន ពាហនៈ មានចំនួនប៉ុណ្ណេះៗ ប្រាថ្នានឹងពោលថា ខ្ញុំមិនឲ្យទ្រព្យមានប្រមាណប៉ុណ្ណេះ ដល់យោសកៈជាកូនរបស់ខ្ញុំទេ្បីយ តែវជាពោលថា ខ្ញុំឲ្យ ។ កូនស្រីសេដ្ឋីស្តាប់ពាក្យនោះហើយ គិតថា សេដ្ឋីនេះ កាលពោលគប្បីពោលពាក្យអ្វីដទៃ ធ្វើដួចក្តៅក្រហាយដោយសេចក្តីសោក រំសាយសក់ទ្រហោយំពោលថា លោកឪពុកពោលអ្វីនេះ ពួកខ្ញុំស្តាប់ពាក្យរបស់លោក ពួកខ្ញុំមិនមានបុណ្យហ្ន៎ ដូច្នេះហើយ ទើបយកក្បាលប្រហារសេដ្ឋីនោះ ត្រង់កណ្តាលដើមទ្រូង ក៏យកក្បាលចោកត្រង់ដើមទ្រូងសេដ្ឋីនោះ សម្តែងអាការសោយសោក រហូតសេដ្ឋីមិនអាចពោលបានទៀត សេដ្ឋីក៏បានធ្វើមរណកាលក្នុងខណៈនោះឯង ។

ជនទាំងឡាយបានឮថា សេដ្ឋីធ្វើអនិច្ចកម្មហើយ ទើបទៅក្រាបទូលព្រះបាទឧទេន ។ ព្រះបាទឧទេនទ្រង់ឲ្យធ្វើឈាបនកិច្ចសរីរៈរបស់សេដ្ឋីនោះ ហើយត្រាស់សួរថា កូនប្រុស ឬកូនស្រីរបស់សេដ្ឋីនោះមានដែរឬទេ ជនទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ មាន កូនប្រុសរបស់សេដ្ឋីនោះឈ្មោះ

យោសកៈ សេដ្ឋីនោះប្រគល់ទ្រព្យសម្បត្តិទាំងអស់ ឲ្យដល់យោសកៈនោះ ហើយ ក៏ដល់នូវអនិច្ចកម្ម ។ ព្រះរាជាទ្រង់ឲ្យហៅសេដ្ឋីបុត្រមកហើយក្នុង កាលដទៃ ក្នុងថ្ងៃដែលមានភ្លៀងធ្លាក់ ។ ត្រង់លានព្រះរាជវាំង មានទឹកជក់ ក្នុងទីនោះៗ សេដ្ឋីបុត្រទៅហើយដោយបំណងថា នឹងគាល់ព្រះរាជា ។ ព្រះ រាជាទ្រង់បើកបង្អួចទតមើលនាយយោសកៈនោះ កំពុងដើរមក ទ្រង់ឃើញ លោតរំលងទឹកត្រង់លានព្រះរាជវាំងដើរមក ទើបត្រាស់សួរយោសកៈដែល មកថ្វាយបង្គំ ហើយឈរថា នែបា បាឈ្មោះយោសកៈឬ កាលយោសកៈ ទូលថា ត្រូវហើយព្រះអង្គ ទ្រង់លួងលោមយោសកៈថា បាកុំទោមនស្ស ឡើយថា បិតារបស់អញអនិច្ចកម្មហើយ យើងនឹងឲ្យតំណែងសេដ្ឋី ដែលជា របស់ឪពុកបាដល់បានោះឯង ដូច្នេះហើយ ទ្រង់បញ្ជូនយោសកៈទៅថា ចូរបា ទៅចុះ ។ ព្រះរាជាបានប្រថាប់ឈរមើលយោសកៈ ដែលកំពុងទៅនោះឯង យោសកៈមិនលោតរំលងទឹក ដែលគេលោតក្នុងកាលមក បានចុះទៅ សន្សឹមៗ នោះឯង ។

កាលនោះ ព្រះរាជាត្រាស់ឲ្យហៅយោសកៈនោះមកអំពីទីនោះឯង រួច ត្រាស់សួរថា នែបា ព្រោះហេតុអ្វីហ្ន៎ កាលអ្នកមកកាន់សម្នាក់យើង លោត រំលងទឹកមក កាលទៅ ក៏ចុះទៅសន្សឹមៗ ដើរទៅ ។ នាយយោសកៈទូល ថា យ៉ាងនោះឯងព្រះអង្គ កាលនោះទូលបង្គំនៅជាកុមារ នេះឈ្មោះថា ជា កាលដែលត្រូវលេង ក្នុងកាលនេះ ទូលបង្គំបានទទួលតំណែងអំពីព្រះអង្គ ហើយ ព្រោះដូច្នោះ កាលដែលទូលបង្គំមិនត្រាច់ទៅដូចក្នុងកាលមុន ហើយ

ដើរសន្សឹមៗ ទៅ ទើបគួរក្នុងកាលឥឡូវនេះ ។

ព្រះរាជាស្តាប់ពាក្យនោះហើយ ទ្រង់ត្រិះរិះថា បុរសនេះជាអ្នកមានបញ្ញា អញនឹងឲ្យតំណែងជាសេដ្ឋីដល់គេក្នុងកាលឥឡូវនេះចុះ ដូច្នេះហើយ ប្រទានភោគៈដែលបិតាបរិភោគហើយ បានប្រទានតំណែងសេដ្ឋី មួយអន្ទើដោយវត្ថុមួយមុខៗ ១០០ ។

យោសកៈនោះ ឈរនៅលើរថ បានធ្វើប្រទក្សិណព្រះនគរហើយ ទីដែលនាយយោសកៈនោះសម្ទឹងមើលហើយ រមែងញាប់ញ័រ ។ កូនស្រីរបស់សេដ្ឋីអង្គុយប្រឹក្សាជាមួយកាឡីស្រីបម្រើថា នែកាឡី សម្បត្តិមានប្រមាណប៉ុណ្ណេះ សម្រេចហើយដល់សេដ្ឋីបុត្រ ក៏ព្រោះអាស្រ័យខ្ញុំ ។ នាងកាឡីពោលថា ព្រោះហេតុអ្វី ។ សេដ្ឋីធីតាពោលថា ព្រោះយោសកៈនេះចងសំបុត្រសម្ទាប់ខ្ជូនត្រង់ជាយសំពត់ មកកាន់ផ្ទះរបស់ខ្ញុំ ។ កាលនោះ ខ្ញុំហែកសំបុត្រនោះចោលសរសេរសំបុត្រដទៃដើម្បីធ្វើការមង្គលជាមួយខ្ញុំ ខ្ញុំរក្សាគាត់អស់កាល មានប្រមាណប៉ុណ្ណេះ ។

នាងកាឡីពោលថា អ្នកនាងដឹងត្រឹមតែប៉ុណ្ណេះ តែសេដ្ឋីបំណងនឹងសម្ទាប់សេដ្ឋីបុត្រ តាំងអំពីនៅជាកុមារ ក៏មិនអាចសម្ទាប់បាន អាស្រ័យលោកម្ចាស់យោសកៈនេះតែម្យ៉ាង អស់ទ្រព្យសន្ធឹកសន្ធាប់ ។ សេដ្ឋីធីតាពោលថា លោកសេដ្ឋីធ្វើកម្មធ្ងន់ហ្នឹ ។ សេដ្ឋីធីតានោះ យើញនាយយោសកៈនោះធ្វើប្រទក្សិណនគរ ចូលទៅកាន់ផ្ទះ ទើបអស់សំណើចដោយគិតថា សម្បត្តិមានប្រមាណប៉ុណ្ណេះ សម្រេចហើយព្រោះអាស្រ័យអញ ។

គ្រានោះ សេដ្ឋីបុត្រឃើញអាការនោះ ទើបសួរថា នាងសើចអ្វី សេដ្ឋី-ធីតាពោលថា ព្រោះអាស្រ័យហេតុមួយ សេដ្ឋីបុត្រពោលថា ចូរប្រាប់ហេតុនោះមកចុះ សេដ្ឋីធីតានោះពោលថា មិនប្រាប់ ទើបសេដ្ឋីបុត្រនោះសម្ដែតថា បើមិនប្រាប់ ខ្ញុំនឹងកាប់ជាពីរកំណាត់ ដូច្នេះ ទើបដកដាវចេញហើយ ។

ទើបសេដ្ឋីធីតានោះប្រាប់ថា ខ្ញុំសើចក៏ព្រោះគិតថា សម្បត្តិមានប្រមាណប៉ុណ្ណេះ លោកបានហើយក៏ព្រោះអាស្រ័យខ្ញុំ ។ សេដ្ឋីពោលថា បើឪពុករបស់ខ្ញុំប្រគល់មត៌ករបស់ខ្លួនឲ្យដល់ខ្ញុំហើយ នាងនឹងទាក់ទិនអ្វីក្នុងទ្រព្យនេះ ។ បានឮថា សេដ្ឋីមិនដឹងរឿងអ្វីសោះ អស់កាលមានប្រមាណប៉ុណ្ណេះ ព្រោះដូច្នោះ ទើបមិនជឿពាក្យរបស់សេដ្ឋីធីតានោះ គ្រានោះ សេដ្ឋីធីតានោះបាននិទានរឿងទាំងអស់នោះដល់សេដ្ឋីបុត្រនោះថា បិតារបស់លោកឲ្យសំបុត្រសម្ងាប់លោកបញ្ជូនលោកមកហើយ ខ្ញុំធ្វើកម្មយ៉ាងនេះៗ រក្សាលោកហើយ ។ សេដ្ឋីបុត្រពោលថា នាងនិយាយមិនពិត ទើបគិតថា អញនឹងសួរនាងកាឡី ដូច្នោះហើយ ទើបពោលថា នែនាងកាឡី បានឮថា សេចក្ដីនេះយ៉ាងនោះឬ ទើបនាងកាឡីពោលថា បពិត្រលោកម្ចាស់ តាំងអំពីលោកម្ចាស់នៅជាកុមារ សេដ្ឋីបំណងនឹងសម្ងាប់លោកម្ចាស់ តែមិនអាចសម្ងាប់បាន អាស្រ័យលោកម្ចាស់អស់ទ្រព្យសន្ធឹកសន្ធាប់ លោកម្ចាស់រួចផុតហើយអំពីសេចក្ដីស្លាប់ក្នុងទី ៧ កន្លែង ឥឡូវនេះ មកហើយ អំពីស្រុកសួយ សូម្បីជំណែងសេដ្ឋីនេះ មួយអន្ទើដោយវត្ថុសព្វយ៉ាង មួយមុខៗ ១០០ ។

សេដ្ឋីស្ដាប់ពាក្យនោះហើយគិតថា អញធ្វើកម្មធ្ងន់ហ្ន៎ អញផុតអំពីសេចក្ដី

ស្លាប់បែបនេះ ហើយរស់នៅដោយសេចក្តីប្រមាទមិនសមគួរឡើយ អញនឹងមិនប្រមាទដូច្នេះ លះទ្រព្យមួយថ្ងៃមួយពាន់ ផ្តើមធ្វើនូវទាន ដើម្បីអ្នកដើរផ្លូវឆ្ងាយ និងមនុស្សកំព្រាជាដើមហើយ ។

កុដុម្ពិកៈឈ្មោះមិត្តៈ បានជាអ្នកទ្វល់ទ្វាយ ក្នុងទានរបស់សេដ្ឋីនោះឯង ការកើតឡើងរបស់យោសកសេដ្ឋីដូច្នេះ ។

ក្នុងកាលនោះ សេដ្ឋីឈ្មោះកទ្រវតិយៈ ក្នុងកទ្រវតីនគរ បានជាអទិដ្ឋ-បុព្វសហាយ គឺសម្លាញ់ដែលមិនដែលឃើញគ្នារបស់យោសកសេដ្ឋីហើយ ។ យោសកសេដ្ឋីបានស្តាប់សម្បត្តិ វ័យ និងប្រទេសរបស់កទ្រវតិយសេដ្ឋី ក្នុងសម្នាក់របស់ពួកឈ្មួញ ដែលមកហើយអំពីកទ្រវតីនគរ ប្រាថ្នានូវភាពជាសម្លាញ់ជាមួយសេដ្ឋីនោះ ទើបបញ្ជូនបណ្ណាការទៅហើយ ។ កទ្រវតិយសេដ្ឋីបានស្តាប់សម្បត្តិ វ័យ និងប្រទេសរបស់យោសកសេដ្ឋី ក្នុងសម្នាក់របស់ពួកឈ្មួញដែលមកហើយអំពីក្រុងកោសម្ពី ប្រាថ្នាភាពជាសម្លាញ់ជាមួយសេដ្ឋី ទើបបញ្ជូនគ្រឿងបណ្ណាការទៅហើយ សេដ្ឋីទាំងពីរនោះ បានជាអទិដ្ឋបុព្វសហាយនៃគ្នានិងគ្នាហើយយ៉ាងនេះ ។

ក្នុងកាលដទៃ អហិវាតករោគធ្លាក់ចុះហើយក្នុងផ្ទះរបស់កទ្រវតិយសេដ្ឋី កាលអហិវាតករោគនោះធ្លាក់ចុះហើយ រុយស្លាប់មុន បន្ទាប់អំពីនោះ កណ្ហបកណ្ហរ មាន់ ជ្រូក ឆ្កែ ឆ្មា គោ អ្នកបម្រើស្រី អ្នកបម្រើប្រុស ស្លាប់ទៅដោយលំដាប់នោះឯង មនុស្សម្នាស់ផ្ទះ ស្លាប់ក្រោយគេ ។ ក្នុងជនទាំងនោះ ពួកជនណាទម្លាយជញ្ជាំងផ្ទះគេចទៅ ជននោះរមែងបានរួចជីវិត ។ កាលនោះ

សេដ្ឋី ភរិយា និងកូនស្រីក៏គេចទៅដោយវិធីនោះ ប្រាថ្នានឹងឃើញយោសក-សេដ្ឋី ទើបធ្វើដំណើរទៅកាន់ក្រុងកោសម្ពី ។ ជន ៣ នាក់នោះ មានស្បៀងអស់ក្នុងវាងផ្លូវ មានសរីរៈទាន់ខ្សោយ ដោយឃ្លាន និងកម្ដៅថ្ងៃ និងដោយការស្រេកឃ្លាន ដល់ក្រុងកោសម្ពីដោយលំបាក ងូតទឹកក្នុងទីដែលសប្បាយដោយទឹកហើយ ក៏ចូលទៅកាន់សាលាមួយ ត្រង់ទ្វារក្រុង ។

ក្នុងកាលនោះ សេដ្ឋីពោលនឹងភរិយាថា នែនាង បុគ្គលមកដោយទំនងនេះ រមែងមិនត្រូវចិត្តសូម្បីម្ដាយបង្កើត បានឮថាសម្ងាញ់របស់យើងលះទ្រព្យមួយថ្ងៃមួយពាន់ ឲ្យទានដល់អ្នកដំណើរ មនុស្សកំព្រាជាដើម យើងបញ្ជូនកូនស្រីទៅក្នុងទីនោះ ឲ្យនាំអាហារមកទំនុកបម្រុងសរីរៈក្នុងទីនេះឯង ១ ថ្ងៃ ២ ថ្ងៃហើយ សឹមសួរសុខទុក្ខសម្ងាញ់ នាងទទួលថា សាធុ ។ ជនទាំងពីរនាំគ្នាស្នាក់នៅក្នុងសាលានោះឯង ។ ក្នុងថ្ងៃស្អែកឡើង កាលមហាជនជ្រាប់កាលហើយ មនុស្សកំព្រា អ្នកដើរផ្លូវជាដើម កំពុងទៅដើម្បីអាហារ ទើបមាតា និងបិតា បញ្ជូនកូនស្រីទៅដោយពាក្យថា នែនាង ចូរនាងទៅនាំអាហារដើម្បីពួកយើង ។ ធីតារបស់ត្រកូលដែលមានភោគៈច្រើន មិនខ្វាស ព្រោះភាពដែលខ្លួនមានការខ្វាសដែលការវិបត្តិកាត់ផ្ដាច់ហើយ កាន់ថាសទៅដើម្បីអាហារជាមួយមនុស្សអនាថា កាលមិត្តកុដុម្ពិកៈសួរថា នាងនឹងទទួលប៉ុន្មានចំណែក ក៏ជ្រាប់ថា ៣ ចំណែក ពោលនោះ មិត្តកុដុម្ពិកៈឲ្យកន្លាហារ ៣ ចំណែកដល់នាង ។ កាលនាងនាំកត្តមកហើយ ជនទាំង ៣ ក៏អង្គុយដើម្បីបរិភោគរួមគ្នា ទើបមាតា និងកូនស្រី ពោលនឹងសេដ្ឋីថា បពិត្រលោកម្ចាស់

ការវិបត្តិតែងកើតឡើងសូម្បីត្រកូលធំ កុំគិតពួកខ្ញុំឡើយ សូមបរិភោគចុះ ។ អង្វរដោយប្រការផ្សេងៗ ញុំាងសេដ្ឋីនោះឲ្យបរិភោគហើយ ដោយប្រការយ៉ាងនេះ ។

សេដ្ឋីនោះបរិភោគហើយ មិនអាចឲ្យអាហាររលាយបាន កាលអរុណរះឡើង ក៏ធ្វើកាលកិរិយាហើយ មាតា និងកូនស្រីយំសោកដោយប្រការផ្សេងៗ ក្នុងថ្ងៃស្អែកឡើង កុមារិកាដើរយំទៅដើម្បីអាហារ មិត្តកុដុម្ពិក:នោះឃើញហើយ សួរថា នាងទទួលប៉ុន្មានចំណែក ទើបជ្រាប់ថា ពីរចំណែក ។ មិត្តកុដុម្ពិក:នោះក៏ឲ្យ ២ ចំណែក ។ នាងនាំមកហើយ ក៏អង្វរឲ្យមាតាបរិភោគ មាតាកាលធីតារបស់ខ្លួនអង្វរហើយ ក៏បរិភោគ ហើយមិនអាចឲ្យអាហាររលាយបានក្នុងថ្ងៃនោះ ក៏ធ្វើកាលកិរិយាហើយ ។ ក្មេងស្រីម្នាក់ឯងប៉ុណ្ណោះយំរៀបរាប់ ជាអ្នកមានសេចក្តីទុក្ខ ព្រោះសេចក្តីឃ្លានដែលកើតឡើងហើយដ៏ខ្លាំងក្លា ព្រោះការកើតឡើងនៃសេចក្តីទុក្ខនោះ ថ្ងៃស្អែកឡើង ក៏ដើរយំទៅដើម្បីអាហារ ជាមួយពួកជនក្រីក្រ មិត្តកុដុម្ពិក:សួរថា នាងទទួលប៉ុន្មានចំណែក ទើបជ្រាប់ថា មួយចំណែក ។ មិត្តកុដុម្ពិក:ចាំនាងដែលទទួលភត្តបានទាំងបីថ្ងៃ ព្រោះហេតុនោះ ទើបពោលនឹងនាងថា ចូរវិនាសចុះ ស្រីថោកទាប ថ្ងៃនេះ នាងស្គាល់ប្រមាណក្នុងពោះរបស់នាងឬ ។ ធីតាមានត្រកូល បរិបូណ៌ដោយហិរិឱត្តប្បៈ ដូចត្រូវប្រហារដោយលំពែងត្រង់ទ្រូង និងដូចស្រោចដោយទឹកក្បុងត្រង់ជំហៅ សួរថា តើលោកនិយាយអ្វី ។ មិត្តកុដុម្ពិក:ពោលថា ថ្ងៃមុន នាងទទួលយកទៅបីចំណែក ម្សិលមិញពីរចំណែក ថ្ងៃនេះ

ទទួលមួយចំណែក ថ្ងៃនេះ នាងជីងប្រមាណក្នុងពោះរបស់នាងហើយឬ ។ កុលធីតាពោលថា នែលោក លោកកុំយល់ថា ខ្ញុំទទួលទៅដើម្បីបរិភោគម្នាក់ឯង ។ មិត្តកុដុម្ពិកៈពោលថា បើយ៉ាងនោះ ហេតុអ្វី ទើបទទួលបីចំណែក ។ កុលធីតាពោលថា ថ្ងៃមុន ពួកខ្ញុំមានគ្នាបីនាក់ មរ្យែលមិញ មានពីរនាក់ ថ្ងៃនេះមានតែខ្ញុំម្នាក់ឯងប៉ុណ្ណោះ ។ ទើបមិត្តកុដុម្ពិកៈសួរថា សេចក្តីនេះដូចម្តេច ។ បានស្តាប់រឿងទាំងអស់ដែលនាងប្រាប់ហើយ តាំងអំពីដើមមិនអាចទប់ទឹកភ្នែកបាន កើតនូវទោមនស្សដ៏ខ្លាំងពន់ប្រមាណ ទើបប្រាប់ថា នែនាង បើមានហេតុយ៉ាងនេះ កុំគិតថ្ងីឡើយ នាងជាធីតារបស់កទូវតិយសេដ្ឋី ចាប់អំពីថ្ងៃនេះទៅ ចូរនាងជាធីតារបស់ខ្ញុំចុះ ដូច្នេះហើយ ថើបត្រង់ក្បាលនាំទៅកាន់ផ្ទះ ទុកក្នុងតំណែងជាកូនស្រីច្បងរបស់ខ្លួនហើយ ។

សេដ្ឋីធីតានោះស្តាប់សំឡេងខ្ញៀវខ្ញារក្នុងរោងទាន ទើបសួរថា លោកឪពុក ហេតុអ្វី ទើបមិនធ្វើជនទាំងនេះឲ្យស្វាត់ស្ងៀម ហើយឲ្យទាន ទើបមិត្តកុដុម្ពិកៈពោលថា នែនាង មិនអាចធ្វើបានទេ សេដ្ឋីធីតាពោលថា បពិត្រលោកឪពុក អាចធ្វើបាន មិត្តកុដុម្ពិកៈពោលថា នែនាង តើធ្វើដូចម្តេច សេដ្ឋីធីតាពោលថា បពិត្រលោកឪពុក សូមលោកឪពុកព័ទ្ធរោងទាន ទុកទ្វារពីរកន្លែង លួមប្រមាណបុគ្គលម្នាក់ចូលទៅបានប៉ុណ្ណោះ ហើយប្រាប់ថា ពួកអ្នកចូលតាមទ្វារមួយ ចេញតាមទ្វារមួយ ដោយអាការយ៉ាងនេះ ជនទាំងឡាយ នឹងស្វាត់ស្ងៀម ហើយទទួលទាន ។

មិត្តកុដុម្ពិកៈនោះស្តាប់ពាក្យនោះហើយ ទើបពោលថា នែនាង ឧបាយ

នេះល្អ ដូច្នេះ ឲ្យធ្វើដូច្នោះហើយ ។ សូម្បីសេដ្ឋីធីតានោះ ក្នុងកាលមុន ឈ្មោះ សាមា តែព្រោះនាងឲ្យធ្វើរបង ទើបឈ្មោះថា សាមាវតី តាំងអំពីកាលនោះ ការកោលាហលក្នុងរោងទានក៏បាត់អស់ទៅ ។ ឃោសកសេដ្ឋីបានស្តាប់សំឡេងនោះក្នុងកាលមុន ក៏ពេញចិត្តថា នេះជាសំឡេងក្នុងរោងទានរបស់អញ តែកាលមិនបានឮសំឡេង ២-៣ ថ្ងៃ ទើបសួរមិត្តកុដុម្ភិក: ដែលមកកាន់កន្លែងរបស់ខ្លួនថា នែអ្នក ទានដើម្បីមនុស្សកំព្រា និងមនុស្សធ្វើដំណើរឆ្ងាយជាដើម អ្នកនៅតែឲ្យឬ មិត្តកុដុម្ភិក:ឆ្លើយថា បាទ លោកម្ចាស់ ។ ឃោសកសេដ្ឋីពោលថា បើយ៉ាងនេះ ហេតុអ្វី ទើបខានឮសំឡេង ២-៣ ថ្ងៃ មិត្តកុដុម្ភិក: ឆ្លើយថា ខ្ញុំធ្វើឧបាយដោយអាការដែលពួកគេមិនមានសំឡេង ហើយទទួល ។ ឃោសកសេដ្ឋីពោលថា បើយ៉ាងនេះ ព្រោះហេតុអ្វី ទើបអ្នកមិនធ្វើក្នុងកាលមុន មិត្តកុដុម្ភិក:ពោលថា ព្រោះខ្ញុំមិនដឹង ។ ឃោសកសេដ្ឋីសួរថា ចុះឥឡូវនេះ អ្នកដឹងបានដូចម្តេច មិត្តកុដុម្ភិក:ពោលថា កូនស្រីរបស់ខ្ញុំជាអ្នកប្រាប់ ។ ឃោសកសេដ្ឋីពោលថា កូនស្រីរបស់អ្នកដែលខ្ញុំមិនស្គាល់មានឬ ។ មិត្តកុដុម្ភិក:នោះ និទានរឿងរបស់កទុវតិយសេដ្ឋីទាំងអស់ ចាប់តាំងអំពីកើតអហិវាតកវេគហើយ ក៏ប្រាប់ភាពដែលខ្លួនតាំងធីតារបស់សេដ្ឋីនោះ ក្នុងតំណែងជាកូនស្រីច្បងរបស់ខ្លួន ។

គ្រានោះ សេដ្ឋីពោលនឹងមិត្តកុដុម្ភិក:នោះថា កាលបើដូច្នេះ ព្រោះហេតុអ្វីទើបអ្នកមិនប្រាប់ដល់ខ្ញុំ ធីតារបស់សម្លាញ់ខ្ញុំ ក៏ឈ្មោះថាជាធីតារបស់ខ្ញុំដែរ ដូច្នេះហើយ ឲ្យហៅនាងសាមាវតីនោះមកសួរថា នែនាង នាងជាកូនស្រីសេដ្ឋី

ឬ នាងសាមាវតីឆ្លើយ ពិតហើយលោកឪពុក ។ ឃោសកសេដ្ឋីពោលថា បើដូច្នោះ នាងកុំគិតថ្លៃឡើយ នាងជាធីតារបស់ខ្ញុំដូច្នេះ ថើបនាងសមាវតីនោះ ត្រង់ក្បាល ឲ្យស្រី ៥០០ ដល់នាងសាមាវតីនោះ ដើម្បីប្រយោជន៍ដល់ភាពជាបរិវារ តាំងនាងសាមាវតីនោះក្នុងតំណែងធីតាច្បងរបស់ខ្លួនហើយ ។

សម័យថ្ងៃមួយ ក្នុងនគរនោះប្រកាសនក្ខត្តឫក្សហើយ ក្នុងបុណ្យនក្ខត្ត-ឫក្សនោះ កុលធីតាទាំងឡាយ ដែលមិនបានចេញទៅខាងក្រៅ ក៏ត្រូវនាំគ្នាដើរទៅកាន់ស្ទឹង ងូតទឹកជាមួយបរិវារវៀងៗ ខ្លួន ។ ព្រោះហេតុនោះ ក្នុងថ្ងៃនោះនាងសាមាវតីដែលស្រី ៥០០ ចោមរោមហើយ ក៏បានទៅងូតទឹក កាត់តាមលានព្រះរាជវាំងដូចគ្នា ។ ចំណែកព្រះបាទឧទេន ប្រថាប់ត្រង់សីហបញ្ជរ ទតឃើញនាងសាមាវតីនោះ ទើបត្រាស់សួរថា ស្រីទាំងនេះជាស្រីរបាំរបស់អ្នកណា រាជបុរសទូលថា បពិត្រព្រះអង្គ មិនជាស្រីរបាំរបស់អ្នកណាឡើយ ។ ព្រះបាទឧទេនត្រាស់ថា បើយ៉ាងនោះជាកូនស្រីរបស់អ្នកណា រាជបុរសពិតថា បពិត្រព្រះអង្គ ជាកូនស្រីរបស់ឃោសកសេដ្ឋី នាងឈ្មោះសាមាវតី ។

ព្រះបាទឧទេនទតឃើញ ទ្រង់ក៏កើតស្នេហា ទើបត្រាស់ឲ្យបញ្ជូនរាជ-សាសន៍ទៅឲ្យសេដ្ឋីថា លោកសេដ្ឋី ចូរបញ្ជូនធីតាមកឲ្យខ្ញុំចុះ សេដ្ឋីក្រាបថា បពិត្រព្រះអង្គ បញ្ជូនមិនបានទេ ។ ព្រះបាទឧទេនត្រាស់ថា សូមលោកសេដ្ឋីកុំធ្វើយ៉ាងនេះឡើយ លោកសេដ្ឋី ចូរបញ្ជូនមកឲ្យខាងតែបាន សេដ្ឋីពោលថា ពួកទូលបង្គំជាគហបតីឲ្យមិនបាន ព្រោះខ្លាចភ័យដោយការវាយតប រុញច្រានរបស់នាងកុមារិកា ។

ព្រះរាជាទ្រង់ពិរោធ ទើបត្រាស់ឲ្យវាយត្រាផ្ចុះចាប់សេដ្ឋី និងភរិយារបស់សេដ្ឋីទុកខាងក្រៅ នាងសាមាវតីងូតទឹកហើយត្រឡប់មក មិនបានឱកាសចូលកាន់ផ្ទះ ទើបសួរថា បពិត្រលោកឪពុក តើមានរឿងអ្វី សេដ្ឋីឆ្លើយថា នែនាង ព្រះរាជាបញ្ជូនរាជសាសន៍មក ព្រោះហេតុតែនាង កាលពួកយើងពោលថា មិនឲ្យ ទើបទ្រង់បញ្ជាឲ្យវាយត្រាផ្ទះ ហើយបញ្ជាឲ្យធ្វើពួកយើងនៅខាងក្រៅ ទើបនាងសាមាវតីពោលថា បពិត្រលោកឪពុក លោកឪពុកធ្វើកម្មជួនហើយ ធម្មតាព្រះរាជាកាលបញ្ជូនរាជសាសន៍មកហើយ មិនគួរទូលថា មិនឲ្យ គួរទូលថា បើព្រះអង្គទ្រង់ទទួលធីតារបស់ទូលបង្គំ ព្រមទាំងបរិវារ ក៏នឹងថ្វាយ សេដ្ឋីពោលថា សាធុ បើនាងពេញចិត្ត ឪពុកនឹងធ្វើយ៉ាងនោះ ដូច្នេះហើយ ទើបបញ្ជូនដំណឹងទៅថ្វាយព្រះរាជាតាមនោះ ។

ព្រះរាជាទទួលថា សាធុ ទ្រង់នាំនាងសាមាវតីនោះមក មួយអន្ទើដោយបរិវារ ទ្រង់អភិសេកតាំងទុកក្នុងតំណែងអគ្គមហេសីហើយ ។ ស្រីដ៏សេសក៏បានជាបរិវាររបស់នាងដូចគ្នា ។ នេះជារឿងរបស់នាងសាមាវតី ។

ចំណែកព្រះបាទឧទេន មានព្រះទេវីមួយអង្គទៀត ព្រះនាមថា ព្រះនាងវាសុលទត្តា ជាព្រះរាជធីតារបស់ព្រះបាទចណ្ឌប្បជ្ជោត ។ សេចក្តីពិស្តារថា ក្នុងក្រុងឧជ្ជេនី មានព្រះរាជាទ្រង់ព្រះនាមចណ្ឌប្បជោត ។ ថ្ងៃមួយ ទ្រង់យោងមកអំពីព្រះរាជឧទ្យាន ទតមើលសម្បត្តិរបស់ព្រះអង្គហើយ ត្រាស់ថា សម្បត្តិបែបនេះ បុគ្គលដទៃណាម្នាក់មានដែរឬហ្ន៎ កាលអមាត្យក្រាបទូលថា ឈ្មោះថា សម្បត្តិណាមួយ សម្បត្តិរបស់ព្រះបាទឧទេន ក្នុងក្រុងកោសម្ពី

ច្រើនពេកណាស់ ដូច្នេះហើយ ត្រាស់ថា បើយ៉ាងនោះ យើងនឹងចាប់ស្តេចឧទេននោះ អមាត្យពោលថា បុគ្គលណាម្នាក់ក៏មិនអាចចាប់ទ្រង់បានដែរ ។ ព្រះរាជាត្រាស់ថា យើងនឹងធ្វើឧបាយណាមួយចាប់ឲ្យបាន ។ អមាត្យទូលថា មិនអាចទេ ព្រះអង្គ ។ ព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី អមាត្យទាំងនោះពោលថា ព្រោះព្រះបាទឧទេននោះចេះសិប្បៈឈ្មោះហត្ថិកន្តៈ ទ្រង់រាយមន្តហើយ ដេញពិណហត្ថិកន្តៈ នឹងឲ្យដំរីគេចទៅក៏បាន នឹងចាប់យកក៏បាន បុគ្គលដែលដល់ព្រមដោយពាហនៈ គឺដំរីជួចទ្រង់ មិនមានឡើយ ។ ព្រះរាជាត្រាស់ថា យើងមិនអាចចាប់ស្តេចអង្គនោះបានឬ អមាត្យទូលថា បពិត្រព្រះអង្គ បើទ្រង់មានព្រះហឫទ័យដូច្នេះ ដោយចំណែកមួយហើយ បើដូច្នោះ សូមទ្រង់បញ្ជាឲ្យជាងធ្វើដំរីឈើ ហើយបញ្ជូនទៅកាន់លំនៅរបស់ព្រះបាទឧទេននោះ ព្រះរាជាទ្រង់ឮដល់ពាហនដំរី ឬពាហនសេះហើយ រមែងយ៉ាងទៅ សូម្បីនៅឆ្ងាយ យើងអាចចាប់ទ្រង់ ដែលយាងមកក្នុងទីនោះបាន ។

ព្រះរាជាត្រាស់ថា ឧបាយនេះប្រើការបាន ដូច្នេះហើយ ទើបប្រាប់ឲ្យជាងឈើធ្វើដំរីយន្តសម្រេចដោយឈើ យកសំពត់ចាស់ស្រោបខាងក្រៅ ធ្វើឲ្យស្អាត ឲ្យលៃងទៅត្រង់មាត់ស្រះមួយកន្លែង ក្នុងទីជិតដែនរបស់ព្រះបាទឧទេននោះ ។ បុរស ៦០ នាក់ដើរទៅមកក្នុងពោះដំរី ពួកគេនាំមូលដំរីមកចោលក្នុងទីនោះៗ ។ ព្រានព្រៃម្នាក់ឃើញដំរីហើយក៏គិតថា ដំរីនេះគួរដល់ស្តេចផែនដីរបស់យើង ដូច្នេះហើយ ទើបទៅក្រាបទូលព្រះបាទឧទេនថា បពិត្រព្រះអង្គ ទូលបង្គំជួបដំរីដ៏ប្រសើរ មានពណ៌សសុទ្ធ មានចំណែកប្រៀបដោយ

កំពូលភ្នំកៃលាស គួរដល់ព្រះអង្គនោះឯង ។ ព្រះបាទឧទេនឲ្យព្រាននោះឯងនាំផ្លូវ ឡើងលើដីរ ព្រមដោយបរិវារ ទ្រង់ចេញទៅហើយ ។ ពួកចារបុរសជ្រាបការយោងមករបស់ទ្រង់ ទើបទៅក្រាបទូលដល់ព្រះបាទចណ្ឌប្បជ្ជោត ។ ព្រះបាទចណ្ឌប្បជ្ជោតនោះយោងមកហើយ បង្កប់ពលនិកាយទាំងពីរខាង បើកផ្លូវត្រង់កណ្តាល ព្រះបាទឧទេនមិនបានជ្រាបដល់ការយោងមករបស់ទ្រង់ ទើបដេញតាមដីរទៅ ។ មនុស្សដែលនៅខាងក្នុង ប្រញាប់នាំដីរឈើគេចទៅដោយរហ័ស កាលព្រះរាជាទ្រង់រាយមន្តដេញពិណ ដីរឈើធ្វើហាក់ដូចមិនបានឮសំឡេងខ្សែពិណ គេចទៅតែម្យ៉ាង ។ ព្រះរាជាមិនអាចដេញទាន់ដីរបាន ទើបទ្រង់ផែលសេះដេញតាមទៅ ។ កាលទ្រង់ប្រញាប់តាមទៅដោយរហ័ស ពល-និកាយក៏នៅខាងក្រោយ ព្រះរាជាទ្រង់ដាច់អំពីគេមួយអង្គឯងប៉ុណ្ណោះ កាលនោះ ពួកបុរសរបស់ព្រះបាទចណ្ឌប្បជ្ជោត ដែលបង្កប់កម្ចាំងហើយទាំងសងខាងផ្លូវ ទើបចាប់ព្រះរាជា ថ្វាយស្តេចផែនដីរបស់ខ្លួន លុះពលនិកាយរបស់ទ្រង់ជ្រាបថា ព្រះរាជារបស់ខ្លួនធ្លាក់ក្នុងអំណាចរបស់សត្រូវហើយ ក៏ចោះបន្ទាយនៅខាងក្រៅ ។

ចំណែកព្រះបាទចណ្ឌប្បជ្ជោត ទ្រង់បញ្ជាឲ្យចាប់ព្រះបាទឧទេន ហើយខាំងក្នុងគុកសម្រាប់ជាក់ចោរមួយកន្លែង ឲ្យបិទទ្វារ ទ្រង់ផឹកនូវទឹកជយបាន: អស់ ៣ ថ្ងៃ ក្នុងថ្ងៃទី ៨ ព្រះបាទឧទេនសួរអ្នកយាមថា នែបាទាំងឡាយ ស្តេចផែនដីរបស់ពួកអ្នកទៅណា ពួកអ្នកយាមទូលថា ស្តេចផែនដីទ្រង់សោយទឹកជយបាន: ទ្រង់ត្រេកអរថា យើងចាប់បច្ចាមិត្របានហើយ ។

ព្រះបាទឧទេនត្រាស់ថា ស្តេចផែនដីរបស់ពួកអ្នក មានកិរិយាដូចមនុស្សស្រី ការចាប់ស្តេចផែនដីដែលជាសត្រូវបានហើយ ដោះលែង ឬសម្លាប់ ទើបគួរ មិនមែនឬ តែនេះបែរជាយកយើងមកឲ្យជាទុក្ខ ហើយទៅអង្គុយជីកទឹកជយបាន: ។

អ្នកយាមទាំងនោះ ក៏នាំគ្នាទូលសេចក្តីនោះដល់ព្រះរាជា ព្រះរាជាយាងទៅត្រាស់សួរថា បានឮថា ទ្រង់ពោលយ៉ាងនេះមែនឬ ព្រះបាទឧទេនទូលថា មែនហើយមហារាជ ព្រះបាទចណ្ឌប្បជ្ជោតពោលថា សាធុ ខ្ញុំនឹងដោះលែងទ្រង់ តែបានឮថា ទ្រង់មានមន្តដូច្នេះ ទ្រង់ឲ្យមន្តនោះដល់ខ្ញុំដែរឬទេ ព្រះបាទឧទេនពោលថា យល់ព្រម ខ្ញុំនឹងឲ្យ តែក្នុងពេលរៀនត្រូវថ្វាយបង្គំខ្ញុំ ហើយរៀនមន្តនោះ តើទ្រង់ថ្វាយបង្គំខ្ញុំដែរឬទេ ។ ព្រះបាទចណ្ឌប្បជ្ជោតពោលថា ខ្ញុំថ្វាយបង្គំទ្រង់ដូចម្តេចបាន ព្រះឧទេនពោលថា ទ្រង់មិនថ្វាយបង្គំឬ ព្រះបាទចណ្ឌប្បជ្ជោតពោលថា ខ្ញុំមិនថ្វាយបង្គំទ្បើយ ព្រះបាទឧទេនពោលថា បើដូច្នោះ ខ្ញុំមិនឲ្យ ព្រះបាទចណ្ឌប្បជ្ជោតពោលថា បើដូច្នោះខ្ញុំនឹងជាក់រាជអាជ្ញាដល់ទ្រង់ ព្រះបាទឧទេនពោលថា សូមយាងចុះ ទ្រង់ជាឥស្សរៈដល់រាងកាយរបស់ខ្ញុំ តែមិនជាឥស្សរៈដល់ចិត្តទ្បើយ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យដ៏អង់អាចរបស់ព្រះបាទឧទេនហើយ ទើបទ្រង់ត្រិះរិះថា អញនឹងរៀនមន្តរបស់ស្តេចឧទេននេះបានដូចម្តេចហ្ន៎ ហើយទ្រង់គិតបានថា អញមិនអាចឲ្យអ្នកដទៃចេះមន្តនេះ អញនឹងឲ្យធីតារបស់អញរៀនក្នុងសម្នាក់ព្រះបាទឧទេននេះ ហើយសឹមរៀនបន្តក្នុងសម្នាក់របស់នាង ។ លំដាប់

នោះ ទើបព្រះរាជាត្រាស់នឹងព្រះបាទឧទេននោះថា តើទ្រង់ឲ្យដល់បុគ្គលដទៃដែលថ្វាយបង្គំហើយ រៀនដែរឬទេ ព្រះបាទឧទេនពោលថា បើយ៉ាងនោះបាន មហារាជ ។ បើដូច្នោះ ក្នុងផ្ទះខ្ញុំមានស្រីគមម្នាក់ ទ្រង់ឈរខាងក្រៅកំផែងនន ចូរប្រាប់មន្តដល់ស្រីនោះ ដែលអង្គុយខាងក្នុងកំផែងនន ចុះ ។ ព្រះបាទឧទេនពោលថា សាធុ មហារាជ ទោះនាងជាស្រីគម ឬទ្វិនក៏ដោយចុះ កាលនាងថ្វាយបង្គំ ខ្ញុំនឹងឲ្យ ។

លំដាប់នោះ ព្រះរាជាក៏យាងទៅត្រាស់ប្រាប់ព្រះនាងវាសុលទត្តាព្រះរាជធីតាថា កូនស្រី បុរសរោគឃ្លង់ល្មៀម្នាក់ ចេះមន្តមានតម្លៃកាត់ថ្លៃមិនបាន បិតាមិនអាចឲ្យអ្នកដទៃចេះមន្តនោះបាន ។ ចូរនាងអង្គុយខាងក្នុងកំផែងនថ្វាយបង្គំបុរសនោះ ហើយរៀនមន្ត បុរសនោះឈរខាងក្រៅកំផែងនន នឹងប្រាប់ដល់នាង បិតានឹងរៀនអំពីសម្ងាក់របស់នាង ។ ព្រះបាទចណ្ឌប្បជ្ជោតនោះត្រាស់ឲ្យព្រះរាជធីតាធ្វើជាស្រីគម ចំណែកព្រះបាទឧទេន ឲ្យជាបុរសឃ្លង់ល្មៀយ៉ាងនេះ ព្រោះទ្រង់ខ្លាចជនទាំងពីរនោះ ធ្វើសន្តវៈគ្នានិងគ្នា ។ ព្រះបាទឧទេននោះប្រថាប់ឈរខាងក្រៅកំផែងនហើយ បានត្រាស់ប្រាប់មន្តដល់ព្រះនាង ដែលថ្វាយបង្គំ ហើយអង្គុយខាងក្នុងកំផែងនន ។

សម័យតមក ព្រះបាទឧទេនត្រាស់នឹងព្រះនាង សូម្បីទ្រង់ត្រាស់ប្រាប់រឿយៗ ក៏មិនអាចពោលបទនៃមន្តបានថា វ៉ីយ ស្រីគម មាត់របស់នាងមិនមានបបូរ ហើយថ្ពាល់របស់នាងក្រាស់ពេក ហាងចូរថាទៅយ៉ាងនេះ ។ ព្រះនាងទ្រង់ពិរោធ ទើបត្រាស់ថា វ៉ីយ អាឃ្លង់ជូជាតិ អានិយាយអ្វី មនុស្ស

ដូចអញ្ចឹងនេះឬ ឈ្មោះថាស្រីគម ដូច្នេះហើយ ព្រះនាងបើកជ្រុងវាំងននឡើង កាលព្រះបាទឧទេនសួរថា នាងជានរណា ទើបត្រាស់ប្រាប់ថា យើងឈ្មោះ វាសុលទត្តា ធីតារបស់ស្តេចផែនដី ព្រះបាទឧទេនពោលថា បិតារបស់នាង ប្រាប់នាងដល់ខ្ញុំថាជាស្រីគម ។ នាងវាសុលទត្តាពោលថា កាលត្រាស់ប្រាប់ ដល់ខ្ញុំ ព្រះបិតាក៏ពោលថា អ្នកជាមនុស្សឃ្លង់ល្ពៅ ជនទាំងពីរនោះត្រិះរិះថា ពាក្យនោះ ព្រះរាជាគង់ត្រាស់ដោយខ្លាចក្រែងយើងធ្វើសន្តវៈគ្នា ហើយទ្រង់ ក៏ធ្វើសន្តវៈគ្នាក្នុងវាំងនននោះឯង ។

ចាប់តាំងអំពីនោះ ទើបការរៀនមន្ត ឬការរៀនសិប្បៈ មិនមាន ។ ព្រះ រាជាទ្រង់សួរព្រះធីតាជានិច្ចថា នាងរៀនសិប្បៈឬ ព្រះនាងត្រាស់ថា បពិត្រ ព្រះបិតា ខ្ញុំម្ចាស់នៅរៀន ។ ថ្ងៃមួយ ព្រះបាទឧទេនត្រាស់ទីឃព្រះនាងថា នែ នាងដ៏ចម្រើន ឈ្មោះថា កិច្ចដែលប្តីគប្បីធ្វើ មាតាបិតា បងប្អូនប្រុស និងបង ប្អូនស្រី មិនអាចធ្វើបានឡើយ បើនាងឲ្យជីវិតដល់យើង យើងនឹងឲ្យស្រី ៥០០ ជាបរិវារ ហើយឲ្យតំណែងអគ្គមហេសីដល់នាង ព្រះនាងត្រាស់ថា បើ ទ្រង់អាចតាំងនៅក្នុងព្រះតម្រាស់នេះ ខ្ញុំម្ចាស់នឹងថ្វាយជីវិតទាននេះដល់ព្រះ អង្គ ។ ព្រះបាទឧទេនត្រាស់ថា នែប្អូនស្រី យើងនឹងអាច ព្រះនាងទទួល ព្រះតម្រាស់ថា យល់ព្រម ដូច្នេះហើយ ក៏យាងទៅកាន់សម្នាក់ព្រះបិតា ថ្វាយ បង្គំហើយ បានឈរក្នុងចំណែកម្ខាង ។ លំដាប់នោះ ព្រះរាជាត្រាស់សួរថា សិប្បៈសម្រេចហើយឬ នាងវាសុលទត្តាត្រាស់ថា បពិត្រព្រះបិតា សិប្បៈ មិនទាន់សម្រេចទេ ។ លំដាប់នោះ ព្រះបាទចណ្ឌប្បជ្ជោតត្រាស់សួរព្រះនាង ថា ហេតុអ្វី ទើបមិនសម្រេច នាងវាសុលទត្តាពោលថា បពិត្រព្រះបិតា ខ្ញុំ

ម្ចាស់គួរបានទ្វារមួយ និងពាហនៈមួយ ព្រះបាទចណ្ឌប្បជ្ជោតពោលថា ហេតុអ្វី ក៏ដូច្នេះទៅវិញ នាងវាសុលទត្តាពោលថា បពិត្របិតា បានឮថា មានឱសថមួយប្រភេទ ត្រូវយកក្នុងពេលយប់ ដោយសញ្ញាដួងតារា ដើម្បីប្រយោជន៍ ជាឧបការៈនៃមន្ត ព្រោះដូច្នោះ ក្នុងកាលដែលខ្ញុំម្ចាស់ចេញទៅក្នុងកាល ឬមិនមែនកាល ទើបគួរបានទ្វារមួយ និងពាហនៈមួយ ។ ព្រះរាជាត្រាស់ថា បាន ។ ព្រះបាទឧទេន និងព្រះនាងវាសុលទត្តានោះ ទ្រង់បានទ្វារមួយដែលខ្លួនពេញចិត្ត ក្នុងកណ្តាប់ដៃហើយ ។

ព្រះរាជាមានពាហនៈ ៥ គឺដីរញ្ជឺ ១ ឈ្មោះភទ្រវតី ដើរបានមួយថ្ងៃ ៥០ យោជន៍ ទាសៈឈ្មោះកាកៈ ដើរបានមួយថ្ងៃ ៦០ យោជន៍ សេះពីរ គឺសេះវលៃកំសិ និងសេះឈ្មោះមុញ្ជកេសិ ទៅបានមួយថ្ងៃ ១០០ យោជន៍ និងដីរនាឡាគីរីទៅបានមួយថ្ងៃ ១២០ យោជន៍ ។

បានឮមកថា ព្រះរាជាអង្គនោះ ក្នុងកាលព្រះពុទ្ធមិនទាន់កើតឡើង ជាអ្នកបម្រើរបស់ឥស្សរជនម្នាក់ ។ ក្នុងសម័យថ្ងៃមួយ កាលឥស្សរជននោះទៅក្រៅព្រះនគរងូតទឹកហើយមក ព្រះបច្ចេកពុទ្ធមួយអង្គ ចូលកាន់ព្រះនគរដើម្បីបិណ្ឌបាត មិនបានកិក្ខាសូម្បីមួយវែក ព្រោះអ្នកក្រុងទាំងមូល ត្រូវមានបណ្តាលចិត្ត មានបាត្រដែលលាងហើយ គឺបាត្រទទេចេញទៅ ។ គ្រានោះមារចូលទៅរកព្រះបច្ចេកពុទ្ធនោះ ដោយភេទដែលមិនមានអ្នកណាស្គាល់ ហើយសួរក្នុងខណៈដែលលោកនិមន្តដល់ទ្វារនគរថា បពិត្រលោកម្ចាស់ លោកម្ចាស់ បានអ្វីខ្លះឬ ព្រះបច្ចេកពុទ្ធត្រាស់ថា អ្នកធ្វើអាការ គឺការដែល

មិនបានដល់អាត្មាហើយ មិនមែនឬ មារពោលថា បើដូច្នោះ សូមលោកម្ចាស់ត្រឡប់ទៅវិញ គ្រានេះ ខ្ញុំនឹងមិនធ្វើ ។ ព្រះបច្ចេកពុទ្ធពោលថា អាត្មាមិនត្រឡប់ទៀយ ។

បើព្រះបច្ចេកពុទ្ធគប្បីត្រឡប់សោត មារនោះគប្បីចូលសណ្ឋិតក្នុងសរីរៈរបស់អ្នកនគរទាំងមូល ហើយទះដៃធ្វើការសើចចំអកទៀត កាលព្រះបច្ចេក-ពុទ្ធមិនត្រឡប់ មារក៏អន្តរធានទៅក្នុងទីនោះឯង ។ ខណៈនោះ ឥស្សរជននោះឃើញព្រះបច្ចេកពុទ្ធនិមន្តមក ដោយបាត្រដែលលាងហើយ ទើបថ្វាយបង្គំសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់បានអ្វីខ្លះឬ ព្រះបច្ចេកពុទ្ធត្រាស់ថា អ្នកមានអាយុ អាត្មាត្រាច់ទៅហើយ ចេញមកហើយ បុរសនោះគិតថា លោកម្ចាស់មិនឆ្លើយពាក្យដែលអញសួរ បែរជាពោលពាក្យដទៃ គង់មិនបានអ្វីឡើយក្នុងរំពេចនោះ គាត់ក្រឡេងមើលបាត្ររបស់លោក ឃើញបាត្រទទេ ក៏ជាអ្នកភ្លៀវភ្លាតែមិនអាចទទួលបាត្រ ព្រោះមិនទាន់ដឹងថា កត្តុកម្យ៉ងផ្ទះរបស់ខ្លួនសម្រេចហើយ ឬមិនសម្រេច ទើបពោលថា បពិត្រលោកម្ចាស់ សូមបង្អង់បន្តិចសិនចុះ ដូច្នេះហើយ ក៏ទៅកាន់ផ្ទះដោយរហ័ស សួរថា កត្តុសម្រាប់ខ្ញុំសម្រេចហើយឬ កាលអ្នកបម្រើឆ្លើយថា ស្រេចហើយ ទើបពោលនឹងអ្នកបម្រើនោះថា នែបា អ្នកដទៃដែលសម្បូរដោយសម្ភុះជាងអ្នក មិនមាន ។ ដោយសម្ភុះជើងដ៏រហ័ស អ្នកចូរទៅដល់លោកម្ចាស់អង្គនោះ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យបាត្រមកចុះ ហើយទទួលបាត្រមកដោយរហ័ស ។ បុរសនោះរត់ទៅដោយពាក្យប្រើត្រឹមតែមួយមាត់ប៉ុណ្ណោះ ទទួលបាត្រនាំមក

ហើយ ឥស្សរជនធ្វើបាត្រឲ្យពេញដោយភោជនរបស់ខ្លួន ហើយពោលថា ឯង ចូរប្រញាប់ទៅប្រគេនបាត្រនេះដល់លោកម្ចាស់ ខ្ញុំនឹងឲ្យចំណែកបុណ្យដែល សម្រេចអំពីទាននេះដល់អ្នក ។ បុរសនោះទទួលបាត្រហើយ ទៅដោយកម្លាំង ជើងដ៏រហ័ស ប្រគេនបាត្រដល់ព្រះបច្ចេកពុទ្ធ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយពោលថា បពិត្រលោកម្ចាស់ កាលវេលាជិតហួសហើយ ខ្ញុំទៅនិងមក ដោយសម្ទុះជើងដ៏រហ័សក្រៃលែង ដោយផលនៃសម្ទុះជើងរបស់ខ្ញុំនេះ សូម ពាហនៈទាំងឡាយ ៥ ដែលអាចទៅបានមួយថ្ងៃ ៥០ យោជន៍ ៦០ យោជន៍ ១០០ យោជន៍ ១២០ យោជន៍ កើតឡើងដល់ខ្ញុំ រាងកាយរបស់ខ្ញុំ មក និង ទៅ ត្រូវកម្តៅព្រះអាទិត្យជុតរោលហើយ ដោយផលនៃរាងកាយត្រូវកម្តៅ ព្រះអាទិត្យនោះ សូមអាជ្ញារបស់ខ្ញុំផ្សាយទៅដូចពន្លឺនៃព្រះអាទិត្យ ក្នុងទីដែល ខ្ញុំកើតហើយ ចំណែកបុណ្យព្រោះបិណ្ឌបាតនេះ ដែលចៅហ្វាយឲ្យហើយ ដល់ខ្ញុំ ដោយអានិសង្សនៃបុណ្យនោះ សូមឲ្យខ្ញុំជាអ្នកមានចំណែកនៃធម៌ ដែលលោកម្ចាស់ឃើញហើយ ព្រះបច្ចេកពុទ្ធត្រាស់ថា សេចក្តីប្រាថ្នាដែល អ្នកតម្កល់តាំងទុកនេះ ចូរសម្រេចចុះ ហើយបានធ្វើអនុមោទនាថា សូម ឥដ្ឋផល គឺផលជាទីគប្បីចិត្តដែលអ្នកប្រាថ្នាហើយ តាំងចិត្តហើយ ចូរសម្រេច ដល់អ្នកឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សូមតម្រិះត្រូវទាំងពួង ចូរពេញដល់អ្នក ដូចព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត ។ សូមឥដ្ឋផល គឺផលជាទីគប្បីចិត្តដែលអ្នក ប្រាថ្នាហើយ តាំងចិត្តហើយ ចូរសម្រេចដល់អ្នកឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សូមតម្រិះត្រូវទាំងពួង ចូរពេញដល់អ្នក ដូចកែវមណី មានរស្មីដ៏រុងរឿង ជាកែវវិសេស អាចញុំាងសេចក្តីប្រាថ្នាទាំងពួងឲ្យសម្រេចបាន ។

បានឮថា គាថាពីរនេះឯង ឈ្មោះថា គាថាអនុមោទនារបស់ព្រះបច្ចេក-ពុទ្ធទាំងឡាយ រតនៈ គឺកែវមណី ដែលឲ្យបំណងជ្រាបថ្នាទាំងពួងសម្រេច ហៅថា កែវមណីជោតិរស ក្នុងគាថានោះ ។ នេះជាបុព្វចរិតរបស់អ្នកបម្រើនោះ ។ បុរសនោះ បានជាព្រះបាទចណ្ឌប្បជ្ជោតក្នុងកាលឥឡូវនេះ ។ និងដោយផលដែលហូរចេញអំពីកម្មនោះ ទើបពាហនៈទាំង ៥ នេះកើតឡើង ។

ថ្ងៃមួយ ព្រះរាជាយាងចេញដើម្បីលេងកីឡាក្នុងព្រះរាជឧទ្យាន ។ ព្រះបាទឧទេនទ្រង់ត្រិះរិះថា អញគួរគេចទៅក្នុងថ្ងៃនេះ ទើបទ្រង់ដាក់ថង់ស្បែកធំៗ ឲ្យពេញដោយមាស និងជ្រាក់ ដាក់លើខ្នងដីរញ៉ើ ហើយនាំព្រះនាងវាសុលទត្តា ភៀសខ្លួនទៅ ។ ទាហានរក្សារាំងទាំងឡាយ ឃើញព្រះបាទឧទេនកំពុងគេចទៅ ទើបក្រាបទូលដល់ព្រះរាជា ព្រះរាជាទ្រង់បញ្ជូនពលទៅដោយព្រះតម្រាស់ថា ពួកអ្នកចូរទៅឲ្យរហ័ស ។ ព្រះបាទឧទេនទ្រង់ជ្រាបថា ពលនិកាយដេញតាម ទើបទ្រង់ស្រាយថង់កហាបណៈ ធ្វើកហាបណៈឲ្យធ្លាក់ចុះ ។ ពួកមនុស្សរើសកហាបណៈហើយដេញតាមទៅទៀត ។ ចំណែកព្រះបាទឧទេន ទ្រង់ស្រាយថង់មាសនោះ ហើយធ្វើឲ្យធ្លាក់ ពួកមនុស្សទាំងនោះរវល់តែយឺតយូរព្រោះចង់បានក្នុងមាស ទ្រង់ក៏យាងដល់បន្ទាយរបស់ព្រះអង្គ ដែលតាំងនៅខាងក្រៅ ។ ខណៈនោះ ពលនិកាយគ្រាន់តែឃើញទ្រង់យាងមក ក៏ចោមរោមជង្អែចូលទៅកាន់ព្រះនគររបស់ខ្លួន ។ ព្រះរាជាកាលយាងទៅហើយ ក៏អភិសេកនាងវាសុលទត្តា តាំងទុកក្នុងតំណែងអគ្គមហេសី ។

នេះជារឿងរបស់ព្រះនាងវាសុលទត្តា

ថ្ងៃមួយ ស្រីជនៃទៀត ឈ្មោះនាងមាគន្ធិយា ក៏បានតំណែងនៃអគ្គមហេសី អំពីសម្ដាក់របស់ព្រះរាជា ។ បានឮថា នាងជាកូនស្រីរបស់ព្រាហ្មណ៍ ឈ្មោះ មាគន្ធិយៈក្នុងដែនកុរុ សូម្បីមាតារបស់នាង ក៏ឈ្មោះថា មាគន្ធិយាដូចគ្នា ។ សូម្បីឪពុកមារបស់នាងក៏ឈ្មោះថា មាគន្ធិយៈដែរ នាងជាមនុស្សមានរូបស្អាត ប្រៀបដូចទេពអប្សរ ។ ឪពុករបស់នាង កាលមិនបានប្ដីដែលសមគួរដល់ នាង ទោះជាត្រូវត្រកូលធំៗ អង្វរ ក៏ទ្រគោះបោះបោកថា ពួកអ្នកមិនផ្គូផ្គង ដល់កូនស្រីរបស់ខ្ញុំ ហើយដេញទៅ ។ សម័យថ្ងៃមួយ ព្រះសាស្ដា ទ្រង់ ប្រមើលមើលសត្វលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញឧបនិស្សយនៃអនាគាមិ-ផលរបស់មាគន្ធិយព្រាហ្មណ៍ មួយអន្លើដោយបជាបតី គឺប្រពន្ធរបស់គាត់ ទ្រង់កាន់ជាត្រ និងចីវរ ហើយបានយាងទៅកាន់ទីបម្រើភ្លើងរបស់ព្រាហ្មណ៍ នោះ ខាងក្រៅនិគម ។ ព្រាហ្មណ៍នោះ ក្រឡេកឃើញអត្តភាពដ៏ប្រសើរដោយ លម្អនៃព្រះរូបរបស់ព្រះតថាគតហើយ ក៏គិតថា ឈ្មោះថាបុរសជនៃដូចបុរស នេះ រមែងមិនមាន ក្នុងលោកនេះ បុរសនេះសមជល់ធីតារបស់អញៗ នឹង ឲ្យធីតារបស់អញជល់បុរសនេះ ដើម្បីប្រយោជន៍បានមើលថែគ្នា ដូច្នេះហើយ ទើបពោលថា បពិត្រសមណៈ កូនស្រីរបស់ខ្ញុំមានម្នាក់ ខ្ញុំមិនទាន់ឃើញ បុរសដែលសមនឹងនាង អស់កាលមានប្រមាណប៉ុណ្ណេះ អ្នកជាបុគ្គលសម ជល់នាងហើយនាង ក៏ជាបុគ្គលសមនឹងអ្នកពិត គួរអ្នកបាននាងទុកជាបាទ-បរិចារិកា នាងក៏គួរបានអ្នកជាភស្ដា ខ្ញុំនឹងឲ្យនាងជល់អ្នក អ្នកចូរឈរក្នុង ទីនេះឯង ទម្រាំខ្ញុំទៅ ហើយត្រឡប់មក ។ ព្រះសាស្ដា មិនត្រាស់ពាក្យណា

មួយ ទ្រង់បានធ្វើតុណ្ហីភាព ។ ព្រាហ្មណ៍ទៅកាន់ផ្ទះដោយរហ័ស ពោលនឹងព្រាហ្មណីថា នែនាង ខ្ញុំឃើញបុគ្គលដែលសមនឹងកូនស្រីរបស់យើងហើយ ។ ចូរនាងតែងខ្លួនកូនឲ្យរហ័ស ឲ្យធីតានោះតែងខ្លួនហើយនាំទៅ មួយអន្ទើដោយព្រាហ្មណី បានទៅកាន់សម្នាក់របស់ព្រះសាស្តា ។ ពួកអ្នកនគរក៏ក្រាក់ផ្អើលថា ព្រាហ្មណ៍នេះ មិនឲ្យកូនស្រីដល់បុគ្គលណា ដោយអាងថា ជាបុរសមិនសមដល់កូនស្រីខ្លួនអស់កាលមានប្រមាណប៉ុណ្ណេះ ។ បានឮថា ថ្ងៃនេះគាត់ឃើញបុរសសមនឹងកូនស្រីរបស់គាត់ហើយ បុរសនោះជានរណាហ្ន៎ ពួកយើងនឹងមើលបុរសនោះ ។ ទើបមហាជនចេញទៅជាមួយព្រាហ្មណ៍នោះដែរ កាលព្រាហ្មណ៍នោះនាំធីតាមក ព្រះសាស្តាមិនបានប្រថាប់ក្នុងទីដែលព្រាហ្មណ៍នោះពោលទេ ទ្រង់បង្ហាញចេតិយ គឺស្នាមព្រះបាទក្នុងទីនោះ ហើយបានយាងទៅប្រថាប់ឈរក្នុងទីជនៃ ។ ពិតហើយ ចេតិយ គឺស្នាមព្រះបាទរបស់ព្រះពុទ្ធទាំងឡាយ រមែងប្រាកដក្នុងទីដែលទ្រង់អធិដ្ឋានហើយ ជាន់ទុកប៉ុណ្ណោះ រមែងមិនប្រាកដក្នុងទីជនៃ ។ ម្យ៉ាងទៀត ចេតិយ គឺស្នាមព្រះបាទជាវត្ថុដែលទ្រង់អធិដ្ឋាន ដើម្បីបំណងដល់បុគ្គលណា បុគ្គលទាំងនោះប៉ុណ្ណោះ រមែងឃើញចេតិយ គឺស្នាមព្រះបាទនោះ ។ ឯសត្វ មានជីវជាដើម ទោះជាន់ក្តី មហាមេឃគឹកភ្លៀងទោះធ្លាក់ក្តី ខ្យល់កំបុតត្បូង ទោះបក់ក្តី កាលនឹងឲ្យបុគ្គលទាំងនោះមិនឃើញបុគ្គលណាម្នាក់ ក៏មិនអាចលុបចេតិយ គឺស្នាមព្រះបាទនោះបានឡើយ ។ លំដាប់នោះ ព្រាហ្មណីពោលនឹងព្រាហ្មណ៍ថា បុរសនោះនៅឯណា ព្រាហ្មណ៍គិតថា ខ្ញុំនិយាយនឹងគេថា អ្នកចូរឈរក្នុងទីនេះ គេទៅក្នុងទីណា

ហ្ន៎ ក្រេឡកមើលក៏ឃើញចេតិយ គឺស្នាមព្រះបាទ ទើបពោលថា នេះជាស្នាមជើងរបស់បុគ្គលនោះ ។ ព្រាហ្មណីរាយលក្ខណមន្ត ហើយពិនិត្យមើលលក្ខណៈនៃស្នាមព្រះបាទ ព្រោះភាពជាអ្នកជំនាញក្នុងវេទទាំង ៣ ព្រមទាំងមន្តសម្រាប់ទាយលក្ខណៈ ពោលថា នែព្រាហ្មណ៍ នេះមិនមែនស្នាមជើងរបស់អ្នកលេងកាមគុណ ៥ ហើយពោលគាថា

បុគ្គលដែលច្រើនដោយរាគៈ មានស្នាមជើងកំពុងកណ្តាល បុគ្គលដែលប្រកបដោយទោសៈ រមែងមានស្នាមជើងស្រុតខាងក្រោយ បុគ្គលដែលជាមោហៈ រមែងមានស្នាមជើងជ្រៅខាងមុខ បុគ្គលដែលមានកិលេស ជាគ្រឿងប្រកបើកហើយ មានស្នាមជើងយ៉ាងនេះ ។

លំដាប់នោះ ព្រាហ្មណ៍ពោលនឹងនាងថា នែនាង នាងជាអ្នកមានប្រក្រតីឃើញមន្ត ដូចក្រពើក្នុងពាងទឹក ដូចចោរនៅក្នុងកណ្តាលផ្ទះ ចូរស្ងៀមចុះ ។ ព្រាហ្មណីពោលថា នែព្រាហ្មណ៍ អ្នកចង់ពោលពាក្យណា ចូរពោលពាក្យនោះចុះ ស្នាមជើងនេះមិនមែនស្នាមជើងអ្នកសេពកាមគុណ ៥ ទេ ។ ព្រាហ្មណ៍ក្រេឡកមើលឆ្វេងស្តាំ ឃើញព្រះសាស្តាហើយពោលថា នុ៎ះ គឺបុរសនោះ ទើបចូលទៅពោលថា បពិត្រសមណៈ ខ្ញុំនឹងឲ្យធីតាដើម្បីបានចិញ្ចឹមគ្នា ព្រះសាស្តាមិនត្រាស់ថា តថាគតមានសេចក្តីត្រូវការដោយធីតារបស់អ្នក ឬក៏មិនត្រូវការ តែត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតពោលហេតុមួយដល់អ្នក ។ ព្រាហ្មណ៍ពោលថា សូមសមណៈពោលមកចុះ ទើបត្រាស់ប្រាប់ការដែល

ព្រះអង្គត្រូវមារជាប់តាមតាំងអំពីចេញបួស រហូតដល់គល់អជបាលនិគ្រោធ និងការប្រលោម ដែលមារធីតាទាំងឡាយមក ដើម្បីរម្ងាប់សេចក្តីសោករបស់មារនោះ ដែលសោកសៅថា ឥឡូវនេះ សមណគោតមនេះ កន្ទងបង់នូវវិស័យរបស់អញហើយ ប្រកបឡើងដោយអំណាចនៃកេទកុមារិកាជាដើម ត្រង់គល់អជបាលនិគ្រោធ ហើយត្រាស់ព្រះគាថានេះថា

> *តថាគត មិនមានការពេញចិត្តក្នុងមេថុន ព្រោះឃើញនាង តណ្ហា នាងអរតី និងនាងរាគាផង នឹងមានសេចក្តីញ្ញេញចិត្ត ព្រោះឃើញកូនស្រីរបស់អ្នក ដែលពេញទៅដោយមូត្រ និងកវីសជូចម្តេចបាន តថាគតមិនប្រាថ្នាពាល់ត្រូវធីតារបស់អ្នក សូម្បីដោយជើង ។*

ក្នុងទីបំផុតនៃគាថា ព្រាហ្មណ៍ និងព្រាហ្មណីតាំងនៅក្នុងអនាគាមិផល ។ ចំណែកនាងមាគន្ទិយាជាធីតា ចងអាឃាតក្នុងព្រះសាស្តាថា បើសមណៈនេះមិនត្រូវការអញទេ ក៏គួរពោលថា មិនត្រូវការ តែសមណៈនេះ បែរជាធ្វើឲ្យអញពេញទៅដោយមូត្រ និងលាមក ណ្ហើយចុះ អញអាស្រ័យការដល់ព្រមដោយជាតិ ត្រកូល ប្រទេស ភោគៈ យស និងវ័យ បានកស្តាបែបនោះហើយ អញនឹងជីងកម្មដែលគួរធ្វើដល់សមណគោតម ។

សួរថា តើព្រះសាស្តា ទ្រង់ជ្រាបការកើតឡើងនៃអាឃាតក្នុងព្រះអង្គរបស់នាង ឬមិនជ្រាប ឆ្លើយថា ទ្រង់ជ្រាបដូចគ្នា សួរថា កាលទ្រង់ជ្រាបហេតុអ្វីទើបត្រាស់ព្រះគាថា ឆ្លើយថា ទ្រង់ត្រាស់គាថា ដោយអំណាចនៃ

ព្រាហ្មណ៍ និងព្រាហ្មណី ។

ធម្មតា ព្រះពុទ្ធទាំងឡាយទ្រង់មិនពិចារណាដល់ការអាឃាត ទ្រង់សម្តែងធម៌ ដោយអំណាចនៃបុគ្គលដែលគួរសម្រេចមគ្គផលប៉ុណ្ណោះ ។ មាតាបិតានាំនាងមាគន្ទិយានោះ ទៅផ្ទើនឹងនាយចូឡមាគន្ទិយៈ ដែលជាប្អូនប្រុស ហើយទៅកាន់សម្នាក់ព្រះសាស្តា ជនទាំងពីរបួសហើយ ក៏សម្រេចអរហត្ត ។

ចំណែកនាយចូឡមាគន្ទិយៈគិតថា កូនស្រីរបស់អញមិនគួរដល់បុគ្គលថោកទាប គួរដល់ព្រះរាជាតែម្យ៉ាង ទើបនាំនាងទៅកាន់ក្រុងកោសម្ពី តែងខ្លួនដោយគ្រឿងអលង្ការទាំងពួង បានថ្វាយដល់ព្រះបាទឧទេន ដោយពាក្យថា ឥត្តីរតនៈនេះ គួរដល់ព្រះសម្មតិទេព ។ ព្រះបាទឧទេន គ្រាន់តែទតឃើញ ក៏កើតស្នេហាជ្រាំងក្នា ទើបប្រទានការអភិសេក ធ្វើមាតុគ្រាម ៥០០ ឲ្យជាបរិវាររបស់នាង តាំងក្នុងតំណែងនៃអគ្គមហេសីហើយ ។

នេះជារឿងរបស់នាងមាគន្ទិយា

ព្រះបាទឧទេននោះ មានអគ្គមហេសី ៣ អង្គ មានស្រីស្នំ ១៥០០ ជាបរិវារ ដោយប្រការដូច្នេះ ។

ក្នុងសម័យនោះឯង ក្រុងកោសម្ពីមានសេដ្ឋី ៣ នាក់ គឺឃោសកសេដ្ឋី ១ កុក្កុដសេដ្ឋី ១ ឃាវិកសេដ្ឋី ១ ។ សេដ្ឋីទាំងនោះ កាលវស្សូបនាយិកាជិតចូលមកហើយ ឃើញតាបស ៥០០ មកអំពីហិមវន្តប្បទេស កំពុងត្រាច់ទៅដើម្បីភិក្ខាក្នុងព្រះនគរក៏ជ្រះថ្លា ទើបនិមន្តឲ្យគង់ឲ្យធាន់ហើយ ទទួល

ប្តេជ្ញាឲ្យនៅក្នុងសម្នាក់របស់ខ្លួនអស់កាល ៤ ខែ ឲ្យប្តេជ្ញាដល់ការមកទៀត ក្នុងសម័យដែលជោកជាំដោយភ្លៀង ហើយបញ្ជូនទៅ ។ ចាប់តាំងអំពីកាលនោះ សូម្បីតាបសទាំងឡាយ នៅក្នុងហិមវន្តប្បទេសអស់ ៨ ខែហើយ ទើបមកនៅក្នុងសម្នាក់របស់សេដ្ឋីទាំងនោះ អស់កាល ៤ ខែ ។ តាបសទាំងនោះ កាលមកអំពីហិមវន្តប្បទេស ក្នុងកាលជនៃ ឃើញដើមជ្រៃធំមួយ ក្នុងដែនអវញ្ញ ទើបអង្គុយត្រង់គល់ជ្រៃនោះ ។ បណ្តាតាបសទាំងនោះ តាបសដែលជាប្រធានគិតថា ទេវតាដែលអាស្រ័យនៅត្រង់ដើមឈើនេះ នឹងមិនមែនជាទេវតាតូចតាចឡើយ ទេវរាជដែលមានសក្តិធំនោះឯង គប្បីនៅត្រង់ដើមជ្រៃនេះ ជាការល្អហ្ន៎ បើទេវរាជនេះគប្បីឲ្យទឹកដែលគួរផឹកដល់ពួកឥសី ។ ទេវរាជនោះបានប្រគេនទឹកផឹកហើយ ។ តាបសគិតដល់ទឹកងូត ទេវរាជក៏បានប្រគេនទឹកងូតនោះ ។ បន្ទាប់អំពីនោះ តាបសដែលជាប្រធាន ក៏គិតដល់ភោជន ទេវរាជក៏ប្រគេនភោជននោះ ។ លំដាប់នោះ តាបសក៏មានបរិវិតក្កថាទេវរាជនេះឲ្យវត្ថុសព្វយ៉ាងដែលអញគិតហើយ អើហ្ន៎ អញគប្បីឃើញទេវរាជនោះ ទេវរាជនោះ ជ្រែកដើមឈើបង្ហាញខ្លួនហើយ ។ ខណៈនោះតាបសទាំងឡាយសួរទេវរាជនោះថា នែ ទេវរាជ អ្នកមានសម្បត្តិច្រើន សម្បត្តិនេះអ្នកបានហើយ ព្រោះធ្វើកម្មអ្វីហ្ន៎ ។ ទេវរាជពោលថា សូមលោកម្ចាស់កុំសាកសួរឡើយ តាបសពោលថា ចូរប្រាប់មកចុះ ។ ទេវរាជនោះខ្មាសអៀនព្រោះកម្មដែលខ្លួនធ្វើជាកម្មតិចតួច ទើបមិនហ៊ានប្រាប់ តែកាលតាបសនោះអង្វរវារៀយៗ ក៏ពោលថា បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយស្តាប់ ដូច្នេះ

ហើយ ទើបតំណាលរឿងរបស់ខ្លួនថា

បានឮថា ទេវរាជនោះ ជាអ្នកក្រីក្រម្នាក់ ស្វែងរកការងារសុីឈ្នួល បានការងារក្នុងសម្នាក់របស់អនាថបិណ្ឌិកសេដ្ឋីហើយ ក៏អាស្រ័យការងារនោះ ចិញ្ចឹមជីវិត ។ សម័យតមក កាលដល់ថ្ងៃឧបោសថ អនាថបិណ្ឌិកសេដ្ឋីមកអំពីវិហារហើយសួរថា ក្នុងថ្ងៃនេះ បុគ្គលណាបានប្រាប់ភាពជាថ្ងៃឧបោសថដល់កូនឈ្នួលនោះហើយឬ មនុស្សក្នុងផ្ទះឆ្លើយថា បពិត្រលោកម្ចាស់ មិនទាន់បានប្រាប់ទេ ។ អនាថបិណ្ឌិកពោលថា បើដូច្នោះ ពួកអ្នកចូរចម្អិនអាហារល្ងាចសម្រាប់គេផង ។ គ្រានោះ មនុស្សទាំងនោះ ក៏ចម្អិនបាយមួយចំណែកដើម្បីបុរសនោះ ។ បុរសនោះ ធ្វើការងារក្នុងព្រៃពេញមួយថ្ងៃ មកក្នុងវេលាល្ងាច កាលគេដួសបាយឲ្យ ក៏មិនប្រញាប់បរិភោគ ដោយគិតថា អញជាអ្នកឃ្លាន ហើយគិតថា ក្នុងថ្ងៃទាំងឡាយដទៃ កោលាហលធំរមែងមានក្នុងផ្ទះនេះថា អ្នកចូរឲ្យបាយ អ្នកចូរឲ្យសម្ល អ្នកចូរឲ្យម្ហូប ក្នុងថ្ងៃនេះ មនុស្សគ្រប់គ្នា ជាអ្នកស្ងប់ស្ងៀម ដេកហើយ នាំគ្នាអត់អាហារ ទុកដើម្បីអញតែម្នាក់ប៉ុណ្ណោះ សេចក្តីនេះដូចម្តេចហ្ន៎ ទើបសួរថា មនុស្សដ៏សេស បរិភោគហើយឬ មនុស្សទាំងឡាយឆ្លើយថា មិនបរិភោគទេអ្នក អ្នកសុីឈ្នួលសួរថា ព្រោះហេតុអ្វីហ្ន៎ មនុស្សទាំងឡាយពោលថា ក្នុងផ្ទះនេះ គេមិនចម្អិនអាហារក្នុងពេលល្ងាចថ្ងៃឧបោសថទាំងឡាយទេឬយ មនុស្សគ្រប់គ្នា ជាអ្នករក្សាឧបោសថ ដោយហោច សូម្បីទារកដែលនៅថ្ងៅដោះ លោកមហាសេដ្ឋីក៏ឲ្យខ្ទមមាត់ ឲ្យដាក់របស់មានមធុរស ៤ យ៉ាង ចូលក្នុងមាត់ ធ្វើឲ្យជាអ្នករក្សា

ឧបោសថហើយ កាលប្រទីបដែលលាយដោយទឹកប្រអូបកំពុងភ្លឺ កុមារតូចធំទាំងឡាយទៅកាន់ទីដេកហើយ ស្វាធ្យាយអាការ ៣២ តែពួកយើងមិនបានធ្វើសតិ ដើម្បីប្រាប់ភាពដែលថ្ងៃនេះជាថ្ងៃឧបោសថដល់អ្នក ព្រោះហេតុនោះ ទើបពួកខ្ញុំចម្អិនបាយដើម្បីអ្នកម្នាក់ឯង អ្នកចូរបរិភោគអាហារនោះចុះ ។

អ្នកស៊ីឈ្នួលពោលថា បើការដែលខ្ញុំជាអ្នករក្សាឧបោសថក្នុងឥឡូវនេះគួរសោត ខ្ញុំក៏គប្បីជាអ្នករក្សាឧបោសថដែរ ។ មនុស្សទាំងឡាយពោលថា លោកសេដ្ឋីរមែងជឿងរឿងនេះ អ្នកស៊ីឈ្នួលពោលថា បើដូច្នោះ សូមពួកអ្នកសួរលោកសេដ្ឋីនោះ ។ មនុស្សទាំងនោះទៅសួរសេដ្ឋីហើយ សេដ្ឋីពោលយ៉ាងនេះថា បុរសនោះមិនបរិភោគក្នុងឥឡូវនេះ ខ្ចីមាត់ហើយ អធិដ្ឋានអង្គឧបោសថទាំងឡាយ នឹងបានឧបោសថកម្មពាក់កណ្តាល ។ ចំណែកអ្នកស៊ីឈ្នួលស្តាប់ពាក្យនោះ បានធ្វើតាមនោះហើយ កាលគាត់ស្រេចឃ្លានហើយព្រោះធ្វើការងារពេញមួយថ្ងៃ ខ្យល់កម្រើកហើយក្នុងសរីរៈ គាត់យកខ្សែចងពោះ ចាប់ត្រង់ចុងខ្សែហើយ បម្រុះនៀល សេដ្ឋីស្តាប់ព្រឹត្តហេតុនោះហើយ មានមនុស្សកាន់គប់ភ្លើង ឲ្យមនុស្សកាន់យកមធុរស ៤ ប្រភេទ មកកាន់សម្នាក់របស់បុរសនោះ សួរថា តើអ្នកកើតអ្វី អ្នកស៊ីឈ្នួលប្រាប់ថា បពិត្រលោកម្ចាស់ ខ្យល់កម្រើដល់ខ្ញុំ សេដ្ឋីពោលថា បើយ៉ាងនោះ អ្នកចូរក្រោកឡើង បរិភោគភេសជ្ជៈនេះ អ្នកស៊ីឈ្នួលពោលថា បពិត្រលោកម្ចាស់ សូម្បីអ្នកទាំងឡាយទទួលទានហើយឬ សេដ្ឋីពោលថា ជំងឺរបស់ពួកយើងមិនមាន អ្នកបរិភោគចុះ បុរសនោះពោលថា បពិត្រលោកម្ចាស់ ខ្ញុំកាលធ្វើ

ឧបោសថកម្ម មិនអាចធ្វើឧបោសថកម្មទាំងមូលបាន សូម្បីក្នុងឧបោសថកម្ម ពាក់កណ្តាលរបស់ខ្ញុំ កុំបីជារបស់ខ្វះខាតឡើយ ដូច្នេះហើយ ក៏មិនប្រាថ្នានឹង បរិភោគ ។ បុរសនោះ ដែលសេដ្ឋីពោលថា អ្នកកុំធ្វើយ៉ាងនេះ ក៏មិនប្រាថ្នា ហើយ កាលអរុណរះ ធ្វើកាលកិរិយាហើយ ដូចផ្កាដែលស្រពោន ដូច្នោះ កើតជាទេវតាត្រង់ជើមជ្រៃនោះ ព្រោះហេតុនោះ ទេវតាកាលពោលសេចក្តី នេះហើយ ទើបពោលថា សេដ្ឋីនោះជាអ្នកវាប់អានព្រះពុទ្ធថា ជារបស់យើង វាប់អានព្រះធម៌ថា ជារបស់យើង វាប់អានព្រះសង្ឃថា ជារបស់យើង សម្បត្តិនោះ ខ្ញុំបានហើយ ដោយអានិសង្សនៃឧបោសថកម្មពាក់កណ្តាល ដែលខ្ញុំអាស្រ័យសេដ្ឋីនោះធ្វើហើយ ។

តាបស ៥០០ គ្រាន់តែស្តាប់ពាក្យថាព្រះពុទ្ធ ក៏ក្រោកឡើងផ្គងអញ្ជលី ចំពោះទេវតាពោលថា អ្នកនិយាយថាព្រះពុទ្ធ ដូច្នោះហើយ ឲ្យទេវតានោះ ប្តេជ្ញា ៣ ដងថា ខ្ញុំពោលថាព្រះពុទ្ធ ហើយបន្ទឹងទានថា យោសៈនេះឯងរក បានកម្រក្នុងលោក ហើយពោលថា នែទេវតា ពួកខ្ញុំដែលអ្នកឲ្យស្តាប់សំឡេង ដែលមិនធ្លាប់ឮហើយ អស់សែនកប្បជាអនេក ។ ក្នុងលំដាប់នោះ ពួក តាបសដែលជាអន្តេវាសិក បានពោលពាក្យនេះនឹងអាចារ្យថា បើដូច្នោះ ពួក យើងនឹងនាំគ្នាទៅកាន់សម្នាក់របស់ព្រះសាស្តា ។ អាចារ្យពោលថា នែបា ទាំងឡាយ សេដ្ឋីបីនាក់ ជាអ្នកមានឧបការៈច្រើនដល់ពួកយើង ។ ស្អែកនេះ ពួកយើងទទួលភិក្ខា ក្នុងលំនៅរបស់សេដ្ឋីទាំងនោះ ច្រាប់ដល់សេដ្ឋីទាំងនោះ ហើយ សឹមទៅ បាទាំងឡាយ ពួកបាចូរឈប់បង្អង់សិន ។ តាបសទាំងនោះ

បង្អង់ហើយ ។ ស្អែកឡើង ពួកសេដ្ឋី ត្រៀមបបរ និងកត្តហើយ ក្រាល អាសនៈ ដឹងថា ថ្ងៃនេះជាថ្ងៃមករបស់លោកម្ចាស់នៃយើងទាំងឡាយ ធ្វើការ ទទួលតាបសទាំងនោះទៅកាន់លំនៅ និមន្តឲ្យអង្គុយ បានថ្វាយកិក្ខាហើយ ។ តាបសទាំងនោះ ធ្វើកត្តកិច្ចស្រេចហើយពោលថា លោកសេដ្ឋីទាំងឡាយ ពួកអាត្មានឹងទៅ ។ សេដ្ឋីពោលថា លោកម្ចាស់ទាំងឡាយទទួលប្តេជ្ញារបស់ ពួកខ្ញុំអស់ ៤ ខែ ក្នុងរដូវក្តៀងហើយ មិនមែនឬ ឥឡូវនេះលោកម្ចាស់ទាំង- ឡាយ នឹងទៅណា តាបសពោលថា បានឮថា ព្រះពុទ្ធកើតឡើងហើយក្នុង លោក ព្រះធម៌ក៏កើតឡើងហើយ ព្រះសង្ឃក៏កើតឡើងហើយ ព្រោះដូច្នោះ យើងទាំងឡាយនឹងទៅកាន់សម្នាក់របស់ព្រះសាស្តា ។ សេដ្ឋីពោលថា ការ ទៅក្នុងសម្នាក់ព្រះសាស្តាអង្គនោះ គួរដល់លោកម្ចាស់ទាំងឡាយប៉ុណ្ណោះឬ តាបសឆ្លើយថា សូម្បីមនុស្សដទៃក៏គួរ មិនហាមឃាត់ឡើយ អាវុសោ ។ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយ បង្អង់សិន ពួកខ្ញុំនឹងធ្វើការប្រុងប្រៀបហើយក៏ទៅ ។

តាបសទាំងនោះពោលថា បើអ្នកទាំងឡាយធ្វើការប្រុងប្រៀប ការយឺត យូរមែងមានដល់ពួកយើង ពួកយើងទៅមុន អ្នកទាំងឡាយគប្បីមកឯក្រោយ ដូច្នេះហើយ ក៏ទៅមុន គាល់ព្រះសម្មាសម្ពុទ្ធ សរសើរហើយ ថ្វាយបង្គំ អង្គុយក្នុងចំណោកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់អនុបុព្វីកថា សម្តែងធម៌ដល់តាបសទាំង នោះ ។ ក្នុងទីបំផុតនៃទេសនា តាបសទាំងពួងសម្រេចអរហត្ត មួយអន្ទើដោយ

បដិសម្ភិទាទាំងឡាយហើយ ទូលសូមបព្វជ្ជា បានជាបុគ្គលទ្រទ្រង់នូវបាត្រ និងចីវរ សម្រេចដោយឬទ្ធិ ដូចព្រះថេរៈមានវស្សាមួយរយ ក្នុងលំដាប់នៃ ព្រះតម្រាស់ថា អ្នកទាំងឡាយ ចូរជាភិក្ខុចុះ ។

សេដ្ឋីទាំងឡាយនោះឯង រៀបចំរទេះម្នាក់ ៥០០ ផ្ទុកគ្រឿងឧបការណ៍ ដល់ទាន មានសំពត់ គ្រឿងស្ងៀកដណ្តប់ សប្បិ ទឹកឃ្មុំ និងទឹកអំពៅជាដើម ទៅដល់ក្រុងសាវត្ថីហើយ ទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តា ស្តាប់ធម្ម-កថាហើយ ក្នុងទីបំផុតនៃកថា ក៏តាំងនៅក្នុងសោតាបត្តិផល ថ្វាយទានក្នុង សម្នាក់របស់ព្រះសាស្តា ប្រមាណកន្ទេះខែហើយ អារាធនាព្រះសាស្តាដើម្បី ប្រយោជន៍យាងទៅកាន់ក្រុងកោសម្ពី កាលព្រះសាស្តាប្រទានប្ពេជ្ជា ដោយ ត្រាស់ថា ម្នាលគហបតីទាំងឡាយ ព្រះតថាគតទាំងឡាយ រមែងត្រេកអរក្នុង ផ្ទះស្ងាត់ ទើបសេដ្ឋីទូលថា បពិត្រព្រះអង្គ សេចក្តីនោះខ្ញុំព្រះអង្គជ្រាបហើយ ការដែលព្រះអង្គយាងមកដោយដំណឹង ដែលពួកខ្ញុំព្រះអង្គបញ្ជូនមក រមែង គួរ ដូច្នេះហើយ ទៅកាន់ក្រុងកោសម្ពី ឲ្យសាងវិហារបីកន្ទែង គឺយោសក-សេដ្ឋី សាងយោសិតារាម កុក្កុដសេដ្ឋី សាងកុក្កុដារាម បាវារិកសេដ្ឋី សាង បាវារិការាម ហើយបញ្ជូនដំណឹងទៅ ដើម្បីជាប្រយោជន៍ដល់ការយាងមក របស់ព្រះសាស្តា ។

ព្រះសាស្តាទ្រង់ស្តាប់ដំណឹងរបស់សេដ្ឋីទាំងនោះ ក៏យាងទៅក្នុងទីនោះ ហើយ ។ សេដ្ឋីទាំងនោះទទួល ទូលអារាធនាព្រះសាស្តាឲ្យយាងចូលទៅក្នុង វិហារហើយ រៀរថ្វាយ ៣ ដងថា ខ្ញុំព្រះអង្គសូមថ្វាយវិហារនេះ ដល់ភិក្ខុ-

សង្ឃ ដែលមកអំពីទិសទាំង ៤ មានព្រះពុទ្ធជាប្រធាន ដូច្នេះហើយ បដិបត្តិតាមវារៈ ។ ព្រះសាស្តាប្រថាប់នៅក្នុងវិហារនីមួយៗ រាល់ៗ ថ្ងៃ ប្រថាប់នៅក្នុងវិហារបស់សេដ្ឋីណា ទ្រង់ក៏យាងទៅបិណ្ឌបាត ត្រង់ទ្វារផ្ទះរបស់សេដ្ឋីនោះ ។

សេដ្ឋីទាំង ៣ នាក់នោះ មានមាលាការឈ្មោះសុមនៈជាអ្នកឧបដ្ឋាកសុមនមាលាការនោះ ពោលនឹងសេដ្ឋីទាំងនោះយ៉ាងនេះថា ខ្ញុំជាអ្នកធ្វើការឧបដ្ឋាកលោកទាំងឡាយអស់កាលជ័យូរ ជាអ្នកច្រូថ្នាជើម្បីញ៉ាំងព្រះសាស្តាឲ្យសោយ សូមលោកទាំងឡាយឲ្យព្រះសាស្តាដល់ខ្ញុំមួយថ្ងៃ ។

សេដ្ឋីទាំង ៣ នោះពោលថា នែអ្នក បើដូច្នោះ ចូរនិមន្តព្រះសាស្តាសោយក្នុងថ្ងៃស្អែកចុះ សុមនមាលាការនោះទទួលថា សាធុ ដូច្នោះ ទើបនិមន្តព្រះសាស្តា ត្រៀមគ្រឿងសក្ការៈ ។ ក្នុងកាលនោះ ព្រះរាជាព្រះរាជ-ទានកហាបណៈ ៨ ឲ្យជាតម្លៃផ្កា ឲ្យនាងសាមាវតី រាល់ៗ ថ្ងៃ ទាសីរបស់នាងសាមាវតីនោះ ឈ្មោះនាងខុជ្ជុត្តរាទៅកាន់សម្នាក់របស់សុមនមាលាការទទួលផ្កាទាំងឡាយជានិច្ច ។ បន្ទាប់មក មាលាការពោលនឹងនាងខុជ្ជុត្តរានោះ ដែលមកក្នុងថ្ងៃនោះថា ខ្ញុំនិមន្តព្រះសាស្តាហើយ ថ្ងៃនេះ ខ្ញុំនឹងបូជាព្រះសាស្តាដោយផ្កាដ៏ប្រសើរ ចូរនាងបង្អង់ជួយក្នុងការអង្គាសភិក្ខុ ស្តាប់ធម៌សិន ហើយសឹមទទួលផ្កាទៅ នាងទទួលថា សាធុ ។

សុមនៈអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ បានទទួលបាត្រដើម្បីប្រយោជន៍ដល់ការធ្វើអនុមោទនា ។ ព្រះសាស្តា ទ្រង់ផ្តើមធម្មទេសនា

ជាគ្រឿងអនុមោទនាហើយ ចំណែកនាងខុជ្ជុត្តរាស្តាប់ធម្មកថារបស់ព្រះសាស្តា នោះឯង តាំងនៅក្នុងសោតាបត្តិផលហើយ ។ ក្នុងថ្ងៃទាំងឡាយដទៃ នាងកាន់យក ៤ កហាបណៈសម្រាប់ខ្លួន ទិញផ្តាទៅដោយ ៤ កហាបណៈ ។ ក្នុងថ្ងៃនោះ នាងទទួលផ្តាទៅ ទាំង ៨ កហាបណៈ ។

លំដាប់នោះ នាងសាមាវតីពោលនឹងនាងខុជ្ជុត្តរានោះថា នែនាង ព្រះរាជាប្រទានតម្លៃផ្តាដល់ខ្ញុំបន្ថែមឡើងពីរដងឬ នាងខុជ្ជុត្តរាពោលថា បពិត្រព្រះនាង មិនមែនដូច្នោះឡើយ ។ នាងសាមាវតីពោលថា បើយ៉ាងនេះ ព្រោះហេតុអ្វី ទើបផ្តាច្រើនជាងមុន នាងខុជ្ជុត្តរាពោលថា ក្នុងថ្ងៃទាំងឡាយដទៃ ខ្ញុំម្ចាស់កាន់យក ៤ កហាបណៈសម្រាប់ខ្លួនឯង នាំផ្តាមក ៤ កហាបណៈប៉ុណ្ណោះ ។ នាងសាមាវតីពោលថា ក្នុងថ្ងៃនេះ ព្រោះហេតុអ្វី ទើបមិនកាន់យក នាងខុជ្ជុត្តរាពោលថា ព្រោះខ្ញុំម្ចាស់ស្តាប់ធម្មកថារបស់ព្រះសម្មាសម្ពុទ្ធហើយសម្រេចធម៌ ។

លំដាប់នោះ នាងសាមាវតីមិនបានគំរាមនាងខុជ្ជុត្តរានោះ ដោយពាក្យថា វុឌ្ឍិយ ទាសីអាក្រក់ ហាងចូរឲ្យកហាបណៈដែលកាន់យកហើយអស់កាលមានប្រមាណប៉ុណ្ណោះដល់អញ បែរជាពោលថា នែនាង ចូរនាងធ្វើយើងទាំង-ឡាយឲ្យផឹកអមតរស ដែលនាងផឹកហើយ ។ កាលនាងពោលថា បើយ៉ាងនោះ សូមព្រះនាងញ៉ាំងខ្ញុំឲ្យងូតទឹក ទើបឲ្យនាងងូតទឹកដោយក្អមទាំង ១៦ ហើយ ប្រើឲ្យប្រទានសាដកសាច់ល្អ ២ ផ្ទាំង នាងខុជ្ជុត្តរានោះ ស្លៀកមួយផ្ទាំង ដណ្តប់មួយផ្ទាំង ឲ្យក្រាលអាសនៈហើយ ឲ្យនាំផ្ងិតមកមួយ អង្គុយលើ

អាសនៈចាប់ផ្ដិតដ៏វិចិត្រ ហៅមាតុគ្រាម ៥០០ មកហើយ សម្ដែងធម៌ដល់ស្រីទាំងនោះ ដោយទំនងដែលព្រះសាស្ដាទ្រង់សម្ដែងហើយនោះឯង ។ ស្រីទាំងឡាយនោះ ស្ដាប់ធម្មកថារបស់នាងហើយ ក៏តាំងនៅក្នុងសោតាបត្តិផល ស្រីទាំងឡាយនោះ ថ្វាយបង្គំនាងខុជ្ជុត្តរាហើយ ពោលថា នែនាង តាំងអំពីថ្ងៃនេះទៅ នាងកុំធ្វើការងារដែលសៅហ្មង ចូរតាំងនៅក្នុងឋានៈនៃមាតា និងឋានៈនៃអាចារ្យរបស់ពួកខ្ញុំ ទៅកាន់សម្នាក់ព្រះសាស្ដា ស្ដាប់ធម៌ដែលព្រះសាស្ដាទ្រង់សម្ដែងហើយ ចូរពោលដល់ពួកខ្ញុំ ។ នាងខុជ្ជុត្តរាធ្វើយ៉ាងនោះ ក្នុងកាលជនៃ ក៏ជាអ្នកទ្រទ្រង់ព្រះត្រៃបិដកហើយ ។

សម័យតមក ព្រះសាស្ដា ទ្រង់តាំងនាងខុជ្ជុត្តរានោះ ក្នុងតំណែងជាឯតទគ្គថា ម្នាលភិក្ខុទាំងឡាយ ខុជ្ជុត្តរាជាកំពូលជាងបណ្ដាឧបាសិកាសាវិការបស់តថាគតខាងធម្មកថិក ។ ស្រី ៥០០ នោះឯង ពោលនឹងនាងខុជ្ជុត្តរាយ៉ាងនេះថា នែនាង ពួកខ្ញុំប្រាថ្នាដើម្បីគាល់ព្រះសាស្ដា សូមនាងបង្ហាញព្រះសាស្ដាដល់យើងខ្ញុំទាំងឡាយ ពួកខ្ញុំនឹងបូជាព្រះសាស្ដានោះ ដោយគ្រឿងសក្ការបូជា មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ។ នាងខុជ្ជុត្តរាពោលថា ព្រះនាងទាំងឡាយ ឈ្មោះថា រាជត្រកូលជាការៈធ្ងន់ ខ្ញុំមិនអាចនាំព្រះនាងទាំងឡាយទៅខាងក្រៅបានទេ ។ ស្រីទាំងនោះពោលថា នែនាង នាងកុំឲ្យពួកខ្ញុំវិនាសឡើយ សូមនាងបង្ហាញព្រះសាស្ដាដល់ពួកខ្ញុំចុះ នាងខុជ្ជុត្តរាពោលថា បើយ៉ាងនោះ ការសម្ងំមើល ជាការដែលព្រះនាងអាចធ្វើបានដោយប្រហោងមានប្រមាណប៉ុណ្ណា ចូរចោះប្រហោង មានប្រមាណប៉ុណ្ណោះ

ត្រង់ជញ្ជាំងបន្ទប់ដែលជាលំនៅរបស់ពួកព្រះនាង ឲ្យនាំគ្រឿងក្រអូប និង កម្រងផ្កាជាដើមមកហើយ ឈរខាងក្នុងទីនោះៗ ចូរសម្លឹងមើល ចូរលាព្រះ ហស្តទាំងពីរចេញ ថ្វាយបង្គំ និងចូរបូជាព្រះសាស្តា ដែលទ្រង់យាងទៅ កាន់ផ្ទះរបស់សេដ្ឋីទាំងបី ។

ស្រីទាំងនោះ ធ្វើយ៉ាងនោះហើយ សម្លឹងមើលព្រះសាស្តាដែលយាងទៅ និងយាងមក ថ្វាយបង្គំ និងបូជាហើយ ។

សម័យថ្ងៃមួយ ព្រះនាងមាគន្ធិយាយាងចេញអំពីផ្ទៃប្រាសាទរបស់ខ្លួន ទៅកាន់លំនៅរបស់ស្រីទាំងនោះ ឃើញប្រហោងក្នុងបន្ទប់ទាំងឡាយហើយ ទើបសួរថា នេះជាប្រហោងអ្វី កាលស្រីទាំងនោះ មិនដឹងនូវការអាឃាតដែល ព្រះនាងនោះចងក្នុងព្រះសាស្តា ទើបឆ្លើយថា ព្រះសាស្តាយាងមកនគរយើង ពួកខ្ញុំម្ចាស់ឈរក្នុងទីនេះ រមែងថ្វាយបង្គំ និងបូជាព្រះសាស្តា ដូច្នេះហើយ គិតថា ព្រះសមណគោតមមកហើយកាន់នគរនេះ ឥឡូវនេះ អញនឹងធ្វើកម្ម ដែលគួរដល់ព្រះសមណគោតមនេះ សូម្បីស្រីទាំងនោះ ក៏ជាឧបដ្ឋាយិកា របស់ព្រះគោតមនោះ អញនឹងជីងកម្មដែលគប្បីធ្វើដល់ស្រីទាំងនេះ ទើបទៅ ក្រាបទូលដល់ព្រះរាជាថា បពិត្រមហារាជ ស្រី ៥០០ មួយអន្លើដោយនាង សាមាវតី មានការប្រាថ្នាខាងក្រៅ ព្រះអង្គនឹងមិនមានព្រះជន្មក្នុងរយៈ ២-៣ ថ្ងៃពិត ។ ព្រះរាជាទ្រង់មិនជឿ ដោយទ្រង់ព្រះតម្រិះថា ស្រីទាំងនេះនឹងមិន ធ្វើកម្មបែបនេះ ។ កាលព្រះនាងមាគន្ធិយាក្រាបទូលទៀត ក៏ទ្រង់មិនជឿ នោះឯង ។

លំដាប់នោះ ទើបព្រះនាងមាគន្ទិយាក្រាបទូលព្រះរាជានោះ កាលក្រាបទូលយ៉ាងនេះអស់ ៣ ដង ទ្រង់ក៏នៅតែមិនជឿ ទើបពោលថា បើព្រះអង្គមិនជឿខ្ញុំម្ចាស់សោត បពិត្រមហារាជ សូមទ្រង់យាងទៅកាន់លំនៅរបស់ស្រីទាំងនោះហើយ ទ្រង់ពិចារណាចុះ ។ ព្រះរាជាយាងទៅទតឃើញប្រហោងក្នុងបន្ទប់ទាំងឡាយ ទើបត្រាស់សួរថា នេះប្រហោងអ្វី កាលស្រីទាំងនោះក្រាបទូលសេចក្តីនោះហើយ ទ្រង់មិនពិរោធចំពោះស្រីទាំងនោះ មិនត្រាស់ពាក្យឯណានីមួយទៀយ បញ្ជាឲ្យបិទប្រហោងទាំងឡាយចេញ ហើយឲ្យធ្វើបង្អួចមានប្រហោងតូចក្នុងបន្ទប់ទាំងពួង ។ បានឮថា បង្អួចមានប្រហោងតូចទាំងឡាយកើតឡើង ហើយក្នុងកាលនោះ ។

ព្រះនាងមាគន្ទិយាមិនអាចធ្វើអ្វីដល់ស្រីទាំងនោះបាន ក៏ត្រិះរិះថា អញនឹងធ្វើកម្មដែលគួរធ្វើដល់ព្រះសមណគោតមឲ្យបាន ទើបឲ្យឈ្នួលដល់អ្នកស្រុក ហើយពោលថា ពួកអ្នកមួយអន្ទើដោយពួកបុរសដែលជាទាសៈ និងកម្មករ ចូរដេរបរិកាសព្រះសមណគោតម ដែលចូលទៅខាងក្នុងព្រះនគរ ឲ្យគេចទៅ ។ ពួកមិច្ឆាទិដ្ឋិមិនជ្រះថ្លាក្នុងរតនៈ ៣ ក៏ជាប់តាមព្រះសាស្តា ដែលយាងទៅខាងក្នុងព្រះនគរ ហើយដេរបរិកាស ដោយអាកាសវត្ថុ ១០ យ៉ាង ថា អ្នកជាចោរ អ្នកជាបុគ្គលពាល អ្នកជាមនុស្សឆ្កួត អ្នកជាសត្វអូដ្ឋ អ្នកជាគោ អ្នកជាលា អ្នកជាសត្វនរក អ្នកជាសត្វតិរច្ឆាន សុគតិរបស់អ្នកមិនមាន អ្នកមានតែទុគ្គតិតែម្យ៉ាង ។ ព្រះអានន្ទស្តាប់ពាក្យនោះហើយ ក្រាបទូលពាក្យនេះដល់ព្រះសាស្តាថា បពិត្រព្រះអង្គ អ្នកក្រុងទាំងនេះ ដេរ បរិកាស

ពួកយើង ពួកយើងនឹងទៅក្នុងទីដទៃអំពីទីនេះ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលអានន្ទ យើងនឹងទៅទីណា ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទៅកាន់ក្រុងដទៃ ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ កាលពួកមនុស្សក្នុងក្រុងនោះជេរទៀត យើងនឹងទៅក្នុងទីណាទៀត ព្រះអានន្ទពោលថា បពិត្រព្រះអង្គ ទៅកាន់ក្រុងដទៃអំពីក្រុងនោះទៀត ។ ព្រះសាស្តាត្រាស់ថា បើពួកមនុស្សក្នុងក្រុងនោះជេរទៀត យើងនឹងទៅទីណាវិញ ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទៅកាន់ក្រុងដទៃអំពីក្រុងនោះទៀត ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ កាលធ្វើយ៉ាងនេះមិនគួរ អធិករណ៍កើតឡើងក្នុងទីណា កាលអធិករណ៍នោះរម្ងាប់ហើយក្នុងទីនោះឯង ទើបគួរទៅក្នុងទីដទៃ ម្នាលអានន្ទ ឯពួកជនដែលជេរនោះជានរណា ព្រះអានន្ទត្រាស់ថា បពិត្រព្រះអង្គ ជនទាំងនោះជាអ្នកក្រ មួយអន្ទើដោយទាសៈ និងកម្មករ ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ តថាគតដូចស្តេចដ៏រុះកាន់សង្គ្រាម ការអត់ធន់នឹងព្រួញដែលមកអំពីទិសទាំង ៤ រមែងជាការៈរបស់ដ៏រដែលចុះកាន់សង្គ្រាម យ៉ាងណា ឈ្មោះថា ការអត់ធន់ចំពោះពាក្យសម្តី ដែលបុគ្គលទ្រុស្តសីលជាច្រើនពោលហើយ ក៏ជាការៈរបស់យើងដូច្នោះដូចគ្នា ដូច្នេះហើយ កាលទ្រង់ប្រោរព្ធព្រះអង្គសម្តែងធម្មកាសិតទាំង ៣ នេះ ក្នុងនាគវគ្គថា

តថាគតនឹងអត់ទ្រាំពាក្យល្មើស ដូចដ៏រកាលអត់ទ្រាំចំពោះព្រួញ ដែលរបូតចេញអំពីធ្នូក្នុងសង្គ្រាមដូច្នោះ ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ ។ ពួកជនតែងនាំវាហនៈដែលទូន្មានហើយ ទៅកាន់ទីប្រជុំ ព្រះរាជាស្តេចតែង

ឡើងកាន់វាហនៈដែលទូន្មានហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណា អត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថា បុគ្គលប្រសើរបំផុត ។ ពួកសេះអស្សតរក្តី សេះអាជានេយ្យក្តី សេះសិន្ធពក្តី ដំរីកុញ្ជរដ៏ប្រសើរក្តី ដែលបុគ្គលប្រៀនប្រដៅបានបទហើយ រាប់ថាជាសត្វប្រសើរ បុគ្គលដែលមានខ្លួនទូន្មានបានបទហើយ ប្រសើរជាងសត្វទាំងអស់នោះ ។

ធម្មកថាបានជាប្រយោជន៍ដល់មហាជន ដែលជួបព្រមហើយ ព្រះសាស្តាកាលទ្រង់សម្តែងធម៌យ៉ាងនោះហើយ ត្រាស់ថា ម្នាលអានន្ទ អ្នកកុំគិតឡើយ ជនទាំងនោះ នឹងជេរបានត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះ ក្នុងថ្ងៃទី ៧ នឹងជាអ្នកស្លៀម ព្រោះថា អធិកវណ៌ដែលកើតឡើងដល់ព្រះពុទ្ធទាំងឡាយ រមែងមិនលើស ៧ ថ្ងៃ ។

ព្រះនាងមាគន្ទិយា ឲ្យមនុស្សជេរព្រះសាស្តាហើយ តែមិនអាចឲ្យគេចទៅបាន ទើបគិតថា អញនឹងធ្វើដូចម្តេចហ្ន៎ ដូច្នេះហើយ គិតថា ស្រីទាំងនេះជាអ្នកឧបត្ថម្ភព្រះសមណគោតមនោះ អញនឹងធ្វើការវិនាសឲ្យដល់ស្រីទាំងនោះថ្ងៃមួយ កាលធ្វើនូវការបម្រើក្នុងទីសោយទឹកចណ្ឌនៃព្រះរាជា បញ្ជូនដំណឹងទៅឲ្យឪពុកមាថា សូមជ្រាបថា ខ្ញុំត្រូវការមាន់ទាំងឡាយ សូមឪពុកមានាំយកមាន់ស្ងាប់ ៨ មាន់រស់ ៨ មក កាលបញ្ជូនមាន់មកហើយ ចូរឈរត្រង់ជណ្តើរ ច្រាប់ភាពដែលខ្លួនមកហើយ កាលច្រាប់ថា ចូរចូលមក ក៏កុំចូលទៅចូរបញ្ជូនមាន់រស់ ៨ ទៅមុន បញ្ជូនមាន់ស្ងាប់ ៨ ក្រៅអំពីនេះទៅក្រោយ

ព្រះនាងបានប្រទានថ្លៃឈ្នួលដល់អ្នកបម្រើ ដោយប្រាប់ថា អ្នកគប្បីធ្វើតាមពាក្យរបស់យើង ។

នាយមាគន្ធិយៈមកហើយ ទូលដល់ព្រះរាជាឲ្យទ្រង់ជ្រាប កាលប្រាប់ថា ចូរចូលមក ក៏ពោលថា ខ្ញុំនឹងមិនចូលទៅកាន់ទីសោយទីកចណ្ឌរបស់ព្រះរាជាចំណែកនាងមាគន្ធិយា បញ្ជូនអ្នកបម្រើទៅដោយពាក្យថា នែបា បាចូរទៅកាន់សម្នាក់របស់ឪពុកមាយើង ចូលទៅហើយ នាំមាន់រស់ ៨ ដែលនាយមាគន្ធិយៈនោះឲ្យហើយមក ក្រាបទូលថា បពិត្រសម្មតិទេព បុរោហិតបញ្ជូនគ្រឿងបណ្ណាការមកហើយ ។ ព្រះរាជាត្រាស់ថា ល្អហើយ សម្ភដ្ឋវិភង្គកើតឡើងដល់ពួកយើងហើយ អ្នកណាហ្ន៎គួរស្ញ ។ ព្រះនាងមាគន្ធិយាក្រាបទូលថា បពិត្រមហារាជ ស្រី ៥០០ មានព្រះនាងសាមាវតីជាប្រធាន ជាអ្នកមិនមានការងារ ដើរចុះឡើង សូមទ្រង់បញ្ជូនទៅឲ្យស្រីទាំងនោះៗ ស្ងូហើយ នឹងនាំមក ។ ព្រះរាជាទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា អ្នកចូរទៅឲ្យដល់ស្រីទាំងនោះ បានឮថា ស្រីទាំងនោះ ចូរកុំឲ្យក្នុងដៃអ្នកជនៃ ចូរសម្ងាប់ស្ងួនឯងនោះឯង ។ អ្នកបម្រើទទួលព្រះតម្រាស់ថា សាធុ ព្រះអង្គ ហើយទៅប្រាប់យ៉ាងនោះ ស្រីទាំងនោះជំទាស់ហើយថា ពួកខ្ញុំមិនធ្វើបាណាតិបាត ទើបមកក្រាបទូលសេចក្តីនោះដល់ព្រះរាជា ព្រះនាងមាគន្ធិយាក្រាបទូលថា បពិត្រមហារាជ ទ្រង់ឃើញទេ ឥឡូវនេះ ព្រះអង្គទ្រង់នឹងជ្រាបការធ្វើឬមិនធ្វើបាណាតិបាតនៃស្រីទាំងនោះ សូមទ្រង់ត្រាស់ថា ស្រីទាំងនោះ ចូរស្ងូបញ្ជូនទៅថ្វាយដល់ព្រះសមណគោតមដូច្នេះចុះ ព្រះរាជាត្រាស់យ៉ាងនោះហើយបញ្ជូនទៅ ។ អ្នក

បម្រើ កាន់មាន់ធ្វើជាដើរចេញទៅហើយ ឲ្យមាន់ទាំងនោះដល់បុរោហិត ទទួលមាន់ស្ងាប់ទៅកាន់សម្នាក់របស់ស្រីទាំងនោះ ពោលថា បានឮថា ពួកព្រះនាងចូរស្ងមាន់នេះហើយ បញ្ជូនទៅកាន់សម្នាក់ព្រះសាស្តា ។ ស្រីទាំងនោះទទួលថា នែអ្នក ចូរនាំមកចុះ ឈ្មោះថា ការស្ងមាន់ស្ងាប់នេះ ជាកិច្ចរបស់ពួកយើងដូច្នេះហើយ ក៏ទទួល ។ អ្នកបម្រើនោះ មកកាន់សម្នាក់របស់ព្រះរាជា កាលព្រះរាជាសួរថា សេចក្តីនេះដូចម្តេច ទើបក្រាបទូលថា ខ្ញុំព្រះអង្គគ្រាន់តែពោលថា សូមពួកព្រះនាងស្ងបញ្ជូនទៅថ្វាយព្រះសមណគោតមប៉ុណ្ណោះ ស្រីទាំងនោះក៏សុះមកទទួលយកហើយ ។ ព្រះនាងមាគន្ទិយាក្រាបទូលថា បពិត្រមហារាជ សូមមើលចុះ ស្រីទាំងនោះ មិនធ្វើដល់បុគ្គលដូចព្រះអង្គឡើយ កាលខ្ញុំម្ចាស់ទូលថា ស្រីទាំងនោះមានសេចក្តីប្រាថ្នាខាងក្រៅ ទ្រង់ក៏មិនជឿ ។ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះ ទ្រង់ក៏អត់សង្កត់នៅស្ងៀមដូចមុន ។ ព្រះនាងមាគន្ទិយាគិតថា យើងនឹងធ្វើដូចម្តេចហ្ន៎ ។

ក្នុងកាលនោះ ព្រះរាជាទ្រង់រមែងឈប់សម្រាកអស់ ៧ ថ្ងៃ តាមវារៈ គឺក្នុងប្រាសាទនៃស្រីទាំង ៣ នោះ គឺព្រះនាងសាមាវតី ព្រះនាងវាសុលទត្តា និងព្រះនាងមាគន្ទិយា ។ លំដាប់នោះ ព្រះនាងមាគន្ទិយាដឹងថា ស្ងែកនេះ ឬខានស្ងែក ព្រះរាជានឹងយាងទៅកាន់ប្រាសាទរបស់ព្រះនាងសាមាវតី ទើបបញ្ជូនដំណឹងទៅដល់ឪពុកមាថា សូមជ្រាបថា ខ្ញុំត្រូវការដោយពស់ សូមឪពុកមាជកចង្កឹមពស់ទាំងឡាយ ហើយបញ្ជូនពស់មកមួយក្បាល ។ នាយមាគន្ទិយៈធ្វើយ៉ាងនោះ ហើយបញ្ជូនទៅ ។ ព្រះរាជាទ្រង់កាន់យកពិនហត្ថីកន្ទៈ

យាងទៅកាន់ទីដែលទ្រង់យាងទៅ ។ ក្នុងស្នូកពិណានោះ មានប្រហោងមួយ ព្រះនាងមាគន្ទិយា លែងពស់ចូលក្នុងប្រហោងនោះ ហើយបិទប្រហោង ដោយផ្កា ។ ពស់បាននៅក្នុងពិណានោះឯង អស់ ២-៣ ថ្ងៃ ។ ក្នុងថ្ងៃយាងទៅនៃព្រះរាជា ព្រះនាងមាគន្ទិយាទូលសួរថា បពិត្រព្រះសម្មតិទេព ថ្ងៃនេះ ទ្រង់យាងទៅប្រាសាទរបស់មហេសីអង្គណា កាលត្រាស់ថា របស់នាងសាមាវតី ទើបក្រាបទូលថា បពិត្រមហារាជ ថ្ងៃនេះ ខ្ញុំម្ចាស់សុបិនឃើញហេតុមិនជាទីពេញចិត្ត បពិត្រព្រះសម្មតិទេព ទ្រង់មិនអាចយាងទៅក្នុងថ្ងៃនោះបានទេ ។ ព្រះរាជាត្រាស់ថា យើងនឹងទៅឲ្យបាន ព្រះនាងយាត់ដល់ ៣ ដង ហើយទូលថា បើដូច្នោះ ខ្ញុំម្ចាស់នឹងទៅជាមួយទ្រង់ដែរ ព្រះរាជាឲ្យត្រឡប់ក៏មិនត្រឡប់ ក្រាបទូលថា ខ្ញុំម្ចាស់មិនជ្រាបថា នឹងមានហេតុអ្វី ដូច្នោះហើយ ក៏បានទៅជាមួយព្រះរាជាទាល់តែបាន ។ ព្រះរាជាទ្រង់សំពត់ផ្កា គ្រឿងក្រអូប និងគ្រឿងអាភរណៈដែលពួកញាតិ មួយអន្ទើដោយព្រះនាងសាមាវតីថ្វាយ សោយភោជនដ៏ល្អ ដាក់ពិណាខាងលើសីសៈ ហើយផ្ងើលើទីបន្ទំ ។ ព្រះនាងមាគន្ទិយា ធ្វើជាដើរទៅមក បាននាំផ្កាចេញអំពីប្រហោងពិន ។ ពស់អត់អាហារ ២-៣ ថ្ងៃ លូនចេញអំពីប្រហោងនោះ ព្រោះពិសបើកពពារដេកលើទីបន្ទំហើយ ។ ព្រះនាងមាគន្ទិយាឃើញពស់នោះ ក៏ស្រែកឡើងថា ពស់ ព្រះអង្គ កាលជេរព្រះរាជា និងស្រីទាំងនោះ ទើបពោលថា ស្តេចផែនដីល្ងង់អង្គនេះ មិនមានវាសនា មិនស្តាប់ពាក្យរបស់អញ សូម្បីស្រីទាំងនេះ ក៏ជាមនុស្សមិនមានសិរី ក្បាលរឹង ពួកវា មិនបានអ្វីអំពីសម្ងាក់របស់

ស្តេចផែនដីឬ ពួកនាងកាលស្តេចផែនដីអង្គនេះសោយទិវង្គតហើយ នឹងជាអ្នកនៅសប្បាយឬ កាលស្តេចផែនដីនៅមានព្រះជន្ម ពួកនាងនៅលំបាកឬ ថ្ងៃនេះ យើងឃើញសុបិនអាក្រក់ហើយ បពិត្រព្រះអង្គ ព្រះអង្គមិនស្តាប់សំឡេងរបស់ខ្ញុំម្ចាស់ដែលអង្វរថា មិនគួរយាងទៅប្រាសាទរបស់ព្រះនាងសាមាវតីទេ ។

ព្រះរាជាទតឃើញពស់ ក៏ទ្រង់ស្តុតព្រះហឫទ័យ ខ្លាចចំពោះមរណៈ បានឆេះសន្ធោសន្ធៅដោយសេចក្តីពិរោធថា ស្រីទាំងនេះធ្វើកម្មបែបនេះ ហ៊ឺ អញក៏អាក្រក់ មិនជឿពាក្យរបស់នាងមាគន្ទិយា ដែលប្រាប់ភាពដែលស្រីទាំងនេះជាមនុស្សលាមក ក្នុងកាលមុន វាចោះប្រហោងក្នុងបន្ទប់ទាំងឡាយរបស់ខ្លួន អង្គុយហើយ កាលអញបញ្ជូនមាន់ទៅឲ្យ ក៏បញ្ជូនត្រឡប់មកវិញថ្ងៃនេះ លែងពស់លើទីដេក ។

ចំណែកនាងសាមាវតី ក៏បានឲ្យឱវាទដល់ស្រី ៥០០ ថា នែនាងទាំងឡាយ ទីពឹងរបស់ពួកយើងមិនមាន ចូរនាងញុំាងមេត្តាចិត្តដ៏ស្មើនោះឯង ឲ្យប្រព្រឹត្តទៅក្នុងព្រះរាជា ដែលជាកំពូលនៃនរជន ក្នុងព្រះទេវី និងក្នុងខ្លួននាងទាំងឡាយ កុំធ្វើសេចក្តីក្រោធចំពោះបុគ្គលណាម្នាក់ឡើយ ព្រះរាជាទ្រង់កាន់ធ្នូ មានសណ្ឋានដូចភ្នុកដីរ ដែលមានកម្លាំងរបស់មនុស្ស ១ ពាន់ ទ្រង់ទាញខ្សែហើយ ផ្ចាប់ព្រួញដែលលាបដោយពិស ធ្វើនាងសាមាវតីឲ្យនៅខាងមុខ ឲ្យស្រីទាំងនោះឈរតាមលំដាប់គ្នាហើយ ទើបលែងព្រួញទៅត្រង់ព្រះឧរៈរបស់ព្រះនាងសាមាវតី ។ ព្រួញនោះបែរមុខមករកព្រះរាជាហើយ ហាក់ដូច

ចូលទៅកាន់ហាទយៈរបស់ព្រះរាជា បានតាំងនៅហើយ ដោយមេត្តានុភាពរបស់ព្រះនាងសាមាវតីនោះ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ព្រួញដែលអញបាញ់ទៅ រមែងទម្លុះបានសូម្បីថ្ម សូម្បីហានៈដែលប៉ះក្នុងអាកាស ក៏មិនមានបើដូច្នេះ ព្រួញនេះបែរមុខមកវកបេះដូងរបស់អញដូចម្តេចហ្ន៎ ពិតហើយ ព្រួញនេះមិនមានចិត្ត មិនមែនសត្វ មិនមែនរបស់មានជីវិត គង់ជឿគុណរបស់នាងសាមាវតី ឯអញជាមនុស្ស ហេតុអ្វីក៏មិនជឿគុណ ។

ព្រះរាជាបោះធ្នូចោល ទ្រង់ផ្គងអញ្ជលី អង្គុយច្រហោងទៀបបាទារបស់ព្រះនាងសាមាវតី ត្រាស់ព្រះគាថានេះថា

ខ្ញុំញាប់ញ័រ រង្វេង ទិសទាំងពួងងងឹតដល់ខ្ញុំ នែសាមាវតី
ចូរនាងជាទីអាស្រ័យ ចូរនាងជាទីពឹងរបស់ខ្ញុំ ។

ព្រះនាងសាមាវតី ស្តាប់ព្រះតម្រាស់ព្រះរាជាហើយ ក៏មិនបានក្រាបទូលថា សាធុ សម្មតិទេព ទ្រង់ដល់នូវខ្ញុំម្ចាស់ជាទីពឹងចុះ តែក្រាបទូលថា បពិត្រមហារាជ ខ្ញុំម្ចាស់ដល់បុគ្គលណាជាទីពឹង សូមព្រះអង្គដល់បុគ្គលនោះឯងជាទីពឹងចុះ ។

ព្រះនាងសាមាវតី ដែលជាសាវិការបស់ព្រះសម្មាសម្ពុទ្ធ កាលពោលពាក្យនេះហើយ ក៏ពោលថា

សូមទ្រង់កុំដល់ខ្ញុំម្ចាស់ជាទីពឹងឡើយ ខ្ញុំម្ចាស់ដល់បុគ្គលណាជាទីពឹង បពិត្រមហារាជ បុគ្គលនោះ គឺព្រះពុទ្ធ ព្រះពុទ្ធអង្គនោះជាកំពូល សូមទ្រង់ដល់នូវព្រះពុទ្ធអង្គនោះ ជាទីពឹងផង ទ្រង់ជា

ទីពឹង របស់ខ្ញុំម្ចាស់ផង ។

ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់នាងសាមាវតីនោះហើយ ទើបត្រាស់ថា ឥឡូវនេះ យើងរីងរឹតតែខ្លាចខ្លាំងឡើង ហើយត្រាស់គាថានេះថា ខ្ញុំវង្វេងក្រៃលែងឡើង ទិសទាំងពួងងងឹតដល់ខ្ញុំ នែសាមាវតី ចូរនាងជាទីអាស្រ័យនៃខ្ញុំ និងជាទីពឹងរបស់ខ្ញុំ ។

លំដាប់នោះ ព្រះនាងសាមាវតីក៏ទូលសួរព្រះរាជាទៀត ដោយនយមុននោះឯង កាលព្រះរាជាត្រាស់ថា បើដូច្នោះ ខ្ញុំសូមដល់នាង និងព្រះសាស្តាជាទីពឹង ហើយខ្ញុំនឹងឲ្យពរដល់នាង ដូច្នេះហើយ ទើបក្រាបទូលថា បពិត្រមហារាជ ពរសូមជារបស់ដែលខ្ញុំម្ចាស់បានទទួលចុះ ។ ព្រះរាជាយាងចូលទៅគាល់ព្រះសាស្តា ទ្រង់ដល់ព្រះពុទ្ធជាសរណៈហើយ ទ្រង់និមន្តព្រះសាស្តា ថ្វាយទានដល់ភិក្ខុសង្ឃអស់ ៧ ថ្ងៃ ទ្រង់ហៅព្រះនាងសាមាវតីមកត្រាស់ថា នាងចូរក្រោកឡើងទទួលពរ ។ ព្រះនាងសាមាវតីក្រាបទូលថា បពិត្រមហារាជ ខ្ញុំម្ចាស់ត្រូវការដោយវត្ថុទាំងឡាយ មានប្រាក់ជាដើមឡើយ បពិត្រព្រះអង្គ សូមទ្រង់ព្រះរាជទានពរនេះដល់ខ្ញុំម្ចាស់ គឺព្រះសាស្តា មួយអន្ទើដោយភិក្ខុ ៥០០ រូប នឹងយាងមកក្នុងទីនេះជានិច្ច បានដោយប្រការណា សូមទ្រង់ធ្វើដោយប្រការនោះចុះ ខ្ញុំម្ចាស់នឹងស្តាប់ធម៌ ។ ព្រះរាជាថ្វាយបង្គំព្រះសាស្តាហើយ ទូលថា បពិត្រព្រះអង្គ សូមទ្រង់យាងមកក្នុងទីនេះជានិច្ច ព្រមដោយភិក្ខុ ៥០០ ។ ពួកស្រីដែលរួមទាំងព្រះនាងសាមាវតីចូលផង ពោលថា ខ្ញុំម្ចាស់នឹងស្តាប់ធម៌ ។

ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ធម្មតាការទៅក្នុងទីតែមួយជានិច្ច រមែងមិនគួរដល់ព្រះពុទ្ធទាំងឡាយ ព្រោះមហាជនទន្ទឹងចំពោះព្រះពុទ្ធ ។

ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ បើយ៉ាងនោះ សូមទ្រង់បញ្ជូនភិក្ខុមួយរូបចុះ ។

ព្រះសាស្តា ទ្រង់ប្រគល់នាទីដល់ព្រះអានន្ទត្ថេរហើយ ។ ចាប់តាំងអំពីកាលនោះ ព្រះអានន្ទត្ថេរក៏នាំភិក្ខុ ៥០០ ទៅកាន់រាជត្រកូលជានិច្ច ព្រះទេវីទាំងនោះ អង្គាសព្រះថេរៈ មួយអន្ទើដោយបរិវារស្តាប់ធម៌ជានិច្চកាល ។

ថ្ងៃមួយ ស្រីទាំងនោះ ស្តាប់ព្រះធម្មកថារបស់ព្រះអានន្ទត្ថេរហើយ ជ្រះថ្លា បានធ្វើការបូជាធម៌ដោយសំពត់ឧត្តរាសង្គៈ ៥០០ ផ្ទាំង ។ ឧត្តរាសង្គៈនីមួយៗ មានតម្លៃ ៥០០ ។ ព្រះរាជាទ្រង់មិនឃើញសំពត់មួយផ្ទាំងរបស់ស្រីទាំងនោះ ទើបត្រាស់សួរថា សំពត់ឧត្តរាសង្គៈនៅឯណា ស្រីទាំងនោះក្រាបទូលថា ខ្ញុំម្ចាស់ប្រគេនដល់លោកម្ចាស់ ។ ព្រះរាជាត្រាស់ថា លោកម្ចាស់អង្គនោះទទួលទាំងអស់ឬ ស្រីទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ លោកទទួលទាំងអស់ ។

ព្រះរាជាយាងចូលទៅរកព្រះអានន្ទត្ថេរហើយ ត្រាស់សួរភាពដែលស្រីទាំងនោះប្រគេនសំពត់ឧត្តរាសង្គៈ ទ្រង់ស្តាប់ភាពដែលសំពត់ ដែលស្រីទាំងនោះ ប្រគេនហើយ និងភាពដែលព្រះថេរៈទទួលហើយ ទើបត្រាស់សួរថា បពិត្រលោកម្ចាស់ សំពត់ទាំងឡាយច្រើនពេកមិនមែនឬ លោកម្ចាស់នឹងធ្វើអ្វីដោយសំពត់មានប្រមាណប៉ុណ្ណេះ ព្រះអានន្ទត្ថេរពោលថា បពិត្រមហារាជ

អាត្មាទទួលសំពត់ល្មមដល់អាត្មាកាពហើយ នឹងប្រគេនសំពត់ដ៏សេសដល់កិកូទាំងឡាយ ដែលមានចីវរចាស់ ។ ព្រះរាជាត្រាស់ថា កិកូទាំងឡាយ នឹងធ្វើចីវរចាស់របស់ខ្លួនឲ្យជាអ្វី ព្រះថេរៈពោលថា នឹងឲ្យដល់កិកូដែលមានចីវរចាស់ជាងទាំងឡាយ ។ ព្រះរាជាត្រាស់ថា កិកូទាំងនោះនឹងធ្វើចីវរចាស់របស់ខ្លួនឲ្យជាអ្វី ព្រះថេរៈពោលថា លោកនឹងធ្វើឲ្យជាសំពត់ក្រាលដេក ។ ព្រះរាជាត្រាស់ថា លោកនឹងធ្វើសំពត់ក្រាលដេកចាស់ឲ្យជាអ្វី ព្រះថេរៈពោលថា លោកធ្វើឲ្យជាសំពត់កម្រាលផ្ទៃ ។ ព្រះរាជាត្រាស់ថា លោកនឹងធ្វើសំពត់កម្រាលផ្ទៃចាស់ឲ្យជាអ្វី ព្រះថេរៈពោលថា សូមថ្វាយព្រះពរ លោកនឹងធ្វើឲ្យជាសំពត់ជូតជើង ។ ព្រះរាជាត្រាស់ថា លោកនឹងធ្វើសំពត់ជូតជើងចាស់ឲ្យជាអ្វី ព្រះថេរៈពោលថា លោកនឹងជាន់ឲ្យល្អិត ហើយផ្សំជាមួយដីឥដ្ឋបូកជញ្ជាំង ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ សំពត់ទាំងឡាយដែលប្រគេនដល់លោកម្ចាស់ នឹងមិនវិនាស ព្រោះធ្វើកម្មមានប្រមាណប៉ុណ្ណោះឬ ព្រះថេរៈពោលថា យ៉ាងនោះឯងមហាបពិត្រ ។ ព្រះរាជាទ្រង់ជ្រះថ្លាហើយ ទ្រង់ត្រាស់ឲ្យនាំសំពត់ ៥០០ ដទៃទៀត ឲ្យតាំងទុកទៀបបាទមូលរបស់ព្រះថេរៈហើយ ។

បានឮថា ព្រះថេរៈបានសំពត់មានតម្លៃ ៥០០ ដែលព្រះរាជាទ្រង់ដាក់ត្រង់ទៀបបាទមូល ដោយចំណែក ៥០០ ដល់ទៅ ៥០០ ដង បានសំពត់មានតម្លៃមួយពាន់ ដែលព្រះរាជាទ្រង់ដាក់ទៀបបាទមូល ប្រគេនដោយចំណែកមួយពាន់ ដល់ទៅ ១ ពាន់ដង បានសំពត់មានតម្លៃមួយសែន ដែលព្រះរាជា

ទ្រង់ដាក់ទៀបបាទមូល ប្រគេនដោយចំណែកមួយសែន ដល់ទៅមួយសែនជង ឈ្មោះថា ការរាប់សំពត់ដែលព្រះអានន្ទបានហើយ ដោយន័យជាដើមថា ១-២-៣-៤-៥-១០ ដូច្នេះ មិនមាន ។ បានឮថា កាលព្រះតថាគតបរិនិព្វានហើយ ព្រះថេរៈត្រាច់ទៅពេញជម្ពូទ្វីប បានប្រគេនបាត្រ និងចីវរទាំងឡាយ ដែលជារបស់ខ្លួននោះឯង ដល់ភិក្ខុទាំងឡាយក្នុងវិហារទាំងពួងហើយ ។

ព្រះនាងមាគន្ធិយាគិតថា អញធ្វើវត្តុណា វត្តុនោះមិនបានយ៉ាងនោះ បែរជាបានដទៃទៅវិញ អញនឹងធ្វើដូចម្តេចហ្ន៎ ដូច្នេះហើយ គិតថា ឧបាយនេះប្រើការបាន កាលព្រះរាជាយាងទៅកាន់ទីកីឡា ក្នុងព្រះរាជឧទ្យាន ទើបបញ្ជូនដំណឹងដល់ឪពុកមាថា សូមឪពុកមាទៅកាន់ប្រាសាទរបស់នាងសាមាវតី ឲ្យបើកឃ្លាំងសំពត់ និងឃ្លាំងប្រេង ហើយជ្រលក់សំពត់ក្នុងពាងប្រេង រួចរុំសសរ ធ្វើស្រីទាំងនោះទុកជាមួយគ្នា បិទទ្វារ ជាក់គន្ធីះខាងក្រៅ យកគប់ភ្លើងមានជង់ជុតដំណាក់ហើយ ចូរទៅចុះ ។ នាយមាគន្ធិយៈនោះ ទៅជិតកាន់ប្រាសាទ ឲ្យបើកឃ្លាំងទាំងឡាយ ជ្រលក់សំពត់ក្នុងពាងប្រេងហើយរុំសសរ ។

លំដាប់នោះ ស្រីទាំងឡាយ មានព្រះនាងសាមាវតីជាប្រធាន ពោលនឹងនាយមាគន្ធិយៈថា លោកមាធ្វើអ្វី ចូលទៅរកហើយ នាយមាគន្ធិយៈពោលយ៉ាងនេះថា ព្រះនាងទាំងឡាយ ព្រះរាជាប្រាប់ឲ្យរុំសសរទាំងនេះដោយសំពត់ ជ្រលក់ប្រេង ដើម្បីប្រយោជន៍ធ្វើឲ្យរឹងមាំ ធម្មតាក្នុងព្រះរាជវាំង

កម្មដែលប្រកបល្អ និងអាក្រក់ ជារបស់ដ៏ធំបានដោយលំបាក កុំនៅក្នុងទីជិតខ្ញុំឡើយ ដូច្នេះហើយ ឲ្យស្រីទាំងនោះមកហើយ ចូលទៅខាងក្នុងបន្ទប់ បិទទ្វារហើយ ជាក់គន្ធីះខាងក្រៅ ជុតភ្លើង តាំងអំពីដើមចុះមកហើយ ។

ព្រះនាងសាមាវតី បានឲ្យឱវាទដល់ស្រីទាំងនោះថា ការកំណត់អត្តភាពដែលត្រូវភ្លើងឆេះយ៉ាងនេះរបស់ពួកយើង ដែលអន្ទោលទៅក្នុងសង្សារ មិនមានទីបំផុតខាងដើម សូម្បីពុទ្ធញ្ញាណ ក៏ធ្វើមិនបានដោយងាយ អ្នកទាំងឡាយចូរជាអ្នកមិនប្រមាទចុះ ។ ស្រីទាំងនោះ កាលដំណាក់ត្រូវភ្លើងឆេះ មនសិការដល់វេទនាបរិគ្គហកម្មដ្ឋាន ជនពួកខ្លះសម្រេចផលទី ២ ជនពួកខ្លះសម្រេចផលទី ៣ ។

ព្រោះដូច្នោះ ទើបធម្មសង្គាហកាចារ្យពោលថា គ្រានោះឯង ភិក្ខុជាច្រើនត្រឡប់អំពីបិណ្ឌបាតខាងក្រោយភត្ត ព្រះដ៏មានព្រះភាគ ប្រថាប់នៅទីណាចូលទៅគាល់ដោយទីនោះ កាលចូលទៅគាល់ហើយ ធ្វើអភិវាទព្រះដ៏មានព្រះភាគ អង្គុយហើយក្នុងចំណែកម្ខាង ភិក្ខុទាំងនោះ ដែលអង្គុយហើយក្នុងចំណែកម្ខាង បានក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ប្រទានព្រះវរោកាស ខាងក្នុងបុរីរបស់ព្រះបាទឧទេន ដែលទ្រង់យាងទៅកាន់ព្រះរាជឧទ្យាន ត្រូវភ្លើងឆេះហើយ ស្រី ៥០០ មាននាងសាមាវតីជាប្រធានធ្វើកាលកិរិយាហើយ បពិត្រព្រះអង្គដ៏ចម្រើន គតិរបស់ឧបាសិកាទាំងនោះដូចម្តេច សម្បរាយភពចំពោះមុខដូចម្តេច ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងឧបាសិកាទាំងនេះ ឧបាសិកាដែលជាសោតបន្នក៏មាន ជា

ព្រះសកទាគាមីក៏មាន ជាអនាគាមីក៏មាន ឧបាសិកាទាំងអស់នោះ ជាអ្នកមិនឥតផល ធ្វើកាលកិរិយាទេ ។

លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់ជ្រាបសេចក្តីនោះហើយ ទ្រង់បន្ទឺព្រះឧទាននេះ ក្នុងពេលនោះថា

សត្វលោក មានមោហៈជាចំណង ប្រកបដូចជាមានរបងម្រើន បុគ្គលពាល មានឧបធិក្កិលេសជាចំណង ត្រូវងងឹត គឺអវិជ្ជាចោមរោមហើយ ប្រកបដូចជាទៀងទាត់ សេចក្តីកង្វល់មានរាគៈជាដើមរបស់បុគ្គលអ្នកពិចារណា ឃើញច្បាស់ មិនមានទេ ។

កាលត្រាស់យ៉ាងនោះហើយ ទ្រង់សម្តែងធម៌ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាសត្វទាំងឡាយ អន្ទោលទៅក្នុងវដ្តៈ ជាអ្នកមិនប្រមាទអស់កាលជានិច្ច ធ្វើបុញ្ញកម្មក៏មាន ជាបុគ្គលមានសេចក្តីប្រមាទ ធ្វើបាបកម្មក៏មាន ហេតុនោះ សត្វដែលត្រាច់ទៅក្នុងវដ្តៈ ទើបសោយសុខខ្លះ ទុក្ខខ្លះ ។

ព្រះរាជាទ្រង់ឮថា ដំណាក់របស់ព្រះនាងសាមាវតីត្រូវភ្លើងឆេះ ទ្រង់ក៏យាងមកដោយរហ័ស ក៏មិនអាចទាន់ដំណាក់ដែលភ្លើងមិនទាន់ឆេះបាន កាលយាងមកហើយ ទ្រង់ញាំងដំណាក់ឲ្យរលត់ហើយ ទ្រង់កើតទោមនស្សដ៏មានកម្លាំង ចោមរោមដោយពួកអមាត្យ ប្រថាប់គង់អនុស្សរណៈដល់គុណរបស់ព្រះនាងសាមាវតី ទ្រង់ព្រះតម្រិះថា នេះជាការធ្វើរបស់អ្នកណាហ្ន៎ ដូច្នេះហើយ ទ្រង់ជ្រាបថា កម្មនេះ នឹងជាកម្មដែលនាងមាគន្ទិយាឲ្យធ្វើហើយ ទ្រង់ព្រះតម្រិះថា នាងមាគន្ទិយានោះ បើអញធ្វើឲ្យភ័យខ្លាចហើយសួរ គង់មិនប្រាប់ អញ

នឹងសួរដោយខបាយសន្សឹមៗ ទើបត្រាស់នឹងអាមាត្យទាំងឡាយថា នែអ្នកទាំងឡាយ ក្នុងកាលមុន យើងក្រោកឡើងហើយ ជាអ្នកសង្រួយដោយជុំវិញនោះឯង នាងសាមាវតីស្វែងរកទោសយើងជានិច្ច នាងក៏ស្លាប់ទៅហើយ ឥឡូវនេះ យើងនឹងត្រជាក់ចិត្តបាន យើងនឹងបាននៅដោយសេចក្តីសុខ ។ ពួកអមាត្យក្រាបទូលថា បពិត្រសម្មតិទេព កម្មនេះ អ្នកណាហ្ន៎ធ្វើហើយ ព្រះរាជាត្រាស់តបថា នឹងដែលបុគ្គលណាម្នាក់ធ្វើហើយ ដោយការស្រឡាញ់យើង ។ ព្រះនាងមាគន្ទិយាឈរគាល់ក្នុងទីជិត ស្តាប់ព្រះតម្រាស់នោះហើយ ទើបក្រាបទូលថា អ្នកដទៃនឹងធ្វើ មិនអាចធ្វើបាន បពិត្រព្រះអង្គ កម្មនេះ ខ្ញុំម្ចាស់ធ្វើហើយ ខ្ញុំម្ចាស់ប្រើឱពុកមាឲ្យធ្វើ ។ ព្រះរាជាត្រាស់ថា ឈ្មោះថា សត្វមានសេចក្តីស្រឡាញ់ក្នុងយើងជាងដទៃលើកទុកចុះ ក្រៅអំពីនាងរ៉មែងមិនមាន យើងពេញចិត្តព្រះទេវី យើងនឹងឲ្យពរដល់នាង នាងចូរហៅពួកញាតិរបស់ខ្លួនមក ។ បញ្ជូនដំណឹងទៅដល់ពួកញាតិថា ព្រះរាជាទ្រង់ពេញព្រះហឫទ័យ នឹងព្រះរាជទានពរដល់ខ្ញុំ ចូរមកឲ្យរហ័ស ។

ព្រះរាជា បញ្ជាឲ្យធ្វើសក្ការៈធំដល់ញាតិទាំងឡាយ របស់ព្រះនាងមាគន្ទិយាដែលមកហើយ សូម្បីពួកជនដែលមិនមែនញាតិរបស់ព្រះនាងមាគន្ទិយា ឃើញសក្ការៈនោះហើយ ក៏ឲ្យសំណូកពោលថា ពួកយើងខ្ញុំជាញាតិរបស់ព្រះនាងមាគន្ទិយា នាំគ្នាមកហើយ ។ ព្រះរាជាបញ្ជាឲ្យចាប់មនុស្សទាំងនោះ ហើយឲ្យជីករណ្តៅទាំងឡាយ ប្រមាណត្រឹមផ្ចិត ត្រង់លានព្រះរាជវាំងហើយ ឲ្យមនុស្សទាំងនោះអង្គុយក្នុងរណ្តៅទាំងនោះ យកដីលុប

ឲ្យជាក់ចំបើងអំពីខាងលើ ហើយដុតភ្លើង ក្នុងពេលដែលស្បែកត្រូវភ្លើងឆេះ ហើយ បញ្ចាឲ្យក្តួរដោយទង្គ័លដែកទាំងឡាយ ធ្វើឲ្យជាកំណាត់ និងមិនមានកំណាត់ ឬធ្វើឲ្យជាចម្រៀក និងមិនជាចម្រៀក ។ ព្រះរាជាទ្រង់បញ្ជាឲ្យឆ្កូតសាច់អំពីសរីរៈរបស់នាងមាគន្ធិយា ត្រង់ទីដែលមានសាច់នៅ ដោយកាំបិតដ៏មុតហើយ ឲ្យលើកឡើងកាន់ចង្ក្រានដែលក្តៅដោយខ្លាញ់ ឲ្យចៀនដូចនំ ហើយឲ្យទំពាស៊ីសាច់ទាំងនោះឯង ។

ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាក្នុងរោងធម្មសភាថា ការស្លាប់បែបនេះ របស់ឧបាសិកាដែលដល់ព្រមដោយសទ្ធាបែបនេះ មិនសមគួរសោះហ្ន៎ អាវុសោទាំងឡាយ ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ ។ កាលពួកភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះ ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការស្លាប់របស់ស្រីទាំងឡាយនោះ មាននាងសាមាវតីជាប្រធាន មិនគួរហើយក្នុងអត្តភាពនេះតែការស្លាប់របស់ស្រីទាំងនោះ សមគួរដល់កម្មដែលនាងធ្វើក្នុងកាលមុន ។ ភិក្ខុទាំងនោះ ទូលអារាធនាថា បពិត្រព្រះអង្គ កម្មអ្វីដែលស្រីទាំងនោះធ្វើក្នុងកាលមុន សូមទ្រង់ត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គទាំងឡាយ ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល កាលស្តេចព្រហ្មទត្តគ្រងរាជ្យក្នុងក្រុងពារាណសី ព្រះបច្ចេកពុទ្ធ ៨ អង្គ ឆាន់ក្នុងព្រះរាជវាំងជានិច្ច ស្រី ៥០០ នាក់ រមែងទំនុក

បម្រុងព្រះបច្ចេកពុទ្ធទាំងនោះ ។ បណ្តាព្រះបច្ចេកពុទ្ធទាំងនោះ ព្រះបច្ចេកពុទ្ធ ៧ អង្គ ទៅកាន់ហិមវន្តប្បទេស មួយអង្គទៀត ចូលឈានត្រង់ទីស៊ុមទ្រុម ដោយស្មៅមួយកន្ទែង កែ្បរមាត់ស្ទឹង ។ ថ្ងៃមួយ កាលព្រះបច្ចេកពុទ្ធទាំងឡាយ ទៅហើយ ព្រះរាជានាំស្រីទាំងនោះទៅ ដើម្បីលេងទឹកក្នុងស្ទឹង ។ ក្នុងទីនោះ ស្រីទាំងនោះលេងទឹក រហូតអស់ចំណែកនៃថ្ងៃ ឡើងមកហើយ ត្រូវងារបៀត បៀន ប្រាថ្នានឹងអាំងភ្លើង ពោលថា អ្នកទាំងឡាយគប្បីរកទីសម្រាប់បង្កាត់ ភ្លើងរបស់ពួកយើង ដើរទៅមកៗ ឃើញទីស៊ុមទ្រុមដោយស្មៅនោះ ទើប ឈរជុំវិញ បង្កាត់ភ្លើងហើយ ដោយសម្គាល់ថាជាគំនរស្មៅ កាលស្មៅទាំង-ឡាយឆេះហើយ ក៏រលត់ ស្រីទាំងនោះឃើញព្រះបច្ចេកពុទ្ធ ទើបពោលថា ពួកយើងវិនាសហើយ ពួកយើងវិនាសហើយ ព្រះបច្ចេកពុទ្ធរបស់ព្រះរាជា ត្រូវភ្លើងឆាបឆេះ ព្រះរាជាទ្រង់នឹងធ្វើពួកយើងឲ្យអន្តរធាន យើងនឹងធ្វើ លោកឲ្យឆេះទាំងអស់ ជនទាំងនោះ នាំឧសមកអំពីទិសផ្សេងៗ ធ្វើឲ្យជា គំនរខាងលើនៃព្រះបច្ចេកពុទ្ធនោះ គំនរឧសធំបានកើតមានហើយ ។ គ្រានោះ ស្រីទាំងនោះដុតគំនរឧសនោះហើយចៀសចេញទៅ ដោយសម្គាល់ថា ឥឡូវ នេះ និងឆេះអស់ ។ កាលមុនស្រីទាំងនោះ ជាអ្នកមិនមានចេតនា ត្រូវកម្ម ជាប់តាមហើយក្នុងឥឡូវនេះ ។ មនុស្សទាំងឡាយ នាំឧសមួយពាន់រទេះ មក ដុតក៏មិនអាចធ្វើព្រះបច្ចេកពុទ្ធដែលនៅក្នុងសមាបត្តិ ឲ្យមានអាការត្រឹមតែក្តៅ បាន ។ ព្រោះដូច្នោះ ព្រះបច្ចេកពុទ្ធនោះ ក្នុងថ្ងៃទី ៧ ទើបក្រោកឡើង ទៅ តាមសប្បាយហើយ ។ ស្រីទាំងនោះ ឆេះក្នុងនរកអស់ប្រើនពាន់ឆ្នាំ ព្រោះកម្ម

ដែលធ្វើហើយ ឆេះហើយក្នុងផ្ទះដែលត្រូវភ្លើងឆេះ ដោយទំនងនេះឯង អស់មួយរយអត្តភាព ដោយវិបាកដ៏សេសនៃកម្មនោះឯង ។ នេះជាបុព្វកម្មរបស់ស្រីទាំងនោះ ដោយប្រការដូច្នេះ ។

កាលព្រះសាស្តា ត្រាស់យ៉ាងនោះហើយ ភិក្ខុទាំងឡាយទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ចុះនាងខុជ្ជុត្តរាព្រោះកម្មដូចម្តេច ទើបកើតជាស្រីគម ព្រោះកម្មដូចម្តេច ទើបមានបញ្ញាច្រើន ព្រោះកម្មដូចម្តេច ទើបសម្រេចសោតាបត្តិផល ព្រោះកម្មដូចម្តេច ទើបកើតជាអ្នកបម្រើរបស់អ្នកដទៃ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដែលព្រះរាជាអង្គនោះឯង គ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះបច្ចេកពុទ្ធអង្គនោះដូចគ្នា បានជាបុគ្គលមានជាតុនៃមនុស្សគមបន្តិច ។ លំដាប់នោះ ស្រីឧបដ្ឋាយិកាម្នាក់ដណ្តប់សំពត់កម្ពល កាន់ផ្តិលមាស ធ្វើជាមនុស្សគម សម្តែងអកប្បកិរិយា ត្រាច់ទៅនៃព្រះបច្ចេកពុទ្ធអង្គនោះ ដោយពោលថា ព្រះបច្ចេកពុទ្ធរបស់ពួកយើងរមែងត្រាច់ទៅយ៉ាងនេះ និងយ៉ាងនេះ ព្រោះផលដែលហូរចេញនៃកម្មនោះ ទើបនាងជាស្រីគម ។

ម្យ៉ាងទៀត ក្នុងថ្ងៃដំបូង ព្រះរាជាទ្រង់និមន្តព្រះបច្ចេកពុទ្ធទាំងនោះ ឲ្យគង់ក្នុងព្រះរាជមន្ទីរហើយ ឲ្យរាជបុរសទទួលបាត្រ ជាក់បាត្រឲ្យពេញដោយបាយាស ហើយប្រគេន ។ ព្រះបច្ចេកពុទ្ធទាំងឡាយ កាន់បាត្រដែលពេញដោយបាយាសក្តៅ ត្រូវផ្ងាស់ប្តូរដៃរឿយៗ ស្រីនោះ ឃើញលោកធ្វើយ៉ាងនោះ ក៏ប្រគេនកងដៃភ្នក ៨ ដែលជារបស់ផ្ទាល់ខ្លួន ពោលថា សូមលោក

ម្ចាស់ជាក់លើកង់ដៃនេះ ហើយកាន់យក ។ ព្រះបច្ចេកពុទ្ធទាំងនោះ ធ្វើយ៉ាងនោះ ហើយសម្លឹងមើលស្រីនោះ ។ នាងជ្រាបបំណងរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ទើបពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនត្រូវការកង់ទាំងនេះទេ ខ្ញុំបរិច្ចាគកង់ទាំងនោះហើយ ដល់លោកម្ចាស់ទាំងឡាយនោះឯង សូមលោកម្ចាស់ទទួលចុះ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ទទួលហើយ បាននៅកាន់ញាកភ្នំឈ្មោះនន្ទមូលកៈ ។ សូម្បីសព្វថ្ងៃនេះ កង់ទាំងនោះក៏នៅល្អនោះឯង ។ ព្រោះផលដែលហូរចេញនៃកម្មនោះ ក្នុងឥឡូវនេះ ទើបនាងជាអ្នកទ្រទ្រង់ព្រះត្រៃបិដក មានបញ្ញាច្រើន ។ ព្រោះផលដែលហូរចេញនៃការឧបដ្ឋាកដែលនាងធ្វើដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ទើបនាងសម្រេចសោតាបត្តិផល ។ នេះជាបុព្វកម្ម ក្នុងសម័យពុទ្ធន្តរបស់នាង ។

ចំណែកក្នុងកាលនៃព្រះសម្មាសម្ពុទ្ធកស្សបៈ កូនស្រីសេដ្ឋីក្រុងពារាណសីម្នាក់ចាប់កញ្ចក់ អង្គុយតែងខ្លួនក្នុងកាលមានស្រមោលចម្រើន គឺពេលរសៀល ។ លំដាប់នោះ កិកុនីជាទាសីណាស្រពមួយរូប ជាអ្នកស្និទ្ធស្នាលរបស់នាង បាននៅជើម្បីសួរសុខទុក្ខ ពិតហើយ កិកុនីសូម្បីជាទាសីណាស្រព ក៏ជាអ្នកប្រាថ្នាដើម្បីឃើញត្រកូលឧបដ្ឋាក ក្នុងពេលល្ងាច ។ ក្នុងខណៈនោះ ស្រីបម្រើណាមួយក្នុងសម្នាក់របស់ធីតារបស់សេដ្ឋីនោះមិនមានឡើយ ទើបនាងពោលថា ខ្ញុំថ្វាយបង្គំព្រះនាង សូមហុចកំប្រោងគ្រឿងប្រដាប់នោះ ឲ្យដល់ខ្ញុំបន្តិច ។ ព្រះថេរីគិតថា បើអញមិនហុចកំប្រោងនេះឲ្យដល់នាងសោត នាងនឹងធ្វើអាឃាតក្នុងអាត្មាអញ ហើយកើតក្នុងនរក តែបើអញហុចឲ្យ នាងគង់

កើតជាស្រីបម្រើរបស់អ្នកដទៃ ណ្ហើយចុះ កាពជាអ្នកបម្រើរបស់អ្នកដទៃ ប្រសើរជាងការក្តៅក្រហាយក្នុងនរក ។ ព្រះថេរីនោះអាស្រ័យកុណា ទើបហុចកំប្រោងគ្រឿងប្រដាប់នោះឲ្យដល់នាង ។ ព្រោះអានិសង្សនៃកម្មនោះ ទើបនាងបានជាអ្នកបម្រើរបស់អ្នកដទៃ ។

ថ្ងៃស្អែកឡើង ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា ស្រី ៥០០ មានព្រះនាងសាមាវតីជាប្រធាន ត្រូវភ្លើងឆេះហើយក្នុងដំណាក់ ពួកញាតិរបស់ព្រះនាងមាគន្ទិយា ត្រូវជុតដោយចំបើងដែលគ្របខាងលើ ហើយទម្លាយដោយនង្គ័លដែក ព្រះនាងមាគន្ទិយា ត្រូវចៀនដោយខ្លាញ់ដ៏ក្តៅ ក្នុងមនុស្សទាំងនោះ អ្នកណាហ្ន៎ ឈ្មោះថា រស់នៅ អ្នកណាហ្ន៎ ឈ្មោះថា ស្លាប់ហើយ ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលពួកភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះ ដូច្នេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកជនឯណាមួយប្រមាទហើយ ជនទាំងនោះ សូម្បីរស់នៅមួយរយឆ្នាំ ក៏ឈ្មោះថា ស្លាប់ហើយពិត បុគ្គលពួកណាមិនប្រមាទ បុគ្គលនោះស្លាប់ហើយ ក៏ឈ្មោះថារស់នៅ ព្រោះដូច្នោះ នាងមាគន្ទិយា ទោះបីរស់នៅក្តី ស្លាប់ក្តី ក៏ឈ្មោះថា ស្លាប់ហើយនោះឯង ស្រី ៥០០ មាននាងសាមាវតីជាប្រធាន សូម្បីស្លាប់ហើយ ក៏ឈ្មោះថា រស់នៅនោះឯង ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលមិនប្រមាទ ឈ្មោះថា មិនស្លាប់ ដូច្នេះហើយ ទ្រង់ភាសិតគាថាទាំងឡាយថា

អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ

អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា ។
ឯតំ វិសេសតោ ញត្វា អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា ។
តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ ។

សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិត បានជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា (ទើបឋិតនៅ) ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរក្នុងធម៌ជាគោចរ នៃអរិយបុគ្គលទាំងឡាយ មានការពិនិត្យជាប្រក្រតី មានព្យាយមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញាតែងប៉ះពាល់នូវព្រះនិព្វាន ជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាត ដ៏ប្រសើរបំផុត ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បមាទោ** *រមែងសម្តែងអត្ថទូលំទូលាយ កាន់យកអត្ថទូលាយតាំងនៅ ។ ពិតហើយ ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកទាំងមូល ដែលអាចារ្យទាំងឡាយនាំមកពោល រមែងឈមចុះកាន់ការមិនប្រមាទ*

នោះឯង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្នាមជើងណាមួយ របស់សត្វទាំងឡាយ ដែលត្រាច់ទៅលើផែនដី ស្នាមជើងទាំងពួងនោះ រមែងដល់នូវការប្រជុំចុះក្នុងស្នាមជើងដំរី ស្នាមជើងដំរីដែលសត្វលោកហៅថា ជាកំពូលនៃស្នាមជើងទាំងនោះ ព្រោះស្នាមជើងដំរីនេះជារបស់ធំយ៉ាងណា ម្នាលភិក្ខុទាំងឡាយ កុសលធម៌ណាមួយ កុសលធម៌ទាំងអស់នោះ មានការមិនប្រមាទជាឫសគល់ មានការមិនប្រមាទជាទីប្រជុំចុះ ការមិនប្រមាទដែលតថាគតពោលថា ជាកំពូលនៃធម៌ទាំងនោះដូច្នោះដូចគ្នា ។

ការមិនប្រមាទនោះដោយអត្ថ ឈ្មោះថាការមិននៅប្រាសចាកសតិ ព្រោះពាក្យថា ការមិនប្រមាទនោះ ជាឈ្មោះរបស់សតិដែលតាំងមាំជានិច្ច ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អមតំ បទំ** *ព្រះនិព្វាន ព្រះមានព្រះភាគត្រាស់ហៅថា* **អមត** *ព្រោះព្រះនិព្វាននោះ ឈ្មោះថា មិនចាស់ មិនស្លាប់ ព្រោះជាធម្មជាតមិនកើត ហេតុនោះ ទើបទ្រង់ត្រាស់ហៅព្រះនិព្វានថា អមតៈ សត្វទាំងឡាយរមែងដល់ អធិប្បាយថា រមែងសម្រេចអមតៈ ដោយការមិនប្រមាទនេះ ហេតុនោះ ទើបការមិនប្រមាទនេះ ឈ្មោះថា ជាគ្រឿងដល់ លោកអធិប្បាយថា ជាឧបាយគ្រឿងសម្រេចអមតៈ ទើបឈ្មោះថា* **អមតំ បទំ** ។

ការៈ គឺការស្រេវឹង ឈ្មោះថា ការប្រមាទ ។ ពាក្យថា ការប្រមាទនោះ ជាឈ្មោះរបស់ការបណ្តែតបណ្តោយសតិ ពោល គឺការមិនមានស្មារតី ។

បទថា **មច្ចុនោ** *ប្រែថា នៃសេចក្តីស្លាប់ ។ បទថា* **បទំ** *គឺជាឧបាយ

បានដល់ ជាផ្លូវ ។ ពិតហើយ ជនដែលប្រមាទហើយ រមែងមិនប្រព្រឹត្តទៅកន្លងនូវជាតិបាន សូម្បីកើតហើយ ក៏រមែងចាស់ រមែងស្លាប់ ហេតុនោះ ទើបការប្រមាទ ឈ្មោះថា ជាផ្លូវនៃមច្ចុ គឺរមែងនាំចូលរកសេចក្តីស្លាប់ ។

បាទព្រះគាថាថា **អប្បមត្តា ន មីយន្តិ** *សេចក្តីថា បុគ្គលប្រកបដោយសតិ ឈ្មោះថា បុគ្គលមិនប្រមាទហើយ ។ បុគ្គលណាម្នាក់មិនគប្បីកំណត់ថា បុគ្គលមិនប្រមាទហើយរមែងមិនស្លាប់ គឺជាបុគ្គលមិនចាស់ មិនស្លាប់ ដូច្នេះ ព្រោះថា សត្វណាមួយ ឈ្មោះថា មិនចាស់ និងមិនស្លាប់ រមែងមិនមាន ។ តែឈ្មោះថាវដ្តៈរបស់សត្វដែលប្រមាទហើយ កំណត់មិនបាន វដ្តៈរបស់បុគ្គលមិនប្រមាទកំណត់បាន ហេតុនោះ សត្វដែលប្រមាទហើយ ទោះរស់នៅ ក៏ឈ្មោះថា ស្លាប់ហើយដោយពិត ព្រោះភាពជាបុគ្គលមិនផុតចាកទុក្ខ មានជាតិជាដើម ចំណែកបុគ្គលមិនប្រមាទ ចម្រើនអប្បមាទលក្ខណៈហើយ ធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផលដោយឆាប់រួសរាន់ រមែងមិនកើតក្នុងអត្តភាពទី ២ និងទី ៣ ហេតុនោះ សត្វមិនប្រមាទទាំងនោះ រស់នៅក្តី ស្លាប់ហើយក្តី ឈ្មោះថា មិនស្លាប់ដោយពិត ។*

បាទព្រះគាថាថា **យេ បមត្តា យថា មតា** *សេចក្តីថា ចំណែកសត្វឯណាប្រមាទហើយ សត្វទាំងនោះរមែងដូចសត្វដែលស្លាប់ហើយ ដោយការផ្តាច់ជីវិតិន្ទ្រិយ មានវិញ្ញាណទៅប្រាសហើយ ដូចគ្នានឹងអង្គតំឧសដូច្នោះឯង ព្រោះភាពដែលមនុស្សស្លាប់ហើយ ដោយសេចក្តីស្លាប់ គឺការប្រមាទ មែនពិត ចិត្តមួយដួងដែលកើតឡើងថា អញនឹងឲ្យទាន អញនឹងរក្សាសីល អញនឹង*

ធ្វើឧបោសថកម្មដូច្នេះ រមែងមិនកើតទៀងដល់បុគ្គលទាំងឡាយដែលជាគ្រហស្ថ ចិត្តមួយដួងដែលកើតទៀងថា អញនឹងបំពេញវត្តទាំងឡាយ មានអាចរិយវត្ត និងឧបជ្ឈាយវត្តជាដើម អញនឹងសមាទានធុតង្គ ចម្រើនភាវនាដូច្នេះ រមែងមិនកើតទៀងដល់សត្វទាំងនោះ សូម្បីជាបព្វជិត ដូចចិត្តមួយដួងមិនកើតទៀងដល់សត្វដែលស្លាប់ហើយដូច្នោះ សត្វដែលប្រមាទហើយនោះ ទោះរស់ បុគ្គលមានអ្វីជាគ្រឿងធ្វើឲ្យផ្សេងអំពីសត្វ ដែលស្លាប់ហើយនោះ ព្រោះដូច្នោះ ក៏ដូចជាបុគ្គលដែលស្លាប់ហើយ ។

បាទព្រះគាថាថា **ឯតំ វិសេសតោ ញត្វា** *សេចក្តីថា ដឹងសេចក្តីនោះដោយប្លែកគ្នាថា ការស្ទុះចេញចាកវដ្តៈរបស់បុគ្គលដែលប្រមាទហើយ រមែងមិនមាន របស់បុគ្គលមិនប្រមាទហើយ មាន ។*

មានបុច្ឆាថា បុគ្គលណារមែងដឹងសេចក្តីប្លែកគ្នានោះ មានវិសជ្ជនាថា បណ្ឌិតទាំងឡាយ តាំងនៅក្នុងសេចក្តីមិនប្រមាទ រមែងដឹង អធិប្បាយថា បណ្ឌិត គឺបុគ្គលដែលមានមេធា បានដល់ជាអ្នកមានប្រាជ្ញាពួកណា តាំងនៅក្នុងការមិនប្រមាទរបស់ខ្លួនហើយ ចម្រើនទូវការមិនប្រមាទ បណ្ឌិតទាំងនោះ រមែងដឹងហេតុដែលប្លែកគ្នានោះ ។

បាទព្រះគាថាថា **អប្បមាទេ បមោទន្តិ** *សេចក្តីថា បណ្ឌិតទាំងនោះ កាលដឹងយ៉ាងនេះហើយ រមែងត្រេកអរ គឺជាអ្នកមានមុខញញឹមញញែម បានដល់ ត្រេកអរីករាយក្នុងការមិនប្រមាទរបស់ខ្លួននោះ ។*

បាទព្រះគាថាថា **អរិយានំ គោចរេ រតា** *សេចក្តីថា បណ្ឌិតទាំងនោះ*

ត្រេកអរក្នុងការមិនប្រមាទយ៉ាងនោះ ចម្រើននូវការមិនប្រមាទនោះហើយ រមែងជាអ្នកត្រេកអរ គឺត្រេកអរក្នុងពោធិបក្ខិយធម៌ ៣៧ ចែកចេញជាសតិប្បដ្ឋាន ៤ ជាដើម និងក្នុងលោកុត្តរធម៌ ៩ ប្រការ ដែលរាប់ថា ធម៌ជាគ្រឿងគោចរបស់ព្រះអរិយៈទាំងឡាយ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវ័ករបស់ព្រះពុទ្ធទាំងឡាយ ។

ពីរបទថា **តេ ឈាយិនោ** *សេចក្តីថា បណ្ឌិតជាអ្នកមិនប្រមាទទាំងនោះ ជាបុគ្គលមានការសម្ងំដោយឈានទាំង ២ យ៉ាង គឺដោយអារម្មណូបនិជ្ឈាន ពោល គឺសមាបត្តិ ៨ និងដោយលក្ខណូបនិជ្ឈាន ពោល គឺវិបស្សនាមគ្គ និងផល ។*

បទថា **សាតតិកា** *សេចក្តីថា ជាបុគ្គលមានសេចក្តីព្យាយាម ដែលប្រព្រឹត្តទៅដោយកាយ និងចិត្ត ប្រព្រឹត្តទៅហើយជាប់ត ចាប់តាំងអំពីកាលដែលចេញបួស រហូតដល់សម្រេចអរហត្ត ។*

ជាទព្រះគាថាថា **និច្ចំ ធន្តុបរក្កមា** *សេចក្តីថា បុគ្គលប្រកបដោយសេចក្តីព្យាយាមបែបនេះថា គុណជាតណា ដែលបុគ្គលគប្បីដល់ ដោយកម្លាំងរបស់បុរស ដោយសេចក្តីព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស បើមិនទាន់ដល់នូវគុណជាតនោះទេ នឹងមិនបញ្ឈប់នូវសេចក្តីព្យាយាមរបស់បុរសឡើយ ។ ដូច្នេះ ឈ្មោះថា ព្យាយាម ឈ្មោះថា ប្រព្រឹត្តទៅហើយជានិច្ច ព្រោះមិនរួញរាក្នុងចន្លោះ ។*

ក្នុងពាក្យថា **ផុសន្តិ** *នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ការពាល់*

ត្រូវមាន ២ គឺញាណផុសនា គឺការពាល់ត្រូវដោយបញ្ញា ១ វិបាកផុសនា គឺការពាល់ត្រូវដោយវិបាក ១ ។ ក្នុងផុសនា ២ យ៉ាងនោះ មគ្គ ៤ ឈ្មោះថា **ញាណផុសនា** *ផល ៤ ឈ្មោះថា* **វិបាកផុសនា** *។ ក្នុងផុសនា ២ យ៉ាងនោះ វិបាកផុសនា ព្រះមានព្រះភាគទ្រង់បំណងយកក្នុងបទថា* **ផុសន្តិ** *នេះ ។ បណ្ឌិតដែលជាអ្នកប្រាជ្ញ កាលធ្វើនិព្វានឲ្យជាក់ច្បាស់ដោយអរិយផល ឈ្មោះថា រមែងធ្វើនិព្វានឲ្យជាក់ច្បាស់ដោយវិបាកផុសនា ។*

បាទព្រះគាថាថា **យោគក្ខេមំ អនុត្តរំ** *សេចក្តីថា នូវព្រះនិព្វាន ដែលជាដែនក្សេម គឺមិនមានភ័យអំពីយោគៈ ៤ ដែលញុំាងមហាជនឲ្យលិចចុះក្នុងវដ្តៈ ឈ្មោះថា ជាកំពូល ព្រោះជាវត្ថុដែលប្រសើរជាងលោកិយធម៌ និងលោកុត្តរធម៌ទាំងពួង ។*

ក្នុងទីបំផុតនៃទេសនា ជនជាច្រើនបានជាព្រះអរិយបុគ្គល មានសោតាបន្នជាដើម ទេសនាជាកថាមានប្រយោជន៍ដល់មហាជន ដូច្នេះ ៗ

រឿងព្រះនាងសាមាវតី ចប់

រឿង កុម្ភយោសកៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះ កុម្ភ-យោសកៈ ត្រាស់ព្រះធម្មទេសនានេះថា **ឧដ្ឋានវតោ** ជាដើម ។

សេចក្តីពិស្តារថា ក្នុងនគររាជគ្រឹះ អហិវាតករោគកើតឡើងក្នុងផ្ទះរបស់រាជគហសេដ្ឋី កាលអហិវាតករោគនោះកើតឡើងហើយ សត្វតិរច្ឆាន ចាប់តាំងអំពីរុយរហូតដល់គោ រមែងស្លាប់មុន បន្ទាប់អំពីនោះមក ក៏ស្លាប់ទាសៈ និងកម្មករ ខាងក្រោយបង្អស់ ទើបស្លាប់ម្ចាស់ផ្ទះ ព្រោះដូច្នេះ ទើបរោគនោះកើតលើលោកសេដ្ឋី និងភរិយាក្រោយគេបង្អស់ ។ ស្វាមីភរិយានោះ រោគពាល់ត្រូវហើយ សម្លឹងមើលបុត្រដែលឈរក្នុងទីមិនឆ្ងាយ នេត្រាទាំងគូជាមដោយទឹកភ្នែក និយាយនឹងកូនថា នែបា បានឮថា កាលរោគប្រភេទនេះកើតឡើង ជនទាំងឡាយទម្លាយជញ្ជាំងផ្ទះគេចទៅ រមែងរួចផុតជីវិត ខ្លួនបាកុំបីជាប់ជំពាក់ក្នុងយើងទាំងពីរឡើយ គប្បីគេចទៅ បើមានជីវិត សឹមត្រឡប់មកវិញ គប្បីជីកយកទ្រព្យ ៤០ កោដិ ដែលយើងទាំងពីរកប់ក្នុងទីឈ្មោះនោះ ចិញ្ចឹមជីវិតចុះ ។

កុមារស្តាប់ពាក្យរបស់មាតា និងបិតានោះហើយ ទ្រហោយំ ថ្វាយបង្គំមាតាបិតា ខ្វាចចំពោះភ័យ គឺសេចក្តីស្លាប់ ទម្លាយជញ្ជាំងគេចទៅកាន់ព្រៃស្មុកនៃភ្នំ នៅក្នុងទីនោះអស់ ១២ ឆ្នាំ ទើបត្រឡប់មកកាន់លំនៅរបស់មាតាបិតា ។

គ្រានោះ បុគ្គលណាម្នាក់ក៏មិនស្គាល់គេ ព្រោះកាលទៅ នៅជាកុមារ

ត្រឡប់មកក្នុងកាលមានសក់ និងពុកមាត់ពុកចង្កាស្រមូម ។

បុរសនោះទៅកាន់ទីកប់ទ្រព្យដោយអំណាចនៃសញ្ញា ដែលមាតា និងបិតាទុកឲ្យ ដឹងថាទ្រព្យមិនវិនាសទើបគិតថា បុគ្គលណាម្នាក់ចាំអាត្មាអញមិនបាន បើអញជីកទ្រព្យប្រើប្រាស់សោត ជនទាំងឡាយគប្បីគិតថា បុគ្គលក្រីក្រម្នាក់ជីកទ្រព្យខ្លីងហើយ គប្បីចាប់អញ បៀតបៀន បើដូច្នោះ អញគប្បីធ្វើការស៊ីឈ្នួល រស់នៅក្នុងទីនេះ ។ គាត់ស្លៀកសំពត់ចាស់មួយផ្ទាំង ដើរសួរថា មានអ្នកណាត្រូវការ ដោយអ្នកស៊ីឈ្នួលដែរឬទេ ទៅដល់វិថីដែលជាលំនៅរបស់បុគ្គលម្នាក់ស៊ីឈ្នួលហើយ ។

ខណៈនោះ ពួកចៅកែឃើញគាត់ហើយពោលថា បើអ្នកធ្វើការងាររបស់ពួកយើងបានត្រឹមតែមួយសោត ពួកយើងនឹងឲ្យថ្លៃឈ្នួលសម្រាប់ទិញភត្ត ។ បុរសនោះសួរថា ឈ្មោះថា ការងារអ្វីដែលពួកអ្នកនឹងធ្វើ ពួកចៅកែឆ្លើយថា ការងារ គឺការក្រោក និងការជាស់តឿន បើអ្នកអាចធ្វើបានសោត ចូរក្រោកខ្លីងអំពីព្រលឹម ដើរប្រាប់ថា នែអ្នកទាំងឡាយ អ្នកទាំងឡាយ ចូរក្រោកខ្លីង ចូរត្រៀមរទេះទាំងឡាយ ចូរទឹមគោក្នុងពេលដែលសត្វពាហនៈផ្សេងៗ មានដំរី និងសេះជាដើម ទៅដើម្បីស៊ីស្មៅ នែនាងទាំងឡាយ ពួកនាង ចូរក្រោកខ្លីង ដាំបបរ ដាំបាយ គាត់ទទួលថា បាន ។

លំដាប់នោះ ពួកអ្នកជួលបានឲ្យផ្ទះមួយខ្នងដល់គេ ដើម្បីជាប្រយោជន៍ដល់ការនៅក្នុងទីជិត គេបានធ្វើការងារនោះរាល់ថ្ងៃ ។

ថ្ងៃមួយ ព្រះរាជាព្រះនាមពិម្ពិសារ បានស្តាប់សំឡេងរបស់គេហើយ ។

បានឮថា ព្រះរាជាទ្រង់ជ្រាបក្នុងសំឡេងរបស់សត្វទាំងពួង ព្រោះដូច្នោះ ទើបត្រាស់ថា នោះជាសំឡេងរបស់អ្នកមានទ្រព្យច្រើន ។

ខណៈនោះ នាងស្នំរបស់ព្រះរាជាម្នាក់ឈរក្នុងទីជិត គិតថា ព្រះរាជាមិនត្រាស់ពាក្យផ្តេសផ្តាស អញគួរស្គាល់បុរសនេះ ទើបបញ្ជូនបុរសម្នាក់ទៅសើបមើលដោយពាក្យថា នែបា ចូរបាទៅចុះ ចូរជ្រាបបុរសនោះហើយត្រឡប់មក ។

បុរសនោះរួតរះទៅ ជួបកុម្ភយោសកៈនោះហើយ ក៏ត្រឡប់មកជ្រាប់ថា នុ៎ះជាមនុស្សកំព្រាម្នាក់ ដែលធ្វើការស៊ីឈ្នួលរបស់ថៅកែទាំងឡាយ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យបុរសនោះហើយ ក៏ទ្រង់តុណ្ហីភាព ។ ក្នុងថ្ងៃទី ២ ក្តី ទី ៣ ក្តី កាលទ្រង់ស្តាប់សំឡេងរបស់កុម្ភយោសកៈនោះហើយ ក៏ត្រាស់យ៉ាងនោះដូចគ្នា ។

ស្រីស្នំនោះ ក៏គិតយ៉ាងនោះដូចគ្នា បញ្ជូនបុរសទៅច្រើនដង កាលបុរសនោះជ្រាប់ថា ជាមនុស្សកំព្រា ទើបគិតថា ព្រះរាជាទ្រង់ស្តាប់ពាក្យថា នុ៎ះជាមនុស្សកំព្រា ក៏ទ្រង់មិនជឿ នៅតែត្រាស់ថា នុ៎ះសំឡេងបុរសមានទ្រព្យច្រើន ក្នុងសេចក្តីនេះពិតជាមានហេតុ អញគួរតែស្គាល់បុរសនោះតាមសេចក្តីពិត ។ ស្នំនោះក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់កាលបានទ្រព្យ ១ ពាន់ និងនាំធីតាទៅ រកឧបាយឲ្យទ្រព្យនោះចូរកាន់រាជត្រកូលឲ្យបាន ។

ព្រះរាជាត្រាស់ឲ្យព្រះរាជទានទ្រព្យ ១ ពាន់ ដល់នាងហើយ ។ នាងទទួលទ្រព្យនោះហើយ បានឲ្យធីតាស្លៀកសំពត់ចាស់មួយផ្ទាំង ចេញអំពីព្រះ

រាជមន្ទីរ មួយអន្ទើដោយធីតានោះ ធ្វើហាក់ដូចជាអ្នកជំណើរ ទៅកាន់វិថី ដែលជាលំនៅថៅកែនោះ ចូលទៅកាន់ផ្ទះមួយខ្នងពោលថា បពិត្រអ្នកស្រី ខ្ញុំ ទាំងពីរធ្វើដំណើរមកហត់នឿយ សូមសម្រាកក្នុងផ្ទះនេះ ត្រឹមតែពីរថ្ងៃហើយ នឹងទៅ ។

ស្រីម្ចាស់ផ្ទះពោលថា នែនាង មនុស្សក្នុងផ្ទះមានច្រើន នាងមិនអាច ស្នាក់នៅក្នុងផ្ទះនេះបានទេ ផ្ទះរបស់កុម្ភយោសក:នោះទំនេរ សូមនាងទៅក្នុង ផ្ទះនោះចុះ នាងទៅត្រង់ផ្ទះកុម្ភយោសក:នោះហើយពោលថា នែអ្នក ខ្ញុំទាំងពីរ ជាអ្នកដំណើរ សូមសម្រាកក្នុងផ្ទះនេះត្រឹមតែពីរថ្ងៃ ។ ទោះត្រូវបុរសនោះ ហាមហើយច្រើនដង ក៏ពោលអង្វរថា នែអ្នក ខ្ញុំទាំងពីរនឹងសូមសម្រាកត្រឹម តែមួយថ្ងៃ លុះព្រលឹមក៏នឹងចេញទៅ ។ មិនប្រាថ្នានឹងចេញទៅហើយ ។ នាង សម្រាកនៅក្នុងផ្ទះរបស់កុម្ភយោសក:នោះឯង ស្អែកឡើងក្នុងវេលានឹងចូល ព្រៃ ទើបពោលថា នែអ្នក សូមអ្នកប្រគល់តម្លៃអាហារសម្រាប់អ្នកទុក ហើយ សឹមទៅ ខ្ញុំនឹងចាត់ចែងជាំស្ងួកដើម្បីអ្នក កាលបុរសនោះពោលថា កុំឡើយ ខ្ញុំជាំខ្លួនឯងក៏បាន ទើបអង្វរវឿយៗ រហូតសម្រេច ធ្វើទ្រព្យដែលគេឲ្យ ឲ្យហាក់ ដូចជាខ្លួនបានទទួលហើយនោះឯង នាំភោជន និងវត្ថុផ្សេងៗ មានអង្ករដែល បរិសុទ្ធជាដើម មកអំពីផ្សារជាំឲ្យទន់ល្អ និងធ្វើម្ហូបពីរបីមុខដែលមានរសឆ្ងាញ់ ដូចចម្អិនក្នុងរាជត្រកូល ឲ្យដល់កុម្ភយោសក:ដែលមកអំពីព្រៃ កាលដឹងថា បុរសនោះបរិភោគហើយ ដល់នូវភាពជាអ្នកមានចិត្តត្រេកអរ ទើបពោលថា នែអ្នក ខ្ញុំទាំងពីរជាអ្នកហត់នឿយ សូមសម្រាកក្នុងផ្ទះនេះឯងត្រឹមពីរថ្ងៃចុះ

បុរសនោះទទួលថា បាន ។

ពេលនោះ នាងក៏ចម្អិនភត្តយ៉ាងឆ្ងាញ់ទាំងពេលល្ងាច និងពេលព្រឹក ហើយឲ្យដល់កុម្ភយោសកៈ ។ កាលជ្រាបភាពដែលបុរសនោះ ជាអ្នកមានចិត្តត្រេកអរហើយ ក៏អង្វរថា នែអ្នក ខ្ញុំទាំងពីរសុំនៅផ្ទះត្រឹមពីរបីថ្ងៃ ដូច្នេះហើយនៅក្នុងផ្ទះនោះ យកសស្ត្រាដ៏មុត កាត់ជើងត្រៃរបស់បុរសនោះខាងក្រោម មេត្រៃក្នុងទីនោះៗ ។ កាលបុរសនោះមក គ្រាន់តែអង្គុយប៉ុណ្ណោះ ត្រៃក៏បាក់ ធ្លាក់ទៅខាងក្រោម បុរសនោះពោលថា ហេតុអ្វីត្រៃនេះបាក់ទៅយ៉ាងនេះ ស្រីស្នំពោលថា ឱអ្នក ខ្ញុំមិនអាចហាមពួកក្មេងកំលោះៗ បាន ពួកគេមកប្រជុំគ្នា លេងក្នុងទីនេះ ។ កុម្ភយោសកៈពោលថា ព្រោះអាស្រ័យបុគ្គលពីរនាក់ ទើបទុក្ខនេះកើតដល់ខ្ញុំ ក្នុងកាលមុនខ្ញុំទៅក្នុងទីណាៗ ក៏បិទទ្វារហើយទៅ ។ ស្រីស្នំពោលថា តើយើងនឹងធ្វើដូចម្តេចបាន នែអ្នក ខ្ញុំមិនអាចឃាត់បាន ។

នាងកាត់ជើងត្រៃដោយទំនងនេះឯង អស់ ២-៣ ថ្ងៃ សូម្បីត្រៃបុរសនោះតិះដៀលស្តីថា ក៏នៅតែពោលដោះស្រាយយ៉ាងនោះហើយ កាត់ខ្សែដែលសល់ ខ្សែតូចៗ ២-៣ សរសៃ ។

ថ្ងៃនោះ កាលគាត់អង្គុយចុះប៉ុណ្ណោះ ត្រៃទាំងអស់ក៏បាក់ធ្លាក់ចុះត្រង់ផែនដី ក្បាលរបស់គាត់ទង្គិច មួយអន្ទើនឹងក្បាលជង្គង់ទាំងពីរ គាត់ក្រោកឡើង ក៏បានពោលថា ខ្ញុំនឹងធ្វើអ្វីបាន ឥឡូវនេះ នឹងទៅណាបាន ខ្ញុំជាបុគ្គលត្រូវពួកនាងធ្វើមិនឲ្យជាម្ចាស់របស់ត្រៃដេកនេះ ។

ស្រីស្នំលួងលោមថា ធ្វើដូចម្តេចហ្ន៎ បើខ្ញុំមិនអាចហាមក្មេងៗ ដែលស្និទ្ធស្នាលបាន ណ្ហើយចុះ កុំខ្វល់ឡើយ អ្នកកុំទៅណាក្នុងពេលនេះ ដូច្នេះហើយ ហៅធីតាប្រាប់ថា នែនាង នាងចូរធ្វើឱកាសសម្រាប់ជាទីដេករបស់បងប្រុសនាង ។

ធីតានោះដេកម្នាងហើយពោលថា នែអ្នក សូមមកដេកទីនេះ សូម្បីនាងស្នំក៏ពោលនឹងកុម្ភយោសក:នោះថា សូមអ្នកទៅដេកជាមួយប្អូនស្រីចុះ បុរសនោះដេកលើគ្រែជាមួយធីតាស្រីស្នំនោះ បានធ្វើការជិតស្និទ្ធគ្នាក្នុងថ្ងៃនោះឯង ។

នាងកុមារិកាយំហើយ ពេលនោះ ទើបមាតាសួរថា នាងយំធ្វើអ្វី ធីតាពោលថា កម្មឈ្មោះនេះកើតឡើងហើយ មាតាពោលថា ណ្ហើយចុះ យើងអាចធ្វើអ្វីបាន បើនាងមានប្តីម្នាក់ក៏ល្អ កុម្ភយោសក:នេះបានបាទបរិចារិកាម្នាក់ក៏ល្អ រមែងសមគួរ ដូច្នេះហើយ បានធ្វើកុម្ភយោសក:នោះឲ្យជាកូនប្រសាជនទាំងពីរនាក់នៅរួមគ្នាហើយ ។

ក្នុងកាលកន្លងទៅ ២-៣ ថ្ងៃ ស្រីស្នំនោះក៏បញ្ជូនដំណឹងដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព សូមទ្រង់បញ្ជាឲ្យធ្វើការឃោសនាថា សូមពួកប្រជានុរាស្ត្រ ធ្វើមហោស្រព ក្នុងវិថីនៃជនស៊ីឈ្នួល ជនណាមិនធ្វើមហោស្រពក្នុងផ្ទះ ពិន័យប្រមាណប៉ុណ្ណោះ រមែងមានដល់បុគ្គលនោះ ។

ព្រះរាជាត្រាស់ឲ្យធ្វើយ៉ាងនោះ ។ គ្រានោះ ម្តាយក្មេកពោលនឹងកុម្ភ-យោសក:ថា នែបា យើងត្រូវធ្វើមហោស្រពក្នុងវិថីនៃអ្នកស៊ីឈ្នួល តាមព្រះរាជានត្តិ តើយើងនឹងធ្វើដូចម្តេច ។

កុម្ភយោសកៈពោលថា អ្នកម៉ែ ខ្ញុំធ្វើការស៊ីឈ្នួលស្ទើរតែមិនអាចរស់បាន និងធ្វើមហោស្រពបានដូចម្តេច ម្តាយក្មេកពោលថា នែបា ធម្មតាបុគ្គលដែលនៅគ្រប់គ្រងផ្ទះទាំងឡាយ រមែងទទួលយកបំណុល ព្រះករុណាជីវិតតម្កល់លើត្បូងទ្រង់បញ្ជា មិនធ្វើមិនបាន យើងអាចផុតចាកពិន័យបានដោយឧបាយណាមួយ នែបា ចូរបានាំ ១ កហាបណៈ ឬ ២ កហាបណៈ អំពីទីណាក៏បាន ។

កុម្ភយោសកៈត្រិះរិះបណ្តើរ ទៅនាំកហាបណៈមួយកហាបណៈ អំពីទីកប់ទ្រព្យ ៤០ កោដិ នាងក៏បញ្ជូនកហាបណៈទៅ ថ្វាយដល់ព្រះរាជាហើយធ្វើមហោស្រពដោយកហាបណៈរបស់ខ្លួន ក្នុងកាលកន្លងទៅ ២-៣ ថ្ងៃ ក៏បញ្ជូនដំណឹងយ៉ាងនោះទៀត ។

ព្រះរាជាទ្រង់បញ្ជាទៀតថា ប្រជានុរាស្ត្រចូរធ្វើមហោស្រព កាលបុគ្គលណាមិនធ្វើ នឹងពិន័យទ្រព្យមានប្រមាណប៉ុណ្ណោះ ។ កុម្ភយោសកៈនោះ ត្រូវម្តាយក្មេករំអុកដូចមុននោះឯង ទើបទៅនាំកហាបណៈមួយកហាបណៈមកទៀត នាងក៏បញ្ជូនកហាបណៈនោះទៅថ្វាយដល់ព្រះរាជា ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ក៏បញ្ជូនទៅថ្វាយទៀតថា ឥឡូវនេះ សូមទ្រង់បញ្ជូនបុរសមក ឲ្យហៅកុម្ភយោសកៈនេះទៅ ។ ព្រះរាជាទ្រង់បញ្ជូនបុរសទៅហើយ ។

ពួកបុរសទៅកាន់វិថីដែលអ្នកស៊ីឈ្នួលនោះនៅហើយ សួរថា អ្នកណាឈ្មោះកុម្ភយោសកៈ ដើរតាមរកក៏ជួប ប្រាប់ថា នែអ្នក ចូរមកចុះ ព្រះរាជាត្រាស់ឲ្យហៅអ្នក ។

កុម្ភយោសក:ខ្លាចហើយ ពោលពាក្យដោះខ្លួនថា ព្រះរាជាទ្រង់មិនស្គាល់ខ្ញុំទេ ហើយមិនជ្រាបថានឹងទៅ ។ ពេលនោះ ទើបពួកបុរសចាប់ត្រង់អវយវ:ទាំងឡាយ មានដៃជាដើម ទាញមកដោយកម្លាំង ។

ស្រីនោះឃើញបុរសទាំងនោះហើយ ទើបធ្វើជាសម្តែងថា អើ អ្នកក្បាលរឹង ពួកអ្នកមិនសមគួរចាប់កូនប្រសារបស់ខ្ញុំ ត្រង់អវយវ:ទាំងឡាយ មានដៃជាដើម ហើយលួងលោមថា នែបា សូមបាកុំខ្លាចឡើយ ខ្ញុំគាល់ព្រះរាជាហើយ នឹងទូលឲ្យកាត់ដៃរបស់អ្នកដែលចាប់អវយវ:ជាដើម របស់កូននោះឯង ហើយនាំកូនស្រីទៅមុន ដល់ព្រះរាជមន្ទីរហើយ ប្តូរកេទ តែងគ្រឿងអលង្ការសព្វយ៉ាង បាននឃរគាល់ក្នុងចំណែកម្ខាង ចំណែកកុម្ភយោសក:ត្រូវគេអូសនាំមករហូតបាន ។

ខណៈនោះ ព្រះរាជាត្រាស់នឹងកុម្ភយោសក:នោះ ដែលថ្វាយបង្គំហើយឈរគាល់ថា អ្នកឬឈ្មោះកុម្ភយោសក: កុម្ភយោសក:ពោលថា បពិត្រព្រះសម្មតិទេព ពិតហើយ ព្រះអង្គ ។ ព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី ទើបអ្នកបិទបាំងទ្រព្យជាច្រើនប្រើប្រាស់ កុម្ភយោសក:ពោលថា ទ្រព្យរបស់ខ្ញុំព្រះអង្គមានអំពីណា ខ្ញុំព្រះអង្គស៊ីឈ្នួលគេចិញ្ចឹមជីវិត ព្រះរាជាត្រាស់ថា បើយ៉ាងនោះ កុំធ្វើយ៉ាងនោះ អ្នកចោកបញ្ឆោតយើងធ្វើអ្វី កុម្ភយោសក:ពោលថា ខ្ញុំព្រះអង្គ មិនចោកបញ្ឆោតទេ ទ្រព្យរបស់ខ្ញុំព្រះអង្គ មិនមាន ។

ពេលនោះ ព្រះរាជាទ្រង់បង្ហាញកហាបណៈទាំងនោះ ដល់កុម្ភយោសក:ហើយត្រាស់ថា កហាបណៈទាំងនេះជារបស់អ្នកណា ។ កុម្ភយោសក:ចាំ

កហាបណៈបានគិតថា អញវិនាសហើយ ហេតុអ្វីហ្ន៎ទើបកហាបណៈទាំងនេះ ធ្លាក់ដល់ដៃរបស់ព្រះរាជា ក្រឡេកមើលឆ្វេងស្តាំ ក៏ឃើញស្រីទាំងពីរនោះ ប្រដាប់គ្រឿងអលង្ការ ឈរគាល់ត្រង់មាត់ទ្វារបន្ទប់ ទើបគិតថា កម្មនេះសំខាន់ណាស់ ប្រហែលព្រះរាជាក្លែងស្រីទាំងនេះ ទៅបញ្ឆោតពិតប្រាកដ ។

ខណៈនោះ ព្រះរាជាត្រាស់ថា និយាយចុះអ្នក ហេតុអ្វី ទើបអ្នកធ្វើយ៉ាងនោះ កុម្ភយោសកៈពោលថា ព្រោះទីពឹងរបស់ទូលបង្គំមិនមាន ព្រះរាជាត្រាស់ថា មនុស្សដូចយើងមិនគួរជាទីពឹងរបស់អ្នកឬ កុម្ភយោសកៈពោលថា បពិត្រព្រះសម្មតិទេព បើទ្រង់ជាទីពឹងរបស់ខ្ញុំព្រះអង្គ ក៏ជាការសមគួរ ។ ព្រះរាជាត្រាស់ថា បាន ទ្រព្យរបស់អ្នកមានប៉ុនណា កុម្ភយោសកៈពោលថា បពិត្រព្រះអង្គ មាន ៤០ កោដិ ព្រះរាជាត្រាស់ថា បានអ្វីជាបញ្ជូនទើបគួរ កុម្ភយោសកៈ ពោលថា បពិត្រព្រះអង្គ រនេះច្រើនគ្រឿង ។

ព្រះរាជាបញ្ជាឲ្យរៀបចំរនេះច្រើនរយបញ្ជូនទៅ ឲ្យជញ្ជូនទ្រព្យនោះមក ធ្វើជាគំនរទុកត្រង់លានព្រះរាជវាំងហើយ បញ្ជាឲ្យអ្នកក្រុងរាគ្រីះមកប្រជុំគ្នាហើយ ត្រាស់សួរថា ក្នុងនគរនេះអ្នកណាមានទ្រព្យប្រមាណប៉ុណ្ណេះខ្លះ កាលប្រជានុរាស្ត្រក្រាបទូលថា មិនមានទេព្រះអង្គ ក៏ត្រាស់សួរថា យើងគប្បីធ្វើអ្វីដល់គេទើបគួរ កាលជនទាំងនោះក្រាបទូលថា ទ្រង់ធ្វើការលើកតម្កើងដល់គេទើបគួរ ។ ទើបទ្រង់តាំងកុម្ភយោសកៈនោះក្នុងតំណែងសេដ្ឋី ដោយសក្ការៈដ៏ច្រើន ព្រះរាជទានបុត្រីរបស់ស្រីនោះ ដល់កុម្ភយោសកៈហើយ យាងទៅកាន់សម្នាក់ព្រះសាស្តាជាមួយកុម្ភយោសកៈ ថ្វាយបង្គំហើយ ក្រាបទូលថា

បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទតបុរសនេះ ឈ្មោះថាបុគ្គលមានបញ្ញាបែបនេះមិនមាន បុរសនេះមានសម្បត្តិ ៤០ កោដិ ក៏មិនធ្វើការលើកតម្កើង ឬអាការត្រឹមតែតម្កើងខ្លួន ធ្វើដូចមនុស្សកំព្រា ស្បៃកសំពត់ចាស់ៗ ធ្វើការស៊ីឈ្នួលត្រង់វិថីរបស់អ្នកស៊ីឈ្នួល ចិញ្ចឹមជីវិត ខ្ញុំព្រះអង្គដឹងបានដោយឧបាយឈ្មោះនេះ ។ កាលដឹងហើយ ឲ្យហៅមកដេញដោលឲ្យទទួលថា មានទ្រព្យហើយ ឲ្យជញ្ជូនទ្រព្យនោះមក តែងតាំងក្នុងតំណែងសេដ្ឋី មិនតែប៉ុណ្ណោះ ខ្ញុំព្រះអង្គឲ្យបុត្រីដល់គេទៀតផង បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលមានបញ្ញាបែបនេះ ខ្ញុំព្រះអង្គមិនធ្លាប់ឃើញទេ្បីយ ។

ព្រះសាស្តាស្តាប់រឿងនោះហើយ ត្រាស់ថា បពិត្រមហារាជ ជីវិតរបស់បុគ្គលដែលរស់នៅយ៉ាងនោះ ឈ្មោះថា រស់នៅប្រកបដោយធម៌ កម្មមានចោរកម្មជាដើម រមែងបៀតបៀនអ្នកធ្វើក្នុងលោកនេះផង ក្នុងលោកខាងមុខផង ឈ្មោះថា សេចក្តីសុខ ដែលមានកម្មនោះជាហេតុក៏មិនមាន បុរសធ្វើការស៊ីឈ្នួលក្តី ធ្វើស្រែក្តី ចិញ្ចឹមជីវិតក្នុងកាលវិនាសទ្រព្យនោះឯង ឈ្មោះថា ជីវិតប្រកបដោយធម៌ ភាពជាធំរមែងចម្រើនទេ្បីងតែម្យ៉ាង ដល់បុគ្គលដែលដល់ព្រមដោយសេចក្តីព្យាយាម បរិបូណ៌ដោយសតិ មានការងារបរិសុទ្ធតាមទ្វារទាំងឡាយ មានកាយ និងវាចាជាដើម មានប្រក្រតីពិចារណាដោយបញ្ញាហើយ ទើបធ្វើ ជាអ្នកសង្រួមក្នុងទ្វារទាំងបី មានកាយទ្វារជាដើម ចិញ្ចឹមជីវិតដោយធម៌ តាំងនៅក្នុងការមិនប្រាសចាកសតិបែបនោះដូច្នេះហើយ ត្រាស់គាថានេះថា

ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ

សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ។

យសតែងចម្រើនកុះករដល់បុគ្គលអ្នកមានសេចក្តីប្រឹងប្រែង មានស្មារតី មានការងារស្អាត (ឥតទោស) ជាអ្នកពិចារណា រួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌ មិនមានសេចក្តីប្រមាទ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឧដ្ឋានវតោ** *គឺជាអ្នកមានសេចក្តីព្យាយាមជាហេតុក្រោកឡើង ។ បទថា* **សតីមតោ** *គឺសម្បុរដោយសតិ ។*

បទថា **សុចិកម្មស្ស** *គឺប្រកបដោយការងារទាំងឡាយ មានការងារតាមផ្លូវកាយជាដើម ដែលមិនមានទោស គឺមិនមានកំហុស ។*

បទថា **និសម្មការិនោ** *បានដល់ ពិចារណា គឺត្រិះរិះយ៉ាងនេះថា បើផលយ៉ាងនេះមាន អញនឹងធ្វើយ៉ាងនេះ ឬថា កាលការងារនេះ ដែលអញធ្វើហើយយ៉ាងនេះ ផលនេះនឹងមាន ដូច្នេះហើយ ធ្វើការងារទាំងពួង ដូចគ្រូពេទ្យពិនិត្យមើលហេតុហើយ ទើបព្យាបាល ដូច្នោះ ។*

បទថា **សញ្ញតស្ស** *បានដល់ សង្រួមហើយ គឺមិនមានចន្លោះដោយទ្វារទាំងឡាយ មានកាយទ្វារជាដើម ។*

បទថា **ធម្មជីវិនោ** *គឺបុគ្គលជាគ្រហស្ថ រៀរការកោងផ្សែងៗ មានកោងដោយជញ្ជីងជាដើម ចិញ្ចឹមជីវិតដោយការងារដ៏ប្រពៃទាំងឡាយ មានធ្វើស្រែនិងចិញ្ចឹមគោជាដើម បើជាបព្វជិត រៀរអនេសនាកម្មទាំងឡាយ មានវេជ្ជកម្ម*

និងទូតកម្មជាដើម ចិញ្ចឹមជីវិតដោយកិក្ខាចារដោយធម៌ គឺដោយប្រពៃ ។

បទថា **អប្បមត្តស្ស** គឺមានសតិមិនភ្លាយ ។ បទថា **យសោភិវឌ្ឍតិ** សេចក្តីថា យស បានដល់ ភាពជាធំ ការមានភោគសម្បត្តិ និងការរាប់អាន និងបានដល់កាលមានកិត្តិយស និងការពោលសរសើរ រមែងចម្រើន ។

ក្នុងកាលចប់ព្រះគាថា កុម្ភឃោសក:តាំងនៅក្នុងសោតាបត្តិផល ជនជទៃជាច្រើន សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ទេសនាសម្រេចជាប្រយោជន៍ដល់មហាជនយ៉ាងនេះឯង ៕

រឿង កុម្ភឃោសក: ចប់

រឿង ចូឡបន្ថកត្ថេរ

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះ ចូឡបន្ថក: ត្រាស់ធម្មទេសនានេះថា **ឧដ្ឋានេនប្បមាទេន** ជាដើម ។

បានឮមកថា ជីតានៃត្រកូលរបស់សេដ្ឋីក្នុងនគរពារាណសីនោះ ក្នុងកាលចម្រើនវ័យ មាតាបិតារក្សាយ៉ាងតឹងរ៉ឹង ត្រង់ជាន់លើនៃប្រាសាទ ៧ ជាន់ តែងាជាស្រីឡេះឡោះក្នុងបុរស ព្រោះជាអ្នកស្រវឹងក្នុងភាពជាក្រមុំ ទើបធ្វើសន្តវៈជាមួយទាសៈរបស់ខ្លួនឯង ខ្ជាចក្រែងអ្នកជទៃដឹងកម្មរបស់ខ្លួន ទើបពោលយ៉ាងនេះថា យើងទាំងពីរមិនអាចនៅទីនេះបានទេ បើមាតាបិតារបស់ខ្ញុំដឹង ការវិនាសនេះ នឹងធ្វើឲ្យយើងជាប់ជាកំណាត់តូចធំ យើងនឹងទៅកាន់ទឹកដីជទៃ

ហើយរស់នៅ ។ ជនទាំងពីរនោះ កាន់យកទ្រព្យក្នុងផ្ទះដែលជាសារៈ ដែលគប្បីនាំទៅបានដោយដៃ ចេញទៅតាមទ្វារខាងជើងហើយ បបួលគ្នាថា យើងទាំងពីរត្រូវទៅនៅក្នុងទីណាមួយ ដែលជនដទៃមិនស្គាល់ ដូច្នេះហើយ ទាំងពីរនាក់ ក៏ធ្វើដំណើរទៅ ។

កាលជនទាំងពីរនៅក្នុងទីមួយកន្លែង នាងតាំងគភ៌ហើយ ព្រោះអាស្រ័យការនៅរួមគ្នា ។

នាងអាស្រ័យភាពដែលគភ៌ចាស់ ទើបប្រឹក្សានឹងប្តីនោះថា គភ៌របស់ខ្ញុំចាស់ហើយ ធម្មតាការប្រសូតបុត្រក្នុងទីឆ្ងាយអំពីពួកញាតិ រមែងជាហេតុនាំសេចក្តីទុក្ខមកឲ្យដល់យើងទាំងពីរ យើងទាំងពីរទៅកាន់ផ្ទះនៃត្រកូលចុះ ស្វាមីពោលពន្យារថា ថ្ងៃនេះសឹមទៅ ស្អែកនេះសឹមទៅចុះ ញុំាងថ្ងៃទាំងឡាយឲ្យកន្លងទៅហើយព្រោះខ្លាចថា បើយើងទៅទីនោះ ជីវិតរបស់យើងរមែងមិនមាន នាងគិតថា បុរសនេះល្ងង់ មិនអាចទៅព្រោះភាពដែលខ្លួនមានទោសច្រើន ធម្មតាឪពុកម្តាយ មានការឧបការៈដោយចំណែកមួយប៉ុណ្ណោះ បុរសនេះទៅក្តី មិនទៅក្តី អញនឹងទៅ ។ កាលនាងចេញអំពីផ្ទះទៅហើយ នាងទុកដាក់ផ្ទះសម្បែង ប្រាប់ភាពដែលខ្លួនទៅកាន់ត្រកូល ប្រាប់អ្នកភូមិផងរបងជាមួយហើយធ្វើដំណើរទៅ ។ ចំណែកស្វាមីត្រឡប់មកផ្ទះ មិនឃើញភរិយា សួរអ្នកស្និទ្ធស្នាល ដឹងថាទៅផ្ទះនៃត្រកូល ទើបប្រញាប់រត់តាមទៅទាន់ក្នុងវាងផ្លូវ ។ សូម្បីភរិយានោះ ក៏ប្រសូតបុត្រក្នុងវាងផ្លូវនោះឯង ។ បុរសនោះសួរថា នែនាង នេះជាអ្វី ភរិយាឆ្លើយថា កូនប្រុសម្នាក់ប្រសូតហើយ ។ ស្វាមីពោល

ថា ឥឡូវនេះ យើងនឹងធ្វើដូចម្តេច ។ ជនទាំងពីរគិតឃើញរួមគ្នាថា យើងទាំងពីរទៅកាន់ផ្ទះនៃត្រកូល ដើម្បីប្រយោជន៍ដល់កម្មណា កម្មនោះសម្រេចហើយ ក្នុងរវាងផ្លូវនោះឯង យើងនឹងទៅទីនោះធ្វើអ្វី នាំគ្នាត្រឡប់ចុះ ដូច្នេះហើយ ក៏នាំគ្នាត្រឡប់ ។

ជនទាំងពីរបានដាក់ឈ្មោះកូននោះថា បន្ថកៈ ព្រោះកើតក្នុងផ្លូវ ។ ចំណែរកាលមិនយូរប៉ុន្មាន នាងក៏មានគភ៌ទៀត ។ ព្រឹត្តិការណ៍ទាំងពួងគប្បីឲ្យពិស្តារដោយន័យមុននោះឯង ។

ព្រោះក្មេងនោះកើតក្នុងផ្លូវ ទើបមាតាបិតាដាក់ឈ្មោះបុត្រដែលកើតមុនថា មហាបន្ថកៈ តាំងឈ្មោះកូនដែលកើតក្រោយថា ចូឡបន្ថកៈ ។

ស្វាមីភរិយានោះ ក៏នាំក្មេងទាំងពីរទៅលំនៅរបស់ខ្លួនវិញ ។ កាលប្តីប្រពន្ធពីរនាក់នៅក្នុងទីនោះ កុមារមហាបន្ថកៈ បានឮក្មេងប្រុសដទៃៗ ហៅថា មា អំ និងហៅថា តា យាយ ទើបសួរម្តាយថា បពិត្រអ្នកម៉ែ កុមារដទៃ ហៅបុគ្គលនោះថា តា ហៅបុគ្គលនោះថា យាយ ពួកញាតិរបស់យើង មិនមានទេឬ ។

មាតាពោលថា អើបា ពួកញាតិរបស់យើងក្នុងទីនេះ មិនមានទេ តែតារបស់ពួកឯង ឈ្មោះធនសេដ្ឋីមាននៅក្នុងនគរពារាណសីគ្រឹះ ពួកញាតិរបស់យើងជាច្រើន មាននៅក្នុងនគរនោះ ។ មហាបន្ថកៈពោលថា ហេតុអ្វីទើបពួកយើងមិនទៅក្នុងទីនោះ ។ នាងប្រាប់ហេតុដែលខ្លួនមកដល់បុត្រ កាលបុត្រទាំងពីរពោលរំអុកពេក ទើបប្រាប់ដល់ប្តីថា កូនទាំងនេះរំអុកខ្ញុំពន់ពេក មាតាបិតា

ឃើញពួកយើងហើយ នឹងស៊ីសាច់ឬ មក ឥឡូវនេះ យើងទាំងពីរនឹងបង្ហាញ ត្រកូលតាយាយដល់កូនទាំងឡាយ ។ ស្វាមីពោលថា ខ្ញុំមិនអាចជួបមុខបាន តែអាចនាំពួកនាងទៅបាន ។ ភរិយាពោលថា សាធុ ក្មេងទាំងពីរគួរឃើញ ត្រកូលរបស់ជីតា ដោយឧបាយណាមួយពិត ។

ជនទាំងពីរនាំកុមារ ទៅដល់នគរវាជគ្រឹះដោយលំដាប់ ស្នាក់នៅត្រង់ សាលាមួយខ្នងក្បែរទ្វារនគរ ។ ម្តាយកុមារទាំងពីរ នាំក្មេងទាំងពីរទៅហើយ ប្រាប់ភាពដែលខ្លួនមកដល់មាតាបិតា ។

មាតាបិតាទាំងពីរនោះ បានឮដំណឹងនោះហើយពោលថា ធម្មតាជនទាំង ឡាយ ដែលនៅអនោលទៅក្នុងសង្សារ ឈ្មោះថា មិនធ្លាប់ជាកូនប្រុស មិន ធ្លាប់ជាកូនស្រីមិនមាន មនុស្សទាំងនោះធ្វើឧសចំពោះយើងដ៏ធំ ពួកគេមិន អាចតាំងនៅក្នុងគន្ធង់ចក្ខុរបស់យើងបានទេ ជនទាំងពីរចូរយកទ្រព្យប្រមាណ ប៉ុណ្ណោះទៅកាន់ទីផាសុកចិញ្ចឹមជីវិតចុះ តែចូរបញ្ជូនក្មេងទាំងពីរមកក្នុងទីនេះ ។

ស្វាមីភរិយានោះ ទទួលទ្រព្យដែលជនទាំងពីរនោះ បញ្ជូនមកហើយ ប្រគល់ជនទាំងពីរក្នុងដៃអ្នកបម្រើ ដែលមកហើយនោះឯង បញ្ជូនទៅហើយ ក្មេងទាំងពីរចម្រើនវ័យក្នុងត្រកូលរបស់តាយាយនោះឯង ។

ក្នុងកុមារទាំងពីរនោះ ចូឡបន្ថកៈនៅក្មេងពេក ។ ចំណែកមហាបន្ថកៈ ទៅស្តាប់ធម្មកថា របស់ព្រះទសពលជាមួយជីតា ។ កាលចូលទៅកាន់សម្នាក់ របស់ព្រះសាស្តាជានិច្ច ចិត្តក៏បង្អោនទៅហើយក្នុងបព្វជ្ជា ។ កុមារនិយាយនឹង ជីតាថា បើលោកតាអនុញ្ញាតខ្ញុំសោត ខ្ញុំគប្បីបួស ។

លោកសេដ្ឋីពោលថា បានិយាយអ្វី ការបួសរបស់ចៅជាការល្អដល់តាជាងការបួសរបស់មនុស្សទូទៅក្នុងលោក បើចៅអាចសោត ក៏ចូរបួសចុះដូច្នេះហើយ នាំទៅកាន់សម្នាក់ព្រះសាស្តា កាលទ្រង់ត្រាស់សួរថា ម្នាលគហបតី អ្នកមានកូនឬ ក៏ក្រាបទូលថា បពិត្រព្រះអង្គ កុមារនេះជាចៅរបស់ខ្ញុំព្រះអង្គ បំណងនឹងបួសក្នុងសម្នាក់របស់ព្រះអង្គ ។

ព្រះសាស្តា ត្រាស់បញ្ជាភិក្ខុដែលសមាទានបិណ្ឌបាតជាវត្តរបណាមួយថា អ្នកចូរឲ្យកុមារនេះបួស ។ ព្រះថេរៈប្រាប់តចបញ្ចកកម្មដ្ឋានដល់កុមារហើយឲ្យបព្វជ្ជា ។

លោករៀនព្រះពុទ្ធវចនៈបានច្រើន មានអាយុគ្រប់បានឧបសម្បទាហើយធ្វើកម្មក្នុងយោនិសោមនសិការ សម្រេចអរហត្តហើយ ។

លោកញុំាងកាលឲ្យកន្លងទៅ ដោយសុខក្នុងឈាន និងសុខដែលកើតអំពីផល គិតថា អញអាចឲ្យសុខនេះដល់ចូឡបន្ថកៈឬហ្ន៎ ខាងក្រោយបានទៅកាន់សម្នាក់របស់សេដ្ឋីជាជីតា ហើយពោលយ៉ាងនេះថា លោកមហាសេដ្ឋី បើអ្នកអនុញ្ញាតសោត អាត្មាគប្បីឲ្យចូឡបន្ថកៈបួស សេដ្ឋីពោលថា សូមលោកម្ចាស់ឲ្យគេបួសចុះ ។ បានឮថា សេដ្ឋីជ្រះថ្លាល្អហើយ ក្នុងព្រះសាសនា តែកាលត្រូវសួរថា កុមារនេះជាបុត្ររបស់ធីតាណារបស់អ្នក នឹងឆ្លើយថា របស់កូនស្រីដែលគេចទៅក៏ខ្មាស ព្រោះដូច្នោះ ទើបអនុញ្ញាតការបួសដល់ចៅទាំងពីរនោះ បានដោយងាយ ។

ព្រះថេរៈបានឲ្យចូឡបន្ថកៈបួសហើយ ឲ្យតាំងនៅក្នុងសីលទាំងឡាយ ។

សូម្បីចូឡបន្ថកៈនោះបួសហើយ បានជាបុគ្គលល្ងង់ខ្លៅ ។

ព្រះថេរៈកាលទូន្មាន ពោលគាថានេះថា

ផ្កាឈូកឈ្មោះកោកនុទៈ មានក្លិនក្រអូប រីកអំពីព្រឹក មានក្លិនមិនបានទៅជ្រាស យ៉ាងណាមិញ អ្នកចូរមើលព្រះដ៏មានព្រះភាគ មានរស្មីផ្សាយចេញពីព្រះអង្គដ៏រុងរឿង ដូចព្រះអាទិត្យ ដែលរុងរឿង ក្នុងកណ្តាលពពក ក៏យ៉ាងនោះឯង ។

មួយគាថាប៉ុណ្ណោះ ដោយ ៤ ខែ លោកក៏មិនអាចរៀនចាំ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា បានឮថា លោកបួសក្នុងកាលព្រះកស្សបសម្មាសម្ពុទ្ធ ជាអ្នកមានបញ្ញា បានធ្វើការសើចចំអកក្នុងកាលដែលភិក្ខុល្ងង់មួយរូប រៀនខទេ្ទស ភិក្ខុនោះខ្មាសព្រោះការសើចនោះ ក៏ឈប់រៀនខទេ្ទស មិនធ្វើការស្វាធ្យាយ ។

ព្រោះកម្មនោះ ចូឡបន្ថកៈនេះលុះបួសហើយ ទើបជាបុគ្គលល្ងង់ ។ បទដែលរៀនហើយ កាលដែលលោករៀនតទៅក៏ភ្លេចអស់ទៅ កាលលោកព្យាយាមរៀនគាថានេះឯង ៤ ខែកន្លងទៅហើយ ។

ពេលនោះ ព្រះមហាបន្ថកៈបានពោលនឹងលោកថា ចូឡបន្ថកៈ អ្នកជាមនុស្សអភព្វក្នុងសាសនានេះ ព្រោះ ៤ ខែ សូម្បីមួយគាថាក៏មិនអាចរៀនបាន អ្នកនឹងធ្វើកិច្ចនៃបព្វជិតឲ្យដល់ទីបំផុតបានដូចម្តេច ចូរចេញអំពីនេះចុះ ដូច្នេះហើយ ក៏បណ្តេញចេញអំពីវិហារ ។

ព្រះចូឡបន្ថកៈ មិនជ្រាបថ្នាក់ភាពជាគ្រហស្ថ ព្រោះការជាប់ជំពាក់ក្នុងព្រះ

ពុទ្ធសាសនា ។ ក្នុងកាលនោះ ព្រះមហាបន្ថក:ជាភត្តុទ្ទេសក: ។ ពេទ្យជីវកកោមារភច្ច កាន់កម្រងផ្កា គ្រឿងក្រអូប និងគ្រឿងលាបដ៏ច្រើន ទៅកាន់អម្ពវ័ន បូជាព្រះសាស្តា ស្តាប់ធម៌ ក្រោកចាកអាសន: ថ្វាយបង្គំព្រះទសពលហើយ ចូលទៅរកព្រះមហាបន្ថក: សួរថា កិកុក្ខន្ធសម្នាក់របស់ព្រះសាស្តាមានចំនួនប៉ុន្មាន ព្រះមហាបន្ថក:ពោលថា កិកុមានប្រមាណ ៥០០ រូប ពេទ្យជីវកពោលថា បពិត្រលោកម្ចាស់ ស្អែកនេះ សូមលោកម្ចាស់នាំកិកុ ៥០០ រូប មានព្រះពុទ្ធជាប្រធាន ទៅទទួលកិក្ខាក្នុងផ្ទះរបស់ខ្ញុំ ។ ព្រះមហាបន្ថក:ពោលថា ឧបាសក កិកុល្អង់មួយរូប ឈ្មោះចូឡបន្ថក: មានធម៌មិនរីកចម្រើន អាត្មាវៀរលោកចេញ ហើយនិមន្តកិកុទាំងឡាយដ៏សេស ។

ព្រះចូឡបន្ថក:ស្តាប់ពាក្យនោះហើយ គិតថា ព្រះថេរ:កាលទទួលនិមន្តដើម្បីកិកុទាំងឡាយមានប្រមាណប៉ុណ្ណោះ ក៏វៀរអញហើយ ទើបទទួល ចិត្តរបស់បង្ក្រុសអញនឹងញែក មិនជាប់ជំពាក់ក្នុងអញហើយ ដោយឥតសង្ស័យ ឥឡូវនេះ អញត្រូវការអ្វីដោយសាសនានេះ អញនឹងទៅជាគ្រហស្ថធ្វើបុណ្យផ្សេងៗ មានទានជាដើម ចិញ្ចឹមជីវិតវិញ ។ ស្អែកឡើងលោកទៅដើម្បីសឹកអំពីព្រលឹម ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោក ចំពោះក្នុងពេលជិតភ្លឺ ឃើញហេតុនេះហើយ ទើបទ្រង់យាងទៅមុន ទ្រង់បានឈប់ចង្រ្កមត្រង់ខ្វាងទ្វារ ដែលព្រះចូឡបន្ថក:ទៅ ។ ព្រះចូឡបន្ថក:និមន្តទៅជួបព្រះសាស្តា ទើបចូលទៅគាល់ថ្វាយបង្គំ ។

ខណៈនោះ ព្រះសាស្តាត្រាស់នឹងលោកថា ចូឡបន្ថក: តើអ្នកនឹងទៅ

ទីណាក្នុងកាលនេះ ព្រះចូឡបន្ថកៈទូលថា បងប្រុសបណ្តេញខ្ញុំព្រះអង្គ ព្រោះ ហេតុនោះ ខ្ញុំព្រះអង្គទៅដើម្បីសឹក ។ ព្រះសាស្តាត្រាស់ថា ម្នាលចូឡបន្ថកៈ ឈ្មោះថា បព្វជ្ជាក្នុងសម្នាក់របស់តថាគត បងប្រុសបណ្តេញ ហេតុអ្វីមិន មកកាន់សម្នាក់របស់តថាគត មកចុះ អ្នកនឹងត្រូវការអ្វីដោយភាពជាគ្រហស្ថ អ្នកត្រូវនៅក្នុងសម្នាក់របស់តថាគត ដូច្នេះហើយ ទ្រង់យកព្រះហស្តដែល មានស្បែកដ៏វិចិត្រទៅដោយចក្រ ស្មាបត្រង់សីសៈ ហើយនាំទៅគង់ត្រង់ មុខព្រះគន្ធកុដិ ប្រទានកំណាត់សំពត់ស្អាត ដែលទ្រង់និម្មិតឡើងដោយឫទ្ធ ដោយព្រះតម្រាស់ថា ចូឡបន្ថកៈ អ្នកចូរបែរមុខទៅទិសខាងកើត ស្មាប កំណាត់សំពត់នេះ ដោយបរិកម្មថា **រជោហរណំ រជោហរណំ** *សំពត់ជូត ធូលី សំពត់ជូតធូលីនោះឯង កាលបុរសក្រាបទូលកាលហើយ មានកិកូ សង្ឃចោមរោម យាងទៅផ្ទះរបស់ជីវក ប្រថាប់គង់លើអាសនៈដែលគេ តាក់តែង ។*

ចំណែកព្រះចូឡបន្ថកៈ អង្គុយសម្ងឹងមើលព្រះអាទិត្យបណ្តើរ ស្មាប សំពត់នោះបណ្តើរ បរិកម្មថា **រជោហរណំ រជោហរណំ** *កាលលោកអង្អែល កំណាត់សំពត់នោះ កំណាត់សំពត់បានសៅហ្មងហើយ ។ គ្រានោះ ទើបគិតថា កំណាត់សំពត់នេះស្អាតពិត តែអាស្រ័យអត្តភាពនេះ ទើបលះប្រក្រតីដើម ក្លាយជារបស់សៅហ្មងយ៉ាងនេះបាន ។ សង្ខារទាំងឡាយមិនទៀងហ្ន៎ ដូច្នេះ ហើយផ្តើមតាំងការអស់ និងការសូន្យ ចម្រើនវិបស្សនា ។*

ព្រះសាស្តា ទ្រង់ជ្រាបថា ចិត្តរបស់ព្រះចូឡបន្ថកៈឡើងកាន់វិបស្សនា

ហើយ ទើបត្រាស់ថា ចូឡបន្ថកៈ អ្នកកុំធ្វើការសម្គាល់កំណាត់សំពត់នោះថា សៅហ្មងហើយ ជាប់ធូលី ធូលីទាំងឡាយ មានរាគធូលីជាដើម មាននៅខាងក្នុងរបស់អ្នក អ្នកចូរនាំ គឺកម្ចាត់ចេញ ដូច្នេះហើយ ទ្រង់បញ្ចេញព្រះរស្មី ជាអ្នកមានរូបប្រាកដដូចប្រថាប់គង់ចំពោះមុខ ទ្រង់បានភាសិតគាថាទាំងនេះថា

> *ធូលី គឺរាគៈ មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះនៃរាគៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីនុ៎ះ ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី។ ធូលី គឺទោសៈ មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះនៃទោសៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីនុ៎ះហើយ សម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។ ធូលី គឺមោហៈ មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះនៃមោហៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីនុ៎ះ ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។*

ក្នុងកាលចប់គាថា ចូឡបន្ថកៈសម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយ ។ បិដក ៣ មកដល់លោក មួយអន្ទើដោយបដិសម្ភិទានោះឯង ។

បានឮថា ក្នុងកាលកន្ទងទៅហើយ លោកជាស្តេចផែនដី ទ្រង់ធ្វើប្រទក្សិណព្រះនគរ កាលព្រះសេទោហូរចេញអំពីព្រះនលាដ ទ្រង់យកសំពត់សស្អាត

ជូតព្រះនលាដ ។ សំពត់បានសៅហ្មងហើយ ព្រះរាជាត្រឡប់បានអនិច្ចសញ្ញា ថា សំពត់ស្អាតនេះ អាស្រ័យសរីរៈនេះ លះប្រក្រតីប្រែជាសៅហ្មងទៅបាន សង្ខារទាំងឡាយមិនទៀងហ្ន៎ ព្រោះហេតុនោះ ទើបសំពត់សម្រាប់ជូតធួលី នោះឯង ជាបច្ច័យរបស់លោកហើយ ។

ចំណែកពេទ្យជីវកកោមារភច្ច បានបង្អោនទឹកទក្ខិណោទកចូលទៅថ្វាយ ព្រះទសពល ព្រះសាស្តាទ្រង់បិទបាត្រដោយព្រះហស្ត ត្រាស់ថា ម្នាលជីវក ភិក្ខុក្នុងវិហារ នៅមានមិនមែនឬ ។

ព្រះមហាបន្តកៈក្រាបទូលថា ក្នុងវិហារភិក្ខុមិនមានមិនមែនឬ ព្រះសាស្តា ត្រាស់ថា មានជីវក ពេទ្យជីវកបញ្ជូនបុរសទៅដោយប្រាប់ថា នែអ្នក បើ ដូច្នោះ អ្នកចូរទៅ ចូរដឹងថា ភិក្ខុក្នុងវិហារមាន ឬមិនមាន ។

ក្នុងខណៈនោះ ព្រះចូឡបន្តកៈគិតថា បងប្រុសរបស់អញពោលថា ភិក្ខុក្នុងវិហារមិនមាន អញនឹងប្រកាសការដែលភិក្ខុក្នុងវិហារមានដល់លោក ដូច្នេះហើយ ទើបនិម្មិតឲ្យអម្ពវនទាំងមូល ពេញដោយភិក្ខុទាំងអស់ ភិក្ខុពួក ខ្លះដេរចីវរ ពួកខ្លះជ្រលក់ចីវរ ពួកខ្លះធ្វើការស្វាធ្យាយ និម្មិតភិក្ខុមួយពាន់មិន ដូចគ្នានិងគ្នា យ៉ាងនេះ ។

បុរសនោះឃើញភិក្ខុជាច្រើនក្នុងវិហារ ទើបត្រឡប់មកប្រាប់ដល់ជីវក ថា លោកម្ចាស់ អម្ពវនទាំងមូល ពេញដោយភិក្ខុទាំងឡាយ ។

ព្រះធម្មសង្គាហិកាចារ្យពោលថា ចំណែកព្រះថេរៈ ឈ្មោះចូឡបន្តកៈ និម្មិតខ្លួនមួយពាន់ដង គឺជាភិក្ខុមួយពាន់រូបក្នុងអម្ពវនោះឯង ហើយគង់ក្នុង

អម្ពវនដ៏ជាទីមនោរម្យ រហូតដល់បុរសមកជ្រាប់កាល ។

លំដាប់នោះ ព្រះសាស្តាត្រាស់ទឹងបុរសនោះថា អ្នកចូរទៅវិហារជ្រាប់ថា ព្រះសាស្តាហៅរកភិក្ខុឈ្មោះចូឡបន្ថកៈ ។

កាលបុរសនោះទៅជ្រាប់តាមបញ្ជាហើយ សំឡេងរាប់ពាន់ក៏លាន់ឮថា អាត្មាឈ្មោះចូឡបន្ថកៈ អាត្មាឈ្មោះចូឡបន្ថកៈ ។

បុរសនោះត្រឡប់ទៅក្រាបទូលទៀតថា បពិត្រព្រះអង្គ ភិក្ខុគ្រប់រូបឈ្មោះចូឡបន្ថកៈទាំងអស់ ព្រះសាស្តាត្រាស់ថា បើដូច្នោះ អ្នកចូរទៅ បុគ្គលណានិយាយមុនថា អាត្មាឈ្មោះចូឡបន្ថកៈ ចូរចាប់ដៃភិក្ខុនោះ ភិក្ខុដទៃក៏ទឹងអន្តរធានទៅ ។

បុរសនោះបានធ្វើតាមពាក្យបញ្ជា ភិក្ខុប្រមាណមួយពាន់រូប ជាត់ទៅហើយមួយរំពេចនោះឯង ព្រះថេរៈបានទៅជាមួយបុរសនោះ ។

ក្នុងកាលស្រេចភត្តកិច្ច ព្រះសាស្តាត្រាស់ហៅពេទ្យជីវកមក ជ្រាប់ថា ម្នាលជីវក អ្នកចូរទទួលថ្នាំត្រវបស់ចូឡបន្ថកៈចុះ ចូឡបន្ថកៈនេះ ទឹងធ្វើអនុមោទនាដល់អ្នក ។ ពេទ្យជីវកបានធ្វើយ៉ាងនោះហើយ ។ ព្រះថេរៈបន្ទឹសីហនាទ ដូចសីហៈជំទង់ដែលកំពុងសម្តែងឫទ្ធ បានធ្វើអនុមោទនា ញុំងព្រះត្រៃបិដកឲ្យខ្ទរខ្ទារហើយ ។

ព្រះសាស្តាទ្រង់ក្រោកអំពីអាសនៈ មានភិក្ខុសង្ឃចោមរោម យាងទៅកាន់វិហារ កាលភិក្ខុទាំងឡាយសម្តែងវត្តហើយ ទ្រង់ក្រោកអំពីអាសនៈ ទ្រង់ឈរត្រង់យ៉ាមុខនៃព្រះគន្ធកុដិ ប្រទានសុគតោវាទ ត្រាស់កម្មដ្ឋានដល់ភិក្ខុសង្ឃ

ទ្រង់បញ្ជូនភិក្ខុសង្ឃទៅហើយ ទ្រង់ចូលកាន់ព្រះគន្ធកុដិ ដែលអប់ដោយក្លិនក្រអូបឈ្ងុយឈ្ងប់ ទ្រង់ផ្ទំសីហាសេយ្យាដោយព្រះបង្អែងស្តាំ ។

ក្នុងពេលល្ងាច ភិក្ខុទាំងឡាយគង់ប្រជុំគ្នាខាងនេះ និងខាងនោះ ដូចព័ន្ធរាំងនូវសំពត់កម្ពល ប្រារព្ធដល់រឿងព្រះគុណរបស់ព្រះសាស្តាថា អាវុសោ ព្រះមហាបន្ថកៈមិនជ្រាបអធ្យាស្រ័យរបស់ព្រះចូឡបន្ថកៈទើបមិនអាចឲ្យរៀនគាថាមួយបទ អស់កាល ៤ ខែបាន បណ្តេញចេញអំពីវិហារ ដោយយល់ថា ភិក្ខុរូបនេះល្ងង់ តែព្រះសាស្តាសម្មាសម្ពុទ្ធ បានប្រទានព្រះអរហត្ត មួយអន្ទើដោយបដិសម្ភិទា ក្នុងរវាងធាន់អាហារមួយពេលប៉ុណ្ណោះ ព្រោះទ្រង់ជាព្រះធម្មរាជាដ៏កំពូល មិនមានបុគ្គលប្រៀប ព្រះត្រៃបិដកមានមកព្រមជាមួយបដិសម្ភិទានោះឯង គួរសរសើរ ឈ្មោះថា កម្លាំងរបស់ព្រះពុទ្ធទាំងឡាយមានច្រើន ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបរឿងរ៉ាវនេះ ក្នុងរោងធម្មសភាហើយ ទ្រង់ត្រែរិះថា ថ្ងៃនេះតថាគតទៅ គួរទ្រង់ក្រោកចាកពុទ្ធសេយ្យាសនៈ ទ្រង់ស្លៀកសំពត់ពីរជាន់ ដែលជ្រលក់ល្អហើយ ចងវត្តពន្ធចង្កេះ ដូចផ្កេកបន្ទោរ ទ្រង់ដណ្តប់មហាបង្សុកូលចីវរ ត្រូវនឹងទំហំសុគតប្រមាណ ប្រៀបដូចសំពត់រត្តកម្ពល ទ្រង់ចេញចាកព្រះគន្ធកុដិដែលមានក្លិនក្រអូប ទៅកាន់រោងធម្មសភាដោយលីលា នៃអកប្បកិរិយាដែលទ្រង់យាងទៅហើយ ដូចស្តេចគជសារចុះប្រេង និងដូចសីហៈដោយព្រះពុទ្ធលីលាមិនមានទីបំផុត ទ្រង់ឡើងកាន់បវរពុទ្ធាសនៈដែលបានគេរៀបចំ ត្រង់កណ្តាលនៃមណ្ឌបដែលបុគ្គលប្រដាប់ហើយ

ប្រថាប់គង់ត្រង់កណ្តាលអាសនៈ ទ្រង់បញ្ចេញព្រះពុទ្ធរស្មីមានពណ៌ ៦ ប្រការ ប្រៀបដូចទេវតាដ៏វិសេស បណ្តាលផ្ទៃមហាសមុទ្រឲ្យរញ្ជួយ និងដូចសុរិយោទ័យ បញ្ចេញពន្លឺស្រទន់លើភ្នំយុគន្ធរ ដូច្នោះ ។ កាលព្រះសម្មាសម្ពុទ្ធយាងមកដល់ ភិក្ខុសង្ឃក៏ឈប់សន្ទនា អង្គុយស្ងៀម ។

ព្រះសាស្តាទ្រង់ពិចារណាមើលបរិស័ទ ដោយព្រះហឫទ័យដ៏ស្រទន់ ទ្រង់អាវជ្ជនៈថា បរិស័ទនេះស្រស់ត្រកាលពន់ពេក ការឆ្អាំឆ្អងដោយដៃក្តី ឆ្អាំឆ្អងដោយជើងក្តី សំឡេងក្អកក្តី សំឡេងកណ្តាស់ក្តី របស់ភិក្ខុមួយរូបរមែងមិនមាន ភិក្ខុទាំងអស់នេះ មានការគោរពដោយពុទ្ធគារវៈ ដែលតេជៈនៃព្រះពុទ្ធគំរាមហើយ កាលតថាគតនៅស្ងៀម មិនពោលជរាបអស់អាយុក៏ភិក្ខុរូបណាមួយ មិនអាចលើករឿងណាមួយពោលមុនបាន ឈ្មោះថា ទំនៀមរបស់ការលើករឿងឡើង តថាគតគួរដឹង តថាគតនឹងពោលឡើងមុន ដូច្នេះហើយ ត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះសូរសៀងដ៏ពីរោះ ដូចសំឡេងព្រហ្ម សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នា ដោយរឿងអ្វី រឿងអ្វីដែលពួកអ្នកផ្ដាកក្នុងចន្លោះ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូឡបន្ថកៈ មិនមែនល្ងង់តែក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏បានជាបុគ្គលល្ងង់ហើយដូចគ្នា ម្យ៉ាងទៀត តថាគតជាទីពំនាក់អាស្រ័យរបស់លោក តែក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានជាទីពំនាក់អាស្រ័យហើយដូចគ្នា ។ ក្នុងកាលមុន តថាគតបានធ្វើចូឡបន្ថកៈនេះ ឲ្យជាម្ចាស់នៃ

លោកិយទ្រព្យហើយ ឥឡូវនេះ បានធ្វើឲ្យជាម្ចាស់នៃលោកុត្តរទ្រព្យ កាល ភិក្ខុទាំងឡាយ ប្រាថ្នានឹងស្តាប់សេចក្តីនោះដោយពិស្តារ ទូលស្នើហើយ ទ្រង់នាំអតីតនិទានមកពោលថា

ក្នុងអតីតកាល មាណពអ្នកនគរពារាណសីម្នាក់ ទៅកាន់ក្រុងតក្កសិលា ជាធម្មន្តេវាសិករបស់អាចារ្យទិសាបាមោក្ខ ដើម្បីបំណងរៀនសិប្បៈ បានជា អ្នកឧបការៈដល់អាចារ្យក្រៃលែង ក្នុងរវាងមាណព ៥០០ ធ្វើកិច្ចគ្រប់យ៉ាង មានច្របាច់ជើងជាដើម តែព្រោះជាបុគ្គលល្ងង់ ទើបមិនអាចរៀនអ្វីបាន អាចារ្យសូម្បីព្យាយាមដោយគិតឃើញថា សិស្សនេះ មានឧបការៈដល់អញ ច្រើន នឹងឲ្យគេសិក្សាឲ្យបាន ក៏មិនអាចឲ្យសិក្សាអ្វីមួយបាន ។

បុរសនោះនៅអស់កាលជ័យូរ សូម្បីមួយគាថាក៏មិនអាចរៀនបាន ទឹកវ័អែងចិត្ត លាអាចារ្យថានឹងទៅ ។ អាចារ្យគិតថា សិស្សនេះមានឧបការៈច្រើន ដល់អញ អញក៏បំណងភាពជាបណ្ឌិតដល់សិស្សនេះ តែមិនអាចធ្វើភាពជា បណ្ឌិតនោះបាន អញចាំបាច់ត្រូវធ្វើឧបការៈតបដល់សិស្សនេះឲ្យបាន អញ នឹងចងមន្តឲ្យគេបានមួយបទ នាំសិស្សនោះចូលទៅកាន់ព្រៃ ចងមន្តនេះថា **ឃដេសិ ឃដេសិ កិកាវណា ឃដេសិ អមាំបិ តំ ជានាមិ ជានាមិ** *ដូច្នេះហើយ ឲ្យរៀនច្រាស់ទៅច្រាស់មកច្រើនវេរជង ហើយសួរថា អ្នកចាំ បានហើយឬ កាលគាត់ឆ្លើយថា ខ្ញុំចាំបានហើយ ក៏ប្រាប់ថា ធម្មតាសិប្បៈ ដែលបុគ្គលល្ងង់ធ្វើព្យាយាមឲ្យស្ទាត់ហើយ វ័មែងមិនភ្លេចភ្លាំង រួចឲ្យស្បៀង ធ្វើដំណើរ ដោយប្រាប់ថា អ្នកចូរទៅអាស្រ័យមន្តនេះចិញ្ចឹមជីវិតចុះ តែដើម្បី*

ប្រយោជន៍មិនឲ្យមន្តវិនាសទៅ អ្នកគប្បីស្វាធ្យាយមន្តនោះជានិច្ច ដូច្នេះហើយ ក៏បញ្ជូនទៅ ។

ក្នុងកាលបុរសនោះដល់នគរពោរាណសី មាតាបិតាបានធ្វើសក្ការៈស្និទ្ធ-ស្នាលដ៏ធំ ដោយត្រេកអរថា កូនរបស់អញសិក្សាសិប្បៈត្រឡប់មកហើយ ។

ក្នុងកាលនោះ ព្រះបាទពោរាណសីទ្រង់ពិចារណាថា ទោសប្រការខ្លះ ព្រោះកម្មទាំងឡាយ មានកាយកម្មជាដើមមានឬហ្ន៎ ទ្រង់មិនឃើញកម្មណាមួយ ដែលមិនជាទីពេញព្រះហឫទ័យរបស់ព្រះអង្គ ក៏ទ្រង់ត្រិះរិះថា ធម្មតាទោសរបស់ខ្លួនមិនប្រាកដដល់ខ្លួនឡើយ រមែងប្រាកដដល់អ្នកដទៃ អញនឹងកំណត់ការប្រព្រឹត្តទៅរបស់ពួកអ្នកស្រុក ដូច្នេះហើយ ទើបទ្រង់ក្លែងភេទយាងចេញទៅក្នុងពេលល្ងាច ទ្រង់ត្រិះរិះថា ធម្មតាការសន្ទនា ប្រាស្រ័យរបស់ពួកមនុស្ស ដែលអង្គុយបរិភោគអាហារក្នុងពេលល្ងាច រមែងមានប្រការផ្សេងៗគ្នា បើអញគ្រងរាជ្យដោយអធម៌ ជនទាំងឡាយគង់នឹងពោលថា ពួកយើងត្រូវស្តេចផែនដីមិនតាំងនៅដោយធម៌ ជាមនុស្សអាក្រក់ បៀតបៀនដោយពន្ធអាករ និងពលីជាដើម បើអញគ្រងរាជ្យដោយធម៌ ជនទាំងឡាយនឹងពោលពាក្យជាដើមថា ព្រះរាជានៃយើងទាំងឡាយ សូមទ្រង់មានព្រះជន្មាយុយឺតយូរចុះ ហើយក៏សរសើរគុណរបស់អញ ដូច្នេះហើយ ទើបទ្រង់ត្រាច់ទៅតាមលំដាប់ ជញ្ជាំងផ្ទះនោះៗ ។

ក្នុងខណៈនោះ ពួកចោរដែលរកស៊ីជីកឧម្មុង្គ កំពុងជីកឧម្មុង្គក្នុងរវាងផ្ទះពីរខ្នង ដើម្បីចូលផ្ទះទាំងពីរដោយឧម្មុង្គតែមួយ ព្រះរាជាទតឃើញចោរ

ហើយ ទ្រង់ពួនក្នុងស្រមោលផ្ទះ ក្នុងកាលពួកចោរជីកខុមង្គ្គចូលផ្ទះបាន ហើយ ពិនិត្យមើលទ្រព្យ មាណពក្អាក់ឡើងហើយ ក៏ស្វាធ្យាយមន្តនោះថា **ឃដេសិ ឃដេសិ កិំការណា ឃដេសិ អហំបិ តំ ជានាមិ ជានាមិ ។**

ចោរទាំងនោះ បានស្តាប់ពាក្យនោះហើយ ភិតភ័យតក្កមា ចោះសំពត់ សូម្បីដែលខ្លួនស្លៀកចោល គេចទៅដោយជណ្តើមគ្នាខាងមុខនោះឯង ដោយប្រាប់គ្នាថា បានឮថា បុរសម្នាក់នេះស្គាល់ពួកយើង វានឹងធ្វើឲ្យពួកយើងវិនាសក្នុងកាលឥឡូវនេះ ។

ព្រះរាជាទតឃើញចោរទាំងនោះកំពុងគេចទៅ ទ្រង់ស្តាប់សំឡេងមាណពនេះស្វាធ្យាយមន្ត ទ្រង់កំណត់ការប្រព្រឹត្តទៅ របស់ពួកអ្នកក្រុងបានហើយ ទើបយាងចូលព្រះរាជនិវេសន៍ តែកាលរាត្រីភ្លឺហើយ ក៏បញ្ជាឲ្យហៅបុរសម្នាក់មកគាល់ ត្រាស់ថា នែអ្នក ចូរអ្នកទៅ ពួកចោរជីកខុមង្គ្គក្នុងផ្ទះឈ្មោះនោះ ក្នុងថ្នល់នោះ ក្នុងផ្ទះនោះ មានមាណពរៀនសិប្បៈមកអំពីនគរតក្ក-សិលា ចូរអ្នកនាំបុរសនោះមក ។ បុរសទៅជ្រាប់ថា នែអ្នក ព្រះរាជាទ្រង់ឲ្យហៅអ្នក ហើយនាំមាណពមក លំជាប់នោះ ព្រះរាជាត្រាស់សួរថា នែអ្នកអ្នកជាមាណពដែលរៀនសិប្បៈ មកអំពីនគរតក្កសិលាឬ ។ មាណពពោលថា បពិត្រព្រះអង្គ គឺទូលបង្គំនេះឯង ។ ព្រះរាជាត្រាស់ថា អ្នកឲ្យសិប្បៈដល់យើងបានដែរឬទេ មាណពទូលថា សាធុ សូមទ្រង់ប្រថាប់លើអាសនៈស្មើគ្នាហើយរៀនចុះ ។

លំជាប់នោះ ព្រះរាជាទ្រង់ធ្វើយ៉ាងនោះ ទ្រង់រៀនមន្តនោះអំពីបុរសហើយ

បានព្រះរាជទានទ្រព្យមួយពាន់ ដោយព្រះតម្រាស់ថា នេះជាចំណែកបូជាអាចារ្យ របស់អ្នក ។

ក្នុងកាលនោះ សេនាបតីពោលនឹងភូសាមាលារបស់ស្តេចផែនដីថា អ្នកតាក់តែងព្រះមស្សុរបស់ព្រះរាជាក្នុងកាលណា ភូសាមាលាពោលថា ស្អែកនេះ ឬខាន់ស្អែកនេះឯង ។ សេនាបតីនោះ ឲ្យទ្រព្យមួយពាន់ដល់បុរសនោះ ហើយពោលថា ខ្ញុំមានកិច្ចមួយ កាលបុរសនោះសួរថា កិច្ចអ្វីលោកម្ចាស់ ក៏ប្រាប់ថា ចូរអ្នកធ្វើដូចជាកោរព្រះមស្សុឲ្យព្រះរាជា សំលៀងកាំបិតកោរឲ្យមុតកាត់បំពង់កទ្រង់ចុះ អ្នកនឹងបានជាសេនាបតី ខ្ញុំនឹងធ្វើស្តេចផែនដី បុរសនោះទទួលថា បាន ។ ក្នុងថ្ងៃកោរព្រះមស្សុថ្វាយព្រះរាជា យកទឹកក្រអូបស្រង់ព្រះមស្សុឲ្យសើម សំលៀងកាំបិតកោរ ចាប់ត្រង់ជាយព្រះនលាដ គិតថា កាំបិតកោរមានមុខមុត អញគួរកាត់បំពង់កដោយឆាប់ប៉ុណ្ណោះ ដូច្នេះហើយ ទើបឈរក្នុងទីខ្ជាងសំលៀកកាំបិតទៀត ។

ក្នុងខណៈនោះ ព្រះរាជាទ្រង់រឭកដល់មន្តរបស់ទ្រង់បាន កាលទ្រង់ធ្វើការស្វាធ្យាយ ក៏ត្រាស់ថា **ឃដេសិ ឃដេសិ កំការណា ឃដេសិ អមាំបិ តំ ជានាមិ ជានាមិ** *អ្នកព្យាយាមទៅចុះ ព្យាយាមទៅចុះ ព្រោះហេតុអ្វី ទើបអ្នកព្យាយាម អញក៏ដឹងហេតុនោះ អញក៏ដឹងហេតុនោះ ។*

ញើសហូរច្រោក ចេញអំពីថ្ងាសរបស់ភូសាមាលាហើយ គាត់យល់ថា ព្រះរាជាទ្រង់ជ្រាបអញ ភ័យខ្លាចហើយ ទើបចោះកាំបិតកោរចោលត្រង់ផែនដី ហើយក្រាបទៀបបាទានោះឯង ។

ធម្មតាព្រះរាជាទាំងឡាយ រមែងជាបុគ្គលឈ្លាស ព្រោះដូច្នោះ ទើបទ្រង់ត្រាស់នឹងបុរសនោះថា វ៉ីយ នាយកូសាមាលាកំណាច អាយល់ថា ស្តេចផែនដីមិនដឹងអាឬ កូសាមាលាពោលថា សូមទ្រង់ព្រះរាជទានអភ័យដល់ខ្ញុំព្រះអង្គចុះ ព្រះរាជាត្រាស់ថា ណ្ហើយចុះ កុំខ្លាចឡើយ ចូរច្រាប់មកចុះ ។ នាយកូសាមាលាពោលថា បពិត្រព្រះអង្គ សេនាបតីឲ្យទ្រព្យមួយពាន់ដល់ទូលបង្គំច្រាប់ថា ចូរអ្នកធ្វើជាកោរព្រះមស្សុរបស់ព្រះរាជា កាត់បំពង់កទ្រង់ចុះ កាលទ្រង់សោយទិវង្គតហើយ ខ្ញុំនឹងធ្វើជាស្តេចផែនដី តែងតាំងឯងឲ្យជាសេនាបតី ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់ត្រិះរិះថា អញបានជីវិតព្រោះអាស្រ័យអាចារ្យ ដូច្នេះហើយ ទើបត្រាស់ឲ្យហៅសេនាបតីមក ត្រាស់ថា នែសេនាបតី ឈ្មោះថា អ្វីដែលអ្នកមិនបានហើយអំពីសម្នាក់របស់យើង ឥឡូវនេះ យើងមិនអាចសម្លឹងមើលអ្នកបាន ចូរអ្នកចេញទៅអំពីដែនរបស់យើង បញ្ជាឲ្យនិទេ្ទសចាកដែនហើយ ក៏ប្រើឲ្យហៅមាណព ដែលជាអាចារ្យចូលគាល់ ត្រាស់ថា លោកអាចារ្យខ្ញុំមានជីវិតព្រោះអាស្រ័យលោក ដូច្នេះហើយ ទ្រង់ធ្វើសក្ការៈធំ បានព្រះរាជទានតំណែងសេនាបតីដល់អាចារ្យនោះហើយ ។ មាណពក្នុងកាលនោះ បានជាចូឡបន្ថកៈ ព្រះសាស្តាជាអាចារ្យទិសាបាមោក្ខ ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន ចូឡបន្ថកៈក៏ល្ងង់យ៉ាងនេះដូចគ្នា ក្នុងកាលនោះ តថាគតក៏បានជាទីពឹងពំនាក់របស់លោក ញុំាងលោកឲ្យតាំងនៅក្នុងលោកិយ-

ទ្រព្យហើយ ។ ស្អែកឡើង កាលកថាតាំងឡើងថា គួរសរសើរហ្ន៎ ព្រះសាស្តាជាទីពឹងពំនាក់របស់ចូឡបន្ថកៈហើយ ត្រាស់និទានរឿងអតីត ក្នុងចូឡសេដ្ឋិជាតក ហើយត្រាស់គាថាថា

អ្នកប្រាជ្ញឈ្វាសវៃ រមែងតាំងខ្លួនបាន ដោយទ្រព្យជាដើមទុន សូម្បីមានប្រមាណតិច ដូចបុគ្គលបង្កាត់ភ្លើងដ៏តូច ។

ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាទីពឹងពំនាក់របស់ចូឡបន្ថកៈនេះ ចំពោះតែក្នុងឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានជាទីពឹងពំនាក់ហើយ តែក្នុងកាលមុនតថាគតបានធ្វើចូឡបន្ថកៈនេះ ឲ្យជាម្ចាស់របស់លោកិយទ្រព្យ ឥឡូវនេះ ធ្វើឲ្យជាម្ចាស់លោកុត្តរទ្រព្យ ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ចូឡកន្តេវាសិកក្នុងកាលនោះ បានជាចូឡបន្ថកៈ ក្នុងឥឡូវនេះ ។ ចំណែកចូឡកសេដ្ឋី ដែលជាអ្នកឈ្វាសយល់ក្នុងព្យាករនក្ខត្តឫក្ស ក្នុងកាលនោះ គឺតថាគតនោះឯង ។

ក្នុងថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោ ព្រះចូឡបន្ថកៈមិនអាចរៀនគាថា ៤ បទ ក្នុង ៤ ខែបាន ក៏មិនលះសេចក្តីព្យាយាមតាំងនៅក្នុងអរហត្តហើយ ឥឡូវនេះបានជាម្ចាស់ទ្រព្យ គឺលោកុត្តរធម៌ហើយ ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនារបស់

តថាគត ប្រារព្ធសេចក្តីព្យាយាមហើយ រមែងជាម្ចាស់នៃលោកុត្តរធម៌បាន នោះឯង ដូច្នេះ ត្រាស់គាថានេះថា

ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច
ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។

អ្នកប្រាជ្ញគប្បីសាងកោះ គឺ អរហត្តផលជាកោះដែលជំនន់ គឺ កិលេសជន់ពន្លិចមិនបាន ដោយសេចក្តីប្រឹងប្រែងផង ដោយសេចក្តីមិនប្រមាទផង ដោយការសង្រួមក្នុងចតុប្បារិសុទ្ធសីលផង ដោយការទូន្មានឥន្ទ្រិយផង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ទីបំ កយិរាថ** *សេចក្តីថា បុគ្គលមានបញ្ញា ប្រកបព្រមហើយដោយបញ្ញាដ៏រុងរឿងក្នុងធម៌ គប្បីធ្វើ គឺគប្បីធ្វើបានដល់ អាចធ្វើកោះ គឺអរហត្តផល ដែលជាទីពឹងពំនាក់របស់ខ្លួនក្នុងសាគរ គឺសង្សារដ៏ជ្រៅក្រៃលែង ដោយភាពជាទីពឹង ដែលបានដោយលំបាកក្រៃលែងនេះ ដោយធម៌ជាហេតុ ៤ ប្រការ គឺដោយការប្រឹងប្រែង ពោល គឺសេចក្តីព្យាយាម ១ ដោយការមិនប្រមាទ ពោល គឺការនៅជ្រាសចាកសតិ ១ ដោយការសង្រួម ពោល គឺចតុប្បារិសុទ្ធសីល ១ ដោយការទូន្មានឥន្ទ្រិយ ១ ។*

សួរថា គប្បីធ្វើកោះដូចម្តេច ឆ្លើយថា គប្បីធ្វើកោះដែលអន្ទង់ទឹកជន់លិចមិនបាន អធិប្បាយថា គប្បីធ្វើកោះដែលអន្ទង់ទឹក គឺកិលេសទាំង ៤

យ៉ាង មិនអាចលិច គឺកម្ចាត់បាន ។ ពិតហើយ អរហត្ត គឺឱឃ: មិនអាចជន់លិចបានឡើយ ។

ក្នុងកាលចប់គាថា មហាជនបានជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម ។ ទេសនាមានប្រយោជន៍ ដល់បុគ្គលដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង ព្រះចូឡបន្ថកត្ថេរ ចប់

រឿង ពាលនក្ខត្តបុក្ឃ
លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនក្ខត្តប្រក្សរបស់បុគ្គលពាល ត្រាស់ព្រះធម្មទេសនានេះថា **បមាទមនុយុញ្ជន្តិ** ជាដើម ។

សេចក្តីពិស្តារថា បានឣមកថា សម័យមួយ គេប្រកាសពាលនក្ខត្តប្រក្សក្នុងនគរសាវត្ថី ។ ក្នុងនក្ខត្តប្រក្សនោះ ពួកជនពាលអ្នកមានប្រាជ្ញាថោកថយ យកធ្យូង និងគោម័យ គឺលាមកគោ លាបរាងកាយ ត្រាច់ពោលវាចារបស់អសប្ឃុរសរហូត ៧ ថ្ងៃ ។ ឃើញបុគ្គលណាម្នាក់ជាញាតិក្តី ជាសម្ងាញ់ក្តី ជាបព្វជិតក្តី ឈ្មោះថា ខ្មាសមិនមាន ឈរពោលវាចារបស់អសប្ឃុរស ត្រង់ទ្វារគ្រប់ៗ ទ្វារ មនុស្សទាំងឡាយ មិនអាចស្តាប់អសប្ឃុរិសវាទរបស់បុគ្គលនោះបាន ទើបបញ្ជូនទ្រព្យកន្ទះបាទខ្ទះ ១ បាទខ្ទះ ១ កហាបណៈខ្ទះ តាម

កម្ចាំង ពួកជនទាំងនោះកាន់យកទ្រព្យដែលបានហើយ ត្រង់ទ្វារផ្ទះរបស់មនុស្សទាំងនោះហើយ ក៏ចៀសចេញទៅ ។

ក្នុងកាលនោះ នគរសាវត្ថីមានអរិយសាវ័កប្រមាណ ៥ កោដិ លោកទាំងនោះបញ្ជូនដំណឹងទៅថ្វាយព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ មួយអន្ទើដោយភិក្ខុសង្ឃ កុំចូលទៅកាន់នគរ សូមប្រថាប់នៅតែក្នុងវិហារ ៧ ថ្ងៃចុះ ។ ក្នុង ៧ ថ្ងៃនោះ នឹងបញ្ជូនបបរ ភត្តជាដើមទៅកាន់វិហារនោះឯង ដើម្បីភិក្ខុសង្ឃ សូម្បីខ្លួនឯងក៏មិនអាចចេញអំពីផ្ទះ ។

កាលនក្ខត្តឫក្សស្ងប់ហើយ ក្នុងថ្ងៃទី ៨ អរិយសាវ័កទាំងនោះនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យយាងចូលទៅកាន់ព្រះនគរ ថ្វាយមហាទានហើយ អង្គុយក្នុងចំណែកម្ខាង ក្រាបទូលថា បពិត្រព្រះអង្គ ៧ ថ្ងៃ របស់ខ្ញុំព្រះអង្គ កន្លងទៅដោយលំបាកក្រៃលែង កាលពួកខ្ញុំព្រះអង្គបានឮវាចា មិនមែនរបស់សប្បុរសរបស់ពួកបុគ្គលពាល ត្រចៀកទាំងពីរ ហាក់បីដូចជាល់នូវអាការបែកធ្លាយ ។ បុគ្គលណាម្នាក់ក៏មិនខ្វាសដល់បុគ្គលណា ព្រោះដូច្នោះ ទើបពួកខ្ញុំព្រះអង្គ មិនឲ្យទ្រង់យាងចូលខាងក្នុងព្រះនគរ សូម្បីពួកខ្ញុំព្រះអង្គក៏មិនអាចចេញអំពីផ្ទះ ។

ព្រះសាស្តាទ្រង់ស្តាប់វាចារបស់អរិយសាវ័កទាំងនោះហើយ ត្រាស់ថា កិរិយារបស់ពួកអ្នកមានប្រាជ្ញាថោកថយ រមែងដូច្នេះ ចំណែកអ្នកមានបញ្ញាទាំងឡាយ រក្សាសេចក្តីមិនប្រមាណ ដូចទ្រព្យដែលជាសារៈ រមែងសម្រេចសម្បត្តិ គឺអមតមហានិព្វាន ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា
អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំ វ រក្ខតិ ។
មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ
អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ។

ពួកជនពាល អប្បតិតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្តីមិនប្រមាទដូចទ្រព្យយ៉ាងប្រសើរ ។ អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗ នូវសេចក្តីប្រមាទ ចូរកុំប្រកបរឿយៗ នូវសេចក្តីរីករាយត្រេកអរក្នុងកាមទ្បើយ ដ្បិតបុគ្គលអ្នកមិនប្រមាទ ទំសង្កេតពិនិត្យ រមែងបាននូវសេចក្តីសុខដ៏ទូលាយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ពាលា** *បានដល់ ដែលប្រកបដោយភាពជាជនពាល គឺដែលមិនស្គាល់ប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ ។*

បទថា **ទុម្មេធិនោ** *គឺឥតប្រាជ្ញា ។ ពួកជនពាលនោះ កាលមិនឃើញទោសក្នុងសេចក្តីប្រមាទ ឈ្មោះថា រមែងប្រកបរឿយៗ នូវសេចក្តីប្រមាទ គឺរមែងឲ្យកាលកន្លងទៅដោយសេចក្តីប្រមាទ ។*

បទថា **មេធាវី** *ជាដើម សេចក្តីថា ចំណែកបណ្ឌិតប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ រមែងរក្សាការមិនប្រមាទ ដូចទ្រព្យ គឺរតន: ៧ ប្រការដ៏ប្រសើរ គឺឧត្តម បន្តជាប់គ្នាមកអំពីវង្សត្រកូល ។ អធិប្បាយថា ឧបមាដូច*

ជនទាំងឡាយ កាលឃើញអានិសង្សក្នុងទ្រព្យថា យើងទាំងឡាយអាស្រ័យ ទ្រព្យដ៏ខត្តម និងដល់សម្បត្តិ គឺកាមគុណ និងធ្វើផ្ទូវជាទីទៅកាន់បរលោកឲ្យ បរិសុទ្ធបាន រមែងរក្សាទ្រព្យនោះ យ៉ាងណា សូម្បីបណ្ឌិតក៏ដូច្នោះ ឃើញ អានិសង្សក្នុងការមិនប្រមាទថា បុគ្គលមិនប្រមាទហើយ រមែងបានចំពោះនូវ ឈានទាំងឡាយ មានបឋមជ្ឈានជាដើម រមែងសម្រេចលោកុត្តរធម៌ មានមគ្គ និងផលជាដើម រមែងញ្ចុាំងវិជ្ជា ៣ អភិញ្ញា ៦ ឲ្យដល់ព្រមបាន រមែងរក្សា ការមិនប្រមាទ ដូចទ្រព្យដ៏ប្រសើរ ។

បទថា **មា បមាទំ** សេចក្តីថា ព្រោះដូច្នោះ អ្នកទាំងឡាយកុំតាមប្រកប នូវសេចក្តីប្រមាទ គឺកុំឲ្យកាលកន្ងទៅដោយសេចក្តីប្រមាទ ។

បាទគាថាថា **មា កាមរតិសន្ថវំ** សេចក្តីថា កុំតាមប្រកប គឺកុំគិត បានដល់ កុំបានចំពោះនូវការស្និទ្ធស្នាលដោយអំណាចនៃតណ្ហា ពោល គឺការ ត្រេកអរក្នុងវត្ថុកាម និងកិលេសកាម ។

បទថា **អប្បមត្តោ ហិ** ជាដើម សេចក្តីថា ព្រោះថា បុគ្គលមិនប្រមាទ ហើយ ដោយភាពជាបុគ្គលមានសតិតាំងមាំ សម្ងឹងពិចារណា រមែងសម្រេច និព្វានសុខដ៏បរិបូណ៌ គឺខឡារ ។

ក្នុងកាលចប់គាថា ជនជាច្រើនបានជាអរិយបុគ្គល មានសោតាបន្ន ជាដើម ។ ទេសនាមានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។

រឿងពាលនក្ខត្តមុក្ឃ ចប់

រឿង ព្រះមហាកស្សបត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះមហាកស្សបត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **បមាទំ អប្បមាទេន** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះថេរៈនៅក្នុងបិប្ផលិគុហា ត្រាច់ទៅបិណ្ឌ-បាត ខាងក្រោយភត្ត អង្គុយចម្រើនអលោកកសិណ ប្រមើលមើលសត្វទាំងឡាយ ដែលប្រមាទហើយ និងមិនប្រមាទហើយ ដែលចុតិ និងកើតក្នុងទីទាំងឡាយ មានទឹក ផែនដី និងភ្នំជាដើម ដោយទិព្វចក្ខុ ។

ព្រះសាស្តា ប្រថាប់គង់ក្នុងវត្តជេតពននោះឯង ទ្រង់ប្រមើលមើលដោយទិព្វចក្ខុថា ថ្ងៃនេះកស្សបៈដែលជាបុត្ររបស់តថាគត នៅដោយវិហារណាហ្ន៎ ទ្រង់ជ្រាបថា កំពុងប្រមើលមើលចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ទើបត្រាស់ថា ឈ្មោះថា ចុតិ និងការកើតនៃសត្វទាំងឡាយ សូម្បីពុទ្ធញាណទ្រង់មិនកំណត់ បុគ្គលណាម្នាក់ក៏មិនអាចធ្វើការកំណត់សត្វទាំងឡាយ ដែលបដិសន្ធិក្នុងផ្ទៃរបស់មាតា ដែលមាតាបិតាមិនទាន់ស្គាល់ ក៏ចុតិហើយបាន ។ ការដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងនោះ មិនមែនវិស័យរបស់អ្នក វិស័យរបស់អ្នកមានប្រមាណតិច ចំណែកការដឹង ការឃើញសត្វទាំងឡាយដែលចុតិ និងកើត ដោយប្រការទាំងពួង ជាវិស័យរបស់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ ដូច្នេះហើយ ទ្រង់ផ្សាយព្រះរស្មីទៅ ហាក់បីដូចប្រថាប់គង់នៅក្នុងទីចំពោះមុខ ត្រាស់ព្រះគាថានេះថា

បមាទំ អប្បមាទេន យទា ឧទតិ បណ្ឌិតោ
បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនឹ បជំ
បព្ពតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។

កាលណាបណ្ឌិតបន្ទោបង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ កាលណោះ លោកនឹងឡើងកាន់ប្រាសាទ គឺបញ្ញា ជាបុគ្គលមិនសោក រមែងឃើញពួកសត្វដែលមានសោក ជីវជនតែងឃើញពួកជនពាល ដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើលពួកជនដែលឋិតនៅលើផែនដី ដូច្នោះឯង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឧទតិ** *ជាដើម សេចក្តីថា កាលណាបណ្ឌិតកំពូននូវធម៌ មានការមិនប្រមាទជាលក្ខណៈ មិនឲ្យឱកាសដល់ការប្រមាទឈ្មោះថា រមែងបន្ទោបង់ គឺរមែងបណ្តេញនូវសេចក្តីប្រមាទនោះ ។ ដោយកម្លាំងនៃសេចក្តីមិនប្រមាទ ដូចទឹកថ្លឹហូរចូលស្រះបោក្ខរណី ញ៉ាំងទឹកចាស់ឲ្យរញ្ជួយហើយ មិនឲ្យឱកាសដល់ទឹកចាស់នោះ រមែងរុញ គឺច្រានទឹកចាស់នោះឲ្យហូរចេញទៅ ដោយទីបំផុតរបស់ខ្លួនដូច្នោះឯង ។ កាលនោះ បណ្ឌិតនោះ មានសេចក្តីប្រមាទដែលបន្ទោបង់ហើយ បំពេញបដិបទាដែលសមគួរដល់ការមិនប្រមាទនោះ ។ ឡើងកាន់បញ្ញា ប្រៀបដូចប្រាសាទ ពោល គឺទិព្វចក្ខុដ៏បរិសុទ្ធ ដោយអត្ថថា ខ្ពង់ខ្ពស់ ដោយបដិបទានោះ ដូចបុគ្គលឡើងកាន់ប្រាសាទតាមជណ្តើរ ដូច្នោះ ឈ្មោះថា មិនសោយសោក ព្រោះភាពជា*

បុគ្គលលះនូវបង់ព្រួញ គឺសេចក្តីសោកចេញបានហើយ ។ រមែងពិចារណាឃើញ គឺរមែងមើលឃើញប្រជា គឺពួកសត្វ ដែលឈ្មោះថា មានសេចក្តីសោក ព្រោះភាពជាបុគ្គលមិនទាន់បានលះសរ គឺសេចក្តីសោក ដែលចុតិនិងបជិសន្ធិដោយទិព្វចក្ខុ ។

សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា ដូចបុគ្គលឈរលើកំពូលភ្នំ រមែងសម្លឹងឃើញជនដែលឈរលើផែនដីបានដូច្នោះ អធិប្បាយថា បុគ្គលឈរលើកំពូលភ្នំ រមែងមើលឃើញជនដែលឈរត្រង់ផែនដីបាន ឬឈរលើប្រាសាទខាងលើ រមែងមើលឃើញជនដែលឈរក្នុងបរិវេណនៃប្រាសាទបាន ដោយមិនលំបាក យ៉ាងណា អ្នកប្រាជ្ញ គឺបណ្ឌិត បានដល់ ព្រះមហាខីណាស្រពនោះ ក៏រមែងពិចារណាឃើញបុគ្គលពាលទាំងឡាយ ដែលមិនទាន់ដកពូជ គឺវដ្តៈបាន ចុតិ និងបជិសន្ធិ ដោយមិនលំបាក ដូច្នោះ ។

ក្នុងកាលចប់គាថា មហាជនធ្វើឲ្យជាក់ច្បាស់ហើយ នូវព្រះអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

រឿងមហាកស្សបត្ថេរ ចប់

រឿង ភិក្ខុ ២ អង្គជាសម្វាញ់នឹងគ្នា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុពីររូប ជាសម្វាញ់នឹងគ្នា ត្រាស់ព្រះធម្មទេសនានេះថា **អប្បមត្តោ បមត្តេសុ** ជាដើម ។

បានញ្ចថា ភិក្ខុពីររូបនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ចូលទៅកាន់វិហារ ដែលតាំងនៅក្នុងព្រៃ ។ ក្នុងភិក្ខុពីររូបនោះ ភិក្ខុមួយរូបរកខសមកអស់កាលមួយថ្ងៃហើយ រៀបជើងក្រាន អង្គុយអាំងភ្លើង សន្ទនានឹងពួកភិក្ខុកំលោះ និងសាមណេរអស់បឋមយាម ។ មួយរូបទៀត មិនប្រមាទ ធ្វើសមណធម៌ ជាស់តឿនភិក្ខុនោះថា អាវុសោ អ្នកកុំធ្វើយ៉ាងនោះ ព្រោះអបាយ ៤ ជាផ្ទះ ជាទីដេកនៃពួកជនដែលប្រមាទហើយ ។ ធម្មតាព្រះពុទ្ធទាំងឡាយ ដែលបុគ្គលអួតអាង មិនអាចឲ្យត្រេកអរបាន ។ លោកមិនស្តាប់ពាក្យជាស់តឿនរបស់ភិក្ខុនោះ ។ ភិក្ខុនោះគិតថា ភិក្ខុនេះមិនជឿពាក្យអាត្មាអញ ទើបមិនប្រាថ្នានឹងជាស់តឿន លោកមិនប្រមាទហើយ បានធ្វើសមណ-ធម៌ ។ ចំណែកព្រះថេរៈដែលខ្ជិលច្រអូស អាំងភ្លើងក្នុងបឋមយាមហើយ ក្នុងកាលដែលភិក្ខុ ១ អង្គទៀតដើរចង្ក្រមហើយ ចូលទៅកាន់បន្ទប់ ទើបចូលទៅពោលថា អ្នកខ្ជិលច្រអូសច្រើន អ្នកចូលមកកាន់ព្រៃដើម្បីការដេកឬ បុគ្គលរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះពុទ្ធហើយ ក្រោកឡើងធ្វើសមណធម៌ អស់កាលយប់ និងថ្ងៃមិនគួរឬ ដូច្នេះហើយ ក៏ចូលទៅកាន់លំនៅរបស់ខ្លួនហើយដេក ចំណែកភិក្ខុក្រៅអំពីនេះ សម្រាកក្នុងមជ្ឈិមយាមហើយ ត្រឡប់ក្រោក

ឡើង ធ្វើសមណធម៌ក្នុងបច្ឆិមយាម លោកមិនប្រមាទយ៉ាងនោះ អស់កាលមិនយូរ ក៏សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយ ។ ភិក្ខុទ្វិលច្រអូសក្រៅអំពីនេះ ឲ្យកាលកន្លងទៅដោយសេចក្តីប្រមាទតែម្យ៉ាង ។ ភិក្ខុពីរូបនោះ ចេញវស្សាហើយ ទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។

ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយភិក្ខុពីរូបនោះហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនប្រមាទ ធ្វើសមណធម៌ហើយឬ កិច្ចនៃបព្វជិតរបស់ពួកអ្នក ដល់ទីបំផុតហើយឬ ភិក្ខុអ្នកប្រមាទក្រាបទូលថា បពិត្រព្រះអង្គ ការមិនប្រមាទរបស់ភិក្ខុនោះ នឹងមានមកអំពីណា តាំងអំពីទៅលោកដេកលក់ ឲ្យកាលវេលាកន្លងទៅហើយ ។ ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ ចុះអ្នកវិញ ភិក្ខុទ្វិលច្រអូសក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរកឧសមកក្នុងពេលថ្ងៃ រៀបជើងក្រានហើយ អង្គុយអាំងភ្លើងអស់បឋមយាម មិនដេកលក់ ឲ្យកាលវេលាកន្លងទៅហើយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា អ្នកប្រមាទហើយ ឲ្យកាលកន្លងទៅទទេ នៅមកពោលថា ខ្លួនមិនប្រមាទ ហើយធ្វើបុគ្គលមិនប្រមាទឲ្យជាអ្នកប្រមាទ ។ អ្នកដូចជាសេះដែលមានខ្លួនទុព្វល មានថ្ងៃជើងអន់ថយហើយ ក្នុងសម្នាក់នៃបុត្រតថាគត ចំណែកបុត្ររបស់តថាគតនេះ ដូចជាសេះដែលមានថ្ងៃជើងរហ័ស ក្នុងសម្នាក់របស់អ្នក ដូច្នេះហើយ ទើបត្រាស់គាថានេះថា

អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ
អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ ។

បណ្ឌិតមានប្រាជ្ញាមុះមុត កាលបុគ្គលកំពុងប្រមាទ លោកមិនប្រមាទ កាលបុគ្គលកំពុងដេកលក់ លោកភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែបនោះ ដូចសេះលឿនដែលទៅចោលនូវសេះមានកម្លាំងទន់ទាប ដូច្នោះឯង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បមត្តោ** *សេចក្តីថា ឈ្មោះថា បុគ្គលដល់ព្រមដោយការមិនប្រមាទ ព្រោះជាអ្នកដល់នូវការបរិបូណ៌នៃសតិ បានដល់ព្រះខីណាស្រព ។*

បទថា **បមត្តេសុ** *សេចក្តីថា កាលសត្វទាំងឡាយ តាំងនៅហើយក្នុងការបណ្តែតបណ្តាយសតិ ។ បទថា* **សុត្តេសុ** *គឺកាលសត្វទាំងឡាយ ឈ្មោះថា ប្រព្រឹត្តដេកលក់ គ្រប់ឥរិយាបថនោះឯង ព្រោះមិនមានធម៌ជាគ្រឿងភ្ញាក់រឭក គឺសតិ ។ បទថា* **ពហុជាគរោ** *បានដល់ តាំងនៅក្នុងធម៌ជាគ្រឿងភ្ញាក់រឭក គឺបរិបូណ៌នៃសតិដ៏ច្រើន ។ បទថា* **អពលស្សំវ** *សេចក្តីថា ដូចសេះសន្ធពអាជានេយ្យ មានសម្ពុះជើងរហ័ស រត់ចោលសេះដែលមានកម្លាំងខ្សោយ មានសម្ពុះអន់ហើយ ដោយភាពជាសេះមានជើងជាប់ទៅ ដូច្នោះ ។*

បទថា **សុមេធសោ** *ជាជើម សេចក្តីថា បុគ្គលមានបញ្ញាដ៏កំពូល រមែងលះបុគ្គលបែបនោះទៅ ដោយអាគមន គឺបរិយត្តិខ្លះ ដោយអធិគមន គឺការ*

សម្រេចមគ្គផលខ្លះ អធិប្បាយថា កាលបុគ្គលមានបញ្ញាទន់ខ្សោយ ព្យាយាមរៀនព្រះសូត្រ មួយសូត្រនោះឯង ។ បុគ្គលមានបញ្ញាល្អ រមែងរៀនបានមួយវគ្គ រមែងលះទៅដោយអាគមន គឺបរិយត្តិយ៉ាងនេះមុន ។ ម្យ៉ាងទៀត កាលបុគ្គលមានបញ្ញាអន់ខ្សោយ កំពុងព្យាយាមធ្វើទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃនោះឯង និងរៀនកម្មដ្ឋាន ស្វាធ្យាយនុ៎ះឯង ក្នុងកាលជាចំណែកខាងដើម បុគ្គលដែលមានបញ្ញាល្អ ចូលទៅកាន់ទីសម្រាកពេលយប់ ឬទីសម្រាកពេលថ្ងៃ ដែលអ្នកជំទែធ្វើ ពិចារណាកម្មដ្ឋាន ញុំាងកិលេសសព្វយ៉ាងឲ្យអស់ទៅ ធ្វើនវលោកុត្តរធម៌ ៩ ប្រការ ឲ្យតាំងនៅក្នុងកណ្តាប់ដៃបាន បុគ្គលមានបញ្ញាល្អ រមែងលះទៅបានដោយអធិគមន គឺការសម្រេចមគ្គផលយ៉ាងនេះ ។ ម្យ៉ាងទៀត បុគ្គលមានបញ្ញាល្អ លះ គឺចោលបុគ្គលមានបញ្ញាអាក្រក់នោះនៅក្នុងវដ្ដៈ ដកខ្លួនចេញអំពីវដ្ដៈទៅដោយពិត ។

ក្នុងកាលចប់គាថា មហាជនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ភិក្ខុ ២ អង្គជាសម្ងាញ់នឹងគ្នា ចប់

រឿង សក្កនេវរាជ

លំនាំដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យក្រុងវេសាលី គង់នៅក្នុងកូដាគារ-សាលា ទ្រង់ប្រារព្ធសក្កទេវរាជ ត្រាស់ធម្មទេសនានេះថា **អប្បមាទេន មឃវា** ជាដើម ។

សេចក្តីពិស្តារថា ស្តេចលិច្ឆវីព្រះនាមថាមហាលិ នៅក្នុងក្រុងវេសាលី ។ ទ្រង់ស្តាប់ទេសនាក្នុងសក្កបញ្ហសូត្រ របស់ព្រះតថាគតហើយ ទ្រង់ត្រិះរិះថា ព្រះសម្មាសម្ពុទ្ធ ត្រាស់សម្បត្តិរបស់សក្កទេវរាជជាច្រើន ព្រះអង្គទ្រង់ឃើញហើយ ទើបត្រាស់ ឬទ្រង់មិនឃើញហើយត្រាស់ហ្ន៎ ទ្រង់ស្គាល់ស្តេចសក្កឬហ្ន៎ អញនឹងទូលសួរព្រះអង្គ ។

គ្រានោះឯង ស្តេចលិច្ឆវី ព្រះនាមមហាលិ ចូលទៅគាល់ដល់ទីដែលព្រះដ៏មានព្រះភាគគង់នៅ កាលចូលទៅគាល់ហើយ ទើបថ្វាយបង្គំព្រះដ៏មានព្រះភាគ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ស្តេចមហាលិលិច្ឆវី កាលអង្គុយក្នុងទីសមគួរនាចំណែកម្ខាងហើយ បានក្រាបទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សក្កទេវរាជជាស្តេចនៃទេវតាទាំងឡាយ ព្រះអង្គឃើញហើយឬ ។

ព្រះដ៏មានព្រះភាគត្រាស់ថា មហាលិ សក្កទេវរាជជាស្តេចនៃទេវតាទាំងឡាយ តថាគតឃើញហើយ ។ មហាលិពោលថា បពិត្រព្រះអង្គ សក្កទេវរាជនោះ ជាសក្កៈកែងក្បាយពិត ព្រោះថា សក្កទេវរាជទាំងឡាយ បុគ្គល

ឃើញបានដោយលំបាក ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលមហាលិ តថាគត ស្គាល់សក្ក:ផង ស្គាល់ធម៌ដែលធ្វើឲ្យជាសក្ក:ផង សក្កទេវរាជ ដល់នូវភាព ជាសក្ក: ព្រោះសមាទាននូវធម៌ណា តថាគតស្គាល់ធម៌ទាំងនោះឯង ។ ម្នាល មហាលិ សក្កទេវរាជ ជាស្តេចនៃទេវតាទាំងឡាយ ក្នុងកាលមុនជាមនុស្ស បានជាមាណពឈ្មោះមឃ: ព្រោះដូច្នោះ ទើបគេហៅថា **ស្តេចមឃវា** *។ ម្នាលមហាលិ សក្កទេវរាជ ជាស្តេចនៃទេវតាទាំងឡាយ ក្នុងកាលមុន ជា មនុស្ស បានឲ្យទានមុនគេ ព្រោះដូច្នោះ ទើបគេហៅថា* **ស្តេចបុរិន្ទ:** *។ ម្នាលមហាលិ សក្កទេវរាជ ជាស្តេចនៃទេវតាទាំងឡាយ ក្នុងកាលមុន ជា មនុស្ស បានឲ្យទានដោយគោរព ព្រោះដូច្នោះ ទើបគេហៅថា* **ស្តេចសក្ក:** *។ ម្នាលមហាលិ សក្កទេវរាជ ជាស្តេចនៃទេវតាទាំងឡាយ ក្នុងកាលមុន ជា មនុស្ស បានឲ្យទីស្នាក់អាស្រ័យ ព្រោះដូច្នោះ ទើបគេហៅថា* **ស្តេចវាសវ:** *។ ម្នាលមហាលិ សក្កទេវរាជ ជាស្តេចនៃទេវតាទាំងឡាយ ទ្រង់ត្រិះរិះនូវនន័យ មួយពាន់បានមួយរំពេច ព្រោះដូច្នោះ ទើបគេហៅថា* **សហស្សក្ខ** *។ ម្នាល មហាលិ នាងអសុរកញ្ញា ឈ្មោះសុជាតា ជាបជាបតីរបស់សក្ក: ជាស្តេចនៃ ទេវតាទាំងឡាយ ព្រោះដូច្នោះ ទើបគេហៅថា* **ស្តេចសុជម្បតី** *។ ម្នាល មហាលិ សក្កទេវរាជ ជាស្តេចនៃទេវតាទាំងឡាយ សោយរាជសម្បត្តិជា ឥស្សរិយាធិបតី នៃទេវតាទាំងឡាយ ជាន់តាវត្តិង្ស ព្រោះដូច្នោះ ទើបគេ ហៅថា* **ទេវានមិន្ទ:** *។ ម្នាលមហាលិ សក្កទេវរាជ ជាស្តេចសក្ក:ហើយ ព្រោះបានសមាទានវត្តបទ ៧ ណា វត្តបទ ៧ នោះ ឈ្មោះថា ស្តេចសក្ក:*

ជាកំពូលនៃទេវតាទាំងឡាយ ក្នុងកាលមុន ជាមនុស្ស សមាទានឲ្យបរិបូណ៌ហើយ ។ វត្តបទ ៧ ប្រការដូចម្តេច ។ គឺអាត្មាអញ គប្បីជាអ្នកចិញ្ចឹមមាតាបិតាអស់មួយជីវិត ១ គប្បីជាអ្នកមានប្រក្រតីប្រព្រឹត្តឱនលំទោនចំពោះអ្នកធំក្នុងត្រកូលអស់មួយជីវិត ១ គប្បីជាអ្នកពោលពាក្យផ្អែមល្ហែមអស់មួយជីវិត ១ គប្បីជាអ្នកមិនពោលញុះញង់អស់មួយជីវិត ១ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ ១ មានគ្រឿងបរិច្ចាគលះបង់ហើយ មានបាតដៃលាងហើយ ត្រេកអរហើយក្នុងការលះ គួរដល់ការសួរ ត្រេកអរក្នុងការចែកទាន គប្បីគ្រប់គ្រងផ្ទះអស់មួយជីវិត ១ ជាអ្នកពោលពាក្យសច្ចៈអស់មួយជីវិត ១ ជាអ្នកមិនក្រោធអស់មួយជីវិត ១ ។ បើសេចក្តីក្រោធ គប្បីកើតដល់អញសោត អញនឹងកាច់បំបាក់ចោលមួយរំពេច ដូច្នេះ ម្នាលមហាលិ ស្តេចសក្កៈដល់នូវភាពជាសក្កៈ ព្រោះបានសមាទានវត្តបទ ៧ ណា វត្តបទ ៧ នោះ បានជារបស់ស្តេចសក្កៈ ដែលជាស្តេចនៃទេវតាទាំងឡាយ កាលកើតជាមនុស្សក្នុងកាលមុន សមាទាន ឲ្យបរិបូណ៌ហើយ ដូច្នេះឯង ។

ព្រះដ៏មានព្រះភាគ កាលត្រាស់វេយ្យាករណ៍នេះហើយ បានត្រាស់ព្រះពុទ្ធវចនៈខាងក្រោយថា

ពួកទេវតានៅឋានតាវត្តិង្ស បានហៅជនអ្នកចិញ្ចឹមមាតាបិតា អ្នកកោតក្រែងបុគ្គលជាច្បងក្នុងត្រកូល មានវាចាល្អិតទន់ និយាយតែពាក្យផ្អែមល្ហែម លះបង់ពាក្យញុះញង់ ប្រកបក្នុងការលះបង់សេចក្តីកំណាញ់ មានសម្តីទៀងទាត់ ជាជនគ្របសង្កត់សេចក្តី

ក្រោធនោះឯង ថាជាសប្បុរស ។

ព្រះដ៏មានព្រះភាគត្រាស់ថា មហាលិ កម្មនេះ សក្កៈធ្វើក្នុងគ្រាជាមយ-មាណព ដូច្នេះហើយ កាលមហាលិលិច្ឆវី ជ្រាបថ្នាំនឹងស្តាប់កិច្ចបដិបត្តិរបស់សក្កៈនោះដោយពិស្តារ ទើបទូលសួរទៀតថា បពិត្រព្រះអង្គ មយមាណព បដិបត្តិដូចម្តេច ទើបត្រាស់ថា ម្នាលមហាលិ បើដូច្នោះ ចូរស្តាប់ចុះ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល មាណពឈ្មោះមយៈ ក្នុងអចលគាម ជែនមគធៈ ទៅកាន់ទីធ្វើការងារក្នុងស្រុក ឃុសធូលីដោយចុងម្រាមជើងក្នុងទីដែលខ្ជិនឈរហើយ បានធ្វើឲ្យជាទីរមណីយដ្ឋាន ហើយស្នាក់នៅ ។ បុគ្គលម្នាក់ទៀតយកដៃច្រានគាត់ចេញអំពីទីនោះហើយ បានស្នាក់នៅក្នុងទីនោះខ្លួនឯង គាត់មិនក្រោធចំពោះបុគ្គលនោះ បានធ្វើទីដទៃឲ្យជារមណីយដ្ឋានហើយស្នាក់នៅ អ្នកដទៃក៏យកដៃច្រានគាត់ចេញអំពីទីនោះហើយ បានស្នាក់នៅក្នុងទីនោះខ្លួនឯង ។ គាត់មិនក្រោធចំពោះបុគ្គលនោះ បានធ្វើទីដទៃឲ្យជារមណីយដ្ឋាន ហើយស្នាក់នៅ ។ បុរសទាំងឡាយដែលចេញទៅហើយអំពីផ្ទះ ក៏យកដៃច្រានគាត់ចេញអំពីទីដែលគាត់ជម្រះហើយ ដោយប្រការដូច្នេះ ។ គាត់គិតថា ជនទាំងអស់នោះ ជាអ្នកបានទទួលសេចក្តីសុខហើយ កម្មនេះ គប្បីជាកម្មឲ្យសេចក្តីសុខដល់អញ ដូច្នេះហើយ ស្អែកឡើង កាន់យកចបទៅធ្វើទីប៉ុនមណ្ឌលនៃលានឲ្យជារមណីយដ្ឋានហើយ ។ ពពួកជនបានទៅស្នាក់នៅក្នុងទីនោះឯង ។

ក្នុងរដូវរងា គាត់បានបង្កាត់ភ្លើងឲ្យជនទាំងនោះ ក្នុងរដូវក្តៅ បានឲ្យទឹក

បន្ទាប់មក គាត់គិតថា ឈ្មោះថា រមណីយដ្ឋាន ជាទីស្រឡាញ់របស់ជនទាំងពួង ឈ្មោះថា មិនជាទីស្រឡាញ់របស់បុគ្គលណាម្នាក់មិនមាន តាំងអំពីនេះទៅ អញគួរធ្វើផ្លូវឲ្យរាបស្មើ ដូច្នេះហើយ ទើបចេញទៅអំពីស្រុកទាំងព្រលឹមធ្វើផ្លូវឲ្យរាបស្មើ កាប់មែកឈើដែលគួរកាប់ ។

ក្រោយមក បុរសម្នាក់ទៀតឃើញគាត់ហើយពោលថា នែសម្លាញ់ តើអ្នកធ្វើអ្វី មឃមាណពពោលថា ខ្ញុំធ្វើផ្លូវជាទីទៅឋានសួគ៌របស់ខ្ញុំ បុរសនោះពោលថា បើដូច្នោះ ខ្ញុំក៏ជាសម្លាញ់របស់អ្នក មឃមាណពពោលថា ចូរជាសម្លាញ់របស់ខ្ញុំចុះ ធម្មតាឋានសួគ៌រមែងជាស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន ។

បន្ទាប់អំពីនោះមក ក៏បានគ្នាពីរនាក់ ។ ចំណែកបុរសដទៃទៀត ឃើញជនទាំងពីរហើយ សួរយ៉ាងនោះឯង លុះជ្រាបហើយ ក៏ជាសម្លាញ់របស់ជនទាំងពីរ មនុស្សដទៃៗ ទៀត ក៏បានធ្វើយ៉ាងនោះ រួមមនុស្សទាំងអស់ ទើបជា ៣៣ នាក់ ដោយប្រការដូច្នេះ ។

ជនទាំងអស់មានដៃកាន់វត្ថុ មានចបជាដើម ធ្វើផ្លូវឲ្យរាបស្មើបានចម្ងាយប្រមាណមួយយោជន៍ និងពីរយោជន៍ ។

មេស្រុកឃើញបុរសទាំងនោះហើយ គិតថា មនុស្សទាំងនេះប្រកបហើយ ក្នុងឋាន:ដែលមិនគួរប្រកប បើជនទាំងនេះគប្បីនាំវត្ថុទាំងឡាយ មានត្រី និងសាច់ជាដើមមកអំពីព្រៃ ឬធ្វើស្រាហើយផឹក ឬធ្វើកម្មបែបនោះដទៃអញ គប្បីបានចំណែកខ្លះណាមួយ ។

លំដាប់នោះ ទើបមេស្រុកហៅជនទាំងនោះមកសួរថា ពួកឯងធ្វើអ្វី ជនទាំងនោះពោលថា ធ្វើផ្លូវទៅឋានសួគ៌ ។ មេស្រុកពោលថា ធម្មតាអ្នកគ្រប់គ្រងផ្ទះទាំងឡាយ ធ្វើយ៉ាងនោះមិនគួរ គួរនាំវត្ថុទាំងឡាយ មានត្រី និងសាច់ ជាដើមមកអំពីព្រៃ គួរធ្វើស្រាផឹក និងគួរធ្វើការងារទាំងឡាយ មានប្រការផ្សេងៗ ។

ជនទាំងនោះ ជំទាស់ពាក្យរបស់មេស្រុកនោះ ។ សូម្បីត្រូវមេស្រុកពោលដដែលៗ ក៏ជំទាស់រឿយៗ ទៅ ។ មេស្រុកក្រោធហើយ គិតថា អញនឹងឲ្យពួកវាវិនាស ទើបទៅកាន់សម្នាក់របស់ព្រះរាជា ក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំឃើញពួកចោរត្រាច់ទៅដោយចង្គាជាពួក កាលព្រះរាជាត្រាស់ថា អ្នក ចូរទៅ ចូរចាប់ពួកវា ហើយនាំមក ។ មេស្រុកបានធ្វើតាមបញ្ជា ហើយបង្ហាញដល់ព្រះរាជា ។ ព្រះរាជាទ្រង់មិនទាន់ពិចារណា ទ្រង់បង្គាប់ថា ពួកអ្នក ចូរឲ្យជីវិតជាន់ ។

មយមាណពបានឲ្យឱវាទដល់ជនទាំងឡាយថា សម្ងាញ់ទាំងឡាយ វៀរមេត្តាហើយ ទីពឹងរបស់ពួកយើងមិនមាន អ្នកទាំងឡាយមិនត្រូវធ្វើសេចក្តីក្រោធក្នុងបុគ្គលណាឡើយ ចូរជាអ្នកមានចិត្តស្មើដោយមេត្តាចិត្ត ក្នុងព្រះរាជា ក្នុងមេស្រុក ក្នុងជីវ និងក្នុងមនុស្សជនទាំងនោះ ក៏បានធ្វើយ៉ាងនោះ ។

លំដាប់នោះ ជីវមិនអាចចូលជិតបាន ព្រោះអានុភាពនៃមេត្តារបស់ជនទាំងនោះ ។ ព្រះរាជាទ្រង់ស្តាប់សេចក្តីនោះហើយត្រាស់ថា ជីវាឃើញមនុស្សច្រើន ទើបមិនអាចជាន់បាន អ្នកទាំងឡាយចូរទៅយកកន្ទេលផែនគ្រប ហើយ

សីមឲ្យជាន់ ។ ជីរ ទោះគេយកកន្ទេលផែងគ្របជនទាំងនោះ ចូលទៅជាន់ក៏ថយក្រោយ ឈរអំពីចម្ងាយនោះឯង ។ ព្រះរាជាទ្រង់ស្តាប់ព្រឹត្តិហេតុនោះហើយ ទ្រង់ត្រិះរិះថា ក្នុងរឿងនេះពិតជាមានហេតុ ហើយបញ្ជាឲ្យហៅជនទាំងនោះមក ត្រាស់សួរថា នែបាទាំងឡាយ ពួកអ្នកអាស្រ័យយើង មិនបានអ្វីឬ ជនទាំងនោះពោលថា បពិត្រព្រះអង្គ តើមានរឿងអ្វី ព្រះរាជាត្រាស់ថា បានឮថា ពួកអ្នកជាចោរ ត្រាច់ទៅក្នុងព្រៃដោយការចងគ្នាជាពួក ជនទាំងនោះពោលថា បពិត្រព្រះអង្គ អ្នកណាក្រាបទូលយ៉ាងនោះ ព្រះរាជាត្រាស់ថា មេស្រុក ជនទាំងនោះពោលថា បពិត្រព្រះអង្គ ពួកទូលបង្គំមិនមែនជាចោរ តែពួកទូលបង្គំជម្រះផ្លូវទៅកាន់ស្ថានសួគ៌ រៀងៗ ខ្លួន ទើបធ្វើកម្មនេះ និងកម្មនេះ ។ មេស្រុកដឹកនាំពួកទូលបង្គំក្នុងការធ្វើអកុសល បំណងឲ្យពួកខ្ញុំព្រះអង្គ ដែលមិនធ្វើតាមពាក្យរបស់ខ្លួនឲ្យវិនាស ក្រោធហើយ ទើបក្រាបទូលយ៉ាងនោះ ។

លំដាប់នោះ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ជនទាំងនោះ ជាបុគ្គលដល់នូវសោមនស្សត្រាស់ថា បាទាំងឡាយ សត្វតិរច្ឆាននេះគង់ស្គាល់គុណរបស់ពួកអ្នក យើងជាមនុស្សក៏មិនអាចស្គាល់ ចូរអ្នកអត់ទោសដល់យើងចុះ កាលត្រាស់យ៉ាងនោះហើយ បានព្រះរាជទានមេស្រុក មួយអន្ទើដោយបុត្រ និងភរិយា ឲ្យធ្វើជាទាសៈ ជីរនោះឲ្យជាពាហនៈសម្រាប់ជិះ និងស្រុកនោះឲ្យជាគ្រឿងប្រើប្រាស់តាមសប្បាយ ដល់ជនទាំងនោះ ។

ជនទាំងនោះពោលថា ពួកយើងឃើញអានិសង្សនៃបុណ្យក្នុងបច្ចុប្បន្ន

នេះឯង ក៏មានចិត្តផូរផង់ដោយប្រមាណក្រៃលែង ផ្ទាស់វេណគ្នាជិះដំរីនោះ ទៅប្រឹក្សាគ្នាថា ឥឡូវនេះ ពួកយើងគួរធ្វើបុណ្យឲ្យក្រៃលែងឡើង សាកសួរគ្នាថា ពួកយើងនឹងធ្វើអ្វីហ្ន៎ ក៏ស្រែះស្រួលគ្នាថា នឹងសាងសាលាជាទីសម្រាករបស់មហាជនឲ្យមាំទាំ ក្នុងផ្លូវធំដែលមានមុំ ៤ ទើបពួកគេបញ្ជាឲ្យរកជាងឈើមកហើយ ចាប់ផ្តើមធ្វើសាលា តែព្រោះប្រាសចាកការពេញចិត្តក្នុងមាតុគ្រាម ទើបមិនបានឲ្យចំណែកបុណ្យ ក្នុងសាលានោះដល់មាតុគ្រាមទាំងឡាយ។

ក្នុងផ្ទះរបស់មឃមាណពមានស្រី ៤ នាក់ គឺនាងសុនន្ទា សុចិត្រា សុធម្មា និងសុជាតា ។ បណ្តាស្រី ៤ នាក់នោះ នាងសុធម្មារួមគំនិតនឹងជាងឈើពោលថា នែបង សូមធ្វើខ្ញុំឲ្យជាធំក្នុងសាលានេះចុះ ដូច្នេះហើយ បានឲ្យថ្លៃឈ្នួលដល់មេជាង ជាងឈើទទួលពាក្យថា បាន ហើយហាលឈើសម្រាប់ធ្វើហោជាង ឲ្យស្ងួតមុនវត្តដទៃ ហើយចាំងធ្វើហោជាងឲ្យសម្រេច ហើយឆ្លាក់អក្សរថា សាលាសុធម្មា ដូច្នេះហើយ យកសំពត់រុំរក្សាទុក ។

កាលជាងឈើសាងសាលាស្រេចហើយ ក្នុងថ្ងៃលើកហោជាង ទើបពោលនឹងជន ៣៣ នាក់នោះថា នែអ្នក ខ្ញុំនឹកកិច្ចដែលគួរធ្វើម្យ៉ាងមិនបាន ជនទាំងនោះពោលថា នែអ្នក កិច្ចនោះឈ្មោះអ្វី មេជាងពោលថា គឺហោជាង ។ ពួកជនទាំងនោះពោលថា ណ្ហើយចុះ ពួកយើងនឹងនាំហោជាងនោះមកឯង មេជាងពោលថា ខ្ញុំមិនអាចធ្វើដោយឈើដែលកាត់ឥឡូវនេះបាន ត្រូវបានឈើហោជាងដែលគេកាត់ ចាំងហើយរក្សាទុកអំពីមុននោះឯង ទើបប្រើបាន ជនទាំងនោះពោលថា ឥឡូវនេះ ពួកយើងគួរធ្វើដូចម្តេច ជាងឈើពោលថា បើ

ក្នុងផ្ទះរបស់បុគ្គលណា មានហោជាងដែលធ្វើទុកលក់ ដែលគេធ្វើសម្រេច ហើយ រក្សាទុកសោត គួរស្វែងរកហោជាងនោះ ។

ពួកជនទាំងនោះស្វែងរក ឃើញក្នុងផ្ទះរបស់នាងសុធម្មា ហើយឲ្យទ្រព្យ មួយពាន់ ក៏មិនបានដោយទ្រព្យដែលជាតម្លៃ កាលនាងសុធម្មាពោលថា បើ ពួកអ្នកធ្វើខ្ញុំឲ្យមានចំណែកបុណ្យ ក្នុងសាលាផងសោតខ្ញុំនឹងឲ្យ ជនទាំងនោះ ឆ្លើយថា ពួកខ្ញុំមិនឲ្យចំណែកបុណ្យដល់ពួកមាតុគ្រាម ។ លំដាប់នោះ ជាង ឈើពោលនឹងមនុស្សទាំងនោះថា នែអ្នក ពួកអ្នកនិយាយអ្វី វៀរតែព្រហ្មលោក ទីដទៃឈ្មោះថាមិនមានមាតុគ្រាម រមែងមិនមាន ពួកអ្នកចូរទទួលយកហោជាង ចុះ កាលបើដូច្នោះ ការងាររបស់ពួកយើងក៏នឹងដល់នូវការសម្រេច ។ ពួក ជនទាំងនោះទទួលថា សាធុ ហើយទទួលយកហោជាងនោះ សាងសាលាឲ្យ សម្រេចហើយ ចែកជា ៣ ចំណែក គឺក្នុងចំណែកមួយ សាងជាទីសម្រាប់នៅ របស់ពួកឥស្សរជន ចំណែកមួយសម្រាប់បុគ្គលក្រីក្រ ចំណែកមួយសម្រាប់ អ្នកមានជំងឺ ។

ជន ៣៣ នាក់ ឲ្យក្រាលក្តារ ៣៣ បន្ទះ ហើយឲ្យសញ្ញាដល់ដំរីថា បុគ្គលជាក្បៀវមកអង្គុយលើបន្ទះក្តារ ដែលបុគ្គលណាក្រាល ចូរនាំក្បៀវនោះ ទៅឲ្យសម្រាកនៅត្រង់ផ្ទះរបស់បុគ្គលនោះ ដែលជាម្ចាស់របស់បន្ទះក្តារនោះ ឯង ។ ការច្រចាប់ជើង ការច្រចាប់ខ្នង របស់គួរទំពា គួរបរិភោគ ទឹដេកគ្រប់ យ៉ាង និងជានាទីរបស់បុគ្គលនោះ ដែលជាម្ចាស់របស់បន្ទះក្តារនោះឯង ។

ដំរីទទួលបុគ្គលដែលមកហើយ នាំទៅកាន់ផ្ទះរបស់ម្ចាស់បន្ទះក្តារនោះ

ឯង ។ ក្នុងថ្ងៃនោះម្ចាស់របស់បន្ទះក្តារនោះ រមែងធ្វើកិច្ចដែលគួរធ្វើដល់បុគ្គលដែលដំរីនាំទៅនោះ ។ មឃមាណព ជាំដើមរលួសផ្អែមមួយដើមទុកមិនឆ្ងាយអំពីសាលា ហើយក្រាលបន្ទះថ្មត្រង់គល់រលួសផ្អែមនោះ ។ ពួកជនដែលចូលទៅហើយកាន់សាលា សម្លឹងមើលហោជាង អានអក្សរហើយ រមែងជ្រាប់គ្នាថា សាលាសុធម្មា ឈ្មោះរបស់ជន ៣៣ នាក់មិនជ្រាកដ ។ នាងសុនន្ទាគិតថា ជនទាំងនេះកាលធ្វើសាលា ធ្វើពួកយើងមិនឲ្យមានចំណែកបុណ្យ តែនាងសុធម្មា ក៏ធ្វើហោជាងរួមចំណែកទាល់តែបាន ព្រោះភាពជាបុគ្គលឈ្វាសអញក៏គួរធ្វើអ្វីមួយ តើនឹងធ្វើអ្វីហ្ន៎ ក្នុងរំពេចនោះ នាងក៏គិតដូច្នេះថា បុគ្គលដែលមកកាន់សាលា គួរបានទឹកផឹក និងទឹកងូត ។ អញនឹងឲ្យជីកស្រះបោក្ខ-រណី នាងឲ្យគេជីកស្រះបោក្ខរណីហើយ នាងសុចិត្រាគិតថា នាងសុធម្មាបានឲ្យហោជាង នាងសុនន្ទាបានឲ្យស្រះបោក្ខរណី អញគួរធ្វើអ្វីមួយ តើនឹងធ្វើអ្វីហ្ន៎ ពេលនោះ នាងដូច្នេះថា ក្នុងកាលដែលពួកជនមកកាន់សាលា ផឹកទឹក ងូតទឹកហើយទៅ គួរប្រដាប់កម្រងផ្កា ហើយទៅ អញនឹងធ្វើសួនផ្កា ។ នាងបានឲ្យគេសាងសួនផ្កា ដែលគួរជាទីមនោរម្យហើយ ។ បុគ្គលដែលហាមាត់ថា ក្នុងសួននោះមិនមានដើមឈើ ដែលចេញផ្កា ចេញផ្លែ ឈ្មោះនោះដូច្នេះ មិនមាន ។

ចំណែកនាងសុជាតាគិតថា អញជាកូនរបស់អ៊ំនៃមឃមាណពផង ជាបាទបរិចារិកាផង កម្មដែលមឃមាណពនោះធ្វើហើយ ក៏ឈ្មោះថា អញធ្វើដូចគ្នា កម្មដែលអញធ្វើហើយ ក៏ឈ្មោះថាមឃមាណពនោះធ្វើដូចគ្នា ដូច្នេះហើយ

មិនបានធ្វើអ្វីមួយ រវល់តែតែងខ្លួនប៉ុណ្ណោះ ឲ្យកាលកន្លងទៅហើយ ។

ចំណែកមយមាណព បំពេញវត្តបទទាំង ៧ គឺទំនុកបម្រុងមាតាបិតា ១ ប្រព្រឹត្តខ្មិនលំទោនចំពោះបុគ្គលចម្រើនក្នុងត្រកូល ១ ពោលពាក្យសច្ចៈ ១ មិនពោលពាក្យគ្រោតគ្រាត ១ មិនពោលពាក្យញុះញង់ ១ កម្ចាត់សេចក្តីកំណាញ់ ១ មិនក្រោធ ១ ដល់នូវភាពជាបុគ្គលគួរសរសើរយ៉ាងនេះថា

ពួកទេវតានៅស្ថានតាវត្តិង្ស បានហៅជនអ្នកចិញ្ចឹមមាតាបិតា អ្នកកោតក្រែងបុគ្គលជាច្បងក្នុងត្រកូល មានវាចាល្អិតទន់ និយាយតែពាក្យផ្អែមល្ហែម លះបង់ពាក្យញុះញង់ ប្រកបក្នុងការលះបង់សេចក្តីកំណាញ់ មានសម្តីទៀងទាត់ ជាជនគ្របសង្កត់សេចក្តីក្រោធនោះឯង ថាជាសប្បុរស ។

ក្នុងកាលអស់ជីវិត បានកើតជាសក្កទេវរាជក្នុងស្ថានតាវត្តិង្ស ។ សម្ងាញ់របស់ជនទាំងនោះ ក៏កើតក្នុងទីនោះដូចគ្នា ។ ជាងឈើកើតជាវិស្សកម្ម-ទេវបុត្រ ។

ក្នុងកាលនោះ ពួកអសុរនៅក្នុងកពតាវត្តិង្ស អសុរទាំងនោះគិតថាទេវបុត្រថ្មីៗ កើតហើយ ទើបត្រៀមពិធីលៀងដោយទឹកទិព្វ ។ សក្កទេវរាជទ្រង់ឲ្យសញ្ញាដល់បរិស័ទរបស់ព្រះអង្គ បំណងមិនឲ្យបុគ្គលមួយណាផឹក ពួកអសុរផឹកទឹកទិព្វស្រវឹងគ្រប់គ្នាហើយ ។ សក្កទេវរាជទ្រង់ត្រិះរិះថា អាត្មាអញនឹងត្រូវការអ្វីដោយភាពជាស្តេច ដែលទូទៅដោយជនទាំងនេះ ទ្រង់ឲ្យសញ្ញាដល់បរិស័ទរបស់ព្រះអង្គហើយ នាំគ្នាចាប់អសុរទាំងនោះត្រង់ជើងទាំងពីរ

គ្រវែងធ្លាក់ទៅក្នុងមហាសមុទ្រ ។ អសុរទាំងនោះ មានក្បាលសំយុងចុះទៅក្នុងសមុទ្រហើយ ។ ខណៈនោះ អសុរវិមានបានកើតត្រង់ផ្ទៃខាងក្រោយនៃជើងភ្នំសិនេរុ ដោយអានុភាពនៃបុណ្យរបស់ពួកគេ ។ ឈើឈ្នះចិត្តបាដលិគឺដើមច្រនៀង ក៏កើតហើយ ។

កាលសង្គ្រាមទេវតា និងអសុរប្រកៀកគ្នា កាលពួកអសុរបរាជ័យហើយឈ្មោះថា ទេវនគរក្នុងជាន់តាវត្តិង្ស ប្រមាណមួយម៉ឺនយោជន៍កើតឡើងហើយ ។ ក្នុងរវាងទ្វារទិសខាងកើត និងទិសខាងលិចនៃព្រះនគរនោះ មានផ្ទៃប្រមាណមួយម៉ឺនយោជន៍ ចន្លោះទ្វារទិសខាងត្បូង និងទិសខាងជើងក៏ស្មើគ្នា ។ ម្យ៉ាងទៀត ព្រះនគរនោះប្រកបដោយទ្វារមួយពាន់ ប្រដាប់ដោយឧទ្យាន និងស្រះបោក្ខរណី ។ ប្រាសាទឈ្មោះថា វេជយ័ន្ត កម្ពស់ ៧០០ យោជន៍ ប្រដាប់ដោយកែវ ៧ ប្រការ និងទង់ទាំងឡាយកម្ពស់ ៣០០ យោជន៍ ផុសឡើង ដោយផលនៃសាលាត្រង់កណ្តាលព្រះនគរនោះ ។ មានដងជាមាស មានទង់ជាកែវមណី ត្រង់ដងជាកែវមណី មានទង់ជាមាស ត្រង់ដងជាកែវប្រពាល មានទង់ជាកែវមុក្តា ត្រង់ដងជាកែវមុក្តា មានទង់ជាកែវប្រពាល ត្រង់ដងជាកែវ ៧ ប្រការ មានទង់ជាកែវ ៧ ប្រការ ទង់ដែលតាំងនៅកណ្តាល មានកម្ពស់ ៣០០ យោជន៍ ប្រាសាទកម្ពស់មួយពាន់យោជន៍ សម្រេចហើយដោយកែវ ៧ ប្រការ កើតហើយដោយផលនៃសាលា ដោយប្រការដូច្នេះ ។

ដើមបារិច្ឆត្តកៈ មានបរិមណ្ឌលផ្សាយទៅ ៣០០ យោជន៍ ដោយជុំវិញ

កើតឡើងដោយផលនៃការដាំដើមរលួសផ្អុង ។ បណ្ឌុកម្ពលសិលា មានពណ៌ដូចផ្ការជយព្រឹក្ស មានពណ៌ស្រគាំ និងពណ៌ឈូករោយ ដោយបណ្តោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្ពស់ ១៥ យោជន៍ ពាក់កណ្តាលនៃព្រះវរកាយ លិចចុះក្នុងវេលាអង្គុយ ប៉ោងឡើងក្នុងវេលាក្រោកឡើង កើតឡើងត្រង់គល់ បារិច្ឆត្តក: ដោយផលនៃការក្រាលបន្ទះថ្ម ។

ចំណែកជំរី កើតជាទេវបុត្រឈ្មោះឯរាវណ ពិតហើយ សត្វតិរច្ឆានទាំង-ឡាយ រមែងមិនមានក្នុងទេវលោក ព្រោះដូច្នោះ ក្នុងវេលាសក្កទេវរាជទ្រង់ចេញដើម្បីប្រពាតព្រះឧទ្យាន ទើបទេវបុត្រនោះកាឡាខ្ជូនជាជំរី ឈ្មោះឯរាវណ កម្ពស់ប្រមាណ ១៥០ យោជន៍ ។ ហត្ថីទេវបុត្រនោះ និម្មិតពោង ៣៣ ដើម្បីជាប្រយោជន៍ដល់ជន ៣៣ នាក់ ក្នុងពោងទាំងនោះ ពោងនីមួយៗ វង្វង់ប្រមាណ ៣ គាវុត បណ្តោយប្រមាណកន្ទះយោជន៍ ហត្ថីទេវបុត្រនោះ និម្មិតពោងឈ្មោះសុទស្សន: ប្រមាណ ៣០ យោជន៍ ត្រង់កណ្តាលពោងទាំងនោះ ដើម្បីជាប្រយោជន៍ដល់សក្កទេវរាជ ខាងលើនៃពោងនោះមានមណ្ឌបកែវប្រមាណ ១២ យោជន៍ មានទង់រចនាដោយកែវ ៧ ប្រការ កម្ពស់មួយយោជន៍ តាំងឡើងក្នុងចន្ទោះៗ ក្នុងមណ្ឌបកែវនោះ ។ បណ្តាញ កណ្តឹង ដែលត្រូវខ្យល់ស្រទន់បក់ហើយ មានសំឡេងដូចតន្ត្រីទិព្ធ អមដោយសំឡេងតន្ត្រីមានអង្គ ៥ សំយុងចុះត្រង់ជាយដោយជុំវិញ ។ បល្ទ័ង្កកែវ មណីប្រមាណមួយយោជន៍ជាព្រះទែន ដែលគេរៀបចំល្អហើយ ដើម្បីសក្ក-ទេវរាជ ត្រង់កណ្តាលមណ្ឌប សក្ក:រមែងគង់លើបល្ទ័ង្កនោះ ។ ទេវបុត្រ

៣៣ អង្គ អង្គុយលើរតនបល្ល័ង្ក ក្នុងពោធរបស់ខ្លួន ។ បណ្តាពោធ ៣៣ ពោធនីមួយៗ ហត្ថីទេវបុត្រនោះនិម្មិតភ្ញុក ៧ ក្នុងភ្ញុកទាំងនោះ ភ្ញុកនីមួយៗ ប្រវែង ៥០ យោជន៍ ក្នុងភ្ញុកនីមួយៗ មានស្រះបោក្ខរណី ៧ ក្នុងស្រះបោក្ខរណីមួយ មានគុម្ពឈូក ៧ គុម្ព ក្នុងគុម្ពនីមួយៗ មានផ្កា ៧ ក្នុងផ្កានីមួយៗ មានត្របក ៧ ត្របកនីមួយៗ មានទេពធីតារំ ៧ អង្គ មហោស្រពរមែងមានលើភ្ញុកដ៏រ ក្នុងទី ៥០ យោជន៍ ដោយជុំវិញយ៉ាងនេះឯង ។ សក្កទេវរាជសោយយសធំ ទ្រង់ត្រាច់ទៅ ដោយប្រការដូច្នេះ ។

នាងសុធម្មា លុះអស់អាយុហើយ បានទៅកើតក្នុងកពតាវត្តិង្សនោះដូចគ្នា ទេវសភាឈ្មោះសុធម្មាមានប្រមាណ ៥០០ យោជន៍ បានកើតហើយដល់នាង ។ បានឮថា ឈ្មោះថាទីដទៃដែលគួរត្រេកអរជាងនោះ រមែងមិនមានក្នុងអដ្ឋមីនៃខែ មានការស្តាប់ធម៌ក្នុងទីនោះឯង ។ រហូតដល់ថ្ងៃនេះ ជនទាំងឡាយឃើញទីដែលគួរត្រេកអរណាមួយហើយ ក៏គង់ពោលថា ដូចទេវសភាឈ្មោះសុធម្មា ។

នាងសុនន្ទា អស់អាយុហើយ បានទៅកើតក្នុងកពតាវត្តិង្សនោះដូចគ្នា ស្រះបោក្ខរណីឈ្មោះសុនន្ទា មានប្រមាណ ៥០០ យោជន៍ កើតហើយដល់នាង ។

សូម្បីនាងសុចិត្រា អស់អាយុហើយ ក៏បានទៅកើតក្នុងកពតាវត្តិង្សនោះដូចគ្នា សួនឈ្មោះចិត្តលតា មានប្រមាណ ៥០០ យោជន៍ ដែលពួកទេវបុត្រនាំពួកទេវបុត្រដែលមានបុព្វនិមិត្តកើតហើយ ឲ្យវង្វេងត្រាច់ទៅ កើតហើយ

ដល់នាង ។

ចំណែកនាងសុជាតា អស់អាយុហើយ កើតជាកុកញីក្នុងញកក្នុំមួយកន្លែង សក្កទេវរាជទ្រង់ប្រមើលមើលបាវិចារិការបស់ព្រះអង្គ ទ្រង់ជ្រាបថា នាងសុធម្មា កើតហើយក្នុងទីនេះដូចគ្នា ។ នាងសុនន្ទា និងនាងសុចិត្រាក៏យ៉ាងនោះ ទ្រង់ត្រិះរិះថា នាងសុជាតាកើតទីណាហ្ន៎ ឃើញនាងកើតក្នុងញកក្នុំនោះហើយ ទ្រង់ត្រិះរិះថា នាងសុជាតានេះល្ងង់ខ្លៅ មិនធ្វើបុណ្យណាមួយ ឥឡូវនេះកើតក្នុងកំណើតតិរច្ឆាន ឥឡូវនេះគួរអាត្មាអញ ឲ្យនាងធ្វើបុណ្យហើយនាំមកទីនេះ ដូច្នេះហើយ ទើបទ្រង់កាឡាអត្តភាពយាងទៅកាន់សម្នាក់របស់នាង ដោយកេរដែលគេមិនស្គាល់ត្រាស់សួរថា នាងត្រាច់ធ្វើអ្វីនៅទីនេះ កុកញីឆ្លើយថា នែអ្នក អ្នកគឺនរណា សក្កៈពោលថា ខ្ញុំឈ្មោះមឃៈជាប្តីរបស់នាង កុកពោលថា អ្នកកើតក្នុងទីណា សក្កៈពោលថា ខ្ញុំកើតក្នុងតាវត្តិង្សទេវលោក នាងដឹងទីកើតនៃស្រីជាសម្ងាញ់របស់នាងហើយឬ កុកញីពោលថា មិនដឹងទេ សក្កៈពោលថា ស្រីទាំងនោះ កើតក្នុងសម្នាក់ខ្ញុំដូចគ្នា នាងនឹងសួរសុខទុក្ខស្រីសម្ងាញ់របស់នាងឬទេ កុកញីពោលថា ខ្ញុំនឹងទៅទីនោះបានដូចម្តេច សក្កៈត្រាស់ថា ខ្ញុំនឹងនាំទៅក្នុងទីនោះ ដូច្នេះហើយ នាំទៅកាន់ទេវលោក លែងត្រង់មាត់ស្រះបោក្ខរណីឈ្មោះនន្ទា ត្រាស់ប្រាប់ដល់មហេសីទាំង ៣ ក្រៅអំពីនេះថា ពួកនាងនឹងមើលនាងសុជាតាសម្ងាញ់របស់ពួកនាងឬទេ មហេសីពោលថា បពិត្រព្រះអង្គ នាងនៅទីណា សក្កទេវរាជពោលថា នៅត្រង់ប្រាំងស្រះបោក្ខរណី ឈ្មោះនន្ទា ។

ព្រះមហេសីទាំង ៣ នោះ យាងទៅទីនោះធ្វើការចំអកថា ឱ រូបរបស់នាង ឱផលនៃការតែងខ្លួន គ្រានេះអ្នកទាំងឡាយ ចូរមើលចំពុះ មើលស្មង មើលជើងរបស់នាង អត្តភាពរបស់នាងប្រហែលជាស្អាតពិត ដូច្នេះហើយ ក៏ជៀសចេញទៅ ។

សក្កទេវរាជ យាងទៅសម្នាក់របស់នាងទៀត ត្រាស់សួរថា នាងជួបសម្ងាញ់ហើយឬ កាលនាងទូលថា ព្រះមហេសីទាំង ៣ នោះ ខ្ញុំម្ចាស់បានជួបហើយ គេនាំគ្នាចំអកខ្ញុំម្ចាស់ហើយក៏ទៅ សូមទ្រង់នាំខ្ញុំម្ចាស់ទៅត្រង់ញកក្នុំនោះវិញចុះ ដូច្នេះហើយ ទ្រង់នាំកុកញីនោះទៅកាន់ញកក្នុំវិញ លែងក្នុងទីនោះហើយ ត្រាស់សួរថា នាងឃើញសម្បត្តិរបស់ស្រីទាំង ៣ នោះហើយឬ កុកញីពោលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់ឃើញហើយ សក្កទេវរាជពោលថា នាងក៏គួរធ្វើឧបាយដែលជាហេតុឲ្យកើតក្នុងទីនោះ ។ កុកញីពោលថា បពិត្រព្រះអង្គ ខ្ញុំនឹងធ្វើដូចម្តេច សក្កទេវរាជត្រាស់ថា នាងនឹងរក្សាឱរាទដែលខ្ញុំឲ្យបានទេ កុកញីពោលថា បពិត្រព្រះអង្គ រក្សាបាន ។

លំដាប់នោះ សក្កទេវរាជក៏ប្រទានសីល ៥ ដល់នាង ហើយត្រាស់ថា ចូរនាងជាបុគ្គលកុំប្រមាទ រក្សាចុះ ដូច្នេះហើយ ក៏ចៀសចេញទៅ ។

ចាប់ពីកាលនោះមក នាងត្រាច់រកស៊ីតែត្រីដែលស្លាប់ឯងប៉ុណ្ណោះ ដោយកាលកន្លងទៅ ២-៣ ថ្ងៃ សក្កទេវរាជយាងទៅដើម្បីបំណងពិសោធចិត្តរបស់នាង ទើបកាឡាខ្លួនជាត្រីស្លាប់ ដេកផ្ងារត្រង់ផ្នែរឡាច់ ។ កុកញីឃើញត្រីនោះហើយ បានពាំយកដោយសម្គាល់ថាជាត្រីស្លាប់ ក្នុងកាលនឹងលេប ត្រីក៏កម្រើក

កន្ទុយទៀង កុកញ៉ីដឹងថាត្រីរស់ ទើបលែងក្នុងទឹក សក្កទេវរាជទ្រង់បណ្តាយ ឲ្យកាលកន្ទងទៅបន្តិចហើយ ទើបទ្រង់ធ្វើជាដេកផ្ងារខាងមុខកុកទៀត កុកញ៉ីក៏ពាំទៀត ដោយសម្គាល់ថាត្រីស្លាប់ ក្នុងកាលនឹងលេប ឃើញត្រីកម្រើកកន្ទុយ ទើបលែងដោយដឹងថា ត្រីរស់ ។ សក្កទេវរាជទ្រង់សាកល្បងយ៉ាងនោះគ្រប់ ៣ ដងហើយត្រាស់ថា នាងវក្ខាសីលបានល្អ ឲ្យកុកស្គាល់ព្រះអង្គហើយត្រាស់ថា ខ្ញុំមកដើម្បីប្រយោជន៍សាកល្បងនាង នាងវក្ខាសីលបានល្អ កាលវក្ខាបានយ៉ាងនោះមិនយូរប៉ុន្មាន ក៏នឹងកើតក្នុងសម្នាក់របស់ខ្ញុំពិត ចូរនាងជាបុគ្គលមិនប្រមាទចុះ ដូច្នេះហើយ ទ្រង់ចៀសចេញទៅ ។

ចាប់តាំងពីកាលនោះមក នាងបានត្រីដែលស្លាប់ឯងខ្លះ មិនបានខ្លះ កាលមិនបាន ដោយកាលកន្ទងទៅ ២-៣ ថ្ងៃប៉ុណ្ណោះក៏ស្គាំងស្គម ធ្វើកាលកិរិយាហើយ កើតជាធីតារបស់នាយស្ងួនធ្នាំងក្នុងក្រុងពារាណសី ដោយផលនៃសីលនោះ ។

បន្ទាប់មក ក្នុងកាលដែលនាងមានអាយុ ១៥-១៦ ឆ្នាំ សក្កទេវរាជទ្រង់ពិចារណាថា នាងកើតទីណាហ្ន៎ បានឃើញហើយទ្រង់ព្រះតម្រិះថា ឥឡូវនេះ គួរអញទៅទីនោះ ដូច្នេះហើយ ទើបទ្រង់យកកែវ ៧ ប្រការដែលប្រាកដដោយពណ៌ដូចផ្លែល្មៅ ជាក់ពេញរនេះតួច បរចូលទៅកាត់ក្រុងពារាណសី យាងទៅកាន់ថ្នល់ស្រែកប្រកាសថា អ្នកទាំងឡាយមកយកល្មៅចុះ តែត្រាស់នឹងបុគ្គលដែលយកសណ្តែកបាយ និងសណ្តែកវាជមាសជាដើមថា ខ្ញុំមិនឲ្យដោយតម្លៃ កាលទូលសួរថា អ្នកនឹងឲ្យដូចម្តេច ត្រាស់ថា ខ្ញុំឲ្យដល់ស្ត្រីអ្នក

រក្សាសីល ពួកអ្នកក្រុងពោលថា នែអ្នក ឈ្មោះថា សីលដូចម្តេច ពណ៌ខ្មៅ ឬពណ៌ខៀវជាដើម សក្កទេវរាជពោលថា ពួកអ្នកមិនស្គាល់សីល ថាដូចម្តេច នឹងរក្សាសីលនោះបានយ៉ាងណា តែខ្ញុំនឹងឲ្យដល់ស្ត្រីអ្នករក្សាសីល ពួកអ្នកស្រុកពោលថា នែអ្នក កូនស្រីរបស់នាយស្មូនឆ្នាំងនោះគ្រាច់ពោលថា ខ្ញុំរក្សាសីល ចូរឲ្យដល់ស្ត្រីនោះចុះ ។

សូម្បីធីតារបស់នាយស្មូនឆ្នាំងនោះ ក៏ទូលព្រះអង្គថា បើដូច្នោះ ក៏ឲ្យដល់ខ្ញុំចុះ សក្កទេវរាជពោលថា នាង គឺនរណា កូនស្រីនាយស្មូនឆ្នាំងពោលថា ខ្ញុំ គឺស្ត្រីមិនលះបង់សីល ៥ ។

សក្កទេវរាជពោលថា ល្អៅទាំងនោះខ្ញុំក៏នាំមកឲ្យចំពោះនាង ។ សក្កទេវរាជទ្រង់បរយានតូចទៅកាន់ផ្ទះនាងហើយ ប្រទានទ្រព្យដែលទេវតាគប្បីឲ្យដោយពណ៌ដូចផ្លែល្អៅ ធ្វើមិនឲ្យអ្នកជនៃលួចយកទៅបាន បង្ហាញខ្លួនព្រះអង្គឲ្យស្គាល់ហើយត្រាស់ថា នេះទ្រព្យសម្រាប់ចិញ្ចឹមជីវិតរបស់នាង ចូរនាងរក្សាសីល ៥ កុំឲ្យដាច់ ហើយចៀសចេញទៅ ។

ចំណែកធីតានាយស្មូនឆ្នាំងនោះ ចុតិអំពីអត្តភាពនោះហើយ កើតក្នុងផ្ទះរបស់បុគ្គលដែលមានពៀរចំពោះសក្កទេវរាជ ជាធីតារបស់អសុរ ដែលជាប្រធានក្នុងកពអសុរ ព្រោះភាពដែលនាងរក្សាសីលល្អហើយពីរអត្តភាព ទើបនាងជាអ្នកមានរូបស្អាត មានពណ៌សម្បុរដូចមាស ប្រកបដោយរូបសិរីដែលមិនសាធារណៈ គឺមិនទូទៅដល់ស្រីទាំងពួង ។ ស្តេចអសុរឈ្មោះថាវេបចិត្តិ ពោលនឹងបុគ្គលដែលមកហើយថា ពួកអ្នកមិនសមគួរដល់ធីតារបស់

ខ្ញុំ ហើយក៏មិនឲ្យធីតានោះដល់បុគ្គលណាមួយ គិតថា ធីតារបស់យើងនឹងជ្រើសរើសស្វាមីដែលសមគួរ ដល់ខ្លួនដោយខ្លួនឯង ដូច្នេះហើយ ទើបឲ្យពួកពលដែលជាអសុរប្រជុំគ្នា ហើយបានឲ្យកម្រងផ្កាក្នុងដៃរបស់ធីតានោះដោយប្រាប់ថា ចូរនាងទទួលបុគ្គលសមគួរជាប្តីដល់នាង ។

ក្នុងខណៈនោះ សក្កទេវរាជទ្រង់ប្រមើលមើលទីដែលនាងកើត ជ្រាបព្រឹត្តិហេតុនោះហើយ ទ្រង់ត្រិះរិះថា ឥឡូវនេះសមគួរដែលអញនឹងនាំយកនាងមក ដូច្នេះហើយ ទ្រង់បាននិម្មិតភេទជាអសុរចាស់ ទៅឈរខាងចុងបរិស័ទ ។ នាងអសុរកញ្ញានោះ កាលសម្លឹងមើលឆ្វេងស្តាំ លុះឃើញសក្កទេវរាជនោះ ក៏ជាអ្នកមានហឫទ័យស្រឡាញ់កើតឡើង ដោយអំណាចបុព្វសន្និវាសគ្របសង្កត់ហើយដូចអន្ទង់ទឹកធំ ក៏ជាក់ចិត្តថា នុ៎ះប្តីរបស់អញ ទើបបោះកម្រងផ្កាទៅខាងលើសក្កទេវរាជនោះ ពួកអសុរនីកាសថា ព្រះរាជារបស់ពួកយើងមិនបានបុគ្គលដែលសមគួរ ដល់ព្រះធីតាអស់កាលប្រមាណប៉ុណ្ណោះ ឥឡូវនេះបានហើយ បុគ្គលដែលចាស់ជាងគានេះឯង សមគួរដល់ធីតារបស់ទ្រង់ ដូច្នេះហើយ ទើបចៀសចេញទៅ ។

ចំណែកសក្កទេវរាជ ទ្រង់ចាប់អសុរកញ្ញានោះត្រង់ដៃហើយ ទ្រង់ប្រកាសថា យើងជាសក្កទេវរាជ ហើយទ្រង់ហោះទៅកាន់អាកាស ។ ពួកអសុរជឿថា ពួកយើងត្រូវសក្កទេវរាជបោកប្រាសហើយ ទើបនាំគ្នាដេញតាមសក្ក-ទេវរាជនោះទៅ ទេវបុត្រដែលជាសារថី ឈ្មោះមាតលិនាំវេជយ័ន្តរថមកបញ្ឈរក្នុងរវាងផ្លូវ ។ សក្កទេវរាជទ្រង់បីនាងឡើងក្នុងរថនោះហើយ បែរព្រះ

ភក្ត្រទៅកាន់ព្រះនគរ យាងទៅហើយ ។ ក្នុងកាលដែលសក្កទេវរាជនោះ យាងដល់សិម្ពលិវ័ន កូនគ្រុឌបានឮសំឡេងរថ កិតភ័យស្រែកយំហើយ ។ សក្កទេវរាជ ទ្រង់បានស្តាប់សំឡេងកូនគ្រុឌទាំងនោះហើយ ត្រាស់សួរមាតលិថា នុ៎ះសំឡេងសត្វអ្វីស្រែក មាតលិទូលថា បពិត្រព្រះអង្គ នុ៎ះជាសំឡេងកូនគ្រុឌ សក្កទេវរាជពោលថា ព្រោះហេតុអ្វី ទើបសត្វនោះយំ មាតលិពោលថា ព្រោះបានឮសំឡេងរថហើយខ្លាចស្លាប់ សក្កទេវរាជត្រាស់ថា អាស្រ័យយើងម្នាក់ឯង បក្សីប្រមាណប៉ុណ្ណេះ ត្រូវសម្លុះរបស់រថឲ្យលំបាកហើយ សត្វទាំងនេះ កុំបីវិនាសឡើយ ចូរអ្នកបររថត្រឡប់ចុះ ។ មាតលិ-ទេវបុត្រនោះឲ្យសញ្ញាដល់សេះសន្ធពមួយពាន់ ដោយខ្សែតីត្រឡប់រថហើយ ។ ពួកអសុរឃើញកិរិយានោះ គិតថា សក្កទេវរាជគេចទៅតាំងអំពីអសុរបុរីឥឡូវនេះ ត្រឡប់រថហើយ លោកនឹងបានអ្នកជំនួយដោយពិត ទើបត្រឡប់ចូលទៅកាន់អសុរបុរី តាមផ្លូវដែលមកហើយនោះឯង មិនអើតសីសៈឡើងទៀត ។

ចំណែកសក្កទេវរាជ ទ្រង់នាំនាងអសុរកញ្ញា ឈ្មោះសុជាតាទៅកាន់ទេវនគរហើយ ទ្រង់ស្តាបនាក្នុងតំណែងជាប្រធាននៃស្រីទេពអប្សរពីរកោដិកន្លះ ។ នាងទូលសូមពរនឹងសក្កទេវរាជថា បពិត្រមហារាជ មាតាបិតាឬបងប្រុស បងស្រីរបស់ខ្ញុំម្ចាស់ក្នុងទេវលោកនេះមិនមាន ទ្រង់ទៅទីណាមួយ គប្បីនាំខ្ញុំម្ចាស់ទៅទីទាំងនោះ សក្កទេវរាជបានប្រទានប្តេជ្ញាដល់នាងថា សាធុ ។

តាំងអំពីកាលនោះមក កាលផ្តាច់ត្តជាដលិរីក ពួកអសុរបំណងនឹងច្បាំង

ជាមួយសក្កទេវរាជ ទ្បើងមកដើម្បីបំណងនឹងច្បាំង ដោយសម្គាល់ថាជាកាល ដែលផ្តាបារិច្ឆត្តកទិព្វរបស់ពួកយើងរីក សក្កទេវរាជបានប្រទានការពារក្បាជល់ ពួកនាគខាងក្នុងបាតសមុទ្រ បន្ទាប់អំពីនោះពួកគ្រុឌ បន្ទាប់អំពីនោះពួកកុម្ភណ្ឌ បន្ទាប់អំពីនោះពួកយក្ខ បន្ទាប់អំពីនោះពួកចាតុម្មហារាជ ចំណែកជាន់លើ បង្អស់ ទ្រង់ប្រតិស្ឋានរូបឥន្ទសិប្បនិមិត្ត ដែលមានវជិរាវុធក្នុងដៃ ត្រង់ទ្វារ ព្រះនគរ ។ ពួកអសុរ សូម្បីឈ្នះពួកនាគជាដើមហើយ ឃើញរូបឥន្ទសិប្ប-និមិត្តអំពីចម្ងាយ រមែងគេចទៅដោយយល់ថា សក្កទេវរាជយាងមកហើយ ។

ព្រះសាស្តាត្រាស់ថា មហាលិ មយមាណពបដិបត្តិអប្បមាទបដិបទា យ៉ាងនេះ មយមាណពនោះមិនប្រមាទយ៉ាងនេះ ទើបដល់នូវភាពជាធំបែបនេះ ទ្រង់សោយរាជ្យក្នុងទេវលោកទាំងពីរ ឈ្មោះថា ការមិនប្រមាទនោះ បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើមសរសើរហើយ ព្រោះថា ការសម្រេចគុណ-វិសេសដែលជាលោកិយ និងលោកុត្តរទាំងអស់ រមែងមានព្រោះអាស្រ័យសេចក្តីមិនប្រមាទ ដូច្នេះហើយ ទើបត្រាស់គាថានេះថា

អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ
អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។

មយមាណព ដល់នូវភាពជាបុគ្គលប្រសើរបំផុត ជាង ទេវតាទាំងឡាយ ព្រោះតែសេចក្តីមិនប្រមាទ អ្នកប្រាជ្ញទាំង-ឡាយ តែងសរសើរនូវសេចក្តីមិនប្រមាទ តួះតិះដៀលនូវ សេចក្តីប្រមាទ សព្វៗ កាល ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បមាទេន** គឺព្រោះការមិនប្រមាទ ដែលធ្វើទុកតាំងអំពីដើម ឆ្ពោះផ្លូវ ភូមិ ប្រទេសក្នុងអចលគ្រាម ។

បទថា **មឃវា** ជាដើម សេចក្តីថា មឃមាណពដែលប្រាកដឈ្មោះថា មឃវៈ ក្នុងឥន្ទ្រវនេះ ឈ្មោះថា ដល់នូវភាពជាបុគ្គលប្រសើរជាងទេវតាទាំងឡាយ ព្រោះភាពជាព្រះរាជានៃទេវលោកទាំងពីរ ។

បទថា **បសំសន្តិ** សេចក្តីថា បណ្ឌិតទាំងឡាយមានព្រះពុទ្ធជាដើម រមែងសរសើរសេចក្តីមិនប្រមាទតែម្យ៉ាង ។ សួរថា ព្រោះហេតុអ្វី វិសជ្ជនាថា ព្រោះសេចក្តីមិនប្រមាទជាហេតុឲ្យបានគុណវិសេស ដែលជាលោកិយ និងលោកុត្តរទាំងអស់ ។

បាទព្រះគាថាថា **បមាទោ គរហិតោ សទា** សេចក្តីថា ចំណែកការប្រមាទដែលព្រះអរិយៈទាំងនោះតិះដៀល គឺនិន្ទាហើយជានិច្ច ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះការប្រមាទជាឫសគល់នៃវិបត្តិគ្រប់យ៉ាង ។ ពិតមែនភាពជាបុគ្គលមានជោគអាក្រក់ក្នុងមនុស្សក្តី ចូលដល់អបាយក្តី សុទ្ធតែមានសេចក្តីប្រមាទជាមូលទាំងអស់ ដូច្នេះ ។

ក្នុងវេលាចប់គាថា ស្តេចលិច្ឆវី ព្រះនាមថាមហាលិ ទ្រង់តាំងនៅក្នុងសោតាបត្តិផលហើយ សូម្បីបរិស័ទដែលប្រជុំគ្នាជាច្រើន ក៏បានជាព្រះអរិយបុគ្គល មានសោតាបន្នជាដើម ដូច្នេះឯង ॥

រឿង សក្កនេវាទ ចប់

រឿង អញ្ញតរភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុរូបណាមួយ ត្រាស់ព្រះធម្មទេសនានេះថា **អប្បមាទរតោ ភិក្ខុ** ជាដើម ។

បានឮមកថា ភិក្ខុរូបនោះញុំាងព្រះសាស្តាឲ្យប្រាប់ហើយនូវកម្មដ្ឋាន អំពីភាពជាព្រះអរហន្ត ចូលព្រៃបំពេញព្យាយាម ក៏មិនអាចសម្រេចអរហត្តបាន លោកគិតថា អញនឹងទៅទូលព្រះសាស្តាឲ្យត្រាស់ប្រាប់កម្មដ្ឋាន ឲ្យវិសេសក្រៃលែងទៀត ដូច្នេះហើយ ចេញអំពីព្រៃនោះ កំពុងនិមន្តមកកាន់សម្នាក់ព្រះសាស្តា ឃើញភ្លើងព្រៃឆាំងឡើងជាច្រើនក្នុងរវាងផ្លូវ ប្រញាប់ប្រញាល់ឡើងលើភ្នំមួយ អង្គុយមើលភ្លើងដែលកំពុងឆេះ កាន់យកជាអារម្មណ៍ថា ភ្លើងនេះ ដុតនូវពួជទាំងឡាយ ច្រើន និងតិច យ៉ាងណា សូម្បីភ្លើង គឺអរិយមគ្គញ្ញាណ ក៏នឹងដុតនូវសំយោជន:ទាំងឡាយ ច្រើន និងតិចទៅក៏ដូច្នោះ ។

ព្រះសាស្តា ប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ជ្រាបវារចិត្តរបស់លោកហើយ ត្រាស់ថា ម្នាលភិក្ខុយ៉ាងនោះឯង សំយោជន:ទាំងឡាយល្អិត និងគ្រោតគ្រាត ដែលកើតខាងក្នុងនៃសត្វទាំងនេះ ដូចពួជច្រើនខ្លះ តិចខ្លះ ដូច្នោះ ការដុតសំយោជន:ទាំងនោះដោយភ្លើង គឺញាណហើយ ធ្វើឲ្យជារបស់មិនគួរកើតទៀត ដូច្នេះហើយ ទ្រង់បញ្ចេញព្រះរស្មីប្រាកដបីដូចប្រថាប់គង់ក្នុងទីចំពោះមុខរបស់ភិក្ខុនោះ ត្រាស់គាថានេះថា

អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា
សញ្ញោជនំ អណុំ ថូលំ ឌហំ អគ្គីវ គច្ឆតិ ។

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទ តែងជុតចោលនូវសំយោជនៈ ទាំងតូចទាំងធំ ដូចភ្លើងឆេះ (វាលនូវកម្ទេច ទាំងតូចទាំងធំ) ដូច្នោះឯង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បមាទរតោ** *សេចក្តីថា ត្រេកអរ គឺអភិរម្យហើយក្នុងសេចក្តីមិនប្រមាទ បានដល់ ញុំាងកាលឲ្យកន្លងទៅដោយសេចក្តីមិនប្រមាទ ។*

បានព្រះគាថាថា **ភយទស្សិ វា** *សេចក្តីថា បុគ្គលឃើញភ័យក្នុងសេចក្តីប្រមាទ មានការចូលជល់នរកជាដើម ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកឃើញនូវសេចក្តីប្រមាទ ដោយភាពជាភ័យព្រោះសេចក្តីប្រមាទនោះ ជាឫសគល់នៃការកើតទ្បើងទាំងនោះ ។*

បទថា **សញ្ញោជនំ** *សេចក្តីថា សំយោជនៈ ១០ យ៉ាង ជាគ្រឿងប្រកបគ្រឿងចងពួកសត្វក្នុងវដ្តទុក្ខ អាចញុំាងសត្វឲ្យលិចចុះក្នុងវដ្តៈបាន ។*

បទថា **អណុំ ថូលំ** *គឺតូចនិង ធំ ។*

បានព្រះគាថាថា **ឌហំ អគ្គីវ គច្ឆតិ** *សេចក្តីថា ភិក្ខុនោះត្រេកអរហើយក្នុងសេចក្តីមិនប្រមាទ រមែងជុតសំយោជនៈនោះដោយភ្លើង គឺញាណ ដែលខ្លួនសម្រេចហើយ ដោយសេចក្តីមិនប្រមាទ គឺធ្វើឲ្យជារបស់មិនគួរកើតទ្បើងតទៅទៀត ដូចភ្លើងឆេះពូជ នៃភ្លើងច្រើន និងតិចនោះឯងទៅ ដូច្នោះ ។*

ក្នុងកាលចប់គាថា ភិក្ខុនោះអង្គុយដូចមុននោះឯង ជុតសំយោជនៈទាំង

អស់ហើយ សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំង៤ព្រាយ មកតាមអាកាស សរសើរព្រះសរីរៈរបស់ព្រះតថាគត ដែលមានពណ៌ដូចមាសហើយថ្វាយបង្គំចៀសចេញទៅ ដូច្នេះឯង ៕

រឿង អញ្ញតរភិក្ខុ ចប់

រឿង ព្រះតិស្សត្ថេរអ្នកមានប្រក្រតីនៅក្នុងនិគមលំនាំដើម

ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះតិស្សត្ថេរអ្នកមានប្រក្រតីនៅក្នុងនិគម ត្រាស់ធម្មទេសនានេះថា **អប្បមាទរតោ** *ជាដើម ។*

សេចក្តីពិស្តារថា កុលបុត្រម្នាក់កើតចម្រើនឡើងក្នុងស្រុក ដែលតាំងនៅក្នុងនិគមមួយកន្លែងមិនឆ្ងាយអំពីក្រុងសាវត្ថី បព្វជ្ជាហើយ បានឧបសម្បទាក្នុងសាសនារបស់ព្រះសាស្តាហើយ ប្រាកដឈ្មោះថា និគមតិស្សត្ថេរ ជាអ្នកប្រាថ្នាតិច សន្តោស ស្ងាត់ ប្រារព្ធព្យាយាម លោកគ្រាច់បិណ្ឌបាតតែក្នុងផ្ទះរបស់ញាតិជានិច្ច ។ កាលមនុស្សទាំង៤ព្រាយ មានអនាថបិណ្ឌិកសេដ្ឋីជាដើម ធ្វើមហាទានក្តី កាលព្រះបាទបសេនទិកោសលទ្រង់បំពេញអសទិសទានក្តី ក៏មិនមកក្រុងសាវត្ថី ។

ទើបពួកភិក្ខុសន្ទនាគ្នាថា ព្រះនិគមតិស្សត្ថេរនេះ ក្រោកឡើងស្រួលបួល

ហើយ ក៏ច្រឡូកច្រឡំដោយញាតិ កាលជនទាំងឡាយ មានអនាថបិណ្ឌិកសេដ្ឋី ជាដើមធ្វើមហាទានក្តី កាលព្រះបាទបសេនទិកោសល ទ្រង់បំពេញអសទិសទានក្តី លោកមិនមកទេឬយ ដូច្នេះហើយ ទើបក្រាបទូលព្រះសាស្តា ។

ព្រះសាស្តា ត្រាស់ឲ្យហៅភិក្ខុនោះមកហើយ ត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកធ្វើយ៉ាងនោះពិតឬ កាលលោកក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនមានការច្រឡូកច្រឡំដោយញាតិ ខ្ញុំព្រះអង្គអាស្រ័យពួកមនុស្សដែលជាញាតិទាំងនោះ រមែងបានអាហារល្មមទំពាបាន ខ្ញុំព្រះអង្គគិតថា កាលអាត្មាអញបានអាហារអាក្រក់ក្តី ប្រណីតក្តី ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានហើយ ប្រយោជន៍អ្វីដោយការស្វែងរកអាហារទៀត ដូច្នេះហើយ ទើបមិនមក ឈ្មោះថា ការច្រឡូកច្រឡំដោយពួកញាតិ មិនមានដល់ខ្ញុំព្រះអង្គ តាមប្រក្រតីព្រះអង្គក៏ទ្រង់ជ្រាបអធ្យាស្រ័យរបស់លោក ទើបប្រទានសាធុការថា សាធុ សាធុ ភិក្ខុ ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុ ការដែលអ្នកបានអាចារ្យដូចតថាគតហើយ បានជាអ្នកប្រាថ្នាតិចមិនអស្ចារ្យទេឬយ ព្រោះថា ឈ្មោះថាភាពជាអ្នកប្រាថ្នាតិចនេះ ជាលំអានរបស់តថាគត ជាបវេណីរបស់តថាគត ដូច្នេះហើយ កាលភិក្ខុទាំងឡាយទូលអារាធនាហើយ ទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល សត្វសេកច្រើនពាន់ នៅក្នុងព្រៃល្វាមួយកន្លែង ជិតប្រាំងស៊ីងគង្គា ក្នុងព្រៃហិមពាន្ត ។ បណ្តាសេកទាំងនោះ ស្តេចសេកមួយ កាលផ្លែឈើដែលខ្លួនអាស្រ័យអស់ហើយ ចឹកស៊ីដែលពន្លកស្វាយ ឬសម្បកដែលនៅសល់ ផឹកទឹកក្នុងស៊ីងគង្គា ជាសត្វមានសេចក្តីប្រាថ្នាតិចក្រៃលែង សន្តោស

មិនទៅក្នុងទីដទៃ ដោយគុណ គឺសេចក្តីជ្រាបថ្នាតិច និងសន្តោសរបស់ស្តេចសេកនោះ សក្តពិភពញាប់ញ័រហើយ ។

សក្កទេវរាជ ទ្រង់ធ្វើអាវជ្ជនៈឃើញហេតុនោះហើយ ទ្រង់បណ្តាលឲ្យដើមឈើនោះក្រៀមស្វួត ដោយអានុភាពរបស់ខ្លួន ដើម្បីសាកល្បងស្តេចសេកនោះ ដើមឈើបាក់ហើយ សល់នៅត្រឹមតែជង្គត់ប៉ុណ្ណោះ ជាប្រហោងតូចប្រហោងធំ គឺពុក ។ កាលខ្យល់បក់មក ក៏ឮសំឡេងដូចត្រូវបុគ្គលគោះ តាំងនៅហើយ ខ្នុតទាំងឡាយហើរចេញអំពីប្រហោងរបស់ដើមឈើនោះ ។ ស្តេចសេកចឹកស៊ីលម្អិតខ្នុតទាំងនោះ ហើយផឹកទឹកក្នុងស៊ីងគង្គា មិនទៅក្នុងទីដទៃ មិនជ្រកខ្យល់ និងកម្តៅថ្ងៃ ទំត្រង់ចុងជង្គត់ល្ហានោះឯង ។ សក្កទេវរាជ ទ្រង់ជ្រាបភាពដែលស្តេចសេកនោះ មានការជ្រាបថ្នាតិចក្រៃលែង ទ្រង់ត្រិះរិះថា អញនឹងឲ្យស្តេចសេកនោះ ពោលគុណនៃមិត្តធម៌ ហើយឲ្យពរដល់បក្សីនោះ ធ្វើដើមល្ហាឲ្យមានផ្លែមិនចេះអស់ហើយ ដូច្នេះហើយ និម្មិតព្រះកាយជាស្តេចហង្សមួយ នាំនាងអសុរកញ្ញាឈ្មោះសុជាតាខាងមុខ យាងទៅព្រៃល្ហានោះ ទំត្រង់មែកនៃដើមឈើមួយ ក្នុងទីមិនឆ្ងាយ កាលសន្ទនាជាមួយស្តេចសេកនោះ ត្រាស់គាថានេះថា

> *ដើមឈើទាំងឡាយច្រើនណាស់ ដែលមានស្លឹកខៀវ មានផ្លែជាអនេក ព្រោះហេតុអ្វីហ្ន៎ បានជាសេកនេះមានចិត្តរីករាយជានិច្ចតែនឹងជង្គត់ឈើពុកស្វួត ។*

សុវជាតកទាំងអស់ បណ្ឌិតគប្បីឲ្យពិស្តារតាមនយ ដែលពោលមក

ហើយ ក្នុងនវកនិបាតនោះឯង តែការកើតឡើងនៃរឿងប៉ុណ្ណោះ ក្នុងនវកនិបាត និងក្នុងទីនេះផ្សេងគ្នា ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា សក្ក-ទេវរាជក្នុងកាលនោះ បានជាអានន្ទ ស្តេចសេកបានជាតថាគត ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថាភាពជាបុគ្គលមានការប្រាថ្នាតិច នេះជាបែបផែន ជាបវេណីរបស់តថាគត ការដែលតិស្សៈអ្នកមានប្រក្រតីនៅក្នុងនិគម បុត្ររបស់តថាគតបានអាចារ្យដូចតថាគតហើយ ជាអ្នកមានការប្រាថ្នាតិច មិនគួរអស្ចារ្យឡើយ ធម្មតាភិក្ខុគប្បីជាអ្នកមានការប្រាថ្នាតិច ដូចតិស្សៈដែលមានប្រក្រតីនៅក្នុងនិគម ព្រោះថា ភិក្ខុបែបនេះ ជាអ្នកមិនគួរវិនាសចាកមគ្គ និងផល រមែងជាអ្នកនៅជិតព្រះនិព្វានដោយពិតនោះឯង ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ ។

ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ ឈ្មោះថា ស្ថិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ជាទព្រះគាថាថា **អភព្វោ បរិហានាយ** សេចក្តីថា ភិក្ខុបែបនោះ មិនគួរដើម្បីវិនាសចាកធម៌ គឺសមថៈ និងវិបស្សនា ឬចាកមគ្គ

និងផល គឺវិនាសចាកគុណធម៌ដែលខ្លួនសម្រេចហើយ ក៏មិនមែន នឹងមិនសម្រេចគុណធម៌ដែលខ្លួនមិនបានសម្រេច ក៏មិនមែន ។

ចាទព្រះគាថាថា **និព្វានសេរ្ច សន្តិកេ** *សេចក្តីថា តាំងនៅក្នុងទីជិតនៃកិលេសបរិនិព្វានក៏មាន អនុបាទាបរិនិព្វានក៏មាន ។*

ក្នុងកាលចប់ព្រះគាថា ព្រះតិស្សត្ថេរ ជាអ្នកមានប្រក្រតីនៅក្នុងនិគមសម្រេចអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយហើយ ។ ជនដទៃជាច្រើនបានជាអរិយបុគ្គល មានសោតាបន្នជាដើម ។ ទេសនាមានផលច្រើនដល់មហាជនដូច្នេះឯង ។

រឿង ព្រះតិស្សត្ថេរអ្នកមានប្រក្រតីនៅក្នុងនិគម ចប់

អប្បមាទវគ្គទី ២ ចប់

ព្រះ

សុត្តន្តបិដក

និង

បរមត្ថជោតិកា អដ្ឋកថា

សេចក្តីប្រែជាភាសាខ្មែរ

ខុទ្ទកនិកាយ

ខុទ្ទកបាឋ ធម្មបទគាថា ឧទាន

បឋមភាគ

ចាលីប្រែ ៥២



ជោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣

សុត្តន្តបិដក ខុទ្ទកនិកាយ

ធម្មបទគាថា ចិត្តវគ្គទី ៣

[១៣] *អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បាន ដូចអ្នកធ្វើព្រួញពត់ព្រួញឲ្យត្រង់ ។ ចិត្តនេះដែលបុគ្គលលើកទ្បើងចាកអាលយ គឺកាមគុណ ៥ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្ដៈ ជាទីនៅនៃមារ រមែងញាប់ញ័រ ។ ដូចត្រីដែលគេលើកទ្បើងចាកទីនៅ គឺទឹក បោះទៅលើគោកដូច្នោះឯង ។*

ការទូន្មានចិត្ត ដែលសង្កត់សង្កិន បានដោយលំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច (ព្រោះថា) ចិត្តដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ (ព្រោះថា) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

អ្នកទាំងឡាយណា នឹងសង្រ្គមចិត្តដែលនៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហា គឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ។

ប្រាជ្ញា រមែងមិនបរិបូណ៌ដល់បុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ ។ ភ័យ រមែងមិនមានដល់បុគ្គលអ្នកមានចិត្តមិនទន់ទីកដោយរាគៈ មានចិត្តដែលទោសខ្លាំងរួបមិនបាន មានបុណ្យ និងបាបលះចោលហើយ ភ្ញាក់រឭកជានិច្ច ។ បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាឆ្នាំង គប្បីបិទនូវចិត្តនេះ ឲ្យដូចជាបិទទ្វារនគរ ដើម្បីច្បាំងនូវមារដោយអាវុធ គឺបញ្ញា គប្បីរក្សាទុកនូវធម៌ ដែលខ្លួនឈ្នះហើយ មិនគប្បីជាអ្នកជំអក់នៅ (ក្នុងធម៌នោះ) ឡើយ ។

ឱហ្ន៎ មិនយូរប៉ុន្មានទេតើ កាយនេះ មានវិញ្ញាណទៅច្រាស គេយកទៅចោលផុតហើយ មុខជានឹងដេកស្តូកស្តឹងលើផែនដី ដូចជាអង្កត់ឧសរកប្រយោជន៍គ្មាន ។

ចោរក្រឡេកឃើញចោរផងគ្នា ឬក៏បុគ្គលមានពៀរ ក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តីវិនាសណាមួយ ដល់គ្នា ចិត្តដែលបុគ្គលតាំងទុកខុសហើយ រមែងធ្វើបុគ្គលនោះ ឲ្យអាក្រក់ក្រៃលែងជាងសេចក្តីវិនាសនោះទៅទៀត ។

មាតា បិតា មិនគប្បីធ្វើហេតុនោះបាន ឬជនទាំងឡាយដទៃជាញាតិមិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្ត ដែលបុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាងហេតុនោះបាន ។

ចិត្តវគ្គទី ៣ ចប់

អដ្ឋកថា

ចិត្តវគ្គទី ៣

រឿង មេឃិយត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅត្រង់ភ្នំឈ្មោះចាលិកា ទ្រង់ប្រារព្ធដល់ព្រះមេឃិយៈ ត្រាស់ធម្មទេសនានេះថា **ផន្ទនំ ចបលំ ចិត្តំ** *ជាដើម ។*

មេឃិយសូត្រ[1] ទាំងអស់ បណ្ឌិតគប្បីសម្តែងឲ្យពិស្តារ ដើម្បីឲ្យរឿងនៃព្រះមេឃិយត្ថេរនោះជាក់ច្បាស់ ព្រះសាស្តាត្រាស់ហៅព្រះមេឃិយត្ថេរដែលមិនអាចប្រកបសេចក្តីព្យាយាមក្នុងអម្ពវនោះបាន ព្រោះភាពដែលលោកត្រូវវិតក្ក ៣ គ្របសង្កត់ហើយ ត្រាស់ថា ម្នាលមេឃិយៈ អ្នកលះបង់តថាគតដែលអង្វរហើយថា ម្នាលមេឃិយៈ តថាគតនៅម្នាក់ឯង ចូរអ្នកបង្អង់សិនទម្រាំភិក្ខុដទៃរូបខ្លះប្រាកដ ដូច្នេះ ទុកតថាគតនៅតែឯង ហើយទៅ ឈ្មោះថាធ្វើកម្មដ៏ធ្ងន់ ។ ឈ្មោះថា ភិក្ខុមិនគួរជាធម្មជាតសុះទៅរហ័ស ការញ៉ាំងចិត្តនោះឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន រមែងគួរ ដូច្នេះហើយ ទើបទ្រង់ភាសិតព្រះគាថា ២ ព្រះគាថានេះថា

១- បិ. ៥៣ ទំ. ១៩២ ។

ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ
ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ ។
វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ
បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ ។

អ្នកប្រាជ្ញតែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយ កម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បាន ដូចអ្នកធ្វើ ព្រួញ ពត់ព្រួញឲ្យត្រង់ ។ ចិត្តនេះ ដែលបុគ្គលលើកទ្បើងចាក អាលយពីកាមគុណ ៥ ចោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បី លះបង់នូវវដ្តៈ ជាទីនៅនៃមារ រមែងញាប់ញ័រ ដូចត្រីដែលគេ លើកទ្បើង ចាកទីនៅ គឺទឹក ចោះទៅលើគោក ដូច្នោះឯង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ផន្ទនំ** *គឺអន្ទះអន្ទែងនៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ។*

បទថា **ចបលំ** *សេចក្តីថា មិនតាំងនៅក្នុងអារម្មណ៍មួយបាន ដូចទារកក្នុងស្រុក មិនស្ងៀមនៅដោយឥរិយាបថមួយដូច្នោះ ទើបឈ្មោះថាញាប់ញ័រ ។*

បទថា **ចិត្តំ** *បានដល់ វិញ្ញាណ ។ វិញ្ញាណនោះ ព្រះដ៏មានព្រះភាគ ត្រាស់ហៅថា ចិត្ត ព្រោះជាធម្មជាតវិចិត្រដោយភូមិ វត្ថុ អារម្មណ៍ និង វិថីចិត្ត មានកិរិយាចិត្តជាដើម ។*

បទថា **ទុរក្ខំ** *សេចក្តីថា ឈ្មោះថា ដែលបុគ្គលរក្សាបានដោយលំបាក*

ព្រោះតាំងទុកបានលំបាកក្នុងអារម្មណ៍ ដែលជាទីសប្បាយមួយនោះឯង ដូចគោដែលធ្លាប់ទំពាស៊ីស្រូវក្នុងស្រែ ដែលដេរជាសទៅដោយសម្ហូង ដូច្នោះ ។

បទថា **ឧន្និវារយំ** សេចក្តីថា ឈ្មោះថាដែលបុគ្គលហាមបានលំបាក ព្រោះជាធម្មជាតដែលរក្សាបានលំបាក ដើម្បីនឹងហាម គឺរារាំងចិត្តដែលទៅកាន់វិសភាគារម្មណ៍ ។

ពីរបទថា **ឧស្សុកាវោ ទេជនំ** សេចក្តីថា ជាងព្រួញនាំយកកំណាត់ឈើមួយមកអំពីព្រៃហើយ ធ្វើមិនឲ្យមានសម្បក ហើយលាបដោយទឹកបាយ និងប្រេង រាលត្រង់អំបែងរងើកភ្លើង ពត់ត្រង់ប្រគាបឈើ ធ្វើឲ្យបាត់រៀចគឺឲ្យត្រង់ ឲ្យជារបស់គួរបាញ់រោមទ្រាយបាន កាលធ្វើហើយ ទើបសម្តែងសិប្ប:ដល់ព្រះរាជា និងរាជមហាមាត្យ រមែងបានសក្ការ: និងការរាប់អានដ៏ច្រើន យ៉ាងណា បុរសអ្នកមានប្រាជ្ញា គឺបុរសឈ្លាស បានដល់ បុគ្គលដឹងច្បាស់ ក៏ដូច្នោះដូចគ្នា គឺធ្វើចិត្តនេះដែលមានសភាពញាប់ញ័រជាដើម ឲ្យអស់សម្បក គឺឲ្យប្រាសចាកកិលេសដែលគ្រោតគ្រាត ដោយអំណាចធុតង្គ និងការនៅក្នុងព្រៃ ហើយលាបដោយជ័រ គឺសទ្ធា រាលដោយការព្យាយាម ដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងតាមចិត្ត ពត់ត្រង់ប្រគាប គឺសមថ: និងវិបស្សនា ធ្វើឲ្យត្រង់ គឺមិនឲ្យរៀច បានដល់ ឲ្យអស់ព្យសន៍ កាលធ្វើហើយ ពិចារណាសង្ខារទាំងឡាយ ទម្លាយបង់នូវគំនរអវិជ្ជាធំបានហើយ ធ្វើគុណវិសេសនេះ គឺវិជ្ជា ៣ អភិញ្ញា ៦ លោកុត្តរធម៌ ៩ ឲ្យនៅក្នុងកណ្តាប់ដៃនោះឯង រមែងបានជាទក្ខិណេយ្យបុគ្គលដ៏កំពូល ។

បទថា **វារិជោវ** *ប្រែថា ដូចត្រី ។ ពីរបទថា* **ថលេ ខិត្តោ** *បានដល់ ដែលព្រានសន្ធូចបោះទៅលើគោកដោយដៃ ជើង ឬដោយគ្រឿងជាក់ មាន សំណាញ់ជាដើម ណាមួយ ។*

គប្បីជ្រាបវិនិច្ឆ័យក្នុងបាទព្រះគាថាថា **ឱកមោកតឧព្ភតោ** *ដូចតទៅ នេះ ទឹក ឈ្មោះថា* **ឱក** *ក្នុងពាក្យនេះថា* **ឱកបុណ្ណោហិ ចីវរេហិ កិលន្ត-រូបា យេន សាវត្ថី** *កិកុអ្នកក្រុងជាហ៊ ក៏មានចីវរទាំងឡាយទទឹកជោក បាន សេចក្តីលំបាកកាយ នាំគ្នាដើរសំដៅទៅកាន់ក្រុងសាវត្ថី ។ អាលយ ឈ្មោះ ថា* **ឱក** *ដូចក្នុងពាក្យនេះថា* **ឱកំ បហាយ អនិកេតសារី** *ព្រះតថាគត លះបង់នូវផ្ទះ (អាលយ) ជាអ្នកមិនមានការអន្ទោលទៅរកកន្លែងស្នាក់ (អារម្មណ៍ទាំង ៦) ។ ពាក្យទាំងពីរ ក៏រមែងបានក្នុងបាទព្រះគាថានេះ ។ ក្នុងបទថា* **ឱកមោកតោ** *នេះ មានអត្ថដូច្នេះ ចាកលំនៅ គឺទឹក ចាក អាលយ ពោល គឺទឹក ។ បទថា* **ឧព្ភតោ** *ប្រែថា ដែលព្រានសន្ធូចលើក ឡើងហើយ ។*

បាទព្រះគាថាថា **បវិជន្តុតិទំ ចិត្តំ** *សេចក្តីថា ចិត្តនេះ គឺដែលត្រេកអរ ហើយ ក្នុងអាលយ គឺកាមគុណ ៥ ដែលព្រះយោគាវចរលើកឡើងហើយ ចាកអាលយ គឺកាមគុណ ៥ នោះ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន រោល ដោយការព្យាយាម ដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងចិត្ត ដើម្បីលះវដ្ដៈ ពោល គឺអន្ទាក់មារ រមែងអន្ទះអន្ទែង គឺរមែងមិនអាចតាំងនៅក្នុងវិបស្សនា-កម្មដ្ឋាននោះបានដូចត្រីនោះ កាលព្រានសន្ធូចលើកឡើងអំពីអាលយ គឺទឹក*

ហើយបោះទៅលើគោក កាលមិនបានទឹករមែងអន្ទះអន្ទែង ដូច្នោះ ។ កាលបើដូច្នេះ បុគ្គលអ្នកមានបញ្ញា មិនជាក់ជុះ: រមែងធ្វើចិត្តនោះឲ្យត្រង់ គឺឲ្យគួរដល់ការងារ ដោយនយដែលពោលហើយនោះឯង ។

ម្យ៉ាងទៀត ចិត្តនេះ កាលលះអន្ទាក់មារ គឺកិលេសវដ្តមិនបាន តាំងនៅ រមែងអន្ទះអន្ទែងដូចត្រី ដូច្នោះ ព្រោះដូច្នោះ ព្រះយោគាវចរ គួរលះអន្ទាក់មារ គឺគួរលះអន្ទាក់មារ ពោល គឺកិលេសវដ្ត ដែលជាហេតុអន្ទះអន្ទែងនៃចិត្តនោះ ដូច្នេះឯង ។

ក្នុងកាលចប់គាថា ព្រះមេឃិយត្ថេរបានតាំងនៅក្នុងសោតាបត្តិផល ជនជ័ច្រើន ក៏បានជាអរិយបុគ្គល មានសោតាបន្នបុគ្គលជាដើមដូច្នេះឯង ៕

រឿង ព្រះមេឃិយត្ថេរ ចប់

រឿង អញ្ញតរភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអញ្ញតរភិក្ខុ ១ អង្គ ត្រាស់ព្រះធម្មទេសនានេះថា **ទន្ធិគ្គហាសប្ប លហុនោ** ជាដើម ។

បានឮថា មានស្រុកមួយឈ្មោះមាតិកគ្រាម ក្បែរជើងភ្នំក្នុងដែនរបស់ព្រះបាទកោសល ។ ថ្ងៃមួយ ភិក្ខុប្រមាណ ៦០ រូប ទូលអារាធនា សូមព្រះមានព្រះភាគត្រាស់ប្រាប់កម្មដ្ឋាន អំពីភាពជាព្រះអរហន្ត ក្នុងសម្នាក់នៃព្រះ

សាស្តាហើយ ទៅកាន់ស្រុកនោះ ចូលទៅដើម្បីបិណ្ឌបាត ។ លំដាប់នោះ ម្ចាស់របស់ស្រុកនោះ ឈ្មោះថាមាតិកៈ ជាមាតារបស់ជាម្ចាស់ស្រុកនោះ ឃើញភិក្ខុទាំងនោះហើយ និមន្តឲ្យគង់ក្នុងផ្ទះ អង្គាសដោយបបរ និងភត្តមានរសដ៏ប្រសើរផ្សេងៗ សួរថា លោកម្ចាស់ទាំងឡាយ បំណងនឹងទៅក្នុងទីណា ភិក្ខុទាំងនោះប្រាប់ថា មហាឧបាសិកា ពួកអាត្មាបំណងនឹងទៅតាមជាសុកនាងដីងថា ភិក្ខុទាំងឡាយប្រហែលជាស្វែងរកទីកន្លែងសម្រាប់ចាំវស្សា ទើបក្រាបចុះទៀបបាទ ហើយពោលថា បើលោកម្ចាស់ទាំងឡាយនៅក្នុងទីនេះ ៣ ខែសោត ខ្ញុំនឹងទទួលសរណៈ ៣ សីល ៥ នឹងធ្វើឧបោសថកម្ម ។ ភិក្ខុទាំងឡាយប្រឹក្សាគ្នាថា យើងទាំងឡាយ កាលអាស្រ័យឧបាសិកានេះ មិនមានសេចក្តីលំបាកដោយភិក្ខា អាចធ្វើការរលាស់ចេញចាកកិលេសបាន ដូច្នេះហើយទើបទទួលពាក្យ នាងបានជម្រះវិហារដែលជាលំនៅ ប្រគេនដល់ភិក្ខុទាំងនោះ ។

ភិក្ខុទាំងនោះ កាលនៅក្នុងទីនោះ ថ្ងៃមួយ បានប្រជុំគ្នាហើយ ជាសំតៀនគ្នានិងគ្នាថា អាវុសោ ពួកយើងមិនគួរប្រព្រឹត្តដោយសេចក្តីប្រមាទ ព្រោះមហានរក ៨ រណ្តៅ មានទ្វារបើករង់ចាំពួកយើង ដូចផ្ទះរបស់ខ្ងុនោះឯង ឯពួកយើងបានរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះពុទ្ធ ដែលទ្រង់គង់ព្រះជន្មនៅឡើយ ហើយទើបមក ធម្មតាព្រះពុទ្ធទាំងឡាយ បុគ្គលណាម្នាក់ដែលជាអ្នកអួតអាង សូម្បីត្រាច់ទៅតាមស្នាមព្រះបាទ ក៏មិនអាចឲ្យទ្រង់ប្រោសប្រាណបាន តែបុគ្គលដែលមានអធ្យាស្រ័យជាប្រក្រតីប៉ុណ្ណោះ អាចឲ្យទ្រង់ប្រោសប្រាណ

បាន អ្នកទាំងឡាយ ចូរជាបុគ្គលមិនប្រមាទចុះ ។ ពួកយើងមិនគួរឈរ មិនគួរអង្គុយ ក្នុងទីមួយកន្លែងពីរបួប តែក្នុងកាលទំនុកបម្រុងព្រះថេរៈក្នុងពេលល្ងាច និងកាលដែលជាកិច្ចាចារក្នុងពេលព្រឹកប៉ុណ្ណោះ សឹមពួកយើងជួបជុំគ្នា តែក្នុងកាលដ៏សេស នឹងមិននៅរួមគ្នាពីរបួប ម្យ៉ាងទៀត កាលភិក្ខុមិនមានផាសុក គឺមានជំងឺ វាយជួងក្នុងកណ្តាលវិហារហើយ សឹមពួកយើងមកតាមសញ្ញានៃជួង ធ្វើថ្នាំឲ្យដល់ភិក្ខុនោះ ។

កាលភិក្ខុទាំងនោះ ធ្វើកតិកាគ្នាយ៉ាងនេះ ថ្ងៃមួយ ឧបាសិកានោះឲ្យបុគ្គលកាន់កេសជ្រៈទាំងឡាយ មានសប្បិ និងទឹកអំពៅជាដើម ដែលជនទាំងឡាយមានទាសៈ និងកម្មករជាដើម ចោមរោមដើរទៅកាន់វិហារនោះ ក្នុងពេលល្ងាច មិនឃើញភិក្ខុទាំងឡាយក្នុងវិហារហើយ ទើបសួរពួកបុរសថា លោកម្ចាស់ទាំងឡាយទៅក្នុងទីណាអស់ហ្ន៎ កាលពួកជនទាំងនោះជ្រាប់ថា លោកម្ចាស់ទាំងឡាយ ជាអ្នកអង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃវៀងៗ ខ្ទួនប៉ុណ្ណោះ ទើបពោលតទៅថា ខ្ញុំធ្វើដូចម្តេចហ្ន៎ ទើបអាចជួបលោកម្ចាស់ទាំងនោះបាន ។

លំដាប់នោះ មនុស្សទាំងឡាយដែលដឹងកតិកាវត្តរបស់ភិក្ខុសង្ឃ ទើបជ្រាប់ឧបាសិកានោះថា បពិត្រអ្នកម្ចាយ លោកម្ចាស់ទាំងឡាយនឹងប្រជុំគ្នាក្នុងកាលបុគ្គលមកវាយជួង ទើបនាងឲ្យវាយជួង ភិក្ខុទាំងឡាយបានឮសំឡេងជួងហើយ ចេញអំពីលំនៅវៀងៗ ខ្ទួន ដោយសម្គាល់ថាភិក្ខុរបួសខ្លះ នឹងមិនមានផាសុក ទើបប្រជុំគ្នាត្រង់កណ្តាលវិហារ ភិក្ខុឈ្មោះថា និមន្តដោយផ្លូវជាមួយ

គ្នាពីរូបមិនមាន ។

ឧបាសិកាឃើញកិកុមួយរូបៗ ប៉ុណ្ណោះ ដើរមកអំពីទីកន្លែងនីមួយៗ ទើបគិតថា ប្រហែលលោកម្ចាស់ដែលជាកូនរបស់អញ ធ្វើនូវការឈ្លោះទាស់ទែងនូវគ្នានិងគ្នា ដូច្នេះហើយ ថ្វាយបង្គំកិកុសង្ឃពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយបានធ្វើនូវការឈ្លោះគ្នាឬ កិកុទាំងឡាយពោលថា មហាឧបាសិកា ពួកអាត្មាមិនបានធ្វើការឈ្លោះទាស់ទែងគ្នាឡើយ ។ ឧបាសិកាពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ទាំងឡាយមិនមានការវិវាទគ្នាសោត បើដូច្នោះ ហេតុអ្វី ទើបមិននិមន្តមកដូចកាលមកកាន់ផ្ទះរបស់ខ្ញុំ មកដោយរួមគ្នាទាំងអស់ តែពេលនេះ បែរជាមកមួយអង្គៗ អំពីទីមួយកន្លែងៗ ។ កិកុទាំងឡាយពោលថា មហាឧបាសិកា ពួកអាត្មាអង្គុយធ្វើសមណធម៌ ក្នុងទីមួយកន្លែងរៀងៗ ខ្លួន ។ ឧបាសិកាពោលថា លោកម្ចាស់ទាំងឡាយ ឈ្មោះថាសមណធម៌នោះ គឺអ្វី កិកុទាំងឡាយពោលថា មហាឧបាសិកា ពួកអាត្មាស្វាធ្យាយអាការ ៣២ ផ្តើមតាំងនូវការអស់ទៅ សូន្យទៅក្នុងអត្តភាព ។ ឧបាសិកាពោលថា បពិត្រលោកម្ចាស់ ការស្វាធ្យាយអាការ ៣២ និងការផ្តើមតាំងនូវការអស់ទៅ សូន្យទៅក្នុងអត្តភាព រមែងសមគួរដល់លោកម្ចាស់ទាំងឡាយប៉ុណ្ណោះឬ ឬអាចសមគួរដល់យើងខ្ញុំដែរ ។ កិកុទាំងឡាយពោលថា មហាឧបាសិកា ធម៌នេះ ព្រះដ៏មានព្រះភាគ ទ្រង់មិនបានហាមដល់បុគ្គលណាម្នាក់ឡើយ ។ ឧបាសិកាពោលថា បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយឲ្យអាការ ៣២ នឹងសូមជ្រាប់ការផ្តើមចម្រើននូវការអស់ទៅ និងសូន្យទៅក្នុង

អត្តភាពដល់ខ្ញុំផងចុះ ។ ភិក្ខុទាំងឡាយពោលថា មហាឧបាសិកា បើយ៉ាងនោះ ចូរនាងរៀនយកចុះ ហើយឲ្យរៀនយកទាំងអស់ ។

ចាប់តាំងអំពីនោះ ឧបាសិកានោះក៏បានធ្វើការស្វាធ្យាយនូវអាការ ៣២ និងផ្តើមនូវការអស់ទៅ សូន្យទៅក្នុងខ្លួន បានសម្រេចមគ្គ ៣ ផល ៣ មុន ភិក្ខុទាំងនោះឯង បដិសម្ភិទា ៤ និងលោកិយអភិញ្ញា បានមកដល់ឧបាសិកានោះដោយមគ្គនោះឯង ។ នាងចេញអំពីសុខដែលកើតអំពីមគ្គ និងផលហើយ សម្ងំងមើលដោយទិព្វចក្ខុ ពិចារណាថា កាលណាហ្ន៎ ទើបលោកម្ចាស់ជាកូនរបស់អញសម្រេចធម៌នេះ ។ ហើយអាវជ្ជនៈតទៅថា លោកម្ចាស់ទាំង-ឡាយនេះនៅមានរាគៈ នៅមានទោសៈ នៅមានមោហៈ លោកម្ចាស់ទាំងនោះមិនមានគុណធម៌ត្រឹមតែឈាន និងវិបស្សនាឡើយ ឧបនិស្ស័យនៃអរហត្តរបស់លោកម្ចាស់ ដែលជាកូនរបស់អញមានឬហ្ន៎ ឃើញថា មានដូច្នេះហើយ ទើបអាវជ្ជនៈថា សេនាសនៈដែលជាសប្បាយមានឬ មិនមានហ្ន៎ ឃើញសេនាសនៈជាទីសប្បាយហើយ ទើបពិចារណាថា លោកម្ចាស់ទាំង-ឡាយរបស់អញ មិនទាន់បានបុគ្គលជាទីសប្បាយឬ ក៏ឃើញបុគ្គលជាទីសប្បាយហើយទើបពិចារណាទៀតថា លោកម្ចាស់ទាំងឡាយ មិនបានអាហារជាទីសប្បាយឬ ក៏បានឃើញថា អាហារដែលជាទីសប្បាយ មិនមានដល់ពួកលោក ។ ចាប់តាំងអំពីនោះមក ក៏រៀបចំបបរដែលមានបែបផែនៗ និងរបស់ទំពាជាច្រើនប្រការ និងភោជនមានរសដ៏លើសផែនៗ ហើយនិមន្តភិក្ខុទាំងឡាយឲ្យគង់ហើយ ទើបប្រគេនទឹកទក្ខិណោទកហើយ ប្រគេនដោយ

ពាក្យថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយពេញចិត្តវត្ថុណាមួយ សូមកាន់យកវត្ថុនោះៗ ធាន់ចុះ ។

ភិក្ខុទាំងនោះទទួលយកវត្ថុទាំងឡាយ មានបបរជាដើមហើយ ក៏បរិភោគតាមគាប់ចិត្ត ។ កាលភិក្ខុទាំងនោះ បានអាហារជាទីសប្បាយ ចិត្តក៏ជាធម្មជាតមានអារម្មណ៍មួយ ។ ពួកលោកមានចិត្តចុះស៊ប់ ចម្រើនវិបស្សនាក្នុងកាលមិនយូរ ក៏បានសម្រេចអរហត្ត មួយអន្ទើដោយឫទ្ធិទាំងឡាយ ហើយគិតថា គួរអរគុណមហាឧបាសិកា ជាទីពឹងរបស់ពួកយើង បើពួកយើងមិនបានអាហារ ដែលជាទីសប្បាយហើយសោត ការសម្រេចមគ្គ និងផល ក៏គង់មិនមានដល់ពួកយើង ឥឡូវនេះ ពួកយើងនៅចាំវស្សាបវារណាហើយនឹងទៅកាន់សម្នាក់របស់ព្រះសាស្តា ។

ភិក្ខុទាំងឡាយលាមហាឧបាសិកាថា ពួកអាត្មានឹងគាល់ព្រះសាស្តា មហាឧបាសិកាពោលថា សាធុ លោកម្ចាស់ ហើយជូនដំណើរភិក្ខុទាំងនោះ ពោលពាក្យដែលជាទីស្រឡាញ់ដ៏ច្រើនថា សូមលោកម្ចាស់ទាំងឡាយ មកសួរសុខទុក្ខខ្ញុំទៀត ដូច្នេះជាដើម ហើយទើបត្រឡប់ ។

ចំណែកភិក្ខុទាំងនោះឯង កាលដល់នគរសាវត្ថីហើយ ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង កាលព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកល្មមអត់ធន់បានដែរឬ ពួកអ្នកល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានដែរឬ ម្យ៉ាងទៀត ពួកអ្នកមិនលំបាកដោយបិណ្ឌបាតទេឬ ទើបក្រាបទូលថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គល្មមអត់ធន់បាន ល្មម

ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ម្យ៉ាងទៀត ពួកខ្ញុំព្រះអង្គមិនលំបាកដោយបិណ្ឌបាតឡើយ ព្រោះឧបាសិកាម្នាក់ ឈ្មោះមាតិកមាតាជ្រាបវារចិត្តរបស់ពួកខ្ញុំព្រះអង្គ ។ កាលពួកខ្ញុំព្រះអង្គគិតថា ធ្វើម្តេចហ្ន៎ មហាឧបាសិកាគប្បីចាត់ចែងអាហារឈ្មោះនេះ ដើម្បីពួកយើង នាងក៏ចាត់ចែងអាហារប្រគេនតាមដែលពួកខ្ញុំព្រះអង្គគិតហើយ ដូច្នេះហើយ ក៏ពោលសរសើរគុណរបស់មហា-ឧបាសិកានោះ ។

ភិក្ខុមួយរូប ស្តាប់ពាក្យសរសើរគុណរបស់មហាឧបាសិកានោះហើយ ជាអ្នកប្រាថ្នានឹងទៅក្នុងទីនោះ រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តាហើយ ទូលលាព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅកាន់ស្រុកនោះ ហើយចេញអំពីវត្តជេតពន ដល់ស្រុកនោះដោយលំដាប់ ក្នុងថ្ងៃដែលខ្លួនចូលទៅកាន់វិហារ គិតថា បានឮថា ឧបាសិកានេះរមែងដឹងដល់ហេតុដែលបុគ្គលជំទៃគិតហើយ ឯអាត្មាអញហត់នឿយហើយ ក្នុងការដើរផ្លូវ មិនអាចចោសវិហារបាន ធ្វើម្តេចហ្ន៎ ឧបាសិកានេះ គប្បីបញ្ជូនមនុស្សអ្នកជម្រះវិហារ មកដើម្បីយើង ។

ឧបាសិកាអង្គុយក្នុងផ្ទះនោះឯង ជ្រាបសេចក្តីនោះហើយ ទើបបញ្ជូនមនុស្សទៅដោយពាក្យថា ចូរអ្នកទៅជម្រះវិហារហើយសឹមមក ចំណែកភិក្ខុក្រៅអំពីនេះចង់ផឹកទឹក គិតថា ធ្វើម្តេចហ្ន៎ឧបាសិកានេះគប្បីធ្វើទឹកផឹក លាយដោយស្ករផែន បញ្ជូនមកឲ្យដល់អញ ឧបាសិកាក៏បានបញ្ជូនទឹកនោះមកឲ្យ ។ លោកគិតទៀតថា ចូរឧបាសិកាបញ្ជូនបបរ ដែលមានរសប្រណីត និងសម្

ឧត្តរិភង្គ មកដើម្បីអញក្នុងថ្ងៃស្អែកនេះ អំពីព្រលឹមចុះ ។ ឧបាសិកាបានធ្វើយ៉ាងនោះ ។

ភិក្ខុធាន់បបរហើយគិតថា ធ្វើម្តេចហ្ន៎ ឧបាសិកាគប្បីបញ្ជូនរបស់ទំពាបែបនេះមកដើម្បីអញ ។ ឧបាសិកាក៏បានបញ្ជូនខាទនីយនោះទៅហើយ លោកគិតថា ឧបាសិកានេះបញ្ជូនវត្ថុដែលអញគិតហើយគ្រប់ៗ វត្ថុមក អញចង់ជួបឧបាសិកានោះ ធ្វើម្តេចហ្ន៎ នាងគប្បីឲ្យមនុស្សកាន់កោជន មានរសផ្សេងៗដើម្បីអញ មកដោយខ្លួនឯង ។ ឧបាសិកាគិតថា ភិក្ខុជាកូនរបស់អញបំណងនឹងឃើញអញ ទន្ទឹងការទៅរបស់អញ ដូច្នេះហើយ ទើបឲ្យមនុស្សកាន់កោជនទៅកាន់វិហារហើយ បានប្រគេនដល់ភិក្ខុនោះ ។ ភិក្ខុនោះ ធ្វើភត្តកិច្ចហើយសួរថា មហាឧបាសិកា នាងឬ ឈ្មោះមាតិកមាតា ឧបាសិកាពោលថា ត្រូវហើយលោកម្ចាស់ ។ ភិក្ខុនោះពោលថា ឧបាសិកា នាងជ្រាបចិត្តរបស់អ្នកជនៃឬ ឧបាសិកាពោលថា លោកម្ចាស់សួរខ្ញុំធ្វើអ្វី ភិក្ខុនោះពោលថា នាងបានធ្វើវត្ថុគ្រប់យ៉ាងដែលអាត្មាគិតហើយ ព្រោះដូច្នោះ ទើបអាត្មាសួរនាង ។ ឧបាសិកាពោលថា បពិត្រលោកម្ចាស់ ភិក្ខុដែលដឹងចិត្តរបស់អ្នកជនៃ ក៏មានច្រើន ភិក្ខុនោះពោលថា អាត្មាមិនបានសួរដល់អ្នកជនៃ សួរចំពោះឧបាសិកាប៉ុណ្ណោះ ។

តែទោះជាយ៉ាងនោះ ឧបាសិកាក៏មិនបានប្រាប់ត្រង់ៗ ថា ខ្ញុំដឹងចិត្តរបស់អ្នកជនៃ ប្រែខ្វែងជាពោលថា បពិត្រអយ្យបុត្រ ធម្មតាមនុស្សទាំងឡាយដែលដឹងចិត្តរបស់អ្នកជនៃ រមែងធ្វើយ៉ាងនោះបាន ។

កិកុ្ខនោះគិតថា កម្មនេះធ្ងន់ហ្ន៎ ធម្មតាបុថុជ្ជនរមែងគិតដល់អារម្មណ៍ដែលស្អាតខ្លះ មិនស្អាតខ្លះ បើអញនឹងគិតដល់វត្ថុដែលមិនសមគួរហើយសោត ឧបាសិកានេះ ក៏គប្បីញ៉ាំងអញឲ្យដល់ប្រការប្លែក ដូចចាប់ចោរត្រង់ផ្ងងសក់មួយអន្ទើដោយកស្តុតាង ដូច្នោះ ។ អញគួរគេចទៅអំពីទីនេះ ហើយពោលថា ឧបាសិកា អាត្មានឹងលាទៅ ឧបាសិកាពោលថា លោកម្ចាស់នឹងទៅទីណា កិកុ្ខនោះពោលថា នឹងទៅកាន់សម្នាក់ព្រះសាស្តា ឧបាសិកាពោលថា សូមលោកម្ចាស់នៅក្នុងទីនេះសិនចុះ កិកុ្ខនោះពោលថា អាត្មាមិននៅទេ នឹងត្រូវទៅដោយពិតប្រាកដ ហើយបានដើរចេញអំពីទីនោះ ទៅកាន់សម្នាក់របស់ព្រះសាស្តា ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរកិកុ្ខនោះថា ម្នាលកិកុ្ខ អ្នកនៅក្នុងទីនោះមិនបានឬ កិកុ្ខនោះពោលថា បពិត្រព្រះអង្គ យ៉ាងនោះឯង ខ្ញុំព្រះអង្គមិនអាចនៅទីនោះបាន ។ ព្រះសាស្តាត្រាស់ថា ម្នាលកិកុ្ខ ព្រោះហេតុអ្វី កិកុ្ខនោះពោលថា បពិត្រព្រះអង្គ ព្រោះឧបាសិកានោះ ជីងជល់រឿងដែលអ្នកដទៃគិតហើយគ្រប់ប្រការ ខ្ញុំព្រះអង្គគិតថា ធម្មតាបុថុជ្ជន រមែងគិតអារម្មណ៍ដែលស្អាតខ្លះ មិនស្អាតខ្លះ បើអញគិតដល់វត្ថុខ្លះ ដែលមិនសមគួរហើយសោត ឧបាសិកានោះក៏នឹងញ៉ាំងអញ ឲ្យដល់នូវប្រការដែលប្លែក ដូចចាប់ចោរត្រង់ផ្ងងសក់ មួយអន្ទើដោយកស្តុតាង ដូច្នោះ ដូច្នេះហើយ ទើបមក ។ ព្រះសាស្តាត្រាស់ថា ម្នាលកិកុ្ខ អ្នកគួរនៅក្នុងទីនោះឯង កិកុ្ខនោះក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនអាច ខ្ញុំព្រះអង្គនឹងនៅទីនោះ មិនបាន ។

ព្រះសាស្តាត្រាស់ថា ម្នាលកិកុ្ខបើយ៉ាងនោះ ចូរអ្នករក្សាវត្តមួយប៉ុណ្ណោះ

បានឬទេ ភិក្ខុនោះពោលថា បពិត្រព្រះអង្គ តើរក្សាអ្វី ព្រះសាស្តាត្រាស់ថា ចូរអ្នករក្សាចិត្តរបស់អ្នកនោះឯង ធម្មតាចិត្តនេះ បុគ្គលរក្សាបានលំបាក អ្នកចូរសង្កត់ចិត្តរបស់អ្នកឲ្យបាន កុំគិតដល់អារម្មណ៍ណាមួយដទៃឡើយ ធម្មតាចិត្តបុគ្គលសង្កត់បានលំបាក ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ
ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។

ការទូន្មានចិត្ត ដែលសង្កត់សង្កិនបានដោយលំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច (ព្រោះថា ចិត្ត) ដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

សេចក្តីអធិប្បាយ

បណ្ឌិតគប្បីជ្រាបវិគ្គហៈក្នុងព្រះគាថានោះដូចតទៅនេះថា ធម្មតាចិត្តនេះ បុគ្គលសង្កត់សង្កិនបានលំបាក ព្រោះហេតុនោះ ទើបឈ្មោះថា **ទុន្និគ្គហំ ។**

ចិត្តនេះ រមែងកើត និងរលត់រហ័ស ព្រោះហេតុនោះ ទើបឈ្មោះថា **លហុ** *នូវចិត្តដែលសង្កត់បានលំបាក ដែលកើត និងរលត់រហ័សនោះ ។*

បានព្រះគាថាថា **យត្ថ កាមនិបាតិនោ** *សេចក្តីថា រមែងធ្លាក់ទៅក្នុងអារម្មណ៍ឯណានីមួយនោះឯង ។ ពិតហើយ ចិត្តនេះ រមែងមិនស្គាល់ហានៈដែលខ្លួនគួរបាន ឬហានៈដែលមិនគួរបាន ហានៈដែលគួរ ឬហានៈដែលមិនគួរ រមែងមិនពិចារណាមើលជាតិ មិនពិចារណាមើលគោត្រ មិនពិចារណាមើល*

វិយ រមែងធ្លាក់ទៅក្នុងអារម្មណ៍ ដែលខ្លួនប្រាថ្នាតែម្យ៉ាង ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ចិត្តនេះ ធ្លាក់ទៅក្នុងអារម្មណ៍ តាមសេចក្តីប្រាថ្នា ។

ការទូន្មានចិត្តបែបនេះជាការល្អ គឺភាពនៃចិត្តដែលបុគ្គលទូន្មានដោយអរិយមគ្គ ៤ បានដល់ភាពនៃចិត្ត ដែលបុគ្គលធ្វើហើយដោយប្រការដែលចិត្តអស់ព្យសន៍បាន ជាការល្អ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា ចិត្តនេះ ដែលបុគ្គលទូន្មានហើយ រមែងជាហេតុនាំសុខមកឲ្យ គឺចិត្តដែលបុគ្គលហ្វឹកហាត់ហើយ បានដល់ ធ្វើឲ្យអស់ព្យសន៍ រមែងនាំមកនូវសេចក្តីសុខ ដែលកើតអំពីមគ្គផល និងសុខ គឺព្រះនិព្វាន ដែលជាបរមត្ថ ។

ក្នុងកាលចប់ទេសនា បរិស័ទដែលមកប្រជុំគ្នាច្រើន បានជាអរិយបុគ្គលមានព្រះសោតាបន្នជាដើម ទេសនាសម្រេចប្រយោជន៍ដល់មហាជនហើយ ។

ព្រះសាស្តា កាលប្រទានឱវាទនេះដល់ភិក្ខុនោះហើយ ទើបទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា ទៅចុះភិក្ខុ អ្នកកុំគិតវត្ថុណាមួយដទៃ ចូរនៅក្នុងទីនោះឯង ។ ភិក្ខុនោះ បានព្រះឱវាទអំពីសម្ងាក់របស់ព្រះសាស្តាហើយ ទើបទៅក្នុងទីនោះ មិនគិតអ្វីមួយដែលនាំឲ្យគិតខាងក្រៅឡើយ ។

ចំណែកមហាឧបាសិកា កាលប្រមើលមើលដោយទិព្វចក្ខុ ក៏ឃើញព្រះថេរៈហើយ កំណត់ដោយញាណរបស់ខ្លួននោះឯងថា ឥឡូវនេះ ភិក្ខុដែលជាបុត្ររបស់អញ បានអាចារ្យឲ្យឱវាទហើយ ទើបត្រឡប់មកទៀត ហើយបានចាត់ចែងអាហារដែលជាទីសប្បាយដល់ព្រះថេរៈនោះ ។

ព្រះថេរៈនោះបានកោជនជាទីសប្បាយហើយ ក្នុងពេល ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចអរហត្ត សម្រាកសម្រាន្តនៅដោយសេចក្តីសុខ ដែលកើតអំពីមគ្គ និងផល គិតថា គួរតបញ្ចិត្តហ្ន៎ មហាឧបាសិកាបានជាទីពឹងរបស់អញហើយ អញអាស្រ័យមហាឧបាសិកានេះ ទើបដល់នូវការសុះចេញអំពីភពបានហើយពិចារណាថា មហាឧបាសិកានេះ បានជាទីពឹងរបស់អញ ក្នុងអត្តភាពនេះប៉ុណ្ណោះឬហ្ន៎ កាលអញអន្ទោលទៅក្នុងសង្សារ មហាឧបាសិកានេះ ធ្លាប់ជាទីពឹងក្នុងអត្តភាពជទៃៗ ឬទេ ហើយទើបរពឹកជាតិថយក្រោយទៅ ៩៩ អត្តភាព ។ សូម្បីមហាឧបាសិកានោះ ក៏បានជាបុព្វបរិចារិការបស់ព្រះថេរៈនោះក្នុងអត្តភាពទី ៩៩ ជាអ្នកមានចិត្តប្រតិព័ទ្ធក្នុងបុរសជទៃ ទើបឲ្យសម្លាប់ព្រះថេរៈនោះ ឲ្យដាច់ចាកជីវិត ។

ព្រះថេរៈ កាលឃើញទោសរបស់មហាឧបាសិកានោះត្រឹមប៉ុណ្ណោះហើយ ទើបគិតថា គួរសង្វេគហ្ន៎ មហាឧបាសិកានេះ បានធ្វើកម្មជ្ងន់មកហើយ ។

ចំណែកមហាឧបាសិកាអង្គុយក្នុងផ្ទះនោះឯង ពិចារណាបណ្តើរថា កិច្ចនៃបព្វជិតរបស់កិក្ខុជាបុត្រអញ ដល់ទីបំផុតហើយឬនៅហ្ន៎ ក៏បានដឹងថា ព្រះថេរៈនោះ សម្រេចអរហត្តហើយ ទើបពិចារណាក្រៃលែងឡើងទៅ ក៏ជ្រាបថា កិក្ខុជាបុត្ររបស់អញសម្រេចអរហត្តហើយ ទើបគិតថា គួរត្រេកអរពិតហ្ន៎ ឧបាសិកានេះបានជាទីពឹងរបស់អញយ៉ាងសំខាន់ ដូច្នេះហើយ ពិចារណាតទៅទៀតថា សម្បីក្នុងកាលកន្លងទៅហើយ ឧបាសិកានេះធ្លាប់ជាទីពឹងរបស់អញឬហ្ន៎ ក៏រពឹកជាតិទៅរហូត ៩៩ អត្តភាព តែអញបានស្និទ្ធស្នាន់ជាមួយ

ប្រុសជនៃ ផ្តាច់ជីវិតព្រះថេរៈក្នុងអត្តភាពទី ៩៩ ព្រះថេរៈនេះឯងឃើញទោសមានប្រមាណប៉ុណ្ណេះរបស់អញហើយ គិតថា គួរសង្វេគ ឧបាសិកាបានធ្វើកម្មធ្ងន់ហើយ នាងពិចារណាតទៅទៀតថា អាត្មាអញកាលអនោលទៅក្នុងសង្សារវដ្ត អញមិនបានធ្លាប់ធ្វើឧបការៈដល់កិក្ខុ ដែលជាបុត្រសោះឬហ្ន៎ បានរឭកដល់អត្តភាពទី ១០០ ដែលក្រៃលែងជាង ៩៩ អត្តភាពនោះ ក៏ជ្រាបថា ក្នុងអត្តភាពទី ១០០ អញជាបាទបរិចារិកានៃព្រះថេរៈនោះ បានឲ្យជីវិតទានក្នុងទីដែលប្រហារជីវិតមួយកន្លែង ។ គួរត្រេកអរ អញធ្វើឧបការៈច្រើនដល់កិក្ខុដែលជាបុត្ររបស់អញ អង្គុយក្នុងផ្ទះនោះឯងពោលថា សូមលោកម្ចាស់ពិចារណាមើលឲ្យពិសេសក្រៃលែងទៅចុះ ។

ព្រះថេរៈនោះ បានស្តាប់សំឡេងរបស់ឧបាសិកានោះ ដោយសោតធាតុដែលជាទិព្វហើយ រឭកដល់អត្តភាពទី ១០០ ឲ្យវិសេសទៅហើយ ឃើញភាពដែលឧបាសិកានោះ បានឲ្យជីវិតដល់ខ្លួនក្នុងអត្តភាពនោះ ទើបគិតថា គួរត្រេកអរហ្ន៎ ឧបាសិកានេះធ្លាប់ធ្វើឧបការៈដល់អញ ដូច្នេះហើយ មានចិត្តត្រេកអរ ពោលបញ្ហាក្នុងមគ្គ ៤ ផល ៤ ដល់ឧបាសិកាក្នុងទីនោះឯង បានបរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ។

រឿង អញ្ញតរភិក្ខុ ចប់

រឿង ឧក្កណ្ឋិតភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុដែលអផ្សុកមួយអង្គ ត្រាស់ធម្មទេសនានេះថា **សុខុទ្ធសំ** ជាដើម ។

បានឮមកថា កាលព្រះសាស្តាប្រថាប់នៅក្នុងក្រុងសាវត្ថី សេដ្ឋីបុត្រម្នាក់ចូលទៅរកព្រះថេរៈ ដែលជាជីតុនរបស់ខ្លួនសាកសួរថា បពិត្រលោកម្ចាស់ ខ្ញុំប្រាថ្នានឹងផុតចាកទុក្ខ សូមលោកម្ចាស់ប្រាប់អាការ សម្រាប់ផុតចាកទុក្ខដល់ខ្ញុំ ។ ព្រះថេរៈពោលថា សាធុអាវុសោ បើអ្នកប្រាថ្នានឹងផុតចាកទុក្ខសោត ចូរអ្នកថ្វាយសលាកភត្ត បក្ខិកភត្ត ថ្វាយវិស្សាវាសិកភត្ត ថ្វាយបច្ចយទាំងឡាយមានចីវរជាដើម ចែករំលែកទ្រព្យសម្បត្តិរបស់ខ្លួនឲ្យជា ៣ ចំណែក ប្រកបការងារដោយទ្រព្យ ១ ចំណែក ចិញ្ចឹមបុត្រ និងភរិយាដោយទ្រព្យ ១ ចំណែក ថ្វាយទ្រព្យ ១ ចំណែកក្នុងព្រះពុទ្ធសាសនា ។ សេដ្ឋីបុត្រទទួលថា សាធុ លោកម្ចាស់ ហើយធ្វើកិច្ចគ្រប់យ៉ាងតាមលំដាប់នៃកិច្ចដែលព្រះថេរៈប្រាប់ហើយ សាកសួរព្រះថេរៈទៀតថា ខ្ញុំនឹងធ្វើបុណ្យអ្វីដទៃដែលក្រៃលែងឡើងជាងនេះទៀតឬ ព្រះថេរៈឆ្លើយថា អាវុសោ ចូរអ្នកទទួលត្រៃសរណៈ និងសីល ៥ ។ គាត់បានទទួលត្រៃសរណៈ និងសីល ៥ ទាំងនោះហើយទើបសាកសួរដល់បុញ្ញកម្ម ដែលក្រៃលែងឡើងជាងនោះ ។ ព្រះថេរៈក៏ទូន្មានថា បើដូច្នោះ ចូរអ្នកទទួលសីល ១០ សេដ្ឋីបុត្រពោលថា សាធុ លោកម្ចាស់ ហើយក៏ទទួលសីល ១០ ព្រោះគាត់ធ្វើបុញ្ញកម្មយ៉ាងនោះតាមលំដាប់

ទើបគាត់មានឈ្មោះថា អនុបុព្ពសេដ្ឋីបុត្រ ។ គាត់សាកសួរទៀតថា បុណ្យដែលខ្ញុំគប្បីធ្វើឲ្យក្រៃលែងឡើងទៅជាងនេះ នៅមានឬ លោកម្ចាស់ កាលព្រះថេរៈពោលថា បើយ៉ាងនោះ ចូរអ្នកបួស ទើបចេញបួសហើយ ។ ភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្មមួយរូប បានជាអាចារ្យរបស់លោក ភិក្ខុទ្រទ្រង់វិនយមួយរូប ជាព្រះឧបជ្ឈាយ៍ ។ ក្នុងវេលាដែលភិក្ខុនោះ បានឧបសម្បទាហើយ មកកាន់សម្នាក់របស់ខ្លួន អាចារ្យពោលបញ្ហាក្នុងព្រះអភិធម្មថា ឈ្មោះថាក្នុងព្រះពុទ្ធសាសនា ភិក្ខុធ្វើកិច្ចនេះ ទើបគួរ ធ្វើកិច្ចនេះ មិនគួរ ។

ចំណែកព្រះឧបជ្ឈាយ៍ ក៏ពោលបញ្ហាក្នុងព្រះវិនយ ក្នុងកាលដែលភិក្ខុនោះមកកាន់សម្នាក់របស់ខ្លួនថា ឈ្មោះថា ក្នុងព្រះពុទ្ធសាសនា ភិក្ខុធ្វើវត្ថុនេះ គួរ វត្ថុនេះ មិនគួរ វត្ថុនេះ សម វត្ថុនេះ មិនសម ។

លោកគិតថា ឱកម្មនេះធ្ងន់ហ្ន៎ អញច្រឡំថ្នាំនឹងផុតចាកទុក្ខ ទើបបួស តែក្នុងព្រះពុទ្ធសាសនានេះ ស្ថានជាទីលាដៃរបស់អញមិនច្រកដ អញតាំងនៅក្នុងផ្ទះ ក៏អាចផុតទុក្ខក្នុងវដ្តៈបាន អញគួរជាគ្រហស្ថល្អជាង ។ តាំងអំពីនោះ លោកក៏អផ្សុក អស់សេចក្តីត្រេកអរ មិនធ្វើការស្វាធ្យាយក្នុងអាការ ៣២ មិនរៀនឧទ្ទេស ស្តាំងស្តម ស្ងេកស្ងាំង មានខ្លួនរាមដោយសរសៃ ត្រូវសេចក្តីខ្វិលច្រអូសគ្របសង្កត់ ដេរជាសហើយដោយកម្មរមាស់ ។

គ្រានោះ ពួកភិក្ខុកំលោះ និងសាមណេរសួរលោកថា អាវុសោ ហេតុអ្វី ទើបលោកឈរសំកុក ក្នុងទីដែលឈរហើយ អង្គុយសំកុក ក្នុងទីដែលអង្គុយហើយ ត្រូវរោគស្តមលៀងគ្របសង្កត់ ស្តាំងស្តមស្ងេកស្ងាំង មានខ្លួន

រវាមដោយសរសៃ ត្រូវសេចក្តីខ្ជិលច្រអូសគ្របសង្កត់ ដេរដាសហើយ ដោយកមរមាស់ លោកធ្វើកម្មអ្វី ភិក្ខុនោះពោលថា អាវុសោ ខ្ញុំជាមនុស្ស អផ្សុក ភិក្ខុកំលោះ និងសាមណេរសួរថា ព្រោះហេតុអ្វី ។

ភិក្ខុនោះ ប្រាប់ព្រឹត្តិការណ៍នោះហើយ ភិក្ខុកំលោះ និងសាមណេរទាំងនោះ ប្រាប់ដល់អាចារ្យ និងឧបជ្ឈាយ៍របស់លោកហើយ ។ អាចារ្យ និងឧបជ្ឈាយ៍ បាននាំគ្នាទៅកាន់សម្នាក់ព្រះសាស្តា ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមកធ្វើអ្វី អាចារ្យ និងឧបជ្ឈាយ៍ទូលថា បពិត្រព្រះអង្ត ភិក្ខុរូបនេះអផ្សុកក្នុងសាសនារបស់ព្រះអង្ត ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ យ៉ាងនោះឬ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្ត យ៉ាងនោះឯង ព្រះសាស្តាត្រាស់ថា ព្រោះហេតុអ្វី ភិក្ខុនោះពោលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គប្រាថ្នានឹងផុតចាកទុក្ខ ទើបបានបួស អាចារ្យរបស់ខ្ញុំព្រះអង្គពោលអភិធម្មកថា ឧបជ្ឈាយ៍ពោលវិនយ-កថា ខ្ញុំព្រះអង្គបានធ្វើនូវការសង្វេគថា ក្នុងព្រះពុទ្ធសាសនានេះ ស្ថានជាទីលាដៃរបស់អញមិនមានឡើយ អញជាគ្រហស្ថក៏អាចផុតទុក្ខបាន អញនឹងជាគ្រហស្ថ ដូច្នេះ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ បើអ្នកអាចរក្សារបស់ម្យ៉ាងប៉ុណ្ណោះបានកិច្ច គឺការរក្សារបស់ទាំងឡាយដ៏សេស រមែងមិនមាន ។ ភិក្ខុនោះពោលថា បពិត្រព្រះអង្ត របស់នោះជាអ្វី ព្រះសាស្តាត្រាស់ថា អ្នកអាចរក្សាចំពោះចិត្តរបស់អ្នកបានឬទេ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្ត អាចរក្សាបាន ។

ព្រះសាស្តាប្រទានឱវាទថា បើដូច្នោះ ចូរអ្នករក្សាចំពោះចិត្តរបស់ខ្លួន អ្នកនឹងផុតចាកទុក្ខបាន ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។

អ្នកមានប្រាជ្ញា គួររក្សាចិត្ត ដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ (ព្រោះថា) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សុទុទ្ទសំ** *បានដល់ លំបាកនឹងឃើញបានដោយល្អ ។ បទថា* **សុនិបុណំ** *បានដល់ ល្អិតក្រៃលែង ។*

បានព្រះគាថាថា **យត្ថ កាមនិបាតិនំ** *សេចក្តីថា ច្រើនដោយការមិនពិចារណាមើលហេតុ:ទាំងឡាយ មានជាតិជាដើម ធ្លាក់ទៅក្នុងអារម្មណ៍ណាមួយ ក្នុងហេតុ:ដែលគប្បីបាន ឬមិនគប្បីបាន សមគួរ ឬមិនសមគួរ ។*

បានព្រះគាថាថា **ចិត្តំ រក្ខេថ មេធាវី** *សេចក្តីថា បុគ្គលអន្ធពាលមានបញ្ញាថោកថយ ឈ្មោះថាអាចរក្សាចិត្តរបស់ខ្លួនបាន មិនមាន ។ បុគ្គលនោះជាអ្នកប្រព្រឹត្តទៅក្នុងអំណាចចិត្ត រមែងដល់នូវសេចក្តីវិនាសអន្តរធាន រីបុគ្គលអ្នកមានបញ្ញា គឺជាបណ្ឌិតអាចរក្សាចិត្តបាន ។ ព្រោះហេតុនោះ ចូរអ្នកគ្រប់គ្រងរក្សាចិត្តឲ្យបាន ព្រោះថា ចិត្តដែលរក្សាបាន ជាហេតុនាំសុខមកឲ្យ*

គឺរមែងនាំមកនូវសេចក្តីសុខ ដែលកើតអំពីមគ្គផល និងនិព្វាន ដូច្នេះ ។

ក្នុងវេលាចប់ទេសនា ភិក្ខុនោះសម្រេចសោតបត្តិផលហើយ ជនដទៃជាច្រើន បានជាអរិយបុគ្គល មានព្រះសោតាបន្នជាដើម ទេសនាបានសម្រេចជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

រឿង ឧក្កណ្ឋិតភិក្ខុ ចប់

រឿង ក្មួយរបស់ព្រះសង្ឃរក្ខិតត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុឈ្មោះសង្ឃ-រក្ខិតៈ ត្រាស់ព្រះធម្មទេសនានេះថា **ទ្វារដ្ឋំ ឯកចរំ** *ជាដើម ។*

បានឮមកថា កុលបុត្រម្នាក់ក្នុងក្រុងសាវត្ថី ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយចេញបួស បានឧបសម្បទាហើយ មានឈ្មោះសង្ឃរក្ខិតត្ថេរ ក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ ក៏សម្រេចអរហត្តផល ។ ប្អូនប្រុសរបស់លោកបានកូនហើយ ក៏បានតាំងឈ្មោះរបស់ព្រះថេរៈដល់បុត្រនោះ ។ កុមារនោះមានឈ្មោះថា កាគិនេយ្យសង្ឃរក្ខិតៈ ចម្រើនវ័យហើយ បានបំពេញបព្វជ្ជា ឧបសម្បទា ក្នុងសម្នាក់របស់ព្រះថេរៈ ចូលទៅចាំវស្សាក្នុងវត្តជិតស្រុកណាមួយ បានសំពត់វស្សាវាសិកសាដកពីរផ្ទាំង បាណ្តាយ ៧ ហត្ថមួយផ្ទាំង ៨ ហត្ថមួយផ្ទាំង កំណត់ថា សំពត់វែង ៨ ហត្ថ នឹងជារបស់ព្រះឧបជ្ឈាយ៍

របស់អញ សំពត់ ៧ ហត្ថ នឹងជារបស់អញ ចេញវស្សាហើយ បំណងនឹងសួរសុខទុក្ខព្រះឧបជ្ឈាយ៍ ដើរមកបណ្តើរ ត្រាច់បិណ្ឌបាតក្នុងរវាងផ្លូវ លុះមកដល់ហើយ កាលព្រះថេរៈមិនទាន់ត្រឡប់មកកាន់វិហារនោះឯង ក៏ចូលទៅកាន់វិហារ ហើយបោសទីសម្រាកពេលថ្ងៃរបស់ព្រះថេរៈ រៀបចំទឹកលាងជើង ក្រាលអាសនៈ ហើយអង្គុយមើលផ្លូវព្រះថេរៈ កាលជ្រាបភាពដែលព្រះថេរៈមកដល់ហើយ ធ្វើការទទួលបាត្រ និងចីវរ អារាធនាព្រះថេរៈឲ្យគង់ដោយពាក្យថា សូមលោកម្ចាស់និមន្តគង់ចុះ កាន់ផ្ទៃតស្វីកត្មោតបក់ហើយ ប្រគេនទឹកឆាន់ លាងជើងទាំងពីរហើយ នាំសំពត់សាដកនោះមកដាក់ទៀបបាទា ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ប្រើប្រាស់សំពត់សាដកនេះ ហើយបានឈរបក់ ។

លំដាប់នោះ ព្រះថេរៈពោលនឹងលោកថា សង្ឃរក្ខិតៈ ចីវររបស់ខ្ញុំបរិបូណ៌ហើយ អ្នកនោះឯងចូរប្រើប្រាស់ចុះ ។

ព្រះសង្ឃរក្ខិតៈពោលថា បពិត្រលោកម្ចាស់ សំពត់នេះខ្ញុំកំណត់ដើម្បីលោកម្ចាស់តាំងអំពីកាលដែលខ្ញុំបានហើយ សូមលោកម្ចាស់ប្រើប្រាស់ចុះ ។ ព្រះថេរៈពោលថា ណ្ហើយចុះ សង្ឃរក្ខិតៈ ចីវររបស់ខ្ញុំបរិបូណ៌ អ្នកនុ៎ះឯងចូរប្រើប្រាស់ចុះ ។

ព្រះសង្ឃរក្ខិតៈពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំធ្វើយ៉ាងនេះឡើយ ព្រោះកាលលោកម្ចាស់ប្រើប្រាស់សំពត់សាដកនេះ ផលច្រើននឹងមានដល់ខ្ញុំ ។

កាលនោះ លុះព្រះសង្ឃរក្ខិតៈនោះពោលអង្វរហើយអង្វរទៀត ព្រះថេរៈក៏នៅតែមិនប្រាថ្នាសំពត់សាដកផ្ទាំងនោះ ។ លោកឈរបក់បណ្តើរ គិតបណ្តើរថា ក្នុងកាលជាគ្រហស្ថ អញជាកូយរបស់ព្រះថេរៈ ក្នុងកាលបួសហើយ អញក៏ជាសន្ទិវិហារិក កាលបើដូច្នោះ ព្រះឧបជ្ឈាយ៍មិនបំណងប្រើប្រាស់រួមជាមួយអញ បើព្រះឧបជ្ឈាយ៍នេះមិនរួមប្រើប្រាស់ជាមួយអញ អញនឹងត្រូវការអ្វីដោយភាពជាសមណៈ អញនឹងទៅជាគ្រហស្ថវិញ ។

ខណៈនោះ លោកគិតឃើញថា ការគ្រប់គ្រងផ្ទះ តាំងខ្លួនបានលំបាក អញនឹងលក់សំពត់សាដកប្រវែង ៨ ហត្ថ ហើយទិញមេពពែមួយ ធម្មតាមេពពែរមែងកើតកូនធាប់ អញនឹងលក់កូនពពែដែលកើតហើយ ធ្វើជាដើមទុន កាលប្រមូលទុនបានច្រើនហើយ នឹងនាំស្រីម្នាក់មកជាភរិយា នាងនឹងកើតបានកូនម្នាក់ កាលបើដូច្នោះ អញនឹងជាក់ឈ្មោះលោកអ៊ំរបស់អញជល់កូននោះ ហើយឲ្យអង្គុយក្នុងយានតូច នាំបុត្រ និងភរិយារបស់អញមកថ្វាយបង្គំលោកអ៊ំ កាលធ្វើដំណើរមក នឹងពោលជាមួយភរិយារបស់អញ ក្នុងវាងផ្លូវថា នាងចូរឲ្យកូនជល់ខ្ញុំមុន យើងនឹងនាំកូននោះទៅ នាងនឹងពោលថា អ្នកត្រូវការអ្វីដោយបុត្រ អ្នកចូរមក ចូរបរយានតូចនេះទៅ ហើយទទួលយកបុត្រទៅ តាំងចិត្តថា អញនឹងនាំកូននោះទៅ កាលមិនអាចពាទៅបាន ក៏ទុកចោលត្រង់ស្នាមកង់រនេះ កាលបើដូច្នេះ អញនឹងសង្កត់ក្បាលរបស់នាងលំជាប់នោះ អញនឹងនិយាយនឹងនាងថា នាងមិនបានឲ្យកូនរបស់ខ្ញុំជល់ខ្ញុំ នាងមិនអាចពកូននោះទៅបាន កូននោះរមែងឈ្មោះថានាងធ្វើឲ្យវិនាសហើយ

និងយកដងជន្ជញ្ជាវាយខ្នង ។

ព្រះថេរៈក្ជួយប្រុសនោះ គិតយ៉ាងនោះបណ្តើរ ឈរបក់បណ្តើរ ក៏យកផ្ទិតជាងត្នោត វាយព្រះសីសៈព្រះថេរៈហើយ ។

ព្រះថេរៈពិចារណាថា ព្រោះហេតុអ្វីហ្នឹ ទើបត្រូវសង្ឃរក្ខិតៈវាយក្បាលជ្រាបរឿងដែលក្ជួយប្រុសនោះគិតហើយទាំងអស់ ទើបពោលថា សង្ឃរក្ខិតៈ អ្នកមិនអាចឲ្យប្រហារមាតុគ្រាម ក្នុងរឿងនេះ ព្រះថេរៈចាស់មានទោសអ្វី ។

លោកគិតថា អញវិនាសហើយ បានញ្ជថា ព្រះឧបជ្ឈាយ៍ដឹងរឿងអញគិតហើយ អញត្រូវការអ្វីដោយភាពជាសមណៈ ដូច្នេះហើយ ចោលផ្ទិតស្ទឹកត្នោត ប្រាវញ្ជដើម្បីគេចទៅ ។

លំដាប់នោះ ភិក្ខុកំលោះ និងសាមណេរទាំងឡាយដេញតាមចាប់ភិក្ខុនោះ នាំមកកាន់សម្នាក់ព្រះសាស្តា ។ ព្រះសាស្តាទតឃើញភិក្ខុនោះហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមកធ្វើអ្វី ពួកអ្នកបានភិក្ខុមួយរូបឬ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្ត យ៉ាងនោះឯង ពួកខ្ញុំព្រះអង្តនាំភិក្ខុកំលោះរូបនេះ ដែលអផ្សុកហើយលបគេចទៅ មកកាន់សម្នាក់របស់ព្រះអង្ត ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ បានញ្ជថា អ្នកធ្វើយ៉ាងនោះឬ សង្ឃ-រក្ខិតៈភិក្ខុពោលថា បពិត្រព្រះអង្ត យ៉ាងនោះឯង ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ អ្នកធ្វើកម្មធ្ងន់យ៉ាងនោះ ដើម្បីអ្វី អ្នកជាបុត្រព្រះពុទ្ធមួយអង្ត ប្រាវញ្ជសេចក្តីព្យាយាម បួសក្នុងសាសនារបស់ព្រះពុទ្ធ ដូចតថាគតមិនមែនឬ មិនអាចឲ្យគេហៅខ្ជួនថា ជាព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ឬ

ព្រះអរហន្ត បានធ្វើកម្មជ្ងន់យ៉ាងនោះដើម្បីអ្វី ព្រះសង្ឃរក្ខិតៈពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គអផ្សុក ។ ព្រះសាស្តាត្រាស់ថា ព្រោះហេតុអ្វី ទើបអ្នកអផ្សុកព្រះសង្ឃរក្ខិតៈនោះ ក្រាបទូលរឿងនោះដល់ព្រះសាស្តា ចាប់តាំងអំពីថ្ងៃដែលខ្លួនឲ្យសំពត់វស្សាវាសិកសាដក រហូតដល់យកផ្ងិតស្លឹកត្នោតវាយព្រះថេរៈ ហើយក្រាបទូលថា បពិត្រព្រះអង្គ ព្រោះហេតុនេះ ទើបខ្ញុំព្រះអង្គលបគេចទៅ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងលោកថា មកចុះភិក្ខុ អ្នកកុំគិតថ្ងៃទ្បើយ ធម្មតាចិត្តនេះ មានកិច្ចទទួលអារម្មណ៍ សូម្បីមាននៅក្នុងទីឆ្ងាយ គួរភិក្ខុព្យាយាមដើម្បីជាប្រយោជន៍ដល់ការផុតចាកគ្រឿងចង គឺរាគៈ ទោសៈ មោហៈ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ
យេ ចិត្តំ សញ្ញមស្សន្តិ មោក្ខន្តិ មារពន្ធនា ។

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហា គឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទូរង្គមំ** *ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅ ឈ្មោះថា ការទៅ និងការមករបស់ចិត្ត ដោយចំណែកនៃទិស មានទិសបូព៌

ជាដើម សូម្បីប្រមាណប៉ុនសរសៃពីងពាង មិនមាន ចិត្តនោះ រមែងទទួលអារម្មណ៍ដែលមាននៅក្នុងទីឆ្ងាយ ព្រោះដូច្នោះ ទើបឈ្មោះថា **ទូរង្គមំ** ។

ម្យ៉ាងទៀត ចិត្ត ៧-៨ ដួង ឈ្មោះថា អាចកើតឡើងរួមជាជាប់ដោយការរួមគ្នាក្នុងខណៈមួយ មិនមាន ។ ក្នុងកាលដែលកើតឡើង ចិត្តកើតឡើងមួយដួងៗ កាលចិត្តដួងនោះរលត់ហើយ ចិត្តដួងថ្មីក៏កើតឡើងមួយដួងទៀត ព្រោះហេតុនោះ ទើបឈ្មោះថា **ឯកចរំ** ។

សរីរសណ្ឋានក្តី ប្រភេទនៃពណ៌ មានពណ៌ខៀវជាដើមក្តី របស់ចិត្តមិនមាន ព្រោះហេតុនោះ ទើបឈ្មោះថា **អសរីរំ** ។

គុហា គឺមហាភូតរូប ៤ ឈ្មោះថា គុហា ។ ចិត្តដែលអាស្រ័យហទយរូបប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **គុហាសយំ** ។

ពីរបទថា **យេ ចិត្តំ** *សេចក្តីថា ជនពួកណាមួយ ទោះជាបុរសក្តី ស្ត្រីក្តី ជាគ្រហស្ថក្តី បព្វជិតក្តី កាលមិនឲ្យកិលេសដែលមិនទាន់កើត ឲ្យកើតឡើង លះកិលេសដែលកើតឡើងហើយ ព្រោះការរាយមាយនៃសតិ ឈ្មោះថា នឹងសង្រួមចិត្ត គឺនឹងធ្វើចិត្តឲ្យស្ងប់ បានដល់ មិនឲ្យរាយមាយ ។*

បាទព្រះគាថាថា **មោក្ខន្តិ មារពន្ធនា** *សេចក្តីថា ជនពួកនោះ ឈ្មោះថា ផុតចាកវដ្តៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលរាប់ថាជាចំណងនៃមារ ព្រោះមិនមានគ្រឿងចង គឺកិលេស ។*

ក្នុងកាលចប់ទេសនា ព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរ សម្រេចសោតាបត្តិផលហើយ ។ ជនដទៃជាច្រើន បានជាអរិយបុគ្គល មានសោតាបន្នជាដើមហើយ ។ ទេសនាបានសម្រេចប្រយោជន៍ដល់មហាជនដូច្នេះឯង ។

រឿង ក្មួយរបស់ព្រះសង្ឃរក្ខិតត្ថេរ ចប់

រឿង ព្រះចិត្តហត្ថត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះចិត្តហត្ថៈ ត្រាស់ព្រះធម្មទេសនានេះថា **អនវដ្ឋិតចិត្តស្ស** *ជាដើម ។*

បានឮថា កុលបុត្រអ្នកនគរសាវត្ថីម្នាក់ស្វែងរកគោដែលបាត់ទៅ ទើបចូលទៅក្នុងព្រៃ ជួបគោក្នុងពេលថ្ងៃត្រង់ លែងចូលហូរគោហើយ គិតថា អញនឹងបានវត្ថុត្រឹមតែអាហារ ក្នុងសម្នាក់របស់ភិក្ខុទាំងឡាយដោយពិត ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយ ទើបចូលទៅកាន់វិហារដល់សម្នាក់របស់ភិក្ខុទាំងឡាយ ថ្វាយបង្គំហើយ បានឈរក្នុងចំណែកម្ខាង ។ ក្នុងសម័យនោះឯង កត្តដែលសល់អំពីភិក្ខុទាំងឡាយធាន់ មាននៅក្នុងថាសសម្រាប់ដាក់កត្តដែលជារបស់សល់ ភិក្ខុទាំងនោះឃើញគាត់ត្រូវសេចក្តីឃ្លានគ្របសង្កត់ហើយ ទើបពោលថា សូមអ្នកកាន់យកកត្តបរិភោគចុះ ។ ឈ្មោះថា ក្នុងសម័យពុទ្ធកាល សម្ភ និងម្ហូបច្រើន រមែងកើតឡើង ។ គាត់ទទួល

ភត្តល្មមញ្ជាំងអត្តភាពអំពីថាសនោះ បរិភោគហើយ ផឹកទឹក លាងដៃ ថ្វាយ បង្គំភិក្ខុទាំងឡាយហើយ សួរថា បពិត្រលោកម្ចាស់ ថ្ងៃនេះ លោកម្ចាស់ ទាំងឡាយបានទៅកាន់ទីនិមន្តហើយឬ ភិក្ខុទាំងឡាយឆ្លើយថា ឧបាសក ថ្ងៃ មិនមាន ភិក្ខុទាំងឡាយ រមែងបានភត្តាហាររឿយៗ ដោយទំនងនេះឯង ។

បុរសនោះគិតថា ពួកយើងក្រោកឡើងហើយ កាលក្រោកឡើងហើយ ធ្វើការងាររឿយៗ អស់យប់ និងថ្ងៃ ក៏គង់មិនបានភត្តដែលឆ្ងាញ់យ៉ាងនេះ បានញ្ចថា ភិក្ខុទាំងនេះ ឆាន់រឿយៗ អញនឹងត្រូវការអ្វីដោយភាពជាគ្រហស្ត អញនឹងបួសជាភិក្ខុ ដូច្នេះហើយ ទើបចូលទៅរកភិក្ខុទាំងឡាយ សូមបព្វជ្ជា ហើយ ។ លំដាប់នោះ ពួកភិក្ខុពោលនឹងបុរសនោះថា ឧបាសក ជាការល្អ ហើយ ឲ្យបុរសនោះបព្វជ្ជាហើយ ។ បុរសនោះបានឧបសម្បទាហើយ ធ្វើវត្ត នឹងបដិវត្ត ដែលជាឧបការៈដល់ភិក្ខុទាំងពួង ។ លោកមានសរីរៈធាត់ដោយ កាលកន្ងងទៅ ២-៣ ថ្ងៃ ព្រោះលាភ និងសក្ការៈកើតឡើងដល់ព្រះពុទ្ធ ទាំងឡាយ ។

បន្ទាប់អំពីនោះ ភិក្ខុនោះគិតថា អញនឹងត្រូវការអ្វីដោយការត្រាច់ទៅ ដើម្បីភិក្ខាចិញ្ចឹមជីវិត អញនឹងជាគ្រហស្ត ។ លោកសឹកចូលកាន់ផ្ទះហើយ ។ កាលកុលបុត្រដែលសឹកថ្មីនោះ ធ្វើការងារនៅក្នុងផ្ទះបាន ២-៣ ថ្ងៃប៉ុណ្ណោះ សរីរៈក៏ស្គម ។ បន្ទាប់អំពីនោះ គាត់គិតថា ប្រយោជន៍អ្វីរបស់អញដោយ សេចក្តីទុក្ខនេះ អញនឹងជាសមណៈ ដូច្នេះហើយ ក៏ត្រឡប់មកបួសជាថ្មី ។ លោកសម្រាកសម្រាន្តនៅបានប៉ុន្មានថ្ងៃ ក៏អផ្សុកឡើងហើយសឹក តែលោក

ជាអ្នកមានឧបការៈដល់ពួកភិក្ខុក្នុងកាលបួសដោយ ២-៣ ថ្ងៃប៉ុណ្ណោះ លោកក៏នឿយណាយទៀត ទើបគិតថា ប្រយោជន៍អ្វីរបស់អញដោយភាពជាគ្រហស្ថ អញនឹងបួស ទើបទៅថ្វាយបង្គំភិក្ខុទាំងឡាយ សូមបព្វជ្ជាហើយ ។ គ្រានោះ ភិក្ខុទាំងឡាយឲ្យបុរសនោះបព្វជ្ជាទៀតហើយ ដោយអំណាចនៃឧបការៈ ភិក្ខុនោះបួសហើយសឹកយ៉ាងនេះអស់វារៈ ៦ ដង ។ ភិក្ខុទាំងឡាយគិតថា ភិក្ខុនេះប្រព្រឹត្តទៅក្នុងអំណាចនៃចិត្តគ្រាច់ទៅ ទើបប្រគេនព្រះនាមដល់លោកថា ចិត្តហត្ថត្ថេរ ។

កាលចិត្តហត្ថៈនោះទៅមកៗ យ៉ាងនេះឯង ភរិយាមានគភ៌ហើយ ។ ក្នុងវារៈទី ៧ គាត់លើនង្គ័លអំពីព្រៃទៅផ្ទះ ទុកជាក់គ្រឿងប្រើប្រាស់ហើយ ចូលបន្ទប់ដោយបំណងថា នឹងដេរសំពត់កាសាវៈរបស់ខ្លួន ក្នុងខណៈនោះ ភរិយារបស់គាត់កំពុងដេកលក់ សំពត់ដែលនាងស្បៀករលុង ទឹកមាត់ក៏ហូរចេញអំពីមាត់ ច្រមុះក៏ស្រមុក គ្រូកៗ ហាមាត់សង្កៀតធ្មេញ ប្រាកដដល់គាត់ដូចសរីរៈដែលហើមប៉ោង គាត់គិតថា សរីរៈនេះមិនទៀង ជាទុក្ខ អញបួសអស់កាលប៉ុណ្ណោះហើយ អាស្រ័យសរីរៈនេះ ទើបមិនអាចតាំងនៅក្នុងភិក្ខុភាវៈបានដូច្នេះហើយ ក៏យកសំពត់កាសាវៈរុំពោះបណ្តើរ ចេញចាកផ្ទះបណ្តើរ ។ គ្រានោះ ម្តាយក្មេករបស់គាត់ ឈរត្រង់ផ្ទះជាប់តគ្នា ឃើញគាត់កំពុងដើរទៅដោយអាការយ៉ាងនោះ សង្ស័យថា បុរសនេះត្រឡប់ទៅទៀតហើយ គេមកអំពីព្រៃអម្បាញ់មិញនេះឯង រុំសំពត់កាសាវៈត្រង់ពោះ ចេញដើរបែរមុខទៅកាន់វិហារ កើតហេតុអ្វីអេះ ទើបចូលទៅកាន់ផ្ទះ ឃើញកូនស្រីដេកលក់ ដឹង

ថា បុរសនេះ ឃើញកូនស្រីរបស់អញនេះ មានសេចក្តីរំខាន បានចេញទៅ ហើយ ទើបជាស់កូនស្រីពោលថា នាងអាក្រក់ ជួជាតិ ចូរក្រោកឡើង ប្តី របស់ហង៎ឃើញហង៎កំពុងដេកលក់ មានសេចក្តីរំខាន ទៅបាត់ហើយ តាំង អំពីនេះ ហង៎នឹងមិនមានរូបគេ កូនស្រីពោលថា បពិត្រអ្នកម៉ែ ទៅក៏ទៅចុះ គាត់នឹងទៅខាងណា ២-៣ ថ្ងៃទៀតប៉ុណ្ណោះ ក៏នឹងមកវិញ ។

នាយចិត្តហត្ថៈនោះទន្ទេញទៅថា មិនទៀង ជាទុក្ខ កំពុងដើរទៅ សម្រេច សោតាបត្តិផលហើយ ចូលទៅថ្វាយបង្គំភិក្ខុទាំង៦ព្រះអង្គហើយ ក៏សូមបព្វជ្ជា ។ ភិក្ខុទាំង៦ព្រះអង្គពោលថា ពួកយើង៏មិនអាចឲ្យអ្នកបព្វជ្ជាបាន ភាពជាសមណៈ របស់អ្នកនឹង៏មានអំពីណា ក្បាលរបស់អ្នកជូចគ្នានឹង៏ថ្មសំលៀងកាំបិត បុរស នោះពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំង៦ព្រះអង្គអនុគ្រោះឲ្យខ្ញុំ បួសក្នុង៏គ្រានេះម្តង៏ទៀតចុះ ទើបភិក្ខុទាំង៏នោះឲ្យបួសហើយ ដោយអំណាចនៃ ឧបការៈ ។

បាន ២-៣ ថ្ងៃប៉ុណ្ណោះ លោក៏សម្រេចអរហត្ត មួយអន្ទើដោយបដិ-សម្ភិទា ភិក្ខុទាំង៏នោះពោលនឹង៏លោកថា ចិត្តហត្ថៈ លោកជឹង៏សម័យដែល លោកនឹង៏ទៅដោយពិត ហេតុអ្វីក្នុង៏ពេលនេះទើបលោកយឺតយូរទៅវិញ លោក ពោលថា ខ្ញុំទៅហើយក្នុង៏កាលដែលមានការជាប់ជំពាក់ទេ ការជាប់ជំពាក់នោះ ខ្ញុំកាត់បានហើយ ។ បន្តទៅ ខ្ញុំនឹង៏មិនទៅជាធម្មតា ។ ពួកភិក្ខុនាំគ្នាទៅកាន់ សម្នាក់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនោះត្រូវពួកខ្ញុំ ព្រះអង្គពោលយ៉ាង៏នេះ ពោលយ៉ាង៏នេះ លោកព្យាករអរហត្ត លោកពោល

ពាក្យមិនពិត ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយយ៉ាងនោះឯង បុត្ររបស់តថាគតបានធ្វើការទៅ និងការមក ក្នុងវេលាមិនស្គាល់ព្រះសទ្ធម្ម ក្នុងវេលាដែលខ្លួននៅមានចិត្តមិនមាំទាំ ឥឡូវនេះ បុត្ររបស់តថាគតនោះ លះបុណ្យ និងបាបបានហើយ ត្រាស់គាថាពីរថា

អនវដ្ឋិតចិត្តស្ស សទ្ធម្មំ អវិជានតោ
បរិប្លវប្បសាទស្ស បញ្ញា ន បរិប្ផុរតិ ។
អនវស្សុតចិត្តស្ស អនន្វាហតចេតសោ
បុញ្ញបាបប្បហីនស្ស នត្ថិ ជាគរតោ ភយំ ។

ប្រាជ្ញា រមែងមិនបរិបូណ៌ដល់បុគ្គល ដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ ។ ភ័យ រមែងមិនមានដល់បុគ្គល ដែលមានចិត្តមិនទន្ទឹកដោយរាគៈ មានចិត្តដែលទោសខ្ពាំងរួបមិនបាន មានបុណ្យ និងបាបលះចោលហើយ ភ្ញាក់រឭកជានិច្ច ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អនវដ្ឋិតចិត្តស្ស** *ព្រះសាស្តាទ្រង់សម្តែងអត្ថថា ឈ្មោះថា ចិត្តនេះ របស់បុគ្គលណា មិនមានពិតប្រាកដ ឬមាំទាំ បុគ្គលណា មិនតាំងនៅក្នុងភាវៈណា ដូចគ្នានឹងត្រឡាចដែលជាក់លើខ្នងសេះ ដូចគ្នានឹងបង្គោលដែលចោះក្នុងគំនរអង្កាម ដូចគ្នានឹងផ្លាកូម្ព ជាក់លើក្បាលតម្ពែក ជួនកាល ជាសេវកៈ គឺអ្នកបម្រើ ជួនកាល ជាអាជីវក ជួនកាល*

ជានិគ្រន្ថ ជួនកាល ជាតាបស ។ បុគ្គលបែបនេះ ឈ្មោះថា មានចិត្តមិនតាំងមាំ បញ្ញាដែលជាកាមាវចរក្តី ជារូបាវចរជាដើមក្តី រមែងមិនបរិបូណិ ដល់បុគ្គលនោះ ដែលមានចិត្តមិនមាំទាំ មិនដឹងព្រះសទ្ធម្មនេះ មានពោធិ-បក្ខិយធម៌ ៣៧ ឈ្មោះថា មានសេចក្តីជ្រះថ្លាអណ្តែតអណ្តូង ព្រោះជាអ្នកមានសទ្ធាតិច ឬព្រោះជាអ្នកមានសទ្ធាញាប់ញ័រ កាលបញ្ញាជាកាមាវចរមិនបរិបូណិ បញ្ញាដែលជារូបាវចរ អរូបាវចរ និងលោកុត្តរ នឹងបរិបូណិបានអំពីណា ។

បទថា **អនវស្សុតចិត្តស្ស** បានដល់ ជាបុគ្គលមានចិត្តត្រូវរាគៈមិនទទឹកហើយ ។

ក្នុងបទថា **អនន្ធាហតចេតសោ** ព្រះដ៏មានព្រះភាគត្រាស់ការដែលចិត្តត្រូវទោសៈប៉ះខូប់ហើយ ក្នុងអាកតដ្ឋានថា មានចិត្តត្រូវទោសៈប៉ះខូប់ដូចសរសរ ខ្រឿន ។

តែក្នុងបទថា **អនន្ធាហតចេតសោ** នេះ បណ្ឌិតគប្បីជ្រាបអត្ថថា បុគ្គលមានចិត្តដែលទោសៈមិនប៉ះខូប់ ។

បទថា **បុញ្ញចាបប្បហីនស្ស** សេចក្តីថា ជាអ្នកលះបុណ្យ និងបាបបានដោយមគ្គទី ៤ គឺបុគ្គលអស់អាសវៈហើយ ។

បាទព្រះគាថាថា **នត្ថិ ជាគរតោ ភយំ** សេចក្តីថា ការមិនមានភ័យ ដូចព្រះដ៏មានព្រះភាគត្រាស់សម្រាប់បុគ្គលដែលអស់អាសវៈ ភ្រាក់រឲកនោះ ឯង បុគ្គលដែលអស់អាសវៈនោះ ឈ្មោះថា ភ្រាក់ហើយ ព្រោះប្រកបដោយ

ធម៌ ជាហេតុភ្លាក់រឭកទាំងឡាយ មានសទ្ធាជាដើម ។ ព្រោះដូច្នេះ លោក ភ្លាក់ក្តី មិនភ្លាក់ក្តី ភ័យ គឺកិលេស ឈ្មោះថា មិនមាន ព្រោះកិលេសទាំង-ឡាយ មិនមានការវិលត្រឡប់មក ។ ពិតណាស់ កិលេសទាំងឡាយ ឈ្មោះ ថា មិនជាប់តាមលោក ព្រោះកិលេសទាំងឡាយ ដែលលោកលះបានហើយ ដោយមគ្គនោះៗ មិនមានការចូលទៅរកលោកទៀតឡើយ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា កិលេសពួកណាដែលព្រះអរិយបុគ្គលលះ បានហើយ ដោយសោតាបត្តិមគ្គ មិនមករក គឺមិនត្រឡប់មកកាន់កិលេស ទាំងនោះទៀត កិលេសពួកណាដែលអរិយបុគ្គលលះបានហើយ ដោយ សកទាគាមិមគ្គ អនាគាមិមគ្គ និងអរហត្តមគ្គ លោកមិនមករក គឺមិន ត្រឡប់មកកាន់កិលេសទាំងនោះទៀត ដូច្នេះ ។

ទេសនាមានប្រយោជន៍ មានផលជាប់មហាជនហើយ ។

ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាថា អាវុសោទាំងឡាយ ឈ្មោះថា កិលេសទាំងនេះគ្រោតគ្រាតពេក កុលបុត្រដែលដល់ព្រមដោយឧបនិស្ស័យ នៃអរហត្តបែបនេះ គង់ត្រូវកិលេសឲ្យសៅហ្មងបាន ត្រូវត្រឡប់ទៅជាគ្រហស្ថ អស់ ៧ ដង បួស ៧ ដង ។ ព្រះសាស្តាទ្រង់ស្តាប់បវត្តិកថារបស់ភិក្ខុ នោះ ទើបយាងទៅកាន់ធម្មសភា ដោយការទៅដោយសមគួរដល់ខណៈនោះ ប្រថាប់លើពុទ្ធាសនៈហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកប្រជុំ ដោយពាក្យសម្តីដូចម្តេចហ្ន៎ កាលពួកភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះ ហើយទើបត្រាស់ថា កាលពួកភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះហើយ

ទើបត្រាស់ថា យ៉ាងនោះឯងភិក្ខុទាំងឡាយ ឈ្មោះថា កិលេសទាំងឡាយ ជាសភាវៈគ្រោតគ្រាត បើកិលេសទាំងនេះមានរូបរាង ដែលបុគ្គលណាម្នាក់ គប្បីអាចទុកជាក់បានក្នុងទីមួយកន្លែង ចក្រវាឡនឹងចង្អៀត ព្រហ្មលោកក៏ទាបឱកាសរបស់កិលេសទាំងនោះ មិនគប្បីមានកន្លែងជាក់ឡើយ ។ កិលេសទាំងនេះ រមែងធ្វើបុរសអាជានេយ្យ ដែលដល់ព្រមដោយបញ្ញាដូចតថាគត ឲ្យសៅហ្មងបាន នឹងពោលថ្វីក្នុងជនដ៏សេស ។ មែនពិត តថាគតធ្លាប់អាស្រ័យថ្ពៅ និងស្លួយត្រឹមកន្ទុះនាឡិ និងចបរិលមួយ បួសសឹកហើយអស់ ៦ ជង ។

ភិក្ខុទាំងនោះក្រាបទូលសួរថា បពិត្រព្រះអង្គ រឿងនោះកើតឡើងក្នុងកាលណា ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកនឹងស្តាប់ឬ ភិក្ខុទាំងនោះក្រាបទូលថា ករុណា ព្រះអង្គ ព្រះសាស្តាត្រាស់ថា បើដូច្នោះ ចូរពួកអ្នកស្តាប់ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិក្នុងក្រុងពារាណសី បុរសម្នាក់ឈ្មោះកុទ្ទាលបណ្ឌិត បួសជាអ្នកបួសខាងក្រៅ នៅក្នុងព្រៃហិមពន្ត ៨ ខែ កាលទឹកជីសើមជោកជាំក្នុងសម័យដែលភ្លៀងធ្លាក់ខ្លាំង គិតថា ក្នុងផ្ទះរបស់អញនៅមានគ្រាប់ថ្ពៅ និងគ្រាប់ស្លួយប្រមាណកន្ទុះនាឡិ និងចបរិលមួយ ពូជ គឺថ្ពៅ និងស្លួយកុំបីវិនាសឡើយ ទើបសឹក យកចបជម្រះដីមួយកន្លែង សាបព្រោះពូជនោះ កាំងរបងក្នុងកាលដែលគ្រាប់ពូជចាស់ ក៏ច្រូតបេះពូជទុកប្រមាណមួយនាឡិ បរិភោគពូជដ៏សេស លោកគិតថា ឥឡូវនេះប្រយោជន៍អ្វីដោយផ្ទះរបស់អញ អញនឹងបួស ៨ ខែ ទើបចេញបួសហើយ ។

លោកអាស្រ័យគ្រាប់ថ្ពៅ និងគ្រាប់ស្ពួយប្រមាណមួយនាឡិ និងចបរិល ក៏សឹកទៅជាគ្រហស្ថអស់ ៧ ជង បួស ៧ ជង ដោយទំនងនេះឯង តែក្នុងគ្រាទី ៧ គិតថា អញអាស្រ័យចបរិលនេះ មកជាគ្រហស្ថហើយបួស អស់ ៧ ជង អញនឹងចោលវាក្នុងទីណាមួយកន្លែង លោកទៅកាន់ច្រាំងស្ទឹងគង្គា ហើយគិតថា កាលអញឃើញទីធ្លាក់គង់ត្រូវចុះរាវយកវិញ អញនឹងចោលវា ដោយអាការដែលអញមិនឃើញទីដែលវាធ្លាក់ ទើបយកសំពត់ចាស់ខ្ចប់ពូជប្រមាណមួយនាឡិ ហើយចងសំពត់ចាស់ត្រង់បន្ទុះចប ចាប់ចបត្រង់ចុងជង ឈរត្រង់ច្រាំងស្ទឹង បិទភ្នែកគ្រវីលើក្បាល ៣ ជង គ្រវែងចោលទៅក្នុងស្ទឹងគង្គា បែរមើលទៅមិនឃើញទីធ្លាក់ បានបន្ទឺសំឡេងថា អញឈ្នះហើយ អញឈ្នះហើយ អស់វារៈ ២ ជង ។ ខណៈនោះ ព្រះបាទក្រុងពារាណសី ទ្រង់បង្គ្រាបបច្ចន្តជនបទឲ្យរាបទាប ហើយយាងមក ឲ្យបោះព្រះពន្លាក្បែរឆ្នេរស្ទឹង ស្តេចចុះកាន់ស្ទឹង ដើម្បីស្រង់ ទ្រង់បានឮសំឡេងនោះ ។ ធម្មតាសំឡេងថា អញឈ្នះហើយ អញឈ្នះហើយ រមែងមិនពេញព្រះហឫទ័យរបស់ព្រះរាជាទាំងឡាយ ទើបទ្រង់យាងទៅកាន់សម្នាក់របស់កុទ្ទាលបណ្ឌិតនោះ ត្រាស់សួរថា យើងធ្វើការបង្គ្រាបអមិត្តមកអម្បាញ់មិញនេះ ដោយគិតថា យើងឈ្នះ ចំណែកអ្នក ស្រែកថា អញឈ្នះហើយ អញឈ្នះហើយ សេចក្តីនេះដូចម្តេច ទើបកុទ្ទាលបណ្ឌិតទូលថា ព្រះអង្គទ្រង់ឈ្នះពួកចោរខាងក្រៅ ការឈ្នះដែលទ្រង់ឈ្នះហើយ រមែងត្រឡប់ជាមិនឈ្នះទៀតបានពិត ចំណែកចោរ គឺលោភៈ ដែលមាននៅខាងក្នុងដែលទូលបង្គំឈ្នះហើយ ចោរ

គឺសេចក្តីលោភនោះ នឹងមិនត្រឡប់ឈ្នះទូលបង្គំទៀត ឈ្នះចោរ គឺលោភៈនោះតែម្យ៉ាង ទើបល្អ ដូច្នេះហើយ ទើបពោលគាថានេះថា

សេចក្តីឈ្នះណា ត្រឡប់ចាញ់វិញបាន សេចក្តីឈ្នះនោះ មិនឈ្មោះថា ឈ្នះប្រពៃទេ សេចក្តីឈ្នះណា មិនត្រឡប់ចាញ់វិញបាន សេចក្តីឈ្នះនោះ ទើបឈ្មោះថា ឈ្នះប្រពៃមែនពិត ។

ក្នុងខណៈនោះឯង លោកសម្ងីងមើលស្ងឹងគង្គា ញុំាងកសិណ មានទឹកជាអារម្មណ៍ឲ្យកើតឡើង សម្រេចគុណវិសេសហើយ អង្គុយពត់ក្អែនក្នុងអាកាស ។ ព្រះរាជាទ្រង់ស្តាប់ធម្មកថារបស់មហាបុរស ថ្វាយបង្គំហើយ ទ្រង់សូមបួស ទ្រង់បួសមួយអន្ទើដោយពួកពល មានបរិស័ទប្រមាណ ១ យោជន៍ សូម្បីក្សត្រសាមន្តរាជដទៃ ទ្រង់ស្តាប់ភាពដែលព្រះបាទក្រុងពារាណសីនោះបួសហើយ យាងមកដោយបំណងថា អញនឹងកាន់យករាជសម្បត្តិរបស់ស្តេចក្រុងពារាណសីនោះ ទ្រង់ឃើញព្រះនគរដែលមាំទាំយ៉ាងនោះទេ ទើបត្រិះរិះថា ព្រះរាជាកាលទ្រង់ចោះបង់នគរបែបនេះបួស ទ្រង់នឹងមិនបួសក្នុងឋានៈដែលថោកថយ សូម្បីអញបួសក៏គួរ ដូច្នេះហើយ ទ្រង់យាងទៅទីនោះ ចូលទៅរកមហាបុរស ទ្រង់សូមបួស មួយអន្ទើដោយបរិស័ទហើយ ។ ព្រះរាជា ៧ អង្គ ទ្រង់បួសដោយទំនងដូចគ្នានេះ ។ អាស្រមក៏ផ្សាយទៅដល់ ៧ យោជន៍ ។ ព្រះរាជា ៧ អង្គ ទ្រង់ចោលភោគៈទាំងឡាយ នាំជនមានប្រមាណប៉ុណ្ណោះបួសហើយ ។ មហាបុរសនៅប្រព្រឹត្តព្រហ្មចរិយៈ ជាអ្នកចូលដល់ព្រហ្មលោកហើយ ។

ព្រះសាស្តាកាលទ្រង់នាំធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុទ្ទាលបណ្ឌិតក្នុងកាលនោះ បានជាតថាគត ឈ្មោះថា កិលេសទាំងនេះ ជាសភាវៈគ្រោតគ្រាតយ៉ាងនោះ ៗ

រឿង ព្រះចិត្តហាត្ថត្ថេរ ចប់

រឿង ភិក្ខុប្រារព្ធវិបស្សនា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធពួកភិក្ខុដែលប្រារព្ធវិបស្សនា ត្រាស់ធម្មទេសនានេះថា **កុម្ភូបមំ** *ជាដើម ។*

បានឮថា ភិក្ខុ ៥០០ រូប ក្នុងក្រុងសាវត្ថី រៀនកម្មដ្ឋានអំពីភាពជាព្រះអរហន្ត ក្នុងសម្នាក់ព្រះសាស្តាហើយ គិតថា អញនឹងធ្វើសមណធម៌ ទៅអស់ចម្ងាយផ្លូវប្រមាណមួយរយយោជន៍ បានដល់តំបន់ធំមួយ លំជាប់នោះ ពួកមនុស្សឃើញភិក្ខុទាំងនោះ ទើបនិមន្តឲ្យគង់លើអាសនៈដែលគេបានរៀបចំអង្គាសដោយកត្តាហារទាំងឡាយ មានបបរដ៏ប្រណីតជាដើមហើយ សួរថា លោកម្ចាស់ទាំងឡាយនឹងទៅណា កាលភិក្ខុទាំងនោះពោលថា ពួកអាត្មានឹងទៅតាមផាសុក ទើបនិមន្តថា សូមនិមន្តលោកម្ចាស់ទាំងឡាយ នៅក្នុងទីនេះអស់កាល ៣ ខែចុះ ពួកខ្ញុំនឹងតាំងនៅក្នុងសរណៈ នឹងរក្សាសីល ក្នុងសម្នាក់លោកម្ចាស់ទាំងឡាយ ។ ជ្រាបការនិមន្តរបស់ភិក្ខុទាំងនោះហើយ ទើបសួរ

ថា ក្នុងទីមិនឆ្ងាយ មានដងព្រៃធំច្រើន និមន្តលោកម្ចាស់ស្នាក់នៅត្រង់ដងព្រៃនោះចុះ ដូច្នេះហើយ បញ្ជូនទៅ ។ ភិក្ខុទាំងនោះទៅកាន់ដងព្រៃនោះហើយ ។

ពួកទេវតាដែលអាស្រ័យនៅក្នុងដងព្រៃនោះគិតថា លោកម្ចាស់ទាំង-ទ្បាយមានសីល មកដល់ដងព្រៃនេះដោយលំដាប់ហើយ បើលោកម្ចាស់ទាំងទ្បាយស្នាក់នៅក្នុងទីនេះ ការដែលពួកយើងនាំបុត្រ និងភាតាឡើងដើមឈើមិនគួរឡើយ ទើបអង្គុយលើផែនដីគិតថា លោកម្ចាស់ទាំងទ្បាយនៅក្នុងទីនេះមួយយប់ក្នុងថ្ងៃនេះ ស្អែកនេះនឹងទៅពិត ។ ចំណែកពួកភិក្ខុ ត្រាច់ទៅបិណ្ឌបាតក្នុងស្រុក ក្នុងថ្ងៃស្អែកឡើងហើយ ក៏ត្រឡប់មកកាន់ដងព្រៃនោះឯង ។ ពួកទេវតាគិតថា បុគ្គលណាម្នាក់នឹងនិមន្តភិក្ខុសង្ឃឲ្យឆាន់ក្នុងថ្ងៃស្អែកនេះ ព្រោះដូច្នោះ ទើបត្រឡប់មក ។ ថ្ងៃនេះ មិនទៅ ស្អែកនេះ ប្រហែលជាទៅពិត ដូច្នេះហើយ ក៏នាំគ្នាស្នាក់នៅត្រង់ផែនដីនោះឯង ប្រមាណកន្លះខែដោយឧបាយនេះ ។ បន្ទាប់អំពីនោះមក ពួកទេវតាគិតថា លោកម្ចាស់ទាំង-ទ្បាយ ប្រហែលជានៅក្នុងទីនេះឯងអស់កាល ៣ ខែនេះ កាលលោកម្ចាស់ទាំងទ្បាយនៅក្នុងទីនេះ ពួកយើងឡើងអង្គុយលើដើមឈើក៏មិនគួរ នឹងត្រូវនាំកូន និងចៅអង្គុយលើផែនដីអស់ ៣ ខែ ក៏ជាទុក្ខរបស់ពួកយើង ពួកយើងនឹងធ្វើដូចម្តេចឲ្យភិក្ខុទាំងនេះគេចទៅបាន ។ ទេវតាទាំងនោះ ក៏ផ្តើមសម្តែងសរីរៈខ្មោចឥតក្បាល នឹងឲ្យឮសំឡេងអមនុស្ស ក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ និងក្នុងទីបំផុតនៃទីចង្ក្រមនោះៗ រោគទាំងទ្បាយមានក្អកកណ្តាសជាដើម កើតដល់ពួកភិក្ខុហើយ ភិក្ខុទាំងនោះសួរគ្នានិងគ្នាថា

អាវុសោ រោគអ្វីចាក់ដោតលោក រោគអ្វីចាក់ដោតលោកម្ចាស់ ពោលថា រោគកណ្តាសចាក់ដោតខ្ញុំ រោគក្អកចាក់ដោតខ្ញុំ ដូច្នេះហើយ ពោលថា អាវុសោ ថ្ងៃនេះ ខ្ញុំបានឃើញខ្មោចកំបុតក្បាលក្នុងទីបំផុតនៃទីចង្រ្តម ខ្ញុំបានឃើញខ្មោចក្នុងទីសម្រាកពេលយប់ ខ្ញុំបានឮសំឡេងអមនុស្សក្នុងទីសម្រាកពេលថ្ងៃ ទីនេះ ជាទីដែលគួរវៀរ ក្នុងទីនេះ ការមិនផាសុកមានដល់ពួកយើង ពួកយើងនឹងទៅកាន់សម្នាក់របស់ព្រះសាស្តា ។ ភិក្ខុទាំងនោះ ចេញទៅកាន់សម្នាក់របស់ព្រះសាស្តាដោយលំដាប់ ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនអាចនៅក្នុងទីនោះឬ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ យ៉ាងនោះឯង ព្រោះអារម្មណ៍ដែលគួរខ្លាចបែបនេះ ប្រាកដដល់ខ្ញុំព្រះអង្គទាំងឡាយ ដែលស្នាក់នៅក្នុងទីនោះ ព្រោះហេតុនោះ ទើបមានការមិនផាសុកបែបនេះ ។ ដោយហេតុនោះ ទើបខ្ញុំព្រះអង្គទាំងឡាយគិតថា ទីនេះ ជាទីដែលគួរវៀរ ចោលទីនោះ មកកាន់សម្នាក់របស់ព្រះអង្គហើយ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកទៅក្នុងទីនោះឯងសមគួរ ភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនអាចទេ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនយកអាវុធទៅ ឥឡូវនេះ ពួកអ្នក ចូរយកអាវុធទៅចុះ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ កាន់យកអាវុធប្រភេទណាទៅ ព្រះសាស្តាត្រាស់ថា តថាគតនឹងឲ្យអាវុធដល់ពួកអ្នក ចូរពួកអ្នកកាន់

យកអាវុធដែលតថាគតឲ្យទៅ ដូច្នេះហើយ ត្រាស់មេត្តសូត្រទាំងមូលថា

កិច្ចណា (ដែលព្រះអរិយៈ) បានត្រាស់ដឹងនូវបទដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន (បានធ្វើហើយ) កិច្ចនោះ កុលបុត្តអ្នកឈ្លាសក្នុងប្រយោជន៍គួរធ្វើ (កុលបុត្តនោះ) ជាអ្នកអាចហ៊ានផង ត្រង់ដោយកាយ និងវាចាផង ត្រង់ល្អដោយចិត្តផង គេប្រជៅងាយផង មានសុភាពទន់ភ្លន់ផង មិនមានមានះដ៏ក្រៃលែងផង ដូច្នេះជាដើម ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកគប្បីស្វាធ្យាយមេត្តសូត្រនេះ ចាប់តាំងអំពីដងព្រៃខាងក្រៅវិហារ ចូលទៅខាងក្នុងវិហារ ដូច្នេះហើយ ទ្រង់បញ្ជូនទៅហើយ ។ ភិក្ខុទាំងនោះថ្វាយបង្គំព្រះសាស្តា ចេញទៅដល់ដងព្រៃនោះដោយលំដាប់ នាំគ្នាស្វាធ្យាយជាក្រុមខាងក្រៅវិហារ ចូលទៅកាន់ដងព្រៃហើយ ។

ពួកទេវតាក្នុងដងព្រៃទាំងអស់ ក៏ប្រែត្រឡប់បាននូវមេត្តាចិត្ត ធ្វើការទទួលភិក្ខុទាំងនោះ សួរដោយអើពើដល់ការទទួលបាត្រចីវរ ។ សួរដោយអើពើដល់ការគក់ច្រចាច់រាងកាយ ធ្វើការរក្សាយ៉ាងមានរបៀបក្នុងទីនោះដល់ពួកលោក ទេវតាបានជាអ្នកអង្គុយស្ងប់ ដូចចក្រដែលឈប់វិល ។ ឈ្មោះថា សំឡេងនៃអមនុស្ស ឈប់មានហើយក្នុងទីណាមួយ ចិត្តរបស់ភិក្ខុទាំងនោះ មានអារម្មណ៍មួយ ពួកលោកអង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ញុំងចិត្តឲ្យឈមចុះក្នុងវិបស្សនា តាំងនូវសេចក្តីព្យាយាមអស់នូវការអន្តរាយក្នុងខ្លួន គិតថា ឈ្មោះថា អត្តភាពនេះ ដូចគ្នានឹងភាជន៍ដីព្រោះអត្ថថា ត្រូវបែក មិនមាំទាំ ដូច្នេះ ចម្រើនវិបស្សនាហើយ ។

ព្រះសម្មាសម្ពុទ្ធ ប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ជ្រាបថាភិក្ខុទាំងនោះផ្តើមវិបស្សនាហើយ ទើបទ្រង់ហៅភិក្ខុទាំងនោះត្រាស់ថា ម្នាលភិក្ខុទាំងឡាយយ៉ាងនោះឯង ឈ្មោះថា អត្តភាពនេះ ដូចគ្មានទឹងភាជន៍ដីដោយពិត ព្រោះអត្តថា ត្រូវបែក មិនមាំទាំ ដូច្នេះហើយ ទ្រង់ផ្សាយព្រះឱកាសទៅសូម្បីប្រថាប់នៅក្នុងទីមួយរយៈយោជន៍ ក៏ហាក់ដូចប្រថាប់គង់ក្នុងទីចំពោះមុខរបស់ភិក្ខុទាំងនោះ ទ្រង់ផ្សាយព្រះឆព្វណ្ណរង្សី មានព្រះរូបប្រាកដ ត្រាស់ព្រះគាថានេះថា

កុម្ភូបមំ កាយមិមំ វិទិត្វា ឆគ្ឃរូបមំ ចិត្តមិទំ ឋបេត្វា
យោធេថ មារំ បញ្ញាវុធេន ជិតញ្ច រក្ខេ អនិវេសិនោ សិយា ។

បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាឆ្នាំង គប្បីបិទនូវចិត្តនេះ ឲ្យដូចជាបិទទ្វារនគរ គប្បីច្បាំងនូវមារដោយអាវុធ គឺបញ្ញា គប្បីរក្សាទុកនូវធម៌ ដែលខ្លួនឈ្នះហើយ មិនគប្បីជាអ្នកជំអក់នៅ (ក្នុងធម៌នោះ) ឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឆគ្ឃរូបមំ** *សេចក្តីថា ស្គាល់នូវកាយនេះគឺដែលរាប់ថាប្រជុំនៃអាការ មានសក់ជាដើម ឈ្មោះថា ប្រៀបដូចឆ្នាំង គឺដូចភាជន៍ដី ព្រោះអត្តថា មិនមានកម្លាំង និងខ្សោយកម្លាំង ព្រោះអត្តថា ប្រព្រឹត្តទៅម្តងម្កាល ដោយភាពជាកាយមិនស្ថិតស្ថេរ ។*

បាទព្រះគាថាថា **ឆគ្ឃរូបមំ ចិត្តមិទំ ឋបេត្វា** *ជាដើម សេចក្តីថា ធម្មតា*

នគរមានគូទឹកជ្រៅ ព័ទ្ធដោយកំពែង ប្រកបដោយទ្វារ និងប៉ម ឈ្មោះថា មាំទាំ ខាងក្រៅ ដល់ព្រមដោយផ្លូវបែកជា ៤ មានផ្សារក្នុងចន្លោះ ឈ្មោះថា រៀបចំល្អខាងក្នុង ពួកចោរខាងក្រៅមកកាន់នគរនោះ ដោយគិតថា អញនឹងប្លន់ ក៏មិនអាចចូលទៅបាន រមែងហាក់ដូចជាប៉ះនូវភ្នំ ខ្លាតត្រឡប់ទៅយ៉ាងណា កុលបុត្រដែលជាបណ្ឌិតក៏ដូច្នោះដូចគ្នា រក្សាវិបស្សនាចិត្តរបស់ខ្លួនធ្វើឲ្យមាំទាំ គឺឲ្យដូចគ្នានឹងនគរ ហាមកិលេសដែលមគ្គនោះៗ គប្បីសម្លាប់ដោយអាវុធគឺបញ្ញា ដែលសម្រេចហើយដោយវិបស្សនា និងសម្រេចហើយដោយអរិយមគ្គ ឈ្មោះថា គប្បីច្បាំង គឺគប្បីប្រហារកិលេសមារនោះ ដូចអ្នកចម្បាំងឈរក្នុងនគរ ច្បាំងពួកចោរដោយអាវុធ មានប្រការផ្សេងៗ មានអាវុធដែលមានមុខតែម្ខាង ដូច្នោះ ។

ពីរបទថា **ឯតញ្ច រក្ខេ** *សេចក្តីថា កុលបុត្រកាលត្រូវសេពអាវាសជាទីសប្បាយ ឧតុជាទីសប្បាយ បុគ្គលជាទីសប្បាយ និងការស្តាប់ធម៌ជាហេតុសប្បាយជាដើម ចូលសមាបត្តិក្នុងចន្លោះៗ ចេញអំពីសមាបត្តិនោះ ពិចារណាសង្ខារទាំងឡាយដោយចិត្តបរិសុទ្ធ ឈ្មោះថា គប្បីរក្សាធម៌ ដែលឈ្នះហើយ គឺវិបស្សនាយ៉ាងទន់ ដែលខ្លួនឲ្យកើតឡើងហើយ ។*

ពីរបទថា **អនិវេសនោ សិយា** *បានដល់ គប្បីជាអ្នកមិនមានអាល័យ អធិប្បាយថា ឧបមាដូចអ្នកចម្បាំងធ្វើជម្រកជាទីសម្រាកនៃពល ក្នុងបទេសដែលប្រឈមមុខនៃសង្គ្រាម ច្បាំងជាមួយពួកអមិត្ត ជាអ្នកឃ្លាន ឬស្រេកហើយ កាលក្រោះធូរ ឬកាលអាវុធក្លាត់ធ្លាក់ ក៏ចូលទៅកាន់ជម្រកជាទីសម្រាក*

របស់ពួកពល សម្រាកបរិភោគ ផឹក ចងនូវក្រោះ ចាប់អាវុធហើយ ចេញ ច្បាំងទៀត ញាំញីសេនានៃបរបក្ស ឈ្នះបច្ចាមិត្តដែលមិនទាន់បានឈ្នះ រក្សា ជ័យជម្នះដែលឈ្នះហើយ បើអ្នកចម្បាំងនោះ កាលសម្រាកយ៉ាងនោះ ក្នុង ជម្រកដែលជាទីសម្រាកនៃពល ត្រេកអរក្នុងជម្រកនោះ គប្បីស្នាក់នៅ ក៏គប្បី ធ្វើរាជសម្បត្តិ ឲ្យប្រព្រឹត្តទៅក្នុងកណ្តាប់ដៃរបស់សត្រូវយ៉ាងណា ភិក្ខុនោះក៏ ដូច្នោះដូចគ្នា ព្យាយាមចូលសមាបត្តិ ចេញអំពីសមាបត្តិនោះ ពិចារណាសង្ខារ ទាំងឡាយ ដោយចិត្តដ៏បរិសុទ្ធ រមែងអាចរក្សាវិបស្សនាយ៉ាងទន់ ដែលបាន ចំពោះហើយ រមែងឈ្នះកិលេសមារដោយការបានចំពោះនូវមគ្គដ៏ប្រសើរ តែ បើភិក្ខុនោះ ពេញចិត្តក្នុងសមាបត្តិតែម្យ៉ាង មិនព្យាយាមពិចារណាសង្ខារ ទាំងឡាយដោយចិត្តដ៏បរិសុទ្ធទេ មិនអាចធ្វើនូវការចាក់ផ្លុះមគ្គ និងផលបាន ឡើយ ព្រោះហេតុនោះ ភិក្ខុកាលរក្សាធម៌ដែលគួររក្សា គប្បីជាអ្នកមិនជាប់ នៅ គឺគប្បីធ្វើសមាបត្តិឲ្យជាទីសម្រាកហើយ មិនជាប់នៅ បានដល់ មិនគប្បី ធ្វើអាល័យក្នុងសមាបត្តិនោះ ។ ព្រះសាស្តាត្រាស់ថា អ្នកទាំងឡាយ ចូរធ្វើ យ៉ាងនោះ ។ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ភិក្ខុទាំងឡាយនោះ ដោយ ប្រការដូច្នេះ ។

ក្នុងពេលចប់ធម្មទេសនា ភិក្ខុ ៥០០ រូប អង្គុយក្នុងទីអង្គុយនោះ សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយ សរសើរផង ថ្វាយ បង្គំព្រះសរីរៈ ដ៏ប្រកបដោយវណ្ណៈដូចមាសរបស់ព្រះតថាគតផង និមន្តមក ហើយ ដូច្នេះឯង ។

រឿង បូតិគត្តិស្សត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះបូតិគត្តិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អចិរំ វតយំ កាយោ** ជាដើម ។

បានឮថា កុលបុត្រអ្នកក្រុងសាវត្ថីមួយរូប ស្តាប់ធម្មកថាក្នុងសម្នាក់របស់ព្រះសាស្តា ថ្វាយជីវិតក្នុងព្រះសាសនា បានបព្វជ្ជាឧបសម្បទាហើយ បានឈ្មោះថា ព្រះតិស្សត្ថេរ ។ កាលកន្លងទៅ រោគកើតឡើងក្នុងសរីរៈរបស់លោក ពកទាំងឡាយ ប្រមាណប៉ុនគ្រប់ស្មៅផុសឡើង ពកនោះធំឡើងតាមលំដាប់ ប្រមាណប៉ុនគ្រប់សណ្តែកបាយ ប្រមាណប៉ុនគ្រប់សណ្តែកខ្មៅ ប្រមាណប៉ុនគ្រប់ក្រៅ ប្រមាណប៉ុនផ្លែកន្ធួតព្រៃ ប្រមាណប៉ុនផ្លែញៅ បែកហើយ ។ សរីរៈទាំងនោះ បានជាប្រហោងតូចធំ ឈ្មោះរបស់លោកកើតឡើងហើយថា ព្រះបូតិគត្តិស្សត្ថេរ គឺព្រះតិស្សត្ថេរមានកាយស្អុយ ។ បន្ទាប់មក ក្នុងកាលជាចំណែកជនៃ ឆ្អឹងរបស់លោកបែកហើយ លោកបានជាបុគ្គល ដែលបុគ្គលណាមួយបដិបត្តិ គឺបម្រើមិនបាន ។ សំពត់ស្បៃក និងសំពត់ដណ្តប់ ប្រឡាក់ដោយខ្ទុះ និងឈាម បានដូចជានំពុម្ព ។ ពួកភិក្ខុមានសទ្ធិវិហារិកជាដើម មិនអាចបដិបត្តិបាន លះបង់លោកហើយ លោកជាបុគ្គលមិនមានទីពឹង សិងហើយ ។

ធម្មតាព្រះសម្ពុទ្ធទាំងឡាយ ទ្រង់មិនលះបង់ កាលប្រមើលមើលសត្វលោក អស់ពីវារៈ គឺក្នុងពេលទៀបភ្លឺ កាលទ្រង់ប្រមើលមើលលោក ទ្រង់

ប្រមើលតាំងអំពីកណ្តាប់នៃចក្រវាល ធ្វើព្រះញាណឲ្យបែរមុខចំពោះព្រះគន្ធ-
កុដិ កាលទ្រង់ប្រមើលក្នុងពេលល្ងាច ទ្រង់ប្រមើលចាប់ពីព្រះគន្ធកុដិ ធ្វើព្រះ
ញាណឲ្យបែរមុខចំពោះទីខាងក្រៅ ។ ក្នុងសម័យនោះ ព្រះបូតិគត្តិស្សត្ថេរ
ប្រាកដហើយខាងក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះដ៏មានព្រះភាគ ។ ព្រះ
សាស្តាទ្រង់ឃើញឧបនិស្សយនៃអរហត្តរបស់ព្រះតិស្សភិក្ខុ ទ្រង់ត្រិះរិះថា ភិក្ខុ
នេះត្រូវពួកសទ្ធិវិហារិកជាដើមលះបង់ហើយ ឥឡូវនេះ ភិក្ខុនេះ រៀវតថាគត
ចេញ មិនមានទីពឹងដទៃឡើយ ដូច្នេះហើយ ទើបទ្រង់យាងចេញអំពីព្រះ
គន្ធកុដិ ដូចយាងចារិកក្នុងវិហារ ទ្រង់ទៅកាន់រោងភ្លើង ទ្រង់លាងឆ្នាំងដាក់
ទឹក លើកដាក់លើជើងក្រាន កាលទ្រង់រង់ចាំឲ្យទឹកក្តៅ បានប្រថាប់ឈរ
ក្នុងរោងភ្លើងនោះឯង ទ្រង់ជ័ងភាពដែលទឹកក្តៅហើយ យាងទៅចាប់ចុងត្រែ
ដែលតិស្សភិក្ខុសិង ។ ក្នុងកាលនោះ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ
សូមទ្រង់យាងទៅ បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គនឹងលើកឯង ហើយលើក
ត្រែ នាំទៅកាន់រោងភ្លើង ។ ព្រះសាស្តាទ្រង់ឲ្យនាំស្នូកមក ទ្រង់ចាក់ទឹកក្តៅ
ហើយ ទ្រង់ប្រាប់ភិក្ខុនោះឲ្យដោះយកសំពត់ដណ្តប់របស់លោក ឲ្យញីដោយ
ទឹកក្តៅ ហើយឲ្យហាលថ្ងៃ ។ លំដាប់នោះ ព្រះសាស្តាប្រថាប់ឈរក្នុងទីជិត
លោក ទ្រង់ស្រោចសរីរៈនោះឲ្យសើមដោយទឹកក្តៅ ហើយជូតសរីរៈរបស់
លោក ឲ្យលោកងូតហើយ ។ ក្នុងទីបំផុតនៃការងូតរបស់លោក សំពត់ដណ្តប់
នោះស្ងួតហើយ ។ ពេលនោះ ព្រះសាស្តាទ្រង់គ្រាហ៍លោកឲ្យស្លៀកសំពត់
ដណ្តប់នោះ ទ្រង់ឲ្យបោកសំពត់កាសាវៈដែលលោកស្លៀកដោយទឹក ហើយ

ឲ្យហាលថ្ងៃ ។ ពេលនោះ កាលទឹកត្រង់កាយរបស់លោកស្ងួត សំពត់ស្បៃក នោះក៏ស្ងួត ។ លោកស្បៃកសំពត់កាសាវៈមួយផ្ទាំង ដណ្តប់សំពត់កាសាវៈ មួយផ្ទាំង ជាអ្នកមានសរីរៈស្រាល មានអារម្មណ៍ជាឯកគ្គតា សិងលើគ្រែ ហើយ ។ ព្រះសាស្តាប្រថាប់ឈរក្នុងទីខាងលើសីសៈរបស់លោក ត្រាស់ថា ម្នាលភិក្ខុ កាយរបស់អ្នកនេះមានវិញ្ញាណទៅច្រាសហើយ មិនមានឧបការៈ នឹងដេកលើផែនដីដូចអង្គត់ឧស ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អចិរំ វតយំ កាយោ បឋវឹ អធិសេស្សតិ
ឆុទ្ធោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។

ឱហ្ន៎ មិនយូរប៉ុន្មានទេតើ កាយនេះ មានវិញ្ញាណទៅ ច្រាស គេយកទៅចោលផុតហើយ មុខជានឹងដេកស្តូក ស្តឹងលើផែនដី ដូចជាអង្គត់ឧសរកប្រយោជន៍គ្មាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អចិរំ វត** *ជាដើម សេចក្តីថា ភិក្ខុ ក្នុងកាលមិនយូរឡើយ កាយនេះ នឹងដេកសង្កត់លើផែនដី គឺដេកខាងលើនៃផែនដី ដែលសត្វដេកហើយ ដោយការដេកប្រក្រតីនេះ ។*

ដោយបទថា **ឆុទ្ធោ** *ព្រះសាស្តាទ្រង់សម្តែងអត្ថថា កាយនេះនឹងជារបស់ឈ្មោះថា ទទេ ព្រោះការមានវិញ្ញាណទៅច្រាស ត្រូវបោះចោលហើយដេក ។ សេចក្តីនេះ ដូចអ្វី ដូចអង្គត់ឧសមិនមានប្រយោជន៍ អធិប្បាយថា ដូចអង្គត់ឧសដែលមិនមានឧបការៈ មិនមានប្រយោជន៍ ។ មែនពិត ពួកមនុស្សដែល*

មានសេចក្តីត្រូវការដោយទព្វសម្ភារៈ ចូលកាន់ព្រៃហើយ កាប់ឈើត្រង់ដោយ សណ្ឋាននៃឈើត្រង់ ឈើវៀចដោយសណ្ឋាននៃឈើវៀច កាន់យកជាទព្វ-សម្ភារៈ តែកាប់ឈើជាប្រហោង ឈើពុក ឈើមិនមានខ្វិម ឈើពកតូចធំ ជ័សេស ចោលក្នុងព្រៃនោះឯង មនុស្សពួកជនៃ ដែលត្រូវការដោយទព្វ-សម្ភារៈ មកហើយ ឈ្មោះថា បំណងកាន់យកចម្រៀកឈើដែលត្រូវចោល នោះ មិនមាន មនុស្សទាំងនោះសម្លឹងមើលឈើនោះហើយ កាន់យកឈើ ដែលមានឧបការៈដល់ខ្លួនប៉ុណ្ណោះ ឈើក្រៅអំពីនេះ ជាឈើសង្កត់ផែនដី តែម្យ៉ាង ។ ឈើនោះ គប្បីជាឈើមិនមានបុគ្គលណាម្នាក់ អាចធ្វើជាជើង រោងគ្រែ ឬជ្រញ៉ាទ្រាប់ជើង ឬថា ធ្វើជាតាំងបន្ទះក្តារដោយឧបាយនោះៗ បាន បណ្តាអាការ ៣២ ក្នុងអត្តភាពនេះ មួយចំណែក ឈ្មោះថា ចូលដល់នូវ ភាពជារបស់ដែលគប្បីកាន់យកបាន ដោយអំណាចនៃឧបករណ៍វត្ថុ មាន ទ្រនល់ព្រែជាដើម ឬដោយមុខ មានឧបការៈជនៃ មិនមាន កាយនេះ មាន វិញ្ញាណទៅច្រាសហើយ ក្នុងថ្ងៃបន្តិចបន្តួចប៉ុណ្ណោះ ក៏ទីងដេកលើផែនដី ដូច អង្គត់ឧស មិនមានប្រយោជន៍ដូច្នោះ ដូច្នេះឯង ។

ក្នុងកាលចប់ទេសនា ព្រះបូតិគត្តិស្សត្ថេរសម្រេចអរហត្តមួយអន្ទើដោយ បដិសម្ភិទាហើយ មហាជនក៏បានជាព្រះអរិយបុគ្គល មានសោតបន្នជាដើម ។ ចំណែកព្រះថេរៈសម្រេចអរហត្តហើយ បរិនិព្វាន ។ ព្រះសាស្តាឲ្យធ្វើសរីរ-កិច្ចរបស់លោក ទ្រង់ទុកអដ្ឋិធាតុហើយ ឲ្យធ្វើចេតិយបញ្ចុះ ។

ពួកភិក្ខុក្រាបទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ព្រះបូតិគត្តិស្សត្ថេរ

កើតក្នុងទីណា ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បរិនិព្វានហើយ ពួកភិក្ខុពោលថា បពិត្រព្រះអង្គ កាយរបស់ភិក្ខុដែលដល់ព្រមដោយឧបនិស្សយនៃអរហត្តបែបនោះ កើតជាកាយស្អុយ ព្រោះហេតុដូចម្តេច ឆ្អឹងទាំងឡាយបែកហើយ ព្រោះហេតុដូចម្តេច អ្វីជាហេតុដល់នូវភាពជាឧបនិស្សយនៃអរហត្តរបស់លោក ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផលទាំងអស់នេះ កើតហើយដល់តិស្សៈនោះ ក៏ព្រោះកម្មដែលខ្លួនធ្វើ ។ ភិក្ខុទាំងនោះសួរថា បពិត្រព្រះអង្គ តើកម្មដែលលោកធ្វើនោះដូចម្តេច ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរពួកអ្នកស្តាប់ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមក ត្រាស់ដូចតទៅនេះ

តិស្សភិក្ខុនេះ ជាព្រានបក្សី ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធ ព្រះនាមកស្សបៈ សម្ងាប់បក្សីជាច្រើន ទំនុកបម្រុងឥស្សរជន លក់បក្សីជ័រសេស អំពីបក្សីដែលឲ្យដល់ឥស្សរជនទាំងនោះ ។ គិតថា សត្វដែលសល់អំពីលក់ បើអញសម្ងាប់រក្សាទុក ក៏នឹងស្អុយខូច ទើបកាប់ឆ្អឹងស្មង និងឆ្អឹងស្ងាបរបស់បក្សីទាំងនោះ ធ្វើឲ្យហើរមិនបាន ហើយគរទុក ។ គាត់លក់បក្សីទាំងនោះក្នុងថ្ងៃស្អែក ក្នុងកាលដែលបានបក្សីច្រើន ក៏ឲ្យអាំងដើម្បីជាប្រយោជន៍ដល់ខ្លួន ។ ថ្ងៃមួយ កាលភោជនមានរសរបស់គាត់ឆ្អិនហើយ ព្រះខីណាស្រពមួយអង្គ ត្រាច់ទៅបិណ្ឌបាត បានឈរត្រង់ទ្វារផ្ទះរបស់គាត់ គាត់ឃើញព្រះថេរៈហើយ ញុំាងចិត្តឲ្យជ្រះថ្លា គិតថា សត្វមានជីវិតជាច្រើន ត្រូវអញសម្ងាប់ឲ្យស្លាប់ លោកម្ចាស់ឈរត្រង់ទ្វារផ្ទះរបស់អញ ភោជនដែលមានរសក៏មានព្រមក្នុងផ្ទះ អញ

នីងប្រគេនបិណ្ឌបាតដល់លោក ។ ដូច្នេះហើយ ទើបទទួលបាត្រវបស់ព្រះខីណាស្រពនោះ ជាក់កោជនដែលមានរសនោះ ឲ្យពេញក្នុងបាត្រហើយប្រគេនបិណ្ឌបាតដែលមានរស ហើយថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋានពោលថា បពិត្រលោកម្ចាស់ ខ្ញុំគប្បីដល់ទីបំផុតនៃធម៌ដែលលោកម្ចាស់ឃើញចុះ ។ ព្រះថេរៈធ្វើអនុមោទនាថា ចូរសម្រេចយ៉ាងនោះចុះ ។

ម្នាលភិក្ខុទាំងឡាយ ផលទាំងអស់នោះសម្រេចដល់តិស្សៈ ដោយអំណាចនៃកម្មដែលតិស្សៈធ្វើហើយក្នុងកាលនោះឯង កាយរបស់តិស្សកើតរោគស្អុយរលួយ ហើយឆ្អែងទាំងឡាយបែក ក៏ដោយផលនៃការវាយឆ្អែងបក្សីទាំងឡាយ តិស្សៈសម្រេចអរហត្ត ក៏ដោយផលនៃការថ្វាយបិណ្ឌបាតដែលមានរសដល់ព្រះខីណាស្រពដូច្នេះឯង ។

រឿង ព្រះឫតិគត្តិស្សត្ថេរ ចប់

រឿង ឆន្នគោចាលកៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងកោសលជនបទ ទ្រង់ប្រារព្ធនាយគោបាលកៈ ឈ្មោះនន្ទៈ ត្រាស់ព្រះធម្មទេសនានេះថា **ឯសោ ឯសំ** *ជាដើម ។*

បានឮមកថា នាយគោបាលកៈឈ្មោះនន្ទៈ ក្នុងក្រុងសាវត្ថី ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានសម្បត្តិច្រើន រក្សាហ្វូងគោរបស់គហបតីឈ្មោះ

អនាថបិណ្ឌិក ។ បានឮថា នាយនន្ទគោបាលក:នោះ លបគេចអំពីរាជភ័យ ព្រោះភាពជាអ្នកចិញ្ចឹមគោ ដូចជដិលឈ្មោះកេណិយៈ លបគេចនូវការបៀតបៀននៃព្រះរាជាដោយភេទបព្វជិត រក្សាកំណប់ទ្រព្យរបស់ខ្លួន ។ គាត់កាន់យកបញ្ចគោរស អស់កាលដ៏សមគួរដល់កាល មកកាន់សម្នាក់របស់អនាថ-បិណ្ឌកសេដ្ឋី ជួបព្រះសាស្តាស្តាប់ធម៌ហើយ ទូលអារាធនាព្រះសាស្តាដើម្បីឲ្យទ្រង់យាងមកកាន់លំនៅរបស់ខ្លួន ។

ព្រះសាស្តា ទ្រង់រង់ចាំភាពចាស់ក្លានៃញាណរបស់បុរសនោះ ទ្រង់មិនយាងទៅឡើយ កាលទ្រង់ជ្រាបភាពដែលគាត់មានបញ្ញាចាស់ក្លាហើយ ថ្ងៃមួយទ្រង់មានមហាភិក្ខុសង្ឃចោមរោមហើយ យាងចារិកទៅ ទ្រង់គេចអំពីផ្លូវប្រថាប់គង់ហើយត្រង់គល់ឈើមួយកន្លែង ដែលជិតលំនៅរបស់នន្ទគោបាលក:នោះ ។

នាយនន្ទ:ចូលទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំ ធ្វើបដិសណ្ឋារ:និមន្តព្រះសាស្តាហើយ បានថ្វាយបញ្ចគោរសទាន ដ៏ប្រណីតដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាស្រេចហើយ ត្រាស់អនុបុព្វីកថា មានទានកថាជាដើម ក្នុងកាលចប់កថា នាយគោបាលក:ឈ្មោះនន្ទ: តាំងនៅក្នុងសោតាបត្តិផល ទទួលបាត្ររបស់ព្រះសាស្តាតាមជូនដំណើរព្រះសាស្តាទៅ កាលព្រះសាស្តាទ្រាប់ឲ្យត្រឡប់ ដោយព្រះតម្រាស់ថា ឧបាសក អ្នកចូរឈប់ចុះ ថ្វាយបង្គំព្រះសាស្តាត្រឡប់ហើយ ។ លំដាប់នោះ នាយព្រានម្នាក់បានបាញ់គាត់ស្លាប់ហើយ ។

ពួកភិក្ខុមកឯក្រោយឃើញហើយ ទើបទៅក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ នាយនន្ទគោបាលក:ថ្វាយមហាទាន តាមជួនដំណើរទ្រង់ហើយត្រឡប់ទៅ ត្រូវនាយព្រានសម្លាប់បង់ហើយ ក៏ព្រោះភាពដែលព្រះអង្គយាងមកក្នុងទីនេះ បើព្រះអង្គមិនយាងមកហើយសោត ការស្លាប់នឹងមិនមានដល់គាត់ឡើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលតថាគតមកក្តី មិនបានមកក្តី ឈ្មោះថា ឧបាយជាគ្រឿងផុតចាកការស្លាប់របស់នាយនន្ទ:នោះ សូម្បីទៅកាន់ទិសធំ ៤ ទិសតូច ៤ មិនមាន ដ្បិតថា ចិត្តប៉ុណ្ណោះដែលតម្កល់ខុសហើយ ដែលប្រព្រឹត្តទៅខាងក្នុងសត្វទាំងនេះ រមែងធ្វើសេចក្តីវិនាសដែលពួកចោរ ឬពួកមនុស្សដែលចងពៀរធ្វើមិនបានដូច្នេះ ត្រាស់ព្រះគាថានេះថា

ឯសោ ឯសំ យន្តំ កយិរា វេរី វា បន វេរិនំ
មិច្ឆាបណិហិតំ ចិត្តំ បាបិយោ នំ តតោ ករេ ។

ចោរក្រឡេកឃើញចោរផងគ្នា ឬក៏បុគ្គលមានពៀរ ក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តីវិនាសណាមួយដល់គ្នា ចិត្តដែលបុគ្គលតាំងទុកខុសហើយ រមែងធ្វើបុគ្គលនោះឲ្យអាក្រក់ក្រៃលែង ជាងសេចក្តីវិនាសនោះទៅទៀត ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ឯសោ ឯសំ** *ប្រែថា ចោរឃើញចោរ ។ សព្ទថា* **ឯស្សា** *ជាព្រះបាលីដ៏សេស គឺបណ្ឌិតគប្បីបន្ថែមចូល ។ ពីរបទថា* **យន្តំ កយិរា** *សេចក្តីថា គប្បីធ្វើនូវសេចក្តីវិនាសនោះដល់ចោរ ឬបុគ្គលចង*

ពៀរនោះ ។ សូម្បីក្នុងបទទី ២ ក៏មានន័យដូចគ្នា ។

ព្រះដ៏មានព្រះភាគ បានត្រាស់ជាពាក្យអធិប្បាយដូច្នេះថា ចោរ ជា អ្នកប្រទូស្តចំពោះមិត្តណាម្នាក់ កាលខុសក្នុងបុត្រ ភរិយា ស្រែ ចម្ការ គោ និងក្របីជាដើមរបស់ចោរណាម្នាក់ ចោរខុសចំពោះចោរណា ឃើញចោរនោះ ដែលខុសក្នុងខ្លួនយ៉ាងនោះឯង ឬថាបុគ្គលចងពៀរ ឃើញបុគ្គលដែលចងពៀរ ទុកដោយហេតុណាមួយយ៉ាងនោះឯង ដែលឈ្មោះថាអ្នកចងពៀរ ។ ដែល ឈ្មោះថាគប្បីធ្វើសេចក្តីវិនាសឯណាដល់ចោរ ឬបុគ្គលចងពៀរនោះ គឺគប្បី បៀតបៀនបុត្រ និងភរិយារបស់ចោរ ឬអ្នកចងពៀរនោះ គប្បីធ្វើវត្ថុផ្សេងៗ មានស្រែជាដើមរបស់ចោរ ឬរបស់បុគ្គលចងពៀរនោះឲ្យវិនាស ឬគប្បីផ្តាច់ ជីវិតចោរ ឬបុគ្គលចងពៀរនោះ ព្រោះភាពដែលខ្លួនជាអ្នកកាចសាហាវ ឬ ព្រោះភាពដែលខ្លួនជាបុគ្គលយោរយៅ ចិត្ត ឈ្មោះថា តម្កល់ខុស ព្រោះភាព ជាចិត្តតម្កល់ខុសក្នុងអកុសលកម្មបថ ១០ គប្បីធ្វើឲ្យបុគ្គលនោះអាក្រក់ ថោកទាបក្រៃលែងជាងការវិនាសនោះ គឺធ្វើបុរសនោះឲ្យជាអ្នកលាមកជាង ហេតុនោះទៅទៀត ។ ពិតហើយ ចោរក្តី បុគ្គលចងពៀរក្តី មានប្រការដូច ពោលហើយ គប្បីញុំាងទុក្ខឲ្យកើត ឬគប្បីធ្វើនូវការអស់ទៅនៃជីវិតដល់ចោរ ឬដល់បុគ្គលចងពៀរបានក្នុងអត្តភាពនេះប៉ុណ្ណោះ ។ ចំណែកចិត្តនេះ ដែល បានតម្កល់ក្នុងអកុសលកម្មបថទាំងឡាយ រមែងញុំាងបុគ្គលឲ្យដល់នូវសេចក្តី វិនាសក្នុងទិដ្ឋធម្មខ្លះ បន្ទាត់ទៅក្នុងអបាយ ៤ រមែងមិនឲ្យងើបកញ្ជាលឡើង បានក្នុងពាន់អត្តភាពខ្លះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ទេសនាមានប្រយោជន៍ដល់មហាជនហើយ ។

កម្មដែលឧបាសកបានធ្វើក្នុងវារាងកព ពួកភិក្ខុមិនបានទូលសួរ ព្រោះហេតុដូច្នោះ ទើបកម្មនោះ ព្រះសាស្តាមិនបានត្រាស់ប្រាប់ ដូច្នេះឯង

រឿង ឧទ្ធគោចាលកៈ ចប់

រឿង សោរេយ្យត្ថេរ

លំនាំដើម

ព្រះសាស្តាញុំាងព្រះធម្មទេសនានេះថា **ឯតំ មាតា បិតា កយិរា** *ជាដើម ដែលតាំងឡើងក្នុងសោរេយ្យនគរ ឲ្យចប់ក្នុងនគរសាវត្ថី ។*

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី កូនប្រុសរបស់សោរេយ្យសេដ្ឋីក្នុងសោរេយ្យនគរ អង្គុយលើយានតូច ដែលមានសេចក្តីសុខជាមួយសម្ភាញ់ម្នាក់ ចេញទៅអំពីនគរ ដើម្បីប្រយោជន៍នឹងងូតទឹក ដោយបរិវារដ៏ច្រើន ។ ខណៈនោះ ព្រះមហាកច្ចាយនត្ថេរ មានបំណងនឹងចូលទៅកាន់សោរេយ្យ-នគរដើម្បីបិណ្ឌបាត ដណ្តប់សំពត់សង្ឃាដីខាងក្រៅព្រះនគរ ។ សរីរៈរបស់ព្រះថេរៈមានពណ៌ដូចមាស កូនប្រុសរបស់សោរេយ្យសេដ្ឋីឃើញលោកហើយ ទើបគិតថា ស្អាតពិតហ្ន៎ ព្រះថេរៈរូបនេះ គួរជាភរិយារបស់អញ ឬពណ៌នៃសរីរៈរបស់ភរិយាអញ គប្បីដូចជាពណ៌នៃសរីរៈរបស់ព្រះថេរៈនោះ ។ ក្នុង

ខណៈគ្រាន់តែចិត្តគិតហើយប៉ុណ្ណោះ ភេទប្រុសរបស់សេដ្ឋីបុត្រនោះក៏វិនាសទៅ ភេទស្រីបានប្រាកដហើយ ។ គាត់មានការខ្មាសអៀន ទើបចុះអំពីរទេះគេចទៅ បុគ្គលអ្នកជិតស្និទ្ធ ចំណាំនូវកូនប្រុសរបស់សេដ្ឋីនោះមិនបាន ទើបពោលថា អ្ញុំ៎ះ អ្ញុំ៎ះ សូម្បីនាងក៏ដើរទៅកាន់ផ្លូវ ដែលទៅកាន់ក្រុងតក្កសិលា ។

ចំណែកសម្លាញ់របស់នាង សូម្បីដើរកខាងនោះ និងខាងនេះក៏មិនជួបជនទាំងពួងងូតស្រេចហើយ បានត្រឡប់ទៅកាន់ផ្ទះ ។ កាលជនទាំងឡាយពោលថា សេដ្ឋីបុត្រទៅណា ជនដែលទៅជាមួយឆ្លើយថា ពួកខ្ញុំស្មានថាគាត់ងូតទឹកត្រឡប់មកហើយ ។ ខណៈនោះ មាតា និងបិតារបស់សេដ្ឋីបុត្រ គយគន់មើលក្នុងទីនោះៗ កាលមិនឃើញ ទើបទ្រហោយំរៀបរាប់ បានថ្វាយកត្តដើម្បីអ្នកស្លាប់ ដោយសម្គាល់ថា កូនប្រុសរបស់ខ្លួនស្លាប់ហើយ ។

នាងឃើញពួករទេះទៅកាន់ក្រុងតក្កសិលា ទើបដើរតាមក្រោយយានតូចទៅ ។ ខណៈនោះ ពួកមនុស្សឃើញនាងហើយពោលថា នាងដើរតាមក្រោយយានតូចរបស់ពួកយើងធ្វើអ្វី ពួកយើងមិនស្គាល់នាងថា នាងជាកូនស្រីរបស់អ្នកណា នាងពោលថា នែអ្នក ពួកអ្នកចូរបររទេះតូចពួកអ្នកទៅចុះ ខ្ញុំនឹងដើរទៅ កាលដើរទៅហត់នឿយខ្លាំង បានដោះចិញ្ចៀនសម្រាប់ពាក់ត្រង់ម្រាមដៃឲ្យហើយ ធ្វើឱកាសក្នុងយានតូចមួយកន្លែងដើម្បីខ្លួន ។

ពួកមនុស្សគិតថា ភរិយារបស់សេដ្ឋីបុត្រនៃពួកយើង ក្នុងក្រុងតក្កសិលាមិនទាន់មាន យើងទាំងឡាយនឹងប្រាប់ដល់លោក បណ្តាការធំនឹងមានដល់ពួក

យើង ។ ពួកជនទាំងនោះទៅហើយ សួរថា បពិត្រលោកម្ចាស់ ឥត្ថីកែវខ្ញុំបាន នាំមកហើយដើម្បីលោកម្ចាស់ កូនប្រុសរបស់សេដ្ឋីនោះបានស្តាប់ហើយ ឲ្យ ហៅនាងមក ឃើញនាងសមនឹងវ័យរបស់ខ្លួន មានរូបស្អាតគួរពេញចិត្ត មាន សេចក្តីស្រឡាញ់កើតឡើង ទើបបានឲ្យធ្វើជាភរិយាក្នុងផ្ទះរបស់ខ្លួន ។

មែនពិត ពួកបុរស ឈ្មោះថា មិនធ្លាប់ក្លាយកេទជាស្រី ឬពួកស្រីមិន ធ្លាប់ក្លាយកេទជាប្រុស មិនមាន ។ ព្រោះថា ពួកបុរសប្រព្រឹត្តកន្ទងក្នុងភរិយា ទាំងឡាយរបស់ជនដទៃ ធ្វើកាលកិរិយាហើយ ឆេះក្នុងនរកអស់សែននៃឆ្នាំជា ច្រើន កាលត្រឡប់មកកាន់ជាតិជាមនុស្ស រមែងដល់នូវភាវៈជាស្រីអស់រយ អត្តភាព សូម្បីព្រះអានន្ទត្ថេរ ដែលជាអរិយសាវក មានបារមីបំពេញមកហើយ រាប់សែនកប្ប អន្ទោលទៅក្នុងសង្សារ ក្នុងអត្តភាពមួយ បានកើតក្នុងត្រកូល ជាងមាសធ្វើបរទារកម្ម ឆេះក្នុងនរកហើយ ដោយផលកម្មដ៏សេសបានត្រឡប់ មកជាស្រីបាទបរិចារិកានៃបុរសអស់ ១៤ អត្តភាព ដល់នូវភាវជកពូជ គឺ ត្រូវគេក្រៀវអស់ ៧ អត្តភាព ។ ចំណែកស្រីទាំងឡាយ ធ្វើបុណ្យទាំងឡាយ មានទានជាដើម នឿយណាយក្នុងភាពជាស្ត្រី ក៏តាំងចិត្តថា បុណ្យរបស់ខ្ញុំនេះ ចូរប្រព្រឹត្តទៅ ដើម្បីត្រឡប់បានជាអត្តភាពជាបុរស ធ្វើកាលកិរិយាហើយ រមែងត្រឡប់បានអត្តភាពជាបុរស ។ ពួកស្រីដែលមានប្តីដូចទេវតា ត្រឡប់ បានអត្តភាពជាបុរស ដោយអំណាចនៃការប្រតិបត្តិក្នុងស្វាមីដូចគ្នា ។ ចំណែក កូនសេដ្ឋីនេះ ញ៉ាំងចិត្តឲ្យកើតឡើងក្នុងព្រះថេរៈដោយមិនមែនឧបាយ ក៏ ត្រឡប់ បានភាវៈជាស្រី ក្នុងអត្តភាពនេះ មួយរំពេច ។

គកិបានតាំងក្នុងផ្ទៃរបស់នាង ព្រោះអាស្រ័យការនៅរួមជាមួយបុរសកូនសេដ្ឋីក្នុងនគរតក្កសិលា ។ ដោយកាលកន្លងទៅ ១០ ខែ នាងបានបុត្រក្នុងកាលដែលបុត្ររបស់នាងដើរបាន ក៏បានបុត្រមួយទៀត ដោយអាការយ៉ាងនេះ ទើបបុត្ររបស់នាងមាន ៤ នាក់ គឺបុត្រដែលនៅក្នុងផ្ទៃ ២ នាក់ បុត្រដែលកើតព្រោះអាស្រ័យខ្លួនកាលនៅជាបុរស ក្នុងសោរយ្យនគរ ២ នាក់ ។

ក្នុងកាលនោះ កូនប្រុសសេដ្ឋីដែលជាសម្លាញ់របស់នាង ចេញអំពីសោរយ្យនគរ ទៅកាន់ក្រុងតក្កសិលាដោយរទេះ ៥០០ អង្គុយលើយានតូចដែលមានសេចក្តីសុខ ចូលទៅកាន់ព្រះនគរ ។ ខណៈនោះ នាងបើកបង្អួចលើប្រាសាទជាន់លើ ឈរមើលរវាងផ្លូវ ឃើញសម្លាញ់នោះ ចាំបានយ៉ាងច្បាស់ ទើបបញ្ជូនស្រីបម្រើ ឲ្យទៅអញ្ជើញសេដ្ឋីបុត្រនោះមកហើយ ឲ្យអង្គុយលើទីដែលមានតម្លៃច្រើន បានធ្វើសក្ការៈ និងសេចក្តីរាប់អានយ៉ាងធំ ។ គ្រានោះ សម្លាញ់នោះពោលនឹងនាងថា នែនាង ក្នុងកាលមុនអំពីនេះ ខ្ញុំមិនធ្លាប់ឃើញនាង ។ កាលបើដូច្នេះ ហេតុអ្វី ទើបបានជានាងធ្វើសក្ការៈដ៏ធំដល់ខ្ញុំ នាងស្គាល់ខ្ញុំឬ នាងពោលថា ខ្ញុំស្គាល់ អ្នកជាអ្នកស្រុកសោរយ្យនគរ មិនមែនឬ សេដ្ឋីបុត្រពោលថា នែនាង ពិតមែនហើយ ។

នាងបានសួរដល់សេចក្តីសុខសប្បាយ របស់មាតាបិតា របស់ភរិយា មួយអន្ទើដោយកូនប្រុសទាំង ២ សម្លាញ់ក្រៅអំពីនេះឆ្លើយថា អើនាង ជនទាំងនោះសុខសប្បាយ ហើយសួរថា នែនាង នាងស្គាល់ជនទាំងនោះឬ នាងពោលថា អើអ្នក ខ្ញុំស្គាល់ កូនប្រុសរបស់លោកទាំងនោះមានម្នាក់ តើគាត់

ទៅណា សេដ្ឋីបុត្រពោលថា នែនាង នាងកុំសួរដល់គេឡើយ ខ្ញុំនិងគេ ថ្ងៃមួយ បានអង្គុយក្នុងយានតូចយ៉ាងមានសេចក្តីសុខ ចេញទៅដើម្បីងូតទឹក មិនជ្រាបទីទៅរបស់គេឡើយ កាលក្រឡេកមើលខាងនោះ ខាងនេះក៏មិនឃើញ ទើបប្រាប់ដល់ឪពុកម្តាយរបស់គេ ឪពុកម្តាយទាំងពីររបស់គេ បានទ្រហោយំរៀបរាប់ ធ្វើកិច្ចដែលគួរធ្វើដល់បុគ្គលដែលស្លាប់ទៅហើយ ។ នាងពោលថា នែអ្នក ខ្ញុំ គឺសេដ្ឋីបុត្រនោះឯង សម្លាញ់នោះពោលថា នែនាង ចូរចៀសចេញទៅ នាងពោលអ្វី សម្លាញ់របស់ខ្ញុំស្អាតដូចជាកូនទេវតា គេជាប្រុសនាងពោលថា ណ្ហើយចុះអ្នក ខ្ញុំ គឺសេដ្ឋីបុត្រនោះ ។

ខណៈនោះ ទើបសម្លាញ់នោះសួរនាងថា រឿងនេះដូចម្តេច នាងពោលថា ថ្ងៃនោះ អ្នកឃើញព្រះមហាកច្ចាយនត្ថេរដែរឬទេ សម្លាញ់នោះពោលថា ខ្ញុំឃើញ នាងពោលថា ខ្ញុំឃើញព្រះមហាកច្ចាយនៈហើយ បានគិតថា ស្អាតពិតហ្ន៎ ព្រះថេរៈរូបនេះ គួរជាភរិយារបស់អញ ឬថា ពណ៌នៃសរីរៈរបស់ភរិយាអញ គប្បីដូចពណ៌នៃសរីរៈរបស់ព្រះថេរៈនោះ ក្នុងខណៈខ្ញុំគិតហើយនោះឯង កេទប្រុសបានអន្តរធានទៅ កេទស្រីបានប្រាកដឡើង កាលបើដូច្នេះ ខ្ញុំមិនអាចប្រាប់ដល់អ្នកណាបាន ដោយការខ្មាស ទើបគេចទៅអំពីទីនោះ មកក្នុងទីនេះ សម្លាញ់នោះពោលថា ឱហ្ន៎ អ្នកធ្វើកម្មធ្ងន់ហើយ ហេតុអ្វីទើបអ្នកមិនដល់ខ្ញុំ អើ អ្នកបានឲ្យព្រះថេរៈអត់ទោសហើយឬ នាងពោលថា មិនទាន់ឲ្យលោកអត់ទោសឡើយ អ្នកដឹងឬ ព្រះថេរៈនៅក្នុងទីណា សម្លាញ់នោះពោលថា អាស្រ័យនគរនេះឯង នាងពោលថា បើលោកគ្រាប់បិណ្ឌបាត

គប្បីមកក្នុងទីនេះសោត ខ្ញុំគប្បីប្រគេនភិក្ខាហារដល់ព្រះថេរៈរបស់ខ្ញុំ សម្លាញ់នោះពោលថា បើដូច្នោះ សូមនាងប្រញាប់ធ្វើសក្ការៈ ខ្ញុំនឹងញ៉ាំងលោកម្ចាស់ឲ្យអត់ទោសឲ្យ ។

សេដ្ឋីបុត្រទៅកាន់លំនៅព្រះថេរៈ ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង និមន្តថា បពិត្រលោកម្ចាស់ សូមលោកនេះសូមនិមន្តលោកម្ចាស់ទទួលភិក្ខារបស់ខ្ញុំ ព្រះថេរៈពោលថា នែសេដ្ឋីបុត្រ ក្រែងអ្នកជាក្បៀវមិនមែនឬ សេដ្ឋីបុត្រពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំសួរភាពដែលខ្ញុំជាក្បៀវឡើយ សូមនេះ សូមនិមន្តលោកម្ចាស់ទទួលភិក្ខារបស់ខ្ញុំចុះ ។

ព្រះថេរៈទទួលនិមន្តហើយ ។ សក្ការៈជាច្រើន គេបានត្រៀមរៀបចំក្នុងផ្ទះដើម្បីព្រះថេរៈ ។ ស្អែកឡើង ព្រះថេរៈបានទៅកាន់ទ្វារផ្ទះ ។ ខណៈនោះ សេដ្ឋីបុត្រនិមន្តលោកឲ្យគង់ហើយ អង្គាសដោយអាហារដ៏ប្រណីត នាំស្រីនោះមកហើយ ឲ្យក្រាបចុះទៀបបាទារបស់ព្រះថេរៈ ពិតថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់អត់ទោសដល់ស្រី ជាសម្លាញ់របស់ខ្ញុំផង ព្រះថេរៈពោលថា តើមានរឿងអ្វី សេដ្ឋីបុត្រពោលថា បពិត្រលោកម្ចាស់ ក្នុងកាលមុន បុគ្គលនេះជាសម្លាញ់ ជាទីស្រឡាញ់របស់ខ្ញុំ ជួបលោកម្ចាស់ហើយ បានគិតយ៉ាងនេះ យ៉ាងនេះ កាលបើដូច្នោះ កេទប្រុសរបស់គេក៏អន្តរធានទៅ កេទស្រីបានច្រោកដហើយ សូមលោកម្ចាស់អត់ទោសចុះ ។

ព្រះថេរៈពោលថា បើយ៉ាងនោះ ចូរអ្នកក្រោកឡើង អាត្មាអត់ទោសឲ្យដល់អ្នក ។ គ្រាន់តែព្រះថេរៈហាមាត់ថា អាត្មាអត់ទោសប៉ុណ្ណោះ កេទ

ស្រីបានវិនាសទៅ កេទប្រុសបានប្រាកដហើយ កាលកេទប្រុសបានត្រឡប់ប្រាកដឡើងប៉ុណ្ណោះ សេដ្ឋីបុត្រក្នុងក្រុងតក្កសិលាបានពោលនឹងសេដ្ឋីបុត្រនោះថា សម្លាញ់អ្នកកួរមទុក្ខ កូនពីរនាក់នេះ ជាកូនរបស់យើងទាំងពីរពិត ព្រោះជាអ្នកនៅក្នុងផ្ទៃរបស់អ្នក និងព្រោះជាអ្នកអាស្រ័យខ្ញុំកើត យើងទាំងពីរនឹងនៅក្នុងនគរនេះឯង អ្នកកុំក្រវល់ក្រវាយឡើយ ។

សោរេយ្យសេដ្ឋីបុត្រពោលថា អ្នកកួរមទុក្ខ ខ្ញុំដល់នូវអាការចម្លែក គឺកាលពីដើម ខ្ញុំជាបុរស ហើយដល់នូវភាពជាស្រី ហើយត្រឡប់ជាប្រុសបានទៀត ដោយអត្តភាពមួយប៉ុណ្ណោះ កាលមុនបុត្រពីរនាក់អាស្រ័យខ្ញុំកើតឡើងឥឡូវនេះ បុត្រពីរនាក់ ប្រសូតចេញអំពីផ្ទៃខ្ញុំ អ្នកកុំសម្គាល់ថា ខ្ញុំនោះដល់នូវអាការចម្លែកដោយអត្តភាពមួយ នឹងមិននៅក្នុងផ្ទះតទៅទៀត ខ្ញុំនឹងបួសក្នុងសម្នាក់នៃលោកម្ចាស់របស់យើង កុមារពីរនាក់នេះ ចូរជាការៈរបស់អ្នក អ្នកកុំបោះបង់ក្មេងទាំងពីរនេះ ដូច្នេះហើយ ថើបកូនទាំងពីរ អង្អែលខ្នងហើយប្រគល់ដល់ឪពុក ចេញទៅបួសក្នុងសម្នាក់ព្រះថេរៈ ចំណែកព្រះថេរៈឲ្យលោកបព្វជ្ជាឧបសម្បទាស្រេចហើយ នាំត្រាច់ចារិកទៅ បានដល់ក្រុងសាវត្ថីដោយលំដាប់ ។ ឈ្មោះរបស់លោកបានប្រាកដថា សោរេយ្យត្ថេរ ។

អ្នកជនបទដឹងរឿងនោះហើយ នាំគ្នាក្រាក់ផ្អើល ចូលទៅសួរថា បានឮថា រឿងនេះពិតយ៉ាងនោះឬ សោរេយ្យត្ថេរពោលថា អាវុសោ រឿងនេះពិតហើយ ។ អ្នកជនបទពោលថា បពិត្រលោកម្ចាស់ ហេតុនេះមានពិតឬ បានឮថា កូនពីរនាក់កើតក្នុងផ្ទៃរបស់លោកម្ចាស់ កូនពីរនាក់អាស្រ័យលោកម្ចាស់

កើត បណ្តាកូនពីរពួកនោះ លោកម្ចាស់មានសេចក្តីស្រឡាញ់ច្រើនក្នុងកូនពួកណា សោរេយ្យត្ថេរពោលថា អាវុសោ អាត្មាស្រឡាញ់កូនដែលនៅក្នុងផ្ទៃ ។

ជនដែលមកហើយ ក៏សួរយ៉ាងនោះឯងរឿយៗ ទៅ ។ ព្រះថេរៈច្រាប់ហើយដូចមុនថា មានសេចក្តីស្រឡាញ់ក្នុងកូនដែលនៅក្នុងផ្ទៃនោះឯងច្រើន ។ កាលលោកមានសេចក្តីរំខាន ទើបអង្គុយមួយអង្គឯង ។ លោកចូលដល់ភាពជាបុគ្គលម្នាក់ឯងប៉ុណ្ណោះ ផ្តើមចម្រើនឧបការអស់ទៅ និងសូន្យទៅ ក្នុងអត្តភាព សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយហើយ ។

បន្ទាប់មក ពួកជនដែលមកហើយសួរលោកថា បពិត្រលោកម្ចាស់ បានឮថា ហេតុឈ្មោះនេះមានហើយពិតឬ ព្រះសោរេយ្យៈពោលថា អើអាវុសោ ពិតហើយ ពួកជនពោលថា លោកម្ចាស់មានសេចក្តីស្នេហាច្រើនក្នុងកូនពួកណា ព្រះសោរេយ្យៈពោលថា ឈ្មោះថា ការស្រឡាញ់ក្នុងកូនណាម្នាក់របស់អាត្មា មិនមាន ។

ភិក្ខុទាំងឡាយក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុរូបនេះពោលអ្វីមិនពិត ក្នុងថ្ងៃមុនៗ ពោលថា មានសេចក្តីស្នេហាក្នុងកូនដែលនៅក្នុងផ្ទៃច្រើនជាង ឥឡូវនេះ ពោលថា ការស្រឡាញ់ក្នុងកូនណាម្នាក់របស់អាត្មាមិនមាន រមែងព្យាករអរហត្តផល ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតមិនមែនព្យាករអរហត្តផលទេ ព្រោះថា តាំងអំពីកាលដែលបុត្ររបស់តថាគតឃើញមគ្គទស្សនៈដោយចិត្តដែលតាំងទុកដោយប្រពៃហើយ សេចក្តីស្នេហាក្នុងបុត្រ

ណាម្នាក់ មិនកើតឡើយ ចិត្តប៉ុណ្ណោះដែលប្រព្រឹត្តទៅខាងក្នុងរបស់សត្វទាំងនេះ រមែងឲ្យសម្បត្តិដែលមាតាបិតាមិនអាចធ្វើឲ្យបាន ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

ន តំ មាតា បិតា កយិរា អញ្ញេ ញាតិ ច ញាតកា
សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ ។

មាតាបិតា មិនគប្បីធ្វើហេតុនោះបាន ឬជនទាំងឡាយដទៃជាញាតិ មិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្តដែលបុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាងហេតុនោះបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ន តំ** *សេចក្តីថា មាតាបិតា និងញាតិដទៃមិនធ្វើហេតុនោះបានឡើយ ។*

បទថា **សម្មាបណិហិតំ** *គឺឈ្មោះថាតាំងទុកប្រពៃហើយ ព្រោះភាពជាធម្មជាតតាំងទុកប្រពៃក្នុងកុសលកម្មបថ ១០ ។*

បទព្រះគាថាថា **សេយ្យសោ នំ តតោ ករេ** *សេចក្តីថា គប្បីធ្វើ គឺរមែងធ្វើបុគ្គលឲ្យប្រសើរជាង គឺក្រៃលែងជាង បានដល់ ឲ្យឧត្តមជាងហេតុនោះ ។*

ពិតណាស់ មាតាបិតាកាលនឹងឲ្យទ្រព្យដល់បុត្រទាំងឡាយ រមែងអាចឲ្យទ្រព្យសម្រាប់មិនចាំបាច់ធ្វើការងារ ហើយចិញ្ចឹមជីវិតដោយសប្បាយ ក្នុង

អត្តភាពមួយប៉ុណ្ណោះ សូម្បីមាតាបិតារបស់នាងវិសាខា មានទ្រព្យច្រើន មានកោគៈច្រើន បានឲ្យទ្រព្យសម្រាប់ចិញ្ចឹមជីវិតដោយសប្បាយដល់នាង ក្នុងអត្តភាពមួយប៉ុណ្ណោះ ធម្មតាមាតាបិតាដែលអាចឲ្យសិរី គឺភាពជាស្តេចចក្រពត្តិក្នុងទ្វីបទាំង ៤ រមែងមិនមានដល់កូនទាំងឡាយ នឹងពោលទៅថ្វីដល់ទិព្វសម្បត្តិ ឬបឋមជ្ឈានសម្បត្តិជាដើមនោះ ក្នុងការឲ្យលោកុត្តរសម្បត្តិ មិនចាំបាច់ពោលដល់ឡើយ ។ តែចិត្តតម្កល់ដោយប្រពៃហើយ អាចឲ្យសម្បត្តិទាំងអស់បាន ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **សេយ្យសោ នំ តតោ ករេ ។**

ក្នុងកាលចប់ទេសនា មហាជនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាបានជាប្រយោជន៍ដល់មហាជនដូច្នេះឯង ។

រឿងព្រះសោរេយ្យត្ថេរ ចប់

ចិត្តវគ្គទី ៣ ចប់

សុត្តន្តបិដក

ធម្មបទគាថា បុប្ផវគ្គទី ៤

[១៤] *អ្នកណានឹងជីងច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន អ្នកណានឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្តែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កា ដូច្នោះឯង ។*

ព្រះសេក្ខបុគ្គលនឹងជីងច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន ព្រះសេក្ខ-បុគ្គល នឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្តែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កា ដូច្នោះ ។

ភិក្ខុ កាលជីងច្បាស់នូវកាយនេះថា ដូចជាជុំពពុះទឹក ជីងច្បាស់នូវកាយនេះថា មានសភាពដូចព្រេញថ្លៃ គប្បីកាត់នូវផ្កាជាប្រធាននៃមារ គឺវដ្ដៈ ៣ ទៅកាន់ស្ថានជាទីមិនឃើញនៃមច្ចុរាជ ។

មច្ចុ គឺសេចក្តីស្លាប់ តែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ នោះឯង ដូចទឹកជំនន់ធំ ដែលកួចយកអ្នកស្រុកកំពុងដេកលក់ទៅ ដូច្នោះឯង ។

អ្នកធ្វើទីបំផុត គឺមរណៈ តែងក្រុងសត្វ ដែលមានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ មិនឆ្អែតឆ្អន់ក្នុងកាមទាំងឡាយនោះឯង ឲ្យនៅក្នុងអំណាចរបស់ខ្លួន ។

ភមរជាតិ មិនធ្វើផ្ការឈើ ដែលមានពណ៌ និងក្លិនឲ្យវិនាសទេ ក្រែបយកតែរសហើរទៅ យ៉ាងណាមិញ អ្នកប្រាជ្ញ គប្បីត្រាច់ទៅក្នុងស្រុក ក៏យ៉ាងនោះឯង ។

ពាក្យចាក់ជោតទាំងឡាយរបស់ជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេ កិច្ចដែលធ្វើហើយ និងមិនទាន់ធ្វើហើយរបស់ជនដទៃ (ដែលមិនមែនជាមុខការរបស់ខ្លួន) បុគ្គលមិនគួរពិនិត្យមើលទេ បុគ្គលគួរពិនិត្យពិចារណា តែកិច្ចការទាំងឡាយដែលធ្វើហើយ និងមិនទាន់ធ្វើហើយ របស់ខ្លួនតែម្យ៉ាង ។

ផ្ការឈើមានទ្រង់ទ្រាយល្អ មានពណ៌ (ល្អ) តែគ្មានក្លិន (ប្រអូប) (រមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្តេចមិញ វាចាជាសុភាសិត រមែងគ្មានផលដល់អ្នកដែលមិនធ្វើតាមដូច្នោះ ផ្ការឈើដែលមានទ្រង់ទ្រាយល្អ មានពណ៌ មានក្លិន (រមែងក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្តេចមិញ វាចាជាសុភាសិត រមែងមានផលដល់អ្នកដែលធ្វើតាមដោយគោរព ដូច្នោះឯង ។

មាលាការ ចេះធ្វើសំណុំនៃកម្រងផ្កាអំពីគំនរនៃផ្កា (ផ្សេងៗ គ្នា) ឲ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើនយ៉ាងនោះ ។

ក្លិនផ្ការឈើ ផ្សាយទៅច្រាសខ្យល់មិនបាន ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាក្តី ក្លិនផ្កាម្លិះរតក្តី ក៏ផ្សាយទៅច្រាសខ្យល់មិនបាន ចំណែកក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរស រមែងផ្សាយទៅបានគ្រប់ទិស ។ ក្លិននៃសីល ជាគុណជាតិប្រសើរបំផុតជាងគន្ធជាតិ

ទាំងនេះ គឺខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្ទិះលា ។

កិនក្រស្នា និងកិនចន្ទន៍ណា កិននេះ ក្រអូបមានប្រមាណតិចទេ ចំណែកកិននៃបុគ្គលមានសីលទាំងឡាយណា កិននោះ ទើបក្រអូបលើសលុបផ្សាយទៅក្នុងទេវលោក និងមនុស្សលោកបាន ។

មារាធិរាជ (ទុកជាខំស្វែងរក) ក៏មិនជួបនូវផ្លូវ របស់លោកអ្នកមានសីលបរិបូណ៌ អ្នកនៅដោយសេចក្តីមិនប្រមាទ អ្នករួចស្រឡះ (ចាកធម៌ជាគ្រឿងសៅហ្មង) ព្រោះដឹងច្បាស់តាមហេតុ ។

ផ្កាឈូក ទុកជាកើតក្នុងគំនរសំរាម ដែលគេចាក់ចោលក្បែរផ្លូវធំនោះ ក៏គង់មានកិនក្រអូប ជាទីរីករាយនៃចិត្តបាន ដូចម្តេចមិញ បណ្តាជន ដែលដូចជាគំនរសំរាម សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងរុងរឿងកន្ទុងផុតបុថុជ្ជនទាំងឡាយ ដែលល្ងិតល្ងង់ ដោយប្រាជ្ញា (របស់ខ្លួន) ដូច្នោះឯង ។

បុប្ផវគ្គទី ៤ ចប់

អដ្ឋកថា

ធម្មបទដ្ឋកថា ខុទ្ទកនិកាយ គាថាធម្មបទ

បុប្ផវគ្គ

រឿង ភិក្ខុ ៥០០ ដែលខ្វល់ខ្វាយក្នុងបឋវីកថា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុ ៥០០ រូប ដែលខ្វល់ខ្វាយក្នុងបឋវីកថា ត្រាស់ធម្មទេសនានេះថា **កោ ឥមំ បឋវឹ វិជេស្សតិ** *ជាដើម ។*

បានឮមកថា ភិក្ខុទាំងនោះត្រាច់ចារិកទៅក្នុងជនបទ ជាមួយព្រះសាស្តា មកដល់វត្តជេតពនហើយ អង្គុយនៅក្នុងរោងឆាន់ក្នុងពេលល្ងាច និយាយដល់រឿងផែនដី ក្នុងទីដែលខ្លួនទៅហើយថា ក្នុងទីដែលទៅក្នុងស្រុកឈ្មោះនោះ អំពីស្រុកនោះ ដីរាបស្មើ មិនរាបស្មើ មានភក់ច្រើន មានគ្រោះច្រើន មានដីខ្មៅ មានដីក្រហម ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងផែនដីក្នុងទីដែលខ្ញុំព្រះអង្គទៅហើយ ដូច្នេះហើយ

ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នុ៎ះ ឈ្មោះថា ផែនដីខាងក្រៅ ការដែលពួកអ្នកធ្វើបរិកម្មក្នុងផែនដីខាងក្នុង ទើបគួរ ដូច្នេះហើយ ទ្រង់បានភាសិត ២ គាថានេះថា

កោ ឥមំ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ
កោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ ។
សេក្ខោ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ
សេក្ខោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ ។

អ្នកណា នឹងជំនះច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន អ្នកណានឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្តែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កា ដូច្នោះឯង ។ ព្រះសេក្ខបុគ្គលនឹងជំនះច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន ព្រះសេក្ខបុគ្គលនឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្តែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កា ដូច្នោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **កោ ឥមំ** *សេចក្តីថា បុគ្គលណានឹងជំនះច្បាស់នូវផែនដីនេះ ពោល គឺអត្តភាព ។*

បទថា **វិជេស្សតិ** *សេចក្តីថា នឹងជឿនច្បាស់ គឺចាក់ធ្លុះ បានដល់ ធ្វើឲ្យជាក់ច្បាស់ដោយញាណរបស់ខ្លួន ។*

បទថា **យមលោកញ្ច** *បានដល់ អបាយលោក ៤ យ៉ាងផង ។*

ពីរបទថា **ឥមំ សទេវកំ** *សេចក្តីថា អ្នកណានឹងជឿនច្បាស់ គឺនឹងជ្រាបច្បាស់ បានដល់ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវមនុស្សលោកនេះផង មួយអន្លើដោយទេវលោកផង ព្រះសាស្តារមែងត្រាស់សួរដូច្នេះ ។*

បាទព្រះគាថាថា **កោ ធម្មបទំ សុទេសិតំ** *សេចក្តីថា បុគ្គលណានឹងជ្រើសរើស បានដល់ពិចារណាឃើញ ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវបទធម៌ ពោល គឺពោធិបក្ខិយធម៌ ៣៧ ដែលឈ្មោះថាតថាគតសម្តែងល្អហើយ ព្រោះភាពជាធម៌ដែលតថាគតពោលហើយតាមសេចក្តីពិត ដូចនាយមាលាការអ្នកឈ្លាសជ្រើសរើសនូវផ្កា ដូច្នោះ ។*

បទថា **សេក្ខោ** *ជាដើម សេចក្តីថា ព្រះអរិយបុគ្គល ៧ ពួក តាំងអំពីលោកដែលតាំងនៅក្នុងសោតាបត្តិមគ្គ រហូតដល់លោកដែលតាំងនៅក្នុងអរហត្តមគ្គ ឈ្មោះថា ព្រះសេក្ខៈ ព្រោះនៅសិក្សាសិក្ខាទាំង ៣ នេះ គឺអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ប្រាន ចេញនូវឆន្ទរាគៈ ចាកអត្តភាពនោះដោយអរហត្តមគ្គ ឈ្មោះថា ដឹងច្បាស់ គឺនឹងជ្រាបច្បាស់ បានដល់ ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវផែនដី ពោល គឺអត្តភាពនេះ ។*

បទថា **យមលោកញ្ច** *ជាដើម សេចក្តីថា ព្រះសេក្ខៈនោះឯង នឹងដឹងច្បាស់ គឺនឹងជ្រាបច្បាស់ បានដល់ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវយមលោក មាន*

ប្រការដែលពោលហើយយ៉ាងនោះ និងមនុស្សលោកនេះ ព្រមទាំងទេវលោក ទាំងឡាយ ឈ្មោះថា ព្រមទាំងទេវលោក ។ លោកអ្នកដែលនៅសិក្សា ៧ ពួកនោះឯង ឈ្មោះថា សេក្ខៈ អធិប្បាយថា នាយមាលាការអ្នកឈ្លាស ចូលទៅកាន់សួនផ្កាហើយ រៀរផ្កាដែលខ្ចី និងក្រពុំ ផ្កាដែលត្រូវសត្វចោះ ផ្កាក្រៀម និងផ្កាដែលមិនល្អចេញហើយ ជ្រើសយកចំពោះតែផ្កាដែលល្អ ដែលកើតល្អហើយ យ៉ាងណា ព្រះសេក្ខៈនឹងជ្រើសរើស គឺចម្រាញ់ បាន ដល់ ពិចារណាឃើញ ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវបទនៃពោធិបក្ខិយធម៌នេះ ដែលតថាគតពោលល្អហើយ គឺសម្តែងល្អហើយ ដូច្នេះនោះឯង ។

ព្រះសាស្តា ទ្រង់ធ្វើយបញ្ហាឯងនោះឯង ។ ក្នុងវេលាចប់ទេសនា ភិក្ខុ ៥០០ រូប សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយហើយ ។ ទេសនាមានប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាដូច្នេះឯង ៗ

រឿង ភិក្ខុ ៥០០ ដែលឲ្យលាយក្នុងបឋមវិកថា ចប់

រឿង ព្រះថេរៈចម្រើនមរិចិកម្មដ្ឋាន

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុមួយអង្គដែល ចម្រើនមរីចិកម្មដ្ឋាន ត្រាស់ព្រះធម្មទេសនានេះថា **ផេណូបមំ** *ជាដើម ។*

បានឮមកថា ព្រះថេរៈនោះរៀនកម្មដ្ឋាន ក្នុងសម្នាក់ព្រះសាស្តាហើយ

គិតថា អញនឹងធ្វើសមណធម៌ ដូច្នេះហើយ ចូលទៅកាន់ព្រៃ ព្យាយាមហើយ ព្យាយាមទៀត ក៏មិនអាចសម្រេចអរហត្តបាន ទើបត្រឡប់មកកាន់សម្នាក់ព្រះសាស្តា ដោយតាំងចិត្តថា នឹងទូលអារាធនាឲ្យទ្រង់ត្រាស់ប្រាប់ព្រះកម្មដ្ឋានឲ្យវិសេស ។ យើញថ្ងៃបណ្តើរកូនក្នុងរវាងផ្លូវ ចម្រើនមរីចិកម្មដ្ឋានថា កម្តៅថ្ងៃនេះ តាំងឡើងហើយក្នុងរដូវក្តៅ រមែងប្រាកដដល់បុគ្គលទាំងឡាយ ដែលឈរក្នុងទីធ្លាយ ដូចមានរូបរាង តែមិនប្រាកដដល់បុគ្គលដែលមកកាន់ទីជិតយ៉ាងណា អត្តភាពនេះក៏មានការប្រៀបធៀបយ៉ាងនោះ ព្រោះអត្ថថា កើតឡើងនិងសូន្យទៅ និមន្តមកហើយ ហត់នឿយក្នុងរវាងផ្លូវ ស្រង់ទឹកក្នុងស្ទឹងអចិរវតី គង់ត្រង់ម្លប់ឈើក្បែរធ្នេរស្ទឹង ដែលមានក្រឱ្យហូរខ្ទួលខ្ទាញ់មួយកន្លែង យើញពពុះទឹកធំ តាំងឡើងដោយកម្លាំងនៃទឹកប៉ះខ្ទប់គ្នាហើយបែកទៅ បានកាន់យកជាអារម្មណ៍ថា សូម្បីអត្តភាពនេះក៏មានរូបរាងយ៉ាងនោះដូចគ្នា ព្រោះអត្ថថា កើតឡើងហើយក៏បែកទៅ ។

ព្រះសាស្តា គង់នៅត្រង់ព្រះគន្ធកុដិនោះឯង ទតយើញព្រះថេរៈនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុ យ៉ាងនោះឯង អត្តភាពនេះ មានរូបយ៉ាងនោះឯង មានការកើតឡើង និងបែកធ្លាយទៅជាសភាវៈពិត ដូចជុំពពុះទឹក និងថ្ងៃបណ្តើរកូន ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ផេណូបមំ កាយមិមំ វិទិត្វា មរីចិធម្មំ អភិសម្ពុទ្ធានោ
ធេត្វាន មារស្ស បបុប្ផកានិ អទស្សនំ មចុរាជស្ស គច្ឆេ ។

ភិក្ខុកាលដឹងច្បាស់នូវកាយនេះថា ដូចជាជុំពពុះទឹក ដឹងច្បាស់នូវ

កាយនេះថា មានសភាពដូចព្រៃញ្ជ្រៃ គប្បីកាត់នូវផ្តាជាប្រធាន នៃមារ គឺវដ្តៈ ៣ ទៅកាន់ស្ថានជាទីដែលមិនឃើញនៃមច្ចុរាជ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឥណ្ឌូបមំ** *សេចក្តីថា ជីងច្បាស់នូវកាយនេះ គឺដែលរាប់ថា ជាទីប្រជុំនៃកោដ្ឋាសផ្សេងៗ មានសក់ជាដើម ។ ប្រៀបដូចជុំពពុះទឹក ព្រោះអត្ថថា មិនមានកម្លាំង មានកម្លាំងថោកថយ មិនតាំងនៅយូរ និងជារបស់មួយរយៈខណៈ ។*

បទថា **មរីចិធម្មំ** *ជាដើម សេចក្តីថា ជីងច្បាស់ គឺជីង បានដល់ ជ្រាបថា សូម្បីកាយនេះ ឈ្មោះថា មានថ្លៃបណ្តើរកូនជាសភាវៈ ព្រោះអត្ថថា ប្រព្រឹត្តទៅមួយរយៈខណៈ និងប្រាកដតិចតួច ដូចថ្លៃបណ្តើរកូន ឃើញហាក់ដូចមានរូបរាង និងជាហេតុចូលដល់ភាពជារបស់ដែលគួរកាន់យកបាន ដល់បុគ្គលទាំងឡាយ ដែលឈរនៅក្នុងទីឆ្ងាយ តែកាលបុគ្គលចូលទៅជិត រមែងប្រាកដជារបស់ទទេ ចូលដល់នូវភាពជារបស់កាន់យកមិនបាន ដូច្នោះ ។*

ពីរបទថា **មារស្ស បទុប្ផកានិ** *ជាដើម សេចក្តីថា ភិក្ខុដែលជាព្រះខីណាស្រព កាត់នូវវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ពោល គឺកម្រងផ្ការបស់មារចេញបានដោយអរិយមគ្គហើយ គប្បីបានដល់នូវទីដែលមិនឃើញ គឺដែលមិនឃើញ គឺដែលមិនជាវិស័យនៃមច្ចុរាជ បានដល់ អមតមហានិព្វាន ។*

ក្នុងកាលចប់គាថា ព្រះថេរៈសម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយហើយ សរសើរ ថ្វាយបង្គំព្រះសរីរៈរបស់ព្រះសាស្តា ដែលមាន

ពណ៌ដូចមាស មកហើយ ដូច្នេះឯង ៣

រឿង ព្រះថេរៈចម្រើនមរីចិកម្មដ្ឋាន ចប់

រឿង ព្រះចាធវិឌូឌភៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងនគរសាវត្ថី ទ្រង់ប្រារព្ធព្រះបាទវិឌូឌភៈ មួយអន្ធើដោយបរិស័ទ ដែលត្រូវទឹកជំនន់កួចឲ្យសោយទិវង្គតហើយ ត្រាស់ព្រះធម្មទេសនានេះថា **បុច្ឆានិ ហោវ បចិនន្ត**ំ ជាដើម ។ អនុបព្វីកថាក្នុងរឿងនោះ មានដូចតទៅនេះ

កុមារ ៣ អង្គ គឺព្រះរាជឱរសរបស់ព្រះបាទមហាកោសល ក្នុងនគរសាវត្ថី ព្រះនាមបសេនទិកុមារ ១ កុមាររបស់ស្តេចលិច្ឆវី ក្នុងនគរវេសាលី ព្រះនាមមហាលិ ១ ឱរសរបស់ព្រះបាទមល្ល: ក្នុងនគរកុសិនារា ព្រះនាមពន្ធុល: ១ យាងទៅនគរតក្កសិលា ដើម្បីរៀនសិប្ប:ក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ មកជួបគ្នាត្រង់សាលាក្រៅព្រះនគរ ក៏សួរដល់ហេតុដែលមកត្រកូល និងព្រះនាមនៃគ្នានិងគ្នាហើយ ក៏ធ្វើជាសម្ចាញ់នឹងគ្នា រួមគ្នាចូលទៅរកអាចារ្យ មិនយូរប៉ុន្មានក៏រៀនសិប្ប:សម្រេច ទើបថ្វាយបង្គំលាអាចារ្យ ព្រមគ្នា យាងចេញអំពីនគរតក្កសិលា បានទៅលំនៅរៀងៗ ខ្លួន ។

បណ្តាកុមារទាំង ៣ អង្គនោះ បសេនទិកុមារ ទ្រង់សម្តែងសិប្ប:ថ្វាយ

ព្រះជនក ព្រះជនកទ្រង់ជ្រះថ្លាហើយ ទើបអភិសេកក្នុងរាជសម្បត្តិ ។

មហាលិកុមារ ដើម្បីសម្តែងសិប្ប: ដល់ស្តេចលិច្ឆវីទាំងឡាយ ទ្រង់សម្តែងដោយភាពឧស្សាហ៍ខ្លាំង ព្រះនេត្រក៏បែកទៅហើយ ។ ស្តេចលិច្ឆវីប្រឹក្សាគ្នាថា ឱហ្ន៎ អាចារ្យរបស់ពួកយើងដល់នូវការខូចភ្នែកហើយ ពួកយើងមិនបោះបង់លោក នឹងទំនុកបម្រុងលោក ដូច្នេះហើយ ទើបបានថ្វាយទ្វារមួយដែលដកសួយបានមួយថ្ងៃ ១ សែន ដល់មហាលិកុមារនោះ ។ ទ្រង់អាស្រ័យទ្វារនោះ ឲ្យឱរសរបស់ស្តេចលិច្ឆវី ៥០០ អង្គ សិក្សាសិប្ប:ហើយ ។

ចំណែកពន្ធុលកុមារ កាលពួកត្រកូលមល្លរាជពោលថា សូមពន្ធុល-កុមារ កាប់ឫស្សីទាំងនេះ ដូច្នេះហើយ បានលោតទ្បើងទៅកាន់អាកាសកម្ពស់ ៨០ ហត្ថ យកជាវកាប់ចាប់ឫស្សី ៦០ ដើម ដែលពួកស្តេចមល្ល:យកឫស្ស ៦០ ដើម ញាត់ដៃកត្រង់កណ្តាលហើយ ឲ្យលើកទ្បើងតម្កល់ជាប់ហើយ ពន្ធុលកុមារនោះ បានឮសំឡេងក្រីកខ្លាំង របស់ដៃកក្នុងចាប់ឫស្សីចុងក្រោយ ទើបសួរថា នេះអ្វី បានឮថា គេយកដៃកញាត់ក្នុងឫស្សីគ្រប់ចាប់ហើយ ទើបបោះជាវចោល ស្រែកយំពោលថា ញាតិ និងមិត្តរបស់អញ មានប្រមាណប៉ុណ្ណេះ សូម្បីតែម្នាក់ដែលជាអ្នកស្រឡាញ់ក្នុងអញ មិនបានប្រាប់ហេតុនេះដល់អញ បើអញដឹងសោត គប្បីកាប់មិនឲ្យឮសំឡេងខ្លាំងដូច្នេះឡើយ ហើយទូលដល់ព្រះជនក និងព្រះជននីថា ទូលបង្គំនឹងសម្លាប់ស្តេចមល្ល:ទាំងអស់នេះ ហើយគ្រងរាជសម្បត្តិ កាលព្រះជនក និងព្រះជននីឃាត់ហើយដោយប្រការផ្សេងៗ ជាដើមថា នែកូន នេះជារាជបវេណី កូនមិនគប្បីធ្វើ

យ៉ាងនោះ ទើបទូលថា បើដូច្នោះ ខ្ញុំនឹងទៅកាន់សម្នាក់សម្ងាញ់របស់ខ្ញុំដូច្នេះ បានទៅកាន់ក្រុងសាវត្ថីហើយ ។

ព្រះបាទបសេនទិកោសល ទ្រង់ជ្រាបការយាងមករបស់ពន្ធុលៈនោះ ទ្រង់ទទួលយាងឲ្យចូលព្រះនគរដោយសក្ការៈធំហើយ ទ្រង់តាំងទុកក្នុងតំណែងសេនាបតី ។ ពន្ធុលសេនាបតីនោះ ឲ្យយាងព្រះជនក និងព្រះជននីមកអាស្រ័យ នៅក្នុងក្រុងសាវត្ថីនោះឯង ។

សម័យថ្ងៃមួយ ព្រះរាជាទ្រង់ប្រថាប់ឈរលើប្រាសាទជាន់លើ ទតទៅកាន់រាងផ្លូវ ឃើញភិក្ខុច្រើនពាន់រូប និមន្តទៅដើម្បីធ្វើភត្តកិច្ច ក្នុងគេហដ្ឋានជនទាំងនេះ គឺអនាថបិណ្ឌិកសេដ្ឋី ចូឡអនាថបិណ្ឌិកសេដ្ឋី នាងវិសាខា នាងសុប្បវាសា ទើបត្រាស់សួរថា លោកម្ចាស់ទាំងឡាយនិមន្តទៅណា ពួកអាជ-បុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព ភិក្ខុពីរពាន់រូបទៅដើម្បីប្រយោជន៍ដល់ភត្តទាំងឡាយ មានទិច្ចភត្ត សាលាកភត្ត និងគិលានភត្តជាដើម ក្នុងគេហដ្ឋានរបស់អនាថបិណ្ឌិកសេដ្ឋីរាល់ៗ ថ្ងៃ ។ ភិក្ខុ ៥០០ រូប ទៅគេហដ្ឋានរបស់ចូឡអនាថបិណ្ឌិកសេដ្ឋីជានិច្ច របស់នាងវិសាខា និងនាងសុប្បវាសាក៏ដូចគ្នា ដូច្នេះហើយ ទ្រង់ព្រះបំណងនឹងទំនុកបម្រុងភិក្ខុសង្ឃ ដោយព្រះអង្គឯងខ្លះ ទើបយាងទៅកាន់វិហារ ទ្រង់និមន្តព្រះសាស្តា មួយអន្ទើដោយភិក្ខុ ១ ពាន់រូប ថ្វាយទានដោយព្រះហស្តអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ថ្វាយបង្គំព្រះសាស្តាហើយ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទទួលកិច្ចារបស់ខ្ញុំព្រះអង្គ មួយអន្ទើដោយភិក្ខុ ៥០០ រូប ជានិច្ចចុះ ។

ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ធម្មតាព្រះពុទ្ធទាំងឡាយ រមែងមិនទទួលកិក្ខាប្រចាំក្នុងទីមួយកន្លែង មហាជនដ៏ច្រើនរមែងទន្ទឹងចំពោះការមករបស់ព្រះពុទ្ធទាំងឡាយ ។

ព្រះរាជាត្រាស់ថា បើដូច្នោះ សូមទ្រង់បញ្ជូនភិក្ខុមួយរូបមកជាប្រចាំចុះ ព្រះសាស្តា ទ្រង់បានធ្វើឲ្យជាការៈរបស់ព្រះអានន្ទត្ថេរ ។

ព្រះរាជាមិនចាត់ចែងនាទីថា កាលភិក្ខុសង្ឃមកហើយ ជនទាំងនេះទទួលបាត្រ ហើយចូរអង្គាស ទ្រង់អង្គាសដោយព្រះអង្គឯងប៉ុណ្ណោះអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៨ ទ្រង់ក៏ភ្ញេច ទ្រង់ធ្វើឲ្យយឺតយូរហើយ ។

ធម្មតាក្នុងរាជត្រកូល ជនទាំងឡាយ ដែលព្រះរាជាទ្រង់មិនបានបញ្ជាហើយ រមែងមិនបានក្រាលអាសនៈទាំងឡាយ និមន្តពួកភិក្ខុឲ្យគង់ហើយអង្គាស ពួកភិក្ខុក៏គិតគ្នាថា យើងមិនអាចឈប់បង្អង់ក្នុងទីនេះបាន នាំគ្នាចៀសចេញទៅច្រើនរូប ។ សូម្បីក្នុងថ្ងៃទីពីរ ព្រះរាជាក៏ទ្រង់ភ្ញេចហើយ សូម្បីក្នុងថ្ងៃទីពីរ ភិក្ខុជាច្រើនក៏នាំគ្នាចៀសចេញទៅ ។ ក្នុងថ្ងៃទីបី ព្រះរាជាក៏ទ្រង់ភ្ញេច ក្នុងកាលនោះ វៀរព្រះអានន្ទត្ថេរមួយអង្គប៉ុណ្ណោះ ពួកភិក្ខុដ៏សេស នាំគ្នាចៀសចេញទៅ ។

ធម្មតាអ្នកមានបុណ្យទាំងឡាយ ជាអ្នកប្រព្រឹត្តទៅក្នុងអំណាចនៃហេតុ ទើបរក្សាការជ្រះថ្លាឲ្យត្រកូលទាំងឡាយបាន ។ សាវ័ករបស់ព្រះតថាគតទាំងអស់ ដែលដល់នូវហានន្តរ តាំងអំពីជនទាំង ៨ នោះ បានដល់ អគ្គសាវ័កពីររូប គឺព្រះសារីបុត្តត្ថេរ ព្រះមហាមោគ្គល្លានត្ថេរ អគ្គសាវិកាពីររូប គឺនាង

ខេមា នាងឧប្បលវណ្ណា បណ្តាឧបាសកទាំងឡាយ ឧបាសកដែលជាអគ្គសាវក ពីរនាក់ គឺចិត្តគហបតី ហត្ថកឧបាសកអ្នកក្រុងអាឡវី បណ្តាឧបាសិកាទាំង-ឡាយ ឧបាសិកាដែលជាអគ្គសាវិកាពីរនាក់ គឺម្តាយរបស់នន្ទមាណពឈ្មោះ វេឡុកណ្ឌកី នាងខុជ្ជុត្តរា សុទ្ធសីងតែជាអ្នកមានបុណ្យច្រើន សម្បូរដោយ អភិនីហារ ព្រោះជាអ្នកបំពេញបារមី ១០ ដោយឯកទេស ។

សូម្បីព្រះអានន្ទត្ថេរ មានបារមីបំពេញហើយអស់សែនកប្ប សម្បូរដោយ អភិនីហារ មានបុណ្យច្រើន កាលនឹងរក្សាសេចក្តីជ្រះថ្លារបស់ត្រកូល ទើប បានឈប់បង្អង់ ព្រោះភាពដែលខ្លួនប្រព្រឹត្តទៅក្នុងអំណាចនៃហេតុ ពួករាជ-បុរសនិមន្តលោកមួយអង្គប៉ុណ្ណោះ ឲ្យគង់ហើយអង្គាស ។ ព្រះរាជាមកក្នុង កាលដែលពួកភិក្ខុទៅហើយ ទតឃើញខាទនីយៈ និងភោជនីយៈតាំងនៅយ៉ាង នោះឯង ទើបត្រាស់សួរថា លោកម្ចាស់ទាំងឡាយមិនបាននិមន្តមកឬ ទ្រង់ បានឮថា ព្រះអានន្ទត្ថេរនិមន្តមកមួយរូបប៉ុណ្ណោះ ទ្រង់ពិរោធភិក្ខុទាំងឡាយថា លោកម្ចាស់ទាំងឡាយ បានធ្វើការកាត់ផ្តាច់ចំពោះអញ មានប្រមាណប៉ុណ្ណោះ ពិត ទើបយាងទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរៀបចំភិក្ខាដើម្បីភិក្ខុ ៥០០ បានឮថា ព្រះអានន្ទត្ថេរមួយរូបប៉ុណ្ណោះ និមន្តមក ភិក្ខាដែលខ្ញុំព្រះអង្គរៀបចំហើយ តាំងនៅយ៉ាងនោះឯង ភិក្ខុ ៥០០ រូប មិនធ្វើការសម្គាល់ក្នុងព្រះរាជវាំងរបស់ខ្ញុំព្រះអង្គឡើយ នឹងមានហេតុអ្វី ។

ព្រះសាស្តា មិនត្រាស់ទោសរបស់ពួកភិក្ខុ ត្រាស់ថា បពិត្រមហារាជ សាវករបស់តថាគត មិនមានការស្និទ្ធស្នាលជាមួយព្រះអង្គ ព្រោះហេតុនោះ

ភិក្ខុទាំងឡាយនឹងមិនទៅហើយ ដើម្បីទ្រង់ប្រកាសហេតុនៃការមិនចូលទៅ និងហេតុនៃការចូលទៅកាន់ត្រកូលទាំងឡាយ ត្រាស់ហៅភិក្ខុទាំងឡាយមក ហើយ ត្រាស់សូត្រនេះថា

ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ ដែលភិក្ខុមិនទាន់ចូលទៅ ក៏មិនគួរចូលទៅ បើភិក្ខុចូលជ្រុលទៅហើយ ក៏មិនគួរអង្គុយ ។ ត្រកូលប្រកបដោយអង្គ ៩ តើដូចម្តេចខ្លះ ។ គឺគេមិនក្រោកទទួលដោយសេចក្តីពេញចិត្ត ១ មិនថ្វាយបង្គំដោយសេចក្តីពេញចិត្ត ១ មិនឲ្យអាសនៈដោយសេចក្តីពេញចិត្ត ១ លាក់របស់ដែលមាន ១ របស់មានច្រើនឲ្យតិច ១ មានរបស់ដែលថ្លៃថ្លាឲ្យរបស់សៅហ្មង ១ ឲ្យដោយមិនគោរព មិនឲ្យដោយគោរព ១ មិនចូលទៅអង្គុយជិតដើម្បីស្តាប់ធម៌ដោយគោរព ១ មិនត្រេកអរនឹងការសិតរបស់ភិក្ខុនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ នេះឯង ដែលភិក្ខុមិនធ្លាប់ចូលទៅ ក៏មិនគួរចូលទៅ ឬចូលជ្រុលទៅហើយ ក៏មិនគួរអង្គុយ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ ដែលភិក្ខុមិនទាន់ចូលទៅ ក៏គួរចូលទៅបាន ឬចូលទៅហើយក៏គួរអង្គុយបាន ។ ត្រកូលប្រកបដោយអង្គ ៩ តើដូចម្តេចខ្លះ ។ គឺគេក្រោកទទួលដោយសេចក្តីពេញចិត្ត ១ ថ្វាយបង្គំដោយសេចក្តីពេញចិត្ត ១ ឲ្យអាសនៈដោយសេចក្តីពេញចិត្ត ១ មិនលាក់របស់ដែលមាន ១ របស់ដែលមានច្រើនឲ្យច្រើន ១ របស់ដែលថ្លៃថ្លាឲ្យរបស់ថ្លៃថ្លា ១ ឲ្យដោយគោរព មិនឲ្យដោយមិនគោរព ១ ចូលទៅអង្គុយជិតដើម្បីស្តាប់ធម៌ ១ ត្រេកអរនឹងការសិតរបស់ភិក្ខុនោះ ១ ។

ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ នេះឯង ដែលភិក្ខុមិនទាន់ចូលទៅ ក៏គួរចូលទៅបាន ឬចូលទៅហើយ ក៏គួរអង្គុយបាន ។

ជូចេ្នះហើយ ទើបត្រាស់ថា មហាបពិត្រ ភិក្ខុសាវ័កបរស់តថាគត កាលមិនបាននូវការស្និទ្ធស្នាល អំពីសម្លាក់របស់ព្រះអង្គ នឹងមិនទៅដោយប្រការយ៉ាងនេះឯង ។ ពិតហើយ បុរាណបណ្ឌិតទាំងឡាយ សូម្បីគេទំនុកបម្រុងដោយសេចក្តីគោរពក្នុងទីដែលមិនស្និទ្ធស្នាល ដល់នូវទុក្ខវេទនាទៀបនឹងស្លាប់ ក៏បានទៅកាន់ទីរបស់អ្នកស្និទ្ធស្នាលដូចគ្នា កាលព្រះរាជាទូលសួរថា បពិត្រព្រះអង្គ តើក្នុងកាលណា ទ្រង់ក៏នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល ស្តេចព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះរាជាព្រះនាមកេសវៈ ទ្រង់លះរាជសម្បត្តិបួសជាឥសី ។ បុរស ៥០០ នាក់ ចេញបួសតាមព្រះរាជានោះ បានព្រះនាមថាកេសវតាបស ។ ម្យ៉ាងទៀត នាយកូសាមាណរបស់ព្រះអង្គ បានបួសតាមជាអន្តេវាសិក ឈ្មោះកប្បកៈ ។ កេសវតាបស និងបរិស័ទ នៅក្នុងហិមវន្តប្បទេសអស់ ៨ ខែ ក្នុងរដូវក្តៀងកាលត្រូវការសេពរសប្រៃ និងជូរ ទៅដល់ក្រុងពារាណសីហើយ ចូលទៅកាន់នគរដើម្បីភិក្ខា លំដាប់នោះ ព្រះរាជាទតឃើញតាបសនោះ ទ្រង់ជ្រះថ្លា ទ្រង់ទទួលប្តេជ្ញាដើម្បីប្រយោជន៍ ដល់ការនៅក្នុងសម្លាក់របស់ព្រះអង្គអស់ ៤ ខែ និមន្តឲ្យស្នាក់នៅក្នុងព្រះរាជឧទ្យាន ទ្រង់យាងទៅកាន់ទីបម្រើតាបសនោះ ទាំងល្ងាច ទាំងព្រឹក ពួកតាបសដ៏សេស ស្នាក់នៅ ២-៣ ថ្ងៃ រំខានដោយសំឡេងអឺងកងផ្សេងៗ មានសំឡេងដំរីជាដើម ទើបពោលថា លោកអាចារ្យ

ពួកខ្ញុំរំខានចិត្តនឹងនៅ កេសវៈពោលថា នែបា អ្នកនឹងនៅណា អន្តេវាសិក ជ្រាបថា បពិត្រលោកអាចារ្យ នៅកាន់ព្រៃហិមវន្តប្បទេស កេសវៈពោលថា ក្នុងថ្ងៃដែលពួកយើងមកនោះឯង ស្តេចផែនដីទ្រង់ទទួលប្តេជ្ញាដើម្បីប្រយោជន៍ដល់ការនៅក្នុងទីនេះ អស់ ៤ ខែ ពួកអ្នកនឹងនៅបានដូចម្តេច ។

អន្តេវាសិកពោលថា លោកអាចារ្យមិនជ្រាបពួកខ្ញុំជាមុន ទើបថ្វាយប្តេជ្ញា ។ ពួកខ្ញុំមិនអាចនៅក្នុងទីនេះបាន នឹងនៅក្នុងទីល្មមស្តាប់ការប្រព្រឹត្តទៅរបស់លោកអាចារ្យបាន ដែលមិនឆ្ងាយអំពីទីនេះដូច្នេះ នាំគ្នាថ្វាយបង្គំអាចារ្យហើយចៀសចេញទៅ ។ អាចារ្យនៅជាមួយអន្តេវាសិក ឈ្មោះកប្បកៈប៉ុណ្ណោះ ។

ព្រះរាជាយាងមកកាន់ទីបម្រើគ្រាស់សួរថា លោកម្ចាស់ទាំងឡាយនិមន្តទៅណា កេសវតាបសទូលថា បពិត្រមហារាជ ពួកតាបសទាំងនោះជ្រាបថា ពួកខ្ញុំរំខានចិត្ត ដូច្នេះហើយ ក៏នៅកាន់ហិមវន្តប្បទេស ។

ក្នុងកាលតមកមិនយូរ សូម្បីកប្បកតាបសក៏រំខានហើយ សូម្បីត្រូវអាចារ្យឃាត់រឿយៗ ក៏ពោលថា ខ្ញុំមិនអាចនៅក្នុងទីនេះបានទេ ដូច្នេះហើយក៏ទៅ ។

តែកប្បកតាបសនោះ មិននៅកាន់សម្នាក់របស់ពួកតាបសក្រៅអំពីនេះ រង់ចាំស្តាប់ដំណឹងរបស់អាចារ្យក្នុងទីក្បែរៗ នោះ ។

ក្នុងកាលតមក កាលអាចារ្យគិតដល់ពួកអន្តេវាសិក រោគក្នុងពោះក៏កើតឡើង ព្រះរាជាទ្រង់បញ្ជាឲ្យពេទ្យព្យាបាល រោគក៏មិនស្ងប់បាន ទើបតាបសទូលថា បពិត្រមហារាជ ទ្រង់បំណងឲ្យរោគរបស់អាត្មាភាពស្ងប់ឬ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ បើខ្ញុំអាច ក៏គប្បីធ្វើសេចក្តីផាសុកដល់លោក

ម្ចាស់ឥឡូវនេះឯង តាបសពោលថា បពិត្រមហារាជ បើទ្រង់ប្រាថ្នាសេចក្តីសុខ ដល់អាត្មាសោត សូមបញ្ជូនអាត្មាទៅកាន់សម្នាក់អន្តេវាសិកទាំងឡាយចុះ ។

ព្រះរាជាត្រាស់ថា សាធុ លោកម្ចាស់ ហើយឲ្យតាបសនោះសិងលើគ្រែតូច ទ្រង់បញ្ជូនអមាត្យទៅ ៤ នាក់ មាននាទអមាត្យជាប្រធាន ហើយត្រាស់ថា ពួកអ្នកចូរជ្រាបជំណឹងរបស់លោកម្ចាស់ហើយ គប្បីបញ្ជូនដំណឹងដល់យើង ។

កប្បកអន្តេវាសិកជ្រាបថា អាចារ្យមក ក៏ធ្វើនូវការទទួល កាលអាចារ្យពោលថា ជនក្រៅអំពីនេះទៅកាន់ទីណា ទើបប្រាប់ថា បានឮថា នៅក្នុងទីឈ្មោះនោះ ។

អន្តេវាសិកទាំងនោះជ្រាបថាអាចារ្យមកហើយ ក៏មកប្រជុំគ្នាក្នុងទីនោះឯង ប្រគេនទឹកក្តៅហើយ ថ្វាយផលាផលដល់អាចារ្យ រោគស្ងប់ហើយក្នុងខណៈនោះឯង ។ តាបសនោះមានពណ៌ដូចមាសក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ លំដាប់នោះ នាទអមាត្យសួរថា

កេសវតាបស មានព្រះភាគ (របស់យើងខ្ញុំ) នេះ លះបង់ព្រះបាទពារាណសី ជាធំជាងមនុស្ស អ្នកឲ្យសម្រេចសេចក្តីប្រាថ្នាទាំងពួង ហើយត្រេកអរសប្បាយក្នុងអាស្រម របស់កូនសិស្សឈ្មោះកប្បកៈ តើដោយឧបាយដូចម្តេច ។

កេសវតាបសនិយាយថា ម្នាលអមាត្យ រសទាំងឡាយដ៏ឆ្ងាញ់ គួរឲ្យរីករាយក៏មាន ដើមឈើទាំងឡាយ ជាទីរីករាយចិត្តក៏មាន ពាក្យជាសុភាសិត

ទាំងឡាយរបស់កប្បកៈ តែងធ្វើឲ្យអាត្មាត្រេកអរបាន ។

នារទាមាត្យ ពោលថា លោកម្ចាស់ ធាន់ចង្ហាន់ស្រូវសាលី ដែលលាយដោយសាច់ដ៏ស្អាត ហេតុដូចម្តេច បានជាស្រែឆៃ និងស្មៅគែលលក ដែលមិនមានរសប្រៃសោះ ធ្វើឲ្យលោកម្ចាស់ត្រេកអរបាន ។

កេសវតាបសនិយាយតបថា បុគ្គលមានសេចក្តីស្និទ្ធស្នាល បរិភោគភោជន ទោះបីឆ្ងាញ់ក្តី មិនឆ្ងាញ់ក្តី តិចក្តី ច្រើនក្តី ក្នុងកន្លែងណា ភោជន (ណាមួយដែលបុគ្គលបរិភោគហើយ ក្នុងទីកន្លែងនោះជាភោជនប្រសើរ) ព្រោះរស មានសេចក្តីស្និទ្ធស្នាលជាយ៉ាងក្រៃលែង ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់សមោធានជាតក ត្រាស់ថា ព្រះរាជាក្នុងកាលនោះ បានជាមោគ្គល្លាន នារទអមាត្យ បានជាសារីបុត្ត អន្តេវាសិកឈ្មោះកប្បកៈបានជាអានន្ទ កេសវតាបស គឺតថាគតនេះឯង ដូច្នេះហើយ ត្រាស់ថា មហាបពិត្រ បណ្ឌិតក្នុងកាលមុនដល់នូវវេទនាស៊ើរនឹងស្ងាប់ បានទៅកាន់ទីដែលមានការស្និទ្ធស្នាលហើយ សាវ័កទាំងឡាយរបស់តថាគត ប្រហែលជាមិនបាននូវការស្និទ្ធស្នាល ក្នុងសម្នាក់របស់ទ្រង់ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា អាត្មាអញគួរធ្វើនូវការស្និទ្ធស្នាលជាមួយភិក្ខុសង្ឃ អញនឹងធ្វើម្តេចហ្ន៎ ដូច្នេះហើយ ទ្រង់ព្រះតម្រិះទៀតថា គួរធ្វើព្រះធីតានៃព្រះញាតិរបស់ព្រះសម្មាសម្ពុទ្ធ ទុកក្នុងព្រះរាជមន្ទីរ កាលបើដូច្នេះ ពួកភិក្ខុកំលោះ និងពួកសាមណេរ ក៏នឹងស្និទ្ធស្នាលហើយមកកាន់សម្នាក់របស់

អញ្ជាជានិច្ច ដោយគិតថា ព្រះរាជាជាព្រះញាតិរបស់ព្រះសម្មាសម្ពុទ្ធ ដូច្នេះ ទ្រង់ព្រះរាជសាសន៍ទៅសម្នាក់ស្តេចសក្យៈទាំងឡាយថា ស្តេចសក្យៈទាំង-ឡាយ ចូរប្រទានព្រះរាជធីតាមួយអង្គដល់ខ្ញុំ ហើយបញ្ជាទូតទាំងឡាយថា ពួកអ្នកគប្បីសួរថា ជាធីតានៃសក្យៈអង្គណា ហើយសឹមមក ។

ពួកទូតទៅហើយ ទូលសូមរាជធីតាមួយអង្គនឹងសក្យៈទាំងឡាយ ស្តេចសក្យៈទាំងនោះប្រជុំគ្នាហើយ ទ្រង់ព្រះតម្រិះថា ព្រះរាជាជាបរបក្ខ បើពួកយើងមិនឲ្យសោត ទ្រង់នឹងធ្វើឲ្យពួកយើងវិនាស ឯត្រកូលទ្រង់ មិនស្មើនឹងយើងទេឬយ ពួកយើងគួរធ្វើដូចម្តេចល្អ ស្តេចមហានាមត្រាស់ថា កូនរបស់ខ្ញុំ ឈ្មោះវាសភខត្តិយា កើតក្នុងផ្ទៃទាសី ដល់នូវភាពជាអ្នកមានរូបស្អាតមាន ពួកយើងនឹងឲ្យនាងនោះ ដូច្នេះហើយ ទើបប្រាប់ពួកទូតថា ប្រពៃណាស់ ពួកយើងនឹងថ្វាយព្រះរាជកញ្ញាដល់ព្រះរាជា ពួកទូតពោលថា ជាព្រះរាជ-ធីតារបស់សក្យៈអង្គណា ស្តេចសក្យៈពោលថា ជាធីតារបស់មហានាម សក្យរាជ ដែលជាព្រះឱរសរបស់ម្ចាស់ពូនៃព្រះសម្មាសម្ពុទ្ធ ឈ្មោះវាសភ-ខត្តិយា ទូតទាំងនោះទៅក្រាបទូលដល់ព្រះរាជារបស់ខ្លួន ព្រះរាជាត្រាស់ថា បើយ៉ាងនោះក៏ប្រពៃ ពួកអ្នកចូរនាំមកចុះ ធម្មតាពួកក្សត្រមានកលមាយាច្រើន គប្បីបញ្ជូនកូនស្រីរបស់ទាសីមកក៏ថាបាន ពួកអ្នកចូរនាំធីតា ដែលសោយភោជនជាមួយព្រះបិតាមក ដូច្នេះហើយ ទ្រង់បញ្ជូនទូតទាំងឡាយទៅ ។

ពួកគេទៅហើយក្រាបទូលថា បពិត្រព្រះអង្គ ព្រះរាជាទ្រង់ប្រាប្តាព្រះធីតាដែលសោយរួមជាមួយព្រះអង្គ ស្តេចមហានាមត្រាស់ថា នែបា បាន ទើប

ឲ្យតាក់តែងនាងក្នុងពេលសោយរបស់ព្រះអង្គ ត្រាស់ឲ្យហៅនាងមក សម្តែងអាការ ហាក់ដូចសោយរួមគ្នាជាមួយនាងហើយ ប្រគល់ដល់ទូតទាំងឡាយ ។ ពួកគេនាំនាងទៅកាន់ក្រុងសាវត្ថីហើយ ក្រាបទូលរឿងនោះដល់ព្រះរាជា ។

ព្រះរាជាទ្រង់ពេញព្រះហឫទ័យ តាំងនាងឲ្យជាធំជាងស្រី ៥០០ អភិសេកក្នុងតំណែងអគ្គមហេសី ក្នុងកាលមិនយូរ នាងក៏ប្រសូតព្រះឱរស មានពណ៌ដូចមាស ។ សម័យតមក ក្នុងថ្ងៃថ្វាយព្រះនាមព្រះឱរសនោះ ព្រះរាជាទ្រង់បញ្ជូនព្រះរាជសាសន៍ទៅកាន់សម្នាក់ព្រះអយ្យិកាថា ព្រះនាងវាសភខត្តិយាធីតានៃសក្យរាជ ប្រសូតព្រះឱរសហើយ ទ្រង់ថ្វាយព្រះនាមកុមារនោះដូចម្តេច ។

ចំណែកអមាត្យ ត្រចៀកថ្ងង់ ទទួលព្រះរាជសាសន៍នោះទៅហើយ ។ អមាត្យទៅហើយ ក៏ក្រាបទូលដល់ព្រះអយ្យិការបស់ព្រះរាជា ។

ព្រះអយ្យិកានោះ ទ្រង់ស្តាប់រឿងនោះហើយត្រាស់ថា ព្រះនាងវាសភខត្តិយា មិនប្រសូតព្រះឱរស ក៏បានគ្រប់គ្រងជនទាំងអស់ ឥឡូវនេះ នាងនឹងជាទីប្រោសប្រាណក្រៃលែងរបស់ព្រះរាជា ។

អមាត្យត្រចៀកថ្ងង់ ស្តាប់ពាក្យថា វល្លកា មិនសូវច្បាស់ យល់ថា វិឌូឌភៈ កាលចូលគាល់ព្រះរាជាហើយ ក៏ក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ថ្វាយព្រះនាមព្រះរាជកុមារថា វិឌូឌភៈចុះ ព្រះរាជាទ្រង់ព្រះតម្រិះថា ពាក្យថា វិឌូឌភៈ ជាឈ្មោះប្រចាំត្រកូលរបស់អញ ទើបបានថ្វាយព្រះនាមថា វិឌូឌភៈ ។

សម័យតមក ព្រះរាជាបានប្រទានតំណែងសេនាបតី ដល់វិឌូឌកកុមារ នោះ ក្នុងកាលដែលទ្រង់ពេញកំលោះនោះឯង ដោយតាំងព្រះហឫទ័យថា នឹងធ្វើឲ្យជាទីប្រោសប្រាណរបស់ព្រះសាស្តា ។

វិឌូឌកៈនោះ ទ្រង់ចម្រើនដោយគ្រឿងទំនុកបម្រុងសម្រាប់កុមារ ក្នុងកាលមានព្រះជន្ម ៧ ឆ្នាំ ទ្រង់ឃើញរបស់លេងផ្សេងៗ មានរូបដំរី និងរូបសេះជាដើមរបស់កុមារដទៃ ដែលបុគ្គលនាំមកអំពីត្រកូលជីដូន ទើបសួរព្រះមាតាថា បពិត្រមាតា បុគ្គលដទៃៗ គេនាំបណ្ណាការមកអំពីត្រកូលជីដូនដើម្បីពួកកុមារ ញាតិណាមួយរមែងមិនបញ្ជូនបណ្ណាការណាមួយមកដើម្បីខ្ញុំសោះ មាតាមិនមានព្រះជនក ព្រះជននីឬ ។

បន្ទាប់អំពីនោះ ទើបព្រះមាតាលួងលោមឱរសនោះថា នែបា ស្តេចសក្យៈ ជាជីដូនរបស់អ្នក មានតែនៅឆ្ងាយ ហេតុនោះ ទើបពួកលោកមិនបានបញ្ជូនគ្រឿងបណ្ណាការណាមួយមកដើម្បីអ្នក ។

ក្នុងកាលមានព្រះជន្មវស្សា ១៦ ទើបព្រះរាជកុមារទូលព្រះមាតាទៀតថា បពិត្រមាតា ខ្ញុំប្រាថ្នានឹងសួរសុខទុក្ខត្រកូលរបស់ព្រះអយ្យិកា សូម្បីត្រូវព្រះមាតាឃាត់ថា នែកូន អ្នកកុំទៅឡើយ កូននឹងទៅធ្វើអ្វីក្នុងទីនោះ ព្រះរាជ-កុមារក៏អង្វរវារៀយៗ ទៅ ។ ពេលនោះ ព្រះមាតារបស់ព្រះរាជកុមារ ក៏ទ្រង់យល់ព្រមថា បើយ៉ាងនោះ ទៅក៏ទៅចុះ ។

ព្រះរាជកុមារក្រាបទូលព្រះរាជបិតាហើយយាងទៅ មួយអន្លើដោយបរិវារដ៏ច្រើន ។ ព្រះនាងវាសភខត្តិយា ទ្រង់បញ្ជូនដំណឹងទៅមុនថា ខ្ញុំម្ចាស់

នៅក្នុងទីនេះសុខសប្បាយជាទេ ព្រះញាតិទាំងឡាយ កុំសម្តែងទោសណា មួយ របស់ព្រះស្វាមីដល់កុមារនោះឡើយ ។

ស្តេចសក្យៈទ្រង់ជ្រាបថាវិឌូឌភកុមារយាងមក ទ្រង់ប្រឹក្សាថា ពួកយើង មិនអាចថ្វាយបង្គំវិឌូឌភៈបាន ទើបបញ្ជូនព្រះរាជកុមារទាំងឡាយដែលក្មេងៗ ជាងវិឌូឌភៈនេះទៅកាន់ជនបទហើយ កាលវិឌូឌភកុមារនោះយាងដល់កបិល-វត្ថុបុរី ក៏ប្រជុំគ្នាក្នុងរាជមន្ទីរ វិឌូឌភកុមារបានយាងទៅគង់នៅក្នុងទីនោះ ។

លំដាប់នោះ ពួកសក្យៈពោលនឹងព្រះរាជកុមារនោះថា នែបា នេះជាតា របស់បា នេះជាអ៊ំ វិឌូឌភកុមារនោះត្រាច់ថ្វាយបង្គំសក្យៈទាំងអស់ មិនបាន ឃើញសក្យៈសូម្បីមួយអង្គដែលថ្វាយបង្គំខ្លួន ទើបទូលសួរថា ហេតុអ្វីហ្ន៎ ទើបមិនមានស្តេចសក្យៈទាំងឡាយថ្វាយបង្គំខ្ញុំខ្ញុះ ។

ពួកស្តេចសក្យៈត្រាស់ថា នែបា កុមារដែលជាបួនរបស់បា យាងទៅ ជនបទអស់ហើយ ទ្រង់ធ្វើសក្ការៈធំដល់ព្រះកុមារនោះ ។ ព្រះអង្គក៏គង់ នៅអស់ ២-៣ ថ្ងៃ ក៏យាងចេញអំពីព្រះនគរដោយបរិវារច្រើន ។

លំដាប់នោះ ទាសីម្នាក់ស្រែកជេរថា នេះជាបន្ទុះក្តារដែលកូននាងទាសី ឈ្មោះវាសភខត្តិយាអង្គុយ ដូច្នេះហើយ លាងបន្ទុះក្តារដែលព្រះរាជកុមារនោះ អង្គុយក្នុងរាជមន្ទីរ ដោយទឹកលាយដោយទឹកដោះ ។ មហាតលិកម្នាក់ក្លេច អាវុធរបស់ខ្លួន ត្រឡប់ទៅយកអាវុធនោះ បានឮសំឡេងជេរវិឌូឌភកុមារ ទើបសួរទោសនោះ ជ្រាបថា នាងវាសភខត្តិយា កើតក្នុងផ្ទៃរបស់ទាសីមហា នាមសក្យៈ ទើបប្រាប់ដល់ពួកពល មានការគោះឡាយ៉ាងធំថា បានឮថា

ព្រះនាងវាសភខត្តិយាជាកូនស្រីរបស់ទាសី ។

ព្រះបាទវិឌូឌភ:ស្តាប់ពាក្យនោះ បានតាំងព្រះហឫទ័យថា ស្តេចសក្យៈទាំងនោះ លាងបន្ទុះក្តារដែលអញអង្គុយ ដោយទឹកលាយដោយទឹកដោះសិនចុះ តែក្នុងកាលដែលអញតាំងនៅក្នុងរាជសម្បត្តិហើយ អញនឹងយកឈាមបំពង់ករបស់ស្តេចសក្យៈទាំងនោះ លាងបន្ទុះក្តារដែលអញអង្គុយ កាលទ្រង់យាងដល់ក្រុងសាវត្ថី ពួកអមាត្យក៏ក្រាបទូលរឿងនោះដល់ព្រះរាជា ។

ព្រះរាជាទ្រង់ពិរោធស្តេចសក្យៈថា បានឲ្យធីតានាងទាសីដល់អញ ទើបទ្រង់បញ្ជាដកគ្រឿងបរិហារ ដែលទ្រង់ព្រះរាជប្រទានដល់ព្រះនាងវាសភខត្តិយានិងព្រះឱរស ឲ្យព្រះរាជទានត្រឹមតែវត្ថុដែលជាទាស: និងទាសីគប្បីបានប៉ុណ្ណោះ ។

ក្នុងកាលតមក ២-៣ ថ្ងៃ ព្រះសាស្តាទ្រង់យាងទៅកាន់ព្រះរាជនិវេសន៍ប្រថាប់គង់ហើយ ។ ព្រះរាជាយាងមកថ្វាយបង្គំហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ព្រះញាតិរបស់ព្រះអង្គប្រទានធីតានៃទាសីដល់ខ្ញុំព្រះអង្គព្រោះដូច្នោះ ទើបខ្ញុំព្រះអង្គដកគ្រឿងបរិហាររបស់នាងវាសភខត្តិយានោះ ព្រមទាំងបុត្រ ឲ្យត្រឹមតែរបស់ដែលទាស: និងទាសីគួរបានប៉ុណ្ណោះ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ស្តេចសក្យៈទាំងឡាយធ្វើកម្មមិនសមគួរ ធម្មតាកាលឲ្យ ក៏គួរឲ្យធីតាដែលមានជាតិស្មើគ្នា មហាបពិត្រ តថាគតទូលព្រះអង្គថា នាងវាសភខត្តិយាជាធីតារបស់ខត្តិយរាជ បានអភិសេកក្នុងព្រះរាជមន្ទីរបស់ខត្តិយរាជ ចំណែកវិឌូឌភកុមារ ក៏ទ្រង់អាស្រ័យខត្តិយរាជ

នោះឯងប្រសូតហើយ ធម្មតាគោត្រខាងមាតា នឹងមានប្រយោជន៍អ្វី គោត្រខាងបិតាប៉ុណ្ណោះជាសំខាន់ ដូច្នេះហើយ ត្រាស់ថា បុរាណបណ្ឌិតទាំងឡាយ បានព្រះរាជទានតំណែងអគ្គមហេសីដល់ស្រីកម្សត់ ឈ្មោះកដ្ឋហារិកា គឺស្រីរកខស និងព្រះរាជកុមារដែលកើតក្នុងផ្ទៃរបស់ស្រីនោះ ក៏ដល់នូវភាពជាព្រះរាជា ក្នុងនគរពារាណសី ទំហំ ១២ យោជន៍ ទ្រង់ព្រះនាមថា កដ្ឋវាហនៈ ហើយត្រាស់កដ្ឋហារិយជាតក ។

ព្រះរាជាទ្រង់ស្តាប់ព្រះធម្មកថា ទ្រង់ត្រេកអរថា បានឮថា គោត្រខាងបិតាប៉ុណ្ណោះជាសំខាន់ ទើបទ្រង់បញ្ជាឲ្យព្រះរាជទានគ្រឿងបរិហារអំពីមុននោះ ដល់មាតា និងបុត្រ ។

ភរិយារបស់ពន្ធុលសេនាបតី ឈ្មោះមល្លិកា ជាធីតារបស់ស្តេចមល្លៈ ក្នុងកុសិនារនគរ មិនមានបុត្រអស់កាលយូរ ។ តមក ពន្ធុលសេនាបតី បញ្ជូននាងទៅថា ចូរនាងទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួនចុះ នាងគិតថា អញនឹងគាល់ព្រះសាស្តាហើយសឹមទៅ ទើបចូលទៅកាន់វត្តជេតពន ឈរថ្វាយបង្គំព្រះដ៏មានព្រះភាគ ។ កាលព្រះសាស្តាត្រាស់សួរថា នាងនឹងទៅក្នុងទីណា ក៏ក្រាបទូលថា បពិត្រព្រះអង្គ ស្វាមីបញ្ជូនខ្ញុំម្ចាស់ទៅកាន់ផ្ទះនៃត្រកូល ព្រះសាស្តាត្រាស់ថា ព្រោះហេតុអ្វី នាងពោលថា ព្រោះខ្ញុំម្ចាស់ជាស្រីអារមិនមានបុត្រ ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ កិច្ច គឺការទៅមិនមាន ចូរនាងត្រឡប់ចុះ ។ នាងសប្បាយចិត្ត ថ្វាយបង្គំព្រះសាស្តាត្រឡប់ទៅកាន់និវេសន៍ កាលប្តីសួរថា ត្រឡប់មកធ្វើអ្វី ឆ្លើយថា ព្រះទសពលឲ្យខ្ញុំត្រឡប់

ពន្ធុលៈគិតថា ព្រះសាស្តាទ្រង់យើញហេតុឆ្ងាយ នឹងជាហេតុនេះទើបទទួល ។ មិនយូរប៉ុន្មាន នាងក៏មានគភ៌ កើតនូវការចាញ់ផ្ទៃ ប្រាប់ថា ការចាញ់ផ្ទៃកើតហើយដល់ខ្ញុំ ពន្ធុលៈពោលថា នាងចាញ់ផ្ទៃដូចម្តេច នាងពោលថា ខ្ញុំប្រាថ្នានឹងចុះងូត ហើយផឹកទឹកដែលគួរផឹកក្នុងស្រះបោក្ខរណី ដែលជាមង្គលក្នុងការងារអភិសេកនៃគណៈរាជត្រកូលក្នុងនគរវេសាលី ។ ពន្ធុលៈពោលថា សាធុ ហើយកាន់ធ្នូ ដែលបុគ្គលគប្បីយឹតដោយកម្លាំងរបស់បុរស ១ ពាន់ បីនាងឡើងរថ ចេញអំពីក្រុងសាវត្ថី បររថចូលទៅកាន់ក្រុងវេសាលី ដោយទ្វារដែលស្តេចលិច្ឆវី ឲ្យដល់មហាលិលិច្ឆវី ។

លំនៅអាស្រ័យរបស់ស្តេចលិច្ឆវី ឈ្មោះមហាលិ មាននៅក្បែរទ្វារនោះឯង គ្រាន់តែបានឮសំឡេងប៉ះនឹងធរណីទ្វារក៏ដឹងថា សំឡេងរថរបស់ពន្ធុលៈពោលថា ថ្ងៃនេះ ភ័យនឹងកើតដល់ស្តេចលិច្ឆវី ។

ការរក្សាស្រះបោក្ខរណីតឹងរឹង ទាំងខាងក្នុង និងខាងក្រៅ ខាងលើ សន្ធឹងដោយសំណាញ់ដែក សូម្បីតែបក្សី ក៏មិនមានឱកាស ។

ចំណែកពន្ធុលសេនាបតីចុះអំពីរថ វាយពួកមនុស្សអ្នកយាមដោយផ្តៅ ឲ្យគេចទៅ ហើយកាត់សំណាញ់ដែកឲ្យភរិយាចុះងូតហើយ សូម្បីខ្លួនឯងក៏ងូតខាងក្នុងស្រះបោក្ខរណីហើយ បីនាងឡើងរថ ចេញអំពីព្រះនគរបរទៅដោយផ្លូវដែលមកហើយនោះឯង ។

ពួកភ្នាក់ងារអ្នករក្សា ទូលរឿងដល់ស្តេចលិច្ឆវី ស្តេចលិច្ឆវីពិរោធ ទ្រង់ឡើងរថ ៥០០ គ្រឿង បរចេញទៅដោយចេតនាថា នឹងចាប់ខ្លួនពន្ធុលមល្ល:

បានប្រាប់រឿងនោះដល់មហាលិ ។

ស្តេចមហាលិត្រាស់ថា ពួកអ្នកកុំយាងទៅ ពន្ធុលៈនោះនឹងសម្លាប់អ្នកទាំងអស់ សូម្បីស្តេចលិច្ឆវីក៏នៅតែត្រាស់ថា ពួកយើងនឹងទៅឲ្យបាន ។ ស្តេចមហាលិត្រាស់ថា បើដូច្នោះ ពួកទ្រង់ឃើញកង់រថលិចចុះក្នុងផែនដីដល់ដុំហើយ គប្បីយាងត្រឡប់ បើមិនត្រឡប់អំពីនោះ នឹងបានឮសំឡេងដូចអសនីបាត គឺរន្ទះនៅខាងមុខ គប្បីត្រឡប់អំពីទីនោះ បើមិនត្រឡប់អំពីនោះ កាលណាឃើញប្រហោងក្នុងចន្ទោលរថរបស់ពួកអ្នក គប្បីត្រឡប់អំពីទីនោះ កុំទៅខាងមុខជាច់ខាត ។

ស្តេចលិច្ឆវីទាំងនោះ មិនត្រឡប់តាមពាក្យរបស់មហាលិ នាំគ្នាដេញតាមពន្ធុលៈទៅ នាងមល្លិកាឃើញហើយពោលថា នែអ្នក រថទាំងឡាយរមែងប្រាកដ ពន្ធុលៈពោលថា បើដូច្នោះ ក្នុងកាលណារថប្រាកដជួរតែមួយ នាងគប្បីប្រាប់ខ្ញុំ ។

ក្នុងកាលរថទាំងឡាយប្រាកដហាក់ដូចតែមួយ ទើបនាងប្រាប់ថា នែអ្នកចន្ទោលរថប្រាកដតែមួយហើយ ពន្ធុលៈពោលថា បើដូច្នោះ ចូរនាងចាប់ខ្សែទាំងនេះ ហើយឲ្យខ្សែដល់នាង ឈរត្រង់កណ្តាលរថ ទាញថ្នមឡើង កង់រថលិចចុះក្នុងផែនដីដល់ដុំ ស្តេចលិច្ឆវីទ្រង់ឃើញទីនោះហើយ ក៏នៅតែទៅ ពន្ធុលៈទៅបានបន្តិច ក៏លែងខ្សែថ្នម សំឡេងថ្មនោះលាន់ហាក់បីដូចអសនីបាត ស្តេចលិច្ឆវីទាំងនោះ ក៏មិនត្រឡប់អំពីទីនោះ នៅតែដេញតាមទៅនោះឯង ។

ពន្ធុលៈឈរលើរថនោះឯង បាញ់ព្រួញមួយទៅ ព្រួញនោះធ្វើចន្ទោល

រថ ៥០០ ឲ្យដុះហើយ ទម្លុះព្រះរាជា ៥០០ ក្នុងទីដែលចងក្រោះ ហើយលិចចុះទៅក្នុងផែនដី ។

ស្តេចលិច្ឆវីទាំងនោះ មិនដឹងថា ខ្លួនត្រូវសរទម្លុះហើយ ត្រាស់ថា វ៎ុយ ឈប់សិន វ៎ុយ ឈប់សិន នៅតែដេញតាមនោះឯង ។ ពន្ធុលសេនាបតី បញ្ឈប់រថហើយ ពោលថា ពួកអ្នកជាមនុស្សស្លាប់ ឈ្មោះថា ការច្បាំងរបស់ខ្ញុំជាមួយមនុស្សស្លាប់ទាំងឡាយ មិនមាន ស្តេចលិច្ឆវីពោលថា ឈ្មោះថា មនុស្សស្លាប់មិនមែនមានសភាពដូចយើង ពន្ធុលៈពោលថា បើដូច្នោះ ចូរពួកអ្នកស្រាយក្រោះរបស់មនុស្ស ដែលនៅក្រោយគេបង្អស់មើលចុះ ។ ពួកស្តេចលិច្ឆវីទាំងនោះឲ្យស្រាយហើយ ស្តេចលិច្ឆវីអង្គនោះ ក៏ដួលចុះអស់ជីវិត ក្នុងខណៈស្រាយក្រោះចេញហើយនោះឯង ។ ខណៈនោះ ទើបពន្ធុលៈពោលនឹងស្តេចលិច្ឆវីទាំងនោះថា ពួកអ្នកទាំងអស់ក៏ដូចគ្នា យាងទៅផ្ទះរៀងៗខ្លួនហើយ សឹមរៀបចំវត្ថុដែលគួររៀបចំ ប្រៀនប្រដៅប្រពន្ធកូន ហើយសឹមស្រាយក្រោះចេញ ។ ស្តេចលិច្ឆវីទាំងនោះ ធ្វើយ៉ាងនោះគ្រប់ៗ អង្គ ក៏អស់ជីវិតហើយ ។

ចំណែកពន្ធុលៈនាំនាងមល្លិកាមកកាន់ក្រុងសាវត្ថី នាងប្រសូតបុត្រក្មេះជល់ទៅ ១៦ ដង ។ សូម្បីកូនរបស់នាងទាំងអស់ បានជាអ្នកក្បៀវក្បា ជល់ព្រមដោយកម្លាំង សុទ្ធសឹងសម្រេចសិប្បៈទាំងអស់ ។ កូនទីមួយៗ មានបុរសមួយពាន់ជាបរិវារ ។ លានព្រះរាជវាំងពេញទៅដោយកូនទាំងនោះឯង ដែលទៅវាជនិវេសន៍ជាមួយបិតា ។

ថ្ងៃមួយ ពួកមនុស្សចាញ់ក្តីកោងក្នុងការវិនិច្ឆ័យ ឃើញពន្ធុលៈកំពុងដើរមក ក៏ទ្រហោយំ ប្រាប់ការធ្វើក្តីកោងរបស់ពួកអមាត្យអ្នកវិនិច្ឆ័យ ដល់ពន្ធុលៈនោះ ។ ពន្ធុលៈទៅកាន់រោងវិនិច្ឆ័យនោះហើយ បានធ្វើបុគ្គលជាម្ចាស់របស់នោះឯង ឲ្យជាម្ចាស់របស់ មហាជនឲ្យសាធុការប្រព្រឹត្តទៅដោយសំឡេងខ្លាំងអឺងកង ។

ព្រះរាជាទ្រង់ស្តាប់សំឡេងនោះត្រាស់សួរថា នេះសំឡេងអ្វី កាលទ្រង់ជ្រាបរឿងនោះហើយ ទ្រង់សោមនស្ស ឲ្យជកពួកអមាត្យទាំងអស់នោះ ទ្រង់ប្រគល់ការវិនិច្ឆ័យដល់ពន្ធុលៈប៉ុណ្ណោះ ។ តាំងអំពីនោះមក ពន្ធុលៈក៏វិនិច្ឆ័យដោយត្រឹមត្រូវ ។ ចាប់តាំងអំពីថ្ងៃនោះមក ពួកអមាត្យអ្នកវិនិច្ឆ័យជំនាន់ចាស់មិនបានថ្លៃឈ្នួល រកចំណូលបានតិច ញុះញង់ក្នុងរាជត្រកូលថា ពន្ធុលៈប្រាថ្នាជាព្រះរាជា ។

ព្រះរាជាទ្រង់ជឿពាក្យរបស់អមាត្យទាំងនោះ មិនអាចសង្កត់ព្រះហឫទ័យបាន ទ្រង់ព្រះតម្រិះថា បើពន្ធុលៈត្រូវសម្លាប់ក្នុងទីនេះឯង ការនិន្ទាក៏នឹងកើតឡើងដល់អញ ទ្រង់បញ្ជាឲ្យបុរសដែលតែងតាំង រាយជណ្តើមបច្ចន្តនគរ ហើយត្រាស់ឲ្យហៅពន្ធុលៈមក ទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា បានឮថា ជនបទជាយដែនចោរបះបោរឡើង អ្នក ព្រមទាំងបុត្រ ចូរទៅចាប់ចោរមក ហើយទ្រង់បញ្ជូននាយទាហានដែលជាធំ ដែលមានសមត្ថភាពពួកដទៃទៅជាមួយពន្ធុលៈសេនាបតីនោះ ដោយព្រះតម្រាស់ថា ពួកអ្នកចូរកាត់ក្បាលពន្ធុលសេនាបតី ព្រមទាំងកូន ៣២ នាក់ ក្នុងទីនោះ ហើយនាំមក ។

កាលពន្ធុលៈនោះដល់ជនបទជាយដែន ពួកចោរដែលព្រះរាជាទ្រង់រៀបចំពោលថា បានឮថា លោកសេនាបតីមកហើយ នាំគ្នាគេចអស់ទៅ ។

ពន្ធុលសេនាបតីនោះ ញុាំងបទេសនោះឲ្យស្ងប់រម្ងាប់ហើយ ក៏ត្រឡប់មក ។ លុះជាប់នោះ ទាហានទាំងនោះក៏កាត់ក្បាលពន្ធុលសេនាបតី មួយអន្ទើដោយកូនទាំងអស់ ក្នុងទីជិតព្រះនគរ ។

ថ្ងៃនោះ នាងមល្លិកាទេវី និមន្តអគ្គសាវ័កទាំងពីរ មួយអន្ទើដោយភិក្ខុ ៥០០ ។ ក្នុងពេលព្រឹក ពួកមនុស្សបាននាំសំបុត្រមកឲ្យនាង ដែលមានសេចក្តីថា ចោរកាត់ក្បាលប្តី ព្រមទាំងកូនរបស់នាង នាងដឹងរឿងនោះហើយ មិនប្រាប់ដល់បុគ្គលណាម្នាក់ បត់សំបុត្រជាក់ក្នុងថ្នក់សំពត់ អង្គាសភិក្ខុសង្ឃរឿយៗ ទៅ ។

ខណៈនោះ អ្នកបម្រើរបស់នាង ប្រគេនភត្តដល់ភិក្ខុហើយ នាំថាសសប្បិមក ធ្វើថាសបែកត្រង់ចំពោះមុខព្រះថេរៈ ព្រះធម្មសេនាបតីពោលថា របស់មានការបែកធ្លាយជាធម្មតា ក៏បែកទៅហើយ បុគ្គលណាម្នាក់មិនគួរគិត ។

នាងមល្លិកានោះ នាំយកសំបុត្រចេញអំពីថ្នក់ ប្រាប់ព្រះថេរៈថា គេនាំសំបុត្រនេះមកដល់ខ្ញុំ ដែលមានសេចក្តីថា ពួកចោរកាត់ក្បាលឪពុក ព្រមទាំងកូន ៣២ នាក់ ខ្ញុំស្តាប់រឿងនេះហើយក៏មិនគិត គ្រាន់តែថាសសប្បិបែក ខ្ញុំនឹងគិតដូចម្តេច ។ ព្រះធម្មសេនាបតីពោលពាក្យជាដើមថា

ជីវិតរបស់សត្វទាំងឡាយ ក្នុងលោកនេះ មិនមាននិមិត្ត បុគ្គលណាមួយក៏កំណត់មិនបាន ខ្វះខាតផង មានប្រមាណតិចផង ជីវិត

នោះ ប្រកបដោយទុក្ខ ។

សម្តែងធម៌ស្រេចហើយ ក្រោកអំពីអាសនៈ បានទៅវិហារហើយ ។ ចំណែកនាងមល្លិកា បានហៅកូនប្រសាទាំង ៣២ នាក់ មកហើយ ប្រៀនប្រដៅថា ប្តីរបស់ពួកនាងមិនមានការខុស បានទទួលផលកម្មពីជាតិមុនរបស់ខ្លួន អ្នកទាំងឡាយកុំសោយសោក កុំបរិទេវនាការ កុំធ្វើការចងចិត្តអាក់អន់លើព្រះរាជា ។

ចារបុរសរបស់ព្រះរាជា ស្តាប់ពាក្យនោះហើយ ក្រាបទូលភាពដែលជនទាំងនោះ មិនមានទោសចំពោះព្រះរាជា ព្រះរាជាទ្រង់ដល់នូវការសង្វេគ យាងទៅកាន់និវេសន៍នាងមល្លិកានោះ ឲ្យនាងមល្លិកា និងកូនប្រសារបស់នាងអត់ទោសហើយ បានព្រះរាជទានពរដល់នាងមល្លិកា នាងក្រាបទូលថា ពរព្រះអង្គខ្ញុំម្ចាស់គ្រាន់តែទទួលទៅចុះ ។ កាលព្រះរាជាយាងទៅហើយ ថ្វាយកត្តជើម្បីអ្នកស្លាប់ ងូតទឹកហើយ ចូលគាល់ព្រះរាជាទូលថា បពិត្រព្រះអង្គ ទ្រង់ប្រទានពរដល់ខ្ញុំម្ចាស់ហើយ ម្យ៉ាងទៀត ខ្ញុំម្ចាស់មិនត្រូវការដោយរបស់ដទៃ សូមទ្រង់អនុញ្ញាតឲ្យកូនប្រសា ៣២ នាក់របស់ខ្ញុំម្ចាស់ និងខ្លួនខ្ញុំម្ចាស់ត្រឡប់ទៅកាន់ផ្ទះនៃត្រកូលចុះ ។

ព្រះរាជាទ្រង់ទទួលហើយ ។ នាងមល្លិកាបញ្ជូនកូនប្រសា ៣២ នាក់ទៅកាន់ត្រកូល រៀងៗ ខ្លួន ដោយខ្លួនឯង ចំណែកនាងបានទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួនក្នុងកុសិនារនគរ ។

ចំណែកព្រះរាជាបានព្រះរាជទានតំណែងសេនាបតី ដល់ទីឃការាយនៈ

ដែលត្រូវជាក្មួយរបស់ពន្ធុលសេនាបតី ។

ទីយការាយន:នោះ គ្រាច់ស្វែងរកទោសរបស់ព្រះរាជាដោយគិតថា អំរបស់អញត្រូវព្រះរាជាអង្គនេះឲ្យស្លាប់ហើយ ។ បានឮថា ចាប់តាំងអំពីពន្ធុល: មិនមានកំហុសត្រូវសម្លាប់ហើយ ព្រះរាជាទ្រង់មានវិប្បដិសារ: មិនបានទទួលនូវការសប្បាយព្រះហឫទ័យ មិនបានសោយសុខក្នុងរាជសម្បត្តិឡើយ ។

គ្រានោះ ព្រះសាស្តា ទ្រង់អាស្រ័យនិគមឈ្មោះមេទលុប: របស់ពួកស្តេចសក្យ:គង់នៅ ព្រះរាជាយាងទៅទីនោះហើយ ទ្រង់ឲ្យបោះព្រះពន្លាក្នុងទីមិនឆ្ងាយអំពីអារាម ហើយយាងទៅវិហារដោយបរិវារច្រើន ដោយទ្រង់ព្រះតម្រិះថា ទីឆ្ងាយបង្គំព្រះដ៏មានព្រះភាគ ព្រះរាជទានគ្រឿងរាជកកុធភណ្ឌទាំង ៥ ដល់ទីយការាយន:ហើយ ទ្រង់យាងមួយព្រះអង្គឯងប៉ុណ្ណោះ ចូលកាន់ព្រះគន្ធកុដិ ។ គប្បីជ្រាបរឿងទាំងអស់ ដោយទំនងនៃធម្មចេតិយសូត្រ កាលទ្រង់យាងចូលកាន់ព្រះគន្ធកុដិហើយ ទើបទីយការាយន:កាន់យកគ្រឿងរាជ-កកុធភណ្ឌទាំងនោះ ធ្វើវិឌូឌភ:ឲ្យជាព្រះរាជា បន្សល់នូវសេះមួយ និងស្រីបម្រើម្នាក់ ហើយបានត្រឡប់ទៅកាន់ក្រុងសាវត្ថី ។

ព្រះរាជាត្រាស់បិយកថាជាមួយព្រះសាស្តាហើយ ទ្រង់យាងចេញ ទ្រង់មិនឃើញសេនា ទើបត្រាស់សួរស្រីនោះ ទ្រង់ស្តាប់រឿងនោះហើយ ទ្រង់ព្រះតម្រិះថា អញនឹងនាំក្មួយរបស់អញទៅចាប់វិឌូឌភ: ដូច្នេះហើយ យាងទៅកាន់ក្រុងរាជគ្រឹះ ដល់ព្រះនគរ កាលព្រះនគរត្រូវគេបិទហើយក្នុងវេលាវិកាល ផ្ទំហើយក្នុងសាលាមួយកន្លែង ទ្រង់នឿយព្រះកាយពល ព្រោះខ្សល់ និងកម្តៅ

ថ្ងៃ បានសោយទិវង្គតក្នុងទីនោះឯង ក្នុងកណ្តាលរាត្រី ។ កាលរាត្រីអស់ហើយ មហាជនបានឮសំឡេងស្រីនោះយំសោកថា បពិត្រព្រះសម្មតិទេព ជាធំនៃអ្នកកោសល ទ្រង់មិនមានទីពឹងហើយ ទើបក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់ទទួល ឲ្យធ្វើសរីរកិច្ចរបស់ម្ចាស់អំពៅដោយសក្ការៈដ៏ធំ ។

ព្រះបាទវិឌូឌភៈបានរាជសម្បត្តិហើយ ទ្រង់រឭកដល់ពៀរនោះ ទ្រង់ព្រះតម្រិះថា អញនឹងញុំាងស្តេចសក្យៈទាំងអស់ឲ្យស្ងាប់ ដូច្នេះហើយ ទើបយាងចេញទៅដោយសេនាធំ ។ ក្នុងថ្ងៃនោះ ព្រះសាស្តាទ្រង់ប្រមើលមើលលោក ក្នុងពេលទៀបភ្លឺ ទ្រង់ឃើញការវិនាសនៃពួកញាតិហើយ ទ្រង់ព្រះតម្រិះថា តថាគតគួរធ្វើញាតិសង្គហៈ ក្នុងវេលាព្រឹកទ្រង់ត្រាច់ទៅដើម្បីបិណ្ឌបាត ត្រឡប់អំពីបិណ្ឌបាតហើយ ទ្រង់សម្រេចសីហសេយ្យាក្នុងព្រះគន្ធកុដិ ក្នុងពេលល្ងាច ទ្រង់យាងទៅតាមអាកាស ប្រថាប់ត្រង់គល់ឈើដែលមិនមានម្លប់ ជិតក្រុងកបិលពស្តុ ។ បន្ទាប់អំពីនោះទៅ មានដើមជ្រៃធំ មានម្លប់ត្រឈឹងត្រឈៃមួយដើម នៅក្នុងវជ្ជសីមារបស់ព្រះបាទវិឌូឌភៈ ។ ព្រះបាទវិឌូឌភៈ ទតឃើញព្រះសាស្តា ទើបយាងចូលទៅគាល់ ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី ទើបទ្រង់ប្រថាប់គង់ហើយ ត្រង់គល់ឈើដែលមានម្លប់សើងរើងនេះ ក្នុងវេលាក្តៅបែបនេះ សូមទ្រង់ប្រថាប់គង់ត្រង់គល់ជ្រៃ ដែលមានម្លប់ត្រជាក់ល្អនេះចុះ ។ កាលព្រះសាស្តាត្រាស់ឆ្លើយថា មហាបពិត្រ ណ្ហើយចុះ ឈ្មោះថា ម្លប់របស់ពួកញាតិ ជារបស់ត្រជាក់ ទើបព្រះរាជាទ្រង់ព្រះតម្រិះថា ព្រះសាស្តាទ្រង់យាងមកដើម្បីបំណងរក្សាពួកញាតិ

ទើបថ្វាយបង្គំព្រះសាស្តា យាងត្រឡប់ចូលកាន់ក្រុងសាវត្ថីនោះឯង ។ សូម្បីព្រះសាស្តាក៏ទ្រង់ហោះទៅកាន់វត្តជេតពនដូចគ្នា ។ ព្រះរាជាទ្រង់រឭកដល់ទោសាស្តេចសក្យៈ យាងចេញទៅហើយក្នុងលើកទី ២ ទតឃើញព្រះសាស្តាក្នុងទីនោះឯង ក៏យាងត្រឡប់ទៀត ។ ទ្រង់យាងទៅក្នុងលើកទី ៣ ទតឃើញព្រះសាស្តាក្នុងទីនោះឯង ក៏យាងត្រឡប់ ។ តែកាលព្រះបាទវិឌូឌភៈនោះយាងចេញទៅក្នុងគ្រាទី ៤ ព្រះសាស្តា ទ្រង់ពិចារណាឃើញបុព្វកម្មរបស់សក្យៈទាំងឡាយ ទ្រង់ជ្រាបភាពដែលកម្មលាមក គឺការបាចថ្នាំពុលក្នុងស្ទឹងរបស់ស្តេចសក្យៈទាំងនោះ ជាកម្មដែលបុគ្គលណាម្នាក់ មិនអាចឃាត់បាន មិនបានយាងចេញទៅក្នុងលើកទី ៤ ព្រះបាទវិឌូឌភៈយាងចេញទៅហើយដោយពលធំ ដោយត្រិះរិះថា អញនឹងសម្លាប់ស្តេចសក្យៈ ។

ព្រះញាតិទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធ ជាអ្នកមិនសម្លាប់សត្វ សូម្បីស្លាប់ ក៏មិនផ្តាច់ជីវិតរបស់សត្វដទៃ ។

សក្យៈទាំងនោះគិតថា ពួកយើងហ្វឹកហាត់ដៃហើយ មានគ្រឿងចងស៊កដែលធ្វើហើយ ជាអ្នកមានថ្វីដៃច្រើន តែពួកយើងមិនអាចសម្លាប់សត្វដទៃឲ្យឃ្លាតចាកជីវិតបាន ពួកយើងនឹងសម្តែងកម្មរបស់ខ្លួនឲ្យគេចទៅ ។ស្តេចសក្យៈទាំងនោះទ្រង់មានគ្រឿងក្រោះដែលធ្វើហើយ ទើបយាងចេញធ្វើការប្រយុទ្ធ ។ ព្រួញដែលស្តេចសក្យៈទាំងនោះបាញ់ទៅ ទៅតាមចន្លោះៗ ពួកបុរសរបស់ព្រះបាទវិឌូឌភៈ ចេញទៅតាមប្រហោងខែល និងប្រឡោះត្រចៀកជាដើម ព្រះបាទវិឌូឌភៈទតឃើញ ទើបត្រាស់ថា អ្នកទាំងឡាយ ស្តេចសក្យៈត្រាស់ថា ពួក

យើងជាអ្នកមិនសម្លាប់សត្វមិនមែនឬ កាលបើដូច្នេះ ហេតុអ្វី ទើបពួកស្តេចសក្យៈបាញ់បុរសរបស់ពួកយើងឲ្យវិនាស ។ លំដាប់នោះ បុរសម្នាក់ក្រាបទូលព្រះបាទវិឌូឌភៈនោះថា បពិត្រព្រះអង្គ ព្រះអង្គទ្រង់ពិនិត្យមើលហើយឬ ព្រះបាទវិឌូឌភៈត្រាស់ថា ពួកស្តេចសក្យៈញុំាងបុរសរបស់យើងឲ្យវិនាស ។ ពួកបុរសពោលថា បុរសណាម្នាក់របស់ព្រះអង្គ ឈ្មោះថា ស្លាប់ហើយ មិនមាន សូមទ្រង់ឲ្យរាប់បុរសទាំងនោះចុះ ។

ព្រះបាទវិឌូឌភៈកាលបញ្ជាឲ្យរាប់ ទ្រង់មិនឃើញបាត់ត្រឹមតែម្នាក់ ។ទ្រង់យាងត្រឡប់អំពីទីនោះហើយត្រាស់ថា នែអ្នក បុគ្គលណាម្នាក់ជ្រាបថា ពួកយើងជាស្តេចសក្យៈ អ្នកទាំងឡាយ ចូរសម្លាប់អ្នកទាំងអស់នោះ តែចូរឲ្យជីវិតដល់បុគ្គលដែលឈរនៅក្នុងសម្នាក់របស់សក្យមហានាម ដែលជាអយ្យកោរបស់យើង ។

ស្តេចសក្យៈទាំងឡាយ មិនបានឃើញគ្រឿងដែលខ្លួនគប្បីកាន់យក ពួកខ្លះវែកស្មៅ ពួកខ្លះ ឈរកាន់ដើមបបុស ។ ត្រូវសួរថា ពួកអ្នកជាស្តេចសក្យៈ ឬមិនមែន ព្រោះសក្យៈទាំងនោះសូម្បីស្លាប់ ក៏មិនពោលពាក្យកុហក ពួកដែលវែកស្មៅពោលថា មិនមែនសក្យៈ គឺស្មៅ ពួកដែលឈរកាន់ដើមបបុស ពោលថា មិនមែនសក្យៈ គឺបបុស ស្តេចសក្យៈទាំងនោះឯង សក្យៈណាដែលឈរនៅក្នុងសម្នាក់របស់ស្តេចមហានាម បានរួចជីវិតហើយ ។

បណ្តាស្តេចសក្យៈទាំងនោះ ស្តេចសក្យៈដែលវែកស្មៅ ឈ្មោះថា សក្យៈស្មៅ ពួកដែលឈរកាន់ដើមបបុស ឈ្មោះថា សក្យៈបបុស ។

ព្រះបាទវិឌូឌភៈ បញ្ជាឲ្យសម្លាប់សក្យៈដ៏សេសទាំងឡាយ មិនទុកសូម្បីទារកដែលនៅបៅដោះ ញាំងស្ទឹង គឺឈាមឲ្យហូរទៅ ហើយបញ្ជាឲ្យលាងបន្ទះក្តារអង្គុយ ដោយឈាមក្នុងបំពង់កស្តេចសក្យៈទាំងនោះ ។

សក្យវង្ស ដែលព្រះបាទវិឌូឌភៈចូលទៅកាត់ គឺផ្តាច់វង្សហើយ ដោយអាការយ៉ាងនេះ ។ ព្រះបាទវិឌូឌភៈនោះ បញ្ជាឲ្យចាប់ស្តេចសក្យមហានាមយាងត្រឡប់ហើយ ក្នុងពេលសោយអាហារព្រឹក ទ្រង់ព្រះតម្រិះថា អញនឹងសោយអាហារព្រឹក ដូច្នេះហើយ ទ្រង់ឈប់ក្នុងទីមួយកន្លែង កាលភោជនដែលបុគ្គលនាំចូលទៅហើយ ត្រាស់ឲ្យហៅព្រះអយ្យកោមក ដោយព្រះតម្រាស់ថា នឹងសោយរួមគ្នា ។

តែក្សត្រទាំងឡាយ ទោះបីលះបង់ជីវិត ក៏មិនព្រមសោយរួមជាមួយកូននាងទាសី ព្រោះដូច្នោះ ស្តេចមហានាមទតឃើញស្រះមួយ ទើបត្រាស់ថា ខ្ញុំមានរាងកាយស្មោកគ្រោក ខ្ញុំនឹងងូតទឹក ។ ព្រះបាទវិឌូឌភៈត្រាស់ថា ប្រពៃណាស់ ព្រះអយ្យកោ សូមទ្រង់ស្រង់ចុះ ព្រះបាទមហានាមទ្រង់ព្រះតម្រិះថា វិឌូឌភៈនេះ ទោះបីសម្លាប់អញ ក៏អញមិនបរិភោគរួម ការស្លាប់ឯងរបស់អញ ប៉ុណ្ណោះប្រសើរជាង ដូច្នេះហើយ ទើបទ្រង់រំសាយសក់ យកមេជើងស៊ក ចូលទៅក្នុងសក់ ចងឲ្យជាកំណួចត្រង់ចុង ប្រមៀលចុះទៅក្នុងទឹក ។

ចំណែកតេជៈ នៃគុណរបស់ស្តេចមហានាមនោះ នាគពិភពក៏សម្តែងអាការក្តៅ ស្តេចនាគពិចារណាថា រឿងអ្វីហ្ន៎ ហើយទើបមកកាន់សម្នាក់របស់ស្តេចមហានាមនោះ ឲ្យស្តេចមហានាមប្រថាប់លើពពារ ហើយយាងទៅកាន់

នាគពិភព ។ ព្រះបាទមហានាមនោះឯង នៅក្នុងភពនាគនោះអស់ ១២ ឆ្នាំ ។

ចំណែកព្រះបាទវិឌូឌភៈ ប្រថាប់គង់រង់ចាំដោយព្រះតម្រិះថា ព្រះអយ្យកោរបស់អញនឹងមកក្នុងឥឡូវនេះ កាលព្រះបាទមហានាមទ្រង់យឺតយូរ ទើបបញ្ជាឲ្យមើលក្នុងស្រះ ពិនិត្យមើលរវាងបុរសដោយពន្លឺប្រទីប មិនឃើញហើយក៏ចៀសចេញទៅ ដោយទ្រង់ព្រះតម្រិះថា ព្រះអយ្យកោយាងទៅហើយ ។

ព្រះបាទវិឌូឌភៈយាងដល់ស្ទឹងអចិរវតីក្នុងពេលរាត្រី បញ្ជាឲ្យបោះព្រះពន្ធាហើយ ។ បុគ្គលពួកខ្លះដេកហើយត្រង់ឆ្នេរខ្សាច់ខាងក្នុងស្ទឹង ពួកខ្លះដេកលើគោកខាងក្រៅ ។ បណ្តាជនដែលដេកហើយខាងក្នុង ជនដែលមានបាបកម្មមិនបានធ្វើហើយក្នុងកាលមុនមាន ។ បណ្តាជនដែលដេកហើយខាងលើ ដែលមានបាបកម្មបានធ្វើហើយក្នុងកាលមុនមាន ស្រមោចភ្លើងទាំងឡាយប្រាកដឡើងហើយ ក្នុងទីដែលមនុស្សទាំងនោះដេកហើយ ។

ជនទាំងនោះពោលថា ស្រមោចក្រហមប្រាកដឡើងហើយក្នុងទីដែលខ្ញុំដេក ស្រមោចក្រហមប្រាកដឡើងហើយក្នុងទីដែលខ្ញុំដេក ទើបក្រោកឡើង ។ ពួកជនដែលមានបាបកម្មមិនបានធ្វើ ក្រោកឡើងទៅដេកខាងលើគោក ពួកជនមានបាបកម្មបានធ្វើហើយ ចុះទៅដេកលើឆ្នេរខ្សាច់ ។

ខណៈនោះ មហាមេឃតាំងឡើង ញាំងភ្លៀងធំឲ្យធ្លាក់ហើយ ទឹកជំនន់ហូរមកញាំងព្រះបាទវិឌូឌភៈ មួយអន្ទើដោយបរិស័ទឲ្យដល់សមុទ្រហើយនោះឯង ។ ជនទាំងអស់បានជាចំណីត្រី និងអណ្តើកក្នុងសមុទ្រនោះហើយ ។ មហាជនញាំងកថាឲ្យតាំងឡើងថា ការស្លាប់របស់ស្តេចសក្យៈទាំងឡាយ មិន

សមគួរសោះ ការស្លាប់នេះ គឺពួកសក្យៈដែលព្រះបាទវិឌូឌភៈវាយហើយ យ៉ាងនេះឲ្យស្លាប់ ទើបមិនសមគួរ ។

ព្រះសាស្តាស្តាប់ពាក្យនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការស្លាប់យ៉ាងនេះ មិនសមគួរដល់ស្តេចសក្យៈទាំងឡាយ ក្នុងអត្តភាពនេះ ក៏ពិត តែការស្លាប់ដែលពួកស្តេចសក្យៈទាំងនោះបានហើយ ក៏គួរដោយពិត ដោយអំណាចនៃកម្មលាមក ដែលបានធ្វើក្នុងកាលមុន ។

ភិក្ខុទាំងឡាយពោលថា បពិត្រព្រះអង្គ ស្តេចសក្យៈទាំងឡាយនោះ បានធ្វើកម្មអ្វីក្នុងកាលមុន ព្រះសាស្តាត្រាស់ថា ក្នុងកាលមុន ស្តេចសក្យៈនោះ រួមគ្នាជាពួក បាចថ្នាំពុលក្នុងស្ទឹង ។

ស្អែកឡើង ភិក្ខុទាំងឡាយ ញុំាងកថាឲ្យតាំងឡើងក្នុងរោងធម្មសភាថា ព្រះបាទវិឌូឌភៈញុំាងស្តេចសក្យៈទាំងឡាយ ប្រមាណប៉ុណ្ណេះឲ្យស្លាប់ហើយ យាងមក កាលមនោរថរបស់ខ្លួនដល់ទីបំផុតហើយនោះឯង នាំជនមានប្រមាណប៉ុណ្ណោះទៅ កើតជាចំណីនៃត្រី និងអណ្តើកក្នុងសមុទ្រហើយ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលមនោរថរបស់សត្វទាំងនោះ មិនដល់ទីបំផុតនោះឯង មច្ចុរាជផ្តាច់ជីវិតន្ទ្រិយហើយ ឲ្យលិចចុះក្នុងមហាសមុទ្រ គឺអបាយ ៤ ដូចជនទន់ទឹកធំកួចអ្នកស្រុកដែលដេកលក់ដូច្នោះដូច្នេះហើយ ទើបទ្រង់ត្រាស់គាថានេះថា

បុថ្ជានិ ហោវ បចិនន្តំ ព្យាសត្តមនសំ នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ជតិ ។

មច្ចុ គឺសេចក្តីស្លាប់ តែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កាគឺកាមគុណ ៥ នោះឯង ដូចទឹកជំនន់ធំ ដែលកួចយកអ្នកស្រុក កំពុងដេកលក់ទៅ ដូច្នោះឯង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **ព្យាសត្តមនសំ នរំ** *សេចក្តីថា បុគ្គលមានចិត្តជាប់ជំពាក់ហើយ ក្នុងអារម្មណ៍ដែលដល់ព្រមហើយ ឬមិនទាន់ដល់ព្រម ។*

ព្រះដ៏មានព្រះភាគ ត្រាស់ពាក្យអធិប្បាយនេះថា នាយមាលាការចូលទៅកាន់សួនផ្កា គិតថា នឹងបេះផ្កាទាំងឡាយ ហើយមិនបេះយកផ្កាអំពីក្នុងសួននោះ ប្រាថ្នាគុម្ពដទៃៗ ឈ្មោះថា បញ្ជូនចិត្តទៅក្នុងសួនផ្កាទាំងអស់ ឬគិតថា អញនឹងបេះផ្កាអំពីគុម្ពនេះ ហើយមិនបេះយកផ្កាអំពីគុម្ពនោះ បញ្ជូនចិត្តទៅក្នុងទីដទៃ ជ្រើសរើសនូវគុម្ពឈើនោះឯង ឈ្មោះថា ដល់នូវការប្រមាទ យ៉ាងណា នរៈពួកខ្លះក៏ដូច្នោះដូចគ្នា ឈមចុះក្នុងកណ្តាលកាមគុណ ៥ ដូចគ្នានឹងសួនផ្កា បានរូបដែលគាប់ចិត្តហើយ ប្រាថ្នាក្លិន រស ផោដ្ឋព្ធៈ ដែលជាទីពេញចិត្តណាមួយ ឬបានបណ្តាអារម្មណ៍ មានសំឡេងជាដើមនោះណាមួយហើយ គង់ប្រាថ្នាអារម្មណ៍ណាមួយទៀត ឬបានរូបនោះឯងហើយ

គង់ប្រាថ្នាអារម្មណ៍ណាមួយ ឈ្មោះថា រមែងត្រេកអរក្នុងអារម្មណ៍នោះឯង ឬបានបណ្តាអារម្មណ៍ មានសំឡេងជាដើមណាមួយ ហើយប្រាថ្នាអារម្មណ៍ណាមួយ ឈ្មោះថា រមែងត្រេកអរក្នុងអារម្មណ៍ដែលខ្លួនបានហើយនោះ ។ ក្នុងសវិញ្ញាណកទ្រព្យ និងអវិញ្ញាណកទ្រព្យ មានគោ ក្របី ទាសី ទាសៈ ស្រែ ចម្ការ ស្រុក និគម និងជនបទជាដើម ក៏មានន័យនោះឯង ។ ក្នុងបរិវេណវិហារ និងបច្ចយ មានបាត្រ និងចីវរជាដើម របស់បព្វជិត ក៏នយ័នោះដូចគ្នា មច្ចុ រមែងនាំនរជនដែលមានចិត្តជាប់ជំពាក់ក្នុងកាមគុណ ដែលដល់ព្រមហើយ ឬមិនទាន់ដល់ព្រមហើយ ដែលកំពុងជ្រើសរើសនូវផ្កាពោល គឺកាមគុណ ៥ យ៉ាងនេះ ដោយប្រការដូច្នេះ ។

ពីរបទថា **សុត្តំ គាមំ** *សេចក្តីថា ឈ្មោះថា ការដេកលក់ដោយអំណាចការដេកលក់នៃទព្វសម្ភារៈទាំងឡាយ មានជញ្ជាំងផ្ទះជាដើមនៃស្រុក មិនមាន តែស្រុក ឈ្មោះថា លក់ហើយ ព្រោះប្រៀបធៀបភាពដែលសត្វទាំងឡាយជាអ្នកប្រមាទហើយ ហាក់ដូចជាដេកលក់ហើយ មច្ចុនាំនរជនទៅ ដូចជំនន់ទឹកធំ និងជម្រៅ ២-៣ យោជន៍ កួចអ្នកស្រុកដែលដេកលក់ហើយយ៉ាងនោះទៅដូច្នោះ គឺថា ជំនន់ទឹកធំនោះ ញាំងអ្នកស្រុកទាំងអស់នោះ មិនឲ្យសត្វណាម្នាក់ ក្នុងបណ្តាស្ត្រី បុរស គោ ក្របី និងមាន់ជាដើម ឲ្យសល់មួយ ឲ្យដល់មហាសមុទ្រហើយ ធ្វើឲ្យជាចំណីរបស់ត្រី និងអណ្តើក យ៉ាងណា មច្ចុរាជ គឺសេចក្តីស្លាប់ នាំនរៈដែលមានចិត្តជាប់ជំពាក់ហើយ ក្នុងអារម្មណ៍ផ្សេងៗ គឺកាត់នូវជីវិតិន្ទ្រិយរបស់នរៈនោះ ឲ្យលិចចុះក្នុងសមុទ្រ គឺ*

អបាយទាំង ៤ ក៏ដូច្នេះដូចគ្នា ។ ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ទេសនាមានប្រយោជន៍ដល់មហាជនដូច្នេះឯង ។

រឿង ព្រះចាធវិឌូឌភ: ចប់

រឿង នាងបតិបូជិកា

លំនាំដើម

ព្រះមានព្រះភាគ កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធស្រីឈ្មោះបតិបូជិកា ត្រាស់ព្រះធម្មទេសនានេះថា **បុច្ឆានិ ហោវ** ជាដើម ។ រឿងកើតឡើងក្នុងតាវត្តិង្សទេវលោក ។

បានឲ្យថា ទេវបុត្រឈ្មោះមាលាភេរី ក្នុងតាវត្តិង្សទេវលោកនោះ មានស្រីទេពអប្សរមួយពាន់ចោមរោមហើយ ទៅកាន់ឧទ្យាន ។ ទេពធីតា ៥០០ ឡើងកាន់ដើមឈើ ញ្ចាំងផ្ការឲ្យធ្លាក់ចុះ ទេពធីតា ៥០០ រើសយកផ្ការដែលទេពធីតា ៥០០ នោះឲ្យធ្លាក់ហើយ ប្រដាប់ទេវបុត្រ ។ បណ្តាទេពធីតាទាំងនោះ ទេពធីតាមួយអង្គចុតិលើមែកឈើនោះឯង សរីរៈរលត់ទៅដូចអណ្តាតប្រទីប នាងបដិសន្ធិក្នុងផ្ទះនៃត្រកូលមួយ ក្នុងក្រុងសាវត្ថី ក្នុងកាលដែលនាងកើតហើយ ជាស្រីរឲ្យកជាតិបាន រឲ្យកថា អញជាភរិយារបស់មាលាភេរីទេវ-បុត្រ ដល់នូវការចម្រើន ធ្វើការបូជាដោយគ្រឿងក្រអូប និងផ្ការជាដើម ប្រាថ្នា

ការកើតចំពោះក្នុងសម្នាក់ប្តី សូម្បីនាងទៅកាន់ត្រកូលដទៃ ។ ក្នុងកាលមានអាយុ ១៦ ឆ្នាំ ថ្វាយសលាកភត្ត បក្ខិកភត្ត និងវស្សាវាសិកភត្តជាដើមហើយ រមែងពោលថា ដោយចំណែកនៃបុណ្យនេះ សូមជាបច្ច័យដើម្បីជាប្រយោជន៍ដល់ការកើតឡើងក្នុងសម្នាក់ប្តីខ្ញុំ ។

លំដាប់នោះ ភិក្ខុទាំងឡាយជ្រាបថា ស្រីនេះក្រោកឡើងស្រេចបាច់ហើយ រមែងប្រាថ្នាប្តីប៉ុណ្ណោះ ទើបដាក់ឈ្មោះថា បតិបូជិកា ។

នាងបតិបូជិកានោះ រមែងបដិបត្តិរោងធាន់ ចូលទៅតម្កល់ទឹកធាន់ ក្រាលអាសនៈជានិច្ច ។ មនុស្សពួកជដទៃប្រាថ្នាដើម្បីថ្វាយសលាកភត្តជាដើម នាំមកប្រគល់ឲ្យដោយពាក្យថា នែនាង ចូរនាងចាត់ចែងភត្តនេះដល់ភិក្ខុសង្ឃ នាងដើរទៅដើរមកដោយទំនងនោះ បានកុសលធម៌ ៥៦ គ្រប់ជំហាន នាងមានគភ៌ហើយ នាងក៏ប្រសូតបុត្រដោយកាលកន្លងទៅ ១០ ខែ ។ ក្នុងកាលកូននោះដើរបាន នាងក៏បានកូនដទៃៗ រួមជា ៤ នាក់ ។ ក្នុងថ្ងៃមួយ នាងថ្វាយទានធ្វើការបូជា ស្តាប់ធម៌ រក្សាសិក្ខាបទក្នុងកាលជាទីបំផុតនៃថ្ងៃ ធ្វើកាលកិរិយាដោយរោគឯណានីមួយ ដែលកើតឡើងក្នុងខណៈនោះ ហើយបដិសន្ធិក្នុងសម្នាក់ប្តីរបស់ខ្លួន ។

ចំណែកទេពធីតាក្រៅអំពីនេះ កំពុងប្រដាប់នោះឯង អស់កាលមានប្រមាណប៉ុណ្ណោះ ទេវបុត្រឃើញទេពអប្សរនោះពោលថា នាងបាត់មុខតាំងអំពីព្រឹក នាងទៅទីណា ទេពធីតាពោលថា បពិត្រអ្នក ខ្ញុំចុតិ ទេវបុត្រពោលថា នាងនិយាយអ្វី ទេពធីតាពោលថា សេចក្តីនោះយ៉ាងនេះ ទេវបុត្រ

ពោលថា នាងកើតហើយក្នុងទីណា ទេពធីតាពោលថា កើតក្នុងផ្ទះនៃត្រកូលក្នុងក្រុងសាវត្ថី ទេវបុត្រពោលថា នាងតាំងនៅក្នុងក្រុងសាវត្ថីនោះ អស់កាលមានប្រមាណប៉ុណ្ណា ទេពធីតាពោលថា បពិត្រអ្នក ខ្ញុំកើតអំពីផ្ទៃមាតាដោយកាលកន្លងទៅ ១០ ខែ ក្នុងកាលអាយុ ១៦ ឆ្នាំ ទៅកាន់ត្រកូលប្តីប្រសូតបុត្រ ៤ នាក់ ធ្វើបុណ្យ មានឲ្យទានជាដើម ប្រាប់ដល់អ្នក មកកើតហើយក្នុងសម្នាក់របស់អ្នកវិញ ទេវបុត្រពោលថា អាយុរបស់មនុស្ស មានប្រមាណប៉ុនណា ទេពធីតាពោលថា ប្រមាណមួយរយឆ្នាំ ទេវបុត្រពោលថា ប៉ុណ្ណោះឯងឬ ទេពធីតាពោលថា ពិតហើយអ្នក ទេវបុត្រពោលថា ពួកមនុស្សកាន់យកអាយុប្រមាណប៉ុណ្ណោះ កើតហើយ ជាអ្នកប្រមាទ ដូចដេកលក់ ញាំងកាលឲ្យកន្លងទៅឬ ឬធ្វើបុណ្យ មានទានជាដើម ទេពធីតាពោលថា អ្នកនិយាយអ្វី ពួកមនុស្សប្រមាទជានិច្ច ប្រៀបដូចអាយុរាប់អស់ឆ្នើយ្យ កើតហើយ ហាក់បីដូចជាមិនចាស់ មិនស្លាប់ ។

ការសង្វេគជាខ្លាំង បានកើតឡើងដល់មាលាកេរីទេវបុត្រថា បានឮថា ពួកមនុស្សកាន់យកអាយុប្រមាណមួយរយឆ្នាំ កើតហើយ ប្រមាទ ដូចដេកលក់ កាលណាហ្ន៎ ទើបផុតចាកទុក្ខបាន ។

១០០ ឆ្នាំរបស់ពួកយើងជា ១ យប់ ១ ថ្ងៃរបស់ពួកទេវតាជាន់តាវត្តិង្ស ៣០ រាត្រីជា ១ ខែ កំណត់ដោយ ១២ ខែ ដោយខែនោះជា ១ ឆ្នាំ ១ ពាន់ឆ្នាំទិព្វដោយឆ្នាំនោះ ជាប្រមាណអាយុរបស់ទេវតាជាន់តាវត្តិង្ស ១ ពាន់ឆ្នាំទិព្វនោះ ដោយការរាប់ក្នុងមនុស្សជា ៣ កោដិ ៦ លានឆ្នាំ ។

ព្រោះដូច្នោះ ១ ថ្ងៃរបស់ទេវបុត្រនោះ ក៏មិនទាន់កន្លងទៅ ប្រៀបដូចកាលមួយសម្លុះប៉ុណ្ណោះ ។ ឈ្មោះថា ការប្រមាទរបស់សត្វដែលមានអាយុតិចបែបនេះ មិនគួរយ៉ាងក្រៃលែង ដូច្នេះ ។

ក្នុងថ្ងៃស្អែកឡើង ពួកភិក្ខុចូលទៅកាន់ស្រុក ឃើញរោងធាន់មិនទាន់រៀបចំអាសនៈ មិនទាន់ក្រាល ទឹកធាន់មិនទាន់បានតម្កល់ ទើបពោលថា នាងបតិបូជិកាទៅណា អ្នកស្រុកពោលថា បពិត្រលោកម្ចាស់ យើងទាំងឡាយឃើញនាងក្នុងទីណា មរ្យៃលមិញ្ញនេះ កាលលោកម្ចាស់ធាន់ហើយ ត្រឡប់ទៅ នាងស្លាប់ក្នុងពេលល្ងាច ។

ភិក្ខុបុថុជ្ជនស្តាប់ពាក្យនោះហើយ រឭកដល់ឧបការៈរបស់នាងនោះ មិនអាចទប់ទឹកភ្នែកបាន ធម្មសង្វេគកើតដល់ព្រះខីណាស្រព ភិក្ខុទាំងនោះធ្វើភត្តកិច្ចហើយ ទៅវិហារថ្វាយបង្គំព្រះសាស្តាទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ឧបាសិកាឈ្មោះបតិបូជិកា ក្រោកឡើងស្រួលបួលហើយ ធ្វើបុណ្យមានប្រការផ្សេងៗ ប្រាថ្នាដល់ប្តីប៉ុណ្ណោះ ឥឡូវនេះ នាងស្លាប់ហើយ ទៅកើតក្នុងទីណា ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នាងកើតក្នុងសម្នាក់ប្តីរបស់នាងនោះឯង ភិក្ខុទាំងឡាយពោលថា បពិត្រព្រះអង្គ ក្នុងសម្នាក់ប្តីមិនមាន ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នាងប្រាថ្នាដល់ប្តីនោះ ក៏មិនមែន មាលាកេរីទេវបុត្រក្នុងតាវត្តិង្សពិភព ជាប្តីរបស់នាង នាងឃ្លាតចាកទីប្រជាប់ផ្ការបស់ប្តីនោះហើយ ទៅកើតក្នុងសម្នាក់ប្តីនោះឯងទៀត ភិក្ខុទាំងឡាយពោលថា បពិត្រព្រះអង្គ យ៉ាងនោះឬ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ

ទាំងឡាយ យ៉ាងនោះឯង ។ ភិក្ខុទាំងឡាយពោលថា គួរសង្វេគ ជីវិតរបស់សត្វទាំងឡាយ មានប្រមាណតិច នាងអង្គាសខ្ញុំព្រះអង្គក្នុងពេលព្រឹក ពេលល្ងាចស្លាប់ដោយព្យាធិដែលកើតឡើង ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំង-ទ្ឡាយ យ៉ាងនោះឯង ឈ្មោះថា ជីវិតរបស់សត្វទាំងឡាយតិច ហេតុនោះឯង មច្ចុដែលធ្វើនូវទីបំផុត ញុំាងសត្វទាំងនេះ ដែលមិនឆ្អែតដោយវត្ថុកាម និង កិលេសកាមនោះឯង ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនហើយ រមែងកួច យកសត្វដែលកន្ទក់កន្ទេញទៅ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

បុច្ឆាមិ ហោ បចិឆន្តំ ព្យាសត្តមនសំ នរំ
អតិត្តំយេវ កាមេសុ អន្តកោ កុរុតេ វសំ ។

អ្នកធ្វើទីបំផុត គឺមរណៈ តែងក្រុងសត្វដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាម-គុណ ៥ មិនឆ្អែតឆ្អន់ក្នុងកាមទាំងឡាយនោះឯង ឲ្យនៅក្នុងអំណាចរបស់ខ្លួន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ជាទព្រះគាថា **បុច្ឆាមិ ហោ បចិឆន្តំ** *សេចក្តីថា បុគ្គលរវៀរជ្រើសរើសនូវផ្កា គឺកាមគុណទាំងឡាយ ដែលទាក់ទងដោយអត្តភាព និងទាក់ទងដោយគ្រឿងឧបករណ៍ ដូចនាយមាលាការជ្រើសរើសនូវផ្កាច្រើនប្រភេទ ក្នុងសួនផ្កា ដូច្នោះ ។*

ជាទព្រះគាថាថា **ព្យាសត្តមនសំ នរំ** *សេចក្តីថា បុគ្គលមានចិត្តរាយមាយ*

ទៅដោយអាការផ្សេងៗ ក្នុងអារម្មណ៍ដែលមិនទាន់មកដល់ហើយ ដោយអំណាចនៃសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ដែលដល់ហើយ ដោយអំណាចនៃសេចក្តីត្រេកអរ ។

បាទព្រះគាថាថា **អតិត្តំយេវ កាមេសុ** *សេចក្តីថា បុគ្គលមិនឆ្អែតក្នុងវត្ថុកាម និងកិលេសកាមទាំងឡាយនោះឯង ដោយការស្វែងរកខ្លះ ដោយការបានចំពោះខ្លះ ដោយការប្រើប្រាស់ខ្លះ ដោយការរក្សាខ្លះ ។*

បាទព្រះគាថាថា **អន្តកោ កុរុតេ វសំ** *សេចក្តីថា មច្ចុដែលធ្វើនូវទីបំផុតពោល គឺមរណៈ នាំនរៈដែលកន្ទក់កន្ទេញទៅ ឲ្យដល់នូវអំណាចនៃខ្លួន ។*

ក្នុងពេលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ៕

រឿង ឆាឆបតិបូជិកា ចប់

រឿង កោសិយសេដ្ឋី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះកោសិយៈ ជាអ្នកមានសេចក្តីកំណាញ់ ត្រាស់ព្រះធម្មទេសនានេះថា **យថាបិ ភមរោ បុប្ផំ** *ជាដើម ។ រឿងនេះ កើតឡើងក្នុងក្រុងរាជគ្រឹះ ។*

បានឮមកថា ក្នុងទីមិនឆ្ងាយអំពីក្រុងរាជគ្រឹះ មានឧគមឈ្មោះសក្ករៈ

សេដ្ឋីម្នាក់ឈ្មោះកោសិយៈ មានសេចក្តីកំណាញ់ មានសម្បត្តិ ៨០ កោដិ នៅក្នុងនិគមនោះ ។ គាត់មិនឲ្យតំណាក់ប្រេង សូម្បីត្រឹមមួយតំណាក់ដែលជ្រលក់ ដោយចុងស្មៅដល់អ្នកដទៃ ។ ទាំងមិនបរិភោគដោយខ្លួនឯង ។ សម្បត្តិរបស់គាត់មិនមានប្រយោជន៍ដល់បិយជនទាំងឡាយ មានកូន និងប្រពន្ធជាដើម មិនមានប្រយោជន៍ដល់សមណ :និងព្រាហ្មណ៍ទាំងឡាយ នៅជារបស់មិនបានប្រើប្រាស់ តាំងនៅដូចស្រះបោក្ខរណី ដែលមានអារក្សទឹកហួងហែង ដោយប្រការដូច្នេះឯង ។

ថ្ងៃមួយ វេលាបច្ចូសសម័យ ព្រះសាស្តាយាងចេញអំពីសមាបត្តិ ដែលប្រកបដោយសេចក្តីករុណាធំ ទ្រង់ប្រមើលមើលសត្វដែលជាផៅពង្ស ដែលលួមទួន្ទានក្នុងការគ្រាស់ជីងបាន នៅក្នុងសកលលោកធាតុ ទ្រង់បានឃើញឧបនិស្ស័យសោតាបត្តិផលរបស់សេដ្ឋី ព្រមទាំងភរិយាក្នុងទីចម្ងាយ ៤៥ យោជន៍ ។ ក្នុងថ្ងៃមុនអំពីនោះ សេដ្ឋីនោះទៅកាន់ព្រះរាជមន្ទីរ ដើម្បីគាល់ព្រះរាជា ធ្វើការបម្រើព្រះរាជាហើយត្រឡប់មក ឃើញមនុស្សស្រុកក្រៅម្នាក់ត្រូវសេចក្តីឃ្លានគ្របសង្កត់ កំពុងបរិភោគនំកុម្មាស គឺនំអំបែង ឲ្យកើតសេចក្តីស្រេកឃ្លានក្នុងនំនោះ ទ្បើងទៅកាន់ផ្ទះរបស់ខ្លួនហើយ គិតថា បើអញប្រាប់ថា ចង់បរិភោគនំអំបែងសោត មនុស្សជាច្រើន ក៏នឹងនាំគ្នាចង់បរិភោគជាមួយអញយ៉ាងនោះ វត្ថុជាច្រើន មានល្អ អង្ករ សប្បិ ទឹកអំពៅជាដើមរបស់អញ ក៏នឹងដល់នូវការអស់ទៅ ។ អញនឹងមិនប្រាប់ដល់បុគ្គលណាម្នាក់ដូច្នេះហើយ អត់សង្កត់នូវចំណង់ត្រាច់ទៅ កាលវេលាកន្លងទៅគាត់ក៏ស្គម

លឿងជាលំដាប់ មានខ្លួនរវាមដោយសរសៃ បន្ទាប់អំពីនោះ មិនអាចអត់សង្កត់នូវចំណង់បាន ចូលបន្ទប់ហើយ ដេកឱបត្រែ ។ គាត់សូម្បីដល់សេចក្តីទុក្ខយ៉ាងនេះ ក៏មិនប្រាប់អ្វីដល់បុគ្គលណាម្នាក់ ព្រោះខ្លាចវិនាសទ្រព្យ ។

លំដាប់នោះ ភរិយាចូលទៅរកគាត់ អង្អែលខ្នងសួរថា អ្នកមានជំងឺឬ សេដ្ឋីពោលថា ជំងឺរបស់ខ្ញុំណាមួយមិនមាន ភរិយាពោលថា ព្រះរាជាទ្រង់ពិរោធនឹងអ្នកឬ សេដ្ឋីពោលថា សូម្បីព្រះរាជាក៏មិនពិរោធនឹងខ្ញុំ ភរិយាពោលថា បើយ៉ាងនោះការមិនពេញចិត្តណាមួយ ដែលពួកកូនប្រុសកូនស្រី ឬបរិជនមានទាសកម្មករជាដើម ធ្វើដល់អ្នកមានឬ សេដ្ឋីពោលថា សូម្បីកម្មបែបនោះក៏មិនមាន ភរិយាសួរថា អ្នកមានចំណង់ក្នុងអ្វីឬ ។ ទោះបីភរិយាពោលយ៉ាងនោះ គាត់ក៏មិនពោលពាក្យណាមួយ ដេកស្ងាត់សំឡែងព្រោះខ្លាចអស់ទ្រព្យ ។

លំដាប់នោះ ភរិយាពោលនឹងគាត់ថា នែអ្នក សូមប្រាប់ចុះ អ្នកចង់បរិភោគអ្វី ។ សេដ្ឋីនោះលេបពាក្យ ឆ្លើយថា ខ្ញុំមានចំណង់ ភរិយាសួរថា តើអ្នកចង់បរិភោគអ្វី សេដ្ឋីពោលថា ខ្ញុំចង់សុីនំអំបែង ភរិយាពោលថា បើដូច្នោះ ហេតុអ្វីមិនប្រាប់ដល់ខ្ញុំ អ្នកជាបុគ្គលក្រីក្រឬ ឥឡូវនេះ ខ្ញុំនឹងចៀននំអំបែងឲ្យដល់មនុស្សដែលនៅក្នុងសក្ករនិគមទាំងអស់ សេដ្ឋីពោលថា ប្រយោជន៍អ្វីរបស់នាង ដោយជនទាំងនោះ ពួកគេធ្វើការរបស់ខ្លួន នឹងសុីរបស់ខ្លួន ។ ភរិយាពោលថា បើដូច្នេះ ខ្ញុំនឹងចៀននំអំបែង ឲ្យដល់មនុស្សដែលនៅក្នុងច្រកជាមួយគ្នា សេដ្ឋីពោលថា ខ្ញុំដឹងថា នាងជាអ្នកមានទ្រព្យហើយ ភរិយាពោលថា ខ្ញុំនឹងចៀនឲ្យគ្រប់គ្រាន់ដល់មនុស្សទាំងអស់ ដែលនៅក្នុងទីជិតផ្ទះ

នេះ សេដ្ឋីពោលថា ខ្ញុំដឹងថា នាងជាអ្នកមានអធ្យាស្រ័យទូលាយហើយ ភរិយាពោលថា បើដូច្នោះ ខ្ញុំនឹងចៀនឲ្យគ្រប់គ្រាន់ត្រឹមតែកូន ប្រពន្ធរបស់អ្នកប៉ុណ្ណោះ សេដ្ឋីពោលថា ប្រយោជន៍អ្វីរបស់នាងដោយមនុស្សទាំងនោះ ។ ភរិយាពោលថា ខ្ញុំនឹងចៀនឲ្យល្មមដល់អ្នក និងខ្ញុំឬ សេដ្ឋីពោលថា នាងនឹងធ្វើ គឺបរិភោគធ្វើអ្វី ភរិយាពោលថា បើដូច្នោះ ខ្ញុំនឹងចៀនឲ្យល្មមដល់អ្នកប៉ុណ្ណោះ សេដ្ឋីពោលថា បើនាងចៀននំនេះ មនុស្សជាច្រើន រមែងមានបំណងចង់ស៊ីដែរ ចូរនាងរៀរអង្ករដែលល្អទាំងអស់ កាន់យកចុងអង្ករ ជើងក្រាន អំបែង កាន់យកទឹកដោះស្រស់ សប្បិ ទឹកឃ្មុំ និងទឹកអំពៅបន្តិចហើយឡើងទៅជាន់ខាងលើនៃប្រាសាទជាន់ទី ៧ ហើយចៀនចុះ ខ្ញុំម្នាក់ឯងប៉ុណ្ណោះនឹងអង្គុយស៊ីក្នុងទីនោះ ។

នាងទទួលពាក្យថា សាធុ ហើយឲ្យទាសីកាន់របស់ដែលគួរកាន់ ឡើងទៅកាន់ប្រាសាទ ហើយដេញទាសីទៅ ឲ្យហៅលោកសេដ្ឋីមក ។ សេដ្ឋីនោះបិទទ្វារជាក់គន្ធីះគ្រប់ទ្វារ តាំងអំពីទ្វារដំបូងមក ហើយឡើងទៅកាន់ជាន់ទី ៧ បិទទ្វារហើយអង្គុយក្នុងទីនោះ ។ ចំណែកភរិយារបស់គាត់ បង្ហាត់ភ្លើងត្រង់ជើងក្រាន លើកអំបែងដាក់ ហើយផ្តើមចៀននំ ។

គ្រានោះ ព្រះសាស្តាត្រាស់ហៅព្រះមហាមោគ្គល្លានត្ថេរមកអំពីព្រលឹមត្រាស់ថា ម្នាលមោគ្គល្លាន ក្នុងសក្ករនិគមមិនធ្លាយអំពីក្រុងរាជគ្រឹះ សេដ្ឋីកំណាញ់ម្នាក់ គិតថា អញនឹងបរិភោគនំអំបែង ទើបឲ្យភរិយាចៀននំខាងលើប្រាសាទ ៧ ជាន់ ព្រោះខ្លាចអ្នកដទៃឃើញ ចូរអ្នកទៅក្នុងទីនោះ ហើយ

ទន្នានសេដ្ឋី ធ្វើឲ្យអស់ព្យសន៍ ឲ្យប្តីប្រពន្ធទាំងពីរកាន់នំ ខីរៈ សប្បិ ទឹកឃ្មុំ និងទឹកអំពៅហើយ នាំមកកាន់វត្តជេតពន ដោយកម្លាំងរបស់ខ្លួន ថ្ងៃនេះ តថាគតមួយអន្ទើដោយភិក្ខុ ៥០០ រូប នឹងអង្គុយក្នុងវិហារនោះឯង ធ្វើភត្តកិច្ចដោយនំប៉័ណ្ណោះ ។

ព្រះថេរៈទទួលព្រះតម្រាស់របស់ព្រះសាស្តាថា សាធុព្រះអង្គ ហើយទៅកាន់និគមនោះដោយកម្លាំងឫទ្ធិរំពេចនោះឯង ជាអ្នកស្ទៀកដណ្តប់រៀបរយឈរត្រង់មាត់បង្អួចនៃប្រាសាទនោះ ដូចរូបកែវមណីអណ្តែតនៅលើអាកាសនោះឯង ព្រោះឃើញព្រះថេរៈនោះឯង ហឫទ័យរបស់សេដ្ឋីក៏ញាប់ញ័រ គិតថា អញមកទីនេះព្រោះខ្លាចបុគ្គលទាំងឡាយ មានសភាពយ៉ាងនេះឯង តែសមណៈនេះមកឈរត្រង់បង្អួចបាន កាលមិនឃើញគ្រឿងឧបករណ៍ ដែលខ្លួនគួរកាន់យក ក្តៅក្រហាយធ្វើសំឡេង តៈដៈ តៈដៈ ដូចអំបិលដែលបោះក្នុងភ្លើង ទើបពោលយ៉ាងនេះថា សមណៈអ្នកឈរនៅក្នុងអាកាស នឹងបានអ្វី សូម្បីអ្នកចង្រ្កម បង្ហាញស្នាមជើងក្នុងអាកាស ដែលមិនមានស្នាមក៏នឹងមិនបានដូចគ្នា ។ ព្រះថេរៈចង្រ្កមត្រឡប់ទៅត្រឡប់មកក្នុងទីនោះឯង សេដ្ឋីពោលថា អ្នកចង្រ្កមនឹងបានអ្វី សូម្បីអង្គុយពត់ភ្នែនក្នុងអាកាស ក៏មិនបានដូចគ្នា ទើបព្រះថេរៈអង្គុយពត់ភ្នែន ។

គ្រានោះ សេដ្ឋីពោលថា អ្នកអង្គុយក្នុងអាកាសនឹងបានអ្វី សូម្បីឈរត្រង់ធរណីបង្អួច ក៏មិនបាន ។ ព្រះថេរៈបានឈរត្រង់ធរណីបង្អួចហើយ ។ កាលនោះ សេដ្ឋីពោលថា អ្នកឈរត្រង់ធរណីបង្អួចនឹងបានអ្វី សូម្បីបង្គុយ

ផ្សែងហើយ ក៏នឹងមិនបានដូចគ្នា ។ ព្រះថេរៈក៏បង្អុយផ្សែង ។ ប្រាសាទទាំងមូល មានផ្សែងគ្របជណ្តប់ពាសពេញ ។ អាការនោះ ហាក់ដូចជាកាលដែលចាក់ភ្នែកទាំងពីរបស់សេដ្ឋីដោយម្ជុល សេដ្ឋីពោលថា ទោះបីអ្នកឲ្យឆេះដោយភ្លើង ក៏មិនបាន ព្រះថេរៈក៏ធ្វើជាភ្លើង ព្រោះខ្លាចភ្លើងឆេះផ្ទះ គិតថា សមណៈនេះនឹងជាអ្នកជាប់ជំពាក់យ៉ាងមាំ បើមិនបានហើយនឹងមិនចេញទៅ អញនឹងឲ្យនំមួយចម្រៀកដល់លោក ហើយពោលនឹងភរិយាថា នែនាង នាងចូរចៀននំមួយចម្រៀកតូច ឲ្យដល់សមណៈ ហើយបញ្ជូនលោកទៅចុះ ។ នាងដាក់មេរ្យាក្នុងអំបែងបន្តិច តែនំហាក់ដូចជាធំ បានរីកឡើងពេញថាសតាំងនៅហើយ ។ សេដ្ឋីឃើញហេតុនោះ ពោលថា ប្រហែលជានាងដាក់មេរ្យាច្រើនពេក ដូច្នេះហើយ ដួសមេរ្យាបន្តិចដោយជ្រុងវែកហើយចៀនដោយខ្លួនឯង នំរីងរឹតតែធំជាងមុន ។ សេដ្ឋីចៀននំណាមួយ ដោយអាការយ៉ាងនោះ នំទាំងនោះក៏រីងរឹតតែធំនោះឯង ។ គាត់ធុញទ្រាន់ ទើបពោលនឹងភរិយាថា នែនាង ចូរនាងឲ្យនំដល់សមណៈនេះមួយបន្ទុះចុះ ។ កាលនាងចាប់នំមួយអំពីល្អី នំទាំងអស់ក៏ជាប់គ្នាតែមួយ ទើបនាងពោលនឹងសេដ្ឋីថា នែអ្នក នំទាំងអស់ជាប់គ្នាតែមួយហើយ ខ្ញុំមិនអាចធ្វើឲ្យបែកគ្នាបាន សូម្បីគាត់ពោលថា ខ្ញុំនឹងធ្វើឯង ហើយក៏មិនអាចធ្វើបាន សូម្បីទាំងពីរនាក់ចាប់ត្រង់ជាយនំទាញចេញ ក៏មិនអាចបំបែកចេញពីគ្នាបានឡើយ កាលសេដ្ឋីនោះ ព្យាយាមបំបែកនំ ញើសក៏ហូរចេញអំពីសរីរៈហើយ ការឃ្លានក៏បាត់ទៅ ។ គ្រានោះ គាត់ពោលនឹងភរិយាថា នែនាង ខ្ញុំមិនត្រូវការដោយនំ នាងចូរឲ្យដល់សមណៈ

ចុះ នាងលើកល្អីហើយ ចូលទៅរកព្រះថេរៈ ព្រះថេរៈសម្តែងធម៌ដល់ជនទាំងពីរ ពោលគុណព្រះរតនត្រ័យ សម្តែងផលទាន ដែលបុគ្គលឲ្យហើយជាដើម ឲ្យដួចព្រះចន្ទ្រក្នុងលម្អថា ទានដែលបុគ្គលឲ្យហើយ រមែងមានផលយញ្ញដែលបុគ្គលបូជា រមែងមានផល សេដ្ឋីស្តាប់ធម៌នោះហើយ មានចិត្តជ្រះថ្លាពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់និមន្តមកគង់ធាន់លើបល្ល័ង្កនេះចុះ ។

ព្រះថេរៈពោលថា មហាសេដ្ឋី ព្រះសម្មាសម្ពុទ្ធប្រថាប់គង់ក្នុងវិហារជាមួយភិក្ខុ ៥០០ រូប ដោយតាំងព្រះហឫទ័យថា នឹងសោយនំ បើអ្នកមានការពេញចិត្ត ចូរឲ្យភរិយាកាន់យកនំ និងវត្ថុជទៃ មានទឹកដោះជាដើម ពួកយើងនឹងទៅកាន់សម្នាក់ព្រះសាស្តា ។ សេដ្ឋីពោលថា ឥឡូវនេះ ព្រះសាស្តាគង់នៅក្នុងទីណា ព្រះថេរៈពោលថា គង់នៅក្នុងវត្តជេតពនមហាវិហារ ក្នុងទីបំផុតនៃទី ៤៥ យោជន៍អំពីទីនេះ ។ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ ពួកយើងនឹងទៅអស់ចម្ងាយផ្លូវមានប្រមាណប៉ុណ្ណេះ មិនហួសកាលទៅហើយឬ ។ ព្រះថេរៈពោលថា បើលោកសេដ្ឋីពេញចិត្ត អាត្មានឹងនាំអ្នកទាំងពីរទៅដោយកម្លាំងរបស់ខ្លួន ក្បាលជណ្តើរប្រាសាទរបស់អ្នក នឹងមានក្នុងទីរបស់ខ្លួននេះឯង តែជើងជណ្តើរនឹងមានត្រង់ឃ្លោងទ្វារវត្តជេតពន អាត្មានឹងនាំទៅកាន់វត្តជេតពន ដោយកាលប្រហែលគ្នានឹងចុះអំពីប្រាសាទជាន់លើ ទៅកាន់ជាន់ខាងក្រោម សេដ្ឋីទទួលថា សាធុ ។ ព្រះថេរៈធ្វើក្បាលជណ្តើរក្នុងទីនោះឯងហើយ អធិដ្ឋានថា សូមជើងជណ្តើរមានត្រង់ខ្វោងទ្វារវត្តជេតពន ជណ្តើរ

បានកើតហើយយ៉ាងនោះឯង ព្រះថេរៈឲ្យសេដ្ឋី និងភរិយាដល់វត្តជេតពន រហ័សដូចកាលដែលចុះអំពីប្រាសាទជាន់លើ ទៅកាន់ជាន់ក្រោម ។

ប្តីប្រពន្ធទាំងពីរនាក់នោះ ចូលគាល់ព្រះសាស្តាហើយ ក្រាបទូលកាល ។ ព្រះសាស្តាយាងចូលកាន់ភេងធាន់ហើយ ប្រថាប់គង់លើពុទ្ធាសនៈ ដែលគេក្រាលហើយ មួយអន្ទើដោយភិក្ខុសង្ឃ ។ មហាសេដ្ឋីបានថ្វាយទក្ខិណោទកដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ភរិយាជាក់នំក្នងជាត្រារបស់ព្រះតថាគតហើយ សូម្បីមហាសេដ្ឋី មួយអន្ទើដោយភរិយា ក៏បរិភោគនំសមគួរដល់សេចក្តីត្រូវការ ការអស់នំមិនប្រាកដឡើយ ។ កាលគាត់ប្រគេននំដល់ភិក្ខុក្នុងវិហារទាំងមូល ឲ្យដល់អ្នកស៊ីដែលទាំងឡាយហើយ ការអស់ទៅនៃនំក៏មិនប្រាកដនោះឯង ។ ទើបគាត់ទាំងពីរ ក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន នំមិនអស់ឡើយ ព្រះសាស្តាត្រាស់ថា បើដូច្នោះ អ្នកទាំងពីរចូរបោះចោលត្រង់ខ្វាងទ្វារវត្តជេតពន ។ ជនទាំងពីរក៏បោះចោលត្រង់ជ្រុង មិនឆ្ងាយអំពីខ្វាងទ្វារ សព្វថ្ងៃនេះ ទីនោះ ក៏នៅប្រាកដឈ្មោះថាជ្រុងនំអំបែង ។ មហាសេដ្ឋីព្រមទាំងភរិយា ចូលទៅគាល់ព្រះដ៏មានព្រះភាគ បានឈរក្នុងទីសមគួរនោចំណែកម្ខាងហើយ ។ ព្រះសាស្តាបានធ្វើអនុមោទនាហើយ ។ ក្នុងកាលចប់អនុមោទនា ប្តីប្រពន្ធទាំងពីរតាំងនៅក្នុងសោតាបត្តិផលហើយ ថ្វាយបង្គំព្រះសាស្តា ទ្បើងជណ្តើរត្រង់ខ្វាងទ្វារវត្តជេតពន ហើយស្ថិតនៅលើប្រាសាទរបស់ខ្លួននោះឯង ។ តាំងអំពីនោះមក សេដ្ឋីបានចំណាយទ្រព្យចំនួន ៨០ កោដិ ក្នុងព្រះពុទ្ធសាសនានោះឯង ។

ស្អែកឡើង ក្នុងវេលាល្ងាច ពួកភិក្ខុប្រជុំគ្នាក្នុងរោងធម្មសភា អង្គុយ ហើយ ពោលនូវគុណកថារបស់ព្រះថេរៈថា អាវុសោទាំងឡាយ អ្នកទាំង-ឡាយ ចូរមើលអានុភាពរបស់ព្រះមហាមោគ្គល្លាន លោកជាអ្នកមិនបៀត បៀនទាំងសទ្ធា មិនបៀតបៀនទាំងកោគៈ ទូន្មានសេដ្ឋីដែលមានសេចក្តី កំណាញ់ មួយរយៈខ្លី ធ្វើឲ្យអស់ព្យសន៍ហើយ ឲ្យកាន់នំនាំមកកាន់វត្ត ជេតពន ធ្វើត្រង់ព្រះកក្ត្រព្រះសាស្តាហើយ ឲ្យតាំងនៅក្នុងសោតាបត្តិផល គួរ អស្ចារ្យ ព្រះថេរៈមានអានុភាពច្រើន ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ពួកភិក្ខុ ដោយព្រះសោតធាតុដែលជាទិព្វ យាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុ ទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នា ដោយរឿងអ្វីហ្ន៎ ។ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់សរសើរ ព្រះថេរៈថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុអ្នកទូន្មាន មិនប៉ះពាល់ទាំងសទ្ធា មិនប៉ះពាល់ទាំងកោគៈ មិនឲ្យត្រកូលខូចខាត មិនបៀតបៀនត្រកូល ដូច ជាឃ្មុំយកលម្អងអំពីផ្កា ចូលទៅរកត្រកូលហើយ គួរឲ្យដឹងពុទ្ធគុណ ។ មោគ្គល្លានបុត្ររបស់តថាគតក៏ដូច្នោះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

យថាបិ ភមរោ បុប្ផំ វណ្ណគន្ធំ អហេឋយំ
បលេតិ រសមាទាយ ឯវំ គាមេ មុនីចរេ ។

ភមរជាតិ មិនធ្វើផ្កាឈើដែលមានពណ៌ និងក្លិនឲ្យវិនាស ទេ ក្រេបយកតែរស ហើរទៅ យ៉ាងណាមិញ អ្នកប្រាជ្ញ គប្បីត្រាច់ទៅក្នុងស្រុក ក៏យ៉ាងនោះឯង ។

សេចក្តីអធិប្បាយ

ជាតិនៃសត្វដែលធ្វើជាតិផ្អែមណាមួយ ឈ្មោះថា ភមរៈ ក្នុងព្រះគាថានេះ ។ បទថា **ឃុម្ពំ** ជាដើម សេចក្តីថា ឃ្មុំកាលហើរទៅក្នុងសួនផ្កា ក៏មិនញ៉ាំងផ្កា ពណ៌ និងក្លិនឲ្យខូច គឺមិនឲ្យវិនាស ហើរទៅ ។

បទថា **បលេតិ** សេចក្តីថា កាលហើរទៅយ៉ាងនោះហើយ ក្របរសគ្រប់គ្រាន់ដល់សេចក្តីត្រូវការ ពាំយករសដទៃទៅ ដើម្បីប្រយោជន៍ដល់ការធ្វើទឹកផ្អែម ហើយហើរទៅ ។ ឃ្មុំនោះត្រាច់ចុះកាន់ព្រៃស្តុកណាមួយ ហើយក្របរសដែលលាយលម្អងនោះ ទុកក្នុងប្រហោងឈើមួយកន្លែងហើយ ធ្វើទឹកផ្អែមឲ្យជាទឹកឃ្មុំដោយលំដាប់ ។ ផ្កាពណ៌ និងក្លិនរបស់ផ្កានោះ មិនខូចខាត ព្រោះការត្រាច់ទៅក្នុងសួនផ្កានៃឃ្មុំនោះជាបច្ច័យឡើយ ដែលពិត វត្ថុទាំងអស់នោះ តាំងនៅជាប្រក្រតីនោះឯង ។

បាទព្រះគាថាថា **ឯវំ គាមេ មុនិ ចរេ** សេចក្តីថា ព្រះអនាគារិយមុនីមានសេក្ខៈ និងអសេក្ខៈក៏ដូច្នោះ ត្រាច់ទទួលភិក្ខាក្នុងស្រុក ដោយលំដាប់ត្រកូល ។

មែនពិត ការវិនាសសទ្ធា ឬការវិនាសភោគៈមិនមានដល់ត្រកូលទាំងឡាយ ព្រោះការត្រាច់ទៅក្នុងស្រុករបស់មុនីជាបច្ច័យឡើយ សទ្ធាក្តី ភោគៈក្តី នៅជាប្រក្រតីនោះឯង ឯព្រះសេក្ខមុនី និងអសេក្ខមុនី កាលត្រាច់ទៅយ៉ាងនោះ ចេញមកហើយ ព្រះសេក្ខមុនីក្រាលសង្ឃាដី អង្គុយក្នុងទីដែលសប្បាយដោយទឹកខាងក្រៅស្រុក ហើយពិចារណាបិណ្ឌបាត ដោយអំណាចនៃការប្រៀបធៀបដោយប្រេងបន្តក់ភ្លៅវេធ សំពត់រុំដំបៅ និងសាច់កូន ហើយឆាន់បិណ្ឌបាត

គេចចូលទៅកាន់ជង្ឃព្រៃបែបនោះ ពិចារណាកម្មដ្ឋាន ប្រព្រឹត្តទៅខាងក្នុង ធ្វើមគ្គ ៤ និងផល ៤ ឲ្យនៅក្នុងកណ្តាប់ដៃឲ្យបាន ចំណែកព្រះអសេក្ខមុនី ប្រកបការនៅសប្បាយក្នុងទិដ្ឋធម៌រឿយៗ ។ បណ្ឌិតគប្បីជ្រាបភាពដែលមុនីនោះ គួរឃើញស្មើគ្នានឹងឃ្មុំ ដោយការធ្វើទឹកផ្អែមបែបនេះ ។ តែក្នុងទីនេះទ្រង់បំណងយកព្រះខីណាស្រព ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ព្រះសាស្តា កាលត្រាស់ព្រះធម្មទេសនានេះហើយ ដើម្បីប្រកាសគុណរបស់ព្រះថេរៈឲ្យក្រៃលែង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានទូន្មានសេដ្ឋីកំណាញ់នេះ ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន លោកក៏ទូន្មានហើយ ឲ្យដឹងការទាក់ទងគ្នានៃកម្ម និងផលរបស់កម្មដូចគ្នា ដូច្នេះហើយ កាលទ្រង់ប្រកាសសេចក្តីនេះ ទើបនាំអតីតនិទានមកសាធកៈ ដោយឥល្ថិសជាតកនេះថា

ជាង្ឃកោរកាត់ពោធិសត្វពោលថា

ជនទាំង ២ នាក់ខ្វក ជនទាំង ២ នាក់ក្លែង ជនទាំង ២ នាក់មានភ្នែកស្រេលៀង ពកកើត (លើក្បាល) របស់ជនទាំង ២ នាក់ ខ្ញុំព្រះអង្គមិនស្គាល់ (អ្នកណា) ជាឥល្ថិសសេដ្ឋីទេ ។

រឿងកោសិយសេដ្ឋី ចប់

រឿង ចាដិកាជីវក

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធអាជីវក ឈ្មោះបាដិក: ត្រាស់ធម្មទេសនានេះថា **ន បរេសំ វិលោមានិ** ជាដើម ។

បានឲ្យមកថា ស្រីមេផ្ទះក្នុងក្រុងសាវត្ថី បដិបត្តិអាជីវក ឈ្មោះបាដិក: តាំងនៅក្នុងហាន:ដូចកូន ។ មនុស្សក្នុងផ្ទះរបស់នាង ស្តាប់ធម្មទេសនារបស់ព្រះសាស្តាហើយ មកពណ៌នាគុណដោយប្រការផ្សេងៗ ជាដើមថា ព្រះធម្មទេសនារបស់ព្រះពុទ្ធទាំងឡាយ គួរអស្ចារ្យពន់ពេក ។

ស្រីមេផ្ទះនោះ ស្តាប់ពាក្យសរសើរគុណរបស់ព្រះសម្ពុទ្ធហើយ បំណងនឹងទៅកាន់វិហារ ហើយស្តាប់ធម៌ ទើបប្រាប់សេចក្តីនោះដល់អាជីវក ហើយពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងទៅសម្នាក់របស់ព្រះសម្ពុទ្ធ អាជីវកនោះយាត់ថា កុំទៅឡើយ ហើយក៏ហាមនាងដែលអង្វរហើយអង្វរទៀតនោះឯង ។

នាងគិតថា លោកម្ចាស់នេះ មិនឲ្យអញទៅវិហារស្តាប់ធម៌ អញនឹងនិមន្តព្រះសាស្តាមក ហើយស្តាប់ធម៌ក្នុងទីនេះឯង ដូច្នេះហើយ ក្នុងពេលល្ងាចទើបហៅកូនប្រុសមកហើយ បញ្ជូនទៅដោយពាក្យថា ចូរឯងទៅនិមន្តព្រះសាស្តាមក ដើម្បីសោយភត្តាហារក្នុងថ្ងៃស្អែក ។

កូនប្រុសនោះ មុននឹងទៅក៏ទៅកាន់លំនៅរបស់អាជីវកមុន ថ្វាយបង្គំអាជីវកហើយអង្គុយ ។ ពេលនោះអាជីវកសួរថា អ្នកទៅណា កូននោះពោលថា ខ្ញុំទៅនិមន្តព្រះសាស្តាតាមពាក្យរបស់អ្នកម្តាយ អាជីវកពោលថា កុំទៅ

កាន់សម្នាក់របស់ទ្រង់ទ្បើយ កូននោះពោលថា មិនបានទេលោកម្ចាស់ ខ្ញុំនឹងទៅ អាជីវកពោលថា យើងទាំងពីរនាក់ នឹងបរិភោគគ្រឿងសក្ការៈ ដែលម្តាយរបស់ឯងធ្វើថ្វាយព្រះសាស្តានោះ កុំទៅទ្បើយ កូននោះពោលថា មិនបានទេលោកម្ចាស់ ម៉ែនឹងវាយខ្ញុំ អាជីវកពោលថា បើដូច្នោះ ទៅក៏ទៅចុះ តែកាលទៅហើយ ចូរនិមន្ត តែកុំប្រាប់ថា ទ្រង់គប្បីយាងទៅផ្ទះពួកខ្ញុំព្រះអង្គក្នុងទីនោះ ក្នុងផ្លូវនោះ ក្នុងច្រកនោះ ធ្វើដូចជាឈរក្នុងទីជិត ដូចនឹងទៅដោយផ្លូវដទៃ ហើយចូរគេចមកចុះ ។

កូននោះស្តាប់ពាក្យរបស់អាជីវកហើយ ទៅកាន់សម្នាក់ព្រះសាស្តា និមន្តហើយ ធ្វើកិច្ចសព្វយ៉ាងដោយទំនងអាជីវកពោលហើយនោះឯង ហើយទៅកាន់សម្នាក់របស់អាជីវកនោះ ត្រូវអាជីវកសួរថា អ្នកធ្វើដូចម្តេច ទើបប្រាប់ថា អ្វីដែលលោកម្ចាស់ប្រាប់ទាំងអស់ ខ្ញុំធ្វើហើយ ។ អាជីវកពោលថា ឯងធ្វើល្អហើយ យើងទាំងពីរនឹងបរិភោគគ្រឿងសក្ការៈ ដែលម្តាយរបស់អ្នកធ្វើដើម្បីព្រះសាស្តានោះ ដូច្នេះហើយ ស្អែកឡើង អាជីវកបានទៅកាន់ផ្ទះនោះអំពីព្រលឹម ពួកមនុស្សក្នុងផ្ទះនាំអាជីវកនោះ ឲ្យទៅអង្គុយត្រង់បន្ទប់ក្រោយ ពួកមនុស្សស្និទ្ធស្នាល បូកលាបផ្ទះនោះ ដោយអាចម៍គោស្រស់ រោយផ្កាដែលមានលាជជាគម្រប់ ៥ ហើយក្រាលអាសនៈ មានតម្លៃច្រើនដ៏សមគួរ ដើម្បីជាប្រយោជន៍ដល់ការប្រថាប់គង់របស់ព្រះសាស្តា ។ ពិតហើយ ពួកមនុស្សដែលមិនស្និទ្ធស្នាលជាមួយព្រះសម្ពុទ្ធ រមែងមិនចេះក្នុងការក្រាលអាសនៈ ។

ម្យ៉ាងទៀត ឈ្មោះថា កិច្ចទាក់ទងដោយការបង្ហាញផ្លូវ រមែងមិនមាន ដល់ព្រះពុទ្ធទាំងឡាយ ព្រោះផ្លូវទាំងអស់ ជាក់ច្បាស់ដល់ព្រះពុទ្ធទាំងអស់ ហើយថា ផ្លូវនេះទៅកាន់នរក ផ្លូវនេះទៅកាន់តិរច្ឆាន ផ្លូវនេះទៅកាន់បិត្តិវិស័យ នេះទៅកាន់មនុស្សលោក នេះទៅកាន់ទេវលោក នេះទៅអមតមហានិព្វាន ក្នុងថ្ងៃដែលទ្រង់ញុាំងលោកធាតុមួយម៉ឺនឲ្យញាប់ញ័រ ហើយសម្រេចសម្ពោធិញ្ញាណ ត្រង់គល់ពោធិព្រឹក្សនោះឯង ។ ទើបមិនមានពាក្យដែលគួរពោលក្នុងផ្លូវនៃទឹកន្ទែងផ្សេងៗ មានគាមនិគមជាដើមឡើយ ព្រោះដូច្នោះ ព្រះសាស្តា ទ្រង់កាន់បាត្រ និងចីវរហើយ យាងទៅកាន់ទ្វារផ្ទះរបស់មហាឧបាសិកាអំពីព្រលឹម ។ នាងចេញអំពីផ្ទះ ថ្វាយបង្គំព្រះសាស្តា ដោយបញ្ចង្គបដិស្ឋាន យាងឲ្យទ្រង់ចូលទៅខាងក្នុងផ្ទះ និមន្តឲ្យគង់លើអាសនៈ ហើយថ្វាយទក្ខិណោទក អង្គាសដោយខាទនីយៈ និងភោជនីយៈដ៏ប្រណីត ។ ឧបាសិកាបំណងឲ្យព្រះសាស្តាដែលធ្វើកត្តកិច្ចស្រេចហើយ ទ្រង់ធ្វើអនុមោទនាទើបទទួលបាត្រហើយ ។

ព្រះសាស្តា ទ្រង់ផ្តើមធម្មកថា សម្រាប់អនុមោទនាដោយព្រះសូរសៀងដ៏ពីរោះ ។ ឧបាសិកាស្តាប់បណ្តើរ ឲ្យសាធុការបណ្តើរថា សាធុ សាធុ ។ អាជីវកនោះ អង្គុយក្នុងបន្ទប់ក្រោយនោះឯង បានឮសំឡេងនាងឲ្យសាធុការ ហើយស្តាប់ធម៌ មិនអាចអត់ធន់បាន ទើបចេញទៅដោយគិតថា ពេលនេះនាងមិនមែនជារបស់អញ ដូច្នេះហើយ ជេរឧបាសិកា និងព្រះសាស្តា ដោយប្រការផ្សេងៗ ថា មេកាឡកិណី ហាងជាបុគ្គលវិនាស ហាងចូរធ្វើសក្ការៈនេះ

ជល់សមណៈនេះចុះ ដូច្នេះជាដើម ហើយចៀសចេញទៅ ។

ឧបាសិកាខ្មាស ព្រោះពាក្យរបស់អាជីវកនោះ មិនអាចបញ្ជូនចិត្តដែលជល់នូវការរាយមាយទៅតាមក្រសែនៃទេសនាបាន ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា ឧបាសិកា នាងមិនអាចធ្វើចិត្តឲ្យទៅតាមគន្ធងទេសនាបានឬ ឧបាសិកាពោលថា ករុណាព្រះអង្គ ព្រោះពាក្យសម្តីរបស់អាជីវកនេះ ចិត្តរបស់ខ្ញុំព្រះអង្គ ចូលជល់នូវការរាយមាយហើយ ។

ព្រះសាស្តាត្រាស់ថា មិនគួរព្រួកជល់ពាក្យដែលជនមិនស្មើកាគគ្នាបែបនេះពោល ការមិនពិចារណាជល់ពាក្យបែបនេះហើយ ពិនិត្យមើលកិច្ចដែលធ្វើហើយ និងមិនទាន់បានធ្វើរបស់ខ្លួនប៉ុណ្ណោះ ទើបគួរ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ន បរេសំ វិលោមានិ ន បរេសំ កតាកតំ
អត្តនោ វ អវេក្ខេយ្យ កតានិ អកតានិ ច ។

ពាក្យចាក់ដោតទាំងឡាយ របស់ជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេ កិច្ចដែលធ្វើហើយ និងមិនទាន់ធ្វើហើយ របស់ជនដទៃ (ដែលមិនមែនជាមុខការរបស់ខ្លួន) បុគ្គលមិនគួរពិនិត្យមើលទេ បុគ្គលគួរពិនិត្យពិចារណាតែកិច្ចការទាំងឡាយ ដែលធ្វើហើយ និងមិនទាន់ធ្វើហើយ របស់ខ្លួនតែម្យ៉ាង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **ន បរេសំ វិលោមានិ** សេចក្តីថា មិនគួរធ្វើពាក្យព្រើរភេម គឺពាក្យគ្រោតគ្រាត បានដល់ ពាក្យដែលកាត់បង់នូវសេចក្តីស្រឡាញ់ របស់បុគ្គលពួកជទៃទុកក្នុងចិត្តឡើយ ។

បាទព្រះគាថាថា **ន បរេសំ កតាកតំ** សេចក្តីថា មិនគួរមើលកម្មដែលធ្វើហើយ និងមិនទាន់ធ្វើហើយ របស់បុគ្គលជទៃយ៉ាងនេះថា ឧបាសកនោះ មិនមានសទ្ធា មិនជ្រះថ្លា សូម្បីវត្ត មានបាយមួយវែកជាដើមក្នុងផ្ទះ ក៏មិនឲ្យ សលាកភត្តជាដើមក៏មិនឲ្យ ការឲ្យបច្ចុយ មានចីវរជាដើមមិនមានដល់ឧបាសកនោះ ឧបាសិកានោះក៏ដូចគ្នា មិនមានសទ្ធា មិនជ្រះថ្លា បាយមួយវែកជាដើមក្នុងផ្ទះ ក៏នាងមិនឲ្យ សលាកភត្តជាដើមក៏មិនឲ្យ ការឲ្យបច្ចុយ មានចីវរជាដើម ក៏មិនមានដល់ឧបាសិកានោះ ។ ភិក្ខុនោះក៏ដូចគ្នា មិនមានសទ្ធា មិនជ្រះថ្លា មិនញុំាងឧបជ្ឈាយវត្ត មិនធ្វើអាចរិយវត្ត មិនធ្វើអាគន្តុកវត្ត មិនធ្វើវត្តដើម្បីភិក្ខុដែលត្រៀមនឹងទៅ មិនធ្វើវត្តទ្រង់លានព្រះចេតិយ មិនធ្វើវត្តក្នុងរោងឧបោសថ មិនធ្វើវត្តត្រង់រោងធាន់ មិនធ្វើវត្ត មានវត្តក្នុងរោងភ្លើងជាដើម ទាំងធុតង្គណាមួយក៏មិនមានដល់លោក សូម្បីត្រឹមតែការឧស្សាហ៍ ត្រឹមតែជាបុគ្គលមានការនាមកជាទីត្រេកអរ ក៏មិនមាន ។

បាទព្រះគាថាថា **អត្តនោ វ អវេក្ខេយ្យ** សេចក្តីថា កុលបុត្រអ្នកបួសដោយសទ្ធា កាលរឭកដល់ឱវាទនេះថា បពូជិតគប្បីពិចារណារឿយៗ ថា យប់ថ្ងៃកន្លងទៅ អញធ្វើអ្វី ជួច្នេះហើយ គប្បីមើលកិច្ចដែលធ្វើហើយ និងមិនទាន់បានធ្វើរបស់ខ្លួនយ៉ាងនេះថា អញមិនអាចលើកខ្លួនឡើងកាន់ត្រៃលក្ខណ៍ គឺ

អនិច្ចំ ទុក្ខំ អនត្តា ហើយធ្វើឲ្យក្សេមចាកយោគៈឬហ្ន៎ ។

ក្នុងកាលចប់ទេសនា ឧបាសិកាតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាបានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

រឿង ចាដិកាជីវក ចប់

រឿង ធម្មចារិឧបាសក

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធធម្មចារិឧបាសក ត្រាស់ព្រះធម្មទេសនានេះថា **យថា ចិ រុចិរំ បុប្ផំ** *ជាដើម ។*

សេចក្តីពិស្តារថា ក្នុងក្រុងសាវត្ថី មានឧបាសកម្នាក់ ឈ្មោះធម្មចារិ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ជាព្រះអនាគាមី ។ ឧបាសកនោះ ជាអ្នករក្សាឧបោសថអំពីព្រលឹម បានទៅកាន់ទីបម្រើព្រះសាស្តា ។ មែនពិត ឈ្មោះថាឧបោសថកម្ម មិនមានដល់ព្រះអរិយសាវ័កដែលជាអនាគាមីទាំងឡាយ ដោយអំណាចនៃការសមាទានឡើយ ព្រហ្មចរិយៈ និងការបរិភោគកត្តម្ពង របស់អរិយសាវ័កដែលជាអនាគាមីទាំងនោះ មកហើយដោយមគ្គនោះឯង ព្រោះហេតុនោះឯង ទើបព្រះដ៏មានព្រះភាគត្រាស់ថា បពិត្រមហារាជ ឃដិការស្មូនឆ្នាំង ជាអ្នកបរិភោគកត្តតែ ១ ពេល ប្រព្រឹត្តធម៌ដ៏ប្រសើរ ជាអ្នកមានសីលមានកល្យាណធម៌ ។ ដោយប្រក្រតីនោះឯង ព្រះអនាគាមីទាំងឡាយ ជាអ្នក

បរិភោគកត្តម្ពង និងមានប្រក្រតីប្រព្រឹត្តព្រហ្មចរិយៈយ៉ាងនោះ ។ ឧបាសកនោះ ក៏ជាអ្នករក្សាឧបោសថយ៉ាងនោះដូចគ្នា ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយស្តាប់ធម្មកថា ។

ក្នុងសម័យនោះ ព្រះបាទបសេនទិកោសល បានយាងទៅកាន់ទីបម្រើព្រះសាស្តា ឧបាសកឃើញព្រះរាជាយាងមក គិតថា អញគួរក្រោកឡើងដែរឬទេហ្ន៎ ដូច្នេះហើយ ក៏មិនក្រោកឡើង ដោយសម្គាល់ថា អញអង្គុយក្នុងសម្នាក់របស់អគ្គរាជា ការដែលអញឃើញស្តេចបរទេសរាជ ហើយក្រោកឡើងទទួលមិនគួរ កាលអញមិនក្រោកឡើង ព្រះរាជាទ្រង់នឹងពិរោធ កាលព្រះរាជាទ្រង់ពិរោធ អញក៏មិនក្រោកទទួល ព្រោះថា អញឃើញព្រះរាជាហើយក្រោកឡើង ឈ្មោះថា ជាការធ្វើសេចក្តីគោរពព្រះរាជា មិនធ្វើសេចក្តីគោរពព្រះសាស្តា អញមិនក្រោកឡើងឡើយ ។

ធម្មតាបុរសដែលជាបណ្ឌិត ឃើញបុគ្គលដែលអង្គុយក្នុងសម្នាក់របស់បុគ្គលដែលគួរគោរពជាង មិនក្រោកឡើង រមែងមិនក្រោធ ។ តែព្រះរាជាឃើញឧបាសកនោះមិនក្រោកឡើង មានព្រះហឫទ័យអាក់អន់ ថ្វាយបង្គំព្រះសាស្តាហើយ ប្រថាប់គង់ក្នុងទីសមគួរ នាចំណែកម្ខាង ។ ព្រះសាស្តា ទ្រង់ជ្រាបភាពដែលព្រះរាជាពិរោធ ទើបត្រាស់ពណ៌នាគុណឧបាសកថា បពិត្រមហារាជ ឆត្តបាណិឧបាសកនេះជាបណ្ឌិត មានធម៌ឃើញហើយ ទ្រទ្រង់ព្រះត្រៃបិដក ឈ្វាសក្នុងប្រយោជន៍ និងមិនជាប្រយោជន៍ ។ កាលព្រះរាជាទ្រង់ស្តាប់គុណកថារបស់ឧបាសកនោះឯង ព្រះហឫទ័យក៏ទោរទន់ ។

ក្រោយមកថ្ងៃមួយ ព្រះរាជាប្រថាប់ឈរលើប្រាសាទខាងលើ ទតឃើញឆត្តបាណិឧបាសក ធ្វើកត្តកិច្ចស្រេចហើយ កាន់ឆត្រ ពាក់ស្បែកជើង ដើរតាមលានព្រះរាជវាំង ទើបត្រាស់ឲ្យរាជបុរសហៅមក ឧបាសកនោះតម្ងោះឆត្រ ដោះស្បែកជើងចេញហើយ ចូលទៅរកព្រះរាជា ថ្វាយបង្គំហើយ បានឈរនៅក្នុងទីសមគួរ នាចំណែកម្ខាង គ្រានោះ ព្រះរាជាត្រាស់និងឧបាសកនោះថា នែឧបាសក ហេតុអ្វី ទើបអ្នកតម្ងោះឆត្រ និងដោះស្បែកជើងចេញ ឧបាសកពោលថា ទូលបង្គំបានឮថា ទ្រង់ត្រាស់ហៅរក ទើបមកហើយ ។ ព្រះរាជាត្រាស់ថា ភាពដែលខ្ញុំជាព្រះរាជា ប្រហែលជាអ្នកទើបតែដឹងក្នុងថ្ងៃនេះទេដឹង ឧបាសកពោលថា ទូលបង្គំជ្រាបភាពដែលទ្រង់ជាព្រះរាជាសព្វកាល ព្រះរាជាត្រាស់ថា បើយ៉ាងនោះ ហេតុអ្វី ក្នុងថ្ងៃមុន អ្នកអង្គុយក្នុងសម្នាក់ព្រះសាស្តា ឃើញខ្ញុំហើយ មិនក្រោកឡើងទទួល ឧបាសកពោលថា បពិត្រមហារាជ ទូលបង្គំអង្គុយក្នុងសម្នាក់របស់អគ្គរាជា បើឃើញព្រះរាជាដែលជាបទេសរាជ ហើយក្រោកឡើង ឈ្មោះថា មិនគោរពក្នុងព្រះសាស្តា ព្រោះដូច្នេះ ទើបទូលបង្គំមិនក្រោកឡើង ព្រះរាជាត្រាស់ថា ណ្ហើយចុះ អ្នក សេចក្តីនេះស្មុះទុកសិន បានឮថា អ្នកឈ្វាសក្នុងប្រយោជន៍ និងមិនមែនជាប្រយោជន៍ ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ និងសម្បរាយភព ទ្រទ្រង់ព្រះត្រៃបិដក ចូរប្រាប់ធម៌ដល់ខ្ញុំខាងក្នុងវាំងចុះ ឧបាសកពោលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនអាចទេ ព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី ឧបាសកពោលថា ព្រោះថា ឈ្មោះថា ព្រះរាជមន្ទីរ រមែងជាទីកន្លែងដែលមានទោស

ច្រើន បពិត្រព្រះសម្មតិទេព ក្នុងព្រះរាជមន្ទីរនេះ កម្មដែលបុគ្គលប្រកបអាក្រក់ និងល្អ រមែងជាកម្មជូន់ ព្រះរាជាត្រាស់ថា អ្នកកុំពោលយ៉ាងនោះ កុំធ្វើសេចក្តីរង្កៀសថា ថ្ងៃមុន ឃើញខ្ញុំហើយ មិនក្រោកឡើង ឧបាសកពោលថា បពិត្រព្រះសម្មតិទេព ឈ្មោះថា ទីកន្លែងដែលត្រាច់របស់ពួកគ្រហស្ថ ជាទីដែលមានទោស សូមទ្រង់និមន្តបព្វជិតមួយរូបមកហើយ ឲ្យត្រាស់ធម៌ចុះ ។

ព្រះរាជា ទ្រង់បញ្ជូនឥត្តបាណិឧបាសកនោះទៅដោយព្រះវាចាថា សាធុអ្នក ចូរអ្នកទៅចុះ ដូច្នេះហើយ ទ្រង់ទៅកាន់ទីគាល់ព្រះសាស្តា ទូលសូមនិងព្រះសាស្តាថា បពិត្រព្រះអង្គ នាងសម្ងិកាទេវី និងនាងវាសភខត្តិយា ពោលថា ចង់រៀនធម៌ សូមទ្រង់ មួយអន្ទើដោយភិក្ខុ ៥០០ រូប យាងទៅកាន់វាំងរបស់ខ្ញុំព្រះអង្គជានិច្ច ទ្រង់សម្តែងធម៌ដល់នាងទាំងពីរ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ធម្មតាព្រះពុទ្ធទាំងឡាយ ទៅក្នុងទីមួយកន្លែងជានិច្ចមិនមាន ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ បើយ៉ាងនោះ សូមទ្រង់ប្រទានភិក្ខុដទៃ ។

ព្រះសាស្តា ទ្រង់បានប្រគល់ការៈឲ្យដល់ព្រះអានន្ទត្ថេរ ។ ព្រះថេរៈទៅសម្តែងព្រះបាលីដល់ព្រះនាងទាំងនោះជានិច្ច ។ ក្នុងព្រះនាងទាំងនោះ ព្រះនាងមល្លិកាទេវីបានរៀន បានទន្ទេញ និងឲ្យព្រះថេរៈទទួលព្រះបាលីដោយគោរព ចំណែកព្រះនាងវាសភខត្តិយា មិនរៀន មិនទន្ទេញដោយគោរពនោះឯង មិនអាចឲ្យព្រះថេរៈទទួលព្រះបាលីដោយគោរពបាន ។ ថ្ងៃមួយ ព្រះសាស្តាត្រាស់សួរព្រះថេរៈថា ម្នាលអានន្ទ ឧបាសិកាទាំងពីរនៅរៀនធម៌ឬ ព្រះអានន្ទ

ទូលថា បពិត្រព្រះអង្គ នៅរៀន ព្រះសាស្តាត្រាស់ថា ឧបាសិកាមួយណា រៀនដោយគោរព ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ព្រះនាងមល្លិកាទេវីរៀនដោយគោរព ទន្ទេញដោយគោរព អាចឲ្យខ្ញុំព្រះអង្គទទួលព្រះបាលីដោយគោរព ចំណែកធីតាដែលជាព្រះញាតិរបស់ព្រះអង្គ មិនរៀនដោយគោរព មិនទន្ទេញដោយគោរព មិនអាចឲ្យខ្ញុំព្រះអង្គ ទទួលព្រះបាលីដោយគោរពបានឡើយ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ព្រះថេរៈហើយ ត្រាស់ថា ម្នាលអានន្ទ ធម្មតាធម៌ដែលតថាគតពោលហើយ រមែងមិនមានផលដល់អ្នកមិនស្តាប់ មិនរៀន មិនទន្ទេញ មិនសម្តែងដោយគោរព ដូចផ្កាមិនសម្បុរដោយពណ៌ មិនមានក្លិន ដូច្នោះ តែមានផលច្រើន មានអានិសង្សច្រើន ដល់បុគ្គលដែលធ្វើកិច្ចទាំងឡាយ មានការស្តាប់ដោយគោរពជាដើម ដូច្នេះហើយ បានត្រាស់ព្រះគាថា ២ គាថាថា

យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ អគន្ធកំ
ឯវំ សុភាសិតា វាចា អផលា ហោតិ អកុព្វតោ ។
យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ សគន្ធកំ
ឯវំ សុភាសិតា វាចា សផលា ហោតិ សុកុព្វតោ ។

ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌ (ល្អ) តែគ្មានក្លិន (ក្រអូប) (រមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្តេចមិញ វាចាជាសុភាសិត រមែងគ្មានផលដល់អ្នក

ដែលមិនធ្វើតាមដូច្នោះ ផ្កាឈើដែលមានទ្រង់ទ្រាយល្អ មានពណ៌ល្អ មានក្លិន (រមែងក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្តេចមិញ វាចាជាសុភាសិត រមែងមានផលដល់អ្នកដែលធ្វើតាមដោយគោរព ដូច្នោះឯង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **រុចិរំ** *គឺស្អាត ។ បទថា* **វណ្ណវន្តំ** *គឺបរិបូណ៌ដោយពណ៌ និងទ្រង់ទ្រាយ ។ បទថា* **អគន្ធកំ** *គឺប្រាសចាកក្លិន មានផ្កាសិរមាន់ ផ្កាកណិការ និងផ្កាជយព្រឹក្សជាដើម ជាប្រភេទ ។ បានព្រះគាថាថា* **ឯវំ សុភាសិតា វាចា** *សេចក្តីថា ព្រះពុទ្ធវចនៈ គឺបិដក ៣ ឈ្មោះថាវាចាសុភាសិត ។ ព្រះពុទ្ធវចនៈនោះ ដូចផ្កាឈើសម្បូរដោយពណ៌ និងទ្រង់ទ្រាយ មិនមានក្លិន ។ ដូចផ្កាមិនមានក្លិន ក្លិនរមែងមិនផ្សាយ ទៅក្នុងសរីរៈបុគ្គលអ្នកទ្រទ្រង់នូវផ្កាមិនមានក្លិននោះ យ៉ាងណា សូម្បីព្រះពុទ្ធវចនៈនេះក៏ដូច្នោះ រមែងមិននាំក្លិន គឺការស្តាប់ ក្លិន គឺការទ្រទ្រង់ និងក្លិន គឺកិច្ចបដិបត្តិមកឲ្យ ឈ្មោះថា រមែងមិនមានផលដល់បុគ្គលមិនតាំងចិត្តប្រព្រឹត្តព្រះពុទ្ធវចនៈនោះដោយអើពើ ដោយកិច្ចទាំងឡាយ មានការស្តាប់ជាដើម ឈ្មោះថា ជាអ្នកមិនមានកិច្ចដែលគួរធ្វើក្នុងព្រះពុទ្ធវចនៈនោះ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា វាចាសុភាសិតក៏ដូច្នោះ រមែងមិនមានផល ដល់បុគ្គលដែលមិនធ្វើ ។*

បទថា **សគន្ធកំ** *បានដល់ ផ្កាចម្ប៉ា និងឈូកខៀវជាដើមជាប្រភេទ ។*

បទថា **ឃរំ** ជាដើម សេចក្តីថា កុំនរមែងផ្សាយទៅក្នុងសរីរៈរបស់បុគ្គលដែលទ្រទ្រង់ផ្តានោះយ៉ាងណា សូម្បីវាចាសុភាសិត ពោល គឺព្រះពុទ្ធវចនៈ បានដល់ព្រះត្រៃបិដកក៏ដូច្នោះ រមែងមានផល គឺឈ្មោះថា មានផលច្រើន មានអានិសង្សច្រើន ព្រោះនាំកុំន គឺការស្តាប់ កុំន គឺការទ្រទ្រង់ចាំ កុំន គឺកិច្ចបដិបត្តិមក ឲ្យដល់បុគ្គលអ្នកធ្វើល្អ គឺបុគ្គលដែលតាំងចិត្តធ្វើកិច្ចដែលគួរធ្វើក្នុងព្រះពុទ្ធវចនៈនោះ ដោយកិច្ចទាំងឡាយ មានការស្តាប់ជាដើម ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាក៏បានកើតជាប្រយោជន៍ដល់មហាជនដូច្នោះឯង ។

រឿង ធត្តចាណិឧបាសក ចប់

រឿង ធាតិវិសាខា

លំនាំដើម

ព្រះសាស្តា កាលទ្រង់ចូលទៅអាស្រ័យក្រុងសាវត្ថី ប្រថាប់នៅក្នុងបុព្វារាម ទ្រង់ប្រារព្ធឧបាសិកាឈ្មោះវិសាខា ត្រាស់ធម្មទេសនានេះថា **យថាបិ បុប្ផរាសិម្ហា** ជាដើម ។

បានឮមកថា នាងវិសាខាឧបាសិកានោះ កើតក្នុងផ្ទៃនាងសុមនាទេវី ភរិយាធំរបស់ធនញ្ជយសេដ្ឋី ជាកូនមេណ្ឌកសេដ្ឋី ក្នុងភទ្ទិយនគរ ដែនអង្គៈ

ក្នុងកាលដែលនាងមានអាយុ ៧ ឆ្នាំ ព្រះសាស្តាទ្រង់យើញឧបនិស្សយសម្បត្តិ របស់សត្វ ដែលមានផៅពង្សគប្បីទូន្មាន ដើម្បីការត្រាស់ដឹង មានសេល-ព្រាហ្មណ៍ជាដើម មានមហាភិក្ខុសង្ឃជាបរិវារ ទ្រង់ចារិកទៅដល់នគរនោះ ។

ក្នុងសម័យនោះ មេណ្ឌកគហបតី ជាប្រធានរបស់អ្នកមានបុណ្យច្រើន ៥ នាក់ គ្រប់គ្រងតំណែងសេដ្ឋីក្នុងនគរនោះ ។ បុគ្គលមានបុណ្យច្រើន ៥ នាក់ គឺមេណ្ឌកសេដ្ឋី ១ ភរិយាធំរបស់សេដ្ឋីឈ្មោះចន្ទបទុមា ១ កូនប្រុសច្បងរបស់សេដ្ឋីឈ្មោះធនញ្ជ័យ ១ ភរិយារបស់ធនញ្ជ័យឈ្មោះសុមនាទេវី ១ អ្នកបម្រើនរបស់មេណ្ឌកសេដ្ឋីឈ្មោះបុណ្ណៈ ១ ។

មិនមែនមានតែមេណ្ឌកសេដ្ឋី ១ ប៉ុណ្ណោះទេ ក្នុងដែនរបស់ព្រះបាទពិម្ពិសារ ក៏មានបុគ្គលអ្នកមានភោគៈរាប់មិនអស់ ចំនួន ៥ នាក់ គឺជោតិកៈ ១ ជដិលៈ ១ មេណ្ឌកៈ ១ បុណ្ណកៈ ១ កាកវលិ្យៈ ១ ។

ក្នុងជនទាំងនោះ មេណ្ឌកសេដ្ឋីបានជ្រាបភាពដែលព្រះទសពល យាងមកដល់នគរបស់ខ្លួន ទើបហៅទារិកាឈ្មោះវិសាខា ដែលជាកូនស្រីធនញ្ជ័យ-សេដ្ឋី ដែលជាកូនមកប្រាប់ថា នែនាង ជាមង្គលដល់នាងផង ដល់យើងផង នាង និងទារិកាបរិវាររបស់នាង ៥០០ ចូរឡើងរទេះសេះ ៥០០ ចោមរោមដោយទាសី ៥០០ ទៅធ្វើការទទួលព្រះទសពល នាងទទួលថា សាធុ ហើយបានធ្វើយ៉ាងនោះ ។ តែព្រោះភាពដែលនាងជាក្មេងឈ្លាស ក្នុងហេតុដែលគួរ និងមិនគួរ ទើបទៅដោយយាន ដែលលួមយានទៅបាន ចុះអំពីយានហើយ ក៏ដើរទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ឈរក្នុងទីសមគួរ

នាចំណែកម្ខាង ។ កាលនោះ ព្រះសាស្តាទ្រង់សម្តែងធម៌ ដោយអំណាចបុព្វចរិយារបស់នាង ។

ក្នុងកាលចប់ទេសនា នាង មួយអន្ទើដោយទាវិកា ៥០០ តាំងនៅក្នុងសោតាបត្តិផលហើយ ។ ចំណែកមេណ្ឌកសេដ្ឋី ចូលគាល់ព្រះសាស្តា ស្តាប់ធម្មកថា តាំងនៅក្នុងសោតាបត្តិផលហើយ ទើបនិមន្តដើម្បីសោយក្នុងថ្ងៃស្អែក អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយៈ ភោជនីយៈដ៏ប្រណីតត្រង់ផ្ទះរបស់ខ្លួន បានថ្វាយមហាទានដោយឧបាយនេះឯង រហូតកន្លះខែ ។ ព្រះសាស្តាប្រថាប់នៅក្នុងកត្តិយនគរ តាមសមគួរដល់ព្រះហឫទ័យហើយ ទ្រង់ចៀសចេញទៅ ។

សម័យនោះឯង ព្រះបាទពិម្ពិសារ និងព្រះបាទបសេនទិកោសល ដែលជាបងប្អូនថ្លៃនឹងគ្នា ថ្ងៃមួយ ព្រះបាទកោសលទ្រង់ព្រះតម្រិះថា បុគ្គលមានភោគៈរាប់មិនអស់ ជាអ្នកមានបុណ្យច្រើនទាំង ៥ នាក់ នៅក្នុងដែនព្រះបាទពិម្ពិសារ ឯក្នុងដែនរបស់អញ បុគ្គលមានសភាពបែបនោះ សូម្បីតែម្នាក់ក៏មិនមាន ។ កុំដូច្នោះទៀយ អញគប្បីទៅកាន់សម្នាក់របស់ព្រះបាទពិម្ពិសារ សុំអ្នកមានបុណ្យច្រើនណាម្នាក់ ។

ទ្រង់យាងទៅក្នុងនគរនោះហើយ កាលព្រះរាជា ទ្រង់ធ្វើបដិសណ្ឋារៈទូលសួរថា ទ្រង់យាងមកព្រោះហេតុអ្វី ទើបត្រាស់ថា ខ្ញុំមកដោយបំណងថា បុគ្គលមានភោគៈរាប់មិនអស់ មានបុណ្យច្រើនទាំង ៥ នាក់ នៅក្នុងដែនរបស់ទ្រង់ ខ្ញុំនឹងនាំយកបុគ្គលណាម្នាក់ ក្នុងបណ្តាជនទាំង ៥ នោះទៅ សូមទ្រង់

ប្រទានបុគ្គលណាម្នាក់ក្នុងជនទាំង ៥ នោះដល់ខ្ញុំចុះ ព្រះបាទពិម្ពិសារត្រាស់ ថា ខ្ញុំមិនអាចឲ្យត្រកូលធំៗ ផ្ទាស់ទីកន្លែងបាន ព្រះបាទបសេនទិកោសល ត្រាស់ថា បើខ្ញុំមិនបាន ក៏មិនទៅ ។

ព្រះរាជា ទ្រង់ប្រឹក្សាជាមួយពួកអមាត្យហើយត្រាស់ថា ឈ្មោះថា ការ បំបែកត្រកូលធំៗ មានជោតិកត្រកូលជាដើម ហាក់ដូចជាធ្វើផែនដីឲ្យកម្រើក ។ កូនរបស់មេណ្ឌកមហាសេដ្ឋី ឈ្មោះធនញ្ជយសេដ្ឋីមាន ទូលបង្គំប្រឹក្សាជា មួយគាត់ស្រេចហើយ និងថ្វាយចម្ងើយដល់ព្រះអង្គ ដូច្នេះហើយ បញ្ជូឲ្យ ហៅធនញ្ជយសេដ្ឋីមកហើយត្រាស់ថា នែបា ព្រះបាទកោសលត្រាស់ថា នឹង នាំយកសេដ្ឋីមានទ្រព្យម្នាក់ទៅ ចូរអ្នកទៅជាមួយព្រះអង្គចុះ ធនញ្ជយសេដ្ឋី ពោលថា បើទ្រង់បញ្ជូនទូលបង្គំទៅ ទូលបង្គំនឹងទៅ ព្រះបាទពិម្ពិសារត្រាស់ ថា បើដូច្នោះ ចូរអ្នកត្រៀមទៅចុះ សេដ្ឋីនោះបានធ្វើកិច្ចដែលគួរធ្វើរបស់ ខ្លួនហើយ ចំណែកព្រះរាជាទ្រង់ធ្វើសក្ការៈធំដល់សេដ្ឋីនោះ ទ្រង់បញ្ជូនព្រះ បាទបសេនទីកោសល ទៅដោយព្រះតម្រាស់ថា សូមទ្រង់នាំសេដ្ឋីនោះទៅ ចុះ ។ ព្រះរាជានាំធនញ្ជយសេដ្ឋីនោះយាងទៅ ដោយការស្នាក់នៅមួយរាត្រី ក្នុងទីទាំងពួង សម្រេចដល់ទីដែលជាផាសុកមួយកន្លែងហើយក៏ឈប់ ។

គ្រានោះ ធនញ្ជយសេដ្ឋីទូលសួរព្រះរាជាថា នេះជាដែនរបស់អ្នកណា ព្រះបាទបសេនទិកោសលត្រាស់ថា លោកសេដ្ឋី គឺរបស់យើង ធនញ្ជយ ពោលថា ក្រុងសាវត្ថី បន្ទាប់អំពីនេះទៅចម្ងាយប៉ុន្មាន ព្រះបាទបសេនទិកោ- សលត្រាស់ថា ក្នុងទីបំផុត ៧ យោជន៍ ។ ធនញ្ជយសេដ្ឋីពោលថា ខាង

ក្នុងព្រះនគរចង្អៀត បរិវារជនរបស់ទូលបង្គំមានច្រើន បើទ្រង់អនុគ្រោះសោត ខ្ញុំព្រះអង្គគប្បីនៅក្នុងទីនេះឯង ព្រះរាជាត្រាស់ថា សាធុ ដូច្នេះហើយ បានឲ្យសាងក្រុងក្នុងទីនោះ បានព្រះរាជទានដល់សេដ្ឋីនោះហើយយាងទៅ ។ ក្រុងបានឈ្មោះថា **សាកេត** ព្រោះកាពនៃទីលំនៅក្នុងប្រទេសនោះ ដែលសេដ្ឋីចងចិត្តទុកហើយក្នុងពេលល្ងាច ។

ក្នុងក្រុងសាវត្ថី កូនរបស់មិគាសេដ្ឋី ឈ្មោះបុណ្ណវឌ្ឍនកុមារ ចម្រើនវយហើយ គ្រានោះ មាតាបិតាពោលនឹងបុណ្ណវឌ្ឍនៈថា នែបា ចូរបាជ្រើសរើសទារិកាម្នាក់ ក្នុងទីជាទីពេញរបស់បាចុះ ។ បុណ្ណវឌ្ឍនកុមារពោលថា កិច្ចដោយករិយារបស់ខ្ញុំមិនមាន មាតាបិតាពោលថា បាកុំធ្វើយ៉ាងនេះ ធម្មតាត្រកូលដែលមិនមានកូន តាំងនៅមិនបាន ។

កុមារត្រូវមាតាបិតានិយាយពន្យល់ហើយ ទើបពោលថា បើដូច្នោះ ខ្ញុំកាលបានស្ត្រីប្រកបដោយលម្អ ៥ យ៉ាង នឹងធ្វើតាមពាក្យពុកម៉ែ មាតាបិតាពោលថា ឈ្មោះថា លម្អ ៥ យ៉ាងនោះ គឺអ្វី បុណ្ណវឌ្ឍនកុមារពោលថា គឺលម្អសក់ លម្អសាច់ លម្អធ្មឹង លម្អស្បែក លម្អវយ ។ សក់របស់ស្រីដែលមានបុណ្យច្រើន ដូចគ្នានឹងកាំនៃកន្ទុយក្ងោក ធ្លាក់រំសាយដល់ជាយសំពត់ស្លៀកហើយ ក៏មានចុង-ងឡើងតាំងនៅ ។ នេះ ឈ្មោះថា ល្អសក់ បបូរមាត់ដូចគ្នានឹងផ្ទែបាសទុំ ដល់ព្រមដោយពណ៌រាបស្មើល្អ នេះ ឈ្មោះថា លម្អសាច់ ។ ធ្មញសរាបស្មើមិនរង្វើល ស្អាតដូចជួរនៃពេជ្រដែលគេតម្រៀបនិងដូចជួរនៃសង្ខដែលគេខាត់ល្អហើយ នេះ ឈ្មោះថា លម្អធ្មឹង ។ ពណ៌

សម្បុរបស់ស្រីខ្មៅ មិនលាបដោយគ្រឿងលាបជាដើម ក៏ខ្មៅសុទ្ធ ប្រៀបដូចកម្រងផ្កាឧប្បលខៀវរបស់ស្រីដែលស ប្រៀបដូចកម្រងផ្កាកណិការ នេះឈ្មោះថា លម្អស្បែក ។ ស្រីដែលប្រសូតហើយ ១០ ជង ដូចប្រសូតម្តងនៅក្នុងជដែល នេះ ឈ្មោះថា លម្អវ័យ ។

គ្រានោះ មាតាបិតារបស់នាយបុណ្ណវឌ្ឍនកុមារនោះ អញ្ជើញព្រាហ្មណ៍ ១០៨ នាក់ ឲ្យមកបរិភោគហើយ សួរថា ឈ្មោះថា ស្រីដែលត្រូវដោយលក្ខណៈបញ្ចកល្យាណីមានឬ ព្រាហ្មណ៍ឆ្លើយថា មាន សេដ្ឋីពោលថា បើដូច្នោះ ជន ៨ នាក់ ចូរទៅស្វែងរកទារិកាបែបនេះ ដូច្នេះហើយ ឲ្យទ្រព្យជាច្រើន ប្រាប់ថា ក្នុងកាលពួកអ្នកត្រឡប់ យើងខ្ញុំនឹងជីងវត្ថុដែលគួរធ្វើដល់ពួកអ្នក អ្នកទាំងឡាយ ចូរទៅស្វែងរកស្ត្រីបែបនោះចុះ ក្នុងកាលដែលអ្នកជួបហើយ គប្បីពាក់កម្រងមាសនេះ ដូច្នេះហើយ ឲ្យកម្រងផ្កាមាសដែលមានតម្លៃមួយសែន បញ្ជូនទៅហើយ ។

ព្រាហ្មណ៍ទាំងនោះ ទៅកាន់នគរធំៗ ស្វែងរក មិនឃើញស្រីដែលត្រូវដោយលក្ខណៈបញ្ចកល្យាណី ត្រឡប់មកដល់ក្រុងសាកេតដោយលំដាប់ ក្នុងថ្ងៃមានបុណ្យនក្ខត្តឫក្ស ទើបគិតគ្នាថា ការងារបស់ពួកយើងគង់សម្រេចក្នុងថ្ងៃនេះ ។

ក្នុងនគរនោះ ឈ្មោះថា បុណ្យនក្ខត្តឫក្ស រមែងមានប្រចាំឆ្នាំ ។ ក្នុងកាលនោះ សូម្បីត្រកូលដែលមិនចេញខាងក្រៅ ក៏ចេញអំពីផ្ទះជាមួយបរិវារមានរាងកាយមិនបានបិទបាំង ទៅកាន់ស្ទឹងដោយជើងនោះឯង ក្នុងថ្ងៃនោះ

សូម្បីកូនទាំងឡាយរបស់ខត្តិយមហាសាលជាដើម ក៏ឈរក្បែរផ្លូវនោះៗ ដោយតាំងចិត្តថា ពួកយើងជួបទារិកាដែលមានត្រកូល ដែលគួរពេញចិត្ត មានជាតិស្មើគ្នាហើយ នឹងពាក់ដោយកម្រងផ្កា ។

ព្រាហ្មណ៍ទាំងនោះទៅដល់សាលាមួយ ជិតឆ្នេរស៊ីងហើយ ក៏ឈរ ។ ខណៈនោះ នាងវិសាខាមានអាយុ ១៥-១៦ ឆ្នាំ ប្រដាប់ដោយគ្រឿងអាភរណៈគ្រប់យ៉ាង ដែលពួកកុមារី ៥០០ ចោមរោមហើយ គិតថា អញនឹងទៅកាន់ស៊ីងហើយ ងូតទឹក ដល់បទេសនោះហើយ ។ គ្រានោះឯង ពពកតាំងខ្ពើង ក៏ញាំងភ្លៀងឲ្យធ្លាក់ ។ ទារិកា ៥០០ រួតរះជើរចូលកាន់សាលា ពួកព្រាហ្មណ៍ពិចារណាមើល ក៏មិនឃើញក្មេងស្រីទាំងនោះ សូម្បីត្រឹមតែម្នាក់ ដែលត្រូវដោយលក្ខណៈបញ្ចកល្យាណី ។ នាងវិសាខាចូលទៅកាន់សាលា ដោយការជើរតាមប្រក្រតីនោះឯង សំពត់ និងអាភរណៈសើមជោក ។ ពួកព្រាហ្មណ៍ឃើញលម្អ ៤ យ៉ាងរបស់នាងហើយ បំណងនឹងឃើញធ្មេញ ទើបពោលនឹងគ្នាថា កូនស្រីរបស់យើងជាស្រីយឺតយាវ ប្តីរបស់ស្រីនេះប្រហែលជាមិនបាន សូម្បីត្រឹមតែចុងអង្គរ ពេលនោះ វិសាខាពោលនឹងព្រាហ្មណ៍នោះយ៉ាងនេះថា ពួកលោកថាឲ្យអ្នកណា ព្រាហ្មណ៍ពោលថា ខ្ញុំថាឲ្យនាងហ្នឹង ។

បានឮថា សំឡេងដ៏ពីរោះរបស់នាង បានបង្ហើរចេញប្រៀបដូចសំឡេងជួង លំដាប់នោះ ទើបនាងសួរព្រាហ្មណ៍ទាំងនោះ ដោយសំឡេងដ៏ពីរោះទៀតថា ព្រោះហេតុអ្វី ទើបថាឲ្យខ្ញុំ ព្រាហ្មណ៍ពោលថា ស្រីបរិវារបស់

នាងមិនឲ្យសំពត់ និងគ្រឿងអលង្ការសើម ប្រញាប់ចូលកាន់សាលា កិច្ច សូម្បីត្រឹមតែការប្រញាប់មកកាន់ទីប្រមាណប៉ុណ្ណោះរបស់នាង មិនមាន នាង បណ្តាយឲ្យសំពត់ និងគ្រឿងអាភរណៈសើមហើយ ព្រោះដូច្នោះ ទើបពួក យើងនាំគ្នាថា នាងវិសាខាពោលថា លោកឪពុកទាំងឡាយ ពួកលោកកុំ ពោលយ៉ាងនេះ ខ្ញុំរឹងមាំជាងក្មេងស្រីទាំងនោះ តែខ្ញុំកំណត់ហេតុការណ៍ហើយ ទើបមិនមកដោយរហ័ស ព្រាហ្មណ៍ពោលថា នែនាង តើហេតុអ្វីទៅ នាង វិសាខាពោលថា លោកឪពុកទាំងឡាយ ជន ៤ ពួករត់រមែងមិនល្អជាហេតុ ១ សូម្បីហេតុដទៃទៀត ក៏នៅមាន ព្រាហ្មណ៍ពោលថា ជន ៤ ពួក ពួក ណាខ្លះ កាលរត់ មិនល្អ នាងវិសាខាពោលថា លោកឪពុកទាំងឡាយ ព្រះ រាជាដែលអភិសេកហើយ ទ្រង់គ្រឿងអលង្ការហើយ ដោយអាភរណៈទាំង ពួង កាលចង់ក្បួនរត់ទៅក្នុងលានព្រះរាជវាំង មិនល្អ តែងបានទួរការនិទ្ទា ដោយពិតប្រាកដថា ហេតុអ្វី ទើបព្រះរាជាអង្គនេះរត់ដូចគហបតី ទ្រង់យាង ទៅសន្សឹមៗ នោះឯង ទើបល្អ ជីវមង្គលរបស់ព្រះរាជា ដែលតាក់តែងគ្រឿង អលង្ការហើយ រត់ទៅក៏មិនល្អ លុះតែដើរទៅដោយហត្ថិលីលា ទើបល្អ ។ បព្វជិតកាលរត់ក៏មិនល្អ រមែងបានទួរការនិទ្ទាតែម្យ៉ាងប៉ុណ្ណោះថា ហេតុអ្វី ទើបសមណៈរូបនេះរត់ទៅដូចគ្រហស្ថ តែរមែងស្អាតដោយការដើរ ដោយ អាការរបស់អ្នកស្ងប់ស្ងៀម ស្ត្រីកាលរត់ក៏មិនល្អ ត្រូវគេតិះដៀលតែម្យ៉ាងថា ហេតុអ្វី ទើបស្រីនេះរត់ដូចបុរស តែរមែងល្អដោយការដើរតាមធម្មតា នៃ លោកឪពុកទាំងឡាយ ជន ៤ ពួកនេះ បើរត់ទៅ មិនល្អ ។

ព្រាហ្មណ៍ពោលថា ហេតុដទៃទៀតនៅមានដូចម្តេច នាងវិសាខាពោលថា លោកឪពុកទាំងឡាយ ធម្មតាមាតាបិតាថែរក្សាអវយវៈតូចធំ មើលថែរក្សាកូនស្រី ព្រោះថា ពួកខ្ញុំ ឈ្មោះថា ជារបស់ដែលមាតាបិតាគប្បីលក់ដូរ មាតាបិតាចិញ្ចឹមខ្ញុំមក ដើម្បីបញ្ជូនទៅកាន់ត្រកូលដទៃ បើក្នុងកាលពួកខ្ញុំរត់ទៅជាន់ជាយសំពត់ ឬជួលចុះត្រង់ផែនដី ដៃ ឬជើងគប្បីបាក់ ពួកខ្ញុំក៏គប្បីជាការៈរបស់ត្រកូលនោះឯង ចំណែកគ្រឿងអលង្ការសើមហើយក៏និងស្ងួត ខ្ញុំកំណត់ហេតុនេះ ទើបមិនរត់ ពួកព្រាហ្មណ៍ឃើញការដល់ព្រមនៃធ្មេញ ក្នុងកាលដែលនាងនិយាយ ទើបឲ្យសាធុការដល់នាងថា សម្បត្តិបែបនេះ ពួកយើងមិនធ្លាប់ឃើញទ្បើយ ហើយពោលថា នែនាង កម្រងផ្កានេះ សមគួរដល់នាងប៉ុណ្ណោះ ដូច្នេះហើយ ទើបបំពាក់កម្រងផ្កាមាសនោះឲ្យ លំដាប់នោះ ទើបនាងសួរពួកព្រាហ្មណ៍ថា លោកឪពុកទាំងឡាយ ពួកលោកមកអំពីនគរណា ព្រាហ្មណ៍ពោលថា មកអំពីនគរសាវត្ថី នាងវិសាខាពោលថា ត្រកូលសេដ្ឋីឈ្មោះអ្វី ព្រាហ្មណ៍ពោលថា ឈ្មោះមិគារសេដ្ឋី នាងវិសាខាពោលថា កូនប្រុសរបស់លោកឈ្មោះអ្វី ព្រាហ្មណ៍ពោលថា ឈ្មោះបុណ្ណវឌ្ឍនកុមារ ។

នាងវិសាខាទទួលថា ត្រកូលរបស់យើងស្មើគ្នា ដូច្នេះហើយ ទើបបញ្ជូនដំណឹងដល់បិតាថា សូមលោកឪពុកអ្នកម្តាយ បញ្ជូនរថមកឲ្យខ្ញុំចុះ ។ ក្នុងកាលដែលមក នាងដើរមកក៏ពិត តែកាលដែលប្រដាប់ដោយកម្រងផ្កាមាសហើយ មិនបានទៅដូច្នោះ ឃើញស្រីទាំងឡាយដែលមានឥស្សរៈ រមែងទៅដោយយាន មានរថជាដើម ស្រីក្រៅអំពីនេះឡើងយានធម្មតា ជាំងធត្រ ឬ

ស្លឹកត្នោតខាងលើ កាលធត្រ ឬស្លឹកត្នោតនោះមិនមាន ក៏លើកជាយសំពត់ឡើងមកបាំងលើស្មានោះឯង ។ ចំណែកបិតារបស់នាងវិសាខានោះ បញ្ជូនរថទៅ ៥០០ គ្រឿង នាងវិសាខាឡើងរថទៅហើយ សូម្បីពួកព្រាហ្មណ៍ក៏បានទៅជាមួយគ្នា ។

ពេលនោះ លោកសេដ្ឋីសួរព្រាហ្មណ៍ទាំងនោះថា ពួកអ្នកមកអំពីណា ព្រាហ្មណ៍ពោលថា បពិត្រលោកសេដ្ឋី ខ្ញុំមកពីក្រុងសាវត្ថី សេដ្ឋីពោលថា សេដ្ឋីរបស់អ្នកឈ្មោះអ្វី ព្រាហ្មណ៍ពោលថា ឈ្មោះមិគារសេដ្ឋី សេដ្ឋីពោលថា កូនរបស់គេឈ្មោះអ្វី ព្រាហ្មណ៍ពោលថា ឈ្មោះបុណ្ណវឌ្ឍនកុមារ សេដ្ឋីពោលថា មានទ្រព្យប៉ុន្មាន ព្រាហ្មណ៍ពោលថា បពិត្រលោកសេដ្ឋី ៤០ កោដិ សេដ្ឋីស្តាប់ពាក្យហើយគិតថា ទ្រព្យប៉ុណ្ណោះ បើប្រៀបធៀបនឹងទ្រព្យរបស់ខ្ញុំស្មើគ្នានឹងមួយកាកណិក ។ តែប្រយោជន៍អ្វីដោយហេតុដទៃ ចាប់តាំងអំពីកាលដែលនាងទាវិកា បានហេតុត្រឹមតែការរក្សា សេដ្ឋីនោះធ្វើសក្ការៈដល់ព្រាហ្មណ៍ទាំងនោះ ឲ្យស្នាក់នៅ ២-៣ ថ្ងៃ ហើយបញ្ជូនត្រឡប់ទៅ ។

ពួកព្រាហ្មណ៍ទៅកាន់ក្រុងសាវត្ថីហើយ ជម្រាបលោកសេដ្ឋីថា ពួកខ្ញុំបាននាងទាវិកាហើយ សេដ្ឋីពោលថា កូនស្រីរបស់អ្នកណា ព្រាហ្មណ៍ពោលថា របស់ធនញ្ជយសេដ្ឋី សេដ្ឋីនោះគិតថា នាងទាវិកានៃត្រកូលធំដែលយើងបានហើយ យើងគួរតែនាំនាងមកដោយរហ័ស ដូច្នេះហើយ ក្រាបទូលដល់ព្រះរាជា ដើម្បីទៅក្នុងក្រុងនោះ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា ត្រកូលធំនោះ យើងនាំមកអំពីសម្ងាត់របស់

ព្រះបាទពិម្ពិសារ ហើយឲ្យនៅអាស្រ័យក្នុងក្រុងសាកេត គួរធ្វើការលើកតម្កើងដល់ត្រកូលនោះ ដូច្នេះហើយ ត្រាស់ថា សូម្បីយើងក៏ទៅ ។ សេដ្ឋីទូលថា សាធុ ព្រះអង្គ ដូច្នេះហើយ ក៏បញ្ជូនដំណឹងទៅប្រាប់ដល់ធនញ្ជយសេដ្ឋីថា កាលខ្ញុំមក ព្រះរាជាក៏នឹងយាងមក ពលរបស់ព្រះរាជាច្រើន អ្នកនឹងអាចធ្វើកិច្ចដែលគួរធ្វើ ដល់ជនមានប្រមាណប៉ុណ្ណោះ ឬក៏មិនអាចទេ ។

សេដ្ឋីបានបញ្ជូនដំណឹងទៅថា សូម្បីព្រះរាជាទ្រង់យាងមកត្រឹម ១០ អង្គ ក៏សូមយាងមកចុះ ។ មិគារសេដ្ឋីវៀរត្រឹមតែអ្នកយាមផ្ទះ នាំជនដ៏សេសក្នុងនគរធំ ដែលមានប្រមាណប៉ុណ្ណោះទៅ ឈប់សម្រាកក្នុងរវាងផ្លូវកន្លះយោជន៍ ហើយ បញ្ជូនដំណឹងទៅថា ពួកខ្ញុំមកហើយ ។

ធនញ្ជយសេដ្ឋី បញ្ជូនគ្រឿងបណ្ណាការជាច្រើនទៅ ហើយប្រឹក្សានឹងកូនស្រីថា នែនាង បានឮថា ឪពុកក្មេករបស់នាង មកជាមួយព្រះបាទកោសល យើងគួរវៀបចំផ្ទះមួយណា សម្រាប់ឪពុកក្មេករបស់នាង ផ្ទះខ្នងណាសម្រាប់ព្រះរាជា ផ្ទះខ្នងណាសម្រាប់ឥស្សរជន មានឧបរាជជាដើម សេដ្ឋីធីតាអ្នកឈ្លាស មានញាណមុតស្រួចដូចកំពូលពេជ្រ តាំងសេចក្តីប្រាថ្នាអស់សែនកប្ប បរិបូណ៌ហើយដោយអភិនីហារ ប្រាប់ថា អ្នកទាំងឡាយ ចូរវៀបចំផ្ទះមួយនោះ ដើម្បីឪពុកក្មេករបស់យើង ផ្ទះមួយនោះ ដើម្បីព្រះរាជា ផ្ទះមួយនោះ ដើម្បីឧបរាជជាដើម ដូច្នេះហើយ ឲ្យហៅទាសៈ និងកម្មករមកប្រាប់ថា ពួកអ្នកប៉ុណ្ណោះនាក់ ចូរធ្វើកិច្ចដែលគួរធ្វើដល់ព្រះរាជា ប៉ុណ្ណោះនាក់ ចូរធ្វើកិច្ចដែលគួរធ្វើដល់ឧបរាជជាដើម ពួកអ្នកនោះឯង ចូរមើលថែពាហនៈ មានដំរី

និងសេះជាដើម ។ សូម្បីអ្នកចងសេះជាដើមមកដល់ហើយ និងបានសរសើរ មហោស្រព ក្នុងការងារមង្គល ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមនុស្សពួកខ្លះ កុំបីមានពាក្យ ពោលថា អញ្ជើមង្គលនៃនាងវិសាខា មិនបានអ្វីសោះ ធ្វើតែកិច្ចមានការ ឃ្វាលសេះជាដើម មិនបានដើរតាមសប្បាយ ។

ក្នុងថ្ងៃនោះឯង បិតារបស់នាងវិសាខាបានហៅជាងមាស ៥០០ នាក់ មកហើយ ពោលថា ពួកអ្នកចូរធ្វើគ្រឿងអលង្ការឈ្មោះមហាលតាបសាធន៍ ដល់កូនស្រីរបស់ខ្ញុំ ដូច្នេះហើយ បញ្ជាឲ្យយកមាស និងប្រាក់ កែវមណី កែវមុក្តា កែវប្រពាល និងពេជ្រជាដើម លុមសមគ្នានឹងមាសនោះ ។

ព្រះរាជាប្រថាប់នៅ ២-៣ ថ្ងៃហើយ ទ្រង់បញ្ជូនដំណឹងទៅដល់ធនញ្ជយ-សេដ្ឋីថា សេដ្ឋីមិនអាចធ្វើការអង្គាសពួកយើងបានទេ ចូរសេដ្ឋីដឹងកាលទៅ នៃនាងទាវិកាចុះ ។

ចំណែកសេដ្ឋីនោះ បញ្ជូនដំណឹងទៅទូលព្រះរាជាថា ឥឡូវនេះ រដូវ ភ្លៀងមកដល់ហើយ បុគ្គលណាម្នាក់ មិនអាចត្រាច់ទៅអស់កាល ៤ ខែបាន ការដែលពួកពលរបស់ព្រះអង្គបានវត្ថុណាមួយសមគួរ វត្ថុទាំងអស់នោះ ជាការៈរបស់ទូលបង្គំ ទ្រង់នឹងយាងទៅបាន ក្នុងកាលដែលទូលបង្គំបញ្ជូនទ្រង់ទៅ ។ ចាប់តាំងអំពីកាលនោះ នគរសាកេតបានជានគរ ហាក់ដូចជាមាន នក្ខត្តឫក្សជានិច្ច ។

វត្ថុមានកម្រងផ្កា គ្រឿងក្រអូប និងសំពត់ជាដើម ជារបស់ដែលសេដ្ឋី

នោះរៀបចំហើយ ដល់ជនទាំងអស់ ចាប់តាំងអំពីព្រះរាជាជាដើម ។ ជនទាំងនោះគិតគ្នាថា សេដ្ឋីធ្វើសក្ការៈដល់ពួកយើងតែម្យ៉ាងអស់កាល ៣ ខែហើយ ដោយអាការយ៉ាងនេះ ។ ចំណែកគ្រឿងប្រដាប់ក៏មិនទាន់សម្រេច អ្នកគ្រប់គ្រងការងារមកប្រាប់ដល់សេដ្ឋីថា វត្ថុដទៃដែលឈ្មោះថាមិនមាន ក៏មិនមាន ។ តែខសសម្រាប់ចម្អិនបបរ និងភត្តដើម្បីពួកពលមិនគ្រប់គ្រាន់ ។ សេដ្ឋីពោលថា ទៅចុះបាទាំងឡាយ ចូរពួកអ្នកជញ្ជូនយករោងដំរីចាស់ៗ ជាដើម និងផ្ទះចាស់ៗ ក្នុងនគរនេះ ដុតដាំស្ងចុះ ។

កាលដាំស្ងយ៉ាងនេះ កន្ងះខែកន្ងងទៅហើយ លំដាប់នោះ អ្នកគ្រប់គ្រងការងារមកប្រាប់ដល់លោកសេដ្ឋីម្តងទៀតថា ខសមិនមាន សេដ្ឋីពោលថា បុគ្គលណាម្នាក់ មិនអាចបានខសក្នុងពេលនេះ ចូរពួកអ្នកបើកឃ្ងាំងសំពត់ទាំងឡាយ ហើយយកសំពត់សាច់គ្រោតគ្រាត មូរជាធ្ងុងជ្រលក់ប្រេងដាំស្ងចុះ ។ ជនទាំងនោះ បានធ្វើយ៉ាងនោះអស់កន្ងះខែ ។ ៤ ខែកន្ងងទៅហើយ ដោយអាការយ៉ាងនេះ ។ សូម្បីគ្រឿងប្រដាប់ក៏សម្រេចហើយ ។

ពេជ្ជ ៤ នាឡិ បានដល់ការប្រកបចូលក្នុងគ្រឿងប្រដាប់នោះ កែវមុក្តា ១១ នាឡិ កែវប្រពាល ២០ នាឡិ កែវមណី ៣៣ នាឡិ គ្រឿងប្រដាប់នោះ ដល់នូវការសម្រេចដោយរតនៈទាំងនេះឯង និងរតនៈដទៃ ដោយប្រការដូច្នេះ ។ គ្រឿងប្រដាប់មិនសម្រេចដោយអំបោះ ការងារដែលធ្វើដោយអំបោះ គេធ្វើហើយដោយប្រាក់ គ្រឿងប្រដាប់នោះ ពាក់ត្រង់ក្បាលហើយ ទៅទល់គ្នានឹងខ្នងជើង ឡេវដែលគេប្រកបក្នុងទីនោះៗ ធ្វើដោយមាស អន្ទាក់

ឡេវ ធ្វើដោយប្រាក់ ឡេវមួយជាក់ត្រង់កណ្តាលក្បាល ឡេវពីរជាក់ត្រង់ត្រចៀកទាំងសងខាង ឡេវមួយជាក់ត្រង់កញ្ចឹង-ក ឡេវពីរជាក់ត្រង់ជង្គង់ទាំងពីរ ឡេវពីរជាក់ត្រង់កែងដៃទាំងពីរ ឡេវពីរជាក់ត្រង់ចង្កេះទាំងសងខាង ។ ក្នុងគ្រឿងប្រដាប់នោះឯង គេធ្វើក្លោកមួយ រោមស្ងាបស្តាំ ៥០០ ធ្វើដោយមាស រោមស្ងាបឆ្វេង ៥០០ ចំពុះធ្វើដោយកែវប្រពាល ក្អែកធ្វើដោយកែវមណី ក និងកន្ទុយក៏ដូចគ្នា ឆ្អឹងទ្រនុងស្ងាបធ្វើដោយប្រាក់ ជើងក៏ដូចគ្នា ក្លោកនោះ ស្ថិតនៅត្រង់កណ្តាលក្បាលនៃនាងវិសាខា ប្រាកដហាក់បីដូចក្លោកពេនពង់លើកំពូលភ្នំ ។ សំឡេងស្ងាបមួយពាន់ ប្រព្រឹត្តទៅប្រៀបដូចទិព្វសង្គីតៈ និងប្រៀបដូចសំឡេងគឹកកង នៃតន្ត្រីប្រកបដោយអង្គ ៥ ។ ជនទាំងឡាយដែលចូលទៅកាន់ទីជិតប៉ុណ្ណោះ ទើបដឹងថា ក្លោកនោះ មិនមែនក្លោកពិត ។ គ្រឿងប្រដាប់មានតម្លៃ ៩ កោដិ លោកសេដ្ឋី បានឲ្យតម្លៃហត្ថកម្ម ១ សែន ។

សួរថា គ្រឿងប្រដាប់នោះ នាងវិសាខានោះបានហើយ ព្រោះផលនៃកម្មដូចម្តេច ឆ្លើយថា បានឮថា ក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ នាងថ្វាយចីវរសាដកដល់ភិក្ខុ ២ ម៉ឺនរូបហើយ បានប្រគេនអំបោះខ្លះ ម្ជុលខ្លះ គ្រឿងជ្រលក់ខ្លះ ដែលជារបស់ខ្លួននោះឯង នាងបានហើយនូវគ្រឿងប្រដាប់នោះ ព្រោះផលនៃចីវរទាននោះ ។ ចីវរទានរបស់ស្រីទាំងឡាយ រមែងដល់ទីបំផុតដោយគ្រឿងប្រដាប់ឈ្មោះមហាលតាបសាធន៍ ។ ចីវរទានរបស់បុរសទាំង-ឡាយ រមែងដល់ទីបំផុតដោយបាត្រ និងចីវរ ដែលសម្រេចហើយដោយឫទ្ធិ ។

មហាសេដ្ឋីធ្វើការត្រៀមដើម្បីកូនស្រីអស់កាល ៤ ខែយ៉ាងនោះហើយ កាលនឹងឲ្យទេយ្យធម៌ដល់កូនស្រីនោះ បានឲ្យរទេះពេញដោយកហាបណៈ ៥០០ បានឲ្យរទេះពេញដោយកាជន៍មាស ៥០០ ពេញដោយកាជន៍ប្រាក់ ៥០០ ពេញដោយកាជន៍ទង់ដែង ៥០០ ពេញដោយកាជន៍សីរ៉ឹទ្ធ ៥០០ ពេញដោយសំពត់សូត្រ ៥០០ ពេញដោយសប្បិ ៥០០ ពេញដោយប្រេង ៥០០ ពេញដោយទឹកអំពៅ ៥០០ ពេញដោយអង្ករ ៥០០ ពេញដោយស្រូវសាលី ៥០០ ពេញដោយគ្រឿងឧបករណ៍ មានឆ្នាំល និងផាល ៥០០ ។

បានឮថា ការគិតយ៉ាងនេះមានដល់មហាសេដ្ឋីនោះថា ក្នុងទីកន្លែងដែលកូនស្រីរបស់យើងទៅហើយ នាងកុំចាំបាច់បញ្ជូនមនុស្សទៅកាន់ទ្វាររបស់អ្នកដទៃថា ខ្ញុំត្រូវការដោយវត្ថុឈ្មោះនោះ ព្រោះដូច្នោះ ទើបមហាសេដ្ឋីបានឲ្យគ្រឿងឧបករណ៍គ្រប់យ៉ាង ។ មហាសេដ្ឋីបានឲ្យរថ ៥០០ អ្នកបម្រើរូបស្អាតដែលប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង លើរទេះមួយបីនាក់ៗ ។ បានឲ្យនាងបារិចារិកា ១ ពាន់ ៥០០ នាក់ ដោយប្រាប់ថា ពួកអ្នកប៉ុណ្ណោះចូរឲ្យកូនរបស់យើងងូត ប៉ុណ្ណោះចូរឲ្យបរិភោគ ប៉ុណ្ណោះជាអ្នកតែងខ្លួនត្រាច់ទៅ ។

គ្រានោះ មហាសេដ្ឋីមានការគិតយ៉ាងនេះថា អញនឹងឲ្យគោដល់កូនស្រីរបស់អញ លោកបញ្ជាបុរសថា នែអ្នក ចូរពួកអ្នកទៅបើកទ្វារក្រោលតូចហើយ ឈរវាយស្គរបីនៅក្នុងទី ៣ គាវុត ឈរក្នុងទីទាំងសងខាង ក្នុងទីប្រមាណ ១ ឧសភៈ ដោយចំណែកទទឹង បន្ទាប់អំពីនោះ ចូរកុំឲ្យមេគោទាំងឡាយទៅទីដទៃ គប្បីវាយស្គរសញ្ញា ក្នុងកាលមេគោឈប់ហើយយ៉ាង

នេះ ។ បុរសទាំងនោះ បានធ្វើយ៉ាងនោះហើយ ។ កាលមេគោចេញអំពីក្រោលបាន ១ គាវុត ពួកគេបានវាយស្គរសញ្ញាឡើង ក្នុងវេលាមេគោទៅបានកន្លះយោជន៍ បានវាយស្គរឲ្យសញ្ញាទៀត ក្នុងពេលមេគោទៅបាន ៣ គាវុត ពួកគេបានហាមការទៅដោយចំណែកទទឹងទៀត មេគោទាំងឡាយបានឈរប្រជ្រៀតគ្នា ក្នុងទីប្រមាណ ៣ គាវុត ទទឹងប្រមាណ ១ ឧសភៈដោយប្រការដូច្នោះ ។

មហាសេដ្ឋី បានឲ្យបិទទ្វារក្រោលដោយពាក្យថា គោប្រមាណប៉ុណ្ណេះ ល្មមហើយដល់ធីតារបស់ខ្ញុំ ចូរពួកអ្នកបិទទ្វារចុះ ។ កាលគេបិទទ្វារក្រោលហើយ ព្រោះផលបុណ្យរបស់នាងវិសាខា គោដែលមានកម្ទាំង និងមេគោទឹកដោះទាំងឡាយ ក៏លោតចេញទៅហើយ ។ កាលពួកមនុស្សឃ្លាត់នោះឯង គោដែលមានកម្ទាំង ៦ ម៉ឺន និងមេគោទឹកដោះ ៦ ម៉ឺន ចេញហើយ កូនគោឈ្មោលមានកម្ទាំង មានចំនួនប៉ុណ្ណោះចេញទៅហើយ ពួកគោឧសភៈរបស់មេគោទឹកដោះទាំងនោះ ក៏បានជាប់តាមទៅហើយ ។

សួរថា គោទាំងឡាយទៅហើយយ៉ាងនោះ ព្រោះផលនៃកម្មអ្វី ឆ្លើយថា ព្រោះផលនៃទានដែលនាងវិសាខា បានថ្វាយហើយដល់ភិក្ខុកំលោះ និងសាមណេរដែលកំពុងឃ្លាត់ ។

បានឮថា ក្នុងកាលព្រះកស្សបសម្មាសម្ពុទ្ធ នាងជាបួនពៅរបស់ធីតាទាំង ៧ របស់ព្រះបាទកិកិ ឈ្មោះនាងសង្ឃទាសី កាលថ្វាយបញ្ចគោរសទានដល់ភិក្ខុ ២ ម៉ឺនរូប កាលភិក្ខុកំលោះ និងសាមណេរបិទបាត្រឃ្លាត់ថា ល្មមហើយ

ល្មមហើយ ក៏នៅតែប្រាប់ថា របស់នេះធ្ងាញ់ របស់នេះគួរឆាន់ ហើយបានប្រគេនទៀត ។ ព្រោះផលនៃកម្មនោះ គោទាំងនោះសូម្បីឃាត់ ក៏ចេញទៅហើយយ៉ាងនោះ ។

ក្នុងកាលដែលសេដ្ឋីឲ្យទ្រព្យប៉ុណ្ណោះហើយ ភរិយារបស់សេដ្ឋីបានពោលថា វត្ថុទាំងអស់ដែលអ្នករៀបចំហើយដល់កូនស្រីរបស់យើង តែអ្នកបម្រើប្រុសស្រីដែលធ្វើការបម្រើ អ្នកមិនទាន់បានចាត់ចែង សេចក្តីនោះព្រោះហេតុអ្វី សេដ្ឋីពោលថា បានជាខ្ញុំមិនចាត់ចែង ដើម្បីជីងមនុស្សដែលមានការស្រឡាញ់និងស្អប់ក្នុងកូនស្រីរបស់យើង ព្រោះយើងនឹងចាប់កបុគ្គលដែលមិនទៅជាមួយធីតាបញ្ជូនទៅមិនបាន តែក្នុងកាលឡើងយានទៅនោះឯង ខ្ញុំនឹងពោលថា អ្នកណាចង់ទៅជាមួយនាងវិសាខា ចូរទៅចុះ អ្នកដែលមិនចង់ទៅ កុំទៅ ។

លំដាប់នោះ សេដ្ឋីគិតថា ធីតារបស់អញនឹងទៅស្មែកនេះ អង្គុយក្នុងបន្ទប់ ឲ្យធីតាអង្គុយក្នុងទីជិតហើយ ឲ្យឱវាទថា នែនាង ធម្មតាស្រីដែលនៅក្នុងត្រកូលប្តី រក្សាមារយាទនេះ និងមារយាទនេះ ទើបគួរ សូម្បីមិគារសេដ្ឋីនោះអង្គុយក្នុងបន្ទប់បន្ទាប់នោះ បានឮឱវាទរបស់ធនញ្ជយសេដ្ឋីហើយ ។

ចំណែកធនញ្ជយសេដ្ឋីនោះ ទូន្មានកូនស្រីយ៉ាងនោះហើយ ឲ្យឱវាទ ១០ ថា នែនាង ធម្មតាស្រីដែលនៅក្នុងត្រកូលប្តី មិនគួរនាំភ្លើងខាងក្នុងចេញទៅខាងក្រៅ មិនគួរនាំភ្លើងខាងក្រៅចូលទៅខាងក្នុង គប្បីឲ្យដល់បុគ្គលដែលឲ្យប៉ុណ្ណោះ មិនគប្បីឲ្យដល់បុគ្គលដែលមិនឲ្យ គប្បីឲ្យដល់បុគ្គលដែលឲ្យផង ដែលមិនឲ្យផង គប្បីអង្គុយជាសុខ គប្បីបរិភោគជាសុខ គប្បីដេកជាសុខ

គប្បីបម្រើក្តៅ គប្បីនមស្ការទេវតាខាងក្នុង ដូច្នេះហើយ ក្នុងថ្ងៃស្អែកឡើង ហៅប្រជុំសេនាទាំងអស់ហើយ ទើបកាន់យកកុដុម្ភិកៈ ៨ នាក់ ឲ្យជាអ្នកមើលការខុសត្រូវ ក្នុងជំនុំរាជសេនាហើយពោលថា បើទោសកើតឡើងដល់កូនស្រីរបស់ខ្ញុំក្នុងទីដែលទៅហើយ ពួកអ្នកគប្បីវិនិច្ឆ័យ ដូច្នេះហើយ តាក់តែងធីតាដោយគ្រឿងអលង្ការឈ្មោះមហាលតាបសាធន៍ ដែលមានតម្លៃ ៩ កោដិ ឲ្យទ្រព្យ ៥៤ កោដិ ជាតម្លៃគ្រឿងលម្អិតសម្រាប់ងូត ឲ្យឡើងកាន់យានហើយ ឲ្យមនុស្សវាយស្គរប្រកាសក្នុងស្រុកសួយ ១៤ តំបន់ ដែលជារបស់ខ្លួន ប៉ុនអនុរាធបុរី ជុំវិញក្រុងសាកេតថា អ្នកចង់ទៅជាមួយកូនស្រីរបស់ខ្ញុំ ក៏ចូរទៅចុះ ។

អ្នកស្រុក ១៤ តំបន់បានឮសំឡេង ទើបចេញទៅមិនមានសេសសល់បុគ្គលម្នាក់ឡើយ ដោយគិតថា មានប្រយោជន៍អ្វីដល់ពួកយើងក្នុងទីនេះក្នុងកាលដែលអ្នកនាងរបស់យើងទៅហើយ ។ ចំណែកធនញ្ជយសេដ្ឋី ធ្វើសក្ការៈដល់ព្រះរាជា និងមិគារសេដ្ឋីហើយ ក៏តាមជូនដំណើរធីតាជាមួយនឹងជនទាំងនោះទៅបន្តិច ។

មិគារសេដ្ឋីអង្គុយក្នុងយានតូច ទៅខាងក្រោយយានទាំងអស់ ឃើញពួកពលហើយ ទើបសួរថា ជនទាំងនោះជាអ្នកណា ពួកអ្នកបម្រើជ្រាប់ថាជាទាសី និងទាសៈរបស់កូនប្រសាលោកម្ចាស់ មិគារសេដ្ឋីពោលថា អ្នកណានឹងចិញ្ចឹមមនុស្សមានចំនួនប៉ុណ្ណោះបាន ចូរពួកអ្នកដេញវាយមនុស្សទាំងនោះឲ្យគេចទៅ ចូរទាញពួកជនដែលមិនគេចចេញអំពីទីនេះ នាងវិសាខាពោលថា

ចូរចៀសចេញទៅ កុំឃាត់គេទៀយ ពលទាំងនោះឯង នឹងឲ្យកត្តដល់ពល ។

កាលនាងពោលយ៉ាងនោះ សេដ្ឋីក៏នៅតែពោលថា នែនាង យើងមិនត្រូវការដោយជនទាំងនោះ អ្នកណានឹងចិញ្ចឹមជនទាំងនោះបាន ដូច្នេះហើយ ទើបឲ្យវាយដោយដុំថ្ម ដុំដី និងដំបងជាដើមឲ្យគេចទៅហើយ នាំពួកដ៏សេសទៅដោយគិតថា យើងលួមដោយមនុស្សចំនួនប៉ុណ្ណេះ ។

កាលដល់ទ្វារនគរសាវត្ថី នាងវិសាខាគិតថា អញនឹងអង្គុយក្នុងយានដែលបិទចូលទៅ ឬឈរលើរថចូលទៅ ។ ពេលនោះ នាងបានសម្រេចចិត្តយ៉ាងនេះថា បើអញចូលទៅដោយយានដែលបិទ កាពវិសេសនៃគ្រឿងប្រដាប់ឈ្មោះមហាលតាបសាធន៍ នឹងមិនប្រាកដ ឈរលើរថបង្ហាញខ្លួនដល់អ្នកនគរទាំងមូល ទៅកាន់នគរហើយ ។ អ្នកក្រុងសាវត្ថីឃើញសម្បត្តិរបស់នាងវិសាខាហើយ ទើបនិយាយគ្នាថា ស្រីនោះឈ្មោះវិសាខា សម្បត្តិបែបនេះសមគួរដល់នាងពិត ។

នាងវិសាខានោះ ចូលទៅកាន់ផ្ទះរបស់សេដ្ឋីដោយសម្បត្តិច្រើន ដោយប្រការដូច្នេះឯង ។ ក្នុងថ្ងៃដែលនាងមកដល់ អ្នកនគរទាំងមូលបានបញ្ជូនបណ្ណាការទៅតាមកម្ទាំង ដោយគិតថា ធនញ្ជយសេដ្ឋីបានធ្វើសក្ការៈច្រើនសន្ធឹកសន្ធាប់ដល់ពួកយើង នាងវិសាខាបានឲ្យបណ្ណាការដែលគេបញ្ជូនមកហើយធ្វើឲ្យជាប្រយោជន៍គ្រប់យ៉ាង ក្នុងត្រកូលជានៃៗ ក្នុងនគរនោះឯង ។

នាងពោលពាក្យជាទីស្រឡាញ់ សមគួរដល់វ័យរបស់មនុស្សទាំងនោះថា អ្នកចូរឲ្យវត្ថុនេះដល់អ្នកម៉ែរបស់ខ្ញុំ ចូរឲ្យវត្ថុទាំងនេះដល់លោកឪពុករបស់

ខ្ញុំ ចូរឲ្យវត្ថុនេះដល់បងប្រុស ប្អូនប្រុសរបស់ខ្ញុំ ចូរឲ្យវត្ថុនេះដល់បងស្រីប្អូនស្រីរបស់ខ្ញុំ ដូច្នេះហើយ បញ្ជូនបណ្ណាការទៅ បានធ្វើអ្នកនគរទាំងអស់ឲ្យដូចជាពួកញាតិ ដោយប្រការដូច្នេះ ។

បន្ទាប់មក ក្នុងរវាងកណ្តាលយប់ លាញីជាមេសេះអាជានេយ្យរបស់នាងកើតកូន នាងឲ្យពួកទាសីកាន់យកប្រទីបអុជទៅក្នុងទីនោះហើយ ញុាំងលាឲ្យងូតដោយទឹកក្តៅ ឲ្យលាបដោយប្រេង ហើយបានទៅកាន់លំនៅរបស់ខ្លួនវិញ ។

មិគារសេដ្ឋីកាលធ្វើអាវាហមង្គលរបស់បុត្រ មិនបាននឹកដល់ព្រះតថាគតដែលប្រថាប់នៅក្នុងវិហារជិតឡើយ ឯសេចក្តីស្រឡាញ់ តាំងនៅចំពោះក្នុងពួកសមណៈអាក្រាតអស់កាលយូរ នាំឲ្យគាត់គិតថា អញនឹងធ្វើសក្ការៈដល់លោកម្ចាស់របស់អញ ដូច្នេះហើយ ថ្ងៃមួយ ឲ្យមនុស្សចម្អិនបាយាសដែលមានទឹកតិច ជាក់ក្នុងកាជន៍ថ្មីច្រើនរយសម្រាប់ ឲ្យនិមន្តពួកអចេលក៍ ៥០០ ឲ្យចូលទៅកាន់ផ្ទះហើយ ទើបបញ្ជូនដំណឹងដល់នាងវិសាខាថា កូនប្រសារបស់ខ្ញុំ ចូរមកថ្វាយបង្គំព្រះអរហន្តទាំងឡាយ ។

នាងវិសាខាអរិយសាវិកាជាសោតាបន្ន គ្រាន់តែឮពាក្យថា ព្រះអរហន្តក៏ជាអ្នកត្រេកអរ មកកាន់ទីបរិភោគនៃអចេលក៍ទាំងនោះ សម្ញឹងមើលអចេលក៍ទាំងនោះហើយគិតថា បុគ្គលវៀរចាកហិរិឱត្តប្បៈបែបនេះ មិនមែនជាព្រះអរហន្តឡើយ ហេតុអ្វី ទើបលោកឪពុកឲ្យហៅខ្ញុំមក តិះដៀលសេដ្ឋីហើយក៏ទៅកាន់លំនៅរបស់ខ្លួនវិញ ។

ពួកអចេលក៍ ឃើញអាការរបស់នាងវិសាខានោះហើយ ទើបតិះដៀលសេដ្ឋីដោយសំឡេងតែមួយថា នែគហបតី លោកមិនមានស្រីដទៃទេឬ ទើបឲ្យសាវិការបស់សមណគោតម ដែលជាស្រីកាឡកិណីចូលមកក្នុងទីនេះ ចូរបណ្តេញនាងចេញអំពីផ្ទះនេះឲ្យរហ័ស ។ សេដ្ឋីគិតថា អញមិនអាចបណ្តេញចេញទៅដោយត្រឹមតែពាក្យរបស់ជនទាំងនេះប៉ុណ្ណោះ នាងជាកូនស្រីរបស់ត្រកូលធំ ដូច្នេះហើយ ទើបពោលថា លោកម្ចាស់ទាំងឡាយ ធម្មតាទារិកាជឿងខ្លះ មិនជឿងខ្លះ សូមលោកទាំងឡាយស្ងប់ស្ងៀមសិនចុះ បញ្ជូនអចេលក៍នោះទៅហើយ អង្គុយលើអាសនៈដែលមានតម្លៃច្រើន បរិភោគបាយាសដែលមានទឹកតិច ក្នុងថាសមាស ។

ក្នុងសម័យនោះ ព្រះថេរៈអ្នកសមាទានការត្រាច់បិណ្ឌបាតជាវត្តមួយអង្គកំពុងត្រាច់បិណ្ឌបាត បានចូលទៅកាន់ផ្ទះនោះហើយ នាងវិសាខាឈរបក់ផ្ងើតឲ្យឪពុកក្មេក ឃើញព្រះថេរៈរូបនោះគិតថា ការប្រាប់ឪពុកក្មេកមិនគួរ ទើបបានចៀសចេញទៅឈរដោយអាការ ដែលលួមឪពុកក្មេកនោះ ឃើញព្រះថេរៈបាន ។ តែសេដ្ឋីនោះជាបុគ្គលពាល សូម្បីឃើញព្រះថេរៈ ក៏ក្លែងធ្វើជាមិនឃើញ ឈ្ងោកមុខបរិភោគនោះឯង ។

នាងវិសាខាដឹងថា ឪពុកក្មេករបស់ខ្លួន ឃើញព្រះថេរៈក៏មិនយកចិត្តទុកដាក់ ទើបពោលថា បពិត្រលោកម្ចាស់ សូមនិមន្តទៅឯមុខចុះ ឪពុកក្មេករបស់ខ្ញុំ កំពុងបរិភោគរបស់ចាស់ សេដ្ឋីនោះអត់ធន់បាន ក្នុងកាលដែលពួកនិគ្រន្ថប្រាប់ តែក្នុងខណៈដែលនាងវិសាខាពោលថា បរិភោគរបស់ចាស់

នោះឯង ក៏ទម្លាក់ដៃពោលថា អ្នកទាំងឡាយ ចូរនាំបាយាសនេះចេញអំពីទីនេះ ចូរដេញស្រីនោះចេញអំពីផ្ទះនេះ ស្រីនេះធ្វើឲ្យយើង ឈ្មោះថាជាអ្នកស៊ីរបស់មិនស្អាត ក្នុងកាលមង្គលបែបនេះ ។

ឯទាសៈ និងកម្មករទាំងអស់ក្នុងផ្ទះនោះ សុទ្ធតែជាមនុស្សរបស់នាងវិសាខា ទើបមិនអាចចូលជិតបាន បុគ្គលណានឹងចាប់នាងត្រង់ដៃ និងជើងសូម្បីជាអ្នកអាចពោលដោយមាត់ក៏មិនមាន ។

នាងវិសាខាស្តាប់ពាក្យរបស់ឪពុកក្មេកហើយពោលថា លោកឪពុក ខ្ញុំនឹងចេញទៅដោយហេតុមានប្រមាណប៉ុណ្ណេះ លោកឪពុកមិនបាននាំខ្ញុំមក ដូចនាំនាងកុម្ភទាសី មកអំពីកំពង់ទឹក ធម្មតាកូនស្រីរបស់មាតាបិតាដែលនៅមានជីវិត នឹងមិនចេញទៅដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រោះហេតុនោះឯង ក្នុងកាលមកទីនេះ លោកឪពុករបស់ខ្ញុំបានហៅកុដុម្ពិកៈ ៨ នាក់មក ពោលថា បើទោសកើតឡើងដល់កូនស្រីរបស់ខ្ញុំ ដូច្នេះហើយ ក៏ប្រគល់ខ្ញុំទុកក្នុងដៃរបស់កុដុម្ពិកៈទាំងនោះ សូមលោកឪពុកឲ្យហៅជនទាំងនោះមកហើយ ជម្រះទោសរបស់ខ្ញុំចុះ ។

សេដ្ឋីគិតថា នាងវិសាខានេះនិយាយល្អ ទើបឲ្យហៅកុដុម្ពិកៈទាំង ៨ មកហើយប្រាប់ថា នាងទារិកានេះថាខ្ញុំ ដែលអង្គុយទទួលទានបាយាស ដែលមានទឹកតិចក្នុងថាសមាស ក្នុងវេលាមង្គលថា ជាអ្នកបរិភោគរបស់មិនស្អាត ចូរពួកលោកលើកទោសនាងវិសាខានេះឡើងហើយ ចូរអូសនាងចេញអំពីផ្ទះនេះ ។ កុដុម្ពិកៈពោលថា បានឮថា សេចក្តីនោះយ៉ាងនោះឬ នាងវិសាខាពោល

ថា ខ្ញុំមិនបានពោលយ៉ាងនោះទេ្បីយ តែកាលព្រះថេរៈ អ្នកសមាទានបិណ្ឌ-
បាតជាវត្តមួយរូប និមន្តមកឈរត្រង់ទ្វារផ្ទះ ឪពុកក្មេករបស់ខ្ញុំកំពុងទទួល
ទានមធុបាយាស ដែលមានទឹកតិច មិនអើពើដល់ព្រះថេរៈនោះ ខ្ញុំគិតថា
ឪពុកក្មេករបស់ខ្ញុំមិនធ្វើបុណ្យក្នុងអត្តភាពនេះ បរិភោគតែបុណ្យចាស់ប៉ុណ្ណោះ
ទើបពោលថា សូមនិមន្តទៅខាងមុខចុះ លោកម្ចាស់ ឪពុកក្មេករបស់ខ្ញុំកំពុង
បរិភោគរបស់ចាស់ ទោសឯណាមួយរបស់ខ្ញុំ មានព្រោះហេតុនេះដែរឬទេ
កុដុម្ពិកៈពោលថា លោកសេដ្ឋី ទោសព្រោះហេតុនេះមិនមាន កូនស្រីរបស់ខ្ញុំ
ពោលប្រពៃ ហេតុអ្វី ទើបលោកខឹង សេដ្ឋីពោលថា អ្នកទាំងឡាយទោស
នេះផុតក៏ផុតសិនចុះ តែថ្ងៃមួយ ក្នុងមជ្ឈិមយាម នាងវិសាខានេះ ដែលអ្នក
បម្រើស្រីចោមរោមហើយ បានទៅខាងក្រោយផ្ទះ កុដុម្ពិកៈពោលថា បានឮ
ថា សេចក្តីនេះយ៉ាងនោះឬ នាងវិសាខាពោលថា លោកឪពុកទាំងឡាយ ខ្ញុំ
មិនបានទៅព្រោះហេតុដទៃ កាលលាញីជាមេសេះអាជានេយ្យ កើតកូនហើយ
ក្បែរផ្ទះនេះ ខ្ញុំគិតថា កាលដែលអង្គុយព្រងើយមិនយកជាធុរៈ មិនសមគួរ
ទើបឲ្យមនុស្សកាន់ប្រទីប ហើយទៅជាមួយស្រីបម្រើ ធ្វើការបរិហារដល់
មេលាដែលកើតកូនហើយ ព្រោះហេតុនេះ ខ្ញុំនឹងមានទោសដូចម្តេច កុដុម្ពិកៈ
ពោលថា លោកសេដ្ឋី កូនស្រីរបស់ខ្ញុំធ្វើកម្ម សូម្បីពួកស្រីបម្រើ មិនគប្បី
ធ្វើក្នុងផ្ទះរបស់លោក លោកនៅឃើញទោសអ្វី ព្រោះហេតុនេះ សេដ្ឋីពោល
ថា អ្នកទាំងឡាយ ក្នុងរឿងនេះមិនមានទោសក៏ហីទៅចុះ តែឪពុករបស់នាង
វិសាខានេះ កាលពោលប្រៀនប្រដៅក្នុងវេលាមកទីនេះ បានឲ្យឱវាទ ១០

ប្រការ ដែលមានអាថ៌កំបាំង ខ្ញុំមិនជ្រាបសេចក្តីនៃឱវាទនោះ ចូរនាងប្រាប់សេចក្តីនៃឱវាទនោះដល់ខ្ញុំ បិតារបស់នាងបានប្រាប់ថា ភ្លើងក្នុងមិនគប្បីនាំចេញទៅខាងក្រៅ ពួកយើងអាចឬហ្ន៎ ដើម្បីមិនឲ្យភ្លើង ដល់ផ្ទះអ្នកជិតខាងទាំងពីរចំណែក ហើយនៅបាន ។

កុដុម្ពិកៈពោលថា សេចក្តីនេះយ៉ាងនោះឬ ។ នាងវិសាខាពោលថា លោកឪពុកទាំងឡាយ បិតារបស់ខ្ញុំមិនបានពោលសម្តៅសេចក្តីដូច្នោះឡើយ តែបានពោលបំណងដូច្នេះថា បើនាងឃើញទោសរបស់ម្តាយក្មេក ឪពុកក្មេក និងស្វាមីរបស់នាងហើយ កុំគប្បីពោលខាងក្រៅ គឺក្នុងផ្ទះនោះៗ ព្រោះថា ឈ្មោះថា ភ្លើង ដូចគ្នានឹងភ្លើងប្រកែកនេះ មិនមាន ។

សេដ្ឋីពោលថា អ្នកទាំងឡាយ សេចក្តីនោះលើកទុកសិនចុះ បិតារបស់នាងវិសាខានេះពោលថា ភ្លើងខាងក្រៅមិនគប្បីឲ្យចូលទៅខាងក្នុង ពួកយើងអាចមិនទៅនាំភ្លើងមកអំពីខាងក្រៅឬ ក្នុងកាលភ្លើងក្នុងផ្ទះរលត់ កុដុម្ពិកៈពោលថា បានឮថា សេចក្តីនេះ យ៉ាងនោះឬ នាងវិសាខាពោលថា លោកឪពុកទាំងឡាយ បិតារបស់ខ្ញុំមិនបានពោលសម្តៅសេចក្តីដូច្នោះឡើយ តែបានពោលសម្តៅសេចក្តីដូច្នេះថា បើស្រី ឬបុរសទាំងឡាយក្នុងផ្ទះជិតខាងរបស់នាង ពោលដល់ទោសរបស់ម្តាយក្មេក ឪពុកក្មេក និងស្វាមី នាងកុំនាំយកពាក្យដែលជនទាំងនោះពោលហើយ មកពោលទៀតថា ជនឈ្មោះនោះពោលលើកទោសយ៉ាងនេះរបស់អ្នកទាំងឡាយ ព្រោះឈ្មោះថា ភ្លើង ដូចគ្នានឹងភ្លើងនោះ មិនមាន ។

នាងវិសាខាបានរួចទោសព្រោះហេតុនេះយ៉ាងនេះ ។ នាងក៏ផុតទោស ព្រោះហេតុនេះយ៉ាងណា សូម្បីក្នុងពាក្យដ៏សេស នាងក៏ផុតទោស ដូច្នោះ ។

ក្នុងឱវាទទាំងនោះ គប្បីជ្រាបអធិប្បាយដូច្នេះថា ពាក្យដែលបិតារបស់នាងទូន្មានថា នាងគួរឲ្យដល់ជនទាំងឡាយដែលឲ្យប៉ុណ្ណោះ សេដ្ឋីបំណងយកសេចក្តីនេះថា គួរឲ្យដល់បុគ្គលដែលកាន់គ្រឿងឧបករណ៍ ដែលខ្ចីទៅហើយយកមកឲ្យវិញប៉ុណ្ណោះ ។ ពាក្យថា មិនគួរឲ្យដល់បុគ្គលដែលមិនឲ្យ សេដ្ឋីពោលសម្តៅសេចក្តីថា មិនគួរឲ្យដល់បុគ្គល ដែលកាន់យកគ្រឿងឧបករណ៍ដែលខ្ចីទៅហើយមិនយកមកឲ្យវិញ ។ ពាក្យថា គួរឲ្យដល់បុគ្គលទាំងដែលឲ្យ ទាំងដែលមិនឲ្យនេះ សេដ្ឋីពោលសម្តៅសេចក្តីថា កាលញាតិ និងមិត្តដែលក្រីក្រមកដល់ហើយ ជនទាំងនោះអាចនឹងសងក្តី មិនសងក្តី ។ ឲ្យដល់ញាតិ និងមិត្តទាំងនោះឯង គួរ ។ ពាក្យថា គប្បីអង្គុយជាសុខនេះ សេដ្ឋីពោលសម្តៅសេចក្តីថា ការអង្គុយក្នុងទីដែលឃើញម្តាយក្មេក ឪពុកក្មេក និងប្តីហើយ ត្រូវក្រោកឡើង គួរ ។ ចំណែកពាក្យថា គប្បីបរិភោគជាសុខនេះ សេដ្ឋីពោលសម្តៅសេចក្តីថា ការមិនបរិភោគមុនម្តាយក្មេក ឪពុកក្មេក និងប្តី អង្គាសជនទាំងនោះ ដឹងវត្តុដែលលោកទាំងនោះបានគ្រប់គ្នាហើយ ឬមិនទាន់បាន ខ្លួនឯងបរិភោគឯក្រោយ ទើបគួរ ។ ពាក្យថា គប្បីដេកជាសុខនេះ សេដ្ឋីពោលសម្តៅសេចក្តីថា មិនគប្បីចូលកាន់ដំណេកមុនម្តាយក្មេក ឪពុកក្មេក និងប្តី គួរធ្វើវត្តបដិបត្តិ ដែលខ្លួនគួរធ្វើដល់លោកទាំងនោះហើយ ខ្លួនឯងដេកឯក្រោយ ទើបគួរ ។ ពាក្យថា គប្បីបម្រើភ្លើងនេះ សេដ្ឋីពោលសម្តៅ

សេចក្តីថា ការឃើញម្តាយក្មេក ឪពុកក្មេក និងប្តីឲ្យដូចជាគំនរភ្លើង និងដូចស្តេចនាគ ទើបគួរ ។ ពាក្យថា គប្បីនមស្ការទេវតាខាងក្នុងនេះ សេដ្ឋីពោលសម្តៅសេចក្តីថា ការឃើញម្តាយក្មេក ឪពុកក្មេក និងប្តី ឲ្យដូចជាទេវតា ទើបគួរ ។

សេដ្ឋីបានស្តាប់អត្ថនៃឱវាទ ១០ នេះ យ៉ាងនោះហើយ មិនឃើញពាក្យឆ្លើយ ក៏អង្គុយឱនមុខហើយ ។

គ្រានោះ កុដុម្ពិកៈទាំងឡាយសួរសេដ្ឋីនោះថា លោកសេដ្ឋី ទោសជទៃនៃធីតារបស់ខ្ញុំនៅមានឬ សេដ្ឋីពោលថា មិនមានទេ កុដុម្ពិកៈពោលថា កាលបើដូច្នោះ ហេតុអ្វី ទើបលោកបណ្តេញនាងដែលមិនមានកំហុស ចេញចាកផ្ទះ ដោយមិនមានហេតុដូច្នេះ ។

កុដុម្ពិកៈទាំងឡាយពោលយ៉ាងនោះហើយ នាងវិសាខាបានពោលថា លោកឪពុកទាំងឡាយ កាលដែលខ្ញុំមិនទៅមុនតាមពាក្យរបស់ឪពុកក្មេក មិនសមគួរឡើយ តែក្នុងកាលមក បិតារបស់ខ្ញុំបានប្រគល់ខ្ញុំក្នុងដៃរបស់លោកទាំងឡាយ ដើម្បីជម្រះទោសរបស់ខ្ញុំ កាលដែលខ្ញុំមិនមានទោស លោកទាំងឡាយជ្រាបហើយ ឥឡូវនេះ ខ្ញុំគួរទៅបាន ដូច្នេះហើយ ទើបបញ្ជាអ្នកបម្រើស្រីប្រុសទាំងឡាយថា ចូរពួកអ្នកនាំគ្នារៀបចំពាហនៈ មានយានជាដើម ។ ពេលនោះ សេដ្ឋីទាញកុដុម្ពិកៈហើយ ពោលនឹងនាងថា នែកូនឪពុកមិនដឹង ពោលទៅហើយ ចូរអត់ទោសឲ្យឪពុកចុះ នាងវិសាខាពោលថា លោកឪពុក ខ្ញុំអត់ទោស ដែលគួរអត់ឲ្យដល់លោកឪពុកបានដោយពិត

តែខ្ញុំជាកូនស្រីរបស់ត្រកូលអ្នកមានសេចក្តីជ្រះថ្លា ដែលមិនញាប់ញ័រក្នុងព្រះពុទ្ធសាសនា ពួកខ្ញុំវៀរភិក្ខុសង្ឃហើយ ជាអ្នកនៅមិនបាន បើខ្ញុំបានទំនុកបម្រុងភិក្ខុសង្ឃតាមការពេញចិត្តរបស់ខ្ញុំ ទើបខ្ញុំនៅ សេដ្ឋីពោលថា នែកូន ចូរនាងទំនុកបម្រុងសមណៈរបស់នាងតាមគាប់ចិត្តចុះ ។

នាងវិសាខាចាត់មនុស្សឲ្យទៅនិមន្តព្រះទសពល យាងឲ្យទ្រង់ចូលកាន់និវេសន៍ក្នុងថ្ងៃស្អែក ។ ចំណែកពួកសមណៈអាក្រាត បានឮថា ព្រះសាស្តាយាងទៅកាន់ផ្ទះរបស់មិគារសេដ្ឋី ទើបទៅអង្គុយព័ទ្ធផ្ទះ ។ នាងវិសាខាថ្វាយទឹកទក្ខិណោទកហើយ បញ្ជូនដំណឹងទៅថា ខ្ញុំតាក់តែងគ្រឿងសក្ការៈទាំងពួងហើយ សូមអញ្ជើញឪពុកក្មេករបស់ខ្ញុំមកអង្គាសព្រះទសពលចុះ គ្រានោះ ពួកអជីវកហាមមិគារសេដ្ឋីដែលចង់មកថា នែគហបតី លោកកុំទៅកាន់សម្នាក់របស់ព្រះសមណគោតមឡើយ ។ សេដ្ឋីបញ្ជូនដំណឹងទៅថា កូនស្រីរបស់ខ្ញុំ ចូរអង្គាសឯងចុះ ។ នាងអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន កាលស្រេចភត្តកិច្ចហើយ បានបញ្ជូនដំណឹងទៅទៀតថា សូមអញ្ជើញឪពុកក្មេករបស់ខ្ញុំមកស្តាប់ធម្មកថាចុះ ។ ពេលនោះ ពួកអាជីវកពោលនឹងសេដ្ឋីនោះ ដែលគិតថា ឈ្មោះថា ការមិនទៅក្នុងគ្រានេះ មិនគួរយ៉ាងក្រៃលែង ហើយកំពុងទៅ ព្រោះភាពដែលខ្លួនចង់ស្តាប់ធម៌ទៀតថា បើដូច្នោះ លោកកាលស្តាប់ធម៌របស់ព្រះសមណគោតម ចូរអង្គុយស្តាប់ខាងក្រៅវាំងនន ដូច្នេះហើយ ទើបទៅមុនសេដ្ឋីនោះហើយ ជាំងនូវវាំងនន សេដ្ឋីក៏ទៅអង្គុយខាងក្រៅវាំងនន ។

ព្រះសាស្តាត្រាស់ថា អ្នកអង្គុយក្រៅវាំងននក្តី ត្រង់ជញ្ជាំងផ្ទះអ្នកជនៃ

ក្តី ជញ្ជាំងក្នុងនោះក្តី ជញ្ជាំងក្នុងក្រវាលក្តី តថាគតឈ្មោះថាជាព្រះពុទ្ធ រមែងអាចឲ្យអ្នកបានឮសំឡេងរបស់តថាគតបាន ដូច្នេះហើយ ទ្រង់ផ្តើមអនុបុព្វីកថា ដើម្បីសម្តែងធម៌ ដូចចាប់ដើមព្រឹងធំអង្រួនឲ្យញ័រ និងដូចញាំងភ្លៀងគឺអមតធម៌ឲ្យធ្លាក់ចុះ ។

កាលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងធម៌ ជនដែលឈរខាងមុខក្តី ខាងក្រោយក្តី នៅហួសចក្រវាលមួយរយមួយពាន់ក្តី នៅក្នុងអកនិដ្ឋភពក្តី ពោលថា ព្រះសាស្តារមែងទតមើលអាត្មាអញនោះឯង ទ្រង់សម្តែងធម៌ប្រោសអញនោះឯង ។ ពិតហើយ ព្រះសាស្តាហាក់ដូចទតមើលជននោះៗ និងដូចត្រាស់ជាមួយនឹងជនទាំងនោះ ។

បានឮថា ព្រះពុទ្ធទាំងឡាយឧបមាដូចព្រះចន្ទ រមែងប្រាកដដូចប្រថាប់ឈរត្រង់ទីចំពោះមុខនៃសត្វទាំងឡាយ ដែលឈរក្នុងទីណាមួយ ដូចព្រះចន្ទអណ្តែតនៅក្នុងវេហាស៍ រមែងប្រាកដដល់ពួកសត្វថា ព្រះចន្ទនៅលើក្បាលរបស់ពួកយើង ព្រះចន្ទនៅលើក្បាលរបស់ពួកយើងដូច្នោះ ។ បានឮថា នេះជាផលនៃទានដែលព្រះពុទ្ធទាំងឡាយ ទ្រង់កាត់ក្បាលដែលប្រដាប់ហើយ ទ្រង់ខ្វេះភ្នែកដែលបន្តក់ល្អហើយ ទ្រង់ពន្លះសាច់ហទយៈហើយ ទ្រង់បរិច្ចាគឱរសដូចជាជាលី ទ្រង់បរិច្ចាគធីតាដូចជាកណ្ហាជិនា បជាបតីដូចជានាងមទ្រី ឲ្យហើយ ដើម្បីជាទាសៈរបស់អ្នកដទៃ ។

ឯមិគារសេដ្ឋី កាលព្រះសាស្តាទ្រង់ពង្រីកព្រះធម្មទេសនា អង្គុយខាងក្រៅវាំងនននោះឯង តាំងនៅក្នុងសោតាបត្តិផល ដែលប្រដាប់ដោយនយមួយ

ពាន់ ប្រកបដោយអចលសទ្ធា ជាបុគ្គលអស់សង្ស័យក្នុងរតនៈ ៣ លើក ជាយវាំងននឡើង យកមាត់ថៅដោះកូនប្រសា តាំងនាងទុកក្នុងតំណែងជាម្ដាយ ដោយពាក្យថា សូមនាងជាម្ដាយរបស់ខ្ញុំតាំងអំពីថ្ងៃនេះទៅចុះ ។

ចាប់តាំងអំពីថ្ងៃនោះមក នាងវិសាខា បានឈ្មោះថា ជាមិគារមាតា ហើយ ។ ខាងក្រោយបានបុត្រប្រុស ទើបបានតាំងឈ្មោះបុត្រនោះថា មិគារ ។

មហាសេដ្ឋីលែងដោះកូនប្រសាហើយ ទៅក្រាបទៀបព្រះបាទារបស់ព្រះដ៏មានព្រះភាគ ច្របាច់ព្រះបាទដោយដៃ ជញ្ជក់ដោយមាត់ និងប្រកាសឈ្មោះបីដងថា ខ្ញុំព្រះអង្គឈ្មោះមិគារៈដូច្នេះជាដើមហើយ ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនជ្រាបអស់កាលមានប្រមាណប៉ុណ្ណោះ ទានដែលបុគ្គលឲ្យហើយក្នុងសាសនានេះមានផលច្រើន ខ្ញុំព្រះអង្គជ្រាបផលនៃទានក្នុងឥឡូវនេះក៏ព្រោះអាស្រ័យកូនប្រសាខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាអ្នកផុតហើយចាកអបាយទុក្ខទាំងពួង កូនស្រីប្រសារបស់ខ្ញុំព្រះអង្គកាលមកកាន់ផ្ទះនេះ ក៏មកហើយដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ខ្ញុំព្រះអង្គ ដូច្នេះហើយ បានពោលគាថានេះ

> ខ្ញុំព្រះអង្គរមែងដឹងទូទៅ ដល់ទានដែលបុគ្គលឲ្យហើយ ក្នុងខេត្តដែលបុគ្គលឲ្យហើយ មានផលច្រើនក្នុងថ្ងៃនេះ កូនប្រសាល្អរបស់ខ្ញុំព្រះអង្គ មកកាន់ផ្ទះនេះ ដើម្បីប្រយោជន៍ដល់ខ្ញុំព្រះអង្គហ្ន៎ ។

នាងវិសាខា ទូលនិមន្តព្រះសាស្ដាដើម្បីសោយក្នុងថ្ងៃស្អែក ។ ក្នុងថ្ងៃស្អែកឡើង ម្ដាយក្មេកបានសម្រេចសោតាបត្តិផលហើយ ។ ចាប់តាំងអំពី

កាលនោះ ផ្ទះនោះបានបើកទ្វារហើយ ដើម្បីព្រះសាសនា ។

លំដាប់នោះ សេដ្ឋីគិតថា កូនប្រសារបស់អញមានឧបការៈច្រើន អញនឹងធ្វើបណ្ណាការឲ្យដល់នាង ព្រោះគ្រឿងប្រដាប់របស់កូនប្រសានោះធ្ងន់ពេក មិនអាចប្រដាប់អស់កាលជានិច្ចបាន ។ អញនឹងឲ្យជាងធ្វើគ្រឿងប្រដាប់ស្រាលៗ ដល់នាង គួរដល់ការប្រដាប់គ្រប់តំរិយាបថ ទាំងក្នុងពេលថ្ងៃ និងពេលយប់ ដូច្នេះហើយ ទើបឲ្យជាងធ្វើគ្រឿងប្រដាប់ឈ្មោះយនមដ្ឋកៈ ដែលមានតម្លៃមួយសែន កាលគ្រឿងប្រដាប់នោះស្រេចបាច់ហើយ និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆាន់ដោយសេចក្តីគោរពហើយ ឲ្យនាងវិសាខាងូតដោយទឹកក្រអូប ១៦ ក្អម ឲ្យឈរថ្វាយបង្គំព្រះសាស្តាក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះសាស្តាហើយ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាហើយ យាងចូលកាន់វិហារវិញ ។

ចាប់តាំងអំពីកាលនោះ នាងវិសាខាធ្វើបុណ្យមានទានជាដើម បានពរ ៨ ប្រការអំពីសម្នាក់ព្រះសាស្តា ជ្រុកជញ្ជាក់បីដូចចន្ទលេខាក្នុងលំហ ដល់នូវការចម្រើនដោយបុត្រ និងធីតាហើយ បានឮមកថា នាងមានកូនប្រុស ១០ នាក់ មានកូនស្រី ១០ នាក់ បណ្តាកូនទាំងនោះ កូននីមួយៗ មានកូនប្រុស ១០ នាក់ មានកូនស្រី ១០ នាក់ដែរ បណ្តាចៅទាំងនោះ ចៅនីមួយៗ មានកូនប្រុស ១០ នាក់ មានកូនស្រី ១០ នាក់ ចំនួនមនុស្សទាំងអស់មានដល់ទៅ ៨៤២០ នាក់ ប្រព្រឹត្តទៅដោយអំណាចនៃការបន្តរបស់កូនចៅ និងចៅទួតរបស់នាងវិសាខានោះយ៉ាងនេះ ដោយប្រការដូច្នេះ ។ នាង

វិសាខាមានអាយុ ១២០ ឆ្នាំ សក់លើក្បាលមួយសរសៃដែលស្កូវ មិនមាន នាងហាក់បីដូចក្មេងស្រីអាយុប្រមាណ ១៦ ឆ្នាំជានិច្ច ។ ជនទាំងឡាយ ឃើញនាងមានកូន និងចៅជាបរិវារដើរទៅកាន់វិហារ រមែងសួរគ្នាថា ស្រី ទាំងនេះ ណាមួយជានាងវិសាខា ជនដែលឃើញនាងដើរទៅ រមែងគិតថា ឥឡូវនេះ សូមនាងដើរទៅបន្តិចចុះ អ្នកនាងរបស់ខ្ញុំដើរទៅរមែងស្អាត ។ ជន ដែលឃើញនាងឈរ អង្គុយ ដេក ក៏រមែងគិតថា ឥឡូវនេះ សូមនាងដេក បន្តិចចុះ អ្នកនាងរបស់ខ្ញុំដេកហើយ រមែងស្អាត នាងជាបុគ្គលដែលបុគ្គល ណាម្នាក់និយាយមិនបានថា ក្នុងឥរិយាបថទាំង ៤ នាងរមែងមិនស្អាត ក្នុង ឥរិយាបថឈ្មោះនោះ ដោយប្រការដូច្នោះ នាងវិសាខានោះមានកម្លាំងស្មើនឹង ដំរី ៥ ។ ព្រះរាជាទ្រង់ព្រះតថា នាងវិសាខាទ្រទ្រង់នូវកម្លាំងស្មើនឹងដំរី ៥ ក្នុង កាលនាងទៅវិហារ ស្តាប់ធម៌ហើយត្រឡប់មក មានព្រះបំណងសាកល្បង នូវកម្លាំង ទើបឲ្យលែងដំរីទៅ ។ ដំរីនោះបួងប្រមោយ បានរត់ចូលទៅព្រេច នាងវិសាខាហើយ ។ ស្រីបរិវាររបស់នាង ៥០០ ពួកខ្លះក៏រត់គេចទៅ ពួក ខ្លះមិនលះបង់នាង កាលនាងវិសាខាសួរថា នេះជាអ្វី ទើបជ្រាប់ថា បានឮ ថា ព្រះរាជាទ្រង់បំណងល្បងនូវកម្លាំងរបស់អ្នកនាង ទើបឲ្យលែងដំរី ។ នាង វិសាខាគិតថា ប្រយោជន៍អ្វីដោយការឃើញដំរីនេះហើយរត់ទៅ អញនឹង ចាប់ដំរីនោះដូចម្តេចហ្ន៎ ទើបគិតថា បើអញចាប់ដំរីនោះយ៉ាងមាំ ដំរីនោះ គប្បីវិនាស ដូច្នេះហើយ ទើបយកម្រាមដៃពីរចាប់ប្រមោយហើយច្រានទៅ ។ ដំរីមិនអាចទប់ខ្លួនបាន បានដួលចុះត្រង់លានព្រះរាជវាំងហើយ មហាជនបាន ឲ្យសាធុការ នាង មួយអន្ទើដោយបរិវារ បានត្រឡប់ទៅកាន់ផ្ទះ ដោយ

សួស្តីហើយ ។

សម័យនោះឯង នាងវិសាខាមិគារមាតាមានកូនច្រើន មានចៅច្រើន មានកូនមិនមានរោគ មានចៅមិនមានរោគ សន្មតថាជាបុគ្គលយ៉ាងក្រៃលែង ក្នុងក្រុងសាវត្ថី បណ្តាកូនចៅរាប់ពាន់មានចំនួនប៉ុណ្ណោះ សូម្បីតែម្នាក់ឈ្មោះថាស្លាប់ក្នុងចន្លោះមិនមានឡើយ ។ ក្នុងមហោស្រពដែលជាមង្គល អ្នកក្រុងសាវត្ថីរមែងអញ្ជើញនាងវិសាខាឲ្យបរិភោគជាមុន ។ ក្នុងថ្ងៃមហោស្រពមួយ កាលមហាជនតែងខ្ជួនទៅកាន់វិហារដើម្បីស្តាប់ធម៌ សូម្បីនាងវិសាខា បរិភោគក្នុងទីដែលគេអញ្ជើញហើយ ក៏តែងគ្រឿងមហាលតាបសាធន៍ ទៅវិហារ មួយអន្ទើដោយមហាជន បានដោះគ្រឿងអាភរណៈឲ្យដល់ស្រីបម្រើ ដែលព្រះធម្មសង្គាហកាចារ្យពោលសម្តៅយកពាក្យនេះថា សម័យនោះឯង ក្នុងក្រុងសាវត្ថីមានមហោស្រព មនុស្សទាំងឡាយតែងខ្ជួនហើយទៅវត្ត ។ សូម្បីនាងវិសាខាមិគារមាតាក៏តែងខ្ជួនទៅវិហារ ។ គ្រានោះឯង នាងវិសាខាមិគារតាមដោះគ្រឿងប្រដាប់ ចងឲ្យជាបង្វេចត្រង់សំពត់ដណ្តប់ហើយ បានឲ្យដល់អ្នកបម្រើថា នែនាង ចូរនាងទទួលបង្វេចនេះចុះ ។

បានឮថា នាងវិសាខានោះ កាលកំពុងដើរទៅវិហារ គិតថា កាលដែលអញពាក់គ្រឿងប្រដាប់ដែលមានតម្លៃច្រើនបែបនេះនៅលើក្បាល ហើយប្រដាប់គ្រឿងអលង្ការរហូតដល់ខ្នងជើង ចូលទៅកាន់វិហារមិនគួរ ទើបដោះខ្លប់គ្រឿងប្រដាប់នោះ ហើយបញ្ជូនឲ្យក្នុងដៃស្រីបម្រើដែលមានកម្លាំងស្មើនឹងដំរី ៥ ដែលកើតដោយបុណ្យរបស់ខ្លួនដូចគ្នា ។ ស្រីបម្រើនោះម្នាក់ប៉ុណ្ណោះ

អាចទទួលគ្រឿងប្រដាប់មហាលតាបសាធន៍នោះបាន ព្រោះហេតុនោះ ទើប
នាងពោលនឹងស្រីបម្រើនោះថា នែនាង ចូរនាងទទួលគ្រឿងប្រដាប់នេះ ខ្ញុំ
នឹងពាក់ក្នុងកាលត្រឡប់មកអំពីសម្នាក់របស់ព្រះសាស្តា ។ នាងវិសាខាកាល
ឲ្យគ្រឿងប្រដាប់មហាលតាបសាធន៍នោះហើយ ទើបពាក់គ្រឿងប្រដាប់ឈ្មោះ
ឃនមដ្ឋកៈ បានចូលទៅគាល់ព្រះសាស្តាស្តាប់ធម៌ហើយ ។ ក្នុងទីបំផុតការ
ស្តាប់ធម៌ នាងថ្វាយបង្គំព្រះមានព្រះភាគ ក្រោកចាកអាសនៈចៀសទៅហើយ
ចំណែកស្រីបម្រើរបស់នាង ភ្លេចគ្រឿងប្រដាប់នោះហើយ ។ កាលបរិស័ទ
ស្តាប់ធម៌ចៀសចេញទៅហើយ បើបុគ្គលណាភ្លេចរបស់អ្វីមួយ ព្រះអានន្ទត្ថេរ
រមែងរើសរបស់នោះទុកជាក់ ។ ព្រោះហេតុដូច្នេះ ក្នុងថ្ងៃនោះ លោកឃើញ
គ្រឿងមហាលតាបសាធន៍ហើយ ទើបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ
នាងវិសាខាភ្លេចគ្រឿងអលង្ការ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអានន្ទ
ចូររើសទុកក្នុងទីបំផុតនាចំណែកម្ខាងចុះ ។ ព្រះថេរៈលើកគ្រឿងប្រដាប់នោះ
ព្យួរត្រង់ក្បាលជណ្តើរ ។

ចំណែកនាងវិសាខា ដើរទៅខាងក្នុងវិហារជាមួយនាងសុប្បិយា តាំង
ចិត្តថា នឹងដឹងវត្តុដែលគួរធ្វើដល់អាគន្តុកភិក្ខុ កិក្ខុត្រៀមធ្វើដំណើរ និងភិក្ខុ
មានជំងឺជាដើម ។ ដោយប្រក្រតី ភិក្ខុកំលោះ និងសាមណេរដែលត្រូវការ
សប្បិ ទឹកឃ្មុំ និងប្រេងជាដើម ឃើញឧបាសិកាទាំងនោះខាងក្នុងវិហារហើយ
រមែងកាន់យកភាជនៈ មានថាសជាដើមដើរចូលទៅរក ។ ក្នុងថ្ងៃនោះ ក៏ធ្វើ
ហើយយ៉ាងនោះដូចគ្នា ពេលនោះ នាងសុប្បិយាឃើញភិក្ខុឈឺមួយរូប ទើប

សួរថា លោកម្ចាស់ត្រូវការអ្វី ទើបភិក្ខុឈឺរូបនោះឆ្លើយថា ត្រូវការរសនៃសាច់ នាងឆ្លើយថា បាន លោកម្ចាស់ ខ្ញុំនឹងបញ្ជូនទៅ ។ ក្នុងថ្ងៃទីពីរ កាលមិនបានសាច់ដែលជាកប្បិយៈ ទើបធ្វើកិច្ចដែលគួរធ្វើ ដោយសាច់ក្មេវបស់ខ្លួន ដោយការជ្រះថ្លា ក្នុងព្រះសាស្តា ក៏ត្រឡប់ជាអ្នកមានសរីរៈតាំងនៅដូចប្រក្រតីនោះឯង ចំណែកនាងវិសាខា ពិនិត្យមើលភិក្ខុកំលោះ និងសាមណេរដែលជាអ្នកឈឺហើយ ក៏ចេញទៅដោយទ្វារដទៃ ឈរត្រង់ឧបចារវិហារហើយពោលថា នែនាង ចូរនាងយកគ្រឿងប្រជាប់មក ខ្ញុំនឹងស្បៀកពាក់ ។ ក្នុងគ្រានោះ ស្រីបម្រើនោះដឹងថាខ្លួន ភ្លេចហើយចេញមក ទើបឆ្លើយថា បពិត្រអ្នកនាង ខ្ញុំភ្លេចហើយ នាងវិសាខាពោលថា បើដូច្នោះ ចូរទៅយកមក តែបើលោកម្ចាស់អានន្ទរបស់យើង រើសទុកជាក់ក្នុងទីដទៃ នាងកុំយកមកឡើយ ខ្ញុំនឹងបរិច្ចាគគ្រឿងប្រជាប់នោះប្រគេនលោកម្ចាស់នោះឯង ។ បានឮថា នាងវិសាខាដឹងថា ព្រះថេរៈតែងរើសរបស់ដែលពួកមនុស្សភ្លេច ព្រោះដូច្នោះ ទើបពោលយ៉ាងនោះ ។

ចំណែកព្រះថេរៈ លុះឃើញអ្នកបម្រើនោះក៏សួរថា នាងមកដើម្បីបំណងអ្វី កាលអ្នកបម្រើនោះឆ្លើយថា ខ្ញុំភ្លេចគ្រឿងប្រជាប់របស់ម្ចាស់ខ្ញុំ ទើបពោលថា អាត្មារើសទុកត្រង់ក្បាលជណ្តើរនោះ ចូរនាងយកចុះ ។ ស្រីបម្រើឆ្លើយថា បពិត្រលោកម្ចាស់ បង្វែចកណ្ឌៈដែលលោកម្ចាស់យកដៃពាល់ត្រូវហើយ ម្ចាស់របស់ខ្ញុំប្រាប់មិនឲ្យយកទៅឡើយ ដូច្នេះហើយ ក៏មានដៃទទេត្រឡប់ទៅ ត្រូវនាងវិសាខាសួរថា តើមានរឿងអ្វី ទើបប្រាប់សេចក្តីនោះ ។ នាងវិសាខា

ពោលថា ខ្ញុំនឹងមិនប្រដាប់គ្រឿងដែលលោកម្ចាស់ពាល់ត្រូវឡើយ ខ្ញុំនឹងបរិច្ចាគ ហើយ តែលោកម្ចាស់រក្សាទុកជាការលំបាក ខ្ញុំនឹងចំណាយគ្រឿងប្រដាប់នោះ ហើយ នឹងបង្អោនជារបស់កប្បិយៈ នាងចូរទៅយកគ្រឿងប្រដាប់នោះមក ។ អ្នកបម្រើនោះទៅនាំយកមកហើយ ។ នាងវិសាខាមិនតែងគ្រឿងប្រដាប់នោះ ឲ្យហៅជាងមាសមកហើយ ឲ្យវាយតម្លៃ កាលជាងមាសទាំងនោះឆ្លើយថា មានតម្លៃ ៩ កោដិ តែសម្រាប់តម្លៃឈ្នួលដល់មួយសែន ។ ទើបដាក់គ្រឿង ប្រដាប់លើយាន ហើយពោលថា បើដូច្នោះ ពួកអ្នកចូរលក់គ្រឿងប្រដាប់ នោះ ។ មិនមានបុគ្គលណាអាចឲ្យត្រឹមចំនួនប៉ុណ្ណោះទទួលបាន ព្រោះស្រី ដែលសមគួរប្រដាប់គ្រឿងប្រដាប់នោះ រកបានដោយលំបាក ។ ពិតហើយ ស្រី ៣ នាក់ប៉ុណ្ណោះក្នុងបឋវីមណ្ឌល បាននូវគ្រឿងប្រដាប់មហាលតាបសាធន៍ គឺនាងវិសាខាមហាឧបាសិកា ១ នាងមល្លិកា ភរិយារបស់ពន្ធុលមលសេនាបតី ១ កូនស្រីរបស់សេដ្ឋីក្រុងពារាណសី ១ ព្រោះដូច្នោះ ទើបនាងវិសាខាទិញ គ្រឿងប្រដាប់នោះ ខ្នងឯងនោះឯង ឲ្យជញ្ជូនទ្រព្យ ៩ កោដិ ១ សែន ដាក់ លើរទេះនាំទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា បពិត្រ ព្រះអង្គ ព្រះអានន្ទត្ថេររបស់ខ្ញុំម្ចាស់ យកដៃពាល់ត្រូវគ្រឿងប្រដាប់របស់ខ្ញុំ ម្ចាស់ហើយ ចាប់តាំងអំពីកាលដែលលោកពាល់ត្រូវហើយ ខ្ញុំម្ចាស់មិនអាច ប្រដាប់បាន តែខ្ញុំម្ចាស់ឲ្យលក់គ្រឿងប្រដាប់នោះដោយគិតថា ចំណាយបង្អោន យកវត្ថុដែលជាកប្បិយៈមក មិនឃើញអ្នកដទៃអាចទទួលបាន ទើបឲ្យទទួល គ្រឿងប្រដាប់នោះខ្នងឯងមកហើយ ខ្ញុំម្ចាស់នឹងបង្អោនចូលក្នុងបច្ច័យណាបណ្តា

បច្ចុយ ៤ នោះ ព្រះសាស្តាត្រាស់ថា នាងគួរធ្វើលំនៅដើម្បីសង្ឃក្បែរទ្វារទិសខាងកើតចុះ ។ នាងវិសាខាទទួលថា សមគួរព្រះអង្គ មានចិត្តរីករាយទើបយកទ្រព្យ ៩ កោដិទិញដី នាងផ្តើមសាងវិហារដោយទ្រព្យ ៩ កោដិក្រៅអំពីនេះ ។

ថ្ងៃមួយ ព្រះសាស្តាប្រមើលមើលលោកក្នុងវេលាទៀបភ្លឺ បានឃើញឧបនិស្សយសម្បត្តិរបស់សេដ្ឋីបុត្រឈ្មោះកទុិយៈ ដែលចុតិអំពីទេវលោកហើយកើតក្នុងត្រកូលសេដ្ឋីក្នុងកទុិយនគរ ទ្រង់ធ្វើកត្តកិច្ចក្នុងផ្នូរបស់អនាថ-បិណ្ឌិកសេដ្ឋីហើយ ក៏បែរព្រះភក្ត្រទៅកាន់ទិសឧត្តរ ។ តាមប្រក្រតីព្រះសាស្តាទ្រង់ទទួលកិក្ខាក្នុងផ្នូរបស់នាងវិសាខាហើយ ក៏យាងចេញតាមទ្វារទិសទក្សិណប្រថាប់ក្នុងវត្តជេតពន ។ ទ្រង់ទទួលកិក្ខាក្នុងផ្នូរអនាថបិណ្ឌិកសេដ្ឋីហើយ ក៏យាងចេញតាមទ្វារទិសខាងកើត ប្រថាប់នៅក្នុងបុព្វារាម ។ ជនទាំងឡាយឃើញព្រះដ៏មានព្រះភាគ ទ្រង់យាងបែរព្រះភក្ត្រទៅកាន់ទ្វារទិសឧត្តរហើយរមែងដឹងបានថា ទ្រង់យាងទៅកាន់ទីចារិក ។ ក្នុងថ្ងៃនោះ នាងវិសាខាគ្រាន់តែដឹងថា ព្រះសាស្តាទ្រង់យាងបែរព្រះភក្ត្រទៅកាន់ទ្វារទិសឧត្តរ ទើបប្រញាប់ប្រញាល់ទៅ ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់បំណងយាងទៅកាន់ទីចារិកឬ ព្រះសាស្តាត្រាស់ថា ម្នាលនាងវិសាខា យ៉ាងនោះឯង ។ នាងវិសាខាពោលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងបរិច្ចាគទ្រព្យចំនួនប៉ុណ្ណោះសាងវិហារថ្វាយព្រះអង្គ សូមទ្រង់ត្រឡប់ចុះ ។

ព្រះសាស្តាត្រាស់ថា ម្នាលនាងវិសាខា នេះជាការទៅមិនត្រឡប់ ។

នាងវិសាខាគិតថា ព្រះមានព្រះភាគ ទ្រង់ឃើញបុគ្គលណាម្នាក់ ដែលសម្បូរដោយហេតុពិត ទើបក្រាបទូលថា បើដូច្នោះ សូមទ្រង់ត្រាស់ប្រាប់ភិក្ខុមួយរូបដែលឃល់ក្នុងការងារ ដែលខ្ញុំម្ចាស់ធ្វើហើយ ឬមិនទាន់បានធ្វើត្រឡប់ហើយទ្រង់យាងចុះ ព្រះសាស្តាត្រាស់ថា នាងគាប់ចិត្តភិក្ខុរូបណា ចូរទទួលបាត្រភិក្ខុរូបនោះចុះ ។

សូម្បីនាងជ្រួនចិត្តក្នុងព្រះអានន្ទត្ថេរក៏ពិត តែគិតថា ព្រះមហាមោគ្គល្លាន ជាអ្នកមានឫទ្ធិ ការងាររបស់យើងនឹងធាប់សម្រេច ព្រោះអាស្រ័យព្រះថេរៈនោះ ដូច្នេះហើយ ទើបទទួលបាត្ររបស់ព្រះថេរៈ ។ ព្រះថេរៈសម្ដែងព្រះសាស្តា ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន អ្នកចូរនាំបរិវារ ៥០០ ត្រឡប់ចុះ ។ លោកបានធ្វើតាមព្រះតម្រាស់នោះហើយ ។ ដោយអានុភាពរបស់លោក ពួកមនុស្សរទៅដើម្បីឈើ និងថ្ម រយៈផ្លូវ ៥០-៦០ យោជន៍ ក៏ជញ្ជូនយកឈើ និងថ្មមកបានភ្លាមក្នុងថ្ងៃនោះឯង សូម្បីលើកឈើ និងថ្មដាក់រនេះក៏មិនលំបាក ភ្ជាររនេះក៏មិនបាក់ ក្នុងកាលមិនយូរឡើយ ពួកជនទាំងនោះ សាងប្រាសាទពីរជាន់សម្រេច ។ ប្រាសាទនោះ បានជាប្រាសាទប្រដាប់ដោយបន្ទប់មួយពាន់ គឺខាងក្រោម ៥០០ ខាងលើ ៥០០ ។ ព្រះសាស្តាទ្រង់ចារិកទៅ អស់កាល ៩ ខែហើយ ទើបយាងត្រឡប់មកកាន់ក្រុងសាវត្ថីវិញ សូម្បីការងារក្នុងប្រាសាទរបស់នាងវិសាខា ក៏សម្រេចក្នុងរយៈពេល ៩ ខែដូចគ្នា ។ នាងឲ្យសាងកំពូលប្រាសាទចំណុះទឹកបាន ៦០ ភ្នួម ដោយមាសទឹក ១០ ដែលផែជាបន្ទះនោះឯង ។ នាងបានឮថា ព្រះសាស្តាយាងមកកាន់ជេតពនមហា-

វិហារ ទើបធ្វើការទទួល នាំព្រះសាស្តាទៅកាន់វិហារបស់ខ្លួនហើយ ទទួលប្តេជ្ញាថា បពិត្រព្រះអង្គ សូមទ្រង់នាំភិក្ខុសង្ឃប្រថាប់នៅក្នុងវិហារនេះឯង អស់កាល ៤ ខែនេះ ខ្ញុំម្ចាស់នឹងធ្វើការឆ្លងប្រាសាទ ។ ព្រះសាស្តាទ្រង់ទទួលហើយ ។

ចាប់តាំងអំពីកាលនោះ នាងវិសាខានោះរមែងថ្វាយទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានក្នុងវិហារនោះឯង កាលនោះ ស្រីជាសម្លាញ់ម្នាក់របស់នាង កាន់សំពត់មួយផ្ទាំងដែលមានតម្លៃមួយពាន់មកហើយពោលថា សម្លាញ់ខ្ញុំចង់ក្រាលសំពត់នេះដោយសង្ឃឹមថា ជាកម្រាលផ្ទៃក្នុងប្រាសាទរបស់នាង សូមនាងជួយប្រាប់ទីដែលគួរក្រាលដល់ខ្ញុំ ។ នាងវិសាខាពោលថា សម្លាញ់ បើខ្ញុំប្រាប់ដល់នាងថា ឱកាសមិនមាន នាងក៏នឹងសម្គាល់ថាមិនប្រាថ្នាឲ្យឱកាសដល់អញ ចូរនាងពិនិត្យមើលផ្ទៃនៃប្រាសាទពីរជាន់ និងបន្ទប់មួយពាន់ រួចដឹងទីដែលគួរក្រាលខ្លួនឯងចុះ ។ ស្រីសម្លាញ់នោះ កាន់សំពត់ដែលមានតម្លៃមួយពាន់ ដើរវែកមើលក្នុងទីនោះៗ មិនឃើញសំពត់ដែលមានតម្លៃតិចជាងសំពត់របស់ខ្លួននោះហើយ ក៏ដល់នូវការគោមនស្សថា អញមិនបានចំណែកបុណ្យក្នុងប្រាសាទនេះ ទើបឈរយំក្នុងទីមួយកន្លែង ។ គ្រានោះ ព្រះអានន្ទឃើញស្រីនោះ ទើបសួរថា នាងយំព្រោះហេតុអ្វី នាងប្រាប់សេចក្តីនោះហើយ ។ ព្រះថេរៈពោលថា នាងកុំគិតឡើយ អាត្មានឹងប្រាប់ទីដែលត្រូវក្រាលដល់នាង ហើយពោលថា ចូរនាងក្រាលត្រង់ជណ្តើរ ធ្វើជាសំពត់ជូតជើង ភិក្ខុទាំងឡាយលាងជើងហើយ ជូតជើងត្រង់សំពត់នោះមុន ទើបចូលទៅខាងក្នុង កាលបើ

ដូច្នោះ ផលជាច្រើននឹងមានដល់នាង ។ បានឮថា ទីនោះជាស្ថានដែលនាងវិសាខាមិនបានកំណត់ ។ នាងវិសាខាបានថ្វាយទានដល់កិក្ខុសង្ឃ មានព្រះសម្ពុទ្ធជាប្រធាន ខាងក្នុងវិហារអស់កាល ៤ ខែ ។ ក្នុងថ្ងៃចុងក្រោយ បានថ្វាយសំពត់សាដក ដើម្បីធ្វើចីវរដល់កិក្ខុសង្ឃ ។ សំពត់សាដកដើម្បីធ្វើចីវរដែលកិក្ខុថ្មីក្នុងសង្ឃបានហើយ មានតម្លៃមួយពាន់ ។ នាងបានប្រគេនភេសជ្ជៈពេញបាត្រដល់កិក្ខុគ្រប់រូប ។ ព្រោះកាលបរិច្ចាគទាន ទ្រព្យបានអស់ទៅរហូត ៩ កោដិ ។ នាងវិសាខាបរិច្ចាគទ្រព្យក្នុងព្រះពុទ្ធសាសនាទាំងអស់ ២៧ កោដិ គឺទិញដីធ្វើវិហារ ៩ កោដិ សាងវិហារ ៩ កោដិ ឆ្លងវិហារ ៩ កោដិដោយប្រការដូច្នេះ ។

ឈ្មោះថា ការបរិច្ចាគបែបនេះ រមែងមិនមានដល់ស្រីជនៃដែលតាំងនៅក្នុងការៈនៃស្ត្រី ដែលនៅក្នុងផ្ទះរបស់ត្រកូលមិច្ឆាទិដ្ឋិ ។

ក្នុងថ្ងៃនៃការឆ្លងវិហារស្រេច វេលារសៀល នាងវិសាខាដែលមានកូននិងចៅចោមរោមហើយ គិតថា ការប្រាថ្នាណាដែលអញតាំងទុកហើយក្នុងកាលមុន ការប្រាថ្នាទាំងអស់នោះដល់ទីបំផុតហើយ ។ ជើរប្រទក្សិណជុំវិញប្រាសាទ បន្ទឺឧទានដោយសំឡេងដ៏ពីរោះ ៥ គាថាថា

សេចក្តីត្រិះរិះរបស់ខ្ញុំថា តើកាលណា ខ្ញុំនឹងថ្វាយប្រាសាទថ្មីដែលបូកលាបដោយបាយអ និងដី ជាវិហារទាន ដូច្នេះបរិបូណ៌ហើយ ។ សេចក្តីត្រិះរិះរបស់ខ្ញុំថា តើកាលណា ខ្ញុំនឹងបានថ្វាយគ្រែ តាំង ពូក និងខ្នើយ ជាសេនាសនកណ្ឌៈ

ដូច្នេះ បរិបូណ៌ហើយ ។ សេចក្តីត្រិះរិះរបស់ខ្ញុំថា តើកាលណា ខ្ញុំនឹងថ្វាយសលាកភត្ត ផ្សំដោយសាច់ដ៏ស្អាត ជាភោជនទាន ដូច្នេះ បរិបូណ៌ហើយ ។ សេចក្តីត្រិះរិះរបស់ខ្ញុំថា តើកាលណា ខ្ញុំនឹងថ្វាយសំពត់កាសិកពស្ត្រ សំពត់សម្បកឈើ និងសំពត់កប្បាសជាចីវរទាន ដូច្នេះ បរិបូណ៌ហើយ ។ សេចក្តីត្រិះរិះរបស់ខ្ញុំថា តើកាលណា ខ្ញុំនឹងថ្វាយសប្បិ នវនីត ទឹកឃ្មុំ ប្រេង និងទឹកអំពៅ ជាភេសជ្ជទាន ដូច្នេះ បរិបូណ៌ហើយ ។

កិកុទាំងឡាយបានឮសំឡេងរបស់នាងហើយ ក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ឈ្មោះថាការច្រៀងរបស់នាងវិសាខា ពួកខ្ញុំព្រះអង្គមិនធ្លាប់ឃើញអស់កាលដ៏យូរមានប្រមាណប៉ុណ្ណោះ ។ ថ្ងៃនេះ នាង ដែលកូន និងចៅចោមរោមហើយ ច្រៀងដើរប្រទក្សិណជុំវិញប្រាសាទ ប្រមាត់របស់នាងកម្រើកឬហ្ន៎ ឬនាងខូចចរិតទៅហើយ ។ ព្រះសាស្តាត្រាស់ថា ម្នាលកិកុទាំងឡាយ កូនស្រីរបស់តថាគតមិនមែនច្រៀងឡើយ តែអធ្យាស្រ័យផ្ទាល់ខ្លួនរបស់នាងពេញបរិបូណ៌ហើយ នាងត្រេកអរក្នុងចិត្តថា សេចក្តីប្រាថ្នាដែលអញតាំងទុកជល់ទីបំផុតហើយ ទើបដើរបន្ទឹមទាន ។ កាលកិកុទាំងឡាយក្រាបទូលថា តើនាងតាំងសេចក្តីប្រាថ្នាតាំងពីអង្កាល់ណា ទើបព្រះអង្គត្រាស់ថា ម្នាលកិកុទាំងឡាយ អ្នកនឹងស្តាប់ឬ កាលកិកុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងស្តាប់ ទើបទ្រង់នាំអតីតនិទានមកត្រាស់ដូច្នេះថា

ម្នាលភិក្ខុទាំងឡាយ ក្នុងទីបំផុតមួយសែនកប្បអំពីកប្បនេះទៅ ព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់កើតឡើងហើយក្នុងលោក ព្រះអង្គមានព្រះជន្ម ១ សែនឆ្នាំ មានភិក្ខុខីណាស្រពមួយសែនជាបរិវារ ។ នគរឈ្មោះហង្សវតី ព្រះជនកជាព្រះរាជា ព្រះនាមសុនន្ទៈ ព្រះជននីជាព្រះទេវី ព្រះនាមសុជាតា ឧបាសិកាជាកំពូលឧបដ្ឋាយិការបស់ព្រះសាស្តាអង្គនោះ ទូលសូមពរ ៨ ប្រការ ហើយតាំងនៅក្នុងឋានៈដូចមាតា ទំនុកបម្រុងព្រះសាស្តាដោយបច្ច័យ រមែងទៅកាន់ទីបម្រើទាំងល្ងាច និងព្រឹក ។ ស្រីជាសម្លាញ់ម្នាក់របស់ឧបាសិកានោះ រមែងទៅវិហារជាមួយឧបាសិកានោះជានិច្ច ស្រីនោះឃើញឧបាសិកានោះចរចាជាមួយព្រះសាស្តា ដោយសេចក្តីស និទ្ធស្នាល និងឃើញភាពជាអ្នកជិតស និទ្ធជាមួយព្រះសាស្តា គិតថា នាងធ្វើកម្មអ្វីហ្ន៎ ទើបជាបុគ្គលស និទ្ធស្នាលជាមួយព្រះសម្ពុទ្ធយ៉ាងនេះ ដូច្នេះហើយ ទើបទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ស្រីនេះជាអ្វីនឹងព្រះអង្គ ព្រះសាស្តាត្រាស់ថា នាងជាកំពូលនៃស្រីដែលជាឧបដ្ឋាយិកា ស្រីនោះពោលថា បពិត្រព្រះអង្គ នាងធ្វើកម្មអ្វី ទើបជាកំពូលនៃស្រីដែលជាឧបដ្ឋាយិកា ព្រះសាស្តាត្រាស់ថា នាងតាំងសេចក្តីប្រាថ្នាអស់មួយសែនកប្ប ។ ស្រីនោះពោលថា ឥឡូវនេះ ខ្ញុំម្ចាស់នឹងប្រាថ្នា តើអាចបានដែរឬទេ ព្រះសាស្តាត្រាស់ថា អាច ។ ស្រីនោះក្រាបទូលថា បពិត្រព្រះអង្គ បើដូច្នោះ សូមទ្រង់ និងភិក្ខុមួយសែនរូប ទទួលភិក្ខារបស់ខ្ញុំម្ចាស់ ៧ ថ្ងៃចុះ ។ ព្រះសាស្តាទ្រង់ទទួលហើយ ។ ស្រីនោះថ្វាយទាន គ្រប់ ៧ ថ្ងៃ ក្នុងថ្ងៃទីបំផុត បានថ្វាយសាជកដើម្បីធ្វើចីវរហើយ ថ្វាយបង្គំ

ព្រះសាស្តា ក្រាបចុះទៀបបាទមូល តាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ ដោយផលនៃទាននេះ ខ្ញុំម្ចាស់ប្រាថ្នាភាពជាធំ ក្នុងទេវលោកជាដើមណាមួយ ក៏មិនមែន ខ្ញុំម្ចាស់គប្បីបានពរ ៨ ប្រការ ក្នុងសម្នាក់នៃព្រះពុទ្ធ ដូចគ្នានឹងព្រះអង្គ ហើយតាំងនៅក្នុងឋានៈដូចមាតា ជាកំពូលនៃឧបាសិកាដែលអាចទំនុកបម្រុងដោយបច្ច័យ ៤ ព្រះសាស្តាទ្រង់ពិចារណាថា សេចក្តីប្រាថ្នារបស់ស្រីនេះ នឹងសម្រេចឬហ្ន៎ ទ្រង់ពិចារណាដល់អនាគតកាល ប្រមើលមើលរហូតសែនកប្បហើយ ទើបត្រាស់ថា ក្នុងទីបំផុតនៃកប្បទីមួយសែន ព្រះពុទ្ធព្រះនាមគោតម ទ្រង់នឹងកើតឡើង ។ ក្នុងកាលនោះ នាងនឹងបានជាឧបាសិកាឈ្មោះថា វិសាខា បានពរ ៨ ប្រការក្នុងសម្នាក់របស់ព្រះអង្គ ហើយតាំងនៅក្នុងឋានៈដូចមាតា ជាកំពូលនៃស្រីជាឧបដ្ឋាយិកា ដែលទំនុកបម្រុងដោយបច្ច័យ ៤ ។ សម្បត្តិនោះ នាងហាក់បីដូចបានក្នុងថ្ងៃស្អែក ។

នាងធ្វើកុសលជរាបជល់អស់អាយុហើយ ចុតិអំពីអត្តភាពនោះ កើតក្នុងទេវលោក អន្ទោលទៅក្នុងទេវលោក និងមនុស្សលោក ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ កើតជាព្រះធីតាព្រះនាមសង្ឃទាសី ដែលជាបងប្អូនរបស់បណ្ឌាធីតា ៧ អង្គ របស់ព្រះបាទកាសីព្រះនាមកិកិ ជាអ្នកមិនបានទៅកាន់ត្រកូលដទៃ ព្រះនាងធ្វើបុណ្យមានទានជាដើម ជាមួយបងស្រីទាំងនោះអស់កាលយូរ បានធ្វើសេចក្តីប្រាថ្នាទៀបបាទមូលនៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈថា ក្នុងអនាគតកាល ខ្ញុំម្ចាស់គប្បីបានពរ ៨ ប្រការ ក្នុងសម្នាក់នៃព្រះពុទ្ធដូចទ្រង់ ហើយតាំងនៅក្នុងឋានៈដូចមាតា ជាកំពូលឧបាសិកា

ដែលថ្វាយបង្គំ ៤ ។ ចាប់តាំងពីកាលនោះ នាងអន្ទោលទៅក្នុងទេវលោក និងមនុស្សលោក ក្នុងអត្តភាពនេះ កើតជាកូនស្រីរបស់ធនញ្ជយសេដ្ឋី ដែលជាកូនរបស់មេណ្ឌកសេដ្ឋី ។ បានធ្វើបុណ្យជ្រើនក្នុងសាសនារបស់តថាគត ។

ព្រះសាស្តា កាលទ្រង់សម្តែងអតីតនិទានចប់ហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធីតារបស់តថាគត មិនមែនច្រៀងដោយប្រការដូច្នេះឯង តែនាងឃើញសេចក្តីសម្រេចនៃការប្រាថ្នាដែលតាំងទុក ទើបបន្ទឹខទាន កាលទ្រង់សម្តែងធម៌ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មាលាការអ្នកឈ្លាសធ្វើគំនរផ្កាផ្សេងៗ ឲ្យជាគំនរហើយ រមែងធ្វើកម្រងផ្កា មានប្រការផ្សេងៗបាន យ៉ាងណា ចិត្តរបស់នាងវិសាខា រមែងបង្អោនទៅដើម្បីធ្វើកុសល មានប្រការផ្សេងៗ ក៏ដូច្នោះដូចគ្នា ដូច្នេះហើយ ត្រាស់គាថានេះថា

យថាបិ បុប្ផរាសិម្ហា កយិរា មាលាគុណ្ឌេ ពហូ
ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ ។

មាលាការចេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា (ផ្សេងៗគ្នា) ឲ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើន យ៉ាងនោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បុប្ផរាសិម្ហា** *បានដល់ អំពីគំនរនៃផ្កាដែលមានប្រការផ្សេងៗ ។ បទថា* **កយិរា** *ប្រែថា គប្បីធ្វើ ។ ពីរបទថា* **មាលា-គុណ្ឌេ ពហូ** *សេចក្តីថា នូវមាលាវិកតិច្រើនប្រភេទ ដោយប្រភេទមានផ្កា*

ដែលមានទង់តែម្ខាងជាដើម ។ បទថា **មច្ចុន** *សេចក្តីថា សត្វដែលបានឈ្មោះថា* **មច្ចុ** *ព្រោះជាបុគ្គលដែលគប្បីស្លាប់ជាសភាវៈ គួរធ្វើកុសលមានការថ្វាយចីវរជាដើមឲ្យបានច្រើន ។ សព្ទ គឺ* **បុប្ផរាសិ** *ក្នុងគាថានោះ មានការសម្តែងផ្កាច្រើនជាអត្ថ ។*

បើផ្កាមានតិច នាយមាលាការឈ្វាសវៃ ក៏រមែងមិនអាចធ្វើកម្រងផ្កាឲ្យច្រើនបានឡើយ ចំណែកមាលាការដែលមិនឈ្វាស កាលផ្កា ទោះបីមានតិចក្តី ច្រើនក្តី រមែងមិនអាចដោយពិត តែបើផ្កាមានច្រើន មាលាការដែលឈ្វាស ឧស្សាហ៍ មុតស្រួច រមែងធ្វើពួកផ្កាឲ្យច្រើន យ៉ាងណា បើសទ្ធារបស់បុគ្គលខ្លះ មានតិច ភោគៈមានច្រើន បុគ្គលនោះ រមែងមិនអាចធ្វើកុសលឲ្យច្រើនបានឡើយ ឯកាលសទ្ធាមានតិច ទាំងភោគៈក៏តិច បុគ្គលនោះ ក៏រមែងមិនអាច តែកាលសទ្ធាច្រើន ភោគៈតិច បុគ្គលនោះ ក៏រមែងមិនអាចដូចគ្នា តែបើសទ្ធាមានច្រើន ភោគៈក៏ច្រើន បុគ្គលរមែងអាចធ្វើកុសលឲ្យច្រើនបាន ដូច្នោះ នាងវិសាខាឧបាសិកាជាបុគ្គលបែបនោះឯង ព្រះសាស្តាទ្រង់សម្តែងយកនាងវិសាខានោះ ទើបត្រាស់ពាក្យជាព្រះគាថាដូច្នេះថា

មាលាការចេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា (ផ្សេងៗ គ្នា) ឲ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើនយ៉ាងនោះឯង ។

មាលាការចេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា (ផ្សេងៗ គ្នា) ឲ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យបាន

ច្រើនយ៉ាងនោះ ។

ក្នុងពេលចប់ទេសនា មហាជនបានជាអរិយបុគ្គល មានសោតាបន្ន ជាដើម ទេសនាមានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។

រឿង ឆានវិសាខា ចប់

រឿង បញ្ហារបស់ព្រះអានន្ទត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី កាលទ្រង់ស្រាយបញ្ហារបស់ព្រះអានន្ទត្ថេរ ត្រាស់ធម្មទេសនានេះថា **ឯ បុប្ផគន្ធោ បដិវាតមេតិ** *ជាដើម ។*

បានឮមកថា ព្រះថេរៈពួនសម្ងំហើយក្នុងពេលល្ងាច គិតថា ព្រះដ៏មានព្រះភាគ ត្រាស់ក្លិនដ៏ឧត្តម ៣ យ៉ាង គឺក្លិនកើតអំពីឫស ក្លិនកើតអំពីខ្លឹម ក្លិនកើតអំពីផ្កា ក្លិនរបស់គន្ធជាតិទាំងនោះ ផ្សាយទៅតាមខ្យល់ប៉ុណ្ណោះ មិនផ្សាយទៅច្រាស់ខ្យល់ឡើយ ក្លិនរបស់គន្ធជាតិណាផ្សាយទៅបានច្រាស់ខ្យល់ គន្ធជាតិនោះមានឬហ្ន៎ ។ គ្រានោះ លោកមានការគិតថា ប្រយោជន៍អ្វីរបស់អញដោយបញ្ហាដែលវិនិច្ឆ័យដោយខ្លួនឯង អញនឹងទូលសួរព្រះសាស្តានោះឯងល្អជាង ចូលទៅគាល់ព្រះសាស្តាហើយ ទូលសួរ ។ ព្រោះហេតុនោះឯង ទើបព្រះធម្មសង្គាហកាចារ្យពោលថា គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូល

ទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កិនៃគន្ធជាតិដែលផ្សាយទៅកាន់ទីបណ្តាយខ្យល់បាន ទៅច្រាស់ខ្យល់មិនបាននេះមាន ៣ យ៉ាង ។ គន្ធជាតិ ៣ យ៉ាង តើដូចម្តេច ។ គឺកិនឫស ១ កិនខ្លឹម ១ កិនផ្កា ១ ។ បពិត្រព្រះអង្គដ៏ចម្រើន កិនគន្ធជាតិទាំង ៣ នេះឯង ផ្សាយទៅបានតែទីបណ្តាយ ខ្យល់ទៅច្រាសខ្យល់ មិនបានទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្រែងមានកិនគន្ធជាតិអ្វី ដែលផ្សាយទៅបណ្តាយខ្យល់ក៏បាន ផ្សាយទៅច្រាសខ្យល់ក៏បាន ផ្សាយទៅទាំងបណ្តាយខ្យល់ និងច្រាស់ខ្យល់ក៏បាន មានដែរឬទេ ។ គ្រានោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ឆ្លើយបញ្ជាដល់ព្រះអានន្ទ ទើបត្រាស់ថា ម្នាលអានន្ទ កិនគន្ធជាតិដែលផ្សាយទៅបណ្តាយខ្យល់ក៏បាន ទៅច្រាស់ខ្យល់ក៏បាន ទៅបណ្តាយខ្យល់ និងច្រាស់ខ្យល់ក៏បាន មានដែរ ។

ព្រះអានន្ទទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ចុះគន្ធជាតិដែលផ្សាយទៅបណ្តាយខ្យល់ក៏បាន ច្រាស់ខ្យល់ក៏បាន ទាំងបណ្តាយខ្យល់ និងច្រាស់ខ្យល់ក៏បាន តើដូចម្តេច ។

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ក្នុងលោកនេះ ស្ត្រីក្តី បុរសក្តី ក្នុងស្រុក ឬនិគមណា បានដល់ព្រះពុទ្ធជាទីរឭក បានដល់ព្រះធម៌ជាទីរឭក បានដល់ព្រះសង្ឃជាទីរឭក វៀរចាកការសម្លាប់សត្វ វៀរចាកការលួចលាក់យក

វត្ថុដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាម វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ជាអ្នកមានសីល មានធម៌ល្អ មានចិត្តប្រាសចាកសេចក្តីកំណាញ់ជាមន្ទិល នៅគ្រប់គ្រងផ្ទះ ជាអ្នកមានទានបរិច្ចាគហើយ មានដៃលាងស្អាតហើយ ជាអ្នកត្រេកអរក្នុងការលះ ជាអ្នកគួរគេសូមបាន ត្រេកអរក្នុងការឲ្យនិងការចែករំលែក សមណព្រាហ្មណ៍ក្នុងទិសទាំងឡាយ រមែងសរសើរបុគ្គលនោះថា ស្ត្រីក្តី បុរសក្តី ក្នុងស្រុក ឬនិគមឈ្មោះឯណោះ ដល់ព្រះពុទ្ធជាទីរឭក ។បេ។ ត្រេកអរក្នុងការចែករំលែកទាន ។ សូម្បីពួកទេវតាក៏តែងសរសើរបុគ្គលនោះថា ស្ត្រីក្តី បុរសក្តី ក្នុងស្រុក ឬនិគមឈ្មោះឯណោះ ជាអ្នកដល់ព្រះពុទ្ធជាទីរឭក ។បេ។ គួរគេសូមបាន ត្រេកអរក្នុងការចែករំលែកទាន ។ ម្នាលអានន្ទ កិនែនៃគន្ធជាតិនេះឯង ទើបផ្សាយទៅបណ្តាយខ្យល់ក៏បាន ច្រាស់ខ្យល់ក៏បាន ទាំងបណ្តាយខ្យល់ ទាំងច្រាស់ខ្យល់ក៏បាន ។

ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

ន បុប្ផគន្ធោ បដិវាតមេតិ ន ចន្ទនំ តគរមល្លិកា វា
សតញ្ច គន្ធោ បដិវាតមេតិ សព្វា ទិសា សប្បុរិសោ បវាយតិ ។
ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី
ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។

កិនផ្កាឈើផ្សាយទៅច្រាស់ខ្យល់មិនបាន កិនខ្ញីមចន្ទន៍ក្តី កិនខ្ញីមក្រស្នាក្តី កិនផ្កាម្ទិះរួតក្តី ក៏ផ្សាយទៅច្រាស់ខ្យល់មិនបាន ចំណែក

កិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាស់ខ្យល់បាន ព្រោះសប្បុរស រមែងផ្សាយទៅបានគ្រប់ទិស ។ កិនៃនៃសីល ជាគុណជាតប្រសើរបំផុត ជាងគន្ធជាតិទាំងនេះ គឺខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្ល៉ះលា ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ន បុប្ផគន្ធោ** *សេចក្តីថា ដើមបាវិតត្តក:ក្នុងកពតាវត្តិង្សដោយបណ្តាយ និងទទឹង មានប្រមាណ ១០០ យោជន៍ រស្មីផ្ការបស់ដើមបាវិតត្តក:នោះ ផ្សាយចេញទៅ ៥០ យោជន៍ កិនផ្សាយទៅបាន ១០០ យោជន៍ សូម្បីកិននោះក៏ផ្សាយទៅបានតាមខ្យល់ប៉ុណ្ណោះ មិនអាចផ្សាយទៅច្រាស់ខ្យល់បានត្រឹមតែមួយជ្ជាប់ឡើយ កិនផ្កាបែបនេះ ផ្សាយទៅច្រាស់ខ្យល់មិនបាន ។ បទថា* **ចន្ទនំ** *បានដល់ កិនចន្ទន៍ ។ ដោយបទថា* **តគរមល្លិកា វា** *នេះ ទ្រង់បំណងយកកិនរបស់គន្ធជាតិទាំងនេះដូចគ្នា ។ ពិតហើយ កិនរបស់ចន្ទន៍ក្រហមក្តី របស់ក្រស្នា និងម្ល៉ះលាក្តី ដែលជាកំពូលនៃកិន កើតអំពីខ្លឹមទាំងឡាយ រមែងផ្សាយទៅបានតាមខ្យល់ប៉ុណ្ណោះ ផ្សាយទៅច្រាស់ខ្យល់មិនបានឡើយ ។ ពីរបទថា* **សតញ្ច គន្ធោ** *សេចក្តីថា ចំណែកកិនសីលរបស់សប្បុរស គឺរបស់ព្រះពុទ្ធ និងព្រះសាវ័កទាំងឡាយ រមែងផ្សាយទៅច្រាស់ខ្យល់បាន ។*

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសប្បុរស រមែងផ្សាយខ្លួនៗទៅសព្វទិស ។ អធិប្បាយថា ព្រោះសប្បុរស រមែងផ្សាយគ្របដណ្តប់ទៅ

សព្វទិសដោយក្លិនសីល ដូច្នោះ សប្បុរសដែលបណ្ឌិតគួរពោលបានថា ក្លិនរបស់លោកផ្សាយទៅច្រាស់ខ្យល់បាន ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **បដិវាតមេតិ ។** *បទថា* **វាសុក្កី** *បានដល់ ផ្កាម្ល៉ិះ ។*

បទថា **ឯតេសំ** *ជាដើម សេចក្តីថា ក្លិនសីលរបស់សប្បុរសដែលមានសីលនោះឯង ជាក្លិនដ៏កំពូលជាងក្លិននៃគន្ធជាតិ មានចន្ទន៍ក្រហមជាដើមនេះ គឺបើក្លិនដែលដូចមិនមាន បានដល់ មិនមានចំណែកប្រៀបបាន ។*

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាមានប្រយោជន៍ ដល់មហាជនហើយ ដូច្នោះឯង ។

រឿង បញ្ហារបស់ព្រះអានន្ទ ចប់

រឿង ប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរ លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អប្បមត្តោ អយំ គន្ធោ** *ជាដើម ។*

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះមហាកស្សបៈចេញអំពីនិរោធសមាបត្តិ ដោយកន្លងទៅ ៧ ថ្ងៃ ចេញទៅហើយដោយគិតថា នឹងត្រាច់បិណ្ឌបាតតាម

លំដាប់ច្រកក្នុងក្រុងរាជគ្រឹះ ។ ក្នុងសម័យនោះ ទេពអប្សរប្រមាណ ៥០០ មានជើងដូចជើងព្រាប ជាបាទបរិចារិការបស់សក្កទេវរាជ កើតនូវឧស្សាហ៍ថា នឹងប្រគេនបិណ្ឌបាតដល់ព្រះថេរៈ ទើបត្រៀមបិណ្ឌបាត ៥០០ សម្រាប់ហើយកាន់មកឈរក្នុងរវាងផ្លូវពោលថា សូមលោកម្ចាស់ទទួលបិណ្ឌបាតនេះ សូមលោកម្ចាស់ ធ្វើសេចក្តីអនុគ្រោះដល់ពួកខ្ញុំចុះ ។

ព្រះថេរៈពោលថា ចូរពួកនាងទៅចុះ អាត្មានឹងធ្វើសេចក្តីអនុគ្រោះដល់ពួកអ្នកក្រ ។ ទេពអប្សរពោលថា សូមលោកម្ចាស់កុំឲ្យពួកខ្ញុំវិនាសឡើយ សូមធ្វើសេចក្តីសង្គ្រោះពួកខ្ញុំចុះ ។

ព្រះថេរៈដឹងហើយទើបហាមទៀត ហើយផ្ចាត់ម្រាមដៃច្រាប់ស្រីទេព-អប្សរទាំងឡាយ ដែលមិនប្រាថ្នានឹងចៀសចេញទៅ កំពុងនៅអង្វរថា ពួកនាងមិនស្គាល់ប្រមាណ ចូរចៀសចេញទៅ ។ ទេពអប្សរទាំងនោះឮសំឡេងម្រាមដៃរបស់ព្រះថេរៈហើយ មិនអាចនៅឈរវាំងផ្លូវបាន ទើបគេចទៅកាន់ទេវលោកវិញ សក្កទេវរាជត្រាស់សួរថា ពួកនាងទៅណា មកអំពីណា ទើបទូលថា ខ្ញុំម្ចាស់នាំគ្នាទៅដោយបំណងថា នឹងប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរ ដែលចេញអំពីសមាបត្តិ សក្កទេវរាជត្រាស់ថា ពួកនាងប្រគេនហើយឬ ស្រីទេពអប្សរច្រាប់ថា ព្រះថេរៈមិនប្រាថ្នានឹងទទួល សក្ក-ទេវរាជត្រាស់ថា ព្រះថេរៈពោលដូចម្តេច ទេពអប្សរច្រាប់ថា លោកពោលថា នឹងធ្វើសេចក្តីសង្គ្រោះពួកអ្នកក្រីក្រ សក្កទេវរាជពោលថា ពួកនាងទៅដោយអាការដូចម្តេច ស្រីទេពអប្សរច្រាប់ថា ទៅដោយអាការយ៉ាងនេះឯង ។

សក្កទេវរាជគ្រាស់ថា ស្រីដូចពួកនាងនីងប្រគេនបិណ្ឌបាតដល់ព្រះថេរៈបានដូចម្តេច បំណាងនីងប្រគេនដោយខ្លួនឯង ទើបកាឡាខ្លួនជាមនុស្សចាស់គ្រាំគ្រាដោយអំណាចជរា មានធ្មេញបាក់ មានសក់ស្កូវ ខ្លងកោង ជាជាងតម្បាញចាស់ ទ្រង់នាំនាងសុជាតាទេពធីតា ឲ្យធ្វើជាស្រីចាស់យ៉ាងនោះដូចគ្នាហើយ ទ្រង់និម្មិតផ្លូវនៃជាងតម្បាញមួយខ្សែ ប្រថាប់សន្ធឹងកីតម្បាញ ។

ចំណែកព្រះថេរៈនិមន្តបែរមុខចូលក្រុង ដោយបំណងថានីងធ្វើសេចក្តីសង្គ្រោះពួកអ្នកក្រីក្រ ឃើញផ្លូវមួយខ្សែនោះ ក្រៅក្រុងនោះឯង សម្លឹងមើលក៏បានឃើញជនពីរនាក់ ។ ខណៈនោះ សក្កទេវរាជកំពុងទាញកីតម្បាញនាងសុជាតារវៃអំបោះ ។ ព្រះថេរៈគិតថា ជនពីរនាក់នេះក្នុងកាលចាស់ ក៏នៅតែធ្វើការ ក្នុងក្រុងនេះ មិនមានអ្នកក្រីក្រជាងជនទាំងពីរនេះទៀយ អាត្មាអញនីងទទួលភត្តល្មមប្រមាណមួយវែក ដែលជនទាំងពីរប្រគេនហើយ ធ្វើនូវសេចក្តីសង្គ្រោះដល់ជនទាំងពីរនេះ ។ ព្រះថេរៈបានបែរមុខទៅត្រង់ផ្ទះរបស់ជនទាំងពីរនោះឯង ។

សក្កទេវរាជទតឃើញព្រះថេរៈនោះ ទើបគ្រាស់នីងនាងសុជាតាថា នែនាង ព្រះថេរៈជាម្ចាស់នៃយើងនិមន្តមកផ្លូវនេះ ចូរនាងអង្គុយធ្វើដូចជាមិនឃើញលោកចុះ ខ្ញុំនីងបញ្ឆោតលោកមួយភ្លែត ហើយសឹមប្រគេនបិណ្ឌបាត ។ ព្រះថេរៈបានមកឈរត្រង់ទ្វារផ្ទះហើយ ។ ជនទាំងពីរនាក់ប្តីប្រពន្ធនោះ ក៏ធ្វើដូចជាមិនឃើញ ធ្វើតែការងាររបស់ខ្លួនតែម្យ៉ាង រង់ចាំបន្តិចហើយ ។ គ្រានោះ សក្កៈគ្រាស់ថា ត្រង់ទ្វារផ្ទះហាក់ដូចជាមានព្រះថេរៈឈរមួយរូប ចូរនាងទៅ

ពិនិត្យមើលសិន ។ នាងសុជាតាឆ្លើយថា អ្នកទៅពិនិត្យមើលចុះ ។ សក្កទេវរាជ ចេញអំពីផ្ទះហើយ ទ្រង់ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋានហើយ យកដៃទាំងពីរច្រត់ក្បាលជង្គង់ ហើយដកដង្ហើមធំក្រោកឡើង បង្អង់មួយសម្ទុះ ត្រាស់ថា លោកម្ចាស់ជាព្រះថេរៈអង្គណាហ្ន៎ ហើយត្រាស់បន្តថា ក្អែករបស់ខ្ញុំវាស្រាំង ដូច្នេះហើយ ទ្រង់ជាក់ដៃចាំងត្រង់ថ្ងាស ទ្រង់សម្លឹងមើលហើយ ត្រាស់ថា ឱហ្ន៎ លោកម្ចាស់មហាកស្សបត្ថេររបស់ខ្ញុំ យូរៗ ទើបមកកាន់ទ្វារខូមរបស់ខ្ញុំ នាងមានអ្វីក្នុងផ្ទះខ្លះដែរឬទេ នាងសុជាតាធ្វើជាទ្រមួនបន្តិចហើយ បានឲ្យចម្លើយថា មានអ្នក សក្កទេវរាជត្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំគិតថា ទានសៅហ្មង ឬប្រណីត សូមធ្វើសេចក្តីសង្គ្រោះដល់ខ្ញុំទាំងពីរចុះ ដូច្នេះហើយ ទ្រង់ក៏ទទួលបាត្រ ។ ព្រះថេរៈគិតថា ទានដែលជនពីរនាក់ប្តីប្រពន្ធនេះឲ្យហើយ ទោះជាទឹកជ្រក់ ឬកុណ្ឌកមួយក្តាប់ក៏ដោយ អាត្មាអញនឹងធ្វើសេចក្តីសង្គ្រោះដល់ជនពីរនាក់ប្តីប្រពន្ធនេះ ដូច្នេះហើយ ទើបឲ្យបាត្រទៅ ។ សក្កទេវរាជនោះចូលទៅខាងក្នុងផ្ទះហើយ ទ្រង់ដួសបាយចេញអំពីឆ្នាំងជាក់ពេញបាត្រហើយ ជាក់ក្នុងដៃព្រះថេរៈ ។ បិណ្ឌបាតនោះ មានសូបព្យញ្ជនៈច្រើន បានក្រអូបឈ្ងុយពេញក្រុងរាគ្រឹះហើយ ។

ក្នុងកាលនោះព្រះថេរៈគិតថា បុរសនេះមានសក្តិតូច បិណ្ឌបាតមានសក្តិច្រើន ដូចគ្នានឹងភោជនរបស់សក្កទេវរាជ ជននេះជាអ្នកណាហ្ន៎ កាលនោះព្រះថេរៈជ្រាបបុរសនោះថាជាសក្កៈ ទើបពោលថា ទ្រង់ដណ្តើមសម្បត្តិអ្នកក្រីក្រ ឈ្មោះថា ធ្វើកម្មធ្ងន់ហើយ អ្នកណាក៏ដោយដែលជាអ្នកក្រីក្រ បានឲ្យ

ទានដល់អាត្មាក្នុងថ្ងៃនេះ នឹងបានតំណែងសេនាបតី ឬតំណែងសេដ្ឋី សក្ក-
ទេវរាជត្រាស់ថា អ្នកក្រីក្រជាងខ្ញុំមិនមានឡើយ ព្រះថេរៈពោលថា ទ្រង់
សោយសិរីសម្បត្តិក្នុងទេវលោក ឈ្មោះថា ជាអ្នកក្រដូចម្តេច សក្កទេវរាជ
ត្រាស់ថា លោកម្ចាស់ថាក៏ត្រូវ តែកាលព្រះពុទ្ធមិនមានកើតឡើង ខ្ញុំបានធ្វើ
កល្យាណកម្ម កាលព្រះពុទ្ធកើតឡើងកំពុងប្រព្រឹត្តទៅ ទេវបុត្រមានសក្តិ
ស្មើគ្នា ៣ អង្គ គឺចូឡរថទេវបុត្រ មហារថទេវបុត្រ អនេកវណ្ណទេវបុត្រ ធ្វើ
កល្យាណកម្មហើយ បានកើតក្នុងទីជិតខ្ញុំ មានតេជៈច្រើនជាងខ្ញុំ កាលទេវ-
បុត្រ ៣ អង្គនោះ នាំពួកបារិចារិកាចុះកាន់ផ្លូវ ដោយគិតថា នឹងលេង
នក្ខត្តឬក្ស ខ្ញុំត្រូវគេចចូលទៅកាន់ដំណាក់ ព្រោះតេជៈចេញអំពីសរីរៈរបស់
ទេវបុត្រទាំង ៣ នោះ គ្របសង្កត់សរីរៈរបស់ខ្ញុំ តេជៈអំពីសរីរៈរបស់ខ្ញុំមិន
គ្របសង្កត់សរីរៈរបស់ទេវបុត្រទាំង ៣ នោះ អ្នកណាក្រជាងខ្ញុំហ្ន៎ ព្រះថេរៈ
ពោលថា អើ បើយ៉ាងនោះ តាំងអំពីថ្ងៃនេះទៅ សូមទ្រង់កុំបោកបញ្ឆោតឲ្យ
ទានដល់អាត្មាយ៉ាងនេះ ។ សក្កទេវរាជត្រាស់ថា បើខ្ញុំបោកបញ្ឆោតលោក
ម្ចាស់ថ្វាយទាន កុសលនឹងមានដល់ខ្ញុំដែរទេ ព្រះថេរៈត្រាស់ថា មាន សក្ក-
ទេវរាជត្រាស់ថា បើយ៉ាងនោះ ការធ្វើកុសលកម្ម ចាត់ជាកិច្ចរបស់ខ្ញុំចុះ ។

សក្កទេវរាជត្រាស់យ៉ាងនោះហើយ ទ្រង់ថ្វាយបង្គំព្រះថេរៈ នាំនាង
សុជាតា ធ្វើប្រទក្សិណព្រះថេរៈហើយ ហោះទៅកាន់អាកាស ទ្រង់បន្ទឺឧទាន
ថា ឱទាន ដែលខ្ញុំឲ្យហើយជាទានដ៏កំពូល ខ្ញុំបានធ្វើល្អហើយក្នុងព្រះ
កស្សបៈ ។

ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមហាកស្សបៈដ៏មានអាយុ នៅក្នុងបិប្ផលិ-គុហា អង្គុយដោយភ្នែនតែមួយ ចូលសមាធិណាមួយអស់ ៧ ថ្ងៃ លុះកន្លង ៧ ថ្ងៃនោះហើយ ព្រះមហាកស្សបៈដ៏មានអាយុ ក៏ចេញអំពីសមាធិនោះ ។ កាលដែលព្រះមហាកស្សបៈដ៏មានអាយុ ចេញអំពីសមាធិនោះហើយ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញចូលទៅបិណ្ឌបាតឯក្រុងរាជគ្រឹះចុះ ។ សម័យនោះឯង ពួកទេវតាចំនួន ៥០០ អង្គ ដល់នូវការខ្វល់ខ្វាយ ដើម្បីប្រគេនបិណ្ឌបាតចំពោះព្រះមហាកស្សបៈដ៏មានអាយុ ។ គ្រានោះ ព្រះមហាកស្សបៈដ៏មានអាយុ ហាមឃាត់ពួកទេវតាទាំង ៥០០ អង្គនោះហើយ ស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាតឯក្រុងរាជគ្រឹះ ។

សម័យនោះឯង សក្កៈជាធំជាងពួកទេវតា មានប្រាថ្នាដើម្បីប្រគេនបិណ្ឌបាត ចំពោះព្រះមហាកស្សបៈដ៏មានអាយុ បាននិម្មិតភេទខ្លួនជាជាងតម្បាញ កំពុងត្បាញនូវតម្បាញ ។ ឯអសុរកញ្ញាឈ្មោះសុជាតា ក៏ការអម្បោះឲ្យពេញខ្នារ ។ គ្រានោះ ព្រះមហាកស្សបៈដ៏មានអាយុ កំពុងត្រាច់បិណ្ឌបាតសព្វច្រក ក្នុងក្រុងរាជគ្រឹះ បានចូលទៅកាន់លំនៅរបស់ទេវរាជឈ្មោះសក្កៈ ជាធំជាងពួកទេវតា ។ សក្កៈជាធំជាងពួកទេវតា បានឃើញព្រះមហាកស្សបៈដ៏មានអាយុ កំពុងតែនិមន្តមកអំពីចម្ងាយ លុះបានឃើញ

ហើយ ក៏ចេញអំពីផ្ទះ ទៅទទួលយកជាត្រអំពីព្រះហស្ត ចូលទៅកាន់ផ្ទះ ដួសបាយអំពីឆ្នាំង ដាក់ឲ្យពេញជាត្រ រួចប្រគេនចំពោះព្រះមហាកស្សប: ដ៏មានអាយុ ។ បិណ្ឌបាតនោះ មានសម្លច្រើនមុខ មានម្ហូបក្រៀមច្រើនមុខ ។ លំដាប់នោះ ព្រះមហាកស្សប:ដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា សត្វនេះជាអ្វីហ្ន៎ បានជាមានឥទ្ធានុភាព មានសភាពយ៉ាងនេះ ។ លំដាប់នោះ ព្រះមហាកស្សប:ដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះទៀតថា ឱហ្ន៎ សក្ក: ជាធំជាងពួកទេវតាទេតើ ។ លុះព្រះមហាកស្សប:ដ៏មានអាយុ បានដឹងច្បាស់ដូច្នេះហើយ និយាយនឹងសក្ក:ជាធំជាងទេវតាថា បពិត្រកោសិយ: ព្រះអង្គ បានធ្វើអំពើនេះហើយ ក្រោយទៅ ព្រះអង្គកុំធ្វើអំពើយ៉ាងនេះទៀតឡើយ ។ បពិត្រព្រះកស្សប:ដ៏ចម្រើន យើងខ្ញុំក៏មានសេចក្តីត្រូវការដោយបុណ្យដែរ យើងខ្ញុំគួរធ្វើបុណ្យបានដែរ ។ លំដាប់នោះ សក្ក:ជាធំជាងពួកទេវតា ថ្វាយបង្គំព្រះមហាកស្សប:ដ៏មានអាយុ រួចធ្វើប្រទក្សិណ ហើយហោះទៅឯអាកាស បន្ទឺនូវឧទាន ក្នុងអាកាសជាទីវាលអស់វារៈ ៣ ដងថា

> ឱហ្ន៎ ទានដែលអាត្មាអញបានតម្កល់ទុកល្អហើយ ក្នុងព្រះមហាកស្សប: ហៅពេញជាទានឧត្តម ឱហ្ន៎ ទានដែលអាត្មាអញ បានតម្កល់ទុកល្អហើយ ក្នុងព្រះមហាកស្សប: ហៅពេញជាទានឧត្តម ។

ព្រះមានព្រះភាគ ទ្រង់បានឮឧទានដោយទិព្វសោតធាតុដ៏បរិសុទ្ធ កន្ធង បង់សោតធាតុរបស់មនុស្សធម្មតា ដែលសក្ក:ជាធំជាងពួកទេវតា កំពុង

ហោះទៅកាន់វេហាស៍ ហើយបន្ទឺអស់វារៈ ៣ ដង ក្នុងអាកាសជាទីវាលថា

ឱហ្ន៎ ទានដែលអាត្មាអញបានតម្កល់ទុកល្អហើយ ក្នុងព្រះមហាកស្សប ហៅពេញជាទានដ៏ឧត្តម ឱហ្ន៎ ទានដែលអាត្មាអញបានតម្កល់ទុកល្អហើយ ក្នុងព្រះមហាកស្សបៈ ហៅពេញជាទានដ៏ឧត្តម ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ទេវតាទាំងឡាយ រមែងស្រឡាញ់ភិក្ខុ អ្នកប្រព្រឹត្តបិណ្ឌបាតជាវត្ត អ្នកចិញ្ចឹមតែខ្លួន មិនចិញ្ចឹមបុគ្គលដទៃ ជាអ្នកនឹងធឹង សូប់រម្ងាប់ មានស្មារតីគ្រប់កាល[1] ។

១- បិ. ៥២ ទំ. ១៧៨ ។

កាលទ្រង់បន្ទឺឧទាននេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សក្កទេវរាជជាស្តេចនៃទេវតា បានយាងមកប្រគេនបិណ្ឌបាតដល់បុត្រៃរបស់តថាគត ព្រោះកិនៃសីល ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អប្បមត្តោ អយំ គន្ធោ ឃ្វាយំ តគរចន្ទនី
យោ ច សីលវតំ គន្ធោ វាតិ តេវេសុ ឧត្តមោ ។

កិនក្រស្នា និងកិនចន្ទន៍ណា កិននេះក្រអូបមានប្រមាណតិចទេ ចំណែកកិននៃបុគ្គលមានសីលទាំងឡាយណា ទើបកិននោះក្រអូបលើសលប់ផ្សាយទៅក្នុងទេវលោក និងមនុស្សលោកបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បមត្តោ** *គឺមានប្រមាណតិចតួច ។ ពីរបទថា* **យោ ច សីលវតំ** *សេចក្តីថា ចំណែកកិនសីលរបស់អ្នកមានសីលទាំងឡាយណា កិនសីលនោះមិនមែនជាកិនតិចតួច ដូចកិនក្រស្នា និងកិនចន្ទន៍ក្រហមទ្បើយ គឺជាកិនដ៏ឧឡារ ផ្សាយទៅក្រៃលែង ដោយហេតុនោះឯង កិនសីល ទើបជាកិនដ៏ឧត្តម គឺប្រសើរលើសលប់ ផ្សាយទៅក្នុងពួកទេវតា និងពួកមនុស្ស គឺផ្សាយទៅក្នុងពួកទេវតា និងពួកមនុស្ស បានដល់ក្រអូបទូទៅនោះឯង ។*

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាមានប្រយោជន៍ ដល់មហាជនហើយ ដូច្នេះឯង ॥

រឿង ប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរ ចប់

រឿង ព្រះគោធិកត្ថេរ

លំនាំដើម

ព្រះសាស្តា កាលទ្រង់ចូលទៅអាស្រ័យក្រុងរាជគ្រឹះ គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបរិនិព្វានរបស់ព្រះគោធិកត្ថេរ ត្រាស់ធម្មទេសនានេះថា **តេសំ សម្បន្នសីលានំ** *ជាដើម ។*

សេចក្តីពិស្តារថា លោកដ៏មានអាយុអង្គនោះ នៅជិតគុហាកាឡសិលា ក្បែរភ្នំឥសិគិលិ ជាអ្នកមិនប្រមាទ មានសេចក្តីព្យាយាម មានខ្លួនបញ្ជូនទៅ ហើយ ពាល់ត្រូវនូវចេតាវិមុត្តិ ដែលកើតឡើងក្នុងសម័យ គឺកើតម្តងម្កាល វិនាសចាកចេតោវិមុត្តិនោះ ដោយអំណាចអាពាធណាមួយ ដែលរើឡើង ។ លោកញ៉ាំងឈានទី ២ ខ្លះ ទី ៣ ខ្លះឲ្យកើតឡើងដល់ទៅ ៦ ជង ហើយក៏ វិនាស ក្នុងគ្រាទី ៧ ឲ្យកើតឡើងហើយក៏គិតថា អញវិនាសចាកឈានដល់ ទៅ ៦ ជង គតិរបស់បុគ្គលមានឈានសាបសូន្យហើយ មិនពិតប្រាកដ ពេលនេះ អញនឹងនាំសស្តាមក ដូច្នេះហើយ ទើបកាន់កាំបិតសម្រាប់កោរ សក់ សិងលើត្រែតូចដើម្បីអារបំពង់កហើយ ។

មារដ៏ងចិត្តរបស់លោកហើយគិតថា ភិក្ខុនេះប្រាថ្នានឹងនាំសស្តាមក ឯ ភិក្ខុទាំងឡាយកាលនាំសស្តាមក រមែងជាអ្នកអស់អាល័យក្នុងជីវិត ភិក្ខុទាំង នោះផ្តើមតាំងវិបស្សនាហើយ រមែងសម្រេចអរហត្តបាន បើអញឃាត់ភិក្ខុនោះ លោកមិនធ្វើតាមពាក្យរបស់អញ អញនឹងទូលព្រះសាស្តាឲ្យឃាត់ ដូច្នេះហើយ ទើបចូលទៅគាល់ព្រះសាស្តា ដោយភេទដែលអ្នកដទៃមិនស្គាល់ ក្រាបទូលថា

បពិត្រព្រះអង្គ អ្នកមានព្យាយាមធំ មានប្រាជ្ញាច្រើន
រុងរឿងដោយឫទ្ធិ និងយស កន្ធងបង់នូវពៀរ និងភ័យ
គ្រប់ប្រការ ទ្រង់មានចក្ខុ ខ្ញុំព្រះអង្គសូមក្រាបថ្វាយបង្គំ
ព្រះបាទា បពិត្រព្រះអង្គ អ្នកមានព្យាយាមធំ សាវក
របស់ព្រះអង្គ ត្រូវសេចក្តីស្ងាប់គ្របសង្កត់ ប្រាថ្នាគិត

នូវសេចក្តីស្ងាប់ បពិត្រព្រះអង្គ អ្នកទ្រទ្រង់នូវអានុភាព
សូមព្រះអង្គ យាត់នូវសាវកនោះ បពិត្រព្រះមាន
ព្រះភាគ អ្នកល្បីក្នុងប្រជុំជន សាវករបស់ព្រះអង្គ ជា
សេក្ខបុគ្គល មានបំណងមិនទាន់សម្រេច នៅត្រេកអរ
ក្នុងសាសនា គប្បីធ្វើមរណកាល ដូចម្តេចបាន ។

ក្នុងខណៈនោះ ព្រះថេរៈនាំសស្ត្រាមកហើយ ។ ព្រះសាស្តាទ្រង់ជ្រាបថា បុគ្គលនេះជាមារ ទើបត្រាស់គាថានេះថា

ពិតមែន អ្នកប្រាជ្ញទាំងឡាយ តែងធ្វើយ៉ាងនេះឯង
រមែងមិននឹកស្តាយនូវជីវិត គោធិកភិក្ខុ បានដកតណ្ហា
ព្រមទាំងឬស បរិនិព្វានហើយ ។

គ្រានោះឯង ព្រះដ៏មានព្រះភាគបានយាងទៅកាន់ទីដែលព្រះថេរៈនាំសស្ត្រាមក សិងហើយ មួយអន្ទើដោយភិក្ខុដ៏ច្រើន ។ ខណៈនោះ មារមានចិត្តបាបគិតថា បដិសន្ធិវិញ្ញាណរបស់ព្រះគោធិកៈនេះ តាំងនៅហើយក្នុងទីណាហ្នឹ ដូច្នេះហើយ ធ្វើជាជុំផ្សែង និងជុំពពក ស្វែងរកវិញ្ញាណរបស់ព្រះថេរៈក្នុងទិសទាំងពួង ព្រះដ៏មានព្រះភាគទ្រង់បង្ហាញភាពដែលមារនោះធ្វើជាផ្សែង និងជុំពពកនោះ ដល់ភិក្ខុទាំងឡាយហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មារមានចិត្តបាបនោះឯង ស្វែងរកវិញ្ញាណរបស់គោធិកកុលបុត្រ ដោយគិតថា វិញ្ញាណរបស់កុលបុត្រឈ្មោះគោធិកៈតាំងនៅហើយក្នុងទីណា ម្នាលភិក្ខុទាំងឡាយ គោធិក-កុលបុត្រមានវិញ្ញាណមិនតាំងនៅឡើយ បរិនិព្វានហើយ មារ កាលមិនអាច

ឃើញទីតាំងនៃវិញ្ញាណរបស់ព្រះគោធិកៈនេះបាន ទើបកាឡាខ្លួនជាកុមារកាន់ពិណមានពណ៌លឿងដូចផ្លែញៅ ចូលទៅគាល់ព្រះសាស្តា ទូលសួរថា

ខ្ញុំព្រះអង្គបានស្វែងរក (វិញ្ញាណ) របស់គោធិក-កុលបុត្ត ក្នុងទិសខាងលើផង ខាងក្រោមផង ទិសទទឹងផង ទិសជំ ទិសតូចផង មិនបានជួបប្រទះសោះឡើយ ចុះគោធិកៈនោះ ទៅក្នុងទីណា ។

គ្រានោះ ព្រះសាស្តា ត្រាស់ទីឃមារនោះថា

គោធិកភិក្ខុ ជាអ្នកប្រាជ្ញ បរិបូណ៌ដោយប្រាជ្ញា ជាអ្នកមានឈាន អ្នកត្រេកអរក្នុងឈានសព្វកាល ខំប្រឹងប្រែងទាំងថ្ងៃ ទាំងយប់ មិនគិតស្តាយជីវិត បានឈ្នះសេនារបស់មច្ចុ មិនមកកាន់កពថ្មីទៀត ដកតណ្ហាព្រមទាំងឫស បរិនិព្វានហើយ ។

កាលព្រះសាស្តាត្រាស់យ៉ាងនោះហើយ ពិណបានក្លាត់ធ្លាក់អំពីក្លៀករបស់មារនោះ ជាអ្នកដែលសេចក្តីសោកគ្របសង្កត់ លំដាប់នោះ យក្ខនោះអាក់អន់ចិត្ត ក៏អន្តរធានទៅក្នុងទីនោះឯង ដោយប្រការដូច្នេះ ។

ព្រះសាស្តាត្រាស់ថា មារមានចិត្តបាប អ្នកត្រូវការអ្វីដោយទីកន្លែងដែលកុលបុត្រឈ្មោះគោធិកៈកើតហើយ ព្រោះបុគ្គលដូចអ្នកវាប់រយវាប់ពាន់ ក៏មិនអាចឃើញទីដែលគោធិកៈនោះកើត ដូច្នេះហើយ បានត្រាស់ព្រះគាថានេះថា

តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ
សម្មទញ្ញាវិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។

មារាធិរាជ (ទុកជាខំស្វែងរក) ក៏មិនជួបនូវផ្លូវរបស់លោកអ្នកមានសីលបរិបូណ៌ អ្នកនៅដោយសេចក្តីមិនប្រមាទ អ្នករួចស្រឡះ (ចាកធម៌ជាគ្រឿងសៅហ្មង) ព្រោះដឹងច្បាស់តាមហេតុ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **តេសំ** *គឺនៃបុគ្គលដែលបរិនិព្វាន ដូចកុលបុត្រឈ្មោះគោធិក: មានវិញ្ញាណមិនតាំងនៅ បរិនិព្វានហើយដូច្នោះ ។*

បទថា **សម្បន្នសីលានំ** *គឺមានសីលបរិបូណ៌ហើយ ។ បទថា* **អប្ប-មាទវិហារិនំ** *គឺជាអ្នកនៅដោយសេចក្តីមិនប្រមាទ ពោលគឺការមិននៅច្រាសចាកសតិ ។*

បាទព្រះគាថាថា **សម្មទញ្ញាវិមុត្តានំ** *សេចក្តីថា ជាអ្នករួចផុតវិសេសហើយដោយវិមុត្តិទាំង ៥ នេះ គឺតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និស្សរណវិមុត្តិ ព្រោះដឹងនូវហេតុ គឺដោយនយ ដោយហេតុ ។*

បាទព្រះគាថាថា **មារោ មគ្គំ ន វិន្ទតិ** *សេចក្តីថា មារសូម្បីស្វែងរកឲ្យពេញទំហឹង រមែងមិនជួប គឺរមែងមិនបានចំពោះ បានដល់ រមែងមិនឃើញផ្លូវនៃព្រះខីណាស្រពទាំងឡាយបែបនេះទៅហើយ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ។ ទេសនាមានប្រយោជន៍ ដល់មហាជនដូច្នេះឯង ។

រឿង បរិនិព្វានរបស់ព្រះគោធិកមហាស្ថេរ ចប់

រឿង គរហាទិន្ន

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសាវ័ករបស់និគ្រន្ថឈ្មោះគរហទិន្ន ត្រាស់ព្រះធម្មទេសនានេះថា **យថា សង្ការធានស្មឹ** *ជាដើម ។*

សេចក្តីពិស្តារថា ក្នុងក្រុងសាវត្ថីមានជនពីរនាក់ ជាសម្លាញ់នឹងគ្នា គឺ សិរិគុត្ត ១ គរហទិន្ន ១ ។ ក្នុងជនពីរនាក់នោះ សិរិគុត្តជាឧបាសក គរហទិន្នជាសាវ័ករបស់និគ្រន្ថ ។ ពួកនិគ្រន្ថរមែងពោលនឹងគរហទិន្ននោះរឿយៗ យ៉ាងនេះថា ការដែលអ្នកនិយាយនឹងសិរិគុត្តសម្លាញ់របស់អ្នកថា ឯងចូលទៅរកព្រះសមណគោតមធ្វើអ្វី ឯងនឹងបានអ្វី ក្នុងសម្នាក់របស់ព្រះសមណគោតមនោះ ដូច្នេះហើយ ពោលប្រៀនប្រដៅដោយអាការដែលសិរិគុត្តចូលមករកពួកយើង ហើយនឹងឲ្យទេយ្យធម៌ដល់ពួកយើង មិនគួរឬ គរហទិន្នស្តាប់ពាក្យរបស់និគ្រន្ថទាំងនោះហើយ ក៏ព្យាយាមទៅពោលជាមួយសិរិគុត្តក្នុងទីដែលសិរិគុត្តឈរ និងអង្គុយហើយជាដើម យ៉ាងនេះថា នែសម្លាញ់ ប្រយោជន៍អ្វី

របស់អ្នកដោយព្រះសមណគោតមនោះ អ្នកទៅរកព្រះសមណគោតមនោះ នឹងបានអ្វី ការដែលអ្នកចូលទៅរកលោកម្ចាស់របស់យើងហើយ ឲ្យទានដល់លោកម្ចាស់ទាំងនោះ មិនគួរឬ សិរិគុត្តស្តាប់ពាក្យរបស់គហទិន្ន ក៏អង្គុយស្ងៀម អស់ច្រើនថ្ងៃ សម្រាកសម្រាន្តហើយ ថ្ងៃមួយ ទើបពោលថា នែសម្ងាញ់ អ្នកព្យាយាមមកពោលជាមួយខ្ញុំ ក្នុងទីដែលឈរហើយជាដើមយ៉ាងនេះថា អ្នកទៅរកព្រះសមណគោតមហើយ នឹងបានអ្វី អ្នកចូលទៅរកលោកម្ចាស់របស់យើង ថ្វាយទានដល់លោកម្ចាស់ទាំងនោះ អ្នកចូរប្រាប់ដល់ខ្ញុំសិន លោកម្ចាស់ទាំងឡាយរបស់អ្នកដឹងអ្វីខ្លះ ។

គហទិន្នពោលថា ឱសម្ងាញ់ អ្នកកុំពោលយ៉ាងនេះ ឈ្មោះថា វត្ថុដែលលោកម្ចាស់ទាំងឡាយរបស់យើងមិនដឹងមិនមាន លោកម្ចាស់ទាំងឡាយរមែងដឹងហេតុជាអតីត អនាគត និងបច្ចុប្បន្នទាំងអស់ កាយកម្ម វចីកម្ម មនោកម្មទាំងអស់ រមែងដឹងហេតុដែលគួរ និងមិនគួរទាំងអស់ ហេតុនេះនឹងមាន ហេតុនេះនឹងមិនមាន ។ សិរិគុត្តពោលថា អ្នកនិយាយថា លោកម្ចាស់របស់អ្នក រមែងដឹងដូច្នេះ មិនមែនឬ ។ គហទិន្នពោលថា ខ្ញុំនិយាយយ៉ាងនោះឯង ។ សិរិគុត្តពោលថា បើយ៉ាងនោះ អ្នកមិនប្រាប់សេចក្តីនោះដល់ខ្ញុំអស់កាលមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ធ្វើកម្មធ្ងន់ហើយ ថ្ងៃនេះ ខ្ញុំនឹងដឹងអានុភាពនៃញាណរបស់លោកម្ចាស់ទាំងឡាយហើយ នែសម្ងាញ់ អ្នកចូរទៅចុះ ហើយនិមន្តលោកម្ចាស់ទាំងឡាយតាមពាក្យរបស់ខ្ញុំ ។

គហទិន្ននោះ ចូលទៅកាន់សម្នាក់របស់ពួកនិគ្រន្ថ ថ្វាយបង្គំនិគ្រន្ថទាំង

នោះហើយពោលថា សិរីគុត្តសម្ងាញ់របស់ខ្ញុំនិមន្តលោកម្ចាស់ឆាន់ក្នុងថ្ងៃស្អែក និគ្រន្ថពោលថា សិរីគុត្តពោលនឹងអ្នកខ្លួនឯងឬ គរហទិន្នពោលថា យ៉ាងនោះឯងលោកម្ចាស់ ។ និគ្រន្ថទាំងនោះត្រេកអរហើយពោលថា កិច្ចរបស់ពួកយើងសម្រេចហើយ ចាប់តាំងអំពីកាលដែលសិរីគុត្តជ្រះថ្លាក្នុងពួកយើងហើយ សម្បត្តិណាមួយ នឹងមានដល់ពួកយើង លំនៅរបស់សិរីគុត្តក៏ធំ ។

សិរីគុត្តនោះ ប្រើមនុស្សឲ្យជីករណ្តៅវែងសងខាង ក្នុងរវាងផ្ទះពីរខ្នងនោះហើយ ក៏ឲ្យយកលាមកពពួងជាក់រហូតពេញ ប្រើបង្គោលចោះក្នុងទីបំផុតសងខាង ខាងក្រៅរណ្តៅ ឲ្យចងខ្សែត្រង់បង្គោលទាំងនោះ ឲ្យជាក់ជើងមុខរបស់អាសនៈទាំងឡាយលើមាត់រណ្តៅ ជើងក្រោយត្រង់ខ្សែ សម្គាល់ថា ក្នុងកាលដែលអង្គុយហើយយ៉ាងនេះឯង ពួកនិគ្រន្ថនឹងមានក្បាលជាំចុះ ឲ្យមនុស្សក្រាលកម្រាលលើអាសនៈទាំងឡាយ ដោយអាការដែលរណ្តៅមិនប្រាកដឲ្យមនុស្សលាងពាងធំៗ ហើយ ចងមាត់ដោយស្បឹកចេក និងសំពត់ចាស់ធ្វើពាងទទេនោះឯង ឲ្យលាបដោយគ្រប់បបរ គ្រប់ថ្នាយ សប្បិ ទឹកអំពៅ និងនំខាងក្រៅហើយ ឲ្យតាំងទុកខាងក្រោយផ្ទះ ។

គរហទិន្នប្រញាប់ទៅផ្ទះរបស់សិរីគុត្តនោះអំពីព្រលឹម សួរថា អ្នកចាត់ចែងសក្ការៈដើម្បីលោកម្ចាស់ទាំងឡាយហើយឬ សិរីគុត្តពោលថា អើសម្ងាញ់ខ្ញុំរៀបចំហើយ គរហទិន្នពោលថា សក្ការៈនោះនៅឯណា សិរីគុត្តពោលថា បបរនៅក្នុងពាងទាំងឡាយនោះប្រមាណប៉ុណ្ណេះ ថ្នាយក្នុងពាងប្រមាណប៉ុណ្ណេះ សប្បិ ទឹកអំពៅ នំជាដើមក្នុងពាងប្រមាណប៉ុណ្ណេះ អាសនៈក្រាលហើយ ។

គរហទិន្នៈនោះពោលថា សាធុ ហើយក៏ទៅ ។ ក្នុងវេលាដែលគរហទិន្ន
នោះទៅហើយ ពួកនិគ្រន្ថប្រមាណ ៥០០ ក៏មក ។ សិរិគុត្តចេញអំពីផ្ទះថ្វាយ
បង្គំពួកនិគ្រន្ថដោយបញ្ចង្គប្រតិស្ឋានហើយ ឈរផ្គងអញ្ជលីខាងមុខនៃពួក
និគ្រន្ថទាំងនោះ គិតថា បានឮថា លោកម្ចាស់ទាំងឡាយ រមែងដឹងហេតុសព្វ
យ៉ាង មានហេតុជាអតីតជាដើម ឧបដ្ឋាករបស់ពួកលោកម្ចាស់ ប្រាប់ដល់ខ្ញុំ
ហើយយ៉ាងនេះ បើលោកម្ចាស់ទាំងឡាយដឹងហេតុទាំងអស់ ពួកលោកម្ចាស់
កុំចូលទៅកាន់ផ្ទះរបស់ខ្ញុំ ព្រោះកាលលោកម្ចាស់ចូលទៅកាន់ផ្ទះរបស់ខ្ញុំហើយ
បបរមិនមានឡើយ ចាយជាដើមក៏មិនមាន បើលោកម្ចាស់មិនដឹង ក៏សូម
ចូលទៅ ខ្ញុំឲ្យលោកម្ចាស់ទាំងឡាយធ្លាក់ក្នុងរណ្តៅលាមក ហើយនឹងឲ្យវាយ
កាលគិតយ៉ាងនោះហើយ ទើបឲ្យសញ្ញាដល់ពួកបុរសថា ពួកអ្នកចូរដឹងការៈ
គឺការអង្គុយរបស់និគ្រន្ថទាំងនោះហើយ ឈរនៅខាងក្រោយ គប្បីនាំគ្រឿង
កម្រាលខាងលើនៃអាសនៈទាំងឡាយចេញហើយ អាសនៈទាំងនោះកុំប្រឡាក់
ដោយរបស់មិនស្អាតឡើយ ។ កាលនោះ សិរិគុត្តនិយាយនឹងពួកនិគ្រន្ថថា
និមន្តមកខាងនេះចុះលោកម្ចាស់ ពួកនិគ្រន្ថចូលទៅហើយ ក៏ប្រារព្ធដើម្បី
អង្គុយលើអាសនៈដែលគេក្រាលហើយ ។ ពេលនោះ មនុស្សទាំងឡាយ
ពោលនឹងនិគ្រន្ថទាំងនោះថា ចូរបង្អង់សិន កុំទាន់អង្គុយលោកម្ចាស់ និគ្រន្ថ
សួរថា ព្រោះហេតុអ្វី មនុស្សទាំងឡាយពោលថា ការដែលលោកម្ចាស់
ទាំងឡាយ ចូលទៅកាន់ផ្ទះរបស់ពួកខ្ញុំ ដឹងទំនៀមហើយ សឹមអង្គុយ រមែង
សមគួរ ។ និគ្រន្ថពោលថា ធ្វើដូចម្តេច ទើបសមគួរ មនុស្សទាំងឡាយ

ពោលថា ការដែលលោកម្ចាស់ទាំងឡាយ ឈរក្បែរអាសនៈ រៀងៗ ខ្លួន ហើយអង្គុយព្រមគ្នានោះឯង ទើបគួរ ។

បានឮថា សិរីគុត្តនោះឲ្យធ្វើពិធីនេះដោយគិតថា បើនិគ្រន្ថម្នាក់ធ្លាក់ក្នុងរណ្តៅហើយ និគ្រន្ថដ៏សេសមិនអង្គុយ ។ និគ្រន្ថទាំងនោះពោលថា ល្អហើយ គិតថា ការដែលពួកយើងធ្វើតាមពាក្យរបស់មនុស្សទាំងនេះ ប្រាប់ហើយ គួរ ។

កាលនោះ និគ្រន្ថទាំងអស់បានឈរនៅក្បែរអាសនៈដែលត្រូវបានហើយ ដល់ខ្លួនដោយលំដាប់ ។ លំដាប់នោះ ពួកមនុស្សពោលនឹងនិគ្រន្ថទាំងនោះថា សូមលោកម្ចាស់ប្រញាប់អង្គុយព្រមគ្នានោះឯង ដំណាវៈ គឺការអង្គុយរបស់និគ្រន្ថទាំងនោះហើយ ទើបនាំគ្រឿងកម្រាលលើអាសនៈទាំងឡាយចេញ ។ ពួកនិគ្រន្ថអង្គុយព្រមគ្នានោះឯង ជើងអាសនៈដែលតាំងនៅលើខ្សែ ភ្លាត់ធ្លាក់ហើយ ពួកនិគ្រន្ថមានក្បាលជាំចុះទៅក្នុងរណ្តៅ ។ សិរីគុត្តកាលពួកនិគ្រន្ថនោះធ្លាក់ហើយ ទើបបិទទ្វារឲ្យឃកដំបងវាយពួកនិគ្រន្ថ ដែលប្រាឡើងហើយ ដោយពោលថា ពួកលោកម្ចាស់មិនដឹងហេតុដែលជាអតីត អនាគត និងបច្ចុប្បន្ន ព្រោះហេតុអ្វី ហើយប្រាប់ថា ការធ្វើប៉ុណ្ណេះនឹងសមគួរដល់ពួកនិគ្រន្ថទាំងនោះដូច្នេះហើយ ទើបបើកទ្វារ ។ ពួកនិគ្រន្ថទាំងនោះចេញហើយ ប្រារព្ធដើម្បីគេចទៅ ឯក្នុងផ្លូវទៅនៃពួកនិគ្រន្ថទាំងនោះ សិរីគុត្តឲ្យមនុស្សធ្វើផែនដី បរិកម្មដោយបាយ-អនុកឲ្យរអិល សិរីគុត្តឲ្យវាយពួកនិគ្រន្ថនោះ ដែលឈរក្នុងទីនោះឲ្យដួលចុះហើយ ទើបបញ្ជូនទៅដោយពាក្យថា ការធ្វើប៉ុណ្ណេះសមគួរដល់លោកម្ចាស់ទាំងឡាយ ។ និគ្រន្ថទាំងនោះកន្ទក់កន្ទេញថា ពួកយើងត្រូវ

អ្នក ធ្វើឲ្យវិនាស ពួកយើង ត្រូវអ្នកធ្វើឲ្យវិនាស បានទៅកាន់ទ្វារផ្ទះរបស់ឧបដ្ឋាកហើយ ។

*គរហទិន្នយើញប្រការចម្លែកនោះ របស់និគ្រន្ថទាំងនោះហើយ ក្រោធគិតថា អញត្រូវសិរិគុត្តឲ្យវិនាសហើយ វាឲ្យវាយលោកម្ចាស់ទាំងឡាយរបស់អញ ដែលជាបុញ្ញក្ខេត្ត ដែលបានឈ្មោះថាអាចឲ្យនូវទេវលោកទាំង ៦ ដល់មនុស្សទាំងឡាយ ដែលបុគ្គលលាដៃចេញថ្វាយបង្គំតាមគាប់ចិត្ត ឲ្យដល់នូវសេចក្តីវិនាសហើយ ទៅកាន់រាជត្រកូលក្រាបទូលឲ្យព្រះរាជា ទ្រង់ធ្វើពិន័យដល់សិរិគុត្តនោះ ១ ពាន់កហាបណៈ ។ គ្រានោះ ព្រះរាជាទ្រង់ព្រះបញ្ជូនសាសន៍ទៅដល់សិរិគុត្តនោះ ។ សិរិគុត្តនោះ ទៅថ្វាយបង្គំព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់សាកសួរហើយ សឹមកាត់សេចក្តី បើទ្រង់មិនបានសាកសួរ កុំកាត់សេចក្តីឡើយ ព្រះរាជាត្រាស់ថា យើងសាកសួរមើលហើយ ទើបកាត់សេចក្តី សិរិគុត្តពោលថា សាធុ ព្រះអង្គ បើដូច្នោះ សូមទ្រង់កាត់សេចក្តីចុះ ព្រះរាជាត្រាស់ថា បើដូច្នោះ អ្នកចូរនិយាយចុះ ។ សិរិគុត្តក្រាបទូលការប្រព្រឹត្តទៅនោះទាំងអស់ តាំងអំពីដើម យ៉ាងនេះថា បពិត្រព្រះអង្គ សម្ងាញ់របស់ទូលបង្គំ ជាសាវ័ករបស់និគ្រន្ថ ចូលទៅរកខ្ញុំព្រះអង្គហើយ ពោលយ៉ាងនេះរឿយៗ ក្នុងទីឈរ និងទីអង្គុយជាដើមថា នែសម្ងាញ់ ប្រយោជន៍អ្វីរបស់អ្នក ដោយព្រះសមណគោតមនោះ អ្នកទៅរកព្រះសមណគោតមនោះនឹងបានអ្វី ដូច្នេះហើយ ក្រាបទូលថា បពិត្រព្រះអង្គ បើការពិន័យព្រោះហេតុនេះគួរហើយ សូមទ្រង់កាត់សេចក្តីចុះ ព្រះរាជា ទត

គរហទិន្ន ត្រាស់ថា បានឮថា អ្នកពោលយ៉ាងនោះពិតឬ គរហទិន្នពោលថា ពិតហើយ ក្រាបទូល ព្រះរាជាត្រាស់ថា អ្នកសេពគប់ពួកនិគ្រន្ថ ដែលមិនដឹងហេតុប៉ុណ្ណេះត្រាច់ទៅ ដោយគិតថា ជាគ្រូ ប្រាប់ដល់សាវ័ករបស់ព្រះតថាគតថា រមែងដឹងសព្វយ៉ាង ព្រោះហេតុអ្វី ពិន័យដែលអ្នកលើកឡើងចូរមានដល់អ្នកចុះ ។

គរហទិន្ននោះ ត្រូវព្រះរាជាទ្រង់ពិន័យហើយ ដោយអាការយ៉ាងនេះ ពួកនិគ្រន្ថដែលចូលដល់ត្រកូលរបស់គរហទិន្ននោះឯង ត្រូវសិរិគុត្តវាយបណ្តេញចេញហើយ ។

គហវទិន្ន ខឹងនឹងសិរិគុត្តនោះហើយ មិននិយាយជាមួយអស់កាលប្រមាណកន្លះខែ គិតថា ការត្រាច់ទៅដោយអាការយ៉ាងនេះ មិនគួរដល់អញ កាលដែលអញធ្វើសេចក្តីវិនាសដល់ពួកភិក្ខុ ដែលចូលដល់ត្រកូលរបស់សិរិគុត្តនោះ រមែងគួរ ដូច្នេះហើយ ចូលទៅរកសិរិគុត្តពោលថា នែសិរិគុត្តសម្វាញ់ សិរិគុត្តពោលថា មានការអ្វីសម្វាញ់ គរហទិន្នពោលថា ធម្មតាញាតិ និងសម្វាញ់ទាំងឡាយ រមែងមានការឈ្លោះគ្នាខ្លះ វិវាទគ្នាខ្លះ អ្នកមិនពោលពាក្យណាមួយ ព្រោះហេតុអ្វី ទើបធ្វើយ៉ាងនោះ ។

សិរិគុត្តពោលថា នែសម្វាញ់ ខ្ញុំមិននិយាយក៏ព្រោះអ្នកមិននិយាយជាមួយខ្ញុំ កម្មណាដែលខ្ញុំធ្វើហើយ កម្មនោះគ្រាន់តែធ្វើហើយចុះ យើងទាំងពីរមិនទម្លាយមេត្រីដល់គ្នានិងគ្នា ។

ចាប់តាំងអំពីកាលនោះ សម្វាញ់ទាំងពីរឈរ អង្គុយក្នុងទីជាមួយគ្នា ។

ក្នុងកាលថ្ងៃមួយ សិរិគុត្តពោលនឹងគរហទិន្នថា ប្រយោជន៍អ្វីរបស់អ្នកដោយពួកនិគ្រន្ថ អ្នកទៅរកនិគ្រន្ថទាំងនោះនឹងបានអ្វី ការចូលទៅរកព្រះសាស្តារបស់ខ្ញុំក្តី ការថ្វាយទានដល់លោកម្ចាស់ទាំងឡាយក្តី នឹងមិនគួរដល់អ្នកឬ សូម្បីគរហទិន្នានោះរមែងរង់ចាំហេតុនេះដូចគ្នា ព្រោះដូច្នោះ ពាក្យសម្តីសិរិគុត្តនោះទើបបានហាក់ដូចជាអេះបូសដោយក្រចក ។ គរហទិន្នានោះ សួរសិរិគុត្តថា ព្រះសាស្តារបស់អ្នកដឹងអ្វី សិរិគុត្តពោលថា នែអ្នក អ្នកកុំពោលយ៉ាងនោះឈ្មោះថា វត្តុដែលព្រះសាស្តារបស់យើងមិនដឹង មិនមាន ព្រះសាស្តារបស់យើងនោះ រមែងដឹងហេតុសព្វយ៉ាង មានហេតុជាអតីតជាដើម រមែងកំណត់ចិត្តរបស់សត្វទាំងឡាយ ដោយអាការ ១៦ យ៉ាងបាន ។

គរហទិន្នពោលថា ខ្ញុំមិនជ្រាបយ៉ាងនោះ ព្រោះហេតុអ្វីទើបអ្នកមិនជ្រាប់ដល់ខ្ញុំអស់កាលមានប្រមាណប៉ុណ្ណោះ បើដូច្នោះ អ្នកចូរទៅ ចូរទូលនិមន្តព្រះសាស្តាដើម្បីសោយក្នុងថ្ងៃស្អែកនេះ ខ្ញុំនឹងឲ្យសោយ អ្នកចូរក្រាបទូលដើម្បីទ្រង់ទទួលភិក្ខារបស់ខ្ញុំ មួយអន្ទើដោយភិក្ខុ ៥០០ រូប ។

សិរិគុត្តចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គ គរហទិន្នសម្លាញ់របស់ខ្ញុំព្រះអង្គ ជ្រាប់ឲ្យទូលនិមន្តព្រះអង្គ សូមទ្រង់ទទួលភិក្ខារបស់គរហទិន្ននោះ មួយអន្ទើដោយភិក្ខុ ៥០០ រូប ក្នុងស្អែកនេះ ដ្បិតក្នុងថ្ងៃមុនកម្មឈ្មោះនេះ ខ្ញុំព្រះអង្គធ្វើហើយដល់ពួកនិគ្រន្ថដែលចូលដល់ត្រកូលរបស់គរហទិន្ននោះ ខ្ញុំព្រះអង្គមិនជ្រាបការធ្វើតបដល់កម្មដែលខ្ញុំព្រះអង្គធ្វើហើយ ខ្ញុំព្រះអង្គមិនជ្រាបសូម្បីភាពដែលគរហទិន្ននោះ

ប្រាថ្នានឹងថ្វាយភិក្ខាដល់ព្រះអង្គ ដោយចិត្តជ័ប្រសិទ្ធ ព្រះអង្គទ្រង់ពិចារណា
ហើយ បើសមគួរសូមទ្រង់ទទួល បើមិនសមគួរទ្រង់កុំទទួលទៅយ ។ ព្រះ
សាស្តាទ្រង់ពិចារណាថា គរហទិន្នោះប្រាថ្នានឹងថ្វាយដល់តថាគតឬហ្ន៎ ទ្រង់
បានឃើញថា គរហទិន្នោះបានឲ្យមនុស្សជីករណ្តៅធំ ត្រង់ចន្លោះផ្ទះពីរខ្នង
ហើយបានឲ្យមនុស្សនាំឈើគគីរមកប្រមាណ ៨០ រទេះ ដុតភ្លើងហើយ ត្រូវ
ការឲ្យតថាគតធ្លាក់ចុះក្នុងរណ្តៅរងើកភ្លើង ហើយសង្កត់សង្កិន ទ្រង់ពិចា-
រណាទៀតថា ព្រោះតថាគតទៅក្នុងទីនោះជាបច្ច័យ ប្រយោជន៍នឹងមាន ឬ
មិនមានហ្ន៎ លំដាប់នោះ ទ្រង់បានឃើញហេតុនេះថា តថាគតនឹងឈានជើង
ជាន់លើរណ្តៅរងើកភ្លើង កន្លែងដែលជាក់ចិទ្ធាំងរណ្តៅរងើកភ្លើងនោះ
នឹងវិនាសទៅ ផ្តាំឈូកធំប្រមាណប៉ុនកង់រទេះ នឹងផុសឡើងទម្លាយរណ្តៅ
រងើកភ្លើង កាលបើដូច្នោះ តថាគតនឹងជាន់ត្រូបកឈូក ទៅអង្គុយលើអាសនៈ
ភិក្ខុទាំង ៥០០ នឹងទៅអង្គុយយ៉ាងនោះដូចគ្នា មហាជននឹងប្រជុំគ្នា តថាគត
នឹងធ្វើអនុមោទនា ដោយគាថា ២ គាថា ក្នុងសមាគមនោះ ក្នុងពេលចប់
អនុមោទនា ការត្រាស់ដឹងធម៌ រមែងមានដល់សត្វ ៨៤០០០ ។ សិរីគុត្ត និង
គរហទិន្នទីងបានជាសោតាបន្ន នឹងដាក់គំនរទ្រព្យរៀងៗ ខ្លួនក្នុងសាសនា ។
កាលដែលតថាគតអាស្រ័យកុលបុត្រនេះ ទៅ រមែងសមគួរ ដូច្នេះហើយ
ទើបទ្រង់ទទួលភិក្ខា ។ សិរីគុត្តជ្រាបការទទួលរបស់ព្រះសាស្តាហើយ ទើប
ប្រាប់ដល់គរហទិន្ន ហើយប្រាប់ថា អ្នកចូរធ្វើសក្ការៈដល់ព្រះលោកជេដ្ឋៈ ។

គរហទិន្នគិតថា ឥឡូវនេះ អញនឹងដឹងកិច្ចដែលគួរធ្វើដល់ព្រះសមណ-

គោតមនោះ ទើបឲ្យជីករណ្តៅធំក្នុងរវាងផ្ទះពីរខ្នង ឲ្យទាំឈើគគីរប្រមាណ ៨០ រទេះ ឲ្យដុតភ្លើងមួយយប់ទាល់ភ្លឺហើយ ឲ្យធ្វើគំនរអង្កើកភ្លើង ដាក់ឈើដែលរាបស្មើលើមាត់រណ្តៅ ឲ្យបិទដោយកន្ទេលផែង ឲ្យលាបដោយអាចម៍គោ ក្រាលកំណាត់ឈើពុកត្រង់ចំណែកម្ខាង ហើយឲ្យធ្វើផ្លូវជាទីទៅដោយសម្គាល់ថា ក្នុងពេលដែលពួកសមណៈជាន់ហើយយ៉ាងនេះ កំណាត់ឈើទាំងឡាយបាក់ហើយ ពួកសមណៈនឹងរអិលធ្លាក់ទៅក្នុងរណ្តៅរអង្កើកភ្លើង ឲ្យតាំងទៀនទេក្នុងចំណែកខាងក្រោយផ្ទះ ដោយវិធីដែលសីវិគុត្តតាំងហើយដូចគ្នា ។ ឲ្យក្រាលអាសនៈទាំងឡាយយ៉ាងនោះដូចគ្នា ។ សីវិគុត្តទៅផ្ទះរបស់គរហទិន្នៈនោះអំពីព្រលឹមហើយ ពោលថា សម្ងាញ់ អ្នកធ្វើសក្ការៈហើយឬ គរហទិន្នៈពោលថា អើ ធ្វើហើយសម្ងាញ់ សីវិគុត្តពោលថា សក្ការៈនោះនៅឯណា គរហទិន្នៈឆ្លើយថា ចូរមកមើលចុះ ហើយបង្ហាញរបស់ទាំងអស់ដោយវិធីដែលសីវិគុត្តបង្ហាញហើយដូចគ្នា ។ សីវិគុត្តពោលថា ល្អណាស់ សម្ងាញ់ ។ មហាជនប្រជុំហើយ កាលព្រះសាស្តាដែលបុគ្គលមិច្ឆាទិដ្ឋិនិមន្តហើយ ការប្រជុំធំរមែងមាន ។ ចំណែកពួកមិច្ឆាទិដ្ឋិ រមែងប្រជុំគ្នាដោយគិតថា ពួកយើងនឹងឃើញប្រការដែលប្លែករបស់ព្រះសមណគោតម ចំណែកពួកជនសម្មាទិដ្ឋិ រមែងប្រជុំគ្នាដោយគិតថា ថ្ងៃនេះ ព្រះសាស្តាទ្រង់នឹងសម្តែងព្រះធម្មទេសនាយ៉ាងធំ ពួកយើងនឹងកំណត់ពុទ្ធវិស័យ ពុទ្ធលីលា ។ ក្នុងថ្ងៃស្អែកទៀត ព្រះសាស្តាបានយាងទៅកាន់ទ្វារផ្ទះរបស់គរហទិន្នជាមួយនឹងភិក្ខុ ៥០០ រូប ។ គរហទិន្នៈនោះចេញអំពីផ្ទះហើយ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ឈរផ្គង់

អញ្ជលីខាងមុខព្រះកក្រ្តគិតថា បពិត្រព្រះអង្គ ឧបដ្ឋាករបស់ព្រះអង្គជ្រាប់ ដល់ខ្ញុំព្រះអង្គយ៉ាងនេះថា បានឮថា ព្រះអង្គទ្រង់ជ្រាបហេតុសព្វយ៉ាង មានហេតុជាអតីតជាដើម ទ្រង់រមែងកំណត់ចិត្តរបស់សត្វទាំងឡាយដោយអាការ ១៦ យ៉ាងបាន បើទ្រង់ជ្រាប សូមទ្រង់កុំចូលទៅកាន់ផ្ទះរបស់ខ្ញុំព្រះអង្គ ព្រោះកាលទ្រង់ចូលទៅហើយ បបរមិនមានឡើយ កត្តជាដើមក៏មិនមាន ឯខ្ញុំព្រះអង្គនឹងញ៉ាំងលោកម្ចាស់ទាំងអស់ឲ្យធ្លាក់ក្នុងរណ្តៅរងើកភ្លើង ហើយសង្កត់សង្កិនកាលគិតយ៉ាងនោះហើយ ទើបទទួលបាត្ររបស់ព្រះសាស្តាក្រាបទូលថា សូមព្រះដ៏មានព្រះភាគ ទ្រង់យាងមកផ្លូវនេះ ហើយក្រាបទូលថា បពិត្រព្រះអង្គអ្នកមកកាន់ផ្ទះរបស់ខ្ញុំព្រះអង្គ ដ៏ងទំនៀមហើយសឹមមក ទើបគួរ ព្រះសាស្តាត្រាស់ថា តថាគតធ្វើដូចម្តេច ទើបគួរ គរហទិន្នពោលថា ក្នុងកាលដែលភិក្ខុមួយរូបៗ ចូលទៅខាងមុខអង្គុយហើយ ភិក្ខុដទៃមកក្នុងកាលខាងក្រោយ ទើបគួរ ។

បានឮថា គរហទិន្ននោះមានការគិតយ៉ាងនេះថា ភិក្ខុដ៏សេសសល់ញាភិក្ខុដែលទៅខាងមុខ ធ្លាក់ចុះក្នុងរណ្តៅភ្លើងហើយ រមែងមិនមក អញនឹងឲ្យភិក្ខុធ្លាក់គ្រប់រូប ហើយសង្កត់សង្កិន ។ ព្រះសាស្តាត្រាស់ថា សាធុ ហើយទ្រង់ចូលទៅតែមួយព្រះអង្គឯង ។ គរហទិន្នដល់រណ្តៅរងើកភ្លើងហើយ ថយចេញទៅឈរក្រាបទូលថា សូមទ្រង់យាងទៅខាងមុខចុះ ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ឈានព្រះបាទចុះលើរណ្តៅរងើកភ្លើងកន្លះផែងក៏បាត់ទៅហើយ ផ្កាឈូកប្រមាណប៉ុនកង់រទេះ ផុសឡើងទម្លាយ

រណ្តៅរងើកភ្លើង ។ ព្រះសាស្តាទ្រង់ជាន់ត្របកឈូកយាងទៅប្រថាប់គង់លើ ពុទ្ធាសនៈដែលគេក្រាលហើយ ។ សូម្បីភិក្ខុទាំងឡាយ ក៏ទៅអង្គុយលើ អាសនៈទាំងនោះដូចគ្នា កម្ពៅតាំងទ្បើងអំពីកាយរបស់គរហទិន្នហើយ ។ គាត់ ទៅដោយរហ័ស ចូលទៅរកសិរិគុត្ត ប្រាប់ថា សម្ចាញ់ សូមអ្នកជាទីពឹង របស់ខ្ញុំចុះ សិរិគុត្តពោលថា អ្នកកើតអ្វី គរហទិន្នពោលថា បបរឬកត្តជាដើម ដើម្បីភិក្ខុ ៥០០ រូបមិនមានក្នុងផ្ទះ ខ្ញុំធ្វើដូចម្តេចហ្ន៎ សិរិគុត្តពោលថា អ្នក ធ្វើអ្វី គរហទិន្នពោលថា ខ្ញុំឲ្យគេធ្វើរណ្តៅរងើកភ្លើងធំ ក្នុងរវាងផ្ទះពីរខ្នង ពេញដោយរងើកភ្លើង ដោយបំណងថា នឹងឲ្យពួកភិក្ខុធ្លាក់ទៅក្នុងរណ្តៅរងើក ភ្លើងនោះហើយសង្កត់សង្កិន ។ ពេលនោះ ផ្កាឈូកធំផុសទ្បើងទម្លាយរណ្តៅ រងើកភ្លើងនោះ ភិក្ខុទាំងអស់ជាន់ត្របកឈូក ដើរទៅគង់លើអាសនៈដែលគេ ក្រាល ឥឡូវនេះខ្ញុំនឹងធ្វើដូចម្តេច សិរិគុត្តពោលថា អ្នកប្រាប់ដល់ខ្ញុំអម្បាញ់ មិញនេះឯងថា ពាងបបរប៉ុណ្ណោះ ពាងកត្តជាដើមប៉ុណ្ណោះមិនមែនឬ គរហទិន្ន ពោលថា ខ្ញុំកុហកទេ ពាងទាំងនោះទទេទាំងអស់ ។ សិរិគុត្តពោលថា ណ្ហើយ ចុះ អ្នកចូរទៅពិនិត្យមើលបបរជាដើមក្នុងពាងទាំងនោះ ។ ក្នុងខណៈនោះឯង បបរក្នុងពាងទាំងឡាយណា ដែលគរហទិន្ននោះប្រាប់ហើយ ពាងទាំងនោះ ពេញដោយបបរ កត្តជាដើមក្នុងពាងទាំងឡាយណា ដែលគរហទិន្នប្រាប់ហើយ ពាងទាំងនោះ បានពេញហើយដោយកត្តជាដើម ព្រោះបានឃើញសម្បត្តិនោះ សិរីវៈរបស់គរហទិន្នពេញដោយបីតិ និងបាមោជ្ជ មានចិត្តជ្រះថ្លាហើយ គាត់ អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយសេចក្តីគោរព ប្រាថ្នាឲ្យទ្រង់

ធ្វើអនុមោទនា ទើបទទួលបាត្រវបស់ព្រះសាស្តា ដែលទ្រង់ធ្វើភត្តកិច្ចហើយ ។

ព្រះសាស្តា កាលទ្រង់ធ្វើអនុមោទនាត្រាស់ថា សត្វទាំងនេះមិនដឹងគុណនៃសាវ័កវបស់តថាគត និងព្រះពុទ្ធសាសនា ព្រោះមិនមានបញ្ញាចក្ខុ ឈ្មោះថា ជាអ្នកងងឹត អ្នកមានបញ្ញា ឈ្មោះថា មានចក្ខុ ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

យថា សង្ការធានស្មឹ ឧជ្ឈិតស្មឹ មហាបថេ
បទុមំ តត្ថ ជាយេថ សុចិគន្ធំ មនោរមំ ។
ឯវំ សង្ការភូតេសុ អន្ធភូតេ បុថុជ្ជនេ
អតិរោចតិ បញ្ញាយ សម្មាសម្ពុទ្ធសាវកោ ។

ផ្កាឈូកទុកជាកើតក្នុងគំនរសំរាម ដែលគេចាក់ចោលក្បែរផ្លូវធំនោះ ក៏គង់មានក្លិនក្រអូប ជាទីរីករាយនៃចិត្តបាន ដូចម្តេចមិញ បណ្តាជនដែលដូចជាគំនរសំរាម សាវ័កវបស់ព្រះសម្មាសម្ពុទ្ធ រមែងរុងរឿងកន្ធងផុតបុថុជ្ជនទាំងឡាយ ដែលល្ងិតល្ងង់ដោយប្រាជ្ញា (របស់ខ្លួន) ដូច្នោះឯង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សង្ការធានស្មឹ** *គឺក្នុងទីដែលចោលសំរាម អធិប្បាយថា ក្នុងគំនរសំរាម ។ ពីរបទថា* **ឧជ្ឈិតស្មឹ មហាបថេ** *គឺដែលបុគ្គលចោលហើយក្នុងផ្លូវធំ ។ បទថា* **សុចិគន្ធំ** *គឺមានក្លិនក្រអូប ។ បទថា* **មនោរមំ** *មានវិគ្គហៈថា ចិត្តរមែងត្រេកអរក្នុងផ្កាឈូកនេះ ហេតុនោះ ផ្កា*

ឈូកនោះ ឈ្មោះថា ជាទីត្រេកអរនៃចិត្ត ។ បទថា **សង្ឃារក្ខតេសុ** *គឺដូចជាសំវាម ។ បទថា* **បុថុជ្ជនេ** *សេចក្តីថា ដែលលោកិយមហាជនទាំងឡាយ អ្នកមានឈ្មោះដែលបានហើយយ៉ាងនោះ ព្រោះញុំាងកិលេសក្រាស់ឲ្យកើត ។*

ព្រះដ៏មានព្រះភាគត្រាស់ពាក្យនេះថា ផ្កាឈូកមានក្លិនល្អ គប្បីកើតក្នុងគំនរសំវាម ដែលបុគ្គលចោលហើយជិតផ្លូវធំ សូម្បីមិនស្អាត គួរខ្ពើមជារបស់បដិកូល ផ្កាឈូកនោះ គប្បីជាទីគាប់ចិត្ត គឺជារបស់គួរជ្រាបថ្នា ជាទីត្រេកអរ នៃចិត្ត បានដល់ គប្បីជារបស់គួរប្រតិស្ឋានលើក្បាលនៃឥស្សរជនទាំងឡាយ មានព្រះរាជា និងអមាត្យរបស់ព្រះរាជាជាដើម យ៉ាងណា សាវករបស់ព្រះសម្មាសម្ពុទ្ធ គឺភិក្ខុដែលជាខីណាស្រពក៏ដូច្នោះដូចគ្នា កាលនៅជាបុថុជ្ជន ហាក់ដូចជាគំនរសំវាមកើតហើយ សូម្បីកើតក្នុងរវាងនៃមហាជនដែលមិនមានបញ្ញា មិនមានចក្ខុ រមែងរុងរឿងកន្ទងបង់ដោយកម្ទាំងនៃបញ្ញារបស់ខ្លួន ឃើញទោសក្នុងកាមទាំងឡាយ និងអានិសង្ស ក្នុងការចេញបួសចេញបួសហើយ រមែងរុងរឿងដោយគុណ ត្រឹមតែការបំពេញបព្វជ្ជា សូម្បីលើកខ្លួនឡើងកាន់សីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ ក្រៃលែងជាងគុណត្រឹមតែការបំពេញបព្វជ្ជានោះ រមែងរុងរឿង គឺស្អាតក្រៃលែងជាងបុថុជ្ជនដែលឆ្ងីតទាំងឡាយ ។

ក្នុងវេលាចប់ទេសនា ការត្រាស់ដឹងធម៌មានហើយដល់សត្វ ៨៤០០០ គរហទិន្ន និងសិរីគុត្ត សម្រេចសោតាបត្តិផលហើយ ។ ជនទាំងពីរនាក់នោះសាបព្រោះទ្រព្យរបស់ខ្លួនទាំងអស់ ក្នុងព្រះពុទ្ធសាសនាហើយ ។ ព្រះសាស្តា

បានយាងក្រោកអំពីអាសនៈទៅកាន់វិហារ ។

ភិក្ខុទាំងឡាយញុំាងកថាឲ្យកើតឡើងក្នុងរោងធម្មសភា ក្នុងវេលាល្ងាចថា គួរជ្រះថ្លា ធម្មតាគុណរបស់ព្រះពុទ្ធគួរអស្ចារ្យ ។ ផ្កាឈូកផុសឡើងទម្លាយគំនរងើកភ្លើងគគីរបែបនោះហើយ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលផ្កាឈូកផុសឡើងអំពីគំនរងើកភ្លើងដើម្បីតថាគត ដែលជាព្រះពុទ្ធក្នុងកាលឥឡូវនេះ មិនគួរអស្ចារ្យក្នុងកាលមុន ផ្កាឈូកទាំងនោះក៏ផុសឡើងហើយដើម្បីតថាគត ដែលនៅជាពោធិសត្វ ប្រព្រឹត្តទៅនៅក្នុងបទេសញ្ញាណ កាលភិក្ខុទាំងនោះទូលអារាធនាថា បពិត្រព្រះអង្គ ផ្កាឈូកនោះផុសក្នុងកាលណា សូមទ្រង់ត្រាស់ប្រាប់ដល់យើងខ្ញុំទាំងឡាយ ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមក ត្រាស់ទិវង្គារ-ជាតកនេះឲ្យពិស្តារថា

តាមពិត ខ្ញុំព្រះអង្គស៊ូមានជើងឡើងលើ មានក្បាលចុះក្រោម ហើយធ្លាក់ទៅកាន់នរក ខ្ញុំនឹងពុំធ្វើអំពើមិនប្រសើរទេ បើដូច្នោះ សូមព្រះអង្គទទួលនូវចង្ហាន់បិណ្ឌបាតចុះ ដូច្នេះឯង ។

រឿងគមារធិន្ទ ចប់

អធិប្បាយបុប្ផវគ្គ ចប់

ចតុត្ថវគ្គ ចប់

សុត្តន្តបិដក

ធម្មបទគាថា ពាលវគ្គទី៥

[១៥] រាត្រីវែង ចំពោះតែអ្នកក្រាក់រឭក (អ្នកដេកមិនលក់) យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្តវែង ចំពោះតែបុគ្គលពាល មិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

បុគ្គលកាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯង ឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថា សហាយតាគុណ មិនមានក្នុងបុគ្គលពាលឡើយ ។ ជនពាល តែងព្រួយលំបាក ដោយសេចក្តីសម្គាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន ចំណង់បើកូនទាំងឡាយ នឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថា មានអំពីណាបាន ។

អ្នកណា ជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថាជាពាល អ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួន ថាជាពាលនោះ ម្យ៉ាងទៀត អ្នកណា ជាមនុស្សពាល មានសេចក្តីប្រកាន់ថា ខ្លួនជាបណ្ឌិត អ្នកនោះ ឈ្មោះថា ជាមនុស្សពាលដោយពិត ។ មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិត ក៏ឥតមានដឹងរសធម៌អ្វីឲ្យច្បាស់លាស់ឡើយ ដូចវែក ដែលមិនដឹងរសសម្ល ។

វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងយល់រសធម៌ ដោយឆាប់រហ័ស ដូចអណ្តាតដឹងនូវរសសម្ល ។

ពួកជនពាល មិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវ តែងធ្វើកម្មលាមក ដែលជាអំពើមានផលក្តៅក្រហាយ ។

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ឬមានមុខប្រឡាក់ដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ ឈ្មោះថា ជាកម្មមិនល្អទេ្បីយ ។

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ ឬដល់នូវសេចក្តីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អ ។

បាបមិនទាន់ឲ្យផលត្រឹមណា ជនពាល តែងសម្គាល់នូវបាបនោះថា ដូចទឹកឃ្មុំ លុះតែកាលណាបាបឲ្យផល ជនពាល ទើបប្រទះនូវសេចក្តីទុក្ខក្នុងកាលណោះ ។

ជនពាល ទុកជាបរិភោគភោជនដោយចុងស្មៅរាល់ៗ ខែ ជនពាលនោះ ក៏មិនដល់មួយចំណិតនៃចំណែកទី ១៦ៗ លើក របស់បុគ្គលទាំង-ទ្បាយ ដែលមានធម៌បានដឹង ឬបានពិចារណាហើយទេ្បីយ ។

កម្មលាមក ដែលជនពាលធ្វើហើយ មិនទាន់ឲ្យផលនោះក៏មាន ដូចទឹកដោះស្រស់ ដែលមិនទាន់ប្រែក្លាយ (ក្នុងមួយរំពេច) ដូច្នោះ បាបកម្មនោះ តាមដុតបុគ្គលពាល ដូចរងើកភ្លើងដែលបិទបាំងទុកដោយផេះ ដូច្នោះ ។

ការចេះដឹង កើតទ្បើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះ រមែងញាំងបញ្ញាឲ្យធ្លាក់ចុះ បំផ្លេចបំផ្លាញចំណែកធម៌ស គឺកុសល

របស់បុគ្គលពាលនោះ ។ កិកូពាល រមែងប្រាថ្នានូវសេចក្តីសរសើរ ដែលមិនមាន (ក្នុងខ្លួន) ផង នូវការធ្វើក្នុងខាងមុខ គឺជាប្រមុខ ក្នុងពួកកិកូផង នូវភាពជាឥស្សរៈ ក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយ ក្នុងត្រកូលនៃជនទាំងឡាយដទៃផង កិកូពាលតែងមានសេចក្តីត្រិះរិះថា គ្រហស្ថ និងបព្វជិតទាំង ២ ពួក ចូរសម្គាល់នូវកិច្ច ដែលមនុស្សដទៃធ្វើហើយ ថាជាកិច្ចរបស់អញវិញ អំណាចដ៏ក្រៃលែងរបស់អញ ចូរមានក្នុងកិច្ចតូច ធំណាៗ មួយ (កាលបើយ៉ាងនេះ) ឫស្សា និងមានៈ រមែងចម្រើន ។ បដិបទាអាស្រ័យនូវលោកផ្សេង បដិបទាជាដំណើរទៅកាន់ព្រះនិព្វានផ្សេង កិកូជាសាវ័ករបស់ព្រះពុទ្ធ ដឹងច្បាស់នូវហេតុនោះ យ៉ាងនេះហើយ មិនគួរត្រេកអរចំពោះសក្ការៈឡើយ គប្បីញុំាងវិវេកឲ្យចម្រើន ដោយលំដាប់ ។

ពាលវគ្គទី ៥ ចប់

អដ្ឋកថា

ពាលវគ្គ

រឿង អញ្ញត្របុរស

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបាទបសេន-ទិកោសល និងបុរសម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ឱឃោ ជាគរតោ រត្តិ** *ជាដើម ។*

បានឮថា ក្នុងថ្ងៃមហោស្រពមួយ ព្រះរាជាព្រះនាមបសេនទិកោសល គង់លើជីវសុទ្ធមួយឈ្មោះបុណ្ណវីកៈ ដែលតាក់តែងហើយ ទ្រង់ធ្វើប្រទក្សិណ នគរ ដោយអានុភាពនៃព្រះរាជាដ៏ធំ ។ កាលអាជ្ញាជាហេតុឲ្យបុគ្គលក្រោកទៅ គឺទាហានស្តេចដេញបុគ្គលដែលឈរតាមផ្លូវ កំពុងប្រព្រឹត្តទៅ ។ មហាជន ត្រូវរាជបុរសវាយដោយវត្ថុ មានដុំដី និងដំបងជាដើមគេចទៅ ក៏នៅឱប-ក ត្រឡប់សម្លឹងមើលនោះឯង ។ បានឮថា សេចក្តីនេះជាផលនៃទានដែលព្រះ រាជាទាំងឡាយ ទ្រង់ថ្វាយល្អហើយ ។

ភរិយារបស់ទុគ្គតបុរសម្នាក់ ឈរត្រង់ផ្ទៃខាងលើនៃប្រាសាទ ៧ ជាន់ បើកស្បៃបង្ហួចសម្លឹងមើលព្រះរាជា ហើយក៏ត្រឡប់ទៅ ។ ការត្រឡប់ទៅ របស់ ស្រីនោះ ប្រាកដដល់ព្រះរាជាហាក់បីដូចព្រះចន្ទពេញវង់ ចូលកាន់

ស្រេទាប់ពពក ។ ព្រះរាជាទ្រង់មានព្រះហឫទ័យប្រតិពទ្ធក្នុងស្រីនោះ ហាក់បីដូចដល់នូវអាការធ្លាក់អំពីលើ-កជីវ ទ្រង់ប្រញាប់ប្រញាល់ធ្វើប្រទក្សិណព្រះនគរ ហើយចូលទៅកាន់ខាងក្នុងព្រះរាជវាំង ត្រាស់នឹងអមាត្យស្និទ្ធស្នាលម្នាក់ថា ប្រាសាទដែលខ្ញុំមើលក្នុងទីឈ្មោះនោះ អ្នកឃើញដែរឬទេ ។ អមាត្យទូលថា បពិត្រព្រះអង្គ ទូលបង្គំឃើញ ព្រះរាជាត្រាស់ថា អ្នកបានឃើញស្រីម្នាក់ក្នុងប្រាសាទនោះដែរឬទេ អមាត្យទូលថា បពិត្រព្រះអង្គ ទូលបង្គំបានឃើញ ព្រះរាជាត្រាស់ថា អ្នកចូរទៅ ចូរដឹងថា ស្រីនោះមានប្តីហើយឬនៅ ។

អមាត្យនោះទៅហើយ ជ្រាបសេចក្តីដែលស្រីនោះមានប្តី ទើបមកក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះអង្គ ស្រីនោះមានប្តីហើយ ។ ពេលនោះ ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរអ្នកហៅប្តីរបស់ស្រីនោះមក អមាត្យនោះទៅពោលថា នែអ្នក ព្រះរាជាត្រាស់ឲ្យហៅ ។ បុរសនោះគិតថា ភ័យគប្បីកើតឡើងដល់អញព្រោះអាស្រ័យភរិយា កាលមិនអាចជំទាស់ព្រះរាជអាជ្ញា ទើបបានទៅថ្វាយបង្គំព្រះរាជាហើយឈរ ។ ខណៈនោះ ព្រះរាជាត្រាស់នឹងបុរសនោះថា អ្នកចូរទំនុកបម្រុងយើង ។ បុរសនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព កុំឡើយ ទូលបង្គំធ្វើការងាររបស់ខ្លួន ថ្វាយសួយដល់ព្រះអង្គ ការចិញ្ចឹមជីវិតនោះ សូមមានដល់ទូលបង្គំចុះ ។ ព្រះរាជាត្រាស់ថា ខ្ញុំមិនត្រូវការដោយសួយរបស់អ្នក ចាប់តាំងអំពីថ្ងៃនេះទៅ អ្នកចូរមកប្រើខ្ញុំចុះ ហើយព្រះរាជទានខែល និងអាវុធដល់បុរសនោះ ។

បានឮថា ព្រះរាជាទ្រង់ត្រិះរិះយ៉ាងនេះថា អញនឹងចាប់ទោសណាមួយ របស់បុរសនេះ ហើយសម្លាប់ចោល យកភរិយា ។ ពេលនោះ បុរសនោះ ខ្លាចអំពីមរណភ័យ ជាអ្នកមិនប្រមាទ បម្រើព្រះរាជាហើយ ។ ព្រះរាជា ទ្រង់មិនឃើញឱកាសនៃបុរសនោះ កាលទ្រង់ក្តៅក្រហាយ ព្រោះកាមចម្រើន ទ្រង់ព្រះតម្រិះថា អញនឹងលើកទោសណាមួយរបស់បុរសនោះឡើង ហើយ ដាក់រាជអាជ្ញា ទើបបញ្ជាឲ្យហៅបុរសនោះមក ហើយត្រាស់យ៉ាងនេះថា នែ អ្នក អ្នកចូរទៅអំពីទីនេះ ទៅកាន់ទីឈ្មោះនោះនៃស្ទឹងក្នុងទីបំផុតប្រមាណ ៥ យោជន៍ នាំយកផ្លាកោមុទ ផ្លាឧប្បល និងជីពណ៌អរុណ ឲ្យទាន់ក្នុងកាល ដែលខ្ញុំងូតទឹកក្នុងពេលល្ងាច បើអ្នកមកមិនទាន់ក្នុងខណៈនោះ ខ្ញុំនឹងដាក់ អាជ្ញាដល់អ្នក ។

បានឮថា សេវកៈលំបាកជាងទាសា និងទាសី ។ ពិតហើយ ទាសៈ ទាំងឡាយ មានទាសៈដែលគេលោះមកដោយទ្រព្យជាដើម គង់បានពោល ថា ខ្ញុំឈឺក្បាល ខ្ញុំឈឺខ្នង ហើយសម្រាក ។

ពាក្យដែលទាសៈពោលហើយ បានសម្រាកនោះ រមែងមិនមានដល់ សេវកៈឡើយ ។ សេវកៈធ្វើការងារតាមបញ្ជាប៉ុណ្ណោះ ព្រោះហេតុនោះ បុរសនោះគិតថា អញត្រូវទៅដោយពិត ឈ្មោះថា ជីពណ៌អរុណ ផ្លាកោមុទ និងផ្លាឧប្បល រមែងកើតក្នុងពិភពនាគ អញនឹងបានអំពីណា ។ ខ្លាចចំពោះ មរណភ័យ ទៅផ្ទះហើយ ពោលថា នែនាង កត្តសម្រាប់ខ្ញុំសម្រេចហើយឬ ភរិយាពោលថា នែអ្នក កំពុងតាំងនៅលើជើងក្រាន ។ បុរសនោះមិនអាច

រង់ចាំរហូតកវិយាជាក់កត្តចុះបាន ទើបឲ្យកវិយាយកបាយដងទឹកបាយ ចាក់បាយដែលជ្រាយនោះឯងចូលក្នុងល្អីតាមតែបានកាន់យកហើយ ធ្វើដំណើរទៅហើយ អស់ចម្ងាយផ្លូវមួយយោជន៍ ។

កាលកំពុងដើរនោះឯង កត្តបានឆ្អិនហើយ ។ គាត់បែងចែកកត្តបន្តិចធ្វើមិនឲ្យជាសំណល់ បរិភោគ ជួបអ្នកដំណើរម្នាក់ ទើបពោលថា កត្តបន្តិចប៉ុណ្ណោះខ្ញុំបែងចែកធ្វើមិនឲ្យជារបស់សល់មាន អ្នកចូរទទួលបរិភោគចុះ ។ បុរសនោះទទួលបរិភោគហើយ ។ ទុគិតបុរសនោះ ក៏ជាក់កត្តចុះក្នុងទឹកមួយក្តាប់ ខ្ចុរមាត់ហើយប្រកាស ៣ ដងដោយសំឡេងខ្លាំងថា សូមពួកនាគ គ្រុឌ និងទេវតាដែលអាស្រ័យនៅក្នុងស្ទឹងនេះ ស្តាប់ពាក្យរបស់ខ្ញុំ ព្រះរាជាទ្រង់ប្រោថ្នាជាក់អាជ្ញាដល់ខ្ញុំ ទ្រង់បញ្ជាខ្ញុំថា ចូរអ្នកនាំយកជីពណ៌អរុណ ផ្តាកោមុទ និងផ្តាឧប្បលមក កត្តដែលខ្ញុំឲ្យដល់មនុស្សអ្នកធ្វើដំណើរហើយ ទានដែលខ្ញុំឲ្យហើយនោះ មានអានិសង្សរាប់ពាន់ កត្តដែលខ្ញុំឲ្យដល់ត្រីទាំងឡាយក្នុងទឹក ទានដែលខ្ញុំឲ្យនោះមានអានិសង្សរាប់រយ ខ្ញុំនឹងឲ្យផលបុណ្យប្រមាណប៉ុណ្ណោះ ឲ្យជាចំណែកបុណ្យដល់អ្នកទាំងឡាយ សូមលោកទាំងឡាយនាំជីពណ៌អរុណ ផ្តាកោមុទ និងផ្តាឧប្បលមកឲ្យខ្ញុំចុះ ។

ស្តេចនាគអាស្រ័យនៅក្នុងប្រទេសនោះ បានឮសំឡេងនោះ ទើបទៅកាន់សម្នាក់បុរសនោះដោយភេទជាមនុស្សចាស់ពោលថា អ្នកនិយាយអ្វី ទើបបុរសនោះពោលដូចមុននោះឯង ស្តេចនាគពោលថា ចូរអ្នកឲ្យចំណែកបុណ្យនោះដល់ខ្ញុំ ទើបបុរសនោះពោលថា ខ្ញុំឲ្យដល់អ្នក កាលស្តេចនាគពោលទៀត

ថា អ្នកចូរឲ្យ ក៏ពោលថា ខ្ញុំឲ្យដល់អ្នក ស្តេចនាគនោះឲ្យទាំចំណែកបុណ្យ មកយ៉ាងនោះអស់ ២-៣ ដងហើយ ទើបឲ្យដីពណ៌អរុណ ផ្ការកោមុទ និង ផ្ការឧប្បលដល់បុរសនោះ ។

ចំណែកព្រះរាជាទ្រង់ព្រះតម្រិះថា ធម្មតាមនុស្សទាំងឡាយ មានមន្តច្រើន បើបុរសនោះបានរបស់នោះ ដោយឧបាយណាមួយសោត កិច្ចរបស់អញមិន សម្រេច ទ្រង់បញ្ជាឲ្យបិទទ្វារតាំងអំពីថ្ងៃហើយ ឲ្យទាំកូនសោទៅកាន់សម្នាក់ របស់ព្រះអង្គ ។

បុរសនោះ មកទាន់ក្នុងកាលព្រះរាជាទ្រង់ស្រង់ទឹកដូចគ្នា កាលមិនមាន ទ្វារចូល ទើបហៅអ្នកយាមទ្វារពោលថា សូមអ្នកបើកទ្វារ អ្នកយាមទ្វារពោល ថា ខ្ញុំមិនអាចបើកបានទេ ព្រះរាជាបញ្ជាឲ្យទាំកូនសោទៅកាន់ព្រះរាជមន្ទីរតាំង អំពីថ្ងៃនោះឯង ។ បុរសនោះ ទោះបីប្រាប់ថា ខ្ញុំជារាជទូត អ្នកចូរបើកទ្វារ កាលមិនបានទ្វារ ទើបគិតថា ឥឡូវនេះអញនឹងមិនមានជីវិត អញនឹងធ្វើដូច ម្តេចហ្ន៎ ហើយចោះដុំដីទៅត្រង់ធរណីទ្វារខាងលើ ព្យួរផ្លាលើធរណីទ្វារនោះ ស្រែកឡើង ៣ ដងថា អ្នកនគរជ័ចម្រើនទាំងឡាយ សូមអ្នកទាំងឡាយជ័ង ភាពដែលកិច្ចរបស់ខ្ញុំធ្វើតាមបញ្ជារបស់ព្រះរាជាហើយចុះ ព្រះរាជាទ្រង់ប្រាថ្នា ធ្វើខ្ញុំឲ្យវិនាសដោយហេតុមិនសមគួរ ហើយគិតថា អញនឹងទៅទីណាហ្ន៎ បាន ធ្វើសេចក្តីសង្វេគថា ធម្មតាភិក្ខុទាំងឡាយជាអ្នកមានចិត្តទន់ភ្លន់ អញនឹងទៅ កាន់វិហារហើយដេក ។ ធម្មតាសត្វទាំងនេះក្នុងវេលាបានទទួលសុខ មិនជ្រាប ភាពដែលភិក្ខុទាំងឡាយមាន លុះត្រូវសេចក្តីទុក្ខគ្របសង្កត់ ទើបប្រាថ្នានឹងទៅ

វិហារ ព្រោះហេតុនោះ សូម្បីបុរសនោះ ក៏គិតថា ទីពឹងជនៃរបស់អញមិនមាន ទើបទៅកាន់វិហារ ដេកក្នុងទីសមគួរមួយកន្លែង កាលព្រះរាជាមិនបានឮវាការផ្ដាំលក់អស់មួយរាត្រី ព្រោះទ្រង់គិតដល់ស្រីនោះ ការរោលរាលព្រោះកាមកើតឡើងហើយ ព្រះរាជាទ្រង់គិតថា ក្នុងខណៈរាត្រីអស់ហើយនោះឯង អញនឹងឲ្យសម្លាប់បុរសនោះ ហើយនាំយកស្រីនោះមក ។

ក្នុងខណៈនោះឯង បុរស ៤ នាក់កើតក្នុងនរកឈ្មោះលោហកុម្ភី ដែលមានជម្រៅ ៦០ យោជន៍ ត្រូវភ្លើងនរកឆេះនៀលទៅមក ដូចអង្គរក្នុងឆ្នាំងដែលកំពុងពុះកញ្ជ្រែល លិចចុះដល់បាតខាងក្រោម ៣ ម៉ឺនឆ្នាំហើយ អណ្ដែតឡើងមកត្រង់មាត់ខាងលើ ៣ ម៉ឺនឆ្នាំទៀត សត្វនរកទាំងនោះងើបក្បាលឡើងសម្លឹងមើលគ្នានិងគ្នាហើយ ប្រាថ្នានឹងពោលម្នាក់មួយគាថា តែមិនអាចពោលបាន ទើបពោលបានតែមួយអក្ខរៈ ហើយវិលចុះទៅកាន់ខាងក្រោមដូចដើម ។

ព្រះរាជា កាលទ្រង់មិនបានការផ្ដាំលក់ ក៏ឮសំឡេងនោះ ក្នុងវាងមជ្ឈិមយាម ទ្រង់តក់ស្លុត មានព្រះហឫទ័យខ្លាច ទ្រង់ត្រិះរិះថា អន្តរាយនៃជីវិតនឹងមានដល់អញឬហ្ន៎ ឬនឹងមានដល់អគ្គមហេសី ឬរាជសម្បត្តិរបស់អញនឹងវិនាស មិនអាចបិទព្រះនេត្រទាំងពីរបានមួយយប់ទាល់ភ្លឺ ។ លុះថ្ងៃរះឡើង ទើបទ្រង់ឲ្យហៅបុរោហិតមកហើយ ត្រាស់ថា លោកអាចារ្យ សំឡេងដែលគួរខ្លាចក្រៃលែង ខ្ញុំបានឮក្នុងចន្លោះនៃមជ្ឈិមយាម ខ្ញុំមិនជ្រាបថា អន្តរាយនឹងមានដល់រាជសម្បត្តិ ដល់អគ្គមហេសី ដល់ខ្ញុំ ឬដល់អ្នកណា ព្រោះហេតុនោះ ទើបខ្ញុំអញ្ជើញលោកមក ។

បុរោហិតពោលថា បពិត្រមហារាជ សំឡេងដែលទ្រង់ឮដូចម្តេច ព្រះរាជាត្រាស់ថា លោកអាចារ្យ ខ្ញុំឮសំឡេងទាំងនេះថា **ឧ ស ឆ សោ** *អ្នកចូរពិចារណាផលសម្រេចនៃសំឡេងទាំងនេះមើល ។*

ហេតុណាមួយ រមែងមិនជ្រាកដដល់ព្រាហ្មណ៍ ហាក់បីដូចចូលទៅកាន់ទីងងឹតធំ ។ បុរោហិតនោះខ្លាចពោលថា បើអញទូលថា ទូលបង្គំមិនជ្រាបដូច្នេះ លាភសក្ការៈរបស់អញនឹងវិនាស ទើបទូលថា បពិត្រមហារាជ ហេតុនេះធ្ងន់ ព្រះរាជាត្រាស់ថា ហេតុអ្វីលោកអាចារ្យ បុរោហិតទូលថា អន្តរាយនៃជីវិតនឹងជ្រាកដដល់ព្រះអង្គ ។

ព្រះរាជាទ្រង់តក់ស្លុតទ្វេគុណត្រាស់ថា លោកអាចារ្យ ហេតុដើម្បីបំបាត់ភាពទាំងនេះណាមួយមានឬ បុរោហិតទូលថា បពិត្រមហារាជ មាន សូមទ្រង់កុំព្រួយព្រះហឫទ័យឡើយ ទូលបង្គំចេះនូវវេទទាំង ៣ ។ ព្រះរាជាត្រាស់ថា ខ្ញុំបានអ្វី ទើបគួរ បុរោហិតទូលថា បពិត្រព្រះអង្គ សូមទ្រង់បូជាយញ្ញ មានសត្វមួយមុខមួយរយ គ្រប់យ៉ាង ហើយនឹងរួចជីវិត ។

ព្រះរាជាត្រាស់ថា បានអ្វី ទើបគួរ ។

បុរោហិតនោះ កាលឲ្យចាប់បាណជាតិប្រភេទនីមួយៗ ឲ្យបានមួយមុខមួយរយ យ៉ាងនេះ គឺជ្រី ១០០ សេះ ១០០ គោឧសភៈ ១០០ មេគោទឹក ដោះ ១០០ ពពែ ១០០ ចៀម ១០០ មាន់ ១០០ ជ្រូក ១០០ ក្មេងប្រុស ១០០ ក្មេងស្រី ១០០ ទើបគិតថា បើអញចាប់យកតែពួកសត្វប៉ុណ្ណោះ ជនទាំងឡាយក៏ពោលថា បុរោហិតឲ្យចាប់តែរបស់ដែលស៊ីបានសម្រាប់ខ្លួនប៉ុណ្ណោះ

ព្រោះហេតុនោះ ទើបឲ្យចាប់ទាំងជីរី សេះ និងមនុស្សផងដែរ ។ ព្រះរាជាទ្រង់ត្រិះរិះថា ការរស់នៅរបស់យើងនោះឯង ជាលាភរបស់យើង ទើបត្រាស់ថា អ្នកចូរចាប់សត្វគ្រប់ប្រភេទឲ្យរហ័ស ពួកមនុស្សដែលបានទទួលបញ្ជា ក៏ចាប់យកមកច្រើនលើសប្រមាណ ។

ពិតហើយ ព្រះធម្មសង្គាហកាចារ្យពោលពាក្យនេះ ក្នុងកោសល-សំយុត្តថា សម័យនោះឯង មហាយញ្ញជាអាការប្រាកដចំពោះដល់ព្រះបាទបសេនទិកោសលហើយ ។

> *សម័យនោះ ព្រះបាទបសេនទិកោសល តាំងផ្តើមធ្វើមហា-យញ្ញ (បូជាធំ) ។ ពួកគោឧសភៈ ៥០០ កូនគោឈ្មោល ៥០០ កូនគោញី ៥០០ ពពែ ៥០០ ចៀម ៥០០ គេចង ក្លាប់ទឹងសសរយញ្ញ ដើម្បីបូជា ។ ពួកជនណា ដែលជាខ្ញុំប្រុសក្តី ជាអ្នកបម្រើក្តី ជាអ្នកធ្វើការងារក្តី ជនទាំងនោះ ត្រូវអាជ្ញាគំរាមហើយ ត្រូវភ័យគំរាមហើយ ក៏មានមុខទទឹកដោយទឹកភ្នែក ស្រែកយំ ធ្វើនូវបរិកម្មទាំងឡាយ (ការរំពឹងគិត) ។*

មហាជនទួញសោក ដើម្បីប្រយោជន៍ដល់ពួកញាតិរៀងៗ ខ្លួន បានធ្វើសំឡេងខ្ទាំងហើយ សំឡេងនោះហាក់ដូចជាសំឡេងស្រុតមហាប្រឹថពី ។ គ្រានោះ នាងមល្លិកាទេវីស្តាប់សំឡេងនោះហើយ ឃាងចូលទៅកាន់រាជសម្នាក់ទូលសួរថា បពិត្រមហារាជ ព្រោះហេតុអ្វីហ្ន៎ ឥន្ទ្រិយរបស់ព្រះអង្គ មិនជា

ប្រក្រតី ទ្រង់ប្រោកជព្រះរូបស្ងិតស្រេពោន ព្រះរាជាត្រាស់ថា ប្រយោជន៍អ្វី របស់នាង នាងមិនដឹងអាសិរពិសលួនក្បែរត្រចៀករបស់យើងឬ នាងមល្លិកា ទូលថា តើមានហេតុអ្វីព្រះអង្គ ព្រះរាជាត្រាស់ថា ក្នុងចំណែកវាត្រី ខ្ញុំបាន ឮសំឡេងបែបនេះ ទើបខ្ញុំសួរបុរោហិត បានឮថា អន្តរាយនៃជីវិត បាន ប្រោកជជល់ព្រះអង្គ ព្រះអង្គទ្រង់បូជាយញ្ញ មានសត្វមួយមុខមួយរយគ្រប់ ប្រភេទ ទើបបាននូវជីវិត ទើបយើងគិតថា ការរស់នៅរបស់យើងនោះឯង ជាលាភរបស់យើង ទើបបញ្ជាឲ្យចាប់សត្វទាំងនោះហើយ ។

ព្រះនាងមល្លិកាទេវីទូលថា បពិត្រមហារាជ ទ្រង់ជាបុគ្គលពាល ទ្រង់ មានកិក្ខាច្រើន ទ្រង់រមែងសោយភោជនដែលចម្អិនដោយអង្គរមួយនាឡិ មាន សុបៈ និងព្យញ្ជនៈច្រើនយ៉ាង ព្រះអង្គគ្រងរាជ្យក្នុងដែនទាំងពីរក៏ពិត តែព្រះ បញ្ញារបស់ព្រះអង្គល្ងង់ខ្លៅ ។ ព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី ទើបនាង ពោលយ៉ាងនោះ នាងមល្លិកាទូលថា ការបានជីវិតរបស់អ្នកជនៃ ព្រោះការ ស្លាប់របស់អ្នកជនៃ ព្រះអង្គធ្លាប់ឃើញក្នុងទីណា ព្រោះហេតុអ្វី ទើបទ្រង់ ជឿពាក្យសម្តីរបស់ព្រាហ្មណ៍អន្ធពាល ហើយបោះនូវសេចក្តីទុក្ខលើមហាជន ទៅវិញ ព្រះសាស្តាទ្រង់ជាអគ្គបុគ្គលនៃលោក និងទេវលោក មានព្រះ ញាណមិនទើសទាក់ក្នុងកាលទាំងឡាយ មានអតីតកាលជាដើម ប្រថាប់នៅ ក្នុងវិហារជិតបង្កើយ ទ្រង់ទូលសួរព្រះសាស្តានោះហើយ សូមទ្រង់ធ្វើតាម ឱវាទរបស់ព្រះអង្គចុះ ។

គ្រានោះឯង ព្រះរាជាយាងទៅកាន់វិហារជាមួយព្រះនាងមល្លិកា ដោយ

យានដែលស្រាល ត្រូវមរណភ័យគំរាមហើយ មិនអាចទូលពាក្យណាមួយ បាន ថ្វាយបង្គំព្រះសាស្តាហើយ ប្រថាប់នៅនាចំណែកម្ខាង ។ លំដាប់នោះ ព្រះសាស្តាទ្រង់ពាក់ទាក់ព្រះរាជានោះមុនថា មហាបពិត្រ ទ្រង់យាងទៅណា ទាំងថ្ងៃ ដូច្នេះ ព្រះរាជាក៏ទ្រង់នៅស្ងៀម ។ លំដាប់នោះ ព្រះនាងមល្លិកា ក្រាបទូលដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ បានឮថា ព្រះរាជាទ្រង់ស្តាប់សំឡេងចម្រៀកក្នុងចន្លោះនៃមជ្ឈិមយាម កាលបើដូច្នោះ ទើបទ្រង់ជ្រាប់ហេតុនោះដល់បុរោហិត បុរោហិតក្រាបទូលថា អន្តរាយនៃជីវិតនឹងមានដល់ព្រះអង្គ កាលទ្រង់ចាប់សត្វមួយមុខមួយរយ បូជាយញ្ញដោយឈាមបំពង់ករបស់សត្វទាំងនោះ ដើម្បីប្រយោជន៍កម្ចាត់នូវអន្តរាយនោះ ទ្រង់នឹងបានជីវិត ។ ព្រះរាជាឲ្យចាប់សត្វជាច្រើន ព្រោះហេតុនោះ ទើបខ្ញុំម្ចាស់នាំព្រះរាជាមកក្នុងទីនេះ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ បានឮថា សេចក្តីនោះ យ៉ាងនោះឬ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ សេចក្តីនោះ យ៉ាងនោះឯង ព្រះសាស្តាត្រាស់ថា សំឡេងដែលទ្រង់ស្តាប់ហើយដូចម្តេច ព្រះរាជាទូលដោយទំនងដែលទ្រង់ស្តាប់ហើយ ។ ពន្លឺតែមួយបានប្រាកដដល់ព្រះតថាគត ព្រោះទ្រង់ស្តាប់សេចក្តីនោះ ។ លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះរាជានោះថា សូមទ្រង់កុំតក់ស្លុតឡើយ អន្តរាយមិនមានដល់ព្រះអង្គ សត្វទាំងឡាយដែលមានកម្មលាមក កាលធ្វើទុក្ខរបស់ខ្លួនឲ្យជាក់ច្បាស់ ទើបពោលយ៉ាងនេះ ។ ព្រះរាជាទូលថា បពិត្រព្រះអង្គ កម្មអ្វីដែលសត្វទាំងនោះធ្វើ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងកម្មរបស់សត្វនរកទាំងនោះ ទើបត្រាស់ថា បើដូច្នោះ សូមទ្រង់ស្តាប់ ហើយទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល កាលមនុស្សមានអាយុ ២ ម៉ឺនឆ្នាំ ព្រះដ៏មានព្រះភាគព្រះនាមកស្សបៈ កើតឡើងក្នុងលោក ទ្រង់ចារិកទៅ មួយអន្ទើដោយព្រះវិណាស្រេព ២ ម៉ឺនអង្គ ដល់ក្រុងពារាណសី អ្នកក្រុងពារាណសី ២ នាក់ខ្លះ ៣ នាក់ខ្លះ ច្រើនជាងនោះខ្លះ រួមជាពួកតែមួយ ញ៉ាំងអាគន្តុកទានឲ្យប្រព្រឹត្តទៅហើយ ក្នុងកាលនោះ ក្នុងក្រុងពារាណសីមានសេដ្ឋីបុត្រ ៤ នាក់ មានសម្បត្តិ ៤០ កោដិ ជាសម្លាញ់នឹងគ្នា សេដ្ឋីបុត្រទាំងនោះប្រឹក្សាគ្នាថា ក្នុងផ្ទះរបស់ពួកយើងមានទ្រព្យច្រើន ពួកយើងនឹងធ្វើអ្វីដោយទ្រព្យនោះ ។

កាលព្រះសម្ពុទ្ធមានសកាពបែបនោះ ទ្រង់ចារិកទៅ បណ្តាសេដ្ឋីបុត្រទាំងនោះមិនបានពោលថា ពួកយើងនឹងថ្វាយទាន នឹងធ្វើការបូជា នឹងរក្សាសីល សេដ្ឋីបុត្រម្នាក់ពោលយ៉ាងនេះមុនថា ពួកយើងផឹកសុរាដែលចាស់ ទំពាស៊ីសាច់ដែលមានរសឆ្ងាញ់ នឹងត្រាច់ទៅ ជីវិតរបស់ពួកយើងនឹងមានផល ។

ម្នាក់ទៀត ពោលយ៉ាងនេះថា ពួកយើងនឹងបរិភោគភត្តនៃអង្គរស្រែវសាលី ដែលមានក្លិនក្រអូប ដែលទុកក្នុងជង្រុក ៣ ឆ្នាំ ដោយរសដ៏ប្រសើរផ្សេងៗ ត្រាច់ទៅ ។

ម្នាក់ទៀត ពោលយ៉ាងនេះថា ពួកយើងនឹងឲ្យគេចៀនរបស់គួរទំពាប្លែកៗ មានប្រការផ្សេងៗ ទំពាស៊ី ត្រាច់ទៅ ។

ម្នាក់ទៀត ពោលយ៉ាងនេះថា នែសម្ចាញ់ ពួកយើងមិនធ្វើកិច្ចណាមួយដទៃទ្បើយ ស្រីទាំងឡាយ កាលយើងពោលថា នឹងឲ្យទ្រព្យ ឈ្មោះថាមិនប្រាថ្នា មិនមាន ព្រោះហេតុនោះ ពួកយើងប្រមូលទ្រព្យហើយ នឹងលួងលោមស្រីទាំងនោះ ធ្វើបរទារកម្ម គឺការប្រព្រឹត្តខុសក្នុងភរិយារបស់អ្នកដទៃ ។

សេដ្ឋីបុត្រទាំងអស់ទទួលថា ល្អណាស់ បានតាំងនៅក្នុងពាក្យរបស់ជនទី ៤ នោះ ។ តាំងអំពីនោះមក សេដ្ឋីបុត្រទាំងនោះបញ្ជូនទ្រព្យទៅដើម្បីស្រីដែលមានរូបស្អាត ធ្វើបរទារកម្មអស់ ២ ម៉ឺនឆ្នាំ ធ្វើកាលកិរិយាហើយ កើតក្នុងអវីចីមហានរក ។

សេដ្ឋីបុត្រទាំងនោះ ធេះហើយក្នុងនរកអស់មួយពុទ្ធន្តរ ធ្វើកាលកិរិយាក្នុងនរកនោះ ដោយសេសសល់ផលកម្ម ក៏កើតក្នុងលោហកុម្ភីនរក ដែលមានជម្រៅ ៦០ យោជន៍ លិចចុះទៅខាងក្រោម ៣ ម៉ឺនឆ្នាំ អណ្តែតមកលើដល់មាត់ឆ្នាំង ៣ ម៉ឺនឆ្នាំទៀត ជាអ្នកប្រាថ្នានឹងពោលគាថាមួយម្នាក់ មិនអាចពោលបាន ពោលបានតែមួយអក្ខរ: ហើយក៏លិចចុះទៅកាន់បាតខ្ទះដូចមុនទៀត ។ មហាបពិត្រ សូមទ្រង់ប្រាប់ តើទ្រង់បានស្តាប់សំឡេងដូចម្តេច ជាដំបូង ។ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្ត គឺសំឡេងថា ឧ ព្រះសាស្តាកាលទ្រង់សម្តែងគាថា ដែលសត្វនរកនោះពោលមិនពេញ ឲ្យពេញ ទើបត្រាស់យ៉ាងនេះថា

ឧុជ្ជីវិតមជីវម្ហ យេសន្តេ ន ឧឧម្ហសេ
សន្តេសុ ឧយ្យ ធម្មេសុ ឧីបំ នាកម្ហ មត្តនោ ។

ពួកយើងរស់នៅដោយលំបាក ព្រោះទេយ្យធម៌មាន

យើងមិនបានឲ្យ កាលទេយ្យធម៌មាន យើងមិនបាន
ធ្វើទីពឹងដល់ខ្ជូនសោះ ។

លំដាប់នោះ ព្រះសាស្តាកាលទ្រង់ប្រកាសអត្ថនៃគាថានេះដល់ព្រះរាជា ហើយ ទើបត្រាស់សួរថា មហាបពិត្រ សំឡេងទី ២ សំឡេងទី ៣ សំឡេងទី ៤ ទ្រង់បានញ្ជូចម្តេច កាលព្រះរាជាទូលថា គឺសំឡេងយ៉ាងនេះ ព្រះអង្ត កាលទ្រង់ញ្ចាំងអត្ថដ៏សេសឲ្យបរិបូណ៌ ទើបត្រាស់ថា

សជ្ជីវស្ស្សសហស្ស្សានិ បរិបុណ្ណានិ សព្វសោ
និរយេ បច្ចមានានំ កទា អន្តោ ភវិស្ស្សតិ ។

ពួកយើងធេះនៅក្នុងនរកពេញ ប្រាំមួយម៉ឺន
(៦០០០០) ឆ្នាំគ្រាប់គ្រាន់ តើទីបំផុតនឹង
មានក្នុងវេលាណា ។

នត្ថិ អន្តោ កុតោ អន្តោ ន អន្តោ បដិទិស្ស្សតិ
តថា ហិ បកតំ ទាបំ មម តុយ្ហញ្ច មារិស ។

ពួកយើងមិនមានទីបំផុតទេ ពួកយើងនឹងមានទីបំផុត
មកពីណា ទីបំផុត នឹងមិនប្រាដកដល់យើងឡើយ
ម្នាលអ្នក ព្រោះតែខ្ញុំក្តី អ្នកក្តី បានធ្វើបាប ។

សោហិ ន្ធន ឥតោ គន្ត្វា យោនឹ លទ្ធាន មានុសឹ
វទញ្ញ សីលសម្ឈន្នោ កាហាមិ កុសលំ ពហុន្តិ ។

ប្រសិនបើខ្ញុំ បានរដោះរួចចាកនរកនេះទៅ បានកើត

ជាមនុស្ស សូមជាអ្នកបរិបូណ៌ដោយសីលធ្វើកុសល
ឲ្យច្រើន អំពីកាលដ៏ឆ្គីទៅ ។

ព្រះសាស្តា កាលត្រាស់គាថាទាំងនេះដោយលំដាប់ ប្រកាសអត្តហើយ ទើបត្រាស់ថា មហាបពិត្រ ជនទាំង ៤ នោះប្រាថ្នានឹងពោលគាថា ម្នាក់មួយគាថា កាលមិនអាចពោលបាន ពោលត្រឹមតែមួយអក្ខរៈប៉ុណ្ណោះ នឹងចុះទៅកាន់លោហកុម្ភីនោះឯងទៀត ដោយប្រការដូច្នេះឯង ។

បានឮថា ចាប់តាំងអំពីកាលនៃសំឡេងនោះ ដែលព្រះបាទបសេនទិកោសលទ្រង់ឮហើយ ជនទាំងនោះលិចចុះទៅខាងក្រោមដូចមុន សូម្បីមកទល់ថ្ងៃនេះ ក៏មិនទាន់កន្លងជល់មួយពាន់ឆ្នាំ ការសង្វេគធំកើតឡើងជល់ព្រះរាជា ព្រោះទ្រង់ស្តាប់ទេសនានោះ ។ ព្រះរាជាទ្រង់ត្រិះរិះថា ឈ្មោះថាបរទារកម្មនេះ ធ្ងន់ហ្ន៎ បានឮថា ជនទាំង ៤ នេះហើយក្នុងអវីចីនរកអស់មួយពុទ្ធន្តរ ចុតិអំពីអវីចីនរកនោះហើយ កើតក្នុងលោហកុម្ភីដែលមានជម្រៅ ៦០ យោជន៍ នេះហើយក្នុងលោហកុម្ភីនោះអស់ ៦ ម៉ឺនឆ្នាំយ៉ាងនេះ កាលជាទីផុតទុក្ខរបស់ជនទាំងនោះមិនប្រាកដ ឯអញធ្វើនូវការជាប់ជំពាក់ក្នុងភរិយារបស់បុរសដទៃ មិនបានដេកលក់អស់មួយយប់ ឥឡូវនេះ តាំងអំពីនេះទៅ អញនឹងមិនចងការពេញចិត្ត ក្នុងភរិយារបស់បុរសដទៃ ទើបក្រាបទូលព្រះតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រាបភាពដែលរាត្រីយូរ ក្នុងថ្ងៃនេះ ។

ចំណែកបុរសនោះ អង្គុយក្នុងទីនោះឯង ស្តាប់ពាក្យនោះហើយ គិតថា

បច្ចុយមានកម្លាំងអញ្ចឹងបានហើយ ទើបក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះរាជាទ្រង់ជ្រាបភាពដែលរាត្រីយូរក្នុងថ្ងៃនេះ ចំណែកខ្ញុំព្រះអង្គបានជ្រាបភាពនៃយោជន៍ឆ្ងាយក្នុងកាលម្សិលមិញ ។

ព្រះសាស្តាទ្រង់ប្រៀបធៀបពាក្យសម្តីរបស់ជនទាំងពីរហើយ ត្រាស់ថា រាត្រីរបស់បុគ្គលពួកខ្លះរមែងយូរ យោជន៍របស់បុគ្គលពួកខ្លះឆ្ងាយ ចំណែកសង្សារបស់បុគ្គលពាល រមែងជាសភាវៈវែង កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ
ទីឃោ ពាលាន សំសារោ សទ្ធម្មំ វិជានតំ ។

រាត្រីវែង ចំពោះតែអ្នកភ្ញាក់រឭក (អ្នកដេកមិនលក់)
យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្តវែង
ចំពោះតែបុគ្គលពាលមិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទីឃា** *ជាដើម សេចក្តីថា ឈ្មោះថា រាត្រីនេះមានត្រឹម ៣ យាមប៉ុណ្ណោះ តែសម្រាប់បុគ្គលភ្ញាក់ រាត្រីនៅយូរ គឺរមែងប្រាកដហាក់បីដូច ២-៣ ជង បុគ្គលអ្នកឱ្យលច្រអូសច្រើន ធ្វើខ្លួនឲ្យជាចំណីរបស់សង្កើច ដេកបម្រះនទៀលរហូតព្រះអាទិត្យរះឡើងក្តី បុគ្គលសេពកាមបរិភោគភោជនដែលល្អហើយ ដេកនៅលើគ្រែដែលជាសិរីក្តី រមែងមិនដឹងភាពដែលរាត្រីនោះយូរ ចំណែកព្រះយោគាវចរ ដែលជាអ្នកតម្កល់នូវសេចក្តី*

ព្យាយាមមួយយប់ទល់ភ្លឺក្តី ព្រះធម្មកថិក សម្តែងព្រះធម្មកថាមួយយប់ទល់ភ្លឺក្តី បុគ្គលអង្គុយស្តាប់ធម៌ក្នុងទីជិតអាសន្នៈមួយយប់ទល់ភ្លឺក្តី ដែលត្រូវរោគទាំងឡាយ មានរោគក្បាលជាដើមពាល់ត្រូវហើយ ឬជល់នូវសេចក្តីទុក្ខ មានការកាត់ដៃ និងជើងជាដើម ត្រូវវេទនាគ្របសង្កត់ក្តី អ្នកដើរផ្លូវឆ្ងាយ ដើរផ្លូវ អស់មួយយប់ក្តី រមែងជីងភាពដែលវាត្រីនោះឃួរ ។

បទថា **យោជនំ** *ជាដើម សេចក្តីថា ១ យោជន៍មានត្រឹម ៤ គាវុតប៉ុណ្ណោះ ។ សម្រាប់បុគ្គលដែលអស់កម្លាំងហើយ ដែលទន់ខ្សោយហើយនៅឆ្ងាយ គឺរមែងជ្រាកជហាក់បីដូច ២-៣ ជង ។ ពិតហើយ អ្នកដើរអស់ ១ ថ្ងៃ នឿយហត់ហើយ ជួបអ្នកធ្វើដំណើរមកសួរថា ស្រុកខាងមុខនៅឆ្ងាយប៉ុនណា កាលគេឆ្លើយថា ចម្ងាយមួយយោជន៍ ទៅបានបន្តិច ក៏សួរមនុស្សដទៃទៀត កាលមនុស្សនោះជ្រាប់ថា មួយយោជន៍ ទៅបន្តិចក៏សួរទៀត សូម្បីអ្នកដទៃទៀត គេក៏ពោលថា មួយយោជន៍ ជនទាំងនោះត្រូវអ្នកដំណើរនោះសួរហើយ ក៏ជ្រាប់ថា មួយយោជន៍ បុរសនោះគិតថា យោជន៍នេះឆ្ងាយពិតហ្ន៎ រមែងសម្គាល់មួយយោជន៍ហាក់បីដូច ២-៣ យោជន៍ ។*

បទថា **ពាលានំ** *ជាដើម សេចក្តីថា ចំណែកសង្ឃារបស់ជនពាលទាំងឡាយ ដែលមិនដឹងប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ គឺមិនអាចធ្វើទីបំផុតនៃសង្ឃារវដ្ត ដែលមិនដឹងច្បាស់នូវព្រះសទ្ធម្ម មានពោធិបក្ខិយធម៌ ៣៧ ប្រការជាដើម ដែលព្រះអរិយៈទាំងឡាយដឹងហើយ ធ្វើទីបំផុតនៃសង្ឃារបាន ឈ្មោះថា វែង ។ ពិតហើយ សង្ឃារនោះ ឈ្មោះថា*

វែង តាមធម្មតារបស់ខ្លួនឯង ។ សមដូចព្រះពុទ្ធវចនៈដែលព្រះមានព្រះភាគ
ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះមានទីបំផុត ដែលបុគ្គលដឹងមិន
បានខាងដើម និងខាងចុង រមែងមិនប្រាកដ ។ តែសម្រាប់ជនពាលទាំងឡាយ
បុគ្គលមិនអាចនឹងធ្វើទីបំផុតបាន រមែងវែងនោះឯង ។

ក្នុងកាលចប់ទេសនា បុរសនោះសម្រេចសោតាបត្តិផលហើយ ជនដទៃ
ជាច្រើន សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ទេសនា
មានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។

ព្រះរាជាថ្វាយបង្គំព្រះសាស្តាហើយ កំពុងយាងទៅ ទ្រង់បញ្ជាឲ្យលែង
សត្វទាំងនោះចាកចំណងហើយ ។ បណ្តាមនុស្ស និងសត្វទាំងនោះ ស្រី និង
បុរសទាំងឡាយផុតចាកចំណង យកទឹកលាបក្បាលហើយ ទៅកាន់ផ្ទះរៀងៗ
ខ្លួន ពោលសរសើរគុណព្រះនាងមល្លិកាថា យើងទាំងឡាយបានជីវិត ព្រោះ
អាស្រ័យព្រះទេវីអង្គណា សូមព្រះនាងមល្លិកាទេវីអង្គនោះ ដែលជាម្តាយរបស់
យើងទាំងឡាយ សូមព្រះនាងគង់ព្រះជន្មអស់កាលយូរហោង ។

ក្នុងពេលល្ងាច ភិក្ខុទាំងឡាយសន្ទនាក្នុងរោងធម្មសភាថា គួរសរសើរ
ព្រះនាងមល្លិកានេះឈ្មោះវៃហ្ន៎ ព្រះនាងអាស្រ័យបញ្ញារបស់ព្រះនាង បានឲ្យ
ជីវិតទានដល់ជនមានប្រមាណប៉ុណ្ណេះហើយ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់
មិញ្ញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយពាក្យដូចម្តេចហ្ន៎ កាលភិក្ខុទាំង
នោះក្រាបទូលថា ដោយពាក្យឈ្មោះនេះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំង-

ឡាយ ព្រះនាងមល្លិកាអាស្រ័យបញ្ញារបស់ខ្លួន ឲ្យជីវិតដល់មហាជនក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ព្រះនាងក៏បានឲ្យហើយដូចគ្នា កាលទ្រង់ប្រកាសសេចក្តីនេះ ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល ឱរសរបស់ព្រះបាទពារាណសី ចូលទៅកាន់ដើមជ្រៃមួយហើយ ទ្រង់បន់ស្រន់ទេវតាដែលកើតត្រង់ដើមជ្រៃនោះថា បពិត្រទេវរាជ ក្នុងជម្ពូទ្វីបនេះ មានព្រះរាជា ១០១ និងអគ្គមហេសី ១០១ បើខ្ញុំនឹងបានរាជ-សម្បត្តិ ដោយកាលកន្លងទៅនៃបិតាសោត ខ្ញុំនឹងធ្វើពលីដោយឈាម ក្នុងបំពង់ករបស់ស្តេច និងអគ្គមហេសីទាំងនោះ ។ រាជកុមារនោះ កាលព្រះបិតាសោយទិវង្គតហើយ បានទទួលរាជសម្បត្តិ ទ្រង់ក៏គិតថា អញបានទទួលរាជសម្បត្តិដោយអានុភាពរបស់ទេវតា អញនឹងធ្វើពលីដល់ទេវតានោះ ទើបយាងចេញទៅដោយសេនាធំ ញុំាងព្រះរាជាមួយអង្គឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនហើយ ធ្វើព្រះរាជាអង្គជទៃ និងជទៃទៀត មួយអន្ទើដោយព្រះរាជាអង្គនោះ ឲ្យនៅក្នុងអំណាចរបស់ខ្លួន ធ្វើព្រះរាជាទាំងអស់ឲ្យនៅក្នុងអំណាចរបស់ខ្លួន ដោយប្រការដូច្នេះ ហើយទ្រង់នាំទៅ មួយអន្ទើដោយព្រះអគ្គ-មហេសីទាំងឡាយ ទ្រង់ដោះលែងព្រះនាងធម្មទិន្នា ដែលទ្រង់ព្រះគភ៌គ្រប់ខែដែលជាអគ្គមហេសីរបស់ព្រះរាជា ព្រះនាមថា ឧគ្គសេន ដែលជាព្រះរាជាដែលតូចជាង ព្រះរាជាទាំងពួងយាងទៅ ទ្រង់ព្រះតម្រិះថា អញនឹងឲ្យជនទាំងនេះផឹកថ្នាំពិសឲ្យស្លាប់ ទើបឲ្យជនទាំងឡាយ ជម្រះគល់ជ្រៃឲ្យស្អាតហើយ ។

ទេវតាគិតថា ព្រះរាជាអង្គនេះ កាលចាប់ព្រះរាជាប្រមាណប៉ុណ្ណេះ ទ្រង់អាស្រ័យអញ ទើបចាប់ ព្រះរាជាទ្រង់ប្រាថ្នាធ្វើពលីកម្មដល់អញ ដោយឈាមក្នុងបំពង់ករបស់ព្រះរាជាទាំងនោះ បើព្រះរាជានេះទ្រង់សម្រេចទោសព្រះរាជាទាំងនោះសោត ព្រះរាជវង្សក្នុងជម្ពូទ្វីបនឹងដាច់សូន្យ សូម្បីគល់ឈើរបស់អញក៏មិនស្អាត អញអាចឃាត់ព្រះរាជានោះបានដែរឬទេហ្ន៎ ទេវតានោះពិចារណា ក៏ដឹងថា អាត្មាអញមិនអាចឡើយ ទើបចូលទៅរកទេវតាអង្គជទៃ ប្រាប់សេចក្តីនោះហើយ ពោលថា អ្នកអាចឬ ទេវតានោះ កាលទេវតានោះឃាត់ហើយ ទើបចូលទៅរកទេវតាក្នុងចក្រវាលទាំងមូលយ៉ាងនេះ គឺចូលទៅរកទេវតាអង្គជទៃ និងអង្គជទៃ សូម្បីត្រូវទេវតាទាំងនោះឃាត់ហើយ ទើបទៅកាន់សម្នាក់របស់មហារាជទាំង ៤ ក្នុងកាលដែលមហារាជទាំង ៤ នោះឃាត់ហើយដោយពាក្យថា ពួកខ្ញុំមិនអាច តែព្រះរាជារបស់យើងទាំងឡាយ ជាបុគ្គលវិសេសជាងពួកយើងដោយបុណ្យ និងបញ្ញា ចូរអ្នកទូលសួរព្រះរាជានោះចុះ ដូច្នេះហើយ ទើបចូលទៅគាល់សក្កទេវរាជ ក្រាបទូលសេចក្តីនោះហើយ ដោយពាក្យថា បពិត្រតេជៈ កាលទ្រង់ដល់នូវការខ្វល់ខ្វាយតិច ខត្តិយវង្សនឹងដាច់សូន្យ សូមទ្រង់ជាទីពឹងពុំនាក់នៃវង្សស្តេចទាំងនោះចុះ ។

សក្កទេវរាជត្រាស់ថា សូម្បីខ្ញុំក៏មិនអាចឃាត់ព្រះរាជានោះ តែខ្ញុំប្រាប់ឧបាយដល់អ្នក ហើយទ្រង់ប្រាប់ឧបាយថា ទៅចុះអ្នក កាលព្រះរាជាទ្រង់ឃើញនោះឯង អ្នកចូរស្ងៀកសំពត់ក្រហម សម្តែងអាការដូចជាចេញអំពីដើមឈើ

របស់ខ្លួន កាលបើដូច្នោះ ព្រះរាជាទ្រង់ត្រិះរិះថា ទេវតារបស់អញកំពុងទៅអញនឹងឲ្យទេវតានោះត្រឡប់មក ហើយនឹងអង្វរដោយប្រការផ្សេងៗ កាលបើដូច្នោះ អ្នកគប្បីពោលនឹងព្រះរាជានោះថា អ្នកប្រាប់យើងថា នឹងនាំព្រះរាជា ១០១ មួយអន្ទើដោយអគ្គមហេសីទាំងឡាយ ធ្វើពលីដោយឈាមក្នុងចំពង់ក របស់ព្រះរាជាទាំងនោះ ទ្រង់លះបង់ព្រះទេវីរបស់ខ្លួនសេន ហើយយាងមក ខ្ញុំមិនទទួលពលីរបស់អ្នកពោលកុហកដូចទ្រង់ឡើយ ដ្បិតថា កាលបើអ្នកពោលយ៉ាងនេះ ព្រះរាជានឹងនាំព្រះទេវីនោះមក ព្រះទេវីនោះនឹងសម្តែងធម៌ដល់ព្រះរាជា ឲ្យជីវិតទានដល់ជនមានប្រមាណប៉ុណ្ណោះ ។ សក្កទេវរាជប្រាប់ឧបាយនេះដល់ទេវតាដោយហេតុនេះ ទេវតាបានធ្វើតាមនោះហើយ សូម្បីព្រះរាជា ក៏បញ្ជាឲ្យនាំព្រះទេវីនោះមកហើយ ។

ព្រះទេវីនោះ មកថ្វាយបង្គំព្រះរាជាជាស្វាមីរបស់ខ្លួនប៉ុណ្ណោះ ហើយប្រថាប់គង់ក្នុងទីបំផុតនៃព្រះរាជាទាំងនោះ ព្រះរាជាពិរោធចំពោះព្រះទេវីនោះថា កាលអញតាំងនៅក្នុងតំណែងជាធំជាងព្រះរាជាទាំងពួង នាងនៅតែថ្វាយបង្គំប្តីរបស់ខ្លួន ដែលជាអ្នកតូចតាចជាងព្រះរាជាទាំងពួង ។ លំដាប់នោះ ព្រះទេវីទូលព្រះរាជានោះថា រឿងអ្វីរបស់ខ្ញុំម្ចាស់ត្រូវទាក់ទងក្នុងព្រះអង្គ ព្រះរាជាអង្គនេះ ជាស្វាមីឲ្យនូវភាពជាធំដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់មិនថ្វាយបង្គំព្រះរាជាអង្គនេះហើយ នឹងថ្វាយបង្គំព្រះអង្គព្រោះហេតុអ្វី កាលជនទាំងនោះកំពុងឃើញនុ៎ះឯង រុក្ខទេវតាពោលថា យ៉ាងនោះឯងព្រះទេវីដ៏ចម្រើន យ៉ាងនោះឯងព្រះទេវីដ៏ចម្រើន ហើយបូជាព្រះទេវីនោះដោយផ្ការួយក្តាប់ ។

ព្រះរាជាត្រាស់ថា បើនាងមិនថ្វាយបង្គំយើងសោត ព្រោះហេតុអ្វី ទើបមិនថ្វាយបង្គំទេវតារបស់យើង ដែលមានអានុភាពច្រើនយ៉ាងនេះ ជាអ្នកឲ្យនូវសិរីនៃភាពជាព្រះរាជា ។ ព្រះទេវីទូលថា បពិត្រមហារាជ ព្រះរាជាទាំងឡាយ ដែលទ្រង់តាំងនៅក្នុងបុណ្យរបស់ខ្លួន ទើបចាប់បាន មិនមែនទេវតាចាប់ថ្វាយឡើយ ។ ទេវតាពោលនឹងព្រះទេវីទៀតថា យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន យ៉ាងនោះឯងព្រះទេវីដ៏ចម្រើន ហើយបូជាយ៉ាងនោះទៀត ។

ព្រះទេវីនោះ ទូលព្រះរាជាទៀតថា ទ្រង់ត្រាស់ថា ព្រះរាជាទាំងឡាយមានប្រមាណប៉ុណ្ណេះ ទេវតាចាប់ឲ្យដល់យើង ឥឡូវនេះដើមជ្រៃត្រូវភ្លើងឆេះខាងឆ្វេងនៃចំណែកខាងលើរបស់ទេវតារបស់ទ្រង់ ព្រោះហេតុអ្វី ទើបទេវតានោះមិនអាចញ្ចុាំងភ្លើងនោះឲ្យរលត់បាន បើទេវតាមានអានុភាពច្រើនយ៉ាងនោះ ។ ទេវតាពោលនឹងព្រះទេវីទៀតថា យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន ហើយបូជាយ៉ាងនោះទៀត ។

ព្រះទេវីឈរទ្រង់ព្រះកន្សែងផង ទ្រង់សើចផង ។ លំដាប់នោះ ព្រះរាជាត្រាស់នឹងព្រះទេវីនោះថា នាងឆ្ពួតហើយឬ ព្រះទេវីត្រាស់ថា ព្រោះហេតុអ្វី ទើបទ្រង់ត្រាស់យ៉ាងនោះ ស្រីទាំងឡាយដូចខ្ញុំម្ចាស់ មិនមែនឆ្ពួតឡើយ ព្រះរាជាត្រាស់ថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបនាងយំហើយសើច ព្រះទេវីទូលថា សូមទ្រង់ស្តាប់ចុះមហារាជ ក្នុងអតីតកាល ខ្ញុំជាកុលធីតា កាលនៅក្នុងត្រកូលប្តី ឃើញភ្ជៀវជាសម្លាញ់របស់ប្តីមកហើយ ប្រាថ្នានឹងដាំស្លដើម្បីភ្ជៀវនោះ ទើបឲ្យកហាបណៈដល់ទាសីដោយប្រាប់ថា ចូរនាង

ទិញសាច់មក ទាសីនោះមិនបានសាច់មកហើយពោលថា សាច់មិនមាន ទើបកាត់ក្បាលមេពពែដែលដេកខាងក្រោយផ្ទះ ចាត់ចែងកត្តស្រេច ខ្ញុំនោះឯងកាត់ក្បាលមេពពែមួយក្បាល ឆេះក្នុងនរក ដោយសេសសល់ផលកម្ម ទើបត្រូវគេកាត់ក្បាលអំបាលរាប់ដោយរោមពពែនោះ ទ្រង់សម្រេចទោសជនមានប្រមាណប៉ុណ្ណេះ កាលណានឹងផុតទុក្ខ ខ្ញុំរឭកដល់ទុក្ខដ៏ធំរបស់ព្រះអង្គ ដូច្នេះទើបខ្ញុំយំ ដូច្នេះហើយ ទើបត្រាស់គាថានេះថា

ខ្ញុំកាត់ក្បាលពពែមួយ ឆេះហើយក្នុងនរកដោយការរាប់រោមពពែ
បពិត្រព្រះអង្គដ៏ជាក្សត្រ ទ្រង់កាត់ក្បាលរបស់មនុស្សដ៏ច្រើន
នឹងធ្វើដូចម្តេច ។

ព្រះរាជាត្រាស់ថា បើដូច្នោះ នាងសើចព្រោះហេតុអ្វី ព្រះទេវីត្រាស់ថា បពិត្រមហារាជ ខ្ញុំម្ចាស់ត្រេកអរថា អញនឹងផុតទុក្ខនោះហើយទើបសើច ។

ទេវតាពោលនឹងព្រះទេវីនោះទៀតថា យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន ហើយបូជាផ្តាមួយក្តាប់ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា គួរសង្វេគ កម្មរបស់អញធ្ងន់ហ្ន៎ បានឮថា ព្រះទេវីនេះសម្លាប់មេពពែមួយ ឆេះក្នុងនរកហើយ ដោយសេសសល់ផលកម្ម ត្រូវគេកាត់ក្បាលអំបាលស្មើនឹងរោមពពែនោះ អញសម្លាប់ជនមានប្រមាណប៉ុណ្ណេះ នឹងដល់នូវសួស្តីក្នុងកាលណា ដូច្នេះហើយ ទ្រង់ដោះលែងព្រះរាជាទាំងអស់ ថ្វាយបង្គំព្រះរាជាដែលចាស់ជាង ទ្រង់ផ្តងអញ្ជលីដល់ព្រះរាជាដែលក្មេងជាង ញុំាងព្រះរាជាទាំងអស់ឲ្យអត់ទោស ហើយទ្រង់បញ្ជូនទៅកាន់

ទីលំនៅរបស់ខ្លួន ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយត្រាស់ថា យ៉ាងនោះឯងភិក្ខុទាំងឡាយ ព្រះនាងមល្លិកាអាស្រ័យបញ្ញារបស់ខ្លួន ឲ្យនូវជីវិតទានដល់មហាជន ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនព្រះនាងក៏បានប្រទានហើយដូចគ្នា ហើយទ្រង់ប្រជុំរឿងអតីតថា ព្រះបាទពារាណសីក្នុងកាលនោះ បានជាព្រះបាទបសេនទិកោសល ព្រះនាងធម្មទិន្នាទេវី បានជាព្រះនាងមល្លិកា រុក្ខទេវតា គឺតថាគតនេះឯង ។ កាលទ្រង់ប្រជុំអតីតនិទានយ៉ាងនោះហើយ កាលទ្រង់សម្តែងធម៌ទៀត ទើបត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ឈ្មោះថា បាណាតិបាត ជាទោស មិនសមគួរដែលបុគ្គលគប្បីធ្វើ ព្រោះថា បុគ្គលអ្នកសម្លាប់សត្វជាប្រក្រតី រមែងសោយសោកអស់កាលយូរ ទើបត្រាស់ព្រះគាថានេះថា

បើសត្វទាំងឡាយគប្បីដឹងយ៉ាងនេះថា ជាតិសម្ភវៈនេះ ជាទុក្ខ សត្វមិនគប្បីសម្លាប់សត្វឡើយ ព្រោះថា អ្នកសម្លាប់សត្វជាប្រក្រតី រមែងសោយសោក ។

រឿង អញ្ញតរបុរស ចប់

រឿង សទ្ធិវិហារិកវត្តរបស់ព្រះមហាកស្សបត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធសទ្ធិវិហារិករបស់ព្រះមហាកស្សបៈ ត្រាស់ព្រះធម្មទេសនានេះថា **ចរញ្ចេ នាធិគច្ឆេយ្យ** ជាដើម ។

ទេសនាតាំងឡើងនៅក្នុងក្រុងរាជគ្រឹះ ។ បានឮថា សទ្ធិវិហារិកពីរូប ឧបជ្ឈាកព្រះថេរៈ ដែលអាស្រ័យក្រុងរាជគ្រឹះ ក្នុងបិប្ផលិគុហា ។ បណ្តាភិក្ខុពីរូបនោះ មួយរូបធ្វើវត្តដោយគោរព មួយរូបសម្តែងវត្តដែលភិក្ខុនោះធ្វើហើយ ដូចខ្លួនធ្វើ ជីងកាពដែលទឹកលប់មុខ និងឈើសូនដែលភិក្ខុនោះចាត់ចែងហើយ ទើបសួរព្រះថេរៈថា ទឹកលប់មុខ និងឈើសូន ខ្ញុំចាត់ចែងហើយ សូមលោកម្ចាស់ប្រើប្រាស់ចុះ ។ សូម្បីក្នុងការធ្វើកិច្ច មានការលាងជើង និងស្រង់ទឹកជាដើម ក៏រមែងប្រាប់យ៉ាងនោះដូចគ្នា ។

ភិក្ខុក្រៅអំពីនេះគិតថា ភិក្ខុនេះបង្ហាញវត្តដែលអញធ្វើហើយ ហាក់ដូចជាខ្លួនធ្វើហើយអស់កាលជានិច្ច ណ្ហើយចុះ សេចក្តីនេះអញនឹងធ្វើវត្តដែលគួរធ្វើជូលោក ។ កាលភិក្ខុនោះឆាន់ហើយសិងលក់នោះឯង ជាំទឹកងូតហើយដួសជាក់ក្នុងឆ្នាំងមួយ តាំងទុកខាងក្រោយទីសម្រាប់ងូត តែបន្សល់ទឹកទុកក្នុងភាជនៈដែលជាំនោះ ប្រមាណមួយត្រឡោក ហើយទុកឲ្យផុតចំហាយ ។

ក្នុងវេលាល្ងាច ភិក្ខុមួយទៀតភ្ញាក់ឡើង ឃើញចំហាយទឹកហុយចេញ គិតថា នឹងជាទឹកដែលភិក្ខុនោះជាំហើយតម្កល់ទុកក្នុងទីសម្រាប់ងូត រួតរះទៅថ្វាយបង្គំព្រះថេរៈហើយប្រាប់ថា ទឹកខ្ញុំតម្កល់ទុកក្នុងទីសម្រាប់ងូត សូមលោក

ម្ចាស់ស្រង់ចុះ ហើយចូលទៅកាន់ទីសម្រាប់ងូតជាមួយព្រះថេរៈ ព្រះថេរៈ កាលមិនឃើញទឹក ទើបពោលថា នែលោក ទឹកនៅឯណា ភិក្ខុកំលោះទៅកាន់ភេងភ្លើង លុកត្រឡោកចូលក្នុងភាជនៈ ដឹងភាពដែលភាជនៈទទេ ទើបពោលទោសថា សូមលោកម្ចាស់មើលកម្មរបស់ភិក្ខុក្បាលរឹង លោកលើកភាជនៈទទេដាក់លើចង្រ្កាន ហើយទៅបាត់ ខ្ញុំជ្រាប់ដោយស្មានថាទឹកមានក្នុងទីសម្រាប់ងូតដូច្នេះហើយ បានកាន់យកឆ្នាំងទៅកាន់កំពង់ទឹក ។

ចំណែកភិក្ខុក្រៅអំពីនេះ នាំយកទឹកខាងក្រោយទីសម្រាប់ងូត ហើយតាំងទុកក្នុងទីសម្រាប់ងូត ។ ព្រះថេរៈគិតថា ភិក្ខុកំលោះរូបនេះពោលថា ទឹកខ្ញុំដាំតម្កល់ទុកក្នុងទីសម្រាប់ងូតហើយ សូមលោកម្ចាស់ស្រង់ចុះ ឥឡូវនេះពោលទោស កាន់យកឆ្នាំងទទេទៅកាន់កំពង់ទឹក ហេតុនេះដូចម្តេចហ្ន៎ ពិចារណាមើល ក៏ដឹងថា ភិក្ខុកំលោះរូបនោះ ប្រកាសកិច្ចវត្តដែលភិក្ខុនេះធ្វើហើយ ហាក់ដូចជាខ្លួនធ្វើហើយអស់កាលប៉ុណ្ណោះ បានឱ្យឱវាទដល់លោកដែលមកអង្គុយក្នុងពេលល្ងាចថា លោក ឈ្មោះថាភិក្ខុពោលកិច្ចដែលខ្លួនធ្វើហើយនោះឯងថា ខ្ញុំធ្វើហើយរមែងគួរ នឹងពោលកិច្ចដែលខ្លួនមិនបានធ្វើថាជាកិច្ចដែលខ្លួនធ្វើហើយ មិនគួរឡើយ ឥឡូវនេះ អ្នកពោលថា ទឹកខ្ញុំតម្កល់ទុកក្នុងទីសម្រាប់ងូត សូមលោកម្ចាស់ស្រង់ចុះ កាលខ្ញុំទៅឈរកាន់ឆ្នាំងទឹកពោលទោសអ្នកដទៃ ឈ្មោះថា បព្វជិតធ្វើយ៉ាងនោះ រមែងមិនគួរ ។

ភិក្ខុនោះពោលថា លោកទាំងឡាយ ចូរលោកមើលកម្មរបស់ព្រះថេរៈ ព្រះថេរៈអាស្រ័យហេតុត្រឹមតែទឹក ទើបពោលនឹងខ្ញុំយ៉ាងនេះ ក្រោធហើយ

ក្នុងថ្ងៃស្អែកឡើង មិនចូលទៅបិណ្ឌបាតជាមួយព្រះថេរៈ ។ ព្រះថេរៈទៅកាន់ប្រទេសមួយកន្លែងជាមួយភិក្ខុក្រៅអំពីនេះ ។ កាលព្រះថេរៈទៅហើយ ភិក្ខុនោះទៅកាន់ត្រកូលឧបដ្ឋាករបស់ព្រះថេរៈ ត្រូវឧបដ្ឋាកសួរថា ព្រះថេរៈនិមន្តទៅណា ទើបភិក្ខុនោះប្រាប់ថា ការមិនផាសុកកើតដល់ព្រះថេរៈ លោកគង់ក្នុងវិហារនោះឯង ។ ឧបដ្ឋាកពោលថា បានអ្វីប្រគេនលោក ទើបសមគួរ ភិក្ខុនោះពោលថា អ្នកទាំងឡាយ ចូរឲ្យអាហារឈ្នោះនេះ ។

ឧបដ្ឋាកទាំងឡាយ បានចាត់ចែងតាមទំនង ដែលភិក្ខុពោលនោះឯង ប្រគេនហើយ ។ ភិក្ខុនោះ ឆាន់អាហារនោះតាមផ្លូវទៅកាន់វិហារហើយ ។

ចំណែកព្រះថេរៈ បានសំពត់សាច់ល្អិតមួយផ្ទាំងធំក្នុងទីដែលទៅហើយ ក៏បានឲ្យដល់ភិក្ខុកំលោះ ដែលទៅជាមួយលោក ។ ភិក្ខុកំលោះនោះ ជ្រលក់សំពត់នោះហើយ បានធ្វើជាសំពត់សម្រាប់ដណ្តប់របស់ខ្លួន ។ ក្នុងថ្ងៃស្អែកឡើង ព្រះថេរៈទៅកាន់ត្រកូលឧបដ្ឋាកនោះ ។ កាលពួកឧបដ្ឋាកពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំបានឮថា ការមិនផាសុកកើតដល់លោកម្ចាស់ ទើបរៀបចំអាហារផ្ញើទៅ ដោយទំនងដែលភិក្ខុកំលោះពោលហើយនោះឯង ផាសុកកើតដល់លោកម្ចាស់ ព្រោះឆាន់ហើយឬ ព្រះថេរៈក៏ស្ងៀមនៅ ហើយនិមន្តទៅកាន់វិហារ ពោលនឹងភិក្ខុកំលោះនោះ ដែលថ្វាយបង្គំហើយ អង្គុយក្នុងពេលល្ងាចយ៉ាងនេះថា នែលោក បានឮថា មរ្យែលមិញ្ញនេះ លោកធ្វើកម្មឈ្នោះនេះ កម្មនេះ មិនសមគួរដល់បព្វជិតទាំងឡាយ បព្វជិតធ្វើវិញ្ញត្តិហើយឆាន់ រមែងមិនគួរ ។

កិក្ខុនោះក្រោធហើយ ចង់អាឃាតក្នុងព្រះថេរៈថា ថ្ងៃមុនព្រះថេរៈអាស្រ័យ ហេតុត្រឹមតែទឹក ធ្វើអញឲ្យជាមនុស្សនិយាយកុហក ក្នុងថ្ងៃនេះ ព្រោះអញ បរិភោគភត្តមួយក្តាប់ក្នុងត្រកូលរបស់ខ្លួន ទើបពោលនឹងអញថា បព្វជិតធ្វើ វិញ្ញត្តិបរិភោគមិនគួរ ឯសំពត់ លោកក៏ឲ្យដល់កិក្ខុដែលបម្រើលោកប៉ុណ្ណោះ ឱ កម្មរបស់ព្រះថេរៈធ្ងន់ អញនឹងដឹងវត្តដែលគួរធ្វើដល់ព្រះថេរៈនោះ ក្នុងថ្ងៃ ស្អែកទៀង កាលព្រះថេរៈចូលទៅកាន់ស្រុក ខ្លួនលោកស្នាក់នៅក្នុងវិហារ ចាប់ ដំបងវាយវត្តទាំងឡាយ មានភាជនៈសម្រាប់ប្រើប្រាស់ជាដើម ហើយដុតភ្លើង ត្រង់បណ្ណសាលារបស់ព្រះថេរៈ វត្តណាភ្លើងមិនឆេះ យកដំបងវាយបំបែក វត្តនោះ ហើយចៀសចេញទៅ ធ្វើកាលកិរិយាហើយកើតក្នុងអវីចិមហានរក ។ មហាជនលើករឿងសន្ធនាគ្នាថា បានឮថា សទ្ធិវិហារិករបស់ព្រះថេរៈ មិន អត់ធន់ហេតុត្រឹមតែការពោលទូន្មាន ទើងក្រោធ ដុតបណ្ណសាលាហើយ ចៀសចេញទៅ ។

សម័យក្រោយមក កិក្ខុមួយរូបចេញអំពីក្រុងរាជគ្រឹះ ប្រាថ្នានឹងគាល់ ព្រះសាស្តា ទៅដល់វត្តជេតពន ថ្វាយបង្គំព្រះសាស្តា កាលព្រះសាស្តាទ្រង់ ធ្វើបដិសណ្ឋារៈហើយ ត្រាស់សួរថា អ្នកមកអំពីណា កិក្ខុនោះទូលថា បពិត្រ ព្រះអង្គ ខ្ញុំព្រះអង្គមកអំពីក្រុងរាជគ្រឹះ ព្រះសាស្តាត្រាស់ថា មហាកស្សបៈ បុត្រតថាគតនៅដោយសប្បាយឬ កិក្ខុនោះឆ្លើយថា បពិត្រព្រះអង្គ សប្បាយ តែសទ្ធិវិហារិករបស់លោកមួយរូប ក្រោធដោយហេតុត្រឹមតែការប្រៀនប្រដៅ ដុតបណ្ណសាលា ហើយចៀសចេញទៅ ។

ព្រះសាស្តាត្រាស់ថា ភិក្ខុនោះស្តាប់ឱវាទហើយ ខឹងក្រោធក្នុងឥឡូវនេះ ប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ក្រោធហើយដូចគ្នា ភិក្ខុនោះប្រទូស្តកុដិក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន ក្នុងកាលមុនក៏ប្រទូស្តហើយដូចគ្នាដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ។ សត្វគ្រេនគ្រោងមួយ ធ្វើសម្បុកក្នុងហេមវន្តប្បទេសសម័យមួយ កាលភ្លៀងកំពុងធ្លាក់ ស្វាមួយញ័រចំប្រប់ព្រោះរងា បានទៅកាន់ប្រទេសនោះ ។ គ្រេនគ្រោងឃើញស្វានោះ ទើបពោលគាថានេះថា

នែពានរ ក្បាល ដៃ និងជើងរបស់អ្នក ដូចជាមនុស្សដែរ
តែព្រោះហេតុអ្វី បានជាផ្ទះរបស់អ្នកគ្មាន ។

ស្វានោះគិតថា ដៃ និងជើងរបស់អញមានក៏ពិត តែអញពិចារណាហើយ គប្បីធ្វើផ្ទះដោយបញ្ញាណា បញ្ញារបស់អញនោះមិនមាន ប្រាថ្នានឹងប្រកាសសេចក្តីនោះ ទើបពោលគាថានេះថា

នែគ្រេនគ្រោង ក្បាល ដៃ និង ជើងរបស់ខ្ញុំ ដូច
មនុស្សមែនហើយ តែប្រាជ្ញាណាដែលបោពាណាចារ្យពោល
ថា ប្រសើរក្នុងពួកមនុស្ស ប្រាជ្ញានោះរបស់ខ្ញុំមិនមានទេ ។

លំដាប់នោះ គ្រេនគ្រោងតិះដៀលស្វានោះថា ការនៅគ្រប់គ្រងផ្ទះ នឹងសម្រេចដល់អ្នកបានដូចម្តេច ទើបពោលពីរគាថាថា

ធម្មតាអ្នកមានចិត្តមិននឹងនួន មានចិត្តរបុិលរបួច ជាអ្នកប្រទូស្ត ចំពោះមិត្ត មានមារយោទមិនទៀងជានិច្ច តែងមិនមានសេចក្តីសុខ ។

នៃពានវ អ្នកនោះ ចូរធ្វើនូវអានុភាព (ឲ្យកើតបញ្ញា) ចូរផ្ទាស់មារយោទចេញ ចូរធ្វើខ្លួនជាគ្រឿងការពារនូវត្រជាក់ និងខ្យល់ ។

ស្វាគិតថា គ្រលេងគ្រលោងនេះ ធ្វើអញឲ្យជាអ្នកមានចិត្តមិនមាំទាំ មានចិត្តស្រាល ច្រើនដោយការទ្រុស្តមិត្ត មានប្រក្រតីមិនស្ថិតស្ថេរ ។ ឥឡូវនេះ អញនឹងសម្តែងភាពដែលអញ ច្រើនដោយភាពជាអ្នកទ្រុស្តមិត្តចំពោះវា ទើបបោចសម្បុកបោះចោលហើយ ។ គ្រលេងគ្រលោង កាលស្វានោះចាប់បោចសម្បុកនោះឯង គេចទៅដោយចំណែកម្ខាងហើយ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ស្វាក្នុងកាលនោះបានជាភិក្ខុប្រទូស្តកុដិក្នុងកាលឥឡូវនេះ គ្រលេងគ្រលោងគឺកស្សបៈ ។ កាលទ្រង់សមោធានជាតកហើយ ទើបត្រាស់ថា យ៉ាងនោះឯង ភិក្ខុទាំងឡាយ ភិក្ខុនោះប្រទូស្តកុដិក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែនសូម្បីក្នុងកាលមុន ភិក្ខុនោះក្រោធព្រោះឱវាទហើយ ក៏ប្រទូស្តកុដិហើយដូចគ្នា ការនៅរបស់កស្សបៈ បុត្រតថាគតម្នាក់ឯងប៉ុណ្ណោះ ល្អជាងការនៅរួមជាមួយនឹងបុគ្គលពាលបែបនោះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ

ឯកចរិយំ ទឡ្ហំ កយិរា ឧត្តិ ពាលេ សហាយតា ។

បុគ្គលកាលស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯងឲ្យ ខ្ជាប់ខ្ជួនវិញ ព្រោះថា សហាយ-តាគុណ មិនមានក្នុងបុគ្គលពាលឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ចរំ** *បណ្ឌិតគប្បីជ្រោបការត្រាច់ទៅដោយចិត្ត មិនទាក់ទងដោយការត្រាច់ទៅដោយឥរិយាបថ អធិប្បាយថា កាលស្វែងរកកល្យាណមិត្ត ។*

ជាទព្រះគាថាថា **សេយ្យំ សទិសមត្តនោ** *សេចក្តីថា បើមិនបានសម្វាញ់ដែលក្រៃលែងជាង ឬស្មើគ្នាដោយគុណ គឺសីល សមាធិ បញ្ញារបស់ខ្លួន ។*

បទថា **ឯកចរិយំ** *សេចក្តីថា ក្នុងសម្វាញ់ទាំងនោះ បុគ្គលកាលបានសម្វាញ់ដែលល្អជាង រមែងចម្រើនដោយគុណទាំងឡាយ មានសីលគុណជាដើម កាលបានសម្វាញ់ស្មើគ្នា រមែងមិនវិនាសចាកគុណទាំងឡាយ មានសីលជាដើមឡើយ តែកាលនៅដោយរួមគ្នាជាមួយសម្វាញ់ល្អហើយ ធ្វើការសម្គោគនិងបរិភោគ ដោយភាពជាពួកតែមួយ រមែងវិនាសចាកគុណទាំងឡាយ មានសីលជាដើម ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ពាក្យនេះថា បុគ្គលបែបនោះ ដែលបណ្ឌិតមិនគប្បីសេព មិនគប្បីគប់រក មិនគប្បីចូលទៅអង្គុយជិត រៀរតែការអាណិត រៀរតែការអនុគ្រោះ ។*

ព្រោះហេតុនោះ បើបុគ្គលអាស្រ័យភាពករុណាគិតថា បុគ្គលនេះអាស្រ័យអញ នឹងចម្រើនដោយគុណទាំងឡាយ មានសីលគុណជាដើម មិនប្រាថ្នាការតបស្នង នៅដោយវត្ថុណាមួយអំពីបុគ្គលនោះ ឈ្មោះថារមែងសង្គ្រោះបុគ្គលនោះបាន ការអាស្រ័យសេចក្តីករុណា សង្គ្រោះដូច្នេះនោះជាការល្អ បើមិនអាចសង្គ្រោះបាន គប្បីធ្វើការត្រាច់ទៅម្នាក់ឯងឲ្យមាំទាំ គឺធ្វើនូវភាពជាបុគ្គលម្នាក់ឯងប៉ុណ្ណោះឲ្យមាំទាំ នៅតែម្នាក់ឯងក្នុងឥរិយាបថទាំងពួង ។

សួរថា ព្រោះហេតុអ្វី ឆ្វើយថា ព្រោះសហាយតាគុណ រមែងមិនមានក្នុងជនពាល អធិប្បាយថា ចុល្លសីល មជ្ឈិមសីល មហាសីល កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាគុណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ ឈ្មោះថា សហាយតាគុណ សហាយតាគុណនេះ មិនមានព្រោះអាស្រ័យបុគ្គលពាល ។

ក្នុងកាលចប់ទេសនា អាគន្តុកភិក្ខុសម្រេចសោតាបត្តិផលហើយ ជនដទៃជាច្រើន ក៏សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាបានប្រព្រឹត្តទៅដោយប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

រឿង សធ្ទិវិហារិការបស់ព្រះមហាកស្សបត្ថេរ ចប់

រឿង អានន្ទសេដ្ឋី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធអានន្ទសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះថា **បុត្តា មត្ថិ ធនមត្ថិ** ជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថី សេដ្ឋីឈ្មោះអានន្ទ មានសម្បត្តិប្រមាណ ៨០ កោដិ ជាបុគ្គលកំណាញ់ច្រើន អានន្ទសេដ្ឋីនោះ ឲ្យញាតិប្រជុំគ្នារៀងរាល់កន្លះខែហើយ ទូន្មានកូនរបស់ខ្លួនឈ្មោះមូលសិរី ក្នុងបីពេលយ៉ាងនេះថា អ្នកកុំធ្វើសេចក្តីសម្គាល់ថា ទ្រព្យ ៤០ កោដិនេះច្រើន អ្នកមិនគួរឲ្យទ្រព្យដែលមាន គួរញ៉ាំងទ្រព្យថ្មីឲ្យកើតឡើង ព្រោះកាលបុគ្គលធ្វើកហាបណៈមួយឲ្យវិនាសទៅ ទ្រព្យ រមែងអស់ដូចគ្នា ព្រោះហេតុនោះ

បុគ្គលអ្នកឈ្លាស គប្បីឃើញការអស់នៃថ្នាំ សម្រាប់បន្តក់ភ្នែក ការចម្រើននៃដំបូកកណ្តៀរទាំងឡាយ និងការប្រមូលមកនៃឃ្មុំទាំងឡាយ គប្បីនៅគ្រប់គ្រងផ្ទះ ។

សម័យដទៃមកទៀត អានន្ទសេដ្ឋីនោះមិនបានប្រាប់កំណប់ទ្រព្យធំ ៥ កន្លែងរបស់ខ្លួនដល់កូន អាស្រ័យទ្រព្យ មានការសៅហ្មងព្រោះមន្ទិល គឺសេចក្តីកំណាញ់ ធ្វើកាលកិរិយាហើយ បដិសន្ធិក្នុងផ្ទៃរបស់ស្រីចណ្ឌាលម្នាក់ ក្នុងពួកចណ្ឌាលមួយពាន់ត្រកូល ដែលនៅអាស្រ័យក្នុងស្រុក ជិតទ្វារនគរមួយកន្លែងនៃនគរនោះឯង ។ ព្រះរាជាទ្រង់ជ្រាបការធ្វើកាលកិរិយារបស់អានន្ទសេដ្ឋីហើយ បញ្ជាឲ្យហៅមូលសិរីដែលជាកូនរបស់គាត់មក ទ្រង់

តែងតាំងក្នុងតំណែងសេដ្ឋី ។

ត្រកូលនៃមនុស្សចណ្ឌាលមួយពាន់នោះ ធ្វើការងារស៊ីឈ្នួលមួយពួកនោះឯងរស់នៅ ចាប់តាំងពីបដិសន្ធិរបស់ទារកនោះ មិនបានឈ្នួល ទាំងមិនបានសូម្បីដុំបាយ ច្រើនជាងអាហារដែលល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ។ ជនទាំងនោះពោលថា ឥឡូវនេះ យើងទាំងឡាយធ្វើការងារ មិនបានអាហារត្រឹមតែដុំបាយ ស្រីកាឡកិណីគប្បីមានក្នុងវាងពួកយើងទាំងឡាយ ដូច្នេះហើយ ទើបចែកគ្នាជាពីរពួកបន្តៗ រហូតញែកមាតាបិតារបស់ទារកនោះនៅដោយឡែក ដេញមាតារបស់ទារកនោះចេញដោយគិតថា មនុស្សកាឡកិណីកើតក្នុងត្រកូលនេះ ។ ទារកនោះនៅក្នុងផ្ទៃរបស់ស្រីនោះជរាបណា ស្រីនោះបានអាហារ ត្រឹមតែញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយផុតផើយជរាបនោះ រហូតដល់ពេលប្រសូតហើយ ។

ទារកនោះមានដៃនិងជើង ក្អែក ត្រចៀក ត្រមុះនិងមាត់មិនតាំងនៅក្នុងទីតាមប្រក្រតី ។ ទារកនោះប្រកបដោយការវិកលនៃអាវយវៈបែបនោះ មានរូបគួរខ្ពើមពន់ពេក ដូចបិសាចប្រឡាក់ធូលី ។ កាលបើដូច្នេះ មាតាក៏មិនលះបុត្រនោះ ។ ពិតហើយ ម្ចាយ មានការជាប់ជំពាក់ជាកម្មាំងក្នុងបុត្រដែលនៅក្នុងផ្ទៃ នាងចិញ្ចឹមទារកនោះដោយភាពខ្វះខាត ក្នុងថ្ងៃដែលនាំកូននោះទៅមិនបានរបស់អ្វីឡើយ ក្នុងថ្ងៃដែលឲ្យកូននោះនៅផ្ទះ ហើយទៅម្នាក់ឯងនោះឯង ទើបបានថ្លៃឈ្នួល ។

សម័យតមក ក្នុងកាលទារកនោះអាចដើរទៅដើម្បីដុំបាយចិញ្ចឹមខ្លួនបាន

នាងដាក់អំបែងលើដៃហើយ ពោលនឹងបុត្រនោះថា ពុកម៉ែអាស្រ័យឯង ទើបដល់នូវសេចក្តីលំបាកខ្លាំង ឥឡូវនេះ ម៉ែមិនអាចចិញ្ចឹមឯងបាន អាហារ-វត្ថុទាំងឡាយ មានបាយជាដើម ដែលគេរៀបចំដើម្បីមនុស្សទាំងឡាយ មានមនុស្សកំព្រា និងមនុស្សជើរផ្លូវជាដើម មាននៅក្នុងនគរនេះ ឯងចូរដើរទៅដើម្បីភិក្ខាក្នុងនគរនោះចិញ្ចឹមជីវិតចុះ ដូច្នេះហើយ លែងបុត្រនោះទៅ ។ ទារកនោះត្រាច់ទៅតាមលំជាប់ផ្ទះ ដល់ទីដែលខ្លួនកើតក្នុងកាលជាអានន្ទសេដ្ឋី ហើយ ជាអ្នកវព្វកជាតិបាន ចូលទៅកាន់ផ្ទះរបស់ខ្លួន ។ បុគ្គលណាម្នាក់មិនបានសង្កេតកុមារនោះក្នុងខ្លោងទ្វារទាំង ៣ ក្នុងខ្លោងទ្វារទី ៤ ពួកកូនរបស់មូលសិរិសេដ្ឋីនោះឃើញ មានចិត្តភ័យខ្លាចស្រែកយំហើយ លំជាប់នោះ ពួកបុរសរបស់សេដ្ឋីពោលនឹងទារកនោះថា ឯងចូរចេញទៅ មនុស្សកាឡកិណី វាយបណ្តើរ នាំចេញទៅចោះត្រង់គំនរសំរាម ។

ព្រះសាស្តា មានព្រះអានន្ទត្ថេរជាបច្ឆាសមណៈ ទ្រង់បិណ្ឌបាតដល់ទីនោះហើយ ទតមើលព្រះថេរៈ ព្រះថេរៈទូលសួរហើយ ត្រាស់ប្រាប់ព្រឹត្តិការណ៍នោះ ព្រះថេរៈនោះបានឲ្យមូលសិរិសេដ្ឋីមកហើយ ពួកមហាជនប្រជុំគ្នាហើយ ។ ព្រះសាស្តាត្រាស់ហៅមូលសិរិសេដ្ឋីមកហើយ ត្រាស់សួរថា អ្នកស្គាល់ទារកនោះដែរឬទេ មូលសិរិសេដ្ឋីទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនស្គាល់ទេ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ទារកនោះ គឺអានន្ទសេដ្ឋី បិតារបស់អ្នក ហើយញ៉ាំងទារកនោះឲ្យប្រាប់កំណប់ទ្រព្យ ដោយព្រះតម្រាស់ថា អានន្ទសេដ្ឋី អ្នកចូរប្រាប់កំណប់ទ្រព្យធំ ៥ កន្លែងដល់កូនរបស់អ្នក ទ្រង់

ញុំងមូលសិរិសេដ្ឋីដែលមិនជឿ ឲ្យជឿហើយ ។ មូលសិរិសេដ្ឋីនោះបានដល់ព្រះសាស្តាជាសរណៈហើយ ។ ព្រះសាស្តា កាលទ្រង់សម្តែងធម៌ដល់មូលសិរិសេដ្ឋីនោះ ទើបត្រាស់ព្រះគាថានេះថា

បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ
អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោធនំ ។

ជនពាល តែងព្រួយលំបាក ដោយសេចក្តីសម្គាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន ចំណង់បើកូនទាំងឡាយនឹងរាប់ថា មានមកអំពីណាបាន ទ្រព្យ នឹងរាប់ថា មានមកអំពីណាបាន ។

សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃគាថានោះថា ជនពាលរមែងក្តៅក្រហាយដោយចំណង់ក្នុងបុត្រ និងចំណង់ក្នុងទ្រព្យថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន គឺរមែងលំបាក រមែងដល់នូវទុក្ខ គឺរមែងក្តៅក្រហាយថា កូនទាំង-ឡាយរបស់អញវិនាសហើយ រមែងក្តៅក្រហាយថា កំពុងវិនាស ។រមែងក្តៅក្រហាយថា នឹងវិនាស សូម្បីក្នុងទ្រព្យក៏មាននយដូចគ្នា ។ បុគ្គលពាលរមែងក្តៅក្រហាយដោយអាការ ៦ យ៉ាង ដោយប្រការដូច្នេះ បុគ្គលពាល សូម្បីព្យាយាមក្នុងទីទាំងឡាយ មានផ្លូវគោក និងផ្លូវទឹកជាដើម ទាំងពេលយប់ និងពេលថ្ងៃដោយប្រការផ្សេងៗ ដោយគិតថា អញនឹងចិញ្ចឹមកូនទាំងឡាយ ឈ្មោះ

ថា រមែងក្តៅក្រហាយ សូម្បីធ្វើកម្មទាំងឡាយ មានការធ្វើស្រែ និងការជួញដូរជាដើម ដោយគិតថា អញនឹងញុំាងទ្រព្យឲ្យកើតឡើង ឈ្មោះថា រមែងក្តៅក្រហាយជូចគ្នា កាលក្តៅក្រហាយយ៉ាងនេះ ខ្លួនឯងឈ្មោះថា រមែងមិនមានដល់ខ្លួន កាលបុគ្គលមិនអាចធ្វើខ្លួនឲ្យដល់នូវសេចក្តីទុក្ខ ដោយការចង្អៀតចង្អល់នោះ ឲ្យដល់នូវសុខបានក្នុងបច្ចុប្បន្នកាល ខ្លួនរបស់បុគ្គលនោះឯង ឈ្មោះថា រមែងមិនមានដល់ខ្លួន កាលបុគ្គលនោះដេកលើគ្រែសម្រាប់ស្លាប់ ត្រូវវេទនាទាំងឡាយ មានការស្លាប់ជាទីបំផុត ជុតរោលហាក់ដូចត្រូវអណ្តាតភ្លើងឆេះ កាលគ្រឿងត និងគ្រឿងចងជាប់ទៅ កាលសរីរឆ្អឹងបែកទៅ កាលបុគ្គលនោះបិទភ្នែក ឃើញលោកខាងមុខ បើកភ្នែក ឃើញលោកនេះ ខ្លួនឯងសូម្បីគេងូតឲ្យដោយទឹកមួយថ្ងៃពីរដង ឲ្យបរិភោគមួយថ្ងៃ ៣ ដង ប្រដាប់ដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម ចិញ្ចឹមហើយដរាបដល់អស់ជីវិត ឈ្មោះថា រមែងមិនមានដល់ខ្លួន ព្រោះភាពដែលខ្លួនជាអ្នកមិនអាចធ្វើគ្រឿងការពារនូវទុក្ខដោយភាពជាសម្ងាញ់បាន កូននឹងមានអំពីទីណា ទ្រព្យនឹងមានអំពីទីណា គឺក្នុងសម័យនោះ កូន ឬទ្រព្យនឹងធ្វើអ្វីបាន ។ កាលអានូសេដ្ឋីមិនឲ្យទ្រព្យអ្វីមួយ ដល់បុគ្គលណាម្នាក់ ប្រមូលទ្រព្យទុកដើម្បីប្រយោជន៍ដល់កូន ដេកលើគ្រែសម្រាប់ស្លាប់ក្នុងកាលមុនក្តី ដល់នូវទុក្ខនេះក្នុងបច្ចុប្បន្ននេះក្តី បុត្រអំពីទីណា ទ្រព្យអំពីទីណា គឺបុត្រ ឬទ្រព្យនាំទុក្ខអ្វីទៅបាន ឬឲ្យសុខអ្វីកើតឡើងបាន ។

ក្នុងកាលចប់ទេសនា ការត្រាស់ដឹងធម៌មានដល់សត្វ ៨៤០០០ ទេសនាមានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។

រឿង អានន្តសេដ្ឋី ចប់

រឿង គណ្ឋិភេទកចោរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកចោរទម្លាយកំណប ត្រាស់ព្រះធម្មទេសនានេះថា **យោ ពាលោ មញ្ញតិ ពាល្យំ** *ជាដើម ។*

បានឮថា ចោរពីរនាក់នោះជាសម្លាញ់នឹងគ្នា ទៅកាន់វត្តជេតពនជាមួយមហាជនដែលទៅដើម្បីស្តាប់ធម៌ ចោរម្នាក់បានស្តាប់ធម្មកថាហើយ ចោរម្នាក់សម្លឹងមើលរបស់ដែលខ្លួនគួរកាន់យក ។ បណ្តាចោរទាំងពីរនោះ ចោរដែលស្តាប់ធម៌សម្រេចសោតាបត្តិផលហើយ ។ ចោរម្នាក់ទៀត បានទ្រព្យប្រមាណ ៥ មាសក ដែលខ្ចប់ទុកត្រង់ជាយសំពត់របស់ឧបាសកម្នាក់ ទ្រព្យនោះបានជាថ្លៃអាហារក្នុងផ្ទះរបស់ចោរហើយ រមែងមិនសម្រេចផលក្នុងផ្ទះរបស់ចោរដែលជាសោតាបន្នក្រៅអំពីនេះ ។

គ្រានោះ ចោរជាសម្លាញ់ និងភរិយារបស់ខ្លួន កាលនឹងសើចចំអកចោរដែលជាសោតាបន្ននោះ ទើបពោលថា អ្នកមិនញ៉ាំងសូម្បីត្រឹមតែថ្លៃអាហារឲ្យសម្រេចក្នុងផ្ទះរបស់ខ្លួន ព្រោះភាពដែលខ្លួនឆ្លាតពេក ។ សម្លាញ់ដែលជា

សោតាបន្នក្រៅអំពីនេះគិតថា បុគ្គលនេះរមែងសម្គាល់ភាពដែលខ្លួនជាបណ្ឌិត ដោយភាពជាបុគ្គលពាលហ្ន៎ ដើម្បីក្រាបទូលការប្រព្រឹត្តទៅនោះដល់ព្រះសាស្តា ទើបទៅកាន់វត្តជេតពន មួយអន្ទើដោយញាតិទាំងឡាយ ក្រាបទូលហើយ ។

ព្រះសាស្តា កាលទ្រង់សម្តែងធម៌ដល់បុគ្គលនោះ ទើបត្រាស់ព្រះគាថានេះថា

យោ ពាលោ មញ្ញតី ពាល្យំ បណ្ឌិតោ វាបិ តេន សោ
ពាលោ ច បណ្ឌិតមានី ស វេ ពាលោតិ វុច្ចតិ ។

អ្នកណា ជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថាជាពាល អ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួនថាជាពាលនោះ ម្យ៉ាងទៀត អ្នកណា ជាមនុស្សពាល មានសេចក្តីប្រកាន់ថា ខ្លួនជាបណ្ឌិត អ្នកនោះឈ្មោះថា ជាមនុស្សពាលដោយពិត ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យោ ពាលោ** *សេចក្តីថា បុគ្គលណាជាមនុស្សល្ងង់ គឺមិនមែនជាបណ្ឌិត រមែងសម្គាល់ថា គឺរមែងដឹងនូវភាពដែលខ្លួនជាមនុស្សល្ងង់ គឺភាពជាបុគ្គលល្ងង់ខ្លៅនោះដោយខ្លួនឯងថា អាត្មាអញជាបុគ្គលល្ងង់ខ្លៅ ។*

ពីរបទថា **តេន សោ** *សេចក្តីថា ដោយហេតុនោះ បុគ្គលនោះ ជាបណ្ឌិតបានខ្លះ ឬដូចគ្នានឹងបណ្ឌិតបានខ្លះ ។*

បុគ្គលនោះដឹងថា អញជាមនុស្សល្ងង់ ចូលទៅរក ចូលទៅអង្គុយជិត អ្នកដទៃដែលជាបណ្ឌិត ដែលបណ្ឌិតនោះពោលប្រៀនប្រដៅ ទូន្មាន ដើម្បីប្រយោជន៍ដល់ភាពជាបណ្ឌិត រៀនយកឱវាទនោះហើយ រមែងជាបណ្ឌិត ឬជាបណ្ឌិតច្រើនជាង ។

ពីរបទថា **ស វេ ពាលោ** *សេចក្តីថា ចំណែកបុគ្គលណាជាអ្នកល្ងង់ខ្លៅជាបុគ្គលមានសេចក្តីសម្គាល់ថា ខ្លួនជាបណ្ឌិតតែម្យ៉ាងយ៉ាងនេះថា បុគ្គលដទៃណា ទោះជាពហូសូត ជាធម្មកថិកទ្រទ្រង់វិនយ មានវាទៈពោលគុណជាគ្រឿងកម្ចាត់កិលេស ដូចគ្នានឹងអាត្មាអញមាន បុគ្គលនោះមិនចូលទៅរក មិនចូលទៅអង្គុយជិតបុគ្គលដទៃដែលជាបណ្ឌិត រមែងមិនរៀនបរិយត្តទ្បើយ រមែងមិនបំពេញបដិបទា រមែងដល់នូវភាពជាបុគ្គលល្ងង់ដោយចំណែកមួយ បុគ្គលនោះរមែងដូចចោរទម្ងាយកំណួចដួច្នោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះថា* **ស វេ ពាលោតិ វុច្ចតិ ។**

ក្នុងកាលចប់ទេសនា មហាជនមួយអន្ទើដោយញាតិទាំងឡាយរបស់ចោរដែលជាសោតាបន្នក្រៅអំពីនេះ សម្រេចសោតាបត្តិផលហើយដួច្នោះឯង ៕

រឿង គណ្ឋិភេទចោរ ចប់

រឿង ព្រះឧទាយិត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះឧទាយិត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យាវជីវម្បិ ចេ ពាលោ** ជាដើម ។

បានឮថា ព្រះឧទាយិត្ថេរនោះ កាលព្រះថេរៈធំចៀសចេញទៅហើយ ទៅកាន់រោងធម្មសភាហើយ អង្គុយលើធម្មាសនៈ ។ ថ្ងៃមួយ ពួកភិក្ខុជាអាគន្តុកៈឃើញព្រះឧទាយិត្ថេរនោះហើយយល់ថា ភិក្ខុនេះប្រហែលជាព្រះមហាថេរៈដែលជាពហូសូត ទើបសួរបញ្ហាទាក់ទងដោយខន្ធជាដើមហើយ តិះដៀលលោកដែលមិនដឹងនូវព្រះពុទ្ធវចនៈណាមួយថា នេះព្រះថេរៈអ្វី នៅក្នុងព្រះវិហារជាមួយនឹងព្រះពុទ្ធ មិនចេះធម៌សូម្បីត្រឹមតែខន្ធ ធាតុ និងអាយតនៈដូច្នេះហើយ ទើបក្រាបទូលការប្រព្រឹត្តទៅនោះដល់ព្រះសាស្តា ។ គ្រានោះ ព្រះសាស្តាទ្រង់សម្តែងធម្មកថា ដល់អាគន្តុកភិក្ខុនោះ ទើបត្រាស់គាថានេះថា

យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ
ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា ។

មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិត ក៏ឥតមានដឹងរសធម៌អ្វីឲ្យច្បាស់លាស់ឡើយ ដូចវែកដែលមិនដឹងរសសម្ល ។

សេចក្តីអធិប្បាយ

គប្បីជ្រាបសេចក្តីនៃព្រះគាថានេះថា ឈ្មោះថា បុគ្គលពាល ចូលទៅ

អគ្គិយជិតបណ្ឌិតជរាបអស់ជីវិត រមែងមិនជីងបរិយត្តិធម៌យ៉ាងនេះថា នេះជា ព្រះពុទ្ធវចនៈ ព្រះពុទ្ធវចនៈមានប្រមាណប៉ុណ្ណេះ ឬនូវបដិបត្តិធម៌ និងបដិ-វេធធម៌យ៉ាងនេះថា ធម៌នេះជាគ្រឿងនៅ ធម៌នេះជាមារយាទ នេះជាគោចរកម្ម នេះប្រព្រឹត្តទៅដោយទោស កម្មនេះមិនមានទោស កម្មនេះគួរសេព កម្មនេះ មិនគួរសេព វត្តុនេះគប្បីចាក់ចុះ វត្តុនេះគួរធ្វើឲ្យជាក់ច្បាស់ ។

សួរថា ដូចអ្វី ឆ្លើយថា ដូចវែកមិនជីងរសសម្ល ដូច្នោះ អធិប្បាយថា ឧបមាដូចវែក សូម្បីមនុស្សស្ទេច្រើនប្រភេទ មានប្រការផ្សេងៗ រហូតសឹក រិចរិល រមែងមិនជីងរសសម្លថា នេះរសប្រៃ នេះរសសាប នេះរសល្វីង នេះរសក្វាវ នេះរសហឺរ នេះរសជូរ នេះរសចត់ យ៉ាងណា បុគ្គលពាល ចូលទៅអគ្គិយជិតបណ្ឌិតជរាបជល់អស់ជីវិត រមែងមិនជីងធម៌ មានប្រការ ដូចពោលហើយ ដូច្នោះដូចគ្នា ។

ក្នុងកាលចប់ទេសនា ចិត្តរបស់អាគន្តុកភិក្ខុ រួចផុតហើយចាកអាសវៈ ទាំងឡាយ ដូច្នេះឯង ។

រឿង ព្រះឧធាយិត្ថេរ ចប់

រឿង ភិក្ខុអ្នកក្រុងថាវា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកក្រុងថាវា ប្រមាណ ៣០ រូប ត្រាស់ព្រះធម្មទេសនានេះថា **មុហុត្តម្បិ ចេ វិញ្ញូ** ជាដើម ។

សេចក្តីពិស្តារថា ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងធម៌ត្រាដំបូងក្នុងព្រៃចម្ការកប្បាសដល់សម្ងាញ់ ៣០ នាក់នោះ ដែលស្វែងរកស្រី ។ ក្នុងកាលនោះសម្ងាញ់ទាំងអស់ដល់នូវភាពជាឯហិភិក្ខុ ជាអ្នកទ្រទ្រង់ចាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ សមាទានធុតង្គ ១៣ ប្រព្រឹត្តកន្លងទៅនៃកាលយូរចូលទៅគាល់ព្រះសាស្តាទៀត ស្តាប់អនមតគ្គធម្មទេសនា សម្រេចអរហត្តលើអាសនៈនោះឯង ។

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា គួរអស្ចារ្យហ្ន៎ ភិក្ខុទាំងនេះដឹងច្បាស់នូវធម៌ធាប់រួសរាន់នោះឯង ។ ព្រះសាស្តា ទ្រង់ស្តាប់កថានោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះ សូម្បីក្នុងកាលមុន ភិក្ខុទាំងនេះជាអ្នកលេង ជាសម្ងាញ់នឹងគ្នាប្រមាណ ៣០ នាក់ ស្តាប់ធម្ម-ទេសនារបស់ជ្រូក ឈ្មោះមហាតុណ្ឌិលៈ ក្នុងតុណ្ឌិលជាតក ដឹងច្បាស់នូវធម៌បានធាប់រួសរាន់នោះឯង សមាទានសីល ៥ ហើយ ព្រោះឧបនិស្ស័យនោះឯង ទើបបុគ្គលទាំងនោះសម្រេចអរហត្ត លើអាសនៈដែលខ្ជួនអង្គុយហើយនោះឯង ក្នុងកាលឥឡូវនេះ ជួបច្នេះហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់គាថានេះថា

មុហុត្តម្បិ ចេ វិញ្ញូ　　បណ្ឌិតំ បយិរុបាសតិ
ខិប្បំ ធម្មំ វិជានាតិ　　ជិវ្ហា សូបរសំ យថា ។

វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងយល់នូវធម៌ ដោយឆាប់រហ័ស ដូចអណ្តាតជីងនូវរសសម្ល ។

សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានេះថា បើវិញ្ញូជន គឺបុរសដែលជាបណ្ឌិត ចូលទៅអង្គុយជិតបណ្ឌិតជាទៃ សូម្បីតែមួយរំពេច បុគ្គលនោះរៀន សាកសួរក្នុងសម្នាក់បណ្ឌិតជាទៃនោះ ឈ្មោះថា រមែងជីងច្បាស់នូវបរិយត្តិធម៌ ដោយឆាប់រួសរាន់នោះឯង បន្ទាប់អំពីនោះ បុគ្គលនោះឲ្យបណ្ឌិតប្រាប់កម្មដ្ឋានហើយ ព្យាយាមក្នុងបដិបទាជាបណ្ឌិត រមែងជីងច្បាស់នូវលោកុត្តរធម៌ ឆាប់រួសរាន់នោះឯង ។ ដូចបុរសមានជិវ្ហាបសាទ ដែលរោគមិនរាវាំងហើយ គ្រាន់តែជាក់អាហារត្រង់ចុងអណ្តាតដើម្បីជីងរស រមែងជីងរស មានរសប្រែជាដើមដូច្នោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុជាច្រើនសម្រេចអរហត្តហើយដូច្នេះឯង ។

រឿង ភិក្ខុអ្នកក្រុងចាបា ចប់

រឿង សុប្បពុទ្ធកុដ្ឋិ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រោរព្ធបុរសរោគឃ្លង់ ឈ្មោះសុប្បពុទ្ធ ត្រាស់ព្រះធម្មទេសនានេះថា **ចរន្តិ ពាលា ទុម្មេធា** ជាដើម ។

រឿងសុប្បពុទ្ធនេះ មកហើយក្នុងគម្ពីរឧទាននោះឯង ។ ក្នុងកាលនោះ សុប្បពុទ្ធកុដ្ឋិ អង្គុយខាងចុងបរិស័ទ ស្តាប់ធម្មទេសនារបស់ព្រះដ៏មានព្រះភាគ ហើយសម្រេចសោតាបត្តិផល ប្រាថ្នានឹងក្រាបទូលគុណដែលខ្លួនបានហើយ ដល់ព្រះសាស្តា តែមិនអាចឈរមកចុះក្នុងកណ្តាលបរិស័ទ បានទៅកាន់វិហារ ក្នុងកាលមហាជនថ្វាយបង្គំព្រះសាស្តាត្រឡប់ទៅហើយ ។

ខណៈនោះ សក្កទេវរាជជ្រាបថាសុប្បពុទ្ធកុដ្ឋិនេះ ប្រាថ្នាដើម្បីនឹងធ្វើគុណ ដែលខ្លួនបានក្នុងសាសនារបស់ព្រះសាស្តាឲ្យប្រាកដ ទ្រង់ព្រះតម្រិះថា អាត្មាអញនឹងសាកល្បងសុប្បពុទ្ធកុដ្ឋិនោះ ឃាងទៅឈរក្នុងអាកាសហើយ បានត្រាស់ពាក្យនេះថា សុប្បពុទ្ធ អ្នកជាមនុស្សក្រីក្រ ជាមនុស្សទុគ៌ត ខ្ញុំនឹងឲ្យទ្រព្យរាប់មិនអស់ដល់អ្នក អ្នកចូលពោលថា ព្រះពុទ្ធមិនមែនព្រះពុទ្ធ ព្រះធម៌មិនមែនព្រះធម៌ ព្រះសង្ឃមិនមែនព្រះសង្ឃ ខ្ញុំមិនដល់នូវព្រះពុទ្ធ ខ្ញុំមិនដល់នូវព្រះធម៌ ខ្ញុំមិនដល់នូវព្រះសង្ឃ ។ លំដាប់នោះ សុប្បពុទ្ធកុដ្ឋិនោះពោលនឹងសក្កទេវរាជនោះថា អ្នកជានរណា សក្កទេវរាជពោលថា ខ្ញុំជាសក្កទេវរាជ សុប្បពុទ្ធកុដ្ឋិពោលថា អ្នកជាបុគ្គលអន្ធពាលមិនខ្វាស អ្នកជាបុគ្គលមិនសមគួរពោលជាមួយខ្ញុំ អ្នកពោលនឹងខ្ញុំថា ជាមនុស្សក្រីក្រ ជាមនុស្សទុគ៌ត ជា

មនុស្សកំព្រា ខ្ញុំមិនមែនក្រីក្រ មិនមែនទុគ៌ត ខ្ញុំជាអ្នកដល់នូវសេចក្តីសុខ មានទ្រព្យច្រើន ។

ទ្រព្យ គឺសទ្ធា ទ្រព្យ គឺសីល ទ្រព្យ គឺហិរិ ទ្រព្យ គឺឱត្តប្បៈ ទ្រព្យ គឺសុតៈ ទ្រព្យ គឺចាគៈ ទ្រព្យ គឺបញ្ញា ជាគម្រប់ ៧ ។

បុគ្គលណា ទោះស្ត្រីក្តី បុរសក្តី មានទ្រព្យទាំងនេះ អ្នកប្រាជ្ញទាំង-ឡាយ ហៅបុគ្គលនោះថា ជាអ្នកមិនទ័លក្រឡើយ ការរស់នៅរបស់បុគ្គលនោះ មិនសោះសូន្យឡើយ ។

ព្រោះហេតុនោះ អរិយទ្រព្យមាន ៧ យ៉ាងនេះ មានដល់ជនទាំងឡាយណា ជនទាំងនោះ ដែលព្រះពុទ្ធទាំងឡាយ ឬព្រះបច្ចេកពុទ្ធទាំងឡាយ មិនពោលថា ជាអ្នកក្រីក្រឡើយ ។

សក្កទេវរាជ ទ្រង់ស្តាប់ពាក្យរបស់សុប្បពុទ្ធនោះហើយ ទ្រង់លះបង់សុប្បពុទ្ធកុដ្ឋិក្នុងរវាងផ្លូវ ចូលទៅកាន់សម្នាក់របស់ព្រះសាស្តា ក្រាបទូលការឆ្លើយតបនូវពាក្យទាំងអស់នោះ ដល់ព្រះសាស្តាហើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់នឹងសក្កៈនោះថា សក្កៈដូចអ្នកវាប់រយវាប់ពាន់អង្គ ក៏មិនអាចឲ្យសុប្បពុទ្ធកុដ្ឋិពោលថា ព្រះពុទ្ធមិនមែនព្រះពុទ្ធ ព្រះធម៌មិនមែនព្រះធម៌ ឬព្រះសង្ឃមិនមែនព្រះសង្ឃបានឡើយ ។

ចំណែកសុប្បពុទ្ធ ទៅកាន់សម្នាក់ព្រះសាស្តា មានការត្រេកអរដែលព្រះសាស្តាទ្រង់ធ្វើហើយ ក្រាបទូលគុណដែលខ្លួនបានហើយដល់ព្រះសាស្តា ក្រោកអំពីអាសនៈចៀសទៅហើយ ។ ខណៈនោះ មេគោកូនខ្ចីបុះសុប្បពុទ្ធ

នោះ ដែលចៀសទៅហើយ ក្នុងកាលមិនយូរ ឲ្យអស់ជីវិតហើយ ។

បានឮថា មេគោកូនខ្ចីនោះជាយក្ខិនីម្នាក់ ជាមេគោកាឡាខ្ចូន ជនទាំង ៤ គឺកុលបុត្រឈ្មោះបុក្កុសាតិ ១ ពាហិយទារុចីរិយៈ ១ ចោរឃាតកៈឈ្មោះតម្ពាទាឋិកៈ ១ សុប្បពុទ្ធកុដ្ឋិ ១ ឲ្យជាច់ជីវិតម្នាក់មួយរយអត្តភាព ។ បានឮថា ក្នុងអតីតកាល ជនទាំងនេះជាកូនសេដ្ឋី ៤ នាក់ នាំស្រីបេសា ដែលជានគរសោភិនីម្នាក់ទៅកាន់សួនឧទ្យាន សោយសម្បត្តិ អស់មួយថ្ងៃហើយ ក្នុងវេលាល្ងាច ប្រឹក្សាគ្នាយ៉ាងនេះថា ក្នុងទីនេះមិនមានអ្នកដទៃ យើងទាំង-ឡាយ នឹងកាន់យកកហាបណៈ ១ ពាន់ និងគ្រឿងអលង្ការទាំងអស់ ដែលយើងឲ្យដល់ស្រីនេះហើយ សម្លាប់ស្រីនេះចោលតែម្តង ។ ស្រីនោះស្តាប់ពាក្យរបស់សេដ្ឋីបុត្រ ទាំងនោះហើយ គិតថា ជនទាំងនេះ មិនមានទ្វាសប្បាយជាមួយអញហើយ ឥឡូវនេះ ប្រាថ្នានឹងសម្លាប់អញ អញនឹងដឹងកិច្ចដែលគួរធ្វើដល់ជនទាំងនេះ កាលជនទាំងនោះសម្លាប់ បានធ្វើសេចក្តីប្រាថ្នាថា សូមឲ្យខ្ញុំកើតជាយក្ខិនី ដែលអាចសម្លាប់ជនទាំងនោះ ដូចដែលជនទាំងនេះសម្លាប់ខ្ញុំដូច្នោះដូចគ្នា ។

ភិក្ខុច្រើនរូប ក្រាបទូលការធ្វើកាលកិរិយារបស់សុប្បពុទ្ធនោះដល់ព្រះដ៏មានព្រះភាគ ទូលសួរថា គតិរបស់សុប្បពុទ្ធនោះដូចម្តេច ព្រោះហេតុអ្វី ទើបគាត់មានរោគឃ្លង់ ។

ព្រះសាស្តាទ្រង់ព្យាករភាពដែលសុប្បពុទ្ធនោះ សម្រេចសោតាបត្តិផលហើយ កើតក្នុងតាវត្តិង្សពិភព និងការឃើញព្រះតគរសិខីបច្ចេកពុទ្ធ ទាកស្មោះ

ទឹកមាត់ ហើយចៀសចេញទៅផ្លូវខាងឆ្វេង នេះហើយក្នុងនរកអស់កាលយូរ ដោយវិបាកដ៏សេស ជល់នូវភាពជាបុគ្គលមានរោគឃ្លង់ក្នុងកាលឥឡូវនេះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងនេះត្រាច់ធ្វើកម្ម មានផល ក្តៅក្រហាយជល់ខ្លួនឯង ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិ សម្តែងធម៌ឲ្យក្រៃលែងឡើង ទើបត្រាស់ព្រះគាថានេះថា

ចរន្តិ ពាលា ទុម្មេធា អមិត្តេនេវ អត្តនា
ករោន្តា បាបកំ កម្មំ យំ ហោតិ កដុកប្ផលំ ។

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ឬមានមុខប្រឡាក់ដោយទឹកភ្នែក ស្រែកយំទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ ឈ្មោះថា កម្មមិនល្អឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ចរន្តិ** *សេចក្តីថា ត្រាច់ធ្វើអកុសលតែម្យ៉ាង ដោយឥរិយាបថ ៤ ។*

ជនទាំងឡាយដែលមិនដឹងប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ ឈ្មោះថា ពាលក្នុងបទថា **ពាលា** *នេះ ។*

បទថា **ទុម្មេធា** *គឺមិនមានប្រាជ្ញា ។ បទថា* **អមិត្តេនេវ** *សេចក្តីថា ហាក់បីដូចបុគ្គលមានពៀរ ដែលមិនមែនមិត្រ ។ បទថា* **កដុកប្ផលំ** *សេចក្តីថា មានផលរឹង គឺមានទុក្ខជាផល ។*

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង សុប្បពុទ្ធកុដ្ឋិ ចប់

រឿង អ្នកស្រែ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអ្នកស្រែម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ន តំ កម្មំ កតំ សាធុ** ជាដើម ។

បានញ្ចថា អ្នកស្រែនោះភ្ជួរស្រែមួយកន្ទែង ដែលនៅមិនឆ្ងាយអំពីក្រុងសាវត្ថី ពួកចោរចូលទៅកាន់ព្រះនគរតាមលូទឹក ទម្ងាយខម្មង្គក្នុងត្រកូលស្តុកស្តម្ភមួយ ចូលទៅកាន់យកប្រាក់ និងមាសជាច្រើន ហើយចេញទៅតាមលូទឹកនោះឯង ។ ចោរម្នាក់បាកបញ្ជោតចោរទាំងនោះ ធ្វើថង់ដែលពេញដោយទ្រព្យមួយពាន់ ទុកត្រង់ជាយសំពត់ហើយទៅដល់ស្រែនោះ ចែកភណ្ឌៈជាមួយនឹងចោរទាំងឡាយហើយ កាន់សំពត់ដើរទៅ មិនបានកំណត់ដល់ថង់ទ្រព្យមួយពាន់ ដែលធ្លាក់អំពីបង្វេចសំពត់ ។

ក្នុងថ្ងៃនោះពេលទៀបភ្លឺ ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោក ទ្រង់ឃើញអ្នកស្រែនោះ ចូលទៅខាងក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ហើយទ្រង់ពិចារណាថា នឹងមានហេតុអ្វីហ្នឹ ទ្រង់បានឃើញហេតុនេះថា អ្នក

ស្រែនេះនឹងទៅក្ជូរស្រែអំពីព្រលឹម សូម្បីពួកម្ចាស់ទ្រព្យ ទៅតាមស្នាមជើងរបស់ចោរទាំងឡាយហើយ ឃើញថង់ដែលដាក់ទ្រព្យមួយពាន់ក្នុងស្រែ របស់អ្នកស្រែនោះហើយ នឹងចាប់អ្នកស្រែនោះ រៀរតថាគតហើយ អ្នកដទៃឈ្មោះថាជាបន្ទាល់របស់អ្នកស្រែនោះ មិនមាន សូម្បីឧបនិស្សយនៃសោតាបត្តិមគ្គរបស់អ្នកស្រែនោះក៏មាន តថាគតទៅទីនោះ គួរ ។ ចំណែកអ្នកស្រែនោះ ទៅដើម្បីក្ជូរស្រែអំពីព្រលឹម ព្រះសាស្តា មានព្រះអានន្ទត្ថេរជាបច្ចាសមណ: បានយាងទៅក្នុងទីនោះហើយ ។ អ្នកស្រែឃើញព្រះសាស្តាហើយ ទៅថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយផ្តើមក្ជូរស្រែទៀត ។ ព្រះសាស្តាមិនត្រាស់ពាក្យណាមួយជាមួយគាត់ឡើយ ទ្រង់យាងទៅកាន់ទីដែលថង់ទ្រព្យមួយពាន់ធ្លាក់ចុះ ទតថង់នោះហើយ ទើបត្រាស់នឹងព្រះអានន្ទត្ថេរថា អានន្ទ អ្នកឃើញអាសិរពិសទេ ព្រះអានន្ទត្ថេរទូលថា ឃើញព្រះអង្គ អាសិរពិសកាច អ្នកស្រែបានឮពាក្យនោះហើយ គិតថា ពេលនេះជាកាលទៅ ឬមិនមែនកាលរបស់អញបានឮថា អាសិរពិសមានក្នុងទីនោះ កាលព្រះសាស្តាត្រាស់ពាក្យមានប្រមាណប៉ុណ្ណេះ ទ្រង់យាងទៅហើយ ទើបកាន់យករំពាត់ គឺជងជន្ជូញទៅដោយតាំងចិត្តថា អញនឹងសម្លាប់អាសិរពិសនោះ ។ ឃើញថង់ដាក់ទ្រព្យមួយពាន់ គិតថា ពាក្យនោះ ជាពាក្យដែលព្រះសាស្តាត្រាស់សំដៅយកថង់ដាក់ទ្រព្យមួយពាន់នេះ ទើបកាន់យកថង់ដាក់ទ្រព្យមួយពាន់នោះត្រឡប់ទៅ ព្រោះភាពដែលខ្ជូនជាអ្នកមិនឈ្លាស ទើបញាត់ទុកក្នុងទីសមគួរមួយកន្ជែង លុបដោយធូលីហើយផ្តើមក្ជូរស្រែទៀត ។

សូម្បីពួកមនុស្ស កាលរាត្រីអស់ហើយ ឃើញកម្ចដែលពួកចោរធ្វើក្នុងផ្ទះ ទើបដើរតាមស្នាមជើងទៅដល់ស្រែនោះហើយ ឃើញទីដែលពួកចោរចែកភណ្ឌៈគ្នាក្នុងស្រែនោះ បានឃើញស្នាមជើងរបស់អ្នកស្រែហើយ ។ មនុស្សទាំងនោះទៅតាមស្នាមជើងរបស់អ្នកស្រែនោះ

ឃើញថង់ទ្រព្យដែលអ្នកស្រែរក្សាទុក កាយធូលីចេញហើយ កាន់យកថង់ទ្រព្យ គំរាមថា ឯងប្ចន់ផ្ទះហើយ ត្រាច់ទៅធ្វើជាភ្ជួរស្រែឬ រាយដោយដំបងនាំទៅបង្ហាញដល់ព្រះរាជាហើយ ។ ព្រះរាជា ទ្រង់ស្តាប់ការប្រព្រឹត្តទៅនោះហើយ ទើបបញ្ជាឲ្យប្រហារជីវិតអ្នកស្រែនោះ ។ ពួករាជបុរសចងស្ចាបសេករាយដោយផ្តៅ នាំទៅកាន់ផ្ទូវបែកជា ៤ ហើយ អ្នកស្រែនោះត្រូវរាជបុរសរាយដោយផ្តៅ មិនពោលពាក្យណាដទៃទ្បើយ ពោលតែពាក្យថា ម្នាលអានន្ទ អ្នកឃើញអាសិរពិសទេ បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឃើញ អាសិរពិសកាចដើរទៅ ។ គ្រានោះ ពួករាជបុរសសួរថា ឯងពោលពាក្យរបស់ព្រះសាស្តានិងព្រះអានន្ទត្ថេរប៉ុណ្ណោះ តើមានរឿងអ្វី អ្នកស្រែឆ្ងើយថា បើខ្ញុំបានគាល់ព្រះរាជា ទើបប្រាប់ ទើបនាំទៅកាន់សម្នាក់របស់ព្រះរាជា ក្រាបទូលការប្រព្រឹត្តទៅនោះដល់ព្រះរាជាហើយ ។

លំដាប់នោះ ព្រះរាជាត្រាស់សួរអ្នកស្រែនោះថា ព្រោះហេតុអ្វី ទើបពោលដូច្នោះ អ្នកស្រែនោះក្រាបទូលថា បពិត្រព្រះសម្ចតិទេព ខ្ញុំព្រះអង្គមិនមែនចោរទេ ហើយក៏ក្រាបទូលរឿងទាំងអស់នោះដល់ព្រះរាជា តាំងអំពីកាលដែលខ្ជួនចេញទៅដើម្បីភ្ជួរស្រែ ។ ព្រះរាជា ទ្រង់ស្តាប់ពាក្យអ្នកស្រែ

នោះហើយ ត្រាស់ថា នែអ្នក អ្នកស្រែនេះយកព្រះសាស្តាដែលជាអគ្គបុគ្គល ក្នុងលោកជាសាក្សី យើងលើកទោសដល់អ្នកស្រែមិនសមគួរ យើងនឹងដឹងវត្ថុដែលគួរធ្វើក្នុងរឿងនេះ ដូច្នេះហើយ ទ្រង់នាំអ្នកស្រែនោះ ទៅកាន់សម្នាក់របស់ព្រះសាស្តាក្នុងពេលល្ងាច ទូលសួរព្រះសាស្តាថា បពិត្រព្រះដ៏មានព្រះភាគ ទ្រង់បានយាងទៅកាន់ទីក្លែវស្រែរបស់អ្នកស្រែនោះ ជាមួយនឹងព្រះអានន្ទត្ថេរមែនឬ ព្រះសាស្តាត្រាស់ថា សូមថ្វាយព្រះពរ ពិតមែនហើយ ។ ព្រះរាជាត្រាស់ថា ទ្រង់ទតឃើញអ្វីក្នុងស្រែនោះ ព្រះសាស្តាត្រាស់ថា មហាបពិត្រតថាគតឃើញថង់ទ្រព្យមួយពាន់ ព្រះរាជាត្រាស់ថា ទតឃើញហើយ ត្រាស់ដូចម្តេច ព្រះសាស្តាត្រាស់ថា តថាគតត្រាស់ពាក្យនេះ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ បើបុរសនេះ មិនបានធ្វើការអាងបុគ្គលដូចគ្នានឹងព្រះអង្គហើយសោត គាត់នឹងមិនបានជីវិត តែគាត់ពោលពាក្យដែលទ្រង់ត្រាស់ហើយ ទើបបាននូវជីវិត ។

ព្រះសាស្តា ទ្រង់ស្តាប់ព្រះរាជតម្រាស់នោះហើយត្រាស់ថា សូមថ្វាយព្រះពរមហាបពិត្រ តថាគតពោលពាក្យមានប្រមាណប៉ុណ្ណោះហើយក៏ទៅ ការតាមក្តៅក្រហាយក្នុងកាលខាងក្រោយរមែងមាន ព្រោះធ្វើកម្មណា កម្មនោះបុគ្គលឈ្មោះថាជាបណ្ឌិតមិនគប្បីធ្វើ ដូច្នេះ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ
យស្ស អស្សុមុខោ រោទំ វិបាកំ បដិសេវតិ ។

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ឬមានមុខ ប្រឡាក់ដោយទឹកភ្នែកស្រែកយំ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ ឈ្មោះថា ជាកម្មមិនល្អទេ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **យំ កត្វា** *សេចក្តីថា បុគ្គលធ្វើកម្មណា គឺដែលអាចឲ្យកើតក្នុងអបាយភូមិទាំងឡាយ មាននរកជាដើម បានដល់ មានទុក្ខជាផល កាលតាមរឭកដល់ ឈ្មោះថា ក្តៅក្រហាយក្នុងកាលជាខាងក្រោយ គឺរមែងសោយសោកក្នុងកាលជាខាងក្រោយ ក្នុងខណៈដែលរឭកដល់ហើយ កម្មនោះដែលបុគ្គលធ្វើហើយមិនល្អ គឺមិនស្អាត បានដល់ មិនស្អាតស្អំ ។*

ពីរបទថា **យស្ស អស្សុមុខោ** *សេចក្តីថា មានមុខជោកដោយទឹកភ្នែក រមែងសោយផលកម្មណា ។*

ក្នុងកាលចប់ទេសនា ឧបាសកអ្នកស្រែសម្រេចសោតាបត្តិផលហើយ ភិក្ខុដែលប្រជុំគ្នាជាច្រើន ក៏សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងអ្នកស្រែ ចប់

រឿង សុមនមាលាការ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធមាលាការឈ្មោះសុមនៈ ត្រាស់ព្រះធម្មទេសនានេះថា **តញ្ច កម្មំ កតំ សាធុ** ជាដើម ។

បានឮមកថា មាលាការនោះផ្គត់ផ្គង់ព្រះបាទពិម្ពិសារដោយផ្កាម៉ិះ ៨ នាឡិ អំពីព្រលឹមរាល់ថ្ងៃ រមែងបានមួយថ្ងៃ ៨ កហាបណៈ ។ សម័យថ្ងៃមួយ កាលមាលាការនោះកាន់ផ្កាចូលទៅកាន់ព្រះនគរ ព្រះដ៏មានព្រះភាគ ដែលមហាភិក្ខុសង្ឃចោមរោម ទ្រង់បញ្ចេញព្រះរស្មីមានពណ៌ ៦ ចូលទៅកាន់ព្រះនគរ ដើម្បីបិណ្ឌបាត ដោយពុទ្ធានុភាពដ៏ធំ ដោយព្រះពុទ្ធលីលាដ៏ធំ ។ ពិតហើយ ក្នុងកាលខ្លះ ព្រះដ៏មានព្រះភាគ ទ្រង់បិទព្រះរស្មីដែលមាន ៦ ពណ៌ ដោយចីវរ ហើយយាងទៅដូចភិក្ខុអ្នកត្រាច់បិណ្ឌបាតជាវត្ត អង្គណាមួយអង្គ ដូចជាកាលយាងទៅទទួលអង្គុលីមាល៍ អស់ចម្ងាយផ្លូវ ៣០ យោជន៍ ក្នុងកាលខ្លះ ទ្រង់បញ្ចេញឆព្ពណ្ណរង្សី ដូចកាលយាងទៅកាន់ក្រុងកបិលវត្ថុជាដើម ក្នុងថ្ងៃនោះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ចេញឆព្ពណ្ណរង្សីអំពីព្រះសរីរៈ យាងទៅកាន់ក្រុងរាជគ្រឹះ ដោយពុទ្ធានុភាពធំ ដោយព្រះពុទ្ធលីលាធំ ។

គ្រានោះ មាលាការឃើញអត្តភាពព្រះដ៏មានព្រះភាគ ដូចគ្មានទីឆវតនៈដ៏មានតម្លៃ និងមាសដ៏មានតម្លៃ សម្ងឹងមើលព្រះសរីរៈដែលប្រដាប់ហើយដោយមហាបុរិសលក្ខណៈ ៣២ មានចំណែកលម្អដោយសិរី គឺអនុព្យញ្ជនៈ ៨០ មានចិត្តជ្រះថ្លាហើយ គិតថា អញនឹងធ្វើការបូជាដ៏ក្រៃលែង ដល់ព្រះ

សាស្តា ដូចម្តេចហ្ន៎ កាលមិនឃើញវត្ថុដទៃ ទើបគិតថា អាត្មាអញនឹងបូជាព្រះដ៏មានព្រះភាគដោយផ្កាទាំងនេះ គិតទៀតថា ផ្កាទាំងនេះជាផ្កាសម្រាប់ផ្គត់ផ្គង់ព្រះរាជាជាប្រចាំ បើព្រះរាជាទ្រង់មិនបានផ្កាទាំងនេះ គប្បីចងអញក្តី គប្បីសម្លាប់អញក្តី គប្បីបំបរបង់អញចេញចាកដែនក្តី អញនឹងធ្វើដូចម្តេចហ្ន៎ ។ គ្រានោះ ការគិតយ៉ាងនេះមានដល់មាលាការនោះថា ទោះព្រះរាជាសម្លាប់អញក្តី បណ្តេញអញចេញចាកដែនក្តី ព្រះរាជានោះ ទោះព្រះរាជទានដល់អញ គប្បីព្រះរាជទានទ្រព្យត្រឹមតែចិញ្ចឹមជីវិតក្នុងអត្តភាពនេះ ចំណែកការបូជាព្រះសាស្តា អាចដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់អញ ក្នុងកោដិកប្បជាអនេក លះបង់ជីវិតរបស់ខ្លួនដល់ព្រះសាស្តាហើយ ។ មាលាការនោះ គិតថា ចិត្តជ្រះថ្លារបស់អញមិនប្រែប្រួលដរាបណា អញនឹងធ្វើការបូជាដរាបនោះឯង ជាអ្នកត្រេកអរហើយ មានចិត្តរីករាយ និងផ្សះផ្សង់ បូជាព្រះសាស្តាហើយ ។

មាលាការនោះបូជាដូចម្តេច ដំបូងមាលាការបាចផ្កាពីរក្តាប់ឡើងទៅខាងលើនៃព្រះតថាគតមុន ។ ផ្កាពីរក្តាប់នោះ បានតាំងជាពិតានខាងលើព្រះសីសៈ គាត់បាចផ្កាពីរក្តាប់ទៀត ផ្កាពីរក្តាប់នោះ បានសំយុងចុះមកតាំងនៅខាងស្តាំព្រះហស្ត ដោយអាការមាលាចាំង ។ គាត់បាចពីរក្តាប់ទៀត ផ្កាពីរក្តាប់នោះ សំយុងចុះមកតាំងនៅខាងក្រោយព្រះបិដ្ឋិយ៉ាងនោះដូចគ្នា គាត់បាចពីរក្តាប់ទៀត ផ្កានោះសំយុងចុះតាំងនៅត្រង់ព្រះហស្តឆ្វេងយ៉ាងនោះដូចគ្នា ។ ផ្កា ៨ នាឡិ ជា ៨ ក្តាប់ ចោមរោមព្រះតថាគតក្នុងឋានៈទាំង ៤ ដោយប្រការ

ដូច្នេះ ។ មានផ្លូវល្មមជាទ្វារដើរទៅខាងមុខប៉ុណ្ណោះ ទង់ផ្តាទាំងឡាយបែរចូលទៅខាងក្នុង ត្របកចេញមកខាងក្រៅ ។ ព្រះដ៏មានព្រះភាគ ហាក់បីដូចចោមរោមដោយបន្ទះប្រាក់ យាងទៅហើយ ។ ផ្តាទាំងឡាយមិនមានចិត្ត អាស្រ័យបុគ្គលដែលមានចិត្ត មិនបែកគ្នា មិនធ្លាក់ចុះ រមែងទៅជាមួយព្រះសាស្តានោះឯង រមែងឈប់ក្នុងទីដែលទ្រង់ប្រថាប់ឈរ ។ រស្មីដូចផ្លកបន្ទោររាប់ខ្សែចេញអំពីព្រះសរីរៈរបស់ព្រះសាស្តា ។ រស្មីដែលចេញអំពីព្រះកាយនោះ ចេញទាំងខាងមុខ ទាំងខាងខ្នង ទាំងខាងស្តាំ ទាំងខាងធ្វេង ទាំងខាងលើព្រះសីស: ។ ព្រះរស្មីសូម្បីតែមួយខ្សែ មិនបាត់ទៅត្រង់ទីចំពោះព្រះភក្ត្រ រស្មីទាំងអស់ធ្វើប្រទក្សិណព្រះសាស្តា ៣ ជុំហើយ ផ្តុំជាព្រះរស្មីមានប្រមាណប៉ុនដើមត្នោតជំទង់ បាញ់ត្រង់ទៅខាងមុខតែម្យ៉ាង ។

នគរទាំងមូលភ្រាក់ផ្អើលហើយ ។ បណ្តាជន ១៨ កោដិ គឺខាងក្នុងនគរ ៩ កោដិ ខាងក្រៅនគរ ៩ កោដិ ស្ត្រី ឬបុរសសូម្បីតែម្នាក់ ឈ្មោះថា មិនកាន់យកភិក្ខាចេញទៅ មិនមាន ។ មហាជនបន្ទឺសីហនាទ ធ្វើការលើកទង់ជ្វាលារាប់ពាន់ខាងមុខព្រះសាស្តានោះឯង ។ ព្រះសាស្តា ដើម្បីធ្វើគុណរបស់មាលាការឲ្យប្រាកដ បានយាងទៅក្នុងព្រះនគរប្រមាណ ៣ គាវុធ ដោយផ្លូវដែលត្រាច់ទៅដោយស្តរនោះឯង ។ សរីរៈទាំងមូលរបស់មាលាការពេញទៅដោយបីតិទាំង ៥ មាលាការនោះ ត្រាច់ទៅជាមួយព្រះតថាគតបន្តិចប៉ុណ្ណោះ ចូលទៅខាងក្នុងពុទ្ធរស្មី ហាក់បីដូចលិចចុះក្នុងរសនៃមនោសិលា សរសើរថ្វាយបង្គំព្រះសាស្តាហើយ បានកាន់យកកំប្រោងទទេនោះឯងទៅកាន់ផ្ទះ ។

គ្រានោះ ភរិយាសួរថា ផ្ការនៅឯណា មាលាការពោលថា ខ្ញុំបួជាព្រះសាស្តាហើយ ។ ភរិយាពោលថា ឥឡូវនេះ អ្នកនឹងធ្វើដូចម្តេចចំពោះព្រះរាជា មាលាការពោលថា ព្រះរាជាសម្លាប់ខ្ញុំក្តី បណ្តេញខ្ញុំចាកដែនក្តី ខ្ញុំលះបង់ជីវិតបួជាព្រះសាស្តាហើយ ផ្ការទាំងអស់មាន ៨ ក្តាប់ បួជា ហេតុបែបនេះកើតឡើងហើយ មហាជនធ្វើការស្រែកវាប់ពាន់ គ្រាច់ទៅជាមួយព្រះសាស្តានោះ ជាសំឡេងស្រែករបស់មហាជនក្នុងទីនោះ ។

លំដាប់នោះ ភរិយារបស់គាត់ជាស្រីអន្ធពាល មិនញ៉ាំងការជ្រះថ្លាក្នុងបាដិហារ្យបែបនោះឲ្យកើត ដេរហើយពោលថា ធម្មតាព្រះរាជាទាំងឡាយជាអ្នកកាចក្រៃក្រោធហើយ ក៏នឹងធ្វើសេចក្តីវិនាសច្រើន ដោយការកាត់ដៃ និងជើងជាដើម ការវិនាសគប្បីមានដល់ខ្ញុំ ព្រោះកម្មដែលអ្នកធ្វើ នាំកូនទាំងឡាយទៅកាន់រាជត្រកូល ។ កាលព្រះរាជាហៅមកសួរថា តើមានរឿងអ្វី ទើបក្រាបទូលថា ប្តីរបស់ខ្ញុំម្ចាស់យកផ្ការសម្រាប់ទំនុកបម្រុងទ្រង់ បួជាព្រះសាស្តាហើយ មានដៃទទេមកកាន់ផ្ទះ ត្រូវខ្ញុំម្ចាស់សួរថា ផ្ការនៅឯណា ក៏ពោលពាក្យឈ្មោះនេះ ខ្ញុំជេរគាត់ហើយថា ធម្មតាព្រះរាជាទាំងឡាយជាអ្នកកាចក្រៃក្រោធតែម្តង ក៏ធ្វើនូវការវិនាសច្រើន ដោយការកាត់ដៃ និងជើងជាដើម ការវិនាសគប្បីមានដល់ខ្ញុំ ព្រោះកម្មដែលអ្នកធ្វើ ដូច្នេះហើយ ក៏ចោលគាត់មកក្នុងទីនេះ កម្មដែលគាត់ធ្វើទោះជាកម្មល្អក្តី កម្មអាក្រក់ក្តី កម្មនោះសូមជារបស់គាត់តែម្នាក់ សូមទ្រង់ជ្រាបភាពដែលគាត់ ត្រូវខ្ញុំម្ចាស់លែងលះចោលហើយ ។

ព្រះរាជាទ្រង់សម្រេចសោតាបត្តិផល ដល់ព្រមដោយសទ្ធា ជាអរិយ-សាវ័កដោយការជួបជំបូងនោះឯង ទ្រង់ត្រិះរិះថា ឱ ស្រីនេះជាអន្ធពាល មិនញ៉ាំងការជ្រះថ្លាក្នុងគុណបែបនេះឲ្យកើតឡើង ទ្រង់ធ្វើជាក្រោធត្រាស់ថា នាងនិយាយអ្វី មាលាការនោះធ្វើការបូជាដោយផ្កាសម្រាប់ទំនុកបម្រុងយើងឬ ស្រីនោះទូលថា ពិតហើយព្រះអង្គ ។ ព្រះរាជាត្រាស់ថា ល្អណាស់ ដែលនាងលះបង់គេ យើងនឹងដឹងកិច្ចដែលគួរធ្វើដល់មាលាការ ដែលជាអ្នកធ្វើការបូជាដោយផ្កាទាំងឡាយរបស់យើង ។ ទ្រង់បញ្ជូនស្រីនោះទៅហើយ ប្រញាប់យាងទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំហើយ យាងទៅជាមួយព្រះសាស្តានោះឯង ។ ព្រះសាស្តា ទ្រង់ជ្រាបការជ្រះថ្លានៃព្រះហឫទ័យរបស់ព្រះរាជានោះ ទ្រង់យាងទៅកាន់ព្រះនគរតាមវិថី ដែលត្រាច់ទៅដោយស្តួរហើយ បានយាងទៅកាន់ទ្វារនៃព្រះរាជមន្ទីរបស់ព្រះរាជា ។ ព្រះរាជាទទួលបាត្រ ទ្រង់មានបំណងយាងព្រះសាស្តាចូលទៅកាន់ព្រះរាជមន្ទីរ ។ ចំណែកព្រះសាស្តាទ្រង់បានសម្តែងព្រះអាការប្រថាប់គង់ ក្នុងលានព្រះរាជវាំងនោះឯង ។ ព្រះរាជាទ្រង់ជ្រាបព្រះអាការនោះហើយ ត្រាស់ឲ្យធ្វើបុស្បកក្នុងខណៈនោះឯង ដោយព្រះតម្រាស់ថា អ្នកទាំងឡាយ ចូរធ្វើបុស្បកដោយរហ័ស ។ ព្រះសាស្តាប្រថាប់គង់ជាមួយនឹងពួកភិក្ខុហើយ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះសាស្តាមិនចូលកាន់ព្រះរាជមន្ទីរ ឆ្លើយថា បានឮថា បរិវិតក្កយ៉ាងនេះមានដល់ទ្រង់ថា បើតថាគតចូលទៅខាងក្នុងសោត មហាជនមិនបានឃើញតថាគត គុណរបស់មាលាការនឹងមិនប្រាកដ

តែមហាជន នឹងបានឃើញតថាគតអង្គុយក្នុងលានព្រះរាជវាំង គុណរបស់មាលាការនឹងប្រាកដ ។

មែនពិត ព្រះពុទ្ធនៃយើងប៉ុណ្ណោះ ដែលអាចធ្វើគុណរបស់បុគ្គលដែលមានគុណទាំងឡាយឲ្យប្រាកដ ជនដ៏សេសកាលនឹងពោលគុណរបស់បុគ្គលមានគុណទាំងឡាយ រមែងប្រព្រឹត្តកំណាញ់ គឺដោយអម ។ បន្ទះផ្ការ ៤ បន្ទះបានតាំងនៅក្នុងទិសទាំង ៤ ហើយ ។ មហាជនចោមរោមព្រះសាស្តាហើយ ។ ព្រះរាជាទ្រង់អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយអាហារដ៏ប្រណីត ។ ក្នុងកាលស្រេចភត្តកិច្ច ព្រះសាស្តាទ្រង់ធ្វើអនុមោទនាហើយ ញុំាងកម្រាលផ្ការ ៤ ផ្ទាំង ដែលចោមរោមដោយនយមុននោះឯង ដែលមហាជនបន្ទឺសីហនាទចោមរោម ទ្រង់ទៅកាន់វិហារហើយ ព្រះរាជាជូនដំណើរព្រះសាស្តា ហើយយាងត្រឡប់ ត្រាស់ឲ្យហៅមាលាការមកហើយ សួរថា ហេតុអ្វី ទើបអ្នកបូជាព្រះសាស្តាដោយផ្ការ ដែលខ្ជួនគប្បីនាំមកដើម្បីយើង មាលាការក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំគិតថា ទោះបីព្រះរាជាសម្លាប់អញក្តី បណ្តេញអញចេញចាកដែនក្តី ដូច្នេះហើយ ទើបលះបង់ជីវិតបូជាព្រះសាស្តា ព្រះរាជាត្រាស់ថា អ្នកជាមហាបុរស ហើយព្រះរាជទានរបស់ដែលគួរឲ្យមួយមុខ ៨ៗ នៃវត្ថុទាំងនេះ គឺជីរ ៨ សេះ ៨ ទាសៈ ៨ ទាសី ៨ គ្រឿងប្រដាប់ធំ ៨ កហាបណៈ ៨ ពាន់ នារី ៨ អង្គ ដែលនាំមកអំពីរាជត្រកូល ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង និងស្រុក ៨ ។

ព្រះអានន្ទត្ថេរគិតថា ថ្ងៃនេះតាំងអំពីព្រលឹម សំឡេងសីហនាទរាប់ពាន់

និងការលើកកំណាត់សំពត់ឡើងរាប់ពាន់ រមែងប្រព្រឹត្តទៅ ។ វិបាករបស់មាលាការដូចម្តេចហ្ន៎ ។ ព្រះថេរៈនោះទូលសួរព្រះសាស្តាហើយ ។ លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះថេរៈថា ម្នាលអានន្ទ អ្នកកុំកំណត់ថា កម្មមានប្រមាណតិចដែលមាលាការនោះធ្វើហើយ ឯមាលាការនេះ លះបង់ជីវិតធ្វើការបូជាតថាគតហើយ ញុំាងចិត្តឲ្យជ្រះថ្លាក្នុងតថាគតដោយអាការយ៉ាងនេះ មិនទៅកាន់ទុគ្គតិអស់សែននៃកប្ប ដូច្នេះហើយ ត្រាស់ថា

មាលាការតាំងនៅក្នុងទេវតា និងមនុស្សទាំងឡាយ និងមិនទៅកាន់ទុគ្គតិ អស់សែនកប្ប នេះជាផលនៃកម្មនោះ ក្នុងកាលអនាគត នឹងបានជាព្រះបច្ចេក ពុទ្ធនាមថា សុមនៈ ។

ក្នុងកាលព្រះសាស្តាយាងដល់វិហារ ចូលទៅកាន់ព្រះគន្ធកុដិ ផ្ការាំងនោះធ្លាក់ចុះត្រង់មាត់ទ្វារហើយ ។

ក្នុងវេលាល្ងាច ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា ឱ កម្មរបស់មាលាការគួរអស្ចារ្យ គាត់លះបង់ជីវិតដើម្បីព្រះសម្ពុទ្ធ ដែលកំពុងគង់ព្រះជន្មនៅ ធ្វើការបូជាដោយផ្ការហើយ បាននូវរបស់ព្រះរាជទានមួយមុខ ៨ៗ ក្នុងខណៈនោះឯង ។ ព្រះសាស្តាចេញចាកព្រះគន្ធកុដិហើយ ទៅកាន់រោងធម្មសភា ដោយការយាងទៅ ៣ យ៉ាងណាមួយ ប្រថាប់គង់លើពុទ្ធាសនៈ ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ការក្តៅក្រហាយក្នុងកាល

ជាខាងក្រោយ រមែងមិនមាន សោមនស្សប៉ុណ្ណោះ រមែងកើតឡើងក្នុងខណៈដែលវេកហើយ ព្រោះបុគ្គលធ្វើនូវកម្មណា កម្មបែបនោះ បុគ្គលគួរធ្វើពិតកាលបន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ ។

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ ឬជល់នូវសេចក្តីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យំ កត្វា** សេចក្តីថា បុគ្គលធ្វើកម្មណា គឺកម្មដែលអាចញុំាងសម្បត្តិនៃទេវតា សម្បត្តិនៃមនុស្ស និងនិព្វានសម្បត្តិឲ្យកើត គឺមានសុខជាផល រមែងមិនតាមក្តៅក្រហាយដោយពិត បុគ្គលនោះឈ្មោះថា ជាអ្នកឆ្អែតហើយ ដោយកម្លាំងនៃបីតិ និងឈ្មោះថា មានចិត្តល្អដោយកម្លាំងនៃសោមនស្ស ក្នុងខណៈដែលវេកដល់រឿយៗ ជាអ្នកកើតបីតិ និងសោមនស្សក្នុងកាលតទៅ រមែងសោយផលក្នុងទិដ្ឋធម៌នោះឯង កម្មនោះដែលបុគ្គលធ្វើហើយជាកម្មល្អ គឺជាសុចរិតកម្ម បានដល់ កម្មប្រពៃ ។

ក្នុងវេលាចប់ទេសនា ការត្រាស់ដឹងធម៌មានដល់សត្វ ៨៤០០០ ហើយជួបច្នេះឯង ។

រឿង សុមនមាលាការ ចប់

រឿង ឧប្បលវណ្ណាថេរី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរីឈ្មោះ ឧប្បលវណ្ណា ត្រាស់ព្រះធម្មទេសនានេះថា **មធុវា មញ្ញតិ ពាលោ** ជាដើម ។

បានឮមកថា ព្រះថេរីនោះ បានតាំងសេចក្តីប្រាថ្នាទៀបបាទមូលរបស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ធ្វើបុណ្យទាំងឡាយអស់សែនកប្ប អានួលាទៅក្នុងទេវតា និងមនុស្ស ចុតិអំពីទេវលោក បដិសន្ធិក្នុងត្រកូលសេដ្ឋី ក្នុងក្រុងសាវត្ថី ក្នុងពុទ្ធុប្បាទកាលនេះ ។ មាតាបិតាជាក់ឈ្មោះនាងថា ឧប្បលវណ្ណា ព្រោះនាងមានពណ៌ដូចត្របកឧប្បលខៀវ សម័យតមក ក្នុងកាលដែលនាងចម្រើនវ័យហើយ ព្រះរាជា និងសេដ្ឋីទាំងឡាយក្នុងសកលជម្ពូទ្វីប បញ្ជូនបណ្ណាការទៅកាន់សម្នាក់របស់សេដ្ឋីថា សូមលោកសេដ្ឋីឲ្យធីតាដល់ខ្ញុំ ។ ឈ្មោះថា បុគ្គលមិនបញ្ជូនបណ្ណាការទៅមិនមាន ។ លំដាប់នោះ សេដ្ឋីគិតថា អញមិនអាចយកចិត្តមនុស្សទាំងឡាយបាន តែអញនឹងធ្វើឧបាយណាមួយ ។ សេដ្ឋីនោះហៅកូនស្រីមកហើយពោលថា នែនាង នាងអាចបួសដែរឬទេ ។ ពាក្យរបស់បិតាហាក់ដូចជាប្រែង ដែលចម្រាញ់ហើយរាប់រយដង ដែលគេស្រោចលើសីសៈ ព្រោះនាងមានភពជាទីបំផុត ព្រោះដូច្នោះ ទើបនាងឆ្លើយនឹងបិតាថា បពិត្រលោកឪពុក ខ្ញុំនឹងបួស ។ សេដ្ឋីធ្វើសក្ការៈដ៏ច្រើនដល់នាង ហើយនាំទៅកាន់សម្នាក់ភិក្ខុនី ហើយឲ្យបួស ។

កាលនាងបួសហើយមិនយូរ ក្នុងវារៈក្បត្រដោកទ្វារក្នុងរោងឧបោសថ

ដល់ហើយ នាងអុជប្រទីប ជោសរោងឧជោសថ ឈរកាន់យកនិមិត្តនៃអណ្តាត ប្រទីប សម្ងឹងមើលហើយមើលទៀត ញុំងឈានមានតេជោកសិណជាអារម្មណ៍ ឲ្យកើតហើយ ធ្វើឈាននោះឯងឲ្យជាបាទសម្រេចអរហត្ត មួយអន្ធើដោយ បដិសម្ភិទា និងអភិញ្ញាទាំងឡាយហើយ ។ ដោយសម័យដទៃ ព្រះថេរីនោះ ត្រាច់ចារិកទៅក្នុងជនបទ ត្រឡប់មកហើយ ចូលទៅកាន់ព្រៃអន្ធវន ។ ក្នុង កាលនោះ ព្រះសាស្តា ទ្រង់មិនទាន់ហាមការនៅព្រៃរបស់ភិក្ខុនី ។ គ្រានោះ ពួកមនុស្សធ្វើតូប ដាក់គ្រែ បាំងវាំងនន ទុកក្នុងព្រៃនោះ ដល់ព្រះថេរីនោះ ។ ព្រះថេរីចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីចេញមកហើយ ។

ចំណែកនន្ទមាណព ជាកូននៃអ៊ំរបស់ព្រះថេរីនោះ មានចិត្តប្រតិព័ទ្ធតាំង អំពីកាលព្រះថេរីនៅជាគ្រហស្ថ ស្តាប់ភាពដែលព្រះថេរីមក ទើបទៅកាន់ព្រៃ អន្ធវនមុនព្រះថេរីមកនោះឯង ចូលទៅកាន់តូប លាក់ខ្លួនក្រោមគ្រែ លុះព្រះ ថេរីមកហើយ ចូលទៅកាន់តូបបិទទ្វារអង្គុយលើគ្រែ កាលភាពងងឹតក្នុងគន្ធ ចក្ខុមិនទាន់បាត់ ព្រោះមកអំពីទីភ្ងឹ ត្រូវកម្តៅថ្ងៃខាងក្រៅ ទើបនន្ទមាណពចេញ អំពីក្រោមគ្រែ ឡើងលើគ្រែហើយ ត្រូវព្រះថេរីយាត់ថា ជនពាល អ្នកកុំវិនាស ឡើយ ជនពាល អ្នកកុំវិនាសឡើយ ចាប់បង្ខំធ្វើកម្មដែលខ្លួនប្រាថ្នាហើយ ចៀសចេញទៅ ។ កាលនោះ ផែនដីធំ ហាក់ដូចជាមិនអាចទ្រទ្រង់នូវទោស របស់មាណពបាន ក៏ប្រេះជាពីរចំណែកហើយ មាណពចូលទៅកាន់ផែនដី កើតក្នុងអវីចីមហានរកហើយ ។

ចំណែកព្រះថេរី ប្រាប់សេចក្តីនោះដល់ភិក្ខុនីទាំងឡាយហើយ ពួកភិក្ខុនី

ប្រាប់សេចក្តីនោះដល់ភិក្ខុទាំងឡាយ ពួកភិក្ខុក្រាបទូលដល់ព្រះសាស្តា ។

ព្រះសាស្តា កាលស្តាប់រឿងនោះហើយ ត្រាស់ហៅភិក្ខុទាំងឡាយមក ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ណាមួយ ជាបុគ្គលពាល កាលធ្វើកម្មលាមក ជាអ្នកត្រេកអរ ហាក់ដូចជាផ្សាយឡើង រមែងធ្វើបាន ដូចបុរសទំពាស៊ីនូវរសផ្អែម មានទឹកឃ្មុំ និងស្ករអំពៅជាដើមណាមួយ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ត្រាស់ព្រះគាថានេះថា

មធុវា មញ្ញតិ ពាលោ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតិ បាបំ អថ (ពាលោ) ទុក្ខំ និគច្ឆតិ ។

បាបមិនទាន់ឲ្យផលត្រឹមណា ជនពាលតែងសម្គាល់នូវបាបនោះថា ដូចទឹកឃ្មុំ លុះតែកាលណាបាបឲ្យផល ទើបជនពាលប្រទះនូវសេចក្តីទុក្ខក្នុងកាលណោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មធុវា** *ជាដើម សេចក្តីថា កាលបុគ្គលពាលធ្វើបាប គឺអកុសលកម្ម កម្មនោះរមែងប្រាកដដូចទឹកឃ្មុំ គឺហាក់ដូចជាផ្អែម បានដល់ ហាក់ដូចគួរប្រាថ្នា គួរពេញចិត្ត បុគ្គលពាលនោះរមែងសម្គាល់នូវបាបនោះដូចទឹកឃ្មុំ ដោយប្រការដូច្នេះ ។*

បទថា **យាវ** *គឺអស់កាលត្រឹមណា ។*

ពីរបទថា **បាបំ ន បច្ចតិ** *សេចក្តីថា បុគ្គលពាលរមែងសម្គាល់នូវបាប

នោះយ៉ាងនោះ ដរាបណាបាបមិនទាន់ឲ្យផលក្នុងទិដ្ឋធម៌ ឬក្នុងសម្បរាយភព ។

បទថា **យថា ច** សេចក្តីថា ក្នុងកាលណា កាលបុគ្គលពាលនោះត្រូវធ្វើកម្មផ្សេងៗ ក្នុងទិដ្ឋធម៌ ឬសោយទុក្ខធំក្នុងអបាយ មាននរកជាដើមក្នុងសម្បរាយភព បាបនោះ ឈ្មោះថា ឲ្យផលក្នុងកាលនោះ បុគ្គលពាលនោះ រមែងចូលដល់ គឺជួប បានដល់ បាននូវសេចក្តីទុក្ខ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

សម័យក្រោយមក មហាជនសន្ទនាគ្នាក្នុងធម្មសភាថា ព្រះខីណាស្រពទាំងឡាយ ប្រហែលជានៅត្រេកអរក្នុងកាមសុខ នៅសេពកាម ហេតុអ្វីថាមិនសេព ព្រោះព្រះខីណាស្រពទាំងនោះ មិនមែនឈើពុក មិនមែនដំបូកមានសាច់ស្រស់ ឈាមស្រស់ដូចគ្នា ព្រោះដូច្នោះ សូម្បីព្រះខីណាស្រពទាំងនោះ គង់នៅត្រេកអរក្នុងកាមសុខ នៅសេពកាម ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាដោយរឿងអ្វី កាលពួកភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះខីណាស្រពទាំងឡាយមិនត្រេកអរក្នុងកាមសុខ មិនសេពកាម ដូចតំណក់ទឹកលើស្លឹកឈូក រមែងមិនជាប់ មិនតាំងនៅ រមែងរមៀលធ្លាក់ទៅនោះឯង និងដូចគ្រាប់ស្ពៃមិនជាប់ មិនតាំងនៅត្រង់ចុងដែកស្រួច រមែងរអិលធ្លាក់ទៅដោយពិត យ៉ាងណា កាមពីរយ៉ាង រមែងមិនជ្រួតជ្រាប មិនតាំងនៅក្នុងចិត្តរបស់ព្រះខីណាស្រព ដូច្នោះ

ដូច្នេះហើយ កាលនឹងបន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះ ក្នុងព្រាហ្មណវគ្គថា

បុគ្គលណា មានចិត្តមិនបានជាប់នៅក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

អត្ថនៃព្រះគាថានេះ នឹងជាក់ច្បាស់ក្នុងព្រាហ្មណវគ្គនោះឯង ។

ព្រះសាស្តា ត្រាស់ឲ្យយាងព្រះបាទបសេនទិកោសលមកហើយ ត្រាស់ថា មហាបពិត្រ កុលធីតាទាំងឡាយក្នុងសាសនានេះ លះពួកញាតិដ៏ធំ និងគំនរនៃកោគៈច្រើនបួសហើយ រមែងនៅក្នុងព្រៃដូចកុលបុត្រទាំងឡាយដូចគ្នា បុគ្គលលាមក ត្រូវរាគៈទទឹកហើយ រមែងបៀតបៀនភិក្ខុនីទាំងនោះ ដែលនៅក្នុងព្រៃ ដោយអំណាចនៃការមើលងាយខ្លះ ដល់នូវអន្តរាយនៃព្រហ្មចរិយៈខ្លះ ព្រោះដូច្នោះ ទ្រង់គួរធ្វើលំនៅខាងក្នុងព្រះនគរដល់ភិក្ខុនីសង្ឃ ព្រះរាជាទ្រង់ទទួលថា សាធុ ដូច្នេះហើយ ឲ្យសាងលំនៅដើម្បីភិក្ខុនីសង្ឃ ត្រង់ចំណែកម្ខាងនៃព្រះនគរ ចាប់តាំងពីកាលនោះមក ពួកភិក្ខុនីរមែងនៅក្នុងចន្លោះស្រុកប៉ុណ្ណោះ ។

រឿង ឧប្បលវណ្ណាថេរី ចប់

រឿង ជម្ពុកាជីវក

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធជម្ពុកាជីវក ត្រាស់ព្រះធម្មទេសនានេះថា **មាសេ មាសេ កុសគ្គេន** ជាដើម ។

បានឮថា ក្នុងអតីតកាល ក្នុងកាលព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ កុដុម្ពិកៈម្នាក់ សាងវិហារប្រគេនដល់ភិក្ខុមួយរូបហើយ ទំនុកបម្រុងព្រះថេរៈនៅក្នុងវិហារនោះដោយបច្ច័យ ៤ ព្រះថេរៈធាន់ក្នុងផ្ទះរបស់កុដុម្ពិកៈនោះជានិច្ច ។ កាលនោះ ភិក្ខុនីណាស្រេពមួយរូប ត្រាច់បិណ្ឌបាតក្នុងពេលថ្ងៃ ដល់ទ្វារផ្ទះរបស់កុដុម្ពិកៈនោះៗ ឃើញព្រះនីណាស្រេពនោះហើយ ជ្រះថ្លាក្នុងឥរិយាបថរបស់លោក និមន្តឲ្យចូលទៅកាន់ផ្ទះអង្គាសដោយកោជនដ៏ប្រណីត ប្រគេនសំពត់សាដកផ្ទាំងធំដោយពិតថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ជ្រលក់សំពត់សាដកនេះស្បៃកជណ្តប់ចុះ ដូច្នេះហើយ ប្រាប់ថា បពិត្រលោកម្ចាស់ សក់របស់លោកម្ចាស់វែង ខ្ញុំនឹងនាំជាងកោរកាត់មក ដើម្បីប្រយោជន៍ដល់ការកោរសក់របស់លោកម្ចាស់ និងរៀបចំត្រៃដើម្បីប្រយោជន៍ដល់ការសិង កុលុបកភិក្ខុដែលធាន់ក្នុងផ្ទះជានិច្ច ឃើញសក្ការៈនោះរបស់ព្រះនីណា-ស្រេពនោះ មិនអាចញ៉ាំងចិត្តឲ្យជ្រះថ្លាបាន គិតថា កុដុម្ពិកៈនេះធ្វើសក្ការៈបែបនេះ ដល់ភិក្ខុដែលខ្លួនឃើញហើយមួយរំពេច តែមិនធ្វើដល់អញដែលធាន់ក្នុងផ្ទះជានិច្ច ដូច្នេះហើយ បានទៅកាន់វិហារ ។ សូម្បីភិក្ខុនីណាស្រេពទៅជាមួយនឹងភិក្ខុនោះឯង ជ្រលក់សំពត់សាដកដែលកុដុម្ពិកៈប្រគេន ស្បៃក

ជណ្តប់ហើយ សូម្បីកុដុម្ពិកៈនាំជាងកោរកាត់ ទៅឲ្យកោរសក់របស់ព្រះថេរៈ ឲ្យមនុស្សលាតត្រៃហើយ ពិតថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់សិង លើត្រៃនេះឯង និមន្តព្រះថេរៈទាំងពីរបួប ដើម្បីឆាន់ក្នុងថ្ងៃស្អែក ក៏ចៀសចេញទៅ ភិក្ខុម្ចាស់អាវាសមិនអាចអត់ធន់ក្នុងសក្ការៈកុដុម្ពិកៈ ដែលធ្វើដល់ព្រះខីណាស្រពនោះបាន ។

លុះដល់ពេលល្ងាច លោកទៅកាន់ទីដែលព្រះថេរៈសិងហើយ ជេរដោយអាការ ៤ យ៉ាងថា អាវុសោអាគន្តុកៈ លោកទំពាស៊ីលាមក ប្រសើរជាងបរិភោគភត្តក្នុងផ្ទះរបស់កុដុម្ពិកៈ លោកឲ្យជកសក់ដោយជាងឆ្នោត ប្រសើរជាងការកោរសក់ដោយជាងកោរកាត់ ដែលកុដុម្ពិកៈនាំមក លោកអាក្រាតកាយត្រាច់ទៅ ប្រសើរជាងការស្លៀកសំពត់សាជក ដែលកុដុម្ពិកៈឲ្យ លោកដេកលើផែនដី ប្រសើរជាងការដេកលើត្រៃដែលកុដុម្ពិកៈនាំមក ។ ចំណែកព្រះថេរៈគិតថា បុគ្គលពាលនេះកុំវិនាសព្រោះអាស្រ័យអាត្មាអញទៅយ ដូច្នេះហើយ មិនអើពើដល់ការនិមន្ត ក្រោកទៅងអំពីព្រលឹម បានទៅតាមសប្បាយហើយ ។ ចំណែកភិក្ខុម្ចាស់អាវាស ធ្វើវត្តដែលគួរធ្វើក្នុងវិហារ អំពីព្រលឹមហើយ គោះជួងដោយចុងក្រចកប៉ុណ្ណោះ ដោយសម្គាល់ថា ពេលនេះជាពេលដែលត្រាច់បិណ្ឌបាត ឥឡូវនេះ អាគន្តុកភិក្ខុកំពុងលក់ លោកគប្បីក្រាក់ដោយសំឡេងជួង ដូច្នេះហើយ ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ កុដុម្ពិកៈនោះធ្វើសក្ការៈហើយ ទន្ទឹងមើលផ្លូវព្រះថេរៈទាំងពីរ ឃើញភិក្ខុម្ចាស់អាវាសហើយសួរថា បពិត្រលោកម្ចាស់ ព្រះថេរៈទៅណា ពេលនោះភិក្ខុម្ចាស់អាវាសពោល

និងកុដុម្ពិកៈនោះថា អាវុសោកុំពោលដល់ឡើយ កុលុបកភិក្ខុរបស់អ្នកចូលកាន់បន្ទប់តូច ក្នុងពេលដែលអ្នកចេញទៅកាលពីម្សិលមិញ ឈានចុះកាន់និទ្រា កាលអាត្មាធ្វើសំឡេងបោសវិហារក្តី សំឡេងចាក់ទឹកក្នុងក្អមធាន់ និងក្អមសម្រាប់ប្រើក្តី សំឡេងជួងក្តី តាំងអំពីព្រលឹមក៏នៅតែមិនភ្រាក់ ។ កុដុម្ពិកៈគិតថា ឈ្មោះថាការដេកលក់អស់កាលមានប្រមាណប៉ុណ្ណោះ រមែងមិនមានដល់លោកម្ចាស់របស់អញ ដែលប្រកបដោយឥរិយាបថសម្បត្តិបែបនោះ តែលោកម្ចាស់រូបនេះ ពោលពាក្យណាមួយពិតប្រាកដ ព្រោះយើញអញធ្វើសក្ការៈដល់លោក ។ ព្រោះភាពដែលខ្ជូនជាបណ្ឌិត ទើបកុដុម្ពិកៈនោះនិមន្តឲ្យភិក្ខុធាន់ដោយគោរព លាងបាត្ររបស់លោកឲ្យល្អហើយ ដាក់ភោជនមានរសប្រសើរផ្សងៗ ពេញបាត្រ ហើយពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់យើញលោកម្ចាស់របស់ខ្ញុំ សូមលោកម្ចាស់ប្រគេនបិណ្ឌបាតនេះ ដល់លោកម្ចាស់នោះ ។ ភិក្ខុនោះទទួលបិណ្ឌបាតនោះហើយក៏គិតថា បើភិក្ខុនោះធាន់បិណ្ឌបាតបែបនេះសោត លោកនឹងជាប់ជំពាក់ក្នុងទីនេះប៉ុណ្ណោះ ចោលបិណ្ឌបាតនោះក្នុងរវាងផ្ទូវ ទៅកាន់លំនៅរបស់ព្រះថេរៈ សម្ថឹងមើលព្រះថេរៈនោះក្នុងទីនោះមិនបានយើញហើយ ។ ពេលនោះ សមណធម៌ដែលលោកធ្វើអស់ ២ ម៉ឺនឆ្នាំ មិនអាចរក្សាលោកបាន ព្រោះធ្វើកម្មមានប្រមាណប៉ុណ្ណោះ ក្នុងកាលអស់អាយុ លោកកើតក្នុងអវីចី សោយទុក្ខដ៏ខ្លាំងក្លាអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទ-កាលនេះ កើតក្នុងផ្ទះនៃត្រកូលដែលមានបាយ និងទឹកច្រើន ក្នុងនគររាជគ្រឹះ ។

ចាប់តាំងអំពីកាលដែលដើរបានដោយជើង កុមារនោះមិនប្រាថ្នាដើម្បី

ដេកលើដំណេក មិនប្រាថ្នាបរិភោគកត្តុ បរិភោគតែសរីរវិលញ្ជៈរបស់ខ្លួន ប៉ុណ្ណោះ ។ មាតាបិតាចិញ្ចឹមទារកនោះដោយសម្គាល់ថា កូនមិនដឹងព្រោះនៅតូច ទើបធ្វើ ។ លុះដល់ធំ បុរសនោះមិនប្រាថ្នាដើម្បីស្មៀកសំពត់ ជាអ្នកអាក្រាតកាយត្រាច់ទៅដេកលើផែនដីទំពាស៊ីតែសរីរវិលញ្ជៈរបស់ខ្លួនប៉ុណ្ណោះ ។ លំដាប់នោះ មាតាបិតារបស់គាត់គិតថា ក្មេងនេះមិនសមគួរដល់ផ្ទះនៃត្រកូលក្មេងនេះសមគួរដល់ពួកអាជីវក ដូច្នេះហើយ ទើបនាំទៅកាន់សម្នាក់នៃអាជីវកទាំងនោះ បានប្រគល់ឲ្យថា សូមលោកម្ចាស់ទាំងឡាយឲ្យក្មេងនេះបួសចុះ ។ លំដាប់នោះ អាជីវកទាំងនោះញុាំងគាត់ឲ្យបួសហើយ កាលឲ្យបួសហើយ អាជីវកទាំងនោះ ជាក់គាត់ក្នុងរណ្តៅប្រមាណត្រឹម-ក ជាក់បន្ទះក្តារលើស្មាទាំងពីរ អង្គុយលើក្តារនោះ ជកសក់ដោយជាងក្នោត ។ លំដាប់នោះ មាតាបិតារបស់គាត់ អញ្ជើញអាជីវកទាំងនោះដើម្បីធាន់ក្នុងថ្ងៃស្អែក ចៀសចេញទៅ ។ ស្អែកឡើង ពួកអាជីវកពោលនឹងអាជីវកនោះថា ចូរលោកមក ពួកយើងចូលទៅកាន់ស្រុក ។ អាជីវកនោះពោលថា សូមលោកម្ចាស់ទាំងឡាយទៅចុះ ខ្ញុំនឹងនៅក្នុងទីនេះឯង ដូច្នេះហើយ ក៏មិនប្រាថ្នា ។ គ្រានោះ អាជីវកទាំងឡាយបាន លះអាជីវកដែលពោលហើយពោលទៀត មិនប្រាថ្នានឹងទៅ ។ ចំណែកគាត់ជ្រាបភាពដែលអាជីវកទាំងនោះទៅហើយ បើកទ្វារវច្ចកុដិចុះទៅបរិភោគលាមក ពូតឲ្យជាពំនូតដោយដៃទាំងពីរ ពួកអាជីវកបញ្ជូនអាហារទៅអំពីស្រុក ដើម្បីអាជីវកនោះ គាត់មិនប្រាថ្នានូវអាហារនោះ សូម្បីត្រូវពួកអាជីវកពោលរឿយៗ ក៏ពោលថា ខ្ញុំមិនត្រូវការអាហារនេះ អាហារខ្ញុំបាន

ហើយ ។ ពួកអាជីវកសួរថា លោកបានអាហារក្នុងទីណា គាត់ឆ្លើយថា បានក្នុងទីនេះឯង ។

ក្នុងថ្ងៃទី ២-៣-៤ ត្រូវពួកអាជីវកនោះពោលច្រើនយ៉ាងនោះ ក៏នៅតែពោលថា ខ្ញុំនៅក្នុងទីនេះឯង មិនប្រាថ្នាទៅស្រុក ។ ពួកអាជីវកគិតថា អាជីវកនេះមិនប្រាថ្នាចូលស្រុកវាល់ៗ ថ្ងៃ មិនប្រាថ្នាបរិភោគអាហារ ដែលពួកគេនាំមកឲ្យ ពោលថា អាហារខ្ញុំបានហើយក្នុងទីនេះឯង អាជីវកនេះធ្វើអ្វីហ្ន៎ ពួកយើងនឹងចាប់កំហុសគេ ដូច្នេះហើយ កាលចូលទៅកាន់ស្រុក រៀរអាជីវកម្នាក់ ឬពីរនាក់ ដើម្បីចាំឃ្លាំមើលអាជីវកនោះ ហើយទៅ ។ អាជីវកនោះ ចូលទៅខាងក្រោយ ពួនហើយ ។ អាជីវកនោះ ដឹងភាពដែលអាជីវកទាំងនោះទៅហើយ ចុះកាន់វច្ចកុដិ បរិភោគលាមកដោយន័យមុននោះឯង ។ ពួកអាជីវកក្រៅអំពីនេះ ឃើញកិរិយារបស់គាត់ហើយ ទើបប្រាប់ដល់អាជីវកទាំងឡាយ ពួកអាជីវកស្តាប់ពាក្យនោះហើយ គិតថា ឱ កម្មធ្ងន់ហ្ន៎ បើសាវ័កបស់ព្រះសមណគោតមដ៏ឆ្ងាសោត គប្បីប្រកាសការខូចកិត្តិយសរបស់ពួកយើងថា អាជីវកទាំងឡាយស៊ីលាមក អាជីវកនេះមិនសមគួរដល់ពួកយើង ទើបបណ្តេញចេញអំពីសម្នាក់របស់ខ្លួនហើយ អាជីវកនោះ ត្រូវពួកអាជីវកទាំងនោះដេញចេញហើយ ។ មានថ្មជាមួយដុំ ដែលគេតាំងទុកក្នុងទីបន្ទោបង់ឧច្ចារៈរបស់មហាជន មានថ្មកំលើផ្ទាំងថ្មនោះ មហាជនអាស្រ័យថ្មជាទីបន្ទោបង់ឧច្ចារៈ ចូលទៅក្នុងទីនោះ បរិភោគលាមកក្នុងពេលយប់ ក្នុងកាលដែលមហាជនមកបន្ទោបង់ឧច្ចារៈ គោងដុំថ្មដោយដៃម្ខាង លើកជើងម្ខាង

ឡើងជាក់លើក្បាលជង្គង់ ឈរងើយមុខហាមាត់ ។ មហាជនឃើញហើយ ចូលទៅរក ថ្វាយបង្គំហើយ សួរថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វី ទើប លោកម្ចាស់ឈរហាមាត់ អាជីវកពោលថា ព្រោះអាត្មាមានខ្យល់ជាអាហារ អាហារដទៃរបស់អាត្មាមិនមាន ។

មហាជនពោលថា បើដូច្នោះ ព្រោះហេតុអ្វី ទើបលោកម្ចាស់លើកជើង ម្ខាងជាក់លើក្បាលជង្គង់ហើយឈរ អាជីវកពោលថា អាត្មាមានតបៈខ្ពស់ មានតបៈខ្លាំងក្លា ផែនដីត្រូវអាត្មាជាន់ដោយជើងទាំងពីរ រមែងញាប់ញ័រ ព្រោះ ដូច្នោះ ទើបអាត្មាលើកជើងម្ខាងជាក់លើក្បាលជង្គង់ឈរ ឯអាត្មាឈរតែម្យ៉ាង ញុំាងកាលឲ្យកន្លងទៅ មិនអង្គុយ មិនដេក ។

ឈ្មោះថា ពួកមនុស្សដោយច្រើន រមែងជឿតែម៉ត់តែពាក្យសម្តីប៉ុណ្ណោះ ព្រោះដូច្នោះ ទើបអ្នកដែនអង្គៈ និងដែនមគធៈដោយច្រើនល្បីថា គួរអស្ចារ្យ ពិត អ្នកមានតបៈបែបនេះមានហ្ន៎ បុគ្គលបែបនេះ ពួកយើងមិនធ្លាប់ឃើញ ដូច្នេះហើយ រមែងនាំសក្ការៈជាច្រើនទៅរាល់ៗ ថ្ងៃ ។ អាជីវកនោះពោលថា ខ្ញុំបរិភោគខ្យល់តែម្យ៉ាង មិនបរិភោគអាហារដទៃ ព្រោះកាលយើងបរិភោគ អាហារដទៃ តបៈរមែងវិនាសទៅ ដូច្នេះហើយ មិនប្រុងប្រាថ្នារបស់ណាមួយដែល ពួកមនុស្សទាំងនោះនាំមក ។ ពួកមនុស្សអង្វរវៀរៗ ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំឲ្យពួកខ្ញុំវិនាសឡើយ ការបរិភោគដែលបុគ្គលមានតបៈ ខ្លាំងក្លាដូចលោកម្ចាស់ធ្វើហើយ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បី សេចក្តីសុខដល់ពួកខ្ញុំអស់កាលយូរ ។ អាជីវកពោលថា អាត្មាមិនគាប់ចិត្ត

ដល់អាហារដទៃ តែត្រូវមហាជនបៀតបៀនដោយការអង្វរ ទើបដាក់កេសជ្ជៈ និងទឹកអំពៅជាដើម ដែលជនទាំងនោះនាំមកត្រង់ចុងអណ្តាត ដោយប្រើចុងស្បូវភ្លាំង បញ្ជូនទៅដោយពាក្យថា អ្នកទាំងឡាយ ចូរទៅចុះ ប៉ុណ្ណេះរមែងគ្រប់គ្រាន់ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយ ។ អាជីវកនោះ ជាបុគ្គលអាក្រាត បរិភោគលាមក ដកសក់ ដេកលើផែនដី ឲ្យកាលកន្លងទៅ ៥៥ ឆ្នាំ ដោយប្រការដូច្នេះ ។

ការប្រមើលមើលសត្វលោក ក្នុងពេលទៀបភ្លឺ ជាពុទ្ធកិច្ចដែលព្រះពុទ្ធទាំងឡាយ ទ្រង់មិនលះបង់ដោយពិត ព្រោះដូច្នោះ កាលព្រះដ៏មានព្រះភាគទ្រង់ពិចារណាមើលសត្វលោកក្នុងពេលទៀបភ្លឺថ្ងៃមួយ ជម្ពុកាជីវកនេះ មកប្រាកដខាងក្នុងសំណាញ់ញាណហើយ ។ ព្រះសាស្តាទ្រង់ពិចារណាថា អ្វីហ្ន៎ នឹងមាន ទ្រង់ឃើញឧបនិស្ស័យនៃអរហត្ត មួយអន្លើដោយបដិសម្ភិទារបស់អាជីវកហើយទ្រង់ជ្រាបថា អញនឹងធ្វើជម្ពុកាជីវកនោះឲ្យជាហេតុហើយ ពោលមួយគាថា ក្នុងកាលចប់គាថាសត្វ ៨៤០០០ នឹងត្រាស់ដឹងធម៌ អាស្រ័យកុលបុត្រនេះ មហាជននឹងដល់នូវការសួស្តី ដូច្នេះហើយ ក្នុងថ្ងៃស្អែកឡើង ទ្រង់យាងទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ទ្រង់ត្រឡប់អំពីបិណ្ឌបាតហើយ ត្រាស់នឹងអានន្ទត្ថេរថា អានន្ទ យើងនឹងទៅកាន់សម្នាក់របស់ជម្ពុកាជីវក ។ ព្រះអានន្ទទូលថា ទ្រង់តែមួយអង្គប៉ុណ្ណេះយាងទៅឬ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអានន្ទយ៉ាងនោះឯង តថាគតម្នាក់ឯងនឹងទៅ ។

ព្រះសាស្តា កាលត្រាស់យ៉ាងនោះហើយ ក្នុងពេលរសៀល ទ្រង់យាង

ទៅកាន់សម្នាក់របស់ជម្ពុកាជីវកនោះ ទេវតាទាំងឡាយគិតថា ព្រះសាស្តាទ្រង់យាងទៅកាន់សម្នាក់របស់ជម្ពុកាជីវកក្នុងពេលល្ងាច ឯជម្ពុកាជីវកនោះនៅលើថ្មជាគួរខ្ពើម ដែលជាទីបន្ទោបង់ឧច្ចារៈ បស្សាវៈ សៅហ្មងដោយឈើសូន់ ពួកយើងគួរឲ្យក្លៀងធ្លាក់ ដូច្នេះហើយ ទើបញ៉ាំងភ្លៀងឲ្យធ្លាក់មួយរំពេចប៉ុណ្ណោះ ដោយអានុភាពរបស់ខ្លួន ថ្មជាបានស្អាតជ្រះសចាកមន្ទិលហើយ ។ លំដាប់នោះ ទេវតាទាំងឡាយ ញ៉ាំងភ្លៀងជាវិការនៃផ្កា ៥ ពណ៌ ឲ្យធ្លាក់លើថ្មជានោះ ។ ក្នុងពេលល្ងាចព្រះសាស្តាយាងទៅកាន់សម្នាក់របស់ជម្ពុកាជីវកហើយ បានបន្ទឹព្រះសូរសៀងថា ជម្ពុកៈ ។ ជម្ពុកៈ គិតថា នរណាហ្ន៎ដ៏ងបានលំបាកហៅអញដោយពាក្យថាជម្ពុកៈ ទើបគិតថា នុ៎ះជានរណា ។ ព្រះសាស្តាត្រាស់ថា ម្នាលជម្ពុកៈ គឺតថាគត ជម្ពុកៈពោលថា មានរឿងអ្វីមហាសមណៈ ព្រះសាស្តាត្រាស់ថា ថ្ងៃនេះ ចូរអ្នកឲ្យទីលំនៅនេះដល់តថាគត ត្រឹមតែមួយយប់ចុះ ជម្ពុកៈពោលថា មហាសមណៈ ទីលំនៅក្នុងទីនេះមិនមានទេ ព្រះសាស្តាត្រាស់ថា ម្នាលជម្ពុកៈ អ្នកកុំធ្វើយ៉ាងនោះ ចូរអ្នកឲ្យលំនៅដល់តថាគតមួយយប់ចុះ ឈ្មោះថាពួកបព្វជិត រមែងប្រាថ្នាបព្វជិត ពួកមនុស្សរមែងប្រាថ្នាពួកមនុស្ស ពួកបសុសត្វរមែងប្រាថ្នាពួកបសុសត្វ ។ ជម្ពុកៈពោលថា អ្នកជាបព្វជិតឬ ព្រះសាស្តាត្រាស់ថា អើ តថាគតជាបព្វជិត ជម្ពុកៈពោលថា អើ បើលោកជាបព្វជិត ឃ្លោករបស់លោក នៅឯណា វែកសម្រាប់បក់ផ្សែងរបស់លោកនៅឯណា អំពោះសម្រាប់បូជាយញ្ញរបស់លោក នៅឯណា ។

ព្រះសាស្តាត្រាស់ថា ឃ្លោកជាដើមនោះរបស់តថាគតមាន តែការកាន់

យកជាផ្នែកៗ ត្រាច់ទៅលំបាក ព្រោះដូច្នោះ ទើបតថាគតទុកខាងក្នុងប៉ុណ្ណោះ ត្រាច់ទៅ ។ អាជីវកនោះក្រោធពោលថា លោកមិនកាន់ឃ្លោកជាដើមនោះ ត្រាច់ទៅបានឬ លំជាប់នោះ ព្រះសាស្តាត្រាស់នឹងអាជីវកនោះថា ណ្ហើយចុះ ជម្ពុក: អ្នកកុំក្រោធឡើយ ចូរអ្នកជ្រាប់លំនៅដល់តថាគតចុះ អាជីវកពោលថា មហាសមណ: ទីលំនៅក្នុងទីនេះមិនមាន ។

ព្រះសាស្តា កាលទ្រង់ចង្អុលញ្ជកមួយកន្លែង ដែលមាននៅក្នុងទីមិនឆ្ងាយអំពីលំនៅរបស់គាត់ ទើបត្រាស់ថា ញ្ជកនោះនរណានៅ ជម្ពុក: ពោលថា មហាសមណ: ញ្ជកនោះមិនមាននរណានៅឡើយ ។ ព្រះសាស្តាត្រាស់ថា បើដូច្នោះ ចូរអ្នកឲ្យញ្ជកនោះដល់តថាគត ជម្ពុក:ពោលថា មហាសមណ: ចូរលោកជីងឯងចុះ ព្រះសាស្តាទ្រង់ក្រាលនិសីទន: ប្រថាប់គង់ត្រង់ញ្ជកនោះហើយ ។

គ្រានោះ ទេវរាជទាំង ៤ ធ្វើទិសទាំង ៤ ឲ្យភ្លឺស្វាងក្នុងទិសតែមួយ មកកាន់ទីបម្រើក្នុងបឋមយាម ជម្ពុក:ឃើញពន្លឺហើយ គិតថា នុ៎ះពន្លឺអ្វីហ្ន៎ ក្នុងមជ្ឈិមយាមសក្កទេវរាជយាងមកហើយ ។ ជម្ពុក:ឃើញសក្កទេវរាជនោះ គិតថា នុ៎ះជាអ្នកណាហ្ន៎ ក្នុងបច្ឆិមយាមមហាព្រហ្ម ដែលអាចញាំងចក្កវាឡមួយឲ្យភ្លឺដោយម្រាមដៃមួយ ញាំងចក្កវាឡពីរឲ្យភ្លឺដោយម្រាមដៃពីរ ញាំងចក្កវាឡ ១០ ឲ្យភ្លឺដោយម្រាមដៃ ១០ ធ្វើព្រៃទាំងមូលឲ្យមានពន្លឺតែមួយ យាងមកហើយ ជម្ពុក:ឃើញមហាព្រហ្មនោះគិតថា នុ៎ះជាអ្នកណាហ្ន៎ ដូច្នេះហើយ ទើបទៅកាន់សម្នាក់ព្រះសាស្តាអំពីព្រលឹម ធ្វើបដិសណ្ឋារ:ហើយឈរ

ក្នុងទីសមគួរនោចំណែកម្ខាង ទូលសួរព្រះសាស្តាថា មហាសមណៈ អ្នកណាញ៉ាំងទិសទាំង ៤ ឲ្យភ្លឺស្វាងមកកាន់សម្នាក់របស់លោកក្នុងបឋមយាម ព្រះសាស្តាត្រាស់ថា ស្តេចមហារាជទាំង ៤ ជម្ពុកៈពោលថា មកព្រោះហេតុអ្វី ព្រះសាស្តាត្រាស់ថា មកដើម្បីបម្រើតថាគត ជម្ពុកៈពោលថា លោកជាបុគ្គលប្រសើរជាងស្តេចមហារាជទាំង ៤ ឬ ។

ព្រះសាស្តាត្រាស់ថា អើជម្ពុកៈ តថាគតជាព្រះរាជាប្រសើរជាងព្រះរាជាទាំងឡាយ ជម្ពុកៈសួរថា ចុះអ្នកណាមកក្នុងមជ្ឈិមយាម ព្រះសាស្តាត្រាស់ថា គឺសក្កទេវរាជ ជម្ពុកៈពោលថា មកព្រោះហេតុអ្វី ព្រះសាស្តាត្រាស់ថា ដើម្បីបម្រើតថាគតដូចគ្នា ជម្ពុកៈពោលថា លោកជាបុគ្គលប្រសើរជាងសក្កទេវរាជឬ ព្រះសាស្តាត្រាស់ថា អើជម្ពុកៈ តថាគតជាបុគ្គលប្រសើរជាងសក្កទេវរាជ សក្កទេវរាជនោះជាគិលានុប្បដ្ឋាករបស់តថាគត ដូចគ្នានឹងសាមណេរដែលជាកប្បិយការកៈ ជម្ពុកៈសួរថា ចុះអ្នកណាញ៉ាំងព្រៃទាំងមូលឲ្យភ្លឺស្វាងមកហើយក្នុងបច្ឆិមយាម ព្រះសាស្តាត្រាស់ថា ជនទាំងឡាយមានព្រាហ្មណ៍ជាដើមក្នុងលោក កណ្តាស់ហើយ ភ្លាត់ហើយរមែងពោលថា ការនមស្ការចូរមានដល់មហាព្រហ្ម អាស្រ័យបុគ្គលណា បុគ្គលនោះឯងជាមហាព្រហ្ម ជម្ពុកៈពោលថា លោកជាបុគ្គលប្រសើរជាងមហាព្រហ្មឬ ព្រះសាស្តាត្រាស់ថា អើជម្ពុកៈ តថាគតជាព្រហ្មក្រៃលែងជាងព្រហ្ម ជម្ពុកៈពោលថា មហាសមណៈ លោកជាបុគ្គលអស្ចារ្យ ខ្ញុំនៅក្នុងទីនេះអស់ ៥៥ ឆ្នាំ បណ្តាទេវតាទាំងនោះសូម្បីមួយអង្គ ក៏មិនធ្លាប់មកដើម្បីបម្រើខ្ញុំ ខ្ញុំជាបុគ្គលមានខ្យល់ជាអាហារឈរ

តែម្យ៉ាង អស់កាលមានប្រមាណប៉ុណ្ណោះកន្លងទៅហើយ ទេវតាទាំងនោះមិនធ្លាប់មកកាន់ទីបម្រើរបស់ខ្ញុំឡើយ ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងជម្ពុកៈនោះថា ជម្ពុកៈ អ្នកបោកបញ្ឆោតមហាជនអន្ធពាលក្នុងលោក គង់ប្រាថ្នានឹងបញ្ឆោតតថាគត អ្នកទំពាស៊ីលាមកប៉ុណ្ណោះ ដេកលើផែនដីតែម្យ៉ាង ជាអ្នកអាក្រាតត្រាច់ទៅ ជកសក់ដោយជាងត្នោតអស់ ៥៥ ឆ្នាំមិនមែនឬ កាលបើដូច្នោះ អ្នកបោកបញ្ឆោតសត្វលោកពោលថា ខ្ញុំជាអ្នកមានខ្យល់ជាអាហារ ឈរជើងម្ខាង មិនអង្គុយមិនដេក ជាអ្នកប្រាថ្នានឹងបោកតថាគតផងឬ ក្នុងកាលមុនអ្នកអាស្រ័យទិដ្ឋិដ៏លាមក ជាអ្នកមានលាមកជាអាហារអស់កាលមានប្រមាណប៉ុណ្ណោះ ជាអ្នកដេកលើផែនដីអាក្រាតកាយត្រាច់ទៅ ដល់នូវការជកសក់ដោយជាងត្នោត ក្នុងឥឡូវនេះ អ្នកនៅកាន់យកទិដ្ឋិដ៏អាក្រក់លាមកដូចមុន ជម្ពុកៈពោលថា មហាសមណៈ ខ្ញុំបានធ្វើកម្មអ្វី ។

លំដាប់នោះព្រះសាស្តាត្រាស់ប្រាប់កម្ម ដែលគាត់ធ្វើហើយក្នុងកាលមុនដល់ជម្ពុកៈនោះ ។ កាលព្រះសាស្តាកំពុងត្រាស់នោះឯង សង្វេគកើតខ្លាំងដល់គាត់ហើយ ហឫទ័ត្តប្បៈប្រាកដហើយ គាត់អង្គុយច្រហោងហើយ ។ គ្រានោះ ព្រះសាស្តា ទ្រង់បានបោះសំពត់សាជកសម្រាប់ងូតទឹក ទៅឲ្យជម្ពុកៈនោះ ជម្ពុកៈស្លៀកសំពត់នោះហើយ ថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ចំណែកព្រះសាស្តាត្រាស់អនុបុព្វីកថា សម្តែងធម៌ដល់ជម្ពុកៈ ក្នុងកាលចប់ទេសនា ជម្ពុកៈសម្រេចអហរត្ត មួយអន្ទើដោយបដិ-

សម្ពិទា ថ្វាយបង្គំព្រះសាស្តាហើយ ក្រោកឡើងអំពីអាសនៈ ទូលសូមបព្វជ្ជា និងឧបសម្បទា ដោយអាការមានប្រមាណប៉ុណ្ណេះ កម្មក្នុងកាលមុនរបស់ ជម្ពុកៈនោះអស់ហើយ ។ ជម្ពុកៈនេះ ជេរព្រះមហាថេរៈដែលជាព្រះខីណា-ស្រព ដោយអក្កោសវត្ថុ ៤ យ៉ាង នេះហើយក្នុងអវីចី ដរាបដល់មហាប្រឹថពី ជុះឡើងមួយយោជន៍ និង ៣ គាវុត ជល់នូវអាការដែលគួរខ្ពើមអស់ ៥៥ ឆ្នាំ ដោយសេសនៃផលកម្ម ព្រោះការជេរនោះ កម្មនោះរបស់លោកអស់ហើយ ព្រោះសម្រេចអរហត្ត កម្មដែលលោកធ្វើហើយនោះ មិនអាចញ៉ាំងផលនៃ សមណធម៌ ដែលជម្ពុកៈនេះធ្វើហើយអស់ ២ ម៉ឺនឆ្នាំឲ្យវិនាសបាន ព្រោះ ដូច្នោះ ទើបព្រះសាស្តាទ្រង់លាព្រះហស្តខាងស្តាំ ត្រាស់នឹងជម្ពុកៈនោះថា ចូរអ្នកជាភិក្ខុចុះ ចូរប្រព្រឹត្តព្រហ្មចរិយៈចុះ ។ ខណៈនោះឯង កេទគ្រហស្ថ របស់លោកបាត់ទៅហើយ លោកជាអ្នកទ្រទ្រង់បរិក្ខារ ៨ ដូចព្រះថេរៈមាន វស្សា ៦០ ហើយ ។

បានឮថា ថ្ងៃនោះ ជាថ្ងៃដែលអ្នកអង្គៈ និងមគធៈកាន់សក្ការៈមកដើម្បី ជម្ពុកៈនោះ ព្រោះដូច្នោះ អ្នកជែនទាំងពីរកាន់សក្ការៈមកហើយ ឃើញព្រះ តថាគតហើយ ទើបគិតថា ជម្ពុកៈលោកម្ចាស់របស់ពួកយើងជាធំឬហ្ន៎ ឬ ព្រះសមណគោតមជាធំ គិតថា បើព្រះសមណគោតមគប្បីជាធំ ជម្ពុកៈនេះ គប្បីចូលទៅកាន់សម្នាក់របស់ព្រះសមណគោតម តែព្រោះភាពដែលជម្ពុកៈ ជាធំ ទើបព្រះសមណគោតមយាងមកកាន់សម្នាក់ជម្ពុកាជីវកនេះ ។

ព្រះសាស្តា ទ្រង់ជ្រាបបរិវិតក្កបស់មហាជន ទើបត្រាស់ថា ជម្ពុកៈ ចូរ

អ្នកដោះសេចក្តីសង្ស័យរបស់ឧបដ្ឋាកទាំងឡាយរបស់អ្នក លោកក្រាបទូលថា សូម្បីខ្ញុំព្រះអង្គក៏រង់ចាំព្រះពុទ្ធតម្រាស់ មានប្រមាណប៉ុណ្ណេះដូចគ្នា ដូច្នេះហើយ ចូលចតុត្ថជ្ឈាន ក្រោកឡើង ហោះទៅកាន់អាកាសប្រមាណមួយជួរដើមត្នោត ក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក ចុះមកថ្វាយបង្គំ ហោះឡើងទៅកាន់អាកាសប្រមាណ ៧ ជួរដើមត្នោតទៀត ដោយអាការយ៉ាងនេះ គឺប្រមាណ ២ ជួរដើមត្នោត ប្រមាណ ៣ ជួរដើមត្នោត ហើយចុះមកញុំាងមហាជន ឲ្យជ្រាបភាពដែលខ្លួនជាសាវក មហាជនឃើញហេតុនោះហើយ គិតថា ឱ ធម្មតាព្រះពុទ្ធទាំងឡាយជាបុគ្គលគួរអស្ចារ្យ ជាអ្នកមានព្រះគុណមិនថោកថយឡើយ ។

ព្រះសាស្តា កាលត្រាស់នឹងមហាជន ត្រាស់យ៉ាងនេះថា ជម្ពុកៈនេះជាក់សក្ការៈ ដែលពួកអ្នកនាំមកហើយ ត្រង់ចុងអណ្តាតដោយចុងស្បូវភ្ញាំងអស់កាលមានប្រមាណប៉ុណ្ណេះ នៅក្នុងទីនេះដោយបំណងថា អញបំពេញការប្រព្រឹត្តតបៈ បើអ្នកគប្បីបំពេញតបៈ ១០០ ឆ្នាំដោយឧបាយនេះសោត ឯការបំពេញតបៈនោះ មិនដល់ចំណែកទី ១៦ នៃកុសលចេតនា ជាគ្រឿងកាត់កត្តរបស់អ្នកដែលរង្គៀសត្រកូល ឬភត្ត ហើយមិនបរិភោគក្នុងកាលឥឡូវនេះដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ត្រាស់ព្រះគាថានេះថា

មាសេ មាសេ កុសគ្គេន ពាលោ ភុញ្ជេថ ភោជនំ
ន សោ សង្ខាតធម្មានំ កលំ អគ្ឃតិ សោឡសឹ ។

ជនពាលទុកជាបរិភោគភោជនដោយចុងស្បូវរាល់ៗ ខែ ជន

ពាលនោះ ក៏មិនដល់មួយចំណិតនៃចំណែកទី ១៦ៗ លើក របស់បុគ្គលទាំងឡាយ ដែលមានធម៌បានដឹង ឬបានពិចារណាហើយឡើយ ។

សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃគាថានោះថា បើបុគ្គលពាល គឺបុគ្គលមានធម៌មិនទាន់កំណត់ដឹង ឆ្ងាយចាកគុណ មានសីលជាដើម បួសក្នុងលិទ្ធិតិរ្ថិយ បរិភោគភោជនដោយចុងស្បូវភ្លាំងវាល់ៗ ខែដែលដល់ហើយ ដោយបំណងថា អញនឹងបំពេញការប្រព្រឹត្តតបៈ ឈ្មោះថា គប្បីបរិភោគភោជនអស់ ១០០ ឆ្នាំ ។

ក្នុងកន្លះគាថាថា **ន សោ សង្ខាតធម្មានំ កលំ អគ្ឃតិ សោឡសឹ** *សម្តែងជាបុគ្គលាទិដ្ឋានថា បុគ្គលមានធម៌ដឹងហើយ គឺបុគ្គលមានធម៌ប្លឹងបានហើយ ហៅថាអ្នកមានធម៌រាប់បានហើយ បណ្តាលោកទាំងនោះ ដោយហោចមានខាងក្រោមព្រះសោតាបន្ន ឈ្មោះថា មានធម៌ដែលរាប់បានហើយ ដោយហោចខាងលើព្រះខីណាស្រព ឈ្មោះថា ជាបុគ្គលមានធម៌រាប់បានហើយ ជនពាលនោះ រមែងមិនដល់ចំណែកទី ១៦ របស់បុគ្គលមានធម៌រាប់បានហើយទាំងនេះ ។*

ចំណែកអត្ថក្នុងកន្លះគាថានេះ គប្បីជ្រាបដូច្នេះថា ចេតនារបស់បុគ្គលពាលនោះ ដែលបំពេញការប្រព្រឹត្តតបៈយ៉ាងនោះ អស់មួយរយឆ្នាំ ប្រព្រឹត្តទៅអស់រាត្រីយូរមានប្រមាណប៉ុណ្ណោះ រមែងមិនដល់ចម្រៀកទី ១៦ នៃកុសលចេតនា ជាគ្រឿងកាត់កត្តម្ភង់ របស់បុគ្គលដែលមានធម៌រាប់បាន

ហើយ រង្គៀសត្រកួល ឬភត្តហើយមិនបរិភោគ ។

ព្រះសាស្តា ត្រាស់អធិប្បាយដូច្នេះថា ផលនៃចំណែកនីមួយៗ ចាក ចំណែកទី ១៦ ដែលធ្វើផលនៃចេតនារបស់បុគ្គល ដែលមានធម៌រាប់បានហើយ នោះឲ្យជា ១៦ ចំណែកហើយ ធ្វើចំណែកនីមួយៗ អំពីចំណែក ១៦ នោះឲ្យ ជា ១៦ ចំណែកទៀត គង់ច្រើនជាងការប្រព្រឹត្តតបៈរបស់ជនពាលនោះ ។

ក្នុងកាលចប់ទេសនា ធម្មាភិសមយ ក៏បានមានដល់សត្វ ៨៤០០០ ហើយដូច្នេះឯង ។

រឿង ជម្ពុកាជីវក ចប់

រឿង អហិប្រេត

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធអហិប្រេត ១ ត្រាស់ព្រះគាថានេះថា **ឯ ហិ ចាបំ កតំ កម្មំ** *ជាដើម ។*

សេចក្តីពិស្តារថា ក្នុងថ្ងៃមួយ ព្រះលក្ខណត្ថេរក្នុងចំណោមជជិលទាំង មួយពាន់ និងព្រះមហាមោគ្គល្លានត្ថេរ ចុះអំពីភ្នំគិជ្ឈកូដដោយគិតថា អាត្មាអញ នឹងបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ។ បណ្តាព្រះថេរៈពីររូបនោះ ព្រះមហាមោគ្គល្លាន ឃើញអហិប្រេតមួយ ទើបធ្វើការញញឹមឲ្យប្រាកដ កាលនោះ ព្រះលក្ខណត្ថេរ សួរហេតុ អាវុសោ ព្រោះហេតុអ្វី ទើបលោកធ្វើការញញឹមឲ្យប្រាកដ ព្រះ

ថេរៈក៏ឆ្លើយថា អាវុសោនេះ មិនមែនកាលដើម្បីវិសជ្ជនាបញ្ហានេះ លោកម្ចាស់គប្បីសួរខ្ញុំក្នុងសម្នាក់ព្រះដ៏មានព្រះភាគចុះ ។ កាលព្រះថេរៈទាំងពីរនោះ ត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ទៅកាន់សម្នាក់ព្រះដ៏មានព្រះភាគអង្គុយហើយ ព្រះលក្ខណត្ថេរសួរថា អាវុសោមោគ្គល្លាន លោកចុះអំពីភ្នំគិជ្ឈកូដ ធ្វើការញញឹមឲ្យប្រាកដ ខ្ញុំសួរដល់ហេតុនៃការញញឹមបានពោលថា លោកគប្បីសួរខ្ញុំក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ឥឡូវនេះ សូមលោកម្ចាស់ប្រាប់ហេតុនោះចុះ ។

ព្រះថេរៈពោលថា អាវុសោ ខ្ញុំឃើញអហិប្រេតមួយ ទើបធ្វើការញញឹមឲ្យប្រាកដ អត្តភាពរបស់ប្រេតបែបនេះ ក្បាលរបស់ប្រេតនោះដូចក្បាលមនុស្ស អត្តភាពដ៏សេសរបស់ប្រេតនោះដូចពស់នោះឈ្មោះអហិប្រេតដោយប្រមាណ ២៥ យោជន៍ ។ អណ្តាតភ្លើងតាំងឡើងអំពីក្បាល រាលទៅដល់ចុងកន្ទុយ តាំងឡើងអំពីកន្ទុយរហូតដល់ក្បាល តាំងឡើងត្រង់កណ្តាលនេះទៅដល់ទាំងសងខាង តាំងឡើងសងខាងរាលមកដល់ត្រង់កណ្តាល ។ បានឮថា អត្តភាពរបស់ប្រេតទាំងពីរនោះឯងប្រមាណ ២៥ យោជន៍ ប្រេតដ៏សេសប្រមាណ ៣ គាវុត ប្រេតនោះ និងកាកប្រេតប្រមាណ ២៥ យោជន៍ បណ្តាប្រេតទាំងពីរនោះ នឹងពោលអហិប្រេតមានប្រមាណប៉ុណ្ណោះសិន ។

ព្រះមហាមោគ្គល្លាន ឃើញកាកប្រេតដែលនេះនៅត្រង់កំពូលភ្នំគិជ្ឈកូដ កាលនឹងសួរបុព្វកម្មរបស់ប្រេតនោះ ទើបពោលគាថានេះថា

អណ្តាតរបស់អ្នកប្រមាណ ៥ យោជន៍ ក្បាលរបស់អ្នកប្រមាណ

៩ យោជន៍ កាយរបស់អ្នកកម្ពស់ប្រមាណ ២៥ យោជន៍ អ្នក ធ្វើកម្មអ្វីទុក ទើបជល់នូវទុក្ខដូច្នេះ ។

គ្រានោះ ប្រែតកាលនឹងប្រាប់ដល់ព្រះថេរៈនោះ ទើបពោលគាថានេះថា

ព្រះមោគ្គល្លានដ៏ចម្រើន ខ្ញុំទំពាស៊ីកត្តដែលគេនាំមកដើម្បីសង្ឃ របស់ព្រះពុទ្ធព្រះនាមថាកស្សបៈ ទ្រង់ស្វែងរកគុណធំ តាម ប្រាថ្នា ។

*ដូច្នោះហើយ ទើបពោលថា បពិត្រលោកម្ចាស់ ក្នុងកាលព្រះពុទ្ធព្រះនាមកស្សបៈ ពួកភិក្ខុច្រើនរូបចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ពួកមនុស្សឃើញព្រះថេរៈទាំងឡាយហើយ ស្រឡាញ់ និមន្តឲ្យគង់ត្រង់រោងធាន់ លាងជើងលាបដោយប្រេង ឲ្យធាន់នូវបបរ ប្រគេនរបស់គួរទំពា រង់ចាំបិណ្ឌបាតកាលអង្គុយស្តាប់ធម៌ ក្នុងកាលចប់ធម្មកថា ពួកមនុស្សទទួលបាត្ររបស់ព្រះថេរៈទាំងឡាយហើយ ញ៉ាំងបាត្រឲ្យពេញដោយភោជនមានរសដ៏ប្រសើរផ្សេងៗ ក្នុងផ្ទះរៀងៗខ្លួនហើយនាំមក ។ ក្នុងគ្រានោះ ខ្ញុំជាភ្នែកទំត្រង់ដំបូលនៃរោងធាន់ ឃើញភោជននោះហើយ បានពាំយកដុំបាយ ៣ ដុំពេញមាត់ ៣ ដង អំពីបាត្រដែលមនុស្សម្នាក់កាន់ តែកត្តនោះមិនទាន់ជារបស់សង្ឃឡើយ មិនមែនជាកត្តដែលគេកំណត់ថ្វាយដល់សង្ឃ ជាកត្តដែលសល់អំពីភិក្ខុទាំង-ឡាយធាន់ ដែលពួកមនុស្សគប្បីនាំទៅកាន់ផ្ទះរបស់ខ្លួនបរិភោគ ក៏មិនមែនត្រឹមតែជាកត្តដែលគេនាំមកចំពោះសង្ឃតែម្យ៉ាងប៉ុណ្ណោះ ខ្ញុំពាំដុំបាយ ៣ ដុំ អំពីបាត្រនោះ កម្មមានប្រមាណប៉ុណ្ណោះ ជាបុព្វកម្មរបស់ខ្ញុំ ខ្ញុំនោះ ធ្វើកាល-

កិរិយាហើយ ឆេះក្នុងអវីចី ព្រោះវិបាកនៃកម្មនោះ ក្នុងឥឡូវនេះ កើតជាកាកប្រេត សោយទុក្ខនេះ ត្រង់ភ្នំគិជ្ឈកូដ ដោយផលកម្មដ៏សេស ព្រោះកម្មនោះ ។ រឿងកាកប្រេតមានប្រមាណប៉ុណ្ណេះ ។

តែក្នុងរឿងនេះព្រះថេរៈពោលថា ខ្ញុំឃើញអហិប្រេត ទើបធ្វើការញញឹមឲ្យប្រាកដ ។ លំដាប់នោះ ព្រះសាស្តាទ្រង់ជាសាក្សីរបស់ព្រះថេរៈនោះ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលពិត ឯតថាគតឃើញប្រេតនោះក្នុងថ្ងៃសម្រេចសម្ពោធិញ្ញាណដូចគ្នា តែតថាគតមិនពោល ព្រោះករុណាជនជំទៃ ព្រោះជនណាមិនជឿពាក្យរបស់តថាគត ការមិនជឿនោះ គប្បីប្រព្រឹត្តទៅដើម្បីវត្តដែលមិនមែនប្រយោជន៍ដល់ជនទាំងនោះ ។ ក្នុងកាលព្រះមោគ្គល្លានឃើញហើយនោះឯង ព្រះសាស្តាទ្រង់ជាសាក្សីរបស់លោក ត្រាស់រឿង ២០ រឿងក្នុងលក្ខណសំយុត្តហើយ សូម្បីរឿងនេះ ព្រះថេរៈក៏ពោលយ៉ាងនេះដូចគ្នា ។ ភិក្ខុទាំងឡាយស្តាប់រឿងនោះហើយ ទើបទូលសួរបុព្វកម្មរបស់ប្រេតនោះ ។ សូម្បីព្រះសាស្តាក៏ត្រាស់ដល់ភិក្ខុទាំងនោះថា

បានឮថា ក្នុងអតីតកាល ពួកជនអាស្រ័យក្រុងពារាណសី សាងបណ្ណសាលា ដើម្បីព្រះបច្ចេកពុទ្ធក្បែរឆ្នេរស្ទឹង ។ ព្រះបច្ចេកពុទ្ធនោះ នៅក្នុងបណ្ណសាលានោះ តែងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងជានិច្ច ។ សូម្បីពួកអ្នកក្រុងមានដៃកាន់នូវសក្ការៈ គ្រឿងក្រអូប និងផ្កាជាដើម ទៅកាន់ទីបម្រើរបស់ព្រះបច្ចេកពុទ្ធទាំងល្ងាច ទាំងព្រឹក ។ បុរសអ្នកក្រុងពារាណសីម្នាក់ អាស្រ័យផ្លូវនោះ ក្បែរស្រែ មហាជនទៅកាន់ទីបម្រើព្រះបច្ចេកពុទ្ធ រមែងជាន់ស្រែនោះ

ទៅទាំងល្ងាច ទាំងព្រឹក ។ អ្នកស្រែឃាត់ថា សូមអ្នកទាំងឡាយកុំជាន់ស្រែរបស់ខ្ញុំ ក៏មិនអាចឃាត់បាន ។ គ្រានោះ អ្នកស្រែនោះមានគំនិតយ៉ាងនេះថា បើបណ្ណសាលារបស់ព្រះបច្ចេកពុទ្ធមិនមានក្នុងទីនេះសោត ជនទាំងឡាយ ក៏មិនជាន់ស្រែរបស់អញ ក្នុងកាលដែលព្រះបច្ចេកពុទ្ធចូលទៅបិណ្ឌបាត អ្នកស្រែនោះវាយភាជនៈ គ្រឿងប្រើប្រាស់ ហើយដុតបណ្ណសាលាចោល ។ ព្រះបច្ចេកពុទ្ធ ឃើញបណ្ណសាលានោះត្រូវភ្លើងឆេះ ទើបចៀសចេញទៅតាមសប្បាយ ។ មហាជនកាន់យកគ្រឿងក្រអូប និងកម្រងផ្កាមក ឃើញបណ្ណ-សាលាត្រូវភ្លើងឆេះ ទើបពោលថា លោកម្ចាស់របស់ពួកយើងទៅក្នុងទីណាហ្ន៎ អ្នកស្រែនោះក៏មកជាមួយមហាជនដូចគ្នា ឈរត្រង់កណ្តាលមហាជន ពោលយ៉ាងនេះថា ខ្ញុំដុតបណ្ណសាលារបស់ព្រះបច្ចេកពុទ្ធ ។ គ្រានោះ ជនទាំងឡាយពោលថា ចូរពួកអ្នកចាប់ ពួកយើងអាស្រ័យបុរសអាក្រក់នេះ ទើបមិនបានឃើញព្រះបច្ចេកពុទ្ធ ដូច្នេះហើយ ក៏វាយអ្នកស្រែនោះ ដោយគ្រឿងប្រហារ មានដំបងជាដើម ឲ្យដល់នូវការអស់ជីវិតហើយ អ្នកស្រែនោះកើតក្នុងអវីចី ឆេះក្នុងនរកជ្រាបស្មើនឹងផែនដីនេះ ដែលដុះឡើងប្រមាណមួយយោជន៍ ដោយផលកម្មដែលសេសសល់ ទើបកើតជាអហិប្រេត ត្រង់ភ្នំគិជ្ឈកូដ ។

ព្រះសាស្តា កាលត្រាស់បុព្វកម្មនេះ របស់អហិប្រេតនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា បាបកម្មនោះ ដូចគ្នានឹងទឹកដោះទឹកដោះដែលបុគ្គលកំពុងរឹត រមែងមិនប្រែប្រួលទៅ យ៉ាងណា កម្មដែលបុគ្គល

កំពុងធ្វើ ដែលមិនទាន់ឲ្យផលក៏ដូច្នោះ តែក្នុងកាលណាកម្មឲ្យផល កាលនោះ បុគ្គលអ្នកធ្វើ រមែងប្រកបដោយទុក្ខបែបនោះ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ន ហិ ចាបំ កតំ កម្មំ សជ្ជុឡីរំវ មុច្ចតិ
ឌហន្តំ ពាលមន្វេតិ ភស្មាច្ចន្នោវ ចាវកោ ។

កម្មលាមក ដែលជនពាលធ្វើហើយ មិនទាន់ឲ្យផលនោះ ក៏មាន ដូចទឹកដោះស្រស់ដែលមិនទាន់ប្រែក្លាយ (ក្នុងមួយរំពេច) ដូច្នោះ បាបកម្មនោះ តាមដុតបុគ្គលពាល ដូចរងើកភ្លើង ដែលបិទបាំងទុកដោយផេះ ដូច្នោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សជ្ជុឡីរំ** *សេចក្តីថា ទឹកដោះដែលហូរចេញអំពីដោះរបស់មេគោក្នុងខណៈនោះឯងនៅក្តៅ រមែងមិនផ្លាស់ប្តូរ គឺរមែងមិនប្រែប្រួលទៅ ។ ព្រះសាស្តាត្រាស់ដូច្នេះថា ទឹកដោះដែលគេរឹតក្នុងខណៈនោះ រមែងមិនផ្លាស់ប្តូរ គឺមិនប្រែប្រួល បានដល់ មិនលះប្រក្រតីក្នុងខណៈនោះឯង តែដែលគេរឹតទុកក្នុងភាជនៈណា រមែងមិនលះប្រក្រតីដរាបប៉ុណ្ណោះ ដែលមិនទាន់បានដាក់របស់ជូរ មានតក្ក:ជាដើមចូលក្នុងភាជនៈនោះ គឺដរាបណាមិនដល់ភាជនៈរបស់តក្ក: មានភាជនៈទឹកដោះជូរជាដើម រមែងលះក្នុងកាលខាងក្រោយ យ៉ាងណា សូម្បីបាបកម្មដែលបុគ្គលកំពុងធ្វើ ក៏រមែងមិនឲ្យផលដូច្នោះដូចគ្នា បើបាបកម្មគប្បីឲ្យផលក្នុងខណៈធ្វើ បុគ្គលណាមួយមិន*

អាចធ្វើបាបកម្មបាន ឯខន្ធទាំងឡាយដែលកើតដោយកុសល តាំងនៅជរាបណា ខន្ធទាំងនោះ រមែងរក្សាបុគ្គលនោះបានជរាបនោះ កាលខន្ធទាំងឡាយកើតក្នុងអបាយ ព្រោះខន្ធទាំងនោះបែកធ្លាយ បាបកម្មរមែងឲ្យផល កាលឲ្យផល ឈ្មោះថា តាមដុតរោលបុគ្គលពាល ។

សួរថា សេចក្តីនេះប្រៀបដូចអ្វី ឆ្លើយថា ប្រៀបដូចភ្លើងដែលផេះបិទបាំង អធិប្បាយថា ដូចរងើកភ្លើងប្រាសចាកអណ្តាត ដែលផេះបិទបាំង សូម្បីបុគ្គលជាន់ហើយក៏មិនទាន់ឆេះ ព្រោះផេះបិទបាំង តែកាលផេះក្តៅហើយ រមែងឆេះរហូតដល់ខ្លួរដោយអំណាចឆេះអាយវៈ មានស្បែកជាដើម យ៉ាងណា សូម្បីបាបកម្មក៏ដូច្នោះដូចគ្នា ជាបាបកម្មដែលបុគ្គលធ្វើ រមែងតាមដុតបុគ្គលនោះ ដែលជាបុគ្គលពាលកើតហើយក្នុងអបាយ មាននរកជាដើម ក្នុងអត្តភាពទី ២ ឬទី ៣ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង អហិប្រេត ចប់

រឿង សដ្ឋិកូដប្រេត

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសដ្ឋិកូដប្រេត ត្រាស់ព្រះធម្មទេសនានេះថា **យាវតេវ អនត្ថាយ** ជាដើម ។

សេចក្តីពិស្តារថា ព្រះមហាមោគ្គល្លានត្ថេរចុះអំពីភ្នំគិជ្ឈកូដ មួយអន្ទើ ដោយព្រះលក្ខណាត្ថេរ ធ្វើការញញឹមក្នុងបទេសណាមួយ ដោយនយមុននោះ ឯង ត្រូវព្រះថេរៈសួរដល់ហេតុនៃការញញឹម ទើបពោលថា លោកម្ចាស់ គប្បីសួរខ្ញុំក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ក្នុងកាលព្រះមហាមោគ្គល្លានត្ថេរ ត្រាច់ទៅបិណ្ឌបាត ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំ អង្គុយហើយ ត្រូវ ព្រះថេរៈសួរទៀត ទើបពោលថា អាវុសោ ខ្ញុំឃើញប្រេតមួយ មានអត្តភាព ប្រមាណ ៣ គាវុត ញញួរដែក ៦ ម៉ឺនដែលភ្លើងឆេះសន្ធោសន្ធៅហើយ ធ្លាក់ លើអំបែងក្បាលរបស់ប្រេតនោះតាំងឡើង ទម្ងាយក្បាលរបស់ប្រេតបែក ហើយ រមែងតាំងឡើងទៀតដោយអត្តភាពនេះ អត្តភាពបែបនេះ ខ្ញុំមិនធ្លាប់ ឃើញ ខ្ញុំឃើញអត្តភាពនោះ ទើបធ្វើការញញឹមឲ្យប្រាកដ ។ ពិតហើយ ក្នុង រឿងប្រេត ព្រះមហាមោគ្គល្លានត្ថេរសំដៅយកប្រេតនោះឯង ទើបពោល ពាក្យជាដើមថា

> ញញួរដែកដែលពេញប្រាំមួយម៉ឺន (៦០០០០) ដ៏
> គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់អ្នក ញញួរដែក
> ទាំងនោះ វាយទម្ងាយក្បាល ។

ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ព្រះថេរៈហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វនេះតថាគតអង្គុយត្រង់ពោធិមណ្ឌលបទេស ក៏ឃើញហើយដូចគ្នា តែតថាគតមិនសម្តែង ដើម្បីអនុគ្រោះដល់ជនដទៃ ព្រោះជនពួកណាមិនជឿពាក្យរបស់តថាគត ការមិនជឿនោះគប្បីមានដើម្បីកម្មមិនជាប្រយោជន៍ដល់បុគ្គលទាំងនោះ តែឥឡូវនេះ តថាគតជាបន្ទាល់របស់មោគ្គល្លាន ទើបជ្រាប់បាន ។ ភិក្ខុទាំងឡាយស្តាប់ព្រះតម្រាស់នោះហើយ ទើបសួរដល់បុព្វកម្មរបស់ប្រេតនោះ ។ ព្រះសាស្តាក៏ត្រាស់ដល់ភិក្ខុទាំងនោះថា

បានឮមកថា ក្នុងអតីតកាល ក្នុងក្រុងពារាណសី មានបុរសខ្វិនម្នាក់ដល់នូវសេចក្តីសម្រេចក្នុងសិប្បៈរបស់បុគ្គលដែលផ្ងាត់គ្រាប់ក្រួស ។ បុរសនោះអង្គុយក្រោមដើមជ្រៃមួយដើម ក្បែរទ្វារព្រះនគរ ពួកក្មេងអ្នកស្រុកពោលថា សូមអ្នកផ្ងាត់ជុំក្រួសទម្លុះស្លឹកជ្រៃនោះ ធ្វើជារូបដំរីដល់ពួកខ្ញុំ ធ្វើជារូបសេះដល់ពួកខ្ញុំ ក៏បង្ហាញរូបទាំងឡាយដែលពួកក្មេងជ្រាប្ថាហើយ បានវត្ថុមានរបស់ទំពាជាដើមអំពីសម្នាក់ពួកក្មេងទាំងនោះ ។ សម័យមួយ ព្រះរាជាយាងទៅកាន់ព្រះរាជឧទ្យាន ដល់បទេសនោះ ។ ពួកក្មេងញាត់បុរសនោះក្នុងព្រៃជ្រៃហើយក៏គេចទៅ កាលព្រះរាជាចូលទៅកាន់គល់ជ្រៃ ក្នុងថ្ងៃត្រង់ស្រមោលចាំងចំព្រះសរីរៈ ទ្រង់ត្រិះរិះថា នេះអ្វីហ្ន៎ ទ្រង់ទតមើលខាងលើឃើញរូប មានរូបដំរីជាដើម ត្រង់ស្លឹកឈើទាំងឡាយ ទើបត្រាស់សួរថា នេះជាកម្មរបស់អ្នកណា ទ្រង់បានឮថា របស់មនុស្សខ្វិន ទើបត្រាស់បញ្ជាឲ្យរកបុរសខ្វិននោះមក ហើយត្រាស់ថា បុរោហិតរបស់យើងមាត់រឹងពេក កាល

យើងនិយាយ សូម្បីតិចតួច ក៏ពោលច្រើន រមែងបៀតបៀនយើង តើអ្នកអាច ផ្ទាត់អាចម៍ពពែប្រមាណមួយនាឡិ ចូលក្នុងមាត់របស់បុរោហិតនោះបានដែរឬ បុរសខ្វិនទូលថា បពិត្រព្រះអង្គ ទូលបង្គំអាច សូមទ្រង់ឲ្យមនុស្សនាំមូល ពពែមក ហើយប្រថាប់គង់ ខាងក្នុងវាំងននជាមួយបុរោហិត ទូលបង្គំដឹងកម្ម ដែលគួរធ្វើក្នុងរឿងនេះ ។ ព្រះរាជាបានធ្វើយ៉ាងនោះ ។ បុរសខ្វិននេះ ឲ្យធ្វើ ប្រហោងវាំងននដោយចុងកន្ត្រៃ កាលបុរោហិតនិយាយជាមួយព្រះរាជា គ្រាន់ តែហាមាត់ ក៏ផ្ទាត់អាចម៍ពពែទៅម្ដងមួយដុំៗ ។ បុរោហិតលេបអាចម៍ពពែ ដែលចូលមាត់ហើយ កាលអាចម៍ពពែអស់ ទើបបុរសខ្វិនកន្ត្រាក់វាំងនន ព្រះរាជាទ្រង់ជ្រាបភាពដែលអាចម៍ពពែអស់ ដោយសញ្ញានោះហើយ ទើប ត្រាស់ថា លោកអាចារ្យ ខ្ញុំនិយាយជាមួយលោក មិនអាចចាំពាក្យបាន សូម្បីលោកលេបអាចម៍ពពែមួយនាឡិហើយ ក៏មិនដល់នូវភាពជាអ្នកស្ងៀម ព្រោះភាពដែលអ្នកមានមាត់រឹង ។ ព្រាហ្មណ៍ដល់នូវការខ្មាស ចាប់តាំងអំពី នោះមក មិនអាចហាមាត់ជាមួយព្រះរាជាបាន ព្រះរាជាទ្រង់ឲ្យហៅបុរស ខ្វិនមកហើយត្រាស់ថា យើងបានសេចក្ដីសុខ ព្រោះអាស្រ័យអ្នក ទ្រង់ពេញ ព្រះហឫទ័យ ទើបព្រះរាជទានវត្ថុមួយមុខ ៨ ដល់គាត់ បានព្រះរាជទានស្រុក សួយ ៤ ក្នុងទិសទាំង ៤ នៃក្រុង អមាត្យដែលប្រៀនប្រដៅអត្ថ និងធម៌ របស់ព្រះរាជា ជ្រាបសេចក្ដីនោះហើយ ទើបពោលគាថានេះថា

ធម្មតាសិល្បសាស្ត្រយ៉ាងណាក៏ដោយ សុទ្ធតែសម្រេចប្រយោជន៍
សូមព្រះអង្គទត ស្រុកសួយទាំង ៤ ទិស ដែលបុរសខ្វិនបាន

ហើយ ដោយការផ្ចាត់ (អាចម៍ពពែ) នៃបុរសខ្វិន ។

អមាត្យនោះ ក្នុងកាលនោះបានជាតថាគតនោះឯង ។ គ្រានោះ បុរសម្នាក់ឃើញសម្បត្តិបុរសខ្វិនបានហើយ ទើបគិតថា បុរសជាមនុស្សខ្វិនអាស្រ័យសិប្បៈនេះ ទើបដល់ហើយនូវសម្បត្តិធំ ឯអាត្មាអញសិក្សានូវសិប្បៈនេះក៏គួរ គាត់ចូលទៅរកបុរសខ្វិនថ្វាយបង្គំហើយពោលថា លោកអាចារ្យ សូមលោកឲ្យសិប្បៈនេះដល់ខ្ញុំចុះ ។ បុរសខ្វិនពោលថា នែបា ខ្ញុំមិនអាចឲ្យបានទេ ។ គាត់ត្រូវបុរសខ្វិននោះឃាត់ហើយគិតថា ណ្ហើយចុះ អញនឹងញុំងបុរសខ្វិននោះឲ្យត្រេកអរ ទើបធ្វើកិច្ចមានការគក់ច្របាច់ដៃជើងជាដើម ដល់បុរសខ្វិននោះ ឲ្យបុរសខ្វិននោះ ត្រេកអរហើយអស់កាលយូរ អង្វរវ្រើយៗហើយ ។ បុរសខ្វិនគិតថា ជននេះមានឧបការៈដល់អញពន់ពេក ទើបមិនអាចឃាត់បាន ឲ្យសិក្សាសិប្បៈហើយ ពោលថា នែបា សិប្បៈរបស់អ្នកសម្រេចហើយ ឥឡូវនេះ អ្នកនឹងធ្វើអ្វី បុរសនោះពោលថា ខ្ញុំនឹងទៅសាកល្បងសិប្បៈនៅខាងក្រៅ បុរសខ្វិនពោលថា អ្នកនឹងធ្វើដូចម្តេច បុរសនោះពោលថា ខ្ញុំនឹងផ្ចាត់មេគោឬ មនុស្សឲ្យស្លាប់ បុរសខ្វិនពោលថា នែបា បើអ្នកសម្លាប់មេគោសំណង់នឹងមានមួយរយកហាបណៈ បើសម្លាប់មនុស្សសំណង់នឹងមានមួយពាន់កហាបណៈ អ្នកមួយអន្លើដោយបុត្រ និងភរិយាមិនអាចដោះបំណុលនោះបាន ចូរអ្នកកុំវិនាសឡើយ កាលអ្នកប្រហារបុគ្គលណា ដែលមិនមានបំណុល អ្នកចូរពិនិត្យមើលបុគ្គលណាម្នាក់ដែល មិនមានមាតាបិតា ដូច្នោះ ។ បុរសនោះទទួលថា សាធុ ហើយយកដុំក្រួសដាក់

ថ្នក់ ត្រាច់សម្លឹងមើលបុគ្គលដែលមានសភាពដូច្នោះ ឃើញមេគោហើយ មិនអាចផ្ចាត់បាន ដោយគិតថា មេគោនេះមានម្ចាស់ ឃើញមនុស្សហើយមិនអាចផ្ចាត់បាន ដោយគិតថា មនុស្សនេះមានមាតាបិតា ។

ដោយសម័យនោះព្រះបច្ចេកពុទ្ធឈ្មោះសុនេត្តៈ អាស្រ័យព្រះនគរ នៅក្នុងបណ្ណសាលា ។ បុរសនោះឃើញព្រះបច្ចេកពុទ្ធនោះ ចូលទៅដើម្បីបិណ្ឌបាត ឈរនៅក្នុងរវាងទ្វារនគរគិតថា ព្រះបច្ចេកពុទ្ធនេះ ជាបុគ្គលមិនមានមាតាបិតា កាលអាត្មាអញផ្ចាត់បុគ្គលនេះ មិនចាំបាច់មានពិន័យ អញនឹងផ្ចាត់ព្រះបច្ចេក-ពុទ្ធនេះ ដើម្បីល្បងសិប្បៈ ដូច្នេះហើយ ទើបផ្ចាត់ជុំក្រួសទៅតម្រង់រន្ធត្រចៀកខាងស្តាំរបស់ព្រះបច្ចេកពុទ្ធ ជុំក្រួសចូលទៅតាមរន្ធត្រចៀកខាងស្តាំ ចេញទៅតាមរន្ធត្រចៀកខាងឆ្វេង ទុក្ខវេទនាកើតឡើងហើយ ។ ព្រះបច្ចេក-ពុទ្ធមិនអាចត្រាច់ទៅបិណ្ឌបាតបាន ទើបទៅកាន់បណ្ណសាលាតាមអាកាស បរិនិព្វានហើយ ។ ពួកមនុស្សកាលព្រះបច្ចេកពុទ្ធមិននិមន្តមក គិតថា ការមិនផាសុកណាមួយនឹងមាន ទើបទៅត្រង់បណ្ណសាលានេះ ឃើញលោកបរិព្វានហើយ ទ្រហោយំរៀបរាប់ ។ បុរសនោះឃើញមហាជនទៅត្រង់បណ្ណសាលានោះហើយ ចាំព្រះបច្ចេកពុទ្ធនោះបាន ទើបពោលថា ព្រះបច្ចេកពុទ្ធអង្គនេះ កាលចូលទៅដើម្បីបិណ្ឌបាត ជួបខ្ញុំត្រង់រវាងទ្វារ កាលខ្ញុំសាកល្បងសិប្បៈរបស់ខ្លួន ទើបប្រហារព្រះបច្ចេកពុទ្ធនេះ ពួកមនុស្សពោលថា បានឮថា មនុស្សអាក្រក់នេះ ប្រហារព្រះបច្ចេកពុទ្ធ ចូរពួកអ្នកចាប់វាយបុរសនោះ ឲ្យដល់នូវការអស់ជីវិតក្នុងទីនោះឯង ។ បុរសនោះ កើតក្នុងអវីចី នេះហើយ

រហូតផែនដីដុះឡើងបានមួយយោជន៍ ដោយសេសសល់ផលកម្ម កើតជាសដ្ឋិ-កូដប្រេតត្រង់កំពូលភ្នំគិជ្ឈកូដដូច្នេះ ។

ព្រះសាស្តា កាលត្រាស់បុព្វកម្មនេះរបស់ប្រេតនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សិប្ប: ឬឥស្សរៈកើតឡើងដល់បុគ្គលពាល រមែងកើតឡើងដើម្បីសេចក្តីវិនាស ព្រោះថា បុគ្គលពាលបានសិប្ប: ឬភាពជាឥស្សរៈហើយ រមែងធ្វើសេចក្តីវិនាសដល់ខ្លួនតែម្យ៉ាង ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិនៃធម៌ ទើបត្រាស់ព្រះគាថានេះថា

យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ
ហន្តិ ពាលស្ស សុក្កំសំ មុទ្ធំ អស្ស វិបាតយំ ។

ការចេះដឹងកើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះ រមែងញ៉ាំងបញ្ញាឲ្យធ្លាក់ចុះ បំផ្ចេចបំផ្លាញចំណែកនៃធម៌ស គឺកុសលរបស់បុគ្គលពាលនោះ ។

សេចក្តីអធិប្បាយ

សព្ទថា **យាវទេវ** ក្នុងគាថានោះ ជានិបាត ចុះក្នុងអត្ថ គឺការកំណត់ទូវែង ។ ការ: គឺការដឹង ឈ្មោះថា **ញត្តំ** ។ បុគ្គលរមែងដឹងសិប្ប:ណា ឬបុគ្គលតាំងនៅក្នុងភាពជាបុគ្គលធំណា ឬដោយការដល់ព្រមដោយយសណា ដែលជនរមែងស្គាល់ គឺប្រាកដ បានដល់ ជាអ្នកខ្ចង់ខ្ចស់ ។ ពាក្យថា **ញត្តំ** នេះ ជាឈ្មោះនៃសិប្ប:ភាពជាធំ និងការដល់ព្រមដោយយសនោះ ។ ពិតហើយ សិប្ប: ឬភាពជាធំជាដើម រមែងកើតដល់បុគ្គលពាល ដើម្បីភាព

វិនាសតែម្យ៉ាង គឺបុគ្គលពាលនោះអាស្រ័យសិប្បៈជាដើមនោះ រមែងធ្វើនូវការវិនាសដល់ខ្លួនតែម្យ៉ាង ។ បទថា **ហន្តិ** *បានដល់ ឲ្យវិនាស ។ បទថា* **សុក្កំសំ** *គឺចំណែកនៃកុសល អធិប្បាយថា សិប្បៈ ឬភាពជាធំ កាលកើតទ្បើងដល់បុគ្គលពាល រមែងកើតទ្បើងសម្លាប់នូវចំណែកដែលជាកុសលធម៌តែម្យ៉ាង ។ បទថា* **មុទ្ធំ** *នេះ ជាឈ្មោះរបស់បញ្ញា ។ បទថា* **វិចាតយំ** *គឺកម្ចាត់ អធិប្បាយថា ការដឹងនោះ សម្លាប់ចំណែកកុសលរបស់បុគ្គលពាលនោះ ញាំងមុទ្ធា ពោល គឺបញ្ញាឲ្យធ្លាក់ទៅ គឺកម្ចាត់នោះឯង ឈ្មោះថា សម្លាប់ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

រឿង សង្ខិក្ខជប្រេត ចប់

រឿង ព្រះសុធម្មត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសុធម្មត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អសន្តំ ភាវមិច្ឆេយ្យ** *ជាដើម ។*

ទេសនានេះតាំងទ្បើងហើយ ក្នុងមច្ឆិកាសណ្ឌនគរ ចប់ហើយក្នុងក្រុងសាវត្ថី ។

សេចក្តីពិស្តារថា ចិត្តគហបតីក្នុងមច្ឆិកាសណ្ឌនគរ ឃើញព្រះមហា-នាមត្ថេរក្នុងពួកបញ្ចវគ្គិយភិក្ខុត្រាច់បិណ្ឌបាត ជ្រះថ្លាក្នុងឥរិយាបថរបស់ព្រះថេរៈហើយ ទើបទទួលបាត្រនិមន្តឲ្យចូលទៅកាន់ផ្ទះ ឲ្យឆាន់ហើយ ក្នុងកាលស្រេចភត្តកិច្ច ស្តាប់ធម្មកថាសម្រេចសោតាបត្តិផលហើយ ជាអ្នកមានសទ្ធាមិនញាប់ញ័រ ប្រាថ្នាដើម្បីធ្វើឧទ្យានរបស់ខ្លួនដែលមានឈ្មោះថា អញ្ជកវន គឺចម្ការម្លាក់ឲ្យជាសង្ឃារាម ទើបប្រោចទឹកលើដៃព្រះថេរៈ ប្រគេនហើយ ។ ក្នុងខណៈនោះ មហាប្រឋពីធ្វើឲ្យទីបំផុតនៃទឹកញាប់ញ័រ ដោយប្រាប់ហេតុថា ព្រះពុទ្ធសាសនាតាំងមាំហើយ ។

មហាសេដ្ឋីឲ្យសាងវិហារធំក្នុងឧទ្យាន បានជាបុគ្គលមានទ្វារបើកជានិច្ច ដើម្បីពួកភិក្ខុដែលមកអំពីទិសទាំងពួងហើយ ។ ព្រះសុធម្មត្ថេរបានជាម្ចាស់អាវាស នៅក្នុងមច្ឆិកាសណ្ឌៈនោះ ។

សម័យក្រោយតមក អគ្គសាវ័កទាំងពីរ ស្តាប់កថាពណ៌នាគុណរបស់ចិត្តគហបតីហើយ ប្រាថ្នានឹងធ្វើការសង្គ្រោះដល់គហបតីនោះ ទើបបាននៅកាន់មច្ឆិកាសណ្ឌនគរ ។ ចិត្តគហបតី ជ្រាបការមករបស់អគ្គសាវ័កទាំងពីរនោះ ទើបទៅទទួលអស់ចម្ងាយផ្លូវប្រមាណកន្លះយោជន៍ នាំអគ្គសាវ័កទាំងពីរនោះមកហើយនិមន្តឲ្យចូលទៅកាន់វិហាររបស់ខ្លួន ធ្វើអាគន្តុកវត្តហើយ អារាធនាព្រះធម្មសេនាបតីថា បពិត្រលោកម្ចាស់ ខ្ញុំប្រាថ្នាស្តាប់ធម្មកថាតិចតួច ។ គ្រានោះ ព្រះថេរៈពោលនឹងគហបតីថា ឧបាសក អាត្មាទាំងឡាយហត់នឿយហើយ ដោយផ្លូវឆ្ងាយ ម្យ៉ាងទៀត ចូរអ្នកស្តាប់ត្រឹមតែបន្តិចបន្តួចចុះ ដូច្នេះ

ហើយ ពោលធម្មកថាដល់ឧបាសកនោះ ។ គហបតីនោះស្តាប់ធម្មកថារបស់ព្រះថេរៈនោះឯង សម្រេចអនាគាមិផលហើយ ។ ថ្វាយបង្គំអគ្គសាវ័កទាំងពីរហើយ និមន្តថា បពិត្រលោកម្ចាស់ ស្អែកនេះ សូមលោកម្ចាស់ទាំងពីរជាមួយភិក្ខុ ១ ពាន់រូប ទទួលភិក្ខាត្រង់ផ្ទះខ្ញុំចុះ ហើយនិមន្តព្រះសុធម្មត្ថេរដែលជាម្ចាស់អាវាស តាមក្រោយថា បពិត្រលោកម្ចាស់ ស្អែកនេះ សូមលោកម្ចាស់មកជាមួយព្រះថេរៈទាំងឡាយចុះ ។

ព្រះសុធម្មត្ថេរនោះក្រោធថា ឧបាសកនេះនិមន្តអញក្រោយ ទើបប្រកែកកាលគហបតីអង្វរវារឿយៗ ក៏ប្រកែកនោះឯង ។ ឧបាសកពោលថា សូមលោកម្ចាស់ពិតប្រាកដចុះ ហើយចៀសចេញទៅ ក្នុងថ្ងៃស្អែកឡើង រៀបចំមហាទានក្នុងលំនៅរបស់ខ្លួន ។ ក្នុងពេលជិតភ្លឺ សូម្បីព្រះសុធម្មត្ថេរគិតថា គហបតីចាត់ចែងសក្ការៈអ្វីហ្ន៎ ដើម្បីអគ្គសាវ័កទាំងពីរ ស្អែកនេះ អញនឹងទៅមើលហើយបានកាន់ចាត្រ និងចីវរ ទៅកាន់ផ្ទះរបស់គហបតីនោះ អំពីព្រលឹម ។ ព្រះសុធម្មត្ថេរនោះ សូម្បីគហបតីពោលថា សូមលោកម្ចាស់និមន្តគង់ចុះ ក៏ពោលថា អាត្មាមិនគង់ អាត្មាត្រាច់បិណ្ឌបាត ហើយពិនិត្យមើលសក្ការៈដែលគហបតីរៀបចំដើម្បីអគ្គសាវ័កទាំងពីរ ជ្រាបថានឹងបៀតបៀនគហបតីដោយជាតិ ទើបពោលថា នែគហបតី សក្ការៈរបស់អ្នកគ្រប់គ្រាន់ តែក្នុងសក្ការៈនេះ មិនមានរបស់ម្យ៉ាងប៉ុណ្ណោះ គហបតីពោលថា របស់អ្វីលោកម្ចាស់ ព្រះថេរៈឆ្លើយថា គឺនំត្រាបល្ង ត្រូវគហបតីបៀតបៀនដោយវាចាឧបមាអំពីក្អែក ក្រោធហើយ ពោលថា នែគហបតី នុ៎ះអាវាសរបស់អ្នក

ហើយចៀសចេញទៅ ។ គហបតីឃាត់ដល់ ៣ ដង ក៏ចៀសទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលពាក្យដែលចិត្តគហបតីនឹងខ្លួនពោលហើយ ។

ព្រះសាស្តាត្រាស់ថា ឧបាសកជាអ្នកមានសទ្ធាជ្រះថ្លា ត្រូវអ្នកជេរដោយពាក្យអាក្រក់ ដូច្នេះហើយ ទ្រង់ជាក់ទោសដល់ព្រះសុធម្មត្ថេរនោះឯង ហើយប្រាប់ឲ្យសង្ឃជាក់បដិសារណីយកម្ម ហើយទ្រង់បញ្ជូនទៅថា ចូរអ្នកទៅឲ្យចិត្តគហបតីអត់ទោសឲ្យ ព្រះថេរៈទៅក្នុងទីនោះហើយ ពោលថា គហបតីនុ៎ះទោសរបស់អាត្មាប៉ុណ្ណោះ ចូរអ្នកអត់ទោសដល់អាត្មាចុះ គហបតីនោះប្រកែកថា ខ្ញុំមិនអត់ទោសឡើយ ក៏ខ្មាសអៀន មិនអាចឲ្យគហបតីនុ៎ះ អត់ទោសបាន ទើបត្រឡប់មកកាន់សម្នាក់ព្រះសាស្តាទៀត ។ ព្រះសាស្តាទ្រង់ជ្រាបថា ឧបាសកមិនអត់ទោសដល់ព្រះសុធម្មៈនេះ ទ្រង់ត្រិះរិះថា កិក្ខុនេះរឹងត្អឹងព្រោះមានះ ចូលទៅកាន់ផ្លូវ ៣ យោជន៍ ហើយត្រឡប់មក ទើបទ្រង់មិនប្រាប់ឧបាយឲ្យអត់ទោសឡើយ ហើយទ្រង់បញ្ជូនទៅ ។

ក្នុងកាលដែលព្រះសុធម្មត្ថេរនោះត្រឡប់មក ព្រះសាស្តាប្រទានកិក្ខុដែលអនុគ្រោះដល់លោក ដែលនាំមានះចេញហើយត្រាស់ថា ចូរអ្នកទៅចុះ ទៅជាមួយកិក្ខុនេះ ចូរឲ្យឧបាសកអត់ទោស ដូច្នេះហើយ ត្រាស់ថា ធម្មតាសមណៈមិនគួរធ្វើមានះ ច្រណែនថា វិហាររបស់អញ លំនៅរបស់អញ ឧបាសករបស់អញ ឧបាសិការបស់អញ ព្រោះកាលសមណៈធ្វើយ៉ាងនោះ ពួកកិលេស មានឥស្សា និងមានះជាដើម រមែងចម្រើន កាលទ្រង់បន្តអនុសន្ធិ ទើបត្រាស់ព្រះគាថានេះថា

អសន្តំ ភាវមិច្ចេយ្យ **បុរេក្ខារញ្ច ភិក្ខុសុ**
អាវាសេសុ ច ឥស្សរិយំ **បូជា បរកុលេសុ ច ។**
មមេវ កត មញ្ញន្តុ **គិហិប្បព្វជិតា ឧភោ**
មមេវ អតិវសា អស្សុ **កិច្ចាកិច្ចេសុ កិស្មិចិ**
ឥតិ ពាលស្ស សង្ឋប្បោ **ឥស្សា មានោ ច វឌ្ឍតិ ។**

ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរ ដែលមិនមាន (ក្នុងខ្លួន) ផង នូវការធ្វើក្នុងខាងមុខ គឺជាប្រមុខក្នុងពួកភិក្ខុផង នូវភាពជាឥស្សរៈក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយ ក្នុងត្រកូលនៃជនទាំងឡាយដទៃផង ភិក្ខុពាល រមែងមានសេចក្តីត្រិះរិះថា គ្រហស្ត និងបព្វជិតទាំងពីរពួក ចូរសម្គាល់នូវកិច្ច ដែលមនុស្សដទៃធ្វើហើយ ថាជាកិច្ចរបស់អញវិញ អំណាចដ៏ក្រៃលែងរបស់អញ ចូរមានក្នុងកិច្ចតូចធំណាៗ មួយ (កាលបើយ៉ាងនេះ) ឬស្សានិងមានះ រមែងចម្រើន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អសន្តំ** *សេចក្តីថា ភិក្ខុពាល គប្បីប្រាថ្នាសេចក្តីសរសើរដែលមិនមាន គឺភិក្ខុពាល មិនមានសទ្ធា ជាអ្នកទ្រុស្តសីល ជាអ្នកស្តាប់តិច មិនស្ងប់ស្ងាត់ ខ្ជិលច្រអូស មានសតិមិនតាំងមាំ មានចិត្តមិន*

មាំទាំ មានបញ្ញាចេាកថយ មិនមែនខីណាសវៈ រមែងប្រាថ្នាការលើកតម្កើង ដែលមិនមាននេះថា ធ្វើម្តេចហ្ន៎ ជនគប្បីស្គាល់អញថា ភិក្ខុនេះ ជាអ្នកមាន សទ្ធា មានសីល ជាពហូសូត ជាអ្នកស្វាត់ ប្រារព្ធសេចក្តីព្យាយាម មាន សតិតាំងមាំ មានចិត្តមាំទាំ មានបញ្ញា ជាព្រះខីណាស្រព ដោយន័យដែល លោកពោលក្នុងបាបិច្ឆតានិទ្ទេសថា ភិក្ខុជាបុគ្គលមិនមានសទ្ធាឡើយ រមែង ប្រាថ្នាថា ចូរជនស្គាល់អញថា ជាអ្នកមានសទ្ធាជាដើម ។

បទថា **បុរេក្ខារំ** *គឺនូវបរិក្ខារ អធិប្បាយថា ភិក្ខុពាល តាំងនៅក្នុង ការប្រព្រឹត្តដោយអំណាច គឺការចង់បានយ៉ាងនេះថា ធ្វើម្តេចហ្ន៎ ភិក្ខុក្នុងវិហារ ទាំងមូលគប្បីចេាមរេាមសួរបញ្ហា ឈ្មោះថា រមែងប្រាថ្នាការចេាមរេាមក្នុង ភិក្ខុទាំងឡាយ ។*

បទថា **អាវាសេសុ** *បានដល់ក្នុងអាវាសដែលជារបស់សង្ឃ អធិប្បាយ ថា ភិក្ខុពាលចាត់សេនាសនៈប្រណីត ត្រង់កណ្តាលវិហារ ដើម្បីភិក្ខុទាំងឡាយ មានភិក្ខុដែលជាសម្ងាញ់ធ្លាប់ឃើញ និងសម្ងាញ់ស្និទ្ធស្នាលជាដើមរបស់ខ្លួន ដោយប្រាប់ថា ចូរពួកលោកនៅក្នុងសេនាសនៈនេះ ចំណែកខ្លួនជ្រៀតជ្រៀត យកសេនាសនៈដែលល្អ រៀបចំសេនាសនៈដែលអាក្រក់ និងសេនាសនៈ ដែលអមនុស្សហួងហែងហើយ តាំងនៅក្នុងទីបំផុត ដើម្បីអាគន្តុកភិក្ខុ ដ៏សេសទាំងឡាយ ដោយប្រាប់ថា ចូរពួកលោកនៅក្នុងសេនាសនៈនេះ ឈ្មោះថា រមែងប្រាថ្នាភាពជាធំក្នុងអាវាស ។*

បាទព្រះគាថាថា **ឫជា បរកុលេសុ ច** *សេចក្តីថា ភិក្ខុពាល រមែងមិន*

ប្រាថ្នាការបូជាដោយបច្ច័យ ៤ ក្នុងត្រកូលរបស់មាតា និងបិតាឡើយ និង របស់ពួកញាតិក៏មិនប្រាថ្នា ។ តែរមែងប្រាថ្នាក្នុងត្រកូលរបស់ជនដទៃប៉ុណ្ណោះ យ៉ាងនេះថា ធ្វើម្តេចហ្ន៎ ជនទាំងនេះគប្បីប្រគេនដល់អញតែម្នាក់ មិនគប្បីឲ្យដល់កិក្ខុទាំងនោះ ។

បាទព្រះគាថាថា **មមេវ កត មញ្ញន្តុ** *សេចក្តីថា ឯការត្រិះរិះរមែងកើតឡើងដល់កិក្ខុពាលថា ពួកគ្រហស្ថ និងបព្វជិតទាំងពីរ ចូរសម្គាល់កិច្ចដែលខ្លួនធ្វើហើយ គឺដែលសម្រេចហើយ ព្រោះអាស្រ័យអាត្មាអញប៉ុណ្ណោះ ដោយបំណងយ៉ាងនេះថា នវកម្មណាមួយដែលគេធ្វើហើយក្នុងវិហារ ដោយអំណាចការធ្វើនវកម្ម មានរោងឧបោសថជាដើម នវកម្មទាំងអស់នោះ ដែលព្រះថេរៈរបស់ពួកយើងធ្វើហើយ ។*

បាទព្រះគាថាថា **មមេវ អតិវិសា អស្សុ** *សេចក្តីថា ការត្រិះរិះរមែងកើតឡើងដល់កិក្ខុដែលជាពាលនោះថា គ្រហស្ថ និងបព្វជិតទាំងអស់ ចូរប្រព្រឹត្តទៅក្នុងអំណាចរបស់អញតែម្នាក់ គឺពាហនៈ និងគ្រឿងឧបករណ៍ទាំងឡាយជាដើមថា រទេះ គោ កាំបិត ពូថៅ ឬដោយហោចកិច្ចទាំងឡាយជាដើម ដូចជាកម្មៅបបរហើយបបរិភោគ ដែលគ្រហស្ថ និងបព្វជិតគប្បីបានក៏ដោយចុះ តែបណ្តាកិច្ចតូច និងកិច្ចធំ គឺបណ្តាករណីយកិច្ចទាំងតូចទាំងធំបែបនេះ គ្រហស្ថ ឬបព្វជិតទាំងឡាយ ចូរប្រព្រឹត្តទៅក្នុងអំណាចរបស់អាត្មាអញប៉ុណ្ណោះ ក្នុងកិច្ចណាមួយ គឺក្នុងកិច្ចឯណាមួយ អធិប្បាយថា ចូរសួរអាត្មាអញប៉ុណ្ណោះ ហើយសឹមធ្វើ ។*

ពីរបទថា **ឥតិ ពាលស្ស** *សេចក្តីថា ការចង់បាននោះ និងការត្រិះរិះបែបនេះ របស់មេងកើតឡើងដល់កិក្ខុពាលណា វិបស្សនា មគ្គ និងផលរបស់មេងមិនចម្រើនដល់កិក្ខុពាលនោះ ។ តែតណ្ហាដែលកើតឡើងក្នុងទ្វារ ៦ និងមានៈ ៩ យ៉ាង របស់មេងចម្រើនដល់កិក្ខុពាលនោះតែម្យ៉ាង ដូចទឹកចម្រើនដល់សមុទ្រ ក្នុងកាលព្រះចន្ទរះឡើង ជួបច្នោះ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

ព្រះសុធម្មត្ថេរស្តាប់ឱវាទនេះហើយ ថ្វាយបង្គំព្រះសាស្តា ក្រោកឡើងអំពីអាសនៈធ្វើប្រទក្សិណហើយ ទៅជាមួយកិក្ខុដែលជាអនុទូតនោះ សម្តែងអាបត្តិក្នុងគន្ធង់ចក្ខុរបស់ឧបាសក ញុំាងឧបាសកឲ្យអត់ទោសហើយ ។ ព្រះសុធម្មត្ថេរនោះ កាលឧបាសកអត់ទោសដោយពាក្យថា ខ្ញុំអត់ទោសដល់លោកម្ចាស់ បើទោសរបស់ខ្ញុំមាន សូមលោកម្ចាស់អត់ទោសដល់ខ្ញុំ ។ ព្រះថេរៈតាំងនៅក្នុងឱវាទដែលព្រះសាស្តាប្រទានហើយ ២-៣ ថ្ងៃប៉ុណ្ណោះ ក៏សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទា ។

ចំណែកឧបាសកគិតថា អញមិនទាន់បានគាល់ព្រះសាស្តាឡើយ កាលសម្រេចសោតាបត្តិផលហើយ មិនទាន់បានគាល់ព្រះសាស្តាដូចគ្នា កាលតាំងនៅក្នុងអនាគាមិនផល អញគួរគាល់ព្រះសាស្តាដោយពិត ។ គហបតីនោះទឹមរនេះ ៥០០ ជាក់ពេញដោយវត្ថុ មានល្ង អង្ករ សប្បិ ទឹកអំពៅ និងសំពត់ជណ្តប់ជាដើមហើយ ឲ្យពិតដល់កិក្ខុទាំងឡាយថា លោកម្ចាស់ទាំងឡាយណា

បំណងនឹងគាល់ព្រះសាស្តា សូមលោកម្ចាស់ទាំងឡាយនោះនិមន្តទៅ នឹងមិនលំបាកដោយបិណ្ឌបាតជាដើម ដូច្នេះហើយ ក៏ឲ្យពិតដល់ភិក្ខុនីទាំងឡាយ និងប្រាប់ដល់ពួកឧបាសក និងឧបាសិកា ។ ភិក្ខុប្រមាណ ៥០០ រូប ភិក្ខុនីប្រមាណ ៥០០ រូប ពួកឧបាសកប្រមាណ ៥០០ រូប ឧបាសិកាប្រមាណ ៥០០ រូប ចេញទៅជាមួយគហបតីនោះ ។ គាត់ត្រៀមរៀបចំហើយដោយប្រការ ដែលមិនមានការខ្វះខាតសូម្បីតិចតួចដោយបាយ យាគូ និងភត្តជាដើម អស់ចម្ងាយផ្លូវ ៣០ យោជន៍ ដើម្បីជន ៣ ពាន់នាក់ គឺដើម្បីភិក្ខុជាដើមទាំងនោះឯង និងដើម្បីបរិស័ទរបស់ខ្លួន ។ ចំណែកពួកទេវតា ជ្រាបភាពដែលឧបាសកនោះចេញទៅហើយ ចោះជំរំស្នាក់នៅរៀងរាល់មួយយោជន៍ ទំនុកបម្រុងជនទាំងនោះដោយអាហារវត្ថុ មានបបរ របស់ទំពា ភត្ត និងទឹកជាដើមដែលជាទិព្វ ការខ្វះខាតដោយវត្ថុណាមួយ មិនមានហើយដល់បុគ្គលណាមួយឡើយ មហាជនដែលទេវតាទាំងឡាយ ទំនុកបម្រុងយ៉ាងនោះ ធ្វើដំណើរបានមួយថ្ងៃមួយយោជន៍ៗ មួយខែដល់ក្រុងសាវត្ថី ។ រនេះទាំងឡាយ ៥០០ នៅពេញបរិបូណ៌ដូចដើមនោះឯង ។ គហបតីបានលះបណ្ណាការ ដែលពួកទេវតានោះឯង និងមនុស្សទាំងឡាយនាំមកហើយទៅ ។

ព្រះសាស្តាត្រាស់នឹងព្រះអានន្ទត្ថេរថា អានន្ទ ក្នុងពេលរសៀលថ្ងៃនេះ ចិត្តគហបតីដែលឧបាសក ៥០០ ចោមរោមហើយនឹងមកថ្វាយបង្គំតថាគត ។

ព្រះអានន្ទសួរថា បពិត្រព្រះអង្គ ក្នុងកាលចិត្តគហបតីនោះ ថ្វាយបង្គំព្រះអង្គ បាដិហារ្យណាមួយនឹងមានឬ ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ

មាន អានន្ទសួរថា បពិត្រព្រះអង្គ តើបាដិហារ្យនោះជាអ្វី ព្រះសាស្តាត្រាស់ ថា ក្នុងកាលចិត្តគហបតីនោះមកថ្វាយបង្គំតថាគត ភ្លៀងបោក្ខរពស្សិ ផ្គាំដែល ជាទឹកមាន ៥ ពណ៌ និងធ្លាក់ប្រមាណត្រឹមក្បាលជង្គង់ ក្នុងទីប្រមាណ ៨ កំរិស ដោយវិធីរាប់របស់ស្តេច ។

អ្នកក្រុងស្តាប់ដំណឹងនោះហើយគិតថា បានឮថា ចិត្តគហបតី មាន បុណ្យច្រើនយ៉ាងនោះ មកថ្វាយបង្គំព្រះសាស្តាក្នុងថ្ងៃនេះ បានឮថា បាដិហារ្យ បែបនេះនឹងមាន ឯពួកយើងនឹងបានឃើញអ្នកមានបុណ្យច្រើននោះ ដូច្នេះ ហើយ បានកាន់យកគ្រឿងបណ្ណាការទៅឈរសងខាងផ្លូវ ក្នុងកាលដែល ចិត្តគហបតីមកជិតវិហារ កិកុ ៥០០ រូបមកជល់មុន ។ ចិត្តគហបតីពោល នឹងឧបាសិកាថា នែពួកនាងទាំងឡាយ ចូរនាងមកខាងក្រោយ ចំណែក ឧបាសក ៥០០ ចោមរោមហើយ បានទៅកាន់សម្នាក់របស់ព្រះសាស្តា ។ ជនទាំងឡាយដែលឈរក្តី អង្គុយក្តី ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធទាំង-ឡាយ មិនមានខាងនេះ ឬខាងនោះ រមែងឈរណែនណាន់តាន់តាប់ទាំងសង ខាងនៃពុទ្ធវិថី ។ ចិត្តគហបតី ចូលកាន់ពុទ្ធវិធីធំហើយ ។ ទីដែលព្រះអរិយ-សាវក អ្នកដល់នូវផល ៣ សម្ងំមើល ញាប់ញ័រហើយ ។ មហាជនសម្ងំ មើលហើយដោយគិតថា បានឮថា ជននោះ គឺចិត្តគហបតី ។ គហបតីនោះ ចូលគាល់ព្រះសាស្តា ចូលទៅខាងក្នុងពុទ្ធរស្មីមាន ៦ ពណ៌ ចាប់ព្រះបាទ ព្រះសាស្តាត្រង់កព្រះបាទទាំងពីរថ្វាយបង្គំហើយ ក្នុងខណៈនោះឯង ភ្លៀងផ្គា មានប្រការដូចពោលមក ធ្លាក់ហើយ សំឡេងសាធុការរាប់ពាន់ ប្រព្រឹត្តទៅ

ហើយ ។

គហបតីនោះ នៅក្នុងសម្នាក់ព្រះសាស្តាអស់កាលមួយខែ បាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យគង់ក្នុងវិហារនោះឯង ថ្វាយមហាទានហើយ ។ ធ្វើភិក្ខុដែលមកជាមួយខ្លួននៅក្នុងវិហារនោះឯង ទំនុកបម្រុងហើយ មិនចាំបាច់ចាប់យករបស់ណាមួយក្នុងរនេះរបស់ខ្លួន សូម្បីត្រឹមមួយថ្ងៃ ។ បានធ្វើកិច្ចគ្រប់យ៉ាងដោយបណ្ណាការ ដែលទេវតា និងមនុស្សទាំងឡាយនាំមកប៉ុណ្ណោះ ចិត្តគហបតីនោះ ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមកដោយតាំងចិត្តថា នឹងថ្វាយទានដល់ព្រះអង្គ បានស្នាក់នៅក្នុងរវាងផ្លូវមួយខែ ខ្ញុំព្រះអង្គនៅក្នុងទីនេះកន្លងទៅមួយខែហើយ ខ្ញុំព្រះអង្គមិនបានកាន់យករបស់ណាមួយដែលខ្ញុំព្រះអង្គនាំមកឡើយ បានថ្វាយទានអស់កាលមានប្រមាណប៉ុណ្ណោះ ដោយបណ្ណាការដែលទេវតា និងមនុស្សទាំងឡាយ នាំមកប៉ុណ្ណោះ បើខ្ញុំព្រះអង្គនោះនៅក្នុងទីនេះមួយឆ្នាំ ក៏មិនបានថ្វាយទេយ្យធម៌របស់ខ្ញុំព្រះអង្គពិត ខ្ញុំព្រះអង្គប្រថ្នាធ្វើរនេះឲ្យស្រាលហើយទៅ សូមទ្រង់មេត្តាប្រាប់ទីសម្រាប់រក្សាដល់ខ្ញុំព្រះអង្គចុះ ។

ព្រះសាស្តាត្រាស់ជាមួយអានន្ទត្ថេរថា ម្នាលអានន្ទ ចូរអ្នកឲ្យទីទំនេរមួយកន្លែងដល់ឧបាសក ព្រះថេរៈឲ្យធ្វើយ៉ាងនោះហើយ ។ បានឮថា ព្រះសាស្តាទ្រង់អនុញ្ញាតកប្បិយភូមិដល់ចិត្តគហបតីហើយ ឯឧបាសក និងជន ៣ ពាន់នាក់ដែលមកជាមួយខ្លួន ធ្វើដំណើរត្រឡប់ដោយរនេះទៅហើយ ។ ពួកទេវតា និងមនុស្សក្រោកឡើងហើយ ពោលថា បពិត្រឧបាសក អ្នកធ្វើកម្ម

គឺការធ្វើដំណើរទៅដោយរនេះទេ ដូច្នេះហើយ ក៏ជាក់រនេះឲ្យពេញដោយ រតន: ៧ ប្រការ ។ គហបតីនោះ បានទំនុកបម្រុងមហាជនដោយបណ្ណាការ ដែលនាំមកដើម្បីខ្លួនទៅហើយ ។

ព្រះអានន្ទត្ថេរ ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ ចិត្តគហបតីកាលមកកាន់សម្នាក់របស់ព្រះអង្គ មកហើយដោយខែមួយ នៅ ក្នុងទីនេះអស់មួយខែដូចគ្នា បានថ្វាយទានដោយបណ្ណាការដែលទេវតា និង មនុស្សនាំមកប៉ុណ្ណោះអស់កាលប៉ុណ្ណេះ ។ បានឮថា ឥឡូវនេះ គហបតីនោះ ធ្វើរនេះ ៥០០ ឲ្យទេ នឹងទៅដោយខែមួយដូចគ្នា ទេវតា និងមនុស្សទាំង- ទ្វាយ ក្រោកឡើងហើយពោលដល់គហបតីនោះថា បពិត្រឧបាសក អ្នកធ្វើ កម្ម គឺការធ្វើដំណើរទៅដោយរនេះទេ ដូច្នេះហើយ ក៏ផុករតន: ៧ ប្រការ ពេញក្នុងរនេះ បានឮថា គហបតីទំនុកបម្រុងមហាជនដោយគ្រឿងបណ្ណាការ ដែលទេវតា និងមនុស្សនាំមកដើម្បីខ្លួននោះឯង និងត្រឡប់ទៅ ។ សក្ការៈ នេះកើតឡើងដល់គហបតីនេះ ដែលមកកាន់សម្នាក់របស់ព្រះអង្គប៉ុណ្ណោះឬ ឬក្នុងទីដទៃកើតឡើងដូចគ្នា ។

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ចិត្តគហបតីនោះ មកកាន់សម្នាក់ តថាគតក្តី ទៅកាន់ទីដទៃក្តី សក្ការៈរមែងកើតឡើងទាំងអស់ ព្រោះឧបាសក នេះ ជាអ្នកមានសទ្ធាជ្រះថ្លា មានសីលបរិបូណ៌ ឧបាសកបែបនេះ រមែងទៅ បទេសណាមួយ លាភសក្ការៈ រមែងកើតឡើងដល់បុរសនោះ ក្នុងបទេស នោះៗ ឯង ដូច្នេះហើយ ត្រាស់ព្រះគាថាក្នុងបកិណ្ណកវគ្គថា

បុគ្គលមានសទ្ធា បរិបូណ៌ដោយសីល ស្តាប់ស្តាល់
ដោយយស និងភោគសម្បត្តិ គប់រកប្រទេសណាៗ
គេតែងបូជាក្នុងប្រទេសនោះៗ ។

ឯអត្ថនៃព្រះគាថានោះ ជាក់ច្បាស់ក្នុងបកិណ្ណកវគ្គនោះឯង ។

ព្រះសាស្តាត្រាស់យ៉ាងនោះហើយ ទើបព្រះអានន្ទត្ថេរទូលសួរបុព្វកម្ម របស់ចិត្តគហបតី ។ លំដាប់នោះ ព្រះសាស្តាកាលនឹងត្រាស់ដល់ព្រះអានន្ទ ទើបត្រាស់ថា ម្នាលអានន្ទ ចិត្តគហបតីនេះ មានអភិនីហារបានធ្វើហើយ ទៀបបាទមូលរបស់ព្រះដ៏មានព្រះភាគ ព្រះនាមបទុមុត្តរៈ អន្លងទៅក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវការចម្រើនហើយ ។ ថ្ងៃមួយ កាលភ្លៀងធ្លាក់កាន់លំពែងដើរចូលព្រៃ ដើម្បីរកម្រឹគ សម្លឹងមើលពួកម្រឹគ ឃើញភិក្ខុមួយរូបអង្គុយទទួរក្បាល ត្រង់ញកដែលកើតឯងមួយកន្លែង គិតថា លោកម្ចាស់មួយរូប អង្គុយធ្វើសមណធម៌ អញនឹងនាំអាហារមក ដើម្បីលោកម្ចាស់នោះដូច្នេះហើយ ប្រញាប់ទៅកាន់ផ្ទះ ឲ្យមនុស្សអាំងសាច់ដែលខ្លួននាំមកកាលពីម្សិលមិញលើចង្ក្រានមួយ ឲ្យដាំបាយលើចង្ក្រានមួយ ឃើញភិក្ខុត្រាច់បិណ្ឌបាតពួកជនៃ ទទួលបាត្ររបស់ភិក្ខុទាំងនោះ និមន្តឲ្យគង់លើអាសនៈដែលខ្លួនចាត់ចែង ត្រៀមភិក្ខាហើយ ប្រាប់អ្នកជនៃថា ចូរពួកអ្នកអង្គាសលោកម្ចាស់ទាំងឡាយ ហើយជាក់កត្តនោះក្នុងល្អីកាន់ដើរទៅ បេះផ្កាផ្សេងៗ ក្នុងរវាងផ្លូវ ខ្ចប់ដោយស្លឹកឈើ ទៅកាន់ទីដែលព្រះថេរៈគង់ ហើយពោលថា បពិត្រ

លោកម្ចាស់ សូមលោកម្ចាស់ធ្វើសេចក្តីសង្គ្រោះដល់ខ្ញុំចុះ ដូច្នេះហើយ ទទួលបាត្រ ឲ្យពេញដោយភត្តហើយ ដាក់ក្នុងដៃរបស់ព្រះថេរៈ ធ្វើការបូជាដោយផ្កាទាំងនោះ តាំងសេចក្តីប្រាថ្នាថា បិណ្ឌបាតមានរសនេះ ព្រមដោយផ្កាដែលជាគ្រឿងបូជា ញុំាងចិត្តរបស់ខ្ញុំឲ្យត្រេកអរ យ៉ាងណា សូមបណ្ណាការមួយពាន់ មកញុំាងចិត្តរបស់ខ្ញុំឲ្យត្រេកអរ ក្នុងទីដែលខ្ញុំកើតហើយយ៉ាងនោះ ។ សូមភ្លៀងផ្កាដែលមានពណ៌ ៥ ធ្លាក់ចុះ ។ បុរសនោះបំពេញកុសលជរាបជល់អស់ជីវិតហើយ កើតក្នុងទេវលោក ។ ភ្លៀងផ្កាទិព្វធ្លាក់ហើយ ប្រមាណត្រឹមជង្គង់ក្នុងទីដែលគាត់កើតហើយ ។ សូម្បីក្នុងកាលនេះ ភ្លៀងផ្កាក៏ធ្លាក់ក្នុងថ្ងៃដែលគាត់កើតហើយ កាលគាត់មកក្នុងទីនេះ ការនាំបណ្ណាការមក និងការដែលរនេះពេញដោយរតនៈ ៧ ប្រការ ក៏ជាផលនៃកម្មនោះឯង ៗ

រឿងព្រះសុធម្មត្ថេរ ចប់

រឿង ព្រះវនវាសីតិស្សត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះតិស្សត្ថេរ ដែលមានប្រក្រតីនៅព្រៃ ត្រាស់ព្រះធម្មទេសនានេះថា **អញ្ញា ហិ លាភូ-បនិសា** ជាដើម ។

ទេសនាតាំងឡើងហើយក្នុងក្រុងរាជគ្រឹះ បានឲ្យថា សម្ងាញ់របស់វង្គន្ត-ព្រាហ្មណ៍ដែលជាបិតារបស់ព្រះសារីបុត្តត្ថេរ ឈ្មោះមហាសេនព្រាហ្មណ៍ នៅក្នុងក្រុងរាជគ្រឹះ ។ ថ្ងៃមួយ ព្រះសារីបុត្តត្រាច់បិណ្ឌបាត បានទៅកាន់ទ្វារផ្ទះ របស់ព្រាហ្មណ៍នោះ ដើម្បីអនុគ្រោះដល់គាត់ តែព្រាហ្មណ៍មានសម្បត្តិអស់ហើយ ក្ងាយជាមនុស្សក្រីក្រ គិតថា កូនរបស់អញនឹងមកដើម្បីត្រាច់បិណ្ឌ-បាត ត្រង់ទ្វារផ្ទះរបស់អញ តែអញជាមនុស្សក្រីក្រ កូនរបស់អញប្រហែល ជាមិនជ្រាបភាពដែលអញជាមនុស្សក្រីក្រ ទេយ្យធម៌ណាមួយ របស់អញ មិនមាន កាលមិនអាចជួបព្រះថេរៈនោះបាន ទើបរត់ពួន ។ សូម្បីក្នុងថ្ងៃដទៃ ព្រះថេរៈបានទៅទៀត ។ ព្រាហ្មណ៍បានរត់ពួនយ៉ាងនោះដូចគ្នា ។ គាត់គិតថា អញបានវត្ថុអ្វីមួយដើម្បីប្រគេនហ្នឹ ក៏មិនបានវត្ថុណាមួយ ។ ថ្ងៃក្រោយមក គាត់បានថាសពេញដោយបាយាស មួយអន្ទើដោយសំពត់សាដកសាច់គ្រោត គ្រាត ក្នុងទីប្រាប់លទ្ធិរបស់ព្រាហ្មណ៍មួយកន្ទែង កាន់ទៅដល់ផ្ទះ នឹកដល់ព្រះ ថេរៈថា កាលដែលអញប្រគេនបិណ្ឌបាតនេះដល់ព្រះថេរៈ គួរ ។

ក្នុងខណៈនោះឯង ព្រះថេរៈចូលឈាន ចេញអំពីឈានសមាបត្តិហើយ

ឃើញព្រាហ្មណ៍នោះគិតថា ព្រាហ្មណ៍បានទេយ្យធម៌ហើយ ទន្ទឹងនូវកម្មរបស់អាត្មាអញ ការដែលអាត្មាអញទៅក្នុងទីនោះគួរ ដូច្នេះហើយ ទើបដណ្តប់សំពត់សង្ឃាដិ កាន់បាត្រ បង្ហាញខ្លួនឈរហើយត្រង់ទ្វារផ្ទះរបស់ព្រាហ្មណ៍នោះឯង ។ ព្រោះឃើញព្រះថេរៈប៉ុណ្ណោះ ចិត្តរបស់ព្រាហ្មណ៍ជ្រះថ្លាហើយ ។ លំដាប់នោះ គាត់ចូលទៅរកព្រះថេរៈនោះ ថ្វាយបង្គំហើយ ធ្វើបដិសណ្ឋារៈនិមន្តឲ្យគង់ខាងក្នុងផ្ទះ កាន់ថាសដែលពេញដោយបាយាស កៀរទម្លាក់ទៅក្នុងបាត្រព្រះថេរៈ ។ ព្រះថេរៈទទួលពាក់កណ្តាលហើយ យកដៃបិទបាត្រ ។ ពេលនោះ ព្រាហ្មណ៍ពោលនឹងព្រះថេរៈនោះថា បពិត្រលោកម្ចាស់ បាយាសនេះ ត្រឹមតែជាចំណែករបស់បុគ្គលម្នាក់ប៉ុណ្ណោះ សូមលោកម្ចាស់ធ្វើសេចក្តីសង្គ្រោះក្នុងចរលោកដល់ខ្ញុំចុះ កុំធ្វើសេចក្តីសង្គ្រោះក្នុងលោកនេះទៀតឡើយ ខ្ញុំប្រាថ្នាប្រគេន មិនឲ្យសេសសល់ឡើយ ដូច្នេះហើយ ទើបជាក់ទាំងអស់ ។ ព្រះថេរៈឆាន់ក្នុងទីនោះឯង ។ កាលក្នុងវេលាស្រេចភត្តកិច្ច គាត់ថ្វាយសំពត់សាដកនោះដល់ព្រះថេរៈនោះ ថ្វាយបង្គំហើយ ពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ ខ្ញុំគប្បីសម្រេចធម៌ដែលលោកម្ចាស់ឃើញហើយជួចគ្នា ។ ព្រះថេរៈធ្វើអនុមោទនាដល់ព្រាហ្មណ៍នោះថា ចូរសម្រេចយ៉ាងនោះចុះ ក្រោកឡើងចាកអាសនៈចៀសទៅ ត្រាច់ចារិកដោយលំដាប់ ដល់វត្តជេតពនហើយ ។

ទានដែលបុគ្គលឲ្យហើយ ក្នុងគ្រាដែលក្រីក្រ រមែងញុំាងអ្នកឲ្យ ឲ្យត្រេកអរក្រៃលែង ព្រោះដូច្នោះព្រាហ្មណ៍ថ្វាយទាននោះហើយ មានចិត្តជ្រះថ្លាកើតសោមនស្សហើយ បានធ្វើសេចក្តីស្រឡាញ់ក្រៃលែងក្នុងព្រះថេរៈ ដោយ

ការស្រឡាញ់ក្នុងព្រះថេរៈនោះឯង ព្រាហ្មណ៍នោះធ្វើកាលកិរិយាហើយ បដិសន្ធិក្នុងត្រកូលឧបដ្ឋាករបស់ព្រះថេរៈ ក្នុងក្រុងសាវត្ថី ។ ក្នុងខណៈនោះឯង មាតារបស់ទារកជ្រាប់ដល់ប្តីថា សត្វកើតក្នុងគភ៌របស់ខ្ញុំហើយ ។ ប្តីនោះបានឲ្យគ្រឿងបរិហារគភ៌ដល់មាតារបស់ទារកនោះហើយ ។ កាលនាងវៀរចាកការបរិភោគអាហារវត្ថុមានរបស់ដែលក្តៅពេក ត្រជាក់ពេក ជូរពេកជាដើម រក្សាគភ៌ដោយសប្បាយ ការចាញ់គភ៌កើតឡើងបែបនេះថា ធ្វើម្តេចហ្ន៎ អញគប្បីនិមន្តភិក្ខុ ៥០០ រូប មានព្រះសារីបុត្តត្ថេរជាប្រធាន ឲ្យអង្គុយក្នុងផ្ទះប្រគេនបាយាស លាយដោយទឹកដោះ ខ្លួនឯងស្លៀកកាសាវពស្ត្រ កាន់ផ្តិលមាសអង្គុយខាងចុងនៃអាសនៈ ហើយបរិភោគបាយាសដែលសល់របស់ភិក្ខុប្រមាណប៉ុណ្ណោះ ។ បានឮថា ការចាញ់គភ៌ចង់ស្លៀកកាសាវពស្ត្ររបស់នាងនោះ បានជាបុព្វនិមិត្តនៃការចេញបព្វជ្ជាក្នុងព្រះពុទ្ធសាសនារបស់កូនក្នុងផ្ទៃ ។ លំដាប់នោះ ពួកញាតិរបស់នាងគិតថា ការចាញ់គភ៌របស់កូនស្រីអញប្រកបដោយធម៌ ដូច្នេះហើយ ទើបប្រគេនបាយាស លាយដោយទឹកដោះសុទ្ធដល់ភិក្ខុ ៥០០ រូប ធ្វើព្រះសារីបុត្តត្ថេរឲ្យជាសង្ឃត្ថេរ សូម្បីនាងក៏ស្លៀកកាសាវពស្ត្រមួយផ្ទាំង ដណ្តប់មួយផ្ទាំង កាន់ផ្តិលមាស អង្គុយក្នុងទីបំផុតនៃអាសនៈ បរិភោគបាយាស ដែលជាសំណល់របស់ភិក្ខុ ។ ការចាញ់គភ៌របស់នាងស្ងប់ហើយ ក្នុងមង្គលដែលគេធ្វើហើយក្នុងចន្លោះៗ ដល់នាងនោះ អស់កាលសត្វកើតក្នុងគភ៌ រហូតប្រសូតក្តី មង្គលដែលគេធ្វើដល់នាងប្រសូតបុត្រហើយដោយកន្លងទៅ ១០ ខែក្តី ពួកញាតិក៏បានថ្វាយមធុបាយាស ដែលមានទឹក

តិចជាល់កិក្ខុប្រមាណ ៥០០ រូប មានព្រះសារីបុត្តត្ថេរជាប្រធានដូចគ្នា ។ បានឮថា នេះជាផលនៃបាយាស ដែលទារកប្រគេនហើយ ក្នុងកាលដែលខ្លួនជាព្រាហ្មណ៍ក្នុងកាលមុន ។ ក្នុងថ្ងៃមង្គលដែលពួកញាតិធ្វើក្នុងថ្ងៃដែលទារកកើត ពួកញាតិឲ្យទារកនោះងូតទឹកអំពីព្រលឹម ប្រដាប់ហើយ ឲ្យដេកលើសំពត់កម្ពលមានតម្លៃមួយសែន ត្រង់ទីដេកដ៏មានសិរី ។

ទារកនោះដេកលើសំពត់កម្ពលនោះឯង សម្លឹងមើលព្រះថេរៈហើយគិតថា ព្រះថេរៈនេះជាបុព្វាចារ្យរបស់អញ អញបានសម្បត្តិនេះព្រោះអាស្រ័យព្រះថេរៈនេះ ការដែលអញធ្វើការបរិច្ចាគវត្ថុអ្វីមួយដល់លោកគួរ កាលញាតិនាំទៅដើម្បីប្រយោជន៍ ដល់ការទទួលសិក្ខាបទ បានយកដៃខ្ទាំសំពត់កម្ពលនោះ ។ កាលនោះ ញាតិទាំងឡាយរបស់ទារកនោះគិតថា សំពត់កម្ពលជាប់ត្រង់ដៃហើយ ប្រាថ្នានឹងយកចេញ ។ ទារកនោះស្រែកហើយ ពួកញាតិពោលថា ចូរពួកអ្នកចៀសចេញចុះ អ្នកទាំងឡាយកុំធ្វើទារកឲ្យយំទៀតឡើយ ដូច្នេះហើយ ទើបនាំទៅ មួយអន្ទើដោយសំពត់នោះឯង ។ ក្នុងពេលថ្វាយបង្គំព្រះថេរៈ ទារកនោះលាដៃចេញអំពីសំពត់កម្ពល ឲ្យសំពត់ធ្លាក់ចុះទៀបបាទជើងរបស់ព្រះថេរៈ ។ លំដាប់នោះ ពួកញាតិមិនពោលថា កុមារមិនដឹងធ្វើហើយ តែបែរជាពោលថា បពិត្រលោកម្ចាស់ សំពត់ដែលកូនរបស់ខ្ញុំប្រគេនហើយ សូមជាការបរិច្ចាគហើយនោះឯង ដូច្នេះហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យសិក្ខាបទ ដល់ទាសៈរបស់លោកម្ចាស់ ដែលធ្វើការបូជាដោយសំពត់កម្ពលមានតម្លៃមួយសែននោះឯង ព្រះថេរៈសួរថា ទារកនេះ

ឈ្មោះអ្វី ពួកញាតិជ្រាប់ថា ឈ្មោះដូចលោកម្ចាស់នោះឯង ព្រះថេរៈពោលថា ឈ្មោះតិស្សៈឬ ។

បានឮថា ព្រះថេរៈកាលនៅជាគ្រហស្ថ មានឈ្មោះថាឧបតិស្សមាណព សូម្បីម្តាយរបស់ក្មេងនោះក៏គិតថា អញមិនគួរទម្លាយអធ្យាស្រ័យបុត្រ ។ ពួកញាតិកាលធ្វើមង្គល គឺការដាក់ឈ្មោះដល់ក្មេងយ៉ាងនោះហើយ ក្នុងមង្គល គឺការបរិភោគអាហាររបស់ក្មេងនោះក្តី ក្នុងមង្គល គឺការចោះត្រចៀករបស់ក្មេងនោះក្តី ក្នុងមង្គល គឺការស្បៃកសំពត់របស់ក្មេងនោះក្តី ក្នុងមង្គល គឺការកោរជុកបស់ក្មេងនោះក្តី បានប្រគេនបាយាសដែលមានទឹកតិចដល់ភិក្ខុប្រមាណ ៥០០ រូប មានព្រះសារីបុត្តត្ថេរជាប្រធាន ។ កុមារចម្រើនវ័យហើយ ពោលនឹងម្តាយក្នុងកាលមានអាយុ ៧ ឆ្នាំថា បពិត្រអ្នកម៉ែ ខ្ញុំនឹងបួសក្នុងសម្នាក់របស់ព្រះថេរៈ ម្តាយនោះទទួលថា សាធុកូន កាលមុនម៉ែក៏តាំងចិត្តថា អញមិនគួរទម្លាយអធ្យាស្រ័យរបស់កូន ចូរកូនបួសចុះ ដូច្នេះហើយ ឲ្យមនុស្សនិមន្តព្រះថេរៈមក ថ្វាយភិក្ខាដល់ព្រះថេរៈនោះដែលមកហើយ ពោលថា បពិត្រលោកម្ចាស់ ទាសៈរបស់លោកម្ចាស់ពោលថានឹងបួស ខ្ញុំនឹងនាំទាសៈរបស់លោកម្ចាស់នេះ ទៅកាន់វិហារក្នុងពេលល្ងាច បញ្ជូនព្រះថេរៈទៅហើយ ក្នុងពេលល្ងាចនាំកូនទៅកាន់វិហារដោយសក្ការៈ និងសម្មានៈជាច្រើន ហើយក៏ប្រគល់ដល់ព្រះថេរៈ ។

ព្រះថេរៈពោលនឹងកុមារនោះថា តិស្សៈ ឈ្មោះថា ការបួសជារបស់ដែលធ្វើបានលំបាក កាលសេចក្តីត្រូវការដោយរបស់ក្តៅមាន រមែងបាន

របស់ត្រជាក់ កាលសេចក្តីត្រូវការរបស់ត្រជាក់មាន រមែងបានរបស់ក្តៅ ឈ្មោះថា អ្នកបួសទាំងឡាយ រមែងរស់នៅដោយលំបាក ឯអ្នកសោយសុខ មកហើយ តិស្សកុមារពោលថា បពិត្រលោកម្ចាស់ ខ្ញុំអាចធ្វើបានគ្រប់យ៉ាង តាមទំនងដែលលោកម្ចាស់ប្រាប់ហើយ ។

ព្រះថេរៈពោលថា សាធុ ហើយប្រាប់តចបញ្ចកកម្មដ្ឋានដោយអំណាច នៃការធ្វើទុកក្នុងចិត្ត ជារបស់បដិបូលដល់កុមារនោះ ឲ្យកុមារបួសហើយ ។ ពិតហើយ ការដែលភិក្ខុប្រាប់អាការ ៣២ ទាំងអស់គួរពិត កាលមិនអាចប្រាប់បានទាំងអស់ គប្បីប្រាប់តចបញ្ចកកម្មដ្ឋានក៏បាន ព្រោះថា កម្មដ្ឋាននេះ ព្រះពុទ្ធគ្រប់អង្គទ្រង់មិនលះដោយពិត ការកំណត់ភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ដែលសម្រេចអរហត្ត ក្នុងបណ្តាអាការទាំងឡាយ មានសក់ ជាដើម ចំណែកនីមួយៗ រមែងមិនមាន ។ ភិក្ខុទាំងឡាយដែលមិនឈ្វាស កាលញ៉ាំងកូនឲ្យបួស រមែងញ៉ាំងឧបនិស្សយនៃអរហត្តឲ្យវិនាស ព្រោះហេតុនោះ ព្រះថេរៈប្រាប់កម្មដ្ឋានហើយ ទើបឲ្យបួស ឲ្យតាំងនៅក្នុងសីល ១០ ។ មាតាបិតាធ្វើសក្ការៈដល់បុត្រដែលបួសហើយ បានថ្វាយមធុបាយាស ដែលមានទឹកតិចប៉ុណ្ណោះដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ក្នុងវិហារនោះឯង អស់ ៧ ថ្ងៃ ។ ចំណែកភិក្ខុទាំងឡាយពោលទោសថា យើងទាំងឡាយមិនអាចឆាន់មធុបាយាស មានទឹកតិចជានិច្ចបាន ។ មាតាបិតារបស់សាមណេរនោះ បានទៅកាន់ផ្ទះក្នុងពេលល្ងាច ក្នុងថ្ងៃទី ៧ ។ ក្នុងថ្ងៃទី ៨ សាមណេរទៅបិណ្ឌបាតជាមួយភិក្ខុទាំងឡាយ ។

អ្នកក្រុងសាវត្ថីពោលថា បានឮថា សាមណេរចូលទៅបិណ្ឌបាតក្នុងថ្ងៃនេះ ពួកយើងនឹងធ្វើសក្ការៈដល់សាមណេរនោះ ដូច្នេះហើយ ទើបធ្វើឈ្នួតក្បាលដោយសំពត់សាដកប្រមាណ ៥០០ ផ្ទាំង ចាត់ចែងបិណ្ឌបាតប្រមាណ ៥០០ សម្រាប់ បានកាន់ទៅឈរស្ទាក់ផ្លូវប្រគេនហើយ ។ ក្នុងថ្ងៃស្អែកឡើង បានមកកាន់ព្រៃក្បែរវិហារ ប្រគេនហើយ ។ សាមណេរបានបិណ្ឌបាតមួយពាន់ សំពត់សាដកមួយពាន់ផ្ទាំងក្នុង ២ ថ្ងៃប៉ុណ្ណោះ ដោយអាការយ៉ាងនេះ បានឲ្យមនុស្សប្រគេនដល់ភិក្ខុសង្ឃហើយ ។ បានឮថា នុ៎ះជាផលនៃសំពត់សាដកសាច់គ្រោតគ្រាត ដែលសាមណេរប្រគេនហើយ ក្នុងកាលនៅជាព្រាហ្មណ៍ ។ លំដាប់នោះ ភិក្ខុទាំងឡាយដាក់ឈ្មោះឲ្យសាមណេរនោះថា បិណ្ឌបាតទាយកតិស្សៈ ។ ថ្ងៃមួយ ក្នុងរដូវវស្សា សាមណេរត្រាច់ចារិកទៅក្នុងវិហារ ឃើញភិក្ខុទាំងឡាយអាំងភ្លើងក្នុងរោងភ្លើងជាដើមក្នុងទីនោះៗ ទើបសាកសួរថា បពិត្រលោកម្ចាស់ ហេតុអ្វី ទើបលោកម្ចាស់អង្គុយអាំងភ្លើង ។

ពួកភិក្ខុពោលថា នែសាមណេរ រដូវបៀតបៀនពួកយើង សាមណេរពោលថា បពិត្រលោកម្ចាស់ ធម្មតារដូវវស្សា លោកម្ចាស់ទាំងឡាយ គួរដណ្តប់សំពត់កម្ពល ព្រោះសំពត់កម្ពលនោះ អាចការពាររដូវបាន ។

ពួកភិក្ខុពោលថា សាមណេរ ខ្លួនអ្នកមានបុណ្យច្រើន គប្បីបានសំពត់កម្ពល ពួកយើងនឹងបានសំពត់កម្ពលអំពីទីណា សាមណេរពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយដែលត្រូវការសំពត់កម្ពលមកតាមខ្ញុំចុះ ហើយឲ្យជ្រាបដល់ភិក្ខុក្នុងវិហារទាំងអស់ ។ ភិក្ខុទាំងឡាយគិត

ថា ពួកយើងនឹងទៅជាមួយសាមណេរ ហើយនាំសំពត់កម្ពលមក អាស្រ័យសាមណេរដែលមានអាយុ ៧ ឆ្នាំ ចេញទៅហើយប្រមាណមួយពាន់រូប ។ សាមណេរនោះ មិនឲ្យចិត្តកើតឡើងថា អញនឹងបានសំពត់អំពីណាដើម្បីភិក្ខុប្រមាណប៉ុណ្ណេះ ។ ពួកភិក្ខុទាំងនោះ បែរមុខទៅកាន់ព្រះនគរហើយ មែនពិតទានដែលបុគ្គលឲ្យល្អហើយ រមែងមានអានុភាពបែបនេះ ។ សាមណេរនោះ ត្រាច់ទៅតាមលំដាប់ផ្ទះ ខាងក្រៅព្រះនគរប៉ុណ្ណោះ បានសំពត់កម្ពលប្រមាណ ៥០០ ហើយនាំចូលទៅខាងក្នុងព្រះនគរ ។ ពួកមនុស្សនាំសំពត់កម្ពលមកអំពីនោះទីនេះ ។ ចំណែកបុរសម្នាក់ដើរទៅតាមផ្លូវក្នុងផ្សារ ឃើញអ្នកលក់សំពត់ម្នាក់អង្គុយអង្អែលសំពត់ ៥០០ ផ្ទាំង ទើបពោលថា នែអ្នក សាមណេរមួយរូបកំពុងប្រមូលសំពត់កម្ពល ចូរអ្នកលាក់សំពត់កម្ពលរបស់អ្នកសិនចុះ អ្នកផ្សារពោលថា សាមណេរនោះកាន់យកតែសំពត់ដែលគេឲ្យហើយ ឬកាន់យកសំពត់ដែលគេមិនបានឲ្យ បុរសនោះពោលថា កាន់យកសំពត់ដែលគេឲ្យហើយ ។ អ្នកផ្សារពោលថា បើដូច្នោះ បើយើងចង់ឲ្យ យើងនឹងឲ្យ បើយើងមិនចង់ឲ្យ ក៏មិនឲ្យចូរអ្នកទៅចុះ ដូច្នេះហើយ ក៏បញ្ជូនទៅ ។

មែនពិត ពួកមនុស្សកំណាញ់ ដែលជាអន្ធពាល កាលជនដទៃឲ្យទានយ៉ាងនេះ ក៏កំណាញ់ហើយ ទើបកើតក្នុងនរក ដូចកាឡអមាត្យឃើញអសទិសទានហើយ កំណាញ់ដូច្នោះ ។ អ្នកលក់គិតថា បុរសនេះមកដោយធម្មតារបស់ខ្លួនពោលនឹងអញថា ចូរលាក់សំពត់កម្ពលរបស់អ្នក អញក៏បានពោលថា សាមណេរនោះ កាន់យកវត្ថុដែលគេឲ្យ បើអញប្រាថ្នា អញនឹងឲ្យរបស់

អញ បើមិនជ្រាបថ្នា អញក៏មិនឲ្យ កាលអញមិនឲ្យរបស់ដែលសាមណេរឃើញ ហើយ ការខ្វាសរមែងកើតឡើង បើអញលាក់របស់ខ្លួន រមែងមិនមានទោស បណ្តាសំពត់កម្ពល ៥០០ នេះ សំពត់កម្ពលពីរផ្ទាំង មានតម្លៃរាប់សែន ការ លាក់សំពត់ពីរផ្ទាំងនេះគួរ ដូច្នេះហើយ ទើបចងសំពត់កម្ពលទាំងពីរផ្ទាំង ធ្វើ ឲ្យជាជាយដោយជាយ គឺចងភ្ជាប់គ្នា លាក់ក្នុងរវាងសំពត់ទាំងនោះ ។ សាមណេរដល់បទេសនោះ មួយអន្ទើដោយភិក្ខុមួយពាន់ ។ ព្រោះឃើញ សាមណេរប៉ុណ្ណោះ សេចក្តីស្រឡាញ់ប្រៀបដូចកូនកើតឡើងដល់អ្នកនោះ សរីរៈទាំងមូលបានពេញហើយដោយសេចក្តីស្រឡាញ់ គិតថា សំពត់កម្ពល ទាំងឡាយ ចូរស្ទុះទុកសិនចុះ អញឃើញសាមណេរនេះហើយ ទោះបីឲ្យ បេះដូង ក៏គួរ ។ អ្នកផ្សារនោះ នាំសំពត់ទាំងពីរផ្ទាំងនោះ ចេញមកជាក់ទៀប បាទារបស់សាមណេរ ថ្វាយបង្គំហើយពោលថា បពិត្រលោកម្ចាស់ ខ្ញុំគប្បី មានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយ សាមណេរនោះអនុមោទនា ថា ចូរសម្រេចយ៉ាងនោះចុះ ។ សាមណេរបានសំពត់កម្ពល ៥០០ ខាងក្នុង ព្រះនគរ ក្នុងមួយថ្ងៃប៉ុណ្ណោះ បានសំពត់កម្ពលមួយពាន់ប្រគេនដល់ភិក្ខុមួយ ពាន់រូប ដោយប្រការដូច្នេះ ។ គ្រានោះ ភិក្ខុទាំងឡាយដាក់ឈ្មោះសាមណេរ នោះថា កម្ពលទាយកតិស្សៈ ។ សំពត់កម្ពលដែលសាមណេរប្រគេនក្នុងថ្ងៃ ដាក់ឈ្មោះ ដល់នូវភាពជាសំពត់កម្ពលមួយពាន់ ក្នុងកាលខ្លួនមានអាយុ ៧ ឆ្នាំ ដោយប្រការដូច្នេះ ។

របស់តិចតួចដែលបុគ្គលឲ្យហើយ ក្នុងឋានៈណា រមែងមានផលច្រើន

របស់ច្រើនបុគ្គលឲ្យហើយក្នុងហាន:ណា រមែងមានផលច្រើនជាង ហាន:ដទៃនោះ រៀវព្រះពុទ្ធសាសនាចេញ រមែងមិនមាន ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ របស់តិចដែលបុគ្គលឲ្យហើយក្នុងពួកភិក្ខុបែបណាមានផលច្រើន របស់ច្រើនដែលបុគ្គលឲ្យហើយ ក្នុងភិក្ខុពួកណាមានផលច្រើនជាង ភិក្ខុទាំងនេះក៏ដូច្នោះ ។ សូម្បីសាមណេរមានអាយុ ៧ ឆ្នាំ បានសំពត់កម្ពលមួយពាន់ដោយផលនៃសំពត់កម្ពលមួយផ្ទាំង ដោយប្រការដូច្នេះ ។

កាលសាមណេរនោះនៅក្នុងវត្តជេតពន ពួកក្មេងដែលជាញាតិមកកាន់សម្នាក់ ពោលចរចាប្រស្រ័យរឿយៗ ។ សាមណេរនោះគិតថា កាលអញនៅក្នុងទីនេះ កាលក្មេងដែលជាញាតិមកពោល មិនអាចមិនពោលបាន ដោយការយឺតយូរ គឺការសន្ទនាជាមួយក្មេងទាំងនេះ អញមិនអាចធ្វើទីពឹងដល់ខ្លួនបើដូច្នេះ អញនឹងរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ គប្បីចូលព្រៃ ។

តិស្សសាមណេរនោះ ចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ទូលសូមឲ្យព្រះសាស្តាត្រាស់ប្រាប់កម្មដ្ឋានអំពីអរហត្ត ថ្វាយបង្គំឧបជ្ឈាយ៍ហើយ កាន់បាត្រ និងចីវរចេញទៅអំពីវិហារហើយគិតថា បើអញនៅក្នុងទីជិតសោត ពួកញាតិនឹងហៅអញទៅ ទើបបានធ្វើដំណើរអស់ចម្ងាយផ្លូវ ១២០ យោជន៍ ។ គ្រានោះ សាមណេរដើរទៅកាត់តាមភូមិមួយ ឃើញបុរសចំណាស់ម្នាក់ សួរថា ឧបាសក វិហារក្នុងព្រៃរបស់ភិក្ខុទាំងឡាយ ដែលនៅក្នុងប្រទេសនេះមានដែរឬទេ ឧបាសកពោលថា មាន លោកម្ចាស់ សាមណេរសួរថា បើដូច្នោះ

សូមអ្នកជួយប្រាប់ផ្លូវដល់អាត្មាចុះ ។

សេចក្តីស្រឡាញ់ប្រៀបដូចបុត្រ កើតឡើងដល់ឧបាសក ព្រោះឃើញសាមណេរនោះ ។ លំដាប់នោះ ឧបាសកឈរក្នុងទីនោះឯង មិនប្រាប់ដល់សាមណេរនោះពោលថា និមន្តមកចុះ ខ្ញុំនឹងប្រាប់ដល់លោកម្ចាស់ បាននាំសាមណេរទៅហើយ ។ សាមណេរបានទៅជាមួយឧបាសកចាស់នោះ ឃើញបទេស គឺតំបន់ ៦ កន្លែង ៥ កន្លែង ប្រដាប់ហើយដោយផ្កា និងផ្លែផ្សេងៗ ក្នុងរវាងផ្លូវ ទើបសួរថា បទេសនេះឈ្មោះអ្វី ឧបាសកប្រាប់ឈ្មោះបទេសទាំងនោះដល់សាមណេរ ទៅដល់វិហារដែលតាំងនៅក្នុងព្រៃហើយពោលថា បពិត្រលោកម្ចាស់ ទីនេះជាទីសប្បាយ សូមលោកម្ចាស់នៅក្នុងទីនេះចុះ ហើយសួរឈ្មោះថា លោកម្ចាស់ឈ្មោះអ្វី សាមណេរប្រាប់ថា អាត្មាឈ្មោះវនវាសីតិស្សៈ ទើបពោលថា ស្អែកនេះលោកម្ចាស់គួរទៅបិណ្ឌបាតក្នុងស្រុករបស់ពួកខ្ញុំ ហើយត្រឡប់ទៅកាន់ស្រុករបស់ខ្លួននោះឯង ប្រាប់ដល់ពួកមនុស្សថា សាមណេរឈ្មោះវនវាសីតិស្សៈមកកាន់វិហារហើយ ចូរអ្នកទាំងឡាយចាត់ចែងអាហារវត្ថុ មានយាគូ និងភត្តជាដើម ដើម្បីសាមណេរនោះ ។ គ្រាជំបូងនោះឯង សាមណេរឈ្មោះតិស្សៈ បន្ទាប់ពីនោះ បានឈ្មោះបីទៀត គឺបិណ្ឌបាតទាយកតិស្សៈ កម្ពលទាយកតិស្សៈ វនវាសីតិស្សៈ បានឈ្មោះ ៤ ក្នុងអាយុ ៧ ឆ្នាំ ។ ស្អែកឡើងសាមណេរនោះ ចូលទៅបិណ្ឌបាតកាន់ស្រុកនោះអំពីព្រលឹមពួកមនុស្សប្រគេនភិក្ខា ថ្វាយបង្គំហើយ ។ សាមណេរពោលថា អ្នកទាំងឡាយចូរដល់នូវសេចក្តីសុខ ចូរផុតចាកទុក្ខចុះ ។ សូម្បីមនុស្សម្នាក់ថ្វាយភិក្ខាដល់

សាមណេរនោះហើយ ក៏មិនអាចត្រឡប់ទៅកាន់ផ្ទះបាន គ្រប់គ្នាបានឈរមើល សាមណេរនោះក៏ទទួលកត្តុមញ្ជុំងអត្តភាពឲ្យប្រព្រឹត្តទៅដើម្បីខ្លួន ។ អ្នកស្រុកទាំងអស់ ក្រាបចុះដោយទ្រូង ទៀបបាទារបស់សាមណេរនោះ ហើយពោលថា បពិត្រលោកម្ចាស់ កាលលោកម្ចាស់នៅក្នុងទីនេះ អស់ត្រីមាសនេះ ពួកខ្ញុំនឹងទទួលសរណៈ ៣ តាំងនៅក្នុងសីល ៥ ធ្វើឧបាសថកម្ម ៨ ដង ក្នុងមួយខែ សូមលោកម្ចាស់ឲ្យប្តេជ្ញាដល់យើងខ្ញុំទាំងឡាយ ដើម្បីជាប្រយោជន៍នៃការនៅក្នុងទីនេះ ។ សាមណេរនោះកំណត់ឧបការៈ ទើបឲ្យប្តេជ្ញាដល់មនុស្សប៉ុណ្ណោះ ត្រាច់បិណ្ឌបាតក្នុងស្រុកនោះឯងជាប្រចាំ ។ ក្នុងខណៈដែលគេថ្វាយបង្គំហើយ ពោលចំពោះពីរបទថា ចូរអ្នកទាំងឡាយ ជល់នូវសេចក្តីសុខ ចូរផុតចាកទុក្ខចុះ ដូច្នេះហើយ ចៀសចេញទៅ ។ សាមណេរនោះឲ្យខែទីមួយ និងខែទីពីរកន្លងទៅហើយ ក្នុងទីនោះ កាលខែទីបីកន្លងទៅ ក៏សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទា ។

កាលបវារណាចេញវស្សាហើយ ឧបជ្ឈាយ៍របស់សាមណេរនោះ ចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងទៅកាន់សម្នាក់តិស្សសាមណេរ ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្ត ចូរអ្នកទៅចុះ ព្រះសារីបុត្តត្ថេរនោះ កាលនាំភិក្ខុប្រមាណ ៥០០ រូប ដែលជាបរិវារជនរបស់ខ្លួនចៀសចេញទៅពោលថា អាវុសោមោគ្គល្លាន ខ្ញុំនឹងទៅកាន់សម្នាក់តិស្សសាមណេរ ព្រះមហាមោគ្គល្លានត្ថេរពោលថា អាវុសោ ខ្ញុំក៏ទៅដែរ ដូច្នេះហើយ ចេញទៅព្រមជាមួយភិក្ខុប្រមាណ ៥០០ រូប ។ ព្រះមហាសាវកទាំង

ពួង គឺព្រះមហាកស្សបត្ថេរ ព្រះអនុរុទ្ធត្ថេរ ព្រះឧបាលិត្ថេរ ព្រះបុណ្ណត្ថេរជាដើម ចេញទៅមួយអន្ទើដោយភិក្ខុប្រមាណមួយអង្គ ៥០០ រូប ។ ដោយឧបាយនោះឯង បរិវារបស់សាវកទាំងអស់បានជាភិក្ខុប្រមាណ ៤ ម៉ឺនរូប ។ ឧបាសកដែលទំនុកបម្រុងសាមណេរជាប្រចាំ ឃើញភិក្ខុទាំងនោះធ្វើដំណើរប្រមាណ ១២០ យោជន៍ ដល់គោចរគាមហើយក្នុងទ្វារស្រុកនោះឯង ថ្វាយបង្គំហើយ ។ លុំដាប់នោះ ព្រះសារីបុត្តត្ថេរសួរឧបាសកនោះថា ឧបាសក វិហារតាំងនៅក្នុងព្រៃ ក្នុងប្រទេសនេះមានឬ ។

ឧបាសកពោលថា មាន លោកម្ចាស់ ព្រះថេរៈសួរថា តើភិក្ខុមានឬទេ ឧបាសកឆ្លើយថា មាន លោកម្ចាស់ ព្រះថេរៈសួរថា អ្នកណានៅក្នុងទីនោះ ឧបាសកឆ្លើយថា វនវាសីតិស្សសាមណេរ លោកម្ចាស់ ព្រះថេរៈពោលថា បើដូច្នេះ ចូរពួកអ្នកប្រាប់ផ្លូវដល់ពួកអាត្មា ឧបាសកសួរថា លោកម្ចាស់ជាភិក្ខុពួកណា ព្រះថេរៈប្រាប់ថា ពួកអាត្មាមកកាន់សម្នាក់របស់សាមណេរ ។

ឧបាសកសម្លឹងមើលភិក្ខុទាំងនោះ ចាំព្រះមហាសាវកទាំងអស់បាន តាំងអំពីព្រះធម្មសេនាបតីជាដើម ។ អ្នកស្រុកទាំងនោះមានសរីរៈដែលបីតិពាល់ត្រូវហើយ មិនមានចន្លោះពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បង្អង់សិន ហើយចូលទៅកាន់ស្រុកដោយរហ័សប្រកាសថា ព្រះអសីតិមហាសាវកទាំងឡាយ មានព្រះសារីបុត្តជាដើមមកកាន់សម្នាក់របស់សាមណេរ មួយអន្ទើដោយបរិវារវៀងៗខ្លួន អ្នកទាំងឡាយ ចូរកាន់យកគ្រឿងប្រើប្រាស់ មាន

ត្រៃ តាំង កម្រាល ប្រទីប និងប្រែងជាដើម ចេញទៅដោយរហ័សចុះ ។ រំពេចនោះឯង ពួកមនុស្សជញ្ជូនត្រៃជាដើម ធ្វើដំណើរតាមស្នាមជើងព្រះថេរៈទៅ ចូលទៅកាន់វិហារ មួយអន្ទើដោយព្រះថេរៈនោះឯង ។ សាមណេរ ចាំកិក្ខុបាន ទទួលបាត្រ និងចីវរព្រះមហាថេរៈ ២-៣ អង្គហើយ បានធ្វើវត្ត ។ កាលសាមណេរនោះចាត់ចែងលំនៅដើម្បីព្រះថេរៈទាំងឡាយ ទុកបាត្រ និងចីវរនោះឯង ក៏យប់ងងឹតល្មម ។ ព្រះសារីបុត្តត្ថេរពោលនឹងពួកឧបាសកថា ឧបាសកទាំងឡាយ ពួកអ្នកទៅចុះ ការងងឹត កើតដល់ពួកអ្នក ។

ពួកឧបាសកពោលថា បពិត្រលោកម្ចាស់ ថ្ងៃនេះជាថ្ងៃស្តាប់ធម៌ ពួកខ្ញុំមិនទៅទេ្បីយ នឹងស្តាប់ធម៌ ក្នុងកាលមុនអំពីនេះ សូម្បីការស្តាប់ធម៌ក៏មិនមានដល់យើងខ្ញុំទាំងឡាយ ។ ព្រះថេរៈពោលថា សាមណេរ បើដូច្នេះ ចូរអ្នកអុជប្រទីប ប្រកាសកាលស្តាប់ធម៌ចុះ សាមណេរបានធ្វើយ៉ាងនោះហើយ ។

លំដាប់នោះ ព្រះថេរៈពោលនឹងសាមណេរថា តិស្ស: ពួកឧបដ្ឋាករបស់អ្នកពោលថា ពួកខ្ញុំទាំងឡាយប្រាថ្នានឹងស្តាប់ធម៌ ចូរអ្នកពោលធម៌ដល់ឧបដ្ឋាកទាំងនោះ ។ ពួកឧបាសកក្រោកទៅឯព្រមគ្នានោះឯងពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់របស់ពួកខ្ញុំទាំងឡាយចេះតែ ២ បទ គឺចូរអ្នកទាំងឡាយមានសេចក្តីសុខ ចូរផុតចាកទុក្ខចុះ មិនចេះធម្មកថាជនៃទេ្បីយ សូមលោកម្ចាស់ទាំងឡាយឲ្យធម្មកថីកជនៃដល់ពួកខ្ញុំចុះ ។ ឯសាមណេរ ទោះបីសម្រេចអរហត្តហើយ ក៏មិនបានពោលធម្មកថាដល់ឧបដ្ឋាកទាំងនោះទេ្បីយ ។

ក្នុងកាលនោះ ព្រះឧបជ្ឈាយ៍ពោលនឹងសាមណេរនោះថា នែសាមណេរ

មនុស្សទាំងឡាយ នឹងមានសេចក្តីសុខបានដូចម្តេច នឹងផុតចាកទុក្ខបានដូចម្តេច ចូរអ្នកពោលអត្ថនៃបទទាំងពីរនេះដល់យើងទាំងឡាយ សាមណេរនោះទទួលថា សាធុ ហើយកាន់យកផ្ទិតដ៏វិចិត្រ ឡើងកាន់ធម្មាសន: ទាយយកផល និងហេតុមកអំពីនិកាយទាំង ៥ ចែកខន្ធ ធាតុ អាយតន: និងពោធិ-បក្ខិយធម៌ ដូចមហាមេឃតាំងឡើងក្នុងទ្វីបទាំង ៤ ញ្ចាំងភ្លៀងបោក្ខរពស៌សិ ឲ្យធ្លាក់ចុះ ពោលធម្មកថាដោយកំពូល គឺអរហត្ត ហើយពោលថា អ្នកទាំង-ឡាយសេចក្តីសុខ មានដល់បុគ្គលដែលសម្រេចអរហត្តយ៉ាងនេះ បុគ្គលសម្រេចអរហត្តហើយនោះឯង រមែងផុតចាកទុក្ខ មនុស្សដ៏សេសមិនផុតចាកជាតិទុក្ខជាដើមឡើយ នឹងផុតចាកទុក្ខក្នុងនរកជាដើមបានឡើយ ព្រះថេរ: ពោលថា សាធុ សាមណេរ ការពោលដោយបទ អ្នកពោលល្អហើយ ឥឡូវនេះ ចូរពោលសរភញ្ញចុះ ។ សាមណេរនោះ ពោលសរភញ្ញហើយ ។ កាលថ្ងៃរះឡើង ពួកមនុស្សដែលទំនុកបម្រុងសាមណេរ បែកគ្នាជាពីរពួក ។ ពួកខ្លះក្រោធថា ក្នុងកាលមុន ពួកយើងមិនធ្លាប់ជួបមនុស្សអាក្រក់បែបនេះ ហេតុអ្វីសាមណេរចេះធម្មកថាដល់ម្ល៉ះ មិនពោលបទធម៌សូម្បីតែមួយបទ ដល់ពួកមនុស្សដែលតាំងនៅក្នុងឋាន:ដូចមាតាបិតា ហើយឧបដ្ឋាកអស់កាលមានប្រមាណប៉ុណ្ណេះ ។ ពួកខ្លះត្រេកអរថា ជាលាភរបស់ពួកយើងហ្នឹ បុគ្គលមិនដឹងគុណ ឬទោស ទំនុកបម្រុងលោកម្ចាស់បែបនេះ តែឥឡូវនេះ ពួកយើងបានស្តាប់ធម៌ក្នុងសម្នាក់របស់លោកដ៏ចម្រើននោះ ។ ក្នុងវេលាជិតភ្លឺថ្ងៃនោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រមើលមើលលោក ទ្រង់យើញពួកឧបដ្ឋាករបស់

វនវាសីតិស្សសាមណេរ ចូលទៅខាងក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ទ្រង់ពិចារណាថា ហេតុអ្វីនឹងមានហ្ន៎ ទ្រង់ពិចារណាអត្តនេះថា ពួកឧបជ្ឈាករបស់វនវាសីតិស្សសាមណេរ ពួកខ្វះ ក្រោធ ពួកខ្វះ ត្រេកអរ ពួកដែលក្រោធសាមេណេរ ដែលជាបុត្រតថាគតនឹងទៅកាន់នរក តថាគតគួរទៅក្នុងទីនោះចុះ កាលតថាគតទៅ មនុស្សទាំងអស់ នឹងធ្វើមេត្តាចិត្តក្នុងសាមណេរ ហើយផុតចាកទុក្ខ ។ មនុស្សទាំងនោះ និមន្តភិក្ខុសង្ឃហើយក៏ទៅកាន់ស្រុក ឲ្យមនុស្សធ្វើមណ្ឌប រៀបចំអាហារវត្ថុ មានបបរ និងភត្តជាដើម ក្រាលអាសនៈហើយ អង្គុយទន្ទឹងការមកបស់ភិក្ខុសង្ឃ ។ ភិក្ខុទាំងឡាយធ្វើការជម្រះសរីរៈហើយ ចូលទៅកាន់ស្រុក ក្នុងវេលាត្រាច់ភិក្ខា ទើបសួរសាមណេរថា តិស្សៈ អ្នកទៅជាមួយពួកយើង ឬទៅឯក្រោយ សាមណេរពោលថា ខ្ញុំនឹងទៅក្នុងកាលតាមដែលខ្ញុំធ្លាប់ទៅ សូមលោកម្ចាស់ទាំងឡាយ និមន្តទៅចុះ ។ ភិក្ខុទាំងឡាយកាន់បាត្រ និងចីវរចូលទៅហើយ ។

ព្រះសាស្តា ទ្រង់ដណ្តប់ចីវរក្នុងវត្តជេតពននោះឯង ហើយទ្រង់កាន់បាត្រយាងទៅដោយខណៈចិត្តមួយប៉ុណ្ណោះ ទ្រង់សម្តែងព្រះកាយ ប្រថាប់ឈរខាងមុខភិក្ខុទាំងឡាយនោះឯង ។ អ្នកស្រុកទាំងមូល បានត្រេកអរដួចគ្នាថា ព្រះសម្មាសម្ពុទ្ធយាងមក ។ ពួកមនុស្សត្រេកអរ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យគង់ហើយ ថ្វាយបបរ ថ្វាយរបស់ទំពាហើយ ។ កាលភត្តមិនទាន់សម្រេចនោះឯង ។ សាមណេរចូលទៅខាងក្នុងស្រុកហើយ ។ អ្នកស្រុកបាននាំចេញទៅប្រគេនភិក្ខាដល់សាមណេរដោយគោរព សាមណេរនោះទទួលភិក្ខា

ត្រឹមតែញុំាងអត្តភាពឲ្យប្រព្រឹត្តទៅហើយ ទៅកាន់សម្នាក់ព្រះសាស្តា បង្អោនបាត្រចូលទៅហើយ ។ ព្រះសាស្តាត្រាស់ថា នាំមកចុះតិស្សៈ ហើយទ្រង់លាព្រះហស្តទទួលបាត្រ ទ្រង់សម្តែងដល់ព្រះថេរៈថា សារីបុត្ត ចូរមើលបាត្រសាមណេររបស់អ្នក ។ ព្រះថេរៈទទួលបាត្រអំពីព្រះហស្តរបស់ព្រះសាស្តាឲ្យដល់សាមណេរហើយពោលថា ចូរទៅធ្វើកត្តកិច្ចក្នុងទីដែលសមគួរដល់ខ្លួន ។ អ្នកស្រុកអង្គាសកិកុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយទូលសូមអនុមោទនានឹងព្រះសាស្តា ។ ព្រះសាស្តា កាលទ្រង់ធ្វើអនុមោទនា ទើបត្រាស់ពាក្យយ៉ាងនេះថា ឧបាសក និងឧបាសិកាទាំងឡាយ ជាលាភរបស់អ្នកទាំងឡាយ ដែលបានឃើញអសីតិមហាសាវក គឺសារីបុត្ត មោគ្គល្លាន កស្សបៈជាដើមព្រោះអាស្រ័យសាមណេរចូលដល់ត្រកូល រៀងៗ ខ្លួន សូម្បីតថាគតក៏មកហើយ ព្រោះអាស្រ័យសាមណេរ ដែលចូលដល់ត្រកូលរបស់អ្នកទាំងឡាយដូចគ្នា ការឃើញតថាគត ដែលអ្នកទាំងឡាយបានហើយ ព្រោះអាស្រ័យសាមណេរនេះឯង ជាលាភរបស់អ្នកទាំងឡាយ អ្នកទាំងឡាយបានល្អហើយ ។ មនុស្សទាំងឡាយគិតថា គួរត្រេកអរហ្ន៎ ជាលាភរបស់ពួកយើង ពួកយើងបានឃើញលោកម្ចាស់របស់ពួកយើង ដែលក្នុងការញុំាងព្រះពុទ្ធ និងភិក្ខុសង្ឃឲ្យជ្រោសជ្រាណ រមែងបានថ្វាយទេយ្យធម៌ដល់លោកម្ចាស់នោះ ។ ពួកមនុស្សដែលក្រោធនឹងសាមណេរ ក៏ត្រេកអរហើយ ។ ពួកដែលត្រេកអរហើយរីឯតែជ្រះថ្លាក្រៃលែង ។ ក្នុងកាលចប់អនុមោទនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ព្រះ

សាស្តាទ្រង់ក្រោកចាកអាសនៈយាងទៅហើយ ។ ពួកមនុស្សទាំងឡាយតាមជូនដំណើរព្រះសាស្តា ថ្វាយបង្គំហើយត្រឡប់ ។ ព្រះសាស្តាយាងទៅដោយព្រះធុរៈដ៏ស្មើជាមួយសាមណេរ ត្រាស់សួរបទេសដែលឧបាសកប្រាប់ហើយដល់សាមណេរនោះ ក្នុងកាលមុនថា សាមណេរ បទេសនេះ ឈ្មោះអ្វី បទេសនេះ ឈ្មោះអ្វី ដូច្នេះហើយ បានយាងទៅ សាមណេរក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បទេសនេះ ឈ្មោះនេះ បទេសនេះ ឈ្មោះនេះ ។

ព្រះសាស្តា យាងដល់លំនៅរបស់សាមណេរនោះហើយ ទ្រង់ទ្បើងកាន់កំពូលភ្នំ ។ មហាសមុទ្ររមែងប្រកាសដល់បុគ្គលដែលឈរលើកំពូលភ្នំនោះ ព្រះសាស្តាត្រាស់សួរសាមណេរថា តិស្សៈ អ្នកឈរលើកំពូលភ្នំសម្លឹងមើលខាងនោះ និងខាងនេះ ឃើញអ្វី សាមណេរតបថា បពិត្រព្រះអង្គ ឃើញមហាសមុទ្រ ព្រះសាស្តាត្រាស់ថា ឃើញមហាសមុទ្រហើយ គិតដូចម្តេច សាមណេរតបថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គគិតយ៉ាងនេះថា កាលខ្ញុំព្រះអង្គយំក្នុងកាលដែលដល់នូវសេចក្តីទុក្ខ ទឹកភ្នែកគប្បីច្រើនជាងទឹកក្នុងមហាសមុទ្រទាំង ៤ ព្រះសាស្តាត្រាស់ថា សាធុ សាធុ តិស្សៈ សេចក្តីនេះ យ៉ាងនោះឯង ព្រោះទឹកភ្នែកដែលហូរមក ក្នុងពេលដែលសត្វម្នាក់ៗ ដល់នូវសេចក្តីទុក្ខគប្បីជារបស់ច្រើនជាងទឹកក្នុងមហាសមុទ្រទាំង ៤ ដោយពិត កាលត្រាស់ពាក្យនេះហើយ ទើបត្រាស់ព្រះគាថានេះថា

ទឹកក្នុងមហាសមុទ្រទាំង ៤ តិចតួចទេ ទឹក គឺទឹកភ្នែករបស់នរៈ ដែលសេចក្តីទុក្ខពាល់ត្រូវហើយ យំសោកមានប្រមាណមិនតិចឡើយ ច្រើនជាងទឹក

ក្នុងមហាសមុទ្រទាំង ៤ នោះ សម្លាញ់ ព្រោះហេតុអ្វី ទើបអ្នកប្រមាទ ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរសាមណេរនោះទៀតថា តិស្សៈ អ្នកនៅក្នុងទីណា សាមណេរតបថា បពិត្រព្រះអង្គ នៅត្រង់ញាកភ្នំនេះ ព្រះសាស្តាត្រាស់ថា កាលនៅទីនេះ អ្នកគិតដូចម្តេច សាមណេរពោលថា ខ្ញុំព្រះអង្គគិតថា ការកំណត់ទីជាកំចុះនូវសីរៈ ដែលអាត្មាអញជាអ្នកស្លាប់ ធ្វើហើយក្នុងទីនេះមិនមាន ព្រះសាស្តាត្រាស់ថា សាធុ សាធុ តិស្សៈ សេចក្តីនេះយ៉ាងនោះឯង ព្រោះឈ្មោះថា ទីនៃសត្វទាំងនេះ ដែលមិនធ្លាប់ដេកស្លាប់លើផែនដី មិនមាន ដូច្នេះហើយ ទើបត្រាស់ឧបសាឡ្ហកជាតក ក្នុងទុក្កនិបាតថា

ពួកញាតិឈ្មោះឧបសាឡ្ហក[1] ចំនួន ១៤០០០ នាក់ គេដុតហើយក្នុងប្រទេសនេះ ក្នុងលោក រកទីដែលមិនមានគេស្លាប់មិនមានឡើយ ។

សច្ចៈ ១ ធម្មៈ ១ អហិសា ១ សញ្ញមៈ ១ ទមៈ ១ មាននៅក្នុងបុគ្គលណា ព្រះអរិយៈទាំងឡាយ រមែងសេពគប់នូវបុគ្គលនុ៎ះ គុណជាតនុ៎ះ ឈ្មោះថា មិនចេះស្លាប់ ក្នុងលោក ។

កាលសត្វទាំងឡាយ ធ្វើការជាក់ចុះនូវសីរៈលើផែនដី សត្វទាំងឡាយឈ្មោះថា ស្លាប់ក្នុងបទេសដែលមិនធ្លាប់ស្លាប់ រមែងមិនមាន ដោយប្រការដូច្នេះ ។ ចំណែកព្រះថេរៈទាំងឡាយ ដូចគ្នានឹងព្រះអានន្ទត្ថេរ រមែងបរិនិព្វានក្នុងបទេស ដែលសត្វមិនធ្លាប់ស្លាប់ ។

១- គួរប្រែថា ព្រាហ្មណ៍ ឈ្មោះឧបសាឡ្ហក ចំនួន ១៤០០០ នាក់ ត្រូវញាតិដុតហើយក្នុងបទេសនេះ ទើបត្រូ តាមន័យរបស់អដ្ឋកថា ។

បានឮមកថា ព្រះអានន្ទត្ថេរ ពិចារណាអាយុសង្ខារក្នុងកាលដែលមានអាយុ ១២០ ឆ្នាំ ជ្រាបភាពដែលអាយុនោះអស់ដោយជុំវិញ ទើបប្រាប់ថា ខ្ញុំនឹងបរិនិព្វានក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ ។ បណ្តាមនុស្សដែលនៅត្រង់ច្រាំងទាំងពីរនៃស្ទឹងរោហិណី ជ្រាបដំណឹងនោះហើយ អ្នកដែលនៅត្រើយអាយពោលថា ពួកយើងជាអ្នកមានឧបការៈច្រើនដល់ព្រះថេរៈ ព្រះថេរៈនឹងបរិនិព្វានក្នុងសម្នាក់របស់ពួកយើង ។ អ្នកដែលនៅត្រើយនាយក៏ពោលថា ពួកយើងមានឧបការៈច្រើនដល់ព្រះថេរៈ ព្រះថេរៈនឹងបរិនិព្វានក្នុងសម្នាក់របស់ពួកយើង ។ ព្រះថេរៈស្តាប់ពាក្យរបស់ជនទាំងនោះហើយ គិតថា ពួកជនដែលនៅត្រង់ច្រាំងទាំងពីរ មានឧបការៈដល់អាត្មាអញទាំងអស់ អាត្មាអញមិនអាចពោលថា ជនទាំងនេះមិនមានឧបការៈ បើអញបរិនិព្វានត្រង់ត្រើយអាយ អ្នកនៅត្រើយនាយ នឹងធ្វើការឈ្លោះជាមួយពួកអ្នកត្រើយអាយ ដើម្បីនឹងកាន់យកជាតុ បើអញបរិនិព្វានត្រង់ត្រើយនាយ អ្នកដែលនៅត្រើយអាយ នឹងធ្វើនូវជម្លោះយ៉ាងនោះ ជម្លោះ កាលនឹងកើតឡើង ក៏កើតអាស្រ័យអាត្មាអញពិត កាលស្លាប់ ក៏នឹងស្លាប់អាស្រ័យអញដូចគ្នា ដូច្នេះហើយ ពោលថា អ្នកនៅត្រើយអាយ មានឧបការៈដល់អាត្មា ឯពួកអ្នកដែលនៅត្រើយនាយក៏មានឧបការៈដល់អាត្មា បុគ្គលណាម្នាក់ ឈ្មោះថា មិនមានឧបការៈមិនមានអ្នកដែលនៅត្រើយអាយ ចូរប្រជុំគ្នាត្រង់ត្រើយអាយនេះឯង អ្នកដែលនៅត្រើយនាយ ក៏ចូរប្រជុំគ្នាត្រង់ត្រើយនាយនោះឯង ។ ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនោះ ព្រះថេរៈអង្គុយពត់ភ្លៃនក្នុងអាការប្រមាណ ៧ ជួរដើមត្នោត ត្រង់

ពាក់កណ្តាលស្មើង ពោលធម្មកថាដល់មហាជនហើយ អធិដ្ឋានថា ចូរសរីរៈរបស់អាត្មាអញបែកពាក់កណ្តាល មួយចំណែក ចូរធ្លាក់ត្រង់ត្រើយអាយ មួយចំណែក ចូរធ្លាក់ត្រង់ត្រើយនាយ ។ គង់តាមប្រក្រតីនោះឯង ចូលសមាបត្តិ មានតេជោធាតុជាអារម្មណ៍ អណ្តាតភ្លើងតាំងឡើងហើយ សរីរៈបែកហើយត្រង់ពាក់កណ្តាល មួយចំណែកធ្លាក់ត្រង់ត្រើយអាយ មួយចំណែកធ្លាក់ត្រង់ត្រើយនាយ មហាជនស្រែកយំហើយ សំឡេងទ្រហោយំហាក់បីដូចសំឡេងផែនដីស្រុត គួរអាណាចអាធ័ម ជាងសំឡេងទ្រហោយំក្នុងថ្ងៃបរិ-និព្វានៃព្រះសាស្តា ។ ពួកមនុស្សទ្រហោយំអស់កាល ៤ ខែ កន្ទក់កន្ទេញថា កាលព្រះថេរៈទទួលបាត្រចីវរបស់ព្រះសាស្តា ឋិតនៅ បានប្រាកដដល់ពួកយើង ដូចការដែលព្រះសាស្តាគង់ព្រះជន្មនៅ ឥឡូវនេះ ព្រះសាស្តារបស់ពួកយើងបរិនិព្វានហើយ ។

ព្រះសាស្តាត្រាស់សួរសាមណេរទៀតថា តិស្សៈ អ្នកមិនខ្លាច ព្រោះសំឡេងនៃសត្វទាំងឡាយ មានសំឡេងខ្លាំងជាដើម ក្នុងព្រៃនេះទេឬ សាមណេរក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនខ្លាចទេ ម្យ៉ាងទៀត ឈ្មោះថា ការត្រេកអរក្នុងព្រៃ រមែងកើតឡើងដល់ខ្ញុំព្រះអង្គព្រោះស្តាប់សំឡេងសត្វទាំងនោះ ហើយពោលពណ៌នាព្រៃដោយគាថាប្រមាណ ៦០ ។

គ្រានោះ ព្រះសាស្តាត្រាស់ហៅសាមណេរនោះថា តិស្សៈ សាមណេរតបថា ករុណាព្រះអង្គ ព្រះសាស្តាត្រាស់ថា ពួកយើងនឹងទៅ តើអ្នកទៅ ឬ មួយក៏ត្រឡប់ សាមណេរទូលថា បើឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គ នាំខ្ញុំព្រះអង្គ

ទៅ ខ្ញុំព្រះអង្គនឹងទៅ បើឲ្យខ្ញុំព្រះអង្គត្រឡប់ ខ្ញុំព្រះអង្គនឹងត្រឡប់ ។

ព្រះសាស្តា ចៀសចេញទៅជាមួយភិក្ខុសង្ឃ តែអធ្យាស្រ័យរបស់សាមណេរត្រឡប់តែម្យ៉ាង ព្រះថេរៈជ្រាបអធ្យាស្រ័យនោះ ទើបពោលថា តិស្សៈ បើអ្នកប្រាថ្នាត្រឡប់ក៏ត្រឡប់ចុះ សាមណេរថ្វាយបង្គំព្រះសាស្តា និងភិក្ខុសង្ឃ ហើយត្រឡប់ ។ ព្រះសាស្តាទ្រង់យាងទៅកាន់វត្តជេតពនហើយ ។

ការសន្ទនារបស់ភិក្ខុទាំងឡាយ កើតឡើងក្នុងធម្មសភាថា គួរអស្ចារ្យហ្ន៎ តិស្សសាមណេរធ្វើកម្មដែលបុគ្គលធ្វើបានលំបាក ចាប់តាំងអំពីបដិសន្ធិ ពួកញាតិរបស់លោក បានប្រគេនបាយាសមានទឹកតិចដល់ភិក្ខុប្រមាណ ៥០០ ក្នុងថ្ងៃដែលជាមង្គលអស់វារៈ ៧ ដង ក្នុងកាលបួសហើយ ក៏បានប្រគេនមធុបាយាសមានទឹកតិចដូចគ្នាដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ខាងក្នុងវិហារអស់ ៧ ថ្ងៃ កាលបួសហើយ ក្នុងថ្ងៃទី ៨ ចូលទៅកាន់ស្រុកបានបិណ្ឌបាតមួយពាន់ និងសំពត់សាដកមួយពាន់ក្នុងពេលពីរថ្ងៃប៉ុណ្ណោះ ស្អែកឡើងបានសំពត់កម្ពលមួយពាន់ ក្នុងពេលលោកនៅក្នុងទីនេះ លាភ និងសក្ការៈច្រើនកើតឡើងហើយ ដោយប្រការដូច្នេះ ឥឡូវនេះ លោកលះបង់លាភ និងសក្ការៈបែបនេះចោល ហើយទៅកាន់ព្រៃ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយអាហារដែលលាយគ្នា សាមណេរធ្វើកម្មដែលគេធ្វើបានដោយកម្រហ្ន៎ ។

ព្រះសាស្តា យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង

ឈ្មោះថា បដិបទាដែលចូលទៅអាស្រ័យលាកនោះដទៃ បដិបទាដែលញុំងសត្វឲ្យដល់ព្រះនិព្វានដទៃ ។ អបាយ ៤ មានទ្វារបើកហើយនោះឯងតាំងនៅ កាលភិក្ខុរក្សាបដិបទា ចូលទៅអាស្រ័យលាក ដោយអំណាចនៃការសមា-ទានធុតង្គ មានការនៅព្រៃជាដើម ដោយបំណងថា អញនឹងបានលាក ដោយបដិបត្តិយ៉ាងនេះ ចំណែកភិក្ខុដែលលះលាក និងសក្ការៈដែលកើតឡើង ដោយបដិបទាដែលញុំងសត្វឲ្យដល់នូវព្រះនិព្វាន ហើយចូលទៅកាន់ព្រៃ ព្យាយាម រមែងកាន់យកអរហត្តបាន ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិ សម្តែងធម៌ ទើបត្រាស់គាថានេះថា

អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី
ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ
សក្ការំ នាភិនន្ទិយ វិវេកមនុព្រូហយេ ។

បដិបទា អាស្រ័យនូវលាកផ្សេង បដិបទាជាដំណើរទៅកាន់ព្រះនិព្វានផ្សេង ភិក្ខុជាសាវ័ករបស់ព្រះពុទ្ធ ដឹងច្បាស់នូវហេតុនុ៎ះ យ៉ាងនេះហើយ មិនគួរត្រេកអរចំពោះសក្ការៈទេ្បីយ គប្បីញុំងវិវេកឲ្យចម្រើន ដោយលំដាប់ ។

សេចក្តីអធិប្បាយ

បណ្តាបទថាទាំងនោះ ជាព្រះគាថាថា **អញ្ញា ហិ លាភូបនិសា** *សេចក្តីថា ឈ្មោះថាបដិបទាដែលចូលទៅអាស្រ័យលាកនេះយ៉ាងនេះ បដិបទាដែលញុំងសត្វឲ្យដល់នូវព្រះនិព្វានដោយឡែក ។ ពិតហើយ ភិក្ខុដែលឲ្យលាក*

កើតឡើង គួរធ្វើអកុសលកម្មតិចតួច ។ ការមិនត្រង់នៃកាយជាដើម លោកគប្បីធ្វើ ព្រោះថា ក្នុងកាលណាភិក្ខុធ្វើការវៀចណាមួយ មានការមិនត្រង់នៃកាយជាដើម ក្នុងកាលនោះ លាភរមែងកើតឡើង ។ កាលភិក្ខុសណ្តូកដៃចុះត្រង់ៗ ក្នុងថាសដែលគេដាក់បាយាស មិនធ្វើឲ្យងហើយលើកឡើង ដៃគ្រាន់តែប្រឡាក់ប៉ុណ្ណោះ តែកាលសណ្តូកចុះ ធ្វើឲ្យងហើយលើកឡើង ដៃរមែងច្រមដុំបាយាសចេញមកបានពិត លាភសក្តារ: រមែងកើតឡើងក្នុងគ្រាធ្វើការវៀចវេរដោយកាយជាដើមយ៉ាងនេះ នេះចាត់ជាបដិបទា ដែលចូលទៅអាស្រ័យលាភ មិនប្រពៃតាមធម៌ ។ តែលាភដែលកើតឡើងដោយហេតុបែបនេះ គឺការដល់ព្រមដោយឧបធិ ការទ្រទ្រង់ទុកនូវចីវរ គឺការគ្រងចីវរ ភាពជាពហូសូត ការមានបរិវារ ការនៅព្រៃ ឈ្មោះថា ប្រកបដោយធម៌ ភិក្ខុកាលបំពេញបដិបទាដែលញ្ចុាំងសត្វឲ្យដល់នូវព្រះនិព្វាន គប្បីលះការវៀចដោយកាយជាដើមចេញ កាលភិក្ខុដែលបំពេញបដិបទា ដែលនាំសត្វឲ្យដល់ព្រះនិព្វាន មិនមែនមនុស្សខ្វាក់ តែធ្វើដូចជាមនុស្សខ្វាក់ មិនមែនមនុស្សគរ តែធ្វើដូចជាមនុស្សគរ មិនមែនមនុស្សថ្ងង់ ធ្វើដូចជាមនុស្សថ្ងង់ ទើបគួរ ។

បទថា **ឯវមេតំ** ជាដើម សេចក្តីថា ភិក្ខុឈ្មោះថាជាសាវ័កព្រោះអត្ថថា កើតក្នុងទីបំផុតនៃការស្តាប់ ឬព្រោះអត្ថថា ស្តាប់ឧវាទ និងអនុសាសនីរបស់បុគ្គលឈ្មោះថាពុទ្ធ ព្រោះអត្ថថា ត្រាស់ដឹងសង្ខតធម៌ និងអសង្ខតធម៌ទាំងអស់ ជ្រាបបដិបទាជាគ្រឿងញ្ចុាំងលាភឲ្យកើតឡើង និងបដិបទាដែលញ្ចុាំងសត្វឲ្យដល់ព្រះនិព្វាននោះយ៉ាងនេះហើយ មិនគប្បីត្រេកអរនឹងសក្តារ:

គឺបច្ចុយ ៤ ដែលមិនប្រកបដោយធម៌ គឺមិនគប្បីហាមឃាត់សក្ការ:ដែលប្រកបដោយធម៌នោះឯង គប្បីចម្រើនវិវេក មានកាយវិវេកជាដើម ។

បណ្តាវិវេកទាំងនោះ ភាពជាបុគ្គលមានកាយម្នាក់ឯង ឈ្មោះថាកាយវិវេក សមាបត្តិ ៨ ឈ្មោះថា ចិត្តវិវេក ព្រះនិព្វាន ឈ្មោះថាឧបធិវិវេក ។

បណ្តាវិវេកទាំងនោះ កាយវិវេក រមែងបន្ទោបង់នូវការច្រឡូកច្រឡំដោយពួកគណ: ចិត្តវិវេក រមែងបន្ទោបង់ការត្រាំដោយកិលេស ។ ឧបធិវិវេក រមែងបន្ទោបង់នូវការជាប់ជំពាក់ក្នុងសង្ខារ កាយវិវេក រមែងជាបច្ចុយនៃចិត្តវិវេក ។ ចិត្តវិវេក រមែងជាបច្ចុយនៃឧបធិវិវេក ។ សមដូចពាក្យរបស់ព្រះសារីបុត្តត្ថេរពោលថា កាយវិវេក (កើតមាន) ដល់ពួកបុគ្គលដែលចេញចាកពួក ត្រេកអរក្នុងការចេញចាកកាមផង ចិត្តវិវេក (កើតមាន) ដល់ពួកបុគ្គលដែលមានចិត្តបរិសុទ្ធ ដល់នូវសេចក្តីផូរផង់ក្រៃលែងផង ឧបធិ-វិវេក (កើតមាន) ដល់ពួកបុគ្គលដែលមិនមានកិលេស ដល់នូវព្រះនិព្វានដែលប្រាកចាកសង្ខារផង ។ គប្បីចម្រើន គឺគប្បីកើនឡើង អធិប្បាយថាចូលទៅសម្រេចវិវេក ៣ នេះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងវនវាសីតិស្សត្ថេរ ចប់

ពាលវគ្គធី ៥ ចប់

សុត្តន្តបិដក

ធម្មបទគាថា បណ្ឌិតវគ្គទី ៦

[១៦] បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យ ដូច្នោះ គួរគប់អ្នកប្រាជ្ញបែបនោះ (ព្រោះថា) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះ ហើយ រមែងមានសេចក្តីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។

បណ្ឌិតគួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់នូវជនទាំងឡាយ ចាកអំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់សប្បុរសតែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ ។

បុគ្គលមិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់ ។

បណ្ឌិតដែលមានសេចក្តីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរ ក្នុងធម៌ដែលព្រះអរិយៈ ប្រកាសទុកហើយ គ្រប់ពេល ។

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញតែងពត់ព្រួញ (ឲ្យត្រង់) អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួន (ដូច្នោះដែរ) ។

ភ្នំថ្មតាន់មិនរំកើបព្រោះខ្យល់ ដូចម្តេចមិញ បណ្ឌិតទាំងឡាយ ក៏មិនរំភើប ព្រោះពាក្យតិះដៀល និងពាក្យសរសើរ (ជាដើម) ដូច្នោះឯង ។

អង្ឃ៌ទឹកដែលជ្រៅ រមែងថ្លា មិនល្អក់យ៉ាងណា បណ្ឌិតទាំងឡាយ បើបានស្តាប់ធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់សួន យ៉ាងនោះ ។

ពួកសប្បុរស តែងលះ (ឆន្ទរាគ) ក្នុងធម៌ទាំងពួង ពួកលោកអ្នកស្ងប់ រមែងមិនរអែរអូវ ព្រោះសេចក្តីប្រាថ្នាក្នុងកាម ពួកបណ្ឌិតបើសេចក្តីសុខ ឬទុក្ខពាល់ត្រូវហើយ រមែងមិនសម្តែងអាការឡើងចុះឡើយ ។

បណ្ឌិតមិនគួរធ្វើអាក្រក់ ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់ ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នាសិទ្ធិ ដើម្បីខ្លួនដោយហេតុមិនមែនជាធម៌ឡើយ លោកគួរជាអ្នកមានសីល មានប្រាជ្ញាប្រកបដោយធម៌ ។ បណ្តាមនុស្សទាំងឡាយ ពួកជនណា ដែលឆ្លងដល់ត្រើយ គឺព្រះនិព្វាន ពួកជននោះ មានប្រមាណតិចចំណែកពួកសត្វក្រៅនេះ រមែងស៊ុះទៅកាន់ត្រើយ (គឺសក្កាយទិដ្ឋិ) ។

ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលព្រះតថាគត ទ្រង់សម្តែងទុកហើយដោយប្រពៃ ជនទាំងនោះនឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបាន ហើយដល់នូវព្រះនិព្វាន ។

បណ្ឌិតគួរលះបង់ធម៌ខ្មៅចេញ ញុំាងធម៌សឲ្យចម្រើនឡើង (ដោយវិធី) ចេញចាកអាល័យ គឺកាមគុណ ហើយឈមទៅរកព្រះនិព្វាន ជាធម្ម-ជាតមិនមានអាល័យ គប្បីលះបង់កាមទាំងឡាយចេញ ជាអ្នកមិនមានកង្វល់ ប្រាថ្នានូវសេចក្តីត្រេកអរក្នុងវិវេក ដែលពួកសត្វត្រេកអរបានដោយក្រនោះ បណ្ឌិតគួរញុំាងខ្លួនឲ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត ។ ចិត្តដែលបណ្ឌិតទាំង-

ទ្បាយណា បានអប់រំល្អហើយ ក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងទ្បាយ ឬបណ្ឌិតទាំងទ្បាយណា មិនប្រកាន់មាំ ត្រេកអរតែក្នុងការលះនូវសេចក្តីប្រកាន់មាំ បណ្ឌិតទាំងទ្បាយនោះៗ រមែងជាអ្នកអស់អាសវៈ មានសេចក្តីរុងរឿង បរិនិព្វានក្នុងលោក ។

បណ្ឌិតវគ្គទី ៦ ចប់

អដ្ឋកថា

បណ្ឌិតវគ្គទី ៦

រឿង ព្រះរាធត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះរាធៈ ត្រាស់ព្រះធម្មទេសនានេះថា **និធីនំវ បវត្តារំ** *ជាដើម ។*

បានឮថា ព្រះរាធៈនោះក្នុងកាលជាគ្រហស្ថ បានជាព្រាហ្មណ៍ក្រីក្រនៅក្នុងក្រុងសាវត្ថី ។ គាត់គិតថា អញនឹងចិញ្ចឹមជីវិតនៅក្នុងសម្នាក់របស់ភិក្ខុទាំងឡាយ ដូច្នេះហើយ ទៅកាន់វិហារ ឆ្ពោះស្មៅ ចោសបរិវេណ ប្រគេនវត្ថុមានទឹកលប់មុខជាដើម នៅក្នុងវិហារហើយ ។ ភិក្ខុទាំងឡាយបានសង្គ្រោះហើយក៏ដោយ តែក៏មិនប្រាថ្នាឲ្យគាត់បួស ។ គាត់កាលមិនបានបួស ក៏ស្គមស្គាំងហើយ ។

ថ្ងៃក្រោយមក ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោក ក្នុងពេលទៀបភ្លឺ ទតឃើញព្រាហ្មណ៍នោះហើយ ទ្រង់ពិចារណាថា ហេតុអ្វីហ្ន៎ ដូច្នេះហើយ ទ្រង់ជ្រាបថា រាធព្រាហ្មណ៍នឹងបានជាព្រះអរហន្តក្នុងពេលល្ងាច ទ្រង់យាងចារិកទៅក្នុងវិហារ ចូលកាន់សម្នាក់របស់ព្រាហ្មណ៍ហើយត្រាស់សួរថា ម្នាលព្រាហ្មណ៍ អ្នកធ្វើអ្វី ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គ

ធ្វើវត្តបដិបត្តិដល់ភិក្ខុទាំងឡាយ ។ ព្រះសាស្តាត្រាស់ថា អ្នកបានការសង្រ្គោះ អំពីសម្នាក់របស់ភិក្ខុទាំងនោះឬ ព្រាហ្មណ៍នោះតបថា បពិត្រព្រះអង្គ បាន ខ្ញុំ ព្រះអង្គបានត្រឹមតែអាហារ តែលោកមិនឲ្យខ្ញុំព្រះអង្គបួសសោះ ។

ព្រះសាស្តា ត្រាស់ឲ្យភិក្ខុសង្ឃប្រជុំគ្នាព្រោះរឿងនោះហើយ ត្រាស់សួរ សេចក្តីនោះហើយ ទើបសួរថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយរឭកដល់ គុណរបស់ព្រាហ្មណ៍នេះបាន មានដែរឬទេ ព្រះសារីបុត្តត្តេរក្រាបទូលថា បពិត្រ ព្រះអង្គ ខ្ញុំព្រះអង្គរឭកបាន កាលខ្ញុំព្រះអង្គត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ព្រាហ្មណ៍នេះឲ្យមនុស្សប្រគេនភិក្ខាមួយវែក ដែលគេនាំមកដើម្បីខ្លួន ខ្ញុំព្រះ អង្គរឭកដល់គុណរបស់ព្រាហ្មណ៍នេះបាន ។ កាលព្រះសាស្តាត្រាស់ថា ម្នាល សារីបុត្ត ការដែលអ្នកដោះព្រាហ្មណ៍អ្នកមានឧបការៈ ដែលធ្វើហើយយ៉ាង នេះ ឲ្យចាកផុតទុក្ខមិនគួរទេឬ ព្រះសារីបុត្តក្រាបទូលថា សាធុ ព្រះអង្គ ខ្ញុំ ព្រះអង្គនឹងឲ្យគាត់បួស ទើបឲ្យព្រាហ្មណ៍បួសហើយ ។

អាសនៈចុងក្រោយ នៃអាសនៈក្នុងភេងធាន់ រមែងដល់លំដាប់របស់ លោក លោកលំបាកដោយការរកវត្តុ មានបបរ និងភត្តជាដើម ព្រះថេរៈនាំ លោកចៀសចេញទៅកាន់ទីចារិកហើយ ឲ្យឱវាទទួន្មានរឿយៗ ថា វត្តុនេះ លោកម្ចាស់គួរធ្វើ វត្តុនេះ មិនគួរធ្វើជាដើម ។ លោកបានជាបុគ្គលប្រដៅ ងាយ មានប្រក្រតីទទួលយកឱវាទដោយគោរពហើយ ព្រោះដូច្នោះ កាល លោកបដិបត្តិតាមពាក្យដែលព្រះថេរៈទូន្មាន ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេច អរហត្ត ហើយព្រះថេរៈនាំលោកទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំ

អង្គុយហើយ ។

លំដាប់នោះ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈដល់លោក ហើយត្រាស់ថា ម្នាលសារីបុត្ត អន្តេវាសិករបស់អ្នកប្រជៅងាយឬ ព្រះថេរៈទូលថា បពិត្រព្រះអង្គ យ៉ាងនោះឯង លោកជាបុគ្គលប្រជៅងាយពន់ពេក ទោសណាមួយដែលខ្ញុំព្រះអង្គពោលទូន្មានមិនធ្លាប់ខឹងក្រោធឡើយ ។ ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្ត បើអ្នកបានសទ្ធិវិហារិកបែបនេះ គប្បីទទួលបានប្រមាណប៉ុណា ព្រះថេរៈពោលថា ខ្ញុំព្រះអង្គគប្បីទទួលបានច្រើននោះឯង ។

សម័យក្រោយមក ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា បានឮថា ព្រះសារីបុត្តត្ថេរ ជាអ្នកកតញ្ញូកតវេទី រឭកដល់ឧបការៈត្រឹមតែបាយមួយវែក ឲ្យព្រាហ្មណ៍បួសហើយ សូម្បីព្រះរាជត្ថេរ ក៏ជាអ្នកអត់ធន់ចំពោះឱវាទរមែងបានបុគ្គលគួរដល់ការឲ្យឱវាទដូចគ្នា ។

ព្រះសាស្តា ទ្រង់ស្តាប់កថារបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ទោះបីក្នុងកាលមុន សារីបុត្តក៏ជាបុគ្គលកតញ្ញូកតវេទីដូចគ្នា ដូច្នេះហើយ ដើម្បីនឹងប្រកាសសេចក្តីនោះ ទើបត្រាស់អលីនចិត្តជាតក ក្នុងទុក្កនិបាតនេះឲ្យពិស្តារថា

ព្រះសាស្តាត្រាស់ថា សេនាដ៏ច្រើន មានចិត្តរីករាយ ព្រោះអាស្រ័យនូវអលីនចិត្តកុមារ បានញាំងជំរឿឲ្យចាប់យកព្រះបាទកោសលទាំងរស់ ដែលមិនត្រេកអរហើយ ដោយរាជសម្បត្តិរបស់ខ្លួន យ៉ាងណាមិញ ។

ភិក្ខុអ្នកបរិបូណ៌ដោយនិស្សយ មានសេចក្តីព្យាយាមប្រារព្ធហើយ កាលចម្រើនទូវកុសលធម៌ ដើម្បីសម្រេចនូវព្រះនិព្វានជាទីក្សេមចាកយោគៈ គប្បីដល់នូវការអស់ទៅនៃសំយោជនៈទាំងពួងដោយលំដាប់ ក៏យ៉ាងនោះដែរ ។

បានឮថា ជីវមួយត្រាច់ទៅម្នាក់ឯង ជីងឧបការៈដែលពួកជាងឈើធ្វើហើយដល់ខ្លួនដោយការៈ គឺធ្វើជើងឲ្យជាសៈស្បើយ ហើយឲ្យកូនជីវសុទ្ធជីវក្នុងកាលនោះ បានជាព្រះសារីបុត្តត្ថេរហើយ ។

ព្រះសាស្តា កាលត្រាស់ជាតកប្រារព្ធព្រះថេរៈយ៉ាងនោះហើយ ទ្រង់ប្រារព្ធព្រះរាជត្តេរត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគួរជាអ្នកប្រដៅងាយដូចរាជៈ សូម្បីអាចារ្យចង្អុលទោសប្រៀនប្រដៅក៏មិនខឹងក្រោធគួរឃើញបុគ្គលអ្នកឲ្យឱវាទ ដូចបុគ្គលអ្នកប្រាប់កំណប់ទ្រព្យដូច្នោះ ដូច្នេះហើយ ទើបទ្រង់បន្តអនុសន្ធិសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា

និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ
និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ
តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ ។

បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្តឹត់សង្តិន ចង្អុលប្រាប់ទោស ដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យដូច្នោះ គួរគប់អ្នកប្រាជ្ញបែបនោះ (ព្រោះថា) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្តី

គាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឯធិនំ** *បានដល់ ឆ្នាំងនៃកំណប់ទ្រព្យដែលពេញដោយប្រាក់ មាសជាដើម ដែលគេកប់រក្សាក្នុងទីនោះៗ ។*

បទថា **បវត្តារំ** *គឺជូចបុគ្គលធ្វើនូវការអនុគ្រោះជនក្រីក្រ ដែលរស់នៅដោយលំបាក ហើយប្រាប់ថា ចូរអ្នកមក ខ្ញុំនឹងចង្អុលឧបាយចិញ្ចឹមជីវិតដោយស្រួលដល់អ្នក ដូច្នេះហើយ នាំទៅកាន់ទីកប់ទ្រព្យហើយ លាដៃចេញប្រាប់ថា ចូរអ្នកកាន់យកទ្រព្យនេះ ចិញ្ចឹមជីវិតតាមសប្បាយចុះ ។*

វិនិច្ឆ័យក្នុងបទថា **វជ្ជឧស្សិនំ** *កិកុចង្អុលទោស មានពីរពួក គឺកិកុចាំសម្ងឹងទោសដោយគិតថា អញនឹងសង្កត់សង្កិនកិកុនោះដោយមារយាទដែលមិនសមគួរ ឬដោយកម្លាំងបែបនេះក្នុងកាលកណ្តាលជំនុំសង្ឃជូច្នេះ ១ ពួក កិកុតាំងនៅហើយតាមសភាវៈ ដោយអំណាចនៃការគាំទ្រ ដោយការសម្ងឹងមើលទោសនោះៗ ដើម្បីប្រយោជន៍ឲ្យដឹងវត្តុដែលមិនទាន់ដឹង ដើម្បីឲ្យបានរឭកដល់វត្តុដែលដឹងហើយ ព្រោះភាពជាអ្នកប្រាជ្ញាការចម្រើននៃគុណ មានសីលជាដើម ដល់បុគ្គលនោះ ១ ពួក កិកុពួកក្រោយនេះ ព្រះដ៏មានព្រះភាគទ្រង់បំណងយកក្នុងបទថា* **វជ្ជឧស្សិនំ** *នេះ ។ មនុស្សក្រីក្រ ត្រូវអ្នកដទៃគំរាមក្តី វាយក្តី ចង្អុលកំណប់ទ្រព្យឲ្យថា ចូរអ្នកកាន់យកទ្រព្យនេះ រមែងមិនធ្វើការខឹងក្រោធ មានតែត្រេកអរតែម្យ៉ាង យ៉ាងណា កាលបុគ្គលបែបនោះឃើញមារយាទមិនសមគួរក្តី ការភ្ញាំងភ្ញាត់ក្តី ហើយប្រាប់ អ្នកទទួលនូវការ*

ប្រាប់ មិនគួរធ្វើការខឹងក្រោធ គួរជាអ្នកត្រេកអរតែម្យ៉ាងដូច្នោះ គួរបវារណាថា បពិត្រលោកម្ចាស់ កម្មដ៏ធំដែលលោកម្ចាស់តាំងនៅក្នុងឋានៈជាអាចារ្យជាឧបជ្ឈាយ៍របស់ខ្ញុំហើយ ទូន្មានធ្វើហើយ សូម្បីតទៅ សូមលោកម្ចាស់ឲ្យឱវាទដល់ខ្ញុំ ដូច្នេះ ។

បទថា **និគ្គយ្ហាតិ** *សេចក្តីថា អាចារ្យខ្លះឃើញមារយាទដែលមិនសមគួរក្តី ការភ្ញាំងភ្ញាត់ក្តី របស់អន្តេវាសិក មានសទ្ធិវិហារិកជាដើមហើយ មិនអាចនិយាយដោយខ្លាចក្រែងថា សិស្សនេះឧបដ្ឋាកអញដោយកិច្ចវត្ត មានឲ្យទឹកក្តុរមាត់ជាដើមដល់អញដោយគោរព បើអញស្តីថាឲ្យលោកសោត លោកនឹងមិនឧបដ្ឋាកអញ ការវិនាសនឹងមានដល់អញដោយអាការយ៉ាងនេះ ដូច្នេះ មិនឈ្មោះថា ជាអ្នកពោលនិគ្គហៈទ្បើយ បុគ្គលនោះ ឈ្មោះថា ជាអ្នកពង្រាយនូវសំវាមក្នុងសាសនានេះ ។ ចំណែកអាចារ្យណាឃើញទោសបែបនោះហើយ គំរាមបណ្តេញ ជាក់ទណ្ឌកម្ម បណ្តេញចេញអំពីវិហារតាមសមគួរដល់ទោសឲ្យសិក្សា ។ អាចារ្យនេះ ឈ្មោះថា ពោលនិគ្គហៈ ដូចព្រះសម្មាសម្ពុទ្ធ ។ ពិតហើយ ព្រះដ៏មានព្រះភាគត្រាស់ពាក្យនេះថា ម្នាលអានន្ទ តថាគតនឹងពោលសង្កត់សង្កិន ម្នាលអានន្ទ តថាគតនឹងលើកសរសើរបុគ្គលណាជាសារៈ បុគ្គលនោះ នឹងតាំងនៅបាន ។*

បទថា **មេធាវឺ** *គឺប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ ។*

បទថា **តាទិសំ** *ជាដើម សេចក្តីថា បុគ្គលគប្បីគប់រក គឺគប្បីចូលទៅអង្គុយជិតបណ្ឌិតបែបនោះ ។ ព្រោះកាលអន្តេវាសិក សេពគប់អាចារ្យ*

បែបនោះ គុណដ៏ប្រសើររមែងមាន ទោសដ៏លាមករមែងមិនមាន គឺមានតែសេចក្តីចម្រើនតែម្យ៉ាង មិនមានការវិនាសឡើយ ។

ក្នុងទីបំផុតនៃទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងព្រះរាធត្ថេរ ចប់

រឿង អស្សជិភិក្ខុ និងបុនព្វសុកៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអស្សជិ និងបុនព្វសុកៈ ត្រាស់ព្រះធម្មទេសនានេះថា **ទ្វាទេយ្យាឧសាសេយ្យ** ជាដើម ។ ទេសនានេះតាំងឡើងហើយត្រង់កិជាគិរី ។

បានឮមកថា ភិក្ខុពីរបួបនោះ ជាសទ្ធិវិហារិករបស់អគ្គសាវ័កក៏ពិត តែលោកក៏ក្លាយជាអលជ្ជី ជាភិក្ខុអាក្រក់ ភិក្ខុពីរបួបនោះ កាលនៅត្រង់កិជាគិរី ជាមួយភិក្ខុ ៥០០ រូបដែលជាបរិវារបស់ខ្លួន សុទ្ធសឹងតែជាមនុស្សអាក្រក់ ធ្វើអនាចារច្រើនបែបច្រើនយ៉ាងជាដើម ដាំដើមឈើខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យដាំខ្លះ ធ្វើកម្មនៃភិក្ខុដែលប្រទូស្តត្រកូល ចិញ្ចឹមជីវិតដោយបច្ច័យដែលកើតអំពីកម្មនោះ បានធ្វើអាវាសនោះមិនឲ្យជាលំនៅនៃពួកភិក្ខុ ដែលមានសីលជាទីស្រឡាញ់ ។ ព្រះសាស្តាទ្រង់ស្តាប់ដំណឹងនោះហើយ ត្រាស់ហៅអគ្គសាវ័ក

ទាំងពីរ មួយអន្ទើដោយបរិវារមក ដើម្បីបំណងធ្វើបព្វាជនីយកម្មដល់ភិក្ខុទាំងនោះ ហើយត្រាស់ថា ម្នាលសារីបុត្ត និងមោគ្គល្លាន ពួកអ្នកនាំគ្នាទៅចុះក្នុងភិក្ខុទាំងនោះ ភិក្ខុណាមិនស្តាប់ពាក្យរបស់អ្នក ចូរធ្វើបព្វាជនីយកម្មដល់ភិក្ខុទាំងនោះ ចំណែកភិក្ខុណាស្តាប់ ចូរពោលប្រៀនប្រដៅភិក្ខុទាំងនោះ ធម្មតាការប្រៀនប្រដៅ រមែងមិនជាទីស្រឡាញ់របស់បុគ្គលដែលមិនមែនបណ្ឌិតប៉ុណ្ណោះ តែជាទីស្រឡាញ់ពេញចិត្តរបស់បណ្ឌិតទាំងឡាយ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ឱវាទេយ្យានុសាសេយ្យ អសព្ភា ច និវារយេ
សតំ ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ ។

បណ្ឌិតគួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់នូវជនទាំងឡាយ ចាកអំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់សប្បុរសតែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឱវាទេយ្យ** *សេចក្តីថា កាលកើតរឿងឡើង ហើយទើបពោល ឈ្មោះថាឱវាទ កាលមិនទាន់កើតរឿង ចង្អុលទោសដែលមិនទាន់មកដល់ ដោយពាក្យជាដើមថា ទោសនឹងគប្បីមានដល់អ្នក ដូច្នេះ ឈ្មោះថា អនុសាសនៈ កាលពោលចំពោះមុខ ឈ្មោះថា ឱវាទ បើបញ្ជូនទូតឬសាសន៍ទៅក្នុងទីកំបាំង ឈ្មោះថា អនុសាសនៈ បើពោលតែម្តង ឈ្មោះថា ឱវាទ បើពោលរឿយៗ ឈ្មោះថាអនុសាសនៈ ម្យ៉ាងទៀត កំពុងឲ្យឱវាទនោះ*

ឯង ឈ្មោះថា អនុសាសនៈ គប្បីពោលប្រៀនប្រដៅយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា **អសព្ភា** សេចក្តីថា គប្បីហាមចាកអកុសលធម៌ គប្បីឲ្យតាំងនៅក្នុងកុសលធម៌ ។ បទថា **សតំ** សេចក្តីថា បុគ្គលបែបនេះ រមែងជាទីស្រឡាញ់នៃសប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម តែបុគ្គលពោលប្រៀនប្រដៅនោះ រមែងមិនជាទីស្រឡាញ់នៃពួកបុគ្គលមិនឃើញធម៌ មានបរលោកដែលឆ្ងងហើយ ជាអ្នកឃើញដល់អាមិស បួសដើម្បីប្រយោជន៍ដល់ការចិញ្ចឹមជីវិតទាំងនោះ ឈ្មោះថា អសប្បុរស ជាបុគ្គលចាក់ដោយលំពែង គឺមាត់យ៉ាងនេះថា លោកមិនមែនឧបជ្ឈាយ៍ ឬអាចារ្យរបស់ពួកខ្ញុំទេ ហេតុអ្វីប្រៀនប្រដៅពួកខ្ញុំ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ។

ចំណែកព្រះសារីបុត្ត និងព្រះមោគ្គល្លាន ទៅត្រង់កិជាគីរីនោះ ពោលប្រៀនប្រដៅភិក្ខុទាំងនោះហើយ ក្នុងភិក្ខុទាំងនោះ ភិក្ខុពួកខ្លះ ក៏ទទួលឱវាទតាំងចិត្តប្រព្រឹត្តបដិបត្តិ ពួកខ្លះ ក៏សឹកទៅ ភិក្ខុពួកខ្លះ ក៏ត្រូវបព្វាជនីយកម្មដូច្នេះឯង ។

រឿងអស្សជិភិក្ខុ និងបុនព្វសុកៈ ចប់

រឿង ព្រះឆន្នត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះឆន្នត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ឧ ភជេ ចាបកេ មិត្តេ** *ជាដើម ។*

បានឮមកថា ព្រះឆន្ននោះជេរព្រះអគ្គសាវកទាំងពីរថា ខ្ញុំកាលតាមទ្រង់ចេញមហាភិនេស្ក្រមណ៍ ជាមួយអយ្យបុត្រនៃយើងទាំងឡាយ ក្នុងពេលនោះ មិនបានឃើញអ្នកជនៃ សូម្បីត្រឹមតែម្នាក់ តែឥឡូវនេះ លោកទាំងនេះត្រាច់មកពោលថា ខ្ញុំឈ្មោះសារីបុត្ត ខ្ញុំឈ្មោះមោគ្គល្លាន ពួកខ្ញុំជាអគ្គសាវក ។ ព្រះសាស្តា ទ្រង់ឮដំណឹងនោះអំពីសម្នាក់ភិក្ខុទាំងឡាយហើយ ត្រាស់ឲ្យហៅព្រះឆន្នត្ថេរមកទូន្មានហើយ ។ លោកស្ងៀមក្នុងខណៈនោះប៉ុណ្ណោះ ត្រឡប់ទៅជេរព្រះថេរៈទាំងឡាយយ៉ាងនោះទៀត ។ ព្រះសាស្តា ត្រាស់ឲ្យហៅលោកដែលកំពុងជេរមកហើយ ត្រាស់ប្រៀនប្រដៅយ៉ាងនោះអស់វារៈ ៣ ដង ហើយទ្រង់ជាស់តឿនថា ម្នាលឆន្ន ឈ្មោះថា អគ្គសាវកទាំងពីរ ជាកល្យាណមិត្ត ជាបុរសដ៏ឧត្តមរបស់អ្នក ចូរអ្នកសេពគប់កល្យាណមិត្តបែបនេះ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ឧ ភជេ ចាបកេ មិត្តេ ឧ ភជេ បុរិសាធមេ
ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ ។

បុគ្គលមិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់ ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា បុគ្គលត្រេកអរក្នុងអកុសលកម្ម មានកាយទុច្ចរិតជាដើម ឈ្មោះថាជាបមិត្ត បុគ្គលជឹកនាំក្នុងហេតុដែលមិនសមគួរ មានការកាត់ទី-តជាដើមក្តី មានការស្វែងរកមិនសមគួរ ២១ យ៉ាងក្តី ឈ្មោះថា បុរសថោកទាប ។ ម្យ៉ាងទៀត ជនពីរពួកនោះ ឈ្មោះថាជាជាបមិត្តផង ជាបុរសថោកទាបផង បុគ្គលមិនគួរគប់ មិនគួរអង្គុយជិតបុគ្គលទាំងនោះ ចំណែកជនដែលខុសផ្ទុយគ្នា ឈ្មោះថាជាកល្យាណមិត្តផង ជាសប្បុរសផង បុគ្គលគួរគប់ គឺគួរអង្គុយជិតលោកទាំងនោះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ។

ចំណែកព្រះឆន្នត្ថេរ សូម្បីបានស្តាប់ព្រះឱវាទហើយ ក៏នៅតែជេរពួកភិក្ខុដូចនយមុននោះឯងទៀត ។ ពួកភិក្ខុក៏ក្រាបទូលដល់ព្រះសាស្តាទៀត ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលតថាគតនៅមានជីវិត ពួកអ្នកមិនអាចឲ្យឆន្នសិក្សាបានឡើយ តែកាលតថាគតបរិនិព្វានហើយទើបអាច ដូច្នេះហើយ កាលព្រះអានន្ទទូលសួរក្នុងកាលជិតបរិនិព្វានថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គគប្បីបដិបត្តិក្នុងព្រះឆន្នត្ថេរដូចម្តេច ទើបទ្រង់ត្រាស់ថា ម្នាលអានន្ទ ពួកអ្នកគប្បីដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុចុះ ។

ឆន្នភិក្ខុនោះ កាលព្រះសាស្តាបរិនិព្វានហើយ បានស្តាប់ព្រហ្មទណ្ឌដែលព្រះអានន្ទត្ថេរលើកឡើងហើយ មានទុក្ខ ខូចចិត្ត ដួលសន្លប់អស់ ៣ ដង ហើយអង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំឲ្យខ្ញុំវិនាសឡើយ ដូច្នេះ

ហើយ បំពេញវត្តដោយប្រពៃ ក្នុងកាលមិនយូរប៉ុន្មានក៏សម្រេចអរហត្ត មួយ អន្ទើដោយបដិសម្ភិទាទាំងឡាយហើយ ដូច្នេះឯង ។

រឿង ព្រះធន្នត្ថេរ ចប់

រឿង ព្រះមហាកប្បិនត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះមហាកប្បិនត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ធម្មបីតិ សុខំ សេតិ** ជាដើម ។ ក្នុងរឿងនោះ មានអនុបុព្វីកថាដូចតទៅនេះ

បានឮថា ក្នុងអតីតកាល ព្រះមហាកប្បិន មានអភិនីហារបានធ្វើទៀប បាទមូលរបស់ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរ: អន្ទោលទៅក្នុងសង្សារ កើតជា ប្រធាននៃជាងតម្បាញ ក្នុងស្រុកជាងតម្បាញមួយកន្ទើង មិនឆ្ងាយអំពីក្រុង ពារាណសី ។ គ្រានោះ ព្រះបច្ចេកពុទ្ធប្រមាណមួយពាន់អង្គ នៅក្នុងហិម-វន្តប្បទេស ៨ ខែ នៅក្នុងជនបទ ៤ ខែ ក្នុងរដូវភ្លៀង ។ គ្រាមួយ ព្រះ បច្ចេកពុទ្ធទាំងនោះ ស្នាក់នៅក្នុងទីមិនឆ្ងាយអំពីក្រុងពារាណសី ហើយបញ្ជូន ព្រះបច្ចេកពុទ្ធពីររូប ទៅកាន់សម្នាក់របស់ព្រះរាជាដោយពាក្យថា លោក ទាំងឡាយ ចូរទូលសុំហត្ថកម្ម ដើម្បីប្រយោជន៍ដល់ការធ្វើសេនាសន: ។ ក្នុងកាលនោះ ជាពេលវប្បមង្គល គឺច្រត់ព្រះនង្គ័លរបស់ព្រះរាជា ព្រះរាជា

បានឮថា ព្រះបច្ចេកពុទ្ធទាំង៤ព្រាយនិមន្តមក ទើបយាងចេញទៅ ត្រាស់សួរដល់ហេតុដែលមក ហើយត្រាស់ថា បពិត្រលោកម្ចាស់ ថ្ងៃនេះ មិនទាន់មានឱកាស ព្រោះស្អែកនេះ យើង៤ទាំង៤ព្រាយមានន្ទូវវប្បមង្គល ។ យើង៤នឹងធ្វើក្នុងថ្ងៃទី ៣ ទ្រង់មិនអាចធនាព្រះបច្ចេកពុទ្ធទាំង៤ព្រាយទ្បើយ ទ្រង់ចូលទៅហើយ ព្រះបច្ចេកពុទ្ធទាំង៤ព្រាយគិតថា ពួកយើងនឹងទៅកាន់ស្រុកដទៃ ហើយចៀសចេញទៅ ។

ខណៈនោះ ភរិយាជាងតម្បាញដែលជាប្រធានទៅកាន់ក្រុងពារាណសី ដោយកិច្ចឯណានីមួយ ឃើញព្រះបច្ចេកពុទ្ធទាំង៤នោះ នមស្ការហើយសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់មកខុសកាលព្រោះហេតុអ្វី បានជ្រាបការប្រព្រឹត្តទៅនោះតាំងអំពីដើមដល់ចប់ ជាស្រីមានសទ្ធា ដល់ព្រមដោយបញ្ញា និមន្តថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំង៤ព្រាយ ទទួលភិក្ខារបស់យើង៤ក្នុងថ្ងៃស្អែកនេះ ។

ព្រះបច្ចេកពុទ្ធត្រាស់ថា ម្នាលប្អូនស្រី ពួកអាត្មាមានច្រើន ស្រីនោះពោលថា មានប្រមាណប៉ុន្មានលោកម្ចាស់ ព្រះបច្ចេកពុទ្ធពោលថា ម្នាលប្អូនស្រី មានប្រមាណមួយពាន់រូប ។ ស្រីនោះពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំមានប្រមាណមួយពាន់នាក់នៅក្នុងស្រុកនេះ មនុស្សម្នាក់នឹងប្រគេនភិក្ខាដល់លោកម្ចាស់មួយរូបៗ សូមលោកម្ចាស់ទាំង៤ព្រាយទទួលភិក្ខាចុះ ខ្ញុំម្ចាស់ឯងនឹងប្រគេនទីលំនៅ ដល់លោកម្ចាស់ទាំង៤ព្រាយ ។

ព្រះបច្ចេកពុទ្ធទាំង៤ព្រាយទទួលហើយ នាងចូលទៅកាន់ស្រុកប្រកាសថា

ខ្ញុំយើញព្រះបច្ចេកពុទ្ធប្រមាណមួយពាន់អង្គ ខ្ញុំនិមន្តហើយ អ្នកទាំងឡាយ ចូរចាត់ចែងទីអង្គុយជល់លោកម្ចាស់ទាំងឡាយ ចូររៀបចំអាហារវត្ថុទាំងឡាយ មានបបរ និងចុយជាដើម ជល់លោកម្ចាស់ទាំងឡាយចុះ ហើយឲ្យសាងបុស្បកត្រង់កណ្តាលស្រុក ក្រាលអាសនៈ ក្នុងថ្ងៃស្អែកឡើង ទើបនិមន្តព្រះបច្ចេកពុទ្ធទាំងឡាយឲ្យគង់ អង្គាសដោយភោជនដ៏ប្រណីត ក្នុងពេលស្រេចភត្តកិច្ច ទើបនាំស្រីទាំងអស់ក្នុងស្រុកនោះ មួយអន្ទើដោយស្រីទាំងនោះ នមស្ការព្រះបច្ចេកពុទ្ធទាំងឡាយហើយ ទទួលយកប្តេជ្ញា ដើម្បីប្រយោជន៍ជល់ការនៅអស់ត្រីមាស ហើយប្រកាសជល់អ្នកស្រុកទៀតថា នែនាង និងអ្នកទាំងឡាយ បុរសនីមួយៗ អំពីត្រកូលនីមួយៗ ចូរកាន់យកគ្រឿងឧបករណ៍ មានកាំបិតជាដើម ចូលទៅកាន់ព្រៃនាំយកទព្វសម្ភារៈ មកធ្វើលំនៅរបស់ព្រះបច្ចេកពុទ្ធទាំងឡាយចុះ ។

ពួកអ្នកស្រុកតាំងនៅក្នុងពាក្យរបស់នាងហើយ មនុស្សម្នាក់ៗ ធ្វើទីកន្លែងនីមួយៗ ហើយសាងសាលាប្រក់ដោយស្លឹកឈើចំនួនមួយពាន់ខ្នង មួយអន្ទើដោយទីសម្រាកពេលយប់ និងពេលថ្ងៃ ហើយឧបដ្ឋាកព្រះបច្ចេកពុទ្ធនៅចាំវស្សាក្នុងបណ្តាសាលារៀងៗ ខ្លួន ដោយតាំងចិត្តថា យើងនឹងឧបដ្ឋាកដោយគោរព យើងនឹងឧបដ្ឋាកដោយគោរព ។

ក្នុងពេលចេញវស្សាហើយនាងបបួលថា អ្នកទាំងឡាយចូរត្រៀមសំពត់ដើម្បីចីវរ ប្រគេនដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ដែលនៅចាំវស្សាក្នុងបណ្តាសាលារៀងៗ ខ្លួនចុះ ហើយឲ្យប្រគេនចីវរដែលមានតម្លៃមួយពាន់ ដល់ព្រះ

បច្ចេកពុទ្ធមួយអង្គៗ ។ ព្រះបច្ចេកពុទ្ធទាំងឡាយចេញវស្សាហើយ ធ្វើអនុមោទនាហើយ ក៏ចៀសចេញទៅ ។

ពួកអ្នកស្រុកកាលធ្វើបុណ្យនេះហើយ ចុតិចាកអត្តភាពនោះ កើតក្នុងភពតាវត្តិង្ស មានឈ្មោះថា គណទេវបុត្រ ។ ទេវបុត្រទាំងនោះ សោយទិព្ធ-សម្បត្តិក្នុងស្ថានតាវត្តិង្សនោះ ក្នុងកាលព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សប: មកកើតក្នុងផ្ទះកុដុម្ពិក: ក្នុងក្រុងពារាណសី ។ ប្រធានជាងតម្បាញ បានជាកូនរបស់កុដុម្ពិក:ដែលជាធំ ចំណែកភរិយារបស់គេ បានជាធីតារបស់កុដុម្ពិក: ដែលជាធំដូចគ្នា ។ ស្រីទាំងអស់នោះដល់នូវការចម្រើនវ័យហើយ កាលទៅកាន់ត្រកូលស្វាមី បានទៅកាន់ផ្ទះរបស់បុរសទាំងនោះឯង ។

សម័យមួយ គេប្រកាសការស្តាប់ធម៌ក្នុងវិហារ ។ កុដុម្ពិក:ទាំងអស់នោះបានឮថា ព្រះសាស្តាទ្រង់សម្តែងធម៌ ប្រឹក្សាគ្នាថា យើងទាំងឡាយនឹងស្តាប់ធម៌ ហើយទៅកាន់វិហារជាមួយភរិយា ។ ក្នុងខណ:ដែលជនទាំងនោះចូលទៅកាន់វិហារ ភ្លៀងបានធ្លាក់ហើយ ។ បព្វជិតទាំងឡាយ មានសាមណេរជាដើមដែលជាកុលុបក: ឬជាញាតិរបស់ជនទាំងឡាយណាមាន ជនទាំងនោះ ក៏ចូលទៅកាន់បរិវេណរបស់បព្វជិតទាំងនោះ តែកុដុម្ពិក:ទាំងនោះ មិនអាចចូលទៅក្នុងទីណាបាន ព្រោះកុលុបក: ឬញាតិបែបនោះមិនមាន បានឈរត្រង់កណ្តាលវិហារនោះឯង ។

លំដាប់នោះ ទើបកុដុម្ពិក:ដែលជាប្រធាន ពោលនឹងកុដុម្ពិក:ដែលជាបរិវារទាំងនោះថា អ្នកទាំងឡាយ ចូរមើលអាការគួរខ្ពើមរបស់ពួកយើង ធម្មតា

កុលបុត្រទាំងឡាយ ខ្ញុំសដោយហេតុមានប្រមាណប៉ុណ្ណេះ សមគួរហើយ បរិវារពោលថា បពិត្រលោកម្ចាស់ ពួកយើងនឹងធ្វើដូចម្តេច កុដុម្ពិកៈពោលថា ពួកយើងជល់នូវអាការគួរខ្ញុំសនេះ ព្រោះមិនមានទីកន្លែងដែលមានមនុស្សស្និទ្ធស្នាលគ្នា យើងទាំងអស់រៃទ្រព្យគ្នាសាងបរិវេណចុះ បរិវារពោលថា សាធុ លោកម្ចាស់ ។

កុដុម្ពិកៈជាប្រធានឲ្យទ្រព្យមួយពាន់ ជនដ៏សេសឲ្យម្នាក់ ៥០០ ពួកស្រីៗ ឲ្យម្នាក់ ២៥០ ជនទាំងនោះ ប្រមូលទ្រព្យនោះហើយ ផ្តើមសាងបរិវេណធំ ដើម្បីប្រយោជន៍ជាទីប្រថាប់របស់ព្រះសាស្តា ដែលមានផ្ទះកំពូលមួយពាន់ជាបរិវារ ។ កាលទ្រព្យមិនគ្រប់គ្រាន់ ព្រោះនវកម្មជាការងារធំ ទើបចេញម្នាក់ពាក់កណ្តាល អំពីទ្រព្យដែលខ្លួនឲ្យហើយក្នុងកាលមុន កាលបរិវេណស្រេចហើយ ជនទាំងនោះធ្វើការឆ្លងវិហារ ទើបថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ហើយចាត់ចែងចីវរដើម្បីភិក្ខុមួយពាន់រូប ។

ចំណែកភរិយារបស់កុដុម្ពិកៈដែលជាប្រធាន មិនធ្វើឲ្យមានចំណែកស្មើដោយជនទាំងអស់ តាំងនៅដោយបញ្ញារបស់ខ្លួន គិតថា អញនឹងបូជាព្រះ-សាស្តា ធ្វើឲ្យក្រៃលែងជាងគេ ទើបកាន់យកប្រអប់ ជាក់ផ្ការនោង និងសំពត់សាដក ដែលមានពណ៌ដូចផ្ការនោងតម្លៃមួយពាន់ ក្នុងពេលអនុមោទនាបូជាព្រះសម្ពុទ្ធដោយផ្ការនោង ហើយជាក់សំពត់សាដកនោះ ទៀបបាទមូលរបស់ព្រះសាស្តា តាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ សូមសរីរៈរបស់ខ្ញុំម្ចាស់ដូចផ្ការនោងនេះឯង ក្នុងទីដែលខ្ញុំម្ចាស់កើតហើយ ខ្ញុំម្ចាស់សូមមាន

ឈ្មោះថា អនោជានុ៎ះឯង ។ ព្រះសាស្តាទ្រង់បានធ្វើអនុមោទនាថា ចូរសម្រេចយ៉ាងនេះចុះ ។

ជនទាំងអស់នោះ តាំងនៅជរាបអស់អាយុហើយ ចុតិអំពីអត្តភាពនោះ កើតក្នុងទេវលោក ក្នុងពុទ្ធុប្បាទកាលនេះ ចុតិអំពីទេវលោកហើយ កុដុម្ពិកៈជាប្រធានកើតក្នុងរាជត្រកូល ក្នុងកុក្កុដវតីនគរ ដល់នូវសេចក្តីចម្រើនវ័យហើយ បានជាព្រះរាជាព្រះនាមមហាកប្បិន ជនដ៏សេសកើតក្នុងត្រកូលអមាត្យ ភរិយារបស់កុដុម្ពិកៈជាប្រធាន កើតក្នុងរាជត្រកូល ក្នុងសាគលនគរក្នុងមត្តរដ្ឋ ព្រះនាងមានព្រះសរីរៈដូចគ្នានឹងពណ៌នៃផ្កានោងនោះឯង ទើបព្រះញាតិថ្វាយព្រះនាមដល់ព្រះនាងថា អនោជា នុ៎ះឯង ។ ព្រះនាងដល់នូវការចម្រើនវ័យហើយ ទៅកាន់ព្រះរាជមន្ទីរនៃព្រះបាទកប្បិន បានជាព្រះទេវីមានព្រះនាមអនោជាហើយ សូម្បីស្រីទាំងឡាយដ៏សេស កើតក្នុងត្រកូលអមាត្យទាំងឡាយ ដល់នូវការចម្រើនវ័យហើយ ក៏បានទៅកាន់ផ្ទះនៃបុត្រអមាត្យទាំងនោះដូចគ្នា ។ ជនទាំងនោះ បានសោយសម្បត្តិដូចគ្នានឹងសម្បត្តិរបស់ព្រះរាជា ។ ក្នុងកាលណាព្រះរាជា ទ្រង់ប្រដាប់គ្រឿងអលង្ការទាំងពួងគង់លើខ្នងដីរត្រាច់ទៅ ក្នុងកាលនោះ ជនទាំងនោះ ក៏ត្រាច់ទៅយ៉ាងនោះ កាលព្រះរាជាយាងទៅដោយសេះ ឬដោយរថ ជនទាំងនោះ ក៏ត្រាច់ទៅយ៉ាងនោះដូចគ្នា ។ ជនទាំងនោះ សោយសម្បត្តិរួមគ្នាដោយអានុភាពនៃបុណ្យដែលធ្វើរួមគ្នា ដោយប្រការដូច្នេះ ។

សេះរបស់ព្រះរាជាមាន ៥ គឺ សេះឈ្មោះពល ១ ពលវាហនៈ ១

បុប្ផៈ ១ បុប្ផវាហនៈ ១ សុបត្តៈ ១ ។ បណ្តាសេះទាំងនោះ សេះឈ្មោះសុបត្តៈ ព្រះរាជាគង់ដោយព្រះអង្គឯង សេះ ៤ ក្រៅអំពីនេះ ទ្រង់ព្រះរាជទានជាសេះបម្រើ ដើម្បីប្រយោជន៍ក្នុងការនាំសារទៅមក ។

ព្រះរាជា ឲ្យសេះបម្រើទាំងនោះស៊ីអំពីព្រលឹមហើយ ទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា ចូរពួកអ្នកទៅចុះ ត្រាច់ទៅ ២-៣ យោជន៍ ហើយចូរជ្រាបថា ព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃកើតហើយ ចូរនាំដំណឹងដែលនាំឲ្យកើតសុខមកដល់ខ្ញុំ ។ សេះបម្រើទាំងនោះ ចេញដោយទ្វារទាំង ៤ ត្រាច់ទៅបាន ២-៣ យោជន៍ មិនបានដំណឹងក៏ត្រឡប់មក ។

សម័យថ្ងៃមួយ ព្រះរាជាគង់លើសេះឈ្មោះសុបត្តៈ ដែលអមាត្យមួយពាន់ចោមរោម យាងទៅកាន់ព្រះរាជឧទ្យាន ទតឃើញពួកឈ្មួញប្រមាណ ៥០០ មានរាងកាយទន់ខ្សោយកម្ងាច ចូលកាន់ព្រះនគរ ហើយទ្រង់ព្រះតម្រិះថា ជនទាំងនេះ លំបាកក្នុងការធ្វើដំណើរផ្លូវឆ្ងាយ អញនឹងបានស្តាប់ដំណឹងល្អណាមួយ អំពីសម្នាក់នៃជនទាំងនេះឯងដោយពិត ទើបឲ្យហៅឈ្មួញទាំងនោះមកត្រាស់សួរថា អ្នកទាំងឡាយមកអំពីស្រុកណា ឈ្មួញទូលថា បពិត្រព្រះអង្គ ពួកទូលបង្គំមកអំពីនគរឈ្មោះសាវត្ថី មាននៅក្នុងទីបំផុតប្រមាណ ១២០ យោជន៍អំពីនគរនេះ ។ ព្រះរាជាត្រាស់ថា ដំណឹងណាមួយកើតឡើងក្នុងបទេសរបស់ពួកអ្នកមានដែរឬ ឈ្មួញទូលថា បពិត្រព្រះអង្គ ដំណឹងដទៃណាមួយមិនមានទេ តែព្រះសម្មាសម្ពុទ្ធ ទ្រង់កើតឡើងហើយ ។

ព្រះរាជាមានព្រះសរីរៈ ដែលបរិបូណ៌ទាំង ៥ ពាល់ត្រូវហើយ ក្នុងរំពេច

នោះឯង មិនអាចកំណត់អ្វីមួយបាន ទ្រង់ទ្រឹងមួយស្របក់ហើយត្រាស់សួរថា នែបា ពួកអ្នកពោលអ្វី ពួកឈ្មួញក្រាបទូលថា បពិត្រព្រះអង្គ ព្រះពុទ្ធទ្រង់កើតឡើងហើយ សូម្បីលើកទី ២ លើកទី ៣ ព្រះរាជាក៏ទ្រង់ទ្រឹងនៅដូចគ្នា ក្នុងវារៈទី ៤ ទ្រង់ត្រាស់សួរថា នែបា ពួកអ្នកពោលដូចម្តេច កាលឈ្មួញទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ព្រះពុទ្ធទ្រង់កើតឡើងហើយ ទើបត្រាស់ថា នែបាទាំងឡាយ ខ្ញុំឲ្យទ្រព្យដល់ពួកអ្នកមួយសែន ហើយត្រាស់សួរថា នែបា ដំណឹងណាមួយ ដទៃទៀតមានដែរឬទេ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះអង្គ មាន ព្រះធម៌កើតឡើងហើយ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់ទ្រឹងនៅអស់កាល ៣ ដងដោយនយមុននោះឯង ក្នុងវារៈទី ៤ កាលពួកឈ្មួញក្រាបទូលថា **ធម្មោ** *ទើបត្រាស់ថា ក្នុងបទនេះ ខ្ញុំឲ្យទ្រព្យដល់ពួកអ្នកមួយសែន ហើយត្រាស់សួរថា នែបា ដំណឹងដទៃទៀត មានដែរឬទេ ។ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះអង្គ មាន ព្រះសង្ឃរតនៈកើតឡើងហើយ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់ទ្រឹងអស់ ៣ ដងដូចគ្នា ក្នុងវារៈទី ៤ កាលពួកឈ្មួញក្រាបទូលថា* **សង្ឃោ** *ទើបត្រាស់ថា ព្រោះបទនេះ ខ្ញុំឲ្យទ្រព្យដល់ពួកអ្នកមួយសែន ហើយទ្រង់សម្លឹងមើលអមាត្យមួយពាន់ ត្រាស់សួរថា បាទាំងឡាយ ពួកអ្នកនឹងធ្វើដូចម្តេច អមាត្យទូលថា បពិត្រព្រះអង្គ ចុះព្រះអង្គគិតធ្វើដូចម្តេច ព្រះរាជាត្រាស់ថា នែបាទាំងឡាយ ខ្ញុំបានឮថា ព្រះពុទ្ធកើតឡើងហើយ ព្រះធម៌កើតឡើងហើយ ព្រះសង្ឃកើតឡើងហើយ ខ្ញុំមិនត្រឡប់វិញឡើយ ខ្ញុំនឹងឧទ្ទិសចំពោះព្រះសាស្តា ទៅកាន់*

សម្នាក់របស់ព្រះអង្ត ។ អមាត្យទូលថា ទូលបង្គំទាំងឡាយ ក៏នឹងបួសជាមួយព្រះអង្គដែរ ។

ព្រះរាជាត្រាស់ឲ្យភ្នាក់ងារយកលក្គចារឹកអក្សរ ដាក់ក្នុងដំបារមាសហើយត្រាស់នឹងពួកឈ្ងួញថា ព្រះទេវីឈ្មោះអនោជា នឹងព្រះរាជទានទ្រព្យ ៣ សែនដល់ពួកអ្នក ពួកអ្នកគប្បីពោលយ៉ាងនេះថា បានញថា ព្រះរាជាទ្រង់លះភាពជាធំថ្វាយដល់ព្រះនាងហើយ ព្រះនាងសោយរាជសម្បត្តិតាមសប្បាយចុះ បើព្រះទេវីសួរពួកអ្នកថា តើព្រះរាជាយាងទៅឯណា ពួកអ្នកគប្បីប្រាប់ថា ព្រះរាជាត្រាស់ថា នឹងបួសឧទ្ទិសព្រះសាស្តាយាងទៅហើយ ។

អមាត្យទាំងឡាយ ក៏បញ្ជូនដំណឹងដល់ភរិយារៀងៗ ខ្ជូនយ៉ាងនោះដូចគ្នា ។ ព្រះរាជាទ្រង់បញ្ជូនពួកឈ្ងួញទៅហើយ មានអមាត្យមួយពាន់ចោមរោមយាងចេញទៅក្នុងខណៈនោះឯង ។

ក្នុងថ្ងៃនោះ ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោកក្នុងពេលទៀបភ្លឺ បានទតឃើញព្រះបាទមហាកប្បិន មួយអន្ធើដោយបរិវារ ទ្រង់ព្រះតម្រិះថា ព្រះបាទមហាកប្បិននេះ ទ្រង់បានស្តាប់ភាពដែលរតន: ៣ កើតឡើងអំពីសម្នាក់របស់ពួកឈ្ងួញហើយ ទ្រង់បូជាពាក្យរបស់ឈ្ងួញទាំងនោះ ដោយទ្រព្យ ៣ សែន ទ្រង់លះរាជសម្បត្តិដែលអមាត្យមួយពាន់ចោមរោម ទ្រង់បំណងដើម្បីនឹងបួសឧទ្ទិសចំពោះតថាគត ទ្រង់ចេញទៅក្នុងថ្ងៃស្អែកនេះ ព្រះរាជា មួយអន្ធើដោយបរិវារនឹងសម្រេចអរហត្ត មួយអន្ធើដោយបដិសម្ភិទាទាំងឡាយ តថាគតនឹងធ្វើការទទួលទ្រង់ ដូច្នេះហើយ ក្នុងថ្ងៃស្អែកឡើង ព្រះ

សាស្តាទ្រង់ជាត្រៃ និងចីវរដោយព្រះអង្គឯងនោះឯង ទ្រង់ចេញទៅទទួលអស់ចម្ងាយផ្លូវ ១២០ យោជន៍ ដូចស្តេចចក្រពត្តិ ទ្រង់ទទួលសេនាបតី ដូច្នោះ ទ្រង់ប្រថាប់គង់បញ្ជូញព្រះវស្សី មាន ៦ ពណ៌ ខាងក្រោមគល់និគ្រោធ ត្រង់ឆ្នេរស៊ីងចន្ទកាគានទី ។

ចំណែកព្រះរាជា យាងមកដល់ច្រាំងមួយកន្លែងហើយ ត្រាស់សួរថា នេះឈ្មោះថា ស៊ីងអ្វី អមាត្យទូលថា បពិត្រព្រះអង្គ ឈ្មោះអារវបច្ឆានទី ព្រះរាជាត្រាស់ថា នែបាទាំងឡាយ ស៊ីងនេះមានប្រមាណប៉ុនណា អមាត្យទូលថា បពិត្រព្រះអង្គ ដោយជម្រៅ ១ គាវុត ដោយទទឹង ២ គាវុត ព្រះរាជាត្រាស់ថា ក្នុងស៊ីងនេះ ទូក ឬក្បូនមានដែរឬទេ អមាត្យទូលថា មិនមានទេ ព្រះអង្គ ព្រះរាជាត្រាស់ថា កាលយើងទាំងឡាយរវល់តែរកយាន មានទូកជាដើម ជាតិរមែងនាំទៅកាន់ជរា ជរារមែងនាំទៅកាន់មរណៈ ខ្ញុំមិនមានសេចក្តីសង្ស័យ ចេញបួសឧទ្ទិសចំពោះព្រះរតនត្រ័យ ដោយអានុភាពនៃព្រះរតនត្រ័យនោះ ទឹកនេះ កុំបីដូចជាទឹកឡើយ ដូច្នេះហើយ ទ្រង់រឭកដល់គុណព្រះរតនត្រ័យ រឭកដល់ពុទ្ធានុស្សតិថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ជាព្រះអរហត្តសម្មាសម្ពុទ្ធ ដោយហេតុឈ្មោះនេះជាដើម មួយអន្ទើដោយបរិវារ យាងទៅលើផ្ទៃទឹកដោយសេះមួយពាន់ ។ សេះសន្ធពទាំងឡាយ ក៏រត់ទៅដូចរត់លើផែនថ្ម ចុងក្រចក ក៏មិនសើម ។

ព្រះរាជាឆ្លងស៊ីងហើយ យាងទៅខាងមុខទតឃើញស៊ីងដទៃទៀត ទើបត្រាស់សួថា ស៊ីងនេះឈ្មោះអ្វី អមាត្យទូលថា បពិត្រព្រះអង្គ ស៊ីងនេះឈ្មោះ

នីលវាហនានទី ព្រះរាជាត្រាស់ថា ស្ទឹងនេះមានប្រមាណប៉ុនណា អមាត្យទូលថា បពិត្រព្រះអង្គ ជម្រៅក្តី ទទឹងក្តី ប្រមាណកន្លះយោជន៍ ។ ពាក្យដ៏សេសដូចគ្នានឹងពាក្យមុននោះឯង ។

ព្រះរាជាទតឃើញទឹកនោះហើយ ទ្រង់រឭកដល់ធម្មានុស្សតិថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគត្រាស់ល្អហើយជាដើម ទ្រង់ឃាងទៅហើយ ។ កាលទ្រង់ឆ្លងស្ទឹងនោះទៅបានហើយ ទតឃើញស្ទឹងដទៃទៀត ទើបត្រាស់សួរថា ស្ទឹងនេះឈ្មោះអ្វី អមាត្យទូលថា បពិត្រព្រះអង្គ ស្ទឹងនេះឈ្មោះចន្ទភាគានទី ព្រះរាជាត្រាស់ថា ស្ទឹងនេះមានប្រមាណប៉ុនណា អមាត្យទូលថា បពិត្រព្រះអង្គ ជម្រៅក្តី ទទឹងក្តី ប្រមាណមួយយោជន៍ ពាក្យដ៏សេសដូចគ្នានឹងពាក្យមុននោះឯង ។

ព្រះរាជាទ្រង់ទតឃើញស្ទឹងនេះហើយ ទ្រង់រឭកដល់សង្ឃានុស្សតិថា ព្រះសង្ឃជាសាវ័ករបស់ព្រះដ៏មានព្រះភាគ ជាអ្នកបដិបត្តិល្អហើយជាដើម ឃាងទៅហើយ ។ កាលទ្រង់ឆ្លងទឹកនោះទៅ បានទតឃើញឆព្ពណ្ណរង្សីដែលផ្សាយចេញអំពីសរីរៈរបស់ព្រះសាស្តា មែកឈើក្តី ប្រគាបក្តី ស្វឹកក្តីនៃដើមនិគ្រោធ ហាក់បីដូចជាវិចិត្រដោយមាស ។

ព្រះរាជាទ្រង់ព្រះតម្រិះថា ពន្លឺនេះមិនមែនពន្លឺព្រះចន្ទ មិនមែនពន្លឺព្រះអាទិត្យ មិនមែនពន្លឺនៃទេវតា មារ ព្រហ្ម នាគ គ្រុឌជាដើមណាមួយឡើយ អញឧទ្ទិសចំពោះព្រះសាស្តាហើយមក នេះពិតជាព្រះមហាគោតមសម្ពុទ្ធ ទ្រង់ឃើញហើយដោយពិត ។ ក្នុងវារៈចនោះឯង ទ្រង់ចុះអំពីខ្នងសេះ ឱនព្រះសរីរៈ

ចូលទៅគាល់ព្រះសាស្តាតាមខ្សែព្រះវស្មី ស្តេចចូលទៅខាងក្នុងនៃព្រះពុទ្ធវស្មី ហាក់បីដូចមុជចុះទៅក្នុងមនោសិលាវស ថ្វាយបង្គំព្រះសាស្តាហើយ ប្រថាប់គង់ក្នុងចំណែកម្ខាង មួយអន្ទើដោយអមាត្យមួយពាន់ ។

ព្រះសាស្តា ទ្រង់សម្តែងអនុបុព្វីកថាហើយ ក្នុងកាលចប់ទេសនា ព្រះរាជា មួយអន្ទើដោយបរិវារ តាំងនៅហើយក្នុងសោតាបត្តិផល ។ លំដាប់នោះ ជនទាំងអស់នោះក្រោកឡើង ទូលសូមបព្វជ្ជាហើយ ។

ព្រះសាស្តាទ្រង់ពិចារណាថា ជាត្រ ចីវរ សម្រេចដោយឫទ្ធិរបស់កុល-បុត្រទាំងនេះនឹងមកឬហ្ន៎ ទ្រង់ជ្រាបថា កុលបុត្រទាំងនេះបានឲ្យចីវរមួយពាន់ផ្ទាំង ដល់ព្រះបច្ចេកពុទ្ធមួយពាន់អង្គ ក្នុងកាលព្រះពុទ្ធព្រះនាមកស្សបៈ បានថ្វាយចីវរ ២ ម៉ឺន ដល់ភិក្ខុ ២ ម៉ឺនរូប ការមកនៃជាត្រ និងចីវរដែលសម្រេចដោយឫទ្ធិរបស់កុលបុត្រទាំងនេះ មិនគួរអស្ចារ្យឡើយ ដូច្នេះហើយ ទ្រង់លាព្រះហស្តស្តាំត្រាស់ថា ចូរអ្នកទាំងឡាយមកជាភិក្ខុចុះ ចូរអ្នកទាំងឡាយប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីធ្វើទីបំផុតទុក្ខដោយប្រពៃចុះ ។ រំពេចនោះឯង កុលបុត្រទាំងនោះហាក់បីដូចជាព្រះថេរៈមានវស្សាមួយរយ ទ្រទ្រង់នូវបរិក្ខារ ៨ ហោះ ឡើងកាន់វេហាស៍ ត្រឡប់មកថ្វាយបង្គំព្រះសាស្តា គង់នៅហើយ ។

ចំណែកឈ្មួញទាំងនោះ ទៅកាន់រាជត្រកូលហើយ ឲ្យភ្ញាក់ងារក្រាបទូលដំណឹងដែលព្រះរាជាបញ្ជូនទៅ កាលព្រះទេវីជ្រាបថា ចូលមកចុះ ក៏ចូលទៅថ្វាយបង្គំហើយ បានឈរនៅក្នុងចំណែកម្ខាង ។ គ្រានោះ ព្រះទេវីត្រាស់សួរឈ្មួញទាំងនោះថា នែបាទាំងឡាយ ពួកអ្នកមកព្រោះហេតុអ្វី ឈ្មួញទូល

ថា ព្រះរាជាទ្រង់បញ្ជូនពួកទូលបង្គំដោយនយ័ថា សូមព្រះរាជទានទ្រព្យ ៣ សែន ដល់ពួកទូលបង្គំ ។

ព្រះទេវីពោលថា នែបាទាំង៦ឡាយ ពួកអ្នកពោលច្រើនពេក ពួកអ្នកបានធ្វើអ្វីដល់ព្រះរាជា ព្រះរាជាជ្រះថ្លាក្នុងអ្វីរបស់ពួកអ្នក ទើបបញ្ជាឲ្យព្រះរាជទានទ្រព្យមានប្រមាណដល់ម្ល៉ះ ឈ្មួញទូលថា បពិត្រព្រះនាង អ្វីដទៃពួកទូលបង្គំមិនបានធ្វើទេ តែពួកទូលបង្គំបានក្រាបទូលដំណឹងដល់ព្រះរាជា ។ ព្រះទេវីពោលថា នែបាទាំង៦ឡាយ ពួកអ្នកអាចប្រាប់ដល់យើង៦បានដែរឬទេ ឈ្មួញពោលថា បពិត្រព្រះនាង បាន ព្រះទេវីពោលថា នែបាទាំង៦ឡាយ បើដូច្នោះចូរពួកអ្នកប្រាប់មកចុះ ។ ឈ្មួញទូលថា បពិត្រព្រះនាង ព្រះពុទ្ធកើតឡើងហើយក្នុងលោក ។

សូម្បីព្រះទេវី ព្រះនាងស្តាប់ពាក្យនោះហើយ មានព្រះសរីរៈដែលបីតិពាល់ត្រូវហើយ ដោយនយ័មុននោះឯង ព្រះនាងកំណត់អ្វីមួយមិនបាន អស់វារៈ ៣ ដង ក្នុងវារៈទី ៤ ព្រះនាងស្តាប់បទថា **ពុទ្ធោ** *ហើយ ទើបត្រាស់ថា នែបាទាំង៦ឡាយ ព្រោះបទនេះព្រះរាជាព្រះរាជទានអ្វី ឈ្មួញទូលថា បពិត្រព្រះនាង ទ្រព្យមួយសែន ព្រះទេវីពោលថា នែបាទាំង៦ឡាយ ព្រះរាជាទ្រង់ស្តាប់ដំណឹង៦បែបនេះហើយ ព្រះរាជទានទ្រព្យមួយសែន ដល់ពួកអ្នកទាំង-៦ឡាយ ឈ្មោះថា ធ្វើមិនសមគ្នាសោះ តែខ្ញុំនឹង៦ឲ្យពួកអ្នក ៣ សែន ចាត់ជាវង្វាន់តិចតួចរបស់ខ្ញុំ ដំណឹង៦អ្វីទៀតដែលអ្នកទាំង៦ឡាយទូលហើយ ។ ឈ្មួញទាំង៦នោះក្រាបទូលដំណឹង៦ពីរយ៉ាង៦ដទៃទៀតថា ដំណឹង៦យ៉ាង៦នេះ ដំណឹង៦*

យ៉ាងនេះ ។

ព្រះទេវីមានព្រះសរីរៈ ដែលបីតិពាល់ត្រូវហើយដោយឧស្ម័យមុននោះឯង ព្រះនាងកំណត់អ្វីមួយមិនបាន អស់កាល ៣ ដង ក្នុងគ្រានី ៤ ទ្រង់ស្តាប់យ៉ាងនោះដូចគ្នាហើយ ព្រះនាងបញ្ជាឲ្យព្រះរាជទានទ្រព្យម្តង ៣ សែន ។ ឈ្មួញទាំងនោះ បានទ្រព្យទាំងអស់ ១២ សែន ដោយប្រការដូច្នេះ ។

លំដាប់នោះ ព្រះទេវីត្រាស់សួរឈ្មួញទាំងនោះថា នែបាទាំងឡាយ ព្រះរាជាយាងទៅណា ឈ្មួញពោលថា បពិត្រព្រះនាង ព្រះរាជាទ្រង់ត្រាស់ថា ខ្ញុំនឹងបួសឧទ្ទិសចំពោះព្រះសាស្តាយាងទៅហើយ ព្រះទេវីត្រាស់ថា ដំណឹងអ្វីដែលទ្រង់ព្រះរាជទានដល់ខ្ញុំ ឈ្មួញទូលថា ព្រះរាជាទ្រង់លះភោគជាធំថ្វាយដល់ព្រះនាង សូមព្រះនាងសោយសម្បត្តិតាមបំណងចុះ ។

ព្រះទេវីត្រាស់ថា នែបា ពួកអមាត្យទៅណា ឈ្មួញទូលថា បពិត្រព្រះនាង អមាត្យទាំងនោះពោលថា ខ្ញុំនឹងបួសជាមួយព្រះរាជាដូចគ្នា ហើយក៏ទៅ ។ ព្រះនាងត្រាស់ឲ្យហៅភរិយារបស់អមាត្យទាំងនោះមកហើយ ត្រាស់ថា នែនាងទាំងឡាយ ប្តីរបស់ពួកនាងពោលថា អញនឹងបួសជាមួយព្រះរាជាហើយ ក៏ទៅ ពួកនាងនឹងធ្វើដូចម្តេច ស្រីទាំងនោះទូលថា បពិត្រព្រះនាង ដំណឹងអ្វី ដែលពួកគេបញ្ជូនមកដើម្បីពួកខ្ញុំម្ចាស់ ព្រះទេវីត្រាស់ថា បានឮថា អមាត្យទាំងនោះ លះបង់សម្បត្តិរៀងៗ ខ្លួនដល់ពួកនាងហើយ បានឮថា ចូរពួកនាងបរិភោគសម្បត្តិនោះតាមគាប់ចិត្តចុះ ។ ស្រីទាំងនោះទូលថា ព្រះនាងគិតធ្វើដូចម្តេច ព្រះទេវីពោលថា នែនាងទាំងឡាយ ដំបូង ព្រះរាជា

ទ្រង់ស្តាប់ដំណឹងហើយ ប្រថាប់ឈរក្នុងរវាងផ្លូវនោះឯង ទ្រង់បូជាព្រះរតន-ត្រ័យដោយទ្រព្យ ៣ សែន ទ្រង់លះបង់សម្បត្តិដូចដុំទឹកមាត់ ត្រាស់ថា ខ្ញុំនឹងបួស ហើយយាងចេញទៅ ចំណែកខ្ញុំបានស្តាប់ដំណឹងព្រះរតនត្រ័យហើយ បូជាព្រះរតនត្រ័យ ដោយទ្រព្យ ៩ សែន ឈ្មោះថា សម្បត្តិនេះមិនបាននាំទុក្ខមកដល់ព្រះរាជាប៉ុណ្ណោះ រមែងជាហេតុនាំទុក្ខមកដល់ខ្ញុំដូចគ្នា បុគ្គលណានឹងលុតជង្គង់ទទួលយកដុំទឹកមាត់ដែលព្រះរាជា ទ្រង់ស្តោះហើយដោយមាត់នោះ ខ្ញុំមិនត្រូវការដោយសម្បត្តិ ឯខ្ញុំក៏នឹងទៅបួសឧទ្ទិសព្រះសាស្តាដែរ ។

ស្រីទាំងនោះទូលថា បពិត្រព្រះនាង សូម្បីពួកខ្ញុំម្ចាស់ក៏នឹងបួសជាមួយព្រះនាងដូចគ្នា ព្រះទេវីត្រាស់ថា នែនាង បើពួកនាងអាចក៏ជាការល្អ ស្រីទាំងនោះទូលថា បពិត្រព្រះនាង ខ្ញុំម្ចាស់អាច ព្រះទេវីត្រាស់ថា បើដូច្នោះ ចូរនាងមក ដូច្នេះហើយ បញ្ជាឲ្យទីមរថមួយពាន់ ព្រះនាងឡើងរថចេញទៅជាមួយស្រីទាំងនោះ ទតឃើញស្ទឹងខ្សែទឹមួយក្នុងរវាងផ្លូវ ត្រាស់សួរដូចព្រះរាជាត្រាស់សួរហើយដូចគ្នា ព្រះនាងស្តាប់ការប្រព្រឹត្តទៅទាំងអស់ហើយត្រាស់ថា ចូរពួកនាងមើលផ្លូវដែលយាងទៅរបស់ព្រះរាជា ស្រីទាំងនោះក្រាបទូលថា ពួកខ្ញុំម្ចាស់មិនឃើញស្នាមជើងសេះសន្ធពទេព្រះនាង នាងក៏ត្រិះរិះថា ព្រះរាជាទ្រង់ពិតជាធ្វើសច្ចកិរិយាថា ខ្ញុំចេញបួសឧទ្ទិសព្រះរតនត្រ័យ ហើយយាងទៅសូម្បីខ្ញុំក៏ចេញបួសឧទ្ទិសព្រះរតនត្រ័យ ដោយអានុភាពនៃព្រះរតនៈទាំងនោះឯង សូមទឹកនេះកុំដូចជាទឹកឡើយ ដូច្នេះហើយ ព្រះនាងព្យាករដល់គុណព្រះ

រតនត្រ័យ បញ្ជូនរថមួយពាន់ទៅ ទឹកក៏ហាក់ដូចជាផ្ទាំងថ្ម ចុងនៃក្លៀវនេះ និងខ្នងកង់នៃរថក៏មិនសើមឡើយ ។ ព្រះនាងឆ្ងល់ស្ទឹងទាំងពីរក្រៅអំពីនេះទៅ បាន ដោយឧបាយនោះដូចគ្នា ។

ព្រះសាស្តាទ្រង់ជ្រាបការយាងមករបស់ព្រះទេវី ទ្រង់បានធ្វើដោយប្រការដែលភិក្ខុទាំងឡាយ អង្គុយក្នុងសម្នាក់របស់ព្រះអង្គមិនឲ្យប្រាកដ ។ ព្រះទេវីកំពុងយាងទៅ ទតឃើញព្រះរស្មី ផ្សាយចេញអំពីព្រះសរីរៈរបស់ព្រះសាស្តា ព្រះនាងត្រេកអរយ៉ាងនោះដូចគ្នា ហើយយាងចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ប្រថាប់ឈរក្នុងចំណែកម្ខាង ទូលសួរថា បពិត្រព្រះអង្គ ព្រះមហាកប្បិនយាងចេញបួសឧទ្ទិសចំពោះព្រះអង្គ ទ្រង់ប្រហែលជាយាងមកក្នុងទីនេះហើយ ព្រះរាជាប្រថាប់នៅឯណា ទ្រង់មិនបង្ហាញដល់ពួកខ្ញុំម្ចាស់ទេឬ ។

ព្រះសាស្តាត្រាស់ថា ចូរនាងទាំងឡាយអង្គុយសិន នឹងឃើញព្រះរាជាក្នុងទីនេះឯង ។ ស្រីទាំងអស់នោះ មានចិត្តត្រេកអរហើយ អង្គុយដោយគិតថា ពួកយើងអង្គុយក្នុងទីនោះឯង នឹងឃើញពួកស្វាមី ។

ព្រះសាស្តា ត្រាស់អនុបុព្វីកថាហើយ ក្នុងពេលចប់ទេសនា ព្រះនាងអនោជាទេវី មួយអន្ទើដោយបរិវារ សម្រេចសោតាបត្តិផលហើយ ។

ព្រះមហាកប្បិនត្ថេរ មួយអន្ទើដោយបរិវារស្តាប់ព្រះធម្មទេសនា ដែលព្រះសាស្តាទ្រង់ពង្រីកដល់ស្រីទាំងនោះហើយ ក៏បានសម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយ ។ ក្នុងខណៈនោះ ព្រះសាស្តាទ្រង់បង្ហាញភិក្ខុទាំងនោះ ដែលសម្រេចអរហត្តហើយ ដល់ស្រីទាំងនោះ ។

បានឮថា ក្នុងខណៈដែលស្រីទាំងនោះមកអង្គុយនោះឯង ចិត្តរបស់នាង មិនមានអារម្មណ៍តែមួយ ព្រោះឃើញប្តីរៀងៗខ្លួន ដែលទ្រទ្រង់សំពត់ជ្រលក់ ដោយទឹកអមូត មានក្បាលត្រងោល ព្រោះហេតុនោះ ស្រីទាំងនោះមិនអាច សម្រេចមគ្គផលបាន ព្រោះដូច្នោះ ក្នុងពេលស្រីទាំងនោះតាំងមាំនៅក្នុងសទ្ធា ដែលមិនញាប់ញ័រហើយ ទើបព្រះសាស្តាទ្រង់បង្ហាញភិក្ខុទាំងនោះដែលសម្រេច ព្រះអរហត្តហើយ ដល់ស្រីទាំងនោះ ។ ស្រីទាំងនោះ ឃើញភិក្ខុទាំងនោះ ហើយ នមស្ការដោយបញ្ចង្គប្រតិស្ឋានហើយពោលថា បពិត្រលោកម្ចាស់ កិច្ច បព្វជិតរបស់លោកម្ចាស់ទាំងឡាយ ដល់ទីបំផុតមុន ដូច្នេះហើយ ថ្វាយបង្គំ ព្រះសាស្តា ឈរនៅក្នុងចំណែកម្ខាង ហើយទូលសូមបព្វជ្ជា ។

អាចារ្យពួកខ្លះពោលថា បានឮថា កាលស្រីទាំងនោះក្រាបទូលយ៉ាងនោះ ហើយ ព្រះសាស្តាទ្រង់ត្រិះរិះឲ្យព្រះនាងឧប្បលវណ្ណាថេរីនិមន្តមក ។

ព្រះសាស្តាត្រាស់នឹងឧបាសិកាទាំងនោះថា នាងទាំងឡាយគប្បីទៅកាន់ ក្រុងសាវត្ថី បព្វជ្ជាក្នុងសម្នាក់នៃពួកភិក្ខុនីចុះ ។ ឧបាសិកាទាំងនោះ ត្រាច់ចារិក ទៅដោយលំដាប់ មានសក្ការៈ និងការគោរពរាប់អាន ដែលមហាជននាំមក ក្នុងរវាងផ្លូវ ធ្វើដំណើរទៅដោយជើងអស់ចម្ងាយផ្លូវ ១២០ យោជន៍ បួស ក្នុងសម្នាក់នៃភិក្ខុនី បានសម្រេចអរហត្តហើយ ។ ព្រះសាស្តា ទ្រង់ក៏បាននាំ ភិក្ខុមួយពាន់រូប យាងទៅកាន់វត្តជេតពនតាមអាកាសនោះឯង ។

បានឮថា ក្នុងភិក្ខុទាំងនោះ ព្រះមហាកប្បិនត្រាច់បន្ទឹងទានក្នុងទីទាំង-ទ្វាយ មានទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃថា សុខហ្ន៎ សុខហ្ន៎

ភិក្ខុទាំងឡាយក្រាបទូលដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ ព្រះមហាកប្បិនបន្ទឺឧទានថា សុខហ្ន៎ សុខហ្ន៎ លោកប្រហែលជាប្រាថ្នាសុខក្នុងរាជសម្បត្តិរបស់ខ្លួន ។

ព្រះសាស្តា ត្រាស់ឲ្យហៅព្រះមហាកប្បិននោះមកហើយ ត្រាស់សួរថា ម្នាលកប្បិន បានឮថា អ្នកបន្ទឺឧទានប្រាថ្នាសុខក្នុងកាម សុខក្នុងរាជសម្បត្តិពិតឬ ព្រះមហាកប្បិនទូលថា បពិត្រព្រះអង្គ ព្រះអង្គក៏ទ្រង់ជ្រាបការបន្ទឺ ឬមិនបន្ទឺប្រាថ្នាកាមសុខ ក្នុងរាជសុខនោះ របស់ខ្ញុំព្រះអង្គ ។ ព្រះសាស្តា ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគត រមែងបន្ទឺឧទានប្រាថ្នាសុខក្នុងកាម សុខក្នុងរាជសម្បត្តិក៏មិនមែន តែការឆ្អែតក្នុងធម៌ រមែងកើតឡើងដល់បុត្ររបស់តថាគត បុត្ររបស់តថាគតនោះ រមែងបន្ទឺឧទានយ៉ាងនោះ ព្រោះប្រាថ្នាអមតមហានិព្វាន ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ធម្មប្បីតិ សុខំ សេតិ វិប្បសន្នេន ចេតសា
អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។

បណ្ឌិត ដែលមានសេចក្តីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរក្នុងធម៌ ដែលព្រះអរិយៈប្រកាសទុកហើយគ្រប់ពេល ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ធម្មប្បីតិ** សេចក្តីថា ជាអ្នកឆ្អែតក្នុងធម៌

អធិប្បាយថា ជាអ្នកផឹកនូវធម៌ ។ ឈ្មោះថា ព្រះធម៌នេះ បុគ្គលណាម្នាក់ មិនអាចនឹងផឹកបានដូចទឹក ឬបបរជាដើមដោយកាជនៈ ដូច្នោះ បុគ្គលពាល់ ត្រូវលោកុត្តរធម៌ ៩ យ៉ាងដោយនាមកាយ ធ្វើឲ្យជាក់ច្បាស់ដោយភាពជា អារម្មណ៍ ចាក់ធ្លុះនូវអរិយសច្ច មានទុក្ខជាដើមដោយកិច្ច មានការសម្រេច ធម៌ដោយការកំណត់ដឹងជាដើម ឈ្មោះថា រមែងផឹកនូវធម៌ ។

ពាក្យថា **សុខំ សេតិ** *នេះ ត្រឹមតែជាមាតិកានៃទេសនា អធិប្បាយថា រមែងនៅជាសុខដោយឥរិយាបថ ៤ ។ បទថា* **វិប្បសន្នេន** *គឺមិនល្អក់កករ បានដល់ មិនមានឧបក្កិលេស ។*

បទថា **អរិយប្បវេទិតេ** *សេចក្តីថា ក្នុងពោធិបក្ខិយធម៌ មានសតិប្បដ្ឋាន ជាដើម ដែលព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើមប្រកាសហើយ ។*

ពីរបទថា **សធា រមតិ** *សេចក្តីថា បណ្ឌិតដែលឆ្អែតក្នុងធម៌បែបនោះ មានចិត្តផូរផង់មកតាមព្រមហើយ ដោយភាពជាបណ្ឌិត រមែងត្រេកអរ គឺ រមែងសរសើរគ្រប់កាល ។*

ក្នុងកាលចប់ទេសនា មហាជនបានជាព្រះអរិយបុគ្គល មានព្រះសោតាបន្ន ជាដើមហើយ ដូច្នេះឯង ។

រឿង ព្រះមហាកប្បិនត្ថេរ ចប់

រឿង បណ្ឌិតសាមណេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបណ្ឌិតសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា **ឧឧកំ ហិ ឧយន្តិ** ជាដើម ។

បានឮមកថា ក្នុងអតីតកាល ព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ មានព្រះទីណាស្រេព ២ ម៉ឺនរូបជាបរិវារ បានយាងទៅកាន់ក្រុងពារាណសី មនុស្សទាំងឡាយកំណត់កម្ចាំងរៀងៗ ខ្លួនហើយ រួមគ្នា ៨ នាក់ខ្លះ ១០ នាក់ខ្លះ បានថ្វាយអាគន្តុកទានហើយ ។

តមកថ្ងៃមួយ ក្នុងកាលដែលស្រេចកត្តកិច្ច ព្រះសាស្តាទ្រង់បានធ្វើអនុមោទនាយ៉ាងនេះថា ឧបាសក ឧបាសិកាទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ គិតថា អញឲ្យរបស់ខ្លួនប៉ុណ្ណោះគួរ ប្រយោជន៍អ្វីដោយការបបួលអ្នកដទៃដូច្នេះហើយ ទើបឲ្យទានដោយខ្លួនឯងប៉ុណ្ណោះ មិនបបួលអ្នកដទៃ បុគ្គលនោះ រមែងបានភោគសម្បត្តិ មិនបានបរិវារសម្បត្តិក្នុងទីដែលខ្លួនកើតហើយ បុគ្គលខ្លះ បបួលអ្នកដទៃ ខ្លួនឯងមិនឲ្យ រមែងបានបរិវារសម្បត្តិ មិនបានភោគសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ ។ បុគ្គលខ្លះមិនបានឲ្យដោយខ្លួនឯង មិនបានបបួលអ្នកដទៃ បុគ្គលនោះរមែងមិនបានភោគសម្បត្តិ មិនបានបរិវារសម្បត្តិ ជាអ្នកស៊ីដែល ញ៉ាំងជីវិតឲ្យរស់នៅក្នុងទីដែលខ្លួនកើតហើយ ។ បុគ្គលខ្លះ ខ្លួនឯងឲ្យទានផង បបួលអ្នកដទៃផង បុគ្គលនោះ រមែងបាននូវភោគសម្បត្តិផង បាននូវបរិវារសម្បត្តិផង ក្នុងទីដែលខ្លួនកើតហើយ ។

បុរសបណ្ឌិតម្នាក់ឈរក្នុងទីជិត បានស្តាប់អនុមោទនាកថានោះហើយ គិតថា ឥឡូវនេះ អញនឹងធ្វើឲ្យសម្បត្តិទាំងពីរមានដល់អញ អញនឹងថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា ស្អែកនេះ សូមទ្រង់ទទួលភិក្ខាបស់ខ្ញុំព្រះអង្គ ។

ព្រះសាស្តាទ្រង់ត្រាស់ថា តើអ្នកត្រូវការភិក្ខុប៉ុន្មាន បណ្ឌិតបុរសទូលថា បរិវារបស់ព្រះអង្គមានប៉ុន្មាន ព្រះសាស្តាត្រាស់ថា មានភិក្ខុ ២ ម៉ឺនរូប ។ បណ្ឌិតបុរសពោលថា បពិត្រព្រះអង្គ ស្អែកនេះ សូមទ្រង់ មួយអន្ទើដោយភិក្ខុទាំងអស់ ទ្រង់ទទួលភិក្ខាបស់ខ្ញុំព្រះអង្គ ។

ព្រះសាស្តា ទ្រង់ទទួលនិមន្តហើយ បុរសនោះចូលទៅកាន់ស្រុកហើយដើរប្រាប់បុណ្យថា បពិត្រអ្នកម៉ែ និងលោកឪពុកទាំងឡាយ ស្អែកនេះ ខ្ញុំនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីទទួលភិក្ខា អ្នកទាំងឡាយ ចូរប្រគេនដល់ភិក្ខុតាមចំនួនដែលអាច ។ កាលជនទាំងឡាយ កំណត់កម្ចាំង រៀងៗ ខ្លួនហើយពោលថា ពួកយើងនឹងប្រគេន ១០ រូប ពួកយើងនឹងប្រគេន ២០ រូប ពួកយើងនឹងប្រគេន ១០០ រូប ពួកយើងនឹងប្រគេន ៥០០ រូប ដូច្នេះហើយទើបកត់ពាក្យរបស់ជនទាំងឡាយក្នុងបញ្ជី តាំងពីដើមមក ។

សម័យនោះ ក្នុងនគរនោះ មានបុរសម្នាក់ប្រាកដឈ្មោះថា មហា-ទុគ្គតៈ ព្រោះជាអ្នកក្រីក្រពន់ពេក ។ បុរសបណ្ឌិតនោះ ឃើញជនក្រីក្រនោះមកចំពោះមុខ ទើបប្រាប់ថា នែទុគ្គតៈសម្លាញ់ ខ្ញុំបាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ស្អែកនេះ អ្នកស្រុកនឹងថ្វាយ

ទាន អ្នកអង្គាសភិក្ខុប៉ុន្មានរូប មហាទុគ្គតៈពោលថា ឱ ! អ្នក ខ្ញុំត្រូវការអ្វី ដោយភិក្ខុទាំងនោះ ឈ្មោះថា ការត្រូវការភិក្ខុ ជារបស់អ្នកមានទ្រព្យ ឯខ្ញុំ គ្រាន់តែអង្គរមួយនាឡិ ដើម្បីប្រយោជន៍ដល់បបរក្នុងស្អែកនេះក៏មិនមាន ខ្ញុំ ធ្វើការងារស៊ីឈ្នួលចិញ្ចឹមជីវិត ខ្ញុំត្រូវការអ្វីដោយភិក្ខុ ។

ធម្មតាអ្នកបបួល គប្បីជាអ្នកឈ្លាស ព្រោះដូច្នោះ បុរសបណ្ឌិតនោះ កាលមហាទុគ្គតៈពោលថា មិនមាន ក៏មិនស្ងៀម នៅតែពោលយ៉ាងនេះថា មហាទុគ្គតៈសម្លាញ់ មនុស្សជាច្រើនក្នុងក្រុងនេះ បរិភោគភោជនយ៉ាងល្អ ស្បៀកសំពត់សាច់ម៉ដ្ត តែងខ្ជួនដោយគ្រឿងអាភរណៈផ្សេងៗ ដេកលើដំណេក ដ៏ប្រសើរ រមែងសោយសម្បត្តិ ចំណែកអ្នកធ្វើការស៊ីឈ្នួលអស់ថ្ងៃ ក៏មិន បានអាហារពេញពោះ កាលបើដូច្នេះ អ្នកនៅមិនដឹងថា អញមិនបានអ្វីមួយ ព្រោះមិនបានធ្វើបុណ្យណាមួយក្នុងកាលមុន មហាទុគ្គតៈពោលថា ខ្ញុំដឹង ហើយអ្នក បណ្ឌិតបុរសពោលថា បើដូច្នោះ ហេតុអ្វី ឥឡូវនេះ ទើបអ្នកមិន ធ្វើបុណ្យ អ្នកនៅជាកំលោះ មានកម្លាំងកំហែងបរិបូណ៌ អ្នកធ្វើការស៊ីឈ្នួល ហើយ ឲ្យទានតាមកម្លាំងមិនគួរឬ ។ មហាទុគ្គតៈនោះ កាលបណ្ឌិតបុរស កំពុងពោលដល់នូវសេចក្តីសង្វេគ ទើបពោលថា បួរអ្នកចុះបញ្ជីភិក្ខុឲ្យខ្ញុំបាន មួយរូប ខ្ញុំនឹងធ្វើការងារស៊ីឈ្នួលណាមួយ ហើយនឹងប្រគេនភិក្ខាដល់ភិក្ខុ មួយរូប ។ បុរសបណ្ឌិតនោះគិតថា ភិក្ខុមួយរូប នឹងកត់ចូលក្នុងបញ្ជីធ្វើអ្វី ដូច្នេះហើយ ទើបមិនកត់ចូល ។

ចំណែកមហាទុគ្គតៈ ទៅកាន់ផ្ទះហើយ និយាយនឹងភរិយាថា នែនាង

ស្អែកនេះ អ្នកស្រុកគេរៀបចំភត្តដើម្បីសង្ឃ ខ្ញុំត្រូវគេបបួលថា ចូរថ្វាយកិក្ខា ដល់កិក្ខុមួយរូប ពួកយើងនឹងថ្វាយកិក្ខាដល់កិក្ខុមួយរូបក្នុងថ្ងៃស្អែកនេះ លំដាប់ នោះ ភរិយារបស់គាត់មិនពោលថា ពួកយើងជាអ្នកក្រ អ្នកទទួលពាក្យគេធ្វើ អ្វី តែពោលថា នែអ្នក អ្នកធ្វើល្អហើយ កាលមុនយើងមិនឲ្យវត្ថុណាមួយ ទើបជាតិនេះកើតជាមនុស្សក្រីក្រ យើងទាំងពីរនាក់ធ្វើការស៊ីឈ្នួលហើយ នឹង ប្រគេនដល់កិក្ខុមួយរូប ។ ទាំងពីរនាក់បានទៅកាន់ទីស៊ីឈ្នួល ។ មហាសេដ្ឋី ឃើញមហាទុគ្គតៈ ទើបសួរថា មហាទុគ្គតៈសម្លាញ់ អ្នកនឹងធ្វើការងារស៊ី ឈ្នួលឬ មហាទុគ្គតៈពោលថា បាទ លោកម្ចាស់ មហាសេដ្ឋីពោលថា អ្នក នឹងធ្វើអ្វី មហាទុគ្គតៈពោលថា ស្រេចតែលោកម្ចាស់ឲ្យធ្វើ មហាសេដ្ឋីពោល ថា បើយ៉ាងនោះ ស្អែកនេះ ខ្ញុំអង្គាសកិក្ខុ ២-៣ រយរូប ចូរអ្នកពុះអុសចុះ ហើយឲ្យយកកាំបិត និងពូថៅមកឲ្យ ។ មហាទុគ្គតៈពួយយ៉ាងពេញកម្លាំង ដល់នូវភាពឧស្សាហ៍ ជាក់កាំបិត ចាប់ពូថៅ ចោះពូថៅចាប់កាំបិត ពុះអុស រឿយៗ ទៅ ។

លំដាប់នោះ សេដ្ឋីពោលនឹងមហាទុគ្គតៈថា នែសម្លាញ់ ថ្ងៃនេះ អ្នក ខ្នះខ្នែងធ្វើការពន់ពេក មានរឿងអ្វីឬ មហាទុគ្គតៈពោលថា បាទ លោកម្ចាស់ ខ្ញុំអង្គាសកិក្ខុមួយរូប ។

សេដ្ឋីស្តាប់ពាក្យនោះហើយ មានចិត្តជ្រះថ្លា គិតថា គួរជ្រះថ្លាពិតហ្ន៎ មហាទុគ្គតៈនេះ ធ្វើកម្មដែលគេធ្វើបានដោយក្រ បុរសនេះមិនព្រងើយកន្តើយ ដោយគិតថា អញក្រីក្រ ពោលថា នឹងធ្វើការស៊ីឈ្នួល ហើយអង្គាសកិក្ខុ

មួយរូប ។

ចំណែកភរិយាសេដ្ឋីឃើញប្រពន្ធរបស់មហាទុគ្គត:នោះហើយ ក៏សួរថា នែនាង នាងធ្វើការងារអ្វី នាងក៏ឆ្លើយថា ស្រេចតែអ្នកស្រីប្រើឲ្យធ្វើ ទើបចូលទៅកាន់រោងត្បាល់ក្តឹង ហើយប្រគល់គ្រឿងឧបករណ៍ មានចង្អេរ និងអង្រែជាដើមឲ្យហើយ ។ នាងត្រេកអរវីកវាយ បុកផង ផាត់អង្គរផង ដូចគេរាំល្ងាន ។

លំដាប់នោះ ភរិយាសេដ្ឋីសួរថា នែនាង នាងត្រេកអរក្នុងការងារពន់ពេក មានហេតុអ្វីឬ នាងពោលថា បពិត្រអ្នកស្រី ពួកខ្ញុំធ្វើការស៊ីឈ្នួលហើយ ទឹងអង្គាសកិក្ខុមួយរូប ។

ចំណែកភរិយាសេដ្ឋីស្តាប់ពាក្យនោះហើយ ជ្រះថ្លាក្នុងនាងថា គួរជ្រះថ្លាហ្ន៎ ស្រីនេះ ធ្វើកម្មដែលគេធ្វើបានដោយក្រ ។

ក្នុងពេលដែលមហាទុគ្គត:ពុះអុសស្រេច សេដ្ឋីប្រើឲ្យគេយកអង្គរស្រូវសាលី ៤ នាឡិមកឲ្យដោយពោលថា នេះថ្លៃឈ្នួលរបស់អ្នក ហើយប្រាប់ឲ្យគេយក ៤ នាឡិមកឲ្យទៀតពោលថា នេះជាចំណែកបន្ថែមព្រោះខ្ញុំត្រេកអរនឹងអ្នក ។

គាត់ទៅកាន់ផ្ទះប្រាប់ភរិយាថា ខ្ញុំស៊ីឈ្នួលបានអង្គរស្រូវសាលីមកចំណែកនេះ នឹងបានជាម្ហូប ចូរនាងកាន់យករបស់ គឺទឹកដោះជូរ ប្រេង និងគ្រឿងទេសដោយតម្លៃ ដែលនាងបានហើយ ។

ចំណែកភរិយាសេដ្ឋី បានឲ្យសប្បិមួយដប ទឹកដោះជូរមួយក្រឡតូច

មួយអន្ទើដោយគ្រឿងទេស និងអង្ករស្រូវសាលីមួយនាឡិដល់នាង ជនទាំង ពីរមានអង្ករ ៥ នាឡិ ដោយប្រការដូច្នេះ ។

ជនពីរនាក់ប្តីប្រពន្ធត្រេកអរថា យើងបានទេយ្យធម៌ហើយ ក្រោកឡើង អំពីព្រលឹម ភរិយាពោលនឹងមហាទុគ្គតៈថា សូមអ្នកទៅរកបន្លែមកចុះ គាត់ មិនឃើញបន្លែក្នុងផ្សារ ទើបទៅកាន់មាត់ស្ទឹង មានចិត្តត្រេកអរថា នឹងបាន ប្រគេនកោជនដល់លោកម្ចាស់ ស្រែកច្រៀងបណ្តើរ បេះបន្លែបណ្តើរ ។ អ្នក ប្រមង់ឈរបង់សំណាញ់ធំ ដឹងថា ជាសំឡេងរបស់មហាទុគ្គតៈ ទើបហៅ មកសួរថា អ្នកមានចិត្តសប្បាយពន់ពេក ស្រែកច្រៀង មានហេតុអ្វីហ្ន៎ មហា ទុគ្គតៈពោលថា នែសម្លាញ់ ខ្ញុំបេះបន្លែ អ្នកប្រមង់ពោលថា អ្នកបេះបន្លែ ធ្វើអ្វី មហាទុគ្គតៈប្រាប់ថា ខ្ញុំអង្គាសភិក្ខុមួយរូប អ្នកប្រមង់ពោលថា ឱ ! ឆ្កែតឬ ភិក្ខុដែលឆាន់បន្លែរបស់អ្នក មហាទុគ្គតៈពោលថា នែសម្លាញ់ អ្នក ធ្វើអ្វីបាន ខ្ញុំត្រូវអង្គាសភិក្ខុដោយបន្លែដែលបាន អ្នកប្រមង់ពោលថា បើ ដូច្នោះ ចូរអ្នកមកណេះចុះ មហាទុគ្គតៈពោលថា អ្នកនឹងធ្វើអ្វីសម្លាញ់ អ្នក ប្រមង់ពោលថា ចូរកាន់យកត្រីទាំងនេះដោតឲ្យជាចង្ការ ដែលមានតម្លៃ មួយបាតខ្នះ កន្ទុះបាតខ្នះ មួយកហាបណៈខ្នះ គាត់បានធ្វើយ៉ាងនោះ ។

អ្នកស្រុកទិញត្រីដែលមហាទុគ្គតៈដោតយកទៅ ដើម្បីប្រយោជន៍ដល់ ភិក្ខុដែលខ្លួននិមន្តហើយ កាលគាត់កំពុងដោតត្រីនោះឯង ក៏ដល់ពេលភិក្ខាចារ ហើយ គាត់កំណត់កាលហើយពោលថា នែសម្លាញ់ ខ្ញុំត្រូវទៅហើយ នេះជា ពេលដែលភិក្ខុនិមន្តមក អ្នកប្រមង់ពោលថា ចង្ការត្រីទាំងនោះនៅមានដែរ

ឬទេ មហាទុគ្គតៈពោលថា មិនមានទេ អស់ហើយសម្លាញ់ អ្នកប្រមង់ពោលថា បើដូច្នោះ ត្រីឆ្ពិន ៤ ខ្ញុំកប់ក្នុងខ្សាច់ដើម្បីប្រយោជន៍ដល់ខ្លួន បើអ្នកត្រូវការអង្គាសភិក្ខុ ចូរយកត្រីទាំងនេះទៅចុះ ដូច្នេះហើយ ក៏បានឲ្យត្រីឆ្ពិនទាំងនោះដល់មហាទុគ្គតៈ ។

ថ្ងៃនោះ ព្រះសាស្តា ទ្រង់ប្រមើលមើលសត្វលោកក្នុងពោលទៀបភ្លឺ ទ្រង់ឃើញមហាទុគ្គតៈចូលទៅខាងក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ទ្រង់អាវជ្ជនៈថា មានហេតុអ្វីហ្ន៎ ទ្រង់ត្រិះរិះថា មហាទុគ្គតៈគិតថា នឹងអង្គាសភិក្ខុមួយរូប ទើបបានធ្វើការស៊ីឈ្នួលជាមួយភរិយារហើយ កាលពីម្សិលមិញបុរសនេះនឹងបានភិក្ខុរូបណាហ្ន៎ ទ្រង់ពិចារណាថា មនុស្សទាំងឡាយនឹងនាំភិក្ខុទៅតាមឈ្មោះ ដែលខ្លួនកត់ក្នុងបញ្ជីហើយ ឲ្យអង្គុយក្នុងផ្ទះ រៀងៗ ខ្លួន មហាទុគ្គតៈរៀតថាគតហើយ នឹងមិនបានភិក្ខុជាទៃ ។

បានឮថា ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងធ្វើសេចក្តីអនុគ្រោះក្នុងពួកមនុស្សក្រីក្រ ព្រោះដូច្នោះ ព្រះសាស្តា ទ្រង់ធ្វើសរីរៈកិច្ចអំពីព្រលឹមហើយ យាងចូលកាន់ព្រះគន្ធកុដិ ប្រថាប់គង់ដោយទ្រង់ព្រះតម្រិះថា នឹងសង្គ្រោះមហាទុគ្គតៈ កាលមហាទុគ្គតៈកំពុងកាន់យកត្រីចូលទៅកាន់ផ្ទះ បណ្ឌុកម្ពល-សិលាអាសនៈរបស់សក្កទេវរាជសម្តែងអាការក្តៅ ទ្រង់ពិចារណាថា មានហេតុអ្វីហ្ន៎ ទ្រង់ត្រិះរិះថា ម្សិលមិញនេះ មហាទុគ្គតៈ បានធ្វើការងារស៊ីឈ្នួលជាមួយភរិយារបស់ខ្លួនដោយតាំងចិត្តថា នឹងថ្វាយភិក្ខាដល់ភិក្ខុមួយរូប មហាទុគ្គតៈនឹងបានភិក្ខុរូបណាហ្ន៎ ទ្រង់ជ្រាបថា ភិក្ខុជាទៃមិនមានសម្រាប់គេ

តែព្រះសាស្តាប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ដោយតាំងព្រះហឫទ័យថា នឹងសង្គ្រោះមហាទុគ្គតៈ ។ មហាទុគ្គតៈគប្បីថ្វាយបបរ ជាយ អន្ទក់ និងសម្ជូចដែលខ្លួនបរិភោគឯងដល់ព្រះតថាគត បើដូច្នោះ អាត្មាអញ គួរទៅកាន់ផ្ទះរបស់មហាទុគ្គតៈ ធ្វើនាទីជាចុងភៅ ដូច្នេះហើយ ទើបទ្រង់កាឡាខ្លួនមិនឲ្យអ្នកណាស្គាស់ យាងទៅជិតផ្ទះរបស់មហាទុគ្គតៈនោះ ហើយត្រាស់សួរថា បុគ្គលណាមួយ មានការងារស៊ីឈ្នួលអ្វីខ្លះឬ មហាទុគ្គតៈឃើញសក្កទេវរាជហើយ ទើបពោលថា នែសម្លាញ់ អ្នកនឹងធ្វើការអ្វី សក្កៈពោលថា ខ្ញុំចេះវិជ្ជាការគ្រប់យ៉ាង ឈ្មោះថា អ្វីដែលខ្ញុំមិនចេះ មិនយល់ មិនមានឡើយ ចេះទាំងការចម្អិនបបរ ជាយជាដើម ។ មហាទុគ្គតៈពោលថា នែសម្លាញ់ ខ្ញុំត្រូវការដោយការងាររបស់អ្នក តែមិនមានតម្លៃ ដែលគួរឲ្យដល់អ្នក សក្កៈពោលថា អ្នកត្រូវការឲ្យខ្ញុំធ្វើអ្វី មហាទុគ្គតៈពោលថា ខ្ញុំបំណងនឹងប្រគេនភិក្ខាដល់ភិក្ខុមួយរូប បំណងនឹងរៀបចំបបរ ជាយ ប្រគេនភិក្ខុនោះ ។ សក្កៈពោលថា បើអ្នកប្រគេនដល់ភិក្ខុ ខ្ញុំមិនត្រូវការថ្លៃឈ្នួល មិនគួរឬ មហាទុគ្គតៈពោលថា នែសម្លាញ់ បើដូច្នោះ ក៏ជាការល្អ សូមអ្នកចូលមកចុះ ។

សក្កៈនោះ ចូលទៅក្នុងផ្ទះរបស់មហាទុគ្គតៈនោះហើយ ឲ្យយកអង្ករជាដើមមក ហើយទ្រង់បញ្ជូនមហាទុគ្គតៈនោះទៅដោយពាក្យថា ទៅចុះអ្នក ចូរនាំភិក្ខុដែលដល់លំដាប់ខ្លួនមក ។

ចំណែកអ្នកចាត់ការទាន បានចែកភិក្ខុទៅកាន់ផ្ទះរបស់ពួកជនទាំងនោះតាមបញ្ជីដែលកត់នោះឯង ។ មហាទុគ្គតៈទៅកាន់សម្នាក់របស់បុរសនោះ

ហើយពោលថា ចូរឲ្យភិក្ខុដល់ខ្ញុំចុះ គាត់មានស្មារតីឡើងក្នុងខណៈនោះ ទើបពោលថា ខ្ញុំភ្លេចភិក្ខុសម្រាប់អ្នកទៅហើយ មហាទុគ្គតៈហាក់បីដូចត្រូវប្រហារត្រង់ពោះដោយលំពែងដ៏មុត ផ្គងដើមដៃទ្រហោយំថា ហេតុអ្វី ទើបឲ្យខ្ញុំវិនាស ខ្ញុំត្រូវអ្នកបបួលហើយ កាលពីម្សិលមិញ ខ្ញុំ និងភរិយាធ្វើការស៊ីឈ្នួលអស់មួយថ្ងៃ ថ្ងៃនេះ តាំងអំពីព្រលឹម ត្រាច់ទៅត្រង់ច្រាំងស្ទឹង ដើម្បីបន្ទៃហើយ ទើបមក សូមអ្នកឲ្យភិក្ខុដល់ខ្ញុំមួយរូបចុះ ។

មនុស្សទាំងឡាយប្រជុំគ្នាហើយសួរថា មហាទុគ្គតៈ តើអ្នកកើតអ្វី ។ គាត់ជ្រាប់សេចក្តីនោះ មនុស្សទាំងនោះសួរអ្នកចាត់ការថា នែសម្លាញ់ ពិតឬបានឮថា មហាទុគ្គតៈនេះ អ្នកបបួលថា ចូរធ្វើការស៊ីឈ្នួល ហើយប្រគេនភិក្ខាដល់ភិក្ខុមួយរូប ។

អ្នកចាត់ការពោលថា ត្រូវហើយអ្នក មនុស្សទាំងនោះពោលថា អ្នកចាត់ការភិក្ខុមានប្រមាណប៉ុណ្ណោះ មិនបានឲ្យដល់មហាទុគ្គតៈនេះត្រឹមតែមួយរូប អ្នកធ្វើកម្មធ្ងន់ហើយ ។

បុរសនោះខ្វាសក្នុងចិត្តដោយវាចារបស់មនុស្សទាំងនោះ ទើបនិយាយនឹងមហាទុគ្គតៈនោះថា មហាទុគ្គតៈសម្លាញ់ កុំឲ្យខ្ញុំវិនាសឡើយ ខ្ញុំដល់នូវសេចក្តីលំបាកធំ ព្រោះហេតុនៃអ្នក មនុស្សទាំងឡាយ នាំភិក្ខុដែលដល់លំដាប់ខ្លួនទៅតាមបញ្ជីដែលកត់ ឈ្មោះថា បុគ្គលនឹងដកភិក្ខុដែលអង្គុយក្នុងផ្ទះរបស់ខ្លួនឲ្យ មិនមាន ។ ចំណែកព្រះសាស្តា ទ្រង់ស្រេពព្រះភក្ត្រហើយប្រថាប់គង់នៅក្នុងព្រះគន្ធកុដិនោះឯង ស្តេចផែនដី ឃុវរាជ និងបុគ្គលធំៗ

មានសេនាបតីជាដើម អង្គុយរង់ចាំការយាងចេញអំពីព្រះគន្ធកុដិនៃព្រះសាស្តា គិតថា នឹងទទួលបាត្រចីវរបស់ព្រះសាស្តាទៅ ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់រមែងធ្វើសេចក្តីអនុគ្រោះក្នុងមនុស្សក្រីក្រ ចូរអ្នកទៅវិហារក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គជាមនុស្សក្រីក្រ សូមទ្រង់ធ្វើសេចក្តីសង្រ្គោះដល់ខ្ញុំព្រះអង្គចុះ បើអ្នកមានបុណ្យ អ្នកនឹងបានពិត មហាទុគ្គតៈទៅកាន់វិហារហើយ ។

លំដាប់នោះ ស្តេចផែនដី និងយុវរាជជាដើម ត្រាស់នឹងបុរសនោះថា មហាទុគ្គតៈ មិនមែនជាពេលភត្ត អ្នកមកធ្វើអ្វី ព្រោះធ្លាប់ឃើញគាត់ដោយភាពជាអ្នកស៊ីដែលក្នុងវិហារ ក្នុងថ្ងៃដទៃៗ ។ មហាទុគ្គតៈក្រាបទូលថា ទូលបង្គំជ្រាបថា មិនមែនភត្តកាល តែខ្ញុំព្រះអង្គមកដើម្បីថ្វាយបង្គំព្រះសាស្តាដូច្នេះហើយ ទើបឱនក្បាលចុះត្រង់ធរណីទ្វារព្រះគន្ធកុដិ ថ្វាយបង្គំដោយបញ្ចង្គ-ប្រតិស្ឋាន ក្រាបទូលថា អ្នកដែលក្រីក្រជាងខ្ញុំក្នុងនគរនេះ មិនមាន សូមទ្រង់ជាទីពឹងដល់ខ្ញុំព្រះអង្គចុះ សូមទ្រង់ធ្វើសេចក្តីសង្រ្គោះដល់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តា ទ្រង់បើកទ្វារព្រះគន្ធកុដិ ទ្រង់នាំបាត្រប្រទានក្នុងដៃរបស់មហា-ទុគ្គតៈ គាត់ហាក់ដូចបានជាស្តេចចក្រពត្តិដ៏មានសិរី ស្តេចផែនដី និងយុវរាជជាដើម ទ្រង់សម្លឹងមើលព្រះភក្ត្រគ្នានិងគ្នា ។

ពិតហើយ បុគ្គលណាម្នាក់ ឈ្មោះថា អាចទទួលបាត្រដែលព្រះសាស្តាប្រទានដល់មហាទុគ្គតៈដោយអំណាចភាពជាធំ មិនមាន តែការពោលយ៉ាងនេះថា មហាទុគ្គតៈសម្លាញ់ ចូរអ្នកឲ្យបាត្ររបស់ព្រះសាស្តាដល់ពួកយើង ពួក

យើងនឹងឲ្យទ្រព្យមានប្រមាណប៉ុណ្ណោះ គឺមួយពាន់ ឬមួយសែនដល់អ្នក អ្នកជាបុគ្គលក្រីក្រ ចូរយកទ្រព្យចុះ ប្រយោជន៍អ្វីរបស់អ្នក ដោយបាត្រនោះ មហាទុគ្គតៈឆ្លើយថា ខ្ញុំមិនឲ្យដល់អ្នកណាឡើយ ខ្ញុំមិនត្រូវការដោយទ្រព្យនឹងឲ្យព្រះសាស្តាប៉ុណ្ណោះសោយ ។ ជនទាំងឡាយដ៏សេស អង្វរមហាទុគ្គតៈមិនបានបាត្រហើយ ទើបត្រឡប់ទៅ ។

ចំណែកស្តេចផែនដីទ្រង់ព្រះតម្រិះថា មហាទុគ្គតៈ សូម្បីគេលួងលោមដោយទ្រព្យក៏មិនឲ្យបាត្រព្រះសាស្តា បុគ្គលណាម្នាក់មិនអាចទទួលបាត្រដែលព្រះសាស្តាប្រទានហើយដោយព្រះអង្គឯងបាន ទេយ្យធម៌របស់មហាទុគ្គតៈនេះ នឹងមានប្រមាណប៉ុនណា ក្នុងពេលមហាទុគ្គតៈនេះ ថ្វាយទេយ្យធម៌ស្រេច យើងនឹងនាំព្រះសាស្តាទៅកាន់ព្រះរាជវាំង ថ្វាយអាហារដែលគេរៀបចំសម្រាប់យើង ដូច្នេះហើយ ទើបយាងទៅជាមួយព្រះសាស្តានោះឯង ។

ចំណែកសក្កទេវរាជរៀបចំភត្តាហារ មានបបរ ជាយ និងបន្លែជាដើម ក្រាលអាសនៈដែលសមគួរ ជាទីប្រថាប់នៃព្រះសាស្តាហើយ ប្រថាប់គង់ ។ មហាទុគ្គតៈនាំព្រះសាស្តាទៅហើយក្រាបទូលថា សូមទ្រង់យាងចូលព្រះអង្គ ។ ឯផ្ទះដែលជាលំនៅរបស់គាត់ទៀត បុគ្គលដែលមិនឱន មិនអាចចូលទៅបាន តែធម្មតាព្រះពុទ្ធទាំងឡាយ កាលយាងចូលកាន់ផ្ទះ មិនចាំបាច់ទ្រង់ឱនចូលទៅ ព្រោះថា ក្នុងពេលទ្រង់យាងចូលកាន់ផ្ទះ មហាប្រឹថពីរមែងស្រុតចុះក្រោម ឬផ្ទះខ្ពស់ឡើង នេះជាផលនៃទាន ដែលព្រះពុទ្ធទាំងឡាយថ្វាយល្អហើយ ។ ក្នុងពេលដែលទ្រង់យាងចេញទៅហើយ វត្តជាប្រក្រតីក៏ដូចដើម

វិញ ព្រោះដូច្នោះ ព្រះសាស្តា ប្រថាប់ឈរនោះឯង ទ្រង់យាងចូលកាន់ផ្ទះ ហើយ ប្រថាប់គង់លើអាសនៈដែលសក្តៈក្រាលហើយ ។ កាលព្រះសាស្តា ប្រថាប់គង់ហើយ ព្រះរាជាត្រាស់ថា មហាទុគ្គតៈសម្លាញ់ អ្នកមិនឲ្យបាត្រ របស់ព្រះសាស្តា ដល់ពួកយើងដែលខំអង្វរ ពួកយើងនឹងមើលសិន សក្ការៈ ដែលអ្នករៀបចំថ្វាយព្រះសាស្តាដូចម្តេច ។ លំដាប់នោះ សក្កទេវរាជបើក ឆ្នាំងបបរ និងកត្តចេញ ក្លិនអប់កត្តាហារទាំងនោះ បានក្រអូបពេញព្រះនគរ ។ ព្រះរាជាទ្រង់ទតបបរជាដើមហើយ ក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះ អង្គ ខ្ញុំព្រះអង្គគិតថា ទេយ្យធម៌របស់មហាទុគ្គតៈមានត្រឹមប៉ុណ្ណា កាល មហាទុគ្គតៈនេះថ្វាយទេយ្យធម៌ហើយ នឹងនាំព្រះសាស្តាទៅកាន់ព្រះរាជវាំង ថ្វាយអាហារដែលគេរៀបចំសម្រាប់ខ្លួន ដូច្នេះ ទើបមកហើយ អាហារបែប នេះ ខ្ញុំព្រះអង្គមិនធ្លាប់ឃើញទេ្បីយ កាលខ្ញុំព្រះអង្គនៅក្នុងទីនេះ មហាទុគ្គតៈ ត្រូវលំបាកពន់ពេក ខ្ញុំព្រះអង្គនឹងត្រឡប់ ថ្វាយបង្គំព្រះសាស្តាហើយ ទ្រង់ ចៀសចេញទៅ ។

ចំណែកសក្កទេវរាជ ថ្វាយយាគូជាដើម ទ្រង់អង្គាសព្រះសាស្តាដោយ គោរព ព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចហើយ ទ្រង់ធ្វើអនុមោទនាក្រោកចាកអាសនៈ យាងទៅហើយ ។ សក្កទេវរាជ បានឲ្យសញ្ញាដល់មហាទុគ្គតៈ ។ គាត់ទទួល បាត្រធ្វើដំណើរតាមព្រះសាស្តា ។ សក្កទេវរាជយាងត្រឡប់ ប្រថាប់ឈរត្រង់ ផ្ទះរបស់មហាទុគ្គតៈ ទ្រង់សម្ដែងអាកាសហើយ ភ្លៀងកែវ ៧ ប្រការ ធ្លាក់ចុះ មកអំពីអាកាស ពេញកាជនៈទាំងអស់ក្នុងផ្ទះរបស់គាត់ហើយ ហៀរទៅពេញ

ផ្ទះ ។ ក្នុងផ្ទះរបស់គាត់មិនមានចន្ទោះ ភរិយារបស់គាត់បានដឹកដៃកូននាំចេញទៅឈរខាងក្រៅ ។ មហាទុគ្គតៈតាមព្រះសាស្តាទៅហើយត្រឡប់មក ឃើញកូននៅត្រង់ផ្លូវ ទើបសួរថា តើមានរឿងអ្វី ភរិយាឆ្លើយថា នែអ្នក ផ្ទះរបស់យើងពេញទៅដោយកែវ ៧ ប្រការ មិនមានចន្ទោះដែលចូលទៅបាន ។ គាត់គិតថា ទានរបស់គាត់ឲ្យផលក្នុងថ្ងៃនេះឯង ដូច្នេះហើយ ទើបទៅកាន់ព្រះរាជសម្នាក់ ថ្វាយបង្គំព្រះរាជាហើយ កាលព្រះរាជាត្រាស់សួរថា តើអ្នកមកធ្វើអ្វី ទើបក្រាបទូលថា បពិត្រព្រះអង្គ ផ្ទះរបស់ទូលបង្គំពេញទៅដោយកែវ ៧ ប្រការ សូមទ្រង់កាន់យកទ្រព្យនោះចុះ ព្រះរាជាទ្រង់ត្រិះរិះថា គួរអស្ចារ្យទានដែលបុរសនេះថ្វាយដល់ព្រះពុទ្ធទាំងឡាយ ដល់ទីបំផុតថ្ងៃនេះឯង ដូច្នេះហើយ ទើបត្រាស់នឹងមហាទុគ្គតៈថា អ្នកគួរនឹងបានអ្វី មហាទុគ្គតៈពោលថា សូមទ្រង់ព្រះរាជទានរនេះមួយពាន់ ដើម្បីនាំទ្រព្យមក ។

ព្រះរាជាទ្រង់បញ្ជូនរនេះមួយពាន់ទៅ ឲ្យនាំទ្រព្យមកគរត្រង់លានព្រះរាជវាំង គំនរទ្រព្យកម្ពស់ប្រមាណស្មើដើមត្នោត ។ ព្រះរាជាទ្រង់បញ្ជាឲ្យអ្នកនគរប្រជុំគ្នាហើយត្រាស់សួរថា ក្នុងនគរនេះ អ្នកមានទ្រព្យប្រមាណប៉ុណ្ណេះមានដែរឬទេ អ្នកនគរទូលថា បពិត្រព្រះអង្គ មិនមានទេ ព្រះរាជាត្រាស់ថា តើគួរធ្វើដូចម្តេចដល់បុគ្គល ដែលមានទ្រព្យច្រើនដល់ម្ល៉ះ អ្នកនគរទូលថា បពិត្រព្រះអង្គ គួរលើកជាសេដ្ឋី ។

ព្រះរាជាទ្រង់ធ្វើសក្ការៈជាច្រើន ដល់មហាទុគ្គតៈហើយ ត្រាស់ឲ្យព្រះរាជទានតំណែងសេដ្ឋី ។ លំដាប់នោះ ព្រះរាជាត្រាស់ប្រាប់ត្រង់ផ្ទះរបស់សេដ្ឋី

ម្នាក់ក្នុងកាលមុន ដល់មហាទុគ្គត:ហើយ ត្រាស់ថា អ្នកចូរធ្ការគុម្ពឈើដែល កើតក្នុងទីនេះ ហើយសង់ផ្ទះនៅចុះ កាលគាត់ធ្ការទីនោះ ជីកដីធ្វើឲ្យរាប ធ្នាំងទ្រព្យបានផុសឡើងតម្រៀបលើគ្នា ។ គាត់ក៏ក្រាបទូលដល់ព្រះរាជា ទើប ព្រះរាជាត្រាស់ថា ធ្នាំងទ្រព្យនោះ កើតព្រោះបុណ្យរបស់អ្នកនោះឯង ចូរអ្នក កាន់យកចុះ ។

គាត់បានសង់ផ្ទះហើយ បានថ្វាយមហាទានដល់ភិក្ខុសង្ឆ មានព្រះពុទ្ធ ជាប្រធានអស់ ៧ ថ្ងៃ ខាងមុខអំពីនោះ គាត់បានបំពេញបុណ្យដរាបដល់ អស់អាយុ ក្នុងទីបំផុតអាយុ បានទៅកើតក្នុងទេវលោក សោយទិព្វសម្បត្តិ អស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ ចុតិអំពីនោះហើយ បដិសន្ធិក្នុង ផ្ទៃធីតាច្បង ក្នុងត្រកូលឧបដ្ឋាករបស់ព្រះសារីបុត្តត្ថេរ ក្នុងក្រុងសាវត្ថី ។ គ្រា នោះ មាតាបិតារបស់នាង ដឹងថា នាងមានគភ៌ ទើបឲ្យគ្រឿងបរិហារគភ៌ ។ ដោយសម័យដទៃ នាងចាញ់គភ៌ដូច្នេះថា ឧ អញគប្បីឲ្យទានដល់ភិក្ខុ ៥០០ រូប ចាប់តាំងអំពីព្រះធម្មសេនាបតី ដោយរសត្រីធ្ពិនហើយ ស្ងៀកសំពត់ ជ្រលក់ទឹកមូត់ អង្គុយក្នុងទីបំផុតអាសន: បរិភោគភត្តដែលសល់អំពីភិក្ខុ ទាំងនោះ នាងប្រាប់ដល់មាតាបិតាហើយ ក៏បានធ្វើតាមបំណង ។ ការចាញ់ គភ៌ក៏រម្ងាប់ទៅហើយ ។ តមក ក្នុងការងារមង្គល ៧ ដងដទៃអំពីនោះ ។ មាតាបិតារបស់នាងអង្គាសភិក្ខុ ៥០០ រូប មានព្រះធម្មសេនាបតីសារីបុត្ត ជាប្រធាន ដោយរសត្រីធ្ពិនដូចគ្នា ។

គប្បីជ្រាបរឿងទាំងអស់ ដោយន័យដែលពោលហើយ ក្នុងរឿងតិស្ស-

កុមារនោះឯង ។ តែនេះជាផលនៃការថ្វាយរសត្រីឆ្ពិន ក្នុងកាលដែលនៅជាទុគ្គតៈនោះឯង ។

ក្នុងថ្ងៃដាក់ឈ្មោះ កាលមាតារបស់ក្មេងនោះពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យសិក្ខាបទទាំង៥ឡាយដល់ទាសៈរបស់លោកម្ចាស់ចុះ ទើបព្រះថេរៈពោលថា កុមារនេះឈ្មោះអ្វី ម្តាយរបស់កុមារឆ្លើយថា បពិត្រលោកម្ចាស់ បុគ្គលល្ងង់ខ្លៅក្នុងផ្ទះនេះ ក៏ត្រឡប់ទៅជាមនុស្សឈ្លាស តាំងអំពីកាលដែលកុមារនេះបដិសន្ធិក្នុងផ្ទៃ ព្រោះដូច្នោះ កូនរបស់ខ្ញុំ និងមានឈ្មោះថា បណ្ឌិត ចុះ ។ ព្រះថេរៈឲ្យសិក្ខាបទទាំង៥ឡាយហើយ ។ តាំងអំពីថ្ងៃបណ្ឌិតកុមារកើតមក ការគិតកើតឡើងដល់មាតារបស់កុមារថា អាត្មាអញនឹងមិនទម្លាយអធ្យាស្រ័យរបស់កូនអញឡើយ ក្នុងកាលដែលកុមារមានអាយុបាន ៧ ឆ្នាំ ក៏ពោលនឹងមាតាថា ខ្ញុំចង់បួសក្នុងសម្នាក់ព្រះថេរៈ នាងពោលថា នែចា បាន ម៉ែបានគិតហើយយ៉ាងនេះថា នឹងមិនទម្លាយអធ្យាស្រ័យរបស់អ្នក ដូច្នេះហើយ ទើបនិមន្តព្រះថេរៈឲ្យឆាន់ ហើយពោលថា បពិត្រលោកម្ចាស់ ទាសៈរបស់លោកម្ចាស់ចង់បួស ខ្ញុំនឹងនាំកុមារនេះទៅវិហារក្នុងពេលល្ងាច ជូនដំណើរព្រះថេរៈទៅហើយ ឲ្យពួកញាតិប្រជុំគ្នា ពោលថា ខ្ញុំនឹងធ្វើសក្ការៈ ដែលគួរធ្វើដល់កូនរបស់ខ្ញុំក្នុងពេលជាគ្រហស្ថក្នុងថ្ងៃនេះឯង ដូច្នេះហើយ ក៏ឲ្យធ្វើសក្ការៈយ៉ាងច្រើន នាំបណ្ឌិតកុមារនោះទៅកាន់វិហារ បានប្រគល់ដល់ព្រះថេរៈថា សូមលោកម្ចាស់ឲ្យកុមារនេះបួសចុះ ។ ព្រះថេរៈជ្រាប់ភាពដែលបួស ជាកិច្ចដែលធ្វើបានលំបាកហើយ កាលកុមារទទួល

ថា ខ្ញុំនឹងធ្វើតាមឱវាទរបស់លោកម្ចាស់ ទើបពោលថា បើដូច្នោះ ចូរមកចុះ លាបសក់ឲ្យសើមហើយ ជ្រាប់តចបញ្ចកកម្មដ្ឋានឲ្យបួសហើយ ។ សូម្បី មាតាបិតារបស់បណ្ឌិតសាមណេរនោះ ក៏នៅក្នុងវិហារនោះឯងអស់ ៧ ថ្ងៃ ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយរសត្រីឆ្ងិនតែម្យ៉ាង ក្នុងថ្ងៃទី ៧ ពេលល្ងាច ទើបបានទៅកាន់ផ្ទះ ។

ក្នុងថ្ងៃទី ៨ ព្រះថេរៈកាលទៅខាងក្នុងស្រុក នាំសាមណេរនោះទៅ មិនបានទៅជាមួយពួកភិក្ខុ ព្រោះហេតុអ្វី ព្រោះថា ការដណ្តប់ចីវរ និងកាន់បាត្រ ឬឥរិយាបថរបស់លោក មិនទាន់គួរឲ្យជ្រះថ្លានៅឡើយ ម្យ៉ាងទៀត វត្តដែលគប្បីធ្វើក្នុងវិហាររបស់ព្រះថេរៈនៅមាន ម្យ៉ាងទៀត ព្រះថេរៈកាលភិក្ខុសង្ឃចូលទៅខាងក្នុងស្រុកហើយ ត្រាច់ទៅពេញវិហារ ឱាសទីដែលមិនទាន់បានឱាស តម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ទុកក្នុងភាជនៈដែលទទេ ទុកជាក់គ្រែ និងតាំងជាដើម ដែលមិនទាន់បានទុកជាក់រៀបរយ ទើបចូលទៅកាន់ស្រុកជាក្រោយ ។ ម្យ៉ាងទៀត លោកគិតថា ពួកតិរ្ថិយចូលទៅកាន់វិហារទទេហើយ កុំបីពោលថា មើលចុះអាសនៈពួកសាវកព្រះគោតម ដូច្នេះហើយ ទើបបានចាត់ចែងវិហារទាំងមូល ហើយចូលទៅកាន់ស្រុកឯក្រោយ ព្រោះដូច្នោះ ក្នុងថ្ងៃនោះ ព្រះថេរៈឲ្យសាមណេរនោះឯង កាន់បាត្រ ចីវរចូលទៅកាន់ស្រុកយ៉ឺតយូរបន្តិច ។

សាមណេរទៅជាមួយព្រះឧបជ្ឈាយ៍ ឃើញប្រទ្បាយក្នុងរវាងផ្លូវ ទើបសាកសួរថា បពិត្រលោកម្ចាស់ នេះ គេហៅថា អ្វី ព្រះថេរៈពោលថា អើ

សាមណេរ នេះ គេហៅថា ប្រឡាយ សាមណេរពោលថា គេធ្វើអ្វីដោយប្រឡាយនេះ ព្រះថេរៈពោលថា គេបង្ហូរទឹក ហើយធ្វើការងារទាក់ទងដោយសម្ផឹងរបស់ខ្លួន សាមណេរពោលថា បពិត្រលោកម្ចាស់ ទឹកនេះ មានចិត្តដែលឬទេ ព្រះថេរៈពោលថា មិនមានទេ សាមណេរពោលថា ជនទាំង-ឡាយ រមែងបង្ហូរទឹកដែលមិនមានចិត្តបែបនេះ ទៅកាន់ទីដែលខ្លួនប្រាថ្នា ហើយបានឬ ព្រះថេរៈពោលថា អើ សាមណេរ បាន ។

សាមណេរនោះគិតថា បើមនុស្សទាំងឡាយ បង្ហូរទឹកដែលមិនមានចិត្តបែបនេះ ទៅកាន់ទីដែលខ្លួនប្រាថ្នា ហើយធ្វើការងារបាន ហេតុអ្វី មនុស្សមានចិត្តពិតៗ មិនអាចធ្វើចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅក្នុងអំណាចហើយ បំពេញសមណធម៌ ។ លោកដើរបន្តទៅទៀត ឃើញពួកជាងព្រួញ កំពុងយកព្រួញរោលភ្លើង សម្ផឹងដោយកន្ទុយភ្នែកពត់ឲ្យត្រង់ ទើបសាកសួរថា បពិត្រលោកម្ចាស់ ជនទាំងនេះ ឈ្មោះអ្វី ព្រះថេរៈពោលថា ឈ្មោះជាងព្រួញ សាមណេរៗ ពោលថា តើពួកគេធ្វើអ្វី ព្រះថេរៈពោលថា គេរោលត្រង់ភ្លើង ហើយពត់ព្រួញឲ្យត្រង់ ។ សាមណេរពោលថា ព្រួញនោះ មានចិត្តដែរឬទេ ព្រះថេរៈពោលថា មិនមានចិត្តទេ សាមណេរគិតថា បើមនុស្សទាំងឡាយកាន់យកព្រួញដែលមិនមានចិត្តរោលភ្លើង ហើយពត់ឲ្យត្រង់បាន ព្រោះហេតុអ្វី ទើបមនុស្សមានចិត្ត មិនអាចធ្វើចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅក្នុងអំណាច ហើយបំពេញសមណធម៌ ។

កាលសាមណេរនិមន្តទៅទៀត ឃើញជាងឈើធ្វើគ្រឿងទព្វសម្ភារៈ មាន

កាំ ខ្នងកង់ និងដុំជាដើម ទើបសាកសួរថា បពិត្រលោកម្ចាស់ ជនទាំងនេះ ឈ្មោះអ្វី ព្រះថេរៈប្រាប់ថា នែសាមណេរ ឈ្មោះជាងឈើ សាមណេរសួរថា ពួកគេធ្វើអ្វី ព្រះថេរៈប្រាប់ថា គេកាន់យកឈើហើយ ធ្វើកង់នៃយានតូចជាដើម សាមណេរសួរថា ឈើនោះ មានចិត្តដែរឬទេ ព្រះថេរៈប្រាប់ថា មិនមានទេ ។

ពេលនោះ សាមណេរគិតយ៉ាងនេះថា បើមនុស្សទាំងឡាយ កាន់យកកំណាត់ឈើដែលមិនមានចិត្ត ធ្វើជាកង់រទេះជាដើមបាន ហេតុអ្វី ទើបបុគ្គលមានចិត្តមិនអាចធ្វើចិត្តរបស់ខ្លួន ឲ្យប្រព្រឹត្តទៅក្នុងអំណាច ហើយបំពេញសមណធម៌បាន ។ លោកឃើញហេតុទាំងនេះហើយ ទើបពិតព្រះថេរៈថា បពិត្រលោកម្ចាស់ បើលោកម្ចាស់អាចកាន់បាត្រ និងចីវររបស់លោកម្ចាស់បាន ខ្ញុំនឹងត្រឡប់ ព្រះថេរៈមិនបានកើតគំនិតថា សាមណេរតូចនេះបួសថ្មីៗ ដើរតាមអញមក ហើយពោលយ៉ាងនេះ បែរជាពោលថា នែសាមណេរ ចូរអ្នកយកមកចុះ ហើយទទួលបាត្រ និងចីវររបស់ខ្លួន ។

ចំណែកសាមណេរ ថ្វាយបង្គំឧបជ្ឈាយ៍ហើយ កាលនឹងត្រឡប់ ទើបពិតថា បពិត្រលោកម្ចាស់ បើលោកម្ចាស់នាំអាហារមកដើម្បីខ្ញុំ សូមនាំយកវេសត្រីឆ្ពិនមកចុះ ព្រះថេរៈពោលថា អើសាមណេរ ខ្ញុំនឹងបានអំពីណា សាមណេរពិតថា បើមិនបានដោយបុណ្យរបស់លោកម្ចាស់ គង់បានដោយបុណ្យរបស់ខ្ញុំ ។ ព្រះថេរៈគិតថា អន្តរាយគប្បីមានដល់សាមណេរតូច ដែលអង្គុយខាងក្រៅ ទើបឲ្យកូនសោទៅ ហើយប្រាប់ថា គួរបើកទ្វារបន្ទប់របស់

ខ្ញុំ ហើយចូលទៅអង្គុយខាងក្នុង ។ លោកបានធ្វើយ៉ាងនោះហើយ អង្គុយ ញ៉ាំងចិត្តឲ្យឈមចុះក្នុងកាយគតាសតិ ពិចារណាអត្តភាពរបស់ខ្លួន ។

គ្រានោះ ទីប្រថាប់របស់សក្កទេវរាជ សម្តែងអាការក្តៅដោយតេជៈនៃគុណរបស់សាមណេរនោះ ទ្រង់ពិចារណាថា នឹងមានហេតុអ្វីហ្ន៎ ទ្រង់ត្រិះរិះបានថា បណ្ឌិតសាមណេរឲ្យបាត្រ និងចីវរដល់ឧបជ្ឈាយ៍ ហើយត្រឡប់ដោយតាំងចិត្តថា នឹងធ្វើសមណធម៌ សូម្បីអាត្មាអញក៏គួរទៅក្នុងទីនោះ ដូច្នេះហើយ ទើបហៅមហារាជទាំង ៤ មកត្រាស់ថា ចូរអ្នកទៅដេញបក្សាបក្សីដែលស្រែកយំខ្ទៀវខ្ទារក្នុងព្រៃ កែ្សវិហារឲ្យគេចទៅ ហើយធ្វើការរក្សាដោយជុំវិញ ត្រាស់នឹងចន្ទទេវបុត្រថា ចូរអ្នកទាញមណ្ឌលព្រះចន្ទ ត្រាស់នឹងសុរិយទេវបុត្រថា ចូរអ្នកទាញមណ្ឌលព្រះអាទិត្យ ដូច្នេះហើយ ព្រះអង្គឯងបានយាងទៅប្រថាប់ឈរធ្វើការរក្សា ។ ក្នុងវិហារ សូម្បីត្រឹមតែសំឡេងស្ទឹកឈើចាស់ក៏មិនមាន ។ ចិត្តរបស់សាមណេរ មានអារម្មណ៍ជាឯកគ្គតាហើយ ។ លោកពិចារណាអត្តភាពហើយ សម្រេចផល ៣ ក្នុងរវាងកត្តនោះឯង ។

ចំណែកព្រះថេរៈគិតថា សាមណេរអង្គុយហើយក្នុងវិហារ អាត្មាអញអាចបានភោជន ដែលសមបំណងដល់លោក ក្នុងត្រកូលឈ្មោះនោះ ដូច្នេះហើយ ទៅកាន់ត្រកូលឧបដ្ឋាកមួយ ដែលប្រកបដោយសេចក្តីស្រឡាញ់ និងគោរព ។ ក្នុងថ្ងៃនោះ មនុស្សទាំងឡាយក្នុងត្រកូលនោះ បានត្រឹធ្វើជាច្រើនអង្គុយទន្ទឹងការមកបរបស់ព្រះថេរៈ ។ មនុស្សទាំងនោះ ឃើញព្រះថេរៈកំពុង

និមន្តមក ទើបពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់មកទីនេះធ្វើកម្មចម្រើនហើយ ហើយនិមន្តឲ្យចូលទៅខាងក្នុង ប្រគេនបបរ និងរបស់គួរទំពាជាដើម ហើយ បានថ្វាយបិណ្ឌបាតដោយរសត្រីឆ្ងិន ព្រះថេរៈសម្តែងអាការនាំទៅ ។ ពួកមនុស្សជ្រាប់ថា និមន្តឆាន់ចុះលោកម្ចាស់ លោកម្ចាស់ទឹងបានភត្តសម្រាប់នាំទៅ ។ ក្នុងពេលស្រេចភត្តកិច្ចរបស់ព្រះថេរៈ បានយកកោជនប្រកបដោយរសត្រីឆ្ងិន ដាក់ពេញបាត្រប្រគេនហើយ ។ ព្រះថេរៈគិតថា សាមណេររបស់អាត្មាអញឃ្លានហើយ ទើបរួតរះទៅ ។

ក្នុងថ្ងៃនោះ ព្រះសាស្តាសោយអំពីព្រឹកហើយយាងទៅកាន់វិហារ ទ្រង់ពិចារណាថា បណ្ឌិតសាមណេរឲ្យបាត្រ និងចីវរដល់ឧបជ្ឈាយ៍ ហើយត្រឡប់ទៅដោយតាំងចិត្តថា នឹងធ្វើសមណធម៌ កិច្ចនៃបព្វជិតរបស់សាមណេរ នឹងសម្រេចដែរឬទេ ទ្រង់ជ្រាបថា សាមណេរសម្រេចផល ៣ ហើយ ទ្រង់ពិចារណាថា ឧបនិស្ស័យនៃអរហត្តមាន ឬមិនមានហ្ន៎ ទ្រង់ឃើញថា មានហើយទ្រង់ពិចារណាថា សាមណេរអាចសម្រេចអរហត្តមុនភត្ត ឬក៏មិនអាចហ្ន៎ ទ្រង់បានជ្រាបថា នឹងអាច ។ លំដាប់នោះ ទ្រង់មានបរិវិតក្កយ៉ាងនេះថា សារីបុត្រកាន់ភត្តដើម្បីសាមណេរ រួតរះមក សារីបុត្តគប្បីធ្វើអន្តរាយដល់សាមណេរនោះក៏បាន តថាគតនឹងអង្គុយកាន់យកការពារក្បាត្រង់ខ្ញោងទ្វារ រួចសួរបញ្ហា ៤ យ៉ាងដល់សារីបុត្ត កាលសារីបុត្តកំពុងឆ្លើយ សាមណេរនឹងសម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទា ដូច្នេះហើយ ទើបទ្រង់យាងទៅអំពីវិហារ ប្រថាប់ឈរត្រង់ខ្ញោងទ្វារ ត្រាស់សួរបញ្ហា ៤ យ៉ាងជាមួយនឹង

ព្រះថេរៈ។ មកដល់ហើយ ក៏ឆ្លើយបញ្ហាដែលព្រះសាស្តាត្រាស់សួរ ។

ក្នុងបញ្ហានោះ មានបុច្ឆា និងវិសជ្ជនាដូចតទៅនេះ បានឮថា ព្រះសាស្តាត្រាស់នឹងព្រះថេរៈថា សារីបុត្ត អ្នកបានអ្វីមក ព្រះថេរៈទូលថា បពិត្រព្រះអង្គ បានអាហារ ព្រះសាស្តាត្រាស់សួរថា ម្នាលសារីបុត្ត ឈ្មោះថា អាហារមែងនាំអ្វីមក ព្រះថេរៈទូលថា បពិត្រព្រះអង្គ វេទនា ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្ត វេទនាមែងនាំអ្វីមក ព្រះថេរៈទូលថា បពិត្រព្រះអង្គ រូប ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្ត ចុះរូបរមែងនាំអ្វីមក ព្រះថេរៈទូលថា បពិត្រព្រះអង្គ ផស្សៈ ។

ក្នុងបញ្ហានោះ មានអធិប្បាយថា ពិតហើយ អាហារដែលមនុស្សស្រេកឃ្លានបរិភោគហើយ កម្ចាត់នូវការស្រេកឃ្លានរបស់បុគ្គលនោះ ហើយនាំសុខវេទនាមកឲ្យ កាលសុខវេទនាកើតឡើងដល់បុគ្គលដែលមានសុខព្រោះការបរិភោគអាហារ វណ្ណសម្បត្តិរមែងមានក្នុងសរីរៈ ទើបវេទនាឈ្មោះថានាំរូបមកដោយប្រការយ៉ាងនេះ ឯបុគ្គលដែលមានសុខសោមនស្សដោយអំណាចរូបដែលកើតអំពីអាហារ ដេកក្តី អង្គុយក្តី ដោយគិតថា ឥឡូវនេះ អស្សាទៈកើតឡើងដល់អញហើយ រមែងបាននូវសុខផស្សៈ ។

ព្រះថេរៈឆ្លើយបញ្ហា ៤ យ៉ាងនេះហើយ សាមណេរក៏បានសម្រេចអរហត្តមួយអន្ទើដោយបដិសម្ភិទា ។ ចំណែកព្រះសាស្តា ត្រាស់នឹងព្រះថេរៈថា ទៅចុះសារីបុត្ត ចូរអ្នកឲ្យកត្តជល់សាមណេររបស់អ្នក ។ ព្រះថេរៈគោះទ្វារហើយ សាមណេរចេញមកទទួលបាត្រអំពីដៃព្រះថេរៈ ទុកក្នុងចំណែកម្ខាងហើយ ទើប

យកផ្ទិតស្លឹកស្នោតបក់ព្រះថេរៈ ព្រះថេរៈពោលដល់លោកថា សាមណេរ ចូរអ្នកធ្វើកត្តកិច្ចចុះ ។ សាមណេរពិតថា បពិត្រលោកម្ចាស់ ចុះលោកម្ចាស់ វិញ ព្រះថេរៈពោលថា ខ្ញុំធ្វើកត្តកិច្ចស្រេចហើយ ចូរអ្នកធ្វើចុះ ។

កុមារអាយុ ៧ ឆ្នាំបួសហើយ ក្នុងថ្ងៃទី ៨ សម្រេចអរហត្ត ហាក់ដូច ជាផ្កាឈូកវីកហើយ ក្នុងខណៈនោះ បានគង់ពិចារណាត្រង់ទីជាក់កត្ត ធ្វើ កត្តកិច្ចហើយ ក្នុងខណៈដែលលោកលាងបាត្រទុកជាក់ហើយ ចន្ទទេវបុត្រ ក៏លែងចន្ទមណ្ឌល សុរិយទេវបុត្រក៏លែងសុរិយមណ្ឌល មហារាជទាំង ៤ រក្សាទិសទាំង ៤ សក្កទេវរាជ ក៏រៀរការរក្សាត្រង់សន្ទះទ្វារ ព្រះអាទិត្យលយ លឿន ជ្រេទៅហើយអំពីថ្ងៃត្រង់ ។

ភិក្ខុទាំងឡាយពោលទោសថា ស្រមោលជ្រេហួសប្រមាណហើយ ព្រះអាទិត្យគោចរទៅអំពីថ្ងៃត្រង់ សាមណេរធាន់ស្រេចអម្បាញ់មិញនេះឯង តើមានរឿងអ្វីហ្ន៎ ព្រះសាស្តាទ្រង់ជ្រាបការប្រព្រឹត្តទៅនោះហើយ ទ្រង់យាង មកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសន្ទនាគ្នាអំពីរឿងអ្វី ភិក្ខុ ទាំងឡាយទូលថា បពិត្រព្រះអង្គ រឿងឈ្មោះនេះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ក្នុងពេលបុគ្គលមានបុណ្យធ្វើសមណធម៌ ចន្ទទេវបុត្រ បញ្ឈប់មណ្ឌលព្រះចន្ទ សុរិយទេវបុត្រ បញ្ឈប់មណ្ឌលព្រះ អាទិត្យ មហារាជទាំង ៤ រក្សាក្នុងទិសទាំង ៤ ក្នុងព្រៃជិតវិហារ សក្កទេវរាជ មកឈរការក្សាត្រង់សន្ទះទ្វារ តថាគតមានការខ្វល់ខ្វាយតិច ដោយគិតថា ជា ព្រះពុទ្ធក៏មិនបានអង្គុយនៅ គង់ទៅឈរការក្សាបុត្ររបស់តថាគតត្រង់ខ្ទោងទ្វារ

ពួកបណ្ឌិតឃើញមនុស្សបង្ហូរទឹក បង្ហូរទឹកទៅអំពីប្រឡាយ ជាងព្រួញកំពុងពត់ព្រួញឲ្យត្រង់ ជាងឈើកំពុងចាំងឈើ កាន់យកហេតុប៉ុណ្ណោះ ឲ្យជាអារម្មណ៍ទូន្មានខ្លួនហើយ រមែងទាញយកបាននូវអរហត្តនោះឯង ដូច្នេះហើយ កាលនឹងបន្តអនុសន្ធិសម្តែងធម៌ ត្រាស់ព្រះគាថានេះថា

ឧទកញ្ហិ នយន្តិ នេត្តិកា ឧសុការា នមយន្តិ តេជនំ
ទារុំ នមយន្តិ តច្ឆកា អត្តានំ ទមយន្តិ បណ្ឌិតា ។

ជម្មតា អ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់) អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួន (ដូច្នោះដែរ) ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឧទកំ** *ជាដើម សេចក្តីថា ជនទាំងឡាយជីកត្រង់ទួលលើផែនដី បំពេញត្រង់ទំនាប ហើយធ្វើប្រឡាយ ឬដាក់រហាត់ រមែងបង្ហូរទឹកទៅកាន់ទីដែលខ្លួនត្រូវការ ព្រោះដូច្នោះ ទើបឈ្មោះថា បង្ហូរទឹក ។ បទថា* **តេជនំ** *បានដល់ ព្រួញ ។*

មានព្រះពុទ្ធាធិប្បាយត្រាស់ដូច្នេះថា

ពួកអ្នកបង្ហូរទឹក រមែងបង្ហូរទឹកទៅតាមគាប់ចិត្តរបស់ខ្លួនបាន សូម្បីជាងព្រួញ រមែងរោលពត់នូវព្រួញ គឺធ្វើឲ្យត្រង់ សូម្បីជាងឈើ កាលនឹងចាំងដើម្បីប្រយោជន៍ដល់ទព្វសម្ភារៈ មានខ្នងកង់ជាដើម រមែងពត់ឈើ គឺធ្វើឲ្យត្រង់ ឬកោងតាមគាប់ចិត្តរបស់ខ្លួន បណ្ឌិតទាំងឡាយ ធ្វើហេតុមានប្រមាណ

ប៉ុណ្ណោះឲ្យជាអារម្មណ៍យ៉ាងនោះហើយ ញុំាងមគ្គ មានសោតាបត្តិមគ្គជាដើម ឲ្យកើតឡើង ឈ្មោះថា ទូន្មានខ្លួន តែកាលសម្រេចអរហត្តហើយ រមែងឈ្មោះថា ទូន្មានដោយចំណែកមួយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង បណ្ឌិតសាមណេរ ចប់

រឿង ព្រះលកុណ្ឌកភទ្ទិយត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធលកុណ្ឌកភទ្ទិយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **សេលោ យថា** *ជាដើម ។*

បានឮថា សហធម្មិក មានសាមណេរជាដើមដែលជាបុថុជ្ជន ឃើញព្រះថេរៈហើយ ចាប់ត្រង់ក្បាលខ្លះ ត្រង់ត្រចៀកខ្លះ ច្រមុះខ្លះពោលថា បពិត្រលោកម្ចាស់ៗ មិនអផ្សុក នៅត្រេកអរមាំទាំ ក្នុងព្រះសាសនាឬ ព្រះថេរៈមិនក្រោធ មិនប្រទូស្តក្នុងសហធម្មិកទាំងនោះទេឬ ។

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងពេលធម្មសភាថា អាវុសោទាំងឡាយ ចូរពួកអ្នកមើលចុះ សហធម្មិក មានសាមណេរជាដើម ឃើញព្រះលកុណ្ឌកភទ្ទិ-យត្ថេរហើយ រមែងលេងយ៉ាងនេះ តែលោកមិនក្រោធ មិនប្រទូស្តក្នុង

សហធម្មិកទាំងនោះឡើយ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនិយាយអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា រឿងឈ្មោះនេះព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ធម្មតាព្រះខីណាស្រព រមែងមិនក្រោធ មិនប្រទូស្តឡើយ ព្រោះលោកទាំងនោះមិនញាប់ញ័រ មិនកម្រើក ដូចគ្នានឹងថ្មភ្នំតាន់ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ត្រាស់ព្រះគាថានេះថា

សេលោ យថា ឯកឃនោ វាតេន ន សមីរតិ

ឯវំ ឥញ្ជាបសំសាសុ ន សម្មិញ្ជន្តិ បណ្ឌិតា ។

ថ្មភ្នំតាន់ មិនរំភើបព្រោះខ្យល់ ដូចម្តេចមិញ បណ្ឌិតទាំងឡាយ ក៏មិនរំភើប ព្រោះពាក្យតិះដៀល និងពាក្យសរសើរ (ជាដើម) ដូច្នោះឯង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ក្នុងបទថា **ឥញ្ជាបសំសាសុ** នេះ ព្រះដ៏មានព្រះភាគត្រាស់លោកធម៌ពីរក៏ពិត តែគប្បីជ្រាបដោយអំណាចនៃលោកធម៌ទាំង ៨ អធិប្បាយថា ដូចថ្មភ្នំសុទ្ធជាដុំតែមួយ គឺមិនមានប្រហោង រមែងមិនញាប់ញ័រ គឺមិនទោរទន់ មិនកម្រើកដោយខ្យល់ មានខ្យល់ដែលបក់មកអំពីទិសខាងកើតជាដើម យ៉ាងណា កាលលោកធម៌ទាំង ៨ គ្របសង្កត់ បណ្ឌិតទាំងឡាយ រមែងមិនទោរទន់ គឺមិនញាប់ញ័រ មិនកម្រើក ដោយអំណាចការប្រទូស្ត ឬត្រេកអរ ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

រឿង ព្រះលកុណ្ឌកភទ្ទិយត្ថេរ ចប់

រឿង មាតារបស់នាងកាណា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធម្តាយរបស់នាងកាណា ត្រាស់ព្រះធម្មទេសនានេះថា **យថាបិ រហោ គម្ភីរោ** *ជាដើម ។*

រឿងនេះមកហើយ ក្នុងវិនัยនោះឯង ។

គ្រានោះ ក្នុងកាលមាតារបស់នាងកាណាចៀនំដើម្បីបញ្ជូនកូនស្រីឲ្យជាបុគ្គលមិនមានដៃទេ ទៅកាន់ត្រកូលស្វាមីហើយ ប្រគេនដល់ភិក្ខុ ៤ រូប អស់វារៈ ៤ ដង ។ ព្រះសាស្តា ទ្រង់បញ្ញត្តសិក្ខាបទព្រោះរឿងនោះ កាលស្វាមីរបស់នាងកាណានាំភរិយាថ្មីមកហើយ នាងកាណា បានស្តាប់រឿងនោះ ទើបជេរបរិភាសពួកភិក្ខុ ដែលខ្លួនបានឃើញហើយថា ការគ្រប់គ្រងផ្ទះរបស់ខ្ញុំ ភិក្ខុទាំងនេះឲ្យវិនាសហើយ ។ ភិក្ខុទាំងឡាយមិនអាចដើរទៅកាន់ផ្លូវនោះបាន ។

ព្រះសាស្តា ទ្រង់ជ្រាបរឿងនោះហើយ ទើបយាងទៅក្នុងទីនោះ មាតារបស់នាងកាណា ថ្វាយបង្គំព្រះសាស្តាហើយ និមន្តឲ្យប្រថាប់គង់លើអាសនៈ

ដែលខ្លួនរៀបចំ បានថ្វាយបបរ និងរបស់គួរទំពាហើយ ។

ព្រះសាស្តា សោយព្រះក្រយាហារព្រឹកហើយ ត្រាស់សួរថា កាណា ទៅណា កាណាមាតាពោលថា បពិត្រព្រះអង្គ នាងឃើញព្រះអង្គហើយ ជាអ្នកខ្វាសអៀន ឈរយំ ព្រះសាស្តាត្រាស់ថា ព្រោះហេតុដូចម្តេច កាណាមាតាទូលថា នាងជេរបរិភាសពួកភិក្ខុ ព្រោះដូច្នោះ នាងឃើញព្រះអង្គហើយ ទើបជាអ្នកខ្វាសអៀន ហើយឈរយំ ។

លំដាប់នោះ ព្រះសាស្តា ត្រាស់ឲ្យហៅនាងកាណាមកហើយ សួរថា នែកាណា នាងឃើញតថាគតហើយ ខ្វាសអៀន ពួនយំធ្វើអ្វី ត្រានោះ មាតារបស់នាងក្រាបទូលកិរិយាដែលនាងធ្វើហើយឲ្យទ្រង់ជ្រាប ។ ពេលនោះ ព្រះសាស្តា ត្រាស់នឹងមាតារបស់នាងកាណាថា កាណាមាតា សាវ័កទាំងឡាយរបស់តថាគត កាន់យករបស់ដែលនាងឲ្យហើយ ឬមិនទាន់បានឲ្យ កាណាមាតាពោលថា បពិត្រព្រះអង្គ កាន់វត្ថុដែលខ្ញុំម្ចាស់ឲ្យហើយ ព្រះសាស្តាត្រាស់ថា សាវ័ករបស់តថាគតត្រាច់បិណ្ឌបាតដល់ទ្វារផ្ទះរបស់នាងហើយ កាន់យករបស់ដែលនាងឲ្យហើយ នឹងមានទោសអ្វី កើតដល់សាវ័កទាំងនោះ កាណាមាតាពោលថា បពិត្រព្រះអង្គ ទោសរបស់លោកម្ចាស់ទាំងឡាយ មិនមានទេ ទោសរបស់កូនស្រីរបស់ខ្ញុំម្ចាស់ប៉ុណ្ណោះមាន ព្រះសាស្តាត្រាស់នឹងនាងកាណាថា នែកាណា បានឮថា សាវ័ករបស់តថាគតត្រាច់បិណ្ឌបាត មកដល់ទ្វារផ្ទះនេះហើយ កាលបើដូច្នេះ មាតារបស់នាងបានឲ្យនំដល់សាវ័កទាំងនោះ ក្នុងរឿងនេះ ឈ្មោះថា ទោសនឹងមានដល់ពួកសាវ័កទាំងឡាយរបស់

តថាគតឬ នាងកាណាទូលថា បពិត្រព្រះអង្គ ទោសរបស់លោកម្ចាស់ទាំង-ទ្បាយ មិនមានទេ ខ្ញុំម្ចាស់ប៉ុណ្ណោះ ជាអ្នកមានទោស ។ នាងថ្វាយបង្គំព្រះសាស្តា សូមឲ្យទ្រង់អត់ទោសឲ្យហើយ ។ គ្រានោះ ព្រះសាស្តា បានត្រាស់អនុបុព្វីកថាដល់នាង នាងសម្រេចសោតាបត្តិផលហើយ ។

ព្រះសាស្តា ទ្រង់ក្រោកចាកអាសនៈហើយ កាលនឹងយាងទៅកាន់វិហារ បានយាងទៅតាមលានព្រះរាជវាំង ។ ព្រះរាជាទតឃើញហើយត្រាស់សួរថា នែអ្នក មើលនុ៎ះ ដូចព្រះសាស្តា រាជបុរសក៏ទូលថា បពិត្រព្រះអង្គ ពិតមែនហើយ ដូច្នេះហើយ ទើបបញ្ជូនទៅដោយព្រះតម្រាស់ថា ចូរអ្នកទៅក្រាបទូលភាពដែលខ្ញុំថ្វាយបង្គំ ហើយបានចូលទៅគាល់ព្រះសាស្តា ដែលប្រថាប់ឈរក្នុងលានព្រះរាជវាំង ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានហើយ ទូលសួរថា បពិត្រព្រះអង្គ ទ្រង់យាងទៅណា ព្រះសាស្តាត្រាស់ថា មហាបពិត្រ តថាគតទៅកាន់ផ្ទះកាណាមាតា ព្រះរាជាទូលថា បពិត្រព្រះអង្គ ទ្រង់យាងទៅព្រោះហេតុអ្វី ព្រះសាស្តាត្រាស់ថា បានឮថា នាងកាណាជេរបរិភាសភិក្ខុ តថាគតទៅ ព្រោះហេតុនោះ ព្រះរាជាទូលថា បពិត្រព្រះអង្គ ទ្រង់ធ្វើភាពដែលនាងមិនជេរហើយឬ ព្រះសាស្តាត្រាស់ថា មហាបពិត្រ តថាគតធ្វើនាងមិនឲ្យជាអ្នកជេរភិក្ខុហើយ នឹងឲ្យជាម្ចាស់របស់ទ្រព្យដែលជាលោកុត្តរហើយ ព្រះរាជាទូលថា ទ្រង់ធ្វើនាងឲ្យជាម្ចាស់ទ្រព្យ ដែលជាលោកុត្តរក៏ធ្វើទៅចុះ ឯខ្ញុំព្រះអង្គ នឹងធ្វើនាងឲ្យជាម្ចាស់របស់ទ្រព្យ ដែលជាលោកិយ ដូច្នេះហើយថ្វាយបង្គំព្រះសាស្តាយាងត្រឡប់ហើយ ទ្រង់បញ្ជូនយានធំដែលបិទបាំងទៅ

គ្រាស់ឲ្យហៅនាងកាណាមកហើយ តាក់តែងគ្រឿងអាភរណៈគ្រប់យ៉ាង ទ្រង់តាំងនាងក្នុងតំណែងជាធីតាច្បង គ្រាស់ថា អ្នកណាអាចចិញ្ចឹមកូនស្រីរបស់ខ្ញុំបាន បុគ្គលនោះ ចូរទទួលយកនាងចុះ ។

គ្រានោះ អមាត្យម្នាក់ ដែលជាអ្នកសម្រេចរាជកិច្ចគ្រប់យ៉ាងក្រាបទូលថា ទូលបង្គំនឹងចិញ្ចឹមធីតារបស់ទ្រង់ ដូច្នេះហើយ នាំនាងទៅកាន់ផ្ទះរបស់ខ្លួន ប្រគល់ភាពជាធំគ្រប់យ៉ាងឲ្យហើយ ពោលថា ចូរនាងធ្វើបុណ្យតាមគាប់ចិត្តចុះ ។

ចាប់តាំងអំពីកាលនោះមក នាងកាណាឲ្យបុរស ៤ នាក់ឃាមត្រង់ទ្វារ ក៏មិនបានកិក្ខុ និងកិក្ខុនីដែលខ្លួនគប្បីទំនុកបម្រុង ។ របស់គួរទំពា និងរបស់គួរបរិភោគ ដែលនាងកាណាត្រៀមត្រង់ទ្វារផ្ទះ ប្រៀបដូចជំនន់ទឹកធំ ។

ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោ ក្នុងកាលមុនព្រះថេរៈ ៤ រូប ធ្វើការក្តៅក្រហាយឲ្យដល់នាងកាណា នាងជាអ្នកក្តៅក្រហាយយ៉ាងនោះ អាស្រ័យព្រះសាស្តា បាននូវការដល់ព្រមដោយសទ្ធាហើយ ព្រះសាស្តាទ្រង់ធ្វើផ្ទះរបស់នាង ឲ្យជាទីដែលគួរចូលទៅរបស់ពួកភិក្ខុទៀត ឥឡូវនេះ សូម្បីនាងស្វែងរកភិក្ខុ ឬភិក្ខុនីទាំងឡាយ ដែលខ្លួនគប្បីទំនុកបម្រុងក៏មិនបានឱ ! ធម្មតាព្រះពុទ្ធទាំងឡាយ មានគុណអស្ចារ្យពិតហ្ន៎ ។

ព្រះសាស្តា យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាដូចម្តេចហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ កថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ

ចាស់ទាំងនោះ ធ្វើការក្តៅក្រហាយដល់នាងកាណា មិនមែនតែក្នុងឥឡូវនេះ ប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ពួកលោកធ្វើហើយដូចគ្នា ម៉្យាងទៀត តថាគត ធ្វើឲ្យនាងកាណា ធ្វើតាមពាក្យរបស់តថាគត មិនមែនតែក្នុងកាលឥឡូវនេះ ប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនតថាគតក៏ធ្វើហើយដូចគ្នា កាលពួកភិក្ខុប្រុជ្ឈានឹងស្តាប់សេចក្តីនោះ ទូលអារាធនាហើយ ទើបត្រាស់ពុទ្ធជាតកដោយពិស្តារថា

ព្រះសាស្តា ត្រាស់ថា ឆ្នាំមួយ បានកណ្តុរក្នុងទីណា ឆ្នាំជាគម្រប់ពីរ គម្រប់បី គម្រប់បួន រមែងកើតក្នុងទីនោះ ឆ្នាំរទាំងនោះ (ប្រហារ) នូវវន្ធនេះ ហើយដល់នូវសេចក្តីស្លាប់ ។

ហើយទ្រង់ប្រជុំជាតកថា ភិក្ខុចាស់ ៤ រូបក្នុងឥឡូវនេះ គឺជាឆ្នា ៤ ក្នុងកាលនោះ កណ្តុរជានាងកាណា ជាងកែវ គឺតថាគតនោះឯង ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នាងកាណា បានជាអ្នកមានចិត្តក្តៅក្រហាយ មានចិត្តល្អក់កករយ៉ាងនេះ តែបានជាអ្នកមានចិត្តផូរផង់ ដូចអន្ទង់ទឹកដែលមានទឹកថ្លា ព្រោះពាក្យរបស់តថាគត កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យថាបិ រហោទោ គម្ភីរោ វិប្បសន្នោ អនាវិលោ
ឯវំ ធម្មានិ សុត្វាន វិប្បសីទន្តិ បណ្ឌិតា ។

អន្ទង់ទឹកដែលជ្រៅ រមែងថ្លា មិនល្អក់យ៉ាងណា បណ្ឌិតទាំងឡាយ បើបានស្តាប់ធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់សួនយ៉ាងនោះ ។

សេចក្តីអធិប្បាយ

អន្ទង់ទឹកណា កាលចតុរង្គសេនាកំពុងឆ្លង រមែងមិនល្អក់កករ អន្ទង់ទឹកបែបនេះ ឈ្មោះថា **រហោ** *ក្នុងព្រះគាថានោះ ។*

នីលមហាសមុទ្រ ដែលមានជម្រៅ ៨៤០០០ យោជន៍ ដោយអាការទាំងពួង ឈ្មោះថា អន្ទង់ទឹក ពិតហើយ ទឹកក្នុងទីប្រមាណ ៤ ពាន់យោជន៍ ខាងក្រោមមហាសមុទ្រនោះ រមែងញាប់ញ័រព្រោះហ្វូងត្រី ទឹកក្នុងទីមានប្រមាណប៉ុណ្ណោះ គឺខាងលើ រមែងញាប់ញ័រព្រោះខ្យល់ ចំណែកទឹកដែលមានប្រមាណ ៤ ពាន់យោជន៍ត្រង់កណ្តាល មិនញាប់ញ័រតាំងនៅ នេះឈ្មោះថា អន្ទង់ទឹកជ្រៅ ។

បទថា **ធម្មានិ** *បានដល់ ធម្មទេសនាទាំងឡាយ ។ ព្រះដ៏មានព្រះភាគ ត្រាស់ពាក្យអធិប្បាយនេះថា អន្ទង់ទឹកនោះ ឈ្មោះថា ថ្លា ព្រោះជាទឹកមិនគួរឲ្យខ្ពើម ឈ្មោះថា មិនល្អក់ ព្រោះជាទឹកមិនញាប់ញ័រ យ៉ាងណា បណ្ឌិតទាំងឡាយ ស្តាប់ធម្មទេសនារបស់តថាគតហើយ ដល់នូវភាពជាបុគ្គលមានចិត្តប្រាសចាកឧបក្កិលេស ដោយអំណាចនៃមគ្គ មានសោតាបត្តិមគ្គជាដើម ឈ្មោះថា រមែងផូរផង់ ដូច្នោះ ចំណែកបុគ្គលដែលសម្រេចអរហត្តហើយ រមែងជាអ្នកផូរផង់ ដោយចំណែកមួយ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងមាតារបស់នាងកាណា ចប់

រឿង ភិក្ខុ ៥០០ រូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រោរព្ធភិក្ខុ ៥០០ រូប ត្រាស់ធម្មទេសនានេះថា **សព្វត្ត វេ សប្បុរិសា រាជន្តិ** ជាដើម ។

ធម្មទេនាតាំងឡើងក្នុងក្រុងវេរញ្ជា ។

សេចក្តីពិស្តារថា ក្នុងបឋមពោធិកាល ព្រះដ៏មានព្រះភាគយាងទៅកាន់ក្រុងវេរញ្ជា ដែលព្រាហ្មណ៍ឈ្មោះវេរញ្ជៈទូលនិមន្តហើយ ទើបទ្រង់ចាំវស្សាមួយអន្ទើដោយភិក្ខុ ៥០០ រូប ។ វេរញ្ជព្រាហ្មណ៍ត្រូវមារបណ្តាលចិត្តមិនឲ្យកើតសតិ ប្រោរព្ធដល់ព្រះសាស្តាត្រឹមតែមួយថ្ងៃ ។ កាលវេរញ្ជា ក្លាយជាស្រុកដែលមានអង្ករថ្លៃហើយ ។ ពួកភិក្ខុត្រាច់ទៅបិណ្ឌបាតពេញក្រុងវេរញ្ជាទាំងខាងក្នុងទាំងខាងក្រៅ កាលមិនបានបិណ្ឌបាត ទើបដល់នូវសេចក្តីលំបាក ។

ពួកឈ្មួញរទេះមកវៀបចំភិក្ខា មានអង្ករក្រហាមប្រហែលមួយទូកដៃៗ ដើម្បីភិក្ខុទាំងនោះ ។ ព្រះមហាមោគ្គល្លាន ឃើញភិក្ខុទាំងនោះលំបាក មានបំណងនឹងឲ្យភិក្ខុធាន់ក្រមរផែនដី និងបំណងឲ្យពួកភិក្ខុចូលទៅកាន់ឧត្តរកុរុទ្វីប ដើម្បីបិណ្ឌបាត ព្រះសាស្តាទ្រង់ហាមហើយ ។ ក្នុងមួយថ្ងៃ ពួកភិក្ខុមិនបានមានសេចក្តីតក់ស្លុតព្រោះប្រោរព្ធបិណ្ឌបាត ។ ភិក្ខុទាំងឡាយ រៀរការប្រព្រឹត្តដោយអំណាចការចង់បានហើយ ។

ព្រះសាស្តា ប្រថាប់ក្នុងក្រុងវេរញ្ជានោះ អស់ត្រីមាសហើយ ទ្រង់លាវេរញ្ជព្រាហ្មណ៍ មានសក្ការៈ និងការរាប់អានដែលព្រាហ្មណ៍នោះធ្វើហើយ

ទ្រង់ឲ្យព្រាហ្មណ៍តាំងនៅក្នុងសរណៈហើយ យាងចេញចាកក្រុងវេរញ្ជានោះ ចារិកទៅដោយលំដាប់ ។ សម័យមួយ ទ្រង់យាងដល់ក្រុងសាវត្ថី ប្រថាប់នៅក្នុងវត្តជេតពន អ្នកក្រុងសាវត្ថីធ្វើអាគន្តុកភត្តដល់ព្រះសាស្តាហើយ ។

ក្នុងកាលនោះ ពួកអ្នកស៊ីដែលប្រមាណ ៥០០ នាក់ អាស្រ័យពួកភិក្ខុដែលនៅខាងក្នុងវិហារនោះឯង ។ ពួកគេបរិភោគភោជនដ៏ប្រណីត ដែលសល់អំពីពួកភិក្ខុទាំងឆ្ងាយធាន់ហើយ ក៏ដេកលក់ ក្រោកឡើងហើយទៅកាន់ច្រាំងស៊ីង ស្រែកហ៊ោកញ្ជ្រៀវ លោតលេងប្រលែងគ្នា ប្រព្រឹត្តអនាចារប៉ុណ្ណោះទាំងខាងក្នុងវិហារ ទាំងខាងក្រៅវិហារ ។

ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ មើលចុះ ក្នុងពេលកើតទុព្ភិក្ខភ័យ ពួកអ្នកស៊ីដែលទាំងនេះ មិនបានសម្តែងវិការណាមួយក្នុងក្រុងវេរញ្ជា តែឥឡូវនេះ បរិភោគភោជនដ៏ប្រណីតបែបនេះហើយ សម្តែងអាការប្លែកៗ ជាអនេក ចំណែកពួកភិក្ខុជាអ្នកនៅស្ងៀមក្នុងក្រុងវេរញ្ជា ទោះក្នុងឥឡូវនេះ ក៏នាំគ្នានៅស្ងប់ស្ងៀមដូចគ្នា ។

ព្រះសាស្តាយាងទៅកាន់រោងធម្មសភាហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសន្ទនាគ្នាអំពីរឿងអ្វី កាលពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ រឿងឈ្មោះនេះ ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន អ្នកស៊ីដែលទាំងនេះ កើតក្នុងកំណើតលា ជាលា ៥០០ បានផឹកទឹកមានរសតិច ជាទឹកអាក្រក់ ដែលដល់នូវការរាប់ថា ទឹកចុង ព្រោះគេយកទឹកដែលច្របាច់ពីកាក ដែលត្រាំធ្វើទឹកចណ្ឌមានរសឆ្ងាញ់ ដែលសេះសន្ធពជាតិ

អាជានេយ្យ ៥០០ ផឹកហើយ ទើបត្រង់ដោយសំពត់សម្បកឆ្មៃចាស់ៗ ជារបស់ស្រវឹង ផ្អែម ក៏ស្រែកហ៊ោកញ្ជ្រៀវ កាលទ្រង់សម្តែងកិរិយារបស់លាទាំងនោះ ដែលព្រះពោធិសត្វជាព្រះរាជា ទ្រង់ស្តាប់សំឡេងរបស់លាទាំងនោះ ត្រាស់សួរហើយ បានក្រាបទូលព្រះរាជា ត្រាស់វាលោទកជាតកនេះដោយពិស្តារថា

ព្រះរាជាពារាណសីត្រាស់ថា សេចក្តីស្រវឹងកើតឡើងដល់ពួកលា ព្រោះផឹកទឹកដែលច្រោះដោយសម្បកក្រចៅ មានរសតិច ជារបស់ថោកទាប សេចក្តីស្រវឹងមិនកើតដល់ពួកសេះសិន្ធវៈ ព្រោះផឹកទឹកមានរសដ៏ឧត្តមនេះទេ ។

អមាត្យពោធិសត្វក្រាបទូលថា បពិត្រព្រះអង្គជាធំជាងជនសត្វដែលមានជាតិថោកទាប ផឹកទឹកមានរសតិចហើយ សត្វនោះ ត្រូវទឹកមានរសតិចពាល់ត្រូវហើយ រមែងស្រវឹង ចំណែកសត្វអ្នកនាំនូវធុរៈ នឹងមានមារយាទ កើតក្នុងត្រកូល (ដ៏ខ្ពស់) បានផឹកទឹកមានរសដ៏ប្រសើរ រមែងមិនស្រវឹងទេ ។

ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សប្បុរសរៀរសេចក្តីលោកហើយ រមែងជាអ្នកមិនមានវិការឡើយ ទាំងក្នុងពេលជួបនូវសេចក្តីសុខ ទាំងក្នុងពេលជួបនូវសេចក្តីទុក្ខយ៉ាងនេះ កាលទ្រង់បន្តអនុសន្ធិ បានត្រាស់ព្រះគាថានេះថា

សព្វត្ថ វេ សប្បុរិសា វជន្តិ ន កាមកាមា លបយន្តិ សន្តោ

សុខេន ផុដ្ឋា អថ វា ទុខេន ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ ។

ពួកសប្បុរស តែងលះ (ឆន្ទរាគៈ) ក្នុងធម៌ទាំងពួង ពួកលោកអ្នកស្ងប់ រមែងមិនរអែរអូវ ព្រោះសេចក្តីប្រាថ្នាក្នុងកាម ពួកបណ្ឌិត បើសេចក្តីសុខ ឬទុក្ខពាល់ត្រូវហើយ រមែងមិនសម្តែងអាការខ្សឹងខុះខ្សឿយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សព្ពត្ថ** *បានដល់ ក្នុងធម៌ទាំងអស់ ដោយធម៌ មានខន្ធជាដើម ។ បុរសល្អឈ្មោះថា* **សប្បុរិសោ ។**

បទថា **វជន្តិ** *សេចក្តីថា សប្បុរស កាលទាញឆន្ទរាគៈចេញហើយ អរហត្តមគ្គញ្ញាណ ឈ្មោះថា រមែងវៀរឆន្ទរាគៈ ។*

បទថា **ន កាមកាមា** *បានដល់ ដែលប្រាថ្នាកាម ម្យ៉ាងទៀត បានដល់ ព្រោះហេតុនៃកាម គឺព្រោះកាមជាហេតុ ។*

ពីរបទថា **លបយន្តិ សន្តោ** *សេចក្តីថា សប្បុរសទាំងឡាយ មានព្រះសម្ពុទ្ធជាដើម រមែងមិនរអែរអូវដោយខ្លួនឯងឡើយ ទាំងមិនញុំាងអ្នកដទៃឲ្យរអែរអូវព្រោះហេតុនៃកាម ។ ពិតហើយ ភិក្ខុពួកណាចូលទៅដើម្បីភិក្ខា តាំងនៅក្នុងឥច្ឆាចារ ពោលពាក្យជាដើមថា ឧបាសក បុត្រភរិយារបស់អ្នកសុខសប្បាយដែរឬទេ ឧបទ្រវៈណាមួយ ដោយអំណាចនៃរាជភ័យ និងចោរភ័យជាដើម មិនមានក្នុងសត្វជើង ២ និងជើង ៤ ទេឬ ភិក្ខុទាំងនោះ ឈ្មោះថា រមែងរអែរអូវឯង ។ កាលពោលយ៉ាងនោះហើយ និយាយឲ្យគេនិមន្តខ្លួនថា*

យ៉ាងនោះឯង ពួកខ្ញុំគ្រប់គ្នាមានសេចក្តីសុខសប្បាយ ឧបទ្រវៈណាមួយមិនមានឥឡូវនេះ ផ្ទះរបស់ពួកខ្ញុំមានជាយ និងទីកពោរពាស សូមនិមន្តលោកម្ចាស់នៅក្នុងទីនេះឯង ដូច្នេះ ឈ្មោះថា ឲ្យបុគ្គលជនៃវអែវអូវ ។ ចំណែកសប្បុរសទាំងឡាយ រមែងមិនធ្វើការនិយាយវអែវអូវទាំងពីរយ៉ាងនេះ ។

ពាក្យថា **សុខេន ដុដ្ឋា អថ វា ទុខេន** នេះ ឈ្មោះថា ជាទេសនាអធិប្បាយថា បណ្ឌិតទាំងឡាយដែលលោកធម៌ ៨ ពាល់ត្រូវហើយ រមែងមិនសម្តែងអាការឡើងចុះ ដោយអំណាចនៃភាពជាបុគ្គលត្រេកអរ និងភាពជាបុគ្គលខ្ជាសអៀន ឬដោយអំណាចនៃការពោលគុណ និងទោស ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ភិក្ខុ ៥០០ រូប ចប់

រឿង ព្រះថេរៈតាំងនៅក្នុងធម៌

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះធម្មកត្តារត្រាស់ព្រះធម្មទេសនានេះថា **ន អត្តហេតុ** ជាដើម ។

បានឮថា ឧបាសកម្នាក់ ក្នុងក្រុងសាវត្ថី គ្រប់គ្រងផ្ទះដោយធម៌ ។ ឧបាសកនោះ ជាអ្នកប្រាថ្នានឹងបួស ថ្ងៃមួយ អង្គុយសន្ទនាជល់ពាក្យប្រារព្ធ

សុខជាមួយភរិយា ទើបពោលថា នែនាង ខ្ញុំប្រាថ្នានឹងបួស ភរិយាអង្វរថា នែអ្នក បើដូច្នោះ សូមអ្នកបង្អង់សិន ទម្រាំខ្ញុំប្រសូតបុត្រក្នុងផ្ទៃសិនចុះ ។ គាត់រង់ចាំហើយ ក្នុងកាលដែលទារកដើរបាន ទើបលានាងម្តងទៀត កាលនាងអង្វរថា នែអ្នក សូមអ្នកបង្អង់សិន ទម្រាំក្មេងនេះចម្រើនវ័យចុះ ។ ទើបគាត់គិតថា ប្រយោជន៍អ្វីរបស់អញដោយស្រីនេះ ដែលអញលាហើយ ឬមិនលា អញនឹងធ្វើការរលាស់ចេញចាកទុក្ខដល់ខ្លួន ដូច្នេះហើយ ចេញទៅបួស ។ លោករៀនកម្មដ្ឋាន ព្យាយាមញុំាងកិច្ចរបស់បព្វជិត របស់ខ្លួនឲ្យសម្រេចហើយ ទើបត្រឡប់មកក្រុងសាវត្ថីវិញ ដើម្បីសួរសុខទុក្ខបុត្រ និងភរិយាទាំងនោះ ហើយបានសម្តែងធម្មកថាដល់បុត្រ ។

សូម្បីកូននោះក៏ចេញបួសហើយ កាលបួសហើយមិនយូរប៉ុន្មានក៏សម្រេចអរហត្ត ។ ភរិយាអំពីមុនរបស់កិកុគិតថា អញនៅគ្រប់គ្រងផ្ទះដើម្បីប្រយោជន៍ដល់អ្នកណា ជនទាំងពីរនាក់នោះក៏បួសហើយ ឥឡូវនេះ ប្រយោជន៍អ្វីរបស់អញដោយការគ្រប់គ្រងផ្ទះ អញនឹងបួស ហើយទើបចេញទៅបួសក្នុងសម្នាក់កិកុនី កាលបួសហើយ មិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត ។

ថ្ងៃមួយ ពួកកិកុសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ធម្មិក-ឧបាសកចេញបួសសម្រេចអរហត្តហើយ បានជាទីពឹងដល់កូនផង ភរិយាផងក៏ព្រោះភាពដែលខ្លួនតាំងនៅក្នុងធម៌ ។

ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលពួកភិក្ខុក្រាបទូលថា

ដោយរឿងឈ្មោះនេះ ព្រះអង្គ ហើយទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាបណ្ឌិត មិនគប្បីប្រាថ្នាសេចក្តីសម្រេចព្រោះហេតុនៃខ្លួន និងមិនគប្បីប្រាថ្នាការសម្រេច ព្រោះហេតុនៃអ្នកដទៃឡើយ តែគប្បីជាអ្នកតាំងនៅក្នុងធម៌ មានធម៌ជាទីពឹងដោយពិត កាលទ្រង់បន្តអនុសន្ធិ ទើបត្រាស់ព្រះគាថានេះថា

ន អត្តហេតុ ន បរស្ស ហេតុ ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ
ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ ស សីលវា បញ្ញវាធម្មិកោ សិយា ។

បណ្ឌិត មិនគួរធ្វើអាក្រក់ ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់ ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នាសមិទ្ធិដើម្បីខ្លួន ដោយហេតុមិនមែនជាធម៌ឡើយ លោកគួរជាអ្នកមានសីល មានប្រាជ្ញាប្រកបដោយធម៌ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ន អត្តហេតុ** *សេចក្តីថា ធម្មតាបណ្ឌិតរមែងមិនធ្វើបាប ព្រោះហេតុនៃខ្លួន ឬព្រោះហេតុនៃបុគ្គលដទៃ ។*

បទថា **ន បុត្តមិច្ឆេ** *សេចក្តីថា បណ្ឌិតមិនគប្បីប្រាថ្នាកូន ឬទ្រព្យ ឬដែនដោយកម្មដ៏លាមក បណ្ឌិតកាលប្រាថ្នាវត្ថុទាំងនោះ រមែងមិនធ្វើកម្មលាមកឡើយ ។*

បទថា **សមិទ្ធិមត្តនោ** *សេចក្តីថា បណ្ឌិត មិនគប្បីប្រាថ្នាសូម្បីការសម្រេចដើម្បីខ្លួនដោយមិនជាធម៌ អធិប្បាយថា បណ្ឌិត រមែងមិនធ្វើបាប*

ព្រោះហេតុនៃសេចក្តីសម្រេច ។

បទថា **ស សីលវា** *សេចក្តីថា បុគ្គលបែបនេះ គប្បីជាអ្នកមានសីល មានបញ្ញា តាំងនៅក្នុងធម៌ អធិប្បាយថា មិនគប្បីជាបុគ្គលដទៃ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះថេរៈតាំងនៅក្នុងធម៌ ចប់

រឿង ការស្តាប់ធម៌

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការស្តាប់ធម៌ ត្រាស់ព្រះធម្មទេសនានេះថា **អប្បកា តេ មនុស្សេសុ** *ជាដើម ។*

បានឮមកថា ពួកមនុស្សដែលនៅតាមវិថីមួយជាមួយគ្នា ក្នុងក្រុងសាវត្ថី ជាអ្នកព្រមព្រៀងគ្នា ថ្វាយទានរួមគ្នាជាគណៈហើយ ក៏ឲ្យធ្វើការស្តាប់ធម៌មួយយប់ទល់ភ្លឺ តែមិនអាចស្តាប់ធម៌ទល់ភ្លឺ បុគ្គលពួកខ្លះ ជាអ្នកអាស្រ័យការត្រេកអរក្នុងកាម ក៏ត្រឡប់ទៅផ្ទះមុនគេ ពួកខ្លះ ជាអ្នកអាស្រ័យទោសៈទៅហើយ ។ តែពួកខ្លះ ដែលងោកងុយពេញទំហឹង អង្គុយងក់ក្នុងទីនោះឯង មិនអាចស្តាប់បាន ស្អែកឡើង ពួកភិក្ខុញុំាងពាក្យឲ្យតាំងឡើងក្នុងរោងធម្មសភា ដល់រឿងនោះ ។ ព្រះសាស្តាទ្រង់យាងមក ត្រាស់សួរថា ម្នាលភិក្ខុ

ទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាសត្វទាំងនេះអាស្រ័យភពហើយ ជាប់ជំពាក់ក្នុងភពនោះឯង ដោយច្រើន បុគ្គលដែលស្គាប់មានចំនួនតិច កាលទ្រង់បន្តអនុសន្ធិ បានត្រាស់ព្រះគាថានេះថា

អប្បកា តេ មនុស្សេសុ យេ ជនា បារគាមិនោ
អថាយំ ឥតរា បជា តីរមេវានុធាវតិ ។
យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ
តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ។

បណ្តាមនុស្សទាំងឡាយ ពួកជនណាដែលឆ្លងដល់ត្រើយ គឺព្រះនិព្វាន ពួកជននោះ មានប្រមាណតិច ចំណែកពួកសត្វក្រៅនេះ រមែងសុះទៅកាន់ត្រើយ (គឺសក្កាយទិដ្ឋិ)។ ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលព្រះតថាគត ទ្រង់សម្តែងទុកហើយដោយប្រពៃ ជនទាំងនោះនឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបាន ហើយដល់នូវព្រះនិព្វាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បកា** *គឺបន្តិចបន្តួច បានដល់ មិនច្រើន ។ បទថា* **បារគាមិនោ** *គឺសម្រេចព្រះនិព្វាន ។ បានព្រះគាថាថា* **អថាយំ ឥតរា**

បជា *សេចក្តីថា ចំណែកប្រជាជ៏សេសនេះ រមែងសុះទៅកាន់ត្រើយ គឺ សក្កាយទិដ្ឋិនេះមានច្រើន ។*

បទថា **សម្មទក្ខាតេ** *គឺត្រាស់ដោយប្រពៃ បានដល់ ត្រាស់ត្រឹមត្រូវ ។ បទថា* **ធម្មេ** *គឺក្នុងធម្មទេសនា ។ បទថា* **ធម្មានុវត្តិនោ** *សេចក្តីថា ប្រព្រឹត្ត សមគួរដល់ធម៌ ដោយអំណាចនៃការស្តាប់ធម៌នោះហើយ បំពេញបដិបទា សមគួរដល់ធម៌នោះហើយ ធ្វើមគ្គផលឲ្យជាក់ច្បាស់ ។*

បទថា **ចារមេស្សន្តិ** *សេចក្តីថា ជនទាំងនោះ គឺបែបនោះ នឹងដល់នូវ ត្រើយ គឺព្រះនិព្វាន ។ បទថា* **មច្ចុធេយ្យំ** *បានដល់ វដ្តៈដែលប្រព្រឹត្តទៅ ក្នុងភូមិ ដែលជាទីនៅអាស្រ័យរបស់មច្ចុ ពោល គឺកិលេសមារ ។*

បទថា **សុទុត្តរំ** *សេចក្តីថា ជនទាំងឡាយណាប្រព្រឹត្តធម៌សមគួរដល់ ធម៌ ជនទាំងនោះ កន្ទង គឺរំលងអន្ទាក់មារដែលធ្លងបានលំបាក គឺឈាន កន្ទងបានលំបាកហើយនោះ នឹងដល់នូវត្រើយ គឺព្រះនិព្វាន ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ការស្តាប់ធម៌ ចប់

រឿង អាគន្តុកភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអាគន្តុកភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា **កណ្ហំ ធម្មំ វិប្បហាយ** ជាដើម ។

បានឮមកថា ភិក្ខុប្រមាណ ៥០០ រូប ចាំវស្សានៅក្នុងដែនកោសល ចេញវស្សាហើយ ប្រឹក្សាគ្នាថានឹងគាល់ព្រះសាស្តា ទើបទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តាហើយ គង់នៅក្នុងទីបំផុតក្នុងទីមួយកន្លែង ព្រះសាស្តា ទ្រង់ពិចារណាធម៌ ដែលជាបដិបក្ខដល់ចរិយារបស់ពួកលោក កាលទ្រង់សម្តែងធម៌ បានត្រាស់គាថាទាំងនេះថា

កណ្ហំ ធម្មំ វិប្បហាយ សុក្កំ ភាវេថ បណ្ឌិតោ
ឱកា អនោកមាគម្ម វិវេកេ យត្ថ ទូរមំ ។
តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ
បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ ។
យេសំ សម្ពោធិយង្គេសុ សម្មា ចិត្តំ សុភាវិតំ
អាទានបដិនិស្សគ្គេ អនុចាយាយ យេ រតា
ខីណាសវា ជុតិមន្តោ តេ លោកេ បរិនិព្វុតា ។

ជនទាំងឡាយណា ប្រព្រឹត្តក្នុងធម៌ ដែលព្រះតថាគត ទ្រង់សម្តែងទុកហើយដោយប្រពៃ ជនទាំងនោះ នឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបាន ហើយដល់នូវព្រះនិព្វាន ។ បណ្ឌិតគួរលះបង់ធម៌ខ្មៅចេញ ញុំាងធម៌ស

ឲ្យចម្រើនឡើង (ដោយវិធី) ចេញចាកអាលយ គឺ កាមគុណ ហើយឈមទៅរកព្រះនិព្វាន ជាធម្មជាតមិន មានអាលយ គប្បីលះបង់កាមទាំង៣ឲ្យចេញ ជាអ្នក មិនមានកង្វល់ ប្រាថ្នានូវសេចក្តីត្រេកអរក្នុងវិវេក ដែល ពួកសត្វត្រេកអរបានដោយក្រនោះ បណ្ឌិតគួរញុាំងខ្លួន ឲ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត ។ ចិត្តដែលបណ្ឌិត ទាំង៣ឲ្យបានអប់រំល្អហើយ ជាអង្គនៃធម៌ ជាគ្រឿង ត្រាស់ដឹងទាំង៣ឲ្យ ឬបណ្ឌិតទាំង៣ឲ្យណា មិន ប្រកាន់មាំ ត្រេកអរតែក្នុងការលះនូវសេចក្តីប្រកាន់មាំ បណ្ឌិតទាំង៣ឲ្យនោះ រមែងជាអ្នកអស់អាសវៈ មាន សេចក្តីរុងរឿង បរិនិព្វានក្នុងលោក ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **កណ្ហំ ធម្មំ** សេចក្តីថា លះ គឺលះ អកុសលធម៌ មានកាយទុច្ចរិតជាដើម ។

ពីរបទថា **សុក្កំ ភាវេថ** សេចក្តីថា ភិក្ខុដែលជាបណ្ឌិតគួរចម្រើនធម៌ ស មានកាយសុចរិតជាដើម តាំងអំពីចេញបួស រហូតដល់អហរត្តមគ្គ ។ ចម្រើនដូចម្តេច គឺចេញចាកអាលយ ប្រារព្ធធម៌ដែលមិនមានអាលយ ។

អធិប្បាយថា ធម៌ជាហេតុឲ្យអាលយ ត្រាស់ហៅថា **ចក្ក** ធម៌ជាហេតុ ឲ្យមិនមានអាលយ ត្រាស់ហៅថា **អនោក** បណ្ឌិតចេញចាកធម៌ ជាហេតុ

ឲ្យអាលយ័ហើយ ឧទ្ទិស គឺប្រារព្ធព្រះនិព្វាន ពោល គឺធម៌ជាហេតុមិនមាន អាលយ័ កាលប្រាថ្នាព្រះនិព្វាននោះ គួរចម្រើនធម៌ស ។

បាទព្រះគាថាថា **តត្រាភិរតិមិច្ឆេយ្យ** *សេចក្តីថា គប្បីប្រាថ្នាសេចក្តីត្រេកអរក្រៃលែងក្នុងវិវេក ដែលរាប់ថា ជាធម៌មិនមានអាលយ័ គឺព្រះនិព្វាន ដែលសត្វទាំងនោះ អភិរម្យបានដោយលំបាក ។*

ពីរបទថា **ហិត្វា កាមេ** *សេចក្តីថា លះវត្ថុកាម និងកិលេសកាម ហើយ ជាអ្នកអស់កង្វល់ គប្បីប្រាថ្នាសេចក្តីត្រេកអរក្រៃលែងក្នុងវិវេក ។*

បទថា **ចិត្តក្ខេសេហិ** *សេចក្តីថា គប្បីធ្វើខ្លួនឲ្យសផ្សវផង់ គឺឲ្យបរិសុទ្ធ ចាកនីវរណៈ ៥ ។*

បទថា **សម្ពោធិយង្គេសុ** *បានដល់ ក្នុងធម៌ជាគ្រឿងត្រាស់ដឹង ។*

បាទព្រះគាថាថា **សម្មា ចិត្តំ សុភាវិតំ** *សេចក្តីថា ជនទាំងឡាយណា អប់រំ គឺចម្រើនចិត្តដោយល្អហើយ តាមហេតុ គឺតាមនយ ។*

បាទព្រះគាថាថា **អាទានបដិនិស្សគ្គេ** *សេចក្តីថា ការប្រកាន់ ត្រាស់ហៅថា ការប្រកាន់មាំ ជនទាំងឡាយណា មិនប្រកាន់មាំនូវវត្ថុណាមួយ ដោយឧបាទាន ៤ ត្រេកអរហើយក្នុងការមិនប្រកាន់មាំ ពោល គឺការលះបង់នូវការប្រកាន់នោះ ។*

បទថា **ឋិតត្តោ** *សេចក្តីថា ជាអ្នកមានអានុភាព គឺជាអ្នកញុំាងធម៌មានខន្ធជាដើមឲ្យរុងរឿង ហើយតាំងមាំ ដោយការរុងរឿង គឺញាណដែលទាក់ទងដោយអរហត្តមគ្គ ។ពីរបទថា* **តេ លោកេ** *ជាដើម សេចក្តីថា ជន*

ទាំងនោះ ឈ្មោះថា រលត់ឥតសេសសល់ហើយ ក្នុងខន្ធាទិលោកនេះ គឺ បរិនិព្វានហើយ ដោយបរិនិព្វាន ២ យ៉ាង គឺដោយសឧបាទិសេសបរិនិព្វាន ព្រោះកិលេសវដ្តដែលខ្ជួនឲ្យអស់ទៅហើយ តាំងអំពីពេលសម្រេចអរហត្ត និងដោយអនុបាទិសេសបរិនិព្វាន ព្រោះខន្ធវដ្តដែលខ្ជួនឲ្យអស់ទៅហើយ ដោយរម្ងាប់ចរិមចិត្ត គឺដល់នូវការមិនមានបញ្ញត្តិ ដូចប្រទីបមិនមានកំញ្ចម ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ៗ

រឿងអាគន្តុកភិក្ខុ ចប់

បណ្ឌិតវគ្គ ចប់

វគ្គទី ៦ ចប់

សុត្តន្តបិដក

ធម្មបទគាថា អរហន្តវគ្គទី ៧

[១៧] សេចក្តីក្តៅក្រហាយ រមែងមិនមានដល់លោកអ្នក មានផ្លូវ ឆ្ងាយដើរដល់ហើយ មិនមានសេចក្តីសោក រួចស្រឡះចាកធម៌ទាំងពួង (មាន ខន្ធជាដើម) មានកិលេសជាគ្រឿងចាក់ស្រេះទាំងពួង លះបង់ហើយ ។

ព្រះខីណាស្រពនទាំងឡាយ មានស្មារតី រមែងខ្វល់ខ្វាយ រមែងត្រេកអរ ក្នុងទីនៅអាស្រ័យ លោកលះបង់ចោលស្រឡះ នូវអាលយទាំងអស់ ដូច ហង្សលះបង់ពួកហើរទៅ ដូច្នោះ ។ ពួកជនណា មិនមានសេចក្តីសន្សំ ពួក ជនណា កំណត់ដឹងភោជនហើយ ជនណាមានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិតវិមោក្ខ ជាគោចរ គតិ គឺដំណើរបស់ពួកជននោះៗ គេកម្រ ដឹងបាន ដូចដំណើរនៃពួកសត្វស្ថាបព្ធដ៏អាកាស ដូច្នោះ ។

ជនណា អស់អាសវៈហើយ ទាំងមិនអាស្រ័យ (តណ្ហា និងទិដ្ឋិ) ក្នុងអាហារ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិត-វិមោក្ខ ជាគោចរ ដំណើរបស់ជននោះ គេកម្រដឹងបាន ដូចដំណើរនៃពួក សត្វស្ថាបព្ធដ៏អាកាស ដូច្នោះ ។

ឥន្ទ្រិយទាំងឡាយ របស់អ្នកណា ដល់នូវការស្ងប់រម្ងាប់ ដូចសេះ ដែលនាយសារថី ហ្វឹកហ្វឺនរាបហើយ សូម្បីទេវតា និងមនុស្សទាំងឡាយក៏ ស្រឡាញ់អ្នកនោះឯង ដែលមានមានះលះបង់ហើយ មិនមានអាសវៈ ជា បុគ្គលមានចិត្តនឹងធឹង មិនញាប់ញ័រ ។

កិក្ខុមានចិត្តដូចផែនដី មិនក្រោធ មានវត្តល្អ មានចិត្តនឹងធឹងដូចសសរគោល មានចិត្តថ្លា ដូចអន្ទង់ប្រាសចាកកក់ សង្ឃរទាំងឡាយ របស់កិក្ខុបែបនោះ រមែងមិនមាន ។

ចិត្តស្ងប់ វាចាស្ងប់ និងកាយកម្មស្ងប់ រមែងមានដល់លោក ដែលដឹងដោយប្រពៃ ផុតស្រឡះ (ចាករាគាទិក្កិលេស) ជាអ្នកស្ងប់រម្ងាប់ជូរច្នោះ ។

នរជនណា មិនជឿអ្នកដទៃផង ស្គាល់ព្រះនិព្វានផង កាត់នូវគ្រឿងតគឺវដ្ដៈផង មានឱកាសកម្ចាត់បង់ហើយផង មានសេចក្ដីប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះ ជាឧត្តមបុរស ។

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្ដី ព្រៃក្ដី ទីទាបក្ដី ទីទួលក្ដី ទីនោះឯង ជាភូមិគួរត្រេកអរ ។

ជន (អ្នកស្វែងរកកាម) រមែងមិនត្រេកអរ ក្នុងព្រៃដែលគួររីករាយទេ ព្រះខីណាស្រពដែលមានរាគៈទៅប្រាសហើយ ទើបត្រេកអរក្នុងព្រៃនោះ ព្រោះលោកជាអ្នកមិនស្វែងរកកាម ។

អរហន្តវគ្គទី ៧ ចប់

អដ្ឋកថា

អរហន្តវគ្គទី ៧

រឿង ពេទ្យជីវក

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងចម្ការស្វាយរបស់ពេទ្យជីវក ទ្រង់ប្រារព្ធបញ្ហាដែលពេទ្យជីវកទូលសួរហើយ ត្រាស់ព្រះធម្មទេសនានេះថា **គតទ្ធិនោ** *ជាដើម ។ រឿងពេទ្យជីវក លោកឲ្យពិស្តារក្នុងខន្ធកៈហើយ ។*

សេចក្តីពិស្តារថា សម័យមួយ ទេវទត្តជាអ្នករួមគំនិតនឹងព្រះបាទអជាតសត្តុ ឡើងកាន់ភ្នំគិជ្ឈកូដ មានចិត្តប្រទូស្ត គិតថា អញនឹងផ្តាច់ព្រះជន្មព្រះសាស្តា ទើបប្រមៀលថ្មចុះ កំពូលភ្នំពីរទទួលថ្មនោះ ។ បំណែកថ្មបែកចេញអំពីថ្មនោះ ខ្ចាតទៅចំព្រះបាទារបស់ព្រះដ៏មានព្រះភាគ ញាំងព្រះលោហិតឲ្យពុះពងហើយ ។ វេទនាដ៏ខ្លាំងក្លាប្រព្រឹត្តទៅហើយ ។

ភិក្ខុទាំងឡាយ នាំព្រះសាស្តាទៅកាន់ឧទ្យានមទ្ទកុច្ឆិ[1] ។ ព្រះសាស្តាមានបំណងនឹងយាងចេញអំពីឧទ្យានមទ្ទកុច្ឆិនោះ ទៅកាន់ចម្ការស្វាយរបស់ពេទ្យជីវក ទើបត្រាស់ថា អ្នកទាំងឡាយ ចូរនាំតថាគតទៅកាន់ចម្ការស្វាយ

១- ឧទ្យានរំលូតកូន បានឮថា ព្រះនាងវេទេហីព្យាយាមរំលូតព្រះបាទអជាតសត្តុក្នុងឧទ្យាននេះ ។

របស់ពេទ្យជីវកនោះ ។ ពួកភិក្ខុបាននាំព្រះដ៏មានព្រះភាគ ទៅកាន់ចម្ការស្វាយរបស់ពេទ្យជីវកហើយ ។

ពេទ្យជីវកជ្រាបរឿងនោះ ទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយកេសជ្ជៈដើម្បីប្រយោជន៍ដល់ការផ្សះដំបៅ រុំមុខរបួសស្រេចហើយ បានក្រាបទូលពាក្យនេះដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គធ្វើកេសជ្ជៈដល់មនុស្សម្នាក់ខាងក្នុងព្រះនគរ ខ្ញុំព្រះអង្គនឹងទៅកាន់សម្នាក់របស់មនុស្សនោះហើយនឹងត្រឡប់មកគាល់វិញ សូមទ្រង់តាំងនៅដោយនិយាម ដែលខ្ញុំព្រះអង្គរុំនោះឯង ទម្រាំខ្ញុំព្រះអង្គត្រឡប់មក ។

ពេទ្យជីវក ទៅធ្វើកិច្ចដែលគួរធ្វើដល់បុរសនោះហើយ ត្រឡប់មកក្នុងកាលដែលគេបិទទ្វារ ។ ពេលនោះ គាត់មានបរិវិតក្កយ៉ាងនេះថា ស៊ីយហ្នឹ អញធ្វើកម្មធ្ងន់ហើយ ដែលអញថ្វាយកេសជ្ជៈដ៏ចាស់ រុំរបួសត្រង់ព្រះបាទរបស់ព្រះតថាគតដូចមនុស្សសាមញ្ញ ពេលនេះ ជាពេលដែលត្រូវស្រាយរបួសនោះ បើរបួសនោះមិនបានស្រាយ ការក្តៅក្នុងព្រះសរីរៈរបស់ព្រះដ៏មានព្រះភាគ នឹងតាំងឡើងមួយយប់ទល់ភ្លឺ ។

ខណៈនោះ ព្រះសាស្តា ត្រាស់ហៅព្រះអានន្ទត្ថេរមកគាល់ ត្រាស់ថា ម្នាលអានន្ទ ពេទ្យជីវកមកក្នុងពេលល្ងាចមិនទាន់ទ្វារ ជីវកគិតថា ពេលនេះជាពេលស្រាយរបួស ចូរអ្នកស្រាយរបួសនោះ ព្រះថេរៈស្រាយហើយដំបៅក៏ជាដូចដើម ដូចក្រមរឈើជ្រុះអំពីដើមឈើ ។

ពេទ្យជីវក រួតរះមកកាន់សម្នាក់ព្រះសាស្តា ខាងក្នុងអរុណនោះឯង

ទូលសួរថា បពិត្រព្រះអង្គ ការក្តៅក្រហាយកើតក្នុងព្រះសរីរៈរបស់ព្រះអង្គ ដែរឬ ព្រះសាស្តាត្រាស់ថា ជីវក ការក្តៅក្រហាយទាំងពួងរបស់តថាគត ស្ងប់រម្ងាប់ហើយ ត្រង់គល់ពោធិព្រឹក្សនោះឯង ដូច្នេះហើយ កាលទ្រង់បន្ត អនុសន្ធិ ទើបត្រាស់ព្រះគាថានេះថា

គតទ្ធិនោ វិសោកស្ស វិប្បមុត្តស្ស សព្វធិ
សព្វគន្ថប្បហីនស្ស បរិឡាហោ ន វិជ្ជតិ ។

សេចក្តីក្តៅក្រហាយ រមែងមិនមានដល់លោកអ្នកមានផ្លូវឆ្ងាយដើរដល់ហើយ មិនមានសេចក្តីសោក រួចស្រឡះចាកធម៌ទាំងពួង (មានខន្ធជាដើម) មាន កិលេសជាគ្រឿងចាក់ស្រែះទាំងពួង លះបង់ហើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **គតទ្ធិនោ** *បានដល់ ដែលមានផ្លូវឆ្ងាយដល់ហើយ ។ ផ្លូវឆ្ងាយមានពីរយ៉ាង ផ្លូវឆ្ងាយ គឺកន្តារ ១ ផ្លូវឆ្ងាយ គឺវដ្តៈ ១ ។ បណ្តាផ្លូវឆ្ងាយពីរយ៉ាងនោះ បុគ្គលដើរផ្លូវកន្តារ មិនទាន់ដល់ទីដែលខ្លួនប្រាថ្នាដរាបណា ក៏ឈ្មោះថា ជាអ្នកដើរផ្លូវឆ្ងាយរឿយៗ ដរាបនោះ តែកាលផ្លូវឆ្ងាយនោះ ដែលបុគ្គលនោះចូលដល់ហើយ រមែងជាបុគ្គល ឈ្មោះថា មានផ្លូវឆ្ងាយដល់ហើយ ចំណែកសត្វទាំងឡាយ ដែលដើរក្នុងផ្លូវវដ្តៈ ខ្លួននៅក្នុងវដ្តៈដរាបណា ក៏ឈ្មោះថា ជាអ្នកដើរផ្លូវឆ្ងាយរឿយៗ ទៅដរាបនោះ ។ មានពាក្យសួរជ្រៀតចូលមកថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភាពដែលវដ្តៈ*

ដែលខ្លួនមិនទាន់លះបាន ។ ព្រះអរិយបុគ្គលទាំង៤ប្បាយ មានព្រះសោតាបន្ន ជាដើម ក៏ឈ្មោះថា ដើរផ្លូវឆ្ងាយដូចគ្នា ចំណែកព្រះខីណាស្រព ញុំាងវដ្ដៈ ឲ្យអស់ទៅបានហើយ តាំងនៅ រមែងជាបុគ្គល ឈ្មោះថា មានផ្លូវឆ្ងាយដល់ហើយ ។ ដល់ព្រះខីណាស្រពដែលមានផ្លូវឆ្ងាយ ដល់ហើយនោះ ។

បទថា **វិសោកស្ស** *គឺឈ្មោះថាជាអ្នកមិនមានសេចក្ដីសោក ព្រោះភាព ដែលសេចក្ដីសោក មានវដ្ដៈជាមូលទៅប្រាសហើយ ។*

បាទព្រះគាថាថា **វិប្បមុត្តស្ស សព្វធិ** *គឺរួចផុតហើយក្នុងធម៌ មានខន្ធ ទាំងពួងជាដើម ។*

បាទព្រះគាថាថា **សព្វគន្ថប្បហីនស្ស** *គឺឈ្មោះថា ជាអ្នកលះកិលេស ជាគ្រឿងរួបរឹតទាំងពួងបាន ព្រោះភាពដែលកិលេសជាគ្រឿងរួបរឹត ៤ យ៉ាង ដែលខ្លួនលះបានហើយ ។*

បាទព្រះគាថាថា **បរិឡាហោ ន វិជ្ជតិ** *សេចក្ដីថា ការក្ដៅក្រហាយ មានពីរយ៉ាង គឺក្ដៅក្រហាយប្រព្រឹត្តទៅតាមកាយ ១ ក្ដៅក្រហាយប្រព្រឹត្តទៅ ផ្លូវចិត្ត ១ ។ បណ្ដាការក្ដៅក្រហាយពីរយ៉ាងនោះ ការក្ដៅក្រហាយប្រព្រឹត្ត ទៅតាមកាយ ដែលកើតឡើងដល់ព្រះខីណាស្រព ដោយអំណាចនៃផស្សៈ មានវេទនា និងក្ដៅជាដើម មិនទាន់រលត់ឡើយ ពេទ្យជីវកទូលសួរសំដៅដល់ ការក្ដៅក្រហាយ ដែលប្រព្រឹត្តទៅតាមកាយនោះ ។ តែព្រះសាស្ដា ទ្រង់បង្ហើសព្រះធម្មទេសនា ដោយអំណាចនៃការក្ដៅក្រហាយ ដែលប្រព្រឹត្តទៅ តាមផ្លូវចិត្ត ព្រោះភាពដែលទ្រង់ជាអ្នកឈ្វាសក្នុងទេសនាវិធី ព្រោះភាពដែល*

ទ្រង់ជាព្រះធម្មរាជា ទើបត្រាស់ថា ជីវក ដោយបរមត្ត ការក្តៅក្រហាយ រមែងមិនមានដល់ព្រះខីណាស្រព ដែលជាអ្នកឃើញបែបនោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ពេទ្យជីវក ចប់

រឿង ព្រះមហាកស្សបត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធព្រះមហាកស្សបត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ឧយ្យុញ្ជន្តិ** *ជាដើម ។*

សេចក្តីពិស្តារថា សម័យមួយ ព្រះសាស្តាទ្រង់ចាំវស្សានៅក្នុងក្រុងរាជគ្រឹះ ទ្រង់ត្រាស់ដល់ភិក្ខុទាំងឡាយថា ក្នុងកាលកន្លងទៅកន្លះខែ តថាគតនឹងទៅកាន់ទីចារិក ។

បានឮថា ការត្រាស់ដល់ភិក្ខុទាំងឡាយថា ឥឡូវនេះ នឹងចៀសទៅកាន់ទីចារិក ដោយកាលកន្លងទៅកន្លះខែដូច្នេះ ដោយទ្រង់បំណងថា ភិក្ខុទាំងឡាយនឹងធ្វើកិច្ចផ្សេងៗ មានការអប់បាត្រ និងជ្រលក់ចីវរជាដើមរបស់ខ្លួនហើយនឹងទៅតាមសប្បាយដោយអាការយ៉ាងនេះ នេះជាទំនៀមរបស់ព្រះពុទ្ធទាំងឡាយ ដែលមានបំណងចារិកទៅ មួយអន្លើដោយពួកភិក្ខុ ។ កាលភិក្ខុទាំង-

ឡាយកំពុងធ្វើកិច្ចផ្សេងៗ មានការអប់ជ្រាលដើម ព្រះមហាកស្សបត្ថេរក៏បោកចីវរទាំងឡាយហើយ ។

ពួកភិក្ខុលើកទោសថា ព្រោះហេតុអ្វី ទើបព្រះថេរៈបោកចីវរក្នុងព្រះនគរនេះ ទាំងខាងក្នុង និងខាងក្រៅ មានមនុស្សអាស្រ័យនៅ ១៨ កោដិ បណ្តាមនុស្សទាំងនោះ ពួកណាមិនជាញាតិរបស់ព្រះថេរៈ មនុស្សពួកនោះជាឧបដ្ឋាក មនុស្សពួកណាមិនជាឧបដ្ឋាក មនុស្សពួកនោះជាញាតិ ជនទាំងនោះ រមែងធ្វើការរាប់អាន និងធ្វើសក្ការៈដល់ព្រះថេរៈដោយបច្ច័យទាំង ៤ ព្រះថេរៈនោះ នឹងលះឧបការៈមានប្រមាណប៉ុណ្ណោះ ទៅក្នុងទីណាបាន បើគប្បីទៅបាន ក៏មិនទៅហួសអំពីញាតិឈ្មោះមាបមាន ។

បានឮមកថា ព្រះសាស្តាយាងដល់ញាតិណាហើយ រមែងត្រាស់ប្រាប់ភិក្ខុទាំងឡាយដែលគួរទ្រង់ឲ្យត្រឡប់ថា ចូរអ្នកទាំងឡាយត្រឡប់ត្រឹមនេះ កុំប្រមាទ ញាតិនោះសត្វលោកហៅថា ញាតិមាបមានៈ ពាក្យនុ៎ះ ភិក្ខុទាំងឡាយពោលសំដៅយកញាតិមាបមានៈនោះ ។

ព្រះសាស្តាទ្រង់យាងចៀសចេញទៅកាន់ទីចារិក ទ្រង់ត្រិះរិះបណ្តើរថា ក្នុងនគរទាំងខាងក្នុងទាំងខាងក្រៅ មានមនុស្ស ១៨ កោដិ ដែលភិក្ខុនឹងទៅក្នុងទីដែលធ្វើការមង្គល និងអវមង្គលរបស់មនុស្សទាំងឡាយមាន តថាគតមិនអាចធ្វើវិហារឲ្យទទេបាន តថាគតនឹងឲ្យនណារហ៌ត្រឡប់ ។

លំដាប់នោះ ទ្រង់មានបរិវិតក្កយ៉ាងនេះថា ពួកមនុស្សទាំងនោះជាញាតិផង ឧបដ្ឋាកផងរបស់កស្សបៈ តថាគតគួរឲ្យកស្សបៈត្រឡប់ចុះ ។ ទ្រង់ត្រាស់

នឹងព្រះថេរៈថា ម្នាលកស្សបៈ តថាគតមិនអាចធ្វើវិហារឲ្យទទេបាន សេចក្តីត្រូវការដោយកិកូក្នុងទីដែលធ្វើមង្គល និងអវមង្គលទាំងឡាយរបស់ពួកមនុស្សមាន អ្នក មួយអន្ទើដោយបរិស័ទរបស់ខ្លួនចូរត្រឡប់ចុះ ។ ព្រះថេរៈទូលថា សាធុ ព្រះអង្គ ហើយនាំបរិស័ទត្រឡប់ ។ កិកូទាំងឡាយពោលទោសថា អាវុសោទាំងឡាយ ពួកអ្នកឃើញដែរឬទេ ពួកយើងពោលអម្បាញ់មិញនេះឯង មិនមែនឬ ពាក្យដែលពួកយើងពោលថា ព្រោះហេតុអ្វី ទើបព្រះមហាកស្សបៈបោកចីវរ លោកនឹងមិនទៅជាមួយព្រះសាស្តា ដូច្នេះនោះឯង ក្លាយជាការពិតហើយ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់កិកូទាំងឡាយហើយ ទ្រង់យាងត្រឡប់ ប្រថាប់ឈរត្រាស់ថា ម្នាលកិកូទាំងឡាយ ពួកអ្នកពោលអ្វីហ្ន៎ កិកូទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គពោលប្រារព្ធព្រះមហាកស្សបត្ថេរ ដូច្នេះហើយ ក្រាបទូលរឿងរ៉ាវទាំងអស់ តាមទំនងដែលខ្លួនពោលហើយនោះឯង ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា ម្នាលកិកូទាំងឡាយ ពួកអ្នកពោលទោសកស្សបៈថា ជាប់ជំពាក់ហើយក្នុងត្រកូល និងក្នុងបច្ច័យទាំងឡាយ តែសេចក្តីពិត កស្សបៈត្រឡប់ដោយធ្វើទុកក្នុងចិត្តថា អញនឹងធ្វើតាមពាក្យរបស់ព្រះតថាគត ។ កស្សបៈនោះ សូម្បីក្នុងកាលមុន កាលធ្វើសេចក្តីប្រាថ្នានោះឯង ក៏បានធ្វើសេចក្តីប្រាថ្នាថា អាត្មាអញមិនគប្បីជាអ្នកជាប់ជំពាក់ក្នុងបច្ច័យទាំង ៤ មានឧបមាដូចព្រះចន្ទ អាចចូលទៅកាន់ត្រកូល

ទាំងឡាយបាន កស្សបៈនោះ មិនមានការជាប់ជំពាក់ក្នុងត្រកូល ឬក្នុងបច្ច័យទាំងឡាយ តថាគតកាលពោលបដិបទា ដែលឧបមាដូចព្រះចន្ទ និងបដិបទានៃអរិយវង្ស ក៏ពោលអាងកស្សបៈឲ្យជាដើម ។

ភិក្ខុទាំងឡាយទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ព្រះថេរៈតាំងសេចក្តីប្រាថ្នាពីអង្គាល់ណា ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកបំណងនឹងស្តាប់ឬ ភិក្ខុទាំងឡាយក្រាបទូលថា ករុណាព្រះអង្គ ។

ព្រះសាស្តាត្រាស់ដល់ភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ក្នុងទីបំផុតនៃសែនកប្បអំពីកប្បនេះ ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់កើតហើយក្នុងលោកដូច្នេះហើយ ត្រាស់ការប្រព្រឹត្តក្នុងកាលមុនរបស់ព្រះថេរៈ តាំងអំពីដើម លោកតាំងសេចក្តីប្រាថ្នាក្នុងកាលនៃព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ។ បុព្វចរិតនោះ ព្រះធម្មសង្គាហកាចារ្យឲ្យពិស្តារហើយក្នុងព្រះបាលី ដែលសម្តែងប្រវត្តិរបស់ព្រះថេរៈនោះឯង ។

ព្រះសាស្តា កាលត្រាស់បុព្វចរិតរបស់ព្រះថេរៈឲ្យពិស្តារហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រោះយ៉ាងនេះឯង ទើបតថាគតពោលបដិបទាដែលប្រៀបដូចព្រះចន្ទ និងបដិបទានៃអរិយវង្ស ដោយលើកយកកស្សបបុត្តរបស់តថាគតឲ្យជាគំរូ ។ ឈ្មោះថា ការជាប់ជំពាក់ក្នុងបច្ច័យក្តី ត្រកូលក្តី វិហារក្តី បរិវេណក្តី រមែងមិនមានដល់បុត្ររបស់តថាគត ។ បុត្ររបស់តថាគត មិនជាប់ជំពាក់ក្នុងរបស់ណាមួយឡើយ ដូចស្តេចហង្សចុះក្នុងកក់ត្រាច់ទៅក្នុងកក់នោះហើយ ក៏ហើរទៅដូច្នោះ ដូច្នេះហើយ កាលទ្រង់បន្ត

អនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ឧយ្យុញ្ជន្តិ សតីមន្តោ ន និកេតេ រមន្តិ តេ
ហំសាវ បល្វលំ ហិត្វា ឱកមោកំ ជហន្តិ តេ ។

ព្រះខីណាស្រពទាំឡាយ មានស្មារតី រមែងខ្វល់ខ្វាយ រមែងត្រេកអរក្នុងទីនៅអាស្រ័យ លោកលះបង់ចោលស្រះ នូវអាលយទាំងអស់ ដូចហង្សលះបង់កក់ ហើរទៅ ដូច្នោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បានព្រះគាថាថា **ឧយ្យុញ្ជន្តិ សតីមន្តោ** *សេចក្តីថា បុគ្គលដែលដល់នូវភាពបរិបូណ៌នៃសតិ ឈ្មោះថា មានអាសវៈអស់ហើយ រមែងខ្វល់ខ្វាយរឿយៗ ក្នុងគុណដែលខ្លួនចាក់ឫសហើយ មានឈាន និងវិបស្សនាជាដើម ដោយអាវជ្ជនៈ ដោយចូលសមាបត្តិ ដោយចេញចាកសមាបត្តិ ដោយការតាំងចិត្តនៅក្នុងសមាបត្តិ និងដោយការពិចារណា ។*

បានព្រះគាថាថា **ន និកេតេ រមន្តិ តេ** *គឺឈ្មោះថា ការត្រេកអរក្នុងទីហួងហែងរបស់លោក រមែងមិនមាន ។*

បទថា **ហំសាវ** *នេះ ជាចំណុចនៃទេសនា ។ នេះការអធិប្បាយក្នុងពាក្យនេះថា ហង្សបក្សី គឺយកចំណីរបស់ខ្លួនក្នុងកក់ដែលបរិសុទ្ធដោយចំណីហើយក្នុងកាលទៅ មិនធ្វើការហួងហែងតិចតួចក្នុងទីនោះថា ទឹករបស់អញ ផ្កាឈូករបស់អញ ផ្កាឧប្បលរបស់អញ ផ្កាបុណ្ឌរីករបស់អញ ស្មៅរបស់អញ មិនមានការស្តាយឡើយ លះបង់ទេសនោះសុះហើរទៅក្នុងអាកាស យ៉ាង*

ណា ព្រះខីណាស្រពតាំងឡាយនោះក៏ដូច្នោះឯង សូម្បីនៅក្នុងទីណាមួយ មិនជាប់ជំពាក់ហើយក្នុងត្រកូលជាដើម ក្នុងគ្រោទៅ លះទីនោះទៅ មិនមានការសោកស្តាយថា វិហាររបស់អញ បរិវេណរបស់អញ ឧបដ្ឋាករបស់អញ ត្រាច់ទៅ ។

បទថា **ទុកមោកំ** *គឺអាល័យ សេចក្តីថា លះនូវការហួងហែងទាំងពួង ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

រឿង ព្រះមហាកស្សបត្ថេរ ចប់

រឿង ព្រះវេឡុដ្ឋសីសត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះវេឡុដ្ឋសីសៈ ត្រាស់ព្រះធម្មទេសនានេះថា **យេសំ សន្និច្ចយោ ឆត្តិ** *ជាដើម ។*

បានឮមកថា ព្រះថេរៈនោះត្រាច់បិណ្ឌបាតក្នុងវិថីមួយខាងក្នុងស្រុក ធ្វើភត្តកិច្ចហើយ ត្រាច់បិណ្ឌបាតក្នុងវិថីមួយទៀត កាន់យកបាយក្រៀមទៅក្នុងវិហារក្បាទុក គិតឃើញថា ឈ្មោះថា ការត្រាច់ស្វែងរកបិណ្ឌបាតរឿយៗទៅ ជាទុក្ខ ញុំងថ្ងៃតិចតួចឲ្យកន្លងទៅដោយសុខក្នុងឈានហើយ កាលត្រូវការដោយអាហារ រមែងឆាន់បាយក្រៀមនោះ ។ ពួកភិក្ខុដែលដឹងតិះដៀល

ហើយ ទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ព្រះសាស្តាសូម្បីទ្រង់បញ្ញត្តិសិក្ខាបទដល់ភិក្ខុទាំងឡាយ ដើម្បីប្រយោជន៍វៀរការសន្សំតទៅ ព្រោះហេតុនោះហើយ កាលទ្រង់ប្រកាសការមិនមានទោសរបស់ព្រះថេរៈ ព្រោះការទុកជាក់អាហារនោះ ព្រោះព្រះថេរៈអាស្រ័យការប្រាថ្នាតិច ធ្វើក្នុងកាលដែលទ្រង់មិនទាន់បញ្ញត្តសិក្ខាបទ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា

យេសំ សន្និច្ចយោ នត្ថិ យេ បរិញ្ញាតភោជនា
សុញ្ញតោ អនិមិត្តោ ច វិមោក្ខោ យេស គោចរោ
អាកាសេវ សកុន្តានំ គតិ តេសំ ទុរន្នយា ។

ពួកជនណា មិនមានសេចក្តីសន្សំ ពួកជនណា កំណត់ដឹងភោជនហើយ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិតវិមោក្ខ ជាគោចរ គតិ គឺដំណើរបស់ពួកជននោះៗ គេកម្រដឹងបាន ដូចដំណើរនៃពួកសត្វស្លាបក្នុងអាកាសដូច្នោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ក្នុងបទថា **សន្និច្ចយោ** *សន្សំមាន ២ យ៉ាង គឺ សន្សំកម្ម ១ សន្សំបច្ច័យ ១ ក្នុងការសន្សំ ២ យ៉ានោះ កម្មដែលជាកុសលនិងអកុសល ឈ្មោះថា សន្សំកម្ម ។ បច្ច័យ ៤ ឈ្មោះថា សន្សំបច្ច័យ ក្នុងការសន្សំ ២ យ៉ាងនោះ សន្សំបច្ច័យ រមែងមិនមានដល់ភិក្ខុដែលនៅក្នុង*

វិហារ ទុកជាក់ទីកស្តារអំពៅមួយដុំ សប្បិត្រឹមតែចំណែកទី ៤ និងអង្គរត្រឹម មួយនាឡិ រមែងមិនមានដល់កិក្ខុដែលទុកជាក់ច្រើនជាងនោះ សន្សំ ២ យ៉ាង នេះរបស់ជនពួកណា មិនមាន ។

បទថា **បរិញ្ញាតភោជនា** *គឺកំណត់ដឹងភោជនដោយបរិញ្ញា ៣ ការដឹង ភោជនមានបបរជាដើម ដោយភាពជាបបរជាដើម ឈ្មោះថា ញាតប្បរិញ្ញា កំណត់ដឹងដោយការដឹងហើយ ។ ឯការកំណត់ដឹងភោជន ដោយអំណាច សម្គាល់ឃើញក្នុងអាហារបដិកូល ឈ្មោះថា តីរណប្បរិញ្ញា ។ ញាណជា ហេតុដកទូវតម្រេក ដោយអំណាចការពេញចិត្តក្នុងភោជនាហារចេញ ឈ្មោះ ថា បហានប្បរិញ្ញា ជនពួកណា កំណត់ដឹងភោជនដោយបរិញ្ញា ៣ នេះ ។*

ក្នុងបាទព្រះគាថាថា **សុញ្ញតោ អនិមិត្តោ ច** *នេះ សូម្បីអប្បណិហិត-វិមោក្ខ ក៏ទ្រង់កាន់យកដោយពិត ។ ព្រោះថា បទទាំង ៣ នោះ ជាឈ្មោះនៃ ព្រះនិព្វាននោះឯង ។ ពិតហើយ ព្រះនិព្វាន លោកពោលថា សុញ្ញតវិមោក្ខ ព្រោះថា ទទេ ព្រោះមិនមានរាគៈ ទោសៈ និងមោហៈ និងផុតចាករាគៈ ទោសៈ មោហៈនោះ ព្រះនិព្វាននោះ លោកពោលថា ជាអនិមិត្តវិមោក្ខ ព្រោះថា មិនមាននិមិត្ត ព្រោះមិនមាននៃនិមិត្ត មានរាគៈជាដើម និងផុត ហើយចាកនិមិត្តទាំងនោះ ម្យ៉ាងទៀត លោកពោលថា អប្បណិហិតវិមោក្ខ ព្រោះមិនបានតាំងនៅ ព្រោះមិនមានបណិធិ គឺកិលេសជាហេតុតាំងនៅ មាន រាគៈជាដើម និងរួចផុតហើយចាកបណិធិទាំងនោះ ។ វិមោក្ខ ៣ យ៉ាងនេះ ជាអារម្មណ៍របស់ជនពួកណា បុគ្គលធ្វើព្រះនិព្វាននោះឲ្យជាអារម្មណ៍ ដោយ*

អំណាចចូលសមាបត្តិ សម្បយុត្តដោយផលចិត្ត ។

បាទព្រះគាថាថា **គតិ តេសំ ឧរន្ធយា** *សេចក្តីថា ដូចផ្លូវទៅរបស់ហ្វូងបក្សីដែលទៅហើយដោយអាកាស ទៅតាមលំបាក គឺមិនអាចដឹង ព្រោះមិនឃើញគន្ធង យ៉ាងណា គតិរបស់ជនទាំងឡាយ ដែលជាអ្នកសន្សំពីរយ៉ាងនេះ មិនបានកំណត់ដឹងកោជនដោយបរិញ្ញា ៣ នេះ និងជាបុគ្គលមានវិមោក្ខមានប្រការដែលពោលហើយនេះជាអារម្មណ៍ ក៏ទៅតាមលំបាក គឺមិនអាចបញ្ញត្តិ ព្រោះមិនប្រាកដនៃការទៅថា ទៅហើយក្នុងចំណែក ៥ នេះ គឺភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ សត្តាវាស ៩ ដោយចំណែកឈ្មោះនេះៗ ដូច្នោះឯង ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះវេឡុដ្ឋសីសត្ថេរ ចប់

រឿង ព្រះអនុរុទ្ធត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះអនុរុទ្ធត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យស្សាសវា បរិក្ខីណា** *ជាដើម ។*

សេចក្តីពិស្តារថា ក្នុងថ្ងៃមួយ ព្រះថេរៈមានចីវរចាស់ហើយ ស្វែងរក

ចីវរ ក្នុងទីទាំងឡាយ មានគំនរសំរាមជាដើម ស្រីកវិយាចាស់របស់ព្រះថេរៈនោះ ក្នុងអត្តភាពទី ៣ បន្ទាប់អំពីអត្តភាពនេះ បានកើតជាទេពធីតាឈ្មោះជាលិនី ក្នុងស្ថានតាវត្តិង្ស នាងជាលិនីទេពធីតានោះ ឃើញព្រះថេរៈស្វែរកកំណាត់សំពត់ កាន់សំពត់ទិព្វ ៣ ផ្ទាំង បណ្តាយ ១៣ ហត្ថ ទទឹង ៤ ហត្ថ ហើយគិតថា បើអញប្រគេនដោយទំនងនេះ ព្រះថេរៈនឹងមិនទទួល ទើបដាក់លើគំនរសំរាមមួយកន្លែងខាងមុខព្រះថេរៈនោះ

ដែលកំពុងស្វែរកសំពត់ទាំងឡាយ ដោយអាការត្រឹមតែជាយសំពត់នោះប្រាកដបាន ។ ព្រះថេរៈស្វែរកកំណាត់សំពត់ដោយផ្លូវនោះ ឃើញជាយសំពត់នោះហើយ ទើបចាប់ត្រង់ជាយសំពត់នោះទាញមក ឃើញសំពត់ទិព្វមានប្រមាណដូចពោលហើយ កាន់យកដោយគិតថា សំពត់នេះ ជាសំពត់បង្សុកូលយ៉ាងឧត្រិដ្ឋហ្ន៎ ដូច្នេះហើយ ចៀសចេញទៅ ។

ក្នុងថ្ងៃធ្វើចីវរបស់ព្រះថេរៈ ព្រះសាស្តាមានភិក្ខុ ៥០០ រូបជាបរិវារយាងទៅវិហារប្រថាប់គង់ហើយ ។ អសីតិមហាសាវ័កក៏អង្គុយហើយយ៉ាងនោះដូចគ្នា ។ ព្រះមហាកស្សបត្ថេរ អង្គុយហើយខាងដើម ដើម្បីដេរចីវរ ព្រះសារីបុត្តអង្គុយត្រង់កណ្តាល ព្រះអានន្ទត្ថេរអង្គុយក្នុងទីបំផុត កិច្ចសង្ឃរុំអំបោះ ។ ព្រះសាស្តាទ្រង់ជោតអំបោះក្នុងគូថម្ភូល ព្រះមហាមោគ្គល្លានត្ថេរសេចក្តីត្រូវការដោយវត្តុណាមាន ជាអ្នកនាំវត្តុនោះៗ មកហើយ ។ ទេពធីតាចូលទៅខាងក្នុងស្រុកហើយ ដឹកនាំឲ្យទទួលភិក្ខាថា នែអ្នកទាំងឡាយ ព្រះសាស្តាទ្រង់ធ្វើចីវរដល់ព្រះអនុរុទ្ធត្ថេរ លោកម្ចាស់របស់យើងទាំងឡាយ ក្នុង

ថ្ងៃនេះ ដែលព្រះអសីតិមហាសាវ័កចោមរោម ប្រថាប់គង់នៅក្នុងវិហារជាមួយភិក្ខុ ៥០០ រូប ចូរពួកអ្នកកាន់យកបបរជាដើមទៅកាន់វិហារ សូម្បីព្រះមហាមោគ្គល្លានត្ថេរ នាំចំណិតព្រឹងធំមកហើយក្នុងរវាងភត្ត ។ ភិក្ខុ ៥០០ រូបមិនអាចទំពាឆាន់ឲ្យអស់បាន សក្ករបានធ្វើការជ្រោះព្រំក្នុងទីដែលធ្វើចីវរ ។ ផ្ទៃផែនដីហាក់បីដូចជ្រលក់ដោយទឹកលក្ត ។ គំនរធំនៃបបរ របស់ទំពា និងភត្តដែលភិក្ខុទាំងឡាយឆាន់សល់មានហើយ ។

ភិក្ខុទាំងឡាយពោលទោសថា ប្រយោជន៍អ្វីរបស់ភិក្ខុ មានប្រមាណប៉ុណ្ណេះ ដោយបបរជាដើមដ៏ច្រើនយ៉ាងនេះ ញាតិ និងឧបដ្ឋាកដែលភិក្ខុទាំង-ឡាយកំណត់ប្រមាណហើយ គប្បីពោលថា ចូរពួកអ្នកនាំវត្ថុមានប្រមាណប៉ុណ្ណេះមក មិនមែនឬ ព្រះអនុរុទ្ធត្ថេរប្រហែលបំណងឲ្យគេដឹងភាពនៃញាតិ និងឧបដ្ឋាករបស់ខ្លួនមានច្រើន ។ លំដាប់នោះ ព្រះសាស្តា ត្រាស់សួរភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនិយាយអ្វី ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ និយាយរឿងឈ្មោះនេះ ទើបត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសម្គាល់ថា សេចក្តីនេះ អនុរុទ្ធឲ្យនាំមកហើយឬ ភិក្ខុទាំងឡាយក្រាបទូលថា យ៉ាងនោះឯងព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អនុរុទ្ធបុត្រតថាគត មិនពោលពាក្យបែបនោះទេ ឡើយ ។ ពិតហើយ ព្រះខីណាស្រពទាំងឡាយ រមែងមិនពោលកថាបដិសំយុត្តដោយបច្ច័យ ។ បិណ្ឌបាតនេះកើតហើយដោយអានុភាពរបស់ទេវតា កាលទ្រង់បន្ត អនុសន្ធិ ទើបត្រាស់គាថានេះថា

យស្សាសវា បរិក្ខីណា អាហារេ ច អនិស្សិតោ
សុញ្ញតោ អនិមិត្តោ ច វិមោក្ខោ យស្ស គោចរោ
អាកាសេវ សកុន្តានំ បទន្តស្ស ទុរន្នយំ ។

ជនណាអស់អាសវៈហើយ ទាំងមិនអាស្រ័យ (តណ្ហា និង ទិដ្ឋិ) ក្នុងអាហារ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្ត-វិមោក្ខ និងអប្បណិហិតវិមោក្ខជាគោចរ ដំណើរបស់ជន នោះ គេកម្រដឹងបាន ដូចដំណើរនៃពួកសត្វស្វាប ឮដ៏ អាកាស ដូច្នោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យស្សាសវា** *សេចក្តីថា អាសវៈ ៤ របស់បុគ្គលណាអស់ហើយ ។ បានព្រះគាថាថា* **អាហារេ ច អនិស្សិតោ** *សេចក្តីថា ដែលតណ្ហានិស្សយ និងទិដ្ឋិនិស្សយមិនអាស្រ័យហើយក្នុងអាហារ ។*

បានព្រះគាថាថា **បទន្តស្ស ទុរន្នយំ** *សេចក្តីថា ដែលបុគ្គលមិនអាចនឹងដឹងស្នាមរបស់បក្សីទាំងឡាយ ដែលទៅក្នុងអាកាសថា បក្សីទាំងឡាយជាន់ដោយជើងក្នុងទីនេះហើយទៅហើយ ទង្គិចទីនេះដោយទ្រូងហើយទៅហើយ ប៉ះទីនេះដោយក្បាល ដោយស្វាបទាំង ២ យ៉ាងណា បុគ្គលណាមួយ ក៏មិនអាចបញ្ញត្តិនូវស្នាមរបស់ភិក្ខុបែបនេះដោយនយជាដើមថា ភិក្ខុនេះទៅហើយដោយផ្លូវនេះក ឬទៅហើយដោយផ្លូវតិរច្ឆានដូច្នោះដូចគ្នា ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

រឿង ព្រះអនុរុទ្ធត្ថេរ ចប់

រឿង ព្រះមហាកច្ចាយនត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តបុព្វារាម ទ្រង់ប្រារព្ធព្រះមហាកច្ចាយនត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យស្សិន្ទ្រិយានិ** ជាដើម ។

សេចក្តីពិស្តារថា ក្នុងសម័យមួយ ព្រះសាស្តាដែលព្រះមហាសាវ័ក ចោមរោមហើយ ប្រថាប់គង់ខាងក្រោមប្រាសាទរបស់មិគារមាតា ក្នុងថ្ងៃមហាបវារណា ។ ក្នុងសម័យនោះ ព្រះមហាកច្ចាយនត្ថេរ នៅក្នុងអវន្តីជនបទ មកហើយអំពីចម្ងាយ រមែងសរសើរការស្តាប់ធម៌នោះឯង ព្រោះដូច្នោះព្រះថេរ: ធំៗ ទាំងឡាយ កាលអង្គុយ ក៏អង្គុយវៀរអាសន:ដើម្បីព្រះមហាកច្ចាយនត្ថេរ ។ សក្កទេវរាជ យាងមកអំពីទេវលោកទាំងពីរ មួយអន្ទើដោយទេវបរិស័ទ ទ្រង់បូជាព្រះដ៏មានព្រះភាគដោយគ្រឿងក្រអូប និងកម្រងផ្កាដែលជាទិព្វជាដើមហើយ ប្រថាប់ឈរ មិនបានឃើញព្រះមហាកច្ចាយនត្ថេរ ទើបទ្រង់ពិចារណាថា ព្រោះហេតុអ្វីហ្នឹ ទើបលោកម្ចាស់របស់យើងមិនប្រាកដ បើលោកម្ចាស់របស់យើងមក ការមករបស់ពួកលោកជាការល្អ ។ ព្រះថេរ:

មកហើយក្នុងខណៈនោះឯង បង្ហាញខ្លួន អង្គុយហើយលើអាសនៈរបស់ខ្លួន នោះឯង ។ សក្កទេវរាជទតឃើញព្រះថេរៈហើយ ទ្រង់ចាប់កជើងទាំងពីរ យ៉ាងមាំ ហើយត្រាស់ថា លោកម្ចាស់របស់យើងមកហើយហ្ន៎ ខ្ញុំទន្ទឹងការ មកបរបស់លោកម្ចាស់នោះឯង ដូច្នេះហើយ ទ្រង់ច្របាច់ជើងទាំងពីររបស់ព្រះ ថេរៈ ដោយដៃទាំងពីរ បូជាដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម ថ្វាយ បង្គំហើយ បានប្រថាប់ឈរក្នុងចំណែកម្ខាង ។

ភិក្ខុទាំងឡាយពោលទោសថា សក្កទេវរាជទ្រង់យល់មុខ ទើបធ្វើសក្ការៈ មិនធ្វើសក្ការៈបែបនេះដល់មហាសាវ័កដ៏សេស ឃើញព្រះមហាកច្ចាយនត្ថេរ ហើយ ចាប់កជើងទាំងពីរដោយរហ័សត្រាស់ថា លោកម្ចាស់របស់យើងមក ល្អហ្ន៎ ខ្ញុំទន្ទឹងការមករបស់លោកម្ចាស់នោះឯង ដូច្នេះហើយ ទ្រង់ច្របាច់ជើង ទាំងពីរដោយដៃទាំងពីរបូជាហើយ ថ្វាយបង្គំហើយ ប្រថាប់ឈរក្នុងចំណែក ម្ខាង ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានទ្វារដែលខ្លួនគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ ដូចគ្នានឹងមហាកច្ចាយនៈ បុត្រតថាគត រមែងជាទីស្រឡាញ់របស់ពួកទេវតា នោះឯង កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យស្សិន្ទ្រិយានិ សមថង្គតានិ អស្សា យថា សារថិនា សុទន្តា
បហីនមានស្ស អនាសវស្ស តេវាបិ តស្ស បិហយន្តិ តាទិនោ ។

ឥន្ទ្រិយទាំងឡាយ របស់អ្នកណា ដល់នូវការស្ងប់រម្ងាប់ ដូចសេះ ដែលនាយសារថីហ្វឹកហ្វឺនរាបហើយ សូម្បីទេវតា និងមនុស្សទាំង-

ឡាយ ក៏ស្រឡាញ់អ្នកនោះឯង ដែលមានមានះលះបង់ហើយ មិនមានអាសវៈ ជាបុគ្គលមានចិត្តនឹងធឹង មិនញាប់ញ័រ ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះដូច្នេះថា ឥន្ទ្រិយ ៦ របស់ភិក្ខុណាដល់នូវការស្ងប់ គឺភាពជាឥន្ទ្រិយដែលខ្ជួនទូន្មានហើយ បានដល់ ភាពជាឥន្ទ្រិយអស់នូវឰស្សន៍កំណាច ដូចសេះដែលនាយសារថីអ្នកឈ្លាស បង្វឹកល្អហើយ ដូច្នោះ ។ ចំពោះភិក្ខុនោះ ដែលឈ្មោះថាមានមានះលះបង់ហើយ ព្រោះលះមានះមាន ៩ យ៉ាង តាំងនៅ ឈ្មោះថា មិនមានអាសវៈ ព្រោះមិនមានអាសវៈ ៤ ។ បទថា **តាទិនោ** *សេចក្តីថា ទាំងពួកទេវតា ទាំងពួកមនុស្សរមែងស្រឡាញ់ គឺរមែងប្រាថ្នាការឃើញ និងការមកបស់ភិក្ខុបែបនោះ ដែលតាំងនៅដោយភាវៈនៃតាទិបុគ្គល ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះមហាកច្ចាយនត្ថេរ ចប់

រឿង ព្រះសារីបុត្តត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **បឋវីសមោ** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ ព្រះសារីបុត្តចេញវស្សាហើយ ប្រាថ្នានឹងចៀសទៅកាន់ទីចារិក ទើបទូលលាព្រះដ៏មានព្រះភាគ ថ្វាយបង្គំហើយ ចេញទៅ មួយអន្ទើដោយបរិវារបស់ខ្លួន ។ ភិក្ខុទាំងឡាយដទៃ តាមជូនព្រះថេរៈហើយ ។ ព្រះថេរៈប្រាស្រ័យនឹងភិក្ខុទាំងឡាយ ដែលប្រាកដដោយអំណាចឈ្មោះ និងគោត្រ តាមឈ្មោះ និងគោត្រហើយ ទើបប្រាប់ឲ្យត្រឡប់ ។ ភិក្ខុដែលមិនប្រាកដ ដោយអំណាចឈ្មោះ និងគោត្ររូបណាមួយគិតថា ឧហ្នុ៉ ព្រះថេរៈ គួរសរសើរប្រាស្រ័យនឹងយើងខ្លះ ដោយអំណាចឈ្មោះ និងគោត្រ ហើយគប្បីឲ្យត្រឡប់ ព្រះថេរៈមិនទាន់កំណត់ដល់លោកក្នុងរវាងនៃភិក្ខុសង្ឆជាច្រើន ភិក្ខុនោះអាឃាតក្នុងព្រះថេរៈថា ព្រះថេរៈមិនសរសើរអញដូចភិក្ខុដទៃទាំងឡាយ ។ រមូរសង្ឆាដីរបស់ព្រះថេរៈ ត្រូវសរីរៈរបស់ភិក្ខុនោះហើយ ដោយហេតុនោះ ភិក្ខុនោះក៏ត្រូវអាឃាតហើយដូចគ្នា ។ ភិក្ខុនោះដឹងថា ឥឡូវនេះ ព្រះថេរៈនឹងកន្ធងឧបចារវិហារ ទើបចូលទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ ព្រះសារីបុត្តប្រហារខ្ញុំព្រះអង្គ ដូចទម្លាយគុម្ពត្រចៀក មិនញ្ញុាំងខ្ញុំព្រះអង្គឲ្យអត់ទោស ចៀសទៅកាន់ទីចារិក ដោយសម្គាល់ថា ជាអគ្គសាវ័ករបស់ព្រះអង្គ ។ ព្រះសាស្តា ត្រាស់ឲ្យហៅ

ព្រះថេរ:មកហើយ ។

ក្នុងខណ:នោះ ព្រះមហាមោគ្គល្លាន និងព្រះអានន្ទគិតហើយថា ព្រះសាស្តាទ្រង់មិនជ្រាបភាពដែលភិក្ខុនេះ ដែលបងប្រុសរបស់ពួកយើងមិនប្រហារហើយក៏មិនមែន តែទ្រង់បំណងឲ្យលោកបន្ទឹសីហនាទ អញនឹងឲ្យបរិស័ទប្រជុំគ្នា ព្រះថេរ:ទាំងពីរមានកូនសោនៅក្នុងដៃ បើកទ្វារបរិវេណហើយ ពោលថា ចូរអាវុសោទាំងឡាយចេញ ចូរអាវុសោទាំងឡាយចេញ ឥឡូវនេះ ព្រះសារីបុត្តនឹងបន្ទឹសីហនាទ ក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តា ឲ្យមហាភិក្ខុសង្ឆប្រជុំគ្នាហើយ ។ ចំណែកព្រះថេរ:មកថ្វាយបង្គំព្រះសាស្តា អង្គុយហើយ ។ លំដាប់នោះ ព្រះសាស្តាត្រាស់សួរសេចក្តីនោះជាមួយព្រះថេរ:ហើយ ។ ព្រះថេរ:មិនក្រាបទូលភ្លាមថា ភិក្ខុនេះ ខ្ញុំព្រះអង្គមិនប្រហារហើយ កាលនឹងពោលគុណកថារបស់ខ្លួន ទើបក្រាបទូលថា បពិត្រព្រះអង្គ សតិប្រព្រឹត្តទៅក្នុងកាយ ដែលភិក្ខុណាមិនគប្បីចូលទៅតាំងទុកហើយក្នុងកាយ ភិក្ខុនោះប៉ះពាល់សព្រហ្មចារីរូបណាមួយក្នុងសាសនានេះ មិនសុំទោសហើយ គប្បីចៀសទៅកាន់ទីចារិកពិត ដូច្នេះហើយ ប្រកាសភាពដែលខ្លួនមានចិត្តស្មើដោយផែនដីស្មើដោយទឹក ភ្លើង ខ្យល់ សំពត់ជូតធូលី ក្មេងចណ្ឌាល គោឧសភ:បាក់ស្នែងការខ្ពើមរអើមដោយកាយរបស់ខ្លួន ដូចសាកសពពស់ជាដើម និងការបរិហារកាយរបស់ខ្លួន ដូចភាជន:ខ្លាញ់ខាប់ ដោយន័យជាដើមថា បុគ្គលរមែងចោលរបស់ស្អាតខ្លះ រមែងចោលរបស់មិនស្អាតខ្លះ លើផែនដី យ៉ាងណា ។ កាលព្រះថេរ:ពោលគុណរបស់ខ្លួន ដោយឧបមា ៩ យ៉ាងនេះ មហាប្រឹថពី

កម្រើករហូតដល់ទីបំផុតទឹក ក្នុងវារៈទាំង ៩ ហើយ ។ ក្នុងវេលានាំឧបមា ដោយសំពត់ជូតធូលី ក្នុងចណ្ឌាល និងភាជនៈខ្វាញ់ខាប់មក ភិក្ខុដែលជាបុថុជ្ជនមិនអាចទប់ទឹកភ្នែកបាន ធម្មសង្វេគកើតដល់ភិក្ខុដែលជាខីណាស្រពទាំងឡាយហើយ ។ កាលព្រះថេរៈពោលគុណរបស់ខ្លួននោះឯង ការក្តៅក្រហាយ កើតឡើងក្នុងសរីរៈទាំងមូល របស់ភិក្ខុដែលពោលបង្កាច់ហើយ រំពេចនោះឯង ភិក្ខុនោះ ក្រាបចុះទៀបបាទាទាំងទ្វេ របស់ព្រះដ៏មានព្រះភាគ ប្រកាសទោស ព្រោះការពោលទោសដោយពាក្យដែលមិនពិត សម្តែងទោស ដែលប្រព្រឹត្តកន្លងហើយ ។

ព្រះសាស្តាត្រាស់ហៅព្រះថេរៈមកហើយត្រាស់ថា ម្នាលសារីបុត្ត ចូរអ្នកអត់ទោសឲ្យមោឃបុរសនេះចុះ ទាន់សីសៈរបស់ភិក្ខុនេះមិនទាន់បែកជា ៧ ភាគ ព្រះថេរៈអង្គុយច្រហោងផ្តងអញ្ជលី ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គ អត់ទោសចំពោះអាវុសោនុ៎ះហើយ សូម្បីអាវុសោនុ៎ះ ក៏សូមអត់ទោសចំពោះខ្ញុំព្រះអង្គ បើទោសរបស់ខ្ញុំព្រះអង្គមាន ភិក្ខុទាំងឡាយពោលថា អាវុសោទាំងឡាយ ចូរអ្នកទាំងឡាយមើលព្រះថេរៈមានគុណមិនថោកថយ ព្រះថេរៈមិនធ្វើសេចក្តីក្រោធ ឬការប្រទូស្តសូម្បីមានប្រមាណតិចតួច ចំពោះភិក្ខុដែលពោលទោសដោយមុសាវាទបែបនេះ ខ្លួនឯងអង្គុយច្រហោង ផ្តងអញ្ជលីឲ្យភិក្ខុនោះអត់ទោស ។

ព្រះសាស្តាទ្រង់ស្តាប់កថានោះហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនិយាយអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា កថាឈ្មោះនេះ ព្រះអង្គ

ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយមិនអាចឲ្យសេចក្តីក្រោធ ឬការប្រទូស្តកើតឡើងដល់ភិក្ខុដូចសារីបុត្តបានឡើយ ម្នាលភិក្ខុទាំង-ឡាយ ចិត្តរបស់សារីបុត្តដូចគ្នានឹងមហាប្រឹថពី ដូចគ្នានឹងសសរខឿន ដូចគ្នានឹងអន្ទង់ទឹកថ្លា កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

បឋវីសមោ នោ វិរុជ្ឈតិ ឥន្ទខីលូបមោ តាទិ សុព្ភតោ
រហទោវ អបេតកទ្ទមោ សំសារា ន ភវន្តិ តាទិនោ ។

ភិក្ខុមានចិត្តដូចផែនដី មិនក្រោធ មានវត្តល្អ មានចិត្តនឹងធឹងដូចសសរគោល មានចិត្តថ្លា ដូចអន្ទង់ប្រាសចាកភក់ សង្សារទាំង-ឡាយរបស់ភិក្ខុបែបនោះ រមែងមិនមាន ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយរមែងចោលរបស់ស្អាត មានរបស់ក្រអូប និងកម្រងផ្កាជាដើមខ្លះ រមែងចោលរបស់មិនស្អាត មានមូត្រ និងលាមកជាដើមខ្លះលើផែនដី ។ ម្យ៉ាងទៀត ក្នុងជាដើម រមែងបន្ទោបង់បស្សាវៈខ្លះ រមែងបន្ទោបង់ឧច្ចារៈខ្លះ ស្រោចសសរខឿនដែលគេកប់ក្បែរទ្វារក្រុង តែជនទាំងឡាយជនៃ រមែងធ្វើសក្ការៈសសរខឿននោះដោយវត្ថុ មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ព្រោះការធ្វើនោះ សេចក្តីត្រេកអរ ឬការអាក់អន់រមែងមិនកើតដល់ផែនដី ឬសសរខឿននោះ យ៉ាងណា ភិក្ខុដែលជាខីណាស្រពនេះ ឈ្មោះថា ជាតាទិបុគ្គល ព្រោះភាពជាអ្នកមិនញាប់ញ័រដោយលោកធម៌ទាំង ៨ ឈ្មោះថា ជាអ្នកមានវត្តល្អ ព្រោះភាពនៃ

វត្តទាំងឡាយស្អាត ភិក្ខុទាំងនោះក៏ដួចោះដួចគ្នា កាលជនទាំងឡាយធ្វើសក្ការៈ និងអសក្ការៈ រមែងមិនត្រេកអរ រមែងមិនអាក់អន់ថា ជនទាំងនេះ រមែងធ្វើសក្ការៈអញដោយបច្ច័យ ៤ តែជនទាំងនេះមិនធ្វើសក្ការៈដោយពិត ភិក្ខុដែលជាព្រះខីណាស្រពនោះ រមែងជាអ្នកស្មើដោយផែនដី និងជាអ្នកប្រៀបដូចសសរខឿននោះឯង ។ អន្ធង់ទឹកដែលមានកក់ទៅប្រាសហើយ ជាអន្ធង់ទឹកថ្លា យ៉ាងណា ភិក្ខុដែលជាព្រះខីណាស្រពនោះ ឈ្មោះថា មានកក់ទៅប្រាសហើយ ដោយកក់ទាំងឡាយ មានរាគៈជាដើម ព្រោះភាពជាបុគ្គលមានកិលេសទៅប្រាសហើយ រមែងជាអ្នកផូរផង់នោះឯងដូច្នោះ ។

បទថា **តាទិនោ** *សេចក្តីថា ឈ្មោះថា សង្ឃរាទាំងឡាយ ដោយអំណាចនៃការអន្ទោលទៅក្នុងសុគតិ និងទុគ្គតិទាំងឡាយ រមែងមិនមានដល់ភិក្ខុនោះ គឺដល់ភិក្ខុបែបនោះ ។*

ក្នុងកាលចប់ទេសនា ភិក្ខុ ៩ ពាន់រូបបានសម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។

រឿង ព្រះសារីបុត្តត្ថេរ ចប់

រឿង ព្រះតិស្សត្ថេរអ្នកក្រុងកោសម្ពី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសាមណេររបស់ព្រះតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **សន្តំ តស្ស មនំ ហោតិ** ជាដើម ។

បានឮមកថា កុលបុត្រអ្នកក្រុងកោសម្ពីម្នាក់ បួសក្នុងព្រះសាសនា បានឧបសម្បទាហើយ ប្រាកដឈ្មោះថា កោសម្ពិវាសីតិស្សត្ថេរ ។ កាលព្រះថេរៈនោះចាំវស្សានៅក្នុងក្រុងកោសម្ពី ឧបដ្ឋាកនាំត្រៃចីវរ សប្បិ ទឹកអំពៅមកជាក់ក្បែរបាទា កាលនោះ ព្រះថេរៈពោលនឹងឧបដ្ឋាកនោះថា ឧបាសក នុ៎ះអ្វី ឧបដ្ឋាកពោលថា ខ្ញុំនិមន្តលោកម្ចាស់ឲ្យនៅចាំវស្សាមិនមែនឬ ពួកភិក្ខុដែលនៅចាំវស្សាក្នុងវិហាររបស់ពួកខ្ញុំ រមែងបានលាភនោះ សូមលោកម្ចាស់ទទួលចុះ ព្រះថេរៈពោលថា ណ្ហើយចុះ ឧបាសក សេចក្តីត្រូវការដោយវត្តុនេះរបស់អាត្មា មិនមាន ឧបដ្ឋាកពោលថា បពិត្រលោកម្ចាស់ តើព្រោះហេតុអ្វី ព្រះថេរៈពោលថា សាមណេរជាកប្បិយការិកក្នុងសម្នាក់របស់អាត្មាក៏មិនមាន ឧបដ្ឋាកពោលថា បពិត្រលោកម្ចាស់ បើកប្បិយការិកមិនមានកូនរបស់ខ្ញុំ នឹងជាសាមណេរក្នុងសម្នាក់របស់លោកម្ចាស់ ព្រះថេរៈទទួលហើយ ឧបាសកនាំកូនរបស់ខ្លួន មានអាយុ ៧ ឆ្នាំ ទៅកាន់សម្នាក់របស់ព្រះថេរៈហើយ បានប្រគេនថា សូមលោកម្ចាស់ឲ្យក្មេងនេះបួសចុះ ។ គ្រានោះ ព្រះថេរៈលាបសក់របស់ក្មេងនោះឲ្យសើម ហើយកោរ ឲ្យតចបញ្ចកកម្មដ្ឋាន ឲ្យបួសហើយ ។ ក្នុងវេលាកោរសក់ស្រេចនោះឯង កុមារនោះ ក៏

សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទា ។ ព្រះថេរៈ កាលឲ្យកុមារនោះ បួសហើយ នៅក្នុងទីនោះអស់កន្ទុះខែហើយ គិតថា នឹងគាល់ព្រះសាស្តា ទើបឲ្យសាមណេរវេចខ្ចប់កណ្ឌៈ ធ្វើដំណើរទៅកាន់វិហារមួយកន្លែង ក្នុងរវាងផ្លូវ ។ សាមណេរកាន់យកសេនាសនៈដែលចាត់ចែង ដើម្បីព្រះឧបជ្ឈាយ៍ហើយ ។ កាលសាមណេរនោះ រៀបចំសេនាសនៈនោះឯង ក៏អស់ពេល ។ ព្រោះហេតុនោះ ទើបសាមណេរមិនអាចរៀបចំសេនាសនៈ ដើម្បីខ្លួនបាន ។

គ្រានោះ ព្រះថេរៈសួរសាមណេរដែលមកកាន់ទីបម្រើ កំពុងអង្គុយហើយសួរថា សាមណេរ អ្នករៀបចំទីលំនៅរបស់ខ្លួនហើយឬ សាមណេរឆ្លើយថា ខ្ញុំមិនបានឱកាសដើម្បីរៀបចំទេ លោកម្ចាស់ ។

ព្រះថេរៈពោលថា បើដូច្នោះ អ្នកចូរនៅក្នុងលំនៅរបស់ខ្ញុំចុះ ការនៅក្នុងទីអាគន្តុកៈលំបាក ។ នាំសាមណេរនោះឯងចូលទៅកាន់សេនាសនៈហើយ ។ ឯព្រះថេរៈជាបុថុជ្ជន គ្រាន់តែសិងប៉ុណ្ណោះ ក៏ឈមចុះកាន់ការនិទ្រា ។ សាមណេរគិតថា ថ្ងៃនេះ ជាថ្ងៃទី ៣ របស់អញ ដែលនៅក្នុងសេនាសនៈជាមួយព្រះឧបជ្ឈាយ៍ បើអាត្មាអញដេកលក់ ព្រះថេរៈគប្បីត្រូវសហសេយ្យាបត្តិ អញនឹងអង្គុយតែម្យ៉ាង ញ៉ាំងកាលឲ្យកន្លងទៅ ។ សាមណេរអង្គុយពត់ក្អែន ក្បែរក្បែរបស់ឧបជ្ឈាយ៍នោះឯង ញ៉ាំងរាត្រីឲ្យកន្លងទៅហើយ ។ ព្រះថេរៈក្រោកឡើងក្នុងវេលាទៀបភ្លឺ គិតថា គួរឲ្យសាមណេរចេញ ទើបចាប់ផ្ងិតដែលនៅក្បែរគ្រែ យកចុងផ្ងិតវាយកន្ទេលផែងរបស់សាមណេរហើយ លើកផ្ងិតឡើងលើ ពោលថា សាមណេរ ចូរចេញទៅខាងក្រៅ ចុងផ្ងិតក៏ចាក់ក្អែក

បែកហើយ មួយរំពេចនោះឯង សាមណេរពោលថា មានការអ្វីលោកម្ចាស់ ព្រះថេរៈពោលថា ចូរអ្នកក្រោកឡើងចេញទៅខាងក្រៅចុះ សាមណេរក៏មិន ពោលថា ក្អែករបស់ខ្ញុំបែកហើយ បិទក្អែកដោយដៃម្ខាងចេញទៅ ។ ក្នុង ពេលធ្វើវត្ត សាមណេរមិនអង្គុយស្ងៀម ដោយគិតថា ក្អែករបស់អាត្មាអញ បែកហើយ ខូបក្អែកដោយដៃម្ខាង កាន់អំបោសដោយដៃម្ខាង បោសវច្ចកុដិ និងទីលុបមុខ តម្កល់ទីកលុបមុខទុកហើយ បោសបរិវេណ ប្រគេនឈើសូនដល់ព្រះឧបជ្ឈាយ៍ ក៏ប្រគេនដោយដៃម្ខាង ។

គ្រានោះ ឧបជ្ឈាយ៍ពោលនឹងសាមណេរនោះថា សាមណេរនេះមិនបាន សិក្សាហ្ន៎ ទើបប្រគេនឈើសូនដល់អាចារ្យ និងឧបជ្ឈាយ៍ដោយដៃម្ខាង ។ សាមណេរពោលថា បពិត្រលោកម្ចាស់ ខ្ញុំជ្រាបថា នុ៎ះមិនមែនជាវត្ត តែ ដៃម្ខាងរបស់ខ្ញុំមិនទំនេរ ព្រះថេរៈសួរថា នែសាមណេរ តើមានរឿងអ្វី ។

សាមណេរជ្រាប់ការប្រព្រឹត្តទៅនោះតាំងពីរដើមដល់ចប់ហើយ ព្រះថេរៈ ស្តាប់ហើយ មានចិត្តសង្វេគពោលថា ឱកម្មធ្ងន់អាត្មាអញធ្វើហើយ ពោលថា សូមអត់ទោសដល់ខ្ញុំចុះសប្បុរស ខ្ញុំមិនជ្ងឹសេចក្តីនោះ សូមអ្នកជាទីពឹងរបស់ ខ្ញុំ ដូច្នេះហើយ ផ្តងអញ្ជលី អង្គុយច្រហោងទៀបបាទរបស់សាមណេរអាយុ ៧ ឆ្នាំ ។ លំដាប់នោះ សាមណេរជ្រាប់ព្រះថេរៈនោះថា ខ្ញុំមិនបានពោលដើម្បី ហេតុនោះទេ ខ្ញុំកាលតាមរក្សាចិត្តរបស់លោកម្ចាស់ ទើបបានពោលហើយ យ៉ាងនេះ ។ ក្នុងសេចក្តីនេះ ទោសរបស់លោកម្ចាស់ក៏មិនមាន ទោសរបស់ ខ្ញុំក៏មិនមាន នុ៎ះជាទោសរបស់វដ្តៈប៉ុណ្ណោះ សូមលោកម្ចាស់កុំគិតឡើយ ខ្ញុំ

រក្សាការក្តៅក្រហាយរបស់លោកម្ចាស់នោះឯង ទើបមិនច្រាប់ ។ ព្រះថេរៈ កាលសាមណេរឲ្យធូរស្រាលចិត្ត ក៏មិនធូរស្រាលចិត្ត មានសេចក្តីសង្វេគកើតឡើងហើយ កាន់ភណ្ឌៈរបស់សាមណេរ ទៅកាន់សម្នាក់ព្រះសាស្តាហើយ ។ ព្រះសាស្តា ប្រថាប់គង់ទតការមករបស់ព្រះថេរៈនោះដូចគ្នា ព្រះថេរៈនោះទៅថ្វាយបង្គំព្រះសាស្តា ធ្វើសេចក្តីត្រេកអរជាមួយនឹងព្រះសាស្តាហើយ កាលព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ អ្នកល្មមអត់ធន់បានដែរឬ ការមិនផាសុកដ៏ខ្លាំងក្លាណាមួយ មិនមានទេឬ ទើបក្រាបទូលថា បពិត្រព្រះអង្គ ល្មមអត់ធន់បាន ការមិនផាសុកដ៏ខ្លាំងក្លាណាមួយរបស់ខ្ញុំព្រះអង្គ មិនមាន ។ ម្យ៉ាងទៀត អ្នកជនៃដែលមានគុណយ៉ាងក្រៃលែង ដូចសាមណេរតូចនេះ ខ្ញុំព្រះអង្គមិនធ្លាប់ឃើញទេ ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ កម្មអ្វីដែលសាមណេរធ្វើហើយ ព្រះថេរៈក្រាបទូលការប្រព្រឹត្តទៅទាំងអស់នោះ តាំងអំពីដើមដល់ចប់ ដល់ព្រះដ៏មានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គ សាមណេរនេះ កាលខ្ញុំព្រះអង្គឲ្យអត់ទោសយ៉ាងនេះ ពោលនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ក្នុងសេចក្តីនេះ ទោសរបស់លោកម្ចាស់មិនមានទេ ទោសរបស់ខ្ញុំក៏មិនមាន ទុ៎ះជាទោសរបស់វដ្តៈប៉ុណ្ណោះ សូមលោកម្ចាស់កុំគិតទេ ។ សាមណេរ ញុំាងខ្ញុំព្រះអង្គឲ្យធូរស្បើយហើយនោះឯង ដោយប្រការដូច្នេះ មិនធ្វើសេចក្តីក្រោធ មិនធ្វើសេចក្តីប្រទូស្តក្នុងខ្ញុំព្រះអង្គទេ បពិត្រព្រះអង្គ បុគ្គលសម្បូរដោយគុណបែបនេះ ខ្ញុំព្រះអង្គ ពុំធ្លាប់ឃើញទេ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះថេរៈថា ម្នាលភិក្ខុ ធម្មតា ព្រះខីណាស្រពទាំងឡាយ មិនក្រោធ មិនប្រទូស្តចំពោះបុគ្គលណា ជាអ្នកមានឥន្ទ្រិយស្ងប់ហើយ ជាអ្នកមានចិត្តស្ងប់ហើយនោះឯង ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

សន្តំ តស្ស មនំ ហោតិ សន្តា វាចា ច កម្ម ច
សម្មទញ្ញា វិមុត្តស្ស ឧបសន្តស្ស តាទិនោ ។

ចិត្តស្ងប់ វាចាស្ងប់ និងកាយកម្មស្ងប់ រមែងមានដល់លោកដែលដឹងដោយប្រពៃ ផុតស្រឡះ (ចាករាគ-ទិក្កិលេស) ជាអ្នកស្ងប់រម្ងាប់ដូច្នោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សន្តំ** *សេចក្តីថា ចិត្តរបស់សមណៈដែលជាខីណាស្រពនោះ ឈ្មោះថា ស្ងប់ហើយពិត គឺរម្ងាប់ បានដល់ រលត់ ព្រោះការមិនមាននៃមនោទុច្ចរិតទាំងឡាយ មានអភិជ្ឈាជាដើម ម្យ៉ាងទៀត វាចា ឈ្មោះថា ស្ងប់ហើយ ព្រោះការមិនមាននៃវចីទុច្ចរិតទាំងឡាយ មានមុសាវាទជាដើម និងកាយកម្ម ឈ្មោះថា ស្ងប់ហើយនោះឯង ព្រោះការមិនមាននៃកាយទុច្ចរិត មានបាណាតិបាតជាដើម ។*

បទព្រះគាថាថា **សម្មទញ្ញា វិមុត្តស្ស** *សេចក្តីថា បុគ្គលរួចផុតវិសេសហើយដោយវិមុត្តិ ៥ ព្រោះដឹងដោយនយ ដោយហេតុ ។*

បទថា **ឧបសន្តស្ស** *សេចក្តីថា ឈ្មោះថា ជាអ្នកស្ងប់រម្ងាប់ហើយ*

ព្រោះការស្ងប់រម្ងាប់នៃកិលេស មានរាគៈជាដើមខាងក្នុង ។

បទថា **តាទិនោ** គឺជាអ្នកសម្បូរដោយគុណបែបនោះ ។

ក្នុងកាលចប់ទេសនា ព្រះតិស្សត្តេរអ្នកក្រុងកោសម្ពី បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ធម្មទេសនាបានជាប្រយោជន៍ដល់មហា ជនដ៏សេសដូច្នេះឯង ។

រឿង ព្រះតិស្សត្តេរអ្នកក្រុងកោសម្ពី ចប់

រឿង ព្រះសារីបុត្តត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អស្សទ្ធោ** ជាដើម ។

សេចក្តីពិស្តារថា ភិក្ខុអ្នកនៅព្រៃជាវត្តប្រមាណ ៣០ រូប ថ្ងៃមួយចូលទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំអង្គុយហើយ ។ ព្រះសាស្តាទ្រង់ជ្រាបឧបនិស្ស័យនៃអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយរបស់ភិក្ខុទាំងនោះហើយ ត្រាស់ហៅព្រះសារីបុត្តត្ថេរមក ត្រាស់សួរបញ្ហាប្រារព្ធឥន្ទ្រិយ ៥ យ៉ាងនេះថា ម្នាលសារីបុត្ត អ្នកជឿឬ ឥន្ទ្រិយ គឺសទ្ធាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងឈមចុះដល់អមតៈ មានអមតៈជាទីបំផុត ។ ព្រះថេរៈទូលដោះស្រាយបញ្ហានោះយ៉ាងនេះថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គ

រមែងមិនដល់នូវការជឿចំពោះព្រះដ៏មានព្រះភាគក្នុងឥន្ទ្រិយ ៥ នេះឯងថា ឥន្ទ្រិយ គឺសទ្ធា ។បេ។ មានអមតៈជាទីបំផុត ខ្ញុំព្រះអង្គចម្រើនឥន្ទ្រិយ គឺសទ្ធា នោះ ដែលជនទាំងឡាយណាមិនដឹងហើយ មិនស្តាប់ហើយ មិនឃើញហើយ មិនជ្រាបហើយ មិនធ្វើឲ្យជាក់ច្បាស់ហើយ មិនពាល់ត្រូវហើយដោយបញ្ញា ជនទាំងនោះគប្បីដល់ដោយការជឿចំពោះជនដទៃក្នុងឥន្ទ្រិយ ៥ នោះថា ឥន្ទ្រិយ គឺសទ្ធា ។បេ។ មានអមតៈជាទីបំផុត ។ ភិក្ខុទាំងឡាយស្តាប់ពាក្យនោះហើយ ញុំាងកថាឲ្យតាំងឡើយថា ព្រះសារីបុត្តត្ថេរឆ្លើយហើយ ដោយការយល់ខុស នោះឯង ក្នុងថ្ងៃនេះ ព្រះថេរៈមិនជឿចំពោះព្រះសម្មាសម្ពុទ្ធនោះឯង ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលពាក្យដូចម្តេច តថាគតសួរថា ម្នាលសារីបុត្ត អ្នកជឿឬទេថា ឈ្មោះថា បុគ្គលមិនអប់រំឥន្ទ្រិយ ៥ មិនចម្រើនសមថៈ និងវិបស្សនា អាចធ្វើមគ្គ និងផលឲ្យជាក់ច្បាស់មាន សារីបុត្តពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនជឿថា បុគ្គលធ្វើឲ្យជាក់ច្បាស់យ៉ាងនោះ ឈ្មោះថា មាន សារីបុត្តមិនជឿផលវិបាកនៃទានដែលបុគ្គលឲ្យហើយ ឬនៃកម្មដែលបុគ្គលធ្វើហើយ ក៏មិនមែន ម្យ៉ាងទៀត សារីបុត្តមិនជឿគុណរបស់ព្រះរតនត្រ័យរបស់ព្រះពុទ្ធជាដើម ក៏មិនមែន តែសារីបុត្តនោះ មិនដល់នូវការជឿចំពោះបុគ្គលដទៃក្នុងធម៌ គឺឈាន វិបស្សនា មគ្គ និងផលដែលខ្លួនបានចំពោះហើយ ព្រោះដូច្នោះ ទើបសារីបុត្ត ជាបុគ្គលដែលបុគ្គលណាម្នាក់មិនគួរតិះដៀល ។ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថាថា

អស្សទ្ធោ អកតញ្ញូ ច សន្ធិច្ឆេទោ ច យោ នរោ
ហតាវកាសោ វន្តាសោ ស វេ ឧត្តមបោរិសោ ។

នរជនណាមិនជឿអ្នកដទៃផង ស្គាល់ព្រះនិព្វានផង កាត់នូវគ្រឿងត គឺវដ្ដៈផង មានឱកាសកម្ចាត់បង់ហើយផង មានសេចក្តីប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះជាឧត្តមបុរស ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អស្សទ្ធោ** *ជាដើម គប្បីជ្រាបវិគ្គហៈដូច្នេះថា នរៈ ឈ្មោះថា អស្សទ្ធោ ព្រោះអត្ថថា មិនជឿគុណដែលខ្លួនចាក់ធ្លុះហើយដោយពាក្យរបស់ជនដទៃ ឈ្មោះថា អកតញ្ញូ ព្រោះអត្ថថា ជីងព្រះនិព្វានដែលបច្ច័យធ្វើមិនបានហើយ អធិប្បាយថា មានព្រះនិព្វានដែលខ្លួនធ្វើឲ្យជាក់ច្បាស់ហើយ ។ ឈ្មោះថា* **សន្ធិច្ឆេទោ** *ព្រោះអត្ថថា កាត់នូវទី-ត គឺវដ្ដៈ ទី-ត គឺសង្សារ តាំងនៅ ។ ឈ្មោះថា* **ហតាវកាសោ** *ព្រោះអត្ថថា ឱកាសនៃការកើតឡើង ឈ្មោះថា ដែលនរៈកម្ចាត់ហើយ ព្រោះភាពដែលពួជ គឺកុសលកម្ម និងអកុសលកម្មអស់ហើយ ។ ឈ្មោះថា* **វន្តាសោ** *ព្រោះអត្ថថា ការប្រាថ្នាទាំងពួង ឈ្មោះថា នរៈនេះខ្ជាក់ចោលហើយ ព្រោះភាពដែលកិច្ចដែលខ្លួនគួរធ្វើដោយមគ្គ ៤ ដែលខ្លួនធ្វើហើយ ។ នរៈបែបនេះណា នរៈនោះឯង ឈ្មោះថា ឧត្តមបុរស ព្រោះអត្ថថា ដល់នូវភាពខ្ពង់ខ្ពស់ក្នុងបុរសទាំងឡាយដោយភាពដែលលោកុត្តរធម៌ ខ្លួនចាក់ធ្លុះហើយ ។*

ក្នុងកាលចប់ព្រះគាថា ភិក្ខុ ៣០ រូប ដែលនៅព្រៃទាំងនោះ សម្រេច

អរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយហើយ ។

ព្រះធម្មទេសនា មានប្រយោជន៍ដល់មហាជនដ៏សេស ដូច្នេះឯង ។

រឿង ព្រះសារីបុត្តត្ថេរ ចប់

រឿង ព្រះខទិរវនិយរេវតត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះរេវតត្ថេរ ដែលនៅក្នុងព្រៃគគីរ ត្រាស់ព្រះធម្មទេសនានេះថា **គាមេ វា** *ជាដើម ។*

សេចក្តីពិស្តារថា ព្រះសារីបុត្តលះទ្រព្យ ៨៧ កោដិបួសហើយ បបួលបួនស្រី ៣ នាក់ គឺនាងចាលា នាងឧបចាលា នាងសីសុបចាលា និងបួនប្រុស ២ នាក់ គឺចុន្ទ និងឧបសេន ឲ្យបួសហើយ ។ រេវតកុមារម្នាក់ប៉ុណ្ណោះដែលនៅសល់ក្នុងផ្ទះ ។ លំដាប់នោះ ម្តាយលោកគិតថា ឧបតិស្សៈកូនរបស់អញលះទ្រព្យប្រមាណប៉ុណ្ណេះបួសហើយ បបួលបួនស្រី ៣ នាក់ បួនប្រុស ២ នាក់ឲ្យបួសផង រេវតៈម្នាក់ប៉ុណ្ណោះនៅសល់ បើលោកបបួលរេវតៈនេះឲ្យបួសសោត ទ្រព្យរបស់អញមានប្រមាណប៉ុណ្ណេះក៏នឹងវិនាស វង្សត្រកូលនឹងជាប់សូន្យ អញនឹងចងរេវតៈនោះ ដោយការនៅគ្រប់គ្រងផ្ទះ ក្នុងកាលដែលនៅជាកុមារចុះ ។

ចំណែកព្រះសារីបុត្ត ផ្តាំភិក្ខុទាំងឡាយមុនថា អាវុសោ បើរេវតៈចង់

បួស មកសោត លោកគប្បីឲ្យគេបួសដោយគ្រាន់តែមកដល់ប៉ុណ្ណោះ ព្រោះ ញោមស្រីញោមប្រុសរបស់ខ្ញុំជាមនុស្សមិច្ឆាទិដ្ឋិ ។ ប្រយោជន៍អ្វីដោយលោក ទាំងពីរនោះ ដែលវេត:លាមកបួស ខ្ញុំនេះឯងជាមាតា និងបិតារបស់វេត: នោះ ។

មាតារបស់ព្រះសារីបុត្តនោះ បំណងនឹងចងវេតកុមារ ដែលមាន អាយុ ៧ ឆ្នាំប៉ុណ្ណោះ ដោយគ្រឿងចង គឺផ្ទះ ទើបនាំក្មេងស្រីក្នុងត្រកូលដែល មានជាតិស្មើគ្នា កំណត់ថ្ងៃហើយ ប្រជាប់តាក់តែងកុមារហើយ បាននាំទៅកាន់ ផ្ទះរបស់ញាតិខាងស្រី មួយអន្ទើដោយបរិវារជាច្រើន ។ លំដាប់នោះ កាល ពួកញាតិរបស់គេទាំងពីរធ្វើការមង្គល ប្រជុំគ្នាហើយ ពួកញាតិឲ្យគេទាំងពីរ ជ្រលក់ដៃក្នុងថាសទឹកហើយ ពោលមង្គលទាំងឡាយ ច្រូចថ្នាសេចក្តីចម្រើន ដល់ក្មេងស្រី ទើបពោលថា ចូរនាងឃើញធម៌ដែលយាយរបស់នាងឃើញ ហើយ ចូរនាងរស់នៅអស់កាលយឺនយូរដូចយាយ ។ វេតកុមារក៏បានគិត ថា នេះអ្វីហ្ន៎ ឈ្មោះថា ធម៌ដែលយាយឃើញហើយ ទើបសួរថា អ្នកណា ជាយាយរបស់ទារិកា ។ លំដាប់នោះ ពួកញាតិច្រូចវេត:ថា នែចា លោក យាយនេះមានអាយុ ១២០ ឆ្នាំ មានធ្មេញចាក់ សក់ស្កូវ ស្បែកជ្រីវជ្រួញ ខ្លួនញ័រទ្រើក ខ្នងកោងដូចបង្គង់ផ្ទះ អ្នកមិនឃើញទេឬ ន៎ុះជាជីដូនរបស់ ទារិកានោះ វេត:សួរថា ទារិកានេះនឹងទៅជាយ៉ាងនោះឬ ពួកញាតិពោលថា បើនាងរស់នៅ សោត ក៏នឹងទៅជាយ៉ាងនោះ ។

វេត:នោះគិតថា ឈ្មោះថា សរីរៈបែបនេះ នឹងដល់នូវប្រការប្រែប្រួល

នេះព្រោះជវា ឧបតិស្សៈបង ប្រុសអញ្ជាឃើញហេតុនេះហើយ អញគួរតែគេច ចេញទៅបួសក្នុងថ្ងៃនេះឯង ពេលនោះ ពួកញាតិពន្ធីឯកាន់យានតែមួយ ជាមួយទាវិកានាំចេញទៅហើយ វេតៈទៅបានបន្តិច អាឯជល់ការបន្ទោបង់ ឧច្ចារៈ ពោលថា ចូរអ្នកទាំងឡាយបញ្ឈប់យានសិន ខ្ញុំចុះទៅហើយនឹង ត្រឡប់មក ដូច្នោះហើយ ចុះអំពីយានបង្អែបង្អង់បន្តិចត្រង់គុម្ពឈើមួយ ហើយទើបទៅ ។ ទៅបានបន្តិចហើយ ចុះទៅដោយការអាឯនោះឯងទៀត ទ្បើងហើយ ក៏បានធ្វើយ៉ាងនោះដូចគ្នាទៀត ។

លំដាប់នោះ ពួកញាតិកំណត់ថា វេតៈនេះបំណងទៅពិតៗ ទើបមិន បានធ្វើការរក្សាឲ្យតឹងរ៉ឹង ។ វេតៈទៅបានបន្តិច ក៏ចុះទៅដោយការអាឯនោះ ឯងទៀត ពោលថា សូមពួកលោកបរទៅខាងមុខ ខ្ញុំនឹងដើរសន្សឹមៗ អំពីក្រោយ ទើបចុះទៅហើយ បែរមុខទៅកាន់គុម្ពោតព្រៃ ។

ពួកញាតិរបស់វេតៈ បរយានទៅដោយសម្គាល់ថា វេតៈនឹងមកតាម ក្រោយ ចំណែកវេតៈនោះគេចទៅអំពីទីនោះហើយ ទៅកាន់សម្នាក់របស់ ភិក្ខុប្រមាណ ៣០ រូប ដែលនៅក្នុងប្រទេសមួយកន្លែង ថ្វាយបង្គំហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយឲ្យខ្ញុំបួសចុះ ភិក្ខុ ទាំងឡាយសួរថា អាវុសោ អ្នកប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង ពួក អាត្មាមិនស្គាល់ថា អ្នកជាព្រះរាជឱរស ឬជាកូនរបស់អមាត្យ នឹងឲ្យបួស ដូចម្តេចបាន វេតៈពោលថា លោកម្ចាស់មិនស្គាល់ខ្ញុំឬ ពួកភិក្ខុពោលថា អើ អាវុសោ វេតៈពោលថា ខ្ញុំជាប្អូនប្រុសរបស់ឧបតិស្សៈ ពួកភិក្ខុពោលថា

ឈ្មោះឧបតិស្សៈនោះជាអ្នកណា វេតៈពោលថា លោកម្ចាស់ទាំងឡាយហៅបងប្រុសខ្ញុំថា សារីបុត្ត ព្រោះដូច្នោះ កាលខ្ញុំប្រាប់ថាឧបតិស្សៈ ទើបលោកម្ចាស់ទាំងឡាយមិនស្គាល់ ។ ពួកភិក្ខុពោលថា អ្នកជាប្អូនប្រុសរបស់ព្រះសារីបុត្តឬ វេតៈពោលថា យ៉ាងនោះឯង លោកម្ចាស់ ។

ភិក្ខុទាំងនោះពោលថា បើដូច្នោះ មកចុះ បងប្រុសរបស់អ្នកអនុញ្ញត្តហើយផងដែរ ដូច្នេះហើយ ឲ្យដោះគ្រឿងអាភរណៈចេញ ព្យួរក្នុងទីបំផុតនាចំណែកម្ខាង ឲ្យបួសហើយ ទើបបញ្ជូនដំណឹងដល់ព្រះថេរៈ ។

ព្រះថេរៈស្តាប់ដំណឹងនោះហើយ ក៏ក្រាបទូលដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ ភិក្ខុទាំងឡាយឲ្យដំណឹងមកថា ពួកភិក្ខុដែលនៅព្រៃឲ្យវេតៈបួស ខ្ញុំព្រះអង្គទៅសួរសុខទុក្ខលោកហើយ នឹងត្រឡប់មក ។

ព្រះសាស្តា ទ្រង់មិនព្រមឲ្យទៅ ដោយព្រះតម្រាស់ថា សារីបុត្ត ចូរអ្នកបង្អង់សិន ។ ដោយកាលកន្ទងទៅ ២-៣ ថ្ងៃ ព្រះថេរៈក៏ទូលលាព្រះសាស្តាម្តងទៀត ។ ព្រះសាស្តាទ្រង់មិនអនុញ្ញត្តឲ្យទៅ ដោយព្រះតម្រាស់ថា សារីបុត្ត ចូរបង្អង់សិន ព្រោះតថាគតក៏នឹងទៅ ។

ចំណែកសាមណេរគិតថា បើអញនៅក្នុងទីនេះសោត ពួកញាតិនឹងឲ្យមនុស្សតាមហៅអញត្រឡប់ ទើបរៀនកម្មដ្ឋានរហូតអរហត្ត អំពីសម្នាក់របស់ភិក្ខុទាំងនោះ កាន់បាត្រ និងចីវរ ត្រាច់ទៅដល់ព្រៃគីរ ក្នុងទីប្រមាណ ៣០ យោជន៍អំពីទីនោះ ។ ក្នុងរវាង ៣ ខែ ខាងក្នុងវស្សានោះឯង សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយ ។

ព្រះថេរៈបវារណាហើយ ទូលលាព្រះសាស្តាដើម្បីទៅក្នុងទីនោះទៀត ព្រះសាស្តាត្រាស់ថា សារីបុត្ត ឯតថាគតក៏ទៅ ទ្រង់យាងទៅមួយអន្ទើដោយភិក្ខុ ៥០០ រូប ។ ក្នុងពេលយាងទៅបានបន្តិច ព្រះអានន្ទត្ថេរឈរត្រង់ផ្លូវបែកជាពីរ ក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ បណ្តាផ្លូវដែលទៅកាន់សម្នាក់របស់វេរតៈ ផ្លូវនេះជាផ្លូវអមប្រមាណ ៦០ យោជន៍ ជាទីនៅរបស់មនុស្ស ផ្លូវនេះជាផ្លូវត្រង់ប្រមាណ ៣០ យោជន៍ ដែលអមនុស្សគ្រប់គ្រង ពួកយើងទៅដោយផ្លូវណា ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ សីវលីមកជាមួយពួកយើងដែរឬទេ ព្រះអានន្ទទូលថា បពិត្រព្រះអង្គ សីវលីមកដែរ ព្រះសាស្តាត្រាស់ថា បើសីវលីមក ចូរអ្នកកាន់យកផ្លូវត្រង់នោះឯង ។

បានឮថា ព្រះសាស្តាមិនបានត្រាស់ថា តថាគតនឹងញុំាងបបរ ជាយឲ្យកើតឡើងដល់ពួកអ្នក ចូរពួកអ្នកកាន់យកផ្លូវត្រង់ ទ្រង់ជ្រាបថា ទីនោះ ជាទីឲ្យផលនៃបុណ្យដល់ជននោះៗ ទើបត្រាស់ថា បើសីវលីមក ចូរអ្នកកាន់យកផ្លូវត្រង់ ។ កាលព្រះសាស្តាទ្រង់យាងទៅផ្លូវនោះ ពួកទេវតាគិតថា ពួកយើងនឹងធ្វើសក្ការៈដល់ព្រះសីវលិត្ថេរ លោកម្ចាស់របស់យើង ជានិម្មិតវិហារក្នុងទីមួយយោជន៍ ១ មួយយោជន៍ ១ មិនឲ្យឆ្ងាយជាងមួយយោជន៍ ក្រោកឡើងអំពីព្រលឹមកាន់យកវត្ថុ មានបបរជាដើមដែលជាទិព្វ ហើយដើរទៅដោយតាំងចិត្តថា ព្រះសីវលិត្ថេរ លោកម្ចាស់របស់យើង គង់ក្នុងទីណា ។

ព្រះថេរៈឲ្យទេវតាប្រគេនភត្ត ដែលនាំមកដើម្បីខ្ជួនដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ព្រះសាស្តា មួយអន្ទើដោយបរិវារ សោយផលបុណ្យរបស់

ព្រះសីវលិត្ថេរតែមួយអង្គ បានយាងកាត់ផ្លូវកន្លារប្រមាណ ៣០ យោជន៍ ។

ចំណែកព្រះរេវតត្ថេរ ជ្រាបការយាងមករបស់ព្រះសាស្តា ទើបនិម្មិតព្រះគន្ធកុដិជើម្បីព្រះដ៏មានព្រះភាគ និម្មិតផ្ទះកំពូល ៥០០ ទីចង្រ្កម ៥០០ ទី សម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ៥០០ ។ ព្រះសាស្តា ប្រថាប់នៅក្នុងសម្នាក់របស់ព្រះរេវត:នោះអស់កាលប្រមាណ ១ ខែដូច្នេះ សូម្បីប្រថាប់នៅក្នុងទីនោះ ក៏សោយផលបុណ្យរបស់ព្រះសីវលិត្ថេរនោះឯង ។

បណ្តាភិក្ខុទាំងនោះ ភិក្ខុចាស់ពីររូប ក្នុងពេលព្រះសាស្តាយាងចូលទៅកាន់ព្រៃគគីរ គិតហើយយ៉ាងនេះថា ភិក្ខុនេះធ្វើនវកម្ម គឺកសាងប្រមាណប៉ុណ្ណេះនឹងអាចធ្វើសមណធម៌បានដូចម្តេច ព្រះសាស្តាទ្រង់ធ្វើកិច្ច គឺការយល់មុខដោយទ្រង់ព្រះតម្រិះថា ជាប្អូនប្រុសរបស់ព្រះសារីបុត្ត ទើបយាងមកកាន់សម្នាក់របស់លោក ដែលប្រកបនវកម្មបែបនេះ ។

ក្នុងថ្ងៃនោះ ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញភិក្ខុទាំងនោះហើយ ទ្រង់ជ្រាបវារ:ចិត្តរបស់ភិក្ខុទាំងនោះហើយ ព្រោះហេតុនោះ ប្រថាប់នៅក្នុងទីនោះអស់កាលប្រមាណ ១ ខែហើយ ក្នុងថ្ងៃយាងចេញទៅ ទ្រង់អធិដ្ឋានឲ្យភិក្ខុទាំងនោះភ្ជួចបំពង់ប្រេង បំពង់ទឹក តម្រង ទឹក និងស្បែកជើងរបស់ខ្លួនយាងចេញទៅ ក្នុងពេលយាងចេញទៅខាងក្រៅឧបចារវិហារ ទើបព្រះថេរ:រំសាយឫទ្ធិ ។

គ្រានោះ ភិក្ខុទាំងនោះពោលថា ខ្ញុំភ្លេចរបស់នេះ និងរបស់នេះ ខ្ញុំក៏ភ្លេច

ដូច្នេះហើយ ទាំងពីររូបក៏ត្រឡប់ទៅ មិនកំណត់ទីនោះ ត្រូវបន្ទាគគីរ[1] មុត គ្រាច់ទៅ ជួបរបស់ដែលខ្ជិនក្ងេច ព្យួរត្រង់ដើមគគីរមួយដើម កាន់យក ហើយ ក៏ចៀសចេញទៅ ។

ព្រះសាស្តា ទ្រង់នាំភិក្ខុសង្ឃទៅ សោយផលបុណ្យរបស់ព្រះសីវលី អស់កាលប្រមាណ ១ ខែនោះឯងទៀត ឃាងចូលទៅកាន់បុព្វារាម ។ គ្រានោះ ភិក្ខុចាស់ទាំងនោះលុបមុខអំពីព្រលឹម ដើរទៅដោយតាំងចិត្តថា ពួកយើងនឹងឆាន់បបរក្នុងផ្ទះរបស់នាងវិសាខា ដែលថ្វាយអាគន្តុកភត្ត ឆាន់បបរ ហើយ ឆាន់របស់ទំពាអង្គុយនៅ ។

លំដាប់នោះ នាងវិសាខាសួរភិក្ខុចាស់ទាំងនោះថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយ បានទៅលំនៅរបស់ព្រះវេតត្តេរជាមួយព្រះសាស្តាឬ ភិក្ខុចាស់ពោលថា អើ ឧបាសិកា នាងវិសាខាពោលថា បពិត្រលោកម្ចាស់ លំនៅរបស់ព្រះថេរៈគួរជាទីត្រេកអរឬ ។ ភិក្ខុចាស់ពោលថា លំនៅរបស់ព្រះថេរៈនោះ ជាទីត្រេកអរមកអំពីណា ទីនោះច្រេងច្រាំងដោយដើមគគីរ មានបន្ទាពណ៌ស ដូចគ្នានឹងលំនៅរបស់ពួកប្រេត ។

គ្រានោះ ភិក្ខុកំលោះពីររូបដទៃមកហើយ ។ ឧបាសិកាប្រគេនបបរ និង របស់គួរទំពាទាំងឡាយ ដល់ភិក្ខុកំលោះទាំងនោះហើយ សួរយ៉ាងនោះដូចគ្នា ភិក្ខុទាំងនោះពោលថា ឧបាសិកា ពួកអាត្មាមិនអាចពណ៌នាបាន លំនៅរបស់

១- ដើមគគីរមិនមានបន្ទាទេ តែដោយបាលី លោកពោលថា ខទិរវនកណ្ដកេហិ ទើបយើងប្រែថា បន្ទាគគីរ ។

ព្រះថេរៈដូចគ្នានឹងទេវសភា ឈ្មោះសុធម្មា តាក់តែងដោយឫទ្ធិ ។

ឧបាសិកាគិតថា ភិក្ខុដែលមកមុនពោលមួយបែប ភិក្ខុពួកនេះពោលមួយបែប ភិក្ខុដែលមកមុនភ្លេចរបស់អ្វីមួយពិត ត្រឡប់ទៅក្នុងកាលដែលឫទ្ធិរំសាយហើយ ចំណែកភិក្ខុទាំងនេះ នឹងទៅក្នុងពេលដែលព្រះថេរៈនិម្មិតទីកន្លែងដោយឫទ្ធិ ព្រោះភាពដែលខ្លួនជាបណ្ឌិតទើបជ្រាបសេចក្តីនោះ បានឈរហើយបំណងថា នឹងទូលសួរក្នុងកាលដែលព្រះសាស្តាយាងមក មួយរំពេចនោះឯង ព្រះសាស្តាដែលភិក្ខុសង្ឃចោមរោម យាងទៅកាន់ផ្ទះរបស់នាងវិសាខា ប្រថាប់គង់លើអាសនៈដែលគេរៀបចំហើយ នាងអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដោយគោរព ក្នុងពេលស្រេចភត្តកិច្ច ថ្វាយបង្គំព្រះសាស្តាហើយទូលសួរចំពោះថា បពិត្រព្រះអង្គ បណ្តាភិក្ខុដែលទៅជាមួយព្រះអង្គ ភិក្ខុពួកខ្លះ ពោលថា លំនៅរបស់ព្រះរេវតៈ ជាព្រៃស្តុកដោយដើមគគីរ ពួកខ្លះពោលថា ជាទីគួរត្រេកអរ តើលំនៅរបស់ព្រះថេរៈនោះ ដូចម្តេចហ្ន៎ ។

ព្រះសាស្តា ស្តាប់ពាក្យនោះហើយ ត្រាស់ថា ឧបាសិកា ស្រុកក្តី ព្រៃក្តី ព្រះអរហន្តទាំងឡាយនៅក្នុងទីណា ទីនោះ គួរត្រេកអរពិត ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

គាមេ វា យទិ វា រញ្ញេ និន្នេ វា យទិ វា ថលេ
យត្ថ អរហន្តោ វិហរន្តិ តំ ភូមិរាមណេយ្យកំ ។

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី ទីទាបក្តី ទីទួលក្តី ទីនោះឯងជាភូមិគួរត្រេកអរ ។

សេចក្តីអធិប្បាយ

ក្នុងព្រះគាថានោះ សេចក្តីថា ព្រះអរហន្តទាំងឡាយរមែងមិនបានកាយវិវេកខាងក្នុងស្រុកក៏ពិត តែរមែងបានចិត្តវិវេកយ៉ាងពិតប្រាកដ ព្រោះអារម្មណ៍ទាំងឡាយប្រៀបដូចរបស់ទិព្វ រមែងមិនអាចធ្វើចិត្តរបស់ព្រះអរហន្តទាំងនោះឲ្យញាប់ញ័របាន ព្រោះហេតុនោះ ទោះជាស្រុក ឬជាទីណាមួយ មានព្រៃជាដើម ព្រះអរហន្តទាំងឡាយ រមែងនៅក្នុងទីណា ។ បានព្រះគាថាថា **តំ ភូមិរាមណេយ្យកំ** សេចក្តីថា ភូមិស្ថាននោះ ជាទីគួរត្រេកអរពិត ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ក្នុងសម័យដទៃទៀត ភិក្ខុទាំងឡាយសន្ទនាគ្នាថា អាវុសោទាំងឡាយ ព្រោះហេតុអ្វីហ្ន៎ ទើបព្រះសីវលិត្ថេរនៅក្នុងផ្ទៃមាតារហូត ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ព្រោះកម្មអ្វី ទើបឆេះហើយក្នុងនរក ព្រោះកម្មអ្វី ទើបជាអ្នកមានលាភដ៏ក្រៃលែង និងមានយសដ៏ក្រៃលែងយ៉ាងនេះ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំង-ឡាយ ពួកអ្នកសន្ទនាអំពីរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ កថាឈ្មោះនេះ ដូច្នេះហើយ កាលនឹងត្រាស់បុព្វកម្មរបស់ព្រះសីវលិត្ថេរនោះ ទើបត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះដ៏មានព្រះភាគព្រះនាមវិបស្សី ទ្រង់កើតឡើងក្នុងលោកហើយ សម័យមួយ ទ្រង់យាងចារិកទៅក្នុងជនបទ ត្រឡប់មកកាន់នគរបស់ព្រះបិតា ។ ព្រះរាជាទ្រង់ត្រៀម

អាគន្តុកទានដើម្បីភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទ្រង់បញ្ជូនដំណឹងដល់អ្នកនគរថា ចូរជនទាំងឡាយ មកជាសម្ងាញ់របស់យើង ។ ជនទាំងនោះធ្វើយ៉ាងនោះហើយគិតថា ពួកយើងនឹងថ្វាយទាន ឲ្យក្រៃលែងជាងទានដែលព្រះរាជាថ្វាយហើយ ទើបទូលនិមន្តព្រះសាស្តា ក្នុងថ្ងៃស្អែកឡើង តាក់តែងទានហើយ បញ្ជូនដំណឹងទៅទូលដល់ព្រះរាជា ។ ព្រះរាជាយាងមកទតឃើញទានរបស់ជនទាំងនោះហើយ ទ្រង់ព្រះតម្រិះថា អញនឹងថ្វាយទានឲ្យក្រៃលែងជាងទាននេះ ក្នុងថ្ងៃស្អែកឡើង ទ្រង់និមន្តព្រះសាស្តាហើយ ។ ព្រះរាជាទ្រង់មិនអាចឲ្យអ្នកនគរចុះចាញ់បាន សូម្បីអ្នកនគរក៏មិនអាចឲ្យព្រះរាជាចាញ់បាន ។ ក្នុងគ្រាទី ៦ អ្នកនគរគិតថា ឥឡូវនេះ ពួកយើងនឹងថ្វាយទានក្នុងថ្ងៃស្អែកនេះ ដោយប្រការដែលបុគ្គលណាម្នាក់មិនអាចពោលបានថា មិនមានវត្ថុឈ្នោះនេះក្នុងទានរបស់ជនទាំងនោះ ដូច្នេះហើយ ក្នុងថ្ងៃស្អែកឡើង ចាត់ចែងរបស់ថ្វាយស្រេចហើយ ពិនិត្យមើលថា អ្វីហ្ន៎ មិនទាន់មានក្នុងទាននេះ ក៏មិនបានឃើញទឹកឃ្មុំផៅ ចំណែកទឹកឃ្មុំឆ្អិនមានច្រើន ។ ជនទាំងនោះ បានកាន់យកទ្រព្យ ៤ ពាន់ហើយ បញ្ជូនទៅក្នុងទ្វារនៃព្រះនគរទាំង ៤ ដើម្បីទឹកឃ្មុំផៅ ។

គ្រានោះ អ្នកស្រុកក្រៅម្នាក់ មកសួរសុខទុក្ខមេស្រុក ឃើញសម្បុកឃ្មុំក្នុងរវាងផ្លូវ ដេញមេឃ្មុំឲ្យហើរទៅហើយ កាប់មែកឈើត្រង់បង្គន់ មួយអន្ទឹដោយក្បាលទឹកនោះឯង ចូលទៅកាន់ព្រះនគរដោយតាំងចិត្តថា អញនឹងឲ្យដល់មេស្រុក ។ បុរសដែលទៅដើម្បីរកទឹកឃ្មុំ ជួបបុរសស្រុកក្រៅនោះហើយ សួរថា នែអ្នក ទឹកឃ្មុំរបស់អ្នកលក់ដែរឬទេ អ្នកស្រុកក្រៅពោលថា

មិនលក់ទេ បុរសនោះពោលថា សូមអ្នកទទួលយកកហាបណៈនេះ ហើយ ឲ្យឃ្មុំដល់ខ្ញុំចុះ អ្នកស្រុកក្រៅនោះគិតថា ឃ្មុំនេះមានតម្លៃត្រឹមតែមួយបាទ តែបុរសនេះឲ្យមួយកហាបណៈ ប្រហែលជាមានកហាបណៈច្រើន អញគួរ ជំទ្បើងតម្លៃ ។ លំដាប់នោះ ទើបគាត់ឆ្ងើយនឹងបុរសនោះថា ខ្ញុំឲ្យមិនបានទេ បុរសនោះពោលថា បើដូច្នេះ សូមអ្នកទទួលយក ២ កហាបណៈចុះ អ្នក ស្រុកក្រៅពោលថា សូម្បី ២ កហាបណៈក៏ខ្ញុំឲ្យមិនបាន ។

គេជំទ្បើងតម្លៃដោយអាការយ៉ាងនោះ រហូតដល់បុរសនោះពោលថា បើដូច្នោះ សូមអ្នកទទួលយកទ្រព្យមួយពាន់កហាបណៈនេះ ដូច្នេះហើយ ហុច កញ្ចប់កណ្ហៈទៅ ។ ពេលនោះ អ្នកស្រុកក្រៅពោលនឹងបុរសនោះថា អ្នកឆ្កួត ឬហ្ន៎ ឬមិនបានឱកាសជាទីទុកកហាបណៈ ទឹកឃ្មុំនេះតម្លៃមិនដល់មួយបាទ អ្នក នៅតែពោលថា សូមយកកហាបណៈមួយពាន់ ហើយឲ្យឃ្មុំដល់ខ្ញុំ ឈ្មោះថា មានហេតុដូចម្តេច បុរសនោះពោលថា នែអ្នក ខ្ញុំជីងកម្មរបស់ខ្ញុំដោយទឹកឃ្មុំ នេះមាន ព្រោះហេតុនោះ ទើបខ្ញុំពោលយ៉ាងនោះ អ្នកស្រុកក្រៅពោលថា តើ កម្មនោះជាកម្មអ្វី បុរសនោះពោលថា ពួកខ្ញុំត្រៀមធ្វើមហាទានដើម្បីព្រះវិបស្សី សម្មាសម្ពុទ្ធ ដែលមានសមណៈ ៦ លាន ៨ សែនជាបរិវារ ក្នុងមហាទាន នោះ ខ្វះតែទឹកឃ្មុំតៅប៉ុណ្ណោះ ព្រោះដូច្នោះ ទើបខ្ញុំសុំទិញដោយអាការយ៉ាង នោះ អ្នកស្រុកក្រៅពោលថា បើយ៉ាងនោះ ខ្ញុំឲ្យដោយមិនគិតថ្លៃ បើខ្ញុំបាន ចំណែកបុណ្យខ្លះ ក្នុងទាននោះសោត ។

បុរសនោះ ទៅប្រាប់សេចក្តីនោះដល់អ្នកនគរ អ្នកនគរកាលជ្រាបភាព

ដែលសទ្ធារបស់គាត់មានកម្លាំង ទើបទទួលថា សាធុ សូមបុរសនោះបានចំណែកបុណ្យចុះ ។ ពួកអ្នកនគរនោះនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យគង់ហើយ ថ្វាយបបរ និងរបស់ទំពា ឲ្យមនុស្សនាំថាសមាសយ៉ាងធំ មកច្របាច់សម្បុកឃ្មុំហើយ សូម្បីបំពង់ទឹកដោះដែលមនុស្សនោះនាំមក ដើម្បីជាវង្វាន់មាន ។ គេចាក់ទឹកដោះនោះចូលក្នុងថាសហើយ លាយជាមួយទឹកឃ្មុំនោះ ប្រគេនដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ចាប់តាំងអំពីដើមអាសនៈ ។ ទឹកឃ្មុំនោះទូទៅដល់ភិក្ខុគ្រប់រូប ដែលទទួលយកហូតគ្រប់គ្រាន់ តាមសេចក្តីត្រូវការបានសល់ហូរហៀរ ។ បុគ្គលណាម្នាក់មិនគួរគិតថា ទឹកឃ្មុំតិចយ៉ាងនោះ គ្រប់គ្រាន់ដល់ភិក្ខុច្រើនដល់ម្ល៉ោះបានដូចម្តេច ពិតហើយ ទឹកឃ្មុំនោះគ្រប់គ្រាន់ បានដោយអានុភាពនៃព្រះសម្ពុទ្ធ ។ ពុទ្ធវិស័យ បុគ្គលមិនគួរគិត ។ ពិតហើយ ហេតុ ៤ យ៉ាង ដែលព្រះដ៏មានព្រះភាគត្រាស់ថា ជារឿងដែលមិនគួរគិត ។ បុគ្គលណាម្នាក់គិតហេតុទាំងនោះ រមែងជាអ្នកមានចំណែកនៃមនុស្សឆ្កួតនោះឯង ដោយប្រការដូច្នេះ ។

បុរសនោះ ធ្វើកម្មប្រមាណប៉ុណ្ណោះហើយ ក្នុងកាលជាទីបំផុតនៃអាយុ កើតក្នុងទេវលោក អន្ទោលទៅមកអស់កាលមានប្រមាណប៉ុណ្ណោះ ក្នុងសម័យមួយ ចុតិអំពីទេវលោកមកកើតក្នុងរាជត្រកូល ក្នុងនគរពារាណសី ដោយកាលដែលព្រះជនកសោទិវង្គត ដល់នូវភាពជាព្រះរាជាហើយ ។ ទ្រង់ព្រះតម្រិះថា នឹងដណ្តើមយកនគរមួយ ទើបយាងទៅព័ទ្ធនគរនោះ ហើយទ្រង់បញ្ជូនសាសន៍ទៅដល់អ្នកនគរថា ឲ្យរាជសម្បត្តិ ឬក៏ច្បាំង អ្នកនគរទាំងនោះ

ឆ្លើយថា នឹងមិនឲ្យទាំងរាជសម្បត្តិ នឹងមិនឲ្យទាំងការច្បាំង ដូច្នេះហើយ ក៏ចេញទៅនាំខ្ញុស និងទឹកជាដើមមកតាមទ្វារតូចៗ ធ្វើកិច្ចគ្រប់យ៉ាង ។

ចំណែកព្រះរាជា រក្សាទ្វារធំទាំង ៤ ព័ទ្ធព្រះនគរអស់ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ។ ក្នុងកាលតមក ព្រះជនន៏របស់ព្រះរាជានោះត្រាស់សួរថា បុត្ររបស់យើងធ្វើដូចម្តេច ព្រះនាងស្តាប់រឿងនោះថា ទ្រង់ធ្វើកម្មឈ្មោះនេះ ទើបត្រាស់ថា បុត្ររបស់ខ្ញុំល្ងង់ ចូរពួកអ្នកទៅទូលដល់បុត្ររបស់យើងនោះថា ចូរបិទទ្វារតូចៗ ព័ទ្ធព្រះនគរ ។ ព្រះរាជាទ្រង់ស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជនន៏ហើយ ក៏បានធ្វើយ៉ាងនោះ ។

ចំណែកអ្នកក្រុង កាលមិនបានចេញទៅខាងក្រៅ ក្នុងថ្ងៃទី ៧ ទើបផ្តាច់ព្រះជន្មព្រះរាជារបស់ខ្លួន ថ្វាយរាជសម្បត្តិដល់ព្រះរាជានោះ ។ ទ្រង់ធ្វើកម្មនេះហើយ ក្នុងទីបំផុតនៃអាយុទៅកើតក្នុងអវីចី នេះហើយក្នុងនរកជាបជាប់ផែនដីដុះឡើងប្រមាណមួយយោជន៍ ចុតិអំពីអត្តភាពនោះហើយ បដិសន្ធិក្នុងផ្ទៃរបស់មាតានោះឯង នៅក្នុងផ្ទៃអស់ ៧ ឆ្នាំ ៧ ខែ នៅទទឹងទ្វារមាសអស់ ៧ ថ្ងៃ ព្រោះភាពដែលខ្លួនបិទទ្វារតូចៗ ទាំង ៤ ។

ម្នាលភិក្ខុទាំងឡាយសីវលីនេះហើយក្នុងនរកអស់កាលប្រមាណប៉ុណ្ណោះ ព្រោះកម្មដែលព័ទ្ធព្រះនគរ ជណ្តើមយកក្នុងកាលនោះ បដិសន្ធិក្នុងផ្ទៃរបស់មាតានោះឯង នៅក្នុងផ្ទៃអស់កាលប្រមាណប៉ុណ្ណោះ ព្រោះសីវលីបិទទ្វារតូចៗ ទាំង ៤ ជាអ្នកដល់នូវភាពជាបុគ្គលមានលាភដ៏កំពូល មានយសដ៏កំពូល ព្រោះសីវលីបានថ្វាយទឹកឃ្មុំស្រស់ ដោយប្រការយ៉ាងនេះ ។

ក្នុងថ្ងៃស្អែកឡើង ភិក្ខុទាំងឡាយសន្ទនាគ្នាថា សាមណេរតែមួយរូប និម្មិតផ្ទះកំពូល ៥០០ ដើម្បីភិក្ខុ ៥០០ រូប មានលាភ មានបុណ្យគួរសរសើរពិតហ្នឹ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញពួកអ្នកអង្គុយប្រជុំគ្នាដោយកថាដូចម្តេចហ្នឹ កាលភិក្ខុទាំងនោះក្រាបទូលថាបពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតមិនមានបុណ្យ មិនមានបាប ព្រោះបុណ្យនិងបាបទាំងពីរ បុត្រតថាគតលះហើយ បានត្រាស់ព្រះគាថានេះនៅក្នុងព្រាហ្មណវគ្គថា

> បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យ និងបាបទាំង ២ និងកិលេសជាគ្រឿងជំពាក់ (មានរាគៈជាដើម) ចេញហើយ តថាគតហៅបុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តីសោកមានធូលី គឺកិលេសអស់ហើយ ជាអ្នកបរិសុទ្ធថាជាព្រាហ្មណ៍។

រឿង ព្រះទធិរវនិយរេវតត្តេរ ចប់

រឿង អញ្ញតរិត្ថី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្រីម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **រមណីយាធិ** ជាដើម ។

បានឮមកថា កិក្ខុសមាទានបិណ្ឌបាតមួយរូប រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តាហើយ ចូលទៅកាន់ឧទ្យានដែលគេចោះបង់មួយ ធ្វើសមណ-ធម៌ ។ គ្រានោះ ស្រីដែលធ្វើឲ្យនគរស្អាតម្នាក់ ធ្វើការណាត់ជាមួយបុរសថា ខ្ញុំនឹងទៅកាន់ទីឈ្មោះនោះ អ្នកគប្បីមកក្នុងទីនោះ បានទៅហើយ ។ បុរសនោះមិនមក នាងចាំមើលផ្លូវបុរសនោះមិនឃើញ អផ្សុកកើតឡើង ទើបត្រាច់ទៅខាងនោះខាងនេះ ចូលទៅកាន់ឧទ្យាននោះ ជួបព្រះថេរៈកំពុងអង្គុយពត់ក្អែន សម្លឹងមើលឆ្វេងស្តាំមិនឃើញអ្នកដទៃ គិតថា បុគ្គលនេះក៏ជាប្រុសដូចគ្នា អញនឹងញុំាងចិត្តរបស់បុគ្គលនេះឲ្យវង្វេង ឈរខាងមុខរបស់ព្រះថេរៈនោះ ដោះសំពត់ស្បៃកហើយ ធ្វើជាស្បៃកវិញរឿយៗ រំសាយសក់ហើយចងវិញ ទះដៃ ហើយសើច ។

ការសង្វេគកើតឡើងដល់ព្រះថេរៈ ផ្សាយជ្រួតជ្រាបពេញសរីរៈ លោកគិតថា មានរឿយអ្វីហ្ន៎ ។

ចំណែកព្រះសាស្តាទ្រង់ពិចារណាថា ការប្រព្រឹត្តទៅរបស់កិក្ខុដែលរៀនកម្មដ្ឋានអំពីសម្នាក់របស់តថាគត ទៅហើយ ដោយតាំងចិត្តថា នឹងធ្វើសមណធម៌ យ៉ាងណាហើយហ្ន៎ ទ្រង់ឃើញស្រីនោះហើយ ទ្រង់ជ្រាបកិរិយា

អនាចាររបស់ស្រីនោះ នឹងការកើតឡើងនៃសេចក្តីសង្វេគរបស់ព្រះថេរៈ ប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ត្រាស់នឹងព្រះថេរៈថា ម្នាលកិកុ ទីដែលមិនត្រេកអររបស់ពួកបុគ្គលអ្នកស្វែងរកកាមនោះឯង ជាទីត្រេកអររបស់បុគ្គលដែលមានរាគៈទៅប្រាសហើយ ។ កាលទ្រង់ត្រាស់យ៉ាងនោះហើយ ទ្រង់បញ្ចេញឱកាសទៅ កាលទ្រង់សម្តែងធម៌ដល់កិកុនោះ ត្រាស់ព្រះគាថានេះថា

រមណីយានិ អរញ្ញានិ យត្ថ ន រមតី ជនោ
វីតរាគា រមេស្សន្តិ ន តេ កាមគវេសិនោ ។

ជន (អ្នកស្វែងរកកាម) រមែងមិនត្រេកអរក្នុងព្រៃដែលគួររីករាយទេ ព្រះខីណាស្រពដែលមានរាគៈទៅប្រាសហើយ ទើបត្រេកអរក្នុងព្រៃនោះ ព្រោះលោកជាអ្នកមិនស្វែងរកកាម ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អរញ្ញានិ** *សេចក្តីថា ធម្មតាព្រៃទាំងឡាយដែលប្រជាប់ដោយដងព្រៃ មានដើមឈើជំទង់ៗ មានផ្តាំរីកហើយ សម្បូរដោយទឹកថ្លាស្អាត ជាទីគួរត្រេកអរ ។ បទថា* **យត្ថ** *ជាដើម សេចក្តីថា ជនអ្នកស្វែងរកកាម រមែងមិនត្រេកអរក្នុងព្រៃទាំងឡាយណា ដូចសត្វរុយស្រុកមិនត្រេកអរក្នុងគូថឈ្លូក ដែលមានផ្តាំរីកហើយ ដូច្នោះ ។*

បទថា **វីតរាគា** *ជាដើម សេចក្តីថា បុគ្គលដែលមានរាគៈទៅប្រាស*

ហើយទាំងឡាយ គឺព្រះខីណាស្រព នឹងត្រេកអរក្នុងព្រៃទាំងឡាយបែបនោះ ដូចកន្ទង់ និងឃ្មុំត្រេកអរក្នុងគុម្ពឈូក ដូច្នោះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះលោកមានរាគៈទៅប្រាសហើយទាំងនោះ ជាអ្នកមានប្រក្រតីមិនស្វែងរកកាម អធិប្បាយថា ព្រោះលោកទាំងនោះ មិនជាអ្នកមានប្រក្រតីស្វែងរកកាមឡើយ ទើបត្រេកអរក្នុងព្រៃទាំងឡាយ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ព្រះថេរៈនោះ អង្គុយតាមប្រក្រតីនោះឯង សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ មកតាមអាកាស ធ្វើនូវការសរសើរ ថ្វាយបង្គំបាទាទាំងទ្វេរបស់ព្រះតថាគត បានទៅហើយ ដូច្នេះឯង ។

រឿងអញ្ញតរិត្ថី ចប់

អរហន្តវគ្គ ចប់

វគ្គទី ៧ ចប់

សុត្តន្តបិដក

ធម្មបទគាថា សហស្សវគ្គទី ៨

[១៨] បើវាចា សូម្បី ១ ពាន់ម៉ាត់ ជាវាចាប្រកបដោយបទឥតប្រយោជន៍ វាចានោះ ពុំប្រសើរឡើយ អ្នកណា ស្តាប់បទមានប្រយោជន៍ណាហើយ រមែងស្ងប់រម្ងាប់បាន បទមានប្រយោជន៍នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

បើគាថា សូម្បី ១ ពាន់ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថានោះ ពុំប្រសើរឡើយ អ្នកណា ស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

អ្នកណា គប្បីពោលគាថា មួយរយ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថាដែលអ្នកនោះពោលហើយនោះ ពុំប្រសើរឡើយ អ្នកណា ស្តាប់បទនៃធម៌ហើយ រមែងស្ងប់រម្ងាប់បាន បទនៃធម៌នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

អ្នកណា គប្បីឈ្នះពួកមនុស្ស ក្នុងសង្គ្រាមអស់ ១ ពាន់ៗ ជង គឺ ១ លាន ចំណែកអ្នកណា ឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះ ឈ្មោះថា ជាមនុស្សខ្ពង់ខ្ពស់ ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ ។

ខ្លួនឯងដែលឈ្នះហើយ ប្រសើរជាង ចំណែកពួកសត្វក្រៅពីនេះដែលគេឈ្នះហើយ មិនប្រសើរឡើយ កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើ

នូវជម្ពុ របស់សត្វមានសភាពដូច្នោះ ឲ្យត្រឡប់ចាញ់វិញបានឡើយ ។

អ្នកណា បូជា (លោកិយមហាជន) ដោយទ្រព្យមួយពាន់រាល់ខែៗ អស់ ១ រយឆ្នាំគត់ ចំណែកអ្នកណា គប្បីបូជាចំពោះបុគ្គលដែលមានខ្លួនអប់រំហើយ តែមួយនាក់ សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាង ការបូជារបស់អ្នកដែលបូជាអស់ ១ រយឆ្នាំនោះ ការបូជាអស់ ១០០ ឆ្នាំ មិនប្រសើរឡើយ ។

ជនណា បម្រើភ្លើងក្នុងព្រៃអស់ ១០០ ឆ្នាំ ចំណែកអ្នកណាបូជាលោកដែលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីមួយរំពេច ការបូជានោះឯងប្រសើរជាងការបូជារបស់ជននោះ ការបូជាអស់ ១០០ ឆ្នាំ មិនប្រសើរឡើយ ។

បុគ្គលអ្នកក្រុថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជា ធំ តូចណាមួយក្នុងលោកអស់ ១ ឆ្នាំ ការបូជាទាំងអស់នោះឯង រមែងមិនដល់នូវចំណែកទី ៤ នៃការអភិវាទន៍ ចំពោះលោកទាំងឡាយ ដែលប្រព្រឹត្តត្រង់ហើយប្រសើរជាង ។

ធម៌ ៤ ប្រការ គឺអាយុ ១ វណ្ណៈ ១ សុខ ១ ពល ១ រមែងចម្រើនដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំជាប្រក្រតី មានសេចក្តីក្រោតក្រែង ដល់បុគ្គលដែលចម្រើនជាងខ្លួន អស់កាលជានិច្ច ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានសីល មានការពិនិត្យពិចារណាជាប្រក្រតី ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានប្រាជ្ញា មានការពិនិត្យពិចារណាជាប្រក្រតី ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមានចិត្តធ្ងន់រេរាក់ក្នុងអកុសលវិតក្ក មានព្យាយាមថោកថយ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលប្រារព្ធសេចក្តីព្យាយាមមាំមួន ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញការកើតឡើង និងការវិនាសទៅ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលឃើញការកើតឡើង និងការវិនាសទៅ ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញផ្លូវព្រះនិព្វាន ការរស់នៅសូម្បីតែ ១ ថ្ងៃ របស់លោកអ្នកឃើញផ្លូវព្រះនិព្វាន ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់ ការរស់នៅសូម្បីតែ ១ ថ្ងៃ របស់លោកអ្នកឃើញធម៌ដ៏ខ្ពង់ខ្ពស់ ប្រសើរជាង ។

សហស្សវគ្គទី ៨ ចប់

អដ្ឋកថា

សហស្សវគ្គ

រឿង តម្ពធាបិកចោរឃាតក

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធពេជ្ឈឃាតមានពុកមាត់ក្រហម ត្រាស់ព្រះធម្មទេសនានេះថា **សហស្សមបិ ចេ វាចា** *ជាដើម ។*

បានឮមកថា ចោរ ៤៩៩ នាក់ ធ្វើកម្មមានការប្លន់ស្រុកជាដើម សម្រេចការរស់នៅហើយ ។ គ្រានោះ បុរសម្នាក់មានភ្នែកក្រហម មានពុកមាត់ក្រហម ទៅកាន់សម្នាក់របស់ចោរទាំងនោះពោលថា ខ្ញុំនឹងនៅជាមួយពួកអ្នក ។ ពេលនោះពួកចោរ បង្ហាញបុរសនោះដល់មេចោរ ហើយពោលថា បុរសនេះចង់នៅក្នុងសម្នាក់របស់ពួកយើង ។ គ្រានោះ មេចោរសម្លឹងមើលបុរសនោះហើយគិតថា បុរសនេះរឹងត្អឹងពន់ពេក អាចកាត់ដោះរបស់ម្តាយ ឬឈាមក្នុងបំពង់ករបស់ឪពុក ហើយបរិភោគបាន ។ ទើបឃាត់ថា កិច្ច គឺការនៅក្នុងសម្នាក់របស់ពួកយើងសម្រាប់បុរសនេះមិនមាន ។ បុរសនោះត្រូវមេចោរឃាត់យ៉ាងនោះក៏មិនទៅ ទំនុកបម្រុងសិស្សម្នាក់របស់មេចោរនោះឯងឲ្យពេញចិត្តហើយ ចោរនោះនាំបុរសនោះ ចូលទៅរកមេចោរហើយអង្វរថា លោកនាយ បុគ្គល

នេះជាមនុស្សល្អ មានឧបការៈដល់ពួកយើង សូមលោកនាយសង្គ្រោះគេផង ចុះ មេចោរនោះទទួលហើយ ។ ថ្ងៃក្រោយមក ពួកអ្នកស្រុករួមគ្នាជាមួយពួករាជបុរស ចាប់ចោរទាំងនោះបាន នាំទៅកាន់សម្នាក់របស់ពួកអមាត្យដែលជាអ្នកវិនិច្ឆ័យក្តីទាំងឡាយ ។ ពួកអមាត្យបញ្ជាឲ្យកាត់ក្បាលរបស់ចោរទាំងនោះដោយពូថៅ ។ លំដាប់នោះ អ្នកស្រុកប្រឹក្សាគ្នាថា អ្នកណាហ្ន៎ហ៊ានសម្ងាប់ចោរទាំងនេះ ស្វែងរកក៏មិនឃើញអ្នកណាម្នាក់ ហ៊ានសម្ងាប់ចោរទាំងនោះ ទើបនិយាយនឹងមេចោរថា អ្នកសម្ងាប់ចោរទាំងនេះហើយ អ្នកនឹងបានរួចជីវិត បាននូវការរាប់អានទៀតផង ចូរអ្នកសម្ងាប់ចោរទាំងនោះ ។ សូម្បីមេចោរនោះ ក៏មិនប្រាថ្នាសម្ងាប់ ព្រោះភាពដែលពួកចោរនោះ អាស្រ័យខ្លួនរស់នៅហើយ ពួកអ្នកស្រុកសួរចោរ ៤៩៩ ដោយឧបាយនោះ ។ ចោរទាំងអស់ក៏មិនប្រាថ្នាហើយ ។ ពួកអ្នកស្រុកសួរនាយតម្ពទាឋិកៈ គឺបុរសពុកមាត់ក្រហម ភ្នែកក្រហមនោះក្រោយគេបង្អស់ ។ នាយតម្ពទាឋិកៈនោះទទួលថាសាធុ ហើយសម្ងាប់ចោរទាំងអស់នោះ បាននូវជីវិតផង បាននូវការរាប់អានផង ។

ពួកអ្នកស្រុកនាំចោរ ៥០០ មកអំពីទិសខាងត្បូងនៃក្រុងហើយ បង្ហាញដល់ពួកអមាត្យដោយឧបាយនោះ កាលពួកអមាត្យនោះបញ្ជាឲ្យកាត់ក្បាលចោរទាំងនោះ ទើបសួរតាំងអំពីមេចោរជាដើមទៅ មិនឃើញអ្នកណាហ៊ានសម្ងាប់ ទើបសួរថា ក្នុងថ្ងៃមុនបុរសម្នាក់សម្ងាប់ចោរ ៥០០ នាក់ហើយបុរសនោះនៅឯណាហ្ន៎ កាលជនទាំងឡាយឆ្លើយថា ពួកខ្ញុំឃើញគាត់ក្នុងទី

ឈ្មោះនោះ ទើបឲ្យហៅគាត់មកហើយ ប្រាប់ថា ចូរអ្នកសម្លាប់ចោរទាំងនេះ អ្នកនឹងបាននូវការរាប់អាន ។ តម្ពទាឋិក:នោះទទួលថា សាធុ ហើយសម្លាប់ចោរទាំងនោះ បាននូវការរាប់អានហើយ ។

កាលនោះ អ្នកនគរទាំងនោះពិភាក្សាគ្នាថា បុរសនេះល្អ ពួកយើងនឹងធ្វើគាត់ឲ្យជាអ្នកសម្លាប់ចោរជាប្រចាំនោះឯង ដូច្នេះហើយ ទើបឲ្យតំណែងនោះដល់គាត់ ធ្វើនូវការរាប់អានហើយ ។

នាយតម្ពទាឋិក:នោះ សម្លាប់ចោរ ម្ពង ៥០០ៗ ដែលគេនាំមកពីទិសខាងលិចខ្លះ ទិសខត្តរខ្លះ ។ គាត់សម្លាប់ចោរអស់ ២ ពាន់នាក់ ដែលនាំមកអំពីទិសទាំង ៤ ដោយខបាយយ៉ាងនោះ ។ ចាប់តាំងអំពីនោះ កាលសម្លាប់មនុស្សដែលគេនាំមក ម្នាក់ ឬពីរនាក់រាល់ៗ ថ្ងៃ បានធ្វើការសម្លាប់ចោរអស់ ៥៥ ឆ្នាំ ក្នុងពេលគាត់ចាស់ មិនអាចកាត់ក្បាលចោរត្រឹមតែម្ពងបាន ត្រូវកាប់ពីរ ឬបីដង ធ្វើឲ្យអ្នកស្លាប់ទាំងឡាយលំបាក ។ ពួកអ្នកស្រុកគិតគ្នាថា អ្នកសម្លាប់ចោរដទៃនឹងកើតឡើង បុគ្គលនេះ ធ្វើមនុស្សទាំងឡាយឲ្យលំបាកពន់ពេក តើត្រូវការអ្វីដោយបុគ្គលនេះ ទើបដកតំណែងរបស់គាត់នោះ ។

នាយតម្ពទាឋិក:នោះ សម្លាប់ចោរក្នុងកាលមុន មិនបានកិច្ច ៤ យ៉ាង គឺស្លៀកសំពត់ថ្មី ១ ពិសាបបរលាយដោយទឹកដោះផ្សំដោយសប្បិ ១ ប្រដាប់នូវផ្ការម្ងិះ ១ លាបនូវគ្រឿងក្រអូប ១ ។ ក្នុងថ្ងៃដែលត្រូវចេញពីតំណែង គាត់ពោលថា ចូរអ្នកទាំងឡាយដាំបបរលាយទឹកដោះដល់ខ្ញុំ ហើយឲ្យមនុស្សកាន់យកសំពត់ថ្មី កម្រងផ្ការម្ងិះ និងគ្រឿងលាប ទៅកាន់ស្ទឹងងូតទឹក ហើយស្លៀក

សំពត់ប្តី ប្រដាប់ផ្កា មានខ្លួនលាបដោយគ្រឿងក្រអូប មកកាន់ផ្ទះអង្គុយហើយ ។ ពេលនោះ ជនទាំងឡាយ ជាក់បបរលាយដោយទឹកដោះ ផ្សំដោយសប្បិអំពីខាងមុខគាត់ហើយ នាំទឹកសម្រាប់លាងដៃមក ។

ក្នុងខណៈនោះ ព្រះសារីបុត្តត្ថេរចេញអំពីសមាបត្តិ ពិចារណាផ្លូវបិណ្ឌបាតរបស់ខ្លួនថា ថ្ងៃនេះ អាត្មាអញគួរទៅបិណ្ឌបាតទីណាហ្ន៎ ឃើញបបរទឹកដោះក្នុងផ្ទះរបស់តម្ពទាឋិកៈនោះ ពិចារណាថា បុរសនេះ គួរធ្វើការសង្គ្រោះឬហ្ន៎ ដឹងថា បុរសនេះឃើញអាត្មាអញហើយ នឹងធ្វើការសង្គ្រោះដល់អញ កុលបុត្រនេះ កាលធ្វើហើយ នឹងបានសម្បត្តិធំ ទើបដណ្តប់ចីវរកាន់បាត្របង្ហាញខ្លួន ត្រង់ទ្វារផ្ទះរបស់តម្ពទាឋិកៈនោះឯង ។

តម្ពទាឋិកៈនោះគ្រាន់តែឃើញព្រះថេរៈ ក៏មានចិត្តជ្រះថ្លាគិតថា អញធ្វើចោរយាតកម្មមកអស់កាលជ័យូរ អញសម្លាប់មនុស្សជាច្រើន ឥឡូវនេះ ក្នុងផ្ទះរបស់អញតាក់តែងបបរ លាយដោយទឹកដោះ ។ ឯព្រះថេរៈក៏មកឈរត្រង់ទ្វារផ្ទះរបស់អញ អញនឹងប្រគេនទេយ្យធម៌ដល់លោកម្ចាស់ក្នុងកាលនេះក៏គួរជូនច្នេះហើយ ទើបនាំយកបបរដែលគេជាក់ចំពោះមុខចេញទៅ ចូលទៅរកព្រះថេរៈ ថ្វាយបង្គំហើយ និមន្តឲ្យគង់ខាងក្នុងផ្ទះ ដួសយាគូដែលផ្សំដោយទឹកដោះដាក់ក្នុងបាត្រ រោយដោយទឹកដោះស្រស់ ឈរបក់ព្រះថេរៈ ។ ពេលនោះ អធ្យាស្រ័យដើម្បីបរិភោគបបរលាយទឹកដោះមានកម្លាំង ព្រោះគាត់មិនធ្លាប់បានហើយអស់កាលយូរ ព្រះថេរៈដឹងអធ្យាស្រ័យរបស់តម្ពទាឋិកៈនោះ ទើបនិយាយនឹងគាត់ថា ឧបាសក ចូរអ្នកបរិភោគបបររបស់ខ្លួនចុះ ។ គាត់ឲ្យផ្ងិត

ក្នុងដៃដល់អ្នកដទៃ ហើយបរិភោគខ្លួនឯង ។ ព្រះថេរៈនិយាយនឹងបុរសដែលបក់ផ្ដិតថា ចូរអ្នកបក់ឲ្យឧបាសកចុះ ។ គាត់កាលបុរសនោះបក់ បរិភោគបបរពេញពោះហើយ មកឈរបក់ព្រះថេរៈ បានទទួលបាត្រវេរបស់ព្រះថេរៈដែលធ្វើកត្តកិច្ចស្រេចហើយ ។ ព្រះថេរៈក៏ផ្ដើមអនុមោទនាដល់បុរសនោះ ។ គាត់មិនអាចធ្វើចិត្តរបស់ខ្លួន ឲ្យទៅតាមធម្មទេសនារបស់ព្រះថេរៈបាន ព្រះថេរៈសង្កេតបាន ទើបសួរថា ឧបាសក ហេតុអ្វី ទើបអ្នកមិនអាចធ្វើចិត្តឲ្យទៅតាមធម្មទេសនាបាន ។ តម្ពទាឋិកៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំធ្វើកម្មថោកទាបមកអស់កាលដ៏ឃ្លង មនុស្សជាច្រើនត្រូវខ្ញុំសម្លាប់ឲ្យស្លាប់ ខ្ញុំរឭកដល់កម្មរបស់ខ្លួននោះ ទើបមិនអាចធ្វើចិត្ត ឲ្យទៅតាមទេសនារបស់លោកម្ចាស់បាន ។ ព្រះថេរៈគិតថា អាត្មាអញនឹងបញ្ឆោតបុរសនេះ ទើបពោលថា អ្នកបានធ្វើតាមពេញចិត្តរបស់ខ្លួន ឬត្រូវអ្នកដទៃឲ្យធ្វើ តម្ពទាឋិកៈពោលថា បពិត្រលោកម្ចាស់ ព្រះរាជាឲ្យខ្ញុំធ្វើ ព្រះថេរៈពោលថា ឧបាសក បើដូច្នោះអកុសលនឹងមានដល់អ្នកបានដូចម្ដេចហ្ន៎ ។

ឧបាសកជាមនុស្សមានជាតុក្រាស់ ត្រូវព្រះថេរៈពោលយ៉ាងនោះ មានសេចក្ដីសម្គាល់ថាអកុសលមិនមានដល់ខ្លួន ទើបពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់ពោលធម៌ចុះ ឧបាសកនោះ កាលព្រះថេរៈធ្វើអនុ-មោទនា មានចិត្តជាឯកគ្គតាស្ដាប់ធម៌ ញុំាងខន្ដីឲ្យប្រព្រឹត្តទៅក្នុងអនុលោម (ដល់អរិយសច្ច) ខាងក្នុងនៃសោតាបត្តិមគ្គឲ្យកើតឡើងហើយ ។ ព្រះថេរៈធ្វើអនុមោទនាហើយ ក៏ចៀសចេញទៅ ។

យក្ខិនីម្នាក់ មកហើយដោយភេទនៃមេគោកូនខ្ចី បុះត្រង់ទ្រូងឧបាសក ដែលតាមជូនដំណើរព្រះថេរៈបន្តិចហើយត្រឡប់ឲ្យស្ងាប់ ឧបាសកនោះ ធ្វើកាលកិរិយាហើយ កើតក្នុងតុសិតបុរី ។

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា បុរសសម្លាប់ចោរ ធ្វើកម្មគ្រោតគ្រោតអស់ ៥៥ ឆ្នាំ ផុតចាកកម្មនោះក្នុងថ្ងៃនេះឯង ថ្វាយភិក្ខាជល់ព្រះថេរៈក្នុងថ្ងៃនេះដូចគ្នា ធ្វើកាលកិរិយាក្នុងថ្ងៃនេះឯង គាត់កើតក្នុងទីណាហ្ន៎ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកសន្ទនាគ្នាដោយពាក្យអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយពាក្យឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុរសនោះកើតក្នុងតុសិតបុរី ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គ ទ្រង់ត្រាស់អ្វី បុរសនោះសម្លាប់មនុស្សប៉ុណ្ណោះ អស់កាលប៉ុណ្ណោះ ហើយកើតក្នុងតុសិតវិមាន ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង បុរសនោះបានកល្យាណមិត្តធំ ព្រោះស្តាប់ធម្មទេសនារបស់សារីបុត្ត ញុំាងអនុលោម-ញាណឲ្យកើតហើយ ឃ្លាតចាកលោកនេះហើយ កើតក្នុងតុសិតវិមានដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

បុរសសម្លាប់ចោរក្នុងក្រុង ស្តាប់ពាក្យជាសុភាសិតហើយ បាន
នូវអនុលោមខន្តី ទៅកាន់ទេវលោកដ៏ជាទិព្វ រមែងត្រេកអរ ។

ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ ធម្មតាអនុមោទនាកថាមានកម្លាំងបុរសនោះធ្វើអកុសលច្រើន ញុំាងគុណវិសេសឲ្យកើត ដោយហេតុប៉ុណ្ណោះ

បានដូចម្តេច ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំកាន់យកប្រមាណនៃធម៌ ដែលតថាគតសម្តែងហើយថា មានប្រមាណតិច ឬច្រើន ព្រោះថា វាចាមួយម៉ាត់ ដែលអាស្រ័យប្រយោជន៍ប្រសើរដោយពិត កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

សហស្សមបិ ចេ វាចា អនត្ថបទសញ្ហិតា
ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

បើវាចាសូម្បីមួយពាន់ម៉ាត់ ជាវាចាប្រកបដោយបទឥតប្រយោជន៍ វាចានោះពុំប្រសើរឡើយ អ្នកណាស្តាប់បទមានប្រយោជន៍ណាហើយ រមែងស្ងប់រម្ងាប់បាន បទមានប្រយោជន៍នោះ សូម្បីតែមួយបទក៏ឈ្មោះថាប្រសើរជាង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សហស្សមបិ** *ជាពាក្យសម្រាប់កំណត់អធិប្បាយថា បើវាចាដែលគេកំណត់ដោយពាន់យ៉ាងនេះ គឺមួយពាន់ ពីរពាន់ សោត វាចាទាំងនោះមិនប្រកបដោយបទដែលជាប្រយោជន៍ គឺប្រកបដោយបទទាំងឡាយដែលមិនជាប្រយោជន៍ ដែលប្រកាសតែរឿងពណ៌នាអាកាសពណ៌នាភ្នំ ពណ៌នាព្រៃជាដើម មិនសម្តែងព្រះនិព្វាន មានច្រើនដរាបណា ក៏ជាវាចាអាក្រក់នោះឯងដរាបនោះ ។*

ពីរបទថា **ឯកំ អត្ថបទំ** *សេចក្តីថា ចំណែកបុគ្គលស្តាប់បទណាដែលជាប្រយោជន៍ សូម្បីតែមួយបទបែបនេះថា នេះកាយ នេះសតិក្នុងកាយ វិជ្ជា*

៣ អាត្មាអញតាមសម្រេចហើយ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ អាត្មាអញធ្វើហើយ ។ រមែងស្ងប់រម្ងាប់ ដោយការស្ងប់រម្ងាប់កិលេស មានរាគៈជាដើមបាន បទនោះសម្រេចប្រយោជន៍ ប្រកបដោយនិព្វាន គឺសម្ពន្ធ ខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ ពល ពោជ្ឈង្គ និងសតិប្បដ្ឋានសូម្បីតែមួយបទ គង់ប្រសើរជាងដោយពិត ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង តម្ពដាឋិកចោរឃាតក ចប់

រឿង ព្រះធម្មរុចិរិយត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះធម្មរុចិរិយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **សហស្សមបិ ចេ គាថា** *ជាដើម ។*

សេចក្តីពិស្តារថា ក្នុងកាលមួយមនុស្សជាច្រើន ចេញសំពៅទៅកាន់មហាសមុទ្រ កាលសំពៅលិចក្នុងមហាសមុទ្រ ក៏បានជាចំណីអណ្តើក និងត្រីហើយ ។ បណ្តាមនុស្សទាំងនោះ បុរសម្នាក់តោងបន្ទះក្តារបានមួយបន្ទះ ព្យាយាមហែលទៅកាន់ត្រើយនៃកំពង់ឈ្មោះសុប្បារកៈ ។ គាត់មិនមានសំពត់ជាប់ ។ បុរសនោះ មិនឃើញអ្វីដទៃ ទើបយកឆ្នែចងកំណាត់ឈើស្ងួតធ្វើ

ជាសំពត់ស្បៃក កាន់យកអំបែងអំពីទេវស្ថាន បានទៅកាន់កំពង់ ឈ្មោះ សុប្បារកៈ ។ មនុស្សទាំងឡាយឃើញគាត់ហើយ ឲ្យបបរ និងភត្តជាដើម ហើយសរសើរថា បុគ្គលនេះ ជាព្រះអរហន្តមួយអង្គ ។ បុរសនោះ កាលមនុស្សទាំងឡាយនាំសំពត់ទៅឲ្យ គិតថា បើអញស្បៃក និងដណ្តប់ លាភសក្ការៈរបស់អញនឹងវិនាស ទើបឃាត់សំពត់ដែលគេនាំមក ស្បៃកដណ្តប់តែសម្បកឈើប៉ុណ្ណោះ ។

គ្រានោះ កាលគាត់ត្រូវមនុស្សជាច្រើនពោលថាជាព្រះអរហន្ត ការបរិវិតក្កនៃចិត្ត ទើបកើតឡើងយ៉ាងនេះថា ព្រះអរហន្ត ឬអ្នកសម្រេចអរហត្ត-មគ្គណាមួយក្នុងលោក បណ្តាព្រះអរហន្តទាំងនោះ អញក៏ជាព្រះអរហន្តមួយអង្គដែរ ។ ពេលនោះ ទេវតាជាសាលោហិតក្នុងកាលមុននៃបុរសនោះ ក៏គិតហើយយ៉ាងនោះ ។

ពាក្យថា ជាសាលោហិតក្នុងកាលមុន គឺធ្លើសមណធម្មរួមគ្នាក្នុងកាលមុន បានឮថា ក្នុងកាលមុន កាលសាសនារបស់ព្រះទសពល ព្រះនាមកស្សបៈសាបសូន្យទៅ ភិក្ខុ ៧ រូបឃើញអាការប្លែកនៃបព្វជិតទាំងឡាយ មានសាមណេរជាដើមហើយ ដល់នូវការសង្វេគ គិតថា ការអន្តរធាននៃព្រះសាសនា មិនមានដោយប្រការណា ពួកយើងនឹងធ្វើទីពឹងដល់ខ្លួនដោយប្រការនោះ ថ្ងាយបង្គំសុវណ្ណចេតិយ ហើយចូលទៅកាន់ព្រៃ ឃើញភ្នំមួយ ទើបពោលថា អ្នកណាមានអាល័យក្នុងជីវិត ចូរត្រឡប់ទៅវិញចុះ អ្នកណាមិនមានអាល័យ ចូរឡើងភ្នំនេះ ច្រានជណ្តើរចោលហើយ ជនទាំងនោះ ឡើងភ្នំនោះ ច្រាន

ជណ្តើរចោល ហើយធ្វើសមណធម៌ ។ បណ្តាភិក្ខុទាំងនោះ ព្រះសង្ឃត្ថេរ សម្រេចអរហត្ត ដោយកន្ទងទៅត្រឹមមួយរាត្រីប៉ុណ្ណោះ ព្រះថេរៈនោះទំពាឈើសូនឈ្មោះនាគលតា ក្នុងអនោតត្តស្រះ នាំបិណ្ឌបាតមកអំពីឧត្តរកុរុទ្វីប ហើយពោលនឹងភិក្ខុទាំងនោះថា អាវុសោទាំងឡាយ ពួកអ្នកទំពាឈើសូននេះ ខ្ចីមាត់ហើយ ចូរឆាន់បិណ្ឌបាតនេះ ភិក្ខុទាំងនោះពោលថា បពិត្រលោកម្ចាស់ ពួកយើងធ្វើកតិកាគ្នាយ៉ាងនេះថា ភិក្ខុណាសម្រេចអរហត្តមុនភិក្ខុទាំងឡាយដ៏សេស នឹងឆាន់បិណ្ឌបាតដែលភិក្ខុនោះនាំមកឬ ព្រះថេរៈពោលថា អាវុសោ សេចក្តីនោះ មិនមានឡើយ ភិក្ខុទាំងឡាយពោលថា បើដូច្នោះ ពួកខ្ញុំគប្បីញុំាងគុណវិសេសឲ្យកើតដូចលោកម្ចាស់ ពួកខ្ញុំនឹងនាំមកបរិភោគឯង ដូច្នេះហើយ ក៏មិនជ្រាបថ្នា ។ ក្នុងថ្ងៃទីពីរ ព្រះថេរៈអង្គទីពីរ សម្រេចអនាគាមិផលហើយ ។ សូម្បីព្រះថេរៈនោះនាំបិណ្ឌបាតមកហើយ ក៏និមន្តភិក្ខុក្រៅអំពីនេះយ៉ាងនោះដូចគ្នា ភិក្ខុទាំងនោះពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ ពួកយើងធ្វើកតិកាគ្នាយ៉ាងនេះថា ពួកយើងមិនបរិភោគបិណ្ឌបាតដែលមហាថេរៈនាំមក តែនឹងបរិភោគបិណ្ឌបាត ដែលព្រះអនុថេរៈនាំមកឬ ព្រះថេរៈអង្គទីពីរពោលថា អាវុសោ សេចក្តីនោះមិនមានឡើយ ។ ភិក្ខុទាំងនោះពោលថា កាលបើដូច្នោះ ពួកខ្ញុំនឹងញុំាងគុណវិសេសឲ្យកើតដូចលោកម្ចាស់ហើយ អាចបរិភោគដោយសេចក្តីព្យាយាមនៃកម្លាំងបុរសរបស់ខ្លួនបានទើបបរិភោគ ដូច្នេះហើយ ក៏មិនជ្រាបថ្នា ។

បណ្តាភិក្ខុទាំងនោះ ភិក្ខុសម្រេចអរហត្តបរិនិព្វានហើយ ភិក្ខុដែលជា

អនាគាមីកើតក្នុងព្រហ្មលោក ភិក្ខុ ៥ រូបក្រៅអំពីនេះ មិនអាចញុំាងគុណ វិសេសឲ្យកើតបាន ស្ពាំងស្គមហើយ ធ្វើកាលកិរិយាក្នុងថ្ងៃទី ៧ កើតក្នុងទេវលោក ក្នុងពុទ្ធុប្បាទកាលនេះ ចុតិអំពីទេវលោកនោះហើយ កើតក្នុងផ្ទះនៃត្រកូលនោះៗ ។

បណ្តាជនទាំងនោះ បុគ្គលម្នាក់បានជាព្រះរាជា ឈ្មោះបុក្កុសាតិ ម្នាក់ទៀតបានជាកុមារកស្សបៈ ម្នាក់ទៀតបានជាទារុចីរិយៈ ម្នាក់ទៀតបានជាទព្ម-មល្លបុត្រ ម្នាក់ទៀតបានជាបរិព្វាជកឈ្មោះសភិយៈ ។ ពាក្យថា ទេវតា ដែលជាសាលោហិតក្នុងកាលមុននេះ លោកពោលសំដៅយកភិក្ខុ ដែលកើតក្នុងព្រហ្មលោកនោះ ។

ព្រហ្មនោះ មានបរិវិតក្កយ៉ាងនេះថា បុរសនេះ ជាក់ជណ្តើរហើយ ទ្បើងភ្នំ បានធ្វើសមណធម៌ជាមួយអញ ឥឡូវនេះ កាន់លទ្ធិនេះ ត្រាច់ទៅដើម្បីសេចក្តីវិនាស អញនឹងញុំាងបុរសនេះឲ្យសង្វេគ ។ ពេលនោះ ព្រហ្មនោះចូលទៅរកបុរសនោះហើយ ពោលយ៉ាងនេះថា ពាហិយៈ អ្នកមិនមែនជាព្រះអរហន្តទេ អ្នកមិនទាន់បានសម្រេចអរហត្តមគ្គឡើយ សូម្បីបដិបទារបស់អ្នកជាហេតុឲ្យបានជាព្រះអរហន្ត ឬជាអ្នកសម្រេចអរហត្តមគ្គ ក៏មិនមាន ។ ពាហិយៈសម្លឹងមើលមហាព្រហ្ម ដែលកំពុងឈរក្នុងអាកាស ទើបគិតថា ឱ អញធ្វើកម្មធ្ងន់ហ្ន៎ អញគិតថា ខ្លួនអញជាព្រះអរហន្ត ឯមហាព្រហ្មនេះនិយាយនឹងអញថា អ្នកមិនមែនព្រះអរហន្ត អ្នកមិនទាន់បានសម្រេចអរ-ហត្តមគ្គឡើយ ព្រះអរហន្តដទៃ មាននៅក្នុងលោកនេះឬ ពេលនោះ គាត់សួរ

មហាព្រហ្មនោះថា អ្នកជាទេវតា ឥឡូវនេះ ព្រះអរហន្ត ឬអ្នកសម្រេចអរ-
ហត្តមគ្គ មាននៅក្នុងលោកឬ ។ គ្រានោះ ទេវតាជ្រាបពាហិយៈនោះថា
ពាហិយៈ នគរឈ្មោះសាវត្ថី មាននៅក្នុងជនបទនាទិសឧត្តរ ឥឡូវនេះ ព្រះ
ដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធនោះ ប្រថាប់នៅក្នុងព្រះនគរនោះ ពាហិយៈ
ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះអរហន្តផង ទ្រង់សម្តែងធម៌ដើម្បីភាពជា
ព្រះអរហន្តផង ។

ពាហិយៈស្តាប់ពាក្យរបស់ទេវតាក្នុងចំណែកវត្រីហើយ មានចិត្តសង្វេគ
ក្នុងវារៈចនោះឯង ចេញអំពីកំពង់សុប្បារកៈ ទៅដល់ក្រុងសាវត្ថី ដោយការ
ស្នាក់នៅមួយរាត្រី គាត់បានធ្វើដំណើរប្រមាណ ១២០ យោជន៍ ដោយការ
ស្នាក់នៅមួយរាត្រីប៉ុណ្ណោះ កាលទៅ ទៅហើយដោយអានុភាពរបស់ទេវតា
អាចារ្យពួកខ្លះពោលថា ទៅដោយអានុភាពរបស់ព្រះសម្ពុទ្ធក៏មាន ។

ក្នុងខណៈនោះ ព្រះសាស្តាយាងទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត
ពាហិយៈនោះ សួរភិក្ខុទាំងឡាយដែលឆាន់អាហារព្រឹកហើយ ដើរចង្រ្កមក្នុង
ទីវាល ដើម្បីដោះនូវភាពធ្ងន់នៃកាយ ដោយពាក្យថា ឥឡូវនេះ ព្រះសាស្តា
ប្រថាប់នៅក្នុងទីណា ។ ភិក្ខុទាំងឡាយក៏ឆ្លើយថា យាងចូលទៅកាន់ក្រុងសាវត្ថី
ដើម្បីបិណ្ឌបាត ហើយសួរបុរសនោះថា អ្នកមកអំពីណា ទារុចរិយៈពោលថា
ខ្ញុំមកអំពីកំពង់សុប្បារកៈ ភិក្ខុទាំងឡាយពោលថា អ្នកចេញមកក្នុងកាលណា
ទារុចរិយៈពោលថា ខ្ញុំចេញមកក្នុងពេលល្ងាចម្សិលមិញនេះ ភិក្ខុទាំងឡាយ
ពោលថា អ្នកមកអំពីទីឆ្ងាយ ចូរអ្នកអង្គុយសិនចុះ លាងជើងហើយ លាប

ដោយប្រេង ចូរសម្រាកឲ្យបាត់នឿយហត់សិនចុះ អ្នកនឹងឃើញព្រះសាស្តា ក្នុងកាលដែលទ្រង់យាងមក ទារុចីរិយ:ពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនជឹងអន្តរាយនៃជីវិតរបស់ព្រះសាស្តា ឬជីវិតរបស់ខ្ញុំ ខ្ញុំមិនបានឈប់ មិនបានអង្គុយក្នុងទីណា ដើរមកអស់ផ្លូវ ១២០ យោជន៍ មួយយប់ប៉ុណ្ណោះ ទាល់តែខ្ញុំឃើញព្រះសាស្តាហើយ ទើបសម្រាក ។

ពាហិយ:នោះ ពោលយ៉ាងនោះហើយ មានអាកប្បកិរិយារួសរាន់ចូលទៅកាន់ក្រុងសាវត្ថី ឃើញព្រះដ៏មានព្រះភាគកំពុងត្រាច់បិណ្ឌបាត ដោយពុទ្ធសិរីប្រៀបមិនបាន គិតថា យូរហើយហ្នឹ អញឃើញព្រះគោតមសម្ម-សម្ពុទ្ធ ដូច្នេះហើយ ក៏បន្ទន់ខ្លួនដើរចូលទៅតាំងអំពីទីដែលខ្លួនឃើញ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានក្នុងរវាងផ្លូវ ចាប់ត្រង់កព្រះបាទទាំងគូ ហើយក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គ សូមទ្រង់សម្តែងធម៌ដល់ខ្ញុំព្រះអង្គ សូមព្រះសុគត ទ្រង់សម្តែងធម៌ ដែលគប្បីប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់ខ្ញុំព្រះអង្គ អស់កាលយូរចុះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់យាត់ថា ពាហិយ: មិនមែនជាកាលតថាគតចូលទៅកាន់ចន្លោះផ្លូវដើម្បីបិណ្ឌបាត ។ ពាហិយ: ស្តាប់ពុទ្ធតម្រាស់នោះហើយ ក្រាបទូលថា បពិត្រព្រះអង្គ បុគ្គលអន្ទោលទៅក្នុងសង្សារ មិនធ្លាប់បានអាហារ គឺជុំបាយឬ ខ្ញុំព្រះអង្គមិនជឹងអន្តរាយនៃជីវិតរបស់ទ្រង់ ឬរបស់ខ្ញុំព្រះអង្គទ្បើយ សូមទ្រង់សម្តែងធម៌ដល់ខ្ញុំព្រះអង្គចុះ ។ លើកទី ២ ព្រះសាស្តាក៏ត្រាស់ហាមហើយដូចគ្នា ។ បានឮថា ព្រះសាស្តាទ្រង់បរិវិតក្ត

យ៉ាងនេះថា ចាប់តាំងអំពីពាហិយៈឃើញតថាគតហើយ សរីរៈទាំងមូលជោរជន់ដោយបីតិមិនមានចន្លោះ ជាអ្នកមានបីតិជាកម្លាំង សូម្បីស្តាប់ធម៌ហើយក៏មិនអាចចាក់ចេញបាន បុគ្គលនេះ ចូរតាំងនៅក្នុងឧបេក្ខា គឺការមធ្យត្តជាមុនសិន សូម្បីកាពក្រវល់ក្រវាយរបស់សត្វនេះមានកម្លាំង ព្រោះធ្វើដំណើរមកអស់ផ្លូវ ១២០ យោជន៍ ដោយមួយរាត្រីប៉ុណ្ណោះ សូម្បីការក្រវល់ក្រវាយនោះ ក៏ចូរម្ងាប់សិន ។ ព្រោះដូច្នោះ ទើបព្រះសាស្តាហាមអស់វារៈពីរដង ត្រូវគាត់អាភធនាលើកទី ៣ ប្រថាប់ឈរក្នុងរវាងផ្លូវនោះឯង ទ្រង់សម្តែងធម៌ ដោយនយជាដើមថា ពាហិយៈ ព្រោះហេតុនោះ អ្នកគប្បីសិក្សាក្នុងសាសនានេះយ៉ាងនេះថា រូបដែលអញបានឃើញហើយ រូប ត្រឹមតែអញឃើញ ។ ពាហិយៈនោះ កំពុងស្តាប់ធម៌របស់ព្រះសាស្តានោះឯង ញុំាងអាសវៈឲ្យអស់ទៅ សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទា ៤ ហើយ ខណៈនោះឯង គាត់ទូលសូមបព្វជ្ជានឹងព្រះសាស្តា ទ្រង់ត្រាស់សួរថា ចាត្រចីវរបស់អ្នកគ្រប់គ្រាន់ហើយឬ ពាហិយៈទូលតបថា មិនគ្រប់គ្រាន់ទេព្រះអង្គ ពេលនោះ ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ ចូរអ្នកស្វែងរកចាត្រចីវរហើយចៀសចេញទៅ ។

បានឮថា ពាហិយៈនោះធ្វើសមណធម៌អស់ ២ ម៉ឺនឆ្នាំ គិតថា ធម្មតាភិក្ខុបានបច្ច័យដោយខ្លួនហើយ មិនសម្លឹងមើលអ្នកដទៃ បរិភោគឯងប៉ុណ្ណោះទើបគួរ ដូច្នេះហើយ មិនបានធ្វើការសង្គ្រោះដោយចាត្រ ឬចីវរ សូម្បីដល់ភិក្ខុមួយរូប ។ ព្រោះដូច្នោះ ព្រះសាស្តាទ្រង់ជ្រាបថា ចាត្រចីវរដែលសម្រេចដោយ

ឫទ្ធិមិនកើតឡើង ទើបមិនបានប្រទានបព្វជ្ជាដោយឯហិភិក្ខុដល់គាត់ ។ ពាហិយៈនោះ កំពុងស្វែងរកបាត្រ និងចីវរនោះឯង យក្ខិនីម្នាក់ មកដោយរូបជាមេគោកូនខ្ចី បុះត្រង់ក្លៅខាងឆ្វេង ឲ្យដល់នូវការអស់ជីវិត ។

ព្រះសាស្តាត្រាច់បិណ្ឌបាត ធ្វើកត្តកិច្ចស្រេចហើយ យាងចេញទៅព្រមជាមួយភិក្ខុជ៏ច្រើន ទ្រង់ឃើញសរីរៈរបស់ពាហិយៈ ស្តុកស្តឹងក្នុងគំនរសំរាម ទើបទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរឈរក្បែរទ្វារផ្ទះណាមួយ យកត្រែមកហើយ នាំសរីរៈនេះចេញអំពីក្រុងបូជាហើយ សាងព្រះស្តូប ភិក្ខុទាំងឡាយធ្វើយ៉ាងនោះហើយ កាលធ្វើហើយ ទៅកាន់វិហារ ចូលគាល់ព្រះសាស្តា ទូលកិច្ចដែលខ្លួនធ្វើហើយ សួរអំពីអភិសម្បរាយភពរបស់ពាហិយៈនោះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ត្រាស់ប្រាប់ភាពដែលពាហិយៈនោះបរិនិព្វានដល់ភិក្ខុទាំងនោះ ទ្រង់តែងតាំងក្នុងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ ពាហិយទារុចីរិយៈ ជាកំពូលជាងភិក្ខុសាវ័កបស់តថាគត ខាងត្រាស់ដឹងរហ័ស លំដាប់នោះ ភិក្ខុទាំងឡាយទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ទ្រង់ត្រាស់ថា ពាហិយទារុចីរិយៈសម្រេចអរហត្ត តើសម្រេចអរហត្តក្នុងកាលណា ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដែលគេស្តាប់ធម៌របស់តថាគត ភិក្ខុទាំងឡាយទូលសួរថា តើទ្រង់ត្រាស់ធម៌ដល់ពាហិយៈពីអង្គាល់ណា ព្រះសាស្តាត្រាស់ថា តថាគតកំពុងត្រាច់បិណ្ឌបាត ឈរក្នុងរវាងផ្លូវសម្តែងធម៌ដល់ពាហិយៈ ភិក្ខុទាំងឡាយពោលថា បពិត្រ

ព្រះអង្គ ធម៌ដែលទ្រង់ប្រថាប់ឈរក្នុងរវាងផ្លូវ ត្រាស់ហើយ មានប្រមាណតិចតួច តើនឹងញុំាងគុណវិសេសឲ្យកើតដោយធម៌ មានប្រមាណដល់ម្ល៉ោះដូចម្តេច ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំរាប់ធម៌របស់តថាគតថា តិច ឬច្រើន ព្រោះថាគាថាមួយពាន់ជាអនេក ដែលមិនអាស្រ័យប្រយោជន៍ មិនប្រសើរឡើយ ចំណែកបទនៃគាថា សូម្បីមួយ អាស្រ័យប្រយោជន៍ ប្រសើរជាង ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា
ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

បើគាថាសូម្បីមួយពាន់ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថានោះ ពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ឯកំ គាថាបទំ** *សេចក្តីថា សូម្បីគាថាមួយបែបនេះថា សេចក្តីមិនប្រមាទជាផ្លូវនៃសេចក្តីមិនស្លាប់ ។បេ។ ជនទាំងឡាយដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ប្រសើរជាង ។ បទដ៏សេសគប្បីជ្រាបតាមន័យមុននោះឯង ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះនារុចិរិយត្ថេរ ចប់

រឿង ព្រះនាងកុណ្ឌលកេសីថេរី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងកុណ្ឌលកេសី ត្រាស់ព្រះធម្មទេសនានេះថា **យោ ច គាថា សតំ ភាសេ** *ជាដើម ។*

បានឮមកថា កូនស្រីសេដ្ឋីម្នាក់ក្នុងក្រុងរាជគ្រឹះ អាយុ ១៦ ឆ្នាំ មាន រូបស្អាតគួរគយគន់ នារីទាំងឡាយតាំងនៅក្នុងវ័យនោះ រមែងមានការចាប់ចិត្ត ក្នុងបុរស ខ្សេះខ្សោះក្នុងបុរស ។ គ្រានោះ មាតាបិតាឲ្យធីតានោះនៅក្នុងបន្ទប់ ជ័មានសិរី លើផ្ទៃប្រាសាទជាន់ទី ៧ បានធ្វើទាសីម្នាក់ប៉ុណ្ណោះឲ្យជាអ្នក បម្រើ ។

គ្រានោះ ពួករាជបុរសចាប់កុលបុត្រម្នាក់ដែលធ្វើចោរកម្ម ចងស្ងាបសេក រាយដោយផ្តៅមួង ៤ សរសៃ ហើយនាំទៅកាន់ទីសម្រាប់ពិឃាដ កូនស្រី សេដ្ឋីបានឮសំឡេងមហាជន គិតថា នេះអ្វីហ្ន៎ ឈរសម្លឹងមើលលើផ្ទៃប្រាសាទ ឃើញចោរនោះហើយ មានចិត្តប្រតិព័ទ្ធ ហាមអាហារហើយដេកលើគ្រែ ។ លំដាប់នោះ មាតាសួរនាងថា នែនាង តើនាងកើតអ្វី ធីតាសេដ្ឋីពោលថា

បើខ្ញុំបានបុរសដែលគេចាប់នាំទៅថាជាចោរនោះសោត ខ្ញុំនឹងរស់នៅ បើមិនបាន ជីវិតខ្ញុំក៏មិនមាន ខ្ញុំនឹងស្លាប់ក្នុងទីនេះឯង ។ មាតាពោលថា នែនាង នាងកុំធ្វើយ៉ាងនេះឡើយ នាងនឹងបានប្តីដទៃដែលស្មើគ្នាដោយជាតិ និងកោគៈរបស់យើង ធីតាសេដ្ឋីពោលថា កិច្ចដោយបុរសដទៃសម្រាប់ខ្ញុំមិនមាន បើខ្ញុំមិនបានបុរសនេះ ខ្ញុំនឹងស្លាប់ ។

មាតា កាលមិនអាចញុំាងធីតាឲ្យយល់ព្រមបាន ទើបប្រាប់ដល់បិតា សូម្បីបិតានោះក៏មិនអាចញុំាងធីតានោះឲ្យយល់ព្រមបាន គិតថា យើងអាចធ្វើអ្វីបាន បញ្ជូនកញ្ចប់កណ្ហៈមួយពាន់ដល់រាជបុរស ដែលចាប់ចោរនោះ ហើយដើរទៅដោយពាក្យថា ចូរអ្នកទទួលកណ្ហៈនេះហើយ ឲ្យបុរសនោះដល់ខ្ញុំ ។ រាជបុរសនោះទទួលថា សាធុ ហើយទទួលកហាបណៈ លែងចោរនោះទៅ សម្លាប់បុរសដទៃហើយ ក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះអង្គ ទូលបង្គំសម្លាប់ចោរហើយ ។

សេដ្ឋីបានឲ្យធីតាដល់ចោរនោះហើយ នាងគិតថា នឹងញុំាងស្វាមីឲ្យត្រេកអរ ទើបតាក់តែងគ្រឿងអលង្ការទាំងពួង រៀបចំយាគូជាដើមដល់ចោរនោះឯង ។

ក្នុងកាលកន្លងទៅបាន ២-៣ ថ្ងៃ ចោរគិតថា ក្នុងកាលណាហ្ន៎ អញនឹងបានសម្លាប់ស្រីនេះ កាន់យកគ្រឿងអលង្ការរបស់ស្រីនេះ ស៊ីផឹកក្នុងភេសុរាមួយ ចោរនោះគិតថា ឧបាយនេះមាន ទើបហាមអាហារ ហើយដេកលើគ្រែ ពេលនោះ ធីតាសេដ្ឋីចូលទៅរកចោរនោះហើយ សួរថា នែអ្នក អ្វី

ចាក់ដោតអ្នកឬ ចោរពោលថា អ្វីមិនបានចាក់ដោតខ្ញុំទេ ធីតាសេដ្ឋីពោលថា មាតាបិតារបស់ខ្ញុំខឹងក្រោធនឹងអ្នកឬ ចោរពោលថា មិនខឹងក្រោធទេ ធីតាសេដ្ឋីពោលថា បើដូច្នោះ តើអ្នកកើតអ្វី ចោរពោលថា នែនាង ខ្ញុំត្រូវចាប់នាំទៅក្នុងថ្ងៃនោះ ខ្ញុំបានបន់ស្រន់ទេវតា ដែលស្ថិតនៅត្រង់ក្នុំទម្ងាក់ចោរ បាននូវជីវិតហើយ សូម្បីនាង ខ្ញុំក៏បានដោយអានុភាពនៃទេវតានោះដូចគ្នា នែនាង ខ្ញុំគិតថា នឹងធ្វើពលីកម្មនោះចំពោះទេវតា ។ ធីតាសេដ្ឋីពោលថា នែអ្នក អ្នកកុំគិតថ្វីឡើយ ខ្ញុំនឹងធ្វើពលីកម្ម សូមអ្នកប្រាប់ តើត្រូវការអ្វីខ្លះ ចោរពោលថា ត្រូវធ្វើមធុបាយាស ដែលមានទឹកតិច និងផ្ការមានលាជជាគម្រប់ ៥ ។ ធីតាសេដ្ឋីពោលថា សាធុ ខ្ញុំនឹងរៀបចំ ។

ធីតាសេដ្ឋីនោះរៀបចំពលីកម្មគ្រប់យ៉ាងហើយ ទើបពោលថា មកចុះអ្នក យើងនឹងទៅទាំងអស់គ្នា ។ ចោរពោលថា នែនាង បើដូច្នោះ សូមនាងឲ្យពួកញាតិត្រឡប់ចុះ កាន់យកសំពត់និងគ្រឿងអលង្ការដែលមានតម្លៃច្រើនហើយតែងខ្លួន យើងនឹងសើចលេងបណ្តើរ ដើរទៅបណ្តើរយ៉ាងសប្បាយ ។

នាងបានធ្វើយ៉ាងនោះហើយ ។ ពេលនោះ ក្នុងវេលាជល់ជើងភ្នំ ចោរនោះពោលនឹងនាងថា នែនាង ខាងមុខអំពីនេះ យើងនឹងទៅពីរនាក់ ចូរនាងឲ្យមនុស្សជ័សេសត្រឡប់ មួយអន្ទើដោយយាន លើកកាជនៈពលីកម្មដើរទៅឯង នាងបានធ្វើយ៉ាងនោះ ចោរនាំនាងឡើងកាន់ភ្នំសម្រាប់ទម្ងាក់ចោរ ។

មនុស្សទាំងឡាយ ឡើងទៅក្នុងចំណែកម្ខាងនៃភ្នំនោះ ចំណែកម្ខាងទៀតជាជ្រោះ មនុស្សទាំងឡាយឈរលើកំពូលភ្នំហើយ រមែងទម្ងាក់ចោរទាំងឡាយ

ក្នុងទីម្ខាងនោះ ចោរទាំងនោះដាច់ជាកំណាត់តូចធំ ធ្លាក់ទៅត្រង់ផែនដី ព្រោះដួចុះ ទើបគេហៅថា ភ្នំចោលចោរ ។ នាងឈរលើកំពូលភ្នំនោះ ពោលថា នែអ្នក សូមអ្នកធ្វើពលីកម្មរបស់អ្នក ចោរនោះបាននៅស្ងៀមហើយ ។ កាលនាងពោលទៀតថា នែអ្នក ហេតុអ្វី ទើបអ្នកនៅស្ងៀម ក៏ជ្រាប់ថា ខ្ញុំមិនត្រូវការពលីកម្មទេ តែខ្ញុំចេកបញ្ឆោតដើម្បីនាំនាងមក ធីតាសេដ្ឋីពោលថា ព្រោះហេតុអ្វី ចោរពោលថា ដើម្បីសម្ងាប់នាង ហើយកាន់យកគ្រឿងអលង្ការរបស់នាង គេចទៅ ។

នាងត្រូវមរណភ័យគំរាមហើយ ពោលថា នែអ្នក ខ្ញុំក្តី គ្រឿងអលង្ការក្តី ជារបស់អ្នកប៉ុណ្ណោះ ហេតុអ្វី ទើបអ្នកពោលយ៉ាងនេះ ចោរនោះត្រូវនាងអង្វរវារឿយៗ ថា សូមអ្នកកុំធ្វើយ៉ាងនេះ ក៏ពោលថា ខ្ញុំនឹងសម្ងាប់ឲ្យបាន នាងពោលថា បើដូច្នោះ អ្នកត្រូវការអ្វីដោយការស្ងាប់របស់ខ្ញុំ អ្នកកាន់យកគ្រឿងអលង្ការទាំងនេះ ហើយឲ្យជីវិតដល់ខ្ញុំចុះ ចាប់តាំងអំពីនេះ អ្នកចូរចាំខ្ញុំថា ស្ងាប់ហើយ ឬថា ទុកខ្ញុំជាទាសីរបស់អ្នកធ្វើហត្ថកម្ម ដូច្នេះហើយ ពោលគាថានេះថា

ខ្សែមាសទាំងនេះ សុទ្ធតែសម្រេចដោយកែវពិទូរ្យ នែអ្នក សូម
អ្នកកាន់យកទាំងអស់ ហើយចូរប្រកាសថា ខ្ញុំជាទាសីចុះ ។

ចោរស្តាប់ពាក្យនោះហើយ ពោលថា បើយើងធ្វើយ៉ាងនោះ នាងទៅហើយ នឹងជ្រាប់ដល់ឪពុកម្តាយឲ្យសម្ងាប់យើងបាន នាងកុំសោយសោកឡើយ ដូច្នេះហើយ ពោលគាថាថា

នាងកុំសោយសោកឡើយ ចូរប្រញាប់ខ្ជប់របស់របរចុះ ជីវិត របស់នាងមិនមានទេ យើងនឹងកាន់យករបស់ទាំងអស់នេះ ។

នាងគិតថា ឱ ! កម្មនេះធ្ងន់ ឈ្មោះថា បញ្ញា ជាធម្មតាមិនមែនសាងមក ទុកស្មុសឡើយ ដែលពិត សាងមកដើម្បីប្រយោជន៍ពិចារណា អញនឹងដឹងវត្ថុដែលគួរធ្វើដល់ចោរនេះ ។

លំដាប់នោះ នាងពោលនឹងចោរនោះថា នែអ្នក អ្នកត្រូវចាប់នាំទៅថា ជាចោរក្នុងកាលណា ក្នុងកាលនោះ ខ្ញុំជ្រាបដល់ឪពុកម្តាយ លោកទាំងពីរ លះទ្រព្យមួយពាន់ឲ្យនាំអ្នកមក ចាប់តាំងអំពីនោះ ខ្ញុំក៏ឧបការៈអ្នក ថ្ងៃនេះ សូមអ្នកឲ្យខ្ញុំធ្វើខ្លួនអ្នកឲ្យឃើញច្បាស់ ហើយថ្វាយបង្គំ ។

ចោរនោះពោលថា សាធុ ចូរនាងធ្វើខ្លួនខ្ញុំឲ្យឃើញច្បាស់ ហើយថ្វាយបង្គំចុះ ដូច្នេះហើយ ក៏ឈរលើកំពូលភ្នំ ពេលនោះ នាងធ្វើប្រទក្សិណ ៣ ជុំ ថ្វាយបង្គំចោរនោះក្នុងទី ៤ ស្តាន ហើយពោលថា នែអ្នក នេះជាការឃើញចុងក្រោយរបស់ខ្ញុំ ឥឡូវនេះ ការដែលអ្នកឃើញខ្ញុំ ឬការដែលខ្ញុំឃើញអ្នក មិនមានឡើយ ហើយឱបខាងមុខ ខាងក្រោយ ឈរអំពីខាងខ្នង យកដៃម្ខាងចាប់ចោរដែលជាអ្នកប្រមាទ ឈរលើកំពូលភ្នំត្រង់ក យកដៃម្ខាងចាប់ត្រង់ក្បៀកខាងក្រោយ ច្រានចោរទម្លាក់ទៅក្នុងជ្រោះ ចោរនោះត្រូវប៉ះទង្គិចត្រង់ថ្មភ្នំ ជាច់ជាចម្រៀកតូចធំ ធ្លាក់ចុះទៅហើយ ត្រង់ផែនដី ។

ទេវតាដែលស្ថិតនៅលើកំពូលភ្នំជាទីទម្លាក់ចោរ ឃើញកិរិយារបស់ជនទាំងពីរនោះ ទើបឲ្យសាធុការដល់ស្រីនោះ ហើយពោលគាថានេះថា

បុរសនោះ ជាបណ្ឌិតក្នុងទីគ្រប់ស្ថាន ក៏មិនមែន សូម្បីស្ត្រីជា អ្នកមានបញ្ញា ឃើញប្រចក្ស ក៏ជាបណ្ឌិតបានក្នុងទីនោះៗ ។

ធីតាសេដ្ឋីនោះ កាលច្រានចោរធ្លាក់ទៅក្នុងជ្រោះហើយ គិតថា បើអញទៅផ្ទះ ឪពុកម្តាយនឹងសួរថា ប្តីរបស់នាងទៅណា បើអញត្រូវសួរយ៉ាងនោះ នឹងឆ្លើយថា ខ្ញុំសម្លាប់ហើយ លោកនឹងចាក់ដោតអញដោយលំពែង គឺមាត់ថា កូនក្បាលរឹង នាងឲ្យទ្រព្យមួយពាន់ ឲ្យនាំប្តីមក ឥឡូវនេះ ក៏សម្លាប់គេចោល កាលអញប្រាប់ថា ចោរនោះប្រាថ្នានឹងសម្លាប់ខ្ញុំ ដើម្បីគ្រឿងអលង្ការ លោកក៏មិនជឿ ណ្ហើយចុះ មានប្រយោជន៍អ្វីដោយផ្ទះរបស់អញ ដូច្នេះហើយ ចោះគ្រឿងអលង្ការចោលក្នុងទីនោះឯង ចូលទៅកាន់ព្រៃត្រាច់ទៅដោយលំដាប់ ដល់អាស្រមរបស់ពួកបរិព្វាជកមួយកន្លែង ថ្វាយបង្គំហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយ ឲ្យខ្ញុំបព្វជ្ជាក្នុងសម្នាក់របស់លោកម្ចាស់ផងចុះ លំដាប់នោះ បរិព្វាជកទាំងឡាយ ឲ្យនាងបព្វជ្ជាហើយ ។

ធីតាសេដ្ឋីនោះ បួសហើយសួរថា បពិត្រលោកម្ចាស់ អ្វីជាទីបំផុតនៃបព្វជ្ជារបស់លោកម្ចាស់ បរិព្វាជកពោលថា នែនាង បុគ្គលធ្វើបរិកម្មក្នុងកសិណ ១០ ហើយ គប្បីញុំាងឈានឲ្យកើតខ្លះ គប្បីរៀនវាទៈមួយពាន់ខ្លះ នេះជាប្រយោជន៍ដ៏ឧត្តមនៃបព្វជ្ជារបស់ពួកយើង ធីតាសេដ្ឋីពោលថា ខ្ញុំមិនអាចញុំាងឈានឲ្យកើតឡើងបាន តែនឹងរៀនវាទៈមួយពាន់ ។ គ្រានោះ បរិព្វាជកទាំងនោះ ញុំាងនាងឲ្យរៀននូវវាទៈមួយពាន់ហើយ ពោលថា សិប្បៈ នាងរៀនហើយ ឥឡូវនេះ ចូរនាងត្រាច់ទៅលើផែជម្ពូទ្វីប ពិនិត្យមើលបុគ្គលណា

អាចពោលបញ្ហាជាមួយនាង៦ ហើយឲ្យមែកព្រីងក្នុងដៃដល់នាង៦ បញ្ជូនទៅថា ទៅចុះនាង៦ បើបុគ្គលណាជាគ្រហស្ថ អាចពោលបញ្ហាជាមួយនាង៦បាន នាង៦ ចូរជាបាទបរិចារិការបស់បុគ្គលនោះឯង៦ បើជាបព្វជិត ចូរនាង៦បួសក្នុង៦សម្នាក់ បុគ្គលនោះចុះ ។ នាង៦មានឈ្មោះថា ជម្ពុបរិព្វាជិកា តាមឈ្មោះឈើ ចេញ អំពីទីនោះ ត្រាច់សួរបញ្ហានឹង៦អ្នកដែលខ្លួនជួបប្រទះហើយ ជនដែលឈ្មោះថា អាចឆ្លើយនឹង៦នាង៦បាន មិនមានឡើយ ។ មនុស្សទាំង៦ឡាយគ្រាន់តែឮថា នាង៦ ជម្ពុបរិព្វាជិកាមកក្នុង៦ទីនេះ រមែង៦គេចទៅ ។ នាង៦ចូលទៅកាន់ស្រុក ឬតំបន់ ដើម្បីភិក្ខា គរដីខ្ពាច់ជាពំនូក ត្រង់ទ្វារស្រុក ដោតមែកព្រីង៦លើគំនរខ្ពាច់ នោះ ពោលថា អ្នកណាអាចពោលជាមួយខ្ញុំ ចូរជាន់មែកព្រីង៦ចុះ ហើយ ក៏ចូលទៅកាន់ស្រុក ។ បុគ្គលណាម្នាក់ ឈ្មោះថា ចូលទៅកាន់ទីនោះមិនមាន សូម្បីនាង៦កាន់មែកឈើដទៃ ក្នុង៦កាលមែកព្រីង៦ចាស់ក្រៀមស្វិត ។ ត្រាច់ទៅ ដោយទំនង៦នេះដល់ក្រុង៦សាវត្ថី ដោតមែកព្រីង៦ក្បែរទ្វារស្រុក ពោលដោយ នយដូចពោលមកហើយនោះ ចូលទៅដើម្បីភិក្ខា ក្មេង៦ជាច្រើន បានឈរ ចោមរោមមែកឈើហើយ ។

ក្នុង៦កាលនោះ ព្រះសារីបុត្តត្រាច់ទៅដើម្បីបិណ្ឌបាត ធ្វើភត្តកិច្ចហើយ ចេញទៅអំពីក្រុង៦ ឃើញក្មេង៦ទាំង៦នោះចោមរោមមែកព្រីង៦ទើបសួរថា នេះជា អ្វី ក្មេង៦ទាំង៦ឡាយប្រាប់រឿងនោះដល់ព្រះថេរៈហើយ ។ ព្រះថេរៈពោលថា នែកុមារទាំង៦ឡាយ បើយ៉ាង៦នោះពួកអ្នកចូរជាន់មែកព្រីង៦នេះ កុមារទទួលថា បពិត្រលោកម្ចាស់ ពួកខ្ញុំខ្លាច ព្រះថេរៈពោលថា អាត្មានឹង៦ពោលបញ្ហា ចូរ

ពួកអ្នកជាន់ចុះ ។ ក្មេងទាំងនោះ កើតឧស្សាហ៍ដោយពាក្យរបស់ព្រះថេរៈ ធ្វើយ៉ាងនោះ ស្រែកហ៊ោ បាចធូលីឡើងហើយ ។

បរិព្វាជិកាមកហើយ សម្តីក្មេងទាំងនោះ ពោលថា កិច្ចដោយបញ្ញារបស់យើងនឹងពួកអ្នកមិនមាន ហេតុអ្វី ទើបពួកអ្នកនាំគ្នាជាន់មែកឈើរបស់យើង កុមារទាំងឡាយពោលថា ពួកខ្ញុំត្រូវលោកម្ចាស់ឲ្យជាន់ បរិព្វាជិកាពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ឲ្យពួកក្មេងជាន់មែកឈើរបស់ខ្ញុំឬ ព្រះថេរៈពោលថា អើ ប្អូនស្រី បរិព្វាជិកាពោលថា បើយ៉ាងនោះ លោកម្ចាស់ពោលបញ្ហាជាមួយខ្ញុំ ព្រះថេរៈពោលថា សាធុ អាត្មានឹងពោល ។

បរិព្វាជិកានោះ បានទៅកាន់សម្នាក់របស់ព្រះថេរៈ ដើម្បីសួរបញ្ហាក្នុងវេលាម្ចប់ឈើមិនចម្រើន គឺពេលរសៀល ។ មនុស្សក្នុងក្រុងគោទ្បាថា ពួកយើងនឹងស្តាប់វាទៈ របស់បណ្ឌិតទាំងពីរ ។ ពួកអ្នកក្រុងបានទៅជាមួយនឹងបរិព្វាជិកានោះដូចគ្នា ថ្វាយបង្គំព្រះថេរៈហើយ បានអង្គុយក្នុងចំណែកម្ខាង ។

បរិព្វាជិកាពោលនឹងព្រះថេរៈថា បពិត្រលោកម្ចាស់ ខ្ញុំនឹងសួរបញ្ហាជាមួយលោកម្ចាស់ ព្រះថេរៈពោលថា សួរចុះប្អូនស្រី ។

នាងសួរវាទៈមួយពាន់ហើយ ព្រះថេរៈឆ្លើយបញ្ហាដែលនាងសួរហើយលំដាប់នោះ ព្រះថេរៈពោលនឹងនាងថា បញ្ហារបស់នាងមានប៉ុណ្ណេះ បញ្ហាដទៃមានទៀតឬ បរិព្វាជិកាពោលថា បពិត្រលោកម្ចាស់ មានប៉ុណ្ណេះឯង ព្រះថេរៈពោលថា នាងសួរបញ្ហាជាច្រើន អាត្មានឹងសួរបញ្ហាត្រឹមតែមួយ នាងឆ្លើយបានដែរឬទេ បរិព្វាជិកាពោលថា បើខ្ញុំដឹង ខ្ញុំនឹងឆ្លើយ សូមលោកម្ចាស់សួរ

ចុះ ព្រះថេរៈសួរបញ្ហាថា អ្វីមានតែមួយ បរិព្វាជិកានោះ មិនដឹងថា បញ្ហានេះ គួរឆ្លើយយ៉ាងនេះ ទើបសួរថា តើនុ៎ះជាអ្វីលោកម្ចាស់ ព្រះថេរៈពោលថា ម្នាលប្អូនស្រី នុ៎ះឈ្មោះថា ពុទ្ធមន្ត បរិព្វាជិកាពោលថា សូមលោកម្ចាស់ឲ្យពុទ្ធមន្តនោះដល់ខ្ញុំខ្ញុះ ព្រះថេរៈពោលថា បើនាងដូចអាត្មា អាត្មានឹងឲ្យ បរិព្វាជិកាពោលថា បើដូច្នោះ សូមលោកម្ចាស់ញ៉ាំងខ្ញុំឲ្យបព្វជ្ជាចុះ ។

ព្រះថេរៈ ច្រាប់ដល់កិកូនីទាំងឡាយឲ្យបព្វជ្ជាហើយ នាងកាលបាននូវបព្វជ្ជាឧបសម្បទាហើយ មានឈ្មោះថាកុណ្ឌលកេសីថេរី សម្រេចអរហត្តមួយអន្ទើដោយបដិសម្ភិទាទាំងឡាយ ក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ ។

កិកូទាំងឡាយ សន្ទនាគ្នាក្នុងរោងធម្មសភាថា ការស្តាប់ធម៌របស់នាងកុណ្ឌលកេសីថេរីមិនច្រើន កិច្ចនៃបព្វជិតរបស់នាងដល់ទីបំផុតហើយ បានឮថា នាងធ្វើមហាសង្គ្រាមជាមួយចោរម្នាក់ឈ្នះហើយមក ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយកថាដូចម្តេច កាលភិក្ខុទាំងឡាយនោះក្រាបទូលថា ពាក្យសម្តីឈ្នះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំរាប់ធម៌ដែលតថាគតសម្តែងហើយថា តិច ឬច្រើន បទដែលមិនជាប្រយោជន៍មួយរយបទ មិនប្រសើរឡើយ ចំណែកបទនៃធម៌ សូម្បីតែមួយបទ ប្រសើរជាង ម្យ៉ាងទៀត កាលបុគ្គលឈ្នះចោរដ៏សេស មិនឈ្មោះថាឈ្នះឡើយ ចំណែកបុគ្គលឈ្នះចោរ គឺកិលេសដែលប្រព្រឹត្តទៅខាងក្នុងនោះឯង ទើបឈ្មោះថា ឈ្នះ កាលទ្រង់បន្តអនុសន្ធិ ទើបត្រាស់ព្រះគាថាទាំងនេះ

យោ ច គាថាសតំ ភាសេ　　អនត្ថបទសញ្ហិតា
ឯកំ ធម្មបទំ សេយ្យោ　　យំ សុត្វា ឧបសម្មតិ ។
យោ សហស្សំ សហស្សេន　　សង្គាមេ មានុសេ ជិនេ
ឯកញ្ច ជេយ្យមត្តានំ　　ស វេ សង្គាមជុត្តមោ ។

អ្នកណា គប្បីពោលគាថាមួយរយ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថាដែលអ្នកនោះពោលហើយ ពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃធម៌ហើយ រមែងស្ងប់រម្ងាប់បាន បទនៃធម៌នោះសូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។ អ្នកណា គប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាម អស់មួយពាន់ៗ ដង គឺមួយលាន ចំណែកអ្នកណា ឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះ ឈ្មោះថា ជាមនុស្សខ្ជង់ខ្ជាស់ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **គាថាសតំ** *សេចក្តីថា បុគ្គលណាគប្បីពោលគាថាមួយរយ គឺច្រើនគាថា ។ បានព្រះគាថាថា* **អនត្ថបទសញ្ហិតា** *សេចក្តីថា ប្រកបដោយបទទាំងឡាយដែលមិនមានប្រយោជន៍ ដោយអំណាចពណ៌នាអាកាសជាដើម ។*

បទដែលបដិសំយុត្តដោយធម៌ មានខន្ធជាដើម សម្រេចប្រយោជន៍ ឈ្មោះថា បទធម៌ ។ បណ្តាធម៌ ៤ ដែលព្រះសាស្តាត្រាស់យ៉ាងនេះថា បរិព្វាជកទាំងឡាយ បទធម៌មាន ៤ បទធម៌ ៤ គឺអ្វីខ្លះ បរិព្វាជកទាំងឡាយ

បទធម៌ គឺការមិនសម្ងឹង បទធម៌ គឺការមិនប្រទូស្ត បទធម៌ គឺការរឭកត្រូវ បទធម៌ គឺការតាំងចិត្តប្រពៃ បទធម៌ សូម្បីតែមួយប្រសើរជាង ។

ជាទព្រះគាថាថា **យោ សហស្សំ សហស្សេន** *សេចក្តីថា បុគ្គលណា គឺអ្នកច្បាំងក្នុងសង្គ្រាម គប្បីឈ្នះមនុស្សមួយពាន់ៗ ដង ក្នុងសង្គ្រាមម្តង ជានដល់ ឈ្នះមនុស្ស ១០ សែន ហើយនាំជ័យជម្នះមក បុគ្គលនេះ មិនឈ្មោះថា ជាកំពូលនៃជនទាំងឡាយ ដែលឈ្នះក្នុងសង្គ្រាមឡើយ ។*

ជាទព្រះគាថាថា **ឯកញ្ច ជេយ្យមត្តានំ** *សេចក្តីថា ចំណែកបុគ្គលណា ពិចារណាកម្មដ្ឋាន ដែលប្រព្រឹត្តទៅខាងក្នុង ក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ គប្បីឈ្នះខ្លួនដោយការឈ្នះកិលេស មានលោភៈជាដើមរបស់ខ្លួនបាន ។*

ជាទព្រះគាថាថា **ស វេ សង្គ្រាមជុត្តមោ** *សេចក្តីថា បុគ្គលនោះឈ្មោះថា ជាកំពូល គឺប្រសើរនៃជនទាំងឡាយដែលឈ្នះក្នុងសង្គ្រាម បានដល់ ជាអ្នកចម្បាំងដ៏កំពូល ក្នុងសង្គ្រាម ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងកុណ្ឌលកេសីថេរី ចប់

រឿង អនត្តបុច្ឆកព្រាហ្មណ៍

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអនត្តបុច្ឆកព្រាហ្មណ៍ ត្រាស់ព្រះគាថានេះថា **អត្តា ហវេ** ជាដើម ។

បានឮថា ព្រាហ្មណ៍នោះគិតថា ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបវត្តុដែលជាប្រយោជន៍តែម្យ៉ាងឬហ្ន៎ ឬទ្រង់ជ្រាបវត្តុដែលមិនជាប្រយោជន៍ដែរ អញនឹងទូលសួរទ្រង់ ដូច្នេះហើយ ទើបចូលទៅគាល់ព្រះសាស្តា ទូលសួរថា បពិត្រព្រះអង្គ ទ្រង់ឃើញ ទ្រង់ជ្រាបវត្តុដែលជាប្រយោជន៍តែម្យ៉ាង មិនជ្រាបវត្តុដែលមិនមែនប្រយោជន៍ទេឬ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតដឹងវត្តុដែលជាប្រយោជន៍ផង វត្តុដែលមិនជាប្រយោជន៍ផង ។ ព្រាហ្មណ៍ពោលថា បើយ៉ាងនោះ សូមទ្រង់ត្រាស់ប្រាប់វត្តុដែលមិនជាប្រយោជន៍ដល់ខ្ញុំព្រះអង្គចុះ ។ លំដាប់នោះ ព្រះសាស្តាត្រាស់ព្រះគាថានេះ ដល់ព្រាហ្មណ៍នោះថា

> ការដេកលក់ជួតដល់ថ្ងៃរះ ការរួញច្រមុះ ការកាច ការពន្យាពេល ការធ្វើដំណើរឆ្ងាយរបស់បុគ្គលម្នាក់ឯង ការចូលទៅសេពកវិយារបស់អ្នកដទៃ ម្នាលព្រាហ្មណ៍ អ្នកចូរសេពកម្ម ៦ យ៉ាងនេះចុះ វត្តុមិនមែនជាប្រយោជន៍ នឹងមានដល់អ្នក ។

ព្រាហ្មណ៍ស្តាប់ព្រះពុទ្ធតម្រាស់នោះហើយ បានឲ្យសាធុការថា សាធុ សាធុ ទ្រង់ជាអាចារ្យរបស់គណៈ ទ្រង់ជាធំក្នុងគណៈ ទ្រង់រមែងជ្រាបវត្តុដែល

ជាប្រយោជន៍ផង វត្ថុដែលមិនជាប្រយោជន៍ផង ។

ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ យ៉ាងនោះឯង ឈ្មោះថា បុគ្គលជីងវត្ថុដែលជាប្រយោជន៍ និងវត្ថុមិនជាប្រយោជន៍ដូចតថាគតរមែងមិនមាន ។

លំដាប់នោះ ព្រះសាស្តាទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់ព្រាហ្មណ៍នោះហើយ ទើបត្រាស់សួរថា ម្នាលព្រាហ្មណ៍ អ្នករស់នៅចិញ្ចឹមជីវិតដោយការងារអ្វី ព្រាហ្មណ៍ទូលថា បពិត្រព្រះគោតម ដោយការងារ គឺលេងបាស្តា ព្រះសាស្តាត្រាស់ថា អ្នកឈ្នះ ឬចាញ់ ។ កាលព្រាហ្មណ៍នោះទូលថា ឈ្នះខ្លះ ចាញ់ខ្លះ ដូច្នេះហើយ ទើបទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ នុ៎ះនៅមានប្រមាណតិច ឈ្មោះថា ការឈ្នះរបស់បុគ្គលដែលឈ្នះអ្នកដទៃ មិនប្រសើរឡើយ ចំណែកបុគ្គលណាឈ្នះខ្លួនបាន ដោយឈ្នះកិលេស ការឈ្នះរបស់បុគ្គលនោះប្រសើរ ព្រោះថាបុគ្គលណាម្នាក់មិនអាចធ្វើជ័យជម្នះនោះ ឲ្យត្រឡប់ចាញ់បាន កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថាទាំងនេះថា

អត្តា ហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា បជា
អត្តទន្តស្ស ចោសស្ស និច្ចំ សញ្ញតចារិនោ ។
នេវ ទេវោ ន គន្ធព្ពោ ន មារោ សហ ព្រហ្មុនា
ជិនំ អបជិតំ កយិរា តថារូបស្ស ជន្តុនោ ។

ខ្លួនឯងដែលឈ្នះហើយប្រសើរជាង ចំណែកពួកសត្វក្រៅពីនេះ ដែលគេឈ្នះហើយ មិនប្រសើរឡើយ កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច ទេវតា

គន្ធព្ធ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើនូវជម្នះរបស់សត្វ មានសភាពដូច្នោះ ឲ្យត្រឡប់ចាញ់វិញបានឡើយ ។

សេចក្តីអធិប្បាយ

ក្នុងព្រះគាថានោះ សព្ទថា **មារោ** *ត្រឹមតែជានិបាត ។*

សព្ទថា **ជិតំ** *ជាលិង្គវិបល្លាស សេចក្តីថា ខ្លួនដែលបុគ្គលឈ្នះហើយ ដោយការឈ្នះកិលេសរបស់ខ្លួន ប្រសើរ ។*

បាទព្រះគាថាថា **យោ ចាយំ ឥតរោ បជា** *សេចក្តីថា ចំណែកពួកសត្វនេះ គឺសត្វដ៏សេស គប្បីជាបុគ្គលដែលគេឈ្នះដោយការលេងបាស្កាក្តី ដោយការឆេាកទ្រព្យក្តី ដោយការគ្របសង្កត់ដោយកម្លាំងក្នុងសង្គ្រាមក្តី ការឈ្នះដែលបុគ្គលឈ្នះពួកសត្វនោះ ឈ្នះហើយ មិនប្រសើរសោះឡើយ ។*

សួរថា ហេតុអ្វី ការឈ្នះនោះប៉ុណ្ណោះប្រសើរ ការឈ្នះនេះមិនប្រសើរ ឆ្លើយថា ព្រោះកាលបុរសទូន្មានខ្លួនហើយ ។បេ។ របស់សត្វបែបនោះឲ្យត្រឡប់ចាញ់មិនបាន ។

ព្រះសាស្តា ត្រាស់ពាក្យនេះថា ព្រោះថា កាលបុរស ឈ្មោះថាទូន្មានខ្លួនហើយ ព្រោះជាអ្នកដែលឥតកិលេស មិនមានកិលេសដូចទីទួល មានប្រក្រតីប្រព្រឹត្តសង្រួមតាមផ្លូវកាយជាដើមជានិច្ច ទេវតាក្តី គន្ធព្ធក្តី មារ ព្រមទាំងព្រហ្មក្តី សូម្បីព្យាយាមថា អញនឹងធ្វើជ័យជម្នះរបស់បុគ្គលនោះឲ្យត្រឡប់ចាញ់ នឹងធ្វើកិលេសទាំងឡាយ ដែលគេលះបានដោយមគ្គភាវនាឲ្យកើតទៀត ក៏មិនអាចធ្វើការឈ្នះរបស់សត្វនោះ គឺជាអ្នកសង្រួមហើយ

ដោយការសង្រ្គមតាមផ្លូវកាយជាដើមនេះ ឲ្យត្រឡប់ចាញ់ ដូចអ្នកចាញ់ដោយទ្រព្យដែលជាបរបក្ខឡើយ ជ័យជម្នះដែលបុគ្គលក្រៅពីនេះឈ្នះហើយ គប្បីធ្វើឲ្យត្រឡប់ចាញ់ទៀត ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង អនត្តបុច្ឆកព្រាហ្មណ៍ ចប់

រឿង ព្រាហ្មណ៍ជាអីរបស់ព្រះសារីបុត្តត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រាហ្មណ៍ជាអីរបស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **មាសេ មាសេ** *ជាដើម ។*

បានឮថា ព្រះថេរៈទៅកាន់សម្នាក់របស់ព្រាហ្មណ៍នោះហើយសួរថា នែព្រាហ្មណ៍ អ្នកធ្វើកុសលណាមួយខ្លះដែរឬទេ ព្រាហ្មណ៍ឆ្លើយថា ធ្វើលោកម្ចាស់ ព្រះថេរៈសួរថា ធ្វើកុសលអ្វី ព្រាហ្មណ៍ឆ្លើយថា ខ្ញុំឲ្យទាន ដោយបរិច្ចាគទ្រព្យមួយពាន់រៀងរាល់ខែ ព្រះថេរៈសួរថា ឲ្យដល់អ្នកណា ព្រាហ្មណ៍ឆ្លើយថា ឲ្យដល់ពួកនិគ្រន្ថ លោកម្ចាស់ ព្រះថេរៈសួរថា តើអ្នកប្រាថ្នាអ្វី ព្រាហ្មណ៍ឆ្លើយថា ខ្ញុំប្រាថ្នាព្រហ្មលោក ព្រះថេរៈសួរថា នេះជាផ្លូវនៃព្រហ្មលោកឬ ព្រាហ្មណ៍ឆ្លើយថា យ៉ាងនោះឯងលោកម្ចាស់ ព្រះថេរៈសួរថា អ្នកណាពោល

យ៉ាងនេះ ព្រាហ្មណ៍ឆ្លើយថា អាចារ្យទាំងឡាយរបស់ខ្ញុំជាអ្នកពោល ។

ព្រះថេរៈពោលថា អ្នកមិនដឹងផ្លូវនៃព្រហ្មលោកឡើយ សូម្បីអាចារ្យទាំងឡាយរបស់អ្នកក៏មិនដឹង ព្រះសាស្តាមួយអង្គប៉ុណ្ណោះទ្រង់ដឹង នែព្រាហ្មណ៍ចូរមកចុះ អាត្មានឹងទូលអារាធនា ឲ្យទ្រង់ត្រាស់ប្រាប់ផ្លូវទៅកាន់ព្រហ្មលោកដល់អ្នក ដូច្នេះហើយ នាំព្រាហ្មណ៍នោះទៅកាន់សម្នាក់របស់ព្រះសាស្តា ក្រាបទូលរឿងនោះថា បពិត្រព្រះអង្គ ព្រាហ្មណ៍នេះពោលយ៉ាងនេះ ហើយក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ត្រាស់ប្រាប់ផ្លូវនៃព្រហ្មលោកដល់ព្រាហ្មណ៍នេះ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលព្រាហ្មណ៍ បានឮថា សេចក្តីនោះ យ៉ាងនេះឬ កាលព្រាហ្មណ៍នោះទូលថា បពិត្រព្រះគោតម យ៉ាងនោះឯង ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ ការសម្លឹងមើលសាវ័ករបស់តថាគត ដោយចិត្តជ្រះថ្លា ត្រឹមតែមួយរំពេច ឬការឲ្យអាហារវត្ថុត្រឹមតែបាយមួយវែក មានផលច្រើនជាងទាន ដែលអ្នកឲ្យយ៉ាងនោះ អស់រយឆ្នាំ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

មាសេ មាសេ សហស្សេន យោ យជេថ សតំ សមំ
ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ
សា យេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។

អ្នកណា បូជា (លោកិយមហាជន) ដោយទ្រព្យមួយពាន់រាល់ខែៗ អស់មួយរយឆ្នាំគត់ ចំណែកអ្នកណា គប្បីបូជាចំពោះ

បុគ្គលដែលមានខ្លួនអប់រំហើយ តែមួយនាក់ សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជា របស់អ្នកដែលបូជាអស់ មួយរយឆ្នាំនោះ ការបូជាអស់មួយរយឆ្នាំ មិនប្រសើរឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សហស្សេន** *សេចក្តីថា ដោយបរិច្ចាគទ្រព្យមួយពាន់ ។*

បានព្រះគាថាថា **យោ យជេថ សតំ សមំ** *សេចក្តីថា បុគ្គលណាកាលបរិច្ចាគទ្រព្យមួយពាន់ រៀងរាល់ខែ គប្បីឲ្យទានដល់លោកិយមហាជន អស់មួយរយឆ្នាំ ។*

បានព្រះគាថាថា **ឯកញ្ច ភាវិតត្តានំ** *សេចក្តីថា ចំណែកបុគ្គលណា គប្បីបូជាបុគ្គល ដែលមានខ្លួនអប់រំហើយ ដោយអំណាចនៃគុណតែម្នាក់ ដោយហោចត្រឹមតែបុគ្គលថ្នាក់ទាប ជាព្រះសោតាបន្ន ដោយហោចត្រឹមតែបុគ្គលថ្នាក់ខ្ពស់ ជាព្រះខីណាស្រព ដែលមកដល់ទៀបទ្វារផ្ទះ ដោយអំណាចភិក្ខាមួយវែក ដោយអំណាចអាហារល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ឬដោយត្រឹមតែប្រគេនសំពត់សាច់គ្រោតគ្រោត ការបូជារបស់បុគ្គលនោះឯង ប្រសើរ គឺកំពូល បានដល់ ឧត្តមជាងការបូជា ដែលបុគ្គលក្រៅអំពីនេះបូជាហើយ អស់មួយរយឆ្នាំ ។*

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះសម្រេចសោតាបត្តិផលហើយ ជន

ជនៃជាច្រើន សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រាហ្មណ៍ជាអ៊ីរបស់ព្រះសារីបុត្តត្ថេរ ចប់

រឿង ព្រាហ្មណ៍ជាក្មួយរបស់ព្រះសារីបុត្តត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធក្មួយរបស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជន្តុ** ជាដើម ។

សេចក្តីពិស្តារថា ព្រះថេរៈចូលទៅរកក្មួយនោះហើយសួរថា នែព្រាហ្មណ៍ អ្នកធ្វើកុសលឬ ព្រាហ្មណ៍ឆ្លើយថា បពិត្រលោកម្ចាស់ យ៉ាងនោះឯង ព្រះថេរៈសួរថា អ្នកធ្វើកុសលអ្វី ព្រាហ្មណ៍នោះឆ្លើយថា សម្លាប់សត្វចិញ្ចឹមមួយ ហើយបម្រើភ្លើងរៀងរាល់ខែ ព្រះថេរៈសួរថា ធ្វើយ៉ាងនោះដើម្បីអ្វី ព្រាហ្មណ៍ឆ្លើយថា បានឮថា ទុំ៎ជាផ្លូវទៅព្រហ្មលោក ព្រះថេរៈសួរថា អ្នកណាពោលយ៉ាងនោះ ព្រាហ្មណ៍ឆ្លើយថា ពួកអាចារ្យរបស់ខ្ញុំ ព្រះថេរៈពោលថា អ្នកមិនដឹងផ្លូវនៃព្រហ្មលោក សូម្បីពួកអាចារ្យរបស់អ្នកក៏មិនដឹង មកចុះយើងនឹងទៅកាន់សម្នាក់ព្រះសាស្តា ដូច្នេះហើយ នាំក្មួយនោះទៅកាន់សម្នាក់របស់ព្រះសាស្តា ទូលរឿងនោះហើយ ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ប្រាប់ផ្លូវនៃព្រហ្មលោក ដល់ព្រាហ្មណ៍នេះ ។ ព្រះសាស្តា ត្រាស់សួរថា

បានឮថា សេចក្តីនោះ យ៉ាងនេះឬ កាលព្រាហ្មណ៍ទូលថា បពិត្រព្រះគោតម យ៉ាងនោះឯង ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ ការបម្រើភ្លើងរបស់អ្នក ដែលអ្នកបម្រើយ៉ាងនោះ អស់មួយរយឆ្នាំ រមែងមិនដល់សូម្បីត្រឹមការបូជាសាវ័ករបស់តថាគតត្រឹមតែមួយខណៈទ្បើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យោ ច វស្សសតំ ជន្តុ អគ្គិំ បរិចរេ វនេ
ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ
សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។

ជនណា បម្រើភ្លើងក្នុងព្រៃ អស់មួយរយឆ្នាំ ចំណែកអ្នកណា បូជាលោកដែលមានខ្លួនអប់រំហើយតែមួយនាក់ សូម្បីមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជា របស់ជននោះ ការបូជាអស់មួយរយឆ្នាំ មិនប្រសើរទ្បើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ជន្តុ** *នេះ ត្រឹមតែជាឈ្មោះរបស់សត្វ ។ បានព្រះគាថាថា* **អគ្គិំ បរិចរេ វនេ** *សេចក្តីថា សូម្បីចូលទៅកាន់ព្រៃដោយប្រាថ្នាភាពជាបុគ្គលមិនមានធម៌ជាគ្រឿងយឺតយូរ គប្បីបម្រើភ្លើងក្នុងព្រៃនោះ ។*

ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលមានក្នុងកាលមុននោះឯង ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍សម្រេចសោតាបត្តិផល ជនដទៃជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

រឿង ព្រាហ្មណ៍ជាសម្ភាញ់របស់ព្រះសារីបុត្តត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រាហ្មណ៍ដែលជាសម្ភាញ់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យង្កិញ្ចិ យិដ្ឋញ្ច** *ជាដើម ។*

សេចក្តីពិស្តារថា ព្រះថេរៈចូលទៅរកព្រាហ្មណ៍នោះហើយ សួរថា នែព្រាហ្មណ៍ អ្នកធ្វើកុសលខ្លះដែរឬទេ ព្រាហ្មណ៍ឆ្លើយថា បពិត្រលោកម្ចាស់ ធ្វើដែរ ព្រះថេរៈសួរថា ធ្វើកុសលអ្វី ព្រាហ្មណ៍ឆ្លើយថា បូជាយញ្ញដូចដែលគេបូជា ។

បានឮថា កាលណោះ ជនទាំងឡាយរមែងបូជាយញ្ញនោះ ដោយបរិច្ចាគដ៏ច្រើន ។ បន្ទាប់អំពីនេះ ព្រះថេរៈសួរដោយន័យមុននោះឯង រួចនាំព្រាហ្មណ៍នោះ ទៅកាន់សម្ភាក់របស់ព្រះសាស្តា ទូលរឿងនោះហើយ ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ត្រាស់ប្រាប់ផ្លូវនៃព្រហ្មលោកដល់ព្រាហ្មណ៍នេះ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលព្រាហ្មណ៍ ឮថា សេចក្តីនេះយ៉ាងនោះឬ កាលព្រាហ្មណ៍ទទួលថា យ៉ាងនោះឯង ព្រះអង្គ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ ទានដែលអ្នកបូជាយញ្ញ ដូចដែលគេធ្លាប់បូជា ឲ្យដល់លោកិយមហាជនរាប់ឆ្នាំ រមែងមិនដល់ចំណែកទី ៤ នៃកុសលចេតនាដែលកើតឡើងដល់មនុស្សទាំងឡាយ ដែលថ្វាយបង្គំសាវ័កបស់តថាគត ដោយចិត្តជ្រះថ្លា កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យង្កិញ្ចិ យិដ្ឋំ វ ហុតំ វ លោកេ សំវច្ឆរំ យជេថ បុញ្ញបេក្ខោ
សព្វំបិ តំ ន ចតុភាគមេតិ អភិវាទនា ឧជុគតេសុ សេយ្យោ។

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជាធំតូចណាមួយ ក្នុងលោកអស់មួយឆ្នាំ ការបូជាទាំងអស់នោះឯង រមែងមិនដល់នូវចំណែកទី ៤ នៃការអភិវាទន៍ចំពោះលោកទាំង-ទ្បាយ ដែលប្រព្រឹត្តត្រង់ហើយ ប្រសើរជាង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យង្កិញ្ចិ** *នេះ ជាពាក្យសរុប កាន់យកមិនមានចំណែកសល់ ។ បទថា* **យិដ្ឋំ** *បានដល់ ទានដែលគេឲ្យ ដោយអំណាចការធ្វើមង្គលជាដើមដោយច្រើន ។ បទថា* **ហុតំ** *បានដល់ ទានដើម្បីភ្ញៀវដែលគេរៀបចំធ្វើ និងទានដែលបុគ្គលជឿកម្ម និងផលនៃកម្មធ្វើ ។*

ពីរបទថា **សំវច្ឆរំ យជេថ** *សេចក្តីថា គប្បីឲ្យទានមានប្រការដូចពោលហើយ ដល់លោកិយមហាជនក្នុងចក្កវាឡទាំងមូល អស់មួយឆ្នាំមិនមានរវាងចន្លោះ ។ បទថា* **បុញ្ញបេក្ខោ** *បានដល់ អ្នកប្រាថ្នាបុណ្យ ។ បទថា* **ឧជុ-គតេសុ** *សេចក្តីថា ដោយហោចយ៉ាងទាបក្នុងព្រះសោតាបន្ន ដោយហោចយ៉ាងខ្ពស់ ក្នុងព្រះខីណាស្រព ។*

ពាក្យនេះ ជាពាក្យដែលព្រះសាស្តាត្រាស់ថា ទានទាំងអស់ មិនដល់ត្រឹមចំណែកទី ៤ អំពីផលនៃកុសលចេតនារបស់បុគ្គល ដែលបង្អោនសរីរៈថ្វាយបង្គំដោយចិត្តជ្រះថ្លាបែបនោះ ព្រោះដូច្នោះ ការអភិវាទន៍ក្នុងបុគ្គល

ដែលប្រព្រឹត្តត្រង់ប៉ុណ្ណោះ ប្រសើរបំផុត ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍សម្រេចសោតាបត្តិផលហើយ ជនជនៃជាច្រើន សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រាហ្មណ៍ជាសម្ងាញ់របស់ព្រះសារីបុត្តត្ថេរ ចប់

រឿង អាយុវឌ្ឍនកុមារ

លំនាំដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យទីឃលម្ពិកនគរ ប្រថាប់នៅក្នុងកុដិក្នុងព្រៃ ទ្រង់ប្រារព្ធកុមារដែលអាយុវែង ត្រាស់ព្រះធម្មទេសនានេះថា **អភិ-ហាឧឆសីលិស្ស** ជាដើម ។

បានឮថា ព្រាហ្មណ៍ពីរនាក់ រស់នៅក្នុងទីឃលម្ពិកនគរ បួសក្នុងលទ្ធិខាងក្រៅ បំពេញតប:អស់ ៤៨ ឆ្នាំ បណ្តាព្រាហ្មណ៍ពីរនាក់នោះ ព្រាហ្មណ៍ម្នាក់ គិតថា បវេណីរបស់អញនឹងបាត់បង់ អញនឹងសឹក ដូច្នេះហើយ ទើបលក់បរិក្ខារតប:ដែលខ្លួនធ្វើដល់អ្នកជនៃ បានភរិយា មួយអន្ទើដោយគោមួយរយក្បាល និងទ្រព្យមួយរយកហាបណៈ បានជាដើមទុន ។ គ្រានោះ ភរិយារបស់គាត់ប្រសូតបុត្រ ។

ចំណែកសម្ងាញ់របស់គាត់ ចេញអំពីទីនោះទៅកាន់ទឹកដីជនៃ ត្រឡប់

មកកាន់នគរនោះទៀត ។ គាត់បានឮដំណឹងសម្លាញ់នោះមក ទើបនាំបុត្រ និង ភរិយាទៅដើម្បីសួរសុខទុក្ខសម្លាញ់ កាលដល់ហើយ ឲ្យបុត្រក្នុងដៃរបស់មាតា ហើយ ក៏ថ្វាយបង្គំឯងមុន មាតាឲ្យបុត្រក្នុងដៃបិតាហើយក៏ថ្វាយបង្គំ សម្លាញ់ នោះពោលថា សូមអ្នកអាយុវែង តែកាលមាតាឲ្យបុត្រថ្វាយបង្គំហើយ សម្លាញ់ នោះក៏នៅស្ងៀម ។

លំដាប់នោះ ព្រាហ្មណ៍ពោលនឹងសម្លាញ់នោះថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វី កាលខ្ញុំថ្វាយបង្គំ លោកម្ចាស់ពោលថា សូមអ្នកមានអាយុវែង ក្នុងកាលដែលកុមារនេះថ្វាយបង្គំ មិនពោលពាក្យអ្វីសោះ សម្លាញ់នោះពោល ថា នែព្រាហ្មណ៍ អន្តរាយមួយរបស់ក្មេងនេះមាន ព្រាហ្មណ៍ពោលថា ក្មេង រស់នៅអស់កាលមានប្រមាណប៉ុនណា សម្លាញ់នោះពោលថា នែព្រាហ្មណ៍ ៧ ថ្ងៃទៀតប៉ុណ្ណោះ ព្រាហ្មណ៍សួរថា មានវិធីការពារដែរឬទេ សម្លាញ់នោះ ពោលថា ខ្ញុំមិនដឹងហេតុជាគ្រឿងការពារ ។ ព្រាហ្មណ៍ពោលថា អ្នកណា គប្បីដឹង លោកម្ចាស់ សម្លាញ់នោះឆ្លើយថា ព្រះសមណគោតម ចូរអ្នកទៅ កាន់សម្នាក់របស់ទ្រង់ហើយ សួរចុះ ព្រាហ្មណ៍ពោលថា ខ្ញុំទៅក្នុងទីនោះ ខ្លាចអំពីការវិនាសនៃតបៈ សម្លាញ់នោះពោលថា បើការស្រឡាញ់ក្នុងបុត្រ របស់អ្នកមាន កុំគិតដល់ការវិនាសនៃតបៈឡើយ ចូរទៅកាន់សម្នាក់របស់ ព្រះគោតមនោះសួរចុះ ។

ព្រាហ្មណ៍នោះ ទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំឯងជាបឋម ព្រះសាស្តាត្រាស់ថា ចូរអ្នកមានអាយុវែង សូម្បីក្នុងពេលដែលបជាបតីថ្វាយ

បង្គំ ក៏ត្រាស់ដល់នាងយ៉ាងនោះដូចគ្នា ក្នុងកាលដែលព្រាហ្មណ៍ឲ្យបុត្រថ្វាយបង្គំ ទ្រង់ក៏នៅស្ងៀម ។ គាត់ទូលសួរព្រះសាស្តាដោយនយមុននោះឯង សូម្បីព្រះសាស្តា ក៏ទ្រង់ព្យាករដល់គាត់យ៉ាងនោះដូចគ្នា ។

បានឮថា ព្រាហ្មណ៍នោះមិនចាក់ផ្ទុះសព្វញ្ញុតញ្ញាណ ទើបប្រៀបធៀបមន្តរបស់ខ្លួនជាមួយសព្វញ្ញុតញ្ញាណ តែមិនដឹងឧបាយជាគ្រឿងការពារ ។

ព្រាហ្មណ៍ទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ឧបាយជាគ្រឿងការពារមានដែរឬទេ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ មាន ព្រាហ្មណ៍ទូលថា គប្បីមានដូចម្តេច ព្រះសាស្តាត្រាស់ថា បើអ្នកអាចធ្វើមណ្ឌបក្បែរទ្វារផ្ទះរបស់ខ្លួន ធ្វើតាំងត្រង់កណ្តាលមណ្ឌបនោះ ហើយក្រាលអាសនៈ ៨ ឬ ១៦ ព័ទ្ធជុំវិញតាំងនោះ ឲ្យសាវ័ករបស់តថាគតអង្គុយលើអាសនៈទាំងនោះ ធ្វើព្រះបរិត្ត ៧ ថ្ងៃ មិនមានចន្លោះ អន្តរាយរបស់ក្មេងនោះ គប្បីវិនាសទៅដោយឧបាយយ៉ាងនេះ ។

ព្រាហ្មណ៍ពោលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គអាចធ្វើមណ្ឌបជាដើមបាន តែនឹងបានសាវ័ករបស់ទ្រង់ដូចម្តេច ព្រះសាស្តាត្រាស់ថា បើអ្នកធ្វើកិច្ចប៉ុណ្ណេះហើយ តថាគតនឹងឲ្យសាវ័ករបស់តថាគតទៅ ព្រាហ្មណ៍ទទួលថា សាធុ ព្រះគោតម ហើយធ្វើកិច្ចទាំងអស់នោះជិតទ្វារផ្ទះរបស់ខ្លួនហើយ បានទៅកាន់សម្នាក់របស់ព្រះសាស្តា ។

ព្រះសាស្តាទ្រង់បញ្ជូនភិក្ខុទាំងឡាយទៅ ភិក្ខុទាំងនោះអង្គុយក្នុងមណ្ឌបនោះ ព្រាហ្មណ៍ស្វាមីភរិយាឲ្យកុមារដេកលើតាំងហើយ ភិក្ខុទាំងឡាយសូត្រ

ព្រះបរិត្ត ៧ យប់ ៧ ថ្ងៃមិនមានចន្លោះ ។ ក្នុងថ្ងៃទី ៧ ព្រះសាស្តាយាងមកឯង កាលព្រះសាស្តាយាងទៅហើយ ពួកទេវតាក្នុងចក្កវាឡទាំងមូលប្រជុំគ្នាហើយ ។

ឯអវុទ្ធកយក្ខ បម្រើព្រះបាទវេស្សវណ ១២ ឆ្នាំ កាលបានពរអំពីសម្ងាក់ព្រះបាទវេស្សវណានោះ បានពោលថា ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ អ្នកគប្បីចាប់យកទារកនេះ ព្រោះដូច្នោះ ទើបយក្ខនោះមកឈរ កាលព្រះសាស្តាយាងទៅក្នុងមណ្ឌបនោះ ពួកទេវតាមានសក្តិធំប្រជុំគ្នា ពួកទេវតាមានសក្តិតូច ក៏ថយទៅ មិនបានឱកាស ចៀសចេញទៅអស់ ១២ យោជន៍ សូម្បីអវុទ្ធកយក្ខ ក៏បានចៀសទៅឈរយ៉ាងនោះដូចគ្នា ។

ព្រះសាស្តា ទ្រង់បានធ្វើព្រះបរិត្តមួយយប់ទល់ភ្លឺ កាលថ្ងៃទី ៧ កន្លងហើយ អវុទ្ធកយក្ខមិនបានទារក ក្នុងថ្ងៃទី ៨ គ្រាន់តែអារុណរះទ្បើងប៉ុណ្ណោះ ស្វាមីភរិយា នាំកុមារឲ្យថ្វាយបង្គំព្រះសាស្តា ព្រះសាស្តាត្រាស់ថា ចូរអ្នកមានអាយុវែងចុះ ព្រាហ្មណ៍ទូលថា បពិត្រព្រះគោតម កុមារនេះតាំងនៅយូរប៉ុនណា ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ ១២០ ឆ្នាំ ។

លំដាប់នោះ ស្វាមីភរិយាទាំងពីរ ដាក់ឈ្មោះក្មេងនោះថា អាយុវឌ្ឍន-កុមារ ។ អាយុវឌ្ឍនកុមារនោះ ចម្រើនធំធាត់ហើយ មានឧបាសក ៥០០ ចោមរោមគ្រាច់ទៅ ។

ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងភេងធម្មសភាថា អាវុសោទាំងឡាយ ចូរអ្នកទាំងឡាយមើល បានឮថា អាយុវឌ្ឍនកុមារគប្បីស្លាប់ក្នុងថ្ងៃទី ៧ ឥឡូវ

នេះ អាយុវឌ្ឍនកុមារនោះ មានឧបាសក ៥០០ ចោមរោម ត្រាច់ទៅ ហេតុជាគ្រឿងចម្រើនអាយុរបស់សត្វទាំងនេះ ប្រហែលជាមាន ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាយុចម្រើនតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន សត្វទាំងនេះថ្វាយបង្គំបុគ្គលដែលមានគុណ រមែងចម្រើនដោយហេតុ ៤ ប្រការ ផុតចាកអន្តរាយ តាំងនៅដរាបដល់អាយុនោះឯង ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុវណ្ណោ សុខំ ពលំ ។

ធម៌ ៤ ប្រការ គឺអាយុ ១ វណ្ណៈ ១ សុខ ១ ពល ១ រមែងចម្រើន ដល់អ្នកដែលមានសេចក្តីឱនកាយ ថ្វាយបង្គំជាប្រក្រតី មានសេចក្តីកោតក្រែង ដល់បុគ្គលដែលចម្រើនជាងខ្លួនអស់កាលជានិច្ច ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អភិវាទនសីលិស្ស** *គឺដែលថ្វាយបង្គំជាប្រក្រតី ចានដល់ ជាអ្នកខ្វល់ខ្វាយដោយកិច្ច គឺការថ្វាយបង្គំរឿយៗ ។ បទថា* **វុឌ្ឍាបចាយិនោ** *សេចក្តីថា ដល់គ្រហស្ថដែលឱនលំទោន ឬដែលបូជា*

ជានិច្ច ដោយការថ្វាយបង្គំ សូម្បីក្នុងភិក្ខុកំលោះ និងសាមណេរដែលបួសក្នុងថ្ងៃនោះ ឬដល់បព្វជិតជាអ្នកឱនលំទោន ឬបួជាជានិច្ច ដោយការក្រាបថ្វាយបង្គំក្នុងបុគ្គលដែលចាស់ជាងដោយបព្វជ្ជា ឬដោយឧបសម្បទា ឬក្នុងបុគ្គលដែលចម្រើនដោយគុណ ។

ពីរបទថា **ចត្តារោ ធម្មា** *សេចក្តីថា កាលអាយុចម្រើន អាយុនោះរមែងចម្រើនអស់កាលប៉ុនណា ធម៌ទាំង៤ប្រាយក្រៅអំពីនេះ ក៏ចម្រើនអស់កាលប៉ុណ្ណោះដូចគ្នា ព្រោះថា បុគ្គលណាធ្វើកុសលដែលញុំាងអាយុ ៥០ ឆ្នាំ ឲ្យប្រព្រឹត្តទៅ អន្តរាយនៃជីវិតរបស់បុគ្គលនោះ គប្បីកើតឡើងក្នុងកាលមានអាយុ២៥ ឆ្នាំ អន្តរាយនោះ រមែងរម្ងាប់បាន ដោយភាពជាអ្នកថ្វាយបង្គំជាប្រក្រតី ។ បុគ្គលនោះ រមែងតាំងនៅបានដរាបដល់អស់អាយុនោះឯង ។ សូម្បីពណ៌សម្បុរជាដើមរបស់បុគ្គលនោះ រមែងចម្រើនព្រមជាមួយអាយុនោះឯង ។*

នយក្រៃលែងជាងនេះ ក៏យ៉ាងនេះឯង ។ ឈ្មោះថា ការចម្រើននៃអាយុ ដែលប្រព្រឹត្តទៅ ដោយមិនមានអន្តរាយ ក៏មិនមែន ។

ក្នុងកាលចប់ទេសនា អាយុវឌ្ឍនកុមារតាំងនៅក្នុងសោតាបត្តិផល មួយអន្ទើដោយឧបាសក ៥០០ ហើយ សូម្បីជនដទៃជាច្រើន ក៏សម្រេចអរិយផលទាំង៤ប្រាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

រឿង អាយុវឌ្ឍនកុមារ ចប់

រឿង សង្គិច្ចសាមណេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសង្គិច្ចសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជីវេ** ជាដើម ។

បានឮថា កុលបុត្រប្រមាណ ៣០ នាក់ ក្នុងក្រុងសាវត្ថី ស្តាប់ធម្មកថាហើយ បួសថ្វាយជីវិតក្នុងសាសនារបស់ព្រះសាស្តា ភិក្ខុទាំងនោះឧបសម្បទាបាន ៥ វស្សា ចូលគាល់ព្រះសាស្តា ស្តាប់ធុរៈពីរប្រការ គឺគន្ថធុរៈ និងវិបស្សនាធុរៈ មិនធ្វើឧស្សាហ៍ក្នុងគន្ថធុរៈ ព្រោះជាអ្នកបួសឯចាស់ កាលបំណងនឹងបំពេញវិបស្សនាធុរៈ ទូលសូមព្រះសាស្តា ឲ្យត្រាស់ប្រាប់កម្មដ្ឋានអំពីអរហត្ត ទើបទូលលាព្រះសាស្តាថា ខ្ញុំព្រះអង្គនឹងទៅកាន់ព្រៃមួយកន្លែង ។

ព្រះសាស្តាត្រាស់សួរថា ពួកអ្នកនឹងទៅក្នុងទីណា កាលភិក្ខុទាំងនោះក្រាបទូលថា ក្នុងទីឈ្មោះនោះ ទ្រង់បានជ្រាបថា ភ័យនឹងកើតឡើងក្នុងទីនោះដល់ភិក្ខុទាំងនោះ ព្រោះអាស្រ័យមនុស្សស៊ីដែលម្នាក់ តែបើសង្គិច្ចសាមណេរទៅហើយ ភ័យនឹងរម្ងាប់ កាលបើដូច្នោះ កិច្ចបព្វជិតរបស់ភិក្ខុទាំងនោះនឹងដល់នូវភាពបរិបូណ៌ ។

សាមណេររបស់ព្រះសារីបុត្ត ឈ្មោះសង្គិច្ចសាមណេរ មានអាយុ ៧ ឆ្នាំអំពីកំណើត ។ បានឮថា មាតារបស់សង្គិច្ចសាមណេរនោះ ជាកូនស្រីរបស់ត្រកូលស្តុកស្តម្ភ ក្នុងក្រុងសាវត្ថី ។ កាលសាមណេរនោះ នៅក្នុងផ្ទៃមាតានោះ បានធ្វើកាលកិរិយាក្នុងខណៈនោះឯង ដោយជំងឺឯណានីមួយ ។

កាលមាតា នោះត្រូវដុត សាច់ចំណែកដ៏សេសសេះទៅ រៀវតែសាច់ផ្ទៃពោះ ។ លំដាប់នោះ ពួកព្ភុកលើកសាច់ពោះរបស់នាងចុះអំពីជើងថ្ពរ ចាក់ដោយដែកស្រួច ក្នុងទីពីរបីកន្លែង ចុងដែកក៏ចាក់ត្រង់កន្ទុយភ្នែករបស់ទារក ពួកអ្នកព្ភុកចាក់សាច់ពោះយ៉ាងនោះហើយ ទើបបោះទៅលើគំនរអង្កើកភ្លើង លុបដោយរអង្កើកភ្លើងនោះឯង ហើយចៀសចេញទៅ សាច់ពោះសេះហើយ ។ ចំណែកទារកហាក់ដូចជាដុំមាសលើគំនរអង្កើកភ្លើង ដូចដេកនៅក្នុងត្របកផ្កាឈូក ។ ពិតហើយ សត្វដែលមានកពចុងក្រោយ សូម្បីត្រូវភ្នំសិនេរុសង្កត់ បើមិនទាន់សម្រេចអរហត្ត ជីវិតមិនអស់ឡើយ ។ ក្នុងថ្ងៃស្អែកឡើង ពួកអ្នកព្ភុកមកដោយគិតថា នឹងពន្ធត់ជើងថ្ពរ ឃើញទារកដេកយ៉ាងនោះ កើតអស្ចារ្យចម្លែកក្នុងចិត្ត គិតថា មានរឿងអ្វីកើតឡើងហ្ន៎ សរីរៈទាំងមូលដុតលើឧសប៉ុណ្ណោះ ទារកមិនឆេះហើយ នឹងមានហេតុអ្វីហ្ន៎ ទើបពទារកនោះនាំទៅក្នុងស្រុកហើយ សាកសួរពួកហោរាទាយនិមិត្ត ។ ពួកហោរាទាយនិមិត្តពោលថា ទារកនេះ បើនៅគ្រប់គ្រងផ្ទះ ពួកញាតិ ៧ តំណត្រកូលនឹងមិនធ្លាក់ក្រីក្រ បើចេញបួស នឹងជាបុគ្គលមានសមណៈ ៥០០ ចោមរោម ត្រាច់ទៅ ។ ពួកញាតិដាក់ឈ្មោះថា សង្កិច្ចៈ ព្រោះកន្ទុយភ្នែករបស់ទារកមុតដោយដែកស្រួច ។

គ្រាក្រោយមក កុមារនោះប្រាកដថា សង្កិច្ចៈ ។ គ្រានោះ ពួកញាតិចិញ្ចឹមទារក ដោយគិតគ្នាថា ណ្ហើយចុះ ក្នុងកាលដែលទារកធំហើយ ពួកយើងនឹងឲ្យបួសក្នុងសម្នាក់ព្រះសារីបុត្ត លោកម្ចាស់របស់យើង ។ ក្នុងពេល

ដែលកុមារបានអាយុ ៧ ឆ្នាំ សង្កិច្ចៈនោះបានឮពាក្យរបស់ក្មេងៗ ថា ក្នុងកាលដែលឯងនៅក្នុងពោះ ម៉ែរបស់ឯងធ្វើកាលកិរិយាហើយ កាលសរីរៈម៉ែរបស់ឯងនោះត្រូវដុត ឯងក៏មិនឆេះ ទើបប្រាប់ដល់ពួកញាតិថា បានឮថា ខ្ញុំរួចផុតអំពីភ័យបែបនោះ ប្រយោជន៍អ្វីរបស់ខ្ញុំដោយផ្ទះ ខ្ញុំនឹងបួស ។ ញាតិទាំងនោះទទួលថា សាធុ ហើយនាំទៅកាន់សម្នាក់ព្រះសារីបុត្តត្ថេរ ប្រគេនដោយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យក្មេងនេះ បួសចុះ ។ ព្រះថេរៈឲ្យតចបញ្ចកកម្មដ្ឋានហើយឲ្យបួស ។ សាមណេរនោះ សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទា ក្នុងពេលកោរសក់ស្រេចនោះឯង ឈ្មោះថា សង្កិច្ចសាមណេរ មានប្រមាណប៉ុណ្ណេះ ។

ព្រះសាស្តាទ្រង់ជ្រាបថា កាលសាមណេរនេះទៅហើយ ភ័យនឹងរម្ងាប់កាលបើដូច្នោះ កិច្ចនៃបព្វជិតរបស់ភិក្ខុទាំងនោះនឹងដល់នូវភាពបរិបូណ៌ ដូច្នេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នកលាសារីបុត្តបង់ប្រុសរបស់អ្នកហើយសឹមទៅ ។ ភិក្ខុទាំងនោះទទួលថា សាធុ ហើយទៅកាន់សម្នាក់របស់ព្រះថេរៈ កាលព្រះថេរៈសួរថា ពួកលោកមានការអ្វី ទើបពោលថា ខ្ញុំរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ មានបំណងនឹងចូលទៅកាន់ព្រៃ ទើបទូលលា កាលបើដូច្នោះ ទើបព្រះសាស្តាត្រាស់យ៉ាងនេះដល់ពួកខ្ញុំថា ពួកអ្នកលាបង់ប្រុសរបស់ពួកអ្នកហើយសឹមទៅ ដោយហេតុនោះ ទើបពួកខ្ញុំមកទីនេះ ។

ព្រះថេរៈគិតថា ភិក្ខុទាំងនេះ ប្រហែលជាព្រះសាស្តាទ្រង់ឃើញហេតុណាមួយហើយបញ្ជូនមកទីនេះ តើមានរឿងអ្វីហ្ន៎ ដឹងរឿងនោះហើយ ទើប

ពោលថា អាវុសោ សាមណេររបស់ពួកអ្នកមានដែរឬទេ ភិក្ខុឆ្លើយថា មិនមានទេ អាវុសោ ព្រះថេរៈពោលថា បើមិនមាន ចូរពួកលោកនាំសាមណេរនេះទៅ ពួកភិក្ខុពោលថា កុំឡើយអាវុសោ ព្រោះអាស្រ័យសាមណេរ ការកង្វល់នឹងមានដល់ពួកខ្ញុំ ប្រយោជន៍អ្វីដោយសាមណេរ សម្រាប់ពួកភិក្ខុដែលនៅក្នុងព្រៃ ។ ព្រះថេរៈពោលថា អាវុសោ ព្រោះអាស្រ័យសាមណេរនេះ ការកង្វល់មិនមានដល់ពួកលោកឡើយ តែព្រោះអាស្រ័យពួកលោក កង្វល់នឹងមានដល់សាមណេរនេះ សូម្បីព្រះសាស្តា កាលទ្រង់បញ្ជូនពួកអ្នកមកកាន់សម្នាក់ខ្ញុំ ទ្រង់ចង់ឲ្យសាមណេរទៅជាមួយពួកលោក ទើបទ្រង់បញ្ជូនមក ចូរពួកលោកនាំសាមណេរនេះទៅចុះ ។

ភិក្ខុទាំងនោះទទួលថា សាធុ មានគ្នាគម្រប់ ៣១ រូប ទាំងសាមណេរ លាព្រះថេរៈចេញអំពីវិហារ ត្រាច់ទៅដល់ស្រុកមួយ មានត្រកូល ១០០០ ក្នុងចម្ងាយ ១២០ យោជន៍ ។ ពួកមនុស្សឃើញភិក្ខុទាំងនោះ មានចិត្តជ្រះថ្លា អង្គាសដោយគោរពហើយ សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយនិមន្តទៅណា កាលភិក្ខុទាំងនោះឆ្លើយថា ទៅរកទីស្តានដែលជាផាសុក ទើបក្រាបចុះទៀបបាទជើងនិមន្តថា បពិត្រលោកម្ចាស់ បើលោកម្ចាស់អាស្រ័យស្រុកនេះ អស់កាលខាងក្នុងវស្សា ពួកខ្ញុំនឹងសមាទានសីល ៥ និងរក្សាឧបោសថ ព្រះថេរៈទាំងឡាយទទួលហើយ ។ គ្រានោះ ពួកភិក្ខុរៀបចំទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃ ទីចង្រ្កម និងបណ្ណសាលា ដល់នូវភាពឧស្សាហ៍ថា ថ្ងៃនេះ ពួកយើង ស្អែកនេះ ពួកយើងបានធ្វើការទំនុក

បម្រុងភិក្ខុទាំងនោះ ។

ក្នុងថ្ងៃចាំវស្សា ព្រះថេរៈទាំងឡាយធ្វើកតិកាគ្នាថា អាវុសោ ពួកយើងរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសម្ពុទ្ធ ដែលទ្រង់គង់ព្រះជន្មនៅឡើយ តែរឿរការដល់ព្រមដោយបដិបទា ពួកយើងមិនអាចញុំាងព្រះពុទ្ធទាំងឡាយឲ្យត្រេកអរបាន ។ ម៉្យាងទៀត ទ្វារអបាយក៏បើកហើយ សម្រាប់ពួកយើងនោះឯង ព្រោះដូច្នោះ រឿរពេលភិក្ខាចារក្នុងពេលព្រឹក និងពេលទំនុកបម្រុងព្រះថេរៈពេលល្ងាច ក្នុងកាលដ៏សេស ពួកយើងនឹងមិននៅក្នុងទីតែមួយពីររូបឡើយ ការមិនផាសុកមានដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវាយជួង ពួកយើងនឹងទៅកាន់សម្នាក់លោកម្ចាស់អង្គនោះ ដើម្បីធ្វើថ្នាំ ក្នុងចំណែកពេលយប់ ឬក្នុងចំណែកពេលថ្ងៃ ដទៃក្រៅអំពីនេះ ពួកយើងកុំប្រមាទប្រកបកម្មដ្ឋានរឿយៗ ។

កាលភិក្ខុទាំងនោះធ្វើកតិកាយ៉ាងនោះ បុរសទុគ៌តម្នាក់ អាស្រ័យកូនស្រីរស់នៅ កាលទុព្ភិក្ខភ័យកើតឡើងក្នុងទីនោះ មានបំណងនឹងអាស្រ័យកូនដទៃរស់នៅ ទើបធ្វើដំណើរទៅ សូម្បីព្រះថេរៈទាំងឡាយត្រាច់ទៅបិណ្ឌបាតក្នុងស្រុក មកដល់លំនៅ ងូតទឹកក្នុងស្ទឹងមួយកន្លែងក្នុងរវាងផ្លូវនោះ អង្គុយលើឆ្នេរខ្សាច់ធ្វើភត្តកិច្ច ។ ក្នុងខណៈនោះ បុរសនោះដល់ទីនោះហើយ បានឈរនៅក្នុងទីបំផុតនាចំណែកម្ខាង ។ លំដាប់នោះ ព្រះថេរៈទាំងឡាយសួរថា តើអ្នកទៅណា បុរសនោះប្រាប់សេចក្តីនោះហើយ ។ ព្រះថេរៈទាំងឡាយកើតសេចក្តីករុណាក្នុងបុរសនោះ ទើបពោលថា ឧបាសក អ្នកឃ្លានខ្លាំង ចូរទៅ

នាំស្លឹកឈើមក ពួកអាត្មានឹងឲ្យដុំកត្តដល់អ្នកមួយរូបមួយដុំ កាលគាត់នាំស្លឹកឈើមកហើយ ទើបច្របល់ដោយសម្ង និងម្ហូប ដោយទំនងដែលធាន់រៀងៗខ្លួន បានឲ្យដុំកត្តមួយរូបមួយដុំ ។ បានឮថា ទំនៀមមានដូច្នោះ ភិក្ខុបើឲ្យកត្តដល់អ្នកមកដល់ក្នុងពេលធាន់ មិនឲ្យអនាមដ្ឋកត្ត គប្បីឲ្យតិចតួចខ្លះ ច្រើនខ្លះ ដោយទំនងដែលធាន់ដោយខ្លួននោះឯង ព្រោះដូច្នោះ ទើបភិក្ខុទាំងនោះមិនបានឲ្យយ៉ាងនោះ ។ បុរសនោះធ្វើកត្តកិច្ចហើយ ថ្វាយបង្គំព្រះថេរៈទាំង-ទ្វាយ សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងទ្វាយ បុគ្គលណាមួយនិមន្តទុកឬ ភិក្ខុទាំងនោះ ពោលថា ឧបាសក មិនមានការនិមន្តទេ ពួកមនុស្សឲ្យអាហារបែបនេះរៀងរាល់ថ្ងៃ ។

ទុគ្គតបុរសគិតថា អញសូម្បីប្រឹងប្រែងធ្វើការងារអស់កាលជានិច្ច ក៏មិនអាចបានអាហារបែបនោះ ប្រយោជន៍អ្វីរបស់អញដោយការទៅកាន់ទីដទៃ អញនឹងនៅក្នុងសម្នាក់របស់ភិក្ខុទាំងនេះឯង ។ លំដាប់នោះ ទើបពោលនឹងភិក្ខុទាំងនោះថា ខ្ញុំប្រាថ្នានឹងធ្វើវត្តបដិបត្តិក្នុងសម្នាក់របស់ពួកលោកម្ចាស់ ភិក្ខុទាំងនោះពោលថា សាធុ ឧបាសក ។

គាត់ចូលទៅត្រង់លំនៅរបស់ភិក្ខុទាំងនោះ ជាមួយភិក្ខុទាំងនោះ ធ្វើវត្តបដិបត្តិដ៏ល្អ ញ៉ាំងពួកភិក្ខុឲ្យស្រឡាញ់ក្រៃលែងអស់ ២ ខែ ប្រាថ្នាទៅសួរសុខទុក្ខកូនស្រី គិតថា បើអញលាលោកម្ចាស់ទាំងទ្វាយ លោកម្ចាស់ទាំងទ្វាយ នឹងមិនឲ្យអញទៅ ដូច្នេះ អញមិនលាទៅយ ដូច្នេះហើយ ក៏មិនប្រាប់ដល់ភិក្ខុទាំងនោះ លួចចេញទៅហើយ ។ បានឮថា ការដែលបុរសនោះ

មិនលាពួកភិក្ខុចៀសចេញទៅប៉ុណ្ណោះ ក៏មានអន្តរាយធំក្នុងផ្លូវទៅរបស់បុរសនោះ មានព្រៃមួយកន្លែង ។ ថ្ងៃទី ៧ ជាថ្ងៃរបស់ចោរ ៥០០ ធ្វើការបន់ស្រន់ទេវតាថា អ្នកណាចូលកាន់ព្រៃនេះ ពួកយើងនឹងសម្លាប់អ្នកនោះ ហើយធ្វើពលីកម្មដល់លោក ដោយសាច់ និងឈាមរបស់បុគ្គលនោះឯង ហើយនៅក្នុងព្រៃនោះ ។

ព្រោះដូច្នោះ ក្នុងថ្ងៃទី ៧ មេចោរឡើងដើមឈើ ពិនិត្យមើលពួកមនុស្ស ឃើញបុរសនោះដើរមក ទើបឲ្យសញ្ញាដល់ពួកចោរ ។ ចោរទាំងនោះដឹងភាពដែលបុរសនោះចូលកាន់ព្រៃ ទើបព័ទ្ធចាប់ ធ្វើការចង់ឃ៉ាងមាំទាំ កួតភ្លើងដោយឈើកួតភ្លើង ជញ្ជួនឧសមកគរជាគំនរធំ សម្រួចលំពែង ។ បុរសនោះ ឃើញកិរិយារបស់ចោរទាំងនោះ សួរថា នែអ្នក ក្នុងទីនេះ ខ្ញុំមិនឃើញជ្រូក និងម្រឹគជាដើមឡើយ ហេតុអ្វី ទើបពួកអ្នកធ្វើលំពែងនេះ ពួកចោរឆ្លើយថា ពួកយើងនឹងសម្លាប់ឯង ធ្វើពលីកម្មដល់ទេវតាដោយសាច់ និងឈាមរបស់ឯង ។

បុរសនោះត្រូវមរណភ័យគ្រប់សង្កត់ មិនបានគិតដល់ឧបការៈរបស់ពួកភិក្ខុ គិតរក្សាជីវិតរបស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះ ទើបពោលយ៉ាងនេះថា នែអ្នក ខ្ញុំជាមនុស្សស៊ីដែល បរិភោគភត្តដែលជាសំណល់ធំធាត់ ឈ្មោះថា បុគ្គលស៊ីដែល ជាមនុស្សកាឡកិណី ឯពួកព្រះថេរៈចេញបួសអំពីត្រកូលណាមួយ ជាក្សត្រនោះឯង ភិក្ខុ ៣១ រូបនៅក្នុងទីឈ្មោះនោះ ពួកអ្នកបួរសម្លាប់ភិក្ខុទាំងនោះ ហើយធ្វើកម្ម ទេវតារបស់ពួកអ្នកនឹងត្រេកអរយ៉ាងក្រៃលែង ។

ពួកចោរស្តាប់ពាក្យនោះហើយគិតថា បុគ្គលនេះនិយាយត្រូវ ប្រយោជន៍អ្វីដោយមនុស្សកាឡកិណីនេះ ពួកយើងនឹងសម្លាប់ពួកក្សត្រធ្វើពលីកម្ម ដូច្នេះហើយ ទើបពោលថា មកចុះ ចូរអ្នកបង្ហាញលំនៅរបស់កិកូទាំងនោះ ហើយឲ្យបុរសនោះឯងធ្វើជាអ្នកនាំផ្លូវ ដល់ទីនោះហើយ មិនឃើញពួកកិកូក្នុងវិហារ ទើបសួរថា ពួកកិកូទៅណា បុរសនោះដឹងកតិកាវត្តរបស់កិកូទាំងនោះ ព្រោះនៅបាន ២ ខែ ទើបពោលយ៉ាងនេះថា ពួកកិកូអង្គុយក្នុងទីសម្រាកពេលយប់ និងពេលថ្ងៃរបស់ខ្លួន ចូរវាយជួងនោះ ពួកកិកូនឹងប្រជុំគ្នាដោយសំឡេងជួង ។ មេចោរវាយជួងហើយ ពួកកិកូបានឮសំឡេងជួងគិតថា អ្នកណាវាយជួងខុសកាល ការមិនផាសុកនឹងមានដល់អ្នកណា ដូច្នេះហើយ ទើបមកអង្គុយលើផ្ទាំងថ្ម ដែលគេរៀបចំដោយលំដាប់ត្រង់កណ្តាលវិហារ ព្រះសង្ឃត្តេរសម្លឹងមើលពួកចោរហើយ សួរថា ឧបាសក អ្នកណាវាយជួង មេចោរឆ្លើយថា ខ្ញុំលោកម្ចាស់ ព្រះសង្ឃត្តេរសួរថា ព្រោះហេតុអ្វី មេចោរឆ្លើយថា ពួកខ្ញុំបន់ស្រន់ទេវតាប្រចាំព្រៃថា នឹងចាប់កិកូមួយរូបទៅ ដើម្បីធ្វើពលីកម្មដល់ទេវតានោះ ។

ព្រះមហាថេរៈស្តាប់ពាក្យនោះហើយ ទើបពោលនឹងពួកកិកូនោះថា អាវុសោធម្មតាកិច្ចកើតដល់ពួកបួនៗ បងត្រូវជួយស្រោចស្រង់ ខ្ញុំនឹងលះបង់ជីវិតរបស់ខ្លួនដើម្បីពួកលោក ទៅជាមួយចោរទាំងនេះ សូមអន្តរាយកុំបីមានដល់លោកគ្រប់រូប សូមពួកលោកជាអ្នកមិនប្រមាទ ធ្វើសមណធម៌ចុះ ។ ព្រះអនុត្តេរពោលថា បពិត្រលោកម្ចាស់ ធម្មតាកិច្ចរបស់បងប្រុស រមែងជាការៈរបស់បួនប្រុស ខ្ញុំនឹងទៅ សូមលោកទាំងឡាយជាអ្នកមិនប្រមាទចុះ ។ ដោយឧបាយ

នេះ ភិក្ខុទាំង ៣០ ក្រោកឡើងនិយាយជាលំដាប់ថា ខ្ញុំឯង ខ្ញុំឯង ដោយប្រការដូច្នេះ ។ ភិក្ខុទាំងអស់មិនមែនជាបុត្ររួមមាតាជាមួយគ្នាឡើយ មិនជាបុត្ររបស់បិតាជាមួយគ្នាឡើយ ទាំងមិនទាន់អស់រាគៈ តែរមែងលះបង់ជីវិតតាមលំដាប់ ដើម្បីប្រយោជន៍ដល់ភិក្ខុដ៏សេស បណ្តាភិក្ខុទាំងនោះ សូម្បីភិក្ខុមួយរូប ឈ្មោះថា អាចពោលថា សូមលោកទៅចុះ មិនមានឡើយ ។

សង្កិច្ចសាមណេរបានស្តាប់ពាក្យរបស់ភិក្ខុទាំងនោះ ទើបពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឈប់ចុះ ខ្ញុំនឹងលះបង់ជីវិតដើម្បីលោកម្ចាស់ទាំងឡាយ ពួកភិក្ខុពោលថា អាវុសោ យើងទាំងអស់សូម្បីត្រូវស្លាប់រួមគ្នា ក៏មិនព្រមលះបង់រូបលោកតែមួយរូប សាមណេរពោលថា ព្រោះហេតុអ្វី ពួកភិក្ខុពោលថា អាវុសោ ព្រោះលោកជាសាមណេររបស់ព្រះធម្មសេនាបតីសារីបុត្តត្ថេរ បើខ្ញុំលះបង់លោក ព្រះថេរៈនឹងតិះដៀលថា ពួកភិក្ខុនាំសាមណេររបស់ខ្ញុំទៅ ប្រគល់ឲ្យដល់ពួកចោរ ខ្ញុំមិនអាចរលាស់ចោលនូវពាក្យតិះដៀលទាំងនោះបានឡើយ ដោយហេតុនោះ ខ្ញុំមិនលះបង់លោកឡើយ សាមណេរពោលថា បពិត្រលោកម្ចាស់ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជូនពួកលោកម្ចាស់ទៅកាន់សម្នាក់ឧបជ្ឈាយ៍របស់ខ្ញុំក្តី ព្រះឧបជ្ឈាយ៍របស់ខ្ញុំក្តី បញ្ជូនខ្ញុំមកជាមួយលោកម្ចាស់ទាំងឡាយ ទ្រង់បានឃើញហេតុទាំងអស់នេះហើយ ទើបបញ្ជូនមក ឈប់ចុះ ខ្ញុំនេះឯងនឹងទៅ ។

សាមណេរនោះថ្វាយបង្គំភិក្ខុទាំង ៣០ រូបហើយពោលថា បពិត្រលោកម្ចាស់ បើទោសរបស់ខ្ញុំមាន សូមលោកម្ចាស់អត់ទោស ដូច្នេះហើយ ចេញ

ទៅ ការសង្វេគយ៉ាងធំ កើតឡើងដល់ពួកភិក្ខុហើយ ក្អែកពេញទៅដោយទឹកភ្នែក ហទយៈញាប់ញ័រហើយ ។ ព្រះមហាថេរៈពោលនឹងពួកចោរថា ឧបាសក កុមារនេះ ឃើញអ្នកបង្កាត់ភ្លើង សម្រួចលំពែង ក្រាលស្បឹកឈើនឹងខ្លាច អ្នកទាំងឡាយជាក់សាមណេរនេះក្នុងចំណែកមួយ គប្បីធ្វើកិច្ចទាំងនោះ ។ ពួកចោរនាំសាមណេរទៅក្នុងទីមួយកន្លែង ហើយធ្វើកិច្ចទាំងពួង ។

ក្នុងពេលស្រេចកិច្ច មេចោរបានហូតដាវ ដើរតម្រង់ទៅរកសាមណេរ កាលសាមណេរអង្គុយ ក៏អង្គុយចូលឈាន ។ មេចោរគ្រវីដាវតម្រង់កសាមណេរ ជាវបត់មុខទាល់នឹងមុខ ។ មេចោរនោះសម្គាល់ថា អញប្រហារមិនល្អ ទើបពត់ដាវនោះឲ្យត្រង់ហើយប្រហារទៀត ។ ដាវក៏រមូរដូចស្បឹកគ្នោតរហូតដល់គល់ដាវ ។ ពិតហើយ បុគ្គលយកភ្នំសិនេរុសង្កត់សាមណេរនោះឈ្មោះថា អាចឲ្យសាមណេរស្ងាប់មិនមានឡើយ នឹងពោលថ្វី ត្រឹមតែយកដាវកាប់ឲ្យស្ងាប់ ។ មេចោរឃើញឫទ្ធិបាដិហារ្យនោះហើយ គិតថា កាលមុនដាវរបស់អញ រមែងកាត់សសរថ្ម ឬដង្គត់គគីរផុយដូចដើមចេក ឥឡូវនេះដាវរបស់អញឯម្តង ម្តងទៀតក៏រមូលដូចស្បឹកគ្នោត ដាវនេះមិនមានចេតនាគង់ដឹងគុណសាមណេរនេះ ឯអញមានចេតនា ហេតុអ្វី មិនដឹង ។

មេចោរនោះចុះដាវចោលលើផែនដី យកលំពែងចាក់ក្បែរជើងរបស់សាមណេរហើយសួរថា បពិត្រលោកម្ចាស់ ខ្ញុំចូលមកក្នុងព្រៃនេះព្រោះត្រូវការទ្រព្យ បុរសមានប្រមាណមួយពាន់នាក់ឃើញពួកខ្ញុំអំពីចម្ងាយ ញាប់ញ័រចំប្រប់ មិនអាចនិយាយពីរបីម៉ាត់បាន សម្រាប់លោកម្ចាស់ ត្រឹមតែការតក់

ស្តុតនៃចិត្តក៏មិនមាន មុខរបស់លោកម្ចាស់ផ្ទះផង់ដូចមាសក្នុងស្មប់ និងដូចផ្កាកណិការដែលរីកល្អ ហេតុអ្វីហ្ន៎ ទើបពោលគាថានេះថា

ការតក់ស្តុតមិនមានដល់លោកម្ចាស់ ការខ្លាចក៏មិនមាន ពណ៌សម្បុរ ផ្ទៃមុខក្រៃពេក ហេតុអ្វី ទើបលោកម្ចាស់ មិនសោយសោក ព្រោះភ័យធំ ដែលមានសភាពបែបនេះ ។

សាមណេរចេញអំពីឈាន កាលនឹងសម្តែងធម៌ដល់មេចោរនោះ ទើបពោលថា នែអ្នក ឈ្មោះថា អត្តភាពរបស់ព្រះខីណាស្រព រមែងដូចការៈគឺរបស់ធ្ងន់ដែលដាក់លើក្បាល ព្រះខីណាស្រពនោះ កាលអត្តភាពនោះបែកធ្លាយទៅ រមែងត្រេកអរនោះឯង រមែងមិនខ្លាចឡើយ ដូច្នេះហើយ ក៏បានពោលគាថានេះថា

នែអ្នក ទុក្ខផ្ទួរចិត្ត រមែងមិនមានដល់បុគ្គល ដែលមិនមានការជាប់ជំពាក់ លោកអ្នកដែលស្វែងរកគុណ អស់សំយោជនៈហើយ ឈានកន្ទងភ័យគ្រប់យ៉ាងបាន តណ្ហាដែលនាំទៅកាន់ភពរបស់ព្រះខីណាស្រពនោះ អស់ហើយ លោកឃើញធម៌ហើយ តាមសេចក្តីពិត ឬដោយពិត ការស្ងាប់របស់លោកអស់ភ័យ ដូចជាក់ការៈចុះ ដូច្នោះ ។

មេចោរនោះស្តាប់សាមណេរនោះហើយ សម្លឹងមើលចោរ ៥០០ ពោលថា ពួកអ្នកនឹងធ្វើអ្វី ពួកចោរពោលថា ចុះលោកនាយវិញ មេចោរពោលថា កិច្ចក្នុងការគ្រប់គ្រងផ្ទះរបស់ខ្ញុំមិនមាន ព្រោះឃើញជាជិហ្វាបែបនេះ ខ្ញុំនឹង

បួសក្នុងសម្នាក់លោកម្ចាស់ ពួកចោរពោលថា ខ្ញុំក៏យ៉ាងនោះដូចគ្នា មេចោរពោលថា សាធុ លំដាប់នោះ ចោរទាំង ៥០០ ថ្វាយបង្គំសាមណេរហើយទើបសូមបព្វជ្ជា សាមណេរនោះកាត់សក់ និងសំពត់ដោយជាវរបស់ចោរទាំងនោះឯង ជ្រលក់ដោយជីក្រហម ឲ្យគ្រងកាសាវពស្ត្រទាំងនោះ ឲ្យតាំងនៅក្នុងសីល ១០ កាលនាំសាមណេរទាំងនោះទៅគិតថា បើអញមិនសួរសុខទុក្ខព្រះថេរៈទាំងឡាយ ព្រះថេរៈទាំងនោះនឹងមិនអាចធ្វើសមណធម៌បាន ចាប់តាំងពីពួកចោរចាប់អាត្មាអញមក ព្រះថេរៈទាំងនោះ សូម្បីត្រឹមតែមួយរូបក៏មិនអាចទប់ទឹកភ្នែកបាន បើព្រះថេរៈទាំងនោះគិតថា សាមណេរត្រូវចោរសម្លាប់ហើយឬនៅហ្ន៎ កម្មដ្ឋាននឹងមិនបាន ព្រោះដូច្នោះ អញសួរសុខទុក្ខលោកហើយនោះឯង សឹមទៅ ។

សាមណេរនោះមានសាមណេរ ៥០០ រូបជាបរិវារនៅក្នុងទីនោះ កាលភិក្ខុទាំងនោះ បាននូវការធូរស្បើយចិត្ត ព្រោះឃើញលោកហើយ ពោលថា សង្ឃិចសប្បុរស លោកបានជីវិតហើយឬ ទើបឆ្លើយថា យ៉ាងនោះឯងលោកម្ចាស់ ចោរទាំងនេះប្រុងថ្នាសម្លាប់ខ្ញុំឲ្យស្លាប់ ក៏មិនអាចសម្លាប់បាន ជ្រះថ្លាក្នុងគុណធម៌របស់ខ្ញុំ ស្តាប់ធម៌ហើយបួស ខ្ញុំមកដោយបំណងថាសួរសុខទុក្ខលោកម្ចាស់ហើយនឹងទៅ សូមលោកម្ចាស់ជាបុគ្គលមិនប្រមាទ ធ្វើសមណធម៌ចុះ ខ្ញុំនឹងទៅកាន់សម្នាក់ព្រះសាស្តា ហើយថ្វាយបង្គំភិក្ខុទាំងនោះ នាំសាមណេរក្រៅអំពីនោះទៅកាន់សម្នាក់ព្រះឧបជ្ឈាយ៍ កាលលោកសួរថា សង្ឃិចៈ អ្នកបានអន្តេវាសិកហើយឬ ទើបឆ្លើយថា ពិតហើយ លោកម្ចាស់ ដូច្នេះហើយ

ក៏តំណាលរឿងនោះ កាលព្រះថេរៈពោលថា សង្កិច្ចៈ ចូរអ្នកទៅគាល់ព្រះសាស្តា លោកក៏ទទួលថា សាធុ ហើយថ្វាយបង្គំព្រះថេរៈ នាំសាមណេរទាំងនោះទៅកាន់សម្នាក់ព្រះសាស្តា កាលព្រះសាស្តាត្រាស់សួរថា ម្នាលសង្កិច្ចៈ អ្នកបានអន្តេវាសិកហើយឬ ទើបក្រាបទូលរឿងនោះ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា សេចក្តីនេះយ៉ាងនោះឬ កាលពួកភិក្ខុទទួលថា យ៉ាងនោះឯងព្រះអង្គ ទើបត្រាស់ថា ការតាំងនៅក្នុងសីលហើយ សូម្បីរស់នៅមួយថ្ងៃក្នុងឥឡូវនេះ ប្រសើរជាងការដែលបុគ្គលធ្វើចោរកម្ម តាំងនៅក្នុងភាពទ្រុស្តសីលអស់មួយរយឆ្នាំ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានសីល មានការពិនិត្យ ពិចារណាជាប្រក្រតី ប្រសើរជាង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទុស្សីលោ** *គឺមិនមានសីល ។ បទថា* **សីលវន្តស្ស** *សេចក្តីថា ការរស់នៅត្រឹមតែមួយថ្ងៃ គឺត្រឹមតែមួយរំពេចរបស់អ្នកមានសីល មានឈាន ដោយឈាន ២ ប្រការ ប្រសើរ គឺឧត្តមជាង*

ការរស់នៅមួយរយឆ្នាំរបស់បុគ្គលទ្រុស្តសីល ។

ក្នុងកាលចប់ទេសនា ភិក្ខុ ៥០០ នោះសម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយ ធម្មទេសនាមានប្រយោជន៍ដល់មហាជន ដែលប្រជុំគ្នាហើយ ។

*ដោយសម័យដទៃទៀត សង្គិច្ចៈបានឧបសម្បទាហើយ មានវស្សា ១០ ទើបទទួលសាមណេរ សាមណេរនោះជាក្មួយរបស់លោក ឈ្មោះអធិមុត្តក-សាមណេរ ។ គ្រានោះ ព្រះថេរៈហៅសាមណេរនោះមកក្នុងកាលមានអាយុគ្រប់ បញ្ជូនទៅដោយពាក្យថា ខ្ញុំនឹងធ្វើការឧបសម្បទាលោក ចូរលោកទៅសួរចំនួនអាយុក្នុងសម្នាក់ពួកញាតិហើយ ចូរមក ។ អធិមុត្តកសាមណេរនោះកាលទៅកាន់សម្នាក់របស់មាតាបិតា ត្រូវពួកចោរ ៥០០ បំណងនឹងសម្លាប់ឲ្យស្លាប់ ដើម្បីធ្វើពលីកម្មក្នុងរវាងផ្លូវ សម្តែងធម៌ដល់ចោរទាំងនោះ កាលពួកចោរមានចិត្តជ្រះថ្លា ដោះលែងទៅហើយដោយពាក្យថា សូមលោកម្ចាស់កុំប្រាប់ភាពដែលពួកខ្ញុំមាននៅក្នុងទីនេះ ដល់បុគ្គលណាម្នាក់ឡើយ ឃើញមាតាបិតា ដើរបញ្ឆោសផ្លូវមក រក្សាសច្ចៈ មិនប្រាប់ដល់មាតាបិតាទាំងនោះ ដើរទៅផ្លូវនោះឯង កាលមាតាបិតានោះ ត្រូវពួកចោរបៀតបៀន ពោលថាប្រហែលជាលោក ក៏ជាបក្សពួកតែមួយជាមួយពួកចោរ ទើបមិនប្រាប់ដល់យើង ចោរទាំងនោះ បានឮសំឡេងហើយ ដឹងភាពដែលសាមណេរមិនប្រាប់ដល់មាតាបិតា ក៏មានចិត្តជ្រះថ្លាសូមបព្វជ្ជា ។ សូម្បីអធិមុត្តកសាមណេរនោះ ក៏ញុំាងចោរទាំងអស់នោះឲ្យបួសហើយ ដូចសង្គិច្ចសាមណេរ នាំមក

កាន់សម្នាក់ព្រះឧបជ្ឈាយ៍ ដែលព្រះឧបជ្ឈាយ៍នោះ បញ្ជូនទៅកាន់សម្នាក់ព្រះសាស្តា នាំភិក្ខុទាំងនោះ ទៅក្រាបទូលរឿងនោះដល់ព្រះសាស្តាហើយ ។ ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា សេចក្តីនោះ យ៉ាងនេះឬ កាលពួកភិក្ខុក្រាបទូលថា ករុណា ព្រះអង្គ កាលទ្រង់បន្តអនុសន្ធិដោយនយមុននោះឯង ទើបត្រាស់ព្រះគាថានេះថា

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល
មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ
របស់លោក ដែលមានសីល មានការពិនិត្យពិចារណា
ជាប្រក្រតី ប្រសើរជាង រឿងអធិមុត្តកសាមណេរ ខ្ញុំ
ក៏ពោលហើយ ដោយគាថានេះដូចគ្នា ។

រឿង សង្ខិច្ចសាមណេរ ចប់

រឿង ព្រះខានុកោណ្ឌញ្ញត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះខានុកោណ្ឌញ្ញៈ ត្រាស់ព្រះគាថានេះថា **យោ ច វស្សសតំ ជីវេ** ជាដើម ។

បានឮថា ព្រះថេរៈនោះ រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាក្នុងព្រៃ សម្រេចអរហត្តហើយ គិតថា និងទូលលាព្រះសាស្តា កាលមកអំពីទីនោះ

ហត់នឿយក្នុងរវាងផ្លូវ គេចចេញអំពីផ្លូវ អង្គុយចូលឈានលើថ្មដាមួយកន្លែង ។ គ្រានោះ ចោរ ៥០០ ប្លន់ស្រុកមួយកន្លែងហើយ រៀបទ្រព្យរបស់តាមសមគួរដល់កម្លាំងរបស់ខ្លួន យកក្បាលទូល ដើរទៅ កាលដើរទៅឆ្ងាយនឿយហត់គិតថា អញមកឆ្ងាយហើយ នឹងសម្រាកលើថ្មដានេះ គេចចេញអំពីផ្លូវទៅកាន់ទីជិតថ្មដា សូម្បីឃើញព្រះថេរៈ ក៏មានសេចក្តីសម្គាល់ថា នេះជាដង្គត់ឈើ លំដាប់នោះ ចោរម្នាក់ដាក់បង្វែចទ្រព្យ លើសីសៈព្រះថេរៈ ។ ចោរដទៃៗ ក៏ដាក់បង្វែចទ្រព្យលើព្រះថេរៈនោះ ។ ដោយប្រការដូច្នេះ ចោរទាំង ៥០០ នាក់យកបង្វែច ៥០០ ដាក់លើព្រះថេរៈ សូម្បីខ្លួនឯងក៏ដេកលក់ក្រាក់ឡើងក្នុងពេលថ្ងៃរះ ទាញបង្វែចរៀងៗ ខ្លួន បានឃើញព្រះថេរៈ ក៏ផ្តើមគេចទៅដោយសម្គាល់ថា ជាអមនុស្ស ។

រំពេចនោះ ព្រះថេរៈពោលនឹងចោរទាំងនោះថា កុំខ្លាចឡើយឧបាសក អាត្មាជាបព្វជិត ។ ចោរទាំងនោះក្រាបចុះទៀបបាទជើងព្រះថេរៈ ឲ្យព្រះថេរៈអត់ទោសដោយពាក្យថា សូមលោកម្ចាស់អត់ទោសចុះ ពួកខ្ញុំសម្គាល់ថាដង្គត់ឈើ កាលមេចោរប្រាប់ថា ខ្ញុំនឹងបួសក្នុងសម្នាក់លោកម្ចាស់ ពួកចោរដ៏សេសក៏ពោលថា ពួកខ្ញុំក៏នឹងបួស មានឆន្ទៈតែមួយសូមបព្វជ្ជានឹងព្រះថេរៈ ។ ព្រះថេរៈបានឲ្យចោរទាំងអស់នោះបួស ដូចសង្គិច្ចសាមណេរដែរ ។ ចាប់តាំងអំពីនោះ ព្រះថេរៈប្រាកដឈ្មោះថា ខានុកោណ្ឌញ្ញៈ ។ លោកទៅកាន់សម្នាក់ព្រះសាស្តា មួយអន្លើដោយភិក្ខុទាំងនោះ ។ កាលព្រះសាស្តាត្រាស់សួរថា ម្នាលកោណ្ឌញ្ញៈ អ្នកបានអន្តេវាសិកហើយឬ ទើបក្រាបទូលរឿងនោះ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា សេចក្តីនេះយ៉ាងនោះឬ កាលភិក្ខុទាំងនោះទទួលថា ករុណាព្រះអង្គ ពួកខ្ញុំព្រះអង្គមិនធ្លាប់ឃើញអានុភាពបែបនោះរបស់បុគ្គលដទៃឡើយ ដោយហេតុនោះ ទើបពួកខ្ញុំព្រះអង្គបួស ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការរស់នៅមួយថ្ងៃរបស់ពួកអ្នក ប្រព្រឹត្តក្នុងបញ្ញាសម្បទាក្នុងឥឡូវនេះ ប្រសើរជាងការតាំងនៅក្នុងកម្មរបស់បុគ្គលដែលមានបញ្ញាថោកថយបែបនោះ ដែលរស់នៅអស់មួយរយឆ្នាំដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃរបស់លោកដែលមានប្រាជ្ញា មានការពិនិត្យពិចារណាជាប្រក្រតី ប្រសើរជាង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទុប្បញ្ញោ** *សេចក្តីថា ជាអ្នកឥតបញ្ញា ។ បទថា* **បញ្ញវន្តស្ស** *សេចក្តីថា ដែលប្រព្រឹត្តទៅដោយបញ្ញា ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលមានក្នុងកាលមុននោះឯង ។*

ក្នុងកាលចប់ទេសនា ភិក្ខុ ៥០០ រូប សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាហើយ ។ ព្រះធម្មទេសនាមានប្រយោជន៍ដល់មហាជនដែលប្រជុំគ្នាហើយដូច្នេះឯង ॥

រឿង ព្រះសប្បទាសត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសប្បទាសត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជីវេ** ជាដើម ។

បានឮមកថា កុលបុត្រម្នាក់ក្នុងក្រុងសាវត្ថី ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ បព្វជ្ជា បានឧបសម្បទាហើយ ដោយសម័យដទៃទៀត ក៏អផ្សុកឡើង ទើបគិតថា ឈ្មោះថា ការៈនៃគ្រហស្ថ មិនគួរដល់កុលបុត្រដូចអញ សូម្បីការតាំងនៅក្នុងបព្វជ្ជាហើយស្លាប់ទៅ ជាការល្អរបស់អញ ដូច្នេះហើយ ក៏គ្រាច់រកឧបាយដើម្បីការស្លាប់របស់ខ្លួន ។

ថ្ងៃមួយ ភិក្ខុទាំងឡាយស្រង់ទឹកអំពីព្រលឹម ធ្វើកត្តកិច្ចស្រេចហើយ ទៅកាន់វិហារ ឃើញពស់ត្រង់រោងភ្លើង ទើបជាក់ពស់នោះក្នុងធ្នាំងមួយ បិទគម្របហើយ កាន់ចេញអំពីវិហារ ។ ចំណែកភិក្ខុដែលអផ្សុកធ្វើកត្តកិច្ចហើយ ដើរមកឃើញភិក្ខុទាំងនោះ ទើបសួរថា អាវុសោ នេះជាអ្វី កាលពួកភិក្ខុប្រាប់ថា អាវុសោ គឺពស់ ទើបសួរថា តើធ្វើអ្វីដល់ពស់នេះ ភិក្ខុទាំងនោះប្រាប់ថា យកវាទៅចោល ទើបភិក្ខុនោះគិតថា អញនឹងឲ្យពស់នេះចឹកស្លាប់ ទើបពោលថា យកមកចុះខ្ញុំនឹងចោលឲ្យ ទទួលធ្នាំងអំពីដៃរបស់ភិក្ខុទាំងនោះហើយ អង្គុយក្នុងទីមួយ ក៏ឲ្យពស់នោះចឹក ។ ពស់មិនប្រាថ្នានឹងចឹក ភិក្ខុនោះយកដៃលូកចូលក្នុងធ្នាំងហើយ ត្រឡប់ខាងនោះខាងនេះ ហែកមាត់ពស់ហើយ ស៊ីកម្រាមដៃចូលទៅ ពស់ក៏មិនចឹកលោកឡើយ ។ លោកគិតថា

ពស់នេះមិនមែនពស់ពិស ជាពស់ផុះ ទើបលែងពស់នោះ ហើយទៅកាន់វិហារ ។

លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងលោកថា អាវុសោ លោកលែងពស់ហើយឬ ភិក្ខុអផ្សុកពោលថា អាវុសោ នុ៎ះមិនមែនពស់ពិស ជាពស់ផុះ ភិក្ខុពោលថា អាវុសោ ពស់នោះជាពស់ពិសនោះឯង បើកពពារធំបញ្ចេញសំឡេងស៊ូតៗ ខ្ញុំចាប់បានដោយលំបាក ព្រោះហេតុអ្វី ទើបលោកពោលយ៉ាងនេះ ភិក្ខុអផ្សុកពោលថា អាវុសោ ខ្ញុំឲ្យពស់នោះចឹកអាវយវៈខ្លះស៊ីកដៃចូលក្នុងមាត់ខ្លះ ក៏មិនអាចឲ្យវាចឹកបាន ។

ពួកភិក្ខុស្តាប់ពាក្យនោះហើយ ក៏អង្គុយស្ងៀម ។ ថ្ងៃក្រោយមក ខ្នាន់ព្រះកេសកាន់កាំបិតកោរ ២-៣ ដើមទៅវិហារ ជាក់កាំបិតកោរមួយនៅត្រង់ផែនដី យកកាំបិតកោរមួយកោរសក់របស់ភិក្ខុទាំងឡាយ ។ ទើបភិក្ខុអផ្សុកនោះចាប់កាំបិតកោរដែលនៅត្រង់ផែនដី ហើយគិតថា អញអារ-កដោយកាំបិតកោរនេះ ទើបឈរផ្អែកត្រង់ដើមឈើមួយដើម ហើយជាក់កាំបិតត្រង់បំពង់ក ពិចារណាដល់សីលរបស់ខ្លួន តាំងអំពីកាលឧបសម្បទា បានឃើញសីលមិនមានមន្ទិល ដូចព្រះចន្ទ្រាសចាកមន្ទិល និងដូចមណ្ឌលនៃកែវមណីដែលគេខាត់ល្អហើយ កាលលោកពិចារណាមើលសីលនោះ បីតិកើតផ្សាយទៅពេញសរីរៈ ។ លោកសង្កត់បីតិបានហើយ ចម្រើនវិបស្សនា សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយ ទើបកាន់កាំបិតកោរចូលទៅកណ្តាលវិហារ ។ លំដាប់នោះ ភិក្ខុទាំងឡាយសួរលោកថា អាវុសោ លោក

ទៅណា កិក្ខុអផ្សុកពោលថា អាវុសោ ខ្ញុំទៅដោយគិតថា នឹងយកកាំបិតកោរ នេះអារបំពង់ក កិក្ខុទាំងនោះពោលថា បើដូច្នោះ ហេតុអ្វីក៏មិនស្ងាប់ កិក្ខុ អផ្សុកពោលថា ឥឡូវនេះ ខ្ញុំជាបុគ្គលមិនគួរនាំសស្ត្រាមក ព្រោះខ្ញុំគិតថា នឹងកាត់បំពង់កដោយកាំបិតកោរនេះ តែបែរជាកាត់កិលេសអស់ ដោយ កាំបិតកោរ គឺញាណ ។ ពួកកិក្ខុក្រាបទូលដល់ព្រះដ៏មានព្រះភាគថា កិក្ខុនេះ ព្យាករអរហត្ត ដោយពាក្យមិនពិត ព្រះដ៏មានព្រះភាគ ទ្រង់ស្តាប់ពាក្យរបស់ កិក្ខុទាំងនោះ ទើបត្រាស់ថា ម្នាលកិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រព មិន ផ្តាច់ជីវិតដោយដៃរបស់ខ្លួនឡើយ ពួកកិក្ខុទូលថា បពិត្រព្រះអង្គ ទ្រង់ត្រាស់ ថា កិក្ខុនេះជាព្រះខីណាស្រព កិក្ខុនេះសម្បុរដោយឧបនិស្ស័យនៃព្រះអរហត្ត យ៉ាងនេះ ហេតុអ្វី ទើបអផ្សុក អ្វីជាហេតុនៃឧបនិស្ស័យនៃអរហត្តរបស់កិក្ខុ នោះ ហេតុអ្វី ទើបពស់មិនចឹកកិក្ខុនោះ ព្រះសាស្តាត្រាស់ថា ម្នាលកិក្ខុទាំង-ឡាយ ពស់នោះ ជាខ្ញុំប្រុសរបស់កិក្ខុនេះក្នុងអត្តភាពទី ៣ បន្ទាប់អំពីអត្តភាព នេះ ពស់នោះ មិនអាចទាំសរីរៈរបស់បុគ្គលដែលជាចៅហ្វាយបាន ។

ព្រះសាស្តាទ្រង់ត្រាស់ប្រាប់ហេតុមួយ ដល់កិក្ខុទាំងនោះ ដោយប្រការ ដូច្នេះ តាំងអំពីនោះមក កិក្ខុនោះ បានឈ្មោះថា សប្បទាសៈ ។

បានឮមកថា ក្នុងកាលនៃព្រះកស្សបសម្ពុទ្ធ បុត្រនៃគហបតីម្នាក់ស្តាប់ ធម៌របស់ព្រះសាស្តាហើយ កើតការសង្វេគ ទើបបព្វជ្ជា បានឧបសម្បទា ហើយ ។ សម័យក្រោយមកទៀត កាលការនឿយណាយកើតឡើង ទើប ប្រាប់ដល់កិក្ខុដែលជាសម្លាញ់មួយរូប ។ សម្លាញ់នោះ ពោលទោសក្នុងភាវៈ

នៃគ្រហស្ថ ដល់លោកវឿយៗ ភិក្ខុនោះស្តាប់ពាក្យនោះហើយ ក៏ត្រេកអរ ក្នុងព្រះសាសនា អង្គុយជុំសសមណបរិក្ខារទាំងឡាយ ដែលមានច្រែះចាប់ ក្នុងកាលដែលលោកនៀយណាយអំពីមុន ឲ្យអស់មន្ទិលក្បែរមាត់ស្រះមួយ កន្លែង ចំណែកសម្ងាញ់របស់ភិក្ខុនោះ អង្គុយក្នុងទីជិតនោះឯង ។ គ្រានោះ ភិក្ខុនោះពោលនឹងសម្ងាញ់នោះយ៉ាងនេះថា អាវុសោ បើខ្ញុំសឹក នឹងឲ្យបរិក្ខារ ទាំងនេះដល់លោក ។ សម្ងាញ់នោះ មានការចង់បានកើតឡើង គិតថា អញ ត្រូវការអ្វីដោយភិក្ខុនេះ ដែលនៅបួស ឬសឹក ឥឡូវនេះ អញនឹងញុំាងបរិក្ខារ ទាំងឡាយឲ្យវិនាស ។ តាំងអំពីនោះមក សម្ងាញ់នោះនិយាយពាក្យជាដើម ថា អាវុសោ ឥឡូវនេះ ប្រយោជន៍អ្វីដល់ជីវិតរបស់ពួកយើង ដែលមានដៃ កាន់អំបែង ត្រាច់ទៅដើម្បីជុំបាយក្នុងត្រកូលដទៃ ថែមទាំងមិនបានសន្ទនា ប្រាស្រ័យនឹងបុត្រភរិយា ដូច្នេះហើយ ក៏ពោលគុណនៃភាវៈរបស់គ្រហស្ថ ។ ភិក្ខុនោះស្តាប់ពាក្យសម្ងាញ់នោះហើយ ក៏អផ្សុកម្តងទៀត គិតថា សម្ងាញ់ នេះ កាលអញពោលថា ខ្ញុំអផ្សុក ក៏ពោលទោសក្នុងភាវៈនៃគ្រហស្ថ ឥឡូវ នេះ ពោលដល់គុណវឿយៗ សេចក្តីនេះដូចម្តេចហ្ន៎ ក៏ជឿថា ព្រោះចង់ បានក្នុងសមណបរិក្ខារទាំងនេះ ទើបត្រឡប់ចិត្តរបស់ខ្លួន ដោយខ្លួនឯងនោះ ឯង ព្រោះភាពដែលភិក្ខុមួយរូប ត្រូវខ្លួនធ្វើឲ្យអផ្សុកហើយ ក្នុងកាលនៃ ព្រះកស្សបសម្ពុទ្ធ ឥឡូវនេះ ទើបការអផ្សុកកើតឡើងដល់ភិក្ខុនោះ ដោយ ប្រការដូច្នេះ ។ សមណធម្មិណា ដែលភិក្ខុនោះបំពេញមកពីរម៉ឺនឆ្នាំ សមណ-ធម្មិនោះ បានជាឧបនិស្សយនៃអរហត្តរបស់ភិក្ខុនោះក្នុងកាលឥឡូវនេះឯង ។

ភិក្ខុទាំងនោះ ស្តាប់សេចក្តីនេះអំពីសម្នាក់ព្រះដ៏មានព្រះភាគ ទើបទូលសួរក្រៃលែងឡើងថា បពិត្រព្រះអង្គ ជាន់ថា ភិក្ខុនេះ ឈរយកកាំបិតកោរផ្តងត្រង់បំពង់ករ ហើយសម្រេចអរហត្ត អរហត្តមគ្គកើតឡើងបាន ដោយខណៈមានប្រមាណប៉ុណ្ណោះឬ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង កាលភិក្ខុប្រារព្ធព្យាយាម លើកជើងឡើង ជាក់លើផែនដី កាលជើងមិនទាន់ដល់ផែនដី អរហត្តមគ្គក៏បានកើតឡើង ពិតណាស់ ការរស់នៅត្រឹមមួយជួរខណៈរបស់បុគ្គល ដែលប្រារព្ធព្យាយាម ប្រសើរជាងការរស់នៅមួយរយឆ្នាំ របស់បុគ្គលខ្ជិលច្រអូស ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ
ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឬ្ហំ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមានចិត្តធ្ងន់ក្នុងអកុសលវិតក្ក មានព្យាយាមថោកថយ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលប្រារព្ធសេចក្តីព្យាយាមមាំមួន ប្រសើរជាង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កុសីតោ** *បានដល់ បុគ្គលដែលញាំងកាលឲ្យកន្លងទៅដោយវិតក្ក ៣ មានកាមវិតក្កជាដើម ។ បទថា* **ហីនវីរិយោ** *គឺ មិនមានសេចក្តីព្យាយាម ។*

បានព្រះគាថាថា **វីរិយំ អារភតោ ឧត្តរំ** សេចក្តីថា បុគ្គលប្រារព្ធសេចក្តីព្យាយាមមាំទាំ ឈ្មោះថា អាចញ៉ាំងឈាន ២ ប្រការឲ្យកើត ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលមានក្នុងកាលមុននោះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះសប្បទាសត្ថេរ ចប់

រឿង ឆានបជាចារា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងបជាបតិថេរី ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជីវេ** ជាដើម ។

បានឮមកថា នាងបជាបតិចារានោះ ជាធីតារបស់សេដ្ឋីអ្នកមានទ្រព្យ ៤០ កោដិ ក្នុងក្រុងសាវត្ថី មានរូបស្រស់ត្រកាល ពេលមានអាយុ ១៦ ឆ្នាំ ម្តាយឪពុកកាលរក្សា ទើបឲ្យនាងនៅលើប្រាសាទជាន់ទី ៧ ។ កាលបើដូច្នោះ នាងក៏នៅតែសមាគមជាមួយបុរសអ្នកបម្រើរបស់ខ្លួន ។ កាលនោះមាតាបិតារបស់នាង លើកឲ្យដល់បុរសកំលោះម្នាក់ ក្នុងត្រកូលដែលមានជាតិស្មើគ្នា ហើយកំណត់ថ្ងៃវិវាហៈ ។ កាលថ្ងៃវិវាហៈនោះជិតចូលមកដល់ នាងក៏ពោលនឹងអ្នកបម្រើប្រុសនោះថា បានឮថា ឪពុកម្តាយខ្ញុំ លើកខ្ញុំឲ្យដល់ត្រកូលឈ្មោះនោះ

ក្នុងកាលដែលខ្ញុំទៅកាន់ត្រកូលប្តី អ្នក សូម្បីកាន់បណ្ណាការដើម្បីខ្ញុំមកហើយ ក៏នឹងមិនបានចូលទៅក្នុងទីនោះ បើអ្នកស្រឡាញ់ខ្ញុំ សូមនាំខ្ញុំគេចទៅដោយផ្លូវណាមួយក្នុងកាលឥឡូវនេះឯង ។ អ្នកបម្រើនោះទទួលថា សាធុនាង ហើយពោលថា បើយ៉ាងនោះ ខ្ញុំនឹងឈរក្នុងទីឈ្មោះនោះនៃទ្វារក្រុងអំពីព្រលឹមស្អែកនេះ នាងគប្បីចេញទៅដោយឧបាយណាមួយហើយ មកក្នុងទីនោះ ក្នុងថ្ងៃទី ២ ក៏ឈរក្នុងទីដែលបានមត់គ្នា ។

ចំណែកធីតាសេដ្ឋីនោះ ស្បៃកសំពត់ចាស់ៗ រំសាយសក់ យកកន្ត្រក់លាបខ្លួន កាន់ភ្នមទឹកចេញអំពីផ្ទះ ដើរទៅជាមួយពួកទាសី បានទៅកាន់ទីនោះ អំពីព្រលឹម អ្នកបម្រើនោះ នាំនាងទៅឆ្ងាយហើយ សម្រេចការអាស្រ័យនៅក្នុងស្រុកមួយកន្លែង ភូវស្រែក្នុងព្រៃហើយ បាននាំឧស និងបន្លែជាដើមមក ។ ធីតាសេដ្ឋីនាំយកភ្នមទឹកមកហើយ ធ្វើកិច្ច មានការបុកអង្ករ និងចម្អិនជាដើមដោយដៃខ្លួនឯង សោយផលនៃអំពើអាក្រក់របស់ខ្លួន ។ គ្រានោះ សត្វកើតក្នុងគភ៌តាំងឡើងក្នុងផ្ទៃរបស់នាងហើយ នាងមានគភ៌ចាស់ហើយ អង្វរប្តីថា ជនឯណានីមួយជាអ្នកឧបការៈរបស់យើងមិនមានក្នុងទីនេះ ធម្មតាមាតាបិតាជាអ្នកមានចិត្តទន់ភ្លន់ក្នុងបុត្រទាំងឡាយ ចូរអ្នកនាំខ្ញុំទៅកាន់សម្នាក់របស់លោកចុះ ខ្ញុំនឹងប្រសូតបុត្រក្នុងទីនោះ ។ ស្វាមីនោះជំទាស់ថា នែនាង នាងនិយាយអ្វី មាតាបិតារបស់នាងឃើញខ្ញុំហើយ គប្បីធ្វើទណ្ឌកម្មផ្សេងៗ ខ្ញុំមិនអាចទៅក្នុងទីនោះបានទេ ។ សូម្បីនាងអង្វរហើយអង្វរទៀត ក៏មិនបាននូវការយល់ព្រម ក្នុងកាលដែលប្តីនោះទៅព្រៃ ទើបហៅមនុស្សដែលស្និទ្ធស្នាលមកផ្តាំថា

បើប្តីខ្ញុំមកមិនឃើញខ្ញុំ បើគាត់សួរថា ខ្ញុំទៅណា សូមអ្នកប្រាប់ភាពដែលខ្ញុំទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួន ដូច្នេះហើយ ក៏បិទទ្វារផ្ទះចៀសចេញទៅ ។

ចំណែកស្វាមីនោះមកហើយ មិនឃើញកិរិយានោះ ទើបសួរអ្នកស្និទ្ធស្នាល ស្តាប់រឿងនោះហើយ ក៏រត់តាមទៅ ដោយគិតថា នឹងឲ្យនាងត្រឡប់ជួបនាងហើយ អង្វរដោយប្រការផ្សេងៗ ក៏មិនអាចឲ្យនាងត្រឡប់បាន ។ ពេលនោះ ខ្សល់កម្មជវាតរបស់នាងក៏កម្រើកហើយក្នុងទីមួយកន្លែង នាងចូលទៅក្នុងរវាងគុម្ពឈើមួយ ពោលថា នែអ្នក ខ្សល់កម្មជវាតរបស់ខ្ញុំកម្រើកហើយ ដេកបម្រះនៀលលើផែនដី ប្រសូតទារកដោយលំបាក ហើយគិតថា អញគប្បីទៅកាន់ផ្ទះនៃត្រកូលដើម្បីប្រយោជន៍ណា ប្រយោជន៍នោះសម្រេចហើយ ទើបត្រឡប់មកកាន់ផ្ទះជាមួយស្វាមី សម្រេចការនៅជាមួយគ្នាទៀត ។

សម័យក្រោយមក គកិរបស់នាងក៏មានទៀត ។ នាងមានគកិចាស់ហើយ ទើបអង្វរប្តីដោយន័យមុននោះឯង កាលមិនបាននូវការយល់ព្រម ទើបពកួនដោយចង្កេះចៀសចេញទៅយ៉ាងនោះឯង ត្រូវប្តីនោះរត់តាមទៅទាន់ហើយ ក៏មិនប្រាថ្នានឹងត្រឡប់ ។

គ្រានោះ កាលជនទាំងនោះដើរទៅ មហាមេឃពុំជួកាលកើតឡើង ។ ផ្លែលម្អមានធ្លាទឹកធ្លាក់ចុះមិនមានចន្លោះ ផ្លូវបន្ទោរវាសឆ្ងៀលឆ្ងាត់ដោយជុំវិញ ហាក់ដូចទម្លាយចុះនូវសំឡេងគ្រហឹមនៃមេឃ ។ ខណៈនោះ ខ្សល់កម្មជវាតរបស់នាងកម្រើកហើយ នាងហៅស្វាមីមកពោលថា នែអ្នក ខ្សល់

កម្មជ្ជាតរបស់ខ្ញុំកម្រើកហើយ ខ្ញុំមិនអាចអត់ធន់បាន សូមអ្នកដឹងទីដែលក្មៀង មិនប៉ះពាល់ខ្ញុំចុះ ។ ប្តីនោះមានកាំបិតនៅក្នុងដៃ ក្រឡេកមើលឆ្វេងស្តាំឃើញ គុម្ពឈើដែលកើតនៅលើដំបូកមួយកន្លែងហើយផ្តើមនឹងកាប់ ។ លំដាប់នោះ អាសិរពិសកាច លូនចេញមកអំពីដំបូក ចឹកបុរសនោះក្នុងខណៈនោះឯង ។ សរីរៈរបស់បុរសនោះ មានពណ៌ខៀវដូចត្រវៀភ្លើងឆេះ តាំងឡើងខាងក្នុង ដួលចុះក្នុងទីនោះឯង ចំណែកភរិយាសោយទុក្ខមហន្ត ចាំមើលផ្លូវរបស់ប្តី មិនបានឃើញ ទើបប្រសូតបុត្រម្នាក់ឯងទៀត ។ ទារកទាំង ២ អត់ធន់នឹង កម្តាំងខ្យល់ និងក្មៀងមិនបាន ក៏យំរំពង ។ នាងយកទារកទាំង ២ ដាក់ ក្រោមដើមទ្រូង លត់ជង្គង់លើផែនដី ដៃទាំងពីរច្រត់ទប់ខ្លួន ឲ្យរាត្រីកន្លងទៅ ហើយ សរីរៈទាំងមូលដូចគ្នានឹងស្លឹកឈើពណ៌លឿង ហាក់ដូចមិនមាន ឈាម ។ កាលថ្ងៃរះឡើង នាងបីបុត្រម្នាក់ ដែលមានពណ៌ដូចដុំសាច់ត្រង់ ចង្កេះ ដៃម្ខាងដឹកដៃកូនច្បង ពោលថា មកចុះបា ឪពុករបស់អ្នកទៅដោយ ផ្លូវនេះ ដួចុះហើយ ក៏ដើរតាមផ្លូវដែលប្តីទៅ ឃើញប្តីនោះដួលស្លាប់លើ ដំបូក មានពណ៌ខៀវ ខ្លួនរីងក្រញាង ទ្រហោយំរៀបរាប់ថា ព្រោះអាស្រ័យ ខ្ញុំ ទើបអ្នកស្លាប់ក្នុងផ្លូវនេះ ដួចុះហើយ ធ្វើដើរទៅ ។

នាងឃើញស្ទឹងអចិរវតី ពេញប្រៀបដោយទឹកត្រឹមក្បាលជង្គង់ ត្រឹម ដោះ ព្រោះក្មៀងធ្លាក់មួយយប់ទល់ភ្លើង មិនអាចចុះទឹកមួយអន្ទៀដោយទារក ពីរនាក់បាន ព្រោះខ្លួនមិនសូវចេះហែលទឹក ទើបដាក់បុត្រច្បងនៅត្រង់ត្រើយ អាយ បីកូនប្អូន ទៅកាន់ត្រើយនាយ ក្រាលមែកឈើឲ្យទារកដេកហើយ

គិតថា នីឆនេះទៅនាំបុត្រក្រៅអំពីនេះ មិនអាចលះបង់កូនតូចបាន ត្រឡប់មកមើលហើយមើលទៀតដើរទៅ ។ ក្នុងកាលដែលនាងដល់កណ្តាលស្ទឹង ខ្វែងមួយឃើញក្មេងនោះ ទើបបោះពួយចុះមកអំពីអាកាស ដោយសម្គាល់ថាជាជុំសាច់ នាងឃើញខ្វែងបោះពួយចុះមកដើម្បីបុត្រ ទើបលើកដៃទាំងពីរឡើងស្រែកដោយសំឡេងខ្លាំង ៣ ដងថា សូក ! សូក ! ខ្វែងមិនបានឮសំឡេងនោះ ព្រោះនៅឆ្ងាយ ទើបទាំងរកហើរឡើងទៅកាន់អាកាសហើយ ។ បុត្រដែលឈរត្រើយអាយ ឃើញមាតាលើកដៃទាំងពីរឡើង ស្រែកដោយសំឡេងខ្លាំង កណ្តាលស្ទឹង ទើបលោតចុះទៅក្នុងស្ទឹងដោយរហ័ស ដោយសម្គាល់ថា ម្តាយហៅ ។ ខ្វែងធាបកូនខ្វែរបស់នាងទៅ កូនច្បងត្រូវទឹកកួចទៅ ដោយប្រការដូច្នេះ ។

នាងដើរយំរៀបរាប់ថា កូនរបស់ខ្ញុំម្នាក់ត្រូវខ្វែងធាបទៅ កូនម្នាក់ត្រូវទឹកកួចទៅ ប្តីក៏ស្លាប់ក្នុងអព្វា ជួបបុរសម្នាក់ដើរមកអំពីក្រុងសាវត្ថី ទើបសួរថា នែអ្នក អ្នកនៅទីណា បុរសនោះឆ្លើយថា ខ្ញុំនៅក្នុងក្រុងសាវត្ថី ធីតាសេដ្ឋីពោលថា ត្រកូលឈ្មោះនោះនៅក្បែរផ្លូវឈ្មោះនោះក្នុងក្រុងសាវត្ថីមាន តើអ្នកជ្រាបឬទេ បុរសនោះពោលថា នែនាង ខ្ញុំជ្រាប តែកុំសួរដល់ត្រកូលនោះអី បើនាងស្គាល់ត្រកូលដទៃ ក៏ចូរសួរចុះ ។

ធីតាសេដ្ឋីពោលថា កម្មជោយត្រកូលដទៃរបស់ខ្ញុំមិនមាន ខ្ញុំសួរដល់ត្រកូលនោះប៉ុណ្ណោះឯង បុរសនោះពោលថា នែនាង បើខ្ញុំប្រាប់ក៏មិនគួរ ធីតាសេដ្ឋីពោលថា សូមប្រាប់ខ្ញុំមកចុះ បុរសនោះពោលថា ថ្ងៃនេះ នាងឃើញ

ភ្លៀងធ្លាក់មួយយប់ទល់ភ្លឺដែរឬទេ ធីតាសេដ្ឋីពោលថា ខ្ញុំឃើញ ភ្លៀងនោះ ធ្លាក់មួយយប់ទល់ភ្លឺ ដើម្បីខ្ញុំប៉ុណ្ណោះ មិនមែនធ្លាក់ដើម្បីអ្នកដទៃទេ្បីយ តែខ្ញុំ នឹងប្រាប់ហេតុដែលភ្លៀងធ្លាក់ដើម្បីខ្ញុំដល់អ្នក ក្នុងកាលជាក្រោយ សូមអ្នក ប្រាប់ការប្រព្រឹត្តទៅក្នុងផ្ទះរបស់សេដ្ឋីនោះដល់ខ្ញុំមុន ។ បុរសនោះ ពោលថា នែនាង ថ្ងៃនេះ ក្នុងកណ្តាលយប់ ផ្ទះរលំសង្កត់ជនទាំង ៣ គឺសេដ្ឋី ១ ភរិយាសេដ្ឋី ១ បុត្រសេដ្ឋី ១ ជនទាំង ៣ នោះ ត្រូវជុតលើជើងថ្ពរតែមួយ នែនាង នុ៎ះផ្សែង កំពុងប្រាកជនៅទេ្បីយ ។

ក្នុងខណៈនោះ នាងមិនដឹងសំពត់របូត ដល់នូវភាពជាមនុស្សវិកលចរិត ហើយឈរធ្មឹង ទ្រហោយំរៀបរាប់ថា កូនពីរនាក់ស្លាប់ហើយ ប្តីរបស់ខ្ញុំក៏ស្លាប់ ត្រង់អជ្ជា មាតាបិតា និងបងប្រុស ក៏ត្រូវជុតលើជើងថ្ពរតែមួយ ។

មនុស្សទាំងឡាយឃើញនាងហើយ សម្គាល់ថា ជាស្រីឆ្កួត ទើបកាន់ យកសំរាម ធូលីរោយលើក្បាល គ្រវែងដោយដុំដី ។

ព្រះសាស្តា ប្រថាប់គង់សម្តែងធម៌ក្នុងកណ្តាលបរិស័ទ ៤ ក្នុងជេតពន មហាវិហារ បានទតឃើញនាងដែលបំពេញជ្រាមីមកមួយសែនកប្ប សម្បូរ ដោយអកិនីហារដើរមក ។

បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ នាងបជាចារនេះ ឃើញ ព្រះថេរី អ្នកទ្រទ្រង់វិនយមួយរូប ដែលព្រះបទុមុត្តរសាស្តា ស្ថាបនាក្នុង តំណែងឯតទគ្គៈ ដូចសក្កទេវរាជ ចាប់ត្រង់ដើមដៃ យកទៅជាក់ទុកក្នុង ឧទ្យានទួនវែន ទើបធ្វើគុណ គឺសេចក្តីល្អហើយ តាំងសេចក្តីប្រាថ្នាថា ខ្ញុំម្ចាស់

គប្បីបានតំណែងកំពូលជាងព្រះថេរី ខាងទ្រទ្រង់វិនយទាំងឡាយ ក្នុងសម្នាក់ព្រះពុទ្ធដូចព្រះអង្គ ។ ព្រះបទុមុត្តរៈ ទ្រង់ទតអនាគតដោយអនាគតំសញ្ញាណ ក៏ទ្រង់ជ្រាបថា ការប្រាថ្នានឹងសម្រេច ទើបទ្រង់ព្យាករថា ក្នុងអនាគត ស្រីនេះ នឹងបានជាកំពូលជាងព្រះថេរី ខាងទ្រទ្រង់វិនយទាំងឡាយ មានឈ្មោះថា បជាបតី ក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធ ។

ព្រះសាស្តា ទ្រង់ឃើញនាងមានសេចក្តីប្រាថ្នាតាំងទុកហើយយ៉ាងនោះ ជាអ្នកសម្បូរដោយអភិនីហារ កំពុងដើរមកអំពីចម្ងាយ ទ្រង់ព្រះតម្រិះថា លើកលែងតថាគតចេញហើយ អ្នកដទៃឈ្មោះថា អាចជាទីពឹងរបស់ស្រីនេះមិនមាន ទើបទ្រង់ធ្វើនាងដោយប្រការ ដែលនាងបែរមុខមកកាន់វិហារដើរមក ។

បរិសទ្យឃើញនាងហើយ ទើបពោលថា អ្នកទាំងឡាយ កុំឲ្យស្រីឆ្កួតនេះ មកទីនេះ ។ ព្រះសាស្តាត្រាស់ថា ចូរពួកអ្នកចៀសចេញ ទៅកុំឃាត់នាងឡើយ ក្នុងពេលនាងចូលមកជិត ទើបត្រាស់ថា ម្នាលប្អូនស្រី ចូរនាងបាននូវស្មារតីចុះ ។ នាងត្រឡប់បានសតិដោយពុទ្ធានុភាពក្នុងខណៈនោះឯង ។ ក្នុងពេលនោះ នាងកំណត់កាពដែលសំពត់ របូតបានហើយ កើតនូវហិរិ-ឱត្តប្បៈខ្លឹង ទើបអង្គុយចុះ ។

គ្រានោះ បុរសម្នាក់ ចោះសំពត់ដណ្តប់ឲ្យនាង នាងស្លៀកសំពត់នោះហើយចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានទៀបបាទមូលទាំងទ្វេ ដែលមានពណ៌ដូចមាស ហើយទូលថា បពិត្រព្រះអង្គ សូមទ្រង់

ជាទីពឹងរបស់ខ្ញុំម្ចាស់ចុះ ព្រោះថា ខ្លែងឆាបកូនម្នាក់របស់ខ្ញុំម្ចាស់ទៅ កូនម្នាក់ ត្រូវទឹកបន្សាត់ទៅ ប្តីស្លាប់កណ្តាលអធ្យា មាតាបិតា និងបងប្រុសត្រូវផ្ទះសង្កត់ស្លាប់ ដុតលើជើងថ្ពរតែមួយ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់នាង ទើបត្រាស់ថា កុំគិតឡើយ បដាចារា នាងមកកាន់សម្នាក់របស់បុគ្គល ដែលអាចជាទីពឹងរបស់នាងបានហើយ ឥឡូវនេះ ទោះជាកូនម្នាក់របស់នាងត្រូវខ្លែងឆាបទៅ កូនម្នាក់ត្រូវទឹកកួចទៅ ប្តីស្លាប់ហើយត្រង់អធ្យ័ន មាតាបិតា និងបងប្រុសត្រូវផ្ទះបាក់សង្កត់យ៉ាងណា ទឹកភ្នែកដែលហូររបស់នាង ដែលយំក្នុងសង្សារនេះ ក្នុងកាលដែលបិយជន មានកូនជាដើមស្លាប់ គង់ច្រើនជាងទឹកក្នុងមហាសមុទ្រទាំង ៤ ក៏ដូច្នោះដូចគ្នា ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ទឹកក្នុងមហាសមុទ្រទាំង ៤ មានប្រមាណតិច ទឹក
ភ្នែករបស់បុគ្គល ដែលត្រូវសេចក្តីទុក្ខពាល់ត្រូវ
ហើយ សោយសោកមិនមែនតិច ច្រើនជាងទឹកក្នុង
មហាសមុទ្រនោះ ហេតុអ្វី ទើបនាងប្រមាទ ។

កាលព្រះសាស្តា ត្រាស់អនមតគ្គបរិយាយសូត្រយ៉ាងនោះ សេចក្តីសោកក្នុងសរីរៈរបស់នាង បានដល់នូវការស្រាកស្រាន្តហើយ ។ លំដាប់នោះ ព្រះសាស្តាទ្រង់ជ្រាបភាពដែលនាងមានសេចក្តីសោក ស្រាកស្រាន្តហើយ ទ្រង់ដាស់តឿនទៀត ដោយព្រះតម្រាស់ថា បដាចារា ឈ្មោះថា បិយជន មានកូនជាដើម មិនអាចជាទីជ្រកកោន ជាទីពឹង ឬជាទីការពាររបស់នាង ទៅកាន់

បរលោកឡើយ ព្រោះដូច្នោះ កូនជាដើមនោះ ទោះបីមាន ក៏ឈ្មោះមិនមាន នោះឯង ចំណែកបណ្ឌិតជម្រះសីលហើយ គួរជម្រះផ្លូវដែលញ្ចុំងសត្វឲ្យ ដល់នូវព្រះនិព្វានរបស់ខ្លួនប៉ុណ្ណោះ កាលទ្រង់សម្តែងធម៌ បានត្រាស់ព្រះ គាថាទាំងនេះថា

> កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយ មិន
> មានដើម្បីជាទីពឹង បិតា ក៏មិនមាន ទាំងផៅពង្ស ក៏មិន
> មានដើម្បីជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិទាំង-
> ឡាយ ក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះ
> ហើយគួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់
> ជម្រះផ្លូវជាទីទៅកាន់ព្រះនិព្វានឲ្យបាន ។

ក្នុងកាលចប់ទេសនា នាងបដាចារាដុតកិលេស មានប្រមាណប៉ុនធូលី ក្នុងមហាប្រឹថពីហើយ តាំងនៅក្នុងសោតាបត្តិផល មហាជនដទៃសម្រេច អរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

ចំណែកនាងបដាចារានោះ បានជាព្រះសោតាបន្នហើយ ទូលសូមបព្វជ្ជា នឹងព្រះសាស្តា ។ ព្រះសាស្តា ទ្រង់បញ្ជូននាងទៅកាន់សម្នាក់របស់ពួកភិក្ខុនី ឲ្យបព្វជ្ជាហើយ ។ នាងបានឧបសម្បទាហើយ ប្រាកដឈ្មោះថាបដាចារា ព្រោះនាងត្រឡប់ការប្រព្រឹត្តបាន ។ ថ្ងៃមួយ នាងកំពុងយកក្អមដងទឹកលាង ជើង ចាក់ទឹកចុះ ទឹកនោះហូរទៅបន្តិចហើយ ក៏រីងស្ងួត លើកទីពីរទឹកដែល នាងចាក់ បានហូរទៅឆ្ងាយជាងនោះ លើកទីបីទឹកដែលនាងចាក់ បានហូរទៅ

ឆ្ងាយជាងនោះទៀត ដោយប្រការដូច្នេះ នាងកាន់យកទឹកនោះឯងជាអារម្មណ៍ កំណត់វ័យទាំងបីហើយ គិតថា សត្វទាំងនេះ ស្ងាប់ក្នុងបឋមវ័យក៏មាន ដូចទឹកដែលអញចាក់ជំបូង ស្ងាប់ក្នុងមជ្ឈិមវ័យក៏មាន ដូចទឹកដែលអញចាក់លើកទីពីរហូរទៅឆ្ងាយជាងនោះ ស្ងាប់ក្នុងបច្ឆិមវ័យក៏មាន ដូចទឹកដែលអញចាក់លើកទីបី ហូរទៅឆ្ងាយជាងនោះទៀត ។

ព្រះសាស្តា ប្រថាប់គង់នៅក្នុងព្រះគន្ធកុដិ ទ្រង់ផ្សាយព្រះរស្មីទៅ ហាក់ដូចប្រថាប់ឈរចំពោះមុខរបស់នាង ត្រាស់ថា បជាចារ សេចក្តីនោះយ៉ាងនោះឯង ព្រោះថា ការរស់នៅមួយថ្ងៃក្តី មួយខណៈក្តីរបស់បុគ្គលដែលឃើញការកើតឡើង និងការវិនាសនៃបញ្ចក្ខន្ធទាំងនោះ ប្រសើរជាងការរស់នៅមួយរយឆ្នាំរបស់អ្នកមិនឃើញការកើត និងការវិនាសនៃបញ្ចក្ខន្ធ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្ពយំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្ពយំ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញការកើតឡើង និងការវិនាសទៅ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលឃើញការកើតឡើង និងការវិនាសទៅ ប្រសើរជាង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បានព្រះគាថាថា **អបស្សំ ឧទយព្ពយំ** *សេចក្តីថា មិនឃើញការកើតឡើង និងការសូន្យទៅដោយលក្ខណៈ ២៥ នៃបញ្ចក្ខន្ធ ។*

បានទ្រង់ព្រះគាថាថា **បស្សតោ ឧទយព្ពយំ** សេចក្តីថា ការស់នៅសូម្បីត្រឹមតែមួយថ្ងៃ របស់អ្នកឃើញការកើតឡើង និងការវិនាសនៃបញ្ចក្ខន្ធទាំងនោះ ប្រសើរជាងការស់នៅរបស់បុគ្គលនេះ ។

ក្នុងកាលចប់ទេសនា នាងបជាបតីសម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។

រឿង នាងបជាបតី ចប់

រឿង កិសាគោតមី

លំនាំដើម

ព្រះសាស្តា កាលគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងកិសាគោតមី ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជីវេ** ជាដើម ។

បានឮថា ទ្រព្យ ៤០ កោដិក្នុងផ្ទះរបស់សេដ្ឋីម្នាក់ក្នុងក្រុងសាវត្ថី បានក្លាយជាធ្យូងទាំងអស់ តាំងនៅ ។ សេដ្ឋីឃើញហេតុនោះ កើតសេចក្តីសោក ដេកអត់អាហារលើគ្រែតូច សម្លាញ់ម្នាក់របស់សេដ្ឋីនោះ សួរថា នែសម្លាញ់ ហេតុអ្វីទើបអ្នកសោកសៅ ស្តាប់ការប្រព្រឹត្តទៅនោះហើយ ពោលថា នែសម្លាញ់ សូមអ្នកកុំសោកឡើយ ខ្ញុំជីងឧបាយមួយ ចូរធ្វើឧបាយនោះចុះ សេដ្ឋីសួរថា នែសម្លាញ់ តើធ្វើដូចម្តេច សេដ្ឋីម្នាក់ទៀតពោលថា សូមសម្លាញ់ក្រាលកន្ទេលផែនត្រង់ផ្សារ ធ្វើល្បែងឲ្យជាគំនរ ចូរអង្គុយដូចអ្នកលក់ បណ្តា

មនុស្សដែលមកហើយ បុគ្គលណានិយាយយ៉ាងនេះថា ជនដ៏សេសសល់ សំពត់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ចំណែកអ្នកអង្គុយលក់ឆ្ងួង អ្នកគប្បីពោលនឹងមនុស្សទាំងនោះថា ខ្ញុំមិនលក់របស់ខ្លួន តើនឹងធ្វើអ្វី ចំណែកបុគ្គលណាពោលនឹងអ្នក យ៉ាងនេះថា ជនដ៏សេសសល់សំពត់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ចំណែកអ្នកអង្គុយលក់ប្រាក់ និងមាស អ្នកគប្បីនិយាយនឹងជននោះថា ឯណាមាស និងប្រាក់ កាលគេពោលថា នេះ អ្នកគប្បីពោលថា សូមនាំប្រាក់មាសនោះមក ហើយទទួលដោយដៃទាំងពីររបស់ដែលជននោះឲ្យក្នុងដៃរបស់អ្នកយ៉ាងនោះ នឹងក្លាយជាប្រាក់ និងមាស បុគ្គលនោះ បើជាស្រីក្រមុំ ចូរនាំនាង មកដើម្បីបុត្រក្នុងផ្ទះរបស់អ្នក ប្រគល់ទ្រព្យ ៤០ កោដិឲ្យដល់នាង គប្បីប្រើប្រាស់ ប្រាក់មាសដែលនាងឲ្យ បើជាបុរស អ្នកគប្បីឲ្យកូន ស្រីដែលចម្រើនវ័យហើយ ក្នុងផ្ទះរបស់អ្នកដល់បុគ្គលនោះ ហើយប្រគល់ទ្រព្យ ៤០ កោដិឲ្យដល់បុរសនោះ ប្រើប្រាស់ទ្រព្យដែលគេឲ្យ ។ សេដ្ឋីពោលថា ឧបាយនេះល្អ ទើបជញ្ជូនឆ្ងួងឲ្យជាគំនរក្នុងផ្សាររបស់ខ្លួន អង្គុយធ្វើដូចអ្នកលក់ មនុស្សពួកណា ពោលនឹងសេដ្ឋីនោះយ៉ាងនេះថា ជនដ៏សេសទាំងឡាយលក់សំពត់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម អ្នកអង្គុយលក់ឆ្ងួង ក៏ឲ្យចម្ងើយដល់មនុស្សទាំងនោះថា ខ្ញុំមិនលក់របស់ខ្លួន តើនឹងធ្វើអ្វី ។

គ្រានោះ ទាវិកាម្នាក់ឈ្មោះគោតមី ប្រកដឈ្មោះថា កិសាគោតមី ព្រោះមានរាងស្គីង ជាធីតារបស់ត្រកូលបុរាណ ទៅកាន់ផ្សារដោយកិច្ចឯណា

នីមួយរបស់ខ្លួន ឃើញសេដ្ឋីនោះ ទើបពោលយ៉ាងនេះថា នែលោកឪពុក ជនដ៏សេសសល់សំពត់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ហេតុអ្វី ទើបលោកអង្គុយលក់ប្រាក់ និងមាស សេដ្ឋីសួរថា ឯណាប្រាក់ និងមាស នាងគោតមីពោលថា លោកអង្គុយចាប់ប្រាក់មាសនោះឯង មិនមែនឬ សេដ្ឋីពោលថា ចូរនាំប្រាក់មាសនោះមកសិន ។

នាងកើបពេញដៃហើយ ដាក់ត្រង់ដៃសេដ្ឋីនោះ ធ្យូងនោះក៏ក្លាយជាប្រាក់ និងមាសទាំងអស់ ។ លំដាប់នោះ សេដ្ឋីសួរនាងថា នែនាង ផ្ទះរបស់នាងនៅឯណា កាលនាងប្រាប់ថា ក្នុងទីឈ្មោះនោះ ជីងកាពដែលនាងមិនទាន់មានប្តីហើយ ទើបរក្សាទ្រព្យ នាំនាងមកដើម្បីកូនរបស់ខ្លួន ឲ្យរក្សាទ្រព្យ ៤០ កោដិ ។ ទ្រព្យទាំងអស់បានក្លាយជាប្រាក់ និងមាសដូចដើម ។

សម័យដទៃ នាងតាំងគភ៌កន្លងទៅ ១០ ខែ ប្រសូតបុត្រហើយ បុត្រនោះធ្វើកាលកិរិយាហើយ ក្នុងកាលដែលចេះដើរ ។ នាងឃាត់ពួកជនដែលនាំកូននោះទៅដុត ព្រោះនាងមិនធ្លាប់ឃើញការស្លាប់ ពសាកសពបុត្រដែលស្លាប់ហើយដោយឆាប់ឆេះ ដោយបំណងថា នឹងសួរដល់ថ្នាំដើម្បីកូនខ្លួន ដើរសួរទៅតាមលំដាប់ផ្ទះថា អ្នកទាំងឡាយ ស្គាល់ថ្នាំដើម្បីកូនរបស់ខ្ញុំដែរឬទេ ពេលនោះ មនុស្សទាំងឡាយនិយាយនឹងនាងថា នែនាង នាងឆ្កួតហើយឬ នាងសួរដល់ថ្នាំដើម្បីកូនដែលស្លាប់ហើយ នាងសម្គាល់ថា នឹងបានមនុស្សដែលចេះថ្នាំ ដើម្បីកូនរបស់នាងពិត ទើបត្រាច់ទៅ ។

ពេលនោះ បុរសដែលជាបណ្ឌិតម្នាក់ ឃើញនាងហើយគិតថា កូនស្រី

របស់អញនេះប្រសូតបុត្រដំបូង មិនធ្លាប់ឃើញការស្លាប់ អញជាទីពឹងរបស់ស្រីនេះ ទើបគួរ ទើបពោលថា នែនាង ខ្ញុំមិនចេះថ្នាំ តែខ្ញុំស្គាល់អ្នកដែលចេះថ្នាំ នាងគោតមីពោលថា បពិត្រលោកឪពុក អ្នកណាចេះ បណ្ឌិតនោះពោលថា នែនាង ព្រះសាស្តាទ្រង់ជ្រាប ចូរនាងទៅទូលសួរព្រះអង្គចុះ ។ នាងពោលថា បពិត្រលោកឪពុក ខ្ញុំនឹងទៅ នឹងទូលសួរ ដូច្នោះហើយ ចូលទៅរកព្រះសាស្តា ថ្វាយបង្គំហើយ ឈរក្នុងទីបំផុតនាចំណែកម្ខាង ទូលសួរថា បានឮថា ព្រះអង្គទ្រង់ចេះថ្នាំដើម្បីកូនរបស់ខ្ញុំម្ចាស់ឬ ព្រះសាស្តាត្រាស់ថា អើ នាង តថាគតដឹង នាងគោតមីទូលថា បានអ្វី ទើបគួរព្រះអង្គព្រះសាស្តាត្រាស់ថា បានគ្រាប់ស្ពៃត្រីមមួយចិប គួរនាងគោតមីទូលថា នឹងបានព្រះអង្គ តែបានក្នុងផ្ទះអ្នកណា ទើបគួរ ព្រះសាស្តាត្រាស់ថា បុត្រ ឬធីតាណាម្នាក់ក្នុងផ្ទះរបស់បុគ្គលណា មិនធ្លាប់ស្លាប់ បានក្នុងផ្ទះរបស់បុគ្គលនោះ ទើបគួរ នាងទទួលថា ករុណា ព្រះអង្គ ហើយថ្វាយបង្គំព្រះសាស្តា ពកូនដែលស្លាប់ហើយដោយចង្កេះ ចូលទៅខាងក្នុងស្រុក ឈរត្រង់ទ្វារផ្ទះទីមួយ ពោលថា គ្រាប់ស្ពៃខាងក្នុងផ្ទះនេះមានខ្លះឬទេ ព្រោះថា គ្រាប់ស្ពៃនោះជាថ្នាំដើម្បីកូនរបស់ខ្ញុំ កាលគេឆ្លើយថា មាន ទើបពោលថា បើយ៉ាងនោះ សូមឲ្យខ្ញុំចុះ ។ កាលមនុស្សទាំងនោះ នាំគ្រាប់ស្ពៃមកឲ្យ ទើបសួរថា ក្នុងផ្ទះនេះ កូនប្រុស ឬកូនស្រីធ្លាប់ស្លាប់ មានដែរឬទេ កាលគេឆ្លើយថា នាង និយាយអ្វី ព្រោះមនុស្សដែលរស់មានតិចតួច មនុស្សដែលស្លាប់នោះឯងមានច្រើន ទើបពោលថា បើយ៉ាងនោះ សូមទទួលគ្រាប់ស្ពៃរបស់អ្នកវិញចុះ

នោះមិនមែនជាថ្នាំសម្រាប់កូនខ្ញុំទេឬយ ហើយបានឲ្យទៅវិញ ដើរសួរដោយទំនងនេះ តាំងអំពីផ្ទះទីមួយជាដើមទៅ ។ នាងមិនទទួលគ្រាប់ស្ពៃក្នុងផ្ទះមួយក្នុងពេលល្ងាច គិតថា ឱ ! កម្មជូនប្អូ អញធ្វើសេចក្តីសម្គាល់ថា កូនរបស់អញប៉ុណ្ណោះស្លាប់ ក្នុងស្រុកទាំងមូល មនុស្សដែលស្លាប់ប៉ុណ្ណោះច្រើនជាងអ្នករស់ ។ កាលនាងកំពុងគិតយ៉ាងនេះ ហទយៈដែលទន់ដោយការស្រឡាញ់បុត្រ បានដល់នូវការរីងហើយ ។ នាងដាក់កូននោះក្នុងព្រៃ ទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំហើយ ឈរក្នុងទីបំផុត នាចំណែកម្ខាង ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងនាងថា នាងបានគ្រាប់ស្ពៃប្រមាណមួយចិបហើយឬ នាងគោតមីទូលថា មិនបានទេព្រះអង្គ ព្រោះក្នុងស្រុកទាំងមូលអ្នកស្លាប់នោះឯងច្រើនជាងអ្នករស់ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា នាងយល់ថា កូនរបស់អញប៉ុណ្ណោះស្លាប់ ការស្លាប់នោះ ជាធម្មិស្តិតស្ថេរសម្រាប់សត្វទាំងឡាយ ព្រោះថា មច្ចុរាជអូសទាញសត្វទាំងអស់ ដែលមានអធ្យាស្រ័យមិនពេញលេញនោះឯង ឲ្យធ្លាក់ក្នុងសមុទ្រ គឺអបាយ ដូចអន្ធង់ទឹកធំ ជួរច្នោះ កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

> មច្ចុ គឺសេចក្តីស្លាប់ តែងនាំយកនរជនអ្នកស្រើបស្រាលជ្រុបក្នុងកូន និងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ នោះ ដូចជំនន់ទឹកធំ នាំយកអ្នកស្រុកកំពុងដេកលក់ ។

ក្នុងកាលចប់ទេសនា នាងកិសាគោតមី តាំងនៅក្នុងសោតាបត្តិផល សូម្បីមហាជនដទៃ ក៏សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផល ជាដើម ដូច្នេះឯង ។

ចំណែកនាងកិសាគោតមីនោះ ទូលសូមបព្វជ្ជានឹងព្រះសាស្តាហើយ ព្រះសាស្តាទ្រង់បញ្ជូនទៅកាន់សម្នាក់ភិក្ខុនី ឲ្យបព្វជ្ជាហើយ ។ នាងបាន ឧបសម្បទាហើយ ប្រាកដឈ្មោះថា កិសាគោតមីថេរី ។

ថ្ងៃមួយ នាងដល់វារៈក្នុងរោងឧបោសថ អង្គុយអុជប្រទីប ឃើញ អណ្តាតប្រទីបឆេះឡើង និងថយចុះ បានកាន់យកជាអារម្មណ៍ថា សត្វទាំង នេះ ក៏យ៉ាងនោះដូចគ្នា កើតឡើង និងរលត់ទៅដូចអណ្តាតប្រទីប បុគ្គល ដល់ព្រះនិព្វាន មិនប្រាកដយ៉ាងនោះ ។

ព្រះសាស្តា ប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ផ្សាយព្រះរស្មីទៅ ដូចគង់ត្រាស់ចំពោះមុខ ត្រាស់ថា យ៉ាងនោះឯងគោតមី សត្វទាំងនោះ រមែង កើត និងរលត់ដូចអណ្តាតប្រទីប ដល់នូវព្រះនិព្វានហើយ រមែងមិនប្រាកដ យ៉ាងនោះ កាពជាអ្នករស់នៅត្រឹមមួយខណៈ របស់អ្នកឃើញព្រះនិព្វាន ប្រសើរជាងការស់នៅមួយរយឆ្នាំ របស់អ្នកមិនឃើញព្រះនិព្វានយ៉ាងនោះ ដូច្នោះហើយ ទើបទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យោ ច វស្សសតំ ជីវេ អបស្សំ អមតំ បទំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ អមតំ បទំ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញផ្លូវព្រះនិព្វាន

ការរស់នៅសូម្បីមួយថ្ងៃ របស់លោកអ្នកឃើញផ្លូវព្រះនិព្វាន ប្រសើរជាង ។

បណ្តាបទទាំងនោះ ពីរបទថា **អមតំ បទំ** សេចក្តីថា អមតមហានិព្វាន ដែលជាចំណែកវៀរចាកនូវមរណៈ ។

ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលមានក្នុងកាលមុននោះឯង ។

ក្នុងកាលចប់ទេសនា នាងកិសាគោតមីអង្គុយនៅតាមប្រក្រតីនោះឯង តាំងនៅក្នុងអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ॥

រឿង កិសាគោតមី ចប់

រឿង ពហុបុត្តិកាថេរី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងពហុបុត្តិកាថេរី ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជីវេ** ជាដើម ។

បានឮថា ក្នុងត្រកូលមួយ នាក្រុងសាវត្ថី ស្ត្រីម្នាក់មានកូនប្រុស ៧ និងកូនស្រី ៧ កូនប្រុស និងកូនស្រីទាំងអស់នោះចម្រើនវ័យហើយ តាំងនៅក្នុងផ្ទះបានដល់នូវសេចក្តីសុខ តាមធម្មតារបស់ខ្លួន ។ សម័យដទៃមក ឪពុករបស់ជនទាំងនោះ បានធ្វើកាលកិរិយាហើយ ។

មហាឧបាសិកា សូម្បីស្វាមីអនិច្ចកម្មទៅហើយ ក៏មិនបែងចែកទ្រព្យឲ្យ កូនទាំងឡាយ ។ កាលនោះ កូនទាំងឡាយពោលនឹងមាតានោះថា កាលបិតា របស់ខ្ញុំស្លាប់ទៅហើយ ប្រយោជន៍អ្វីរបស់ម៉ែដោយគំនរទ្រព្យ ពួកខ្ញុំមិនអាច ចិញ្ចឹមម៉ែបានឬ នាងស្តាប់ពាក្យរបស់កូនទាំងនោះហើយ ក៏អង្គុយស្ងៀម ត្រូវ កូនទាំងនោះពោលរឿយៗ ទើបគិតថា ពួកកូនៗ នឹងទំនុកបម្រុងអញ ប្រ-យោជន៍អ្វីរបស់អញ ដោយគំនរទ្រព្យមួយចំណែក បានបែងចែកទ្រព្យ សម្បត្តិទាំងអស់ ពាក់កណ្តាលឲ្យទៅ ។

ក្នុងកាលកន្ទងទៅ ២-៣ ថ្ងៃ ភរិយារបស់បុត្រច្បងពោលនឹងម៉ែក្មេក នោះថា ឱ អ្នកម៉ែពួកយើង មកផ្ទះនេះប៉ុណ្ណោះ ដូចនឹងឲ្យពីរចំណែក ដល់ កូនប្រុសច្បង ។ ភរិយារបស់កូនដ៏សេស ក៏ពោលយ៉ាងនោះដូចគ្នា ។

ចាប់តាំងអំពីកូនស្រីច្បង ក៏ពោលនឹងនាងដូចគ្នា ក្នុងវេលាដែលនាង ទៅកាន់ផ្ទះរបស់ធីតានោះៗ ។ នាងត្រូវមើលងាយ គិតថា ប្រយោជន៍អ្វី ដោយការនៅក្នុងសម្នាក់របស់មនុស្សទាំងនេះ អញនឹងបួសជាភិក្ខុនី ហើយ ទៅកាន់សម្នាក់របស់ភិក្ខុនី សូមបព្វជ្ជាហើយ ។ ភិក្ខុនីទាំងនោះឲ្យនាងបព្វជ្ជា ហើយ នាងបានឧបសម្បទាហើយ ប្រាកដឈ្មោះថា ពហុបុត្តិកាថេរី ។ នាង គិតថា អញបួសក្នុងកាលឯចាស់ អញមិនគួរជាបុគ្គលប្រមាទ ទើបធ្វើវត្ត

បជិបត្តិដល់ភិក្ខុនីទាំងឡាយ គិតថា នឹងធ្វើសមណធម៌មួយឃប់ទល់ភ្លឺ ទើប យកដៃចាប់សសរមួយដើម ខាងក្រោមប្រាសាទ ដើរឆ្វែលសសរនោះធ្វើ សមណធម៌ កាលដើរចង្រ្កម ក៏យកដៃចាប់ដើមឈើ ដោយគិតថា ក្បាល របស់អញគប្បីទង្គិចដើមឈើ ឬទីណាមួយក្នុងទីងងឹត ដូច្នេះហើយ ដើរឆ្វែល ដើមឈើនោះ ធ្វើសមណធម៌ ពិចារណាដល់ធម៌ ដោយគិតថា នឹងធ្វើតាម ធម៌ដែលព្រះសាស្តាទ្រង់សម្តែង តាមរឭកដល់ធម៌ ត្រាច់ធ្វើសមណធម៌ ។

កាលនោះ ព្រះសាស្តាទ្រង់ប្រថាប់គង់ក្នុងព្រះគន្ធកុដិហើយ ទ្រង់ផ្សាយ ព្រះរស្មីទៅ ហាក់ដូចប្រថាប់គង់ចំពោះមុខដោយព្រះតម្រាស់ថា ពហុបុត្តិកា ការរស់នៅ សូម្បីត្រឹមមួយរំពេចរបស់អ្នកឃើញធម៌ ដែលតថាគតសម្តែង ប្រសើរជាងការរស់នៅមួយរយឆ្នាំ របស់បុគ្គលមិនពិចារណា មិនឃើញធម៌ ដែលតថាគតសម្តែង កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថា នេះដូច្នេះថា

យោ ច វស្សសតំ ជីវេ អបស្សំ ធម្មមុត្តមំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ធម្មមុត្តមំ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់ ការរស់នៅ សូម្បីតែមួយថ្ងៃ របស់លោកអ្នកឃើញធម៌ ដ៏ខ្ពង់ខ្ពស់ ប្រសើរជាង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ធម្មមុត្តមំ** បានដល់លោកុត្តរធម៌ ៩ យ៉ាង ។ លោកុត្តរធម៌នោះ ឈ្មោះថា ជាធម៌ដ៏ឧត្តម បុគ្គលណាមិនឃើញធម៌ដ៏កំពូលនោះ ភាពជាអ្នករស់នៅ សូម្បីតែមួយរំពេច គឺសូម្បីតែមួយខណៈរបស់អ្នកឃើញ គឺចាក់ធ្លុះនូវធម៌នោះ ប្រសើរជាងការរស់នៅមួយរយឆ្នាំរបស់បុគ្គលនោះ ។

ក្នុងកាលចប់ទេសនា ព្រះនាងពហុបុត្តិកាថេរីតាំងនៅក្នុងអរហត្ត មួយអន្ទើជាយបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។

រឿងពហុបុត្តិកាថេរី ចប់

សហស្សវគ្គ ចប់

វគ្គទី ៨ ចប់

សុត្តន្តបិដក

ធម្មបទគាថា ចាបវគ្គទី ៩

[១៩] បុគ្គលគួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ។ បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយៗ ឡើយ កុំគប្បីធ្វើសេចក្តីពេញចិត្តក្នុងបាបនោះ (ព្រោះថា) ការសន្សំបាប តែងនាំសេចក្តីទុក្ខមកឲ្យ ។

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឲ្យរឿយៗ គួរធ្វើសេចក្តីពេញចិត្តក្នុងបុណ្យនោះ (ព្រោះថា) ការសន្សំបុណ្យ តែងនាំសេចក្តីសុខមកឲ្យ ។

បាប មិនទាន់ឲ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែសេចក្តីចម្រើនត្រឹមនោះ លុះកាលណា បាបឲ្យផល មនុស្សបាប ទើបឃើញបាបក្នុងកាលនោះ ។

អំពើល្អ មិនទាន់ឲ្យផលត្រឹមណា មនុស្សល្អ នៅឃើញតែបាបត្រឹមនោះ លុះកាលណា អំពើល្អឲ្យផល មនុស្សល្អ ទើបឃើញល្អក្នុងកាលនោះ ។

បុគ្គលមិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឲ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញដោយតំណក់ទឹក ដែលធ្លាក់ចុះ

យ៉ាងណា បុគ្គលពាល កាលសន្សំបាប សូម្បីបន្តិចម្តងៗ គង់ពេញបាន ដោយបាប យ៉ាងនោះដែរ ។

បុគ្គលមិនគួរមើលងាយបុណ្យថា មានប្រមាណតិច នឹងមិនឲ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្តងៗ គង់ពេញបានដោយ បុណ្យយ៉ាងនោះ ។

បុគ្គលគួរចៀសវាងបាបទាំងឡាយ ឲ្យដូចពាណិជដែលមានទ្រព្យ ច្រើន តែមានគ្នាតិច ចៀសវាងផ្លូវគួរខ្លាច ឬដូចជាបុរសប្រាថ្នារស់នៅ ចៀសវាងថ្នាំពិស ដូច្នោះដែរ ។

បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីនាំយកថ្នាំពិសដោយបាតដៃ ថ្នាំពិសតែងមិនជ្រាបចូលទៅកាន់បាតដៃដែលគ្មានដំបៅ យ៉ាងណា បាបរមែង មិនមានដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះដែរ ។ បុគ្គលណា ប្រទូស្តអ្នកមិន ប្រទូស្តតប ជាសត្វស្អាត មិនមានកិលេសដូចជាទីទួល បាបរមែងត្រឡប់ មករកបុគ្គលពាលនោះវិញ ដូចធូលីល្អិតដែលបុគ្គលបាចសាចទៅកាន់ទី ច្រាស់ខ្យល់ ។

ជនពួកខ្លះ កើតក្នុងគភ៌មនុស្ស ពួកអ្នកមានអំពើអាក្រក់ទៅកាន់នរក

ពួកអ្នកមានគតិល្អ ទៅកាន់ស្ថានសួគ៌ ពួកអ្នកមិនមានអាសវៈបរិនិព្វាន ។

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលស្ថិតនៅហើយ គប្បីរួចចាកបាបកម្មបាននោះ មិនដែលមានឡើយ ។

បុគ្គលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះនៃភ្នំទាំងឡាយ ក៏មិនរួចចាកសេចក្តីស្លាប់បាន ព្រោះប្រទេសលើផែនដីដែលបុគ្គលឋិតនៅហើយ សេចក្តីស្លាប់គ្របសង្កត់មិនបាននោះ មិនដែលមានឡើយ ។

ចាបវគ្គទី ៩ ចប់

អដ្ឋកថា

ធម្មបទដ្ឋកថា

ខុទ្ទកនិកាយ គាថាធម្មបទ

ចាបវគ្គទី ៩

រឿង ព្រាហ្មណ៍ ឈ្មោះ ចូឡេកសាដក

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធចូឡេកសាដក-ព្រាហ្មណ៍ ត្រាស់ព្រះធម្មទេសនានេះថា **អភិត្តរេថ កល្យាណេ** *ជាដើម ។*

សេចក្តីពិស្តារថា ក្នុងកាលនៃព្រះវិបស្សីទសពល មានព្រាហ្មណ៍ម្នាក់ ឈ្មោះមហាឯកសាដក ។ តែក្នុងកាលនោះ ព្រាហ្មណ៍នេះជាព្រាហ្មណ៍ឈ្មោះចូឡេកសាដកក្នុងក្រុងសាវត្ថី ។ សំពត់សាដកសម្រាប់ស្លៀករបស់ព្រាហ្មណ៍នោះមានតែមួយផ្ទាំង សូម្បីរបស់នាងព្រាហ្មណីក៏មានតែមួយផ្ទាំង ទាំងពីរនាក់ប្តីប្រពន្ធ មានសំពត់ដណ្តប់មួយផ្ទាំងប៉ុណ្ណោះ ។ ក្នុងពេលចេញទៅខាងក្រៅព្រាហ្មណ៍ ឬព្រាហ្មណី រមែងដណ្តប់សំពត់មួយផ្ទាំងនោះ ។ ក្រោយមក កាលគេប្រកាសការស្តាប់ធម៌ក្នុងវិហារ ព្រាហ្មណ៍ពោលថា នែនាង គេប្រកាសការស្តាប់ធម៌ នាងនឹងទៅទីស្តាប់ធម៌ក្នុងពេលថ្ងៃ ឬពេលយប់ ព្រោះ

យើងទាំងពីរមិនអាចទៅព្រមគ្នាបាន ព្រោះមិនមានសំពត់ដណ្តប់ ព្រាហ្មណីឆ្លើយថា នែអ្នក ខ្ញុំនឹងទៅពេលថ្ងៃ ហើយនឹងដណ្តប់សំពត់សាដកទៅ ។

ព្រាហ្មណ៍សម្ងំនៅក្នុងផ្ទះអស់មួយថ្ងៃ លុះពេលយប់ ទើបបានទៅអង្គុយស្តាប់ធម៌ ចំពោះព្រះភក្ត្រព្រះសាស្តា ។ គ្រានោះ បីតិ ៥ យ៉ាងជ្រួតជ្រាបពេញសរីរៈរបស់ព្រាហ្មណ៍នោះកើតឡើងហើយ ។ គាត់ជាបុគ្គលប្រាថ្នានឹងបូជាព្រះសាស្តា គិតថា បើអញថ្វាយសំពត់សាដកនេះសោត សំពត់ដណ្តប់របស់នាងព្រាហ្មណីនឹងមិនមាន របស់អញក៏មិនមាន ខណៈនោះ ចិត្តប្រកបដោយសេចក្តីកំណាញ់រាប់ពាន់កើតឡើងហើយដល់គាត់ ចិត្តប្រកបដោយសទ្ធាមួយជួនកើតឡើងទៀត ចិត្តប្រកបដោយសេចក្តីកំណាញ់រាប់ពាន់ កើតឡើងគ្របសង្កត់ចិត្តសទ្ធានោះទៀត ។ សេចក្តីកំណាញ់របស់គាត់មានកម្លាំង ចាំតែគ្របសង្កត់ចិត្តដែលជាសទ្ធា ដូចត្រូវចាប់ចងនោះឯង ដោយប្រការដូច្នេះ ។

កាលព្រាហ្មណ៍កំពុងគិតថា តើថ្វាយ ឬមិនថ្វាយ ដូច្នោះនោះឯង បឋមយាមកន្លងទៅហើយ បន្ទាប់អំពីនោះ ក៏ដល់មជ្ឈិមយាម ព្រាហ្មណ៍មិនអាចថ្វាយក្នុងមជ្ឈិមយាមនោះបាន លុះដល់បច្ឆិមយាម គាត់គិតថា កាលអញច្បាំងជាមួយសទ្ធាចិត្ត និងមច្ឆរិយចិត្តនោះឯង ពីរយាមកន្លងទៅហើយ មច្ឆរិយចិត្តរបស់អញមានប្រមាណប៉ុណ្ណោះចម្រើន នឹងមិនឲ្យងើបក្បាលឡើងអំពីអបាយ ៤ អញនឹងថ្វាយសំពត់សាដកនេះ ព្រាហ្មណ៍សង្កត់សេចក្តីកំណាញ់រាប់ពាន់បានហើយ ដោយធ្វើសទ្ធាចិត្តឲ្យជាបុរេចារិក កាន់សំពត់សាដកទៅជាក់ទៀបបាទមូលព្រះសាស្តា បានបន្ទឺសំឡេងខ្លាំង ៣ ដងថា ខ្ញុំ

ឈ្នះហើយ ខ្ញុំឈ្នះហើយជាដើម ។

ព្រះបាទបសេនទិកោសលកំពុងស្តាប់ធម៌ បានស្តាប់សំឡេងនោះហើយ ត្រាស់ថា ពួកអ្នកចូរសួរព្រាហ្មណ៍នោះមើល បានឮថា គេឈ្នះអ្វី ។

ព្រាហ្មណ៍នោះ ត្រូវពួករាជបុរសសួរ បានប្រាប់សេចក្តីនោះ ព្រះរាជាបានស្តាប់សេចក្តីនោះហើយ ទ្រង់ត្រិះរិះថា ព្រាហ្មណ៍ធ្វើវត្តដែលបុគ្គលធ្វើបានលំបាក អញនឹងធ្វើការសង្គ្រោះដល់ព្រាហ្មណ៍ ទើបទ្រង់ព្រះរាជទានសំពត់សាដកមួយគូ ។

គាត់បានថ្វាយសំពត់នោះដល់ព្រះសាស្តាជូចគ្នា ទើបព្រះរាជា បញ្ជាឲ្យព្រះរាជទានធ្វើឲ្យជាទ្វេគុណ គឺ ២ គូ ៤ គូ ៨ គូ ១៦ គូ គាត់បានថ្វាយសំពត់នោះ ដល់ព្រះសាស្តានោះឯង ។ បន្ទាប់មកព្រះរាជាត្រាស់ឲ្យព្រះរាជទានសំពត់ សាដក ៣២ គូដល់ព្រាហ្មណ៍ ។

ព្រាហ្មណ៍កាលការពារវាទៈថា ព្រាហ្មណ៍មិនកាន់យកដើម្បីខ្លួន លះបង់សំពត់ដែលបានហើយទាំងអស់ ទើបកាន់យកសំពត់សាដកពីរគូ អំពីសំពត់សាដក ៣២ គូនោះ គឺដើម្បីខ្លួនមួយគូ ដើម្បីនាងព្រាហ្មណីមួយគូ បានថ្វាយសំពត់សាដក ៣០ គូដល់ព្រះសាស្តានោះឯង ។ ចំណែកព្រះរាជា កាលព្រាហ្មណ៍នោះថ្វាយដល់ ៧ ដង មានព្រះរាជបំណងនឹងព្រះរាជទានទៀត ។ ព្រាហ្មណ៍ឈ្មោះមហាឯកសាដកក្នុងកាលមុន កាន់យកសំពត់សាដកពីរគូក្នុងចំនួនសំពត់សាដក ៦៤ គូ ។ ចំណែកព្រាហ្មណ៍ឈ្មោះចូឡកសាដកនេះ បានកាន់យកសំពត់សាដកពីរគូ ក្នុងពេលដែលខ្លួនបានសំពត់សាដក ៣២ គូ ។

ព្រះរាជាទ្រង់បង្គាប់ពួកភាជបុរសថា នែអ្នក ព្រាហ្មណ៍ធ្វើវត្តុដែលធ្វើបានកម្រ អ្នកទាំងឡាយគប្បីនាំយកសំពត់កម្ពលពីរផ្ទាំង ក្នុងវាំងរបស់យើងមក ពួកភាជបុរសបានធ្វើយ៉ាងនោះ ។ ព្រះរាជាត្រាស់ឲ្យព្រះរាជទានសំពត់កម្ពលពីរផ្ទាំង ដែលមានតម្លៃមួយសែនដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍គិតថា សំពត់កម្ពលទាំងនេះ មិនសមគួរពាល់ត្រូវត្រង់សរីរៈរបស់អញ សំពត់ទាំងនោះសមគួរដល់ព្រះពុទ្ធសាសនាប៉ុណ្ណោះ ទើបបានចងសន្ធឹងសំពត់កម្ពលមួយផ្ទាំង ធ្វើជាពិជានខាងលើទីបន្ទំរបស់ព្រះសាស្តា ខាងក្នុងព្រះគន្ធកុដិ ចងសន្ធឹងមួយផ្ទាំង ធ្វើជាពិជាន ក្នុងទីធ្វើកត្តកិច្ចរបស់ភិក្ខុដែលឆាន់ជានិច្ចក្នុងផ្ទះរបស់ខ្លួន ក្នុងពេលល្ងាច ព្រះរាជាយាងចូលទៅកាន់សម្នាក់របស់ព្រះសាស្តា ទ្រង់ចាំសំពត់កម្ពលនោះបានហើយ ទូលសួរថា បពិត្រព្រះអង្គ អ្នកណាធ្វើការបូជា កាលព្រះសាស្តាត្រាស់ថា ព្រាហ្មណ៍ឈ្មោះឯកសាដក ដូច្នេះហើយ ទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍ជ្រះថ្លាក្នុងហានៈដែលអញជ្រះថ្លាដូចគ្នា ត្រាស់ឲ្យព្រះរាជទានវត្តុគ្រប់យ៉ាង ១ មុខ ៤ៗ រហូតដល់មួយរយនៃវត្តុទាំងអស់ដល់ព្រាហ្មណ៍នោះយ៉ាងនេះ គឺជីរ ៤ សេះ ៤ កហាបណៈ ៤ ពាន់ ស្ត្រី ៤ ទាសី ៤ បុរស ៤ ស្រុកសួយ ៤ ។

ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងរោងធម្មសភាថា ឱកម្មរបស់ព្រាហ្មណ៍ឈ្មោះ ចូឡកសាដកគួរអស្ចារ្យ មួយរំពេចប៉ុណ្ណោះគាត់បានវត្តុសព្វយ៉ាងមួយមុខ៤ៗ សុចរិតកម្មដែលគាត់ធ្វើក្នុងស្រែឥឡូវនេះឯងឲ្យផលក្នុងថ្ងៃនេះ ។

ព្រះសាស្តា យាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ

នេះ ពួកអ្នកទាំងឡាយ អង្គុយសន្ទនាគ្នា ដោយកថាដូចម្តេច កាលពួកភិក្ខុ ក្រាបទូលថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើឯកសាដកនេះ ឲ្យដល់តថាគតក្នុងបឋមយាមសោត នឹងបានវត្ថុសព្វយ៉ាង មួយមុខ ១៦ បើឲ្យក្នុងមជ្ឈិមយាមសោត នឹងបានវត្ថុសព្វយ៉ាង មួយមុខ ៨ តែព្រោះឲ្យក្នុងកាលទៀបភ្លឺ ទើបព្រាហ្មណ៍បានវត្ថុមួយមុខ ៤ ពិតហើយ សុចរិតកម្មដែលបុគ្គលគប្បីធ្វើ មិនញុំាងចិត្តកើត ក៏ដល់នូវសេចក្តីវិនាស គួរធ្វើភ្លាមៗនោះឯង ព្រោះថា កុសលដែលបុគ្គលធ្វើយឺតយូរ កាលឲ្យសម្បត្តិ រមែងឲ្យយឺតយូរដូចគ្នា ព្រោះដូច្នោះ គប្បីធ្វើសុចរិតកម្មក្នុងលំដាប់នៃចិត្តុប្បាទនោះឯង កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

អភិត្តរេថ កល្យាណេ ចាចា ចិត្តំ និវារយេ
ទន្ធំ ហិ ករតោ បុញ្ញំ ចាបស្មឹ រមតី មនោ ។

បុគ្គលគួរប្រញាប់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អភិត្តរេថ** *សេចក្តីថា គប្បីធ្វើដោយប្រញាប់គឺរហ័ស ។ ពិតហើយ គ្រហស្ថ កាលចិត្តកើតឡើងថា នឹងធ្វើកុសលឯណានីមួយ ក្នុងទានកុសលទាំងឡាយ មានសលាកភត្តជាដើម គួរធ្វើរំពេចនោះ*

ឯង ដោយគិតថា អញនឹងធ្វើ អញនឹងធ្វើ ដោយប្រការដែលជនដទៃមិនបានឱកាស ដូច្នោះ ។ ឬបព្វជិត កាលធ្វើវត្តទាំងឡាយ មានឧបជ្ឈាយវត្តជាដើម មិនឲ្យឱកាសដល់អ្នកដទៃ គួរធ្វើដោយរហ័សនោះឯង ដោយគិតថា អញនឹងធ្វើអញ នឹងធ្វើ ។

ពីរបទថា **ចាចា ចិត្តំ** សេចក្តីថា បុគ្គលគប្បីហាមចិត្តចាកចាបកម្ម មានកាយទុច្ចរិតជាដើម ឬចាកអកុសលចិត្តុប្បាទក្នុងទីគ្រប់អន្ទឹ ។

ពីរបទថា **ឧទ្ធំ ហិ ករតោ** សេចក្តីថា បុគ្គលណាគិតយ៉ាងនេះថា អញនឹងឲ្យ នឹងធ្វើ ផលនេះនឹងសម្រេចដល់អញឬទេ ឈ្មោះថា ធ្វើបុណ្យយឺតយូរ ដូចបុគ្គលដើរផ្លូវអាក្រ ក់ សេចក្តីអាក្រក់របស់បុគ្គលនោះរមែងបានឱកាស ដូចជាមច្ឆរិយចិត្តមួយពាន់ របស់ព្រាហ្មណ៍ឈ្មោះឯកសាដក ដូច្នោះ ។ កាលបើដូច្នោះ ចិត្តរបស់បុគ្គលនោះ រមែងត្រេកអរក្នុងចាប ព្រោះថា ក្នុងកាលដែលធ្វើកុសលកម្មប៉ុណ្ណោះ ចិត្តរមែងត្រេកអរក្នុងកុសលកម្ម ផុតអំពីនោះ រមែងបង្អោនទៅកាន់សេចក្តីអាក្រក់បានពិត ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រាហ្មណ៍ចូឡេកសាដក ចប់

រឿង ព្រះសេយ្យសកត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសេយ្យសកត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ចាបញ្ចេ បរិសោ កយិរា** *ជាដើម ។*

បានឮមកថា ព្រះសេយ្យសកត្ថេរនោះ ជាសន្ទិវិហារិករបស់ព្រះលោឡុទាយិត្ថេរ ប្រាប់ការមិនត្រេកអររបស់ខ្លួន ដល់ព្រះលោឡុទាយីនោះ ត្រូវលោកដឹកនាំក្នុងការធ្វើបឋមសង្ឃាទិសេស កាលការមិនត្រេកអរកើតទ្វេឡើង បានធ្វើកម្មនោះហើយ ។

ព្រះសាស្តា បានស្តាប់កិរិយារបស់លោក ទ្រង់ត្រាស់ឲ្យហៅមកហើយសួរថា បានឮថា អ្នកធ្វើយ៉ាងនោះពិតឬ កាលលោកទូលថា យ៉ាងនោះឯង ព្រះអង្គ ទើបត្រាស់ថា នែមោឃបុរស ហេតុអ្វី ទើបអ្នកធ្វើកម្មជ្រុនជ្រែលមិនសមគួរ ទ្រង់តិះដៀលដោយប្រការផ្សេងៗ ទ្រង់បញ្ញត្តសិក្ខាបទហើយត្រាស់ថា កម្មបែបនេះ ជាកម្មញុំាងសត្វឲ្យប្រព្រឹត្តទៅដើម្បីទុក្ខតែម្យ៉ាង ទាំងក្នុងភពនេះ ទាំងក្នុងភពខាងមុខ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ចាបញ្ចេ បុរិសោ កយិរា ន នំ កយិរា បុនប្បុនំ
ន តម្ហិ ឆន្ទំ កយិរាថ ទុក្ខោ ចាបស្ស ឧច្ចយោ ។

បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយៗ ឡើយ កុំធ្វើសេចក្តីពេញចិត្តក្នុងបាបនោះ (ព្រោះថា) ការសន្សំបាប តែងនាំសេចក្តីទុក្ខមកឲ្យ ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានេះថា បើបុគ្គលធ្វើនូវកម្មលាមកម្តង គួរពិចារណាក្នុងខណៈនោះឯង សិក្សាថា កម្មនេះមិនសមគួរ ជាកម្មគ្រោតគ្រោត មិនគួរធ្វើកម្មនោះរឿយៗ គប្បីបន្ទោរបង់ មិនគួរធ្វើនូវការពេញចិត្ត ឬការគាប់ចិត្តក្នុងបាបនោះ ដែលគប្បីកើតឡើងឡើយ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា ការសន្សំ គឺការសន្សំនូវបាបជាហេតុឲ្យកើតទុក្ខ គឺរមែងនាំតែទុក្ខមកឲ្យទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះសេយ្យសកត្ថេរ ចប់

រឿង ជាផលាជទេពធីតា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាឆលាជទេព-ធីតា ត្រាស់ព្រះធម្មទេសនានេះថា **បុញ្ញញ្ចេ បុរិសោ កយិរា** *ជាដើម រឿងកើតឡើងហើយ ក្នុងនគររាជគ្រឹះ ។*

សេចក្តីពិស្តារថា ព្រះមហាកស្សបដែលនៅត្រង់បិប្ផលិគុហា ចូលឈានហើយ ចេញក្នុងថ្ងៃទី ៧ ប្រមើលមើលទីដែលត្រូវទៅដើម្បីបិណ្ឌបាតដោយទិព្វចក្ខុ ឃើញស្រីចាំស្រូវសាលីម្នាក់ក្តិចក្បរស្រូវធ្វើលាជ ពិចារណាថា ស្រី

នេះមានសទ្ធាដែរឬហ្ន៎ ដីឆថា មានសទ្ធា ពិចារណាថា នាងនឹងអាចធ្វើការសង្គ្រោះដល់អាត្មាអញបានឬហ្ន៎ ដីឆថា កុលធីតាជាស្រីក្លាហាន នឹងធ្វើការសង្គ្រោះដល់អញ កាលធ្វើហើយនឹងបានសម្បត្តិដ៏ច្រើន ទើបឃ្លុំចីវរ កាន់បាត្រ បានឈរនៅទីជិតស្រែស្រូវសាលី ។ កុលធីតាឃើញព្រះថេរៈ មានចិត្តជ្រះថ្លា មានសរីរៈដែលបីតិទាំង ៥ ពាល់ត្រូវហើយ ពោលថា សូមលោកម្ចាស់និមន្តរង់ចាំសិន កាន់លាជទៅដោយរហ័ស កៀរទម្ងាក់ក្នុងបាត្ររបស់ព្រះថេរៈហើយ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន បានធ្វើសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ ខ្ញុំគប្បីជាអ្នកមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយ ។

ព្រះថេរៈបានធ្វើអនុមោទនាថា សេចក្តីប្រាថ្នាយ៉ាងនោះ ចូរសម្រេចចុះ ចំណែកនាងថ្វាយបង្គំព្រះថេរៈហើយ គិតដល់ទានដែលខ្លួនឲ្យហើយ ត្រឡប់ទៅ ។ ក្នុងផ្លូវដែលនាងដើរទៅលើភ្លឺស្រែ មានពស់កាចដេកក្នុងរន្ធមួយកន្លែង ពស់មិនអាចចឹកស្មងព្រះថេរៈ ដែលបិទបាំងដោយកាសាវពស្ត្របាន ។ នាងរឭកដល់ទានត្រឡប់ទៅដល់ទីនោះ ពស់លូនចេញអំពីរន្ធ ចឹកនាងឲ្យដួលចុះក្នុងទីនោះឯង នាងមានចិត្តជ្រះថ្លាធ្វើកាលកិរិយាហើយ ទៅកើតក្នុងវិមានមាសប្រមាណ ៣០ យោជន៍ ក្នុងតាវត្តិង្សពិភព មានអត្តភាពប្រមាណ ៣ គាវុត ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ដូចដេកលក់ ហើយភ្ញាក់ឡើង ។

នាងស្ទុះសំពត់ទិព្វប្រមាណ ១២ ហត្ថ មួយផ្ទាំង ដណ្តប់មួយផ្ទាំង ចោមរោមដោយទេពអប្សរមួយពាន់ ដើម្បីប្រកាសបុព្វកម្ម ទើបឈរត្រង់ទ្វារ

វិមាន ដែលប្រដាប់ដោយផ្តិលមាស ពេញដោយលាជមាសសំយុងនៅ សម្លឹងមើលទិព្វសម្បត្តិរបស់ខ្លួន ពិចារណាដោយទិព្វចក្ខុថា អញធ្វើកម្មអ្វីហ្ន៎ ទើបបានសម្បត្តិនេះ បានដឹងថា សម្បត្តិនេះ អញបានហើយ ព្រោះផលនៃលាជដែលអញប្រគេនដល់លោកម្ចាស់កស្សបត្ថេរ នាងគិតថា អញបានសម្បត្តិបែបនេះ ព្រោះកម្មតិចតួចយ៉ាងនេះ ឥឡូវនេះ អញមិនគួរប្រមាទ អញនឹងធ្វើវត្តបដិបត្តិដល់លោកម្ចាស់ ធ្វើសម្បត្តិនេះឲ្យស្ថិតស្ថេរ ទើបកាន់អំបោសនិងកំជ្រោង សម្រាប់ចាក់សំរាម សម្រេចដោយមាស ទៅបោសបរិវេណរបស់ព្រះថេរៈ ហើយដងទឹកធាន់ ទឹកប្រើជ្រាស់អំពីព្រលឹម ។

ព្រះថេរៈឃើញដូច្នោះ សម្គាល់ថាជាវត្តដែលកិក្ខុ ឬសាមណេររូបខ្លះធ្វើ ។ ក្នុងថ្ងៃទី ២ នាងក៏បានធ្វើយ៉ាងនោះ ចំណែកព្រះថេរៈក៏សម្គាល់ដូច្នោះដូចគ្នា ។ តែក្នុងថ្ងៃទី ៣ ព្រះថេរៈបានឮសំឡេងអំបោសរបស់នាង និងឃើញពន្លឺអំពីសរីរៈចាំងចូលទៅតាមរន្ធកន្ទុយ ទើបបើកទ្វារចេញមកសួរថា អ្នកណាបោស នាងឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំជាឧបដ្ឋាយិការបស់លោកម្ចាស់ឈ្មោះលាជទេពធីតា ព្រះថេរៈឆ្លើយថា ឧបដ្ឋាយិការបស់អាត្មាឈ្មោះយ៉ាងនេះដូចជាមិនមាន ។ នាងឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំយាមស្រូវប្រគេនលាជហើយ មានចិត្តជ្រះថ្លា កំពុងត្រឡប់ទៅត្រូវពស់ចឹក ធ្វើកាលកិរិយាហើយកើតក្នុងទេវលោកជាន់តាវត្តិង្ស ខ្ញុំគិតថា សម្បត្តិដែលអញបានព្រោះអាស្រ័យលោកម្ចាស់ ឥឡូវនេះ អញនឹងធ្វើវត្តដល់លោក ធ្វើសម្បត្តិឲ្យស្ថិតស្ថេរទើបមក ព្រះថេរៈពោលថា មរ្យាលមិញក្តី មរ្យាលម៉្លេះក្តី នាងបោសទីនេះ ហើយ

តម្កល់ទឹកធាន់ ទឹកប្រើប្រាស់ឬ នាងពោលថា បពិត្រលោកម្ចាស់ យ៉ាងនោះ ឯង ព្រះថេរៈពោលថា នែទេពធីតា ចូរចៀសចេញទៅ វត្តដែលនាងធ្វើ ហើយ ក៏ធ្វើហើយចុះ តាំងអំពីនេះទៅ នាងកុំមកទីនេះ ទេពធីតាពោលថា បពិត្រលោកម្ចាស់ កុំឲ្យខ្ញុំវិនាសឡើយ សូមលោកម្ចាស់ឲ្យខ្ញុំធ្វើវត្តជល់ លោកម្ចាស់ ធ្វើសម្បត្តិរបស់ខ្ញុំឲ្យមាំទាំចុះ ព្រះថេរៈពោលថា នែទេពធីតា ចូរចៀសចេញទៅ នាងកុំធ្វើឲ្យអាត្មាត្រូវធម្មកថិកទាំងឡាយ អង្គុយចាប់ផ្ចិត ដ៏វិចិត្រ ពោលក្នុងអនាគតថា បានឮថា ទេពធីតាមួយរូប មកធ្វើវត្តបដិបត្តិ ចូលទៅតម្កល់ទឹកធាន់ ទឹកប្រើប្រាស់ដើម្បីព្រះមហាកស្សបត្ថេរ តាំងអំពី នេះទៅ នាងកុំមកក្នុងទីនេះឡើយ ចូរត្រឡប់ទៅចុះ ទើបនាងអង្វរដដែល ទៀតថា សូមលោកម្ចាស់ កុំឲ្យខ្ញុំវិនាសឡើយ ។

ព្រះថេរៈគិតថា ទេពធីតានេះមិនស្តាប់ពាក្យរបស់អញ ទើបទះដៃដោយ ពោលថា នាងមិនស្គាល់ប្រមាណ ។ នាងមិនអាចតាំងនៅក្នុងទីនោះបាន ភួត ឡើងទៅក្នុងអាកាស ផ្គងអញ្ជលីទ្រហោយំក្នុងអាកាសថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំឲ្យសម្បត្តិរបស់ខ្ញុំវិនាសឡើយ សូមឲ្យខ្ញុំធ្វើឲ្យមាំទាំចុះ ។

ព្រះសាស្តាប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ស្តាប់សំឡេងទេពធីតា នោះយំ ទ្រង់ផ្សាយព្រះរស្មីដូចប្រថាប់គង់ក្នុងទីចំពោះមុខទេពធីតានោះ ត្រាស់ ថា ម្នាលទេពធីតា ការធ្វើសំវរៈនោះឯង ជាការៈរបស់កស្សបបុត្រតថាគត តែការកំណត់ថា នេះជាប្រយោជន៍របស់អញ ហើយបំណងធ្វើតែបុណ្យ រមែង ជាការៈរបស់អ្នកមានសេចក្តីត្រូវការដោយបុណ្យ ព្រោះថា ការធ្វើបុណ្យ ជា

ហេតុឲ្យកើតសុខតែម្យ៉ាង ទាំងក្នុងភពនេះ ទាំងក្នុងភពខាងមុខ ដូច្នេះ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ
តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ ។

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឲ្យរឿយៗ គួរធ្វើសេចក្តីពេញចិត្តក្នុងបុណ្យនោះ (ព្រោះថា) ការសន្សំបុណ្យតែងនាំសេចក្តីសុខមកឲ្យ ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា បើបុរសគប្បីធ្វើបុណ្យសោត មិនគប្បីវៀរដោយយល់ថា អញធ្វើបុណ្យម្តងហើយ គ្រប់គ្រាន់ដោយបុណ្យត្រឹមប៉ុណ្ណេះ គប្បីធ្វើរឿយៗ ក្នុងខណៈធ្វើបុណ្យនោះ គប្បីធ្វើការពេញចិត្ត គឺការគាប់ចិត្តបានដល់ ការឧស្សាហ៍ក្នុងបុណ្យនោះឯង សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះការសន្សំបុណ្យនាំឲ្យកើតសុខ អធិប្បាយថា ព្រោះការសន្សំ គឺការប្រមូលនូវបុណ្យ ឈ្មោះថា ញ៉ាំងសេចក្តីសុខឲ្យកើត ព្រោះជាហេតុនាំសេចក្តីសុខមកឲ្យ ក្នុងលោកនេះ និងលោកខាងមុខ ។

ក្នុងកាលចប់ទេសនា នាងលាជទេពធីតានោះឈរក្នុងទីបំផុត ៤៥ យោជន៍នោះឯង បានសម្រេចសោតាបត្តិផលហើយដូច្នេះឯង ។

រឿង នាងលាជទេពធីតា ចប់

រឿង អនាថបិណ្ឌិកសេដ្ឋី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះអនាថបិណ្ឌិក ត្រាស់ព្រះធម្មទេសនានេះថា **ចាចោបិ បស្សតិ ភទ្រំ** ជាដើម ។

សេចក្តីពិស្តារថា អនាថបិណ្ឌិកសេដ្ឋីចំណាយទ្រព្យ ៥៤ កោដិក្នុងព្រះពុទ្ធសាសនាចំពោះវិហារប៉ុណ្ណោះ កាលព្រះសាស្តាប្រថាប់នៅក្នុងវត្តជេតពន ទៅកាន់ទីទំនុកបម្រុងធំ ៣ កន្លែងរាល់ថ្ងៃ កាលនឹងទៅ គិតថា សាមណេរក្តី ភិក្ខុកំលោះក្តី គប្បីសម្លឹងមើលដៃរបស់អញដោយការនឹកថា សេដ្ឋីនោះកាន់អ្វីមកខ្លះដូច្នេះ មិនធ្លាប់ជាអ្នកមានដៃទទេទៅឡើយ ទៅក្នុងពេលព្រឹកឲ្យមនុស្សកាន់បបរទៅ បរិភោគអាហារព្រឹកហើយ ឲ្យមនុស្សកាន់ភេសជ្ជៈទាំងឡាយមានសប្បិ នវនីតជាដើមទៅ ក្នុងពេលល្ងាច បានកាន់វត្ថុផ្សេងៗ មានកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប និងសំពត់ជាដើមទៅកាន់វិហារ ថ្វាយទានរក្សាសីលយ៉ាងនេះ រាល់ៗ ថ្ងៃអ សប់កាលជានិច្ច ។

សម័យតមក សេដ្ឋីដល់នូវការអស់ទៅនៃទ្រព្យ ទាំងពួកពាណិជ ក៏ខ្ចីទ្រព្យ ១៨ កោដិ អំពីដៃសេដ្ឋីនោះ ។ ប្រាក់ ១៨ កោដិ ជាសម្បត្តិនៃត្រកូលរបស់សេដ្ឋី ដែលកប់ក្បែរមាត់ស៊ឹង កាលប្រាំងបាក់ព្រោះទឹកប្រោះក៏ហូរទៅកាន់មហាសមុទ្រ ទ្រព្យរបស់សេដ្ឋីនោះ ដល់នូវការអស់ទៅដោយលំដាប់ ដោយប្រការយ៉ាងនេះ ។

សេដ្ឋីសូម្បីខ្លួនយ៉ាងនោះហើយ ក៏នៅតែថ្វាយទាន ដល់សង្ឃរឿយៗ

ទៅ តែមិនអាចធ្វើឲ្យប្រណីតបាន ។ ក្នុងថ្ងៃមួយ សេដ្ឋី កាលព្រះសាស្តា
ត្រាស់ថា ម្នាលគហបតី ទានក្នុងត្រកូលអ្នកនៅតែឲ្យឬ ក៏ក្រាបទូលថា
បពិត្រព្រះអង្គ ទានក្នុងត្រកូលខ្ញុំព្រះអង្គ នៅតែឲ្យ តែទាននោះ ជាបាយចុង
អង្ករ មានទឹកជ្រក់ជាគម្រប់ពីរ ។

ពេលនោះ ព្រះសាស្តាត្រាស់នឹងសេដ្ឋីនោះថា ម្នាលគហបតី អ្នកកុំគិត
ថា អញឲ្យទានសៅហ្មងឡើយ ព្រោះថា កាលចិត្តប្រណីតហើយ ទាន
ដែលបុគ្គលថ្វាយដល់ព្រះអរហន្តទាំងឡាយ មានព្រះពុទ្ធជាដើម ឈ្មោះថា
សៅហ្មង រមែងមិនមាន ម្នាលគហបតី ម្យ៉ាងទៀត អ្នកបានថ្វាយទានដល់
ព្រះអរិយបុគ្គលទាំង ៨ ហើយ ចំណែកតថាគត ក្នុងកាលនៅជាវេលាម-
ព្រាហ្មណ៍នោះ ធ្វើអ្នកជម្ពូទ្វីបទាំងមូលឲ្យឈប់ភ្លូវស្រែ ញ៉ាំងមហាទានឲ្យ
ប្រព្រឹត្តទៅមិនបានទក្ខិណេយ្យបុគ្គលណាម្នាក់ សូម្បីជាអ្នកដល់នូវត្រៃសរណៈ
ឈ្មោះថា ទក្ខិណេយ្យបុគ្គលទាំងឡាយ លំបាកដែលបុគ្គលបាន ដោយប្រការ
ដូច្នេះ ព្រោះហេតុនោះ អ្នកកុំគិតឡើយថា ទានរបស់អញសៅហ្មង ដូច្នេះ
ហើយត្រាស់វេលាមសូត្រ ជល់សេដ្ឋីនោះ ។

គ្រានោះ ទេវតាដែលស្ថិតនៅត្រង់ខ្ញោងទ្វាររបស់សេដ្ឋី កាលព្រះ
សាស្តា និងសាវ័កទាំងឡាយចូលទៅកាន់ផ្ទះ មិនអាចតាំងនៅបាន ព្រោះ
តេជៈព្រះដ៏មានព្រះភាគ និងសាវ័កទាំងនោះ គិតថា ព្រះសាស្តា និងសាវ័ក
ទាំងនេះ មិនចូលទៅកាន់ផ្ទះដោយប្រការណា អញនឹងញុះញង់គហបតីដោយ
ប្រការនោះ ច្រាច្នានឹងពោលជាមួយសេដ្ឋីនោះ ក៏មិនបានដើម្បីពោលនូវពាក្យ

ណាមួយ ក្នុងកាលដែលសេដ្ឋីជាឥស្សរៈ គិតថា ឥឡូវនេះ សេដ្ឋីនេះក្រីក្រ ហើយ គង់នឹងជឿពាក្យរបស់អញ ក្នុងពេលរាត្រី ចូលទៅកាន់បន្ទប់ដែលជាសិរីរបស់សេដ្ឋី ឈរនៅក្នុងអាកាស ។ ខណៈនោះ សេដ្ឋីឃើញទេវតានោះហើយ សួរថា នុ៎ះជាអ្នកណា ទេវតាពោលថា លោកមហាសេដ្ឋី ខ្ញុំជាទេវតាអាស្រ័យនៅត្រង់ខ្ងោងទ្វារទី ៤ របស់អ្នក មកដើម្បីជាស់តឿនអ្នក សេដ្ឋីពោលថា បើដូច្នោះ សូមអ្នកនិយាយចុះ ទេវតាពោលថា លោកសេដ្ឋី លោកមិនសម្លឹងមើលដល់កាលខាងក្រោយទេឬយ ចាយទ្រព្យជាច្រើន ក្នុងសាសនារបស់ព្រះសមណគោតម ឥឡូវនេះ លោកជាអ្នកក្រីក្រហើយ ក៏នៅតែមិនលះបង់ការចាយទ្រព្យទៀត កាលលោកប្រព្រឹត្តយ៉ាងនេះ នឹងមិនបានវត្ថុត្រឹមតែអាហារ និងគ្រឿងស្លៀកដណ្តប់ត្រឹម ២-៣ ថ្ងៃពិត លោកត្រូវការអ្វី ដោយព្រះសមណគោតម សូមលោកឈប់បរិច្ចាគហួសកម្លាំង ហើយប្រកបការងារទាំងឡាយ ប្រមូលសម្បត្តិចុះ សេដ្ឋីពោលថា នេះជាឱវាទដែលអ្នកឲ្យដល់ខ្ញុំឬ ទេវតាពោលថា អើ លោកមហាសេដ្ឋី សេដ្ឋីពោលថា សូមអ្នកទៅចុះ បុគ្គលដូចអ្នករាប់រយ រាប់ពាន់ រាប់សែន ក៏មិនអាចធ្វើខ្ញុំឲ្យញាប់ញ័របាន អ្នកពោលពាក្យមិនសមគួរ នឹងត្រូវការអ្វី ដោយអ្នកដែលនៅក្នុងផ្ទះរបស់ខ្ញុំ ចូរអ្នកចេញអំពីផ្ទះរបស់ខ្ញុំឲ្យរហ័ស ។

ទេវតានោះ ស្តាប់ពាក្យរបស់សេដ្ឋី ដែលជាសោតាបន្នអរិយសាវក ហើយ មិនអាចស្ថិតនៅបាន ទើបនាំទារកទាំងឡាយចេញទៅ កាលចេញទៅហើយ មិនបានទីលំនៅក្នុងទីដទៃ ទើបគិតថា អញនឹងឲ្យលោកសេដ្ឋីអត់ទោស

ហើយនៅក្នុងកន្លែងដើមនោះឯង ចូលទៅរកទេវបុត្រអ្នករក្សាព្រះនគរ ច្រាប់នូវកំហុស ដែលខ្លួនធ្វើហើយ ពោលថា សូមអ្នកមកចុះ សូមអ្នកនាំខ្ញុំទៅកាន់សម្នាក់របស់សេដ្ឋី ឲ្យលោកសេដ្ឋីអត់ទោស ហើយឲ្យទីលំនៅដល់ខ្ញុំ ទេវបុត្រឃាត់ទេវតានោះថា អ្នកធ្វើមិនសមគួរ ខ្ញុំមិនអាចទៅកាន់សម្នាក់របស់សេដ្ឋីនោះបាន ។ ទើបទេវតានោះចូលទៅកាន់សម្នាក់របស់មហារាជទាំង ៤ ក៏ត្រូវមហារាជទាំងនោះឃាត់ ទើបចូលទៅកាន់សម្នាក់សក្កទេវរាជ ក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាបហើយ ទូលអង្វរដ៏គួរឲ្យអាណិតថា បពិត្រព្រះអង្គ ទូលបង្គំមិនបានទីលំនៅ ត្រូវដីកដៃទាវកទាំងឡាយ ដើរក្នុងទីផ្សេងៗ រកទីពឹងមិនបាន សូមទ្រង់ឲ្យសេដ្ឋីឲ្យនូវទីលំនៅ ដល់ទូលបង្គំចុះ ។

គ្រានោះ សក្កទេវរាជត្រាស់នឹងទេវតានោះថា ខ្ញុំមិនអាចពោលនឹងសេដ្ឋី ព្រោះហេតុនៃអ្នកបាន តែនឹងប្រាប់ឧបាយមួយដល់អ្នក ទេវតាពោលថា សាធុ ព្រះអង្គ សូមទ្រង់មេត្តាប្រាប់ចុះ សក្កទេវរាជពោលថា ចូរអ្នកទៅចុះ កាឡាខ្លួនជាស្មៀនរបស់សេដ្ឋី ឲ្យបុគ្គលណាម្នាក់នាំបញ្ជីអំពីដៃសេដ្ឋីមកហើយ នាំទៅឲ្យអ្នកជំពាក់បំណុលសងទ្រព្យ ១៨ កោដិ ដែលពួកឈ្មួញកាន់យកទៅ ដោយអានុភាពរបស់ខ្លួនហើយ ជាក់ឲ្យពេញក្នុងបន្ទប់ទេ ទ្រព្យ ១៨ កោដិ ដែលហូរទៅកាន់មហាសមុទ្រក្តី ទ្រព្យ ១៨ កោដិដទៃដែលមិនមានម្ចាស់ នៅក្នុងទីឈ្មោះនោះក្តី ចូរប្រមូលទ្រព្យទាំងអស់នោះ ជាក់ឲ្យពេញក្នុងបន្ទប់ទេរបស់សេដ្ឋី កាលធ្វើកម្មឈ្មោះនេះ ឲ្យជាទណ្ឌកម្មហើយ សឹមសូមខមាទោសនឹងលោកសេដ្ឋី ។

ទេវតានោះទទួលថា សាធុព្រះអង្គ ហើយធ្វើកម្មគ្រប់យ៉ាងតាមន័យដែល សក្កទេវរាជប្រាប់ហើយនោះឯង ញាំងបន្ទប់ដែលជាសិរីរបស់សេដ្ឋីឲ្យភ្លឺ តាំងនៅក្នុងអាកាស កាលលោកសេដ្ឋីពោលថា នុ៎ះជាអ្នកណា ទើបឆ្លើយថា ខ្ញុំជាទេវតាអន្ធពាល ស្ថិតនៅត្រង់ខ្ងោងទ្វារទី ៤ របស់លោក ពាក្យណាដែលខ្ញុំពោលហើយ ក្នុងសម្នាក់របស់លោក ដោយភាពជាអន្ធពាល សូមលោកអត់ទោសនោះដល់ខ្ញុំចុះ ខ្ញុំបានធ្វើទណ្ឌកម្មដោយការប្រមូលទ្រព្យ ៥៤ កោដិមកជាក់ពេញបន្ទប់ទេ តាមបញ្ជារបស់សក្កទេវរាជ ខ្ញុំមិនមានទីលំនៅរមែងលំបាក ។

អនាថបិណ្ឌិកសេដ្ឋី ចិន្តនាការថា ទេវតានេះពោលថា ទណ្ឌកម្មខ្ញុំបានធ្វើហើយដូច្នេះ នឹងដឹងនូវទោសរបស់ខ្លួន អញនឹងបង្ហាញទេវតានោះដល់ព្រះសម្មាសម្ពុទ្ធ លោកសេដ្ឋីនាំទេវតានោះទៅកាន់សម្នាក់របស់ព្រះសាស្តា ក្រាបទូលកម្មដែលទេវតានោះធ្វើហើយទាំងអស់ ទេវតាក្រាបចុះដោយសិរសា គឺត្បូង ទៀបព្រះឃុគលបាទនៃព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនជ្រាបព្រះគុណទាំងឡាយរបស់ទ្រង់ បានពោលពាក្យប៉ោកទាបព្រោះភាពជាអន្ធពាល សូមទ្រង់អត់ទោសនូវពាក្យនោះដល់ខ្ញុំព្រះអង្គ បានឲ្យព្រះសាស្តាអត់ទោសហើយ ទើបឲ្យមហាសេដ្ឋីអត់ទោសឲ្យ ក្នុងកាលជាក្រោយ ។

ព្រះសាស្តា កាលទ្រង់ទូន្មានសេដ្ឋី និងទេវតា ដោយអំណាចវិបាកនៃកម្មល្អ និងកម្មអាក្រក់នោះឯង ទើបត្រាស់ថា ម្នាលគហបតី បុគ្គលអ្នកធ្វើ

ចុទ្ទស ក្នុងលោកនេះ រមែងឃើញចុទ្ទស ថាល្អ អស់កាលដែលចុទ្ទសមិនទាន់ឲ្យផល តែកាលណា ចុទ្ទសរបស់បុគ្គលនោះឲ្យផល កាលនោះ បុគ្គលនោះ ឃើញនូវចុទ្ទសថា អាក្រក់ពិតៗ ចំណែកបគ្គលអ្នកធ្វើកម្មល្អ រមែងឃើញកម្មល្អថា អាក្រក់ ដរាបណាដែលកម្មល្អមិនទាន់ឲ្យផល តែកាលណា កម្មល្អរបស់បុគ្គលនោះឲ្យផល កាលនោះ បុគ្គលនោះ រមែងឃើញកម្មល្អថា ល្អពិតៗ ដូច្នេះហើយ កាលទ្រង់បន្តអានុសន្ធិសម្តែងធម៌ ទើបភាសិតព្រះគាថានេះថាទុកថា

ចាចោបិ បស្សតី ភទ្រំ យាវ ចាបំ ន បច្ចតិ
យទា ច បច្ចតី ចាបំ អថ (ចាចោ) ចាចានិ បស្សតិ ។
ភទ្រោបិ បស្សតី ចាបំ យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតី ភទ្រំ អថ (ភទ្រោ) ភទ្រានិ បស្សតិ ។

ចុទ្ទសមិនទាន់ឲ្យផលត្រឹមណា មនុស្សចុទ្ទស ក៏នៅឃើញតែសេចក្តីចម្រើនត្រឹមណោះ លុះកាលណា ចុទ្ទសឲ្យផលមនុស្សចុទ្ទស ទើបឃើញចុទ្ទសក្នុងកាលនោះ ។

អំពើល្អ មិនទាន់ឲ្យផលត្រឹមណា មនុស្សល្អ នៅឃើញតែចុទ្ទសត្រឹមណោះ លុះកាលណា អំពើល្អឲ្យផល មនុស្សល្អ ទើបឃើញល្អ ក្នុងកាលនោះ ។

សេចក្តីអធិប្បាយ

បុគ្គលដែលប្រកបចុទ្ទសកម្ម មានកាយទុច្ចរិតជាដើម ឈ្មោះថា បុគ្គល

បាប ក្នុងព្រះគាថានេះ ។

បុគ្គលនោះ កាលសោយសុខ ដែលកើតឡើងដោយអានុភាពនៃសុចរិតកម្មក្នុងកាលមុន រមែងឃើញបាបកម្មថា ល្អ ។

បាទព្រះគាថាថា **យាវ ចាបំ ន បច្ចតិ** *ជាដើម សេចក្តីថា បាបកម្មរបស់បុគ្គលនោះ មិនទាន់ឲ្យផលក្នុងបច្ចុប្បន្នភព ឬសម្បរាយភពជាបណា បុគ្គលធ្វើបាប រមែងឃើញបាបថាល្អជារបនោះ តែកាលបាបកម្មរបស់បុគ្គលនោះឲ្យផលក្នុងបច្ចុប្បន្នភព ឬក្នុងសម្បរាយភព កាលនោះ អ្នកធ្វើបាបនោះ កាលសោយកម្មករណៈផ្សេងៗ ក្នុងបច្ចុប្បន្នភព និងទុក្ខក្នុងអបាយ ក្នុងសម្បរាយភព រមែងឃើញបាបថា អាក្រក់ ដោយចំណែកមួយ ។*

ក្នុងព្រះគាថាទី ២ គប្បីជ្រាបសេចក្តីដូចតទៅនេះ បុគ្គលដែលប្រកបកម្ម ដែលមានកាយសុចរិតជាដើម ឈ្មោះថា អ្នកធ្វើកម្មល្អ បុគ្គលធ្វើកម្មល្អនោះ កាលសោយទុក្ខដែលកើតឡើង ដោយអានុភាពនៃទុច្ចរិតក្នុងកាលមុន រមែងឃើញកម្មល្អថា អាក្រក់ ។

បាទព្រះគាថាថា **យាវ ភទ្រំ ន បច្ចតិ** *ជាដើម សេចក្តីថា កម្មល្អរបស់បុគ្គលនោះ មិនទាន់ឲ្យផលក្នុងបច្ចុប្បន្នភព ឬក្នុងសម្បរាយភពជារបណា ។ បុគ្គលធ្វើកម្មល្អ រមែងឃើញល្អថា អាក្រក់ជារបនោះ តែកាលណាកម្មល្អនោះឲ្យផល កាលនោះ អ្នកធ្វើកម្មល្អនោះ កាលសោយសុខដែលអាស្រ័យអាមិស មានលាភ និងសក្ការៈជាដើមក្នុងបច្ចុប្បន្នភព និងសុខដែលអាស្រ័យសម្បត្តិ ដែលជាទិព្វក្នុងសម្បរាយភព រមែងឃើញកម្មល្អ ថាល្អ*

ពិតៗ ដូច្នេះ ។

ក្នុងកាលចប់ទេសនា ទេវតានោះ តាំងនៅក្នុងសោតាបត្តិផល ព្រះធម្មទេសនា មានប្រយោជន៍ដល់បរិស័ទដែលមកប្រជុំគ្នា ដូច្នេះឯង ។

រឿង អនាថបិណ្ឌិកសេដ្ឋី ចប់

រឿង ភិក្ខុមិនទុកជាក់បរិក្ខារ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ដែលមិនទុកជាក់បរិក្ខារ ត្រាស់ព្រះធម្មទេសនានេះថា **មាវមញ្ញេថ ចាបស្ស** *ជាដើម ។*

បានឮថា ភិក្ខុនោះប្រើប្រាស់បរិក្ខារ មានត្រៃ និងតាំងជាដើមឯណានីមួយខាងក្រៅហើយ ទុកចោលក្នុងទីនោះឯង បរិក្ខារមែងវិនាសទៅ ព្រោះភ្លៀងខ្លះ កម្តៅថ្ងៃខ្លះ ពួកសត្វ មានកណ្តៀរជាដើមខ្លះ ។ ភិក្ខុនោះ កាលពួកភិក្ខុពោលជាស់តឿនថា អាវុសោ ធម្មតាបរិក្ខារ ភិក្ខុគួរទុកជាក់ មិនមែនឬ បែរជាពោលថា អាវុសោ កម្មដែលខ្ញុំធ្វើនោះតូចតាច បរិក្ខារនោះមិនមានចិត្តការវិចិត្រក៏មិនមាន ដូច្នេះហើយ នៅតែធ្វើយ៉ាងនោះដដែល ។ ភិក្ខុទាំងឡាយក្រាបទូលកិរិយារបស់លោកដល់ព្រះសាស្តា ។

ព្រះសាស្តាត្រាស់ឲ្យហៅភិក្ខុនោះមកហើយ ត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកធ្វើយ៉ាងនោះពិតឬ ភិក្ខុនោះត្រូវព្រះសាស្តាត្រាស់សួរហើយ ក៏ក្រាបទូលបែបមើលងាយយ៉ាងនោះឯងថា បពិត្រព្រះមានព្រះភាគ សេចក្តីនោះមានជាការអ្វី ខ្ញុំព្រះអង្គធ្វើកម្មតិចតួច បរិក្ខារនោះមិនមានចិត្ត ការវិចិត្រក៏មិនមាន ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ អ្នកធ្វើយ៉ាងនោះមិនគួរ ឈ្មោះថា បាបកម្ម បុគ្គលមិនគួរមើលងាយថា តិចតួច ឧបមាដូចភាជនៈ ដែលគេបើកគម្របទុកក្នុងទីវាល កាលភ្លៀងធ្លាក់ចុះ មិនពេញដោយតំណក់ទឹកដោយពិត តែកាលភ្លៀងធ្លាក់រឿយៗ ភាជនៈនោះរមែងពេញបានពិត យ៉ាងណា បុគ្គលដែលធ្វើបាបកម្ម រមែងធ្វើគំនរបាបឲ្យធំទ្បើងដោយលំដាប់បានដោយពិត ក៏ដូច្នោះដូចគ្នា ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

មាវមញ្ញេថ បាបស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
អាបូរតិ ពាលោ បាបស្ស ថោកំ ថោកំបិ អាចិនំ ។

បុគ្គល មិនគួរមើលងាយបាប ថាមានប្រមាណតិច នឹងមិនឲ្យផលដូច្នេះទ្បើយ ប្រៀបដូចភ្នមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា បុគ្គលពាលកាលសន្សំបាប សូម្បីបន្តិចម្តងៗ គង់ពេញបានដោយបាប យ៉ាងនោះដែរ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មាវមញ្ញេថ** *សេចក្តីថា បុគ្គលមិនគួរមើលងាយ ។ បទថា* **ចាបស្ស** *ប្រែថា នូវបាប ។ បានព្រះគាថាថា* **ន មត្តំ អាគមិស្សតិ** *សេចក្តីថា បុគ្គលមិនគួរមើលងាយបាបយ៉ាងនេះថា អញធ្វើបាបមានប្រមាណតិច ធ្វើម្តេចបាបនោះនឹងឲ្យផល ។*

បទថា **ឧទកុម្ភោបិ** *សេចក្តីថា ភាជន:ដីប្រភេទណាមួយ ដែលគេបើកមាត់ដាក់ក្នុងទីដែលភ្លៀងធ្លាក់ រមែងពេញដោយតំណក់ទឹក ដែលធ្លាក់ចុះម្តងមួយតំណក់ៗ ដោយលំដាប់បាន យ៉ាងណា ។ បុគ្គលល្ងង់ខ្លៅ កាលសន្សំ គឺចម្រើននូវបាបសូម្បីតិចតួច តែងពេញដោយបាបបានដូច្នោះដូចគ្នា ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ភិក្ខុណាមួយ លាត ឬសន្ធឹងខ្លួនឯងក្តី ឲ្យគេលាតក្តី នូវគ្រែក្តី តាំងក្តី ពូកក្តី កៅអីក្តី ដែលជារបស់សង្ឃក្នុងទីវាល ហើយកាលនឹងដើរចេញទៅមិនបានរើយកគ្រឿងសេនាសន: មានគ្រែជាដើមនោះ មកទុកជាក់ឯង មិនបានប្រើគេឲ្យរើសយកមកទុកជាក់ ហើយឥតបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ: ៗ

រឿង ភិក្ខុមិនទុកជាក់បរិក្ខារ ចប់

រឿង សេដ្ឋី ឈ្មោះ ពិឡាលបទកៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះ ពិឡាលបទកៈ គឺសេដ្ឋីជើងឆ្មា ត្រាស់ព្រះធម្មទេសនានេះថា **មាវមញ្ញេថ បុញ្ញស្ស** *ជាដើម ។*

សេចក្តីពិស្តារថា សម័យមួយ អ្នកក្រុងសាវត្ថីនាំគ្នាថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយទាក់ទងជាពួកតែមួយ ។ ថ្ងៃមួយ ព្រះសាស្តា កាលទ្រង់ធ្វើអនុមោទនាត្រាស់យ៉ាងនេះថា ម្នាលឧបាសក ឧបាសិកាទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទានដោយខ្លួនឯង តែមិនដឹកនាំអ្នកដទៃ បុគ្គលនោះ រមែងបានទូវកោគសម្បត្តិ តែមិនបានបរិវារសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ បុគ្គលពួកខ្លះ មិនឲ្យទានដោយខ្លួនឯង បបួលតែអ្នកដទៃ បុគ្គលនោះ រមែងបានបរិវារសម្បត្តិ តែមិនបានកោគសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ បុគ្គលពួកខ្លះ មិនឲ្យទានដោយខ្លួនឯងផង មិនបបួលអ្នកដទៃផង បុគ្គលនោះ រមែងមិនបានកោគសម្បត្តិ មិនបានបរិវារសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ ក្លាយជាបុគ្គលស៊ីដែល ។ បុគ្គលពួកខ្លះ ឲ្យទានដោយខ្លួនឯងផង បបួលអ្នកដទៃផង បុគ្គលនោះ រមែងបានទូវកោគសម្បត្តិផង បរិវារសម្បត្តិផង ក្នុងទីដែលខ្លួនកើតហើយ ។

គ្រានោះ បណ្ឌិតបុរសម្នាក់ស្តាប់ធម្មទេសនានោះហើយគិតថា ឱ ហេតុនេះគួរអស្ចារ្យ ឥឡូវនេះ អញនឹងធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីសម្បត្តិទាំងពីរ

ទើបក្រាបទូលព្រះសាស្តាក្នុងកាលទ្រង់ក្រោកទៅថា បពិត្រព្រះអង្គ ស្អែកនេះ សូមទ្រង់ទទួលភិក្ខាវបស់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា អ្នកត្រូវការភិក្ខុប៉ុន្មាន បុរសនោះទូលថា បពិត្រព្រះអង្គ ភិក្ខុទាំងអស់ ។

ព្រះសាស្តាទ្រង់ទទួលហើយ បុរសនោះក៏ទៅកាន់ផ្ទះ ត្រាច់ប្រកាសថា បពិត្រអ្នកម្តាយ និងលោកឪពុកទាំងឡាយ ខ្ញុំនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដើម្បីឆាន់ភត្តាហារក្នុងថ្ងៃស្អែក ។ បុគ្គលណាអាចប្រគេនដល់ភិក្ខុទាំងឡាយមានប្រមាណប៉ុនណា បុគ្គលនោះ ចូរឲ្យវត្ថុផ្សេងៗ មានអង្ករជាដើម ដើម្បីជាប្រយោជន៍ដល់អាហារ មានយាគូជាដើម ដើម្បីភិក្ខុទាំងឡាយ មានប្រមាណប៉ុណ្ណោះ ពួកយើងនឹងឲ្យចម្អិនក្នុងទីតែមួយ ហើយថ្វាយទាន ។

ពេលនោះ សេដ្ឋីម្នាក់ ឃើញបុរសនោះមកដល់វានផ្សារបស់ខ្លួន ក៏ខឹងសម្បាថា បុរសនេះមិននិមន្តភិក្ខុឲ្យល្មមកម្ចាំងរបស់ខ្លួន ចាំបាច់ដើរមកបបួលអ្នកស្រុកទាំងអស់ទៀត ទើបប្រាប់ថា ឯងចូរនាំយកភាជន:ដែលឯងកាន់មកដួចេះហើយ យកម្រាមដៃ ៣ ច្បិចអង្ករបន្តិច សណ្តែកបាយបន្តិច សណ្តែកពាជមាសក៏ដួចគ្នាហើយឲ្យ ។ តាំងអំពីនោះ ទើបសេដ្ឋីនោះឈ្មោះថា ពិឡាលបទកសេដ្ឋី កាលឲ្យភេសជ្ជ: មានសប្បិ និងទឹកអំពៅជាដើម ក៏ផ្សៀងមាត់ជបចូលត្រង់ឆ្នាំង ធ្វើឲ្យមាត់ជបនោះជាប់ជាមួយគ្នា ឲ្យភេសជ្ជ: មានសប្បិ និងទឹកអំពៅជាដើម ហូរចូលមួយតំណក់ៗ បានឲ្យបន្តិចប៉ុណ្ណោះ ។

ឧបាសកធ្វើវត្តុទាន ដែលអ្នកជនៃឲ្យរួមគ្នា តែបានកាន់យកវត្តុដែលសេដ្ឋីនេះឲ្យទុកដោយឡែក ។ សេដ្ឋីនោះ ឃើញកិរិយារបស់បុរសនោះហើយ

គិតថា ហេតុអ្វីហ្ន៎ ទើបបុរសនេះទទួលរបស់អញឲ្យ ទុកដោយឡែក ទើប បញ្ជូនចូទ្បុប្បជ្ជាកម្នាក់ ទៅអំពីក្រោយប្រាប់ថា ចូរអ្នកទៅ ចូរដឹងកម្មដែល បុរសនោះធ្វើ ។ ឧបាសកនោះទៅហើយពោលថា សូមឲ្យផលធំមានដល់សេដ្ឋី ដូច្នេះហើយ ជាក់អង្ករមួយ ឬពីរគ្រាប់ ដើម្បីប្រយោជន៍ដល់បបរ ភត្ត និងនំ ជាក់សណ្តែកបាយ សណ្តែកវាជមាសខ្លះ បន្តក់ប្រេង និងទឹកអំពៅជាដើមខ្លះ ចូលក្នុងកាជនៈ គ្រប់ៗ កាជនៈ ចូទ្បុប្បជ្ជាកទៅប្រាប់ដល់សេដ្ឋីនោះហើយ សេដ្ឋីស្តាប់ពាក្យនោះហើយ គិតថា បើបុរសនោះ ពោលទោសរបស់អញ ក្នុងបរិស័ទសោត គ្រាន់តែវាចេញឈ្មោះអញប៉ុណ្ណោះ អញនឹងប្រហារវាឲ្យ ស្លាប់ ។ ក្នុងថ្ងៃស្អែកឡើង ទើបលាក់អាវុធក្នុងរវាងសំពត់ស្ទៀក បានទៅ ឈរត្រង់រោងចុងភៅ ។ បុរសនោះអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយក្រាបទូលដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គបបួល មហាជនថ្វាយទាននេះ ពួកមនុស្សដែលខ្ញុំព្រះអង្គបបួលហើយក្នុងទីនោះ បាន ឲ្យអង្ករជាដើមច្រើនខ្លះ តិចខ្លះ តាមកម្លាំងរបស់ខ្លួន សូមផលដ៏វិសាល មានដល់មហាជនទាំងអស់នោះ ។

សេដ្ឋីបានឮពាក្យនោះហើយគិតថា អញមកដោយតាំងចិត្តថា គ្រាន់តែ វាចេញឈ្មោះរបស់អញឡើងថា សេដ្ឋីឈ្មោះនោះ យកអង្ករជាដើមច្បិចដោយ ម្រាមដៃឲ្យ អញនឹងសម្លាប់បុរសនេះឲ្យស្លាប់ តែបុរសនេះធ្វើទានឲ្យរួមគ្នាទាំង អស់ ហើយពោលថា ទានដែលជនពួកណាវាល់ដោយនាឡិជាដើមហើយឲ្យ ក្តី ទានដែលជនពួកណា កាន់យកដោយច្បិចដោយម្រាមដៃហើយឲ្យក្តី សូម

ផលដ៏វិសាលមានដល់ជនទាំងអស់នោះ បើអញមិនឲ្យបុរសបែបនេះអត់ទោស សោត អាជ្ញារបស់ព្រះម្ចាស់សួគ៌ នឹងធ្លាក់លើអំបែងក្បាលអញ សេដ្ឋីនោះ ក្រាបចុះទៀបបាតជើងរបស់ឧបាសកនោះហើយ ពោលថា នែអ្នក សូមអ្នក អត់ទោសឲ្យខ្ញុំផង ត្រូវឧបាសកនោះសួរថា តើមានរឿងអ្វី ទើបប្រាប់រឿងទាំងអស់នោះ ។

ព្រះសាស្តាទ្រង់ឃើញកិរិយានោះហើយ ត្រាស់សួរបុរសដែលខ្វល់ខ្វាយក្នុងទានថា តើមានរឿងអ្វី ទើបបុរសនោះក្រាបទូលរឿងទាំងអស់ ដែលកើតឡើងហើយ ។

ពេលនោះ ព្រះសាស្តាត្រាស់សួរសេដ្ឋីនោះថា បានឮថា សេចក្តីនោះយ៉ាងនេះឬ កាលសេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គយ៉ាងនោះឯង ទើបទ្រង់ត្រាស់ថា ម្នាលឧបាសក ឈ្មោះថា បុណ្យបុគ្គលណាម្នាក់ មិនគួរមើលងាយថា មានប្រមាណតិចតួច កាលបុគ្គលថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធដូចតថាគតជាប្រធានហើយ មិនគួរមើលងាយថាជារបស់តិចតួច ដ្បិតថាបុរសដែលជាបណ្ឌិតធ្វើបុណ្យ រមែងពេញទៅដោយបុណ្យដោយលំដាប់ពិតប្រៀបដូចកាជនៈដែលបើកមាត់ រមែងពេញទៅដោយទឹក ដូច្នោះ ដូច្នេះ ហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
អាបូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។

បុគ្គល មិនគួរមើលងាយបុណ្យ ថាមានប្រមាណតិច នឹងមិនឲ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្តងៗ គង់ពេញបានដោយបុណ្យយ៉ាងនោះ ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា មនុស្សដែលជាបណ្ឌិតធ្វើបុណ្យហើយ កុំមើលងាយ គឺមិនគួរមើលស្រាលបុណ្យយ៉ាងនេះថា អញធ្វើបុណ្យមានប្រមាណតិច បុណ្យមានប្រមាណតិចនឹងមកដល់ ដោយអំណាចនៃវិបាកឡើយ បើយ៉ាងនេះ កម្មតិចតួចនឹងឃើញអញអំពីណា ឬថា អញនឹងឃើញកម្មនោះអំពីណា កាលណាបុណ្យនោះនឹងឲ្យផល ដូចភាជនៈដីដែលបុគ្គលបើកគម្របតម្កល់ទុកចោល រមែងពេញដោយតំណក់ទឹក ដែលស្រក់ចុះមកមិនដាច់ខ្សែបាន យ៉ាងណា ធីរជន គឺបុរសដែលជាបណ្ឌិតកាលសន្សំបុណ្យម្តងបន្តិចៗ ឈ្មោះថា ពេញដោយបុណ្យបាន ដូច្នោះ ។

ក្នុងកាលចប់ទេសនា សេដ្ឋីនោះ បានសម្រេចសោតាបត្តិផលហើយ ព្រះធម្មទេសនាមានប្រយោជន៍ដល់បរិស័ទដែលមកប្រជុំគ្នា ដូច្នេះឯង ។

រឿង សេដ្ឋីឈ្មោះពិឡាលបទកៈ ចប់

រឿង មហាធនពាណិជ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឈ្មួញមានទ្រព្យច្រើន ត្រាស់ព្រះធម្មទេសនានេះថា **វាណិជោ អយំ មគ្គំ** ជាដើម ។

បានឮមកថា ពួកចោរ ៥០០ នាក់ ស្វែងរកឱកាសក្នុងផ្ទះរបស់ឈ្មួញនោះមិនបានហើយ ។ សម័យដទៃ ឈ្មួញនោះ ផ្ទុកទំនិញក្នុងរទេះ ៥០០ ហើយឲ្យប្រាប់ដល់កិក្ខុទាំងឡាយថា ខ្ញុំនឹងទៅកាន់ទីឈ្មោះនោះ ដើម្បីលក់ដូរ លោកម្ចាស់ទាំងឡាយណាចង់ទៅក្នុងទីនោះ សូមនិមន្តលោកម្ចាស់ទាំង-ឡាយនោះទៅចុះ នឹងមិនលំបាកដោយកិក្ខាតាមផ្លូវ កិក្ខុ ៥០០ រូបស្តាប់ពាក្យនោះហើយ បានធ្វើដំណើរទៅជាមួយឈ្មួញនោះ ។ សូម្បីចោរទាំងនោះ ក៏បានដំណឹងថា បានឮថា ឈ្មួញនោះចេញទៅហើយ បានចោះជំរំក្នុងព្រៃ ។

ចំណែកឈ្មួញទៅហើយ កាន់យកទីសម្រាកក្បែរភូមិមួយកន្លែង ត្រង់មាត់ព្រៃ រៀបចំគោ និងរទេះជាដើមអស់ ២-៣ ថ្ងៃ និងប្រគេនកិក្ខា ដល់កិក្ខុទាំងនោះជានិច្ច ។ ពួកចោរ កាលឈ្មួញនោះយឺតយូរ ទើបបញ្ជូនបុរសម្នាក់ទៅ ដោយប្រាប់ថា ចូរអ្នកទៅ ចូរដឹងថ្ងៃចេញដំណើរ របស់ឈ្មួញនោះហើយ ចូរមក ។ បុរសនោះ ទៅដល់ស្រុកនោះហើយ សួរសម្ងាញ់ម្នាក់ថា ឈ្មួញចេញទៅអង្កាល់ សម្ងាញ់នោះឆ្លើយថា កន្លងទៅ ២-៣ ថ្ងៃទៀត ដូច្នេះហើយ ពោលថា ចុះអ្នកសួរដើម្បីអ្វី ពេលនោះ បុរសនោះប្រាប់ថា ពួកខ្ញុំជាចោរ ៥០០ ពួននៅក្នុងព្រៃដើម្បីប្លន់ឈ្មួញនោះ ។ ចំណែកសម្ងាញ់នោះ

ពោលថា បើដូច្នោះ សូមអ្នកទៅចុះ ឈ្មួញនឹងចេញទៅឆាប់ៗ បញ្ជូនបុរសនោះទៅហើយ គិតថា អញនឹងឃាត់ពួកចោរ ឬឃាត់ឈ្មួញហ្នឹ៎ក ក៏សម្រេចចិត្តថា ប្រយោជន៍អ្វីរបស់អញដោយពួកចោរ ភិក្ខុ ៥០០ រូប អាស្រ័យឈ្មួញរស់នៅ អញនឹងឲ្យសញ្ញាដល់ឈ្មួញ ហើយបានទៅកាន់សម្នាក់របស់ឈ្មួញនោះ សួរថា អ្នកទៅអង្កាល់ ឈ្មួញឆ្លើយថា ក្នុងថ្ងៃទី ៣ ក៏ពោលថា សូមអ្នកធ្វើតាមពាក្យរបស់ខ្ញុំ បានឮថា ពួកចោរ ៥០០ ស្កាត់នៅត្រង់ព្រៃដើម្បីអ្នក អ្នកកុំប្រញាប់ទៅធ្វើអ្វី ឈ្មួញសួរថា អ្នកដឹងដូចម្តេច បុរសនោះប្រាប់ថា សម្ងាញ់របស់ខ្ញុំមាននៅក្នុងពួកចោរទាំងនោះ ខ្ញុំដឹង ព្រោះការប្រាប់របស់គេ ឈ្មួញពោលថា បើយ៉ាងនោះ ប្រយោជន៍អ្វីរបស់ខ្ញុំដោយការទៅអំពីទីនេះ ខ្ញុំនឹងត្រឡប់ទៅផ្ទះ ។

កាលឈ្មួញនោះយឺតយូរ ពួកចោរក៏បញ្ជូនបុរសនោះមកទៀត មកដល់ហើយសួរសម្ងាញ់នោះ បានស្តាប់ការប្រព្រឹត្តទៅនោះហើយ ទៅប្រាប់ដល់ពួកចោរថា បានឮថា ឈ្មួញនឹងត្រឡប់ គឺទៅផ្ទះនោះឯង ។ ពួកចោរស្តាប់ពាក្យនោះហើយ បានចេញអំពីព្រៃនោះ ទៅស្កាត់ត្រង់មាត់ផ្លូវក្រៅអំពីនេះ កាលឈ្មួញនោះយឺតយូរ ចោរទាំងនោះ ក៏បញ្ជូនបុរសនោះ ទៅកាន់សម្នាក់របស់សម្ងាញ់នោះទៀត សម្ងាញ់នោះ ដឹងភាពដែលពួកចោរស្កាត់ក្នុងទីនោះហើយ ក៏ប្រាប់ដល់ឈ្មួញទៀត ឈ្មួញគិតថា ក្នុងទីនេះ ការអត្តភាពរបស់អញ មិនមាន បើដូច្នេះ អញមិនទៅខាងនោះ មិនទៅខាងនេះ នឹងនៅទីនេះឯង ដូច្នេះហើយ ទៅកាន់សម្នាក់ភិក្ខុទាំងឡាយ ប្រាប់ថា បពិត្រលោកម្ចាស់

ពួកចោរបំណងប្លន់ខ្ញុំ នៅត្រង់មាត់ផ្លូវ ជានញ្ចថា ឥឡូវនេះ ឈ្ងួញនឹងត្រឡប់មកទៀត ទើបទៅស្ការត់ត្រង់មាត់ផ្លូវក្រៅអំពីនេះ ខ្ញុំនឹងមិនទៅខាងនោះ ខាងនេះ នឹងស្នាក់នៅក្នុងទីនេះឯងមួយរយៈ បើលោកម្ចាស់ទាំងឡាយ បំណងនៅក្នុងទីនេះក៏នៅចុះ បើបំណងទៅ សូមនិមន្តតាមគាប់ចិត្តចុះ ។

ភិក្ខុទាំងឡាយពោលថា បើដូច្នោះ ពួកអាត្មានឹងត្រឡប់ លាឈ្ងួញហើយ ក្នុងថ្ងៃស្អែកឡើង ទៅកាន់ក្រុងសាវត្ថី ថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងទីសមគួរហើយ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនទៅជាមួយ ឈ្ងួញមានទ្រព្យច្រើនទេឬ កាលពួកភិក្ខុនោះក្រាបទូលថា យ៉ាងនោះឯងព្រះអង្គ ពួកចោរស្ការត់ត្រង់មាត់ផ្លូវទាំងសងខាង ដើម្បីប្លន់ឈ្ងួញដែលមានទ្រព្យច្រើន ព្រោះហេតុនោះ ទើបគាត់ស្នាក់នៅក្នុងទីនោះឯង ឯពួកខ្ញុំព្រះអង្គ លាគាត់ត្រឡប់មក ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្ងួញមានទ្រព្យច្រើន រមែងវៀរផ្លូវដែលមានភ័យ ព្រោះភាពដែលពួកចោរមាន បុរសសូម្បីប្រាថ្នានឹងរស់នៅ រមែងវៀរចាកថ្នាំពិសដ៏ពន្លឹក សូម្បីភិក្ខុជ្រាបថា ភព ៣ ដូចគ្នានឹងផ្លូវដែលពួកចោរស្ការត់ ហើយវៀរកម្មអាក្រក់ចេញ គួរ ដូច្នេះហើយ ដើម្បីទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

វាណិជោវ ភយំ មគ្គំ អប្បសត្តោ មហាធុនោ
វិសំ ជីវិតុកាមោវ ចាចានិ បរិវជ្ជយេ ។

បុគ្គល គួរចៀសវាងបាបទាំងឡាយ ឲ្យដូចពាណិជដែល មានទ្រព្យច្រើន តែមានគ្នាតិច ចៀសវាងផ្លូវគួរខ្លាច ឬដូច បុរសប្រាថ្នារស់ ចៀសវាងថ្នាំពិស ដូច្នោះដែរ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ភយំ** *បានដល់ ដែលគួរខ្លាច អធិប្បាយ ថា ដែលមានភ័យចំពោះមុខ ព្រោះជាផ្លូវដែលពួកចោរស្កាត់ផ្លូវ ។ លោក បានអធិប្បាយពាក្យនេះថា ឈ្មួញមានទ្រព្យច្រើន មានគ្នាតិច វៀរផ្លូវដែល មានភ័យចំពោះមុខ យ៉ាងណា បុគ្គលត្រូវការរស់នៅ រមែងវៀរថ្នាំពិស ដែលមានពិសដ៏ពន្លឹក យ៉ាងណា ភិក្ខុដែលជាបណ្ឌិត គួរវៀរបាបទាំងឡាយ សូម្បីមានប្រមាណតិចក៏ដូច្នោះ ។*

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះសម្រេចអរហត្ត មួយអន្លើដោយបដិ-សម្ភិទាទាំងឡាយ ព្រះធម្មទេសនាបានជាប្រយោជន៍ដល់មហាជន ដែលមក ប្រជុំគ្នាហើយ ដូច្នោះឯង ។

រឿងមហាធនពាណិជ ចប់

រឿង កុក្កុជមិត្ត

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធព្រានឈ្មោះកុក្កុជ-មិត្ត ត្រាស់ព្រះធម្មទេសនានេះថា **ទាណិម្ហិ ចេ វណោ នាស្ស** ជាដើម ។

បានឣថា ធីតាសេដ្ឋីម្នាក់ ក្នុងក្រុងរាជគ្រឹះ ចម្រើនវ័យហើយ ដើម្បីជាប្រយោជន៍ក្នុងការរក្សា ទើបមាតាបិតាប្រគល់ស្រីបម្រើម្នាក់ ឲ្យនៅក្នុងបន្ទប់លើប្រាសាទ ៧ ជាន់ ។ ល្ងាចថ្ងៃមួយ ក្រឡេកទៅចន្ទោះផ្ទូវតាមមាត់បង្អួចឃើញព្រានម្នាក់ ឈ្មោះកុក្កុជមិត្តកាន់អន្ទាក់ ៥០០ ចម្រូង ៥០០ សម្ងាប់ម្រឹគទាំងឡាយចិញ្ចឹមជីវិត បានម្រឹគ ៥០០ ហើយ ដាក់ពេញរទេះធំ លក់ម្រឹគទាំងនោះ អង្គុយលើទូករទេះ ចូលទៅកាន់ព្រះនគរដើម្បីលក់សាច់ ជាអ្នកមានចិត្តប្រតិព័ទ្ធក្នុងព្រាននោះ ឲ្យបណ្ណាការក្នុងដៃស្រីបម្រើ បញ្ជូនទៅថាចូរនាងទៅ ចូរឲ្យបណ្ណាការដល់បុរសនោះ ចូរដឹងពេលទៅរបស់គាត់ រួចហើយសឹមត្រឡប់មក ។

ស្រីបម្រើទៅហើយ ឲ្យបណ្ណាការដល់ព្រាននោះហើយ សួរថា អ្នកទៅវិញអង្កាល់ ព្រានឆ្ងើយថា ថ្ងៃនេះ ខ្ញុំលក់សាច់ហើយ នឹងចេញទៅដោយទ្វារឈ្មោះនោះ អំពីព្រលឹមនោះឯង ។ ស្រីបម្រើស្តាប់ពាក្យព្រាននោះប្រាប់ហើយ ត្រឡប់មកប្រាប់ដល់នាង ។

ធីតាសេដ្ឋីប្រមូលសំពត់ និងអាភរណៈ ដែលគួរដល់ភាវៈជារបស់ខ្ជូនដែលគួរកាន់យក ស្ងៀកសំពត់ចាស់ កាន់ក្អមទឹកចេញទៅអំពីព្រលឹម ដូច

ទៅកាន់កំពង់ទឹកជាមួយពួកនាងទាសី ដល់ទីនោះហើយ បានឈរទន្ទឹងការមករបស់ព្រាន ។ ព្រានក៏បររទេះចេញទៅអំពីព្រលឹម ចំណែកនាងក៏ដើរតាមក្រោយរទេះនោះទៅ បុរសនោះឃើញ ទើបពោលថា ខ្ញុំមិនស្គាល់នាងថាជាកូនស្រីរបស់បុគ្គលឈ្មោះនោះ នែនាង នាងកុំដើរតាមខ្ញុំទ្បើយ ។ នាងធ្វើយថា លោកមិនបានហៅខ្ញុំមក ខ្ញុំមកតាមធម្មតារបស់ខ្ញុំ សូមលោកនៅស្ងៀម បររទេះរបស់ខ្ជូនចុះ ។ បុរសនោះហាមហើយ ហាមទៀតនោះឯង ។ នាងក៏ពោលថា ការហាមឃាត់សិរី ដែលមកកាន់សម្នាក់ខ្ជូន មិនគួរ ព្រានជ្រាបការមករបស់នាងដើម្បីខ្ជូនដោយឥតសង្ស័យហើយ បានបីនាងដាក់លើរទេះទៅ ។

មាតាបិតារបស់នាងឲ្យមនុស្សរកក្នុងទីផ្សេងៗ ក៏មិនជួប សម្គាល់ថានាងស្លាប់ហើយ ទើបធ្វើមត្តកភត្ត ។ នាងអាស្រ័យការនៅរួមជាមួយព្រាននោះ បានកូន ៧ នាក់ដោយលំដាប់ ចងបុត្រទាំងនោះដែលចម្រើនវ័យហើយ ដោយគ្រឿងចង គឺផ្ទះ បានដល់ ឲ្យមានប្រពន្ធ ។

ថ្ងៃមួយ ព្រះសាស្តា ទ្រង់ប្រមើលមើលលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញព្រានកុក្ក្ុដមិត្ត កូនប្រុស និងកូនប្រសា ចូលទៅខាងក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ទ្រង់ពិចារណាថា ហេតុនោះដូចម្តេចហ្នឹ ទ្រង់ឃើញ ឧបនិស្ស័យនៃសោតាបត្តិមគ្គរបស់ជនទាំងនោះហើយ ទ្រង់កាន់បាត្រ និងចីវរ បានយាងទៅកាន់ទីដាក់អន្ទាក់របស់ព្រាននោះអំពីព្រលឹម ។ ថ្ងៃនោះម្រឹគ សូម្បីតែមួយ ក៏មិនបានជាប់អន្ទាក់ ។

ព្រះសាស្តា ទ្រង់ប្រតិស្ថានស្នាមព្រះបាទ ក្នុងទីជិតអន្ទាក់របស់ព្រាន ហើយប្រថាប់គង់ក្រោមម្លប់ឈើមួយគុម្ពខាងមុខ ។ ព្រានកុក្កុដមិត្តកាន់ធ្នូទៅមើលអន្ទាក់តាំងពីព្រលឹម ពិនិត្យមើលអន្ទាក់តាំងពីដើមរហូតដល់អស់ មិនបានសត្វសូម្បីតែមួយក្បាលដែលជាប់អន្ទាក់ បានឃើញស្នាមព្រះបាទរបស់ព្រះសាស្តាហើយ ត្រិះរិះថា អ្នកណាដើរដោះសត្វជាប់អន្ទាក់របស់អញ ។ គាត់ចងអាឃាតក្នុងព្រះសាស្តា កាលដើរទៅ ក៏ជួបព្រះសាស្តាប្រថាប់គង់ត្រង់គុម្ពឈើ គិតថា សមណៈនេះដោះសត្វរបស់អញ អញនឹងសម្លាប់សមណៈនេះបង់មេរៀត ដូច្នេះហើយ ក៏យឺតធ្នូ ។

ព្រះសាស្តាឲ្យធ្នូកោងបាន តែមិនឲ្យព្រួញចេញ គាត់មិនអាចលែងព្រួញទៅផង មិនអាចដាក់ចុះ មានធ្នឹងជំនីរទាំងពីរហាក់បែក មានទឹកមាត់ហូរចេញអំពីមាត់ ជាអ្នកអស់កម្លាំង បានឈរហើយ ។ គ្រានោះ កូនប្រុសរបស់គាត់ចូលទៅផ្ទះនិយាយគ្នាថា ឪពុករបស់យើងយឺតយូរ តើមានហេតុអ្វីហ្ន៎ ទើបម្តាយបញ្ជូនទៅថា នែបាទាំងឡាយ ចូរពួកអ្នកទៅកាន់សម្នាក់របស់ឪពុក ក៏នាំគ្នាកាន់ធ្នូទៅ ឃើញឪពុកឈរបែបនោះ គិតថា បុគ្គលនេះ ពិតជាបច្ចាមិត្តរបស់ឪពុកពួកយើង ទាំង ៧ នាក់ យឺតធ្នូហើយ បានឈរនៅដូចឪពុករបស់ពួកខ្លួនហើយ ដោយអានុភាពនៃព្រះសម្មាសម្ពុទ្ធ ។

លំដាប់នោះ ម្តាយរបស់ជនទាំងនោះ គិតថា ហេតុអ្វីហ្ន៎ ទើបឪពុកនិងកូនយឺតយូរ បានទៅជាមួយកូនប្រសា ៧ នាក់ ឃើញជនទាំងនោះឈរយ៉ាងនោះ គិតថា ជនទាំងនេះបាញ់អ្នកណាហ្ន៎ ក្រឡេកទៅឃើញព្រះសាស្តា

ទើបផ្គងដើមដៃទាំងពីរស្រែកខ្លាំងៗ ថា ពួកអ្នក កុំធ្វើឪពុករបស់ខ្ញុំឲ្យវិនាស ពួកអ្នក កុំធ្វើឪពុករបស់ខ្ញុំឲ្យវិនាសឡើយ ។

ព្រោនកុក្កុជមិត្តបានឮសំឡេងនោះហើយ គិតថា អញវិនាសហើយហ្ន៎ បានឮថា បុគ្គលនេះ ជាឪពុករបស់អញ ឱហ្ន៎ ! អញធ្វើកម្មធ្ងន់ ។ សូម្បីកូនប្រុសរបស់គាត់ក៏គិតថា បានឮថា ជននេះ ជាជីតារបស់អញ ឱហ្ន៎ ! អញធ្វើកម្មធ្ងន់ ។ ព្រោនកុក្កុជមិត្តតាំងនូវមេត្តាចិត្តថា បុគ្គលនេះជាឪពុករបស់អញ សូម្បីពួកកូនប្រុសរបស់គាត់ ក៏ចូលទៅតាំងមេត្តាចិត្តថា បុគ្គលនេះជាជីតារបស់ពួកយើង ។ ខណៈនោះ ធីតាសេដ្ឋីដែលជាម្តាយពោលថា ចូរពួកអ្នកជាក់ធ្មចុះឲ្យរហ័ស ឲ្យឪពុករបស់ខ្ញុំអត់ទោស ។

ព្រះសាស្តា កាលទ្រង់ជ្រាបចិត្តរបស់ជនទាំងនោះទន់ភ្លន់ហើយ ទើបឲ្យជាក់ធ្មចុះបាន ។ ជនទាំងអស់ថ្វាយបង្គំព្រះសាស្តាហើយ ឲ្យទ្រង់អត់ទោសថា បពិត្រព្រះអង្គ សូមទ្រង់អត់ទោសដល់ខ្ញុំព្រះអង្គ ដូច្នេះហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ លំដាប់នោះ ព្រះសាស្តាត្រាស់អនុបុព្វីកថាដល់ពួកជនទាំងនោះ ក្នុងកាលចប់ទេសនា ព្រោនកុក្កុជមិត្ត កូនប្រុស និងកូនប្រសាទាំង ១៥ នាក់ តាំងនៅក្នុងសោតាបត្តិផលហើយ ព្រះសាស្តាយាងទៅបិណ្ឌបាតបានទៅកាន់វិហារខាងក្រោយភត្ត ។ លំដាប់នោះ ព្រះអានន្ទត្ថេរទូលសួរថា បពិត្រព្រះអង្គ ថ្ងៃនេះទ្រង់យាងទៅទីណា ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ តថាគតទៅកាន់សម្នាក់របស់កុក្កុជមិត្ត ព្រះអានន្ទទូលថា បពិត្រព្រះអង្គ កុក្កុជ-មិត្ត ទ្រង់ធ្វើឲ្យជាបុគ្គលមិនធ្វើកម្ម គឺបាណាតិបាតហើយឬ ព្រះសាស្តាត្រាស់

ថា អើអានន្ទ ព្រោនកុក្កុដមិត្តនោះមានខ្លួនជាគម្រប់ ១៥ តាំងនៅក្នុងសទ្ធាមិនញាប់ញ័រ ជាអ្នកអស់នូវសេចក្តីសង្ស័យក្នុងវត្តនៈ ៣ ជាអ្នកមិនធ្វើកម្ម គឺបាណាតិបាតឡើយ ។

ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ ភរិយារបស់គាត់មាន មិនមែនឬ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង នាងជាកុមារិកាក្នុងផ្ទះរបស់អ្នកមានត្រកូល សម្រេចសោតាបត្តិផលហើយ ។

ពួកភិក្ខុសន្ទនាគ្នាថា បានឮថា ភរិយារបស់ព្រោនកុក្កុមិត្ត សម្រេចនូវសោតាបត្តិផល ក្នុងកាលជាកុមារីនោះឯង ហើយទៅកាន់ផ្ទះរបស់ព្រោននោះ បានកូន ៧ នាក់ នាងកាលស្វាមីប្រើអស់កាលប៉ុណ្ណោះថា ចូរនាងយកធ្នូមក យកព្រួញមក យកលំពែងមក យកចម្រូងមក យកអន្ទាក់មក បានឲ្យវត្ថុទាំងនោះហើយ ព្រោននោះកាន់គ្រឿងប្រហារដែលនាងឲ្យ ទៅធ្វើបាណាតិបាតសូម្បីព្រះសោតាបន្នទាំងឡាយ នៅធ្វើបាណាតិបាតឬ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សោតាបន្ន មិនធ្វើបាណាតិបាត តែនាងធ្វើយ៉ាងនោះ ដោយគិតថា អញនឹងធ្វើតាមពាក្យប្តី ចិត្តរបស់នាងមិនមានឡើយថា ចូរប្តីនោះកាន់យកគ្រឿងប្រហារនេះ ទៅធ្វើបាណាតិបាត ពិតហើយ កាលជំពៅក្នុងបាតដៃមិនមាន ថ្នាំពិសនោះ ក៏មិនអាចឲ្យទោសដល់អ្នកកាន់ថ្នាំពិសបាន យ៉ាងណា ឈ្មោះថា ចាប មិនមាន

ដល់អ្នកមិនធ្វើបាប សូម្បីនាំគ្រឿងប្រហារទាំងឡាយ មានធ្នូជាដើមហុចឲ្យ ព្រោះមិនមានអកុសលចេតនាដូច្នោះដូចគ្នា ដូច្នេះហើយ កាលទ្រង់បន្តអនុ-សន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ចាណិម្ហិ ចេ វណោ នាស្ស ហារេយ្យ ចាណិនា វិសំ
នាព្ភណំ វិសមន្វេតិ នត្ថិ បាបំ អកុព្វតោ ។

បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីកាន់នាំយកថ្នាំពិសដោយបាតដៃ ថ្នាំពិសតែងមិនជ្រាបចូលទៅកាន់បាតដៃដែលគ្មានដំបៅ យ៉ាងណា បាប រមែងមិនមានដល់បុគ្គល អ្នកមិនធ្វើយ៉ាងនោះដែរ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **នាស្ស** *ប្រែថា មិនគប្បីមាន ។ បទថា* **ហារេយ្យ** *ប្រែថា គប្បីអាចនាំទៅបាន ។ សួរថា ព្រោះហេតុអ្វី ទើបថា ព្រោះថ្នាំពិសមិនជ្រាបទៅកាន់បាតដៃដែលមិនមានដំបៅ ។ ពិតហើយ ថ្នាំពិស រមែងមិនអាចជ្រាបចូលកាន់បាតដៃដែលមិនមានដំបៅ យ៉ាងណា ឈ្មោះថា បាប រមែងមិនមានដល់បុគ្គលដែលមិនធ្វើបាប នាំគ្រឿងប្រហារទាំងឡាយ មានធ្នូជាដើមមកឲ្យ ព្រោះមិនមានអកុសលចេតនាដូច្នោះដូចគ្នា ។ មែនពិត បាប រមែងមិនជាប់តាមចិត្តរបស់បុគ្គលនោះ ដូចថ្នាំពិសមិនជ្រាបចូលទៅក្នុងបាតដៃដែលមិនមានដំបៅ ដូច្នោះ ដូច្នេះឯង ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន

សោតាបត្តិផលជាដើម ដូច្នេះឯង ។

សម័យមួយ ពួកភិក្ខុសន្ទនាគ្នាថា អ្វីហ្ន៎ ជាឧបនិស្សយនៃសោតាបត្តិ-មគ្គរបស់ព្រានកុក្កុជមិត្ត កូនប្រុស និងកូនប្រសាស្រី ។ ព្រានកុក្កុជមិត្តនេះ កើតក្នុងត្រកូលរបស់ព្រានម្រឹគ ព្រោះហេតុអ្វី ។

ព្រះសាស្តាយាងមក ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នា ដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ពួកជនរៀបចំធ្វើព្រះចេតិយ បញ្ចុះព្រះធាតុរបស់ព្រះកស្សប-ទសពល និយាយគ្នាយ៉ាងនេះថា អ្វីហ្ន៎ជាដីឥដ្ឋ អ្វីហ្ន៎ ជាទឹកបន្សាររនៃចេតិយនេះ ។

ពេលនោះ ពួកជនទាំងនោះត្រិះរិះថា ហរតាល និងមនោសិលាជាដីឥដ្ឋ ប្រេងល្ហុងជាទឹកបន្សារ ។ ពួកជនទាំងនោះបុកហរតាល និងមនោសិលាហើយ លាយនឹងប្រេងល្ហុង កដោយឥដ្ឋ បិទដោយមាស គូរក្បាច់ក្បូរខាងក្នុង ។ ត្រង់ខាងមុខផ្នែកខាងក្រៅ មានឥដ្ឋជាជុំមាស ឥដ្ឋនីមួយៗ មានតម្លៃមួយសែន ។ ពួកជនទាំងនោះ កាលធ្វើចេតិយស្រេចហើយ រហូតដល់កាលបញ្ចុះព្រះធាតុ គិតគ្នាថា ក្នុងកាលបញ្ចុះព្រះធាតុ ត្រូវការទ្រព្យច្រើន ពួកយើងនឹងធ្វើអ្នកណាហ្ន៎ ឲ្យជាប្រធាន ។

ខណៈនោះ សេដ្ឋីស្រុកក្រៅម្នាក់ពោលថា ខ្ញុំនឹងជាប្រធាន បានដាក់ប្រាក់មួយកោដិក្នុងទីបញ្ចុះព្រះធាតុ អ្នកដែនឃើញកិរិយានោះ តិះដៀលថា

សេដ្ឋីក្រុងនេះ ប្រមូលទ្រព្យទុកជាក់តែម្យ៉ាង មិនអាចជាប្រធាន ក្នុងចេតិយ បែបនេះ បានចំណែកសេដ្ឋីស្រុកក្រៅជាក់ទ្រព្យមួយកោដិ ធ្វើជាប្រធាន ។

សេដ្ឋីក្នុងក្រុងនោះ បានឮពាក្យរបស់ជនទាំងនោះហើយពោលថា អញនឹងឲ្យទ្រព្យពីរកោដិ ហើយធ្វើជាប្រធាន បានជាក់ទ្រព្យពីរកោដិហើយ ។ សេដ្ឋីស្រុកក្រៅគិតថា អញនេះឯងនឹងជាប្រធាន បានឲ្យទ្រព្យ ៣ កោដិ ។ សេដ្ឋីទាំងពីរបន្ថែមទ្រព្យដោយអាការយ៉ាងនោះ សេដ្ឋីក្នុងក្រុងបានឲ្យទ្រព្យ ៨ កោដិហើយ ។

ចំណែកសេដ្ឋីស្រុកក្រៅ មានទ្រព្យ ៩ កោដិប៉ុណ្ណោះក្នុងផ្ទះ សេដ្ឋីក្នុងក្រុងមានទ្រព្យ ៤០ កោដិ ។ ព្រោះដូច្នោះ សេដ្ឋីស្រុកក្រៅគិតថា បើអញជាក់ទ្រព្យ ៩ កោដិសោត សេដ្ឋីនេះនឹងពោលថា ខ្ញុំជាក់ ១០ កោដិ កាលបើដូច្នោះ ការអស់ទ្រព្យរបស់អញនឹងប្រាកដ ទើបគាត់ពោលយ៉ាងនេះថា ខ្ញុំនឹងឲ្យទ្រព្យប្រមាណប៉ុណ្ណោះ ហើយខ្ញុំ កូន និងប្រពន្ធ នឹងធ្វើជាទាសៈរបស់ចេតិយ ដូច្នេះហើយ នាំកូនទាំង ៧ កូនប្រសាទាំង ៧ និងភរិយា ប្រគល់ជល់ចេតិយ មួយអន្ទើដោយខ្លួនឯង ។

អ្នកដែនធ្វើសេដ្ឋីស្រុកក្រៅនោះឲ្យជាប្រធាន ដោយអាងថា ឈ្មោះថាទ្រព្យអ្នកណាក៏អាចឲ្យកើតឡើងបាន តែសេដ្ឋីស្រុកក្រៅ មួយអន្ទើដោយបុត្រ និងភរិយា ប្រគល់ខ្លួនចំពោះចេតិយ សេដ្ឋីនេះឯងនឹងជាប្រធាន ។ ជនទាំង ១៦ នាក់ បានជាទាសៈរបស់ចេតិយដោយប្រការដូច្នេះ តែអ្នកដែនបានធ្វើពួកគាត់ឲ្យជាអ្នកជា ។ កាលបើដូច្នោះ ពួកគាត់ក៏បដិបត្តិចេតិយនោះឯង ដរាប

ដល់អស់ជីវិត ។ ចុតិអំពីអត្តភាពនោះហើយ កើតក្នុងទេវលោក កាលជនទាំងនោះនៅក្នុងទេវលោកអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ ភរិយាចុតិអំពីទេវលោកនោះ កើតជាធីតាសេដ្ឋីក្នុងក្រុងរាជគ្រឹះ ។

នាងនៅជាកុមារីនោះឯង សម្រេចសោតាបត្តិផលហើយ ។ ឈ្មោះថាបដិសន្ធិរបស់សត្វដែលមិនទាន់ឃើញសច្ចៈ ជាការៈធ្ងន់ ព្រោះដូច្នោះ ស្វាមីរបស់នាងវិលទៅកើតក្នុងត្រកូលព្រានម្រឹគ សេចក្តីស្រឡាញ់ក្នុងកាលមុនបានគ្របសង្កត់ចិត្តធីតាសេដ្ឋី ដោយគ្រាន់តែឃើញព្រានកុក្កុជមិត្តនោះឯង ។ ពិតហើយ ព្រះដ៏មានព្រះភាគ ក៏បានត្រាស់ពាក្យនេះថា

> សេចក្តីស្រឡាញ់នោះ រមែងកើតដោយហេតុ ២ យ៉ាង គឺដោយធ្លាប់នៅរួមគ្នាក្នុងកាលមុន ១ ដោយការទំនុកបម្រុងគ្នាក្នុងបច្ចុប្បន្ននេះ ១ ដូចជាឧប្បលដែលដុះក្នុងទឹកដោយហេតុ ២ យ៉ាង គឺទឹក ១ ភក់ ១ ។

ធីតាសេដ្ឋីនោះ បានទៅកាន់ត្រកូលរបស់ព្រានម្រឹគ ព្រោះសេចក្តីស្នេហាក្នុងកាលមុន ។ សូម្បីពួកកូនប្រុសរបស់នាង ក៏ចុតិអំពីទេវលោក បដិសន្ធិក្នុងផ្ទៃរបស់នាងនោះឯង ។ សូម្បីកូនប្រសារបស់នាង កើតទ្បើងក្នុងទីនោះៗ ចម្រើនវ័យហើយ បានទៅកាន់ផ្ទះរបស់ជនទាំងនោះឯង ។ ជនទាំងនោះបដិបត្តិចេតិយក្នុងកាលនោះហើយ ទើបបានសម្រេចសោតាបត្តិផល ដោយអានុភាពនៃកម្មនោះ ដូច្នេះឯង ។

រឿង កុក្កុជមិត្ត ចប់

រឿង ព្រានសុនខ ឈ្មោះ កោកៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រានឆ្កែឈ្មោះ កោកៈ ត្រាស់ព្រះធម្មទេសនានេះថា **យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ** ជាដើម ។

បានឮថា ព្រឹកថ្ងៃមួយ ព្រាននោះកាន់ធ្នូ មានឆ្កែចោមរោមចេញទៅព្រៃ ជួបភិក្ខុសមាទានបិណ្ឌបាតជាវត្តមួយរូប កំពុងត្រាច់បិណ្ឌបាតក្នុងវេលាផ្លូវ ខឹងក្រោធហើយ គិតបណ្តើរថា អញជួបមនុស្សកាឡកិណី ថ្ងៃនេះ នឹងមិនបានវត្ថុណាមួយឡើយ ដូច្នេះ ទើបចៀសចេញទៅ ។ ចំណែកព្រះថេរៈត្រាច់បិណ្ឌបាតក្នុងស្រុក ធ្វើភត្តកិច្ចហើយ ទើបត្រឡប់ទៅកាន់វិហារវិញ ។

ឯព្រានត្រាច់ទៅក្នុងព្រៃ មិនបានសត្វសោះ កាលត្រឡប់មក ក៏ជួបព្រះថេរៈទៀត ទើបគិតថា ថ្ងៃនេះ អញជួបមនុស្សកាឡកិណី ហើយទៅព្រៃមិនបានសត្វណាមួយ ឥឡូវនេះ លោកបានមកជួបមុខអញទៀត អញនឹងឲ្យឆ្កែទាំងឡាយខាំភិក្ខុរូបនេះ ដូច្នេះហើយ ទើបឲ្យសញ្ញាលែងឆ្កែទៅ ។

ព្រះថេរៈឃាត់ថា ឧបាសក អ្នកកុំធ្វើយ៉ាងនោះឡើយ ។ គាត់ស្រែកប្រាប់ថា ថ្ងៃនេះ អញមិនបានសត្វណាមួយ ព្រោះជួបឯង ឯងមកជួបអញទៀត អញនឹងឲ្យឆ្កែខាំឯង ដូច្នេះហើយ ទើបឲ្យឆ្កែខាំ ព្រះថេរៈប្រញាប់ឡើងដើមឈើមួយដើមដោយរហ័ស អង្គុយក្នុងទីកម្ពស់មួយជួរបុរសឆ្កែ ទាំងឡាយ ក៏នាំគ្នាចោមរោមដើមឈើនោះ ។

ព្រោនក្រោធហើយ ស្រែកប្រាប់ថា ឯងឡើងដើមឈើ ក៏មិនអាចរួចខ្លួនបាន ដូច្នេះហើយ ទើបចាក់បាតជើងព្រះថេរៈដោយព្រួញ ព្រះថេរៈបានតែយាត់ថា អ្នកកុំធ្វើដូច្នោះឡើយ នាយកោកៈនេះមិនពិចារណាដល់ពាក្យរបស់លោក ចាក់កាន់តែខ្លាំង ព្រះថេរៈកាលបាតជើងម្ខាងត្រូវចាក់ ទើបលើកជើងនោះឡើង ជាក់ជើងទីពីរចុះ កាលជើងទីពីរនោះត្រូវចាក់ ទើបលើកជើងនោះឡើង នាយកោកៈ មិនពិចារណាដល់ពាក្យឃាត់របស់ព្រះថេរៈ ចាក់ជើងទាំងពីរដោយអាការយ៉ាងនេះ សរីរៈរបស់ព្រះថេរៈ ហាក់ដូចជារោលដោយគប់ភ្លើង ។ លោកសោយវេទនា មិនអាចគ្រប់គ្រងសតិបាន ចីវរដែលលោកឃ្លុំ សូម្បីរហូតចុះ ក៏កំណត់មិនបាន ។ ចីវរនោះកាលធ្លាក់ចុះ ក៏ធ្លាក់គ្របនាយកោកៈតាំងអំពីក្បាលនោះឯង ។

ចំណែកឆ្កែសុះចូលទៅក្នុងរវាងចីវរ ដោយសម្គាល់ថា ព្រះថេរៈធ្លាក់ចុះមក ដូច្នេះហើយ ចោមរោមខាំស៊ីម្ចាស់របស់ខ្លួន ធ្វើឲ្យសល់ត្រឹមតែឆ្អឹងឆ្កែទាំងឡាយចេញមកពីក្នុងចីវរហើយ បានឈរខាងក្រៅ ពេលនោះ ទើបព្រះថេរៈកាច់មែកឈើងាប់មួយមែក គ្រវែងឆ្កែទាំងនោះ ឆ្កែឃើញព្រះថេរៈនោះដឹងថា ពួកខ្លួនខាំស៊ីម្ចាស់របស់ខ្លួនឯង ទើបគេចចូលព្រៃ ។

ព្រះថេរៈកើតការសង្វេយថា បុរសនោះ ចូលក្នុងចីវររបស់អាត្មាអញវិនាសហើយ សីលរបស់អាត្មាអញមិនពេញ ពាលទេឬហ្ន៎ ចុះអំពីដើមឈើហើយ ទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលរឿងនោះតាំងអំពីដើមរហូតដល់ចប់ហើយ ទូលសួរថា បពិត្រព្រះអង្គ ឧបាសកនោះ អាស្រ័យចីវររបស់

ខ្ញុំព្រះអង្គ វិនាសហើយ សីលរបស់ខ្ញុំព្រះអង្គ ពព្រុស ពពាលដែរឬ សមណភាពរបស់ខ្ញុំព្រះអង្គ នៅមានដែរឬ ។

ព្រះសាស្តាទ្រង់ស្តាប់វាចារបស់ព្រះថេរៈនោះហើយត្រាស់ថា ម្នាលភិក្ខុ សីលរបស់អ្នកមិនពព្រុស មិនពពាល សមណភាពរបស់អ្នកនៅមាន ព្រោនប្រទូស្តចំពោះអ្នកមិនប្រទូស្ត ជល់នូវការវិនាស មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងអតីតកាល ក៏ប្រទូស្តចំពោះអ្នកមិនប្រទូស្ត ជល់នូវសេចក្តីវិនាសហើយដូចគ្នា ដូច្នេះហើយ កាលទ្រង់ប្រកាសសេចក្តីនោះ ទ្រង់នាំអតីតនិទានមកត្រាស់ថា

រឿងមានមកថា ក្នុងអតីតកាល គ្រូម្នាក់ត្រាច់ទៅដល់ភូមិមួយ ដើម្បីធ្វើវេជ្ជកម្ម មិនបានកម្មណាមួយ ត្រូវសេចក្តីស្រេកឃ្លានបៀតបៀនហើយ ចេញទៅឃើញក្មេងៗ ជាច្រើន កំពុងលេងត្រង់ទ្វារស្រុក ទើបគិតថា អញនឹងឲ្យពស់ចឹកក្មេងទាំងនេះ ហើយព្យាបាល នឹងបានអាហារ ដូច្នេះហើយ ទើបបង្ហាញពស់ដេកអើតក្បាល ក្នុងព្រង់ឈើមួយកន្លែង ប្រាប់ថា នែកុមារទាំងឡាយ នុ៎ះ កូនសត្វសាលិកា ចូរពួកអ្នកចាប់វា ។

រំពេចនោះ ក្មេងតូចម្នាក់ចាប់ពស់ត្រង់កយ៉ាងតឹងទាញចេញមក ដឹងថាជាពស់ ទើបស្រែកឡើង រលាស់ទៅលើក្បាលរបស់គ្រូនោះ ដែលកំពុងឈរមិនឆ្ងាយ ពស់រុំត្រង់ករបស់គ្រូ ចឹកយ៉ាងខ្លាំងឲ្យដល់នូវការអស់ជីវិត ក្នុងទីនោះឯង នាយកោកៈព្រោនឆ្កែនេះ ក្នុងកាលមុន ក៏ប្រទូស្តអ្នកមិនប្រទូស្ត ជល់នូវសេចក្តីវិនាសហើយយ៉ាងនេះដូចគ្នា ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ កាលទ្រង់បន្តអនុ-សន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ សុទ្ធស្ស ទោសស្ស អនង្គណស្ស
តមេវ ពាលំ បចេ្ចតិ ចាបំ សុខុមោ រជោ បដិវាតំវ ខិត្តោ ។

បុគ្គលណា ប្រទូស្តចំពោះអ្នកមិនប្រទូស្តតប ជាសត្វស្អាត មិនមានកិលេសដូចជាទីទួល ចាប រមែងត្រឡប់មករកបុគ្គលពាលនោះវិញ ដូចធូលីល្អិត ដែលបុគ្គលបាចសាចទៅកាន់ទីប្រាស់ខ្យល់ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បទុដ្ឋស្ស** *គឺបុគ្គលមិនប្រទូស្តចំពោះខ្លួន ឬចំពោះសព្វសត្វ ។ បទថា* **នរស្ស** *បានដល់ សត្វ ។ បទថា* **ទុស្សតិ** *ប្រែថា រមែងប្រព្រឹត្តខុស ។ បទថា* **សុទ្ធស្ស** *គឺជាអ្នកមិនមានកំហុស ។ ពាក្យថា* **ទោសស្ស** *នេះ ជាឈ្មោះរបស់សត្វនោះឯង ដោយអាការជាទៃ ។*

បទថា **អនង្គណស្ស** *គឺមិនមានកិលេស ។ ពាក្យថា* **បចេ្ចតិ** *កាត់បទជា* **បដិ ឯតិ** *ប្រែថា រមែងត្រឡប់ដល់ ។ បទថា* **បដិវាតំ** *ជាដើម សេចក្តីថា ធូលីដែលល្អិត ដែលបុរសម្នាក់បាចទៅ ដោយភាពជាអ្នកប្រាថ្នាប្រហារអ្នកជាទៃ ដែលឈរលើខ្យល់ រមែងត្រឡប់ដល់បុរសនោះឯង គឺធ្លាក់ចុះខាងលើរបស់អ្នកបាចទៅនោះឯង យ៉ាងណា បុគ្គលណា កាលឲ្យនូវការប្រហារដោយដៃជាដើម ឈ្មោះថា រមែងប្រទូស្តចំពោះបុរសដែលមិនប្រទូស្ត ចាប នោះឲ្យផលក្នុងបច្ចុប្បន្ននេះ ឬក្នុងអបាយទាំងឡាយ មាននរកជាដើម ក្នុងភព*

ខាងមុខ ឈ្មោះថា រមែងត្រឡប់ដល់បុគ្គលនោះឯង ដែលជាបុគ្គលពាល ដោយអំណាចវិបាកទុក្ខ ដូច្នោះដូចគ្នា ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះ តាំងនៅក្នុងអរហត្តផល ។ ព្រះធម្ម-ទេសនា មានប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយដូច្នោះឯង ។

រឿង ព្រាន១សុន១ ឈ្មោះ កោកៈ ចប់

រឿង ព្រះតិស្សត្ថេរកុលុបកៈរបស់ជាងកែវ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះ តិស្សៈ ដែលជាអ្នកចូលទៅកាន់ត្រកូលជាងកែវ ត្រាស់ព្រះធម្មទេសនានេះ ថា **គព្ភមេកេ ឧបជ្ជន្តិ** *ជាដើម ។*

បានឮថា ព្រះថេរៈនោះ ឆាន់ភត្តនៅក្នុងត្រកូលរបស់មណីការម្នាក់ អស់ ១២ ឆ្នាំ ។ ភរិយា និងស្វាមីក្នុងត្រកូលនោះ តាំងនៅក្នុងឋានៈដូច មាតាបិតា បដិបត្តិព្រះថេរៈហើយ ។

សម័យថ្ងៃមួយ មណីការកំពុងហាន់សាច់ខាងមុខព្រះថេរៈ ក្នុងខណៈ នោះ ព្រះបាទបសេនទិកោសល ទ្រង់បញ្ជូនកែវមណីមួយទៅ ដោយត្រាស់ ថា ចូរជាងកែវដុសខាត់ និងថ្លៃកែវមណីនេះ ហើយបញ្ជូនទៅ ។ មណីការ ទទួលកែវនោះដោយដៃទាំងប្រឡាក់ឈាម ដាក់លើជ្រញ់ ហើយចូលទៅ

ខាងក្នុងដើម្បីលាងដៃ ។

ក្នុងផ្ទះនោះ សត្វក្រៀលដែលគាត់ចិញ្ចឹមមាន ក្រៀលនោះលេបកែវមណីនោះដោយសម្គាល់ថាសាច់ ព្រោះភ្ជិនឈាម កាលព្រះថេរៈកំពុងឃើញនោះឯង មណីការមកហើយមិនឃើញកែវមណី ទើបសួរភរិយា ធីតា និងបុត្រ ដោយលំដាប់ថា ពួកអ្នកយកកែវមណីទៅឬ កាលជនទាំងនោះពោលថា មិនបានយកទេ ទើបគិតថា ប្រហែលជាព្រះថេរៈយក ទើបប្រឹក្សានឹងភរិយាថា កែវមណីប្រហែលព្រះថេរៈយក ភរិយាជ្រាបថា នែអ្នក អ្នកកុំពោលយ៉ាងនោះ ខ្ញុំមិនធ្លាប់ឃើញទោសណាមួយរបស់ព្រះថេរៈ អស់កាលប្រមាណប៉ុណ្ណោះ លោកមិនកាន់យកកែវនោះទេ ។ មណីការសួរព្រះថេរៈថា បពិត្រលោកម្ចាស់ លោកម្ចាស់យកកែវមណីក្នុងទីនេះឬ ព្រះថេរៈឆ្លើយថា ឧបាសក អាត្មាមិនបានកាន់យកទេ មណីការពោលថា ក្នុងទីនេះ មិនមានអ្នកដទៃទេ លោកម្ចាស់យកទៅដោយពិតជ្រាកដ សូមលោកម្ចាស់ឲ្យកែវមណីដល់ខ្ញុំចុះ ។

កាលព្រះថេរៈមិនទទួល ទើបនិយាយនឹងភរិយាថា ព្រះថេរៈយកកែវមណីពិត ខ្ញុំនឹងជំរិតសួរលោក ភរិយាឆ្លើយថា នែអ្នក អ្នកកុំឲ្យពួកយើងវិនាសទៅ ពួកយើងចូលដល់ភាពជាទាសៈប្រសើរជាង ការចាប់ទោសព្រះថេរៈបែបនេះ មិនប្រសើរទេ ។

ជាងកែវនោះពោលថា ពួកយើងទាំងអស់គ្នាចូលដល់នូវភាពជាទាសៈក៏មិនស្មើនឹងតម្លៃកែវមណី ដូច្នេះហើយ ទើបកាន់យកខ្សែ រុំក្បាលព្រះថេរៈមួលដោយកូនកំព្រា ។ ឈាមហូរចេញអំពីក្បាល ត្រចៀក និងច្រមុះរបស់

ព្រះថេរៈ ក្អែកទាំងពីរដល់នូវអាការលៀនចេញ លោកឈឺចាប់ខ្លាំង ក៏រលំចុះត្រង់ផែនដី សត្វក្រៀលមកដោយកិនឈាម បរិភោគឈាម ។

ខណៈនោះ ទើបមណីការទាត់ក្រៀលដោយជើងបណ្តើរ ពោលបណ្តើរថា អាមកធ្វើអ្វី ដោយកម្លាំងសេចក្តីក្រោធដែលកើតឡើងក្នុងព្រះថេរៈ សត្វក្រៀលនោះដួលស្លាប់ ដោយការទាត់ត្រឹមមួយជើងប៉ុណ្ណោះ ។ ព្រះថេរៈឃើញក្រៀលនោះ ទើបពោលថា ឧបាសក ចូរអ្នកបន្ទរខ្សែ ត្រង់ក្បាលរបស់អាត្មាសិន ហើយពិចារណាមើលក្រៀលនេះថា ស្លាប់ហើយ ឬនៅ លំដាប់នោះ ទើបជាងកែវពោលថា លោកក៏នឹងស្លាប់ដូចក្រៀលនោះ ព្រះថេរៈពោលថា ឧបាសក កែវមណីនោះ ក្រៀលនេះលេបហើយ បើក្រៀលនេះមិនទាន់ស្លាប់សោត ទោះបីអាត្មាស្លាប់ ក៏មិនជ្រាបកែវមណីដល់អ្នក ។

គាត់វិះពោះក្រៀលនោះ ឃើញកែវមណីហើយ មានចិត្តរន្ធត់ក្រាបចុះទៀបជាតជើងរបស់ព្រះថេរៈពោលថា សូមលោកម្ចាស់អត់ទោសដល់ខ្ញុំ ខ្ញុំមិនដឹង ទើបធ្វើហើយ ។ ព្រះថេរៈពោលថា ឧបាសក ទោសរបស់អ្នកមិនមាន របស់អាត្មាក៏មិនមាន នេះជាទោសរបស់វដ្តៈប៉ុណ្ណោះ អាត្មាអត់ទោសដល់អ្នក មណីការពោលថា បើលោកម្ចាស់អត់ទោសឲ្យខ្ញុំសោត សូមលោកម្ចាស់ ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំដូចសព្វមួយដងចុះ ព្រះថេរៈពោលថា ឧបាសក តាំងអំពីថ្ងៃនេះទៅ អាត្មាមិនចូលក្នុងសំយាបផ្ទះរបស់អ្នកជនៃឡើយ ព្រោះថា នេះជាទោសនៃការចូលទៅខាងក្នុងផ្ទះដោយត្រង់ តាំងអំពីនេះទៅ កាលជើងទាំងពីរនៅជើរបាន អាត្មានឹងឈរត្រង់ទ្វារផ្ទះប៉ុណ្ណោះ ទទួលភិក្ខា

ដូច្នេះហើយ សមាទានធុតង្គ ពោលគាថានេះថា

កត្តក្នុងត្រកូលទាំងឡាយតិចតួច ដែលគេចម្អិនទុកដើម្បីមុនី
អាត្មានឹងត្រាច់ទៅដោយកម្លាំងស្មងរបស់អាត្មាដែលមាន ។

កាលព្រះថេរៈពោលគាថានេះហើយ ក្នុងកាលមិនយូរ ក៏បរិនិព្វានដោយ ព្យាធិនោះឯង ។

សត្វក្រៀល បានបដិសន្ធិក្នុងផ្ទៃនៃភរិយារបស់ជាងកែវនោះ ។ ជាងកែវធ្វើកាលកិរិយាហើយកើតក្នុងនរក ភរិយារបស់ជាងកែវ ធ្វើកាលកិរិយាហើយកើតក្នុងទេវលោក ព្រោះអ្នកមានចិត្តទន់ក្នុងព្រះថេរៈ ។ ភិក្ខុទាំងឡាយទូលសួរអភិសម្បរាយភពរបស់ជនទាំងនោះនឹងព្រះសាស្តា ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ រមែងកើតក្នុងគភ៌ ពួកខ្លះធ្វើកម្មលាមក រមែងកើតក្នុងនរក សត្វពួកខ្លះធ្វើកម្មល្អហើយ រមែងកើតក្នុងទេវលោក ចំណែកអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

គព្ភមេកេ ឧបប្បជ្ជន្តិ និរយំ ចាបកម្មិនោ
សគ្គំ សុគតិនោ យន្តិ បរិនិព្វន្តិ អនាសវា ។

ជនពួកខ្លះ កើតក្នុងគភ៌មនុស្ស ពួកអ្នកមានអំពើអាក្រក់ ទៅកាន់នរក ពួកអ្នកមានគតិល្អ ទៅកាន់ស្ថានសួគ៌ ពួកអ្នកមិនមានអាសវៈ បរិនិព្វាន ។

សេចក្តីអធិប្បាយ

ក្នុងបទទាំងនោះ គកិមនុស្ស ព្រះសាស្តាទ្រង់បំណងយកក្នុងបទថា **គភ្ភំ** នេះ ពាក្យដ៏សេសក្នុងគាថានេះ មានអត្ថងាយយល់ទាំងអស់ហើយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងព្រះតិស្សត្ថេរកុលុបកៈរបស់ជាងកែវ ចប់

រឿងជន ៣ ពួក

លំនាំដើម

ព្រះសាស្តា កាលគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធជន ៣ ពួក ត្រាស់ព្រះធម្មទេសនានេះថា **ឯ អន្ធលិក្ខេ ឯ សមុទ្ទមច្ឆេ** ជាដើម ។

បានឮថា កាលព្រះសាស្តា គង់នៅក្នុងវត្តជេតពន ភិក្ខុច្រើនរូបមកបំណងដើម្បីគាល់ព្រះសាស្តា ចូលទៅកាន់ភូមិមួយ ដើម្បីបិណ្ឌបាត អ្នកស្រុកទទួលបាត្ររបស់ភិក្ខុទាំងនោះហើយ និមន្តឲ្យគង់ក្នុងរោងធាន់ ប្រគេនបបរ និងរបស់ទំពា កាលរង់ចាំពេលបិណ្ឌបាត អង្គុយស្តាប់ធម៌ហើយ ។ ខណៈនោះ អណ្តាតភ្លើងឆេះឡើងអំពីជើងក្រានរបស់ស្រីម្នាក់ដែលចម្អិនបាយ ហើយចម្អិនសូបៈ និងព្យញ្ជនៈដល់ដំបូល រង្វេលស្មៅមួយហោះឡើងអំពីដំបូលនោះ ដែលភ្លើងឆេះ ទៅកាន់អាកាស ។ ក្នុងខណៈនោះ ក្អែកមួយហើរមកតាមអាកាស ស៊កកចូលទៅក្នុងរង្វេលស្មៅនោះ ត្រូវរង្វេលស្មៅរុំហើយ

ឆេះធ្លាក់ស្ទាប់ត្រង់កណ្តាលស្រុក ។ ពួកភិក្ខុឃើញហេតុនោះ គិតថា ឱកម្មធ្ងន់អាវុសោអ្នកទាំងឡាយ ចូរមើលអាការប្លែក ដែលក្អែកដល់ហើយ បើវៀរព្រះសាស្តា អ្នកណានឹងជឿងកម្មដែលក្អែកនេះធ្វើហើយ ពួកយើងនឹងទូលសួរកម្មរបស់ក្អែកនោះនឹងព្រះសាស្តា ដូច្នេះហើយ ក៏នាំគ្នាចៀសចេញទៅ ។

ភិក្ខុមួយពួកទៀត ធ្វើដំណើរតាមសំពៅទៅដើម្បីគាល់ព្រះសាស្តា សំពៅបានកៀងកណ្តាលសមុទ្រ ។ ពួកមនុស្សនាំគ្នាគិតថា មនុស្សកាឡកិណីគប្បីមានក្នុងសំពៅនេះ ដូច្នេះហើយ ទើបឲ្យចាប់ស្វាក ។ ភរិយានាយសំពៅតាំងនៅក្នុងបឋមវ័យគួរមើល ស្វាកក៏ដល់នាងនោះ ។ ពួកមនុស្សនាំគ្នាពោលថា ចូរចែកស្វាកសាជាថ្មី ហើយឲ្យចាប់ដល់ ៣ ដង ស្វាកត្រូវនាងនោះដល់ទៅ ៣ ដង ពួកមនុស្សមើលមកនាយសំពៅពោលថា ធ្វើយ៉ាងណាលោក នាយសំពៅពោលថា ខ្ញុំមិនអាចឲ្យមហាជនវិនាសដើម្បីប្រយោជន៍ដល់នាងនេះ ចូរពួកអ្នកបោះនាងទៅក្នុងទឹកចុះ ។ ស្រីនោះ កាលពួកមនុស្សចាប់បោះទៅក្នុងទឹក ខ្លាចចំពោះមរណភ័យ បានស្រែកយំហើយ ។ នាយសំពៅបានឮសម្រែកនោះ ទើបពោលថា ប្រយោជន៍អ្វីដោយអាកវណៈ ដែលដល់នូវសេចក្តីវិនាសទៅ ចូរពួកអ្នកដោះគ្រឿងអាកវណៈទាំងអស់ ឲ្យស្ងៀកសំពត់ចាស់មួយផ្ទាំង ហើយបោះស្រីនោះ ឯខ្ញុំមិនអាចមើលស្រីនោះ ដែលអណ្តែតលើផ្ទៃទឹកបាន ព្រោះដូច្នោះ ចូរពួកអ្នកយកក្អម ដែលពេញដោយដីខ្សាច់ ចងត្រង់កហើយ បោះទៅក្នុងមហាសមុទ្រចុះ ដោយប្រការដែលខ្ញុំមិនឃើញនាង ។ មនុស្សទាំងនោះ បានធ្វើតាមនោះហើយ ។ ត្រី និងអណ្តើក ចោមរោមស៊ី

ស្រីនោះក្នុងទីដែលជ្រាក់នោះឯង ។ ពួកភិក្ខុឃើញរឿងនោះហើយក៏គិតថា ជនដទៃវៀរព្រះសាស្តាហើយ នឹងដឹងកម្មរបស់ស្រីនោះមិនមាន ពួកយើងនឹងទូលសួរកម្មរបស់ស្រីនោះនឹងព្រះសាស្តា ដល់ទីដែលច្រូថ្នាហើយ ទើបនាំគ្នាចុះអំពីសំពៅចៀសចេញទៅ ។

ភិក្ខុ ៧ រូបមួយពួកទៀត ទៅអំពីបច្ចន្តជនបទដើម្បីគាល់ព្រះសាស្តា ក្នុងពេលល្ងាចចូលទៅកាន់វត្តមួយ ហើយសួរដល់ទីសម្រាក ក្នុងគុហាមួយកន្លែងមានគ្រែ ៧ កាលភិក្ខុទាំងនោះបានគុហានោះឯង សិងលើគ្រែនោះហើយលុះដល់ពេលយប់ ផ្ទាំងថ្មប៉ុនផ្ទះកំពូលរមៀលចុះមកបិទទ្វារគុហា ។ ពួកភិក្ខុពោលថា ពួកយើងឲ្យគុហានេះដល់អាគន្តុកភិក្ខុ ផ្ទាំងថ្មធំនេះបានបិទទ្វារគុហាហើយ ។ ពួកយើងនឹងប្រមៀលផ្ទាំងថ្មនោះចេញ ហើយឲ្យប្រជុំពួកមនុស្ស ៧ ស្រុកដោយជុំវិញ កាលព្យាយាមក៏មិនអាចធ្វើផ្ទាំងថ្មនោះឲ្យឃ្លាតចាកទី ។

សូម្បីពួកភិក្ខុដែលចូលទៅខាងក្នុង ក៏ព្យាយាមដូចគ្នា កាលបើដូច្នោះក៏នៅតែមិនអាចធ្វើផ្ទាំងថ្មនោះឲ្យឃ្លាតចាកទីបាន រហូត ៧ ថ្ងៃ ពួកអាគន្តុកភិក្ខុត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ អស់ ៧ ថ្ងៃ សោយទុក្ខធំហើយ ។ ក្នុងថ្ងៃទី ៧ ផ្ទាំងថ្មក៏បានរមៀលទៅឯង ពួកភិក្ខុចេញទៅហើយគិតថា បាបរបស់ពួកយើងនេះ វៀរព្រះសាស្តាចេញហើយ អ្នកណានឹងដឹងបាន ពួកយើងនឹងទូលសួរព្រះសាស្តា ដូច្នេះហើយ នាំគ្នាចៀសចេញទៅ ។

ភិក្ខុទាំងនោះ មកជួបគ្នាជាមួយពួកភិក្ខុពួកមុនក្នុងរវាងផ្លូវ រួមគ្នាជាពួកតែមួយ ចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយនាចំណែកម្ខាង មាន

បដិសណ្ឋារៈ ដែលព្រះសាស្តាទ្រង់ធ្វើហើយ ទើបទូលសួរដល់ហេតុដែលខ្លួនឃើញ និងដែលខ្លួនសោយមកហើយតាមលំដាប់ សូម្បីព្រះសាស្តាក៏ត្រាស់ព្យាករដល់ភិក្ខុទាំងនោះដោយលំដាប់យ៉ាងនេះ ។

ម្នាលភិក្ខុទាំងឡាយ ក្អែកនោះបានសោយកម្មដែលខ្លួនធ្វើហើយនោះឯង ដោយពិត ។ ក្នុងអតីតកាល អ្នកស្រែម្នាក់ក្នុងក្រុងពារាណសី បង្វឹកគោរបស់ខ្លួន មិនអាចបង្វឹកបាន ដ្បិតថា គោរបស់គាត់នោះ ដើរទៅបានបន្តិចហើយក៏ដេក សូម្បីបុរសនោះវាយឲ្យក្រោកឡើងហើយ ដើរទៅបានបន្តិចក៏ដេកដូចមុននោះឯង ។ អ្នកស្រែនោះព្យាយាមហើយ ក៏មិនអាចបង្វឹកគោនោះបាន ជាបុគ្គលត្រូវសេចក្តីក្រោធគ្របសង្កត់ហើយ ទើបពោលថា ឥឡូវនេះ ឯងដេកឲ្យសុខតាំងអំពីនេះទៅ ដូច្នេះហើយ យកចំបើងរុំកគោនោះ ហើយដុតដោយភ្លើង ។ គោត្រូវភ្លើងឆេះស្លាប់ក្នុងទីនោះឯង ម្នាលភិក្ខុទាំងឡាយ ចាបកម្មនោះ ដែលក្អែកនោះធ្វើហើយក្នុងកាលនោះ ។ បុរសនោះ ឆេះក្នុងនរកអស់កាលយូរ ដោយផលនៃវិបាកដែលសេសសល់នៃចាបកម្មនោះ កើតហើយក្នុងកំណើតក្អែក ៧ ជង ត្រូវភ្លើងឆេះស្លាប់ក្នុងអាកាស យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ស្រីនោះសោយផលកម្មដែលខ្លួនធ្វើហើយដូចគ្នា ។ ក្នុងអតីតកាល ស្រីនោះជាភរិយារបស់គហបតីម្នាក់ ក្នុងក្រុងពារាណសី បានធ្វើកិច្ចគ្រប់យ៉ាង មានរែកទឹក បុកអង្ករ ចម្អិនអាហារជាដើមដោយដៃរបស់ខ្លួន ឆ្កែមួយរបស់នាងអង្គុយមើលនាងនោះ ដែលធ្វើកិច្ចគ្រប់យ៉ាងក្នុងផ្ទះ ។ កាលស្រីនោះនាំកត្តៅទៅស្រែក្តី ទៅព្រៃដើម្បីរកវត្ថុផ្សេងៗ មានឧស និងបន្លែ

ជាដើមក្តី ឆ្កែនោះរមែងទៅជាមួយនាងនោះឯងជានិច្ច ។ ពួកកំលោះឃើញ ដូច្នោះ រមែងចំអន់ថា នែបា ព្រោនឆ្កែចេញដំណើរហើយ ថ្ងៃនេះពួកយើងនឹង ស៊ីបាយជាមួយសាច់ នាងខ្ចាសព្រោះពាក្យនិយាយរបស់ពួកមនុស្សទាំងនោះ ទើបប្រហារឆ្កែនោះដោយដុំដី និងអង្កត់ឧសជាដើមឲ្យគេចចេញទៅ ។ ឆ្កែត្រឡប់ ហើយក៏តាមទៅទៀត ។ បានឮថា ឆ្កែនោះ ត្រូវជាប្តីរបស់នាងក្នុងអត្តភាពទី ៣ ហេតុនោះ ទើបឆ្កែនោះមិនអាចកាត់សេចក្តីស្នេហាបាន មែនពិត បុគ្គលណាម្នាក់ ឈ្មោះថាមិនធ្លាប់ជាប្រពន្ធ ឬជាប្តីគ្នានិងគ្នា ក្នុងសង្សារ ដែលមិនមានទីបំផុត មិនមានដោយពិត តែសេចក្តីស្រឡាញ់មានប្រមាណក្រៃលែង រមែងមានក្នុងបុគ្គលដែលជាញាតិនឹងគ្នាក្នុងអត្តភាពមិនឆ្ងាយ ហេតុនោះ ទើបឆ្កែនោះមិនអាចលះស្រីនោះបាន ។ នាងក្រោធនឹងឆ្កែនោះ កាលនាំបបរទៅដើម្បីប្តីឯស្រែ ទើបយកខ្សែជាក់ក្នុងជាយថ្នក់ហើយទៅ ឆ្កែទៅជាមួយនាងដូចគ្នា ។ នាងឲ្យបបរដល់ប្តីហើយ កាន់ក្អមទទេទៅកាន់កំពង់ទឹកមួយកន្លែង ជាក់ខ្សាច់ពេញក្អមហើយ ធ្វើសំឡេងដល់ឆ្កែដែលឈរមើលក្នុងទីជិត ។ ឆ្កែសប្បាយថា យូរហើយហ្ន៎ អញបានពាក្យពីរោះក្នុងថ្ងៃនេះ ទើបបក់កន្ទុយចូលទៅរក ។ នាងចាប់ឆ្កែនោះយ៉ាងមាំត្រង់កហើយ ទើបយកចុងខ្សែម្ខាងចងក្អមចុងម្ខាង ចងត្រង់កឆ្កែ ប្រមៀលក្អមចូលទៅក្នុងទឹក ឆ្កែក៏ដោយតាមក្អមទៅជ្រាក់ក្នុងទឹក ស្លាប់ក្នុងទឹកនោះឯង ។ ស្រីនោះ ឆេះក្នុងនរកអស់កាលយូរ ព្រោះវិបាករបស់កម្មនោះ ។ ដោយវិបាកដ៏សេស ទើបនាងត្រូវគេយកក្អមពេញដោយជីខ្សាច់ ចងត្រង់កបោះទៅក្នុងទឹក ធ្វើកាលកិរិយាយ៉ាងនេះ

អស់មួយរយអត្តភាព ។

ម្នាលភិក្ខុទាំងឡាយ ពួកអ្នកក៏មានការសោយកម្ម ដែលខ្លួនធ្វើហើយជួបគ្នា ។ ក្នុងអតីតកាល ក្នុងក្រុងពារាណសី ក្មេងគង្វាលគោ ៧ នាក់ ត្រាច់ឃ្វាលគោមួយកន្លែង ៧ ថ្ងៃ ក្នុងទីជិតព្រៃមួយកន្លែង ។ ថ្ងៃមួយ ឃ្វាលគោហើយ ត្រឡប់មកជួបទន្សាយធំមួយ ទើបដេញតាម ទន្សាយគេចចូលទៅកាន់ដំបូកមួយ ឯរន្ធនៃដំបូកនោះមាន ៧ ពួកក្មេងប្រឹក្សាគ្នាថា ឥឡូវនេះ ពួកយើងមិនអាចចាប់បាន ស្អែកនេះ សឹមនាំគ្នាមកចាប់ ដូច្នេះហើយ ម្នាក់ៗកាន់យកមែកឈើដែលកាច់ ម្នាក់មួយក្តាប់ៗ ទាំង ៧ នាក់ នាំគ្នាចុករន្ធទាំង ៧ ហើយចៀសចេញទៅ ។ ក្នុងថ្ងៃស្អែកឡើង ក្មេងទាំងនោះមិនបាននឹកដល់ទន្សាយនោះ ឃ្វាលគោក្នុងទីដទៃ លុះគ្រប់ ៧ ថ្ងៃ នាំគ្នាត្រឡប់មក ជួបដំបូកនោះ ក៏បានទូវស្សារតីគិតគ្នាថា ទន្សាយនោះជូចម្តេចទៅហើយហ្ន៎ ទើបជកធ្មុកដែលបិទហើយ ។ ទន្សាយអស់អាល័យក្នុងជីវិត សល់តែស្បែកជណ្តប់ឆ្អឹងលួនចេញមក ក្មេងទាំងនោះឃើញដូច្នេះហើយ កើតទូវការអណិត ពោលថា ពួកយើងកុំសម្លាប់វាឡើយ គ្នាអត់អាហារអស់ ៧ ថ្ងៃ ទើបស្មូបខ្នងទន្សាយនោះហើយលែងទៅដោយពោលថា ចូរឯងទៅតាមសប្បាយចុះ ក្មេងទាំងនោះមិនធ្លាក់ក្នុងនរក ព្រោះមិនបានសម្លាប់ទន្សាយ តែជនទាំង ៧ នោះ បានជាអ្នកអត់ជាយរួមគ្នា ៧ ថ្ងៃៗ អស់ ១៤ អត្តភាព ។ ម្នាលភិក្ខុទាំងឡាយ កម្មនោះ ពួកអ្នកជាក្មេងឃ្វាលគោ ៧ នាក់ ធ្វើហើយ ក្នុងកាលនោះ ។

ព្រះសាស្តា ទ្រង់ព្យាករបញ្ហាដែលភិក្ខុនោះទូលសួរហើយ ដោយប្រការ

ដូច្នេះ ។

គ្រានោះ ភិក្ខុមួយរូប ទូលព្រះសាស្តាថា បពិត្រព្រះអង្គ ការរួចផុតរមែងមិនមានដល់សត្វដែលធ្វើបាបកម្មហើយ ទោះហោះទៅក្នុងអាកាសក្តី នៅក្នុងមហាសមុទ្រក្តី ចូលកាន់រូងភ្នំក្តី ដូច្នេះឬ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ក្នុងទីទាំងឡាយ មានអាកាសជាដើម ប្រទេសត្រឹមតែមួយដែលបុគ្គលនៅហើយ គប្បីផុតចាកបាបកម្ម មិនមាន កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ ន បព្វតានំ វិវរំ បវិសំ
ន វិជ្ជតី សោ ជគតិប្បទេសោ យត្ថដ្ឋិតោ មុញ្ចេយ្យ បាបកម្មា ។

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលស្ថិតនៅហើយ គប្បីរួចចាកបាបកម្មបាននោះ មិនដែលមានឡើយ ។

សេចក្តីអធិប្បាយ

សេចក្តីនៃព្រះគាថានោះថា បើបុគ្គលខ្លះគិតថា អញនឹងផុតចាកបាបកម្មដោយឧបាយនេះ គប្បីអង្គុយក្នុងអាកាសក្តី គប្បីចូលទៅមហាសមុទ្រ ដែលមានជម្រៅ ៨៤០០០ យោជន៍ក្តី គប្បីអង្គុយក្នុងញកភ្នំក្តី បុគ្គលនោះ មិនគប្បីផុតចាកកម្មអាក្រក់បានឡើយ ព្រោះថា ក្នុងចំណែកនៃផែនដី គឺភាគនៃប្រឹថពី មានទិសខាងកើតជាដើម ឱកាសប្រមាណប៉ុនចុងរោមទ្រាយ ដែល

បុគ្គលនៅហើយ គប្បីអាចរួចផុតចាកចុបកម្មបានមិនមាន ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ព្រះធម្មទេសនាជាកថាមានប្រយោជន៍ ដល់មហាជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង ៨ន ៣ ពួក ចប់

រឿង ព្រះចាឧសុប្បពុទ្ធសក្យៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារឰសក្យរាជព្រះនាមសុប្បពុទ្ធ ត្រាស់ព្រះធម្មទេសនានេះថា **ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ** ជាដើម ។

បានឮមកថា ព្រះបាទសុប្បពុទ្ធអង្គនោះ ចង់អាឃាតព្រះសាស្តាដោយហេតុ ២ យ៉ាង គឺព្រះសមណគោតមនេះ ចោលកូនស្រីរបស់អញចេញបួស ១ ឲ្យកូនប្រុសរបស់អញបួសហើយ តាំងនៅក្នុងឋានៈជាសត្រូវចំពោះកូនប្រុសអញ ១ ។ ថ្ងៃមួយ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ អញនឹងមិនឲ្យព្រះសមណគោតមនោះ ទៅឆាន់ក្នុងទីដែលនិមន្តដូច្នេះ ទើបបិទផ្លូវដែលយាង ទៅអង្គុយសោយទឹកចណ្តក្នុងរវាងចន្ទោះផ្លូវ ។

លំដាប់នោះ កាលព្រះសាស្តា មានភិក្ខុសង្ឃចោមរោមយាងមកទីនោះ

ពួកមហាតលិកក្រាបទូលថា ព្រះសាស្តាយាងមកហើយ ព្រះរាជាត្រាស់ថា ចូរពួកអ្នកទៅមុន ច្រាប់សមណៈនោះថា ព្រះសមណគោតម មិនជាធំជាងយើងទេឬយ យើងនឹងមិនឲ្យផ្លូវដល់សមណគោតមនោះ សូម្បីពួកមហាតលិកទូលជាស់តឿនហើយ ក៏នៅប្រថាប់គង់ត្រាស់យ៉ាងនោះហើយ ។

ព្រះសាស្តា មិនបានផ្លូវអំពីសម្នាក់របស់ព្រះមាតុលៈហើយ ទើបយាងត្រឡប់អំពីទីនោះ ។ សូម្បីព្រះរាជាក៏ទ្រង់បញ្ជូនចារបុរសម្នាក់ទៅដោយត្រាស់ថា ចូរអ្នកទៅស្តាប់ពាក្យរបស់សមណគោតមនោះ ហើយត្រឡប់មក ។

ព្រះសាស្តាយាងត្រឡប់មក ទ្រង់ធ្វើការញញឹម ព្រះអានន្ទត្ថេរទូលថា បពិត្រព្រះអង្គ អ្វីហ្ន៎ជាបច្ច័យនៃកម្ម គឺការញញឹមឲ្យច្រើនដង ទើបព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ អ្នកឃើញព្រះបាទសុប្បពុទ្ធដែរឬទេ ព្រះថេរៈទូលថា បពិត្រព្រះអង្គ ឃើញ ព្រះសាស្តាត្រាស់ថា ព្រះបាទសុប្បពុទ្ធនោះមិនឲ្យផ្លូវដល់ព្រះពុទ្ធដូចតថាគត ធ្វើកម្មធ្ងន់ហើយ ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ ទ្រង់នឹងចូលទៅកាន់ផែនដី ក្នុងទីជិតជណ្តើរ ខាងក្រោមប្រាសាទ ។

ចារបុរសបានស្តាប់ព្រះតម្រាស់នោះហើយ ទៅកាន់សម្នាក់របស់ព្រះបាទសុប្បពុទ្ធ ព្រះរាជាត្រាស់សួរថា ក្មួយរបស់យើងកាលត្រឡប់ទៅនិយាយអ្វីខ្លះ ទើបក្រាបទូលតាមដែលខ្លួនបានឮ ។

ព្រះរាជាបានស្តាប់ពាក្យរបស់ចារបុរសនោះហើយ ត្រាស់ថា ឥឡូវនេះ ក្នុងការនិយាយខុសនៃក្មួយរបស់យើងមិនមាន ទ្រង់ត្រាស់ពាក្យណា ពាក្យនោះ ត្រូវពិតដូច្នោះឯង កាលបើដូច្នេះ ឥឡូវនេះ យើងនឹងចាប់កំហុសរបស់

ទ្រង់ ដោយការនិយាយកុហក ព្រោះទ្រង់មិនត្រាស់ជាមួយយើងដោយចំពោះថា ព្រះបាទសុប្បពុទ្ធនឹងត្រូវធរណីស្រូបក្នុងថ្ងៃទី ៧ តែត្រាស់ថា យើងនឹងត្រូវធរណីស្រូបក្នុងទីជិតជណ្តើរខាងក្រោមប្រាសាទ តាំងអំពីថ្ងៃនេះទៅ យើងនឹងមិនទៅកាន់ទីនោះ កាលបើដូច្នោះ យើងមិនត្រូវធរណីស្រូបក្នុងទីនោះ ហើយនឹងសង្កត់សង្កិនទ្រង់ដោយការពោលកុហក ។

ព្រះរាជាត្រាស់ឲ្យពួកមហាតលិកជញ្ជួនគ្រឿងប្រើប្រាស់របស់ទ្រង់ចេញទាំងអស់ទុកលើប្រាសាទ ៧ ជាន់ ឲ្យដកជណ្តើរ បិទទ្វារ តាំងមនុស្សដែលមានកម្លាំងទុកត្រង់ទ្វារ មួយទ្វារពីរនាក់ ត្រាស់ថា បើយើងចុះទៅខាងក្រោមដោយប្រមាទសោត ពួកអ្នកត្រូវឃាត់យើង ដូច្នេះហើយ ប្រថាប់គង់ក្នុងបន្ទប់ដ៏មានសិរី លើផ្ទៃប្រាសាទជាន់ទី ៧ ។

ព្រះសាស្តា ទ្រង់ស្តាប់រឿងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទសុប្បពុទ្ធ មិនមែនគង់លើផ្ទៃប្រាសាទតែម្យ៉ាង ទោះបីហោះទៅកាន់អាកាស អង្គុយលើអាកាសក្តី ទៅកាន់សមុទ្រដោយទូកក្តី ចូលញាកភ្នំក្តី ធម្មតាព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយ មិនបែកជាពីរឡើយ ព្រះរាជានឹងត្រូវធរណីស្រូប ក្នុងទីដែលតថាគតពោលនោះឯង កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ ន បព្វតានំ វិវរំ បវិស្ស

ន វិជ្ជតិ សោ ជគតិប្បទេសោ យត្រត្ថិតំ ន ប្បសហេយ្យ មច្ចុ ។

បុគ្គលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះនៃភ្នំទាំង-ទ្បាយ ក៏មិនរួចចាកសេចក្តីស្លាប់បាន ព្រោះប្រទេសលើផែនដី ដែលបុគ្គលស្ថិតនៅហើយ សេចក្តីស្លាប់គ្របសង្កត់មិនបាននោះ មិនដែលមានទ្បើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ន ប្បសហេយ្យ មច្ចុ** *សេចក្តីថា ប្រទេសគឺផែនដី សូម្បីត្រឹមប៉ុនចុងសក់ ដែលមរណៈមិនគប្បីញាំញី គឺមិនគប្បីគ្របសង្កត់បុគ្គលស្ថិតនៅរមែងមិនមាន ពាក្យដ៏សេស ក៏ដូចគ្នានឹងពាក្យមុននោះឯង ។ ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងទ្បាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។*

ក្នុងថ្ងៃទី ៧ ក្នុងពេលដែលព្រះបាទសុប្បពុទ្ធបិទផ្លូវកិច្ចាការរបស់ព្រះសាស្តា សេះមង្គលរបស់ព្រះបាទសុប្បពុទ្ធ នៅខាងក្រោមប្រាសាទស្រែកកញ្ជ្រៀវ ទង្គិចនូវជញ្ជាំងនោះ ។

ព្រះរាជាប្រថាប់គង់លើប្រាសាទនោះឯង បានស្តាប់សំឡេងរបស់សេះនោះគ្រាស់សួរថា នុ៎ះជាសំឡេងអ្វី មហាតលិកទូលថា សេះមង្គលកញ្ជ្រៀវចំណែកសេះនោះ គ្រាន់តែឃើញព្រះបាទសុប្បពុទ្ធ ក៏នៅស្ងៀម ។

ខណៈនោះ ព្រះរាជាមានបំណងនឹងចាប់សេះនោះ បានចុះអំពីទីប្រថាប់ បែរមុខមកកាន់ទ្វារ ទ្វារទាំងឡាយបើកឯងនោះឯង ជណ្តើរតាំងនៅក្នុងទីរបស់ខ្លួនដូចមុន បុរសមានកម្លាំងឈរត្រង់ទ្វារ ចាប់ព្រះរាជាត្រង់ក រុញឲ្យមានមុខចុះមកខាងក្រោម ។ ដោយឧបាយនោះ ទ្វារត្រង់ផ្ទៃប្រាសាទទាំង ៧ ក៏បើកឯងនោះឯង ជណ្តើរទាំងឡាយក៏តាំងនៅដូចដើម ពួកបុរសដែលមានកម្លាំងចាំយាមក្នុងទីនោះៗ ចាប់ព្រះរាជាត្រង់កហើយ ច្រានព្រះរាជាឲ្យមានមុខចុះមក ។

ខណៈនោះ មហាប្រឹថពីប្រះរង់ចាំព្រះបាទសុប្បពុទ្ធនោះ ដែលដល់ត្រង់ទីជិតជណ្តើរខាងក្រោមប្រាសាទនោះឯង ព្រះរាជាទៅកើតក្នុងអវីចីនរកហើយ ៗ

រឿងព្រះចាឧសុប្បពុទ្ធសក្យៈ ចប់

ចាបវគ្គ ចប់

វគ្គទី ៩ ចប់

សុត្តន្តបិដក

ធម្មបទគាថា ឧណ្ហវគ្គទី ៥

[២០] *សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំង-ឡាយ តែងខ្លាចចំពោះសេចក្តីស្លាប់គ្រប់ៗ រូប បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមា ហើយ មិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។*

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា (ព្រោះថា) ជីវិត ជាទីស្រឡាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមាហើយ មិនគួរ ប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។ ជនណា ស្វែងរក សេចក្តីសុខ ដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្តីសុខ ដោយអាជ្ញា ជននោះលះលោកនេះទៅហើយ នឹងមិនបានសេចក្តីសុខឡើយ។ ជនណា ស្វែងរកសេចក្តីសុខ ដើម្បីខ្លួន តែមិនបៀតបៀនសត្វទាំងឡាយ អ្នកដែលប្រាថ្នាសេចក្តីសុខ ដោយអាជ្ញា ជននោះ លះលោកនេះទៅហើយ រមែងបានសេចក្តីសុខ ។

អ្នកកុំនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនទាំងឡាយដែល អ្នកស្តីថាឲ្យហើយ គេគប្បីស្តីថាតបមកអ្នកវិញ ព្រោះថា ការពោលពាក្យ ប្រណាំងប្រជែង ជាហេតុនាំឲ្យកើតទុក្ខ ការតស៊ូទាំងឡាយ គប្បីប៉ះពាល់នូវ អ្នក ។ បើអ្នកធ្វើខ្លួនមិនឲ្យញាប់ញ័រ ដូចរគាំងដែលចៀរមាត់ចេញ ហើយ (រមែងមិនលាន់ឮសូរ) ដូច្នោះ អ្នកនុ៎ះ ជាបុគ្គលដល់នូវព្រះនិព្វាន ការប្រណាំងប្រជែង មិនមានដល់អ្នក ។

គង្វាលគោ រមែងកៀងគោទៅកាន់ទីគោចរ ដោយអាជ្ញា ដូចម្តេចមិញ ជរា និងមច្ចុ តែងកៀងអាយុរបស់សត្វទាំងឡាយ ដូច្នោះឯង ។

បុគ្គលមិនមានប្រាជ្ញា កាលធ្វើអំពើអាក្រក់ រមែងមិនក្លាក់ខ្លួន លុះកាលជាខាងក្រោយ ទើបក្តៅក្រហាយ ដោយសារកម្មរបស់ខ្លួន ដូចត្រូវភ្លើងឆេះ ។

បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡាចិត្ត (ឆ្គួត) ១ រឹបជាន់អំពីស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់ពួកញាតិវិលឆ ១ ពុកផុយភោគសម្បត្តិទាំងឡាយ ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ ១ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។ ការប្រព្រឹត្តអាក្រាតកាយ ទុកសក់ ដេកលើកក់ មិនបរិភោគថ្ងៃ ដេកលើផែនដី ប្រឡាក់ខ្លួនដោយធូលី ព្យាយាមអង្គុយច្រហោង មិនជម្រះសត្វដែលមិនទាន់ឆ្លងផុតសេចក្តីសង្ស័យបានទេ ។

បើបុគ្គលណា មានខ្លួនប្រដាប់ស្អិតស្អាងហើយ (ដោយគ្រឿងអម្ពរ) តែគប្បីប្រព្រឹត្តស្មើ អ្នកស្ងប់រម្ងាប់ ទូន្មាន (ឥន្ទ្រិយ) ជាបុគ្គលទៀង (ចំពោះមគ្គផល) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញា ក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះ ហៅថា ព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថាភិក្ខុក៏បាន ។

បុរសអ្នកកម្ចាត់បង់នូវអកុសលវិតក្ក ដោយសេចក្តីខ្នាសបាប មានតិចក្នុងលោក បុគ្គលណាបន្ទោបង់ នូវការដេកលក់ ដូចសេះល្អខ្លាចព្រោះរំពាត់ បុរសនោះ រកបានដោយក្រក្នុងលោក ។

សេះល្អ ដែលនាយសារថីទូន្មាន ដោយរំពាត់ តក់ស្លុត យ៉ាងណា អ្នកទាំងឡាយ ចូរជាបុគ្គលមានព្យាយាម មានសេចក្តីតក់ស្លុតយ៉ាងនោះឯង បើអ្នកទាំងឡាយ ប្រកបព្រមដោយសទ្ធាផង សីលផង ព្យាយាមផង សមាធិផង ធម្មវិនិច្ឆ័យផង ជាអ្នកមានវិជ្ជា និងចរណៈដ៏បរិបូណ៌ មានស្មារតីតម្កល់មាំ រមែងលះបង់ទុក្ខ មានប្រមាណច្រើននេះមិនខាន ។

ធម្មតាអ្នកបង្ហូរ តែងបង្ហូរទឹក អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់) អ្នកចាំង តែងចាំងឈើ អ្នកមានវត្តល្អ តែងទូន្មានខ្លួន ។

ទណ្ឌវគ្គទី ១០ ចប់

អដ្ឋកថា

ឧណ្ហវគ្គទី ១០

រឿង ឆព្វគ្គិយភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឆព្វគ្គិយភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា **សព្វេ តសន្តិ** *ជាដើម ។*

សេចក្តីពិស្តារថា សម័យមួយ កាលសេនាសនៈដែលសត្តរសវគ្គិយភិក្ខុជួសជុលហើយ ឆព្វគ្គិយភិក្ខុពោលថា ចូរពួកលោកចេញទៅ ពួកខ្ញុំចាស់ជាងសេនាសនៈនោះដល់លំដាប់ពួកខ្ញុំ កាលសត្តរសវគ្គិយភិក្ខុទាំងនោះពោលថា ពួកខ្ញុំមិនឲ្យ ព្រោះពួកខ្ញុំជួសជុលមុន ដូច្នេះហើយ ទើបប្រហារភិក្ខុទាំងនោះ ។ សត្តរសវគ្គិយភិក្ខុត្រូវមរណភ័យគំរាមហើយ ទើបយំទ្រហឹង ។

ព្រះសាស្តា ទ្រង់ស្តាប់សំឡេងរបស់ភិក្ខុទាំងនោះ ទើបត្រាស់សួរថា តើមានរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ រឿងឈ្មោះនេះដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចាប់តាំងអំពីនេះទៅ ធម្មតាភិក្ខុមិនគួរធ្វើយ៉ាងនោះ ភិក្ខុណាធ្វើ ភិក្ខុនោះត្រូវអាបត្តិឈ្មោះនេះ ដូច្នេះហើយ ទ្រង់បញ្ញត្តបហារទានសិក្ខាបទ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុដឹងថា អាត្មាអញរមែងតក់ស្លុតចំពោះអាជ្ញា ខ្លាចចំពោះសេចក្តីស្លាប់ យ៉ាងណា

សូម្បីសត្វដទៃ ក៏រមែងតក់ស្លុតចំពោះអាជ្ញា ខ្លាចចំពោះសេចក្តីស្លាប់ដូច្នោះ ដូចគ្នា មិនគួរប្រហារឯង មិនគួរប្រើឲ្យសម្លាប់អ្នកដទៃ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

សព្ពេ តសន្តិ ទណ្ឌស្ស សព្ពេ ភាយន្តិ មច្ចុនោ
អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។

សត្វទាំងឡាយ គ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំងឡាយ តែងខ្លាចចំពោះសេចក្តីស្លាប់គ្រប់ៗ រូប បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមាហើយ មិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **សព្ពេ តសន្តិ** *សេចក្តីថា សត្វទាំងអស់កាលអាជ្ញាធ្លាក់ដល់ខ្លួន រមែងតក់ស្លុតចំពោះអាជ្ញានោះ ។*

បទថា **មច្ចុនោ** *បានដល់ រមែងខ្លាចចំពោះសេចក្តីស្លាប់ពិត ។*

ព្យញ្ជនៈនៃទេសនានេះមិនមានសល់ ចំណែកអត្ថនៅមានសល់ ឧបមាដូចកាលព្រះរាជាប្រើឲ្យពួករាជបុរសវាយស្គរប្រកាសថា ជនទាំងអស់ ចូរប្រជុំគ្នា ជនទាំងឡាយដ៏សេស រៀវព្រះរាជា និងអមាត្យ រមែងប្រជុំគ្នាយ៉ាងណា កាលព្រះសាស្តាត្រាស់ថា សត្វទាំងអស់ រមែងតក់ស្លុត ដូច្នេះ សត្វទាំងឡាយដ៏សេស រៀវសត្វពិសេស ៤ ពួក គឺដីរអាជានេយ្យ សេះអាជានេយ្យ គោឧសភអាជានេយ្យ និងព្រះខីណាស្រព បណ្ឌិតគប្បីជ្រាបថា

រមែងតក់ស្លុតដូច្នោះដូចគ្នា ។ ពិតហើយ បណ្តាសត្វវិសេសទាំងនេះ ព្រះខីណាស្រពមិនឃើញសត្វដែលស្ងាប់ ព្រោះលោកលះសក្កាយទិដ្ឋិចេញបានហើយ ទើបមិនខ្លាច សត្វវិសេស ៣ ពួកក្រៅអំពីនេះ មិនឃើញសត្វដែលជាបដិបក្ខចំពោះខ្លួន ព្រោះសក្កាយទិដ្ឋិមានកម្លាំង ទើបមិនខ្លាច ។

ព្រះគាថាថា **ន មានេយ្យ ន ឃាតយេ** សេចក្តីថា បុគ្គលដឹងថាអាត្មាអញ យ៉ាងណា សត្វដទៃក៏ដូច្នោះ ដូច្នេះហើយ ក៏មិនសម្លាប់ឯង មិនគួរឲ្យអ្នកដទៃសម្លាប់ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៗ

រឿង ឆព្វគ្គិយភិក្ខុ ចប់

រឿង ឆព្វគ្គិយភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកឆព្វគ្គិយភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា **សព្ពេ តសន្តិ** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ ពួកឆព្វគ្គិយភិក្ខុងារទូវល់ពែង គឺបាតដៃជល់ពួកសត្តរសវគ្គិយភិក្ខុទាំងនោះ ដោយហេតុដែលខ្លួនប្រហារពួកសត្តរស-

វគ្គិយភិក្ខុក្នុងសិក្ខាបទមុននោះឯង តែក្នុងរឿងនេះ ព្រះសាស្តាទ្រង់ស្តាប់សំឡេងរបស់ភិក្ខុទាំងនោះហើយ ត្រាស់សួរថា តើមានរឿងអ្វី ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ រឿងឈ្មោះនេះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចាប់តាំងអំពីនេះទៅ ធម្មតាភិក្ខុមិនគួរធ្វើយ៉ាងនេះ ភិក្ខុណាធ្វើ ភិក្ខុនោះ ត្រូវអាបត្តិឈ្មោះនេះ ដូច្នេះហើយ ទ្រង់បញ្ញត្តតលសត្តិកសិក្ខាបទ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុដឹងថា សូម្បីសត្វពួកជង្កៃ រមែងតក់ស្លុតចំពោះអាជ្ញាតែម្យ៉ាង ដូចអាត្មាអញដូចគ្នា ម្យ៉ាងទៀត ជីវិតក៏រមែងជាទីស្រឡាញ់របស់សត្វទាំងនោះ ដូចអាត្មាអញដោយពិត មិនគួរប្រហារឯង មិនគួរប្រើអ្នកដទៃឲ្យសម្លាប់ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

សព្ពេ តសន្តិ ទណ្ឌស្ស សព្ពេសំ ជីវិតំ បិយំ
អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា (ព្រោះថា) ជីវិត ជាទីស្រឡាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមាហើយ មិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បានព្រះគាថាថា **សព្ពេសំ ជីវិតំ បិយំ** *សេចក្តីថា ជីវិតរមែងជាទីស្រឡាញ់ក្រៃលែងរបស់ពួកសត្វដ៏សេស រៀវព្រះខីណាស្រព

ចេញ ឯព្រះខីណាស្រព ជាអ្នកព្រងើយក្នុងជីវិត ឬក្នុងមរណៈដោយពិត ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលមានអំពីមុននោះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ធម្មគ្គិយភិក្ខុ ចប់

រឿង កុមារច្រើនឆាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុមារជាច្រើន ត្រាស់ព្រះធម្មទេសនានេះថា **សុខកាមានិ ភូតានិ** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះសាស្តាទ្រង់កាន់បាត្រ ចូលទៅកាន់ក្រុងសាវត្ថី ទ្រង់ឃើញក្មេងជាច្រើន យកដំបងវាយពស់ផុះមួយ ក្នុងចន្លោះផ្លូវ ត្រាស់សួរថា នែកុមារទាំងឡាយ ពួកអ្នកធ្វើអ្វី ក្មេងទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ពួកខ្ញុំយកដំបងវាយពស់ ទើបត្រាស់ទៀតថា ព្រោះហេតុអ្វី ទើបពួកក្មេងក្រាបទូលថា បពិត្រព្រះអង្គ ព្រោះខ្លាចវាចឹក ទើបត្រាស់ថា ពួកអ្នកវាយពស់នេះដោយគិតថា អ្នកនឹងធ្វើសេចក្តីសុខដល់ខ្លួន នឹងជាបុគ្គលមិនបានទទួលសេចក្តីសុខក្នុងទីដែលខ្លួនកើតហើយ ពិតហើយ បុគ្គល កាលប្រាថ្នាសុខដល់ខ្លួន តែប្រហារសត្វដទៃ រមែងមិនគួរ ដូច្នេះហើយ កាល

ទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបទ្រង់ភាសិតព្រះគាថានេះថា

សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឹសតិ
អត្តនោ សុខមេសានោ បេច្ច សោ ន លភតេ សុខំ ។
សុខកាមានិ ភូតានិ យោ ទណ្ឌេន ន ហឹសតិ
អត្តនោ សុខមេសានោ បេច្ច សោ លភតេ សុខំ ។

ជនណា ស្វែងរកសេចក្តីសុខដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្តីសុខដោយអាជ្ញា ជននោះ លះលោកនេះទៅហើយ នឹងមិនបានសេចក្តីសុខឡើយ ។

ជនណា ស្វែងរកសេចក្តីសុខដើម្បីខ្លួន តែមិនបៀតបៀនសត្វទាំងឡាយ អ្នកដែលប្រាថ្នាសេចក្តីសុខដោយអាជ្ញា ជននោះលះលោកនេះទៅហើយ រមែងបានសេចក្តីសុខ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **យោ ទណ្ឌេន** *សេចក្តីថា បុគ្គលណាបៀតបៀនអ្នកដទៃដោយដំបង ឬវត្ថុទាំងឡាយ មានដុំដីជាដើម ។*

បាទព្រះគាថា **បេច្ច សោ ន លភតេ សុខំ** *សេចក្តីថា បុគ្គលនោះរមែងមិនបានសុខសម្រាប់មនុស្ស សុខដែលជាទិព្វ ឬសុខ គឺព្រះនិព្វានដែលជាបរមត្តសុខ ក្នុងលោកខាងមុខ ។ ក្នុងគាថាទីពីរ បទជាច្រើនថា* **បេច្ច សោ លភតេ សុខំ** *សេចក្តីថា បុគ្គលនោះ រមែងបានសុខទាំង ៣ យ៉ាង មានប្រការដូចពោលហើយ ក្នុងបរលោក ។*

ក្នុងកាលចប់ទេសនា ក្មេងទាំង ៥០០ តាំងនៅក្នុងសោតាបត្តិផល ដូច្នេះឯង ។

រឿង កុមារច្រើនឆាក់ ចប់

រឿង ព្រះកោណ្ឌធានត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះ កោណ្ឌធាន ត្រាស់ព្រះធម្មទេសនានេះថា **មាភោច ជរុសំ កញ្ចិ** *ជាដើម ។*

បានឮមកថា ចាប់តាំងអំពីថ្ងៃដែលព្រះថេរៈនោះបួសហើយ រូបស្ត្រីម្នាក់ ត្រាច់ទៅជាមួយព្រះថេរៈ តែព្រះថេរៈមិនឃើញរូបស្ត្រីនោះ ។ ចំណែកមហាជនឃើញ កាលលោកត្រាច់បិណ្ឌបាតខាងក្នុងស្រុក ពួកមនុស្សប្រគេនភិក្ខាមួយវែក ហើយពោលថា បពិត្រលោកម្ចាស់ នេះជាចំណែកសម្រាប់លោកម្ចាស់ តែចំណែកនេះសម្រាប់ស្ត្រី ដែលជាសម្ងាញ់របស់លោកម្ចាស់ ដូច្នេះហើយ ក៏ប្រគេនភិក្ខាពីរវែក ។

សួរថា បុព្វកម្មរបស់លោកដូចម្តេច ឆ្លើយថា ជាឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ ភិក្ខុពីររូបជាសម្ងាញ់នឹងគ្នា ជាអ្នកស្រឡាញ់គ្នាយ៉ាងក្រៃលែង ដូចកើតអំពីផ្ទៃម្តាយតែមួយ ។

ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធដែលមានព្រះជន្មវែង ភិក្ខុទាំងឡាយរមែងប្រជុំគ្នា ដើម្បីប្រយោជន៍ដោយការធ្វើឧបោសថរៀងរាល់មួយឆ្នាំម្តង ឬ ៦ ខែម្តង ព្រោះដូច្នោះ ព្រះថេរៈទាំងពីររូបនោះ ក៏ចេញអំពីលំនៅដោយគិតថា នឹងទៅកាន់ភេងឧបោសថ ។

ទេវតាកើតក្នុងជាន់តាវត្តិង្សមួយរូប ឃើញព្រះថេរៈទាំងពីរ គិតថា ភិក្ខុនេះស្រឡាញ់គ្នាពន់ពេក អញអាចបំបែកភិក្ខុទាំងនេះបានឬហ្ន៎ ដូច្នេះហើយបានមកក្នុងលំជាប់ដែលខ្លួនគិតហើយនោះឯង ព្រោះភាពដែលខ្លួនជាបុគ្គលក្អែងក្អាង ។ ក្នុងភិក្ខុពីររូបនោះ កាលមួយរូបពោលថា អាវុសោ សូមរង់ចាំមួយភ្លែត ខ្ញុំបន្ទោបង់ឧច្ចារៈ ទើបនិម្មិតភេទជាស្រីមនុស្សម្នាក់ កាលដែលព្រះថេរៈចូលទៅក្នុងវាំងគុម្ពឈើ ហើយចេញមក យកដៃម្ខាងប្រមូលសក់ ដៃម្ខាងស្មៀកសំពត់ដើរចេញមកតាមក្រោយព្រះថេរៈនោះ ។ លោកមិនឃើញស្រីនោះ ។ តែភិក្ខុមួយរូបដែលឈរខាងមុខដែលរង់ចាំលោក ក្រឡេកមកឃើញស្រីនោះ ធ្វើយ៉ាងនោះ ដើរតាមក្រោយមក ។

ទេវតានោះដឹងភាវៈនៃខ្លួនដែលភិក្ខុនោះឃើញហើយ ក៏អន្តរធានទៅ ។ ភិក្ខុដែលរង់ចាំនោះ និយាយនឹងភិក្ខុនោះក្នុងកាលដែលមកជិតខ្លួនថា អាវុសោ សីលរបស់លោកបែកធ្លាយហើយ ភិក្ខុពោលថា អាវុសោ កម្មបែបនោះរបស់ខ្ញុំមិនមាន ភិក្ខុរង់ចាំពោលថា អម្បាញ់មិញនេះ ស្រីវ័យក្មេងដើរតាម ចេញមកខាងក្រោយលោក លោកធ្វើកម្មឈ្មោះនេះ ខ្ញុំឃើញហើយ លោកហ៊ាននិយាយបដិសេធថា កម្មបែបនេះរបស់ខ្ញុំមិនមានឬ ។

ភិក្ខុនោះ ហាក់បីដូចត្រូវនេះធ្លាក់ចុះត្រង់អំបែងក្បាល ពោលអង្វរថា អាវុសោ សូមកុំឲ្យខ្ញុំវិនាសឡើយ កម្មបែបនោះរបស់ខ្ញុំមិនមានពិត ។

ភិក្ខុមួយរូបទៀតពោលថា ខ្ញុំឃើញដោយភ្នែកទាំងពីរ នឹងជើរលោកដូចម្តេចបាន ដូច្នេះហើយ ក៏បែកគ្នាដូចកំណាត់ឈើ ហើយចៀសទៅ ។ ក្នុងវេន ឧបោសថ ក៏អង្គុយដោយតាំងចិត្តថា អញនឹងមិនធ្វើឧបោសថជាមួយភិក្ខុនេះ ។

ភិក្ខុដែលត្រូវចោទប្រាប់ដល់ភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ ចំណុចខ្នៅសូម្បីប៉ុនគ្រាប់ល្ង រមែងមិនមានក្នុងសីលរបស់ខ្ញុំ ភិក្ខុមួយរូបទៀតក៏ពោលអះអាងថា កម្មលាមកនោះ ខ្ញុំឃើញឯង ។

ទេវតាឃើញភិក្ខុរូបដែលវង់ចាំនោះ មិនប្រាថ្នាធ្វើឧបោសថ ជាមួយភិក្ខុមួយរូបទៀត គិតថា អញធ្វើកម្មធ្ងន់ហើយដូច្នេះ ទើបប្រាប់ថា ការបែកធ្លាយសីលរបស់លោកម្ចាស់មិនមាន តែខ្ញុំធ្វើកម្មលាមកនោះ ដោយអំណាចការសាកល្បងមើល សូមលោកម្ចាស់ធ្វើឧបោសថជាមួយលោកម្ចាស់ចុះ ភិក្ខុដែលវង់ចាំនោះ កាលទេវតានោះតាំងនៅក្នុងអាកាស ចង្អុលបង្ហាញ ទើបជើរហើយធ្វើឧបោសថរួមគ្នា តែមិនបានជិតស្និទ្ធក្នុងព្រះថេរៈដូចកាលមុនឡើយ ។

បុព្វកម្មរបស់ទេវតាមានប្រមាណប៉ុណ្ណោះ ក្នុងកាលអស់អាយុ ព្រះថេរៈទាំងនោះ កើតក្នុងទេវលោក ។ ចំណែកទេវតា កើតក្នុងអវីចីហើយ ឆេះក្នុងអវីចីនោះអស់មួយពុទ្ធន្តរ ។ ក្នុងពុទ្ធុប្បាទកាលនេះ បានកើតក្នុងក្រុងសាវត្ថី ដល់នូវការចម្រើនវ័យហើយ បានបព្វជ្ជាឧបសម្បទាក្នុងព្រះសាសនា តាំងអំពីថ្ងៃដែលបួសហើយ រូបស្រីនោះ ក៏បានប្រាកដយ៉ាងនោះឯង ដោយហេតុនោះ

ឯង ទើបភិក្ខុទាំងឡាយដាក់ឈ្មោះថា កោណ្ឌធាន ។

ភិក្ខុទាំងឡាយ ឃើញលោកត្រាច់ទៅយ៉ាងនោះ ទើបប្រាប់អនាថបិណ្ឌិក សេដ្ឋីថា លោកសេដ្ឋី សូមលោកបណ្តេញភិក្ខុទ្រុស្តសីលនេះចេញអំពីវិហារ របស់លោកចុះ ព្រោះថា ការវិនាសនឹងកើតឡើងដល់ភិក្ខុដ៏សេស ។ សេដ្ឋី ពោលថា បពិត្រលោកម្ចាស់ ព្រះសាស្តាមិនមានក្នុងវិហារឬ ភិក្ខុប្រាប់ថា មាន លោកសេដ្ឋី ។ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ ព្រះសាស្តាគង់ នឹងជ្រាប ។ ភិក្ខុទាំងឡាយ ក៏ទៅប្រាប់នាងវិសាខាយ៉ាងនោះដូចគ្នា សូម្បី នាងវិសាខាក៏បានឆ្លើយដល់ភិក្ខុទាំងនោះដូចគ្នា ។

ចំណែកភិក្ខុទាំងឡាយ កាលជនទាំងនោះមិនទទួលពាក្យរបស់ខ្លួន ទើប ទូលដល់ព្រះរាជាថា មហាបពិត្រ ភិក្ខុឈ្មោះកោណ្ឌធាន នាំស្រីម្នាក់ដើរទៅ នឹងញុំាងសេចក្តីវិនាសឲ្យកើតដល់ភិក្ខុគ្រប់រូប សូមមហាបពិត្របណ្តេញភិក្ខុ រូបនោះចេញអំពីដែនរបស់ព្រះអង្គចុះ ព្រះរាជាត្រាស់ថា ភិក្ខុនោះនៅឯណា ពួកភិក្ខុប្រាប់ថា មហាបពិត្រ នៅក្នុងវិហារ ។ ព្រះរាជាត្រាស់ថា នៅក្នុង សេនាសនៈមួយណា ភិក្ខុពោលថា ក្នុងសេនាសនៈឈ្មោះនោះ ព្រះរាជាត្រាស់ ថា បើដូច្នោះ សូមលោកម្ចាស់និមន្តទៅចុះ ខ្ញុំនឹងបញ្ជាឲ្យរាជបុរសចាប់ភិក្ខុរូប នោះ ។

ក្នុងពេលល្ងាច ព្រះរាជាយាងទៅកាន់វិហារ បញ្ជាឲ្យពួករាជបុរសព័ទ្ធ សេនាសនៈនោះហើយ បានបែរព្រះកន្ត្រៃទៅកាន់លំនៅរបស់ព្រះថេរៈៗ បាន ឮសំឡេងកោកកាក ទើបចេញអំពីវិហារឈរត្រង់ឃ្លីមុខ ។ ព្រះរាជាបានទត

ឃើញស្ត្រីនោះឈរខាងក្រោយខ្នងព្រះថេរៈនោះ ។ ព្រះថេរៈដឹងថា ព្រះរាជាយាងមក ទើបឡើងទៅកាន់វិហារអង្គុយហើយ ។ ព្រះរាជាមិនថ្វាយបង្គំព្រះថេរៈ ព្រោះបានទតឃើញស្ត្រីនោះ ទ្រង់រកមើលតាមជ្រុងទ្វារខ្ទះ ក្រោមគ្រែខ្ទះ ក៏មិនបានជួប ទើបត្រាស់នឹងព្រះថេរៈថា បពិត្រលោកម្ចាស់ ខ្ញុំបានឃើញស្រីម្នាក់ក្នុងទីនេះ តើស្រីនោះទៅណា ព្រះថេរៈទូលថា មហាបពិត្រ អាត្មាមិនឃើញ កាលព្រះរាជាត្រាស់ថា អម្បាញ់មិញ ខ្ញុំឃើញស្ត្រីឈរខាងក្រោយខ្នង ក៏ទូលបដិសេធថា មហាបពិត្រ អាត្មាមិនឃើញទេ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា តើមានរឿងអ្វីហ្ន៎ ហើយត្រាស់ថា សូមនិមន្តលោកម្ចាស់ចេញអំពីទីនេះសិន កាលព្រះថេរៈចេញទៅអំពីទីនោះ ឈរត្រង់យ៉ាមុខ ស្ត្រីនោះក៏បានឈរខាងក្រោយខ្នងព្រះថេរៈទៀត ព្រះរាជាទតឃើញស្រីនោះហើយ ទើបយាងឡើងទៅជាន់លើទៀត ។ ព្រះថេរៈជ្រាបភាពដែលព្រះរាជាយាងមកហើយ ទើបអង្គុយ ។ ព្រះរាជាទ្រង់ពិនិត្យមើលស្ត្រីនោះក្នុងទីគ្រប់កន្លែងទៀត ក៏មិនបានជួប ទើបត្រាស់សួរព្រះថេរៈដដែលទៀតថា ស្រីនោះនៅឯណា ព្រះថេរៈឆ្លើយថា មហាបពិត្រ អាត្មាមិនឃើញស្ត្រីនោះទេ ព្រះរាជាត្រាស់ថា សូមលោកម្ចាស់ប្រាប់ចុះ ខ្ញុំឃើញស្ត្រីឈរខាងក្រោយខ្នងលោកម្ចាស់អម្បាញ់មិញនេះឯង ព្រះថេរៈពោលថា សូមថ្វាយព្រះពរមហាបពិត្រ សូម្បីមហាជនក៏ពោលថា ស្ត្រីត្រាច់ទៅខាងក្រោយខ្នងអាត្មាភាព ឯអាត្មាភាពមិនឃើញស្រីនោះឡើយ ។

ព្រះរាជាទ្រង់កំណត់ថា នុ៎ះគប្បីជារូបសិប្បនិមិត្ត ហើយត្រាស់នឹងព្រះ

ថេរៈទៀតថា សូមលោកម្ចាស់ចុះអំពីទីនេះសាកមើល កាលព្រះថេរៈចុះទៅ ឈរត្រង់យ៉ាមុខ ក៏បានទតឃើញស្រីនោះ ឈរខាងក្រោយខ្នងរបស់ព្រះថេរៈ នោះទៀត កាលយាងឡើងទៅខាងលើ ក៏មិនបានទតឃើញ ។ ព្រះរាជាទ្រង់សាកសួរព្រះថេរៈទៀត កាលព្រះថេរៈទូលថា អាត្មាមិនឃើញ ក៏ទ្រង់សន្និដ្ឋានបានថា នុ៎ះជារូបសិប្បនិមិត្តដោយពិត ទើបត្រាស់នឹងព្រះថេរៈថា បពិត្រលោកម្ចាស់ កាលសង្ឃិលេសបែបនោះ ជាប់តាមពីខាងក្រោយលោកម្ចាស់ បុគ្គលដទៃៗ នឹងមិនប្រគេនភិក្ខាដល់លោកម្ចាស់ សូមលោកម្ចាស់និមន្តទៅវាំងរបស់ខ្ញុំជានិច្ចចុះ ខ្ញុំនឹងទំនុកបម្រុងលោកម្ចាស់ដោយបច្ច័យ ៤ ទ្រង់និមន្តព្រះថេរៈហើយ ក៏ចៀសចេញទៅ ។ ភិក្ខុទាំងឡាយលើកទោសថា អាវុសោទាំងឡាយ លោកទាំងឡាយ ចូរមើលកិរិយារបស់ព្រះរាជាលាមក កាលពួកយើងទូលថា សូមទ្រង់បណ្តេញភិក្ខុនោះចេញអំពីវិហារ ក៏យាងមក បែរជានិមន្តភិក្ខុនោះដោយបច្ច័យ ៤ ហើយយាងត្រឡប់ ។

ភិក្ខុទាំងឡាយក៏ពោលនឹងព្រះថេរៈនោះថា វុឌ្ឍបុគ្គលទ្រុស្តសីល ឥឡូវនេះ ព្រះរាជាក្លាយជាមនុស្សអាក្រក់ហើយ ។ ព្រះថេរៈនោះ ក្នុងកាលមុនមិនអាចពោលអ្វីជាមួយភិក្ខុទាំងឡាយបាន ឥឡូវនេះ ពោលបានរហ័សថា ពួកលោក ជាមនុស្សទ្រុស្តសីល ជាមនុស្សអាក្រក់ ពួកលោកនាំស្រីដើរទៅ ។

ភិក្ខុទាំងនោះទៅក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ កោណ្ឌធានកាលខ្ញុំព្រះអង្គពោលហើយ បែរជាពោលជេរដោយពាក្យផ្សេងៗ ជាដើមថា ពួកលោកក៏ជាបុគ្គលទ្រុស្តសីល ។

ព្រះសាស្តា ឲ្យត្រាស់ហៅព្រះកោណ្ឌធាននោះមកហើយ ត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកពោលយ៉ាងនោះពិតឬ ព្រះថេរៈទូលថា ករុណាព្រះអង្គ ព្រះសាស្តាត្រាស់ថា ហេតុអ្វីទើបអ្នកពោលយ៉ាងនោះ ព្រះថេរៈទូលថា ព្រោះភិក្ខុទាំងនោះពោលនឹងខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុអ្វី ទើបពួកអ្នកពោលនឹងភិក្ខុនេះយ៉ាងនោះ ។

ពួកភិក្ខុទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឃើញស្រីដើរទៅខាងក្រោយភិក្ខុនេះ ទើបពោលយ៉ាងនោះ ព្រះសាស្តាត្រាស់ថា បានឮថា ភិក្ខុទាំងនេះឃើញស្រីត្រាច់ទៅជាមួយអ្នក ទើបពោលយ៉ាងនោះ ចំណែកខ្លួនអ្នកមិនបានឃើញទេឬយ ព្រោះហេតុអ្វី ទើបអ្នកពោលនឹងភិក្ខុទាំងនេះយ៉ាងនោះ ផលនេះកើតឡើងព្រោះអាស្រ័យទិដ្ឋិលាមករបស់អ្នក ក្នុងកាលមុនមិនមែនឬ ហេតុអ្វី ឥឡូវនេះ ទើបអ្នកប្រកាន់នូវទិដ្ឋិលាមកនោះទៀត ។ ពួកភិក្ខុទូលសួរថា បពិត្រព្រះអង្គ ភិក្ខុនេះធ្វើកម្មដូចម្តេចក្នុងកាលមុន ។

ពេលនោះ ព្រះសាស្តា ត្រាស់បុព្វកម្មរបស់លោកដល់ភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុ អ្នកអាស្រ័យកម្មលាមកនេះ ទើបដល់នូវប្រការប្លែកបែបនេះហើយ ឥឡូវនេះ អ្នកប្រកាន់នូវទិដ្ឋិដ៏លាមកបែបនោះទៀត មិនគួរ អ្នកកុំពោលពាក្យណាមួយជាមួយភិក្ខុទាំងឡាយទៀត ចូរជាអ្នកមិនមានសំឡេង ដូចគ្នានឹងជួងដែលគេកាត់កណ្តាប់មាត់ហើយ កាលធ្វើយ៉ាងនោះនឹងជាបុគ្គល ឈ្មោះថា សម្រេចព្រះនិព្វាន ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបទ្រង់ភាសិតព្រះគាថាទាំងនេះថា

មាវោច ផរុសំ កញ្ចិ　　វុត្តា បដិវទេយ្យុ តំ
ទុក្ខា ហិ សារម្ភកថា　　បដិទណ្ឌា ផុសេយ្យុ តំ ។
សចេ នេរេសិ អត្តានំ　　កំសោ ឧបហតោ យថា
ឯស បត្តោសិ និព្វានំ　　សារម្ភោ តេ ន វិជ្ជតិ ។

អ្នកកុំនិយាយពាក្យអាក្រក់ នឹងអ្នកណាមួយឡើយ ជនទាំងឡាយដែលអ្នកស្តីថាឲ្យហើយ គេគប្បីស្តីថាតបមកអ្នកវិញ ព្រោះថា ការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឲ្យកើតទុក្ខ ការតស៊ូទាំងឡាយគប្បីប៉ះពាល់នូវអ្នក ។ បើអ្នកធ្វើខ្លួនមិនឲ្យញាប់ញ័រ ដូចគ្រាំងដែលចៀរមាត់ចេញហើយ (រមែងមិនលាន់ឮសូរ) ដូច្នោះ អ្នកនុ៎ះជាបុគ្គលដល់នូវព្រះនិព្វាន ការប្រណាំងប្រជែង មិនមានដល់អ្នក ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កញ្ចិ** *សេចក្តីថា កុំពោលពាក្យគ្រោតគ្រាតដល់បុគ្គលណាម្នាក់ គឺសូម្បីជាមួយបុគ្គលម្នាក់ ។*

បទថា **វុត្តា** *សេចក្តីថា ជនដទៃត្រូវអ្នកពោលថា ពួកអ្នកទ្រុស្តសីលគប្បីពោលឆ្លើយឆ្លងជាមួយអ្នកខ្លះ នូវពាក្យយ៉ាងនោះដូចគ្នា ។*

បទថា **សារម្ភកថា** *ឈ្មោះថា ការពោលប្រណាំងប្រជែង ហេតុនោះនាំឲ្យកើតទុក្ខ ។*

បទថា **បដិទណ្ឌា** *សេចក្តីថា កាលអ្នកប្រហារអ្នកដទៃដោយអាជ្ញាទាំង

ឡាយ មានកាយអាជ្ញាជាដើម អាជ្ញាត្រឡប់បែបនោះឯង គប្បីធ្លាក់លើអំបែងក្បាលរបស់អ្នក ។

បទថា **សចេ នេវេសិ** *សេចក្តីថា បើអ្នកអាចធ្វើខ្លួនមិនឲ្យញាប់ញ័របាន សោត ។*

បាទព្រះគាថាថា **កំសោ ឧបហតោ យថា** *សេចក្តីថា ដូចជួងដែលគេចៀរមាត់ ធ្វើឲ្យសល់តែខ្លួន ។ ពិតហើយ ជួងបែបនោះ សូម្បីបុគ្គលវាយហើយដោយដៃ ជើង ឬដោយដំបង ក៏មិនឮខ្ទាំង ។*

ពីរបទថា **ឯស បត្តោសិ** *សេចក្តីថា បើអ្នកអាចជាបុគ្គលបែបនោះ បានសោត អ្នកនោះបំពេញបដិបទានេះ ជាអ្នកមិនប្រមាទហើយក្នុងឥឡូវនេះ ឈ្មោះថា សម្រេចព្រះនិព្វាន ។*

បាទព្រះគាថាថា **សារម្ភោ តេ ន វិជ្ជតិ** *សេចក្តីថា កាលបើយ៉ាងនោះ សូម្បីការប្រណាំងប្រជែងគ្នា មានការពោលធ្វើឲ្យក្រៃលែងជាងគ្នាជាលក្ខណៈជាដើមយ៉ាងនេះថា អ្នកជាអ្នកទ្រុស្តសីល ឬថា ពួកអ្នកជាអ្នកទ្រុស្តសីលដូច្នេះ រមែងមិនមាន គឺនឹងមិនមានដល់អ្នកឡើយ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ។ ព្រះកោណ្ឌធានត្ថេរ តាំងនៅក្នុងព្រះឱវាទដែលព្រះសាស្តាប្រទានហើយ បានសម្រេចអរហត្តផល ក្នុងកាលមិនយូរប៉ុន្មានឡើយ លោកបានហោះឡើងទៅក្នុងអាកាស ចាប់ស្លាកគ្រាដំបូងដូច្នេះឯង ។

រឿង ឧចោសថកម្ម

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តបុព្វារាម ទ្រង់ប្រារព្ធឧបោសថកម្ម របស់ឧបាសិកាទាំងឡាយ មាននាងវិសាខាជាដើម ត្រាស់ព្រះធម្មទេសនានេះថា **យថាឧណ្ហេន គោចាលោ** ជាដើម ។

បានឮមកថា ក្នុងថ្ងៃឧបោសថមួយ ស្ត្រីប្រមាណ ៥០០ ក្នុងនគរសាវត្ថី ជាអ្នករក្សាឧបោសថ បានទៅកាន់វិហារ ។ នាងវិសាខាចូលទៅរកស្រីចាស់ៗ ក្នុងចំនួនស្រី ៥០០ នោះហើយសួរថា នែនាងទាំងឡាយ ពួកនាងរក្សាឧបោសថ ដើម្បីអ្វី កាលស្រីទាំងនោះឆ្លើយថា ពួកខ្ញុំប្រាថ្នាទិព្វសម្បត្តិ ទើបរក្សាឧបោសថ ។ សួរពួកស្រីវ័យកណ្តាល កាលពួកស្រីទាំងនោះប្រាប់ថា ពួកខ្ញុំរក្សាឧបោសថ ដើម្បីរួចផុតអំពីការនៅជាមួយស្រីរួមប្តី ។ សួរពួកស្រីក្មេងៗ កាលពួកគេប្រាប់ថា ពួកខ្ញុំរក្សាឧបោសថដើម្បីបានកូនប្រុស ក្នុងការមានគភ៌ដំបូង សួរស្រីវ័យក្រមុំ កាលពួកគេប្រាប់ថា ពួកខ្ញុំរក្សាឧបោសថដើម្បីទៅកាន់ត្រកូលប្តី ក្នុងវ័យស្រេករៗ គ្នា ។ នាងបានស្តាប់ពាក្យទាំងអស់របស់ស្រីទាំងនោះហើយ ក៏នាំពួកស្រីទាំងនោះទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលតាមលំដាប់ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា ម្នាលនាងវិសាខា ធម្មតាសភាវធម៌ទាំងឡាយ មានជាតិជាដើមរបស់សត្វទាំងនេះ ដូចគ្នានឹងគោបាលដែលមានដំបងក្នុងដៃ ជាតិបញ្ជូនសត្វទៅកាន់សម្នាក់ជរា ជរាបញ្ជូនទៅកាន់សម្នាក់ព្យាធិ ព្យាធិបញ្ជូនទៅកាន់សម្នាក់មរណៈ មរណៈរមែងកាត់

បង់នូវជីវិត ដូចបុគ្គលកាប់នូវដើមឈើដោយពូថៅ កាលបើយ៉ាងនោះ ពួកសត្វ ឈ្មោះថា ប្រាថ្នាវិវដ្ដៈរមែងមិនមាន ប្រាថ្នាតែវដ្ដៈប៉ុណ្ណោះ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យថា ឧណ្ហេន គោចាលោ គាវោ ចាជេតិ គោចរំ
ឯវំ ជរា ច មច្ចុ ច អាយុំ ចាជេន្តិ ចាណិនំ ។

គង្វាលគោ រមែងកៀងគោទៅកាន់ទីគោចរ ដោយអាជ្ញា ដូចម្តេចមិញ ជរា និងមច្ចុ តែងកៀងអាយុរបស់សត្វទាំងឡាយ ដូច្នោះឯង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ចាជេតិ** *សេចក្តីថា គោបាលដ៏ឈ្លាសកៀងគោទាំងឡាយ ដែលចូលទៅកាន់វាំងក្តីស្រែដោយជំពង វាយដោយជំពងនោះ ឯងនាំទៅ ឈ្មោះថា រមែងកៀងនូវគោទាំងឡាយទៅកាន់ទីគោចរ ដែលមានស្មៅ និងទឹកបរិភោគបានងាយ ។*

ពីរបទថា **អាយុំ ចាជេន្តិ** *សេចក្តីថា រមែងកាត់នូវឥន្ទ្រិយ គឺជីវិត គឺរមែងញាំងជីវិតិន្ទ្រិយឲ្យអស់ទៅ ។ក្នុងព្រះគាថានេះ មានពាក្យឧបមាឧបមេយ្យដូច្នេះថា ជរា និងមច្ចុ ប្រៀបដូចគោបាល ជីវិតិន្ទ្រិយប្រៀបដូចហ្វូងគោ មរណៈ ប្រៀបដូចទីគោចរ ។ បណ្តាសភាវធម៌ទាំងនោះ ជាតិបញ្ជូនឥន្ទ្រិយគឺជីវិតរបស់សត្វទាំងឡាយទៅកាន់សម្នាក់ជរា ជរាបញ្ជូនទៅកាន់សម្នាក់ព្យាធិ ព្យាធិបញ្ជូនទៅកាន់សម្នាក់មរណៈ មរណៈនោះឯង កាត់នូវជីវិតិន្ទ្រិយរបស់*

សត្វទាំងឡាយ ដូចបុគ្គលកាត់ដើមឈើដោយពូថៅ ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ឧទោសថកម្ម ចប់

រឿង អជគរប្រេត

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធអជគរប្រេត ត្រាស់ព្រះធម្មទេសនានេះថា **អថ ចាចានិ កម្មានិ** *ជាដើម ។*

សេចក្តីពិស្តារថា សម័យមួយព្រះមហាមោគ្គល្លាន និងព្រះលក្ខណៈ ចុះអំពីភ្នំគិជ្ឈកូដ បានឃើញសត្វឈ្មោះអជគរប្រេត ប្រមាណ ២៥ យោជន៍ ដោយទិព្វចក្ខុ ។ អណ្តាតភ្លើងឆេះឡើងអំពីក្បាលរបស់ប្រេតនោះ រហូតដល់កន្ទុយ ឆេះឡើងអំពីកន្ទុយរហូតដល់ក្បាល ឆេះឡើងទាំងសងខាង ទៅប្រជុំត្រង់កណ្តាលខ្លួន ។

ព្រះថេរៈកាលឃើញប្រេតនោះហើយទើបញញឹម កាលព្រះលក្ខណត្ថេរសួរហេតុនៃការញញឹមហើយ ក៏ឆ្លើយថា អាវុសោ កាលនេះ មិនមែនកាលព្យាករបញ្ហានេះ លោកចាំសួរក្នុងសម្នាក់ព្រះសាស្តាចុះ កាលត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះស្រេចហើយ ចូលទៅកាន់សម្នាក់ព្រះសាស្តា ព្រះលក្ខណត្ថេរ

សួរហើយ ទើបឆ្លើយថា អាវុសោ ខ្ញុំបានឃើញប្រេតមួយក្នុងទីនោះ អត្តភាពរបស់ប្រេតនោះ មានសភាពយ៉ាងនេះ ខ្ញុំឃើញហើយ ទើបធ្វើការញញឹមឲ្យប្រាកដ ព្រោះគិតថា អត្តភាពបែបនេះ ខ្ញុំមិនធ្លាប់ឃើញឡើយ ។

ព្រះសាស្តា កាលត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ សាវករបស់តថាគត ជាអ្នកមានចក្ខុហ្ន៎ ទ្រង់ទទួលពាក្យរបស់ព្រះថេរៈហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រេតនោះ តថាគតក៏បានឃើញហើយត្រង់ពោធិមណ្ឌលដ្ឋានដូចគ្នា តែតថាគតមិនពោល ព្រោះថា ជនទាំងឡាយណាមិនជឿពាក្យរបស់តថាគត ការមិនជឿនោះ របស់បុគ្គលទាំងនោះ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ឥឡូវនេះ តថាគតបានមោគ្គល្លានជាបន្ទាល់ហើយ ទើបនិយាយបាន ។ កាលភិក្ខុទាំងឡាយ ទូលសួរបុព្វកម្មរបស់ប្រេតនោះហើយ ទើបទ្រង់ព្យាករថា

បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ សេដ្ឋីឈ្មោះសុមង្គលក្រាលផែដីដោយឥដ្ឋមាស សាងវិហារក្នុងទីប្រមាណ ២០ ឧសភៈ ដោយទ្រព្យប្រមាណប៉ុណ្ណោះហើយ បានធ្វើការឆ្លងដោយទ្រព្យប្រមាណប៉ុណ្ណោះទៀត ។ ថ្ងៃមួយ លោកសេដ្ឋីទៅកាន់សម្នាក់ព្រះសាស្តាអំពីព្រលឹម ឃើញចោរម្នាក់ដេកយកសំពត់កាសាវពស្ត្រជណ្តប់រហូតដល់ក្បាល មានជើងប្រឡាក់ភក់នៅក្នុងសាលាមួយជិតទ្វារនគរ ទើបពោលថា បុរសនេះ មានជើងប្រឡាក់ភក់ប្រហែលជាអ្នកដើរយប់ហើយ ទើបមកដេក ។

ចោរបើកមុខឡើងឃើញសេដ្ឋីហើយគិតក្នុងចិត្តថា ណ្ហើយចុះ អញនឹង

ជីងកម្មដែលគួរធ្វើដល់វា ដូច្នេះហើយ ក៏ចងនូវអាឃាត បានជុតស្រែរបស់សេដ្ឋី ៧ ជង កាត់ជើងគោទាំងឡាយក្នុងក្រោល ៧ ជង ជុតផ្ទះ ៧ ជង ចោរនោះមិនអាចធ្វើនូវការអាក់អន់ឲ្យរលត់បាន សូម្បីដោយទារុណកម្ម មានប្រមាណប៉ុណ្ណោះ ទើបធ្វើការជិតស្និទ្ធជាមួយអ្នកបម្រើរបស់សេដ្ឋីនោះ ហើយសួរថា អ្វីជាទីស្រឡាញ់របស់លោកសេដ្ឋីរបស់អ្នក បុរសនោះប្រាប់ថា បានឮថា វត្ថុជាស្រឡាញ់ក្រៃលែងរបស់សេដ្ឋី ក្រៅអំពីព្រះគន្ធកុដិមិនមាន ទើបគិតថា ណ្ហើយចុះ អញនឹងជុតព្រះគន្ធកុដិ ញុាំងការខឹងក្រោធឲ្យរលត់ ។ កាលព្រះសាស្តាចូលទៅបិណ្ឌបាត ទើបវាយក្អមទឹកសម្រាប់ផឹក និងសម្រាប់ប្រើប្រាស់ បានជុតព្រះគន្ធកុដិហើយ ។

សេដ្ឋីបានឮថា ព្រះគន្ធកុដិត្រូវភ្លើងឆេះ ដើរមកក្នុងកាលដែលព្រះគន្ធកុដិត្រូវភ្លើងឆេះហើយទើបមកដល់ សម្លឹងព្រះគន្ធកុដិដែលត្រូវភ្លើងឆេះ មិនបានធ្វើការអាក់អន់សូម្បីប៉ុនចុងរោមទ្រាយ លើកដៃខាងឆ្វេង ទះដៃខាងស្តាំយ៉ាងខ្លាំង ។ ខណៈនោះ មហាជនដែលឈរក្នុងទីជិតសួរលោកសេដ្ឋីថា បពិត្រលោកសេដ្ឋី ព្រោះហេតុអ្វី ទើបលោកទះដៃក្នុងកាលដែលព្រះគន្ធកុដិ ដែលលះទ្រព្យប្រមាណប៉ុណ្ណោះសាងត្រូវភ្លើងឆេះ ។ សេដ្ឋីឆ្លើយថា អ្នកទាំងឡាយខ្ញុំធ្វើកម្មប្រមាណប៉ុណ្ណោះ ឈ្មោះថា បានកប់ទ្រព្យក្នុងព្រះសាសនា ដែលមិនសាធារណៈដល់អន្តរាយ មានភ្លើងជាដើម ទើបខ្ញុំមានចិត្តត្រេកអរ ទះដៃដោយគិតថា អញនឹងបានចំណាយទ្រព្យប្រមាណប៉ុណ្ណោះ សាងព្រះគន្ធកុដិថ្វាយព្រះសាស្តាទៀត ។

លោកសេដ្ឋីលះទ្រព្យប្រមាណប៉ុណ្ណោះ សាងព្រះគន្ធកុដិទៀត បានថ្វាយដល់ព្រះសាស្តា ដែលមានភិក្ខុ ២ ម៉ឺនរូបជាបរិវារ ។ ចោរឃើញកិរិយានោះហើយគិតថា អញមិនសម្ងាប់សេដ្ឋីនេះ នឹងមិនអាចធ្វើឲ្យបាត់ខ្មាសអៀនបានណ្តើយចុះ អញនឹងសម្ងាប់វាចោល ដូច្នេះហើយ ទើបសៀតកាំបិតស្នៀតក្នុងសំពត់ស្បៃក ដើរវេរវាំងក្នុងវិហារអស់ ៧ ថ្ងៃ ក៏មិនបានឱកាស ។

ចំណែកមហាសេដ្ឋី ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ បុរសម្នាក់ជុតស្រែខ្ញុំព្រះអង្គអស់ ៧ ដង កាត់ជើងគោក្នុងក្រោលអស់ ៧ ដង ដុតផ្ទះ ៧ ដង ឥឡូវនេះ សូម្បីព្រះគន្ធកុដិ ប្រហែលជាបុរសនោះឯងដុត ខ្ញុំព្រះអង្គសូមឲ្យចំណែកបុណ្យក្នុងទាននេះ ដល់បុរសនោះមុនគេ ។

ចោរបានឮពាក្យនោះ មានការភ្ញាក់ក្រហាយកើតឡើងថា អញធ្វើកម្មធ្ងន់ហ្ន៎ កាលបើយ៉ាងនោះ បុរសនេះក៏មិនមានត្រឹមតែការអាក់អន់ក្នុងអញដែលធ្វើខុស ឲ្យចំណែកបុណ្យក្នុងទាននេះដល់អញមុនទៀតផង អញប្រទូស្តក្នុងបុរសនេះមិនគួរឡើយ ទៅទណ្ឌគប្បីធ្លាក់លើអំបែងក្បាលរបស់អញ ដែលមិនឲ្យបុរសបៃបនេះអត់ទោសឲ្យ ដូច្នេះហើយ ទើបទៅក្រាបចុះទៀបជាតជើងរបស់សេដ្ឋីពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់មេត្តាអត់ទោសដល់ខ្ញុំចុះ កាលសេដ្ឋីពោលថា មានរឿងអ្វី ទើបជ្រាប់ថា ខ្ញុំបានធ្វើកម្មប្រមាណប៉ុណ្ណោះ សូមលោកម្ចាស់អត់ទោសនោះដល់ខ្ញុំចុះ ។

ពេលនោះ សេដ្ឋីសួរកម្មគ្រប់យ៉ាងថា អ្នកធ្វើកម្មនេះផងៗ ប្រមាណ

ប៉ុណ្ណោះដល់ខ្ញុំឬ កាលចោរសារភាពថា បាទ ខ្ញុំធ្វើ ទើបសួរថា ខ្ញុំមិនធ្លាប់ឃើញអ្នកឡើយ ហេតុអ្វី ទើបខឹងក្រោធ បានធ្វើយ៉ាងនោះដល់ខ្ញុំ ។

ចោរនោះជាសំគាល់ឲ្យសេដ្ឋីរឭកដល់ពាក្យ ដែលគាត់ចេញអំពីព្រះនគរក្នុងថ្ងៃមួយពោលហើយ បានជ្រាប់ថា ខ្ញុំកើតទុក្ខការអាក់អន់ព្រោះហេតុនេះ ។

សេដ្ឋីរឭកដល់ការៈនៃពាក្យដែលខ្លួនពោលបានហើយ ឲ្យចោរអត់ទោសឲ្យដោយពាក្យថា អើបាខ្ញុំពោលពិត សូមបាអត់ទោសដល់ខ្ញុំចុះ ហើយពោលថា ក្រោកឡើងចុះ ខ្ញុំអត់ទោសឲ្យដល់អ្នក ចូរអ្នកទៅចុះ ចោរពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់អត់ទោសដល់ខ្ញុំសោត សូមធ្វើខ្ញុំ មួយអន្ទើដោយកូនប្រពន្ធឲ្យជាទាសៈក្នុងផ្ទះរបស់លោកម្ចាស់ចុះ សេដ្ឋីពោលថា នែបា កាលខ្ញុំពោលពាក្យមានប្រមាណប៉ុណ្ណោះ អ្នកក៏បានធ្វើការកាត់បៃបនេះ ខ្ញុំមិនអាចពោលពាក្យណាមួយជាមួយអ្នកដែលនៅក្នុងផ្ទះបានឡើយ ។ ខ្ញុំមិនមានកិច្ចទាក់ទងដោយអ្នកនៅក្នុងផ្ទះ ខ្ញុំអត់ទោសឲ្យដល់អ្នក ចូរអ្នកទៅចុះ ។

កាលចោរធ្វើកម្មនោះហើយ ក្នុងកាលអស់អាយុ កើតឡើងហើយក្នុងអវីចី ឆេះក្នុងអវីចីអស់កាលយូរ ក្នុងកាលឥឡូវនេះ កើតជាអជគរប្រេតត្រូវភ្លើងឆេះត្រង់ក្នុំគិជ្ឈកូដ ដោយវិបាកនៃកម្មដែលសេសសល់ ។

ព្រះសាស្តា កាលត្រាស់បុព្វកម្មរបស់ប្រេតនោះ យ៉ាងនេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាបុគ្គលពាលធ្វើកម្មដ៏លាមក រមែងមិនដឹង តែខាងក្រោយក្តៅក្រហាយ ព្រោះកម្មដែលខ្លួនធ្វើហើយ រមែងដួចគ្នានឹងភ្លើងឆេះព្រៃ ដោយខ្លួនរបស់ខ្លួនឯង ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិ

សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

អថ ចាចាតិ កម្មានិ ករំ ពាលោ ន ពុជ្ឈតិ
សេហិ កម្មេហិ ទុម្មេធោ អគ្គិឌឌ្ឍោវ តប្បតិ ។

បុគ្គលមិនមានប្រាជ្ញា កាលធ្វើអំពើអាក្រក់ រមែងមិនក្រាក់ខ្លួន លុះកាលជាខាងក្រោយ ទើបក្តៅក្រហាយដោយសារកម្មរបស់ខ្លួន ដូចត្រូវភ្លើងឆេះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អថ ចាចាតិ** សេចក្តីថា បុគ្គលពាលមិនមែនធ្វើបាបទាំងឡាយ ដោយអំណាចនៃសេចក្តីក្រោធតែម្យ៉ាងប៉ុណ្ណោះទេ្បីយ ។ សូម្បីធ្វើ ក៏មិនដឹង តែកាលធ្វើបាប ឈ្មោះថា មិនដឹងថា អញធ្វើបាប រមែងមិនមាន ។

ព្រះដ៏មានព្រះភាគត្រាស់ថា រមែងមិនដឹង ព្រោះការមិនដឹងថា ផលរបស់កម្មនេះ មានឈ្មោះបែបនេះ ។

បទថា **សេហិ** សេចក្តីថា ព្រោះកម្មដែលជារបស់ខ្លួនទាំងនោះ ។

បទថា **ទុម្មេធោ** សេចក្តីថា បុគ្គលអ្នកមានបញ្ញាថោកថយ កើតក្នុងនរក រមែងក្តៅក្រហាយ ដូចត្រូវភ្លើងឆេះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង អជគរប្រេត ចប់

រឿង ព្រះមហាមោគ្គល្លានត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធព្រះមហាមោគ្គ-ល្លានត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ ឧឡ្ហាន អឧឡ្ហាសុ** ជាដើម ។

សេចក្តីពិស្តារថា ក្នុងសម័យមួយ ពួកតិរ្ថិយប្រជុំគ្នា គិតថា អាវុសោ លោកទាំងឡាយជ្រាបឬ ហេតុអ្វីទើបលាភសក្ការៈកើតឡើងជាច្រើនដល់ព្រះសមណគោតម តិរ្ថិយម្នាក់ពោលថា ពួកខ្ញុំមិនដឹង ចំណែកពួកលោកដឹងឬ តិរ្ថិយដែលដឹងរឿង ក៏នាំគ្នាឆ្លើយថា ពួកខ្ញុំដឹង លាភសក្ការៈកើតឡើង ព្រោះអាស្រ័យព្រះថេរៈមួយរូប ឈ្មោះមហាមោគ្គល្លាន ព្រោះព្រះថេរៈនោះទៅទេវ-លោក សួរកម្មដែលពួកទេវតាធ្វើហើយ ត្រឡប់មកប្រាប់ពួកមនុស្សថា ទេវតាធ្វើកម្មឈ្មោះនេះ រមែងបានសម្បត្តិបែបនេះ សូម្បីទៅនរក ក៏សួរកម្មរបស់ពួកសត្វដែលកើតក្នុងនរកហើយ ត្រឡប់មកប្រាប់ពួកមនុស្សថា ពួកនេរយិក-សត្វធ្វើកម្មឈ្មោះនេះ រមែងសោយទុក្ខបែបនេះ ពួកមនុស្សបានស្តាប់ពាក្យព្រះថេរៈនោះហើយ រមែងនាំលាភសក្ការៈជាច្រើនទៅប្រគេន ។ បើពួកយើងអាចសម្លាប់ព្រះថេរៈនោះបានសោត លាភសក្ការៈនោះនឹងកើតឡើងដល់ពួកយើង ។

តិរ្ថិយទាំងនោះទទួលថា ឧបាយនេះប្រើបាន ជនទាំងអស់ជាអ្នកមានធនូ: តែមួយសម្រេចថា ពួកយើងនឹងធ្វើកម្មណាមួយ សម្លាប់ព្រះថេរៈនោះចោលដូច្នេះហើយ បបួលឧបដ្ឋាករបស់ខ្លួនបានទ្រព្យ ១ ពាន់កហាបណៈ ឲ្យហៅ

ពួកចោរអ្នកត្រាច់ធ្វើកម្ម គឺសម្ងាប់ មកហើយ ប្រាប់ថា ព្រះថេរៈឈ្មោះមហាមោគ្គល្លាន នៅត្រង់កាឡសិលា ចូរពួកអ្នកទៅក្នុងទីនោះហើយ សម្ងាប់ព្រះថេរៈនោះ ដូច្នេះហើយ ក៏បានឲ្យកហាបណៈដល់ពួកចោរ ។

ពួកចោរទទួលពាក្យ ព្រោះចំណង់ក្នុងទ្រព្យ តាំងចិត្តថា ពួកយើងនឹងសម្ងាប់ព្រះថេរៈ ដូច្នេះហើយ បានព័ទ្ធលំនៅរបស់ព្រះមហាមោគ្គល្លានត្រេរ ។

ព្រះថេរៈជ្រាបភាពដែលខ្លួនត្រូវពួកចោរទាំងនោះ ព័ទ្ធចាប់ហើយ ទើបចេញតាមប្រហោងសោចៀសចេញទៅ ។ ក្នុងថ្ងៃនោះ ពួកចោរមិនឃើញព្រះថេរៈ ស្អែកឡើងទើបទៅព័ទ្ធទៀត ។ ព្រះថេរៈជ្រាបហើយ ក៏ទម្លាយមណ្ឌលហោជាង ហោះទៅកាន់អាកាស កាលបើដូច្នេះ ក្នុងខែដំបូងក្តី ខែកណ្តាលក្តី ពួកតិរ្ថិយនោះក៏មិនអាចចាប់ព្រះថេរៈបាន លុះដល់ខែចុងក្រោយ ព្រះថេរៈជ្រាបភវៈ គឺការទាញមកនៃកម្មដែលខ្លួនបានធ្វើហើយ ទើបមិនបានគេច ។

ពួកចោរចាប់ព្រះថេរៈបានហើយ វាយរហូតឆ្អឹងទាំងឡាយរបស់ព្រះថេរៈបែកជាបំណែកតូចៗ ប៉ុនគ្រាប់អង្កាំដែលជាក់ ពេលនោះ ពួកចោរបោះលោកទៅកាន់គុម្ពឈើមួយកន្លែង ដោយសម្គាល់ថាស្លាប់ហើយ ក៏ចៀសចេញទៅ ។

ព្រះថេរៈគិតថា អញគាល់ព្រះសាស្តាសិនសឹមបរិនិព្វាន ដូច្នេះហើយ ទើបសមោធានអត្តភាពដោយឈាន គឺឲ្យមាំទាំហើយ ទៅកាន់សម្នាក់ព្រះសាស្តាតាមអាកាស ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងបរិនិព្វាន ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន អ្នកនឹងបរិ-និព្វានឬ ព្រះថេរៈទូលថា ករុណាព្រះអង្គ ព្រះសាស្តាត្រាស់សួរថា អ្នកនឹង

បរិនិព្វានក្នុងទីណា ព្រះថេរៈទូលថា ខ្ញុំព្រះអង្គនឹងទៅកាន់ទីឈ្មោះកាឡសិលា ហើយបរិនិព្វាន ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន បើដូច្នេះ ចូរអ្នកសម្តែងធម៌ដល់តថាគត ហើយសឹមទៅ ព្រោះឥឡូវនេះ តថាគតលែងបានឃើញសាវ័កដូចអ្នកទៀតហើយ ។

ព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនោះ ដូច្នេះ ថ្វាយបង្គំព្រះសាស្តា ហោះឡើងទៅកាន់អាកាស សម្តែងឫទ្ធិមានប្រការផ្សេងៗ ដូចព្រះសារីបុត្តសម្តែងឫទ្ធិក្នុងថ្ងៃបរិនិព្វាន ហើយសម្តែងធម៌ ថ្វាយបង្គំព្រះសាស្តា ទៅកាន់ព្រៃក្បែរកាឡសិលាបទេស បរិនិព្វានហើយ ។

ពាក្យល្បីខ្ទរខ្ទាយថា បានឮថា ពួកចោរបានសម្លាប់ព្រះថេរៈហើយដូច្នេះ បានឮសុះសាយទៅពេញជម្ពូទ្វីប ។ ព្រះបាទអជាតសត្រូវ ទ្រង់រៀបចំចារបុរសទៅ ដើម្បីស៊ើបអង្កេតពួកចោរ កាលពួកចោរទាំងនោះកំពុងផឹកស្រាក្នុងរោងស្រា ចោរម្នាក់កែងខ្នងចោរម្នាក់ឲ្យដួលចុះ ចោរដែលដួលនោះគំហកចោរនោះ ហើយនិយាយថា វ៉ឺយ អាក្បាលរឹង ហេតុអ្វី ទើបអាវាយខ្នងអញ ចោរម្នាក់ពោលថា វ៉ឺយ អាចោរកាច ព្រះមោគ្គល្លាន អាជាអ្នកដៃដល់មុនឬ ចោរនោះពោលថា ឯងមិនដឹងថា ព្រះមោគ្គល្លាន ត្រូវអញវាយទេឬ ។

កាលពួកចោរទាំងនោះ នាំគ្នាអួតក្អេងក្អាងថា ព្រះមោគ្គល្លានខ្លួនជាអ្នកវាយហើយ ។ ចារបុរសទាំងនោះបានឮហើយ ទើបចាប់ចោរទាំងនោះចងទាំងអស់ហើយ ក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់ត្រាស់ឲ្យហៅពួកចោរមក

ហើយសួរថា ពួកឯងសម្លាប់ព្រះចេរៈឬ ពួកចោរទូលថា យ៉ាងនោះឯងព្រះអង្គ ព្រះរាជាត្រាស់ថា អ្នកណាឲ្យពួកអ្នកធ្វើ ចោរទូលថា ពួកសមណៈអាក្រាតព្រះអង្គ ។

ព្រះរាជាទ្រង់ឲ្យចាប់សមណៈអាក្រាតប្រមាណ ៥០០ កប់ក្នុងរណ្តៅប្រមាណត្រឹមផ្ចិត ត្រង់លានព្រះរាជវាំង ប្រមូលចោរ ៥០០ លុបដោយចំបើងហើយដុត ។ កាលទ្រង់ជ្រាបថា ជនទាំងនោះត្រូវភ្លើងឆេះហើយ ទើបបញ្ជាឲ្យភ្ជួរដោយនង្គ័លដែក ធ្វើជនទាំងអស់ឲ្យជាកំណាត់តូចកំណាត់ធំ ហើយឲ្យដោតចោរ ៤ នាក់ដោយលំពែង ។

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា គួរសង្វេគហ្ន៎ ព្រះមហាមោគ្គល្លានមរណភាពមិនសមគួរដល់ខ្លួន ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាដូចម្តេចហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមរណភាពមិនសមគួរដល់អត្តភាពនេះប៉ុណ្ណោះ តែមោគ្គល្លានដល់នូវមរណភាពសមគួរដល់កម្មដែលធ្វើក្នុងកាលមុន ។ កាលភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គ បុព្វកម្មរបស់លោកដូចម្តេច ទើបទ្រង់ត្រាស់អតីតនិទានយ៉ាងពិស្តារ ដូចតទៅនេះ ។

បានឮមកថា ក្នុងអតីតកាល កុលបុត្រម្នាក់ជាអ្នកក្រុងពារាណសី ធ្វើកិច្ចផ្សេងៗ មានបុកអង្ករ និងដាំបាយជាដើម ដោយខ្លួនឯង ប្រតិបត្តិមាតា

បិតា ។ តមក មាតាបិតានិយាយនឹងកុលបុត្រនោះថា នែបា បាម្នាក់ឯង ប៉ុណ្ណោះធ្វើការទាំងក្នុងផ្ទះ ទាំងក្នុងព្រៃ រមែងលំបាក ពុកម៉ែនឹងនាំស្រីក្រមុំ ម្នាក់មកឲ្យដល់កូន កុលបុត្រនោះហាមថា ខ្ញុំមិនត្រូវការប្រពន្ធទ្បើយ ខ្ញុំនឹង ទំនុកបម្រុងលោកទាំងពីរដោយដៃខ្ញុំឯង ដរាបណាលោកទាំងពីរនៅមានជីវិត ក៏អង្វរកូនរឿយៗ ហើយ នាំទារិកាមក ។

ស្រីនោះទំនុកបម្រុងឪពុកក្មេក ម្តាយក្មេកបានត្រឹម ២-៣ ថ្ងៃប៉ុណ្ណោះ ក្រោយមកមិនចង់ឃើញលោកទាំងពីរនោះទ្បើយ ទើបប្រាប់ស្វាមីថា ខ្ញុំមិន អាចនៅក្នុងទីជាមួយឪពុកម្តាយរបស់អ្នកបានទេ ដូច្នេះហើយ តិះដៀលដោយ ប្រការផ្សេងៗ កាលប្តីនោះមិនជឿពាក្យរបស់ខ្លួន ក្នុងពេលប្តីចេញទៅក្រៅ កាន់យកសម្បកផ្ទៃ ធ្នឹងផ្ទៃ និងពពុះបបររោយរាយក្នុងទីនោះៗ ឲ្យស្មោកគ្រោក ប្តីមកហើយសួរថា នេះជាអ្វី ក៏ប្រាប់ថា នេះជាកម្មរបស់មនុស្សចាស់ខ្វាក់ភ្នែក ទាំងនេះ មនុស្សចាស់ទាំងពីរធ្វើផ្ទះគ្រប់កន្លែងឲ្យស្មោកគ្រោក ខ្ញុំមិនអាចនៅ ជាមួយមនុស្សចាស់ទាំងពីរនោះបានទេ ។

កាលស្រីនោះរំអុកយ៉ាងនោះ សត្វដែលមានបារមីបានបំពេញហើយ បែបនោះ ក៏បែកអំពីមាតាបិតាបាន គាត់ពោលថា ណ្ហើយចុះ ខ្ញុំនឹងដឹងកម្ម ដែលគួរធ្វើដល់លោកទាំងពីរ ដូច្នេះហើយ ឲ្យមាតាបិតាបរិភោគហើយ បបួល ថា បពិត្រលោកឪពុកអ្នកម្តាយ ពួកញាតិក្នុងទីឈ្មោះនោះ ទន្ទឹងការមករបស់ លោកទាំងពីរ ខ្ញុំនឹងនាំលោកទៅក្នុងទីនោះ ដូច្នេះហើយ ឲ្យលោកទាំងពីរ ទ្បើងយានតូច ហើយបរទៅ ក្នុងកាលដល់កណ្តាលព្រៃ ក៏បញ្ជោតថា សូម

លោកឪពុកកាន់ខ្សែ គោទាំងពីរនឹងទៅដោយសញ្ញានៃជន្លួញ ក្នុងទីនេះ ពួកចោរចាំស្កាត់ ខ្ញុំនឹងចុះទៅ ដូច្នេះហើយ ដាក់ខ្សែក្នុងដៃរបស់ឪពុក ចុះទៅហើយ បានក្លែងសំឡេង ធ្វើឲ្យដូចសំឡេងពួកចោរ ។

មាតាបិតាបានឮសំឡេងនោះដោយសម្គាល់ថា ពួកចោរ ទើបពោលថា ឱកូន ពុក និងម៉ែចាស់ហើយ ចូរកូនរក្សាខ្លួនឲ្យផុតភ័យចុះ ។ កុលបុត្រធ្វើសំឡេងដូចចោរ វាយមាតាបិតាដែលកំពុងស្រែកយ៉ាងនោះ ឲ្យស្លាប់ហើយ បោះចោលក្នុងព្រៃហើយត្រឡប់ទៅ ។

ព្រះសាស្តាកាលត្រាស់បុព្វកម្មនេះរបស់ព្រះមហាមោគ្គល្លាននោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានធ្វើកម្មប្រមាណប៉ុណ្ណោះ នេះក្នុងនរកច្រើនសែនឆ្នាំ ដោយសេសសល់ផលកម្ម ទើបត្រូវវាយយ៉ាងនោះឯង ល្អិតខ្ចិចខ្ចីដល់នូវការស្លាប់អស់មួយរយអត្តភាព មោគ្គល្លានបានមរណៈយ៉ាងនេះ ក៏សមគួរដល់កម្មរបស់ខ្លួនពិត ។ ពួកតិរ្ថិយ ៥០០ និងចោរ ៥០០ ប្រទូស្តចំពោះបុត្រតថាគត ដែលមិនប្រទូស្តក៏បានស្លាប់ សមគួរដល់កម្មរបស់ខ្លួនដូចគ្នា ព្រោះថា បុគ្គលដែលប្រទូស្តចំពោះបុគ្គលដែលមិនប្រទូស្ត រមែងដល់នូវការវិនាសដោយហេតុ ១០ ប្រការពិត ដូច្នេះហើយ កាលនឹងបន្តអនុសន្ធិសម្តែងធម៌ ទើបបានភាសិតព្រះគាថាទាំងនេះថា

យោ ទណ្ឌេន អទណ្ឌេសុ អប្បទុដ្ឋេសុ ទុស្សតិ
ទសន្នមញ្ញតរំ ឋានំ ខិប្បមេវ និគច្ឆតិ
វេទនំ ផរុសំ ជានិំ សរីរស្ស ភេទនំ

គរុកំ វាបិ អាពាធំ ចិត្តក្ខេបំ វ ចាបុណេ

រាជតោ វា ឧបសគ្គំ អព្ភក្ខានំ វ ទារុណំ

បរិក្ខយំ វ ញាតីនំ ភោគានំ វ បភង្គុណំ

អថវស្ស អគារានិ អគ្គិ ឌហតិ ចាវកោ

កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតិ ។

បុគ្គលណាប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡាកចិត្ត (ឆ្គួត) ១ រឹបជាន់អំពីស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់ពួកញាតិវលីង ១ ពុកផុយកោគសម្បត្តិទាំងឡាយ ១ ភ្លើងទីងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ ១ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អនណ្ឌេសុ** *សេចក្តីថា ក្នុងព្រះខីណាស្រពទាំងឡាយ ដែលវៀរចាកអាជ្ញា មានកាយអាជ្ញាជាដើម ។*

បទថា **អប្បទុដ្ឋេសុ** *សេចក្តីថា បុគ្គលមិនមានការខុសក្នុងជនដទៃ ឬក្នុងខ្លួន ។*

បានព្រះគាថាថា **ឧសន្នមញ្ញតរំ ឋានំ** *សេចក្តីថា ក្នុងហេតុនៃទុក្ខ ១០ យ៉ាង នូវហេតុណាមួយ ។*

បទថា **វេឧនំ** *បានដល់ វេទនាដ៏ខ្លាំងក្លា មានរោគក្នុងក្បាលជាដើម ។*

បទថា **ជានី** *បានដល់ ការវិនាសទ្រព្យ ដែលបានដោយលំបាក ។*

បទថា **ភេឧនំ** *បានដល់ ការបែកធ្លាយនៃសរីរៈ មានការកាត់ដៃជាដើម ។*

បទថា **គរុកំ** *បានដល់ អាពាធធ្ងន់ដោយរោគ មានរោគស្វាប់មួយ ចំហៀងខ្លួន ពិការចក្ខុម្ខាង រោគស្វាប់ដៃជើង ខ្វិន និងរោគឃ្លង់ជាដើម ។*

បទថា **ចិត្តក្ខេបំ** *បានដល់ ជាមនុស្សឆ្កួត ។*

បទថា **ឧបសគ្គំ** *បានដល់ មានការរារាំងអំពីព្រះរាជាជាដើមថា ចូរដកតំណែងសេនាបតីជាដើម ។*

បទថា **អព្ភក្ខានំ** *សេចក្តីថា កាលត្រូវពោលចោទយ៉ាងខ្លាំងក្លាបែបនេះថា កម្ម មានការកាត់ទីតជាដើមនេះក្តី កម្ម គឺការប្រព្រឹត្តខុសក្នុងព្រះរាជានេះក្តី អ្នកធ្វើហើយដែលខ្លួនមិនធ្លាប់ឃើញ មិនធ្លាប់បានឮ និងមិនធ្លាប់គិតឡើយ ។*

បានព្រះគាថាថា **បរិក្ខយំ វ ញាតីនំ** *បានដល់ ការវិនាសនៃពួកញាតិដែលអាចជាទីពឹងពំនាក់របស់ខ្លួន ។*

បទថា **បភង្គុណំ** *គឺសេចក្តីវិនាស បានដល់ ការពុកផុយទៅ ឯស្រូវក្នុងជង្រុករបស់បុគ្គលនោះ រមែងដល់នូវការពុកផុយ ។ មាសដល់នូវភាពជាធ្យូង កែវមុក្តាដល់នូវភាពជាគ្រាប់កប្បាស កហាបណៈដល់នូវភាពជាអំបែងជាដើម ។ សត្វជើងពីរ ជើងបួន ដល់នូវភាពជាសត្វខ្វាក់ភ្នែកជាដើម ។*

ពីរបទថា **អគ្គិ ឧហាតិ** *សេចក្តីថា ក្នុងមួយឆ្នាំ កាលភ្លើងដទៃមិនមានភ្លើង គឺរន្ទះរមែងធ្លាក់ចុះដុតបំផ្លាញ ២-៣ ដង គឺភ្លើងព្រៃតាំងឡើងតាមធម្មតារបស់វា រមែងឆេះ ។*

បទថា **និរយំ** *ជាដើម សេចក្តីថា ព្រះដ៏មានព្រះភាគត្រាស់ថា បុគ្គលនោះរមែងចូលដល់នរក ក៏ដើម្បីសម្តែងហានៈ ដែលការកបុគ្គលដល់នូវហានៈ ១០ យ៉ាង ណាមួយក្នុងបច្ចុប្បន្ននេះហើយ ក៏គប្បីដល់ក្នុងសម្បរាយកពដូចគ្នា ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះមហាមោគ្គល្លានត្ថេរ ចប់

រឿង ភិក្ខុមានភណ្ឌៈច្រើន

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមានភណ្ឌៈច្រើន ត្រាស់ព្រះធម្មទេសនានេះថា **ន ឆគ្គចរិយា** *ជាដើម ។*

បានឮថា កុដុម្ពិកៈអ្នកក្រុងសាវត្ថីម្នាក់ មានប្រពន្ធស្លាប់ហើយទើបបួស ។ កាលគាត់បួស ឲ្យគេសាងបរិវេណ ពោងភ្លើង ឃ្លាំងជាក់កណ្ឌៈដើម្បីខ្លួន ជាក់កណ្ឌៈពេញបន្ទប់ទាំងអស់ដោយវត្ថុទាំងឡាយ មានសប្បិ និងប្រេងជាដើម

ហើយទើបបួស ។ កាលបួសហើយ ឲ្យហៅពួកទាស:របស់ខ្លួនមកចម្អិនអាហារ តាមដែលគាប់ចិត្តហើយបរិភោគ ។ បានជាអ្នកមានកណ្ហ:ច្រើន និងមានបរិក្ខារច្រើន សំពត់ស្បៀក សំពត់ជណ្តប់ក្នុងរាត្រីមួយសម្រាប់ក្នុងពេលថ្ងៃមួយសម្រាប់ នៅត្រង់ចុងវិហារ ។

ថ្ងៃមួយ កាលភិក្ខុនោះហាលចីវរ និងកម្រាលសិងរបស់ខ្លួន ភិក្ខុទាំង-ឡាយ ត្រាច់ចារិកទៅតាមសេនាសន: ឃើញហើយសួរថា អាវុសោ ចីវរ និងកម្រាលដេកនេះ ជារបស់អ្នកណា កាលភិក្ខុនោះឆ្លើយថា របស់ខ្ញុំ ដូច្នេះហើយ ទើបពោលថា អាវុសោ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតចីវរត្រឹមតែ ៣ ឯលោក បួសក្នុងសាសនារបស់ព្រះសាស្តា ដែលជាអ្នកមានសេចក្តីប្រាថ្នាតិចយ៉ាងនេះ ហេតុអ្វីទើបជាអ្នកមានបរិក្ខារច្រើនយ៉ាងនេះ ដូច្នេះហើយ បាននាំភិក្ខុនោះទៅកាន់សម្នាក់ព្រះសាស្តាក្រាបទូលថា បពិត្រព្រះអង្គ ភិក្ខុរូបនេះជាអ្នកមានកណ្ហ:ច្រើនពន់ពេក ។ ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំង-ឡាយ បានឮថា សេចក្តីនេះយ៉ាងនោះឬ កាលភិក្ខុនោះក្រាបទូលថា ការុណា ព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ ហេតុអ្វីអ្នកកាលតថាគតសម្តែងធម៌ដើម្បីភាពជាបុគ្គលមានសេចក្តីប្រាថ្នាតិចហើយ បែរជាអ្នកមានកណ្ហ:ច្រើនយ៉ាងនេះទៅវិញ ។

ភិក្ខុនោះក្រោធហើយ ដោយហេតុត្រឹមប៉ុណ្ណោះឯង គិតថា ឥឡូវនេះអញនឹងដើរទៅដោយទំនងនេះ ដូច្នេះហើយ ដោះសំពត់ជណ្តប់ មានចីវរមួយគឺសង្ឃាំ បានឈរត្រង់កណ្តាលបរិសទ ។ គ្រានោះ ព្រះសាស្តា កាលទ្រង់

អបស្សបកិក្ខុនោះ ទើបត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុនអ្នកស្វែងរកហិរិ និងឱត្តប្បៈ ក្នុងកាលជាអារក្សទឹក ក៏ស្វែងរកហិរិឱត្តប្បៈអស់ ១២ ឆ្នាំមិនមែនឬ តែឥឡូវនេះ អ្នកបួសក្នុងព្រះពុទ្ធសាសនា ដ៏គួរគោរពយ៉ាងនេះហើយ ដោះសំពត់ដណ្តប់ លះបង់នូវហិរិ និងឱត្តប្បៈឈរត្រង់កណ្តាលបរិស័ទ ៤ ព្រោះហេតុអ្វី ។

ភិក្ខុនោះបានស្តាប់ព្រះតម្រាស់របស់ព្រះសាស្តាហើយ បាននូវហិរិឱត្តប្បៈដណ្តប់ចីវរនោះ ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ភិក្ខុទាំងឡាយទូលអារាធនាព្រះសាស្តា ដើម្បីឲ្យទ្រង់ប្រកាសសេចក្តីនោះ ទើបព្រះដ៏មានព្រះភាគ នាំអតីតនិទានមកត្រាស់ ដូច្នេះ ។

បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វបដិសន្ធិក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីព្រះបាទពារាណសី ក្នុងថ្ងៃដាក់ឈ្មោះ ជនទាំងឡាយបានថ្វាយព្រះនាមរបស់ព្រះអង្គថា មហិសរាជកុមារ ។ ព្រះកនិដ្ឋភាតា គឺប្អូនប្រុសរបស់ព្រះអង្គមានឈ្មោះថាចន្ទកុមារ កាលព្រះជននីនៃព្រះរាជកុមារទាំងពីរនោះអស់ព្រះជន្មហើយ ព្រះរាជាទ្រង់ស្ថាបនាស្ត្រីជាទៃទុកក្នុងតំណែងជាអគ្គមហេសី ។

ព្រះនាងប្រសូតព្រះឱរសមួយអង្គ ។ ជនទាំងឡាយថ្វាយព្រះនាមរបស់ឱរសនោះថា សុរិយកុមារ ។ ព្រះរាជាទតឃើញសុរិយកុមារនោះហើយ ទ្រង់ពេញព្រះហឫទ័យប្រទានពរថា យើងឲ្យពរដល់បុត្ររបស់នាង ។ ឯព្រះទេវីនោះឯងក្រាបទូលថា ខ្ញុំម្ចាស់នឹងទទួលយកក្នុងពេលដែលត្រូវការ ដូច្នេះហើយ

ក្នុងកាលដែលព្រះរាជឱរសចម្រើនវ័យហើយ ទើបទូលព្រះរាជាថា បពិត្រ ព្រះសម្មតិទេព ទ្រង់បានប្រទានពរហើយ ក្នុងកាលកូនរបស់ខ្ញុំម្ចាស់ប្រសូត សូមទ្រង់ព្រះរាជទានរាជសម្បត្តិដល់បុត្រខ្ញុំម្ចាស់ចុះ ។

ព្រះរាជាទ្រង់ឃាត់ថា កូនទាំងពីររបស់យើងកំពុងរុងរឿងដូចគំនរភ្លើង ត្រាច់ទៅ យើងមិនអាចឲ្យរាជសម្បត្តិដល់សុរិយកុមារនោះបានទេ តែទ្រង់ យើញព្រះនាងអង្វរវើយៗ ទើបព្រះតម្រិះថា ស្រីនេះធ្វើសេចក្តីវិនាសដល់ កូនរបស់អញ ដូច្នេះហើយ ទើបត្រាស់ឲ្យហៅព្រះរាជឱរសទាំងពីរមក ត្រាស់ថា បាទាំងពីរ បិតាបានឲ្យពរក្នុងកាលដែលសុរិយកុមារប្រសូត ឥឡូវ នេះ មាតារបស់សុរិយកុមារទូលសូមរាជសម្បត្តិ បិតាមិនអាចមិនឲ្យដល់ នាងឡើយ មាតារបស់សុរិយកុមារ ធ្វើនូវសេចក្តីវិនាសដល់បុត្រទាំងពីរ ចូរ បាទៅនៅក្នុងព្រៃ ហើយសឹមត្រឡប់មកទទួលរាជសម្បត្តិ ក្នុងកាលដែល បិតាសោយទិវង្គតទៅ ដូច្នេះហើយ ទ្រង់បញ្ជូនទៅ ។

សុរិយកុមារលេងត្រង់លានព្រះរាជវាំង ឃើញព្រះរាជកុមារទាំងពីរនោះ ថ្វាយបង្គំព្រះបិតា ហើយចុះអំពីប្រាសាទ ជ្រាបហេតុនោះហើយ ទើបចេញទៅ ជាមួយព្រះរាជកុមារទាំងនោះដែរ ។ ក្នុងកាលដែលព្រះរាជកុមារនោះចូលទៅ កាន់ហិមវន្តប្បទេស ព្រះពោធិសត្វយាងចេញអំពីផ្លូវ គង់ត្រង់ម្លប់ឈើមួយ ដើម ហើយត្រាស់នឹងសុរិយកុមារថា នែបា ចូរបាទៅកាន់ស្រះនោះងូតទឹក និង សោយទឹក ហើយយកស្លឹកឈូកនាំទឹកមកដើម្បីបងទាំងពីរផង ។ ស្រះនោះ ជាស្រះដែលអារក្សទឹកម្នាក់ បានអំពីសម្នាក់នៃស្តេចវេស្សវណ ព្រះបាទ

វេស្សវណៈ ត្រាស់នឹងអារក្សទឹកនោះថា វៀរតែជនដែលចេះទេវធម៌ប៉ុណ្ណោះ ជនដទៃដែលចុះក្នុងស្រះនេះ អ្នកគប្បីបានទំពាស៊ីនូវជនទាំងនោះ ។ តាំងអំពីនោះមក អារក្សទឹកនោះ សួរទេវធម៌នឹងបុគ្គលដែលចុះហើយកាន់ស្រះនោះ រមែងទំពាស៊ីបុគ្គលដែលមិនចេះ ។

ចំណែកសុរិយកុមារ មិនបានពិចារណាស្រះនោះចុះទៅ ត្រូវអារក្សទឹកនោះសួរថា អ្នកចេះទេវធម៌ឬ ក៏ឆ្លើយថា ព្រះចន្ទ និងព្រះអាទិត្យ ឈ្មោះថាទេវធម៌ ។ លំដាប់នោះ អារក្សទឹកពោលនឹងសុរិយកុមារនោះថា អ្នកមិនចេះទេវធម៌ ហើយក៏ទាញចុះក្នុងទឹក នាំទៅទុកក្នុងកពរបស់ខ្លួន ។ ចំណែកព្រះពោធិសត្វ ឃើញសុរិយកុមារនោះយឺតយូរ ទើបបញ្ជូនចន្ទកុមារទៅ ចន្ទកុមារនោះ ត្រូវអារក្សនោះសួរថា អ្នកចេះទេវធម៌ឬ ក៏ឆ្លើយថា ទិសទាំង ៤ ឈ្មោះថា ទេវធម៌ អារក្សក៏ទាញចន្ទកុមារនោះចុះទឹក ទៅទុកយ៉ាងនោះដូចគ្នា ។

ព្រះពោធិសត្វ កាលចន្ទកុមារនោះយឺតយូរ ទើបគិតថា អន្តរាយគប្បីមាន ដូច្នេះហើយ ទើបទៅឯង ឃើញស្នាមជើងចុះនៃកុមារទាំងពីរហើយ ក៏ដឹងថា ស្រះនេះមានអារក្សទឹករក្សា ទើបស៊កព្រះខ័ន កាន់ធ្នូឈរហើយ ។ អារក្សទឹកឃើញព្រះពោធិសត្វមិនចុះ ទើបកាឡាខ្លួនជាថ្មើរព្រៃមកពោលប្រាស្រ័យថា នែបុរស អ្នកធ្វើដំណើរហត់នឿយ ហេតុអ្វី មិនចុះកាន់ស្រះនេះ ងូតទឹក ផឹកទឹក បរិភោគក្រអៅឈូក ប្រជាប់នូវផ្កាហើយ សឹមទៅ ។

ព្រះពោធិសត្វឃើញបុរសនោះជ្រាបបានថា បុរសនេះជាយក្ខ ទើបពោល

ថា អ្នកចាប់ប្អូនប្រុសទាំងពីររបស់ខ្ញុំឬ យក្ខពោលថា អើខ្ញុំចាប់ ព្រះពោធិ-
សត្វពោលថា ចាប់ធ្វើអ្វី យក្ខពោលថា ខ្ញុំតែងបាន គឺទំពាស៊ីបុគ្គលដែលចុះ
កាន់ស្រះនេះ ព្រះពោធិសត្វសួរថា អ្នករមែងបានគ្រប់គ្នាឬ យក្ខពោលថា
រៀរអ្នកចេះទេវធម៌ ជនដ៏សេសខ្ញុំរមែងបាន ព្រះពោធិសត្វពោលថា អ្នក
ត្រូវការដោយទេវធម៌ឬ យក្ខពោលថា ខ្ញុំត្រូវការ ព្រះពោធិសត្វពោលថា ខ្ញុំ
នឹងពោល យក្ខពោលថា បើដូច្នោះ ចូរអ្នកពោលចុះ ព្រះពោធិសត្វពោល
ថា ខ្ញុំមានខ្លួនកខ្វក់មិនអាចពោលបានទេ ។

យក្ខឲ្យព្រះពោធិសត្វងូតទឹក ឲ្យផឹកទឹកដែលគួរផឹក តាក់តែងកាយ
ឡើងកាន់បល្ល័ង្ក ត្រង់កណ្តាលមណ្ឌប ដែលរៀបចំដោយខ្លួនឯង អង្គុយ
ទៀបបាទមូលរបស់ព្រះពោធិសត្វនោះ ។

លំដាប់នោះ ព្រះពោធិសត្វប្រាប់យក្ខនោះថា ចូរអ្នកស្តាប់ដោយគោរព
ចុះ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ បរិបូណ៌ដោយហិរិ និង
ឱត្តប្ប: តាំងមាំហើយក្នុងធម៌ស លោកពោលថា មានទេវធម៌
ក្នុងលោក ។

យក្ខស្តាប់ទេសនានេះហើយជ្រះថ្លា ពោលនឹងព្រះពោធិសត្វថា លោក
ជាបណ្ឌិត ខ្ញុំជ្រះថ្លាចំពោះលោកហើយ នឹងឲ្យប្អូនប្រុសម្នាក់ តើនាំអ្នកណាមក
ព្រះពោធិសត្វពោលថា ចូរនាំប្អូនពៅមកចុះ យក្ខពោលថា លោកជាបណ្ឌិត
លោកចេះទេវធម៌តែម្យ៉ាងប៉ុណ្ណោះ តែលោកមិនប្រព្រឹត្តក្នុងទេវធម៌ទាំងនោះ

ព្រះពោធិសត្វសួរថា ព្រោះហេតុអ្វី យក្ខឆ្លើយថា ព្រោះលោកឲ្យនាំបួនពៅមក រៀវកូនច្បង រមែងមិនឈ្មោះថាធ្វើអបចាយិកកម្មចំពោះអ្នកមានសេចក្តីចម្រើន ។ ព្រះពោធិសត្វពោលថា នែយក្ខ ខ្ញុំចេះទេវធម៌ផង ប្រព្រឹត្តនៅក្នុងទេវធម៌នោះផង ព្រោះខ្ញុំអាស្រ័យបួនប្រុសពៅនោះ ទើបពួកខ្ញុំចូលព្រៃនេះ ព្រោះថា មាតារបស់បួនប្រុសពៅនោះ ទូលសូមរាជសម្បត្តិនឹងបិតារបស់យើងទាំងពីរ ដើម្បីប្រយោជន៍ដល់បួនពៅនោះ បិតារបស់ខ្ញុំមិនព្រះរាជទានពរនោះ ទ្រង់អនុញ្ញាតការនៅព្រៃ ដើម្បីប្រយោជន៍ដល់ការតាមរក្សាយើងទាំងពីរ កុមារនោះ មិនឃើញទៅ ឃើញតែពួកយើង កាលបើខ្ញុំពោលថា យក្ខក្នុងព្រៃទំពាស៊ីបួនប្រុសពៅនោះ ដូច្នេះ បុគ្គលណាក៏មិនជឿ ព្រោះហេតុនោះ ខ្ញុំភ័យចំពោះការនិន្ទា ទើបឲ្យនាំបួនប្រុសពៅនោះតែម្នាក់មក ។

យក្ខជ្រះថ្លាចំពោះព្រះពោធិសត្វ សរសើរថា សាធុ លោកបណ្ឌិត លោកចេះទេវធម៌ផង ប្រព្រឹត្តក្នុងទេវធម៌ផង ដូច្នេះហើយ ទើបនាំបួនទាំងពីរមកឲ្យលំដាប់នោះ ព្រះពោធិសត្វពណ៌នាទោសក្នុងកំណើតយក្ខហើយ ឲ្យយក្ខនោះតាំងនៅក្នុងសីល ៥ ។ ព្រះពោធិសត្វនោះ ជាអ្នកមានការរក្សាដែលយក្ខនោះធ្វើដោយល្អហើយនៅក្នុងព្រៃនោះ កាលព្រះរាជបិតាសោយទិវង្គតហើយ នាំយក្ខទៅកាន់ក្រុងពារាណសី គ្រប់គ្រងរាជសម្បត្តិហើយ ព្រះរាជទានតំណែងឧបរាជដល់ចន្ទកុមារ ព្រះរាជទានតំណែងសេនាបតីដល់សុរិយកុមារ ឲ្យធ្វើលំនៅក្នុងរមណីយដ្ឋានដល់យក្ខ នឹងបានធ្វើដោយប្រការដែលយក្ខនោះដល់នូវភាពជាបុគ្គលដ៏ប្រសើរដោយលាភ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា អារក្សទឹកក្នុងកាលនោះ បានជាកិកូដែលមានកណ្ឌៈច្រើន សុរិយកុមារបានជាអានន្ទ ចន្ទកុមារបានជាសារីបុត្រ មហិស្សាសកុមារ បានមកជាតថាគតនេះឯង ។

ព្រះសាស្តា កាលត្រាស់ជាតកយ៉ាងនេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន អ្នកស្វែងរកទេវធម៌ ដល់ព្រមដោយហិរិ និងឱត្តប្បៈត្រាច់ទៅយ៉ាងនោះ ។ ឥឡូវនេះ អ្នកឈរដោយទំនងនេះ ក្នុងកណ្តាលនៃបរិស័ទ ៤ ពោលចំពោះមុខតថាគតថា ខ្ញុំមានសេចក្តីជ្រាបច្បាស់ដូច្នេះ ឈ្មោះថា បានធ្វើកម្មដែលមិនសមគួរហើយ ព្រោះថា បុគ្គលឈ្មោះថាជាសមណៈដោយគ្រាន់តែហាមសំពត់សាដកជាដើមក៏មិនមែន ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ន ឆគ្គចរិយា ន ជដា ន បង្កា នានាសកា ថណ្ឌិលសាយិកា វា
រជោជល្លំ ឧក្កដិកប្បធានំ សោធេន្តិ មច្ចំ អវិតិណ្ណកង្ខំ ។

ការប្រព្រឹត្តអាក្រាតកាយ ទុកសក់ ដេកលើភក់ មិនបរិភោគបាយ ដេកលើផែនដី ប្រឡាក់ខ្លួនដោយធូលី ព្យាយាមអង្គុយច្រហោង មិនជម្រះសត្វ ដែលមិនទាន់ឆ្លងផុតសេចក្តីសង្ស័យបានទេ ។

សេចក្តីអធិប្បាយ

បណ្តាបទថាទាំងនោះ បទថា **នានាសកា** កាត់បទជា **ន អនាសកា**

សេចក្តីថា ការហាមភត្ត ។ ការដេកលើផែនដី ឈ្មោះថា **តណ្ហិលសាយិកា ។** *គឺធូលីដែលប្រឡាក់ក្នុងសរីរៈ ដោយអាការ គឺដូចលាបដោយកក់ ឈ្មោះថា* **រជោជល្លំ ។** *សេចក្តីព្យាយាមដែលប្រារព្ធហើយ ដោយកាយជាអ្នកអង្គុយច្រហោង ឈ្មោះថា* **ឧក្កុដិកប្បធានំ ។** *ព្រះដ៏មានព្រះភាគត្រាស់អធិប្បាយពាក្យនេះថា សត្វណាយល់ថា អញនឹងសម្រេចសេចក្តីបរិសុទ្ធ ពោល គឺការចេញចាកលោក ដោយបដិបត្តិយ៉ាងនេះ ដូច្នេះហើយ គប្បីសមាទាន ប្រព្រឹត្តវត្តឯណាមួយ ក្នុងវត្ត មានការប្រព្រឹត្តជាបុគ្គលជាអាក្រាតទាំងនេះជាដើម សត្វនោះគប្បីឈ្មោះថា ចម្រើនដោយការឃើញ និងគប្បីជាអ្នកមានចំណែកនៃសេចក្តីលំបាកដោយចំណែកមួយ ។ ព្រោះថា វត្តទាំងនោះ ដែលសត្វសមាទានល្អហើយ រមែងញុំាងសត្វដែលឈ្មោះថា មិនទាន់កន្ទងនូវសេចក្តីសង្ស័យ មានវត្ត ៥ ដែលខ្លួនមិនទាន់បានឈានកន្ទងហើយ ឲ្យបរិសុទ្ធបានឡើយ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ភិក្ខុមានភណ្ឌៈច្រើន ចប់

រឿង សន្តតិមហាមាត្យ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសន្តតិមហាមាត្យ ត្រាស់ព្រះធម្មទេសនានេះថា **អលង្ឃតោ ចេបិ សមញ្ញវេយ្យ** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ សន្តតិមហាមាត្យនោះ បង្ក្រាបជនបទក្នុងដែនរបស់ព្រះបាទបសេនទិកោសល ដែលបះបោរឲ្យស្ងប់រម្ងាប់ហើយ ត្រឡប់មក គ្រានោះ ព្រះរាជាទ្រង់ពេញព្រះហឫទ័យ ប្រទានរាជសម្បត្តិឲ្យ ៧ ថ្ងៃ បានប្រទានស្ត្រីឈ្មោសក្នុងការរាំ និងច្រៀងម្នាក់ដល់គាត់ ។ គាត់ជាបុគ្គលស្រេវឹងស្រោអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ប្រជាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាងហើយ ឡើងកាន់កជីរដ៏ប្រសើរទៅកាន់កំពង់ទឹក ឃើញព្រះសាស្តាកំពុងយាងចូលទៅបិណ្ឌបាតត្រង់រោងទ្វារ នៅលើកជំរដ៏ប្រសើរនោះឯង ឆក់ក្បាលថ្ងាយបង្គំហើយ ។ ព្រះសាស្តាទ្រង់ធ្វើការញញឹម ព្រះអានន្ទទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុឲ្យទ្រង់ធ្វើការញញឹមឲ្យប្រាកដ កាលត្រាស់ជ្រាប់ហេតុនៃការញញឹម ទើបត្រាស់ថា ម្នាលអានន្ទ ចូរអ្នកមើលសន្តតិមហាមាត្យ ក្នុងថ្ងៃនេះឯង គេប្រជាប់ដោយអាការណៈគ្រប់យ៉ាងមកកាន់សម្នាក់តថាគត នឹងសម្រេចអរហត្តក្នុងកាលចប់គាថា ដែលប្រកបដោយ ៤ បទ អង្គុយលើអាកាស ៧ ជួរដើមត្នោត នឹងបរិនិព្វាន ។ មហាជនបានស្តាប់ព្រះតម្រាស់របស់ព្រះសាស្តា ដែលកំពុងត្រាស់ជាមួយព្រះថេរៈ ។

បណ្តាជនទាំងនោះ ពួកមិច្ឆាទិដ្ឋិគិតថា ចូរអ្នកទាំងឡាយមើលកិរិយា

របស់ព្រះសមណគោតម ទ្រង់ពោលតែមាត់ប៉ុណ្ណោះ បានឮថា ក្នុងថ្ងៃនេះ សន្តតិមហាមាត្យនោះ ស្រវឹងស្រាយ៉ាងនោះ តែងខ្លួនតាមប្រក្រតី ស្តាប់ធម៌ ក្នុងសម្នាក់របស់ព្រះសមណគោតមនោះហើយ ទើបបរិនិព្វានក្នុងថ្ងៃនេះ ពួក យើងនឹងចាប់កំហុសព្រះសមណគោតមនោះ ដោយមុសាវាទ ។

ពួកជនសម្មាទិដ្ឋិគិតគ្នាថា គួរអស្ចារ្យហ្ន៎ ព្រះពុទ្ធទាំងឡាយទ្រង់មាន អានុភាពច្រើន ក្នុងថ្ងៃនេះ យើងទាំងឡាយ នឹងបានមើលភាពអង់អាចរបស់ ព្រះពុទ្ធ និងការអង់អាចរបស់សន្តតិមហាមាត្យ ។

ឯសន្តតិមហាមាត្យ លេងទឹកអស់មួយថ្ងៃ ត្រង់កំពង់ហើយ ទៅកាន់ ឧទ្យាន អង្គុយត្រង់រោងផឹកសុរា ។ ចំណែកស្រីនោះ ចុះទៅក្នុងកណ្តាលទី សម្រាប់រាំ ផ្តើមសម្តែងការរាំ និងការច្រៀង កាលនាងសម្តែងការរាំ និង ការច្រៀងក្នុងថ្ងៃនោះ ខ្យល់មានពិសដូចសស្ត្រាកើតឡើងហើយខាងក្នុងផ្ទៃ កាត់នូវហទយៈហើយ ព្រោះភាពដែលនាងមានអាហារតិចអស់ ៧ ថ្ងៃ ដើម្បី សម្តែងការទន់ល្មូតល្មៃនៃសរីរៈ ក្នុងវារៈចនោះឯង នាងមានមាត់ហា និង បើកភ្នែក បានធ្វើកាលកិរិយាហើយ ។

សន្តតិមហាមាត្យពោលថា ចូរអ្នកទាំងឡាយមើលស្រីនោះ គ្រាន់តែពាក្យ ដែលជនទាំងឡាយពោលថា ស្រីនោះស្លាប់ហើយដូច្នេះ ត្រូវសេចក្តីសោកដ៏ ខ្លាំងក្លាគ្របសង្កត់ហើយ ។ ក្នុងខណៈនោះឯង ស្រាដែលគាត់ផឹកអស់ ៧ ថ្ងៃ ក៏ស្វាងហើយ ប្រៀបដូចតំណក់ទឹកលើអំបែងក្តៅ ដូច្នោះ ។ គាត់គិតថា អ្នកដទៃវៀរព្រះតថាគតចេញ មិនអាចញុំាងសេចក្តីសោករបស់អញឲ្យរលត់

បានឡើយ មានសេនាហែហម ទៅកាន់សម្នាក់ព្រះសាស្តាក្នុងពេលល្ងាច ថ្វាយបង្គំហើយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីសោកបែបនេះកើតឡើងដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គមកហើយដោយបំណងថា ទ្រង់នឹងអាចលត់នូវសោករបស់ខ្ញុំព្រះអង្គបាន សូមទ្រង់ជាទីពឹងរបស់ខ្ញុំព្រះអង្គចុះ ។

គ្រានោះ ព្រះសាស្តាត្រាស់ថា អ្នកមកកាន់សម្នាក់របស់បុគ្គលដែលអាចលត់នូវសេចក្តីសោកបានពិតប្រាកដ ពិតហើយ ទឹកភ្នែកដែលហូររបស់អ្នក ដែលយំក្នុងកាលស្រីនេះស្ងាប់ ដោយហេតុនេះឯង ច្រើនជាងទឹករបស់ទឹកក្នុងមហាសមុទ្រទាំង ៤ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

កិលេសជាគ្រឿងកង្វល់ណាមានក្នុងកាលមុន ចូរអ្នកញ៉ាំងកិលេសគ្រឿងកង្វល់នោះឲ្យរីងស្ងួតទៅ កិលេសជាគ្រឿងកង្វល់ កុំមានដល់អ្នកក្នុងកាលខាងក្រោយឡើយ បើអ្នកមិនប្រកាន់ខន្ធក្នុងកណ្តាល នឹងជាអ្នកស្ងប់រម្ងាប់ត្រាច់ទៅ ។

ក្នុងកាលចប់ព្រះគាថា សន្តតិមហាមាត្យសម្រេចអរហត្តហើយ ពិចារណាមើលនូវអាយុសង្ខារបស់ខ្លួន ជ្រាបការប្រព្រឹត្តទៅមិនបាននៃអាយុសង្ខារនោះហើយ ទើបក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ សូមទ្រង់អនុញ្ញាតបរិនិព្វានដល់ខ្ញុំព្រះអង្គចុះ ។

ព្រះសាស្តាទ្រង់ជ្រាបកម្មដែលសន្តតិមហាមាត្យធ្វើហើយ ក៏ទ្រង់កំណត់ថា ពួកជនមិច្ឆាទិដ្ឋិប្រជុំគ្នា ដើម្បីសង្កត់សង្កិនតថាគតដោយមុសាវាទ នឹងមិនបានឱកាស ពួកសម្មាទិដ្ឋិប្រជុំគ្នាដោយបំណងថា ពួកយើងនឹងមើលនូវកាព

អង់អាចរបស់ព្រះពុទ្ធ និងភាពអង់អាចរបស់សន្តតិមហាមាត្យ ស្តាប់កម្ម ដែលសន្តតិមហាមាត្យនេះធ្វើហើយ នឹងធ្វើនូវការអើពើក្នុងបុណ្យទាំងឡាយ ដូច្នេះហើយ ទើបត្រាស់ថា បើដូច្នោះ ចូរអ្នកប្រាប់កម្មដែលអ្នកធ្វើហើយដល់ជនទាំងនេះ កាលប្រាប់ កុំឈរលើផែនដី ចូរឈរលើអាកាស ៧ ជួរត្នោត ហើយប្រាប់ចុះ ។

សន្តតិមហាមាត្យនោះទទួលថា សាធុ ដូច្នេះហើយ ទើបថ្វាយបង្គំព្រះសាស្តា ហោះឡើងទៅកាន់អាកាសមួយជួរត្នោត ចុះមកថ្វាយបង្គំម្តងទៀត ហោះឡើងទៅអង្គុយពត់ក្អែនលើអាកាស ៧ ជួរដើមត្នោតតាមលំដាប់ហើយ ទូលថា បពិត្រព្រះអង្គ សូមទ្រង់ស្តាប់បុព្វកម្មរបស់ខ្ញុំចុះ ។

ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលព្រះពុទ្ធព្រះនាមវិបស្សី ខ្ញុំព្រះអង្គកើតក្នុងត្រកូលមួយ ក្នុងពន្ធុមតីនគរ គិតហើយថា អ្វីហ្ន៎ជាកម្មដែលមិនធ្វើនូវការកាត់ផ្តាច់ ឬបៀតបៀននូវជនដទៃ ដូច្នេះហើយ កាលពិចារណា ទើបឃើញកម្ម គឺការប្រកាសក្នុងបុណ្យទាំងឡាយ ចាប់តាំងអំពីកាលនោះ ធ្វើកម្មនោះ បបួលមហាជនដើរប្រកាសថា ចូរពួកអ្នកធ្វើបុណ្យទាំងឡាយ ចូរសមាទានឧបោសថក្នុងថ្ងៃឧបោសថទាំងឡាយ ចូរស្តាប់ធម៌ ឈ្មោះថា រតនៈដទៃ ស្មើនឹងពុទ្ធរតនៈមិនមាន ចូរពួកអ្នកធ្វើសក្ការៈរតនៈទាំង ៣ ចុះ ។

ព្រះរាជាជាធំ ព្រះនាមពន្ធុមៈ ជាពុទ្ធបិតា ទ្រង់ស្តាប់សំឡេងរបស់ខ្ញុំព្រះអង្គ ត្រាស់ឲ្យហៅខ្ញុំព្រះអង្គចូលគាល់ហើយត្រាស់សួរថា នែបា បាត្រាច់ធ្វើអ្វី កាលខ្ញុំព្រះអង្គទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំដើរប្រកាសគុណ

រតនៈទាំង ៣ បបួលមហាជនក្នុងការធ្វើបុណ្យទាំងឡាយ ទើបត្រាស់សួរថា អ្នកអង្គុយលើអ្វីត្រាច់ទៅ កាលខ្ញុំព្រះអង្គទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំជើរទៅដោយជើង ទើបត្រាស់ថា នែបា បាមិនគួរជើរទៅយ៉ាងនោះ ចូរប្រដាប់នូវកម្រងផ្កានេះហើយ អង្គុយលើខ្នងសេះត្រាច់ទៅចុះ ដូច្នេះហើយ ព្រះរាជាព្រះរាជទានកម្រងផ្កា ដូចគ្នានឹងកម្រងកែវមុក្តា និងបានព្រះរាជទានសេះដែលបង្វឹកហើយដល់ខ្ញុំព្រះអង្គ ។

សម័យក្រោយមកទៀត ព្រះរាជាត្រាស់ឲ្យខ្ញុំព្រះអង្គ ដែលកំពុងត្រាច់ប្រកាសយ៉ាងនោះឯង ដោយគ្រឿងបរិហារដែលព្រះរាជាប្រទាន ចូលគាល់ហើយត្រាស់សួរថា នែបា បាត្រាច់ធ្វើអ្វី កាលខ្ញុំព្រះអង្គទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំធ្វើកម្មឈ្មោះនោះ ទើបត្រាស់ថា នែបា សូម្បីសេះក៏មិនគួរដល់បា ចូរបាអង្គុយលើរថត្រាច់ទៅចុះ ហើយបានព្រះរាជទានរថ ដែលទឹមដោយសេះ សិន្ធព ៤ ។ ក្នុងគ្រាទី ៣ ព្រះរាជាស្តាប់សំឡេងរបស់ខ្ញុំព្រះអង្គហើយ ត្រាស់ឲ្យចូលគាល់ សួរថា នែបា បាត្រាច់ធ្វើអ្វី កាលខ្ញុំព្រះអង្គទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គធ្វើកម្មឈ្មោះនោះ ទើបត្រាស់ថា នែបា សូម្បីរថក៏មិនគួរដល់បា ហើយព្រះរាជទានភោគៈជាច្រើន និងគ្រឿងប្រដាប់ធំ មួយអន្ទើដោយជីរ ១ ដល់ខ្ញុំព្រះអង្គ ។ ខ្ញុំព្រះអង្គនោះ ប្រដាប់ដោយអាភរណៈគ្រប់យ៉ាង អង្គុយលើ-កជីរ បានធ្វើកម្មរបស់អ្នកប្រកាសធម៌អស់ ៨ ម៉ឺនឆ្នាំ ក្លិនខ្ញីមចន្ទន៍ផ្សាយចេញអំពីកាយរបស់ខ្ញុំព្រះអង្គ ក្លិនឧប្បលផ្សាយចេញអំពីមាត់អស់កាលមានប្រមាណប៉ុណ្ណោះ នេះជាកម្មដែលខ្ញុំព្រះអង្គ

ធ្វើហើយ ។

សន្តតិមហាមាត្យនោះ កាលទូលបុព្វកម្មរបស់ខ្លួនយ៉ាងនោះហើយ អង្គុយលើអាកាសនោះឯង ចូលតេជោកសិណបរិនិព្វានហើយ ។ អណ្តាតភ្លើងកើតឡើងក្នុងសរីរៈ ឆេះសាច់ និងឈាមហើយ ធាតុទាំងឡាយដូចផ្តាម្ជុះនៅសល់ ។

ព្រះសាស្តាទ្រង់លាតសំពត់ស ធាតុទាំងឡាយក៏ធ្លាក់ចុះលើសំពត់នោះ ទ្រង់បញ្ចុះធាតុទាំងនោះហើយ ត្រាស់ឲ្យសាងស្តូបត្រង់ផ្លូវធំ ដែលមានមុំ ៤ ដោយបំណងថា មហាជនថ្វាយបង្គំហើយ និងមានចំណែកនៃបុណ្យ ។

ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោ សន្តតិមហាមាត្យសម្រេចអរហត្តក្នុងកាលចប់មួយព្រះគាថា ទាំងមានគ្រឿងប្រដាប់នោះឯង អង្គុយលើអាកាសបរិនិព្វានហើយ ការហៅលោកថា សមណៈគួរឬហ្ន៎ ឬហៅថាព្រាហ្មណ៍ ទើបគួរ ។

ព្រះសាស្តាទ្រង់យាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងឡាយទូលថា ពួកខ្ញុំព្រះអង្គ អង្គុយប្រជុំគ្នាដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការហៅបុត្ររបស់តថាគតថាសមណៈក៏គួរ ហៅថា ព្រាហ្មណ៍ក៏គួរដូចគ្នា ដូច្នេះ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

អលង្ការោ ចេបិ សមំ ចរេយ្យ
សន្តោ ទន្តោ និយតោ ព្រហ្មចារី

សព្វេសុ ភូតេសុ និធាយ ទណ្ឌំ

សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ ។

បើបុគ្គលណា មានខ្លួនប្រដាប់ស្អិតស្អាងហើយ (ដោយគ្រឿងអម្ពរ) តែគប្បីប្រព្រឹត្តស្មើ អ្នកស្ងប់រម្ងាប់ ទូន្មាន (ឥន្ទ្រិយ) ជាបុគ្គលពាល (ចំពោះមគ្គផល) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញាក្នុងសត្វទាំងពួង ចេញហើយ បុគ្គលនោះ ហៅថា ព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថាភិក្ខុក៏បាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អលង្កតោ** *បានដល់ ប្រដាប់ដោយសំពត់និងអាភរណៈ ។ បណ្ឌិតគប្បីជ្រាបអត្ថនៃព្រះគាថានេះថា បើបុគ្គលប្រកបដោយគ្រឿងអលង្ការ មានសំពត់ជាដើម គប្បីប្រព្រឹត្តស្មើដោយកាយជាដើម ឈ្មោះថាជាអ្នកស្ងប់ ព្រោះការស្ងប់រម្ងាប់នៃរាគៈជាដើម ឈ្មោះថាជាបុគ្គលទូន្មាន ព្រោះទូន្មានឥន្ទ្រិយ ឈ្មោះថាជាបុគ្គលទៀង ព្រោះទៀងក្នុងមគ្គទាំង ៤ ឈ្មោះថាព្រហ្មចារី ព្រោះប្រព្រឹត្តប្រសើរ ឈ្មោះថាដកនូវអាជ្ញាក្នុងសត្វគ្រប់ពួក ព្រោះជាអ្នកដាក់ចុះនូវអាជ្ញាតាមកាយជាដើមហើយ បុគ្គលនោះ គឺបុគ្គលបែបនោះ ដែលបុគ្គលគួរហៅថាព្រាហ្មណ៍ ព្រោះជាអ្នកមានបាបបន្សាត់ហើយក៏បាន ថាសមណៈ ព្រោះជាអ្នកមានបាបស្ងប់ហើយក៏បាន ។ ថាភិក្ខុ ព្រោះជាអ្នកមានកិលេសដែលទម្លាយហើយក៏បាន ដោយពិត ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន

សោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង សន្តតិមហាមាត្យ ចប់

រឿង ព្រះបិលោតិកត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបិលោតិកត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ហិរិនិសេធោ បុរិសោ** *ជាដើម ។*

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះអានន្ទត្ថេរឃើញទារកម្នាក់ស្បៃកសំពត់ចាស់ កាន់អំបែងដើរសូមទាន ទើបពោលថា អ្នកបួសមិនល្អជាងការដើរទៅយ៉ាងនេះឬ កាលកុមារតបថា បពិត្រលោកម្ចាស់ អ្នកណានឹងឲ្យខ្ញុំបួស ទើបធានាថា អាត្មានឹងឲ្យបួស ហើយនាំទៅកាន់វិហារ បានងូតទឹកដោយដៃរបស់ខ្លួន ឲ្យកម្មដ្ឋានហើយក៏ឲ្យបួស ។

ព្រះអានន្ទនោះ ចោកសំពត់ចាស់ដែលទារកនោះស្បៃកហើយ ពិនិត្យមិនឃើញចំណែកណាមួយល្មមប្រើប្រាស់បាន សូម្បីត្រឹមតែធ្វើសំពត់តម្រងទឹក ទើបពាក់ត្រង់មែកឈើជាមួយអំបែង ។

គាត់បានបព្វជ្ជាឧបសម្បទាហើយ បរិភោគលាភសក្ការៈដែលកើតឡើងដើម្បីព្រះពុទ្ធទាំងឡាយ ដណ្តប់ចីវរដែលមានតម្លៃច្រើនត្រាច់ទៅ ជាអ្នកមានសរីរៈធាត់ អផ្សុកហើយគិតថា ប្រយោជន៍អ្វីរបស់អញដោយការដណ្តប់ចីវរ

ដែលជនឲ្យដោយសទ្ធាត្រាច់ទៅ ។ អញនឹងស្មៀកជណ្តប់សំពត់ចាស់របស់ខ្លួននេះឯង ដូច្នេះហើយ ក៏ទៅកាន់ទីនោះ ចាប់យកសំពត់ចាស់នោះឲ្យជាអារម្មណ៍ហើយ ទើបទូន្មានខ្លួនដោយខ្លួនឯងថា អ្នកមិនមានហិរិ អស់នូវឱ្ងាស អ្នកប្រាថ្នាដើម្បីលះហានៈ គឺការស្មៀកជណ្តប់សំពត់ទាំងឡាយបែបនោះ ត្រឡប់ទៅស្មៀកសំពត់ចាស់នេះ មានដៃកាន់អំបែងដើរសូមទានទៀតឬ ។

កាលលោកទូន្មានខ្លួននោះឯង ចិត្តផូរផង់ហើយ លោកក៏ទុកសំពត់ចាស់នោះត្រង់ទីដើមនោះឯង ត្រឡប់ទៅកាន់វិហារវិញ ។ ២-៣ ថ្ងៃកន្លងទៅ លោកអផ្សុកឡើងទៀត ទៅពោលយ៉ាងនោះឯងហើយក៏ត្រឡប់ អផ្សុកឡើងទៀត ក៏ទៅពោលយ៉ាងនោះដូចគ្នា ហើយក៏ត្រឡប់ ដោយប្រការដូច្នេះ ។

ភិក្ខុទាំងឡាយ ឃើញលោកទៅមកៗយ៉ាងនោះហើយទើបសួរថា អាវុសោ អ្នកទៅណា លោកប្រាប់ថា អាវុសោ ខ្ញុំនឹងទៅសម្នាក់អាចារ្យ ដូច្នេះហើយ ក៏ធ្វើសំពត់ចាស់របស់ខ្លួនឯងឲ្យជាអារម្មណ៍ដោយទំនងនោះឯង ហាមខ្លួនបាន ២-៣ ថ្ងៃប៉ុណ្ណោះ ក៏សម្រេចអរហត្តផល ។

ភិក្ខុទាំងឡាយពោលថា អាវុសោ លោកមិនទៅសម្នាក់អាចារ្យទៀតទេឬ ផ្លូវនេះជាផ្លូវត្រាច់ទៅរបស់លោកមិនមែនឬ ព្រះថេរៈឆ្លើយថា អាវុសោ កាលការទាក់ទងដោយអាចារ្យមាន ទើបខ្ញុំទៅ តែឥឡូវនេះ ខ្ញុំកាត់ផ្តាច់នូវការជាប់ជំពាក់បានហើយ ព្រោះដូច្នោះ ទើបខ្ញុំមិនទៅកាន់សម្នាក់អាចារ្យ ។

ពួកភិក្ខុក្រាបទូលរឿងរ៉ាវដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ព្រះបិលោតិកត្ថេរអួតអរហត្តផល ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បិលោតិកៈ

ពោលដូចម្តេច កិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ លោកពោលពាក្យឈ្មោះនេះ ព្រះសាស្តាទ្រង់ស្តាប់ពាក្យនោះហើយត្រាស់ថា ម្នាលកិក្ខុទាំងឡាយ ត្រូវហើយ បុត្ររបស់តថាគត កាលការជាប់ជំពាក់មាន ទើបទៅកាន់សម្នាក់អាចារ្យ តែឥឡូវនេះ ការជាប់ជំពាក់របស់បិលោតិកៈ កាត់បានហើយ លោកហាមខ្លួនដោយខ្លួនឯង សម្រេចអរហត្តហើយ ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

ហិរិនិសេធោ បុរិសោ　　កោចិ លោកស្មិ វិជ្ជតិ

យោ និទ្ទំ អបពោធេតិ　　អស្សោ ភទ្រោ កសាមិវ

អស្សោ យថា ភទ្រោ កសានិវិដ្ឋោ　　អាតាបិនោ សំវេគិនោ ភវាម

សទ្ធាយ សីលេន ច វីរិយេន ច　　សមាធិនា ធម្មវិនិច្ឆយេន ច

សម្បន្នវិជ្ជាចរណា បតិស្សតា　　បហាស្សថ ទុក្ខមិទំ អនប្បកំ។

បុរសអ្នកកម្ចាត់បង់នូវអកុសលវិតក្ក ដោយសេចក្តីខ្វាសជាបមានតិចក្នុងលោក បុគ្គលណាបន្ទោបង់នូវការដេកលក់ ដូចសេះល្អខ្លាចព្រោះរំពាត់ បុរសនោះរកបានដោយកម្រក្នុងលោក សេះល្អដែលនាយសារថីទូន្មានដោយរំពាត់ តក់ស្លុត យ៉ាងណា អ្នកទាំងឡាយចូរជាបុគ្គលមានព្យាយាម មានសេចក្តីតក់ស្លុតយ៉ាងនោះឯង បើអ្នកទាំងឡាយ ប្រកបព្រមដោយសទ្ធាផង សីលផង ព្យាយាមផង សមាធិផង ធម្មវិនិច្ឆ័យផង ជាអ្នកមានវិជ្ជា និងចរណៈដ៏បរិបូណ៌ មានស្មារតីតម្កល់មាំ រមែងលះបង់ទុក្ខមានប្រមាណច្រើននេះមិនខាន ។

សេចក្តីអធិប្បាយ

បុគ្គល ឈ្មោះថា ហិរិនិសេធបុគ្គល ក្នុងព្រះគាថានោះ ក៏ព្រោះអត្តថា ហាមអកុសលវិតក្ក ដែលកើតក្នុងខាងក្នុងដោយហិរិបាន ។

ពីរបទថា **កោចិ លោកស្មិ** សេចក្តីថា បុគ្គលបែបនោះរកបានលំបាក ទើបឈ្មោះថា តិចណាស់ដែលមានក្នុងលោក ។

ពីរបទថា **យោ ឯនំ** សេចក្តីថា បុគ្គលណាមិនប្រមាទហើយ ធ្វើសមណធម៌ ឃ្លាំចាំបណ្តេញនូវការដេកលក់ដែលកើតហើយ ខ្លួនជាអ្នកភ្ញាក់រឭក ព្រោះដូច្នោះ ទើបបុគ្គលនោះ ឈ្មោះថា បន្ទោបង់នូវការដេកលក់ ជាអ្នកភ្ញាក់រឭក ។

បទថា **កសាមិវ** ជាដើម សេចក្តីថា បុគ្គលណាកម្ចាត់ការដេកលក់ជាអ្នកភ្ញាក់ ដូចសេះល្អរវាងប្រយ័ត្នូវខ្សែតី គឺមិនឲ្យធ្លាក់ដល់ខ្លួនបាន ដូច្នោះ បុគ្គលនោះ រកបានលំបាក ។

ក្នុងគាថាទី ២ មានសេចក្តីសង្ខេបដូចតទៅនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាអ្នកមានព្យាយាម មានការសង្វេគ ដូចសេះល្អអាស្រ័យសេចក្តីប្រមាទ ត្រូវគេវាយដោយខ្សែតីហើយ ដឹងខ្លួនថា សូម្បីខ្លួនអញ ត្រូវគេវាយដោយខ្សែតីហើយ ក្នុងកាលតមកវៃមធ្វើសេចក្តីព្យាយាម ដូច្នោះ ។ អ្នកទាំងឡាយជាបុគ្គលយ៉ាងនោះហើយ ប្រកបដោយសទ្ធាពីរយ៉ាង ដែលជាលោកិយ និងលោកុត្តរ ដោយចារិសុទ្ធិសីល ៤ ដោយសេចក្តីព្យាយាមប្រព្រឹត្តទៅតាមផ្លូវកាយ និងចិត្ត ដោយសមាធិដែលសម្បយុត្តដោយសមាបត្តិ ៨ និងដោយគុណជាគ្រឿងវិនិច្ឆ័យធម៌ មានការដឹងហេតុ និងមិនមែនហេតុ

ជាលក្ខណៈ ឈ្មោះថា មានវិជ្ជា និងចរណៈដល់ព្រម ព្រោះការដល់ព្រមនៃវិជ្ជា ៣ ឬវិជ្ជា ៨ និងចរណៈ ១៥ ឈ្មោះថា ជាអ្នកមានសតិមាំទាំ ព្រោះជាអ្នកមានសតិតាំងមាំហើយ និងលះនូវទុក្ខក្នុងវដ្តៈដែលមានប្រមាណមិនតិចនេះបាន ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះបិលោតិកត្ថេរ ចប់

រឿង សុខសាមណេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសុខសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា **ឧទកំ ហិ នយន្តិ នេត្តិកា** *ជាដើម ។*

សេចក្តីពិស្តារ ក្នុងអតីតកាល មានបុត្ររបស់សេដ្ឋីអ្នកក្រុងពារាណសីម្នាក់ ឈ្មោះគន្ធកុមារ កាលបិតារបស់គាត់អនិច្ចកម្មហើយ ព្រះរាជាត្រាស់ឲ្យហៅគាត់មកចូលគាល់ ទ្រង់លួងលោមហើយ បានព្រះរាជទានតំណែងសេដ្ឋីដល់គាត់នោះឯងដោយសក្ការៈដ៏ច្រើន ចាប់តាំងអំពីកាលនោះមក គន្ធ-កុមារនោះ ក៏បានប្រាកដឈ្មោះថា គន្ធសេដ្ឋី ។ គ្រានោះ អ្នករក្សាឃ្លាំងរបស់សេដ្ឋីនោះ បានបើកទ្វារបន្ទប់សម្រាប់ដាក់ទ្រព្យ ជញ្ជូនចេញមកហើយ ចង្អុល

បង្ហាញថា បពិត្រលោកសេដ្ឋី ទ្រព្យរបស់បិតាលោកមានប្រមាណប៉ុណ្ណេះ ទ្រព្យបុព្វបុរស មានជីតាជាដើមមានចំនួនប៉ុណ្ណេះ ។ សេដ្ឋីនោះសម្លឹងមើលគំនរទ្រព្យហើយពោលថា ហេតុអ្វីបុព្វបុរសទាំងនោះមិនបានកាន់យកទ្រព្យទាំងនេះទៅផង អ្នករក្សាឃ្លាំងឆ្លើយថា បពិត្រលោកម្ចាស់ ឈ្មោះថា បុគ្គលដែលកាន់យកទ្រព្យទៅផង មិនមានដោយពិត សត្វទាំងឡាយ នាំយកតែកុសលអកុសល ដែលខ្លួនបានធ្វើប៉ុណ្ណោះទៅ ។

សេដ្ឋីនោះគិតថា បុព្វបុរសទាំងនោះ នាំគ្នាសន្សំទ្រព្យហើយ ក៏លះបង់ចោលទៅ ព្រោះភាពដែលខ្លួនជាមនុស្សល្ងង់ ។ ចំណែកអញ នឹងកាន់យកទ្រព្យនោះទៅផង កាលគន្ធសេដ្ឋីគិតយ៉ាងនោះ មិនបានគិតថា អញនឹងឲ្យទាន ឬនឹងធ្វើការបូជា តែគិតថា អញនឹងបរិភោគទ្រព្យនេះឲ្យអស់ ហើយសឹមទៅ សេដ្ឋីនោះបានចំណាយទ្រព្យមួយសែន ធ្វើទីសម្រាប់ងូតទឹកសម្រេចដោយកែវផលិក ចំណាយទ្រព្យមួយសែនឲ្យធ្វើក្តារសម្រាប់ងូតទឹក ដែលវិចិត្រដោយកែវផលិកដូចគ្នា ចំណាយទ្រព្យមួយសែនឲ្យធ្វើបល្ល័ង្កសម្រាប់អង្គុយ ចំណាយទ្រព្យមួយសែនឲ្យធ្វើថាសសម្រាប់ដាក់ភោជន ចំណាយទ្រព្យមួយសែនឲ្យធ្វើមណ្ឌបក្នុងទីបរិភោគ ចំណាយទ្រព្យមួយសែន ឲ្យធ្វើគ្រែសម្រាប់ដាក់ថាសភោជន ឲ្យសាងសីហបញ្ជរក្នុងផ្ទះដោយទ្រព្យមួយសែនដូចគ្នា បានចំណាយទ្រព្យមួយពាន់ ដើម្បីប្រយោជន៍ដល់អាហារព្រឹករបស់ខ្លួន ចំណាយទ្រព្យមួយពាន់ ដើម្បីជាប្រយោជន៍ដល់អាហារល្ងាច តែក្នុងថ្ងៃពេញបូណ៌មី បានចំណាយទ្រព្យមួយសែន ដើម្បីជាប្រយោជន៍ដល់ភោជន ក្នុងថ្ងៃបរិភោគ

ភត្តនោះ លោកសេដ្ឋីបានចំណាយទ្រព្យមួយសែន តាក់តែងព្រះនគរ ប្រើមនុស្សឲ្យវាយស្គរ ប្រកាសថា សូមមហាជន មើលការបរិភោគភត្តរបស់គន្ធសេដ្ឋី មហាជនបានចងគ្រែត្រួតលើគ្រែ ប្រជុំគ្នា ។

ចំណែកគន្ធសេដ្ឋីនោះ អង្គុយលើបន្ទះក្តារដែលមានតម្លៃមួយសែន ក្នុងទីងូតទឹកដែលមានតម្លៃមួយសែន ងូតទឹកដោយក្អមទឹក ១៦ ក្អម បើកសីហបញ្ជរនោះហើយ អង្គុយលើបល្ល័ង្កនោះ កាលនោះពួកអ្នកបម្រើជាក់ថាសនោះលើគ្រែសម្រាប់ទ្រនោះហើយ ដួសភោជនដែលមានតម្លៃមួយសែន ជើម្បីសេដ្ឋីនោះ ។ សេដ្ឋីកាលអ្នករបាំចោមរោមហើយ បរិភោគភោជននោះដោយសម្បត្តិបែបនេះ ។

សម័យដទៃមក អ្នកស្រុកក្រៅម្នាក់ ជាក់ឧសជាដើមក្នុងយាន ជើម្បីដូរស្បៀងអាហារសម្រាប់ខ្លួន ទៅដល់ព្រះនគរហើយ ក៏ស្នាក់នៅក្នុងផ្ទះរបស់សម្ងាញ់ ។ កាលនោះជាថ្ងៃពេញបូណ៌មី ជនទាំងឡាយវាយស្គរប្រកាសក្នុងព្រះនគរថា ចូរមហាជនមើលការបរិភោគរបស់គន្ធសេដ្ឋី ។ កាលនោះទើបសម្ងាញ់ពោលនឹងសម្ងាញ់ស្រុកក្រៅនោះថា នែសម្ងាញ់ ការបរិភោគភត្តរបស់គន្ធសេដ្ឋី អ្នកធ្លាប់ឃើញឬ បុរសស្រុកក្រៅពោលថា ខ្ញុំមិនធ្លាប់ឃើញទ្បើយ សម្ងាញ់នោះពោលថា បើដូច្នោះ មកចុះសម្ងាញ់ យើងនឹងទៅជាមួយគ្នា អ្នកវាយស្គរនេះត្រាច់ទៅពេញនគរ យើងនឹងមើលមហាសម្បត្តិ ។

សម្ងាញ់ក្នុងក្រុង បាននាំសម្ងាញ់ស្រុកក្រៅចេញទៅហើយ ។ មហាជនក៏បាននាំគ្នាឡើងគ្រែដែលត្រួតលើគ្នានោះ ។ សម្ងាញ់ស្រុកក្រៅបានហិតក្លិន

ភត្ត ក៏ពោលនឹងសម្ងាញ់ក្នងក្រែងថា ខ្ញុំកើតការឃ្លានក្នងភត្តដែលនៅក្នងថាស នោះហើយ សម្ងាញ់ក្នងក្រែងពោលថា នែសម្ងាញ់ អ្នកកុំប្រារព្ធដុំភត្តនោះឡើយ ខ្ញុំមិនអាចយកឲ្យបានទេ សម្ងាញ់ស្រុកក្រៅពោលថា ឱសម្ងាញ់ បើមិនបាន ខ្ញុំក៏មិនអាចរស់ ។

សម្ងាញ់ក្នងក្រែងនោះ កាលមិនអាចឃាត់សម្ងាញ់ស្រុកក្រៅនោះបាន ឈរខាងចុងបរិស័ទ ស្រែកដោយសំឡេងខ្លាំង ៣ ដងថា បពិត្រលោកម្ងាស់ ខ្ញុំថ្វាយបង្គំលោក កាលគន្ធសេដ្ឋីសួរថា អ្នកជានរណា ទើបឆ្លើយថា គឺខ្ញុំ លោកម្ងាស់ សេដ្ឋីសួរថា តើមានរឿងអ្វី គាត់ក៏ឆ្លើយថា បុរសស្រុកក្រៅម្នាក់នេះ មានចំណង់ក្នងដុំភត្តដែលនៅក្នងថាសរបស់លោក សូមលោកមេត្តាឲ្យដុំភត្តមួយដុំចុះ សេដ្ឋីពោលថា មិនអាចទេ សម្ងាញ់នោះពោលថា នែសម្ងាញ់ ពាក្យរបស់សេដ្ឋី សម្ងាញ់បានឮឬទេ បុរសស្រុកក្រៅពោលថា អើ ខ្ញុំបានឮហើយសម្ងាញ់ តែបើមិនបាន ខ្ញុំនឹងមិនអាចរស់នៅបាន ការស្លាប់នឹងមានពិត ។ សម្ងាញ់នោះស្រែកទៀតថា បពិត្រលោកម្ងាស់ បានឮថា បុរសនេះបើមិនបាន នឹងស្លាប់ សូមលោកឲ្យជីវិតដល់គេផងចុះ គន្ធ-សេដ្ឋីពោលថា នែអ្នក ដុំភត្តនេះ រមែងដល់តម្លៃមួយរយក៏មាន ពីររយក៏មាន បុគ្គលណាម្នាក់សូម កាលឲ្យដល់បុគ្គលនោះ ខ្ញុំនឹងបរិភោគអ្វី សម្ងាញ់ក្នងក្រែងពោលថា បពិត្រលោកម្ងាស់ បុរសនេះ បើមិនបាននឹងស្លាប់ សូមលោកម្ងាស់ឲ្យជីវិតដល់គេផងចុះ គន្ធសេដ្ឋីពោលថា ខ្ញុំមិនអាចឲ្យទេៗ បានឡើយ បើបុរសនោះមិនអាចរស់នៅបានសោត បុរសនោះ ចូរធ្វើការស៊ីឈ្នួលក្នងផ្ទះ

របស់ខ្ញុំ ៣ ឆ្នាំចុះ ខ្ញុំនឹងឲ្យកត្តមួយថាសដល់គេ ។

បុរសស្រុកក្រៅស្តាប់ពាក្យនោះហើយ ក៏ពោលនឹងសម្ងាញ់នោះថា ណ្ហើយចុះ សម្ងាញ់ ខ្ញុំយល់ព្រម ដូច្នេះហើយ បានលាបុត្រ និងភរិយា ចូលទៅកាន់ផ្ទះរបស់សេដ្ឋី ដោយបំណងថា នឹងធ្វើការស៊ីឈ្នួលរយៈពេល ៣ ដើម្បីប្រយោជន៍ដល់កត្តមួយថាស ។ បុរសនោះធ្វើការស៊ីឈ្នួល ទទួលធ្វើកិច្ចគ្រប់យ៉ាងដោយល្អ ការងារដែលគួរធ្វើក្នុងស្រុក ក្នុងព្រៃ ពេលថ្ងៃ ពេលយប់ បានជ្រាបជាថា គាត់ធ្វើបានល្អ ។ មហាជនហៅគាត់ថា កត្តកតិកបុរស ពាក្យនោះ បានជ្រាបដទៅពេញព្រះនគរ ។

ក្នុងកាលតមក កាលថ្ងៃស៊ីឈ្នួលរបស់កត្តកតិកៈ គ្រប់បរិបូណ៌ហើយ អ្នករៀបចំកត្តជ្រាប់ថា បពិត្រលោកម្ចាស់ ថ្ងៃស៊ីឈ្នួលរបស់កត្តកតិកបុរស គ្រប់បរិបូណ៌ហើយ គាត់ធ្វើការស៊ីឈ្នួលគ្រប់ ៣ ឆ្នាំ ធ្វើកម្មកម្រដែលអ្នកដទៃធ្វើបាន ការងារណាមួយក៏មិនធ្លាប់ខូចខាត ។ គ្រានោះ លោកសេដ្ឋីបានជ្រាប់ឲ្យគេចំណាយទ្រព្យ ៣ ពាន់ ដល់អ្នករៀបចំកត្តនោះ គឺ ២ ពាន់ដើម្បីប្រយោជន៍អាហារល្ងាច និងអាហារព្រឹករបស់ខ្លួន មួយពាន់ដើម្បីប្រយោជន៍ដល់អាហារព្រឹករបស់កត្តកតិកបុរសនោះ ហើយជ្រាប់អ្នកបម្រើថា ថ្ងៃនេះចូរពួកអ្នកធ្វើការបរិហារ ដែលគប្បីធ្វើដល់ខ្ញុំ ដល់នាយកត្តកតិកៈនោះចុះ កាលជ្រាប់ហើយ ទើបជ្រាប់នឹងជនដ៏សេស រៀរភរិយាជាទីស្រឡាញ់ ឈ្មោះចិន្តាមណីម្នាក់ថា ថ្ងៃនេះ ចូរពួកអ្នកចោមរោមកត្តកតិកបុរសនោះចុះ ដូច្នេះហើយ ក៏ប្រគល់សម្បត្តិទាំងអស់ ឲ្យដល់កត្តកតិកបុរសនោះ ។

កត្តកតិកបុរសនោះ អង្គុយលើបន្ទះក្តារនោះ ក្នុងទីសម្រាប់ឆ្លូតនោះឯង ឆ្លូតទឹកសម្រាប់ឆ្លូតរបស់សេដ្ឋី ស្បៀកសំពត់សាជកសម្រាប់ស្បៀករបស់សេដ្ឋីនោះឯង ហើយអង្គុយលើបល្ល័ង្ករបស់សេដ្ឋីនោះដូចគ្នា ។ លោកសេដ្ឋីក៏ប្រើឲ្យមនុស្សយកស្គរវាយប្រកាសក្នុងព្រះនគរថា នាយកត្តកតិក: ធ្វើការងារស៊ីឈ្នួលអស់ ៣ ឆ្នាំក្នុងផ្ទះរបស់គន្ធសេដ្ឋីបានកត្តមួយថាស សូមជនទាំងឡាយមើលសម្បត្តិនៃការបរិភោគរបស់គាត់ មហាជនបានជាក់ព្រែត្រួតលើគ្នាដើម្បីមើល ។ ទីដែលបុរសស្រុកក្រៅសម្លឹងមើលហើយ ក៏ដល់នូវអាការញាប់ញ័រ ពួកអ្នករបាំបានឈរចោមរោមកត្តកតិកបុរសនោះ ពួកអ្នកបម្រើលើកថាសកត្តមួយជាក់ខាងមុខរបស់កត្តកតិកបុរសនោះហើយ ។

គ្រានោះ ក្នុងកាលដែលកត្តកតិក:នោះលាងដៃ ព្រះបច្ចេកពុទ្ធមួយអង្គនៅត្រង់ក្នុំគន្ធមាទន៍ ចេញអំពីសមាបត្តិក្នុងថ្ងៃទី ៧ ហើយពិចារណាថា ថ្ងៃនេះអាត្មាអញនឹងទៅដើម្បីប្រយោជន៍ដល់កិក្ខាចារក្នុងទីណាហ្ន៎ ក៏បានឃើញកត្ត-កតិកបុរសហើយ គ្រានោះ លោកពិចារណាតទៅទៀតថា កត្តកតិកបុរសនេះធ្វើការស៊ីឈ្នួលអស់ ៣ ឆ្នាំ ទើបបានថាសកត្ត ។ សទ្ធារបស់បុរសនេះមានឬមិនមានហ្ន៎ ពិចារណាទៅ ក៏ជ្រាបបានថា សទ្ធារបស់បុរសនេះមាន គិតទៀតថា ជនពួកខ្វះទោះមានសទ្ធា ក៏មិនអាចធ្វើការសង្គ្រោះបាន កត្តកតិកបុរសនេះតើអាច ឬមិនអាចហ្ន៎ ដើម្បីធ្វើការសង្គ្រោះដល់អាត្មាអញ ក៏ដឹងថា កត្តកតិក: នឹងអាចនោះឯង ព្រមទាំងបានមហាសម្បត្តិព្រោះអាស្រ័យហេតុ គឺការសង្គ្រោះដល់អាត្មាអញទៀតផង ដូច្នេះហើយ ទើបដណ្តប់ចីវរ កាន់បាត្រ ហោះទៅឆ

កាន់វេហាស៍ ទៅដោយរវាងបរិស័ទ បង្ហាញខ្លួនឈរខាងមុខកត្តកតិកបុរស នោះឯង កត្តកតិកបុរសនោះ ឃើញព្រះបច្ចេកពុទ្ធហើយ គិតថា អញបាន ស៊ីឈ្នួលក្នុងផ្ទះអ្នកជនៃអស់ ៣ ឆ្នាំ ដើម្បីប្រយោជន៍ដល់ថាសមួយ ព្រោះ តែអញមិនបានឲ្យទានក្នុងកាលមុន ឥឡូវនេះ កត្តនេះរបស់អញ គប្បីរក្សា អញត្រឹមតែមួយថ្ងៃមួយយប់ បើអញប្រគេនកត្តានោះដល់ព្រះបច្ចេកពុទ្ធ កត្ត នីឯងរក្សាអញ មិនមែនពាន់កោដិកប្ប អញនឹងប្រគេនកត្តានោះដល់លោកម្ចាស់ ចុះ ។ កត្តកតិកបុរសនោះ ធ្វើការស៊ីឈ្នួលអស់ ៣ ឆ្នាំ បានថាសកត្តហើយ មិនទាន់ដាក់កត្តមួយដុំក្នុងមាត់ បន្ទោបង់នូវចំណង់បាន លើកថាសកត្តឡើង ទៅកាន់សម្នាក់ព្រះបច្ចេកពុទ្ធ ឲ្យថាសក្នុងដៃរបស់អ្នកជនៃហើយ ថ្វាយបង្គំ ដោយបញ្ចង្គប្រតិស្ឋាន យកដៃឆ្វេងចាប់ថាសកត្ត យកដៃស្តាំជួសកត្តដាក់ ក្នុងបាត្ររបស់ព្រះបច្ចេកពុទ្ធអង្គនោះ ។ ព្រះបច្ចេកពុទ្ធ បានយកដៃចិទបាត្រ ក្នុងកាលដែលកត្តនៅសល់ពាក់កណ្តាល ។

គ្រានោះ កត្តកតិកៈនោះពិតលោកថា បពិត្រលោកម្ចាស់ កត្តចំណែក មួយប៉ុណ្ណោះ ខ្ញុំមិនអាចចែកជាពីរបាន សូមលោកម្ចាស់កុំសង្គ្រោះខ្ញុំក្នុងលោក នេះឡើយ សូមធ្វើការសង្គ្រោះក្នុងបរលោកចុះ ខ្ញុំនឹងប្រគេនទាំងអស់នោះឯង មិនឲ្យសេសសល់ឡើយ ។ ពិតហើយ ទានដែលបុគ្គលឲ្យមិនបន្សល់ទុក ដើម្បីខ្លួនសូម្បីតិចតួច ឈ្មោះថា ទានមិនមានចំណែកសេសសល់ ទាននោះ រមែងមានផលច្រើន ។ កត្តកតិកបុរសនោះ កាលធ្វើយ៉ាងនោះ ទើបបាន ប្រគេនទាំងអស់ ថ្វាយបង្គំម្តងទៀតហើយ ពោលថា បពិត្រលោកម្ចាស់ ខ្ញុំ

អាស្រ័យភត្តមួយថាស ត្រូវធ្វើការស៊ីឈ្នួលក្នុងផ្ទះអ្នកដទៃអស់ ៣ ឆ្នាំ បានសោយទុក្ខហើយ ។ ឥឡូវនេះ សូមសេចក្តីសុខមានដល់ខ្ញុំ ក្នុងទីដែលខ្ញុំកើតហើយចុះ ខ្ញុំសូមមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយចុះ ។ ព្រះបច្ចេកពុទ្ធពោលថា

សូមតម្រិះត្រូវទាំងពួង ចូរពេញដល់អ្នក ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ដូច្នោះ ។ កាលធ្វើអនុមោទនា ទើបពោលថា

សូមឥដ្ឋផល គឺផលជាទីគាប់ចិត្តដែលអ្នកប្រាថ្នាហើយ តាំងចិត្តហើយ ចូរមានដល់អ្នកឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សូមតម្រិះត្រូវទាំងពួង ចូរពេញដល់អ្នក ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត សូមឥដ្ឋផល គឺផលជាទីគាប់ចិត្តដែលអ្នកប្រាថ្នាហើយ តាំងចិត្តហើយ ចូរមានដល់អ្នកឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សូមតម្រិះត្រូវទាំងពួង ចូរពេញដល់អ្នក ដូចកែវមណីមានរស្មីដ៏រុងរឿងជាកែវវិសេស អាចញុំាងសេចក្តីប្រាថ្នាទាំងពួង ឲ្យសម្រេចបានដូច្នោះ ។

ពិតហើយ អធិដ្ឋានថា សូមមហាជនដែលឈរ ឃើញអាត្មាអញរហូតដល់ភ្នំគន្ធមាទន៍ចុះ ។ បានទៅកាន់ភ្នំគន្ធមាទន៍ដោយអាកាសហើយ សូម្បីមហាជន ក៏បានឃើញនោះឯង ព្រះបច្ចេកពុទ្ធទៅកាន់ភ្នំគន្ធមាទន៍ហើយ បានរំលែកបិណ្ឌបាតនោះប្រគេនដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ព្រះបច្ចេក-ពុទ្ធគ្រប់រូប បានទទួលយកភត្តល្មមសមគួរដល់ខ្លួនហើយ បុគ្គលមិនគួរគិត

ថា បិណ្ឌបាតបន្តិចបន្តួចនឹងគ្រប់គ្រាន់បានដូចម្តេច ព្រោះថា អចិន្តេយ្យ ៤ យ៉ាង ព្រះដ៏មានព្រះភាគត្រាស់ហើយ ក្នុងអចិន្តេយ្យ ៤ យ៉ាងនោះ នេះក៏ជាបច្ចេកពុទ្ធវិស័យ ។

មហាជនក៏ឃើញបិណ្ឌបាត ដែលព្រះបច្ចេកពុទ្ធចែករំលែកដល់ព្រះបច្ចេកពុទ្ធទាំងឡាយ បាននាំគ្នាញុាំងសាធុការរាប់ពាន់ ឲ្យប្រព្រឹត្តទៅហើយ ។ សំឡេងសាធុការ ហាក់បីដូចសំឡេងអសនីបាត ។ គន្ធសេដ្ឋីបានឮសំឡេងនោះហើយ ទើបគិតថា កត្តកតិកបុរស ប្រហែលជាមិនអាចទ្រទ្រង់សម្បត្តិដែលអញឲ្យហើយបាន ព្រោះហេតុនោះ មហាជននេះ កាលធ្វើការសើចចំអក ទើបស្រែកឡើង ។ លោកសេដ្ឋីនោះ បញ្ជូនមនុស្សទៅដើម្បីដឹងរឿងរ៉ាវដែលប្រព្រឹត្តទៅហើយ ។ មនុស្សទាំងនោះមកហើយ ជ្រាប់ថា បពិត្រលោកម្ចាស់ ធម្មតាអ្នកទ្រទ្រង់សម្បត្តិរមែងបែបនេះ ដូច្នេះហើយ ទើបជ្រាប់រឿងរ៉ាវដែលប្រព្រឹត្តទៅហើយនោះ ។

សេដ្ឋីស្តាប់រឿងនោះហើយ ជាអ្នកមានសរីរៈដែលបីតិទាំង ៥ ពាល់ត្រូវហើយទើបពោលថា គួរអស្ចារ្យហ្ន៎ កត្តកតិកបុរសនេះ ធ្វើវត្ថុដែលគេធ្វើបានដោយលំបាក អញតាំងនៅក្នុងសម្បត្តិបែបនេះ អស់កាលមានប្រមាណប៉ុណ្ណេះ គង់មិនអាចឲ្យវត្ថុណាមួយបាន ដូច្នេះហើយ ទើបហៅកត្តកតិកបុរសនោះមកហើយ សួរថា បានឮថា អ្នកធ្វើកម្មឈ្មោះនេះពិតឬ កាលបុរសនោះឆ្លើយថា ពិតហើយលោកម្ចាស់ ទើបពោលថា ណ្លើយចុះ ចូរអ្នកកាន់យកទ្រព្យមួយពាន់ ហើយចែកចំណែកបុណ្យក្នុងទានរបស់អ្នកឲ្យខ្ញុំខ្លះ កត្តកតិកបុរសនោះ

បានធ្វើតាមនោះហើយ សេដ្ឋីក៏បានចែកនូវទ្រព្យពាក់កណ្តាលនៃសម្បត្តិរបស់ខ្លួន ឲ្យដល់កត្តកតិកបុរសនោះ ។

ពិតហើយ ឈ្មោះថា សម្បទា មាន ៤ យ៉ាង គឺវត្ថុសម្បទា ១ បច្ចយសម្បទា ១ ចេតនាសម្បទា ១ គុណាតិរេកសម្បទា ១ ក្នុងសម្បទា ៤ នោះ ព្រះអរហន្ត ឬព្រះអនាគាមី គួរដល់និរោធសមាបត្តិ ជាទក្ខិណេយ្យ-បុគ្គល ឈ្មោះថា វត្ថុសម្បទា កាលកើតឡើងនៃបច្ចយទាំងឡាយ ដោយធម៌ស្មើ ឈ្មោះថា បច្ចយសម្បទា ភាពដែលចេតនាក្នុងកាល ៣ គឺមុនឲ្យ ១ កំពុងឲ្យ ១ ក្រោយឲ្យ ១ សម្បយុត្តដោយញាណ ប្រកបព្រមដោយសោមនស្ស ឈ្មោះថា ចេតនាសម្បទា ចំណែកទក្ខិណេយ្យបុគ្គលចេញអំពីសមាបត្តិ ឈ្មោះថា គុណាតិរេកសម្បទា ។ សម្បទា ៤ យ៉ាង គឺព្រះបច្ចេក-ពុទ្ធ ព្រះខីណាស្រពជាទក្ខិណេយ្យបុគ្គល បច្ចយដែលកើតហើយដោយធម៌ ដោយការដែលធ្វើការស៊ីឈ្នួលបានហើយ ចេតនាបរិសុទ្ធក្នុងកាលទាំង ៣ ព្រះបច្ចេកពុទ្ធដែលចេញអំពីសមាបត្តិ ជាអ្នកក្រៃលែងដោយគុណ សម្រេចហើយដល់កត្តកតិកបុរសនេះ ដោយអានុភាពនៃសម្បទា ៤ នេះ ទើបកត្ត-កតិកៈសម្រេចមហាសម្បត្តិទាន់ភ្នែកនោះឯង ព្រោះដូច្នោះ កត្តកតិកបុរសនោះ ទើបបានសម្បត្តិក្នុងសម្នាក់របស់សេដ្ឋី ។

ក្នុងកាលតមក ព្រះរាជាទ្រង់ស្តាប់កម្មដែលកត្តកតិកបុរសនោះធ្វើហើយ ទើបត្រាស់ឲ្យហៅមកចូលគាល់ ហើយព្រះរាជទានទ្រព្យមួយពាន់ ទ្រង់ទទួលចំណែកបុណ្យ ទ្រង់ពេញព្រះហឫទ័យ ព្រះរាជទានភោគៈច្រើន ហើយបាន

ព្រះរាជទានតំណែងសេដ្ឋីឲ្យ ។ គាត់មានឈ្មោះថា កត្តកតិកសេដ្ឋី ។ កត្ត-កតិកសេដ្ឋីនោះ ជាសម្ងាញ់ទឹងគន្ធសេដ្ឋី បរិភោគផឹករួមគ្នា តាំងនៅជរាបអស់អាយុ ចុតិអំពីអត្តភាពនោះហើយ កើតក្នុងទេវលោកសោយសម្បត្តិជាទិព្វមួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ បានបដិសន្ធិក្នុងត្រកូលឧបដ្ឋាករបស់ព្រះសារីបុត្តត្ថេរ ក្នុងក្រុងសាវត្ថី ។

គ្រានោះ មាតារបស់ទារកនោះ បានទូវគព្ភបរិហារហើយ ដោយកន្លងទៅ ២-៣ ថ្ងៃ ក៏កើតចាញ់គភ៌ថា ឱហ្ន៎ អញប្រគេនភោជនមានរសមួយរយប្រភេទដល់ព្រះសារីបុត្តត្ថេរ មួយអន្ទើដោយភិក្ខុ ៥០០ រូប ស្បៀកសំពត់ជ្រលក់ដោយទឹកមូត់ហើយ កាន់នូវផ្តិលមាស អង្គុយខាងចុងអាសនៈ គប្បីបរិភោគភត្តដែលសល់របស់ភិក្ខុទាំងឡាយនោះ ដូច្នេះហើយ ធ្វើតាមការគិតនោះឯង បន្ទោបង់នូវការចាញ់គភ៌ហើយ ។ នាងនៅក្នុងកាលមង្គលជនៃៗថ្ងាយទានយ៉ាងនោះដូចគ្នា ប្រសូតបុត្រហើយ ក្នុងថ្ងៃដាក់ឈ្មោះ ទើបពិតព្រះថេរៈថា សូមលោកម្ចាស់ឲ្យនូវសិក្ខាបទដល់កូនប្រុសរបស់ខ្ញុំចុះ ព្រះថេរៈសួរថា កុមារនេះឈ្មោះអ្វី កាលមាតារបស់ទារកពិតថា បពិត្រលោកម្ចាស់តាំងអំពីកូនប្រុសរបស់ខ្ញុំបដិសន្ធិ ឈ្មោះថា ទុក្ខ មិនធ្លាប់មានដល់បុគ្គលណាក្នុងផ្ទះនេះឡើយ ព្រោះដូច្នោះ ពាក្យថា សុខកុមារនេះឯង ជាឈ្មោះរបស់កុមារនេះ ទើបកាន់យកពាក្យនោះឯង ជាឈ្មោះរបស់ទារកនោះ បានឲ្យសិក្ខាបទហើយ ក្នុងកាលនោះ ការគិតបានកើតដល់មាតារបស់ទារកនោះយ៉ាងនេះថា អញនឹងមិនទម្លាយអាធ្យាស្រ័យរបស់កូនប្រុសអញឡើយ សូម្បី

ក្នុងកាលមង្គលទាំងឡាយ មានពិធីចោះត្រចៀកជាដើម នាងក៏បានថ្វាយទាន យ៉ាងនោះដូចគ្នា ។

ចំណែកកុមារ ក្នុងកាលមានអាយុ ៧ ឆ្នាំ ក៏ពោលថា បពិត្រអ្នកម៉ែ ខ្ញុំចង់បួសក្នុងសម្នាក់ព្រះថេរៈ ។ នាងឆ្លើយថា សាធុ បា ម៉ែមិនទម្លាយអធ្យាស្រ័យរបស់បាទេ ដូច្នេះហើយ ទើបនិមន្តព្រះថេរៈឲ្យឆាន់ហើយ ពិតថា បពិត្រលោកម្ចាស់ កូនប្រុសរបស់ខ្ញុំចង់បួស ក្នុងពេលល្ងាច សូមនាំកុមារនេះទៅកាន់វិហារផងចុះ ហើយក៏បញ្ជូនព្រះថេរៈទៅ ឲ្យប្រជុំពួកញាតិពោលថា ក្នុងកាលដែលកូនប្រុសរបស់ខ្ញុំជាគ្រហស្ថ ពួកយើងនឹងធ្វើកិច្ចដែលគួរធ្វើក្នុងថ្ងៃនេះឯង ដូច្នេះហើយ ទើបតែងខ្លួនកូនប្រុស នាំទៅកាន់វិហារដោយសិរីដ៏ធំ ហើយប្រគល់ដល់ព្រះថេរៈ ចំណែកព្រះថេរៈពោលនឹងសុខកុមារនោះថា នែបា ធម្មតាបព្វជ្ជាធ្វើបានលំបាក អ្នកអាចអភិរម្យឬ កាលឆ្លើយថា ខ្ញុំអាចធ្វើតាមឱវាទរបស់លោកម្ចាស់ ទើបឲ្យកម្មដ្ឋានបំបួសហើយ ។ មាតាបិតារបស់សុខកុមារនោះ កាលធ្វើសក្ការៈក្នុងកិច្ចបំបួស ក៏ប្រគេនភោជន មានរសមួយរយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន នៅក្នុងវិហារនោះឯងអស់ ៧ ថ្ងៃ ក្នុងពេលល្ងាច ទើបបានទៅកាន់ផ្ទះរបស់ខ្លួន ។ ក្នុងថ្ងៃទី ៣ ព្រះសារីបុត្ត កាលភិក្ខុសង្ឃចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ធ្វើកិច្ចដែលគួរធ្វើក្នុងវិហារហើយ ទើបឲ្យសាមណេរកាន់បាត្រ និងចីវរ ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ។

សាមណេរឃើញប្រឡាយទឹកជាដើមក្នុងរវាងផ្លូវ ទើបសួរព្រះថេរៈដូច

បណ្ឌិតសាមណេរដែរ ។ ព្រះថេរៈក៏ព្យាករដល់សាមណេរនោះយ៉ាងនោះដូចគ្នា ។ សាមណេរស្តាប់ហេតុនោះហើយ ទើបសួរព្រះថេរៈថា បើលោកម្ចាស់អាចទទួលបាត្រ និងចីវរបស់លោកម្ចាស់សោត ខ្ញុំគប្បីត្រឡប់ ព្រះថេរៈមិនទម្លាយអាធ្យាស្រ័យរបស់សាមណេរនោះ ពោលថា ចូរយកបាត្រ និងចីវរបស់ខ្ញុំមកចុះ ទទួលបាត្រ និងចីវរទៅហើយ សាមណេរថ្វាយបង្គំព្រះថេរៈកាលនឹងត្រឡប់ ទើបប្រាប់ព្រះថេរៈថា បពិត្រលោកម្ចាស់ បើនាំអាហារមកដើម្បីខ្ញុំ គប្បីនាំយកកោជនមានរសមួយរយប្រភេទមក ព្រះថេរៈពោលថា តើបានកោជននោះមកអំពីណា សាមណេរពោលថា បើមិនបានដោយបុណ្យរបស់លោកម្ចាស់ គង់នឹងបានដោយបុណ្យរបស់ខ្ញុំ ។

គ្រានោះ ព្រះថេរៈឲ្យកូនសោជល់សាមណេរនោះហើយ ក៏ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត សាមណេរនោះទៅវិហារហើយ បើកបន្ទប់របស់ព្រះថេរៈចូលទៅហើយបិទទ្វារ អង្គុយញុាំងញាណឲ្យឈមចុះក្នុងកាយរបស់ខ្លួនហើយដោយតេជៈនៃគុណរបស់សាមណេរនោះ អាសនៈរបស់សក្កទេវរាជសម្តែងអាការក្តៅហើយ សក្កៈពិចារណាមើលថា នេះហេតុអ្វីហ្ន៎ ឃើញសាមណេរហើយ ទ្រង់ព្រះតម្រិះថា សុខសាមណេរឲ្យចីវរដល់ឧបជ្ឈាយ៍ហើយ ត្រឡប់មកវិហារ ដោយគិតថា នឹងធ្វើសមណធម៌ គួរអញទៅក្នុងទីនោះ ទើបហៅមហារាជទាំង ៤ ហើយបញ្ជូនទៅដោយពាក្យថា នែបាទាំងឡាយ ចូរពួកអ្នកទៅ ចូរដេញបក្សីដែលមានសំឡេងជាទោសកែ្សរព្រៃ នៃវិហារឲ្យគេចទៅមហារាជទាំងឡាយនោះ ធ្វើតាមនោះហើយ ក៏នាំគ្នារក្សាដោយជុំវិញ ។ សក្ក-

ទេវរាជទ្រង់ជ្រាប់ចន្ទទេវបុត្រ និងសុរិយទេវបុត្រថា ចូរពួកអ្នកបញ្ឈប់វិមានរបស់ខ្លួនសិន ចន្ទទេវបុត្រ និងសុរិយទេវបុត្រក៏ធ្វើតាមនោះហើយ សក្កៈខ្លួនឯងក៏ទ្រង់រក្សាត្រង់សន្ទះទ្វារ វិហារស្ងប់ស្ងាត់ជ្រាសចាកសំឡេង ។ សាមណេរចម្រើនវិបស្សនាដោយចិត្តមានអារម្មណ៍មួយ សម្រេចមគ្គ និងផល ៣ ។

ព្រះថេរៈ កាលសាមណេរពោលថា សូមលោកម្ចាស់នាំកោជនមានរសមួយរយមក ដូច្នេះហើយ ក៏គិតថា អាត្មាអញអាចបានក្នុងត្រកូលរបស់អ្នកណាហ្ន៎ ពិចារណាក៏ឃើញត្រកូលឧបដ្ឋាកសម្បូរដោយអាធ្យាស្រ័យមួយ ទើបទៅក្នុងត្រកូលនោះ កាលជនទាំងនោះមានចិត្តត្រេកអរថា បពិត្រលោកម្ចាស់ជាការល្អណាស់ដែលលោកម្ចាស់មកក្នុងទីនេះ ក្នុងថ្ងៃនេះ ទទួលបាត្រ និមន្តឲ្យគង់ប្រគេនយាគូ និងរបស់ទំពាហើយ គេអារាធនាឲ្យធ្វើភត្តាហារ ទើបពោលសារាណីយធម្មកថាដល់ជនទាំងនោះ កំណត់កាលញុំាងធម្មទេសនាឲ្យចប់ហើយ។ ពេលនោះ ទើបជនទាំងឡាយប្រគេនកោជន មានរសមួយរយដល់ព្រះថេរៈនោះ ឃើញព្រះថេរៈទទួលកោជននោះហើយ បំណងត្រឡប់ ទើបជ្រាប់ថា សូមនិមន្តឆាន់ចុះ ពួកខ្ញុំប្រគេនកោជនបែបនេះទៀត ឲ្យព្រះថេរៈឆាន់ហើយ ក៏ប្រគេនដរាបពេញបាត្រទៀត ។ ព្រះថេរៈទទួលកោជននោះហើយ ក៏ប្រញាប់ទៅវិហារដោយគិតថា សាមណេររបស់អញឃ្លានហើយ ។ ថ្ងៃនោះ ព្រះសាស្តា យាងចេញប្រថាប់គង់ក្នុងព្រះគន្ធកុដិអំពីព្រលឹម ទ្រង់អាវជ្ជនៈថា ថ្ងៃនេះ សុខសាមណេរ ឲ្យបាត្រ និងចីវរដល់ឧបជ្ឈាយ៍ហើយត្រឡប់មក ដោយតាំងចិត្តថា នឹងធ្វើសមណធម៌ កិច្ចរបស់សាមណេរសម្រេច

ហើយឬហ្ន៎ ទ្រង់ឃើញត្រឹមតែមគ្គ និងផលទាំង ៣ ដែលសាមណេរសម្រេច ហើយ ទើបទ្រង់ពិចារណាក្រៃលែងឡើងថា សុខសាមណេរនេះ អាច សម្រេចអរហត្តក្នុងថ្ងៃនេះដែរឬហ្ន៎ ចំណែកសារីបុត្តនាំកត្តហើយ ក៏រូតរះ ដោយគិតថា សាមណេររបស់អញឃ្លានហើយ បើសាមណេរនេះមិនទាន់ សម្រេចអរហត្ត សារីបុត្តនាំកត្តមកមុន អន្តរាយនឹងមានដល់សាមណេរនេះ តថាគតគួរទៅរក្សាត្រង់ខ្ញោងទ្វារ ។ កាលទ្រង់ព្រះតម្រិះហើយ ទើបយាង ចេញអំពីគន្ធកុដិ ប្រថាប់ឈរធ្វើការរក្សាត្រង់ខ្ញោងទ្វារ ។ ចំណែកព្រះថេរៈនាំ កត្តមក ។ គ្រានោះ ព្រះសាស្តាត្រាស់សួរប្រស្នា ៤ នឹងព្រះថេរៈនោះ ដោយនយដែលពោលហើយខាងដើមនោះឯង ។ ក្នុងទីបំផុតនៃការវិសជ្ជនា បញ្ហា សាមណេរក៏សម្រេចអរហត្តហើយ ។

ព្រះសាស្តាត្រាស់ហៅព្រះថេរៈមកហើយ ត្រាស់ថា សារីបុត្ត ចូរអ្នក ទៅចុះ ចូរឲ្យកត្តដល់សាមណេររបស់អ្នក ។ ព្រះថេរៈទៅដល់ហើយ គោះ ទ្វារ សាមណេរចេញមកធ្វើវត្តដល់ឧបជ្ឈាយ៍ហើយ កាលព្រះថេរៈជ្រាប់ថា ចូរធ្វើកត្តកិច្ចចុះ ក៏ដឹងថា ព្រះថេរៈមិនត្រូវការដោយកត្ត កុមារអាយុ ៧ ឆ្នាំ សម្រេចអរហត្តក្នុងខណៈនោះឯង ពិនិត្យមើលទីអង្គុយទាបជាង ធ្វើកត្តកិច្ច ហើយ ក៏លាងជាត្រ ។ ក្នុងកាលនោះ មហារាជទាំង ៤ នាំគ្នាលើកការរក្សា សូម្បីចន្ទទេវបុត្រ និងសុរិយទេវបុត្រ ក៏លែងនូវវិមានរបស់ខ្លួន សូម្បីសក្កៈ ក៏ទ្រង់លើកការរក្សាត្រង់សន្ទះទ្វារ ព្រះអាទិត្យជ្រាកដអណ្តែតលយលឿនជ្រៃ ទៅហើយ ។

ភិក្ខុទាំងឡាយនាំគ្នាពោលថា កាលល្ងាចប្រាកដ សាមណេរធ្វើភត្តកិច្ច អម្បាញ់មិញនេះឯង ហេតុអ្វីហ្ន៎ ទើបថ្ងៃនេះ ពេលព្រឹកមានច្រើន ពេលល្ងាចមានតិច ។ ព្រះសាស្តាយាងមក សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ ថ្ងៃនេះ ពេលព្រឹកមានច្រើន ពេលល្ងាចមានតិច សាមណេរទើបតែឆាន់អម្បាញ់មិញនេះឯង ហេតុអ្វី ទើបព្រះអាទិត្យអណ្តែតលយលឿនជ្រេទៅ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងពេលធ្វើសមណធម៌របស់អ្នកមានបុណ្យទាំងឡាយ រមែងដូច្នោះឯង ក្នុងថ្ងៃនេះ មហារាជទាំង ៤ រក្សាដោយជុំវិញ ចន្ទទេវបុត្រ និងសុរិយទេវបុត្រ បញ្ឈប់វិមានរបស់ខ្លួន សក្កទេវរាជរក្សាត្រង់សន្ទុះទ្វារ តថាគតរក្សាត្រង់ខ្ងោងទ្វារ ថ្ងៃនេះ សុខ-សាមណេរឃើញមនុស្សបង្ហូរទឹកចូលប្រឡាយ ជាងព្រួញពត់ព្រួញឲ្យត្រង់ ជាងឈើចាំងនូវទព្វសម្ភារៈទាំងឡាយ មានកង់រថជាដើមហើយ ក៏ទ្ងន់ខ្លួនសម្រេចអរហត្តហើយ ទើបត្រាស់ព្រះគាថានេះថា

ឧទកំ ហិ នយន្តិ នេត្តិកា ឧសុការា នមយន្តិ តេជនំ
ទារុំ នមយន្តិ តច្ឆកា អត្តានំ នមយន្តិ សុព្វតា ។

ធម្មតាអ្នកបង្ហូរ តែងបង្ហូរទឹក អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់) អ្នកចាំង តែងចាំងឈើ អ្នកមានវត្តល្អ តែងទ្ងន់ខ្លួន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សុព្ភតា** *សេចក្តីថា ប្រដៅងាយ គឺគប្បីទូន្មាន គប្បីអនុសាសន៍ដោយស្រួល ។ ពាក្យដ៏សេស មានន័យដូចពោលហើយខាងដើមនោះឯង ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងសុខសាមណេរ ចប់

ឧណ្ហវគ្គ ចប់

វគ្គទី ១០ ចប់

សុត្តន្តបិដក

ធម្មបទគាថា ជរាវគ្គទី ១១

[២១] *កាលបើលោកសន្និវាស ត្រូវភ្លើង មានរាគៈជាដើម ឆេះ ទ្រលោមជានិច្ច ម្តេចក៏សើច ម្តេចក៏ត្រេកត្រអាល អ្នកទាំងឡាយ ត្រូវងងឹត គឺអវិជ្ជារបរឹតហើយ (ម្តេចទៀបយ) ក៏មិនស្វែងរកប្រទីប គឺប្រាជ្ញា ។*

អត្តភាពណា មិនទៀងទាត់ ស្តិតស្ថេរ អ្នកចូរមើលអត្តភាព (នោះ) ដែលកុសលាកុសលកម្ម ធ្វើវិចិត្រហើយ ជាកាយពាសពេញ ដោយដំចៅ ដែលឆ្អឹង ៣០០ កំណាត់ ផ្គុំគ្នាហើយ ជាអត្តភាពក្តៅក្រហាយជានិច្ច ជាទីពឹងត្រិះរិះរបស់ជនច្រើនគ្នា ។

រូបនេះ គ្រាំគ្រាអស់ហើយ ជាទីសម្អាក់នៃរោគ ជារបស់ពុកផុយ រាងកាយជារបស់ស្អុយ (នេះ) តែងបែកធ្លាយទៅវិញ ព្រោះថា ជីវិតមាន សេចក្តីស្លាប់ជាទីបំផុត ។

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាប ដែលគេចោលហើយ ដូចផ្លែឃ្លោកក្នុងសរទកាល សេចក្តីត្រេកអរអ្វីហ្ន៎ (របស់អ្នកទាំងឡាយ) ព្រោះតែឃើញឆ្អឹងទាំងឡាយនោះ ។

សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីប្រកាន់ខ្លួន និងសេចក្តីលុបគុណ ប្រជុំចុះក្នុងសរីរៈណា (សរីរៈនោះ) ដែលកុសលាកុសលកម្ម ធ្វើហើយ ឲ្យជានគររបស់ឆ្អឹងទាំងឡាយ ជាគ្រឿងប្រឡាក់ដោយសាច់ និងឈាម ។ រាជរថទាំងឡាយ ដ៏វិចិត្រល្អ រមែងគ្រាំគ្រា សូម្បីសរីរៈ ក៏ដល់នូវសេចក្តី

គ្រាំគ្រាជូចគ្នា ទើបឯធម៌របស់សប្បុរសទាំងឡាយ មិនដល់នូវសេចក្តីគ្រាំគ្រា (ជូច្នោះ) ទេ សប្បុរសទាំងឡាយ តែងនិយាយឲ្យពួកសប្បុរសផងគ្នាជីងបាន ។ បុរសអ្នកមិនមានការចេះជីងនេះ តែងចាស់ (ឥតអំពើ) ដូចគោបម្រើ សាច់របស់វា តែងចម្រើនឡើង តែប្រាជ្ញារបស់វា មិនចម្រើនឡើយ ។ កាលតថាគតមិនទាន់ជួបប្រទះ (ពោធិញ្ញាណ រវល់តែ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្តមានជាតិដ៏ច្រើន សេចក្តីកើត ជាទុក្ខរឿយៗ ។

នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ (របស់តថាគត) ទៀត មិនបានឡើយ ឆ្អឹងជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ ជាគ្រឿងក្សយតណ្ហាទាំងឡាយហើយ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលខ្ជូននៅជាកំលោះក្រមុំ រមែងសញ្ជប់សញ្ជឹង ដូចសត្វក្រៀលចាស់សំកុកនៅក្នុងភក់ ដែលអស់ត្រីហើយ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យក្នុងកាលខ្ជូននៅកំលោះក្រមុំ រមែងដេកថ្ងូរ សោកស្តាយទ្រព្យចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែបន្ទោះ ជូច្នោះ ។

ជរាវគ្គទី ១១ ចប់

អដ្ឋកថា

ជរាវគ្គធី ១១

រឿង ស្រីសម្ងាញ់របស់នាងវិសាខា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកស្រីដែលជាសម្ងាញ់របស់នាងវិសាខា ត្រាស់ព្រះធម្មទេសនានេះថា **កោ នុ ហាសោ កិមានន្ទោ** ជាដើម ។

បានញ្ចថា កុលបុត្រ ៥០០ នាក់ ក្នុងនគរសាវត្ថី បានប្រគល់ភរិយារបស់ខ្លួននឹងនាងវិសាខាឧបាសិកា ដោយបំណងថា ដោយឧបាយយ៉ាងនេះ ភរិយាទាំងនេះ នឹងជាបុគ្គលនៅដោយសេចក្តីមិនប្រមាទ ។ ស្រីទាំងនោះ កាលទៅឧទ្យានក្តី ទៅវិហារក្តី រមែងទៅជាមួយនាងវិសាខានោះឯង ។

សម័យមួយ កាលគេយោសនាមហោស្រពថា នឹងមានការលេងមហោស្រព ទាក់ទងដោយសុរា ៧ ថ្ងៃ ស្រីទាំងនោះក៏ត្រៀមសុរាដើម្បីប្តីរៀងៗ ខ្លួន ប្តីទាំងនោះលេងមហោស្រព ដែលទាក់ទងនឹងស្រាអស់ ៧ ថ្ងៃ ហើយ ក្នុងថ្ងៃទី ៨ បានចេញទៅដើម្បីធ្វើការងារ ។

ស្រីទាំងនោះបបួលគ្នាថា ពួកយើងមិនបានផឹកស្រាចំពោះមុខប្តី ឯស្រាដែលសល់នៅមាន យើងទាំងឡាយនឹងផឹកស្រានេះដោយវិធីដែលប្តីទាំងនោះ

មិនជីង ដូច្នេះហើយ ទើបទៅក្នុងសម្នាក់របស់នាងវិសាខាពោលថា បពិត្រ អ្នកនាង យើងទាំងឡាយចង់លេងក្នុងឧទ្យាន កាលនាងវិសាខាឆ្លើយថា ប្រពៃ ណាស់អ្នកទាំងឡាយ បើដូច្នោះ ចូរធ្វើកិច្ចដែលគួរធ្វើស្រេចហើយសឹមទៅ ។ បានទៅជាមួយនាងវិសាខានោះ លាក់ស្រោដោយអាការមិនឲ្យអ្នកដទៃឃើញ ផឹករហូតស្រវឹងហើយ ដើរទៅក្នុងឧទ្យាន ។ នាងវិសាខាគិតថា ស្រីទាំងនេះ ធ្វើកម្មមិនសមគួរ ពេលនេះ សូម្បីពួកតិរ្ថិយក៏នឹងតិះដៀលបានថា សាវិកា ទាំងឡាយរបស់ព្រះគោតមផឹកស្រោដើរទៅ ទើបពោលនឹងស្រីទាំងនោះថា នែនាង នាងទាំងឡាយធ្វើកម្មមិនសមគួរ នាំឲ្យកើតអាប់យសដល់ខ្ញុំផង សូម្បីប្តីរបស់នាងក៏ខឹងនឹងពួកនាង ឥឡូវនេះ ពួកនាងនឹងធ្វើដូចម្តេច ស្រី ទាំងនោះឆ្លើយថា បពិត្រអ្នកនាង ខ្ញុំនឹងពុតធ្វើជាឈឺ ទើបនាងវិសាខាពោល ថា បើដូច្នោះ ពួកនាងក៏នឹងប្រាកដដោយកម្មរបស់ខ្លួន ។ ស្រីទាំងនោះ ទៅ ដល់ផ្ទះហើយ ពុតជាឈឺ ពេលនោះ ប្តីរបស់ស្រីទាំងនោះសួរថា ស្រីឈ្មោះ នេះៗ ទៅណា បានឮថា ឈឺ ក៏កំណត់សេចក្តីបានថា ស្រីទាំងនេះ ផឹកស្រា ដែលសល់ពិត ទើបវាយស្រីទាំងនោះឲ្យដល់នូវការវិនាស ។ ក្នុងកាល មហោស្រពក្រោយមកទៀត ស្រីទាំងនោះចង់ផឹកស្រាយ៉ាងនោះទៀត ទើប ចូលទៅរកនាងវិសាខា ពោលថា បពិត្រអ្នកនាង សូមនាំខ្ញុំទៅលេងឧទ្យាន ចុះ ត្រូវនាងវិសាខាឃាត់ថា ក្នុងកាលមុន នាងទាំងឡាយ ធ្វើឲ្យអាប់មុខ មាត់ដល់ខ្ញុំ ចូរនាងទៅឯងចុះ ខ្ញុំមិននាំទៅឡើយ បាននិយាយយកចិត្តថា ពេល នេះ ពួកខ្ញុំមិនធ្វើយ៉ាងនោះឡើយ ហើយចូលទៅរកនាងវិសាខា ពោលជាថ្មីថា

យើងទាំងឡាយបំណងនឹងធ្វើពុទ្ធបូជា សូមនាំយើងទាំងឡាយ ទៅវិហារចុះ ទើបនាងពោលថា នែនាង ឥឡូវនេះ សមគួរពិត នាងទាំងឡាយ ចូរទៅរៀបចំត្រៀមខ្លួនចុះ ។ ស្រីទាំងនោះ ឲ្យមនុស្សកាន់គ្រឿងក្រអូប និងកម្រងផ្កាជាដើម ដោយប្រអប់ដាក់ដបមានសណ្ឋានដូចដៃដែលក្តាប់ ពេញដោយសុរាដោយដៃទាំងពីរ ជណ្តប់សំពត់ផ្ទាំងធំ ចូលទៅរកនាងវិសាខា ហើយចូលទៅកាន់វិហារ មួយអន្ទើដោយនាងវិសាខានោះ អង្គុយក្នុងចំណែកម្ខាង ផឹកស្រោដោយដប ដែលមានសណ្ឋានដូចដៃដែលក្តាប់នោះឯង ហើយគ្រែវែងដបចោល អង្គុយឆ្ពោះព្រះភក្ត្រព្រះសាស្តា ក្នុងរោងធម្មសភា ។ នាងវិសាខាក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់សម្តែងធម៌ដល់ស្រីទាំងនេះ ។ ឯស្រីទាំងនោះ មានខ្លួនញ៉ែរដោយអំណាចស្រវឹង កើតគំនិតឡើងថា យើងទាំង-ឡាយ នឹងរាំ នឹងច្រៀង ។

លំដាប់នោះ ទេវតាមួយអង្គដែលទាក់ទងក្នុងពួកមារ គិតថា ឥឡូវនេះ អញនឹងសណ្ឋិតក្នុងសរីរៈរបស់ស្រីទាំងនេះហើយ នឹងសម្តែងប្រការដែលប្លែកចំពោះព្រះភក្ត្រព្រះសមណគោតម ហើយចូលសណ្ឋិតក្នុងសរីរៈរបស់ស្រីទាំងនោះ បណ្តាស្រីទាំងនោះ ពួកខ្លះផ្តើមទះដៃសើច ពួកខ្លះដើររាំចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ។ ព្រះសាស្តាទ្រង់អាវជ្ជនៈថា តើមានរឿងអ្វីហ្ន៎ ទ្រង់ជ្រាបហេតុនោះហើយ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ តថាគតនឹងមិនឲ្យទេវតាដែលទាក់ទងក្នុងពួកមារបានឱកាស ព្រោះតថាគត កាលបំពេញបារមីអស់កាលប៉ុណ្ណេះ មិនមែនដើម្បីឲ្យពួកទេវតា ដែលជាបក្ខពួករបស់មារបាន

ឱកាសឡើយ ដើម្បីឲ្យស្រីទាំងនោះសង្វេគ ទើបទ្រង់បញ្ចេញព្រះរស្មីអំពីព្រះលោមា ក្នុងរវាងចន្លោះចិញ្ចើម រំពេចនោះឯង ងងឹតអន្ធការមានហើយ ។ ស្រីទាំងនោះភ័យខ្លាច កាលមរណភ័យគំរាមហើយ ដោយហេតុនោះ ទើបស្រាក្នុងពោះរបស់ស្រីទាំងនោះស្វាងទៅ ។ ព្រះសាស្តាទ្រង់ចាត់ទៅ ត្រង់បល្ល័ង្កដែលប្រថាប់គង់ ទ្រង់ប្រថាប់ឈរលើកំពូលភ្នំសិនេរុ ទ្រង់បញ្ចេញព្រះរស្មីអំពីព្រះឧណ្ណាលោម ។ ខណៈនោះ ពន្លឺ មានដូចព្រះចន្ទមួយពាន់ដួង ។ ព្រះសាស្តាត្រាស់ហៅស្រីទាំងនោះមកហើយ ត្រាស់ថា ពួកនាងកាលមកកាន់សម្នាក់របស់តថាគត ប្រមាទហើយ មក មិនគួរ ព្រោះការប្រមាទរបស់ពួកនាងនោះឯង ទើបទេវតាដែលជាបក្ខពួកនៃមារបានឱកាសឲ្យពួកនាងធ្វើកាយវិការ មានសើចជាដើមក្នុងទីដែលមិនគួរធ្វើកាយវិការ មានសើចជាដើម ឥឡូវនេះ ពួកនាងធ្វើសេចក្តីឧស្សាហ៍ ដើម្បីប្រាថ្នាឲ្យភ្លើងរាគៈជាដើមរលត់ទៅ ទើបគួរ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

កោ នុ ហាសោ កិមានន្ទោ និច្চំ បជ្ជលិតេ សតិ
អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ ។

កាលបើលោកសន្និវាស ត្រូវភ្លើង មានរាគៈជាដើមឆេះទ្រលោមជានិច្ច ម្តេចក៏សើច ម្តេចក៏ត្រេកត្រអាល អ្នកទាំងឡាយត្រូវងងឹត គឺអវិជ្ជារួបរឹតហើយ (ម្តេចឡើយ) ក៏មិនស្វែងរកប្រទីប គឺប្រាជ្ញា ។

សេចក្តីអធិប្បាយ

ការត្រេកអរ ឈ្មោះថា **អានន្ទោ** ក្នុងព្រះគាថានោះ ។ ព្រះដ៏មានព្រះភាគ ត្រាស់អធិប្បាយដូច្នេះថា កាលលោកសន្និវាសនេះ ដែលភ្លើង ១១ យ៉ាង មានរាគៈជាដើមឆេះសន្ធោសន្ធៅហើយជានិច្ច អ្នកទាំងឡាយ រវល់តែត្រេកអរ ឬរីករាយអ្វីហ្ន៎ ន៎ុះមិនសមគួរធ្វើឡើយ មិនមែនឬ អ្នកទាំងឡាយដែលងងឹត គឺអវិជ្ជាដែលមានវត្ថុ ៨ គ្របជណ្តប់ ហេតុអ្វី ទើបមិនស្វែងរកគឺមិនធ្វើប្រទីប គឺញាណ ដើម្បីប្រយោជន៍ដល់ការកម្ចាត់ងងឹតនោះ ។

ក្នុងកាលចប់ទេសនា ស្រី ៥០០ តាំងនៅក្នុងសោតាបត្តិផលហើយ ព្រះសាស្តា ទ្រង់ជ្រាបសេចក្តីដែលស្រីទាំងនោះជាអ្នកតាំងមាំនៅក្នុងអចល-សទ្ធាហើយ ទ្រង់ចុះអំពីកំពូលភ្នំសិនេរុ ប្រថាប់គង់លើពុទ្ធាសន: ។

លំដាប់នោះ នាងវិសាខាបានក្រាបទូលព្រះពុទ្ធអង្គថា បពិត្រព្រះអង្គ ឈ្មោះថា សុវានេះ អាក្រក់ថោកទាប ព្រោះថា ស្រីទាំងនេះ មានសភាពបែបនេះ អង្គុយត្រង់ព្រះភក្ត្រព្រះសម្ពុទ្ធដូចទ្រង់ គង់មិនអាចញ៉ាំងត្រឹមតែឥរិយាបថឲ្យរៀបរយបាន ក្រោកឡើងទៀត ធ្វើការសើច ច្រៀង និងរាំជាដើម ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងវិសាខា យ៉ាងនោះឯង ឈ្មោះថា សុវានេះ អាក្រក់ពិត ព្រោះមហាជនអាស្រ័យសុវានេះ ដល់នូវសេចក្តីវិនាសច្រើនរយ កាលនាងវិសាខាក្រាបទូលថា បពិត្រព្រះអង្គ សុវានេះ កើតឡើងក្នុងកាលណា ដើម្បីនឹងត្រាស់ឧប្បត្តិហេតុនៃសុវានោះដល់នាងវិសាខាដោយពិស្តារ ទើបទ្រង់នាំអតីតនិទានមក ហើយត្រាស់កុម្ភជាតកដូច្នេះឯង ។

រឿង នាងសិរិមា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនាងសិរិមា ត្រាស់ព្រះធម្មទេសនានេះថា **បស្ស ចិត្តកតំ ពិម្ពំ** ជាដើម ។

បានឮថា នាងសិរិមានោះ មានរូបស្អាត ជាស្រីនគរសោកិនីក្នុងក្រុងរាជគ្រឹះ ខាងក្នុងវស្សាមួយ បានប្រទូស្តចំពោះឧបាសិកាឈ្មោះខុត្តរា ដែលជាធីតារបស់បុណ្ណកសេដ្ឋី ដែលជាភរិយារបស់សុមនសេដ្ឋីបុត្រ បំណងនឹងឲ្យនាងខុត្តរានោះជ្រះថ្លា ទើបទូលសូមខមាទោសជាមួយព្រះសាស្តា ទ្រង់ធ្វើកត្តកិច្ច ជាមួយភិក្ខុសង្ឃស្រេចហើយ ក្នុងផ្ទះរបស់នាងខុត្តរានោះ ក្នុងថ្ងៃនោះ បានស្តាប់ភត្តានុមោទនារបស់ព្រះទសពល សម្រេចសោតាបត្តិផល ហើយក្នុងកាលចប់ព្រះគាថា ដែលទ្រង់សម្តែងថា

> បុគ្គលគប្បីផ្ចាញ់ មនុស្សក្រោធ ដោយសេចក្តីមិនក្រោធ គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្ចាញ់មនុស្សកំណាញ់ ដោយការឲ្យ គប្បីផ្ចាញ់មនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ។

នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ចំណែកសេចក្តីពិស្តារមានច្បាស់ក្នុងគាថាអនុមោទនានៃកោធវគ្គនោះឯង ។ នាងសិរិមានោះ កាលសម្រេចសោតាបត្តិផលយ៉ាងនោះហើយ និមន្តព្រះទសពល ស្អែកឡើង ថ្វាយទានជាច្រើន ហើយបានតាំងអជ្ជកភត្ត គឺសលាកភត្តសម្រាប់ភិក្ខុ ៨ អង្គជាប្រចាំ ។ តាំង

អំពីថ្ងៃដំបូងមក ភិក្ខុ ៨ រូប ទៅកាន់ផ្ទះនាងជានិច្ច ។ នាងពោលថា និមន្ត លោកម្ចាស់ទាំងឆ្អាយទទួលសប្បិ សូមលោកម្ចាស់ទទួលខីរៈ ដូច្នេះជាដើម ហើយ ជាក់កត្តពេញបាត្រៃរបស់ភិក្ខុទាំងនោះ ។ អាហារបិណ្ឌបាត ដែលភិក្ខុ មួយរូបបានហើយ រមែងគ្រប់គ្រាន់ដល់ភិក្ខុ ៣ រូបខ្លះ ៤ រូបខ្លះ ។ នាង ថ្វាយបិណ្ឌបាតដោយការចំណាយទ្រព្យ ១៦ កហាបណៈរាល់ថ្ងៃ ។ ថ្ងៃមួយ ភិក្ខុមួយរូបធាន់អដ្ឋកកត្តក្នុងផ្ទះរបស់នាងហើយ បានទៅវិហារមួយកន្លែង ក្នុង ទីចម្ងាយ ៣ យោជន៍ ។ គ្រានោះ ពួកភិក្ខុសួរលោក ដែលអង្គុយក្នុងទី បម្រើព្រះថេរៈក្នុងពេលល្ងាចថា អាវុសោ ទៅទទួលភិក្ខាក្នុងទីណា លោក ឆ្លើយថា ខ្ញុំទៅធាន់អដ្ឋកកត្តរបស់នាងសិរិមា ។ ពួកភិក្ខុសួរទៀតថា នាងធ្វើ របស់គួរពេញចិត្តប្រគេនដែរឬ ។

ទើបភិក្ខុនោះពោលគុណរបស់នាងថា ខ្ញុំមិនអាចពណ៌នាកត្តរបស់នាង បានទេ នាងធ្វើប្រគេនដ៏ប្រណីត កត្តដែលភិក្ខុមួយរូបបានទទួល រមែងគ្រប់ គ្រាន់ដល់ភិក្ខុ ៣ រូបខ្លះ ៤ រូបខ្លះ តែការបានឃើញនាងនោះឯងល្អក្រៃលែង ជាងទេយ្យធម៌របស់នាងទៅទៀត ព្រោះនាងស្អាតបែបនេះៗ គ្រានោះ ភិក្ខុមួយ រូប បានស្តាប់ពាក្យដែលពណ៌នាគុណរបស់នាង កើតសេចក្តីស្រឡាញ់ឡើង ហើយ ដោយមិនទាន់បានឃើញផង គិតថា គួរតែអញទៅមើលនាង ហើយ ប្រាប់ចំនួនវស្សារបស់ខ្លួនហើយ សួរសុំជាប់ជាមួយភិក្ខុនោះហើយ បានឮថា អាវុសោ ស្អែកនេះ លោកជាព្រះសង្ឃត្តេរ នឹងបានអដ្ឋកកត្តក្នុងផ្ទះនោះ ទើបទាញបាត្រ និងចីវរ ចៀសចេញទៅក្នុងខណៈនោះឯង ។ កាលអរុណរះ

ឡើងអំពីព្រលឹម ចូលទៅកាន់រោងភត្តរង់ចាំហើយ ជាព្រះសង្ឃត្តេរ បាន អង្គុកកត្តក្នុងផ្ទះរបស់នាង ។

ក្នុងកាលដែលភិក្ខុនោះធាន់ហើយ ចៀសចេញទៅកាលពីមុរិលមិញ នោះឯង រោគបានកើតឡើងក្នុងសរីរៈរបស់នាង ដូច្នោះ ទើបនាងដោះគ្រឿង អាភរណៈចេញហើយដេក ។ ពួកទាសីរបស់នាង ឃើញភិក្ខុទាំងឡាយបាន អង្គុកកត្តមកហើយ ទើបប្រាប់ដល់នាង នាងមិនអាចទទួលបាត្រ ហើយនិមន្ត ឲ្យគង់ ឬអង្គាសដោយដៃរបស់ខ្លួនបាន ទើបប្រាប់ពួកទាសីថា នែនាងទាំង-ឡាយ ពួកនាងទទួលបាត្រហើយ និមន្តលោកម្ចាស់ឲ្យគង់ ឲ្យធាន់បបរ ប្រគេនរបស់ទំពាក្នុងកាលធាន់ភត្ត ចូរដាក់ភត្តឲ្យពេញបាត្រ ហើយប្រគេន ចុះ ទាសីទាំងនោះទទួលថា សាធុ អ្នកនាង ហើយនិមន្តភិក្ខុទាំងឡាយឲ្យ ចូលមក ឲ្យធាន់បបរ ប្រគេនខាទនីយៈ ក្នុងពេលធាន់ភត្ត ដាក់ភត្តពេញបាត្រ ហើយ ប្រាប់ដល់នាង នាងពោលថា ចូរជួយគ្រាហ៍ខ្ញុំទៅកាន់ទីនោះ ខ្ញុំនឹង ថ្វាយបង្គំលោកម្ចាស់ទាំងឡាយ ។ ទាសីទាំងនោះ គ្រាហ៍ទៅកាន់ទីជិតភិក្ខុ ទាំងឡាយហើយ បានថ្វាយបង្គំភិក្ខុទាំងឡាយ ទាំងមានខ្លួនញ័រ ភិក្ខុនោះ សម្លឹងមើលនាងហើយ គិតថា ការស្អាតនៃរូបរបស់ស្រីដែលមានជំងឺនេះ គង់ ស្អាតជល់ម្ល៉ះ ក្នុងកាលមិនទាន់ឈឺ រូបសម្បត្តិរបស់នាងដែលតាក់តែង ហើយ ដោយអាភរណៈគ្រប់យ៉ាង នឹងស្អាតប៉ុនណាហ្ន៎ ។ កាលនោះ កិលេសដែលលោកសន្សំច្រើនកោដិឆ្នាំកម្រើកហើយ ។ ភិក្ខុនោះ មិនមាន ចិត្តទៅកាន់ទីដទៃ គឺមានចិត្តជាប់ឆ្ពោះនាងប៉ុណ្ណោះ មិនអាចធាន់អាហារបាន

ទើបកាន់បាត្រត្រឡប់ទៅវិហារ បិទបាត្រទុកក្នុងចំណែកម្ខាង ក្រាលចីវរសិង ហើយ ។ លំដាប់នោះ ភិក្ខុជាសម្ងាញ់របស់លោកមួយរូប សូម្បីអង្ឃរ ក៏មិន អាចឲ្យលោកឆាន់បាន ភិក្ខុនោះបានអត់អាហារហើយ ។

ក្នុងពេលល្ងាចនោះឯង នាងសិរិមាបានធ្វើកាលកិរិយាហើយ ។ ព្រះរាជា ទ្រង់បញ្ជូនព្រះរាជសាសន៍ទៅថ្វាយព្រះសាស្តាថា បពិត្រព្រះអង្គ នាងសិរិមា ប្អូនស្រីរបស់ពេទ្យជីវក បានធ្វើកាលកិរិយាហើយ ។ ព្រះសាស្តាទ្រង់ស្តាប់ រឿងនោះ ទើបបញ្ជូនដំណឹងទៅកាន់ព្រះរាជាថា កិច្ច គឺការបូជាសពនាង សិរិមា កុំទាន់មានឡើយ ព្រះសាស្តាទ្រង់ត្រាស់ឲ្យយកសពនាងសិរិមានោះ ដាក់ក្នុងព្រៃខ្មោចស្រស់ហើយ ឲ្យរក្សា ដោយក្អែក និងឆ្កែជាដើមស៊ីមិន បាន ។ ព្រះរាជាទ្រង់បានធ្វើតាមព្រះតម្រាស់ហើយ ។ ៣ ថ្ងៃកន្លងទៅហើយ ដោយលំដាប់ ក្នុងថ្ងៃទី ៤ សរីរៈហើមប៉ោងហើយ ។ ពួកដង្កូវហូរចេញអំពី ទ្វារទាំង ៩ ។ សរីរៈទាំងមូល បានបែកធ្លាយដូចជាសស្រៃវាលី ដូច្នោះ ព្រះរាជាឲ្យពួករាជបុរស វាយស្គរឃោសនាក្នុងព្រះនគរថា វៀរកុមារតូចៗ និងអ្នកចាំផ្ទះ អ្នកណាមិនមកមើលនាងសិរិមា ត្រូវពិន័យ ៨ កហាបណៈ ។ ហើយបានបញ្ជូនព្រះរាជសាសន៍ទៅកាន់សម្ងាក់ព្រះសាស្តាថា សូមភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន និមន្តមកមើលនាងសិរិមា ព្រះសាស្តាត្រាស់ឲ្យផ្តៀង ដល់ភិក្ខុទាំងឡាយថា យើងទាំងឡាយនឹងទៅមើលនាងសិរិមា ។ ភិក្ខុកំលោះ រូបនោះ មិនស្តាប់ពាក្យរបស់បុគ្គលណាឡើយអស់ ៤ ថ្ងៃ អត់អាហារ សិង ទទួរហើយ ជាយក្នុងបាត្រអួម ប្រែកក៏តាំងឡើងក្នុងបាត្រ ។ លំដាប់នោះ

ភិក្ខុសម្លាញ់នោះ ទើបចូលទៅរកលោកហើយ ប្រាប់ថា អាវុសោ ព្រះសាស្តាយាងទៅទតនាងសិរិមា ។ ភិក្ខុនោះ សូម្បីត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់យ៉ាងនោះ ក៏ក្រោកឡើងដោយប្រញាប់ ព្រោះបានឮពាក្យថា សិរិមានោះឯង សួរថា លោកពោលដូចម្តេច កាលភិក្ខុសម្លាញ់ឆ្លើយថា ព្រះសាស្តាយាងទៅទតនាងសិរិមា លោកទៅដែរឬទេ ទើបទទួលយ៉ាងប្រញាប់ថា ខ្ញុំទៅហើយចាក់បាយលាងបាត្រដាក់ក្នុងស្មោក បានទៅជាមួយពួកភិក្ខុ ។ ព្រះសាស្តា មានភិក្ខុចោមរោមហើយ បានប្រថាប់នាចំណែកម្ខាង ។ ភិក្ខុនីសង្ឃ ក្តី រាជបរិស័ទក្តី ឧបាសកបរិស័ទក្តី ឧបាសិកាបរិស័ទក្តី បានឈរម្ខាងមួយពួក ។

ព្រះសាស្តាត្រាស់សួរព្រះរាជាថា មហាបពិត្រ នេះជាអ្នកណា ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ នេះជាបួនស្រីរបស់ពេទ្យជីវកឈ្មោះសិរិមា ព្រះដ៏មានព្រះភាគត្រាស់ថា នេះនាងសិរិមាឬ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ គឺនាងសិរិមា ព្រះសាស្តាត្រាស់ថា បើដូច្នោះ សូមមហាបពិត្រឲ្យរាជបុរសវាយស្គរឃោសនាក្នុងព្រះនគរថា អ្នកណាឲ្យទ្រព្យមួយពាន់ ចូរយកនាងសិរិមាទៅចុះ ។ ព្រះរាជាបានធ្វើយ៉ាងនោះហើយ បុគ្គលដែលហាមាត់ថា ខ្ញុំឬថា យើង សូម្បីតែម្នាក់ក៏មិនមាន ។ ព្រះរាជាទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ជនទាំងឡាយមិនទទួល ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ បើដូច្នោះ សូមទ្រង់បន្ថយតម្លៃចុះទៀត ។ ព្រះរាជាត្រាស់ឲ្យវាយស្គរឃោសនាថា អ្នកណាឲ្យទ្រព្យ ៥០០ ចូរយកទៅ មិនឃើញមានបុគ្គលណាម្នាក់ទទួលយក ទើបត្រាស់ឲ្យវាយស្គរឃោសនាថា អ្នកណាឲ្យទ្រព្យ ២៥០-២០០-

១០០-៥០-២៥ កហាបណៈ ១០ កហាបណៈ ៥ កហាបណៈ ១ កហាបណៈ កន្ទះកហាបណៈ ១ ជាទ ១ មាសក ១ កាកណិក ហើយយកនាងសិរិមាទៅចុះ ក៏មិនឃើញអ្នកណាទទួលយកទៅ ទើបឲ្យវាយស្គរឃោសនាថា ចូរយកទទេចុះ បុគ្គលដែលហាមាត់ថា ខ្ញុំ ឬថាយើង សូម្បីតែម្នាក់ក៏មិនមាន ។ ព្រះរាជាទូលថា បពិត្រព្រះអង្គ ឈ្មោះថា បុគ្គលដែលទទួលយកទៅ សូម្បីទទេក៏មិនមាន ។ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយមើល មាតុគ្រាមដែលជាទីស្រឡាញ់ របស់មហាជនក្នុងកាលមុន ជនទាំងឡាយក្នុងនគរនេះ ឲ្យទ្រព្យមួយពាន់ ហើយបានអភិរម្យមួយថ្ងៃឥឡូវនេះ សូម្បីបុគ្គលដែលទទួលយកទទេៗ ក៏មិនមាន រូបបែបនេះ ដល់នូវការអស់ទៅ និងការសូន្យទៅហើយ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ មើលអត្តភាពដែលគួរខ្ពើមរអើម ដូច្នេះហើយ ត្រាស់គាថានេះថា

បស្ស ចិត្តកតំ ពិម្ពំ អរុកាយំ សមុស្សិតំ
អាតុរំ ពហុសង្កប្បំ យស្ស ឧត្តិ ធុវំ ឋិតិ ។

អត្តភាពណា មិនទៀងទាត់ ស្ថិតស្ថេរ ចូរអ្នកមើលអត្តភាព (នោះ) ដែលកុសលាកុសលកម្មធ្វើវិចិត្រហើយ ជាកាយពាសពេញដោយដំបៅ ដែលឆ្អឹង ៣០០ កំណាត់ផ្គុំគ្នាហើយ ជាអត្តភាពក្តៅក្រហាយជានិច្ច ជាទីរំពឹងត្រិះរិះរបស់ជនច្រើនគ្នា ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ចិត្តកតំ** សេចក្តីថា មានការវិចិត្រដែលកម្មធ្វើហើយ គឺដែលកម្មធ្វើឲ្យវិចិត្រដោយវត្ថុផ្សេងៗ មានអាករណៈ គឺសំពត់និងគ្រឿងប្រដាប់ គឺកម្រងផ្កាជាដើម ។ បទថា **ពិម្ពំ** បានដល់ នូវអត្តភាពដែលតាំងនៅ ត្រូវចែកដោយអវយវៈទាំងឡាយតូចធំ មានចំណែកបណ្តាយជាដើម ក្នុងឋានៈដែលសមគួរដល់ភាពជាអវយវៈបណ្តាយជាដើម ។ បទថា **អរុកាយំ** គឺមានកាយជាមុខដំហៀ ដោយអំណាចទ្វារទាំង ៩ ។ បទថា **សមុស្សិតំ** គឺឆ្អឹង ៣០០ កំណាត់លើកឡើងហើយ ។ បទថា **អាតុរំ** សេចក្តីថា ឈ្មោះថា មានជំងឺជាប្រចាំ ព្រោះជាទីដែលត្រូវបរិហារដោយឥរិយាបថជាដើម សព្វកាល ។ បទថា **ពហុសង្កប្បំ** បានដល់ ដែលមហាជនត្រិះរិះគិតហើយ ដោយច្រើន ។ បានព្រះគាថាថា **យស្ស ឆន្តេ ធុវំ ឋិតិ** សេចក្តីថា ចូរអ្នកទាំងឡាយមើលអត្តភាពនេះ ដែលមិនមានការស្ថិតស្ថេរ ឬការមាំទាំ មានការបែករាត់រាយ និងខ្ចាត់ខ្ចាយទៅជាធម្មតាដោយចំណែកមួយ ។

ក្នុងកាលចប់ទេសនា ធម្មាភិសមយមានហើយ ដល់សត្វ ៨៤០០០ សូម្បី កិកូនោះ ក៏បានតាំងនៅក្នុងសោតាបត្តិផលដូច្នោះឯង ។

រឿង ឆាឆសិរិមា ចប់

រឿង ឆាឆខុត្តរាថេរី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងខុត្តរាថេរី ត្រាស់ព្រះធម្មទេសនានេះថា **បរិឯ្ឈាមិទំ រូបំ** *ជាដើម ។*

បានឮមកថា ព្រះថេរីមានអាយុ ១២០ ឆ្នាំអំពីកំណើត ត្រាច់បិណ្ឌបាត បានបិណ្ឌបាតហើយ ឃើញភិក្ខុមួយរូបក្នុងចន្លោះផ្លូវ បានសួរដោយអើពើ ដោយបិណ្ឌបាត កាលភិក្ខុមិនឃាត់ ទទួលយក ក៏ប្រគេនទាំងអស់ ខ្លួននាង បានអត់អាហារហើយ សូម្បីក្នុងថ្ងៃទី ២-៣ ក៏បានប្រគេនកត្តជល់ភិក្ខុនោះឯង ក្នុងទីនោះដូចគ្នា បានអត់អាហារហើយយ៉ាងនោះ ។

ក្នុងថ្ងៃទី ៤ ព្រះថេរីត្រាច់បិណ្ឌបាត ជួបព្រះសាស្តាក្នុងទីចង្អៀតមួយកន្លែង កាលថយក្រោយ ជាន់ជាយចីវរបស់ខ្លួន ទើបដួលចុះ មិនអាចទប់ខ្លួនបាន ដួលចុះហើយ ។ ព្រះសាស្តាឃាត់ទៅជិតហើយ ត្រាស់ថា ម្នាលប្អូនស្រី អត្តភាពរបស់នាងចាស់ហើយ ក្នុងកាលមិនយូរ ក៏នឹងបែកធ្លាយទៅដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

បរិឯ្ឈាមិទំ រូបំ ភោគឯ្គំ បភង្គុណំ
ភិជ្ជតិ ឫតិ សន្តេហោ មរណន្តំ ហិ ជីវិតំ ។

រូបនេះគ្រាំគ្រាអស់ហើយ ជាទីសម្ងាក់នៃរោគ ជារបស់ពុកផុយ រាងកាយជារបស់ស្អុយ (នេះ) តែងបែកធ្លាយទៅវិញ ព្រោះថា ជីវិតមានសេចក្តីស្លាប់ជាទីបំផុត ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា ម្នាលប្អូនស្រី រូបនេះ គឺដែលវាប់ថា សរីរៈ របស់នាង ឈ្មោះថា ចាស់ហើយ ព្រោះជាមនុស្សចាស់ រូបនោះឯង ឈ្មោះ ថាជាសម្បុករបស់រោគ ព្រោះអត្ថថា ជាទីនៅអាស្រ័យរបស់រោគគ្រប់ប្រភេទ ប្រៀបដូចផ្ទៃចចក សូម្បីនៅក្មេង ក៏គេហៅថា ចចកចាស់ ។ វល្លិ៍ផោម សូម្បីនៅខ្ចី ក៏គេហៅថា វល្លិ៍ស្អុយ យ៉ាងណា រូបនេះ ក៏ដូច្នោះ កើតក្នុងថ្ងៃ នោះ សូម្បីជារូបមានពណ៌ដូចមាស ក៏ឈ្មោះថា កាយស្អុយ បែកធ្លាយ ព្រោះអត្ថថា ហូរចេញជានិច្ច ។ កាយរបស់នាងជារបស់ស្អុយ គប្បីជ្រាបចុះ ថា នឹងបែក គឺនឹងបែកធ្លាយក្នុងកាលមិនយូរឡើយ ព្រោះហេតុអ្វី ព្រោះ ជីវិត មានការស្លាប់ជាទីបំផុត ។ ព្រះសាស្តាត្រាស់អធិប្បាយថា ព្រោះជីវិត របស់សព្វសត្វ មានការស្លាប់ជាទីបំផុតទាំងអស់ ។

ក្នុងកាលចប់ទេសនា ព្រះថេរីសម្រេចសោតាបត្តិផលហើយ ។ ទេសនា បានជាកថាមានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។

រឿង នាងខុត្តរាថេរី ចប់

រឿង ព្រះអធិមានិកភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកភិក្ខុដែលមានការសម្គាល់ថា ខ្លួនបានសម្រេចអរហត្តផលច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **យានិមានិ** ជាដើម ។

បានឮថា ភិក្ខុ ៥០០ រូប រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ចូលកាន់ព្រៃ ព្យាយាមញុំាងឈានឲ្យកើតឡើងហើយ សម្គាល់ថា កិច្ចបព្វជិតរបស់ពួកយើងសម្រេចហើយ ព្រោះកិលេសទាំងឡាយមិនផ្សាយឡើង ទើបត្រឡប់មកដោយបំណងថា នឹងក្រាបទូលគុណដែលខ្លួនបានហើយ ដល់ព្រះសាស្តា ។

ក្នុងពេលដែលពួកភិក្ខុដល់ខ្ងោងទ្វារខាងក្រៅប៉ុណ្ណោះ ព្រះសាស្តាត្រាស់នឹងព្រះអានន្ទត្ថេរថា អានន្ទ ការងារទាក់ទងដោយតថាគត ដែលភិក្ខុទាំងនោះ ចូលមកគាល់មិនមាន ភិក្ខុទាំងនោះ ចូលទៅកាន់ព្រៃខ្ងោចស្រស់ជាមុនសិន ត្រឡប់អំពីទីនោះហើយ សឹមគាល់តថាគត ។ ព្រះថេរៈទៅប្រាប់សេចក្តីនោះដល់ពួកលោកហើយ ។ ពួកលោកមិនពោលថា ពួកយើងនឹងបានប្រយោជន៍អ្វីដោយព្រៃខ្ងោចស្រស់ គិតថា ព្រះពុទ្ធទ្រង់ឃើញហេតុធ្លាយទ្រង់នឹងឃើញហេតុ ដូច្នេះហើយ ទៅកាន់ព្រៃខ្ងោចស្រស់ កាលឃើញសពក្នុងទីនោះ ក៏បានទូវការខ្ចីមក្នុងសាកសពដែលចោល ១ ថ្ងៃ ២ ថ្ងៃ ញុំាងតម្រេកឲ្យកើតក្នុងសរីរៈស្រស់ ដែលគេទើបតែចោលក្នុងខណៈនោះ ។ ក្នុង

រំពេចនោះ ក៏ដឹងថា ខ្ជូននៅមានកិលេស ។ ព្រះសាស្តា ប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ផ្សាយព្រះរស្មីទៅ ដូចគ្រាស់ចំពោះមុខរបស់ភិក្ខុទាំងនោះ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញរាងឆ្អឹងដូច្នោះ ញ៉ាំងសេចក្តីត្រេកអរដោយអំណាចរាគៈឲ្យកើត គួរឬ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

យានិមានិ អបត្ថានិ អលាពូនេវ សារទេ

កាបោតកានិ អដ្ឋីនិ តានិ ទិស្វាន កា រតិ ។

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាប ដែលគេចោលហើយ ដូចផ្លែឃ្លោកក្នុងសរទកាល សេចក្តីត្រេកអរអ្វីហ្ន៎ (របស់អ្នកទាំងឡាយ) ព្រោះតែឃើញឆ្អឹងទាំងឡាយនោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អបត្ថានិ** *បានដល់ ដែលគេចោលហើយ ។ បទថា* **សរទេ** *សេចក្តីថា ដូចឃ្លោកដែលខ្យល់ និងកម្តៅថ្ងៃប៉ះខូប ជ្រុះរបកក្នុងទីនោះៗ ក្នុងសរទកាល ។ បទថា* **កាបោតកានិ** *ប្រែថា មានពណ៌ដូចសត្វព្រាប ។ ពីរបទថា* **តានិ ទិស្វាន** *សេចក្តីថា ការត្រេកអរអ្វីរបស់ពួកអ្នក ព្រោះឃើញឆ្អឹងទាំងនោះ គឺបែបនោះ ការធ្វើសេចក្តីត្រេកអរក្នុងកាមសម្បត្តិមិតិចតួច រមែងមិនគួរឡើយ មិនមែនឬ ។*

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះបានសម្រេចអរហត្តផលហើយ តាម

ដែលឈរនៅនោះឯង សរសើរព្រះដ៏មានព្រះភាគ មកថ្វាយបង្គំហើយ ដូច្នេះឯង ។

រឿង ព្រះអធិមានិកភិក្ខុ ចប់

រឿង នាងរូបនន្ទាថេរី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងរូបនន្ទាថេរី ដែលជាស្រីស្អាតក្នុងជនបទ ត្រាស់ព្រះធម្មទេសនានេះថា **អដ្ឋីនំ នគរំ កតំ** ជាដើម ។

បានឮថា ព្រះនាងរូបនន្ទានោះព្រះតម្រិះថា បងប្រុសរបស់អញលះសិរីរាជសម្បត្តិចេញបួស បានជាព្រះពុទ្ធ ជាអគ្គបុគ្គលក្នុងលោក សូម្បីឱរសរបស់ទ្រង់ ព្រះនាមរាហុលកុមារ ក៏បួសហើយ សូម្បីបងរបស់អញ គឺព្រះនន្ទ ក៏បួសហើយ ព្រះមាតារបស់អញ ក៏បួសហើយ កាលគណាញាតិមានប្រមាណប៉ុណ្ណេះបួសហើយ អញនឹងធ្វើអ្វីក្នុងផ្ទះ នឹងបួសដែរ ព្រះនាងយាងចូលទៅកាន់សម្នាក់ភិក្ខុនីទាំងឡាយ ហើយបួស ព្រះនាងបួសព្រោះស្រឡាញ់ក្នុងព្រះញាតិប៉ុណ្ណោះ មិនមែនបួសដោយសទ្ធាទ្បើយ តែព្រោះព្រះនាងជាអ្នកមានព្រះរូបល្អ ទើបប្រាកដឈ្មោះថា រូបនន្ទា ។

ព្រះនាងបានឮថា ព្រះសាស្តាត្រាស់ថា រូបមិនទៀង ជាទុក្ខ ជាអនត្តា

វេទនា សញ្ញា សង្ខារ វិញ្ញាណមិនទៀង ជាទុក្ខ ជាអនត្តា ទើបមិនយោងទៅជួបព្រះភក្ត្រព្រះសាស្តា ដោយព្រះនាងខ្វាចព្រះសាស្តាត្រាស់ទោសក្នុងរូបរបស់ខ្លួនដែលគួរមើល គួរជ្រះថ្លាយ៉ាងនេះ ។

អ្នកនគរសាវត្ថីថ្វាយទានអំពីព្រលឹម សមាទានឧបោសថហើយ ជណ្តប់សំពត់ស្អាត មានដៃកាន់គ្រឿងក្រអូប និងកម្រងផ្កាជាដើម ក្នុងពេលល្ងាចប្រជុំគ្នាស្តាប់ធម៌ក្នុងវត្តជេតពន ។ សូម្បីកិកូនីសង្ឃដែលកើតឆន្ទៈក្នុងព្រះធម្មទេសនារបស់ព្រះសាស្តា ក៏រមែងទៅវិហារស្តាប់ធម៌ ។ អ្នកនគរសាវត្ថីទាំងនោះ កាលស្តាប់ធម៌ហើយ ចូលទៅកាន់ព្រះនគរ ក៏ពោលតែគុណកថារបស់ព្រះសាស្តាប៉ុណ្ណោះចូលទៅ ។

ពិតហើយ ពួកសត្វក្នុងលោកសន្និវាស ដែលមានប្រមាណ ៤ ពួក ឃើញព្រះសាស្តា មិនកើតសេចក្តីជ្រះថ្លា មានចំនួនតិច ។ ពោលដោយចំនួនសត្វដែលជារូបប្បមាណិកា គឺកាន់យករូបជាប្រមាណ ឃើញព្រះសរីរៈរបស់ព្រះដ៏មានព្រះភាគ ដែលប្រដាប់ដោយព្រះលក្ខណៈ និងអនុព្យញ្ជនៈ មានព្រះឆវីវណ្ណដូចមាស រមែងជ្រះថ្លា ។ ពួកសត្វដែលជាឃោសប្បមាណិកា គឺកាន់យកសំឡេងជាប្រមាណ ស្តាប់សំឡេងប្រកាសគុណរបស់ព្រះសាស្តាដែលអាស្រ័យប្រព្រឹត្តទៅហើយរាប់រយជាតិ និងសំឡេងប្រកាសធម្មទេសនាដែលប្រកបដោយអង្គ ៨ រមែងជ្រះថ្លា ។ ពួកសត្វដែលជាលូខប្បមាណិកា គឺកាន់យកការបដិបត្តិសៅហ្មងជាប្រមាណ អាស្រ័យភាពដែលព្រះអង្គជាអ្នកសៅហ្មងដោយបច្ច័យទាំងឡាយ មានចីវរជាដើម រមែងជ្រះថ្លា ។ ពួកសត្វ

ដែលជាធម្មប្បមាណិកា គឺកាន់យកធម៌ជាប្រមាណ រមែងជ្រះថ្លាថា សីលរបស់ព្រះទសពលបែបនេះ សមាធិបែបនេះ បញ្ញាបែបនេះ ព្រះដ៏មានព្រះភាគទ្រង់មិនមានបុគ្គលស្មើ មិនមានបុគ្គលផ្ទឹម មិនមានបុគ្គលក្រៃលែងជាង មិនមានបុគ្គលប្រៀបផ្ទឹមដោយគុណទាំងឡាយ មានសីលជាដើម ។ កាលជនទាំងនោះពណ៌នាគុណរបស់ព្រះតថាគត មាត់ក៏មិនគ្រប់គ្រាន់ ។

ព្រះនាងរូបនន្ទាបានស្តាប់នូវគុណកថា អំពីសម្នាក់ពួកភិក្ខុនី និងពួកឧបាសិកា ទើបទ្រង់ព្រះតម្រិះថា ជនទាំងឡាយរមែងពោលសរសើរបងរបស់អញច្រើននោះឯង ក្នុងថ្ងៃមួយ ទ្រង់នឹងត្រាស់ទោសរូបរបស់អញ នឹងត្រាស់បានត្រឹមប៉ុនណា បើដូច្នោះ អញគប្បីទៅជាមួយពួកភិក្ខុនី មិនបង្ហាញខ្លួនឡើយ គាល់ព្រះតថាគតស្តាប់ធម៌ហើយ គប្បីមក ។ ព្រះនាងត្រាស់ប្រាប់ដល់ពួកភិក្ខុនីថា ថ្ងៃនេះ ខ្ញុំនឹងទៅស្តាប់ធម៌ ពួកភិក្ខុនីត្រេកអរថា យូរណាស់ហើយ កាលដែលព្រះនាងរូបនន្ទា ទ្រង់មានបំណងចូលទៅកាន់ទីបម្រើព្រះសាស្តា កើតឡើងហើយ ថ្ងៃនេះ ព្រះសាស្តា ទ្រង់អាស្រ័យព្រះនាងរូបនន្ទានេះហើយ ទ្រង់នឹងសម្តែងព្រះធម្មទេសនាដ៏វិចិត្រ ដូច្នេះហើយ នាំព្រះនាងចេញទៅហើយ ។ ចាប់តាំងអំពីចេញទៅ ព្រះនាងត្រិះរិះថា អញមិនបង្ហាញខ្លួនឡើយ ។

ព្រះសាស្តាទ្រង់ព្រះតម្រិះថា ថ្ងៃនេះ រូបនន្ទានឹងមកកាន់ទីបម្រើរបស់តថាគត ធម្មទេសនាដូចម្តេចហ្ន៎ទើបជាទីសប្បាយរបស់នាង ទ្រង់ជាក់ព្រះហឫទ័យថា រូបនន្ទានោះ ជ្ងន់ក្នុងរូប ជាប់ជំពាក់ក្នុងអត្តភាពដ៏ខ្ជាំងក្លា ការ

បន្ទោបង់សេចក្តីស្រើបស្រាំងក្នុងរូបដោយរូបនោះឯង ជាទីសប្បាយរបស់នាង ដូច ការយកបន្ទាជោះបន្ទា ដូច្នោះ ។ ក្នុងកាលដែលព្រះនាងចូលទៅកាន់វិហារ ទ្រង់និមិត្តស្រីម្នាក់ អាយុ ១៦ ឆ្នាំ ស្បែកសំពត់ក្រហម ប្រដាប់ហើយដោយ អាភរណៈគ្រប់យ៉ាង កាន់ផ្ទិត ឈរបក់ក្នុងទីជិតព្រះអង្គដោយកម្លាំងឫទ្ធិ ព្រះសាស្តា និងព្រះនាងរូបនន្ទាប៉ុណ្ណោះ ឃើញរូបស្ត្រីនោះ ។ ព្រះនាង យាងចូលទៅកាន់វិហារជាមួយភិក្ខុនីទាំងឡាយ ឈរខាងក្រោយភិក្ខុនី ថ្វាយ បង្គំព្រះសាស្តាដោយបញ្ចង្គប្រតិស្ឋាន អង្គុយក្នុងចន្លោះពួកភិក្ខុនី ឆ្លៀងមើល ព្រះសាស្តាតាំងអំពីព្រះបាទ នាងឃើញព្រះសរីរៈរបស់ព្រះសាស្តា វិចិត្រ ដោយព្រះលក្ខណៈ រុងរឿងដោយអនុព្យញ្ជនៈ មានព្រះរស្មីមួយព្យាមចោម រោមហើយ ព្រះនាងគយគន់ព្រះភក្ត្រដ៏មានសិរី ដូចព្រះចន្ទ្រពេញវង់ បាន ឃើញរូបស្រីឈរក្នុងទីជិតហើយ ។ ព្រះនាងមើលស្រីនោះហើយ សម្លឹង មើលអត្តភាពរបស់ខ្លួន ជីងថា ខ្លួនដូចក្អែកញីនៅក្បែរហង្សមាសញីដូច្នោះ ។ ចាប់តាំងអំពីកាលនាងឃើញរូប ដែលសម្រេចដោយឫទ្ធិនោះឯង ព្រះនេត្រ ទាំងពីររបស់ព្រះនាង ក៏គយគន់មិនជាក់ ។ ព្រះនាងមានចិត្តដែលសិរីរូបនៃ សរីរប្បទេសទាំងអស់ ស្រូបចូលទៅហើយថា ឱ សក់របស់ស្រីនេះក៏ស្អាត ឱ ថ្ងាសក៏ស្អាត ដូច្នេះ មានចិត្តស្រឡាញ់ក្នុងរូបនោះដ៏ខ្លាំងក្លា ។ ព្រះសាស្តា ទ្រង់ជ្រាបការត្រេកអរបំផុត ក្នុងរូបនោះរបស់ព្រះនាង កាលទ្រង់សម្តែងធម៌ ទើបទ្រង់សម្តែងរូបនោះ ឲ្យកន្លងភាវៈបុគ្គលមានអាយុ ១៦ មានអាយុ ២០ ឆ្នាំ ។ ព្រះនាងរូបនន្ទាបានទត មានចិត្តនឿយណាយបន្តិចម្តងថា រូបនេះមិន

ដូចរូបមុនហ្ន៎ ។ ព្រះសាស្តាទ្រង់សម្តែងរូបស្រីនោះ ឲ្យប្រែប្រួលតាមលំដាប់ គឺស្រីស្រករប្រសូតបុត្រម្តង ស្រីកណ្តាលមនុស្ស ស្រីចាស់ ស្រីចាស់គ្រាំគ្រា ព្រោះជរា សូម្បីព្រះនាងក៏នឿយណាយក្នុងរូបនោះ ក្នុងកាលដែលទ្រុឌទ្រោម ព្រោះជរាដោយលំដាប់ដូចគ្នាថា ឱ រូបនេះ វិនាសទៅហើយហ្ន៎ កាលនាងឃើញរូបនោះមានធ្មេញបាក់ សក់ស្កូវ ខ្នងកោង មានឆ្អឹងផុសខ្ចឹង ដូចបង្គន់ផ្ទះ មានឈើច្រត់ទ្រខាងមុខ ដើរទ្រើកៗ ក៏នឿយណាយពន់ពេក ។ គ្រានោះ ព្រះសាស្តាទ្រង់និម្មិតរូបស្រីនោះ ឲ្យជារូបដែលព្យាធិគ្របសង្កត់ក្នុងខណៈនោះឯង ស្រីនោះក៏ចោះឈើច្រត់ និងផ្ងិតស្លឹកត្នោត ស្រែកថ្ងូរ ដួលចុះត្រង់ផែនដី ដេកក្នុងមូត្រ និងលាមករបស់ខ្លួន បម្រះនទៀលទៅមក ព្រះនាងរូបនន្ទាឃើញស្រីនោះហើយ នឿយណាយពន់ពេក ។ ព្រះសាស្តា ទ្រង់សម្តែងមរណៈរបស់ស្រីនោះហើយ ស្រីនោះដល់នូវសភាពជាសពហើមប៉ោងក្នុងខណៈនោះឯង ។ ខ្សែនៃខ្ទុះ និងពួកដង្កូវហូរចេញអំពីមុខដំបៅទាំង ៩ ហ្វូងសត្វមានក្អែកជាដើម ប្រជែងគ្នាស៊ីហើយ ។ ព្រះនាងរូបនន្ទា ពិចារណាសាកសពនោះហើយ នាងឃើញអត្តភាពជាសភាវៈមិនទៀងថា ស្រីនេះដល់នូវការចាស់ ដល់នូវការឈឺ ដល់នូវការស្លាប់ក្នុងទីនេះឯង ការចាស់ ការឈឺ និងការស្លាប់ នឹងមកដល់អត្តភាពនេះយ៉ាងនោះដូចគ្នា ។ និងព្រោះការដែលអត្តភាពជាសភាវៈ ដែលព្រះនាងឃើញហើយដោយសភាពមិនទៀងនោះឯង ទើបអត្តភាពនោះ ព្រះនាងឃើញថាជាទុក្ខ ដោយភាពជាអនត្តានោះឯង ។ លំដាប់នោះ កពតាំង ៣ ប្រាកដដល់ព្រះនាងដូចត្រូវភ្លើងឆេះហើយ និងដូច

សាកសពដែលគេចងព្យួរត្រង់ព្រះសូរង ចិត្តបាញ់ចំពោះកម្មដ្ឋានហើយ ។ ព្រះសាស្តាទ្រង់ជ្រាបថា ព្រះនាងគិតឃើញអត្តភាព ដោយភាពជារបស់មិនទៀងហើយ ទើបទ្រង់ពិចារណាមើលថា នាងអាចធ្វើទីពឹងដល់ខ្លួនឯងបានដែរឬហ្ន៎ ទ្រង់ឃើញថា មិនអាច ទាល់តែព្រះនាងបានបច្ច័យខាងក្រៅជាមុនសិន ទើបសមគួរ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ដោយអំណាចធម្មសប្បាយដល់ព្រះនាង បានត្រាស់ព្រះគាថានេះថា

> *នន្ទា ចូរនាងមើលកាយ ដែលកម្មលើកឡើង គួរខ្ពើម មិនស្អាត ជាកាយស្អុយ ហូរចេញខាងលើ ហូរចេញខាងក្រោម ដែលពាលជនទាំងឡាយ ប្រាថ្នាពន់ពេក សរីរៈរបស់នាង យ៉ាងណា សរីរៈរបស់ស្រីនោះក៏យ៉ាងនោះ សរីរៈរបស់ស្រីនោះ យ៉ាងណា សរីរៈរបស់នាង ក៏យ៉ាងនោះ ចូរនាងឃើញធាតុទាំងឡាយ ជារបស់សោះសូន្យ កុំត្រឡប់មកកាន់លោកនេះទៀតឡើយ ចូរនាងប្រាសចាកតម្រេក គឺការពេញចិត្តក្នុងភពហើយ នឹងជាបុគ្គលស្ងប់ត្រាច់ទៅ ។*

បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់ប្រារព្ធព្រះនាងនន្ទាភិក្ខុនី បានត្រាស់ព្រះគាថាទាំងនេះ ដោយប្រការដូច្នេះឯង ។ ព្រះនាងនន្ទាបញ្ជូនញាណទៅតាមក្រសែទេសនា សម្រេចសោតាបត្តិផលហើយ ។

កាលនោះ ព្រះសាស្តា កាលទ្រង់ត្រាស់សុញ្ញតកម្មដ្ឋាន ដើម្បីអប់រំវិបស្សនា ដើម្បីមគ្គផលទាំង ៣ ក្រៃលែងឡើងដល់ព្រះនាង ទើបត្រាស់ថា

នន្ទា នាងកុំធ្វើការយល់ថា សារៈក្នុងសរីរៈនេះមាន ព្រោះសារៈក្នុងសរីរៈនេះ សូម្បីតិចតួចក៏មិនមាន សរីរៈនេះ ដែលកម្មលើកឆ្នឹង ៣០០ កំណាត់ ទ្បើង សាងឲ្យជានគរឆ្នឹងទាំងឡាយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អដ្ឋីនំ នគរំ កតំ មំសលោហិតលេបនំ

យត្ថ ជរា ច មច្ចុ ច មានោ មក្ខោ ច ឱហិតោ ។

សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីប្រកាន់ខ្លួន និងសេចក្តីលុបគុណ ប្រជុំចុះក្នុងសរីរៈណា (សរីរៈនោះ) ដែលកុសលាកុសលកម្មធ្វើហើយ ឲ្យជានគរបស់ឆ្នឹងទាំងឡាយ ជាគ្រឿងប្រឡាក់ដោយសាច់ និងឈាម ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា ដូចជនទាំងឡាយ លើកឈើទាំងឡាយទ្បើងយកវល្ល៍ចងហើយ បូកដោយដីឥដ្ឋ ធ្វើឲ្យជាផ្ទះខាងក្រៅ ពោល គឺនគរដើម្បីប្រយោជន៍ដល់ការតាំងបុព្វណ្ណជាតិ និងអបរណ្ណជាតិជាដើម យ៉ាងណា សរីរៈដែលប្រព្រឹត្តទៅខាងក្នុងក៏ដូច្នោះ ដែលកម្មញ៉ាំងឆ្នឹង ៣០០ កំណាត់ឲ្យ លើកទ្បើងហើយ ធ្វើឲ្យជានគរដែលសសៃរចង លាបដោយសាច់ និងឈាម ខ្ចប់ដោយស្បែក ដើម្បីប្រយោជន៍នៃការធ្លាក់ចុះនៃជរា ដែលមានការទ្រុឌទ្រោមជាលក្ខណៈនៃមច្ចុ ដែលមានការស្លាប់ជាលក្ខណៈ នៃមានៈ ដែលមានការស្រេវឹង ព្រោះអាស្រ័យការដល់ព្រមដោយការលើកខ្លួនជាដើមជាលក្ខណៈ និងនៃមក្ខៈ មានការធ្វើកម្មដែលគេធ្វើល្អហើយឲ្យវិនាសជាលក្ខណៈ ព្រោះអាពាធ

ដែលប្រព្រឹត្តទៅតាមកាយ និងចិត្តបែបនេះនោះឯង តាំងចុះហើយ ក្នុងសរីរៈនេះ ក្រៅអំពីនេះ ក៏មិនមានអ្វីដែលចូលជល់នូវភាពជារបស់គប្បីកាន់យក ។

ក្នុងកាលចប់ទេសនា ព្រះនាងរូបនន្ទាថេរីបានសម្រេចអរហត្តផល ។ ព្រះធម្មទេសនា បានជាកថាមានប្រយោជន៍ជល់មហាជនហើយ ដូច្នោះឯង ។

រឿង នាងរូបនន្ទាថេរី ចប់

រឿង ព្រះនាងមល្លិកាទេវី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងមល្លិកាទេវី ត្រាស់ព្រះធម្មទេសនានេះថា **ជីវន្តិ វ រាជរថា សុចិត្តា** *ជាដើម ។*

បានឮថា ថ្ងៃមួយ ព្រះនាងមល្លិកាទេវីនោះ យាងចូលទៅកាន់ទីសម្រាប់ស្រង់ទឹក ព្រះនាងជម្រះព្រះឱស្ឋហើយ បង្អោនព្រះសរីរៈចុះដើម្បីជម្រះស្មង មានសុនខដែលព្រះនាងប្រោសប្រាណមួយ ចូលទៅជាមួយព្រះនាងនោះឯង សុនខឃើញព្រះនាងឱនដូច្នោះ ទើបផ្តើមធ្វើអសទ្ធម្ម ព្រះនាងទ្រង់ត្រេកអរនឹងសម្ផស្សនោះ ទើបប្រថាប់ឈរ ព្រះរាជាទតតាមបង្អួចក្នុងប្រាសាទជាន់លើ ទ្រង់ឃើញកិរិយានោះ ក្នុងកាលព្រះនាងយាងមកវិញ ទើបត្រាស់ថា ស្រីថោកទាប ចូរនាងវិនាស ព្រោះហេតុអ្វី ទើបធ្វើកម្មបែបនេះ ព្រះនាងទូលថា ខ្ញុំម្ចាស់ធ្វើអ្វីខុស ព្រះរាជាត្រាស់ថា នាងធ្វើសន្តវៈជាមួយសុនខ ព្រះនាងទូលថា

បពិត្រព្រះអង្គ រឿងនេះ មិនពិតទេ ព្រះរាជាត្រាស់ថា យើងឃើញឯង យើងមិនមែនជឿអ្នកដទៃ ស្រីថោកទាប ចូរវិនាស ព្រះនាងទូលថា បពិត្រព្រះអង្គ បុគ្គលណាម្នាក់ចូលទៅកាន់បន្ទប់ទឹកនេះ តែម្នាក់ប៉ុណ្ណោះក៏ប្រាកដជាពីរនាក់ដល់អ្នកដែលមើលតាមបង្អួចនេះ ព្រះរាជាត្រាស់ថា ស្រីអាក្រក់ នាងពោលមិនពិត ព្រះនាងត្រាស់ថា បពិត្រព្រះអង្គ បើទ្រង់មិនជឿខ្ញុំម្ចាស់ សូមយាងទៅកាន់បន្ទប់ទឹកនោះ ខ្ញុំនឹងមើលទ្រង់តាមបង្អួចនេះ ។

ព្រះរាជា មានជាតិជាបុគ្គលល្ងង់ខ្លៅ ទើបទ្រង់ជឿពាក្យរបស់ព្រះនាង ហើយចូលទៅកាន់បន្ទប់ទឹក ចំណែកព្រះទេវីនោះឯង ទ្រង់ឈរទតត្រង់បង្អួច ទូលថា មហារាជល្ងង់ខ្លៅ រឿងអ្វីទ្រង់ធ្វើសន្តវៈជាមួយពពែ កាលព្រះរាជាត្រាស់ថា នែនាង ខ្ញុំមិនបានធ្វើកម្មបែបនោះ ក៏ទូលថា ខ្ញុំម្ចាស់ឃើញឯង ខ្ញុំម្ចាស់មិនជឿព្រះអង្គទ្បើយ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយទ្រង់ជឿថា បុគ្គលចូលទៅកាន់បន្ទប់ទឹកនេះម្នាក់ឯងប៉ុណ្ណោះ ក៏រមែងប្រាកដជាពីរនាក់ ។ ព្រះនាងមល្លិកាព្រះតម្រិះថា ព្រះរាជានេះអញបញ្ឆោតបានហើយ ព្រោះទ្រង់ល្ងង់ខ្លៅ អញធ្វើកម្មអាក្រក់ហើយ ព្រះរាជានេះ អញពោលទោសដោយពាក្យមិនពិត សូម្បីព្រះសាស្តាទ្រង់ក៏ជ្រាបកម្មនេះរបស់អញ អគ្គសាវ័កទាំងពីរក្តី អសីតិមហាសាវ័កក្តី នឹងជ្រាប ឱហ្ន៎ អញធ្វើកម្មធ្ងន់ហើយ ។ បានឮថា ព្រះនាងមល្លិកានោះ ជាសម្ងាញ់ក្នុងអសទិសទានរបស់ព្រះរាជា ។

ក្នុងអសទិសទាននោះ កិច្ចបរិច្ចាគដែលទ្រង់ធ្វើមួយថ្ងៃ មានតម្លៃដល់ ១៤ កោដិ សេ្វតច្ឆត្រ បល្ល័ង្កប្រថាប់គង់ ជើងចាត្រ តាំងសម្រាប់ទ្រព្រះចាទ

ព្រះតថាគត របស់ ៤ យ៉ាងនេះ មានតម្លៃកាត់ថ្លៃមិនបាន ។ ក្នុងកាលអស់ព្រះជន្ម ព្រះនាងមល្លិកា មិនបាននឹកដល់មហាបរិច្ចាគបែបនោះ នាងរឭកដល់កម្មលាមកតែម្យ៉ាង អស់ព្រះជន្មហើយ កើតក្នុងអវីចី ព្រះនាងមល្លិកានោះ ជាអ្នកប្រោសប្រាណរបស់ព្រះរាជាក្រៃលែង ។

ព្រះរាជាត្រូវសេចក្តីសោកមានកម្លាំងគ្របសង្កត់បញ្ជាឲ្យធ្វើឈាបនកិច្ច ព្រះសរីរៈរបស់ព្រះនាងហើយ ទ្រង់ព្រះតម្រិះថា អញនឹងទូលសួរទីកើតរបស់ព្រះនាង ទើបទៅកាន់សម្នាក់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់បានធ្វើឲ្យព្រះរាជារឭកមិនបាន ។ ទ្រង់ស្តាប់ព្រះធម្មកថា ក្នុងសម្នាក់ព្រះសាស្តាហើយក៏ភ្លេច ក្នុងកាលយាងទៅកាន់ព្រះរាជនិវេសន៍ ទ្រង់រឭកបាន ទើបត្រាស់ថា នែអ្នក ខ្ញុំតាំងចិត្តថានឹងទូលសួរទីដែលព្រះនាងមល្លិកាកើត ទៅកាន់សម្នាក់ព្រះសាស្តា ក៏ភ្លេចឈឹង ស្អែកនេះខ្ញុំនឹងទូលសួរទៀត ដូច្នេះហើយ ក៏យាងទៅ សូម្បីក្នុងថ្ងៃស្អែកឡើង ព្រះសាស្តាក៏បានធ្វើឲ្យព្រះរាជារឭកមិនបានរហូត ៧ ថ្ងៃតាមលំដាប់ ។ ចំណែកព្រះនាងមល្លិកានោះ ធេះក្នុងនរកអស់ ៧ ថ្ងៃប៉ុណ្ណោះ ក្នុងថ្ងៃ ទី ៨ ចុតិអំពីទីនោះហើយ កើតក្នុងតុសិត ។

សួរថា ព្រោះហេតុអ្វីទើបព្រះសាស្តា បានធ្វើភាពដែលព្រះរាជានោះឲ្យទ្រង់រឭកមិនបាន ឆ្លើយថា បានឮថា ព្រះនាងមល្លិកានោះជាទីពេញព្រះហឫទ័យរបស់ព្រះរាជាបំផុត ព្រោះដូច្នោះ បើទ្រង់ជ្រាបថា ព្រះនាងកើតក្នុងនរកហើយ ក៏កើតមិច្ឆាទិដ្ឋិថា បើស្រីសម្បូរដោយសទ្ធាបែបនេះ កើតក្នុងនរកសោត អញនឹងថ្វាយទានធ្វើអ្វី ដូច្នេះហើយ នឹងផ្តាច់និច្ចកត្តដែលប្រព្រឹត្ត

ទៅក្នុងព្រះរាជនិវេសន៍ សម្រាប់ភិក្ខុ ៥០០ ហើយ គប្បីកើតក្នុងនរក ។ ព្រោះដូច្នោះ ទើបព្រះសាស្តា ទ្រង់ធ្វើការពារដែលព្រះរាជានោះ មិនឲ្យព្រួកបាន អស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៨ ទ្រង់យាងទៅដើម្បីបិណ្ឌបាត ចូលទៅកាន់ទ្វារព្រះរាជវាំងដោយព្រះអង្គឯង ។ ព្រះរាជាជ្រាបថា ព្រះសាស្តាយាងមកហើយ ទើបចេញទៅទទួលបាត្រ បម្រុងនិមន្តឡើងកាន់ប្រាសាទ តែព្រះសាស្តាទ្រង់សម្តែងអាការដើម្បីប្រថាប់គង់ត្រង់ពោងវេ ។ ទើបព្រះរាជានិមន្តព្រះសាស្តាឲ្យប្រថាប់គង់ក្នុងទីនោះ ទ្រង់ទទួលដោយបបរ និងរបស់ទំពាហើយ ទើបថ្វាយបង្គំ លុះប្រថាប់គង់ ក៏ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមកដោយបំណងថា នឹងទូលសួរទីកើតរបស់ព្រះនាងមល្លិកាទេវី ហើយចេះតែភ្លេច ព្រះនាងកើតក្នុងទីណាហ្ន៎ ព្រះសាស្តាត្រាស់ថា មហាបពិត្រ នាងកើតក្នុងតុសិត-ភព ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ បើនាងមិនកើតក្នុងតុសិតភព អ្នកដទៃណានឹងកើត ស្រីដូចព្រះនាងមល្លិកានោះ មិនមាន ព្រោះក្នុងទីដែលព្រះនាងអង្គុយជាដើម កិច្ចដទៃវៀរការចាត់ចែងទាន ដោយគិតថា ស្អែកនេះ នឹងថ្វាយវត្តនេះ នឹងធ្វើវត្តនេះដល់ព្រះតថាគត ដូច្នេះ មិនមានឡើយ បពិត្រព្រះអង្គ តាំងអំពីនាងទៅកាន់បរលោកហើយ សរីរៈរបស់ខ្ញុំព្រះអង្គ មិនសូវរីករាយឡើយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា មហាបពិត្រ កុំគិតឡើយ នេះជាធម៌ដែលពិតប្រាកដរបស់សត្វគ្រប់ជំពូក ហើយត្រាស់សួរថា មហាបពិត្រ នេះរថរបស់អ្នកណា ។ ព្រះរាជាទ្រង់ប្រតិស្ថានអញ្ជលីលើត្បូងទូលថា បពិត្រ

ព្រះអង្គ របស់ជីតាខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា នេះជារបស់អ្នកណា ព្រះរាជាត្រាស់ថា របស់បិតាខ្ញុំព្រះអង្គ ។

កាលព្រះរាជាក្រាបទូលយ៉ាងនោះហើយ ព្រះសាស្តាត្រាស់ថា មហាបពិត្រ រថរបស់ជីតា ហេតុអ្វី មិនដូចរថរបស់ព្រះបិតា រថរបស់ព្រះបិតាមិនដូចរថរបស់មហាបពិត្រ ការគ្រាំគ្រា រមែងមកដល់ សូម្បីតែកំណាត់ឈើបែបនេះ នឹងពោលទៅថ្វីការគ្រាំគ្រាថា មិនមកដល់អត្តភាពនេះ មហាបពិត្រ សេចក្តីពិត ធម៌របស់សប្បុរសប៉ុណ្ណោះ មិនមានសេចក្តីជរា ចំណែកសត្វទាំងឡាយ ឈ្មោះថា មិនជរាមិនមាន ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ជីរន្តិ វេ រាជរថា សុចិត្តា អថោ សរីរម្បិ ជរំ ឧបេតិ
សតញ្ហ ធម្មោ ន ជរំ ឧបេតិ សន្តោ ហវេ សព្ភិ បវេទយន្តិ ។

រាជរថទាំងឡាយ ដ៏វិចិត្រល្អ រមែងគ្រាំគ្រា សូម្បីសរីរៈក៏ដល់នូវសេចក្តីគ្រាំគ្រាដូចគ្នា ទើបឯធម៌របស់សប្បុរសទាំងឡាយ មិនដល់នូវសេចក្តីគ្រាំគ្រា (ដូច្នោះ) ទេ សប្បុរសទាំងឡាយ តែងនិយាយឲ្យពួកសប្បុរសផងគ្នាដឹងបាន ។

សេចក្តីអធិប្បាយ

*គប្បីជ្រាបថា **វេ** ក្នុងព្រះគាថានោះ ជានិបាត បទថា **សុចិត្តា** សេចក្តីថា រថទាំងឡាយរបស់ព្រះរាជាទាំងឡាយ ដ៏វិចិត្រល្អហើយ ដោយរតនៈ ៧ និងដោយគ្រឿងប្រដាប់រថដទៃ រមែងគ្រាំគ្រាបាន ។*

*បទថា **សរីរម្បិ** សេចក្តីថា មិនមែនរថតែម្យ៉ាងប៉ុណ្ណោះ សរីរៈដែល*

ផ្សំផ្គុំគ្នាយ៉ាងល្អនេះ ក៏រមែងដល់នូវការទ្រុឌទ្រោម មានភាពជាបុគ្គលធ្មេញ ចាក់ជាដើម ឈ្មោះថា ចូលដល់នូវការគ្រាំគ្រា ។

បទថា **សតញ្ច** សេចក្តីថា តែលោកុត្តរធម៌ ៩ របស់សប្បុរសទាំង-ឡាយ មានព្រះពុទ្ធជាដើម រមែងមិនធ្វើនូវការប៉ះទង្គិចក្នុងទីណាឡើយ ឈ្មោះថា មិនចូលដល់នូវភាពទ្រុឌទ្រោម ។

បទថា **បវេទយន្តិ** សេចក្តីថា សប្បុរសទាំងឡាយ មានព្រះពុទ្ធ ជាដើម ប្រាស្រ័យជាមួយសប្បុរស គឺដោយបណ្ឌិតទាំងឡាយយ៉ាងនេះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះនាងមល្ទិកាទេវី ចប់

រឿង ព្រះលោឡុទាយិត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធលោឡុទាយិត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អប្បស្សតាយំ បុរិសោ** ជាដើម ។

បានឲ្យមកថា ព្រះលោឡុទាយិត្ថេរនោះ ទៅកាន់ផ្ទះរបស់បុគ្គលដែលធ្វើ នូវមង្គល ក៏សូធ្យនូវអវមង្គលដោយន័យជាដើមថា **តិរោកុណ្ឌសុ តិដ្ឋន្តិ** បើ ទៅផ្ទះរបស់អ្នកធ្វើការអវមង្គល ដែលគួរពោលតិរោកុណ្ឌសូត្រជាដើម ក៏ពោល

មង្គលកថា ដោយន័យជាដើមថា **ធានញ្ច ធម្មចរិយា ច** ឬរតនសូត្រជាដើម ថា **យំកិចិ្ច វិត្តំ ឥធ វា ហុរំ វា ។** លោកគិតថា អញនឹងពោលសូត្រដទៃ សូម្បីពោលសូត្រដទៃក្នុងទីនោះៗ យ៉ាងនោះ ក៏មិនដឹងថាអញពោលសូត្រ ដទៃ ។

ភិក្ខុទាំងឡាយស្តាប់កថារបស់លោកហើយ ទើបក្រាបទូលព្រះសាស្តា ថា បពិត្រព្រះអង្គ ហេតុអ្វីលោឡុទាយី ក្នុងទីគេធ្វើមង្គល និងអវមង្គល គួរ ពោលសូត្រដទៃ ក៏បែរជាទៅពោលសូត្រដទៃ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ លោឡុទាយីនោះពោលយ៉ាងនោះ ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិន មែន សូម្បីក្នុងកាលមុន លោឡុទាយី កាលសូត្រដទៃដែលខ្លួនគួរពោល ក៏ បែរជាពោលសូត្រដទៃ កាលភិក្ខុទាំងនោះទូលអារាធនា ទើបទ្រង់នាំអតីត និទានមកថា

ក្នុងអតីតកាល បុត្ររបស់ព្រាហ្មណ៍ឈ្មោះអគ្គិទត្ត ក្នុងក្រុងពារាណសី ឈ្មោះសោមទត្តកុមារ បម្រើព្រះរាជាហើយ ។ កុលបុត្រនោះ បានជាទីប្រោស ប្រាណពេញព្រះហប្ចទ័យរបស់ព្រះរាជា ។ ចំណែកព្រាហ្មណ៍ អាស្រ័យ កសិកម្មចិញ្ចឹមជីវិត ។ ព្រាហ្មណ៍នោះ មានគោពីរ ក្នុងគោពីរនោះ គោមួយ ក្បាលស្លាប់ហើយ ។ ទើបព្រាហ្មណ៍និយាយនឹងកូនប្រុសថា នែបា សោម-ទត្ត ចូរបាសូមព្រះរាជា នាំគោមកឲ្យឪពុកមួយក្បាល ។

មហាតលិកសោមទត្តគិតថា បើអញសូមព្រះរាជទាន ជាមួយព្រះរាជា សោត ភាពជាបុគ្គលវឹកវរនឹងប្រាកដដល់អញ ទើបពោលថា បពិត្រលោក

ឪពុក សូមលោកឪពុក សូមនឹងព្រះរាជាចុះ កាលព្រាហ្មណ៍ពោលថា នែកូន បើដូច្នោះ ចូរនាំឪពុកទៅចុះ ទើបគិតថា ព្រាហ្មណ៍នេះ មានបញ្ញាទន់ខ្សោយ មិនចេះសូម្បីត្រឹមតែពាក្យជាដើមថា ចូរទៅខាងមុខ ចូរថយមកក្រោយ កាលពាក្យដទៃដែលគួរពោលថា ក៏បែរជាពោលពាក្យដទៃទៀត អញនឹងឲ្យសិក្សាហើយសឹមនាំទៅ ។ សោមទត្តនាំឪពុកទៅកាន់ព្រៃខ្មោច ឈ្មោះវីរណត្ថម្ភក: ហើយ ចង់ស្មៅច្រើនបាច់សន្ធតថា បាច់នេះជាព្រះរាជា បាច់នេះជាឧបរាជ បាច់នេះជាសេនាបតីដូច្នេះជាដើម បង្ហាញដល់បិតាតាមលំដាប់ហើយ ប្រាប់ថា ពេលដែលលោកឪពុកចូលទៅកាន់រាជត្រកូល ត្រូវដើរយ៉ាងនេះ ត្រូវថយយ៉ាងនេះ និយាយនឹងព្រះរាជា ត្រូវក្រាបទូលយ៉ាងនេះ ឧបរាជ ត្រូវនិយាយយ៉ាងនេះ លោកឪពុកគាល់ព្រះរាជាហើយ ត្រូវថ្វាយជ័យមង្គលយ៉ាងនេះថា សូមទ្រង់មានជ័យជម្នះចុះ ដូច្នេះ គប្បីពោលគាថានេះហើយ សូមគោចុះ ទើបឲ្យបិតារៀនគាថាថា

បពិត្រមហារាជ គោសម្រាប់ភ្ជួរស្រែរបស់ទូលបង្គំមានពីរ ក្នុងគោពីរនោះ គោមួយស្លាប់ហើយ សូមទ្រង់ព្រះរាជទានគោទីពីរចុះ ។

ព្រាហ្មណ៍នោះ ទន្ទេញគាថានោះយ៉ាងស្ទាត់អស់មួយឆ្នាំ ទើបប្រាប់ភាពដែលគាថានោះស្ទាត់ជំនាញ់ហើយដល់បុត្រ កាលសោមទត្តពោលថា បពិត្រលោកឪពុក បើដូច្នោះ សូមលោកឪពុកកាន់គ្រឿងបណ្ណាការបន្តិចបន្តួចនោះឯងមកចុះ ខ្ញុំទៅមុន ហើយឈរត្រង់ព្រះរាជសម្ងាត់ ទើបពោលថា ប្រពៃណាស់ កូន ហើយកាន់គ្រឿងបណ្ណាការទៅ ជាអ្នកដល់នូវភាពឧស្សាហ៍

ទៅកាន់រាជត្រកូល ក្នុងកាលដែលសោមទត្តឈរក្នុងរាជសម្នាក់ ជាអ្នកមាន ព្រះរាជបដិសណ្ឋារៈ ដែលព្រះរាជាមានព្រះហឫទ័យត្រេកអរ ទ្រង់ធ្វើហើយ កាលទ្រង់ត្រាស់ថា នែអ្នក អ្នកខានមកយូរហើយ នេះទីអង្គុយ ចូរអង្គុយ ហើយនិយាយចុះ អ្នកត្រូវការវត្ថុណា ទើបសូធ្យគាថានេះថា បពិត្រមហារាជ គោសម្រាប់ភ្ជួរស្រែរបស់ទូលបង្គំមានពីរ គោមួយស្លាប់ហើយ សូមទ្រង់កាន់ យកគោទីពីរវិញចុះ ។ កាលព្រះរាជាត្រាស់ថា នែអ្នក អ្នកពោលដូចម្តេច ចូរពោលម្តងទៀត ព្រាហ្មណ៍នោះ ក៏ពោលគាថានោះឯង ព្រះរាជាទ្រង់ជ្រាប ភាពដែលគាថានោះ ព្រាហ្មណ៍ពោលខុស ទ្រង់ញញឹមហើយ ត្រាស់ថា សោមទត្ត គោក្នុងផ្ទះរបស់អ្នក មានច្រើនឬ កាលសោមទត្តក្រាបទូលថា បពិត្រព្រះអង្គ គោទូលបង្គំ បើទ្រង់ព្រះរាជទានហើយ ទើបមានច្រើន ដូច្នេះ ហើយ ទ្រង់ប្រោសប្រាណសោមទត្តពោធិសត្វ ទើបព្រះរាជទានគោ ១៦ ដល់ព្រាហ្មណ៍ ទ្រព្យសម្បត្តិ គ្រឿងអលង្ការ និងផ្ទះដល់ពោធិសត្វនោះ ឲ្យ ជាព្រហ្មទេយ្យហើយ ទើបបញ្ជូនព្រាហ្មណ៍ទៅ ដោយយសធំ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ប្រជុំជាតកថា ស្តេចផែនដីក្នុងកាលនោះ បានជាអានន្ទ ព្រាហ្មណ៍ក្នុងកាលនោះ បានជា លោឡ្ឍទាយី មហាតលិកសោមទត្តក្នុងកាលនោះ ជាតថាគតនេះឯង ទើប ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោឡ្ឍទាយីនេះ កាលពាក្យដទៃដែលខ្ជិនគួរ ពោល ក៏បែរជាពោលពាក្យដទៃទៅវិញ មិនមែនតែក្នុងកាលឥឡូវនេះ ប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន លោឡ្ឍទាយីក៏ពោលហើយ ព្រោះភាពដែល

ខ្លួនមានធម៌បានស្តាប់តិច ព្រោះថា បុគ្គលមានសុតៈតិច ដូចគោបម្រើ ទើបត្រាស់ព្រះគាថាថា

អប្បស្សុតាយំ បុរិសោ ពលិពទ្ទោវ ជីរតិ
មំសានិ តស្ស វឌ្ឍន្តិ បញ្ញា តស្ស ន វឌ្ឍតិ។

បុរសអ្នកមិនមានការចេះដឹងនេះ តែងចាស់ (ឥតអំពើ) ដូចគោបម្រើ សាច់របស់វា តែងចម្រើនឡើង តែប្រាជ្ញារបស់វាមិនចម្រើនឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បស្សុតាយំ** បុគ្គលឈ្មោះថា អប្បស្សុតៈ ព្រោះមានពួកសូត្រ ៥០ មួយពួក ឬពីរពួក ឬព្រោះមិនមានវគ្គនៃសូត្រមួយវគ្គ ឬពីរវគ្គ ដោយកំណត់តិចបំផុត ព្រោះមិនមានសូត្រមួយ ឬពីរសូត្រ តែបានរៀនកម្មដ្ឋានតិចតួច ប្រកបព្យាយាមរឿយៗ ក៏ជាពហុសូតបាននោះឯង ។

ពីរបទថា **ពលិពទ្ទោវ ជីរតិ** សេចក្តីថា ដូចគោបម្រើ កាលចាស់ គឺកាលជរា រមែងធំឡើងដើម្បីប្រយោជន៍ដល់គោមេ មិនជាប្រយោជន៍ដល់គោឈ្មោលឡើយ គោដែលជាបងប្អូនដ៏សេស ក៏មិនមានប្រយោជន៍ដូចគ្នាដោយពិត ចាស់មិនមានប្រយោជន៍ឡើយ យ៉ាងណា សូម្បីអប្បស្សុតជននេះ មិនធ្វើឧបជ្ឈាយវត្ត មិនធ្វើអាចរិយវត្ត មិនធ្វើវត្តដទៃ មានអាគន្តុកវត្តជាដើម មិនប្រកបព្យាយាម សូម្បីត្រឹមតែការនា ឈ្មោះថា រមែងចាស់មិនមានប្រយោជន៍ ដូច្នោះឯង ។

បាទព្រះគាថាថា **មំសានិ តស្ស វឌ្ឍន្តិ** អធិប្បាយថា សាច់របស់គោ បម្រើដែលម្ចាស់គិតថា អានេះ មិនអាចអូសនឹមជាដើមបាន លែងឲ្យស៊ីក្នុងព្រៃ ដើរស៊ី ដើរផឹកក្នុងព្រៃនោះឯង រមែងចម្រើនយ៉ាងណា សាច់របស់អ្នកចេះដឹងតិចនេះដែលព្រះគរុដ្ឋានិយ: មានឧបជ្ឈាយ៍ជាដើមបោះបង់ចោលហើយ អាស្រ័យសង្ឆបានបច្ចុ័យ ៤ ធ្វើសរីរកិច្ចមានបញ្ចុះផ្ទៃជាដើម ចិញ្ចឹមកាយ រមែងចម្រើន គឺរមែងមានរាងកាយធាត់ត្រាច់ទៅ ដូច្នោះ ។

ពីរបទថា **បញ្ញា តស្ស** សេចក្តីថា ចំណែកបញ្ញា ដែលជាលោកិយ និងលោកុត្តររបស់អប្បស្សុតជននោះ សូម្បីមានប្រមាណមួយអង្គុលី ក៏មិន ចម្រើន តែតណ្ហា និងមានះ ៩ យ៉ាង រមែងចម្រើន ព្រោះអាស្រ័យទ្វារ ៦ ដូចគុម្ពស្មៅ លតាវល្ជ៍ជាដើម ចម្រើនក្នុងព្រៃ ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងព្រះលោឡុធាយិត្តេរ ចប់

រឿង បឋមពោធិកាល

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងមណ្ឌលពោធិព្រឹក្ស ទ្រង់បន្ទឹមទាន ដោយអំណាចសោមនស្ស ក្នុងសម័យជង្រៃ ព្រះអានន្ទទូលសួរ ទើបត្រាស់ព្រះធម្មទេសនានេះថា **អនេកជាតិសង្សារំ** ជាដើម ។

ព្រះសម្មាសម្ពុទ្ធអង្គនោះឯង ប្រថាប់គង់ក្នុងមណ្ឌលពោធិព្រឹក្ស កាលព្រះអាទិត្យមិនទាន់អស្តង្គត ទ្រង់កម្ចាត់មារ និងពលហើយ ក្នុងបឋមយាម ទ្រង់ទម្លាយឆទីតដែលបិទបាំងបុព្វេនិវាសញ្ញាណ ។ ក្នុងមជ្ឈិមយាម ទ្រង់ជម្រះទិព្វចក្ខុឲ្យបរិសុទ្ធហើយ ក្នុងបច្ឆិមយាម ទ្រង់អាស្រ័យសេចក្តីករុណាក្នុងពួកសត្វ ទ្រង់ញុំាងព្រះញាណឲ្យចុះក្នុងបច្ចយាការហើយ ទ្រង់ពិចារណាបច្ចយាការនោះដោយអំណាចនៃអនុលោម បដិលោម ។ ក្នុងវេលាអរុណរះ ទ្រង់សម្រេចព្រះសម្មាសម្ពោធិញ្ញាណ មួយអន្ទឹងដោយភាពអស្ចារ្យច្រើនយ៉ាង កាលទ្រង់បន្ទឹមទាន ដែលព្រះពុទ្ធមិនមែនមួយសែន ទ្រង់មិនលះបង់ហើយ ទើបត្រាស់ព្រះគាថាទាំងនេះថា

អនេកជាតិសង្សារំ សន្ធាវិស្សំ អនិព្ពិសំ
គហាការកំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហាការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហាកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

កាលតថាគត មិនទាន់បានជួបប្រទះ (ពោធិញ្ញាណ រាល់តែ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិជ័ច្រើន សេចក្តីកើតជាទុក្ខរឿយៗ ។ នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ (របស់តថាគត) ទៀត មិនបានឡើយ ឆ្អឹងជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគតដល់ព្រះនិព្វាន ដែលមានសង្ខារក្រោសហើយ តថាគតបានដល់ធម៌ជាគ្រឿងក្សយតណ្ហាទាំងឡាយហើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **គហការំ គវេសន្តោ** *សេចក្តីថា តថាគតកាលស្វែងរកជាង គឺតណ្ហាអ្នកធ្វើផ្ទះ ពោល គឺអត្តភាពនេះ កាលអកិនីហារដែលធ្វើហើយ ទៀបបាទមូលនៃព្រះសម្ពុទ្ធព្រះនាមទីបង្ករ ដើម្បីជាប្រយោជន៍ដល់ព្រះញាណ ដែលជាធម្មជាតអាចឃើញនាយជាងនោះបាន គឺព្រះពោធិញ្ញាណ កាលមិនប្រសព្វ មិនជួប គឺមិនបានទូវព្រះញាណនោះឯង ទើបអន្ទោល គឺស្ទុះ បានដល់ វិលវល់ទៅមកកាន់សង្សារ មានជាតិមិនតែមួយ គឺកាន់សង្សារវដ្តនេះ ដែលរាប់បានច្រើនសែនជាតិ អស់កាល មានប្រមាណប៉ុណ្ណេះ ។*

ពាក្យថា **ទុក្ខា ជាតិ បុនប្បុនំ** នេះ ជាពាក្យសម្តែងហេតុនៃការស្វែងរកជាងដែលធ្វើផ្ទះ ។ ព្រោះ ឈ្មោះថា ជាតិនេះ គឺការចូលដល់រឿយៗ ឈ្មោះថា ជាទុក្ខ ព្រោះភាវៈដែលលាយឡំដោយជរា ព្យាធិ និងមរណៈ ជាតិនោះ កាលនាយជាងដែលធ្វើផ្ទះនោះ ដែលបុគ្គលណាម្នាក់មិនជួបហើយ រមែងមិនត្រឡប់ ដូច្នោះ កាលតថាគតស្វែងរកជាងធ្វើផ្ទះ ទើបអន្ទោលទៅ ។

បទថា **ធិដ្ឋោសិ** សេចក្តីថា ឥឡូវនេះ តថាគតត្រាស់ដឹងនូវសព្វញ្ញុ-តញ្ញាណ ជួបអ្នកពិតប្រាកដ ។ បទថា **បុន គេហំ** សេចក្តីថា អ្នកនឹងធ្វើផ្ទះ របស់តថាគត ពោល គឺអត្តភាពក្នុងសង្សារវដ្តនេះទៀត មិនបានឡើយ ។

បាទព្រះគាថាថា **សព្វា តេ ជាសុកា ភគ្គា** សេចក្តីថា ឆ្អឹងជំនីរ ពោល គឺកិលេសដ៏សេសទាំងអស់របស់អ្នក តថាគតបានកាច់ចោលហើយ ។

បាទព្រះគាថាថា **គហកូដំ វិសង្ខតំ** សេចក្តីថា សូម្បីមណ្ឌលមេដំបូល ពោល គឺអវិជ្ជានៃផ្ទះ គឺអត្តភាព ដែលអ្នកសាងហើយនេះ តថាគតក៏រើ ចេញហើយ ។

បាទព្រះគាថាថា **វិសង្ខារគតំ ចិត្តំ** សេចក្តីថា ឥឡូវនេះ ចិត្តរបស់ តថាគតចូលដល់ គឺចូលទៅដល់ធម៌ប្រាសចាកគ្រឿងតាក់តែងហើយ គឺព្រះ និព្វាន ដោយអំណាចធ្វើឲ្យជាអារម្មណ៍ ។

បាទព្រះគាថាថា **តណ្ហានំ ឧយមជ្ឈគា** សេចក្តីថា តថាគតសម្រេច អរហត្ត ពោល គឺធម៌ជាទីអស់ទៅនៃតណ្ហាហើយ ។

រឿង បឋមពោធិកាល ចប់

រឿង សេដ្ឋីបុត្រមានទ្រព្យច្រើន

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងព្រៃឥសិបតនមិគទាយវន ទ្រង់ប្រារព្ធ សេដ្ឋីបុត្រអ្នកមានទ្រព្យច្រើន ត្រាស់ព្រះធម្មទេសនានេះថា **អចិរិត្វា ព្រហ្ម-ចិរិយំ** ជាដើម ។

បានឲ្យមកថា សេដ្ឋីបុត្រនោះកើតហើយក្នុងត្រកូលមានសម្បត្តិ ៨០ កោដិ ក្នុងក្រុងពារាណសី កាលនោះ មាតាបិតារបស់សេដ្ឋីបុត្រនោះ គិតថា ក្នុងត្រកូលរបស់យើង មានគំនរភោគៈច្រើន យើងនឹងប្រគល់គំនរភោគៈនោះ ក្នុងដៃកូនរបស់យើង ធ្វើឲ្យប្រើប្រាស់យ៉ាងសប្បាយ កិច្ចដោយការងារដទៃ មិនចាំបាច់មាន ដូច្នេះហើយ ទើបឲ្យកូនសិក្សាសិប្បៈត្រឹមតែការរាំច្រៀង និងប្រគំតែម្យ៉ាង ។ ក្នុងនគរនោះឯង មានធីតាសេដ្ឋីម្នាក់ កើតហើយក្នុងត្រកូលដទៃ មានសម្បត្តិ ៨០ កោដិ មាតាបិតារបស់នាងក៏គិតហើយយ៉ាងនោះដូចគ្នា ហើយក៏ឲ្យនាងសិក្សាត្រឹមតែសិប្បៈរាំ ច្រៀង និងប្រគំតែម្យ៉ាង កាលជនទាំងពីរចម្រើនវយហើយ បានធ្វើអាវាហវិវាហមង្គលជាមួយគ្នា ក្នុងកាលក្រោយមក ឪពុកម្តាយជនទាំងពីរនោះអនិច្ចកម្មហើយ ទ្រព្យ ១៦០ កោដិ ក៏បានរួមគ្នាក្នុងផ្ទះតែមួយ ។ សេដ្ឋីនោះទៅកាន់ទីបម្រើព្រះរាជាមួយថ្ងៃ ៣ ដង កាលនោះពួកអ្នកលេងក្នុងព្រះនគរនោះគិតគ្នាថា បើសេដ្ឋីបុត្រនេះក្លាយជាអ្នកលេងសុរា ផាសុកនឹងមានដល់ពួកយើង យើងនឹងបង្រៀនបុរសនេះឲ្យក្លាយជាអ្នកលេងសុរា ។ ទើបពួកអ្នកលេងនោះកាន់យកសុរា ចងសាច់សម្រាប់ក្លែម និង

ជុំអំបិលត្រង់ជាយថ្នក់ កាន់មើមស្ពៃ អង្គុយមើលផ្លូវសេដ្ឋីបុត្រនោះ ដែលមកអំពីរាជត្រកូល ឃើញបុរសនោះដើរមក ទើបផឹកសុរា យកជុំអំបិលជាក់ក្នុងមាត់ ទំពាមើមស្ពៃ ពោលថា លោកសេដ្ឋី ចូរវស់នៅមួយរយឆ្នាំចុះ ពួកខ្ញុំអាស្រ័យលោក ទើបអាចក្នុងការទំពា និងការផឹក ។

សេដ្ឋីបុត្រ ស្តាប់ពាក្យអ្នកលេងនោះហើយ ទើបសួរអ្នកបម្រើជិតស្និទ្ធ ដែលមកតាមក្រោយថា ជនទាំងនោះផឹកអ្វី អ្នកបម្រើជ្រាប់ថា ផឹកទឹកប្រកេទម្យ៉ាង សេដ្ឋីបុត្រសួរថា មានរសជាតិឆ្ងាញ់ឬ អ្នកបម្រើជ្រាប់ថា បពិត្រលោកម្ចាស់ ធម្មតាទឹកដែលគួរផឹកដូចគ្នានឹងទឹកនេះ មិនមានក្នុងលោកដែលវស់នៅនេះ ។ សេដ្ឋីបុត្រនោះពោលថា បើដូច្នេះ ខ្ញុំផឹកក៏គួរ ដូច្នេះហើយ ទើបឲ្យយកមកបន្តិចហើយក៏ផឹក តមកមិនយូរប៉ុន្មាន អ្នកលេងទាំងនោះដឹងថា សេដ្ឋីនោះផឹក ទើបនាំគ្នាចោមរោមសេដ្ឋីបុត្រនោះ ក្នុងកាលកន្លងទៅ ក៏មានបរិវារធំ ។ សេដ្ឋីបុត្រនោះឲ្យនាំសុរាមកដោយទ្រព្យ ១០០ ខ្លះ ២០០ ខ្លះផឹក តាំងគំនរកហាបណៈក្នុងទីអង្គុយជាដើមដោយលំដាប់ ផឹកសុរា ពោលថា ចូរនាំយកផ្លាមកដោយកហាបណៈនេះ ចូរនាំយកគ្រឿងក្រអូបមកដោយកហាបណៈនេះ បុគ្គលនេះឈ្លាសក្នុងការច្រៀង បុគ្គលនេះឈ្លាសក្នុងការរាំ បុគ្គលនេះឈ្លាសក្នុងការប្រគំ ចូរឲ្យទ្រព្យមួយពាន់ដល់បុគ្គលនេះ ចូរឲ្យទ្រព្យពីរពាន់ដល់បុគ្គលនេះ ។ កាលខ្លះខ្លាយយ៉ាងនោះ ក្នុងកាលមិនយូរប៉ុន្មាន ក៏ញ៉ាំងទ្រព្យ ៨០ កោដិ ដែលជារបស់ខ្លួនឲ្យអស់ទៅហើយ កាលហិរញ្ញិកជ្រាប់ថា បពិត្រលោកម្ចាស់ ទ្រព្យរបស់លោកម្ចាស់អស់ហើយ ទើបពោលថា ទ្រព្យរបស់ភរិយាខ្ញុំ

នៅមានឬ កាលគេប្រាប់ថា នៅមាន ទើបប្រាប់ថា បើដូច្នោះ ចូរយកទ្រព្យ នោះមក បានញុំាងទ្រព្យនោះឲ្យអស់ទៅហើយយ៉ាងនោះដូចគ្នា ហើយលក់ សម្បត្តិរបស់ខ្លួនទាំងអស់ គឺស្រែ សួនផ្កា ចម្ការ យានពាហនៈជាដើម ដោយ ហោច ភាជនៈជាគ្រឿងប្រើប្រាស់ កម្រាល សំពត់ដណ្តប់ និងសំពត់ក្រាល អង្គុយ ដោយលំដាប់ ហើយទំពាស៊ី ។

ក្នុងកាលដែលគាត់ចាស់ ទើបម្ចាស់ផ្ទះដេញចេញអំពីផ្ទះ ដែលបុរសនោះ មានភោគៈអស់ហើយ លក់ផ្ទះរបស់ខ្លួនដែលធ្លាប់អាស្រ័យនៅ នាំភរិយាទៅ អាស្រ័យសំយាបផ្ទះរបស់អ្នកជនៃ កាន់អំបែងត្រាច់ទៅសូមទាន ប្រារព្ធនឹង បរិភោគកត្តិ ដែលជាសំណល់របស់ពួកជនហើយ ។ កាលនោះ ព្រះសាស្តា ទតឃើញបុរសនោះឈរត្រង់ទ្វារភោងធាន់ រង់ចាំទទួលភោជនដែលសល់អំពី ភិក្ខុកំលោះ និងសាមណេរឲ្យក្នុងថ្ងៃមួយ ទើបទ្រង់ញញឹម ។ លំដាប់នោះ ព្រះអានន្ទទូលសួរដល់ហេតុដែលទ្រង់ញញឹម ។ ព្រះសាស្តា កាលនឹងត្រាស់ ប្រាប់ហេតុដែលទ្រង់ញញឹម ទើបត្រាស់ថា ម្នាលអានន្ទ ចូរអ្នកមើលបុត្រ សេដ្ឋីដែលមានទ្រព្យច្រើននេះ បំផ្លាញទ្រព្យអស់ ១៦០ កោដិ នាំភរិយាដើរ សូមទាន នៅក្នុងនគរនេះឯង បើសេដ្ឋីបុត្រនេះមិនបំផ្លាញទ្រព្យអស់ ប្រកប ការងារក្នុងបឋមវ័យ ក៏នឹងបានជាសេដ្ឋីដ៏កំពូលក្នុងនគរនេះឯង បើចេញបួស នឹងសម្រេចអរហត្ត ភរិយារបស់បុរសនេះ នឹងតាំងនៅក្នុងអនាគាមិផល បើ មិនបំផ្លាញទ្រព្យឲ្យអស់ទៅ នឹងប្រកបការងារក្នុងមជ្ឈិមវ័យ នឹងបានជាសេដ្ឋី លំដាប់ទីពីរ ចេញបួស នឹងបានជាអនាគាមី ភរិយានឹងតាំងនៅក្នុងសកទា-

គាមិផល បើមិនបំផ្លាញទ្រព្យឲ្យអស់ទៅ ប្រកបការងារក្នុងបច្ចិមវ័យ នឹងបានជាសេដ្ឋីលំដាប់ទីបី ចេញបួស នឹងបានសកទាគាមី ភរិយារបស់គេនឹងតាំងនៅក្នុងសោតាបត្តិផល តែឥឡូវនេះ កូនសេដ្ឋីនោះ វិនាសហើយចាកកោគៈរបស់គ្រហស្ថ វិនាសហើយចាកសាមញ្ញផល កាលវិនាសហើយ ទើបដូចជាក្រៀលក្នុងកក់ស្ងួត ដូច្នេះហើយ ទើបទ្រង់ត្រាស់ព្រះគាថានេះថា

អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ
ជិណ្ណាកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្វលេ ។
អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ
សេន្តិ ចាចាតិខីណាវ បុរាណាធិ អនុត្តុនំ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលខ្លួននៅជាកំលោះក្រមុំ រមែងសញ្ជប់សញ្ជឹងដូចសត្វក្រៀលចាស់សំកុកនៅក្នុងកក់ដែលអស់ត្រីហើយ ។ ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យក្នុងកាលខ្លួននៅកំលោះក្រមុំ រមែងដេកថ្ងូរសោកស្តាយទ្រព្យចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែបន្ទោះ ដូច្នោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អចរិត្វា** *សេចក្តីថា មិននៅក្នុងព្រហ្មចរិយាវាស ។ បទថា* **យោព្វនេ** *សេចក្តីថា មិនបានសូម្បីទ្រព្យក្នុងកាលដែលខ្លួនអាចញុំងកោគៈដែលមិនកើតឲ្យកើតឡើង ឬដើម្បីតាមរក្សាកោគៈដែលកើត*

ឡើងហើយ ។ បទថា **ខីណាមច្ចេ** *សេចក្តីថា បុគ្គលល្ងង់ខ្លៅបែបនោះ តែង សោកសៅដូចសត្វក្រៀលចាស់ មានរោមជ្រុះអស់ សោកសៅនៅក្នុងកក់ដែល ឈ្មោះថាអស់ត្រីហើយ ព្រោះមិនមានទឹក អធិប្បាយថា លោកពោលដូច្នេះ ថា ឯការមិនមានលំនៅរបស់បុគ្គលល្ងង់ខ្លៅទាំងនេះ ដូចការមិនមានទឹកក្នុងកក់ ព្រោះមិនមានភោគៈរបស់បុគ្គលល្ងង់ខ្លៅទាំងនេះ ដូចការអស់ត្រី ការមិនអាច រួបរួមភោគៈបានដោយផ្លូវគោក ឬផ្លូវទឹកជាដើម ក្នុងកាលឥឡូវនេះឯងរបស់ បុគ្គលល្ងង់ខ្លៅទាំងនេះ ដូចការមិនមានការផុសឡើង ហើយហើរទៅនៃសត្វ ក្រៀលដែលមានរោមស្វាបជ្រុះ ព្រោះដូច្នោះ បុគ្គលល្ងង់ខ្លៅទាំងនេះ ទើប ដេកសោកសៅក្នុងទីនេះឯង ដូចសត្វក្រៀលមានរោមស្វាបជ្រុះហើយដូច្នោះ ។*

បទថា **ចាចាតិខីណាវ** *សេចក្តីថា របូតចាកបន្ទោះ គឺផុតចាកបន្ទោះ មានពាក្យអធិប្បាយដូច្នេះថា ព្រួញផុតចាកបន្ទោះ ទៅតាមកម្លាំងធ្លាក់ហើយ កាលមិនមានបុគ្គលណាចាប់លើកឡើង ព្រួញនោះក៏ត្រូវក្លាយជាអាហាររបស់ កណ្តៀរក្នុងទីនោះឯង យ៉ាងណា បុគ្គលល្ងង់ខ្លៅទាំងនេះ ក៏ដូច្នោះ កន្ទងវ័យ ទាំង ៣ ទៅហើយ ក៏នឹងចូលដល់មរណៈ ព្រោះការមិនអាចលើកខ្លួនឡើង បានក្នុងកាលឥឡូវនេះ ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា* **សេដ្ឋិ ចាចាតិខីណាវ ។**

បានព្រះគាថាថា **បុរាណានិ អនុត្តុនំ** *សេចក្តីថា រមែងដេកសំកុក គឺ

សោកសៅដល់ការបរិភោគ ការផឹក ការរាំ ការច្រៀង និងការប្រគំជាដើម ដែលខ្ជួនធ្វើហើយក្នុងកាលមុនថា ពួកយើងស៊ីហើយយ៉ាងនេះ ផឹកហើយយ៉ាងនេះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងសេដ្ឋីបុត្រមានទ្រព្យច្រើន ចប់

ជរាវគ្គ ចប់

វគ្គទី ១១ ចប់

សុត្តន្តបិដក

ធម្មបទគាថា អត្តវគ្គទី ១២

[២២] បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួរតែរក្សាខ្លួននោះឲ្យល្អ គួរស្ងួនគ្រង់ខ្លួនទុកក្នុងវ័យទាំង ៣ វ័យណាមួយ ។

បណ្ឌិត គួរតម្កល់ខ្លួនទុកក្នុងគុណ ដ៏សមគួរជាមុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃ ជាខាងក្រោយ (ធ្វើយ៉ាងនេះ) នឹងមិនលំបាកឡើយ ។

បុគ្គលប្រៀនប្រដៅអ្នកដទៃ យ៉ាងណា ត្រូវធ្វើខ្លួនឲ្យបានយ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនកម្រទូន្មានបានពេកណាស់ ។

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។

បាប កើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញីមនុស្សឥតប្រាជ្ញា ដូចពេជ្រសម្រាប់កែវមណី ដែលកើតអំពីថ្ម ដូច្នោះឯង ។

កាពជាអ្នកទ្រុស្តសីលហួសហេតុ គ្របសង្កត់ (នូវអត្តភាព) របស់បុគ្គលណា ដូចវល្លីដែលរួបរឹតដើមឈើ បុគ្គលនោះ ឈ្មោះថា ធ្វើខ្លួនឯងឲ្យវិនាស ដូចជាចោរអ្នកប្រាថ្នាធ្វើបុគ្គលនោះឲ្យវិនាស ដូច្នោះ ។

កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះ ដែលជនពាលធ្វើបានដោយងាយ កម្មណាជាប្រយោជន៍ផង ល្អផង កម្មនោះឯង ដែលជនពាលធ្វើបានដោយលំបាក ។

បុគ្គលណា អប្បញ្ញា អាស្រ័យទិដ្ឋិដ៏លាមក ហាមឃាត់សាសនា របស់ព្រះអរហន្តទាំងឡាយដ៏ប្រសើរ រស់នៅដោយធម៌ ការហាមឃាត់របស់ បុគ្គលនោះ រមែងចេញផល ដើម្បីសម្លាប់ខ្លួន ដូចផ្លែឫស្សី ដូច្នោះ ។

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធ មានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃ ឲ្យបរិសុទ្ធពុំបានទេ ។

បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្ជាប់ខ្ជួនក្នុងប្រយោជន៍របស់ខ្លួន (នោះ) ។

អត្តវគ្គទី ១២ ចប់

អដ្ឋកថា

អត្តវគ្គទី ១២

រឿង ពោធិរាជកុមារ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងកេសកទ្បាវន ទ្រង់ប្រារព្ធពោធិរាជកុមារ ត្រាស់ព្រះធម្មទេសនានេះថា **អត្តានញ្ចេ** *ជាដើម ។*

បានឮមកថា ពោធិរាជកុមារឲ្យសាងប្រាសាទ ឈ្មោះកោកនទៈ មានទ្រង់ទ្រាយមិនដូចប្រាសាទដទៃៗ លើផែនដី តែមានរាងដូចអណ្តែតនៅក្នុងអាកាសហើយ ត្រាស់សួរជាងថា ប្រាសាទដែលមានរូបរាងយ៉ាងនេះ អ្នកធ្លាប់សាងក្នុងទីដទៃខ្លះហើយឬ ឬថា នេះជាសិប្បៈដំបូងរបស់អ្នក កាលមេជាងទូលថា បពិត្រព្រះសម្មតិទេព នេះជាសិប្បៈដំបូងនោះឯង ព្រះរាជាទ្រង់ព្រះតម្រិះថា បើមេជាងនេះសាងប្រាសាទ ដែលមានទ្រង់ទ្រាយបែបនេះដល់អ្នកដទៃសោត ប្រាសាទនេះក៏មិនគួរអស្ចារ្យ កាលដែលអញសម្លាប់មេជាងនេះចោល កាត់ដៃកាត់ជើង ឬខ្វេះភ្នែកទាំងពីរ រមែងគួរ កាលបើដូច្នោះ មេជាងនេះសាងប្រាសាទដល់អ្នកដទៃមិនបាន ព្រះរាជាប្រាប់សេចក្តីនោះដល់មាណពតូច កូនរបស់សញ្ជីវកៈ ដែលជាសម្លាញ់ជិតស្និទ្ធរបស់ខ្លួន ។

មាណពតូចនោះ គិតថា ព្រះរាជកុមារអង្គនេះ បំផ្លាញមេជាងឲ្យវិនាស

ដោយឥតសង្ស័យ មនុស្សដែលមានសិប្បៈកាត់ថ្លៃមិនបាន បើអញនៅមានចូរបុគ្គលនោះកុំវិនាសឡើយ អញនឹងឲ្យសញ្ញាដល់មេជាងនេះ ។ មាណពតូចចូលទៅរកមេជាងហើយសួរថា ការងាររបស់អ្នកឯប្រាសាទ សម្រេចហើយឬនៅ កាលមេជាងប្រាប់ថា សម្រេចហើយ ទើបពោលថា ព្រះរាជកុមារមានបំណងនឹងបំផ្លាញអ្នកឲ្យវិនាស ព្រោះដូច្នោះ អ្នកគប្បីរក្សាខ្លួនឲ្យល្អ ។

មេជាងពោលថា នែអ្នក អ្នកប្រាប់សេចក្តីនោះដល់ខ្ញុំ ធ្វើសុចរិតកម្មហើយ ខ្ញុំនឹងដឹងកិច្ចដែលគួរធ្វើក្នុងរឿងនេះ ដូច្នេះហើយ កាលព្រះរាជកុមារត្រាស់សួរថា សម្ងាញ់ ការងាររបស់អ្នកត្រង់ប្រាសាទរបស់យើង សម្រេចហើយឬ ទើបទូលថា បពិត្រព្រះសម្មតិទេព ការងារត្រង់ប្រាសាទមិនទាន់សម្រេចនៅឡើយ នៅសល់ច្រើនទៀត ។ ព្រះរាជកុមារសួរថា ការងារអ្វីដែលនៅសល់ ជាងទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គនឹងទូលក្នុងកាលជាក្រោយ សូមទ្រង់ត្រាស់ឲ្យបុគ្គលណាម្នាក់ ជញ្ជូនឈើមកសិនចុះ ព្រះរាជកុមារត្រាស់សួរថា នឹងឲ្យជញ្ជូនឈើប្រភេទណាមក មេជាងទូលថា បពិត្រព្រះអង្គ ឈើស្តួតមិនមានខ្ចីម ។

ព្រះរាជាបានឲ្យជញ្ជូនមកហើយ ។ លំដាប់នោះ មេជាងទូលព្រះរាជ-កុមារនោះថា បពិត្រព្រះសម្មតិទេព ចាប់តាំងអំពីនេះទៅ ទ្រង់មិនចាំបាច់យាងមកកាន់សម្នាក់របស់ទូលបង្គំឡើយ ព្រោះកាលទូលបង្គំធ្វើការងារល្អិតល្អន់ បើមានការសន្ទនានឹងអ្នកដទៃ ការរាយមាយក៏គប្បីមាន ម្យ៉ាងទៀតពេលទទួលទានអាហារ ភរិយាទូលបង្គំប៉ុណ្ណោះនឹងនាំអាហារមក ។ ព្រះរាជ-

កុមារទ្រង់ទទួលថា សាធុ ចំណែកជាងនោះ ចាំងឈើទាំងនោះក្នុងបន្ទប់មួយ ធ្វើជាសត្វគ្រុឌ គួរដល់បុត្រភរិយារបស់ខ្លួនអង្គុយខាងក្នុងបាន ក្នុងពេលទទួលទានអាហារ ប្រាប់ភរិយាថា ចូរនាងលក់របស់គ្រប់យ៉ាងក្នុងផ្ទះហើយទទួលយកប្រាក់ និងមាស ។

ចំណែកព្រះរាជកុមារគ្រាស់ឲ្យពន្ធផ្ទះ ទ្រង់រៀបចំការរក្សា ដើម្បីជាប្រយោជន៍កុំឲ្យមេជាងចេញទៅបាន ។ មេជាង ក្នុងកាលដែលបក្សីសម្រេចហើយ ប្រាប់ភរិយាថា ថ្ងៃនេះនាងគប្បីនាំកូនទាំងអស់មក ទទួលទានអាហារព្រឹកស្រេចហើយ ឲ្យបុត្រ និងភរិយាអង្គុយក្នុងពោះគ្រុឌ ចេញតាមបង្អួចលួចគេចទៅហើយ កាលអ្នករក្សាទាំងនោះទូលរៀបរាប់ថា បពិត្រព្រះសម្ម-តិទេព មេជាងលបគេចទៅបាន ដូច្នេះនោះឯង ជាងនោះក៏ទៅចុះត្រង់ហិម-វន្តបទេស សាងនគរមួយបានជាព្រះរាជា ព្រះនាមកដ្ឋវាហនៈក្នុងនគរនោះ ។

ចំណែកព្រះរាជកុមារ ទ្រង់ព្រះតម្រិះថា អញធ្វើការឆ្លងប្រាសាទ ទើបឲ្យនិមន្តព្រះសាស្តា ទ្រង់ធ្វើការប្រោះព្រំក្នុងប្រាសាទ ដោយគ្រឿងគន្ធជាតិ ៤ យ៉ាង ទ្រង់ក្រាលកម្រាលតូចតាំងអំពីធរណីទ្វារទីមួយ បានឮថា ព្រះរាជាមិនមានព្រះឱរស ព្រោះដូច្នោះ ទើបទ្រង់ព្រះតម្រិះថា បើអញបានបុត្រឬធីតាសោត ព្រះសាស្តានឹងជាន់សំពត់តូចនេះ ហើយទើបទ្រង់ក្រាល ។ ព្រះរាជា កាលព្រះសាស្តាយាងមក ថ្វាយបង្គំហើយ ដោយបញ្ចង្គប្រតិស្ឋានទទួលបាត្រ ក្រាបទូលថា សូមនិមន្តទ្រង់យាងចូលចុះ ព្រះសាស្តាមិនយាងចូល ព្រះរាជាទ្រង់និមន្តអស់វារៈ ២-៣ ដង ព្រះសាស្តាក៏មិនយាងចូលទៅ

ទ្រង់មើលព្រះអានន្ទ ។

ព្រះថេរៈ ជ្រាបការដែលទ្រង់មិនជាន់សំពត់ទាំងឡាយ ដោយសញ្ញាដែលទ្រង់ទតនោះឯង ទើបទូលឲ្យព្រះរាជកុមារដកសំពត់ទាំងឡាយចេញដោយពាក្យថា មហាបពិត្រ សូមទ្រង់សាសំពត់ទាំងឡាយចេញចុះ ព្រះសាស្តាទ្រង់មិនជាន់សំពត់នេះទេ្បីយ ព្រោះព្រះតថាគតទ្រង់សម្លឹងមើលមហាជនដែលកើតឯក្រោយ ។

ព្រះរាជាទ្រង់ដកសំពត់ទាំងឡាយហើយ ទូលអារាធនាឲ្យទ្រង់ចូលទៅខាងក្នុង ទ្រង់អង្គាសឲ្យឆ្អែតស្កប់ស្កល់ដោយបបរ និងរបស់ទំពា ហើយគង់ក្នុងទីសមគួរនាចំណែកម្ខាង ថ្វាយបង្គំហើយទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គជាឧបដ្ឋាករបស់ទ្រង់ ដល់នូវទ្រង់ថាជាទីពឹងអស់វារៈ ៣ ដងហើយ បានឮថាព្រះរាជាកាលនៅក្នុងផ្ទៃ ដល់នូវសរណៈជាទីពឹងទីរឭកលើកទី ១ ក្នុងលើកទី ២ ក្នុងកាលដែលខ្ញុំព្រះអង្គជាកុមារ ក្នុងលើកទី ៣ ក្នុងកាលដែលខ្ញុំព្រះអង្គ ដល់នូវភាពជាអ្នកដឹងក្តី ទ្រង់មិនជាន់ផ្ងាំងសំពត់តូចរបស់ខ្ញុំព្រះអង្គនោះ ព្រោះហេតុអ្វី ។ ព្រះសាស្តាត្រាស់ថា ព្រះរាជកុមារ ទ្រង់ត្រិះរិះដូចម្តេច ទើបក្រាលផ្ងាំងសំពត់តូច ព្រះរាជកុមារត្រាស់ថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គគិតថា បើបានបុត្រ ឬធីតាសោត ព្រះសាស្តាទ្រង់នឹងជាន់ផ្ងាំងសំពត់តូចរបស់អញ ហើយទើបក្រាលផ្ងាំងសំពត់តូច ព្រះសាស្តាត្រាស់ថា ព្រះរាជ-កុមារ ព្រោះហេតុនោះ ទើបតថាគតមិនជាន់ ព្រះរាជកុមារទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនបានបុត្រ ឬធីតាទេឬ ព្រះសាស្តាត្រាស់ថា ព្រះរាជកុមារ

យ៉ាងនោះឯង ព្រះរាជកុមារត្រាស់ថា បពិត្រព្រះអង្គ ព្រោះហេតុអ្វី ព្រះសាស្តាត្រាស់ថា ព្រោះទ្រង់ និងព្រះជាយា ជាអ្នកដល់នូវសេចក្តីប្រមាទ ហើយ ក្នុងអតីតភពមុន ព្រះរាជកុមារត្រាស់ថា បពិត្រព្រះអង្គ ក្នុងកាលណា ។ លំដាប់នោះ ព្រះសាស្តា ទ្រង់នាំអតីតនិទានមកសម្តែងដល់ព្រះរាជកុមារនោះថា

បានឮមកថា ក្នុងអតីតកាល មនុស្សច្រើនរយនាក់ធ្វើដំណើរតាមទូកធំទៅកាន់សមុទ្រ ទូកក៏លិចកណ្តាលសមុទ្រ ស្វាមីភរិយាស្រីវាបានបន្ទុះក្តារមួយ ហែលទៅកាន់កោះតូចដែលមានក្នុងចន្លោះ មនុស្សដ៏សេសសល់ទាំងអស់ ក្នុងមហាសមុទ្រនោះឯង ។ ពួកបក្សីជាច្រើននៅត្រង់កោះនោះឯង ជនទាំងពីរមិនឃើញវត្តុដទៃដែលគួរបរិភោគបាន ត្រូវសេចក្តីឃ្លានគ្របសង្កត់ហើយ ទើបដុតស៊ុតបក្សីទាំងឡាយត្រង់រងើកភ្លើង ហើយបរិភោគ កាលស៊ុតបក្សីទាំងនោះ មិនគ្រប់គ្រាន់ ក៏ចាប់កូនបក្សីទាំងឡាយអាំងបរិភោគ កាលកូនបក្សីទាំងនោះ មិនគ្រប់គ្រាន់ ក៏ចាប់មេបក្សីទាំងឡាយបរិភោគ ក្នុងបឋម-វ័យក្តី មជ្ឈិមវ័យក្តី បច្ឆិមវ័យក្តី បានទំពាស៊ីយ៉ាងនោះឯង ក្នុងថ្ងៃមួយ ក៏មិនបានដល់នូវការមិនប្រមាទ ម្យ៉ាងទៀត បណ្តាជនទាំងពីរនោះ សូម្បីបុគ្គលម្នាក់ ក៏មិនបានដល់នូវសេចក្តីមិនប្រមាទ ។

ព្រះសាស្តា កាលទ្រង់សម្តែងបុព្វកម្មនេះរបស់ពោធិរាជកុមារនោះហើយ ត្រាស់ថា ព្រះរាជកុមារ ក្នុងកាលនោះ បើទ្រង់ និងមហេសីដល់នូវការមិនប្រមាទ សូម្បីក្នុងវ័យមួយសោត បុត្រ ឬធីតាគប្បីកើតឡើង ក្នុងវ័យណា

មួយ បើបណ្តាអ្នកទាំងពីរ អ្នកណាម្នាក់ជាអ្នកមិនប្រមាទហើយសោត បុត្រ ឬធីតា នឹងអាស្រ័យបុគ្គលមិនប្រមាទនោះកើតឡើង ម្នាលព្រះរាជកុមារ បុគ្គល កាលសម្គាល់ខ្លួនថាជាទីស្រឡាញ់ គប្បីមិនប្រមាទ រក្សាខ្លួនក្នុងវ័យទាំង ៣ បើមិនអាចយ៉ាងនោះ គប្បីរក្សាឲ្យបានក្នុងវ័យណាមួយ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណំ អញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។

បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឲ្យល្អ គួរស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំង ៣ វ័យណាមួយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យាមំ** *នេះ ព្រះសាស្តាទ្រង់សម្តែងធ្វើវ័យទាំង ៣ វ័យណាមួយ ឲ្យឈ្មោះថា ជាយាម ព្រោះភាពដែលទ្រង់ជាធំក្នុងធម៌ និងព្រោះភាពដែលទ្រង់ឈ្វាសក្នុងទេសនាវិធី ព្រោះហេតុនោះ ក្នុងព្រះគាថានេះ បណ្ឌិតគប្បីជ្រាបសេចក្តីយ៉ាងនេះថា បើបុគ្គលដឹងថា ខ្លួនជាទីស្រឡាញ់ គប្បីរក្សាខ្លួននោះឲ្យជាការរក្សាល្អហើយ គឺគប្បីរក្សាខ្លួននោះដោយប្រការដែលខ្លួនរក្សាល្អហើយ ។*

បណ្តាជនដែលរក្សាខ្លួនទាំងនោះ បើបុគ្គលជាគ្រហស្ថគិតថា នឹងរក្សាខ្លួន ដូច្នេះហើយ ចូលទៅកាន់បន្ទប់ដែលគេបិទឲ្យរៀបរយ ជាបុគ្គលមានការរក្សាបរិបូណ៌ ឡើងលើផ្ទៃប្រាសាទជាន់លើក្តី បុគ្គលជាបព្វជិត នៅក្នុង

គុហាដែលបិទល្អល្អិត មានទ្វារ និងបង្អួចបិទល្អហើយក្តី មិនឈ្មោះថា រក្សាខ្លួនឡើយ តែបុគ្គលជាគ្រហស្ថធ្វើបុណ្យទាំងឡាយ មានឲ្យទាន រក្សាសីលជាដើមតាមកម្លាំង ឬដែលជាបព្វជិត ដល់នូវការខ្វល់ខ្វាយក្នុងវត្ត បដិវត្ត បរិយត្តិ និងការធ្វើទុកក្នុងចិត្ត ឈ្មោះថា រមែងរក្សាខ្លួន ។

បុរសដែលជាបណ្ឌិត កាលមិនអាចធ្វើយ៉ាងនោះបានក្នុងវ័យទាំង ៣ ត្រូវស្ងួនត្រង់ខ្លួនក្នុងវ័យណាមួយ ក៏បានដូចគ្នា បើបុគ្គលជាគ្រហស្ថ មិនអាចធ្វើកុសលបានក្នុងបឋមវ័យ ព្រោះជាអ្នកងប់ងល់ក្នុងការលេងសោត ក្នុងមជ្ឈិមវ័យ គប្បីជាអ្នកមិនប្រមាទ បំពេញកុសល បើក្នុងមជ្ឈិមវ័យ ចាំបាច់ចិញ្ចឹមបុត្រ និងភរិយា មិនអាចបំពេញកុសលបានសោត ក្នុងបច្ឆិមវ័យ គប្បីបំពេញកុសល ឲ្យបានដោយអាការយ៉ាងនេះ ខ្លួនត្រូវជាបុគ្គលស្ងួនត្រង់ខ្លួនឯងនោះឯង តែកាលមិនអាចធ្វើយ៉ាងនោះ ខ្លួន ឈ្មោះថា មិនជាទីស្រឡាញ់ ។ បុគ្គលនោះ ធ្វើខ្លួននោះឲ្យមានអបាយជាទីទៅខាងមុខនោះឯង ។

បើបព្វជិត ក្នុងបឋមវ័យ ធ្វើការស្វាធ្យាយ ទ្រទ្រង់ចាំ ជ្រាប់ ធ្វើវត្ត និងបដិវត្ត ឈ្មោះថា ដល់នូវសេចក្តីប្រមាទ ក្នុងមជ្ឈិមវ័យ គប្បីជាបុគ្គលមិនប្រមាទ បំពេញសមណធម៌ ។

ម្យ៉ាងទៀត បើរវល់តែសាកសួរអដ្ឋកថា និងវិនិច្ឆ័យ និងហេតុនៃព្រះបរិយត្តិ ដែលខ្លួនរៀនហើយក្នុងបឋមវ័យ ឈ្មោះថា ដល់នូវសេចក្តីប្រមាទក្នុងមជ្ឈិមវ័យ ក្នុងបច្ឆិមវ័យ គប្បីជាអ្នកមិនប្រមាទ បំពេញសមណធម៌ដោយអាការយ៉ាងនេះ ខ្លួន ឈ្មោះថា បព្វជិតនោះស្ងួនត្រង់ហើយនោះឯង ។

តែកាលមិនធ្វើយ៉ាងនោះ ខ្លួន ឈ្មោះថា មិនជាទីស្រឡាញ់ បព្វជិតនោះស្មើគ្នានឹងធ្វើខ្លួននោះឲ្យក្តៅក្រហាយ ដោយការតាមក្តៅក្រហាយក្នុងកាលខាងក្រោយពិត ។

កាលចប់ទេសនា ពោធិរាជកុមារតាំងនៅក្នុងសោតាបត្តិផលហើយ ព្រះធម្មទេសនាបានជាប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយដូច្នេះឯង ॥

រឿង ពោធិរាជកុមារ ចប់

រឿង ព្រះឧបនន្ទសក្យបុត្រ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះឧបនន្ទសក្យបុត្រ ត្រាស់ព្រះធម្មទេសនានេះថា **អត្តានមេវ បឋមំ** ជាដើម ។

បានឮមកថា ព្រះថេរៈនោះឈ្លាសក្នុងការពោលធម្មកថា ភិក្ខុជាច្រើនស្តាប់ធម្មកថា ដែលបដិសំយុត្តដោយភាពជាបុគ្គល មានសេចក្តីប្រាថ្នាតិចជាដើមរបស់លោកហើយ ទើបបូជាដោយចីវរទាំងឡាយ សមាទានធុតង្គ ព្រះឧបនន្ទនោះមួយរូប ទទួលយកបរិក្ខារដែលភិក្ខុទាំងនោះលះបង់ហើយ ។

លុះក្នុងរដូវវស្សាជិតចូលមកដល់ ព្រះឧបនន្ទនោះបានទៅកាន់ជនបទហើយ ។ លុះជាប់នោះ ភិក្ខុកំលោះ និងសាមណេរក្នុងវិហារពោលនឹងលោកដោយសេចក្តីស្រឡាញ់ក្នុងធម្មកថិកថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់

ចូលវស្សាក្នុងទីនេះចុះ ព្រះឧបនន្ទសួរថា ក្នុងវិហារនេះបានសំពត់ចំណាំវស្សាប៉ុន្មានផ្ទាំង កាលភិក្ខុទាំងនោះឆ្លើយថា បានមួយអង្គ ១ ផ្ទាំង ទើបទុកស្បែកជើងក្នុងវិហារនោះ បានទៅវិហារដទៃ ដល់វិហារទីពីរហើយសួរថា ក្នុងវិហារនេះភិក្ខុទាំងឡាយបានអ្វី កាលភិក្ខុឆ្លើយថា បានសាដកពីរផ្ទាំង ទើបទុកឈើច្រត់ក្នុងទីនោះ ដល់វិហារទី ៣ សួរថា ក្នុងវិហារនេះភិក្ខុទាំងឡាយបានអ្វី កាលភិក្ខុឆ្លើយថា បានសំពត់សាដក ៣ ផ្ទាំង ទើបទុកធម្មក្រែកក្នុងទីនោះ ដល់វិហារទី ៤ សួរថា ក្នុងវិហារនេះភិក្ខុទាំងឡាយបានអ្វី កាលពួកភិក្ខុឆ្លើយថា បានសាដក ៤ ផ្ទាំង ពោលថា សាធុ ខ្ញុំនឹងនៅទីនេះ ដូច្នេះហើយ ចាំវស្សាក្នុងវិហារនោះ ពោលធម្មកថាដល់គ្រហស្ថ និងភិក្ខុទាំងឡាយនោះឯង គ្រហស្ថ និងភិក្ខុទាំងឡាយនោះ បូជាព្រះឧបនន្ទនោះដោយសំពត់ និងចីវរជាច្រើន ។ ព្រះឧបនន្ទនោះ ចេញវស្សាហើយ ឲ្យដំណឹងទៅវិហារក្រៅអំពីនេះថា ខ្ញុំគួរបានសំពត់ចំណាំវស្សា ព្រោះខ្ញុំទុកបរិក្ខារ ចូរភិក្ខុទាំងឡាយបញ្ជូនសំពត់ចំណាំវស្សាឲ្យខ្ញុំ ឲ្យនាំសំពត់ចំណាំវស្សាទាំងអស់មកហើយ ជាក់ពេញរនេះតូចបរទៅ ។

កាលនោះភិក្ខុពីររូប នៅក្នុងវិហារមួយកន្លែង បានសំពត់សាដកពីរផ្ទាំង សំពត់កម្ពលមួយផ្ទាំង មិនអាចចែកគ្នាបានថា សំពត់សាដកចូរជារបស់លោក សំពត់កម្ពលនឹងជារបស់ខ្ញុំ អង្គុយប្រកែកគ្នាត្រង់កណ្តាលផ្លូវ ភិក្ខុពីររូបនោះឃើញព្រះថេរៈដើរមក ទើបពោលថា សូមលោកម្ចាស់ជួយចែកឲ្យដល់ខ្ញុំផងចុះ ព្រះថេរៈពោលថា ចូរពួកលោកចែកគ្នាដោយខ្លួនឯងចុះ ភិក្ខុទាំងនោះ

ពោលថា ពួកខ្ញុំមិនអាច សូមលោកម្ចាស់ចែកឲ្យពួកខ្ញុំចុះ ព្រះថេរៈសួរថា ពួកលោកតាំងនៅក្នុងពាក្យរបស់ខ្ញុំឬ ពួកភិក្ខុពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំនឹងតាំងនៅ ព្រះថេរៈនោះពោលថា សាធុ បើដូច្នោះ ខ្ញុំនឹងចែក ហើយឲ្យសំពត់សាដកពីរផ្ទាំង ដល់ភិក្ខុពីរូបនោះឯង ពោលថា សំពត់កម្ពលនេះ ចូរជាសំពត់ជណ្តប់របស់ខ្ញុំដែលពោលធម្មកថា ដូច្នេះហើយ ក៏កាន់យកសំពត់កម្ពលដែលមានតម្លៃច្រើន ចៀសចេញទៅ ។ ពួកភិក្ខុកំលោះ ជាអ្នកដល់នូវសេចក្តីក្តៅក្រហាយ ទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលសេចក្តីនោះហើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបនន្ទនេះកាន់យកទ្រព្យរបស់ពួកអ្នក ធ្វើឲ្យពួកអ្នកក្តៅក្រហាយតែក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ធ្វើហើយដូចគ្នា ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល កេពីរ កេមួយរកស៊ីទឹកវាក់ កេមួយរកស៊ីទឹកជ្រៅ ចាប់បានត្រីឆ្ពិនធំមួយ ដល់នូវការឈ្លោះគ្នាថា ក្បាលជារបស់ខ្ញុំ កន្ទុយជារបស់អ្នក មិនអាចចែកគ្នាបាន ឃើញឆ្កែចចកមួយ ទើបពោលថា បពិត្រលោកអ៊ំ សូមអ៊ំជួយចែកត្រីនេះឲ្យដល់ពួកខ្ញុំ ឆ្កែចចកពោលថា យើង គឺព្រះរាជាតាំងទុកក្នុងតំណែងចៅក្រម យើងអង្គុយត្រង់ទីវិនិច្ឆ័យនោះយូរហើយ ទើបមកដើម្បីដើរលេង ឥឡូវនេះ ឱកាសរបស់យើងមិនមាន កេពោលថា សូមអ៊ំកុំធ្វើយ៉ាងនោះឡើយ មេត្តាជួយចែកឲ្យពួកខ្ញុំផងចុះ ចចកពោលថា ពួកអ្នកតាំងនៅក្នុងពាក្យរបស់យើងឬ កេពោលថា ខ្ញុំនឹងតាំងនៅ ។

ចចកនោះពោលថា សាធុ បើដូច្នោះ ខ្ញុំនឹងចែក ទើបការក្បាលទុកម្ខាង កន្ទុយទុកម្ខាង កាលធ្វើហើយ ទើបពោលថា នែបាទាំងពីរ បណ្តាពួកបាទាំងពីរ មួយណាវាសុីទឹកវាក់ មួយនោះត្រូវបានកន្ទុយ មួយណាវាសុីទឹកជ្រៅ មួយនោះត្រូវបានក្បាល ចំណែកកំណាត់កណ្តាលនេះជារបស់ខ្ញុំ ដែលតាំងនៅក្នុងវិនិច្ឆ័យធម៌ កាលឲ្យកេទាំងនោះយល់ព្រម ទើបពោលគាថាថា

ម្នាលកេ អ្នកត្រាច់ទៅតាមឆ្នេរ (អ្នកត្រូវបាន) កន្ទុយ
កេដែលត្រាច់ទៅក្នុងទឹកជ្រៅ (ត្រូវបាន) ក្បាល ដុំជា
កណ្តាល ក្រៅអំពីចំណែកពីរនេះ ត្រូវបាន (យើង) អ្នកស្ថិត
នៅក្នុងតំណែងជម្រះក្តី ។

ដូច្នេះហើយ ពាំកំណាត់កណ្តាល ចៀសចេញទៅ កេទាំងពីរនោះក្តៅក្រហាយ បានឈរមើលចចកនោះហើយ ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា ក្នុងអតីតកាល ឧបនន្ទនេះ បានធ្វើពួកអ្នកឲ្យក្តៅក្រហាយយ៉ាងនេះដូចគ្នា ឲ្យកិក្តីទាំងនោះយល់ព្រមហើយ កាលនឹងតិះដៀលព្រះឧបនន្ទ ទើបត្រាស់ថា

អត្តាឯមេវ បឋមំ បដិរូបេ ឯវេសយេ
អថញ្ញេមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ ។

បណ្ឌិត គួរតម្កល់ខ្លួនទុកក្នុងគុណដ៏សមគួរជាមុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃជាខាងក្រោយ (ធ្វើយ៉ាងនេះ) នឹងមិនលំបាកឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ជាទព្រះគាថាថា **បដិរូបេ និវេសយេ** បានដល់គប្បីញុំាងខ្លួនឲ្យតាំងនៅក្នុងគុណដ៏សមគួរ ព្រះសាស្តាត្រាស់ពាក្យនេះថា បុគ្គលណាចំណងប្រៀនប្រដៅអ្នកដទៃដោយគុណា មានការជ្រុះថ្នាក់ចជាដើម ឬដោយបដិបទារបស់អរិយវង្សជាដើម បុគ្គលនោះគប្បីញុំាងខ្លួននោះឯងឲ្យតាំងនៅក្នុងគុណនោះមុន កាលតាំងខ្លួនទុកយ៉ាងនោះហើយ គប្បីប្រៀនប្រដៅអ្នកដទៃដោយគុណនោះ ក្នុងកាលខាងក្រោយ ព្រោះថា បុគ្គលកាលមិនញុំាងខ្លួនឲ្យតាំងនៅក្នុងគុណនោះ ទូន្មានអ្នកដទៃតែម្យ៉ាងប៉ុណ្ណោះ ជានន្ទូវការនិន្ទាអំពីអ្នកដទៃហើយ ឈ្មោះថា រមែងសៅហ្មង ។ បុគ្គលកាលញុំាងខ្លួនឲ្យតាំងនៅក្នុងគុណនោះហើយ ទូន្មានអ្នកដទៃ រមែងជានទទួលនូវសេចក្តីសរសើរអំពីអ្នកដទៃ ព្រោះដូច្នោះ ទើបឈ្មោះថា រមែងមិនសៅហ្មង បណ្ឌិតកាលធ្វើយ៉ាងនេះ ឈ្មោះថា មិនគប្បីសៅហ្មង ។

ក្នុងកាលចប់ទេសនា ភិក្ខុពីររូបនោះតាំងនៅក្នុងសោតាបត្តិផល ទេសនាជានប្រព្រឹត្តទៅដោយប្រយោជន៍ដល់មហាជនដូច្នេះឯង ។

រឿង ព្រះឧបនន្ទសក្យបុត្រ ចប់

រឿង ព្រះបធានិកតិស្សត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបធានិកតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អត្តានញ្ច** ជាដើម ។

បានឮមកថា ព្រះថេរៈនោះរៀនព្រះកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តា ហើយ ពួកភិក្ខុប្រមាណ ៥០០ រូបទៅចាំវស្សាក្នុងព្រៃ ពោលទូន្មានថា អាវុសោ ទាំងឡាយ ពួកលោករៀនកម្មដ្ឋានក្នុងសម្នាក់ព្រះពុទ្ធដែលគង់ព្រះជន្មនៅ ចូរ ជាអ្នកមិនប្រមាទ ធ្វើសមណធម៌ចុះ ដូច្នេះហើយ ខ្លួនឯងក៏ទៅសិងលក់ ភិក្ខុ ទាំងនោះចង្រ្កមក្នុងបឋមយាមហើយ ចូលទៅកាន់វិហារក្នុងមជ្ឈិមយាម ព្រះ ថេរៈនោះទៅកាន់សម្នាក់របស់ភិក្ខុទាំងនោះ ក្នុងពេលដែលខ្លួនសិងលក់ហើយ ភ្ញាក់ឡើងពោលថា ពួកលោកមកដោយបំណងថា នឹងដេកលក់ដូច្នេះឬ ចូរ ប្រញាប់ចេញទៅធ្វើសមណធម៌ចុះ ដូច្នេះហើយ ខ្លួនឯងក៏ទៅសិងយ៉ាង នោះឯង ។ ពួកភិក្ខុក្រៅអំពីនេះ ចង្រ្កមខាងក្រៅ ក្នុងមជ្ឈិមយាមហើយ ទៅ កាន់វិហារក្នុងបច្ឆិមយាម ព្រះថេរៈនោះភ្ញាក់ឡើងហើយ ទៅកាន់សម្នាក់ របស់ភិក្ខុទាំងនោះ នាំភិក្ខុទាំងនោះចេញអំពីវិហារហើយ ខ្លួនឯងក៏ទៅសិង លក់យ៉ាងនោះទៀត កាលព្រះថេរៈធ្វើយ៉ាងនោះអស់កាលជានិច្ច ភិក្ខុទាំង នោះមិនអាចធ្វើការស្វាធ្យាយ ឬធ្វើព្រះកម្មដ្ឋានក្នុងចិត្តបាន ទើបដល់នូវការ រាយមាយហើយ ។ ភិក្ខុទាំងនោះប្រឹក្សាគ្នាថា អាចារ្យរបស់ពួកយើងប្រារព្ធ ព្យាយាមពន់ពេក ពួកយើងនឹងឃ្លាំមើលលោក កាលឃ្លាំមើលឃើញកិរិយា

របស់ព្រះថេរៈនោះហើយ ពោលថា អាវុសោទាំងឡាយ ពួកយើងវិនាសអាចារ្យរបស់ពួកយើង ស្រែកទទេៗ បណ្តាភិក្ខុទាំងនោះលំបាកពន់ពេកសូម្បីភិក្ខុមួយរូប ក៏មិនអាចញុំាងគុណវិសេសឲ្យកើតបាន ភិក្ខុទាំងនោះចេញវស្សាហើយ ទៅកាន់សម្នាក់របស់ព្រះសាស្តា មានបដិសណ្ឋារៈដែលព្រះសាស្តាទ្រង់ធ្វើហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកជាអ្នកមិនប្រមាទ ធ្វើសមណធម៌ឬ ទើបក្រាបទូលសេចក្តីនោះ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះបានធ្វើអន្តរាយដល់ពួកអ្នកមិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនោះក៏បានធ្វើអន្តរាយដល់ពួកអ្នកដូចគ្នា កាលភិក្ខុទាំងនោះទូលអាភធនាហើយ ទើបទ្រង់ញុំាងអកាលវាវិកុក្កជជាតកឲ្យពិស្តារ តែក្នុងទីនេះមានសេចក្តីសង្ខេបថា[1]

-១ បិដកខ្មែរអកាលវាវិជាតក ។

មាន់នេះ ចម្រើននៅក្នុងសម្នាក់នៃបុគ្គល មិនមែនជាមាតាបិតា កាលនៅក្នុងត្រកូល នៃបុគ្គលមិនមែនជាអាចារ្យ រមែងមិនដឹងច្បាស់នូវកាលគួរវងាវ ឬកាលមិនគួរវងាវ ។

ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុកាលពោលប្រៀនប្រដៅអ្នកដទៃ គប្បីធ្វើខ្លួនដែលទូន្មានល្អហើយ ព្រោះបុគ្គលកាលប្រៀនប្រដៅយ៉ាងនោះ ជាបុគ្គលមានខ្លួនទូន្មានហើយ ឈ្មោះថា រមែងទូន្មានបាន ហើយត្រាស់ព្រះគាថានេះថា

អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ

សុឧន្ទោ វត ឧមេថ អត្ថា ហិ កិរ ឧុឧ្ទមោ ។

បុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើខ្លួនឲ្យបានយ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនកម្រទូន្មានបានពេកណាស់ ។

សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះថា ភិក្ខុពោលហើយថា គប្បីចង្រ្រមក្នុងបឋមយាមជាដើម ឈ្មោះថា ទូន្មានអ្នកដទៃយ៉ាងណា ខ្លួនឯងក៏ដូច្នោះ អធិដ្ឋានកិច្ច មានចង្រ្រមជាដើម ឈ្មោះថា គប្បីធ្វើខ្លួនដូចទូន្មានអ្នកដទៃ កាលបើដូច្នេះ ភិក្ខុនោះជាបុគ្គលមានខ្លួនទូន្មានល្អហើយហ្នឹ គួរទូន្មានអ្នកដទៃ ។

បាទព្រះគាថាថា **សុឧន្ទោ វត ឧមេថ** *សេចក្តីថា ភិក្ខុរមែងប្រៀនប្រដៅអ្នកដទៃដោយហេតុណា ជាបុគ្គលទូន្មានខ្លួនល្អហើយ ដោយខ្លួនដោយគុណនោះ គួរទូន្មានអ្នកដទៃ ។*

បាទព្រះគាថាថា **អត្ថា ហិ កិរ ឧុឧ្ទមោ** *សេចក្តីថា ព្រោះថា ឈ្មោះថាខ្លួននេះ ជាសភាវ:ដែលបុគ្គលទូន្មានបានលំបាក ព្រោះហេតុនោះ បុគ្គលនោះរមែងជាសភាវ: ដែលបុគ្គលទូន្មានល្អហើយដោយប្រការណា គួរទូន្មានខ្លួនដោយប្រការនោះ ។*

ក្នុងកាលចប់ទេសនា ភិក្ខុប្រមាណ ៥០០ រូបនោះសម្រេចអរហត្តផលហើយ ដូច្នោះឯង ។

រឿង ព្រះបធានិកតិស្សត្ថេរ ចប់

រឿង មាតាព្រះកុមារកស្សបត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមាតារបស់ព្រះកុមារកស្សបត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អត្តា ហិ អត្តនោ នាថោ** ជាដើម ។

បានឮមកថា មាតារបស់ព្រះថេរៈនោះ ជាកូនស្រីសេដ្ឋីក្នុងក្រុងរាជគ្រឹះ សូមបព្វជ្ជាហើយ ចាប់តាំងអំពីកាលដែលខ្លួនដឹងក្តី សូម្បីអង្វរវៀយៗ ក៏មិនបានបួសអំពីសម្នាក់មាតា និងបិតា ចម្រើនវ័យហើយ ទៅកាន់ត្រកូលប្តី ជាអ្នកមានប្តីដូចទេវតានៅគ្រប់គ្រងផ្ទះហើយ ។ ក្នុងកាលមិនយូរ សត្វកើតក្នុងគភ៌តាំងឡើងហើយ ក្នុងផ្ទៃរបស់នាង តែនាងមិនជ្រាបភាពដែលគភ៌នោះតាំងឡើងឡើយ ញុាំងស្វាមីឲ្យត្រេកអរហើយ ទើបសូមបួស ។ គ្រានោះ ស្វាមីនាំនាងទៅកាន់សម្នាក់របស់ភិក្ខុនីដោយសក្ការៈធំ មិនជ្រាបថាមានផ្ទៃពោះ ឲ្យបួសក្នុងសម្នាក់របស់ភិក្ខុនី ដែលជាបក្ខពួករបស់ទេវទត្តហើយ ។

សម័យក្រោយមក នាងត្រូវភិក្ខុនីទាំងនោះដឹងថាមានគភ៌ហើយ សួរថា នេះអ្វីហ្ន៎ ទើបឆ្លើយថា បពិត្រអ្នកនាងម្ចាស់ ខ្ញុំមិនជ្រាបថានេះជាអ្វី តែសីលរបស់ខ្ញុំមិនពព្រួស មិនពពាលឡើយ ។ ពួកភិក្ខុនីនាំនាងទៅកាន់សម្នាក់របស់ទេវទត្តហើយសួរថា កិក្ខុនីនេះបួសដោយសទ្ធា ពួកខ្ញុំមិនដឹងកាលនៃគភ៌របស់នាងតាំងឡើង ឥឡូវនេះ ពួកខ្ញុំនឹងធ្វើដូចម្តេច ទេវទត្តកិក្ខុគិតឃើញត្រឹមតែហេតុប៉ុណ្ណោះថា ការវិនាសកេរ្តិ៍ឈ្មោះ ចូរកុំកើតឡើងដល់ពួកភិក្ខុនី ដែលធ្វើតាម

ឱវាទរបស់យើង ទើបពោលថា ចូរពួកនាងឲ្យស្រីនោះសឹក កិកុ្ខនីនោះស្តាប់ពាក្យនោះហើយ ពោលថា បពិត្រអ្នកនាងម្ចាស់ សូមកុំធ្វើឲ្យខ្ញុំវិនាសឡើយ ខ្ញុំមិនបានបួសឧទ្ទិសចំពោះលោកម្ចាស់ទេវទត្តឡើយ សូមនាងម្ចាស់ទាំង-ឡាយ នាំខ្ញុំទៅកាន់វត្តជេតពន ដែលជាសម្នាក់របស់ព្រះសាស្តា កិកុ្ខនីទាំងនោះនាំនាងទៅកាន់វត្តជេតពន ក្រាបទូលដល់ព្រះសាស្តាហើយ ។

ព្រះសាស្តាទ្រង់ជ្រាបថា គកិតាំងឡើងហើយ ក្នុងកាលនាងជាគ្រហស្ត កាលនឹងដោះពាក្យរបស់អ្នកដទៃ ទើបត្រាស់ឲ្យយាងព្រះបាទបសេនទិកោសល អនាថបិណ្ឌិកសេដ្ឋី ចូឡអនាថបិណ្ឌិកសេដ្ឋី វិសាខាឧបាសិកា និងត្រកូលធំៗ មកហើយ ទ្រង់ត្រាស់នឹងព្រះបាលិតេ្តរថា ចូរអ្នកទៅជម្រះកម្មរបស់កិកុ្ខនីនេះ ឲ្យបរិសុទ្ធក្នុងកណ្តាលបរិស័ទ ៤ ។ ព្រះថេរៈ ឲ្យហៅនាងវិសាខាមកចំពោះព្រះភក្ត្រព្រះរាជាហើយ ឲ្យពិនិត្យអធិករណ៍នោះ នាងវិសាខាឲ្យមនុស្សព័ទ្ធដោយគ្រឿងព័ទ្ធ គឺវាំងនន ពិនិត្យមើលដៃ ជើង ផ្ចិត និងទីបំផុតនៃពោះរបស់កិកុ្ខនីនោះ ខាងក្នុងវាំងនន ហើយរាប់ខែថ្ងៃមើល ដឹងថា នាងមានគកិក្នុងកាលនៅជាគ្រហស្ត ទើបជ្រាប់សេចក្តីនោះដល់ព្រះថេរៈ គ្រានោះ ព្រះថេរៈញុំាងភាពដែលនាងជាបុគ្គលបរិសុទ្ធ ឲ្យត្រឡប់តាំងឡើងក្នុងកណ្តាលបរិស័ទហើយ ។ ដោយសម័យដទៃ នាងប្រសូតបុត្រមានអានុភាពច្រើន ដែលមានសេចក្តីជ្រាថ្នា តាំងទុកទៀបបាទមូលរបស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ។

ថ្ងៃមួយ ព្រះរាជាយាងទៅក្នុងទីជិតសម្នាក់របស់កិកុ្ខនី ទ្រង់ឮសំឡេងទារក ទើបត្រាស់សួរថា នេះសំឡេងអ្វី កាលអមាត្យក្រាបទូលថា បពិត្រ

ព្រះអង្គ កូនរបស់កិកុនីនោះកើតហើយ នុ៎ះជាសំឡេងបុត្ររបស់កិកុនីនោះ ។ ទ្រង់នាំកុមារនោះទៅកាន់ព្រះរាជមន្ទីរបស់ទ្រង់ បានប្រទានឲ្យដល់មេដោះទាំងឡាយ ។ ក្នុងថ្ងៃដាក់ឈ្មោះ ជនទាំងឡាយដាក់ឈ្មោះកុមារនោះថា កស្សបៈ ព្រោះកុមារនោះជាបុគ្គលដែលព្រះរាជាទ្រង់ឲ្យចម្រើនហើយ ដោយគ្រឿងរក្សារបស់ព្រះកុមារ ទើបគេហៅថា កុមារកស្សបៈ ។ កុមារនោះវាយក្មេងក្នុងទីលេងកីឡាហើយ កាលពួកក្មេងពោលថា ពួកយើងត្រូវមនុស្សមិនមានម៉ែ មិនមានឪវាយហើយ ។ ទើបចូលទៅគាល់ព្រះរាជាទូលសួរថា បពិត្រព្រះសម្មតិទេព ពួកក្មេងរមែងជេរទូលបង្គំថា មិនមានមាតា និងបិតា សូមទ្រង់ត្រាស់ប្រាប់មាតាដល់ទូលបង្គំចុះ កាលទ្រង់បង្ហាញមេដោះទាំង-ឡាយ ត្រាស់ថា ស្រីទាំងនេះជាមាតារបស់បា ទើបក្រាបទូលថា មាតារបស់ទូលបង្គំមិនមានប៉ុណ្ណេះទេ្លយ មាតារបស់ទូលបង្គំ មានតែមួយ សូមទ្រង់ប្រាប់មាតានោះដល់ទូលបង្គំចុះ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អញមិនអាចបញ្ឆោតកុមារនេះបាន ទើបត្រាស់ថា នែបា មាតារបស់បាជាកិកុនី អ្នក គឺយើងនាំមកអំពីសម្នាក់របស់កិកុនី ។

កុមារនោះ មានសេចក្តីសង្វេគកើតឡើងព្រមហើយ ដោយហេតុមានប្រមាណប៉ុណ្ណោះនោះឯង ក្រាបទូលថា បពិត្របិតា សូមទ្រង់ឲ្យទូលបង្គំបួសចុះ ព្រះរាជាទទួលថា សាធុ ហើយញុំាងកុមារនោះឲ្យបួសក្នុងសម្នាក់របស់ព្រះសាស្តា ដោយសក្ការៈដ៏ច្រើន ។

កុមារកស្សបៈនោះបានឧបសម្បទាហើយ ប្រាកដឈ្មោះថា កុមារកស្ស-

បត្តេវ លោកវៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តា ចូលទៅកាន់ព្រៃ ព្យាយាមហើយ មិនអាចញុំាងគុណវិសេសឲ្យកើតបាន ទើបគិតថា អញនឹងវៀនកម្មដ្ឋានឲ្យវិសេសទៀត មកកាន់សម្នាក់ព្រះសាស្តា នៅក្នុងព្រៃអន្ធវនហើយ កាលនោះ ភិក្ខុធ្វើសមណធម៌រួមគ្នា ក្នុងកាលព្រះកស្សបសម្ពុទ្ធ សម្រេចអនាគាមិផល ហើយកើតក្នុងព្រហ្មលោក មកអំពីព្រហ្មលោក សួរបញ្ហា ១៥ ជាមួយកុមារកស្សបៈនោះហើយ បញ្ជូនទៅដោយពាក្យថា អ្នកដទៃវៀរ ព្រះសាស្តា បុគ្គលដែលអាចព្យាករបញ្ហាទាំងនេះមិនមាន សូមលោកម្ចាស់ ទៅសាកសួរអត្ថរបស់បញ្ហាទាំងនេះ ក្នុងសម្នាក់របស់ព្រះសាស្តាចុះ ។ លោកធ្វើយ៉ាងនោះ សម្រេចអរហត្តផល ក្នុងកាលដែលព្រះសាស្តា ទ្រង់ឆ្លើយបញ្ហាចប់ ។

តាំងអំពីថ្ងៃដែលព្រះថេរៈនោះចេញទៅហើយ ទឹកភ្នែកហូរចេញអំពីរង្វង់ភ្នែកទាំងគូរបស់ភិក្ខុនីជាមាតាអស់កាល ១២ ឆ្នាំ នាងមានទុក្ខ ព្រោះព្រាត់ប្រាសចាកបុត្រ មានមុខជោកជោយទឹកភ្នែកនោះឯង ត្រាច់ទៅដើម្បីភិក្ខា ឃើញព្រះថេរៈក្នុងចន្លោះផ្លូវ ទើបស្រែកថា កូន កូន រត់ចូលទៅដើម្បីចាប់ព្រះថេរៈក៏ដួលហើយ នាងមានទឹកដោះហូរក្រោកឡើង មានចីវរសើមចាប់ព្រះថេរៈហើយ ព្រះថេរៈគិតថា បើម្តាយអញបានឮពាក្យពីរោះអំពីសម្នាក់អញ នាងនឹងវិនាស អញនឹងនិយាយជាមួយមាតានេះ ធ្វើឲ្យគ្រោតគ្រោតហើយ ។ ពេលនោះ ព្រះថេរៈពោលនឹងភិក្ខុនីដែលជាមាតានោះថា នាងត្រាច់ធ្វើអ្វី ទើបមិនអាចកាត់ គ្រាន់តែសេចក្តីស្រឡាញ់បាន នាងគិតថា ឱ ពាក្យរបស់ព្រះថេរៈ

គ្រោតគ្រោត ទើបពោលថា នែបា បានិយាយអ្វី ត្រូវព្រះថេរៈពោលយ៉ាងនោះ ឯងទៀត ទើបគិតថា អញមិនអាចទប់ទឹកភ្នែកបានអស់ ១២ ឆ្នាំ ព្រោះហេតុនៃកូននេះ តែកូនរបស់អញនេះ មានចិត្តរឹងត្អឹង ប្រយោជន៍អ្វីរបស់អញដោយកូននេះ កាត់សេចក្តីស្រឡាញ់ក្នុងបុត្រហើយ សម្រេចអរហត្តផលក្នុងថ្ងៃនោះឯង ។

ក្នុងសម័យដទៃ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ កុមារកស្សបៈ និងព្រះថេរី សម្បូរដោយឧបនិស្សយយ៉ាងនេះ ត្រូវទេវទត្តឲ្យវិនាសហើយ ចំណែកព្រះសាស្តា បានជាទីពឹងរបស់លោកទាំងពីរនោះ ឱ គួរអស្ចារ្យ ធម្មតាព្រះពុទ្ធទាំងឡាយ រមែងជាអ្នកអនុគ្រោះ (សត្វ) លោក ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាបច្ចយ ជាទីពំនាក់អាស្រ័យរបស់ជនទាំងពីរនេះ ក្នុងឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុន តថាគតក៏បានជាទីពឹងរបស់ជនទាំងនេះដូចគ្នា ដូច្នេះហើយ ទើបត្រាស់និគ្រោធជាតកដោយពិស្តារ (តែក្នុងទីនេះមានសេចក្តីសង្ខេប) ថា

បុគ្គល គប្បីសេពនូវម្រឹគ ឈ្មោះនិគ្រោធតែម្យ៉ាង កុំគប្បីសេពនូវម្រឹគឈ្មោះសាខៈឡើយ កាលស្លាប់ក្នុងសម្ពាក់នៃម្រឹគឈ្មោះនិគ្រោធ ជាការប្រសើរ ការរស់នៅក្នុងសម្ពាក់នៃម្រឹគ

ឈ្មោះសាខៈ ពុំប្រសើរឡើយ ។

ទ្រង់ប្រជុំជាតកថា ម្រឹគឈ្មោះសាខៈក្នុងកាលនោះ បានជាទេវទត្តក្នុងកាលឥឡូវនេះ បរិស័ទរបស់ម្រឹគឈ្មោះសាខៈនោះ ក៏ជាបរិស័ទរបស់ទេវទត្តនោះឯង ម្រឹគដែលដល់វេណា បានជាព្រះថេរី កូនម្រឹគ បានជាកុមារកស្សបៈ ចំណែកស្តេចម្រឹគឈ្មោះនិគ្រោធ ដែលទៅលះជីវិតដល់មេម្រឹគ ដែលមានគភ៌ គឺតថាគតនេះឯង ។ កាលទ្រង់ប្រកាសភាពដែលព្រះថេរី កាត់សេចក្តីស្រឡាញ់ក្នុងបុត្រហើយ ធ្វើទីពឹងដល់ខ្លួនឯង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រោះបុគ្គលអាស្រ័យអ្នកដទៃ មិនអាចមានសួគ៌ ឬមគ្គជាទីទៅខាងមុខបានឡើយ ដូច្នោះ ខ្លួននោះឯងជាទីពឹងរបស់ខ្លួន អ្នកដទៃ នឹងធ្វើអ្វីបាន ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា

អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ។

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **នាថោ** *គឺជាទីពឹង ព្រះដ៏មានព្រះភាគត្រាស់ពាក្យនេះថា បុគ្គលតាំងនៅក្នុងខ្លួន គឺសម្បូរហើយដោយខ្លួន អាចធ្វើកុសលហើយដល់នូវសួគ៌ ឬដើម្បីញុំាងមគ្គឲ្យចម្រើន ឬធ្វើឲ្យជាក់ច្បាស់នូវផលបាន*

ព្រោះហេតុនោះឯង ខ្លួនគប្បីជាទីពឹងរបស់ខ្លួន ។ អ្នកដទៃណា គប្បីជាទីពឹងរបស់បុគ្គលណាបាន ព្រោះបុគ្គលមានខ្លួនទូន្មានល្អហើយ គឺមានការសេពខុសទៅច្រាសហើយ រមែងបានទីពឹងដែលបុគ្គលបានដោយកម្រ ពោល គឺអរ-ហត្តផល ។ ពាក្យថា **ឆាឋំ លភតិ ធុល្លភំ** *នេះ ព្រះដ៏មានព្រះភាគ ត្រាស់សម្តៅយកអរហត្ត ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង មាតាព្រះកុមារកស្សបត្ថេរ ចប់

រឿង ឧចាសក ឈ្មោះ មហាកាល

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកដែលជាសោតាបន្នម្នាក់ ឈ្មោះមហាកាល ត្រាស់ព្រះធម្មទេសនានេះថា **អត្តនា ហិ កតំ ចាបំ** *ជាដើម ។*

បានឮថា មហាកាលនោះជាអ្នករក្សាឧបោសថ ៨ ថ្ងៃក្នុងមួយខែ ស្តាប់ធម្មកថាមួយយប់ទល់ភ្លឺក្នុងវិហារ កាលពួកចោរកាត់ទី-តក្នុងផ្ទះមួយខ្នង ក្នុងពេលយប់ កាន់បន្ទេចកណ្តុះទៅ ត្រូវពួកម្ចាស់ផ្ទះភ្ញាក់ឡើង ព្រោះកាជនៈលោហៈទង្គិចគ្នា ដេញតាមហើយ ចោលទ្រព្យដែលខ្លួនកាន់យកហើយ

ចៀសចេញទៅ ។

ចំណែកម្ចាស់ទ្រព្យ ដេញតាមចោរនោះរឿយៗ មក ពួកចោរទាំងនោះ ខ្ចាត់ខ្ចាយគេចទៅក្នុងទិសផ្សេងៗ ចំណែកចោរម្នាក់កាន់យកផ្លូវដែលទៅកាន់ វិហារ ចោលកញ្ចប់ភណ្ឌ:ខាងមុខមហាកាល ដែលស្តាប់ធម្មកថាមួយយប់ទល់ ភ្លឺ លុបមុខត្រង់មាត់ស្រះបោក្ខរណីអំពីព្រលឹម ហើយគេចទៅ ។

ពួកមនុស្សដេញតាមពួកចោរមក ជួបកញ្ចប់ភណ្ឌ:ហើយ ទើបចាប់ មហាកាលនោះ ដោយពោលថា ឯងកាត់ទី-តក្នុងផ្ទះរបស់ពួកយើង លួច កញ្ចប់ភណ្ឌ:មកហើយ ធ្វើដូចជាស្តាប់ធម៌ វាយឲ្យស្លាប់ហើយទុកចោល ។

គ្រានោះ ភិក្ខុកំលោះ និងសាមណេរទាំងឡាយ កាន់ក្អមទឹកផឹកទៅអំពី ព្រលឹម ជួបមហាកាលនោះ ពោលថា ឧបាសកស្តាប់ធម្មកថានៅវិហារ បាន មរណ:មិនសមគួរ ដូច្នេះហើយ ទើបក្រាបទូលដល់ព្រះសាស្តា ។ ព្រះ សាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង កាលឧបាសក បាន មរណ:មិនសមគួរក្នុងអត្តភាពនេះ តែសមគួរដល់កម្មដែលបានធ្វើហើយ ក្នុងកាលមុននោះឯង កាលភិក្ខុកំលោះ និងសាមណេរទាំងនោះទូលអារាធនា ទើបត្រាស់បុព្វកម្មរបស់មហាកាលនោះ

បានញ្ចមកថា ក្នុងអតីតកាល ពួកចោរស្តាត់ផ្លូវត្រង់មាត់ព្រៃមួយកន្លែង នាបច្ចត្តគាម ក្នុងដែនរបស់ព្រះបាទពារាណសី ។ ព្រះរាជាទ្រង់តាំងរាជភដ: ម្នាក់ត្រង់មាត់ផ្លូវ ។ រាជភដ:នោះ ទទួលថ្ងៃឈ្នួលហើយ ក៏នាំមនុស្សអំពី ខាងនេះ ទៅកាន់ខាងនោះ នាំមនុស្សអំពីខាងនោះ មកខាងនេះ ។

គ្រាមួយ បុរសម្នាក់ នាំភរិយាឡើងកាន់យានតូចហើយ បានទៅដល់ទីនោះ ។ រាជភដៈឃើញស្រីនោះ ក៏កើតសេចក្តីស្រឡាញ់ កាលបុរសនោះពោលថា សូមលោកជូនខ្ញុំទាំងពីរឲ្យឆ្លងព្រៃចុះ ក៏ធ្វើយថា ឥឡូវនេះ យប់ព្រលប់ហើយ ចាំព្រឹកខ្ញុំនឹងជូនឲ្យឆ្លងផុតទៅ បុរសនោះពោលថា ពេលនៅមាន សូមនាំខ្ញុំទាំងពីរទៅឥឡូវនេះចុះ រាជភដៈពោលថា ត្រឡប់សិនចុះអ្នក អាហារ និងទីស្នាក់អាស្រ័យ មានក្នុងផ្ទះរបស់ខ្ញុំ ។

បុរសនោះមិនជ្រាប្នានឹងត្រឡប់ឡើយ ចំណែករាជភដៈនេះឲ្យសញ្ញាដល់ពួកបុរស ញ៉ាំងយានតូចឲ្យត្រឡប់ហើយ ឲ្យស្នាក់នៅត្រង់ខ្ងោងទ្វារ ឲ្យចាត់ចែងអាហារដល់បុរសនោះ ដែលមិនជ្រាប្នាឡើយ ។ ក្នុងផ្ទះរាជភដៈនោះមានកែវមណីមួយ គាត់ឲ្យយកកែវមណីនោះ លាក់ក្នុងជ្រុងនៃយានតូចរបស់បុរសនោះហើយ លុះពេលទៀបភ្លឺឲ្យធ្វើសំឡេងជាពួកចោរចូលទៅក្នុងផ្ទះ ។

លំដាប់នោះ ពួកបុរសជ្រាប់ដល់គាត់ថា លោកម្ចាស់ កែវមណីត្រូវចោរលួចយកទៅហើយ គាត់បញ្ជាថា ចូរពួកអ្នកតាំងកម្លាំងរក្សាត្រង់ទ្វារស្រុកទាំងឡាយ ចែកឆេរមើលមនុស្សដែលចេញទៅអំពីក្នុងស្រុក ចំណែកមនុស្សក្រៅអំពីនេះ រៀបចំយានតូចស្រេចហើយ ក៏បរទៅអំពីព្រលឹម ។ ពេលនោះ ពួកអ្នកបម្រើរបស់រាជភដៈ ទើបឆែកឆេរយានតូចរបស់បុរសនោះ ឃើញកែវមណីដែលខ្លួនលាក់ ទើបពោលថា ឯងលួចយកកែវមណីទៅ ដូច្នេះហើយ ក៏វាយបង្ហាញដល់មេស្រុកថា ពួកខ្ញុំចាប់ចោរបានហើយ រាជភដៈពោលថា ខ្ញុំជារាជភដៈ ឲ្យស្នាក់អាស្រ័យក្នុងផ្ទះឲ្យកត្តហើយ ឯងគង់លួចកែវមណីទៅ

បាន ចូរពួកអ្នកចាប់បុរសអាក្រក់នេះ ដូច្នេះហើយ ឲ្យវាយសម្លាប់ហើយបោះចោល នេះជាបុព្វកម្មរបស់មហាកាលនោះ ។ រាជភដៈនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងអវីចី ឆេះក្នុងអវីចីនោះអស់កាលយូរ ដោយសេសសល់ផលកម្ម ត្រូវគេវាយឲ្យស្លាប់យ៉ាងនោះឯងអស់ ១០០ អត្តភាព ។

ព្រះសាស្តា កាលទ្រង់សម្តែងបុព្វកម្មរបស់មហាកាលយ៉ាងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បាបកម្មដែលខ្លួនបានធ្វើហើយនោះឯង រមែងបៀតបៀនសត្វទាំងនោះ ដោយអបាយ ៤ យ៉ាងនេះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អត្តនា វ កតំ បាបំ អត្តជំ អត្តសម្ភវំ
អភិមត្ថតិ ទុម្មេធំ វជិរំវម្ពយំ មណឺ ។

បាបកើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញី មនុស្សឥតប្រាជ្ញា ដូចពេជ្រសម្រាប់កាត់កែវមណីដែលកើតអំពីថ្ម ដូច្នោះឯង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បានព្រះគាថាថា **វជិរំវម្ពយំ មណឺ** *សេចក្តីថា ប្រៀបដូចពេជ្រ ញាំញីកែវមណីដែលកើតអំពីថ្ម លោកអធិប្បាយពាក្យនេះថា ពេជ្រដែលសម្រេចអំពីថ្ម មានថ្មជាដែនកើត កាត់កែវមណីដែលកើតអំពីថ្ម គឺកែវមណីដែលសម្រេចអំពីថ្ម ដែលរាប់ថាជាទីតាំងឡើងរបស់ខ្លួននោះឯង គឺធ្វើឲ្យជាប្រហោងតូច ប្រហោងធំ ឲ្យជាកំណាត់តូចកំណាត់ធំ ធ្វើឲ្យ*

ប្រើប្រាស់មិនបាន យ៉ាងណា ជាបដែលធ្វើហើយ កើតក្នុងខ្លួន មានខ្លួនជាដែនកើត រមែងញាំញី គឺកម្មាត់បុគ្គលដែលមានបញ្ញាថោកថយ គឺបុគ្គលឥតបញ្ញាក្នុងអបាយ ៤ ដូច្នោះដូចគ្នា ។

ក្នុងកាលចប់ទេសនា ភិក្ខុដែលមកប្រជុំ សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ឧចាសក ឈ្មោះ មហាកាល ចប់

រឿង ទេវទត្តភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្តភិក្ខុ ទ្រង់ត្រាស់ធម្មទេសនានេះថា **យស្ស អច្ចន្តទុស្សីល្យំ** *ជាដើម ។*

សេចក្តីពិស្តារ ថ្ងៃមួយ ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក រៃអបអបព្រះបាទអជាតសត្តុ ញុំាងលាភសក្ការៈដ៏ច្រើនឲ្យកើតឡើង បបួលព្រះបាទអជាត-សត្តុ ក្នុងកាលសម្លាប់បិតា ជាអ្នករួមគំនិតជាមួយព្រះបាទអជាតសត្តុនោះ ដើម្បីសម្លាប់ព្រះតថាគត ដោយប្រការផ្សេងៗ ព្រោះតណ្ហាដែលចម្រើនឡើងហើយ ដោយហេតុ គឺភាពជាបុគ្គលទ្រុស្តសីលនោះឯង ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយ

សន្ទនាគ្នាដោយកថាដូចម្តេចហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថា ឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ព្យាយាមដើម្បីសម្លាប់តថាគត ដោយប្រការផ្សេងៗ ដូចគ្នា ដូច្នេះហើយ ទើបត្រាស់ជាតកទាំងឡាយ មានកុរុង្គ-ជាតកជាដើម ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តណ្ហាដែលកើតឡើងព្រោះហេតុ គឺជាអ្នកទ្រុស្តសីល ស្រោចរួបរឹតនូវបុគ្គលដែលទ្រុស្តសីល ឲ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ មានឧរកជាដើម ដូចដើមជ្រៃរួបរឹតដើមសាល-ព្រឹក្ស រហូតជាក់ចុះដូច្នោះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

យស្ស អច្ចន្តទុស្សីល្យំ មាលុវា សាលមិវោត្ថតំ
ករោតិ សោ តថត្តានំ យថា នំ ឥច្ឆតី ទិសោ ។

ភាពជាអ្នកទ្រុស្តសីលហួសហេតុ គ្របសង្កត់ (នូវ អត្តភាព) របស់បុគ្គលណា ដូចវល្លិ៍ដែលរួបរឹតដើមឈើ បុគ្គលនោះ ឈ្មោះថាធ្វើខ្លួនឯងឲ្យវិនាស ដូចជាចោរអ្នកជ្រាបថ្នាធ្វើបុគ្គលនោះឲ្យវិនាស ដូច្នោះ ។

សេចក្តីអធិប្បាយ

ភាពជាអ្នកទ្រុស្តសីលដោយចំណែកមួយ ឈ្មោះថា **អច្ចន្តទុស្សីល្យំ** *ក្នុងព្រះគាថានោះ ។ បុគ្គលជាគ្រហស្ថ ធ្វើអកុសលកម្មបថ ១០ តាំងអំពីកើតក្តី បព្វជិតត្រូវគរុកាបត្តិតាំងអំពីថ្ងៃឧបសម្បទាក្តី ឈ្មោះថាជាអ្នកទ្រុស្តសីលហួសហេតុ ។*

តែបទថា **អច្ចន្តទុស្សីលេ** *នេះ ព្រះដ៏មានព្រះភាគត្រាស់ក្នុងព្រះគាថានេះ ទ្រង់សំដៅយកភាពជាអ្នកទ្រុស្តសីលដែលមកហើយតាមគតិរបស់បុគ្គលដែលទ្រុស្តសីលក្នុង ២-៣ អត្តភាព ។*

ម្យ៉ាងទៀត តណ្ហាដែលអាស្រ័យទ្វារ ៦ របស់បុគ្គលទ្រុស្តសីលកើតឡើង បណ្ឌិតគប្បីជ្រាបថា ភាពជាអ្នកទ្រុស្តសីលក្នុងព្រះគាថានេះ ។

បានព្រះគាថាថា **មាលុវា សាលមិវោត្ថតំ** *សេចក្តីថា ភាពជាអ្នកទ្រុស្តសីល ពោល គឺតណ្ហារួបរឹត គឺហ៊ុមព័ទ្ធអត្តភាពរបស់បុគ្គលណាតាំងនៅដូចដើមជ្រៃ រួបរឹតដើមសាលព្រឹក្ស គឺគ្របជណ្តប់ទូទៅទាំងអស់នោះឯង ដោយអំណាចទទួលទឹកដោយស្វ័យក្នុងកាលភ្លៀងធ្លាក់ ហើយកាច់បំបាក់ដួលច្នោះឯង ។ បុគ្គលនោះ គឺបុគ្គលត្រូវតណ្ហា ពោល គឺភាពទ្រុស្តសីលនោះកាច់បំបាក់ឲ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ ដូចដើមឈើត្រូវពួរជ្រៃកាច់បំបាក់ឲ្យរលំចុះលើផែនដី ដួលច្នោះ ឈ្មោះថា រមែងធ្វើខ្លួនតែម្យ៉ាងជាមួយចោរ ដែលប្រាថ្នាសេចក្តីវិនាស ប្រាថ្នាធ្វើឲ្យ ដួលច្នោះ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

រឿង ឧទេវទត្តភិក្ខុ ចប់

រឿង ទេវទត្តបំបែកសង្ឃ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការព្យាយាមដើម្បីបំបែកសង្ឃ ត្រាស់ព្រះធម្មទេសនានេះថា **សុករានិ** ជាដើម ។

សេចក្តីពិស្តារថា ទេវទត្តភិក្ខុខ្នះខ្នែងដើម្បីបំបែកសង្ឃ ថ្ងៃមួយ ឃើញព្រះអានន្ទកំពុងត្រាច់បិណ្ឌបាត ប្រាប់នូវបំណងរបស់ខ្លួនហើយ ។ ព្រះថេរៈស្តាប់ហើយ ទៅកាន់សម្នាក់របស់ព្រះសាស្តា បានទូលពាក្យនេះ នឹងព្រះសាស្តាថា បពិត្រព្រះអង្គ ព្រឹកមិញ ខ្ញុំព្រះអង្គស្លៀកស្បង់ត្រង់ព្រៃឫស្សីនេះហើយ កាន់បាត្រ និងចីវរ ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ទេវទត្តឃើញខ្ញុំព្រះអង្គត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះហើយ ចូលទៅរកខ្ញុំព្រះអង្គ បានពោលពាក្យនេះថា អាវុសោអានន្ទ ចាប់តាំងអំពីថ្ងៃនេះទៅ ខ្ញុំនឹងធ្វើឧបោសថ និងសង្ឃកម្មបែកអំពីព្រះដ៏មានព្រះភាគ បែកអំពីភិក្ខុសង្ឃ បពិត្រព្រះសាស្តា ថ្ងៃនេះ ទេវទត្តនឹងបំបែកសង្ឃ ធ្វើឧបោសថ និងសង្ឃកម្ម ។

កាលព្រះអានន្ទក្រាបទូលយ៉ាងនោះហើយ ព្រះសាស្តាទ្រង់បន្ទន្ទឹនូវព្រះឧទានថា

អំពើល្អ មនុស្សល្អ ធ្វើបានដោយងាយ អំពើល្អ មនុស្សអាក្រក់ធ្វើបានដោយកម្រ អំពើអាក្រក់ មនុស្សអាក្រក់ ធ្វើបានដោយងាយ អំពើអាក្រក់ ពួកព្រះអរិយៈ ធ្វើបានដោយកម្រ ។

ហើយត្រាស់ថា ម្នាលអានន្ទ ឈ្មោះថាកម្មដែលមិនជាប្រយោជន៍ដល់

ខ្លួនធ្វើបានងាយ កម្មដែលជាប្រយោជន៍ដល់ខ្លួន ធ្វើលំបាកពន់ពេក ហើយ ត្រាស់ព្រះគាថានេះថា

សុករានិ អសាធូនិ អត្តនោ អហិតានិ ច
យំ វេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ ។

កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះ ដែលជនពាលធ្វើបានដោយងាយ កម្មណាជាប្រយោជន៍ផង ល្អផង កម្មនោះឯង ដែលជនពាលធ្វើបានដោយលំបាក ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា កម្មទាំងឡាយណាមិនល្អ គឺមានទោស និងប្រព្រឹត្តទៅដើម្បីអបាយ ឈ្មោះថាមិនជាប្រយោជន៍ដល់ខ្លួនព្រោះធ្វើនោះឯង កម្មទាំងនោះ ធ្វើបានដោយងាយ ចំណែកកម្មណា ឈ្មោះថាជាប្រយោជន៍ដល់ខ្លួន ព្រោះធ្វើ និងឈ្មោះថាល្អដោយអត្ថថា មិនមានទោស គឺប្រព្រឹត្តទៅដើម្បីសុគតិ និងប្រព្រឹត្តទៅដើម្បីព្រះនិព្វាន កម្មនោះសែនលំបាក ប្រៀបដូចទប់ទឹកទន្លេគង្គា ហូរទៅទិសខាងកើត ធ្វើឲ្យហូរត្រឡប់ ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចលោកុត្តរផល មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងទេវទត្តបំបែកសង្ឃ ចប់

រឿង ព្រះកាលត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះកាលត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ សាសនំ** ជាដើម ។

បានឮមកថា ស្រីម្នាក់ក្នុងក្រុងសាវត្ថី តាំងនៅក្នុងនាទីជាមាតា ទំនុកបម្រុងព្រះថេរៈ ។ ពួកមនុស្សក្នុងផ្ទះនៃបុគ្គលស្និទ្ធស្នាលរបស់ស្រីនោះ ស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តាហើយ ត្រឡប់មកកាន់ផ្ទះសរសើរថា ឱ ឈ្មោះថាព្រះពុទ្ធទាំងឡាយអស្ចារ្យ ឱ ព្រះធម្មទេសនាក៏ពីរោះ ។ ស្រីនោះស្តាប់ពាក្យរបស់មនុស្សទាំងនោះហើយ ទើបប្រាប់ដល់ព្រះកាលៈថា បពិត្រលោកម្ចាស់ ខ្ញុំចង់ស្តាប់ធម៌របស់ព្រះសាស្តា ។ ព្រះថេរៈឃាត់ថា កុំទៅទីនេះឡើយ ។ ស្រីនោះក្នុងថ្ងៃស្អែកឡើងក៏សូមទៀត សូម្បីព្រះកាលៈនោះឃាត់អស់ ៣ ដងក៏នៅតែចង់ស្តាប់នោះឯង ។ មានពាក្យសួរជ្រៀតចូលមកថា ហេតុអ្វី ទើបព្រះថេរៈហាម ឆ្លើយថា បានឮថា លោកយល់ឃើញដូច្នេះថា ឧបាសិកានេះបានស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តាហើយ និងបែកអំពីអញ ហេតុនោះទើបឃាត់ ។

ថ្ងៃមួយ ស្រីនោះបរិភោគអាហារស្រេច សមាទានឧបោសថហើយ ប្រាប់កូនស្រីថា ចូរនាងអង្គាសលោកម្ចាស់ឲ្យល្អ ហើយបានទៅកាន់វិហារអំពីព្រលឹម ចំណែកកូនស្រី ក៏អង្គាសព្រះកាលៈដោយផ្ទៃតផ្ទង់ ក្នុងកាលព្រះថេរៈមកក៏សួរថា ឧបាសិកាធំទៅណា ទារិកាឆ្លើយថា ទៅវិហារដើម្បីស្តាប់ធម៌ ។ គ្រាន់តែ

បានឮពាក្យនោះ ញាប់ញ័រព្រោះការតានតឹងតាំងឡើងខាងក្នុង គិតថា ឥឡូវនេះ ឧបាសិកានោះបែកអំពីអញហើយ ម្ចាស់ម្នាទៅ ឃើញស្រីនោះស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ទើបទូលព្រះសាស្តាថា បពិត្រព្រះអង្គ ស្រីនេះល្ងង់ខ្លៅ មិនយល់ធម្មកថាដែលល្អិតជ្រាលជ្រៅទេ សូមទ្រង់កុំត្រាស់ធម្មកថាដែលជាបរមត្ថដោយសភាវធម៌ មានខន្ធជាដើមឡើយ ត្រាស់ត្រឹមតែទានកថា និងសីលកថាក៏គ្រប់គ្រាន់ ។

ព្រះសាស្តា ទ្រង់ជ្រាបអធ្យាស្រ័យរបស់ព្រះថេរៈហើយ ត្រាស់ថា អ្នកជាបុគ្គលអប្បឥតប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ឃាត់នូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ អ្នកព្យាយាមដើម្បីសម្លាប់ខ្លួនឯង ហើយត្រាស់ព្រះគាថានេះថា

យោ សាសនំ អរហតំ អរិយានំ ធម្មជីវិនំ
បដិក្កោសតិ ទុម្មេធោ ទិដ្ឋិំ និស្សាយ បាបិកំ
ផលានិ កដ្ឋកស្សេវ អត្តឃញ្ញាយ ផល្គុតិ ។

បុគ្គលណាអប្បប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ហាមឃាត់សាសនារបស់ព្រះអរហន្តទាំងឡាយដ៏ប្រសើរ រស់នៅដោយធម៌ ការហាមឃាត់របស់បុគ្គលនោះ រមែងចេញផលដើម្បីសម្លាប់ខ្លួន ដូចផ្លែឫស្សី ដូច្នោះ ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា បុគ្គលណាអប្បប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ឃាត់នូវពួកជនដែលពោលថា ខ្ញុំនឹងស្តាប់ធម៌ក្តី ខ្ញុំនឹងថ្វាយទានក្តី ព្រោះខ្លាច

សាបសូន្យសក្ការៈរបស់ខ្លួន ឈ្មោះថាជំទាស់នឹងពាក្យប្រៀនប្រដៅរបស់ព្រះអរិយបុគ្គលដែលជាអរហន្ត មានប្រក្រតីរស់នៅដោយធម៌ គឺព្រះពុទ្ធ ការជំទាស់ក្តី ទិដ្ឋិដ៏ថោកទាបក្តីរបស់បុគ្គលនោះ រមែងដូចជាផ្លែរបស់ឈើមានបន្លា ពោលគឺឫស្សី ហេតុនោះ ឫស្សីកាលចេញផ្លែ រមែងចេញដើម្បីសម្លាប់ខ្លួនប៉ុណ្ណោះយ៉ាងណា បុគ្គលនោះរមែងកើតមកដើម្បីសម្លាប់ខ្លួន គឺកើតមកដើម្បីបំផ្លាញខ្លួនឯង ដូច្នោះ ។ សមដូចប្រពន្ធគាថា ដែលព្រះដ៏មានព្រះភាគត្រាស់ថា

ផ្លែចេក តែងសម្លាប់ដើមចេក ផ្លែឫស្សី តែងសម្លាប់ដើមឫស្សី ផ្លែបបុស តែងសម្លាប់ដើមបបុស សក្ការៈ តែងសម្លាប់បុរសអាក្រក់ ដូចជាគភិតែងសម្លាប់មេសេះអស្សតរៈ ។

ក្នុងកាលចប់ទេសនា ឧបាសិកាតាំងនៅក្នុងសោតាបត្តិផល ទេសនាមានប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយ ដូច្នោះឯង ។

រឿង ព្រះកាលត្តេរៈ ចប់

រឿង ឧបាសក ឈ្មោះ ចុល្លកាល

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកឈ្មោះចុល្លកាល ត្រាស់ព្រះធម្មទេសនានេះថា **អត្តនាវ កតំ បាបំ** *ជាដើម ។*

សេចក្តីពិស្តារ ថ្ងៃមួយ ពួកចោរជីកឧម្មគ្គដែលម្ចាស់ទ្រព្យទាំងឡាយ

ដេញតាមហើយ ទើបចោលបង្វេចកណ្ឌៈខាងមុខឧបាសក ដែលស្តាប់ធម៌ក្នុងវិហារអស់រាត្រី ដើរចេញអំពីវិហារអំពីព្រលឹម មកកាន់ក្រុងសាវត្ថីហើយ ពួកចោរក៏ចៀសចេញទៅ ដោយនយដែលពោលហើយ ក្នុងរឿងមហាកាលនោះឯង ពួកមនុស្សឃើញហើយ ពោលថា បុគ្គលនេះធ្វើចោរកម្មក្នុងរាត្រីហើយ ធ្វើនូវអាកប្បកិរិយាដូចស្តាប់ធម៌ត្រាច់ទៅ ចូរអ្នកទាំងឡាយ នាំគ្នាចាប់វាដូច្នេះហើយ វាយឧបាសកនោះ ។

ពួកនាងកុម្ភទាសីដើរទៅកំពង់ទឹក ជួបនូវហេតុនោះទើបពោលថា នែអ្នកទាំងឡាយ ចូរចៀសចេញទៅ បុរសនេះមិនធ្វើកម្មបែបនោះឡើយ ដូច្នេះហើយ ឲ្យមនុស្សទាំងនោះដោះលែងហើយ ចូលទៅកាន់វិហារ ប្រាប់ដល់ភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវពួកមនុស្សទាំងឡាយឲ្យវិនាសហើយ ខ្ញុំបានជីវិត ព្រោះអាស្រ័យពួកនាងកុម្ភទាសី ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះ ដល់ព្រះតថាគត ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុលកាលឧបាសកបានជីវិត ព្រោះអាស្រ័យនាងកុម្ភទាសីផងភាពដែលខ្លួនមិនបានធ្វើផង ព្រោះថា ធម្មតាសត្វទាំងនេះ ធ្វើបាបកម្មដោយខ្លួនឯងហើយ រមែងសៅហ្មងដោយខ្លួនឯងក្នុងអបាយ មាននរកជាដើម ។ ចំណែកសត្វទាំងឡាយ ធ្វើកុសលហើយ ទៅកាន់សុគតិ និងនិព្វាន រមែងឈ្មោះថា បរិសុទ្ធបានដោយខ្លួនឯង ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អត្តជា វ កតំ ចាបំ អត្តជា សង្ខិលិស្សតិ

អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធមានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃឲ្យបរិសុទ្ធពុំបានទេ ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា អកុសលកម្ម ជាកម្មដែលបុគ្គលណាធ្វើហើយដោយខ្លួន បុគ្គលនោះកាលសោយទុក្ខក្នុងអបាយ ៤ ឈ្មោះថា សៅហ្មងដោយខ្លួនឯង ចំណែកបាបដែលបុគ្គលណាមិនបានធ្វើដោយខ្លួនឯង បុគ្គលនោះ កាលទៅកាន់សុគតិ និងនិព្វាន ឈ្មោះថា បរិសុទ្ធដោយខ្លួនឯង ។ សេចក្តីបរិសុទ្ធ ពោល គឺកុសលកម្ម និងការមិនបរិសុទ្ធ ពោល គឺអកុសលកម្មជារបស់ចំពោះខ្លួន គឺរមែងឲ្យផលចំពោះខ្លួនរបស់សត្វអ្នកធ្វើទាំងឡាយ បុគ្គលដទៃធ្វើបុគ្គលដទៃឲ្យបរិសុទ្ធមិនបាន គឺឲ្យបរិសុទ្ធមិនបានឡើយ ឲ្យសៅហ្មងមិនបានដូចគ្នា ។

ក្នុងកាលចប់ទេសនា ចុលសកាលតាំងនៅហើយក្នុងសោតាបត្តិផល ព្រះធម្មទេសនាមានប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នា ដូច្នោះឯង ។

រឿង ឧចាសក ឈ្មោះ ចុលសកាល ចប់

រឿង ព្រះអត្តទត្តត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះអត្តទត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អត្តទត្តំ បរត្តេន** ជាដើម ។

សេចក្តីពិស្តារថា កាលព្រះសាស្តាត្រាស់ក្នុងកាលដែលទៀបបរិនិព្វាន ថា ម្នាលភិក្ខុទាំងឡាយ ដោយកាលកន្លងទៅ ៤ ខែបន្ទាប់អំពីថ្ងៃនេះ តថាគតនឹងបរិនិព្វាន ភិក្ខុប្រមាណ ៧០០ រូបដែលនៅជាបុថុជ្ជន កើតនូវសេចក្តីសង្វេគមិនលះសម្លាក់ព្រះសាស្តាឡើយ ប្រឹក្សាគ្នាថា អាវុសោ ពួកយើងធ្វើអ្វីហ្ន៎ ។

ចំណែកព្រះអត្តទត្តត្ថេរគិតថា បានឮថា ព្រះសាស្តានឹងបរិនិព្វានដោយកាលកន្លងទៅ ៤ ខែ ឯពួកយើងជាអ្នកមានរាគៈមិនទាន់ទៅជ្រាស កាលព្រះសាស្តាគង់ព្រះជន្មនៅ ព្យាយាមដើម្បីប្រយោជន៍ដល់អរហត្ត ព្រះថេរៈនោះមិនទៅសម្លាក់របស់ភិក្ខុទាំងឡាយ ។ លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងលោកថា អាវុសោ ហេតុអ្វី ទើបមិនមកកាន់សម្លាក់របស់ខ្ញុំ លោកមិនប្រឹក្សារឿងអ្វីមួយ ដូច្នេះហើយ នាំទៅកាន់សម្លាក់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ ភិក្ខុរូបនេះ រមែងធ្វើវត្តឈ្មោះនេះ ។

ព្រះអត្តទត្តត្ថេរនោះ សូម្បីព្រះសាស្តាត្រាស់ថា ហេតុអ្វី ទើបអ្នកធ្វើយ៉ាងនោះ ទើបក្រាបទូលថា បពិត្រព្រះអង្គ បានឮថា ទ្រង់នឹងបរិនិព្វានដោយកាលកន្លងទៅ ៤ ខែ ខ្ញុំព្រះអង្គព្យាយាមដើម្បីសម្រេចអរហត្តក្នុងកាលទ្រង់គង់ព្រះជន្មនៅនេះឯង ។

ព្រះសាស្តា ប្រទានសាធុការដល់ព្រះថេរៈនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមានសេចក្តីស្នេហាក្នុងតថាគត បុគ្គលនោះ គួរជាបុគ្គលដូចអត្តទត្ថភិក្ខុនេះ ព្រោះថា ជនទាំងឡាយបូជាដោយវត្ថុផ្សេងៗ មានគ្រឿងក្រអូបជាដើម រមែងមិនឈ្មោះថាបូជាតថាគត ឯបុគ្គលបូជាដោយការបដិបត្តិធម៌សមគួរដល់ធម៌ ឈ្មោះថា បូជាតថាគត ព្រោះដូច្នោះ ភិក្ខុរូបដទៃក៏គប្បីដូចអត្តទត្ថៈ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ

អត្តទត្ថមភិញ្ញាយ សទត្ថបសុតោ សិយា ។

បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍របស់ដទៃសូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្ជាប់ខ្ជួនក្នុងប្រយោជន៍របស់ខ្លួន (នោះ) ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា បុគ្គលជាគ្រហស្ថ មិនគប្បីញុំាងប្រយោជន៍របស់ខ្លួន សូម្បីប្រមាណមួយកាកណិកឲ្យវិនាស ព្រោះប្រយោជន៍អ្នកដទៃ សូម្បីមានតម្លៃរាប់ពាន់ ព្រោះថា ប្រយោជន៍របស់ខ្លួននៃបុគ្គលនោះឯង សូម្បីប្រមាណមួយកាកណិក ក៏គង់ញុំាងរបស់ទំពា ឬរបស់គួរបរិភោគឲ្យសម្រេចបាន ប្រយោជន៍របស់អ្នកដទៃមិនសម្រេចឡើយ ។ ចំណែកពីរបាទព្រះគាថាទាំងនេះ ព្រះដ៏មានព្រះភាគទ្រង់មិនត្រាស់យ៉ាងនោះ ត្រាស់ដោយមាតិកានៃកម្មដ្ឋាន ព្រោះដូច្នោះ ភិក្ខុតាំងចិត្តថា អញនឹងមិនញុំាងប្រយោជន៍របស់ខ្លួន

ឲ្យវិនាស ដូច្នេះហើយ មិនគប្បីញុាំងកិច្ចមានការជួសជុលព្រះចេតិយជាដើម ដែលកើតឡើងដល់សង្ឃ ឬវត្ត មានឧបជ្ឈាយវត្តជាដើមឲ្យវិនាស ព្រោះថា ភិក្ខុបំពេញអភិសមាចារិកវត្តឲ្យសម្បូរនោះឯង រមែងធ្វើឲ្យជាក់ច្បាស់នូវផលទាំងឡាយ មានអរិយផលជាដើម ព្រោះដូច្នោះ ការបំពេញវត្តឲ្យបរិបូណ៌នេះ ទើបឈ្មោះថា ជាប្រយោជន៍ដល់ខ្លួនពិត ។

ម្យ៉ាងទៀត ភិក្ខុណាមានវិបស្សនាដែលប្រារព្ធក្រៃលែងហើយ ប្រាថ្នាការចាក់ផ្ទុះថា អញនឹងត្រាស់ដឹងក្នុងថ្ងៃនេះៗ ឯង ដូច្នេះហើយ ប្រព្រឹត្ត ភិក្ខុនោះញុាំងវត្ត មានឧបជ្ឈាយវត្តជាដើមឲ្យវិនាសហើយ ក៏គប្បីធ្វើកិច្ចរបស់ខ្លួនឲ្យបាន ។ ភិក្ខុដឹងប្រយោជន៍របស់ខ្លួនបែបនោះ គឺកំណត់បានថា នេះជាប្រយោជន៍របស់អញ គប្បីជាអ្នកខ្វល់ខ្វាយប្រកបក្នុងប្រយោជន៍របស់ខ្លួននោះ ។

ក្នុងកាលចប់ទេសនា ព្រះថេរៈនោះបានតាំងនៅក្នុងអរហត្តផល ទេសនាបានជាប្រយោជន៍ដល់ភិក្ខុដែលប្រជុំគ្នាទាំងឡាយ ដូច្នោះឯង ។

រឿង ព្រះអត្តទត្តត្ថេរ ចប់

អត្តវគ្គទី ១២ ចប់

ភាគទី ៣៤

សុត្តន្តបិដក ខុទ្ទកនិកាយ

ធម្មបទគាថា លោកវគ្គទី ១៣

[២៣] បុគ្គល មិនគួរសេពធម៌ថោកទាប មិនគួរនៅដោយសេចក្តីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សចង្អៀតលោក ។

បុគ្គល មិនគួរប្រមាទក្នុងជុំជ្ជាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតីរមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

បុគ្គល គួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

បុគ្គល ឃើញពពុះទឹក យ៉ាងណា ឃើញព្រេញថ្លៃ យ៉ាងណា ស្តេចមច្ចុ មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ ។

អ្នកទាំងឡាយ ចូរមកមើលលោកនេះ ដ៏ត្រកាល ដូចរាជរថ ជនពាលទាំងឡាយ រមែងលិចលង់ ក្នុងលោកណា សេចក្តីជាប់ជំពាក់ ក្នុងលោកនោះ រមែងមិនមាន ដល់ជនជាបណ្ឌិតទាំងឡាយដែលដឹងច្បាស់ទេ ។

បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយ គេមិនប្រមាទវិញ បុគ្គលនោះ ឈ្មោះថា ញុំាងខន្ធាទិលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រះផុតចាកពពក ។

បុគ្គលណា ធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាបនោះដោយកុសល គឺអរហត្តមគ្គបាន បុគ្គលនោះឈ្មោះថា ញុំាងខន្ធាទិលោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រះផុតចាកពពក ។

លោកិយមហាជននេះ ជាមនុស្សងងឹត បណ្តាជនទាំងនេះ ជនតិចគ្នាដែលឃើញច្បាស់ (នូវខន្ធាទិលោកនេះ ដោយអំណាចអនិច្ចលក្ខណៈជាដើម) ជនតិចគ្នា ដែលទៅកាន់ស្ថានសួគ៌ ដូចសត្វស្វាប (ដែលជាប់សំណាញ់របស់ព្រានហើយ) តិចណាស់ ដែលរួចអំពីសំណាញ់ ដូច្នោះ ។

ពួកហង្ស តែងហើរទៅក្នុងគន្លងផ្លូវព្រះអាទិត្យ អ្នកមានឫទ្ធិ តែងហោះទៅក្នុងអាកាស ដោយឫទ្ធិ អ្នកប្រាជ្ញផ្តាញ់កិលេសមារ ព្រមទាំងវាហនៈគឺតណ្ហាបានហើយ រមែងរលាស់ខ្លួនចេញចាកលោកបាន ។ បុគ្គលប្រព្រឹត្តកន្ទង (ពាក្យសច្ចៈ) ដែលជាធម៌ឯក និយាយតែពាក្យកុហក មានបរលោក លះចោលហើយ ឈ្មោះថា មិនធ្វើអំពើបាប មិនមែនឡើយ ។

បុគ្គល កំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយ មិនសរសើរទានឡើយ ចំណែកអ្នកប្រាជ្ញ តែងអនុមោទនាទាន ព្រោះហេតុនោះ លោកតែងបានសេចក្តីសុខ ក្នុងលោកខាងមុខ ។ សោតាបត្តិផល ជាគុណជាតដ៏ប្រសើរ ជាងភាពនៃឯករាជ្យលើផែនដីផង ជាងដំណើរទៅកាន់ស្ថានសួគ៌ផង ជាងភាពជាធំ ក្នុងលោកទាំងមូលផង ។

លោកវគ្គទី ១៣ ចប់

អដ្ឋកថា

លោកវគ្គទី ១៣

រឿង ភិក្ខុកំលោះ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកំលោះមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **ហីនំ ធម្មំ** *ជាដើម ។*

បានឮថា ព្រះថេរៈមួយរូប មួយអន្ទើដោយភិក្ខុកំលោះ ទៅកាន់ផ្ទះរបស់នាងវិសាខាអំពីព្រលឹម បបរប្រចាំ រមែងជារបស់ដែលគេរៀបចំជានិច្ចដើម្បីភិក្ខុប្រមាណ ៥០០ រូប ក្នុងផ្ទះរបស់នាងវិសាខា ព្រះថេរៈឆាន់បបរហើយ ឲ្យភិក្ខុកំលោះអង្គុយលើផ្ទះរបស់នាងវិសាខានោះ ចំណែកខ្លួនបានទៅកាន់ផ្ទះមួយខ្នងដទៃទៀត ។ សម័យនោះ កូនស្រីរបស់កូននាងវិសាខាតាំងនៅក្នុងឋានៈរបស់យាយ ធ្វើការខ្វល់ខ្វាយដល់ភិក្ខុទាំងឡាយ ។ នាងត្រង់ទឹកដើម្បីភិក្ខុកំលោះនោះ ឃើញស្រមោលមុខរបស់ខ្លួនក្នុងថ្លាង ទើបសើច ភិក្ខុកំលោះសម្លឹងមើលនាងក៏សើច នាងឃើញភិក្ខុកំលោះនោះសើច ទើបពោលថា បុគ្គលជាច់ក្បាលរមែងសើច លំដាប់នោះ ភិក្ខុកំលោះជេរនាងថា នាងក៏ជាច់ក្បាល ម៉ែ និងឪរបស់នាង ក៏ជាច់ក្បាល នាងយំទៅកាន់សម្នាក់របស់ជីដូនក្នុងភេងជាយ កាលនាងវិសាខាពោលថា នែនាង តើនាងកើតអ្វី ទើប

ជ្រាប់សេចក្តីនោះ ។ នាងវិសាខាមកកាន់សម្នាក់របស់ភិក្ខុកំលោះហើយ ពោលថា បពិត្រលោកម្ចាស់ កុំក្រោធឡើយ ពាក្យនោះ មិនជាពាក្យធ្ងន់សម្រាប់លោកម្ចាស់ទេ បុគ្គលមានសក់ និងក្រចកកាត់ហើយ មានសំពត់ដណ្តប់កាត់ជាច់ហើយ កាន់អំបែងដែលកាត់ត្រង់កណ្តាល ត្រាច់ទៅដើម្បីភិក្ខា ។ ភិក្ខុកំលោះពោលថា អើ ឧបាសិកា នាងរមែងដឹងភាពដែលអាត្មាជាអ្នកមានសក់កាត់ជាច់ហើយជាដើម ការដែលចៅរបស់នាងជេរអាត្មាថា មនុស្សជាច់ក្បាលដូច្នេះ គួរឬ នាងវិសាខាមិនអាចឲ្យភិក្ខុកំលោះយល់ព្រមផង មិនអាចឲ្យនាងទាំកាយល់ព្រមផង ខណៈនោះ ព្រះថេរៈមកហើយ សួរថា តើមានរឿងអ្វី ឧបាសិកា ស្តាប់សេចក្តីនោះហើយ កាលពោលប្រៀនប្រដៅភិក្ខុកំលោះ ទើបពោលថា អាវុសោ ចូរលោកចៀសចេញទៅ ស្រីនេះ មិនបានជេរចំពោះលោក ដែលមានសក់ ក្រចក និងសំពត់កាត់ជាច់ហើយ ជាអ្នកមានអំបែងកាត់ត្រង់កណ្តាល ត្រាច់ទៅដើម្បីភិក្ខា ចូរលោកនៅស្ងៀម ភិក្ខុកំលោះពោលថា យ៉ាងនោះឯង លោកម្ចាស់ លោកម្ចាស់មិនគំរាមឧបជ្ឈាយិការបស់ខ្លួន គំរាមខ្ញុំតែម្យ៉ាង ការដែលនាងជេរខ្ញុំថា មនុស្សជាច់ក្បាល គួរឬ ។ ខណៈនោះ ព្រះសាស្តាយាងមក ត្រាស់សួរថា ម្នាលនាងវិសាខា តើមានរឿងអ្វី នាងវិសាខាក្រាបទូលព្រឹត្តិហេតុនោះ តាំងអំពីដើមដល់ចប់ ។

ព្រះសាស្តា ទ្រង់ឃើញឧបនិស្សយនៃសោតាបត្តិផលរបស់ភិក្ខុកំលោះនោះហើយ ទើបទ្រង់ព្រះតម្រិះថា តថាគតអនុលោមតាមភិក្ខុកំលោះនេះគួរដូច្នេះហើយ ទើបត្រាស់នឹងនាងវិសាខាថា ម្នាលនាងវិសាខា ទាំការបស់នាង

ជេរ ធ្វើសាវតែទាំងឡាយរបស់តថាគតឲ្យជាអ្នកមានក្បាលជាច់ ដោយហេតុត្រឹមតែមានសក់កោរហើយជាដើមនោះឯង គួរឬ ភិក្ខុកំលោះក្រោកទ្បើង ផ្គងអញ្ជលីក្នុងវំពេចនោះឯង ក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់រមែងជ្រាបបញ្ហានោះដោយល្អ ឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គ និងមហាឧបាសិកា មិនជ្រាបដោយល្អទ្បើយ ។ ព្រះសាស្តា ទ្រង់ជ្រាបភាពដែលទ្រង់ជាអ្នកអនុគ្រោះដល់ភិក្ខុកំលោះហើយ ត្រាស់ថា ឈ្មោះថា ការកើត គឺការសើច ប្រារព្ធកាមគុណជាធម៌ដ៏លាមក ម្យ៉ាងទៀត ការសេពធម៌ដែលឈ្មោះថាលាមក និងការនៅរួមជាមួយសេចក្តីប្រមាទ មិនគួរ ទើបត្រាស់ព្រះគាថាថា

ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ
មិច្ឆាទិដ្ឋិំ ន សេវេយ្យ ន សិយា លោកវឌ្ឍនោ ។

បុគ្គល មិនគួរសេពធម៌ថោកទាប មិនគួរនៅដោយសេចក្តីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សចង្រៃលើលោក ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ហីនំ ធម្មំ** *បានដល់ ធម៌ គឺបញ្ចកាម-គុណ ។ ពិតហើយ ធម៌ គឺបញ្ចកាមគុណនោះ ដែលជនថោកទាប ដោយហោចសត្វឧជ្ជ និងសត្វគោជាដើមគប្បីសេព ធម៌ គឺបញ្ចកាមគុណ រមែងឲ្យសត្វអ្នកសេពកើតក្នុងឋានៈទាំងឡាយ មាននរកជាដើមដ៏ថោកទាប ព្រោះហេតុនោះ ធម៌ គឺបញ្ចកាមគុណនោះ ទើបឈ្មោះថា ជាធម៌ថោកទាប បុគ្គលមិន*

គប្បីសេពធម៌ដ៏ថោកទាបនោះ ។ បទថា **បមាទេន** *សេចក្តីថា មិនគប្បីនៅរួមដោយសេចក្តីប្រមាទ មានការបណ្តែតបណ្តោយសតិជាលក្ខណៈ ។ បទថា* **ន សេវេយ្យ** *បានដល់ មិនគប្បីកាន់យកនូវមិច្ឆាទិដ្ឋិ ។ បទថា* **លោកវឌ្ឍនោ** *សេចក្តីថា បុគ្គលណាធ្វើយ៉ាងនេះ បុគ្គលនោះ រមែងឈ្មោះថា ជាមនុស្សចង្អៀតលោក ព្រោះហេតុនោះ មិនគប្បីជាមនុស្សចង្អៀតលោកឡើយ ព្រោះមិនធ្វើយ៉ាងនោះ ។*

ក្នុងកាលចប់ទេសនា ភិក្ខុកំលោះនោះតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាបានជាប្រយោជន៍ដល់ជនទាំងឡាយ ដែលប្រជុំគ្នាដូច្នេះឯង ។

រឿង ភិក្ខុកំលោះ ចប់

រឿង ព្រះចាតុសុទ្វោធនៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារព្ធព្រះបិតា ត្រាស់ព្រះធម្មទេសនានេះថា **ឧត្តិដ្ឋេ នប្បមជ្ជេយ្យ** *ជាដើម ។*

សេចក្តីពិស្តារថា សម័យមួយ ព្រះសាស្តាយាងទៅកាន់ក្រុងកបិលវត្ថុ ជាលើកទីមួយ មានការទទួលដែលព្រះញាតិទាំងឡាយធ្វើហើយ ។ ទ្រង់ទៅកាន់និគ្រោធារាម ទ្រង់និម្មិតខ្លួនចង្រ្កមក្នុងអាកាស ចង្រ្កមលើរតនចង្រ្កមនោះ ទ្រង់សម្តែងធម៌ដើម្បីទម្លាយមាននេះ របស់ពួកញាតិទាំងឡាយហើយ ព្រះញាតិ

ទាំងឡាយមានចិត្តជ្រះថ្លាហើយ ថ្វាយបង្គំ ចាប់តាំងអំពីព្រះបាទសុទ្ធោទន មហារាជ ។ ក្មៀងបោក្ខរព័ស្សិធ្លាក់ក្នុងសមាគមនៃព្រះញាតិនោះ ។ កាលមហាជនប្រារព្ធក្មៀងនោះ សន្ធូនាគ្នាហើយ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក្មៀងបោក្ខរ-ព័ស្សិក៏ធ្លាក់ក្នុងសមាគមនៃញាតិរបស់តថាគតដូចគ្នា ដូច្នេះហើយ ទើបត្រាស់វេស្សន្តរជាតក ។ បណ្តាព្រះញាតិដែលស្តាប់ព្រះធម្មទេសនាហើយ ចៀសចេញទៅ សូម្បីមួយអង្គ ក៏មិននិមន្តព្រះសាស្តា សូម្បីព្រះរាជាក៏ទ្រង់មិននិមន្តឡើយ ដោយទ្រង់ព្រះតម្រិះថា បុត្ររបស់អញ បើមិនមកកាន់ផ្ទះ តើនឹងទៅណា ដូច្នេះហើយ ក៏យាងទៅ ។ កាលទ្រង់យាងទៅហើយ ឲ្យមនុស្សតាក់តែងបបរជាដើម ឲ្យក្រាលអាសនៈទាំងឡាយ ដើម្បីភិក្ខុប្រមាណ ២ ម៉ឺនរូប ក្នុងព្រះរាជមន្ទីរ ។

ស្អែកឡើង ព្រះសាស្តាយាងចូលទៅកាន់ព្រះនគរដើម្បីបិណ្ឌបាត ទ្រង់ពិចារណាថា ព្រះពុទ្ធក្នុងអតីតទាំងឡាយ យាងដល់ព្រះនគរព្រះបិតាហើយ យាងទៅកាន់ត្រកូលនៃព្រះញាតិតែម្តងឬហ្ន៎ ឬទៅដើម្បីបិណ្ឌបាតដោយលំដាប់ ទ្រង់ឃើញថា ទៅបិណ្ឌបាតដោយលំដាប់ ដូច្នេះហើយ ទើបយាងទៅដើម្បីបិណ្ឌបាតតាំងអំពីផ្ទះទីមួយ ។ រាហុលមាតា ប្រថាប់គង់លើប្រាសាទឃើញហើយ ទើបក្រាបទូលបវត្តិហេតុនោះដល់ព្រះរាជា ព្រះរាជាទ្រង់រៀបចំសំពត់សាដក ម្ចីម្នាយាងចេញទៅ ថ្វាយបង្គំព្រះសាស្តាហើយ ត្រាស់ថា បពិត្រអយ្យបុត្រ ព្រោះហេតុអ្វី ទើបបុត្រធ្វើឲ្យបិតាវិនាស បុត្រត្រាច់ទៅដើម្បីភិក្ខា

ឲ្យនូវការខ្មាសកើតឡើងហើយដល់បិតាពន់ពេក ឈ្មោះថា កម្មមិនគួរធ្វើ បុត្រធ្វើបានហើយ ការដែលបុត្រត្រាច់ទៅដោយរវាសជាដើម ត្រាច់ទៅដើម្បីភិក្ខាក្នុងនគរនេះឯង ទើបគួរ កូនកុំធ្វើឲ្យបិតាខ្មាសគេឡើយ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ តថាគតមិនមែនឲ្យទ្រង់ខ្មាសឡើយ តែតថាគតប្រព្រឹត្តតាមវង្សត្រកូលរបស់ខ្លួន ព្រះរាជាត្រាស់ថា បពិត្រអយ្យបុត្រ ការត្រាច់ទៅដើម្បីភិក្ខារស់នៅ ជាវង្សរបស់ខ្ញុំឬ ព្រះសាស្តាត្រាស់ថា មហាបពិត្រ នុ៎ះមិនមែនជាវង្សរបស់ទ្រង់ទេ តែជាវង្សរបស់តថាគត ព្រោះព្រះពុទ្ធមិនមែនមួយពាន់អង្គ ទ្រង់ឃាងទៅដើម្បីបិណ្ឌបាតហើយ រស់នៅដូចគ្នាជួច្នេះហើយ កាលទ្រង់សម្តែងធម៌ បានភាសិតគាថាទាំងនេះថា

ឧត្តិដ្ឋេ នប្បមជ្ជេយ្យ ធម្មំ សុចរិតំ ចរេ
ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច ។
ធម្មំ ចរេ សុចរិតំ ន តំ ទុច្ចរិតំ ចរេ
ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច ។

បុគ្គលមិនគួរប្រមាទក្នុងដំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេក

ជាសុខក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទ្វត្តិង្ហេ** *សេចក្តីថា ក្នុងជុំចុយដែលខ្ជួនគប្បីក្រោកឡើងទទួលត្រង់ទ្វារផ្ទះរបស់ជនដទៃ ។ បទថា* **ឆប្បមង្ឃេយ្យ** *សេចក្តីថា កិក្ខុកាលឲ្យទំនៀមរបស់អ្នកត្រាច់បិណ្ឌបាតជាប្រក្រតីវិនាសហើយ រមែងស្វែងរកកោជនដ៏ប្រណីត ឈ្មោះថា រមែងប្រមាទក្នុងជុំចុយ ដែលខ្ជួនគប្បីទទួលជាដើម តែបើត្រាច់ទៅតាមលំដាប់ច្រកដើម្បីបិណ្ឌបាត ឈ្មោះថា មិនប្រមាទ ។ ធ្វើយ៉ាងនេះ ឈ្មោះថា មិនប្រមាទក្នុងជុំចុយ ដែលខ្ជួនគប្បីក្រោកឡើងទទួល ។*

បទថា **ធម្មំ** *សេចក្តីថា កាលលះការស្វែងរកដែលមិនគួរហើយត្រាច់ទៅតាមលំដាប់ច្រក ឈ្មោះថាគប្បីប្រព្រឹត្តធម៌ គឺការត្រាច់ទៅដើម្បីភិក្ខានោះឯងឲ្យជាសុចរិត ។ ពាក្យថា* **សុខំ សេតិ** *នោះ ត្រឹមតែជាទេសនា អធិប្បាយថា កាលប្រព្រឹត្តធម៌ គឺការត្រាច់ទៅដើម្បីភិក្ខា ឈ្មោះថាប្រព្រឹត្តធម៌ជាប្រក្រតី រមែងនៅជាសុខដោយឥរិយាបថទាំង ៤ ក្នុងលោកនេះ និងលោកខាងមុខ ។*

ពីរបទថា **ឆ តំ ទុច្ចរិតំ** *សេចក្តីថា កាលត្រាច់ទៅក្នុងអគោចរ មានកន្លែងស្រីបេសប្យាជាដើម ឈ្មោះថា រមែងប្រព្រឹត្តធម៌ គឺការត្រាច់ទៅដើម្បីភិក្ខាឲ្យជាទុច្ចរិត មិនប្រព្រឹត្តយ៉ាងនោះ គប្បីប្រព្រឹត្តធម៌នោះ ឲ្យជាសុចរិត មិនគប្បីប្រព្រឹត្តធម៌នោះ ឲ្យជាទុច្ចរិតឡើយ ។ ពាក្យដ៏សេស មានអត្ថដូចពោលហើយ ។*

ក្នុងកាលចប់ទេសនា ព្រះរាជាតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់ជនទាំងឡាយដែលប្រជុំគ្នា ដូច្នេះឯង ។

រឿង ព្រះចាតុសុទ្ធោទនៈ ចប់

រឿង ភិក្ខុចម្រើនវិបស្សនា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចម្រើនវិបស្សនា មានប្រមាណ ៥០០ រូប ត្រាស់ព្រះធម្មទេសនានេះថា **យថា បុព្ពុឡកំ បស្ស** *ជាដើម ។*

បានឮថា ភិក្ខុទាំងនោះ រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តាហើយ ចូលទៅកាន់ព្រៃដើម្បីព្យាយាម ក៏មិនបានសម្រេចគុណវិសេស ទើបគិតថា ពួកយើងនឹងរៀនកម្មដ្ឋានឲ្យវិសេស កំពុងត្រឡប់មកកាន់សម្នាក់របស់ព្រះដ៏មានព្រះភាគ ឃើញថ្លៃបណ្តើរកូនក្នុងរវាងផ្លូវ ចម្រើនកម្មដ្ឋាន មានថ្លៃបណ្តើរកូនជាអារម្មណ៍នោះឯងមកហើយ ។ ភ្លៀងធ្លាក់ក្នុងខណៈនៃភិក្ខុទាំងនោះចូលទៅកាន់វិហារនោះឯង ។ ភិក្ខុទាំងនោះ ឈរត្រង់យ៉ាមុខនោះ ឃើញពពុះទឹកទាំងឡាយតាំងឡើងហើយ បែកទៅដោយរហ័សដោយកម្លាំងខ្សែទឹក កាន់យកជាអារម្មណ៍ថា អត្តភាពនេះដូចគ្នានឹងដុំពពុះទឹក ព្រោះអត្តថា កើតឡើងហើយបែកទៅដូចគ្នា ។ ព្រះសាស្តា ប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់សម្ញឹង

មើលភិក្ខុទាំងនោះហើយ ទ្រង់ផ្សាយព្រះឱកាស ត្រាស់ជាមួយភិក្ខុទាំងនោះ ហើយ ដោយព្រះគាថានេះថា

យថា បុព្ពុឡកំ បស្សេ យថា បស្សេ មរីចិកំ
ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។

បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញព្រេញថ្ងៃយ៉ាងណា ស្តេចមច្ចុ មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មរីចិកំ** *គឺថ្ងៃបណ្តើរកូន ពិតហើយ ថ្ងៃបណ្តើរកូន សូម្បីប្រាកដឡើងអំពីចម្ងាយ ដោយអំណាចមានសណ្ឋានដូចផ្ទះជាដើម ជារបស់បុគ្គលនោះ ដល់នូវភាពជារូបដែលកាន់យកមិនបាន ជារបស់ទទេពិត គឺរមែងប្រាកដដល់ជនទាំងឡាយដែលចូលទៅជិត ព្រោះហេតុនោះ ទើបមានអធិប្បាយថា ស្តេចមច្ចុ រមែងមិនឃើញបុគ្គលដែលពិចារណាឃើញនូវលោក មានខន្ធជាដើម ដូចបុគ្គលគប្បីឃើញពពុះទឹក ព្រោះអត្តថា កើតឡើងហើយបែកទៅ និងដូចបុគ្គលឃើញថ្ងៃបណ្តើរកូន ព្រោះជាធម្មជាតិទទេជាដើមដូច្នោះ ។*

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះសម្រេចអរហត្តហើយ ក្នុងទីដែលខ្លួនឈរនោះ ដូច្នេះឯង ។

រឿង ភិក្ខុចម្រើនវិបស្សនា ចប់

រឿង អភយរាជកុមារ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធអភយរាជកុមារ ត្រាស់ព្រះធម្មទេសនានេះថា **ឯវ បសន្នចិត្តំ លោកំ** ជាដើម ។

បានឮថា កាលអភយរាជកុមារនោះ បង្ក្រាបបច្ចន្តជនបទឲ្យស្ងប់រម្ងាប់ហើយ ព្រះបាទពិម្ពិសារដែលជាព្រះបិតា ទ្រង់ពេញព្រះហឫទ័យហើយ ព្រះរាជទានអ្នករថាំម្នាក់ ដែលឈ្លាសក្នុងការរាំ និងច្រៀងហើយ បានព្រះរាជទានរាជសម្បត្តិ ៧ ថ្ងៃ ។ អភយរាជកុមារនោះ មិនយាងចេញខាងក្រៅព្រះរាជដំណាក់ឡើយ សោយសិរីនៃភាពជាព្រះរាជាអស់ ៧ ថ្ងៃ យាងទៅកាន់កំពង់ទឹកក្នុងថ្ងៃទី ៨ ទ្រង់ស្រង់ហើយ ចូលទៅកាន់ព្រះរាជឧទ្យាន គង់ប្រថាប់ទតការរាំ និងការច្រៀងរបស់ស្រីនោះ ដូចសន្តតិមហាមាត្យដែរ ។ ក្នុងខណៈនោះឯង ស្ត្រីនោះក៏បានធ្វើកាលកិរិយា ដោយអំណាចគំនរទ្រាំលែងមុតដូចសស្ត្រា ដូចអ្នករថាំរបស់សន្តតិមហាមាត្យដែរ ព្រះរាជកុមារមានសេចក្តីសោកកើតឡើងហើយ ព្រោះកាលកិរិយារបស់ស្រីរថាំនោះ ទ្រង់ព្រះតម្រិះថា អ្នកជនៃវៀរព្រះសាស្តាចេញ មិនអាចឲ្យសេចក្តីសោករបស់អញនេះ រម្ងាប់បានឡើយ ដូច្នេះហើយ ទើបចូលទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ឲ្យសេចក្តីសោករបស់ខ្ញុំព្រះអង្គរលត់ចុះ ។

ព្រះសាស្តា ទ្រង់លួងលោមព្រះរាជកុមារនោះហើយ ត្រាស់ថា កុមារ ប្រមាណនៃទឹកភ្នែកទាំងឡាយដែលអ្នកយំ ក្នុងកាលដែលស្រីនេះស្លាប់ហើយ

យ៉ាងនេះ ឲ្យប្រព្រឹត្តទៅហើយ រមែងមិនមានក្នុងសង្សារ ដែលមិនមានទីបំផុតខាងដើម ទ្រង់ជ្រាបភាពដែលសេចក្តីសោក មានសភាពធូរស្រាលព្រោះទេសនានោះហើយ ទើបត្រាស់ថា ម្នាលកុមារ អ្នកកុំសោកឡើយ សេចក្តីនោះ ជាហានៈដែលលិចចុះរបស់ជនពាលទាំងឡាយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ
យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ ។

អ្នកទាំងឡាយ ចូរមកមើលលោកនេះដ៏ត្រកាល ដូចរាជរថ ជនពាលទាំងឡាយ រមែងលិចលង់ក្នុងលោកណា សេចក្តីជាប់ជំពាក់ក្នុងលោកនោះ រមែងមិនមានដល់ជនជាបណ្ឌិតទាំងឡាយ ដែលដឹងច្បាស់ទេ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ឯថ បស្សថ** *ព្រះសាស្តាត្រាស់សំដៅយកព្រះរាជកុមារនោះឯង ។ ពីរបទថា* **ឥមំ លោកំ** *បានដល់ អត្តភាពពោល គឺខន្ធលោកជាដើមនេះ ។ បទថា* **ចិត្តំ** *សេចក្តីថា ដែលវិចិត្រដោយគ្រឿងប្រដាប់ មានគ្រឿងប្រដាប់ គឺសំពត់ជាដើម ដូចរាជរថដែលវិចិត្រដោយគ្រឿងប្រដាប់ មានកែវ ៧ ប្រការជាដើម ។ ពីរបទថា* **យត្ថ ពាលា** *សេចក្តីថា បុគ្គលពាលល្ងង់ខ្លៅប៉ុណ្ណោះ លិចលង់ក្នុងអត្តភាពណា ។ បទថា* **វិជានតំ** *សេចក្តីថា តែសម្រាប់ពួកអ្នកជ្រាជ្រ គឺបណ្ឌិតទាំងឡាយ មិនមាន*

ការជាប់ជំពាក់ក្នុងកិលេសជាគ្រឿងជាប់ជំពាក់ មានរាគៈជាដើមណាមួយក្នុងអត្តភាពនេះឡើយ ។

ក្នុងកាលចប់ទេសនា ព្រះរាជកុមារ តាំងនៅក្នុងសោតាបត្តិផលហើយ ព្រះធម្មទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នា ដូច្នេះឯង ។

រឿង អភយរាជកុមារ ចប់

រឿង ព្រះសម្មជ្ជនត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសម្មជ្ជនត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ ច បុព្ពេ បមជ្ជិត្វា** ជាដើម ។

បានឮថា ព្រះថេរៈនោះមិនធ្វើកាលឲ្យជាប្រមាណថា ព្រឹក ឬល្ងាច រមែងបោសច្រាសរឿយៗ ។ ថ្ងៃមួយ ព្រះថេរៈនោះកាន់អំបោសទៅកាន់សម្នាក់ព្រះរេវតៈ ដែលអគ្គិយទីសម្រាកពេលថ្ងៃ ហើយពោលថា ព្រះថេរៈនេះ ជាអ្នកខ្វិលច្រអូសច្រើន បរិភោគរបស់ដែលជនឲ្យដោយសទ្ធា ហើយមកអគ្គិយ ការដែលព្រះថេរៈនោះកាន់យកអំបោសហើយ បោសទីមួយកន្លែងមិនគួរឬ ព្រះថេរៈគិតថា អញនឹងឲ្យឱវាទលោក ដូច្នេះហើយ ទើបពោលថា មកនេះចុះ អាវុសោ ព្រះសម្មជ្ជនត្ថេរពោលថា មានការអ្វីលោកម្ចាស់ ព្រះរេវតត្ថេរពោលថា សូមលោកទៅងូតទឹកហើយ សឹមមក ។ ព្រះសម្មជ្ជនត្ថេរ

នោះ បានធ្វើយ៉ាងនោះហើយ លំដាប់នោះ ព្រះថេរៈឲ្យលោកអង្គុយក្នុងទីបំផុតនាចំណែកម្ខាង ហើយកាលពោលទូន្មាន ទើបពោលថា អាវុសោ ធម្មតាភិក្ខុដែលចោសសព្វកាលមិនគួរ ការដែលភិក្ខុចោសតែពេលព្រឹកហើយ ត្រាច់បិណ្ឌបាត ត្រឡប់អំពីបិណ្ឌបាតហើយ មកអង្គុយក្នុងទីសម្រាកពេលយប់ ឬទីសម្រាកពេលថ្ងៃ ស្វាធ្យាយអាការ ៣២ ផ្តើមចម្រើនទូវការអស់ទៅ សូន្យទៅក្នុងអត្តភាពហើយ ក្រោកឡើង ចោសក្នុងពេលល្ងាច ទើបគួរ ភិក្ខុមិនចោសអស់កាលជានិច្ច ហើយគប្បីធ្វើឱកាសដល់ខ្លួន ។ ព្រះសម្មជ្ជនត្ថេរនោះតាំងនៅក្នុងឱវាទរបស់ព្រះថេរៈហើយ មិនយូរប៉ុន្មាន ក៏សម្រេចអរហត្ត ។ ក្នុងទីនោះៗបានសុខហើយ ។

លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងព្រះសម្មជ្ជនត្ថេរនោះថា អាវុសោ សម្មជ្ជនៈ ក្នុងទីនោះៗ រាត់រាយ ព្រោះហេតុអ្វីទើបលោកមិនចោស ព្រះសម្មជ្ជនៈពោលថា អាវុសោ ខ្ញុំធ្វើហើយយ៉ាងនោះ ក្នុងកាលប្រមាទ ឥឡូវនេះ ខ្ញុំមិនប្រមាទហើយ ។

ភិក្ខុទាំងឡាយ ក្រាបទូលដល់ព្រះសាស្តាថា ព្រះថេរៈនេះព្យាករនូវអរហត្តផល ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង បុត្ររបស់តថាគតចោសក្នុងកាលប្រមាទក្នុងកាលមុន តែឥឡូវនេះ បុត្ររបស់តថាគត សម្ងំនៅដោយសេចក្តីសុខដែលកើតអំពីមគ្គផល ទើបមិនចោសជួចេះហើយ ត្រាស់ព្រះគាថានេះថា

យោ ច បុព្ពេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ

សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយ គេមិនប្រមាទវិញ បុគ្គលនោះ ឈ្មោះថា ញុំាងខន្ធាទិលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទរះផុតចាកពពក ។

សេចក្តីអធិប្បាយ

បណ្ឌិតគប្បីជ្រាបអត្ថនៃព្រះគាថានោះថា បុគ្គលណាប្រមាទហើយក្នុងកាលមុន ដោយការធ្វើវត្ត និងបដិវត្ត ដោយការស្វាធ្យាយជាដើម ក្រោយមក សម្ងំនៅដោយសុខដែលកើតអំពីមគ្គផល ឈ្មោះថា រមែងមិនប្រមាទបុគ្គលនោះ រមែងញុំាងលោក មានខន្ធជាដើមនេះឲ្យភ្លឺស្វាង គឺរមែងធ្វើឲ្យភ្លឺស្វាង ដូចគ្នាដោយមគ្គញ្ញាណ ដូចព្រះចន្ទផុតហើយចាកពពកជាដើម ញុំាងឱកាសលោកឲ្យភ្លឺស្វាង ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះសម្មជ្ជនត្ថេរ ចប់

រឿង អង្គុលីមាលត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអង្គុលីមាលត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យស្ស ចាបំ កតំ កម្មំ** ជាដើម ។

រឿងនេះ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃអង្គុលីមាលសូត្រនោះឯង ។ កាលព្រះថេរៈបួសក្នុងសម្នាក់របស់ព្រះសាស្តា សម្រេចអរហត្តហើយ ។ កាលនោះឯង ព្រះអង្គុលីមាលទៅហើយក្នុងទីស្ងាត់ សម្ងំនៅសោយវិមុត្តិសុខហើយ បន្ទឺឧទាននេះ ក្នុងកាលមុនថា

បុគ្គលណាប្រមាទហើយ ក្នុងកាលមុន ខាងក្រោយ មិនប្រមាទ
បុគ្គលនោះ រមែងញុំាងលោកឲ្យភ្លឺស្វាង ដូចព្រះចន្ទរួចហើយ
អំពីពពក ដូច្នោះ ។

កាលបន្ទឺឧទានហើយ ក៏បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោ ព្រះថេរៈកើតហើយក្នុងទីណាហ្ន៎ ព្រះសាស្តាយាងមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ ពួកអ្នកអង្គុយប្រជុំគ្នាដោយពាក្យសម្តីដូចម្តេចហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយពាក្យប្រារព្ធដល់ទីដែលកើតរបស់អង្គុលីមាលត្ថេរ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតបរិនិព្វានហើយ កាលភិក្ខុទាំងឡាយក្រាបទូលថា ព្រះអង្គុលីមាលត្ថេរ សម្លាប់មនុស្សមានប្រមាណប៉ុណ្ណេះ បរិនិព្វានហើយឬ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង

ព្រោះអង្គុលីមាលនោះ បាននូវបាបមិត្រ ទើបធ្វើនូវបាបមានប្រមាណប៉ុណ្ណោះ ក្នុងកាលមុន តែខាងក្រោយ អង្គុលីមាលបាននូវកល្យាណមិត្រជាបច្ច័យ ទើបជាបុគ្គលមិនប្រមាទ ហេតុនោះ បាបកម្មនោះ ដែលបុត្រប្រសប់តថាគតលះបានហើយ ដោយកុសល ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

យស្ស ចាបំ កតំ កម្មំ កុសលេន បិថីយតិ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

បុគ្គលណាធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាបនោះ ដោយកុសល គឺអរហត្តមគ្គបាន បុគ្គលនោះ ឈ្មោះថា ញុំាងខន្ធាទិលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទរះផុតចាកពពក ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កុសលេន** ព្រះសាស្តាត្រាស់សំដៅយកអរហត្តមគ្គ ពាក្យដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង អង្គុលីមាលត្ថេរ ចប់

រឿង កូនស្រីជាជនតម្បាញ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងចេតិយឈ្មោះអគ្គាឡវៈ ទ្រង់ប្រារព្ធធីតារបស់ជាងតម្បាញម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **អនុភូតោ អយំ លោកោ** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ពួកអ្នកក្រុងអាឡវី កាលព្រះសាស្តាយាងដល់ក្រុងអាឡវីហើយ បានទូលនិមន្តថ្វាយទានហើយ ។ ព្រះសាស្តា កាលទ្រង់ធ្វើអនុមោទនាក្នុងពេលស្រេចភត្តកិច្ច ទើបត្រាស់ថា អ្នកទាំងឡាយ ចូរចម្រើនមរណស្សតិយ៉ាងនេះថា ជីវិតរបស់យើងមិនស្ថិតស្ថេរ ការស្លាប់របស់យើងទៀង យើងគប្បីស្លាប់ពិត ជីវិតរបស់យើងមានសេចក្តីស្លាប់ជាទីបំផុត ជីវិតរបស់យើងមិនទៀង ការស្លាប់ទៀង ។ មរណៈដែលជនទាំងឡាយណាមិនចម្រើនហើយ ក្នុងកាលទីបំផុត ជនទាំងឡាយនោះ ដល់នូវការតក់ស្លុតស្រែកគួរឲ្យខ្លាច ធ្វើនូវកាលកិរិយា ដូចបុរសឃើញអាសិរពិសហើយ ភ័យខ្លាច ដូច្នោះ ចំណែកមរណៈដែលជនទាំងឡាយណាបានចម្រើនហើយ ជនទាំងឡាយនោះ រមែងមិនតក់ស្លុត ក្នុងកាលជាទីបំផុត ដូចបុរសឃើញអាសិរពិសអំពីចម្ងាយ ហើយយកកំណាត់ឈើឆ្ពិះចោល ហើយឈរ ដូច្នោះ ព្រោះដូច្នោះ មរណស្សតិ អ្នកទាំងឡាយ គប្បីចម្រើន ។

ពួកជនដ៏សេសស្តាប់ធម្មទេសនានោះហើយ បានជាអ្នកខ្វល់ខ្វាយក្នុងកិច្ចរបស់ខ្លួនតែម្យ៉ាង ចំណែកធីតារបស់ជាងតម្បាញ អាយុ ១៦ ឆ្នាំម្នាក់គិតថា ឱ ធម្មតាវាចារបស់ព្រះពុទ្ធទាំងឡាយអស្ចារ្យ អញចម្រើនមរណស្សតិ ទើប

គួរ ដូច្នេះហើយ ក៏ចម្រើនមរណស្សតិតែម្យ៉ាង អស់ថ្ងៃ និងយប់ ។ ចំណែក ព្រះសាស្តា យាងចេញអំពីក្រុងអាឡវីហើយ ដល់វត្តជេតពន កុមារិកានោះ ចម្រើនមរណស្សតិអស់ ៣ ឆ្នាំនោះឯង ។ សម័យមួយ ព្រះសាស្តាប្រមើលមើលលោកក្នុងពេលជិតភ្លឺ ទ្រង់ឃើញនាងកុមារិកានោះ ចូលក្នុងសំណាញ់គឺព្រះញាណ ទ្រង់ពិចារណាថា តើមានហេតុអ្វីហ្ន៎ ជ្រាបថា កុមារិកានេះ ចម្រើនមរណស្សតិអស់ ៣ ឆ្នាំហើយ តាំងអំពីថ្ងៃដែលបានស្តាប់ធម៌របស់តថាគត ។ ឥឡូនេះ តថាគតនឹងទៅក្នុងទីនោះ ហើយសួរបញ្ហា ៤ ដល់កុមារិកានេះ កាលនាងឆ្លើយបញ្ហា នឹងឲ្យសាធុការក្នុងឋាន: ៤ ហើយ ភាសិតគាថា ក្នុងកាលចប់គាថា កុមារិកានោះតាំងនៅក្នុងសោតាបត្តិផល ព្រោះអាស្រ័យកុមារិកានោះ ទេសនានឹងមានប្រយោជន៍ដល់មហាជន ដូច្នេះហើយ មានភិក្ខុប្រមាណ ៥០០ រូបជាបរិវារ ចេញអំពីវត្តជេតពន ទៅកាន់អគ្គ-ទ្វារវិហារដោយលំដាប់ ។ អ្នកក្រុងអាឡវីជ្រាបថា ព្រះសាស្តាយាងមកហើយ ទើបទៅវិហារទូលនិមន្តហើយ សូម្បីកុមារិកានោះ ជ្រាបដំណើរយាងមករបស់ព្រះសាស្តា មានចិត្តត្រេកអរថា ព្រះមហាសមណគោតមសម្ពុទ្ធជាបិតា ជាធំ ជាអាចារ្យ ជាបុគ្គលមានព្រះភក្ត្រដូចព្រះចន្ទពេញវង់របស់អញយាងមកហើយ ទើបគិតថា ព្រះសាស្តា ទ្រង់មានពណ៌ដូចមាស ដែលអញធ្លាប់ឃើញកន្លងទៅ ៣ ឆ្នាំអំពីថ្ងៃនេះ ។ ឥឡូវនេះ អញនឹងបានឃើញព្រះសរីរៈដែលមានពណ៌ដូចមាស នឹងស្តាប់ធម៌ដែលជាឱវាទ ដែលមានឱជៈដ៏ពីរោះនៃព្រះសាស្តាអង្គនោះ ។

ចំណែកឪពុករបស់នាង កាលទៅកាន់ភេងតម្បាញបានជ្រាបថា នែនាង សំពត់សាដកដែលជារបស់អ្នកជនៃ អញលើកឡើង សំពត់នោះប្រមាណ ១ ចំអាមមិនទាន់ស្រេច អញនឹងឲ្យសំពត់នោះស្រេចក្នុងថ្ងៃនេះ នាងត្បាញឲ្យ រួច ហើយគប្បីនាំមកឲ្យដល់អញដោយរហ័ស ។ កុមារិកានោះគិតថា អញ ជ្រាបថ្នានឹងស្តាប់ធម៌របស់ព្រះសាស្តា បិតាប្រើអញយ៉ាងនេះ អញស្តាប់ធម៌ របស់ព្រះសាស្តា ឬក៏ត្បាញឲ្យស្រេចហើយ នាំទៅឲ្យដល់បិតា កាលនោះ កុមារិកានោះ មានបរិវិតក្កថា កាលអញមិននាំអំបោះទៅឲ្យបិតា គប្បីទាត់ អញខ្លះ វាយអញខ្លះ ព្រោះដូច្នោះ អញត្បាញឲ្យស្រេចឲ្យដល់លោកហើយ សឹមទៅស្តាប់ធម៌ឯក្រោយ ដូច្នេះហើយ ទើបអង្គុយត្បាញលើតាំង ។ ពួកអ្នក ក្រុងអាឡវីអង្គាសព្រះសាស្តាហើយ បានទទួលបាត្រឈរដើម្បីអនុមោទនា ។ ព្រះសាស្តាប្រថាប់គង់ហើយដោយព្រះតម្រិះថា តថាគតអាស្រ័យកុលធីតាមក ហើយ អស់ចម្ងាយផ្លូវ ៣០ យោជន៍ កុលធីតានោះមិនមានឱកាសក្នុងថ្ងៃនេះ បើកុលធីតានោះបានឱកាស តថាគតនឹងធ្វើអនុមោទនា ។ បុគ្គលណាម្នាក់ក្នុង លោក ព្រមទាំងទេវលោក មិនអាចទូលពាក្យណាមួយនឹងព្រះសាស្តាដែល ទ្រង់ស្ងៀមយ៉ាងនោះបាន ។ កុមារិកានោះ ត្បាញហើយ ជាក់ក្នុងកំប្រោង ដើរ ទៅកាន់សម្នាក់របស់ឪពុក ដល់ទីបំផុតរបស់បរិស័ទហើយ ដើរបណ្តើរ សម្លឹង មើលព្រះសាស្តាបណ្តើរ ហួសទៅ ។ សូម្បីព្រះសាស្តា ក៏ទ្រង់ឆ្វៀងព្រះនេត្រ ទតកុមារិកានោះ កុមារិកានោះបានជ្រាបហើយដោយអាការ ដែលព្រះសាស្តា ទតដូចគ្នាថា ព្រះសាស្តាប្រថាប់គង់ក្នុងកណ្តាលបរិស័ទបែបនោះទតអញ ទ្រង់

ទន្ទឹងការមកបស់អញ ទ្រង់បំណងការមកកាន់សម្នាក់របស់ទ្រង់នោះឯង នាងជាក់កំប្រោងហើយ បានទៅកាន់សម្នាក់របស់ព្រះសាស្តា សួរថា ព្រោះហេតុអ្វី ទើបព្រះសាស្តាទតកុមារិកានោះ ឆ្លើយថា បានឮថា ទ្រង់បរិវិតក្កយ៉ាងនេះថា កុមារិកានោះ កាលទៅអំពីទីនេះ ធ្វើកាលកិរិយាទាំងបុថុជ្ជន ជាអ្នកមានគតិមិនពិតប្រាកដ តែបើមកកាន់សម្នាក់តថាគតហើយសឹមទៅ សម្រេចសោតាបត្តិផលហើយ នឹងមានគតិពិតប្រាកដ កើតក្នុងតុសិតវិមាន ។ បានឮថា ថ្ងៃនោះ ឈ្មោះថា ការរួចផុតអំពីសេចក្តីស្លាប់ មិនមានដល់កុមារិកានោះ ។

កុមារិកានោះ ចូលទៅគាល់ព្រះសាស្តាហើយ ដោយសញ្ញាដែលព្រះសាស្តាទតនោះឯង នាងចូលទៅកាន់ចន្លោះនៃរស្មី ដែលមានពណ៌ ៦ ថ្វាយបង្គំហើយ ឈរនៅក្នុងទីសមគួរ នាចំណែកម្ខាង ។

ក្នុងខណៈដែលកុមារិកានោះ ថ្វាយបង្គំព្រះសាស្តា ដែលប្រថាប់គង់ស្ងៀមកណ្តាលបរិស័ទបែបនោះហើយកំពុងឈរ ព្រះសាស្តាត្រាស់ថា កុមារិកា នាងមកអំពីណា កុមារិកាទូលថា មិនដឹងទេព្រះអង្គ ព្រះសាស្តាសួរថា នាងនឹងទៅក្នុងទីណា កុមារិកាទូលថា មិនដឹងទេព្រះអង្គ ព្រះសាស្តាត្រាស់ថា នាងមិនដឹងឬ កុមារិកាទូលថា ដឹងព្រះអង្គ ព្រះសាស្តាត្រាស់សួរថា នាងដឹងឬ កុមារិកាទូលថា មិនដឹងទេព្រះអង្គ ។ ព្រះសាស្តាត្រាស់សួរបញ្ហា ៤ នឹងកុមារិកានោះ ដោយប្រការដូច្នេះ ។

មហាជនពោលទោសថា អ្នកនិរទុក្ខទាំងឡាយ ចូរអ្នកទាំងឡាយមើលកូនស្រីជាងតម្បាញនេះ និយាយពាក្យដែលខ្លួនប្រាថ្នាហើយ ជាមួយព្រះសម្ពុទ្ធ

កាលព្រះសម្មាសម្ពុទ្ធត្រាស់ថា នាងមកអំពីណា កូនស្រីជាងតម្បាញនេះគួរពោលថា មកអំពីផ្ទះរបស់ជាងតម្បាញ កាលត្រាស់សួរថា នាងនឹងទៅណា គួរពោលថា ទៅរោងជាងតម្បាញ មិនមែនឬ ព្រះសាស្តាទ្រង់ធ្វើមហាជនឲ្យស្ងាត់ហើយ ត្រាស់សួរថា កុមារិកា នាង កាលតថាគតពោលថា មកអំពីណា ហេតុអ្វី ទើបនាងឆ្លើយថា មិនដឹង កុមារិកាទូលថា បពិត្រព្រះអង្គ ទ្រង់ជ្រាបដែលខ្ញុំម្ចាស់មកអំពីផ្ទះជាងតម្បាញ តែទ្រង់កាលត្រាស់សួរថា នាងមកអំពីណា ទ្រង់ចង់សួរថា នាងមកអំពីណា កើតក្នុងទីនេះ តែខ្ញុំម្ចាស់មិនជ្រាបថា អាត្មាអញមកអំពីណា ទើបកើតក្នុងទីនេះ ។

លំដាប់នោះ ព្រះសាស្តា ប្រទានសាធុការទីមួយ ដល់កុមារិកានោះថា សាធុ សាធុ កុមារិកា បញ្ហាដែលតថាគតសួរហើយនោះឯង នាងឆ្លើយបានហើយ ហើយត្រាស់សួរតទៅថា កាលតថាគតសួរហើយថា នាងនឹងទៅក្នុងទីណា ព្រោះហេតុអ្វី ទើបពោលថាមិនដឹង កុមារិកាទូលថា បពិត្រព្រះអង្គ ទ្រង់ជ្រាបខ្ញុំម្ចាស់ ដែលកាន់កំប្រោងដើរទៅកាន់រោងជាងតម្បាញ ទ្រង់មានបំណងសួរថា នាងទៅអំពីលោកនេះហើយ នឹងកើតក្នុងទីណា ខ្ញុំម្ចាស់ចុតិអំពីលោកនេះហើយ មិនដឹងថា នឹងទៅកើតក្នុងទីណាទេ ។

លំដាប់នោះ ព្រះសាស្តាប្រទានសាធុការដល់នាងជាលើកទីពីរថា បញ្ហាដែលតថាគតសួរហើយនោះឯង នាងឆ្លើយបានហើយ ហើយត្រាស់សួរក្នុងបទតទៅថា បើដូច្នោះ កាលតថាគតសួរថា មិនដឹងឬ ព្រោះហេតុអ្វី ទើបពោលថា ដឹង កុមារិកាទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់រមែងដឹងនូវការៈ គឺការស្ងាប់

របស់ខ្ញុំម្ចាស់ប៉ុណ្ណោះ ហេតុនោះ ទើបក្រាបទូលយ៉ាងនោះ ។

លំដាប់នោះ ព្រះសាស្តាប្រទានសាធុការដល់នាងលើកទី ៣ ថា បញ្ហាដែលតថាគតសួរហើយនោះឯង នាងឆ្លើយបានហើយ ហើយត្រាស់សួរសេចក្តីតទៅថា កាលបើដូច្នោះ កាលតថាគតសួរថា នាងរមែងជីងឬ ព្រោះហេតុអ្វី ទើបពោលថា មិនជីង កុមារិកាទូលថា ខ្ញុំម្ចាស់រមែងជីងតែការៈ គឺការស្លាប់របស់ខ្ញុំម្ចាស់ប៉ុណ្ណោះ តែមិនជីងថា ស្លាប់ក្នុងពេលយប់ ពេលថ្ងៃ ឬពេលព្រឹកជាដើម ក្នុងកាលឈ្មោះនោះ ព្រោះហេតុនោះ ទើបពោលយ៉ាងនោះ ។

លំដាប់នោះ ព្រះសាស្តាប្រទានសាធុការលើកទី ៤ ដល់នាងថា បញ្ហាដែលតថាគតសួរហើយ នាងឆ្លើយបានហើយ ទើបត្រាស់ជាសំតៀនបរិសទ្ធថា ពួកអ្នកមិនជីងពាក្យប្រមាណប៉ុណ្ណោះ ដែលកុមារិកានេះពោលហើយ រមែងពោលទោសតែម្យ៉ាងប៉ុណ្ណោះ ព្រោះចក្ខុ គឺបញ្ញារបស់ជនទាំង-ឡាយណាមិនមាន ជនទាំងឡាយនោះ ដូចជាខ្វាក់នោះឯង ចក្ខុ គឺបញ្ញារបស់ជនណាមាន ជនទាំងនោះឯង ដូចជាអ្នកមានភ្នែកភ្លឺ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ
សកុណ្ដោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ។

លោកិយមហាជននេះ ជាមនុស្សខ្វងងឹត បណ្តាជនទាំងនេះ ជនតិចគ្នា ដែលឃើញច្បាស់ (នូវខន្ធាទិលោកនេះ ដោយអំណាចអនិច្ចលក្ខណៈជាដើម) ជនតិចគ្នា ដែល

ទៅកាន់ស្ថានសួគ៌ ដូចសត្វស្វាប (ដែលជាប់សំណាញ់
របស់ព្រានហើយ) តិចណាស់ ដែលរួចអំពីសំណាញ់
ដូច្នោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **អយំ លោកោ** *សេចក្តីថា លោកិយ-*
មហាជន ឈ្មោះថា ដូចមនុស្សភ្នែកខ្វាក់ ព្រោះមិនមានចក្ខុ គឺបញ្ញា ។ ពីរ
បទថា **តនុកេត្ត** *សេចក្តីថា ជនក្នុងលោកនេះ តិចគ្នា គឺមិនច្រើន ដែល*
ឃើញច្បាស់ដោយអំណាចនៃត្រៃលក្ខណ៍ មានមិនទៀងជាដើម ។ បទថា
ជាលមុត្តោវ *សេចក្តីថា បណ្តាហ្វូងបក្សី គឺចាប ដែលនាយព្រានអ្នកឈ្លាស*
វាយដោយសំណាញ់ចាប់យក សត្វចាបតិចតួចប៉ុណ្ណោះ រមែងរួចផុតសំណាញ់
បាន ចាបជើសេស រមែងចូលទៅខាងក្នុងសំណាញ់ទាំងអស់ យ៉ាងណា បណ្តា
សត្វដែលសំណាញ់ គឺមារបបួរមហើយ សត្វជាច្រើន រមែងទៅកាន់អបាយ
តិចគ្នា គឺបុគ្គលខ្លះប៉ុណ្ណោះ ទៅក្នុងស្ថានសួគ៌ គឺដល់សុគតិ ឬព្រះនិព្វាន
ដូច្នោះ ។

ក្នុងកាលចប់ទេសនា កុមារិកានោះ បានតាំងនៅក្នុងសោតាបត្តិផល
ទេសនាមានប្រយោជន៍ដល់មហាជន ដូច្នោះ ។

កុមារិកានោះ កាន់កំប្រោងអំបោះទៅកាន់សម្នាក់របស់បិតាហើយ
បិតានោះអង្គុយនិទ្រាហើយ កាលនឹងទៅមិនកំណត់ បង្អោនកំប្រោងចូល
ទៅ កំប្រោងប៉ះត្រង់ទីបំផុតត្រចៀក ឮសំឡេងធ្លាក់ទៅ បិតានោះភ្ញាក់ឡើង

ហើយ ទាញទីបំផុតត្រាល់ ដោយនិមិត្តដែលខ្លួនចាប់យកនោះឯង ទីបំផុតត្រាល់ទៅប្រហារកុមារិកានោះត្រង់ដើមទ្រូង នាងធ្វើកាលកិរិយាក្នុងទីនោះឯង កើតហើយក្នុងទីបំផុតភព លំដាប់នោះ បិតារបស់នាង សម្លឹងមើលឃើញកូនស្រីខ្លួនមានសរីរៈប្រឡាក់ដោយឈាមដួលស្លាប់ហើយ ។ លំដាប់នោះ សេចក្តីសោកដ៏ធំកើតឡើងដល់បិតានោះ ។ គាត់ទ្រហោយំ គិតថា បុគ្គលដទៃមិនអាចញុំាងសេចក្តីសោករបស់អញ ឲ្យរលត់បានឡើយ ទើបទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលសេចក្តីនោះថា បពិត្រព្រះអង្គ សូមទ្រង់ញុំាងសេចក្តីសោករបស់ខ្ញុំព្រះអង្គឲ្យរលត់ផងចុះ ។ ព្រះសាស្តា ទ្រង់លួងលោមបុរសនោះហើយ ត្រាស់ថា អ្នកកុំសោកឡើយ ព្រោះទឹកភ្នែកដែលហូរចេញហើយ ក្នុងកាលដែលស្លាប់នៃកូនស្រីរបស់អ្នក ដោយអាការយ៉ាងនេះ ក្នុងសង្សារដែលមិនមានទីបំផុតខាងដើម ទឹកភ្នែកនោះ ច្រើនជាងទឹកក្នុងមហាសមុទ្រទាំង ៤ ដូច្នេះហើយ ទើបត្រាស់អនមតគ្គសូត្រ ។ បុរសនោះមានសេចក្តីសោកស្រាកស្រួយ ទូលសូមបព្វជ្ជានឹងព្រះសាស្តា បានឧបសម្បទាហើយ ក្នុងកាលមិនយូរប៉ុន្មានសម្រេចអរហត្តហើយ ដោយប្រការដូច្នេះ ៕

រឿង កូនស្រីជាងតម្បាញ ចប់

រឿង ភិក្ខុ ៣០ រូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ ៣០ រូប ត្រាស់ព្រះធម្មទេសនានេះថា **ហាំសា អាទិច្ចបថេ យន្តិ** ជាដើម ។

សេចក្តីពិស្តារថា ក្នុងថ្ងៃមួយ ភិក្ខុមានប្រក្រតីនៅក្នុងទិសប្រមាណ ៣០ រូបចូលទៅគាល់ព្រះសាស្តា ។ ព្រះអានន្ទត្ថេរ មកក្នុងកាលដែលធ្វើវត្តជល់ព្រះសាស្តា ឃើញភិក្ខុទាំងនោះហើយគិតថា កាលព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយភិក្ខុទាំងនេះហើយអញនឹងធ្វើវត្ត ដូច្នេះហើយ បានឈរត្រង់ខ្ងោងទ្វារ ។ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយភិក្ខុទាំងនោះហើយ ក៏ត្រាស់កថាដែលប្រារព្ធធម៌ ជាគ្រឿងឲ្យរព្រឹកជល់គ្នានិងគ្នាជល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះស្តាប់ធម្មកថានោះហើយ សម្រេចអរហត្ត ហោះទៅតាមអាកាស ព្រះអានន្ទកាលភិក្ខុនោះយឺតយូរ ចូលទៅគាល់ព្រះសាស្តា ទូលសួរថា បពិត្រព្រះអង្គ ភិក្ខុប្រមាណ ៣០ រូបមកហើយក្នុងទីនេះ ភិក្ខុទាំងនោះទៅណា ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ទៅហើយ ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទៅដោយផ្លូវណា ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ទៅតាមអាកាស ព្រះអានន្ទសួរថា បពិត្រព្រះអង្គ ភិក្ខុទាំងនោះជាព្រះខីណាស្រពឬ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ យ៉ាងនោះឯង ភិក្ខុទាំងនោះ ស្តាប់ធម៌ក្នុងសម្នាក់តថាគតសម្រេចអរហត្តហើយ ។

ក្នុងខណៈនោះ ហង្សទាំងឡាយទៅដោយអាកាសហើយ ។ ព្រះសាស្តា

ត្រាស់ថា អានន្ទ ឥទ្ធិបាទ ៤ ដែលបុគ្គលណាចម្រើនល្អហើយ បុគ្គលនោះរមែងទៅដោយអាកាសដូចហង្សដូច្នោះ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

ហំសា ឥច្ចបថេ យន្តិ អាកាសេ យន្តិ ឥទ្ធិយា
នីយន្តិ ធីរា លោកម្ហា ជេត្វា មារំ សវាហនំ ។

ពួកហង្ស តែងហើរទៅក្នុងគន្លងផ្លូវព្រះអាទិត្យ អ្នកមានឫទ្ធិ តែងហោះទៅក្នុងអាកាសដោយឫទ្ធិ អ្នកប្រាជ្ញផ្ងាញ់កិលេសមារ ព្រមទាំងវាហនៈ គឺតណ្ហាបានហើយ រមែងរលាស់ខ្លួនចេញចាកលោកបាន ។

សេចក្តីអធិប្បាយ

បណ្ឌិតគប្បីជ្រាបអត្ថនៃព្រះគាថានោះថា ហង្សទាំងនេះ រមែងទៅក្នុងផ្លូវនៃព្រះអាទិត្យ គឺក្នុងអាកាស ។ ឥទ្ធិបាទដែលជនណាចម្រើនល្អហើយ ជនទាំងនោះ រមែងទៅក្នុងអាកាសដោយឫទ្ធិ ។ ធីរជនទាំងឡាយ គឺបណ្ឌិតឈ្មោះមារ មួយអន្ទើដោយវាហនៈហើយ រមែងចេញទៅ គឺរមែងរលាស់ចេញចាកលោក គឺវដ្តៈនេះ បានដល់ ដល់នូវព្រះនិព្វាន ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ភិក្ខុ ៣០ រូប ចប់

រឿង ចិញ្ចមាណវិកា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងចិញ្ចមាណវិកា ត្រាស់ព្រះធម្មទេសនានេះថា **ឯកំ ធម្មំ អតីតស្ស** ជាដើម ។

សេចក្តីពិស្តារថា ក្នុងបឋមពោធិកាល កាលសាវ័កបស់ព្រះទសពល មានច្រើន មិនមានប្រមាណ កាលពួកទេវតា និងមនុស្សឈមចុះកាន់អរិយភូមិ កាលការកើតឡើងនៃព្រះគុណរបស់ព្រះសាស្តាផ្សាយទៅហើយ លាភសក្ការៈជាច្រើនកើតឡើងហើយ ។ ពួកតិរ្ថិយ ជាបុគ្គលដូចគ្នានឹងពន្លឺអំពិលអំពែក ក្នុងកាលដែលព្រះអាទិត្យរះឡើង ជាអ្នកសាបសូន្យលាភសក្ការៈ ។ ពួកតិរ្ថិយទាំងនោះឈរត្រង់ចន្លោះផ្លូវ ប្រកាសឲ្យពួកមនុស្សដឹងច្បាស់យ៉ាងនេះថា ព្រះសមណគោតមប៉ុណ្ណោះឬជាព្រះពុទ្ធ ពួកយើងក៏ជាព្រះពុទ្ធ ទានដែលគេឲ្យហើយដល់ព្រះសមណគោតមនោះប៉ុណ្ណោះឬ មានផលច្រើន ទានដែលគេឲ្យហើយដល់ពួកយើងទាំងឡាយ ក៏មានផលច្រើនដូចគ្នា អ្នកទាំងឡាយចូរឲ្យ ចូរធ្វើដល់យើងទាំងឡាយខ្លះ ដូច្នេះហើយ បានលាភសក្ការៈហើយ ប្រជុំគ្នាក្នុងទីស្ងាត់ថា ពួកយើងគប្បីញុាំងទោសឲ្យកើតឡើងដល់ព្រះសមណគោតម ក្នុងរវាងមនុស្សទាំងឡាយ គប្បីញុាំងលាភសក្ការៈឲ្យវិនាសដោយឧបាយដូចម្តេចហ្ន៎ កាលនោះ ក្នុងក្រុងសាវត្ថី មានបរិព្វាជិកាម្នាក់ ឈ្មោះចិញ្ចមាណវិកាជាអ្នកទ្រទ្រង់នូវរូបធោម ដល់នូវការក្រៃលែងដោយសម្រស់ ដូចទេពអប្សរដូច្នោះ រស្មីរមែងផ្សាយចេញអំពីសរីរៈរបស់ស្ត្រីនោះ ។

លំដាប់នោះ តិរ្ថិយដែលជាអ្នកឈ្លាសវៃម្នាក់ពោលយ៉ាងនេះថា យើង

ទាំងឡាយ អាស្រ័យនាងចិញ្ចមាណវិកា គប្បីញុំាងទោសឲ្យកើតឡើងដល់ព្រះសមណគោតម ញុំាងលាភសក្ការៈឲ្យវិនាសបាន ។ តិរ្ថិយទាំងនោះទទួលថា ឧបាយនេះមាន ។ បន្ទាប់មក នាងចិញ្ចមាណវិកានោះទៅកាន់អារាមរបស់តិរ្ថិយ ថ្វាយបង្គំហើយឈរ ពួកតិរ្ថិយមិនពោលជាមួយនាងសោះ ទើបគិតថា អញមានទោសអ្វីហ្ន៎ សូម្បីពោលអស់វារៈ ៣ ដងថា លោកម្ចាស់ទាំងឡាយ ខ្ញុំថ្វាយបង្គំ ដូច្នេះហើយ ទើបពោលថា លោកម្ចាស់ទាំងឡាយ ខ្ញុំមានទោសអ្វីឬ ព្រោះហេតុអ្វី ទើបលោកម្ចាស់ទាំងឡាយមិននិយាយជាមួយខ្ញុំ ។

តិរ្ថិយពោលថា នែបួនស្រី នាងមិនជ្រាបទេឬ សមណគោតមបៀតបៀនយើងទាំងឡាយ ធ្វើយើងទាំងឡាយឲ្យវិនាសលាភសក្ការៈទាំងឡាយទេឬ ។ នាងចិញ្ចមាណវិកាពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនដឹងទេ ក្នុងរឿងនេះ ខ្ញុំគួរធ្វើដូចម្តេច តិរ្ថិយពោលថា នែបួនស្រី បើនាងប្រាថ្នាសេចក្តីសុខដល់យើងទាំងឡាយសោត ចូរញុំាងទោសឲ្យកើតឡើងដល់ព្រះសមណគោតមហើយ ញុំាងលាភសក្ការៈឲ្យវិនាសព្រោះអាស្រ័យនាង ។ នាងពោលថា សាធុ លោកម្ចាស់ទាំងឡាយ សេចក្តីនេះសូមជាការៈរបស់ខ្ញុំ លោកម្ចាស់ទាំងឡាយកុំគិតឡើយ ដូច្នេះហើយ ចៀសចេញទៅ ជណ្តប់សំពត់មានពណ៌ដូចមេភ្លៀង មានគ្រឿងក្រអូប និងកម្រងផ្កាជាដើមក្នុងដៃ បែរមុខទៅកាន់វត្តជេតពន ទៅក្នុងសម័យជាទីស្តាប់ធម្មកថា របស់អ្នកក្រុងសាវត្ថី ហើយចេញទៅអំពីវត្តជេតពន ។ តាំងអំពីកាលនោះ ព្រោះនាងជាអ្នកឈ្លាសក្នុងមាយារបស់ស្ត្រី កាលអ្នកដទៃសួរថា នាងទៅណាក្នុងពេលនេះ ទើបពោលថា ប្រយោជន៍អ្វី

របស់អ្នកទាំងឡាយ ដោយការដែលខ្ញុំទៅស្នាក់នៅក្នុងវត្តរបស់ពួកតិរ្ថិយ ក្នុងទីមិនឆ្ងាយអំពីវត្តជេតពន កាលឧបាសកចេញអំពីនគរអំពីព្រលឹម ដោយបំណងថា នឹងថ្វាយបង្គំព្រះដ៏មានព្រះភាគ នាងធ្វើអាកប្បកិរិយា ដូចនៅក្នុងវត្តជេតពន ចូលទៅកាន់ព្រះនគរ កាលឧបាសកសួរថា នាងនៅទីណា ទើបពោលថា ប្រយោជន៍អ្វីរបស់អ្នកទាំងឡាយដោយការរបស់ខ្ញុំ ។ កន្ទងទៅ ១ ឬ ២ ខែ កាលគេសួរ ទើបពោលថា ខ្ញុំនៅក្នុងព្រះគន្ធកុដិជាមួយព្រះសមណ-គោតម ក្នុងវត្តជេតពន ញុំាងសេចក្តីសង្ស័យឲ្យកើតឡើងដល់បុថុជ្ជនទាំង-ឡាយថា សេចក្តីនោះ ពិត ឬមិនពិតហ្ន៎ ។ លុះកន្ទងទៅ ៣-៤ ខែ យកកំណាត់សំពត់រុំពោះសម្តែងកេទរបស់ស្រីមានគភ៌ ឲ្យពួកជនអន្ធពាលកាន់យកថា គភ៌កើតឡើងព្រោះអាស្រ័យព្រះសមណគោតម លុះកន្ទងទៅ ៨ ឬ ៩ ខែ ចងឈើមូលត្រង់ពោះ ជណ្តប់សំពត់ខាងលើ ឲ្យវាយដៃ និងជើង ដោយឈើដែលមានចម្ការមដូចចង្កាគោ សម្តែងអាការហើមឡើង មានឥន្ទ្រិយទន់ខ្សោយ ។ កាលព្រះតថាគតប្រថាប់គង់សម្តែងធម៌លើធម្មាសនៈ ដែលប្រជាប់ហើយក្នុងពេលល្ងាច ទៅកាន់ធម្មសភា ឈរចំពោះព្រះភក្ត្ររបស់ព្រះសាស្តា ហើយពោលថា មហាសមណៈ ទ្រង់គិតតែសម្តែងធម៌ដល់មហាជនប៉ុណ្ណោះ សំឡេងរបស់ព្រះអង្គពីរោះ ព្រះឱស្ឋរបស់ព្រះអង្គជិតល្អ ចំណែកខ្ញុំអាស្រ័យព្រះអង្គ មានគភ៌គ្រប់កំណត់ហើយ ទ្រង់មិនជ្រាបផ្ទះដែលជាទីប្រសូតសម្រាប់ខ្ញុំ ទ្រង់មិនជ្រាបគ្រឿងបរិហារគភ៌ មានសប្បិ និងប្រេងជាដើម បើទ្រង់មិនធ្វើ ក៏គួរប្រាប់ព្រះបាទកោសល ឬអនាថបិណ្ឌិក ឬ

នាងវិសាខាមហាឧបាសិកា បុគ្គលណាម្នាក់ បណ្តាឧបដ្ឋាកទាំងឡាយថា អ្នកចូរធ្វើកិច្ចដែលគួរធ្វើដល់នាងចិញ្ចមាណវិកានេះ ទ្រង់ជ័ងតែក្នុងរឿងអភិរម្យប៉ុណ្ណោះ ទ្រង់មិនជ័ងគព្ភបរិហារសោះ ដូចព្យាយាមចាប់លាមក គ្រវែងនូវមណ្ឌលព្រះចន្ទ ដូច្នោះ ជេរព្រះតថាគតកណ្តាលបរិស័ទហើយ ។

ព្រះតថាគតទ្រង់ផ្តាកធម្មកថាហើយ កាលទ្រង់បន្ទឺសីហនាទ ទើបត្រាស់ថា ម្នាលប្អូនស្រី ពាក្យដែលនាងពោលហើយ ពិត ឬមិនពិត តថាគតនឹងនាងប៉ុណ្ណោះរមែងដឹង នាងចិញ្ចមាណវិកាពោលថា យ៉ាងនោះឯងមហាសមណៈ សេចក្តីនោះ កើតហើយ ដោយការដែលព្រះអង្គនឹងខ្ញុំដឹងហើយ ។

ខណៈនោះ អាសនៈរបស់សក្កៈសម្តែងអាការក្តៅ សក្កៈទ្រង់ពិចារណាដឹងថា នាងចិញ្ចមាណវិកាជេរព្រះសាស្តាដោយពាក្យមិនពិត ហើយទ្រង់ព្រះតម្រិះថា អញនឹងជម្រះរឿងនេះឲ្យបរិសុទ្ធ ទើបយាងមកជាមួយទេវបុត្រ ៤ អង្គ ។ ទេវបុត្រទាំងឡាយ កាឡាខ្លួនជាកូនកណ្តុរកាត់ខ្សែដែលចងដុំឈើមូលដោយកេរតែម្តងប៉ុណ្ណោះ ។ ខ្សែបក់ប៉ើងសំពត់ដណ្តប់ទ្បើង ឈើមូលធ្លាក់ចុះលើខ្នងជើងរបស់នាងចិញ្ចមាណវិកានោះ ។ ចុងជើងទាំងពីរបែកហើយ មនុស្សទាំងឡាយពោលថា នែនាងកាឡកិណី ហាងជេរព្រះសម្មាសម្ពុទ្ធ ស្តោះទឹកមាត់ជាក់លើក្បាលមានដៃកាន់ដុំដី និងអង្គត់ឧសទាញចេញអំពីវត្តជេតពន។

ក្នុងកាលនាងផុតគន្ធង់ព្រះនេត្រព្រះសាស្តាទៅ មហាប្រឹថពីបើកចន្លោះឲ្យហើយ អណ្តាតភ្លើងចេញមកអំពីអវីចី ។ នាងចិញ្ចមាណវិកានោះ ទៅកើតក្នុងអវីចី ដូចដណ្តប់សំពត់កម្ពលដែលត្រកួលឲ្យ ។ លាភសក្ការៈរបស់

ពួកតិរ្ថិយក៏សាបសូន្យទៅ បែរជាចម្រើនដល់ព្រះទសពលដោយប្រមាណ ក្រៃលែង ។

ក្នុងថ្ងៃស្អែកឡើង ពួកភិក្ខុសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ នាងចិញ្ចមាណវិកាជេរព្រះសម្មាសម្ពុទ្ធ ដែលគួរដល់ទក្ខិណាដ៏លើស ជាអ្នក មានគុណក្រៃលែងយ៉ាងនេះដោយពាក្យមិនពិត ដល់នូវសេចក្តីវិនាសធំហើយ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ ពួកអ្នក អង្គុយប្រជុំគ្នាដោយពាក្យអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយវាចា ឈ្មោះនេះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះប៉ុណ្ណោះក៏មិន មែន សូម្បីក្នុងកាលមុន នាងចិញ្ចមាណវិកានោះ ក៏ជេរតថាគតដោយពាក្យ មិនពិត ដល់នូវសេចក្តីវិនាសហើយដូចគ្នា ដូច្នេះហើយ ទើបទ្រង់ត្រាស់ មហាបទុមជាតក ក្នុងទ្វាទសកនិបាតឲ្យពិស្តារថា

ព្រះរាជាជាឥស្សរៈ បើមិនទាន់ឃើញទោសតូចធំ ដោយសព្វ គ្រប់ អំពីសម្នាក់បុគ្គលដទៃ ទាំងមិនទាន់ពិចារណា ឲ្យឃើញ ច្បាស់ដោយខ្លួនឯងទេ មិនគប្បីដាក់អាជ្ញាឡើយ ។

ព្រះសាស្តាត្រាស់ថា បានឮថា ក្នុងកាលនោះ នាងចិញ្ចមាណវិកានោះ ជាអ្នកបួសប្តី គឺមាតាចុងរបស់ព្រះពោធិសត្វ ព្រះនាមមហាបទុមកុមារ ជាអគ្គ-មហេសីរបស់ព្រះរាជា បបួលព្រះមហាសត្វដោយអសទ្ធម្ម មិនបានទូវការ យល់ព្រម របស់ព្រះពោធិសត្វនោះហើយ ធ្វើប្រការចម្លែកក្នុងខ្លួនដោយខ្លួន ឯង សម្តែងអាការធ្វើជាឈឺ ក្រាបទូលដល់ព្រះរាជាថា ព្រះរាជឱរសរបស់

ព្រះអង្គ ញុាំងខ្ញុំម្ចាស់ដែលមិនជ្រាបថ្នា ឲ្យដល់នូវប្រការចម្លែក ព្រះរាជាពិរោធ ទម្លាក់ព្រះពោធិសត្វក្នុងជ្រោះ ដែលជាទីទម្លាក់ពួកចោរ ។

លំដាប់នោះ ទេវតាដែលអាស្រ័យនឹងបាតភ្នំ ទទួលព្រះមហាសត្វនោះហើយ ឲ្យប្រតិស្ឋានលើពពារបស់ស្តេចនាគ ស្តេចនាគនាំព្រះមហាសត្វនោះ ទៅកាន់កពនាគ ទ្រង់ទទួលដោយរាជសម្បត្តិពាក់កណ្តាល ព្រះមហាសត្វនៅក្នុងកពនាគនោះអស់មួយឆ្នាំ ជ្រាបថ្នានឹងបួស ទើបមកកាន់ហេមវន្តប្បទេស បួសហើយ ឲ្យឈាន និងអភិញ្ញាកើតហើយ ។

បន្ទាប់មក ព្រានព្រៃម្នាក់ឃើញមហាសត្វ ទើបក្រាបទូលដល់ព្រះរាជា ព្រះរាជាយាងចូលទៅកាន់សម្នាក់របស់មហាសត្វនោះហើយ មានបដិសណ្ឋារៈដែលព្រះមហាសត្វធ្វើហើយ ទ្រង់ជ្រាបព្រឹត្តិហេតុទាំងអស់នោះ ទ្រង់យាងព្រះមហាសត្វឲ្យសោយសម្បត្តិ ព្រះមហាសត្វឲ្យឱវាទថា កិច្ចដោយរាជសម្បត្តិរបស់ទូលបង្គំមិនមាន ឯទ្រង់កុំធ្វើរាជធម៌ ១០ ប្រការឲ្យកម្រើក សូមទ្រង់លះនូវអគតិចោលហើយ សោយរាជសម្បត្តិដោយធម៌ចុះ ដូច្នេះហើយ ទ្រង់ក្រោកចាកអាសនៈ ព្រះកន្សែងយាងទៅកាន់ព្រះនគរ ទើបត្រាស់សួរអមាត្យទាំងឡាយក្នុងរវាងផ្លូវថា ខ្ញុំព្រាត់ប្រាសចាកកូនដែលសម្បូរដោយអាចារយ៉ាងនេះ ព្រោះអាស្រ័យអ្នកណា អមាត្យទូលថា បពិត្រព្រះអង្គ ព្រោះអាស្រ័យអគ្គមហេសីនោះឯង ។

ព្រះរាជាទ្រង់បញ្ជាឲ្យចាប់អគ្គមហេសីនោះ ឲ្យមានជើងឡើងលើហើយ បោះទៅក្នុងជ្រោះដែលគេចោលចោរ ហើយយាងចូលទៅកាន់នគរ សោយ

រាជសម្បត្តិដោយធម៌ ។ មហាបទុមកុមារក្នុងកាលនោះ បានជាព្រះមហាសត្វ ស្ត្រីរួមប្តីរបស់ព្រះមាតា បានជានាងចិញ្ចមាណវិកា ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាបាបកម្មដែលបុគ្គលលះពាក្យសត្យដែលជាធម៌ឯកហើយ តាំងនៅក្នុងមុសាវាទ ជាអ្នកមានបរលោកលះបង់ហើយ មិនគប្បីធ្វើ រមែងមិនមាន ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

ឯកំ ធម្មំ អតីតស្ស មុសាវាទិស្ស ជន្តុនោ
វិតិណ្ណបរលោកស្ស នត្ថិ បាបំ អការិយំ ។

បុគ្គលប្រព្រឹត្តកន្ទង (ពាក្យសច្ចៈ) ដែលជាធម៌ឯក និយាយតែពាក្យកុហក មានបរលោកលះចោលហើយ ឈ្មោះថា មិនធ្វើបាប មិនមែនទេ្បីយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឯកំ ធម្មំ** *គឺនូវពាក្យសត្យ ។ បទថា* **មុសាវាទិស្ស** *សេចក្តីថា បណ្តាពាក្យ ១០ ពាក្យ ពាក្យសត្យសូម្បីត្រឹមតែមួយ មិនមានដល់បុគ្គលណា បុគ្គលនេះ ឈ្មោះថា ជាបុគ្គលច្រើនដោយការពោលកុហក ។ បទព្រះគាថាថា* **វិតិណ្ណបរលោកស្ស** *បានដល់មានបរលោកលះបង់ហើយ បុគ្គលបែបនេះ រមែងមិនជួបនូវសម្បត្តិ ៣ គឺ មនុស្សសម្បត្តិ ទេវសម្បត្តិ និព្វានសម្បត្តិក្នុងអវសាន ។ ពីរបទថា* **នត្ថិ បាបំ** *សេចក្តីថា សេចក្តីសង្ស័យថា បាបឈ្មោះនេះ ដែលបុគ្គលនោះ គឺ*

បុគ្គលបែបនោះ មិនគប្បីធ្វើ ដូច្នេះ រមែងមិនមាន ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ចិញ្ចមាណវិកា ចប់

រឿង អសទិសទាន

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអសទិសទានត្រាស់ព្រះធម្មទេសនានេះថា **ន វេ កទរិយា** **ទេវលោកំ វជន្តិ** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ ព្រះសាស្តាយាងចារិកទៅហើយ មានភិក្ខុប្រមាណ ៥០០ ជាបរិវារ ទ្រង់ចូលទៅក្នុងវត្តជេតពន ។ ព្រះរាជាយាងទៅវិហារទូលនិមន្តព្រះសាស្តា ថ្ងៃស្អែកឡើងទ្រង់ត្រៀមអាគន្តុកទានហើយ ត្រាស់ហៅអ្នកនគរថា ចូរអ្នកមើលទានរបស់យើង អ្នកនគរមកឃើញទានរបស់ព្រះរាជាហើយ ក្នុងថ្ងៃស្អែកឡើងទូលនិមន្តព្រះសាស្តាត្រៀមទានហើយ បញ្ជូនជំណឹងទៅក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព សូមទ្រង់ទតទានរបស់ពួកខ្ញុំព្រះអង្គ ព្រះរាជាយាងទៅទតទានរបស់អ្នកនគរទាំងនោះហើយ ទ្រង់ព្រះតម្រិះថា ទានដែលក្រៃលែងជាងទានរបស់យើង ដែលជនទាំងនេះធ្វើហើយ យើងនឹងធ្វើទានទៀត ទើបឲ្យត្រៀមទានហើយ ក្នុងថ្ងៃស្អែក ។

អ្នកនគរយើញទាននោះហើយ ក្នុងថ្ងៃស្អែកឡើង ទើបត្រៀមទានហើយ ដោយប្រការដូច្នេះ ។ ដោយប្រការយ៉ាងនេះ ព្រះរាជាមិនអាចឲ្យអ្នកនគរចាញ់បានឡើយ អ្នកនគរក៏មិនអាចឲ្យព្រះរាជាចាញ់បាន ។ តមក ក្នុងវារៈទី ៦ អ្នកនគរបន្តែមរយដង ពាន់ដង ត្រៀមទានដោយប្រការ ដែលបុគ្គលណាមិនអាចនិយាយបានថា វត្តឈ្នះនេះ មិនមានក្នុងទានរបស់អ្នកនគរទាំងនេះ ព្រះរាជាទតទាននោះហើយ ទ្រង់ព្រះតម្រិះថា បើយើងមិនអាចធ្វើទានឲ្យក្រៃលែងជាងទានរបស់អ្នកនគរទាំងនោះសោត ប្រយោជន៍អ្វីរបស់អញដោយជីវិតនេះ ដូច្នេះហើយ បានផ្តុំត្រិះរិះដល់ឧបាយ ។

លំដាប់នោះ ព្រះនាងមល្លិកាទេវីចូលគាល់ព្រះរាជាហើយ ទូលសួរថា បពិត្រមហារាជ ព្រោះហេតុអ្វី ទើបទ្រង់ផ្តុំយ៉ាងនេះ ព្រះរាជាត្រាស់ថា ទេវី ឥឡូវនេះ នាងមិនទាន់ជ្រាបឬ ព្រះទេវីទូលថា ខ្ញុំម្ចាស់មិនជ្រាបទេព្រះអង្គ ។ ព្រះរាជាត្រាស់ប្រាប់សេចក្តីនោះដល់ព្រះនាងហើយ ។

លំដាប់នោះ ព្រះនាងមល្លិកាក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ព្រះអង្គកុំព្រួយឡើយ ព្រះរាជាជាធំក្នុងផែនដី ដែលអ្នកនគរទាំងឡាយឲ្យចាញ់ ទ្រង់ធ្លាប់ទតឬ ធ្លាប់ស្តាប់ហើយឬអំពីណា ខ្ញុំម្ចាស់នឹងចាត់ចែងជំនួសព្រះអង្គ ។

ព្រះនាងក្រាបទូលព្រះរាជាយ៉ាងនោះ ព្រោះភាពដែលព្រះនាង ជាអ្នកប្រាជ្ញានឹងចាត់ចែងអសទិសទាន ហើយក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ត្រាស់ឲ្យគេធ្វើមណ្ឌប សម្រាប់គង់ខាងក្នុងបរិវេណ ដើម្បីកុំប្រមាណ

៥០០ រូប ដោយឈើដែលធ្វើដោយដើមសាលព្រឹក្ស និងដើមភ្លៅនាង ពួកភិក្ខុដ៏សេស នឹងអង្គុយខាងក្រៅរង្វង់ សូមទ្រង់ឲ្យធ្វើស្វេតច្ឆត្រ ៥០០ ដំរីប្រមាណ ៥០០ កាន់ស្វេតច្ឆត្រទាំងនោះឈរជាំងខាងលើនៃភិក្ខុប្រមាណ ៥០០ រូប សូមត្រាស់ឲ្យធ្វើទូកសម្រេចដោយមាសទឹកដប់ ៨ គ្រឿង ឬ ១០ គ្រឿង ទូកទាំងនោះដាក់ក្នុងកណ្តាលមណ្ឌប ខត្តិយធីតាមួយអង្គៗ អង្គុយបុកគ្រឿងក្រអូបក្នុងចន្លោះភិក្ខុ ២ រូបៗ ខត្តិយធីតាមួយអង្គៗ ឈរកាន់ផ្ទិតបក់ភិក្ខុ ២ រូបៗ ខត្តិយធីតាដ៏សេស នឹងនាំគ្រឿងក្រអូបដែលខ្ជូនបុកហើយ មកដាក់ក្នុងទូកមាសទាំងឡាយ បណ្តាខត្តិយធីតាទាំងនោះ ខត្តិយធីតាពួកខ្លះនឹងកាន់នូវផ្តាឧប្បលខៀវ ជ្រលក់គ្រឿងក្រអូបដែលនៅក្នុងទូកហើយ នឹងឲ្យភិក្ខុទទួលយកនូវក្ងិន ព្រោះខត្តិយធីតាមិនមានដល់ពួកអ្នកនគរឡើយ ស្វេតច្ឆត្រក៏មិនមាន ដំរីក៏មិនមាន ពួកអ្នកនគរនឹងចាញ់ដោយហេតុមានប្រមាណប៉ុណ្ណោះ ។ បពិត្រមហារាជ សូមទ្រង់ត្រាស់ឲ្យធ្វើយ៉ាងនេះចុះ ។ ព្រះរាជាទទួលថា សាធុ ព្រះទេវី នេះជាការល្អដែលនាងជ្រាប់ហើយ ទើបត្រាស់ឲ្យធ្វើកិច្ចទាំងអស់ ដោយទំនងដែលព្រះនាងទូលហើយនោះឯង ឯដំរី ១ មិនគ្រប់គ្រាន់ដល់ភិក្ខុមួយរូប ។

លំដាប់នោះ ព្រះរាជាត្រាស់នឹងព្រះនាងមល្លិកាថា នែនាង ភិក្ខុមួយរូបខ្វះដំរីមួយ យើងនឹងធ្វើដូចម្តេច ព្រះទេវីត្រាស់ថា ដំរីមាន ៥០០ មិនមែនឬ ព្រះរាជាត្រាស់ថា មាន តែដំរីដ៏សេស ជាដំរីកាច ដំរីទាំងនោះឃើញភិក្ខុទាំងឡាយ រមែងបៀតបៀន ដូចឲ្យល់វេរម្ភវាត ព្រះទេវីត្រាស់ថា បពិត្រ

ព្រះសម្មតិទេព ខ្ញុំម្ចាស់ជ្រាបទីដែលឈរកាន់ឆត្រវបស់កូនដីរដែលកាចនោះ ព្រះរាជាត្រាស់ថា នឹងជាក់ដីរនោះឈរក្នុងទីណា ព្រះទេវីត្រាស់ថា ឈរក្នុងទីជិតរបស់លោកម្ចាស់ឈ្មោះអង្គុលីមាល ។

ព្រះរាជា ត្រាស់ឲ្យរាជបុរសធ្វើហើយយ៉ាងនោះ ដីរស៊កកន្ទុយចូលក្នុងរវាងភ្លៅ ជាក់ត្រចៀកទាំងពីរទៅក្រោយ បិទភ្នែកឈរហើយ ។ មហាជនសម្លឹងមើលដីរត្រង់ស្មេតច្ឆត្រដើម្បីព្រះថេរៈប៉ុណ្ណោះ ដោយគិតថា អាការរបស់ដីរកាចដល់ម្ល៉េះ ព្រះអង្គុលីមាលរមែងធ្វើបាន ព្រះរាជាទ្រង់អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយអាហារដ៏ប្រណីតហើយ ថ្វាយបង្គំព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន វត្ថុណាជាកប្បិយភណ្ឌ ឬអកប្បិយភណ្ឌក្នុងភោគទាននេះ ខ្ញុំអង្គនឹងថ្វាយវត្ថុទាំងអស់នោះ ដល់សង្ឃប៉ុណ្ណោះ ។

ក្នុងកាលនោះឯង ទ្រព្យមានប្រមាណ ១៤ កោដិ ព្រះរាជាបរិច្ចាគមួយថ្ងៃប៉ុណ្ណោះ ។ របស់ ៤ យ៉ាង គឺស្មេតច្ឆត្រ ១ បល្ល័ង្កសម្រាប់អង្គុយ ១ ជើងចាត្រ ១ តាំងសម្រាប់ជូតជើង ១ ជារបស់កាត់ថ្លៃមិនបាន ដើម្បីព្រះសាស្តា បុគ្គលណាមិនអាចធ្វើទានបែបនេះ ថ្វាយទានដល់ព្រះពុទ្ធទាំងឡាយបានឡើយ ព្រោះហេតុនោះឯង ទើបទាននោះប្រាកដឈ្មោះថា អសទិសទាន បានឮថា អសទិសទាននោះមានដល់ព្រះពុទ្ធគ្រប់អង្គ សម្រាប់មួយព្រះអង្គមានម្ភងប៉ុណ្ណោះ ។ ស្ត្រីប៉ុណ្ណោះរមែងចាត់ចែងទានដើម្បីព្រះសាស្តា និងភិក្ខុទាំងពួង ។

អមាត្យរបស់ព្រះរាជាមាន ២ នាក់ គឺកាឡៈ ១ ជណ្ហៈ ១ បណ្តាអមាត្យ ២ នាក់នោះ កាឡអាមាត្យគិតថា ឱ ការវិនាសដោយជុំវិញនៃរាជ-ត្រកូល ទ្រព្យប្រមាណ ១៤ កោដិ ដល់នូវការអស់ទៅមួយថ្ងៃប៉ុណ្ណោះ ភិក្ខុទាំងនេះបរិភោគទានហើយទៅដេកលក់ ឱ រាជត្រកូលវិនាសហើយ ។ ចំណែកជណ្ហអមាត្យគិតថា ឱ ទានរបស់ព្រះរាជា បុគ្គលណាមួយដែលមិនតាំងនៅក្នុងភាពជាព្រះរាជា មិនអាចថ្វាយទានបែបនេះបានឡើយ ។ ព្រះរាជាឈ្មោះថា មិនឲ្យចំណែកបុណ្យដល់សត្វទាំងពួងមិនមាន អញអនុមោទនាទាននេះ ។ ក្នុងទីបំផុតភត្តកិច្ចនៃព្រះសាស្តា ព្រះរាជាទ្រង់ទទួលបាត្រ ដើម្បីអនុមោទនា ព្រះសាស្តាទ្រង់ព្រះតម្រិះថា ព្រះរាជាថ្វាយមហាទាន ដូចឲ្យជំនាន់ទឹកធំប្រព្រឹត្តទៅ មហាជនអាចញុំាងចិត្តឲ្យជ្រះថ្លាឬហ្ន៎ ទ្រង់ជ្រាបវារចិត្តរបស់អមាត្យទាំងនោះហើយ ទ្រង់ជ្រាបថា បើតថាគតធ្វើអនុមោទនាឲ្យសមគួរដល់ទានរបស់ព្រះរាជាសោត ក្បាលរបស់កាឡអមាត្យនឹងបែកជា ៧ ភាគ ជុំណ្ហអមាត្យនឹងតាំងនៅក្នុងសោតាបត្តិផល ទ្រង់អាស្រ័យសេចក្តីអនុគ្រោះក្នុងកាឡអមាត្យ ទើបត្រាស់គាថា ៤ បាទប៉ុណ្ណោះដល់ព្រះរាជា ដែលទ្រង់ថ្វាយទានបែបនេះប្រថាប់ឈរហើយ ស្តេចក្រោកចាកអាសនៈទៅកាន់វិហារ ។

ភិក្ខុទាំងឡាយសួរព្រះអង្គុលីមាលត្ថេរថា អាវុសោ លោកឃើញដីរកាចឈរជាំងធត្រមិនខ្លាចទេឬ ព្រះអង្គុលីមាលពោលថា អាវុសោទាំងឡាយ ខ្ញុំមិនខ្លាចទេ ភិក្ខុទាំងនោះចូលទៅគាល់ព្រះសាស្តាហើយ ក្រាបទូលថា បពិត្រព្រះអង្គ ព្រះអង្គុលីមាលព្យាករអរហត្តផល ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ

ទាំងឡាយ អង្គុលីមាលមិនខ្លាច ព្រោះថា ភិក្ខុទាំងឡាយដូចបុត្ររបស់តថាគត ស្មើដោយគោដ៏ប្រសើរ ក្នុងរវាងនៃគោ គឺព្រះខីណាស្រពទាំង-ឡាយ មិនខ្លាច ដូច្នេះហើយ ទើបត្រាស់ព្រះគាថាក្នុងព្រាហ្មណវគ្គថា

តថាគតហៅវីរបុរស អ្នកអង់អាច អ្នកប្រសើរ អ្នកស្វែង
រកគុណដ៏ធំ ឈ្នះមារ មិនមានកិលេសជាគ្រឿងញាប់ញ័រ
ឆ្លងតណ្ហាកិលេស ត្រាស់ដឹងសច្ចៈនោះ ថាជាព្រាហ្មណ៍ ។

ព្រះរាជាជល់នូវទោមនស្សថា ព្រះសាស្តាទ្រង់មិនធ្វើអនុមោទនា ឲ្យសមគួរដល់បុគ្គលថ្វាយទាន ហើយឈរក្នុងកណ្តាលបរិស័ទបែបនេះ ហើយទ្រង់ក្រោកចាកអាសនៈទៅ អញនឹងមិនធ្វើទានឲ្យសមគួរដល់ព្រះសាស្តា ធ្វើទានដែលមិនសមគួរ ។ អញនឹងមិនថ្វាយកប្បិយកណ្ឌ ថ្វាយតែអកប្បិយកណ្ឌតែម្យ៉ាងហើយ អញនឹងជាបុគ្គលដែលព្រះសាស្តាទ្រង់អាក់អន់ហើយ ការធ្វើអនុមោទនាដែលសមគួរដល់ទាន របស់បុគ្គលណាម្នាក់នោះឯងទើបគួរ ដូច្នេះហើយ ទើបយាងទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្តាហើយ បានក្រាបទូលពាក្យនេះថា បពិត្រព្រះអង្គ ទានដែលគួរថ្វាយ ខ្ញុំព្រះអង្គមិនបានថ្វាយឬ ឬខ្ញុំព្រះអង្គមិនបានថ្វាយកប្បិយកណ្ឌដែលសមគួរដល់ទាន ថ្វាយតែអកប្បិយកណ្ឌប៉ុណ្ណោះឬ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ តើមានរឿងអ្វី ព្រះរាជាត្រាស់ថា ទ្រង់មិនធ្វើអនុមោទនាដែលសមគួរដល់ទានរបស់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ទ្រង់ថ្វាយទានសមគួរហើយ ទាននោះ ឈ្មោះថា អសទិសទាន

បុគ្គលណាម្នាក់អាចថ្វាយដល់ព្រះពុទ្ធមួយអង្គ ត្រឹមតែម្តងប៉ុណ្ណោះ ធម្មតាទានបែបនេះ ជារបស់លំបាកដែលបុគ្គលនឹងថ្វាយទៀត ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ បើដូច្នោះ ហេតុអ្វីក៏ទ្រង់មិនធ្វើអនុមោទនាឲ្យសមគួរដល់ទានរបស់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា ព្រោះបរិស័ទមិនបរិសុទ្ធ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ ទោសអ្វីហ្ន៎របស់បរិស័ទ ។

លំដាប់នោះ ព្រះសាស្តា ត្រាស់ជ្រាប់វារចិត្តរបស់អមាត្យទាំងពីរនាក់ហើយ ត្រាស់ជ្រាប់ភាពដែលអនុមោទនា ឈ្មោះថា ទ្រង់អាស្រ័យសេចក្តីអនុគ្រោះក្នុងកាឡអមាត្យ ទើបមិនធ្វើហើយដល់ព្រះរាជា ព្រះរាជាត្រាស់សួរថា កាឡៈ បានឮថា អ្នកគិតយ៉ាងនេះឬ កាលកាឡអមាត្យទូលថា បពិត្រព្រះអង្គ សេចក្តីនោះពិត ទើបត្រាស់ថា យើង មួយអន្ទៀដោយបុត្រភរិយារបស់យើង មិនបានកាន់យករបស់ដែលមានរបស់អ្នក ឲ្យរបស់ដែលមានរបស់យើង បៀតបៀនអ្វីដល់អ្នក វត្ថុណាដែលយើងឲ្យដល់អ្នកហើយ វត្ថុនោះជាការឲ្យហើយនោះឯង តែចូរអ្នកចេញអំពីដែនរបស់យើង ដូច្នេះហើយ ទើបទ្រង់និទ៌ិសកាឡអមាត្យនោះចេញអំពីដែន ហើយត្រាស់ឲ្យហៅជុណ្ហ-អមាត្យមក សួរថា បានឮថា អ្នកគិតយ៉ាងនេះពិតឬ កាលជុណ្ហអមាត្យទូលថា បពិត្រព្រះអង្គ សេចក្តីនោះពិត ទើបត្រាស់ថា សាធុ ខ្ញុំជ្រះថ្លា ចូរអ្នកទទួលរាជសម្បត្តិរបស់ខ្ញុំ ហើយឲ្យទាន ៧ ថ្ងៃ ដោយទំនងដែលខ្ញុំឲ្យហើយនោះឯង ។ ព្រះរាជាប្រទានរាជសម្បត្តិដល់ជុណ្ហអមាត្យ ៧ ថ្ងៃហើយ ទើបក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ សូមទ្រង់ទតការធ្វើរបស់បុគ្គល

ពាល បុគ្គលនោះបានឲ្យនូវការលុបគុណក្នុងទាន ដែលខ្ញុំព្រះអង្គថ្វាយហើយ យ៉ាងនេះ ។

ព្រះសាស្តាត្រាស់ថា យ៉ាងនោះឯងមហាបពិត្រ ឈ្មោះថាបុគ្គលពាល មិនត្រេកអរក្នុងទានរបស់អ្នកដទៃទ្បើយ ជាបុគ្គលមានទុគ្គតិជាទីទៅខាងមុខ ចំណែកពួកអ្នកប្រាជ្ញ អនុមោទនាទានរបស់ជនដទៃ គប្បីជាអ្នកមានស្ថានសួគ៌ ជាទីទៅខាងមុខដោយពិត ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

ន វេ កទរិយា ទេវលោកំ វជន្តិ ពាលា ហវេ នប្បសំសន្តិ ទានំ
ធីរោ ច ទានំ អនុមោទមានោ តេនេវ សោ ហោតិ សុខី បរត្ថ ។

បុគ្គលកំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយ មិនសរសើរទានទ្បើយ ចំណែកអ្នកប្រាជ្ញ តែងអនុមោទនាទាន ព្រោះហេតុនោះ លោកតែងបានសេចក្តីសុខក្នុងលោកខាងមុខ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កទរិយា** *គឺជាអ្នកមានសេចក្តីកំណាញ់ស្វិតស្វាញ បុគ្គលមិនជឿនូវប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ ឈ្មោះថា ជាបុគ្គលពាល បណ្ឌិត ឈ្មោះថា ធីរជន ។ បទថា* **សុខី បរត្ថ** *សេចក្តីថា ធីរជននោះ កាលសោយទិព្វសម្បត្តិ ឈ្មោះថា ជាអ្នកមានសេចក្តីសុខក្នុងលោកខាងមុខ និងព្រោះបុណ្យដែលសម្រេចអំពីការអនុមោទនាទាននោះឯង ។*

ក្នុងកាលចប់ទេសនា ជុណ្ហអមាត្យតាំងនៅក្នុងសោតាបត្តិផល ទេសនាមានប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាហើយ ។ ជុណ្ហអមាត្យ កាលបានជាព្រះសោតាបន្នហើយ បានថ្វាយទានដោយទំនង ដែលព្រះរាជាថ្វាយហើយ អស់ ៧ ថ្ងៃដូចគ្នា ដូច្នេះឯង ។

រឿង អសទិសទាន ចប់

រឿង កាឡ:កុមារបស់អនាថបិណ្ឌិកសេដ្ឋី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកូនរបស់អនាថ-បិណ្ឌិក ឈ្មោះកាឡ: ត្រាស់ព្រះធម្មទេសនានេះថា **បថព្យា ឯករជ្ជេន** ជាដើម ។

បានឮថា កាឡ:នោះទោះបីជាកូនរបស់សេដ្ឋីដែលជល់ព្រមដោយសទ្ធាដូច្នោះ ក៏មិនប្រាថ្នាទៅកាន់សម្នាក់របស់ព្រះសាស្តាឡើយ មិនប្រាថ្នានឹងស្តាប់ធម៌ មិនប្រាថ្នានឹងធ្វើការទ្រលំទ្វាយជល់សង្ឃ ត្រូវបិតាពោលថា អ្នកកុំធ្វើយ៉ាងនេះ ក៏មិនស្តាប់ពាក្យរបស់លោក ។

លំដាប់នោះ បិតារបស់កាឡ:គិតថា កាឡ:នេះ កាលកាន់យកនូវទិដ្ឋិបែបនេះត្រាច់ទៅ នឹងជាអ្នកមានអវីចីជាទីទៅខាងមុខ កាលអញនៅរស់ កូនរបស់អញទៅកាន់នរកមិនសមគួរដល់អញឡើយ ឈ្មោះថា សត្វ មិនសម្ងឹង

ក្នុងទ្រព្យមិនមានក្នុងលោកនេះទេ្បីយ អញនឹងទម្លាយទិដ្ឋិរបស់កូននោះដោយទ្រព្យ ។

លំដាប់នោះ សេដ្ឋីនិយាយនឹងកាឡៈនោះថា នែបា ចូរបាជាអ្នករក្សាឧបោសថ ទៅកាន់វិហារស្តាប់ធម៌ហើយមកចុះ ឪពុកនឹងឲ្យកហាបណៈមួយរយដល់អ្នក កាឡៈពោលថា នឹងឲ្យពិតឬ សេដ្ឋីពោលថា អើ ឪពុកឲ្យ ។

កាឡៈនោះសួរបញ្ហាក់បីដងហើយ ជាអ្នករក្សាឧបោសថ បានទៅកាន់វិហារហើយ តែកិច្ចដោយការស្តាប់ធម៌របស់គាត់មិនមាន គាត់ដេកក្នុងទីតាមដែលសុខស្រួលហើយ បានទៅផ្ទះអំពីព្រលឹម ។ លំដាប់នោះ បិតារបស់គាត់ពោលថា កូនរបស់យើងបានជាអ្នករក្សាឧបោសថ ចូរអ្នកទាំងឡាយនាំបបរជាដើមមកឲ្យរហ័ស ដូច្នេះហើយ ប្រើអ្នកបម្រើឲ្យបម្រើ ។ កាឡៈនោះហាមអាហារហើយដោយពោលថា បើខ្ញុំមិនបានកហាបណៈក៏មិនបរិភោគ ។ គ្រានោះ បិតារបស់កាឡៈកាលអត់ធន់នឹងការរំខានមិនបាន ទើបឲ្យកញ្ចប់កហាបណៈហើយ កាឡៈនោះទទួលកហាបណៈប៉ុណ្ណោះក្នុងដៃហើយ ទើបបរិភោគអាហារ ។

ក្នុងថ្ងៃស្អែកទេ្បីង សេដ្ឋីបញ្ជូនទៅដោយពោលថា នែបា ឪពុកនឹងឲ្យកហាបណៈមួយពាន់ដល់ឯង ចូរឯងឈរត្រង់ព្រះភក្ត្រព្រះសាស្តា រៀនយកបទនៃធម៌ឲ្យបានមួយបទ ហើយមក ។ កាឡៈទៅកាន់វិហារ ឈរចំពោះព្រះភក្ត្ររបស់ព្រះសាស្តា ជាអ្នកប្រាថ្នានឹងរៀនយកបទនៃធម៌មួយបទប៉ុណ្ណោះ ហើយគេចទៅ ។ លំដាប់នោះ ព្រះសាស្តាទ្រង់បានធ្វើអាការ គឺមិនឲ្យកាឡៈ

កំណត់បាន កាឡ:កំណត់បទនោះមិនបានហើយ ទើបឈរស្តាប់ហើយនោះឯង ដោយគិតថា អញនឹងរៀនបទបន្តទៅទៀត បានឮថា ជនទាំងឡាយកំពុងស្តាប់ដោយគិតថា អញនឹងរៀនឲ្យបាន ឈ្មោះថាស្តាប់ដោយគោរព ។

ធម្មតា កាលជនទាំងឡាយកំពុងស្តាប់យ៉ាងនេះ ធម៌រមែងឲ្យសោតាបត្តិមគ្គជាដើមដល់កាឡ:នោះ ដែលកំពុងស្តាប់ដោយគិតថា អញនឹងរៀនឲ្យបាន សូម្បីព្រះសាស្តាក៏ទ្រង់ធ្វើអាការ គឺការកំណត់មិនបានដល់កាឡ:ហើយ ។ គាត់កំពុងឈរស្តាប់នោះឯង ដោយគិតថា អញនឹងរៀនតទៅ ទើបតាំងនៅក្នុងសោតាបត្តិផល ។

ព្រឹកឡើង កាឡ:នោះទៅកាន់ក្រុងសាវត្ថី មួយអន្ទើដោយភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាននោះឯង ។ សេដ្ឋីគ្រាន់តែឃើញក៏គិតថា ថ្ងៃនេះ អាត្មាអញពេញចិត្តក្នុងអាការរបស់បុត្រ សូម្បីនាយកាឡ:នោះ ក៏មានបរិវិតក្កដូច្នេះថា ឱហ្ន៎ ថ្ងៃនេះ បិតារបស់អញ កុំឲ្យកហាបណ:ក្នុងទីជិតព្រះសាស្តាឡើយ គប្បីបិទបាំងភាពដែលអញជាអ្នករក្សាឧបោសថ ព្រោះហេតុនៃកហាបណ: តែព្រះសាស្តាបានជ្រាបភាពដែលកាឡ:នោះ ជាអ្នករក្សាឧបោសថព្រោះកហាបណ: ហើយកាលពីមុនមិញ មហាសេដ្ឋីថ្វាយបបរដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ ទើបប្រាប់ឲ្យគេឲ្យដល់បុត្រ កាឡ:នោះជាអ្នកអង្គុយស្ងៀម បរិភោគបបរ ទំពារបស់គួរទំពាហើយបរិភោគភត្ត ។

ក្នុងកាលស្រេចភត្តកិច្ចរបស់ព្រះសាស្តា មហាសេដ្ឋី ឲ្យគេដាក់កញ្ចប់

កហាបណៈមួយពាន់ ត្រង់មុខបុត្រហើយ ពោលថា នែបា ឪពុកនិយាយថា នឹងឲ្យកហាបណៈមួយពាន់ដល់ឯង ទើបឲ្យឯងសមាទានឧបោសថ ទៅកាន់វិហារ នេះកហាបណៈមួយពាន់របស់ឯង ។ កាឡៈនោះ ឃើញកហាបណៈដែលបិតាឲ្យចំពោះព្រះភក្ត្រៗបស់ព្រះសាស្តា មានការខ្មាសអៀន ទើបពោលថា ខ្ញុំមិនត្រូវការកហាបណៈទាំងឡាយ ត្រូវបិតាពោលថា នែបា ចូរបានទទួលយកចុះ ក៏មិនទទួល ។

លំដាប់នោះ បិតារបស់កាឡៈ ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ ថ្ងៃនេះខ្ញុំព្រះអង្គគាប់ចិត្តក្នុងអាការរបស់បុត្រ កាលព្រះសាស្តាត្រាស់សួរថា មហាសេដ្ឋី តើរឿងនោះដូចម្តេច ទើបក្រាបទូលថា ក្នុងថ្ងៃមុនកូនរបស់ខ្ញុំព្រះអង្គនេះ កាលខ្ញុំព្រះអង្គពោលថា ឪពុកនឹងឲ្យកហាបណៈមួយរយដល់អ្នក ហើយបញ្ជូនទៅកាន់វិហារ ស្អែកឡើង មិនទាន់បានទទួលកហាបណៈ ក៏មិនបរិភោគ តែថ្ងៃនេះ គេមិនប្រាថ្នាកហាបណៈដែលខ្ញុំព្រះអង្គឲ្យ ព្រះសាស្តាត្រាស់ថា មហាសេដ្ឋី យ៉ាងនោះឯង ថ្ងៃនេះ សោតាបត្តិផលនោះឯងរបស់កូនអ្នក ប្រសើរជាងសម្បត្តិរបស់ស្តេចចក្រពត្តិ និងក្រៃលែងជាងសម្បត្តិទេវលោក និងព្រហ្មលោក ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

បឋព្យា ឯករជ្ជេន សគ្គស្ស គមនេន វា
សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ ។

សោតាបត្តិផល ជាគុណជាតិដ៏ប្រសើរជាងភាពនៃឯករាជ្យ លើផែនដីផង ជាងដំណើរទៅកាន់ស្ថានសួគ៌ផង ជាងភាពជាធំក្នុងលោកទាំងមូលផង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **បឋព្យា ឯករជ្ជេន** *គឺក្រៃលែងជាងភាពជាស្តេចចក្រពត្តិ ។ បាទព្រះគាថាថា* **សគ្គស្ស គមនេន វា** *សេចក្តីថា ជាងការពោលដល់ស្ថានសួគ៌ ២៦ ជាន់ ។ បាទព្រះគាថាថា* **សព្ពលោកាធិបច្ចេន** *សេចក្តីថា ក្រៃលែងជាងភាពជាធំក្នុងលោកមានប្រមាណប៉ុណ្ណោះៗ គឺក្នុងលោកទាំងពួង មួយអន្ទើដោយនាគ គ្រុឌ និងវេមានិកប្រេត ។ បាទព្រះគាថាថា* **សោតាបត្តិផលំ វរំ** *សេចក្តីថា ព្រោះព្រះរាជា សូម្បីសោយរាជសម្បត្តិក្នុងទីមានប្រមាណប៉ុណ្ណោះ ក៏ជាបុគ្គលមិនផុតចាកនរកជាដើមបានឡើយ ចំណែកព្រះសោតាបន្ន ជាអ្នកមានទ្វារអបាយបិទហើយ សូម្បីមានកម្មាំងទន់ខ្សោយជាងសោតាបន្នទាំងអស់ ក៏មិនកើតក្នុងភពទី ៨ ដូច្នោះ សោតាបត្តិផលនោះឯង ទើបប្រសើរ គឺឧត្តម ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងកាឡៈបត្តរបស់អនាថបិណ្ឌិកសេដ្ឋី ចប់

លោកវគ្គ ចប់

វគ្គទី ១៣ ចប់

សុត្តន្តបិដក

ធម្មបទគាថា ពុទ្ធវគ្គទី ១៧

[២៤] *ជ័យជម្នះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេសណាមួយក្នុងលោក រមែងមិនជាប់តាមជ័យជម្នះ របស់ព្រះពុទ្ធអង្គនោះ នាងទាំងឡាយនីងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើង ម្តេចកើត ។ តណ្ហាដែលមានបណ្តាញផ្សាយទៅ ក្នុងអារម្មណ៍ផ្សេងៗ មិនមានដល់ព្រះពុទ្ធអង្គណា ដើម្បីនឹងនាំទៅ ក្នុងកពណាមួយ នាងទាំងឡាយ នីងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើងម្តេចកើត ។*

អ្នកប្រាជ្ញទាំងឡាយណា ជាអ្នកទ្រលំទ្វាយក្នុងឈាន ត្រេកអរក្នុងនេក្ខម្ម: ជាស្ថានស្ងប់រម្ងាប់កិលេស សូម្បីទេវតា និងមនុស្សទាំងឡាយតែងរាប់រកចំពោះអ្នកប្រាជ្ញទាំងឡាយនោះ ដែលជាអ្នកត្រាស់ដឹងខ្លួនឯងទាំងមានស្មារតី ។

ការត្រឡប់បានអត្តភាពជាមនុស្ស បានដោយកម្រ ការរស់របស់សត្វទាំងឡាយ បានដោយកម្រ ការស្តាប់ធម៌របស់សប្បុរស បានដោយកម្រ ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ បានដោយកម្រ ។ ការមិនធ្វើបាបទាំងពួង ការញុំាងកុសលឲ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រៅរបស់ព្រះពុទ្ធទាំងឡាយ ។

ខន្តិ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយតែងពោលថា ព្រះនិព្វាន ជាធម្មជាតដ៏ឧត្តម បុគ្គលដែលសម្លាប់សត្វដទៃ មិនឈ្មោះថាបព្វជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ ក៏មិនឈ្មោះថា សមណៈឡើយ ។

ការមិនតិះដៀល ១ ការមិនបៀតបៀន ១ ការសង្រួមក្នុងបាតិមោក្ខ ១ ភាពជាអ្នកដឹងប្រមាណក្នុងភត្ត ១ ការដេក និងអង្គុយក្នុងទីស្ងាត់ ១ ការព្យាយាមក្នុងអធិចិត្ត ១ នុ៎ះជាពាក្យប្រដៅ របស់ព្រះពុទ្ធទាំងឡាយ ។ ការស្តប់ស្កល់ក្នុងកាមទាំងឡាយ រមែងមិនមាន ព្រោះកហាបណៈ (ដែលធ្លាក់ចុះ) ដូចទឹកភ្លៀងទេ កាមទាំងឡាយ មានសុខតិច មានទុក្ខច្រើន អ្នកប្រាជ្ញដឹងច្បាស់ យ៉ាងនេះហើយ លោកមិនបានត្រេកអរ ក្នុងកាមទាំងឡាយសូម្បីជាទិព្វឡើយ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងជាអ្នកត្រេកអរ ក្នុងធម៌ ជាគ្រឿងអស់តណ្ហា ។ មនុស្សទាំងឡាយ ច្រើននាក់ ត្រូវភ័យគំរាមហើយ តែងយកភ្នំ អារាម និងវនចេតិយ ជាទីពឹង ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលអាស្រ័យនូវទីពឹងនេះហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួងឡើយ ។

លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ឃើញច្បាស់នូវអរិយសច្ចទាំង ៤ គឺទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ និរោធសច្ច ១ កន្លងទុក្ខ ១ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វានដែលជាទីរម្ងាប់ទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ នេះឯង ជាទីពឹងដ៏ក្សេម នេះឯង ជាទីពឹងដ៏ឧត្តម បុគ្គលអាស្រ័យទីពឹងនេះ រមែងរួចស្រឡះចាកទុក្ខ

ទាំងពួងបាន ។

បុរសអាជានេយ្យ រកបានដោយកម្រ លោកមិនកើតក្នុងសព្វស្ថានឡើយ លោកជាអ្នកមានប្រាជ្ញាកើតក្នុងត្រកូលណា ត្រកូលនោះ តែងដល់នូវសេចក្តីសុខ ។ ការកើតឡើងនៃព្រះពុទ្ធ ជាសុខ ការសម្តែងព្រះសទ្ធម្ម ជាសុខ សេចក្តីព្រមព្រៀងគ្នានៃពួក ជាសុខ តបធម៌របស់បុគ្គលអ្នកព្រមព្រៀងគ្នាទាំងឡាយ ជាសុខ ។

កាលបុគ្គលបូជា ដល់បូជារហបុគ្គល គឺព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ដែលកន្លងផុតបបញ្ចធម៌ ដែលកន្លងផុតសេចក្តីសោក និងខ្សឹកខ្សួល ឬកាលបូជាដល់បូជារហបុគ្គលទាំងនោះ ដែលប្រកបដោយតាទិគុណ លោកមិនមានភ័យអំពីទីណា សូម្បីនិព្វានទៅហើយ បុគ្គលណាមួយ មិនអាចរាប់បុណ្យថា បុណ្យនេះ មានប្រមាណប៉ុណ្ណោះបានឡើយ ។

ពុទ្ធវគ្គទី ១៤ ចប់

បឋមភាណវារ ចប់

អដ្ឋកថា

ពុទ្ធវគ្គទី ១៤

រឿង មារធីតា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងពោធិមណ្ឌលដ្ឋាន ទ្រង់ប្រារព្ធធីតាមារ ត្រាស់ព្រះធម្មទេសនានេះថា **យស្ស ឯតំ** *ជាដើម ។*

ព្រះសាស្តា ទ្រង់ញុំាងព្រះធម្មទេសនាឲ្យតាំងខ្ជឹងក្នុងក្រុងសាវត្ថីហើយ ត្រាស់ដល់ព្រាហ្មណ៍ឈ្មោះមាគន្ទិយៈ ក្នុងដែនកុរុទៀត ។

បានឮថា ក្នុងដែនកុរុ កូនស្រីរបស់មាគន្ទិយព្រាហ្មណ៍ ឈ្មោះថា មាគន្ទិយាដូចគ្នា ជាអ្នកមានរូបឆោមស្រស់ត្រកាល ។ ព្រាហ្មណមហា-សាលជាច្រើន និងពួកខត្តិយមហាសាល ចង់បាននាងមាគន្ទិយានោះ ទើប បញ្ជូនដំណឹងទៅដល់មាគន្ទិយៈថា ចូរឲ្យកូនស្រីដល់យើងទាំងឡាយចុះ ។ មាគន្ទិយព្រាហ្មណ៍ ក៏ឃាត់ព្រាហ្មណមហាសាល ខត្តិយមហាសាលទាំងអស់ ដូចគ្នាថា ពួកអ្នកមិនសមនឹងធីតាខ្ញុំទេ ។

ថ្ងៃមួយ ក្នុងពេលទៀបភ្លឺ ព្រះសាស្តាទ្រង់ប្រមើលមើលលោក ទ្រង់ ឃើញមាគន្ទិយព្រាហ្មណ៍ចូលទៅខាងក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ទើបទ្រង់ពិចារណាថា នឹងមានហេតុអ្វីហ្ន៎ ទ្រង់ឃើញឧបនិស្សយនៃមគ្គ និង

ផលទាំង ៣ របស់ព្រាហ្មណ៍ និងព្រាហ្មណី ។ ចំណែកព្រាហ្មណ៍ ក៏បម្រើភ្លើងជានិច្ចខាងក្រៅស្រុក ។ ព្រះសាស្តា ទ្រង់កាន់បាត្រ និងចីវរទៅកាន់ទីនោះ អំពីព្រលឹម ។ ព្រាហ្មណ៍សម្លឹងមើលរូបសិរីរបស់ព្រះសាស្តាបណ្តើរ គិតបណ្តើរថា ឈ្មោះថា បុរសក្នុងលោកនេះ ដែលនឹងដូចបុរសនេះមិនមាន បុរសនេះ ជាអ្នកសមគួរដល់កូនស្រីរបស់អញ អញនឹងឲ្យកូនស្រីរបស់អញ ដល់បុរសនេះ ហើយក្រាបទូលព្រះសាស្តាថា បពិត្រសមណៈ ខ្ញុំមានធីតាម្នាក់ ខ្ញុំមិនឃើញបុរសដែលសមគួរដល់នាង ទើបមិនបានឲ្យនាងដល់បុគ្គលណាឡើយ ។ ចំណែកលោកជាបុគ្គលសមគួរដល់នាង ខ្ញុំប្រាថ្នានឹងឲ្យធីតាដល់លោក ឲ្យធ្វើជាស្រីបម្រើបាតជើង សូមលោកបង្អង់ចាំក្នុងទីនេះឯង ទម្រាំខ្ញុំនាំធីតានោះមក ។ ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់បុរសនោះហើយ ទ្រង់មិនត្រេកអរ ហើយក៏មិនហាម ។

ចំណែកព្រាហ្មណ៍ទៅផ្ទះហើយ ប្រាប់ព្រាហ្មណីថា នែនាង ថ្ងៃនេះខ្ញុំបានឃើញបុរស ដែលសមគួរដល់ធីតារបស់យើងហើយ ពួកយើងនឹងលើកធីតានោះដល់បុរសនោះ ឲ្យធីតាតាក់តែងកាយហើយ នាំទៅកាន់ទីនោះ មួយអន្លើដោយព្រាហ្មណី សូម្បីមហាជនក៏ភ្ជាក់ផ្អើលនាំគ្នាចេញទៅមើល ។ ព្រះសាស្តាមិនបានប្រថាប់ឈរក្នុងទីដែលព្រាហ្មណ៍ប្រាប់ឡើយ ទ្រង់ប្រតិស្ឋានចេតិយ គឺស្នាមព្រះបាទក្នុងទីនោះហើយ បានប្រថាប់ឈរក្នុងទីដទៃ ។ បានឮថា ចេតិយគឺស្នាមព្រះបាទរបស់ព្រះពុទ្ធទាំងឡាយ រមែងប្រាកដក្នុងទីដែលទ្រង់អធិដ្ឋានថា បុគ្គលឈ្មោះនោះចូរឃើញចេតិយ គឺស្នាមជើងនេះ ហើយទ្រង់ជាន់ទុក

ប៉ុណ្ណោះ ។ ឈ្មោះថា បុគ្គលដែលនឹងឃើញចេតិយ គឺស្នាមព្រះបាទនោះក្នុងទីដ៏សេស មិនមាន ។ ព្រាហ្មណ៍ត្រូវនាងព្រាហ្មណីទៅជាមួយខ្លួនសួរថា បុរសនោះនៅឯណា ទើបប្រាប់ថា ខ្ញុំបានប្រាប់បុរសនោះហើយ សូមលោកបង្អង់នៅក្នុងទីនេះ ក៏រកមើលជួបស្នាមព្រះបាទហើយ ទើបចង្អុលថា នេះស្នាមជើងរបស់បុរសនោះ ។

ព្រាហ្មណីនោះពោលថា នែព្រាហ្មណ៍ នេះ មិនមែនស្នាមជើងរបស់បុគ្គលអ្នកបរិភោគកាមទេ ។ ព្រោះនាងជាបុគ្គលដែលឈ្វាសក្នុងមន្តជាគ្រឿងទាយលក្ខណៈ កាលព្រាហ្មណ៍ពោលថា នែនាងដ៏ចម្រើន នាងទាយដូចឃើញក្រពើក្នុងពាងទឹក សមណៈនោះខ្ញុំប្រាប់ហើយថា ខ្ញុំនឹងឲ្យធីតាដល់គេ ទោះបីគេក៏ទទួលពាក្យយើងហើយ ពោលថា ព្រាហ្មណ៍ អ្នកប្រាប់យ៉ាងនោះក៏ពិត តែស្នាមជើងនេះ ជាស្នាមជើងរបស់បុគ្គលដែលអស់កិលេសនោះឯងដូច្នេះហើយ ពោលគាថានេះថា

បុគ្គលដែលជារាគៈចរិត គប្បីមានស្នាមជើងកំពុងកណ្តាល
បុគ្គលដែលជាទោសៈចរិត រមែងមានស្នាមជើងជ្ងន់ខាងក្រោយ
បុគ្គលដែលជាមោហៈចរិត រមែងមានស្នាមជើងជ្ងន់ខាងមុខ
បុគ្គលមានកិលេសដូចគ្រឿងប្រក់ដែលបើកហើយ មានស្នាមបែបនេះ ។

ពេលនោះ ទើបព្រាហ្មណ៍ប្រាប់នាងព្រាហ្មណីថា នែនាង នាងកុំរអ៊ូខ្វើយ ចូរជាអ្នកស្ងៀមចុះ ទៅជួបព្រះសាស្តាហើយ ទើបបង្ហាញដល់

ព្រាហ្មណ៍នោះថា នេះ គឺបុរសនោះ ហើយចូលទៅគាល់ព្រះសាស្តាទូលថា សមណៈ ខ្ញុំឲ្យធីតា ។ ព្រះសាស្តាមិនត្រាស់ថា តថាគតមិនត្រូវការធីតារបស់អ្នក បែរជាត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតនឹងប្រាប់ហេតុមួយដល់អ្នក តើអ្នកស្តាប់ដែរឬទេ កាលព្រាហ្មណ៍ទូលថា បពិត្រសមណៈ សូមលោកពោលមកចុះ ខ្ញុំនឹងស្តាប់ ទើបទ្រង់នាំរឿងអតីត កាលទ្រង់ចេញមហាកិនិស្ក្រមណ៍មកសម្តែងហើយ ។

សេចក្តីសង្ខេបក្នុងរឿងនោះ មានដូចតទៅនេះ

ព្រះមហាសត្វ ទ្រង់លះសិរីរាជសម្បត្តិ ទ្រង់ឡើងកាន់សេះកណ្ឋកៈ មានឆន្នជាសម្លាញ់ ទ្រង់ចេញមហាកិនិស្ក្រមណ៍ កាលមារឈរត្រង់ទ្វារនៃព្រះនគរពោលថា នែសុទ្ធត្ត ចូរអ្នកត្រឡប់ចុះ រាប់អំពីថ្ងៃនេះទៅ ៧ ថ្ងៃទៀត ចក្កវត្តន៍នឹងប្រាកដដល់អ្នក ទើបត្រាស់ថា នែមារ យើងក៏ដឹងចក្កវត្តន៍នោះ តែយើងមិនត្រូវការដោយចក្កវត្តន៍នោះឡើយ មារពោលថា បើដូច្នោះ អ្នកចេញទៅដើម្បីប្រយោជន៍អ្វី ព្រះមហាសត្វឆ្លើយថា ដើម្បីប្រយោជន៍ដល់សព្វញ្ញុតញ្ញាណ មារពោលថា បើដូច្នោះ ចាប់ពីថ្ងៃនេះទៅ បណ្តាវិតក្ក ៣ មានកាមវិតក្កជាដើម អ្នកកុំត្រិះរិះតិចតួចឡើយ ខ្ញុំនឹងដឹងកិច្ចដែលគួរធ្វើដល់អ្នក ។

តាំងអំពីនោះមក មារឃ្លាំចាំចាប់កំហុសជាប់តាមព្រះមហាសត្វ អស់ ៧ ឆ្នាំ សូម្បីព្រះសាស្តា ទ្រង់ប្រព្រឹត្តទុក្ករកិរិយាអស់ ៦ ឆ្នាំ ទ្រង់អាស្រ័យការធ្វើសេចក្តីព្យាយាមរបស់បុរស ចំពោះព្រះអង្គ ទ្រង់ចាក់ធ្លុះនូវសព្វញ្ញុ-

តញ្ញាណ សោយវិមុត្តិសុខត្រង់មណ្ឌលពោធិព្រឹក្ស ក្នុងសប្តាហ៍ទី ៥ ប្រថាប់គង់ត្រង់មណ្ឌលអជបាលនិគ្រោធ ។

សម័យនោះ មារដល់នូវភាពទោមនស្សហើយ អង្គុយត្រង់ផ្លូវធំ រំពឹងពិចារណាថា អញជាប់តាមមកអស់កាលមានប្រមាណប៉ុណ្ណេះ សូម្បីត្រឹមតែចាប់កំហុស ក៏មិនបានឃើញការភ្ញាំងភ្លាត់ណាមួយរបស់សុទ្ធត្តនេះ ឥឡូវនេះ សុទ្ធត្តឈានកន្ទងវិស័យអញទៅហើយ ។ ពេលនោះ ធីតា ៣ នាក់របស់មារនោះ គឺនាងតណ្ហា នាងអរតី នាងរាគាត្រិះរិះថា បិតារបស់អញមិនប្រាកដឥឡូវនេះ លោកនៅទីណាហ្ន៎ ក៏ត្រាច់រកមើល ឃើញបិតានោះ អង្គុយហើយយ៉ាងនោះ ទើបចូលទៅរកហើយសាកសួរថា បពិត្របិតា ព្រោះហេតុអ្វី ទើបលោកខូចចិត្ត មានិយាយសេចក្តីនោះដល់ធីតាទាំងនោះ លំដាប់នោះ ទើបធីតាទាំងនោះប្រាប់មារជាបិតានោះថា បពិត្របិតា សូមបិតាកុំគិតថ្ងៃឡើយ ពួកខ្ញុំនឹងធ្វើសុទ្ធត្តនោះ ឲ្យនៅក្នុងអំណាចរបស់ខ្លួន ហើយនាំមក មារពោលថា នែនាងទាំងឡាយ បុគ្គលណាម្នាក់ក៏មិនអាចធ្វើសុទ្ធត្តនោះឲ្យនៅក្នុងអំណាចបានដែរ ធីតាមារពោលថា បពិត្រលោកឪពុក ពួកខ្ញុំជាស្រី ពួកខ្ញុំនឹងចងសុទ្ធត្តនោះដោយអន្ទាក់ មានអន្ទាក់ គឺរាគៈជាដើម ហើយនាំមកឥឡូវនេះឯង សូមបិតាកុំគិតឡើយ ហើយនាំគ្នាទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រសមណៈ ពួកខ្ញុំនឹងជាអ្នកបម្រើបាទារបស់ព្រះអង្គ ។

ព្រះសាស្តា ទ្រង់មិនបានជាក់ព្រះហឫទ័យ ដល់ពាក្យរបស់ធីតាមារទាំងនោះឡើយ ទ្រង់មិនបើកព្រះនេត្រទាំងពីរមើលឡើយ ពួកធីតាមារគិត

គ្នាទៀតថា បំណងរបស់ពួកបុរសខ្ពស់ៗ ទាបៗ ពួកខ្លះ ស្រឡាញ់ក្មេងស្រីជំទង់ទាំងឡាយ ពួកខ្លះ ស្រឡាញ់ក្នុងពួកស្រីដែលតាំងនៅក្នុងបឋមវ័យ ពួកខ្លះ មានសេចក្តីស្រឡាញ់ក្នុងពួកស្រី ដែលតាំងនៅក្នុងមជ្ឈិមវ័យ ពួកខ្លះ មានសេចក្តីស្រឡាញ់ក្នុងស្រីដែលតាំងនៅក្នុងបច្ចិមវ័យ ។ ពួកយើងនឹងលួងលោមលោក ដោយប្រការផ្សេងៗ ម្នាក់ៗ និម្មិតអត្តភាពបានមួយរយៗ ដោយអំណាចនៃភេទ មានភេទជាស្រីជំទង់ជាដើម ជាស្រីក្រមុំទាំងឡាយ ជាស្រីមិនទាន់ប្រសូត ជាស្រីប្រសូតម្តង ប្រសូតពីរដង ជាស្រីកណ្តាលមនុស្ស ជាស្រីចាស់ ចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលថា បពិត្រសមណៈ ពួកខ្ញុំនឹងបម្រើបាទាំងពីរបស់ព្រះអង្គ ដូច្នេះអស់ ៦ ជង ព្រះសាស្តាទ្រង់មិនជាក់ព្រះហឫទ័យដល់ពាក្យរបស់ធីតាមារនោះទេ ដោយប្រការដែលទ្រង់បង្អោនទៅក្នុងធម៌ដែលអស់ឧបធិដ៏កំពូល ដោយប្រការដូច្នេះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងធីតាមារ ដែលជាប់តាមមក ដោយហេតុមានប្រមាណប៉ុណ្ណេះថា ពួកនាងចូរចៀសចេញទៅ ពួកនាងឃើញអ្វី ទើបព្យាយាមយ៉ាងនេះ ការធ្វើកម្មបែបនេះ ចំពោះមុខរបស់បុគ្គលដែលមានរាគៈមិនទាន់ទៅប្រាស់ ទើបគួរ ចំណែកតថាគត លះកិលេសទាំងឡាយមានរាគៈជាដើមបានហើយ ពួកនាងនឹងនាំតថាគតទៅក្នុងអំណាចរបស់ខ្លួន ដោយហេតុដូចម្តេច ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

យស្ស ជិតំ ជាវជីយតិ ជិតមស្ស នោយាតិ កោចិ លោកេ
តំ ពុទ្ធំ អនន្តគោចរំ អបទំ កេន បទេន នេស្សថ

យស្ស ជាលិនី វិសត្តិកា តណ្ហា នត្ថិ កុហិញ្ចិ នេតវេ
តំ ពុទ្ធំ អនន្តគោចរំ អបទំ កេន បទេន នេស្សថ ។

ជ័យជម្នះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេសណាមួយ ក្នុងលោក រមែងមិនជាប់តាមជ័យជម្នះរបស់ព្រះពុទ្ធអង្គនោះ នាងទាំងឡាយ នឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរវេកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើងម្តេចកើត ។

តណ្ហាដែលមានបណ្តាញផ្សាយទៅ ក្នុងអារម្មណ៍ផ្សេងៗ មិនមានដល់ព្រះពុទ្ធអង្គណា ដើម្បីនឹងនាំទៅក្នុងភពណាមួយ នាងទាំងឡាយ នឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរវេកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើងម្តេចកើត ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បានព្រះគាថាថា **យស្ស ជិតំ នាវជីយតិ** *សេចក្តីថា កិលេសជាតិ មានរាគៈជាដើម ដែលព្រះសម្មាសម្ពុទ្ធអង្គណា ទ្រង់ឈ្នះហើយដោយមគ្គនោះៗ ទ្រង់មិនត្រឡប់ចាញ់ គឺឈ្នោះថាឈ្នះហើយ មិនល្អ មិនមាន ព្រោះមិនត្រឡប់កើតឡើងទៀត ។*

បទថា **នោយាតិ** *កាត់ជា* **ន ឧយ្យាតិ** *ប្រែថា រមែងមិនទៅតាម*

អធិប្បាយថា បណ្តាកិលេស មានរាគៈជាដើម កិលេសណាមួយ ក្នុងលោក ឈ្មោះថា ត្រឡប់ទៅក្រោយមិនមាន គឺមិនជាប់តាមកិលេសជាតិ ដែលព្រះសម្មាសម្ពុទ្ធអង្គណា ទ្រង់ឈ្នះហើយ ។

បទថា **អនន្តគោចរំ** *សេចក្តីថា ជាអ្នកមានអារម្មណ៍មិនមានទីបំផុត ដោយអំណាចសព្វញ្ញុតញ្ញាណ មានអារម្មណ៍មិនមានទីបំផុត ។*

ពីរបទថា **កេន បទេន** *ជាដើម សេចក្តីថា បណ្តាស្នាម មានស្នាម គឺ រាគៈជាដើម សូម្បីស្នាមមួយមិនមានដល់ព្រះសម្ពុទ្ធអង្គណា ពួកនាឯនីឯនាំ ព្រះសម្មាសម្ពុទ្ធអង្គនោះទៅដោយស្នាមជើងអ្វី គឺសូម្បីតែស្នាមមួយ មិនមានដល់ព្រះពុទ្ធ ពួកនាឯនីឯនាំព្រះពុទ្ធនោះ ដែលមិនមានស្នាមជើងទៅដោយស្នាមជើងអ្វី ។*

វិនិច្ឆ័យក្នុងគាថាទី ២ ឈ្មោះថា តណ្ហានោះ ពាក្យថា **ជាលិនី** *ព្រោះវិគ្គហៈថា មានសំណាញ់ មានប្រក្រតីធ្វើនូវសំណាញ់ ប្រៀបដូចសំណាញ់ ព្រោះអត្ថថា រួបរឹត គឺចង ឈ្មោះថា* **វិសត្តិកា** *ព្រោះជាធម្មជាតផ្សាយទៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ព្រោះប្រៀបដោយអាហារដែលមានពិស ព្រោះប្រៀបដោយផ្កាមានជាតិពុល ព្រោះប្រៀបដោយផ្លែឈើមានជាតិពុល ព្រោះប្រៀបដូចគ្រឿងបរិភោគមានពិស អធិប្បាយថា តណ្ហាបែបនោះ មិនមានដល់ព្រះពុទ្ធអង្គណា ដើម្បីនាំទៅក្នុងភពណា ពួកនាឯនីឯនាំព្រះពុទ្ធអង្គនោះ ដែលមិនមានស្នាមជើង ដោយស្នាមជើងអ្វី ។*

ក្នុងកាលចប់ទេសនា ធម្មាភិសមយមានដល់ទេវតាជាច្រើន សូម្បីមារ-

ធីតាក៏អន្តរធានទៅក្នុងទីនោះឯង ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលមាគន្ធិយៈ ក្នុងកាលមុន តថាគតបានឃើញធីតាមារទាំង ៣ ប្រកបដោយអត្តភាពដូចមាស មិនប្រឡាក់ដោយរបស់ស្មោកគ្រោក មានស្មៅស្មជាដើមក្នុងកាលនោះ តថាគតមិនមានការពេញចិត្តក្នុងមេថុនទេ ឯសរីរៈនៃធីតារបស់អ្នក ពេញទៅដោយសាកសព គឺអាការ ៣២ ដូចឆ្នាំងដែលហូរនូវរបស់មិនស្អាត ដែលស្រស់ត្រកាលសម្រាប់ក្អែកខាងក្រៅ សូម្បីជើងរបស់តថាគត គប្បីជាជើងប្រឡាក់ដោយរបស់មិនស្អាតសោត ហើយធីតារបស់អ្នក គប្បីឈរត្រង់ធរណីទ្វារ ទោះជាយ៉ាងនោះ ក៏តថាគតមិនប្រាថ្នានឹងប៉ះសរីរៈរបស់នាងដោយជើង ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ការពេញចិត្តក្នុងមេថុនធម្មមិនមាន ព្រោះឃើញនាងតណ្ហា នាងអរតី និងនាងរាគា ព្រោះឃើញសរីរៈរបស់កូនស្រីអ្នកនេះ ដែលពេញដោយមូត្រ និងកវែស តថាគតរមែងមិនប្រាថ្នានឹងប៉ះសរីរៈធីតារបស់អ្នកនោះ សូម្បីដោយជើង ក្នុងកាលចប់ទេសនាប្តីប្រពន្ធទាំង ២ តាំងនៅក្នុងអនាគាមិផល ដូច្នេះឯង ។

រឿង មារធីតា ចប់

រឿង យមកបាដិហារ្យ

លំនាំដើម

ព្រះសាស្តាទ្រង់ប្រារព្ធទេវតា និងមនុស្សជាច្រើនត្រង់ទ្វារនៃនគរសង្កស្សៈ ត្រាស់ព្រះធម្មទេសនានេះថា **យេ ឈានប្បសុតា ធីរា** ជាដើម ។ ទេសនានេះកើតឡើងក្នុងក្រុងរាជគ្រឹះ ។

សេចក្តីពិស្តារ សម័យមួយ សេដ្ឋីអ្នកក្រុងរាជគ្រឹះ ឲ្យសន្ធឹងសំណាញ់មានសណ្ឋានដូចជបដើម្បីសេចក្តីផុតភ័យ គឺដើម្បីរក្សាអាភរណៈជាដើមដែលរបូតទៅដោយការភ្លេចភ្លាំង លេងកីឡាក្នុងស្ទឹងគង្គា ។

ក្នុងកាលនោះ ដើមចន្ទន៍មួយដើមកើតឡើងត្រង់ច្រាំងស្ទឹងខាងលើទឹកនៃស្ទឹងគង្គា មានឫសត្រូវទឹកច្រោះ គាល់ជាក់ខ្លាត់ខ្លាយ នៅលើថ្មនោះៗ កាលនោះ ពកមួយមានប្រមាណប៉ុនក្អម ត្រូវថ្នូតត្រូវរលកនាំមកជារបស់រលោង អណ្តែតទៅដោយលំដាប់ ត្រូវសារាយរួបរឹត មកជាប់សំណាញ់របស់សេដ្ឋីនោះ ។

សេដ្ឋីពោលថា នុ៎ះជាអ្វី បានឮថា នុ៎ះជាពកនៃដើមឈើ ទើបឲ្យនាំពកឈើនោះមកចាំងដោយចុងកាំបិត ដើម្បីពិចារណាថា នុ៎ះជាឈើអ្វី ។

រំពេចនោះឯង ចន្ទន៍ក្រហមមានពណ៌ដូចលំពែកក៏ប្រាកដ សេដ្ឋីមិនទាន់ជាសម្មាទិដ្ឋិ មិនជាមិច្ឆាទិដ្ឋិ ជាក់ខ្លួនជាកណ្តាលគិតថា ចន្ទន៍ក្រហមក្នុងផ្ទះរបស់អញមានច្រើន អញនឹងយកចន្ទន៍នេះធ្វើអ្វីហ្ន៎ ពេលនោះគាត់គិតយ៉ាងនេះថា ក្នុងលោកនេះ ជនដែលពោលថា អញជាព្រះអរហន្តមានច្រើន អញមិន

ស្គាល់ព្រះអរហន្តសូម្បីត្រឹមតែមួយ អញនឹងប្រកបគ្រឿងក្រឡឹងទុកក្នុងផ្ទះ ឲ្យក្រឡឹងជាជាត្រហើយ ដាក់សង្រែកសំយុងក្នុងអាកាសប្រមាណ ៦០ ហត្ថ ដោយឫទ្ធិតគ្នា ពោលថា បើព្រះអរហន្តមាន សូមមកតាមអាកាសហើយកាន់យកជាត្រនេះ បុគ្គលណាកាន់យកជាត្រនោះបាន ខ្ញុំ មួយអន្ទើដោយបុត្ត-ភរិយា នឹងដល់បុគ្គលនោះជាសរណៈ ហើយឲ្យក្រឡឹងជាត្រដោយទំនង់ដែលគិតហើយនោះឯង លើកឡើងដោយឫទ្ធិតគ្នា ពោលថា ក្នុងលោកនេះ បុគ្គលណាជាព្រះអរហន្ត សូមបុគ្គលនោះមកតាមអាកាសយកជាត្រនេះចុះ ។

គ្រូទាំងឡាយពោលថា ជាត្រនោះសមគួរដល់ពួកយើង សូមលោកឲ្យជាត្រនោះដល់អាត្មាចុះ សេដ្ឋីនោះពោលថា សូមលោកម្ចាស់ទាំងឡាយ មកតាមអាកាសហើយយកចុះ ។

ក្នុងថ្ងៃទី ៦ និគ្គណ្ឋនាដបុត្រ បញ្ជូនពួកអន្តេវាសិកទៅថា ចូរពួកលោកទៅ ចូរនិយាយនឹងសេដ្ឋីយ៉ាងនេះថា ជាត្រនោះ សមគួរដល់អាចារ្យរបស់ពួកយើង លោកកុំធ្វើការមកតាមអាកាស ព្រោះហេតុត្រឹមតែរបស់តិចតួចឡើយ សូមលោកឲ្យជាត្រនោះចុះ ។ ពួកអន្តេវាសិកពោលនឹងសេដ្ឋីយ៉ាងនោះហើយ សេដ្ឋីពោលថា បុគ្គលដែលអាចមកតាមអាកាស ហើយកាន់យកបានប៉ុណ្ណោះ ចូរយកទៅ ។

នាដបុត្រជាអ្នកប្រាថ្នាទៅឯង ទើបឲ្យសញ្ញាដល់អន្តេវាសិកថា យើងនឹងលើកដៃ លើកជើងម្ខាង ធ្វើអាកប្បកិរិយាប្រាថ្នានឹងហោះ ចូរពួកអ្នកស្រែកប្រាប់យើងថា លោកអាចារ្យ លោកកុំធ្វើឡើយ លោកកុំសម្តែងភាពជាព្រះ

អរហន្តដែលខំបិទបាំង ព្រោះហេតុត្រឹមតែបាត្រឈើដល់មហាជនឡើយ ដូច្នេះ ហើយ ចូរនាំគ្នាចាប់យើងត្រង់ដៃ និងជើង ទាញឲ្យដួលចុះត្រង់ផែនដី ។ គាត់ទៅក្នុងទីនោះហើយ ពោលនឹងសេដ្ឋីថា លោកសេដ្ឋី បាត្រនេះសមគួរដល់អាត្មា មិនសមគួរដល់ជនដទៃឡើយ សូមលោកកុំគាប់ចិត្តនឹងការហោះទៅក្នុងអាកាសរបស់អាត្មា ព្រោះហេតុត្រឹមតែរបស់តូចតាច ចូរឲ្យបាត្រដល់អាត្មាចុះ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ត្រូវហោះឡើងទៅក្នុងអាកាសហើយកាន់យកចុះ ។

លំដាប់នោះ នាជបុត្រពោលថា បើដូច្នោះ ចូរពួកអ្នកចៀសចេញ ពួកអន្តេវាសិកក៏ចៀសចេញទៅហើយ ពោលថា យើងនឹងហោះឡើងទៅក្នុងអាកាស ដូច្នេះហើយ លើកដៃ និងជើងម្ខាងឡើង ។ ពេលនោះ អន្តេវាសិកពោលនឹងអាចារ្យថា លោកអាចារ្យ លោកនឹងធ្វើអ្វីនឹង ប្រយោជន៍អ្វីដោយគុណដែលបិទបាំង ហើយលោកមកសម្តែងដល់មហាជន ព្រោះហេតុត្រឹមតែបាត្រឈើនេះ ហើយនាំគ្នាចាប់នាជបុត្រនោះត្រង់ដៃ និងជើង ទាញមកឲ្យដួលចុះលើផែនដី នាជបុត្រប្រាប់សេដ្ឋីថា លោកសេដ្ឋី អន្តេសិកទាំងនេះមិនឲ្យអាត្មាហោះ ចូរលោកឲ្យបាត្រដល់អាត្មាចុះ ។ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ ត្រូវហោះឡើងហើយកាន់យកចុះ ។

ពួកតិរ្ថិយ សូម្បីព្យាយាមដោយអាការយ៉ាងនេះអស់ ៦ ថ្ងៃ ក៏មិនបានបាត្រនោះឡើយ ។

ក្នុងថ្ងៃទី៧ក្នុងកាលដែលព្រះមហាមោគ្គល្លាន និងព្រះបិណ្ឌោលភារទ្វាជៈ

ទៅឈរត្រង់ថ្នដាមួយកន្លែង ហើយស្រែកដណ្តប់ចីវរ ដោយតាំងចិត្តថានឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ពួកអ្នកលេងជជែកគ្នាថា ម្នាលគ្នាយើង ក្នុងកាលមុន គ្រូទាំង ៦ ពោលថា ពួកយើងជាព្រះអរហន្តក្នុងលោក កាលសេដ្ឋីអ្នកក្រុងរាជគ្រឹះលើកបាត្រហើយ ពោលថា បើព្រះអរហន្តមាន សូមមកតាមអាកាសហើយ កាន់យកចុះ នេះជាថ្ងៃទី ៧ បុគ្គលសូម្បីត្រឹមតែម្នាក់ ដែលហោះទៅក្នុងអាកាស ដោយបង្ហាញខ្លួនថា យើងជាព្រះអរហន្តក៏មិនមាន ថ្ងៃនេះ ពួកយើងដឹងនូវភាពដែលព្រះអរហន្ត មិនមានក្នុងលោកហើយ ។

ចំណែកព្រះមហាមោគ្គល្លាន បានឮពាក្យនោះហើយ ទើបពោលនឹងព្រះបិណ្ឌាលភារទ្វាជៈថា អាវុសោភារទ្វាជៈ លោកបានឮពាក្យរបស់ពួកអ្នកលេងទាំងនេះដែរឬទេ ពួកអ្នកលេងទាំងនេះ ពោលញុះញង់ព្រះពុទ្ធសាសនា លោកម្ចាស់មានឫទ្ធិច្រើន មានអានុភាពច្រើន សូមលោកទៅចុះ សូមមកតាមអាកាស ហើយកាន់យកបាត្រនោះ ។

ព្រះបិណ្ឌាលភារទ្វាជៈពោលថា អាវុសោមោគ្គល្លាន លោកជាកំពូលជាង ខាងបណ្តាសាវ័កអ្នកមានឫទ្ធិ សូមលោកម្ចាស់កាន់យកបាត្រនោះ តែបើលោកមិនកាន់យក ខ្ញុំនឹងកាន់យក ។

កាលព្រះមហាមោគ្គល្លានពោលយ៉ាងនេះថា អាវុសោ សូមលោកកាន់យកចុះ ។ ព្រះបិណ្ឌាលភារទ្វាជៈចូលចតុត្ថជ្ឈាន មានអភិញ្ញាជាបាទ ចេញហើយ យកចុងជើងច្កៀបថ្នដាប្រមាណ ១ គាវុត ហោះឡើងទៅកាន់អាកាសដូចប៉ុយ-គ ហើយប្រទក្សិណខាងលើនគរាជគ្រឹះ ៧ ជុំ ថ្នដានោះ

ប្រាកដដូចជញ្ជាំង សម្រាប់បិទព្រះនគរប្រមាណ ៣ គាវុត ពួកអ្នកនគរខ្លាចស្រែកថា ថ្មនឹងធ្លាក់សង្កត់ពួកយើង ធ្វើគ្រឿងការពារ មានចង្អេរជាដើមខាងលើកំពាល ហើយពួនក្នុងទីនោះៗ ក្នុងវារៈទី ៧ ព្រះថេរៈទម្លាយថ្ម ហើយបង្ហាញខ្លួន ។

មហាជនឃើញព្រះថេរៈហើយ ពោលថា ព្រះបិណ្ឌាលភារទ្វាជៈ សូមលោកម្ចាស់ ចាប់ថ្មរបស់លោកម្ចាស់ឲ្យមាំ កុំឲ្យពួកខ្ញុំទាំងអស់វិនាសថ្វីឡើយ ។ ព្រះថេរៈយកចុងជើងគ្រវាត់ថ្មចោលទៅ ថ្មនោះទៅតាំងនៅក្នុងទីដើមនោះឯង ព្រះថេរៈបានឈរក្នុងទីបំផុតនៃផ្ទះរបស់សេដ្ឋី ។ សេដ្ឋីឃើញលោកហើយក្រាបចុះ ពិតថា សូមលោកម្ចាស់ចុះមកចុះ ។ និមន្តព្រះថេរៈ ចុះអំពីអាកាស ឲ្យគង់ហើយ ឲ្យទាំបាត្រចុះ ធ្វើឲ្យពេញដោយមធុរស ៤ យ៉ាង ហើយថ្វាយដល់ព្រះថេរៈ។ ទទួលបាត្រហើយ បែរមុខទៅកាន់វិហារ ទៅហើយ ។

លំដាប់នោះ ជនទាំងឡាយណាដែលនៅក្នុងព្រៃខ្លះ នៅក្នុងស្រុកខ្លះ មិនឃើញបាដិហារ្យរបស់ព្រះថេរៈ ជនទាំងនោះ ប្រជុំគ្នាហើយអង្វរព្រះថេរៈថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់សម្តែងបាដិហារ្យដល់ពួកខ្ញុំ ដូច្នេះហើយក៏នាំគ្នាជាប់តាមព្រះថេរៈទៅ ។ ព្រះថេរៈនោះ សម្តែងបាដិហារ្យដល់ជនទាំងនោះបណ្តើរ បានទៅកាន់វិហារហើយ ។

ព្រះសាស្តា ទ្រង់ស្តាប់សំឡេងមហាជន ដែលជាប់តាមព្រះថេរៈនោះ ទ្រហឹងអឺងកង ទើបត្រាស់សួរថា ម្នាលអានន្ទ នុ៎ះសំឡេងអ្វី ទ្រង់បានព្រះ

ព្រះបិណ្ឌាលការទ្វាជៈហោះទៅក្នុងអាកាសហើយ កាន់យកបាត្រខ្ចីមចន្ទន៍នោះ សំឡេងក្នុងសម្នាក់របស់លោក ទើបត្រាស់ឲ្យហៅព្រះបិណ្ឌាលការទ្វារជៈមក ត្រាស់សួរថា បានឮថា អ្នកធ្វើយ៉ាងនោះពិតឬ លោកក្រាបទូលថា ពិតព្រះអង្គ ទើបត្រាស់ថា ម្នាលការទ្វាជៈ ហេតុអ្វី ទើបអ្នកធ្វើយ៉ាងនោះ ទ្រង់តិះដៀលព្រះថេរៈហើយ ត្រាស់ឲ្យទម្លាយបាត្រនោះធ្វើជាកំណាត់តូចធំ ចែកដល់ភិក្ខុទាំងឡាយ ដើម្បីប្រយោជន៍ផ្សុំធ្វើជាថ្នាំបន្តក់ភ្នែក ហើយទ្រង់បញ្ញត្តិសិក្ខាបទដល់សាវកទាំងឡាយ ដើម្បីមិនឲ្យធ្វើបាដិហារ្យ ។ ចំណែកពួកតិរ្ថិយបានឮថា ព្រះសមណគោតមឲ្យបំបែកបាត្រនោះហើយ ទ្រង់បញ្ញត្តិសិក្ខាបទដល់សាវកទាំងឡាយ ដើម្បីមិនឲ្យធ្វើបាដិហារ្យ ទើបដើរប្រាប់គ្នាក្នុងផ្លូវ ក្នុងព្រះនគរថា សាវកទាំងឡាយរបស់ព្រះសមណគោតម មិនកន្ទងសិក្ខាបទដែលទ្រង់បញ្ញត្តិ សូម្បីហេតុនៃជីវិត សូម្បីព្រះសមណគោតមក៏រក្សាសិក្ខាបទដែលបញ្ញត្តិនោះដូចគ្នា ឥឡូវនេះ ពួកយើងបានឱកាសហើយ ហើយពោលថា ពួកយើងនឹងរក្សាគុណរបស់ខ្លួន ទើបមិនសម្តែងគុណរបស់ខ្លួនដល់មហាជន ព្រោះហេតុនៃបាត្រក្នុងកាលមុន ពួកសាវករបស់ព្រះសមណគោតមសម្តែងគុណរបស់ខ្លួនដល់មហាជន ព្រោះហេតុនៃបាត្រ ព្រះសមណគោតមត្រាស់ឲ្យបំបែកបាត្រនោះហើយ ទ្រង់បញ្ញត្តិសិក្ខាបទដល់ពួកសាវក ព្រោះទ្រង់ជាបណ្ឌិត ឥឡូវនេះ ពួកយើងនឹងធ្វើបាដិហារ្យជាមួយព្រះសមណគោតមនោះ ។

ព្រះបាទពិម្ពិសារ ទ្រង់ស្តាប់ពាក្យនោះហើយ យាងទៅកាន់សម្នាក់ព្រះ

សាស្តាក្រាបទូលថា បពិត្រព្រះអង្គ បានឮថា ទ្រង់បញ្ញត្តិសិក្ខាបទដល់ពួកសាវ័កដើម្បីមិនឲ្យធ្វើបាដិហារ្យពិតឬ ព្រះសាស្តាត្រាស់ថា ពិតហើយមហារាជ ព្រះរាជាត្រាស់ថា ឥឡូនេះ ពួកតិរ្ថិយនាំគ្នាពោលថា ពួកយើងនឹងធ្វើបាដិហារ្យជាមួយទ្រង់ ឥឡូវនេះ ព្រះអង្គគិតដូចម្តេច ។

ព្រះសាស្តាត្រាស់ថា កាលតិរ្ថិយទាំងនោះធ្វើ តថាគតក៏នឹងធ្វើ ព្រះរាជាត្រាស់ថា ទ្រង់បញ្ញត្តិសិក្ខាបទហើយមិនមែនឬ ព្រះសាស្តាត្រាស់ថា មហាបពិត្រ តថាគតមិនបានបញ្ញត្តិសិក្ខាបទដើម្បីខ្លួន សិក្ខាបទនោះឯង តថាគតបញ្ញត្តិដើម្បីសាវ័កទាំងឡាយ ។

ព្រះរាជាត្រាស់ថា សិក្ខាបទ ឈ្មោះថា ទ្រង់បញ្ញត្តិក្នុងសាវ័កទាំងឡាយរៀរទ្រង់ចេញឬ ព្រះសាស្តាត្រាស់ថា មហាបពិត្រ បើដូច្នោះ តថាគតនឹងសួរព្រះអង្គនោះឯងព្រោះរឿងនេះ មហាបពិត្រ ព្រះរាជឧទ្យានក្នុងដែនរបស់ព្រះអង្គមានឬ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ មាន ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ បើមហាជនបរិភោគផ្លែឈើមានផ្លែស្វាយជាដើម ក្នុងព្រះរាជឧទ្យានរបស់ព្រះអង្គ ទ្រង់គប្បីធ្វើដូចម្តេច ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ គប្បីជាក់ទោស ព្រះសាស្តាត្រាស់ថា ចុះព្រះអង្គសោយបានឬ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ អាជ្ញាមិនមានដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គអាចសោយរបស់ខ្លួនបាន ព្រះសាស្តាត្រាស់ថា មហាបពិត្រ រាជអាជ្ញារបស់តថាគតរមែងផ្សាយទៅក្នុងសែនកោដិចក្រវាល ដូចរាជអាជ្ញារបស់ព្រះអង្គដែលផ្សាយទៅក្នុងដែនប្រមាណ ៣០០ យោជន៍ អាជ្ញាមិនមានដល់ព្រះអង្គ

ដែលសោយផ្លែឈើទាំងឡាយ មានផ្លែស្វាយជាដើម ក្នុងព្រះរាជឧទ្យាន របស់ព្រះអង្គ តែមានដល់ជនដទៃ ឈ្មោះថា ការឈានកន្ទងនូវបញ្ញត្តិ គឺ សិក្ខាបទ រមែងមិនមានដល់ខ្លួន តែរមែងមានដល់សាវ័កដទៃ ទើបតថាគត អាចធ្វើបាដិហារ្យបាន ។

ពួកតិរ្ថិយស្តាប់ពាក្យនោះហើយប្រឹក្សាគ្នាថា ឥឡូវនេះ ពួកយើងវិនាស ហើយ បានឮថា ព្រះសមណគោតម ទ្រង់បញ្ញត្តិសិក្ខាបទដើម្បីពួកសាវ័ក ទាំងនោះ ទ្រង់មិនបញ្ញត្តិដើម្បីខ្លួន បានឮថា ទ្រង់ប្រាថ្នានឹងធ្វើបាដិហារ្យឯង នោះឯង ពួកយើងនឹងធ្វើដូចម្តេច ព្រះរាជាទូលសួរព្រះសាស្តាថា បពិត្រព្រះ អង្គ ទ្រង់នឹងធ្វើបាដិហារ្យក្នុងកាលណា ព្រះសាស្តាត្រាស់ថា មហាបពិត្រ កន្ទងទៅ ៤ ខែទៀត បន្ទាប់អំពីថ្ងៃពេញបូណ៌មីខែអាសាឍ ព្រះរាជាត្រាស់ ថា បពិត្រព្រះអង្គ ទ្រង់នឹងធ្វើក្នុងទីណា ព្រះសាស្តាត្រាស់ថា មហាបពិត្រ តថាគតនឹងធ្វើអាស្រ័យក្រុងសាវត្ថី ។

មានពាក្យសួរជ្រៀតចូលមកថា ហេតុអ្វី ទើបព្រះសាស្តាអាងដល់ ទីធ្លាយយ៉ាងនេះ ឆ្លើយថា ព្រោះទីនោះជាទីធ្វើបាដិហារ្យរបស់ព្រះពុទ្ធគ្រប់អង្គ ម្យ៉ាងទៀត ទ្រង់អាងទីធ្លាយនោះឯង ដើម្បីប្រយោជន៍ឲ្យមហាជនប្រជុំគ្នា ។

ពួកតិរ្ថិយស្តាប់ពាក្យនោះហើយ ពោលថា បានឮថា បន្ទាប់អំពីនេះទៅ ៤ ខែទៀត ព្រះសមណគោតមនឹងធ្វើបាដិហារ្យក្នុងក្រុងសាវត្ថី ឥឡូវនេះ ពួក យើងមិនលះបង់ យើងនឹងជាប់តាមព្រះអង្គទៅ មហាជនឃើញពួកយើងហើយ នឹងសួរថា ពួកលោកម្ចាស់នឹងធ្វើអ្វី ពេលនោះ ពួកយើងនឹងប្រាប់ដល់ជនទាំង

នោះថា ពួកយើងពោលហើយថា នឹងធ្វើបាដិហារ្យជាមួយព្រះសមណគោតម ព្រះគោតមនោះ រមែងគេចទៅ ពួកយើងមិនឲ្យព្រះសមណគោតមនោះគេច ទើបជាប់តាមទៅ ។ ព្រះសាស្តា ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ចេញមកហើយ សូម្បីពួកតិរ្ថិយក៏ចេញមកតាមក្រោយទ្រង់នោះឯង ក្នុងទីជិតៗ ព្រះដ៏មានព្រះភាគដែលទ្រង់ធ្វើភត្តកិច្ច ស្រែកឡើង ពួកតិរ្ថិយបរិភោគអាហារព្រឹក ក្នុងទីដែលខ្ជិននៅហើយ ។ តិរ្ថិយទាំងនោះ ត្រូវពួកមនុស្សសួរថា នេះអ្វី ទើបប្រាប់ដោយន័យនៃពាក្យដែលពោលហើយខាងដើមនោះឯង ។ ឯមហាជនគិតថា ពួកយើងនឹងមើលបាដិហារ្យ ដូច្នេះហើយ បានជាប់តាមទៅ ។ ព្រះសាស្តាជល់នគរសាវត្ថីដោយលំដាប់ ។

ពួកតិរ្ថិយក៏ទៅជាមួយព្រះអង្គដូចគ្នា បបួលឧបដ្ឋាកបានទ្រព្យមួយសែនហើយ ឲ្យធ្វើមណ្ឌបសសរគគីរ ប្រក់ដោយផ្ការឧប្បលខៀវ អង្គុយនិយាយគ្នាថា ពួកយើងនឹងធ្វើបាដិហារ្យក្នុងទីនេះ ។

គ្រានោះ ព្រះបាទបសេនទិកោសល ចូលទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ ពួកតិរ្ថិយធ្វើមណ្ឌបហើយ ខ្ញុំព្រះអង្គនឹងធ្វើមណ្ឌបដើម្បីទ្រង់ ព្រះសាស្តាត្រាស់ថា មហាបពិត្រ កុំឡើយ អ្នកធ្វើមណ្ឌបរបស់តថាគត មានហើយ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ អ្នកដទៃវៀរខ្ញុំព្រះអង្គ តើអ្នកណានឹងធ្វើ ព្រះសាស្តាត្រាស់ថា អ្នកធ្វើ គឺសក្កទេវរាជ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ ទ្រង់នឹងធ្វើបាដិហារ្យក្នុងទីណា ព្រះសាស្តាត្រាស់ថា ត្រង់មណ្ឌលគណ្ឌម្ពព្រឹក្ស ។

ពួកតិរ្ថិយបានឮថា ព្រះសមណគោតម នឹងធ្វើបាដិហារ្យត្រង់គល់ស្វាយ ទើបប្រាប់ឧបដ្ឋាករបស់ខ្លួនឲ្យដកដើមស្វាយតូចៗ ដោយហោចដែលជុះក្នុងថ្ងៃនោះ ក្នុងទីវាងមួយយោជន៍ ហើយឲ្យបោះចោលក្នុងព្រៃ ។

ក្នុងថ្ងៃ ១៥ កើត ខែអាសាឍ ព្រះសាស្តាចូលទៅខាងក្នុងព្រះនគរ អ្នករក្សាចម្ការស្វាយរបស់ព្រះរាជា ឈ្មោះគណ្ឌៈ ឃើញផ្លែស្វាយទុំធំមួយនៅក្នុងសម្បកអង្រួន ដេញក្អែកដែលមកចោមរោមដោយចំណង់ក្នុងក្លិន និងរសនៃផ្លែស្វាយនោះឲ្យគេចទៅហើយ កាន់យកដើម្បីប្រយោជន៍ដល់ព្រះរាជា ដើរទៅឃើញព្រះសាស្តាក្នុងវាងផ្លូវ គិតថា ព្រះរាជាសោយផ្លែស្វាយនេះហើយគប្បីព្រះរាជទានកហាបណៈ ៨ ឬ ១៦ កហាបណៈ កហាបណៈនោះមិនគ្រប់គ្រាន់ដើម្បីចិញ្ចឹមជីវិតក្នុងអត្តភាពមួយរបស់អញ បើអញប្រគេនផ្លែស្វាយនេះដល់ព្រះសាស្តា នឹងជាគុណនាំមកនូវប្រយោជន៍ឲ្យដល់អញអស់កាលមិនមានទីបំផុត ។ ទើបបង្អោនផ្លែស្វាយនោះដល់ព្រះសាស្តា ។

ព្រះសាស្តា ទតព្រះអានន្ទត្ថេរហើយ ។ លំដាប់នោះ ព្រះថេរៈនាំបាត្រដែលមហារាជទាំង ៤ ថ្វាយមកហើយ ដាក់ក្នុងព្រះហស្តរបស់ព្រះអង្គ ។

ព្រះសាស្តា ទ្រង់បង្អោនបាត្រទទួលផ្លែស្វាយហើយ ទ្រង់សម្តែងអាការដើម្បីប្រថាប់គង់ក្នុងទីនោះឯង ។ ព្រះថេរៈបានក្រាលចីវរថ្វាយហើយ លំដាប់នោះ កាលទ្រង់ប្រថាប់គង់លើចីវរនោះ ព្រះថេរៈត្រង់ទឹកថ្វាយ ហើយច្របាច់ផ្លែស្វាយនោះ ធ្វើជាទឹកបានថ្វាយ ។ ព្រះសាស្តាសោយទឹកបានស្វាយហើយ ត្រាស់នឹងគណ្ឌៈថា ចូរអ្នកកាយដីផង់ឡើងហើយ ដាំគ្រាប់ស្វាយនេះក្នុងទីនេះ

ឯង បុរសនោះបានធ្វើយ៉ាងនោះហើយ ។

ព្រះសាស្តាទ្រង់លាងព្រះហស្តលើគ្រាប់ស្វាយនោះ គ្រាន់ព្រះហស្តដែលទ្រង់លាងហើយប៉ុណ្ណោះ គ្រាប់ស្វាយមានដើមប៉ុនចុងនង្គ័លប្រមាណ ៥០ ហត្ថ ដោយកម្ពស់ ដុះឡើងហើយ មែកធំមាន ៥ ចេញទៅគ្រប់ទិសទាំង ៤ និងមែកមួយត្រង់ឡើងលើ មែកនីមួយៗ មានប្រមាណ ៥០ ហត្ថ ។ ដើមស្វាយនោះសម្បូរដោយផ្កា និងផ្លែ បានទ្រទ្រង់នូវចង្ការនៃផ្លែស្វាយទុំ ក្នុងទីមួយកន្លែងក្នុងខណៈនោះឯង ។

ពួកភិក្ខុមកខាងក្រោយ ទំពាធាន់នូវផ្លែស្វាយទុំជួចគ្នា ។ ព្រះរាជាទ្រង់បានឮថា ស្វាយបែបនេះកើតឡើងហើយ ទើបទ្រង់ចាត់ចែងរក្សាដោយព្រះតម្រាស់ថា បុគ្គលណាម្នាក់កុំកាប់ដើមស្វាយនោះ ដើមស្វាយនោះប្រាកដឈ្មោះថា គណ្ឌម្ពព្រឹក្ស ព្រោះគណ្ឌៈជាអ្នកដាំ សូម្បីពួកអ្នកលេងទំពាស៊ីផ្លែស្វាយទុំហើយ ពោលថា ពួកតិរ្ថិយថោកទាប ពួកអ្នកដឹងថាព្រះសមណ-គោតមទ្រង់ធ្វើបាដិហារ្យត្រង់គណ្ឌម្ពព្រឹក្ស ទើបបញ្ជាឲ្យជកដើមស្វាយតូចៗ សូម្បីកើតក្នុងថ្ងៃនោះក្នុងទីមួយយោជន៍ ដើមស្វាយនេះឈ្មោះគណ្ឌម្ពៈ ហើយយកគ្រាប់ស្វាយដែលជាសំណល់ ប្រហារពួកតិរ្ថិយទាំងនោះ ។

សក្កទេវរាជ ទ្រង់ជ្រាបវាតវលាហកទេវបុត្រថា ចូរពួកអ្នកបក់បោកមណ្ឌបរបស់ពួកតិរ្ថិយឲ្យរលំចុះលើផែនដី និងសំរាមទាំងឡាយ ។ ទេវបុត្រនោះបានធ្វើយ៉ាងនោះហើយ ។ សក្កទេវរាជជ្រាបសុរិយទេវបុត្រថា ចូរអ្នកពង្រីកមណ្ឌល ញាំងពួកតិរ្ថិយឲ្យក្តៅក្រហាយ ទេវបុត្រនោះ ក៏បានធ្វើយ៉ាង

នោះហើយ ។ សក្កៈ ទ្រង់បញ្ជាវាតវលាហកទេវបុត្រទៀតថា ចូរអ្នកញុំាង
មណ្ឌបឲ្យរលំ ខ្យល់កំបុតត្បូងឲ្យតាំងឡើងហើយបក់ទៅ ទេវបុត្រនោះ ធ្វើ
យ៉ាងនោះ កូចនូវជួលើលើសរីរៈរបស់ពួកតិរ្ថិយដែលកំពុងបែកញើស ។ ពួក
តិរ្ថិយទាំងនោះ មានខ្លួនដូចកណ្តៀរក្រហម ។ សក្កទេវរាជ ទ្រង់បញ្ជាវស្ស-
វលាហកទេវបុត្រថា ចូរពួកអ្នកឲ្យតំណក់ទឹកធំៗ ធ្លាក់ចុះ ទេវបុត្រនោះ បាន
ធ្វើយ៉ាងនោះហើយ ។ ពេលនោះ កាយរបស់ពួកតិរ្ថិយទាំងនោះ ដូចគ្នានឹង
មេគោពពាលហើយ ពួកគេបែកគ្នាគេចទៅក្នុងទីចំពោះមុខនោះឯង ។ កាល
ពួកជនទាំងនោះទៅយ៉ាងនោះ អ្នកស្រែម្នាក់ជាឧបដ្ឋាករបស់បូរណកស្សបៈ
គិតថា ឥឡូវនេះ ជាពេលធ្វើបាដិហារ្យនៃលោកម្ចាស់របស់យើង យើងនឹង
មើលបាដិហារ្យនោះ ហើយលែងគោ កាន់ឆ្នាំងបបរ និងខ្សែដែលខ្ជួននាំមក
អំពីព្រលឹម ដើរមកឃើញបូរណកស្សបៈវត់ទៅយ៉ាងនោះ ទើបពោលថា
លោកម្ចាស់ ខ្ញុំមកដោយបំណងថា នឹងមើលបាដិហារ្យរបស់លោកម្ចាស់
លោកម្ចាស់ទៅណា បូរណកស្សបៈពោលថា អ្នកត្រូវការអ្វីដោយបាដិហារ្យ
ចូរឲ្យឆ្នាំង និងខ្សែនេះដល់ខ្ញុំ ។ កាន់យកឆ្នាំង និងខ្សែដែលឧបដ្ឋាកនោះឲ្យ
ហើយ ទៅកាន់ច្រាំងស្ទឹង យកខ្សែចងឆ្នាំងនឹងករបស់ខ្លួនហើយ លោតចូល
ទៅក្នុងអន្លង់ទឹក ញុំាងពពុះឲ្យតាំងឡើង ធ្វើកាលកិរិយាកើតក្នុងអវីចីហើយ ។

ព្រះសាស្តា ទ្រង់និម្មិតទីចង្រ្កមកែវក្នុងអាកាស ទីបំផុតនៃទីចង្រ្កមនោះ
ទល់គ្នានឹងកណ្តាប់ចក្រវាលទិសខាងកើត ទីចង្រ្កមមួយទៀត ទល់គ្នានឹង
កណ្តាប់ចក្រវាលទិសខាងលិច ។ ព្រះសាស្តា កាលបរិស័ទមានប្រមាណ

៣៦ យោជន៍ប្រជុំគ្នាហើយ ក្នុងពេលរសៀលទ្រង់ចេញអំពីព្រះគន្ធកុដិ ដោយទ្រង់ព្រះតម្រិះថា ឥឡូវនេះ ជាពេលដែលធ្វើបាដិហារ្យ ហើយបានប្រថាប់ឈរត្រង់យ៉ាមុខ ។

គ្រានោះ ឧបាសិកាជាអនាគាមីម្នាក់ គឺនន្ទមាតាឈ្មោះឃរណី ចូលទៅគាល់ព្រះអង្គហើយក្រាបទូលថា បពិត្រព្រះអង្គ កាលពីតាដូចខ្ញុំម្ចាស់មាន កិច្ចដែលទ្រង់លំបាករមែងមិនមាន ព្រះសាស្តាត្រាស់ថា ម្នាលឃរណី នាងនឹងធ្វើដូចម្តេច ឃរណីពោលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងធ្វើផែនដីធំឲ្យជាល្ងែនៃចក្រវាលមួយ ហើយធ្វើឲ្យទៅជាទឹក ហើយមុជចុះដូចជាឈាមវា បង្ហាញខ្លួនត្រង់កណ្តាប់ចក្រវាលទិសខាងកើត មុជពីកណ្តាប់ចក្រវាលទិសខាងកើត ផុសត្រង់ទិសខាងលិច ទិសខាងជើង ទិសខាងត្បូង ត្រង់កណ្តាលក៏ដូចគ្នា កាលបើដូច្នោះ មហាជនឃើញខ្ញុំម្ចាស់ហើយ កាលបុគ្គលណាម្នាក់ពោលឡើងថា នុ៎ះជាអ្នកណា ក៏ប្រាប់ថា នុ៎ះជានាងឃរណី អានុភាពរបស់ស្រីម្នាក់គង់អស្ចារ្យដល់ម្ល៉ះ ចំណែកអានុភាពរបស់ព្រះពុទ្ធនឹងដូចម្តេចហ្ន៎ ពួកតិរ្ថិយមិនទាន់ឃើញព្រះអង្គ ក៏នឹងគេចទៅដោយអាការយ៉ាងនេះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា ម្នាលឃរណី តថាគតដឹងថា នាងអាចធ្វើបាដិហារ្យបែបនេះបាន តែកម្រងផ្កានេះ គេមិនបានចងដើម្បីប្រយោជន៍ដល់នាង ហើយទ្រង់ហាម ។

នាងឃរណីនោះគិតថា ព្រះសាស្តាទ្រង់មិនអនុញ្ញាតដល់អញ អ្នកដទៃអាចធ្វើបាដិហារ្យក្រៃលែងជាងអញនឹងមានពិត ដូច្នេះហើយ ទើបឈរក្នុង

ចំណែកម្ខាង ។

ចំណែកព្រះសាស្តា ទ្រង់ព្រះតម្រិះថា គុណរបស់សាវ័កទាំងនោះ នឹងប្រាកដដោយអាការយ៉ាងនេះឯង ទ្រង់សម្គាល់ថា ពួកសាវ័កនឹងបន្ទឺសីហនាទក្នុងកណ្តាលបរិស័ទមានប្រមាណ ៣៦ យោជន៍ដោយអាការយ៉ាងនេះ ទើបត្រាស់សួរសាវ័កដទៃថា ពួកអ្នកនឹងធ្វើបាដិហារ្យដូចម្តេច សាវ័កទាំងនោះក្រាបទូលថា ពួកខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនេះៗ ហើយឈរក្នុងទីចំពោះព្រះភក្ត្រនៃព្រះសាស្តានោះឯង បន្ទឺសីហនាទ ។

បណ្តាសាវ័កទាំងនោះ បានឮថា ចូឡអនាថបិណ្ឌិកគិតថា បើអនាគាមី-ឧបាសក ដែលជាបុត្រដូចអាត្មាអញមាន កិច្ចដែលព្រះសាស្តាត្រូវលំបាកមិនមាន ទើបក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យ ត្រូវព្រះសាស្តាត្រាស់សួរថា អ្នកនឹងធ្វើដូចម្តេច ទើបក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងនិម្មិតអត្តភាពដូចព្រហ្ម មានប្រមាណ ១២ យោជន៍ នឹងគ្រហឹមដូចព្រហ្មដោយសំឡេង ដូចគ្នានឹងផ្គរលាន់ក្នុងកណ្តាលបរិស័ទនេះ មហាជនទឹងសួរថា នេះជាសំឡេងអ្វីហ្ន៎ ហើយនឹងពោលថា បានឮថា នេះជាសំឡេងគ្រហឹមដូចព្រហ្មរបស់ចូឡអនាថបិណ្ឌិក ពួកតិរ្ថិយនឹងគិតថា អានុភាពរបស់គហបតីគង់ជល់ម៉្លេះ ចុះអានុភាពរបស់ព្រះពុទ្ធយ៉ាងណាហ្ន៎ ទាំងមិនទាន់បានឃើញព្រះអង្គ ក៏នឹងគេចទៅ ។ ព្រះសាស្តា ក៏ត្រាស់ដូចមុនដូចគ្នាជល់ចូឡ-អនាថបិណ្ឌិកនោះថា តថាគតដឹងអានុភាពរបស់អ្នកហើយ ទ្រង់មិនអនុញ្ញាតការធ្វើបាដិហារ្យ ។

បន្ទាប់មក សាមណេរឈ្មោះវីរអាយុ ៧ ឆ្នាំ សម្រេចបដិសម្ភិទា ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងធ្វើបាដិហារ្យ ព្រះសាស្តាត្រាស់ថា ម្នាលវីរ នាងនឹងធ្វើដូចម្តេច វីរសាមណេរពោលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងនាំក្នុំសិនេរុ ភ្នំកណ្តាប់ចក្រវាល និងភ្នំហិមពន្ត តម្រៀបគ្នាក្នុងទីនេះ ហើយចេញអំពីភ្នំនោះទៅមិនឲ្យទើសទាក់ ដូចហង្សញី មហាជនឃើញខ្ញុំម្ចាស់នឹងសួរថា នុ៎ះជាអ្នកណា នឹងពោលថា វីរសាមណេរ ពួកតិរ្ថិយគិតគ្នាថា សាមណេរអាយុ ៧ ឆ្នាំ គង់មានអានុភាពដល់ម្ល៉េះ អានុភាពរបស់ព្រះពុទ្ធយ៉ាងណាហ្ន៎ ទាំងមិនទាន់បានឃើញព្រះអង្គ ក៏នឹងគេចទៅ ។ ខាងមុខអំពីនេះទៅ គប្បីជ្រាបពាក្យប៉ែបបែនេះ ដោយទំនងដូចពោលហើយនោះឯង ។ ព្រះដ៏មានព្រះភាគ ត្រាស់ដល់សាមណេរីនោះថា តថាគតដឹងអានុភាពរបស់នាង ដូច្នេះហើយ ទ្រង់ក៏មិនអនុញ្ញាតក្នុងការធ្វើបាដិហារ្យ ។

លំដាប់នោះ សាមណេរឈ្មោះចុន្ទ ជាព្រះខីណាស្រព សម្រេចបដិ-សម្ភិទាមួយរូបអាយុ ៧ ឆ្នាំអំពីកំណើត ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយក្រាបទូលថា ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យ ព្រះសាស្តាត្រាស់សួរថា អ្នកធ្វើដូចម្តេច ទើបក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងចាប់ដើមព្រឹងធំដែលជាទង់នៃជម្ពូទ្វីប ត្រង់ដើមហើយអង្រួន នាំយកផ្លែព្រឹងធំមកឲ្យបរិស័ទទាំងនេះទំពាស៊ី ខ្ញុំព្រះអង្គនឹងនាំផ្លាច្រនៀងមកហើយ ថ្វាយបង្គំព្រះអង្គ ព្រះសាស្តាត្រាស់ថា តថាគតដឹងអានុភាពរបស់អ្នក ដូច្នេះហើយ ក៏ទ្រង់ហាមបាដិហារ្យរបស់សាមណេរនោះ ។

លំដាប់នោះ ព្រះថេរីឈ្មោះឧប្បលវណ្ណា ថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងធ្វើបាដិហារ្យ ត្រូវព្រះសាស្តាត្រាស់សួរថា នាងនឹងធ្វើដូចម្តេច ទើបក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងបង្ហាញបរិស័ទប្រមាណ ៣២ យោជន៍ដោយជុំវិញ ជាស្តេចចក្រពត្តិដែលមានបរិស័ទប្រមាណ ៣៦ យោជន៍ដោយមណ្ឌលជុំវិញ ហើយមកថ្វាយបង្គំព្រះអង្គ ព្រះសាស្តាត្រាស់ថា តថាគតជ្រាបអានុភាពរបស់នាងហើយ ទ្រង់ហាមថាដិហារ្យ របស់ព្រះថេរីនោះ ។

លំដាប់នោះ ព្រះមហាមោគ្គល្លានត្ថេរ ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យ ព្រះសាស្តាត្រាស់សួរថា អ្នកនឹងធ្វើអ្វី ទើបក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងជាក់ស្តែចក្ខំសិនេរុលើធ្មេញ ហើយទំពាក្ខំនោះដូចគ្រាប់ស្ពៃ ព្រះសាស្តាត្រាស់ថា អ្នកនឹងធ្វើអ្វីទៀត ព្រះមហាមោគ្គល្លានពោលថា ខ្ញុំព្រះអង្គនឹងមូរផែនដីធំនេះ ដូចកន្ទេលផែង ហើយញាត់ក្នុងចន្លោះម្រាមដៃ ព្រះសាស្តាត្រាស់ថា អ្នកនឹងធ្វើអ្វីទៀត ព្រះមហាមោគ្គល្លានពោលថា ខ្ញុំព្រះអង្គនឹងបង្វិលផែនដីធំ ឲ្យដូចជាក្តារយន្តបង្វិលភាជន៍ដីរបស់ជាងឆ្នាំង ហើយឲ្យមហាជនទំពាស៊ីឱជៈនៃផែនដី ព្រះសាស្តាត្រាស់ថា អ្នកនឹងធ្វើអ្វីទៀត ព្រះមហាមោគ្គល្លានពោលថា ខ្ញុំព្រះអង្គនឹងធ្វើផែនដីទុកក្នុងដៃខាងឆ្វេង ហើយជាក់សត្វទាំងនេះ ក្នុងទ្វីបដទៃដោយដៃខាងស្តាំ ព្រះសាស្តាត្រាស់ថា អ្នកនឹងធ្វើអ្វីទៀត ព្រះមហាមោគ្គល្លានពោលថា ខ្ញុំព្រះអង្គនឹងធ្វើក្ខំសិនេរុជាជងឆត្រ យកផែនដីធំដាក់លើក្ខំសិនេរុនោះ យកដៃ

ម្ខាងកាន់ ដូចកិកីមានឆត្រក្នុងដៃចង្រ្កមក្នុងអាកាស ព្រះសាស្តាត្រាស់ថា តថាគតជីងអានុភាពរបស់អ្នក ដូច្នេះហើយ ទ្រង់មិនអនុញ្ញាតការធ្វើបាដិហារ្យរបស់ព្រះថេរៈនោះ ។ ព្រះថេរៈគិតថា ប្រហែលព្រះសាស្តាទ្រង់ជ្រាបអ្នកអាចធ្វើបាដិហារ្យក្រៃលែងជាងអាត្មាអញ ទើបឈរក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះថេរៈថា ម្នាលមោគ្គល្លាន ផ្តានេះមិនមែនចងដើម្បីប្រយោជន៍ដល់អ្នកទេ ព្រោះថា តថាគតមានធុរៈ មិនមានប្រមាណ បុគ្គលដទៃដែលឈ្មោះថាអាចនាំធុរៈរបស់តថាគតទៅបានមិនមាន ការដែលបុគ្គលអាចនាំធុរៈ របស់តថាគតទៅបានមិនគប្បីមាន ក្នុងកាលឥឡូវនេះ មិនជារបស់អស្ចារ្យ សូម្បីក្នុងកាលដែលតថាគតកើតក្នុងកំណើតសត្វតិរច្ឆាន ដែលជាអហេតុកកំណើត បុគ្គលដទៃដែលអាចនាំធុរៈរបស់តថាគតទៅ ក៏មិនមានដូចគ្នា ព្រះថេរៈទូលសួរថា បពិត្រព្រះអង្គ តើក្នុងកាលណាទើបទ្រង់នាំអតីតនិទាន មកត្រាស់កណ្ហឧសភជាតក[1] នេះ ឲ្យពិស្តារថា

> *ធុរៈធ្ងន់ ក្នុងទីណាៗ ផ្លូវដ៏ជ្រៅក្នុងទីណា កាលនោះឯង ពួកជននាំគ្នាទីមគោឈ្មោះកណ្ហៈ គោឈ្មោះកណ្ហៈនោះ ក៏អូសនូវធុរៈដ៏ធ្ងន់នោះទៅបាន ។*
>
> *កាលទ្រង់សក្រៃលែងឡើង ទើបត្រាស់នូវិសាលជាតកនេះឲ្យពិស្តារថា បុគ្គលគប្បីនិយាយពាក្យជាទីគាប់ចិត្តតែម្យ៉ាង មិនគប្បីនិយាយពាក្យមិនជាទីគាប់ចិត្តក្នុងកាលណាឡើយ កាលព្រាហ្មណ៍និយាយ*

១- បិដកខ្មែរ ជាកណ្ហជាតក ។

ពាក្យជាទីគាប់ចិត្ត (គោនន្ទិវិសាល) បានទាញការៈដ៏ធ្ងន់ រួច ញុាំងព្រាហ្មណ៍នោះឲ្យបានទ្រព្យផង ជាសត្វមានចិត្តរីករាយ ដោយការញុាំងព្រាហ្មណ៍នោះ ឲ្យបានទ្រព្យនោះផង ។

គ្រានោះឯង ព្រះសាស្តាកាលត្រាស់ហើយ ទ្រង់ឡើងកាន់ទីចង្រ្កម កែវខាងមុខ មានបរិស័ទប្រមាណ ១២ យោជន៍ ខាងក្រោយ ខាងឆ្វេង និងខាងស្តាំក៏ដូចគ្នា ចំណែកដោយត្រង់ មានប្រមាណ ២៤ យោជន៍ ។ ព្រះដ៏មានព្រះភាគ ទ្រង់បានធ្វើយមកប្បាដិហារ្យក្នុងកណ្តាលបរិស័ទ យមកប្បាដិហារ្យនោះ បណ្ឌិតគប្បីជ្រាបតាមបាលីយ៉ាងនេះ ។

យមកប្បាដិហិរញ្ញាណ របស់ព្រះតថាគត តើដូចម្តេច ។ ព្រះតថាគតទ្រង់ធ្វើយមកប្បាដិហារ្យ ដែលមិនទូទៅដល់ពួកសាវ័ក ក្នុងលោកនេះ គឺគំនរភ្លើងចេញអំពីព្រះកាយខាងលើ ធ្លាយទឹកចេញអំពីព្រះកាយខាងក្រោម គំនរភ្លើងចេញអំពីព្រះកាយខាងក្រោម ធ្លាយទឹកចេញអំពីព្រះកាយខាងលើ គំនរភ្លើងចេញអំពីព្រះកាយខាងមុខ ធ្លាយទឹកចេញអំពីព្រះកាយខាងក្រោយ គំនរភ្លើងចេញអំពីព្រះកាយខាងក្រោយ ធ្លាយទឹកចេញអំពីព្រះកាយខាងមុខ គំនរភ្លើងចេញអំពីព្រះនេត្រខាងស្តាំ ធ្លាយទឹកចេញអំពីព្រះនេត្រខាងឆ្វេង គំនរភ្លើងចេញអំពីព្រះនេត្រខាងឆ្វេង ធ្លាយទឹកចេញអំពីព្រះនេត្រខាងស្តាំ គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ ធ្លាយទឹកចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌

ខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ គំនរក្លែងចេញ
អំពីរន្ធព្រះនាសិកាខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាង
ឆ្វេង គំនរក្លែងចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង ផ្ការទឹកចេញអំពី
រន្ធព្រះនាសិកាខាងស្តាំ គំនរក្លែងចេញអំពីចង្ហួយព្រះអង្សាខាងស្តាំ
ផ្ការទឹកចេញអំពីចង្ហួយព្រះអង្សាខាងឆ្វេង គំនរក្លែងចេញអំពី
ចង្ហួយព្រះអង្សាខាងឆ្វេង ផ្ការទឹកចេញអំពីចង្ហួយព្រះអង្សាខាង
ស្តាំ គំនរក្លែងចេញអំពីព្រះហស្តខាងស្តាំ ផ្ការទឹកចេញអំពីព្រះ
ហស្តខាងឆ្វេង គំនរក្លែងចេញអំពីព្រះហស្តខាងឆ្វេង ផ្ការទឹក
ចេញអំពីព្រះហស្តខាងស្តាំ គំនរក្លែងចេញអំពីខាងខាងស្តាំ ផ្ការ
ទឹកចេញអំពីខាងខាងឆ្វេង គំនរក្លែងចេញអំពីខាងខាងឆ្វេង ផ្ការ
ទឹកចេញអំពីខាងខាងស្តាំ គំនរក្លែងចេញអំពីព្រះបាទខាងស្តាំ
ផ្ការទឹកចេញអំពីព្រះបាទខាងឆ្វេង គំនរក្លែងចេញអំពីព្រះបាទ
ខាងឆ្វេង ផ្ការទឹកចេញអំពីព្រះបាទខាងស្តាំ គំនរក្លែងចេញអំពី
ព្រះអង្គុលីមួយៗ ផ្ការទឹកចេញអំពីចន្លោះនៃព្រះអង្គុលី គំនរក្លែង
ចេញ អំពីចន្លោះនៃព្រះអង្គុលី ផ្ការទឹកចេញអំពីព្រះអង្គុលីមួយៗ
គំនរក្លែងចេញអំពីព្រះលោមាមួយៗ ផ្ការទឹកចេញអំពីព្រះលោមា
មួយៗ គំនរក្លែងចេញអំពីរណ្តៅព្រះលោមាមួយៗ ផ្ការទឹកចេញ
អំពីរណ្តៅព្រះលោមា (ព្រះមានព្រះភាគទ្រង់បញ្ចេញ) នូវព្រះ
ឆព្ភណ្ណរង្សីរៀវ លឿង ក្រហម ស ហង្សបាទ ផ្លេកៗ ព្រះមាន

ព្រះភាគទ្រង់ចង្រ្កម ព្រះពុទ្ធនិម្មិត ទ្រង់ឈរ ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ឈរ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់គង់ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់គង់ ព្រះមានព្រះភាគទ្រង់ចង្រ្កម ឬទ្រង់គង់ ឬផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ឈរ ព្រះមានព្រះភាគទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់គង់ ព្រះមានព្រះភាគទ្រង់ឈរ ឬទ្រង់គង់ ឬទ្រង់ចង្រ្កម ព្រះពុទ្ធនិម្មិតទ្រង់ផ្ទំ នេះ ឈ្មោះថា យមកប្បាដិហិរញ្ញាណរបស់ព្រះតថាគត ។

ព្រះសាស្តាទ្រង់ចង្រ្កមលើទីចង្រ្កមនោះហើយ ។ ដើម្បីទ្រង់សម្តែងសេចក្តីនោះ ធ្លាភ្លើងរមែងផ្សាយចេញអំពីព្រះកាយខាងលើ ដោយអំណាចតេជោ-កសិណសមាបត្តិរបស់ព្រះសាស្តានោះ ធ្លាទឹកហូរចេញអំពីព្រះកាយខាងក្រោម ដោយអំណាចអាបោកសិណសមាបត្តិ ធ្លាភ្លើងហូរចេញអំពីទីដែលធ្លាទឹកហូរចេញហើយទៀត ធ្លាទឹកក៏ហូរចេញអំពីទីដែលធ្លាភ្លើងហូរចេញទៀត ទើបព្រះសារីបុត្តពោលថា **ហោដ្ឋិមកាយតោ ឧបរិមកាយតោ ។** *ក្នុងបទទាំងពួងក៏ដូច្នេះ ។ ក្នុងយមកប្បាដិហារ្យនេះ ធ្លាភ្លើងមិនលាយជាមួយធ្លាទឹក ម្យ៉ាងទៀត ធ្លាទឹកក៏មិនបានលាយដោយធ្លាភ្លើង បានឮថា ធ្លាភ្លើង និងធ្លាទឹកទាំងពីរនេះ ផ្សាយទៅដល់ព្រហ្មលោក ហើយក៏វិលទៅកាន់កណ្តាប់ចក្រវាល ។ ព្រោះព្រះសារីបុត្តត្ថេរពោលថា* **ឆន្នំ វណ្ណានំ** *ព្រះ*

រស្មីមានពណ៌ ៦ ប្រការរបស់ព្រះសាស្តានោះ ផ្សាយទ្បើងអំពីល្វែងនៃចក្រវាលមួយ ដូចមាសដែលគេរំលាយ ហូរចេញអំពីស្នប់ និងដូចផ្នារទឹកមាសដែលហូរចេញអំពីនាឡិយន្ត រហូតដល់ព្រហ្មលោក ហើយវិលត្រឡប់មកកាន់កណ្តាប់ចក្រវាលវិញ ។ ល្វែងនៃចក្រវាលមួយ ដូចជាខឿនពោធិ-ព្រឹក្សដែលដោតដោយកន្ទះដែលវៀច មានពន្ធឺតែមួយ ។

ក្នុងថ្ងៃនោះ ព្រះសាស្តាទ្រង់យាងចន្ត្រមធ្វើបាដិហារ្យ សម្តែងធម្មកថាដល់មហាជនក្នុងចន្ទោះៗ កាលទ្រង់សម្តែង ទ្រង់មិនធ្វើឲ្យមហាជនធ្ងន់ចិត្ត ប្រទានឲ្យស្រាលចិត្ត ។ ក្នុងខណៈនោះ មហាជនញ្ចុាំងសាធុការឲ្យប្រព្រឹត្តទៅ ហើយ ក្នុងកាលដែលសាធុការរបស់មហាជននោះប្រព្រឹត្តទៅ ព្រះសាស្តាទ្រង់ប្រមើលមើលចិត្តរបស់បរិស័ទ ដែលធំមានប្រមាណប៉ុណ្ណោះ ទ្រង់បានជ្រាបវារចិត្តរបស់បរិស័ទនីមួយៗ ដោយអំណាចអាការ ១៦ យ៉ាង ។ ចិត្តរបស់ព្រះពុទ្ធទាំងឡាយ ប្រព្រឹត្តទៅរហ័សយ៉ាងនេះ បុគ្គលណាម្នាក់ជ្រះថ្ងាក្នុងធម៌ណា និងក្នុងបាដិហារ្យណា ព្រះសាស្តាទ្រង់សម្តែងធម៌ និងធ្វើបាដិហារ្យដោយអំណាចអធ្យាស្រ័យនៃបុគ្គលនោះៗ ។ កាលទ្រង់សម្តែងធម៌ ទ្រង់ធ្វើបាដិហារ្យដោយអាការយ៉ាងនេះ ធម្មាភិសម័យមានដល់មហាជនហើយ ។ ព្រះសាស្តាទ្រង់កំណត់ចិត្តរបស់ទ្រង់ ទ្រង់មិនឃើញបុគ្គលដទៃដែលអាចសួរបញ្ហាក្នុងសមាគមនោះ ទើបទ្រង់និម្មិតពុទ្ធនិម្មិត ។ ព្រះសាស្តាទ្រង់ឆ្ងើយបញ្ហា ដែលពុទ្ធនិម្មិតនោះសួរហើយ ។ ពុទ្ធនិម្មិតនោះ ក៏ឆ្ងើយបញ្ហាដែលព្រះសាស្តាត្រាស់សួរហើយ ។ ក្នុងកាលដែលព្រះដ៏មានព្រះភាគទ្រង់ចន្ត្រម ព្រះពុទ្ធនិម្មិត

សម្រេចឥរិយាបថ មានការឈរជាដើមណាមួយ ក្នុងកាលដែលពុទ្ធនិម្មិតចង្រ្កែម ព្រះសាស្តាទ្រង់សម្រេចឥរិយាបថ មានការប្រថាប់ឈរជាដើមណាមួយ ដើម្បីសម្តែងសេចក្តីនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលពាក្យជាដើមថា ពុទ្ធនិម្មិតចង្រ្កែមខ្លះជាដើម ។

ធម្មាភិសមយមានដល់សត្វ ២០ កោដិ ក្នុងសមាគមនោះ ព្រោះឃើញបាដិហារ្យរបស់ព្រះសាស្តាដែលទ្រង់ធ្វើយ៉ាងនោះ និងព្រោះបានស្តាប់ធម្មកថា ។

ព្រះសាស្តា កំពុងធ្វើបាដិហារ្យនោះឯង ទ្រង់អាវជ្ជនៈថា ព្រះពុទ្ធក្នុងអតីតទាំងឡាយ ធ្វើបាដិហារ្យនេះហើយចាំវស្សាក្នុងទីណាហ្ន៎ ទ្រង់ឃើញថា ចាំវស្សាក្នុងតាវត្តិង្សពិភព ហើយទ្រង់សម្តែងអភិធម្មបិដកដល់ព្រះពុទ្ធមាតាដូច្នេះហើយ ទ្រង់លើកព្រះបាទស្តាំជាន់លើកំពូលភ្នំយុគន្ធរ ទ្រង់លើកព្រះបាទម្ខាងទៀត ជាន់លើភ្នំសិនេរុ វារៈដែលឈានជំហាន ៣ មានហើយក្នុងទី ៦៨ សែនយោជន៍យ៉ាងនេះ ។ ចន្លោះជំហាន ២ ជំហាន បានឈានចេញដូចគ្នា និងការយាងតាមប្រក្រតី ។ បុគ្គលមិនគប្បីកំណត់ថា ព្រះសាស្តាទ្រង់ឈានព្រះបាទហើយ ព្រោះក្នុងកាលដែលទ្រង់លើកព្រះបាទនោះឯង កំពូលភ្នំនោះមកជិតព្រះបាទទទួលហើយ ក្នុងកាលដែលព្រះសាស្តាទ្រង់ជាន់ហើយ កំពូលភ្នំនោះ ក៏ប្រតិស្ឋានក្នុងកន្លែងដើម ។ សក្កទេវរាជ ទតឃើញព្រះសាស្តាហើយ ទ្រង់ព្រះតម្រិះថា ព្រះសាស្តាទ្រង់នឹងចាំវស្សាត្រង់បណ្ឌុកម្ពលសិលាឧបការៈនឹងមានដល់ពួកទេវតាច្រើនហ្ន៎ តែកាលព្រះសាស្តាចាំវស្សាក្នុងទីនោះ ទេវតាជន់ទៃៗ មិនអាចបញ្ឈប់ដៃបាន ឯបណ្ឌុកម្ពលសិលានេះបណ្តាយ ៦០

យោជន៍ ទទឹង ៥០ យោជន៍ កម្រាស់ ១៥ យោជន៍ កាលព្រះសាស្តាប្រថាប់គង់ហើយ ក៏គង់ក្លាយជាទេ ។ ព្រះសាស្តាទ្រង់ជ្រាបអធ្យាស្រ័យរបស់សក្កទេវរាជ ទ្រង់បោះសង្ឃាដីរបស់ព្រះអង្គឲ្យគ្របថ្មហើយ សក្កៈទ្រង់ព្រះតម្រិះថា ព្រះសាស្តាទ្រង់បោះចីវរមកឲ្យគ្របថ្ម ទ្រង់នឹងប្រថាប់គង់ក្នុងទីបន្តិចបន្តួចដោយព្រះអង្គឯង ព្រះសាស្តាទ្រង់ជ្រាបអធ្យាស្រ័យរបស់សក្ក-ទេវរាជ ទើបប្រថាប់គង់ធ្វើបណ្តុកម្ពលសិលាខាងក្នុងផ្នត់ចីវរនោះឯង ហាក់ដូចកិកូដែលទ្រទ្រង់សំពត់មហាបំសុកូល ធ្វើតាំងទាបទុកខាងក្នុងផ្នត់ចីវរដូច្នោះ ។ ខណៈនោះឯង មហាជនរកមើលព្រះសាស្តាក៏មិនឃើញ កាលនោះ ហាក់ដូចជាព្រះចន្ទលិច និងដូចពេលព្រះអាទិត្យលិច មហាជនកន្ទក់កន្ទេញពោលគាថានេះថា

ព្រះសាស្តាយាងទៅកាន់ក្នុំចិត្តកូដ ឬក្នុំកៃលាស ឬក្នុំយុគន្ធរ
បាន ជាពួកយើងមិនឃើញនូវព្រះសម្មាសម្ពុទ្ធ ជាលោកជេដ្ឋ
ប្រសើរជាងនរៈ ។

មួយពួកទៀតយំរៀបរាប់ថា ព្រះសាស្តា ទ្រង់ត្រេកអរហើយក្នុងវិវេក ទ្រង់នឹងទៅកាន់ដែនដទៃ ឬជនបទដទៃហើយ ព្រោះទ្រង់ខ្វាសថា តថាគតធ្វើបាដិហារ្យបែបនេះជល់បរិស័ទបែបនេះ ឥឡូវនេះ យើងទាំងឡាយមិនបានឃើញទ្រង់ ដូច្នេះហើយ ពោលគាថានេះថា

ព្រះសាស្តា ជាអ្នកប្រាជ្ញ ទ្រង់ត្រេកអរហើយក្នុងវិវេក ទ្រង់មិន
ត្រឡប់មកទៀត យើងទាំងឡាយ មិនឃើញព្រះសម្មាសម្ពុទ្ធជា

លោកជេដ្ឋ ជាបុគ្គលប្រសើរជាងនរៈ ដូច្នេះ ។

ជនទាំងនោះសួរព្រះមហាមោគ្គល្លានថា បពិត្រលោកម្ចាស់ ព្រះសាស្តាយាងទៅទីណា លោកជ្រាបក៏ពោលថា ចូរសួរអនុរុទ្ធចុះ ដោយបំណងថា គុណរបស់សាវ័កដទៃៗ ចូរប្រាកដដូច្នេះ ។ ជនទាំងនោះសួរព្រះថេរៈយ៉ាងនោះថា បពិត្រលោកម្ចាស់ ព្រះសាស្តាយាងទៅទីណា ព្រះអនុរុទ្ធតបថា ទ្រង់យាងទៅចាំវស្សាត្រង់បណ្តុកម្ពលសិលាក្នុងស្ថានតាវត្តិង្ស ហើយទ្រង់សម្តែងអភិធម្មបិដកជល់ព្រះពុទ្ធមាតា មហាជនពោលថា បពិត្រលោកម្ចាស់ ទ្រង់នឹងយាងមកក្នុងកាលណា ព្រះអនុរុទ្ធពោលថា ទ្រង់សម្តែងអភិធម្មបិដកអស់កាល ៣ ខែហើយ ទ្រង់នឹងយាងមកក្នុងថ្ងៃមហាបវារណា ។

ជនទាំងនោះនិយាយគ្នាថា ពួកយើងមិនបានឃើញព្រះសាស្តា នឹងមិនទៅ ដូច្នេះហើយ ចោះជម្រកស្នាក់នៅក្នុងទីនោះឯង បានឮថា ជនទាំងនោះមានអាកាសនោះឯងជាគ្រឿងប្រក់ ឈ្មោះថាញើសដែលហូរចេញអំពីខ្លួនរបស់បរិស័ទច្រើនជល់ម្ល៉ោះមិនបានប្រាកដឡើយ ។ ផែនដីបានបើកឱកាសឲ្យហើយ ផែនដីក្នុងទីគ្រប់កន្លែង ជាទីរាបស្មើស្អាតនោះឯង ។ ព្រះសាស្តា បានត្រាស់ប្រាប់ព្រះមហាមោគ្គល្លានមុនហើយថា ម្នាលមោគ្គល្លាន អ្នកគប្បីសម្តែងធម៌ជល់បរិស័ទនោះ ចូរឲ្យអនាថបិណ្ឌិកនឹងឲ្យអាហារ ព្រោះហេតុនោះ ចូរឲ្យ-អនាថបិណ្ឌិក បានឲ្យហើយនូវបបរ ជាយ របស់ទំពា របស់ក្រអូប ផ្កាកម្រង និងគ្រឿងប្រដាប់ជល់បរិស័ទនោះ គ្រប់កាលទាំងព្រឹក និងល្ងាចរហូត ៣ ខែនោះ ។ ព្រះមហាមោគ្គល្លានសម្តែងធម៌ហើយ វិសជ្ជនាបញ្ជាដល់ពួក

ជនដែលមកហើយ ដើម្បីមើលបាដិហារ្យសួរហើយ ។

ទេវតាក្នុងម៉ឺនចក្រវាល ចោមរោមព្រះសាស្តាដែលទ្រង់ចាំវស្សា ត្រង់បណ្ឌុកម្ពលសិលា ដើម្បីទ្រង់សម្តែងអភិធម្មដល់ព្រះមាតា ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា

ក្នុងកាលណាព្រះពុទ្ធ ជាកំពូលបុរសប្រថាប់នៅលើបណ្ឌុកម្ពល-សិលា ត្រង់គល់បារិច្ឆត្តកៈក្នុងស្ថានតាវត្តិង្ស ក្នុងកាលនោះ ទេវតាទាំងឡាយក្នុងម៉ឺនលោកធាតុ ប្រជុំព្រមគ្នាហើយ ចូលគាល់ព្រះសាស្តា ដែលប្រថាប់នៅលើកំពូលភ្នំ ទេវតាអង្គណាមួយ ក៏មិនរុងរឿងជាងព្រះសម្មាសម្ពុទ្ធ ដោយពណ៌សម្បុរឡើយ ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ រមែងរុងរឿងកន្ទងនូវពួកទេវតាទាំងអស់ ។

កាលព្រះសាស្តា ប្រថាប់គង់គ្រប់សង្កត់ទេវតាគ្រប់ពួក ដោយរស្មីព្រះសរីរៈរបស់ទ្រង់យ៉ាងនេះ ពុទ្ធមាតាយាងមកអំពីវិមានជាន់តុសិត ប្រថាប់គង់ខាងស្តាំ ឥន្ទកទេវបុត្រក៏មកអង្គុយខាងស្តាំដូចគ្នា អង្គុរទេវបុត្រអង្គុយខាងឆ្វេង អង្គុរទេវបុត្រនោះ កាលទេវតាទាំងឡាយដែលមានសក្តិធំប្រជុំគ្នា ខ្ចាតចេញទៅហើយ បានឱកាសក្នុងប្រមាណ ១២ យោជន៍ ។ ឥន្ទកទេវបុត្រ អង្គុយក្នុងទីនោះឯង ព្រះសាស្តាទ្រង់ទតទេវបុត្រទាំងពីរនោះហើយ មានព្រះបំណងនឹងញុំាងបរិស័ទឲ្យជ្រាបភាពដែលទាន បុគ្គលឲ្យហើយដល់ទក្ខិណេយ្យបុគ្គលក្នុងសាសនារបស់ព្រះអង្គ មានអានិសង្សច្រើន ទើបត្រាស់យ៉ាងនេះថា អង្គុរៈ អ្នកធ្វើចង្ក្រានបណ្តាយ ១២ យោជន៍ ឲ្យទានសន្ធឹកសន្ធាប់ អស់

កាលមួយម៉ឺនឆ្នាំនេះ ជារយៈកាលយូរ ឥឡូវនេះ អ្នកមកក្នុងសមាគមរបស់តថាគត បានឱកាសក្នុងទីចម្ងាយ ១២ យោជន៍ ឆ្ងាយជាងទេវបុត្រទាំងអស់ អ្វីហ្ន៎ជាហេតុ ក្នុងសេចក្តីនេះ ពិតហើយ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានពោលដូច្នេះថា

ព្រះសម្មាសម្ពុទ្ធទតអង្កុរទេវបុត្រ និងឥន្ទកទេវបុត្រហើយ កាលទ្រង់សរសើរទក្ខិណេយ្យបុគ្គល បានត្រាស់ពុទ្ធវចនៈនេះថា ម្នាលអង្កុរៈ អ្នកឲ្យទានសន្ធឹកសន្ធាប់ អស់កាលជ័យូរ កាលអ្នកមកកាន់សម្នាក់តថាគត អង្គុយឆ្ងាយសន្ធឹម ។ ព្រះសូរសៀងនោះ ឮជល់ផែនដី បរិសទ្ទាំងអស់បានឮសូរសៀងនោះ ។

ព្រះសាស្តា កាលត្រាស់យ៉ាងនោះហើយ អង្កុរទេវបុត្រដែលព្រះដ៏មានព្រះភាគទ្រង់មានខ្ជួនអប់រំហើយ ជាស់តឿនហើយ បានក្រាបទូលពាក្យនេះថា

ប្រយោជន៍អ្វីដោយទាននោះរបស់ខ្ញុំព្រះអង្គ ព្រោះ (ទាននោះ) សូន្យចាកទក្ខិណេយ្យបុគ្គល ឥន្ទកយក្សនេះឯង ឲ្យទានតិចតួចទេ រុងរឿងជាងពួកខ្ញុំព្រះអង្គ ដូចជាព្រះចន្ទ្រក្នុងពួកផ្កាយ ។

បណ្តាបទទាំងនោះ បទថា **ឧជ្ឈា** កែជា **ឧត្ថា** ប្រែថា ឲ្យហើយ កាលអង្កុរទេវបុត្រក្រាបទូលយ៉ាងនោះហើយ ព្រះសាស្តាត្រាស់នឹងឥន្ទកទេវបុត្រថា ម្នាលឥន្ទកៈ អ្នកអង្គុយខាងស្តាំតថាគត ហេតុអ្វីមិនខ្ចាតចេញទៅឆ្ងាយ ឥន្ទកទេវបុត្រក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គបានទក្ខិណេយ្យសម្បត្តិហើយ ដូចអ្នកស្រែព្រោះពូជបន្តិចបន្តួចក្នុងស្រែល្អ ដូច្នេះហើយ កាលប្រកាស

ទក្ខិណេយ្យបុគ្គល ទើបក្រាបទូលថា

ពួជដែលបុគ្គលព្រោះហើយ សូម្បីតិច ក្នុងស្រែដ៏ល្អ កាលភ្លៀងធ្លាក់ស្រួល ផលរមែងញុំាងអ្នកស្រែឲ្យត្រេកអរបាន ដូចម្តេច មិញ សក្ការៈដែលបុគ្គលធ្វើហើយ សូម្បីតិចតួច ក្នុងតាទិបុគ្គលទាំងឡាយ មានសីល មានគុណ បុណ្យរមែងមានផលច្រើន ក៏ដូច្នោះឯង ។

សួរថា បុព្វកម្មរបស់ឥន្ទកទេវបុត្រនោះដូចម្តេច ។ ឆ្លើយថា បានឮថា ឥន្ទកទេវបុត្រនោះ បានប្រគេនបាយមួយវែក ដែលគេនាំមកហើយដើម្បីខ្ជួនដល់ព្រះអនុរុទ្ធត្ថេរ ដែលចូលទៅបិណ្ឌបាតខាងក្នុងស្រុក បុណ្យរបស់ឥន្ទកៈនោះ មានផលច្រើនជាងទាន ដែលអង្គុរទេវបុត្រធ្វើហើយដោយជួរនៃចង្ក្រានប្រវែង ១២ យោជន៍ ឲ្យហើយរាប់ម៉ឺនឆ្នាំ ព្រោះហេតុនោះ ទើបឥន្ទកទេវបុត្រក្រាបទូលយ៉ាងនោះ កាលឥន្ទកទេវបុត្រក្រាបទូលយ៉ាងនោះហើយ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអង្គុរៈ ការជ្រើសរើសមុនហើយ ឲ្យទាន ទើបគួរទាននោះរមែងមានផលច្រើនដោយអាការយ៉ាងនេះ ដូចពួជដែលគេព្រោះល្អក្នុងស្រែល្អដូច្នោះ តែអ្នកមិនបានធ្វើយ៉ាងនោះទេឯយ ហេតុនោះ ទើបទានរបស់អ្នកមិនមានផលច្រើន កាលទ្រង់ប្រកាសអត្ថនេះឲ្យជាក់ច្បាស់ ទើបត្រាស់ថា

ទានដែលបុគ្គលពិចារណាហើយទើបឲ្យ ព្រះសុគតទ្រង់សរសើរ ហើយទក្ខិណេយ្យបុគ្គលណា ដែលមាននៅក្នុងជីវលោកនេះ ទាន

ដែលបុគ្គលឲ្យហើយដល់ទក្ខិណេយ្យបុគ្គលទាំងនោះ រមែងមានផលច្រើន ដូចពូជដែលបុគ្គលព្រោះហើយក្នុងស្រែល្អ ។

កាលទ្រង់សម្តែងធម៌ឲ្យក្រៃលែងឡើង ក៏បានត្រាស់ព្រះគាថានេះថា

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះមានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានរាគៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់អ្នកមានទោសៈអស់ហើយ រមែងជាទានមានផលច្រើន ។

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានមោហៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានសេចក្តីច្រណែនជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានសេចក្តីស្រវែងអស់ហើយ រមែងជាទានមានផលច្រើន ។

ក្នុងកាលចប់ទេសនា អង្គ្គរទេវបុត្រ និងឥន្ទកទេវបុត្រតាំងនៅហើយក្នុងសោតាបត្តិផល ។

លំដាប់នោះ ព្រះសាស្តាប្រថាប់គង់កណ្តាលទេវបរិស័ទ ទ្រង់ប្រារព្ធព្រះមាតា ផ្តើមសម្តែងអភិធម្មបិដកថា **កុសលា ធម្មា អកុសលា ធម្មា អព្យា-**

កតា ធម្មា ដូច្នេះជាដើម ។ ទ្រង់សម្តែងអភិធម្មបិដក ដោយនយនេះរឿយៗ ទៅអស់ ៣ ខែ ។ កាលទ្រង់កំពុងសម្តែង ក្នុងវេលាភិក្ខាចារ ទ្រង់និម្មិតពុទ្ធ-និម្មិតដោយទ្រង់អធិដ្ឋានថា ចូរពុទ្ធនិម្មិតនេះសម្តែងធម៌ឈ្មោះនេះ ទម្រាំតថាគតមក ហើយទ្រង់យាងទៅកាន់ព្រៃហិមពាន្ត ទ្រង់ទំពាឈើសូនឈ្មោះនាគលតា ខ្ពុរព្រះឱស្ឋត្រង់អនោតត្តស្រះ នាំបិណ្ឌបាតមកអំពីឧត្តរកុរុទ្វីប បានប្រថាប់គង់ធ្វើភត្តកិច្ចក្នុងរោងធំហើយ ព្រះសារីបុត្តត្ថេរនិមន្តទៅធ្វើវត្តជល់ព្រះសាស្តាក្នុងទីនោះ ។ ព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចហើយ ត្រាស់ដល់ព្រះថេរៈថា ម្នាលសារីបុត្ត ថ្ងៃនេះ តថាគតសម្តែងធម៌ឈ្មោះនេះ មានប្រមាណប៉ុណ្ណេះ ចូរអ្នកប្រាប់ដល់ភិក្ខុ ៥០០ ដែលជានិស្សិតរបស់ខ្លួន ។ បានឮថា កុលបុត្រ ៥០០ ជ្រះថ្លាក្នុងយមកប្បាដិហារ្យ បួសហើយក្នុងសម្នាក់របស់ព្រះថេរៈ ។ ព្រះសាស្តាត្រាស់ហើយយ៉ាងនោះ ទ្រង់សំដៅយកភិក្ខុទាំងនោះ ។ កាលត្រាស់ហើយ ទ្រង់យាងទៅកាន់ទេវលោក ទ្រង់សម្តែងធម៌ឯងបន្តអំពីព្រះពុទ្ធនិម្មិត ។ ព្រះថេរៈក៏ទៅសម្តែងធម៌ដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះ កាលដែលព្រះសាស្តាយាងទៅក្នុងទេវលោកនោះឯង បានជាអ្នកជំនាញក្នុងបកវណ៌ ៧ ហើយ ។

បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ ភិក្ខុទាំងនោះជាសត្វប្រចៀវ សំយុងខ្លួនត្រង់ញាកភ្នំមួយកន្លែង កាលព្រះថេរៈ ២ រូបចង្រ្កមហើយ ស្វាធ្យាយអភិធម្ម បានស្តាប់កាន់យកនិមិត្តក្នុងសំឡេងហើយ ប្រចៀវទាំងនោះមិនដឹងថា នេះឈ្មោះថាខន្ធ នេះឈ្មោះថាធាតុ ដោយហេតុត្រឹមតែកាន់យក

និមិត្តក្នុងសំឡេងប៉ុណ្ណោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក បាន
សោយទិព្វសម្បត្តិអស់ ១ ពុទ្ធន្តរ ចុតិអំពីទេវលោកនោះហើយ កើតក្នុងផ្ទះ
នៃត្រកូលក្នុងក្រុងសាវត្ថី កើតសេចក្តីជ្រះថ្លាក្នុងយមកប្បាដិហារ្យ បួសក្នុង
សម្នាក់របស់ព្រះថេរៈហើយ បានជាអ្នកជំនាញក្នុងបករណ៍ ៧ មុនភិក្ខុទាំង
ពួង ។ ព្រះសាស្តា ទ្រង់ក៏សម្តែងអភិធម្មដោយទំនងនោះឯងអស់ ៣ ខែ ។

ក្នុងកាលចប់ទេសនា ធម្មាភិសមយមានដល់ទេវតា ៨ ម៉ឺនកោដិ ព្រះ
នាងមហាមាយាក៏តាំងនៅក្នុងសោតាបត្តិផលហើយ ។

បរិសទ្មានបរិមណ្ឌល ៣៦ យោជន៍នោះឯងគិតថា បន្ទាប់អំពីនេះទៅ
ក្នុងថ្ងៃទី ៧ ត្រូវជាថ្ងៃមហាបវារណា ចូលទៅរកព្រះមហាមោគ្គល្លានត្ថេរ ពោល
ថា បពិត្រលោកម្ចាស់ យើងគួរជ្រាបថ្ងៃយាងចុះរបស់ព្រះសាស្តា ព្រោះយើង
ទាំងឡាយ បើមិនឃើញព្រះសាស្តាក៏មិនទៅ ។ ព្រះមហាមោគ្គល្លាន ស្តាប់
ពាក្យនោះហើយទទួលថា សាធុ ហើយមុជចុះក្នុងផែនដីត្រង់នោះឯង អធិដ្ឋាន
ថា ចូរបរិសទ្ឃើញអាត្មាអញ ដែលទៅដល់ជើងភ្នំសិនេរុហើយផុសឡើង
មានរូបច្រូកដូចសំពត់កម្ពល ដែលជោតនៅក្នុងកែវមណី ឡើងទៅហើយ
ត្រង់កណ្តាលភ្នំសិនេរុ សូម្បីពួកមនុស្សក៏ឃើញលោកថា ឡើងទៅហើយមួយ
យោជន៍ ឡើងទៅហើយពីរយោជន៍ជាដើម ព្រះថេរៈឡើងទៅថ្វាយបង្គំព្រះ
យុគលបាទរបស់ព្រះសាស្តា ដូចទូលដោយក្បាល ក្រាបទូលយ៉ាងនេះថា
បពិត្រព្រះអង្គ បរិសទ្បំណងនឹងគាល់ទ្រង់សិនហើយទើបទៅ ទ្រង់យាងចុះ
ក្នុងកាលណា ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន សារីបុត្តបងប្រុសរបស់

អ្នកនៅទីណា ព្រះមោគ្គល្លានទូលថា បពិត្រព្រះអង្គ លោកចាំវស្សាក្នុងសង្គស្ស-នគរ ។ ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ តថាគតនឹងចុះត្រង់ទ្វារនគរសង្គស្សៈ ក្នុងថ្ងៃមហាបវារណា បុគ្គលណាច្រាច្នា នឹងជួបតថាគត ចូរទៅក្នុងទីនោះចុះ ។ សង្គស្សនគរ ឆ្ងាយអំពីក្រុងសាវត្ថី ប្រមាណ ៣០ យោជន៍ ក្នុងផ្លូវប៉ុណ្ណោះ កិច្ចដែលត្រូវត្រៀមស្បៀង រមែងមិនមានដល់បុគ្គលណាម្នាក់ឡើយ អ្នកគប្បីប្រាប់ដល់មនុស្សទាំងនោះថា អ្នកទាំងឡាយ ចូរជាអ្នករក្សាឧបោសថ ដូចទៅកាន់វិហារដែលជិត ដើម្បីស្តាប់ធម៌ចុះ ។

ព្រះថេរៈទូលថា សាធុ ហើយបានប្រាប់តាមបណ្តាំ ។ ព្រះសាស្តាទ្រង់ចាំវស្សាបវារណាហើយ ត្រាស់ប្រាប់ដល់សក្កៈថា មហាបពិត្រ តថាគតនឹងទៅកាន់ទឹកដីមនុស្ស សក្កទេវរាជទ្រង់និម្មិតជណ្តើរ គឺជណ្តើរមាស ជណ្តើរកែវមណី ជណ្តើរប្រាក់ ។ ជើងជណ្តើរទាំងនោះ តាំងនៅត្រង់ខ្វាងទ្វារនគរសង្គស្សៈ ។ កញ្ចាលជណ្តើរទាំងនោះតាំងនៅត្រង់កំពូលភ្នំសិនេរុ ក្នុងជណ្តើរទាំងនោះ ជណ្តើរមាសនៅខាងស្តាំដើម្បីពួកទេវតា ជណ្តើរប្រាក់នៅខាងឆ្វេងដើម្បីមហាព្រហ្មទាំងឡាយ ជណ្តើរកែវមណីនៅត្រង់កណ្តាល ដើម្បីព្រះដ៏មានព្រះភាគ ។ ព្រះសាស្តាប្រថាប់ឈរលើកំពូលភ្នំសិនេរុ ទ្រង់ធ្វើយមកប្បាដិហារ្យក្នុងកាលដែលទ្រង់ចុះអំពីទេវលោក ទ្រង់សម្លឹងមើលខាងលើហើយ ទីដែលទ្រង់ទតហើយទាំងឡាយមានទួល ដូចគ្នាតែមួយដល់ព្រហ្មលោក ទ្រង់ទតខាងក្រោម ទីដែលទ្រង់ទតហើយមានទួល ដូចគ្នាតែមួយដល់អវីចី ទ្រង់

សម្ថឹងមើលទិសធំ និងទិសតូចទាំងឡាយ ចក្រវាលច្រើនសែនមានទូលដូចគ្នាតែមួយ ទេវតាឃើញពួកមនុស្ស ពួកមនុស្សឃើញពួកទេវតា ពួកទេវតា និងមនុស្សទាំងអស់ឃើញគ្នាហើយចំពោះមុខនោះឯង ព្រះសាស្តាទ្រង់បញ្ចេញព្រះឆព្វណ្ណរង្សីទៅហើយ មនុស្សក្នុងបរិស័ទដែលមានបរិមណ្ឌល ៣៦ យោជន៍ បុគ្គលសូម្បីតែម្នាក់ កាលសម្ថឹងមើលសិរីរបស់ព្រះពុទ្ធ ក្នុងថ្ងៃនោះហើយ ឈ្មោះថា មិនប្រាថ្នាភាពជាព្រះពុទ្ធមិនមាន ។ ពួកទេវតាចុះតាមជណ្តើរមាស ពួកមហាព្រហ្មចុះតាមជណ្តើរប្រាក់ ព្រះសម្មាសម្ពុទ្ធយាងចុះតាមជណ្តើរកែវមណី ។ គន្ធព្វទេវបុត្រ ឈ្មោះបញ្ចសិខ: កាន់ពិណពណ៌លឿងដូចផ្ថែញ្ជៅ ឈរខាងស្តាំ បូជាដោយការរាំជល់ព្រះសាស្តាចុះមកមាតលិសង្គាហកទេវបុត្រឈរខាងឆ្វេង កាន់កម្រងផ្កាដែលជាទិព្វ នមស្ការបូជាចុះមកមហាព្រហ្មបាំងឆត្រសុយាមកាន់ផ្ថិតវាលវីជនី ។ ព្រះសាស្តាយាងចុះ មួយអន្ទើដោយបរិវារនេះ ប្រថាប់នៅត្រង់ខ្វោងទ្វារសង្កស្សនគរ ។ ព្រះសារីបុត្តត្ថេរថ្វាយបង្គំព្រះសាស្តាហើយ ព្រោះព្រះសាស្តាយាងចុះដោយពុទ្ធសិរីបែបនោះ ដែលលោកមិនធ្លាប់ឃើញហើយ ក្នុងកាលមុនអំពីនេះ ព្រោះដូច្នោះ ទើបប្រកាសសេចក្តីត្រេកអររបស់ខ្លួនដោយគាថាទាំងឡាយថា

ព្រះសាស្តាទ្រង់មានពាក្យពីរោះ ទ្រង់ជាអាចារ្យនៃគណ: យាងមកអំពីតុសិតយ៉ាងនេះ ខ្ញុំមិនទាន់ឃើញ មិនបានព្ថចំពោះនរណាក្នុងកាលមុនអំពីនេះ ជាដើម ហើយទូលថា បពិត្រព្រះអង្ត ថ្ងៃនេះ ទេវតា និងមនុស្សទាំងឡាយរមែងទន្ទឹងចំពោះព្រះអង្ត ។

លំដាប់នោះ ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្ត ឈ្មោះថាព្រះពុទ្ធដែលប្រកបព្រមដោយគុណបែបនេះ រមែងជាទីស្រឡាញ់របស់ទេវតា និងមនុស្សទាំងឡាយដោយពិត កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យេ ឈានប្បសុតា ធីរា　　នេក្ខម្មូបសមេ រតា
តេវាបិ តេសំ បិហយន្តិ　　សម្ពុទ្ធានំ សតីមតំ ។

អ្នកប្រាជ្ញទាំងឡាយណា ជាអ្នកខ្ងល់ខ្ងាយក្នុងឈាន ត្រេកអរក្នុងនេក្ខម្ម: ជាស្ថានស្ងប់រម្ងាប់កិលេស សូម្បីទេវតា និងមនុស្សទាំងឡាយ តែងរាប់រកចំពោះអ្នកប្រាជ្ញទាំងឡាយនោះ ដែលជាអ្នកត្រាស់ដឹងខ្ជូនឯងទាំងមានស្មារតី ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **យេ ឈានប្បសុតា** *សេចក្តីថា ប្រកបហើយ ខ្ងល់ខ្ងាយហើយក្នុងឈាន ២ យ៉ាងនេះ គឺក្នុងលក្ខណូបនិជ្ឈាន ១ អារម្មណូបនិជ្ឈាន ១ ដោយអាវជ្ជន: ដោយការចូល ដោយការអធិដ្ឋាន ដោយការចេញ និងដោយការពិចារណា ។ បព្ងជ្ជាដែលអ្នកសិក្សាមិនគប្បីកាន់យកថា នេក្ខម្ម: ក្នុងពាក្យថា* **នេក្ខម្មូបសមេ រតា** *នេះ ពាក្យថា នេក្ខម្ម:នោះ ទ្រង់ត្រាស់សំដៅយកការត្រេកអរក្នុងនិព្ងាន ដែលចូលទៅស្ងប់កិលេស ។ បទថា* **តេវាបិ** *សេចក្តីថា ទេវតា និងមនុស្សទាំងឡាយរមែងទន្ទឹង គឺប្រាថ្នាចំពោះព្រះសម្ពុទ្ធទាំងអស់ ។ បទថា* **សតីមតំ** *សេចក្តីថា ទេវតា និងមនុស្ស*

ទាំងឡាយ ប្រាថ្នាភាពជាព្រះពុទ្ធថា គួរអស្ចារ្យពិតហ្ន៎ សូម្បីអញក៏គប្បីជាព្រះពុទ្ធដូច្នេះ ឈ្មោះថា រមែងប្រាថ្នាចំពោះព្រះពុទ្ធទាំងអស់ បុគ្គលមានព្រះគុណបែបនេះ បុគ្គលប្រកបព្រមហើយដោយសតិ ។

ក្នុងកាលចប់ទេសនា ធម្មាភិសមយមានដល់សត្វប្រមាណ ៣០ កោដិ ភិក្ខុ ៥០០ ដែលជាសទ្ធិវិហារិករបស់ព្រះថេរៈ តាំងនៅហើយក្នុងអរហត្ត ។

បានឮថា ការធ្វើយមកប្បាដិហារ្យ ហើយចាំវស្សាក្នុងទេវលោក ចុះត្រង់ទ្វារសង្កស្សនគរ ព្រះពុទ្ធគ្រប់អង្គទ្រង់មិនដែលលះបង់ឡើយ ទីដែលព្រះបាទខាងស្តាំប្រតិស្ឋាន ក្នុងទីដែលទ្រង់ចុះនោះ មានឈ្មោះថា អចលចេតិ-យដ្ឋាន ព្រះសាស្តាប្រថាប់ឈរក្នុងទីនោះ ត្រាស់សួរបញ្ហាក្នុងវិស័យរបស់បុថុជ្ជនជាដើម ពួកបុថុជ្ជនឆ្លើយបញ្ហាក្នុងវិស័យរបស់ខ្លួនប៉ុណ្ណោះ មិនអាចឆ្លើយបញ្ហាក្នុងវិស័យរបស់ព្រះសោតាបន្នបាន ។ ព្រះអរិយបុគ្គលទាំងឡាយមានព្រះសោតាបន្នជាដើមក៏ដូចគ្នា មិនអាចឆ្លើយបញ្ហាក្នុងវិស័យរបស់ព្រះអរិយបុគ្គលទាំងឡាយ មានសកទាគាមីជាដើម ព្រះសាវ័កដ៏សេស មិនអាចឆ្លើយបញ្ហា ក្នុងវិស័យរបស់ព្រះមហាមោគ្គល្លាន ព្រះមហាមោគ្គល្លាន មិនអាចឆ្លើយបញ្ហាក្នុងវិស័យរបស់ព្រះសារីបុត្តត្ថេរបាន ព្រះសារីបុត្តត្ថេរក៏មិនអាចឆ្លើយបញ្ហាក្នុងពុទ្ធវិស័យបានដូចគ្នា ។ ព្រះសាស្តាត្រង់សម្ដឹងមើលទិសទាំងពួង តាំងអំពីទិសបូព៌ ស្ថានទីទាំងពួង មានទួលដូចគ្នានោះឯង ។ ទេវតា និងមនុស្សក្នុងទិសទាំង ៨ និងទេវតាខាងលើទល់នឹងព្រហ្មលោក យក្ខ នាគ និងគ្រុឌដែលនៅត្រង់ផ្នែខាងក្រោម ផ្គងអញ្ជលីក្រាបទូលថា

បពិត្រព្រះអង្គ ឈ្មោះថា បុគ្គលវិសជ្ជនាបញ្ហានេះ មិនមានក្នុងសមាគមនេះ សូមទ្រង់ពិចារណាក្នុងសមាគមនេះឯង ។

ព្រះសាស្តាទ្រង់ព្រះតម្រិះថា សារីបុត្តរមែងលំបាក ព្រោះថា សារីបុត្ត បានស្តាប់បញ្ហាដែលតថាគតសួរហើយ ក្នុងពុទ្ធវិសយនេះថា

ម្នាលអ្នកនិទ្ទុក្ខ បុគ្គលអ្នកមានបញ្ញារក្សាខ្លួន កាលតថាគតសួរដល់ការប្រព្រឹត្តទៅរបស់អ្នក បុគ្គលមានធម៌ដែលរាប់ព្រមហើយទាំងឡាយ និងព្រះសេក្ខៈទាំងឡាយ ដែលមានច្រើនក្នុងលោកនេះ ចូរប្រាប់ការប្រព្រឹត្តទៅនោះដល់តថាគតដូច្នេះ ជាអ្នកអស់សេចក្តីសង្ស័យក្នុងបញ្ហាថា ព្រះសាស្តារមែងត្រាស់សួរដល់បដិបទាជាទីមក គឺមគ្គប្បដិបទារបស់ព្រះសេក្ខៈ និងអសេក្ខៈ ជាមួយអាត្មាអញដូច្នេះក៏ពិត តែក៏គួរសង្ឃឹមអធ្យាស្រ័យរបស់តថាគតថា កាលអញពោលបដិបទានេះដោយមុខណាមួយ ក្នុងធម៌ទាំងឡាយ មានខន្ធជាដើម ទើបអាចកាន់យកអធ្យាស្រ័យរបស់ព្រះសាស្តាបាន សារីបុត្តនោះ កាលតថាគតមិនឲ្យនិយ៍ នឹងមិនអាចឆ្លើយបាន តថាគតនឹងឲ្យនិយ៍ដល់សារីបុត្ត កាលទ្រង់សម្តែងនិយ៍ ត្រាស់ថា ម្នាលសារីបុត្ត ចូរអ្នកពិចារណាឃើញសេចក្តីពិតនេះ ។ បានឮថា ទ្រង់ព្រះតម្រិះយ៉ាងនេះថា សារីបុត្ត កាលកាន់យកអធ្យាស្រ័យរបស់តថាគតឆ្លើយ នឹងឆ្លើយដោយអំណាចខន្ធ បញ្ហានោះ ប្រាកដដល់ព្រះថេរៈរាប់ រយរាប់ពាន់និយ៍ មួយអន្ទើដោយការប្រទាននិយ៍ លោកតាំងនៅក្នុងនិយ៍ដែលព្រះសាស្តាប្រទាន ឆ្លើយបញ្ហានោះបានហើយ បានឮថា អ្នកដទៃវៀរព្រះដ៏មានព្រះភាគចេញ ឈ្មោះថាអាចទាន់នូវ

បញ្ញារបស់ព្រះសារីបុត្តត្ថេរមិនមាន បានឮថា ហេតុនោះឯង ទើបព្រះថេរៈឈរ ចំពោះព្រះភក្ត្រព្រះសាស្តាបន្ទីសីហនាទថា បពិត្រព្រះអង្គ កាលក្បៀងធ្លាក់អស់ មួយកប្ប ខ្ញុំព្រះអង្គក៏អាចរាប់គណនាថា តំណក់ទាំងឡាយ ធ្លាក់ក្នុងមហាសមុទ្រប៉ុណ្ណេះតំណក់ ធ្លាក់លើផែនដីប៉ុណ្ណេះតំណក់ លើភ្នំប៉ុណ្ណេះតំណក់ សូម្បីព្រះសាស្តាក៏ត្រាស់ទីងលោកថា សារីបុត្ត តថាគតក៏ដឹងភាពដែលអ្នកអាចនឹងរាប់បាន ឈ្មោះថា ឧបមាប្រៀបដោយបញ្ញារបស់អ្នកនោះ រមែងមិនមាន ហេតុនោះ ទើបលោកក្រាបទូលថា

ខ្សាច់ក្នុងស៊ីងគង្គាគប្បីអស់ទៅ ទឹកក្នុងមហាសមុទ្រគប្បីអស់ទៅ ដីក្នុងផែនដីគប្បីអស់ទៅ ការឆ្លើយបញ្ហាដោយការដឹងរបស់ខ្ញុំព្រះអង្គ រមែងមិនអស់ ទៅដោយការគណនា ។

មានពាក្យអធិប្បាយដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលសម្បូរដោយការដឹង ជាទីពឹងរបស់លោក បើខ្ញុំព្រះអង្គឆ្លើយបញ្ហាមួយហើយ បុគ្គលគប្បីដាក់ខ្សាច់មួយគ្រាប់ ឬតំណក់ទឹកមួយតំណក់ ឬដីស្អិតមួយដុំ កាលខ្ញុំព្រះអង្គឆ្លើយបញ្ហាមួយរយ ឬមួយពាន់ ឬមួយសែន គប្បីដាក់ខ្ជាច់ទាំង-ឡាយ មានខ្សាច់ជាដើម មួយៗ ក្នុងចំណែកម្ខាងក្នុងស៊ីងគង្គា ខ្ជាច់ទាំង-ឡាយ មានខ្សាច់ជាដើមក្នុងស៊ីងគង្គាជាដើម គប្បីអស់ទៅមុន ការឆ្លើយបញ្ហារបស់ខ្ញុំព្រះអង្គ រមែងមិនអស់នៅឡើយ ។

ភិក្ខុមានបញ្ញាច្រើនយ៉ាងនេះ ក៏មិនឃើញចំណុចខាងដើម ឬចំណុចខាងចុងនៃបញ្ហាដែលព្រះសាស្តាសួរហើយក្នុងពុទ្ធវិសយ ទាល់តែតាំងនៅក្នុងនិយ

ដែលព្រះសាស្តាប្រទានហើយ ទើបឆ្លើយបញ្ហាបាន ។ ភិក្ខុទាំងឡាយ ស្តាប់ដូច្នោះហើយ សន្ធនាថា ជនទាំងអស់ដែលព្រះសាស្តាត្រាស់សួរបញ្ហាណា មិនអាចឆ្លើយបាន ព្រះសារីបុត្តត្ថេរ ដែលជាធម្មសេនាបតីម្នាក់ប៉ុណ្ណោះឆ្លើយបញ្ហានោះបាន ព្រះសាស្តាទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា សារីបុត្តឆ្លើយបញ្ហា ដែលមហាជនមិនអាចឆ្លើយបានក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែនសូម្បីក្នុងកាលមុន សារីបុត្តក៏ឆ្លើយបានហើយដូចគ្នា ដូច្នេះហើយ ទ្រង់នាំអតីតនិទានមក ត្រាស់ជាតកនេះដោយពិស្តារថា

ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងរយនាក់ ជនទាំងនោះ ឥតប្រាជ្ញា គប្បីពិចារណា (នូវអត្ថនៃភាសិត) អស់ ១០០ ឆ្នាំ បុរសណាប្រកបដោយប្រាជ្ញា ជីងច្បាស់នូវអត្ថនៃភាសិត បុរសនោះម្នាក់ឯងប្រសើរវិញ ។

រឿង យមកបាដិហារ្យ ចប់

រឿង ឯរកបត្តនាគរាជ

លំនាំដើម

ព្រះសាស្តា ទ្រង់អាស្រ័យពារាណសីនគរ ប្រថាប់នៅត្រង់ដើមច្រេស ៧ ដើម ទ្រង់ប្រារព្ធស្តេចនាគ ឈ្មោះឯរកបត្ត ត្រាស់ព្រះធម្មទេសនានេះថា **កិច្ឆោមនុស្សបដិលាភោ** ជាដើម ។

បានឣថា ក្នុងសាសនារបស់ព្រះកស្សបសម្ពុទ្ធ ក្នុងកាលមុនស្តេចនាគ នោះជាភិក្ខុកំលោះ ចុះទូកទៅក្នុងស្ទឹងគង្គា ទាញស្ទឹកវៃទឹកមួយក្តាប់ កាលទូកស្ទុះទៅដោយរហ័សក៏មិនលែង វៃទឹកនោះដាច់ហើយ ។ ភិក្ខុកំលោះនោះមិនសម្តែងអាបត្តិដោយគិតថា នេះគ្រាន់តែជាទោសតិចតួច សូម្បីធ្វើសមណធម៌ក្នុងព្រៃអស់ ២ ម៉ឺនឆ្នាំ ក្នុងកាលមរណភាព ឃើញហាក់បីដូចស្ទឹកវៃទឹកមករុំក សូម្បីចង់សម្តែងអាបត្តិ កាលមិនឃើញភិក្ខុដទៃ ក៏ក្តៅក្រហាយឡើងថា អញមានសីលមិនបរិសុទ្ធ ចុតិចាកអត្តភាពនោះហើយ កើតជាស្តេចនាគ មានរាងកាយប្រមាណប៉ុនទូកកំរោល ។ នាគនោះមានឈ្មោះថា ឯរកបត្តនោះឯង ។ ក្នុងខណៈដែលកើតហើយនោះឯង ស្តេចនាគក្រឡេកមើលអត្តភាពហើយ មានការក្តៅក្រហាយថា អញធ្វើសមណធម៌អស់កាលមានប្រមាណប៉ុណ្ណោះ ជាអ្នកកើតក្នុងទីដែលមានកង្កែបជាអាហារ ក្នុងកំណើតអហេតុក-សត្ត ។

ក្នុងកាលតមក នាគបានធីតាម្នាក់ បើកពពារធំលើផ្ទៃទឹកស្ទឹងគង្គា ដាក់ធីតាលើពពារនោះឲ្យរាំច្រៀងហើយ ។

បានឮថា នាគមានការគិតយ៉ាងនេះថា កាលព្រះពុទ្ធកើតឡើង អញនឹងបានឮភាពដែលព្រះពុទ្ធនោះកើតឡើងដោយឧបាយនេះឯង បុគ្គលណានាំយកចម្រៀងឆ្លើយនឹងចម្រៀងរបស់អញបាន អញនឹងឲ្យធីតា មួយអន្លើដោយនាគពិភពដ៏ធំដល់បុគ្គលនោះ ។ ជាក់ធីតានោះលើពពារ ក្នុងថ្ងៃឧបោសថវៀងរាល់កន្លះខែ ។ ធីតានោះឈរាំលើពពារនោះ ច្រៀងយ៉ាងនេះថា បុគ្គលជាធំ ឈ្មោះថា ព្រះរាជាដូចម្តេច ព្រះរាជា ឈ្មោះថា មានធូលីលើក្បាលដូចម្តេច ឈ្មោះថា ប្រាសចាកធូលីដូចម្តេច លោកហៅថាបុគ្គលពាលដូចម្តេច ។

អ្នកជម្ពូទ្វីបទាំងមូលនាំគ្នាមកដោយបំណងថា អញនឹងនាំយកនាងនាគ-មាណវិកា ហើយតែងបទចម្រៀងឆ្លើយ ច្រៀងដោយកម្លាំងបញ្ញាវៀងៗ ខ្លួន ។ នាងតែងបដិសេធចម្រៀងដែលច្រៀងឆ្លើយនោះ កាលនាងឈរលើពពារវៀងរាល់កន្លះខែច្រៀងយ៉ាងនេះប៉ុណ្ណោះ មួយពុទ្ធន្តរកន្លងទៅហើយ ។

គ្រានោះ ព្រះសាស្តាទ្រង់កើតឡើងហើយក្នុងលោក ថ្ងៃមួយ ពេលទៀបភ្លឺ ទ្រង់ប្រមើលមើលលោក ធ្វើឯកបត្តនាគរាជឲ្យជាហេតុ ទ្រង់ឃើញមាណពឈ្មោះឧត្តរៈ ចូលទៅក្នុងសំណាញ់ គឺព្រះញាណរបស់ទ្រង់ ទ្រង់ពិចារណាមើលថា តើនឹងមានហេតុអ្វី ទ្រង់បានឃើញថា ថ្ងៃនេះ ជាថ្ងៃដែលឯកបត្តនាគរាជ ជាក់ធីតាលើពពារហើយឲ្យរាំ ឧត្តរមាណពនេះ រៀនទូវបទចម្រៀងដែលតថាគតឲ្យហើយ នឹងបានជាសោតាបន្ន រៀនយកបទចម្រៀងនោះទៅកាន់សម្នាក់របស់នាគរាជនោះៗ ស្តាប់ចម្រៀងឆ្លើយនោះហើយ នឹងដឹងថា ព្រះពុទ្ធកើតឡើងហើយ នឹងមកកាន់សម្នាក់របស់តថាគត

កាលនាគរាជនោះមកហើយ តថាគតនឹងពោលគាថាក្នុងមហាសមាគម ក្នុងកាលចប់គាថា សត្វប្រមាណ ៨៤០០០ នឹងត្រាស់ដឹងធម៌ ។

ព្រះសាស្តាយាងទៅក្នុងទីនោះហើយ ប្រថាប់គង់ត្រង់គល់ច្រេសមួយក្នុងបណ្តាច្រេស ៧ ដើម ដែលមាននៅមិនឆ្ងាយអំពីក្រុងពារាណសី ។ អ្នកជម្ពូទ្វីប នាំយកបទចម្រៀងឆ្លើយទៅប្រជុំគ្នាហើយ ។ ព្រះសាស្តាទតឃើញឧត្តរមាណពកំពុងទៅក្នុងទីមិនឆ្ងាយ ទើបត្រាស់ថា ឧត្តរៈ ឧត្តរៈពោលថា កុរុណាព្រះអង្គ ព្រះសាស្តាត្រាស់ថា ចូរអ្នកមកណោះសិន ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងឧត្តរមាណពនោះ ដែលមកថ្វាយបង្គំអង្គុយចុះហើយ សួរថា ឧត្តរៈ អ្នកទៅណា ឧត្តរមាណពឆ្លើយថា ទៅកាន់ទីដែលធីតារបស់ឯរកបត្តនាគរាជច្រៀង ព្រះសាស្តាត្រាស់ថា អ្នកដឹងចម្រៀងដែលត្រូវឆ្លើយហើយឬ ឧត្តរមាណពទូលថា បពិត្រព្រះអង្គ មិនដឹងទេ ព្រះសាស្តាត្រាស់ថា ចូរអ្នកពោលចម្រៀងនោះជាមុន ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងឧត្តរមាណព ដែលពោលតាមចំណេះដឹងរបស់ខ្លួនប៉ុណ្ណោះថា នែឧត្តរៈ នុ៎ះមិនមែនជាបទចម្រៀងសម្រាប់ឆ្លើយទេ តថាគតនឹងឲ្យបទចម្រៀង ដែលជាចម្លើយដល់អ្នក អ្នកត្រូវរៀនបទចម្រៀងនោះឲ្យបាន ឧត្តរមាណពទូលថា សាធុ ព្រះអង្គ ។

គ្រានោះ ព្រះសាស្តាត្រាស់ថា ម្នាលឧត្តរៈ ក្នុងកាលដែលនាងនាគ-មាណវិកាច្រៀង អ្នកគប្បីច្រៀងឆ្លើយយ៉ាងនេះថា បុគ្គលជាធំក្នុងទ្វារ ៦ ឈ្មោះថា ជាព្រះរាជា ព្រះរាជាដែលប្រកបដោយតម្រេក ឈ្មោះថា មានធូលី

លើក្បាល បុគ្គលជ្រាសចាកតម្រេក ឈ្មោះថា ជ្រាសចាកធូលី បុគ្គលដែលប្រកបដោយតម្រេក លោក ហៅថា បុគ្គលពាល ។

ចម្រៀងរបស់នាគមាណវិកា មានអធិប្បាយថា បទថា **កិំសុ អធិបតី រាជា** *សេចក្តីថា បុគ្គលជាធំដូចម្តេច ឈ្មោះថា ព្រះរាជា ។*

បាទគាថាថា **កិំសុ រាជា រជស្សិរោ** *សេចក្តីថា ព្រះរាជាដូចម្តេច ជាបុគ្គលឈ្មោះថា មានធូលីលើក្បាល ។*

បទថា **កថំ សុ** *សេចក្តីថា ព្រះរាជាដូចម្តេច ឈ្មោះថាជ្រាសចាកធូលី ។ ចំណែកចម្រៀងឆ្លើយតប មានអធិប្បាយថា បាទព្រះគាថាថា* **ឆទ្វារាធិបតី រាជា** *សេចក្តីថា បុគ្គលណាជាធំនៃទ្វារ ៦ ដែលអារម្មណ៍ទាំង ៦ មានរូបជាដើម គ្របសង្កត់មិនបានក្នុងទ្វារមួយ បុគ្គលនេះ ឈ្មោះថា ជាព្រះរាជា ។*

បាទព្រះគាថាថា **រជមាឆោ រជស្សិរោ** *សេចក្តីថា ព្រះរាជាណាតម្រេកនៅក្នុងអារម្មណ៍ទាំងនោះ ព្រះរាជាដែលតម្រេកនោះ ឈ្មោះថា មានធូលីលើក្បាល ។ បទថា* **អរជំ** *សេចក្តីថា ចំណែកព្រះរាជាដែលមិនតម្រេក ឈ្មោះថា ជាបុគ្គលជ្រាសចាកធូលី ។ បទថា* **រជំ** *សេចក្តីថា ព្រះរាជាដែលតម្រេក លោកហៅថា ជាបុគ្គលពាល ។*

ព្រះសាស្តា កាលប្រទានបទចម្រៀងឆ្លើយដល់ឧត្តរមាណពនោះយ៉ាងនេះហើយត្រាស់ថា ម្នាលឧត្តរៈ កាលអ្នកច្រៀងចម្រៀងនេះ នាងនឹងច្រៀងសួរនូវចម្រៀងរបស់អ្នកយ៉ាងនេះថា បុគ្គលពាល អ្វីរមែងបន្សាត់ទៅ បណ្ឌិតរមែងបន្ទោបង់នូវអ្វី អ្វីទើបបុគ្គលក្សេមចាកយោគៈ អ្នកកាលខ្ញុំសួរហើយ សូម

ប្រាប់សេចក្តីនោះដល់ខ្ញុំ ។

ពេលនោះ អ្នកគប្បីច្រៀងឆ្លើយដល់នាងថា បុគ្គលពាល ដែលជំនន់គឺកាមោឃៈជាដើមរមែងបន្សាត់ទៅ បណ្ឌិតរមែងបន្ទោបង់នូវឱឃៈនោះ ដោយសេចក្តីព្យាយាម បណ្ឌិតដែលមិនប្រកបដោយយោគៈទាំងពួង លោកហៅថា ជាអ្នកមានសេចក្តីក្សេមចាកយោគៈ ។

ចម្រៀងឆ្លើយនោះមានសេចក្តីថា បុគ្គលពាលត្រូវឱឃៈ ៤ មានកាមោឃៈជាដើមបន្សាត់ទៅ បណ្ឌិតរមែងបន្ទោបង់ឱឃៈនោះ ដោយសេចក្តីព្យាយាមពោល គឺសម្មប្បធាន បណ្ឌិតនោះ មិនប្រកបដោយយោគៈទាំងពួង មានកាមយោគៈជាដើម លោកហៅឈ្មោះថា ជាអ្នកមានការក្សេមចាកយោគៈ ។

ឧត្តរមាណព កាលកំពុងរៀនចម្រៀងឆ្លើយនេះ តាំងនៅក្នុងសោតាបត្តិផល គាត់ជាព្រះសោតាបន្ន រៀនគាថានោះ ទៅហើយ ពោលថា អ្នកដ៏ចម្រើន ខ្ញុំនាំចម្រៀងសម្រាប់ឆ្លើយមកហើយ ចូរពួកអ្នកឲ្យឱកាសដល់ខ្ញុំ បានលុតជង្គង់ទៅក្នុងចំណោមមហាជន ឈរប្រជ្រៀតគ្នាហើយ ។ នាងនាគមាណវិកាឈរពាំលើពពារបស់បិតា ហើយច្រៀងថា

បុគ្គលជាធំដូចម្តេច ឈ្មោះថា ជាព្រះរាជាជាដើម ។ ឧត្តរមាណពច្រៀងឆ្លើយថា បុគ្គលជាធំក្នុងទ្វារ ៦ ឈ្មោះថា ជាព្រះរាជាជាដើម នាគមាណវិកាច្រៀងចោទឧត្តរមាណពនោះទៀតថា បុគ្គលពាល អ្វីរមែងបន្សាត់ទៅជាដើម កាលឧត្តរមាណពនោះច្រៀងដល់នាង ទើបពោលគាថានេះថា

បុគ្គលពាល ត្រូវជំនន់បន្សាត់ទៅ ដូច្នេះជាដើម ។ នាគរាជបានស្តាប់

គាថានោះ ជ្រាបភាពដែលព្រះពុទ្ធកើតឡើង ត្រេកអរថា អញមិនធ្លាប់ស្តាប់បទចម្រៀងបែបនេះអស់ ១ ពុទ្ធន្តរ អ្នកដ៏ចម្រើន ព្រះពុទ្ធកើតឡើងក្នុងលោកហើយហ្ន៎ ទើបយកកន្ទុយគោះទឹក រលកធំៗ កើតឡើងហើយ ប្រាំងទាំងពីរបាក់ចុះ ពួកមនុស្សក្នុងទីប្រមាណ ១ ឧសភៈ ត្រើយនាយ និងត្រើយអាយធ្លាក់ចូលទៅក្នុងទឹក ។ នាគរាជនោះ លើកមហាជនមានប្រមាណប៉ុណ្ណោះ ជាក់លើពពារ ហើយជាក់លើគោក ។ នាគរាជនោះ ចូលទៅរកឧត្តរមាណព ហើយ សួរថា នែអ្នក ព្រះសាស្តាប្រថាប់នៅទីណា ឧត្តរមាណពពោលថា ទ្រង់ប្រថាប់គង់ត្រង់គល់ឈើមួយដើម នាគរាជពោលថា មកពួកយើងនឹងនាំគ្នាទៅហើយ បានទៅជាមួយឧត្តរមាណព ចំណែកមហាជន បានទៅជាមួយនាគដូចគ្នា ។ នាគរាជនោះ ទៅដល់ ចូលទៅកាន់ចន្ទោរស្មីដែលមានពណ៌ ៦ ថ្វាយបង្គំព្រះសាស្តាហើយ បានឈរយំ ។ គ្រានោះ ព្រះសាស្តាត្រាស់នឹងនាគរាជនោះថា មហាបពិត្រ មានរឿងអ្វី នាគរាជពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័កបស់ព្រះពុទ្ធដូចគ្នានឹងព្រះអង្គ ធ្វើសមណធម៌ ២ ម៉ឺនឆ្នាំ សូម្បីសមណធម៌នោះក៏មិនអាចជួយខ្ញុំព្រះអង្គបាន ខ្ញុំព្រះអង្គអាស្រ័យហេតុត្រឹមតែឲ្យស្តីកវែទឹកជាច់ទៅមានប្រមាណតិចតួច បដិសន្ធិក្នុងអហេតុកសត្វកើតក្នុងទីដែលត្រូវលួនទៅដោយទ្រូង រមែងមិនបាននូវភាពជាមនុស្សឡើយ មិនបានស្តាប់ធម៌ មិនបានឃើញព្រះពុទ្ធដូចគ្នានឹងព្រះអង្គអស់មួយពុទ្ធន្តរ ។

ព្រះសាស្តា ទ្រង់ស្តាប់វាចារបស់នាគរាជនោះហើយ ត្រាស់ថា មហាបពិត្រ ឈ្មោះថា កាពជាមនុស្សបានដោយកម្រពន់ពេក ការស្តាប់ព្រះសទ្ធម្ម

ក៏យ៉ាងនោះ ការកើតឡើងនៃព្រះពុទ្ធ ក៏រកបានលំបាកដូចគ្នា ព្រោះថា ទាំង ៣ យ៉ាងនេះ បុគ្គលរមែងបានដោយលំបាក កាលទ្រង់សម្តែងធម៌ត្រាស់ព្រះគាថានេះថា

កិច្ឆោ មនុស្សបដិលាភោ កិច្ឆំ មច្ចាន ជីវិតំ
កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ ។

ការត្រឡប់បានអត្តភាពជាមនុស្ស បានដោយកម្រ ការរស់របស់សត្វទាំងឡាយ បានដោយកម្រ ការស្តាប់ធម៌របស់សប្បុរស បានដោយកម្រ ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ បានដោយកម្រ ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះ គប្បីជ្រាបដូច្នេះ ឈ្មោះថា ការបានអត្តភាពជាមនុស្ស ឈ្មោះថា ជាការលំបាក គឺរកបានដោយកម្រ ព្រោះភាពជាមនុស្ស បុគ្គលត្រូវបានដោយសេចក្តីព្យាយាមច្រើន ដោយកុសលច្រើន សូម្បីជីវិតរបស់សត្វទាំងឡាយ ក៏ឈ្មោះថារស់នៅដោយកម្រ ព្រោះធ្វើកម្ម មានកសិកម្ម ជាដើមរឿយៗ ហើយបន្តការប្រព្រឹត្តទៅនៃជីវិតផង ព្រោះជីវិតជារបស់តិចផង ការស្តាប់ព្រះសទ្ធម្មក៏ជាការក្រ ព្រោះបុគ្គលដែលសម្តែងធម៌ រកបានដោយកម្រ ក្នុងកប្បមិនមែនតិច ។ ម្យ៉ាងទៀត ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ជាការក្រជូចគ្នា គឺបានលំបាកពន់ពេក ព្រោះអភិនីហារសម្រេចដោយសេចក្តីព្យាយាមច្រើន និងព្រោះការកើតឡើងនៃបុគ្គលដែលមាន

អកិនីហារសម្រេចហើយ ជាការបានដោយលំបាក ដោយពាន់នៃកោដិកប្ប មិនមែនតិច ។

ក្នុងកាលចប់ទេសនា ពួកសត្វ ៨៤០០០ បានត្រាស់ដឹងធម៌ហើយ ចំណែកនាគរាជគួរបានសោតាបត្តិផលក្នុងថ្ងៃនោះ តែក៏មិនបានព្រោះភាពដែលខ្លួនជាសត្វតិរច្ឆាន ។ នាគរាជនោះដល់នូវភាវៈ គឺការមិនលំបាកក្នុងហានៈទាំង ៥ ពោល គឺការបដិសន្ធិ ការសកស្រេកា ការជាក់ចិត្តឈានចុះកាន់និទ្រា ការសេពមេថុននឹងនាងនាគដែលមានជាតិស្មើគ្នា និងចុតិដែលពួកនាគកាន់យកសីរៈនៃនាគនោះឯង ហើយលំបាក រមែងត្រាច់ទៅដោយរូបនៃមាណពនោះឯង ដូច្នេះ ៗ

រឿង ឋកបត្តនាគរាជ ចប់

រឿង បញ្ហារបស់ព្រះអានន្ទត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហារបស់ព្រះអានន្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **សព្ពចាបល្ល អការណំ** *ជាដើម ។*

បានឮថា ព្រះថេរៈអង្គុយក្នុងទីសម្រាកពេលថ្ងៃគិតថា ព្រះសាស្តាត្រាស់ប្រាប់ហេតុនៃព្រះពុទ្ធ ៧ អង្គគ្រប់យ៉ាង គឺព្រះជននី និងព្រះជនក ការកំណត់ព្រះជន្មាយុ ឈើដែលត្រាស់ដឹង សាវកសន្និបាត អគ្គសាវក ឧបដ្ឋាក តែ

ឧបោសថមិនបានត្រាស់ប្រាប់ ឧបោសថនៃព្រះពុទ្ធទាំងនោះយ៉ាងនេះ ឬដូចម្ដេច ។ ទើបចូលទៅគាល់ព្រះសាស្ដា ហើយទូលសួរសេចក្ដីនោះ ព្រោះការផ្សេងគ្នានៃកាល នៃព្រះពុទ្ធទាំងនោះប៉ុណ្ណោះមានហើយ ។ ការផ្សេងគ្នានៃគាថាមិនមាន ព្រោះថា ព្រះសម្មាសម្ពុទ្ធព្រះនាមវិបស្សី ទ្រង់ធ្វើឧបោសថរៀងរាល់ ៧ ឆ្នាំម្ដង ព្រោះព្រះឱវាទដែលទ្រង់ប្រទានហើយ មួយថ្ងៃប៉ុណ្ណោះលុមប្រព្រឹត្តទៅបាន ៧ ឆ្នាំ ព្រះសម្មាសម្ពុទ្ធព្រះនាមសិខី និងវេស្សភូ ទ្រង់ធ្វើឧបោសថរៀងរាល់ ៦ ឆ្នាំ ទ្រង់ប្រទានក្នុងមួយថ្ងៃប៉ុណ្ណោះ លុមប្រព្រឹត្តទៅបាន ៦ ឆ្នាំ ព្រះសម្មាសម្ពុទ្ធព្រះនាមកកុសន្ធៈ និងកោនាគមនៈ ទ្រង់ធ្វើឧបោសថរៀងរាល់ឆ្នាំ ព្រោះឱវាទដែលទ្រង់ប្រទានមួយថ្ងៃប៉ុណ្ណោះ លុមប្រព្រឹត្តទៅបានមួយឆ្នាំ ព្រះកស្សបទសពល ទ្រង់ធ្វើឧបោសថរៀងរាល់ ៦ ខែ ព្រោះព្រះឱវាទដែលប្រទានមួយថ្ងៃ លុមប្រព្រឹត្តទៅបាន ៦ ខែ ដូច្នោះ ទើបព្រះសាស្ដាត្រាស់ភាពផ្សេងគ្នានៃកាលនេះ របស់ព្រះពុទ្ធទាំងនោះ ហើយត្រាស់ថា ចំណែកឱវាទគាថារបស់ព្រះពុទ្ធទាំងនោះយ៉ាងនេះឯង ដូច្នេះហើយ កាលទ្រង់ធ្វើឧបោសថនៃព្រះពុទ្ធគ្រប់អង្គដែលដូចគ្នានោះឲ្យជាក់ច្បាស់ ទើបត្រាស់ព្រះគាថានេះថា

សព្ពបាបស្ស អករណំ កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ
ខន្តិ បរមំ តបោ តីតិក្ខា និព្ពានំ បរមំ វទន្តិ ពុទ្ធា

ន ហិ បព្ភជិតោ បរូបឃាតី សមណោ ហោតិ

បរំ វិហេឋយន្តោ។

អព្ភបវាហោ អព្ភបឃាតោ ចាតិមោក្ខេ ច សំវរោ

មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ

អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ។

ការមិនធ្វើបាបទាំងពួង ការញុំាងកុសលឲ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

ខន្តិ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំង-ឡាយ តែងពោលថា ព្រះនិព្វានជាធម្មជាតដ៏ឧត្តម បុគ្គលដែល សម្លាប់សត្វដទៃ មិនឈ្មោះថា បព្វជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ ក៏មិនឈ្មោះថាសមណៈឡើយ ។

ការមិនតិះដៀល ១ ការមិនបៀតបៀន ១ ការសង្រួមក្នុងបាតិមោក្ខ ១ ភាពជាអ្នកដឹងប្រមាណក្នុងភត្ត ១ ការដេក និងអង្គុយក្នុងទីស្ងាត់ ១ ការព្យាយាម ក្នុងអធិចិត្ត ១ នុ៎ះជា ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សព្វបាបស្ស** *បានដល់ អកុសលកម្មគ្រប់

ប្រកេទ ។ ការញុំាងកុសលឲ្យកើតឡើងតាំងអំពីចេញបួស រហូតដល់អរ-
ហត្តមគ្គ និងការញុំាងកុសលដែលខ្លួនឲ្យកើតឡើងហើយ ឲ្យចម្រើន ឈ្មោះ
ថា ឧបសម្បទា ។ ការញុំាងចិត្តរបស់ខ្លួនឲ្យផូរផង់ចាកនីវរណៈទាំង ៥
ឈ្មោះថា **សចិត្តបរិយោទបនំ** ។

បាទព្រះគាថាថា **ឯតំ ពុទ្ធានសាសនំ** ដោយអត្ថថា នេះជាវាចាប្រៀន
ប្រដៅរបស់ព្រះពុទ្ធគ្រប់ៗ អង្គ ។

បទថា **ខន្តិ** សេចក្តីថា ឈ្មោះថា ការអត់ធន់ ពោល គឺការអត់សង្កត់
នេះ ជាតបៈដ៏ក្រៃលែង គឺយ៉ាងឧត្តមក្នុងព្រះសាសនានេះ ។

បាទព្រះគាថាថា **និព្វានំ បរមំ វទន្តិ ពុទ្ធា** សេចក្តីថា ពុទ្ធបុគ្គលទាំង
៣ ពួក គឺព្រះសម្មុទ្ធមួយពួក ព្រះបចេ្ចកពុទ្ធមួយពួក ព្រះអនុពុទ្ធមួយពួក
រមែងពោលព្រះនិព្វានថា ជាធម្មជាតដ៏ឧត្តម ។

បទថា **ន ហិ បព្វជិតោ** សេចក្តីថា បុគ្គលដែលបៀតបៀនសត្វដទៃ
ដោយគ្រឿងប្រហារផ្សេងៗ មានបាតដៃជាដើម ឈ្មោះថា ជាអ្នកប្រទូស្តអ្នក
ដទៃ មិនឈ្មោះថាជាបព្វជិត ។ បទថា **សមណោ** សេចក្តីថា បុគ្គលដែល
បៀតបៀនសត្វដទៃ ដោយន័យដែលពោលហើយនោះឯង មិនឈ្មោះថា
ជាសមណៈដូចគ្នា ។ ការមិនតិះដៀលឯង ការមិនញុំាងអ្នកដទៃឲ្យតិះដៀល
ឈ្មោះថា **អនូបឃាតោ** ។ ការមិនបៀតបៀនឯង និងការមិនប្រើអ្នកដទៃឲ្យ
បៀតបៀន ឈ្មោះថា **អនូបឃាតោ** ។

បទថា **ចាតិមោក្ខេ** បានដល់ សីលដែលជាប្រធាន ។ ការបិទ ឈ្មោះ

ថា **សំវរោ។** *ភាពជាអ្នកជីឯល្មម គឺស្គាល់ប្រមាណ ឈ្មោះថា* **មត្តញ្ញុតា។** *បទថា* **បន្តំ** *បានដល់ ស្ងាត់ ។ បទថា* **អធិចិត្តេ** *សេចក្តីថា ក្នុងចិត្តដែលក្រៃលែង ពោល គឺចិត្តដែលសហគតៈដោយសមាបត្តិ ៨ ។ ការធ្វើសេចក្តីព្យាយាម ឈ្មោះថា* **អាយោគោ។** *បទថា* **ឯតំ** *សេចក្តីថា នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់អង្គក្នុងព្រះគាថានេះ ។ ក្នុងព្រះគាថានេះ ព្រះដ៏មានព្រះភាគត្រាស់សីល ដែលប្រព្រឹត្តទៅដោយវាចា ដោយអនុបវាទៈ ត្រាស់សីលដែលប្រព្រឹត្តទៅផ្លូវកាយ ដោយអនុបឃាតៈ ។ ត្រាស់បាតិមោក្ខសីល និងឥន្ទ្រិយសំវរសីល ដោយពាក្យនេះថា* **ចាតិមោក្ខេ ច សំវរោ។** *ត្រាស់អាជីវបារិសុទ្ធិសីល និងបច្ចយសន្និស្សិតសីល ដោយមត្តញ្ញុតា ។ ត្រាស់សេនាសនៈ ដែលជាសប្បាយដោយបន្តៈសេនាសនៈ ។ ត្រាស់សមាបត្តិ ៨ ដោយអធិចិត្ត ដោយប្រការដូច្នេះ ។ សិក្ខាទាំង ៣ ឈ្មោះថា ទ្រង់ត្រាស់ហើយ ដោយព្រះគាថានេះឯង ដូច្នេះ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង បញ្ហារបស់ព្រះអានន្ទត្ថេរ ចប់

រឿង ភិក្ខុមិនត្រេកអរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមិនត្រេកអរ ក្នុងព្រហ្មចរិយមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **ន ករហាមណរាវស្សេន** ជាដើម ។

បានឮថា ភិក្ខុនោះបព្វជ្ជាហើយក្នុងសាសនា បានឧបសម្បទាហើយ កាលព្រះឧបជ្ឈាយ៍បញ្ជូនទៅដោយពាក្យថា ចូរអ្នកទៅទីឈ្មោះនោះ ហើយរៀនខន្ធទេ បានទៅក្នុងទីនោះហើយ ។ កាលនោះ រោគកើតឡើងដល់បិតារបស់លោក ។ បិតានោះប្រាថ្នានឹងឃើញបុត្រ តែមិនមានបុគ្គលណាម្នាក់ដែលអាចហៅបុត្រនោះមកឲ្យបាន ទើបកន្ទក់កន្ទេញព្រោះសេចក្តីសោកដោយបុត្រនោះឯង ជាអ្នកមានសេចក្តីស្ងាប់ខិតចូលមកដល់ហើយ ទើបផ្តាំនឹងប្អូនប្រុសថា អ្នកគប្បីធ្វើទ្រព្យនេះឲ្យជាថ្លៃបាត្រ និងចីវរដល់បុត្ររបស់យើង ហើយឲ្យទ្រព្យមួយរយកហាបណៈ ទុកក្នុងដៃប្អូនប្រុស បានធ្វើកាលកិរិយាហើយ ។

ក្នុងកាលដែលភិក្ខុកំលោះមកហើយ ទើបប្អូនប្រុសនោះ ក្រាបចុះទៀបបាតជើងទ្រហោយំបម្រះនទៀលទៅមកពោលថា បពិត្រលោកម្ចាស់ ញោមរបស់លោកម្ចាស់ កន្ទក់កន្ទេញធ្វើកាលកិរិយាហើយ បិតានោះបានប្រគល់កហាបណៈមួយរយទុកក្នុងដៃរបស់ខ្ញុំ ខ្ញុំនឹងធ្វើដូចម្តេចដោយទ្រព្យនោះ ទើបភិក្ខុកំលោះឃាត់ថា អាត្មាមិនត្រូវការដោយកហាបណៈ ក្នុងកាលតមក ទើបគិតថា ប្រយោជន៍អ្វីរបស់អញ ដោយការគ្រាច់ទៅបិណ្ឌបាតក្នុងត្រកូលដទៃចិញ្ចឹមជីវិត អញអាចអាស្រ័យកហាបណៈមួយរយនោះចិញ្ចឹមជីវិតបាន អញ

និងសីក ។ កិក្ខុនោះ ត្រូវសេចក្តីអផ្សុកបៀតបៀនហើយ ទើបលះនូវការ ស្វាធ្យាយ និងព្រះកម្មដ្ឋាន បានជាអ្នកមានរោគស្គមលឿង ។ គ្រានោះ កិក្ខុ កំលោះ និងសាមណេរសួរលោកថា តើលោកម្ចាស់កើតអ្វី ព្រះថេរៈឆ្លើយថា ខ្ញុំអផ្សុក ទើបនាំគ្នាប្រាប់ដល់អាចារ្យ និងឧបជ្ឈាយ៍ ។ ពេលនោះ អាចារ្យ និងឧបជ្ឈាយ៍ទាំងនោះ នាំលោកទៅកាន់សម្នាក់របស់ព្រះសាស្តា បង្ហាញដល់ ព្រះសាស្តាហើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលកិក្ខុ បានឮថា អ្នកអផ្សុកឬ កាលលោកក្រាប ទូលថា ករុណាព្រះអង្គ ទើបទ្រង់ត្រាស់ថា ព្រោះហេតុអ្វី ទើបអ្នកធ្វើយ៉ាង នោះ អ្វីជាបច្ច័យនៃការចិញ្ចឹមជីវិតរបស់អ្នកមានឬ កិក្ខុនោះ ក្រាបទូលថា បពិត្រព្រះអង្គ មាន ព្រះសាស្តាត្រាស់ថា អ្វីរបស់អ្នកមាន កិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គ កហាបណៈមួយរយ ។

ព្រះសាស្តាត្រាស់ថា បើដូច្នោះ ចូរអ្នកនាំដុំក្រួសមកត្រឹមតិចតួច អ្នក សាកល្បងរាប់មើលនឹងជីងបានថា អ្នកអាចចិញ្ចឹមជីវិតបានដោយកហាបណៈ ចំនួនប៉ុណ្ណោះឬ ឬមិនអាចចិញ្ចឹមជីវិតបាន កិក្ខុកំលោះនោះនាំដុំក្រួសមកហើយ ។

ពេលនោះ ទើបព្រះសាស្តាត្រាស់នឹងកិក្ខុនោះថា ចូរអ្នកជាក់ ៥០ ដើម្បី ប្រយោជន៍ដល់គ្រឿងបរិភោគសិន ជាក់ ២៤ ដើម្បីប្រយោជន៍ដល់គោ ២ ជាក់ប៉ុណ្ណោះដើម្បីប្រយោជន៍ដល់ពូជ ដើម្បីប្រយោជន៍ទឹម និងនង្គ័ល ដើម្បី ប្រយោជន៍ដល់ចប ដើម្បីប្រយោជន៍ដល់កាំបិត និងពូថៅ កាលលោករាប់ ដោយអាការយ៉ាងនេះ កហាបណៈមួយរយនោះ រមែងមិនគ្រប់គ្រាន់ ។ គ្រា

នោះ ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ កហាបណៈរបស់អ្នកមានតិច អ្នកអាស្រ័យកហាបណៈទាំងនោះ និងឲ្យសេចក្តីត្រូវការពេញបានដូចម្តេច ។ បានឮថា ក្នុងអតីតកាល បណ្ឌិតទាំងឡាយ គ្រប់គ្រងចក្រពត្តិរាជសម្បត្តិ អាចញុំាងភ្លៀង គឺរតន: ៧ ឲ្យធ្លាក់ចុះមកត្រឹមចង្កេះ ក្នុងទីប្រមាណ ១២ យោជន៍ ដោយអាការត្រឹមតែទះដៃ សូម្បីគ្រងរាជសម្បត្តិក្នុងទេវលោក អស់ ៣៦ ព្រះឥន្ទ ក្នុងពេលទិវង្គត ក៏មិនញុំាងសេចក្តីប្រាថ្នាឲ្យពេញបានឡើយ បានធ្វើកាលកិរិយាហើយ កាលភិក្ខុនោះអារាធនាហើយ ទ្រង់នាំអតីតនិទានមក ញុំាងមន្ធាតុរាជជាតកឲ្យពិស្តារហើយ ក្នុងលំដាប់នៃព្រះគាថានេះថា

> ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយ (ដើរក្រឡឹង) ភ្លុំសិនេរុ ទិសទាំងឡាយភ្លឺរុងរឿង រហូតទីមានកំណត់ត្រឹមណា សត្វទាំង-ឡាយណា ដែលអាស្រ័យលើផែនដី សត្វទាំងអស់នោះ ជាទាស:របស់ស្តេចមន្ធាតុ រហូតទីមានកំណត់ត្រឹមនោះ ។

បានភាសិតគាថា ២ នេះថា

ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ
អប្បស្សាទា ទុក្ខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោ
អបិ ទិព្វេសុ កាមេសុ រតឹ សោ នាធិគច្ឆតិ
តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ ។

> ការស្កប់ស្កល់ក្នុងកាមទាំងឡាយ រមែងមិនមាន ព្រោះកហាបណៈ(ដែលធ្លាក់ចុះ) ទេ កាមទាំងឡាយមាន

សុខតិច មានទុក្ខច្រើន អ្នកប្រាជ្ញដឹងច្បាស់យ៉ាងនោះ
ហើយ លោកមិនបានត្រេកអរក្នុងកាមទាំងឡាយ សូម្បី
ជាទិព្វទ្បើយ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រ៉មែងជាអ្នក
ត្រេកអរក្នុងធម៌ជាគ្រឿងអស់តណ្ហា ។

សេចក្តីអធិប្បាយ

បណ្តបទថាទាំងនោះ បទថា **កហាបណាវស្សេន** សេចក្តីថា បណ្ឌិត
នោះទះដៃហើយ ញ្ចុាំងភ្លៀង គឺរតន: ៧ ប្រការឲ្យធ្លាក់ចុះបាន ភ្លៀង គឺរតន:
៧ ប្រការនោះ ត្រាស់ឲ្យឈ្មោះថា **កហាបណាវស្សំ** ក្នុងព្រះគាថានេះ
ឈ្មោះថា ការផ្អែតក្នុងវត្ថុកាម និងកិលេសកាម រ៉មែងមិនមាន ព្រោះភ្លៀង
គឺរតន:ទាំង ៧ ប្រការនោះ ចំណង់នោះពេញបានដោយលំបាកដោយ
អាការយ៉ាងនេះ ។

បទថា **អប្បស្សាធា** គឺ ឈ្មោះថា មានសុខតិច ព្រោះកាមមាន
ឧបមាដូចយល់សប្តិជាដើម ។

បទថា **ឧក្ខា** គឺ ឈ្មោះថា មានទុក្ខច្រើន ដោយអំណាចនៃទុក្ខដែល
នាំមកក្នុងទុក្ខក្ខន្ធសូត្រជាដើម ។

បទថា **ឥតិ វិញ្ញាយ** គឺដឹងកាមទាំងឡាយនោះដោយអាការយ៉ាងនេះ ។

បទថា **អបិ ទិព្វេសុ** សេចក្តីថា បើបុគ្គលណាគប្បីអញ្ជើញដោយកាម
ដែលចូលទៅសម្រេចដល់ទេវតាទាំងឡាយយ៉ាងនោះ លោករ៉មែងមិនជូបនូវ
ការត្រេកអរក្នុងកាមនោះទ្បើយ ដូចព្រះសមិទ្ធិ ត្រូវទេវតាអារាធនាដូច្នោះ ។

បទថា **តណ្ហាក្ខយរតោ** *សេចក្តីថា ជាអ្នកត្រេកអរក្រៃលែងក្នុងព្រះអរហត្ត និងក្នុងព្រះនិព្វាន គឺប្រាថ្នាអរហត្ត និងព្រះនិព្វាន ។*

ភិក្ខុយោគាវចរ កើតក្នុងទីបំផុតនៃការស្តាប់ធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយ ឈ្មោះថា ព្រះសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ។ ទេសនាមានប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយ ដូច្នេះឯង ៕

រឿង ភិក្ខុមិនត្រេកអរ ចប់

រឿង អគ្គិទត្តបុរោហិត

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រថាប់គង់លើផ្នូកឥដ្ឋចាប់ទ្រង់ប្រារព្ធបុរោហិតរបស់ព្រះបាទកោសល ឈ្មោះអគ្គិទត្ត ត្រាស់ព្រះធម្មទេសនានេះថា **ពហុំ វេ សរណំ យន្តិ** *ជាដើម ។*

បានឮមកថា អគ្គិទត្តនោះបានជាបុរោហិតរបស់ព្រះបាទមហាកោសល កាលព្រះរាជបិតាសោយទិវង្គតហើយ ព្រះរាជាព្រះនាមបសេនទិកោសលទ្រង់ព្រះតម្រិះថា បុគ្គលនេះជាបុរោហិតនៃព្រះជនករបស់អញ ទើបតាំងទុកក្នុងតំណែងនោះឯងដោយសេចក្តីគោរព ក្នុងកាលបុរោហិតមកកាន់ទីគាល់របស់ព្រះអង្គ ទ្រង់ធ្វើការក្រោកទទួល ត្រាស់ឲ្យព្រះរាជទានអាសនៈស្មើគ្នា

ដោយព្រះតម្រាស់ថា សូមលោកអាចារ្យអង្គុយលើអាសនៈនេះ ។

អគ្គិទត្តនោះគិតថា ព្រះរាជានេះ ទ្រង់ធ្វើសេចក្តីគោរពក្នុងអញយ៉ាងក្រៃលែង តែអញមិនអាចយកចិត្តរបស់ព្រះរាជាទាំងឡាយបាន អស់កាលជានិច្ចឡើយ ម្យ៉ាងទៀត ព្រះរាជានៅក្មេង នៅកំលោះ ឈ្មោះថា ភាពជាព្រះរាជា ដោយបុគ្គលមានវ័យស្មើគ្នានោះឯងជាហេតុឲ្យកើតសុខ ចំណែកអញជាមនុស្សចាស់ អញគួរបួស ។ បុរោហិតក្រាបទូលឲ្យព្រះរាជា ព្រះរាជទានការបួសហើយ ឲ្យមនុស្សវាយស្គរ ត្រាច់ទៅក្នុងព្រះនគរ លះបង់ទ្រព្យរបស់ខ្លួនទាំងអស់ ព្រោះការឲ្យទានជាធំអស់ ៧ ថ្ងៃហើយ បួសជាអ្នកបួសខាងក្រៅព្រះពុទ្ធសាសនា បុរសមួយម៉ឺននាក់អាស្រ័យអគ្គិទត្តនោះបួសតាមហើយ ។ អគ្គិទត្តនោះ មួយអន្ទើដោយអ្នកបួសទាំងនោះ សម្រេចការនៅក្នុងរវាងដែនអង្គ: ដែនមគធ: និងដែនកុរុ ឲ្យឱវាទថា បាទាំងឡាយ បណ្តាអ្នកទាំងឡាយ មានកាមវិតក្កជាដើមកើតឡើង បុគ្គលនោះត្រូវជញ្ជូនឆ្សាច់មួយក្អមអំពីស៊ឹង មកគរក្នុងទីនេះ ។ ពួកអ្នកបួសទាំងនោះទទួលថាសាធុ ក្នុងកាលកាមវិតក្កជាដើមកើតឡើងហើយ ក៏ធ្វើយ៉ាងនោះ ។ ដោយសម័យដទៃទៀត មានគំនរឆ្សាច់ធំហើយ ។ នាគរាជឈ្មោះអហិធត្តហួងហែងគំនរឆ្សាច់ធំនោះ អ្នកអង្គ: អ្នកមគធ: និងអ្នកកុរុ នាំគ្រឿងសក្ការៈជាច្រើនទៅប្រគេនដល់អ្នកបួសទាំងនោះរៀងរាល់ខែ ។

គ្រានោះ អគ្គិទត្តបានឲ្យឱវាទដល់ជនទាំងនោះដូច្នេះថា ចូរពួកអ្នកយកភ្នំជាសរណ: ចូរយកព្រៃជាសរណ: ចូរយកអារាមជាសរណ: ចូរដល់ដើម

ឈើជាសរណៈ ពួកអ្នកនឹងផុតចាកទុក្ខទាំងអស់បាន ដោយអាការយ៉ាងនេះ ពោលទូន្មានដល់អន្តេវាសិករបស់ខ្លួនដោយឱវាទនេះដូចគ្នា ។

ចំណែកព្រះពោធិសត្វ យាងចេញមហាភិនេស្ក្រមណ៍ ទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណហើយ ក្នុងសម័យនោះ ទ្រង់អាស្រ័យក្រុងសាវត្ថី គង់ប្រថាប់នៅក្នុងវត្តជេតពន ក្នុងកាលទៀបភ្លឺ ទ្រង់ប្រមើលមើលសត្វលោក ទ្រង់ឃើញអគ្គិទត្តព្រាហ្មណ៍ មួយអន្ទើដោយអន្តេវាសិក ចូលក្នុងសំណាញ់ញាណរបស់ទ្រង់ហើយ ទ្រង់ជ្រាបថា ជនទាំងអស់នេះជាអ្នកដល់ព្រមដោយឧបនិស្សយនៃអរហត្ត ក្នុងពេលល្ងាច ត្រាស់នឹងមហាមោគ្គល្លានថា ម្នាលមោគ្គល្លាន អ្នកឃើញអគ្គិទត្តព្រាហ្មណ៍ ញុំាងមហាជនឲ្យសុះទៅក្នុងទីដែលមិនមែនផ្លូវដែរឬទេ ចូរអ្នកទៅឲ្យឱវាទដល់មហាជនទាំងនោះ ។

ព្រះថេរៈទូលថា បពិត្រព្រះអង្គ ជនទាំងនោះច្រើន ខ្ញុំព្រះអង្គម្នាក់ឯងសង្កត់សង្កិនមិនបានទ្បើយ បើទ្រង់យាងមកសោត ជនទាំងនោះគប្បីសង្កត់សង្កិនបាន ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន តថាគតនឹងទៅ ចូរអ្នកទៅមុនចុះ ។

ព្រះថេរៈនិមន្តទៅបណ្តើរ គិតបណ្តើរថា ជនទាំងនោះ មានកម្លាំងផងច្រើនផង បើអាត្មាអញពោលពាក្យណាមួយ ក្នុងទីប្រជុំរបស់ជនទាំងពួងសោត ជនទាំងនោះ គប្បីក្រោកឡើងជាពួកៗ ញុំាងភ្លៀងតំណក់ធំៗ ឲ្យធ្លាក់ចុះ និងនាំគ្នាក្រោកឡើងហើយ ទៅកាន់បណ្ណសាលារៀងៗ ខ្លួន ។ ព្រះថេរៈឈរត្រង់ទ្វារបណ្ណសាលារបស់អគ្គិទត្ត ពោលថា អគ្គិទត្ត ។ គាត់បាន

ឮសំឡេងរបស់ព្រះថេរៈហើយ ពោលថា នុ៎ះជាអ្នកណា ព្រោះភាពជាអ្នក រឹងត្អឹងដោយមានះថា ក្នុងលោកនេះ បុគ្គលណាម្នាក់ ដែលអាចហៅអញ ដោយឈ្មោះមិនមាន អ្នកណាហ្ន៎ហៅអញ ដោយចេញឈ្មោះ ព្រះថេរៈ ពោលថា ម្នាលព្រាហ្មណ៍ គឺអាត្មា អគ្គិទត្តពោលថា លោកម្ចាស់ពោលអ្វី ព្រះថេរៈពោលថា សូមលោកប្រាប់ទីសម្រាកក្នុងទីនេះ ដល់ខ្ញុំមួយរាត្រី ក្នុងថ្ងៃនេះ ។ អគ្គិទត្តពោលថា ទីសម្រាកក្នុងទីនេះមិនមាន បណ្ណសាលាមួយ សម្រាប់មនុស្សម្នាក់ប៉ុណ្ណោះ ព្រះថេរៈពោលថា អគ្គិទត្ត ធម្មតា ពួកមនុស្ស រមែងទៅកាន់សម្នាក់របស់ពួកមនុស្ស ពួកគោក៏ទៅកាន់សម្នាក់របស់ពួកគោ ពួកបព្វជិតក៏ទៅកាន់សម្នាក់របស់ពួកបព្វជិត លោកកុំធ្វើយ៉ាងនោះ ចូរឲ្យទីសម្រាកដល់ខ្ញុំ អគ្គិទត្តពោលថា លោកម្ចាស់ជាបព្វជិតឬ ព្រះថេរៈពោលថា អើខ្ញុំជាបព្វជិត អគ្គិទត្តពោលថា បើលោកម្ចាស់ជាបព្វជិតសោត របស់របរគឺសង្រែក បរិក្ខារនៃបព្វជិតរបស់លោកម្ចាស់នៅឯណា ព្រះថេរៈពោលថា បរិក្ខាររបស់ខ្ញុំមាន ខ្ញុំគិតឃើញថា ការកាន់បរិក្ខារនោះជាផ្នែក ត្រាច់ទៅលំបាក ដូច្នេះហើយ ទើបទុកជាក់បរិក្ខារនោះខាងក្នុងនោះឯងត្រាច់ទៅ ។

ព្រាហ្មណ៍ក្រោធនឹងព្រះថេរៈពោលថា លោកម្ចាស់កាន់បរិក្ខារនោះត្រាច់ទៅឬ លំដាប់នោះ ទើបព្រះថេរៈពោលថា អគ្គិទត្ត អ្នកកុំក្រោធ ចូរប្រាប់ទីសម្រាកដល់ខ្ញុំ អគ្គិទត្តពោលថា ទីសម្រាកក្នុងទីនេះមិនមាន ព្រះថេរៈសួរថា ចុះនរណានៅលើគំនរឥដ្ឋចាប់នោះ អគ្គិទត្តពោលថា នាគរាជមួយ ព្រះថេរៈពោលថា ចូរឲ្យទីនោះដល់ខ្ញុំ អគ្គិទត្តពោលថា ខ្ញុំមិនអាចឲ្យបានទេ កម្មរបស់នាគ-

រាជនោះកាចសាហាវ ព្រះថេរៈពោលថា ណ្ហើយចុះ ចូរឲ្យដល់ខ្ញុំចុះ អគ្គិទត្ត ពោលថា បើយ៉ាងនោះ ចូរលោកដឹងឯងចុះ ។

ព្រះថេរៈបែរមុខតម្រង់ទៅកាន់គំនរឫក្សាច់ហើយ នាគរាជឃើញព្រះថេរៈនោះមក ទើបត្រិះរិះថា សមណៈនេះមកខាងនេះ ប្រហែលជាមិនដឹងភាពដែលអញមាន អញនឹងបង្អុយផ្សែងឲ្យសមណៈនោះស្លាប់ បង្អុយផ្សែងហើយ ។

ព្រះថេរៈគិតថា នាគនេះប្រហែលជាយល់ថា អញប៉ុណ្ណោះ អាចបង្អុយផ្សែងបាន ជនដទៃមិនអាច ដូច្នេះហើយ បង្អុយផ្សែងឯង ។ ផ្សែងទាំងឡាយដែលផ្សាយចេញអំពីសរីរៈនៃនាគរាជ និងព្រះថេរៈទាំងពីរចំណែក តាំងឡើងរហូតដល់ព្រហ្មលោក ។ ផ្សែងទាំងពីរចំណែក មិនបៀតបៀនព្រះថេរៈបៀតបៀនតែនាគរាជមួយចំណែក ។ នាគរាជមិនអាចអត់ធន់នឹងកម្លាំងផ្សែងបាន ទើបឲ្យឆេះជាភ្លើង ព្រះថេរៈចូលសមាបត្តិ មានតេជោធាតុជាអារម្មណ៍ហើយ ឲ្យឆេះជាភ្លើងព្រមជាមួយនាគរាជនោះដូចគ្នា ។ ភ្លើងផ្សាយឡើងរហូតដល់ព្រហ្មលោក ។ អណ្តាតភ្លើងទាំងពីរចំណែក មិនបៀតបៀនព្រះថេរៈ បៀតបៀនតែនាគរាជមួយចំណែក ។

លំដាប់នោះ សរីរៈទាំងមូលរបស់នាគរាជនោះ ហាក់ដូចជាត្រូវគប់ភ្លើងទាំងឡាយរោលពេញខ្លួនហើយ ។ ពួកឥសីសម្លឹងមើលហើយគិតថា នាគរាជដុតសមណៈ សមណៈមនុស្សល្អឬហ្ន៎ មិនជឿពាក្យរបស់អញ ទើបវិនាសហើយ ។

ព្រះថេរៈទូន្មាននាគរាជ ធ្វើឲ្យអស់ព្យសន៍ហើយ អង្គុយលើពំនូកឫក្សាច់

នាគរាជយករង្វេលព័ន្ធគំនរខ្សាច់ បើកពពារប្រមាណប៉ុនផ្ទះកំពូល ជាំងខាងលើព្រះថេរៈ ។ ពួកឥសីទៅកាន់សម្នាក់របស់ព្រះថេរៈអំពីព្រលឹម ដោយគិតថា ពួកយើងនឹងជីងនូវសមណៈស្លាប់ ឬ មិនស្លាប់ ឃើញលោកអង្គុយលើគំនរខ្សាច់ហើយ ផ្គងអញ្ជលីសរសើរ ពោលថា សមណៈ នាគរាជមិនបៀតបៀនលោកម្ចាស់ទេឬ ព្រះថេរៈពោលថា អ្នកទាំងឡាយមិនឃើញនាគរាជបើកពពារខាងលើខ្ញុំទេឬ ឥសីទាំងនោះពោលថា គួរអស្ចារ្យហ្ន៎ អានុភាពនៃសមណៈបែបនេះ សមណៈនេះទូន្មាននាគបានហើយ បានឈរជុំជិតព្រះថេរៈ ។

ខណៈនោះ ព្រះសាស្តាយាងមកហើយ ព្រះថេរៈឃើញព្រះសាស្តាហើយក្រោកឡើងថ្វាយបង្គំ ។ លំដាប់នោះ ឥសីទាំងឡាយពោលនឹងព្រះថេរៈថា សមណៈនេះជាធំជាងលោកម្ចាស់ឬ ព្រះថេរៈពោលថា ព្រះដ៏មានព្រះភាគអង្គនោះជាព្រះសាស្តា ខ្ញុំជាសាវ័កបស់ព្រះដ៏មានព្រះភាគអង្គនោះ ។

ព្រះសាស្តា ប្រថាប់គង់លើពំនូកខ្សាច់ហើយ ។ ពួកឥសីផ្គងអញ្ជលីសរសើរព្រះសាស្តាថា អានុភាពរបស់សាវ័កដល់ម្ល៉ះ តើអានុភាពរបស់ព្រះសាស្តា យ៉ាងណាទៅហ្ន៎ ។

ព្រះសាស្តា ត្រាស់ហៅអគ្គិទត្តមកហើយត្រាស់ថា ម្នាលអគ្គិទត្ត អ្នកកាលឲ្យឱវាទដល់សាវ័ក និងឧបជ្ឈាកទាំងឡាយរបស់អ្នក រមែងឲ្យដូចម្តេច អគ្គិទត្តពោលថា ខ្ញុំព្រះអង្គឲ្យឱវាទដល់សាវ័ក និងឧបជ្ឈាកទាំងនោះយ៉ាងនេះថា ចូរអ្នកទាំងឡាយដល់ភ្នំថាជាទីពឹង ចូរដល់ព្រៃ អារាម ចូរដល់ដើមឈើថាជាទីពឹង ព្រោះថាបុគ្គលដល់វត្ថុទាំងឡាយ មានភ្នំជាដើមនោះជាទីពឹងហើយ

រមែងផុតចាកទុក្ខទាំងពួងបាន ។

ព្រះសាស្តាត្រាស់ថា ម្នាលអគ្គិទត្ត បុគ្គលដល់នូវវត្ថុទាំងឡាយ មានភ្នំជាដើមនោះថាជាទីពឹងហើយ រមែងមិនផុតចាកទុក្ខបានឡើយ ចំណែកបុគ្គលដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឆថាជាទីពឹង រមែងផុតចាកទុក្ខក្នុងវដ្ត:ទាំងមូលបាន ដូច្នេះហើយ បានភាសិតព្រះគាថាទាំងឡាយថា

ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច
អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា
នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ
នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ
យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឆញ្ច សរណំ គតោ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្ពមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ
ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

មនុស្សទាំងឡាយច្រើននាក់ ត្រូវភ័យគំរាមហើយ តែងយកភ្នំ អារាម និងរុក្ខចេតិយជាទីពឹង ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលអាស្រ័យនូវទីពឹងនេះហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួងឡើយ លុះតែបុគ្គលណាយក

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹង ឃើញច្បាស់នូវ អរិយសច្ចទាំង ៤ គឺទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ និរោធសច្ចកន្លងទុក្ខ ១ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វាន ដែលជាទីរម្ងាប់ទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ នេះឯងជាទីពឹងដ៏ក្សេម នេះឯងជាទីពឹងដ៏ឧត្តម បុគ្គលអាស្រ័យទីពឹងនេះ រមែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ពហុំ** *បានដល់* **ពហូ** *ប្រែថា ច្រើន ។ បទថា* **បព្វតានិ** *ជាដើម សេចក្តីថា មនុស្សទាំងនោះ ដែលភ័យនោះៗ គំរាមហើយ ចង់ផុតចាកភ័យ ឬប្រុថ្នាលាភទាំងឡាយ មានការបានបុត្រជាដើម រមែងដល់ភ្នំ មានភ្នំឥសិគិលិ ភ្នំវេបុល និងភ្នំវេការៈជាដើម ព្រៃទាំងឡាយ មានព្រៃមហាវន ព្រៃគោសិង្គសាលវនជាដើម អារាមទាំងឡាយ មានវេឡុវន និងជីវកម្ពវនជាដើម និងរុក្ខចេតិយទាំងឡាយ មានខទេនចេតិយ និងគោតមចេតិយជាដើម ក្នុងទីនោះៗ ថាជាទីពឹង ។*

ពីរបទថា **នេតំ សរណំ** *សេចក្តីថា សរណៈទាំងអស់នោះ មិនក្សេម មិនឧត្តម ព្រោះថា បណ្តាសត្វទាំងឡាយដែលមានការកើតជាដើម ជាធម្មតាសូម្បីបុគ្គលម្នាក់ អាស្រ័យសរណៈនោះ រមែងមិនផុតចាកទុក្ខទាំងពួង មានជាតិជាដើមបានឡើយ ។*

ពាក្យថា **យោ ច** *ជាដើមនេះ ព្រះសាស្តាទ្រង់សម្តែងសរណៈដែលមិនក្សេម មិនឧត្តមហើយ ប្រារព្ធដើម្បីសម្តែងសរណៈដ៏ក្សេម ដ៏ឧត្តម ។*

អត្ថនៃពាក្យថា **យោ ច** *ជាដើមនោះ ដូចតទៅនេះថា ចំណែកបុគ្គលណា ជាគ្រហស្ថក្តី ជាបព្វជិតក្តី អាស្រ័យកម្មដ្ឋាន គឺការតាមរឭកដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាដើមថា ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះអរហន្ត-សម្មាសម្ពុទ្ធ ព្រោះហេតុយ៉ាងនេះ ដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃថាជាទីពឹង ដោយអំណាចនៃភាពជាវត្ថុដ៏ប្រសើរ ការដល់សរណៈនោះ របស់បុគ្គលនោះ នៅកម្រើក នៅញាប់ញ័រដោយកិច្ចទាំងឡាយ មានការថ្វាយបង្គំតិរ្ថិយជាដើម ។ តែព្រះសាស្តា ដើម្បីទ្រង់សម្តែងការដល់សរណៈដែលមិនញាប់ញ័រនោះ កាលទ្រង់ប្រកាសសរណៈ ដែលមកហើយដោយយមគ្គនោះឯង ទើបត្រាស់ថា រមែងឃើញអរិយសច្ច ៤ ដោយបញ្ញាប្រពៃ ព្រោះថាបុគ្គលណាដល់រតនៈទាំងឡាយ មានព្រះពុទ្ធរតនៈជាដើមនោះ ថាជាទីពឹងដោយអំណាចនៃការឃើញសច្ចៈទាំងនោះ សរណៈនោះ របស់បុគ្គលនោះ ក្សេម និងឧត្តមបុគ្គលនោះ អាស្រ័យសរណៈនោះ រមែងផុតចាកទុក្ខក្នុងវដ្តៈបាន ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា* **ឯតំ ខោ សរណំ ខេមំ** *ជាដើម ។*

ក្នុងកាលចប់ទេសនា ឥសីទាំងអស់សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយហើយ ថ្វាយបង្គំព្រះសាស្តា ទូលសូមបព្វជ្ជាហើយ ។

ព្រះសាស្តា ទ្រង់លាព្រះហស្តចេញអំពីស្រោមចីវរត្រាស់ថា ចូរអ្នក

ទាំងឡាយមកជាភិក្ខុចុះ ចូរប្រព្រឹត្តព្រហ្មចរិយៈ ។

ខណៈនោះឯង ឥសីទាំងនោះបានជាអ្នកទ្រទ្រង់នូវបរិក្ខារ ៨ ដូចព្រះថេរៈមានវស្សា ១០០ ។ ថ្ងៃនោះជាថ្ងៃដែលអ្នកដែនអង្គៈ ដែនមគធៈ និងដែនកុរុទាំងពួង កាន់នូវគ្រឿងសក្ការៈមក ។ ជនទាំងនោះកាន់គ្រឿងសក្ការៈមកហើយ ឃើញឥសីទាំងនោះបួសហើយគិតថា អគ្គិទត្តព្រាហ្មណ៍របស់ពួកយើងជាធំ ឬព្រះសមណគោតមជាធំហ្ន៎ បានសម្គាល់ថាអគ្គិទត្តជាធំ ព្រោះហេតុដែលព្រះសមណគោតមមកវក ។

ព្រះសាស្តា ទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់ជនទាំងនោះ ហើយត្រាស់ថា អគ្គិទត្ត ចូរអ្នកកាត់សេចក្តីសង្ស័យរបស់បរិស័ទ ។ អគ្គិទត្តនោះក្រាបទូលថា ខ្ញុំព្រះអង្គក៏ទន្ទឹងហេតុមានប្រមាណប៉ុណ្ណោះដូចគ្នា ដូច្នេះហើយហោះទៅកាន់អាកាសដោយកម្លាំងឫទ្ធិ ហើយចុះមកថ្វាយបង្គំព្រះសាស្តារៀយៗអស់ ៧ ដងហើយ ពោលប្រកាសភាពដែលខ្លួនជាសាវ័កថា បពិត្រព្រះអង្គ ព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័កដូច្នេះឯង ។

រឿង អគ្គិទត្តបុរោហិត ចប់

រឿង បញ្ហារបស់ព្រះអានន្ទត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហារបស់ព្រះអានន្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ទុល្លភោ បុរិសាជញ្ញោ** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះថេរៈអង្គុយក្នុងទីសម្រាកពេលថ្ងៃ គិតថា ព្រះសាស្តាកាលត្រាស់ពាក្យថា ជំរីអាជានេយ្យកើតឡើងក្នុងត្រកូលជំរីឆទ្ទន្ត ឬក្នុងត្រកូលជំរីឧបោសថ សេះអាជានេយ្យកើតក្នុងត្រកូលសេះសិន្ធព ឬត្រកូលសេះវលាហក គោអាជានេយ្យ កើតក្នុងទក្ខិណាបថជនបទជាដើម ជាការត្រាស់ទីកើតឡើងនៃសត្វដ៏ប្រសើរ មានជំរីអាជានេយ្យជាដើមហើយ ចំណែកបុរសអាជានេយ្យ រមែងកើតឡើងក្នុងទីណាហ្ន៎ ។

ព្រះថេរៈចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយទូលសួររឿងនោះ ព្រះសាស្តាត្រាស់ថា អានន្ទ ឈ្មោះថាបុរសអាជានេយ្យ រមែងមិនកើតក្នុងទីទូទៅតែកើតឡើងក្នុងទីដែលជាមជ្ឈិមប្រទេស វាស់ដោយបណ្តោយ ៣០០ យោជន៍ ដោយជុំវិញ ៩០០ យោជន៍ កាលកើតឡើង ក៏រមែងមិនកើតឡើងក្នុងត្រកូលសាមញ្ញ រមែងកើតឡើងក្នុងត្រកូលខត្តិយមហាសាល និងព្រាហ្មណមហាសាលត្រកូលណាមួយប៉ុណ្ណោះ ដូច្នេះហើយ ត្រាស់គាថានេះថា

ទុល្លភោ បុរិសាជញ្ញោ ន សោ សព្វត្ថ ជាយតិ
យត្ថ សោ ជាយតី ធីរោ តំ កុលំ សុខមេធតិ ។

បុរសអាជានេយ្យ រកបានដោយកម្រ លោកមិនកើតក្នុងសព្វស្ថានឡើយ លោកជាអ្នកមានប្រាជ្ញា កើតក្នុងត្រកូល

ណា ត្រកូលនោះ តែងដល់នូវសេចក្តីសុខ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឧុល្លកោ** *ជាដើម សេចក្តីថា បុរសអាជានេយ្យ ជាបុគ្គលដែលរកបានដោយកម្រ គឺមិនរកបានងាយដូចជំរីអាជានេយ្យជាដើមឡើយ ។ បុរសអាជានេយ្យនោះ រមែងមិនកើតក្នុងទីទូទៅ ក្នុងបច្ចន្តបទេស ឬក្នុងត្រកូលទាបឡើយ តែរមែងកើតក្នុងត្រកូលណាមួយ បណ្តាត្រកូលក្សត្រ និងត្រកូលព្រាហ្មណ៍ ក្នុងទីដែលជាទីធ្វើសក្ការៈ មានអភិវាទជាដើមនៃមហាជនក្នុងមជ្ឈិមប្រទេសប៉ុណ្ណោះ បុរសអាជានេយ្យនោះជាអ្នកជ្រាជ្រ គឺជាអ្នកមានបញ្ញាដ៏ឧត្តម បានដល់ ព្រះសម្មាសម្ពុទ្ធ ដែលនឹងកើតយ៉ាងនោះ រមែងកើតក្នុងត្រកូលណាមួយនោះ រមែងដល់នូវសេចក្តីសុខ គឺរមែងជាត្រកូលដែលសម្រេចសេចក្តីសុខពិត ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង បញ្ហារបស់ព្រះអានន្ទ ចប់

រឿង សម្ពហុលភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការសនូនារបស់ភិក្ខុច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **សុខោ ពុទ្ធានមុប្បាទោ** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ភិក្ខុ ៥០០ អង្គុយក្នុងសាលាជាទីទំនុកបម្រុងសនូនាគ្នាថា អាវុសោទាំងឡាយ អ្វីហ្នឹជាសុខក្នុងលោកនេះ ។

បណ្តាភិក្ខុទាំងនោះ ពួកខ្លះពោលថា ឈ្មោះថា សុខ ដូចគ្នានឹងសុខក្នុងរាជសម្បត្តិមិនមាន ពួកខ្លះពោលថា ឈ្មោះថា សុខ ដូចគ្នានឹងសុខក្នុងកាមរមែងមិនមាន ពួកខ្លះពោលថា ឈ្មោះថា សុខ ដូចគ្នានឹងសុខដែលកើតអំពីការបរិភោគស្រូវសាលី និងសាច់ មិនមាន ។

ព្រះសាស្តាយាងមកកាន់ទីដែលភិក្ខុទាំងនោះអង្គុយហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយពាក្យអ្វីហ្នឹ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយពាក្យឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលអ្វី សេចក្តីសុខទាំងអស់នេះទាក់ទងដោយទុក្ខក្នុងវដ្ត:ទាំងអស់ តែហេតុនេះប៉ុណ្ណោះ គឺការកើតឡើងនៃព្រះពុទ្ធ ការស្តាប់ធម៌ ការព្រមព្រៀងរបស់ពួកគណ: ភាពជាអ្នកត្រូវរ៉ូវគ្នា ជាសុខក្នុងលោកនេះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

សុខោ ពុទ្ធានមុប្បាទោ　　សុខា សទ្ធម្មទេសនា
សុខា សង្ឆស្ស សាមគ្គី　　សមគ្គានំ តទោ សុខោ ។

ការកើតឡើងនៃព្រះពុទ្ធ ជាសុខ ការសម្តែងព្រះសទ្ធម្ម ជាសុខ សេចក្តីព្រមព្រៀងគ្នាជាពួក ជាសុខ តបធម៌របស់បុគ្គលអ្នកព្រមព្រៀងគ្នាទាំងឡាយ ជាសុខ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ពុទ្ធានមុប្បាទោ** *សេចក្តីថា ព្រះពុទ្ធទាំងឡាយ កាលកើតឡើងរមែងញុំាងមហាជនឲ្យឆ្លងកន្តារទាំងឡាយ មានរាគកន្តារជាដើម ហេតុណា ហេតុនោះការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ទើបឈ្មោះថាជាហេតុនាំមកនូវសុខ ។ សត្វទាំងឡាយដែលមានទុក្ខ មានជាតិជាដើមជាសភាវៈ អាស្រ័យការសម្តែងធម៌របស់សប្បុរស រមែងផុតចាកទុក្ខទាំងឡាយ មានជាតិជាដើម ហេតុណា ហេតុនោះ ទើបការសម្តែងធម៌របស់សប្បុរសឈ្មោះថាជាហេតុនាំសុខមក ។ ភាពជាអ្នកមានចិត្តស្មើគ្នា ឈ្មោះថាសាមគ្គី ។ សាមគ្គីនោះក៏ឈ្មោះថាជាហេតុនាំសុខមកដោយពិត ម៉្យាងទៀត ការរៀនព្រះពុទ្ធវចនៈក្តី ការរក្សាធុតង្គទាំងឡាយក្តី ការធ្វើសមណធម៌ក្តីរបស់ពួកជនដែលព្រមព្រៀងគ្នា គឺមានចិត្តតែមួយ ជាហេតុនាំសុខមក ហេតុណា ហេតុនោះ ទើបព្រះសាស្តាត្រាស់ថា* **សមគ្គានំ តបោ សុខោ** *ព្រោះហេតុនោះឯង ទើបព្រះសាស្តាត្រាស់ថា*

ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនីងប្រជុំគ្នារឿយៗ
ប្រជុំគ្នាដោយច្រើន អស់កាលត្រឹមណា ម្នាល
ភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដ

ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

ក្នុងកាលចប់ទេសនា ភិក្ខុជាច្រើនតាំងនៅក្នុងអរហត្តផលហើយ ទេសនាមានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។

រឿង សម្ពហុលភិក្ខុ ចប់

រឿង ព្រះចេតិយមាសរបស់ព្រះកស្សបទសពល

លំនាំដើម

ព្រះបរមសាស្តា កាលទ្រង់ចារិកទៅ ទ្រង់ប្រារព្ធព្រះចេតិយមាសរបស់ព្រះកស្សបទសពល ទើបត្រាស់ព្រះធម្មទេសនានេះថា **ឫជារហោ** ជាដើម ។

សេចក្តីពិស្តារថា ព្រះតថាគតមានមហាភិក្ខុសង្ឃជាពុទ្ធបរិវារ យាងចេញអំពីនគរសាវត្ថី ទៅកាន់នគរពារាណសីដោយលំដាប់ ដល់ទេវស្ថានមួយកន្លែងក្នុងទីជិតស្រុកតោទេយ្យគាម ក្នុងវាងផ្លូវ ព្រះសុគតបានប្រថាប់ក្បែរទេវស្ថាននោះ ទ្រង់បញ្ជូនព្រះធម្មភណ្ឌាគារិក គឺព្រះអានន្ទ ឲ្យប្រាប់ព្រាហ្មណ៍ដែលកំពុងធ្វើកសិកម្មក្នុងទីមិនឆ្ងាយមកគាល់ ។ ព្រាហ្មណ៍នោះមកហើយ មិនអភិវាទដល់ព្រះតថាគត ថ្វាយបង្គំទេវស្ថានតែម្យ៉ាង ហើយឈរនៅ ។ ព្រះសុគតក៏ត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកសម្គាល់ប្រទេសនេះថាជាអ្វី ទើបព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គថ្វាយបង្គំដោយតាំងចិត្ត

ថា ទីនេះជាចេតិយដ្ឋានតាមប្រពៃណីរបស់ពួកខ្ញុំព្រះអង្គ ។ ទើបព្រះសុគត ឲ្យព្រាហ្មណ៍នោះត្រេកអរថា ម្នាលព្រាហ្មណ៍ អ្នកថ្វាយបង្គំទីស្ថាននេះបានធ្វើ កម្មល្អហើយ ។ ភិក្ខុទាំង៦ព្រោយបានស្តាប់ព្រះពុទ្ធតម្រាស់នោះហើយ ទើបកើត សេចក្តីសង្ស័យឡើងថា ព្រះសាស្តាទ្រង់ឲ្យព្រាហ្មណ៍ត្រេកអរយ៉ាងនេះដោយ ហេតុអ្វីហ្ន៎ ។ លំដាប់នោះ ព្រះតថាគតដើម្បីដោះសេចក្តីសង្ស័យរបស់ភិក្ខុទាំង នោះ ទើបត្រាស់ទេសនាឃដិការសូត្រ ក្នុងមជ្ឈិមនិកាយ ហើយទ្រង់និម្មិតព្រះ ចេតិយមាសរបស់ព្រះកស្សបទសពលកម្ពស់ ១ យោជន៍ និងចេតិយមាស មួយទៀតក្នុងអាកាស ទ្រង់បង្ហាញឲ្យមហាជនឃើញហើយ ត្រាស់ថា ម្នាល ព្រាហ្មណ៍ ការបូជានូវបុគ្គលដែលគួរបូជាបែបនេះ រមែងសមគួរពិត ដូច្នេះ ហើយ ទើបទ្រង់ប្រកាសបូជារហបុគ្គល ៤ ពួក មានព្រះពុទ្ធជាដើម ដោយ នយដូចបានត្រាស់ក្នុងមហាបរិនិព្វានសូត្រនោះឯង ហើយទ្រង់សម្តែងដោយ ពិសេសដល់ចេតិយ ៣ គឺសរីរចេតិយ ១ ឧទ្ទិសចេតិយ ១ បរិភោគចេតិយ ១ ហើយបានភាសិតព្រះគាថាថា

ឫជារហោ ឫជយតោ ពុទ្ធេ យធិ ច សាវកេ
បបញ្ចសមតិក្កន្តេ តិណ្ណោសោកបរិទ្ទវេ
តេ តាទិសេ ឫជយតោ និព្វុតេ អកុតោភយេ
ន សក្កា បុញ្ញំ សង្ខាតុំ ឥមេត្តមបិ កេនចិ ។

កាលបុគ្គលបូជា ដល់បូជារហបុគ្គល គឺព្រះពុទ្ធ ឬសាវ័ករបស់ ព្រះពុទ្ធ ដែលកន្លងផុតបបញ្ចធម៌ ដែលកន្លងផុតសេចក្តីសោក

និងខ្សឹកខ្សួល ឬកាលបូជាដល់បូជារហបុគ្គលទាំងនោះ ដែលប្រកបដោយតាទិគុណ លោកមិនមានភ័យអំពីទីណា សូម្បីនិព្វានទៅហើយ បុគ្គលណាម្នាក់ មិនអាចវាស់បុណ្យថា បុណ្យនេះមានប្រមាណប៉ុណ្ណោះបានឡើយ ។

សេចក្តីអធិប្បាយ

បុគ្គលគួរបូជា ឈ្មោះថា **បូជារហោ** *ក្នុងព្រះគាថានោះ ។ បទថា* **បូជារហោ បូជយតោ** *សេចក្តីថា បុគ្គលបូជាដោយការឱនលំទោន មានការក្រាបថ្វាយបង្គំជាដើម និងដោយបច្ច័យ ៤ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងបូជារហបុគ្គលដោយពាក្យថា* **ពុទ្ធេ** *។ បទថា* **ពុទ្ធេ** *បានដល់ ព្រះសម្មាសម្ពុទ្ធ ។ និបាតសព្ទថា* **យនិ** *បានដល់* **យនិវា** *អធិប្បាយថា* **អថវា** *។ សូម្បីព្រះបច្ចេកពុទ្ធទាំងឡាយ ក៏ឈ្មោះថា ត្រាស់ហើយក្នុងព្រះគាថានោះ ឬសាវកទាំងឡាយផងដែរ ។ បទថា* **បបញ្ចសមតិក្កន្តេ** *សេចក្តីថា បបញ្ចធម៌ គឺតណ្ហា ទិដ្ឋិ មានះ លោកឈានកន្លងបានហើយ ។ បទថា* **តិណ្ណោសោក-បរិទ្ទវេ** *បានដល់ ជាអ្នកមានសេចក្តីសោក និងសេចក្តីខ្សឹកខ្សួលដែលកន្លងផុតហើយ អធិប្បាយថា ឆ្លងផុតបានទាំងពីរយ៉ាង ។ ភាពជាបុគ្គលគួរដល់ការបូជា ព្រះសាស្តាត្រាស់ដោយបទវិសេសន:ទាំងនោះ ។ បទថា* **តេ** *បានដល់ ព្រះពុទ្ធជាដើម ។ បទថា* **តាទិសេ** *បានដល់ បុគ្គលប្រកបដោយគុណបែបនោះ ដោយអំណាចនៃគុណដូចពោលហើយ ។ បទថា* **និព្វុតេ** *បានដល់ និព្វានដោយការរម្ងាប់កិលេស មានរាគៈជាដើម ។ ភ័យអំពីទីណា*

មួយ គឺចាកកាព ឬចាកអារម្មណ៍ រមែងមិនមានដល់បុគ្គលដែលគួរបូជាទាំងនោះ ដូច្នោះ ទើបលោកទាំងនោះ ឈ្មោះថា មិនមានភ័យអំពីទីណាមួយ ។ ន្ទូវលោកជាអ្នកមិនមានភ័យអំពីទីណាទាំងនោះ ។ បទថា **ន សក្កា បុញ្ញំ សង្ខាតុំ** *សេចក្តីថា មិនអាចគណនាបុណ្យបាន បើមានពាក្យសួរជ្រៀតចូលមកថា រាប់ដូចម្តេច គប្បីឆ្លើយថា ដែលបុគ្គលណាម្នាក់មិនអាចរាប់ថាបុណ្យនេះ មានប្រមាណប៉ុណ្ណេះ អធិប្បាយថា ដែលបុគ្គលណាម្នាក់ មិនអាចរាប់ថាបុណ្យនេះ មានប្រមាណប៉ុណ្ណេះ បុណ្យនេះ មានប្រមាណប៉ុណ្ណេះ ។* **អបិ** *សព្ទ គប្បីភ្ជាប់ក្នុងបទថា* **កេនចិ** *អធិប្បាយថា ដែលបុគ្គលណាម្នាក់ ឬដោយរាប់វិធីណាមួយ ។ ក្នុងពាក្យពីរនោះ ពាក្យថា ដែលបុគ្គលណាម្នាក់ បានដល់ ដែលបុគ្គលមានព្រះព្រហ្មជាដើម ។ ពាក្យថា ដោយការរាប់ បានដល់ ដោយការរាប់ ៣ យ៉ាង គឺដោយការគណនា ដោយការថ្លឹង ដោយការវាល់ ។ ការរាប់ចំនួនដោយន័យថា របស់នេះមានប្រមាណប៉ុណ្ណេះ ឈ្មោះថា គណនា ការថ្លឹងដោយជញ្ជីង ឈ្មោះថា ថ្លឹង ការធ្វើឲ្យពេញដោយអំណាចនៃកន្ទុះទូកដៃ មួយទូកដៃ មួយកម្សៀរ និងមួយនាឡិជាដើម ឈ្មោះថា វាល់ ដែលបុគ្គលណាម្នាក់ មិនអាចរាប់បុណ្យរបស់បុគ្គលដែលបូជានូវបុគ្គលដែលគួរបូជា មានព្រះពុទ្ធជាដើម ដោយការរាប់ ៣ យ៉ាងនេះ ដោយអំណាចនៃវិបាក គឺផល ព្រោះវៀរចាកទីបំផុត ដូច្នេះ ។*

ផលរបស់អ្នកបូជាក្នុងស្ថានទាំងពីរដូចម្តេច បុណ្យរបស់បុគ្គលដែលបូជាព្រះពុទ្ធជាដើមដែលគង់ព្រះជន្ម បុគ្គលណាម្នាក់មិនអាចរាប់បាន ក៏ល្មមធ្វើតាម

សមគួរ ។ បុណ្យរបស់បុគ្គលដែលបូជាព្រះពុទ្ធជាដើមបែបនោះ សូម្បីនិព្វាន ហើយ ដោយខន្ធបរិនិព្វាន ដែលមានកិលេសបរិនិព្វានជានិមិត្ត បុគ្គលណា ម្នាក់ក៏មិនអាចរាប់បាន ព្រោះដូច្នោះ គួរផ្សេងគ្នាខ្លះ ព្រោះហេតុនោះ នឹង មានសេចក្តីសង្ស័យនោះឯង ទើបសក្កទេវរាជពោលក្នុងវិមានវត្ថុថា

> កាលព្រះតថាគតស្ថិតនៅក្តី បរិនិព្វានទៅក្តី បើតាំងចិត្តស្មើ ផលក៏ស្មើ ដ្បិតថា សត្វទាំងឡាយ មានការតម្កល់ចិត្តជាហេតុ ទើបទៅកាន់សុគតិបាន ដូច្នេះ ។

ក្នុងអាវសានៃព្រះធម្មទេសនា ព្រាហ្មណ៍នោះ បានជាព្រះសោតា-បន្នហើយ ។

ព្រះចេតិយមាសកម្ពស់ ១ យោជន៍ បានតាំងនៅក្នុងអាកាសនោះឯង អស់ ៧ ថ្ងៃ ។ សមាគមមានហើយដោយជនជាច្រើន ពួកគេបូជាព្រះចេតិយ ដោយប្រការផ្សេងៗ អស់ ៧ ថ្ងៃ ។ បន្ទាប់អំពីនោះ ការបែកផ្សេងគ្នានៃលទ្ធិ របស់អ្នកមានលទ្ធិផ្សេងៗ គ្នា បានកើតមានហើយ ។

ព្រះចេតិយនោះ បានទៅកាន់ទីដើមរបស់ខ្លួនដោយពុទ្ធានុភាព ក្នុងខណៈ នោះ មហាសិលាចេតិយ មានឡើងហើយក្នុងទីនោះឯង សត្វប្រមាណ ៨ ម៉ឺន ៤ ពាន់ បានសម្រេចធម្មាភិសមយហើយក្នុងសមាគមនោះ ៕

រឿងព្រះចេតិយមាសរបស់ព្រះកស្សបទសពល ចប់

ពុទ្ធវគ្គ ចប់

វគ្គទី ១៤ ចប់

សុត្តន្តបិដក

ធម្មបទគាថា សុខវគ្គទី ១៥

[២៥] យើងជាអ្នកមិនមានពៀរ រស់នៅជាសុខពិត ក្នុងពួកមនុស្សមានពៀរ កាលពួកមនុស្សមានពៀរ យើងជាអ្នកមិនមានពៀរ ។ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ (ដោយកិលេស) រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីក្តៅក្រហាយ កាលពួកមនុស្សមានសេចក្តីក្តៅក្រហាយ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ ។ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ក្នុងការស្វែងរក រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីខ្វល់ខ្វាយ កាលពួកមនុស្សមានសេចក្តីខ្វល់ខ្វាយ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ។

យើងមិនមានកង្វល់ តែងរស់នៅជាសុខពិត (ព្រោះ) យើងមានបីតិជាអាហារ ដូចពួកទេវតាជាន់អាភស្សរៈ ។

បុគ្គលអ្នកឈ្នះ តែងរងនូវពៀរ បុគ្គលអ្នកចាញ់ តែងដេកជាទុក្ខ ចំណែកបុគ្គលលះបង់ការឈ្នះ និងការចាញ់ចេញហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ ។

ភ្លើង ស្មើដោយរាគៈ មិនមាន ទោសកំហុស ស្មើដោយទោសៈ មិនមាន ទុក្ខទាំងឡាយ ស្មើដោយខន្ធ មិនមាន សុខ ក្រៅពីសេចក្តីស្ងប់ មិនមាន ។

សេចក្តីស្រេកឃ្លាន ជារោគយ៉ាងក្រៃលែង សង្ខារទាំងឡាយ ជាទុក្ខយ៉ាងក្រៃលែង (អ្នកប្រាជ្ញ) ដឹងច្បាស់សេចក្តីនុ៎ះតាមពិតហើយ (រមែង

ធ្វើឲ្យច្បាស់) នូវព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

លាភ មានការមិនមានរោគ ជាយ៉ាងក្រៃលែង ទ្រព្យ មានសេចក្តីសន្តោស ជាយ៉ាងក្រៃលែង ញាតិ មានសេចក្តីស្និទ្ធស្នាល ជាយ៉ាងក្រៃលែង ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

ភិក្ខុផឹករសវិវេកផង រសព្រះនិព្វាន ជាទីរម្ងាប់កិលេសផង ផឹករសបីតិដែលកើតអំពីធម៌ផង ទើបជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ មិនមានសេចក្តីស្មៅហ្មងឡើយ ។

ការជួបប្រទះព្រះអរិយបុគ្គលទាំងឡាយ ជាការល្អ ការនៅរួមជាមួយព្រះអរិយបុគ្គលទាំងឡាយ ជាហេតុឲ្យកើតសេចក្តីសុខ សព្វកាល បុគ្គលគប្បីមានសេចក្តីសុខ អស់កាលជានិច្ចបាន ព្រោះមិនជួបប្រទះបុគ្គលពាលទាំងឡាយ ។

បុគ្គលអ្នកប្រព្រឹត្តសមគប់ដោយជនពាល រមែងសោកស្តាយអស់កាលយូរអង្វែង ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខ សព្វកាល ។ ដូចជាការនៅរួមជាមួយនឹងសត្រូវ ចំណែកខាងការនៅរួមនឹងធីរជន រមែងជាសុខ ដូចការជួបជុំនៃញាតិទាំងឡាយ ព្រោះហេតុនោះឯង បុគ្គលគួរសេពគប់សប្បុរស ជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីចេះដឹងច្រើនផង មានកិរិយានាំទៅ នូវធុរៈជាប្រក្រតីផង មានសីលវត្ត និងធុតង្គវត្តផង ជាអ្នកឆ្ងាយចាកកិលេសផង មានបញ្ញាល្អផង ប្រាកដដូច្នោះៗ ឲ្យដូចព្រះចន្ទគប់នូវផ្លូវនក្ខត្តឬក្ស ។

សុខវគ្គទី ១៥ ចប់ ។

អដ្ឋកថា

សុខវគ្គទី ១៥

រឿង រម្ងាប់ជម្ងោរនៃពួកញាតិ

លំនាំដើម

ព្រះសាស្តា គង់នៅក្នុងវែនសក្កៈ ទ្រង់ប្រារព្ធពួកព្រះញាតិ ដើម្បីរម្ងាប់នូវជម្ងោះ ទើបត្រាស់ព្រះធម្មទេសនានេះថា **សុសុខំ វត** *ជាដើម ។*

បានឮមកថា ស្តេចសក្យៈ និងកោលិយៈ ឲ្យទប់ស្ទឹងឈ្មោះរោហិណី ដោយទំនប់តែមួយ ក្នុងរវាងនគរកបិលពស្តុ និងនគរកោលិយៈ ហើយឲ្យធ្វើសម្ងួន លុះដល់ដើមខែជេស្ឋ សម្ងួនក្រៀមស្ងួត ពួកកម្មករនគរទាំងពីរប្រជុំគ្នា ។ ក្នុងនគរទាំងពីរនោះ អ្នកកោលិយៈពោលថា ទឹកនេះបើពួកយើងនាំទៅទាំងសងខាងនឹងមិនគ្រប់គ្រាន់ដល់ពួកអ្នក បើពួកអ្នកនាំទៅទាំងសងខាង ក៏នឹងមិនគ្រប់គ្រាន់ដល់ពួកខ្ញុំ តែសម្ងួនរបស់ពួកខ្ញុំ នឹងសម្រេចដោយទឹកតែម្ខាងប៉ុណ្ណោះ ។ ចូរពួកអ្នកឲ្យទឹកនេះដល់ពួកខ្ញុំចុះ ។ ចំណែកអ្នកសក្យៈពោលយ៉ាងនេះថា បើពួកអ្នកធ្វើជង្រុកឲ្យពេញហើយ ពួកខ្ញុំមិនអាចកាន់យកមាសទឹកដប់ កែវពណ៌ខៀវ កែវពណ៌ក្រហម និងកហាបណៈ ហើយមានល្អ និងជាវជាដើមក្នុងដៃ ត្រាច់ទៅត្រង់ទ្វារផ្ទះរបស់ពួកអ្នក សម្ងួនរបស់ពួកខ្ញុំសម្រេចដោយទឹកតែម្ខាងដូចគ្នា ចូរពួកអ្នកឲ្យទឹកនេះដល់ខ្ញុំចុះ ពួកកោលិយៈពោលថា

ពួកខ្ញុំមិនឲ្យ ពួកសក្យៈពោលថា សូម្បីពួកខ្ញុំក៏មិនឲ្យ ។

អ្នកនគរទាំងពីរញ៉ាំងពាក្យឲ្យចម្រើនឡើងយ៉ាងនោះហើយ ប្រហារនូវគ្នានិងគ្នាយ៉ាងនេះ គឺបុគ្គលម្នាក់ក្រោកឡើងហើយ បានឲ្យនូវការប្រហារដល់បុគ្គលម្នាក់ សូម្បីអ្នកដែលត្រូវប្រហារនោះ ក៏បានឲ្យនូវការប្រហារដល់អ្នកដទៃ ការប៉ះទង្គិចដល់ជាតិនៃរាជត្រកូលទាំងឡាយ បង្កនូវជម្លោះឲ្យចម្រើនឡើងហើយ ។ ពួកកម្មករអ្នកកោលិយៈពោលថា ចូរពួកអ្នកនាំក្មេងអ្នកក្រុងកបិលពស្តុទៅចុះ ជនទាំងឡាយណានៅរួមជាមួយបងស្រី ប្អូនស្រីរៀងៗ ខ្លួនដូចឆ្កែស្រុក និងឆ្កែចចកជាដើម ដំរី សេះ ខែល និងអាវុធទាំងឡាយរបស់ជនទាំងនោះ នឹងធ្វើអ្វីដល់ពួកយើងបាន ។

ពួកកម្មករខាងសក្យៈពោលថា ឥឡូវនេះ ចូរពួកអ្នកនាំក្មេងទិលខូចទាំងនេះទៅចុះ ជនទាំងឡាយណាមិនមានទីពឹង មិនមានគតិ នៅត្រង់ដើមក្រៅដូចសត្វតិរច្ឆាន ដំរី សេះ ខែល និងអាវុធរបស់ជនទាំងនោះ នឹងធ្វើអ្វីដល់ពួកយើងបាន ។ ជនទាំងនោះ ទៅប្រាប់ដល់ពួកអមាត្យដែលប្រកបក្នុងកម្មនោះ ពួកអមាត្យទូលដល់រាជត្រកូលទាំងឡាយ ។

លំដាប់នោះ ស្តេចសក្យៈទាំងឡាយគិតថា ពួកយើងនឹងបង្ហាញភាពក្លៀវក្លា និងកម្លាំងរបស់ពួកជនដែលនៅរួមជាមួយពួកបងស្រីប្អូនស្រី ហើយត្រៀមការច្បាំងចេញទៅ ។ ចំណែកស្តេចកោលិយៈទាំងឡាយគិតថា ពួកយើងនឹងបង្ហាញភាពក្លៀវក្លា និងកម្លាំងរបស់ពួកជនដែលនៅត្រង់ដើមក្រៅ ដូច្នេះហើយត្រៀមការច្បាំងចេញទៅ ។

ព្រះសាស្តា ទ្រង់ប្រមើលមើលសត្វលោកក្នុងពេលជិតភ្លឺ ទតឃើញពួកញាតិ ទ្រង់ព្រះតម្រិះថា បើតថាគតមិនទៅ ញាតិទាំងនេះនឹងវិនាស ការដែលតថាគតទៅក៏គួរ ដូច្នេះហើយ ទើបយាងទៅតាមអាកាសមួយព្រះអង្គឯងប៉ុណ្ណោះ ប្រថាប់គង់ពត់ភ្នែនក្នុងអាកាស ត្រង់កណ្តាលស្ទឹងរោហិណី ព្រះញាតិទាំងឡាយ ឃើញព្រះសាស្តាហើយជាក់អាវុធថ្វាយបង្គំ ។ កាលនោះ ព្រះសាស្តាត្រាស់នឹងញាតិទាំងនោះថា មហាបពិត្រ នេះឈ្មោះថាជម្លោះរឿងអ្វី ព្រះញាតិពោលថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គមិនដឹងទេ ព្រះសាស្តាត្រាស់ថា ឥឡូវនេះ តើអ្នកណាដឹង ។

ព្រះញាតិទាំងនោះ សួរដល់ពួកទាសៈ និងកម្មករដោយឧបាយនេះថា ឧបរាជនឹងជ្រាប សេនាបតីនឹងជ្រាបជាដើម ហើយក្រាបទូលថា បពិត្រព្រះអង្គ ឈ្លោះគ្នាព្រោះទឹក ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ តើទឹកមានតម្លៃប៉ុនណា ពួកព្រះញាតិទូលថា បពិត្រព្រះអង្គ មានតម្លៃតិចតួច ព្រះសាស្តាត្រាស់ថា ក្សត្រទាំងឡាយមានតម្លៃប៉ុនណា ពួកព្រះញាតិទូលថា បពិត្រព្រះអង្គ ឈ្មោះថា ក្សត្រទាំងឡាយ មានតម្លៃកាត់ថ្លៃមិនបាន ព្រះសាស្តាត្រាស់ថា ការដែលអ្នកទាំងឡាយ ញុាំងពួកក្សត្រដែលមានតម្លៃកាត់ថ្លៃមិនបានឲ្យវិនាស ព្រោះអាស្រ័យទឹក ដែលមានប្រមាណតិច គួរហើយឬ ។

ព្រះញាតិទាំងនោះនៅស្ងៀមហើយ ។ លំដាប់នោះ ព្រះសាស្តា ជាស់តឿនព្រះញាតិទាំងនោះហើយ ត្រាស់ថា មហាបពិត្រ ព្រោះហេតុអ្វី ទើបពួកអ្នកធ្វើកម្មបែបនេះ កាលតថាគតមិនមានក្នុងថ្ងៃនេះ សូម្បីទឹក គឺឈាម នឹង

ហ្ន៎ អ្នកទាំងឡាយ ធ្វើកម្មមិនសមគួរ អ្នកទាំងឡាយ ជាអ្នកមានបញ្ហាវៃតថាគតមិនមានពៀរ អ្នកទាំងឡាយ ជាអ្នកដល់នូវការក្តៅក្រហាយដោយកិលេស តថាគតមិនមានការក្តៅក្រហាយ អ្នកទាំងឡាយ ជាអ្នកមានសេចក្តីខ្វល់ខ្វាយក្នុងការស្វែងរកកាមគុណ តថាគតមិនមានការខ្វល់ខ្វាយ ហើយទ្រង់ភាសិតគាថានេះថា

សុសុខំ វត ជីវាម	**វេរិនេសុ អវេរិនោ**
វេរិនេសុ មនុស្សេសុ	**វិហារាម អវេរិនោ**
សុសុខំ វត ជីវាម	**អាតុរេសុ អនាតុរា**
អាតុរេសុ មនុស្សេសុ	**វិហារាម អនាតុរា**
សុសុខំ វត ជីវាម	**ឧស្សុកេសុ អនុស្សុកា**
ឧស្សុកេសុ មនុស្សេសុ	**វិហារាម អនុស្សុកា ។**

យើងជាអ្នកមិនមានពៀរ រស់នៅជាសុខពិត ក្នុងពួកមនុស្សមានពៀរ កាលពួកមនុស្សមានពៀរ យើងជាអ្នកមិនមានពៀរ ។ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ (ដោយកិលេស) រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីក្តៅក្រហាយ កាលពួកមនុស្សមានសេចក្តីក្តៅក្រហាយ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ ។ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយក្នុងការស្វែងរក រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីខ្វល់ខ្វាយ កាលពួកមនុស្សមាន

សេចក្តីខ្វល់ខ្វាយ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សុសុខំ** *បានដល់ សប្បាយ ។ ព្រះសាស្តាត្រាស់ពាក្យបរិយាយនេះថា ក្នុងមនុស្សទាំងឡាយដែលមានពៀរ ដោយពៀរ ៥ តថាគតមិនមានពៀរ មនុស្សទាំងឡាយ មានសេចក្តីក្តៅក្រហាយដោយកិលេស តថាគតឈ្មោះថាមិនមានការក្តៅក្រហាយ ព្រោះជាអ្នកមិនមានកិលេស ក្នុងមនុស្សទាំងឡាយដែលមានសេចក្តីខ្វល់ខ្វាយ ក្នុងការស្វែងរកកាមគុណ ៥ តថាគតឈ្មោះថាមិនមានការខ្វល់ខ្វាយ ព្រោះមិនមានការស្វែងរកនោះ ទើបជាអ្នកនៅជាសុខជាងពួកគ្រហស្ថ ដែលញុំាងការប្រព្រឹត្តទៅនៃជីវិតឲ្យកើតឡើង ដោយអំណាចនៃការកាត់ទីតជាដើម ឬជាងពួកបព្វជិតដែលញុំាងការប្រព្រឹត្តទៅនៃជីវិតឲ្យកើតឡើង ដោយអំណាចនៃវេជ្ជកម្មជាដើមហើយពោលថា តថាគតជាអ្នកនៅដោយសេចក្តីសុខ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង រម្ងាប់ជម្ងោរនៃពួកញាតិ ចប់

រឿង មារ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងស្រុកព្រាហ្មណ៍ឈ្មោះបញ្ចសាលា ទ្រង់ប្រារព្ធមារ ត្រាស់ព្រះធម្មទេសនានេះថា **សុសុខំ វត** ជាដើម ។

សេចក្តីពិស្តារថា ក្នុងថ្ងៃមួយ ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិមគ្គរបស់កុមារី ៥០០ ទើបយាងចូលទៅអាស្រ័យស្រុកនោះ ។ ក្មេងស្រីទាំងនោះ ក្នុងថ្ងៃនក្ខត្តឫក្សមួយ ទៅកាន់ស្ទឹងងូតហើយ ប្រជាប់តាក់តែងហើយ បែរមុខទៅកាន់ស្រុក ។ ព្រះសាស្តាយាងចូលទៅកាន់ស្រុកនោះ ត្រាច់ទៅដើម្បីបិណ្ឌបាត ។ មារចូលសណ្ឋិតក្នុងសរីរៈរបស់អ្នកស្រុកទាំងអស់ បានធ្វើឲ្យព្រះសាស្តាមិនបានសូម្បីត្រឹមតែបាយមួយវែក ឈរត្រង់ទ្វារស្រុក ទូល ព្រះសាស្តាដែលយាងចេញមកដោយបាត្រទទេថា បពិត្រសមណៈលោកបានបាយខ្លះទេ ព្រះសាស្តាត្រាស់ថា ម្នាលមារមានចិត្តបាប អ្នកបានធ្វើឲ្យតថាគតមិនបានភិក្ខាឬ មារពោលថា បពិត្រព្រះអង្គ បើដូច្នោះ សូមទ្រង់យាងចូលទៅម្តងទៀតចុះ ។

បានឮថា មារគិតយ៉ាងនេះថា បើសមណៈយាងចូលទៅទៀត អញនឹងចូលសណ្ឋិតក្នុងសរីរៈជនទាំងពួង ហើយទះដៃសើចចំអក ខាងមុខសមណៈនេះ ។ ខណៈនោះ ទារិកាទាំងនោះមកដល់ទ្វារស្រុក ឃើញព្រះសាស្តាហើយថ្វាយបង្គំ ឈរក្នុងចំណែកម្ខាង ចំណែកមារទូលព្រះសាស្តាថា បពិត្រព្រះអង្គ ទ្រង់មិនបានដំបាយ ជាបុគ្គលដែលសេចក្តីទុក្ខកើតអំពីការស្រេកឃ្លាន គ្របសង្កត់ខ្លះដែរឬ ។

ព្រះសាស្តាត្រាស់ថា មារមានចិត្តបាប ក្នុងថ្ងៃនេះ សូម្បីតថាគតមិនបាន អ្វីមួយ ក៏ទីឆ្ងាំងកាលឲ្យកន្ទងទៅដោយសុខដែលកើតអំពីបីតិប៉ុណ្ណោះ ដូច ព្រហ្មលោកជាន់អាភស្សរៈ ហើយត្រាស់ព្រះគាថានេះថា

សុសុខំ វត ជីវាម យេសង្ខោ នត្ថិ កិញ្ចនំ
បីតិភក្ខា ភវិស្សាម ទេវា អាភស្សរា យថា ។

យើងមិនមានកង្វល់ តែងរស់នៅជាសុខពិត (ព្រោះ)
យើងមានបីតិ ជាអាហារ ដូចពួកទេវតាជាន់អាភស្សរៈ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យេសង្ខោ** *សេចក្តីថា បណ្តាកិលេសជាតគ្រឿងកង្វល់ មានរាគៈជាដើម កិលេសជាត គ្រឿងកង្វល់ណាមួយ ដោយអត្ថថា គ្រឿងជាប់ជំពាក់ មិនមានដល់តថាគតពួកណា ។*

បទថា **បីតិភក្ខា** *សេចក្តីថា ពួកទេវតាជាន់អាភស្សរៈ ជាអ្នកមានបីតិជាភក្ខា ញុំាងកាលឲ្យកន្ទងទៅ យ៉ាងណា តថាគតក៏ដូច្នោះ ។*

ក្នុងកាលចប់ទេសនា ភ្លេងស្រីទាំង ៥០០ នោះ តាំងនៅក្នុងសោតាបត្តិផល ដូច្នេះឯង ។

រឿង មារ ចប់

រឿង បរាជ័យរបស់ព្រះចាធកោសល

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបរាជ័យរបស់ព្រះបាទកោសល ត្រាស់ព្រះធម្មទេសនានេះថា **ជយំ វេរំ** ជាដើម ។

បានឮថា ព្រះបាទកោសលនោះ ទ្រង់អាស្រ័យកាសិកគាម ប្បាំងជាមួយនឹងព្រះបាទអជាតសត្តុដែលជាម្ចាស់ក្មួយ ដែលព្រះបាទអជាតសត្តុនោះ ឲ្យចាញ់ ៣ ដង ក្នុងលើកទី ៣ ទ្រង់ព្រះតម្រិះថា អញមិនអាចញុំាងកូនក្មេងដែលមាត់មិនទាន់បាត់ជុំទឹកដោះឲ្យចាញ់បាន ប្រយោជន៍អ្វីដោយការរស់នៅរបស់អញ ព្រះរាជាទ្រង់អត់អាហារ ផ្ទំលើព្រះទែន ។ កាលនោះ ការប្រព្រឹត្តទៅរបស់ព្រះរាជា រីករាលពេញព្រះនគរ ។ ភិក្ខុទាំងឡាយ ក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ បានឮថា ព្រះរាជាទ្រង់អាស្រ័យកាសិក-គាម ដែលព្រះបាទអជាតសត្តុ ឲ្យបរាជ័យហើយអស់ ៣ ដង ឥឡូវនេះ ទ្រង់បរាជ័យត្រឡប់មកហើយ ទ្រង់មិនសោយអាហារ ផ្ទំលើព្រះទែន ដោយព្រះតម្រិះថា អញមិនអាចញុំាងក្មេង ដែលមាត់មិនទាន់បាត់ជុំទឹកដោះឲ្យចាញ់បាន ប្រយោជន៍អ្វីដោយការរស់នៅរបស់អញ ។

ព្រះសាស្តា ទ្រង់ស្តាប់កថារបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកឈ្នះរមែងមានពៀរ អ្នកចាញ់រមែងដេកជាទុក្ខ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ
ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។

បុគ្គលអ្នកឈ្នះតែងវេនទូវៀរ បុគ្គលអ្នកចាញ់តែងដេក ជាទុក្ខ ចំណែកបុគ្គលលះបង់ការឈ្នះ និងការចាញ់ចេញ ហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ជយំ** *សេចក្តីថា អ្នកឈ្នះជនដទៃ រមែងត្រឡប់បានទូវៀរ ។ បទថា* **បរាជិតោ** *សេចក្តីថា អ្នកដែលបុគ្គលដទៃឲ្យចាញ់ហើយ រមែងវេនទូវទុក្ខ គឺលំបាកក្នុងឥរិយាបថទាំងពួងនោះឯង ដោយគិតថា ក្នុងកាលណាហ្ន៎ អញអាចឃើញខ្នង (គឺដេញពីក្រោយ) របស់បច្ចាមិត្ត ។*

បទថា **ឧបសន្តោ** *សេចក្តីថា ព្រះខីណាស្រព ជាអ្នកមានកិលេស គឺរាគៈជាដើមខាងក្នុងស្ងប់ហើយ លះនូវការឈ្នះ និងការចាញ់បាន តែងនៅជាសុខ គឺរមែងនៅដោយសប្បាយក្នុងឥរិយាបថទាំងពួង ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង បរាជ័យរបស់ព្រះចាឧកោសល ចប់

រឿង ស្រីក្នុងត្រកូលណាមួយ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុមារិកាម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ឆត្តិ រាគសមោ អគ្គិ** *ជាដើម ។*

បានឮថា មាតារបស់កុមារិកានោះធ្លាប់អាវាហមង្គល និមន្តព្រះសាស្តាក្នុងថ្ងៃមង្គល ព្រះសាស្តាកាលភិក្ខុហែហមយាងទៅក្នុងទីនោះប្រថាប់គង់ហើយ ។ កូនក្រមុំនោះឯងត្រង់ទឹកជាដើម ដើម្បីពួកភិក្ខុដើរទៅដើរមក ស្វាមីរបស់នាងបានឈរសម្លឹងមើលហើយដោយអំណាចនៃរាគៈ កិលេសខាងក្នុងផ្សាយទ្បើង ត្រូវសេចក្តីមិនដឹងគ្របសង្កត់ហើយ ទើបមិនបម្រើព្រះសម្ពុទ្ធ មិនបម្រើព្រះមហាថេរៈ ៨០ តែបានធ្វើទុកក្នុងចិត្តថា អញនឹងលាដៃចាប់ស្រីនោះ ។ ព្រះសាស្តាទតឃើញអធ្យាស្រ័យរបស់បុរសនោះហើយ បានធ្វើមិនឲ្យបុរសនោះឃើញស្រីនោះ ។ បុរសនោះ មិនឃើញស្រីនោះ ទើបបានឈរសម្លឹងព្រះសាស្តា ក្នុងកាលដែលឈរនោះឯង ព្រះសាស្តាត្រាស់ថា នែកុមារ ឈ្មោះថា ភ្លើង ដូចគ្នានឹងភ្លើង គឺរាគៈ មិនមាន ឈ្មោះថា ទោស ដូចគ្នានឹងទោស គឺទោសៈ មិនមាន ឈ្មោះថា ទុក្ខ ដូចគ្នានឹងទុក្ខព្រោះថែរក្សាខន្ធ មិនមានសុខ ស្មើដោយព្រះនិព្វានមិនមានដូចគ្នា ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ឆត្តិ រាគសមោ អគ្គិ ឆត្តិ ទោសសមោ កលិ
ឆត្តិ ខន្ធសមា ទុក្ខា ឆត្តិ សន្តិបរំ សុខំ ។

ភ្លើង ស្មើដោយរាគៈ មិនមាន ទោសកំហុសស្មើដោយ
ទោសៈ មិនមាន ទុក្ខទាំងឡាយ ស្មើដោយខន្ធ មិនមាន

សុខ ក្រៅពីសេចក្តីស្ងប់មិនមាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឆត្តិ រាគសមោ** *សេចក្តីថា ឈ្មោះថា ភ្លើង ដទៃស្មើដោយរាគៈដែលមិនមានផ្សែង អណ្តាត រងើក នេះខាងក្នុងប៉ុណ្ណោះ ហើយទើបធ្វើគំនរផេះ រមែងមិនមាន ។*

បទថា **កលិ** *សេចក្តីថា សូម្បីទោសស្មើដោយទោសៈរមែងមិនមាន ។*

បទថា **ខន្ធសមា** *បានដល់ ស្មើដោយខន្ធទាំងឡាយ អធិប្បាយថា ឈ្មោះថា ទុក្ខដទៃ ដូចខន្ធទាំងឡាយដែលបុគ្គលបរិហារជាទុក្ខ មិនមាន ។*

ពីរបទថា **សន្តិបរំ សុខំ** *សេចក្តីថា សុខដទៃក្រៃលែងជាងព្រះនិព្វាន រមែងមិនមាន អធិប្បាយថា សេចក្តីពិត សុខដទៃក៏ជាសុខដូចគ្នា តែព្រះនិព្វានជាបរមសុខ ។*

ក្នុងកាលចប់ទេសនា កុមារ និងកុមារិកា តាំងនៅក្នុងសោតាបត្តិផល ហើយ ក្នុងខណៈនោះ ព្រះសាស្តាទ្រង់ត្រាស់អាការៈឲ្យជនទាំងពីរឃើញគ្នា ដូច្នេះឯង ។

រឿង ស្រីក្នុងត្រកូលណាមួយ ចប់

រឿង ឧបាសកម្នាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងអាឡវី ទ្រង់ប្រារព្ធឧបាសកម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ដិយឆ្ឆា** ជាដើម ។

សេចក្តីពិស្តារ ថ្ងៃមួយ ព្រះសាស្តាទ្រង់ប្រថាប់គង់ក្នុងព្រះគន្ធកុដិ ក្នុងជេតពន ទ្រង់ប្រមើលមើលលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញជនទុគ៌តម្នាក់ក្នុងក្រុងអាឡវី ទ្រង់ជ្រាបដល់ឧបនិស្សយសម្បត្តិរបស់បុរសនោះ មានភិក្ខុ ៥០០ ជាបរិវារយាងទៅកាន់ក្រុងអាឡវី ។ អ្នកក្រុងអាឡវីនិមន្តព្រះសាស្តា មនុស្សក្រីក្រម្នាក់បានឮថា ព្រះសាស្តាយាងមក ដូច្នេះហើយ បានតាំងចិត្តថា អញនឹងស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ក្នុងថ្ងៃនោះឯង គោមួយក្បាលរបស់បុរសនោះគេចទៅ គាត់គិតថា អញស្វែងរកគោ ឬស្តាប់ធម៌ហ្ន៎ ហើយគិតថា អញស្វែងរកគោឲ្យចូលហ្វូងហើយ សឹមទៅស្តាប់ធម៌ឯក្រោយ ដូច្នេះហើយ ចេញពីផ្ទះទាំងព្រលឹម អ្នកក្រុងអាឡវីនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យគង់ហើយអង្គាស ទទួលបាត្រដើម្បីប្រយោជន៍ដល់ការអនុមោទនា ។ ព្រះសាស្តាបាននៅស្ងៀម ដោយទ្រង់បំណងថា តថាគតអាស្រ័យបុគ្គលណាមកហើយ អស់ចម្ងាយផ្លូវ ៣០ យោជន៍ បុគ្គលនោះចូលកាន់ព្រៃដើម្បីស្វែងរកគោ កាលបុរសនោះមកហើយ ទើបតថាគតសម្តែងធម៌ ។ បុរសនោះឃើញគោក្នុងពេលថ្ងៃ កៀងគោហើយគិតថា របស់ដទៃមិនមាន អញនឹងធ្វើកិច្ចត្រឹមតែថ្វាយបង្គំព្រះសាស្តា សូម្បីត្រូវសេចក្តីឃ្លានគ្របសង្កត់ ក៏មិនដាក់ចិត្តដើម្បី

ទៅផ្ទះ ម្ដីម្នាមកកាន់សម្នាក់របស់ព្រះសាស្ដា ថ្វាយបង្គំព្រះសាស្ដាហើយ ឈរក្នុងចំណែកម្ខាង ។ ក្នុងពេលដែលឈរ ព្រះសាស្ដាត្រាស់នឹងបុគ្គលដែលខ្វល់ខ្វាយក្នុងទានថា របស់ណាមួយដែលសេសសល់អំពីភិក្ខុសង្ឃមានឬ អ្នកចាត់ចែងទានពោលថា បពិត្រព្រះអង្គ មានគ្រប់យ៉ាង ព្រះសាស្ដាត្រាស់ថា បើដូច្នោះ ចូរឲ្យបុរសនេះបរិភោគ ។

មនុស្សទាំងនោះ ឲ្យបុរសនោះអង្គុយក្នុងទីដែលព្រះសាស្ដាត្រាស់នោះឯង ហើយអង្គាសដោយយបបរ របស់ទំពា និងរបស់គួរបរិភោគដោយគោរព មនុស្សនោះបរិភោគភត្តស្រេច ខ្ចីរមាត់ហើយ ។ បានឮថា ឈ្មោះថាការរៀបចំភត្តរបស់ព្រះតថាគត រមែងមិនមានក្នុងទីដទៃ ក្នុងបិដក ៣ វៀរទីនេះចេញ ។ ចិត្តរបស់បុរសនោះ ដល់នូវការស្ងប់ហើយ ជាចិត្តមានឯកគ្គតា ។ គ្រានោះ ព្រះសាស្ដាត្រាស់អនុបុព្វីកថាហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយដល់បុរសនោះ លុះចប់ទេសនាបុរសនោះតាំងនៅក្នុងសោតាបត្តិផល ព្រះសាស្ដាក៏ទ្រង់ធ្វើអនុមោទនាហើយ ក្រោកចាកអាសនៈចៀសចេញទៅ ។ មហាជនតាមជូនព្រះសាស្ដាហើយ ក៏ត្រឡប់ ។

ភិក្ខុទាំងឡាយដែលទៅជាមួយព្រះសាស្ដានោះ ពោលទោសថា អាវុសោទាំងឡាយ ចូរពួកលោកមើលកម្មរបស់ព្រះសាស្ដាចុះ កម្មបែបនេះរមែងមិនមានក្នុងថ្ងៃទាំងឡាយដទៃ តែថ្ងៃនេះព្រះសាស្ដាទ្រង់អាស្រ័យមនុស្សម្នាក់ ប្រើឲ្យមនុស្សរៀបចំបបរជាដើមឲ្យហើយ ។ ព្រះសាស្ដាយាងត្រឡប់ប្រថាប់ឈរហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនិយាយអ្វី ទ្រង់ស្ដាប់សេចក្ដី

នោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតគិតថា តថាគតមកអស់ ចម្ងាយ ៣០ យោជន៍ ឃើញឧបនិស្ស័យរបស់ឧបាសកនោះហើយ ទើបមក ឧបាសកនោះ ស្រែកឃ្លានណាស់ ក្រោកឡើងអំពីព្រលឹម ហើយដើរកកេរ ក្នុងព្រៃ សូម្បីតថាគតសម្តែងធម៌ ក៏មិនអាចសម្រេចមគ្គផលបាន ព្រោះភាព ជាទុក្ខដែលកើតអំពីសេចក្តីស្រេកឃ្លាន ទើបបានធ្វើយ៉ាងនេះ ម្នាលភិក្ខុ ទាំងឡាយ ដ្បិតថា ឈ្មោះថា រោគ ដូចគ្នានឹងរោគ គឺការឃ្លាន មិនមាន ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

ជិឃច្ឆា បរមា រោគា　　សង្ខារា បរមា ទុក្ខា
ឯតំ ញត្វា យថាភូតំ　　និព្ពានំ បរមំ សុខំ ។

សេចក្តីស្រេកឃ្លាន ជារោគដ៏ក្រៃលែង សង្ខារទាំង-ទ្បាយ ជាទុក្ខយ៉ាងក្រៃលែង (អ្នកប្រាជ្ញ) ដឹងច្បាស់ សេចក្តីនុ៎ះតាមពិតហើយ (រមែងធ្វើឲ្យច្បាស់) នូវ ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បានព្រះគាថាថា **ជិឃច្ឆា បរមា រោគា** *សេចក្តី ថា ព្រោះរោគដទៃព្យាបាលតែម្តងក៏ជា ឬថា បុគ្គលរមែងព្យាបាលបានដោយ អំណាចនៃអង្គនោះៗ គឺម្តងម្កាល ចំណែកសេចក្តីស្រេកឃ្លាន ត្រូវព្យាបាល អស់កាលជានិច្ច ហេតុនោះទើបការឃ្លាននេះ ចាត់ជាកំពូលនៃរោគដ៏សេស ។*

ខន្ធ ៥ ឈ្មោះថា សង្ខារទាំងឡាយ ។ ពីរបទថា **ឯតំ ញត្វា** *សេចក្តីថា*

បណ្ឌិតជ្រាបអត្ថតាមសេចក្តីពិតថា រោគ ស្មើដោយការឃ្លាន មិនមាន ឈ្មោះថា ទុក្ខ ស្មើដោយការថែរក្សាខន្ធ មិនមាន ហើយធ្វើនូវព្រះនិព្វាន ឲ្យជាក់ច្បាស់ ។

បាទព្រះគាថាថា **និព្វានំ បរមំ សុខំ** សេចក្តីថា ព្រោះព្រះនិព្វាននោះជា សុខដ៏កំពូល គឺឧត្តមជាងសុខទាំងអស់ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ឧចាសកម្នាក់ ចប់

រឿង ព្រះចាធបសេនធិកោសល

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបាទបសេន-ទិកោសល ត្រាស់ព្រះធម្មទេសនានេះថា **អារោគ្យបរមា លាភា** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ ព្រះរាជាសោយព្រះក្រយាហារទាំង នាឡិនៃអង្ករ ដោយសូប: និងព្យញ្ជន:ដ៏សមគួរ ដល់ព្រះក្រយាហារនោះ ។ ថ្ងៃមួយ ព្រះរាជាសោយព្រះក្រយាហារព្រឹកហើយ មិនទាន់បន្ទោបង់សេចក្តី ស្រវឹងក្នុងភត្ត យាងទៅកាន់សម្នាក់របស់ព្រះសាស្តា មានព្រះរូបធាត់ ទ្រង់ ប្រែប្រួលទៅធ្វេងទៅស្តាំ ត្រូវងងុយគ្របសង្កត់ កាលមិនអាចផ្ទំត្រង់បាន

ទើបប្រថាប់គង់ក្នុងចំណែកម្ខាង ។ គ្រានោះ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា មហាបពិត្រ ទ្រង់មិនទាន់សម្រាកហើយយាងមកឬ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ យ៉ាងនោះឯង តាំងអំពីពេលបរិភោគហើយ ខ្ញុំព្រះអង្គមានទុក្ខច្រើន ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា មហាបពិត្រ ការបរិភោគច្រើនជាទុក្ខយ៉ាងនេះ ដូច្នេះហើយ ទ្រង់ទូន្មានដោយព្រះគាថានេះថា

ក្នុងកាលណា បុគ្គលជាអ្នកបរិភោគច្រើន ច្រើនដោយការងងុយ និងការដេកលក់ រសាប់រសល់ ដូចជ្រូកធំដែលគេចិញ្ចឹមដោយអាហារ ក្នុងកាលនោះ បុគ្គលនោះ រមែងដេកងក់ រមែងចូលបន្ទប់រឿយៗ ។

ហើយទ្រង់ត្រាស់បន្តថា មហាបពិត្រ ការបរិភោគភោជនតែល្មមប្រមាណ ទើបគួរ ព្រោះអ្នកបរិភោគល្មមប្រមាណ រមែងមានសេចក្តីសុខ កាលទ្រង់ទូន្មានឲ្យក្រៃលែង ទើបត្រាស់គាថានេះថា

បុគ្គលមានសតិគ្រប់កាល ដឹងប្រមាណក្នុងភោជន ដែលបានហើយនោះ មានវេទនាស្រាល អាហារដែលបរិភោគហើយ ចិញ្ចឹមអាយុ រលួយសន្សឹមៗ នៅ ។

ព្រះរាជាមិនអាចរៀនគាថាបាន តែត្រាស់នឹងកុយ្ហឈ្មោះសុទស្សនៈដែលឈរក្នុងទីជិតថា នែកុ ចូរអ្នករៀនគាថានេះ ។ សុទស្សនៈនោះ រៀនគាថានោះហើយ ទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងធ្វើដូចម្តេច កាលនោះព្រះសាស្តាត្រាស់ថា បើព្រះរាជាកំពុងសោយ អ្នកគប្បីពោលគាថា

នេះ ក្នុងកាលសោយពំនូតចុងក្រោយ ព្រះរាជាទ្រង់កំណត់អត្ថបានហើយ ទ្រង់ និងចោលដុំបាយនោះ ក្នុងកាលចម្អិនភត្តដើម្បីព្រះរាជា អ្នកគប្បីបន្ថយអង្ករ មានប្រមាណប៉ុណ្ណោះ ដោយការរាប់គ្រាប់អង្ករក្នុងដុំបាយនោះ ។ សុទស្សនៈ នោះទទួលថា សាធុព្រះអង្គ កាលព្រះរាជាសោយពេលព្រឹកក្តី ពេលល្ងាចក្តី ក៏ពោលគាថានោះឡើងក្នុងកាលសោយពំនូតចុងក្រោយ ហើយឲ្យបន្ថយអង្ករ ដោយការរាប់គ្រាប់អង្ករ ក្នុងដុំបាយដែលព្រះរាជាទ្រង់ចោះបង់ ។ ព្រះរាជា ទ្រង់ស្តាប់គាថារបស់សុទស្សនៈនោះហើយ ទ្រង់ត្រាស់ឲ្យព្រះរាជទានទ្រព្យម្នាង ១ ពាន់ ។

ក្នុងសម័យដទៃទៀត ព្រះរាជាទ្រង់តាំងនៅក្នុងកាជន៍ មានព្រះក្រយាហារ នៃអង្ករត្រឹមតែមួយនាឡិយ៉ាងច្រើន ទ្រង់ដល់នូវសេចក្តីសុខហើយ មានព្រះ សរីរៈស្រាល ។ សម័យថ្ងៃមួយ ព្រះរាជាយាងទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយទូលថា បពិត្រព្រះអង្គ ឥឡូវនេះ សេចក្តីសុខកើត ដល់ខ្ញុំព្រះអង្គហើយ ខ្ញុំព្រះអង្គអាចដេញចាប់ម្រឹគក៏បាន សេះក៏បាន កាលមុន ខ្ញុំព្រះអង្គមានការច្បាំងជាមួយក្មួយ ឥឡូវនេះ ខ្ញុំព្រះអង្គឲ្យធីតាឈ្មោះវជិរកុមារី ដល់ក្មួយហើយឲ្យស្រុកនោះ ធ្វើឲ្យជាតម្លៃទឹកសម្រាប់ងូតរបស់ធីតានោះឯង ។ ការឈ្លោះគ្នានឹងក្មួយស្ងប់ហើយ សុខកើតហើយដល់ខ្ញុំព្រះអង្គ ព្រោះហេតុនោះ សូម្បីកែវមណីរបស់ព្រះបាទកុសរាជ ដែលបាត់ទៅហើយ ក្នុងវាំងរបស់ខ្ញុំ ព្រះអង្គ កាលពីថ្ងៃមុន ឥឡូវនេះ កែវមណីនោះ មកកាន់កណ្តាប់ដៃរបស់ខ្ញុំ ព្រះអង្គហើយ សេចក្តីសុខពិតកើតហើយដល់ខ្ញុំព្រះអង្គ ព្រោះហេតុនេះ ខ្ញុំ

ព្រះអង្គប្រាថ្នាភាពស្និទ្ធស្នាលជាមួយសាវ័ករបស់ព្រះអង្គ ទើបធ្វើធីតានៃញាតិរបស់ព្រះអង្គទុកក្នុងវាំង សេចក្តីសុខកើតហើយដល់ខ្ញុំព្រះអង្គ ព្រោះហេតុនេះ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ឈ្មោះថា ការមិនមានរោគ ជាលាភដ៏ក្រៃលែង ទ្រព្យស្មើគ្មានឹងការសន្តោស ដោយវត្ថុដែលខ្លួនបានហើយមិនមាន ឈ្មោះថា ញាតិ ដូចគ្មានឹងបុគ្គលអ្នកស្និទ្ធស្នាល មិនមាន ឈ្មោះថា សេចក្តីសុខក្រៃលែង ស្មើដោយព្រះនិព្វាន មិនមាន ទើបត្រាស់ព្រះគាថានេះថា

អារោគ្យបរមា លាភា សន្តុដ្ឋិបរមំ ធនំ
វិស្សាសបរមា ញាតិ និព្វានំ បរមំ សុខំ ។

លាភ មានការមិនមានរោគជាយ៉ាងក្រៃលែង ទ្រព្យ មានសេចក្តីសន្តោសជាយ៉ាងក្រៃលែង ញាតិ មានសេចក្តីស្និទ្ធស្នាលជាយ៉ាងក្រៃលែង ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អារោគ្យបរមា** សេចក្តីថា មានភាពជាបុគ្គលមិនមានរោគយ៉ាងក្រៃលែង ពិតហើយ លាភទាំងឡាយ មានដល់បុគ្គលមានរោគ មិនចាត់ជាលាភ ព្រោះដូច្នោះ ទើបលាភទាំងពួង មកដល់បុគ្គលមិនមានរោគប៉ុណ្ណោះ ហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **អារោគ្យបរមា លាភា ។**

បាទព្រះគាថាថា **សន្តុដ្ឋិបរមំ ធនំ** សេចក្តីថា ការៈ គឺការត្រេកអរដោយ

វត្ថុដែលខ្លួនបានហើយ ដែលជារបស់មាននៃខ្លួន របស់គ្រហស្ថ ឬបព្វជិតនោះ ឯង ឈ្មោះថា សន្តោស សន្តោសនោះជាទ្រព្យដ៏ក្រៃលែងជាងទ្រព្យដ៏សេស ។

បានព្រះគាថាថា **វិស្សាសបរមា ញាតី** *សេចក្តីថា មាតាក្តី បិតាក្តី លើទុកចុះ មិនមានការស្និទ្ធស្នាលជាមួយបុគ្គលណា បុគ្គលនោះមិនមែនជាញាតិ តែមានការស្និទ្ធស្នាលជាមួយបុគ្គលណា ទោះបីបុគ្គលនោះមិនជាប់ខ្សែស្រឡាយ ឈ្មោះថា ជាញាតិយ៉ាងក្រៃលែង គឺយ៉ាងខ្ពង់ខ្ពស់ ហេតុនោះ ទើបព្រះសាស្តាត្រាស់ថា* **វិស្សាសបរមា ញាតី ។**

ម្យ៉ាងទៀត ឈ្មោះថា សេចក្តីសុខ ស្មើដោយព្រះនិព្វាន មិនមានហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **និព្វានំ បរមំ សុខំ ។**

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះចាតុបសេនដិកោសល ចប់

រឿង ព្រះតិស្សត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងនគរវេសាលី ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **បរិវេករសំ** ជាដើម ។

សេចក្តីពិស្តារថា កាលព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នៅ ៤ ខែទៀតបន្ទាប់អំពីនេះ តថាគតនឹងបរិនិព្វាន ។ ភិក្ខុ ៧០០ ក្នុងសម្នាក់របស់ព្រះសាស្តា ជល់នូវការសង្វេគហើយ ធម្មសង្វេគកើតឡើងជល់ព្រះខីណាស្រពទាំងឡាយ ភិក្ខុបុថុជ្ជនទាំងឡាយ មិនអាចទប់ទឹកភ្នែកបាន ។ ភិក្ខុទាំងឡាយជាពួកៗ ប្រឹក្សាគ្នាថា ពួកយើងនឹងធ្វើដូចម្តេចហ្ន៎ កាលនោះ ភិក្ខុមួយរូបឈ្មោះតិស្សៈ គិតថា បានឮថា ព្រះសាស្តានឹងបរិនិព្វានដោយកន្លងទៅ ៤ ខែ[1] ឯអាត្មាអញ ជាអ្នកមានរាគៈមិនទាន់ជ្រាសទៅ កាលព្រះសាស្តាមានព្រះជន្មនៅនោះឯង អញគួរកាន់យកអរហត្ត ហើយទើបនៅម្នាក់ឯងប៉ុណ្ណោះ ក្នុងឥរិយាបថ ៤ ។ ការទៅកាន់សម្នាក់របស់ភិក្ខុទាំងឡាយ ឬមិនបានសន្ទនាប្រាស្រ័យជាមួយបុគ្គលណាមួយទេ ។ កាលនោះ ភិក្ខុទាំងឡាយពោលថា អាវុសោតិស្សៈ ហេតុអ្វី ទើបលោកធ្វើយ៉ាងនេះ ។ លោកមិនស្តាប់ពាក្យរបស់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះ ក្រាបទូលការប្រព្រឹត្តទៅនោះ ជល់ព្រះសាស្តា ដោយទូលថា បពិត្រព្រះអង្គ តិស្សៈមិនស្រឡាញ់ក្នុងព្រះតថាគត ព្រះសាស្តាត្រាស់ឲ្យហៅលោកមកហើយ សួរថា តិស្សៈ ហេតុអ្វី ទើបអ្នកធ្វើ

១- រាប់ដោយចំពោះតែ ៣ ខែ ប៉ុណ្ណោះ តែក្នុងទីនេះ លោករាប់យកក្បាលខែ ទើបជា ៤ ខែ ។

យ៉ាងនេះ កាលលោកក្រាបទូលបំណងរបស់ខ្លួនហើយ ប្រទានសាធុការថា សាធុ តិស្សៈ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសេចក្តីស្រឡាញ់ក្នុងតថាគត ចូរជាបុគ្គលដូចតិស្សៈចុះ សូម្បីបុគ្គលធ្វើការបូជាដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម មិនឈ្មោះថា បូជាតថាគតឡើយ តែបុគ្គលដែលបដិបត្តិធម៌សមគួរដល់ធម៌នោះឯង ឈ្មោះថា បូជាតថាគត ហើយត្រាស់ព្រះគាថានេះថា

បវិវេការសំ បិត្វា រសំ ឧបសមស្ស ច
និទ្ទរោ ហោតិ និប្បាបោ ធម្មបីតិរសំ បិវំ ។

ភិក្ខុផឹករសវិវេកផង រសព្រះនិព្វានជាទីរម្ងាប់កិលេសផង ផឹករសបីតិដែលកើតអំពីធម៌ផង ទើបជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ មិនមានសេចក្តីសៅហ្មងឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បវិវេការសំ** *សេចក្តីថា នូវរសដែលកើតហើយអំពីវិវេក អធិប្បាយថា នូវសេចក្តីសុខដែលកើតអំពីការនៅម្នាក់ឯង ។*

បទថា **បិត្វា** *សេចក្តីថា ផឹកហើយដោយអំណាចនៃភាពជាបុគ្គលធ្វើកិច្ចដែលកំណត់ដឹងទុក្ខជាដើម ធ្វើឲ្យជាក់ច្បាស់ដោយភាពជាអារម្មណ៍ ។*

បាទព្រះគាថាថា **រសំ ឧបសមស្ស ច** *សេចក្តីថា ផឹកហើយនូវរសនៃព្រះនិព្វាន ដែលចូលទៅស្ងប់កិលេស ។*

ពីរបទថា **និទ្ទរោ ហោតិ** *សេចក្តីថា ភិក្ខុដែលជាព្រះខីណាស្រពឈ្មោះ*

ថា ជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ និងមិនមានបាប ព្រោះការមិនមាន នៃសេចក្តីក្រវល់ក្រវាយ គឺរាគៈជាដើមខាងក្នុង ព្រោះផឹកនូវសេទាំងពីរយ៉ាង នោះ ។

ពីរបទថា **រសំ បិវំ** សេចក្តីថា កាលរសនៃបីតិ ដែលកើតឡើងហើយ ដោយអំណាចនៃលោកុត្តរធម៌ ៩ រមែងជាបុគ្គលមិនមានសេចក្តីក្រវល់ក្រវាយ និងមិនមានបាប ។

ក្នុងកាលចប់ទេសនា ព្រះតិស្សត្ថេរសម្រេចអរហត្តហើយ ទេសនាមាន ប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

រឿង ព្រះតិស្សត្ថេរ ចប់

រឿង សក្កទេវរាជ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវេឡុវគ្រាម ទ្រង់ប្រារព្ធសក្កទេវរាជ ត្រាស់ព្រះធម្មទេសនានេះថា **សាធុ ទស្សនំ** ជាដើម ។

សេចក្តីពិស្តារថា សក្កទេវរាជទ្រង់ជ្រាបភាពដែលអាពាធ មានការស្ទុះ ទៅនៃព្រះលោហិតជាសមុដ្ឋាន កើតឡើងដល់ព្រះតថាគត ក្នុងកាលទ្រង់ជាក់ អាយុសង្ខារហើយ ទ្រង់ព្រះតម្រិះថា ការដែលអញទៅកាន់សម្នាក់របស់ព្រះ សាស្តា ហើយធ្វើគិលានុបដ្ឋាករមែងគួរ ទ្រង់លះអត្តភាពប្រមាណ ៣ គាវុត

ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ទ្រង់ច្របាច់ព្រះបាទដោយព្រះហស្ត ទាំងពីរ ។ កាលនោះព្រះសាស្តាត្រាស់នឹងសក្កទេវរាជនោះថា អ្នកជានរណា សក្កទេវរាជត្រាស់ថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គជាសក្កៈ ព្រះសាស្តាត្រាស់ថា អ្នកមកធ្វើអ្វី សក្កទេវរាជត្រាស់ថា បពិត្រព្រះអង្គ មកដើម្បីបម្រើទ្រង់ប្រយ៊ួន ព្រះសាស្តាត្រាស់ថា សក្កៈ ក្លិនរបស់មនុស្សរមែងច្រោជកដល់ទេវតាទាំង-ឡាយ ដូចសាកសពដែលចងត្រង់ក ចម្ងាយ ១០០ យោជន៍ឡើងទៅលើ ចូរអ្នកទៅចុះ ភិក្ខុដែលជាគិលានុបដ្ឋាករបស់តថាគតមាន ។

សក្កទេវរាជក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គតាំងនៅក្នុងទីបំផុត ៨៤០០០ យោជន៍ ស្រូបនូវក្លិនសីលរបស់ទ្រង់មកហើយ ខ្ញុំព្រះអង្គនេះឯង នឹងបម្រើ មិនឲ្យបុគ្គលដទៃពាល់ត្រូវកាជនៈព្រះឧច្ចារៈរបស់ព្រះសាស្តាសូម្បី ដោយដៃ ទ្រង់ទូលលើព្រះសីសៈនោះឯងនាំទៅ មិនបានធ្វើសូម្បីអាការជ្រួញ ចិញ្ចើមស្រោពនព្រះភក្ត្រ បាននាំទៅដូចកាជនៈដាក់គ្រឿងក្រអូប សក្កៈបដិបត្តិ ព្រះសាស្តាយ៉ាងនេះហើយ ក្នុងកាលព្រះសាស្តាមានសេចក្តីសុខនោះឯង ទើបចៀសចេញទៅ ។

ភិក្ខុប្រជុំគ្នាពោលថា គួរសើរសើរហ្ន៎ សក្កទេវរាជមានសេចក្តីស្នេហាក្នុង ព្រះសាស្តា ទ្រង់លះទិព្វសម្បត្តិបែបនេះ ទ្រង់នាំកាជនៈសម្រាប់រងព្រះឧច្ចារៈ របស់ព្រះសាស្តាទៅដោយសិរសា គឺត្បូង ទ្រង់មិនធ្វើអាការត្រឹមជ្រួញចិញ្ចើម ស្រោពនព្រះភក្ត្រឡើយ ដូចបុរសនាំកាជនៈ ដែលពេញដោយគ្រឿងក្រអូប ចេញទៅដូច្នោះ ទ្រង់បានធ្វើឧបដ្ឋាកហើយ ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់

ភិក្ខុទាំងនោះហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសន្ទនាគ្នាអំពីរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ រឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលសក្កទេវរាជធ្វើសេចក្តីស្រឡាញ់ក្នុងតថាគតនោះ មិនជាអស្ចារ្យទេ ព្រោះសក្កទេវរាជនេះស្តាប់ធម្មទេសនាហើយ បានជាសោតាបន្ន លះនូវភាពជាសក្កៈចាស់ជរា ដល់នូវភាពជាសក្កៈកំលោះ ព្រោះអាស្រ័យតថាគត ពិតហើយ កាលសក្កៈគង់កណ្តាលបរិស័ទ ក្នុងឥន្ទសាលគុហា ក្នុងកាលខ្លួនត្រូវមរណភ័យគំរាម ធ្វើគន្ធព្វទេវបុត្រឈ្មោះបញ្ចសិខៈអំពីខាងមុខយាងមក តថាគតបានពោលថា

ម្នាលស្តេចវាសវៈ សូមទ្រង់សួរបញ្ហាជាមួយនឹងតថាគត ទ្រង់ជ្រាបថ្នាបញ្ហាឯណានីមួយ ក្នុងព្រះហឫទ័យ តថាគតនឹងធ្វើបំផុតនៃបញ្ហានោះៗរបស់ទ្រង់ជានពិត ។

កាលបន្ទោបង់នូវសេចក្តីសង្ស័យរបស់សក្កៈ ទើបសម្តែងធម្មទេសនាក្នុងកាលចប់ទេសនា ធម្មាភិសមយមានដល់សត្វទាំងឡាយ ប្រមាណ ១៤ កោដិ ចំណែកសក្កទេវរាជ សម្រេចសោតាបត្តិផលក្នុងអាសនៈនោះឯង ជាសក្កៈកំលោះហើយ តថាគតមានឧបការៈច្រើនដល់សក្កៈនោះ ដោយប្រការយ៉ាងនេះ ឈ្មោះថាសេចក្តីស្នេហាក្នុងតថាគតរបស់សក្កទេវរាជនោះ មិនគួរអស្ចារ្យ ម្នាលភិក្ខុទាំងឡាយ ការជួបការឃើញពួកអរិយបុគ្គលក្តី ការនៅក្នុងទីជាមួយអរិយបុគ្គលក្តី នាំឲ្យកើតនូវសុខ តែកិច្ចបែបនោះជាមួយពួកបុគ្គលពាល ឲ្យកើតទុក្ខទាំងអស់ ហើយទើបទ្រង់ភាសិតគាថាទាំងនេះថា

សាធុ ឧស្សនមរិយានំ សន្ទិវាសោ សធា សុខោ
អឧស្សនេន ពាលានំ និច្ចមេវ សុខី សិយា
ពាលសង្គតចារី ហិ ឧីយមទ្ធាន សោចតិ
ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វធា
ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ
តស្មា ហិ
ធីរញ្ច បញ្ញញ្ច ពហុស្សុតញ្ច ធោរយ្ហសីលំ វតវន្តមរិយំ
តំ តាទិសំ សប្បុរិសំ សុមេធំ ភជេថ នក្ខត្តបថំវ ចន្ទិមា

ការជួបប្រទះព្រះអរិយបុគ្គលទាំងឡាយជាការល្អ ការនៅរួមជាមួយព្រះអរិយបុគ្គលទាំងឡាយ ជាហេតុឲ្យកើតសេចក្តីសុខសព្វកាល បុគ្គលគប្បីមានសេចក្តីសុខអស់កាលជានិច្ចបាន ព្រោះមិនជួបប្រទះបុគ្គលពាលទាំងឡាយ ។ បុគ្គលអ្នកប្រព្រឹត្តសមគប់ដោយជនពាល រមែងសោកស្តាយអស់កាលយូរអង្វែង ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខសព្វកាល ដូចការនៅរួមជាមួយនឹងសត្រូវ ចំណែកខាងការនៅរួមនឹងធីរជន រមែងជាសុខ ដូចការជួបជុំនៃញាតិទាំងឡាយ ព្រោះហេតុនោះឯង បុគ្គលគួរសេពគប់សប្បុរស ជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីចេះដឹងច្រើនផង មានកិរិយានាំទៅនូវធុរៈជាប្រក្រតីផង មានសីលវត្ត និងធុតង្គផង

ជាអ្នកឆ្ងាយចាកកិលេសផង មានបញ្ញាល្អផង ប្រាកដដូច្នោះៗ ឲ្យដូចព្រះចន្ទគប់នូវផ្លូវនក្ខត្តឫក្ស ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សាធុ** *បានដល់ ជាការញុំាងប្រយោជន៍ឲ្យសម្រេច គឺជាការស្អាត បានដល់ កម្មដែលចម្រើន ។*

បទថា **សន្និវាសោ** *សេចក្តីថា មិនមែនត្រឹមតែការជួបព្រះអរិយបុគ្គលទាំងនោះតែម្យ៉ាងប៉ុណ្ណោះឡើយ ដល់នូវការកើត គឺជាខ្លួនថា ការអង្គុយរួមជាមួយព្រះអរិយបុគ្គលទាំងនោះក្នុងទីជាមួយគ្នាក្តី ការកើត គឺការបាននូវការធ្វើវត្ត និងបជិវត្តដល់ព្រះអរិយបុគ្គលទាំងនោះក្តី ជាការល្អដោយពិត ។*

បទថា **ពាលសង្គតចារី ហិ** *សេចក្តីថា ព្រោះបុគ្គលណាត្រាច់រួមជាមួយបុគ្គលពាល ។*

ប្រជុំបទថា **ឆិយមទ្ធានំ** *ជាដើម សេចក្តីថា បុគ្គលនោះត្រូវសម្លាញ់ពាលពោលថា ចូរអ្នកមក ព្រោះខ្ញុំនឹងធ្វើកម្ម មានការកាត់ទី-តជាដើម ជាអ្នករួមឆន្ទៈនឹងសម្លាញ់ពាលនោះ ធ្វើកម្មទាំងនោះ ត្រូវព្រះរាជាដាក់កម្មករណៈច្រើនយ៉ាង មានកាត់ដៃជាដើមឈ្មោះថា រមែងសោយសោកអស់កាលយូរ ។*

បទថា **សព្ភេ** *សេចក្តីថា ឈ្មោះថា ការនៅក្នុងទីជាមួយគ្នា ជាមួយសត្រូវដែលកាន់ជាវក្តី ពួកសត្វកាចមានអាសិរពិសជាដើមក្តី ឲ្យកើតទុក្ខជានិច្ច យ៉ាងណា ការនៅរួមជាមួយបុគ្គលពាល ក៏ដូច្នោះដូចគ្នា ។*

ក្នុងបាទព្រះគាថាថា **ធីរោ ច សុខសំវាសោ** *មានវិគ្គហៈថា ការនៅរួម

ដោយអ្នកប្រាជ្ញនោះ ជាសុខ ហេតុនោះ ទើបឈ្មោះថា មានការនៅរួមឲ្យកើតសុខ អធិប្បាយថា ការនៅក្នុងទីជាមួយគ្នាដោយបណ្ឌិត នាំឲ្យកើតសុខ ។ សួរថា ការនៅរួមដោយអ្នកប្រាជ្ញឲ្យកើតសុខដូចម្តេច ឆ្លើយថា ដូចសមាគមនៃពួកញាតិដូច្នោះ អធិប្បាយថា ការសមាគមនៃពួកញាតិដែលជាទីស្រឡាញ់ឲ្យកើតសុខ យ៉ាងណា ការនៅរួមដោយអ្នកប្រាជ្ញ ឲ្យកើតសុខដូច្នោះ ។

បទថា **តស្មា** *សេចក្តីថា ព្រោះការនៅរួមជាមួយបុគ្គលពាល ឲ្យកើតទុក្ខ ជាមួយបណ្ឌិតឲ្យកើតសុខដូច្នោះឯង ចូរអ្នកទាំងឡាយគប់រក គឺចូលទៅអង្គុយជិតលោកដែលជាអ្នកប្រាជ្ញ សម្បូរដោយបញ្ញា និងបុគ្គលសម្បូរដោយបញ្ញា ជាលោកិយ និងលោកុត្តរ ឈ្មោះថា ជាអ្នកមានបញ្ញា និងជាអ្នកជាប់ព្រមដោយអាគម និងអធិគម ដែលឈ្មោះថាពហូសូត ដែលឈ្មោះថានាំធុរៈទៅជាប្រក្រតី ព្រោះភាពជាបុគ្គលមានការនាំធុរៈទៅជាប្រក្រតី គឺឲ្យដល់អរហត្ត បុគ្គលឈ្មោះថាមានវត្ត ព្រោះវត្ត គឺសីល និងវត្ត គឺធុតង្គ ដែលឈ្មោះថា អរិយៈ ព្រោះភាពជាបុគ្គលឆ្ងាយចាកគំនរកិលេស បុគ្គលដែលជាសប្បុរស ជាអ្នកមានបញ្ញាស្អាតបែបនោះ ដូចព្រះចន្ទបញ្ចោញរស្មីក្នុងអាកាសដែលហៅថាគន្ធងនៃកុត្តបូក្ស ដែលមិនអាប់អួ ដូច្នោះ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងសក្កនេវរាជ ចប់

សុខវគ្គទី ១៥ ចប់

សុត្តន្តបិដក

ធម្មបទគាថា បិយវគ្គទី ១៦

[២៦] បុគ្គលកាលប្រកបខ្លួនទុក ក្នុងអំពើដែលមិនគួរប្រកប មិនប្រកបខ្លួនក្នុងអំពើដែលគួរប្រកប លះបង់ប្រយោជន៍ចេញហើយ កាន់យកតាមគាប់ចិត្ត រមែងស្រឡាញ់បុគ្គលអ្នកប្រកបតាមខ្លួន ។ កុំគប់រកសត្វ និងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ ក្នុងកាលណាៗឡើយ ព្រោះថា ការមិនជួបប្រសព្វសត្វ និងសង្ខារជាទីស្រឡាញ់ក្តី ការជួបប្រសព្វសត្វ និងសង្ខារមិនជាទីស្រឡាញ់ក្តី ជាហេតុនាំមកនូវទុក្ខ ។

ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វ និងសង្ខារ ឲ្យជាទីស្រឡាញ់ ព្រោះការព្រាត់ប្រាសចាកសត្វ និងសង្ខារ ជាទីស្រឡាញ់ ជាសភាពអាក្រក់ ការស្រឡាញ់ និងការស្អប់ មិនមានដល់ពួកជនណា កិលេសគ្រឿងចាក់ស្រែះទាំងឡាយ តែងមិនមានដល់ពួកជននោះ ។

សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោក ក៏លែងមាន ភ័យ នឹងមានមកពីណា ។

សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

សេចក្តីសោកកើតអំពីតម្រេក ភ័យកើតអំពីតម្រេក កាលបើរួចស្រឡះចាកតម្រេកហើយ សេចក្តីសោក ក៏លែងមាន ភ័យ នឹងមានមកពីណា ។

សេចក្តីសោកកើតអំពីកាម ភ័យកើតអំពីកាម កាលបើរួចស្រឡះចាកកាមហើយ សេចក្តីសោក ក៏លែងមាន ភ័យ នឹងមានមកពីណា ។

សេចក្តីសោកកើតអំពីតណ្ហា ភ័យកើតអំពីតណ្ហា កាលបើរួចស្រឡះចាកតណ្ហាហើយ សេចក្តីសោក ក៏លែងមាន ភ័យ នឹងមានមកពីណា ។ ជនតែងធ្វើបុគ្គលដែលបរិបូណ៌ ដោយសីល និងការឃើញត្រូវ ស្ថិតនៅក្នុងធម៌ពោលសច្ចធម៌ជាប្រក្រតី ធ្វើកម្មជារបស់ខ្លួននោះ ឲ្យជាទីស្រឡាញ់ ។

បុគ្គលអ្នកមានសេចក្តីប្រាថ្នា ចំពោះព្រះនិព្វាន ដែលគេនិយាយប្រាប់គ្នាមិនបានផង ជាអ្នកមានមគ្គចិត្ត និងផលចិត្ត (ខាងក្រោម) ប៉ះពាល់ហើយផង មានចិត្តមិនប្រតិព័ទ្ធក្នុងកាមផង តថាគតហៅថា ជាអ្នកមានខ្សែមគ្គប្រព្រឹត្តទៅ ក្នុងខាងលើ ។

ពួកញាតិក្តី មិត្តក្តី សម្លាញ់ក្តី រមែងត្រេកអរនឹងបុរសដែលឃ្លាតគ្នាអស់កាលយូរ មកអំពីចម្ងាយដោយសួស្តី មកដល់ហើយ យ៉ាងណាមិញ បុណ្យទាំងឡាយ តែងទទួលបុគ្គលដែលបានធ្វើបុណ្យ ច្យុតអំពីមនុស្សលោកនេះ ទៅកាន់លោកខាងមុខ ដូចញាតិទាំងឡាយ ទទួលបុរសជាទីស្រឡាញ់ទើបមកដល់ ដូច្នោះឯង ។

បិយវគ្គទី ១៦ ចប់

អដ្ឋកថា

បិយវគ្គទី ១៦

រឿង បព្វជិត ៣ រូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបព្វជិត ៣ រូប ត្រាស់ព្រះធម្មទេសនានេះថា **អយោគេ យុញ្ជមត្តានំ** *ជាដើម ។*

បានឮថា មាតាបិតាក្នុងត្រកូលក្នុងក្រុងសាវត្ថី មានបុត្រតូចម្នាក់ប៉ុណ្ណោះ ជាទីស្រឡាញ់ជាទីគាប់ចិត្ត ។ ថ្ងៃមួយ បុត្រតូចនោះស្តាប់ធម្មកថារបស់ពួកភិក្ខុដែលនិមន្តមកក្នុងផ្ទះធ្វើអនុមោទនាចង់បួស ទើបសូមបួសនឹងមាតាបិតា ។ ឪពុកម្តាយមិនអនុញ្ញាត កាលនោះ កុលបុត្រនោះមានការគិតថា កាលឪពុកម្តាយមិនឃើញនោះឯង អញនឹងចេញទៅខាងក្រៅ ហើយបួស តមក បិតារបស់កុមារនោះ កាលចេញទៅខាងក្រៅ បានប្រាប់នឹងមាតាថា គប្បីរក្សាបុត្រតូចនោះ ។ មាតាកាលចេញទៅខាងក្រៅ ក៏ប្រគល់ឲ្យបិតាដូចគ្នា ។

សម័យក្រោយមក កាលបិតារបស់កុមារនោះទៅខាងក្រៅ មាតាតាំងចិត្តថានឹងរក្សាបុត្រ ផ្អែកទ្វារម្ខាង ម្ខាងទៀតយកជើងទាំងពីរខាង ហើយអង្គុយចុះត្រង់ផែនដីខារអាំបោះ ។

កុមារគិតថា អញនឹងបញ្ឆោតមាតានេះហើយគេចទៅដូច្នេះហើយ ពោល

ថា បពិត្រអ្នកម៉ែ៎ ចៀសផ្លូវខ្ញុំបន្តិច ខ្ញុំនឹងបន្ទោបង់ឧច្ចារៈ កាលមាតានោះដកជើងហើយក៏ចេញទៅ លួចរត់ទៅកាន់វិហារដោយរហ័ស ចូលទៅរកភិក្ខុទាំងឡាយអង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បំបួសខ្ញុំចុះ ហើយបួសក្នុងសម្នាក់របស់ភិក្ខុនោះឯង ។

លំដាប់នោះ ឪពុករបស់កុលបុត្រនោះត្រឡប់មកហើយសួរម្តាយថា កូនរបស់យើងទៅណា មាតាឆ្លើយថា អើ អ្នក អម្បាញ់មិញ នៅទីនេះឯង បិតានោះ ក៏រកមើលដើម្បីដឹងថា កូនរបស់អញនៅទីណាហ្ន៎ មិនឃើញហើយ គិតថា កូនរបស់អញទៅវិហារ ទើបទៅកាន់វិហារហើយ ឃើញបុត្របួសហើយ ទ្រហោយំ ពោលថា នែបា ហេតុអ្វី ទើបធ្វើឲ្យពួកយើងវិនាស ដូច្នេះហើយ គិតថា បើកូនរបស់យើងបួសហើយ ឥឡូវនេះ យើងនឹងធ្វើអ្វីក្នុងផ្ទះ ដូច្នេះខ្លួនឯងក៏បួសហើយ ក្នុងសម្នាក់របស់ភិក្ខុទាំងឡាយ ។

លំដាប់នោះ មាតារបស់កុលបុត្រគិតថា ហេតុអ្វីហ្ន៎ កូន និងប្តីរបស់អញ ទើបយឺតយូរ ។ ទៅកាន់វិហារបួសហើយទេដឹង សម្លឹងរកជនទាំងពីរនោះបណ្តើរ ទៅវិហារបណ្តើរ ឃើញជនទាំងពីរបួសហើយ គិតថា ប្រយោជន៍អ្វីដោយផ្ទះ អញក្នុងកាលនៃជនទាំងពីរនេះបួសហើយ សូម្បីខ្លួនឯងក៏ទៅកាន់សម្នាក់ភិក្ខុនី បួសហើយ ។

ជនទាំងបីបួសហើយ មិនអាចបែកគ្នាបាន អង្គុយសន្ទនារួមគ្នាឲ្យថ្លៃកន្ទងទៅទាំងក្នុងវិហារ ទាំងក្នុងសម្នាក់ភិក្ខុនី ហេតុនោះ ទាំងពួកភិក្ខុ ទាំងពួកភិក្ខុនី ទើបត្រូវបៀតបៀនហើយ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយក្រាបទូលនូវការធ្វើរបស់

ជនទាំងបីនោះដល់ព្រះសាស្តា ។

ព្រះសាស្តា ត្រាស់ឲ្យហៅជនទាំងបីមកហើយ ត្រាស់សួរថា បានឮថា ពួកអ្នកធ្វើយ៉ាងនោះពិតឬ កាលជនទាំងនោះទូលថា ពិត ត្រាស់សួរថា ហេតុអ្វី ទើបពួកអ្នកធ្វើយ៉ាងនោះ ព្រោះថា នុ៎ះមិនមែនសេចក្តីព្យាយាមរបស់ពួកបព្វជិត ។

ជនទាំងបីក្រាបទូលថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គមិនអាចនៅបែកគ្នា ។ ព្រះសាស្តាត្រាស់ថា ឈ្មោះថា ការធ្វើយ៉ាងនេះ ចាប់តាំងពីកាលនៃខ្ជូនបួស ហើយមិនគួរ ព្រោះថា ការមិនឃើញសត្វ និងសង្ខារជាទីស្រឡាញ់ និងការឃើញសត្វ និងសង្ខារដែលមិនជាទីស្រឡាញ់ ជាទុក្ខដោយពិត ហេតុនោះ ការធ្វើបណ្តាសត្វ និងសង្ខារទាំងឡាយណាមួយឲ្យជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ រមែងមិនសមគួរ ដូច្នេះហើយ បានភាសិតព្រះគាថានេះថា

អយោគេ យុញ្ជមត្តានំ យោគស្មិញ្ច អយោ ជយំ
អត្តំ ហិត្វា បិយគ្គាហី បិហោតត្តានុយោគិនំ ។
មា បិយេហិ សមាគញ្ឆិ អប្បិយេហិ កុទាចនំ
បិយានំ អទស្សនំ ទុក្ខំ អប្បិយានញ្ច ទស្សនំ ។
តស្មា បិយំ ន កយិរាថ បិយាបាយោ ហិ បាបកោ
គន្ថា តេសំ ន វិជ្ជន្តិ យេសំ ឆន្ទំ បិយាប្បិយំ ។

បុគ្គលកាលប្រកបខ្ជូនទុកក្នុងអំពើដែលមិនគួរប្រកប មិនប្រកបខ្ជូនក្នុងអំពើដែលគួរប្រកប លះបង់ប្រយោជន៍ចេញហើយ កាន់

យកតាមគាប់ចិត្ត រមែងស្រឡាញ់បុគ្គលអ្នកប្រកបតាមខ្លួន ។ កុំគប់រកសត្វ និងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ក្នុងកាលណាៗ ឡើយ ព្រោះថា ការមិនជួបប្រសព្វសត្វ និងសង្ខារជាទីស្រឡាញ់ក្តី ការជួបប្រសព្វសត្វ និងសង្ខារមិនជាទីស្រឡាញ់ក្តី ជាហេតុនាំមកនូវទុក្ខ ។ ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វ និងសង្ខារឲ្យជាទីស្រឡាញ់ ព្រោះការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជាសភាពអាក្រក់ ការស្រឡាញ់ និងការស្អប់ មិនមានដល់ពួកជនណា កិលេសគ្រឿងចាក់ស្រែះទាំងឡាយ តែងមិនមានដល់ពួកជននោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អយោគេ** *សេចក្តីថា ក្នុងវត្ថុដែលមិនគួរប្រកប គឺក្នុងការធ្វើទុកក្នុងចិត្ត ដែលមិនមែនឧបាយ អធិប្បាយថា ការសេពអគោចរ ៦ យ៉ាង មានអគោចរ គឺកន្លែងស្រីពេស្យាជាដើម ឈ្មោះថា ការធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ ក្នុងទីនេះ បុគ្គលប្រកបខ្លួនក្នុងការធ្វើទុកក្នុងចិត្តដោយអយោនិសោមនសិការនោះ ។*

បទថា **យោគស្មឹ** *សេចក្តីថា មិនប្រកបខ្លួនក្នុងយោនិសោមនសិការដែលខុសអំពីអយោនិសោមនសិការនោះ ។*

ពីរបទថា **អត្តំ ហិត្វា** *សេចក្តីថា ពួក ៣ នៃសិក្ខា មានអធិសីលសិក្ខា*

ជាដើម ចាប់តាំងអំពីកាលនៃខ្ជូនបួសហើយ ឈ្មោះថា ប្រយោជន៍លះហើយ នូវប្រយោជន៍នោះ ។

បទថា **បិយគ្គាហី** *សេចក្តីថា កាន់យកនូវអារម្មណ៍ដែលជាទីស្រឡាញ់ ពោលគឺ កាមគុណ ៥ ប៉ុណ្ណោះ ។*

បទថា **បិយោតត្តានុយោគិនំ** *សេចក្តីថា បុគ្គលកាលឃ្លាតចាកសាសនាព្រោះកិច្ចបដិបត្តិនោះ ដល់នូវភាពជាគ្រហស្ថហើយ ខាងក្រោយ រមែងប្រាថ្នាចំពោះបុគ្គលទាំងឡាយដែលតាមប្រកបខ្ជូន ញុំាងគុណទាំងឡាយ មានសីលជាដើម ឲ្យដល់ព្រមហើយ (បាននូវ) សក្ការៈអំពីសម្នាក់ទេវតា និងមនុស្សទាំងឡាយ គឺរមែងប្រាថ្នាថា ឱហ្ន៎ សូម្បីអញក៏គប្បីជាបុគ្គលដូច្នេះ ។*

បទថា **មា បិយេហិ** *សេចក្តីថា បុគ្គលមិនគប្បីសមាគមដោយសត្វ ឬសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ក្នុងកាលណាមួយ គឺក្នុងមួយជួរខណៈ សត្វ ឬសង្ខារទាំងឡាយមិនជាទីស្រឡាញ់ក៏ដូចគ្នា ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះការមិនឃើញសត្វ និងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ ដោយអំណាចការព្រាត់ប្រាសផង ការឃើញសត្វ និងសង្ខារទាំងឡាយ ដែលមិនជាទីស្រឡាញ់ផង ដោយអំណាចការចូលទៅជិតជាទុក្ខ ។*

បទថា **តស្មា** *សេចក្តីថា ការឃើញ និងមិនឃើញ ទាំងពីរនេះជាទុក្ខ ហេតុនោះ បុគ្គលមិនគប្បីធ្វើសត្វ ឬសង្ខារណាមួយឲ្យជាទីស្រឡាញ់ឡើយ ។*

ការទៅប្រាស គឺការព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ ឈ្មោះថា **បិយាចាយោ** *។ បទថា* **ចាបកោ** *បានដល់ អាក្រក់ ។*

បាទព្រះគាថាថា **គន្តា តេសំ ន វិជ្ជន្តិ** *សេចក្តីថា ជនទាំងឡាយណា មិនមានអារម្មណ៍ជាទីស្រឡាញ់ ជនទាំងនោះ រមែងលះកិលេស ជាគ្រឿងរួបរឹតផ្លូវកាយ គឺអកិដ្ឋាបាន ជនពួកណា មិនមានអារម្មណ៍ដែលមិនជាទីស្រឡាញ់ ជនទាំងនោះ រមែងលះគន្ថៈ គឺព្យាបាទចេញបាន កាលលះកិលេស ២ យ៉ាង នោះបានហើយ សូម្បីកិលេសជាគ្រឿងរួបរឹតដ៏សេស ក៏ឈ្មោះថា លះបានហើយដូចគ្នា ហេតុនោះ បុគ្គលមិនគប្បីធ្វើអារម្មណ៍ឲ្យជាទីស្រឡាញ់ ឬមិនឲ្យជាទីស្រឡាញ់ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។ ចំណែកជនទាំង ៣ គិតថា ពួកយើងមិនអាចនៅបែកគ្នាបាន ដូច្នេះហើយ បានសឹកទៅកាន់ផ្ទះដូចមុននោះឯង ៕

រឿង បញ្ចភិត ៣ រូប ចប់

រឿង កុដុម្ពិកៈម្នាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ឥយតោ ជាយតី** *ជាដើម ។*

*សេចក្តីពិស្តារថា កុដុម្ពិកៈនោះ កាលកូនរបស់ខ្លួនធ្វើកាលកិរិយាហើយ កាលសេចក្តីសោកដល់កូនគ្របសង្កត់ ចូលទៅកាន់ព្រៃខ្មោចទ្រហោយំ មិន

អាចឃាត់សេចក្តីសោកដល់បុត្របាន ។

ព្រះសាស្តា ទ្រង់ពិចារណាមើលសត្វលោកក្នុងពេលជិតភ្លឺ ទ្រង់ឃើញឧបនិស្សយសោតាបត្តិមគ្គរបស់កុដុម្ពិក:នោះ ត្រឡប់អំពីបិណ្ឌបាតហើយ ទ្រង់នាំភិក្ខុដែលជាបច្ឆាសមណ:មួយរូប យាងទៅកាន់ទ្វារផ្ទះរបស់កុដុម្ពិក:នោះ កុដុម្ពិក:នោះបានស្តាប់ភាពដែលព្រះសាស្តាយាងមក គិតថា ព្រះសាស្តាទ្រង់បំណងដើម្បីធ្វើបដិសណ្ឋារ:ជាមួយ ទើបអារាធនាព្រះសាស្តាឲ្យចូលកាន់ផ្ទះ ក្រាលអាសន:ក្នុងផ្ទះ កាលព្រះសាស្តាប្រថាប់គង់ហើយ ក៏ថ្វាយបង្គំ អង្គុយក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរកុដុម្ពិក:នោះថា ម្នាលឧបាសក អ្នកត្រូវទុក្ខព្រោះហេតុអ្វីហ្ន៎ កាលកុដុម្ពិក:នោះក្រាបទូលនូវទុក្ខ ព្រោះព្រាត់ប្រាសចាកបុត្រហើយ ត្រាស់ថា កុំគិតឡើយឧបាសក ឈ្មោះថា ការស្លាប់នេះ មិនមែនមានក្នុងទីមួយ និងមិនមែនមានចំពោះដល់បុគ្គលម្នាក់ ឈ្មោះថាការប្រព្រឹត្តទៅនៃភពនៅមានដរាបណា ការស្លាប់ក៏រមែងមានដល់សត្វដរាបនោះដូចគ្នា សូម្បីសង្ខារមួយដែលឈ្មោះថា ទៀង មិនមាន ព្រោះហេតុនោះ អ្នកគប្បីពិចារណាដោយឧបាយប្រាជ្ញាថា ធម្មជាតមានការស្លាប់ជាធម្មតា ស្លាប់ហើយ ធម្មជាតមានការបែកធ្លាយជាធម្មតា បែកធ្លាយហើយ មិនគប្បីសោយសោក ព្រោះថា បុរាណបណ្ឌិតទាំងឡាយ ក្នុងកាលដែលកូនជាទីស្រឡាញ់ស្លាប់ហើយ ពិចារណាថា ធម្មជាតមានការស្លាប់ជាធម្មតា ស្លាប់ហើយ ធម្មជាតមានការបែកធ្លាយជាធម្មតា បែកធ្លាយហើយ ដូច្នេះហើយ

មិនធ្វើនូវសេចក្តីសោក ចម្រើនមរណស្សតិតែម្យ៉ាង កាលកុដុម្ភិកៈទូលអារាធនាថា បពិត្រព្រះអង្គដ៏ចម្រើន បណ្ឌិតក្នុងកាលណា បានធ្វើហើយយ៉ាងនោះ និងបានធ្វើក្នុងកាលណា សូមទ្រង់ត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គ កាលទ្រង់ប្រកាសសេចក្តីនោះ ទើបទ្រង់នាំអតីតនិទានមក ញាំងឧរគជាតក ក្នុងបញ្ចកនិបាតឲ្យពិស្តារហើយ ។

កូនរបស់ខ្ញុំ លះបង់នូវសរីរៈហើយទៅ ដូចជាពស់ លះបង់នូវសំណកចាស់ កាលបើសរីរៈប្រើប្រាស់មិនបាន ធ្វើកាលកិរិយាទៅកាន់លោកខាងមុខយ៉ាងនេះ រាងកាយកាលត្រូវគេដុតរមែងមិនដឹងនូវសេចក្តីខ្វីកខ្វួលនៃញាតិទាំងឡាយ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយចំពោះកូនន៎ុះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

ដូច្នេះហើយ ត្រាស់បន្តទៀតថា បណ្ឌិតក្នុងកាលមុន កាលកូនជាទីស្រឡាញ់ធ្វើកាលកិរិយាហើយយ៉ាងនោះ មិនប្រព្រឹត្តដូចអ្នកបោះបង់ការងារហើយអត់អាហារទ្រហោយំ ឥឡូវនេះ មិនធ្វើសេចក្តីសោក ដោយអំណាចមរណស្សតិភាវនា បរិភោគអាហារ និងអធិដ្ឋានការងារ ព្រោះដូច្នោះ អ្នកកុំគិតថា កូនជាទីស្រឡាញ់ធ្វើកាលកិរិយាហើយ ពិតហើយ សេចក្តីសោកក្តីភ័យក្តី កាលកើត រមែងអាស្រ័យរបស់ជាទីស្រឡាញ់នោះឯងកើត ដូច្នេះ

ហើយ ទើបត្រាស់ព្រះគាថានេះថា

បិយតោ ជាយតី សោកោ បិយតោ ជាយតី ភយំ

បិយតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ។

សេចក្តីសោក កើតអំពីសេចក្តីស្រឡាញ់ ភ័យ កើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ ហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកអំពីណា ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បិយតោ** *ជាដើម សេចក្តីថា សេចក្តីសោកក្តី ភ័យក្តីដែលមានវដ្ត:ជាមូល កាលកើតឡើង រមែងអាស្រ័យសត្វ ឬសង្ខារដែលជាទីស្រឡាញ់ប៉ុណ្ណោះកើត តែសេចក្តីសោក និងភ័យទាំងពីរនោះមិនមានដល់បុគ្គលដែលដោះចាកសត្វ ឬសង្ខារជាទីស្រឡាញ់នោះបានហើយ ។*

ក្នុងកាលចប់ទេសនា កុដុម្ពិក:តាំងនៅហើយក្នុងសោតាបត្តិផល ទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង កុដុម្ពិក:ម្នាក់ ចប់

រឿង នាងវិសាខាឧបាសិកា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងវិសាខឧបាសិកា ត្រាស់ព្រះធម្មទេសនានេះថា **បេមតោ ជាយតិ** ជាដើម ។

បានឮថា នាងវិសាខានោះ តាំងកុមារិកាឈ្មោះសុទត្តី ដែលជាចៅក្នុងនាទីរបស់ខ្លួន ឲ្យធ្វើជាអ្នកខ្នះខ្នែងដល់កិច្ចសង្ឃក្នុងផ្ទះ ។

ដោយសម័យដទៃ កុមារិកានោះបានធ្វើកាលកិរិយាហើយ នាងវិសាខាឲ្យធ្វើការកប់សរីរៈនាងហើយ មិនអាចអត់ធន់សេចក្តីសោកបាន មានទុក្ខទោមនស្ស ទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់ថា ម្នាលនាងវិសាខា ហេតុអ្វីទើបនាងមានទុក្ខទោមនស្ស មានមុខជោកដោយទឹកភ្នែក អង្គុយទ្រហោយំ ទើបនាងទូលសេចក្តីនោះ ហើយក្រាបទូលថា បពិត្រព្រះអង្គ កុមារិកានោះជាទីស្រឡាញ់របស់ខ្ញុំម្ចាស់ ជាអ្នកសម្បូរដោយវត្ត ឥឡូវនេះខ្ញុំម្ចាស់មិនបានឃើញអ្នកណាដែលមានសភាពដូច្នោះ ។ ព្រះសាស្តាត្រាស់ថា ម្នាលនាងវិសាខា ក្នុងក្រុងសាវត្ថីមានមនុស្សប្រមាណប៉ុនណា នាងវិសាខាទូលថា បពិត្រព្រះអង្គ ទ្រង់នោះឯងត្រាស់ដល់ខ្ញុំម្ចាស់ថា ក្នុងក្រុងសាវត្ថីមានមនុស្ស ៧ កោដិ ។

ព្រះសាស្តាត្រាស់ថា បើជនមានប្រមាណប៉ុណ្ណេះ បុគ្គលដូចជាចៅស្រីរបស់នាងសោត នាងគប្បីប្រាថ្នាឬ នាងវិសាខាទូលថា បពិត្រព្រះអង្គ យ៉ាងនោះឯង ព្រះសាស្តាត្រាស់ថា ជនក្នុងក្រុងសាវត្ថីដែលធ្វើកាលកិរិយាមួយថ្ងៃ

ប៉ុន្មាន នាងវិសាខាទូលថា បពិត្រព្រះអង្គ ច្រើនណាស់ ព្រះសាស្តាត្រាស់ថា បើដូច្នេះ ពេលដែលនាងសោយសោក ក៏មិនគប្បីមានមិនមែនឬ នាងដើរយំក្នុងពេលយប់ និងពេលថ្ងៃឬ នាងវិសាខាទូលថា បពិត្រព្រះអង្គ សូមលើកទុកចុះ ខ្ញុំម្ចាស់ជ្រាបហើយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា បើដូច្នោះ នាងកុំសោយសោក សេចក្តីសោកក្តី ការខ្វាចក្តី រមែងកើតអំពីសេចក្តីស្រឡាញ់ ដូច្នេះហើយ ទើបត្រាស់គាថានេះថា

បេមតោ ជាយតី សោកោ បេមតោ ជាយតី ភយំ

បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោក កើតអំពីសេចក្តីស្រឡាញ់ ភ័យ កើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកអំពីណា ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បេមតោ** សេចក្តីថា ព្រោះអាស្រ័យសេចក្តីស្រឡាញ់ក្នុងបុត្រ និងធីតាជាដើមនោះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង នាងវិសាខាឧបាសិកា ចប់

រឿង ស្តេចលិច្ឆវី

លំនាំដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យនៅក្នុងក្រុងវេសាលី ប្រថាប់នៅនាគោជាគារសាលា ទ្រង់ប្រារព្ធស្តេចលិច្ឆវី ត្រាស់ព្រះធម្មទេសនានេះថា **រតិយា ជាយតី** ជាដើម ។

បានឮថា ក្នុងថ្ងៃមហោស្រពមួយ ស្តេចលិច្ឆវីប៉ុណ្ណោះ តែងគ្រឿងអលង្ការមិនដូចគ្នា ចេញអំពីព្រះនគរយាងទៅកាន់ឧទ្យាន ។ ព្រះសាស្តាចូលទៅបិណ្ឌបាត ទ្រង់ឃើញស្តេចលិច្ឆវីទាំងនោះ ទើបត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នកមើលពួកស្តេចលិច្ឆវីជនណាមិនធ្លាប់ឃើញទេវតាជាន់តាវត្តិង្ស ក៏ចូរមើលស្តេចលិច្ឆវីទាំងនោះចុះ ដូច្នេះហើយ យាងចូលទៅកាន់នគរ ។

ស្តេចលិច្ឆវីទាំងនោះ កាលទៅកាន់ឧទ្យាន នាំស្រីនគរសោកិនីម្នាក់អាស្រ័យស្រីនោះ ត្រូវសេចក្តីច្រណែនគ្របសង្កត់ហើយ ប្រហារគ្នានិងគ្នាញ៉ាំងឈាមឲ្យហូរដូចស្ទឹង ។

គ្រានោះ ពួកភ្នាក់ងារយកគ្រែសែងស្តេចលិច្ឆវីទាំងនោះមកហើយ ។ ចំណែកព្រះសាស្តា ទ្រង់ធ្វើកត្តកិច្ចស្រេចហើយ ក៏យាងចេញអំពីព្រះនគរ ។ ពួកភិក្ខុឃើញស្តេចលិច្ឆវី ដែលភ្នាក់ងារនាំទៅយ៉ាងនោះ ទើបក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ ពួកស្តេចលិច្ឆវីកាលអំពីព្រលឹម ប្រដាប់តាក់តែងហើយ ចេញអំពីព្រះនគរដូចពួកទេវតា ឥឡូវនេះ អាស្រ័យស្រីម្នាក់ ដល់នូវសេចក្តីវិនាសនេះហើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីសោកក្តី ភ័យក្តី កាល កើតរមែងកើតអាស្រ័យសេចក្តីត្រេកអរនោះឯង ដូច្នេះហើយ ត្រាស់ព្រះគាថា នេះថា

រតិយា ជាយតី សោកោ រតិយា ជាយតី ភយំ

រតិយា វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោក កើតអំពីតម្រេក ភ័យ កើតអំពីតម្រេក កាលបើរួចស្រឡះចាកតម្រេកហើយ សេចក្តីសោក ក៏លែងមាន ភ័យ នឹងមានមកអំពីណា ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **រតិយា** *សេចក្តីថា តែការត្រេកអរក្នុងកាមគុណ ៥ គឺព្រោះអាស្រ័យសេចក្តីត្រេកអរក្នុងកាមគុណ ៥ នោះ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ស្តេចលិច្ឆវី ចប់

រឿង អនិត្តិគន្ធកុមារ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអនិត្តិគន្ធកុមារ ត្រាស់ព្រះធម្មទេសនានេះថា **កាមតោ ជាយតី** ជាដើម ។

បានឮថា អនិត្តិគន្ធកុមារនោះជាសត្វចុតិអំពីព្រហ្មលោក កើតក្នុងត្រកូលមានកោគៈច្រើនក្នុងក្រុងសាវត្ថី តាំងអំពីកើតហើយមិនប្រាថ្នាទៅជិតស្រី ត្រូវពួកស្រីចាប់ក៏ស្រែកយំ មាតាត្រូវពកុមារនោះដោយសំពត់ជួតក្បាល (តែងខ្លួនធ្វើជាប្រុស) ហើយទើបឲ្យថៅ ។

កុមារនោះចម្រើនវ័យហើយ កាលមាតាបិតាពោលថា នែបា អញធ្វើអាវាហមង្គលដល់អ្នក ក៏ឃាត់ថា ខ្ញុំមិនត្រូវការដោយស្រី កាលត្រូវអង្វរវ៉ីយៗ ទើបឲ្យហៅជាងមាស ៥០០ នាក់ ហើយឲ្យមាសទឹកជប់ មួយពាន់និក្ខៈ ឲ្យធ្វើជារូបស្រីយ៉ាងស្អាត គួរជ្រះថ្លាពន់ពេក កាលមាតាបិតាពោលទៀតថា នែបា កាលបាមិនធ្វើអាវាហមង្គល ត្រកូលវង្សនឹងតាំងនៅមិនបាន អញនឹងនាំកុមារិកាមកឲ្យ ក៏ពោលថា បើដូច្នោះ បើលោកទាំងពីរនាំកុមារិកាដែលមានសភាពដូច្នោះមកឲ្យខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់លោកទាំងពីរ ដូច្នេះហើយ ទើបបង្ហាញរូបមាសនោះ ។

លំដាប់នោះ មាតាបិតាឲ្យពួកព្រាហ្មណ៍មានឈ្មោះល្បីមក ហើយប្រាប់ថា កូនរបស់ខ្ញុំមានបុណ្យច្រើន គង់មានកុមារិកាធ្វើបុណ្យជាមួយបុត្រនេះពិត ចូរពួកអ្នកទៅ ចូរនាំយករូបមាសនេះទៅហើយ នាំនាងកុមារិកាដែលមានរូបដូច្នេះមក ដូច្នេះហើយ បញ្ជូនព្រាហ្មណ៍ទាំងនោះទៅ ។ ព្រាហ្មណ៍ទាំងនោះ

ទទួលថា សាធុ ត្រាច់ចារិកទៅដល់សាគលនគរ ក្នុងជែនមទួ: ។

ក្នុងនគរនោះ មានកុមារិកាម្នាក់មានរូបស្អាត មានអាយុ ១៦ ឆ្នាំ មាតាបិតាឲ្យនាងនៅត្រង់ផ្ទៃប្រាសាទខាងលើជាន់ទី ៧ ព្រាហ្មណ៍ទាំងនោះឯងគិតគ្នាថា បើក្នុងនគរនេះមានកុមារិកាបែបនេះ ជនទាំងឡាយឃើញរូបមាសនេះហើយ ក៏នឹងពោលថា រូបសួននេះ ដូចកូនស្រីរបស់ត្រកូលឈ្មោះនោះ ដូច្នេះហើយ ទើបតម្កល់រូបមាសនោះទុកត្រង់ផ្លូវទៅកាន់កំពង់ទឹក អង្គុយយាមក្នុងចំណែកម្ខាង ។

លំដាប់នោះ ស្រីមេដោះម្នាក់របស់កុមារិកានោះ ឲ្យកុមារិកានោះងូតទឹកហើយ ប្រាប់នឹងងូតឯងម្តង ទើបចុះកាន់កំពង់ទឹក ឃើញរូបនោះសម្គាល់ថាជាកូនស្រីរបស់អញ ទើបពោលថា ឱ ហាងក្បាលរឹង អញឲ្យងូតទឹកហើយចេញមកអម្បាញ់មិញនេះឯង ហាងមកទីនេះមុនអញ ដូច្នេះហើយ ទើបវាយដោយដៃ ដីងភាពដែលរូបនោះរឹង មិនមានវិការ ទើបពោលថា អញស្មានថាស្រីនេះ ជាកូនស្រីរបស់អញ នេះជាអ្វីហ្ន៎ ។

លំដាប់នោះ ព្រាហ្មណ៍ទាំងនោះសួរមេដោះនោះថា នែនាង ធីតារបស់នាងបែបនេះឬ ស្រីមេដោះពោលថា របស់នេះមានតម្លៃអ្វីក្នុងសម្នាក់ធីតារបស់ខ្ញុំ ព្រាហ្មណ៍ពោលថា បើដូច្នោះ ចូរនាងបង្ហាញធីតារបស់នាងដល់ពួកយើង ស្រីមេដោះនោះទៅកាន់ផ្ទះ មួយអន្ទើដោយព្រាហ្មណ៍ទាំងនោះហើយ ក៏ប្រាប់ដល់ចៅហ្វាយ ។ ម្ចាស់ផ្ទះធ្វើការរាក់ទាក់ជាមួយពួកព្រាហ្មណ៍ហើយ ឲ្យធីតាចុះមកឈរក្បែររូបមាស ក្នុងប្រាសាទជាន់ខាងក្រោម រូបមាសបានជារូបអស់

រស្មីហើយ ។ ពួកព្រាហ្មណ៍ឲ្យរូបមាសនោះដល់ម្ចាស់ផ្ទះហើយ នាវកុមារិកា ទុកហើយ ទៅជ្រាបដល់មាតាបិតារបស់អនិត្តិគន្ធកុមារ ។

មាតាបិតានោះមានចិត្តត្រេកអរហើយពោលថា ចូរអ្នកទាំងឡាយទៅនាំ កុមារិកានោះមកដោយរហ័ស ដូច្នេះហើយ បញ្ជូនទៅដោយសក្ការៈដ៏ច្រើន ។

ចំណែកកុមារបានឮដំណឹងនោះ ក៏ញាំងសេចក្តីស្រឡាញ់ឲ្យកើត ដោយ អំណាចការបានឮថា នាវិកាមានរូបស្អាតជាងរូបមាសទៅទៀត ទើបពោលថា អ្នកទាំងឡាយ ចូរនាំមកដោយរហ័សចុះ ។ កុមារិកានោះឯង ដែលគេលើក ឡើងកាន់យានទាំមក មានវេគខ្សល់ព្រោះការរលាក់នៃយានឲ្យកើតឡើងហើយ បានធ្វើកាលកិរិយាក្នុងវាងផ្លូវនោះឯង ព្រោះភាពដែលនាងជាសុខុមាលជាតិ ។

កុមារសួរជានិច្ចថា មកហើយឬ ជនទាំងឡាយមិនជ្រាបដល់កុមារនោះ ដែលសួរដោយសេចក្តីស្នេហាដ៏ក្រៃលែង ដោយរហ័សនោះឯង ពន្យា ២-៣ ថ្ងៃហើយ ទើបជ្រាប់រឿងនោះ ។ កុមារនោះកើតទោមនស្សឡើងថា អញមិន បានសមាគមជាមួយស្រីបែបនោះ បានជាអ្នកដល់នូវសេចក្តីទុក្ខ ដូចភ្នំ សង្កត់ហើយ ។

ព្រះសាស្តា ទ្រង់ឃើញឧបនិស្សយរបស់កុមារនោះ កាលយាងទៅ បិណ្ឌបាត ទើបយាងទៅកាន់ទ្វារផ្ទះនោះ ។ គ្រានោះ មាតាបិតារបស់កុមារ នោះ យាងព្រះសាស្តាចូលទៅខាងក្នុងផ្ទះ ហើយអង្គាសដោយគោរព ។

ក្នុងកាលស្រេចភត្តកិច្ច ព្រះសាស្តាត្រាស់សួរថា អនិត្តិគន្ធកុមារទៅណា មាតាបិតាពោលថា បពិត្រព្រះអង្គ អនិត្តិគន្ធកុមារនោះ ដេកអត់អាហារក្នុង

បន្ទប់ ព្រះសាស្តាត្រាស់ថា ចូរហៅគេមក ។

អនិត្តិគន្ធកុមារនោះ មកថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងចំណែកម្ខាង កាលព្រះសាស្តាត្រាស់សួរថា ម្នាលកុមារ សេចក្តីសោកដ៏មានកម្លាំងកើតឡើងហើយដល់អ្នកឬ ទើបក្រាបទូលថា ករុណាព្រះអង្គ សេចក្តីសោកមានកម្លាំងកើតឡើងដល់ខ្ញុំព្រះអង្គ ព្រោះបានឮថា ស្រីឈ្មោះនេះ ធ្វើកាលកិរិយាក្នុងរវាងផ្លូវហើយ សូម្បីកត្តុ ខ្ញុំព្រះអង្គក៏មិនឃ្លាន ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងកុមារនោះថា ម្នាលកុមារ អ្នកដឹងទេថា សេចក្តីសោក កើតដល់អ្នក ព្រោះអាស្រ័យអ្វី អនិត្តិគន្ធកុមារទូលថា បពិត្រព្រះអង្គ មិនដឹងទេ ព្រះសាស្តាត្រាស់ថា ម្នាលកុមារ សេចក្តីសោកមានកម្លាំង កើតឡើងដល់អ្នក ព្រោះអាស្រ័យកាម ព្រោះសេចក្តីសោកក្តីភ័យក្តី រមែងកើតឡើង ព្រោះអាស្រ័យកាម ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

កាមតោ ជាយតី សោកោ កាមតោ ជាយតី ភយំ
កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោក កើតអំពីកាម ភ័យ កើតអំពីកាម កាលបើរូបស្រឡះចាកកាមហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកអំពីណា ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កាមតោ** សេចក្តីថា ចាកវត្ថុកាម និង

កិលេសកាម អធិប្បាយថា សេចក្តីសោកក្តី ភ័យក្តី រមែងអាស្រ័យកាមទាំង ២ យ៉ាងនោះកើត ។

ក្នុងកាលចប់ទេសនា អនិត្តិគន្ធកុមារតាំងនៅហើយក្នុងសោតាបត្តិផល ដូច្នេះឯង ។

រឿង អនិត្តិគន្ធកុមារ ចប់

រឿង ព្រាហ្មណ៍ម្នាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **តណ្ហាយ ជាយតី** *ជាដើម ។*

បានឮថា ព្រាហ្មណ៍នោះជាមិច្ឆាទិដ្ឋិបុគ្គល ថ្ងៃមួយ ទៅកាន់ច្រាំងស្ទឹង ហើយ ឆ្ការស្រែ ។ ព្រះសាស្តាទ្រង់ឃើញការជល់ព្រមនៃឧបនិស្សយរបស់ ព្រាហ្មណ៍នោះ ទើបយាងទៅកាន់សម្នាក់របស់ព្រាហ្មណ៍ ព្រាហ្មណ៍សូម្បី ឃើញព្រះដ៏មានព្រះភាគ ក៏មិនធ្វើសាមីចិកម្ម បានអង្គុយស្ងៀម ។

គ្រានោះ ព្រះសាស្តាត្រាស់មុនថា ម្នាលព្រាហ្មណ៍ អ្នកកំពុងធ្វើអ្វី ព្រាហ្មណ៍ពោលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គកំពុងឆ្ការស្រែ ព្រះសាស្តា ត្រាស់ត្រឹមប៉ុណ្ណោះហើយ ក៏ចៀសចេញទៅ ។ ក្នុងថ្ងៃស្អែកឡើង ព្រះ សាស្តាយាងទៅកាន់សម្នាក់របស់ព្រាហ្មណ៍នោះ ដែលមកហើយដើម្បីក្លូ

ស្រែ ត្រាស់សួរថា ម្នាលព្រាហ្មណ៍ អ្នកធ្វើអ្វី ទ្រង់បានឮថា បពិត្រព្រះគោតម ខ្ញុំកំពុងក្អួរស្រែ ដូច្នេះហើយ ក៏យាងហួសទៅ សូម្បីក្នុងថ្ងៃបន្ទាប់មក ព្រះសាស្តាក៏យាងទៅ ត្រាស់សួរយ៉ាងនោះ ទ្រង់បានស្តាប់ថា បពិត្រព្រះគោតម ខ្ញុំកំពុងព្រោះ កំពុងបញ្ចូលទឹក កំពុងថែស្រែ ដូច្នេះហើយ ក៏ចៀសចេញទៅ ។

ថ្ងៃមួយ ព្រាហ្មណ៍ក្រាបទូលព្រះអង្គថា ព្រះគោតមយាងមកហើយ តាំងអំពីថ្ងៃដែលខ្ញុំព្រះអង្គធ្លាស្រែ បើសមួយរបស់ខ្ញុំព្រះអង្គឲ្យផល ខ្ញុំព្រះអង្គនឹងចែកជល់ទ្រង់ខ្លះ បើមិនទាន់ថ្វាយទ្រង់ ខ្ញុំព្រះអង្គក៏មិនទំពាស៊ី តាំងអំពីនេះជាដើមទៅ ទ្រង់ជាសម្ងាញ់របស់ខ្ញុំព្រះអង្គ ។

សម័យក្រោយទៀត ស្រូវរបស់ព្រាហ្មណ៍នោះចេញផ្លែហើយ កាលព្រាហ្មណ៍នោះ ធ្វើកិច្ចទាំងពួងដើម្បីច្រូតដោយតាំងចិត្តថា សមួយរបស់អញឲ្យផលហើយ អញនឹងឲ្យច្រូតតាំងអំពីស្អែកនេះទៅ មហាមេឃញាំងភ្លៀងឲ្យធ្លាក់មួយយប់ នាំយកស្រូវទៅអស់ ស្រែហាក់ដូចទីដែលបុគ្គលធ្លាអស់ ។

ព្រះសាស្តា ទ្រង់ជ្រាបហើយក្នុងថ្ងៃដំបូងនោះឯងថា សមួយនោះនឹងមិនឲ្យផល ។ ព្រាហ្មណ៍ទៅហើយអំពីព្រលឹម គិតថា អញពិនិត្យមើលស្រូវឃើញតែស្រែទទេ ទើបកើតសេចក្តីសោកជាខ្លាំង គិតថា ព្រះសមណគោតមមកកាន់ស្រែរបស់អញ តាំងអំពីអញធ្លាស្រែ អញក៏បានពោលនឹងលោកថា កាលសមួយឲ្យផលហើយ ខ្ញុំនឹងចែកចំណែកឲ្យជល់លោក មិនទាន់ឲ្យលោកហើយ ខ្ញុំក៏មិនទំពាស៊ីតាំងអំពីនេះជាដើមទៅ លោកជាសម្ងាញ់របស់អញ

សេចក្តីប្រាថ្នាក្នុងចិត្តរបស់អញនោះ មិនដល់ទីបំផុតហើយ ព្រាហ្មណ៍នោះធ្វើការអត់អាហារ ដេកលើគ្រែតូចហើយ ។

លំដាប់នោះ ព្រះសាស្តា បានយាងទៅកាន់ទ្វារផ្ទះរបស់ព្រាហ្មណ៍នោះ ព្រាហ្មណ៍នោះជ្រាបការយាងមករបស់ព្រះសាស្តា ទើបប្រាប់បរិវារថា ចូរពួកអ្នកនាំសម្ងាញ់របស់អញមក ឲ្យអង្គុយទីនេះ ។ ជនជាបរិវារបានធ្វើយ៉ាងនោះហើយ ព្រះសាស្តាប្រថាប់គង់ហើយ ត្រាស់សួរថា ព្រាហ្មណ៍ទៅណា កាលគេក្រាបទូលថា ដេកក្នុងបន្ទប់ ក៏ត្រាស់ឲ្យហៅមកដោយព្រះពុទ្ធតម្រាស់ថា ចូរពួកអ្នកហៅព្រាហ្មណ៍នោះមក ហើយត្រាស់នឹងព្រាហ្មណ៍ដែលមកអង្គុយហើយ ក្នុងចំណែកម្ខាងថា ម្នាលព្រាហ្មណ៍ តើអ្នកកើតអ្វី ព្រាហ្មណ៍ទូលថា បពិត្រព្រះគោតម លោកមកកាន់សម្នាក់របស់ខ្ញុំ តាំងអំពីថ្ងៃឆ្មារស្រែ សូម្បីខ្ញុំក៏បានពោលថា កាលសម្ងួតឲ្យផុលហើយ នឹងចែកចំណែកលោកខ្លះ ការប្រាថ្នាក្នុងចិត្តរបស់ខ្ញុំមិនសម្រេចឡើយ ព្រោះហេតុនោះ ទើបសេចក្តីសោកកើតហើយដល់ខ្ញុំ សូម្បីកត្តក៏ខ្ញុំមិនឃ្លាន ។

គ្រានោះ ព្រះសាស្តាត្រាស់សួរព្រាហ្មណ៍នោះថា ម្នាលព្រាហ្មណ៍ អ្នកដឹងទេថា សេចក្តីសោកកើតហើយដល់អ្នកព្រោះអាស្រ័យអ្វី កាលព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំមិនជ្រាបទេ លោកជ្រាបឬ ទើបត្រាស់ថា យ៉ាងនោះឯងព្រាហ្មណ៍ សេចក្តីពិត សេចក្តីសោកក្តី ភ័យក្តី កាលនឹងកើតរមែងអាស្រ័យតណ្ហាកើតឡើង ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

តណ្ហាយ ជាយតី សោកោ តណ្ហាយ ជាយតី ភយំ

តណ្ហាយ វិប្បមុត្តស្ស ឯត្ថ សោកោ កុតោ ភយំ ។

សេចក្តីសោក កើតអំពីតណ្ហា ភ័យ កើតអំពីតណ្ហា កាលបើ រួចស្រឡះចាកតណ្ហាហើយ សេចក្តីសោកក៏លែងមាន ភ័យ នឹងមានមកអំពីណា ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **តណ្ហាយ** *បានដល់ តណ្ហាដែលប្រព្រឹត្ត ទៅក្នុងទ្វារ ៦ អធិប្បាយថា សេចក្តីសោកជាដើមរមែងអាស្រ័យតណ្ហានោះ កើតឡើង ។*

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍តាំងនៅហើយ ក្នុងសោតាបត្តិផល ជួបច្នេះឯង ។

រឿង ព្រាហ្មណ៍ម្នាក់ ចប់

រឿង កុមារ ៥០០

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធកុមារ ៥០០ តាមចន្លោះផ្លូវ ត្រាស់ព្រះធម្មទេសនានេះថា **សីលឧស្សន្នសម្បន្នំ** *ជាដើម ។*

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះសាស្តាមានភិក្ខុ ៥០០ ជាបរិវារ មួយអន្ទើដោយព្រះអសីតិមហាថេរៈ ចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត បាន

ទតឃើញកុមារ ៥០០ លើកល្អីនំចេញអំពីក្រុង ហើយទៅឧទ្យានក្នុងថ្ងៃមហោស្រពមួយ កុមារទាំងនោះ ថ្វាយបង្គំព្រះសាស្តាហើយ ចៀសចេញទៅមិនពោលនឹងភិក្ខុត្រឹមតែមួយរូបថា សូមលោកម្ចាស់ទទួលនំ ។

ព្រះសាស្តា ត្រាស់នឹងភិក្ខុទាំងឡាយ ក្នុងកាលដែលភិក្ខុនោះទៅហើយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឆាន់នំដែរឬទេ ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គនំនៅឯណា ព្រះសាស្តាត្រាស់ថា អ្នកទាំងឡាយមិនឃើញពួកក្មេងកាន់ល្អីនំដើរឆ្ងងទៅហើយទេឬ ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ ក្មេងបែបនោះមិនឲ្យនំដល់អ្នកណាឡើយ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្មេងទាំងនោះមិននិមន្តតថាគត ឬអ្នកទាំងឡាយដោយនំក៏ពិត តែភិក្ខុដែលជាម្ចាស់របស់នំកំពុងមកឯក្រោយ ឆាន់នំសិនហើយ សឹមទៅ ទើបគួរ ។

តាមធម្មតាព្រះពុទ្ធទាំងឡាយមិនមានសេចក្តីច្រណែន ឬការប្រទូស្តក្នុងបុគ្គលណាម្នាក់ឡើយ ព្រោះដូច្នោះ ព្រះសាស្តាត្រាស់ពាក្យនេះហើយ ទើបនាំភិក្ខុសង្ឆទៅប្រថាប់គង់ក្រោមម្ងប់ឈើមួយដើម ។

ពួកក្មេងឃើញព្រះកស្សបត្ថេរដើរមកឯក្រោយ កើតសេចក្តីស្រឡាញ់មានសរីរៈពេញដោយកម្ងាំងបីតិ ដាក់ល្អីថ្វាយបង្គំព្រះថេរ: ដោយបញ្ចង្គប្រតិស្ឋាន លើកនំព្រមទាំងល្អីនោះឯង ពោលនឹងព្រះថេរៈថា សូមលោកម្ចាស់និមន្តទទួលចុះ ។

លំដាប់នោះ ព្រះថេរៈពោលនឹងកុមារទាំងនោះថា នុ៉ះព្រះសាស្តានាំភិក្ខុសង្ឆទៅប្រថាប់គង់ហើយត្រង់គល់ឈើ ទើបពួកក្មេងកាន់ទេយ្យធម៌ទៅថ្វាយ

ដល់ភិក្ខុសង្ឃ ពួកក្មេងទទួលពាក្យថា សាធុ លោកម្ចាស់ ហើយត្រឡប់ទៅព្រមជាមួយព្រះថេរៈនោះឯង ប្រគេននំហើយឈរមើលក្នុងចំណែកម្ខាង បានថ្វាយទឹកក្នុងពេលធាន់ស្រេចហើយ ។

ភិក្ខុទាំងឡាយពោលទោសថា ពួកក្មេងប្រគេនភិក្ខាព្រោះយល់មុខ មិនទទួលព្រះសម្មាសម្ពុទ្ធ ឬព្រះមហាថេរៈទាំងឡាយដោយនំ ឃើញព្រះមហាកស្សបត្ថេរហើយ កាន់យកនំ មួយអន្ទៃដោយល្អីនោះឯងមកហើយ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដូចគ្នានឹងកស្សបៈ ដែលជាបុត្ររបស់តថាគត ជាទីស្រឡាញ់របស់ពួកទេវតា និងមនុស្ស ទេវតា និងមនុស្សទាំងឡាយ ធ្វើការបូជាដោយបច្ច័យ ៤ ដល់លោកដោយពិត ដូច្នេះហើយ ត្រាស់ព្រះគាថាថា

សីលទស្សនសម្បន្នំ ធម្មដ្ឋំ សច្ចវាទិនំ
អត្តនោ កម្មកុព្វានំ តញ្ញេវ កុរុតេ បិយំ ។

ជនតែងធ្វើបុគ្គលដែលបរិបូណ៌ដោយសីល និងការឃើញត្រូវ ស្ថិតនៅក្នុងធម៌ ពោលសច្ចធម៌ជាប្រក្រតី ធ្វើកម្មជារបស់ខ្លួននោះឲ្យជាទីស្រឡាញ់ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សីលទស្សនសម្បន្នំ** សេចក្តីថា ជាអ្នកដល់ព្រមដោយចតុប្បារិសុទ្ធិសីល និងការឃើញត្រូវ ដែលសម្បយុត្តដោយមគ្គ និងផល ។

បទថា **ធម្មដ្ឋំ** *សេចក្តីថា ជាអ្នកតាំងនៅក្នុងលោកុត្តរធម៌ ៩ ប្រការ អធិប្បាយថា មានលោកុត្តរធម៌ដែលធ្វើឲ្យជាស់ច្បាស់ហើយ ។*

បទថា **សច្ចាភិនំ** *សេចក្តីថា ឈ្មោះថា មានប្រក្រតីពោលវាចាសត្យ ដោយសច្ចញ្ញាណ ព្រោះភាពដែលសច្ចៈ ៤ លោកធ្វើឲ្យជាស់ច្បាស់ហើយ ដោយអាការ ១៦ ។*

បាទព្រះគាថាថា **អត្តនោ កម្មកុព្វានំ** *សេចក្តីថា សិក្ខា ៣ ឈ្មោះថា ការងារបស់ខ្លួន ដែលបំពេញសិក្ខា ៣ នោះ ។*

ពីរបទថា **តំ ជនោ** *សេចក្តីថា លោកិយមហាជន រមែងធ្វើបុគ្គលនោះ ឲ្យជាទីស្រឡាញ់ គឺដែលប្រាថ្នានឹងឃើញ ប្រាថ្នានឹងថ្វាយបង្គំ ប្រាថ្នានឹងបូជា ដោយបច្ចัย ៤ ដោយពិត ។*

ក្នុងកាលចប់ទេសនា កុមារទាំងអស់ តាំងនៅក្នុងសោតាបត្តិផល ដូច្នេះឯង ។

រឿង កុមារ ៥០០ ចប់

រឿង ព្រះអនាគាមិត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈដែលជាអនាគាមីមួយអង្គ ត្រាស់ព្រះធម្មទេសនានេះថា **ឆន្ទជាតោ** ជាដើម ។

សេចក្តីពិស្តារ ថ្ងៃមួយ ពួកសទ្ធិវិហារិកសួរព្រះថេរៈនោះថា បពិត្រលោកម្ចាស់ ការសម្រេចធម្មវិសេសរបស់លោកម្ចាស់មានឬ ។

ព្រះថេរៈខ្មាស ព្រោះថាសូម្បីជនជាគ្រហស្តក៏គង់សម្រេចអនាគាមិផលបាន ក្នុងពេលសម្រេចអរហត្តហើយនោះឯង អញនឹងប្រាប់សទ្ធិវិហារិកទាំងនោះ ដូច្នេះហើយ មិនពោលពាក្យណាឡើយ ធ្វើកាលកិរិយាហើយកើតក្នុងទេវលោកជាន់សុទ្ធាវាស ។

លំដាប់នោះ ពួកសទ្ធិវិហារិករបស់លោកយំខ្សឹកខ្សួល ទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយទ្រហោយំនោះឯង អង្គុយក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកយំធ្វើអ្វី ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ ឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គធ្វើកាលកិរិយាហើយ ព្រះសាស្តាត្រាស់ថា ណ្ហើយចុះ ភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំគិតថ្វីឡើយ ន៎ុះ ឈ្មោះថា ជាធម៌ទៀង ។ ភិក្ខុទាំងឡាយទូលថា ករុណាព្រះអង្គ សូម្បីខ្ញុំព្រះអង្គក៏ជ្រាប តែពួកខ្ញុំព្រះអង្គបានសួរដល់ការសម្រេចធម៌វិសេសនឹងព្រះឧបជ្ឈាយ៍ លោកមិនប្រាប់ពាក្យណាឡើយ ធ្វើកាលកិរិយាហើយ ហេតុនោះ ទើបពួកខ្ញុំព្រះអង្គជាទុក្ខ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកកុំគិតឡើយ ឧបជ្ឈាយ៍របស់ពួកអ្នកបានអនាគាមិផលហើយ ឮសថា សូម្បីពួកគ្រហស្ថក៏សម្រេចអនាគាមិផលនោះ តែលុះសម្រេចអរហត្តហើយ ទើបប្រាប់ដល់ពួកសទ្ធិវិហារិកនោះ មិនប្រាប់ពាក្យណាមួយដល់អ្នកឡើយ ធ្វើកាលកិរិយាហើយ កើតក្នុងសុទ្ធាវាស ម្នាលភិក្ខុទាំងឡាយ ចូរជាក់ចិត្តចុះ ឧបជ្ឈាយ៍របស់ពួកអ្នកដល់នូវភាពជាបុគ្គល ដែលមានចិត្តមិនអាឡោះអាល័យក្នុងកាមទាំងឡាយ មានក្រសែទៅខាងលើ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

ឆន្ទជាតោ អនក្កាតេ មនសា ច ផុដោ សិយា
កាមេ ច អប្បដិពទ្ធចិត្តោ ឧទ្ធំសោតោតិ វុច្ចតិ ។

បុគ្គលអ្នកមានសេចក្តីប្រាថ្នាចំពោះព្រះនិព្វាន ដែលគេនិយាយប្រាប់គ្នា មិនបានផង ជាអ្នកមានមគ្គចិត្ត និងផលចិត្ត (ខាងក្រោម) ប៉ះពាល់ហើយផង មានចិត្តមិនប្រតិពន្ធក្នុងកាមផង តថាគតហៅថា ជាអ្នកមានខ្សែមគ្គប្រព្រឹត្តទៅក្នុងខាងលើ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឆន្ទជាតោ** *សេចក្តីថា មានឆន្ទៈកើតហើយដោយអំណាចការពេញចិត្តក្នុងភាពជាបុគ្គលប្រាថ្នាដើម្បីធ្វើ គឺដល់នូវឧស្សាហ៍ហើយ ។*

បទថា **អនក្កាតេ** *គឺក្នុងព្រះនិព្វាន ពិតហើយ ព្រះនិព្វាននោះ ឈ្មោះថា*

អនក្ខាត ព្រោះជាធម្មជាតដែលបុគ្គលណាម្នាក់ច្រាប់មិនបានថា ដែលបច្ចុយ នោះធ្វើ ឬបណ្តាពណ៌ផ្សេងៗ មានពណ៌ខៀវជាដើមបែបនេះឡើយ ។

បាទព្រះគាថាថា **មនសា ច ផុដោ សិយា** សេចក្តីថា គប្បីជាបុគ្គលដែលចិត្តសម្បយុត្តដោយមគ្គផល ៣ ខាងក្រោមពាល់ត្រូវហើយ គឺឲ្យពេញហើយ ។ បទថា **អប្បដិពទ្ធចិត្តោ** សេចក្តីថា មានចិត្តមិនប្រតិព័ទ្ធក្នុងកាមទាំងឡាយ ដោយអំណាចនៃព្រះអនាគាមិមគ្គក្តី ។

បទថា **ឧទ្ធំសោតោ** សេចក្តីថា ភិក្ខុបែបនេះ កើតហើយក្នុងអវិហា បន្ទាប់អំពីនោះទៅ ក៏ទៅកាន់អកនិដ្ឋភព ដោយអំណាចបដិសន្ធិ លោកហៅថា ជាអ្នកមានក្រសែទៅខាងលើ ឧបជ្ឈាយ៍របស់ពួកអ្នកជាបុគ្គលបែបនោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះ តាំងនៅហើយក្នុងអរហត្តផល ទេសនាមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

រឿង ព្រះអនាគាមិត្ថេរ ចប់

រឿង នន្ទិយឧបាសក

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តឥសិបតនៈ ទ្រង់ប្រារព្ធនន្ទិយៈ ត្រាស់ព្រះធម្មទេសនានេះថា **ចិរប្បវាសី** ជាដើម ។

បានឮថា ក្នុងក្រុងពារាណសីមានបុត្រនៃត្រកូលមួយ ដល់ព្រមដោយសទ្ធា ឈ្មោះនន្ទិយៈ បានជាអ្នកសម្បូរដោយសទ្ធា ទំនុកបម្រុងភិក្ខុសង្ឃ សង្គ្រោះនូវមាតាបិតា កាលចម្រើនវ័យ មាតាបិតាមានបំណងនាំធីតារបស់អ៊ំឈ្មោះថា នាងវេតីមកអំពីផ្ទះដែលផូយគ្នា (គឺមិនមានសទ្ធា) ។ តែនាងជាមនុស្សមិនមានសទ្ធា មិនមានការឲ្យជាប្រក្រតី ទើបនន្ទិយៈមិនប្រាថ្នា ។

កាលនោះ មាតារបស់នន្ទិយៈពោលនឹងនាងវេតីថា នែនាង ចូរនាងបូកលាបទីនោះរបស់ភិក្ខុសង្ឃ ហើយក្រាលអាសនៈក្នុងផ្ទះនេះ ចូរតម្កល់ជើងបាត្រក្នុងពេលភិក្ខុទាំងឡាយមកហើយ ចូរទទួលបាត្រ និមន្តឲ្យគង់ យកធម្មក្រកត្រង់ទឹកធាន់ប្រគេន ហើយលាងបាត្រក្នុងពេលលោកធាន់ស្រេចកាលនាងធ្វើយ៉ាងនេះ នឹងជាទីជូនចិត្តដល់កូនរបស់ខ្ញុំ ។ នាងបានធ្វើយ៉ាងនោះហើយ ។ បន្ទាប់មក មាតាបិតាពោលដល់ការប្រព្រឹត្តរបស់នាងដល់បុត្រថា នាងជាអ្នកអត់ធន់ចំពោះឱវាទ កាលនន្ទិយៈទទួលថា សាធុ ទើបកំណត់ថ្ងៃហើយធ្វើអាវាហមង្គល ។

លំដាប់នោះ នន្ទិយៈពោលនឹងនាងថា បើនាងបម្រើភិក្ខុសង្ឃ និងមាតារបស់ខ្ញុំ នាងនឹងបានរបស់របរក្នុងផ្ទះនេះ ចូរជាអ្នកមិនប្រមាទចុះ ។ នាងទទួលថា សាធុ ហើយធ្វើជាអ្នកមានសទ្ធា ទំនុកបម្រុង ២-៣ ថ្ងៃ ដរាបដល់មាន

កូន ២ នាក់ ។ មាតាបស់នន្ទិយឧបាសក ធ្វើកាលកិរិយាហើយ ភាពជាធំទាំងអស់ក្នុងផ្ទះ ក៏ធ្លាក់ដល់នាងវេតីតែម្នាក់ ។

ចាប់តាំងអំពីមាតាធ្វើកាលកិរិយាហើយ នន្ទិយឧបាសក ក៏ជាមហា-ទានបតី ត្រៀមតម្កល់ទានសម្រាប់ភិក្ខុសង្ឃ និងផ្តើមតាំងតម្លៃអាហារសម្រាប់មនុស្សកំព្រា និងអ្នកដើរផ្លូវជាដើមត្រង់ទ្វារផ្ទះ ។ ក្នុងកាលបន្តបន្ទាប់មក គាត់ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា កំណត់អានិសង្សក្នុងការថ្វាយអាវាសបានហើយ ឲ្យធ្វើសាលា ៤ មុខ ប្រជាប់ដោយបន្ទប់ ៤ បន្ទប់ ក្នុងមហាវិហារ នាត្រៃឥសិបតន:ហើយ ឲ្យជាក់គ្រែ និងតាំងជាដើម ដើម្បីវេរអាវាសនោះ បានថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយថ្វាយទឹកទក្ខិណោទកដល់ព្រះតថាគត ។ ប្រាសាទទិព្វសម្រេចដោយរតន: ៧ ប្រការ សម្បូរដោយពួកនារីមានប្រមាណ ១២ យោជន៍ក្នុងទិសទាំងពួង ខាងលើប្រមាណ ១ រយយោជន៍ ផុសឡើងក្នុងតាវត្តិង្សទេវលោក ដំណាលគ្នានឹងការច្រួចទឹកទក្ខិណោទកក្នុងព្រះហស្តព្រះសាស្តានោះឯង ។

សម័យក្រោយមក ព្រះមហាមោគ្គល្លាន ទៅកាន់ទីចារិកក្នុងទេវលោក ឈរហើយក្នុងទីមិនឆ្ងាយអំពីប្រាសាទនោះ សួរទេវបុត្រទាំងឡាយ ដែលមកកាន់សម្នាក់របស់ខ្លួនថា ប្រាសាទទិព្វពេញដោយពួកស្រីទេពអប្សរនោះ កើតហើយ ដើម្បីអ្នកណា ។

លំដាប់នោះ ពួកទេវបុត្រនោះ កាលប្រាប់ម្ចាស់របស់វិមានដល់ព្រះថេរៈនោះ ទើបពោលថា បពិត្រលោកម្ចាស់ វិមាននេះកើតហើយដើម្បីប្រយោជន៍

ដល់គហបតិបុត្ត ឈ្មោះនន្ទិយៈ ដែលសាងវិហារថ្វាយព្រះសាស្តា ក្នុងព្រៃឥសិបតនៈ ។ ចំណែកពួកស្រីទេពអប្សរ ឃើញព្រះថេរៈនោះហើយ ចុះអំពីប្រាសាទពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំកើតក្នុងទីនេះដោយបំណងថានឹងជាស្រីបម្រើរបស់នន្ទិយៈ តែមិនឃើញនន្ទិយៈនោះ ជាអ្នកខ្វាចពន់ពេក ព្រោះកាលលះមនុស្សសម្បត្តិ ហើយកាន់យកទិព្វសម្បត្តិ ដូចការទម្លាយថាសដីហើយកាន់យកថាសមាសដូច្នេះ សូមលោកម្ចាស់ប្រាប់គាត់ ដើម្បីប្រយោជន៍ដល់ការមកក្នុងទីនេះ ។

ព្រះថេរៈត្រឡប់មកអំពីទេវលោកនោះហើយ ចូលទៅគាល់ព្រះសាស្តា ទូលសួរថា បពិត្រព្រះអង្គ ទិព្វសម្បត្តិរមែងកើតដល់បុគ្គលដែលធ្វើសេចក្តីល្អ ដែលនៅជាមនុស្សនេះឯងដែរឬទេ ។

ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន ទិព្វសម្បត្តិដែលកើតហើយដល់នន្ទិយៈក្នុងទេវលោក ក្រែងអ្នកឃើញហើយមិនមែនឬ ហេតុអ្វីទើបសួរតថាគតទៅវិញ ព្រះមោគ្គល្លានសួរថា បពិត្រព្រះអង្គ ទិព្វសម្បត្តិកើតបានយ៉ាងនោះឬ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះថេរៈថា មោគ្គល្លាន អ្នកនិយាយអ្វី ឧបមាដូចបុគ្គលដែលឈរត្រង់ទ្វារ ឃើញបុត្របងប្អូនដែលទៅកាន់ទឹកដីឆ្ងាយអស់កាលយូរត្រឡប់មក គប្បីមកកាន់ផ្ទះដោយរហ័សប្រាប់ថា មនុស្សឈ្មោះនោះមកហើយ បើដូច្នោះពួកញាតិរបស់គាត់ក៏ត្រេកអរហើយ ចេញមកដោយរួសរាន់ គប្បីត្រេកអរក្រៃលែងជាមួយបុគ្គលនោះថា ពុកមកហើយ ពុកមកហើយយ៉ាងណា ពួកទេវតាកាន់យកគ្រឿងបណ្ណាការដែលជាទិព្វ ១០ យ៉ាង ទទួល ដោយគិតថា ខ្ញុំមុនៗ ហើយរមែងត្រេកអរនឹងស្ត្រី ឬបុរស ដែលធ្វើ

បុណ្យក្នុងលោកនេះ លះលោកនេះទៅហើយ ទៅកាន់លោកខាងមុខដូច្នោះ ដូចគ្នា ដូច្នេះហើយ បានភាសិតព្រះគាថាទាំងនេះថា

ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ
ញាតី មិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ
តថេវ កតបុញ្ញម្បិ អស្មា លោកា បរំ គតំ
បុញ្ញានិ បដិគ្គណ្ហន្តិ ចិយំ ញាតីវ អាគតំ។

ពួកញាតិក្តី មិត្រក្តី សម្លាញ់ក្តី រមែងត្រេកអរនឹងបុរសដែលឃ្លាតគ្នាអស់កាលយូរ មកអំពីចម្ងាយដោយសួស្តីមកដល់ហើយ យ៉ាងណាមិញ បុណ្យទាំងឡាយ តែងទទួលបុគ្គលដែលបានធ្វើបុណ្យ ច្យុតអំពីមនុស្សលោកនេះទៅកាន់លោកខាងមុខ ដូចញាតិទាំងឡាយទទួលបុរសជាទីស្រឡាញ់ ទើបមកដល់ដូច្នោះឯង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ចិរប្បវាសឹ** *គឺចេញទៅហើយអស់កាលយូរ ។*

បាទព្រះគាថាថា **ទូរតោ សោត្ថិមាគតំ** *សេចក្តីថា បុគ្គលបាននូវលាភគឺមានសម្បត្តិដែលសម្រេចហើយ ព្រោះធ្វើពាណិជ្ជកម្ម ឬព្រោះធ្វើនូវទីដែលរាជបុរសមកហើយអំពីចម្ងាយ ដោយមិនមានឧបទ្រវៈ ។*

បាទព្រះគាថា **ញាតី មិត្តា សុហជ្ជា ច** *សេចក្តីថា ដល់ជនដែលឈ្មោះថា ញាតិ ព្រោះអាចទាក់ទងគ្នាដោយត្រកូល និងឈ្មោះថា មិត្រ*

ព្រោះភាវៈដែលធ្លាប់ឃើញគ្នាជាដើម ហើយឈ្មោះថា មានចិត្តល្អ ព្រោះ ភាពជាអ្នកមានហទយៈល្អ ។

បាទព្រះគាថាថា **អភិនន្ទន្តិ អាគតំ** *សេចក្តីថា ញាតិជាដើម ឃើញ បុរសនោះហើយ រមែងត្រេកអរក្រៃលែងដោយអាការត្រឹមតែពោលថា មក ល្អហើយ ឬដោយអាការត្រឹមតែធ្វើអញ្ជលី ម្យ៉ាងទៀត រមែងត្រេកអរ ក្រៃលែងនឹងបុគ្គលដែលមកដល់ផ្ទះហើយ ដោយអំណាចនាំទៅចំពោះនូវ បណ្ណាការ មានប្រការផ្សេងៗ ។*

បទថា **តថេវ** *ជាដើម សេចក្តីថា បុណ្យទាំងឡាយ តាំងនៅក្នុងឋានៈ ដូចមាតាបិតានាំគ្រឿងបណ្ណាការ ១០ យ៉ាង គឺអាយុ វណ្ណៈ សុខ យស ភាពជាអធិបតី និងភាពជាទិព្វ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈដែលជាទិព្វ ត្រេកអរ ឈ្មោះថា រមែងទទួលបុគ្គលដែលបានធ្វើបុណ្យហើយ ទៅអំពី លោកនេះ កាន់លោកខាងមុខដោយហេតុនោះឯង ។*

ពីរបទថា **ឥយ្យំ ញាតីវ** *សេចក្តីថា ដូចពួកញាតិដ៏សេស ឃើញញាតិ ជាទីស្រឡាញ់មកហើយ ទទួលក្នុងលោកនេះ ដូច្នោះ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងនន្ទិយឧបាសក ចប់

ឥយ្យវគ្គ ចប់

វគ្គទី ១៦ ចប់

សុត្តន្តបិដក

ធម្មបទគាថា កោធវគ្គទី ១៧

[២៧] បុគ្គលគួរលះបង់សេចក្តីក្រោធចេញ គួរលះបង់មានះចេញ គួរកន្ធងសញ្ញោជនធម៌ទាំងអស់ចោលចេញ ទុក្ខទាំងឡាយ តែងមិនជាប់តាមបុគ្គល ដែលមិនជំពាក់ក្នុងនាម និងរូប មិនមានកិលេស គ្រឿងកង្វល់នោះឡើយ ។

បុគ្គលណា ឃាត់សេចក្តីក្រោធ ដែលកើតឡើងហើយ ដូចសារថីទប់រថដែលកំពុងលឿនបាន តថាគតហៅបុគ្គលនោះថាជាសារថី ជនក្រៅពីនេះគ្រាន់តែជាអ្នកកាន់ខ្សែបរ (មិនមែនសារថីឡើយ) ។ បុគ្គលគប្បីផ្តាញ់មនុស្សក្រោធ ដោយសេចក្តីមិនក្រោធ គប្បីផ្តាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្តាញ់មនុស្សកំណាញ់ ដោយការឲ្យ គប្បីផ្តាញ់មនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ។ បុគ្គលគួរពោលពាក្យពិត ១ មិនគួរក្រោធ ១ កាលគេសុំវត្ថុសូម្បីមានតិច ក៏គួរឲ្យ (តាមតិច) ១ បុគ្គលគប្បីទៅកើតក្នុងសម្នាក់ទេវតាទាំងឡាយបាន ដោយហេតុទាំង ៣ នេះឯង ។

ជនទាំងឡាយណាជាអ្នកប្រាជ្ញ មិនបៀតបៀនសត្វដទៃ សង្រួមហើយដោយកាយទ្វារ (ជាដើម) ជានិច្ច ជនទាំងឡាយនោះ រមែងទៅកាន់ស្ថានដ៏មិនប្រែប្រួល ជាស្ថានដែលគេទៅដល់ហើយ តែងមិនសោកស្តាយ ។

អាសវៈទាំងឡាយរបស់បុគ្គល អ្នកភ្ញាក់រឭកសព្វកាល ជាអ្នកសិក្សាត្រៃសិក្ខា ទាំងថ្ងៃ ទាំងយប់ មានចិត្តចុះស៊ប់កាន់ព្រះនិព្វាន តែងដល់នូវការតាំងនៅមិនបានឡើយ ។

ម្នាលអតុលៈ ការតិះដៀល និងការសរសើរនេះ ជារបស់បុរាណ ការតិះដៀល និងការសរសើរនេះ មិនមែនទើបនឹងកើតឡើងក្នុងថ្ងៃនេះទេ (ព្រោះថា) ជនទាំងឡាយ តែងនិន្ទាបុគ្គលអ្នកអង្គុយស្ងៀមក៏មាន និន្ទាបុគ្គលអ្នកនិយាយច្រើនក៏មាន និន្ទាបុគ្គលអ្នកនិយាយល្មមប្រមាណក៏មាន (អ្នកណាៗក៏ដោយ) ក្នុងលោក ដែលមិនត្រូវគេនិន្ទាគ្មានឡើយ បុគ្គលដែលត្រូវគេនិន្ទាតែម្យ៉ាង ឬត្រូវគេសរសើរតែម្យ៉ាង មិនមែនមានមកហើយ តែក្នុងអតីតទេ នឹងមានទៅក្នុងអនាគតក៏ទេ មានតែក្នុងបច្ចុប្បន្ននេះក៏ទេ ។

បើអ្នកប្រាជ្ញទាំងឡាយសង្កេតមើលរាល់ៗ ថ្ងៃ ហើយសរសើរបុគ្គលណា ដែលជាអ្នកប្រព្រឹត្តមិនជាប់ មានប្រាជ្ញា មានចិត្តតម្កល់ខ្ជាប់ក្នុងបញ្ញា និងសីល អ្នកណាគួរនឹងនិន្ទាបុគ្គល ដែលដូចជាឆ្នោរនៃមាសជម្ពោនទនោះបាន សូម្បីទេវតា និងមនុស្សទាំងឡាយ ក៏សរសើរបុគ្គលនោះ ទាំងព្រហ្មក៏សរសើរ (ដូចគ្នា) ។ បុគ្គលគប្បីរក្សានូវការកម្រើកកាយ គប្បីសង្រួមកាយ គប្បីលះបង់កាយទុច្ចរិត គប្បីប្រព្រឹត្តកាយសុចរិត គប្បីរក្សានូវការកម្រើកវាចា គប្បីសង្រួមវាចា គប្បីលះបង់វចីទុច្ចរិត គប្បីប្រព្រឹត្តវចីសុចរិត គប្បីរក្សានូវការកម្រើកចិត្ត គប្បីសង្រួមចិត្ត គប្បីលះបង់មនោទុច្ចរិត គប្បីប្រព្រឹត្តមនោសុចរិត អ្នកប្រាជ្ញទាំងឡាយ បានសង្រួមកាយ សង្រួមវាចា អ្នកប្រាជ្ញទាំងឡាយ បានសង្រួមចិត្តហើយ លោកទាំងនោះឯង ឈ្មោះថាសង្រួមហើយដោយប្រពៃ ។

ភោជវគ្គទី ១៧ ចប់

អដ្ឋកថា

កោធវគ្គធី ៧៣

រឿង ព្រះនាងរោហិណី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារព្ធព្រះនាងរោហិណី ត្រាស់ព្រះធម្មទេសនានេះថា **កោធំ ជហេ** ជាដើម ។

បានឣថា គ្រាមួយ ព្រះអនុរុទ្ធបានទៅកាន់ក្រុងកបិលពស្តុ មួយអន្ធើ ដោយភិក្ខុ ៥០០ កាលនោះ ពួកព្រះញាតិរបស់លោក បានដំណឹងថាព្រះថេរៈ និមន្តមក ទើបទៅកាន់សម្នាក់ព្រះថេរៈ រៀរតែប្អូនស្រីរបស់ព្រះថេរៈ ឈ្មោះ រោហិណី ។ ព្រះថេរៈសួរពួកព្រះញាតិថា ព្រះនាងរោហិណីនៅឯណា ពួក ព្រះញាតិប្រាប់ថា បពិត្រលោកម្ចាស់ នៅក្នុងដំណាក់ ព្រះថេរៈសួរថា ហេតុ អ្វីទើបមិនយាងមក ពួកញាតិប្រាប់ថា ព្រះនាងមិនអាចមកដោយខ្មាស ព្រោះ ថា រោគសើស្បែកកើតត្រង់សរីរៈរបស់នាង ។

ព្រះថេរៈពោលថា ចូរអ្នកទាំងឡាយយាងព្រះនាងមកចុះ ឲ្យទៅយាង ព្រះនាងមកហើយ ទើបពោលយ៉ាងនេះនឹងព្រះនាង ដែលយាងមកហើយថា រោហិណី ហេតុអ្វីទើបព្រះនាងមិនយាងមក ព្រះនាងរោហិណីប្រាប់ថា បពិត្រ លោកម្ចាស់ រោគស្បែកកើតឡើងត្រង់សរីរៈរបស់ខ្ញុំ ហេតុនោះទើបខ្ញុំមិនបាន

មកព្រោះខ្លាស ព្រះថេរៈជ្រាបថា បើព្រះនាងធ្វើបុណ្យមិនគួរឬ ព្រះនាងរោហិណី សួរថា បពិត្រលោកម្ចាស់ តើធ្វើអ្វី ព្រះថេរៈពោលថា ចូរសាងរោងធាន់ ព្រះនាងរោហិណីសួរថា ខ្ញុំនឹងយកអ្វីធ្វើ ព្រះថេរៈជ្រាបថា គ្រឿងប្រដាប់របស់នាងមិនមានឬ ព្រះនាងរោហិណីពោលថា បពិត្រលោកម្ចាស់ មាន ព្រះថេរៈសួរថា តម្លៃប៉ុន្មាន ព្រះនាងរោហិណីទូលថា មានតម្លៃមួយម៉ឺន ។ ព្រះថេរៈពោលថា បើដូច្នោះ ចូរលក់គ្រឿងប្រដាប់នោះឲ្យសាងរោងធាន់ចុះ ។

ព្រះនាងរោហិណីពោលថា បពិត្រលោកម្ចាស់ អ្នកណានឹងធ្វើឲ្យខ្ញុំ ។ ព្រះថេរៈសម្លឹងមើលញាតិដែលឈរក្នុងទីជិតហើយ ពោលថា ចូរជាការៈរបស់ពួកអ្នកទាំងឡាយចុះ ។ ពួកព្រះញាតិពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់នឹងធ្វើអ្វី ព្រះថេរៈពោលថា អាត្មានឹងនៅក្នុងទីនេះដូចគ្នា បើដូច្នោះ ចូរពួកអ្នកនាំទព្វសម្ភារៈមកដើម្បីរោងធាន់នេះ ។ ពួកព្រះញាតិទទួលថា សាធុ លោកម្ចាស់ ទើបនាំមកហើយ ។

ព្រះថេរៈរៀបចំរោងធាន់ ទើបពោលនឹងនាងរោហិណីថា ចូរនាងធ្វើរោងធាន់ពីរជាន់ ចាប់តាំងអំពីកាលដែលឲ្យផ្ទៃជាន់លើរៀបហើយ ចូរបោសផ្ទៃខាងក្រោម ហើយក្រាលអាសនៈជានិច្ច ចូរឲ្យតាំងធ្នាំងទឹកផឹកជានិច្ច ។ ព្រះនាងទទួលថា សាធុលោកម្ចាស់ ហើយចំណាយគ្រឿងប្រដាប់ឲ្យធ្វើរោងធាន់ពីរជាន់ ផ្តើមតាំងអំពីកាលដែលឲ្យផ្ទៃខាងលើរៀបហើយ បានធ្វើកិច្ច មានការបោសផ្ទៃខាងក្រោមជាដើមរឿយៗ ។ ពួកភិក្ខុក៏អង្គុយជានិច្ច ។

លំដាប់នោះ កាលព្រះនាងបោសរោងធាន់នោះឯង រោគស្បែកក៏អន់ថយ

ទៅហើយ ។ កាលភោជនសម្រេច ព្រះនាងនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ បានថ្វាយខាទនីយៈដែលប្រណីតដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានគង់ពេញភោជនសព្រាប់ ។

ព្រះសាស្តា ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ត្រាស់សួរថា នេះជាទានរបស់អ្នកណា ព្រះអនុរុទ្ធពោលថា របស់នាងភេហិណីបួនស្រីរបស់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា នាងទៅណា ព្រះអនុរុទ្ធទូលថា បពិត្រព្រះអង្គ នៅក្នុងជំណាក់ ព្រះសាស្តាត្រាស់ថា ចូរពួកអ្នកហៅនាងមក ។

ព្រះនាងមិនបំណងនឹងយាងមក ពេលនោះព្រះសាស្តាត្រាស់ឲ្យហៅព្រះនាងដែលមិនប្រាថ្នានឹងមកទាល់តែបាន ឯព្រះសាស្តាត្រាស់នឹងព្រះនាងដែលយាងមកថ្វាយបង្គំប្រថាប់គង់ហើយថា ភេហិណី ហេតុអ្វីទើបនាងមិនមក ព្រះនាងភេហិណីទូលថា បពិត្រព្រះអង្គ ភេគស្បែកកើតត្រង់សរីរៈរបស់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់ខ្មាសដោយភេគនោះ ទើបមិនបានមក ។

ព្រះសាស្តាត្រាស់ថា នាងដឹងទេថា ភេគនុ៎ះ អាស្រ័យកម្មអ្វីរបស់នាងទើបកើតឡើង ។ ព្រះនាងភេហិណីទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់មិនដឹងទេ ព្រះសាស្តាត្រាស់ថា ភេគនុ៎ះ អាស្រ័យសេចក្តីក្រោធរបស់នាងទើបកើតឡើងហើយ ព្រះនាងភេហិណីទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់បានធ្វើកម្មអ្វី ។

លំដាប់នោះ ព្រះសាស្តា ទ្រង់នាំអតីតនិទានមកត្រាស់ដល់ព្រះនាងថា

ក្នុងអតីតកាល អគ្គមហេសីរបស់ព្រះបាទពារាណសី ចងអាឃាតក្នុងអ្នករបាំម្នាក់របស់ព្រះរាជា ព្រះនាងត្រិះរិះថា អញនឹងឲ្យទុក្ខដល់ស្រីនេះ ហើយ

ឲ្យគេនាំខ្វែរធំមក ត្រាស់ឲ្យហៅស្រីអ្នករបាំនោះមកកាន់សម្នាក់របស់ខ្លួនហើយ ឲ្យជាក់កមេ្ចខ្វែរលើដំណេក ត្រង់សំពត់ដណ្តប់ និងគ្រឿងប្រើប្រាស់ មានកម្រាលដេកជាដើមរបស់អ្នករបាំនោះ ដោយប្រការដែលនាងមិនដឹងខ្លួន ជាប លើខ្លួនរបស់នាង ធ្វើនូវការចំអកលេង រំពេចនោះឯងខ្លួនប្រាណរបស់អ្នករបាំនោះបានពងឡើងជាជុំតូចជុំធំ នាងអេះ ទៅដេកលើដំណេក កាលនាងត្រូវកមេ្ចខ្វែរលើដំណេកនោះ វេទនាដ៏ខ្លាំងបានកើតឡើងហើយ ។ អគ្គមហេសីក្នុងកាលនោះ បានជាព្រះនាងរោហិណី ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា ម្នាលនាងរោហិណី កម្មនោះ ដែលនាងធ្វើហើយក្នុងកាលនោះ សេចក្តីក្រោធក្តីការច្រណែនក្តី សូម្បីមានប្រមាណតិចតួច រមែងមិនគួរធ្វើឡើយ ដូច្នេះហើយ ទើបត្រាស់ ព្រះគាថានេះថា

កោធំ ជហេ វិប្បជហេយ្យ មានំ សញ្ញោជនំ សព្វមតិក្កមេយ្យ
តណ្ហាមរូបស្មិ មសជ្ជមានំ អកិញ្ចនំ នានុបតន្តិ ទុក្ខា ។

បុគ្គលគួរលះបង់សេចក្តីក្រោធចេញ គួរលះបង់មានះចេញ គួរកន្លងសញ្ញោជនធម៌ទាំងអស់ចោលចេញ ទុក្ខទាំងឡាយតែងមិនជាប់តាមបុគ្គល ដែលមិនចំពាក់ក្នុងនាម និងរូប មិនមានកិលេសគ្រឿងកង្វល់នោះឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កោធំ** *សេចក្តីថា គប្បីលះសេចក្តីក្រោធ*

គ្រប់ៗ អាការក្តី មាន: ៩ យ៉ាងក្តី ។

បទថា **សញ្ញោជនំ** *សេចក្តីថា គប្បីកន្ធងនូវសញ្ញោជន:ទាំង ១០ យ៉ាង មានកាមរាគសញ្ញោជន:ជាដើម ។*

បទថា **មសជ្ជមានំ** *សេចក្តីថា មិនជាប់ជំពាក់ អធិប្បាយថា បុគ្គលណា ទាញយកនាមរូបដោយនយ័ថា រូបរបស់អញ វេទនារបស់អញជាដើម កាលនាមរូបនោះបែកទៅ រមែងសោយសោកក្តៅក្រហាយ បុគ្គលនេះ ឈ្មោះថា ជាប់ជំពាក់ក្នុងនាមរូប ចំណែកបុគ្គលមិនប្រកាន់យ៉ាងនោះ ឈ្មោះថា រមែងមិនជាប់ជំពាក់ ឈ្មោះថា ទុក្ខទាំងឡាយ រមែងមិនធ្លាក់ត្រូវបុគ្គលនោះ បុគ្គលមិនជាប់ជំពាក់នោះ ឈ្មោះថា មិនមានកិលេសជាគ្រឿងកង្វល់ ព្រោះមិនមានរាគ:ជាដើម ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ព្រះនាងរោហិណីក៏តាំងនៅក្នុងសោតាបត្តិផល សរីរ:របស់ព្រះនាងមានពណ៌ដូចមាសក្នុងខណ:នោះឯង ។ ព្រះនាងចុតិចាកអត្តភាពនោះហើយ កើតក្នុងរវាងដែននៃទេវបុត្រ ៤ អង្គ ក្នុងស្ថានតាវត្តិង្ស ជានជាអ្នកគួរជ្រះថ្លា ដល់នូវភាពជាបុគ្គលមានរូបស្អាតក្រៃលែង ទេវបុត្រទាំង ៤ អង្គឃើញនាងហើយ កើតនូវសេចក្តីស្រឡាញ់ដណ្តឹមគ្នាថា នាងកើតក្នុងដែនរបស់យើង នាងកើតក្នុងដែនរបស់យើង ទៅកាន់សម្នាក់របស់សក្កទេវរាជក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គទាំង ៤ កើតនូវក្តីព្រោះអាស្រ័យទេពធីតានេះ សូមទ្រង់វិនិច្ឆ័យ

ក្តីនោះ ។ សក្កទេវរាជគ្រាន់តែឃើញព្រះនាង ក៏កើតសេចក្តីស្រឡាញ់ ត្រាស់យ៉ាងនេះថា ចាប់តាំងពីកាលដែលពួកអ្នកឃើញទេពធីតានេះហើយ ចិត្តកើតឡើងដូចម្តេច ។

លំដាប់នោះ ទេវបុត្រមួយអង្គក្រាបទូលថា ចិត្តរបស់ខ្ញុំព្រះអង្គដូចស្ពារក្នុងពេលសង្គ្រាម មិនអាចស្ងប់បានឡើយ ។ ទេវបុត្រអង្គទី ២ ទូលថា ចិត្តរបស់ខ្ញុំព្រះអង្គដូចទឹកហូរធ្លាក់អំពីកំពូលភ្នំ រមែងប្រព្រឹត្តទៅរហ័សនោះឯង ។ ទេវបុត្រអង្គទី ៣ ទូលថា ចាប់តាំងពីកាលដែលខ្ញុំព្រះអង្គឃើញនាងហើយ ភ្នែកទាំងពីរលៀនចេញហើយ ដូចភ្នែករបស់ក្តាម ។ ទេវបុត្រអង្គទី ៤ ពោលថា ចិត្តរបស់ខ្ញុំព្រះអង្គដូចទង់ដែលគេលើកឡើងលើចេតិយ មិនអាចតាំងនៅស្ងៀមបាន ។

គ្រានោះ សក្កទេវរាជត្រាស់នឹងទេវបុត្រ ៤ អង្គនោះថា បាទាំងឡាយ ចិត្តរបស់ពួកអ្នកល្មមអត់សង្កត់បាន ចំណែកខ្ញុំ កាលបានឃើញទេពធីតានេះទើបជាអ្នករស់នៅ បើមិនបាននឹងស្លាប់ ។ ទើបពួកទេវបុត្រទូលថា បពិត្រមហារាជ ពួកខ្ញុំព្រះអង្គ មិនត្រូវការដោយការស្លាប់របស់ព្រះអង្គ ហើយលះបង់ទេពធីតានោះថ្វាយសក្កទេវរាជ រួចចៀសចេញទៅ ។ ទេពធីតានោះបានជាទីសព្វព្រះហឫទ័យរបស់សក្កទេវរាជ កាលនាងក្រាបទូលថា ខ្ញុំម្ចាស់នឹងទៅកាន់ឧទ្យានឈ្មោះនោះ សក្កទេវរាជក៏មិនអាចជំទាស់ពាក្យរបស់នាងបានឡើយ ដូច្នេះឯង ។

រឿង ព្រះនាងភោគវតី ចប់

រឿង ភិក្ខុមួយរូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅត្រង់អគ្គាឡវចេតិយ ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **យោ វ ឧប្បតិតំ កោធំ** ជាដើម ។

សេចក្តីពិស្តារ ព្រះសាស្តា កាលទ្រង់អនុញ្ញាតសេនាសនៈដល់ភិក្ខុសង្ឃ ហើយ កាលសេនាសនៈទាំងឡាយ ដែលគ្រហស្តទាំងឡាយ មានសេដ្ឋីអ្នកក្រុងរាជគ្រឹះជាដើមកំពុងឲ្យសាង ភិក្ខុក្រុងអាឡវីមួយរូប ធ្វើសេនាសនៈរបស់ខ្លួន ឃើញដើមឈើដែលពេញចិត្តមួយដើមហើយ ផ្តើមនឹងកាប់ ទេវតាកូនខ្ចីមួយអង្គ រូបកើតត្រង់ដើមឈើនោះ ពកូនដោយចង្កេះឈរអង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំកាប់វិមានរបស់ខ្ញុំទ្បើយ ខ្ញុំមិនមានលំនៅ មិនអាចពកូនត្រាច់ ទៅកាន់ទីផ្តេសផ្តាសបានទ្បើយ ។

ភិក្ខុនោះគិតថា អញនឹងមិនបានដើមឈើបែបនេះក្នុងទីដទៃ ទើបមិនអើពើនឹងពាក្យរបស់ទេវតានោះ ។ ទេវតានោះគិតថា ភិក្ខុនេះ ឃើញទារកនេះហើយ គង់នឹងវៀរពិត ទើបដាក់បុត្រត្រង់មែកឈើ ។ ចំណែកភិក្ខុនោះ មិនអាចញាំងពូថៅ ដែលខ្លួនងាឡើងហើយបាន ទើបកាប់ដៃទារកនោះដាច់ហើយ ទេវតាកើតសេចក្តីក្រោធដ៏មានកម្លាំង លើកដៃទាំងពីរឡើង ដោយចេតនាថា នឹងទះភិក្ខុនោះឲ្យស្លាប់ តែគិតទាន់យ៉ាងនេះថា ភិក្ខុនេះជាអ្នកមានសីល បើអញសម្លាប់ភិក្ខុនេះនឹងទៅកាន់នរក សូម្បីទេពធីតាដ៏សេស បានជួបភិក្ខុកាប់ដើមឈើរបស់ខ្លួន នឹងយកតម្រាប់តាមខ្លះថា ទេវតាអង្គនោះ សម្លាប់

កិក្ខុ អញ្ជក៏ធ្វើយ៉ាងនោះដូចគ្នា ហើយនឹងសម្លាប់កិក្ខុទាំងឡាយបង់ កិក្ខុនេះមានម្ចាស់ អញនឹងត្រូវប្រាប់ដល់ម្ចាស់នោះឯង បញ្ឈប់ដៃទាំងពីរហើយទ្រហោយំ ទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំហើយ ឈរក្នុងទីសមគួរ នាចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា ម្នាលទេពធីតា តើនាងមានរឿងអ្វី ទេពធីតានោះពោលថា បពិត្រព្រះអង្គ សាវ័ករបស់ព្រះអង្គធ្វើកម្មឈ្មោះនេះ ខ្ញុំម្ចាស់ប្រាថ្នានឹងសម្លាប់ តែគិតទាន់ ទើបមិនសម្លាប់ ហើយប្រញាប់មកទីនេះឯង ដូច្នេះហើយ ក្រាបទូលរឿងនោះដោយពិស្តារ ។

ព្រះសាស្តា ទ្រង់ស្តាប់រឿងនោះហើយត្រាស់ថា ម្នាលទេពធីតា ត្រឹមត្រូវហើយ នាងសង្កត់សេចក្តីក្រោធដែលកើតឡើងយ៉ាងនោះ ដូចហាមរថកំពុងវិលទៅបាន ឈ្មោះថាធ្វើល្អហើយដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

យោ វេ ឧប្បតិតំ កោធំ រថំ ភន្តំ ធារយេ
តមហំ សារថឹ ព្រូមិ រស្មិគ្គាហោ ឥតរោ ជនោ ។

បុគ្គលណាឃាត់សេចក្តីក្រោធ ដែលកើតឡើងហើយ ដូចសារថីទប់រថដែលកំពុងលឿនបាន តថាគតហៅបុគ្គលនោះថាជាសារថី ជនក្រៅអំពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរ (មិនមែនសារថីឡើយ) ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះបទថា **ឧប្បតិតំ** *បានដល់ ដែលកើតឡើងហើយ ។*

ពីរបទថា **រថំ ភន្តំវ** *សេចក្តីថា ដូចនាយសារថីដែលឈ្វាស ហាមទូរថដែលកំពុងស្ទុះទៅ ដោយសម្ទុះដ៏រហ័ស បញ្ឈប់បានតាមត្រូវការយ៉ាងណា បុគ្គលណាគប្បីសង្កត់ គឺអាចឃាត់សេចក្តីក្រោធដែលកើតឡើងបានក៏ដូច្នោះ ។*

បទថា **តមហំ** *សេចក្តីថា តថាគតហៅបុគ្គលនោះ ថាជាសារថី ។*

ពីរបទថា **ឥតរេ ជនេ** *សេចក្តីថា ចំណែកជនក្រៅអំពីនេះ គឺសារថីរថរបស់ឥស្សរជន មានព្រះរាជា និងឧបរាជជាដើម រមែងឈ្មោះថាត្រឹមតែជាអ្នកកាន់ខ្សែ មិនមែនជាសារថីដ៏កំពូលឡើយ ។*

ក្នុងកាលចប់ទេសនា ទេវតាតាំងនៅក្នុងសោតាបត្តិផល ទេសនាមានប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

ចំណែកទេពធីតា បានជាព្រះសោតាបន្ន ក៏នៅតែឈរយំ ។ គ្រានោះ ព្រះសាស្តាត្រាស់សួរទេវតានោះថា ម្នាលទេពធីតា នាងមានរឿងអ្វី កាលទេវតាទូលថា បពិត្រព្រះអង្គ វិមានរបស់ខ្ញុំម្ចាស់ព្រះអង្គវិនាសហើយ ឥឡូវនេះ ខ្ញុំម្ចាស់ធ្វើដូចម្តេច ទើបត្រាស់ថា កុំឡើយទេពធីតា នាងកុំគិត តថាគតនឹងឲ្យវិមានដល់នាង ហើយចង្អុលដើមឈើមួយដែលទេវតាចុតិទៅ កាលពីថ្ងៃមុន ក្បែរព្រះគន្ធកុដិ ក្នុងវត្តជេតពន ត្រាស់ថា ដើមឈើនោះ នៅក្នុងឱកាសឈ្មោះនោះ ទំនេរ ចូរនាងនៅអាស្រ័យត្រង់ដើមឈើនោះចុះ ។ ទេវតានោះចូលទៅអាស្រ័យដើមនោះហើយ តាំងអំពីនោះ ទេវតាដែលមានសក្តិធំដ៏ងថា វិមានរបស់ទេវតានេះ ព្រះសម្ពុទ្ធទ្រង់ប្រទាន ក៏មិនអាចធ្វើឲ្យនាងញាប់ញ័របាន ។

ព្រះសាស្តា ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុហើយ ទ្រង់បញ្ញត្ត ភូតគាមសិក្ខាបទដល់ភិក្ខុទាំងឡាយ ដូច្នេះឯង ។

រឿង ភិក្ខុមួយរូប ចប់

រឿង ឧត្តរាឧបាសិកា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ធ្វើភត្តកិច្ចក្នុងផ្ទះរបស់នាងឧត្តរាហើយ ទ្រង់ប្រោរព្ធឧត្តរាឧបាសិកា ត្រាស់ព្រះធម្មទេសនានេះថា **អក្កោធេន ជិនេ កោធំ** *ជាដើម ។*

អនុបុព្វីកថាក្នុងរឿងឧត្តរាឧបាសិកានោះដូចតទៅនេះ

បានឮថា អ្នកកម្សត់ទុគ៌តឈ្មោះបុណ្ណៈ អាស្រ័យសុមនសេដ្ឋី ស៊ីឈ្នួលចិញ្ចឹមជីវិត នៅក្នុងក្រុងរាជគ្រឹះ ។ ក្នុងផ្ទះរបស់បុណ្ណៈ មានមនុស្សពីរនាក់ប៉ុណ្ណោះគឺ ភរិយារបស់គេម្នាក់ និងធីតាឈ្មោះឧត្តរាម្នាក់ ។

សម័យមួយ ពួករាជបុរសធ្វើនូវការឃោសនាក្នុងក្រុងរាជគ្រឹះថា អ្នកនគរគប្បីលេងនក្ខត្តឫក្សអស់ ៧ ថ្ងៃ ។ សុមនសេដ្ឋី បានឮពាក្យឃោសនានោះហើយ ទើបហៅបុណ្ណៈមកអំពីព្រលឹមពោលថា នែបា បរិជនរបស់ខ្ញុំបំណងនឹងលេងនក្ខត្តឫក្ស អ្នកនឹងលេងនក្ខត្តឫក្សដែរឬ ឬទៅធ្វើការស៊ីឈ្នួល បុណ្ណមាណពពោលថា បពិត្រលោកម្ចាស់ ឈ្មោះថា ការលេងនក្ខត្តឫក្ស ជា

របស់ពួកអ្នកមានទ្រព្យ ក្នុងផ្ទះរបស់ខ្ញុំ អង្ករសម្រាប់ដាំបាយ ដើម្បីទទួលទានក្នុងថ្ងៃស្អែកនេះក៏មិនមាន ។ ខ្ញុំត្រូវការអ្វីដោយនក្ខត្តឫក្ស ខ្ញុំបានគោហើយក៏និងទៅភ្ជួរស្រែ ។ សុមនសេដ្ឋីពោលថា បើដូច្នោះ ចូរឯងទទួលគោទៅចុះ ។ បុណ្ណមាណពបានទទួលគោដែលមានកម្លាំង និងនង្គ័លហើយ និយាយនឹងភរិយាថា នាងដ៏ចម្រើន អ្នកនគរលេងនក្ខត្តឫក្ស ខ្ញុំត្រូវទៅធ្វើការងារស៊ីឈ្នួល ព្រោះយើងជាមនុស្សក្រីក្រ ថ្ងៃនេះ នាងគប្បីស្ងោរបន្ទៃពីរចំណែកហើយនាំកត្តាទៅឲ្យខ្ញុំ រួចទៅស្រែ ។

ក្នុងកាលនោះ ព្រះសារីបុត្តត្ថេរ ចូលនិរោធសមាបត្តិ ៧ ថ្ងៃហើយ ក្នុងថ្ងៃនោះ ចេញហើយ ពិនិត្យមើលថា ថ្ងៃនេះ អាត្មាអញគួរប្រោសដល់អ្នកណាហ្ន៎ ឃើញបុណ្ណមាណពចូលក្នុងសំណាញ់ញាណរបស់ខ្លួនហើយ ពិចារណាថា បុណ្ណៈនេះមានសទ្ធាឬហ្ន៎ គេអាចសង្គ្រោះដល់អាត្មាអញដែរឬទេ ជ្រាបភាពដែលគេមានសទ្ធា អាចធ្វើការសង្គ្រោះបាន ហើយគេបានទទួលសម្បត្តិធំ ព្រោះបុណ្យនោះជាបច្ច័យហើយ ទើបកាន់យកបាត្រ និងចីវរ ទៅកាន់ទីភ្ជួរស្រែរបស់បុណ្ណៈ ឈរមើលគុម្ពឈើក្បែរមាត់អណ្តូង បុណ្ណៈឃើញព្រះថេរៈហើយ ទើបដាក់នង្គ័លថ្វាយបង្គំព្រះថេរៈ ដោយបញ្ជូនប្រតិស្ថានគិតថា ព្រះថេរៈប្រហែលជាត្រូវការឈើសួន់ ទើបកាត់ឈើដែលជាកប្បិយប្រគេន ។

លំដាប់នោះ ព្រះថេរៈបាននាំយកបាត្រ និងសំពត់តម្រងទឹកចេញមកឲ្យគាត់គិតថា ព្រះថេរៈនឹងត្រូវការដោយទឹកផាន់ ទើបកាន់យកបាត្រ និងសំពត់

តម្រង់ទឹកនោះហើយ ត្រង់ទឹកប្រគេន ។ ព្រះថេរៈគិតថា បុណ្ណៈនេះ នៅផ្ទះចុងគេនៃជនដទៃ បើអាត្មាអញទៅកាន់ផ្ទះរបស់គេ ភរិយារបស់បុណ្ណៈនេះនឹងមិនបានឃើញអាត្មាអញ ដូច្នេះ អាត្មាអញគួរនៅក្នុងទីនេះឯង ទម្រាំភរិយារបស់គេនាំកត្តដើរតាមផ្លូវមក ។ ព្រះថេរៈបានញុំាងកាលឲ្យកន្លងទៅបន្តិចបន្តួចក្នុងទីនោះឯង ជ្រាបភាពដែលភរិយារបស់បុណ្ណៈនោះ ទៅដល់កាន់ផ្លូវហើយ ទើបដើរបែរមុខទៅខាងក្នុងព្រះនគរ ។

នាងជួបព្រះថេរៈក្នុងរវាងផ្លូវហើយ គិតថា ជួនកាល ទេយ្យធម៌របស់អញមាន ជួនកាល កាលអញជួបលោកម្ចាស់ តែទេយ្យធម៌មិនមាន ថ្ងៃនេះអញជួបលោកម្ចាស់ផង ទេយ្យធម៌ក៏មានផង លោកម្ចាស់នឹងធ្វើសេចក្តីអនុគ្រោះដល់អញ ឬអត់ហ្ន៎ នាងដាក់កាជនៈកត្តចុះហើយ ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋានហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំគិតថ្វីថា កត្តនេះសៅហ្មង ឬប្រណីត សូមអនុគ្រោះដល់ទាសៈរបស់លោកម្ចាសផងចុះ ។

ព្រះថេរៈបង្អោនបាត្រចូលទៅ កាលនាងយកដៃម្ខាងទទួលកាជនៈ ម្ខាងទៀតប្រគេនកត្ត កាលបានពាក់កណ្តាលទើបបិទបាត្រ ដោយពោលថា លុមហើយ ។ នាងពោលថា បពិត្រលោកម្ចាស់ ចំណែកត្រឹមតែមួយចំណែកខ្ញុំមិនអាចធ្វើឲ្យជាពីរចំណែកបាន លោកម្ចាស់ មិនចាំបាច់ធ្វើការសង្គ្រោះដល់ទាសៈរបស់លោកម្ចាស់តែក្នុងលោកនេះ សូមធ្វើសេចក្តីសង្គ្រោះក្នុងបរលោកចុះ ខ្ញុំបំណងនឹងប្រគេនមិនឲ្យសេសសល់ឡើយ ដូច្នេះហើយ បានដាក់កត្ត

ទាំងអស់ចូលក្នុងជាត្រព្រះថេរៈ ហើយធ្វើសេចក្តីប្រាថ្នាថា ខ្ញុំគប្បីជាអ្នកមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយនោះឯង ។

ព្រះថេរៈពោលថា ចូរសម្រេចយ៉ាងនោះចុះ ឈរធ្វើអនុមោទនាហើយអង្គុយធ្វើកត្តកិច្ច ក្នុងទីដែលមានទឹកមួយកន្លែង ។

ចំណែកនាង ត្រឡប់ទៅរកអង្គរចម្ងិនជាកត្តហើយ ។ សូម្បីបុណ្ណៈភ្ជួរជីបានប្រមាណកន្ទុះកវែស មិនអាចអត់ធន់នឹងការស្រេកឃ្លានបាន ទើបដោះគោ ចូលទៅកាន់ម្លប់ឈើមួយកន្លែង អង្គុយចាំមើលផ្លូវ ។

លំដាប់នោះ ភរិយារបស់គាត់កាន់កត្តដើរទៅ គ្រាន់តែឃើញគិតថា ប្តីរបស់អញត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ អង្គុយចាំមើលអញហើយ បើគាត់សម្តីតអញថា ម្តេចក៏ហាងយឺតយូរម៉្លេះ ហើយយកដងជន្ធញ្ជាយអញកម្មដែលអញធ្វើហើយ ជារបស់ឥតប្រយោជន៍ អញគួរស្រែកប្រាប់ដល់គាត់មុននោះឯង ដូច្នេះហើយ ទើបពោលយ៉ាងនេះថា អ្នក សូមអ្នកធ្វើចិត្តឲ្យធូរធង់ត្រឹមតែមួយថ្ងៃចុះ ថ្ងៃនេះកុំធ្វើកម្មដែលខ្ញុំធ្វើហើយឲ្យឥតប្រយោជន៍ ខ្ញុំនាំកត្តមកឲ្យអ្នកតាំងអំពីព្រលឹម ជួបព្រះធម្មសេនាបតីក្នុងរវាងផ្លូវ ទើបប្រគេនកត្តរបស់អ្នកដល់ព្រះថេរៈនោះ ហើយទៅចម្ងិនសាជាថ្មី សូមធ្វើចិត្តឲ្យជ្រះថ្លាចុះ ។ បុណ្ណៈសួរថា នែនាង នាងនិយាយអ្វី បានស្តាប់រឿងនោះដដែលទៀត ទើបពោលថា នែនាង នាងប្រគេនកត្តអញដល់លោកម្ចាស់ ជាការធ្វើល្អហើយ កាលពីព្រឹកមិញនេះ អញក៏បានប្រគេនឈើសូន់ និងទឹកខ្ចុរមាត់ដល់លោកម្ចាស់ហើយ មានចិត្តជ្រះថ្លាត្រេកអរនឹងពាក្យនុ៎ះហើយ ជាអ្នកមានកាយទន់

ខ្សោយ ព្រោះបានកត្តក្នុងពេលរសៀល ដាក់ក្បាលកើយភ្លៅរបស់ភរិយានោះ ហើយ ក៏ដេកលក់ទៅ ។

គ្រានោះ ទីដែលបុណ្ណមាណពភ្ជួរអំពីព្រលឹម បានជាមាសទឹកដប់ទាំង អស់ មួយអន្ទើដោយធូលី និងល្អង ក្រហមច្រាលដូចផ្កាកណិការ ។ គាត់ ភ្ញាក់ឡើង សម្លឹងឃើញហើយ ទើបពោលនឹងភរិយាថា នែនាង ទីដែលខ្ញុំភ្ជួរ ហើយនោះ ប្រាកដដល់ខ្ញុំដូចមាសទាំងអស់ ព្រោះខ្ញុំបានកត្តយូរពេក ភ្នែក ប្រហែលជាស្រវាំងទេដឹង ។

ភរិយារបស់គាត់ក៏ទទួលថា ទីនោះក៏រមែងប្រាកដដល់ខ្ញុំយ៉ាងនោះដូចគ្នា គាត់ក្រោកឡើងទៅក្នុងទីនោះ ចាប់មួយដុំវាយនឹងយាមនង្គ័ល ដឹងថាជាមាស ទើបគិតថា ឱ ! ទានដែលយើងប្រគេនព្រះធម្មសេនាបតី ឲ្យផលក្នុងថ្ងៃនេះ ឯង ។ យើងមិនអាចជញ្ជូនទ្រព្យប្រមាណប៉ុណ្ណេះប្រើប្រាស់បានទេ ទើប យកមាសដាក់ពេញថាសបាយ ដែលភរិយាទូលមក ហើយបានទៅកាន់រាជ-ត្រកូល កាលព្រះរាជាប្រទានឱកាសហើយ ទើបចូលទៅថ្វាយបង្គំព្រះរាជា ។ កាលទ្រង់ត្រាស់ថា នែបា នុ៎ះជាអ្វី ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ទីដែលទូលបង្គំបានភ្ជួរហើយ ក្នុងថ្ងៃនេះទាំងអស់ ជាទីពេញទៅដោយមាស តាំងនៅហើយ ព្រះអង្គគួរឲ្យគេជញ្ជូនមក ព្រះរាជាសួរថា អ្នកជាអ្នកណា មាណពទូលថា ទូលបង្គំឈ្មោះ បុណ្ណៈ ព្រះរាជាសួរថា ថ្ងៃនេះ អ្នកធ្វើអ្វី បុណ្ណៈទូលថា ព្រឹកមិញនេះ ទូលបង្គំបានប្រគេនឈើសូន់ និងទឹកខ្ចរមាត់ ដល់ព្រះធម្មសេនាបតី ចំណែកភរិយារបស់ទូលបង្គំ បានប្រគេនកត្តដែលនាង

នាំមកឲ្យទូលបង្គំ ដល់ព្រះធម្មសេនាបតីនោះដូចគ្នា ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា ចាជ័ចម្រើន បានឮថា ទានដែលប្រគេនព្រះធម្មសេនាបតី ឲ្យវិបាកក្នុងថ្ងៃនេះឯង ហើយត្រាស់សួរថា នែចា យើងនឹងធ្វើដូចម្តេច បុណ្ណៈទូលថា សូមទ្រង់បញ្ជូនរនេះច្រើនពាន់ទៅឲ្យនាំមាសមកចុះ ។

ព្រះរាជាទ្រង់បញ្ជូនរនេះទាំងឡាយទៅហើយ កាលពួករាជបុរសពោលថាជារបស់ព្រះរាជាកាន់យក មាសដែលគេកាន់យកហើយ រមែងជាជីដូចមុន ។ ពួករាជបុរសទៅទូលព្រះរាជា កាលទ្រង់ត្រាស់សួរថា ពួកអ្នកពោលដូចម្តេច ទើបកាន់យក ទើបទូលថា ទូលបង្គំពោលថា ជាព្រះរាជទ្រព្យរបស់ព្រះអង្គ ព្រះរាជាត្រាស់ថា មិនមែនជាទ្រព្យរបស់យើងឡើយ ចូរពួកអ្នកទៅ ចូរពោលថាជាទ្រព្យរបស់បុណ្ណៈកាន់យកចុះ ។ ពួករាជបុរសធ្វើយ៉ាងនោះ មាសដែលគេកាន់យកហើយនៅជាមាសពិត ទើបពួកគេជញ្ជូនមាសទាំងអស់នោះ មកធ្វើជាគំនរ ត្រង់លានព្រះរាជវាំង កម្ពស់ប្រមាណ ៨០ ហត្ថ ។

ព្រះរាជាត្រាស់ឲ្យហៅអ្នកនគរប្រជុំគ្នាហើយសួរថា ក្នុងព្រះនគរនេះអ្នកណាមានមាសប្រមាណប៉ុណ្ណេះខ្លះ ពួកអ្នកនគរទូលថា មិនមានទេព្រះអង្គ ព្រះរាជាសួរថា យើងគួរឲ្យអ្វីដល់បុណ្ណមាណព អ្នកនគរទូលថា ឆត្រសម្រាប់សេដ្ឋីក្រាបទូល ព្រះរាជាត្រាស់ថា បុណ្ណៈ ចូរអ្នកជាសេដ្ឋីឈ្មោះពហុធនសេដ្ឋី ហើយបានព្រះរាជទានឆត្រសម្រាប់សេដ្ឋីដល់បុណ្ណៈ មួយអន្ទើដោយភោគៈជ័ច្រើន ។

គ្រានោះ គាត់ក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព ទូលបង្គំទាំងឡាយអាស្រ័យក្នុងត្រកូលជនៃ អស់កាលមានប្រមាណប៉ុណ្ណេះ សូមទ្រង់ព្រះរាជទានលំនៅដល់ទូលបង្គំចុះ ។

ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរអ្នកមើលគុម្ពឈើនោះ ជ្រាកដក្នុងទិសទក្សិណ ចូរឆ្ការគុម្ពឈើចេញឲ្យជាងធ្វើផ្ទះចុះ ដូច្នេះហើយ ក៏ត្រាស់ប្រាប់ទីសង់ផ្ទះរបស់សេដ្ឋីអំពីបុរាណ គាត់ឲ្យជាងធ្វើផ្ទះក្នុងទីនោះបាន ២-៣ ថ្ងៃ ប៉ុណ្ណោះ ធ្វើគេហប្បវេសនមង្គល និងឆត្តមង្គលដ៏ស្អាតដូចគ្នា បានថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អស់កាល ៧ ថ្ងៃ ។ គ្រានោះ ព្រះសាស្តា កាលទ្រង់ធ្វើអនុមោទនា ទើបត្រាស់អនុបុព្វីកថាហើយ ។

ក្នុងកាលចប់ទេសនា ជនទាំងបី គឺបុណ្ណសេដ្ឋី ១ ភរិយា ១ នាងឧត្តរា ដែលជាធីតា ១ បានជាព្រះសោតាបន្នហើយ ។

ក្នុងកាលតមក សេដ្ឋីក្នុងក្រុងរាជគ្រឹះ សូមធីតារបស់បុណ្ណសេដ្ឋីឲ្យបុត្ររបស់ខ្លួន បុណ្ណសេដ្ឋីពោលថា ខ្ញុំឲ្យមិនបាន កាលសេដ្ឋីក្រុងរាជគ្រឹះពោលថា សូមលោកកុំធ្វើយ៉ាងនេះ លោកអាស្រ័យខ្ញុំ អស់កាលមានប្រមាណប៉ុណ្ណេះ ទើបបានសម្បត្តិ ចូរឲ្យធីតាដល់បុត្រខ្ញុំចុះ ទើបពោលថា បុត្ររបស់លោកជាមនុស្សមិច្ឆាទិដ្ឋិ ឯកូនស្រីរបស់ខ្ញុំឆ្ងាយអំពីព្រះរតនត្រ័យហើយ មិនអាចប្រព្រឹត្តទៅបាន ទើបខ្ញុំលើកធីតាឲ្យបុត្ររបស់លោកមិនបាន ។

គ្រានោះ កុលបុត្រទាំងឡាយ មានសេដ្ឋី និងគហបតីជាដើមជាច្រើនអង្វរថា កុំទម្ងាយមិត្តភាពរវាងសេដ្ឋី ក្នុងក្រុងរាជគ្រឹះនោះឡើយ ចូរលើក

ធីតាឲ្យបុត្ររបស់គាត់ចុះ ។ បុណ្ណៈទទួលពាក្យរបស់កុលបុត្រទាំងនោះហើយ បាន លើកធីតាឲ្យក្នុងតិថីពេញបូណ៌មីខែអាសាឍ ។

ចាប់តាំងអំពីពេលទៅកាន់ត្រកូលស្វាមីហើយ នាងមិនបានចូលទៅរកភិក្ខុ ឬភិក្ខុនី ឬដើម្បីថ្វាយទាន ស្តាប់ធម៌ឡើយ ។ កាលវេលាកន្លងទៅបានប្រមាណ ២ ខែកន្លះ ដោយអាការយ៉ាងនេះ ទើបនាងសួរអ្នកបម្រើក្នុងសម្នាក់ថា ពេលនេះខាងក្នុងវស្សាសល់ប៉ុន្មានទៀត ស្រីបម្រើពោលថា នៅសល់កន្លះខែ នាងឧត្តរាបញ្ជូនដំណឹងឲ្យដល់បិតាថា ហេតុអ្វី ទើបបិតាឃុំខាំងខ្ញុំ ក្នុងផ្ទះមានសភាពបែបនេះ កាលដែលបិតាធ្វើខ្ញុំឲ្យជាមនុស្សខូចរូបឆោម ហើយប្រកាសថា ជាទាសីរបស់ជនណាម្នាក់ គង់ប្រសើរជាងការដែលលើកខ្ញុំឲ្យដល់ត្រកូលមិច្ឆាទិដ្ឋិបែបនេះមិនប្រសើរឡើយ តាំងអំពីខ្ញុំមកហើយ ខ្ញុំមិនបានធ្វើបុណ្យសូម្បីតែម្យ៉ាងក្នុងប្រភេទបុណ្យ មានការឃើញភិក្ខុជាដើមឡើយ ។

លំដាប់នោះ បិតារបស់នាងមិនសប្បាយចិត្តដោយគិតថា កូនស្រីរបស់អញបានទទួលទុក្ខហ្ន៎ ទើបបញ្ជូនទ្រព្យ ១ ម៉ឺន ៥ ពាន់កហាបណៈទៅដោយប្រាប់ថា ក្នុងនគរនេះមានស្រីគណិកាឈ្មោះសិរិមា ចូរនាងពោលថា ចូរនាងទទួលទ្រព្យមួយថ្ងៃមួយពាន់កហាបណៈ នាំនាងមកដោយកហាបណៈទាំងនេះ ឲ្យធ្វើជាអ្នកបម្រើរបស់ប្តីហើយ ខ្លួននាង ចូរធ្វើបុណ្យទាំងឡាយចុះ ។

នាងឲ្យអញ្ជើញនាងសិរិមាមកហើយ ពោលថា នែសម្លាញ់ ចូរនាងទទួលកហាបណៈទាំងនេះ ហើយបម្រើបុរសដែលជាសម្លាញ់របស់នាងកន្លះខែនេះចុះ ។ នាងសិរិមានោះទទួលថា សាធុ នាំនាងចូលទៅកាន់សម្នាក់

របស់ស្វាមី កាលប្តីនោះឃើញនាងសិរិមាហើយ ពោលថា តើនេះជាអ្វី ទើបប្រាប់ថា បពិត្រអ្នក សូមឲ្យស្រីសម្ងាញ់របស់ខ្ញុំបម្រើអ្នកអស់កន្លះខែនេះ ខ្ញុំនឹងបានធ្វើទាន ស្តាប់ធម៌ក្នុងកាលកន្លះខែ ។ សេដ្ឋីបុត្រឃើញស្រីស្អាតកើតសេចក្តីស្នេហា ទើបទទួលថា សាធុ ។

នាងខត្តារានិមន្តកិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានថា បពិត្រព្រះអង្គ សូមទ្រង់កុំយាងទៅទីដទៃ គប្បីទទួលកិក្ខាក្នុងផ្ទះនេះមួយកន្លែងអស់កន្លះខែនេះ ។ ទទួលប្តេជ្ញារបស់ព្រះសាស្តាហើយ មានចិត្តត្រេកអរថា ឥឡូវនេះ អញបានឧបដ្ឋាកព្រះសាស្តា និងស្តាប់ធម៌ តាំងអំពីនេះទៅរហូតដល់ថ្ងៃមហាបវារណា ចាត់ចែងកិច្ចគ្រប់យ៉ាងក្នុងរោងចុងកៅធំថា ចូរពួកនាងចម្អិនបបរយ៉ាងនេះ ចូរចំហុយនំយ៉ាងនេះ ។

កាលនោះ ប្តីរបស់នាងគិតថា ស្អែកនេះជាថ្ងៃមហាបវារណា ឈរត្រង់បង្ហួច បែរមុខទៅកាន់មហារោងពិនិត្យមើលគិតថា ស្រីអន្ធពាលនេះដើរធ្វើអ្វីហ្ន៎ ឃើញធីតាសេដ្ឋីនោះប្រឡាក់ទៅដោយញើស ផេះ និងធ្យូងដើរធ្វើយ៉ាងនោះ ទើបគិតថា ឱហ្ន៎ ស្រីអន្ធពាលមិនសោយសម្បត្តិមានសិរីបែបនេះ ក្នុងហានៈបែបនេះ បែរជាត្រេកអរថា អញនឹងឧបដ្ឋាកសមណៈក្បាលត្រងោលត្រាច់ទៅ បានសើចហើយចៀសចេញទៅ ។ កាលសេដ្ឋីបុត្រនោះចៀសចេញទៅហើយ នាងសិរិមាដែលឈរក្បែរនោះគិតថា សេដ្ឋីបុត្រនេះ មើលអ្វីហ្ន៎ ទើបសើច មើលទៅតាមបង្ហួចនោះឯង ឃើញនាងខត្តាហើយ គិតថា សេដ្ឋីបុត្រនេះសើចព្រោះឃើញស្រីនេះ ការស្និទ្ធស្នាលរបស់សេដ្ឋីបុត្រនេះ គង់មាន

ជាមួយនឹងស្រីនេះពិត ។

បានឮថា សិរិមានោះ ជាពាហិរកស្ត្រីក្នុងផ្ទះនោះអស់កន្លះខែ សោយសម្បត្តិនោះ ទើបមិនដឹងខ្លួនថា ជាស្រីខាងក្រៅ បានធ្វើនូវការសម្គាល់ថា ខ្លួនជាមេផ្ទះ នាងចង់អាឃាតចំពោះនាងឧត្តរាថា នឹងត្រូវញុំាងទុក្ខឲ្យកើតឡើងដល់ស្រីនេះ ទើបចុះអំពីប្រាសាទ ចូលទៅកាន់រោងចុងភៅធំ យកវែកជួសសប្បិដ៏ក្តៅក្នុងទីដែលកំពុងចៀននំ ដើរតម្រង់ទៅរកនាងឧត្តរា នាងឧត្តរាឃើញនាងសិរិមាដើរមក ទើបផ្សាយមេត្តាចិត្តទៅដល់នាងថា សម្លាញ់របស់អញធ្វើឧបការៈដល់អញច្រើន ចក្កវាឡក៏ចង្អៀត ព្រហ្មលោកក៏ទាប គុណរបស់សម្លាញ់អញធំមហិមា អញអាស្រ័យនាង ទើបថ្វាយទាន និងស្តាប់ធម៌ បើអញមានសេចក្តីក្រោធលើនាងសិរិមានោះ ចូរសប្បិនេះរលាកអញចុះ បើមិនមាន ចូរកុំរលាកឡើយ សប្បិដែលក្តៅគគុក ដែលនាងសិរិមានោះស្រោចលើនាងឧត្តរា ហាក់ដូចជាទឹកត្រជាក់ ។

លំដាប់នោះ ទាសីរបស់នាងឧត្តរាឃើញនាងជួសសប្បិពេញវែកទៀត ដោយយល់ថា សប្បិនេះត្រជាក់កាន់ដើរមក ទើបគំរាមថា នែស្រីក្បាលរឹង ចូរហាងចៀសចេញទៅ ហាងមិនគួរស្រោចសប្បិដែលក្តៅលើម្ចាស់ស្រីរបស់អញឡើយ ហើយក្រោកឡើងអំពីទីនោះខ្លះ អំពីទីនេះខ្លះ ប្រើដៃខ្លះ ជើងខ្លះ វាយឲ្យដួលចុះលើផែនដី ។ នាងឧត្តរាមិនអាចឃាត់ទាសីទាំងនោះបាន ពេលនោះ ទើបឃាត់ទាសីគ្រប់គ្នា ដែលឈរចោមរោមលើនាងសិរិមានោះហើយសួរថា តើនាងមានបំណងដូចម្តេច ទើបធ្វើកម្មធ្ងន់បែបនេះ ដូច្នេះហើយ ឲ្យ

ជំបូន្មានឆាងសិរិមា ឲ្យងូតដោយទឹកក្តៅ លាបដោយប្រេងដែលចម្រាញ់មួយរយដង ។

ខណៈនោះ នាងសិរិមាជឹងខ្លួនថា ជាស្រីខាងក្រៅហើយ គិតថា អញស្រោចសប្បិដែលក្តៅលើនាងឧត្តរានេះ ព្រោះហេតុត្រឹមតែការសើចរបស់ស្វាមី អញធ្វើកម្មធ្ងន់ហើយ ។ នាងឧត្តរានេះ មិនបញ្ជាទាសីថា ចូរពួកនាងចាប់វា បៃវជាឃាត់ពួកទាសីទាំងអស់ ក្នុងពេលដែលចោមរោមអញ បានធ្វើកម្មដែលគួរដល់អញទាំងអស់ បើអញមិនសូមឲ្យនាងឧត្តរានេះអត់ទោសឲ្យក្បាលរបស់អញនឹងបែកជា ៧ ភាគ ដូច្នេះហើយ ទើបក្រាបចុះទៀបជាតជើងរបស់នាងឧត្តរានោះ ហើយពោលថា បពិត្រអ្នកនាង សូមអ្នកនាងអត់ទោសដល់ខ្ញុំចុះ នាងឧត្តរាពោលថា ខ្ញុំជាធីតាមានបិតា បើបិតាអត់ទោសឲ្យ ខ្ញុំក៏អត់ទោសឲ្យ នាងសិរិមាពោលថា អ្នកនាង សេចក្តីនោះ ចូរលើកទុកចុះ ខ្ញុំនឹងឲ្យបុណ្ណសេដ្ឋីបិតារបស់នាងអត់ទោសឲ្យ នាងឧត្តរាពោលថា បុណ្ណៈជាបិតាបង្កើតក្នុងវដ្ដៈ តែកាលបិតាដែលជាវិវដ្ដៈអត់ទោសឲ្យ ទើបខ្ញុំអត់ទោសឲ្យ នាងសិរិមាពោលថា អ្នកណាជាបិតាវិវដ្ដៈរបស់នាង នាងឧត្តរាពោលថា គឺព្រះសម្មាសម្ពុទ្ធ នាងសិរិមាពោលថា ខ្ញុំមិនមានការស្និទ្ធស្នាលជាមួយទ្រង់ នាងឧត្តរាពោលថា ខ្ញុំនឹងធ្វើឯង ស្អែកនេះ ព្រះសាស្តាទ្រង់នឹងនាំភិក្ខុសង្ឃយាងមកទីនេះ ចូរនាងនាំយកសក្ការៈតាមដែលមានមកទីនេះឯង ហើយសូមឲ្យព្រះអង្គអត់ទោសចុះ ។

នាងសិរិមានោះទទួលថា សាធុ ក្រោកឡើងហើយ ទៅកាន់ផ្ទះរបស់ខ្លួន

ប្រាប់ស្រីជាបរិវារ ៥០០ ឲ្យត្រៀមខាទនីយ: និងសូបេយ្យ:ផ្សេងៗ ស្អែក ឡើងកាន់សក្ការ:នោះមកផ្ទះរបស់នាងឧត្តរា មិនហ៊ានដាក់បាត្រភិក្ខុសង្ឆ មានព្រះពុទ្ធជាប្រធាន ទើបឈរហើយ នាងឧត្តរាទទួលយកវត្ថុទាំងអស់នោះមករៀបចំហើយ ។ ក្នុងកាលស្រេចភត្តកិច្ច នាងសិរិមា មួយអន្ទើដោយបរិវារ ក្រាបចុះទៀបបាទារបស់ព្រះសាស្តា ។ គ្រានោះ ព្រះសាស្តាត្រាស់សួរថា នាងមានកំហុសអ្វី នាងសិរិមាទូលថា បពិត្រព្រះអង្គ ម្សិលមិញ ខ្ញុំម្ចាស់បានធ្វើកម្មឈ្មោះនេះ កាលបើដូច្នោះ សម្ងាញ់របស់ខ្ញុំម្ចាស់នៅតែហាមទាសីដែលបៀតបៀនខ្ញុំម្ចាស់ បានធ្វើឧបការ:ដល់ខ្ញុំម្ចាស់ដោយពិត ខ្ញុំម្ចាស់នោះ ដឹងនូវគុណរបស់ស្រីនេះ ទើបសូមឲ្យនាងអស់ទោស កាលបើដូច្នោះ នាងពោលនឹងខ្ញុំម្ចាស់ថា បើទ្រង់អត់ទោសឲ្យ ទើបនាងអត់ទោសឲ្យ ។

ព្រះសាស្តាត្រាស់ថា ម្នាលនាងឧត្តរា បានញ្ញថា សេចក្តីនេះយ៉ាងនោះឬ នាងឧត្តរាពោលថា បពិត្រព្រះអង្គ យ៉ាងនោះឯង ម្សិលមិញ សម្ងាញ់របស់ខ្ញុំម្ចាស់ បានស្រោចសប្បិដ៏ក្តៅលើក្បាលរបស់ខ្ញុំម្ចាស់ ។ ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ នាងគិតដូចម្តេច នាងឧត្តរាទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់គិតយ៉ាងនេះថា ចក្ការាឡនៅចង្អៀត ព្រហ្មលោកនៅទាប គុណរបស់សម្ងាញ់ខ្ញុំម្ចាស់ប៉ុណ្ណោះធំជាង ព្រោះខ្ញុំម្ចាស់អាស្រ័យនាង ទើបបានថ្វាយទាន និងស្តាប់ធម៌ បើខ្ញុំម្ចាស់មានសេចក្តីក្រោធក្នុងស្រីនេះ ចូរសប្បិក្តៅនេះ រលាកខ្ញុំម្ចាស់ចុះ បើមិនមាន សូមកុំរលាកឡើយ ហើយបានផ្សាយមេត្តាចិត្តទៅកាន់នាងសិរិមានេះ ។

ព្រះសាស្តាត្រាស់ថា សាធុ សាធុ ឧត្តរា ការឈ្នះសេចក្តីក្រោធយ៉ាងនោះសមគួរ ធម្មតាបុគ្គលច្រែនដោយសេចក្តីក្រោធ គប្បីឈ្នះដោយការមិនក្រោធ បុគ្គលគប្បីឈ្នះអ្នកជេរដោយការមិនជេរតប បុគ្គលឈ្នះសេចក្តីកំណាញ់ គប្បីឈ្នះបានដោយការឲ្យទាន គប្បីឈ្នះបុគ្គលនិយាយកុហកដោយពាក្យពិត ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។

បុគ្គល គប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្តីមិនក្រោធ គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្ចាញ់មនុស្សកំណាញ់ ដោយការឲ្យ គប្បីផ្ចាញ់មនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អក្កោធេន** *សេចក្តីថា បុគ្គលច្រែនដោយសេចក្តីក្រោធ គប្បីជាបុគ្គលឈ្នះដោយការមិនក្រោធ ។ បុគ្គលមិនល្អ ជាបុគ្គលមិនចម្រើន បុគ្គលគប្បីឈ្នះដោយសេចក្តីល្អ បុគ្គលកំណាញ់ គឺកំណាញ់ស្វិតស្វាញ បុគ្គលគប្បីឈ្នះដោយចិត្តគិតលះបង់របស់ខ្លួន អ្នកពោលខ្សេះខ្សោះ បុគ្គលគប្បីឈ្នះដោយពាក្យពិត ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់យ៉ាងនេះថា* **អក្កោធេន ជិនេ កោធំ ។បេ។ សច្ចេនាលិកវាទិនំ ។**

ក្នុងកាលចប់ទេសនា នាងសិរិមា មួយអន្លើដោយញាតិទាំង ៥០០ តាំង

នៅហើយក្នុងសោតាបត្តិផល ដូច្នេះឯង ។

រឿង ឧត្តរាឧបាសិកា ចប់

រឿង បញ្ហារបស់ព្រះមហាមោគ្គល្លាន

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហារបស់ព្រះមហាមោគ្គល្លានត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **សច្ចំ កណោ** ជាដើម ។

សេចក្តីពិស្តារថា គ្រាមួយ ព្រះថេរៈទៅកាន់ទេវចារិក ឈរនៅត្រង់ទ្វារវិមានរបស់ទេពធីតាដែលមានសក្តិធំ ហើយពោលយ៉ាងនេះនឹងទេពធីតាអង្គនោះដែលមកកាន់សម្នាក់របស់លោក ថ្វាយបង្គំហើយឈរ ដោយពាក្យថា ម្នាលទេពធីតា សម្បត្តិរបស់នាងច្រើន នាងបានធ្វើកម្មអ្វី ។

ទេពធីតាពោលថា បពិត្រលោកម្ចាស់ កុំសួរខ្ញុំឡើយ ។ បានឮថា ទេពធីតាខ្មាសដោយកម្មតិចតួចរបស់ខ្លួន ទើបពោលយ៉ាងនេះ ទេពធីតានោះ កាលព្រះថេរៈពោលថា ចូរប្រាប់ចុះ ទើបពោលថា បពិត្រលោកម្ចាស់ ទាន ខ្ញុំមិនបានថ្វាយ ការបូជាក៏មិនបានធ្វើ ធម៌ក៏មិនបានស្តាប់ រក្សាត្រឹមតែពាក្យសច្ចៈតែម្យ៉ាង ។

ព្រះថេរៈទៅកាន់ទ្វារវិមានដទៃហើយ សួរទេពធីតាដទៃដែលមកហើយ សូម្បីទេពធីតាទាំងនោះ មិនអាចបិទបាំងព្រះថេរៈបានយ៉ាងនោះឯង ទេពធីតា

មួយអង្គពោលមុនថា បពិត្រលោកម្ចាស់ បណ្តាបុញ្ញកម្ម មានទានជាដើម ឈ្មោះថា បុញ្ញកម្មដែលខ្ញុំធ្វើហើយមិនមាន តែក្នុងពុទ្ធុប្បាទព្រះសម្មាសម្ពុទ្ធ-កស្សបៈ ខ្ញុំបានជាទាសីរបស់អ្នកដទៃ ចៅហ្វាយរបស់ខ្ញុំកាចពន់ពេក យកដំបងខ្លះ អង្កត់អុសខ្លះ ដែលខ្លួនកញ្ជក់បានវាយត្រង់ក្បាល ខ្ញុំកាលសេចក្តីក្រោធកើតឡើង ក៏គិតខ្លួនឯងប៉ុណ្ណោះថា ចៅហ្វាយរបស់អញនេះជាធំ ធ្វើអញឲ្យខូចរូបសម្រស់ក៏បាន កាត់អាវៈយាវៈមានច្រមុះជាដើមរបស់អញក៏បានដែរ អ្នកកុំក្រោធឡើយ ដូច្នេះហើយ ក៏មិនធ្វើសេចក្តីក្រោធ ដោយហេតុនោះ ទើបខ្ញុំបានសម្បត្តិនេះ ។

ទេពធីតាអង្គដទៃ ក៏ប្រាប់ទានបន្តិចបន្តួចដែលខ្លួនធ្វើហើយ ដោយន័យជាដើមថា បពិត្រលោកម្ចាស់ ខ្ញុំរក្សាចម្ការអំពៅ បានប្រគេនអំពៅមួយកំណាត់ដល់ភិក្ខុមួយរូប ទេពធីតាអង្គខ្លះក៏ប្រាប់ថា ខ្ញុំប្រគេនផ្លែទន្លាប់មួយផ្លែ អង្គដទៃក៏ប្រាប់ថា ខ្ញុំប្រគេនល្ពៅមួយផ្លែ អង្គដទៃប្រាប់ថា ខ្ញុំបានប្រគេនផ្លែគូលែនមួយផ្លែ អង្គខ្លះប្រាប់ថា ខ្ញុំបានថ្វាយដំឡូងមួយក្តាប់ អង្គខ្លះប្រាប់ថា ខ្ញុំបានប្រគេនស្ពៃមួយក្តាប់ ដូច្នេះហើយ ក៏ប្រាប់ថា ដោយហេតុនេះ ទើបពួកខ្ញុំបានសម្បត្តិនេះ ។

ព្រះថេរៈស្តាប់កម្មដែលទេពធីតាទាំងនោះធ្វើហើយ ទើបចុះអំពីស្នានសួគ៌ទៅគាល់ព្រះសាស្តាទូលសួរថា បពិត្រព្រះអង្គ បុគ្គលអាចឬទេហ្ន៎ ដើម្បីបានទិព្វសម្បត្តិដោយហេតុត្រឹមតែពាក្យសច្ចៈ ត្រឹមតែរម្ងាប់សេចក្តីក្រោធ ត្រឹមតែថ្វាយទាន មានផ្លែទន្លាប់ជាដើមដែលតិចតួចពន់ពេក ព្រះសាស្តាត្រាស់ថា ម្នាល

មោគ្គល្លាន ព្រោះហេតុអ្វីទើបអ្នកសួរតថាគត ក្រែងពួកទេពធីតាជ្រាប់សេចក្តីនេះដល់អ្នកហើយមិនមែនឬ ព្រះមោគ្គល្លានពោលថា យ៉ាងនោះឯងព្រះអង្គ បុគ្គលបានទិព្វសម្បត្តិ ដោយកម្មមានប្រមាណប៉ុណ្ណោះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះមោគ្គល្លាននោះថា ម្នាលមោគ្គល្លាន បុគ្គលពោលត្រឹមតែពាក្យសត្យក្តី លះត្រឹមតែសេចក្តីក្រោធក្តី ថ្វាយទានត្រឹមបន្តិចបន្តួចក្តី រមែងទៅទេវលោកបានពិត ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

សច្ចំ ភណេ ន កុជ្ឈេយ្យ ទជ្ជា អប្បស្មិ យាចិតោ
ឯតេហិ តីហិ ឋានេហិ គច្ឆេ ទេវាន សន្តិកេ ។

បុគ្គលពោលពាក្យពិត ១ មិនគួរក្រោធ ១ កាលគេសូមនូវវត្ថុសូម្បីមានតិចក៏គួរឲ្យ (តាមតិច) ១ បុគ្គលគប្បីទៅកើតក្នុងសម្នាក់ទេវតាទាំងឡាយបានដោយហេតុទាំង ៣ នេះឯង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **សច្ចំ ភណេ** *សេចក្តីថា គប្បីសម្តែងគឺគប្បីពោលពាក្យសត្យ អធិប្បាយថា គួរតាំងមាំក្នុងសត្យ ។*

បទថា **ន កុជ្ឈេយ្យ** *បានដល់ មិនគួរក្រោធចំពោះបុគ្គលដទៃ ។*

បទថា **យាចិតោ** *សេចក្តីថា បព្វជិតដែលមានសីល ឈ្មោះថា ជាអ្នកសូម ។ សេចក្តីពិត បព្វជិតទាំងនោះមិនសូមថា ចូរអ្នកឲ្យ រមែងឈរត្រង់ទ្វារផ្ទះក៏ពិត តែអត្ត ក៏ឈ្មោះថា រមែងសូមនោះឯង បុគ្គលដែលមាន*

សីល សូមហើយយ៉ាងនោះ កាលទេយ្យធម៌សូម្បីតិចតួចមាន ក៏គប្បីឲ្យ ត្រឹមតែតិចតួច ។

ពីរបទថា **ឯតេហិ តីហិ** *សេចក្តីថា បណ្តាហេតុទាំងនោះ ហេតុសូម្បី ត្រឹមតែមួយ បុគ្គលគប្បីទៅទេវលោកបាន ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើមដូច្នេះឯង ។

រឿង បញ្ហារបស់ព្រះមោគ្គល្លានត្ថេរ ចប់

រឿង បញ្ហាដែលភិក្ខុទូលសួរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាកេត ប្រថាប់នៅត្រង់អញ្ចនវន ទ្រង់ប្រារព្ធបញ្ហាដែលភិក្ខុទូលសួរ ត្រាស់ព្រះធម្មទេសនានេះថា **អហិសកាយេ** *ជាដើម ។*

បានឮមកថា ក្នុងកាលដែលព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម យាងទៅក្រុងសាកេតដើម្បីបិណ្ឌបាត ព្រាហ្មណ៍ចាស់ជរាក្នុងក្រុងសាកេតម្នាក់ កំពុងដើរចេញអំពីព្រះនគរ ជួបព្រះសាស្តាត្រង់រាងទ្វារ ទើបក្រាបទៀប បាទាទាំងទ្វេ ហើយចាប់ត្រង់កព្រះបាទយ៉ាងមាំពោលថា នែបា ធម្មតា ឪពុក និងម្តាយ ដែលពួកកូនគប្បីទំនុកបម្រុង ក្នុងកាលដែលចាស់ជរាហើយ មិន

មែនឬ ហេតុអ្វី ទើបកូនមិនបង្ហាញខ្លួនដល់ខ្ញុំព្រះអង្គ អស់កាលមានប្រមាណប៉ុណ្ណោះ ព្រះអង្គ ដែលខ្ញុំព្រះអង្គឃើញមុន សូមទ្រង់យាងមកសួរសុខទុក្ខមាតាផង ដូច្នេះហើយ ក៏បាននាំព្រះសាស្តាទៅកាន់ផ្ទះរបស់ខ្លួន ព្រះសាស្តាយាងទៅហើយ ប្រថាប់គង់លើអាសនៈដែលគេបានក្រាល មួយអន្ទឹងដោយភិក្ខុសង្ឃ ។

ចំណែកព្រាហ្មណីមកក្រាបទៀបព្រះបាទទាំងពីររបស់ព្រះសាស្តាហើយទូលថា នែបា កូនទៅណាអស់កាលដ៏យូរមានប្រមាណប៉ុណ្ណោះ ធម្មតាមាតានិងបិតា បុត្រធីតាគួរទំនុកបម្រុងក្នុងពេលដែលចាស់មិនមែនឬ ហើយឲ្យបុត្រនិងធីតាទាំងឡាយមកថ្វាយបង្គំដោយពាក្យថា ចូរពួកអ្នកមកថ្វាយបង្គំបងប្រុសរបស់អ្នក ។ ប្តីប្រពន្ធពីរនាក់នោះ មានចិត្តត្រេកអរ អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយទូលថា បពិត្រព្រះអង្គ សូមទ្រង់ទទួលភិក្ខាក្នុងផ្ទះនេះឯងជានិច្ចចុះ កាលព្រះសាស្តាត្រាស់ថា ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់មិនទទួលជានិច្ចក្នុងទីតែមួយប៉ុណ្ណោះ ទើបក្រាបទូលថា បើដូច្នេះ ទ្រង់គប្បីបញ្ជូនពួកជនដែលមកនិមន្តព្រះអង្គ ទៅកាន់សម្នាក់របស់ខ្ញុំព្រះអង្គផង ។

ចាប់តាំងអំពីនោះ ព្រះសាស្តាទ្រង់បញ្ជូនពួកមនុស្សដែលមកដើម្បីនិមន្តទៅដោយព្រះតម្រាស់ថា ចូរពួកអ្នកទៅប្រាប់ដល់ព្រាហ្មណ៍ចុះ ។ មនុស្សដែលមកនិមន្តទាំងនោះ រមែងទៅប្រាប់ព្រាហ្មណ៍ថា យើងទាំងឡាយនិមន្តព្រះសាស្តា ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ។

ថ្ងៃស្អែកឡើង ព្រាហ្មណ៍កាន់យកកាជនកត្ត និងកាជនសម្អំពីផ្ទះរបស់

ខ្លួន ទៅកាន់ទីដែលព្រះសាស្តាប្រថាប់គង់ ។ ក្នុងកាលនិមន្តទៅឆាន់ក្នុងទីជនៃ មិនមាន ព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចក្នុងផ្ទះរបស់ព្រាហ្មណ៍នោះឯង ពីរនាក់ ស្វាមីភរិយានោះ ថ្វាយទេយ្យធម៌របស់ខ្លួនដល់ព្រះតថាគត ស្តាប់ធម្មកថា អស់កាលជានិច្ច សម្រេចអនាគាមិនផលហើយ ។

ភិក្ខុទាំងឡាយ សន្ទូនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ព្រាហ្មណ៍នោះដឹងថា ព្រះបាទសុទ្ធោទន:ជាព្រះបិតារបស់ព្រះតថាគត ព្រះនាង មហាមាយាជាព្រះមាតា ទាំងដឹងយ៉ាងនោះឯង មួយអន្ទើដោយព្រាហ្មណ៍ហៅ ព្រះតថាគតថា បុត្ររបស់អញ ។ ចំណែកព្រះសាស្តា ក៏ទ្រង់ទទួលយ៉ាងនោះ ដូចគ្នា និងមានហេតុអ្វីហ្ន៎ ។

ព្រះសាស្តា ទ្រង់ស្តាប់កថារបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ ប្តីប្រពន្ធពីរនាក់នោះ ហៅបុត្ររបស់ខ្លួនប៉ុណ្ណោះថាបុត្រ ដូច្នេះ ហើយ ទើបទ្រង់នាំអតីតនិទានមក ទ្រង់សម្តែងភាពដែលទ្រង់ជាបុត្ររបស់ ព្រាហ្មណ៍ប្តីប្រពន្ធទាំងពីរនោះអស់ ៣ ពាន់ជាតិថា ម្នាលភិក្ខុទាំងឡាយ ក្នុង អតីតកាល ព្រាហ្មណ៍នេះបានជាបិតារបស់តថាគត ៥០០ ជាតិជាប់តគ្នា ជា ឪពុកមារបស់តថាគត ៥០០ ជាតិ ជាអ៊ំប្រុស ៥០០ ជាតិ សូម្បីព្រាហ្មណី នោះ បានជាមាតារបស់តថាគតជាប់តគ្នា ៥០០ ជាតិ ជាមីងរបស់តថាគត ៥០០ ជាតិ ជាអ៊ំស្រីរបស់តថាគត ៥០០ ជាតិ តថាគតចម្រើនហើយក្នុងដៃ របស់ព្រាហ្មណ៍ ១៥០០ ជាតិ ចម្រើនហើយក្នុងដៃរបស់ព្រាហ្មណី ១៥០០ ជាតិយ៉ាងនេះ ហើយទ្រង់បានភាសិតព្រះគាថាទាំងនេះថា

ចិត្តតាំងនៅស៊ប់ ឬក៏ចិត្តជ្រះថ្លាក្នុងបុគ្គលណា ដែលខ្លួនមិនធ្លាប់ឃើញហើយ ជនតែងស្និទ្ធស្នាលចំពោះបុគ្គលនោះដោយពិត ។

សេចក្តីស្រឡាញ់នោះ រមែងកើតដោយហេតុ ២ យ៉ាង គឺដោយធ្លាប់នៅរួមគ្នាក្នុងកាលមុន ១ ដោយការទំនុកបម្រុងគ្នាក្នុងបច្ចុប្បន្ននេះ ១ ដូចជាឧប្បលដែលដុះក្នុងទឹក ដោយហេតុ ២ យ៉ាង គឺទឹក ១ ភក់ ១ ។

ព្រះសាស្តាទ្រង់អាស្រ័យត្រកូលនោះ ប្រថាប់នៅហើយអស់ត្រៃមាសនោះឯង ចំណែកព្រាហ្មណ៍ និងព្រាហ្មណីទាំង ២ នោះ ធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលហើយ បរិនិព្វាន ក្រោនោះ ជនទាំងឡាយ ធ្វើសក្ការៈដ៏សន្ធឹកសន្ធាប់ដល់ព្រាហ្មណ៍ និងព្រាហ្មណីទាំងនោះហើយ ក៏លើកជនទាំងពីរឡើងកាន់ផ្ទះកំពូលមួយខ្នងនោះឯង នាំទៅហើយ ។

ព្រះសាស្តាមានភិក្ខុ ៥០០ រូបជាបរិវារ យាងទៅកាន់ឈាបនដ្ឋានជាមួយជនទាំងនោះដូចគ្នា ។

មហាជនចេញទៅហើយដោយគិតថា បានឮថា ព្រះសាស្តា និងព្រះបិតារបស់ព្រះពុទ្ធធ្វើកាលកិរិយាហើយ ព្រះសាស្តាបានទៅកាន់សាលាមួយខ្នងក្បែរជ្រោះ ប្រថាប់ឈរហើយ ។ ពួកមនុស្សថ្វាយបង្គំព្រះសាស្តា ហើយឈរក្នុងចំណែកម្ខាង ធ្វើបដិសណ្ឋារៈជាមួយព្រះសាស្តាដោយទូលថា បពិត្រព្រះអង្គ សូមទ្រង់កុំគិតថា ព្រះមាតា និងព្រះបិតារបស់ទ្រង់ធ្វើកាលកិរិយា

ទ្បើយ ។

ព្រះសាស្តាទ្រង់មិនហាមជនទាំងនោះថា ពួកអ្នកកុំពោលយ៉ាងនោះ ទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់បរិស័ទហើយ កាលទ្រង់សម្តែងធម៌ឲ្យសមគួរដល់ខណៈនោះ ទើបត្រាស់ជាសូត្រដោយនយជាដើមថា

ជីវិតនេះតិចណាស់ រមែងស្លាប់ខាងអាយុ អំពី ១០០ ឆ្នាំ បើបុគ្គលណា រស់នៅកន្លងហួស (ពី ១០០ ឆ្នាំ) ទៅ បុគ្គលនោះ គង់ស្លាប់ព្រោះជរាពុំខាន ។

ក្នុងកាលចប់ទេសនា ធម្មាភិសមយមានដល់សត្វ ៨៤០០០ ហើយ ។ ភិក្ខុទាំងឡាយកាលមិនជ្រាបភាពដែលព្រាហ្មណ៍ និងព្រាហ្មណីបរិនិព្វានហើយ ទើបទូលសួរថា បពិត្រព្រះអង្គ កពខាងមុខរបស់ព្រាហ្មណ៍ និងព្រាហ្មណីនោះ ដូចម្តេច ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាអភិសម្បរាយភពរបស់ព្រះអសេក្ខមុនីទាំងឡាយបែបនោះ មិនមាន ព្រោះថា ព្រះអសេក្ខមុនីបែបនោះ រមែងសម្រេចមហានិព្វានដែលមិនចុតិ ដែលមិនស្លាប់ ដូច្នេះហើយ ទើបត្រាស់គាថានេះថា

អហីសកា យេ មុនយោ និច្ចំ កាយេន សំវុតា
តេ យន្តិ អច្ចុតំ ឋានំ យត្ថ គន្ត្វា ន សោចរេ ។

ជនទាំងឡាយណា ជាអ្នកប្រាជ្ញ មិនបៀតបៀនសត្វដទៃ សង្រួមហើយ ដោយកាយទ្វារ (ជាដើម) ជានិច្ច ជន

ទាំងឡាយនោះ រមែងទៅកាន់ស្ថានដ៏មិនប្រែប្រួល ជាស្ថានដែលគេទៅដល់ហើយ តែងមិនសោកស្តាយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មុនយោ** គឺព្រះអសេក្ខមុនីទាំងឡាយ សម្រេចមគ្គ និងផល ដោយមោនេយ្យបដិបទា ។

បទថា **កាយេន** នោះ ត្រឹមតែជាមាតិកានៃទេសនាប៉ុណ្ណោះ អធិប្បាយថា សង្រួមហើយ ដោយទ្វារទាំង ៣ ។

បទថា **អច្ចុតំ** បានដល់ ទៀង ។ បទថា **ឋានំ** បានដល់ ហាន:ដែលមិនកម្រើក គឺហាន:ដែលស្ថិតស្ថេរ ។

បទថា **យន្តិ** ជាដើម សេចក្តីថា មុនីទាំងឡាយរមែងទៅកាន់ហាន: គឺព្រះនិព្វានដែលមនុស្សទាំងឡាយទៅហើយ មិនសោយសោក គឺមិនក្តៅក្រហាយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ॥

រឿង បញ្ហាដែលភិក្ខុទូលសួរ ចប់

រឿង បុណ្ណាធាសី

លំនាំដើម

ព្រះសាស្តា កាលគង់នៅត្រង់ក្នុងគិជ្ឈកូដ ទ្រង់ប្រារព្ធទាសីរបស់សេដ្ឋីក្រុងរាជគ្រឹះ ឈ្មោះនាងបុណ្ណា ត្រាស់ព្រះធម្មទេសនានេះថា **សធាជាគរមានាធំ** *ជាដើម ។*

បានឮថា ថ្ងៃមួយ សេដ្ឋីឲ្យស្រូវជាច្រើនដល់នាងបុណ្ណានោះ ដើម្បីបុក ។ នាងអុជប្រទីបក្នុងពេលយប់បុកស្រូវ មានខ្ជួនជោកដោយញើស ទើបទៅឈរហាលខ្យល់ខាងក្រៅដើម្បីសម្រាក ។

ក្នុងសម័យនោះ ព្រះទព្វមល្លបុត្តជាអ្នកចាត់ចែងសេនាសនៈ ដើម្បីភិក្ខុទាំងឡាយ លោកញ៉ាំងម្រាមដៃឲ្យភ្លឺដើម្បីភិក្ខុទាំងឡាយ ដែលស្តាប់ធម៌ហើយទៅកាន់សេនាសនៈរៀងៗ ខ្លួន និម្មិតភិក្ខុទាំងឡាយទៅខាងមុខ ដើម្បីប្រយោជន៍ដល់ការបង្ហាញផ្លូវ ។ នាងបុណ្ណា ឃើញភិក្ខុទាំងឡាយត្រាច់ទៅលើភ្នំដោយពន្លឺនោះទើបគិតថា អញត្រូវទុក្ខរបស់ខ្លួនបៀតបៀនទើបដេកមិនលក់ សូម្បីក្នុងពេលនេះ ព្រោះហេតុអ្វី ទើបលោកម្ចាស់ទាំងឡាយមិនសិង ដូច្នេះហើយកំណត់ក្នុងចិត្តដោយខ្លួនឯងថា ការមិនផាសុកនឹងមានដល់ភិក្ខុរូបខ្លះ ឬព្រោះឧបទ្រវហេតុព្រោះពស់ នឹងមានក្នុងទីនោះពិត ក្រោកឡើងអំពីព្រលឹមខ្ចប់កន្ទក់ដែលសើមដោយទឹកហើយ ធ្វើនំលើបាតដៃ អាំងលើរងើកភ្លើង ជាក់ក្នុងថ្នក់គិតថា នឹងបរិភោគនំត្រង់ផ្លូវដែលទៅកាន់កំពង់ទឹក ទើបកាន់យកក្អមដើរបែរមុខទៅកាន់កំពង់ទឹក ។

ព្រះសាស្តា ក៏យាងទៅតាមផ្លូវនោះដូចគ្នាដើម្បីចូលស្រុក នាងឃើញព្រះសាស្តាហើយគិតថា ក្នុងថ្ងៃដទៃៗ សូម្បីអញជួបព្រះសាស្តា ទេយ្យធម៌របស់អញក៏មិនមាន កាលទេយ្យធម៌មាន អញមិនជួបព្រះសាស្តា ឥឡូវនេះ ទេយ្យធម៌របស់អញក៏មាន ទាំងព្រះសាស្តាក៏ប្រាកដចំពោះមុខ បើទ្រង់មិនគិតថា ទានរបស់អញសៅហ្មង ឬប្រណីត ហើយគប្បីទទួលសោត អញគប្បីថ្វាយនំនេះ ដូច្នេះហើយ ទើបដាក់ភ្នែកក្នុងចំណែកម្ខាង ថ្វាយបង្គំព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ទទួលទានដែលសៅហ្មងនេះ ធ្វើនូវការសង្គ្រោះដល់ខ្ញុំម្ចាស់ចុះ ។

ព្រះសាស្តាទ្រង់ទតព្រះអានន្ទត្ថេរហើយ ទ្រង់បង្ហោនបាត្រដែលមហារាជថ្វាយ ដែលព្រះអានន្ទត្ថេរនាំមកថ្វាយទទួលនំ ។ សូម្បីនាងបុណ្ណាដាក់នំនោះចូលក្នុងបាត្រព្រះសាស្តា ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ក្រាបទូលថា បពិត្រព្រះអង្គ សូមធម៌ដែលទ្រង់ឃើញហើយនោះ សម្រេចដល់ខ្ញុំចុះ ព្រះសាស្តាប្រថាប់ឈរនោះឯង ទ្រង់ធ្វើអនុមោទនាថា ចូរសម្រេចយ៉ាងនោះចុះ ។

នាងបុណ្ណាគិតថា ព្រះសាស្តាទ្រង់ធ្វើការសង្គ្រោះដល់អញ ទទួលនំក៏ពិតតែទ្រង់ប្រហែលជាមិនសោយនំនោះ ឲ្យដល់ភ្នែក ឬឆ្អែងាងមុខ យាងទៅកាន់ព្រះរាជមន្ទីរបស់ព្រះរាជា ឬផ្ទះរបស់អមាត្យ ហើយសោយភោជនដែលប្រណីតពិត ។

ព្រះសាស្តាទ្រង់ព្រះតម្រិះថា នាងបុណ្ណានោះគិតដូចម្តេចហ្ន៎ ទ្រង់ជ្រាបវារចិត្តរបស់នាងហើយ ទើបទតមើលព្រះអានន្ទ ហើយទ្រង់សម្តែងអាការ

ប្រថាប់គង់ ។ ព្រះថេរៈបានក្រាលចីវរថ្វាយ ។ ព្រះសាស្តាប្រថាប់គង់ធ្វើ កត្តកិច្ចខាងក្រៅព្រះនគរនោះឯង ។ ទេវតាក្នុងល្បែងនៃចក្កវាឡទាំងមូល ជាក់ ព្រះឱជារសដ៏សមគួរដល់ទេវតា និងមនុស្សទាំងឡាយ ឲ្យដួចផ្ទៃតឃុំក្នុង នំនោះ ចំណែកនាងបុណ្ណាបានឈរមើលហើយ ។

ក្នុងពេលស្រេចកត្តកិច្ច ព្រះថេរៈបានថ្វាយទឹក ។ ព្រះសាស្តាទ្រង់ធ្វើ កត្តកិច្ចស្រេចហើយ ត្រាស់ហៅនាងបុណ្ណាមក ត្រាស់ថា ម្នាលនាងបុណ្ណា ព្រោះហេតុអ្វី ទើបនាងរិះគន់សាវ័កទាំងឡាយរបស់តថាគត នាងបុណ្ណា ទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់មិនបានរិះគន់ឡើយ ។

ព្រះសាស្តាត្រាស់ថា បើដូច្នោះ នាងសម្លឹងមើលសាវ័កទាំងឡាយរបស់ តថាគតហើយ គិតដូចម្តេច ។ នាងបុណ្ណាទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់គិត យ៉ាងនេះថា អញមិនបានដេកក៏ព្រោះឧបទ្រវន្តរាយ គឺទុក្ខនេះ លោកម្ចាស់ ទាំងឡាយមិនសឹងដើម្បីអ្វីហ្ន៎ ការមិនជាសុកនឹងមានដល់កិកូរបខ្លះ ឬអន្តរាយ ព្រោះពស់នឹងមានពិត ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់នាងបុណ្ណានោះហើយ ទើបត្រាស់ថា ម្នាលនាងបុណ្ណា នាងមិនដេកព្រោះអន្តរាយ គឺទុក្ខរបស់ខ្លួន សាវ័កទាំងឡាយ របស់តថាគត មិនដេក ព្រោះភាពជាអ្នកប្រកបរឿយៗ នូវធម៌ ជាគ្រឿង ក្រាក់រឭកសព្វកាល ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

សទា ជាគរមានានំ អហោរត្តានុសិក្ខិនំ
និព្វានំ អធិមុត្តានំ អត្ថំ គច្ឆន្តិ អាសវា ។

អាសវៈទាំងឡាយ របស់បុគ្គលអ្នកក្រាក់រឭកសព្វកាល ជាអ្នកសិក្សាត្រៃសិក្ខា ទាំងថ្ងៃ ទាំងយប់ មានចិត្តចុះស៊ប់កាន់ព្រះនិព្វាន តែងដល់នូវការតាំងនៅមិនបានឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បានព្រះគាថាថា **អហោរត្តានុសិក្ខិនំ** *បានដល់ សិក្សាត្រៃសិក្ខាទាំងថ្ងៃទាំងយប់ ។ បានព្រះគាថាថា* **និព្វានំ អធិមុត្តានំ** *បានដល់ មានអធ្យាស្រ័យក្នុងព្រះនិព្វាន ។*

ពីរបទថា **អត្ថំ គច្ឆន្តិ** *សេចក្តីថា អាសវៈទាំងពួងរបស់បុគ្គលបែបនោះ រមែងដល់នូវការតាំងនៅមិនបាន ព្រោះដល់នូវការវិនាស បានដល់ ការមិនមាន ។ ក្នុងកាលចប់ទេសនា នាងបុណ្ណាកំពុងឈរនោះឯង តាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយ ។*

ព្រះសាស្តា កាលទ្រង់ធ្វើភត្តកិច្ចដោយអាំងលើរងើកភ្លើង ដែលធ្វើដោយកន្ទក់ហើយ បានទៅកាន់វិហារ ។

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ កម្មធ្វើបានលំបាក ដែលព្រះសម្មាសម្ពុទ្ធទ្រង់ធ្វើភត្តកិច្ចដោយនំអាំង ដែលធ្វើដោយកន្ទក់ ដែលនាងបុណ្ណាថ្វាយទ្រង់ធ្វើហើយ ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយរឿងឈ្មោះ

នេះ ដូច្នេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនក្នុងឥឡូវនេះ ប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនតថាគតក៏បរិភោគកន្ទក់ ដែលនាងបុណ្ណានេះឲ្យ ហើយដូចគ្នា ហើយទ្រង់នាំអតីតនិទានមក ត្រាស់កុណ្ឌកសិន្ធវាជោតកជាតក នេះឲ្យពិស្តារថា

ព្រះពោធិសត្វ កាលសាកល្បងកូនសេះសិន្ធពនោះ ទើបពោលគាថាទីមួយថា

អ្នកធ្លាប់បរិភោគស្មៅដ៏សល់ ដែលធ្លាប់បរិភោគជាយ
ក្តាំង និងកុណ្ឌកមកហើយ នេះជាភោជនរបស់អ្នក
ឥឡូវនេះ ហេតុអ្វី ក៏អ្នកមិនបរិភោគ ។

កូនសេះសិន្ធពស្តាប់ដូច្នោះហើយ ទើបពោលគាថាពីរថា

បពិត្រមហាព្រហ្ម ជនទាំងឡាយមិនស្គាល់សត្វ ដែល
គួរចិញ្ចឹម ដោយជាតិ ឬដោយមារយាទ ដែលគួរទុកដាន
ក្នុងទីណា ក្នុងទីនោះ ថ្ងៃក៏ខ្ញុំមិនបរិភោគជាយក្តាំង និង
កុណ្ឌកច្រើន ។
ចំណែកខាងលោកស្គាល់ខ្ញុំច្បាស់ថា សេះនេះ ឧត្តម
យ៉ាងណាៗ ខ្ញុំកាលជីង ព្រោះអាស្រ័យអ្នកជាអ្នកជីង
ទើបមិនបរិភោគនូវកុណ្ឌកបស់អ្នក ដូច្នេះឯង ។

រឿង បុណ្ណាទាសី ចប់

រឿង អតុលឧបាសក

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកឈ្មោះអតុលៈ ត្រាស់ព្រះធម្មទេសនានេះថា **ចោរាណមេតំ** ជាដើម ។

សេចក្តីពិស្តារថា អតុលៈនោះជាឧបាសកក្រុងសាវត្ថី មានឧបាសកជាបរិវារ ៥០០ នាក់ ថ្ងៃមួយ នាំពួកឧបាសកទាំងនោះទៅវិហារ ដើម្បីស្តាប់ធម៌ ប្រថ្នានឹងស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះវេតៈ ថ្វាយបង្គំព្រះថេរៈហើយអង្គុយ ។

ព្រះថេរៈជាអ្នកត្រេកអរក្នុងការស្ងប់ស្ងាត់ ត្រាច់ទៅម្នាក់ឯងដូចរាជ-សីហ៍ ដូច្នោះ ទើបមិនពោលពាក្យណាមួយជាមួយឧបាសកនោះ ក្រោធថា ព្រះថេរៈនេះមិននិយាយអ្វីសោះ ទើបក្រោកឡើងទៅកាន់សម្នាក់ព្រះសារីបុត្ត ឈរក្នុងចំណែកម្ខាង កាលព្រះថេរៈពោលថា ពួកអ្នកមកដោយបំណងអ្វី ទើបពោលថា បពិត្រលោកម្ចាស់ ខ្ញុំនាំឧបាសកនេះ ចូលទៅរកព្រះវេតៈ ដើម្បីស្តាប់ធម៌ ព្រះថេរៈមិនពោលអ្វីនឹងខ្ញុំសោះ ខ្ញុំក្រោធនឹងលោក ទើបមកទីនេះ សូមលោកម្ចាស់សម្តែងធម៌ដល់ខ្ញុំចុះ ។

លំដាប់នោះ ព្រះថេរៈពោលថា ឧបាសកទាំងឡាយ បើយ៉ាងនោះ ចូរពួកអ្នកអង្គុយចុះ ហើយសម្តែងអភិធម្មកថាជាច្រើន ។

ឧបាសកក្រោធថា ឈ្មោះថាអភិធម្មកថាជ្រាលជ្រៅពន់ពេក សុខុមពន់ពេក ព្រះថេរៈសម្តែងអភិធម្មច្រើនពេក ពួកយើងត្រូវការអ្វីដោយអភិធម្មនេះដូច្នេះហើយ បាននាំគ្នាទៅកាន់សម្នាក់ព្រះអានន្ទត្ថេរ កាលព្រះថេរៈពោលថា នែឧបាសក តើមានរឿងអ្វី ទើបពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំចូលទៅ

រកព្រះវេតៈត្រូវការដើម្បីស្តាប់ធម៌ មិនបានត្រឹមតែការសន្ទនា និងប្រាស្រ័យក្នុងសម្នាក់របស់លោក ខ្ញុំក៏ក្រោធ ហើយទើបមកកាន់សម្នាក់របស់ព្រះសារីបុត្ត សូម្បីព្រះថេរៈនោះក៏សម្តែងអភិធម្មយ៉ាងល្អិតជាច្រើនដល់ខ្ញុំ ពួកខ្ញុំក្រោធចំពោះព្រះថេរៈនោះថា ពួកយើងត្រូវការអ្វីដោយអភិធម្មនេះ ហើយទើបមកទីនេះ សូមលោកម្ចាស់សម្តែងធម្មកថាដល់ពួកខ្ញុំចុះ ។ ព្រះថេរៈពោលថា បើដូច្នោះ ចូរពួកអ្នកអង្គុយស្តាប់ចុះ ។ ព្រះថេរៈសម្តែងធម៌ដល់ឧបាសកទាំងនោះតែបន្តិច ធ្វើឲ្យងាយយល់ ។

ពួកឧបាសកក្រោធចំពោះព្រះថេរៈហើយ ក៏ទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងឧបាសកទាំងនោះថា ម្នាលឧបាសកទាំងឡាយ ពួកអ្នកមកធ្វើអ្វី ឧបាសកទាំងនោះទូលថា បពិត្រព្រះអង្គ ដើម្បីស្តាប់ធម៌ ព្រះសាស្តាត្រាស់ថា ពួកអ្នកស្តាប់ធម៌ហើយឬ ឧបាសកទូលថា បពិត្រព្រះអង្គ ដំបូងពួកខ្ញុំព្រះអង្គចូលទៅរកព្រះវេតត្ថេរ លោកមិនពោលអ្វីសោះជាមួយខ្ញុំព្រះអង្គ ។ ពួកខ្ញុំព្រះអង្គក្រោធលោកហើយ ទើបទៅរកព្រះសារីបុត្ត ព្រះថេរៈនោះសម្តែងអភិធម្មដល់ខ្ញុំព្រះអង្គច្រើនពេក ខ្ញុំព្រះអង្គកំណត់អភិធម្មនោះមិនបាន ទើបក្រោធ ហើយចូលទៅរកព្រះអានន្ទ ព្រះថេរៈនោះសម្តែងធម៌ដល់ខ្ញុំព្រះអង្គតិចពេក ពួកខ្ញុំព្រះអង្គក្រោធចំពោះលោកហើយមកទីនេះ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ឧបាសកទាំងនោះហើយត្រាស់ថា ម្នាល

អតុលៈ សេចក្តីនោះនរជនធ្លាប់ប្រព្រឹត្តមកតាំងអំពីបុរាណនោះឯង ជនទាំង-ទ្បាយតិះដៀលអ្នកដែលនៅស្ងៀមផង អ្នកនិយាយច្រើនផង អ្នកនិយាយតិចផង ដ្បិតថា បុគ្គលដែលគេមិននិន្ទាតែម្យ៉ាងប៉ុណ្ណោះ ឬដែលគេគប្បីសរសើរតែម្យ៉ាងមិនមាន សូម្បីព្រះរាជាទាំងទ្បាយ មនុស្សពួកខ្លះក៏និន្ទា មនុស្សពួកខ្លះក៏សរសើរ សូម្បីមហាប្រឹថពីក្តី ព្រះចន្ទ និងព្រះអាទិត្យក្តី ជាតុ មានអាកាសជាដើមក្តី ជនពួកខ្លះក៏និន្ទា ពួកខ្លះក៏សរសើរ សូម្បីព្រះសម្មាសម្ពុទ្ធដែលប្រថាប់គង់សម្តែងធម៌កណ្តាលបរិស័ទ ៤ ពួកខ្លះក៏និន្ទា ពួកខ្លះក៏សរសើរ ការនិន្ទា និងការសរសើររបស់ពួកអន្ធពាលមិនជាប្រមាណតែ បុគ្គលដែលត្រូវបណ្ឌិត អ្នកមានប្រាជ្ញាតិះដៀល ទើបឈ្មោះថា ជាការតិះដៀល ដែលបណ្ឌិតសរសើរហើយ ទើបឈ្មោះថា ជាការសរសើរដូច្នេះហើយ ទ្រង់បានភាសិតគាថាទាំងនេះថា

ចោរាណាមេតំ អតុល	នេតំ អជ្ជតនាមិវ
និន្ទន្តិ តុណ្ហីមាសីនំ	និន្ទន្តិ ពហុភាណិនំ
មិតភាណិម្បិ និន្ទន្តិ	នត្ថិ លោកេ អនិន្ទិតោ ។
ន ចាហុ ន ច ភវិស្សតិ	ន ចេតរហិ វិជ្ជតិ
ឯកន្តំ និន្ទិតោ ចោសោ	ឯកន្តំ វា បសំសិតោ ។
យញ្ចេ វិញ្ញូ បសំសន្តិ	អនុវិច្ច សុវេ សុវេ
អច្ឆិទ្ទវុត្តឹ មេធាវឹ	បញ្ញាសីលសមាហិតំ
នេក្ខំ ជម្ពោនទស្សេវ	កោ តំ និន្ទិតុមរហតិ
ទេវាបិ នំ បសំសន្តិ	ព្រហ្មុនាបិ បសំសិតោ ។

ម្នាលអតុលៈ ការតិះដៀល និងការសរសើរនេះ ជារបស់បុរាណ ការតិះដៀល និងការសរសើរនេះ មិនមែនទើបនឹងកើតឡើងក្នុងថ្ងៃនេះទេ (ព្រោះថា) ជនទាំងឡាយ តែងនិន្ទាបុគ្គលអ្នកអង្គុយស្ងៀមក៏មាន និន្ទាបុគ្គលអ្នកនិយាយច្រើនក៏មាន និន្ទាបុគ្គលអ្នកនិយាយល្មមប្រមាណក៏មាន (អ្នកណាៗ ក៏ដោយ) ក្នុងលោក ដែលមិនត្រូវគេនិន្ទាគ្មានឡើយ បុគ្គលដែលត្រូវគេនិន្ទាតែម្យ៉ាង ឬត្រូវគេសរសើរតែម្យ៉ាង មិនមែនមានមកហើយ តែក្នុងអតីតទេ នឹងមានទៅក្នុងអនាគតក៏ទេ មានតែក្នុងបច្ចុប្បន្ននេះក៏ទេ ។

បើអ្នកប្រាជ្ញទាំងឡាយ សង្កេតមើលរាល់ៗ ថ្ងៃ ហើយសរសើរបុគ្គលណា ដែលជាអ្នកប្រព្រឹត្តមិនជាប់ មានប្រាជ្ញា មានចិត្តតម្កល់ខ្ជាប់ក្នុងបញ្ញា និងសីល អ្នកណាគួរនឹងនិន្ទាបុគ្គលដែលដូចជាឆ្មោរនៃមាសជម្ពោនទនោះបាន សូម្បីទេវតា និងមនុស្សទាំងឡាយ ក៏សរសើរបុគ្គលនោះ ទាំងព្រហ្មក៏សរសើរ (ដូចគ្នា) ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **នោ** *គឺការនិន្ទា និងការសរសើរនោះឯង ជារបស់ចាស់ ។*

ព្រះសាស្តាត្រាស់ហៅឧបាសកនោះថា អតុលៈ ។

បាទព្រះគាថាថា **ឯតំ អជ្ជតនាមិវ** សេចក្តីថា ការនិន្ទា ឬការសរសើរនេះ ហាក់ដូចជាមានក្នុងថ្ងៃនេះ គឺកើតអម្បាញ់មិញក៏មិនមែន អធិប្បាយថាពិតហើយ មនុស្សទាំងឡាយ រមែងនិន្ទាបុគ្គលម្នាក់ថា ហេតុអ្វី ទើបបុគ្គលនេះអង្គុយដូចមនុស្សគេរ ដូចមនុស្សត្រេចៀកថ្ងង់ ហាក់ដូចមិនដឹងអ្វីសោះ ដូច្នេះក៏មាន រមែងនិន្ទាបុគ្គលដែលនិយាយច្រើនថា ហេតុអ្វី ទើបបុគ្គលនេះធ្វើសំឡេង កជៈ កជៈ ដូចស្វីកន្ធោតត្រូវខ្យល់បក់ វាចារបស់បុគ្គលនេះមិនមានទីបំផុតសោះ ដូច្នេះ រមែងនិន្ទាបុគ្គលដែលនិយាយល្មមប្រមាណថា ហេតុអ្វី ទើបបុគ្គលនេះ សម្គាល់ទូវពាក្យរបស់ខ្លួនដូចមាស និងប្រាក់ និយាយពាក្យពីរមាត់ហើយ នៅស្ងៀម ដូច្នេះ បុគ្គល ឈ្មោះថា មិនត្រូវនិន្ទា មិនមានក្នុងលោកនេះ ដោយប្រការទាំងពួង ដោយប្រការយ៉ាងនោះ ។

បទថា **ន ចាហុ** ជាដើម បានដល់ មិនមានហើយក្នុងអតីត នឹងមិនមានក្នុងអនាគត ។

ពីរបទថា **យញ្ចេ វិញ្ញូ** សេចក្តីថា ការនិន្ទា ឬសរសើររបស់ពួកជនពាលមិនជាប្រមាណ តែបណ្ឌិតទាំងឡាយពិចារណាហើយ គឺជ្រាបហេតុនៃនិន្ទា ឬហេតុនៃសរសើរហើយរាល់ថ្ងៃ រមែងសរសើរបុគ្គលណា បុគ្គលឈ្មោះថាមានការប្រព្រឹត្តមិនជាច់ខ្សែ ព្រោះជាអ្នកប្រកបដោយសិក្ខាដែលមិនជាច់ ឬដោយការប្រព្រឹត្តទៅនៃជីវិតមិនជាច់ខ្សែ បុគ្គលឈ្មោះថាមានបញ្ញា ព្រោះជាអ្នកប្រកបដោយបញ្ញាដែលរុងរឿងក្នុងធម៌ ឈ្មោះថា តាំងមាំដោយបញ្ញានិងសីល ព្រោះជាការប្រកបដោយបញ្ញា ដែលជាលោកិយ និងលោកុត្តរ និងដោយបារិសុទ្ធិ-

សីល ៤ បុគ្គលណាគួរនិន្ទាបុគ្គលនោះ ដែលដូចជាមាសជម្ពោនទ ដែលវៀរចាកទោសនៃមាសដែលគួរដុសខាត់ ។

បទថា **ឧភាបិ** *ជាដើម បានដល់ ទេវតាក្តី មនុស្សដែលជាបណ្ឌិតក្តី រមែងក្រោកឡើងលើកតម្កើង សរសើរនូវភិក្ខុនោះ ។*

បទថា **ព្រហ្មុនាបិ** *សេចក្តីថា មិនមែនទេវតា និងមនុស្សតែម្យ៉ាង ប៉ុណ្ណោះទេ សូម្បីមហាជនក្នុងមុខចក្រវាល ក៏សរសើរបុគ្គលនោះដូចគ្នា ។*

ក្នុងកាលចប់ទេសនា ឧបាសកទាំង ៥០០ តាំងនៅហើយក្នុងសោតាបត្តិផល ដូច្នេះឯង ។

រឿង អតុលឧបាសក ចប់

រឿង ឆព្វគ្គិយភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធឆព្វគ្គិយភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា **កាយប្បកោបំ** *ជាដើម ។*

សេចក្តីពិស្តារ ថ្ងៃមួយ ព្រះសាស្តាទ្រង់ស្តាប់សំឡេង ១ដៈ ១ដៈ នៃភិក្ខុទាំងនោះ ដែលកាន់ឈើច្រត់ត្រង់ដៃទាំងពីរ ពាក់ទ្រនាប់ជើង ចង្រ្កមលើផ្ទាំងថ្ម ត្រាស់សួរថា អានន្ទ នុ៎ះជាសំឡេងអ្វី ទ្រង់ស្តាប់ថាជាសំឡេង ១ដៈ ១ដៈ នៃពួកឆព្វគ្គិយភិក្ខុ ដែលពាក់ទ្រនាប់ជើងឈើចង្រ្កម ទើបទ្រង់បញ្ញត្ត

សិក្ខាបទ ហើយត្រាស់ថា ធម្មតាភិក្ខុគួរវក្បាទ្វារ មានកាយទ្វារជាដើម ដូច្នេះ ហើយ កាលទ្រង់សម្តែងធម៌ ទើបភាសិតព្រះគាថានេះថា

កាយប្បកោបំ រក្ខេយ្យ	**កាយេន សំវុតោ សិយា**
កាយទុច្ចរិតំ ហិត្វា	**កាយេន សុចរិតំ ចរេ**
វចីបកោបំ រក្ខេយ្យ	**វាចាយ សំវុតោ សិយា**
វចីទុច្ចរិតំ ហិត្វា	**វាចាយ សុចរិតំ ចរេ**
មនោបកោបំ រក្ខេយ្យ	**មនសា សំវុតោ សិយា**
មនោទុច្ចរិតំ ហិត្វា	**មនសា សុចរិតំ ចរេ**
កាយេន សំវុតា ធីរា	**អថោ វាចាយ សំវុតា**
មនសា សំវុតា ធីរា	**តេ វេ សុបរិសំវុតា ។**

បុគ្គលគប្បីរក្សានូវការកម្រើកកាយ គប្បីសង្រួមកាយ គប្បីលះបង់កាយទុច្ចរិត គប្បីប្រព្រឹត្តកាយសុចរិត គប្បីរក្សានូវការកម្រើកវាចា គប្បីសង្រួមវាចា គប្បីលះបង់វចីទុច្ចរិត គប្បីប្រព្រឹត្តវចីសុចរិត គប្បីរក្សានូវការកម្រើកចិត្ត គប្បីសង្រួមចិត្ត គប្បីលះបង់មនោទុច្ចរិត គប្បីប្រព្រឹត្តមនោ-សុចរិត អ្នកប្រាជ្ញទាំងឡាយ បានសង្រួមកាយ សង្រួមវាចា អ្នកប្រាជ្ញទាំងឡាយ បានសង្រួមចិត្តហើយ លោកទាំងនោះឯង ឈ្មោះថា សង្រួមហើយដោយប្រពៃ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កាយប្បកោបំ** បានដល់ គប្បីរក្សាកាយទុច្ចរិត ៣ យ៉ាង ។

ពីរបទថា **កាយេន សំវុតោ** សេចក្តីថា គប្បីហាមការចូលទៅនៃទុច្ចរិតក្នុងកាយទ្វារ សង្រួមហើយ គឺមានទ្វារបិទហើយ ព្រោះបុគ្គលលះកាយ-ទុច្ចរិត ប្រព្រឹត្តកាយសុចរិត ឈ្មោះថា ធ្វើកម្មនោះទាំងពីរយ៉ាង ដូច្នោះ ទើបទ្រង់ត្រាស់ថា **កាយទុច្ចរិតំ ហិត្វា កាយេន សុចរិតំ ចរេ** ក្នុងគាថាជាលំដាប់ទៅ ក៏នយនេះដូចគ្នា ។

បាទព្រះគាថាថា **កាយេន សំវុតា ធីរា** សេចក្តីថា បណ្ឌិតពួកណា កាលមិនធ្វើកាយទុច្ចរិត មានបាណាតិបាតជាដើម ឈ្មោះថា សង្រួមហើយផ្លូវកាយ កាលមិនធ្វើវចីទុច្ចរិត មានមុសាវាទជាដើម ឈ្មោះថា សង្រួមហើយដោយវាចា កាលមិនឲ្យមនោទុច្ចរិត មានអភិជ្ឈាជាដើមតាំងឡើង ឈ្មោះថា សង្រួមហើយផ្លូវចិត្ត បណ្ឌិតទាំងនោះ ឈ្មោះថា សង្រួមល្អហើយ គឺរក្សាល្អហើយ ឃុំគ្រងល្អហើយ មានទ្វារបិទល្អហើយក្នុងលោកនេះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងធម្មគ្គិយភិក្ខុ ចប់

កោធវគ្គ ចប់

វគ្គទី ១៧ ចប់

សុត្តន្តបិដក

ធម្មបទគាថា មលវគ្គទី ១៨

[២៨] ឥឡូវនេះ ខ្លួនអ្នកដូចស្ទឹកឈើទុំហើយ ទាំងពួកបុរសរបស់យមរាជ ប្រាកដជាលល់អ្នកហើយ ខ្លួនអ្នកតាំងនៅក្នុងមាត់សេចក្តីវិនាស សូម្បីស្បៀង គឺកុសលរបស់អ្នក ក៏មិនទាន់មានឡើយ ។ អ្នកចូរធ្វើកុសលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបាន មិនមានទីទួល គឺកិលេស នឹងដល់នូវភូមិរបស់ព្រះអរិយៈ ដូចជាទិព្វបាន ។

ឥឡូវនេះ ខ្លួនអ្នកត្រូវជរាចូលដល់ហើយ ជាអ្នករៀបដំណើរទៅកាន់សម្នាក់យមរាជ មួយទៀត ទីសំចតក្នុងចន្លោះ មិនមានដល់អ្នកទេ សូម្បីស្បៀងក៏មិនមានដល់អ្នក ។

អ្នកចូរធ្វើទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបាន មិនមានទីទួល គឺកិលេស នឹងមិនត្រូវចូលទៅកាន់ជាតិ ជរា ព្យាធិ មរណៈទៀតឡើយ ។

អ្នកមានប្រាជ្ញា គួរកម្ចាត់បង់មន្ទិលរបស់ខ្លួនបន្តិចម្តងៗ រាល់ៗ ខណៈដោយលំដាប់ ដូចជាងមាស ជម្រះស្នឹម ឬប្រែរបស់មាស ដូច្នោះ ។

ប្រែកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ យ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គលអ្នកប្រព្រឹត្តកន្លងបញ្ញា

ជាគ្រឿងជម្រះចិត្ត ឲ្យទៅកាន់ទុគ្គតិ ក៏យ៉ាងនោះឯង ។

មន្តទាំងឡាយ មានការមិនស្វាធ្យាយជាមន្ទិល ផ្ទះទាំងឡាយ មានការមិនថែទាំជាមន្ទិល សេចក្តីខ្ជិល ជាមន្ទិលរបស់ពណ៌សម្បុរ សេចក្តីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

ការប្រព្រឹត្តអាក្រក់ ជាមន្ទិលរបស់សទ្ធា សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ ធម៌អាក្រក់ទាំងឡាយ ជាមន្ទិលក្នុងលោកនេះ និងលោកខាងមុខ ធម្មជាត ជាមន្ទិលដ៏លើសលុប ជាងមន្ទិលទាំងនោះ គឺអវិជ្ជា ជាមន្ទិលដ៏ក្រៃលែង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរលះមន្ទិលទាំងនេះចេញ ចូរកុំជាអ្នកមានមន្ទិលឡើយ ។

បុគ្គលអ្នកមិនមានសេចក្តីអៀនខ្មាស ក្លៀវក្លាដូចសត្វក្អែក កម្ចាត់បង់គុណរបស់អ្នកដទៃ ជាអ្នកឈ្លានពាន (យកមុខ) ជាអ្នកឃ្មើសឃ្មង ជាមនុស្សសៅហ្មង រស់នៅដោយងាយ ។ ចំណែកបុគ្គលអ្នកមានសេចក្តីអៀនខ្មាស ស្វែងរកអំពើស្អាតជានិច្ច មិនឡេះឡោះ មិនឃ្មើសឃ្មង រស់នៅដោយកម្មដ៏បរិសុទ្ធ អ្នកឃើញត្រូវ រស់នៅដោយលំបាក ។

ជនណា សម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យកវត្ថុដែលគេមិនបានឲ្យ ក្នុងលោកផង សេពប្រពន្ធរបស់អ្នកដទៃផង ជនណា ផឹកទឹកសុរា និងមេរ័យផង ជននោះឯងឈ្មោះថា គាស់រម្លើងឫសគល់របស់ខ្លួនក្នុងលោកនេះ ដោយពិត ។

ម្នាលបុរសដ៏ចម្រើន អ្នកចូរដឹងយ៉ាងនេះថា ជនទាំងឡាយមានធម៌

ជ័លាមក រមែងមិនជាអ្នកសង្រួម ដូច្នេះ លោក: និងសភាពមិនមែនធម៌ គឺ ទោស: ចូរកុំបៀតបៀនអ្នក ឲ្យបានសេចក្តីទុក្ខអស់កាលយូរឡើយ ។ ជន រមែងឲ្យតាមសទ្ធា តាមសេចក្តីជ្រះថ្លា បុគ្គលណា ជាអ្នកអៀនខ្មាសក្នុងទឹក និងភោជន របស់ជនទាំងឡាយជទៃ ជននោះ រមែងមិនបានសមាធិ ក្នុង វេលាថ្ងៃ ឬក្នុងវេលាយប់ឡើយ ។

លុះតែសេចក្តីអៀនខ្មាសនោះ បុគ្គលណាបានផ្តាច់ផ្តិលដកឡើង ធ្វើ ឲ្យមានឫសគល់ជាច់ហើយ បុគ្គលនោះឯង ទើបបានសមាធិចិត្ត ក្នុង វេលាថ្ងៃ ឬក្នុងវេលាយប់ ។

ភ្លើង ស្មើដោយរាគៈ មិនមាន ការចាប់ ស្មើដោយទោស: មិនមាន បណ្តាញ ស្មើដោយមោហៈ មិនមាន ស្មើង ស្មើដោយតណ្ហា មិនមាន ។

ទោសរបស់ពួកជនជទៃ ឃើញបានដោយងាយ ចំណែកទោសរបស់ ខ្លួន ឃើញបានដោយលំបាក ព្រោះថា បុគ្គលនោះ រោយទោសទាំងឡាយ ចំពោះពួកជនជទៃ ដូចបុគ្គលរោយអង្កាម ដូច្នោះ តែថា រមែងបិទបាំងទោស របស់ខ្លួនទុក ដូចព្រានបក្សីបិទបាំងអត្តភាព ដោយវត្ថុសម្រាប់បិទបាំង (មានមែកឈើជាដើម) ដូច្នោះ ។

កាលបុគ្គលគយគ្ងាំមើលទោស របស់បុគ្គលជទៃ ជាប្រក្រតី មាន ការសម្គាល់ហេតុ ក្នុងការពោលទោស (អ្នកជទៃ) ជានិច្ច ជាប្រក្រតី អាសវៈទាំងឡាយរបស់បុគ្គលនោះតែងចម្រើន បុគ្គលនោះ ឈ្មោះថា ស្ថិត នៅឆ្ងាយអំពីធម៌ជាគ្រឿងអស់អាសវៈ ។

ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន ពួកសត្វ ត្រេកអរហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ ព្រះតថាគតទាំងឡាយ មិនមាន ធម៌ជាគ្រឿងយឺតយូរឡើយ ។

ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន សង្ខារ ទាំងឡាយជារបស់ទៀង មិនមាន ព្រះពុទ្ធទាំងឡាយ មិនមានកិលេសជា គ្រឿងញាប់ញ័រទេ ។

មលវគ្គទី ១៨ ចប់

អដ្ឋកថា

ធម្មបទដ្ឋកថា ខុទ្ទកនិកាយ គាថាធម្មបទ

មលវគ្គទី ១៨

រឿង ក្មួនរបស់គោឃាតកៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅវត្តជេតពន ទ្រង់ប្រារព្ធបុត្ររបស់គោឃាតកៈ ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **បណ្ឌុបលាសោវធានិសិ** *ជាដើម ។*

បានឮមកថា គោឃាតកៈម្នាក់ក្នុងនគរសាវត្ថី សម្លាប់គោហើយ កាន់យកសាច់ល្អឲ្យអាំងហើយ អង្គុយជាមួយបុត្រ និងភរិយា ទំពាស៊ីសាច់ និងលក់យកតម្លៃ ។ គាត់ធ្វើកម្មរបស់អ្នកសម្លាប់គោយ៉ាងនេះអស់ ៥៥ ឆ្នាំ មិនបានថ្វាយយាគូ និងភត្ត សូម្បីត្រឹមតែមួយវែកក្នុងមួយថ្ងៃដល់ព្រះសាស្តា ដែលប្រថាប់នៅក្នុងវិហារជិត ។ គាត់បើគ្មានសាច់ មិនបរិភោគភត្ត ។ ថ្ងៃមួយ គាត់លក់សាច់ក្នុងពេលថ្ងៃហើយ ឲ្យដុំសាច់មួយដុំដល់ភរិយាដើម្បីអាំង ជាប្រយោជន៍ដល់ខ្លួន ហើយទៅងូតទឹក ។

លំដាប់នោះ សម្លាញ់របស់គាត់មកកាន់ផ្ទះហើយ និយាយនឹងភរិយាថា នែនាង ចូរឲ្យសាច់ដែលគប្បីលក់ដល់ខ្ញុំបន្តិច ព្រោះក្រៀមកឯផ្ទះខ្ញុំ ។

ភរិយាគោឃាតកៈពោលថា សាច់ដែលគប្បីលក់មិនមាន សម្លាញ់របស់

អ្នកលក់សាច់ហើយ ឥឡូវនេះ ទៅឆ្ងូតទឹក ។

សម្ងាញ់នោះពោលថា កុំធ្វើយ៉ាងនេះទៀយ បើដុំសាច់មាន ចូរឲ្យចុះ ។ ភរិយាគោឃាតកៈពោលថា វៀរដុំសាច់ដែលខ្ញុំទុកដើម្បីសម្ងាញ់របស់អ្នក ហើយសាច់ដទៃមិនមាន ។ បុរសនោះគិតថា សាច់ដទៃក្រៅអំពីសាច់ដែលស្រីនេះទុកដើម្បីប្រយោជន៍ដល់សម្ងាញ់របស់អញមិនមាន ម្យ៉ាងទៀត សម្ងាញ់របស់អញនោះវៀរសាច់នេះ មិនបរិភោគ ស្រីនេះនឹងមិនឲ្យ ទើបកាន់យកសាច់នោះដោយខ្លួនឯង ចៀសចេញទៅ ។

ចំណែកគោឃាតកៈ ឆ្ងូតទឹកហើយត្រឡប់មក កាលភរិយានោះជួសភត្តនាំចូលទៅ មួយអន្ទើដោយបន្ទៃស្ងោរដើម្បីខ្លួន ទើបពោលថា សាច់នៅឯណា ភរិយាពោលថា នែអ្នក សាច់មិនមាន គោឃាតកៈពោលថា អញឲ្យសាច់ដើម្បីអាំងហើយ ទើបទៅមិនមែនឬ ភរិយាពោលថា សម្ងាញ់របស់អ្នកមកប្រាប់ថា ក្មៀវរបស់ខ្ញុំមក ចូរនាងឲ្យសាច់ដែលគប្បីឲ្យដល់ខ្ញុំ កាលខ្ញុំធ្វើយថា សាច់ដទៃក្រៅអំពីសាច់ដែលខ្ញុំទុកដើម្បីសម្ងាញ់របស់អ្នកមិនមាន ម្យ៉ាងទៀត សម្ងាញ់របស់អ្នកនោះ វៀរចាកសាច់ រមែងមិនបរិភោគ ក៏កាន់យកសាច់នោះដោយខ្លួនឯង ទៅហើយ ។

គោឃាតកៈពោលថា អញវៀរចាកសាច់មិនបរិភោគភត្ត ចូរនាងនាំភត្តនោះទៅ ភរិយាពោលថា ខ្ញុំអាចធ្វើអ្វីបាន សូមអ្នកបរិភោគចុះ ។

គោឃាតកៈនោះពោលថា អញមិនបរិភោគភត្ត ឲ្យភរិយានាំភត្តនោះទៅហើយ កាន់កាំបិតទៅកាន់សម្ងាក់គោ ដែលកំពុងឈរក្រោយផ្ទះ ហើយលូក

ដៃចូលទៅក្នុងមាត់ ទាញអណ្តាត យកកាំបិតកាត់ត្រង់គល់ ហើយកាន់យកទៅអាំងលើរងើកភ្លើង ជាក់លើកត្តអង្គុយបរិភោគ ដុំកត្តមួយដុំ ជាក់សាច់មួយដុំក្នុងមាត់ ។ ក្នុងខណៈនោះឯង អណ្តាតរបស់គាត់ជាប់ធ្លាក់ចុះក្នុងថាសសម្រាប់ជាក់កត្ត ។ ក្នុងខណៈនោះឯង គាត់បានវិបាកដែលឃើញសមដោយកម្ម គាត់ដូចជាគោដែលឈាមហូរចេញអំពីមាត់ ចូលទៅខាងក្នុងផ្ទះ ដើរដោយជង្គង់ ទ្រហោយំ ។

សម័យនោះ កូនរបស់គោឃាតក: ឈរមើលបិតាក្នុងទីជិត ។ គ្រានោះ មាតាពោលនឹងគាត់ថា នែកូន ចូរកូនមើលឪពុកដែលដើរដោយជង្គង់ទ្រហោយំត្រង់កណ្តាលផ្ទះដូចគោ សេចក្តីទុក្ខនេះ នឹងធ្លាក់លើអំបែងក្បាលរបស់ឯង ឯងមិនត្រូវជាប់ជំពាក់នឹងម៉ែ ចូរធ្វើទូវាសួស្តីដល់ខ្លួនគេចទៅចុះ ។ កូនរបស់គោឃាតក:នោះ ត្រូវមរណភ័យគំរាម ថ្វាយបង្គំមាតាហើយគេចចេញទៅ កាលគេចទៅហើយ ទៅកាន់នគរតក្កសិលា សូម្បីគោឃាតក:ក៏ដូចគ្នានឹងសត្វគោ ស្រែកភេទ័ក្នុងកណ្តាលផ្ទះ ធ្វើកាលកិរិយាហើយកើតក្នុងអវីចី សូម្បីគោក៏បានស្លាប់ហើយ ។ ចំណែកកូនរបស់គោឃាតក: ទៅនគរតក្កសិលារៀនការងាររបស់ជាងមាស ។ លំដាប់នោះ អាចារ្យរបស់គាត់ទៅកាន់ស្រុកផ្តាំថា អ្នកគប្បីធ្វើគ្រឿងប្រដាប់ឈ្មោះនេះ ហើយចៀសចេញទៅ ។ គាត់ក៏បានធ្វើគ្រឿងប្រដាប់បែបនោះហើយ ។ កាលនោះ អាចារ្យរបស់គាត់មកឃើញគ្រឿងប្រដាប់ហើយត្រិះរិះថា បុរសនេះទៅក្នុងទីណាមួយ ជាអ្នកអាចចិញ្ចឹមជីវិតបាន ទើបឲ្យធីតាដែលចម្រើនវ័យរបស់ខ្លួនដល់គាត់ គាត់ចម្រើន

ដោយបុត្រ និងធីតាហើយ ។

លំដាប់នោះ កូនទាំងឡាយរបស់គាត់ចម្រើនវ័យហើយ រៀនសិប្បៈក្នុងកាលតមក ទៅកាន់នគរសាវត្ថី ញ៉ាំងឃរាវាសឲ្យប្រព្រឹត្តទៅក្នុងនគរនោះ បានជាអ្នកមានសទ្ធាជ្រះថ្លា ។ ចំណែកបិតារបស់ពួកគាត់ មិនធ្វើកុសលណាមួយឡើយ ទោះបីនៅក្នុងភាពជរាក្នុងនគរតក្កសិលានោះ ។ លំដាប់នោះ ពួកកុលបុត្ររបស់គាត់ប្រឹក្សាគ្នាថា ឪពុករបស់ពួកយើងចាស់ ហើយឲ្យហៅមកកាន់សម្នាក់របស់ខ្លួនពោលថា ពួកខ្ញុំនឹងថ្វាយទានដើម្បីប្រយោជន៍ដល់លោកឪពុក ហើយនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ស្អែកឡើង ពួកជនទាំងនោះ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យគង់ក្នុងផ្ទះ ហើយអង្គាសដោយគោរព ក្នុងកាលស្រេចភត្តកិច្ច ក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គ ថ្វាយភត្តនេះឲ្យជាជីវភត្តដើម្បីបិតា ។ សូមទ្រង់ធ្វើអនុមោទនាដល់បិតារបស់ខ្ញុំព្រះអង្គចុះ ។

ព្រះសាស្តា ត្រាស់ហៅបិតារបស់ពួកគេមកហើយត្រាស់ថា ឧបាសក អ្នកជាមនុស្សចាស់ មានសរីរៈចាស់ជរា ដូចគ្នានឹងស្លឹកឈើពណ៌លឿង ស្បៀងគឺកុសលដើម្បីទៅកាន់បរលោករបស់អ្នកមិនទាន់មាន ចូរអ្នកធ្វើទីពឹងដល់ខ្លួន ចូរជាបណ្ឌិត កុំជាបុគ្គលពាលឡើយ ដូច្នេះហើយ កាលទ្រង់ធ្វើអនុ-មោទនា ទើបត្រាស់ព្រះគាថានេះថា

បណ្ឌុបលាសោវជានាសិ យមបុរិសាបិ ច តេ ឧបដ្ឋិតា
ឧយ្យោគមុខេ ច តិដ្ឋសិ ថាថេយ្យម្បិ ច តេ ន វិជ្ជតិ

សោ ករោហិ ទីបមត្តនោ ឥប្បំ យាយម បណ្ឌិតោ ភវ
ឥទ្ធមលោ អនង្គណោ ទិព្វំ អរិយភូមិមេហិសិ ។

ឥឡូវនេះ ខ្លួនអ្នកដូចស្លឹកឈើទុំហើយ ទាំងពួកបុរសរបស់យមរាជក្រោកជជល់អ្នកហើយ ខ្លួនអ្នកតាំងនៅក្នុងមាត់នៃសេចក្តីវិនាស សូម្បីស្បៀង គឺកុសលរបស់អ្នក ក៏មិនទាន់មានឡើយ ចូរអ្នកធ្វើកុសលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបាន មិនមានទីទួលគឺកិលេស នឹងដល់នូវភូមិរបស់ព្រះអរិយៈ ដូចជាទិព្វបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បានព្រះគាថាថា **បណ្ឌុបលាសោវ ជានិសិ** *សេចក្តីថា ឧបាសក ឥឡូវនេះ អ្នកដូចជាស្លឹកឈើ ដែលមានពណ៌លឿង ដែលជាប់ធ្លាក់ចុះលើផែនដី ។*

ទូតរបស់ស្តេចយម ព្រះសាស្តាត្រាស់ហៅថា **យមបុរិសា ។** *តែពាក្យនេះ ទ្រង់ត្រាស់សំដៅដល់ការស្លាប់នោះឯង អធិប្បាយថា ការស្លាប់ក្រោកជជល់អ្នកហើយ ។*

បទថា **ឧយ្យោគមុខេ** *សេចក្តីថា អ្នកជាបុគ្គលតាំងនៅក្បែរមាត់នៃសេចក្តីវិនាស គឺជិតមាត់នៃសេចក្តីមិនចម្រើន ។*

បទថា **ថាថេយ្យំ** *សេចក្តីថា ស្បៀង គឺកុសលរបស់អ្នកដែលទៅកាន់

បរលោក ក៏មិនទាន់មាន ដូចស្បៀង មានអង្គ៥ជាដើម របស់បុគ្គលដែល ត្រៀមនឹងទៅ មិនទាន់មាន ដូច្នោះ ។

ពីរបទថា **សោ ករោហិ** *សេចក្តីថា ចូរអ្នកធ្វើទីពឹង គឺកុសលដល់ខ្លួន ដូចបុគ្គលកាលទូកលិចក្នុងសមុទ្រ ធ្វើនូវទីពឹងពោល គឺកោះដល់ខ្លួន ដូច្នោះ កាលអ្នកធ្វើ ចូរប្រញាប់ព្យាយាម គឺចូរប្រារព្ធសេចក្តីព្យាយាមឲ្យរហ័ស ចូរជាបណ្ឌិតដោយការធ្វើទីពឹង ពោល គឺកុសលកម្មដល់ខ្លួន ដ្បិតថា បុគ្គលណាធ្វើកុសល ក្នុងកាលដែលខ្លួនមិនទាន់ដល់មាត់នៃសេចក្តីស្លាប់ អាចនឹងធ្វើបាននោះឯង ។ បុគ្គលនោះ ឈ្មោះថា ជាបណ្ឌិត អធិប្បាយថា ចូរអ្នកជាបុគ្គលដូច្នោះ កុំជាអន្ធពាលឡើយ ។*

ពីរបទថា **ឥពុំ អរិយភូមិ** *សេចក្តីថា អ្នកធ្វើសេចក្តីព្យាយាមយ៉ាងនេះ ឈ្មោះថា កម្ចាត់មន្ទិលបានហើយ ព្រោះភាពជាអ្នកនាំមន្ទិល មានរាគៈជាដើម ចេញបាន ឈ្មោះថា មិនមានកិលេសដែលជាទីទួល គឺអស់កិលេស ព្រោះមិនមានកិលេសដូចទីទួល នឹងដល់ជាន់សុទ្ធាវាសភូមិ ដែលជាលំនៅនៃព្រះអរិយបុគ្គល ដែលបរិសុទ្ធហើយ ៥ ភូមិ ។*

ក្នុងកាលចប់ទេសនា ឧបាសក តាំងនៅក្នុងសោតាបត្តិផលហើយ ។ ទេសនាមានប្រយោជន៍ដល់ពួកជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

កូនទាំងនោះ និមន្តព្រះសាស្តាដើម្បីប្រយោជន៍ក្នុងថ្ងៃស្អែក ថ្វាយទានហើយ បានក្រាបទូលព្រះសាស្តា ទ្រង់ធ្វើភត្តកិច្ចហើយក្នុងកាលទ្រង់អនុមោទនាហើយថា បពិត្រព្រះអង្គ ភត្តនេះពួកខ្ញុំព្រះអង្គថ្វាយឲ្យជាជីវភត្ត ដើម្បីបិតា

របស់ពួកខ្ញុំព្រះអង្គដូចគ្នា សូមទ្រង់ធ្វើអនុមោទនាដល់បិតានេះឯង ។

ព្រះសាស្តា កាលទ្រង់ធ្វើអនុមោទនា បានត្រាស់ពីរគាថាដូច្នេះថា

ឧបនីតវយោ វាឆាឯសិ សម្បយាតោសិ យមស្ស សន្តិកំ
វាសោបិ ច តេ នត្ថិ អន្តរា ចាថេយ្យម្បិ ច តេ ន វិជ្ជតិ
សោ ករោហិ ទីបមត្តនោ ខិប្បំ វាយម បណ្ឌិតោ ភវ
និទ្ធន្តមលោ អនង្គណោ ន បុន ជាតិជរំ ឧបេហិសិ ។

ឥឡូវនេះ ខ្លួនអ្នកត្រូវជរាចូលជល់ហើយ ជាអ្នករៀបដំណើរទៅកាន់សម្នាក់យមរាជ មួយទៀត ទីសំចតក្នុងចន្លោះមិនមានដល់អ្នកទេ សូម្បីស្បៀង ក៏មិនមានដល់អ្នក ។

ចូរអ្នកធ្វើទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបាន មិនមានទីទួល គឺកិលេស នឹងមិនត្រូវចូលទៅកាន់ជាតិ ជរា ព្យាធិ មរណៈទៀតឡើយ ។

សេចក្តីអធិប្បាយ

សព្ទថា **ឧប** ក្នុងបទថា **ឧបនីតវយោ** ក្នុងព្រះគាថានោះ ត្រឹមតែជានិបាត ។ អ្នកមានវ័យដែលជរានាំទៅហើយ គឺមានវ័យកន្លងទៅហើយ បានជល់មានវ័យកន្លងហើយ អធិប្បាយថា ឥឡូវនេះ អ្នកកន្លងវ័យទាំង ៣ ហើយតាំងនៅជិតមាត់របស់សេចក្តីស្លាប់ ។

បានព្រះគាថាថា **សម្បយាតោសិ យមស្ស សន្តិកំ** សេចក្តីថា អ្នក

ត្រៀមទៅកាន់មាត់របស់មច្ចុ តាំងនៅហើយ ។

បាទព្រះគាថាថា **ឯសោបិ ច តេ ឯតិ អន្តរា** *សេចក្តីថា ពួកអ្នកដើរផ្លូវ រមែងស្នាក់ធ្វើកិច្ចនោះៗក្នុងវាងផ្លូវបានយ៉ាងណា បុគ្គលទៅកាន់បរលោករមែងស្នាក់នៅដូច្នោះមិនបាន ព្រោះខ្លួនទៅកាន់បរលោក មិនអាចនឹងពោលពាក្យជាដើមថា សូមអ្នករង់ចាំ ២-៣ ថ្ងៃ ខ្ញុំនឹងឲ្យទានសិន ឬស្តាប់ធម៌សិន ។ បុគ្គលកាលឃ្លាតចាកលោកនេះហើយ រមែងកើតក្នុងបរលោកនោះឯង ពាក្យនោះ ព្រះសាស្តាត្រាស់សំដៅយកសេចក្តីនេះ ។*

បទថា **ឥត្ថេយ្យំ** *នេះ ព្រះសាស្តាបានត្រាស់ខាងដើមហើយក៏ពិត តែព្រះសាស្តាទ្រង់កាន់យកក្នុងព្រះគាថានេះក៏ដើម្បីទ្រង់ធ្វើឲ្យរឿយៗ ដល់ឧបាសក សូម្បីព្យាធិនិងមរណៈ ក៏ឈ្មោះថាទ្រង់កាន់យកក្នុងបទថា* **ជាតិជរំ** *ដូច្នេះដូចគ្នា ។*

ព្រះសាស្តា ត្រាស់អនាគាមិមគ្គដោយព្រះគាថាខាងដើម ត្រាស់អរហត្តមគ្គក្នុងព្រះគាថានេះ ។ កាលបើដូច្នោះ ឧបាសក កាលព្រះសាស្តាទ្រង់សម្តែងធម៌ ដោយអំណាចមគ្គខាងលើ ក៏សម្រេចសោតាបត្តិផលខាងក្រោមហើយ ទើបសម្រេចអនាគាមិផល ក្នុងកាលចប់អនុមោទនានេះ តាមកម្លាំងឧបនិស្សយរបស់ខ្លួន ដូចកាលព្រះរាជាទ្រង់ពូតព្រះក្រយាហារ ទំហំប៉ុនព្រះឱស្ឋរបស់ព្រះអង្គ ហើយទ្រង់នាំចូលទៅដល់ព្រះឱរស ព្រះកុមារទ្រង់ទទួលដោយប្រមាណព្រះឱស្ឋរបស់ព្រះកុមារប៉ុណ្ណោះ ដូច្នេះ ។

ព្រះធម្មទេសនា មានប្រយោជន៍ដល់បរិស័ទដ៏សេសដូច្នេះឯង ។

រឿង ព្រាហ្មណ៍ម្នាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **អនុបុព្វេន មេធាវី** ជាដើម ។

បានឮថា ថ្ងៃមួយ ព្រាហ្មណ៍នោះចេញទៅអំពីព្រលឹម បានឃើញមើលពួកភិក្ខុជណ្តប់ចីវរ ក្នុងទីដែលជាទីជណ្តប់ចីវររបស់ភិក្ខុ ។ ទីនោះមានស្មៅដុះខ្ចីងហើយ ។ ក្រោយមក ភិក្ខុមួយរូបជណ្តប់ចីវរ ជាយចីវរក៏អូសលើស្មៅសើមដោយតំណក់ទឹកសន្សើមហើយ ។ ព្រាហ្មណ៍ឃើញហេតុនោះហើយគិតថា អញគួរធ្វើទីនេះឲ្យប្រាសចាកស្មៅ ក្នុងថ្ងៃស្អែកខ្ចីង ក៏យកចបទៅចាំងទីនោះ ធ្វើឲ្យដូចជាមណ្ឌលលាន ។

ស្អែកខ្ចីង កាលភិក្ខុទៅកាន់ទីនោះដណ្តប់ចីវរ ព្រាហ្មណ៍ឃើញជាយចីវររបស់ភិក្ខុមួយរូបអូសលើផែនដី ប្រឡាក់ដោយធូលី ទើបគិតថា អញរោយខ្សាច់ក្នុងទីនេះគួរ ហើយជញ្ជូនខ្សាច់រោយ ។

ខាងក្រោយមកទៀត ក្នុងពេលមុនភត្តមានកម្តៅខ្លាំង ។ ក្នុងកាលនោះ ព្រាហ្មណ៍ឃើញញើសហូរចេញអំពីកាយរបស់ពួកភិក្ខុ ដែលកំពុងឃ្លុំចីវរ ទើបគិតថា អញសាងមណ្ឌបក្នុងទីនេះគួរ ទើបសាងមណ្ឌបហើយ ។

ស្អែកខ្ចីង មានភ្លៀងធ្លាក់អំពីព្រលឹម ក្នុងកាលនោះព្រាហ្មណ៍សម្លឹងមើលភិក្ខុ ឃើញពួកភិក្ខុមានចីវរសើមគិតថា អញធ្វើសាលាក្នុងទីនេះគួរ ទើបសាងសាលា ហើយគិតថា អញនឹងធ្វើការឆ្លងសាលា ទើបនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យភិក្ខុទាំងឡាយគង់ខាងក្នុងផង ខាងក្រៅផង ថ្វាយ

ទាន ក្នុងពេលស្រេចកត្តកិច្ច ទទួលបាត្រព្រះសាស្តា ដើម្បីប្រយោជន៍ដល់ការអនុមោទនា ហើយក្រាបទូលរឿងទាំងអស់នោះ តាំងអំពីដើមដល់ចប់ថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឈរមើលក្នុងទីនេះ ក្នុងកាលដែលពួកភិក្ខុយ៉ូចីវរយើញហេតុការណ៍យ៉ាងនេះៗ ទើបសាងវត្តនេះៗ ឡើង ។

ព្រះសាស្តា ស្តាប់ពាក្យរបស់បុរសនោះហើយត្រាស់ថា ម្នាលព្រាហ្មណ៍ ធម្មតាបណ្ឌិតទាំងឡាយ ធ្វើកុសលបន្តិចម្តងៗ គ្រប់ៗ ខណៈ រមែងនាំមន្ទិលគឺអកុសលរបស់ខ្លួនចេញដោយលំដាប់នោះឯង ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

អនុបុព្ពេន មេធាវី ថោកំ ថោកំ ខណេ ខណេ
កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។

អ្នកមានប្រាជ្ញា គួរកម្ចាត់បង់មន្ទិលរបស់ខ្លួនបន្តិចម្តងៗ រាល់ៗ ខណៈ ដោយលំដាប់ ដូចជាងមាសជម្រះស្នឹម ឬច្រែះរបស់មាស ដូច្នោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អនុបុព្ពេន** *គឺដោយលំដាប់ ។ បុគ្គលប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ ឈ្មោះថា* **មេធាវី ។**

ពីរបទថា **ខណេ ខណេ** *សេចក្តីថា ធ្វើកុសលគ្រប់ៗ ឱកាស ។*

បទព្រះគាថាថា **កម្មារោ រជតស្សេវ** *សេចក្តីថា បណ្ឌិតធ្វើកុសលរឿយៗ ឈ្មោះថា គប្បីកម្ចាត់មន្ទិល គឺកិលេស មានរាគៈជាដើមរបស់ខ្លួន*

ដ្បិតថា កាលបើយ៉ាងនោះ បណ្ឌិតរមែងជាបុគ្គលឈ្មោះថា មានមន្ទិលដែលកម្ចាត់ហើយ គឺមិនមានកិលេស ដូចជាងមាសរម្ងាយដុំមាសតែម្តងប៉ុណ្ណោះ រមែងមិនអាចដេញមន្ទិលចេញ ហើយធ្វើគ្រឿងប្រដាប់ផ្សេងៗ បាន តែកាលរម្ងាយដុំមាសរឿយៗ រមែងដេញមន្ទិលចេញបាន ខាងក្រោយ រមែងធ្វើឲ្យជាគ្រឿងប្រដាប់ផ្សេងៗ ច្រើនយ៉ាងបាន ដូច្នោះ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍តាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។

រឿង ព្រាហ្មណ៍ម្នាក់ ចប់

រឿង ព្រះតិស្សត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ឈ្មោះតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អយសាវ មលំ សមុដ្ឋិតំ** *ជាដើម ។*

បានឮមកថា កុលបុត្រអ្នកក្រុងសាវត្ថីម្នាក់ បានបួស ឧបសម្បទាហើយ ប្រាកដឈ្មោះថា ព្រះតិស្សៈ ។ សម័យតមក ព្រះតិស្សៈនោះចាំវស្សាក្នុងវិហារក្នុងជនបទ បានសំពត់សាច់គ្រោតគ្រោតប្រមាណ ៨ ហត្ថ ចាំវស្សាបវារណាហើយ កាន់យកសំពត់នោះទៅជាក់ក្បែរដៃបងស្រី បងស្រីនោះត្រិះរិះថា សំពត់សាជកនេះមិនសមគួរដល់ប្អូនប្រុសអញ ហើយកាត់សំពត់

នោះ ដោយកាំបិតដ៏មុត ធ្វើឲ្យជាកំណាត់តូចធំ គ្រលុកក្នុងត្បាល់ ជជុះ សិតខារ រវៃឲ្យជាអំបោះល្អិត ត្បាញជាសំពត់សាដកហើយ ។

ឯព្រះថេរៈក៏ចាត់ចែងអំបោះ និងម្ជុល និមន្តភិក្ខុកំលោះ និងសាមណេរ ដែលធ្វើចីវរឲ្យប្រជុំគ្នាហើយ ទៅកាន់សម្នាក់បងស្រីពោលថា សូមបងឲ្យសំពត់សាដកនោះដល់អាតា្មៗ និងធ្វើចីវរ ។

បងស្រីនោះ នាំសំពត់សាដកប្រមាណ ៩ ហត្ថ មកដាក់ក្បែរដៃរបស់ព្រះថេរៈប្អូនប្រុស ។ លោកទទួលសំពត់សាដកនោះ មកពិចារណាហើយពោលថា សំពត់សាដករបស់អាតា្មសាច់គ្រោតគ្រោត ប្រមាណ ៨ ហត្ថ សំពត់នេះ សាច់ល្អិតប្រមាណ ៩ ហត្ថ សំពត់នេះ មិនមែនសំពត់សាដករបស់អាតា្មទេ ជាសំពត់សាដកបងស្រី អាតា្មមិនត្រូវការសំពត់នេះ ចូរបងស្រីឲ្យសំពត់សាដកផ្ទាំងនោះដល់អាតា្មចុះ ។ បងស្រីឆ្លើយថា បពិត្រលោកម្ចាស់ នេះជាសំពត់របស់លោកម្ចាស់នោះឯង សូមលោកម្ចាស់ទទួលសំពត់នោះចុះ ។ លោកមិនប្រាថ្នាឡើយ ។

លំដាប់នោះ ទើបបងស្រីប្រាប់កិច្ច ដែលខ្លួនធ្វើគ្រប់យ៉ាងដល់ព្រះថេរៈនោះ ហើយបានប្រគេនថា បពិត្រលោកម្ចាស់ នេះជាសំពត់របស់លោកម្ចាស់នោះឯង សូមលោកម្ចាស់ទទួលយកសំពត់នោះចុះ លោកកាន់សំពត់នោះទៅវិហារ ផ្តើមធ្វើចីវរកម្ម ។

លំដាប់នោះ បងស្រីរបស់លោកចាត់ចែងវត្ថុ មានបបរ និងភត្តជាដើម ដើម្បីប្រយោជន៍ដល់ភិក្ខុសាមណេរ ដែលធ្វើចីវររបស់ព្រះតិស្សៈនោះ ក្នុងថ្ងៃ

ដែលចីវរស្រេច បង់ស្រីឲ្យធ្វើសក្ការៈជាច្រើន លោកសម្លឹងមើលចីវរហើយ កើតនូវការជាប់ជំពាក់ក្នុងចីវរនោះ គិតថា ស្អែកនេះ អញនឹងដណ្តប់ចីវរនោះ ហើយពាក់ត្រង់ខ្សែស្បៀង ក្នុងរាត្រីនោះ មិនអាចឲ្យអាហារដែលឆាន់ហើយ រលួយបាន ធ្វើមរណកាលហើយ កើតជាចៃត្រង់ចីវរនោះឯង ។

ចំណែកបង់ស្រី ឮការអនិច្ចធម្មរបស់លោកហើយ ទ្រហោយំបម្រះនទៀលទៀបបាតជើងរបស់ពួកភិក្ខុ ។ ពួកភិក្ខុធ្វើសរីរកិច្ចរបស់លោកហើយ ពោលថា ចីវរនោះជារបស់សង្ឃនោះឯង ព្រោះមិនមានគិលានុបដ្ឋាក ពួកយើងនឹងចែកចីវរនោះ ហើយឲ្យនាំចីវរនោះចេញមក ចៃរត់ស្រែកទៅខាងនោះខាងនេះថា ភិក្ខុពួកនេះចែកចីវរដែលជារបស់អញ ។

ព្រះសាស្តា ប្រថាប់នៅក្នុងព្រះគន្ធកុដិ ទ្រង់ស្តាប់ឮសំឡេងចៃនោះដោយទិព្វសោតត្រាស់ថា អានន្ទ ចូរអ្នកប្រាប់កុំឲ្យពួកភិក្ខុចែកចីវររបស់តិស្សភិក្ខុ ហើយរក្សាទុក ៧ ថ្ងៃ ព្រះថេរៈឲ្យធ្វើយ៉ាងនោះហើយ ។ ចៃនោះ ធ្វើកាលកិរិយាក្នុងថ្ងៃទី ៧ កើតក្នុងវិមានជាន់តុសិតហើយ ក្នុងថ្ងៃទី ៨ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នកចែកចីវររបស់តិស្សៈ ហើយកាន់យក ពួកភិក្ខុធ្វើយ៉ាងនោះហើយ ។ ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា ហេតុអ្វីហ្ន៎ ទើបព្រះសាស្តាឲ្យរក្សា ចីវររបស់ព្រះតិស្សៈអស់ ៧ ថ្ងៃ ហើយទ្រង់អនុញ្ញាតដើម្បីកាន់យកក្នុងថ្ងៃទី ៨ ។

ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាប

ទូលថា ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តិស្សៈកើតជាចៃត្រង់ចីវរបស់ខ្លួន កាលពួកអ្នកចែកចីវរនោះ រត់ទៅ រត់មក ពោលយ៉ាងនេះថា ភិក្ខុទាំងនេះដណ្តើមចីវរដែលជារបស់អញ បើពួកអ្នកកាន់យកចីវរ ចៃនោះអាក់អន់ក្នុងពួកអ្នកហើយ គប្បីកើតក្នុងនរក ព្រោះហេតុនោះ ទើបតថាគតឲ្យរក្សាទុក ឥឡូវនេះ តិស្សៈកើតក្នុងវិមានជាន់តុសិតហើយ ព្រោះហេតុនោះ ទើបតថាគតអនុញ្ញាតការកាន់យកចីវរដល់ពួកអ្នក ។ កាលភិក្ខុនោះក្រាបទូលទៀតថា បពិត្រព្រះអង្គ ឈ្មោះថា តណ្ហានេះ គ្រោតគ្រោតហ្ន៎ ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ឈ្មោះថាតណ្ហារបស់សត្វទាំងនេះគ្រោតគ្រោត ធម្មតាប្រែះតាំងឡើងអំពីដែក រមែងស៊ីដែកនោះឯង រមែងឲ្យដែកវិនាសទៅ ធ្វើឲ្យជារបស់ប្រើប្រាស់មិនបាន យ៉ាងណា តណ្ហានេះក៏ដូច្នោះដូចគ្នា កើតឡើងខាងក្នុងរបស់សត្វទាំងនេះហើយ រមែងឲ្យសត្វទាំងនោះកើតក្នុងអបាយ មាននរកជាដើម ឲ្យដល់នូវសេចក្តីវិនាស ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

អយសា វ មលំ សមុដ្ឋិតំ តទុដ្ឋាយ តមេវ ខាទតិ
ឯវំ អតិធោនចារិនំ សានិ កម្មានិ នយន្តិ ទុគ្គតឹ ។

ប្រែះកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ យ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គលអ្នកប្រព្រឹត្តកន្ធងបញ្ជាជាគ្រឿងជម្រះចិត្ត ឲ្យទៅកាន់ទុគ្គតិក៏យ៉ាងនោះឯង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អយសា** គឺអំពីដែក ។ បទថា **សមុដ្ឋិតំ** គឺតាំងឡើងហើយ ។ បទថា **តទុដ្ឋាយ** គឺកាលតាំងឡើងអំពីដែកនោះ ។

ក្នុងបទថា **អតិឆោឧចារិនំ** បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដូច្នេះថា បញ្ញាជាគ្រឿងពិចារណាបច្ច័យ ៤ ថា ការបរិភោគនេះ ជាប្រយោជន៍ដោយបច្ច័យទាំងនេះ ហើយបរិភោគ ព្រះសាស្តាត្រាស់ថា **ឆោឧ** បុគ្គលប្រព្រឹត្តកន្ទងនូវបញ្ញា ឈ្មោះថា **ឆោឧ** នោះ ឈ្មោះថា **អតិឆោឧចារី** ។

ព្រះសាស្តាត្រាស់ដូច្នេះថា ច្រែះកើតអំពីដែក តាំងឡើងអំពីដែក តែងស៊ីដែកនោះឯង យ៉ាងណា កម្មទាំងឡាយរបស់ខ្លួន គឺកម្មទាំងនោះ ឈ្មោះថាជារបស់ខ្លួននោះឯង ព្រោះតាំងឡើងក្នុងខ្លួន រមែងនាំបុគ្គលដែលមិនពិចារណាបច្ច័យ ៤ ហើយបរិភោគ ឈ្មោះថា ប្រព្រឹត្តឈានកន្ទងនូវបញ្ញា ឈ្មោះថា **ឆោឧ** ទៅកាន់ទុគ្គតិដូច្នោះដូចគ្នា ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះតិស្សត្ថេរ ចប់

រឿង ព្រះលោឡុទាយិត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះលោឡុទាយី ត្រាស់ព្រះធម្មទេសនានេះថា **អសជ្ឈាយមលា មន្តា** ជាដើម ។

បានឮមកថា ពួកអរិយសាវ័កប្រមាណ ៥ កោដិ ក្នុងនគរសាវត្ថីថ្វាយទានមុនភត្តហើយ ក្រោយភត្ត កាន់វត្ថុទាំងឡាយ មានសប្បិ ប្រេង ទឹកឃ្មុំ ទឹកអំពៅ និងសំពត់ជាដើមទៅវិហារ ហើយស្តាប់ធម្មកថា ក្នុងកាលស្តាប់ធម៌ហើយ ដើរទៅ រមែងពោលគុណរបស់ព្រះសារីបុត្ត និងព្រះមោគ្គល្លាន ។

ព្រះឧទាយិត្ថេរ ស្តាប់ពាក្យរបស់អរិយសាវ័កទាំងនោះហើយ ទើបពោលថា ពួកអ្នកស្តាប់ធម្មកថារបស់ព្រះថេរៈទាំងពីរនោះ គង់ពោលដល់ម្ល៉ៃៈ បើស្តាប់ធម្មកថារបស់អាត្មាហើយ នឹងពោលយ៉ាងណាហ្ន៎ ។

ពួកមនុស្សស្តាប់ពាក្យរបស់លោកហើយ គិតថា ព្រះថេរៈនេះប្រហែលជាព្រះធម្មកថិកមួយអង្គ ពួកយើងស្តាប់ធម្មកថារបស់ព្រះថេរៈនេះ គួរ ។ ថ្ងៃមួយ ពួកជនទាំងនោះអារាធនាព្រះថេរៈថា បពិត្រលោកម្ចាស់ ថ្ងៃនេះ ជាថ្ងៃស្តាប់ធម៌របស់ពួកខ្ញុំ ថ្វាយទានដល់ព្រះសង្ឃហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ពោលធម្មកថាក្នុងពេលថ្ងៃចុះ ចំណែកព្រះថេរៈនោះ ទទួលនិមន្តរបស់ពួកមនុស្សនោះហើយ ។

កាលពួកមនុស្សមកក្នុងពេលស្តាប់ធម៌ហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ពោលធម៌ដល់ពួកខ្ញុំចុះ ។ ព្រះលោឡុទាយិត្ថេរអង្គុយលើអាសនៈហើយ ចាប់ផ្តើតដ៏វិចិត្រ ក៏ញ៉ាំមិនឃើញបទធម៌ សូម្បីមួយបទ

ពោលថា អាត្មានឹងសូធ្យសរភញ្ញ សូមភិក្ខុអង្គដទៃពោលធម្មកថាចុះ ដូច្នេះ ហើយ ក៏ចុះអំពីធម្មាសនៈ ។ មនុស្សទាំងនោះ និមន្តភិក្ខុរូបដទៃឲ្យពោល ធម្មកថាហើយ និមន្តព្រះលោឡុទាយីឡើងកាន់អាសនៈទៀត ដើម្បីសូធ្យ សរភញ្ញ ព្រះលោឡុទាយីនោះ មិនឃើញបទធម៌ណាមួយទៀត ទើបពោល ថា អាត្មានឹងពោលក្នុងពេលយប់ សូមភិក្ខុរូបដទៃសូធ្យសរភញ្ញចុះ ហើយក៏ ចុះ មនុស្សទាំងនោះ និមន្តភិក្ខុដទៃឲ្យសូធ្យសរភញ្ញហើយ នាំព្រះថេរៈមក ក្នុងពេលយប់ទៀត ព្រះថេរៈនោះក៏មិនឃើញធម្មបទណាមួយសូម្បីក្នុងពេល យប់ ពោលថា អាត្មានឹងពោលក្នុងពេលទៀបភ្លឺ សូមភិក្ខុរូបដទៃពោលក្នុង ពេលយប់ចុះ ហើយក៏ចុះ ។ មនុស្សទាំងនោះ និមន្តភិក្ខុរូបដទៃឲ្យពោលហើយ ក្នុងពេលទៀបភ្លឺ ក៏នាំព្រះថេរៈនោះមកទៀត ។ ព្រះថេរៈនោះ សូម្បីក្នុង ពេលទៀបភ្លឺ ក៏មិនបានឃើញបទធម៌ណាមួយ ។

មហាជនកាន់យកវត្ថុទាំងឡាយ មានដុំដី និងអង្កត់ឧសជាដើមគំរាមថា កិក្ខុអន្ធពាល កាលពួកខ្ញុំពោលសរសើរព្រះសារីបុត្ត និងព្រះមោគ្គល្លាន លោក ពោលយ៉ាងនេះ និងយ៉ាងនេះ ឥឡូវនេះ ហេតុអ្វីទើបមិនពោល ដូច្នេះហើយ ក៏ជាប់តាមព្រះថេរៈដែលគេចទៅ ។ ព្រះថេរៈនោះ គេចទៅធ្លាក់ក្នុងវច្ចកុដិ មួយកន្លែង ។

មហាជនសន្ធនាគ្នាថា ព្រះលោឡុទាយី កាលពាក្យសរសើរគុណព្រះ សារីបុត្ត និងព្រះមោគ្គល្លានប្រព្រឹត្តទៅ អួតអាងប្រកាសភាពដែលខ្លួនជា ធម្មកថិក កាលពួកមនុស្សធ្វើសក្ការៈហើយ ពោលថា ពួកខ្ញុំនឹងស្តាប់ធម៌

អង្គុយលើអាសនៈអស់ ៤ ជង មិនឃើញបទធម៌ណាមួយដែលគប្បីពោល ត្រូវពួកមនុស្សកាន់វត្តទាំងឡាយ មានជុំជី និងអង្គត់ឧសជាដើម គំរាមថា លោកម្ចាស់លើកខ្លួនផ្ទឹមនឹងព្រះសារីបុត្ត និងព្រះមោគ្គល្លាន លោកម្ចាស់របស់ពួកយើង ដេញឲ្យគេចទៅធ្លាក់ក្នុងវច្ចកុដិហើយ ។

ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី កាលភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះទេ សូម្បីក្នុងកាលមុន លោឡុទាយីនេះ ក៏លិចចុះក្នុងរណ្តៅលាមកដូចគ្នា ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ជាតកនេះ ឲ្យដោយពិស្តារថា

ម្នាលសម្ងាញ់អ្នកមានធុរៈស្មើ ខ្ញុំមានជើង ៤ ម្នាលសម្ងាញ់ អ្នកឯងក៏មានជើង ៤ ដែរ ម្នាលសម្ងាញ់ ចូរអ្នកត្រឡប់មក អ្នកខ្លាចឬ បានជារត់ចេញ ។

ដូច្នេះហើយ ត្រាស់ថា រាជសីហ៍ក្នុងកាលនោះ បានជាសារីបុត្ត ជ្រូកបានជាលោឡុទាយី ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោឡុទាយីរៀនធម៌មានប្រមាណតិចពិត ម្យ៉ាងទៀត មិនបានធ្វើការទន្ទេញសោះ ការរៀនបរិយត្តិណាមួយហើយ មិនធ្វើនូវការស្វាធ្យាយ បរិយត្តិនោះជាមនុលពិត ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

អសជ្ឈាយមលា មន្តា　　អនុដ្ឋានមលា ឃរា

មលំ វណ្ណស្ស កោសជ្ជំ　　បមាទោ រក្ខតោ មលំ ។

មន្តទាំងឡាយ មានការមិនស្វាធ្យាយជាមន្ទិល ផ្ទះទាំងឡាយ មានការមិនថែទាំជាមន្ទិល សេចក្តីខ្ជិល ជាមន្ទិលរបស់ពណ៌សម្បុរ សេចក្តីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អសជ្ឈាយមលា** *ជាដើម សេចក្តីថា ព្រោះបរិយត្តិ គឺសិប្បៈណាមួយ កាលបុគ្គលមិនទន្ទេញ មិនប្រកបរឿយៗ រមែងសាបសូន្យ ឬមិនជ្រាកជជាប់គ្នា ដូច្នោះ ទើបព្រះសាស្តាត្រាស់ថា* **អសជ្ឈាយមលា មន្តា ។**

ម្យ៉ាងទៀត ព្រោះឈ្មោះថា ផ្ទះរបស់បុគ្គលដែលគ្រប់គ្រងផ្ទះ ក្រោកឡើងស្រេចជាប់ហើយ មិនធ្វើកិច្ចមានការជួសជុលផ្ទះដែលទ្រុឌទ្រោមជាដើម រមែងវិនាស ដូច្នោះ ទើបព្រះសាស្តាត្រាស់ថា **អនុដ្ឋានមលា ឃរា ។**

ព្រោះកាយរបស់គ្រហស្ថ ឬបព្វជិតដែលមិនធ្វើការជម្រះសរីរៈ ឬធ្វើការជម្រះបរិក្ខារ ដោយអំណាចការខ្ជិលច្រអូស រមែងមានពណ៌សម្បុរអាប់ ដូច្នោះ ទើបព្រះសាស្តាត្រាស់ថា **មលំ វណ្ណស្ស កោសជ្ជំ ។**

ម្យ៉ាងទៀត ព្រោះកាលបុគ្គលរក្សាគោ ដេកលក់ ឬវង្វេងតែលេងដោយអំណាចសេចក្តីប្រមាទ គោទាំងនោះរមែងដល់នូវសេចក្តីវិនាស ដោយហេតុមានវត់ទៅកាន់ទីដែលមិនមែនកំពង់ជាដើមខ្លះ ដោយអន្តរាយ មានសត្វសាហាវ

និងចោរជាដើមខ្លះ ដោយអំណាចការឈានចុះកាន់ទីទាំងឡាយ មានស្រែស្រូវ សាលីជាដើមរបស់ពួកជនដទៃ ហើយទំពាស៊ីខ្លះ សូម្បីខ្លួនឯងរមែងដល់នូវ អាជ្ញាខ្លះ ការបរិភាសខ្លះ ។

ម្យ៉ាងទៀត កិលេសទាំងឡាយកន្ធងចូលទៅ ដោយអំណាចសេចក្តី ប្រមាទ រមែងញ៉ាំងបព្វជិតដែលមិនរក្សាទ្វារ ៦ ឲ្យឃ្លាតចាកសាសនា ដូច្នោះ ទើបព្រះសាស្តាត្រាស់ថា **បមាទោ រក្ខតោ មលំ** អធិប្បាយថា ការប្រមាទ នោះ ឈ្មោះថា ជាមន្ទិល ព្រោះការប្រមាទ ជាទីតាំងនៃមន្ទិល ដោយការនាំ សេចក្តីវិនាសមក ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះលោឧ្បុធាយិត្តេរ ចប់

រឿង កុលបុត្រម្នាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុលបុត្រម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **មលិត្តិយា ទុច្ចរិតំ** ជាដើម ។

បានឮមកថា មាតា និងបិតានាំកុលធីតាមានជាតិស្មើគ្នា ដើម្បីកុលបុត្រ នោះ ។ នាងបានជាស្រីអ្នកប្រព្រឹត្តក្រៅចិត្តប្តី តាំងអំពីថ្ងៃដែលនាំមកហើយ

កុលបុត្រនោះខ្វាស ព្រោះការប្រព្រឹត្តក្រៅចិត្តរបស់នាង មិនអាចចូលដល់នូវការជួបមុខដល់បុគ្គលណាម្នាក់ រៀវរលែងកុសលកម្ម មានការទំនុកបម្រុងព្រះសម្ពុទ្ធជាដើម ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ព្រះសាស្តាត្រាស់សួរថា ឧបាសក ព្រោះហេតុអ្វី ទើបតថាគតមិនឃើញអ្នក ឧបាសកក្រាបទូលសេចក្តីនោះហើយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងកុលបុត្រនោះថា ឧបាសក ក្នុងកាលមុន តថាគតបានពោលហើយថា ឈ្មោះថា ស្ត្រីទាំងឡាយ ដូចគ្នានឹងស្ទឹងជាដើម បណ្ឌិតមិនគួរធ្វើសេចក្តីក្រោធក្នុងស្ត្រីទាំងនោះ តែអ្នកចាំមិនបាន ព្រោះអន្តរភពបិទបាំង កាលកុលបុត្រនោះអារាធនាហើយ ត្រាស់ជាតកឲ្យពិស្តារថា

> ស្ទឹង ផ្លូវ វោងសុរា វោងជាទីប្រជុំ និងអណ្តូងទឹក យ៉ាងណា ធម្មតាពួកស្រីក្នុងលោក ក៏យ៉ាងនោះដែរ វេលា (នៃសេចក្តីស្រើបក្នុងកាម) របស់ពួកស្រីទាំងនោះ មិនមានឈប់ឈរទេ ។

ដូច្នេះហើយ ត្រាស់ថា ឧបាសក ភាពជាបុគ្គលប្រព្រឹត្តក្រៅចិត្ត ជាមន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ជាមន្ទិលរបស់អ្នកឲ្យទាន អកុសលកម្ម ជាមន្ទិលរបស់សត្វទាំងឡាយក្នុងលោកនេះ និងលោកខាងមុខ ព្រោះអត្តថាជាគ្រឿងញាំងសត្វឲ្យវិនាស តែអវិជ្ជាជាមន្ទិលដ៏ក្រៃលែងជាងមន្ទិលទាំងពួង ដូច្នេះហើយ ទ្រង់បានភាសិតគាថាទាំងនេះថា

មលិត្ថិយា ឧុច្ចរិតំ មច្ចេរំ ឧឧតោ មលំ
មលា វ ទាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច ។
តតោ មលា មលតរំ អវិជ្ជា បរមំ មលំ
ឯតំ មលំ បហន្ត្វាន និម្មលា ហោថ ភិក្ខវោ ។

ការប្រព្រឹត្តអាក្រក់ ជាមន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ ធម៌អាក្រក់ទាំងឡាយ ជាមន្ទិលក្នុងលោកនេះ និងលោកខាងមុខ ធម្មជាតជាមន្ទិលដ៏លើសលុបជាងមន្ទិលទាំងនោះ គឺអវិជ្ជា ជាមន្ទិលដ៏ក្រែលែងម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះមន្ទិលទាំងនេះចេញ ចូរកុំជាអ្នកមានមន្ទិលឡើយ ។

សេចក្តីអធិប្បាយ

ការប្រព្រឹត្តក្រៅចិត្ត ឈ្មោះថាការប្រព្រឹត្តអាក្រក់ក្នុងព្រះគាថានោះ សូម្បីស្វាមី រមែងដេញស្ត្រីដែលប្រព្រឹត្តក្រៅចិត្តចេញទៅខាងក្រៅផ្ទះ ស្រីនោះទៅកាន់សម្នាក់របស់មាតាបិតា ក៏ត្រូវមាតាបិតាបណ្តេញដោយពាក្យថា ហងមិនមានការគោរពត្រកូល អញមិនអាចឃើញហងដោយភ្នែកទាំងពីរ ស្ត្រីនោះអស់ទីពឹង ត្រាច់ទៅ រមែងដល់នូវសេចក្តីលំបាកច្រើន ព្រោះហេតុនោះទើបព្រះសាស្តាត្រាស់ការប្រព្រឹត្តអាក្រក់របស់ស្ត្រីនោះថា ជាមន្ទិល ។

បទថា **ឧឧតោ** *ប្រែថា របស់បុគ្គលអ្នកឲ្យ កាលបុគ្គលណាក្នុងពេលភ្ជូរស្រែគិតថា កាលស្រែនេះសម្បូរហើយ អញនឹងថ្វាយភត្តទាំងឡាយ មាន*

សលាកភត្តជាដើម កាលសម្ងួងឲ្យផលហើយ សេចក្តីកំណាញ់កើតឡើងហាម ចិត្តដែលសម្បយុត្តដោយចាគៈ បុគ្គលនោះ កាលចិត្តសម្បយុត្តដោយចាគៈ មិនជុះជាលឡើងបាន ដោយអំណាចសេចក្តីកំណាញ់ រមែងមិនបានសម្បត្តិ ៣ យ៉ាង គឺមនុស្សសម្បត្តិ ទិព្វសម្បត្តិ និងនិព្វានសម្បត្តិ ព្រោះដូច្នោះ ទើបព្រះសាស្តាត្រាស់ថា ការកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ សូម្បីក្នុងបទជំទៃៗ ដែលមានរូប (សកាព) យ៉ាងនេះ ក៏មានន័យនេះដូចគ្នា ។

ពីរបទថា **ចាបកា ធម្មា** *សេចក្តីថា អកុលសធម៌ទាំងឡាយ ជាមន្ទិលទាំងអស់ ទាំងក្នុងលោកនេះ ទាំងលោកខាងមុខ ។ បទថា* **តនោ** *សេចក្តីថា ជាងមន្ទិលដែលប្រាសហើយខាងដើម ។ បទថា* **មលតរំ** *សេចក្តីថា តថាគតនឹងប្រាប់មន្ទិលដែលក្រៃលែងដល់អ្នកទាំងឡាយ ។*

បទថា **អវិជ្ជា** *សេចក្តីថា ការមិនដឹងដែលមានវត្ថុ ៨ នោះឯង ជាមន្ទិលដ៏ក្រៃលែង ។*

បទថា **បមាទ្ធានេ** *សេចក្តីថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយលះមន្ទិលនោះបានហើយ រមែងជាអ្នកឃាត់នូវមន្ទិលមិនបាន ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង កុលបុត្រម្នាក់ ចប់

រឿង ភិក្ខុឈ្មោះ ចូឡសារី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសទ្ធិវិហារិករបស់ព្រះសារីបុត្តត្ថេរ ឈ្មោះចូឡសារី ទើបត្រាស់ព្រះធម្មទេសនានេះថា **សុជីវំ អហិរិកេន** ជាដើម ។

បានព្ធមកថា ថ្ងៃមួយ ព្រះចូឡសារីនោះ ធ្វើវេជ្ជកម្មហើយ បានភោជនប្រណីតហើយកាន់យកចេញទៅ ជួបព្រះថេរៈតាមផ្លូវ ទើបពិតថា បពិត្រលោកម្ចាស់ ភោជននេះខ្ញុំធ្វើវេជ្ជកម្មបានហើយ លោកម្ចាស់នឹងមិនបានភោជនបែបនេះក្នុងទីដទៃ សូមលោកម្ចាស់ឆាន់ភោជននេះ ខ្ញុំនឹងធ្វើវេជ្ជកម្មនាំអាហារបែបនេះមកដើម្បីលោកម្ចាស់អស់កាលជានិច្ច ។ ព្រះថេរៈស្តាប់ពាក្យរបស់ព្រះចូឡសារីនោះហើយ ក៏អង្គុយស្ងៀម ចៀសចេញទៅហើយ ។ ភិក្ខុទាំងឡាយមកកាន់វិហារហើយ ក្រាបទូលសេចក្តីនោះដល់ព្រះសាស្តា ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាបុគ្គលដែលមិនមានការខ្មាស ជាអ្នកធ្តាំធ្តងដូចក្អែក តាំងនៅក្នុងអនេសនៈ ២១ យ៉ាង រមែងរស់នៅស្រួល ចំណែកបុគ្គលដែលសម្បូរដោយហិរិ និងឧត្តប្បៈ រមែងរស់នៅបានដោយលំបាក ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

សុជីវំ អហិរិកេន	កាកសូរេន ធំសិនា
បក្ខន្ទិនា បគព្ភេន	សង្ហិលិដ្ឋេន ជីវិតំ ។
ហិរីមតា ច ឧជ្ជីវំ	និច្ចំ សុចិគវេសិនា
អលីនេនាបគព្ភេន	សុឧ្ទាជីវេន បស្សតា ។

បុគ្គលមិនមានសេចក្តីអៀនខ្មាស ក្បៀវក្បាដូចសត្វក្អែក កម្ចាត់បង់នូវគុណរបស់អ្នកដទៃ ជាអ្នកឈ្លានពាន (យកមុខ) ជាអ្នកឃ្មើសឃ្មង ជាមនុស្សសៅហ្មង រស់នៅដោយងាយ ។ ចំណែកបុគ្គលអ្នកមានសេចក្តីអៀនខ្មាស ស្វែងរកអំពើស្អាតជានិច្ច មិនខ្ជះខ្ជាះ មិនឃ្មើសឃ្មង រស់នៅដោយកម្មដ៏បរិសុទ្ធ អ្នកឃើញត្រូវ រស់នៅដោយលំបាក ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អហិរិកេន** *គឺបុគ្គលខ្វះនូវហិរិ និងឱត្តប្ប: អធិប្បាយថា ដែលបុគ្គលបែបនោះ អាចហៅស្រីដែលមិនមែនមាតានោះឯងថាមាតារបស់អញ ហៅបុរសទាំងឡាយដែលមិនមែនបិតាជាដើមនោះឯងដោយន័យជាដើមថា បិតារបស់អញ តាំងនៅក្នុងអនេសនា ២១ យ៉ាង ជាអ្នករស់នៅបានស្រួល ។*

បទថា **ការកសូរេន** *បានដល់ ដូចក្អែកក្បៀវក្បា អធិប្បាយថា ដូចក្អែកក្បៀវក្បា ប្រាថ្នានឹងពាំវត្ថុទាំងឡាយ មានបបរជាដើមក្នុងផ្ទះនៃត្រកូលទាំងឡាយទំក្នុងទីទាំងឡាយ មានជញ្ជាំងជាដើមហើយ ដឹងថាគេក្រឡេកមើលខ្លួន ធ្វើដូចជាមិនបានឃើញ ដូចជាបញ្ជូនចិត្តទៅក្នុងទីដទៃ និងធ្វើដូចដេកលក់ កំណត់ការក្លេចខ្លួនរបស់មនុស្សបានហើយ ក៏ធាប កាលពួកមនុស្សដេញថា សុ សុ នោះឯង ក៏ពាំអាហារពេញមាត់អំពីភាជន: ហើយហើរគេចទៅ យ៉ាងណា*

សូម្បីបុគ្គលមិនមានការខ្វាស ក៏ដូច្នោះដូចគ្នា ចូលទៅកាន់ស្រុកជាមួយភិក្ខុ ទាំងឡាយហើយ រមែងកំណត់ទីទាំងឡាយ មានទីតាំងនៃបបរ និងភត្តជាដើម ភិក្ខុទាំងឡាយត្រាច់ទៅបិណ្ឌបាតក្នុងស្រុកនោះ ទទួលយកអាហារ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ទៅកាន់វេឡាធាន់ ពិចារណា ធាន់បបរហើយ ធ្វើកម្មដ្ឋានទុកក្នុងចិត្ត ស្វាធ្យាយ ចោសសម្អាតវេឡាធាន់ ចំណែកបុគ្គលនេះ មិនធ្វើវត្តណាមួយ ជាអ្នកបៃរមុខទៅកាន់ស្រុក ត្រូវភិក្ខុទាំងឡាយប្រាប់ថា ចូរមើលបុគ្គលនេះ ហើយសម្លឹងមើល ក៏ធ្វើដូចជាមិនក្រឡេកមើល ដូចបញ្ជូនទៅក្នុងទីដទៃ ដូចដេកលក់ ធ្វើដូចខ្ជាស់ក្តុំ ធ្វើអកប្បកិរិយាដូចរៀបចំចីវរ ពោលថា ការងាររបស់ខ្ញុំឈ្មោះនេះមាន ក្រោកចាកអាសនៈចូលទៅស្រុក ចូលទៅកាន់ផ្ទះខ្នងឯណានីមួយ បណ្តាផ្ទះដែលបានកំណត់ហើយអំពីព្រលឹម ។ កាលពួកមនុស្សក្នុងផ្ទះរាំងទ្វារហើយ អង្គុយរវៃអំបោះត្រង់មាត់ទ្វារ យកដៃម្ខាងច្រានទ្វារហើយ ចូលទៅខាងក្នុង ។ លំដាប់នោះ មនុស្សទាំងនោះឃើញបុគ្គលនោះហើយ មិនប្រុងប្តូ និមន្តឲ្យអង្គុយលើអាសនៈ រួចថ្វាយរបស់ មានយាគូជាដើមដែលមាន ។ បរិភោគតាមត្រូវការហើយ កាន់យករបស់ចំណែកដ៏សេស ដោយបាត្រ ចៀសចេញទៅ បុគ្គលនេះឈ្មោះថាជាអ្នកក្លៀវក្លាដូចក្អែក ដែលបុគ្គលមិនមានហិរិ បែបនេះ ជាអ្នករស់នៅស្រួល ។

បទថា **ធំសិនា** *សេចក្តីថា ឈ្មោះថា មានប្រក្រតីកម្ងាត់ ព្រោះកាលមនុស្សទាំងឡាយពោលពាក្យជាដើមថា ព្រះថេរៈឈ្មោះនេះជាអ្នកមានសេចក្តី*

ប្រាថ្នាតិច កម្ចាត់នូវគុណរបស់បុគ្គលដទៃចោលដោយពាក្យជាដើមថា សូម្បីពួកយើងមិនជាអ្នកមានសេចក្តីប្រាថ្នាតិចទេឬ មនុស្សទាំងឡាយស្តាប់ពាក្យរបស់បុគ្គលបែបនោះហើយ កាលសម្គាល់ថា សូម្បីបុគ្គលនេះក៏ជាអ្នកប្រកបដោយគុណ មានភាពជាបុគ្គលប្រាថ្នាតិចជាដើម រមែងសម្គាល់របស់ដែលខ្លួនគួរឲ្យ តែចាប់តាំងអំពីនេះទៅ បុគ្គលនោះកាលមិនអាចញុំាងចិត្តរបស់បុរសដែលជាអ្នកប្រាជ្ញទាំងឡាយឲ្យត្រេកអរ រមែងសូន្យចាកលាភនោះ ។ បុគ្គលមានប្រក្រតីកម្ចាត់យ៉ាងនេះ រមែងញុំាងលាភទាំងឡាយរបស់ខ្លួន និងរបស់អ្នកដទៃឲ្យវិនាសដោយពិត ។

បទថា **បក្ខន្ទិនោ** *សេចក្តីថា ជាអ្នកច្រើនដោយការប្រព្រឹត្តសុះទៅ គឺជាអ្នកសម្តែងកិច្ចរបស់អ្នកដទៃឲ្យដូចកិច្ចរបស់ខ្លួន កាលភិក្ខុទាំងឡាយធ្វើវត្តត្រង់លានព្រះចេតិយជាដើម អំពីព្រលឹម អង្គុយដោយការធ្វើទុកក្នុងចិត្តនូវកម្មដ្ឋានបន្តិចហើយក្រោកឡើង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត បុគ្គលនោះលប់មុខហើយ តាក់តែងអត្តភាពដោយជណ្តប់សំពត់កាសាវពស្ត្រ មានពណ៌លឿង បន្តក់ភ្នែក និងលាបក្បាលជាដើម ឲ្យប្រហារដោយអម្បាស ២-៣ ហាក់ដូចជាកំពុងចោស ជាបុគ្គលបែរមុខទៅកាន់ខ្ងោងទ្វារ ពួកមនុស្សមកអំពីព្រលឹមដោយគិតថា នឹងថ្វាយបង្គំព្រះចេតិយ នឹងធ្វើការបូជាដោយផ្កាកម្រង ឃើញបុគ្គលនោះហើយនិយាយគ្នាថា វិហារនេះអាស្រ័យភិក្ខុកំលោះនេះ ទើបបាននូវកិច្ចបដិបត្តិទំនុកបម្រុង អ្នកទាំងឡាយ កុំលះបង់ភិក្ខុនេះ ដូច្នេះហើយ រមែងសម្គាល់របស់ដែលខ្លួនគប្បីឲ្យដល់បុគ្គលនោះ ដែលបុគ្គលច្រើនដោយ*

ការស្ទុះទៅបែបនេះ ក៏ជាអ្នករស់នៅបានស្រួល ។

បទថា **បគព្ភេន** *សេចក្តីថា បុគ្គលប្រកបដោយការធ្លាំធ្លែងដោយកាយជាដើម ។ ពីរបទថា* **សន្ធិលិដ្ឋេន ជីវិតំ** *សេចក្តីថា បុគ្គលដែលចិញ្ចឹមជីវិតរស់នៅយ៉ាងនេះ ឈ្មោះថា ជាអ្នកសៅហ្មងហើយ ។ ការរស់នៅនោះ ឈ្មោះថា រស់នៅអាក្រក់ គឺរស់នៅដ៏លាមក ។*

បទថា **ហិរិមតា ច** *សេចក្តីថា បុគ្គលដែលសម្បូរដោយហិរិ និងឱត្តប្បៈ រស់នៅលំបាក ព្រោះបុគ្គលនោះមិនពោលពាក្យថា មាតារបស់អញជាដើមនឹងស្រីដែលមិនមែនជាមាតាជាដើម ខ្ពើមបច្ចយដែលកើតឡើង ដែលមិនប្រកបដោយធម៌ដូចលាមក ស្វែងរកបច្ចយដោយធម៌ជានិច្ច ត្រាច់បិណ្ឌបាតតាមលំដាប់ច្រក សម្រេចជីវិតរស់នៅសៅហ្មង ។*

បទថា **សុចិគវេសិនា** *សេចក្តីថា ស្វែងរកកម្មទាំងឡាយ មានកាយកម្មជាដើមដ៏ស្អាត ។ បទថា* **អលីនេន** *សេចក្តីថា មិនរួញរាដោយការប្រព្រឹត្តទៅនៃជីវិត ។*

ពីរបទថា **សុទ្ធាជីវេន បសដ្ឋតា** *សេចក្តីថា បុគ្គលបែបនេះ រមែងជាបុគ្គលឈ្មោះថាមានអាជីវៈបរិសុទ្ធ ។ បុគ្គលដែលមានអាជីវៈបរិសុទ្ធហើយយ៉ាងនេះ ឃើញអាជីវៈបរិសុទ្ធនោះឯង ដោយភាពជាសារៈ រមែងជាអ្នករស់នៅលំបាក ដោយអំណាចភាពជាបុគ្គលសៅហ្មង ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ឧបាសក ៥ នាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសក ៥ នាក់ ត្រាស់ព្រះធម្មទេសនានេះថា **យោ ចាណមតិមាបេតិ** ជាដើម ។

សេចក្តីពិស្តារថា បណ្តាឧបាសកទាំងនោះ ឧបាសកម្នាក់រក្សាសិក្ខាបទ គឺបាណាតិបាតតែមួយ ។ ចំណែកឧបាសកទាំងឡាយក្រៅអំពីនេះ រក្សាសិក្ខាបទទាំងឡាយក្រៅអំពីនេះ ។ ថ្ងៃមួយ ឧបាសកទាំងនោះ កើតនូវការប្រកែកគ្នាថា ខ្ញុំតែងធ្វើកម្មដែលធ្វើបានដោយលំបាក ។ ខ្ញុំរក្សាវត្តុដែលរក្សាបានដោយលំបាក ទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំហើយ ក្រាបទូលសេចក្តីនោះ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ឧបាសកទាំងនោះហើយ ទ្រង់មិនបានធ្វើសីលណាមួយឲ្យទាបឡើយ ត្រាស់ថា សីលទាំងអស់ ជារបស់រក្សាបានលំបាកទាំងអស់នោះឯង ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

យោ ចាណមតិមាបេតិ　　មុសាវាទញ្ច ភាសតិ
លោកេ អទិន្នំ អាទិយតិ　　បទារញ្ច គច្ឆតិ ។
សុរាមេរយបានញ្ច　　យោ នរោ អនុយុញ្ជតិ
ឥធេវមេសោ លោកស្មឹ　　មូលំ ខនតិ អត្តនោ ។
ឯវំ ភោ បុរិស ជានាហិ　　បាបធម្មា អសញ្ញតា
មា នំ លោភោ អធម្មោ ច　　ចិរំ ទុក្ខាយ រន្ធយុំ ។

ជនណាសម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យក

វត្ថុដែលគេមិនបានឲ្យក្នុងលោកផង សេពប្រពន្ធរបស់អ្នកដទៃផង ជនណាផឹកទឹកសុរា និងមេរ័យផង ជននោះឯងឈ្មោះថា គាស់រម្លើងឫសគល់របស់ខ្លួន ក្នុងលោកនេះដោយពិត ។ ម្នាលបុរសដ៏ចម្រើន ចូរអ្នកដឹងយ៉ាងនេះថា ជនទាំងឡាយ មានធម៌ដ៏លាមក រមែងមិនជាអ្នកសង្រួមដូច្នេះ លោភៈ និងសភាពមិនមែនធម៌ គឺទោសៈ ចូរកុំបៀតបៀនអ្នកឲ្យបាននូវសេចក្តីទុក្ខ អស់កាលយូរឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បានព្រះគាថាថា **យោ ចាណមតិមាបេតិ** *សេចក្តីថា បណ្តាប្រយោគទាំង ៦ មានសាហត្ថិកប្បយោគជាដើម នរៈណាតែងចូលទៅកាត់នូវជីវិតិន្ទ្រិយរបស់អ្នកដទៃដោយប្រយោគ ១ ។*

បទថា **មុសាវាទំ** *សេចក្តីថា តែងពោលមុសាវាទ ដែលកាច់បំបាក់នូវប្រយោជន៍របស់អ្នកដទៃ ។*

បានព្រះគាថាថា **លោកេ អទិន្នំ អាទិយតិ** *សេចក្តីថា រមែងកាន់យកទ្រព្យដែលបុគ្គលដទៃហួងហែងហើយ ដោយបណ្តាអវហារទាំងឡាយ មានថេយ្យាវហារជាដើម អវហារណាមួយ ក្នុងសត្វលោកនេះ ។*

បានព្រះគាថាថា **បទារញ្ច គច្ឆតិ** *សេចក្តីថា នរៈ កាលខុសក្នុងកណ្តៈទាំងឡាយ ដែលបុគ្គលដទៃរក្សា និងគ្រប់គ្រងហើយ ឈ្មោះថា តែងប្រព្រឹត្តក្រៅផ្លូវ ។*

បទថា **សុរាមេរយចានំ** បានដល់ ការផឹកនូវសុរា និងមេរ័យណាមួយ នោះឯង ។ បទថា **អនុយុញ្ជតិ** គឺរមែងសេព បានដល់ រមែងធ្វើឲ្យច្រើន ។

ពីរបទថា **មូលំ ឧណតិ** សេចក្តីថា បរលោក ចូរលើកទុក ក្នុងលោក នេះឯង នរៈនេះធ្វើនូវការបញ្ចាំ ឬលក់នូវទ្រព្យដែលជាដើមទុន មានស្រែ និងចម្ការជាដើម ដែលជាគ្រឿងគប្បីតម្កល់ខ្ជួនបាន ផឹកនូវសុរា ឈ្មោះថា រមែងជីកនូវឬសគល់របស់ខ្ជួន គឺជាបុគ្គលមិនមានទីពឹង ជាបុគ្គលកំព្រា ត្រាច់ទៅ ។

ព្រះសាស្តា រមែងត្រាស់ហៅបុគ្គលដែលកំណត់កម្ម គឺទ្រុស្តសីល ៥ ដោយពាក្យថា **ឯវំ ភោ** ។ បទថា **ចាបធម្មា** បានដល់ ជាអ្នកមានធម៌លាមក ។ បទថា **អសញ្ញតា** បានដល់ ដែលវៀរហើយ ចាកការសង្រួម មានការសង្រួម ផ្ទូវកាយជាដើម ។ ព្រះបាលីថា **អចេតសា** ដូច្នេះក៏មាន សេចក្តីថា ជាអ្នក មិនមានចិត្ត ។

ពីរបទថា **លោភោ អធម្មោ ច** បានដល់ លោភៈ និងទោសៈ ពិត ហើយ កិលេសជាតទាំងពីរនេះ ជាអកុសលដោយពិត ។

បាទព្រះគាថាថា **ចិរំ ទុក្ខាយ រនូយុំ** សេចក្តីថា ធម៌ទាំងនេះ ចូរកុំ សម្ងាប់ កុំញាំញីនូវអ្នក ដើម្បីប្រយោជន៍ដល់ទុក្ខទាំងឡាយ មានទុក្ខក្នុង នរកជាដើម អស់កាលយូរ ។

ក្នុងកាលចប់ទេសនា ឧបាសក ៥ នាក់នោះតាំងនៅក្នុងសោតាបត្តិផល ហើយ ព្រះធម្មទេសនាមានប្រយោជន៍ដល់មហាជន ដែលប្រជុំគ្នាហើយ

ដូច្នេះឯង ។

រឿង ឧបាសក ៥ នាក់ ចប់

រឿង ភិក្ខុកំលោះ ឈ្មោះ តិស្សៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកំលោះឈ្មោះ តិស្សៈ ត្រាស់ព្រះធម្មទេសនានេះថា **ឧនាតិ ។ យថាសទ្ធំ** *ជាដើម ។*

បានឮថា ព្រះតិស្សៈនោះត្រាច់តិះដៀលទានរបស់ព្រះអរិយសាវក ៥ កោដិ គឺអនាថបិណ្ឌិកគហបតី នាងវិសាខាឧបាសិកាជាដើម ។ សូម្បីអសទិ-សទាន ក៏តិះដៀលដូចគ្នា បានរបស់ត្រជាក់ក្នុងរោងទានរបស់អរិយសាវកទាំងនោះ រមែងតិះដៀលថា ត្រជាក់ បានរបស់ក្តៅតិះដៀលថា ក្តៅ កាលគេឲ្យតិច រមែងតិះដៀលថា ព្រោះហេតុអ្វី ទើបជនទាំងនេះឲ្យរបស់បន្តិចបន្តួច សូម្បីគេឲ្យច្រើន ក៏តិះដៀលថា ក្នុងផ្ទះរបស់ជនទាំងនេះ ប្រហែលជាមិនមានកន្លែងទុកជាក់ ធម្មតាបុគ្គលគួរឲ្យវត្ថុល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅជល់ភិក្ខុទាំងឡាយ មិនមែនឬ យាគូ និងភត្តប៉ុណ្ណោះ រមែងវិបត្តិទៅមិនមានប្រយោជន៍ឡើយ តែពោលប្រារព្ធញាតិរបស់ខ្លួនជាដើមថា គួរសរសើរផ្ទះរបស់ពួកញាតិរបស់ខ្ញុំ ជារោងអង្គាសរបស់ភិក្ខុទាំងឡាយ ដែលមកហើយអំពីទិសទាំង ៤ ដូច្នេះហើយ រមែងញ៉ាំងនូវពាក្យសរសើរឲ្យប្រព្រឹត្តទៅ ។

ព្រះតិស្សៈនោះ ជាកូនរបស់អ្នករក្សាទ្វារម្នាក់ ត្រាច់ទៅជាមួយពួកជាង ឈើ ដែលត្រាច់ទៅកាន់ជនបទ ដល់នគរសាវត្ថី បួសហើយ ។

គ្រានោះ ភិក្ខុទាំងឡាយឃើញលោក ដែលត្រាច់តិះដៀលទានរបស់ មនុស្សទាំងឡាយយ៉ាងនោះ គិតគ្នាថា ពួកយើងនឹងសាកសួរភិក្ខុនោះ ទើប សួរថា អាវុសោ ពួកញាតិរបស់លោកនៅឯណា បានឮថា នៅក្នុងស្រុក ឈ្មោះនោះ ទើបបញ្ជូនភិក្ខុកំលោះទៅ ២-៣ រូប ។

ភិក្ខុកំលោះទាំងនោះទៅកាន់ស្រុកនោះហើយ កាលអ្នកស្រុកនិមន្តឲ្យគង់ ត្រង់ភេងធាន់ហើយ ធ្វើសក្ការៈ ទើបសួរថា កំលោះឈ្មោះតិស្សៈ ចេញអំពី ស្រុកនេះទៅបួសហើយមានឬ ជនពួកណាជាញាតិរបស់តិស្សៈនោះ មនុស្ស ទាំងឡាយគិតថា ក្នុងស្រុកនេះកុមារចេញអំពីផ្ទះនៃត្រកូលទៅបួសហើយមិន មាន ភិក្ខុទាំងនេះពោលដល់អ្នកណាហ្ន៎ ហើយសាកសួរថា បពិត្រលោកម្ចាស់ ពួកយើងទាំងឡាយបានឮថា កូនរបស់អ្នករក្សាទ្វារម្នាក់ ត្រាច់ទៅជាមួយពួក ជាងឈើបួសហើយ លោកម្ចាស់ទាំងឡាយពោលសំដៅយកលោកទេដឹង ។

ភិក្ខុកំលោះទាំងឡាយជ្រាបថា ពួកញាតិរបស់តិស្សភិក្ខុកំលោះនោះ មិន មានក្នុងស្រុកនោះហើយ ទើបនាំគ្នាត្រឡប់ទៅកាន់នគរសាវត្ថី ប្រាប់រឿងនោះ ដល់ភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ ព្រះតិស្សៈរមែងដើរពោលផ្តេសផ្តាស ដល់វត្ថុដែលមិនមានហេតុផល ភិក្ខុទាំងឡាយ ក៏ក្រាបទូលរឿងនោះដល់ព្រះ តថាគត ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថាតិស្សៈនោះ រមែង

ដើរអួតក្នុងកាលឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន លោកក៏ជាអ្នកអួតហើយ កាលភិក្ខុទាំងឡាយអារាធនាហើយ ទ្រង់នាំអតីតនិទានមកហើយ ទ្រង់ញុំាងកជាហកជាតកនេះឲ្យពិស្តារថា

ទាសៈ ឈ្មោះកជាហកនោះ ទៅកាន់ជនបទជនៃ ពោលអួតនូវពាក្យច្រើន សេដ្ឋីជាម្ចាស់មកតាម (ម្តងទៀត) គប្បីប្រទូស្តមិនខាន ។ ម្នាលកជាហក ចូរអ្នកបរិភោគនូវភោគៈទាំងឡាយទៅ ។

ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណា កាលជនដទៃឲ្យនូវវត្ថុតិចក្តី ច្រើនក្តី សៅហ្មងក្តី ប្រណីតក្តី ឬឲ្យវត្ថុដល់ជនដទៃ តែមិនឲ្យដល់ខ្លួន រមែងជាអ្នកខ្វាសអៀន ឈានក្តី វិបស្សនាក្តី មគ្គ និងផលក្តី រមែងមិនកើតឡើងដល់បុគ្គលនោះ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ បានភាសិតព្រះគាថាទាំងនេះថា

ឧឋាតិ វ យថាសទ្ធំ យថាបសាទនំ ជនោ
តត្ថ យោ មង្កុភោ ហោតិ បរេសំ ចានភោជនេ
ន សោ ទិវា វ រត្តឹ វា សមាធឹ អធិគច្ឆតិ ។
យស្ស ចេតំ សមុច្ឆិន្នំ មូលឃច្ចំ សមូហតំ
ស វ ទិវា វ រត្តឹ វា សមាធឹ អធិគច្ឆតិ ។

ជនរមែងឲ្យតាមសទ្ធា តាមសេចក្តីជ្រះថ្លា បុគ្គលណា ជាអ្នកអៀនខ្មាស ក្នុងទឹក និងភោជន របស់ជនទាំងឡាយជនៃ ជននោះ រមែងមិនបានសមាធិចិត្ត ក្នុងវេលាថ្ងៃ ឬក្នុង

វេលាយប់ឡើយ លុះតែសេចក្តីអៀនខ្មាសនោះ បុគ្គលណា
បានផ្តាច់ផ្តិលដកឡើង ធ្វើឲ្យមានឫសគល់ដាច់ហើយ
បុគ្គលនោះឯង ទើបបានសមាធិចិត្តក្នុងវេលាថ្ងៃ ឬក្នុង
វេលាយប់ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **ឧឌាតិ វ យថាសឧំ** *សេចក្តីថា ជន កាលឲ្យនូវបណ្តាវត្ថុ មានរបស់សៅហ្មង និងរបស់ប្រណីតជាដើមឯណា នីមួយ ឈ្មោះថា រមែងឲ្យតាមសទ្ធា គឺតាមសមគួរដល់សទ្ធារបស់ខ្លួន ។*

បទថា **យថាបសាឧនំ** *សេចក្តីថា បណ្តាភិក្ខុដែលជាថេរ: និងភិក្ខុថ្មីជាដើម ការជ្រះថ្លាក្នុងភិក្ខុណាមួយអង្គ រមែងកើតឡើងដល់បុគ្គលនោះ គ្រាថ្វាយទានដល់ភិក្ខុនោះ ឈ្មោះថា រមែងថ្វាយតាមការជ្រះថ្លា គឺតាមគួរដល់សេចក្តីជ្រះថ្លារបស់ខ្លួននោះឯង ។*

បទថា **តត្ត** *ជាដើម សេចក្តីថា រមែងដល់នូវភាពជាអ្នកខ្មាសអៀន ព្រោះទានរបស់ជនដទៃនោះថា អញបានវត្ថុតិចតួច អញបានរបស់សៅហ្មង ។*

បទថា **សមាធឺ** *ជាដើម សេចក្តីថា បុគ្គលនោះតែងមិនសម្រេចសមាធិ ដោយអំណាចនៃឧបចារសមាធិ និងអប្បនាសមាធិ ឬដោយអំណាចនៃមគ្គ និងផល ក្នុងពេលថ្ងៃ និងពេលយប់ ។*

ពីរបទថា **យស្ស ចេតំ** *សេចក្តីថា អកុសលកម្មនោះ ពោល គឺភាពជាអ្នកខ្មាសអៀនក្នុងឋានៈទាំងនេះ កាលបុគ្គលណាកាត់ផ្តាច់ហើយ ដកឡើង*

ធ្វើឲ្យមានឫសជាច់ហើយ ដោយអរហត្តមគ្គញ្ញាណ បុគ្គលនោះ តែងតែសម្រេចសមាធិ មានប្រការដូចពោលហើយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ភិក្ខុកំលោះ ឈ្មោះ តិស្សៈ ចប់

រឿង ឧបាសក ៥ នាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសក ៥ នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ឆត្តិ ភាគសមោ អគ្គិ** *ជាដើម ។*

បានឮថា ឧបាសកទាំងនោះប្រាថ្នានឹងស្តាប់ធម៌ ទៅកាន់វិហារថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងចំណែកម្ខាង ។ កាលត្រិះរិះថា បុគ្គលនេះជាក្សត្រ បុគ្គលនេះជាព្រាហ្មណ៍ បុគ្គលនេះជាអ្នកស្តុកស្តម្ភ បុគ្គលនេះជាអ្នកក្រីក្រ តថាគតសម្តែងធម៌ឲ្យក្រៃលែងដល់បុគ្គលនេះ ឥតមានសម្តែងឲ្យក្រៃលែងដល់បុគ្គលនេះ រមែងមិនកើតឡើងដល់ព្រះពុទ្ធទាំងឡាយឡើយ ។

ព្រះសាស្តា កាលទ្រង់សម្តែងធម៌ប្រារព្ធបុគ្គលណាម្នាក់ រមែងធ្វើនូវការគោរពធម៌ជាធំ ហើយទើបសម្តែង ប្រៀបដូចទេវតាមានឫទ្ធិ បណ្តាលឲ្យទឹកក្នុងអាកាសហូរចុះមក ដូច្នោះ បណ្តាឧបាសកទាំងនោះ ដែលអង្គុយហើយ ក្នុង

សម្ងាក់របស់ព្រះសាស្តា ដែលទ្រង់សម្តែងយ៉ាងនោះ ឧបាសកម្នាក់អង្គុយជេកលក់ហើយ ឧបាសកម្នាក់អង្គុយគូសផែនដីដោយម្រាមដៃ ឧបាសកម្នាក់អង្គុយអង្រែនដើមឈើ ឧបាសកម្នាក់អង្គុយងើយមើលអាកាស តែឧបាសកម្នាក់ ស្តាប់ធម៌ដោយគោរព ។

ព្រះអានន្ទ ថ្វាយនូវការបក់ផ្ទៃព្រះសាស្តា សម្លឹងមើលអាការរបស់ឧបាសកទាំងនោះ ក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ ទ្រង់បន្ទឹមដូចមហាមេឃ ទ្រង់សម្តែងធម៌ដល់ឧបាសកទាំងនេះ តែឧបាសកទាំងនេះ កាលទ្រង់សម្តែងធម៌ អង្គុយធ្វើកម្មនេះឯង ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ អ្នកមិនស្គាល់ឧបាសកទាំងនោះទេឬ ព្រះអានន្ទពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនស្គាល់ទេ ។

ព្រះសាស្តាត្រាស់ថា បណ្តាឧបាសកទាំងនោះ ឧបាសកដែលអង្គុយជេកលក់ហើយនោះ កើតក្នុងកំណើតពស់អស់ ៥០០ ជាតិ ដាក់ក្បាលលើរង្វេលទាំងឡាយជេកលក់ហើយ ។ សូម្បីឥឡូវនេះ ការឆ្អែតក្នុងការជេកលក់របស់ឧបាសកនោះមិនមាន ។ សំឡេងរបស់តថាគតមិនចូលទៅកាន់ត្រចៀករបស់ឧបាសកនោះឡើយ ។ ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទ្រង់ត្រាស់ដោយលំដាប់ ឬត្រាស់ដោយវគ្គៗ ។

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ពិតមែន សូម្បីព្រះសព្វញ្ញុតញ្ញាណក៏មិនអាចកំណត់នូវការកើតរបស់ឧបាសកនោះ ដែលបដិសន្ធិក្នុងចន្លោះៗ យ៉ាងនេះ គឺភាពជាមនុស្សតាមកាល ភាពជាទេវតាតាមកាល ភាពជានាគតាម

កាល តែឧបាសកនេះ កើតហើយក្នុងកំណើតនៃនាគអស់ ៥០០ ជាតិដោយលំដាប់ តែងតែដេកលក់ ការឆ្អែតក្នុងការដេកលក់មិនមានឡើយ ។

ចំណែកបុរស ដែលអង្គុយគូសផែនដីដោយម្រាមដៃ កើតក្នុងកំណើតជន្ទេនអស់ ៥០០ ជាតិដោយលំដាប់ ជីកផែនដីហើយ សូម្បីឥឡូវនេះ ក៏នៅតែគូសផែនដី ដោយអំណាចការប្រព្រឹត្តដែលខ្លួនធ្លាប់ប្រព្រឹត្តហើយក្នុងកាលមុន រមែងមិនស្តាប់សំឡេងរបស់តថាគត ។

ចំណែកបុរស អង្គុយអង្រួនដើមឈើនោះ កើតហើយក្នុងកំណើតស្វាអស់ ៥០០ ជាតិដោយលំដាប់ ។ ឥឡូវនេះ ក៏នៅតែអង្រួនដើមឈើដោយអំណាចនៃការប្រព្រឹត្ត ដែលខ្លួនធ្លាប់ប្រព្រឹត្តមកហើយក្នុងកាលមុននោះឯង ។ សំឡេងរបស់តថាគត មិនចូលត្រចៀករបស់ឧបាសកនោះឡើយ ។

ព្រាហ្មណ៍ដែលអង្គុយងើយមើលអាកាសនោះ ក៏កើតជាហោរ ប្រកបនក្ខត្តឫក្សអស់ ៥០០ ជាតិដោយលំដាប់ ទោះបីឥឡូវនេះ ក្នុងថ្ងៃនេះក៏នៅមើលអាកាស ដោយអំណាចនៃការប្រព្រឹត្ត ដែលខ្លួនធ្លាប់ប្រព្រឹត្តមកហើយក្នុងកាលមុននោះឯង ។ សំឡេងរបស់តថាគត រមែងមិនចូលត្រចៀករបស់ឧបាសកនោះ ។

ចំណែកព្រាហ្មណ៍ ដែលស្តាប់ធម៌ដោយគោរពនោះ កើតជាព្រាហ្មណ៍ដែលទន្ទេញមន្ត ដល់ត្រើយនៃត្រៃវេទអស់ ៥០០ ជាតិដោយលំដាប់ ទោះបីឥឡូវនេះ ក៏ស្តាប់ធម៌ដោយគោរព ហាក់ដូចប្រៀបធៀបមន្ត ។ ព្រះអានន្ទពោលថា បពិត្រព្រះអង្គ ព្រះធម្មទេសនារបស់ព្រះអង្គ រមែងជ្រែកអវយវៈ

ទាំងឡាយ មានស្បែកជាដើម រហូតដល់ខួរក្នុងឆ្អឹងតាំងនៅ ព្រោះហេតុអ្វី បានជាឧបាសកទាំងនេះ កាលទ្រង់សម្តែងធម៌ ទើបមិនស្តាប់ដោយគោរព ។

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ អ្នកប្រហែលជាធ្វើសេចក្តីសម្គាល់ថា ធម៌របស់តថាគត បុគ្គលគប្បីស្តាប់បានដោយងាយទេដឹង ព្រះអានន្ទពោលថា បពិត្រព្រះអង្គ ធម៌របស់ទ្រង់បុគ្គលគប្បីស្តាប់បានដោយលំបាកឬ ។

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ត្រឹមត្រូវហើយ ព្រះអានន្ទពោលថា បពិត្រព្រះអង្គ ព្រោះហេតុអ្វី ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ បទថា **ពុទ្ធោ** *ក្តី* **ធម្មោ** *ក្តី* **សង្ឃោ** *ក្តី ដែលសត្វទាំងនេះមិនធ្លាប់ស្តាប់ហើយ ក្នុងសែនកប្បជ័អនេក ព្រោះជួបច្នោះ ទើបសត្វទាំងនេះ មិនអាចស្តាប់ធម៌នេះបានតែក្នុងសង្ឃារ មានទីបំផុត ដែលបុគ្គលណាម្នាក់តាមដឹងមិនបាន សត្វទាំងនេះស្តាប់តិរច្ឆានកថា មានបែបផែនៗ នោះឯង មកហើយ ព្រោះជួបច្នោះទើប សត្វទាំងនេះ ត្រាច់ច្រៀងរាំក្នុងទីទាំងឡាយ មានរោងសុភ និងសួនសម្រាប់លេងជាដើម ទើបមិនអាចស្តាប់ធម៌បាន ។ ព្រះអានន្ទពោលថា បពិត្រព្រះអង្គ ឧបាសកទាំងឡាយនោះ អាស្រ័យអ្វី ទើបមិនអាច ។*

លំដាប់នោះ ព្រះសាស្តាត្រាស់ដល់ព្រះអានន្ទថា ម្នាលអានន្ទ ឧបាសកទាំងនោះអាស្រ័យរាគៈ អាស្រ័យទោសៈ អាស្រ័យមោហៈ អាស្រ័យតណ្ហា ទើបមិនអាច ឈ្មោះថា ភ្លើង ដូចគ្នានឹងភ្លើង គឺរាគៈ មិនមាន ភ្លើងណាមិនសម្តែងនូវផេះ រមែងឆេះនូវសត្វទាំងឡាយ ពិតហើយ ភ្លើងដែលញុំងកប្បឲ្យវិនាស ដែលអាស្រ័យការប្រាកដនៃព្រះអាទិត្យ ៧ ដួងកើតឡើង រមែង

ឆេះលោក មិនឲ្យវត្តុណាមួយសេសសល់ក៏ពិត តែភ្លើងនោះ រមែងឆេះម្តងម្កាលប៉ុណ្ណោះ ឈ្មោះថា កាល ដែលភ្លើង គឺរាគៈមិនឆេះ មិនមាន ព្រោះដូច្នោះ ឈ្មោះថា ភ្លើង ស្មើដោយរាគៈក្តី ភ្លើង ស្មើដោយទោសៈក្តី សំណាញ់ ស្មើដោយមោហៈក្តី ឈ្មោះថា សឹង ស្មើដោយតណ្ហាក្តី មិនមានដូច្នេះហើយ ទើបទ្រង់ត្រាស់ព្រះគាថានេះថា

ឆត្តិ រាគសមោ អគ្គិ ឆត្តិ ទោសសមោ គហោ
ឆត្តិ មោហសមំ ជាលំ ឆត្តិ តណ្ហាសមា ឆឌី ។

ភ្លើង ស្មើដោយរាគៈ មិនមាន ការចាប់ ស្មើដោយទោសៈ មិនមាន បណ្តាញ ស្មើដោយមោហៈ មិនមាន សឹង ស្មើដោយតណ្ហា មិនមាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **រាគសមោ** *សេចក្តីថា ឈ្មោះថា ភ្លើង ស្មើដោយរាគៈ រមែងមិនមាន ដោយអំណាចនៃការមិនបង្ហាញអ្វីមួយ ដូចជាផ្សែងជាដើម តាំងឡើងជុតខាងក្នុងនោះឯង ។ បទថា* **ទោសសមោ** *សេចក្តីថា អ្នកចាប់ទាំងឡាយ មានអ្នកចាប់ គឺយក្ខ អ្នកចាប់ គឺពស់ថ្លាន់ អ្នកចាប់ គឺក្រពើជាដើម រមែងអាចចាប់បានក្នុងអត្តភាពមួយប៉ុណ្ណោះ តែអ្នកចាប់ គឺទោសៈ រមែងចាប់ដោយចំណែកមួយនោះឯង ព្រោះដូច្នោះ ឈ្មោះថា អ្នកចាប់ ស្មើដោយទោសៈ រមែងមិនមាន ។*

ពីរបទថា **មោហសមំ ជាលំ** *សេចក្តីថា ឈ្មោះថា សំណាញ់ ស្មើ*

ដោយមោហៈ រមែងមិនមាន ព្រោះអត្តថា ចង់រឹត និងរួបរឹត ។

បទថា **តណ្ហាសមា** សេចក្តីថា ពេលពេញក្តី ពេលខ្វះខាតក្តី ពេលរឹងស្ងួតក្តីរបស់ស្តឹងទាំងឡាយ មានស្តឹងគង្គាជាដើមរមែងប្រាកដ តែកាលពេញ ឬ កាលរឹងស្ងួតនៃតណ្ហារមែងមិនមាន ការខ្វះតែម្យ៉ាងរមែងប្រាកដជានិច្ច ព្រោះដូច្នោះ ឈ្មោះថា ស្តឹងស្មើដោយតណ្ហារមែងមិនមាន ព្រោះអត្តថា ឲ្យពេញបានដោយលំបាក ។

ក្នុងកាលចប់ទេសនា ឧបាសកដែលស្តាប់ធម៌ដោយគោរពនោះ តាំងនៅក្នុងសោតាបត្តិផលហើយ ។ ព្រះធម្មទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នោះឯង ។

រឿង ឧបាសក ៥ នាក់ ចប់

រឿង មេណ្ឌកសេដ្ឋី

លំនាំដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យកទ្ទិយនគរ ប្រថាប់នៅក្នុងជាតិយាវន គឺព្រៃម្ទិះ ទ្រង់ប្រារព្ធមេណ្ឌកសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះថា **សុខសង្ឃំ វជ្ជមញ្ញេសំ** ជាដើម ។

បានឮថា ព្រះសាស្តា កាលចារិកទៅក្នុងអង្គុត្តរាបជនបទទាំងឡាយ ទ្រង់ឃើញឧបនិស្សយសោតាបត្តិផលរបស់មនុស្សទាំងនេះ គឺមេណ្ឌកសេដ្ឋី

១ ភរិយារបស់សេដ្ឋីនោះ ឈ្មោះនាងចន្ទបទុមា ១ កូនប្រុសឈ្មោះ ធនញ្ជយសេដ្ឋី ១ កូនប្រសាស្រី ឈ្មោះនាងសុមនទេវី ១ ចៅស្រីឈ្មោះ វិសាខា ១ ទាសៈ ឈ្មោះបុណ្ណៈ ១ ទើបយាងទៅកាន់ភទ្ទិយនគរ ប្រថាប់ នៅក្នុងជាតិយាវន ។ មេណ្ឌកសេដ្ឋីបានស្តាប់ការយាងមករបស់ព្រះសាស្តា ហើយ ។

សួរថា ព្រោះហេតុអ្វី ទើបសេដ្ឋីឈ្មោះថាមេណ្ឌកៈ ឆ្លើយថា បានឮថា ពពែមាសទាំងឡាយ ប្រមាណប៉ុនជីរ សេះ និងគោឧសភ ជ្រែកផែនដី យក ខ្នងទល់គ្នាផុសឡើងក្នុងទីប្រមាណ ៨ ករីស ក្រោយផ្ទះរបស់សេដ្ឋីនោះ ។ បុញ្ញកម្មជាក់ដុំអំបោះ ៥ ពណ៌ ក្នុងមាត់របស់ពពែទាំងនោះ ។ កាលសេចក្តី ត្រូវការដោយកេសជ្ជៈ មានសប្បិ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ឬដោយ វត្ថុ មានសំពត់ គ្រឿងជណ្តប់ ប្រាក់ និងមាសជាដើម ជនទាំងឡាយតែង នាំដុំអំបោះចេញអំពីមាត់របស់ពពែទាំងនោះ សប្បិ ប្រេង ទឹកឃ្មុំ ទឹកអំពៅ សំពត់ គ្រឿងបិទបាំង ប្រាក់ និងមាស រមែងហូរចេញអំពីមាត់ពពែនីមួយៗ គ្រប់គ្រាន់ ដល់មនុស្សក្នុងជម្ពូទីប ។ ចាប់តាំងអំពីនោះមក ទើបសេដ្ឋីនោះ ប្រាកដឈ្មោះថា មេណ្ឌកសេដ្ឋី ។

សួរថា បុព្វកម្មរបស់សេដ្ឋីនោះដូចម្តេច ឆ្លើយថា បានឮថា ក្នុងកាល នៃព្រះពុទ្ធព្រះនាមវិបស្សី សេដ្ឋីនោះ ជាកូយរបស់កុដុម្ពិកៈឈ្មោះអវរោជៈ ឈ្មោះអវរោជៈ គឺឈ្មោះដូចអ៊ំ ។ គ្រានោះ អ៊ំរបស់គាត់ប្រារព្ធសាងព្រះគន្ធកុដិ ដើម្បីព្រះសាស្តា ចូលទៅកាន់សម្នាក់របស់អ៊ំហើយ ពោលថា បពិត្រលោក

អាំ យើងទាំងពីរនឹងសាងរួមគ្នា ក្នុងពេលដែលអាំនោះឃាត់ថា អញតែម្នាក់ប៉ុណ្ណោះនឹងសាង មិនឲ្យសាធារណៈដល់ជនដទៃឡើយ ទើបគិតថា កាលអាំសាងព្រះគន្ធកុដិក្នុងទីនេះហើយ អញគួរបានសាលាក្នុងទីនេះ ទើបឲ្យមនុស្សនាំឈើមកអំពីព្រៃ ឲ្យធ្វើសសរយ៉ាងនេះ គឺសសរមួយដើមស្រោបដោយមាស សសរមួយដើមស្រោបដោយប្រាក់ សសរមួយដើមស្រោបដោយកែវមណី ឲ្យធ្វើជ្ជុម រត សន្ទះទ្វារ សន្ទះបង្អួច បង្គន់ គ្រឿងប្រក់ និងឥដ្ឋទាំងអស់ ស្រោបដោយវត្ថុ មានមាសជាដើម ឲ្យធ្វើសាលាសម្រេចដោយរតន: ៧ ប្រការ ដល់ព្រះតថាគត ត្រង់ទីខាងមុខព្រះគន្ធកុដិ នៅខាងលើសាលានោះ មានកំពូល ៣ ដែលសម្រេចហើយដោយមាសទឹក ១០ និងជុំនៃកែវផលិក និងកែវប្រពាល ឲ្យសាងមណ្ឌបប្រដាប់ដោយកែវ ត្រង់កណ្តាលសាលា តម្កល់ធម្មាសន: ។

ជើងធម្មាសន:នោះ សម្រេចដោយមាស មេគ្រែទាំង ៤ ក៏ដូចគ្នា តែឲ្យធ្វើពពែមាស ៤ តាំងទុកខាងក្រោមនៃជើងទាំង ៤ របស់អាសន: ។ ឲ្យធ្វើពពែមាស ២ ទុកខាងក្រោមតាំងសម្រាប់រងជើង ឲ្យធ្វើពពែមាស ៦ ជាក់ជុំវិញមណ្ឌប ឲ្យត្បាញធម្មាសន:ដោយខ្សែសរសៃល្អិតសម្រេចដោយអំបោះហើយ ទើបឲ្យត្បាញដោយខ្សែដែលសម្រេចដោយមាសត្រង់កណ្តាល ហើយឲ្យត្បាញដោយខ្សែសម្រេចដោយកែវមុក្តាទុកខាងលើ បង្អែកនៃធម្មាសន:នោះសម្រេចដោយដើមចន្ទន៍ ។ កាលឲ្យសាលាសម្រេចយ៉ាងនេះហើយ កាលនឹងធ្វើការឆ្លង ទើបនិមន្តព្រះសាស្តា មួយអន្ទើដោយកិក្ខុ ៦ លាន ៨ សែន បាន

ថ្វាយទានអស់កាល ៤ ខែ ។ ក្នុងថ្ងៃចុងក្រោយ បានថ្វាយត្រៃចីវរ ។ បណ្តាភិក្ខុទាំងនោះចីវរមានតម្លៃមួយពាន់ ធ្លាក់ដល់ភិក្ខុដែលបួសថ្មីក្នុងសង្ឃហើយ ។

បុរសនោះធ្វើបុញ្ញកម្ម ក្នុងកាលព្រះវិបស្សីសម្ពុទ្ធយ៉ាងនោះហើយ ឃ្លាតចាកអត្តភាពនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងកទ្ទកប្បនេះ កើតក្នុងត្រកូលសេដ្ឋីមានភោគៈច្រើន ក្នុងក្រុងពារាណសី មានឈ្មោះថាពារាណសីសេដ្ឋី ។

ថ្ងៃមួយ សេដ្ឋីទៅកាន់ទីបម្រើព្រះរាជា ជួបបុរោហិត ទើបពោលថា លោកអាចារ្យ លោកពិនិត្យមើលឫក្ស និងយាមឬ បុរោហិតពោលថា លោកសេដ្ឋី ខ្ញុំពិនិត្យមើល យើងទាំងឡាយមានការងារអ្វីដទៃ សេដ្ឋីសួរថា បើដូច្នោះ ការប្រព្រឹត្តទៅក្នុងជនបទដូចម្តេច បុរោហិតពោលថា ភ័យមួយនឹងកើតមាន សេដ្ឋីសួរថា ភ័យនុ៎ះជាអ្វី បុរោហិតពោលថា បពិត្រលោកសេដ្ឋី គឺឆាតកភ័យ (ភ័យកើតអំពីការខ្វះអាហារ) សេដ្ឋីពោលថា នឹងមានក្នុងកាលណា បុរោហិតពោលថា នឹងមានក្នុងកាលកន្លងទៅ ៣ ឆ្នាំ បន្ទាប់អំពីឆ្នាំនេះ ។

សេដ្ឋីស្តាប់ពាក្យនោះហើយ ឲ្យមនុស្សធ្វើកសិកម្មជាច្រើន ទិញចំពោះតែស្រូវដោយទ្រព្យដែលមានក្នុងផ្ទះ ឲ្យធ្វើជង្រុក ១២៥០ ដាក់ជង្រុកទាំងអស់ឲ្យពេញដោយស្រូវ កាលជង្រុកមិនគ្រប់គ្រាន់ ក៏ដាក់ក្នុងភាជនៈមានពាងជាដើមឲ្យពេញហើយ ជីករណ្តៅកប់ស្រូវដែលសល់ក្នុងផែនដី ច្របាច់ស្រូវដែលសល់អំពីកប់ជាមួយដីឥដ្ឋបូកជញ្ជាំងទាំងឡាយ ។

សម័យដទៃមកទៀត កាលភ័យ គឺការអត់ឃ្លានចូលមកដល់ហើយ ក៏បរិភោគស្រូវតាមដែលរក្សា កាលស្រូវដែលជាក់ក្នុងជង្រុក និងភាជនៈ មានពាងជាដើមអស់ហើយ ទើបហៅបរិវារជនមកហើយពោលថា នែបាទាំងឡាយ ចូរអ្នកទាំងឡាយទៅកាន់ភ្នំហើយរស់នៅ បើបំណងមកកាន់សម្នាក់យើង ចូរមកក្នុងកាលដែលមានកិក្ខាកបានងាយ បើមិនចង់មកទេ ក៏ចូររស់នៅទីនោះចុះ ជនទាំងនោះបានធ្វើយ៉ាងនោះហើយ ។ ចំណែកអ្នកបម្រើម្នាក់ឈ្មោះបុណ្ណៈ នៅសល់ក្នុងសម្នាក់របស់សេដ្ឋីនោះ រួមជា ៥ នាក់ គឺសេដ្ឋី ១ ភរិយារបស់សេដ្ឋី ១ បុត្ររបស់សេដ្ឋី ១ កូនប្រសារបស់សេដ្ឋី ១ ទាសៈឈ្មោះបុណ្ណៈនោះ ១ ។

ជនទាំងនោះ កាលស្រូវដែលកប់ទុកក្នុងផែនដីអស់ហើយ ដំបំបែកដីដែលបូកត្រង់ជញ្ជាំងត្រាំទឹក ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយស្រូវដែលបានហើយអំពីជញ្ជាំងនោះ ។

គ្រានោះ ភរិយាសេដ្ឋីកាលសេចក្តីឃ្លានគ្របសង្កត់ កាលជីអស់ទៅ ដំជីដែលសល់ក្នុងចំណែកនៃជញ្ជាំងទាំងឡាយហើយត្រាំទឹក បានស្រូវប្រមាណកន្ទុះអាឡ្ហក គឺ ២ នាឡិ បុកហើយកាន់យកអង្គ្រប្រមាណ ១ នាឡិ ដាក់ក្នុងឆ្នាំងមួយ ព្រោះខ្លាចអំពីចោរថា ក្នុងកាលកើតឆាតកភ័យ ចោរមានច្រើនបិទហើយកប់ទុកក្នុងផែនដី ។ លំដាប់នោះ សេដ្ឋីមកអំពីទីបម្រុងព្រះរាជាហើយ ពោលនឹងភរិយាថា នែនាង ខ្ញុំឃ្លាន វត្តុណាមួយមានដៃឬទេ ភរិយាមិនបានពោលដល់វត្តុដែលមានថាមិនមាន តែពោលថា នែអ្នក អង្គ្រមាន ១

នាឡិ សេដ្ឋីពោលថា អង្គរ ១ នាឡិនោះនៅឯណា ភរិយាពោលថា ខ្ញុំកប់ទុក ព្រោះខ្លាចចោរ សេដ្ឋីពោលថា បើដូច្នោះ ចូរនាងគាស់ឡើងមក ហើយចម្អិនចុះ ភរិយាពោលថា បើយើងបបរអាចគ្រប់គ្រាន់ ២ ពេល បើដាំបាយបានត្រឹមមួយពេលប៉ុណ្ណោះ ខ្ញុំនឹងចម្អិនដូចម្តេច សេដ្ឋីពោលថា បច្ចុយជនៃរបស់ពួកយើងមិនមាន ពួកយើងបរិភោគបាយហើយក៏ស្លាប់ ចូរនាងដាំបាយ ។

ភរិយានៃសេដ្ឋីនោះ ចម្អិនបាយហើយ ចែកជា ៥ ចំណែក ដួសបាយមួយចំណែកជាក់ខាងមុខលោកសេដ្ឋី ។

ក្នុងខណៈនោះ ព្រះបច្ចេកពុទ្ធមួយអង្គ នៅត្រង់ភ្នំគន្ធមាទន៍ ចេញអំពីសមាបត្តិ ជ្រាបថា ខាងក្នុងសមាបត្តិ ការស្រេកឃ្លាន រមែងមិនបៀតបៀនព្រោះផលនៃសមាបត្តិ តែកាលព្រះបច្ចេកពុទ្ធទាំងឡាយ ចេញអំពីសមាបត្តិហើយ ការស្រេកឃ្លានដ៏មានកម្លាំងរមែងកើតឡើង ហាក់បីដូចជុតនូវផ្ទៃពោះដូច្នោះ ព្រោះដូច្នោះ ទើបព្រះបច្ចេកពុទ្ធទាំងនោះ ពិចារណាមើលហាន:ដែលអាចបានអាហារហើយ ទើបទៅ ។

ក្នុងថ្ងៃនោះ ជនទាំងឡាយណាបានថ្វាយទានដល់ព្រះបច្ចេកពុទ្ធហើយ រមែងបាននូវសម្បត្តិ មានតំណែងជាសេនាបតីជាដើមណាមួយ ព្រោះដូច្នោះ ព្រះបច្ចេកពុទ្ធនោះ ពិចារណាមើលដោយទិព្វចក្ខុ ត្រិះរិះថា ឆាតកភ័យកើតឡើងហើយក្នុងជម្ពូទ្វីបទាំងមូល ក្នុងផ្ទះសេដ្ឋី គេចម្អិនបាយដែលសម្រេចដោយអង្គរមួយនាឡិ ដើម្បីមនុស្ស ៥ នាក់ អ្នកទាំងនោះនឹងមានសទ្ធាដើម្បីសង្គ្រោះដល់អាត្មាអញដែរឬទេហ្ន៎ ឃើញភាពដែលជនទាំងនោះ ជាអ្នកមាន

សទ្ធាផង អាចធ្វើការសង្គ្រោះផង ទើបកាន់យកជាត្រ និងចីវរ ទៅបង្ហាញខ្លួនត្រង់ទ្វារផ្ទះ អំពីមុខលោកសេដ្ឋី ។ សេដ្ឋីនោះ គ្រាន់តែឃើញក៏មានចិត្តជ្រះថ្លា គិតថា អញជួបនូវឆាតកភ័យបែបនេះ ព្រោះអញមិនបានធ្វើទានក្នុងកាលមុន ភត្តនេះគប្បីរក្សាអញត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ឯភត្តដែលអញប្រគេនហើយដល់លោកម្ចាស់ នឹងនាំមកនូវប្រយោជន៍ដល់អញច្រើនកោដិកប្ប ហើយនាំថាស និងភត្តនោះចេញមក ចូលទៅរកព្រះបច្ចេកពុទ្ធ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន និមន្តឲ្យចូលទៅកាន់ផ្ទះ កាលលោកគង់លើអាសនៈហើយ ទើបលាងជើងរបស់លោក ដាក់ថាសភត្តលើតាំងមាស ហើយកាន់យកភត្តនោះមកដាក់ក្នុងជាត្រ ព្រះបច្ចេកពុទ្ធ កាលភត្តសល់ពាក់កណ្តាល ព្រះបច្ចេកពុទ្ធយកដៃបិទជាត្រ ។

ពេលនោះ ទើបសេដ្ឋីពោលនឹងព្រះបច្ចេកពុទ្ធថា បពិត្រលោកម្ចាស់ នេះជាចំណែកមួយនៃបាយដែលគេចម្អិនដើម្បីមនុស្ស ៥ នាក់ ដោយអង្ករមួយនាឡិ ខ្ញុំមិនអាចចែកភត្តនេះឲ្យជាពីរចំណែកបានទេ សូមលោកម្ចាស់កុំធ្វើការសង្គ្រោះដល់ខ្ញុំតែក្នុងលោកនេះឡើយ ខ្ញុំប្រាថ្នាប្រគេនមិនឲ្យសេសសល់ ហើយបានប្រគេនភត្តទាំងអស់ ។ កាលប្រគេនហើយ បានតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ ខ្ញុំកុំបីជួបឆាតកភ័យបែបនេះ ក្នុងទីដែលខ្ញុំកើតឡើយ តាំងអំពីឥឡូវនេះទៅ ខ្ញុំគប្បីឲ្យនូវភត្តដែលជាពូជដល់មនុស្សក្នុងជម្ពូទ្វីបទាំងមូល មិនចាំបាច់ធ្វើការងារចិញ្ចឹមជីវិត ដោយដៃរបស់ខ្លួនឯង ខណៈដែលខ្ញុំប្រើឲ្យមនុស្សសម្អាតជង្រុក ១២៥០ ហើយ កក់សក់ អង្គុយ

ត្រង់ទ្វារនៃជង្រ្កកទាំងនោះហើយ សម្ដីងមើលខាងលើប៉ុណ្ណោះ ផ្ការនៃស្រាវសាលីគប្បីធ្លាក់ចុះមកកាន់ជង្រ្កកទាំងអស់ឲ្យពេញដើម្បីខ្ញុំ ។ បុគ្គលនោះឯង ចូរជាភរិយា បុគ្គលនេះឯង ចូរជាបុត្រ បុគ្គលនេះឯង ចូរជាកូនប្រសាស្រី បុគ្គលនេះឯង ចូរជាទាសៈរបស់ខ្ញុំ ក្នុងទីដែលខ្ញុំកើតហើយ ។

ចំណែកភរិយារបស់សេដ្ឋីនោះ គិតថា បើប្ដីរបស់អញត្រូវសេចក្ដីឃ្លានបៀតបៀន អញក៏មិនអាចលេបរួច ទើបប្រគេនចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្ដីប្រាថ្នាថា បពិត្រលោកម្ចាស់ តាំងអំពីនេះទៅ ខ្ញុំមិនគប្បីជួបនូវឆាតកភ័យបែបនេះ ក្នុងទីដែលខ្ញុំកើតហើយ ម្យ៉ាងទៀត កាលខ្ញុំជាក់ថាសកត្តភាងមុខ ឲ្យនូវភត្តដល់មនុស្សក្នុងជម្ពូទ្វីបទាំងមូល បើខ្ញុំមិនក្រោកជរាបណា ទីនៃភត្តដែលខ្ញុំដួសហើយ សូមពេញបរិបូណ៌ដូចដើមនោះឯង បុរសនេះសូមជាស្វាមី បុរសនេះសូមជាបុត្រ ស្ត្រីនេះសូមជាកូនប្រសា បុរសនេះសូមជាទាសៈ ។ កូនប្រុសរបស់សេដ្ឋីនោះ ក៏ប្រគេនចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្ដីប្រាថ្នាថា តាំងអំពីនេះទៅ ឆាតកភ័យបែបនេះ កុំបីមានដល់ខ្ញុំឡើយ ម្យ៉ាងទៀត បើខ្ញុំកាន់ថង់ប្រាក់ដាក់កហាបណៈមួយពាន់ សូម្បីឲ្យកហាបណៈដល់មនុស្សក្នុងជម្ពូទ្វីបទាំងមូលថង់នោះ សូមពេញដូចដើម លោកទាំងពីរនោះ សូមជាមាតាបិតា ស្រីនេះសូមជាភរិយា បុរសនេះ សូមជាទាសៈរបស់ខ្ញុំ សូម្បីកូនប្រសាស្រីរបស់សេដ្ឋីនោះ ប្រគេនចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធហើយ បានតាំងសេចក្ដីប្រាថ្នាថា តាំងអំពីនេះទៅ ឆាតកភ័យបែបនេះ កុំបីជួបខ្ញុំឡើយ ម្យ៉ាងទៀត

កាលខ្ញុំកាន់ល្អីស្រូវដាក់ខាងមុខ ឲ្យនូវភត្តដែលជាពូជដល់មនុស្សក្នុងជម្ពូទ្វីបទាំងមូល ការអស់ទៅ កុំបីប្រាកដ លោកទាំងពីរនោះសូមជាមាតាបិតាក្មេក បុរសនោះសូមជាប្តី បុរសនោះសូមជាទាសៈរបស់ខ្ញុំ ។ សូម្បីទាសៈរបស់សេដ្ឋីនោះ ក៏ប្រគេនចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធ ហើយក៏តាំងសេចក្តីប្រាថ្នាថា តាំងអំពីនេះទៅ ខ្ញុំមិនគប្បីយល់នូវឆាតកភ័យបែបនេះឡើយ ជនទាំងអស់សូមជាចៅហ្វាយ កាលខ្ញុំក្អួរស្រែ គន្ធ ៧ ប៉ុនទូកកំពោល គឺខាងនេះ ៣ ខាងនោះ ៣ ត្រង់កណ្តាល ១ ចូរប្រព្រឹត្តទៅ ។ បុណ្ណៈនោះ ទោះបីប្រាថ្នាតំណែងសេនាបតី ក៏អាចបានក្នុងថ្ងៃនោះឯង តែដោយអំណាចស្រឡាញ់ក្នុងម្ចាស់ទាំងឡាយ ទើបតាំងសេចក្តីប្រាថ្នាថា ជនទាំងនោះឯងសូមជាចៅហ្វាយរបស់ខ្ញុំ ។ ក្នុងទីបំផុតនៃវាចារបស់ជនទាំងអស់ ព្រះបច្ចេកពុទ្ធពោលថា ចូរសម្រេចយ៉ាងនោះចុះ ហើយធ្វើអនុមោទនាដោយគាថារបស់ព្រះបច្ចេកពុទ្ធ ហើយគិតថា អញនឹងញុំាងចិត្តរបស់ជនទាំងឡាយនេះ ឲ្យជ្រះថ្លា គួរ ទើបអធិដ្ឋានថា ចូរជនទាំងនេះ ឃើញអាត្មាអញរហូតដល់ភ្នំគន្ធមាទន៍ ដូច្នេះហើយ ក៏ចៀសចេញទៅ សូម្បីជនទាំងនោះ បានឈរមើលនោះឯង ។ ព្រះបច្ចេកពុទ្ធនោះនិមន្តទៅហើយ ចែកភត្តនោះដល់ព្រះបច្ចេកពុទ្ធ ៥០០ ដោយអានុភាពនៃព្រះបច្ចេកពុទ្ធទាំងនោះ ភត្តនោះ គ្រប់គ្រាន់ហើយដល់ព្រះបច្ចេកពុទ្ធទាំងអស់ ។ ជនទាំងនោះ បានឈរមើលនោះឯង ។

ពេលថ្ងៃត្រង់កន្ធទៅហើយ ភរិយាសេដ្ឋីលាងឆ្នាំងបាយហើយបិទទុកចំណែកសេដ្ឋី ត្រូវសេចក្តីឃ្លានគ្របសង្កត់ដេកលក់ទៅ លុះភ្ញាក់ឡើងក្នុងពេល

ល្ងាច ពោលនឹងភរិយារបស់ខ្លួនថា នែនាង ខ្ញុំឃ្លានពន់ពេក ចាយក្តាំងបាត ឆ្នាំង មានខ្លះឬហ្ន៎ ភរិយានោះសូម្បីដឹងថា ខ្លួនបានលាងឆ្នាំងហើយ ក៏មិនពោលថា មិនមាន គិតថា អញ្ជើកឆ្នាំងចាយហើយសឹមជ្រាប់ ដូច្នេះហើយទើបក្រោកឡើងទៅក្បែរឆ្នាំងចាយ ហើយបើក ។

ខណៈនោះឯង ឆ្នាំងចាយពេញដោយភត្ត មានពណ៌ដូចផ្កាម្ទិះក្រពុំ បានទុលគម្របតាំងនៅហើយ ។ ភរិយានោះឃើញភត្តហើយ ជាអ្នកមានសរីរៈពេញដោយបីតិ ពោលនឹងសេដ្ឋីថា សូមក្រោកឡើងចុះ ខ្ញុំលាងឆ្នាំងចាយបិទទុក តែឆ្នាំងនោះពេញដោយភត្ត មានពណ៌ដូចផ្កាម្ទិះក្រពុំ ឈ្មោះថា បុណ្យទាំងឡាយគួរតែធ្វើ ឈ្មោះថា ទានគួរតែឲ្យ សូមអ្នកក្រោកឡើងបរិភោគចុះ ។

ភរិយានោះ បានឲ្យភត្តដល់ឪពុក និងកូនទាំងពីរហើយ កាលឪពុក និងកូននោះបរិភោគហើយ នាងអង្គុយបរិភោគជាមួយកូនប្រសា ហើយឲ្យភត្តដល់បុណ្ណៈ ។ ទីនៃភត្តដែលជនទាំងនោះដួសហើយ មិនអស់ទៅ ប្រាកដចំពោះត្រង់ទីដែលដួសមួយវែកដំបូងប៉ុណ្ណោះ ។

ក្នុងថ្ងៃនោះឯង ជង្រុកជាដើមក៏ពេញហើយដោយទំនងដែលពេញពីមុន នោះឯង នាងឲ្យធ្វើការប្រកាសក្នុងនគរថា ភត្តកើតឡើងហើយក្នុងផ្ទះរបស់សេដ្ឋី បុគ្គលត្រូវការដោយភត្តដែលជាពូជ ចូរមកទទួលយកចុះ ។ មនុស្សទាំងឡាយ កាន់យកភត្តដែលជាពូជអំពីផ្ទះរបស់សេដ្ឋីនោះហើយ សូម្បីមនុស្សក្នុងជម្ពូទ្វីបទាំងមូល ក៏អាស្រ័យសេដ្ឋីនោះ បាននូវជីវិតហើយនោះឯង ។

សេដ្ឋីនោះ ឃ្លាតចាកអត្តភាពនោះហើយ កើតក្នុងទេវលោក អន្ទោល

ក្នុងទេវលោក និងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលសេដ្ឋី ក្នុងភទ្ទិយនគរ សូម្បីកិរិយារបស់គាត់ កើតក្នុងត្រកូលមានភោគៈច្រើន ចម្រើនវ័យហើយ បានទៅកាន់ផ្ទះរបស់លោកសេដ្ឋីនោះឯង ពពែទាំងឡាយ មានប្រការដូចពោលហើយ អាស្រ័យកម្មក្នុងកាលមុនរបស់សេដ្ឋី ក៏ផុសឡើងត្រង់ក្រោយផ្ទះ សូម្បីកូនប្រុស ក៏បានជាកូនប្រុសរបស់លោកនោះឯង ស្រីកូនប្រសាបានជាកូនប្រសាដូចគ្នា ទាសៈក៏បានជាទាសៈនោះឯង ។ ថ្ងៃមួយ សេដ្ឋីប្រាថ្នាដើម្បីល្បងបុណ្យរបស់ខ្លួន ទើបឲ្យមនុស្សសម្អាតជង្រែក ១២៥០ កក់សក់ហើយ អង្គុយត្រង់ទ្វារសម្ងំមើលខាងលើ ជង្រែកទាំងអស់ ពេញហើយដោយស្រូវសាលី មានប្រការដូចពោលហើយ ។ សេដ្ឋីនោះ ប្រាថ្នានឹងសាកល្បងបុណ្យរបស់ជនដ៏សេស ទើបពោលនឹងកិរិយា និងកូនប្រសជាដើមថា អ្នកទាំងឡាយ ចូរពិសោធបុណ្យរបស់ពួកអ្នកចុះ ។ លំដាប់នោះ កិរិយារបស់សេដ្ឋីនោះ ប្រដាប់ហើយដោយគ្រឿងអលង្ការទាំងពួង កាលមហាជនកំពុងមើលនោះឯង ប្រើឲ្យមនុស្សវាល់អង្ករទាំងឡាយ ឲ្យចម្អិនបាយដោយអង្ករទាំងនោះ អង្គុយលើអាសនៈដែលគេក្រាលហើយត្រង់ខ្វាងទ្វារ កាន់វែកមាស ហើយប្រកាសថា បុគ្គលណាត្រូវការដោយភត្ត ចូរមក ហើយបានឲ្យរហូតពេញកាជនៈ ដល់ជនដែលមកហើយ ។ កាលនាងឲ្យអស់មួយថ្ងៃ ប្រាកដចំពោះត្រង់ទីដែលជួសដោយវែកប៉ុណ្ណោះ ។ បទុមលក្ខណៈ កើតត្រង់ជាតដៃខាងឆ្វេង ចន្ទលក្ខណៈ កើតត្រង់ជាតដៃខាងស្តាំ ព្រោះនាងចាប់ឆ្នាំងបាយដោយដៃឆ្វេង ចាប់វែកដោយដៃស្តាំ ហើយប្រគេនភត្តរហូតពេញ

បាត្រដល់ភិក្ខុសង្ឃ របស់ព្រះពុទ្ធទាំងឡាយ ក្នុងកាលមុនដោយប្រការដូច្នេះឯង ព្រោះហេតុដែលនាងកាន់យកធម្មក្រកត្រង់ទឹកប្រគេនដល់ភិក្ខុសង្ឃ ដើរទៅមក ដូច្នោះ ទើបចន្ទលក្ខណៈកើតត្រង់បាតជើងខាងស្តាំរបស់នាង បទុមលក្ខណៈកើតត្រង់បាតជើងខាងឆ្វេងរបស់នាង ព្រោះហេតុនេះ ទើបញាតិទាំងឡាយដាក់ឈ្មោះនាងថា ចន្ទបទុមា ។

ចំណែកកូនប្រុសរបស់សេដ្ឋីនោះ កក់សក់ហើយ កាន់យកថង់កហាបណៈមួយពាន់ពោលថា អ្នកណាត្រូវការកហាបណៈ ចូរមក ហើយឲ្យរហូតពេញភាជនៈក្នុងបណ្តាជនដែលមក កហាបណៈមួយពាន់ក៏មាននៅក្នុងថង់នោះឯង សូម្បីកូនប្រសារបស់សេដ្ឋីនោះ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង កាន់យកល្អីដាក់ស្រូវហើយ អង្គុយត្រង់ទីវាលពោលថា អ្នកត្រូវការភត្តដែលជាពូជ ចូរមក ហើយបានឲ្យពេញភាជនៈក្នុងជនដែលមកហើយ ល្អីស្រូវក៏នៅពេញដូចដើមនោះឯង ។ សូម្បីទាសៈរបស់សេដ្ឋីនោះ ប្រដាប់ហើយដោយគ្រឿងអលង្ការទាំងពួង ទឹមគោទាំងឡាយត្រង់នឹមដែលធ្វើអំពីមាស ដោយខ្សែមាសកាន់យកជង្ជញ្ញមាស ឲ្យនូវគ្រឿងក្រអូបដែលបុគ្គលគប្បីប្រោះដោយម្រាមដៃទាំង ៥ ដល់គោទាំងឡាយ ដែលពាក់ចង្កឹមាសត្រង់ស្នែងទាំងឡាយ ចុះកាន់ស្រែហើយ ភ្ជួរទៅ ។ គន្ធង ៣ គឺខាងឆ្វេង ៣ ខាងស្តាំ ៣ កណ្តាល ១ បានបែកទៅហើយ ។ ចំណែកអ្នកជម្ពូទីប កាន់យកទ្រព្យ មានភត្ត ពូជ ប្រាក់ មាសជាដើម តាមដែលខ្លួនគាប់ចិត្តអំពីផ្ទះរបស់សេដ្ឋីប៉ុណ្ណោះ ។

សេដ្ឋីមានអានុភាពច្រើនយ៉ាងនោះ បានឮថា ព្រះសាស្តាយាងមកហើយ

គិតថា អញនឹងធ្វើការទទួលដំណើរព្រះសាស្តា ចេញទៅជួបពួកតិរ្ថិយក្នុងតាមផ្លូវ សូម្បីត្រូវពួកតិរ្ថិយទាំងនោះឃាត់ថា គហបតី លោកជាកិរិយវាទ ទៅកាន់សម្នាក់របស់ព្រះគោតម ដែលជាអកិរិយវាទធ្វើអ្វី ក៏មិនបានជឿពាក្យរបស់តិរ្ថិយទាំងនោះ ត្រាច់ទៅហើយ ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីបំផុត នាចំណែកម្ខាង ។

លុះជាប់នោះ ព្រះសាស្តាត្រាស់អនុបុព្វីកថាជល់សេដ្ឋីនោះ ក្នុងកាលចប់ទេសនា សេដ្ឋីសម្រេចសោតាបត្តិផល ហើយក្រាបទូលភាពដែលខ្លួនត្រូវពួកតិរ្ថិយពោលទោស ហើយឃាត់ជល់ព្រះសាស្តា ។ កាលនោះ ព្រះសាស្តាត្រាស់នឹងលោកសេដ្ឋីនោះថា ម្នាលគហបតី ឈ្មោះថា សត្វទាំងនេះ មិនឃើញទោសរបស់ខ្លួនសូម្បីច្រើន រមែងឃើញទោសរបស់ជនដទៃ សូម្បីមិនមានធ្វើឲ្យមាន ដូចបុគ្គលបាចអង្កាមទៅក្នុងទីនោះៗ ជូរច្នាះ ជូរច្នះហើយ ទើបត្រាស់ព្រះគាថានេះថា

សុទស្សំ វជ្ជមញ្ញេសំ អត្តនោ បន ទុទ្ទសំ
បរេសំ ហិ សោ វជ្ជានិ ឱបុនាតិ យថាភុសំ
អត្តនោ បន ឆាទេតិ កលិំវ កិតវា សឋោ ។

ទោសរបស់ពួកជនដទៃ ឃើញបានដោយងាយ ចំណែកទោសរបស់ខ្លួន ឃើញបានដោយលំបាក ព្រោះថា បុគ្គលនោះ រោយទោសទាំងឡាយចំពោះពួកជនដទៃ ដូចបុគ្គលរោយអង្កាម ជូរច្នាះ តែថា រមែងបិទបាំងទោសរបស់ខ្លួន ដូច

ព្រោនបក្សី បិទបាំងអត្តភាពដោយវត្ថុសម្រាប់បិទបាំង (មានមែកឈើជាដើម) ដូច្នោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សុឧស្សុំ** *សេចក្តីថា ទោស គឺការក្តាំងក្តាត់របស់បុគ្គលដទៃ សូម្បីមានប្រមាណតិច បុគ្គលឃើញបានងាយ គឺអាចឃើញបានងាយនោះឯង ចំណែកទោសរបស់ខ្លួន សូម្បីធំក្រៃលែង បុគ្គលរមែងឃើញបានដោយលំបាក ។*

បទថា **បរេសំ ហិ** *សេចក្តីថា ព្រោះហេតុនោះឯង បុគ្គលនោះរមែងបាចសាចនូវទោសទាំងឡាយរបស់ជនដទៃ ទៅក្នុងកណ្តាលជំនុំសង្ឃជាដើម ដូចបុគ្គលឈរលើទីខ្ពស់ ហើយរោយនូវអង្កាម ដូច្នោះ ។*

អត្តភាព ឈ្មោះថា **កលិ** *ដោយអំណាចដែលប្រព្រឹត្តខុសក្នុងបក្សីទាំងឡាយ ក្នុងពាក្យថា* **កលិវ កិតវា សឋោ** *នេះ ។*

គ្រឿងបិទបាំង មានមែកឈើដែលលួមកាច់បានជាដើម ឈ្មោះថា **កិតវា** *ក្នុងពាក្យថា* **កិតវា** *នេះ ។*

នាយព្រាន ឈ្មោះថា **សឋោ** *ក្នុងពាក្យថា* **សឋោ** *នេះ អធិប្បាយថា ព្រោនបក្សី បំណងនឹងចាប់បក្សីសម្លាប់ រមែងបិទបាំងអត្តភាពដោយគ្រឿងបិទបាំង យ៉ាងណា បុគ្គលរមែងបិទបាំងទោសរបស់ខ្លួនឯងក៏យ៉ាងនោះ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៗ

រឿង ព្រះឧជ្ឈានសញ្ញិត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈមួយរូប ឈ្មោះឧជ្ឈានសញ្ញី ត្រាស់ព្រះធម្មទេសនានេះថា **បរវជ្ជានុបស្សិស្ស** *ជាដើម ។*

បានឮថា ព្រះថេរៈនោះដើររំពៃតែទោស របស់ភិក្ខុទាំងឡាយប៉ុណ្ណោះ ថា ភិក្ខុនេះរមែងស្លៀកយ៉ាងនេះ ភិក្ខុនេះរមែងដណ្តប់យ៉ាងនេះ ពួកភិក្ខុក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ព្រះថេរៈឈ្មោះនោះរមែងធ្វើយ៉ាងនេះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុតាំងនៅក្នុងកតិកា ពោលប្រៀនប្រដៅយ៉ាងនេះ បុគ្គលមិនគួរតិះដៀល ចំណែកភិក្ខុណាស្វែងរកទោសរបស់អ្នកដទៃ ព្រោះបំណងនឹងលើកទោស ពោលយ៉ាងនេះហើយត្រាច់ទៅ បណ្តាគុណវិសេសមានឈានជាដើម គុណវិសេសណាមួយ រមែងមិនកើតទ្បើងដល់ភិក្ខុនោះ អាសវៈទាំងឡាយប៉ុណ្ណោះ តែងចម្រើនតែម្យ៉ាង ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

បរវជ្ជានុបស្សិស្ស និច្ចំ ឧជ្ឈានសញ្ញិនោ
អាសវា តស្ស វឌ្ឍន្តិ អារា សោ អាសវក្ខយា ។

កាលបុគ្គល គយឃ្លាំមើលទោសរបស់បុគ្គលដទៃជាប្រក្រតី មានការសម្គាល់ហេតុ ក្នុងការពោលទោស (អ្នកដទៃ) ជានិច្ចជាប្រក្រតី អាសវៈទាំងឡាយរបស់បុគ្គលនោះ តែងចម្រើន បុគ្គលនោះ ឈ្មោះថា ស្ថិតនៅឆ្ងាយអំពីធម៌ ជាគ្រឿងអស់អាសវៈ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឧដ្ឋានសញ្ញិនោ** *សេចក្តីថា បណ្តាធម៌ទាំងឡាយ មានឈានជាដើម ធម៌ណាមួយរមែងមិនចម្រើនដល់បុគ្គលដែលឈ្មោះថា ច្រើនទៅដោយការលើកទោស ព្រោះភាពជាបុគ្គលគន់រំពៃទោសរបស់អ្នកដទៃថា គួរស្បែកយ៉ាងនេះ គួរជណ្តប់យ៉ាងនេះជាដើម ។ ដោយពិត អាសវៈទាំងឡាយរមែងចម្រើន ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា ជាអ្នកនៅធ្ងាយ គឺធ្ងាយក្រៃលែងអំពីការអស់ទៅនៃអាសវៈ ពោលគឺអរហត្ត ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះឧដ្ឋានសញ្ញិត្ថេរ ចប់

រឿង សុភទ្ទបរិព្វាជក

លំនាំដើម

ព្រះសាស្តាផ្ទំហើយ លើព្រះទែនដែលជាទីបរិនិព្វាន ក្នុងសាលវនរបស់មល្លក្សត្រទាំងឡាយ ដែលជាទីសម្រាកក្បែរនគរកុសិនារា ទ្រង់ប្រារព្ធបរិព្វាជកឈ្មោះសុភទ្ទ ត្រាស់ព្រះធម្មទេសនានេះថា **អាកាសេ បទំ នត្ថិ** *ជាដើម ។*

បានឮថា ក្នុងអតីតកាល សុភទ្ទបរិព្វាជកនោះ កាលបួនប្រុសឲ្យទានដ៏ប្រសើរដល់ទៅ ៩ ដង ក្នុងសម្ងួមមួយរដូវ មិនប្រាថ្នានឹងឲ្យ រួញរហើយ

បានឲ្យក្នុងកាលជាទីបំផុត ។

ព្រោះដូច្នោះ ទើបមិនបានគាល់ព្រះសាស្តា ទាំងនៅក្នុងបឋមពោធិកាល ទាំងក្នុងមជ្ឈិមពោធិកាល តែក្នុងបច្ឆិមពោធិកាល ក្នុងកាលដែលបរិនិព្វានរបស់ព្រះសាស្តា គិតថា អញសួរសេចក្តីសង្ស័យរបស់ខ្លួនក្នុង ៣ បញ្ហានឹងបរិព្វាជកទាំងឡាយដែលជាមនុស្សចាស់ មិនសួរនឹងព្រះសមណគោតម ដោយសម្គាល់ថាជាក្មេង ឥឡូវនេះ ជាកាលបរិនិព្វានរបស់ព្រះសមណគោតមនោះ វិប្បដិសារីគប្បីកើតដល់អញ ក្នុងកាលជាក្រោយ ព្រោះហេតុមិនសាកសួរព្រះសមណ-គោតម ហើយចូលទៅគាល់ព្រះសាស្តា សូម្បីត្រូវព្រះអានន្ទត្មៃឃាត់ ចូលទៅខាងក្នុងវាំងនន ព្រោះភាពដែលព្រះសាស្តាទ្រង់ឲ្យឱកាសហើយ ត្រាស់ថា អានន្ទ អ្នកកុំឃាត់សុភទ្ទឡើយ ចូរសុភទ្ទសួរបញ្ហាជាមួយតថាគត ទើបអង្គុយក្បែរព្រៃ ទូលសួរបញ្ហាទាំងនេះថា បពិត្រព្រះសមណៈ ឈ្មោះថា ស្នាមជើងក្នុងអាកាសមានឬហ្ន៎ ឈ្មោះថា សមណៈខាងក្រៅសាសនានេះមានឬ សង្ខារទាំងឡាយ ឈ្មោះថា ទៀង មានឬ ។

លំដាប់នោះ ព្រះសាស្តាកាលត្រាស់ប្រាប់ការមិនមាននៃស្នាមជើងក្នុងអាកាសជាដើមដល់សុភទ្ទ ទើបទ្រង់សម្តែងធម៌ដោយព្រះគាថានេះថា

អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរោ
បបញ្ចាភិរតា បជា និប្បបញ្ចា តថាគតា
អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរោ
សង្ខារា សស្សតា នត្ថិ នត្ថិ ពុទ្ធានមិញ្ជិតំ ។

ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន ពួកសត្វត្រេកអរហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ ព្រះតថាគតទាំងឡាយ មិនមានធម៌ជាគ្រឿងយឺតយូរឡើយ ។
ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន សង្ខារទាំងឡាយ ជារបស់ទៀង មិនមាន ព្រះពុទ្ធទាំងឡាយ មិនមានកិលេសជាគ្រឿងញាប់ញ័រទេ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បទំ** *សេចក្តីថា ឈ្មោះថា ស្នាមជើងនៃសត្វណាមួយ ដែលបុគ្គលគប្បីបញ្ញត្តថា មានរូបយ៉ាងនេះ ដោយអំណាចនៃពណ៌ និងសណ្ឋាន ក្នុងអាកាសនេះ មិនមាន ។*

បទថា **តថាគតោ** *សេចក្តីថា ឈ្មោះថា សមណៈដែលតាំងនៅក្នុងមគ្គ និងផល ខាងក្រៅសាសនារបស់តថាគត មិនមាន ។*

បទថា **បជា** *សេចក្តីថា ពួកសត្វ ពោល គឺសត្វលោកត្រេកអរក្រៃលែងហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ មានតណ្ហាជាដើមប៉ុណ្ណោះ ។*

បទថា **និប្ផបញ្ចា** *សេចក្តីថា ចំណែកព្រះតថាគតទាំងឡាយជាបុគ្គលឈ្មោះថា មិនមានធម៌ជាគ្រឿងយឺតយូរ ព្រោះភាពដែលទ្រង់កាត់នូវធម៌ជាគ្រឿងយឺតយូរទាំងពួងជាសមុច្ឆេទហើយ ត្រង់មណ្ឌលពោធិព្រឹក្សនោះឯង ។*

ខន្ធ ៥ ឈ្មោះថា សង្ខារ ក្នុងខន្ធទាំង ៥ នោះ ខន្ធឯណានីមួយ ឈ្មោះថា ទៀង មិនមាន ។

បទថា **ឥញ្ជិតំ** *សេចក្តីថា ជនទាំងឡាយគប្បីកាន់យកថា សង្ខារទាំងឡាយជាសភាពទៀង ដោយបណ្តាកិលេសជាត គ្រឿងញាប់ញ័រ គឺ តណ្ហា មានះ និងទិដ្ឋិឯណា សូម្បីកិលេសជាតជាគ្រឿងញាប់ញ័រនោះណាមួយ ក៏មិនមានដល់ព្រះពុទ្ធទាំងឡាយ ។ ក្នុងកាលចប់ទេសនា សុភទ្ទ-បរិព្វាជក តាំងនៅហើយក្នុងអនាគាមិផល ព្រះធម្មទេសនាមានប្រយោជន៍ដល់បរិសទ ដែលប្រជុំគ្នាហើយដូច្នេះឯង ។*

រឿងសុភទ្ទបរិព្វាជក ចប់

មលវគ្គ ចប់

វគ្គទី ១៨ ចប់

សុត្តន្តបិដក

ធម្មបទគាថា ធម្មដ្ឋវគ្គទី ១៩

[២៩] បុគ្គលកាត់សេចក្តីដោយអាក្រក់ ដោយហេតុណា ឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ ដោយហេតុនោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិតកាត់សេចក្តីទាំង ២ គឺសេចក្តីពិត និងសេចក្តីមិនពិត ណែនាំជនទាំងឡាយដទៃ ដោយមិនអាក្រក់ ដោយសារធម៌តាមសមគួរ (ដល់ទោស) បុគ្គលនោះ ឈ្មោះថា ជាអ្នកមានប្រាជ្ញារក្សាធម៌ ទើបហៅថា តាំងនៅក្នុងធម៌ ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុនណា ឈ្មោះថា ជាបណ្ឌិត ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលដែលមានសេចក្តីក្សេម មិនមានពៀរ មិនមានភ័យ ទើបហៅថា បណ្ឌិតបាន ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុនណា ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ស្តាប់ពុទ្ធវចនៈ សូម្បីមានប្រមាណតិច ហើយឃើញធម៌ដោយនាមកាយ គឺចិត្តបាន បុគ្គលនោះ ទើបឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ បុគ្គលណា មិនមើលងាយធម៌ បុគ្គលនោះឯង ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ។

បុគ្គលមានក្បាលស្កូវហើយ ដោយហេតុណា ឈ្មោះថា ជាថេរៈ ដោយនោះ មិនទាន់បានទេ វ័យរបស់បុគ្គលនោះចាស់ជ្រុលហើយ ហៅថា ចាស់ជាមោឃៈ ។ លុះត្រាតែសច្ចៈផង ធម៌ផង ការមិនបៀតបៀនផង ការ

សង្រ្គមផង ការទូន្មានខ្លួនផង មានក្នុងបុគ្គលណា បុគ្គលនោះឯង ជាអ្នកមានមន្ទិលខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថា ថេរៈ ។

បុគ្គលមានសេចក្តីប្រុងប្រយ័ត្ន មានសេចក្តីកំណាញ់ ជាអ្នកអួតអាង ឈ្មោះថា ជាមនុស្សល្អ ដោយហេតុត្រឹមតែធ្វើការនិយាយពាក្យ (ល្អ) ឬ ដោយភាពជាអ្នកមានសម្បុរជាទីគាប់ចិត្ត ក៏មិនទាន់បានទេ ។

លុះត្រាតែទោសជាត មានប្រុងប្រយ័ត្នជាដើមនេះ បុគ្គលណាបានផ្តាច់ផ្តិលដកឡើង ធ្វើឲ្យមានប្រុងប្រយ័ត្នគាប់ជាច់ហើយ បុគ្គលនោះជាអ្នកមានទោសខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថា ជាមនុស្សល្អបាន ។ បុគ្គលមិនបានឈ្មោះថា ជាសមណៈ ដោយភាពជាអ្នកមានក្បាលត្រងោលទេ បុគ្គលអ្នកមិនមានសីលវត្ត និងធុតង្គវត្ត ពោលតែពាក្យឡេះឡោះ ប្រកបដោយសេចក្តីប្រាថ្នា និងលោភៈ ឈ្មោះថា ជាសមណៈដូចម្តេចបាន ។ លុះត្រាតែបុគ្គលណា រម្ងាប់បាបទាំងឡាយ ទាំងតូច ទាំងធំ ដោយប្រការទាំងពួងបាន ទើបហៅថា សមណៈ ព្រោះបាបទាំងឡាយ ដែលបុគ្គលនោះរម្ងាប់បានហើយ ។

បុគ្គលណា ដើរសូមជនទាំងឡាយដទៃ ដោយហេតុត្រឹមណា បុគ្គលនោះ មិនបានឈ្មោះថា ជាភិក្ខុ ដោយហេតុត្រឹមនោះទេ បុគ្គលសមាទានធម៌ជាពិស ឈ្មោះថា ជាភិក្ខុ ដោយហេតុត្រឹមតែការដើរសូមប៉ុណ្ណោះ មិនទាន់បានទេ ។ លុះត្រាតែបុគ្គលណា ក្នុងលោក បន្សាត់បុណ្យ និងបាបចេញហើយ ជាអ្នកមានការប្រព្រឹត្តដ៏ប្រសើរ ត្រាច់ទៅក្នុងលោក ដោយសេចក្តី

ចេះដឹង បុគ្គលនោះឯង ទើបហៅថា ជាភិក្ខុ ។

បុគ្គលមានសេចក្តីវង្វេង ជាធម្មតា មិនមានការចេះដឹង មិនបានឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិត កាន់យកធម៌ដ៏ប្រសើរ រៀរចាកបាបទាំងឡាយ ដូចបុគ្គលកាន់ជញ្ជីង ហើយថ្លឹងដូច្នោះ បុគ្គលនោះ ទើបឈ្មោះថា ជាមុនី ដោយភាពជាអ្នកស្ងៀមនោះបាន បុគ្គលណា ដឹងប្រយោជន៍ទាំង ២ ក្នុងលោក បុគ្គលនោះ ហៅថា មុនី ដោយហេតុនោះ ។

បុគ្គលបៀតបៀនសត្វទាំងឡាយ ដោយហេតុណា មិនបានឈ្មោះថា ជាអរិយៈ ដោយហេតុនោះទេ បុគ្គលដែលតថាគតហៅថា អរិយៈ ព្រោះមិនបៀតបៀនសត្វទាំងពួង ។

ម្នាលភិក្ខុ បើភិក្ខុមិនទាន់ដល់នូវការអស់អាសវៈទេ កុំអាលទុកចិត្ត ដោយគុណត្រឹមតែសីល និងវត្ត ឬដោយភាពជាអ្នកចេះដឹងច្រើនឡើយ មួយទៀត ដោយការបានសមាធិ ឬដោយការដេកក្នុងទីស្ងាត់ ឬក៏ដោយគុណ មានប្រមាណប៉ុណ្ណោះថា អាត្មាអញពាល់ត្រូវនេក្ខម្មសុខ ដែលបុថុជ្ជនមិនដែលជួបប្រសព្វ ដូច្នេះឡើយ ។

ធម្មដ្ឋវគ្គទី ១៩ ចប់

អដ្ឋកថា

ធម្មដ្ឋវគ្គទី ១៩

រឿង មហាមាត្យអ្នកវិនិច្ឆ័យក្តី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមហាមាត្យអ្នកវិនិច្ឆ័យ ត្រាស់ព្រះធម្មទេសនានេះថា **ន តេន ហោតិ ធម្មដ្ឋោ** *ជាដើម ។*

សេចក្តីពិស្តារ ថ្ងៃមួយ ពួកភិក្ខុត្រាច់បិណ្ឌបាតក្នុងស្រុកក្បែរទ្វារទិសឧត្តរនៃនគរសាវត្ថី ត្រឡប់អំពីបិណ្ឌបាតហើយ មកកាន់វិហារកាត់តាមត្រង់កណ្តាលព្រះនគរ ខណៈនោះ ពពកខ្មៅធំតាំងឡើង ញាំងភ្លៀងឲ្យធ្លាក់ហើយ ។ ភិក្ខុទាំងនោះ ចូលទៅកាន់សាលាសម្រាប់វិនិច្ឆ័យក្តី ដែលតាំងនៅចំពោះមុខ ឃើញពួកមហាមាត្យ ដែលវិនិច្ឆ័យទទួលសំណូកហើយ ធ្វើម្ចាស់ទ្រព្យមិនឲ្យជាម្ចាស់ទ្រព្យ ទើបគិតថា ឱ ! អមាត្យទាំងនេះមិនតាំងនៅក្នុងធម៌ តែពួកយើងមានសេចក្តីសម្គាល់ថា មហាមាត្យទាំងនេះធ្វើការវិនិច្ឆ័យដោយធម៌ កាលភ្លៀងរាំងហើយ មកដល់វិហារ ថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងទីបំផុត នាចំណែកម្ខាងហើយ ក្រាបទូលសេចក្តីនោះ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអមាត្យអ្នកវិនិច្ឆ័យ ជាអ្នកធ្លាក់នៅក្នុងអំណាចអគតិ មានឆន្ទាគតិជាដើម សម្រេចសេចក្តីដោយ

រួសរាន់ មិនឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ ចំណែកពួកដែលសាកសួរនូវកំហុសហើយ កាត់ក្តី ដោយភាពល្អិតល្អន់តាមសមគួរដល់កំហុសនោះឯង ជាបុគ្គលឈ្មោះថាតាំងនៅក្នុងធម៌ ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

ន តេន ហោតិ ធម្មដ្ឋោ យេនត្ថំ សហសា នយេ
យោ ច អត្ថំ អនត្ថញ្ច ឧភោ និច្ឆេយ្យ បណ្ឌិតោ ។
អសាហសេន ធម្មេន សមេន នយតី បរេ
ធម្មស្ស គុត្តោ មេធាវី ធម្មដ្ឋោតិ បវុច្ចតិ ។

បុគ្គលកាត់សេចក្តីដោយអាក្រក់ ដោយសារហេតុណា ឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ ដោយហេតុនោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិត កាត់សេចក្តីទាំងពីរ គឺ សេចក្តីពិត និងសេចក្តីមិនពិត ណែនាំជនទាំងឡាយដទៃ ដោយមិនអាក្រក់ ដោយសារធម៌តាមសមគួរ (ដល់ទោស) បុគ្គលនោះ ឈ្មោះថា ជាអ្នកមានប្រាជ្ញារក្សាធម៌ ទើបហៅថា អ្នកតាំងនៅក្នុងធម៌ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **តេន** *ប្រែថា ព្រោះហេតុត្រឹមតែប៉ុណ្ណោះឯង ។ បទថា* **ធម្មដ្ឋោ** *សេចក្តីថា បុគ្គលតាំងនៅក្នុងធម៌ ជាគ្រឿងវិនិច្ឆ័យដែលស្តេចផែនដីទាំងឡាយគប្បីធ្វើដោយព្រះអង្គ មិនជាបុគ្គល ឈ្មោះថា*

តាំងនៅក្នុងធម៌ទ្បើយ ។ បទថា **យេន** ប្រែថា ព្រោះហេតុណា ។

បទថា **អត្ថំ** សេចក្តីថា នូវក្តីដែលឈមចុះហើយ ដែលគួរសម្រេច ។

ពីរបទថា **សហសា ឆយេ** សេចក្តីថា បុគ្គលតាំងនៅក្នុងអគតិ មានឆន្ទាគតិជាដើម សម្រេចក្តីដោយប្រញាប់ប្រញាល់ គឺដោយពោលកុហក ។ អធិប្បាយថា ពិតហើយ បុគ្គលណា តាំងនៅក្នុងការពេញចិត្ត ពោលមុសាវាទ រមែងធ្វើញាតិ ឬមិត្របស់ខ្លួន ដែលមិនមែនម្ចាស់ទ្រព្យនោះឯង ឲ្យជាម្ចាស់ទ្រព្យ តាំងនៅក្នុងការថ្លឹងថ្លែងពោលកុហក រមែងធ្វើបុគ្គលដែលជាសត្រូវរបស់ខ្លួនដែលជាម្ចាស់របស់ មិនឲ្យជាម្ចាស់របស់ តាំងនៅក្នុងសេចក្តីវង្វេង ទទួលសំណូកហើយ ក្នុងកាលកាត់សេចក្តី ធ្វើហាក់ដូចជាបញ្ជូនចិត្តទៅក្នុងទីដទៃ សម្លឹងមើលខាងនោះខាងនេះ ពោលកុហក តែងនាំបុគ្គលដទៃចេញដោយពាក្យថា បុគ្គលនេះ ឈ្នះ បុគ្គលនេះ ចាញ់ តាំងនៅក្នុងការខ្ចាច រមែងលើកនូវការឈ្នះឲ្យបុគ្គលជាធំ បុគ្គលខ្លះនោះឯងឲ្យដល់នូវការចាញ់ បុគ្គលនេះ ឈ្មោះថា នាំក្តីទៅដោយប្រញាប់ប្រញាល់ បុគ្គលនោះ មិនឈ្មោះថា តាំងនៅក្នុងធម៌ ។

បាទព្រះគាថាថា **យោ ច អត្ថំ អនត្ថញ្ច** សេចក្តីថា នូវហេតុដែលពិត និងមិនពិត ។ ពីរបទថា **ឧភោ និច្ឆេយ្យ** សេចក្តីថា ចំណែកបុគ្គលណា ជាបណ្ឌិត វិនិច្ឆ័យហេតុដែលជាក្តី និងមិនមែនជាក្តីទាំងពីរហើយ រមែងពោល ។

បទថា **អសាហសេន** គឺ ដោយមិនពោលកុហក ។ បទថា **ធម្មេន** ប្រែថា ដោយធម៌ជាគ្រឿងវិនិច្ឆ័យ គឺមិនប្រើដោយអំណាចអគតិ មានឆន្ទាគតិ

ជាដើមឡើយ ។ បទថា **សមេន** *គឺរមែងនាំបុគ្គលពួកដទៃទៅ គឺឲ្យដល់នូវការឈ្នះ ឬការចាញ់ ដោយសមគួរដល់កំហុសនោះឯង ។*

ពីរបទថា **ធម្មស្ស គុត្តោ** *សេចក្តីថា បុគ្គលនោះ ដែលធម៌រក្សាគ្រប់គ្រងហើយ គឺដែលធម៌រក្សាហើយ ប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ ឈ្មោះថាមានបញ្ញា ព្រះដ៏មានព្រះភាគត្រាស់ថា បុគ្គលតាំងនៅក្នុងធម៌ ព្រោះជាអ្នកតាំងនៅក្នុងធម៌ជាគ្រឿងវិនិច្ឆ័យ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង មហាមាត្យអ្នកវិនិច្ឆ័យក្តី ចប់

រឿង ឆព្វគ្គិយភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកឆព្វគ្គិយភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា **ន តេន បណ្ឌិតោ ហោតិ** *ជាដើម ។*

បានឮថា ភិក្ខុទាំងនោះ ធ្វើវោងភត្តឲ្យកខ្វក់ក្នុងវត្តខ្លះ ក្នុងស្រុកខ្លះ ។ សម័យមួយ ភិក្ខុទាំងឡាយសួរភិក្ខុកំលោះ និងសាមណេរដែលធ្វើភត្តកិច្ចក្នុងស្រុកហើយមកថា អាវុសោ វោងភត្តដូចម្តេច ភិក្ខុកំលោះ និងសាមណេរឆ្លើយថា បពិត្រលោកម្ចាស់ កុំសួរឡើយ ពួកឆព្វគ្គិយភិក្ខុពោលថា ពួកយើងជា

អ្នកឈ្លាស ពួកយើងជាបណ្ឌិត នឹងប្រហារកិកូទាំងនេះ រោយសំរាមត្រង់សីសៈ ហើយនាំចេញទៅ ហើយចាប់ខ្នងពួកខ្ញុំរោយសំរាម ក្នុងរោងកគ្គឲ្យកខ្វក់ ។ កិកូទាំងឡាយ ទៅកាន់សម្នាក់ព្រះសាស្តាហើយ ក្រាបទូលរឿងនោះ ។

ព្រះសាស្តាត្រាស់ថា ម្នាលកិកូទាំងឡាយ តថាគតមិនហៅបុគ្គលដែលច្រើនដោយការបៀតបៀនថាជាបណ្ឌិតឡើយ តែតថាគតហៅបុគ្គលដែលមានការក្សេម មិនមានពៀរ មិនមានភ័យថា ជាបណ្ឌិត ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ន តេន បណ្ឌិតោ ហោតិ យាវតា ពហុ ភាសតិ
ខេមី អវេរ អភយោ បណ្ឌិតោតិ បវុច្ចតិ ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុនណា ឈ្មោះថា ជាបណ្ឌិត ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលដែលមានសេចក្តីក្សេម មិនមានពៀរ មិនមានភ័យ ទើបហៅថា បណ្ឌិតបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យាវតា** *ជាដើម សេចក្តីថា បុគ្គលមិនឈ្មោះថា ជាបណ្ឌិត ព្រោះហេតុដែលនិយាយច្រើនក្នុងជំនុំសង្ឃជាដើមឡើយ ចំណែកបុគ្គលណា ខ្លួនឯងជាបុគ្គលមានសេចក្តីក្សេម ឈ្មោះថា មិនមានពៀរ ព្រោះពៀរ ៥ មិនមាន ជាអ្នកមិនមានភ័យ គឺភ័យរមែងមិនមានដល់មហាជន ព្រោះអាស្រ័យបុគ្គលនោះ បុគ្គលនោះ ឈ្មោះថា ជាបណ្ឌិត*

ដូច្នេះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ធព្ធត្ថិយភិក្ខុ

រឿង ព្រះឃកុធានត្ថេរ
លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះខីណាស្រពឈ្មោះឯកុទានត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ន តាវតា ធម្មធរោ** ជាដើម ។

បានឲ្យថា ព្រះថេរៈនោះនៅក្នុងដងព្រៃមួយកន្លែង តែមួយអង្គឯង ខទានតែមួយ ១ ប៉ុណ្ណោះថា

សេចក្តីសោកទាំងឡាយ រមែងមិនមានដល់បុគ្គលដែលមាន
ចិត្តមាំទាំ មិនប្រមាទ ជាមុនី សិក្សាក្នុងផ្លូវនៃមោនបដិបត្តិ ជា
អ្នកមិនញាប់ញ័រ ស្ងប់រម្ងាប់ហើយ មានសតិសព្វកាល ។

បានឲ្យថា ក្នុងថ្ងៃខបោសថ លោកប្រកាសការស្តាប់ធម៌ រមែងពោលគាថានេះ ។ សំឡេងទេវតាសាធុការ ដូចសំឡេងផែនដីស្រុត ។ ខបោសថថ្ងៃមួយ ភិក្ខុទ្រទ្រង់បិដក ២ រូប មានបរិវារមួយរូប ៥០០ បានទៅលំនៅរបស់លោក គ្រាន់តែឃើញភិក្ខុនោះប៉ុណ្ណោះ ក៏មានចិត្តត្រេកអរ ពោលថា

លោកម្ចាស់ទាំងឡាយ និមន្តមកទីនេះជាការល្អហើយ ថ្ងៃនេះ ពួកខ្ញុំនឹងស្តាប់ធម៌ក្នុងសម្នាក់របស់លោកម្ចាស់ទាំងឡាយ ។ ពួកភិក្ខុពោលថា អាវុសោ មនុស្សស្តាប់ធម៌ក្នុងទីនេះ មានឬ ព្រះឯកុទានពោលថា មាន លោកម្ចាស់ ជងព្រៃនេះ មានសំឡេងទេវតាឲ្យសាធុការរំពងព្រៃ ក្នុងថ្ងៃស្តាប់ធម៌ ។

បណ្តាភិក្ខុ ២ រូបនោះ ព្រះថេរៈទ្រទ្រង់ព្រះត្រៃបិដក មួយអង្គសូត្រធម៌ មួយអង្គពោលធម៌ ទេវតាមួយអង្គក៏មិនបានឲ្យសាធុការ ទើបភិក្ខុទាំងនោះ ពោលថា អាវុសោ លោកពោលថា ក្នុងថ្ងៃស្តាប់ធម៌ពួកទេវតាក្នុងជងព្រៃនេះ តែងឲ្យសាធុការដោយសំឡេងខ្លាំង ចុះថ្ងៃនេះដូចម្តេច ព្រះឯកុទានពោលថា ក្នុងថ្ងៃដទៃៗ យ៉ាងនោះ តែថ្ងៃនេះ ខ្ញុំមិនដឹងថា មានរឿងអ្វីឡើយ ពួកភិក្ខុ ពោលថា អាវុសោ បើយ៉ាងនោះ ចូរលោកពោលធម៌ចុះ ។

ព្រះថេរៈចាប់ផ្តើតវាលវិជនី អង្គុយលើអាសនៈហើយ ពោលគាថានោះ ឯង ទេវតាទាំងឡាយបានឲ្យសាធុការដោយសំឡេងខ្លាំង ។ គ្រានោះ ភិក្ខុដែលជាបរិវារព្រះថេរៈទាំងពីរលើកទោសថា ទេវតាក្នុងព្រៃនេះ ឲ្យសាធុការដោយយល់មុខ កាលភិក្ខុទ្រទ្រង់បិដកពោលប្រមាណប៉ុណ្ណោះ ក៏មិនពោលត្រឹមតែការសរសើរ កាលព្រះថេរៈមួយអង្គពោលគាថាមួយហើយ នាំគ្នាឲ្យសាធុការដោយសំឡេងដ៏ខ្លាំង ។ ភិក្ខុទាំងនោះទៅដល់វិហារហើយ ក្រាបទូលសេចក្តីនោះដល់ព្រះសាស្តា ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនហៅអ្នករៀនច្រើន ឬនិយាយច្រើនថាជាអ្នកទ្រទ្រង់ធម៌ ចំណែកបុគ្គលណា រៀនគាថាសូម្បីតែ

មួយ ហើយចាក់ផ្ទុះនូវសច្ចៈទាំង៤ឡាយ បុគ្គលនោះឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ន តាវតា ធម្មធរោ យាវតា ពហុ ភាសតិ
យោ ច អប្បម្បិ សុត្វា ន ធម្មំ កាយេន បស្សតិ
ស វេ ធម្មធរោ ហោតិ យោ ធម្មំ ន ប្បមជ្ជតិ ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុនណា ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ស្តាប់ពុទ្ធវចនៈ សូម្បីមានប្រមាណតិច ហើយឃើញធម៌ដោយនាមកាយ គឺចិត្តបានបុគ្គលនោះ ទើបឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ បុគ្គលណា មិនមើលងាយធម៌ បុគ្គលនោះឯង ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យាវតា** *ជាដើម សេចក្តីថា បុគ្គលមិនឈ្មោះថា ទ្រទ្រង់ធម៌ ព្រោះហេតុដែលពោលច្រើន ដោយហេតុមានការរៀន និងការទ្រទ្រង់ចាំ និងប្រាប់ជាដើម តែឈ្មោះថាតាមរក្សាវង្សរក្សាប្រពៃណី ។*

បទថា **អប្បម្បិ** *ជាដើម សេចក្តីថា ចំណែកបុគ្គលណាស្តាប់ធម៌មានប្រមាណតិច អាស្រ័យធម្ម អាស្រ័យអត្ថ ជាអ្នកបដិបត្តិធម៌សមគួរដល់ធម៌ កំណត់ដឹងសច្ចៈ មានទុក្ខជាដើម ឈ្មោះថា រមែងឃើញសច្ចធម៌ ៤ ដោយនាមកាយ បុគ្គលនោះឯង ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ។*

ជាទព្រះគាថាថា **យោ ធម្មំ នប្បមជ្ជតិ** សេចក្តីថា បុគ្គលណាជាអ្នក មានសេចក្តីព្យាយាមប្រារព្ធហើយ ទន្ទឹងនូវការចាក់ធ្លុះថា អញនឹងចាក់ធ្លុះក្នុងថ្ងៃនេះឯង ឈ្មោះថា រមែងមិនប្រមាទក្នុងធម៌ បុគ្គលនេះ ឈ្មោះថា ទ្រទ្រង់នូវធម៌ដូចគ្នា ។

ក្នុងកាលចប់ទេសនា មហាជនជានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះឃកុធានត្ថេរ ចប់

រឿង ព្រះលកុណ្ឌកភទ្ទិយត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះលកុណ្ឌក-ភទ្ទិយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ន តេន ថេរោ ហោតិ** ជាដើម ។

សេចក្តីពិស្តារ ថ្ងៃមួយ កាលព្រះថេរៈនោះទៅកាន់ទីបម្រើព្រះសាស្តា លុះចៀសចេញទៅហើយ ភិក្ខុនៅព្រៃប្រមាណ ៣០ រូប ក៏យើញលោក រួចមកថ្វាយបង្គំព្រះសាស្តា ហើយអង្គុយ ។ ព្រះសាស្តាទ្រង់ទតយើញឧបនិស្សយ អរហត្តរបស់ភិក្ខុទាំងនោះហើយ ត្រាស់សួរបញ្ហានេះថា ព្រះថេរៈមួយអង្គ ចេញអំពីទីនេះ តើពួកអ្នកយើញដែរឬទេ ពួកភិក្ខុទូលថា បពិត្រព្រះអង្គ មិនយើញទេ ព្រះសាស្តាត្រាស់ថា ពួកអ្នកយើញព្រះថេរៈនោះមិនមែនឬ ពួកភិក្ខុ

ក្រាបទូលថា បពិត្រព្រះអង្គ ឃើញសាមណេរមួយរូប ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នុ៎ះមិនមែនសាមណេរទេ នុ៎ះជាព្រះថេរៈ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ ព្រះថេរៈនោះតូចពេក ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនហៅថា ថេរៈ ព្រោះភាពជាបុគ្គលចាស់ ព្រោះហេតុគ្រាន់តែអង្គុយលើអាសនៈនៃថេរៈទេ ឯបុគ្គលណា ចាក់ផ្តុំនូវសច្ចៈទាំងឡាយ ហើយតាំងនៅក្នុងភាពជាបុគ្គលមិនបៀតបៀនមហាជន បុគ្គលនេះ ឈ្មោះថា ព្រះថេរៈ ដូច្នេះហើយ ជាន ត្រាស់ព្រះគាថានេះថា

ន តេន ថេរោ ហោតិ យេនស្ស បលិតំ សិរោ
បរិបក្កោ វយោ តស្ស មោឃជិណ្ណោតិ វុច្ចតិ ។
យម្ហិ សច្চញ្ច ធម្មោ ច អហិំសា សញ្ញមោ ទមោ
ស វេ វន្តមលោ ធីរោ សោ ថេរោតិ បវុច្ចតិ ។

បុគ្គលមានក្បាលស្កូវហើយ ដោយហេតុណា ឈ្មោះថា ជាថេរៈ ដោយហេតុនោះមិនទាន់បានទេ វ័យរបស់បុគ្គលនោះចាស់ជ្រុលហើយ ហៅថា ចាស់ជាមោឃៈ ។ លុះត្រាតែសច្ចៈផង ធម៌ផង ការមិនបៀតបៀនផង ការសង្រួមផង ការទូន្មានខ្លួនផង មានក្នុងបុគ្គលណា បុគ្គលនោះឯង ជាអ្នកមានមន្ទិលខ្ចាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថា ថេរៈ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បរិបក្កោ** សេចក្តីថា ដែលជរាបង្អោនទៅជុំវិញហើយ គឺដល់នូវភាពជាបុគ្គលចាស់ហើយ ។ បទថា **មោឃជិណ្ណោ** សេចក្តីថា ឈ្មោះថា ចាស់ទេ ព្រោះខាងក្នុងមិនមានធម៌ ជាគ្រឿងធ្វើឲ្យជាថេរៈ ។ បទថា **សច្ចវ្ហោ** សេចក្តីថា បុគ្គលណាមានសច្ចៈទាំង ៤ ព្រោះភាពជាអ្នកចាក់ធ្លុះដោយអាការ ១៦ និងមានលោកុត្តរធម៌ ៩ យ៉ាង ព្រោះភាពជាបុគ្គលធ្វើឲ្យជាក់ច្បាស់ដោយញាណ ។

ពាក្យថា **អហឹសា** នោះ គ្រាន់តែជាមាតិកានៃទេសនា អធិប្បាយថា អប្បមញ្ញាភាវនា ៤ យ៉ាង មានក្នុងបុគ្គលណា ។ ពីរបទថា **សញ្ញមោ ទមោ** បានដល់ សីល និងឥន្ទ្រិយសំវរៈ ។ បទថា **វន្តមលោ** គឺមានមន្ទិលដែលនាំចេញហើយដោយមគ្គញាណ ។ បទថា **ធីរោ** គឺសម្បូរដោយបញ្ញាជាគ្រឿងទ្រទ្រង់ចាំ ។ បទថា **ថេរោ** សេចក្តីថា បុគ្គលនោះ ព្រះមានព្រះភាគត្រាស់ថាថេរៈ ព្រោះជាអ្នកប្រកបដោយធម៌ ជាគ្រឿងធ្វើនូវភាពមាំទាំទាំងនេះ ។

ចប់ទេសនា ភិក្ខុទាំងនោះ តាំងនៅក្នុងអរហត្តហើយដូច្នេះ ។

រឿងព្រះលកុណ្ឌកភទ្ទិយត្ថេរ ចប់

រឿង ភិក្ខុច្រើនរូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **ន រាក្ការណមត្តេន** ជាដើម ។

សេចក្តីពិស្តារ សម័យមួយ ព្រះថេរៈពួកខ្លះ យើញភិក្ខុកំលោះ និងសាមណេរធ្វើការបម្រើទាំងឡាយ មានជ្រលក់ចីវរដល់អាចារ្យជាដើម ដែលប្រាប់ធម៌របស់ខ្លួននោះឯង គិតថា សូម្បីអញក៏ឈ្លាសក្នុងលទ្ធិព្យញ្ជនៈ ផលណាមួយមិនមានដល់អញទ្បើយ បើដូច្នោះ អញគប្បីចូលគាល់ព្រះសាស្តាទូលយ៉ាងនេះថា បពិត្រព្រះអង្ត ពួកខ្ញុំព្រះអង្តជាអ្នកឈ្លាសក្នុងលទ្ធិព្យញ្ជនៈ សូមទ្រង់ប្រាប់ភិក្ខុកំលោះ និងសាមណេរទាំងឡាយថា ចូរពួកអ្នករៀនធម៌ក្នុងសម្នាក់របស់អាចារ្យដទៃហើយ បើមិនទាន់សាកសួរក្នុងសម្នាក់របស់ភិក្ខុទាំងនេះហើយកុំស្វាធ្យាយ លាភសក្ការៈនឹងចម្រើនដល់អ្នកទាំងឡាយដោយអាការយ៉ាងនេះឯង ព្រះថេរៈទាំងនោះ ចូលទៅគាល់ព្រះសាស្តាហើយ ក្រាបទូលយ៉ាងនោះ ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ទ្រង់ជ្រាបថា បុគ្គលណាម្នាក់ពោលយ៉ាងនោះបាន ដោយអំណាចប្រពៃណីក្នុងសាសនានេះប៉ុណ្ណោះ តែភិក្ខុទាំងនេះអាស្រ័យលាភសក្ការៈ ទើបត្រាស់ថា តថាគតមិនហៅពួកអ្នកថាជាបុគ្គលល្អ ព្រោះហេតុត្រឹមតែនិយាយ ចំណែកបុគ្គលណាកាត់បង់នូវធម៌ មានច្រណែនជាដើមទាំងនេះបានហើយ ដោយអរហត្តមគ្ត បុគ្គលនោះឯង ឈ្មោះថាជាមនុស្សល្អ ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

ន វាក្ករណមត្តេន　　វណ្ណោទោក្ករតាយ វា
សាធុរូបោ នរោ ហោតិ　　ឥស្សុកី មច្ឆរី សឋោ ។
យស្ស ចេតំ សមុច្ឆិន្នំ　　មូលឃច្ចំ សមូហតំ
ស វន្តទោសោ មេធាវី　　សាធុរូបោតិ វុច្ចតិ ។

បុគ្គលមានសេចក្តីឫស្យា មានសេចក្តីកំណាញ់ ជាអ្នកអួតអាង ឈ្មោះថា ជាមនុស្សល្អដោយហេតុត្រឹមតែធ្វើការនិយាយពាក្យ (ល្អ) ឬដោយភាពជាអ្នកមានសម្បុរជាទីគាប់ចិត្ត ក៏មិនទាន់បានទេ លុះត្រាតែទោសជាតមានឫស្យាជាដើមនោះ បុគ្គលណាផ្តាច់ផ្តិលដកឡើង ធ្វើឲ្យមានឫសគាល់ជាច់ហើយ បុគ្គលនោះ ជាអ្នកមានទោសខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថា ជាមនុស្សល្អបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ន វាក្ករណមត្តេន** *សេចក្តីថា ព្រោះហេតុត្រឹមតែធ្វើការនិយាយ គឺត្រឹមតែពាក្យដែលដល់ព្រមដោយលក្ខណៈ ។ បទថា* **វណ្ណោទោក្ករតាយ វា** *គឺព្រោះភាពជាអ្នកញុំាងចិត្តឲ្យឆ្អែតដោយមានសរីរៈសម្បុរដោយពណ៌សម្បុរ ។ បទថា* **ឥរោ** *ជាដើម សេចក្តីថា នរៈមិនមានចិត្តប្រណែនព្រោះលាភអ្នកដទៃជាដើម ប្រកបដោយសេចក្តីកំណាញ់ ៥ យ៉ាង ឈ្មោះថា ជាអ្នកអួតអាង ព្រោះគប់រកធម៌ខាងសត្រូវ និងឈ្មោះថា*

បុគ្គលល្អ ព្រោះហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ ។

ពីរបទថា **យស្ស ឯតំ** *ជាដើម សេចក្តីថា ចំណែកបុគ្គលណាកាត់នូវទោសជាត មានការច្រណែនជាដើម បានជាសមុច្ឆេទហើយ ដោយអរហត្ត-មគ្គញ្ញាណជកខ្សែង ធ្វើឲ្យជាច់ឫសគាល់ហើយ បុគ្គលនោះ មានទោសខ្ជាក់ចោលហើយ ប្រកបដោយបញ្ញាជ៏រុងរឿងក្នុងធម៌ ព្រះមានព្រះភាគត្រាស់ថា ជាបុគ្គលល្អ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ភិក្ខុច្រើនរូប ចប់

រឿង ភិក្ខុឈ្មោះ ហាត្ថកៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុឈ្មោះហត្ថកៈ ត្រាស់ព្រះធម្មទេសនានេះថា **ន មុណ្ឌកេន សមណោ** *ជាដើម ។*

បានឮថា ភិក្ខុនោះនិយាយអួតពោលថា លោកទាំងឡាយគប្បីទៅកាន់ទីឈ្មោះនោះ ក្នុងកាលនោះយើងនឹងធ្វើវាទៈ ហើយទៅក្នុងទីនោះមុន ពោលពាក្យទាំងឡាយជាដើមថា មើលចុះលោកទាំងឡាយ ពួកតិរ្ថិយមិនមក ព្រោះខ្លាចខ្ញុំ នេះឯងជាការចាញ់របស់ពួកតិរ្ថិយទាំងនោះ ដើរពោលអួតទៅ

បិទបាំងពាក្យដទៃដោយពាក្យដទៃ ។

ព្រះសាស្តាទ្រង់ឮថា ភិក្ខុឈ្មោះហត្ថក:ធ្វើយ៉ាងនោះ ហើយត្រាស់ឲ្យហៅលោកមកសួរថា ហត្ថក: បានឮថា អ្នកធ្វើយ៉ាងនោះពិតឬ កាលលោកក្រាបទូលថា បពិត្រព្រះអង្គ ពិតមែន ទើបត្រាស់ថា ព្រោះហេតុអ្វី ទើបអ្នកធ្វើយ៉ាងនោះ ព្រោះថា បុគ្គលធ្វើមុសាវាទបែបនោះ និងឈ្មោះថាជាសមណ: ព្រោះហេតុត្រឹមតែមានក្បាលត្រងោលជាដើមប៉ុណ្ណោះក៏ទេ ចំណែកបុគ្គលណាញ៉ាំងបាបតូច និងបាបធំ ឲ្យស្ងប់ហើយ តាំងនៅ បុគ្គលនោះឯង ឈ្មោះថាសមណ: ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

ន មុណ្ឌកេន សមណោ　　អព្វតោ អលិកំ ភណំ
ឥច្ឆាលោភសមាបន្នោ　　សមណោ កឹ ភវិស្សតិ ។
យោ ច សមេតិ បាបានិ　　អណុំថូលានិ សព្វសោ
សមិតត្តា ហិ បាបានំ　　សមណោតិ បវុច្ចតិ ។

បុគ្គលមិនបានឈ្មោះថាជាសមណ: ព្រោះភាពជាអ្នកមានក្បាលត្រងោលទេ បុគ្គលអ្នកមិនមានសីលវត្ត និងធុតង្គវត្ត ពោលតែពាក្យឡេះឡោះ ប្រកបដោយសេចក្តីប្រាថ្នា និងលោភ: ឈ្មោះថា ជាសមណ:ដូចម្តេចបាន ។ លុះត្រាតែបុគ្គលណារម្ងាប់បាបទាំងឡាយ ទាំងតូចទាំងធំដោយប្រការទាំងពួងបាន ទើបហៅថាសមណ: ព្រោះបាបទាំងឡាយ ដែលបុគ្គលនោះរម្ងាប់បានហើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មុណ្ឌកេន** *សេចក្តីថា ព្រោះហេតុត្រឹមតែកប្បាលត្រងោល ។ បទថា* **អព្ភតោ** *គឺរៀរចាកសីលវត្ត និងធុតង្គវត្ត ។ ពីរបទថា* **អលិកំ ភណាំ** *សេចក្តីថា បុគ្គលពោលមុសាវាទ ប្រកបដោយការចង់បានក្នុងអារម្មណ៍ដែលមិនទាន់មកដល់ និងដោយចំណង់ក្នុងអារម្មណ៍ដែលមកដល់ហើយ ឈ្មោះថាជាសមណៈដូចម្តេចបាន ។ បទថា* **សមេតិ** *សេចក្តីថា ចំណែកបុគ្គលណា ញុំាងបាបតូច ឬបាបធំឲ្យស្ងប់ បុគ្គលនោះ ព្រះសាស្តាត្រាស់ថា ជាសមណៈ ព្រោះញុំាងបាបទាំងនោះឲ្យស្ងប់ហើយ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ភិក្ខុឈ្មោះហត្ថកៈ ចប់

រឿង ព្រាហ្មណ៍ម្នាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ន តេន ភិក្ខុ សោ ហោតិ** *ជាដើម ។*

បានឮថា ព្រាហ្មណ៍នោះបួសក្នុងលទ្ធិខាងក្រៅ ត្រាច់ភិក្ខា គិតថា ព្រះសមណគោតម ហៅសាវ័កបស់ខ្លួនដែលត្រាច់ភិក្ខាថា ភិក្ខុ ការដែលព្រះសមណគោតមហៅអញថា ភិក្ខុ ក៏គួរ ។ គាត់ចូលទៅរកព្រះសាស្តាទូលថា

បពិត្រព្រះគោតម ខ្ញុំក៏ត្រាច់កិក្ខាចិញ្ចឹមជីវិត សូមទ្រង់ហៅខ្ញុំថា ភិក្ខុ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រាហ្មណ៍នោះថា ម្នាលព្រាហ្មណ៍ តថាគតមិនហៅថាភិក្ខុព្រោះត្រឹមតែសូមគេនោះឡើយ ព្រោះបុគ្គលសមាទានធម៌ដែលជាពិសហើយប្រព្រឹត្ត ឈ្មោះថាជាភិក្ខុមិនបានឡើយ ឯបុគ្គលណាប្រព្រឹត្តទៅដោយពិចារណាសង្វារទាំងពួង បុគ្គលនោះឈ្មោះថាជាភិក្ខុ ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

ន តេន ភិក្ខុ សោ ហោតិ យាវតា ភិក្ខតេ បរេ
វិសំ ធម្មំ សមាទាយ ភិក្ខុ ហោតិ ន តាវតា ។
យោធ បុញ្ញញ្ច បាបញ្ច ពាហេត្វា ព្រហ្មចរិយវា
សង្ខាយ លោកេ ចរតិ ស វេ ភិក្ខូតិ វុច្ចតិ ។

បុគ្គលណា ដើរសូមជនទាំងឡាយដទៃ ដោយហេតុត្រឹមណា បុគ្គលនោះ មិនបានឈ្មោះថាជាភិក្ខុ ដោយហេតុត្រឹមនោះទេ បុគ្គលសមាទានធម៌ជាពិស ឈ្មោះថា ជាភិក្ខុ ដោយហេតុត្រឹមតែការដើរសូមប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ក្នុងលោកនេះ បន្សាត់បុណ្យ និងបាបចេញ ហើយជាអ្នកមានការប្រព្រឹត្តដ៏ប្រសើរ ត្រាច់ទៅក្នុងលោក ដោយសេចក្តីចេះដឹង បុគ្គលនោះឯង ទើបហៅថា ជាភិក្ខុ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យាវតា** *សេចក្តីថា ឈ្មោះថាជាភិក្ខុ ព្រោះ*

ហេតុត្រឹមតែសូមនឹងជនពួកជទៃក៏មិនមែន ។ បទថា **ទិសំ** *ជាដើម សេចក្តីថា បុគ្គលដែលសមាទានធម៌មិនស្មើ ឬធម៌ មានកាយកម្មជាដើម ដែលមានក្លិនជាពិសកំពុងប្រព្រឹត្ត មិនទាន់ឈ្មោះថាជាភិក្ខុឡើយ ។ បទថា* **យោធ** *ជាដើម សេចក្តីថា បុគ្គលណាក្នុងសាសនានេះ បន្សាត់ គឺបន្ទោបង់នូវបុណ្យ និងបាបទាំងពីរនេះដោយមគ្គព្រហ្មចរិយៈ ឈ្មោះថា ជាអ្នកប្រព្រឹត្តព្រហ្មចរិយៈ ។ បទថា* **សង្ខាយ** *គឺដោយញាណ ។ បទថា* **លោកេ** *ជាដើម សេចក្តីថា បុគ្គលជឹងធម៌ទាំងអស់ក្នុងលោក មានខន្ធលោកជាដើមយ៉ាងនេះថា ខន្ធទាំងនេះ ជាខាងក្នុង ខន្ធទាំងនេះ ជាខាងក្រៅ ត្រាច់ទៅ បុគ្គលនោះ ព្រះសាស្តាត្រាស់ហៅថា ភិក្ខុ ព្រោះជាអ្នកទម្លាយកិលេសទាំងឡាយ ដោយញាណនោះហើយ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រាហ្មណ៍ម្នាក់ ចប់

រឿង តិត្តិរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកតិត្តិរ ត្រាស់ព្រះធម្មទេសនានេះថា **ន មោនេន** *ជាដើម ។*

បានឮថា ពួកតិរ្ថិយទាំងនោះ ធ្វើអនុមោទនាដល់ពួកមនុស្សក្នុងទីដែលខ្ជិនបរិភោគហើយ ពោលមង្គលដោយនយជាដើមថា សេចក្តីក្សេមចូរមាន សេចក្តីសុខចូរមាន អាយុចូរចម្រើន ក្នុងទីឈ្មោះនោះ មានភក់ ក្នុងទីឈ្មោះនោះ មានបន្ទា ការទៅក្នុងទីបែបនោះ មិនគួរ ហើយចៀសចេញទៅ ។ ក្នុងបឋមពោធិកាល កាលដែលព្រះសាស្តាទ្រង់មិនទាន់អនុញ្ញាត អនុមោទនាវិធីជាដើម ភិក្ខុទាំងឡាយក៏មិនធ្វើអនុមោទនាដល់ពួកមនុស្សក្នុងរោងភត្តឡើយ រមែងចៀសចេញទៅ ។ ពួកមនុស្សលើកទោសថា ពួកយើងបានស្តាប់មង្គលអំពីសម្នាក់របស់តិរ្ថិយទាំងឡាយ តែលោកម្ចាស់ទាំងឡាយនៅស្ងៀមចៀសចេញទៅហើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះ ដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តាំងអំពីនេះទៅ ចូរអ្នកទាំងឡាយធ្វើអនុមោទនាក្នុងទីទាំងឡាយ មានរោងភត្តជាដើម តាមសប្បាយចុះ ចូរពោលឧបនិសិន្នកថាចុះ ភិក្ខុទាំងនោះធ្វើយ៉ាងនោះហើយ ។

ពួកមនុស្សស្តាប់អនុមោទនាវិធីជាដើម ដល់នូវឧស្សាហ៍ហើយ និមន្តភិក្ខុទាំងឡាយធ្វើសក្ការៈ ។ ពួកតិរ្ថិយពោលទោសថា ពួកយើងជាមុនីធ្វើនូវភាពជាអ្នកស្ងៀម ពួកសាវ័កបស់ព្រះសមណគោតម ត្រាច់ពោលកថាច្រើនក្នុងទីទាំងឡាយ មានរោងភត្តជាដើម ។

ព្រះសាស្តាទ្រង់ស្តាប់សេចក្តីនោះត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលថាមុនី ដោយហេតុគ្រាន់តែជាអ្នកស្ងៀម ព្រោះបុគ្គលពួកខ្លះមិនដឹង

រមែងមិននិយាយ ពួកខ្លះមិននិយាយព្រោះភាពដែលខ្លួនមិនក្លៀវក្លា ពួកខ្លះមិនពោលព្រោះកំណាញ់ថា ជនពួកដទៃកុំបីដឹងអត្ថដ៏ក្រៃលែងនេះរបស់អញឡើយ ព្រោះដូច្នោះ បុគ្គលមិនឈ្មោះថាជាមុនី ព្រោះហេតុត្រឹមតែជាអ្នកស្ងៀម តែឈ្មោះថា ជាមុនី ព្រោះញុំាងបាបឲ្យស្ងប់ ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

ន មោនេន មុនិ ហោតិ មូឡ្ហរូបោ អវិទ្ទសុ
យោ ច តុលំវ បគ្គយ្ហ វរមាទាយ បណ្ឌិតោ ។
បាបានិ បរិវជ្ជេតិ ស មុនិ តេន សោ មុនិ
យោ មុនាតិ ឧភោ លោកេ មុនិ តេន បវុច្ចតិ ។

បុគ្គលមានសេចក្តីវង្វេងជាធម្មតា មិនមានការចេះដឹង មិនបានឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមទេ លុះត្រាតែបុគ្គលណាជាបណ្ឌិត កាន់យកធម៌ដ៏ប្រសើរ រៀរចាកបាបទាំងឡាយ ដូចបុគ្គលកាន់ជញ្ជីង ហើយថ្លឹងដូច្នោះ ទើបបុគ្គលនោះ ឈ្មោះថា ជាមុនី ដោយភាពជាអ្នកស្ងៀមនោះបាន បុគ្គលណា ដឹងប្រយោជន៍ទាំងពីរក្នុងលោក បុគ្គលនោះ ហៅថា មុនី ដោយហេតុនោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ន មោនេន** *សេចក្តីថា បុគ្គលឈ្មោះថាជាមុនី ព្រោះមោនៈ គឺមគ្គញ្ញាណ ពោល គឺបដិបទាដែលជាមុនីក៏ពិត ។ តែ*

ក្នុងព្រះគាថានេះ ព្រះសាស្តាត្រាស់ថា **មោនេន** *សំដៅយកភាពជាអ្នកស្ងៀម ។ បទថា* **មុទ្ធប្បរោ** *គឺជាអ្នកទទេ ។*

បទថា **អវិទ្ទសុ** *គឺមិនដឹងដោយប្រក្រតី អធិប្បាយថា បុគ្គលបែបនោះ សូម្បីជាអ្នកស្ងៀម ក៏មិនឈ្មោះថាជាមុនី ម្យ៉ាងទៀត មិនឈ្មោះថាមោនេយ្យមុនី តែជាបុគ្គលទទេជាសភាវៈ និងមិនដឹងដោយប្រក្រតី ។*

ជាទព្រះគាថាថា **យោ ច តុលំវ បគ្គយ្ហ** *សេចក្តីថា ដូចបុគ្គលឈរកាន់ជញ្ជីង បើរបស់ច្រើនពេកក៏នាំយកចេញ បើរបស់តិចក៏បន្ថែមចូល យ៉ាងណា បុគ្គលណានាំចេញ ឈ្មោះថាវៀរនូវបាប ដូចបុគ្គលយករបស់ដែលច្រើនចេញ បំពេញកុសល ដូចបុគ្គលបន្ថែមរបស់ដែលតិចចូលដូច្នោះដូចគ្នា កាលបើធ្វើយ៉ាងនោះ ឈ្មោះថាកាន់យកធម៌ដ៏ប្រសើរ គឺឧត្តមនោះឯង ពោល គឺសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ វៀរបង់នូវបាប គឺកម្មដែលជាអកុសលទាំងឡាយ ។ ពីរបទថា* **ស មុនិ** *សេចក្តីថា បុគ្គលនោះឈ្មោះថាជាមុនី ។ ច្រើនបទថា* **តេន សោ មុនិ** *សេចក្តីថា បើមានពាក្យសួរជ្រៀតចូលមកថា ព្រោះហេតុអ្វី ទើបបុគ្គលនោះឈ្មោះថាជាមុនី ត្រូវឆ្លើយថា បុគ្គលនោះ ជាមុនី ព្រោះហេតុដែលពោលហើយខាងដើម ។*

ជាទព្រះគាថាថា **យោ មុនាតិ ឧភោ លោកេ** *សេចក្តីថា បុគ្គលណាដឹងអត្តទាំងពីរនេះក្នុងលោក មានខន្ធលោកជាដើមនេះ ដោយនយជាដើមថា ខន្ធទាំងនេះជាខាងក្នុង ខន្ធទាំងនេះជាខាងក្រៅ ដូចបុគ្គលលើកជញ្ជីងឡើងថ្លឹងជូច្នោះ ។ ច្រើនបទថា* **មុនិ តេន បវុច្ចតិ** *សេចក្តីថា បុគ្គលនោះ ព្រះដ៏មាន*

ព្រះភាគហៅថាជាមុនី ព្រោះហេតុនោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ត្ថិរិយ ចប់

រឿង ព្រាហ្មណសន្ទុចឈ្មោះ អរិយៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណសន្ទុចម្នាក់ ឈ្មោះអរិយៈ ត្រាស់ព្រះធម្មទេសនានេះថា **ន តេន អរិយោ ហោតិ** *ជាដើម ។*

សេចក្តីពិស្តារ ថ្ងៃមួយ ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យនៃសោតា-បត្តិមគ្គរបស់អរិយៈនោះ ទ្រង់យាងបិណ្ឌបាតក្នុងស្រុក តាមទ្វារទិសខាងជើង នៃក្រុងសាវត្ថី ដែលភិក្ខុសង្ឃចោមរោម យាងមកអំពីស្រុកនោះ ។ ខណៈនោះអ្នកសូចត្រី សូចត្រីដោយសន្ទុច ឃើញភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន បានចុះដងសន្ទុចចោលឈរហើយ ។

ព្រះសាស្តា យាងត្រឡប់ ប្រថាប់ឈរមិនឆ្ងាយអំពីព្រាហ្មណសន្ទុចនោះ ត្រាស់សួរឈ្មោះរបស់សាវ័កទាំងឡាយ មានព្រះសារីបុត្តជាដើមថា អ្នកឈ្មោះអ្វី អ្នកឈ្មោះអ្វី សាវ័កទាំងនោះក៏ក្រាបទូលឈ្មោះរបស់ខ្លួនថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឈ្មោះសារីបុត្ត បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឈ្មោះមោគ្គល្លាន

ជាដើម ។ ព្រោនសន្ទូចគិតថា ព្រះសាស្តាត្រាស់សួរឈ្មោះសាវ័កគ្រប់អង្គ
ម្តេចក៏មិនត្រាស់សួរឈ្មោះរបស់អញផង ។

ព្រះសាស្តាទ្រង់ជ្រាបសេចក្តីប្រាថ្នារបស់ព្រោនសន្ទូចនោះ ទើបត្រាស់សួរ
ថា នែអ្នក តើអ្នកឈ្មោះអ្វី កាលបុរសនោះក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំ
ព្រះអង្គឈ្មោះអរិយៈ ទើបត្រាស់ថា នែអ្នក បុគ្គលដែលសម្លាប់សត្វដូចអ្នក
មិនឈ្មោះថាអរិយៈទេ្តយ ចំណែកបុគ្គលដែលតាំងនៅក្នុងការមិនបៀតបៀន
មហាជន ទើបឈ្មោះថា អរិយៈ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ន តេន អរិយោ ហោតិ យេន ចាណានិ ហឹសតិ
អហឹសា សព្វចាណានំ អរិយោតិ បវុច្ចតិ ។

បុគ្គលបៀតបៀនសត្វទាំងឡាយ ដោយហេតុណា មិនបាន
ឈ្មោះថា ជាអរិយៈ ដោយហេតុនោះទេ បុគ្គលដែល
តថាគតហៅថាអរិយៈ ព្រោះមិនបៀតបៀនសត្វទាំងពួង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អហឹសា** សេចក្តីថា ព្រោះមិនបៀតបៀន ។
មានអធិប្បាយដូច្នេះថា បុគ្គលមិនឈ្មោះថាអរិយៈ ព្រោះហេតុដែល
បៀតបៀនសត្វទាំងឡាយ ចំណែកបុគ្គលណាតាំងនៅឆ្ងាយចាកការបៀតបៀន
ព្រោះមិនបៀតបៀនសត្វទាំងពួងដោយជាតដៃជាដើម គឺព្រោះភាពដែលខ្លួន
តាំងនៅហើយ ក្នុងមេត្តាការុណាជាដើម បុគ្គលនេះ ព្រះសាស្តាត្រាស់ហៅ
ថា អរិយៈ ។

ក្នុងកាលចប់ទេសនា ព្រោនសន្ធូច តាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង ព្រោនសន្ធូចឈ្មោះអរិយៈ ចប់

រឿង ភិក្ខុច្រើនរូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនរូបដែលដល់ព្រមដោយគុណ មានសីលជាដើម ត្រាស់ព្រះធម្មទេសនានេះថា **ន សីលព្វតមត្តេន** *ជាដើម ។*

បានឮថា បណ្តាភិក្ខុទាំងនោះ ពួកខ្លះមានការគិតយ៉ាងនេះថា ពួកយើងមានសីលបរិបូណ៌ហើយ ពួកយើងទ្រទ្រង់នូវធុតង្គ ពួកយើងជាពហុស្សូត ពួកយើងនៅក្នុងសេនាសនៈស្ងាត់ ពួកយើងបានឈាន អរហត្ត ពួកយើងបានមិនលំបាក ពួកយើងនឹងសម្រេចអរហត្តក្នុងថ្ងៃដែលពួកយើងត្រូវការនោះឯង បណ្តាភិក្ខុទាំងនោះ ភិក្ខុដែលជាអនាគាមីគិតយ៉ាងនេះថា ឥឡូវនេះ អរហត្ត ពួកយើងបានមិនលំបាក ។ ថ្ងៃមួយ ភិក្ខុទាំងអស់ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ កាលព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ កិច្ចនៃបព្វជិតរបស់ពួកអ្នកដល់ទីបំផុតហើយឬ ក៏ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គបែបនេះ បែបនេះ ព្រោះដូច្នោះ ទើបពួកខ្ញុំព្រះអង្គគិតថា

ពួកយើងអាចសម្រេចអរហត្ត ក្នុងខណៈដែលច្រូច្ចាហើយនោះឯង ដូច្នេះ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ភិក្ខុ ទោះយើញថាទុក្ខក្នុងកពរបស់ពួកយើងតិចតួច ដោយគុណត្រឹមតែភាពជាអ្នកមានសីលបរិសុទ្ធជាដើម ឬដោយគុណត្រឹមតែសេចក្តីសុខរបស់ព្រះអនាគាមី មិនគួរ បើមិនទាន់ដល់នូវការអស់អាសវៈ មិនគប្បីឲ្យនូវការគិតកើតឡើងថា អញដល់សេចក្តីសុខហើយ ទើបត្រាស់ព្រះគាថានេះថា

ន សីលព្វតមត្តេន ពាហុសច្ចេន វា បន
អថវា សមាធិលាភេន វិវិត្តសយនេន វា ។
ផុសាមិ នេក្ខម្មសុខំ អបុថុជ្ជនសេវិតំ
ភិក្ខុ វិស្សាសមាចាធិ អប្បត្តោ អាសវក្ខយំ ។

ម្នាលភិក្ខុ បើភិក្ខុមិនទាន់ដល់នូវការអស់អាសវៈទេ កុំអាលទុកចិត្តដោយគុណត្រឹមតែសីល និងវត្ត ឬដោយភាពជាអ្នកចេះដឹងច្រើនឡើយ មួយទៀត ដោយការបានសមាធិ ឬក៏ដោយការដេកក្នុងទីស្ងាត់ ឬក៏ដោយគុណ មានប្រមាណប៉ុណ្ណោះថា អាត្មាអញពាល់ត្រូវនេក្ខម្មសុខ ដែលបុថុជ្ជនមិនដែលជួបប្រសព្វ ដូច្នេះឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សីលព្វតមេត្តេន** *គឺដោយហេតុត្រឹមតែបារិសុទ្ធិសីល ៤ ឬធុតង្គគុណ ១៣ ។*

បទថា **ពាហុសច្ចេន វា** *សេចក្តីថា ឬដោយហេតុត្រឹមតែភាពជាបុគ្គលរៀនបិដក ៣ ។*

បទថា **សមាធិលាភេន** *សេចក្តីថា ឬដោយការបានសមាបត្តិ ៨ ។*

បទថា **នេក្ខម្មសុខំ** *គឺសុខរបស់ព្រះអនាគាមី ព្រោះដូច្នោះ ភិក្ខុកុំដល់នូវការទុកចិត្ត ដោយហេតុមានប្រមាណត្រឹមតែជើងប៉ុណ្ណោះថា អញពាល់ត្រូវសុខរបស់ព្រះអនាគាមី ។*

បទថា **អបុថុជ្ជនសេវិតំ** *សេចក្តីថា ដែលបុថុជ្ជនទាំងឡាយសេពមិនបាន គឺដែលព្រះអរិយៈសេពហើយតែម្យ៉ាង ។ ភិក្ខុទាំងនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សាកសួរភិក្ខុរូបណាមួយអង្គ ក៏ត្រាស់ថា ភិក្ខុ ។*

បទថា **វិស្សាសមាបាទិ** *សេចក្តីថា កុំដល់នូវការទុកចិត្ត មានពាក្យអធិប្បាយដូច្នេះថា ភិក្ខុ ឈ្មោះថា ជាអ្នកដែលមិនសម្រេចអរហត្ត ពោលគឺការអស់ទៅនៃអាសវៈ មិនគប្បីទុកចិត្តថា កពរបស់អញតិចតួច ដោយហេតុត្រឹមតែភាពជាអ្នកមានគុណ មានសីលបរិបូណ៌ជាដើមប៉ុណ្ណោះ ដូចលាមក សូម្បីមានប្រមាណតិច ក៏នៅតែមានក្លិនស្អុយ យ៉ាងណា កពមានប្រមាណតិច ក៏ជាហេតុឲ្យកើតទុក្ខ ដូច្នោះ ។*

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះតាំងនៅក្នុងអរហត្តហើយ ។ ទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយដូច្នេះ ៕

រឿងភិក្ខុច្រើនរូប ចប់

ធម្មដ្ឋវគ្គទី ១៩ ចប់

សុត្តន្តបិដក

ធម្មបទគាថា មគ្គវគ្គទី ២០

[៣០] ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ បទ ៤ គឺអរិយ-
សច្ច ប្រសើរជាងសច្ចៈទាំងឡាយ វិរាគធម៌ប្រសើរជាងធម៌ទាំងឡាយ មួយ
ទៀត ព្រះតថាគតមានចក្ខុ ប្រសើរជាងសត្វទ្វេបាទទាំងឡាយ ផ្លូវនេះឯង
ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃទស្សនៈ ផ្លូវដទៃមិនមានទេ ។

ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរដើរទៅកាន់ផ្លូវនោះ ផ្លូវនេះជាផ្លូវ
ញុំាងមារឲ្យវង្វេង អ្នកទាំងឡាយដើរទៅកាន់ផ្លូវនេះហើយ អាចនឹងធ្វើឲ្យផុត
ទុក្ខបាន ។ ផ្លូវនេះហើយ ដែលតថាគតដឹងថា ជាផ្លូវកម្ចាត់បង់កូនសរ ប្រាប់
ដល់អ្នកទាំងឡាយ សេចក្តីព្យាយាម ញុំាងកិលេសឲ្យក្តៅសព្វ អ្នកទាំង-
ឡាយគប្បីធ្វើ ព្រះតថាគតទាំងឡាយ គ្រាន់តែជាអ្នកប្រាប់ ជនទាំងឡាយ
មានការពិនិត្យ បើបានដើរទៅហើយ នឹងរួចចាកចំណងរបស់មារបាន ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនទៀង
ដូច្នេះ កាលនោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តី
បរិសុទ្ធ ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង នាំមក
នូវសេចក្តីទុក្ខ ដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះ
ជាផ្លូវនៃសេចក្តីបរិសុទ្ធ ។ កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា ធម៌
ទាំងពួង មិនមែនជារបស់ខ្លួនដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុង
សេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

បុគ្គលនៅកំលោះមានកម្លាំង ទាស់តែប្រកបដោយសេចក្តីខ្ជិលច្រអូស មិនប្រឹងប្រែង ក្នុងកាលដែលគួរប្រឹងប្រែង មានសេចក្តីត្រិះរិះក្នុងចិត្តលិចចុះ ក្នុងអកុសលវិតក្ក ជាមនុស្សខ្ជិល បុគ្គលខ្ជិល (នោះ) រមែងមិនបានផ្លូវបញ្ញាឡើយ ។

បុគ្គលគប្បីជាអ្នករក្សាវាចា សង្រួមឲ្យល្អ ដោយចិត្ត ទាំងមិនគប្បីធ្វើអកុសលដោយកាយ បុគ្គលគប្បីជម្រះកម្មបថទាំង ៣ នេះ និងគប្បីត្រេកអរចំពោះមគ្គ ដែលលោកអ្នកស្វែងរកគុណដ៏ល្អ សម្តែងទុកហើយ ។

ប្រាជ្ញា រមែងកើតអំពីការប្រកប សេចក្តីវិនាសប្រាជ្ញា រមែងកើតអំពីការមិនប្រកប អ្នកមានប្រាជ្ញា ដឹងការប្រកប និងការមិនប្រកបទាំង ២ នេះថា ជាគន្ថៈនៃសេចក្តីចម្រើន និងសេចក្តីវិនាសហើយ ប្រាជ្ញាចម្រើនឡើងដោយប្រការណា គួរតម្កល់ខ្លួនទុក ដោយប្រការនោះ ។

អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃចេញ ចូរកុំកាត់ដើមឈើ (ព្រោះ) ភ័យកើតអំពីកិលេសដូចជាព្រៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ ចូរកាត់កិលេសដូចជាព្រៃផង កិលេសដូចជាដើមឈើដុះក្នុងព្រៃផង ហើយចូរជាអ្នកកុំមានកិលេស ដូចជាព្រៃឡើយ ព្រោះថា កិលេសដូចដើមឈើដុះក្នុងព្រៃរបស់នរជន សូម្បីមានប្រមាណតិចក៏ដោយ បើកាត់មិនជាប់ក្នុងពួកនារីដរាបណា នរជននោះឯង តែងមានចិត្តជាប់ចំពោះក្នុងពួកនារីដូចកូនគោនៅកំពុងបៅដោះ ដែលមានចិត្តជាប់នៅនឹងមេ ដរាបនោះ ។

អ្នកចូរដកសេចក្តីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គលដកផ្កាកុមុទៈ ដែលកើត

ក្នុងសរទកាលដោយដៃ អ្នកចូរបណ្តុះនូវផ្លូវសន្តិភាពតែម្យ៉ាង ព្រះនិព្វាន ព្រះសុគតសម្តែងទុកហើយ ។

អញនឹងនៅក្នុងទីនេះអស់វស្សានរដូវ អញនឹងនៅក្នុងទីនេះក្នុងហេមន្ត-រដូវ និងគិម្ហរដូវ ជនពាល រមែងគិតខុសដូច្នេះ តែងមិនដឹងច្បាស់សេចក្តីអន្តរាយឡើយ ។

មច្ចុ គឺសេចក្តីស្លាប់តែងនាំយកនរជន អ្នកប្រឹងជ្រុប ក្នុងកូន និងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗ នោះ ដូចជំនន់ទឹកធំនាំយកអ្នកស្រុកកំពុងដេកលក់ ។

កាលបុគ្គល ត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយ មិនមានដើម្បីជាទីពឹង បិតា ក៏មិនមាន ទាំងផៅពង្ស ក៏មិនមាន ដើម្បីជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ ជម្រះផ្លូវ ជាទីទៅកាន់ព្រះនិព្វានឲ្យបាន ។

មគ្គវគ្គទី ២០ ចប់

អដ្ឋកថា

មគ្គវគ្គទី ២០

រឿង ភិក្ខុ ៥០០ រូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ ៥០០ រូប ត្រាស់ព្រះធម្មទេសនានេះថា **មគ្គានដ្ឋង្គិកោ** ជាដើម ។

បានឮមកថា ភិក្ខុទាំងនោះ កាលព្រះសាស្តាចារិកទៅក្នុងជនបទ ហើយយាងមកកាន់ក្រុងសាវត្ថីទៀត អង្គុយក្នុងរោងដែលជាទីបម្រើ ពោលមគ្គកថា ប្រារព្ធផ្លូវដែលខ្លួនត្រាច់ទៅហើយ ដោយនយជាដើមថា ផ្លូវនៃស្រុកនោះ ទៅស្រុកនោះ រាបស្មើល្អ ផ្លូវនៃស្រុកនោះ ទៅស្រុកនោះ មិនរាបស្មើ មានក្រួស មិនមានក្រួស ។

ព្រះសាស្តា ទ្រង់ឃើញឧបនិស្ស័យនៃអរហត្តរបស់ភិក្ខុទាំងនោះ យាងមកកាន់ទីនោះហើយ ប្រថាប់គង់លើអាសនៈដែលគេក្រាល ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផ្លូវដែលពួកអ្នកនិយាយដល់នេះ ជាផ្លូវខាងក្រៅ ធម្មតាភិក្ខុធ្វើកម្មក្នុងអរិយមគ្គ ទើបគួរ ព្រោះថា ភិក្ខុកាលធ្វើយ៉ាងនោះ រមែងផុតចាកទុក្ខ

ទាំងពួងបាន ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

មគ្គានដ្ឋង្គិកោ សេដ្ឋោ	សច្ចានំ ចតុរោ បទា
វិរាគោ សេដ្ឋោ ធម្មានំ	ទ្វិបទានញ្ច ចក្ខុមា
ឯសេវ មគ្គោ នត្ថញ្ញោ	ទស្សនស្ស វិសុទ្ធិយា ។
ឯតញ្ហិ តុម្ហេ បដិបជ្ជថ	មារស្សេតំ បមោហនំ
ឯតញ្ហិ តុម្ហេ បដិបន្នា	ទុក្ខស្សន្តំ ករិស្សថ ។
អក្ខាតោ វោ មយា មគ្គោ	អញ្ញាយ សល្យសត្តនំ
តុម្ហេហិ កិច្ចំ អាតប្បំ	អក្ខាតារោ តថាគតា
បដិបន្នា បមោក្ខន្តិ	ឈាយិនោ មារពន្ធនា ។

ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ បទ ៤ គឺ អរិយសច្ច ប្រសើរជាងសច្ចៈទាំងឡាយ វិរាគធម៌ ប្រសើរជាងធម៌ទាំងឡាយ មួយទៀត ព្រះតថាគត មានចក្ខុ ប្រសើរជាងសត្វទ្វេបាទទាំងឡាយ ផ្លូវនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃទស្សនៈ ផ្លូវដទៃមិនមានទេ ។ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរដើរទៅកាន់ផ្លូវនោះ ផ្លូវនេះជាផ្លូវញុំាងមារឲ្យវង្វេង អ្នកទាំងឡាយដើរទៅកាន់ផ្លូវនោះហើយ អាចនឹងធ្វើឲ្យផុតទុក្ខបាន ។ ផ្លូវនេះហើយ ដែលតថាគតដឹងថា ជាផ្លូវកម្ចាត់បង់កូនសរ ប្រាប់ដល់អ្នកទាំងឡាយ សេចក្តីព្យាយាមញុំាងកិលេសឲ្យក្តៅសព្វ អ្នក

ទាំងឡាយគប្បីធ្វើ ព្រះតថាគតទាំងឡាយ គ្រាន់តែជាអ្នក ប្រាប់ ជនទាំងឡាយមានការពិនិត្យ បើបានដើរទៅហើយ នឹងរួចចាកចំណងរបស់មារបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មគ្គានដ្ឋង្គិកោ** *សេចក្តីថា ផ្លូវទាំងឡាយ ជាផ្លូវទៅដោយស្មង់ជាដើមក្តី ជាផ្លូវនៃទិដ្ឋិ ៦២ ក្តី បណ្តាផ្លូវទាំងអស់ ផ្លូវមាន អង្គ ៨ ដែលធ្វើការលះបង់នូវផ្លូវ ៨ មានមិច្ឆាទិដ្ឋិជាដើម ដោយអង្គ ៨ មាន សម្មាទិដ្ឋិជាដើម ។ ធ្វើនិរោធឲ្យជាអារម្មណ៍ ញុំាងកិច្ច មានការកំណត់ដឹងទុក្ខ ជាដើម ក្នុងសច្ចៈទាំង ៤ ឲ្យសម្រេច ប្រសើរ គឺកំពូល ។*

បាទព្រះគាថាថា **សច្চានំ ចតុរោ បទា** *សេចក្តីថា បណ្តាសច្ចៈទាំងអស់ នេះ ចូរជាវចីសច្ចដែលមកហើយក្នុងបាលីថា បុគ្គលគប្បីពោលពាក្យសច្ចៈ មិនគប្បីក្រោធជាដើមក្តី ជាសម្មតិសច្ច មានសច្ចៈជាដើមថា ជាព្រាហ្មណ៍ ពិត ជាក្សត្រពិតក្តី ជាទិដ្ឋិសច្ច ដោយនយថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃ ទៀតជាដើមក្តី ជាបរមត្ថសច្ច មានសច្ចៈជាដើមថា ទុក្ខជារបស់ពិតដ៏ប្រសើរ ក្តី ៤ បទ មានបទថា ទុក្ខជារបស់ពិតដ៏ប្រសើរជាដើម ឈ្មោះថា ប្រសើរ ព្រោះអត្ថថា ទុក្ខ ដែលព្រះយោគាវចរគួរកំណត់ដឹង ព្រោះអត្ថថា សមុទយៈ ដែលព្រះយោគាវចរគួរលះ ព្រោះអត្ថថា និរោធ ដែលព្រះយោគាវចរគួរធ្វើ ឲ្យជាក់ច្បាស់ ព្រោះអត្ថថា មគ្គមានអង្គ ៨ ដែលព្រះយោគាវចរគួរចម្រើន ព្រោះអត្ថថា ចាក់ធ្លុះបានដោយញាណនោះឯង ព្រោះអត្ថថា ចាក់ធ្លុះបាន*

ដោយពិតប្រាកដ ។

បាទព្រះគាថាថា **វិវាគោ សេដ្ឋោ ធម្មានំ** *សេចក្តីថា បណ្តាធម៌ទាំងពួង វិវគៈ ពោល គឺព្រះនិព្វានឈ្មោះថាប្រសើរ ព្រោះព្រះពុទ្ធវចនៈថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដែលបច្ច័យតាក់តែងក្តី ដែលបច្ច័យមិនតាក់តែងក្តី មានប្រមាណត្រឹមណា បណ្តាធម៌ទាំងនោះ វិវគៈ តថាគតពោលថាជាកំពូល ។*

បាទព្រះគាថាថា **ឯបទានញ្ច ចក្ខុមា** *សេចក្តីថា បណ្តាសត្វជើងពីរ មានទេវតា និងមនុស្សជាដើម ព្រះតថាគតមានចក្ខុ ៥ ប្រការប៉ុណ្ណោះ ប្រសើរ ។ ច សព្ទ មានការប្រមូលមកជាអត្ថ រមែងប្រមូលយកអរូបធម៌ទាំងឡាយផង ព្រោះដូច្នោះ បណ្តាអរូបធម៌ទាំងឡាយ ព្រះតថាគតក៏ជាបុគ្គលប្រសើរ គឺឧត្តម ។*

បាទព្រះគាថាថា **ឧស្សេនស្ស វិសុទ្ធិយា** *សេចក្តីថា ផ្លូវណាដែលតថាគតពោលថា ប្រសើរ ផ្លូវនោះប៉ុណ្ណោះ ដើម្បីសេចក្តីបរិសុទ្ធនៃទស្សនៈ គឺមគ្គនិងផល ផ្លូវដទៃមិនមាន ។*

បទថា **ឯតំ ហិ** *សេចក្តីថា ព្រោះហេតុនោះ ចូរអ្នកទាំងឡាយ ដើរផ្លូវនោះឯង ។*

បទថា **មារស្សេតំ បមោហនំ** *នោះ ព្រះសាស្តារមែងត្រាស់ថា ជាទីដែលមារវង្វេង គឺទីដែលកន្ទងពួកមារ ។*

បទថា **ទុក្ខស្សន្តំ** *សេចក្តីថា អ្នកទាំងឡាយនឹងធ្វើទីបំផុត គឺព្រំដែននៃសេចក្តីទុក្ខក្នុងវដ្តៈទាំងមូលបាន ។*

បទថា **សល្ឡសន្តនំ** *ជាដើម សេចក្តីថា តថាគតវៀរចាកកិច្ចទាំងឡាយ មានការបានស្តាប់អំពីអ្នកដទៃជាដើម ដ៏ងនូវផ្លូវនោះ ដែលជាទីរលាស់ចេញ គឺញាំញី បានដល់ ដកឡើងនូវកូនសរទាំងឡាយ មានរាគៈជាដើមដោយប្រចក្ស ដល់ខ្លួនហើយនោះឯង ទើបប្រាប់ផ្លូវនេះ ។ ឥឡូវនេះ អ្នកទាំងឡាយគប្បីធ្វើ បានដល់ គួរធ្វើសេចក្តីព្យាយាម គឺសម្មប្បធាន ដែលដល់នូវការរាប់ថាជាអាតប្បៈ ព្រោះជាគ្រឿងដុតកិលេសទាំងឡាយ ដើម្បីប្រយោជន៍ដល់ការសម្រេចផ្លូវនោះ ព្រោះព្រះតថាគតទាំងឡាយ ជាអ្នកប្រាប់តែម្យ៉ាង ព្រោះដូច្នោះ ជនទាំងឡាយ ដែលបដិបត្តិហើយ ដោយអំណាចនៃផ្លូវ ដែលព្រះតថាគតទាំងនោះត្រាស់ប្រាប់ហើយ មានប្រក្រតីសម្ងំដោយឈាន ២ យ៉ាង រមែងរួចផុតចាកចំណងនៃមារពោល គឺវដ្តៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។*

ក្នុងកាលចប់ព្រះធម៌ទេសនា ភិក្ខុទាំងនោះ បានតាំងនៅហើយ ក្នុងអរហត្តផល ព្រះធម្មទេសនា បានសម្រេចប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង ភិក្ខុ ៥០០ រូប ចប់

រឿង ភិក្ខុ ៥០០ ជាតៃទៀត

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រោរព្ធភិក្ខុ ៥០០ រូប ត្រាស់ព្រះធម្មទេសនានេះថា **សព្ពេ សង្ខារា** ជាដើម ។

បានឮមកថា ភិក្ខុទាំងនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ សូម្បីព្យាយាមក្នុងព្រៃក៏មិនសម្រេចអរហត្ត ទើបគិតថា ពួកយើងនឹងរៀនកម្មដ្ឋានឲ្យវិសេស ដូច្នេះហើយ បានទៅកាន់សម្នាក់ព្រះសាស្តា ។

ព្រះសាស្តាទ្រង់ពិចារណាថា កម្មដ្ឋានណាហ្ន៎ ជាទីសប្បាយរបស់ភិក្ខុទាំងនេះ ទើបទ្រង់ត្រិះរិះថា ភិក្ខុទាំងនេះ ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សប តាមប្រកបហើយក្នុងអនិច្ចលក្ខណៈអស់ ២ ម៉ឺនឆ្នាំ ព្រោះដូច្នោះ ការសម្តែងគាថាអំពីអនិច្ចលក្ខណៈនោះឯងជល់លោកទាំងឡាយ ត្រឹមតែមួយគាថា គួរដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងពួងក្នុងភពទាំងឡាយ មានកាមភពជាដើម ជាសភាពមិនទៀង ព្រោះអត្ថថា មានហើយ ទៅជាមិនមាន ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

សព្ពេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្ពិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនទៀង ដូច្នេះ កាលណោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សព្ពេ សង្ខារា** *ជាដើម សេចក្តីថា កាលណាបណ្ឌិតយើញដោយវិបស្សនាបញ្ញាថា ខន្ធទាំងឡាយកើតឡើងហើយក្នុងភពទាំងឡាយ មានកាមភពជាដើម ឈ្មោះថា មិនទៀង ព្រោះត្រូវរលត់ក្នុងភពនោះៗ ឯង ។ កាលនោះ រមែងនឿយណាយក្នុងទុក្ខ ដែលទាក់ទងដោយការបរិហារខន្ធនេះ កាលនឿយណាយ រមែងចាក់ធ្លុះសច្ចៈទាំងឡាយដោយអំណាចនៃកិច្ច មានការកំណត់ដឹងទុក្ខជាដើម ។*

បាទព្រះគាថាថា **ឯស មគ្គោ វិសុទ្ធិយា** *សេចក្តីថា ការនឿយណាយក្នុងទុក្ខនោះ ជាផ្លូវនៃសេចក្តីបរិសុទ្ធ គឺផ្លូវនៃសេចក្តីផូរផង់ ។*

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះតាំងនៅក្នុងអរហត្តហើយ ទេសនាបានសម្រេចប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿភិក្ខុ ៥០០ ជនៃទៀត ចប់

ក្នុងព្រះគាថាទីពីរ រឿងក៏ប៉ាងនោះដូចគ្នា ក្នុងកាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបភាពដែលភិក្ខុទាំងនោះ ធ្វើសេចក្តីព្យាយាមក្នុងកាលកំណត់សង្ខារដោយភាពជាទុក្ខហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ខន្ធទាំងពួងជាទុក្ខពិត ព្រោះអត្ថថា ត្រូវទុក្ខគ្របសង្កត់ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

សព្ពេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ
អថនិព្ពិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំង ពួងនាំមកនូវសេចក្តីទុក្ខ ដូច្នេះ កាលណោះ រមែងនឿយ ណាយក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទុក្ខា** *សេចក្តីថា ឈ្មោះថា ជាទុក្ខ ព្រោះអត្ថថា ត្រូវទុក្ខបៀតបៀន ។ បទដ៏សេស ក៏ដូចគ្នានឹងបទមុននោះឯង ។*

រឿកិក្ខុ ៥០០ ជនៃទៀត ចប់

ក្នុងព្រះគាថាទីបី រឿងក៏ប៉ាងនោះដូចគ្នា ។ ក្នុងព្រះគាថាទីបីនេះ ព្រះសាស្តាទ្រង់ជ្រាបភាពដែលភិក្ខុទាំងនោះ ជាអ្នកតាមប្រកបហើយក្នុងការកំណត់សង្ខារ ដោយភាពជាអនត្តា ក្នុងកាលមុនដោយឥតសេសសល់ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ខន្ធទាំងពួងជាអនត្តាពិត ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

សព្ពេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ
អថ និព្ពិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា ធម៌ទាំងពួងមិនមែនជារបស់ខ្លួន ដូច្នេះ កាលណោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **សព្វេ ធម្មា** *ព្រះសាស្តាទ្រង់សម្តែងយក ខន្ធ ៥ នេះឯង ។*

បទថា **អនត្តា** *សេចក្តីថា ឈ្មោះថា អនត្តា គឺទទេ មិនមានម្ចាស់ បានដល់ មិនមានឥស្សរៈ ព្រោះអត្តថា មិនប្រព្រឹត្តទៅក្នុងអំណាច ព្រោះបុគ្គលណាម្នាក់មិនអាចឲ្យប្រព្រឹត្តទៅក្នុងអំណាចថា ធម៌ទាំងពួង ចូរកុំចាស់ ចូរកុំស្លាប់ ។ បទដ៏សេស ដូចគ្នានឹងបទដែលមានហើយក្នុងកាលមុននោះឯង ដូច្នេះ ។*

រឿង ភិក្ខុ ៥០០ ជាតិទៀត ចប់

រឿង បធានកម្មិកតិស្សត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបធានកម្មិកតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ឧដ្ឋានកាលម្ហិ** *ជាដើម ។*

បានឮថា កុលបុត្រអ្នកក្រុងសាវត្ថីប្រមាណ ៥០០ នាក់ បួសក្នុងសម្នាក់ព្រះសាស្តា រៀនកម្មដ្ឋានហើយ បានទៅកាន់ព្រៃ ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុមួយរូបស្នាក់នៅក្នុងទីនោះឯង ។ ភិក្ខុដ៏សេស ធ្វើសមណធម៌ក្នុងព្រៃសម្រេចអរហត្ត គិតថា ពួកយើងនឹងក្រាបទូលគុណដែលខ្លួនបានហើយដល់ព្រះមានព្រះភាគ បានត្រឡប់ទៅកាន់ក្រុងសាវត្ថី ។ ឧបាសកម្នាក់ឃើញភិក្ខុទាំងនោះ

ដែលត្រាច់បិណ្ឌបាតនៅក្នុងស្រុកមួយកន្លែង ក្នុងទីប្រមាណមួយយោជន៍អំពីក្រុងសាវត្ថី ទើបទទួលដោយវត្ថុទាំងឡាយ មានបបរ និងកត្តជាដើម បានស្តាប់អនុមោទនាហើយ ទើបនិមន្តដើម្បីប្រយោជន៍ដល់ការឆាន់ក្នុងថ្ងៃស្អែកឡើង ភិក្ខុទាំងនោះ ទៅដល់ក្រុងសាវត្ថីក្នុងថ្ងៃនោះឯង ទុកជាក់បាត្រ និងចីវរហើយ ក្នុងពេលល្ងាច ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំអង្គុយហើយ ។ ព្រះសាស្តាទ្រង់សម្តែងសេចក្តីត្រេកអរក្រៃលែង ជាមួយភិក្ខុទាំងនោះ ទ្រង់បានធ្វើការទទួលហើយ ។

ខណៈនោះ ភិក្ខុសម្ងាញ់នៃភិក្ខុទាំងនោះ ដែលសល់ក្នុងទីនោះ គិតថា កាលព្រះសាស្តា ទ្រង់ធ្វើការទទួលភិក្ខុទាំងនោះ ព្រះឧស្ម័រមែងមិនគ្រប់គ្រាន់តែមិនត្រាស់ប្រាស្រ័យជាមួយអញឡើយ ព្រោះមគ្គ និងផលរបស់អញមិនមាន ។ ក្នុងថ្ងៃនេះឯង អញសម្រេចអរហត្ត នឹងឲ្យព្រះសាស្តាប្រាស្រ័យជាមួយអញ ភិក្ខុទាំងនោះទូលលាព្រះសាស្តាថា ពួកខ្ញុំព្រះអង្គ កាលឧបាសកម្នាក់ក្នុងផ្លូវដែលជាទីមក និមន្តដើម្បីឆាន់ក្នុងពេលព្រឹកស្អែកនេះ នឹងទៅក្នុងទីនោះអំពីព្រលឹម ។ លំដាប់នោះ ភិក្ខុដែលសម្ងាញ់នៃភិក្ខុទាំងនោះ ដើរចង្រ្កមមួយយប់ទល់ភ្លឺ ជួលចុះត្រង់ផ្ទាំងថ្មមួយផ្ទាំងក្នុងទីបំផុតនៃទីចង្រ្កមដោយអំណាចការដេកលក់ ។ ឆ្អឹងស្មងក៏ជាក់ លោកស្រែកដោយសំឡេងខ្លាំង ។

ពួកភិក្ខុជាសម្ងាញ់ទាំងនោះរបស់លោកចាំសំឡេងបាន សុះចូលទៅក្នុងទីនោះទីនេះ ។ អុជប្រទីបធ្វើកិច្ចដែលគួរធ្វើដល់ភិក្ខុនោះឯង ។ អរុណរះឡើង

ហើយ កិក្ខុទាំងនោះក៏មិនបានឱកាសទៅកាន់ស្រុកនោះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងកិក្ខុទាំងនោះថា ម្នាលកិក្ខុទាំងឡាយ ពួកអ្នកមិនទៅកាន់ស្រុក ដែលត្រាច់កិក្ខាទេឬ កិក្ខុទាំងនោះទទួលថា យ៉ាងនោះឯង ព្រះអង្គ ហើយក្រាបទូលរឿងនោះ ។ ព្រះសាស្តាត្រាស់ថា ម្នាលកិក្ខុទាំងឡាយ កិក្ខុនោះធ្វើអន្តរាយលាភរបស់ពួកអ្នក តែក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ធ្វើហើយដូចគ្នា ។ កាលកិក្ខុទាំងនោះទូលអាពាធនាហើយ ទ្រង់នាំអតីតនិទានមក ត្រាស់ជាតកឲ្យពិស្តារថា

> *អំពើទាំងឡាយ ដែលគេត្រូវធ្វើក្នុងកាលមុន នរណា ប្រាថ្នាធ្វើខាងក្រោយវិញ នរនោះ រមែងក្តៅក្រហាយ រឿយៗ ក្នុងកាលជាខាងក្រោយ ដូចជាមាណពដែលកាច់ ឧសឈើថ្ងាន់ ។*

បានឮថា កិក្ខុទាំងនោះបានជាមាពណ ៥០០ ក្នុងកាលមុន មាណពដែលខ្វិលច្រអូសបានជាកិក្ខុនេះ ចំណែកអាចារ្យបានជាតថាគតដោយប្រការដូច្នេះ ។

ព្រះសាស្តា កាលទ្រង់នាំព្រះទេសនានេះមកហើយត្រាស់ថា ម្នាលកិក្ខុទាំងឡាយ បុគ្គលណាមិនធ្វើការខ្វិឃ្នាត ក្នុងកាលដែលគួរខ្វិឃ្នាត ជាអ្នកមានការត្រិះរិះលិចចុះហើយ ជាបុគ្គលខ្វិលច្រអូស បុគ្គលនោះរមែងមិនសម្រេចគុណវិសេស មានឈានជាដើម ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ យុវា ពលី អាលសិយំ ឧបេតោ
សំសន្នសង្កប្បមនោ កុសីតោ បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ ។

បុគ្គលនៅកំលោះ មានកម្លាំង ទាស់តែប្រកបដោយសេចក្តីខ្ជិលច្រអូស មិនប្រឹងប្រែង ក្នុងកាលដែលគួរប្រឹងប្រែង មានសេចក្តីត្រិះរិះក្នុងចិត្តលិចចុះ ក្នុងអកុសលវិតក្ក ជាមនុស្សខ្ជិល បុគ្គលខ្ជិល (នោះ) រមែងមិនបានផ្លូវបញ្ញាឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អនុដ្ឋហានោ** *សេចក្តីថា មិនប្រឹងប្រែង គឺមិនព្យាយាម ។ ពីរបទថា* **យុវា ពលី** *សេចក្តីថា ជាអ្នកតាំងនៅក្នុងភាពជាកំលោះ ដល់ព្រមដោយកម្លាំង ។ ពីរបទថា* **អាលសិយំ ឧបេតោ** *សេចក្តីថា រមែងជាបុគ្គលចូលដល់ហើយនូវភាពជាអ្នកខ្ជិលច្រអូស គឺស៊ីហើយដេក ដេកហើយស៊ី ។ បទថា* **សំសន្នសង្កប្បមនោ** *សេចក្តីថា បុគ្គលមានចិត្តប្រកបដោយការត្រិះរិះដែលលិចចុះ គឺលិចចុះហើយ ព្រោះមិច្ឆាវិតក្ក ៣ ។ បទថា* **កុសីតោ** *បានដល់ មិនមានសេចក្តីព្យាយាម ។ បទថា* **អលសោ** *សេចក្តីថា បុគ្គលនោះខ្ជិលច្រអូសច្រើន កាលមិនឃើញអរិយមគ្គ គប្បីឃើញដោយបញ្ញា ទើបឈ្មោះថារមែងមិនជួប គឺមិនបាន ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង បធានកម្មិកតិស្សត្ថេរ ចប់

រឿង សូករប្រេត

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសូករប្រេត ត្រាស់ព្រះធម្មទេសនានេះថា **វាចានុរក្ខី** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះមហាមោគ្គល្លាន ចុះអំពីភ្នំគិជ្ឈកូដជាមួយព្រះលក្ខណៈ បានធ្វើការញញឹមក្នុងទីមួយកន្លែង កាលព្រះលក្ខណៈសួរថា អាវុសោ ព្រោះហេតុអ្វីហ្ន៎ ជាហេតុនៃការញញឹមឲ្យច្រើនដង ក៏ពោលថា អាវុសោ កាលនេះមិនមែនជាកាលនៃការសួរបញ្ហានេះ ចូរលោកសួរក្នុងសម្នាក់របស់ព្រះសាស្តា ដូច្នេះហើយ ត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះជាមួយព្រះលក្ខណាត្ថេរនោះឯង ត្រឡប់អំពីបិណ្ឌបាតហើយ ទៅកាន់វត្តវេឡុវ័ន ថ្វាយបង្គំព្រះសាស្តាហើយអង្គុយ ។

គ្រានោះ ព្រះលក្ខណៈសួរសេចក្តីនោះ លោកក៏ពោលថា អាវុសោ ខ្ញុំឃើញប្រេតមួយ សរីរៈរបស់ប្រេតនោះប្រមាណ ៣ គាវុត សរីរៈនោះស្រេជៀងនឹងរាងកាយរបស់មនុស្ស ចំណែកក្បាលដូចក្បាលរបស់ជ្រូក កន្ទុយដុះចេញអំពីមាត់ ពួកដង្កូវហូរចេញអំពីមាត់នោះ ខ្ញុំគិតថា ខ្ញុំមិនធ្លាប់ឃើញសត្វមានរូបយ៉ាងនេះ កាលឃើញប្រេតនោះហើយ ទើបធ្វើការញញឹមឲ្យច្រើនដង ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកសាវ័ករបស់តថាគតមានចក្ខុហ្ន៎ ហើយត្រាស់ថា សូម្បីតថាគតក៏បានឃើញសត្វនោះ ត្រង់មណ្ឌលនៃពោធិព្រឹក្សដូចគ្នា តែមិននិយាយដោយអនុគ្រោះដល់ជនដទៃថា ជនពួកណាមិនគប្បីជឿតថាគត ការមិនជឿនោះ គប្បីមានកម្មដែលមិនជាប្រយោជន៍ដល់

ជនទាំងនោះ ។ ឥឡូវនេះ តថាគតបានមោគ្គល្លានជាសាក្សីទើបពោល ម្នាលភិក្ខុទាំងឡាយ មោគ្គល្លាននិយាយពិត ។

ភិក្ខុទាំងឡាយស្តាប់រឿងនេះហើយ ទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គបុព្វកម្មរបស់ប្រេតនោះដូចម្តេច ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើយ៉ាងនោះ ចូរពួកអ្នកស្តាប់ចុះ ហើយទ្រង់នាំអតីតនិទានមក ត្រាស់បុព្វកម្មរបស់ ប្រេតនោះដូចតទៅនេះ ។

បានញមកថា ក្នុងសាសនារបស់ព្រះពុទ្ធកស្សបៈ ព្រះថេរៈពីររូបព្រមព្រៀងគ្នាក្នុងអាវាសជិតភូមិមួយកន្លែង ។ ក្នុងព្រះថេរៈពីររូបនោះ មួយរូបមានវស្សា ៦០ មួយរូបមានវស្សា ៥៩ ភិក្ខុដែលមានវស្សា ៥៩ នោះកាន់បាត្រនិងចីវររបស់ព្រះថេរៈត្រាច់ទៅ បានធ្វើវត្តបដិបត្តិគ្រប់យ៉ាងដូចសាមណេរ ។ ព្រះថេរៈទាំងពីររូបនៅព្រមព្រៀងគ្នាដូចបងប្អូន ដែលរួមផ្ទៃមាតាតែមួយ ព្រះធម្មកថិកមួយរូប មកកាន់លំនៅរបស់ព្រះថេរៈទាំងពីរហើយ ។ ក្នុងកាលនោះជាថ្ងៃស្តាប់ធម៌ ព្រះថេរៈទាំងពីរសង្ត្រោះព្រះធម្មកថិកហើយពោលថា សប្ឋុរសចូរលោកពោលធម្មកថាដល់ពួកយើងចុះ ព្រះធម្មកថិកនោះ ក៏ពោលធម្មកថាហើយ ព្រះថេរៈទាំងពីរមានចិត្តត្រេកអរថា ពួកយើងបានព្រះធម្មកថិកហើយស្អែកឡើង នាំលោកចូលទៅបិណ្ឌបាតក្បែរស្រុកជិតនោះ ធ្វើភត្តកិច្ចស្រេចក្នុងស្រុកនោះហើយពោលថា អាវុសោ សូមលោកពោលធម្មកថាបន្តិចអំពីទីដែលសម្រាកកាលពីម្សិលមិញ ហើយនិមន្តឲ្យលោកពោលធម៌ដល់ពួកមនុស្សពួកមនុស្សស្តាប់ធម្មកថាហើយ និមន្តឲ្យធាន់ក្នុងថ្ងៃស្អែក ព្រះថេរៈទាំងពីរនាំ

ព្រះធម្មកថិកនោះត្រាច់បិណ្ឌបាតក្នុងស្រុក ដែលជាទីត្រាច់ភិក្ខា ក្នុងស្រុក ២ ឬ ៣ ថ្ងៃដោយជុំវិញយ៉ាងនេះ ។ ព្រះធម្មកថិកគិតថា ព្រះថេរៈពីររូបនេះ ទន់ភ្លន់ក្រៃលែង បើអញឲ្យព្រះថេរៈទាំងពីររូបនេះគេចទៅ ហើយនៅក្នុងវត្តនេះ គួរ ។ ក្នុងថ្ងៃល្ងាច លោកទៅកាន់ទីបម្រើរបស់ព្រះថេរៈ ក្នុងកាលដែលភិក្ខុទាំងពីរក្រោកទៅហើយ ត្រឡប់ចូលទៅរកព្រះមហាថេរៈ ពោលថា បពិត្រលោកម្ចាស់ រឿងខ្លះដែលខ្ញុំគួរពោលមាន កាលព្រះមហាថេរៈពោលថា អាវុសោ ចូរពោលចុះ ភិក្ខុនោះគិតបន្តិចហើយពោលថា បពិត្រលោកម្ចាស់ ឈ្មោះថា ការពោល មានទោសច្រើន មិននិយាយហើយចៀសចេញទៅ ព្រះធម្មកថិកនោះ ទៅកាន់សម្នាក់របស់ព្រះអនុត្តេរ ក៏បានធ្វើយ៉ាងនោះដូចគ្នា ។ ក្នុងថ្ងៃទីពីរ លោកក៏ធ្វើយ៉ាងនោះដដែល ។ ក្នុងថ្ងៃទីបី កាលការអល់អែកកើតឡើងដល់ព្រះថេរៈទាំងពីរនោះហើយ ចូលទៅរកព្រះមហាថេរៈ ហើយពោលថា បពិត្រលោកម្ចាស់ ពាក្យខ្លះដែលខ្ញុំគួរពោល មាន តែខ្ញុំមិនអាចពោលក្នុងសម្នាក់របស់លោកម្ចាស់បាន ត្រូវព្រះថេរៈជេញដោលថា អាវុសោ មិនជាការអ្វីទេ ចូរនិយាយចុះ ទើបពោលថា បពិត្រលោកម្ចាស់ ហេតុអ្វីទើបអនុត្តេរមិនត្រូវជាមួយលោកម្ចាស់ ព្រះមហាថេរៈពោលថា សប្បុរស អ្នកពោលអ្វី យើងទាំងពីរដូចគ្នានឹងកូន ដែលនៅពោះម៉ែតែមួយ ខ្ញុំទាំងពីររូប មួយរូបបានរបស់ហើយ មួយរូបក្រៅអំពីនេះក៏បានដូចគ្នា ទោសរបស់ព្រះថេរៈនោះដែលខ្ញុំធ្លាប់ឃើញ មិនមាន អស់កាលមានប្រមាណប៉ុណ្ណេះ ព្រះថេរៈធម្មកថិកពោលថា បពិត្រលោកម្ចាស់ យ៉ាងនោះឬ ព្រះមហាថេរៈ

ពោលថា អាវុសោ យ៉ាងនោះឯង ព្រះធម្មកថិកពោលថា បពិត្រលោកម្ចាស់ ព្រះអនុត្តេរពោលនឹងខ្ញុំយ៉ាងនេះថា សប្បុរស លោកជាកុលបុត្រ លោកកុំធ្វើការគប់រកព្រះមហាថេរៈនោះ ដោយធ្វើក្នុងចិត្តថា ព្រះមហាថេរៈនេះមានការខ្មាសបាប មានសីលជាទីស្រឡាញ់ គួរពិចារណាហើយសឹមធ្វើ តាំងអំពីថ្ងៃដែលខ្ញុំមកដល់ ព្រះអនុត្តេរនោះពោលនឹងខ្ញុំយ៉ាងនេះ ។

ព្រះថេរៈគ្រាន់តែស្តាប់ពាក្យនោះ មានចិត្តក្រោធអាក់អន់បែកហើយដូចភាជនៈដែលធ្វើដោយដី ដែលបុគ្គលជំដោយឈើដូច្នោះ ។ ព្រះធម្មកថិកក្រោកទៅកាន់សម្នាក់របស់ព្រះអនុត្តេរ ហើយពោលយ៉ាងនោះ ។ សូម្បីព្រះអនុត្តេរក៏បានបែកយ៉ាងនោះដូចគ្នា ។ ក្នុងព្រះថេរៈពីររូបនោះ មួយរូបឈ្មោះថាធ្លាប់បែកគ្នាចូលទៅបិណ្ឌបាត មិនមាន អស់កាលមានប្រមាណប៉ុណ្ណោះក៏ពិតតែក្នុងថ្ងៃស្អែកឡើង ព្រះថេរៈទាំងពីរបានបែកគ្នាទៅបិណ្ឌបាត ព្រះអនុត្តេរមកដល់មុន បានឈរត្រង់សាលា ជាទីបម្រើ ព្រះមហាថេរៈ មកដល់ខាងក្រោយ ព្រះអនុត្តេរឃើញលោកហើយ គិតថា អញគួរទទួលបាត្រ និងចីវរបស់ព្រះថេរៈនេះដែរឬហ្ន៎ លោក សូម្បីគិតថា ឥឡូវនេះ នឹងមិនទទួលដូច្នេះហើយ ក៏គង់ធ្វើចិត្តឲ្យទន់បាន ដោយធ្វើក្នុងចិត្តថា ណ្ហើយចុះ កម្មបែបនេះ អញមិនធ្លាប់ធ្វើ ការដែលញុំាងវត្តរបស់ខ្លួនឲ្យខូច មិនគួរ ដូច្នេះហើយចូលទៅរកព្រះថេរៈ ពោលថា បពិត្រលោកម្ចាស់ សូមឲ្យបាត្រ និងចីវរមកចុះ ព្រះថេរៈយកដៃកៀសចេញ ពោលថា ទៅចុះ អាវុសោ អ្នកមិនគួរទទួលបាត្រ និងចីវរបស់ខ្ញុំទេ ។ កាលអនុត្តេរពោលថា ពិតឬ លោកម្ចាស់

ខ្ញុំក៏គិតហើយថា នឹងមិនទទួលបាត្រ និងចីវររបស់លោក ទើបពោលថា អាវុសោ ហេតុអ្វី ទើបលោកគិតថា ការទាក់ទងណាមួយក្នុងវិហារនេះរបស់យើង មាន ។ សូម្បីអនុត្តរក៏ពោលថា បពិត្រលោកម្ចាស់ ហេតុអ្វី ទើបលោកសម្គាល់យ៉ាងនេះថា ការទាក់ទងណាមួយក្នុងវិហារនេះរបស់ពួកយើងមាន នេះជាវិហាររបស់លោក ហើយកាន់បាត្រ និងចីវរចេញទៅ ។ សូម្បីព្រះមហាថេរៈ ក៏បានចេញទៅដូចគ្នា ។

ព្រះថេរៈទាំងពីររូបនោះ មិនទៅផ្លូវតែមួយ មួយរូបកាន់យកផ្លូវទៅទិសខាងលិច មួយរូបកាន់យកផ្លូវទៅទិសខាងកើត ។ ព្រះធម្មកថិកពោលថា បពិត្រលោកម្ចាស់ សូមកុំធ្វើយ៉ាងនេះ សូមកុំធ្វើយ៉ាងនេះ កាលព្រះថេរៈពោលថា អាវុសោ ចូរឈប់ចុះ ហើយត្រឡប់ ។ ស្អែកឡើង ព្រះធម្មកថិកនោះ ចូលទៅស្រុកក្បែរៗ កាលពួកមនុស្សពោលថា លោកម្ចាស់ទាំងពីរទៅណា ក៏ពោលថា នែអ្នកទាំងឡាយ សូមអ្នកកុំសួរឡើយ លោកម្ចាស់ក្នុងត្រកូលរបស់ពួកអ្នក មរិលមិញនេះឈ្លោះគ្នាហើយចេញទៅ អាត្មាឃាត់ក៏មិនត្រឡប់ ។ មនុស្សទាំងនោះ ជនដែលល្ងង់ខ្លៅក៏នៅស្ងៀម ចំណែកមនុស្សដែលឈ្លាសវៃគិតថា ឈ្មោះថា កំហុសណាមួយរបស់លោកម្ចាស់ទាំងពីរ យើងមិនធ្លាប់ឃើញអស់កាលមានប្រមាណប៉ុណ្ណេះ ភ័យកើតឡើងដល់លោកម្ចាស់ទាំងពីរនោះ គង់កើតឡើងព្រោះអាស្រ័យធម្មកថិករូបនេះ ហើយបានជាអ្នកដល់នូវការអាក់អន់ចិត្ត ។ ព្រះថេរៈទាំងនោះ មិនបាននូវការសប្បាយចិត្ត ក្នុងទីដែលទៅហើយ ព្រះមហាថេរៈគិតថា ឱ ! កម្មរបស់អាវុសោ ធ្ងន់ ព្រោះលោកនិយាយនឹង

អាគន្តុកៈដែលខ្ជូនឃើញត្រឹមមួយរំពេចថា លោកកុំធ្វើការគប់រកព្រះមហា-ថេរៈ ។ សូម្បីព្រះអនុត្តេរក៏បានគិតថា ឱ ! កម្មរបស់ព្រះមហាថេរៈធ្ងន់ លោកបាននិយាយនឹងអាគន្តុកៈ ដែលខ្ជូនឃើញហើយត្រឹមតែមួយរំពេចថា លោកកុំគប់រកព្រះអនុត្តេរនេះ ។ ការស្វាធ្យាយ និងយោនិសោមនសិការ មិនមានដល់ព្រះថេរៈទាំងពីរនោះ ។ ពេលវេលាកន្លងទៅមួយរយឆ្នាំ ព្រះថេរៈទាំងពីរនោះបានទៅកាន់វិហារមួយ ក្នុងបច្ចិមបទេស សេនាសនៈជាមួយគ្នានោះឯង ត្រូវបានដល់ព្រះថេរៈទាំងពីរនោះ ។ កាលព្រះមហាថេរៈចូលទៅអង្គុយលើគ្រែហើយ ព្រះអនុត្តេរក៏បានចូលទៅ ។ ព្រះមហាថេរៈឃើញអនុត្តេរនោះក៏ចាំបាន មិនអាចទប់ទឹកភ្នែកបាន សូម្បីព្រះអនុត្តេរក៏ចាំព្រះមហាថេរៈបាន មានភ្នែកពេញហើយដោយទឹកភ្នែក គិតថា អញគួរពោលឬមិនពោលហ្ន៎ ហើយគិតថា ការនុ៎ះមិនគួរផ្សឹ ហើយថ្វាយបង្គំព្រះថេរៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំកាន់បាត្រ និងចីវរដើរ តាមលោកម្ចាស់អស់កាលប្រមាណប៉ុណ្ណេះ មារយាទដែលមិនសមគួរណាមួយ ក្នុងទ្វារទាំង ៦ មានកាយទ្វាររបស់ខ្ញុំ លោកម្ចាស់ធ្លាប់ឃើញហើយឬ ព្រះថេរៈពោលថា អាវុសោ ខ្ញុំមិនធ្លាប់ឃើញទេ ព្រះអនុត្តេរពោលថា បើដូច្នោះ ហេតុអ្វី ទើបលោកម្ចាស់និយាយនឹងធម្មកថិកថា កុំធ្វើការសេពគប់ជាមួយព្រះអនុត្តេរនោះ ព្រះមហាថេរៈពោលថា អាវុសោ ខ្ញុំនិយាយយ៉ាងនោះបានដូចម្តេច បានឮថា លោកពោលយ៉ាងនេះក្នុងវាងខ្ញុំ អនុត្តេរពោលថា បពិត្រលោកម្ចាស់ ខ្ញុំក៏មិនបានពោល ។ ក្នុងខណៈនោះ ព្រះថេរៈទាំងពីរនោះ ក៏ដឹងបានថា ព្រះ

ធម្មកថិកនោះ ប្រាប្តាបំបែកយើងទាំងពីរ ទើបពោលយ៉ាងនោះ ហើយញុំងគ្នានិងគ្នាឲ្យសម្តែងទោសហើយ ។ ព្រះថេរៈទាំងពីរនោះ មិនបាននូវការសប្បាយចិត្តអស់កាលមួយរយឆ្នាំ ជាអ្នកព្រមព្រៀងគ្នាក្នុងថ្ងៃនោះ បបួលគ្នាថា មកយើងនឹងអូសធម្មកថិកនោះ ចេញអំពីវិហារនោះ ហើយធ្វើដំណើរទៅដល់វិហារនោះ ដោយលំដាប់ ។ ព្រះធម្មកថិកឃើញព្រះថេរៈទាំងពីរហើយចូលទៅជិតដើម្បីទទួលបាត្រ និងចីវរ ព្រះថេរៈទាំងពីរពោលថា លោកមិនគួរនៅក្នុងវិហារនេះទៀយ ។ ព្រះធម្មកថិកនោះមិនអាចតាំងនៅបាន គេចចេញទៅមួយរំពេចនោះឯង ។ គ្រានោះ សមណធម៌ដែលលោកចំពេញអស់ ២ ម៉ឺនឆ្នាំ មិនអាចទ្រទ្រង់បាន លោកឃ្លាតចាកអត្តនោះហើយ កើតក្នុងអវីចីអស់ ១ ពុទ្ធន្តរ មានអត្តភាព មានប្រការដូចពោលហើយ សោយទុក្ខត្រង់ក្នុងគិជ្ឈកូដក្នុងឥទ្ធរនេះ ។

ព្រះសាស្តាត្រាស់បុព្វកម្មនេះ របស់សូករប្រេតនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុ គប្បីជាអ្នកចូលទៅស្ងប់ដោយកាយជាដើម ហើយត្រាស់ព្រះគាថានេះថា

វាចានុរក្ខី មនសា សុសំវុតោ កាយេន ច អកុសលំ ន កយិរា
ឯតេ តយោ កម្មបថេ វិសោធយេ អារាធយេ មគ្គ មិសិប្បវេទិតំ ។

បុគ្គលគប្បីជាអ្នករក្សាវាចា សង្រួមឲ្យល្អដោយចិត្ត ទាំងមិនគប្បីធ្វើអកុសលដោយកាយ បុគ្គលគប្បីជម្រះកម្មបថទាំង ៣ នេះ នឹងគប្បីត្រេកអរចំពោះមគ្គ ដែលលោកអ្នកស្វែងរកគុណដ៏ល្អសម្តែងហើយ ។

សេចក្តីអធិប្បាយ

សេចក្តីនៃគាថានោះថា បុគ្គលឈ្មោះថាមានប្រក្រតីតាមរក្សាវាចា ព្រោះវៀរទុច្ចរិត ៤ ឈ្មោះថា សង្រួមចិត្តហើយដោយល្អ ព្រោះមិនញុំាងមនោ-ទុច្ចរិត មានអភិជ្ឈាជាដើមឲ្យកើតឡើង កាលកាយទុច្ចរិត មានបាណាតិបាតជាដើម ឈ្មោះថា មិនគួរធ្វើអកុសលដោយកាយ គប្បីញុំាងកម្មបថ ៣ ឲ្យបរិសុទ្ធដោយអាការយ៉ាងនេះ កាលឲ្យបរិសុទ្ធបានយ៉ាងនោះ ឈ្មោះថា គប្បីត្រេកអរក្នុងមគ្គមានអង្គ ៨ ដែលលោកអ្នកស្វែងរកគុណទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម ស្វែងរកគុណ គឺសីលជាដើម ប្រកាសហើយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង សូការប្រែត ចប់

រឿង ព្រះចោឋិលត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះថាចោឋិលៈ ត្រាស់ព្រះធម្មទេសនានេះថា **យោគា វេ** *ជាដើម ។*

បានឮមកថា ព្រះចោឋិលៈនោះ ទ្រទ្រង់ព្រះត្រៃបិដកក្នុងសាសនាព្រះពុទ្ធ ៧ អង្គ បង្រៀនធម៌ដល់ភិក្ខុ ៥០០ រូប ព្រះសាស្តាទ្រង់ត្រិះរិះថា ភិក្ខុនេះមិនមានការគិតថា អញនឹងធ្វើការរលាស់ចេញចាកទុក្ខដល់ខ្លួន តថាគតនឹង

ញ៉ាំងគេឲ្យសង្វេគ ។

ចាប់តាំងអំពីនោះមក ព្រះសាស្តាត្រាស់នឹងព្រះថេរៈនោះ ក្នុងពេលដែលព្រះថេរៈមកកាន់ទីបម្រុងថា មកចុះភិក្ខុស្វីកវីតទេ អង្គុយចុះភិក្ខុស្វីកវីតទេ ទៅចុះភិក្ខុស្វីកវីតទេ ក្នុងកាលដែលព្រះថេរៈក្រោកទៅ ក៏ត្រាស់ថា ភិក្ខុស្វីកវីតទេទៅហើយ ព្រះពោធិលៈនោះគិតថា អញទ្រទ្រង់នូវព្រះត្រៃបិដក មួយអន្ទើដោយអដ្ឋកថា ប្រាប់ធម៌ដល់ភិក្ខុ ៥០០ រូប រហូតដល់ ១៨ មហាគណៈ កាលបើដូច្នោះ ព្រះសាស្តាត្រាស់ហៅអញរឿយៗ ថា ភិក្ខុ ស្វីកវីតទេ ព្រះដ៏មានព្រះភាគត្រាស់ ហៅអញយ៉ាងនេះ ព្រោះមិនមានគុណវិសេស មានឈានជាដើមពិត ។ លោកមានសេចក្តីសង្វេគកើតឡើងហើយ ទើបគិតថា ឥឡូវនេះ អញនឹងចូលទៅកាន់ព្រៃហើយធ្វើសមណធម៌ ចាត់ចែងជាត្រ និងចីវរឯង ហើយបានចេញទៅ មួយអន្ទើដោយភិក្ខុដែលរៀនធម៌ ហើយចេញទៅខាងក្រោយភិក្ខុនោះទាំងអស់ក្នុងពេលទៀបភ្លឺ ។ ពួកភិក្ខុនោះ ស្វាធ្យាយក្នុងបរិវេណ មិនបានកំណត់លោកថាជាអាចារ្យ ព្រះថេរៈទៅអស់ចម្ងាយ ១២០ យោជន៍ហើយ ។ ចូលទៅរកភិក្ខុ ៣០ រូប ដែលនៅក្នុងអារាម ក្នុងជង្រៃមួយកន្លែង ថ្វាយបង្គំព្រះសង្ឃត្តេរៈហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ជាទីពឹងរបស់ខ្ញុំ ។ ព្រះសង្ឃត្តេរៈពោលថា អាវុសោ លោកជាព្រះធម្មកថិក វត្តណាមួយ ឈ្មោះថា ពួកខ្ញុំគប្បីដឹងបាន ក៏ព្រោះអាស្រ័យលោក ហេតុអ្វី ទើបពោលយ៉ាងនេះ ព្រះពោធិលៈពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំធ្វើយ៉ាងនេះ សូមលោក

ម្ចាស់ជាទីពឹងរបស់ខ្ញុំចុះ ។

ព្រះថេរៈទាំងនោះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ ។ លំដាប់នោះ ព្រះមហាថេរៈបញ្ជូនព្រះចោឋបិលៈនោះ ទៅកាន់សម្នាក់ព្រះអនុត្តរ ដោយគិតថា កិក្ខុនេះមានមានះព្រោះអាស្រ័យចំណេះដ៏ងពិត សូម្បីអនុត្តរនោះក៏ពោលនឹងព្រះចោឋបិលៈនោះយ៉ាងនោះដូចគ្នា ។ សូម្បីព្រះថេរៈទាំងអស់ កាលបញ្ជូនលោកទៅដោយទំនងនេះ ក៏បញ្ជូនទៅកាន់សម្នាក់របស់សាមណេរ អាយុ ៧ ឆ្នាំ ដែលបួសថ្មីជាងសាមណេរទាំងអស់ ដែលអង្គុយធ្វើចីវរកម្មក្នុងទីសម្រាកពេលថ្ងៃ ។ ព្រះថេរៈទាំងឡាយ នាំមានះរបស់លោកចេញបានដោយឧបាយយ៉ាងនេះ ។

ព្រះចោឋបិលៈនោះ មានមានះដែលព្រះថេរៈទាំងឡាយ នាំចេញហើយ ទើបផ្គងអញ្ជលីក្នុងសម្នាក់របស់សាមណេរ ហើយពោលថា សប្បុរស សូមលោកជាទីពឹងរបស់ខ្ញុំ សាមណេរពោលថា ឱហ្ន៎លោកអាចារ្យ លោកនិយាយអ្វី លោកជាថេរៈ ជាពហូសូត ហេតុណាមួយគប្បីជាកិច្ចដែលខ្ញុំគួរដឹង ក៏ដឹងក្នុងសម្នាក់របស់លោកម្ចាស់ ព្រះចោឋបិលៈពោលថា សប្បុរស លោកកុំធ្វើយ៉ាងនេះ សូមលោកជាទីពឹងរបស់ខ្ញុំចុះ សាមណេរពោលថា លោកម្ចាស់ បើលោកម្ចាស់អត់ធន់ចំពោះឱវាទបានសោត ខ្ញុំនឹងជាទីពឹងរបស់លោកម្ចាស់ ព្រះចោឋបិលៈពោលថា សប្បុរស ខ្ញុំធ្វើបាន កាលលោកពោលថា សូមចូលទៅកាន់ភ្លើង ខ្ញុំនឹងចូលទៅកាន់ភ្លើងនោះឯង ។

គ្រានោះ ទើបសាមណេរបង្ហាញស្រះមួយក្នុងទីមិនឆ្ងាយ ហើយពោល

ថា លោកម្ចាស់ លោកម្ចាស់ស្បៀកដូចប្រក្រតីនោះឯង ចុះក្នុងស្រះនេះ ។ ពិតហើយ សាមណេរនោះជីងកាពដែលចីវរពីរជាន់ មានតម្លៃច្រើន ព្រះថេរៈស្បៀកដណ្តប់ហើយ កាលសាកល្បងថា ព្រះថេរៈជាអ្នកអត់ធន់ចំពោះឱវាទមែនឬទេ ទើបពោលយ៉ាងនោះ ។ ព្រះថេរៈក៏ចុះទៅ ដោយពាក្យត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ ។ លុំជាប់នោះ ក្នុងកាលដែលជាយចីវរសើម ទើបសាមណេរពោលថា មកចុះ លោកម្ចាស់ ហើយពោលនឹងលោកដែលមកឈរដោយពាក្យមួយម៉ាត់ប៉ុណ្ណោះថា លោកម្ចាស់ ក្នុងជំបូកមួយ មានវន្ទ ៦ ក្នុងវន្ទនោះ ទន្សែងចូលទៅខាងក្នុងវន្ទនីមួយៗ បុគ្គលប្រាថ្នានឹងចាប់ទន្សែង ទើបចុកវន្ទទាំង ៥ ក្រៅអំពីនេះ បើកវន្ទទី ៦ ហើយទើបចាប់យកដោយវន្ទដែលវាចូលទៅនោះឯង បណ្តាទ្វារទាំង ៦ សូមលោកបិទទ្វារ ៥ យ៉ាងនោះហើយ សូមផ្តើមនូវកម្មនេះក្នុងមនោទ្វារ ។ ដោយន័យមានប្រមាណប៉ុណ្ណោះ ការជាក់ច្បាស់មានដល់ភិក្ខុដែលជាពហូសូត ដូចការឆេះឡើងនៃដួងប្រទីបដូច្នោះ ។ ព្រះចោទិលៈនោះពោលថា សប្បុរស ពាក្យមានប្រមាណប៉ុណ្ណោះឯង សមល្មមហើយ ទើបឈមចុះក្នុងកវជកាយ ប្រារព្ធសមណធម៌ ។

ព្រះសាស្តាប្រថាប់គង់ក្នុងទីបំផុតប្រមាណ ១២០ យោជន៍នោះឯង ទតមើលភិក្ខុនោះហើយត្រិះរិះថា ភិក្ខុនោះជាអ្នកមានបញ្ញាដូចផែនដី ដោយប្រការណា កាលដែលលោកតម្កល់ខ្លួនដោយប្រការនោះឯង សមគួរ ។ ហើយទ្រង់បញ្ចេញព្រះរស្មីទៅហាក់ដូចគ្រាស់ជាមួយភិក្ខុនោះ ដោយព្រះគាថានេះថា

យោគា វេ ជាយតី ភូរិ　　អយោគា ភូរិសង្ខយោ
ឯតំ ទ្វេធា បថំ ញត្វា　　ភវាយ វិភវាយ ច
តថត្តានំ និវេសេយ្យ　　យថា ភូរិ បវឌ្ឍតិ ។

ប្រាជ្ញា រមែងកើតពីការប្រកប សេចក្តីវិនាសប្រាជ្ញា រមែងកើតអំពីការមិនប្រកប អ្នកមានប្រាជ្ញាដឹងការប្រកប និងការមិនប្រកបទាំងពីរនេះថា ជាគន្លងនៃសេចក្តីចម្រើន និងសេចក្តីវិនាសហើយ ប្រាជ្ញាចម្រើនឡើងដោយប្រការណា គួរតម្កល់ខ្លួន ដោយប្រការនោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យោគា** *សេចក្តីថា ព្រោះការធ្វើទុកក្នុងចិត្តដោយយោនិសោមនសិការ ក្នុងអារម្មណ៍ ៣៨ ។*

ពាក្យថា **ភូរិ** *នោះ ជាឈ្មោះនៃបញ្ញាដែលទូលំទូលាយ ស្មើដោយផែនដី សេចក្តីវិនាស ឈ្មោះថា* **សង្ខយោ ។** *ពីរបទថា* **ឯតំ ទ្វេធា បថំ** *គឺនូវការប្រកប និងការមិនប្រកបនោះ ។ បានព្រះគាថាថា* **ភវាយ វិភវាយ ច** *គឺនៃការចម្រើន និងការមិនចម្រើន ។ បទថា* **តថត្តានំ** *សេចក្តីថា បណ្ឌិតគប្បីតម្កល់ខ្លួន ដោយប្រការដែលបញ្ញា ពោល គឺ* **ភូរិ** *នេះ នឹងចម្រើនឡើងបាន ។ ក្នុងកាលចប់ទេសនា ព្រះបោឋិលត្ថេរ តាំងនៅក្នុងអរហត្តហើយ ដូច្នេះឯង ។*

រឿងព្រះបោឋិលត្ថេរ ចប់

រឿង ព្រះថេរៈចាស់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចាស់ច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **វនំ ឆិន្ទថ** ជាដើម ។

បានឮថា ភិក្ខុទាំងនោះ ក្នុងពេលជាគ្រហស្ថ ជាកុដុម្ពិកៈ ជាអ្នកមានស្តុកស្តម្ភ មានទ្រព្យច្រើនក្នុងក្រុងសាវត្ថី ជាសម្ងាញ់នឹងគ្នា ធ្វើបុណ្យរួមគ្នា ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ គិតថា ពួកយើងជាមនុស្សចាស់ ប្រយោជន៍អ្វីដោយការនៅគ្រប់គ្រងផ្ទះរបស់ពួកយើង ដូច្នេះហើយ ទូលសូមបព្វជ្ជាជាមួយព្រះសាស្តា បួសហើយ តែព្រោះភាពជាមនុស្សចាស់ មិនអាចរៀនធម៌បាន ទើបឲ្យមនុស្សសាងបណ្ណសាលាក្នុងទីបំផុតនៃវិហារ ហើយនៅរួមគ្នា កាលត្រាច់ទៅបិណ្ឌបាត ដោយច្រើនក៏ទៅកាន់ផ្ទះរបស់បុត្រ និងកិរិយានោះឯង ហើយឆាន់ ។

ក្នុងភិក្ខុទាំងនោះ ភិក្ខុមួយរូបមានអតីតកិរិយា ឈ្មោះនាងមធុរបាណិកានាងមានឧបការៈដល់ភិក្ខុទាំងនោះគ្រប់រូប ព្រោះដូច្នោះ ភិក្ខុគ្រប់រូប កាន់យកអាហារដែលខ្លួនបានហើយ ទៅអង្គុយឆាន់ត្រង់ផ្ទះរបស់នាងនោះឯង ចំណែកនាងប្រគេនសម្ល និងម្ហូបដល់ភិក្ខុទាំងនោះ តាមដែលខ្លួនបានរៀបចំ ។

នាងកាលអាពាធប្រកេទណាមួយពាល់ត្រូវហើយ បានធ្វើកាលកិរិយាហើយ ។ លំដាប់នោះ ព្រះថេរៈចាស់ទាំងនោះ ប្រជុំគ្នាក្នុងបណ្ណសាលារបស់ព្រះថេរៈដែលជាសម្ងាញ់ ឱបគ្នានឹងគ្នាយំរៀបរាប់ថា ឧបាសិកាមានថ្លើដែធ្ងាញ់ធ្វើកាលកិរិយាហើយ ។ ភិក្ខុទាំងឡាយរត់ចូលទៅដោយជុំវិញ ហើយសួរថា

បពិត្រលោកម្ចាស់ តើមានរឿងអ្វី ទើបពោលថា បពិត្រលោកម្ចាស់ ភរិយាចាស់របស់សម្ងាញ់ពួកខ្ញុំ ធ្វើកាលកិរិយាហើយ នាងមានឧបការៈដល់ពួកខ្ញុំពន់ពេក ឥឡូវនេះ ពួកខ្ញុំនឹងបានឃើញអំពីណា ពួកខ្ញុំយំព្រោះហេតុនេះ ។

ភិក្ខុទាំងឡាយសន្ធនាក្នុងរោងធម្មសភាហើយ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលពួកភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន កាលនាងមធុរបាណិកានោះ កើតក្នុងកំណើតក្អែក ត្រាច់ទៅត្រង់មាត់សមុទ្រ ត្រូវរលកសមុទ្រកួចឲ្យស្លាប់ហើយ ភិក្ខុទាំងនោះកើតជាក្អែក យកនុំក់កនេញហើយគិតថា ពួកយើងនឹងនាំក្អែកញីនោះទៅ ទើបនាំគ្នាបាចមហាសមុទ្រដោយចំពុះ ដល់នូវសេចក្តីលំបាកហើយ ហើយទ្រង់នាំអតីតនិទានមកត្រាស់កាកជាតកឲ្យពិស្តារថា

> អើ ចង្កាយើងក៏រោយ ទាំងមាត់ក៏ស្ងួតក្រៀមក្រោះ យើងមិនអាចបាចទឹកក្នុងសមុទ្រឲ្យរីងបានទេ ព្រោះមហាសមុទ្រនៅតែពេញដដែល ។

ហើយហៅភិក្ខុទាំងនោះមក ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអាស្រ័យព្រៃ គឺរាគៈ ទោសៈ និងមោហៈ ទើបដល់នូវទុក្ខនេះ កាលដែលពួកអ្នកកាប់នូវព្រៃនោះចេញ គួរ ពួកអ្នកនឹងអស់ទុក្ខបានដោយអាការយ៉ាងនេះ ហើយទ្រង់ភាសិតព្រះគាថាទាំងនេះថា

វនំ ឆិន្ទថ មា រុក្ខំ វនតោ ជាយតី ភយំ

ឆេត្វា វនំ វនថម្ភញ្ច និព្វនា ហោថ ភិក្ខវោ ។

យាវញ្ហិ វនថោ ន ឆិជ្ជតិ អណុមត្តោបិ នរស្ស នារិសុ

បដិពទ្ធមនោ វ តាវ សោ វច្ឆោ ខីរបកោវ មាតរិ ។

អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃចេញ ចូរកុំកាត់ដើមឈើ (ព្រោះ) ភ័យកើតអំពីកិលេសដូចជាព្រៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃផង កិលេសដូចជាដើមឈើដុះក្នុងព្រៃផង ហើយចូរជាអ្នកកុំមានកិលេសដូចជាព្រៃឡើយ ព្រោះថា កិលេសដូចដើមឈើ ដុះក្នុងព្រៃរបស់នរជន សូម្បីមានប្រមាណតិចក៏ដោយ បើកាត់មិនជាច់ក្នុងពួកនារីដរាបណា នរជននោះឯង តែងមានចិត្តជាប់ជំពាក់ក្នុងពួកនារី ដូចកូនគោនៅកំពុងផៅដោះ ដែលមានចិត្តជាប់ជំពាក់នៅនឹងមេដរាបនោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មា រុក្ខំ** *សេចក្តីថា កាលព្រះសាស្តាត្រាស់ថា អ្នកទាំងឡាយចូរកាត់ព្រៃ ភិក្ខុទាំងនោះ ដែលបួសមិនទាន់យូរ ការគិតក្នុងការជាអ្នកប្រាថ្នាកាប់ដើមឈើនឹងកើតឡើងថា ព្រះសាស្តាព្រមឲ្យពួកយើងកាន់កាំបិតជាដើមកាប់ព្រៃ កាលបើដូច្នោះ ព្រះសាស្តាកាលទ្រង់ហាមភិក្ខុទាំងនោះថា តថាគតពោលពាក្យនោះ សម្តៅយកព្រៃ គឺកិលេស មានរាគៈជាដើម*

មិនបានសម្តៅយកដើមឈើ ទើបត្រាស់ថា កុំកាប់ដើមឈើ ។

បទថា **វនតោ** *សេចក្តីថា ភ័យកើតអំពីសត្វសាហាវ មានសីហៈជាដើម តែងកើតអំពីព្រៃតាមប្រក្រតី យ៉ាងណា ភ័យមានជាតិជាដើម រមែងកើតអំពីព្រៃ គឺកិលេសក៏ដូច្នោះ ។*

ក្នុងពីរបទថា **វនំ វនថញ្ច** *នេះ គប្បីជ្រាបវិនិច្ឆ័យថា ដើមឈើធំឈ្មោះថា ព្រៃ ដើមឈើតូចដែលតាំងនៅក្នុងព្រៃនោះ ឈ្មោះថា ពួកឈើតាំងនៅក្នុងព្រៃ ម្យ៉ាងទៀត ដើមឈើដែលកើតមុន ឈ្មោះថា ព្រៃ ដែលកើតក្រោយៗ មក ឈ្មោះថា ពួកឈើតាំងនៅក្នុងព្រៃ យ៉ាងណា កិលេសធំៗ ដែលទាញសត្វទុកក្នុងភព ឈ្មោះថា កិលេសដូចព្រៃ កិលេសដែលឲ្យផលក្នុងបច្ចុប្បន្ន ឈ្មោះថា កិលេសដូចពួកឈើតាំងនៅក្នុងព្រៃ ម្យ៉ាងទៀត កិលេសដែលកើតមុន ឈ្មោះថា កិលេសដូចព្រៃ កិលេសដែលកើតបន្តៗមក ឈ្មោះថា កិលេសដូចពួកឈើតាំងនៅក្នុងព្រៃដូច្នោះដូចគ្នា ។ កិលេស-ជាតទាំងពីរយ៉ាងនោះ ដែលព្រះយោគីគប្បីកាត់ដោយញាណ ដែលសម្បយុត្តដោយមគ្គទី ៤ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា ចូរកាត់កិលេសដូចព្រៃ និងដូចពួកឈើដែលតាំងនៅក្នុងព្រៃ ។*

ពីរបទថា **ឆិន្ទថា ភោថ** *សេចក្តីថា អ្នកទាំងឡាយ ចូរជាអ្នកមិនមានកិលេសចុះ ។*

ពីរបទថា **យាវញ្ហិ វនថោ** *សេចក្តីថា ពួកឈើដែលតាំងនៅក្នុងព្រៃ គឺកិលេសនោះ ទោះបីមានប្រមាណតិចតួចរបស់នរជន នៅមិនជាប់ក្នុងពួកនារី*

ទាំងឡាយដរាបណា បុគ្គលនោះ ដូចគ្នានឹងកូនគោដែលនៅជៀដោះមេ មានចិត្តប្រតិព័ទ្ធ គឺមានចិត្តជាប់ជំពាក់ក្នុងមេដរាបនោះ ។

ក្នុងកាលចប់ទេសនា ព្រះថេរៈចាស់ទាំងនោះ តាំងនៅក្នុងសោតាបត្តិផល ហើយទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង ព្រះថេរៈចាស់ ចប់

រឿង សទ្ធិវិហារិកវត្តរបស់ព្រះសារីបុត្តត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសទ្ធិវិហារិកវត្តរបស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ឧច្ឆុ** *ជាដើម ។*

បានឮថា កូនរបស់ជាងមាសម្នាក់មានរូបស្អាត បួសក្នុងសម្នាក់របស់ព្រះថេរៈហើយ ព្រះថេរៈត្រិះរិះថា ពួកភិក្ខុកំលោះមានរាគៈក្រាស់ ហើយបានឲ្យអសុភកម្មដ្ឋានដល់លោក ដើម្បីកម្ចាត់រាគៈ ។ តែកម្មដ្ឋាននោះ មិនជាទីសប្បាយសម្រាប់លោក ព្រោះហេតុនោះ លោកចូលកាន់ព្រៃហើយ ព្យាយាមអស់ ៣ ខែ មិនបានសូម្បីត្រឹមឯកគត្តា ទើបមកកាន់សម្នាក់ព្រះថេរៈ កាលព្រះថេរៈពោលថា អាវុសោ កម្មដ្ឋានប្រាកដដល់លោកហើយឬ ទើបប្រាប់ការប្រព្រឹត្តទៅនោះ ។ គ្រានោះ ព្រះថេរៈពោលថា ការជាក់ចិត្តថា កម្មដ្ឋាន មិនសម្រេចដូច្នេះ រមែងមិនសមគួរ ហើយប្រាប់កម្មដ្ឋាននោះឯង ឲ្យល្អក្រៃលែង

ទ្បើងទៀត ហើយបានឲ្យដល់លោក ។ ក្នុងវារៈទី ២ លោកក៏មិនអាចញុំងគុណវិសេសណាមួយឲ្យកើតទ្បើងបាន ទើបត្រឡប់មកប្រាប់ដល់ព្រះថេរៈ ។ សូម្បីព្រះថេរៈប្រាប់កម្មដ្ឋាននោះឯង ធ្វើឲ្យមានហេតុមានឧបមា លោកក៏មកប្រាប់ភាពដែលកម្មដ្ឋានមិនសម្រេចទៀត ។ ព្រះថេរៈគិតថា កិកូធ្វើសេចក្តីព្យាយាមរមែងជ្រាបនីវរណធម៌ មានកាមច្ឆន្ទៈជាដើម ដែលមាននៅក្នុងខ្លួនថាមាន និងដែលមិនមានថាមិនមាន កិកូនេះជាអ្នកធ្វើសេចក្តីព្យាយាម មិនមែនមិនធ្វើ ជាអ្នកបដិបត្តិ មិនមែនមិនបដិបត្តិ តែអញមិនដឹងអធ្យាស្រ័យរបស់កិកូនេះ កិកូនេះប្រហែលជាពុទ្ធវេនេយ្យ ទើបនាំទៅគាល់ព្រះសាស្តាក្នុងពេលល្ងាច ហើយក្រាបទូលការប្រព្រឹត្តទៅនោះទាំងអស់ថា បពិត្រព្រះអង្គ កិកូនេះជាសទ្ធិវិហារិករបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គឲ្យកម្មដ្ឋានឈ្មោះនេះ ដល់កិកូនេះដោយហេតុនេះ ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងព្រះថេរៈនោះថា ឈ្មោះថា អាសយានុសញ្ញាណានោះ រមែងមានដល់ព្រះពុទ្ធទាំងឡាយ ដែលបំពេញបារមីហើយញុំងលោកធាតុ ១ ម៉ឺនឲ្យកងរំពង ដល់នូវភាពជាសព្វញ្ញូនោះឯង ហើយទ្រង់រំពឹងថា កិកូនេះបួសអំពីត្រកូលណាហ្ន៎ ទ្រង់ជ្រាបថា អំពីត្រកូលជាងមាស ទ្រង់ពិចារណាអត្តភាពដែលកន្លងមកហើយ ទ្រង់ឃើញអត្តភាព ៥០០ របស់កិកូនោះ កើតដោយលំដាប់ក្នុងត្រកូលជាងមាស ហើយទ្រង់ត្រិះរិះថា កិកូនេះ ធ្វើជាងមាសអស់កាលដ៏យូរ រម្ងាយតែមាសទឹកជប់តែម្យ៉ាង ដោយគិតថា អញនឹងធ្វើជាផ្តាកណិការ និងផ្តាឈូកជាដើម ។ អសុកបដិកូល-

កម្មដ្ឋាន មិនសមគួរដល់ភិក្ខុកំលោះនេះ កម្មដ្ឋានដែលពេញចិត្តប៉ុណ្ណោះ ទើបជាកម្មដ្ឋានសប្បាយដល់លោក ទើបត្រាស់ថា សារីបុត្ត អ្នកនឹងឃើញភិក្ខុដែលអ្នកឲ្យកម្មដ្ឋាន លំបាកហើយអស់កាល ៤ ខែ សម្រេចអរហត្តខាងក្រោយភត្ត ក្នុងថ្ងៃនេះឯង ចូរអ្នកទៅចុះ ដូច្នេះហើយ ទ្រង់បញ្ជូនព្រះថេរៈទៅ ទ្រង់និម្មិតផ្ការឈូកមាសប្រមាណប៉ុនចក្រដោយឫទ្ធិ ហើយទ្រង់ធ្វើឲ្យដូចជាហូរនូវដំណក់ទឹកអំពីស្លឹក និងទង ហើយប្រទានឲ្យដោយព្រះតម្រាស់ថា យកចុះភិក្ខុ ចូរអ្នកកាន់យកផ្ការឈូកនោះ ទៅទុកត្រង់គំនរខ្សាច់ខាងចុងវិហារ អង្គុយពត់ក្អែនក្នុងទីចំពោះមុខ ហើយធ្វើបរិកម្មថា **លោហិតកំ លោហិតកំ** *ក្រហម ក្រហម ។ កាលភិក្ខុនោះ ទទួលផ្ការឈូកអំពីព្រះហស្តរបស់ព្រះសាស្តាប៉ុណ្ណោះចិត្តក៏ជ្រះថ្លាហើយ លោកទៅកាន់ខាងចុងវិហារ ពូនខ្សាច់ឡើងដោតទងផ្ការឈូកត្រង់គំនរខ្សាច់នោះហើយ អង្គុយពត់ក្អែនក្នុងទីចំពោះមុខផ្តើមបរិកម្មថា* **លោហិតកំ លោហិតកំ ។**

គ្រានោះ នីវរណៈទាំងឡាយរបស់លោកស្ងប់រម្ងាប់ហើយ ក្នុងខណៈនោះឯង ឧបចារជ្ឈានកើតហើយ ។ លោកញុំាងបឋមជ្ឈានឲ្យកើតឡើងក្នុងលំដាប់នៃឧបចារជ្ឈាននោះ ឲ្យដល់នូវភាពជាអ្នកជំនាញ ដោយអាការ ៥ អង្គុយក្នុងឥរិយាបថនោះឯង សម្រេចឈានទាំងឡាយ មានទុតិយជ្ឈានជាដើមហើយ អង្គុយចូលចតុត្ថជ្ឈានដែលជំនាញហើយ ។

ព្រះមានព្រះភាគទ្រង់ជ្រាបថា ឈានកើតឡើងដល់ភិក្ខុនោះហើយ ទ្រង់ពិចារណាថា ភិក្ខុនេះអាចញុំាងគុណវិសេសដែលក្រៃលែង ឲ្យកើតឡើងតាម

ធម្មតារបស់ខ្លួនបានឬហ្ន៎ ទ្រង់ជ្រាបថា មិនអាច ហើយទ្រង់អធិដ្ឋានថា ចូរផ្កាបទុមនោះរុះរោយទៅ ផ្កាបទុមនោះក៏ក្រៀមស្រពោនមានពណ៌ខ្មៅ ដូចផ្កាបទុមដែលត្រូវឈ្លីដោយដៃដូច្នោះ ។ ភិក្ខុនោះចេញអំពីឈានហើយ សម្លឹងមើលផ្កាបទុមនោះ ឃើញអនិច្ចលក្ខណៈថា ឱហ្ន៎ ផ្កាបទុមនេះ ត្រូវជរាប៉ះពាល់ហើយទើបប្រាកដជាបាន កាលអនុបាទិន្នកសង្ខារ ដែលជរាគ្របសង្កត់បានយ៉ាងនេះ ចំណង់បើឧបាទិន្នកសង្ខារ តើនឹងអាចចៀសបានដូចម្តេច ជរាគង់គ្របសង្កត់ឧបាទិន្នកសង្ខារនេះ កាលអនិច្ចលក្ខណៈនោះដែលលោកឃើញហើយ ទុក្ខលក្ខណៈ និងអនត្តលក្ខណៈ ក៏ឈ្មោះថាឃើញហើយដូចគ្នា ។ ភព ៣ ប្រាកដដល់លោក ដូចភ្លើងដែលឆេះទូទៅហើយ និងដូចសាកសពដែលបុគ្គលចងនៅត្រង់ក ។

ក្នុងខណៈនោះ ពួកក្មេងចុះកាន់ស្រះមួយ ក្នុងទីមិនឆ្ងាយអំពីភិក្ខុនោះ កាច់ផ្កាកុមុទទាំងឡាយហើយ ធ្វើឲ្យជាគំនរទុកលើគោក ។ ភិក្ខុនោះសម្លឹងមើលផ្កាកុមុទទាំងឡាយលើគោក និងក្នុងទឹក លំដាប់នោះ ផ្កាកោមុទក្នុងទឹកស្អាតប្រាកដដល់លោកដូចកំពង់ហូរទឹក ។ ផ្កាកុមុទក្រៅអំពីនេះ ក្រៀមស្វិតហើយត្រង់ចុងត្របក ភិក្ខុនោះ ឃើញអនិច្ចលក្ខណៈជាដើមល្អឡើងថា ជរាមិនប៉ះពាល់អនុបាទិន្នកសង្ខារយ៉ាងនេះ នឹងមិនប៉ះពាល់ឧបាទិន្នកសង្ខារដូចម្តេច ។

ព្រះសាស្តាទ្រង់ជ្រាបថា ឥឡូវនេះ កម្មដ្ឋានប្រាកដដល់ភិក្ខុនោះហើយ ប្រថាប់គង់ក្នុងព្រះគន្ធកុដិ ទ្រង់បញ្ចេញព្រះរស្មីទៅ ព្រះរស្មីនោះប៉ះពាល់នឹងមុខរបស់ភិក្ខុនោះ កាលលោកពិចារណាថា នុ៎ះអ្វីហ្ន៎ ព្រះសាស្តាក៏ហាក់ដូចយាង

មកប្រថាប់ឈរត្រង់ទីចំពោះមុខ ភិក្ខុក្រោកឡើងផ្គងអញ្ជលី ។ លំដាប់នោះ ព្រះសាស្តាទ្រង់កំណត់ធម៌ដែលជាសប្បាយហើយ ទើបត្រាស់ព្រះគាថានេះថា

ឧច្ចិន្ទ សិនេហមត្តនោ កុមុទំ សារទិកំវ ចាណិនា

សន្តិមគ្គមេវ ព្រូហយ និព្វានំ សុគតេន ទេសិតំ ។

ចូរអ្នកជកសេចក្តីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គលជកផ្តាកុមុទ ដែលកើតក្នុងសរទកាលដោយដៃ ចូរអ្នកបណ្តុះនូវផ្លូវសន្តិភាពតែម្យ៉ាង ព្រះនិព្វាន ព្រះសុគតបានសម្តែងហើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឧច្ចិន្ទ** គឺចូរកាត់ដោយអរហត្តមគ្គ ។ បទថា **សារទិកំ** បានដល់ ដែលកើតហើយក្នុងសរទកាល ។

បទថា **សន្តិមគ្គំ** គឺនូវផ្លូវដែលមានអង្គ ៨ ដែលញ្ចុាំងសត្វឲ្យដល់នូវព្រះនិព្វាន ។ បទថា **ព្រូហយ** គឺចូរចម្រើន ។ បទថា **និព្វានំ** សេចក្តីថា ព្រោះព្រះនិព្វាន ព្រះសុគតទ្រង់សម្តែងហើយ ព្រោះដូច្នោះ ចូរអ្នកចម្រើនផ្លូវនៃព្រះនិព្វាននោះ ។ ក្នុងកាលចប់ទេសនា ភិក្ខុនោះ តាំងនៅក្នុងអរហត្តហើយ ដូច្នេះឯង ។

រឿងសធ្ទិវិហារិការបស់ព្រះសារីបុត្តត្តេរ ចប់

រឿង ឈ្មួញមានទ្រព្យច្រើន

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឈ្មួញមានទ្រព្យច្រើន ត្រាស់ព្រះធម្មទេសនានេះថា **ឥធ វស្សំ** ជាដើម ។

បានឮមកថា ឈ្មួញនោះជាក់សំពត់ដែលជ្រលក់ដោយផ្កាដកគាំ ពេញរទេះ ៥០០ ចេញអំពីក្រុងពារាណសីហើយ មកកាន់ក្រុងសាវត្ថីដើម្បីជួញដូរ ដល់ប្រាំងស្ងួងហើយគិតថា ស្អែកនេះនឹងធ្លងស្ងួង ដោះរទេះស្នាក់នៅត្រង់ប្រាំងនោះឯង ។ លុះពេលយប់ មហាមេឃតាំងខ្យើងញាំងភ្លៀងឲ្យធ្លាក់ ។ ស្ងួងពេញដោយទឹកអស់ ៧ ថ្ងៃ ។ ក្នុងព្រះនគរ ពួកជនក៏លេងនក្ខត្តឫក្សអស់ ៧ ថ្ងៃ កិច្ចដោយសំពត់ជ្រលក់ដោយផ្កាដកគាំ មិនមាន ។ ឈ្មួញគិតថា អញមកអំពីចម្ងាយ បើអញទៅទៀត ការយឺតយូរនឹងមាន អញនឹងនៅធ្វើការងាររបស់អញ ក្នុងទីនេះឯងអស់រដូវភ្លៀង រដូវរងា និងរដូវក្តៅ ហើយលក់សំពត់ទាំងនេះ ។

ព្រះសាស្តា ត្រាច់ទៅបិណ្ឌបាតក្នុងព្រះនគរ ទ្រង់ជ្រាបចិត្តរបស់ឈ្មួញហើយ ទ្រង់ធ្វើនូវការញញឹមឲ្យប្រាកដ ព្រះអានន្ទត្ថេរសួរហេតុនៃការញញឹម ទ្រង់ត្រាស់ថា អានន្ទ អ្នកឃើញឈ្មួញមានទ្រព្យច្រើនដែរទេ អានន្ទទូលថា ឃើញព្រះអង្គ ព្រះសាស្តាត្រាស់ថា បុរសនេះមិនដឹងអន្តរាយនៃជីវិត ទើបតាំងចិត្តនៅលក់របស់ក្នុងទីនេះអស់មួយឆ្នាំ អានន្ទទូលថា បពិត្រព្រះអង្គ អន្តរាយនឹងមានដល់គាត់ឬ ព្រះសាស្តាត្រាស់ថា អើអានន្ទ បុរសនេះនៅបាន ៧ ថ្ងៃទៀតប៉ុណ្ណោះ នឹងតាំងនៅក្នុងមាត់នៃមច្ចុ ដូច្នេះហើយ ទ្រង់កាសិតព្រះ

គាថាទាំងនេះថា

ឯការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះ ឯង អ្នកណាអាចដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ អ្នកប្រាជ្ញដែលស្ងប់ទុក្ខហើយ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកម្ចាត់កិលេស ជាអ្នកមិនខ្ជិលច្រអូសអស់ថ្ងៃនិងយប់នោះឯងថា ជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងទៅប្រាប់ឈ្មួញនេះ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ អ្នកស្និទ្ធស្នាលនឹងបុរសនោះ ទៅក៏ទៅចុះ ។

ព្រះថេរៈទៅកាន់ទីដែលរនេះត្រាច់ទៅដើម្បីភិក្ខា ឈ្មួញទទួលព្រះថេរៈដោយអាហារ ។ លុះដាប់នោះ ព្រះថេរៈពោលនឹងឈ្មួញនោះថា អ្នកនៅក្នុងទីនេះអស់កាលមានប្រមាណប៉ុនណា ឈ្មួញពិតថា បពិត្រលោកម្ចាស់ ខ្ញុំមកអំពីឆ្ងាយ បើនឹងទៅទៀតការយឺតយូរនឹងមាន ខ្ញុំនឹងនៅក្នុងទីនេះអស់មួយឆ្នាំលុះរបស់អស់ហើយ នឹងទៅ ។

ព្រះអានន្ទពោលថា ឧបាសក អន្តរាយនៃជីវិតជីងបានលុះបាក ការធ្វើសេចក្តីមិនប្រមាទ ទើបគួរ ឈ្មួញពោលថា បពិត្រលោកម្ចាស់ អន្តរាយនឹងមានឬ ព្រះអានន្ទពោលថា អើ ឧបាសក ជីវិតរបស់អ្នកនៅបាន ៧ ថ្ងៃប៉ុណ្ណោះ បុរសនោះ មានចិត្តសង្វេគហើយ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជា

ប្រធាន ថ្វាយមហាទានអស់ ៧ ថ្ងៃ ហើយទទួលបាត្រដើម្បីប្រយោជន៍ដល់ការអនុមោទនា ។

លំដាប់នោះ ព្រះសាស្តាកាលទ្រង់ធ្វើអនុមោទនាដល់បុរសនោះ ត្រាស់ថា ម្នាលឧបាសក ធម្មតាបណ្ឌិត គិតថា អញនឹងនៅក្នុងទីនេះឯងអស់រដូវភ្លៀងជាដើម នឹងប្រកបការងារបែបនេះៗ រមែងមិនគួរ គួរគិតដល់អន្តរាយនៃជីវិតរបស់ខ្លួនប៉ុណ្ណោះ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

៨ធ វស្សំ វសិស្សាមិ ៨ធ ហេមន្តគិម្ហិសុ
៨តិ ពាលោ វិចិន្តេតិ អន្តរាយំ ន ពុជ្ឈតិ ។

អញនឹងនៅក្នុងទីនេះ អស់វស្សានរដូវ អញនឹងនៅក្នុងទីនេះ ក្នុងហេមន្តរដូវ និងគិម្ហរដូវ ជនពាលតែងគិតខុសដូច្នេះ តែងមិនដឹងច្បាស់នូវសេចក្តីអន្តរាយឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **៨ធ វស្សំ** សេចក្តីថា អញនឹងនៅធ្វើការងារនេះៗ ក្នុងទីនេះ អស់រដូវភ្លៀង ៤ ខែ ។

បទថា **ហេមន្តគិម្ហិសុ** សេចក្តីថា បុគ្គលពាលមិនដឹងប្រយោជន៍ប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ និងសម្បរាយភព រមែងគិតយ៉ាងនេះថា អញនឹងនៅធ្វើការងារនេះៗ ក្នុងទីនេះឯង អស់កាល ៤ ខែ ក្នុងរដូវរងា និងរដូវក្តៅ ។

បទថា **អន្តរាយំ** សេចក្តីថា រមែងមិនដឹងអន្តរាយនៃជីវិតរបស់ខ្លួនថា អញនឹងស្លាប់ក្នុងកាល ក្នុងបទេស ឬក្នុងវ័យឈ្មោះនោះ ។

ក្នុងកាលចប់ទេសនា ឈ្មួញនោះ តាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ។ ចំណែកឈ្មួញនេះ ជូនដំណើរព្រះសាស្តាហើយ ត្រឡប់មកដេកលើដំណេកដោយគិតថា រោគក្នុងក្បាលហាក់ដូចជាកើតទ្បើងដល់អញ ដេកហើយដោយអាការនោះឯង ធ្វើកាលកិរិយាហើយ កើតក្នុងតុសិតវិមាន ដូច្នេះឯង ៗ

រឿង ឈ្មួញមានទ្រព្យច្រើន ចប់

រឿង ជាងកិសាគោតមី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងកិសោគោតមី ត្រាស់ព្រះធម្មទេសនានេះថា **នំ បុត្តបសុសម្មត្តំ** *ជាដើម ។*

រឿងរ៉ាវខ្ញុំបានពោលហើយ ក្នុងកិច្ចពណ៌នាព្រះគាថាក្នុងសហស្សវគ្គថា

> *បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញផ្លូវព្រះនិព្វាន ការរស់នៅសូម្បីតែ ១ ថ្ងៃ របស់លោកអ្នកឃើញផ្លូវព្រះនិព្វាន ប្រសើរជាង ។*

ក្នុងកាលនោះ ព្រះសាស្តាត្រាស់ថា ម្នាលកិសាគោតមី គ្រាប់ស្ពៃប្រមាណមួយចឹប នាងរកបានហើយឬ កិសាគោតមីពោលថា បពិត្រព្រះអង្គ មិនបានទេ ក្នុងស្រុកទាំងមូល អ្នកស្លាប់នោះឯងមានច្រើនជាងអ្នករស់ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា នាងយល់ថាបុត្ររបស់នាងប៉ុណ្ណោះស្លាប់ហើយ ការស្លាប់នោះជាធម្មទៀងពិតរបស់សព្វសត្វ ។ ព្រោះមច្ចុរាជ អូសសព្វសត្វដែលមានអធ្យាស្រ័យមិនទាន់ពេញប៉ុណ្ណោះ បន្សាត់ទៅក្នុងសមុទ្រ គឺអបាយ ដូចជំនន់ទឹកធំដូច្នោះ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

តំ បុត្តបសុសម្បន្នំ ព្យាសត្តមនសំ នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។

មច្ចុ គឺសេចក្តីស្លាប់ តែងនាំយកនរជនអ្នកស្រេកឃ្លានជ្រប់ ក្នុងកូន និងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗនោះ ដូចជំនន់ទឹកធំ នាំយកអ្នកស្រុកកំពុងដេកលក់ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **តំ បុត្តបសុសម្បន្នំ** *សេចក្តីថា នរៈនោះដែលបានបុត្រ និងបសុសត្វទាំងឡាយ ដែលដល់ព្រមដោយរូប និងកម្លាំងជាដើមហើយ ស្រេកឃ្លាន គឺប្រមាទហើយ ដោយបុត្រ និងបសុសត្វទាំង-ឡាយយ៉ាងនេះថា កូនរបស់អញមានរូបស្អាត មានកម្លាំងបរិបូណ៌ ឈ្លាសអាចក្នុងកិច្ចគ្រប់យ៉ាង គោរបស់អញមានរូបស្អាត ជ្រាសចាកពោគ អាចនាំរបស់ទៅបានច្រើន មេគោរបស់អញ មានទឹកដោះច្រើន ។*

បទថា **ព្យាសត្តមនសំ** *សេចក្តីថា ឈ្មោះថា បុគ្គលមានចិត្តជាប់ជំពាក់ហើយ (ក្នុងអារម្មណ៍) ព្រោះបានបណ្តាប្រាក់ និងមាសជាដើម ឬសមណ-*

បរិក្ខារទាំងឡាយ មានបាត្រ និងចីវរជាដើមណាមួយប៉ុណ្ណោះ ហើយប្រាថ្នាក្រៃលែងឡើងជាងនោះ ។ ម្យ៉ាងទៀត ឈ្មោះថា មានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ ព្រោះជាប់ជំពាក់ក្នុងបណ្តាអារម្មណ៍ទាំងឡាយ ដែលគប្បីដឹងដោយចក្ខុជាដើម ឬបណ្តាសមណបរិក្ខារទាំងឡាយ មានប្រការដូចពោលហើយ ក្នុងអារម្មណ៍ និងបរិក្ខារដែលខ្លួនបានហើយនោះឯង ។

ពីរបទថា **សុត្តំ គាមំ** *បានដល់ ពួកសត្វដែលចូលដល់នូវការដេកលក់ ។*

បទថា **មហោឃោវ** *ជាដើម សេចក្តីថា អន្លង់មហានទី ជ្រៅផង ធំផង កួចអ្នកស្រុកបៃបនោះទៅទាំងអស់ ដោយហោចសូម្បីឆ្កែក៏មិនទុក យ៉ាងណា មច្ចុ រមែងនាំនរៈមានប្រការដូចពោលហើយទៅ ដូច្នោះ ។*

ក្នុងកាលចប់ទេសនា នាងកិសាគោតមី តាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់បុគ្គលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង នាងកិសាគោតមី ចប់

រឿង នាងបដាចារ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបដាចារ ត្រាស់ព្រះធម្មទេសនានេះថា **ន សន្តិ បុត្តា** *ជាដើម ។*

រឿងរ៉ាវខ្ញុំពោលពិស្តារហើយ ក្នុងកិច្ចពណ៌នាព្រះគាថា ក្នុងសហស្សវគ្គថា

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញការកើតឡើង និង
ការវិនាសទៅ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោក
ដែលឃើញការកើតឡើង និងការវិនាសទៅ ប្រសើរជាង ។

ក្នុងកាលនោះ ព្រះសាស្តាទ្រង់ជ្រាបនាងបជាចារាថា មានសេចក្តីសោក
ធូរស្រាលហើយ ទើបត្រាស់ថា ម្នាលនាងបជាចារា ឈ្មោះថា បិយជន
ទាំងឡាយ មានកូនជាដើម រមែងមិនអាចជាទីជ្រកកោន ឬការពាររបស់
បុគ្គលទៅកាន់បរលោកបានឡើយ ព្រោះដូច្នោះ ជនទាំងនោះ សូម្បីមាន ក៏
ឈ្មោះថា មិនមានពិត ឯការដែលបណ្ឌិតជម្រះសីលឲ្យបរិសុទ្ធហើយ ជម្រះ
ផ្លូវដែលជាទីទៅកាន់ព្រះនិព្វាន ដើម្បីខ្លួននោះឯង គួរ ដូច្នេះហើយ ទើបទ្រង់
សម្តែងធម៌ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

ន សន្តិ បុត្តា តាណាយ ន បិតា ន បិ ពន្ធវា
អន្តកេនាធិបន្នស្ស ន ត្ថិ ញាតីសុ តាណតា ។
ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ
និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។

កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយមិនមាន
ដើម្បីជាទីពឹង បិតាក៏មិនមាន ទាំងផៅពង្សក៏មិនមាន ដើម្បី
ជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិទាំងឡាយក៏មិនមាន
បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុង
សីល គួរប្រញាប់ប្រញាលជម្រះផ្លូវ ជាទីទៅកាន់ព្រះនិព្វាន
ឲ្យបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **តាណាយ** សេចក្តីថា ដើម្បីភាពជាអ្នកជ្រកកោន គឺដើម្បីប្រយោជន៍ដល់ភាពជាទីពឹង ។

ញាតិ មិត្ត និងបុគ្គលចិត្តល្អដ៏សេស រៀកូន និងមាតាបិតាចេញឈ្មោះថា ផៅពង្ស ។

បទថា **អត្តកេនាធិបន្នស្ស** គឺបុគ្គលត្រូវសេចក្តីស្លាប់គ្របសង្កត់ ។ ពិតហើយ ក្នុងបច្ចុប្បន្នកាល បិយជនទាំងឡាយ មានបុត្រជាដើម សូម្បីជាបុគ្គលជ្រកកោនបាន ដោយការឲ្យបាយ និងទឹកជាដើម និងដោយការជួយកិច្ចដែលកើតឡើងហើយ តែក្នុងពេលស្លាប់ ឈ្មោះថា មិនមានប្រយោជន៍ដល់ការជ្រកកោន គឺដើម្បីប្រយោជន៍ដល់ការការពារ ព្រោះភាពជាបុគ្គលមិនអាចការពារសេចក្តីស្លាប់ ដោយឧបាយណាមួយបាន ព្រោះហេតុនោះឯង ទើបព្រះសាស្តាត្រាស់ថា **ឯតិ ញាតីសុ តាណតា ។**

បទថា **ឯតមត្ថវសំ** សេចក្តីថា បណ្ឌិតជ្រាបហេតុនោះ ពោល គឺភាពដែលជនទាំងនោះជាអ្នកមិនអាច ដើម្បីជាអ្នកជ្រកកោនដល់គ្នានិងគ្នាហើយ ជាអ្នកសង្រួម គឺរក្សា បានដល់ គ្រប់គ្រងដោយបារិសុទ្ធិសីល ៤ គប្បីជម្រះផ្លូវមានអង្គ ៨ ដែលជាទីទៅកាន់ព្រះនិព្វានឲ្យបរិសុទ្ធដោយរួសរាន់ ។

ក្នុងកាលចប់ទេសនា បជាចារាតាំងនៅក្នុងសោតាបត្តិផលហើយ ជនដទៃជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ឆាឆបជាចារ ចប់

មគ្គវគ្គទី ២០ ចប់

សុត្តន្តបិដក

ធម្មបទគាថា បកិណ្ណកវគ្គទី ២១

[៣១] បើឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញសុខធំទូលាយ គប្បីលះសុខល្មមប្រមាណចេញ។

ជនប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយបង្កទុក្ខឲ្យអ្នកដទៃ ជននោះ ឈ្មោះថា ច្របូកច្របល់ហើយ ដោយការជាប់ជំពាក់ គឺពៀរ រមែងមិនរួចចាកពៀរទេ ។

របស់ណាដែលខ្លួនគួរធ្វើ របស់នោះពួកកិក្ខុណាលះបង់ចោលហើយ តែរបស់ដែលមិនគួរធ្វើ ត្រឡប់ជាធ្វើវិញ អាសវៈទាំងឡាយ តែងចម្រើនឡើងដល់ពួកកិក្ខុនោះ ជាអ្នកមានសេចក្តីប្រមាទ មានមានះដូចជាដើមបបុសលើកឡើងហើយ ។

លុះតែសតិប្រព្រឹត្តទៅ ក្នុងកាយជានិច្ច ដែលពួកកិក្ខុណាបានប្រារព្ធប្រពៃហើយ កិក្ខុទាំងនោះ រមែងជាអ្នកធ្វើការដែលគួរធ្វើរឿយៗ មិនធ្វើការដែលមិនគួរធ្វើ អាសវៈទាំងឡាយ របស់ពួកកិក្ខុនោះ ដែលជាអ្នកមានសតិមានសម្បជញ្ញៈ រមែងដល់នូវការអស់ទៅ ។

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានៈដូចបិតាផង សម្លាប់សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ដូចស្តេចជាក្សត្រ ២ ព្រះអង្គផង សម្លាប់អាយតនៈដូចជាដែន ប្រព្រឹត្តទៅ មួយអន្ទើដោយបុរសអ្នកដើរតាម គឺស្មៀនផង រមែងបានទៅជាទីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។ បុគ្គលសម្លាប់តណ្ហាដូចជាមាតាផង សម្លាប់អស្មិមានៈដូចបិតាផង សម្លាប់សស្សត-

ទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ដូចជាស្តេចជាព្រាហ្មណ៍ទាំង ២ ផង សម្ងាប់វិចិកិច្ឆា ដូចជាខ្លាធំ ជាគម្រប់ ៥ ផង (ដែលនៅស្កាត់ផ្លូវ) បានហើយ រមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងព្រះពុទ្ធគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងព្រះធម្មគុណ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងព្រះសង្ឃគុណ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងកាយ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយ ក្នុងការមិនបៀតបៀនគេ ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយ ក្នុងមេត្តាភាវនាទាំងថ្ងៃ ទាំងយប់

ជនពួកនោះ ឈ្មោះថា សាវ័កបស់ព្រះគោតម រមែងក្លាក់រឭកៗ ដោយប្រពៃ សព្វកាល ។

ការចេញបួសបានដោយក្រ ការត្រេកអរត្រូវបានដោយក្រ ផ្ទះទាំងឡាយ មានការនៅគ្រប់គ្រងដោយលំបាក ជាការក្រ ការនៅរួមដោយជនស្មើគ្នា (ដែលមិនមានសេចក្តីកោតក្រែង) ជាការក្រ ជនអ្នកដើរផ្លូវឆ្ងាយគឺវដ្ត តែងត្រូវសេចក្តីទុក្ខធ្លាក់ជាប់តាម ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជាអ្នកត្រូវសេចក្តីទុក្ខជាប់តាមផង ។ បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្គប់ស្គល់ដោយយស និងកោគសម្បត្តិ គប់រកប្រទេសណាៗ គេតែងបូជាក្នុងប្រទេសនោះៗ ។

ពួកសប្បុរស តែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិមពាន្ត ដូច្នោះ ពួកអសប្បុរស (ទុកជាស្ថិតនៅ) ក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ក្នុងវេលាយប់ ។

បុគ្គល គួរគប់រកទីអង្គុយម្នាក់ឯង ទីដេកម្នាក់ឯង ជាអ្នកត្រាច់ទៅម្នាក់ឯង មិនជាអ្នកខ្ជិលច្រអូស ជាអ្នកម្នាក់ឯងទូន្មានខ្លួន គួរជាអ្នកត្រេកអរក្នុងព្រៃស្ងាត់ ។

បកិណ្ណកវគ្គទី ២១ ចប់

អដ្ឋកថា

បកិណ្ណកវគ្គទី ២១

រឿង បុព្វកម្មព្រះសាស្តា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបុព្វកម្មរបស់ព្រះអង្គ ត្រាស់ព្រះធម្មទេសនានេះថា **មត្តាសុខបរិច្ចាគា** *ជាដើម ។*

សេចក្តីពិស្តារ សម័យមួយ ក្រុងវេសាលី បានជាក្រុងមាំទាំទូលំទូលាយ មានជនច្រើន មានមនុស្សកុះករ ។ ក្នុងក្រុងវេសាលីនោះ មានក្សត្រគ្រប់គ្រងរាជសម្បត្តិតាមវារៈរហូតដល់ ៧ ពាន់ ៧ រយអង្គ ។ ប្រាសាទដើម្បីជាប្រយោជន៍ ជាទីប្រថាប់របស់ក្សត្រទាំងនោះ ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ផ្ទះកំពូល ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ទីកន្លែងដែលគួរត្រេកអរ និងស្រះបោក្ខរណី ដើម្បីប្រយោជន៍ជាទីប្រថាប់ក្នុងព្រះរាជឧទ្យាន ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ។

ដោយសម័យដទៃទៀត កាលក្រុងវេសាលីនោះជាក្រុងមានភិក្ខាវកបានលំបាក សម្ងួចក៏អន្តរាយ ។ ដំបូង ពួកមនុស្សដែលក្រីក្រក្នុងក្រុងវេសាលីបានស្លាប់ហើយជាច្រើន ព្រោះទោស គឺការអត់ឃ្លាន ។ ពួកអមនុស្សក៏ចូលទៅក្នុងព្រះនគរ ព្រោះក្លិនសាកសពរបស់មនុស្សទាំងនោះ ដែលគេចោល

ក្នុងទីនោះៗ មនុស្សទាំងឡាយស្ងាប់ច្រើនឡើងៗ ព្រោះឧបទ្រវដែលកើតអំពីអមនុស្ស ។ អហិវាតករោគកើតឡើងដល់សត្វទាំងឡាយ ព្រោះកាពបដិកូលដោយក្លិនសាកសពនៃមនុស្សទាំងនោះ ។ ភ័យ ៣ យ៉ាង គឺភ័យកើតអំពីកិក្ខាវកបានលំបាក ១ ភ័យកើតអំពីអមនុស្ស ១ ភ័យកើតអំពីរោគ ១ កើតឡើងហើយ ដោយប្រការដូច្នេះ ។

អ្នកនគរប្រជុំគ្នាហើយ ក្រាបទូលព្រះរាជាថា បពិត្រមហារាជ ភ័យ ៣ យ៉ាង កើតឡើងហើយក្នុងព្រះនគរនេះ ក្នុងកាលមុនអំពីនេះ រហូតដល់ព្រះរាជា ៧ ជំនាន់ ឈ្មោះថា ភ័យបែបនេះ មិនធ្លាប់កើតឡើងឡើយ ព្រោះថា ក្នុងរជ្ជកាលរបស់ព្រះរាជាដែលទ្រទ្រង់ធម៌ទាំងឡាយ ភ័យបែបនេះ មិនកើតឡើងឡើយ ។

ព្រះរាជា ត្រាស់ឲ្យធ្វើការប្រជុំជនទាំងពួង ក្នុងព្រះរាជមន្ទីរ ហើយត្រាស់ថា បើការមិនទ្រទ្រង់ធម៌របស់យើងមានសោត អ្នកទាំងឡាយ ចូរពិនិត្យមើលនូវហេតុនោះ ។ អ្នកក្រុងវេសាលីពិនិត្យមើលប្រពៃណីគ្រប់យ៉ាង មិនឃើញទោសណាមួយរបស់ព្រះរាជា ទើបក្រាបទូលថា បពិត្រមហារាជ ទោសរបស់ទ្រង់មិនមាន ទើបប្រឹក្សាគ្នាថា ធ្វើម្តេចហ្ន៎ភ័យ របស់ពួកយើងគប្បីដល់នូវសេចក្តីស្ងប់ បណ្តាជនទាំងនោះ កាលជនពួកខ្លះពោលថា ភ័យគប្បីដល់នូវការស្ងប់ដោយពលីកម្ម ដោយការបួងសួង ដោយការធ្វើមង្គលជនទាំងនោះ ធ្វើវិធីទាំងអស់នោះ ក៏មិនអាចការពារបាន ។

ជនពួកខ្លះពោលយ៉ាងនេះថា គ្រូទាំង ៦ មានអានុភាពច្រើន កាលគ្រូ

ទាំង ៦ មកទីនេះហើយ ភ័យគប្បីស្ងប់ ។ ជនពួកខ្លះទៀតពោលថា ព្រះសម្មាសម្ពុទ្ធកើតឡើងក្នុងលោក ព្រះសាស្តាអង្គនោះមានឫទ្ធិច្រើន មានឫវាអានុភាពច្រើន ទ្រង់សម្តែងធម៌ដើម្បីប្រយោជន៍ដល់សព្វសត្វ កាលទ្រង់យាងមកទីនេះហើយ ភ័យទាំងនេះ គប្បីដល់នូវសេចក្តីស្ងប់បាន ។

ជនទាំងអស់ គាប់ចិត្តនឹងពាក្យរបស់ជនទាំងនោះហើយពោលថា ឥឡូវនេះ ព្រះដ៏មានព្រះភាគអង្គនោះ ប្រថាប់នៅក្នុងទីណាហ្ន៎ ក្នុងកាលនោះ ជាតិបីដែលចាំវស្សាទិតជិតចូលមកហើយ ព្រះសាស្តាទ្រង់ព្រះរាជទានប្តេជ្ញាដល់ព្រះបាទពិម្ពិសារ ហើយយាងចូលក្នុងវត្តវេឡុវ័ន ។

គ្រានោះ ស្តេចលិច្ឆវីព្រះនាមមហាលិ ទ្រង់សម្រេចសោតាបត្តិផលមួយអន្ទើដោយព្រះបាទពិម្ពិសារ ក្នុងសមាគមនៃព្រះបាទពិម្ពិសារ ប្រថាប់គង់ក្នុងទីជិតនៃបរិស័ទនោះ ។ អ្នកក្រុងវេសាលី ត្រៀមបណ្ណាការធំបញ្ជូនមហាលិលិច្ឆវី និងបុត្ររបស់បុរោហិតទៅដោយប្រាប់ថា អ្នកទាំងឡាយ ចូរញុំាងព្រះបាទពិម្ពិសារ ឲ្យឃល់ព្រមហើយ នាំព្រះសាស្តាមកក្នុងនគរនេះ ។ មហាលិលិច្ឆវី និងកូនបុរោហិតទៅហើយ ថ្វាយបណ្ណាការដល់ព្រះរាជា ក្រាបទូលការប្រព្រឹត្តទៅឲ្យទ្រង់ជ្រាបហើយ ទូលសូមថា បពិត្រមហារាជ សូមទ្រង់បញ្ជូនព្រះសាស្តាទៅកាន់នគររបស់ខ្ញុំ ព្រះរាជាត្រាស់ថា អ្នកទាំងឡាយ ចូរជីងឯងចុះ ហើយមិនទទួលបណ្ណាការនោះ ។ ជនទាំងនោះចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ទូលអារាធនាថា បពិត្រព្រះអង្គ ក្នុងក្រុងវេសាលីកើតភ័យ ៣ យ៉ាង កាលទ្រង់យាងទៅភ័យនឹងស្ងប់ សូមទ្រង់យាងចុះ ខ្ញុំ

ព្រះអង្គទាំងឡាយនឹងទៅ ។ ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ជនទាំងនោះ ហើយ ទ្រង់ពិចារណា ក៏ជ្រាបថា ក្នុងក្រុងវេសាលី កាលតថាគតសូត្រនូវ រតនសូត្រ អាជ្ញានឹងផ្សាយទៅមួយសែនកោដិចក្កវាឡ ក្នុងកាលចប់ព្រះសូត្រ ការសម្រេចធម៌មានដល់សត្វ ៨៤០០០ ភ័យទាំងនោះនឹងស្ងប់ទៅ ហើយ ទ្រង់ទទួលពាក្យរបស់ជនទាំងនោះ ។

ព្រះបាទពិម្ពិសារទ្រង់ស្តាប់ថា ព្រះសាស្តាទ្រង់ទទួលដើម្បីយាងទៅក្រុង វេសាលី ហើយទ្រង់ធ្វើការប្រកាសក្នុងព្រះនគរ ចូលទៅគាល់ព្រះសាស្តាទូល សួរថា បពិត្រព្រះអង្គ ព្រះអង្គទទួលការយាងទៅក្រុងវេសាលីឬ កាលព្រះ សាស្តាត្រាស់ថា ពិតហើយ មហារាជ ក៏ក្រាបទូលថា បើដូច្នោះ សូមទ្រង់ បង្អង់សិន ទូលបង្គំនឹងរៀបចំផ្លូវជាមុន ហើយត្រាស់ឲ្យពង្រាបដី ៥ យោជន៍ ក្នុងរវាងក្រុងរាជគ្រឹះ និងស្ទឹងគង្គាឲ្យរាបស្មើ ឲ្យចាត់វិហារមួយយោជន៍ៗ ១ ទើបក្រាបទូលកាលយាងទៅ ដល់ព្រះសាស្តា ។

កាលនោះ ព្រះសាស្តាយាងជាមួយភិក្ខុ ៥០០ រូប ព្រះរាជាទ្រង់រោយ ផ្កា ៥ ពណ៌ កម្ពស់ប្រមាណស្មើក្បាលជង្គង់ ក្នុងរវាងមួយយោជន៍ៗ រួច ឲ្យលើកទង់ជ័យ ទង់ជ្វាលា និងដើមចេកជាដើម ឲ្យចាំងស្វេតច្ឆត្រពីរជាន់ ដល់ព្រះសាស្តា ចាំងស្វេតច្ឆត្រមួយជាន់ដល់ភិក្ខុទាំងឡាយ ដែលជាបរិវារ ទ្រង់ធ្វើការបូជាដោយផ្កា និងគ្រឿងក្រអូបជាដើម ទ្រង់អារាធនាព្រះសាស្តា ឲ្យប្រថាប់ក្នុងវិហារនីមួយៗ ថ្វាយមហាទាន ហើយទ្រង់យាងដល់មាត់ច្រាំង ស្ទឹងគង្គា ដោយរយៈកាល ៥ ថ្ងៃ ព្រះរាជាទ្រង់រៀបចំទូកក្នុងទីនោះ ទ្រង់

បញ្ជូនដំណឹងទៅដល់អ្នកក្រុងវេសាលីថា អ្នកក្រុងវេសាលី ចូររៀបចំធ្វើផ្លូវ ធ្វើការទទួលព្រះសាស្តាចុះ ។

អ្នកក្រុងវេសាលីទាំងនោះគិតថា យើងនឹងបូជាទ្វេគុណ ហើយពង្រាបផែនដីប្រមាណ ៣ យោជន៍ក្នុងរវាងក្រុងវេសាលី និងស្ទឹងគង្គាឲ្យស្មើ ហើយត្រៀមស្វេតច្ឆត្រ ដើម្បីព្រះសាស្តា ៤ ជាន់ ដើម្បីភិក្ខុមួយរូប ២ ជាន់ ធ្វើនូវការបូជា បានមកឈរត្រង់ច្រាំងស្ទឹងគង្គាហើយ ។

ព្រះបាទពិម្ពិសារទ្រង់រៀបចំទូក ២ ធ្វើឲ្យល្អ ប្រដាប់ដោយផ្កាជាដើម ក្រាលពុទ្ធាសន:ដោយរតន:គ្រប់យ៉ាង ព្រះសាស្តាប្រថាប់គង់លើពុទ្ធាសន: នោះ សូម្បីភិក្ខុទាំងឡាយក៏ឡើងកាន់ទូក អង្គុយចោមរោមព្រះសាស្តាហើយ ។ ព្រះរាជាកាលតាមជូនដំណើរ បានចុះទៅក្នុងទឹកប្រមាណត្រឹមព្រះសូរង ក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់យាងមកដរាបណា ខ្ញុំព្រះអង្គនឹងនៅត្រង់ច្រាំងស្ទឹងនេះឯងដរាបនោះ បញ្ជូនទូកទៅហើយ ទ្រង់យាងត្រឡប់ ។ ព្រះសាស្តាទៅក្នុងស្ទឹងគង្គាអស់ចម្ងាយ ១ យោជន៍ ដល់ដែនរបស់អ្នកក្រុងវេសាលី ។

ស្តេចលិច្ឆវីទាំងឡាយ ទ្រង់ទទួលព្រះសាស្តា លុយទឹកប្រមាណត្រឹមព្រះសូរង នាំទូកឡើងកាន់ច្រាំងហើយ យាងព្រះសាស្តាចុះអំពីទូក ។ កាលព្រះសាស្តាឡើងអំពីទូក ជាន់ច្រាំងស្ទឹងប៉ុណ្ណោះ មហាមេឃតាំងឡើង ញ្ជាំងភ្លៀងបោក្ខរពស៍សិឲ្យធ្លាក់ហើយ ។ ក្នុងទីគ្រប់អន្ទើ ទឹកប្រមាណត្រឹមក្បាលជង្គង់ត្រឹមភ្លៅ ត្រឹមចង្កេះហូរនាំសាកសពទាំងពួងចូលទៅកាន់ស្ទឹងគង្គាហើយ ភូមិភាគបានស្អាតហើយ ស្តេចលិច្ឆវីទាំងឡាយ ទូលឲ្យព្រះសាស្តាប្រថាប់នៅក្នុង

ទីមួយយោជន៍ថ្វាយមហាទាន ធ្វើការបូជាទ្វេដង នាំចូលទៅកាន់ក្រុងវេសាលី អស់ ៣ ថ្ងៃ ។ សក្កទេវរាជ កាលពួកទេវតាចោមរោម បានយាងមកហើយ ។ អមនុស្សទាំងឡាយបានគេចទៅដោយច្រើន ព្រោះទេវតាទាំងឡាយមានសក្តិធំប្រជុំគ្នាហើយ ។

ព្រះសាស្តា ប្រថាប់ឈរត្រង់ទ្វារនគរក្នុងពេលល្ងាច ត្រាស់ហៅព្រះអានន្ទមកហើយ ត្រាស់ថា អានន្ទ ចូរអ្នករៀនរតនសូត្រនេះ ហើយត្រាច់ទៅជាមួយលិច្ឆវីកុមារទាំងឡាយ ធ្វើព្រះបរិត្តក្នុងរវាងកំពែង ៣ ជាន់ក្នុងក្រុងវេសាលី ។ ព្រះថេរៈរៀនរតនសូត្រដែលព្រះសាស្តាប្រទាន ហើយយកបាត្រសម្រេចដោយថ្ម របស់ព្រះសាស្តាទៅដងទឹក ឈរត្រង់ទ្វារព្រះនគរហើយ ។ រម្ងឹកដល់គុណរបស់ព្រះសាស្តាទាំងអស់ តាំងអំពីផ្តើមសេចក្តីព្យាយាមថា បារមី ៣០ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ មហាបរិច្ចាគ ៥ ចរិយា ៣ គឺលោកត្ថចរិយា ១ ញាតត្ថចរិយា ១ ពុទ្ធត្ថចរិយា ១ ការឈានកន្ងងចុះកាន់គភិក្នុងភពទីបំផុត ការប្រសូតិ ការយាងចេញមហាភិនេស្ក្រមណ៍ ការប្រព្រឹត្តព្យាយាម ការឈ្នះមារ ការចាក់ធ្ងុះសព្វញ្ញុតញ្ញាណ លើរតនបល្ង្ក ត្រង់មណ្ឌលពោធិព្រឹក្ស ការញ្ចាំងធម្មចក្កឲ្យប្រព្រឹត្តទៅ និងព្រះលោកុត្តរធម៌ ៩ ហើយចូលទៅកាន់ព្រះនគរ ត្រាច់ធ្វើព្រះបរិត្តក្នុងរវាងកំពែងទាំង ៣ អស់ ៣ យាមនៃរាត្រី កាលពាក្យថា **យំ កិញ្ចិ** ជាដើមដែលព្រះថេរៈនោះពោលហើយប៉ុណ្ណោះ ទឹកដែលប្រោសឡើងទៅខាងលើធ្លាក់លើក្បាលអមនុស្សទាំងឡាយ ។

ចាប់តាំងអំពីពោលគាថាថា **យានីធ ភូតានិ** *ជាដើម តំណក់ទឹកហាក់បីដូចឈ្នួតប្រាក់ តាំងឡើងនៅក្នុងអាកាស ហើយធ្លាក់ខាងលើមនុស្សទាំង-ទ្វាយដែលឈឺ ។ មនុស្សទាំងទ្វាយ ក៏ជាសះស្បើយរោគក្នុងវេលានោះឯង ហើយក្រោកឡើងចោមរោមព្រះថេរៈ ។ ចាប់តាំងអំពីបទថា* **យំ កិញ្ចិ** *ជាដើម ដែលព្រះថេរៈពោលហើយ អមនុស្សទាំងទ្វាយ ត្រូវតំណក់ទឹកប៉ះខូចហើយ ដែលមិនទាន់គេចទៅកាលអំពីមុន ដែលអាស្រ័យគំនរសំរាម និងចំណែកនៃជញ្ជាំងផ្ទះជាដើម ក៏គេចទៅតាមទ្វារនោះៗ ទ្វារទាំងទ្វាយមិនគ្រប់គ្រាន់ ពួកអមនុស្សទាំងនោះ កាលមិនបានឱកាស ក៏ច្រោះកំពែងគេចទៅ ។ មហាជនច្រោះព្រំព្រះរាជមន្ទីរ ត្រង់កណ្តាលលានព្រះនគរ ដោយគ្រឿងក្រអូបទាំងពួង ចងពិដានដ៏វិចិត្រ ដោយផ្កាយមាសជាដើមខាងលើ តាក់តែងពុទ្ធាសនៈនាំព្រះសាស្តាមកហើយ ។*

ព្រះសាស្តា ប្រថាប់គង់លើអាសនៈដែលតាក់តែងហើយ ភិក្ខុសង្ឃក្តីស្តេចលិច្ឆវីក្តី អង្គុយចោមរោមព្រះសាស្តាហើយ ។ សក្កទេវរាជ ដែលពួកទេវតាចោមរោមហើយ បានប្រថាប់ឈរក្នុងឱកាសសមគួរ ។ ចំណែកព្រះថេរៈត្រាច់ទៅកាន់ព្រះនគរទាំងមូលដោយលំដាប់ហើយ មកជាមួយមហាជនដែលជាសះស្បើយរោគ ថ្វាយបង្គំព្រះសាស្តាអង្គុយហើយ ព្រះសាស្តាត្រួតមើលបរិស័ទហើយ ទ្រង់បានកាសិតរតនសូត្រនោះដដែលទៀត ក្នុងកាលចប់ទេសនាការត្រាស់ដឹងធម៌ មានដល់សត្វ ៨៤០០០ ហើយ ។

ព្រះសាស្តា ទ្រង់សម្តែងរតនសូត្រនោះអស់ ៧ ថ្ងៃ គឺក្នុងស្អែកឡើង

ក៏ទ្រង់សម្តែងយ៉ាងនោះ ទ្រង់ជ្រាបភ័យទាំងពួងស្ងប់ហើយ ត្រាស់តឿនស្តេចលិច្ឆវីហើយ យាងចេញអំពីនគរវេសាលី ស្តេចលិច្ឆវីទាំងឡាយទ្រង់ធ្វើសក្ការៈទេគុណ នាំព្រះសាស្តាទៅកាន់ស្ទឹងគង្គាអស់ ៣ ថ្ងៃ ។

ស្តេចនាគទាំងឡាយ ដែលកើតក្នុងស្ទឹងគង្គាគិតថា មនុស្សទាំងឡាយធ្វើសក្ការៈដល់ព្រះតថាគត យើងទាំងឡាយនឹងធ្វើអ្វីហ្ន៎ ស្តេចនាគទាំងនោះនិម្មិតទូកសម្រេចដោយមាស ប្រាក់ និងកែវមណី រៀបចំបល្ល័ង្កសម្រេចដោយមាស ប្រាក់ និងកែវមណី ធ្វើទឹកឲ្យដេរដាសដោយផ្កាឈូក ៥ ពណ៌ ហើយទូលអារាធនាព្រះសាស្តា ដើម្បីឡើងកាន់ទូកវៀងៗ ខ្លួនថា បពិត្រព្រះអង្គសូមទ្រង់ធ្វើការអនុគ្រោះដល់ខ្ញុំព្រះអង្គទាំងឡាយចុះ មនុស្ស និងនាគទាំង-ឡាយ រមែងធ្វើការបូជាព្រះតថាគត ។

ទេវតាទាំងពួង តាំងអំពីទេវតាដែលស្ថិតក្នុងភាគផែនដី រហូតដល់ព្រហ្មលោកជាន់អកនិដ្ឋៈ គិតថា ពួកយើងនឹងធ្វើអ្វីហ្ន៎ ហើយធ្វើសក្ការៈ ។ បណ្តាមនុស្ស និងអមនុស្សទាំងនោះ នាគទាំងឡាយ លើកស្ងួតច្ឆត្រត្រួតគ្នាឡើង ប្រមាណ ១ យោជន៍ ឆត្រដែលត្រួតគ្នា ដែលមនុស្ស និងអមនុស្សទាំងឡាយ គឺនាគខាងក្រោម មនុស្សត្រង់ផែនដី ភុម្មដ្ឋកទេវតាត្រង់ជើមឈើ គុម្ពឈើ និងភ្នំជាជើម អាកាសដ្ឋកទេវតាលើកត្រង់កណ្តាលហើយ តាំងអំពីនាគពិភព រហូតដល់ព្រហ្មលោក មានជុំវិញចក្កវាឡជាទីបំផុត ដោយប្រការដូច្នេះ ។ ក្នុងវាងឆត្រមានទង់ជ័យ ក្នុងវាងទង់ជ័យមានទង់ជ្វាលា ក្នុងវាងទង់ជ្វាលាមាន គ្រឿងសក្ការៈ មានផ្កាលម្អិត គ្រឿងអប់ និងគ្រឿងក្រអូប

ជាដើម ។ ទេវបុត្រទាំងឡាយ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង កាន់យកភេទនៃអ្នកលេងមហោស្រព ត្រាច់ទៅក្នុងអាកាស ។ បានឮថា សមាគម ៣ កន្លែងប៉ុណ្ណោះ គឺសមាគមក្នុងពេលសម្តែងយមកបាដិហារ្យ ១ សមាគមក្នុងពេលទ្រង់ចុះអំពីទេវលោក ១ សមាគមក្នុងពេលចុះកាន់ស៊ីងគង្គានេះ ១ ជាសមាគមធំ ។

ចំណែកព្រះបាទពិម្ពិសារ ទ្រង់ត្រៀមសក្ការៈទេគុណ អំពីសក្ការៈដែលពួកស្តេចលិច្ឆវីធ្វើ ទ្រង់បានឈរមើលការយោងមកបស់ព្រះសាស្តាត្រង់ត្រើយម្ខាង ។ ព្រះសាស្តាទតនូវការបរិច្ចាគធំបស់ព្រះរាជាទាំងឡាយ ក្នុងត្រើយស៊ីងគង្គា និងទ្រង់ជ្រាបអធ្យាស្រ័យរបស់សត្វទាំងឡាយ មាននាគជាដើមហើយទ្រង់និម្មិតព្រះពុទ្ធនិម្មិតមួយអង្គៗ មានកិក្ខុ ៥០០ ជាបរិវារក្នុងទូកនីមួយៗ ។ ព្រះដ៏មានព្រះភាគ កាលពួកនាគចោមរោមហើយ បានប្រថាប់គង់ខាងក្រោមស្វេតច្ឆត្រនីមួយៗ និងដើមកប្បព្រឹក្ស និងកម្រងផ្កា ។ ទ្រង់និម្មិតព្រះពុទ្ធនិម្មិតមួយអង្គៗ ព្រមទាំងបរិវារក្នុងឱកាសនីមួយៗ ក្នុងទេវតាទាំងឡាយ មានកុម្ភដ្ឋកៈជាដើម ។ ក្នុងល្វែងនៃចក្កវាឡនីមួយៗ ហាក់បីដូចមានមហោស្រពតែមួយ និងមានការលេងតែមួយដោយប្រការដូច្នេះហើយ ព្រះសាស្តាកាលទ្រង់ធ្វើការអនុគ្រោះដល់នាគទាំងឡាយ បានយាងឡើងកាន់ទូកតែមួយ សូម្បីកិក្ខុទាំងឡាយ កិក្ខុមួយរូបៗ ក៏ឡើងកាន់ទូកមួយៗដូចគ្នា ។

ស្តេចនាគទាំងឡាយ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យចូលទៅកាន់នាគពិភព ស្តាប់ធម្មកថាក្នុងសម្នាក់របស់ព្រះសាស្តា អស់មួយប៉ប់ទល់ភ្លឺ

ក្នុងថ្ងៃទី ២ អង្គាសកិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយរបស់គួរទំពា ដោយរបស់គួរបរិភោគដែលជាទិព្វ ។ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាហើយ ចេញអំពីនាគពិភព ដែលទេវតាក្នុងចក្កវាឡទាំងមូលបូជា ទ្រង់ឆ្លងស្ទឹងគង្គាដោយទូក ៥០០ ហើយ ។

ព្រះរាជា ទ្រង់ទទួលព្រះសាស្តាឲ្យចុះអំពីទូក ទ្រង់ធ្វើសក្ការៈទ្វេគុណ ក្រៃលែងជាងសក្ការៈស្តេចលិច្ឆវីទាំងឡាយ ដែលធ្វើក្នុងពេលយាងមក នាំព្រះសាស្តាទៅកាន់ក្រុងរាជគ្រឹះ អស់ ៥ ថ្ងៃ ដោយនយមុននោះឯង ។

ក្នុងថ្ងៃទី ២ កិក្ខុត្រឡប់អំពីបិណ្ឌបាតហើយ ក្នុងពេលល្ងាចអង្គុយប្រជុំគ្នាក្នុងរោងធម្មសភាសន្ទនាគ្នាថា គួរសរសើរអានុភាពរបស់ព្រះពុទ្ធទាំងឡាយ គួរអស្ចារ្យ ទេវតា និងមនុស្សទាំងឡាយនាំគ្នាជ្រះថ្លាក្នុងព្រះសាស្តា ព្រះរាជាទាំងឡាយទ្រង់ធ្វើផែនដីឲ្យស្មើដោយចម្ងាយផ្លូវ ៨ យោជន៍ ទាំងត្រើយអាយ និងត្រើយនាយនៃស្ទឹងគង្គា រោយខ្សាច់ ក្រាលដោយផ្កាមានពណ៌ផ្សេងៗ កម្ពស់ប្រមាណត្រឹមជង្គង់ ដោយការជ្រះថ្លាដែលប្រព្រឹត្តទៅហើយក្នុងព្រះពុទ្ធទីកក្នុងស្ទឹងគង្គាក៏ដេរដាសដោយផ្កាឈូកមាន ៥ ពណ៌ ដោយអានុភាពរបស់នាគ ទេវតាទាំងឡាយក៏លើកធត្រត្រួតៗ គ្នាឡើងរហូតដល់អកនិដ្ឋភព ស្ទឹង ចក្កវាឡទាំងមូល មានគ្រឿងប្រដាប់តែមួយ និងមានមហោស្រពតែមួយ ។

ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រឿងបូជា

និងសក្ការ:នេះ មិនបានកើតឡើងដល់តថាគតដោយពុទ្ធានុភាព មិនបានកើតឡើងដោយអានុភាពរបស់នាគ ទេវតា និងព្រហ្មឡើយ តែកើតដោយអានុភាពនៃការបរិច្ចាគមានប្រមាណតិចតួចក្នុងអតីត កាលភិក្ខុទាំងឡាយទូលអារាធនាហើយ ប្រាថ្នានឹងប្រកាសសេចក្តីនោះ ទើបទ្រង់នាំអតីតនិទាន មកត្រាស់ថា

ក្នុងអតីតកាល ក្នុងនគរតក្កសិលា មានព្រាហ្មណ៍ម្នាក់ ឈ្មោះសង្ខ: មានកូនប្រុសម្នាក់ ឈ្មោះសុសិម: មានអាយុ ១៦ ឆ្នាំ ក្នុងថ្ងៃមួយសុសិម-មាណពនោះ ចូលទៅរកបិតាហើយ ពោលថា បពិត្រលោកឪពុក ខ្ញុំប្រាថ្នានឹងទៅកាន់ក្រុងពារាណសី រៀនមន្ត ។ លំដាប់នោះ បិតាពោលនឹងមាណពថា នែបា បើដូច្នោះ ព្រាហ្មណ៍ឈ្មោះនោះ ជាសម្ងាញ់របស់ឪពុក ចូរបាទៅកាន់សម្នាក់របស់សម្ងាញ់នោះ ហើយរៀនចុះ បុរសនោះទទួលថា សាធុ ហើយទៅដល់ក្រុងពារាណសីដោយលំដាប់ ចូលទៅរកព្រាហ្មណ៍នោះហើយ ប្រាប់ភាពដែលខ្លួនបិតាបញ្ជូនមកហើយ ។

លំដាប់នោះ ព្រាហ្មណ៍នោះទទួលមាណពដោយគិតថា កូនសម្ងាញ់របស់អញ ហើយប្រាប់មន្តដល់មាណព បុគ្គលមានសេចក្តីក្រវល់ក្រវាយស្ងប់រម្ងាប់ហើយ ដោយថ្ងៃចម្រើន សុសិមមាណពនោះរៀនដោយរហ័សផង រៀនបានច្រើនផង ទ្រទ្រង់ចាំនូវមន្តដែលរៀនហើយ មិនឲ្យវិនាសទៅ ហាក់បីដូចខ្ងាញ់សីហ: ដែលគេចាក់ក្នុងភាជន៍មាស ។ ក្នុងកាលមិនយូរប៉ុន្មាន បានរៀនមន្តទាំងឡាយអស់ ដែលខ្លួនគប្បីរៀនអំពីមាត់របស់អាចារ្យ ធ្វើការស្វាធ្យាយរមែងយើញខាងដើម កណ្តាលនៃសិប្ស:ដែលខ្លួនរៀនហើយប៉ុណ្ណោះ មិនយើញ

ទីបំផុត ។ មាណពចូលទៅរកអាចារ្យហើយពោលថា ខ្ញុំឃើញតែខាងជើមនិងកណ្តាលនៃសិប្បៈនេះប៉ុណ្ណោះ មិនឃើញខាងចុង កាលអាចារ្យពោលថា នែបា សូម្បីខ្ញុំក៏មិនឃើញដែរ ទើបសួរថា បពិត្រលោកអាចារ្យ កាលបើដូច្នោះ អ្នកណាដឹងទីបំផុត កាលអាចារ្យពោលថា នែបា ឥសីទាំងឡាយនៅក្នុងព្រៃឥសិបតនៈ ឥសីទាំងនោះ ជីង ចូរអ្នកទៅកាន់សម្នាក់របស់លោកហើយ សួរចុះ ។ ទើបចូលទៅរកព្រះបច្ចេកពុទ្ធទាំងឡាយ ហើយសួរថា បានឮថា លោកម្ចាស់ទាំងឡាយដឹងនូវទីបំផុតឬ ព្រះបច្ចេកពុទ្ធទាំងឡាយពោលថា អើ អាត្មាទាំងឡាយ ជីង សុសិមៈពោលថា បើដូច្នោះ សូមលោកម្ចាស់ទាំង-ឡាយប្រាប់ដល់ខ្ញុំចុះ ព្រះបច្ចេកពុទ្ធពោលថា អាត្មាទាំងឡាយមិនប្រាប់ដល់បុគ្គលដែលមិនមែនបព្វជិត បើអ្នកមានបំណងដឹងទីបំផុត ចូរបួសចុះ ។

សុសិមមាណពទទួលថា សាធុ ហើយបួសក្នុងសម្នាក់ព្រះបច្ចេកពុទ្ធទាំងនោះ ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធទាំងនោះពោលនឹងសុសិមៈថា ចូរសិក្សាសេចក្តីនេះមុន ហើយប្រាប់អភិសមាចារិកវត្តដោយន័យជាដើមថា គប្បីស្មៀកយ៉ាងនេះ គប្បីដណ្តប់យ៉ាងនេះ ។ លោកសិក្សាអភិសមាចារិកវត្តនោះ ព្រោះភាពដែលខ្លួនមានឧបនិស្ស័យបរិបូរ ក្នុងកាលមិនយូរក៏ត្រាស់ដឹងបច្ចេកពោ-ធិញ្ញាណ ប្រាកដក្នុងក្រុងពារាណសីទាំងមូល ដូចព្រះចន្ទពេញវង់ ប្រាកដកណ្តាលអាកាស បានជាបុគ្គលដល់នូវភាពប្រសើរដោយលាភ និងយស ។ ក្នុងកាលមិនយូរឡើយ លោកក៏បរិនិព្វាន ព្រោះភាពនៃកម្មដែលឲ្យផល ជាអ្នកមានអាយុខ្លីដែលលោកបានធ្វើហើយ ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធទាំង-

ទ្បាយ និងមហាជននាំគ្នាធ្វើសរីរកិច្ចរបស់លោក កាន់យកធាតុប្រតិស្ថានព្រះ
ស្តូបទុកក្បែរទ្វារព្រះនគរ ។

ចំណែកសង្ឃព្រាហ្មណ៍គិតថា កូនរបស់អញទៅយូរហើយ អញនឹងដឹង
ការប្រព្រឹត្តទៅរបស់កូនអញ ប្រថ្នានឹងឃើញកូន ទើបចេញពីនគរតក្កសិលា
ដល់នគរពារាណសីដោយលំដាប់ ឃើញពួកមហាជនប្រជុំគ្នាហើយគិតថា ក្នុង
ជនទាំងនេះ សូម្បីជនម្នាក់ស្គាល់ការប្រព្រឹត្តទៅកូនរបស់អញដោយពិត ទើប
ចូលទៅរកហើយសួរថា មាណពឈ្មោះសុសិមៈមកក្នុងទីនេះ អ្នកទាំងឡាយ
ជ្រាបការប្រព្រឹត្តទៅរបស់គេដែរឬ មហាជនឆ្លើយថា អើ ព្រាហ្មណ៍ យើង
ដឹង សុសិមមាណពនោះ ស្វាធ្យាយត្រៃវេទក្នុងសម្នាក់របស់ព្រាហ្មណ៍ឈ្មោះ
នោះ បួសហើយ ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ បរិនិព្វានហើយ
នេះស្តូបរបស់លោក ដែលយើងទាំងឡាយធ្វើហើយ ។ សង្ឃព្រាហ្មណ៍នោះ
ប្រហារដើរដោយដៃ កន្ទក់កន្ទេញហើយ ទៅកាន់លានព្រះចេតិយដកស្មៅ យក
សំពត់វេចខ្ជាច់មករោយត្រង់លានព្រះចេតិយ ប្រោះដោយទឹក ហើយប្រោះព្រំ
ដោយទឹកក្រអូប បូជាដោយផ្កា លើកទង់សំពត់សាដក ចង្កត្រៃរបស់ខ្លួន
អំពីខាងលើនៃព្រះស្តូប ហើយក៏ចៀសចេញទៅ ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា ម្នាលភិក្ខុ
ទាំងឡាយ ក្នុងកាលនោះតថាគតជាសង្ឃព្រាហ្មណ៍ បានដកស្មៅក្នុងលានព្រះ
ចេតិយរបស់ព្រះបច្ចេកពុទ្ធ ឈ្មោះសុសិមៈ ដោយផលនៃកម្មរបស់តថាគត
នោះ ទើបជនទាំងឡាយធ្វើផ្លូវ ៨ យោជន៍ ឲ្យប្រាសចាកជង្គត់ និងបន្ទាឲ្យ

ស្អាត មានផ្ទៃរាបស្មើ តថាគតបានរោយខ្សាច់ក្នុងលានព្រះចេតិយនោះ ដោយផលនៃកម្មរបស់តថាគតនោះ ទើបជនទាំងឡាយក្រាលខ្សាច់ក្នុងផ្លូវប្រមាណ ៨ យោជន៍ហើយ ធ្វើនូវការបូជាដោយផ្កាក្នុងព្រៃ ត្រង់ព្រះស្តូបនោះ ដោយផលនៃកម្មរបស់តថាគតនោះ ទើបជនទាំងឡាយរោយផ្កាមានពណ៌ផ្សេងៗ ក្នុងផ្លូវ ៨ យោជន៍ ទឹកក្នុងគង្គាក្នុងទីប្រមាណមួយយោជន៍ ដេរដាសដោយផ្កាឈូក ៥ ពណ៌ តថាគតបានប្រោះព្រំផ្ទៃដីក្នុងលានព្រះចេតិយនោះ ដោយទឹកក្នុងឃ្មោក ដោយផលនៃកម្មរបស់តថាគតនោះ ទើបភ្លៀងប្រោក្ខរព័ស្សិធ្លាក់ចុះក្នុងនគរវេសាលី តថាគតបានលើកទង់សំពត់ហើយ និងចងធ្នូរអំពីខាងលើព្រះចេតិយនោះ ដោយផលនៃកម្មរបស់តថាគតនោះ ទើបល្ងែងនៃចក្កវាឡទាំងមូល ហាក់បីដូចមានមហោស្រពតែមួយ ដោយទង់ជ័យ ទង់ជ្ញាលា និងធ្នូរតរហូតដល់អកនិដ្ឋកភព ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនេះឯង ទើបសក្ការៈនោះកើតឡើងដល់តថាគត មិនមែនដោយពុទ្ធានុភាពឡើយ កើតឡើងដោយអានុភាពនៃនាគ ទេវតា និងព្រហ្មក៏មិនមែន តែកើតឡើងដោយអានុភាពនៃការបរិច្ចាគមានប្រមាណតិចក្នុងអតីតកាល ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ
ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ ។

បើឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញសុខធំទូលាយ

គប្បីលះសុខល្មមប្រមាណចេញ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មត្តាសុខបរិច្ចាគា** *សេចក្តីថា ព្រោះលះសុខតូចតាចល្មមប្រមាណ ដែលព្រះដ៏មានព្រះភាគត្រាស់ថា* **មត្តាសុខំ** *។ សុខដ៏ឧឡារ បានដល់ សុខ គឺព្រះនិព្វាន ព្រះដ៏មានព្រះភាគត្រាស់ថា សុខដ៏ទូលាយ សេចក្តីថា បើបុគ្គលគប្បីឃើញសុខដ៏ទូលាយនោះ ។*

លោកអធិប្បាយដូច្នេះថា ឈ្មោះថា សុខល្មមប្រមាណ តែងកើតឡើងដល់បុគ្គលដែលឲ្យចាត់ចែងថាសភោជនមួយ ហើយបរិភោគ ចំណែកឈ្មោះថានិព្វានសុខដ៏ទូលាយ គឺដ៏ឧឡារ រមែងកើតឡើងដល់បុគ្គលដែលលះសុខល្មមប្រមាណនោះចេញ ហើយធ្វើឧបោសថខ្ញុះ ឲ្យទានខ្ញុះ ព្រោះហេតុនោះ បើបុគ្គលឃើញសុខដ៏ទូលាយ ព្រោះលះសុខល្មមប្រមាណនោះ យ៉ាងនោះ កាលបើដូច្នោះ បណ្ឌិតកាលឃើញសុខដ៏ទូលាយនោះដោយប្រពៃ ក៏គប្បីលះសុខល្មមប្រមាណនោះចេញ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង បុព្វកម្មព្រះសាស្តា ចប់

រឿង កុមារិកាបរិភោគពងមាន់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុមារិកាដែលស៊ីពងមាន់ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **បរេនុក្ខុបធានេន** ជាដើម ។

បានឮថា ស្រុកមួយឈ្មោះបណ្ឌរៈ នៅមិនឆ្ងាយអំពីក្រុងសាវត្ថី ក្នុងស្រុកនោះមានអ្នកប្រមង់ម្នាក់ បុរសនោះកាលចូលទៅកាន់ក្រុងសាវត្ថី ឃើញពងអណ្តើកត្រង់ប្រាំងស៊ីងអចិរវតីហើយ កាន់យកពងអណ្តើកនោះ ទៅកាន់ក្រុងសាវត្ថី ឲ្យស្ងោរក្នុងផ្ទះមួយខ្នងហើយបរិភោគ បានឲ្យពងមួយដល់កុមារិកាក្នុងផ្ទះនោះ ។ កុមារិកាបានបរិភោគពងអណ្តើកនោះហើយ ចាប់តាំងអំពីនោះមិនប្រាថ្នានូវបស់ទំពាជនៃ ។ កាលនោះ មាតារបស់នាងកាន់យកពងមួយអំពីសម្បុកមាន់ហើយឲ្យដល់កុមារិកានោះ ។ កុមារិកាបរិភោគពងនោះហើយត្រូវចំណង់ក្នុងរសចងហើយ ចាប់តាំងអំពីនោះក៏កាន់យកពងមាន់មកបរិភោគឯង ។ ក្នុងពេលពង មេមាន់ឃើញកុមារិកានោះកាន់យកពងរបស់ខ្លួនទំពាស៊ី ត្រូវកុមារិកានោះបៀតបៀនហើយ ចងអាឃាតតាំងសេចក្តីប្រាថ្នាថា ឥឡូវនេះអញឃ្លាតចាកអត្តភាពនេះហើយ គប្បីកើតជាយក្ខិនី ជាអ្នកអាចទំពាស៊ីទារកបស់ហង ធ្វើកាលកិរិយាហើយកើតជាធ្នាក្នុងផ្ទះនោះឯង ។

នាងកុមារិកានោះ ធ្វើកាលកិរិយាហើយកើតជាមេមាន់ក្នុងផ្ទះនោះ ដូចគ្នា ។ មេមាន់ពងហើយ មេធ្នាទំពាស៊ីនូវពងទាំងនោះហើយ សូម្បីលើកទីពីរ លើកទីបី ក៏ទំពាស៊ីដូចគ្នា ។ មេមាន់ធ្វើសេចក្តីប្រាថ្នាថា ហង៎ទំពាស៊ីពងទាំង-ទ្បាយរបស់អញ ២-៣ ដង ឥឡូវនេះ ចង់ប្រាថ្នានឹងស៊ីអញទៀត អញឃ្លាត

ចាកអត្តភាពនេះហើយ គប្បីស៊ីហង ព្រមទាំងកូន ។ កាលឃ្លាតចាកអត្តភាព នោះហើយ កើតជាមេខ្វា ។

ឯមេឆ្មា ស្លាប់ហើយ កើតជាមេម្រឹគ ។ ក្នុងពេលម្រឹគនោះកើតកូនហើយ មេខ្វាក៏មកទំពាស៊ីមេម្រឹគនោះ មួយអន្ទេដោយកូនទាំងឡាយ ។ សត្វទាំងពីរនោះ ទំពាស៊ីនូវគ្នានិងគ្នាយ៉ាងនេះ ញុាំងទុក្ខឲ្យកើតឡើងដល់គ្នានិងគ្នា អស់ ៥០០ អត្តភាព ក្នុងទីបំផុតនាងម្នាក់កើតជាយក្ខិនី នាងម្នាក់កើតជាកុលធីតាក្នុងក្រុងសាវត្ថី ។

រឿងបន្ទាប់អំពីនេះទៅ គប្បីជ្រាបដោយនយដែលពោលហើយ ក្នុងព្រះគាថាថា **ន ហិ វេរេន វេរានិ** *ជាដើមនោះឯង ។*

តែក្នុងរឿងនេះ ព្រះសាស្តាត្រាស់ថា ពៀរវែងរម្ងាប់ដោយការមិនមានពៀរ វែងមិនរម្ងាប់ដោយពៀរ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ដល់ជនទាំងពីរ ទើបត្រាស់ព្រះគាថានេះថា

បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ
វេរសំសគ្គសំសដ្ឋោ វេរា សោ ន បរិមុច្ចតិ ។

ជនប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយបង្កទុក្ខឲ្យអ្នកដទៃ ជននោះ ឈ្មោះថា ច្របូកច្របល់ហើយដោយការជាប់ជំពាក់ គឺពៀរ វែងមិនរួចចាកពៀរទេ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បរទុក្ខូបធានេន** *សេចក្តីថា ព្រោះញុាំង*

ទុក្ខឲ្យអ្នកដទៃ អធិប្បាយថា ព្រោះញុំាងទុក្ខឲ្យកើតឡើងដល់អ្នកដទៃ ។

បាទព្រះគាថាថា **វេរសំសគ្គសំសដ្ឋោ** *សេចក្តីថា បុគ្គលនោះលាយឡំ ហើយដោយគ្រឿងលាយឡំ គឺពៀរ ដែលខ្ជួនធ្វើឲ្យជល់គ្នានិងគ្នា គឺដោយអំណាចនៃការជេរ និងការជេរតប ការប្រហារ និងការប្រហារតបជាដើម ។*

បាទព្រះគាថាថា **វេរា សោ ន បរិមុច្ចតិ** *សេចក្តីថា រមែងដល់នូវទុក្ខតែម្យ៉ាង អស់កាលជានិច្ច ដោយអំណាចនៃពៀរ ។*

ក្នុងកាលចប់ទេសនា យក្ខិនីតាំងនៅក្នុងសរណៈទាំងឡាយ សមាទានសីល ៥ ផុតហើយចាកពៀរ ចំណែកកុលធីតា តាំងនៅក្នុងសោតាបត្តិផលទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង កុមារិកាបរិភោគពរមាន់ ចប់

រឿង ភិក្ខុអ្នកឯគរភក្ខិយៈ

លំនាំដើម

ព្រះសាស្តា កាលអាស្រ័យភទ្ទិយនគរ ប្រថាប់នៅក្នុងជាតិយាវន ទ្រង់ប្រារព្ធភិក្ខុអ្នកភទ្ទិយនគរ ត្រាស់ព្រះធម្មទេសនានេះថា **យញ្ហិ កិច្ចំ** *ជាដើម ។*

បានឮមកថា ភិក្ខុអ្នកភទ្ទិយនគរទាំងនោះ ជាអ្នកខ្ជល់ខ្ជាយក្នុងការប្រជាប់ទ្រនាប់ជើង សមដូចព្រះឧបាលិត្ថេរពោលថា សម័យនោះឯង ពួកភទ្ទិយភិក្ខុ (ភិក្ខុដែលនៅក្នុងក្រុងភទ្ទិយៈ) មានសេចក្តីខ្ជល់ខ្ជាយក្នុងការប្រជាប់ទ្រនាប់

ជើង មានប្រការផ្សេងៗ គឺធ្វើទ្រនាប់ជើងស្មៅខ្ចីនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅយាប្ចងខ្ចីនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅដំណេកទន្សាយខ្ចីនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្បែកទន្សែខ្ចីនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ។បេ។ ធ្វើទ្រនាប់ជើងសំពត់ ដែលគេត្បាញដោយរោមសត្វខ្ចីនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ហើយលះបង់នូវបាលី អដ្ឋកថា អធិសីល អធិចិត្ត និងអធិប្បញ្ញាសោះ ។ វេលានោះ ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះ ដល់ព្រះមានព្រះភាគ ។

ព្រះសាស្តា ទ្រង់តិះដៀលភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មកដោយកិច្ចដទៃហើយ ខ្វល់ខ្វាយក្នុងកិច្ចដទៃដូច្នេះហើយ កាលទ្រង់សម្តែងធម៌ បានត្រាស់ព្រះគាថាទាំងនេះថា

យញ្ហិ កិច្ចំ តទបវិទ្ធំ អកិច្ចំ បន កយីរតិ
ឧន្នឡានំ បមត្តានំ តេសំ វឌ្ឍន្តិ អាសវា
យេសញ្ច សុសមារទ្ធា និច្ចំ កាយគតា សតិ
អកិច្ចន្តេ ន សេវន្តិ កិច្ចេ សាតច្ចការិនោ
សតានំ សម្បជានានំ អត្ថំ គច្ឆន្តិ អាសវា។

របស់ណាដែលខ្ចីនគួរធ្វើ របស់នោះ ពួកភិក្ខុណា លះបង់ចោលហើយ តែរបស់ដែលមិនគួរធ្វើ ត្រឡប់ជាធ្វើវិញ អាសវៈទាំងឡាយ តែងចម្រើនឡើង ដល់ពួកភិក្ខុនោះ ជាអ្នកមានសេចក្តីប្រមាទ មានមានះដូចជាដើមបបុសលើក

ឡើងហើយ ។ លុះតែសតិប្រព្រឹត្តទៅ ក្នុងកាយជានិច្ច ដែលពួកភិក្ខុណា បានប្រារព្ធប្រពៃហើយ ភិក្ខុទាំងនោះ រមែងជាអ្នកធ្វើការដែលគួរធ្វើរឿយៗ មិនធ្វើការដែលមិនគួរធ្វើ អាសវៈទាំងឡាយ របស់ពួកភិក្ខុនោះ ដែលជាអ្នកមានសតិ មានសម្បជញ្ញៈ រមែងដល់នូវការអស់ទៅ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **យញ្ហិ កិច្ចំ** *សេចក្តីថា កម្មមានយ៉ាងនេះ គឺការគ្រប់គ្រងសីលក្ខន្ធដែលមិនមានប្រមាណ ការនៅព្រៃជាវត្ត ការរក្សាធុតង្គ ភាពជាអ្នកត្រេកអរក្នុងភាវនា ឈ្មោះថា ជាកិច្ចដែលគួរធ្វើរបស់ភិក្ខុ តាំងអំពីកាលបួសហើយ ។ តែភិក្ខុទាំងនេះ លះបង់ គឺរលាស់ចោលនូវកិច្ចដែលគួរធ្វើរបស់ខ្លួន ។*

បទថា **អកិច្ចំ** *ជាដើម សេចក្តីថា ការប្រជាប់ឆត្រ ការប្រជាប់ស្បែកជើង ការប្រជាប់ទ្រនាប់ជើង ជាត្រ ស្មុគ ធម្មក្រក វត្តពន្ធចង្កេះ អង្សក ឈ្មោះថា ជាកិច្ចមិនគួរធ្វើរបស់ភិក្ខុ អធិប្បាយថា ភិក្ខុពួកណា ធ្វើវត្តនោះ អាសវៈទាំង ៤ រមែងចម្រើនដល់ភិក្ខុទាំងនោះ ដែលឈ្មោះថា មានមានះដូចដើមបបុស ដែលលើកឡើងហើយ ព្រោះការលើកមានះ ដូចដើមបបុសត្រាច់ទៅ ឈ្មោះថា ប្រមាទហើយ ព្រោះបណ្តែតបណ្តោយសតិ ។*

បទថា **សុសមារទ្ធា** *បានដល់ ផ្គងល្អហើយ ។ ពីរបទថា* **កាយ-គតាសតិ** *បានដល់ ភាវនាដែលជាគ្រឿងតាមឃើញនូវកាយ ។*

បទថា **អកិច្ចំ** សេចក្តីថា ភិក្ខុទាំងនោះ មិនសេព គឺមិនធ្វើវត្ថុដែលមិនគួរធ្វើនោះ មានការប្រដាប់ឆត្រជាដើម ។

បទថា **កិច្ចេ** សេចក្តីថា ក្នុងវត្ថុដែលខ្លួនគប្បីធ្វើ គឺក្នុងករណី មានការគ្រប់គ្រងសីលក្ខន្ធដែលមិនមានប្រមាណជាដើម ចាប់តាំងអំពីកាលដែលបួសហើយ ។

បទថា **សាតញ្ចការិនោ** បានដល់ មានប្រក្រតីធ្វើរឿយៗ គឺធ្វើមិនឈប់ អធិប្បាយថា អាសវ:ទាំង ៤ របស់ភិក្ខុទាំងនោះ ដែលឈ្មោះថាមានសតិ ព្រោះមិននៅប្រាសចាកសតិ បុគ្គលឈ្មោះថាមានសម្បជញ្ញ: ព្រោះសម្បជញ្ញ: ៤ យ៉ាង គឺសាត្ថកសម្បជញ្ញ: ១ សប្បាយសម្បជញ្ញ: ១ គោចរសម្បជញ្ញ: ១ អសម្មោហសម្បជញ្ញ: ១ រមែងដល់នូវការតាំងនៅមិនបាន គឺដល់នូវការអស់ទៅ បានដល់ មិនមាន ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះ តាំងនៅក្នុងអរហត្តផល ទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង ភិក្ខុអ្នកនតរភធ្ទិយ: ចប់

រឿង លកុណ្ឌកភទ្ទិយត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះលកុណ្ឌក-ភទ្ទិយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **មាតរំ បិតរំ ហន្ត្វា** ជាដើម ។

សេចក្តីពិស្តារ ថ្ងៃមួយ អាគន្តុកភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ ប្រថាប់នៅក្នុងទីប្រថាប់ពេលថ្ងៃ ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ខណៈនោះ ព្រះលកុណ្ឌកភទ្ទិយត្ថេរ ដើរឆ្លងទៅក្នុងទីមិនឆ្ងាយអំពីព្រះដ៏មានព្រះភាគ ។

ព្រះសាស្តា ទ្រង់ជ្រាបវារៈចិត្តរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកឃើញឬ ភិក្ខុនេះសម្លាប់មាតាបិតាហើយ ជាអ្នកមិនមានទុក្ខ ។ កាលភិក្ខុទាំងនោះ មើលមុខគ្នានិងគ្នាហើយ មានសេចក្តីសង្ស័យថា ព្រះសាស្តាត្រាស់អ្វីហ្ន៎ ទើបក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់ត្រាស់ដូចម្តេច កាលទ្រង់សម្តែងធម៌ដល់ភិក្ខុទាំងនោះ ទើបត្រាស់ព្រះគាថានេះ

មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច ខត្តិយេ
រដ្ឋំ សានុចរំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានៈដូចបិតាផង សម្លាប់សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិដូចជាក្សត្រពីរព្រះអង្គផង សម្លាប់អាយតនៈដូចជាដែន ប្រព្រឹត្តទៅមួយអន្ទឹដោយបុរសអ្នកដើរតាម គឺស្មៀនផង រមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សានុចរំ** បានដល់ ប្រព្រឹត្តទៅដោយអ្នកចាត់ការសួយឲ្យសម្រេច គឺភ្នាក់ងារអ្នកគ្រប់គ្រងសួយ ។

ក្នុងព្រះគាថានេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យថា តណ្ហា ឈ្មោះថា មាតា ព្រោះឲ្យសត្វទាំងឡាយកើតក្នុងភព ៣ ព្រោះព្រះបាលីថា តណ្ហាញ៉ាំងបុរសឲ្យកើត ។

អស្មិមានៈ ឈ្មោះថា បិតា ព្រោះអស្មិមានៈអាស្រ័យបិតាកើតឡើងថា អញជារាជឱរសរបស់ព្រះរាជាឈ្មោះនោះ ឬអញជាកូនរបស់អមាត្យ របស់ព្រះរាជាឈ្មោះនោះជាដើម ។

ទិដ្ឋិគ្រប់យ៉ាងតែងអាស្រ័យសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិទាំងពីរ ដូចសត្វលោកអាស្រ័យព្រះរាជា ដូច្នោះ ព្រោះហេតុនោះ ទើបសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ឈ្មោះថា ជាកូន្ត្រពីរព្រះអង្គ ។

អាយតនៈ ១២ ឈ្មោះថា ដែន ព្រោះដូចគ្នានឹងដែន ដោយអត្ថថា ទូលំទូលាយ ។ តម្រេកដោយសេចក្តីត្រេកអរ ដែលអាស្រ័យអាយតនៈនោះ ដូចស្មៀនចាត់ការសួយឲ្យសម្រេច ឈ្មោះថា ជាភ្នាក់ងារកប្បសួយ ។

បទថា **អនីឃោ** បានដល់ មិនមានទុក្ខ ។ បទថា **ព្រាហ្មណោ** បានដល់ បុគ្គលមានអាសវៈអស់ហើយ ។

ក្នុងព្រះគាថានេះ មានអធិប្បាយដូច្នេះថា បុគ្គលឈ្មោះថាមានអាសវៈអស់ហើយ ព្រោះកិលេសទាំងនោះ មានតណ្ហាជាដើម ដែលខ្លួនកម្ចាត់បានដោយដាវ គឺអរហត្តមគ្គញាណ ទើបជាអ្នកមិនមានទុក្ខ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះតាំងនៅក្នុងអរហត្តហើយ ។

រឿងលកុណ្ឌកភទ្ទិយត្ថេរ ចប់

ក្នុងគាថាទីពីរ រឿងក៏ដូចគ្នានឹងរឿងមុននោះឯង ។

ក្នុងកាលនោះ ព្រះសាស្តាទ្រង់ប្រោរព្ធព្រះលកុណ្ឌកភទ្ទិយត្ថេរដូចគ្នា កាលសម្តែងធម៌ដល់ភិក្ខុទាំងនោះ ទើបត្រាស់ព្រះគាថានេះថា

មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច សោត្ថិយេ
វេយ្យគ្ឃបញ្ចមំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានៈដូចបិតាផង សម្លាប់សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិដូចជាស្តេច ជាព្រាហ្មណ៍ទាំងពីរផង សម្លាប់វិចិកិច្ឆា ដូចជាខ្លាធំ ជាគម្រប់ ៥ ផង (ដែលនៅស្តាត់ផ្លូវ) បានហើយ រមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទ្វេ ច សោត្ថិយេ** គឺព្រាហ្មណ៍ទាំងពីរផង ។

ក្នុងព្រះគាថានេះ ព្រះសាស្តាត្រាស់សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ឲ្យជាព្រះរាជា ដែលជាព្រាហ្មណ៍ទាំងពីរ ព្រោះទ្រង់ជាធំក្នុងធម៌ និងព្រោះទ្រង់ជាអ្នកឈ្លាសក្នុងវិធីទេសនា ។

បណ្ឌិតគប្បីជ្រាបវិគ្គហៈ ក្នុងបទ **វេយ្យគ្ឃបញ្ចមំ** *នេះថា ផ្លូវដែលខ្លាធំត្រាច់ទៅមានភ័យដោយជុំវិញ ដើរទៅលំបាក ឈ្មោះថា ផ្លូវដែលខ្លាធំត្រាច់ទៅហើយ ។ វិចិកិច្ឆានីវរណៈ ឈ្មោះថា ជាផ្លូវដែលខ្លាធំត្រាច់ទៅហើយ ព្រោះការដែលវិចិកិច្ឆានីវរណៈនោះ ដូចគ្នានឹងផ្លូវដែលខ្លាធំត្រាច់ទៅហើយនោះ វិចិកិច្ឆានីវរណៈ ដូចគ្នានឹងផ្លូវដែលខ្លាធំត្រាច់ទៅហើយនោះ ជាគម្រប់ ៥ នៃពួក ៥ របស់នីវរណៈនោះ ព្រោះដូច្នោះ ទើបនីវរណ-បញ្ចកៈ ឈ្មោះថា មានវិចិកិច្ឆានីវរណៈ ដូចគ្នានឹងផ្លូវដែលខ្លាធំត្រាច់ទៅហើយ ជាគម្រប់ ៥ ។*

ក្នុងគាថាទីពីរនេះ មានអធិប្បាយដូច្នេះថា បុគ្គលសម្លាប់បញ្ចកនីវរណៈមានវិចិកិច្ឆាជាគម្រប់ ៥ ដូចគ្នានឹងផ្លូវដែលខ្លាធំត្រាច់ទៅហើយនេះ មិនឲ្យមានសេសសល់ដោយជាវ គឺអរហត្តមគ្គញ្ញាណ ជាព្រាហ្មណ៍មិនមានទុក្ខ ត្រាច់ទៅ ។ បទដ៏សេស ដូចគ្នានឹងបទមុននោះឯងដូច្នេះ ។

រឿងលកុណ្ឌកភទ្ទិយត្ថេរ ចប់

រឿង ឆារុសាកជិកៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបុត្ររបស់ឆារុ-សាកជិកៈ ត្រាស់ព្រះធម្មទេសនានេះថា **សុប្បពុទ្ធំ** *ជាដើម ។*

សេចក្តីពិស្តារថា ក្មេងក្នុងនគរពាជគ្រឹះពីរនាក់ គឺកូនរបស់បុគ្គលដែលជាសម្មាទិដ្ឋិម្នាក់ និងកូនរបស់បុគ្គលដែលជាមិច្ឆាទិដ្ឋិម្នាក់ លេងឃ្លីជាមួយគ្នារឿយៗ ។ ក្មេងទាំងពីរនោះ កូនរបស់សម្មាទិដ្ឋិបុគ្គល កាលបាញ់ឃ្លី រឭកដល់ពុទ្ធានុស្សតិថា **ឥមោពុទ្ធស្ស** *ហើយទើបបាញ់ ។ ក្មេងក្រៅពីនេះ រឭកចំពោះគុណទាំងឡាយរបស់ពួកតិរ្ថិយថា* **ឥមោ អរហន្តានំ** *ហើយទើបបាញ់ ក្មេងទាំងពីរ បុត្ររបស់បុគ្គលដែលជាសម្មាទិដ្ឋិ រមែងឈ្នះ ក្មេងក្រៅអំពីនេះ រមែងចាញ់ ។ កូនរបស់មិច្ឆាទិដ្ឋិបុគ្គលនោះ ឃើញកិរិយាបុត្ររបស់បុគ្គលសម្មាទិដ្ឋិនោះហើយ គិតថា សម្លាញ់អញនេះ រឭកយ៉ាងនោះហើយ ពោលយ៉ាងនោះហើយ បាញ់ឃ្លីទៅ ទើបឈ្នះអញ អញនឹងធ្វើយ៉ាងនោះដែរ ដោយធ្វើការសន្សំក្នុងពុទ្ធានុស្សតិហើយ ។*

ថ្ងៃមួយ បិតារបស់ក្មេងដែលជាសម្មាទិដ្ឋិនោះ ទឹមរទេះហើយដើម្បីទៅរកឧស បាននាំកុមារនោះទៅហើយ ជាក់ឈើពេញរទេះក្នុងព្រៃបរមក ដល់ខាងក្រៅនគរ ដោះគោក្នុងទីដែលមានការសម្បូរដោយទឹក ក្នុងទីជិតព្រៃខ្មោច ហើយធ្វើការចាត់ចែងភត្ត ។

លំដាប់នោះ គោរបស់បុរសនោះ ចូលទៅកាន់នគរជាមួយហ្វូងគោដែលចូលទៅកាន់នគរក្នុងពេលល្ងាច ។ សាកជិកៈដើរតាមគោទៅដល់នគរហើយ

ក្នុងពេលល្ងាច ជួបគោហើយដឹកមកមិនទាន់ដល់ទ្វារ ទ្វារបិទហើយ ។ ខណៈនោះ កូនរបស់គាត់ម្នាក់ឯងប៉ុណ្ណោះដេកហើយក្រោមរនេះ ក្នុងចំណែកនៃរាត្រី ឈានចូលកាន់និទ្រាហើយ ។

ក្រុងរាជគ្រឹះតាមប្រក្រតីច្រើនទៅដោយអមនុស្ស ម្យ៉ាងទៀត ក្មេងនេះក៏ដេកហើយក្នុងទីមិនឆ្ងាយអំពីព្រៃខ្មោច ។ ពួកអមនុស្ស ក្នុងទីជិតព្រៃខ្មោចនោះឃើញកុមារហើយ ។ អមនុស្សមួយរូបជាមិច្ឆាទិដ្ឋិ ជាបន្ទាំពោះព្រះសាសនា អមនុស្សមួយទៀត ជាសម្មាទិដ្ឋិ ។

ក្នុងអមនុស្សទាំងពីរនោះ អមនុស្សដែលជាមិច្ឆាទិដ្ឋិពោលថា ក្មេងនេះជាចំណីរបស់ពួកយើង ពួកយើងនឹងទំពាស៊ីក្មេងនេះ ។ អមនុស្សដែលជាសម្មាទិដ្ឋិ ឃាត់អមនុស្សដែលជាមិច្ឆាទិដ្ឋិនោះដោយពាក្យថា កុំឡើយ អ្នកកុំពេញចិត្តឡើយ ។ អមនុស្សដែលជាមិច្ឆាទិដ្ឋិនោះ សូម្បីត្រូវអមនុស្សដែលជាសម្មាទិដ្ឋិនោះឃាត់ ក៏មិនអើពើនឹងពាក្យរបស់អមនុស្សនោះ ចាប់ជើងទាញមកហើយ ។ ក្នុងខណៈនោះក្មេងនោះពោលថា **ឥមោ ពុទ្ធសុ** *ព្រោះភាពជាអ្នកសន្សំក្នុងពុទ្ធានុស្សតិ ។ អមនុស្សនោះខ្លាចកិតភ័យ ទើបថយទៅឈរហើយ ។*

លំដាប់នោះ អមនុស្សដែលជាសម្មាទិដ្ឋិក្រៅអំពីនេះ ពោលនឹងអមនុស្សដែលជាមិច្ឆាទិដ្ឋិនោះថា ពួកយើងធ្វើវត្ថុដែលមិនគួរធ្វើហើយ ពួកយើងចូរធ្វើទណ្ឌកម្មដើម្បីក្មេងនោះចុះ ដូច្នេះហើយ ឈរការពារក្មេងនោះ អមនុស្សដែលជាមិច្ឆាទិដ្ឋិ ចូលទៅកាន់ព្រះនគរ ញុំាងថាសកោជនរបស់ព្រះរាជាឲ្យពេញហើយ

នាំកោជនមក ។

តមក អមនុស្សទាំងពីរហាក់ដូចជាមាតា និងបិតារបស់ក្មេងនោះ លើកក្មេងនោះឲ្យក្រោកឡើង ឲ្យបរិភោគកោជននោះ ប្រកាសការប្រព្រឹត្តទៅនោះ ហើយចារឹកអក្សរត្រង់ថាសកោជន ដោយអនុភាពរបស់យក្ខ ដោយអធិដ្ឋានថា ព្រះរាជាប៉ុណ្ណោះ ចូរឃើញអក្សរទាំងនេះ អ្នកដទៃកុំបីឃើញឡើយ ដូច្នេះហើយ ទើបទៅ ។

ស្អែកឡើង ពួករាជបុរសធ្វើនូវកោលាហលថា ពួកចោរលួចភណ្ឌៈ គឺកាជនៈទៅអំពីរាជត្រកូលហើយ ទើបបិទទ្វារទាំងឡាយរកមើល កាលមិនឃើញក្នុងព្រះនគរ ទើបចេញទៅអំពីព្រះនគរ រកមើលក្នុងទីផ្សេងៗ ក៏ឃើញថាសជាវិការនៃមាសលើរនេះដែលជាក់ឧស ទើបចាប់ក្មេងនោះ ដោយសម្គាល់ថា នេះជាចោរ ដូច្នេះហើយ បង្ហាញដល់ព្រះរាជា ។

ព្រះរាជាទតឃើញអក្សរទាំងឡាយហើយត្រាស់សួរថា នេះជាអ្វី កុមារនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនជ្រាប មាតាបិតារបស់ទូលបង្គំមកឲ្យបរិភោគក្នុងរាត្រី ហើយបានឈរក្បែរ ទូលបង្គំគិតថា មាតាបិតារក្សាអញ ទើបមិនមានការភ័យខ្លាច ចូលដល់នូវការនិទ្រាហើយ ទូលបង្គំជ្រាបត្រឹមតែប៉ុណ្ណោះ ។

លំដាប់នោះ មាតា និងបិតារបស់ក្មេងនោះ បានទៅកាន់ទីនោះហើយ ។ ព្រះរាជាទ្រង់ជ្រាបការប្រព្រឹត្តទៅនោះហើយ ទ្រង់នាំជនទាំង ៣ នោះទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលការប្រព្រឹត្តទៅទាំងពួង ហើយទូលសួរថា

បពិត្រព្រះអង្គ ពុទ្ធានុស្សតិប៉ុណ្ណោះ រមែងជាគុណជាតជាគ្រឿងរក្សាឬ ឬ អនុស្សតិដទៃ មានធម្មានុស្សតិជាដើម ជាគុណជាតជាគ្រឿងរក្សា ។

គ្រានោះ ព្រះសាស្តាត្រាស់ដល់ព្រះរាជានោះថា មហាបពិត្រ ពុទ្ធានុស្សតិតែម្យ៉ាងប៉ុណ្ណោះ ជាគុណជាតជាគ្រឿងរក្សាក៏មិនមែន ចិត្តដែលជនទាំងឡាយណាអប់រំល្អហើយដោយហាន: ៦ កិច្ចដោយការរក្សា និងការការពារដទៃ ឬដោយមន្ត និងឱសថ រមែងមិនមានដល់ជនទាំងនោះ ដូច្នេះហើយ កាលទ្រង់សម្តែងហាន: ៦ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ធម្មគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ សង្ឃគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ កាយគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច អហឹសាយ រតោ មនោ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច ភាវនាយ រតោ មនោ ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងព្រះពុទ្ធគុណ អស់

កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័កបរបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងព្រះធម្មគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័កបរបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងព្រះសង្ឃគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័កបរបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងកាយ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័កបរបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយក្នុងការមិនបៀតបៀនគេ ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័កបរបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយ ក្នុងមេត្តាភាវនា ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃសព្វកាល ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **សុប្បពុទ្ធំ បពុជ្ឈន្តិ** *សេចក្តីថា ជនទាំងនោះ តម្កល់សតិដែលទៅហើយក្នុងព្រះពុទ្ធ កំពុងនិទ្រានោះឯង កាលភ្ញាក់ឡើង ឈ្មោះថា ភ្ញាក់ដោយប្រពៃ ។*

បាទព្រះគាថាថា **សទា គោតមសាវកា** *សេចក្តីថា ឈ្មោះថាជាសាវ័ករបស់ព្រះគោតម ព្រោះភាពដែលខ្លួន ជាអ្នកកើតហើយក្នុងទីបំផុតនៃការស្តាប់របស់ព្រះសម្ពុទ្ធគោតមគោត្រ និងព្រោះភាពជាបុគ្គល គឺដែលស្តាប់អនុសាសនីរបស់ព្រះពុទ្ធអង្គនោះឯង ។*

ពីរបទថា **ពុទ្ធគតា សតិ** *សេចក្តីថា សតិរបស់ជនពួកណាប្រារព្ធពុទ្ធគុណទាំងឭាយមាន* **ឥតិបិ សោ ភគវា** *ជាដើម កើតឡើងអស់កាលជានិច្ច ជនទាំងនោះ ឈ្មោះថា ភ្ញាក់ដោយល្អ សព្វកាល ជនទាំងនោះ កាលមិនអាចធ្វើយ៉ាងនោះបាន ធ្វើនូវពុទ្ធានុស្សតិតែក្នុងចិត្ត ក្នុងមួយថ្ងៃ ៣ ដង ២ ដង ឬ ១ ដង ឈ្មោះថា ភ្ញាក់ដោយល្អដូចគ្នា ។*

ពីរបទថា **ធម្មគតា សតិ** *សេចក្តីថា សតិ ដែលប្រារព្ធធម្មគុណទាំង-ឭាយមាន* **স্বাক্খাতো ভগবតা ধম্মো** *ជាដើម ដែលកើតឡើង ។*

ពីរបទថា **សង្ឃគតា សតិ** *សេចក្តីថា សតិដែលប្រារព្ធសង្ឃគុណ*

ទាំងឡាយ មាន **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ជាដើម ដែលកើតទ្បើង ។*

ពីរបទថា **កាយគតា សតិ** *សេចក្តីថា សតិ ដែលកើតទ្បើងដោយអំណាចនៃអាការ ៣២ ដោយអំណាចនៃការនៅក្នុងព្រៃខ្មោចទាំង ៩ ដោយអំណាចនៃរូបជ្ឈាន មាននីលកសិណដែលប្រព្រឹត្តទៅខាងក្នុងជាដើម ។*

ពីរបទថា **អហឹសាយ រតោ** *សេចក្តីថា ត្រេកអរហើយក្នុងករុណាភាវនា ដែលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះថា ភិក្ខុនោះមានចិត្តសហគតៈដោយករុណា ផ្សាយទៅអស់ទិសមួយ ។*

បទថា **ភាវនាយ** *បានដល់ មេត្តាភាវនា ពិតហើយ ភាវនាដ៏សេសទាំងអស់ ព្រះសាស្តាទ្រង់បំណងយកក្នុងបទថា* **ភាវនាយ** *នេះ ព្រោះភាពដែលករុណាភាវនា ទ្រង់ត្រាស់ហើយខាងដើមដោយពិត តែមេត្តាភាវនាប៉ុណ្ណោះ ទ្រង់បំណងយកក្នុងបទថា* **ភាវនាយ** *នេះ ។ ពាក្យដ៏សេស អ្នកសិក្សាគប្បីជ្រាបដោយនយដែលពោលហើយ ក្នុងគាថានោះឯង ។*

ក្នុងកាលចប់ទេសនា ទារកនោះតាំងនៅក្នុងសោតាបត្តិផល មួយអន្ទឹដោយមាតា និងបិតាហើយ ក្រោយមក ជនទាំងអស់បួស សម្រេចអរហត្តទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយដូច្នេះឯង ॥

រឿង ឧារុសាកដិកៈ ចប់

រឿង ភិក្ខុវជ្ជីបុត្រ

លំនាំដើម

ព្រះសាស្តាកាលទ្រង់អាស្រ័យក្រុងវេសាលី ប្រថាប់នៅក្នុងព្រៃមហាវ័ន ទ្រង់ប្រារព្ធភិក្ខុជាឱរស របស់ស្តេចវជ្ជីមួយរូប ដែលព្រះធម្មសង្គាហាចារ្យ ពោលសំដៅយកថា ភិក្ខុដែលជាឱរសរបស់ស្តេចវជ្ជីអង្គណាមួយអង្គ ក្នុងជង ព្រៃណាមួយ ជិតក្រុងវេសាលី ។ ក្នុងសម័យនោះឯង ក្នុងក្រុងវេសាលីមាន ការលេងមហោស្រព មួយយប់ទល់ភ្លឺ ។ គ្រានោះឯង ភិក្ខុនោះ បានឮ សំឡេងគគ្រឹកគគ្រេងនៃតន្ត្រីដែលគេប្រគំហើយ កន្តក់កន្ទេញពោលគាថានេះ ក្នុងពេលនោះថា

> យើងមកនៅក្នុងព្រៃតែម្នាក់ឯង ដូចជាកំណាត់ឈើដែលគេ ចោលក្នុងព្រៃ ក្នុងរាត្រីប្រាកដ ដូច្នេះ មិនមានអ្នកណាអន់ជាង យើងទៅទៀតទេ ។

ព្រះសាស្តាត្រាស់ព្រះធម្មទេសនានេះថា **ឧប្បព្វជ្ជំ ទុរភិរមំ** ជាដើម ។

បានឮថា ភិក្ខុនោះជារាជឱរសក្នុងដែនវជ្ជី លះរាជសម្បត្តិដែលជល់ហើយ តាមវារៈ បួសហើយក្នុងក្រុងវេសាលី កាលក្នុងព្រះនគរគេប្រជាប់ហើយ ដោយគ្រឿងប្រជាប់ទាំងឡាយ មានទង់ជ័យ និងទង់ជ្រាលាជាដើម ធ្វើឲ្យ ជាប់គ្នាតែមួយ ដូចជាន់ចាតុម្មហារាជ កាលវារៈជាទីលេងមហោស្រព មួយ យប់ទល់ភ្លឺ ក្នុងថ្ងៃ ១៥ កើត ជាទីរីកនៃផ្ការាំងមុនប្រព្រឹត្តទៅ ។ បានឮ សំឡេងកងរំពងនៃតន្ត្រី មានស្គរជាដើមវាយហើយ និងសំឡេងតន្ត្រី មាន ពិណជាដើម ដែលគេប្រគំហើយ កាលព្រះរាជា ៧៧០៧ អង្គ និងទ្វីរាជការ

ទាំងឡាយ មានឧបរាជ និងសេនាបតីជាដើមរបស់ព្រះរាជាទាំងនោះ មានចំនួនប៉ុណ្ណោះដូចគ្នា ដែលមាននៅក្នុងក្រុងវេសាលី ប្រជាប់តាក់តែងហើយឈានចុះកាន់វិថីដើម្បីលេងនក្ខត្តឫក្ស ចង្រ្កមត្រង់ទីចង្រ្កមធំប្រមាណ ៦០ ហត្ថ ឃើញព្រះចន្ទពេញវង់ អណ្តែតក្នុងលម្ហូមេឃ ឈរផ្អែកបន្ទះក្តារ ខាងចុងទីចង្រ្កម ហើយសម្លឹងមើលអត្តភាព ដូចដុំឈើដែលគេទុកចោលក្នុងព្រៃ ព្រោះភាពដែលខ្ជូនវៀរហើយចាកសំពត់សម្រាប់ជូតក្បាល និងគ្រឿងអលង្ការ គិតថា អ្នកជនៃ ដែលអាក្រក់ជាងអាត្មាអញមានឬហ្ន៎ សូម្បីប្រកបដោយគុណមានការនៅព្រៃជាវត្តតាមប្រក្រតីជាដើម ក្នុងខណៈនោះ ត្រូវសេចក្តីមិនត្រេកអរគ្របសង្កត់ ទើបពោលយ៉ាងនោះ ។

ទេវតាដែលអាស្រ័យនៅក្នុងជង្ឃព្រៃនោះបានឮគាថានេះ ដែលលោកពោលហើយ ក៏ពោលតបថា

លោកនៅក្នុងព្រៃតែម្នាក់ឯង ដូចជាកំណាត់ឈើដែលគេចោលនៅក្នុងព្រៃមែន តែមានជនច្រើនគ្នា ស្រឡាញ់លោកនោះ ដូចពពួកសត្វក្នុងស្ថាននរក ស្រឡាញ់ពួកទេវតាក្នុងស្ថានសួគ៌ ។

ដោយបំណងថា អាត្មាអញនឹងញ៉ាំងភិក្ខុនេះឲ្យសង្វេគ ក្នុងថ្ងៃស្អែកឡើងចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយ ។

ព្រះសាស្តាទ្រង់ជ្រាបរឿងនោះហើយ បំណងប្រកាសភាពដែលឃរាវាសជាទុក្ខ ទើបទ្រង់សរុបនូវទុក្ខ ៥ យ៉ាង ហើយត្រាស់ព្រះគាថានេះថា

ទុប្បព្វជ្ជំ ទុរភិរមំ ទុរាវាសា ឃរា ទុខា
ទុក្ខោសមានសំវាសោ ទុក្ខានុបតិតទ្ធគូ
តស្មា ន ចទ្ធគូ សិយា ន ច ទុក្ខានុបតិតោ សិយា ។

ការចេញបួសបានដោយក្រ ការត្រេកអរត្រូវបានដោយក្រ ផ្ទះទាំងឡាយ មានការនៅគ្រប់គ្រងដោយលំបាក ជាការក្រ ការនៅរួមដោយជនស្មើគ្នា (ដែលមិនមានសេចក្តីកោតក្រែង) ជាការក្រ ជនអ្នកដើរផ្លូវឆ្ងាយ គឺវដ្តៈ តែងត្រូវសេចក្តីទុក្ខជ្អាក់ជាប់តាម ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជាអ្នកត្រូវសេចក្តីទុក្ខជ្អាក់ជាប់តាមផង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទុប្បព្វជ្ជំ** *សេចក្តីថា ឈ្មោះថា ការលះគំនរនៃកោគៈតិចក្តី ច្រើនក្តី និងពួកញាតិ បួស ប្រគល់ឧរៈ គឺថ្វាយជីវិតក្នុងសាសនានេះជាការក្រ ។*

បទថា **ទុរភិរមំ** *សេចក្តីថា ការដែលកុលបុត្របួសហើយយ៉ាងនោះ បន្តការប្រព្រឹត្តទៅនៃជីវិត ដោយការត្រាច់ទៅដើម្បីភិក្ខា ដែលល្អក្រៃលែងដោយអំណាចនៃការគ្រប់គ្រងគុណ គឺសីលដែលមិនមានប្រមាណ និងបំពេញបដិបទាដែលសមគួរដល់ធម៌ឲ្យបរិបូណ៌ ជាការលំបាក ។*

បទថា **ទុរាវាសា** *សេចក្តីថា រាជកិច្ចរបស់ព្រះរាជា ឥស្សរកិច្ចរបស់*

ឥស្សរជនទាំងឡាយ ដែលគ្រប់គ្រងផ្ទះត្រូវនាំទៅ ជនជិតខាង និងសមណ-ព្រាហ្មណ៍ដែលប្រព្រឹត្តធម៌ ដែលគ្រប់គ្រងផ្ទះត្រូវសង្គ្រោះ កាលបើយ៉ាងនេះ ការគ្រប់គ្រងផ្ទះក៏បំពេញបានលំបាក ដូចធ្នាំងដែលធ្ងន់ និងមហាសមុទ្រ ព្រោះដូច្នោះ ឈ្មោះថា ផ្ទះទាំងនោះគ្រប់គ្រងមិនល្អ ទើបឈ្មោះថាឲ្យកើតទុក្ខ គឺឲ្យលំបាក ដើម្បីនៅគ្រប់គ្រង ព្រោះហេតុនោះឯង ។

បាទព្រះគាថាថា **ទុក្ខោ សមានសំវាសោ** *សេចក្តីថា ពិតហើយ ជនណាជាគ្រហស្ថ សូម្បីស្មើគ្នាដោយជាតិ គោត្រ ត្រកូល និងភោគៈក្តី ជាបព្វជិត ស្មើគ្នាដោយគុណទាំងឡាយ មានសីល អាចារៈ និងពហុសច្ចៈជាដើមក្តី តែពោលពាក្យជាដើមថា លោកជាអ្នកណា ខ្ញុំជាអ្នកណា ជាអ្នកខ្វល់ខ្វាយក្នុងអធិករណ៍ ជនទាំងនោះ ឈ្មោះថា មិនស្មើគ្នា ឈ្មោះថា ការនៅរួមគ្នាជាមួយជនទាំងនោះជាទុក្ខ ។*

បាទព្រះគាថាថា **ទុក្ខានុបតិតទ្ធគូ** *សេចក្តីថា ជនទាំងឡាយណាឈ្មោះថា ជាអ្នកដើរផ្លូវឆ្ងាយ ព្រោះជាអ្នកដើរទៅកាន់ផ្លូវឆ្ងាយ ពោល គឺវដ្តៈ ជនទាំងនោះ ត្រូវទុក្ខជាប់តាមពិត ។*

ពីរបទថា **តស្មា ន ចទ្ធគូ** *សេចក្តីថា ភាពជាបុគ្គលដែលទុក្ខជាប់តាមជាទុក្ខ សូម្បីភាពជាបុគ្គលអ្នកដើរផ្លូវឆ្ងាយក៏ជាទុក្ខ ព្រោះដូច្នោះ បុគ្គលមិនគប្បីជាអ្នកឈ្មោះថាដើរផ្លូវឆ្ងាយ ព្រោះការដើរផ្លូវឆ្ងាយ ពោល គឺវដ្តៈផង មិនគប្បីជាអ្នកមានទុក្ខ ដូចពោលហើយជាប់តាមផង ។*

ក្នុងកាលចប់ទេសនា កិកុនោះនឿយណាយក្នុងទុក្ខ ដែលទ្រង់ត្រាស់ក្នុង

ហានៈ ៥ ហើយ ទម្លាយសំយោជនៈ ដែលជាចំណែកខាងក្រោម ៥ ដែល ជាចំណែកខាងលើ ៥ តាំងនៅក្នុងអរហត្តហើយ ដូច្នេះឯង ។

រឿង ភិក្ខុវដ្ឋិបុត្រ ចប់

រឿង ចិត្តគហបតី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធចិត្តគហបតី ត្រាស់ព្រះធម្មទេសនានេះថា **សង្ខោ សីលេន សម្បន្នោ** *ជាដើម ។*

រឿងចិត្តគហបតីខ្ញុំឲ្យពិស្តារហើយក្នុងពាលវគ្គថា **អសន្តំ ភាវមិច្ឆេយ្យ** *ជាដើម ។ ព្រះគាថានេះក៏មកហើយក្នុងពាលវគ្គនោះដូចគ្នា ពិតហើយ ក្នុង ពាលវគ្គនោះ ខ្ញុំពោលថា ព្រះអានន្ទត្ថេរទូលសួរព្រះសាស្តាថា បពិត្រព្រះ អង្គ សក្ការៈនេះកើតឡើងដល់ចិត្តគហបតីនោះ ដែលមកកាន់សម្នាក់របស់ ព្រះអង្គតែប៉ុណ្ណោះឬ ឬក្នុងទីដទៃកើតឡើងដូចគ្នា ។*

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ កាលចិត្តគហបតីនោះមកកាន់សម្នាក់ របស់តថាគតក្តី ទៅក្នុងទីដទៃក្តីសក្ការៈរមែងកើតឡើងទាំងអស់ ព្រោះឧបាសក នេះជាអ្នកមានសទ្ធា សម្បូរដោយសីល ឧបាសកនេះទៅបទេសណាមួយ លាភ សក្ការៈរមែងកើតឡើងដល់ចិត្តគហបតីក្នុងបទេសនោះៗ ឯង ដូច្នេះហើយ ទើប ទ្រង់ត្រាស់ព្រះគាថានេះថា

សទ្ធោ សីលេន សម្បន្នោ យសោភោគសមប្បិតោ
យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។

បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្តុបស្តប់ដោយយស និងភោគសម្បត្តិ គប់រកប្រទេសណាៗ គេតែងបូជាក្នុងប្រទេសនោះៗ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សទ្ធោ** *បានដល់ ដែលប្រកបដោយសទ្ធា ដែលជាលោកិយ និងលោកុត្តរ ។*

បទថា **សីលេន** *សេចក្តីថា សីលមាន ២ យ៉ាង គឺសីលសម្រាប់អ្នកគ្រប់គ្រងផ្ទះ ១ សីលសម្រាប់អ្នកមិនគ្រប់គ្រងផ្ទះ ១ ក្នុង ២ យ៉ាងនោះ សីលសម្រាប់អ្នកគ្រប់គ្រងផ្ទះ ព្រះសាស្តាទ្រង់បំណងយកក្នុងបទនេះ ។ សេចក្តីថា ជាអ្នកប្រកបដោយសីលសម្រាប់អ្នកគ្រប់គ្រងផ្ទះនោះ ។*

បាទព្រះគាថាថា **យសោភោគសមប្បិតោ** *សេចក្តីថា ជាអ្នកប្រកបហើយដោយយសសម្រាប់អ្នកគ្រប់គ្រងផ្ទះ ពោល គឺការមានឧបាសក ៥០០ ជាបរិវារ ដូចគ្នានឹងរបស់ជនទាំងឡាយ មានអនាថបិណ្ឌិកសេដ្ឋីជាដើម និងដោយភោគៈ ២ យ៉ាង គឺភោគៈមានទ្រព្យ និងស្រូវជាដើមឯណានីមួយ គឺអរិយទ្រព្យ ៧ យ៉ាង ។*

ពីរបទថា **យំ យំ** *ជាដើម សេចក្តីថា កុលបុត្របែបនេះទៅកាន់ប្រទេសណា ក្នុងទិសទាំងឡាយ មានទិសខាងកើតជាដើម រមែងជាបុគ្គលដែលគេ*

បូជាហើយ ក្នុងប្រទេសនោះៗ ដោយលាភ និងសក្ការៈបែបនោះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ចិត្តគហបតី ចប់

រឿង ចូឡសុភទ្ទា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធធីតារបស់អនាថបិណ្ឌិកសេដ្ឋី ឈ្មោះនាងចូឡសុភទ្ទា ត្រាស់ព្រះធម្មទេសនានេះថា **ទ្វារេ សង្ខោ បកាសេន្តិ** *ជាដើម ។*

បានឮមកថា សេដ្ឋីបុត្រម្នាក់ឈ្មោះឧគ្គៈ អ្នកឧគ្គនគរ ជាសម្ភាញ់របស់អនាថបិណ្ឌិកសេដ្ឋី តាំងអំពីកាលនៅជាកំលោះ សម្ភាញ់ទាំងពីរនោះរៀនសិប្បៈក្នុងត្រកូលអាចារ្យជាមួយគ្នា សន្យានឹងគ្នាថា ក្នុងពេលដែលយើងទាំង ២ ចម្រើនវ័យ បុត្រ និងធីតាកើតហើយ បុគ្គលណាសុំធីតាដើម្បីប្រយោជន៍ដល់បុត្រ បុគ្គលនោះត្រូវឲ្យធីតានោះ ។ ជនទាំងពីរចម្រើនវ័យហើយ គ្រប់គ្រងតំណែងសេដ្ឋីក្នុងនគររៀងៗ ខ្លួន ។

សម័យមួយ ឧគ្គសេដ្ឋីប្រកបការលក់ដូរ បានទៅកាន់ក្រុងសាវត្ថីដោយរទេះ ៥០០ ។ អនាថបិណ្ឌិកសេដ្ឋីហៅនាងចូឡសុភទ្ទាធីតារបស់ខ្លួនមកប្រាប់

ថា នែនាង៎ បិតារបស់នាង៎ឈ្មោះឧគ្គសេដ្ឋីមក កិច្ចដែលគួរធ្វើដល់គេជាការៈរបស់នាង៎ ។

នាង៎ទទួលថា សាធុ បានរៀបចំភោជន មានសម្ប និង៎ម្ហូបជាដើមដោយដៃខ្លួនឯង៎ តាំង៎អំពីថ្ងៃឧគ្គសេដ្ឋីនោះមក ត្រៀមវត្ថុផ្សេង៎ៗ មានកម្រង៎ផ្កា គ្រឿង៎ក្រអូប និង៎គ្រឿង៎លាបជាដើម ក្នុង៎ពេលបរិភោគ ក៏រៀបចំទឹកសម្រាប់ងូតរង៎ចាំលោកសេដ្ឋីនោះ តាំង៎អំពីងូតទៅ រមែង៎ធ្វើកិច្ចគ្រប់យ៉ាង៎សម្រេចរៀបរយ ។

ឧគ្គសេដ្ឋីបានឃើញអាចារសម្បត្តិរបស់នាង៎សុភទ្ទានោះហើយ មានចិត្តជ្រះថ្លា ។ ថ្ងៃមួយ អង្គុយជាមួយអនាថបិណ្ឌិកសេដ្ឋី ដោយកថាប្រារព្ធសេចក្តីសុខ ហើយរឭកបានថា កាលនៅកំលោះ យើង៎ទាំង៎ពីរធ្វើកតិកាឈ្មោះនេះទើបសូមនាង៎ចូឡសុភទ្ទា ដើម្បីប្រយោជន៍ដល់បុត្ររបស់ខ្លួន តែឧគ្គសេដ្ឋីនោះដោយប្រក្រតីជាមិច្ឆាទិដ្ឋិ ព្រោះដូច្នោះ ទើបអនាថបិណ្ឌិកសេដ្ឋីក្រាបទូលសេចក្តីនោះដល់ព្រះទសពល ព្រះសាស្តាទ្រង់ឃើញឧបនិស្សយរបស់ឧគ្គសេដ្ឋីហើយទ្រង់អនុញ្ញាត ។ ទើបប្រឹក្សាជាមួយភរិយា ហើយទទួលពាក្យរបស់ឧគ្គសេដ្ឋីនោះ កំណត់ថ្ងៃរៀបការហើយ ធ្វើសក្ការៈជាច្រើន ដូចធនញ្ជ័យសេដ្ឋី ធ្វើឲ្យនាង៎វិសាខាដែលជាធីតា ហើយបញ្ជូនទៅដូច្នោះ ហៅនាង៎សុភទ្ទាមកហើយឲ្យឱវាទ ១០ ប្រការថា នែនាង៎ ធម្មតាស្ត្រីនៅក្នុង៎ត្រកូលប្តី មិនគួរនាំក្លើងខាង៎ក្នុង៎ចេញទៅខាង៎ក្រៅ ដោយន័យដែលធនញ្ជ័យសេដ្ឋីឲ្យដល់នាង៎វិសាខានោះឯង៎ ។ កាលនឹង៎បញ្ជូនទៅ ប្រគល់កុដុម្ភិកៈ ៨ ឲ្យជាអ្នកធានាថា បើ

ទោសរបស់ធីតាយើង កើតក្នុងទីដែលទៅហើយ ចូរពួកអ្នកជម្រះ ។ ក្នុងថ្ងៃដែលបញ្ជូនធីតានោះទៅ ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ បញ្ជូនធីតាទៅដោយសក្ការៈដ៏ច្រើន ហាក់ដូចសម្តែងសេចក្តីចម្រើននៃផលសុចរិតទាំងឡាយ ដែលធីតាធ្វើហើយ ក្នុងភពមុនឲ្យប្រាកដដល់សត្វលោក ។ ក្នុងពេលនាងទៅដល់ខគ្គនគរដោយលំដាប់ មហាជន មួយអន្លើដោយត្រកូលឪពុកក្មេក បានធ្វើការទទួល ។

ចំណែកនាងចូឡសុភទ្ទានោះ បង្ហាញខ្លួនដល់អ្នកនគរទាំងមូល ដូចនាងវិសាខា ដើម្បីធ្វើសិរីសម្បត្តិរបស់ខ្លួនឲ្យប្រាកដ ឈរនៅលើរថចូលទៅកាន់នគរ ទទួលគ្រឿងបណ្ណាការដែលបញ្ជូនមកហើយទៅដល់ជនទាំងនោះ ដោយអំណាចនៃវត្តតាមសមគួរ បានធ្វើអ្នកនគរទាំងមូលឲ្យជាប់តែមួយដោយគុណរបស់ខ្លួន ។

ក្នុងថ្ងៃមង្គល ឪពុកក្មេករបស់នាង កាលធ្វើសក្ការៈដល់ពួកអ្នកបួសអាក្រាត បញ្ជូនទៅដោយពាក្យថា ចូរនាងមកថ្វាយបង្គំសមណៈទាំងឡាយរបស់ពួកយើង នាងមិនអាចមើលអ្នកបួសអាក្រាតទាំងឡាយព្រោះខ្មាស មិនប្រាថ្នានឹងទៅ លុះឪពុកក្មេកបញ្ជូនដំណឹងទៅរឿយៗ ត្រូវនាងឃាត់ហើយ ទើបក្រោធពោលថា ចូរពួកអ្នកបណ្តេញស្រីនេះទៅចុះ នាងគិតថា ឪពុកក្មេកមិនអាចលើកទោសដល់ខ្លួន ព្រោះហេតុមិនសមគួរបាន ឲ្យហៅកុដុម្ពិកៈមកហើយប្រាប់សេចក្តីនោះ ។ កុដុម្ពិកៈទាំងនោះ ជ្រាបភាពដែលនាងមិនមានទោស ទើបឲ្យសេដ្ឋីយល់ព្រមហើយ សេដ្ឋីប្រាប់ដល់ភរិយាថា កូនប្រសានេះមិនថ្វាយបង្គំ

សមណៈទាំងឡាយរបស់យើង ដោយយល់ថា ជាអ្នកមិនមានទូវការខ្វាស ។

ភរិយាសេដ្ឋីនោះគិតថា សមណៈរបស់កូនប្រសានេះដូចម្តេចហ្ន៎ នាង សរសើរសមណៈទាំងនោះពន់ពេក បានឲ្យមនុស្សហៅនាងមកហើយ ពោលថា សមណៈរបស់នាងដូចម្តេច ទើបនាងសរសើរសមណៈទាំងនោះពន់ពេក សមណៈទាំងនោះមានប្រក្រតីដូចម្តេច មានសមាចារដូចម្តេច កាលយើងសួរហើយ ចូរប្រាប់រឿងនោះដល់យើង ។

លំដាប់នោះ នាងសុភទ្ទាប្រកាសគុណទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធ និងសាវ័ករបស់ព្រះអង្គដល់ម្ចាយក្មេកនោះ ឲ្យម្ចាយក្មេកត្រេកអរហើយដោយពាក្យទាំងឡាយយ៉ាងនេះថា

សមណៈទាំងនោះ ជាអ្នកមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ ដើរក្តី ឈរក្តី សង្រួមល្អ មានភ្នែកជាក់ចុះ និយាយល្មមប្រមាណ សមណៈទាំងឡាយរបស់ខ្ញុំយ៉ាងនេះ ។ កាយកម្មរបស់លោកស្អាត វចីកម្មមិនល្អក់កករ មនោកម្មបរិសុទ្ធ សមណៈទាំងឡាយរបស់ខ្ញុំយ៉ាងនោះ ។ លោកមិនមានមន្ទិលមានរស្មីដូចសង្ខ និងមុក្តា បរិសុទ្ធខាងក្នុងផង ខាងក្រៅផង ពេញហើយដោយធម៌ ដែលបរិសុទ្ធទាំងឡាយ ពួកសមណៈរបស់ខ្ញុំយ៉ាងនោះ លោកមិនប៉ោងឡើងព្រោះលាភ និងមិនអាក់អន់ព្រោះវិនាសលាភ លោកតាំងនៅតែម្យ៉ាង ព្រោះលាភ និងវិនាសលាភ ពួកសមណៈរបស់ខ្ញុំយ៉ាងនោះ លោកមិនប៉ោងឡើងព្រោះយស មិនអាក់អន់ព្រោះវិនាសយស លោកតាំងនៅតែម្យ៉ាង ព្រោះយស និងវិនាសយស ពួកសមណៈរបស់ខ្ញុំយ៉ាងនោះ លោកមិនប៉ោងឡើង

ព្រោះសរសើរ និងមិនអាក់អន់ព្រោះនិន្ទា លោកស្មើក្នុងនិន្ទា និងសរសើរ ពួកសមណៈរបស់ខ្ញុំយ៉ាងនោះ លោកមិនប៉ោងឡើងព្រោះសុខ មិនទោមនស្សព្រោះទុក្ខ លោកមិនញាប់ញ័រព្រោះសុខ និងទុក្ខ ពួកសមណៈរបស់ខ្ញុំ ដូច្នោះ ។

លំដាប់នោះ ម្ដាយក្មេកពោលថា នាងអាចបង្ហាញសមណៈទាំងឡាយដល់ពួកយើងបានដែរឬ នាងឆ្លើយថា អាច ទើបពោលថា បើដូច្នោះ ចូរនាងធ្វើឲ្យពួកយើងឃើញសមណៈទាំងនោះ ។ នាងទទួលថា សាធុ ត្រៀមនូវមហាទានដើម្បីភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ ឈរលើផ្ទៃប្រាសាទខាងលើ បែរមុខទៅកាន់វត្តជេតពន ថ្វាយបង្គំដោយគោរពដោយបញ្ចង្គប្រតិស្ឋាន រឭកដល់ពុទ្ធគុណទាំងឡាយ ធ្វើការបូជាដោយគ្រឿងក្រអូប គ្រឿងអប់ ផ្កា និងធូប ពោលនិមន្តថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីឆាន់ក្នុងថ្ងៃស្អែក ដោយសញ្ញាណរបស់ខ្ញុំម្ចាស់នេះ សូមព្រះមានព្រះភាគជ្រាបថា ខ្ញុំម្ចាស់និមន្តហើយ ដូច្នេះហើយ ទើបបាចផ្កាម្ជិះ ៨ ក្តាប់ ទៅក្នុងអាកាស ។

ផ្កាទាំងឡាយ អណ្តែតជាពិដានសម្រេចដោយរបៀបផ្កា បានទៅតាំងខាងលើព្រះសាស្តា ដែលទ្រង់កំពុងសម្តែងធម៌ ក្នុងកណ្តាលបរិស័ទ ៤ ។

ក្នុងខណៈនោះ សូម្បីអនាថបិណ្ឌិកសេដ្ឋី ស្តាប់ធម្មកថាហើយ និមន្តព្រះសាស្តាដើម្បីសោយក្នុងថ្ងៃស្អែក ព្រះសាស្តាត្រាស់ថា គហបតី តថាគតទទួលភត្តដើម្បីឆាន់ក្នុងថ្ងៃស្អែករួចហើយ កាលអនាថបិណ្ឌិកសេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គ អ្នកដទៃមកមុនខ្ញុំព្រះអង្គមិនមាន ទ្រង់ទទួលភត្តរបស់អ្នក

ណាហ្ន៎ ទើបទ្រង់ត្រាស់ថា ម្នាលគហបតី នាងចូឡសុភទ្ទានិមន្តហើយ កាលលោកសេដ្ឋីពោលថា នាងសុភទ្ទានៅក្នុងទីធ្លាយប្រមាណ ១២០ យោជន៍អំពីនេះ មិនមែនឬ ព្រះសាស្តាត្រាស់ថា គហបតី សប្បុរសទាំងឡាយ សូម្បីនៅក្នុងទីធ្លាយ រមែងប្រាកដដូចនៅក្នុងទីចំពោះមុខ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ
អសន្តេត្ថ ន ទិស្សន្តិ រត្តឹ ខិត្តា យថា សរា ។

ពួកសប្បុរសរមែងប្រាកដក្នុងទីធ្លាយ ដូចភ្នំហិមពាន្ត ដូច្នោះ ពួកអសប្បុរស (ទុកជាស្ថិតនៅ) ក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ក្នុងវេលាយប់ ។

សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា **សន្តោ** ជាដើម សេចក្តីថា អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ឈ្មោះថា សប្បុរស ព្រោះកិលេសទាំងឡាយមានរាគៈជាដើមស្ងប់ហើយ តែក្នុងទីនេះ ព្រះសាស្តាទ្រង់បំណងយកសព្វដែលមានអធិការ គឺបុណ្យដែលបានធ្វើហើយក្នុងព្រះពុទ្ធមុនៗ មានកុសលមូលសន្សំហើយ អប់រំការទាហើយថា សប្បុរស ។*

*បទថា **បកាសេន្តិ** សេចក្តីថា សូម្បីឈរក្នុងទីធ្លាយ កាលមកកាន់គន្ធង់ព្រះញាណនៃព្រះពុទ្ធទាំងឡាយ ឈ្មោះថា ប្រាកដបាន ។*

*បទថា **ហិមវន្តោវ** សេចក្តីថា ដូចភ្នំហិមពាន្ត ទំហំ ៣ ពាន់យោជន៍*

កម្ពស់ ៥០០ យោជន៍ ប្រដាប់ដោយកំពូល ៨៤០០០ រមែងប្រាកដដល់ជនទាំងឡាយ ដែលឈរក្នុងទីឆ្ងាយ ដូចតាំងនៅចំពោះមុខ យ៉ាងណា សប្បុរសទាំងឡាយ រមែងប្រាកដ ដូច្នោះ ។

បទថា **អសន្តេត្ថ** *សេចក្តីថា បុគ្គលពាលធ្ងន់ក្នុងទិដ្ឋធម៌ មានបរលោកឆ្ងងទៅហើយ ឃើញតែអាមិស បួសដើម្បីប្រយោជន៍ដល់ជីវិត ឈ្មោះថា អសប្បុរស អសប្បុរសទាំងនោះ សូម្បីអង្គុយក្នុងទីនេះ គឺក្នុងទីជិតមណ្ឌលនៃព្រះជានុខាងស្តាំរបស់ព្រះពុទ្ធទាំងឡាយ រមែងមិនប្រាកដ គឺមិនជីង ។*

ពីរបទថា **រត្តឹ ទិវត្តា** *គឺដូចព្រួញដែលបាញ់ទៅក្នុងពេលយប់ ក្នុងទីងងឹត ដែលប្រកបដោយអង្គ ៤ អធិប្បាយថា អសប្បុរសទាំងនោះ រមែងមិនប្រាកដ ព្រោះការមិនមានបុព្វហេតុ ដែលជាឧបនិស្សយបែបនោះ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

សក្កទេវរាជទ្រង់ជ្រាបថា ព្រះសាស្តាទ្រង់ទទួលនិមន្ត របស់នាងចូឡ-សុភទ្ទាហើយ ទ្រង់បញ្ជាវិស្សកម្មទេវបុត្រថា ចូរអ្នកនិម្មិតផ្ទះកំពូល ៥០០ ហើយនាំភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានទៅកាន់ឧត្តរគុរុក្នុងថ្ងៃស្អែក ។

ស្អែកទ្បើងវិស្សកម្មទេវបុត្រនោះ និម្មិតផ្ទះកំពូល ៥០០ បានឈរត្រង់ទ្វារនៃវត្តជេតពន ។ ព្រះសាស្តាទ្រង់ជ្រើសរើសហើយ នាំភិក្ខុខីណាស្រពដែលបរិសុទ្ធទាំង ៥០០ រូបនោះ មួយអន្ទើដោយបរិវារ ប្រថាប់គង់ក្នុងផ្ទះកំពូល ហើយយាងទៅកាន់ឧត្តរគុរុ ។

ឧគ្គសេដ្ឋី មួយអន្ទើដោយបរិវារ សម្ថឹងមើលផ្លូវយាងមកនៃព្រះតថាគត ដោយន័យដែលនាងសុភទ្ទាឲ្យហើយ យើញព្រះសាស្តាយាងមកដោយព្រះសិរីសម្បត្តិធំ មានចិត្តជ្រះថ្លាហើយ ធ្វើសក្ការៈដោយវត្ថុទាំងឡាយ មានកម្រងផ្កាជាដើម ទទួលហើយ ថ្វាយបង្គំ ថ្វាយមហាទាន និមន្តដដែលទៀត បានថ្វាយមហាទានអស់ ៧ ថ្ងៃ ។

ព្រះសាស្តា ទ្រង់កំណត់ធម៌ដែលជាសប្បាយរបស់សេដ្ឋីនោះហើយ ទ្រង់សម្តែងធម៌ សត្ថ ៨៤០០០ មានសេដ្ឋីជាដើម បានត្រាស់ដឹងធម៌ហើយ ។

ព្រះសាស្តា ដើម្បីទ្រង់អនុគ្រោះនាងសុភទ្ទា ទើបត្រាស់ឲ្យព្រះអនុរុទ្ធត្ថេរត្រឡប់ដោយព្រះតម្រាស់ថា ចូរអ្នកស្នាក់នៅក្នុងទីនេះឯង ហើយបានយាងទៅកាន់ក្រុងសាវត្ថីនោះឯង តាំងអំពីនោះមក អ្នកនគរនោះមានសទ្ធាជ្រះថ្លាជូច្នេះឯង ។

រឿង នាងចូឡសុភទ្ទា ចប់

រឿង ព្រះថេរៈឈ្មោះ ឯកវិហារី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះឯកវិហារី ត្រាស់ព្រះធម្មទេសនានេះថា **ឯកាសនំ** ជាដើម ។

បានឮថា ព្រះថេរៈនោះបានជាអ្នកប្រាកដក្នុងរវាងបរិស័ទ ៤ ថា អង្គុយម្នាក់ឯង ដើរម្នាក់ឯង ឈរតែម្នាក់ឯង ។ តមក ភិក្ខុទាំងឡាយក្រាបទូលដល់ព្រះតថាគតថា បពិត្រព្រះអង្គ ព្រះថេរៈនេះមានការប្រព្រឹត្តយ៉ាងនេះ ។

ព្រះសាស្តាប្រទានសាធុការថា សាធុ សាធុ ដូច្នេះហើយ ទ្រង់ទូន្មានថា ធម្មតាភិក្ខុគប្បីជាអ្នកស្ងាត់ រួចត្រាស់អានិសង្សក្នុងវិវេក ហើយទើបត្រាស់ព្រះគាថានេះថា

ឯកាសនំ ឯកសេយ្យំ ឯកោ ចរមតន្ទិតោ
ឯកោ ទមយមត្តានំ វនន្តេ រមិតោ សិយា ។

បុគ្គល គួរគប់រកទីអង្គុយម្នាក់ឯង ទីដេកម្នាក់ឯង ជាអ្នកត្រាច់ទៅម្នាក់ឯង មិនជាអ្នកខ្ជិលច្រអូស ជាអ្នកម្នាក់ឯងទូន្មានខ្លួន គួរជាអ្នកត្រេកអរក្នុងព្រៃស្ងាត់ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ឯកាសនំ ឯកសេយ្យំ** សេចក្តីថា ទីអង្គុយរបស់ភិក្ខុ ដែលមិនលះមូលកម្មដ្ឋាន អង្គុយត្រង់កណ្តាលភិក្ខុពាក់ពាន់ដោយការធ្វើទុកក្នុងចិត្តនោះឯង ឈ្មោះថាអង្គុយម្នាក់ឯង ទីដេករបស់ភិក្ខុដែលចូលទៅតាំងសតិ ហើយដេកលើដំណេកដែលគេក្រាលក្នុងព្រះវិហារ ដូចជា

លោហប្រាសាទក្តី ក្នុងកណ្តាលភិក្ខុវាប់ពាន់រូបក្តី ត្រង់កម្រាលដ៏វិចិត្រមានតម្លៃច្រើន ដោយបង្អៀងស្តាំក្តី ដោយមនសិការៈក្នុងមូលកម្មដ្ឋាន ឈ្មោះថាទីដេកម្នាក់ឯង ។ ភិក្ខុគប្បីសេពទីអង្គុយម្នាក់ឯង និងទីដេកម្នាក់ឯងបែបនេះ ។

បទថា **អតន្ទិតោ** សេចក្តីថា ភិក្ខុដែលមិនខ្ជិលច្រអូសដោយការអាស្រ័យកម្លាំងស្មងចិញ្ចឹមជីវិត ត្រាច់ទៅម្នាក់ឯងគ្រប់ឥរិយាបថ ។

បាទព្រះគាថាថា **ឯកោ ទមយមត្តានំ** សេចក្តីថា ជាបុគ្គលម្នាក់ឯងប៉ុណ្ណោះទូន្មានខ្លួន ដោយអំណាចនៃការតាមប្រកបកម្មដ្ឋាន ក្នុងទីទាំងឡាយមានទីសម្រាកពេលយប់ជាដើម ហើយសម្រេចមគ្គ និងផល ។

បាទព្រះគាថាថា **វនន្តេ រមិតោ សិយា** សេចក្តីថា ភិក្ខុកាលទូន្មានខ្លួនយ៉ាងនោះ ឈ្មោះថា គប្បីជាអ្នកត្រេកអរក្រៃលែងក្នុងជង្រៃ ដែលស្ងាត់ចាកសំឡេងទាំងឡាយ មានសំឡេងបុរស និងស្ត្រីជាដើម ។ ព្រោះភិក្ខុអ្នកមានប្រក្រតី នៅច្រឡូកច្រឡំ មិនអាចទូន្មានខ្លួនយ៉ាងនោះបាន ។

ក្នុងកាលចប់ទេសនា ភិក្ខុជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

តាំងអំពីនោះមក មហាជនប្រាថ្នាការនៅម្នាក់ឯងប៉ុណ្ណោះ ដូច្នេះ ។

រឿងព្រះថេរៈឈ្មោះឯកវិហារី ចប់

បកិណ្ណកវគ្គទី ២១ ចប់

សុត្តន្តបិដក

ធម្មបទគាថា និរយវគ្គទី ២២

[៣២] *អ្នកពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ (អំពើអាក្រក់) ហើយ និយាយថា អញមិនធ្វើទេ (បុគ្គលនោះ) រមែងទៅកាន់នរក ជនទាំង ២ នាក់ ដែលមានអំពើទាបថោក (ស្មើគ្នា) នោះ លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នា (ដោយគតិ) ក្នុងលោកខាងមុខទៀត ។*

ពួកជនច្រើននាក់ ដែលមានកពន្ធពន្ធ ដោយសំពត់កាសាវៈ តែ (ប្រព្រឹត្ត) ធម៌ដ៏លាមក មិនបានសង្រួម ពួកជនលាមកទាំងនោះ រមែងទៅកើតក្នុងនរក ដោយសារកម្មទាំងឡាយ ដ៏លាមកនោះ ។

បព្វជិតទ្រុស្តសីល សូវបរិភោគជុំដែក ដែលកំពុងក្តៅ មានពណ៌ដូចអណ្តាតភ្លើង ប្រសើរជាង បព្វជិតទ្រុស្តសីល មិនសង្រួម បរិភោគជុំបាយអ្នកដែន នឹងប្រសើរដូចម្តេចបាន ។

នរជន អ្នកប្រមាទហើយ សេពប្រពន្ធរបស់បុគ្គលដទៃ រមែងដល់នូវហេតុនៃសេចក្តីទុក្ខ ៤ យ៉ាងគឺ ទី ១ បានរបស់មិនមែនជាបុណ្យ ទី ២ ដេកមិនបានតាមប្រាថ្នា ទី ៣ ការតិះដៀល ទី ៤ ការធ្លាក់នរក ។ (ហេតុនៃសេចក្តីទុក្ខ ៤ យ៉ាង ផ្សេងទៀត) គឺបានរបស់មិនជាបុណ្យ ១ មានគតិអាក្រក់ ១ តម្រេករបស់បុរសអ្នកខ្លាច ជាមួយនឹងស្ត្រីដែលខ្លាចដែរ មានប្រមាណតិច ១ ព្រះរាជានឹងដាក់អាជ្ញាយ៉ាងធ្ងន់ ១ ព្រោះហេតុនោះ បុរសមិនគួរសេពប្រពន្ធរបស់បុគ្គលដទៃឡើយ ។

សព្វភ្លាំង ដែលបុគ្គលកាន់មិនចំណាប់ រមែងលះដៃ យ៉ាងណាមិញ ភាពជាសមណៈដែលបព្វជិតកាន់មិនស៊ប់សួនហើយ រមែងទាញបព្វជិតនោះទៅនរក យ៉ាងនោះឯង ។

កម្មណាមួយ ដែលធូរថយក្តី វត្តណាមួយដែលសៅហ្មងក្តី ព្រហ្មចរិយៈ ដែលបុគ្គលរឭកដោយសេចក្តីរង្កៀសក្តី កម្មទាំង ៣ ជារបស់មិនមានផលច្រើនឡើយ ។

បើបុគ្គលធ្វើ គប្បីធ្វើកិច្ចនោះឲ្យមែនទែន គប្បីប្រឹងប្រែងធ្វើកិច្ចនោះឲ្យមាំមួន ព្រោះថា សមណធម៌ជាគ្រឿងរៀរចាកកិលេសធូរថយ រមែងរោយធូលី គឺរាគាទិក្កិលេសដល់បុគ្គលដោយក្រៃលែង ។

អំពើអាក្រក់ ដែលបុគ្គលមិនធ្វើ ប្រសើរជាង (ព្រោះថា) អំពើអាក្រក់ រមែងធ្វើឲ្យក្តៅក្រហាយ ក្នុងកាលខាងក្រោយ បុគ្គលធ្វើអំពើណាហើយ រមែងមិនក្តៅក្រហាយក្រោយ អំពើនោះ ជាអំពើល្អ បើបុគ្គលធ្វើហើយ ឈ្មោះថា បុគ្គលប្រសើរ ។

នគរនៅទីបំផុតដែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុង ទាំងខាងក្រៅ យ៉ាងណា អ្នកទាំងឡាយ គួរឃ្លាំងខ្លួនយ៉ាងនោះ កុំឲ្យខណៈកន្លងអ្នកទាំងឡាយបានឡើយ ព្រោះថា ជនទាំងឡាយ ដែលឲ្យខណៈកន្លងហើយ រមែងសោកស្តាយ ក្នុងនរក មីរដេរដាស ។

សត្វទាំងឡាយដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្វាស ក្នុងហេតុដែលគេមិនត្រូវខ្វាស រមែងមិនខ្វាស ក្នុងហេតុដែលគេត្រូវខ្វាស សត្វទាំងនោះ

តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញក្នុងហេតុដែលគេមិនត្រូវខ្ជាច ថាជាហេតុដែលគេត្រូវខ្ជាចផង យល់ឃើញក្នុងហេតុដែលគេត្រូវខ្ជាច ថាជាហេតុដែលគេមិនត្រូវខ្ជាចផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញក្នុងហេតុដែលឥតទោស ថាជាហេតុមានទោសផង យល់ឃើញក្នុងហេតុដែលមានទោស ថាជាហេតុឥតទោសផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយ ដែលប្រកាន់សម្មាទិដ្ឋិ ដឹងរបស់មានទោស ថាជារបស់មានទោសផង ដឹងរបស់មិនមានទោស ថាជារបស់មិនមានទោសផង សត្វទាំងនោះ តែងទៅកាន់សុគតិ ។

និរយវគ្គទី ២២ ចប់

អដ្ឋកថា

និរយវគ្គទី ២២

រឿង ជាឥបរិព្វាជិកាឈ្មោះ សុន្ទរី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងបរិព្វាជិកាឈ្មោះសុន្ទរី ត្រាស់ព្រះធម្មទេសនានេះថា **អភូតវាទី** *ជាដើម ។*

រឿងមកពិស្តារក្នុងគម្ពីរខុទ្ទាននោះឯងថា សម័យនោះឯង ព្រះសាស្តាដែលមហាជនធ្វើសក្ការៈ ធ្វើសេចក្តីគោរពរាប់អាន បូជាហើយជាដើម ។ ឯអត្ថដោយសង្ខេបក្នុងរឿងនេះ មានដូចតទៅ

បានឮថា កាលលាភសក្ការៈ ជូចគ្នានឹងជំនន់ទឹកធំនៃស្ទឹងទាំង ៥ កើតខ្លឹងដល់ព្រះសាស្តា និងភិក្ខុសង្ឃហើយ ពួកតិរ្ថិយក៏សាបសូន្យលាភសក្ការៈជាអ្នកអាប់រស្មី ដូចអំពិលអំពែកក្នុងពេលព្រះអាទិត្យរះខ្លឹង រួមប្រជុំប្រឹក្សាគ្នាថា តាំងអំពីកាលនៃព្រះសមណគោតមកើតខ្លឹង ពួកយើងក៏វិនាសលាភសក្ការៈ បុគ្គលណាម្នាក់រមែងមិនដឹងភាពដែលពួកយើងទាំងឡាយមាន ពួកយើងគប្បីរួមគ្នាជាមួយអ្នកណាហ្ន៎ បង្កាទោសឲ្យកើតខ្លឹងដល់ព្រះសមណ-គោតម ហើយញុំាងលាភសក្ការៈរបស់លោកឲ្យសាបសូន្យ ។

គ្រានោះ ការគិតបានកើតខ្លឹងដល់តិរ្ថិយទាំងនោះថា ពួកយើងរួមជា

មួយនាង៑សុន្ទរីនឹង៑អាចធ្វើបាន ។ ថ្ងៃមួយ ពួកតិរ្ថិយទាំង៑នោះ ក្លែង៑ធ្វើមិននិយាយ ជាមួយនាង៑សុន្ទរី ដែលចូលទៅកាន់អារាមតិរ្ថិយ ថ្វាយបង្គំហើយឈរ សូម្បី នាង៑ច្រោស្រែ៑យរឿយៗ ក៏មិនបានពាក្យឆ្លើយតប ទើបសួរថា លោកម្ចាស់ ទាំង៑ឡាយត្រូវអ្នកណាបៀតបៀនឬ ពួកតិរ្ថិយពោលថា នែប្អូនស្រី នាង៑មិន ឃើញព្រះសមណគោតម ដែលត្រាច់បៀតបៀនពួកយើង៑ ធ្វើឲ្យវិនាសលាភ សក្ការៈទេឬ ។

នាង៑សុន្ទរីពោលថា ខ្ញុំគួរធ្វើអ្វីក្នុង៑រឿង៑នេះ តិរ្ថិយពោលថា ប្អូនស្រី នាង៑មានរូបស្អាត ដល់នូវភាពជាអ្នកល្អលើស ចូរលើកទោសឡើង៑ដល់ព្រះ សមណគោតម ហើយឲ្យមហាជនជឿពាក្យ ធ្វើឲ្យវិនាសលាភសក្ការៈ ។

នាង៑សុន្ទរីនោះទទួលថា សាធុ ហើយចៀសចេញទៅ តាំង៑អំពីនោះមក នាង៑កាន់យករបស់មានកម្រែ៑ងផ្កា គ្រឿង៑ក្រអូប គ្រឿង៑លាប កប៊ូរ និង៑ គ្រឿង៑ទេសជាដើម ដើរបែរមុខទៅកាន់វត្តជេតពន ក្នុង៑ពេលដែលមហាជន ស្តាប់ព្រះធម្មទេសនា របស់ព្រះសាស្តាហើយ ត្រឡប់ចូលព្រះនគរក្នុង៑ពេល ល្ងាច ត្រូវមហាជនសួរថា នាង៑ទៅណា ក៏ឆ្លើយថា ទៅសម្អាក់ព្រះសមណ-គោតម ខ្ញុំនៅក្នុង៑ព្រះគន្ធកុដិជាមួយព្រះសមណគោតមនោះ ហើយទៅកាន់ អារាមតិរ្ថិយមួយកន្លែង៑ ដើរទៅកាន់ផ្លូវដែលមិនទាន់ដល់វត្តជេតពនអំពីព្រលឹម ដើរបែរមុខមកកាន់ព្រះនគរ ត្រូវមហាជនសួរថា នែសុន្ទរីនាង៑ទៅណា ក៏ឆ្លើយ ថា ខ្ញុំនៅក្នុង៑ព្រះគន្ធកុដិជាមួយព្រះសមណគោតម លោកត្រេកអរដោយការ ត្រេកអរ ព្រោះកិលេសហើយ ទើបខ្ញុំត្រឡប់មក ។

បន្ទាប់អំពីនោះមក កន្លងទៅបាន ២-៣ ថ្ងៃ ពួកតិរ្ថិយឲ្យកហាបណៈ ដល់អ្នកលេងហើយពោលថា ចូរពួកអ្នកទៅសម្លាប់នាងសុន្ទរី ហើយកប់ក្នុងគំនរសំរាម នៃផ្កាដែលស្វិតស្រពោន ក្បែរព្រះគន្ធកុដិរបស់ព្រះសមណ-គោតម ហើយត្រឡប់មក ។ ពួកអ្នកលេងក៏បានធ្វើយ៉ាងនោះ ។

លុះជាប់នោះ តិរ្ថិយទាំងឡាយបានធ្វើកោលាហលឡើងថា ពួកយើងមិនឃើញនាងសុន្ទរី ហើយទូលដល់ព្រះរាជា ត្រូវព្រះរាជាត្រាស់សួរថា តើពួកអ្នកមានសង្ស័យក្នុងទីណា ទូលថា នាងសុន្ទរីនៅក្នុងវត្តជេតពន អស់ថ្ងៃមានប្រមាណប៉ុណ្ណោះ ពួកអាត្មាមិនជ្រាបការប្រព្រឹត្តទៅរបស់នាង ក្នុងវត្តជេតពននោះ កាលព្រះរាជាអនុញ្ញាតថា បើដូច្នោះ ចូរពួកអ្នកទៅរកមើលក្នុងវត្តជេតពននោះចុះ នាំពួកឧបដ្ឋាករបស់ខ្លួន ទៅកាន់វត្តជេតពន រកមើល ក៏ឃើញក្នុងរោងគំនរសំរាមនៃផ្កាដែលគេចោល ទើបលើកឡើងដាក់លើគ្រែ ចូលទៅកាន់ព្រះនគរ ទូលដល់ព្រះរាជាថា សាវ័ករបស់ព្រះសមណគោតម សម្លាប់នាងសុន្ទរី ហើយកប់ក្នុងរោងគំនរសំរាម នៃកម្រងផ្កាដែលគេចោល ដោយគិតថា នឹងបិទបាំងកម្មលាមកដែលព្រះសាស្តាធ្វើ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរពួកអ្នកទៅប្រកាសពេញព្រះនគរចុះ ។ ពួកតិរ្ថិយនាំគ្នាពោលពាក្យជាដើមថា ចូរអ្នកទាំងឡាយ មើលកម្មរបស់ពួកសមណសក្យបុត្តចុះ ក្នុងវិថីនៃព្រះនគរហើយ បានទៅកាន់ទ្វារព្រះរាជនិវេសន៍ទៀត ព្រះរាជាត្រាស់ឲ្យលើកសរីរៈរបស់នាងសុន្ទរីឡើងដាក់លើគ្រែ ទុកក្នុងព្រៃខ្មោចហើយឲ្យរក្សា ។ ពួកអ្នកនគរសោវត្តី រៀរព្រះអរិយសាវ័កដ៏សេសដោយច្រើន នាំ

គ្នាពោលពាក្យជាដើមថា សូមអ្នកទាំងឡាយ មើលកម្មរបស់ពួកសមណ-សក្យបុត្តចុះ ហើយដើរជេរពួកភិក្ខុខាងក្នុងព្រះនគរខ្លះ ខាងក្រៅព្រះនគរខ្លះ ក្នុងព្រៃខ្លះ ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះ ដល់ព្រះតថាគត ។

ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ ចូរពួកអ្នកត្រឡប់ចោទ ពួកមនុស្សទាំងនោះយ៉ាងនេះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អភូតវាទី និរយំ ឧបេតិ យោ វាបិ កត្វា ន กរោមីតិ ចាហ
ឧភោបិ តេ បេច្ច សមា ភវន្តិ ឆហីនកម្មា មនុជា បរត្ថ ។

អ្នកពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ (អំពើអាក្រក់) ហើយនិយាយថា អញមិនធ្វើទេ (បុគ្គលនោះ) រមែងទៅកាន់នរក ជនទាំងពីរនាក់ ដែលមានអំពើទាបថោក (ស្មើគ្នា) នោះ លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នា (ដោយគតិ) ក្នុងលោកខាងមុខទៀត ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អភូតវាទី** *បានដល់ មិនឃើញទោសរបស់បុគ្គលដទៃ ធ្វើនូវការពោលកុហក ចោទអ្នកដទៃដោយពាក្យទេ ។*

បទថា **กត្វา** *សេចក្តីថា បុគ្គលធ្វើកម្មណាមកហើយ ពោលថា ខ្ញុំមិនបានធ្វើកម្មនោះ ។*

ច្រើនបទថា **បេច្ច សមា ភវន្តិ** *សេចក្តីថា ជនទាំងពីរនោះ ទៅកាន់បរលោក រមែងជាអ្នកស្មើគ្នាដោយគតិ ព្រោះការចូលដល់នរក ។ គតិរបស់

ជនទាំងនោះប៉ុណ្ណោះ អ្នកជ្រាជ្រកំណត់ហើយ ។ តែអាយុរបស់បុគ្គលនោះ លោកមិនបានកំណត់ ព្រោះថា ជនទាំងឡាយ ធ្វើបាបកម្មច្រើន រមែងឆេះក្នុងនរក ធ្វើបាបកម្មតិច រមែងឆេះអស់កាលតិចតួចប៉ុណ្ណោះ ព្រោះកម្មដែលលាមករបស់ជនទាំងពីរនោះឯងជាហេតុ ព្រោះដូច្នោះ ទើបព្រះសាស្តាត្រាស់ថា **និហីនកម្មា មនុជា បរត្ថ ។**

បទថា **បរត្ថ** *សម្ពន្ធចូលជាមួយបទថា* **បេច្ច** *ខាងមុខ អធិប្បាយថា ជនមានកម្មអាក្រក់ទាំងនោះ លះទៅក្នុងលោកដទៃ គឺទៅចាកលោកនេះ រមែងជាអ្នកស្មើក្នុងបរលោក ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ព្រះរាជា ទ្រង់បញ្ជូនរាជបុរសទៅដោយព្រះតម្រាស់ថា ចូរពួកអ្នកជីងភាពដែលអ្នកជដទៃ ដែលសម្លាប់នាងសុន្ទរី ។ គ្រានោះ អ្នកលេងទាំងនោះផឹកស្រាដោយកហាបណៈទាំងនោះ ធ្វើនូវការឈ្លោះគ្នានិងគ្នា ជនម្នាក់ពោលនឹងជនម្នាក់ថា ឯងសម្លាប់នាងសុន្ទរីដោយការប្រហារត្រឹមតែម្តង ហើយកប់ក្នុងគំនរផ្តៅដែលស្ងិត ផឹកស្រាដោយកហាបណៈដែលបានអំពីការប្រហារនោះរឿងនោះ លើកទុកចុះ ។ ទើបពួករាជបុរសចាប់អ្នកលេងនោះ ទៅបង្ហាញដល់ព្រះរាជា ។ លំដាប់នោះ ព្រះរាជាត្រាស់សួរអ្នកលេងទាំងនោះថា ពួកអ្នកសម្លាប់នាងសុន្ទរីឬ ពួកអ្នកលេងពោលថា ករុណាថ្លៃវិសេស ព្រះរាជាត្រាស់ថា អ្នកណាប្រើពួកឯងឲ្យសម្លាប់ អ្នកលេងពោលថា បពិត្រព្រះអង្គ

គឺពួកតិរ្ថិយ ។

ព្រះរាជាត្រាស់ឲ្យហៅពួកតិរ្ថិយមកហើយត្រាស់ថា ចូរពួកអ្នកត្រាច់ទៅពោលក្នុងព្រះនគរយ៉ាងនេះថា នាងសុន្ទរី ត្រូវពួកខ្ញុំដែលប្រាថ្នាលើកទោសដល់ព្រះសមណគោតមសម្លាប់ហើយ ទោសសាវ័ករបស់ព្រះសមណគោតមមិនមានឡើយ ជាទោសរបស់ខ្ញុំតែម្យ៉ាង ។ ពួកតិរ្ថិយបានធ្វើយ៉ាងនោះ ។ មហាជនល្ងង់ខ្លៅជឿហើយក្នុងគ្រានោះ ។ ពួកតិរ្ថិយក្តី ពួកអ្នកលេងក្តីដល់នូវអាជ្ញាព្រោះការសម្លាប់មនុស្ស ចាប់តាំងពីនោះមក សក្ការៈមានដល់ព្រះពុទ្ធនិងសាវ័កទាំងឡាយក្រៃលែងឡើង ដូច្នេះឯង ។

រឿង នាងចិញ្ចាមាណវិកាឈ្មោះ សុន្ទរី ចប់

រឿង សត្វដែលត្រូវទុក្ខបៀតបៀន

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសត្វទាំងឡាយដែលអានុភាពនៃផលទុច្ចរិតបៀតបៀន ត្រាស់ព្រះធម្មទេសនានេះថា **ការសាវកឈ្មោ** *ជាដើម ។*

សេចក្តីពិស្តារថា ព្រះមហាមោគ្គល្លានត្ថេរ ចុះអំពីភ្នំគិជ្ឈកូដ មួយអន្ទើដោយព្រះលក្ខណត្ថេរ ឃើញអត្តភាពពួកនេរយិកសត្វ មានប្រេតដែលមានតែរាងឆ្អឹងជាដើម ទើបធ្វើការញញឹម ត្រូវព្រះលក្ខណត្ថេរសួរដល់ហេតុដែល

ធ្វើការញញឹម ក៏ពោលថា អាវុសោ កាលនេះ មិនមែនកាលនៃបញ្ហានេះ អាវុសោគប្បីសួរខ្ញុំក្នុងសម្នាក់ព្រះតថាគត ។ កាលព្រះថេរៈសួរក្នុងសម្នាក់ព្រះតថាគតហើយ ជ្រាប់ភាពដែលខ្លួនឃើញនេរយិកសត្វ គឺប្រេតដែលមានតែរាងឆ្អឹងជាដើមហើយ ទើបជ្រាប់សហជម្មិកទាំង ៥ ដែលក្តៅក្រហាយដោយសមណបរិក្ខារ មានបាត្រ ចីវរ និងវត្តពន្ធជាដើម ដោយនយថា អាវុសោ ខ្ញុំចុះអំពីភ្នំគិជ្ឈកូដ បានឃើញភិក្ខុក្នុងពុទ្ធសាសនានេះ ទៅកាន់អាកាស កាយរបស់ភិក្ខុនោះ ក៏ក្តៅក្រហាយ ។

ព្រះសាស្តា ត្រាស់ជ្រាប់ភាពដែលសត្វទាំងនោះ បួសក្នុងសាសនាព្រះកស្សបទសពលហើយ មិនអាចធ្វើឲ្យសមគួរដល់បព្វជ្ជា ជាភិក្ខុលាមក កាលទ្រង់សម្តែងផលនៃទុច្ចរិតកម្មរបស់ភិក្ខុលាមកទាំងឡាយ ដែលអង្គុយក្នុងទីនោះក្នុងខណៈនោះ ទើបត្រាស់ព្រះគាថានេះថា

កាសាវកណ្ឋា ពហវោ ចាបធម្មា អសញ្ញតា
ចាចា ចាបេហិ កម្មេហិ និរយន្តេ ឧបបជ្ជរេ ។

ពួកជនច្រើននាក់ ដែលមានកព័ន្ធព័ន្ធដោយសំពត់កាសាវៈតែ (ប្រព្រឹត្ត) ធម៌ដ៏លាមក មិនបានសង្រួម ពួកជនលាមកទាំងនោះ រមែងទៅកើតក្នុងនរក ដោយសារកម្មទាំងឡាយ ដ៏លាមកនោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កាសាវកណ្ឋា** បានដល់ បុគ្គលមានក

រុំដោយសំពត់កាសាវៈ ។

បទថា **ចាមចម្មា** *ប្រែថា ដែលមានធម៌លាមក ។*

បទថា **អសញ្ញតា** *បានដល់ ដែលវៀរចាកការសង្រួមផ្លូវកាយជាដើម អធិប្បាយថា បុគ្គលលាមកបែបនោះរមែងចូលដល់នរក ព្រោះអកុសលកម្មទាំងឡាយដែលខ្លួនធ្វើ ជនទាំងនោះ ឆេះក្នុងនរកនោះហើយ ចុតិអំពីនរកនោះ ឆេះក្នុងបេតវិសយទាំងឡាយយ៉ាងនោះ ព្រោះកម្មដែលឲ្យផលនៅសេសសល់ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង សត្វដែលត្រូវទុក្ខបៀតបៀន ចប់

រឿង ភិក្ខុនៅត្រង់ឆ្នេរស្ទឹងឈ្មោះវគ្គុមុទា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងវេសាលី នាព្រៃមហាវន ទ្រង់ប្រារព្ធពួកភិក្ខុដែលនៅត្រង់ឆ្នេរស្ទឹងវគ្គុមុទា ត្រាស់ព្រះធម្មទេសនានេះថា **សេយ្យោ អយោគុឡ្ហោ** *ជាដើម ។*

រឿងនេះមកហើយ ក្នុងឧត្តរិមនុស្សធម្មបារាជិកសិក្ខាបទនោះឯង ។ ក្នុងកាលនោះឯង ព្រះសាស្តាត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ពួក

អ្នកនាំគ្នាពោលគុណនៃឧត្តរិមនុស្សធម្ម នៃគ្នានិងគ្នាដល់ពួកគ្រហស្ថ ដើម្បីតែផ្ទៃឬ ។ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ដូច្នេះហើយ ទ្រង់តិះដៀលភិក្ខុទាំងនោះដោយអនេកបរិយាយ ហើយត្រាស់ព្រះគាថានេះថា

សេយ្យោ អយោគុឡោ ភុត្តោ តត្តោ អគ្គិសិខោបមោ
យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោ ។

បពូជិតទ្រុស្តសីល សូវបរិភោគជុំដែកដែលកំពុងក្តៅ មានពណ៌ដូចអណ្តាតភ្លើងប្រសើរជាង បពូជិតទ្រុស្តសីល មិនសង្រួមបរិភោគ ជុំបាយអ្នកដែន នឹងប្រសើរដូចម្តេចបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **យញ្ចេ ភុញ្ជេយ្យ** *សេចក្តីថា ភិក្ខុទ្រុស្តសីល គឺភិក្ខុមិនមានសីល មិនសង្រួមផ្លូវកាយជាដើម ប្តេជ្ញាខ្លួនថា អញជាសមណៈ ទទួលជុំបាយអ្នកដែនដែលប្រគេនដោយសទ្ធា ដែលឈ្មោះថារដ្ឋបិណ្ឌឯណាហើយគប្បីឆាន់ ជុំដែកក្តៅមានពណ៌ដូចភ្លើងដែលភិក្ខុឆាន់ហើយ ប្រសើរជាង គឺល្អជាងនោះ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអត្តភាពមួយ គប្បីត្រូវភ្លើងឆេះ ព្រោះការបរិភោគជុំដែកនោះជាបច្ច័យ សូម្បីបុគ្គលទ្រុស្តសីល បរិភោគជុំបាយដែលគេប្រគេនដោយសទ្ធា គប្បីឆេះក្នុងនរកទាំងឡាយ រាប់រយអត្តភាព ។ ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។*

រឿង ភិក្ខុនៅត្រង់ច្រេះស្ទឹងឈ្មោះវគ្គុមុទា ចប់

រឿង សេដ្ឋីបុត្រឈ្មោះ ខេមកៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីបុត្រឈ្មោះ ខេមកៈ ដែលជាកូនយរបស់អនាថបិណ្ឌិកសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះថា **ចត្តារិ ឋានានិ** ជាដើម ។

បានឮមកថា ខេមកៈនោះជាបុរសរូបស្អាត ដោយច្រើនស្រីទាំងឡាយ ឃើញគាត់ហើយ ត្រូវរាគៈគ្របសង្កត់ មិនអាចតាំងនៅតាមការៈរបស់ខ្លួនបាន គាត់បានត្រេកអរក្នុងបទារកម្មនោះដូចគ្នា ។

បន្ទាប់មកក្នុងពេលរាត្រី ពួករាជបុរសចាប់នាំទៅបង្ហាញដល់ព្រះរាជា ។ ព្រះរាជាមិនបានត្រាស់ ដោយត្រិះរិះថា យើងខ្វាសចំពោះមហាសេដ្ឋី ហើយឲ្យដោះលែងទៅ ចំណែកខេមកៈនោះ មិនបានរាងចាលទ្បើយ ។ បន្ទាប់មក ពួករាជបុរសក៏ចាប់បង្ហាញដល់ព្រះរាជាអស់វារៈ ២ ដង អស់វារៈ ៣ ដង ព្រះរាជាត្រាស់ឲ្យដោះលែងជដែល ។ សេដ្ឋីជ្រាបរឿងនោះហើយ នាំខេមកៈចូលទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលរឿងនោះហើយទូលថា បពិត្រព្រះអង្គ សូមទ្រង់សម្តែងធម៌ដល់ខេមកៈនេះ ។

ព្រះសាស្តាត្រាស់សង្វេគកថាដល់ខេមកៈហើយ កាលទ្រង់សម្តែងទោសក្នុងការសេពកិរិយាអ្នកដទៃ ទ្រង់ភាសិតព្រះគាថាទាំងនោះថា

ចត្តារិ ឋានានិ នរោ បមត្តោ អាបជ្ជតី បរទារូបសេវី
អបុញ្ញលាភំ ន និកាមសេយ្យំ និន្ទំ តតិយំ និរយំ ចតុត្ថំ ។

អបុញ្ញលាភោ ច គតី ច ចាបិកា ភីតស្ស ភីតាយ រតី ច ថោកិការាជា ច ឧណ្ហំ គរុកំ បណេតិ តស្មា នរោ បឧារំ ន សេវ ។

នរជនអ្នកប្រមាទហើយ សេពប្រពន្ធរបស់បុគ្គលដទៃ រមែងដល់នូវ ហេតុនៃសេចក្តីទុក្ខ ៤ យ៉ាងគឺ ទី ១ បានរបស់មិនមែនជាបុណ្យ ទី ២ ដេកមិនបានតាមប្រាថ្នា ទី ៣ ការតិះដៀល ទី ៤ ការធ្លាក់ នរក ។ (ហេតុនៃសេចក្តីទុក្ខ ៤ យ៉ាងផ្សេងទៀត) គឺបានរបស់ មិនជាបុណ្យ ១ មានគតិអាក្រក់ ១ តម្រេករបស់បុរសអ្នកខ្លាច ជាមួយនឹងស្ត្រីដែលខ្លាចដែរ មានប្រមាណតិច ១ ព្រះរាជានឹង ដាក់អាជ្ញាយ៉ាងធ្ងន់ ១ ព្រោះហេតុនោះ បុរស មិនគួរសេពប្រពន្ធ របស់បុគ្គលដទៃទ្បើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឋានានិ** *បានដល់ ហេតុនៃទុក្ខទាំងឡាយ ។ បទថា* **បមត្តោ** *បានដល់ ប្រកបដោយការបណ្តោយសតិ ។ បទថា* **អាបជ្ជតិ** *គឺរមែងដល់ ។*

បទថា **បរឧារូបសេវី** *សេចក្តីថា ចូលទៅសេពកិរិយារបស់អ្នកដទៃ ឈ្មោះថា ប្រព្រឹត្តក្រៅផ្លូវ ។*

បទថា **អបុញ្ញលាភំ** *បានដល់ ការបាននូវអកុសល ។*

បទថា **ន និកាមសេយ្យំ** *សេចក្តីថា បុគ្គលនោះ មិនបានការដេកតាម*

ប្រាថ្នា រមែងបាននូវការដេកអស់កាលបន្តិចបន្តួចប៉ុណ្ណោះដែលខ្លួនមិនប្រាថ្នា ។

បទថា **អបុញ្ញលាភោ ច** *សេចក្តីថា ការបាននូវវត្ថុ ដែលមិនមែនជាបុណ្យ ១ គតិដ៏លាមក ពោល គឺនរក ព្រោះវត្ថុដែលមិនមែនជាបុណ្យនោះ ជាហេតុ ១ រមែងមិនមានដល់បុគ្គលនោះយ៉ាងនេះ ។*

ពីរបទថា **រតី ច ថោកិកា** *សេចក្តីថា ការត្រេកអររបស់បុរសដែលខ្ជាចនោះ ជាមួយស្រីដែលខ្ជាចមានប្រមាណតិច គឺមានតិចតួច ។*

បទថា **គរុកំ** *សេចក្តីថា ម្យ៉ាងទៀត ព្រះរាជារមែងជាក់នូវអាជ្ញាយ៉ាងធ្ងន់ ដោយអំណាចនៃការកាត់ដៃជាដើម ។*

បទថា **តស្មា** *ជាដើម សេចក្តីថា បុគ្គលសេពកវិយារបស់អ្នកដទៃ រមែងដល់នូវហានៈទាំងឡាយ ដែលមិនមែនជាបុណ្យជាដើមនោះ ព្រោះដូច្នោះ ទើបនរៈមិនគួរសេពកវិយារបស់អ្នកដទៃ ។*

ក្នុងកាលចប់ទេសនា ខេមកៈតាំងនៅក្នុងសោតាបត្តិផល តាំងអំពីនោះមក មហាជនញុំាងកាលឲ្យកន្ទងទៅយ៉ាងសប្បាយ ។

សួរថា បុព្វកម្មរបស់ខេមកៈនោះដូចម្តេច ឆ្លើយថា បានឮមកថា ក្នុងសម័យរបស់ព្រះពុទ្ធព្រះនាមកស្សបទសពល ខេមកៈជាអ្នកប្រជាល់ដែលពូកែបំផុត គាត់លើកទង់មាសពីរបន្ទះឡើង ត្រង់កាពួនស្តូបរបស់ព្រះទសពលហើយ តាំងសេចក្តីប្រាថ្នាថា រៀវតែស្រីដែលជាញាតិចេញ ស្រីដ៏សេសឃើញខ្ញុំព្រះអង្គហើយ សូមមានតម្រេក ។ នេះជាបុព្វកម្មរបស់ខេមកៈដោយប្រការដូច្នេះ ។ ព្រោះដូច្នោះ ស្រីរបស់ជនដទៃឃើញខេមកៈ ក្នុងទីដែលខេមកៈ

កើតហើយ ទើបមិនអាចតាំងនៅតាមការៈរបស់ខ្លួនបាន ដូច្នេះឯង ។

រឿង សេដ្ឋីបុត្រឈ្មោះ ខេមកៈ ចប់

រឿង ភិក្ខុប្រជៅក្រ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រជៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **កុសោ យថា** ជាដើម ។

បានឮមកថា ភិក្ខុមួយរូបមិនក្លៃង គឺធ្វើឲ្យជាច់ស្មៅមួយដើម កាលសេចក្តីរង្គៀសកើតឡើង ទើបចូលទៅរកភិក្ខុមួយរូប ប្រាប់កម្មដែលខ្លួនធ្វើហើយ សួរថា អាវុសោ ភិក្ខុកាត់ស្មៅ ទោសណាមួយរមែងមានដល់ភិក្ខុនោះ លុំជាប់នោះ ភិក្ខុក្រៅអំពីនេះពោលនឹងលោកថា លោកធ្វើការសម្គាល់ថា ទោសណាមួយមាន ព្រោះហេតុនៃស្មៅដែលលោកផ្តាច់ហើយ ទោសណាមួយរមែងមិនមានក្នុងទីនេះ កាលលោកសម្តែងហើយ រមែងផុតបានសូម្បីខ្លួនឯង ក៏បានយកដៃទាំងពីរដកស្មៅហើយកាន់ ភិក្ខុទាំងឡាយ ក្រាបទូលរឿងនោះ ដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់តិះដៀលភិក្ខុនោះដោយអនេកបរិយាយ កាលសម្តែងធម៌ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

កុសោ យថា ទុគ្គហិតោ　　ហត្ថមេវានុកន្តតិ
សាមញ្ញំ ទុប្បរាមដ្ឋំ　　និរយាយូបកឌ្ឍតិ ។
យំ កិញ្ចិ សិថិលំ កម្មំ　　សង្កិលិដ្ឋញ្ច យំ វតំ
សង្កស្សរំ ព្រហ្មចរិយំ　　ន តំ ហោតិ មហប្ផលំ ។
កយិរា ចេ កយិរាថេនំ　　ទឡ្ហមេនំ បរក្កមេ
សិថិលោ ហិ បរិព្ពាជោ　　ភិយ្យោ អាកិរតេ រជំ ។

ស្បៃវក្កាំងដែលបុគ្គលកាន់មិនចំណាប់ រមែងលះដៃ យ៉ាងណាមិញ កាពជាសមណៈ ដែលបព្វជិតកាន់មិនស៊ប់សួនហើយ រមែងទាញបព្វជិតនោះទៅនរក យ៉ាងនោះឯង ។ កម្មណាមួយដែលធូរថយក្តី វត្តណាមួយដែលសៅហ្មងក្តី ព្រហ្មចរិយៈដែលបុគ្គលរព្រឹកដោយសេចក្តីរង្កៀសក្តី កម្មទាំង ៣ នោះ ជារបស់មិនមានផលច្រើនឡើយ។ បើបុគ្គលធ្វើ គប្បីធ្វើកិច្ចនោះឲ្យមែនទែន គប្បីប្រឹងប្រែងធ្វើកិច្ចនោះឲ្យមាំមួន ព្រោះថា សមណធម៌ ជាគ្រឿងរៀរចាកកិលេសធូរថយ រមែងរោយធូលី គឺរាគាទិក្លិសជាប់បុគ្គលដោយក្រៃលែង ។

សេចក្តីអធិប្បាយ

ស្មៅដែលមានជ្រុងមុត ដោយហោចសូម្បីស្មៅគ្នោតឈ្មោះថា **កុសោ** *ក្នុងព្រះគាថានោះ ។ ស្បៃវក្កាំងនោះ បុគ្គលណាចាប់មិនល្អរមែងមុត គឺរមែង*

លះដៃរបស់បុគ្គលនោះ យ៉ាងណា សូម្បីគុណជាគ្រឿងរបស់សមណៈ ពោល គឺសមណធម៌ក៏ដូច្នោះដូចគ្នា ឈ្មោះថា បុគ្គលស្អាបអង្អែលមិនល្អ ព្រោះភាពជាអ្នកមានសីលដាច់ជាដើម ។

បាទព្រះគាថាថា **និរយាយូបកឌ្ឍតិ** *សេចក្តីថា រមែងឲ្យកើតក្នុងនរក ។*

បទថា **សិថិលំ** *បានដល់ ការងារឯណានីមួយដែលបុគ្គលធ្វើ ធ្វើឲ្យជាការកាន់យកធូរថយ ដោយធ្វើឲ្យធូរលុង ។*

បទថា **សង្ខិលិដ្ឋំ** *សេចក្តីថា ឈ្មោះថា សៅហ្មងព្រោះការត្រាច់ទៅក្នុងអគោចរ មានស្រីបេសྱាជាដើម ។*

បទថា **សង្ឃសង្ឃរំ** *បានដល់ គប្បីរឭកដោយការសង្រួយទាំងឡាយ គឺឃើញសង្ឃដែលប្រជុំគ្នាដោយកិច្ចណាមួយ ក្នុងបណ្តាកិច្ច មានឧបោសថជាដើម ហើយរឭកដោយសេចក្តីសង្រួយរបស់ខ្លួន គឺរង្កៀស បានដល់ សង្រួយយ៉ាងនេះថា ភិក្ខុទាំងនេះជ្រាបនូវការប្រព្រឹត្តរបស់អញ មានបំណងនឹងលើកវត្តអញ ទើបប្រជុំគ្នាពិត ។*

ពីរបទថា **ន តំ ហោតិ** *សេចក្តីថា ព្រហ្មចរិយៈ ពោល គឺសមណធម៌នោះ គឺបែបនោះ រមែងមិនមានផលច្រើនដល់បុគ្គលនោះ ព្រោះមិនមានផលច្រើនដល់លោក ក៏រមែងមិនមានផលច្រើនដល់ទាយក ដែលជាអ្នកប្រគេនភិក្ខាផងដែរ ។*

បទថា **កយិរា ចេ** *សេចក្តីថា ព្រោះហេតុនោះ បុគ្គលគប្បីធ្វើការងារណា ចូរធ្វើការងារនោះពិតៗ ។*

បាទព្រះគាថាថា **ឧដ្ឋាមេនំ បវក្កមេ** *សេចក្តីថា គួរធ្វើការងារនោះឲ្យជារបស់ដែលខ្លួនធ្វើមាំទាំ គឺជាអ្នកមានការសមាទានតាំងមាំ ធ្វើការងារនោះ ។*

បទថា **បរិព្ភោជោ** *បានដល់ សមណធម៌ដែលបុគ្គលធ្វើដោយការប្រកាន់ធូរថយ ដែលដល់នូវភាវៈ មានការជាប់ជាដើម ។*

បទថា **អិយ្យោ** *សេចក្តីថា សមណធម៌បែបនោះ រមែងមិនអាចនាំចេញនូវធូលី មានធូលី គឺរាគៈជាដើម ដែលមានក្នុងខាងក្នុងដោយពិត រមែងរោយនូវធូលី មានរាគៈជាដើមដទៃ លើបុគ្គលនោះ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ។ កិក្ខុនោះតាំងនៅក្នុងការសង្រួមហើយ ក្រោយមកចម្រើនវិបស្សនា សម្រេចអរហត្ត ដូច្នេះឯង ។

រឿង ភិក្ខុប្រដៅក្រចប់

រឿង ស្រីឆ្នាស

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្រីកាចម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **អកតំ** *ជាដើម ។*

បានឮមកថា ប្តីរបស់ស្រីនោះ បានធ្វើការស្និទ្ធស្នាលជាមួយស្រីបម្រើក្នុងផ្ទះម្នាក់ ។ ស្រីកាចនោះ ចងដៃចងជើងស្រីបម្រើនោះហើយ កាត់ត្រចៀក

កាត់ច្រមុះ បង្ខាំងក្នុងបន្ទប់តូចមួយបិទទ្វារហើយ ដើម្បីបិទបាំងកម្មអាក្រក់នោះ ដែលខ្លួនធ្វើហើយបបួលប្តីថា មកយើងនឹងទៅស្តាប់ធម៌ នាំប្តីទៅវត្តអង្គុយស្តាប់ធម៌ ។ ខណៈនោះ ពួកញាតិមកពីចម្ងាយរបស់នាង មកកាន់ផ្ទះហើយ បើកទ្វារឃើញអាការចម្លែកនោះហើយ ស្រាយស្រីបម្រើចេញ ។ ស្រីបម្រើនោះទៅវត្ត ក្រាបទូលសេចក្តីនោះជល់ព្រះទសពល ត្រង់កណ្តាលបរិស័ទ ៤ ។ ព្រះសាស្តាស្តាប់ពាក្យរបស់ស្រីបម្រើហើយត្រាស់ថា ឈ្មោះថា ទុច្ចរិត ទោះបីតិចតួចបុគ្គលមិនគួរធ្វើ ដោយការសម្គាល់ថា ជនដទៃតែងមិនដឹងកម្មនោះរបស់អញ ចំណែកសុចរិតនោះឯង ទោះបីបុគ្គលដទៃមិនដឹងក៏គួរធ្វើ ព្រោះថា ឈ្មោះថា ទុច្ចរិត ទោះបីបុគ្គលធ្វើដោយបិទបាំង រមែងធ្វើការដុតរោលក្នុងកាលជាខាងក្រោយ ចំណែកសុចរិត ញុំាងនូវសេចក្តីត្រេកអរតែម្យ៉ាង ឲ្យកើតទ្បើង ដូច្នេះហើយ ទើបត្រាស់គាថានេះថា

អកតំ ទុក្កតំ សេយ្យោ បច្ឆា តប្បតិ ទុក្កតំ
កតញ្ច សុកតំ សេយ្យោ យំ កត្វា នានុតប្បតិ ។

អំពើអាក្រក់ដែលបុគ្គលមិនធ្វើ ប្រសើរជាង (ព្រោះថា) អំពើអាក្រក់ រមែងធ្វើឲ្យក្តៅក្រហាយក្នុងកាលខាងក្រោយ បុគ្គលធ្វើអំពើណាហើយ រមែងមិនក្តៅក្រហាយក្រោយ អំពើនោះ ជាអំពើល្អ បើបុគ្គលធ្វើហើយ ឈ្មោះថា បុគ្គលប្រសើរ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទុក្ខតំ** សេចក្តីថា កម្មដែលមានទោស ញុំងសត្វឲ្យប្រព្រឹត្តទៅក្នុងអបាយ មិនធ្វើល្អជាដ៏ តឺប្រសើរ បានដល់ ឧត្តម ។

ពីរបទថា **បច្ឆា តប្បតិ** សេចក្តីថា ព្រោះកម្មនោះ រមែងដុតរោលក្នុងកាលដែលខ្លួនតាមរឭកដល់ហើយរឿយៗ ទៅ ។ បទថា **សុកតំ** សេចក្តីថា ចំណែកកម្មដែលមិនមានទោស មានសុខជាផល ញុំងសត្វឲ្យប្រព្រឹត្តទៅក្នុងសុគតិតែម្យ៉ាង បុគ្គលធ្វើហើយល្អជាដ៏ ។ ពីរបទថា **យំ កត្វា** សេចក្តីថា បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយក្នុងកាលជាក្រោយ គឺក្នុងកាលដែលរឭកដល់ ឈ្មោះថា រមែងមិនតាមក្តៅក្រហាយ គឺជាអ្នកមានសោមនស្សតែម្យ៉ាង កម្មនោះ ដែលបុគ្គលធ្វើហើយ ប្រសើរ ។

ក្នុងកាលចប់ទេសនា ឧបាសក និងស្រីនោះ តាំងនៅក្នុងសោតាបត្តិផលហើយ ជនទាំងឡាយ ធ្វើស្រីនោះឲ្យជាអ្នកជាក្នុងទីនោះឯង ធ្វើឲ្យជាស្រីមានប្រក្រតីប្រព្រឹត្តធម៌ ដូច្នេះឯង ។

រឿង ស្រីឆ្នាស ចប់

រឿង អាគន្តុកភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារឭអាគន្តុកភិក្ខុច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **ឆគារំ យថា** ជាដើម ។

បានឮថា ពួកភិក្ខុទាំងនោះ ចាំវស្សាក្នុងបច្ចន្តនគរមួយកន្លែង បាននៅជាសុខក្នុងខែដំបូង ក្នុងខែកណ្តាល ពួកចោរបានមកប្លន់ស្រុកដែលជាទីគោចររបស់ភិក្ខុទាំងនោះ ចាប់អ្នកស្រុកជាឈ្លើយ ។ ចាប់តាំងពីកាលនោះ មនុស្សទាំងឡាយបាននាំគ្នាមកថែរក្សាបច្ចន្តនគរនោះ ដើម្បីការពារចោរ មិនបានឱកាសឧបដ្ឋាកភិក្ខុទាំងនោះ ។ ពួកភិក្ខុទាំងនោះ ចាំវស្សាមិនបានសុខស្រួល ចេញវស្សាហើយ បានទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។

ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយភិក្ខុទាំងនោះ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនាំគ្នានៅជាសុខឬ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គនៅជាសុខក្នុងខែដំបូងប៉ុណ្ណោះ ក្នុងខែកណ្តាលពួកចោរបានប្លន់ស្រុក ចាប់តាំងអំពីកាលនោះ មនុស្សទាំងឡាយនាំគ្នាការពារនគរមិនបានឱកាសទំនុកបម្រុងជីតជល់ឡើយ ព្រោះដូច្នោះ ទើបពួកខ្ញុំព្រះអង្គចាំវស្សាមិនមានសេចក្តីសុខ ទើបត្រាស់ថា ណ្ហើយចុះ ភិក្ខុទាំងឡាយ ពួកអ្នកកុំគិតថ្មីឡើយ ធម្មតាការនៅជាសុខអស់កាលជានិច្ច ដែលបុគ្គលរកបានលំបាក ធម្មតាភិក្ខុរក្សាអត្តភាពនោះឯង ដូចគ្នានឹងពួកមនុស្សទាំងនោះ គ្រប់គ្រងនគរដូច្នោះគួរ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ
ឯវំ គោបេថ អត្តានំ ខណោ វោ មា ឧបច្ចគា
ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។

នគរនៅទីបំផុតជែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុង ទាំងខាងក្រៅ យ៉ាងណា អ្នកទាំងឡាយគួរក្សាខ្លួនយ៉ាងនោះ កុំឲ្យខណៈកន្លងអ្នកទាំងឡាយបានឡើយ ព្រោះថា ជនទាំងឡាយដែលឲ្យខណៈកន្លងហើយ រមែងសោកស្តាយក្នុងនរកមីដេវជាស ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សន្តរពាហិរំ** *ជាដើម សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បច្ចន្តនគរនោះ ដែលមនុស្សទាំងនោះនាំគ្នាធ្វើ ទីមាំទាំងឡាយមានទ្វារផ្ទះ និងកំពែងជាដើម ឈ្មោះថា ធ្វើឲ្យមាំទាំងខាងក្នុង គេធ្វើទីមាំទាំងឡាយ មានប៉ម និងគូទឹកជាដើម ឈ្មោះថា ធ្វើឲ្យមាំទាំងខាងក្រៅ ព្រោះហេតុនោះ បច្ចន្តនគរនោះ ទើបជាក្រុងដែលពួកមនុស្សធ្វើឲ្យមាំទាំងខាងក្នុង ទាំងខាងក្រៅ រក្សាហើយ យ៉ាងណា ចូរពួកអ្នកចូលទៅតាំងសតិ ចូរបិទទ្វារទាំង ៦ ដែលជាខាងក្នុង មិនបណ្តាយសតិដែលរក្សាទ្វារ ធ្វើអាយតនៈខាងក្នុង ៦ ឲ្យមាំទាំ ដោយការមិនកាន់យក ដោយប្រការដែលអាយតនៈខាងក្រៅ ៦ ដែលកំពុងប្រកាន់ នឹងប្រព្រឹត្តទៅដើម្បីកម្ចាត់អាយតនៈខាងក្នុង មិនលះសតិដែលរក្សាទ្វារ ដើម្បីមិនឲ្យអាយតនៈខាងក្រៅទាំងនោះ ចូលទៅប្រព្រឹត្ត ឈ្មោះថា រក្សាខ្លួន ដូច្នោះ ។*

បាទព្រះគាថាថា **ខណោ វោ មា ឧបច្চគា** *សេចក្តីថា បុគ្គលណាមិនគ្រប់គ្រងខ្លួនយ៉ាងនោះ ខណៈនេះទាំងអស់ គឺខណៈដែលកើតឡើងនៃព្រះពុទ្ធ*

១ ខណៈដែលកើតក្នុងមជ្ឈិមប្រទេស ១ ខណៈដែលបានសម្មាទិដ្ឋិ ១ ខណៈដែលមិនខ្វះខាតអាយតនៈទាំង ៦ ប្រការ ១ រមែងឈានកន្ធងនូវបុគ្គលនោះ ខណៈនោះ ចូរកុំឈានកន្ធងអ្នកទាំងឡាយឡើយ ។

បទថា **ខណាតីតា** ជាដើម សេចក្តីថា ព្រោះថា បុគ្គលណាកន្ធងនូវខណៈនោះ និងខណៈនោះកន្ធងបង់នូវបុគ្គលនោះ ជនទាំងនោះជាអ្នកកុះករក្នុងនរក គឺកើតក្នុងនរកនោះហើយ សោយសោក ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះកើតនូវសេចក្តីសង្វេគ តាំងនៅក្នុងអរហត្តផលហើយ ដូច្នេះឯង ។

រឿង អាគន្តុកភិក្ខុ ចប់

រឿង ឯគ្គណ្ឌ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនិគ្គណ្ឌ ត្រាស់ព្រះធម្មទេសនានេះថា **អលដ្ឋិតាយេ** ជាដើម ។

សេចក្តីពិស្តារ ថ្ងៃមួយ ភិក្ខុទាំងឡាយឃើញពួកនិគ្គណ្ឌហើយ សន្ទនាគ្នាថា អាវុសោ ពួកនិគ្គណ្ឌទាំងនេះប្រសើរជាងពួកអ្នកបួសអាក្រាត ដែលមិនបិទបាំងដោយប្រការទាំងពួង ព្រោះថា ពួកនិគ្គណ្ឌបិទបាំងខាងមុខតែម្យ៉ាង ប៉ុណ្ណោះ ប្រហែលជាអ្នកមានខ្មាសខ្លះ ពួកនិគ្គណ្ឌស្តាប់ពាក្យនោះហើយ ក៏

ពោលថា ពួកយើងបិទបាំងព្រោះហេតុនោះក៏មិនមែន ពួកយើងបិទបាំងព្រោះហេតុនេះ គឺល្អងធូលីជាដើមនោះឯង ជារបស់ទាក់ទងដល់ជីវិតន្ទ្រិយ កាលបើដូច្នោះ ល្អងផ្សែងៗ មានកម្មេចកម្ចី និងធូលីជាដើមនោះ កុំធ្លាក់ចូលទៅក្នុងភាជនកិក្ខាទាំងឡាយរបស់ពួកយើង ដូច្នេះហើយ និយាយជាមួយភិក្ខុទាំងនោះយ៉ាងច្រើន ដោយអំណាចនៃការលើកវាទៈ ។ ភិក្ខុទាំងឡាយចូលគាល់ព្រះសាស្តា ក្រាបទូលរឿងនោះ ក្នុងកាលដែលខ្លួនអង្គុយហើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ឈ្មោះថាខ្វាសក្នុងវត្ថុដែលមិនគួរខ្វាស មិនខ្វាសក្នុងវត្ថុដែលគួរខ្វាស ជាអ្នកមានទុគ្គតិ ជាទីទៅខាងមុខពិត ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ បានភាសិតព្រះគាថាទាំងនេះថា

អលជ្ជិតាយេ លជ្ជន្តិ លជ្ជិតាយេ ន លជ្ជរេ
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។
អភយេ ភយទស្សិនោ ភយេ ច អភយទស្សិនោ
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្វាសក្នុងហេតុដែលគេមិនត្រូវខ្វាស រមែងមិនខ្វាសក្នុងហេតុដែលគេត្រូវខ្វាស សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញក្នុងហេតុដែលគេមិនត្រូវខ្លាច ថាជាហេតុដែលគេត្រូវខ្លាច

ផង យល់ឃើញក្នុងហេតុដែលគេត្រូវខ្ជាច ថាជាហេតុដែល គេមិនត្រូវខ្ជាចផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អលជ្ជិតាយេ** *បានដល់ ព្រោះភាជនកិក្ខា ដែលមិនគួរខ្មាស ពិតហើយ ភាជនកិក្ខា ឈ្មោះថា វត្តុដែលមិនគួរខ្មាស ។ ឯសត្វទាំងនោះ កាលបិទបាំងភាជនកិក្ខានោះហើយ ត្រាច់ទៅ ឈ្មោះថា ខ្មាសព្រោះភាជនកិក្ខាដែលមិនគួរខ្មាស ។*

បទថា **លជ្ជិតាយេ** *សេចក្តីថា ព្រោះអង្គដែលញុំាងហិរិឲ្យកម្រើកមិនបិទបាំងហើយ ពិតហើយ អង្គដែលញុំាងហិរិឲ្យកម្រើក ឈ្មោះថា វត្តុដែលគួរខ្មាស សត្វទាំងនោះមិនបិទបាំងអង្គ ដែលញុំាងហិរិឲ្យកម្រើកនោះត្រាច់ទៅ ឈ្មោះថា មិនខ្មាសព្រោះវត្តុដែលគួរខ្មាស ព្រោះហេតុនោះ កាលសត្វទាំងនោះ ខ្មាសព្រោះវត្តុដែលមិនគួរខ្មាស មិនខ្មាសព្រោះវត្តុដែលគួរខ្មាស ។ ឈ្មោះថា ជាមិច្ឆាទិដ្ឋិ ព្រោះភាវៈ គឺការប្រកាន់ទេ និងព្រោះភាវៈ គឺការប្រកាន់ដោយប្រការដទៃ សត្វទាំងនោះ សមាទានមិច្ឆាទិដ្ឋិនោះហើយ ត្រាច់ទៅ ឈ្មោះថា សមាទានមិច្ឆាទិដ្ឋិ តែងដល់នូវទុគ្គតិ អបាយ មាននរកជាដើម ។*

បទថា **អភយេ** *ជាដើម សេចក្តីថា ភាជនកិក្ខា ឈ្មោះថា វត្តុដែលមិនគួរខ្ជាចព្រោះកិលេស គឺរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ និងភ័យ គឺទុច្ចរិតមិនកើតឡើង ព្រោះអាស្រ័យភាជនកិក្ខាឡើយ ។ សត្វទាំងឡាយ បិទបាំង*

កាជនៈនោះព្រោះការខ្ជាច ឈ្មោះថា មានប្រក្រតីឃើញក្នុងវត្ថុដែលមិនគួរខ្ជាច ថាគួរខ្ជាច អង្គដែលញុំាងហិរិឲ្យកម្រើកនោះ ឈ្មោះថា វត្ថុដែលគួរខ្ជាច ព្រោះកិលេសទាំងឡាយ មានរាគៈជាដើម កើតឡើងព្រោះអាស្រ័យអង្គដែលញុំាងហិរិឲ្យកម្រើក ។ ព្រោះមិនបិទបាំងអង្គដែលញុំាងហិរិឲ្យកម្រើក ទើបឈ្មោះថា ជាអ្នកមានប្រក្រតីឃើញក្នុងវត្ថុដែលគួរខ្ជាច ថាមិនគួរខ្ជាច ។ សត្វទាំងឡាយ ឈ្មោះថា សមាទានមិច្ឆាទិដ្ឋិ ព្រោះអំណាចដែលខ្លួនសមាទានការប្រកាន់ទេនោះ និងការប្រកាន់ដោយប្រការដទៃ រមែងដល់ទុគ្គតិ ។

ក្នុងកាលចប់ទេសនា ពួកនិគ្គណ្ឋមានចិត្តសង្វេគ ហើយបួស ។ ទេសនាសម្រេចប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង និគ្គណ្ឋ ចប់

រឿង សាវ័កតិ្ថយ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកសាវ័កតិ្ថយ ត្រាស់ព្រះធម្មទេសនានេះថា **អវជ្ជេ** *ជាដើម ។*

សេចក្តីពិស្តារ សម័យមួយ ពួកសាវ័កតិ្ថយ ឃើញកូនទាំងឡាយរបស់ខ្លួន មួយអន្ទើដោយបរិវារ លេងជាមួយពួកកូនរបស់ឧបាសក ដែលជា

សម្មាទិដ្ឋិ ក្នុងកាលកូនទាំងនោះមកផ្ទះហើយ ទើបឲ្យធ្វើប្តេជ្ញាថា ពួកសមណ-សក្យបុត្រ ពួកឯងមិនគប្បីថ្វាយបង្គំ សូម្បីវិហាររបស់សមណៈទាំងនោះ ពួកឯងក៏មិនគប្បីចូលទៅ ។ ថ្ងៃមួយ កូនរបស់ពួកតិរ្ថិយទាំងនោះកំពុងលេងក្នុងទីជិតនៃខ្ងោងទ្វារ ខាងក្រៅវត្តជេតពន ការស្រែកទឹកក៏កើតឡើង ពេលនោះ ក្មេងទាំងនោះ បញ្ជូនក្មេងរបស់ឧបាសកម្នាក់ទៅកាន់វិហារប្រាប់ថា ចូរឯងទៅផឹកទឹកក្នុងវិហារនោះហើយ ដងមកដើម្បីពួកយើងផង ក្មេងនោះក៏ចូលទៅកាន់ព្រះវិហារថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលសេចក្តីនោះ ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងក្មេងនោះថា អ្នកប៉ុណ្ណោះផឹកទឹកហើយ បញ្ជូនពួកក្មេងទាំងនោះមកដើម្បីផឹកទឹកក្នុងទីនេះ កុមារនោះក៏ធ្វើយ៉ាងនោះ ។ ពួកក្មេងទាំងនោះ មកផឹកទឹកហើយ ព្រះសាស្តាហៅក្មេងទាំងនោះមកហើយ ត្រាស់ធម្មកថា ដែលជាទីសប្បាយដល់ក្មេងទាំងនោះ ទ្រង់ធ្វើក្មេងទាំងនោះឲ្យមានសទ្ធាមាំទាំហើយ ឲ្យតាំងនៅក្នុងសរណៈនិងសីល ក្មេងទាំងនោះទៅកាន់ផ្ទះរៀងៗ ខ្លួនហើយ ប្រាប់សេចក្តីនោះដល់មាតានិងបិតា ។ គ្រានោះ មាតានិងបិតា ដល់នូវការទោមនស្សរៀបរាប់ថា កូនរបស់ពួកយើងទៅជាមនុស្សមានទិដ្ឋិវិបត្តិហើយ ។ កាលនោះ មនុស្សអ្នកស្និទ្ធស្នាលរបស់ជនទាំងនោះ ជាអ្នកឈ្លាស មកពោលធម៌ដល់ជនទាំងនោះ ដើម្បីញុំាងទោមនស្សឲ្យស្ងប់ ។

មាតា និងបិតារបស់ក្មេងទាំងនោះ ស្តាប់ពាក្យរបស់ជនទាំងនោះហើយ ទើបពោលថា ពួកយើងនឹងប្រគល់ក្មេងទាំងនេះដល់ព្រះសមណគោតម ដូច្នេះហើយ នាំទៅកាន់វិហារ មួយអន្ទើដោយពួកញាតិជាច្រើន ។

ព្រះសាស្តា កាលទ្រង់ប្រមើលមើលអាសយៈ របស់មនុស្សទាំងនោះ ហើយ កាលទ្រង់សម្តែងធម៌ ទ្រង់បានភាសិតគាថាទាំងនេះថា

អវជ្ជេ វជ្ជមតិនោ វជ្ជេ ច អវជ្ជទស្សិនោ
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។
វជ្ជញ្ច វជ្ជតោ ញត្វា អវជ្ជញ្ច អវជ្ជតោ
សម្មាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ សុគតឹ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញក្នុងហេតុដែលឥតទោស ថាជាហេតុមានទោសផង យល់ឃើញក្នុងហេតុដែលមានទោសថា ជាហេតុឥតទោសផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយដែលប្រកាន់សម្មាទិដ្ឋិ ជីងរបស់មានទោសថាជារបស់មានទោសផង ជីងរបស់មិនមានទោស ថាជារបស់មិនមានទោសផង សត្វទាំងនោះ តែងទៅកាន់សុគតិ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អវជ្ជេ** *គឺក្នុងសម្មាទិដ្ឋិ មានវត្ថុ ១០ និងក្នុងធម៌ដែលជាឧបនិស្សយនៃសម្មាទិដ្ឋិនោះ ។*

បទថា **វជ្ជមតិនោ** *គឺមានមតិកើតឡើងថា នេះមានទោស តែសត្វទាំងនោះ មានប្រក្រតីឃើញថា មិនមានទោសក្នុងធម៌ដែលមានទោស គឺមិច្ឆាទិដ្ឋិ*

មានវត្ថុ ១០ គឺធម៌ដែលជាឧបនិស្សយនៃមិច្ឆាទិដ្ឋិនោះ អធិប្បាយថា សត្វទាំងឡាយ ឈ្មោះថា កាន់យកដោយល្អនូវមិច្ឆាទិដ្ឋិ ព្រោះភាពដែលខ្លួនកាន់យកដោយល្អហើយនូវមិច្ឆាទិដ្ឋិនោះ គឺការដឹងធម៌ដែលមិនមានទោស ដោយភាពជាធម៌មានទោស និងដឹងធម៌ដែលមានទោស ដោយភាពជាធម៌មិនមានទោស ហើយប្រកាន់មាំ រមែងទៅកាន់ទុគ្គតិ ។

សេចក្តីនៃព្រះគាថាទី ២ បណ្ឌិតគប្បីជ្រាបដោយនយផ្ទុយគ្នា តាមដែលពោលហើយ ។

ក្នុងកាលចប់ទេសនា ជនទាំងនោះតាំងនៅក្នុងសរណៈ ៣ ស្តាប់ធម៌ជាទៃៗ ទៀត ក៏បានតាំងនៅក្នុងសោតាបត្តិផល ដូច្នេះឯង ॥

រឿងសាវ័កត្តិរ្យ ចប់

និរយវគ្គ ចប់

វគ្គទី ២២ ចប់

សុត្តន្តបិដក

ធម្មបទគាថា ឆាតវគ្គទី ២៣

[៣៣] តថាគតនឹងអត់ទ្រាំពាក្យល្មើស ដូចជដ៏រកាលអត់ទ្រាំចំពោះព្រួញ ដែលរបួតចេញអំពីធ្នូ ក្នុងសង្គ្រាម ដូច្នោះ ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ ។ ពួកជនតែងនាំវាហន:ដែលទូន្មានហើយ ទៅកាន់ទីប្រជុំ ព្រះរាជាតែងស្តេចឡើងកាន់វាហន: ដែលទូន្មានហើយ បណ្តាមនុស្សទាំង-ទ្បាយ មនុស្សណា អត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះ ជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថា បុគ្គលប្រសើរបំផុត ។ ពួកសេះអស្សតរក្តី សេះអាជានេយ្យក្តី សេះសិន្ធពក្តី ជដ៏រកុញ្ជរដ៏ប្រសើរក្តី ដែលបុគ្គលប្រៀនប្រដៅបានបទហើយ រាប់ថា ជាសត្វប្រសើរ បុគ្គលដែលមានខ្លួនទូន្មាន បានបទហើយ ប្រសើរជាងសត្វទាំងអស់នោះ ។

បុគ្គលទូន្មានខ្លួន បានបទហើយ ទូន្មានខ្លួនល្អហើយ ឈ្មោះថា ទូន្មានហើយ ទើបទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វានបាន ពុំមែនដូចបុគ្គលទៅកាន់ទិស ដែលខ្លួនមិនធ្លាប់ទៅ ដោយសារយានទាំងទ្បាយនោះទ្បើយ ។

ដ៏រឈ្មោះធនបាល ជាសត្វចុះប្រេង ក្បៀវក្បា នាយហត្ថាចារ្យឃាត់បានដោយលំបាក បើនាយហត្ថាចារ្យ ចងក្បាច់ មិនស៊ីស្មៅទេ ព្រោះរឭកដល់ព្រៃខ្ចីង ដែលដ៏រនោះធ្លាប់នៅ ។

កាលណា បុគ្គលអ្នកមានសេចក្តីងោកង៉ុយផង អ្នកបរិភោគភោជនមានប្រមាណច្រើនផង អ្នកដេកលក់ផង អ្នកដេកបម្រះនទៀលផង ដូចជ្រូក

ស្រុកដែលបុគ្គលចិញ្ចឹមដោយសូកវភត្ត កាលនោះ បុគ្គលនោះ ជាមនុស្សខ្វៅ រមែងចូលទៅកាន់គភិរៀយៗ ។

ក្នុងកាលមុនអំពីកាលនេះ ចិត្តនេះបានត្រាច់ទៅកាន់ចារិក តាមអាការដែលខ្លួនប្រាថ្នា តាមអារម្មណ៍ដែលខ្លួនប្រាថ្នា តាមសេចក្តីសប្បាយ ក្នុងថ្ងៃនេះ អញនឹងសង្កត់សង្កិនចិត្តនោះ ដោយឧបាយ ដូចហ្មដំរីកាន់កង្វេរសង្កត់សង្កិនដំរីចុះប្រេង ដូច្នោះដែរ ។

អ្នកទាំងឡាយ ចូរត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ចូររក្សាចិត្តរបស់ខ្លួន ចូររើខ្លួនចេញចាកភក់ គឺកិលេស ដែលធ្លងបានដោយកម្រ ដូចដំរីដែលជាប់នៅក្នុងភក់ រើខ្លួនឲ្យរួចបាន ។

បើបុគ្គលបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងនៅ ញ្ចាំងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតី គ្របសង្កត់សេចក្តីអន្ត-រាយទាំងពួង ហើយត្រាច់ទៅជាមួយនឹងសម្លាញ់នោះឯង ។ បើស្វែងរកមិនបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងញ្ចាំងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែឯកឯងវិញ ដូចព្រះរាជាលះបង់រដ្ឋ ដែលទ្រង់ឈ្នះហើយ ស្តេចទៅតែឯកអង្គ ពុំនោះសោត ដូចដំរីឈ្មោះមាតង្គ: ដែលលះហ្វូងត្រាច់ទៅតែឯកឯង ក្នុងព្រៃ ដូច្នោះដែរ ។

កាលត្រាច់ទៅ របស់បុគ្គលឯកឯង ជាគុណជាតិប្រសើរផុត (ព្រោះ

ថា) សហាយតាគុណ រមែងមិនមាន ក្នុងជនពាលទេ្បីយ បុគ្គលនោះ គប្បី ជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅតែម្នាក់ឯងផង មិនគប្បីធ្វើអំពើ បាបទាំងឡាយផង ដូចជដីរឈ្មោះមាតង្គៈ ជាសត្វមិនមានសេចក្តីខ្វល់ខ្វាយ លះបង់ហ្វូង ត្រាច់ទៅតែឯកឯង ក្នុងព្រៃ ដូច្នោះដែរ ។

កាលបើសេចក្តីត្រូវការ កើតទេ្បីងហើយ សម្ងាញ់ទាំងឡាយ នាំ សេចក្តីសុខមកឲ្យ សេចក្តីត្រេកអរជាបច្ច័យ តាមមាន តាមបាន ជាហេតុនាំ សេចក្តីសុខមកឲ្យ បុណ្យនាំសេចក្តីសុខមកឲ្យ ក្នុងកាលទៀបកន្ល័យជីវិត ការលះបង់ទុក្ខទាំងអស់បាន ជាហេតុនាំសេចក្តីសុខមកឲ្យ ។

សេចក្តីប្រតិបត្តិល្អក្នុងមាតា នាំសេចក្តីសុខមកឲ្យក្នុងលោក មួយ ទៀត សេចក្តីប្រតិបត្តិល្អក្នុងបិតា នាំសេចក្តីសុខមកឲ្យ សេចក្តីប្រតិបត្តិល្អ ក្នុងសមណៈ នាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀត សេចក្តីប្រតិបត្តិល្អ ក្នុងព្រាហ្មណ៍ នាំសេចក្តីសុខមកឲ្យ សីលនាំសេចក្តីសុខមកឲ្យ ជរាប ដល់ចាស់ សទ្ធាដែលបុគ្គលតម្កល់ស៊ប់ហើយ ញុំាងសេចក្តីសុខមកឲ្យ ការ បានប្រាជ្ញា នាំសេចក្តីសុខមកឲ្យ ការមិនធ្វើបាបទាំងឡាយ នាំសេចក្តីសុខ មកឲ្យ ។

នាគវគ្គទី ២៣ ចប់

អដ្ឋកថា

ឆាតវគ្គទី ២៣

រឿង របស់ព្រះសាស្តា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងកោសម្ពី ទ្រង់ប្រារព្ធព្រះអង្គផ្ទាល់ ត្រាស់ព្រះធម្មទេសនានេះថា **អឃំ ឆាតោវ** ជាដើម ។

រឿង ខ្ញុំឲ្យពិស្តារហើយក្នុងពណ៌នានៃគាថាជំបូង ក្នុងអប្បមាទវគ្គនោះឯង ។ ពិតហើយ ក្នុងទីនោះខ្ញុំពោលដូច្នេះថា ព្រះនាងមាគន្ទិយា មិនអាចធ្វើអ្វីដល់ស្រី ៥០០ មានព្រះនាងសាមាវតីជាប្រធានទាំងនោះបាន ទើបត្រិះរិះថា យើងនឹងធ្វើកិច្ចដែលគួរធ្វើដល់ព្រះសមណគោតមឲ្យបាន ដូច្នេះហើយ ឲ្យថ្លៃឈ្នួលដល់អ្នកនគរទាំងឡាយ ពោលថា អ្នកទាំងឡាយ មួយអន្ទើដោយកូនប្រុស ទាសៈ និងកម្មករ ចូរជេរបរិភាសព្រះសមណគោតម ដែលត្រាច់ចូលមកខាងក្នុងព្រះនគរឲ្យគេចទៅ ។

ពួកមិច្ឆាទិដ្ឋិ មិនជ្រះថ្លាក្នុងព្រះរតនត្រ័យ បានជាប់តាមព្រះសាស្តា ដែលយាងចូលទៅខាងក្នុងព្រះនគរ កំពុងជេរ កំពុងបរិភាស ដោយអក្កោសវត្ថុ ១០ ថា ឯងជាចោរ ឯងជាបុគ្គលពាល ឯងជាមនុស្សវង្វេង ឯងជាឧដ្ឋ ឯងជាគោ ឯងជាលា ឯងជាសត្វនរក ឯងជាសត្វតិរច្ឆាន សុគតិមិន

មានសម្រាប់ឯង ទុគ្គតិប៉ុណ្ណោះ ដែលឯងគប្បីដល់ ។

ព្រះអានន្ទស្តាប់ពាក្យនោះហើយ បានក្រាបទូលពាក្យនេះនឹងព្រះសាស្តា ថា បពិត្រព្រះអង្គ អ្នកនគរទាំងនេះ ជេរ បរិភាសយើងទាំងឡាយៗ ទៅក្នុងនគរដទៃក្រៅអំពីនគរនេះចុះ ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ អ្នកទៅណា ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទៅកាន់នគរដទៃ ព្រះសាស្តាត្រាស់ថា បើមនុស្សក្នុងនគរដទៃនោះ ជេរ បរិភាស យើងនឹងទៅទីណាទៀត ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទៅកាន់នគរផ្សេងៗ អំពីនគរនោះទៀត ព្រះសាស្តាត្រាស់ថា បើមនុស្សក្នុងទីនោះជេរ បរិភាស យើងទាំង-ឡាយទៀត តើទៅណា ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទៅកាន់នគរដទៃក្រៅអំពីនេះទៀត ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ធ្វើយ៉ាងនោះ មិនគួរ អធិករណ៍កើតឡើងក្នុងទីណា ត្រូវធ្វើឲ្យស្ងប់ហើយក្នុងទីនោះឯង ការទៅកាន់ទីដទៃ មិនគួរ ម្នាលអានន្ទ តើជនពួកណា ជាអ្នកជេរ ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ជនទាំងអស់ តាំងអំពីទាសៈ និងកម្មករ ។

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ តថាគតដូចគ្នានឹងជ័រដែលចូលកាន់សង្គ្រាម ការអត់ធន់នឹងព្រួញ ដែលហើរមកអំពីទិសទាំង ៤ ជាការៈរបស់ជ័រដែលចូលកាន់សង្គ្រាម យ៉ាងណា ឈ្មោះថា ការអត់ធន់នឹងពាក្យសម្តី ដែលជនទុស្សីលពោលហើយ ជាការៈរបស់តថាគតដូចគ្នា ។ កាលទ្រង់ប្រោរព្ធព្រះអង្គសម្តែងធម៌ ទ្រង់បានភាសិតព្រះគាថាទាំងនេះ ក្នុងនាគវគ្គថា

អហំនាគោវ សង្គាមេ ចាចាតោ បតិតំ សរំ

អតិវាក្យន្តិតក្ខិស្សំ ឧុស្សីលោ ហិ ពហុជ្ជនោ ។
ឧន្តំ ឆយន្តិ សមិតឹ ឧន្តំ រាជាភិរូហតិ
ឧន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យន្តិតក្ខតិ ។
វរមស្សតរា ឧន្តា អាជានីយា វ សិន្ធវា
កុញ្ជរា វ មហានាគា អត្តឧន្តោ តតោ វរំ ។

តថាគត នឹងអត់ទ្រាំពាក្យល្មើស ដូចជំរីកាលអត់ទ្រាំចំពោះព្រួញ ដែលរបួតចេញអំពីធ្នូ ក្នុងសង្គ្រាម ដូច្នោះព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ ។ ពួកជនតែងនាំវាហនៈ ដែលទូន្មានហើយ ទៅកាន់ទីប្រជុំ ព្រះរាជាតែងស្តេចឡើងកាន់វាហនៈ ដែលទូន្មានហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណា អត់សង្កត់នឹងពាក្យល្មើសបានមនុស្សនោះ ជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថា បុគ្គលប្រសើរបំផុត ។ ពួកសេះអស្សតរក្តី សេះអាជានេយ្យក្តី សេះសិន្ធពក្តី ដំរីកុញ្ជរដ៏ប្រសើរក្តី ដែលបុគ្គលប្រៀនប្រដៅ បានបទហើយ រាប់ថា ជាសត្វប្រសើរ បុគ្គលដែលមានខ្លួនទូន្មាន បានបទហើយ ប្រសើរជាងសត្វទាំងអស់នោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឆាតោវ** *គឺដូចជំរី ។ ពីរបទថា* **ចាចាតោ**

បតិតំ *សេចក្តីថារបូតចេញអំពីធ្នូ ។*

បទថា **អតិវាក្យំ** *សេចក្តីថា នូវពាក្យកន្ធងល្មើសដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃអរិយវោហារ ៨ ។*

បទថា **តិតិក្ខិស្សំ** *សេចក្តីថា ជ័រធំដែលគេបង្វឹកហើយ ចូលកាន់សង្គ្រាម ជាសត្វអត់ធន់ មិនតក់ស្លុតនូវព្រួញដែលរបូតចាកអំពីបន្ទោះ ធ្លាក់ចុះលើខ្លួន ឈ្មោះថា អត់ធន់ចំពោះការប្រហារទាំងឡាយ មានប្រហារដោយលំពែងជាដើមបាន យ៉ាងណា តថាគត នឹងអត់ធន់ គឺអត់ធន់ចំពោះពាក្យដែលមានសភាពយ៉ាងនោះ ដូច្នេះដូចគ្នា ។*

បទថា **ពុស្សឿលោ ហិ** *សេចក្តីថា ព្រោះលោកិយមហាជននេះ ដោយច្រើន ជាអ្នកទ្រុស្តសីល ដើរបញ្ចេញវាចាស៊ីកសៀត ដោយអំណាចនៃការពេញចិត្តរបស់ខ្លួន ការអត់ធន់ គឺការប្រងើយកន្តើយក្នុងពាក្យនោះ ជាការៈរបស់តថាគត ។*

បទថា **សមិតី** *សេចក្តីថា ជនទាំងឡាយ កាលទៅកណ្តាលមហាជនក្នុងសមាគម មានឧទ្យាន និងទីលានកីឡាជាដើម ទីមគោ ឬសេះដែលបង្វឹកហើយប៉ុណ្ណោះ ចូលក្នុងយាម នាំទៅ ។*

បទថា **រាជា** *សេចក្តីថា សូម្បីព្រះរាជាកាលនឹងយាងទៅកាន់ទីបែបនោះឯង រមែងជិះសត្វពាហនៈដែលហ្វឹកហើយ ។*

បទថា **មនុស្សេសុ** *សេចក្តីថា ក្នុងមនុស្សទាំងឡាយដែលទូន្មានហើយ គឺមនុស្សដែលអស់ព្យសន៍ហើយ ដោយអរិយមគ្គ ៤ ជ័ប្រសើរ ។*

បទថា **យោតិវាក្យំ** *សេចក្តីថា បុគ្គលណា អត់ធន់ គឺរមែងមិនតបត មិនភ្ញាក់ផ្អើលដល់ពាក្យល្មើសមានសភាពបែបនោះ ដែលបុគ្គលពោលទ្រគោះ បុគ្គលដែលទូន្មានហើយបែបនោះ ជាបុគ្គលប្រសើរ ។*

សេះដែលកើតអំពីមេសេះ ដែលមានជាជាសត្វលា ឈ្មោះថា សេះអស្សតរ ។ បទថា **អាជានីយា** *សេចក្តីថា សេះដែលអាចដឹងហេតុដែលនាយសារថីបង្វឹក ឲ្យធ្វើ ។*

សេះដែលកើតក្នុងដែនសិន្ធព ឈ្មោះថា សេះសិន្ធព ។ ដំរីធំដែលហៅថា កុញ្ជរ ឈ្មោះថា មហានាគ ។

បទថា **អត្តទន្តោ** *ជាដើម សេចក្តីថា សេះអស្សតរក្តី សេះសិន្ធពក្តី ដំរីកុញ្ជរក្តី ទាំងនោះ ដែលហ្វឹកហើយ ជាសត្វប្រសើរ ដែលមិនទាន់បានបង្វឹក មិនប្រសើរឡើយ តែបុគ្គលណា ឈ្មោះថា មានខ្លួនហ្វឹកហើយ គឺអស់ព្យសន៍ហើយ ព្រោះភាពដែលខ្លួនជាអ្នកទូន្មានដោយអរិយមគ្គ ៤ ។ បុគ្គលនេះ ប្រសើរជាងសត្វពាហនៈ មានសេះអស្សតរជាដើមនោះ គឺជាបុគ្គលក្រៃលែងជាងសត្វពាហនៈ មានសេះអស្សតរទាំងអស់នោះជាដើម ។*

ក្នុងកាលចប់ទេសនា មហាជនទាំងអស់នោះ ដែលជាអ្នកទទួលស៊ប់ឈ្នួលជេរហើយ ឈរជេរក្នុងទីទាំងឡាយ មានជង្រំវិថី និងផ្លូវបែកជា ៣ ជាដើម សម្រេចសោតាបត្តិផលហើយ ដូច្នេះឯង ॥

រឿង របស់ព្រះសាស្តា ចប់

រឿង ភិក្ខុធ្លាប់ជាហត្ថាចារ្យ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ដែលធ្លាប់ជាហត្ថាចារ្យ ត្រាស់ព្រះធម្មទេសនានេះថា **ឆ ហិ ឃតេហិ** ជាដើម ។

បានឮថា ថ្ងៃមួយ ភិក្ខុនោះឃើញហ្វូងជីរដែលតាំងចិត្តថា អញបង្ហាត់ជីរមួយ ហើយមិនអាចឲ្យជីរសិក្សាហេតុដែលខ្លួនប្រាថ្នាបាន នៅក្បែរឆ្នេរស្ទឹងអចិរវតី ទើបភិក្ខុនោះហៅភិក្ខុទាំងឡាយ ដែលឈរជិតមកហើយ ពោលថា អាវុសោទាំងឡាយ បើហត្ថាចារ្យនេះ ចាក់ជីរនេះក្នុងទីឈ្មោះនោះសោត គាត់គប្បីឲ្យជីរសិក្សាហេតុនោះបានដោយរហ័ស ។ គាត់ស្តាប់ពាក្យរបស់ភិក្ខុនោះហើយ ទើបធ្វើយ៉ាងនោះ ក៏ហ្វឹកជីរនោះឲ្យរៀបរយបាន ។ ទើបភិក្ខុទាំងនោះក្រាបទូលរឿងនោះដល់ព្រះសាស្តា ។

ព្រះសាស្តាត្រាស់ឲ្យហៅភិក្ខុនោះមកហើយ ត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកនិយាយយ៉ាងនេះពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ទើបទ្រង់តិះដៀលភិក្ខុនោះ ហើយត្រាស់ថា នែមោឃបុរស អ្នកត្រូវការអ្វីដោយយាន គឺជីរ ឬយានជនៃដែលបង្វឹកហើយ ព្រោះ ឈ្មោះថាបុគ្គលដែលអាចទៅកាន់ទីដែលមិនធ្លាប់ទៅ ដោយយានទាំងនេះ មិនមាន តែបុគ្គលដែលទូន្មានខ្លួនល្អហើយ អាចទៅកាន់ទីមិនធ្លាប់ទៅបាន ព្រោះដូច្នោះ អ្នកគប្បីទូន្មានខ្លួនប៉ុណ្ណោះ អ្នកត្រូវការអ្វីដោយការទូន្មានសត្វពាហនៈទាំងនេះ ហើយត្រាស់ព្រះគាថានេះថា

ន ហិ ឃតេហិ យានេហិ　　គច្ឆេយ្យ អគតំ ទិសំ

យថាត្តនា សុទន្តេន　　ទន្តោ ទន្តេន គច្ឆតិ ។

បុគ្គលទូន្មានខ្លួន បានបទហើយ ទូន្មានខ្លួន ល្អហើយ ឈ្មោះថា ទូន្មានហើយ ទើបទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វានបាន ពុំមែនដូចបុគ្គលទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅ ដោយសារយានទាំងឡាយនោះឡើយ ។

សេចក្តីអធិប្បាយ

ព្រះគាថានោះ មានសេចក្តីថា បុគ្គលណាម្នាក់គប្បីទៅកាន់ទិស គឺព្រះនិព្វាន ដែលវាប់ថា មិនទាន់បានទៅ ព្រោះកាពជាទិសដែលខ្លួនមិនធ្លាប់ទៅ ដោយហោច ត្រឹមតែការយល់សប្តិ ដោយយានទាំងឡាយ មានជ័រជាដើមទាំងនេះបានឡើយ ដូចបុគ្គលទូន្មានខ្លួនហើយ គឺជាអ្នកអស់ព្យសន៍ មានបញ្ញាទៅកាន់ទិស ដែលមិនធ្លាប់ទៅ ដូច្នោះ គឺសម្រេចដល់ភូមិនៃលោកអ្នកដែលទូន្មានខ្លួនហើយ ដោយខ្លួនដែលទូន្មានហើយ ដោយការទូន្មានឥន្ទ្រិយក្នុងចំណែកខាងដើម ទូន្មានល្អហើយ ដោយអរិយមគ្គភាវនា ក្នុងចំណែកខាងក្រោយដូច្នោះក៏មិនមែន ព្រោះដូច្នោះ ការទូន្មានខ្លួនប៉ុណ្ណោះ ទើបប្រសើរសម្រាប់អ្នក ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ភិក្ខុធ្លាប់ជាមាតាចារ្យ ចប់

រឿង កូនរបស់ព្រាហ្មណ៍ចាស់ជរា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធពួកបុត្ររបស់ព្រាហ្មណ៍ចាស់ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ឆនចាលកោ** ជាដើម ។

បានឮថា ព្រាហ្មណ៍ម្នាក់នៅក្នុងក្រុងសាវត្ថី មានសម្បត្តិប្រមាណ ៨ សែន រៀបការឲ្យកូន ៤ នាក់ ចម្រើនវ័យហើយ បានឲ្យទ្រព្យ ៤ សែន ។ បន្ទាប់មក កាលព្រាហ្មណីធ្វើកាលកិរិយាទៅហើយ ទើបពួកកូនប្រឹក្សាព្រមគ្នាថា បើឪពុករបស់យើងនាំព្រាហ្មណីដទៃមកសោត ដោយអំណាចនៃបុត្រទាំងឡាយដែលកើតក្នុងផ្ទៃរបស់នាង ត្រកូលនឹងត្រូវទម្លាយ ណ្ហើយចុះ ពួកយើងនាំគ្នាសង្គ្រោះលោក ។ ពួកគេទំនុកបម្រុងព្រាហ្មណ៍ចាស់នោះ ដោយបច្ច័យ មានអាហារ គ្រឿងស្លៀកដណ្តប់ជាដើមដែលប្រណីត ធ្វើកិច្ច មានការគក់ច្រចាច់ដៃ និងជើងជាដើម កាលទំនុកបម្រុងហើយ ថ្ងៃមួយ កាលព្រាហ្មណ៍ចាស់នោះ ដេកលក់ពេលថ្ងៃហើយក្រោកឡើង ទើបច្រចាច់ដៃជើងបណ្តើរ ពោលដល់ទោសក្នុងឃរាវាសផ្សេងៗ ហើយអង្វរថា ពួកខ្ញុំនឹងទំនុកបម្រុងលោកឪពុកយ៉ាងនេះដរាបដល់អស់ជីវិត សូមពុកឲ្យទ្រព្យដែលសេសសល់ដល់ពួកខ្ញុំចុះ ។ ព្រាហ្មណ៍ឲ្យទ្រព្យដល់បុត្រម្នាក់ ១ សែនទៀត ចែកគ្រឿងឧបភោគទាំងអស់ឲ្យជា ៤ ចំណែក ប្រគល់ឲ្យ បន្សល់ត្រឹមតែសំពត់ស្លៀកសំពត់ដណ្តប់របស់ខ្លួន ។ កូនច្បង ទំនុកបម្រុងព្រាហ្មណ៍នោះ ២-៣ ថ្ងៃ ។ ថ្ងៃមួយ កូនប្រសាស្រីឈរត្រង់មាត់ទ្វារ និយាយនឹងព្រាហ្មណ៍ចាស់នោះ ដែលងូតទឹកហើយដើរមកយ៉ាងនេះថា ទ្រព្យមួយរយ ឬមួយពាន់

ដែលលោកឪពុកឲ្យដល់កូនច្បង ក្រៃលែងជាងបុត្រទាំងឡាយមានឬ ឪពុកឲ្យទ្រព្យដល់បុត្រគ្រប់គ្នា ម្នាក់ ២ សែនមិនមែនឬ ហេតុអ្វី ទើបលោកឪពុកមិនស្គាល់ផ្លូវទៅផ្ទះរបស់កូនដ៏សេស ។

សូម្បីព្រាហ្មណ៍គំរាមស្រីនោះថា មេថោកទាប ហាងចូរវិនាស ក្រោធទីងហើយ បានទៅកាន់ផ្ទះរបស់បុត្រដទៃ លុះកន្ទងទៅ ២-៣ ថ្ងៃ ត្រូវកូនប្រសាស្រីដទៃឲ្យចេញពីផ្ទះដោយឧបាយដូចគ្នានោះឯង បានទៅកាន់ផ្ទះកូនដទៃ កាលមិនបានការចូលទៅកាន់ផ្ទះណាមួយយ៉ាងនេះ ដោយប្រការនេះ ទើបបួសស្មៀកសពាក់សត្រាច់រកភិក្ខា ។ ពេលវេលាកន្ទងទៅ គាត់ក៏ទ្រុឌទ្រោមព្រោះជរា មានសរីរៈសៅហ្មងព្រោះភោជនមិនល្អ ដេកលំបាក ត្រាច់រកភិក្ខាត្រឡប់មកជាក់ខ្នងលើដំណេក ឈានចុះកាន់និទ្រាហើយ ក្រោកឡើងអង្គុយមើលខ្លួនទើបមានសេចក្តីក្រវល់ក្រវាយរម្ងាប់ហើយ មិនឃើញទីពឹងរបស់ខ្លួនក្នុងកូនទាំងឡាយ គិតថា បានឮថា ព្រះសមណគោតមមានភក្ត្រមិនស្រពោន មានព្រះភក្ត្រពីរោក មានពាក្យសម្តីពីរោះ ទ្រង់ឈ្វាសក្នុងការទទួល អញអាចទៅរកព្រះគោតមហើយ បានទូវការទទួល ។ គាត់រៀបចំស្មៀកសំពត់ដណ្តប់រៀបរយហើយ ចាប់ភាជន៍ភិក្ខា កាន់ឈើច្រត់ បានទៅកាន់សម្នាក់ព្រះសមុទ្ទ ។

ពិតហើយ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ពោលពាក្យនេះថា គ្រានោះឯង ព្រាហ្មណមហាសាលម្នាក់ ជាអ្នកសៅហ្មង មានសំពត់ដណ្តប់ក៏សៅហ្មង ចូលទៅគាល់ព្រះសាស្តាដល់ទីដែលទ្រង់ប្រថាប់ ។

ព្រះសាស្តា ទ្រង់ធ្វើបដិសណ្ឋារៈជាមួយព្រាហ្មណ៍ ដែលអង្គុយក្នុង

ចំណែកម្ខាងហើយ បានត្រាស់ពាក្យនេះថា ម្នាលព្រាហ្មណ៍ អ្វីហ្ន៎ ទើប លោកជាអ្នកសៅហ្មង មានសំពត់ដ៏សៅហ្មង ។

ព្រាហ្មណ៍ទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គមានបុត្រ ៤ នាក់ក្នុង លោកនេះ បុត្រទាំងនោះត្រូវភរិយាញុះញង់ ទើបបណ្តេញខ្ញុំព្រះអង្គចេញអំពី ផ្ទះ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នេះ ចូរអ្នករៀនគាថាទាំងនេះ កាលពួកមហាជនប្រជុំគ្នាក្នុងទីប្រជុំ កាលកូនទាំងឡាយរបស់អ្នកអង្គុយហើយ ចូរពោលថា

ខ្ញុំត្រេកអរដោយបុត្រដែលកើតហើយណា ទីឯប្រាថ្នាសេចក្តីចម្រើនដល់ បុត្រណា បុត្រទាំងនោះ ត្រូវភរិយាញុះញង់ បៀតបៀនខ្ញុំ ដូចឆ្កែបៀតបៀន ជ្រូក ដូច្នោះ ។ បានឮថា កូនទាំងនោះជាអសប្បុរស ជាអ្នកថោកទាប ហៅខ្ញុំថា ពុក ពុក ពួកកូនទាំងនោះ គឺអារក្សទឹក មកហើយដោយរូបរាងជា បុត្រ បោះបង់ខ្ញុំឲ្យដល់នូវសេចក្តីវិនាស បិតារបស់ជនពាលជាមនុស្សចាស់ ត្រូវដើរសូមទានត្រង់ផ្ទះជនដទៃ ដូចសេះដែលចាស់ធ្វើការមិនបាន ត្រូវគេ ផ្តាច់អាហារដូច្នោះ បានឮថា ឈើច្រត់របស់ខ្ញុំគង់ប្រសើរជាង កូនទាំងឡាយ ដែលមិនស្តាប់បង្គាប់ ទីឯប្រសើរដូចម្តេច ព្រោះឈើច្រត់ការពារគោកាចក៏ បាន ការពារឆ្កែក៏បាន រាវក្នុងទីងងឹតក៏បាន ប្រើច្រត់ចុះទៅក្នុងទីជ្រៅក៏បាន ព្រោះអានុភាពនៃឈើច្រត់ មនុស្សចាស់ជរាដូចខ្ញុំដួលហើយ ក៏ច្រត់ក្រោក ឡើងបាន ។

ព្រាហ្មណ៍រៀនគាថានោះ ក្នុងសម្នាក់ព្រះសាស្តាហើយ កាលពួកបុត្រ

ប្រដាប់តាក់តែងដោយគ្រឿងអលង្ការហើយ ចូលទៅកាន់ទីប្រជុំនោះ អង្គុយលើអាសនៈដែលគួរដល់តម្លៃច្រើន ក្នុងកណ្តាលពួកព្រាហ្មណ៍ ក្នុងថ្ងៃប្រជុំនៃពួកព្រាហ្មណ៍ទាំងនោះ គាត់សម្រេចចិត្តថា កាលនេះជាកាលរបស់អញហើយ ចូលទៅកាន់កណ្តាលទីប្រជុំ លើកដៃឡើងពោលថា អ្នកដ៏ចម្រើន ខ្ញុំបំណងនឹងពោលគាថាដល់អ្នកទាំងឡាយ អ្នកទាំងឡាយស្តាប់ដែរឬទេ កាលព្រាហ្មណ៍ទាំងនោះពោលថា ពោលចុះព្រាហ្មណ៍ ពួកខ្ញុំនឹងស្តាប់ បានឈរពោលគាថាហើយ ។

សម័យនោះ មនុស្សទាំងឡាយមានវត្តយ៉ាងនេះថា កូនណាប្រើប្រាស់ទ្រព្យដែលជារបស់មាតាបិតា តែមិនចិញ្ចឹមមាតាបិតា កូននោះត្រូវសម្លាប់ចោល ។ ព្រោះដូច្នោះ ទើបកូនរបស់ព្រាហ្មណ៍ទាំងនោះ ក្រាបចុះទៀបជាតជើងរបស់បិតា អង្វរថា បពិត្រលោកឪពុក សូមលោកឪពុកឲ្យជីវិតដល់ពួកខ្ញុំចុះ ។ ព្រោះភាពដែលហទយៈរបស់ឪពុកជាធម្មជាតទន់ ទើបពោលថា អ្នកដ៏ចម្រើនទាំងឡាយ អ្នកកុំឲ្យកូនទាំងឡាយរបស់ខ្ញុំវិនាសឡើយ ពួកគេនឹងចិញ្ចឹមខ្ញុំ ។

រំពេចនោះ ទើបមនុស្សទាំងឡាយពោលនឹងបុត្ររបស់ព្រាហ្មណ៍ថា អ្នកដ៏ចម្រើន តាំងអំពីថ្ងៃនេះទៅ បើពួកអ្នកមិនផ្គត់ផ្គង់បិតាឲ្យល្អសោត ពួកយើងនឹងសម្លាប់អ្នកចោល កូនទាំងនោះខ្លាចហើយ អញ្ជើញឪពុកឲ្យអង្គុយលើតាំងលើកឡើងទៅកាន់ផ្ទះដោយខ្លួនឯង លាបសរីរៈដោយប្រេង ជូសខាត់ឲ្យស្អាត ប្រើវត្ថុមានក្លិនក្រអូបជាដើមលាបស្រលាបហើយ ឲ្យហៅព្រាហ្មណ៍ទាំងឡាយ

មកប្រាប់ថា តាំងអំពីថ្ងៃនេះទៅ នាងទាំងឡាយ ចូរចិញ្ចឹមបិតារបស់ពួកខ្ញុំ ឲ្យល្អ បើនាងទាំងឡាយដល់នូវសេចក្តីប្រមាទហើយសោត ពួកខ្ញុំនឹងតិះដៀលនាងទាំងឡាយ ហើយឲ្យបិតាបរិភោគភោជនដ៏ប្រណីត ។

ព្រាហ្មណ៍អាស្រ័យភោជនដែលល្អ ទីដេកដែលសប្បាយ ដោយកាលកន្ទងទៅ ២-៣ ថ្ងៃ ក៏មានកម្លាំងឥន្ទ្រិយស្រស់ថ្លា សម្លឹងមើលអត្តភាពហើយត្រិះរិះថា សម្បត្តិនេះអញបានព្រោះអាស្រ័យព្រះគោតម កាន់យកសំពត់មួយគូ ដើម្បីប្រយោជន៍ជាបណ្ណាការ ទៅកាន់សម្នាក់របស់ព្រះដ៏មានព្រះភាគ មានបដិសណ្ឋារៈដែលទ្រង់ធ្វើហើយ អង្គុយក្នុងចំណែកម្ខាង ជាក់សំពត់ចុះទៀបបាទមូលរបស់ព្រះសាស្តាហើយ ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះថាជាព្រាហ្មណ៍ តែងស្វែងរកទ្រព្យ ដែលជាចំណែកនៃអាចារ្យ ដើម្បីអាចារ្យ សូមព្រះគោតមដែលជាអាចារ្យរបស់ខ្ញុំព្រះអង្គ ទទួលទ្រព្យជាចំណែកអាចារ្យ ។ ព្រះសាស្តា ទ្រង់ទទួលសំពត់គូនោះ ដើម្បីអនុគ្រោះដល់ព្រាហ្មណ៍ហើយ ទ្រង់ក៏សម្តែងធម៌ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍តាំងនៅក្នុងសរណៈហើយ ទើបក្រាបទូលយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គថ្វាយធុវភត្តពីរសម្រាប់អំពីធុវភត្ត ៤ សម្រាប់ ដែលកូនទាំងឡាយឲ្យដល់ខ្ញុំព្រះអង្គ ដល់ទ្រង់ ។

លំដាប់នោះ ព្រះសាស្តាត្រាស់ថា សាធុព្រាហ្មណ៍ តែតថាគតទៅកាន់ទីដែលពេញចិត្តប៉ុណ្ណោះ ហើយទ្រង់បញ្ជូនព្រាហ្មណ៍ទៅ ។

ព្រាហ្មណ៍ទៅដល់ផ្ទះហើយ ប្រាប់កូនទាំងឡាយថា បាទាំងឡាយ ព្រះ

សមណាគោតមជាសម្ងាញ់របស់ឪពុក ចូរបាថ្វាយធុវភត្តពីរសម្រាប់ដល់ទ្រង់ បាទាំងឮយកុំរំលង បើទ្រង់យាងមកដល់ កូនទាំងឮយទទួលថា សាធុ ។

ស្អែកឡើង ព្រះសាស្តាយាងទៅបិណ្ឌបាត បានទៅដល់ទ្វារផ្ទះនៃកូនច្បងរបស់ព្រាហ្មណ៍ បុរសនោះឃើញព្រះសាស្តាហើយ ទទួលបាត្រ យាងព្រះដ៏មានព្រះភាគឲ្យចូលទៅកាន់ផ្ទះ និមន្តឲ្យប្រថាប់គង់លើបល្ល័ង្កដែលមានតម្លៃច្រើន ហើយបានថ្វាយភោជនដ៏ប្រណីត ។ ព្រះសាស្តា បានយាងទៅកាន់ផ្ទះរបស់កូនព្រាហ្មណ៍ទាំងអស់តាមលំដាប់ គឺស្អែកឡើង យាងទៅកាន់ផ្ទះរបស់បុត្រព្រាហ្មណ៍ក្រៅអំពីនេះ ស្អែកឡើង ក៏យាងទៅកាន់ផ្ទះរបស់បុត្រម្នាក់ទៀត កូនទាំងនោះ បានធ្វើសក្ការៈយ៉ាងនោះដូចគ្នា ។

ថ្ងៃមួយ កូនច្បង កាលមង្គលប្រាកដចំពោះហើយ ទើបពោលនឹងបិតាថា បពិត្រ លោកឪពុក ពួកខ្ញុំនឹងឲ្យមង្គលដល់អ្នកណា ព្រាហ្មណ៍ពោលថា ឪពុក មិនស្គាល់អ្នកដទៃ ព្រះសមណាគោតមជាសម្ងាញ់របស់ឪពុកមិនមែនឬ កូនច្បងពោលថា បើដូច្នោះ សូមលោកឪពុកនិមន្តទ្រង់ មួយអន្ទៅដោយភិក្ខុ ៥០០ រូបដើម្បីឆាន់ក្នុងថ្ងៃស្អែក ។

ព្រាហ្មណ៍បានធ្វើយ៉ាងនោះ ស្អែកឡើង ព្រះសាស្តា មួយអន្ទៅដោយភិក្ខុសង្ឃ បានយាងទៅកាន់ផ្ទះរបស់ព្រាហ្មណ៍នោះ គាត់និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យគង់ក្នុងផ្ទះដែលលាបដោយគោម័យស្រស់ ប្រដាប់ដោយអលង្ការគ្រប់យ៉ាង ហើយអង្គាសដោយមធុបាយាស ដែលមានទឹកតិច និងដោយខាទនីយដ៏ប្រណីត ។

ក្នុងវារៈនោះឯង បុត្រ ៤ នាក់របស់ព្រាហ្មណ៍ អង្គុយក្នុងសម្នាក់របស់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គទាំងឡាយផ្តត់ផ្តង់បិតារបស់ខ្ញុំព្រះអង្គ មិនប្រមាទ សូមទ្រង់ទតអត្តភាពរបស់លោកចុះ ។

ព្រះសាស្តាត្រាស់ថា អ្នកទាំងឡាយធ្វើកម្មស្អាតហើយ ឈ្មោះថា ការចិញ្ចឹមមាតាបិតា បុរាណបណ្ឌិតទាំងឡាយធ្លាប់ប្រព្រឹត្តមកហើយដូចគ្នា ហើយត្រាស់មាតុបោសកនាគជាតក[1] ក្នុងឯកាទសកនិបាត ដោយពិស្តារថា ដើមពោនស្វាផង ដើមខ្វែងគងផង ... ព្រោះតែជំរីនោះមិននៅ ដូច្នេះជាដើម ហើយបានភាសិតព្រះគាថានេះថា

ធនចាលកោ នាម កុញ្ជរោ កដុកប្បភេទនោ ទុន្ទិភារយោ
ពន្ធោ កពន្ធំ ន ភុញ្ជតិ សុមរតិ នាគវនស្ស កុញ្ជរោ ។

ជំរីឈ្មោះធនបាល ជាសត្វចុះប្រេង ក្លៀវក្លា នាយហត្ថាចារ្យឃាត់បាន ដោយលំបាក បើនាយហត្ថាចារ្យចងក្តាប់មិនស៊ីស្មៅទេ ព្រោះរឭកដល់ព្រៃខ្ញីង ដែលជំរីនោះធ្លាប់នៅ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ធនចាលកោ នាម** *នោះ ជាឈ្មោះរបស់ជំរីដែលព្រះបាទកាសិករាជ ទ្រង់បញ្ជូននាយហត្ថាចារ្យទៅចាប់ក្នុងនាគវន ដែលជាទីត្រេកអរក្នុងកាលនោះ ។*

បទថា **កដុកប្បភេទនោ** *សេចក្តីថា ចុះប្រេងខ្លាំង ។ ដែលពិត ក្នុង*

១- បិដកខ្មែរជាមាតុបោសកជាតក ។

កាលដែលចុះប្រេងរបស់ជំរីទាំងឡាយ គុម្ពត្រចៀកទាំងពីររមែងរីក តាមប្រក្រតីក្នុងកាលនោះ ជំរីទាំងឡាយរមែងមិននាំនូវកង្វេរ ជន្ជូញ ឬថ្មោង រមែងជាសត្វកាច តែជំរីធនបាលកៈនោះកាចស្រាប់នោះឯង ព្រោះដូច្នោះ ទើបព្រះសាស្តាត្រាស់ថា **ឥជុកប្ឋភេជនោ ជុន្ទិវារយោ ។**

បាទព្រះគាថាថា **ពជ្ជោ ឥពជ្ជំ ន ភុញ្ជតិ** សេចក្តីថា ជំរីធនបាលកៈនោះ មិនបានដោះត្រដោក តែត្រូវគេនាំទៅកាន់រោងជំរីឲ្យបាំងដោយវាំងនន ដ៏វិចិត្រហើយ បញ្ឈរត្រង់ផែនដី ដែលប្រោះព្រំដោយគ្រឿងក្រអូប មានពិដានវិចិត្រខាងលើ ដែលព្រះរាជាទំនុកបម្រុងដោយភោជនមានរសដ៏ប្រសើរផ្សេងៗ គួរដល់ព្រះរាជា ក៏មិនបានត្រេកអរក្នុងការបរិភោគ ។ ពាក្យថា **ពជ្ជោ ឥពជ្ជំ ន ភុញ្ជតិ** ព្រះសាស្តាត្រាស់សំដៅដល់អាការៈត្រឹមតែជំរី ត្រូវបញ្ជូនចូលទៅកាន់រោងជំរី ។

ពីរបទថា **សុមរតិ នាគវនស្ស** សេចក្តីថា ជំរីធនបាលកៈនោះរឲ្យកដល់នាគវន គឺព្រៃខ្ទឹងដែលជាលំនៅគួរត្រេកអរ ប្រមាណមិនបាន មេរបស់ជំរីនោះជាសត្វដល់នូវទុក្ខ ព្រោះព្រាត់អំពីកូនក្នុងព្រៃ ជំរីនោះបំពេញមាតា-បិតុប្ឋដ្ឋានធម៌នោះឯងត្រិះរិះថា ប្រយោជន៍អ្វីរបស់អញដោយភោជននេះ រឲ្យកដល់មាតាបិតុប្ឋដ្ឋានធម៌ ដែលប្រកបដោយធម៌ប៉ុណ្ណោះ ជំរីនោះនៅក្នុងនាគវន នោះឯង អាចបំពេញមាតាបិតុប្ឋដ្ឋានធម៌នោះបាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **សុមរតិ នាគវនស្ស ឥុញ្ជរោ ។**

កាលព្រះសាស្តា ទ្រង់នាំបុព្វចរិយារបស់ព្រះអង្គមកត្រាស់នោះឯង បុត្រ

របស់ព្រាហ្មណ៍ទាំងអស់ ញុាំងអស្សុធារៈឲ្យហូរហើយ មានហទយៈទន់ភ្លន់ ផ្ទៀងនូវសោតៈស្តាប់ហើយ ។ គ្រានោះ ព្រះសាស្តាទ្រង់ជ្រាបដល់ធម៌ជាទីសប្បាយរបស់ពួកកូនទាំងនោះហើយ ទើបទ្រង់សម្តែងធម៌ ប្រកាសសច្ចៈទាំងឡាយ ។ ក្នុងកាលចប់ទេសនា ព្រាហ្មណ៍ បុត្រ និង កូនប្រសាទាំងឡាយតាំងនៅក្នុងសោតាបត្តិផលហើយ ដូច្នេះឯង ॥

រឿង កូនរបស់ព្រាហ្មណ៍ចាស់ជរា ចប់

រឿង ព្រះចាតុបសេនដិកោសល

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបាទបសេន-ទិកោសល ត្រាស់ព្រះធម្មទេសនានេះថា **មិទ្ធី យថា** ជាដើម ។

សេចក្តីពិស្តារ សម័យមួយ ព្រះរាជាសោយព្រះស្ងោយ នៃអង្គរមួយនាឡិជាមួយសូបព្យញ្ជនៈ សមគួរដល់បាយនោះ ។ ថ្ងៃមួយ ព្រះរាជាសោយព្រះក្រយាហារព្រឹកហើយ ទ្រង់មិនទាន់បន្ទោបង់សេចក្តីស្រវឹងក្នុងភត្តបានឡើយ បានយាងទៅកាន់សម្នាក់របស់ព្រះសាស្តា មានព្រះរូបលំបាក បម្រះទៅខាងនេះ និងខាងនោះ ត្រូវងងុយគ្របសង្កត់ មិនអាចផ្ទំត្រង់ៗ បាន ទើបប្រថាប់គង់ក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា មហាបពិត្រ ទ្រង់មិនទាន់

បានសម្រាកឡើយ យាងមកទេដឹង ព្រះរាជាត្រាស់ថា ពិតហើយ ព្រះអង្គ តាំងអំពីបរិភោគហើយ ខ្ញុំព្រះអង្គមានទុក្ខច្រើន ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា មហាបពិត្រ បុគ្គល បរិភោគច្រើន រមែងមានទុក្ខយ៉ាងនេះ ទើបត្រាស់ព្រះគាថានេះថា

មិទ្ធី យទា ហោតិ នហាគ្ឆសោ ច និទ្ទាយិតា សម្ឆរិវត្តសាយី
មហាវរាហោវ និវាបបុដ្ឋោ បុនប្ឆុនំ គព្ភមុបេតិ មន្ទោ ។

កាលណា បុគ្គលអ្នកមានសេចក្តីងោកងុយផង អ្នកបរិភោគភោជន មានប្រមាណច្រើនផង អ្នកដេកលក់ផង អ្នកដេកបម្រះនទៀលផង ដូចជ្រូកស្រុកដែលបុគ្គលចិញ្ចឹមដោយសូករភត្ត កាលនោះ បុគ្គល នោះ ជាមនុស្សខ្ជៅ រមែងចូលទៅកាន់គភិរឿយៗ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មិទ្ធី** *សេចក្តីថា ដែលការរួញរា និងការ ងោកងុយគ្របសង្កត់ ។*

បទថា **មហាគ្ឆសោ** *សេចក្តីថា អ្នកបរិភោគច្រើន ដូចអាហរហត្ថក-ព្រាហ្មណ៍ អលង្សាដកព្រាហ្មណ៍ តត្ថវដ្តកព្រាហ្មណ៍ កាកមាសកព្រាហ្មណ៍ និងភុត្តវម្មិកព្រាហ្មណ៍ណាម្នាក់ ។*

បទថា **និវាបបុដ្ឋោ** *សេចក្តីថា ត្រូវទំនុកបម្រុងហើយដោយសូករភត្ត មានកុណ្ឌកជាដើម ពិតហើយ ជ្រូកស្រុកគេចិញ្ចឹមតាំងពីនៅតូច ក្នុងពេល មានសរីរៈធាត់ មិនបានចេញអំពីផ្ទះទៅខាងក្រៅ ឆ្ជេឆ្ជាទៅមកក្នុងទីផ្សងៗ*

មានក្រោមត្រែជាដើម ហើយរមែងដេកដកដង្ហើមយូរៗ ប៉ុណ្ណោះ ។ លោកអធិប្បាយថា បុគ្គលមានការងោកងុយ ជាអ្នកបរិភោគច្រើន កាលមិនអាចញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយឥរិយាបថដទៃ ច្រើនដោយការដេកលក់បម្រះនៀលទៅមក តាមប្រក្រតី ដូចជ្រូកធំដែលផ្តល់ដោយចំណី ដូច្នោះ ក្នុងខណៈណា ខណៈនោះ បុគ្គលនោះ មិនអាចមនសិការត្រៃលក្ខ័ណ គឺអនិច្ចំ ទុក្ខំ អនត្តាបាន ព្រោះមិនមនសិការត្រៃលក្ខ័ណទាំងនោះ ទើបឈ្មោះថា មានបញ្ញាទន់ខ្សោយ តែងចូលបន្ទប់ គឺមិនផុតអំពីការនៅក្នុងបន្ទប់ ។

ក្នុងកាលចប់ទេសនា ព្រះសាស្តាត្រាស់ព្រះគាថានេះ ដោយឧបការៈដល់ព្រះរាជាថា

បុគ្គលមានសតិសព្វកាល ស្គាល់ប្រមាណក្នុងភោជនដែលបានហើយនោះ រមែងមិនមានរោគ ភ័យ និងអាពាធ មិនចាស់មុនអាយុ មានអាយុយឺនយូរ ដូច្នេះហើយ ឲ្យឧត្តរមាណពរៀន ហើយទ្រង់ឲ្យឧបាយថា អ្នកគប្បីពោលគាថានេះ ក្នុងកាលដែលព្រះរាជាសោយ នឹងគប្បីឲ្យព្រះរាជាទ្រង់បន្តយភោជន ដោយឧបាយនេះ ហើយបានធ្វើយ៉ាងនោះ ។

សម័យក្រោយមក ព្រះរាជាទ្រង់ស្រេសប់បស់ មានព្រះកាយស្រាល ទ្រង់ដល់នូវភាពសុខស្រួល ព្រោះទ្រង់មានព្រះក្រយាហារមួយនាឡិយ៉ាងក្រៃលែង ទ្រង់មានសេចក្តីស្និទ្ធស្នាល កើតឡើងក្នុងព្រះសាស្តាហើយ ទ្រង់ឲ្យអសទិសទានប្រព្រឹត្តទៅ ៧ ថ្ងៃ ។ ព្រោះទ្រង់អនុមោទនាទាន មហាជនប្រជុំគ្នាក្នុងទីនោះ សម្រេចគុណវិសេសធំហើយ ដូច្នេះឯង ॥

រឿង សាឆុសាមណេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសាមណេរឈ្មោះសានុ ត្រាស់ព្រះធម្មទេសនានេះថា **ឥធ ឫរេ** ជាដើម ។

បានឮថា សាមណេរនោះជាបុត្រទោលរបស់ឧបាសិកាម្នាក់ ។ គ្រានោះ ឧបាសិកាឲ្យលោកបព្វជ្ជាក្នុងកាលដែលនៅជាកុមារនោះឯង ។ តាំងអំពីកាលដែលបព្វជ្ជាហើយ លោកជាអ្នកមានសីល សម្បូរដោយវត្ត បានធ្វើវត្តជល់អាចារ្យ ឧបជ្ឈាយ៍ និងអាគន្តុកភិក្ខុទាំងឡាយនោះឯង អស់កាល ៨ ថ្ងៃក្នុងមួយខែ លោកក្រោកឡើងអំពីព្រឹក ចូលទៅតម្កល់ទឹកក្នុងរោងទឹក ចេាសរោងធម្មសួនៈ អុជប្រទីប ប្រកាសធម្មសួនៈដោយសំឡេងដ៏ពីរោះ ភិក្ខុទាំងឡាយជ្រាបកម្ចាំងរបស់លោកហើយ តែងនិមន្តថា ចូរលោកពោលបទកាណចុះ ។ លោកមិនធ្វើការរវាវែកអ្វីឡើយ ដោយពោលថា ខ្យល់សៀតចាក់ដោតហទយៈរបស់ខ្ញុំ ឬរោគក្អកបៀតបៀនខ្ញុំ ឡើងកាន់ធម្មាសនៈពោលបទកាណ ដូចធ្វើឲ្យទឹកក្នុងអាកាសធ្លាក់ចុះ កាលនឹងចុះ រមែងពោលថា ខ្ញុំឲ្យចំណែកបុណ្យ ព្រោះការពោលនេះដល់មាតា និងបិតារបស់ខ្ញុំ ។ មនុស្សទាំងឡាយមិនជ្រាបភាពដែលលោកឲ្យចំណែកបុណ្យដល់មាតាបិតាឡើយ ។

មាតារបស់លោក កើតជាយក្ខិនីក្នុងអត្តភាពជាលំដាប់ នាងមកជាមួយទេវតាទាំងឡាយស្តាប់ធម៌ហើយ កាលអនុមោទនាចំណែកបុណ្យដែលសាមណេរឲ្យ តែងពោលថា ខ្ញុំសូមអនុមោទនា ។ ធម្មតាភិក្ខុទាំងឡាយ ដែលសម្បូរដោយសីល រមែងជាទីស្រឡាញ់របស់លោក ព្រមទាំងទេវលោក ព្រោះដូច្នោះ

ពួកទេវតាដែលមានការខ្មាស មានការគោរពក្នុងសាមណេរ រមែងសម្គាល់លោកដូចមហាព្រហ្ម និងគំនរភ្លើង ។ ហើយរមែងឃើញយក្ខិនីនោះថា គួរគោរព ព្រោះគោរពក្នុងសាមណេរ ក្នុងសម័យទាំងឡាយ មានសម័យស្តាប់ធម៌ និងសម័យយក្ខសន្និបាតជាដើម អមនុស្សទាំងឡាយរមែងឲ្យអាសនៈល្អ ទឹកល្អ អាហារល្អដល់យក្ខិនី ដោយគិតថា យក្ខិនីនេះ ជាម្តាយរបស់សានុ-សាមណេរ យក្សទាំងឡាយដែលមានសក្តិធំ ឃើញយក្ខិនីហើយ មែងចៀសផ្លូវ រមែងក្រោកឡើងចាកអាសនៈ ។

កាលសាមណេរនោះដល់នូវសេចក្តីចម្រើន មានឥន្ទ្រិយចាស់ក្លា ត្រូវសេចក្តីមិនត្រេកអរបៀតបៀន មិនអាចបន្ទោបង់ការមិនត្រេកអរបាន ទុកសក់និងក្រចកវែង មានសំពត់ស្បៃក និងសំពត់ដណ្តប់រយើករយោក មិនច្រាប់ឧបាសិកាឃើញបុត្រហើយ ថ្វាយបង្គំ ពោលថា នែបា ពីមុនបាមកក្នុងទីមួយអន្ទៀដោយអាចារ្យ និងឧបជ្ឈាយ៍ ឬមួយអន្ទៀដោយភិក្ខុកំលោះ និងសាមណេរ ហេតុអ្វីក្នុងថ្ងៃនេះ ទើបបាមកមួយអង្គឯង លោកច្រាប់ភាពដែលលោកអផ្សុកដល់មាតាហើយ ។ ឧបាសិកាជាអ្នកមានសទ្ធា បង្ហាញទោសយាវាសដោយប្រការផ្សេងៗ ជាស់តឿនកូនក៏មិនអាចឲ្យយល់ព្រមបាន ក៏មិនអាចស្រោចស្រង់បានដោយគិតថា បើដូច្នោះ លោកគប្បីកំណត់បានតាមធម្មតារបស់ខ្លួន ហើយពោលថា នែបា ចូរបាបង្អង់រង់ចាំខ្ញុំរៀបចំបបរ និងភត្តដើម្បីបាសិន ខ្ញុំនឹងនាំសំពត់ដែលពេញចិត្តមកប្រគេនដល់បាដែលធាន់បបរ ធ្វើភត្តកិច្ចហើយបានតាក់តែងអាសនៈប្រគេន សាមណេរគង់ហើយ ។ ឧបាសិកាចាត់ចែងបបរ

និងរបស់ទំពាមួយរំពេចប៉ុណ្ណោះ បានប្រគេនហើយ ។ គ្រានោះ ឧបាសិកាគិតថា អញនឹងចាត់ចែងភត្ត អង្គុយក្នុងទីមិនឆ្ងាយលាងអង្គរ ។

សម័យនោះ យក្ខិនីពិចារណាថា សាមណេរទៅទីណាហ្ន៎ លោកបានភិក្ខា ឬមិនទាន់បាន ជ្រាបភាពដែលលោកគង់ហើយ ដោយភាពជាអ្នកប្រាជ្ញានឹងសឹក ទើបគិតថា លោកកុំញាំងការខ្នាសឲ្យកើតឡើងដល់អញក្នុងរវាងទេវតាទាំងឡាយឡើយ អញនឹងទៅធ្វើអន្តរាយក្នុងការសឹករបស់លោកដូច្នេះហើយ ទើបមកចូលសណ្ឋិតក្នុងសរីរៈរបស់សាមណេរនោះ កាច់កឲ្យអោនចុះលើផែនដី មានភ្នែកទាំងពីរលៀន មានទឹកមាត់ហូរ បម្រះនៀលលើផែនដី ឧបាសិកាឃើញការចម្លែករបស់បុត្រ ប្រញាប់មកត្រកងបុត្រហើយឲ្យសិងលើភ្លៅ អ្នកស្រុកទាំងមូល នាំគ្នាមកធ្វើការបួងសួង មានពលីកម្មជាដើម ។ ឧបាសិកាខ្វិកខ្វួល បានពោលគាថានេះថា

> *ខ្ញុំបានឮព្រះអរហន្តទាំងឡាយថា បុគ្គលទាំងឡាយណា រក្សាឧបោសថប្រកបដោយអង្គ ៨ ក្នុងថ្ងៃទី ១៤ ថ្ងៃទី ១៥ និងថ្ងៃទី ៨ នៃបក្ស ទាំងបាវិហារិកបក្ខផង ឈ្មោះថា ប្រព្រឹត្តព្រហ្មចរិយៈ ពួកយក្ខមិនយាយី បុគ្គលនោះឡើយ ឥឡូវថ្ងៃនេះ ខ្ញុំឯងឃើញពួកយក្ខយាយីសានុសាមណេរ ។*

យក្ខិនីស្តាប់ពាក្យរបស់ឧបាសិកាហើយពោលថា

> *នាងបានឮពាក្យព្រះអរហន្តទាំងឡាយ ដោយប្រពៃថា បុគ្គលទាំងឡាយណា រក្សាឧបោសថ ប្រកបដោយអង្គ ៨ ក្នុងថ្ងៃទី*

១៤ ថ្ងៃទី ១៥ និងថ្ងៃទី ៨ នៃបក្ស ទាំងបាវិហារិកបក្ខផង ឈ្មោះថា ប្រព្រឹត្តព្រហ្មចរិយៈ ពួកយក្ខមិនយាយីបុគ្គលទាំងនោះទេ នាងគប្បីនិយាយប្រាប់សានុសាមណេរ ដែលក្រាក់ឡើងថា នេះជាពាក្យរបស់ពួកយក្ខ (ប្រាប់) ថា លោកកុំធ្វើអំពើអាក្រក់ក្នុងទីចំពោះមុខ ឬទីកំបាំងនោះឡើយ បើលោកនឹងធ្វើ ឬកំពុងធ្វើ នូវអំពើលាមក លោកទុកជាហោះរត់ទៅ ក៏មិនរួចអំពីសេចក្តីទុក្ខដែរ ។

យក្ខិនីនោះពោលថា ការរួចផុតមិនមានដល់បុគ្គលដែលធ្វើបាបកម្មយ៉ាងនេះហើយ ហោះគេចទៅដូចបក្សី រួចក៏ដោះលែងសាមណេរ ។

សាមណេរនោះបើកភ្នែកឡើង ឃើញព្រោមស្រីកំពុងរំសាយសក់ទ្រហោយំ និងឃើញអ្នកស្រុកប្រជុំគ្នាហើយ មិនជ្រាបភាពដែលខ្លួនត្រូវយក្សចូលសណ្ឋិត ទើបនឹកសង្ស័យថា មុននេះអញកំពុងអង្គុយលើតាំង មាតារបស់អញលាងអង្គក្នុងទីមិនឆ្ងាយ តែឥឡូវនេះ អញបែរជាដេកលើផែនដី តើមានរឿងអ្វីហ្ន៎ កំពុងសិងនោះឯង ពោលនឹងមាតាថា

ព្រោម ពួកជនតែងយំរកបុគ្គល ដែលស្លាប់បាត់ទៅហើយ ឬបុគ្គលដែលរស់នៅ តែគេមិនឃើញព្រោម ព្រោមឃើញអាត្មានៅរស់នៅឡើយ ព្រោម ហេតុអ្វីក៏ព្រោមយំរកអាត្មា ។

គ្រានោះ មាតាសម្តែងទោសក្នុងការមកជើម្បីសឹក របស់បុគ្គលអ្នកលះវត្ថុកាម និងកិលេសកាមបួសហើយដល់លោក ទើបពោលថា

លោកកូន ជនទាំងឡាយតែងយំរក បុគ្គលដែលស្លាប់ផុតទៅហើយ ឬបុគ្គលដែលរស់នៅ តែគេមិនឃើញ ម្យ៉ាងទៀត បុគ្គលណា លះបង់កាមទាំងឡាយហើយ បែរជាត្រឡប់មករកកាមក្នុងលោកនេះវិញ លោកកូន សូម្បីតែបុគ្គលនោះ ក៏ពួកជនយំរកដែរ ព្រោះថា បុគ្គលនោះ រស់នៅមែន តែទុកដូចជាមនុស្សស្លាប់ហើយ លោកកូន ខ្ញុំបានស្រង់លោកអំពីផេះក្តៅ គឺឃរាវាសហើយ លោកចង់ធ្លាក់ទៅក្នុងផេះក្តៅវិញ លោកកូន ខ្ញុំបានស្រង់ដល់លោក ខ្ញុំនឹងច្រាបដល់អ្នកណាកើត លោក (ចេញអំពីឃរាវាស ទៅបួសហើយ) ដូចជាគ្រឿងភណ្ឌៈ ដែលគេនាំចេញអំពីផ្ទះភ្លើងឆេះ ហើយចង់ឆេះ (ក្នុងឃរាវាស) វិញ ។

កាលពោលយ៉ាងនោះហើយ ដើម្បីសម្តែងទោសក្នុងការគ្រប់គ្រងផ្ទះ ធ្វើការគ្រប់គ្រងផ្ទះឲ្យដូចគ្នានឹងរងើកភ្លើង និងឲ្យដូចជាជ្រោះ ទើបពោលទៀតថា

លោកកូន ខ្ញុំបានស្រង់លោក អំពីផេះក្តៅ គឺឃរាវាសហើយ លោកចង់ធ្លាក់ទៅក្នុងផេះក្តៅវិញ លោកកូន ខ្ញុំបានស្រង់លោក អំពីរណ្តៅហើយ លោកចង់ធ្លាក់ទៅក្នុងរណ្តៅវិញ ។

បន្ទាប់មក កាលសម្តែងថា សូមលោកកូនមានសេចក្តីចម្រើនចុះ ខ្ញុំនឹងដាក់ទុក្ខដល់បុគ្គលណា នឹងឲ្យបុគ្គលណា ជួយគិតសេចក្តីនេះថា កូនតូចរបស់ខ្ញុំនេះ កាលខ្ញុំនាំចេញទៅបួសក្នុងព្រះពុទ្ធសាសនា ហាក់បីដូចភណ្ឌៈដែលត្រូវនាំចេញចាកផ្ទះ ដែលកំពុងត្រូវភ្លើងឆេះហើយ នៅប្រាថ្នាវិលមកក្តៅ

ក្នុងយវាសទៀត សូមអ្នកទាំងឡាយជួយជាសង្គ្រឹន ជួយការពារដល់ខ្ញុំផង *ចុះ ហើយពោលគាថានេះ និងសានុសាមណេរនោះថា*

លោកចូរសុះចេញទៅ សេចក្តីចម្រើន ចូរមានដល់លោក ខ្ញុំនឹងប្រាប់ដល់អ្នកណាកើត លោក (ចេញអំពីយវាសទៅបួសហើយ) ដូចជាគ្រឿងកណ្ឌៈ ដែលគេនាំចេញអំពីផ្ទះភ្លើងឆេះហើយចង់ឆេះ (ក្នុងយវាស) វិញ ។

សានុសាមណេរនោះ កំណត់បានក្នុងកាលមាតាកំពុងពោល ទើបពោលថា ខ្ញុំមិនត្រូវការដោយភាពជាគ្រហស្ថទេ ។ គ្រានោះ មាតារបស់លោកពោលថា សាធុ ពេញចិត្តហើយ ឲ្យបរិភោគភោជនដ៏ប្រណីត សួរថា នែបាវដួវវស្សាប៉ុន្មានហើយ ជ្រាបភាពដែលលោកមានវដួវ មានវស្សាគ្រប់ហើយក៏រៀបចំត្រៃចីវរឲ្យលោក មានបាត្រ ចីវរគ្រប់ បានឧបសម្បទាហើយ ។

ព្រះសាស្តា កាលទ្រង់ញ៉ាំងឧស្សាហ៍ ក្នុងការសង្កត់ចិត្តឲ្យកើតឡើងដល់បុគ្គលដែលឧបសម្បទាហើយថ្មីៗ ទើបត្រាស់ថា ធម្មតាចិត្តនេះត្រាច់ទៅក្នុងអារម្មណ៍ផ្សេងៗ អស់កាលយូរ ឈ្មោះថា សួស្តី មិនមានដល់បុគ្គលដែលមិនសង្កត់ចិត្តនោះបាន ព្រោះដូច្នោះ ទើបគួរធ្វើសេចក្តីព្យាយាមក្នុងការសង្កត់ចិត្ត ដូចហត្ថាចារ្យធ្វើសេចក្តីព្យាយាម ក្នុងការសង្កត់សង្កិនដ៏រឹងប្រែងដោយកង្វេរ ដូច្នោះហើយ ត្រាស់ព្រះគាថានេះថា

ឥទំ បុរេ ចិត្តមចារិ ចារិកំ យេនិច្ឆកំ យត្ថកាមំ យថាសុខំ
តទជ្ជហំ និគ្គហេស្សាមិ យោនិសោ ហត្ថិប្បភិន្នំ វិយ អង្កុសគ្គហោ ។

ក្នុងកាលមុនអំពីកាលនេះ ចិត្តនេះបានត្រាច់ទៅកាន់ចារិក តាមអាការដែលខ្លួនប្រាថ្នា តាមអារម្មណ៍ដែលខ្លួនប្រាថ្នា តាមសេចក្តីសប្បាយក្នុងថ្ងៃនេះ អញនឹងសង្កត់សង្កិនចិត្តនោះដោយឧបាយ ដូចហ្នឹងដីរកាន់កង្វេរសង្កត់សង្កិនដីរចុះប្រេង ដូច្នោះដែរ ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា មុនអំពីនេះ ឈ្មោះថា ចិត្តនេះ ត្រាច់ចារិកទៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើមអស់កាលយូរ ឈ្មោះថា តាមអាការដែលប្រាថ្នាដោយអំណាចនៃកិលេសទាំងឡាយ មានរាគៈជាដើម ដែលជាហេតុប្រាថ្នា ឈ្មោះថា ត្រាច់ទៅតាមអារម្មណ៍ដែលជាទីប្រាថ្នា ដោយអំណាចនៃអារម្មណ៍ដែលជាទីកើតសេចក្តីប្រាថ្នានៃចិត្តនោះឯង ឈ្មោះថា តាមសេចក្តីសប្បាយ ព្រោះកាលចិត្តត្រាច់ទៅដោយអាការណា ទើបសេចក្តីសុខមាន ក៏ត្រាច់ទៅដោយអាការនោះឯង ថ្ងៃនេះ អញនឹងសង្កត់សង្កិនចិត្តដោយយោនិសោមន-សិការ គឺមិនព្រមឲ្យចិត្តឈានកន្ទងបាន ដូចបុរសជាក់កង្វេរក្នុងដៃ បុគ្គលឈ្លាស គឺហត្ថាចារ្យ សង្កត់សង្កិនដីរចុះប្រេង គឺចុះប្រេងដោយកង្វេរនោះ ។

ក្នុងកាលចប់ទេសនា ធម្មាភិសមយមានដល់ទេវតាជាច្រើន ដែលចូលទៅស្តាប់ធម៌ជាមួយសានុ ព្រះថេរៈនោះ រៀនពុទ្ធវចនៈ គឺព្រះត្រៃបិដកហើយបានជាធម្មកថិកដ៏ជំនាញ តម្កល់ជីវិតនៅអស់ ១២០ ឆ្នាំ ញុំងជម្ពូទ្វីបទាំងមូលឲ្យល្បីខ្ចរខ្ចារ ហើយបរិនិព្វាន ដូច្នេះ ॥

រឿង សាធុសាមណេរ ចប់

រឿង ជីរឈ្មោះ ចាវេរកៈ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធជីរឈ្មោះចាវេរកៈ របស់ព្រះបាទកោសល ត្រាស់ព្រះធម្មទេសនានេះថា **អប្បមាទរតា** ជាដើម ។

បានឮថា ជីរនោះ កាលនៅក្មេងជាសត្វមានកម្លាំងច្រើន ដោយសម័យជាទៃទៀត ត្រូវកម្លាំងខ្យល់កើតឡើង ព្រោះជរាបៀតបៀន ចុះទៅកាន់ស្រះធំមួយ ជាប់ក្នុងភក់ហើយមិនអាចឡើងបាន មហាជនឃើញជីរនោះហើយ ទើបសន្ធូនាគ្នាថា ជីរមានសភាពបែបនេះ គង់ដល់នូវទុព្វលភាពបែបនេះ ។ ព្រះរាជាទ្រង់ស្តាប់រឿងនោះហើយ ទ្រង់បង្គាប់នាយហត្ថាចារ្យថា ចូរអ្នកលើកជីរនោះឡើងអំពីភក់ បុរសនោះទៅហើយ សម្តែងការច្បាំងក្នុងទីនោះ ឲ្យវាយស្គរជុំទិសឡើង ។ ជីរជាសត្វមានពូជនៃមានះ ក្រោកឡើងដោយរហ័ស តាំងនៅលើគោកបាន ។ ភិក្ខុទាំងឡាយឃើញហេតុនោះហើយ ទើបក្រាបទូលដល់ព្រះសាស្តាៗ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ជីរនោះរើខ្លួនឡើងចាកភក់ គឺភក់តាមប្រក្រតី ចំណែកអ្នកទាំងឡាយ លិចចុះហើយក្នុងភក់ គឺកិលេសព្រោះដូច្នោះ អ្នកទាំងឡាយ ចូរផ្តើមសេចក្តីព្យាយាម ដោយឧបាយហើយរើខ្លួនឡើងចាកភក់ គឺកិលេសនោះចុះ ហើយត្រាស់ព្រះគាថានេះថា

អប្បមាទរតា ហោថ សចិត្តមនុរក្ខថ
ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ ។

អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្តីមិនប្រមាទ ចូររក្សាចិត្តរបស់ខ្លួន ចូររើខ្លួនចេញចាកភក់ គឺកិលេសដែលធ្ងន

បានដោយកម្រ ដូចជីវិតជាប់នៅក្នុងភក់ រើខ្លួនឲ្យរួចបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បមាទរតា** *សេចក្តីថា អ្នកទាំងឡាយ ចូរត្រេកអរក្នុងការមិននៅប្រាសចាកសតិ ។*

បទថា **សចិត្តំ** *សេចក្តីថា ចូរកាន់ចិត្តរបស់ខ្លួនក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ដោយអាការដែលចិត្តធ្វើនូវការឈានកន្ទងមិនបាន ។*

បទថា **សន្ថោ** *សេចក្តីថា ជីវិតដែលលិចចុះទៅហើយក្នុងភក់នោះ ធ្វើនូវសេចក្តីព្យាយាមដោយជើងមុខ និងជើងក្រោយ ដកខ្លួនឡើងចាកភក់ តាំងនៅលើគោកបាន យ៉ាងណា អ្នកទាំងឡាយ ក៏ចូររើខ្លួនឡើងចាកភក់ គឺកិលេស គឺញុំាងខ្លួនឲ្យតាំងនៅលើគោក គឺព្រះនិព្វានដូច្នោះចុះ ។*

ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុនោះ តាំងនៅហើយក្នុងអរហត្តផលដូច្នេះឯង ។

រឿងជីវិតឈ្មោះចាវេរកៈ ចប់

រឿង សម្ពហុលភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យព្រៃឈ្មោះបាលិលេយ្យកៈ ប្រថាប់នៅក្នុងជង្ឃព្រៃឈ្មោះរក្ខិតៈ ទ្រង់ប្រារព្ធភិក្ខុជាច្រើន ត្រាស់ព្រះធម្មទេសនានេះថា **សចេ លភេថ** ជាដើម ។

រឿងមកក្នុងអដ្ឋកថានៃព្រះគាថាថា **បរេ ច ន វិជានន្តិ** ជាដើម ក្នុងយមកវគ្គនោះឯង ។ ដែលពិត ខ្ញុំពោលរឿងនេះហើយថា ការប្រថាប់នៅរបស់ព្រះតថាគត ដែលស្តេចដំរីក្នុងជង្ឃព្រៃ ឈ្មោះរក្ខិតៈនោះ ទំនុកបម្រុងបានប្រាកដក្នុងសកលជម្ពូទ្វីបហើយ ។ ត្រកូលធំ មានអនាថបិណ្ឌិកសេដ្ឋី នាងវិសាខាមហាឧបាសិកា បញ្ជូនដំណឹងទៅអំពីនគរសាវត្ថីដល់ព្រះអានន្ទត្ថេរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បង្ហាញព្រះសាស្តាដល់យើងខ្ញុំទាំង-ឡាយចុះ ។ ភិក្ខុប្រមាណ ៥០០ រូប សូម្បីមានប្រក្រតីនៅក្នុងទិស ចេញវស្សាហើយ ចូលទៅរកព្រះអានន្ទត្ថេរអង្វរថា អាវុសោអានន្ទ យើងទាំងឡាយខានស្តាប់ធម្មកថា ចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ អស់កាលយូរហើយ សាធុ អាវុសោអានន្ទ យើងទាំងឡាយគប្បីបានស្តាប់ធម្មកថា ក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ។

ព្រះថេរៈនាំភិក្ខុទាំងនោះទៅកាន់ជង្ឃព្រៃ ឈ្មោះរក្ខិតៈនោះហើយ ត្រិះរិះថា ការចូលទៅកាន់សម្នាក់ព្រះតថាគត ដែលមានប្រក្រតីប្រថាប់នៅមួយអន្តឯងអស់ត្រីមាស មួយអន្ទើដោយភិក្ខុមានប្រមាណប៉ុណ្ណោះ មិនសមគួរ ដូច្នេះ

ហើយ មួយអង្គឯងប៉ុណ្ណោះចូលទៅគាល់ព្រះសាស្តា ។ ជីវកឈ្មោះបាលិលេយ្យកៈ ឃើញលោកហើយ ចាប់ឈើសុះទៅ ព្រះសាស្តាទតឃើញហើយ ត្រាស់ថា បាលិលេយ្យកៈ ចូរអ្នកចៀសចេញទៅកុំឃាត់នុ៎ះជាពុទ្ធុប្បដ្ឋាក ជីវកបោះកំណាត់ឈើចោលក្នុងទីនោះឯង សួរដោយអើពើដល់ការទទួលបាត្រ និងចីវរ ។ ព្រះថេរៈមិនបានឲ្យ ។ ជីវកគិតថា បើភិក្ខុនេះជាអ្នកមានវត្តដែលរៀនហើយសោត លោកនឹងមិនជាក់បរិក្ខារបស់ខ្លួន លើផ្ទាំងថ្មដែលជាទីប្រថាបគង់របស់ព្រះមានព្រះភាគ ព្រះថេរៈជាក់បាត្រ និងចីវរលើផែនដី ។ ពិតហើយ ភិក្ខុដែលសម្បូរដោយវត្តទាំងឡាយ រមែងមិនជាក់បរិក្ខារបស់ខ្លួនលើទីអង្គុយ ឬទីដេករបស់គ្រូ ព្រះថេរៈថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងចំណែកម្ខាង ព្រះសាស្តាត្រាស់សួរថា ម្នាលអានន្ទ អ្នកមកមួយរូបប៉ុណ្ណោះឬ ទ្រង់ស្តាប់ភាពដែលព្រះថេរៈ និងភិក្ខុប្រមាណ ៥០០ រូប ត្រាស់ថា ភិក្ខុទាំងនោះនៅទីណា កាលព្រះថេរៈក្រាបទូលថា ខ្ញុំព្រះអង្គកាលនឹងជ្រាបចិត្តរបស់ទ្រង់ ទើបឲ្យលោករង់ចាំក្នុងទីខាងក្រៅ ហើយមកគាល់តែឯង ។ ព្រះសាស្តាត្រាស់ថា ចូរហៅភិក្ខុទាំងនោះមកចុះ ព្រះថេរៈបានធ្វើយ៉ាងនោះ ។ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយនឹងភិក្ខុទាំងនោះហើយ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់ជាបុគ្គលសុខមាលជាតិ និងជាក្សត្រសុខមាលជាតិ ទ្រង់នៅមួយអង្គឯង ប្រថាប់ឈរ ប្រថាប់គង់ អស់ត្រីមាស ទ្រង់ធ្វើកម្មដែលធ្វើបានដោយក្រហើយ បុគ្គលធ្វើវត្ត និងបដិបត្តិក្តី អ្នកថ្វាយវត្ត មានទឹកខ្ពុះព្រះឱស្ឋជាដើមក្តី ប្រហែលជាមិនមាន ទើបទ្រង់ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កិច្ចគ្រប់យ៉ាងដំរីបាលិលេយ្យក: ធ្វើហើយដល់តថាគត ។ ពិតហើយ បុគ្គលកាលបានសម្លាញ់មានសភាពបែបនេះ នៅរួមគ្នា សមគួរ ហើយ កាលបុគ្គលមិនបានសម្លាញ់បែបនេះ ការត្រាច់ទៅម្នាក់ឯងប៉ុណ្ណោះ ជាការប្រសើរ ហើយបានភាសិតព្រះគាថានេះ ក្នុងនាគវគ្គថា

សចេ លភេថ និបកំ សហាយំ សទ្ធឹ ចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ ចរេយ្យ តេនត្តមនោ សតីមា ។
នោ ចេ លភេថ និបកំ សហាយំ សទ្ធឹ ចរំ សាធុវិហារិ ធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។
ឯកស្ស ចរិតំ សេយ្យោ នត្ថិ ពាលេ សហាយតា
ឯកោ ចរេ ន ច ទាទានិ កយិរា អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។

បើបុគ្គលបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងនៅ ញ្ចុាំងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតី គ្របសង្កត់សេចក្តីអន្តរាយទាំងពួង ហើយត្រាច់ទៅជាមួយនឹងសម្លាញ់នោះឯង ។ បើស្វែងរកមិនបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ ជាគ្រឿងញ្ចុាំងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែឯកឯងវិញ ដូចព្រះរាជាលះបង់រដ្ឋដែលទ្រង់ឈ្នះហើយ ស្តេចទៅតែឯកអង្គ ពុំនោះសោត ដូចដំរីឈ្មោះមាតង្គ: ដែលលះហ្វូង ត្រាច់ទៅតែឯកឯង ក្នុងព្រៃ

ដូច្នោះដែរ ។ ការត្រាច់ទៅរបស់បុគ្គលឯកឯង ជាគុណជាតប្រសើរផុត (ព្រោះថា) សហាយតាគុណ រមែងមិនមានក្នុងជនពាលឡើយ បុគ្គលនោះ គប្បីជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅតែម្នាក់ឯងផង មិនគប្បីធ្វើអំពើបាបទាំងឡាយផង ដូចដំរីឈ្មោះមាតង្គៈជាសត្វមិនមានសេចក្តីខ្វល់ខ្វាយ លះបង់ហ្វូង ត្រាច់ទៅតែឯកឯងក្នុងព្រៃដូច្នោះដែរ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **និបកំ** គឺដែលប្រកបដោយបញ្ញា ជាគ្រឿងរក្សាខ្លួន ។

បទថា **សាធុវិហារិ ធីរំ** គឺបុគ្គលដែលមានធម៌ជាគ្រឿងនៅដ៏ចម្រើន ជាបណ្ឌិត ។

បទថា **បរិស្សយានិ** ជាដើម សេចក្តីថា បុគ្គលនោះកាលបានសម្លាញ់ដែលមានមេត្តាជាវិហារធម៌បែបនោះ គប្បីគ្របសង្កត់អន្តរាយទាំងឡាយ គឺអន្តរាយដែលប្រាកដ មានសីហៈ និងខ្លាធំជាដើម និងអន្តរាយកំបាំង មានរាគៈ ទោសៈ ទាំងអស់នេះឯងជាដើមហើយ គប្បីជាអ្នកមានចិត្តត្រេកអរ មានសតិតាំងមាំ ត្រាច់ទៅ គឺនៅជាមួយសម្លាញ់នោះ ។

បទថា **រាជាវ រដ្ឋំ** សេចក្តីថា ដូចព្រះរាជាជាឥស្សរៈ ទ្រង់លះបង់ដែនបួសដូច្នោះ ។ លោកពោលពាក្យអធិប្បាយនេះថា ព្រះរាជាដែលមានប្រទេសដែលទ្រង់ឈ្នះហើយ ទ្រង់លះដែនដែលទ្រង់ឈ្នះជាសមុច្ឆេទហើយ ដោយ

ទ្រង់ត្រែះរិះថា ឈ្មោះថា ភាពជាព្រះរាជានេះ ជាទីតាំងនៃសេចក្តីប្រមាទធំ ប្រយោជន៍អ្វីរបស់អញ ដោយរាជសម្បត្តិ ដែលអញគ្រប់គ្រងហើយ គ្រានោះឯង យាងចូលទៅកាន់ព្រៃធំ បួសជាតាបស ហើយត្រាច់ទៅចំពោះមួយអង្គឯង ដោយឥរិយាបថ ៤ យ៉ាងណា បុគ្គលគប្បីត្រាច់ទៅ ចំពោះម្នាក់ឯង ដូច្នោះ ។

ពីរបទថា **មាតង្គរញ្ញេវ ឆាគោ** *សេចក្តីថា ដូចស្តេចដ៏រឈ្មោះមាតង្គៈ ព្រោះពិចារណាយ៉ាងនេះថា អញនៅច្រឡូកច្រឡំដោយពួកដ៏រស្ត ដ៏រញី ដ៏រជំទង់ និងកូនដ៏រទាំងឡាយ អញតែងទំពាស៊ីស្មៅដែលគេកាត់ត្រង់ចុងហើយ និងរមែងទំពាស៊ីមែក ដែលល្មមកាច់បានហើយ អញរមែងផឹកទឹកដែលល្អក់ កាលអញឈមចុះកាន់កំពង់ទឹក និងឈានឡើង ដ៏រមេរមែងដើរត្រដុសកាយទៅ បើដូច្នោះ គប្បីចៀសចេញអំពីហ្វូង ដូច្នេះហើយ ដើរទៅដោយការដឹងលះបង់ហ្វូងហើយ រមែងត្រាច់ទៅក្នុងព្រៃតាមសប្បាយ ដោយឯកឯងប៉ុណ្ណោះ ក្នុងឥរិយាបថទាំងពួង យ៉ាងណា បុគ្គលគប្បីត្រាច់ទៅម្នាក់ឯងប៉ុណ្ណោះដូច្នោះ ។*

បទថា **ឯកស្ស** *សេចក្តីថា ការត្រាច់ទៅនៃបព្វជិត ដែលត្រេកអរក្រៃលែងហើយក្នុងឯកីភាព តាំងអំពីកាលដែលខ្លួនបួស ឈ្មោះថា ជាបុគ្គលម្នាក់ឯងប៉ុណ្ណោះ ប្រសើរ ។*

បាទព្រះគាថាថា **ឆត្តិ ពាលេ សហាយតា** *សេចក្តីថា ព្រោះគុណធម៌នេះ គឺចុល្លសីល មជ្ឈិមសីល មហាសីល កថាវត្ថុ ១០ ធុតង្គ ១៣ វិបស្សនាញាណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ អមតមហានិព្វាន ១ ឈ្មោះថា*

សហាយតាគុណ ។ បុគ្គលមិនអាចសម្រេចគ្រឿងជាសហាយនោះ ព្រោះអាស្រ័យពួកពាលជន ព្រោះដូច្នោះ គុណជាសម្ងាញ់ ទើបឈ្មោះថា មិនមានក្នុងពាលជន ។

បទថា **ฯเกา** ជាដើម សេចក្តីថា ព្រោះហេតុនេះ បុគ្គលគប្បីជាបុគ្គលម្នាក់ឯងប៉ុណ្ណោះ ត្រាច់ទៅក្នុងឥរិយាបថទាំងពួង និងមិនគប្បីធ្វើបាបទាំងឡាយ សូម្បីមានប្រមាណតិច ។ អធិប្បាយថា បុគ្គលនោះ គប្បីជាបុគ្គលម្នាក់ឯងប៉ុណ្ណោះត្រាច់ទៅ ។ ជីរឈ្មោះមាតង្គៈ មានសេចក្តីខ្វល់ខ្វាយតិច គឺមិនមានអាល័យ ត្រាច់ទៅតាមសប្បាយ ក្នុងទីដែលខ្លួនប្រាថ្នាហើយ ក្នុងព្រៃនេះ ដូច្នោះ មិនគប្បីធ្វើបាបទាំងឡាយ សូម្បីមានប្រមាណតិច ។

ព្រោះដូច្នោះ ព្រះសាស្តា កាលទ្រង់សម្តែងអត្តនេះថា អ្នកទាំងឡាយបើមិនបានសម្ងាញ់ ដែលមានសភាពបែបនេះ គប្បីជាអ្នកត្រាច់ទៅម្នាក់ឯងប៉ុណ្ណោះ ទើបទ្រង់សម្តែងព្រះធម្មទេសនានេះ ដល់ភិក្ខុទាំងនោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំង ៥០០ រូបនោះ តាំងនៅក្នុងអរហត្តផលដូច្នេះឯង ។

រឿងសម្ពហុលភិក្ខុ ចប់

រឿង មារ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងកុដិដែលតាំងនៅក្នុងព្រៃហិមពាន្ត ទ្រង់ប្រារព្ធមារ ត្រាស់ព្រះធម្មទេសនានេះថា **អត្ថទ្ធិ** ជាដើម ។

បានឮថា ក្នុងកាលនោះ ព្រះរាជាទាំងឡាយ គ្រប់គ្រងរាជសម្បត្តិ បៀតបៀនដល់ពួកមនុស្ស ។ គ្រានោះ ព្រះដ៏មានព្រះភាគទតឃើញមនុស្សទាំងឡាយត្រូវបៀតបៀនដោយជាក់អាជ្ញា ក្នុងវេលាសម័យរបស់ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ ទ្រង់ត្រិះរិះដោយអំណាចនៃសេចក្តីករុណា យ៉ាងនេះថា តថាគតអាចគ្រប់គ្រងរាជសម្បត្តិដោយធម៌ មិនបៀតបៀនខ្លួនឯង មិនឲ្យអ្នកដទៃបៀតបៀន មិនឈ្នះខ្លួនឯង មិនឲ្យអ្នកដទៃឈ្នះ មិនសោយសោកឯង មិនឲ្យអ្នកដទៃសោយសោកឬហ្ន៎ ។

មារមានចិត្តបាប ជ្រាបបរិវិតក្កក្នុងសេចក្តីនោះ របស់ព្រះសាស្តាហើយ ទើបត្រិះរិះថា ព្រះសមណគោតមទ្រង់ត្រិះរិះថា អញអាចគ្រប់គ្រងរាជសម្បត្តិឬហ្ន៎ ឥឡូវនេះ ព្រះសមណគោតមនោះ នឹងជាអ្នកប្រាថ្នាដើម្បីគ្រប់គ្រងរាជសម្បត្តិ ឈ្មោះថា រាជសម្បត្តិនេះ ជាទីតាំងនៃសេចក្តីប្រមាទ កាលព្រះសមណគោតមគ្រប់គ្រងរាជសម្បត្តិនោះ អញអាចបានឱកាស អញនឹងទៅញាំងនូវឧស្សាហៈឲ្យកើតឡើងដល់ទ្រង់ ហើយចូលទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់គ្រងរាជសម្បត្តិ សូមទ្រង់គ្រងរាជ-សម្បត្តិដោយធម៌ មិនបៀតបៀនឯង មិនឲ្យអ្នកដទៃបៀតបៀន មិនឈ្នះឯង មិនឲ្យអ្នកដទៃឈ្នះ មិនសោយសោកឯង មិនឲ្យអ្នកដទៃសោយសោក ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងមារនោះថា ម្នាលមារមានចិត្តបាប អ្នកឃើញអ្វីរបស់តថាគត ទើបអ្នកពោលយ៉ាងនេះ កាលមារទូលថា បពិត្រព្រះអង្គ ទ្រង់អប់រំឥទ្ធិបាទ ៤ ល្អហើយ ព្រះដ៏មានព្រះភាគ កាលទ្រង់មានព្រះចំណង ទើបទ្រង់បង្អោនទឹកដល់ស្តេចក្អែហិមពាន្តថា ចូរជាមាស ហើយស្តេចក្អែដែលទ្រង់នឹកដល់នោះ គប្បីជាមាសនោះឯង ខ្ញុំព្រះអង្គនឹងធ្វើកិច្ចដែលគួរធ្វើដោយទ្រព្យដើម្បីព្រះអង្គ ។ ព្រោះហេតុនេះ ទ្រង់នឹងគ្រប់គ្រងរាជសម្បត្តិដោយធម៌ ដូច្នេះហើយ ទ្រង់ញុាំងមារឲ្យសង្វេគដោយគាថាទាំងនេះថា

> *ព្រះអង្គត្រាស់ថា ក្អែមាសសុទ្ធមានសម្បុរល្អ ទោះបីក្អែពីរ ក៏មិនល្មមគ្រាន់ដល់បុគ្គលម្នាក់ឡើយ បុគ្គលដឹងដូច្នេះ គួរប្រព្រឹត្តស្មើសត្វណាបានឃើញសេចក្តីទុក្ខ ដែលមានកាមជាហេតុ សត្វនោះនឹងបង្អោនចិត្តទៅរកកាមដូចម្តេចកើត លុះសត្វបានដឹងច្បាស់នូវឧបធិក្នុងលោកថា ជាគ្រឿងចំពាក់ ដូច្នេះហើយ គួរសិក្សាដើម្បីកម្ចាត់បង់នូវឧបធិនោះចេញ ។*

ហើយទ្រង់ត្រាស់ថា ម្នាលមារមានចិត្តបាប ឱវាទរបស់អ្នកម្យ៉ាង របស់តថាគតក៏ម្យ៉ាង ឈ្មោះថា ការប្រឹក្សាធម៌ជាមួយអ្នក រមែងមិនមានព្រោះតថាគតតែងទូន្មានយ៉ាងនេះ ហើយទ្រង់ភាសិតព្រះគាថាទាំងនេះថា

អត្តត្ថិ ជាតត្ថិ សុខា សហាយា តុដ្ឋី សុខា យា ឥតរីតរេន
បុញ្ញំ សុខំ ជីវិតសង្ខយត្ថិ សព្វស្ស ទុក្ខស្ស សុខំ បហានំ ។

សុខា មត្តេយ្យតា លោកេ អថោ បេត្តេយ្យតា សុខា
សុខា សាមញ្ញតា លោកេ អថោ ព្រហ្មញ្ញតា សុខា ។
សុខំ យាវ ជរា សីលំ សុខា សទ្ធា បតិដ្ឋិតា
សុខោ បញ្ញាបដិលាភោ ទាទានំ អករណំ សុខំ ។

កាលបើសេចក្តីត្រូវការកើតឡើងហើយ សម្ងាញ់ទាំងឡាយ នាំសេចក្តីសុខមកឲ្យ សេចក្តីត្រេកអរដោយបច្ចុយតាមមាន តាមបាន ជាហេតុនាំសេចក្តីសុខមកឲ្យ បុណ្យនាំសេចក្តីសុខមកឲ្យក្នុងកាលទៀបក្ស័យជីវិត ការលះបង់ទុក្ខទាំងអស់បាន ជាហេតុនាំសេចក្តីសុខមកឲ្យ ។ សេចក្តីប្រតិបត្តិល្អក្នុងមាតា នាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀត សេចក្តីប្រតិបត្តិល្អក្នុងបិតា នាំសេចក្តីសុខមកឲ្យ សេចក្តីប្រតិបត្តិល្អក្នុងសមណ: នាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀត សេចក្តីប្រតិបត្តិល្អក្នុងព្រាហ្មណ៍ នាំសេចក្តីសុខមកឲ្យ សីល នាំសេចក្តីសុខមកឲ្យជរាបដល់ចាស់ សទ្ធាដែលបុគ្គលតម្កល់ស៊ីប់ហើយ នាំសេចក្តីសុខមកឲ្យ ការបាន នូវប្រាជ្ញា នាំសេចក្តីសុខមកឲ្យ ការមិនធ្វើបាបទាំងឡាយ នាំសេចក្តីសុខមកឲ្យ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អត្តម្ហិ** *សេចក្តីថា កិច្ច មានការធ្វើចីវរជាដើមក្តី មានការរម្ងាប់អធិករណ៍ជាដើមក្តី កើតឡើងដល់បព្វជិតក៏មាន ។*

កាលកិច្ច មានកសិកម្មជាដើមក្តី មានការដែលត្រូវពួកជនអាស្រ័យរួមដោយចំណែកដែលមានកម្លាំងញាំញីក្តី រមែងកើតឡើងដល់គ្រហស្ថក៏មាន សម្លាញ់ណាអាចញុំាងកិច្ចនោះឲ្យសម្រេចបាន ឬឲ្យស្រួបបាន សម្លាញ់បែបនោះ នាំសេចក្តីសុខមកឲ្យ ។

ពីរបទថា **តុដ្ឋី សុខា** *សេចក្តីថា គ្រហស្ថទាំងឡាយដែលមិនសន្តោសដោយរបស់ខ្លួន ទើបប្រារព្ធទុច្ចរិតកម្ម មានការកាត់ទី-តជាដើម សូម្បីបព្វជិតទាំងឡាយ ដែលមិនសន្តោសហើយដោយបច្ច័យរបស់ខ្លួន ទើបប្រារព្ធអនេសនាមានប្រការផ្សេងៗ ព្រោះហេតុនេះ គ្រហស្ថ និងបព្វជិតទាំងពីរនោះ ទើបមិនជួបនូវសេចក្តីសុខឡើយ ព្រោះដូច្នោះ ការសន្តោសដោយរបស់ដែលមាននៃខ្លួនក្រៅអំពីនេះ គឺតិចតួច ឬច្រើននេះឯង នាំសេចក្តីសុខមកឲ្យ ។*

បទថា **បុញ្ញំ** *សេចក្តីថា បុញ្ញកម្មដែលផ្តើមធ្វើតាមអធ្យាស្រ័យយ៉ាងណានោះឯង នាំសេចក្តីសុខមកឲ្យក្នុងមរណកាល ។*

បទថា **សព្ពសត្ត** *សេចក្តីថា ម្យ៉ាងទៀត អរហត្ត ពោល គឺការលះវដ្តទុក្ខទាំងមូលបាននោះឯង ឈ្មោះថា នាំសេចក្តីសុខមកឲ្យក្នុងលោក ។*

កិច្ចបដិបត្តិប្រពៃក្នុងមាតា ឈ្មោះថា **មត្តេយ្យតា** *បដិបត្តិប្រពៃក្នុងបិតា ឈ្មោះថា* **បេត្តេយ្យតា** *។ ការទំនុកបម្រុងមាតាបិតានេះឯង ព្រះមានព្រះភាគត្រាស់ហើយដោយបទទាំងពីរ ។ មែនពិត មាតា និងបិតាដឹងថា កូនទាំងឡាយមិនទំនុកបម្រុងហើយ រមែងកប់ទ្រព្យដែលជារបស់ខ្លួនចោលក្នុងផែនដីខ្លះ លះឲ្យជនដទៃខ្លះ ម្យ៉ាងទៀត ការនិន្ទារមែងប្រព្រឹត្តទៅដល់បុត្រ*

ទាំងនោះថា ជនទាំងនេះ មិនទំនុកបម្រុងមាតាបិតា បុត្រទាំងនោះ រមែងកើតក្នុងគូថនរក ព្រោះកាយបែកធ្លាយទៅ ចំណែកបុត្រពួកណា ទំនុកបម្រុងមាតាបិតាដោយគោរព បុត្រទាំងនោះ រមែងបានទ្រព្យដែលជារបស់មាតាបិតាទាំងនោះ រមែងបាននូវការសរសើរ ព្រោះរាងកាយបែកធ្លាយទៅ រមែងទៅកើតក្នុងស្ថានសួគ៌ ព្រោះដូច្នោះ ទើបបទទាំងពីរនេះ ព្រះសាស្តាត្រាស់ថា នាំសេចក្តីសុខមកឲ្យ ដូច្នេះ ។

កិច្ចបដិបត្តិប្រពៃក្នុងបព្វជិតទាំងឡាយ ឈ្មោះថា **សាមញ្ញតា** *បដិបត្តិប្រពៃក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវ័កនៃព្រះពុទ្ធទាំងឡាយ មានបាបដែលបន្សាត់ហើយប៉ុណ្ណោះឈ្មោះថា* **ព្រហ្មញ្ញតា** *។ ភាពជាអ្នកទំនុកបម្រុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធសាវ័កទាំងឡាយនោះដោយបច្ច័យ ៤ ព្រះដ៏មានព្រះភាគត្រាស់ហើយដោយបទទាំងពីរ ។ បទនេះ ទ្រង់ក៏ត្រាស់ថា នាំសេចក្តីសុខមកឲ្យក្នុងលោក ។*

បទថា **សីលំ** *ជាដើម សេចក្តីថា មែនពិត គ្រឿងអលង្ការទាំងឡាយមានកែវមណី កុណ្ឌល និងសំពត់ក្រហមជាដើម រមែងស្អាតសម្រាប់ជនដែលតាំងនៅហើយក្នុងវ័យនោះៗ ប៉ុណ្ណោះ គ្រឿងអលង្ការរបស់កំលោះក្រមុំ គង់ស្អាតក្នុងកាលចាស់ ឬគ្រឿងអលង្ការរបស់មនុស្សចាស់ គង់ស្អាតក្នុងកាលកំលោះក្រមុំក៏មិនមែន ម្យ៉ាងទៀត រមែងញ៉ាំងឲ្យកើតសេចក្តីវិនាសតែម្យ៉ាង ព្រោះឲ្យនូវការនិន្ទាកើតឡើងថា ជនទាំងនោះ ប្រហែលជាឆ្កួត (បើតែងខ្លួនខុសវ័យ) ចំណែកសីល ៥ និងសីល ១០ ជាដើម រមែងស្អាតគ្រប់វ័យ*

ទាំងដល់កំលោះក្រមុំ និងមនុស្សចាស់នោះឯង រមែងនាំមកតែសោមនស្ស តែម្យ៉ាង ព្រោះឲ្យនូវការសរសើរកើតឡើងថា ឱ ! បុគ្គលនេះ មានសីលហ្ន៎ ព្រោះដូច្នោះ ទើបព្រះសាស្តាត្រាស់ថា **សុខំ យាវ ជរា សីលំ ។**

ពីរបទថា **សទ្ធា បតិដ្ឋិតា** *សេចក្តីថា សទ្ធាដែលជាលោកិយ និងលោកុត្តរទាំងពីរយ៉ាង ជាគុណជាតមិនញាប់ញ័រ តាំងមាំហើយ នាំសេចក្តីសុខមកឲ្យ ។*

បាទព្រះគាថាថា **សុខោ បញ្ញាបដិលាភោ** *សេចក្តីថា ការបានចំពោះនូវបញ្ញា ដែលជាលោកិយ និងលោកុត្តរ នាំសេចក្តីសុខមកឲ្យ ។*

ពីរបទថា **ចាចានំ អករណំ** *សេចក្តីថា ម្យ៉ាងទៀត ការមិនធ្វើបាបទាំងឡាយ ដោយអំណាចសេតុឃាតៈ គឺអរិយមគ្គ នាំសេចក្តីសុខមកឲ្យក្នុងលោកនេះ ។ ក្នុងកាលចប់ទេសនា ធម្មាភិសមយ មានដល់ទេវតាជាច្រើន ដោយប្រការដូច្នេះឯង ។*

រឿងមារ ចប់

នាគវគ្គ ចប់

វគ្គទី ២៣ ចប់

សុត្តន្តបិដក

ធម្មបទគាថា តណ្ហាវគ្គទី ២៤

[៣៤] តណ្ហា តែងចម្រើនដល់មនុស្សអ្នកមានការប្រព្រឹត្ត ដោយសេចក្តីប្រមាទជាប្រក្រតី ដូចវល្លិ៍ រួបរឹតដើមឈើហើយ ចម្រើនឡើង បុគ្គលនោះ តែងសុះទៅកាន់ភពតូចភពធំ ដូចស្វា កាលប្រាថ្នាផ្លែឈើ លោតទៅក្នុងព្រៃ ដូច្នោះដែរ ។ តណ្ហានុ៎ះ ជាទោសជាតិដ៏លាមក ផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ក្នុងលោក គ្របសង្កត់បុគ្គលណា សេចក្តីសោកស្តាយតែងចម្រើនឡើង ដល់បុគ្គលនោះ ដូចស្បូវរណ្តាស ដែលត្រូវភ្លៀងធ្លាក់ចុះជញ្ជុំ ហើយពន្លក លូតលិចឡើង ដូច្នោះដែរ ។

ចំណែកជនណា គ្របសង្កត់តណ្ហាដ៏លាមកក្នុងលោក ដែលគេឆ្លងបានដោយកម្រនោះ សេចក្តីសោកស្តាយ តែងធ្លាក់ចេញចាកជននោះឯង ដូចដំណក់ទឹកដែលធ្លាក់ចុះចាកស្លឹកឈូក ដូច្នោះដែរ ។

ព្រោះហេតុនោះ បានជាតថាគតប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយមានប៉ុន្មានរូប ដែលមកប្រជុំក្នុងទីនេះ សេចក្តីចម្រើន ចូរមានដល់អ្នកទាំងឡាយ ទាំងប៉ុណ្ណោះចុះ អ្នកទាំងឡាយ ចូររម្ងើឆ្ងល់តណ្ហាចោលចេញ ដូចបុគ្គលត្រូវការដោយស្បូវភ្ញាំង គាស់ស្បូវរណ្តាសចោលចេញ ដូច្នោះ ។

មារកុំរុករានអ្នកទាំងឡាយរឿយៗ ដូចខ្សែទឹកកាច់បំបាក់ដើមបបុស ដូច្នោះឡើយ ។

កាលបើឫសឈើ មិនមានសេចក្តីអន្តរាយ នៅមាំមួនទេ ដើមឈើទុកជាកាប់ចោលហើយ ក៏តែងដុះឡើងទៀតបាន មានឧបមាដូចម្តេចមិញ កាល

បើតណ្ហានុសយ បុគ្គលកម្ចាត់មិនទាន់បានហើយ ទុក្ខ (មានជាតិទុក្ខជាដើម) នេះ ក៏តែងកើតរឿយៗ មានឧបមេយ្យដូច្នោះឯង ។ ខ្សែតណ្ហា ៣៦ ជាធម្មជាតិហូរទៅ ក្នុងអារម្មណ៍ ជាទីគាប់ចិត្ត ជាធម្មជាតិក្លៀវក្លា មានដល់បុគ្គលណា តម្រិះទាំងឡាយដ៏ធំ ដែលអាស្រ័យនូវរាគៈ តែងនាំនូវទិដ្ឋិអាក្រក់របស់បុគ្គលនោះ ។

ខ្សែតណ្ហាទាំងឡាយ តែងហូរទៅក្នុងអារម្មណ៍ទាំងពួង ដូចជាវល្លិ៍ដែលបែកខ្នែងឡើង តាំងនៅដូច្នោះ បើអ្នកទាំងឡាយ ឃើញតណ្ហាដូចជាវល្លិ៍នោះ កើតឡើងហើយ ចូរកាត់ឫសចោលចេញ ដោយកាំបិត គឺបញ្ញា ។

សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្តីស្រឡាញ់ផង រមែងមានដល់សត្វ ពួកសត្វនោះជាអ្នកអាស្រ័យនូវសេចក្តីរីករាយ អ្នកស្វែងរកសេចក្តីសុខ នរជនទាំងឡាយនោះឯង តែងឈមទៅរកជាតិ និងជរា ។

ពួកសត្វដែលតណ្ហា ជាទីញុំាងសត្វឲ្យតក់ស្លុត ក្រុងទុកហើយ តែងរន្ធត់ ដូចទន្សាយ ដែលព្រានទាក់បានហើយដូច្នោះ ពួកសត្វដែលជាប់ក្នុងសំយោជនៈ និងសង្គធម៌ (ធម៌ជាគ្រឿងជំពាក់) តែងដល់នូវសេចក្តីទុក្ខរឿយៗ អស់កាលអង្វែង ។

ពួកសត្វដែលតណ្ហា ជាទីញុំាងសត្វឲ្យតក់ស្លុត ក្រុងទុកហើយ តែងរន្ធត់ ដូចទន្សាយ ដែលនាយព្រានទាក់បានហើយដូច្នោះ ព្រោះហេតុនោះ ភិក្ខុកាលប្រាថ្នាធម៌ ជាគ្រឿងប្រាសចាករាគៈ ដើម្បីខ្លួន គប្បីបន្ទោបង់តណ្ហា

ដែលជាគ្រឿងតក់ស្លុត ចោលចេញ ។

បុគ្គលណា មិនមានអាល័យ ក្នុងគិហិភាពដូចដើមឈើតាំងនៅក្នុងព្រៃ មានចិត្តចុះស៊ប់ក្នុងព្រៃ គឺតបធម៌ ជាអ្នកបួចស្រឡះចាកព្រៃ គឺតណ្ហា ហើយសុះទៅរកព្រៃ គឺតណ្ហាវិញ អ្នកទាំងឡាយ ចូរមើលបុគ្គលនោះឯង បុគ្គលនោះ រួចចាកចំណង គឺឃរាវាសហើយ សុះទៅរកចំណង គឺឃរាវាសវិញ ។ ចំណងណា ដែលកើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅយ៉ាបូងក្តី អ្នកប្រាជ្ញមិនហៅចំណងនោះថា ជាចំណងមាំមួនឡើយ ។

ពួកជនណា ត្រេកអរក្រៃពេក ក្នុងកែវមណី និងកុណ្ឌលទាំងឡាយក្តី សេចក្តីអាឡោះអាល័យ កូន និងប្រពន្ធទាំងឡាយក្តី អ្នកប្រាជ្ញទាំងឡាយ ហៅសេចក្តីត្រេកអរ និងសេចក្តីអាឡោះអាល័យនោះ ថាជាចំណងមាំមួន ជាចំណងនាំចុះ (ទាញសត្វទម្លាក់ទៅក្នុងអបាយ) ជាចំណងធូរទេ ប៉ុន្តែសត្វស្រាយបានដោយកម្រ អ្នកប្រាជ្ញទាំងឡាយ កាត់ចំណងនោះចេញ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់កាមសុខ ហើយចេញបួស ។

ជនណា ត្រេកអរដោយអំណាចរាគៈ ពួកជននោះ តែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាងទម្លាក់ខ្លួនចុះកាន់សំណាញ់ ដែលធ្វើហើយដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយ តែងកាត់ខ្សែតណ្ហានោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះទុក្ខទាំងពួងចេញទៅ ។

អ្នកចូរដោះ (សេចក្តីអាល័យ) ក្នុងកាលមុនចេញ ចូរដោះ (សេចក្តីអាល័យ) ក្នុងខាងក្រោយចេញ ចូរដោះ (សេចក្តីអាល័យ) ក្នុងកាល

ជាកណ្តាលចេញ (កាលបើធ្វើយ៉ាងនេះ) អ្នកនឹងដល់ត្រើយនៃភព នឹង មានចិត្តរួចស្រឡះ ចាកសង្ខតធម៌ទាំងពួង មិនត្រូវទៅកាន់ជាតិ និងជរា ទៀតឡើយ ។

តណ្ហា រមែងចម្រើនក្រៃលែង ដល់ជនដែលវិតក្កញាំញី មានតម្រេក ក្តៀវក្លា យល់ឃើញអារម្មណ៍ថាល្អ បុគ្គលនោះឯង ឈ្មោះថា ធ្វើចំណងឲ្យ មាំមួន ។ លុះតែបុគ្គលណា ត្រេកអរក្នុងអសុភជ្ឈាន ដែលជាហេតុឲ្យស្ងប់ រម្ងាប់នូវវិតក្ក មានស្មារតីសព្វកាល តែងចម្រើនអសុភជ្ឈាន បុគ្គល នោះឯង នឹងធ្វើតណ្ហាឲ្យអស់ទៅបាន បុគ្គលនោះឯង ទើបឈ្មោះថា កាត់ ចំណងមានបាន ។

បុគ្គលណា ដល់សេចក្តីសម្រេច គឺអរហត្ត ជាអ្នកមិនតក់ស្លុត មិន មានតណ្ហា មិនមានកិលេសដូចទឹកទួល បានកាត់កូនសរ គឺកិលេស ជាហេតុ ញ៉ាំងសត្វឲ្យទៅកាន់ភពបានហើយ កាយដែលឆ្អឹង ៣០០ កំណាត់ផ្តុំគ្នា ហើយនេះ របស់បុគ្គលនោះ ឈ្មោះថា តាំងនៅក្នុងទីបំផុត ។

បុគ្គលណា មិនមានតណ្ហា មិនមានសេចក្តីប្រកាន់មាំ ជាអ្នកឈ្លាស ក្នុងនិរុត្តិ (វាចាជាគ្រឿងសម្តែងចេញ) និងបទដ៏សេស ដឹងច្បាស់នូវប្រជុំ នៃអក្ខរៈទាំងឡាយផង នូវខាងដើម និងខាងចុង នៃអក្ខរៈទាំងឡាយផង បុគ្គលនោះឯង តថាគតហៅថា អ្នកមានសរីរៈបិតនៅក្នុងទីបំផុត មានបញ្ញា ច្រើន ជាមហាបុរស ។

តថាគតជាអ្នកគ្របសង្កត់ តេកូមិកធម៌ទាំងអស់ ដឹងច្បាស់ចតុព្ភូមិក-

ធម៌ទាំងអស់ មានចិត្តមិនបានជាប់នៅ ក្នុងតេភូមិកធម៌ទាំងអស់ លះបង់តេភូមិកធម៌ទាំងអស់ មានចិត្តរួចស្រឡះ ព្រោះអស់តណ្ហា បើតថាគតត្រាស់ដឹងធម៌ដោយខ្លួនឯងហើយ ចាំបាច់យកអ្នកណាជាគ្រូអាចារ្យទៀត ។ ធម្មទានឈ្នះអាមិសទានទាំងពួង ធម្មរស ឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ឈ្នះសេចក្តីត្រេកអរទាំងពួង ការអស់តណ្ហា ឈ្នះទុក្ខទាំងពួង ។ កោគៈទាំងឡាយ រមែងសម្ងាប់បុគ្គលអប្បញ្ញា ប៉ុន្តែមិនសម្ងាប់បុគ្គលអ្នកស្វែងរកត្រើយ គឺព្រះនិព្វានទេ ឯបុគ្គលអប្បញ្ញា រមែងសម្ងាប់ខ្លួនឯង ដូចជាសម្ងាប់បុគ្គលដទៃ ព្រោះចំណង់ក្នុងកោគៈ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានរាគៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានទោសៈអស់ហើយ រមែងជាទានមានផលច្រើន ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានមោហៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានសេចក្តីស្រែណោនជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានសេចក្តីស្រែណោនអស់ហើយ រមែងជាទាន មានផលច្រើន ។

តណ្ហាវគ្គទី ២៤ ចប់

អដ្ឋកថា

តណ្ហាវគ្គទី ២៤

រឿង កបិលមច្ចុ:

ចូលទៅកាន់ព្រៃព្យាយាមក៏សម្រេចអរហត្តផល ។

ចំណែកភិក្ខុជាបួនគិតថា អញនៅកំលោះ ក្នុងពេលចាស់សឹមបំពេញវិបស្សនាធុរៈ ទើបផ្តើមតាំងគន្ថធុរៈ រៀនព្រះត្រៃបិដក បរិវារជាច្រើនបានកើតឡើង ព្រោះអាស្រ័យបរិយត្តិរបស់លោក លោកបានកើតឡើងព្រោះអាស្រ័យបរិវារ ស្រវឹងហើយដោយសេចក្តីស្រវឹងក្នុងភាពជាអ្នកស្តាប់ច្រើន ត្រូវការចង់បានក្នុងលាភគ្រប់សង្កត់ហើយ ព្រោះជាអ្នកសម្គាល់ខ្លួនថាឈ្លាសក្រៃលែង រមែងពោលរបស់ដែលជាកប្បិយៈ ដែលមនុស្សជៃពោលហើយថាជាអកប្បិយៈ ពោលវត្ថុដែលជាអកប្បិយៈថាជាកប្បិយៈ ពោលវត្ថុដែលមានទោសថា មិនមានទោស ពោលវត្ថុដែលមិនមានទោសថាមានទោស សូម្បីភិក្ខុអ្នកមានសីលជាទីស្រឡាញ់ទាំងឡាយពោលថា អាវុសោកបិល អ្នកកុំពោលយ៉ាងនេះ ហើយសម្តែងធម៌និងវិនិច្ឆយ ពោលប្រៀនប្រដៅ ហើយក៏ពោលថា ពួកលោកចេះអ្វី ពួកលោកដូចក្តាប់ដៃទទេជាដើមហើយ ក៏ត្រាច់ពោលសម្តែតភិក្ខុទាំង-ឡាយ ។

គ្រានោះ ភិក្ខុទាំងឡាយជ្រាប់សេចក្តីនោះដល់ព្រះសោធនត្ថេរ ដែលជា

បង់ប្រុសរបស់លោក សូម្បីព្រះសោធនត្ថេរ ចូលទៅរកលោកហើយ ជាស់តឿនថា អាវុសោកបិល កិច្ចបដិបត្តិប្រពៃរបស់ភិក្ខុទាំងឡាយដូចអ្នក ឈ្មោះថាជាអាយុនៃសាសនា ព្រោះដូច្នោះ អ្នកកុំលះកិច្ចបដិបត្តិប្រពៃ ហើយពោលជំទាស់វត្តុដែលជាកប្បិយជាដើមយ៉ាងនោះឡើយ លោកមិនបានអើពើនឹងពាក្យរបស់ព្រះថេរៈ កាលបើដូច្នេះ ព្រះថេរៈក៏ជាស់តឿន ២-៣ ដង ដឹងថាលោកមិនទទួលពាក្យជាស់តឿនថា ភិក្ខុនេះមិនធ្វើតាមពាក្យរបស់អញ ទើបពោលថា អាវុសោ បើដូច្នោះ អ្នកនឹងប្រាកដដោយកម្មរបស់ខ្លួន ដូច្នេះហើយ ចៀសចេញទៅ ។

ចាប់តាំងអំពីនោះ ភិក្ខុទាំងឡាយ ដែលជាអ្នកមានសីលជាទីស្រឡាញ់ពួកជនៃចោះបង់លោកហើយ លោកជាអ្នកមានការប្រព្រឹត្តអាក្រក់ ដែលពួកអ្នកមានការប្រព្រឹត្តអាក្រក់ចោមរោម ថ្ងៃមួយគិតថា អញនឹងសូធ្យបាតិមោក្ខ ទើបកាន់ផ្ងិត ទៅអង្គុយលើធម្មាសនៈ ក្នុងរោងឧបោសថ ហើយសួរថា អាវុសោ បាតិមោក្ខរមែងប្រព្រឹត្តទៅដើម្បីភិក្ខុទាំងឡាយ ដែលប្រជុំគ្នាហើយក្នុងទីនេះឬ ឃើញភិក្ខុទាំងឡាយនៅស្ងៀម ដោយគិតថា ប្រយោជន៍អ្វីដោយពាក្យឆ្ងៃយ ដែលអញឲ្យដល់ភិក្ខុនេះ ទើបពោលថា អាវុសោ ធម៌ក្តី វិន័យក្តី មិនមានប្រយោជន៍អ្វីដោយបាតិមោក្ខ ដែលពួកលោកស្តាប់ ឬមិនស្តាប់ ដូច្នេះហើយ ក៏ក្រោកចាកអាសនៈ ញុំាងសាសនា គឺបរិយត្តិរបស់ព្រះកស្សបទសពលឲ្យសាបសូន្យ ដោយអាការយ៉ាងនេះ សូម្បីព្រះសោធនៈក៏បរិនិព្វានក្នុងថ្ងៃនោះឯង ។ ក្នុងកាលអស់អាយុ កបិលភិក្ខុកើតក្នុងអវីចី-

មហានរក មាតា និងប្អូនស្រីរបស់លោក ដល់នូវទិដ្ឋានុគតិរបស់លោកនោះឯង ជេរបរិភាសភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ហើយ ក៏កើតក្នុងអវីចីមហានរកជួចគ្នា ។

ក្នុងកាលនោះ បុរស ៥០០ នាក់ ធ្វើចោរកម្ម មានការប្លន់ស្រុកជាដើម ជាអ្នកនៅដោយកិរិយារបស់ចោរ ត្រូវពួកមនុស្សក្នុងជនបទ តាមចាប់ហើយ គេចចូលព្រៃ មិនឃើញទីពឹងក្នុងព្រៃនោះ ឃើញភិក្ខុនៅព្រៃជាវត្តមួយរូប ថ្វាយបង្គំហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ជាពឹងរបស់ពួកខ្ញុំផងចុះ ។

ព្រះថេរៈពោលថា ឈ្មោះថា ទីពឹង ដូចគ្នានឹងសីល មិនមានដល់អ្នកទាំងឡាយ ពួកអ្នកទាំងអស់ ចូរសមាទានសីល ៥ ចុះ ចោរទាំងនោះទទួលថា សាធុ ដូច្នេះហើយ សមាទានសីលទាំងឡាយ ។ លំដាប់នោះ ព្រះថេរៈជាសត្តឿនចោរទាំងនោះថា ឥឡូវនេះ ពួកអ្នកជាអ្នកមានសីល ពួកអ្នកមិនគួរកន្ទងនូវសីល សូម្បីព្រោះហេតុនៃជីវិតទៀយ ការប្រទូស្តផ្លូវចិត្តក៏មិនគួរធ្វើ ចោរទាំងនោះទទួលថា សាធុ ហើយ ។

គ្រានោះ អ្នកជនបទទាំងនោះមកដល់ទីនោះហើយ រកមើលក្នុងទីផ្សេងៗ ជួបចោរទាំងនោះហើយ ក៏នាំគ្នាផ្តាច់ជីវិតទាំងអស់ ពួកចោរទាំងនោះធ្វើកាលកិរិយាហើយ កើតក្នុងទេវលោក មេចោរបានជាប្រធាននៃទេវបុត្រ ។

ទេវបុត្រទាំងនោះ អានូលេទៅក្នុងទេវលោកអស់ពុទ្ធន្តរមួយ ដោយអំណាចអនុលោម និងបដិលោមក្នុងពុទ្ធុប្បាទកាលនេះ កើតហើយក្នុងស្រុក

អ្នកប្រមង់ ៥០០ ត្រកូលជិតទ្វារនគរសាវត្ថី ។ ប្រធានទេវបុត្របដិសន្ធិក្នុងផ្ទះរបស់ប្រធានអ្នកប្រមង់ ចំណែកទេវបុត្រក្រៅអំពីនេះ បដិសន្ធិក្នុងផ្ទះអ្នកប្រមង់ដទៃៗ ។ កិច្ចបដិសន្ធិ និងការប្រសូតចាកផ្ទៃមាតានៃជនទាំងនោះមានហើយក្នុងថ្ងៃជាមួយគ្នានោះឯង ដោយប្រការដូច្នេះ ។

ប្រធានអ្នកប្រមង់ ឲ្យមនុស្សដើរស្វែងរកថា ពួកទារកដទៃក្នុងស្រុកនេះកើតហើយក្នុងថ្ងៃនេះមានដែរឬទេ ។ បានឫភាពដែលទារកទាំងនោះកើតហើយ ទើបឲ្យទ្រព្យជាតម្ងៃចិញ្ចឹមដល់អ្នកប្រមង់ទាំងនោះដោយតាំងចិត្តថា ពួកទារកនោះ ជាសម្ងាញ់នឹងកូនរបស់យើង ។ ទារកទាំងនោះ ជាសម្ងាញ់លេងធូលីរួមគ្នា បានជាអ្នកចម្រើនវយដោយលំដាប់ហើយ បណ្តាកុមារទាំងនោះ កូនរបស់ប្រធានអ្នកប្រមង់ បានជាបុគ្គលខត្តមដោយយស និងអំណាច ។

កបិលភិក្ខុធេះក្នុងនរកអស់មួយពុទ្ធន្តរហើយ ក្នុងកាលនោះ មកកើតជាត្រីធំក្នុងស្ទឹងអចិរវតី មានពណ៌ដូចមាស មានមាត់ស្អុយ ដោយវិបាកដែលសេសសល់ ។

ថ្ងៃមួយ សម្ងាញ់ទាំងនោះប្រឹក្សាគ្នាថា យើងនឹងចាប់ត្រី ទើបកាន់យកឧបករណ៍ចាប់សត្វទឹក មានសំណាញ់ជាដើម បង់ទៅក្នុងស្ទឹង ពេលនោះត្រីនោះ បានចូលទៅខាងក្នុងសំណាញ់របស់ជនទាំងនោះ អ្នកប្រមង់ទាំងអស់ បានឃើញត្រីនោះហើយ បន្ទឹសំឡេងអ៊ូអរថា កូនរបស់យើងចាប់ត្រីមុនគេ ចាប់បានត្រីមាសហើយ ពេលនេះ ព្រះរាជានឹងព្រះរាជទានទ្រព្យដល់យើងគ្រប់គ្រាន់ ។ សម្ងាញ់ទាំងនោះ យកត្រីដាក់ទូក លើកទូកឡើងហើយ

ទៅកាន់ព្រះរាជសម្នាក់ ។

កាលព្រះរាជាទ្រង់ទតឃើញត្រីនោះ ត្រាស់ថា នុ៎ះជាអ្វី ពួកមាណពក្រាបទូលថា បពិត្រព្រះអង្គ ត្រី ព្រះរាជាទតឃើញត្រីមានពណ៌ដូចមាស ទ្រង់ត្រិះរិះថា ព្រះសាស្តាទ្រង់ទឹងជ្រាបហេតុដែលត្រីនោះជាមាស ដូច្នេះហើយ ត្រាស់ឲ្យមនុស្សកាន់យកត្រីទៅកាន់សម្នាក់ព្រះសាស្តា កាលមាត់ត្រីនោះហាឡើងប៉ុណ្ណោះ វត្តជេតពនទាំងមូល មានក្លិនស្អុយពន់ពេក ។

ព្រះរាជាទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ហេតុអ្វី ត្រីនេះ មានពណ៌ដូចមាស ហេតុអ្វី ទើបក្លិនស្អុយផ្សាយចេញអំពីមាត់របស់ត្រីនេះ ។ ព្រះមានព្រះភាគត្រាស់ថា ត្រីនេះ ជាភិក្ខុឈ្មោះកបិល ជាពហូសូត មានបរិវារច្រើន ក្នុងធម្មវិនយរបស់ព្រះមានព្រះភាគ ព្រះនាមកស្សប ត្រូវចំណង់ក្នុងលាភគ្រប់សង្កត់ហើយ ដេរបរិភាសពួកភិក្ខុដែលមិនកាន់យកពាក្យសម្តីរបស់ខ្លួន ញុាំងសាសនារបស់ព្រះកស្សបសម្ពុទ្ធឲ្យវិនាសហើយ កើតក្នុងអវីចីដោយកម្មនោះ ឥឡូវនេះ កើតជាត្រីដោយវិបាកដែលសេសសល់ ព្រោះលោកប្រាប់ពុទ្ធវចនៈ ពោលសរសើរគុណរបស់ព្រះសម្ពុទ្ធ អស់កាលយូរទើបមានអត្តភាពពណ៌ដូចមាសដោយផលនៃកម្មនោះ ភិក្ខុនោះ បានដេរបរិ-ភាសភិក្ខុទាំងឡាយ ទើបក្លិនស្អុយចេញអំពីមាត់ដោយផលនៃកម្មនោះ មហាបពិត្រ តថាគតនឹងឲ្យត្រីនេះនិយាយ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ សូមទ្រង់ឲ្យនិយាយចុះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរត្រីថា អ្នកឈ្មោះកបិលឬ ត្រីពោល

ថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឈ្មោះកបិល ព្រះសាស្តាត្រាស់ថា អ្នកមកអំពីទីណា ត្រីពោលថា បពិត្រព្រះអង្គ មកអំពីអវីចីមហានរក ព្រះសាស្តាត្រាស់ថា សោធនៈបងប្រុសច្បងរបស់អ្នកទៅឯណា ត្រីពោលថា បពិត្រព្រះអង្គ បរិនិព្វានហើយ ព្រះសាស្តាត្រាស់ថា នាងសាធនីម្តាយរបស់អ្នកទៅឯណា ត្រីពោលថា បពិត្រព្រះអង្គ កើតក្នុងនរក ព្រះសាស្តាត្រាស់ថា នាងតាបនាបួនស្រីរបស់អ្នកទៅឯណា ត្រីពោលថា បពិត្រព្រះអង្គ កើតក្នុងមហានរក ព្រះសាស្តាសួរថា ឥឡូវនេះ អ្នកនឹងទៅណា ត្រីឈ្មោះកបិលមច្ឆៈក្រាបទូលថា បពិត្រព្រះអង្គ នឹងទៅកាន់អវីចីមហានរក ដូច្នេះហើយ ត្រូវសេចក្តីក្តៅក្រហាយគ្របសង្កត់ហើយ យកក្បាលជ្រកនឹងទូក ធ្វើកាលកិរិយាក្នុងទីនោះឯង កើតក្នុងនរកហើយ មហាជនកើតព្រឺរោម ព្រឺស្បែក ដោយប្រការដូច្នេះ ។

គ្រានោះ ព្រះសាស្តាប្រមើលមើលចិត្តរបស់បរិសទ្យ ដែលប្រជុំគ្នាក្នុងខណៈនោះ ដើម្បីទ្រង់សម្តែងធម៌ឲ្យសមគួរដល់ខណៈនោះ ទើបត្រាស់កបិលសូត្រ ក្នុងសុត្តនិបាតថា អ្នកច្រេជ្រទាំងឡាយ បានពោលការប្រព្រឹត្តធម៌ ១ ការប្រព្រឹត្តព្រហ្មចរិយៈ ១ ទុំៈថាជាកែវដ៏ឧត្តមដូច្នេះជាដើមហើយ បានត្រាស់ព្រះគាថាទាំងនេះថា

មនុជស្ស បមត្តចារិនោ តណ្ហា វឌ្ឍតិ មាលុវា វិយ
សោ បលវតី ហុរាហុរំ ផលមិច្ឆំ វនស្មឹ វានរោ ។
យំ ឯសា សហតី ជម្មី តណ្ហា លោកេ វិសត្តិកា
សោកា តស្ស បវឌ្ឍន្តិ អភិវឌ្ឍំ វីរណំ ។

យោ វេ តំ សហតេ ជម្មឹ តណ្ហំ លោកេ ទុរច្ចយំ
សោកា តស្ហា បបតន្តិ ឧទពិន្ទុ វ បោក្ខរា ។
តំ ហោ វទាមិ ភទ្ទំ ហោ យាវន្តេត្ថ សមាគតា
តណ្ហាយ មូលំ ខណថ ឧសីរត្ថោ វ វីរណំ ។
មា ហោ នឡំ វ សោតោ វ មារោ ភញ្ជិ បុនប្បុនំ ។

តណ្ហាតែងចម្រើនដល់មនុស្ស អ្នកមានការប្រព្រឹត្តដោយសេចក្តីប្រមាទជាប្រក្រតី ដូចវល្លិ៍រុបរីតដើមឈើ ហើយចម្រើនឡើង បុគ្គលនោះ តែងសុះទៅកាន់កពតូច កពធំដូចស្វា កាលប្រាថ្នាផ្លែឈើ លោតទៅក្នុងព្រៃ ដូច្នោះដែរ ។ តណ្ហានុ៎ះ ជាទោសជាតិដ៏លាមក ផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ក្នុងលោក គ្របសង្កត់បុគ្គលណា សេចក្តីសោកស្តាយ តែងចម្រើនឡើងដល់បុគ្គលនោះ ដូចស្មៅវរណ្តាស ដែលត្រូវភ្លៀងធ្លាក់ចុះជញ្ជុំ ហើយពន្លកលូតលាចឡើង ដូច្នោះដែរ ។ ចំណែកជនណា គ្របសង្កត់តណ្ហាដ៏លាមកក្នុងលោក ដែលគេឆ្លងបានដោយកម្រនោះ សេចក្តីសោកស្តាយ តែងធ្លាក់ចេញចាកជននោះឯង ដូចតំណក់ទឹកដែលធ្លាក់ចុះចាកស្លឹកឈូក ដូច្នោះដែរ ។ ព្រោះហេតុនោះ បានជាតថាគតប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយ មានប៉ុន្មានរូប ដែលមកប្រជុំ

ក្នុងទីនេះ សេចក្តីចម្រើនចូរមានដល់អ្នកទាំងឡាយ ទាំងប៉ុណ្ណោះចុះ អ្នកទាំងឡាយ ចូររម្ងើបឫសតណ្ហាចោលចេញ ដូចបុគ្គលត្រូវការដោយស្មៅភ្លាំង គាស់ស្មៅរណ្តាសចោលចេញ ដូច្នោះ មារកុំរុករានអ្នកទាំងឡាយរឿយៗ ដូចខ្សែទឹកកាច់បំបាក់ដើមបបុសដូច្នោះឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បមត្តចារិនោ** *សេចក្តីថា ឈានមិនចម្រើន វិបស្សនា មគ្គ និងផល ក៏មិនចម្រើន ដល់បុគ្គលដែលមានប្រក្រតីប្រព្រឹត្តប្រមាទ ដោយសេចក្តីប្រមាទ មានការបណ្តែតបណ្តាយសតិជាលក្ខណៈ អធិប្បាយថា ដូចពួរជ្រៃរួបរឹតនូវដើមឈើ រមែងចម្រើនដើម្បីសេចក្តីវិនាសនៃដើមឈើនោះ យ៉ាងណា តណ្ហាក៏ដូច្នោះ ឈ្មោះថា ចម្រើនដល់បុគ្គលនោះ ព្រោះអាស្រ័យទ្វារទាំង ៦ កើតឡើងរឿយៗ ។*

បាទព្រះគាថាថា **សោ បលវតី ទុរាវហុំ** *សេចក្តីថា បុគ្គលនោះ គឺ បុគ្គលប្រព្រឹត្តទៅក្នុងគតិនៃតណ្ហារមែងក្តៅ គឺសុះទៅក្នុងកពតូចកពធំ ។ សួរថា បុគ្គលនោះរមែងធ្លែទ្លាទៅដូចអ្វី ឆ្លើយថា ដូចស្វាប្រាថ្នាផ្លែឈើ លោតទៅក្នុងព្រៃដូច្នោះ អធិប្បាយថា ពានរ កាលប្រាថ្នាផ្លែឈើ រមែងលោតទៅក្នុងព្រៃចាប់នូវមែកឈើនោះៗ លែងនូវមែកឈើនោះហើយ ចាប់នូវមែកឈើជាទៃ រមែងមិនដល់នូវភាពជាសត្វ ដែលបុគ្គលគួរពោលបានថា ស្វានោះមិនបាននូវមែក ទើបអង្គុយហើយយ៉ាងណា បុគ្គលដែលប្រព្រឹត្តទៅក្នុងគតិនៃ*

តណ្ហាក៏ដូច្នោះដូចគ្នា សុះសាទៅកាន់កពតូចកពធំ រមែងមិនដល់នូវភាពជាបុគ្គល ដែលបុគ្គលណាម្នាក់គួរពោលបានថា បុគ្គលមិនបានអារម្មណ៍ហើយទើបដល់នូវការមិនប្រព្រឹត្តទៅតាមចំណង់តណ្ហា ។

បទថា **យំ** *ជាដើម សេចក្តីថា តណ្ហាដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ នេះ ឈ្មោះថា លាមក ព្រោះភាពជារបស់អាក្រក់ ដល់នូវការរាប់ថា* **វិសត្តិកា** *ព្រោះភាពដែលតណ្ហានោះ ជាធម្មជាតិបន្សាត់ទៅ គឺជាអ្នកជាប់ជំពាក់ក្នុងអារម្មណ៍ មានរូបជាដើម ដោយភាពជាអាហារលាយដោយថ្នាំពិស ដោយភាពដូចជាផ្កាលាយដោយពិស ដោយភាពដូចជាផ្លែឈើលាយដោយពិស ដោយភាពដូចជាគ្រឿងបរិភោគលាយដោយពិស រមែងគ្របសង្កត់បុគ្គលណា សេចក្តីសោកទាំងឡាយ មានវដ្តៈជាមូល រមែងចម្រើនក្រៃលែង ក្នុងខាងក្នុងរបស់បុគ្គលនោះ ដូចស្បូវរណ្តាសដែលភ្លៀងធ្លាក់រឿយៗ រមែងជុះលូតលាស់ក្នុងព្រៃ ដូច្នោះ ។*

បទថា **ឧរុជ្ជយំ** *ជាដើម សេចក្តីថា បុគ្គលណារមែងសង្កត់ គឺរមែងគ្របសង្កត់តណ្ហានោះ គឺមានប្រការដែលខ្ញុំពោលហើយ ឈ្មោះថា លំបាកដែលបុគ្គលណាឆ្លងបាន ព្រោះជារបស់លំបាកនឹងឈានកន្លង គឺលំបាកលះបាន សេចក្តីសោកទាំងឡាយ មានវដ្តៈជាមូល រមែងធ្លាក់អំពីបុគ្គលនោះ គឺមិនតាំងនៅបាន ដូចតំណក់ទឹកធ្លាក់ទៅលើស្លឹកឈូក គឺលើស្លឹកបទុមមិនជាប់ ដូច្នោះ ។*

ច្រើនបទថា **តំ ហោ វទាមិ** *គឺព្រោះហេតុនោះ តថាគតសូមពោលនឹង*

អ្នកទាំងឡាយ ។

ពីរបទថា **ភទ្ទំ វោ** សេចក្តីថា ចូរសេចក្តីចម្រើនមានដល់អ្នកទាំងឡាយ អធិប្បាយថា អ្នកទាំងឡាយកុំបីដល់នូវសេចក្តីវិនាស ដូចកបិលភិក្ខុនេះ ។

បទថា **មូលំ** ជាដើម សេចក្តីថា ចូរអ្នកទាំងឡាយជីកនូវឫសនៃតណ្ហា ដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ នេះ ដោយញាណដែលសម្បយុត្តដោយអរហត្ត-មគ្ត សួរថា ជីកឫសនៃតណ្ហានោះដូចអ្វី ឆ្លើយថា ដូចបុគ្គលត្រូវការស្ឃូវភ្ជាំង ជីកនូវស្ឃូវរណ្តាសដូច្នោះ អធិប្បាយថា បុរសត្រូវការស្ឃូវភ្ជាំង រមែងជីកស្ឃូវរណ្តាសដោយចបធំ យ៉ាងណា ចូរអ្នកទាំងឡាយជីកនូវឫសនៃតណ្ហានោះចោល ដូច្នោះ ។

ពីរបាទគាថាថា **មា វោ នឡំវ សោតោវ មារោ ភញ្ជិ បុនប្បុនំ** សេចក្តីថា កិលេសមារ មរណមារ និងទេវបុត្តមារ ចូរកុំរុករានអ្នកទាំងឡាយ រឿយៗ ដូចក្រសែទឹកហូរមកដោយកម្ជាំង កាច់បំបាក់នូវដើមបបុសដែលកើតត្រង់មាត់ច្រាំង ដូច្នោះ ។

ក្នុងកាលចប់ទេសនា បុត្ររបស់អ្នកប្រមង់ទាំង ៥០០ ដល់នូវសេចក្តីសង្វេគ ប្រាថ្នាធ្វើនូវទីបំផុតនៃទុក្ខ បួសក្នុងសម្នាក់ព្រះសាស្តា ធ្វើទីបំផុតនៃទុក្ខ ក្នុងកាលមិនយូរឡើយ បានជាអ្នកមានការបរិភោគតែមួយ ដោយធម៌ជាគ្រឿងបរិភោគ គឺអនេញ្ជវិហារធម៌ និងសមាបត្តិធម៌ រួមជាមួយនឹងព្រះសាស្តា ដូច្នេះឯង ។

រឿងកបិលមច្ច: ចប់

រឿង ជ្រកញី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធជ្រកញីស៊ីលាមកមួយក្បាល ត្រាស់ព្រះធម្មទេសនានេះថា **យថាបិ ម្ហូលេ** ជាដើម ។

បានឮថា ថ្ងៃមួយ ព្រះសាស្តាចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ទតឃើញជ្រូកមួយ ទើបទ្រង់ធ្វើការញញឹមឲ្យប្រាកដ កាលព្រះអង្គទ្រង់ញញឹម ព្រះអានន្ទត្ថេរ បានឃើញមណ្ឌលនៃទស្សនោកាសន៍ ដែលចេញអំពីព្រះឱស្ឋ ទើបទូលសួរហេតុនៃការញញឹមថា បពិត្រព្រះអង្គ អ្វីជាហេតុ អ្វីជាបច្ច័យនៃការធ្វើនូវការញញឹមឲ្យប្រាកដ ។

លំដាប់នោះ ព្រះសាស្តាត្រាស់ទីឃព្រះអានន្ទថា អានន្ទ អ្នកឃើញជ្រូកញីនោះដែរឬទេ ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ឃើញ ព្រះសាស្តាត្រាស់ថា ជ្រូកញីនោះបានកើតជាមេមាន់ នៅក្នុងជិតរោងធាន់មួយកន្លែង ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមកកុសន្ធៈ មេមាន់នោះ ស្តាប់សំឡេងប្រកាសធម៌របស់ភិក្ខុ ដែលជាយោគាវចរមួយរូប ស្វាធ្យាយវិបស្សនាកម្មដ្ឋាន ចុតិចាកអត្តភាពនោះហើយ បានកើតក្នុងរាជត្រកូល ជារាជធីតា ព្រះនាមឧព្ភរី ក្នុងកាលតមក ព្រះនាងយាងចូលទៅកាន់ទីសម្រាប់បន្ទោបង់ឧច្ចារៈ ទតឃើញពួកជង្ឃវហើយ ញ៉ាំងបុព្វវាសញ្ញាឲ្យកើតឡើងក្នុងទីនោះ បានបឋមជ្ឈានហើយ ព្រះនាងតាំងនៅក្នុងអត្តភាពនោះ ដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយកើតក្នុងព្រហ្មលោក កាលព្រះនាងចុតិអំពីអត្តភាពនោះហើយ ច្រឡូក

ច្រឡំដោយអំណាចគតិ ទើបកើតក្នុងកំណើតជ្រូកក្នុងឥឡូវនេះ ។ តថាគត ឃើញហេតុនេះ ទើបបានធ្វើការញញឹមឲ្យប្រាកដ ។

ភិក្ខុទាំងឡាយ មានអានន្ទត្ថេរជាប្រធាន ស្តាប់រឿងនោះហើយ ដល់នូវសេចក្តីសង្វេគ ។

ព្រះសាស្តា ទ្រង់ញុំាងសេចក្តីសង្វេគ ឲ្យកើតដល់ភិក្ខុទាំងនោះហើយ កាលទ្រង់ប្រកាសទោសនៃវាគតណ្ហា ប្រថាប់ឈរក្នុងរវាងផ្លូវនោះ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ
ឯវម្បិ តណ្ហានុសយេ អព្ភហតេ និព្វត្តតី ទុក្ខមិទំ បុនប្បុនំ ។
យស្ស ឆត្តឹសតីសោតា មនាបស្សវនា ភុសា
មហា វហន្តិ ទុទ្ទិដ្ឋឹ សង្កប្បា រាគនិស្សិតា ។
សវន្តិ សព្ពធី សោតា លតា ឧព្ភិជ្ជ តិដ្ឋតិ
តញ្ច ទិស្វា លតំ ជាតំ មូលំ បញ្ញាយ និន្ទថ ។
សរិតានិ សិនេហិតានិ ច សោមនស្សានិ ភវន្តិ ជន្តុនោ
តេ សាតសិតា សុខេសិនោ តេ វេ ជាតិជរូបគា នរា ។
តសិណាយ បុរក្ខតា បជា បរិសប្បន្តិ សសោវ ពាធិតោ
សញ្ញោជនសង្គសត្តា ទុក្ខមុបេន្តិ បុនប្បុនំ ចិរាយ ។
តសិណាយ បុរក្ខតា បជា បរិសប្បន្តិ សសោវ ពាធិតោ
តស្មា តសិណំ វិនោទយេ ភិក្ខុ អាកង្ខី វិរាគមត្តនោ ។

កាលបើឫសឈើ មិនមានសេចក្តីអន្តរាយ នៅមាំមួនទេ ដើម

ឈើទុកជាកាត់ចោលហើយ ក៏តែងដុះឡើងទៀតបាន មានឧបមាដូចម្តេចមិញ កាលបើតណ្ហានុសយ បុគ្គលកម្ចាត់មិនទាន់បានហើយ ទុក្ខ (មានជាតិទុក្ខជាដើម) នេះ ក៏តែងកើតរឿយៗ មានឧបមេយ្យដូច្នោះឯង ។

ខ្សែតណ្ហា ៣៦ ជាធម្មជាតិហូរទៅក្នុងអារម្មណ៍ជាទីគាប់ចិត្ត ជាធម្មជាតិក្តៀវក្លា មានជល់បុគ្គលណា តម្រិះទាំងឡាយដ៏ធំ ដែលអាស្រ័យនូវរាគៈ តែងទាំនូវទិដ្ឋិអាក្រក់របស់បុគ្គលនោះ ។ ខ្សែតណ្ហាទាំងឡាយ តែងហូរទៅក្នុងអារម្មណ៍ទាំងពួង ដូចជា វល្លិ៍ដែលបែកខ្នែងឡើងតាំងនៅដូច្នោះ បើអ្នកទាំងឡាយ ឃើញតណ្ហាដូចជាវល្លិ៍នោះកើតឡើងហើយ ចូរកាត់ឫសចោលចេញដោយកាំបិត គឺបញ្ញា ។ សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្តីស្រឡាញ់ផង រមែងមានជល់សត្វ ពួកសត្វនោះជា អ្នកអាស្រ័យនូវសេចក្តីរីករាយ ជាអ្នកស្វែងរកសេចក្តីសុខ នរជនទាំងឡាយនោះឯង តែងឈមទៅរកជាតិ និងជរា ។ ពួកសត្វដែលតណ្ហា ជាទីញុំាងសត្វឲ្យតក់ស្លុតក្រុងទុកហើយ តែងរន្ធត់ ដូចទន្សាយដែលព្រានទាក់បានហើយ ដូច្នោះ ពួកសត្វដែលជាប់ក្នុងសំយោជនៈ និងសង្គធម៌ (ធម៌ជាគ្រឿងជំពាក់) តែងជល់នូវសេចក្តីទុក្ខរឿយៗ អស់កាលជាអង្វែង ពួកសត្វដែលតណ្ហាជាទីញុំាងសត្វ

ឲ្យតក់ស្លុតក្រែងទុកហើយ តែងរន្ធត់ ដូចទន្សាយ ដែលនាយព្រានទាក់បានហើយដូច្នោះ ព្រោះហេតុនោះ ភិក្ខុកាលប្រាថ្នាធម៌ជាគ្រឿងប្រាសចាកវាគៈដើម្បីខ្លួន គប្បីបន្ទោបង់តណ្ហា ដែលជាគ្រឿងតក់ស្លុតចោលចេញ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ម្ហលេ** *ជាដើម សេចក្តីថា កាលឫសទាំង ៥ របស់ដើមឈើណា ដែលចាកទៅក្នុងទិសទាំង ៤ និងចាកចុះទៅក្រោម ឈ្មោះថា មិនមានអន្តរាយ ព្រោះអន្តរាយណាមួយ បណ្តាអន្តរាយ មានការកាប់ និងការចោះ ឈ្មោះថា មាំទាំ ព្រោះដល់នូវភាពជារបស់មាំទាំ ដើមឈើនោះ សូម្បីបុគ្គលជកហើយទៅខាងលើ រមែងជុះឡើងបានទៀតនោះឯង ដោយអំណាចមែកធំតូច យ៉ាងណា ទុក្ខនេះ មានជាតិទុក្ខជាដើម កាលអនុស័យមាន ការជេកត្រាំនៃតណ្ហាដែលប្រព្រឹត្តទៅតាមទ្វារ ៦ ដែលអរហត្តមគ្គញាណមិនទាន់កម្ចាត់ គឺមិនទាន់កាត់ផ្តាច់ហើយ រមែងកើតរឿយៗទៅក្នុងកពនោះៗ បាន ដូច្នោះឯង ។*

បទថា **យស្ស** *ជាដើម សេចក្តីថា តណ្ហាប្រកបដោយក្រសែ ៣៦ ដោយអំណាចនៃតណ្ហាវិចរិតទាំងនេះ គឺតណ្ហាវិចរិត អាស្រ័យអាយតនៈខាងក្នុង ១៨ តណ្ហាវិចរិតអាស្រ័យអាយតនៈខាងក្រៅ ១៨ ដោយប្រការដូច្នេះ ឈ្មោះថា ហូរទៅក្នុងអារម្មណ៍ដែលជាប់ចិត្ត ព្រោះអត្ថវិគ្គហៈថា រមែងហូរទៅ គឺប្រព្រឹត្តទៅក្នុងអារម្មណ៍ មានរូបជាដើម ជាធម្មជាតិក្លៀវក្លា គឺមានកម្លាំង តែង*

មានដល់បុគ្គលណា ការត្រិះរិះទាំងឡាយ ឈ្មោះថា ជាធម្មជាតិធំ ព្រោះភាពជារបស់ធំ ដោយកើតឡើងរឿយៗ មិនអាស្រ័យឈាន ឬវិបស្សនា អាស្រ័យរាគៈ រមែងនាំបុគ្គលនោះ ដែលឈ្មោះថាមានទិដ្ឋិអាក្រក់ ព្រោះភាពជាបុគ្គលមានញាណវិបត្តិ ។

បាទព្រះគាថាថា **សវន្តិ សព្វធី សោតា** *សេចក្តីថា ក្រសែតណ្ហាទាំងនេះ ឈ្មោះថា រមែងហូរទៅក្នុងអារម្មណ៍ទាំងពួង ព្រោះហូរទៅក្នុងអារម្មណ៍ទាំងពួង មានរូបជាដើម ដោយអំណាចនៃចក្ខុទ្វារជាដើម ឬព្រោះតណ្ហាទាំងអស់ គឺរូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ហូរទៅក្នុងភពទាំងពួង ។*

បទថា **លតា** *សេចក្តីថា តណ្ហា ឈ្មោះថា* **លតា** *ព្រោះអត្ថវិគ្គហៈថា ដូចជាវល្លិ៍ ព្រោះអត្ថថាជាគ្រឿងរួបរឹត និងដោយអត្ថថា ជាគ្រឿងចង ។*

ពីរបទថា **ឧព្ភិជ្ជ តិដ្ឋតិ** *សេចក្តីថា តណ្ហាដូចវល្លិ៍កើតឡើងដោយទ្វារ ៦ ហើយ រមែងតាំងនៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ។*

ពីរបទថា **តញ្ច ទិស្វា** *សេចក្តីថា បើអ្នកឃើញតណ្ហាដូចវល្លិ៍នោះ ដោយអំណាចដែលតណ្ហានោះកើតហើយថា តណ្ហានេះ កាលនឹងកើត រមែងកើតឡើងក្នុងបិយរូប និងសាតរូបនេះ ។*

បទថា **បញ្ញាយ** *សេចក្តីថា អ្នកទាំងឡាយ ចូរកាត់ត្រង់ឫសដោយមគ្គប្បញ្ញា ដូចបុគ្គលកាត់នូវវល្លិ៍ដែលកើតក្នុងព្រៃ ដោយកាំបិត ដូច្នោះ ។*

បទថា **សរិតានិ** *គឺផ្សាយទៅ បានដល់ ជ្រួតជ្រាបទៅ ។*

បទថា **សិនេហិតានិ ច** *សេចក្តីថា និងប្រឡាក់ដោយតណ្ហា ដូចជាវដោយអំណាចតណ្ហាសិនេហៈ ដែលប្រព្រឹត្តទៅក្នុងបវត្តិ មានចីវរជាដើម អធិប្បាយថា ដែលជាវ គឺតណ្ហាបូកលាបហើយ ។*

បទថា **សោមនស្សានិ** *សេចក្តីថា សោមនស្សទាំងឡាយបែបនោះ រមែងមានដល់សត្វ ដែលប្រព្រឹត្តទៅក្នុងអំណាចតណ្ហា ។*

ពីរបទថា **តេ សាតសិតា** *សេចក្តីថា បុគ្គលទាំងនោះ គឺដែលប្រព្រឹត្តទៅក្នុងអំណាចនៃតណ្ហា ដែលជាបុគ្គលអាស្រ័យសេចក្តីសុខ គឺអាស្រ័យសេចក្តីសុខនោះឯង ទើបជាអ្នកស្វែងរកសេចក្តីសុខ គឺជាអ្នកស្វែងរកសេចក្តីសុខ ។*

បទថា **តេ វ** *ជាដើម សេចក្តីថា ពួកនរៈបែបនេះ រមែងចូលដល់ការកើត ការចាស់ ការឈឺ និងការស្លាប់ពិត ដូច្នោះ ទើបជាបុគ្គលឈ្មោះថាចូលដល់ជាតិ និងជរា ។*

បទថា **បជា** *ជាដើម សេចក្តីថា សត្វទាំងនេះ ជាបុគ្គលដែលតណ្ហាដែលដល់នូវការរាប់ថា* **តសិណា** *គឺការបម្រះនៀល ព្រោះធ្វើនូវការតក់ស្លុតចោមរោម គឺចោមរោមហើយ ។*

បទថា **ពាធិតោ** *សេចក្តីថា សត្វទាំងនោះ រមែងរន្ធត់ គឺតក់ស្លុតដូចទន្សាយដែលជាប់អន្ទាក់ព្រានក្នុងព្រៃ ដូច្នោះ ។*

បទថា **សញ្ញោជនសង្គសត្តា** *សេចក្តីថា សត្វទាំងឡាយជាបុគ្គលដែលសំយោជនៈ ១០ យ៉ាង និងកិលេសជាគ្រឿងចង គឺរាគៈជាដើមចងហើយ ឬជាបុគ្គលជាប់ហើយក្នុងសំយោជនៈជាដើមនោះ ។*

បទថា **ចិរាយ** *សេចក្តីថា សត្វទាំងឡាយរមែងចូលដល់នូវទុក្ខ មានជាតិជាដើមរឿយៗ ទៅ អស់កាលយូរ គឺអស់កាលវែង ។*

បទថា **តស្មា** *ជាដើម សេចក្តីថា ព្រោះសត្វទាំងឡាយដែលតណ្ហាធ្វើនូវសេចក្តីតក់ស្លុតចោមរោម គឺរួបរឹតហើយ ដូច្នោះ កាលភិក្ខុប្រាថ្នានូវធម៌ដែលអស់នូវតម្រេក គឺព្រះនិព្វាន ដែលជាទីទៅប្រាសចាកកិលេស មានរាគៈជាដើមដើម្បីខ្លួន គប្បីបន្ទោបង់ គឺគប្បីបណ្តេញចេញនូវតណ្ហា ដែលធ្វើនូវការតក់ស្លុតនោះ ដោយអំណាចអរហត្តមគ្គនោះឯង ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

មេជ្រូកនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងរាជត្រកូល ក្នុងសុវណ្ណភូមិ ចុតិចាកអត្តភាពនោះហើយ កើតក្នុងក្រុងពារាណសីដូច្នោះឯង ។ ចុតិចាកអត្តភាពនោះហើយ កើតក្នុងផ្ទះអ្នកជំនួញសេះ ត្រង់កំពង់សុប្បារកៈ ចុតិចាកអត្តភាពនោះហើយ កើតក្នុងផ្ទះរបស់នាយទូក ត្រង់កំពង់គាវិរៈ ចុតិចាកអត្តភាពនោះហើយ កើតក្នុងផ្ទះរបស់ឥស្សរជនក្នុងក្រុងអនុរាធបុរី ចុតិចាកអត្តភាពនោះហើយ កើតជាធីតាក្នុងផ្ទះរបស់កុដុម្ពិកៈឈ្មោះសុមនៈ ក្នុងភេក្កន្តគ្រាម ក្នុងទិសទក្សិណរបស់ក្រុងនោះហើយ មានឈ្មោះថាសុមនា តាមឈ្មោះកុដុម្ពិកៈនោះ ។ បន្ទាប់មកឪពុករបស់នាង កាលជនទាំងឡាយលះបង់ស្រុកនោះហើយ បានទៅកាន់ដែនទីឃវាបិ ក្នុងស្រុកឈ្មោះមហាមុនីគ្រាម ។ អមាត្យរបស់ព្រះបាទទុដ្ឋគាមិនី ឈ្មោះលកុណ្ឌកអតិម្ពរៈ ទៅត្រង់ស្រុកនោះ

ដោយការណីយកិច្ចឯណានីមួយ ឃើញនាងហើយ ធ្វើការមង្គលយ៉ាងធំ នាំនាងទៅកាន់ស្រុកមហាបុណ្ណគ្រាមហើយ ។ គ្រានោះ ព្រះមហាអតុលត្ថេរ ជាអ្នកនៅក្នុងវិហារឈ្មោះ កោដិបព្វតៈ ត្រាច់ទៅក្នុងស្រុកនោះដើម្បីបិណ្ឌបាត ឈរត្រង់ទ្វារផ្ទះរបស់នាង ឃើញនាងហើយ ទើបពោលនឹងកិក្ខុទាំងឡាយថា អាវុសោទាំងឡាយ ជ្រូកញីដល់នូវភាពជាកវិយារបស់អមាត្យ ឈ្មោះលកុណ្ឌកអតិម្ពរៈហើយ ឱ ! គួរអស្ចារ្យហ្ន៎ នាងស្តាប់ពាក្យនោះហើយ រឭកជាតិបាន ត្រឡប់បាននូវញាណ ដែលជាហេតុរឭកជាតិក្នុងខណៈនោះឯង នាងមានសេចក្តីសង្វេគកើតឡើងហើយ អង្វរស្វាមីបួសក្នុងសម្នាក់ព្រះថេរី ដែលប្រកបដោយកម្លាំង ៥ ដោយឥស្សរិយយសដ៏ធំ បានស្តាប់កថាពណ៌នាមហាសតិបដ្ឋានសូត្រ ក្នុងតិស្សមហាវិហារហើយ តាំងនៅក្នុងសោតាបត្តិផល ។ ក្រោយមក កាលព្រះបាទទុដ្ឋគាមិនីទ្រង់បង្ក្រាបទមិឡបានហើយ ព្រះនាងម្ចាស់សុមនាថេរីបានទៅកាន់ស្រុកកេកុន្តគ្រាម ដែលជាលំនៅរបស់មាតាបិតានោះឯង នៅក្នុងស្រុកនោះ ស្តាប់អាសីវិសូបមសូត្រក្នុងកាឡកមហាវិហារ សម្រេចអរហត្តហើយ ។

ក្នុងថ្ងៃបរិនិព្វាន នាងត្រូវពួកកិក្ខុនីសាកសួរហើយ បាននិទានប្រវត្តិទាំងអស់នេះយ៉ាងនេះឯងដល់កិក្ខុនីសង្ឃ ហើយសន្ទនាជាមួយព្រះមហាតិស្សត្ថេរ ដែលពោលបទនៃធម៌ ដែលមានប្រក្រតីនៅក្នុងមណ្ឌលារាម ក្នុងកណ្តាលកិក្ខុនីសង្ឃដែលប្រជុំគ្នាហើយពោលថា ក្នុងកាលមុនខ្ញុំចុតិអំពីកំណើតមនុស្សហើយ កើតជាមេមាន់ ដល់នូវការកាត់ក្បាល អំពីសម្នាក់របស់ស្តាំងក្នុងអត្តភាពនោះ

ហើយ ទៅកើតក្នុងក្រុងរាជគ្រឹះ ហើយបួសក្នុងសម្នាក់បរិព្វាជិកាទាំងឡាយ ហើយកើតក្នុងបឋមជ្ឈានភូមិ ចុតិចាកអត្តភាពនោះហើយ កើតក្នុងត្រកូលសេដ្ឋី ក្នុងកាលមិនយូរប៉ុន្មាន ចុតិហើយ ទៅកើតក្នុងកំណើតជ្រូក ចុតិអំពីអត្តភាពនោះហើយ ទៅកាន់សុវណ្ណភូមិ ចុតិចាកអត្តភាពនោះហើយ ទៅកាន់ក្រុងពារាណសី ចុតិចាកអត្តភាពនោះហើយ ទៅកាន់កំពង់ឈ្នោះសុប្បារកៈ ចុតិចាកអត្តភាពនោះហើយ ទៅកាន់កំពង់គាវីៈ ចុតិចាកអត្តភាពនោះហើយ ទៅកាន់ក្រុងអនុរាធបុរី ចុតិចាកអត្តភាពនោះហើយ ទៅកាន់ស្រុកកេកុន្តគ្រាម ខ្ញុំបានដល់អត្តភាព ១៣ ដែលខ្ពស់ និងទាបយ៉ាងនេះ ដោយប្រការដូច្នេះ ឥឡូវនេះ កើតក្នុងអត្តភាពឧក្រិដ្ឋហើយ សូមអ្នកទាំងឡាយញុំាងធម៌ជាកុលសទាំងឡាយ ឲ្យដល់ព្រម ដោយសេចក្តីមិនប្រមាទចុះ ដូច្នេះហើយ ញុំាងបរិស័ទ ៤ ឲ្យសង្វេគហើយ បរិនិព្វាន ដូច្នេះ ៗ

រឿងជ្រូកញី ចប់

រឿង វិញ្ញន្តកភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធវិញ្ញន្តកភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **យោ និព្ធនដ្ឋោ** ជាដើម ។

បានញ្ចថា ភិក្ខុមួយរូប ជាសន្ធិវិហារិករបស់ព្រះមហាកស្សបត្ថេរ ញ្ចុាំងឈាន ៤ ឲ្យកើតឡើងហើយ យើញរូបារម្មណ៍ជាវិសភាគៈក្នុងផ្ទះរបស់ជាងមាស ដែលជាអំរបស់ខ្ជូន មានចិត្តប្រតិព័ទ្ធក្នុងរូបារម្មណ៍នោះ សឹកហើយ ។

បន្ទាប់មក ព្រោះភាពជាអ្នកខ្ជិលច្រអូស ទើបពួកមនុស្សដេញបុគ្គលនោះ ដែលមិនប្រាថ្នានឹងធ្វើការងារចេញអំពីផ្ទះ គាត់ត្រាច់ចិញ្ចឹមជីវិត ដោយធ្វើចោរកម្ម ព្រោះសេពគប់ជាមួយមិត្តអាក្រក់ ។

ថ្ងៃមួយ ពួករាជបុរសចាប់គាត់បានហើយ ចងស្ជាបសេកយ៉ាងណែនវាយដោយផ្តៅក្នុងផ្ជូវបែកជា ៤ ហើយនាំទៅកាន់ត្រឡែងកែង ។

ព្រះថេរៈចូលទៅបិណ្ឌបាត យើញបុរសនោះត្រូវពួករាជបុរសនាំបុរសនោះទៅតាមទ្វារទិសខាងត្បូង ទើបសូមឲ្យពួករាជបុរសបន្ធូរចំណងពោលថាចូរអ្នករញកដល់កម្មដ្ឋាន ដែលអ្នកធ្ជាប់សន្សំហើយក្នុងកាលមុនចុះ គាត់មានសតិឡើងព្រោះឱវាទនោះហើយ ញ្ចុាំងចតុត្ថជ្ឈានឲ្យកើតឡើងជាថ្មី ។

លំដាប់នោះ ពួករាជបុរសនាំចូលទៅកាន់ត្រឡែងកែង ឲ្យបុរសនោះដេកផ្ទារលើលំពែង ដោយគិតថា ពួកយើងនឹងសម្ជាប់ បុរសនោះមិនខ្ជាច មិនតក់ស្ជុតឡើយ ។

លំដាប់នោះ មនុស្សទាំងឡាយដែលឈរក្នុងទិសាភាគៈនោះៗ សូម្បី

ផាគ្រឿងប្រហារទាំងឡាយ មានជាវ លំពែង និងច្ឈូកជាដើមដល់បុរសនោះ យើញគាត់មិនតក់ស្ទុតពោលថា អ្នកដ៏ចម្រើន ចូរពួកអ្នកមើលបុរសនោះចុះ គេមិនញាប់ញ័រ មិនតក់ស្ទុតក្នុងកណ្តាលនៃបុរសដែលមានអាវុធក្នុងដៃសូម្បីច្រើនរយនាក់ ឧ ! គួរអស្ចារ្យពិត ដូច្នេះហើយ កើតនូវការអស្ចារ្យ និងចម្លែកក្នុងចិត្ត ហើយក៏បន្ទឺសំឡេងតគ្នា ហើយក្រាបទូលរឿយនោះដល់ព្រះរាជា ។

ព្រះរាជាស្តាប់ហេតុនោះហើយត្រាស់ថា ចូរពួកអ្នកដោះលែងបុរសនេះចុះ ដូច្នេះហើយ យាងទៅកាន់សម្នាក់ព្រះសាស្តាក្រាបទូលសេចក្តីនោះហើយ ព្រះសាស្តា ទ្រង់បញ្ចេញព្រះឧភាសន៍ទៅហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យោ និព្វនជ្ជោ វនាធិមុត្តោ វនមុត្តោ វនមេវ ធាវតិ
តំ បុគ្គលមេវ បស្សថ មុត្តោ ពន្ធនមេវ ធាវតិ ។

បុគ្គលណា មិនមានអាល័យក្នុងគិហិភាព ដូចដើមឈើតាំងនៅក្នុងព្រៃ មានចិត្តចុះស៊ីប់ក្នុងព្រៃ គឺតបធម៌ ជាអ្នករួចស្រឡះចាកព្រៃ គឺតណ្ហាហើយ ស្ទុះទៅរកព្រៃ គឺតណ្ហាវិញ ចូរអ្នកទាំងឡាយ មើលបុគ្គលនោះឯង បុគ្គលនោះ រួចចាកចំណង គឺយរាវាសហើយ ស្ទុះទៅរកចំណង គឺយរាវាសវិញ ។

សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា បុគ្គលណា ឈ្មោះថា មានអាលយ័ដូចពួកឈើទាំងឡាយ ដែលតាំងនៅក្នុងព្រៃចេញហើយ ព្រោះកាពដែលខ្ជនលះនូវពួកឈើទាំងឡាយដែលតាំងនៅក្នុងព្រៃ ពោល គឺអាលយ័ក្នុងកាពជាគ្រហស្ថ ហើយបួសបង្អោនទៅក្នុងព្រៃ គឺតបៈ ពោល គឺវិហារធម៌ ជាអ្នកផុតចាកព្រៃ គឺតណ្ហា ដែលចាត់ជាគ្រឿងចង គឺការគ្រប់គ្រងផ្ទះហើយ សុះទៅរកព្រៃ គឺតណ្ហានោះឯង ដែលជាគ្រឿងចង គឺការគ្រប់គ្រងផ្ទះនោះទៀត ចូរអ្នកទាំង-ឡាយមើលបុគ្គលនោះយ៉ាងនោះ បុគ្គលនោះផុតចាកចំណង គឺការគ្រប់គ្រងផ្ទះហើយ នៅសុះទៅកាន់ចំណង គឺការគ្រប់គ្រងផ្ទះទៀតនោះឯង ។

បុរសនោះ អង្គុយស្តាប់ធម៌ទេសនានេះ នៅលើលំពែងក្នុងរវាងពួករាជបុរសនោះឯង ផ្តើមតាំងនូវការកើតឡើង និងការអស់ទៅ សូន្យទៅ លើកចិត្តឡើងកាន់ត្រៃលក្ខណ៍ ពិចារណាសង្ខារទាំងឡាយ សម្រេចសោតា-បត្តិផលហើយ សោយសុខដែលកើតអំពីសមាបត្តិ ហោះទៅកាន់អាកាសមកកាន់សម្នាក់ព្រះសាស្តាថ្វាយបង្គំហើយបួស បានសម្រេចអរហត្ត ក្នុងកណ្តាលបរិស័ទ មួយអន្ទើដោយព្រះរាជានោះឯង ដូច្នេះ ៗ

រឿងវិព្ភន្តកភិក្ខុ ចប់

រឿង ពន្ធនាគារ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពន្ធនាគារ ត្រាស់ព្រះធម្មទេសនានេះថា **ន តំ ទឌ្ឍំ** ជាដើម ។

បានឮថា ក្នុងសម័យមួយ ពួករាជបុរសនាំពួកចោរដែលកាត់ទី-ត ប្លន់ស្តាត់ផ្លូវ និងសម្លាប់មនុស្សជាច្រើន ទូលស្តីដល់ព្រះបាទកោសលហើយ ។ ព្រះរាជាត្រាស់ឲ្យចងចោរទាំងនោះ ដោយគ្រឿងចង គឺឃ្នង គ្រឿងចង គឺខ្សែ គ្រឿងចង គឺច្រវាក់ជើងទាំងឡាយ ។ ពួកភិក្ខុអ្នកជនបទមានប្រមាណ ៣០ រូប ប្រាថ្នានឹងគាល់ព្រះសាស្តា មកថ្វាយបង្គំហើយ ក្នុងថ្ងៃស្អែកឡើងត្រាច់ទៅក្នុងក្រុងសាវត្ថីដើម្បីបិណ្ឌបាត ទៅជល់គុក ឃើញចោរទាំងនោះត្រឡប់អំពីបិណ្ឌបាតហើយ ចូលទៅគាល់ព្រះតថាគតក្នុងពេលល្ងាច ក្រាបទូលសួរថា បពិត្រព្រះអង្គ ថ្ងៃនេះ ពួកខ្ញុំព្រះអង្គត្រាច់បិណ្ឌបាត ឃើញចោរជាច្រើនក្នុងគុក ត្រូវចងដោយចំណង មានឃ្នងជាដើម សោយទុក្ខច្រើន ។ ពួកចោរមិនអាចកាត់ចំណងទាំងនោះគេចទៅបាន បពិត្រព្រះអង្គ ឈ្មោះថាចំណងប្រកេទដទៃ ដែលមាំទាំជាងចំណងទាំងនោះ មានឬហ្ន៎ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចំណងនោះមិនឈ្មោះថាជាចំណងឡើយ ឯគ្រឿងចង គឺកិលេស ពោល គឺតណ្ហា ក្នុងសវិញ្ញាណក-ទ្រព្យ និងអវិញ្ញាណកទ្រព្យទាំងឡាយ មានទ្រព្យ គឺស្រូវ កូន ប្រពន្ធជាដើម ជាគ្រឿងចងដែលមាំទាំជាងគ្រឿងចង គឺឃ្នងជាដើមទាំងនោះមួយរយដង មួយពាន់ដង មួយសែនដង តែបុរាណបណ្ឌិតទាំងឡាយ កាត់គ្រឿងចងនោះ

ដែលធំៗ កាត់បានដោយលំបាក ដោយប្រការដូច្នេះហើយ ចូលកាន់ព្រៃ ហិមពាន្ត បួស ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វកើតហើយ ក្នុងត្រកូលគហបតីក្រីក្រមួយ កាលព្រះពោធិសត្វចម្រើនវ័យហើយ បិតាបានធ្វើកាលកិរិយាហើយ ព្រះពោធិសត្វធ្វើការស៊ីឈ្នួលចិញ្ចឹមមាតា ។ បន្ទាប់មក មាតាធ្វើនាងកុលធីតាម្នាក់ទុកក្នុងផ្ទះ ដើម្បីព្រះពោធិសត្វនោះ ដែលមិនប្រាថ្នាដោយកិរិយា ក្នុងកាលបន្តមក មាតាធ្វើកាល-កិរិយាហើយ ។ ចំណែកកិរិយារបស់ព្រះពោធិសត្វនោះ មានទម្ងន់ហើយ ។ ព្រះពោធិសត្វមិនជ្រាបថាគកិតាំងឡើងឡើយ ទើបពោលថា នែនាង ចូរនាងធ្វើការស៊ីឈ្នួលចិញ្ចឹមជីវិតចុះ ខ្ញុំនឹងបួស ។ កិរិយាពោលថា នែអ្នក គកិកើតឡើងដល់ខ្ញុំមិនមែនឬ ចាំខ្ញុំប្រសូតហើយ អ្នកឃើញទារកហើយសឹមបួស ព្រះពោធិសត្វទទួលថា សាធុ ក្នុងកាលនាងប្រសូតហើយ ទើបលាថា នែនាង នាងប្រសូតបុត្រដោយសួស្តីហើយ ឥឡូវនេះខ្ញុំនឹងបួស ពេលនោះនាងពោលនឹងព្រះពោធិសត្វថា សូមអ្នកបង្អង់ចាំសិន ទម្រាំកូនតូចរបស់អ្នកផ្តាច់ដោះហើយក៏មានទម្ងន់ទៀត ។

ព្រះពោធិសត្វត្រិះរិះថា អញមិនអាចឲ្យស្រីនេះយល់ព្រមបាន អញនឹងមិនប្រាប់ដល់នាង ទើបគេចទៅបួសមិនប្រាប់ដល់កិរិយាឡើយ ក្រោកឡើងក្នុងពេលរាត្រី គេចទៅហើយ ។

គ្រានោះ អ្នករក្សាព្រះនគរចាប់ព្រះពោធិសត្វហើយ ព្រះពោធិសត្វ

ពោលថា នែអ្នក ខ្ញុំឈ្មោះថាជាអ្នកចិញ្ចឹមមាតា សូមអ្នកទាំងឡាយលែងខ្ញុំចុះ ។ ពួករាជបុរសលែងខ្ជូនហើយ ស្នាក់នៅក្នុងទីមួយកន្លែង ហើយចូលទៅកាន់ព្រៃហិមពាន្ត បួសជាឥសី ញ្ញុាំងអភិញ្ញា និងសមាបត្តិឲ្យកើតហើយ ជាអ្នកលេងឈាន ។ លោកនៅក្នុងទីនោះឯងបន្ទឺឧទានថា ចំណង គឺបុត្រ និងភរិយា ចំណង គឺកិលេស ដែលបុគ្គលកាត់បានដោយលំបាកបែបនោះ ខ្ញុំកាត់ផ្តាច់បានហើយ ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ កាលទ្រង់ប្រកាសឧទានដែលព្រះពោធិសត្វនោះបន្ទឺហើយ បានត្រាស់ព្រះគាថាទាំងនេះថា

ន តំ ឧឡ្ហំ ពន្ធនមាហុ ធីរា យទាយសំ ទារុជំ បព្វជញ្ច ។
សារត្តរត្តា មណិកុណ្ឌលេសុ បុត្តេសុ ទារេសុ ច យា អបេក្ខា
ឯតំ ឧឡ្ហំ ពន្ធនមាហុ ធីរា ឱហារិនំ សិថិលំ ទុប្បមុញ្ចំ
ឯតំបិ ឆេត្វាន បរិព្វជន្តិ អនបេក្ខិនោ កាមសុខំ បហាយ ។

ចំណងណា ដែលកើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅយាប្ងងក្តី អ្នកប្រាជ្ញមិនហៅចំណងនោះ ថាជាចំណងមាំមួនឡើយ ។ ពួកជនណា ត្រេកអរក្រៃពេកក្នុងកែវមណី និងកុណ្ឌលទាំងឡាយក្តី សេចក្តីអាឡោះអាល័យ កូន និងប្រពន្ធទាំងឡាយក្តី អ្នកប្រាជ្ញទាំង-ឡាយហៅសេចក្តីត្រេកអរ និងសេចក្តីអាឡោះអាល័យនោះថា ជាចំណងមាំមួន ជាចំណងនាំចុះ (ទាញសត្វទម្លាក់ទៅក្នុងអបាយ) ជាចំណងធូរទេ ប៉ុន្តែ សត្វស្រាយបានដោយកម្រ អ្នកប្រាជ្ញទាំង-

ឡាយកាត់ចំណងនោះចេញ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់កាមសុខហើយ ចេញបួស ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ធីរា** ជាដើម សេចក្តីថា បុរសដែលជាបណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម មិនពោលគ្រឿងចងដែលកើតអំពីដែកពោល គឺច្រវាក់ជើង ឈ្មោះថា កើតអំពីដែក ដែលកើតអំពីឈើ ពោលគឺឃ្នាងខ្នោះ និងចំណង គឺខ្សែ ដែលគេយកស្មៅយាប្ជង ឬវត្ថុដទៃ មានព្រាលជាដើម រវញធ្វើជាខ្សែថា ជារបស់មាំទាំឡើយ ព្រោះភាពជាចំណងដែលបុគ្គលអាចកាត់ដោយសស្ត្រាទាំងឡាយ មានជាវជាដើមបាន ។

បទថា **សារត្តរត្តា** បានដល់ ជាអ្នកត្រេកត្រអាលហើយ អធិប្បាយថា ជាអ្នកត្រេកអរដោយរាគ:ខ្លាំងក្លា ។

បទថា **មណិកុណ្ឌលេសុ** គឺក្នុងកែវមណី និងកុណ្ឌលទាំងឡាយ ម្យ៉ាងទៀត ក្នុងកុណ្ឌលទាំងឡាយដែលវិចិត្រដោយកែវមណី ។

បទថា **ធណ្ឌំ** សេចក្តីថា តម្រេកណារបស់ជនទាំងឡាយដែលត្រេកអរក្រៃលែងក្នុងកែវមណី និងកុណ្ឌលទាំងឡាយនោះឯង និងការជាប់ជំពាក់ គឺការចង់បានក្នុងបុត្រ និងភរិយាណា បុរសដែលជាបណ្ឌិតទាំងឡាយ រមែងពោលតម្រេក និងការជាប់ជំពាក់នោះ ដែលជាគ្រឿងចងសម្រេចដោយកិលេសថា ជារបស់មាំទាំ ។

បទថា **ឧហារិនំ** សេចក្តីថា ឈ្មោះថា មានប្រក្រតីទាញទម្លាក់ចុះ

ព្រោះរមែងទាញចុះ គឺនាំទៅកាន់ទីទាប ព្រោះទាញមកហើយ ឲ្យធ្លាក់ទៅក្នុងអបាយ ៤ ។

បទថា **សិថិលំ** សេចក្តីថា ឈ្មោះថា ធូរថយ ព្រោះមិនមុតស្បែកនិងសាច់ គឺរមែងមិននាំលោហិតចេញក្នុងទីដែលត្រូវចង បានដល់ មិនឲ្យដឹងសូម្បីភាពជាចំណង រមែងឲ្យធ្វើការងារទាំងឡាយក្នុងទីទាំងឡាយ មានការងារលើគោក និងការងារក្នុងទឹកជាដើមបាន ។

បទថា **ឧប្បមុញ្ចំ** សេចក្តីថា ឈ្មោះថា ដោះបានដោយលំបាក ព្រោះគ្រឿងចង គឺកិលេស ដែលកើតឡើងដោយអំណាចនៃការលោភ សូម្បីត្រឹមតែម្តង រមែងជាកិលេសជាតិដែលបុគ្គលដោះបានដោយលំបាក ដូចអណ្តើកដោះអំពីទីដែលចង បានលំបាក ដូច្នោះ ។

ពីរបទថា **ឯតំបិ ធេត្វាន** សេចក្តីថា អ្នកប្រាជ្ញទាំងឡាយ កាត់គ្រឿងចង គឺកិលេសនោះ ដែលមាំយ៉ាងនោះដោយព្រះខ័ន គឺញាណ ជាអ្នកអស់នូវការជាប់ជំពាក់ លះកាមសុខហើយ រៀរដោយជុំវិញ គឺចៀសចេញ អធិប្បាយថា បួស ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងពន្ធនាគារ ចប់

រឿង ព្រះនាងខេមា

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះអគ្គមហេសី របស់ព្រះបាទពិម្ពិសារ ព្រះនាមខេមា ត្រាស់ព្រះធម្មទេសនានេះថា **យោ រាគរត្តោ** ជាដើម ។

បានឮមកថា ព្រះនាងខេមានោះ តាំងនូវសេចក្តីប្រាថ្នាទៀបបាទមូល របស់ព្រះបទុមុត្តរសម្ពុទ្ធ បានជាអ្នកមានរូបរាងស្អាត គួរជ្រះថ្លាពន់ពេក ។ ព្រះ នាងបានឮថា ព្រះសាស្តាទ្រង់តិះដៀលទោសរបស់រូប ទើបមិនប្រាថ្នាទៅកាន់ សម្នាក់របស់ព្រះសាស្តា ។ ព្រះរាជាទ្រង់ជ្រាបភាពដែលអគ្គមហេសីនោះ ស្រើឯក្នុងរូប ទើបត្រាស់ឲ្យពួកអ្នកកវីតែងចម្រៀង ពណ៌នាសរសើរវត្ត វេឡុវ័ន ហើយក៏ត្រាស់ឲ្យព្រះរាជទានដល់ពួកអ្នករចាំជាដើម កាលអ្នករចាំ ទាំងនោះកំពុងច្រៀង ព្រះនាងស្តាប់ហើយ វត្តវេឡុវ័នបានហាក់ដូចមិនធ្លាប់ទត និងទ្រង់ស្តាប់ហើយ ។ ព្រះនាងត្រាស់សួរថា ពួកអ្នកច្រៀងច្រើនដល់ឧទ្យាន ណា កាលអ្នកចម្រៀងទូលថា បពិត្រព្រះទេវី សំដៅដល់ឧទ្យានវេឡុវ័នរបស់ ព្រះរាជា ព្រះនាងក៏ប្រាថ្នាយាងទៅព្រះរាជឧទ្យាន ។ ព្រះសាស្តា ទ្រង់ជ្រាប ការយាងមករបស់ព្រះនាង កាលប្រថាប់គង់សម្តែងធម៌ ក្នុងកណ្តាលបរិស័ទ ទើបទ្រង់និម្មិតស្រីរូបស្អាត ឈរកាន់ផ្លិតស្លឹកត្នោតបក់ក្បែរព្រះអង្គ ។

ឯព្រះនាងខេមាទេវីយាងទៅ ទតឃើញស្រីនោះ ទើបព្រះតម្រិះថា ជនទាំងឡាយនិយាយថា ព្រះសម្មាសម្ពុទ្ធត្រាស់ទោសរបស់រូប ស្រីនេះឈរ បក់ផ្លិត ក្នុងសម្នាក់របស់ព្រះអង្គ ។ អញមិនចូលដល់ចំណែកមួយចម្រៀក

របស់ស្រីនេះ រូបស្រីនេះអញមិនធ្លាប់ឃើញ ជនទាំងឡាយប្រហែលពោលទោសព្រះសាស្តាដោយពាក្យមិនពិត ដូច្នេះហើយ មិនបានដាក់ចិត្តជល់ព្រះតម្រាស់របស់ព្រះតថាគត បានប្រថាប់ឈរទតមើលស្រីនោះឯង ។

ព្រះសាស្តា ទ្រង់ជ្រាបភាពដែលព្រះនាងមានមានះខ្លាំង កើតឡើងក្នុងរូបនោះ កាលទ្រង់សម្តែងរូបនោះដោយអំណាចវ័យ មានបឋមវ័យជាដើម ទើបទ្រង់សម្តែង ធ្វើឲ្យសល់ត្រឹមតែឆ្អឹងក្នុងទីបំផុត ដោយនយដែលខ្ញុំពោលហើយខាងដើមនោះឯង ។

ព្រះនាងខេមាទតឃើញរូបនោះ ទើបព្រះតម្រិះថា រូបបែបនេះក៏ជល់នូវការវិនាសទៅមួយរំពេចប៉ុណ្ណោះ សារៈក្នុងរូបនេះមិនមានហ្ន៎ ។

ព្រះសាស្តា ទ្រង់ទតមើលវារចិត្តរបស់ព្រះនាងខេមានោះហើយ ទើបត្រាស់ថា ម្នាលខេមា នាងគិតថា សារៈមាននៅក្នុងរូបនេះឬ ចូរនាងមើលភាពដែលរូបនោះមិនមានសារៈក្នុងឥឡូវនេះ ហើយត្រាស់ព្រះគាថានេះថា

> ម្នាលនាងខេមា ចូរនាងមើលរាងកាយដែលរសាប់រសល់ មិនស្អាត មានក្លិនស្អុយ ជារបស់រលួយ ហូរចេញទាំងខាងលើ ហូរចេញទាំងខាងក្រោម ដែលជនពាលទាំងឡាយប្រាថ្នាក្រៃលែង ។

ក្នុងកាលចប់ទេសនា ព្រះនាងតាំងនៅក្នុងសោតាបត្តិផល ។ លំដាប់នោះ ព្រះសាស្តាត្រាស់ថា ម្នាលនាងខេមា សត្វទាំងនេះត្រេកអរដោយរាគៈ ក្តៅក្រហាយដោយទោសៈ វង្វេងដោយមោហៈ ទើបមិនអាចឈានកន្លងក្រសែតណ្ហារបស់ខ្លួនបាន ត្រូវជាប់ជំពាក់ក្នុងក្រសែតណ្ហានោះឯង ដូច្នេះ

ហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់គាថានេះថា

យោ វាគរត្តានុបតន្តិ សោតំ សយំ កតំ មក្កដកោវ ជាលំ
ឯតម្បិ ឆេត្វាន វជន្តិ ធីរា អនបេក្ខិនោ សព្វទុក្ខំ បហាយ ។

ជនពួកណា ត្រេកអរដោយអំណាចរាគៈ ពួកជននោះ តែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាងទម្លាក់ខ្លួនចុះកាន់សំណាញ់ដែលធ្វើហើយដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយ តែងកាត់ខ្សែតណ្ហានោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះទុក្ខទាំងពួងចេញទៅ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **មក្កដកោវ ជាលំ** *សេចក្តីថា ដូចពីងពាងធ្វើអន្ទាក់ គឺសំណាញ់ហើយ ដេកត្រង់កណ្តាល ហើយប្រញាប់រត់ទៅសម្លាប់កណ្តូប ឬសត្វល្អិត ដែលធ្លាក់ក្នុងសំណាញ់ បីតជញ្ជក់នូវរសរបស់សត្វទាំងនោះហើយ ក៏ត្រឡប់មកដេកក្នុងទីដើមយ៉ាងណា សត្វទាំងឡាយណា ដែលតម្រេកហើយដោយរាគៈ ក្រោធហើយដោយទោសៈ វង្វេងហើយដោយមោហៈ សត្វទាំងនោះរមែងធ្លាក់ទៅកាន់ក្រសែតណ្ហា ដែលខ្លួនធ្វើខ្លួនឯង គឺមិនអាចឈានកន្លងក្រសែតណ្ហានោះទៅបានដូច្នោះដូចគ្នា ក្រសែតណ្ហាបុគ្គលកន្លងបានលំបាកយ៉ាងនេះ ។*

បាទព្រះគាថាថា **ឯតម្បិ ឆេត្វាន វជន្តិ ធីរា** *សេចក្តីថា បណ្ឌិតទាំងឡាយ កាត់នូវគ្រឿងចងនោះហើយ ជាអ្នកអស់នូវការជាប់ជំពាក់ គឺមិនមានអាល័យ លះទុក្ខទាំងពួងដោយអរហត្តមគ្គហើយ ក៏រៀរ គឺទៅ ។*

ក្នុងកាលចប់ទេសនា ព្រះនាងខេមាតាំងនៅក្នុងអរហត្ត ទេសនាមានប្រយោជន៍ដល់មហាជនហើយ ។ព្រះសាស្តាត្រាស់នឹងព្រះរាជាថា មហាបពិត្រ ព្រះនាងខេមានឹងបួស ឬបរិនិព្វានទើបគួរ ។ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ សូមទ្រង់ឲ្យនាងបួសចុះ កុំជ្រុលដល់ដោយការបរិនិព្វាន ។

ព្រះនាងបព្វជ្ជាហើយ ក៏បានជាអគ្គសាវិកាដូច្នេះឯង ៕

រឿង ព្រះនាងខេមា ចប់

រឿង ឧគ្គសេនសេដ្ឋីបុត្រ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធឧគ្គសេន ត្រាស់ព្រះធម្មទេសនានេះថា **មុញ្ច បុរេ** ជាដើម ។

បានឮថា គ្រប់ ៦ ឆ្នាំ ឬ ៦ ខែហើយ អ្នករជុំប្រមាណ ៥០០ ទៅកាន់ក្រុងរាជគ្រឹះ ធ្វើមហោស្រពថ្វាយដល់ព្រះរាជារហូត ៧ ថ្ងៃ បានប្រាក់និងមាសជាច្រើន ការជួនវង្វាន់ក្នុងចន្លោះៗ មិនមានទីបំផុត មហាជនក៏ឈរលើគ្រែជាដើមមើលមហោស្រព ។ លំដាប់នោះ ធីតារបស់អ្នករជុំម្នាក់ឡើងកាន់វ៉ាវ ដើរវាំ និងច្រៀងលើអាកាសក្នុងទីបំផុតនៃវ៉ាវនោះ ។

សម័យនោះ សេដ្ឋីបុត្រឈ្មោះឧគ្គសេន ឈរលើគ្រែដែលត្រួតលើគ្នាជាមួយសម្ងាញ់ សម្លឹងមើលស្រីនោះ មានការស្រឡាញ់កើតឡើងក្នុងអាការ

ទាំងឡាយមានការគ្រវីដៃ និងជើងជាដើមរបស់នាង ទៅកាន់ផ្ទះហើយគិតថា បើអញបាននាងទើបអញមានជីវិត បើមិនបានក៏នឹងស្លាប់ក្នុងទីនេះឯង ដូច្នេះហើយ ក៏អត់អាហារដេកលើគ្រែ ត្រូវមាតាបិតាសួរថា នែបា បាកើតអ្វី ក៏ឆ្លើយថា បើខ្ញុំបានកូនស្រីរបស់អ្នករជាំនោះ នឹងមានជីវិតរស់នៅ បើមិនបានក៏នឹងស្លាប់ក្នុងទីនេះឯង កាលមាតាលួងលោមថា នែបា បាកុំធ្វើយ៉ាងនេះឡើយ ពួកយើងនឹងនាំកុមារិកាដទៃ ដែលសមគួរដល់ត្រកូល និងភោគៈរបស់ពួកយើងមកឲ្យដល់បា ក៏នៅតែដេកពោលយ៉ាងនោះដដែល ។

លំដាប់នោះ បិតារបស់ឧគ្គសេន សូម្បីអង្វរច្រើន កាលមិនអាចឲ្យគេយល់ព្រមបាន ទើបហៅសម្ភាញ់របស់អ្នករជាំនោះមក ឲ្យទ្រព្យមួយពាន់កហាបណៈហើយ បញ្ជូនទៅដោយពាក្យថា ចូរអ្នកទទួលយកកហាបណៈទាំងនេះហើយ ឲ្យកូនស្រីរបស់អ្នកដល់កូនប្រុសរបស់ខ្ញុំចុះ ។

អ្នករជាំនោះពោលថា ខ្ញុំទទួលយកកហាបណៈហើយ ក៏ឲ្យមិនបាន បើកូនប្រុសរបស់លោកមិនបានកូនស្រីរបស់ខ្ញុំហើយ មិនអាចរស់នៅសោត បើដូច្នោះ បុត្ររបស់លោក ចូរត្រាច់ទៅជាមួយពួកខ្ញុំចុះ ពួកខ្ញុំនឹងឲ្យកូនស្រីដល់បុត្ររបស់លោក ។ មាតាបិតាជ្រាបសេចក្តីនោះដល់ឧគ្គសេនហើយ ឧគ្គ-សេនពោលថា ខ្ញុំនឹងដើរតាមពួកអ្នករជាំនោះ មិនអើពើនឹងពាក្យរបស់មាតាបិតាដែលកំពុងអង្វរ បានចេញទៅកាន់សម្នាក់នៃអ្នករជាំហើយ ។

អ្នករជាំនោះ ឲ្យកូនស្រីដល់ឧគ្គសេនហើយ ដើរសម្តែងសិប្បៈក្នុងស្រុកនិគម និងរាជធានីជាមួយគ្នានោះឯង ។ ចំណែកទារិកានោះ អាស្រ័យការនៅ

រួមជាមួយបុត្រសេដ្ឋីនោះ ក្នុងកាលមិនយូរក៏បានបុត្រ កាលនឹងលួងបុត្រនោះ ពោលថា កូនរបស់អ្នកយាមរទេះ កូនអ្នករែករបស់របរ កូនអ្នកមិនចេះអ្វីសោះ ។ ចំណែកសេដ្ឋីបុត្រនោះ ជញ្ជូនស្មៅមកឲ្យគោទាំងឡាយ ក្នុងទីដែលជនទាំងនោះធ្វើការដាក់រទេះហើយ លើកយករបស់របរដែលបានក្នុងទីសម្តែងសិប្ប: ហើយនាំទៅ បានឮថា ស្រីនោះសំដៅយកបុត្រសេដ្ឋីនោះឯង កាលនឹងលួងកូន ទើបពោលយ៉ាងនោះឯង បុត្រសេដ្ឋីជ្រាបភាពដែលនាងច្រៀងប្រាវញ្ជខ្ជូន ទើបសួរថា នាងពោលសំដៅដល់ខ្ញុំឬ ភរិយាពោលថា ចា៎ ខ្ញុំពោលសំដៅដល់អ្នក សេដ្ឋីបុត្រពោលថា បើដូច្នោះខ្ញុំចៀសចេញទៅ ភរិយាពោលថា ប្រយោជន៍អ្វីរបស់ខ្ញុំ ដែលអ្នកគេចទៅឬមកនោះ ដូច្នេះហើយ ច្រៀងបទនោះឯងរឿយៗ ទៅ ។

បានឮថា នាងអាស្រ័យរូបសម្បត្តិរបស់ខ្ជូន និងទ្រព្យចំណូល ទើបមិនក្រែងចិត្តបុត្រសេដ្ឋីនោះ ក្នុងរឿងណាមួយឡើយ ។ បុត្រសេដ្ឋីនោះគិតថា ស្រីនេះមានការប្រកាន់ខ្ជូនបែបនេះ ព្រោះអាស្រ័យអ្វីហ្នឹ ដឹងថា ព្រោះអាស្រ័យសិប្ប: ទើបគិតថា ណ្ហើយចុះ អញនឹងរៀនសិប្ប: ហើយចូលទៅរកឪពុកក្មេក រៀនសិប្ប:របស់ឪពុកក្មេកនោះ សម្តែងសិប្ប:ក្នុងស្រុកនិគមជាដើម មកដល់រាជគ្រឹះដោយលំដាប់ ឲ្យប្រកាសថា ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ បុត្រសេដ្ឋីឈ្មោះឧគ្គសេននឹងសម្តែងសិប្ប:ដល់អ្នកនគរ ។ អ្នកនគរឲ្យចងគ្រែត្រួតៗលើគ្នាជាដើមហើយ ប្រជុំគ្នាក្នុងថ្ងៃទី ៧ ។ ចំណែកឧគ្គសេន ឡើងកាន់រ៉ាវកម្ពស់ ៦០ ហត្ថ ឈរលើចុងរ៉ាវនោះ ។ ក្នុងថ្ងៃនោះ ព្រះសាស្តា

ទ្រង់ប្រមើលមើលសត្វលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញឧគ្គសេននោះចូលក្នុងសំណាញ់ញាណរបស់ព្រះអង្គ ទើបទ្រង់ពិចារណាថា នឹងមានហេតុអ្វីហ្ន៎ បានជ្រាបថា ស្អែកនេះ បុត្រសេដ្ឋី នឹងឈរលើចុងភ៉ាវ ដោយបំណងថា នឹងសម្តែងសិប្បៈ មហាជនប្រជុំគ្នាដើម្បីមើល តថាគតនឹងសម្តែងគាថាប្រកបដោយបទ ៤ ក្នុងសមាគមនោះ ការសម្រេចធម៌នឹងមានដល់សត្វ ៨៤០០០ ព្រោះស្តាប់ធម៌នោះ សូម្បីឧគ្គសេន ក៏តាំងនៅក្នុងអរហត្ត ។

ក្នុងថ្ងៃរះឡើង ទ្រង់កំណត់ពេលហើយ មានភិក្ខុសង្ឃចោមរោម ចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ចំណែកឧគ្គសេន កាលព្រះសាស្តាមិនទាន់យាងទៅខាងក្នុងព្រះនគរនោះឯង ទើបឲ្យសញ្ញាដោយម្រាមដៃដល់មហាជនដើម្បីឲ្យគគ្រឹកគគ្រេង ឈរលើចុងភ៉ាវក្នុងអាកាសនោះឯង ៧ ដង ចុះមកហើយ ឈរលើចុងភ៉ាវទៀត ។

ខណៈនោះ ព្រះសាស្តាកំពុងចូលទៅកាន់ព្រះនគរ ទ្រង់ធ្វើដោយអាការដែលបរិស័ទមិនមើលឧគ្គសេន ឲ្យមើលចំពោះទ្រង់ប៉ុណ្ណោះ ឧគ្គសេនសម្លឹងមើលបរិស័ទហើយ ដល់នូវការអន់ចិត្តថា បរិស័ទទាំងនេះមិនសម្លឹងមើលអញ ទើបគិតថា សិប្បៈដែលអញគប្បីសម្តែងប្រចាំឆ្នាំ កាលព្រះសាស្តាយាងចូលទៅកាន់ព្រះនគរ បរិស័ទមិនមើលអញមើលតែព្រះសាស្តាប៉ុណ្ណោះ ការសម្តែងសិប្បៈរបស់អញទៅហើយហ្ន៎ ។

ព្រះសាស្តា ទ្រង់ជ្រាបការគិតរបស់ឧគ្គសេន ទើបត្រាស់ហៅព្រះមហាមោគ្គល្លានមកហើយត្រាស់ថា មោគ្គល្លាន ចូរអ្នកទៅនិយាយនឹងសេដ្ឋីបុត្រថា

ចូរសម្តែងសិប្បៈចុះ ។ ព្រះថេរៈបានឈរខាងក្រោមរ៉ាវនោះឯង ហៅសេដ្ឋីបុត្រមកហើយ ពោលគាថានេះថា

ឧគ្គសេនកូនអ្នកវេជ្ជ ដែលមានកម្លាំងច្រើន ចូរអ្នកមើល ចូរអ្នកធ្វើសេចក្តីត្រេកអរដល់បរិស័ទចុះ ចូរអ្នកធ្វើឲ្យមហាជនត្រេកអរចុះ ។ ឧគ្គសេនបានឮពាក្យរបស់ព្រះថេរៈហើយ មានចិត្តត្រេកអរ គិតថា ព្រះសាស្តាមានបំណងនឹងទតសិប្បៈរបស់អញ ឈរលើចុងរ៉ាវហើយ ពោលគាថានេះថា បពិត្រព្រះមោគ្គល្លាន លោកម្ចាស់មានបញ្ញាច្រើន មានឫទ្ធិច្រើន សូមលោកម្ចាស់មើល ខ្ញុំនឹងធ្វើការត្រេកអរដល់បរិស័ទ នឹងញុំាងមហាជនឲ្យត្រេកអរ ។

កាលពោលយ៉ាងនោះហើយ ក៏លោតអំពីចុងរ៉ាវឡើងកាន់អាកាសអស់ ១៤ ជង្ហឹកអាកាសហើយ ចុះមកឈរលើចុងរ៉ាវវិញ ។ លំដាប់នោះ ព្រះសាស្តាត្រាស់ថា ឧគ្គសេន ធម្មតាបណ្ឌិតត្រូវលះសេចក្តីអាល័យក្នុងខន្ធទាំងឡាយ ទាំងដែលជាអតីត អនាគត និងបច្ចុប្បន្នចេញ ហើយផុតចាកទុក្ខទាំងឡាយ មានជាតិជាដើមទើបគួរ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

មុញ្ច បុរេ មុញ្ច បច្ឆតោ មជ្ឈេ មុញ្ច ភវស្ស បារគូ
សព្វត្ថ វិមុត្តមានសោ ន បុន ជាតិជរំ ឧបេហិសិ ។

អ្នកចូរដោះ (សេចក្តីអាល័យ) ក្នុងកាលមុនចេញ ចូរដោះ (សេចក្តីអាល័យ) ក្នុងខាងក្រោយចេញ ចូរដោះ (សេចក្តីអាល័យ) ក្នុងកាលជាកណ្តាលចេញ (កាលបើធ្វើយ៉ាងនេះ) អ្នកនឹងដល់ត្រើយនៃភព និងមានចិត្តរួចស្រឡះចាកសង្ខតធម៌

ទាំងពួង មិនត្រូវទៅកាន់ជាតិ និងជរាទៀតឡើយ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **មុញ្ច បុរេ** *សេចក្តីថា ចូរដោះអាល័យ គឺការត្រេកអរ ការងប់ជ្រប់ ការជ្រាបថ្នា ការជាប់ជំពាក់ ការប្រកាន់ ការស្ងួបអង្អែល ការចង់បានក្នុងខន្ធទាំងឡាយ ដែលជាអតីតចេញ ។*

បទថា **បច្ឆតោ** *សេចក្តីថា ចូរដោះនូវអាល័យជាដើមក្នុងខន្ធទាំងឡាយដែលជាអនាគត ។*

បទថា **មជ្ឈេ** *សេចក្តីថា ចូរដោះអាល័យទាំងនោះក្នុងខន្ធទាំងឡាយដែលជាបច្ចុប្បន្នចេញ ។*

ពីរបទថា **ភវស្ស បារគូ** *សេចក្តីថា កាលបដិបត្តិបានយ៉ាងនោះ នឹងជាអ្នកដល់ត្រើយ គឺទៅហើយកាន់ច្រាំងនៃភពទាំង ៣ បាន ដោយអំណាចនៃការកំណត់ដឹង ការលះ ការចម្រើន និងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ក្រៃលែង មានចិត្តរួចផុតហើយក្នុងសង្ខតធម៌ទាំងពួង មានខន្ធ ជាតុ អាយតនៈជាដើម តទៅ មិនត្រូវចូលដល់ជាតិ ជរា និងមរណៈ ។*

ក្នុងកាលចប់ទេសនា ការត្រាស់ដឹងធម៌មានដល់សត្វ ៨៤០០០ ហើយ ។ ចំណែកសេដ្ឋីបុត្រ កំពុងឈរលើចុងក៉ាវ សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាហើយ ចុះអំពីក៉ាវមកកាន់ទីជិតព្រះសាស្តា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ទូលសូមបព្វជ្ជានឹងព្រះសស្តា ។ លំដាប់នោះ ព្រះសាស្តាទ្រង់លាព្រះហស្តខាងស្តាំ ត្រាស់នឹងខគ្គសេនថា ចូរអ្នកមកជាភិក្ខុចុះ ខគ្គសេនក៏បាន

ជាអ្នកទ្រទ្រង់នូវបរិក្ខារ ៨ ហាក់ដូចជាព្រះថេរៈ មានវស្សា ៦០ ក្នុងខណៈនោះឯង ។

បន្ទាប់មក ពួកភិក្ខុសួរលោកថា ឧគ្គសេន កាលលោកចុះអំពីរ៉ាវកម្ពស់ ៦០ ហត្ថ ឈ្មោះថា ការខ្លាចមិនមានទេឬ កាលលោកឆ្លើយថា អាវុសោ ការខ្លាចមិនមានដល់ខ្ញុំឡើយ ទើបក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ឧគ្គសេនពោលថា ខ្ញុំមិនខ្លាច លោកពោលមិនពិត រមែងអួតគុណវិសេស ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុដែលមានសំយោជនៈកាត់បានហើយ ដូចឧគ្គសេនបុត្ររបស់តថាគត ការខ្លាច ការតក់ស្លុត មិនមាន ដូច្នេះហើយ ត្រាស់ព្រះគាថានេះក្នុងព្រាហ្មណវគ្គថា

បុគ្គលណា កាត់សំយោជនៈទាំងអស់បាន មិនតក់ស្លុត តថាគត
ហៅបុគ្គលនោះ ដែលគ្មានកិលេសជាគ្រឿងជំពាក់ អ្នករួច
ស្រឡះចាកកិលេសថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ការសម្រេចធម្មវិសេសមានហើយដល់មហាជន ។ ស្អែកឡើង ពួកភិក្ខុសន្ទនាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ហេតុ គឺ ការអាស្រ័យកូនក្រមុំអ្នករបាំ ត្រាច់ទៅជាមួយអ្នករបាំរបស់កិក្ខុ ដែលដល់ព្រមដោយឧបនិស្ស័យនៃអរហត្តយ៉ាងនេះ ដូចម្តេចហ្ន៎ ហេតុនៃឧបនិស្ស័យអរហត្តដូចម្តេចហ្ន៎ ។ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី កាលភិក្ខុនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ដូច្នេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ហេតុទាំងពីរនោះ ដែលឧគ្គសេនធ្វើហើយ ។ កាលទ្រង់ប្រកាសសេចក្តីនោះ ទើបទ្រង់ទាញអតីតនិទានមកត្រាស់ថា

បានឮថា ក្នុងអតីតកាល កាលសុវណ្ណចេតិយសម្រាប់ព្រះកស្សប-ទសពលគេកំពុងធ្វើ ពួកកុលបុត្រអ្នកនគរពារាណសីផ្ទុករបស់ទំពា របស់បរិភោគ ជាច្រើនក្នុងយានទាំងឡាយ កំពុងទៅកាន់ទីចេតិយ ដោយតាំងចិត្តថា ពួកយើងនឹងធ្វើហត្ថកម្ម ជួបព្រះថេរៈមួយអង្គកំពុងចូលទៅបិណ្ឌបាតក្នុងវាងផ្លូវ លំដាប់នោះ កុលធីតាម្នាក់ឃើញព្រះថេរៈហើយ ពោលនឹងស្វាមីថា នែអ្នក លោកម្ចាស់របស់យើងចូលមកដើម្បីបិណ្ឌបាត ម្យ៉ាងទៀត របស់ទំពា របស់បរិភោគ នៃពួកយើងនៅក្នុងយានមានជាច្រើន សូមអ្នកនាំបាត្ររបស់លោកមក យើងទាំងពីរនឹងប្រគេនកិក្ខា ។ ស្វាមីនាំបាត្រមកហើយ ភរិយាញុំាងបាត្រនោះឲ្យពេញដោយរបស់ទំពា របស់បរិភោគហើយ ឲ្យប្តីយកទៅដាក់ក្នុងដៃរបស់ព្រះថេរៈ ជនទាំងពីរនាក់ធ្វើសេចក្តីប្រាថ្នាថា ទានរបស់ខ្ញុំទាំងពីរ គប្បីមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយនោះឯង ព្រះថេរៈជាព្រះខីណាស្រព ព្រោះដូច្នោះ កាលលោកពិចារណាមើល ដីងការៈដែលនឹងសម្រេចសេចក្តីប្រាថ្នារបស់ជនទាំងពីរនោះហើយ បានធ្វើនូវការញញឹម ស្រីនោះឃើញអាការនោះ ទើបពោលនឹងប្តីថា នែអ្នក លោកម្ចាស់របស់យើងធ្វើអាការញញឹម លោកប្រហែលជាអ្នករបាំទេដឹង ។ ចំណែកប្តីរបស់នាងឆ្លើយថា អើ នាងប្រហែលជាយ៉ាងនោះឯង ដូច្នេះហើយ ចៀសចេញទៅ ។ នេះជាបុព្វកម្មរបស់ជនទាំងពីរ ។

ស្វាមីភរិយានោះ តាំងនៅក្នុងអត្តភាពនោះអស់អាយុហើយ កើតក្នុងទេវលោក ឃ្លាតចាកទីនោះហើយ ស្រីនោះកើតក្នុងត្រកូលអ្នករបាំ ប្រុសកើតក្នុងផ្ទះរបស់សេដ្ឋី ។ ឧគ្គសេនានោះ ព្រោះភាពដែលឲ្យនូវការធ្វើយដល់ភរិយានោះថា អើនាង ប្រហែលជាយ៉ាងនោះឯង ទើបត្រាច់ទៅជាមួយអ្នករបាំ អាស្រ័យបិណ្ឌបាតដែលគេប្រគេនដល់ព្រះថេរៈ ដែលជាព្រះខីណាស្រព ទើបសម្រេចអរហត្តហើយ ។

ធីតារបស់អ្នករបាំនោះគិតថា គតិរបស់ប្តីអញយ៉ាងណា គតិរបស់អញក៏យ៉ាងនោះឯង ដូច្នេះហើយ ក៏បព្វជ្ជាក្នុងសម្នាក់របស់ភិក្ខុនីទាំងឡាយហើយ តាំងនៅក្នុងអរហត្ត ដូច្នេះឯង ៕

រឿង ឧគ្គសេនសេដ្ឋីបុត្រ ចប់

រឿង ចូឡធនុគ្គហាបណ្ឌិត

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកំលោះមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **វិតក្កមឋិតសុត្ត** ជាដើម ។

បានឮមកថា ភិក្ខុកំលោះមួយរូប ចាប់ស្លាករបស់ខ្លួនក្នុងរោងស្លាក កាន់យកបបរតាមស្លាកទៅកាន់រោងឆាន់ ហើយឆាន់ ។ ភិក្ខុនោះ មិនបានទឹកក្នុងរោងឆាន់ ក៏ទៅកាន់ផ្ទះមួយខ្នងដើម្បីទឹក ។ កញ្ញាម្នាក់ក្នុងផ្ទះនោះ បានឃើញភិក្ខុនោះ កើតសេចក្តីស្នេហា ពោលថា បពិត្រលោកម្ចាស់ បើត្រូវការដោយទឹកឆាន់ សូមនិមន្តមកកាន់ផ្ទះនេះទៀតចុះ ។

តាំងអំពីនោះមក ភិក្ខុនោះមិនបានទឹកក្នុងកាលណា ក៏ទៅកាន់ផ្ទះនោះឯងក្នុងកាលនោះ ។ ចំណែកស្រីនោះ ទទួលបាត្ររបស់លោកហើយប្រគេនទឹកឆាន់ ។ ពេលវេលាកន្លងទៅដោយអាការយ៉ាងនោះ ។ ថ្ងៃមួយ នាងប្រគេនបបរ ហើយនិមន្តឲ្យគង់ឆាន់ក្នុងផ្ទះនោះឯងហើយប្រគេនបាយ ។ នាងអង្គុយក្នុងទីជិតភិក្ខុនោះហើយ លែបខាយពាក្យសម្តីឡើងថា បពិត្រលោកម្ចាស់ ក្នុងផ្ទះនេះអ្វីដែលឈ្មោះថាអត់ មិនមានឡើយ ខ្ញុំខ្វះតែអ្នកចាត់ចែងការប៉ុណ្ណោះ ភិក្ខុនោះស្តាប់ពាក្យរបស់ស្រីនោះហើយ ២-៣ ថ្ងៃប៉ុណ្ណោះក៏អផ្សុកហើយ ។

ថ្ងៃមួយ ពួកអាគន្តុកភិក្ខុជួបភិក្ខុនោះ ក៏សួរថា អាវុសោ ហេតុអ្វីទើបលោកស្គមលឿងខ្ចាំងម្ល៉ះ កាលភិក្ខុនោះឆ្លើយថា អាវុសោ ខ្ញុំអផ្សុក ទើបនាំទៅកាន់សម្នាក់អាចារ្យ និងឧបជ្ឈាយ៍ៗ ទាំងនោះ ក៏នាំភិក្ខុនោះទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលសេចក្តីនោះហើយ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកចង់សឹកឬ ភិក្ខុនោះទូលថា ពិតហើយព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ តើព្រោះហេតុអ្វី អ្នកបួសក្នុងសាសនារបស់ព្រះពុទ្ធ ដែលប្រារព្ធសេចក្តីព្យាយាមដូចតថាគត មិនបានឲ្យគេហៅខ្លួនថាជាព្រះសោតាបន្ន ឬព្រះសកទាគាមី បែរជាឲ្យគេហៅថា ជាអ្នកអផ្សុកទៅវិញ អ្នកធ្វើកម្មធ្ងន់ហើយ ទើបទ្រង់សួរថា ព្រោះហេតុអ្វី ទើបអ្នកអផ្សុក ភិក្ខុនោះទូលថា បពិត្រព្រះអង្គ ទារិកាម្នាក់និយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ កិរិយារបស់ស្រីនោះមិនគួរអស្ចារ្យ ព្រោះក្នុងកាលមុន នាងលះបង់បណ្ឌិតដ៏កំពូល លើជម្ពូទ្វីបទាំងមូល ហើយទៅស្នេហាក្នុងបុរសម្នាក់ ដែលខ្លួនឃើញមួយភ្លេតនោះកើតឡើង ធ្វើបណ្ឌិតនោះឲ្យដល់នូវការអស់ជីវិត ។ ភិក្ខុទាំងឡាយទូលអារាធនា ដើម្បីឲ្យព្រះអង្គសម្តែងរឿងនោះ ទើបទ្រង់ធ្វើឲ្យជាក់ច្បាស់នូវភាពដែលចូឡ-ធនុគ្គហបណ្ឌិត រៀនសិប្បៈក្នុងសម្នាក់របស់អាចារ្យទិសាបាមោក្ខ ក្នុងក្រុងតក្កសិលា នាំធីតាដែលអាចារ្យនោះត្រេកអរឲ្យហើយ មកកាន់ក្រុងពារាណសី កាលខ្លួនសម្លាប់ ចោរ ៤៩ នាក់ ដោយព្រួញ ៤៩ ត្រង់មាត់ព្រៃមួយកន្លែង កាលព្រួញអស់ហើយ ទើបចាប់មេចោរឲ្យដួលចុះត្រង់ផែនដី ពោលថា នែនាង ចូរនាងយកជាវមក នាងបែរជាធ្វើសេចក្តីស្រឡាញ់ក្នុងចោរ ដែលខ្លួនឃើញក្នុងខណៈនោះ ហើយជាក់ដងជាវក្នុងដៃចោរ ឲ្យចោរសម្លាប់ហើយក្នុងកាលជាចូឡធនុគ្គហបណ្ឌិតក្នុងអតីតកាល និងការៈដែលចោរនាំស្រីនោះទៅបណ្តើរ គិតបណ្តើរថា ស្រីនេះ ឃើញប្រុសដទៃហើយ នឹងឲ្យគេសម្លាប់

អញដែរ ដូចគ្នានឹងប្តីរបស់ខ្លួន អញត្រូវការអ្វីដោយស្រីនេះ ឃើញស្តឹងមួយខ្សែ ទើបទុកនាងត្រង់ត្រើយអាយ កាន់បង្វេចកណ្ហៈរបស់នាងទៅ ប្រាប់ថា ចូរនាងចាំក្នុងទីនេះឯង ទម្រាំខ្ញុំនាំកណ្ហៈឆ្លងទៅ ទុកនាងចោលក្នុងទីនោះឯង គេចទៅ ។ ហើយព្រះសាស្តា ត្រាស់ចុល្លធនុគ្គហជាតកនេះ ក្នុងបញ្ចកនិបាត ឲ្យពិស្តារថា

ស្ត្រីនោះនិយាយថា ម្នាលព្រាហ្មណ៍ អ្នកនាំយកទ្រព្យទាំងអស់ឆ្លងទៅកាន់ត្រើយនាយ ម្នាលអ្នកជ័ចម្រើន អ្នកចូរត្រឡប់មកវិញយ៉ាងឆាប់រួសរាន់ សូមអ្នកចម្អងខ្ញុំឥឡូវនេះផង ។

ចោរនិយាយថា នាងផ្ញាស់ប្តូរយកអញ អ្នកមិនស្និទ្ធស្នាលដោយប្តីដែលស្និទ្ធស្នាលអស់កាលយូរ ផ្ញាស់ប្តូរយកអញដែលមិនមែនជាប្តីទៀងទាត់ ដោយប្តីទៀងទាត់ នាងនឹងផ្ញាស់ប្តូរយកប្រុសឯទៀតនឹងអញមិនខាន អញនឹងទៅកាន់ទីធ្លាយជាងទីនេះ ។

ចចកនិយាយថា ស្ត្រីនេះជាអ្វី ទើបធ្វើនូវសំណើចយ៉ាងខ្លាំង ទៀបតុម្ពវៃទឹក ការរាំក្តី ច្រៀងក្តី ប្រគំក្តី ដែលគេតាំងទុកដោយល្អ ក្នុងទីនេះមិនមានទេ ម្នាលស្ត្រី មានត្រគាកល្អ មានរូបល្អ ហេតុដូចម្តេច ទើបនាងសើចក្អាកក្អាយ ក្នុងកាលគួរយំ ។

នាងនោះនិយាយថា ម្នាលចចកជម្ពុកៈពាល ឥតប្រាជ្ញា ឯងជាសត្វគ្មានប្រាជ្ញា ឯងសាបសូន្យចាកត្រី និងជុំសាច់ សញ្ជប់សញ្ជឹងដូចសត្វកំព្រា ។

ចចកនិយាយថា ទោសរបស់ជនទាំងឡាយឯងទៀត ឃើញបានដោយងាយ ចំណែកខាងទោសរបស់ខ្លួន ឃើញបានដោយក្រណាស់ នាងឯងជាស្ត្រីសាបសូន្យចាកប្តី និងសហាយ សញ្ជប់សញ្ជឹងជាងអញទៅទៀត ។

នាងនោះនិយាយថា ម្នាលស្តេចម្រឹគជម្ពុកៈ អ្នកនិយាយយ៉ាងណា ពាក្យនុ៎ះយ៉ាងហ្នឹងហើយ ខ្ញុំនោះទៅអំពីទីនេះ និងលុះអំណាចប្តីដោយពិត ។

សក្កទេវរាជពោលថា អ្នកណាហ៊ានលួចកាជន៍ដី អ្នកនោះគង់ហ៊ានលួចកាជន៍សិរីទ្ធទៀត ពុបដែលនាងបានធ្វើ រួចហើយ នាងនឹងធ្វើយ៉ាងនេះទៀត មិនលែងឡើយ ។

ហើយទ្រង់ត្រាស់ថា ក្នុងកាលនោះ ពុលូធនុគ្គហបណ្ឌិត បានជារូបអ្នកស្រីនោះ បានជាទាវិកានោះក្នុងកាលឥឡូវនេះ ។ សក្កទេវរាជ ដែលនិម្មិតរូបជាចចក ធ្វើការសង្កត់សង្កិនស្រីនោះ គឺតថាគតនេះឯង ។ ព្រះសាស្តាទ្រង់ទូន្មានភិក្ខុនោះថា ស្រីនោះ ផ្តាច់ជីវិតបណ្ឌិតដែលជាកំពូល ក្នុងជម្ពូទ្វីបទាំងមូល ឲ្យអស់ជីវិត ព្រោះស្រឡាញ់ក្នុងមនុស្សម្នាក់ដែលខ្លួនឃើញមួយភ្លែតយ៉ាងនេះ ម្នាលភិក្ខុ ចូរអ្នកកាត់តណ្ហារបស់អ្នក ដែលប្រារព្ធស្រីនោះកើតឡើងចោលចេញ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ឲ្យក្រៃលែងឡើង ទើបទ្រង់ភាសិតព្រះគាថាទាំងនេះថា

វិតក្កមថិតស្ស ជន្តុនោ តិព្ភាគស្ស សុភានុបស្សិនោ
អិយ្យា តណ្ហា បវឌ្ឍតិ ឃស ខោ ឌឌ្ហំ ករោតិ ពន្ធនំ ។
វិតក្កូបសមេ ច យោ រតោ អសុភំ ភាវយតី សទា សតោ
ឃស ខោ វ្យន្តិកាហាតិ ឃសច្ឆេច្ឆតិ មារពន្ធនំ ។

តណ្ហា រមែងចម្រើនក្រៃលែងដល់ជនដែលវិតក្កញ៉ាំញី មានតម្រេកក្តៀវក្លា យល់ឃើញអារម្មណ៍ថាល្អ បុគ្គលនោះឯង ឈ្មោះថា ធ្វើចំណងឲ្យមាំមួន ។ លុះតែបុគ្គលណា ត្រេកអរក្នុងអសុភជ្ឈាន ដែលជាហេតុឲ្យស្ងប់រម្ងាប់ នូវវិតក្ក មានស្មារតីសព្វកាល តែងចម្រើនអសុភជ្ឈាន បុគ្គលនោះឯង នឹងធ្វើតណ្ហាឲ្យអស់ទៅបាន បុគ្គលនោះឯង ទើបឈ្មោះថា កាត់ចំណងមារបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **វិតក្កមថិតស្ស** *បានដល់ ដែលត្រូវវិតក្ក ៣ មានកាមវិតក្កជាដើមញ៉ាំញីក្រៃលែង ។*

បទថា **តិព្ភាគស្ស** *គឺជាអ្នកមានរាគៈក្រាស់ ។*

បទថា **សុភានុបស្សិនោ** *សេចក្តីថា ឈ្មោះថាជាអ្នកតាមឃើញអារម្មណ៍ថាស្អាត ព្រោះជាអ្នកមានចិត្ត ដែលបណ្តែតបណ្តោយទៅក្នុងអារម្មណ៍ដែលគួរប្រាថ្នាទាំងឡាយ ដោយអំណាចនៃការប្រកាន់ដោយសុភនិមិត្តជាដើម ។*

បទថា **តណ្ហា** *ជាដើម សេចក្តីថា បណ្តាញាន សូម្បីញានមួយរមែង*

មិនចម្រើនដល់បុគ្គលបែបនោះដោយពិត តណ្ហាកើតតាមទ្វារ ៦ រមែងចម្រើនក្រៃលែង ។

បទថា **ឯស ខោ** *សេចក្តីថា បុគ្គលនោះឯង រមែងធ្វើគ្រឿងចង គឺតណ្ហាឲ្យមាំ ។*

បទថា **វិតក្កូបសមេ** *សេចក្តីថា បណ្តាអសុក ១០ ក្នុងបឋមជ្ឈានពោល គឺធម៌ជាទីរម្ងាប់មិច្ឆាវិតក្កទាំងឡាយ ។*

ពីរបទថា **សទា សតោ** *សេចក្តីថា កិក្ខុណាជាអ្នកត្រេកក្នុងបឋមជ្ឈាននេះ ឈ្មោះថា មានសតិ ព្រោះភាពជាអ្នកមានសតិមាំទាំជានិច្ច ចម្រើនអសុកជ្ឈាននោះ ។*

បទថា **វិញ្ញិកាមាតិ** *សេចក្តីថា កិក្ខុនោះនឹងធ្វើតណ្ហា ដែលនឹងឲ្យកើតក្នុងភព ៣ ឲ្យទៅប្រាសបាន ។*

បទថា **មារពន្ធនំ** *សេចក្តីថា កិក្ខុនោះ នឹងកាត់សូម្បីគ្រឿងចងនៃមារពោល គឺវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ចេញបាន ។*

ក្នុងកាលចប់ទេសនា កិក្ខុនោះតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿងចុល្លធនុគ្គហាបណ្ឌិត ចប់

រឿង មារ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមារ ត្រាស់ព្រះធម្មទេសនានេះថា **និដ្ធន្តគោ** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ក្នុងវេលាវិកាល ព្រះថេរៈជាច្រើន ចូលទៅកាន់ជេតពនមហាវិហារ បានទៅដល់ទីលំនៅរបស់ព្រះរាហុលត្ថេរ ហើយក៏ដេញលោកឲ្យក្រោកឡើង កាលមិនឃើញទីលំនៅដទៃ ទើបសិងត្រង់យ៉មុខព្រះគន្ធកុដិរបស់ព្រះតថាគត គ្រានោះ ភិក្ខុនោះសម្រេចអរហត្តហើយ ទាំងជាបុគ្គលមិនទាន់មានវស្សា ។

មារឈ្មោះវសវត្តី តាំងនៅក្នុងភពនោះឯង ឃើញព្រះរាហុលសិងត្រង់យ៉មុខព្រះគន្ធកុដិ ទើបគិតថា សាមណេរតូចរបស់ព្រះសមណគោតម សិងខាងក្រៅ ចំណែកព្រះអង្គផ្ទំខាងក្នុងព្រះគន្ធកុដិ កាលអញគ្របសង្កត់សាមណេរតូច ឯខ្ជូនព្រះអង្គក៏ដូចជាអញគ្របសង្កត់ដែរ ។ មារនោះនិម្មិតជាដំរីធំមកយកប្រមោយរឹតព្រះសីសៈព្រះថេរៈ ហើយស្រែកដូចសំឡេងក្រៀលដ៏ខ្លាំង ។

ព្រះសាស្តាផ្ទំក្នុងព្រះគន្ធកុដិ ទ្រង់ជ្រាបដំរីនោះជាមារ ទើបត្រាស់ថាម្នាលមារ ជនដូចអ្នកសូម្បីមួយសែន ក៏មិនអាចឲ្យនូវការខ្លាចកើតដល់បុត្ររបស់តថាគតបាន ព្រោះថា បុត្ររបស់តថាគត មានប្រក្រតីមិនតក់ស្ទុត មានតណ្ហាទៅប្រាសហើយ ជាអ្នកមានព្យាយាមធំ មានបញ្ញាច្រើន ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

និដ្ឌង្គតោ អសន្តាសី វីតតណ្ហោ អនង្គណោ
អច្ឆិន្ទិ ភវសល្លានិ អន្តិមោយំ សមុស្សយោ ។
វីតតណ្ហោ អនាទានោ និរុត្តិបទកោវិទោ
អក្ខរានំ សន្និបាតំ ជញ្ញា បុព្ពាបរានិ ច
ស វេ អន្តិមសារីរោ មហាបញ្ញោ មហាបុរិសោតិ វុច្ចតិ ។

បុគ្គលណាដល់នូវសេចក្តីសម្រេច គឺអរហត្ត ជាអ្នកមិនតក់ស្លុត មិនមានតណ្ហា មិនមានកិលេសដូចទីទួល បានកាត់កូនសរ គឺកិលេស ជាហេតុញ៉ាំងសត្វឲ្យទៅកាន់កំពបានហើយ កាយដែលឆ្អឹង ៣០០ កំណាត់ផ្គុំគ្នាហើយនេះរបស់បុគ្គលនោះ ឈ្មោះថា តាំងនៅក្នុងទីបំផុត ។

បុគ្គលណាមិនមានតណ្ហា មិនមានសេចក្តីប្រកាន់មាំ ជាអ្នកឈ្វាសក្នុងនិរុត្តិ (វាចាជាគ្រឿងសម្តែងចេញ) និងបទដ៏សេស ដឹងច្បាស់នូវប្រជុំនៃអក្ខរៈទាំងឡាយផង នូវខាងដើម និងខាងចុងនៃអក្ខរៈទាំងឡាយផង បុគ្គលនោះឯងតថាគតហៅថា អ្នកមានសរីរៈស្ថិតនៅក្នុងទីបំផុត មានបញ្ញាច្រើន ជាមហាបុរស ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **និដ្ឌង្គតោ** *សេចក្តីថា អរហត្ត ឈ្មោះថាការសម្រេចរបស់បព្វជិតទាំងឡាយក្នុងសាសនានេះ ដល់ គឺសម្រេចអរហត្ត*

នោះ ។

បទថា **អសន្ថាសី** *គឺដែលឈ្មោះថាមិនតក់ស្លុត ព្រោះមិនមានកិលេស ជាគ្រឿងតក់ស្លុត មានរាគៈជាដើម ក្នុងខាងក្នុងឡើយ ។*

បាទព្រះគាថាថា **អច្ឆិន្ទិ តវាសល្ហានិ** *គឺបានកាត់នូវសរដែលមានប្រក្រតី ឲ្យទៅកាន់ភពទាំងមូល ។*

បទថា **សមុស្សយោ** *គឺរាងកាយនេះរបស់បុគ្គលនោះមានក្នុងទីបំផុត ។*

បទថា **អនាទានោ** *គឺជាអ្នកមិនមានការប្រកាន់ក្នុងខន្ធជាដើម ។*

បាទព្រះគាថាថា **និវុត្តិបទកោវិទោ** *សេចក្តីថា បុគ្គលឈ្លាសក្នុងបដិសម្ភិទាទាំង ៤ គឺក្នុងនិវុត្តិ និងបទដ៏សេស ។*

ពីរបាទព្រះគាថាថា **អក្ខរានំ សន្និចាតំ ជញ្ញា បុព្វាបរានិ ច** *សេចក្តីថា រមែងដឹងនូវពួកនៃអក្ខរៈ ពោលគឺទីប្រជុំនៃអក្ខរៈទាំងឆ្ពោយ និងដឹងអក្ខរៈខាងចុងដោយអក្ខរៈខាងដើម និងអក្ខរៈខាងដើមដោយអក្ខរៈខាងចុង ឈ្មោះថា ស្គាល់អក្ខរៈខាងចុងដោយអក្ខរៈខាងដើម គឺកាលខាងដើមប្រាកដ កណ្តាល និងទីបំផុតមិនប្រាកដ ក៏រមែងដឹងបានថា នេះជាកណ្តាលនៃអក្ខរៈទាំងនោះ នេះជាទីបំផុត ឈ្មោះថា ស្គាល់អក្ខរៈខាងដើម ដោយអក្ខរៈខាងចុង គឺកាលទីបំផុតប្រាកដ កាលខាងដើម និងកណ្តាលមិនប្រាកដ ក៏រមែងដឹងបានថា នេះជាកណ្តាលនៃអក្ខរៈទាំងនេះ នេះជាដើម កាលកណ្តាលប្រាកដ កាលខាងដើម និងខាងចុងមិនប្រាកដ រមែងជ្រាបបានដូចគ្នាថា នេះជាខាងដើមនៃអក្ខរៈទាំងនេះ នេះជាទីបំផុត ។*

បទថា **មហាបញ្ញោ** សេចក្តីថា លោកអ្នកមានសីរៈ តាំងនៅក្នុងទីបំផុតនោះ ព្រះសាស្តាត្រាស់ហៅថា អ្នកមានបញ្ញាច្រើន ព្រោះជាអ្នកប្រកបដោយបញ្ញាដែលកំណត់កាន់យកនូវអត្ថ ធម៌ និរុត្តិ បដិភាណ និងសីលក្ខន្ធជាដើមដ៏ធំ និងត្រាស់ថាជាមហាបុរស ព្រោះជាអ្នកមានចិត្តរួចផុតហើយ ដោយព្រះបាលីថា ម្នាលសារីបុត្ត តថាគតហៅបុគ្គលមានចិត្តរួចផុតហើយថាមហាបុរស ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

ចំណែកមារមានចិត្តជាបគិតថា ព្រះគោតមទ្រង់ស្គាល់អញហើយ ក៏អន្តរធានទៅក្នុងទីនោះឯង ដូច្នេះ ។

រឿង មារ ចប់

រឿង ឧបកាជីវក

លំនាំដើម

ព្រះសាស្តាគ្រាឮអាជីវកឈ្មោះឧបក:ក្នុងរវាងផ្លូវ ត្រាស់ព្រះធម្មទេសនានេះថា **សព្វាភិភូ** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយព្រះសាស្តាទ្រង់សម្រេចសព្វញ្ញុតញ្ញាណហើយ ទ្រង់ញុាំងកាលឲ្យកន្លងទៅត្រង់មណ្ឌលពោធិព្រឹក្ស ៧ សប្តាហ៍ ទ្រង់កាន់ជាត្រៃ និងចីវរបស់ព្រះអង្គ យាងទៅអស់ចម្ងាយផ្លូវ ១៨ យោជន៍ តម្រង់ទៅកាន់ក្រុងពារាណសី ដើម្បីញុាំងធម្មចក្កឲ្យប្រព្រឹត្តទៅ បានទតឃើញអាជីវកឈ្មោះឧបក:ក្នុងរវាងផ្លូវ ។

ចំណែកឧបកាជីវកនោះ ឃើញព្រះសាស្តាហើយទូលសួរថា អាវុសោ ឥន្ទ្រិយរបស់អ្នកផូរផង់ ពណ៌សម្បុរក៏បរិសុទ្ធ អាវុសោបួសឧទ្ទិសអ្នកណា អ្នកណាជាសាស្តារបស់អ្នក អ្នកគាប់ចិត្តក្នុងធម៌របស់អ្នកណា ។ លំដាប់នោះ ព្រះសាស្តាត្រាស់ថា តថាគតមិនមានឧបជ្ឈាយ៍ ឬអាចារ្យឡើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះដល់ឧបកាជីវកនោះថា

សព្វាភិភូ សព្វវិទូហមស្មិ សព្វេសុ ធម្មេសុ អនូបលិត្តោ
សព្វញ្ជហោ តណ្ហាក្ខយេ វិមុត្តោ សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ ។

តថាគតជាអ្នកគ្របសង្កត់តេភូមិកធម៌ទាំងអស់ ជីងច្បាស់នូវចតុព្ភូមិក-ធម៌ទាំងអស់ មានចិត្តមិនបានជាប់នៅក្នុងតេភូមិកធម៌ទាំងអស់ លះបង់តេភូមិកធម៌ទាំងអស់ មានចិត្តរួចស្រឡះ ព្រោះអស់តណ្ហា បើតថាគត

ត្រាស់ដឹងធម៌ ដោយខ្លួនឯងហើយ ចាំបាច់យកអ្នកណា ជាគ្រូអាចារ្យ ទៀត ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សព្ភាភិភូ** *គឺគ្របសង្កត់ធម៌ក្នុងភូមិ ៣ បានទាំងអស់ ។*

បទថា **សព្វវិទូ** *គឺជាអ្នកមានធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងពួងដែលដឹងហើយ ។*

ពីរបទថា **សព្វេសុ ធម្មេសុ** *សេចក្តីថា បុគ្គលដែលតណ្ហា និងទិដ្ឋិទាំងឡាយបូកលាបមិនបាន ក្នុងធម៌ទាំងអស់ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។*

បទថា **សព្វញ្ហុតោ** *គឺលះធម៌ទាំងអស់ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ តាំងនៅ ។*

ពីរបទថា **តណ្ហក្ខយេ វិមុត្តោ** *គឺផុតហើយព្រោះអរហត្ត ពោល គឺធម៌ជាទីអស់ទៅនៃតណ្ហា ដែលខ្លួនឲ្យកើតឡើងហើយក្នុងទីបំផុតនៃការអស់ទៅនៃតណ្ហា ដោយវិមុត្តិដែលជារបស់ព្រះអាសេក្ខៈ ។*

ពីរបទថា **សយំ អភិញ្ញាយ** *គឺដឹងធម៌ មានអភិញ្ញេយ្យធម៌ជាដើមបានឯង ។*

បទថា **កមុទ្ទិសេយ្យុំ** *សេចក្តីថា តថាគតគប្បីអាងអ្នកណាទៀតថា នេះជាឧបជ្ឈាយ៍ ឬអាចារ្យរបស់តថាគត ។*

ក្នុងកាលចប់ទេសនា ឧបកាជីវកមិនត្រេកអរ មិនជំទាស់ព្រះតម្រាស់

របស់ព្រះតថាគត តែគាត់ងក់ក្បាល លៀនអណ្តាត កាន់យកផ្លូវដែលដើរទៅម្នាក់ឯង បានទៅកាន់ទីអាស្រ័យនៅរបស់ព្រានម្នាក់ហើយ ដូច្នេះឯង ។

រឿង ឧបកាជីវក ចប់

រឿង សក្កនេរវាជ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារឰសក្កទេវរាជ ត្រាស់ព្រះធម្មទេសនានេះថា **សព្ឰានំ** *ជាដើម ។*

សេចក្តីពិស្តារថា ថ្ងៃមួយ ទេវតាក្នុងស្ថានតាវត្តិង្សទេវលោក ប្រជុំគ្នាហើយ តាំងប្រស្នា ៤ ប្រការថា បណ្តាទានទាំងឡាយ ទានប្រភេទណាហ្ន៎ បណ្ឌិតពោលថា កំពូល បណ្តារសទាំងឡាយ រសប្រភេទណាហ្ន៎ បណ្ឌិតពោលថា កំពូល បណ្តាសេចក្តីត្រេកអរទាំងឡាយ ការត្រេកអរប្រភេទណាហ្ន៎ បណ្ឌិតពោលថា កំពូល ការអស់ទៅនៃតណ្ហា បណ្ឌិតពោលថា ប្រសើរបំផុត ព្រោះហេតុអ្វី សូម្បីទេវតាមួយអង្គក៏មិនអាចវិនិច្ឆ័យបញ្ហាទាំងនោះបាន ។ ទេវតាមួយអង្គសួរទេវតាមួយអង្គ ទេវតាមួយអង្គនោះ ក៏សួរទេវតាមួយអង្គទៀត ទេវតាទាំងឡាយសួរគ្នានិងគ្នាយ៉ាងនេះ ដោយអាការយ៉ាងនេះ បានត្រាច់ទៅក្នុងម៉ឺនចក្កវាឡអស់ ១២ ឆ្នាំ ។

ទេវតាក្នុងម៉ឺនចក្កវាឡ មិនឃើញអត្ថនៃបញ្ហាដោយកាល សូម្បីមាន

ប្រមាណប៉ុណ្ណេះប្រជុំគ្នាហើយ ទៅកាន់សម្នាក់ទេវរាជទាំង ៤ កាលទេវរាជ
ពោលថា បាទាំងឡាយ ហេតុអ្វី ទើបមានសន្និបាតធំ ទើបពោលថា ពួកខ្ញុំ
ចងបញ្ហា ៤ ឡើងហើយ កាលមិនអាចវិនិច្ឆ័យបាន ទើបមកកាន់សម្នាក់របស់
លោក កាលមហារាជពោលថា តើបញ្ហានោះដូចម្តេច ទើបជ្រាប់សេចក្តីនោះ
ថា ពួកខ្ញុំមិនអាចវិនិច្ឆ័យបញ្ហាទាំងនេះបាន គឺបណ្តាទាន រស និងសេចក្តី
ត្រេកអរ ទាន រស និងសេចក្តីត្រេកអរប្រកេទណាហ្ន៎ ប្រសើរបំផុត ការ
អស់ទៅនៃតណ្ហា ប្រសើរបំផុត ព្រោះហេតុអ្វី ទើបចូលមកវក ។

មហារាជទាំង ៤ ពោលថា បាទាំងឡាយ ពួកខ្ញុំក៏មិនដឹងអត្ថនៃបញ្ហា
ទាំងនោះឡើយ តែព្រះរាជារបស់ពួកយើង ទ្រង់ត្រិះរិះអត្ថដែលជនរាប់ពាន់គិត
ហើយ ទ្រង់រមែងជ្រាបដោយខណៈមួយប៉ុណ្ណោះ ទ្រង់ប្រសើរវិសេសជាងពួក
យើងទាំងឡាយ ទាំងផ្នែកបញ្ញា និងផ្នែកបុណ្យ ពួកយើងចូលទៅកាន់សម្នាក់
របស់ទ្រង់ចុះ ហើយនាំពួកទេវតាទាំងនោះ ទៅកាន់សម្នាក់របស់សក្កទេវរាជ
សូម្បីសក្កទេវរាជក៏ត្រាស់ថា បាទាំងឡាយ ហេតុអ្វី ទើបមានទេវសន្និបាតធំ
ក៏ក្រាបទូលសេចក្តីនោះ ។

សក្កទេវរាជត្រាស់ថា បាទាំងឡាយ អ្នកជំទៃមិនអាចដឹងអត្ថនៃបញ្ហា
ទាំងនេះបាន បញ្ហាទាំងនោះ ជាវិស័យរបស់ព្រះពុទ្ធ ហើយត្រាស់សួរថា
ឥឡូវនេះ ព្រះសាស្តាប្រថាប់នៅក្នុងទីណា ពួកទេវតាទូលថា ក្នុងជេតពន
មហាវិហារ ទើបសក្កៈត្រាស់ថា មកចុះ ពួកយើងនឹងទៅកាន់សម្នាក់របស់
ព្រះអង្គ មួយអន្ទើដោយពួកទេវតា ឲ្យវត្តជេតពនទាំងមូលភ្លឺហើយ ក្នុង

ចំណែកនៃរាត្រី ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ប្រថាប់ឈរក្នុងចំណែកម្ខាង កាលព្រះសាស្តាត្រាស់ថា មហាបពិត្រ ហេតុអ្វី ទើបទ្រង់យាងមក មួយអន្ទើដោយពួកទេវតាសន្ធឹកសន្ធាប់ ទើបក្រាបទូលថា បពិត្រព្រះអង្គ ពួកទេវតានាំគ្នាតាំងបញ្ហាឈ្មោះនេះ អ្នកដទៃ ឈ្មោះថា អាចដឹងនូវអត្ថនៃបញ្ហាទាំងនេះមិនមាន សូមទ្រង់ប្រកាសអត្ថនៃបញ្ហាទាំងនេះ ដល់ពួកខ្ញុំព្រះអង្គចុះ ។

ព្រះសាស្តាត្រាស់ថា សាធុ មហាបពិត្រ តថាគតបំពេញបារមី ៣០ មហាបរិច្ចាគ ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណហើយ ក៏ដើម្បីកាត់សេចក្តីសង្ស័យរបស់ជនដូចទ្រង់នោះឯង ។ សូមទ្រង់ស្តាប់បញ្ហាដែលទ្រង់សួរហើយចុះ ។ បណ្តាទានគ្រប់យ៉ាង ធម្មទានជាកំពូល បណ្តារសគ្រប់ប្រភេទ រសនៃធម៌ជាកំពូល បណ្តាសេចក្តីត្រេកអរគ្រប់យ៉ាង ការត្រេកអរក្នុងធម៌ប្រសើរ ចំណែកការអស់ទៅនៃតណ្ហាប្រសើរបំផុតពិត ព្រោះជាហេតុឲ្យសត្វសម្រេចអរហត្តដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ
សព្វរតឹ ធម្មរតិ ជិនាតិ តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។

ធម្មទានឈ្នះអាមិសទានទាំងពួង ធម្មរសឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ឈ្នះសេចក្តីត្រេកអរទាំងពួង ការអស់តណ្ហាឈ្នះទុក្ខទាំងពួង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សព្វទានំ** ជាដើម សេចក្តីថា បើបុគ្គលគប្បីថ្វាយត្រៃចីវរ ដូចស្តេចកេកខ្ចីដល់ព្រះពុទ្ធ ព្រះបចេ្ចកពុទ្ធ និងព្រះខីណាស្រពទាំងឡាយ ដែលអង្គុយជាប់គ្នាក្នុងល្វែងនៃចក្កវាឡ ដល់ព្រហ្មលោក ការអនុមោទនា ដែលព្រះពុទ្ធជាដើមទ្រង់ធ្វើដោយគាថា ៤ បាទ ក្នុងសមាគមនោះប្រសើរ ទាននោះមិនមានតម្លៃស្មើនឹងចម្រៀកទី ១៦ នៃព្រះគាថានោះឡើយ ការសម្តែងក្តី ការបង្រៀនក្តី ការស្តាប់ក្តីនូវធម៌ដែលជារបស់ធំដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត បុគ្គលឲ្យធ្វើនូវការស្តាប់ធម៌ អានិសង្សជាច្រើនរមែងមានដល់បុគ្គលនោះពិត ធម្មទាននោះឯង ដែលព្រះពុទ្ធជាដើម ទ្រង់ឲ្យប្រព្រឹត្តទៅហើយ ដោយអំណាចអនុមោទនា ដោយហោចសូម្បីគាថា ៤ បាទ ប្រសើរជាងទាន ដែលទាយកជាក់ជាត្រឲ្យពេញ ដោយបិណ្ឌបាតដ៏ប្រណីត ហើយថ្វាយដល់លោកអ្នកទាំងនោះឯង ក្រៃលែងជាងភេសជ្ជទានដែលទាយកជាក់ពេញជាត្រ ដោយសប្បិ និងប្រេងជាដើមហើយថ្វាយ ជាងសេនាសនទានដែលទាយកឲ្យសាងវិហារ ដូចគ្នានឹងមហាវិហារ និងលោហប្រាសាទទាំងឡាយមួយសែនហើយថ្វាយ ជាងបរិច្ចាគដែលអនាថបិណ្ឌិកសេដ្ឋីជាដើមប្រោព្ធវិហារទាំងឡាយ ហើយធ្វើ ព្រោះហេតុអ្វី ព្រោះថា ជនទាំងឡាយកាលបំពេញបុណ្យបែបនោះ លុះស្តាប់ធម៌ហើយប៉ុណ្ណោះ ទើបធ្វើបាន បើមិនបានស្តាប់ មិនអាចធ្វើបានឡើយ បើសត្វទាំងនេះមិនស្តាប់ធម៌សោត ក៏មិនអាចឲ្យសូម្បីបបរប្រមាណមួយវែក កត្តប្រមាណមួយវែក ព្រោះហេតុនេះ ទើបធម្មទាននោះឯង ប្រសើរជាងទានទាំងអស់ ។

ម្យ៉ាងទៀត រៀវព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធ សូម្បីសាវ័កទាំងឡាយ មានព្រះសារីបុត្តជាដើមដែលប្រកបដោយបញ្ញា ដែលអាចរាប់តំណក់ទឹកបានក្នុងកាលភ្លៀងធ្លាក់អស់មួយកប្ប ក៏មិនអាចសម្រេចសោតាបត្តិផលជាដើមដោយធម្មតារបស់ខ្លួនបាន លុះណាតែស្តាប់ធម៌ដែលព្រះអស្សជិត្ថេរជាដើមសម្តែងហើយ ទើបធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល និងធ្វើឲ្យជាក់ច្បាស់នូវសាវក-បារមីញាណ ដោយព្រះធម្មទេសនារបស់ព្រះសាស្តា ព្រោះហេតុនេះ មហាបពិត្រ ធម្មទាននោះឯង ទើបឈ្មោះថា ប្រសើរបំផុត ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **សព្វទានំ ធម្មទានំ ជិនាតិ ។**

ម្យ៉ាងទៀត រស មានរសកើតអំពីដើមជាដើមគ្រប់ប្រភេទ ដោយចំណែកខ្ពស់ សូម្បីរសនៃសុធាភោជនរបស់ទេវតាទាំងឡាយ រមែងជាបច្ច័យនៃការញុំាងសត្វឲ្យធ្លាក់ទៅក្នុងសង្សារវដ្ត ហើយសោយទុក្ខដោយពិត ។ ចំណែកធម្មរស ពោល គឺពោធិបក្ខិយធម៌ ៣៧ ប្រការ ពោល គឺលោកុត្តរធម៌ ៩ ប្រការនេះឯង ប្រសើរជាងរសទាំងពួង ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **សព្វរសំ ធម្មរសោ ជិនាតិ ។**

ម្យ៉ាងទៀត សេចក្តីត្រេកអរក្នុងបុត្រ សេចក្តីត្រេកអរក្នុងធីតា សេចក្តីត្រេកអរក្នុងទ្រព្យ សេចក្តីត្រេកអរក្នុងស្ត្រី សេចក្តីត្រេកអរមានប្រភេទមិនមែនតែមួយ មានសេចក្តីត្រេកអរក្នុងការច្រៀង និងការប្រគំជាដើម រមែងជាបច្ច័យនៃការញុំាងសត្វឲ្យធ្លាក់ទៅក្នុងសង្សារវដ្ត ហើយសោយទុក្ខដោយពិត ចំណែកការត្រេកអរដែលកើតឡើងខាងក្នុងនៃអ្នកសម្តែងក្តី អ្នកស្តាប់ក្តី បុគ្គល

ពោលទូន្មានក្តីនូវធម៌ រមែងឲ្យកើតការត្រេកអរ ហូរទឹកភ្នែក ឲ្យកើតព្រឺរោម ការត្រេកអរនោះ រមែងធ្វើទីបំផុតនៃសង្សារវដ្ត មានអរហត្ត ជាបរិយោសាន សេចក្តីត្រេកអរក្នុងធម៌បែបនេះឯង ប្រសើរជាងសេចក្តីត្រេកអរទាំងពួង ។ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **សព្វរតឹ ធម្មរតិ ជិនាតិ ។**

ចំណែកការអស់ទៅនៃតណ្ហា គឺព្រះអរហត្ត ដែលកើតឡើងក្នុងទីបំផុតនៃការអស់ទៅរបស់តណ្ហា ព្រះអរហត្តនោះ ប្រសើរជាងរបស់គ្រប់យ៉ាងពិត ព្រោះគ្របសង្កត់វដ្តទុក្ខទាំងមូល ។ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **តណ្ហាក្ខយោ សព្វទុក្ខំ ជិនាតិ ។**

កាលព្រះសាស្តា ត្រាស់អត្ថនៃព្រះគាថានេះដោយប្រការដូច្នេះនោះឯង ធម្មាភិសមយ មានដល់សត្វ ៨៤០០០ ហើយ ។

សក្កទេវរាជ ទ្រង់ស្តាប់ធម្មកថារបស់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តា ហើយទូលថា បពិត្រព្រះអង្គ ដើម្បីប្រយោជន៍អ្វីទើបទ្រង់មិនត្រាស់ឲ្យចំណែកបុណ្យដល់ពួកខ្ញុំព្រះអង្គ ក្នុងធម្មទានដែលកំពូលយ៉ាងនេះ ចាប់តាំងអំពីនេះទៅ សូមទ្រង់ប្រាប់ដល់ភិក្ខុសង្ឃ ឲ្យលោកឲ្យនូវចំណែកបុណ្យដល់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់សក្កៈហើយ ត្រាស់ឲ្យភិក្ខុសង្ឃប្រជុំគ្នាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តាំងអំពីនេះទៅ ពួកអ្នកធ្វើការស្តាប់ធម៌ធំក្តី ស្តាប់ធម៌តាមប្រក្រតីក្តី ពោលឧបនិសិន្នកថាក្តី ដោយហោចសូម្បីត្រឹមតែការអនុមោទនាក្តី ហើយគប្បីឲ្យចំណែកបុណ្យដល់សត្វទាំងពួង ។

រឿងសក្កទេវរាជ ចប់

រឿង អបុត្តកសេដ្ឋី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះអបុត្តក: ត្រាស់ព្រះធម្មទេសនានេះថា **ហានន្តិ ភោគា ទុម្មេធំ** ជាដើម ។

បានឮមកថា ព្រះបាទបសេនទិកោសល ទ្រង់ស្តាប់ការធ្វើកាលកិរិយារបស់សេដ្ឋីនោះហើយ ទើបត្រាស់សួរថា ទ្រព្យសម្បត្តិរបស់បុគ្គលដែលឥតបុត្រគួរបានអ្នកណា ទ្រង់បានស្តាប់ថា គួរដល់ព្រះរាជា ទើបឲ្យនាំទ្រព្យអំពីផ្ទះរបស់សេដ្ឋីនោះមកកាន់រាជត្រកូលអស់ ៧ ថ្ងៃ ហើយទើបយាងចូលទៅកាន់សម្នាក់របស់ព្រះសាស្តា កាលព្រះសាស្តាត្រាស់ថា មហាបពិត្រ ទ្រង់យាងមកអំពីណាទាំងកណ្តាលថ្ងៃ ទើបក្រាបទូលថា បពិត្រព្រះអង្គ គហបតីដែលជាសេដ្ឋីក្នុងក្រុងសាវត្ថីនេះធ្វើកាលកិរិយាហើយ ខ្ញុំព្រះអង្គនាំទ្រព្យសម្បត្តិសេដ្ឋីដែលមិនមានកូននោះ ទៅទុកក្នុងរាជសម្នាក់ ហើយទើបត្រឡប់មក ។

រឿងទាំងពួង គប្បីជ្រាបតាមនយដែលមកក្នុងព្រះសូត្រនោះឯង ។

កាលព្រះរាជាក្រាបទូលយ៉ាងនេះថា បានឮថា សេដ្ឋីនោះ កាលគេនាំភោជន មានរសប្រសើរផ្សេងៗ ចូលទៅដោយថាសមាស ក៏ពោលថា ពួកមនុស្សរមែងបរិភោគភោជនបែបនេះដែរឬ ពួកអ្នកធ្វើការចំអកឲ្យខ្ញុំក្នុងផ្ទះនេះឬ កាលជនទាំងនោះចូលទៅតាំងភោជន ក៏ឲ្យនូវការប្រហារដល់មនុស្សទាំងនោះដោយដុំដី និងអង្កត់ឧសជាដើម ឲ្យគេចទៅហើយ បរិភោគបាយចុងអង្ករ មានទឹកជ្រក់ជាគម្រប់ពីរ ដោយពោលថា នេះទើបជាភោជនរបស់ពួកមនុស្ស ។ កាលគេរៀបចំសំពត់ យាន និងឆត្រដែលគួរពេញចិត្តឲ្យ ក៏

ប្រហារមនុស្សទាំងនោះ ដោយដុំដី និងអង្កត់ឧសជាដើម ឲ្យគេចទៅហើយ ទ្រទ្រង់នូវសំពត់សម្បកឆ្នែ មានឆត្រស្វឹកឈើដែលទ្រទ្រង់ រមែងទៅដោយរទេះចាស់ៗ ទើបព្រះមានព្រះភាគត្រាស់ដល់បុព្វកម្មរបស់អបុត្តកសេដ្ឋីនោះ

មហាបពិត្រ រឿងធ្លាប់មានមកហើយ គហបតីសេដ្ឋីនោះ ទទួលព្រះបច្ចេកពុទ្ធព្រះនាមតគរសិខីដោយបិណ្ឌបាត ពោលថា ចូរអ្នកទាំងឡាយឲ្យបិណ្ឌបាតដល់សមណៈដូច្នេះហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ បានឮថា កាលសេដ្ឋីនោះមិនមានសទ្ធា ជាអ្នកល្ងង់ខ្លៅ ពោលយ៉ាងនោះហើយចៀសចេញទៅ ភរិយារបស់គាត់មានសទ្ធាជ្រះថ្លា គិតថា យូរហើយហ្ន៎ ទើបអញបានឮពាក្យថា ចូរឲ្យអំពីមាត់របស់សេដ្ឋីនេះ មនោរថរបស់អញពេញក្នុងថ្ងៃនេះ អញនឹងថ្វាយបិណ្ឌបាត ហើយទទួលបាត្ររបស់ព្រះបច្ចេកពុទ្ធ ឲ្យពេញដោយភោជនដ៏ប្រណីត ហើយប្រគេន ។ ចំណែកសេដ្ឋីនោះ ត្រឡប់មកឃើញព្រះបច្ចេកពុទ្ធអង្គនោះ ទើបសួរថា សមណៈបានអ្វីហើយឬ ហើយចាប់បាត្រ ឃើញបិណ្ឌបាតដ៏ប្រណីតក៏មានសេចក្តីក្តៅក្រហាយ ទើបគិតយ៉ាងនេះថា ពួកទាសៈ ឬពួកកម្មករគប្បីបរិភោគបិណ្ឌបាតនេះល្អជាង ព្រោះថា ជនទាំងនោះ កាលបរិភោគបិណ្ឌបាតនេះហើយ នឹងធ្វើការងារឲ្យអញ ចំណែកសមណៈនេះ កាលទៅបរិភោគហើយ ក៏នឹងដេកលក់ បិណ្ឌបាតរបស់អញវិនាសទទេ ម្យ៉ាងទៀត សេដ្ឋីនោះផ្តាច់ហើយនូវជីវិតរបស់កុមារម្នាក់ ដែលជាកូនរបស់បងប្រុស ព្រោះហេតុនៃទ្រព្យសម្បត្តិ ។ បានឮថា កុមារនោះចាប់ដៃរបស់សេដ្ឋីនោះត្រាច់ទៅពោលថា យាននេះជារបស់បិតាខ្ញុំ គោនេះក៏ជារបស់

គាត់ ។ លំដាប់នោះ សេដ្ឋីគិតថា ក្នុងឥឡូវនេះ ក្មេងនេះគង់ពោលយ៉ាងនេះ ក្នុងកាលដែលក្មេងនេះ ដល់នូវសេចក្តីចម្រើនហើយ អ្នកណានឹងរក្សាភោគ-ទ្រព្យទាំងឡាយក្នុងផ្ទះនេះបាន ទើបនាំក្មេងនោះទៅកាន់ព្រៃ ចាប់ត្រង់កហើយ ច្របាច់ក ដូចច្របាច់ដំឡូងឲ្យស្លាប់ហើយត្រង់គុម្ពឈើមួយកន្លែង ហើយចោលក្មេងនោះក្នុងទីនោះឯង នេះជាបុព្វកម្មរបស់សេដ្ឋីនោះ ។

ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា មហាបពិត្រ ដោយផលនៃកម្មដែលគហបតីជាសេដ្ឋី ទទួលព្រះបច្ចេកពុទ្ធ ព្រះនាមតគរសិខី ដោយបិណ្ឌបាតនោះឯង ទើបសេដ្ឋីនោះចូលដល់សុគតិ គឺស្ថានសួគ៌អស់ ៧ ជង ដោយផលដ៏សេសនៃកម្មនោះឯង ទើបសេដ្ឋីបានជាសេដ្ឋីក្នុងក្រុងសាវត្ថីនេះអស់ ៧ ជង ។ មហាបពិត្រ ដោយផលនៃកម្មដែលគហបតីជាសេដ្ឋីនោះឲ្យទានហើយ មានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយថា ពួកទាសៈ ឬកម្មករ គប្បីបរិភោគបិណ្ឌបាតនេះល្អជាង ចិត្តរបស់សេដ្ឋីនោះមិនបង្អោនទៅដើម្បីបរិភោគភត្តដែលប្រណីត មិនបង្អោនទៅដើម្បីការប្រើប្រាស់សំពត់ប្រណីត មិនបង្អោនទៅដើម្បីប្រើប្រាស់យានល្អៗ មិនបង្អោនទៅដើម្បីបរិភោគកាមគុណ ៥ ដែលល្អក្រៃលែង មហាបពិត្រ ដោយផលនៃកម្មដែលគហបតីជាសេដ្ឋីនោះ ផ្តាច់នូវជីវិតកុមារម្នាក់របស់បងប្រុស ព្រោះហេតុនៃទ្រព្យសម្បត្តិ ទើបសេដ្ឋីនោះឆេះហើយក្នុងនរកអស់ឆ្នាំជាច្រើន អស់រយឆ្នាំជាច្រើន អស់ពាន់ឆ្នាំជាច្រើន អស់សែនឆ្នាំជាច្រើន ។ ជនទាំងឡាយញុំាងសម្បត្តិ ដែលឥតកូនលើកទី ៧ នេះ ឲ្យចូលកាន់ឃ្នាំងព្រះរាជាដោយផលដ៏សេសនៃកម្មនោះឯង ។

មហាបពិត្រ មួយសោត បុណ្យចាស់របស់គហបតីដែលជាសេដ្ឋីនោះ អស់ហើយ និងបុណ្យថ្មីដែលគហបតីសេដ្ឋីនោះសន្សំហើយ មហាបពិត្រ ក្នុងថ្ងៃនេះ គហបតីដែលជាសេដ្ឋី ឆេះក្នុងមហាពេរុវនរក ។

ព្រះរាជាទ្រង់ស្តាប់ព្រះតម្រាស់របស់ព្រះសាស្តាហើយ ទើបក្រាបទូលថា បពិត្រព្រះអង្គ គួរអស្ចារ្យ នេះជាកម្មធ្ងន់ សេដ្ឋីនោះកាលកោគៈឈ្មោះថាមានប្រមាណប៉ុណ្ណេះមាន មិនប្រើប្រាស់ដោយខ្លួនឯង កាលព្រះពុទ្ធដូចទ្រង់ប្រថាប់នៅក្នុងវិហារជិតបង្កើយ ក៏មិនបានធ្វើបុញ្ញកម្ម ។

ព្រះសាស្តាត្រាស់ថា ពិតហើយ ឈ្មោះថា បុគ្គលមានបញ្ញាថោកថយបាននូវកោគៈទាំងឡាយហើយ រមែងមិនស្វែងរកព្រះនិព្វាន ម៉្យាងទៀត តណ្ហាដែលកើតឡើងព្រោះអាស្រ័យកោគៈទាំងឡាយ រមែងសម្លាប់មនុស្សទាំងនោះអស់កាលយូរ ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថានេះថា

ហានន្តិ ភោគា ទុម្មេធំ យោ ច ចារគវេសិនោ
ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ ។
តិណាទោសានិ ខេត្តានិ រាគទោសា អយំ បជា
តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហាផលំ ។

កោគៈទាំងឡាយ រមែងសម្លាប់បុគ្គលអប្បញ្ញាជា ប៉ុន្តែមិនសម្លាប់បុគ្គលអ្នកស្វែងរកត្រើយ គឺព្រះនិព្វានទេ ឯបុគ្គលអប្បញ្ញា រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃ ព្រោះចំណង់ក្នុងកោគៈ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានរាគៈអស់ហើយ រមែងជាទានមានផលច្រើន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **នោ ច ទារគវេសិនោ** *សេចក្តីថា តែកោគៈទាំងឡាយ មិនសម្ងាប់បុគ្គលដែលស្វែងរកត្រើយ គឺព្រះនិព្វានដោយប្រក្រតីឡើយ ។*

បាទព្រះគាថាថា **ទានិ អញ្ញេវ អត្តនំ** *សេចក្តីថា បុគ្គលដែលមានបញ្ញាថោកថយ រមែងសម្ងាប់ខ្លួនឯងដូចសម្ងាប់បុគ្គលដទៃ ព្រោះការចង់បានដែលកើតឡើងព្រោះអាស្រ័យកោគៈទាំងឡាយ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងអបុត្តកសេដ្ឋី ចប់

រឿង អង្គុរទេវបុត្រ

លំនាំដើម

ព្រះសាស្តា កាលគង់នៅលើទែនបណ្តុកម្ពលសិលា ទ្រង់ប្រារព្ធអង្គុរ-ទេវបុត្រ ត្រាស់ព្រះធម្មទេសនានេះថា **តិណាទោសានិ ខេត្តានិ** ជាដើម ។

ខ្ញុំធ្វើរឿងឲ្យពិស្តារហើយ ក្នុងព្រះគាថាថា **យេ ឈានប្បសុតា ធីរា** ជាដើម សមដូចពាក្យដែលខ្ញុំប្រារព្ធឥន្ទកទេវបុត្រ ពោលក្នុងរឿងនោះ ដូច្នេះថា បានឮថា ឥន្ទកទេវបុត្រនោះ ញ៉ាំងភិក្ខាមួយវែកដែលគេនាំមកដើម្បីខ្ជួនដល់ព្រះអនុរុទ្ធត្ថេរ ដែលចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ បុណ្យរបស់ឥន្ទកទេវបុត្រនោះ មានផលច្រើនជាងទានដែលអង្គុរទេវបុត្រធ្វើដោយចង្រ្កានតម្រៀបគ្នា ១២ យោជន៍ ថ្វាយហើយអស់មួយម៉ឺនឆ្នាំ ព្រោះហេតុនោះ ទើបឥន្ទកទេវបុត្រពោលយ៉ាងនោះ ។ កាលឥន្ទកទេវបុត្រពោលយ៉ាងនោះហើយ ទើបព្រះសាស្តាត្រាស់ថា ម្នាលអង្គុរៈ ឈ្មោះថា ការជ្រើសរើសឲ្យទាន គួរទានរបស់ឥន្ទកៈនោះ ជាទានមានផលច្រើន ដូចពូជដែលព្រោះល្អហើយ ក្នុងស្រែល្អយ៉ាងនេះ តែអ្នកមិនបានធ្វើយ៉ាងនោះ ព្រោះហេតុនោះ ទើបទានរបស់អ្នកមិនមានផលច្រើន កាលទ្រង់ប្រកាសអត្ថនេះ ទើបត្រាស់ថា

> បុគ្គលគួរជ្រើសរើសឲ្យទាន ក្នុងខេត្តដែលខ្ជួនឲ្យហើយ នឹងមានផលច្រើន ព្រោះការជ្រើសរើសឲ្យ ព្រះសុគតទ្រង់សរសើរហើយ ទានដែលឲ្យក្នុងបុគ្គលជាទក្ខិណេយ្យ ក្នុងជីវលោកនេះ ជាទានមានផលច្រើន ដូចពូជដែលព្រោះក្នុងស្រែល្អ ដូច្នោះ ។

កាលទ្រង់សម្តែងឲ្យក្រៃលែងឡើង ទើបទ្រង់ភាសិតព្រះគាថាទាំងនេះ

តិណាទោសានិ ខេត្តានិ　　ទោសទោសា អយំ បជា
តស្មា ហិ វីតទោសេសុ　　ទិន្នំ ហោតិ មហប្ផលំ ។
តិណាទោសានិ ខេត្តានិ　　មោហាទោសា អយំ បជា
តស្មា ហិ វីតមោហេសុ　　ទិន្នំ ហោតិ មហប្ផលំ ។
តិណាទោសានិ ខេត្តានិ　　ឥច្ឆាទោសា អយំ បជា
តស្មា ហិ វីតឥច្ឆេសុ　　ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានទោស:ជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានទោស:អស់ហើយ រមែងជាទានមានផលច្រើន ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានមោហ:ជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានមោហ:អស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានសេចក្តីប្រាថ្នាជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានសេចក្តីប្រាថ្នាអស់ហើយ រមែងជាទានមានផលច្រើន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **តិណាទោសានិ** *សេចក្តីថា សេចក្តីពិតស្មៅទាំងឡាយ មានថ្លៅជាដើមកាលដុះឡើង រមែងប្រទូស្តស្រែនៃបុព្វណ្ណជាតិ*

និងអបរណ្ណជាតិ ព្រោះហេតុនោះ ទើបស្រែទាំងនោះ មិនដុះលូតលាស់ល្អ បាន រាគៈកាលកើតឡើងខាងក្នុងនៃសត្វទាំងឡាយ រមែងប្រទូស្តសត្វទាំង-ឡាយ ព្រោះហេតុនោះ ទានដែលឲ្យក្នុងបុគ្គលដែលត្រូវរាគៈប្រទូស្តទាំងនោះ ទើបជារបស់មិនមានផលច្រើន ចំណែកទានដែលឲ្យក្នុងព្រះខីណាស្រពទាំង-ឡាយ ជារបស់មានផលច្រើន ព្រោះដូច្នោះ ទើបព្រះសាស្តាត្រាស់ថា ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វមានរាគៈជាទោសដូច្នោះឯង ទានដែលឲ្យក្នុងបុគ្គលដែលប្រាសចាករាគៈ ទើបជារបស់មានផលច្រើន ។ ក្នុងគាថាដ៏សេសក៏នយនេះឯង ។

ក្នុងកាលចប់ទេសនា អង្គុរទេវបុត្រ និងឥន្ទកទេវបុត្រតាំងនៅក្នុងសោតាបត្តិផល ។ ទេសនាបានជាប្រយោជន៍ដល់ពួកទេវបុត្រដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿងអង្គុរទេវបុត្រ ចប់

តណ្ហាវគ្គ ចប់

វគ្គទី ២៤ ចប់

សុត្តន្តបិដក

ធម្មបទគាថា ភិក្ខុវគ្គទី ២៥

[៣៥] *ការសង្រួមភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្តាតប្រពៃ ការសង្រួមកាយប្រពៃ ការសង្រួមវាចាប្រពៃ ការសង្រួមចិត្តប្រពៃ ការសង្រួមទាំងអស់ប្រពៃ ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។*

ជនណា សង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាព ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋាន ដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតទាំងឡាយហៅជននោះថា ភិក្ខុ ។

ភិក្ខុណា សង្រួមមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្តមិនរាយមាយ សម្តែងអត្ថផង ធម៌ផងបាន ភាសិតរបស់ភិក្ខុនោះ ទើបឈ្មោះថា ពីរោះ ។

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយៗ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

ភិក្ខុមិនគប្បីមើលងាយលាភរបស់ខ្លួន (ដែលកើតឡើងដោយធម៌) មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ បើចង់បានលាភរបស់ភិក្ខុដទៃ រមែងមិនបានសមាធិឡើយ ។ បើភិក្ខុសូម្បីមានលាភតិច មិនមើលងាយលាភរបស់ខ្លួន ទេវតា និងមនុស្សទាំងឡាយ តែងសរសើរភិក្ខុនោះឯង ដែលជាអ្នកមានព្យាយាមជាគ្រឿងអាស្រ័យរស់នៅដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

បុគ្គលណា មិនមានសេចក្តីប្រកាន់ក្នុងនាម និងរូបថាជារបស់អញ ដោយប្រការទាំងពួង មួយទៀត បុគ្គលណា មិនសោកស្តាយ ព្រោះនាម និងរូបដែលមិនមាន បុគ្គលនោះឯង តថាគតហៅថា កិក្ខុ ។

កិក្ខុណា នៅដោយអំណាចមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា កិក្ខុនោះ រមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។ ម្នាលភិក្ខុ ចូរអ្នកស្តារទូក គឺអត្តភាពនេះ ទូកដែលអ្នកស្តារហើយ នឹងដល់ត្រើយធាប់ អ្នកកាត់រាគៈ និងទោសៈបានហើយ អំពើនោះ នឹងអាចដល់នូវព្រះនិព្វាន ។

កិក្ខុគប្បីកាត់ឱរម្ភាគិយសំយោជនៈ ៥ ផង គប្បីលះបង់ឧទ្ធម្ភាគិយ-សំយោជនៈ ៥ ផង គប្បីចម្រើនឥន្ទ្រិយ ៥ តទៅ កិក្ខុអ្នកកន្លងកិលេសជាគ្រឿងជំពាក់ ៥ (រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ) បានហើយ ទើបតថាគតហៅថា អ្នកឆ្លងអន្ទង់បាន ។

ម្នាលភិក្ខុ ចូរអ្នកពិនិត្យផង ចូរកុំជាអ្នកប្រមាទផង ចិត្តរបស់អ្នក ចូរកុំវិលទៅរកកាមគុណទៀយ អ្នកចូរកុំប្រមាទ ទំពាស៊ីនូវដុំលោហៈ កុំឲ្យជាអ្នកកាលភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះទុក្ខ ដូច្នេះទៀយ ។ ការពិនិត្យ មិនមានដល់បុគ្គល អ្នកមិនមានប្រាជ្ញា ប្រាជ្ញាមិនមានដល់បុគ្គលអ្នកមិនពិនិត្យ ការពិនិត្យ និងប្រាជ្ញា មានក្នុងបុគ្គលណា បុគ្គលនោះឯង ឈ្មោះថាស្ថិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

សេចក្តីត្រេកអរ ដែលមិនមែនជារបស់មនុស្ស រមែងមានដល់កិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នកឃើញធម៌ដោយប្រពៃ ។ កិក្ខុ

ពិចារណាការកើតឡើង និងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះរមែងបានបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។

គុណ ៣ ប្រការនេះ គឺការរក្សាឥន្ទ្រិយ ១ សេចក្តីសន្តោស ១ ការសង្រួមក្នុងបាតិមោក្ខ ១ ជាខាងដើមនៃព្រះនិព្វាននោះ តែងមានដល់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះ (ម្នាលភិក្ខុ) អ្នកចូរគប់រកកល្យាណមិត្ត អ្នកមានព្យាយាមជាគ្រឿងរស់ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

ភិក្ខុគប្បីជាអ្នកប្រព្រឹត្តធ្ងើបដិសណ្ឋារៈ គប្បីជាអ្នកឈ្លាសក្នុងអាចារព្រោះហេតុទាំង ២ នោះ អ្នកនឹងមានបាមោជ្ជច្រើន នឹងធ្វើទីបំផុតទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីជម្រុះរាគៈ និងទោសៈចេញ ដូចម៉ិះជម្រុះផ្តាម៉ិះទាំងឡាយ ដែលស្ងិតហើយ ដូច្នោះ ។

ភិក្ខុអ្នកមានកាយរម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសក្នុងលោក ខ្ចាក់ចោលហើយ ទើបតថាគតហៅថា អ្នកស្ងប់រម្ងាប់ ។

អ្នកចូរជាស់តឿនខ្លួនដោយខ្លួនឯង ចូរពិនិត្យខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះ បើមានស្មារតី រក្សាខ្លួនទុកហើយ នឹងនៅជាសុខ ។

មែនពិត ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯងជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូររវាំងខ្លួន ដូចពាណិជ្ជរវាំងសេះដ៏ល្អ ។

កិកិអ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា រមែងបាននូវបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

កិកិណាអៅកំលោះ ប្រឹងប្រែងក្នុងព្រះពុទ្ធសាសនា កិកិនោះ រមែងញ៉ាំងលោកនេះឲ្យភ្លឺស្វាងបាន ដូចព្រះចន្ទ្រដែលរះផុតអំពីពពក ។

កិកិវគ្គទី ២៥ ចប់

អដ្ឋកថា

ភិក្ខុវគ្គទី ២៥

រឿង ភិក្ខុ ៥ រូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ ៥ រូប ត្រាស់ព្រះធម្មទេសនានេះថា **ចក្ខុនា សំវរោ សាធុ** *ជាដើម ។*

បានឮថា បណ្តាភិក្ខុ ៥ រូបនោះ មួយរូបៗ រក្សាទ្វារទាំង ៥ មានចក្ខុទ្វារជាដើម មួយរូបមួយទ្វារប៉ុណ្ណោះ ។

ថ្ងៃមួយ ពួកលោកប្រជុំគ្នាហើយ ប្រកែកគ្នាថា ខ្ញុំរមែងរក្សាទ្វារដែលរក្សាបានលំបាក ខ្ញុំរក្សាទ្វារដែលរក្សាបានលំបាក ហើយពោលថា ពួកយើងក្រាបទូលព្រះសាស្តាហើយ នឹងជីងសេចក្តីនេះ ទើបចូលទៅគាល់ព្រះសាស្តា ក្រាបទូលសួរថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គរក្សាទ្វារ មានចក្ខុទ្វារជាដើម រមែងសម្គាល់ថា ទ្វារដែលខ្លួនរក្សានោះឯង ជាទ្វារដែលរក្សាបានដោយលំបាក បណ្តាពួកខ្ញុំព្រះអង្គ អ្នកណាហ្ន៎រក្សាទ្វារ ដែលរក្សាបានដោយលំបាក ។

ព្រះសាស្តា ទ្រង់មិនញ៉ាំងភិក្ខុណាមួយឲ្យអាក់អន់ចិត្ត ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទ្វារទាំងអស់នោះជាវត្តុរក្សាបានដោយលំបាកពិត ម៉្យាងទៀត ពួកអ្នកមិនសង្រួមហើយក្នុងទ្វារទាំង ៥ ក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុង

កាលមុន ពួកអ្នកក៏មិនសង្រួមហើយ ពួកអ្នកមិនប្រព្រឹត្តក្នុងឧវាទរបស់បណ្ឌិត ទាំងឡាយ ដល់នូវការអស់ទៅនៃជីវិត ព្រោះភាពដែលទ្វារទាំងនោះ ខ្ជួនមិន បានសង្រួមហើយនោះឯង កាលភិក្ខុទាំងនោះទូលអង្វរថា បពិត្រព្រះអង្គ តើ មិនសង្រួមក្នុងកាលណា ទើបត្រាស់រឿងតក្កសិលាជាតកឲ្យពិស្តារ ហើយ ត្រាស់ព្រះគាថានេះថា

> យើងមិនបានលុះក្នុងអំណាចនៃពួកយក្ខិនីឡើយ ព្រោះ
> មានសេចក្តីព្យាយាមដ៏មាំ ក្នុងឧបាយគ្រឿងណែនាំរបស់
> ព្រះបច្ចេកពុទ្ធ ជាអ្នកឈ្លាសផង ព្រោះភាពជាអ្នកគ្រប
> សង្កត់សេចក្តីខ្លាច និងសេចក្តីតក់ស្លុតផង សុវត្ថិភាព
> ចាកភ័យដ៏ធំនោះ មានដល់ខ្ញុំ ។

ព្រះមហាសត្វបានទទួលអភិសេកហើយ ក្នុងកាលរាជត្រកូលដល់ នូវការអស់ទៅនៃជីវិត ព្រោះអំណាចនៃយក្ខិនីទាំងឡាយ ប្រថាប់គង់លើ រាជអាសនៈខាងក្រោមស្វច្ឆត្រ ទតសិរីសម្បត្តិរបស់ទ្រង់ហើយ ត្រាស់ថា ឈ្មោះថា សេចក្តីព្យាយាមនេះ សត្វទាំងឡាយគួរធ្វើពិត ហើយទ្រង់បន្ទឹ ដោយអំណាចបីតិ ទ្រង់ប្រជុំជាតកថា សូម្បីក្នុងកាលនោះ អ្នកទាំងឡាយ ជាជន ៥ នាក់ មានអាវុធក្នុងដៃ ចោមរោមព្រះមហាសត្វដែលយាងចេញ ទៅដើម្បីប្រយោជន៍គ្រប់គ្រងរាជសម្បត្តិ ក្នុងនគរតក្កសិលា ធ្វើដំណើរទៅ មិនសង្រួមហើយក្នុងអារម្មណ៍ មានរូបារម្មណ៍ជាដើម ដែលយក្ខិនីទាំង-ឡាយនាំចូលមក ដោយអំណាចនៃទ្វារ មានចក្ខុទ្វារជាដើមក្នុងរវាងផ្លូវ មិន

ប្រព្រឹត្តក្នុងឱវាទរបស់បណ្ឌិត សម្ដីងមើល ត្រូវយក្ខិនីទាំងឡាយទំពាស៊ី ដល់នូវការអស់ទៅនៃជីវិត ។ ចំណែកព្រះរាជា ទ្រង់សង្រ្គមក្នុងអារម្មណ៍ទាំងនោះ មិនអើពើដល់យក្ខិនី ដែលនិម្មិតភេទដូចទេពធីតា ដើរទៅអំពីខាងក្រោយ ដល់នគរតក្កសិលាដោយសួស្ដី ហើយបានជាព្រះរាជា គឺតថាគតនេះឯង ហើយត្រាស់ថា ធម្មតាភិក្ខុ គួរសង្រ្គមទ្វារទាំងឡាយ ព្រោះថា ភិក្ខុសង្រ្គមទ្វារទាំងនោះ តែងផុតចាកទុក្ខទាំងពួងបាន ដូច្នេះហើយ កាលទ្រង់សម្ដែងធម៌ បានភាសិតព្រះគាថាទាំងនេះថា

ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ
ឃានេន សំវរោ សាធុ សាធុ ជិវ្ហាយ សំវរោ
កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ
មនសា សំវរោ សាធុ សាធុ សព្វត្ត សំវរោ
សព្វត្ត សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ ។

ការសង្រ្គមភ្នែកប្រពៃ ការសង្រ្គមត្រចៀកប្រពៃ ការសង្រ្គមច្រមុះប្រពៃ ការសង្រ្គមអណ្ដាតប្រពៃ ការសង្រ្គមកាយប្រពៃ ការសង្រ្គមវាចាប្រពៃ ការសង្រ្គមចិត្តប្រពៃ ការសង្រ្គមទាំងអស់ប្រពៃ ភិក្ខុសង្រ្គមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

សេចក្ដីអធិប្បាយ

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចក្ខុនា** *ជាដើមក្នុងព្រះគាថានោះដូចតទៅ*

ក្នុងកាលណារូបារម្មណ៍ មកកាន់គន្ធង់ចក្ខុទ្វារបស់ភិក្ខុ ក្នុងកាលនោះ កាលភិក្ខុមិនត្រេកអរក្នុងអារម្មណ៍ដែលគួរប្រាថ្នា មិនប្រទូស្តក្នុងអារម្មណ៍ដែលមិនគួរប្រាថ្នា មិនញ៉ាំងការវង្វេងឲ្យកើតឡើង ព្រោះការសម្លឹងដែលមិនស្មើការសង្រួម គឺការរារាំង បានដល់ ការបិទ សំដៅដល់ការរក្សា ឈ្មោះថាជាកិរិយាដែលភិក្ខុធ្វើហើយក្នុងទ្វារនោះ ការសង្រួមចក្ខុនោះ បែបនោះរបស់ភិក្ខុនោះ ជាគុណញ៉ាំងប្រយោជន៍ឲ្យសម្រេច នយសូម្បីក្នុងទ្វារដទៃ មានសោតទ្វារជាដើម ក៏ដូចគ្នានឹងនយនេះ ។

ការសង្រួម ឬការមិនសង្រួម រមែងមិនកើតក្នុងទ្វារទាំងឡាយ មានចក្ខុទ្វារជាដើមឡើយ តែការសង្រួម ឬការមិនសង្រួមនេះ រមែងបានក្នុងវិថីនៃជវនចិត្តខាងមុខ ពិតហើយ ក្នុងកាលនោះ ការមិនសង្រួមកាលកើតឡើងជាអកុសលធម៌ ៥ យ៉ាង គឺការមិនជឿ ១ ការមិនអត់ធន់ ១ ការខ្ជិលច្រអូស ១ ការមិនមានស្មារតី ១ ការមិនដឹង ១ រមែងបានក្នុងអកុសលវិថី ។ សេចក្តីសង្រួមកាលកើតឡើង ជាកុសលធម៌ ៥ យ៉ាង គឺការជឿ ១ ការអត់ធន់ ១ សេចក្តីព្យាយាម ១ ការមានស្មារតី ១ ការដឹង ១ រមែងបានក្នុងកុសលវិថី ។

ឯកាយបសាទក្តី ចោបនកាយក្តី រមែងបានក្នុងពីរបទថា **ការយេន សំវរោ** *ពាក្យថា កាយបសាទ និងចោបនកាយទាំងពីរយ៉ាងនោះ គឺកាយទ្វារនោះឯង ។ ក្នុងកាយទ្វារទាំងពីរនោះ ព្រះសាស្តាត្រាស់ការសង្រួម និងការមិនសង្រួមក្នុងបសាទទ្វារនោះឯង ។ ត្រាស់បាណាតិបាត អទិន្នាទាន និង*

មិច្ឆាចារ ដែលមានបសាទទ្វារនោះជាទីតាំងក្នុងចោបនទ្វារ ។ ទ្វារនោះ ឈ្មោះថា ភិក្ខុមិនសង្រួមហើយ ព្រោះអកុសលធម៌ទាំងនោះ ដែលកើតឡើងក្នុងអកុសលវិថី មួយអន្ទើដោយបសាទទ្វារ និងចោបនទ្វារទាំងនោះ ទ្វារនោះ ឈ្មោះថា ភិក្ខុសង្រួមហើយ ព្រោះវិរតិទាំងឡាយ មានចេតនាជាគ្រឿងវៀរចាក បាណាតិបាតជាដើម ដែលកើតឡើងក្នុងកុសលវិថី ។

ចោបនវាចា ត្រាស់ក្នុងពីរបទនេះថា **សាធុ វាចាយ** *ទ្វារនោះឈ្មោះថា ភិក្ខុមិនសង្រួមហើយ ព្រោះវចីទុច្ចរិតទាំងឡាយ មានមុសាវាទជាដើម ដែលកើតឡើង មួយអន្ទើដោយចោបនវាចានោះ ឈ្មោះថាដែលភិក្ខុសង្រួមហើយ ព្រោះវិរតិទាំងឡាយ មានចេតនាជាគ្រឿងវៀរចាកមុសាវាទជាដើម ។*

មនោទុច្ចរិតទាំងឡាយ មានអភិជ្ឈាជាដើម និងដោយចិត្តជនៃចាកចិត្ត ដែលសូរទៅ រមែងមិនមានក្នុងពីរបទនេះថា **មនសា សំវរោ ។** *តែទ្វារនោះ ឈ្មោះថា ភិក្ខុមិនសង្រួមហើយ ព្រោះមនោទុច្ចរិតទាំងឡាយ មានអភិជ្ឈាជាដើម ដែលកើតឡើងក្នុងខណៈនៃជវនចិត្តក្នុងមនោទ្វារ ឈ្មោះថា ភិក្ខុសង្រួមហើយ ព្រោះមនោសុចរិតទាំងឡាយ មានអនភិជ្ឈាជាដើម (ដែលកើតឡើង ក្នុងខណៈនៃជវនចិត្តក្នុងមនោទ្វារ) ។*

ពីរបទថា **សាធុ សព្វត្ថ** *សេចក្តីថា ការសង្រួមក្នុងទ្វារទាំងពួង មានចក្ខុទ្វារជាដើមនោះ ជាគុណញុំងប្រយោជន៍ឲ្យសម្រេច ។ ព្រះមានព្រះភាគទ្រង់សម្តែងទ្វារ ដែលភិក្ខុសង្រួម ៨ យ៉ាង និងទ្វារដែលភិក្ខុមិនសង្រួម ៨ យ៉ាង ដោយព្រះពុទ្ធវចនៈមានប្រមាណប៉ុណ្ណេះ ។ ភិក្ខុដែលតាំងនៅក្នុងទ្វារ*

ដែលមិនសង្រួម ៨ យ៉ាងនោះ រមែងមិនផុតចាកទុក្ខ ដែលមានវដ្ត:ជាមូល ចំណែកភិក្ខុតាំងនៅក្នុងទ្វារដែលសង្រួម រមែងផុតចាកទុក្ខ ដែលមានវដ្ត:ជាមូលទាំងអស់បាន ព្រោះដូច្នោះ ទើបព្រះសាស្តាត្រាស់ថា **សព្វត្ត សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ ។**

ក្នុងកាលចប់ទេសនា ភិក្ខុ ៥ រូបតាំងនៅក្នុងសោតាបត្តិផល ទេសនាមានប្រយោជន៍ដល់មហាជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង ភិក្ខុ ៥ រូប

រឿង ភិក្ខុសម្ងាប់ហង្ស

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកសម្ងាប់ហង្សមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **ហត្ថសញ្ញតោ** ជាដើម ។

បានឣថា សម្ងាញ់ពីរនាក់ក្នុងក្រុងសាវត្ថី បានចេញបព្វជ្ជាឧបសម្បទាក្នុងសម្នាក់ភិក្ខុទាំងឡាយហើយ ដោយច្រើនត្រាច់ទៅរួមគ្នា ។

ថ្ងៃមួយ ភិក្ខុពីររូបនោះ ទៅកាន់ស្ទឹងអចិរវតី ស្រង់ទឹកហើយអាំងកម្តៅថ្ងៃ បានឈរនិយាយគ្នាដល់សារាណីយកថា ក្នុងខណ:នោះ ហង្សពីរហើរមកតាមអាកាស ។

ខណ:នោះ ភិក្ខុមួយរូបរើសជុំក្រួសហើយពោលថា ខ្ញុំនឹងផ្ទាត់ភ្នែករបស់

ហង្សមួយ ភិក្ខុមួយរូបទៀតពោលថា លោកគ្មានសមត្ថភាពទេ ភិក្ខុមួយរូបទៀតពោលថា ក្អែកខាងនេះលើកទុកចុះ ខ្ញុំនឹងផ្ចាត់ក្អែកម្ខាងទៀត ភិក្ខុមួយរូបទៀតពោលថា ក្អែកខាងនោះ លោកក៏មិនអាចផ្ចាត់ចំដូចគ្នា ភិក្ខុមួយរូបទៀតពោលថា បើយ៉ាងនោះ ចូរលោកចាំមើល ហើយផ្ចាត់គ្រាប់ក្រួសមួយដុំទៅអំពីក្រោយហង្ស ហង្សបានឮសំឡេងក្រួស (ជ្រែកខ្យល់) ទើបត្រឡប់ក្រោយដើម្បីមើល ខណៈនោះ លោកក៏ផ្ចាត់ដុំក្រួសទីពីរ ត្រូវក្អែកហង្សម្ខាងធ្លុះទៅម្ខាង ហង្សស្រែក ហើយធ្លាក់ទៀបជើងរបស់ភិក្ខុទាំងនោះឯង ។

ភិក្ខុទាំងឡាយ ឃើរក្នុងទីនោះៗ ឃើញហើយ ទើបពោលថា អាវុសោ អ្នកបួសក្នុងព្រះពុទ្ធសាសនាធ្វើបាណាតិបាត ឈ្មោះថា ធ្វើកម្មមិនសមគួរហើយ នាំភិក្ខុទាំងពីររូបនោះ ទៅគាល់ព្រះតថាគត ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកធ្វើបាណាតិបាតពិតឬ កាលលោកក្រាបទូលថា ករុណាព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនា ដែលជាហេតុនាំសត្វចេញចាកទុក្ខបែបនេះ បានធ្វើហើយយ៉ាងនេះ ព្រោះហេតុអ្វី បណ្ឌិតក្នុងកាលមុន កាលព្រះពុទ្ធមិនទាន់កើតឡើងនៅគ្រប់គ្រងផ្ទះ គង់ធ្វើសេចក្តីរង្គៀសក្នុងឋានៈសូម្បីមានប្រមាណតិចតួច ឯអ្នក បួសក្នុងព្រះពុទ្ធសាសនាបែបនេះ មិនធ្វើសូម្បីត្រឹមតែសេចក្តីរង្គៀសកាលភិក្ខុទាំងនោះទូលអារាធនាហើយ ទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីត កាលព្រះបាទធនញ្ជ័យសោយរាជសម្បត្តិ ក្នុងនគរឈ្មោះឥន្ទបត្ត ក្នុងដែនកុរុ ។ ព្រះពោធិសត្វបដិសន្ធិក្នុងព្រះគភ៌របស់អគ្គមហេសីនៃ

ព្រះរាជាអង្គនោះ ដល់នូវភាពជាអ្នកដឹងក្តីហើយដោយលំដាប់ ទ្រង់រៀនសិប្បៈទាំងឡាយក្នុងនគរតក្កសិលាហើយ ព្រះបិតាទ្រង់ឲ្យតាំងនៅក្នុងតំណែងជាឧបរាជ ។ ចំណែរតមក អំណឹះឥតពីព្រះបិតាទៅ បានទទួលរាជសម្បត្តិហើយ ទ្រង់មិនកន្ទងទសពិធរាជធម៌ ទ្រង់តាំងនៅក្នុងកុរុធម៌ហើយ ។ សីល ៥ ឈ្មោះថា កុរុធម៌ ។ ព្រះពោធិសត្វទ្រង់រក្សាសីល ៥ នោះ ធ្វើឲ្យបរិសុទ្ធ ព្រះជននី ព្រះអគ្គមហេសី ព្រះអនុជ្ជ ឧបរាជ ព្រាហ្មណបុរោហិត អមាត្យអ្នកកាន់ខ្សែ គឺអ្នកវាស់វែង សារថី សេដ្ឋី មហាមាត្យ នាយឃ្លាំង អ្នករក្សាទ្វារ នាងវណ្ណទាសី ដែលជាស្រីធ្វើនគរឲ្យស្អាតរបស់ព្រះពោធិសត្វនោះ តែងរក្សាសីល ៥ ដូចព្រះពោធិសត្វ ដោយប្រការដូច្នេះ ។

កាលជនទាំង ១១ នាក់នោះ រក្សាកុរុធម៌យ៉ាងនោះ កាលព្រះរាជាព្រះនាមកាលិង្គៈ សោយរាជសម្បត្តិក្នុងនគរទន្តបុរីក្នុងដែនកាលិង្គៈ ភ្លៀងមិនបានធ្លាក់ក្នុងដែនរបស់ព្រះអង្គឡើយ ឯជីវមង្គលឈ្មោះអញ្ជនាសកៈរបស់ព្រះមហាសត្វ ជាសត្វមានបុណ្យច្រើន អ្នកដែននាំគ្នាក្រាបទូលដោយសម្គាល់ថា កាលនាំជីវនោះមកហើយ ភ្លៀងនឹងធ្លាក់ ។

ព្រះរាជាទ្រង់បញ្ជូនពួកព្រាហ្មណ៍ទៅដើម្បីនាំជីវនោះមក ។ ព្រាហ្មណ៍ទាំងនោះទៅហើយ ទូលសូមជីវជាមួយព្រះមហាសត្វហើយ ដើម្បីសម្តែងអាការសូមនេះរបស់ព្រាហ្មណ៍ទាំងនោះ ទើបព្រះសាស្តាត្រាស់ជាតក ក្នុងតិកនិបាតនេះជាដើមថា

បពិត្រព្រះជនាធិបតី យើងទាំងឡាយដឹងច្បាស់នូវសទ្ធា និង

សីលរបស់ព្រះអង្គហើយ នឹងទទួលយកនូវជំរីមានសម្បុរ

ប្រាកដស្មើដោយផ្ការអញ្ជន ទៅក្នុងសម្នាក់នៃព្រះបាទកាលិង្គៈ ។

កាលព្រាហ្មណ៍ទាំងឡាយនាំជីរមកហើយ កាលភ្លៀងមិនធ្លាក់ ដោយទ្រង់សម្គាល់ថា ព្រះរាជានោះទ្រង់រក្សាកុរុធម៌ ព្រោះដូច្នោះ ទើបភ្លៀងធ្លាក់ក្នុងដែនរបស់ព្រះអង្គ ទើបព្រះបាទកាលិង្គៈទ្រង់បញ្ជូនពួកព្រាហ្មណ៍ និងអមាត្យទៅទៀត ដោយព្រះតម្រាស់ថា ពួកលោកចូរចារីកកុរុធម៌ដែលព្រះរាជានោះរក្សាក្នុងជំពារមាសហើយនាំមក កាលព្រាហ្មណ៍ និងអមាត្យទាំងនោះទៅទូលសួម ជនទាំងអស់នោះរាប់តាំងអំពីព្រះរាជាជាដើម ធ្វើអាការត្រឹមតែការរង្គៀសណាមួយក្នុងសីលទាំងឡាយរៀងៗ ខ្លួនហើយឃាត់ថា សីលរបស់ពួកយើងមិនបរិសុទ្ធ ត្រូវព្រាហ្មណ៍ និងអមាត្យទាំងនោះអង្វរពេកថា ការបែកធ្លាយនៃសីលមិនមានដោយហេតុត្រឹមប៉ុណ្ណេះទេ្លយ ទើបបានប្រាប់សីលទាំងឡាយ រៀងៗ ខ្លួនហើយ ។

ព្រះបាទកាលិង្គៈ បានទតកុរុធម៌ដែលពួកព្រាហ្មណ៍ និងអមាត្យចារីកក្នុងជំពារមាសនាំមក ទ្រង់សមាទានបំពេញឲ្យបរិសុទ្ធដោយល្អ ទើបភ្លៀងធ្លាក់ក្នុងដែនរបស់ព្រះអង្គ ដែនបានក្សេម មានភិក្ខាភកបានដោយងាយហើយ ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ ទ្រង់ប្រជុំជាតកថា ស្រីផ្កាមាសក្នុងកាលនោះ បានមកជាឧប្បលវណ្ណា អ្នករក្សាទ្វារបានមកជាភិក្ខុឈ្មោះបុណ្ណៈ អមាត្យអ្នកកាន់ខ្សែបានមកជាកច្ចានភិក្ខុ អមាត្យដែលជានាយឃ្នាំងបានមកជាកោលិតៈ សេដ្ឋីក្នុងកាលនោះបានជាសារីបុត្ត នាយសារថីបាន

ជាអនុរុទ្ធ ព្រាហ្មណ៍បានជាកស្សបត្ថេរ ឧបវាជបានជានន្ទបណ្ឌិត ព្រះមហេសី បានជារាហុលមាតា ព្រះជននីបានជាព្រះនាងមាយាទេវី ព្រះបាទកុរុបានជាព្រះពោធិសត្វ ចូរពួកអ្នកចាំជាតកដោយអាការយ៉ាងនេះ ។

ដូច្នេះហើយត្រាស់ថា ម្នាលភិក្ខុ បណ្ឌិតក្នុងកាលមុន កាលសេចក្តីសុខមានប្រមាណតិចកើតឡើងហើយ ធ្វើសីលភេទរបស់ខ្លួនឲ្យជាគ្រឿងរង្គៀសហើយយ៉ាងនេះ ចំណែកអ្នកបួសក្នុងសាសនារបស់ព្រះពុទ្ធដូចតថាគត គង់ធ្វើបាណាតិបាត ឈ្មោះថា ធ្វើកម្មជ្រុនក្រៃពេក ធម្មតាភិក្ខុ គួរជាអ្នកសង្រួមដោយដៃ ជើង និងវាចា ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ហត្ថសញ្ញតោ បាទសញ្ញតោ វាចាយ សញ្ញតោ សញ្ញតត្តមោ
អជ្ឈត្តរតោ សមាហិតោ ឯកោ សន្តុសិតោ តមាហុ ភិក្ខុំ ។

ជនណាសង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាព ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋាន ដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតទាំងឡាយហៅ ជននោះថាភិក្ខុ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ហត្ថសញ្ញតោ** *សេចក្តីថា ឈ្មោះថា ជាអ្នកមានដៃសង្រួមហើយ ព្រោះមិនមានការឆ្មាំឆ្គងដៃជាដើម ឬការប្រហារសត្វជំទៃដោយដៃជាដើម ។ នយក្នុងបទទីពីរ ក៏ដូចគ្នា ។*

ឈ្មោះថាជាអ្នកមានវាចាសង្រួមហើយ ព្រោះមិនបានធ្វើវចីទុច្ចរិត មាន

និយាយកុហកដោយវាចាជាដើម ។

បទថា **សញ្ញតត្តោ** *គឺអ្នកមានអត្តភាពសង្រួមហើយ អធិប្បាយថា ជាអ្នកមិនធ្វើអាការប្លែក មានគ្រែលែងកាយ គ្រឿកប្បាល និងញាក់ចិញ្ចើមជាដើម ។*

បទថា **អជ្ឈត្តរតោ** *សេចក្តីថា ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋានពោល គឺគោចរធម៌ ដែលប្រព្រឹត្តទៅខាងក្នុង ។*

បទថា **សមាហិតោ** *គឺដែលមានចិត្តតាំងមាំដោយល្អហើយ ។*

ពីរបទថា **ឯកោ សន្តុសិតោ** *សេចក្តីថា ជាអ្នកមានប្រក្រតីនៅម្នាក់ឯង ត្រេកអរហើយដោយល្អ គឺមានចិត្តត្រេកអរហើយ ដោយអធិគមនៃខ្លួនចាប់តាំងពីការប្រព្រឹត្តក្នុងវិបស្សនា ពិតហើយ ព្រះសេក្ខបុគ្គលគ្រប់ពួក តាំងអំពីកល្យាណបុថុជ្ជន រមែងត្រេកអរដោយអធិគមនៃខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថាជាអ្នកសន្តោស ចំណែកព្រះអរហន្ត ជាអ្នកត្រេកអរហើយដោយចំណែកមួយ ព្រះដ៏មានព្រះភាគទ្រង់សំដៅយកព្រះអរហន្តនោះ ទើបត្រាស់ពាក្យនោះថា* **ឯកោ សន្តុសិតោ ។**

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ភិក្ខុសម្លាប់មាន់ឆ្អិ ចប់

រឿង កោកាលិកភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុឈ្មោះកោកាលិក: ត្រាស់ព្រះធម្មទេសនានេះថា **យោ មុខសញ្ញតោ** ជាដើម ។

រឿងមកហើយក្នុងព្រះសូត្រថា កាលនោះឯង ភិក្ខុឈ្មោះកោកាលិក: បានទៅគាល់ដោយទីដែលព្រះដ៏មានព្រះភាគប្រថាប់នៅជាដើម ។ អត្ថនៃរឿងនោះ បណ្ឌិតគប្បីជ្រាបដោយនយ ដែលព្រះអដ្ឋកថាចារ្យពោលហើយ ក្នុងអដ្ឋកថានោះឯង ។

កាលកោកាលិក:កើតក្នុងបទុមនរក ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា ឱភិក្ខុឈ្មោះកោកាលិក:ដល់នូវការវិនាសហើយ ព្រោះអាស្រ័យមាត់របស់ខ្លួន កាលលោកជេវអគ្គសាវកទាំងពីរនោះឯង ផែនដីបានឲ្យចន្ទោះហើយ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីអម្បាញ់មិញនេះ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កោកាលិកភិក្ខុវិនាសព្រោះអាស្រ័យមាត់របស់ខ្លួន ក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន កោកាលិកភិក្ខុក៏វិនាសហើយព្រោះអាស្រ័យមាត់របស់ខ្លួនដូចគ្នា កាលភិក្ខុទាំងឡាយ ប្រជ្ញានឹងស្តាប់សេចក្តីនោះ ទូលអារាធនាហើយ កាលទ្រង់ប្រកាសសេចក្តីនោះ ទ្រង់បាននាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល អណ្តើកមួយអាស្រ័យនៅក្នុងស្រះមួយកន្លែង ក្នុងហិមវន្តប្បទេស កូនហង្សពីរត្រាច់ទៅដើម្បីរកចំណី ធ្វើនូវការស្និទ្ធស្នាលជាមួយនឹង

អណ្តើកនោះ ជាអ្នកស្និទ្ធស្នាលយ៉ាងក្រៃលែង ។ ថ្ងៃមួយ ទើបសួរអណ្តើកថា នែសម្លាញ់ លំនៅរបស់ពួកខ្ញុំក្នុងគុហាមាស លើកំពូលភ្នំឈ្មោះចិត្តកូដក្នុងហិមវន្តប្បទេស ជាប្រទេសដែលគួរត្រេកអរ ឯងទៅជាមួយពួកយើងដែរឬទេ អណ្តើកពោលថា តើខ្ញុំទៅបានដូចម្តេច ហង្សពោលថា ពួកយើងនឹងនាំឯងទៅ បើឯងអាចរក្សាមាត់បាន អណ្តើកពោលថា នែសម្លាញ់ ខ្ញុំអាចសូមឯងទាំងពីរនាំខ្ញុំទៅចុះ ហង្សទាំងពីរពោលថា សាធុ ហើយឲ្យអណ្តើកខាំកំណាត់ឈើមួយ ចំណែកខ្លួនឯងពាំចុងទាំងសងខាង នៃកំណាត់ឈើនោះ ហើយហើរទៅកាន់អាកាស ។

ពួកក្មេងអ្នកស្រុក ឃើញអណ្តើកត្រូវហង្សនាំទៅយ៉ាងនោះ ទើបនិយាយគ្នាថា ហង្សពីរនាំអណ្តើកទៅដោយកំណាត់ឈើ ។ អណ្តើកជ្រាបថានឹងពោលថា បើសម្លាញ់ទាំងពីរនាំអញទៅ ប្រយោជន៍អ្វីរបស់ពួកឯងក្នុងរឿងនេះ រ៉ៃយ ពួកក្មេងប្រេតអាក្រក់ ទើបរបូតកំណាត់ឈើដែលខ្លួនពាំ ក្នុងពេលដែលដល់ចំណែកខាងលើព្រះរាជនិវេសន៍ ក្នុងនគរពារាណសី ព្រោះហង្សទាំងពីរជាសត្វមានកម្លាំងរហ័ស ទើបធ្លាក់ត្រង់លានព្រះរាជវាំង បែកជាពីរចំណែក ។

ព្រះសាស្តាទ្រង់នាំអតីតនិទាននេះមកហើយ ទ្រង់ញុំាងពហុការណិជាតកក្នុងទុកនិបាតនេះឲ្យពិស្តារថា

> *អណ្តើក កាលបើឈើ ខ្លួនពាំស៊ប់ហើយ ហានិយាយសម្លាប់នូវខ្លួនឯង ឈ្មោះថា សម្លាប់ដោយវាចារបស់ខ្លួន ។*
>
> *បពិត្រព្រះអង្គអ្នកមានព្យាយាមប្រសើរជាងជន (ឯបណ្ឌិត*

បុរស) ឃើញនូវហេតុនេះហើយ មិនគប្បីបញ្ចេញវាចា ជាកុសល ឲ្យហួសវេលា ព្រះអង្គគង់នឹងទតឃើញអណ្តើក ដែលដល់នូវសេចក្តីវិនាសព្រោះតែនិយាយច្រើន ។

ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីជាអ្នកសង្រួមមាត់ ប្រព្រឹត្តស្មើ មិនរាយមាយ មានចិត្តស្ងប់ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

យោ មុខសញ្ញតោ ភិក្ខុ មន្តភាណី អនុទ្ធតោ
អត្ថំ ធម្មញ្ច ទីបេតិ មធុរំ តស្ស ភាសិតំ ។

ភិក្ខុណាសង្រួមមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្តមិនរាយមាយ សម្តែងអត្ថផង ធម៌ផងបាន ភាសិតរបស់ភិក្ខុនោះ ទើបឈ្មោះថា ពីរោះ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មុខសញ្ញតោ** *សេចក្តីថា ឈ្មោះថា ជាអ្នកសង្រួមហើយដោយមាត់ ព្រោះមិនពោលពាក្យជាដើមថា ឯងជាមនុស្សជាតិអាក្រក់ ជាមនុស្សទ្រុស្តសីលជាមួយមនុស្សទាំងឡាយ មានទាសៈ និងចណ្ឌាលជាដើម ។*

បទថា **មន្តភាណី** *សេចក្តីថា បញ្ញា ព្រះដ៏មានព្រះភាគត្រាស់ហៅថា* **មន្ត** *ជាអ្នកមានប្រក្រតីនិយាយដោយបញ្ញានោះ ។*

បទថា **អនុទ្ធតោ** *បានដល់ ជាអ្នកមានចិត្តស្ងប់ហើយ ។*

បាទព្រះគាថាថា **អត្តំ ធម្មញ្ច ទីបេតិ** *សេចក្តីថា រមែងសម្តែងអត្ថនៃកាសិតផង ធម៌ គឺទេសនាផង ។*

បទថា **មធុរំ** *សេចក្តីថា កាសិតរបស់កិក្ខុបែបនោះ ឈ្មោះថា ពីរោះ ។*

កិក្ខុណាឲ្យអត្តតែមួយជល់ព្រម មិនឲ្យព្រះបាលីជល់ព្រម ឲ្យព្រះបាលីតែម្យ៉ាងជល់ព្រម មិនឲ្យអត្តជល់ព្រម ឬមិនឲ្យទាំងពីរយ៉ាងជល់ព្រម កាសិតរបស់កិក្ខុនោះ ឈ្មោះថា ជាកាសិតមិនពីរោះឡើយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង កោកាលិកភិក្ខុ ចប់

រឿង ព្រះធម្មារាមត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះធម្មារាមត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ធម្មារាមោ ធម្មរតោ** *ជាដើម ។*

បានឮមកថា កាលព្រះសាស្តាត្រាស់ថា បរិនិព្វានរបស់តថាគតនឹងមានដោយកន្លងទៅ ៤ ខែ តាំងអំពីខែនេះទៅ កិក្ខុច្រើនពាន់រូបត្រាច់ចោមរោមព្រះសាស្តាហើយ ។

បណ្តាកិក្ខុទាំងនោះ កិក្ខុដែលជាបុថុជ្ជន មិនអាចអត់សង្កត់ទប់នូវ

ទឹកភ្នែកបាន ធម្មសង្វេគកើតដល់ព្រះខីណាស្រពហើយ ភិក្ខុទាំងពួងប្រឹក្សាគ្នា ថា យើងនឹងធ្វើអ្វីហ្ន៎ ដូច្នេះហើយ ក៏គ្រាច់ទៅដោយរួមគ្នាជាពួកៗ ។

ចំណែកភិក្ខុមួយរូប ឈ្មោះធម្មារាម: មិនចូលទៅកាន់សម្នាក់របស់ភិក្ខុទាំងឡាយ ទោះភិក្ខុទាំងឡាយពោលថា អាវុសោ អ្នកយ៉ាងម៉េចទៅហើយ ក៏មិនឆ្លើយ គិតថា បានឮថា ព្រះសាស្តានឹងបរិនិព្វានក្នុងកាលកន្លងទៅ ៤ ខែ ចំណែកអាត្មាអញ ជាអ្នកមានរាគៈមិនទាន់ទៅប្រាស កាលព្រះសាស្តាគង់ព្រះជន្មនៅនេះឯង អញនឹងព្យាយាមសម្រេចអរហត្ត ដូច្នេះហើយ ជាបុគ្គលម្នាក់ឯងប៉ុណ្ណោះ អារព្ធ: គិត រឭកដល់ធម៌ដែលព្រះសាស្តាទ្រង់សម្តែងហើយ ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះ ដល់ព្រះតថាគតថា បពិត្រព្រះអង្គ ធម្មារាម: មិនបានធ្វើសូម្បីត្រឹមតែការអើពើក្នុងព្រះអង្គ មិនធ្វើសូម្បីត្រឹមតែការប្រឹក្សាជាមួយពួកខ្ញុំព្រះអង្គថា បានឮថា ព្រះសាស្តានឹងបរិនិព្វាន តើពួកយើងនឹងធ្វើអ្វី ។

ព្រះសាស្តា ទ្រង់ឲ្យហៅភិក្ខុនោះមកហើយត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកធ្វើយ៉ាងនោះពិតឬ ព្រះធម្មារាម:ពោលថា ការុណាព្រះអង្គ ព្រះមានព្រះភាគត្រាស់ថា ព្រោះហេតុអ្វី ព្រះធម្មារាម:ពោលថា បានឮថាព្រះអង្គនឹងបរិនិព្វានក្នុងកាលកន្លងទៅ ៤ ខែ ចំណែកខ្ញុំព្រះអង្គជាអ្នកមានរាគៈមិនទាន់ទៅប្រាស កាលព្រះអង្គគង់ព្រះជន្មនោះឯង ខ្ញុំព្រះអង្គនឹងព្យាយាមដើម្បីសម្រេចអរហត្ត ព្រោះហេតុនោះ ទើបខ្ញុំព្រះអង្គអារព្ធ: គិត រឭកដល់ធម៌ដែលទ្រង់សម្តែងហើយ ។

ព្រះសាស្តាប្រទានសាធុការដល់លោកថា សាធុ សាធុ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានសេចក្តីស្រឡាញ់ក្នុងតថាគត គប្បីដូចធម្មារាមភិក្ខុនេះឯង ពិតហើយ ម្នាលភិក្ខុទាំងឡាយ កាលបូជាដោយកម្រងផ្កានិងគ្រឿងក្រអូបជាដើម ឈ្មោះថា មិនធ្វើការបូជាដល់តថាគតឡើយ បុគ្គលបដិបត្តិធម៌សមគួរដល់ធម៌ប៉ុណ្ណោះ ទើបឈ្មោះថាបូជាតថាគត ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ
ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ ។

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយៗ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

សេចក្តីអធិប្បាយ

គប្បីជ្រាបវិគ្គហៈក្នុងបទទាំងនោះថា ធម៌ គឺសមថៈ និងវិបស្សនា ជាទីមកត្រេកអររបស់ភិក្ខុនោះ ព្រោះអត្ថថា ជាលំនៅ ព្រោះហេតុនោះ ឈ្មោះថា ជាអ្នកមានធម៌ជាទីមកត្រេកអរ ជាអ្នកត្រេកអរហើយក្នុងធម៌នោះឯង ព្រោះហេតុនោះ ទើបឈ្មោះថា ជាអ្នកត្រេកអរហើយក្នុងធម៌ ឈ្មោះថា ជាអ្នកពិចារណានូវធម៌ ព្រោះនឹកដល់ធម៌នោះឯងរឿយៗ អធិប្បាយថា ជាអ្នកពិចារណាដល់ធម៌នោះ ។

*បទថា **អនុស្សរំ** បានដល់ រឭកដល់ធម៌នោះឯង ។*

បទថា **សទ្ធម្មា** សេចក្តីថា កិក្ខុបែបនោះ រមែងមិនវិនាសចាកពោធិ-បក្ខិយធម៌ ៣៧ ប្រការ និងលោកុត្តរធម៌ ៩ ។

ក្នុងកាលចប់ទេសនា កិក្ខុនោះតាំងនៅក្នុងអរហត្ត ទេសនាមានប្រយោជន៍ដល់បុគ្គលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង ព្រះធម្មារាមត្ថេរ ចប់

រឿង កិក្កុណភាមួយ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវនៈ ទ្រង់ប្រារព្ធកិក្ខុអ្នកសេពគប់ខុសមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **សលាភំ នាតិមញ្ញេយ្យ** ជាដើម ។

បានឮមកថា កិក្ខុដែលជាបក្ខពួកទេវទត្តមួយរូប ជាសម្លាញ់របស់កិក្ខុរូបនោះ កិក្ខុខាងទេវទត្តនោះ ឃើញកិក្ខុជាសម្លាញ់ត្រាច់ទៅបិណ្ឌបាតជាមួយកិក្ខុទាំងឡាយ ធ្វើភត្តកិច្ចហើយត្រឡប់មកទើបសួរថា អាវុសោ ទៅណា កិក្ខុម្ខាងទៀតពោលថា ខ្ញុំទៅកាន់ទីឈ្មោះនោះដើម្បីបិណ្ឌបាត កិក្ខុដែលជាបក្ខពួកទេវទត្តពោលថា លោកបានបិណ្ឌបាតហើយឬ កិក្ខុមួយរូបទៀតពោលថា អើ ខ្ញុំបានហើយ កិក្ខុខាងទេវទត្តពោលថា ក្នុងទីនេះឯងពួកខ្ញុំមានលាភ និងសក្ការៈជាច្រើន សូមលោកនៅក្នុងទីនេះឯងត្រឹម ២-៣ ថ្ងៃចុះ ។

លោកនៅក្នុងទីនោះ ២-៣ ថ្ងៃតាមពាក្យរបស់កិក្ខុនោះហើយ ទើបទៅ

កាន់លំនៅរបស់ខ្លួន ។ គ្រានោះ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុនេះបរិភោគលាភសក្ការៈ ដែលកើតឡើងដល់ទេវទត្ត ភិក្ខុនេះជាបក្ខពួករបស់ទេវទត្ត ។ ព្រះសាស្តាឲ្យហៅភិក្ខុនោះមកហើយ ត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកធ្វើយ៉ាងនោះឬ ភិក្ខុនោះពោលថា ករុណាព្រះអង្គ ខ្ញុំព្រះអង្គអាស្រ័យភិក្ខុកំលោះមួយរូប នៅក្នុងទីនោះ ២-៣ ថ្ងៃ តែខ្ញុំព្រះអង្គមិនបានគាប់ចិត្តក្នុងលទ្ធិរបស់ទេវទត្តទេ ។

គ្រានោះ ព្រះសាស្តាត្រាស់ថា អ្នកមិនគាប់ចិត្តក្នុងលទ្ធិទេវទត្តក៏ពិត តែអ្នកត្រាច់ទៅ ហាក់បីដូចគាប់ចិត្តនឹងលទ្ធិរបស់ជនដែលអ្នកជួបហើយនោះឯង អ្នកធ្វើយ៉ាងនេះ ក្នុងឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន អ្នកក៏ធ្លាប់បែបនេះដូចគ្នា ។ កាលភិក្ខុទាំងឡាយទូលអារាធនាថា បពិត្រព្រះអង្គ ក្នុងឥឡូវនេះ ពួកខ្ញុំព្រះអង្គឃើញភិក្ខុនេះដោយខ្លួនឯងហើយ តែក្នុងកាលមុនភិក្ខុនេះគាប់ចិត្តក្នុងលទ្ធិរបស់អ្នកណាត្រាច់ទៅ សូមទ្រង់ត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គចុះ ទើបទ្រង់នាំអតីតនិទានមក ទ្រង់ញុំាងមហិឡាមុខជាតកនេះឲ្យពិស្តារថា

> *ជីវជីវត្តម ឈ្មោះមហិឡាមុខៈ បានស្តាប់ពាក្យរបស់ចោរទាំងឡាយមុនហើយ ក៏ប្រព្រឹត្តតាម បានបោកសម្ងាប់ (ហ្វូជីវ) លុះបានស្តាប់ពាក្យពួកលោកអ្នកមានខ្លួនសង្រ្គមល្អហើយ ក៏បានតាំងនៅក្នុងគុណគ្រប់យ៉ាង ។*

ហើយទ្រង់ត្រាស់បន្តថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុជាអ្នកត្រេកអរដោយលាភរបស់ខ្លួនប៉ុណ្ណោះ ការប្រាថ្នាលាភរបស់អ្នកដទៃ មិនសមគួរព្រោះបណ្តាឈាន វិបស្សនា មគ្គ និងផលទាំងឡាយ សូម្បីធម៌ត្រឹមតែម្យ៉ាង មិនកើតឡើងដល់ភិក្ខុដែលប្រាថ្នាលាភរបស់អ្នកដទៃ តែគុណជាតិទាំងឡាយ មានឈានជាដើម តែងកើតឡើងដល់ភិក្ខុដែលត្រេកអរដោយលាភរបស់ខ្លួនប៉ុណ្ណោះ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ បានកាសិតព្រះគាថានេះថា

សលាភំ នាតិមញ្ញេយ្យ ន ញ្ញេសំ បិហយេ មនោ
អញ្ញេសំ បិហយំ ភិក្ខុ សមាធិ នាធិគច្ឆតិ ។
អប្បលាភោបិ ចេ ភិក្ខុ សលាភំ នាតិមញ្ញតិ
តំ វេ ទេវា បសំសន្តិ សុទ្ធាជីវិ មតន្ទិតំ ។

ភិក្ខុមិនគប្បីមើលងាយលាភរបស់ខ្លួន (ដែលកើតឡើងដោយធម៌) មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ បើចង់បានលាភរបស់ភិក្ខុដទៃ តែងមិនបានសមាធិឡើយ ។ បើភិក្ខុសូម្បីមានលាភតិច មិនមើលងាយលាភរបស់ខ្លួន ទេវតា និងមនុស្សទាំងឡាយតែងសរសើរភិក្ខុនោះឯង ដែលជាអ្នកមានព្យាយាម ជាគ្រឿងអាស្រ័យរស់នៅដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សលាភំ** បានដល់ លាភដែលកើតឡើងដល់ខ្លួន ពិតហើយ ភិក្ខុវៀរការត្រាច់ទៅតាមលំដាប់ច្រក ចិញ្ចឹមជីវិតដោយការស្វែងរកដែលមិនសមគួរ ឈ្មោះថាមើលងាយ គឺប្រមាថ បានដល់ រង្កៀសក្នុងលាភរបស់ខ្លួន ព្រោះហេតុនោះ ភិក្ខុមិនគួរមើលងាយលាភរបស់ខ្លួនដោយការមិនធ្វើយ៉ាងនោះ ។

ពីរបទថា **នាញ្ញេសំ បិហាយំ** សេចក្តីថា មិនគួរត្រាច់ប្រាថ្នាលាភរបស់អ្នកដទៃ ។

បាទព្រះគាថាថា **សមាធឹ នាធិគច្ឆតិ** សេចក្តីថា ភិក្ខុកាលប្រាថ្នាលាភរបស់ជនដទៃ ដល់នូវការខ្វល់ខ្វាយក្នុងការធ្វើបរិក្ខារ មានចីវរជាដើម ដល់ជនទាំងនោះ រមែងមិនសម្រេចអប្បនាសមាធិ ឬឧបចារសមាធិ ។

បាទព្រះគាថាថា **សលាភំ នាតិមញ្ញេតិ** សេចក្តីថា ភិក្ខុសូម្បីជាអ្នកមានលាភតិច កាលត្រាច់ទៅតាមលំដាប់ច្រក ដោយលំដាប់នៃត្រកូលខ្ពស់និងទាប ឈ្មោះថា មិនមើលងាយលាភរបស់ខ្លួន ។

បទថា **តំ វ** ជាដើម សេចក្តីថា ទេវតាទាំងឡាយរមែងសរសើរ គឺលើកតម្កើងភិក្ខុនោះ ដែលជាបុគ្គលបែបនោះ ឈ្មោះថា ជាអ្នកមានអាជីវៈបរិសុទ្ធ ព្រោះភាពជាអ្នកមានជីវិតជាសារៈ ឈ្មោះថា មិនខ្វិលច្រអូស ព្រោះជាអ្នកមិនរញ្ជួរ ដោយអាស្រ័យកម្លាំងស្មារចិញ្ចឹមជីវិត ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ॥

រឿងភិក្ខុណាមួយ ចប់

រឿង បញ្ចគ្គទាយកព្រាហ្មណ៍

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ឈ្មោះបញ្ចគ្គទាយក: ត្រាស់ព្រះធម្មទេសនានេះថា **សព្វសោ ធាមរូបស្មឹ** ជាដើម ។

បានឮមកថា ព្រាហ្មណ៍នោះរមែងថ្វាយទានឈ្មោះខត្តគ្គ: ក្នុងពេលនៃស្រូវដែលប្រែតស្រេចហើយនោះឯង ក្នុងពេលដែលជញ្ជូនស្រូវដាក់លាន ក៏ថ្វាយទានឈ្មោះខលគ្គ: ក្នុងពេលបោកបែន ក៏ថ្វាយទានឈ្មោះខលកណ្ឌគ្គ: ក្នុងពេលអង្ករចូលក្នុងឆ្នាំង ក៏ថ្វាយទានឈ្មោះឧក្ខលិកគ្គ: ក្នុងពេលដែលដួសបាយដាក់ភាជន: ក៏ថ្វាយទានឈ្មោះបាដិគ្គ: ព្រាហ្មណ៍រមែងថ្វាយទានដ៏លើស ៥ យ៉ាងនេះ ។ ព្រាហ្មណ៍នោះ ឈ្មោះថាមិនទាន់ឲ្យដល់បដិគ្គាហកដែលមកដល់ហើយ មិនបរិភោគ ព្រោះហេតុនោះ ទើបព្រាហ្មណ៍បានឈ្មោះថាបញ្ចគ្គទាយកនោះឯង ។

ព្រះសាស្តាឃើញឧបនិស្សយផលទាំង ៣ របស់ព្រាហ្មណ៍នោះ និងព្រាហ្មណី ទើបយាងទៅក្នុងពេលបរិភោគរបស់ព្រាហ្មណ៍ ហើយទ្រង់ឈរប្រថាប់ត្រង់ទ្វារ ។ ព្រាហ្មណ៍នោះ អង្គុយបែរមុខទៅខាងក្នុងផ្ទះ បរិភោគត្រង់មាត់ទ្វារ គាត់មិនឃើញព្រះសាស្តាប្រថាប់ឈរត្រង់ទ្វារឡើយ ។

ចំណែកព្រាហ្មណី កំពុងអង្គាសព្រាហ្មណ៍ ឃើញព្រះសាស្តា គិតថាព្រាហ្មណ៍នេះថ្វាយទានដ៏ប្រសើរក្នុងហាន:ទាំង ៥ ហើយទើបបរិភោគ ឥឡូវនេះព្រះសមណគោតម យាងមកប្រថាប់ឈរត្រង់ទ្វារ បើព្រាហ្មណ៍ឃើញព្រះសមណគោតមហើយ នឹងនាំភត្តរបស់ខ្លួនទៅថ្វាយ អញមិនអាចចម្អិនដើម្បី

គាត់ទៀត ។ ហើយនាងគិតទៀតថា ព្រាហ្មណ៍នេះកុំបីឃើញព្រះសមណគោតម ដោយអាការយ៉ាងនេះ ទើបបែរខ្នងឲ្យព្រះសាស្តា បានឈរបាំងព្រះសាស្តា អំពីក្រោយព្រាហ្មណ៍នោះ ដូចបាំងព្រះចន្ទពេញបូណ៌មីដោយបាតដៃ ដូច្នោះ ។ ព្រាហ្មណ៍ឈរយ៉ាងនោះឯង ហើយក៏ឆ្ងៀងមើលព្រះសាស្តាដោយកន្ទុយភ្នែក ព្រោះគិតថា ព្រះសាស្តាយាងទៅហើយឬនៅហ្ន៎ ។

ព្រះសាស្តា បានប្រថាប់ឈរត្រង់ទីដដែលនោះឯង ចំណែកព្រាហ្មណ៍ មិនបានពោលថា សូមទ្រង់និមន្តប្រោសសត្វខាងមុខចុះ ព្រោះខ្លាចព្រាហ្មណ៍ ឮ តែនាងថយទៅពោលតិចៗ ថា សូមទ្រង់និមន្តទៅប្រោសសត្វខាងមុខចុះ ។

ព្រះសាស្តាគ្រវីព្រះសីសៈ ដោយអាការដែលទ្រង់សម្តែងថា តថាគតមិនទៅ កាលព្រះសម្ពុទ្ធដែលជាទីគោរពរបស់សត្វលោក ទ្រង់គ្រវីសីសៈដោយអាការសម្តែងថា តថាគតមិនទៅ នាងមិនអាចទប់បាន ទើបសើចខ្លាំងឡើង ខណៈនោះ ព្រះសាស្តាទ្រង់បញ្ចេញរស្មីទៅត្រង់ជញ្ជាំងផ្ទះ ព្រាហ្មណ៍អង្គុយបែរខ្នងនោះឯង បានឮសំឡេងសើចរបស់ព្រាហ្មណី និងឃើញពន្លឺនៃឆព្ណ្ណរង្សី ៦ ប្រការ ទើបបានឃើញព្រះសាស្តា ។

ធម្មតាព្រះពុទ្ធទាំងឡាយ បើទ្រង់មិនបានបង្ហាញខ្លួនដល់ជនទាំងឡាយ ដែលដល់ព្រមហើយដោយហេតុ ក្នុងស្រុក ឬក្នុងព្រៃហើយ ទ្រង់មិនចៀសចេញទៅ ។ ព្រាហ្មណ៍ឃើញព្រះសាស្តាហើយ ទើបពោលថា នែនាង នាងមិនប្រាប់ព្រះរាជបុត្រ ដែលទ្រង់មកប្រថាប់ឈរត្រង់ទ្វារដល់ខ្ញុំ ឲ្យខ្ញុំវិនាសហើយ នាងធ្វើកម្មធ្ងន់ ដូច្នេះហើយ ក៏កាន់យកកាជនៈនៃភោជន ដែលខ្លួន

បរិភោគហើយ ពាក់កណ្តាល ទៅកាន់សម្នាក់ព្រះសាស្តា ហើយក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គឲ្យទានដ៏ប្រសើរ ក្នុងឋាន:ទាំង ៥ ហើយទើបបរិភោគ តែចំណែកនៃភត្តមួយចំណែកប៉ុណ្ណោះ ខ្ញុំព្រះអង្គរំលែកពាក់កណ្តាលអំពីចំណែកនេះបរិភោគ ចំណែកនៃភត្តមួយចំណែកទៀតសល់ សូមទ្រង់ទទួលភត្តចំណែកនេះរបស់ខ្ញុំព្រះអង្គចុះ ។

ព្រះសាស្តាមិនត្រាស់ថា តថាគតមិនត្រូវការដោយភត្តដែលសល់របស់អ្នក តែទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ចំណែកដ៏ប្រសើរក្តី ភត្តដែលរំលែកពាក់កណ្តាលបរិភោគហើយក្តី ជារបស់សមគួរដល់តថាគតទាំងអស់ សូម្បីដុំភត្តជារបស់សល់ដែល ក៏ជារបស់សមគួរដល់តថាគតដូចគ្នា ម្នាលព្រាហ្មណ៍ ព្រោះតថាគតជាអ្នកអាស្រ័យអាហារដែលអ្នកជនៃឲ្យ ចិញ្ចឹមជីវិត ដូចគ្នានឹងពួកប្រេត ហើយទ្រង់ត្រាស់ព្រះគាថានេះថា

> កិក្ខុអាស្រ័យអាហារដែលបុគ្គលជនៃឲ្យ ចិញ្ចឹមជីវិត បានដុំភត្តណាអំពីចំណែកដ៏ប្រសើរក្តី អំពីចំណែកពាក់កណ្តាលក្តី អំពីចំណែកដែលសល់ក្តី កិក្ខុនោះ ជាអ្នកមិនគួរសរសើរដុំភត្តនោះ និងមិនគួរតិះដៀល ហើយទំពាន់ដុំភត្តនោះ ធីរជនទាំងឡាយរមែងសរសើរនូវកិក្ខុនោះថា ជាមុនី ។

ព្រាហ្មណ៍បានស្តាប់ព្រះគាថានោះ ក៏ជាអ្នកមានចិត្តជ្រះថ្លាហើយ គិតថា ឱ គួរអស្ចារ្យពិត ព្រះរាជបុត្រដែលឈ្មោះថាជាម្ចាស់នៃប្រទីប មិនបានត្រាស់ថា តថាគតមិនត្រូវការដោយភត្តដែលជាសំណល់របស់អ្នក គង់ត្រាស់យ៉ាង

នោះ ហើយឈរត្រង់ទ្វារនោះឯង ទូលសួរបញ្ហានឹងព្រះសាស្តាថា បពិត្រ ព្រះគោតម ទ្រង់ត្រាស់ហៅពួកសាវ័ករបស់ព្រះអង្គថា ភិក្ខុ ដោយហេតុមាន ប្រមាណប៉ុនណា បុគ្គលឈ្មោះថាជាភិក្ខុ ។

ព្រះសាស្តាទ្រង់ពិចារណាថា ធម្មទេសនាដូចម្តេចហ្ន៎ ទើបជាសប្បាយ ដល់ព្រាហ្មណ៍នេះ ទ្រង់ត្រិះរិះថា ជនទាំងពីរនេះ ក្នុងកាលព្រះពុទ្ធព្រះនាម កស្សប បានស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយដែលពោលថា នាមរូប ការដែល តថាគតមិនលះនាមរូបនោះឯង ហើយសម្តែងធម៌ដល់ជនទាំងពីរនោះ គួរ ហើយទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលមិនមានតម្រេក មិនជាប់ជំពាក់ ក្នុងនាមរូប ឈ្មោះថា ជាភិក្ខុ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ
អសតា ច ន សោចតិ ស វៃ ភិក្ខូតិ វុច្ចតិ ។

បុគ្គលណា មិនមានសេចក្តីប្រកាន់ក្នុងនាម និងរូបថាជា របស់អញ ដោយប្រការទាំងពួង មួយទៀត បុគ្គលណា មិនសោកស្តាយ ព្រោះនាម និងរូបដែលមិនមាន បុគ្គល នោះឯង តថាគតហៅថា ភិក្ខុ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សព្វសោ** *គឺក្នុងនាមរូបទាំងពួង ដែល ប្រព្រឹត្តទៅហើយដោយអំណាចខន្ធ ៥ គឺនាមក្ខន្ធ ៤ មានវេទនាជាដើម និង រូបក្ខន្ធ ។*

បទថា **មមាយិតំ** សេចក្តីថា ការប្រកាន់ថា អញ ឬថា របស់អញ មានដល់បុគ្គលណា ។

បាទព្រះគាថាថា **អសតា ច ន សោចតិ** សេចក្តីថា កាលនាមរូបនោះ ដល់នូវការអស់ទៅ និងការវិនាស បុគ្គលណាវៃមិនសោយសោក គឺមិនក្តៅក្រហាយថា រូបរបស់អញអស់ទៅហើយ ។បេ។ វិញ្ញាណរបស់អញអស់ទៅហើយ គឺឃើញតាមសេចក្តីពិតថា នាមរូប មានការអស់ទៅសូន្យទៅជាធម្មតា អស់ទៅហើយ ។

បទថា **ស វេ** ជាដើម សេចក្តីថា បុគ្គលនោះ គឺបុគ្គលបែបនោះ បានដល់ ជាអ្នកវៀរចាកសេចក្តីប្រកាន់ក្នុងនាមរូបដែលមានថា ជារបស់អញក្តី មិនសោយសោកព្រោះនាមរូបនោះ ដែលមិនមានក្តី ព្រះសាស្តាត្រាស់ហៅថា ភិក្ខុ ។

ក្នុងកាលចប់ទេសនា ប្តីប្រពន្ធទាំងពីរ តាំងនៅក្នុងអនាគាមិផលហើយ ទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង បញ្ចង្គធាយកព្រាហ្មណ៍ ចប់

រឿង សម្ពហុលភិក្ខុ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **មេត្តាវិហារី** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ កាលព្រះមហាកច្ចាយន:អាស្រ័យ កុររឃរនគរ ក្នុងអវន្តីជនបទ ត្រង់ភ្នំឈ្មោះបវត្ត: ឧបាសកម្នាក់ឈ្មោះ សោណកុដិកណ្ណ: ជ្រះថ្លាក្នុងធម្មកថារបស់ព្រះថេរ: ប្រាថ្នានិងបួសក្នុងសម្នាក់ របស់ព្រះថេរ: សូម្បីព្រះថេរ:ឃាត់ដល់ទៅ ២ ដងថា នែសោណ: ព្រហ្ម-ចរិយ:មានកត្តព្តង ដេកម្តង ដរាបដល់អស់ជីវិត ជាវត្តុដែលបុគ្គលធ្វើបាន ដោយលំបាក ក៏នៅជាអ្នកមានឧស្សាហ៍យ៉ាងខ្លាំងក្លាក្នុងបព្វជ្ជា ក្នុងវារ:ទី ៣ អង្វរព្រះថេរ: ក៏បព្វជ្ជាហើយ កន្លងទៅ ៣ ឆ្នាំ ទើបបានឧបសម្បទា ព្រោះ ទក្ខិណាជនបទមានភិក្ខុតិច ជាអ្នកប្រាថ្នាគាល់ព្រះសាស្តាចំពោះព្រះភក្ត្រ ទើប លាព្រះឧបជ្ឈាយ៍ កាន់យកដំណឹងដែលឧបជ្ឈាយ៍ឲ្យហើយ ទៅកាន់វត្តជេត-ពនដោយលំដាប់ ថ្វាយបង្គំព្រះសាស្តា បានទទួលបដិសណ្ឋារ:ហើយ កាល ព្រះសាស្តាទ្រង់អនុញ្ញាតសេនាសន: ក្នុងព្រះគន្ធកុដិជាមួយទ្រង់នោះឯង ឲ្យ ភត្រីចំណែកច្រើនកន្លងទៅខាងក្រៅ គឺនៅខាងក្រៅព្រះគន្ធកុដិ ហើយចូល ទៅកាន់ព្រះគន្ធកុដិ ក្នុងកណ្តាលរាត្រី ឲ្យចំណែក នៃរាត្រីនោះកន្លងទៅហើយ ត្រង់សេនាសន:ដែលដល់ហើយដល់ខ្លួន ក្នុងពេលទៀបភ្លឺ កាលព្រះសាស្តា ទ្រង់និមន្តហើយ បានសូត្រព្រះសូត្រអស់ ១៦ សូត្រ ដោយទំនងសរភញ្ញ ដែលចាត់ជាអដ្ឋកវគ្គ ។

កាលនោះ ព្រះដ៏មានព្រះភាគទ្រង់អនុមោទនាជាពិសេស ប្រទានទូវសាធុការដល់លោក ក្នុងកាលចប់សរភញ្ញថា សាធុ សាធុ កិកុ ។

កុម្មជ្ជកទេវតា នាគ និងគ្រុឌស្តាប់សាធុការ ដែលព្រះសាស្តាប្រទានហើយបានឲ្យសាធុការហើយ សំឡេងសាធុការតែមួយ មានហើយរហូតដល់ព្រហ្មលោកយ៉ាងនេះដោយប្រការដូច្នេះ ។ ក្នុងខណៈនោះ សូម្បីទេវតាដែលអាស្រ័យនៅក្នុងផ្ទះរបស់មហាឧបាសិកា ដែលជាញោមស្រីរបស់ព្រះថេរៈក្នុងកុរុរយានគរក្នុងទីចម្ងាយប្រមាណ ១២០ យោជន៍ អំពីជេតពនមហាវិហារបានឲ្យសាធុការ ដោយសំឡេងដ៏ខ្លាំងហើយ ។ កាលនោះ មហាឧបាសិកាសួរទេវតានោះថា អ្នកណាឲ្យសាធុការ ទេវតាពោលថា នែប្អូនស្រី គឺខ្ញុំ ឧបាសិកាសួរថា អ្នកជាអ្នកណា ទេវតាពោលថា ខ្ញុំជាទេវតា អាស្រ័យនៅក្នុងផ្ទះរបស់នាង ឧបាសិកាពោលថា ក្នុងកាលមុននេះ អ្នកមិនបានឲ្យសាធុការដល់ខ្ញុំ ហេតុអ្វី ទើបថ្ងៃនេះបានឲ្យ ទេវតាពោលថា ខ្ញុំមិនបានឲ្យសាធុការដល់នាងទេ ឧបាសិកាពោលថា បើដូច្នោះ អ្នកឲ្យសាធុការដល់នរណា ទេវតាពោលថា ខ្ញុំឲ្យដល់ព្រះសោណកុដិកណ្ណត្ថេរដែលជាកូនរបស់នាង ឧបាសិកាពោលថា កូនរបស់ខ្ញុំធ្វើអ្វី ទេវតាពោលថា ក្នុងថ្ងៃនេះ កូនរបស់នាង នៅក្នុងព្រះគន្ធកុដិជាមួយព្រះសាស្តា ហើយសម្តែងធម៌ដល់ព្រះសាស្តា ព្រះសាស្តាទ្រង់ស្តាប់ធម៌បុត្ររបស់នាងហើយ ទ្រង់ជ្រះថ្លា ទើបប្រទានសាធុការ ព្រោះហេតុនោះ ទើបខ្ញុំឲ្យសាធុការដល់ព្រះថេរៈនោះ ក៏ព្រោះទទួលសាធុការរបស់ព្រះសម្មាសម្ពុទ្ធ ទើបកើតសាធុការតែមួយដូចគ្នា

ទាំងអស់ រាប់តាំងអំពីកុម្ភដ្ឋកទេវតា រហូតដល់ព្រហ្មលោក ឧបាសិកាពោលថា នែអ្នក កូនរបស់ខ្ញុំសម្តែងធម៌ដល់ព្រះសាស្តា ឬព្រះសាស្តាសម្តែងធម៌ដល់កូនរបស់ខ្ញុំ ទេវតាពោលថា កូនរបស់នាងសម្តែងធម៌ដល់ព្រះសាស្តា ។ កាលទេវតាកំពុងពោលយ៉ាងនោះ បីតិ ៥ ប្រការ កើតឡើងដល់ឧបាសិកា ផ្សាយទូទៅពេញសរីរៈទាំងមូល ។ កាលនោះ មហាឧបាសិកាមានគំនិតយ៉ាងនេះថា បើកូនរបស់អញនៅក្នុងព្រះគន្ធកុដិជាមួយព្រះសាស្តា ហើយអាចសម្តែងធម៌ដល់ព្រះសាស្តាបាន ក៏អាចឲ្យសម្តែងធម៌ដល់អញបានដូចគ្នា ក្នុងពេលកូនអញមកដល់ អញនឹងធ្វើការស្តាប់ធម្មកថា ។

ចំណែកព្រះសោណត្ថេរ កាលព្រះសាស្តាប្រទានសាធុការហើយ គិតថា ពេលនេះ ជាពេលសមគួរដែលអញក្រាបទូលពាក្យផ្តាំ ដែលឧបជ្ឈាយ៍ផ្តាំមក ដូច្នេះហើយ ទើបទូលសូមពរ ៥ និងព្រះដ៏មានព្រះភាគ ចាប់តាំងអំពីការឧបសម្បទាដោយគណៈសង្ឃ មានវិនយធរជាគម្រប់ ៥ ក្នុងបច្ចន្តជនបទ ហើយនៅក្នុងសម្នាក់របស់ព្រះសាស្តា ២-៣ ថ្ងៃប៉ុណ្ណោះ ទូលលាព្រះសាស្តាថា ខ្ញុំព្រះអង្គនឹងសួរសុខទុក្ខព្រះឧបជ្ឈាយ៍ បានចេញអំពីជេតពនវិហារ ទៅកាន់សម្នាក់ព្រះឧបជ្ឈាយ៍ដោយលំដាប់ ។

ស្អែកឡើង ព្រះថេរៈនាំលោកទៅបិណ្ឌបាត ដល់ទ្វារផ្ទះរបស់ឧបាសិកាដែលជាញោមស្រី ។ ចំណែកឧបាសិកានោះ ឃើញកូនហើយ ត្រេកអរថ្វាយបង្គំ អង្គាសដោយគោរព ហើយសួរថា បពិត្រលោកកូន បានឮថា លោកកូននៅក្នុងព្រះគន្ធកុដិជាមួយនឹងព្រះសាស្តា ហើយសម្តែងធម្មកថាដល់ព្រះ

សាស្តា មែន ឬមិនមែន ព្រះសោណៈពោលថា ឧបាសិកា រឿងនេះ អ្នកណាប្រាប់ញោម ឧបាសិកាពោលថា ទេវតាអាស្រ័យនៅក្នុងផ្ទះនេះឲ្យសាធុការដោយសំឡេងខ្លាំង កាលញោមសួរថា នុ៎ះជាអ្នកណា ក៏ពោលថា គឺខ្ញុំ ហើយប្រាប់យ៉ាងនោះឯង ព្រោះស្តាប់រឿងនោះ ទើបញោមគិតយ៉ាងនេះថា បើកូនរបស់អញសម្តែងធម្មកថាដល់ព្រះសាស្តាបានសោត ក៏អាចសម្តែងធម៌ដល់អញបានដែរ ។

គ្រានោះ ឧបាសិកាពោលនឹងព្រះសោណៈនោះថា បពិត្រលោកកូន ព្រោះលោកកូនសម្តែងធម៌ចំពោះព្រះភក្ត្រ របស់ព្រះសាស្តាបានហើយ លោកកូនក៏អាចសម្តែងដល់ញោមបានដូចគ្នា ក្នុងថ្ងៃឈ្មោះនោះ ញោមនឹងឲ្យធ្វើការស្តាប់ធម៌ ហើយនឹងស្តាប់ធម៌របស់លោកកូន ព្រះសោណៈទទួលនិមន្តហើយ ។ ឧបាសិកាគិតថា អញថ្វាយទានដល់ភិក្ខុសង្ឃ ធ្វើការបូជាហើយនឹងស្តាប់ធម្មកថាបុត្ររបស់អញ ទើបតាំងស្រីទាសីម្នាក់ប៉ុណ្ណោះ ឲ្យជាអ្នកចាំផ្ទះ ហើយនាំបរិវារជនទាំងអស់ទៅស្តាប់ធម្មកថារបស់ព្រះថេរៈ ដែលឡើងកាន់ធម្មាសនៈដែលគេរៀបចំហើយ ក្នុងមណ្ឌប ដែលខ្ជួនសាងខាងក្នុងព្រះនគរ ដើម្បីប្រយោជន៍ដល់ការស្តាប់ធម៌ ។

ក្នុងពេលនោះ ពួកចោរ ៥០០ ដើរសម្លឹងឱកាសក្នុងផ្ទះរបស់ឧបាសិកានោះ ។ ផ្ទះរបស់ឧបាសិកានោះព័ទ្ធដោយកំពែង ៧ ជាន់ ប្រកបដោយខ្ញោងទ្វារ ៧ ជាន់ គេចងឆ្កែកាចក្នុងទីនោះៗ គ្រប់ខ្ញោងទ្វារ ម្យ៉ាងទៀត គេជីកគូទឹក ក្នុងទីដែលទឹកជ្រាក់ត្រង់សំយាបក្នុងផ្ទះ ហើយឲ្យជាក់សំណាល់តែពេញ

ពេលថ្ងៃ សំណោនោះប្រាកដហាក់ដូចរលាយក្តៅព្រោះកម្តៅថ្ងៃ ក្នុងពេលយប់ ប្រាកដជារបស់រឹង គេបោះចម្រូងដែកធំៗ ក្នុងរវាងគូនោះជាប់ៗ គ្នា ពួកចោរ ទាំងនោះមិនបានឱកាស ព្រោះអាស្រ័យការរក្សានេះ និងព្រោះអាស្រ័យ ភាពដែលឧបាសិកានៅខាងក្នុងផ្ទះ ថ្ងៃនោះ ដឹងថាឧបាសិកានោះទៅហើយ ទើប ជីកឧម្មង្គចូលទៅកាន់ផ្ទះខាងក្រោមគូនៃសំណោ និងចម្រូងដែកនោះឯង ហើយ បញ្ជូនមេចោរទៅកាន់សម្នាក់របស់ឧបាសិកានោះដោយប្រាប់ថា បើឧបាសិកា នោះបានឮថាពួកយើងចូលទៅក្នុងទីនេះហើយ បែរមុខមកកាន់ផ្ទះ ចូរលោក កាប់ឧបាសិកានោះឲ្យស្លាប់ដោយដាវ មេចោរនោះ បានទៅឈរក្នុងសម្នាក់ របស់ឧបាសិកានោះ ។

ចំណែកពួកចោរ ដុតភ្លើងឲ្យភ្លឺខាងក្នុងផ្ទះ ហើយបើកទ្វារបន្ទប់ យក កហាបណៈ ។ ទាសីនោះឃើញពួកចោរហើយ ទើបទៅកាន់សម្នាក់ឧបាសិកា ប្រាប់ថា បពិត្រអ្នកនាងម្ចាស់ ចោរជាច្រើនចូលទៅកាន់ផ្ទះ បើកទ្វារហើយ យកកហាបណៈ ឧបាសិកាពោលថា ពួកចោរចូរជញ្ជូនកហាបណៈ ដែលខ្លួន ឃើញហើយទៅចុះ យើងនឹងស្តាប់ធម្មកថាកូនរបស់យើង កុំធ្វើអន្តរាយដល់ ធម៌របស់យើងឡើយ ចូរនាងទៅផ្ទះចុះ ។

ចំណែកពួកចោរ ធ្វើបន្ទប់ដាក់កហាបណៈ ឲ្យជាបន្ទប់ទទេហើយ ទើប បើកបន្ទប់ប្រាក់ ទាសីក៏មកប្រាប់សេចក្តីនោះម្តងទៀត ឧបាសិកាពោលថា ពួក ចោរចូរជញ្ជូនយកទ្រព្យដែលខ្លួនប្រាថ្នាទៅចុះ យើងនឹងស្តាប់ធម្មកថានៃបុត្រ របស់យើង នាងកុំធ្វើអន្តរាយដល់យើងឡើយ ហើយបញ្ជូនទាសីនោះចេញ

ទៅ ។

ពួកចោរធ្វើបន្ទប់ជាក់ប្រាក់ ឲ្យជាបន្ទប់ទទេហើយ ទើបបើកបន្ទប់មាសទាសីនោះក៏ទៅប្រាប់សេចក្តីនោះដល់ឧបាសិកាទៀត ។ គ្រានោះ ឧបាសិកាហៅទាសីមកហើយពោលថា នែនាងមានខ្លួនល្អ នាងមកសម្លាក់របស់យើងច្រើនជងហើយ យើងក៏បានប្រាប់ថា ពួកចោរចូរជញ្ជូនយកទៅតាមគាប់ចិត្តចុះ យើងនឹងស្តាប់ធម្មកថាបុត្ររបស់យើង នាងកុំធ្វើអន្តរាយដល់យើងឡើយ ក៏មិនអើពើនឹងពាក្យរបស់យើងឡើយ នៅតែចចេសមកម្តងហើយម្តងទៀត លើកនេះ បើនាងនៅតែមក យើងនឹងដឹងវត្តុដែលគួរធ្វើដល់នាង ចូរនាងត្រឡប់ចុះហើយបញ្ជូនទៅ ។

ចោរស្តាប់ពាក្យរបស់ឧបាសិកានោះហើយគិតថា កាលពួកយើងនាំទ្រព្យស្រីបែបនេះទៅ រន្ទះគប្បីបាញ់ត្រង់អំបែងក្បាល ដូច្នេះហើយ ទើបទៅកាន់សម្លាក់ពួកចោរប្រាប់ថា ពួកឯងចូរជញ្ជូនទ្រព្យឧបាសិកាទៅទុកកន្លែងដើមវិញ ឲ្យឆាប់ ចោរទាំងនោះឲ្យបន្ទប់កហាបណៈពេញដោយកហាបណៈ ឲ្យបន្ទប់ប្រាក់ពេញដោយប្រាក់ ឲ្យបន្ទប់មាសពេញដោយមាសហើយ ។ បានឮថា ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ជាធម្មតា ព្រោះហេតុនោះឯង ទើបព្រះដ៏មានព្រះភាគត្រាស់ថា

> ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលសន្សំល្អហើយ រមែងនាំមកនូវសេចក្តីសុខ នេះជាអានិសង្សក្នុងធម៌ ដែលបុគ្គលសន្សំល្អហើយ បុគ្គលអ្នក

ប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។

ពួកចោរបានឈរក្នុងទីស្តាប់ធម៌ ចំណែកព្រះថេរៈសម្តែងធម៌ហើយ កាលរាត្រីភ្លឺស្វាង ទើបចុះចាកអាសនៈ ក្នុងខណៈនោះ មេចោរក្រាបទៀបបាតជើងរបស់ឧបាសិកា ពោលថា បពិត្រអ្នកនាងម្ចាស់ សូមអ្នកនាងម្ចាស់អត់ទោសដល់ខ្ញុំចុះ ឧបាសិកាពោលថា នែអ្នក តើមានរឿងអ្វី មេចោរពោលថា ពួកខ្ញុំចងអាឃាតក្នុងអ្នកនាងម្ចាស់ បំណងនឹងសម្លាប់ ទើបឈរង់ចាំឧបាសិកា ពោលថា អើ អ្នក បើដូច្នោះ ខ្ញុំអត់ទោសឲ្យ ។

សូម្បីពួកចោរដ៏សេស ក៏ធ្វើយ៉ាងនោះដូចគ្នា កាលឧបាសិកាពោលថា បាទាំងឡាយខ្ញុំអត់ទោសឲ្យ ទើបពោលថា បពិត្រអ្នកនាងម្ចាស់ បើអ្នកនាងម្ចាស់អត់ទោសដល់ពួកខ្ញុំសោត សូមអ្នកនាងម្ចាស់ ឲ្យបព្វជ្ជាដល់ពួកខ្ញុំក្នុងសម្នាក់នៃបុត្ររបស់អ្នកនាងម្ចាស់ចុះ ។ ឧបាសិកានោះ ថ្វាយបង្គំព្រះថេរៈហើយពោលថា បពិត្រលោកកូន ពួកចោរទាំងនេះជ្រះថ្លាក្នុងគុណរបស់ញោមនិងធម្មកថារបស់កូន ទើបនាំគ្នាសូមបព្វជ្ជា សូមលោកម្ចាស់ឲ្យចោរទាំងនេះបួសចុះ ។

ព្រះថេរៈពោលថា សាធុ ហើយឲ្យកាត់ជាយសំពត់ដែលចោរទាំងនោះស្លៀកហើយ ជ្រលក់ដោយដីក្រហម ឲ្យពួកចោរបួសហើយ ឲ្យតាំងនៅក្នុងសីល ក្នុងកាលឧបសម្បទាហើយ ព្រះថេរៈបានឲ្យព្រះកម្មដ្ឋានផ្សេងៗ ដល់ភិក្ខុរូបនោះម្តងមួយរយៗ ។ ភិក្ខុ ៥០០ រូបនោះ រៀនកម្មដ្ឋាន ៥ យ៉ាងផ្សេងៗ គ្នា ហើយនាំគ្នាទៅកាន់ភ្នំមួយ អង្គុយធ្វើសមណធម៌ក្រោមម្លប់

ឈើនោះៗ ហើយ ។

ព្រះសាស្តាប្រថាប់គង់ក្នុងជេតពនមហាវិហារ ចម្ងាយ ១២០ យោជន៍ នោះឯង ទ្រង់សម្ដឹងមើលភិក្ខុទាំងនោះ ទ្រង់កំណត់ព្រះធម្មទេសនាដោយការសម្ដឹងចរិយារបស់ភិក្ខុទាំងនោះ ទ្រង់បញ្ចេញព្រះរស្មីទៅ ហាក់បីដូចប្រថាប់គង់ក្នុងទីចំពោះមុខ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

មេត្តាវិហារី យោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។
សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ
ឆេត្វា រាគញ្ច ទោសញ្ច តតោ និព្ពានមេហិសិ ។
បញ្ច ឆិន្ទេ បញ្ច ជហេ បញ្ច ឧត្តរិ ភាវយេ
បញ្ចសង្គាតិគោ ភិក្ខុ ឱឃតិណ្ណោតិ វុច្ចតិ ។
ឈាយ ភិក្ខុ មា ច បមាទោ មា តេ កាមគុណោ ភមស្សុ ចិត្តំ
មា លោហគុឡំ គិលី បមត្តោ មា កន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ ។
ឆន្ទំ ឈានំ អបញ្ញស្ស ឆន្ទំ បញ្ញា អឈាយិនោ
យម្ហិ ឈានញ្ច បញ្ញា ច ស វេ និព្ពានសន្តិកេ ។
សុញ្ញាគារំ បវិដ្ឋស្ស សន្តចិត្តស្ស ភិក្ខុនោ
អមានុសី រតី ហោតិ សម្មា ធម្មំ វិបស្សតោ ។
យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្ពយំ
លភតិ បីតិបាមោជ្ជំ អមតំ តំ វិជានតំ ។
តត្រាយមាទិ ភវតិ ឥធ បញ្ញស្ស ភិក្ខុនោ

ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ ចាតិមោក្ខេ ច សំវរោ
មិត្តេ ភជស្សុ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ ។
បដិសន្ថារវុត្យស្ស អាចារកុសលោ សិយា
តតោ ចាមោជ្ជពហុលោ ទុក្ខស្សន្តំ ករិស្សតិ ។

ភិក្ខុណា នៅដោយអំណាចមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។ ម្នាលភិក្ខុ អ្នកចូរស្តារទូក គឺអត្តភាពនេះ ទូកដែលអ្នកស្តារហើយ នឹងដល់ត្រើយឆាប់ អ្នកកាត់រាគៈ និងទោសៈបានហើយ អំពីនោះ នឹងអាចដល់នូវព្រះនិព្វាន ។ ភិក្ខុគប្បីកាត់ឱរម្ភាគិយសំយោជនៈ ៥ ផង គប្បីលះបង់ឧទ្ធម្ភាគិយសំយោជនៈ ៥ ផង គប្បីចម្រើនឥន្ទ្រិយ ៥ តទៅ ភិក្ខុអ្នកកន្ទងកិលេសជាគ្រឿងចំពាក់ ៥ (រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ) បានហើយ ទើបតថាគតហៅថា អ្នកឆ្លងអន្លង់បាន ។ ម្នាលភិក្ខុ ចូរអ្នកពិនិត្យផង ចូរកុំជាអ្នកប្រមាទផង ចិត្តរបស់អ្នក ចូរកុំវិលទៅរកកាមគុណទៀយ ចូរអ្នកកុំប្រមាទ ទំពាស៊ីនូវដុំលោហៈ កុំឲ្យជាអ្នក កាលភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះទុក្ខ ដូច្នេះទៀយ ។ ការពិនិត្យ មិនមានដល់បុគ្គលអ្នកមិនមានប្រាជ្ញា ប្រាជ្ញា មិនមានដល់បុគ្គលអ្នកមិនពិនិត្យ ការពិនិត្យ និងប្រាជ្ញា មានក្នុងបុគ្គលណា បុគ្គលនោះ

ឯង ឈ្មោះថា ស្ថិតនៅក្នុងទីជិតនៃព្រះនិព្វាន ។ សេចក្តីត្រេកអរ ដែលមិនមែនជារបស់មនុស្ស រមែងមានដល់កិកុអ្នកចូរទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នកឃើញធម៌ដោយប្រពៃ ។ កិកុពិចារណាការកើតឡើង និងការវិនាសខន្ធទាំងឡាយក្នុងកាលណា ក្នុងកាលនោះ កិកុនោះ រមែងបាននូវបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអតមធម៌របស់បណ្ឌិត អ្នកជីងនូវធម៌ទាំងឡាយ ។ គុណ ៣ ប្រការនេះ គឺ ការរក្សាឥន្ទ្រិយ ១ សេចក្តីសន្តោស ១ ការសង្រួមក្នុងបាតិមោក្ខ ១ ជាខាងដើមនៃព្រះនិព្វាននោះ តែងមានដល់កិកុអ្នកមានបញ្ញាក្នុងសាសនានេះ (ម្នាលកិកុ) ចូរអ្នកគប់រកកល្យាណ-មិត្ត អ្នកមានព្យាយាមជាគ្រឿងរស់ដោយបរិសុទ្ធ ជាអ្នកមិនខ្វិលច្រអូស ។

កិកុគប្បីជាអ្នកប្រព្រឹត្តធ្ងៃបដិសណ្ឋារៈ គប្បីជាអ្នកឈ្លាសក្នុងអាចារ ព្រោះហេតុទាំងពីរនោះ អ្នកនឹងមានបាមោជ្ជច្រើន នឹងធ្វើទីបំផុតទុក្ខបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មេត្តាវិហារី** *សេចក្តីថា បុគ្គលធ្វើកម្មក្នុងព្រះកម្មដ្ឋានដែលប្រកបដោយមេត្តាក្តី ជាអ្នកញុំងឈានពួក ៣ និងពួក ៤ ឲ្យកើតឡើងដោយអំណាចនៃមេត្តា ហើយតាំងនៅក្តី ឈ្មោះថា មាន*

ប្រក្រតីនៅដោយមេត្តាពិត ។

ពាក្យថា **បសន្នោ** *សេចក្តីថា កិក្ខុណាជាអ្នកជ្រះថ្លាហើយ អធិប្បាយថា រមែងជាំបណ្តុះនូវសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនានោះឯង ។*

ពីរបទថា **បទំ សន្តំ** *នោះ ជាឈ្មោះនៃព្រះនិព្វាន ពិតហើយ កិក្ខុបែបនោះ រមែងសម្រេច អធិប្បាយថា រមែងជួបដោយពិតនូវព្រះនិព្វានដែលជាចំណែកនៃសេចក្តីស្ងប់ ឈ្មោះថា ជាទីចូលទៅរម្ងាប់សង្ខារ ព្រោះភាពដែលសង្ខារទាំងពួង ជាសភាវៈស្ងប់រម្ងាប់ហើយ ដែលមានឈ្មោះថា សុខ ព្រោះភាពជាសុខយ៉ាងក្រៃលែង ។*

បាទព្រះគាថាថា **សិញ្ច ភិក្ខុ អិមំ នាវំ** *សេចក្តីថា ម្នាលភិក្ខុ ចូរអ្នកស្តារទូក ពោល គឺអត្តភាពនេះ ដែលមានទឹក គឺមិច្ឆាវិតក្កចោល ។*

បាទព្រះគាថាថា **សិត្តា តេ លហុមេស្សតិ** *សេចក្តីថា ដួចទូកដែលពេញហើយដោយទឹកក្នុងសមុទ្រនោះឯង ឈ្មោះថា គេស្តារហើយ ព្រោះភាពដែលទឹកដែលគេបិទប្រហោងទាំងឡាយ ស្តារហើយ ជាទូកដែលស្រាលមិនក្រឡាប់ក្នុងមហាសមុទ្រ រមែងសុះទៅដល់កំពង់បានរហ័ស យ៉ាងណា ទូក គឺអត្តភាពរបស់អ្នកនេះ ដែលពេញហើយដោយទឹក គឺមិច្ឆាវិតក្កក៏ដូច្នោះ ឈ្មោះថា អ្នកស្តារហើយ ព្រោះភាពដែលទឹក គឺមិច្ឆាវិតក្ក ដែលកើតឡើងហើយ ដែលកិក្ខុបិទប្រហោងទាំងឡាយ មានចក្ខុទ្វារជាដើមដោយការសង្រួមស្តារចេញហើយ ទើបស្រាល មិនលិចក្នុងសង្សារវដ្ត នឹងធាប់ដល់ព្រះនិព្វាន ។*

បទថា **ឆេត្វា** *ជាដើម សេចក្តីថា ចូរភិក្ខុកាត់គ្រឿងចង គឺរាគៈ និង ទោសៈ កាលកាត់គ្រឿងចងទាំងនោះហើយ នឹងសម្រេចអរហត្ត អធិប្បាយ ថា បន្ទាប់អំពីនោះ គឺក្នុងកាលតមក នឹងសម្រេចអនុបាទិសេសនិព្វាន ។*

ពីរបទថា **បញ្ច ឆិន្ទេ** *គឺកាត់សំយោជនៈ ដែលមានក្នុងចំណែកខាង ក្រោម ៥ យ៉ាង ដែលញុំាងសត្វឲ្យដល់អបាយជាន់ទាបដោយពួក ៣ នៃអ្នក ជាន់ទាប ដូចបុរសកាត់ខ្សែដែលចងហើយត្រង់ជើង ដោយសស្ត្រាដូច្នោះ ។*

ពីរបទថា **បញ្ច ឆឌោ** *សេចក្តីថា គប្បីលះ គឺចោល អធិប្បាយថា គប្បីកាត់សំយោជនៈដែលមានក្នុងចំណែកខាងលើ ៥ យ៉ាង ដែលញុំាងសត្វ ឲ្យដល់ទេវលោកជាន់ខ្ពស់ ដោយអំណាចអរហត្តមគ្គ ដូចបុរសកាត់ខ្សែដែល ជាប់ត្រង់កដូច្នោះ ។*

បាទព្រះគាថាថា **បញ្ច ឧត្តរិ ភាវយេ** *គឺគប្បីញុំាងឥន្ទ្រិយ ៥ មានសទ្ធា ជាដើមឲ្យចម្រើនក្រៃលែង ដើម្បីប្រយោជន៍ដល់ការលះសំយោជនៈ ដែល មានក្នុងចំណែកខាងលើ ។*

បទថា **បញ្ចសង្គាតិគោ** *សេចក្តីថា កាលបើដូច្នោះ ភិក្ខុឈ្មោះថាជា អ្នកកន្ទងនូវកិលេស ដែលជាគ្រឿងជាប់ជំពាក់ ៥ យ៉ាងបាន ព្រោះឈាន កន្ទងកិលេសជាគ្រឿងជាប់ជំពាក់ គឺរាគៈ ទោសៈ មោហៈ មានៈ និងទិដ្ឋិ ៥ យ៉ាង ព្រះសាស្តាត្រាស់ហៅថាជាអ្នកឆ្លងឱឃៈបាន អធិប្បាយថា ភិក្ខុនោះ ព្រះសាស្តាត្រាស់ហៅថា ជាអ្នកឆ្លងឱឃៈ ៤ បានពិត ។*

ពីរបទថា **ឈាយ ភិក្ខុ** *សេចក្តីថា ម្នាលភិក្ខុ ចូរអ្នកសម្លឹងដោយអំណាច*

ឈាន ២ នេះ ឈ្មោះថា កុំប្រមាទទ្បើយ ព្រោះភាពជាបុគ្គលមានប្រក្រតី មិនប្រមាទក្នុងកាយកម្មជាដើម ។

បទថា **ភមស្សុ** *គឺចិត្តរបស់ភិក្ខុកុំវិលត្រឡប់ទៅក្នុងកាមគុណ ៥ យ៉ាង ។*

បទថា **មា លោហាគុឡំ** *សេចក្តីថា ជនទាំងឡាយដែលប្រមាទហើយ ដោយការភ្លើតភ្លើន មានការបណ្តែតបណ្តោយសតិជាលក្ខណៈ រមែងលេបដុំលោហៈដែលក្តៅហើយក្នុងនរក ព្រោះដូច្នោះ ទើបតថាគតពោលនឹងអ្នក អ្នកកុំជាអ្នកប្រមាទលេបនូវដុំដែក កុំជាអ្នកត្រូវភ្លើងដុតក្នុងនរក កន្ទក់កន្ទេញថា នេះទុក្ខ នេះទុក្ខ ។*

ពីរបទថា **ឆត្តិ ឈានំ** *សេចក្តីថា ឈ្មោះថា ឈាន រមែងមិនមានដល់បុគ្គលឥតប្រាជ្ញា ដោយបញ្ញាជាហេតុព្យាយាមញុំាងឈានឲ្យកើតឡើង ។*

ពីរបទថា **ឆត្តិ បញ្ញា** *សេចក្តីថា បញ្ញាដែលមានលក្ខណៈដែលព្រះដ៏មានព្រះភាគត្រាស់ថា ភិក្ខុមានចិត្តតាំងមាំហើយ រមែងដឹង រមែងឃើញតាមសេចក្តីពិត រមែងមិនមានដល់បុគ្គលដែលមិនសម្ងឹង ។*

បាទព្រះគាថាថា **យម្ហិ ឈានញ្ច បញ្ញា ច** *សេចក្តីថា ឈាន និងបញ្ញា ទាំងពីរនេះ មានក្នុងបុគ្គលណា បុគ្គលនោះ ឈ្មោះថា តាំងនៅហើយ ក្នុងទីជិតនៃព្រះនិព្វានដោយពិតនោះឯង ។*

បាទព្រះគាថាថា **សុញ្ញាគារំ បវិដ្ឋស្ស** *គឺជាអ្នកមិនលះបង់កម្មដ្ឋានអង្គុយដោយការធ្វើកម្មដ្ឋានក្នុងចិត្ត ក្នុងឱកាសដែលស្ងាត់ ទីណាមួយនោះឯង ។*

បទថា **សន្តចិត្តស្ស** គឺជាអ្នកមានចិត្តស្ងប់ហើយ ។

បទថា **សម្មា** ជាដើម សេចក្តីថា ការត្រេកអរ មិនមែនជារបស់មាន នៃមនុស្ស ពោល គឺវិបស្សនាក្តី សេចក្តីត្រេកអរដែលជាទិព្វ ពោល គឺ សមាបត្តិ ៨ ក្តី រមែងមាន អធិប្បាយថា រមែងកើតឡើងដល់បុគ្គលដែល ឃើញច្បាស់នូវធម៌ ដោយហេតុ ដោយការណ៍ ។

បាទព្រះគាថាថា **យតោ យតោ សម្មសតិ** សេចក្តីថា ធ្វើកម្មក្នុងអារម្មណ៍ ៣៨ ប្រការ ដោយអាការណាមួយ គឺធ្វើកម្មក្នុងកាលទាំងឡាយ មានកាល មុនភត្តជាដើម ក្នុងកាលណាមួយដែលខ្លួនពេញចិត្តហើយ ឬធ្វើកម្មក្នុងព្រះ កម្មដ្ឋានដែលខ្លួនពេញចិត្តហើយ ឈ្មោះថា ពិចារណាឃើញ ។

បទថា **ខន្ធយព្វយំ** គឺនូវការកើតឡើងនៃខន្ធ ៥ ដោយលក្ខណៈ ២៥ និងការវិនាសនៃខន្ធ ៥ ដោយលក្ខណៈ ២៥ ដូចគ្នា ។

បទថា **បីតិចាមោជ្ជំ** គឺកាលពិចារណាការកើតឡើង និងការសូន្យទៅ នៃខន្ធទាំងឡាយយ៉ាងនេះ ឈ្មោះថា រមែងបាននូវបីតិក្នុងធម៌ និងបាមោជ្ជ ក្នុងធម៌ ។

បទថា **អមតំ** សេចក្តីថា កាលនាមរូប មួយអន្ទើដោយបច្ចយជាសភាវៈ ប្រាកដតាំងឡើង បីតិ និងបាមោជ្ជដែលកើតឡើងហើយនោះ ឈ្មោះថាជាអមតៈ របស់អ្នកប្រាជ្ញទាំងឡាយ គឺរបស់បណ្ឌិតដោយពិត ព្រោះបីតិ និងបាមោជ្ជ ជាធម៌ឲ្យសត្វដល់អមតមហានិព្វាន ។

បាទព្រះគាថាថា **តត្រាយមាធិ ភវតិ** គឺនេះជាខាងដើម គឺបីតិ និងបាមោជ្ជ

នេះ ជាឋានៈមានខាងដើមក្នុងអមតធម៌នោះ ។

ពីរបទថា **ឥធ បញ្ញស្ស** *គឺជល់កិកុ្ខដែលឈ្មោសក្នុងព្រះសាសនានេះ ។*

ឥឡូវនេះ ព្រះសាស្តាកាលទ្រង់សម្តែងកម្មដ្ឋានដែលមានខាងដើម ដែលទ្រង់ត្រាស់ថា **អាធិ** *នោះ ទើបត្រាស់ពាក្យជាដើមថា* **ឥន្ទ្រិយគុត្តិ** *មែនពិត ជាវិសុទ្ធិសីល ៤ ឈ្មោះថា ជាឋានៈមានខាងដើម ។*

ការសង្រួមឥន្ទ្រិយ ឈ្មោះថា **ឥន្ទ្រិយគុត្តិ** *ក្នុងព្រះគាថានោះ ។ ការសន្តោសដោយបច្ច័យ ៤ ឈ្មោះថា* **សន្តុដ្ឋិ** *។ អាជីវបារិសុទ្ធិសីល និងបច្ចយសន្និស្សិតសីល ព្រះសាស្តាត្រាស់ដោយបទថា* **សន្តុដ្ឋិ** *នោះឯង ។*

ភាពជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីល ដ៏ប្រសើរបំផុត ពោល គឺជាតិមោក្ខ ព្រះសាស្តាត្រាស់ដោយបទថា **ជាតិមោក្ខេ** *។*

បាទព្រះគាថាថា **មិត្តេ ភជស្សុ កល្យាណេ** *សេចក្តីថា លោកលះបង់សម្ងាញ់ដែលមិនសមគួរ មានការងារដែលលះបង់ហើយ ចូរគប់រក គឺចូរសេពកល្យាណមិត្ត ដែលឈ្មោះថាមានអាជីវៈបរិសុទ្ធ ព្រោះមានជីវិតប្រកបដោយសារៈ និងឈ្មោះថាជាអ្នកមិនខ្ជិលច្រអូស ព្រោះអាស្រ័យកម្លាំងស្មងចិញ្ចឹមជីវិត ។*

បាទព្រះគាថាថា **បដិសន្ថារវុត្យស្ស** *គឺគប្បីជាបុគ្គលឈ្មោះថាប្រព្រឹត្តក្នុងបដិសណ្ឋារៈ ព្រោះជាអ្នកប្រព្រឹត្តពេញហើយ ដោយអាមិសបដិសណ្ឋារ និងធម្មបដិសណ្ឋារៈ អធិប្បាយថា គប្បីជាបុគ្គលធ្វើបដិសណ្ឋារៈ ។*

បទថា **អាចារកុសលោ** *សេចក្តីថា សូម្បីសីលក៏ឈ្មោះថា មារយាទ*

សូម្បីវត្ត និងបដិវត្ត ក៏ឈ្មោះថាមារយោទ គប្បីជាអ្នកឈ្លាស អធិប្បាយថា គប្បីជាអ្នកឈ្លាសក្នុងមារយោទនោះ ។

បាទព្រះគាថាថា **តតោ ចាមោជ្ជពហុលោ** *សេចក្តីថា កិកុនោះឈ្មោះថា ជាអ្នកច្រើនដោយបាមោជ្ជ ព្រោះជាអ្នកត្រេកអរក្នុងធម៌ដែលកើតឡើង ហើយចាកការប្រព្រឹត្តបដិសណ្ឋារៈ និងភាពជាអ្នកឈ្លាសក្នុងមារយោទនោះ និងធ្វើទីបំផុតនៃទុក្ខទាំងអស់បាន ។*

បណ្តាបទព្រះគាថាទាំងនេះ ដែលព្រះសាស្តាទ្រង់សម្តែងយ៉ាងនេះ ក្នុងកាលចប់គាថានីមួយៗកិកុមួយរយៗសម្រេចអរហត្តមួយអន្ទើដោយបដិសម្ភិទាទាំងឡាយ ក្នុងទីដែលអង្គុយហើយនោះឯង ហោះឡើងទៅកាន់អាកាសហើយ កិកុទាំងអស់នោះ ឈានកន្ទងផ្លូវកន្តារ ១២០ យោជន៍ តាមផ្លូវអាកាសនោះឯង សរសើរព្រះសរីរៈដែលមានពណ៌ដូចមាសរបស់ព្រះតថាគត ថ្វាយបង្គំព្រះបាទាហើយ ដូច្នេះឯង ។

រឿងសម្ពហុលភិក្ខុ ចប់

រឿង ភិក្ខុ៥០០រូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រមាណ ៥ រយរូប ត្រាស់ព្រះធម្មទេសនានេះថា **វស្សិកា វិយ បុប្ផានិ** ជាដើម ។

បានឮមកថា ភិក្ខុទាំងនោះរៀនកម្មដ្ឋាន ក្នុងសម្នាក់របស់ព្រះសាស្តា បំពេញសមណធម៌ក្នុងព្រៃ ឃើញផ្កាម៉ិះរីកហើយអំពីព្រលឹម ជ្រុះចាកទងក្នុងពេលល្ងាច ទើបនាំគ្នាព្យាយាម ដោយសង្ឃឹមថា ពួកយើងនឹងរួចផុតចាកកិលេស មានរាគៈជាដើម ឲ្យបានមុនផ្កាទាំងឡាយដែលជ្រុះចាកទង ។

ព្រះសាស្តា ទ្រង់ប្រមើលមើលភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីព្យាយាមដើម្បីរួចផុតចាកទុក្ខឲ្យបាន ដូចផ្កាដែលជ្រុះចាកទងដូច្នោះ ប្រថាប់គង់ត្រង់ព្រះគន្ធកុដិនោះឯង ទ្រង់បញ្ចេញព្រះរស្មីទៅហើយ ត្រាស់ព្រះគាថានេះថា

វស្សិកា វិយ បុប្ផានិ មទ្ទវានិ បមុញ្ចតិ
ឯវំ រាគញ្ច ទោសញ្ច វិប្បមុញ្ចេថ ភិក្ខវោ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីជម្រុះរាគៈ និងទោសៈចេញ ដូចម៉ិះជម្រុះផ្កា ម៉ិះទាំងឡាយដែលស្ងិតហើយ ដូច្នោះ ។

សេចក្តីអធិប្បាយ

ផ្កាម៉ិះ ឈ្មោះថា **វស្សិកា** ក្នុងព្រះគាថានោះ ។

បទថា **មទ្ទវានិ** ប្រែថា ក្រៀមស្ងិតហើយ លោកអធិប្បាយថា ផ្កាម៉ិះ

រមែងជម្រុះនូវផ្ការដែលរីកហើយ កាលពីម្សិលមិញ ក្នុងថ្ងៃរះឡើង ជាផ្ការចាស់ ឲ្យជ្រុះចាកទង យ៉ាងណា អ្នកទាំងឡាយ ក៏ចូរជម្រុះនូវទោសទាំងឡាយ មានរាគៈជាដើមនោះចុះ ។ ក្នុងកាលចប់ទេសនា ភិក្ខុទាំងអស់តាំងនៅក្នុងអរហត្តហើយ ដូច្នេះឯង ។

រឿងភិក្ខុ ៥០០ រូប ចប់

រឿង ព្រះសន្តកាយត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសន្តកាយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **សន្តកាយោ** ជាដើម ។

បានញ្ចថា ឈ្មោះថា ការធ្តាំធ្តងដៃ និងជើងរបស់ព្រះថេរៈនោះមិនមានឡើយ លោកជាអ្នកវៀរចាកការទម្រន់កាយ ជាអ្នកមានអត្តភាពស្ងប់ ។

បានញ្ចថា ព្រះថេរៈនោះមកពីកំណើតរាជសីហ៍ ។ បានញ្ចថា រាជសីហ៍ទាំងឡាយ កាន់យកអាហារក្នុងថ្ងៃមួយហើយ ចូលទៅកាន់គុហាប្រាក់ គុហាមាស គុហាកែវមណី គុហាកែវបវាឡ គុហាណាមួយដេកត្រង់លម្អិតនៃមនោ-សិលា និងហរតាលអស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៧ ក្រោកឡើងហើយ ពិនិត្យមើលទីដែលខ្លួនដេកហើយ បើឃើញថាលម្អិតនៃមនោសិលា និងហរតាលខ្ចាត់ខ្ចាយរាត់រាយហើយ ព្រោះភាពដែលកន្ទុយ ត្រចៀក ឬជើងដែលខ្លួន

កម្រើកហើយ គិតថា ការធ្វើបែបនេះមិនសមគួរដល់ជាតិ ឬគោត្រមរបស់អ្នក ហើយក៏ដេកអត់អាហារ ៧ ថ្ងៃទៀត តែកាលមិនមានលម្អិតទាំងឡាយខ្ជាត់ខ្ជាយទៅ ទើបគិតថា ការធ្វើបែបនេះសមគួរដល់ជាតិ និងគោត្រមរបស់អ្នកដូច្នេះហើយ ក៏ចេញចាកទីអាស្រ័យពត់កាយ សម្លឹងមើលទិសទាំងឡាយ បន្ទឺសីហនាទ ៣ ដង ហើយក៏ចេញទៅរកស៊ី ។ ភិក្ខុនេះមកហើយ ដោយកំណើតរាជសីហ៍បែបនេះ ។

ភិក្ខុទាំងឡាយ ឃើញការប្រព្រឹត្តរៀបរយផ្លូវកាយរបស់លោក ទើបក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុដូចព្រះសន្តកាយត្ថេរ ពួកខ្ញុំព្រះអង្គមិនធ្លាប់ឃើញទេ្បីយ ការឆ្មាំឆ្គងដៃ ឆ្មាំឆ្គងជើង ឬការច្រអូសកាយរបស់ភិក្ខុនេះ ក្នុងទីនៃភិក្ខុនេះអង្គុយហើយ មិនមាន ។

ព្រះសាស្តាស្តាប់ពាក្យនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីជាអ្នកសូប់ទ្វារទាំងឡាយ មានកាយទ្វារជាដើមដោយពិត ដូចសន្តកាយត្ថេរ ដូច្នោះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

សន្តកាយោ សន្តវាចោ សន្តមនោ សុសមាហិតោ
វន្តលោកាមិសោ ភិក្ខុ ឧបសន្តោតិ វុច្ចតិ ។

ភិក្ខុអ្នកមានកាយរម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសក្នុងលោកខ្ជាក់ចោលហើយ ទើបតថាគត ហៅថា អ្នកសូប់រម្ងាប់ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សន្តកាយោ** *ជាដើម សេចក្តីថា ឈ្មោះថាជាអ្នកមានកាយស្ងប់ហើយ ព្រោះការមិនមានកាយទុច្ចរិតទាំងឡាយ មានបាណាតិបាតជាដើម ឈ្មោះថាជាអ្នកមានវាចាស្ងប់ហើយ ព្រោះការមិនមានវចីទុច្ចរិតទាំងឡាយ មានមុសាវាទជាដើម ឈ្មោះថា មានចិត្តស្ងប់ហើយ ព្រោះមិនមានមនោទុច្ចរិតទាំងឡាយ មានអភិជ្ឈាជាដើម ឈ្មោះថា ជាអ្នកតាំងមាំល្អហើយ ព្រោះភាពដែលទ្វារទាំង ៣ មានកាយជាដើមតាំងមាំហើយដោយល្អ ឈ្មោះថា មានអាមិសក្នុងលោកខ្ជាក់ចោលហើយ ព្រោះភាពដែលអាមិសក្នុងលោក ជារបស់ដែលខ្ជួនខ្ជាក់ចោលហើយដោយមគ្គ ៤ ព្រះសាស្តាត្រាស់ហៅថា ឈ្មោះថា ជាអ្នកស្ងប់ ព្រោះភាពដែលកិលេសទាំង-ឡាយ មានរាគៈជាដើម ខាងក្នុងស្ងប់រម្ងាប់ហើយ ។*

ក្នុងកាលចប់ទេសនា ព្រះថេរៈតាំងនៅក្នុងអរហត្តហើយ ទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿងព្រះសន្តកាយត្ថេរ ចប់

រឿង ព្រះនង្គលកូដត្តេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនង្គលកូដត្តេរ ត្រាស់ព្រះធម្មទេសនានេះថា **អត្តនា ចោទយត្តានំ** ជាដើម ។

បានឮថា បុរសទុគ៌តម្នាក់ ធ្វើការស៊ីឈ្នួលឲ្យជនដទៃចិញ្ចឹមជីវិត ។ ភិក្ខុមួយរូប ឃើញបុរសនោះស្លៀកសំពត់ចាស់លីនង្គ័លដើរទៅ ទើបពោលយ៉ាងនេះថា បើអ្នកបួស មិនប្រសើរជាងការរស់នៅបែបនេះឬ បុរសទុគ៌តពោលថា អ្នកណានឹងឲ្យខ្ញុំដែលមានសភាពយ៉ាងនេះបួស ភិក្ខុពោលថា បើអ្នកបួស អាត្មានឹងបំបួស បុរសទុគ៌តពោលថា សាធុ បើលោកម្ចាស់ឲ្យខ្ញុំបួស ខ្ញុំនឹងបួស ។

គ្រានោះ ព្រះថេរៈនាំបុរសនោះចូលទៅកាន់វត្តជេតពន ហើយឲ្យងូតទឹកដោយដៃខ្លួនឯង ឲ្យសម្រាកត្រង់រោងហើយ ឲ្យបួស ឲ្យបុរសនោះទុកជាក់នង្គ័ល មួយអន្ទើដោយសំពត់ចាស់ ដែលគាត់ស្លៀកត្រង់មែកឈើក្បែររោងនោះឯង ក្នុងកាលឲ្យឧបសម្បទា លោកបានប្រាកដឈ្មោះថា នង្គលកូដត្តេរនោះឯង ។

ព្រះនង្គលកូដត្តេរនោះ អាស្រ័យលាភសក្ការៈដែលកើតឡើងដើម្បីព្រះសម្ពុទ្ធទាំងឡាយចិញ្ចឹមជីវិត អផ្សុកឡើងហើយ កាលមិនអាចបន្ទោបង់បាន ទើបសម្រេចចិត្តថា ឥឡូវនេះ អញនឹងស្លៀកដណ្តប់កាសាវពស្ត្រទាំងឡាយដែលគេឲ្យដោយសទ្ធា ដូច្នេះហើយ ក៏ទៅកាន់គល់ឈើ ឲ្យឱវាទខ្លួនឯងដោយខ្លួនឯងថា ឯងមិនមានហិរិ មិនមានឱត្តប្បៈ ឯងចង់ស្លៀកដណ្តប់សំពត់

ជាច់ជាចនេះ សឹកទៅធ្វើការស៊ីឈ្នួលចិញ្ចឹមជីវិតឬ ។ កាលលោកទូន្មានខ្លួនយ៉ាងនោះឯង ចិត្តជល់នូវភាពជាធម្មជាតស្រាល ប្រាសចាកអផ្សុកហើយ ។

លោកត្រឡប់មកហើយ កន្លងមក ២-៣ ថ្ងៃ ក៏អផ្សុកទៀត ទើបទូន្មានខ្លួនយ៉ាងនោះឯង លោកប្រែចិត្តបានទៀត ក្នុងកាលអផ្សុកកើតឡើង លោកទៅក្នុងទីនោះហើយ ទូន្មានខ្លួនដោយទំនងនេះឯង ។

គ្រានោះ កិកុទាំងឡាយឃើញលោកទៅក្នុងទីនោះរឿយៗ ទើបសួរថា នង្គលកូដត្ថេរ ហេតុអ្វី ទើបលោកទៅក្នុងទីនោះ ព្រះថេរៈឆ្លើយថា ខ្ញុំទៅកាន់សម្នាក់អាចារ្យ ដូច្នេះហើយ កន្លងមក ២-៣ ថ្ងៃប៉ុណ្ណោះ ក៏សម្រេចអរហត្តផល ។

កិកុទាំងឡាយ កាលធ្វើនូវការលេង ទើបពោលថា នង្គលកូដៈ ផ្លូវត្រាច់ទៅរបស់លោក ហាក់ដូចជារកស្នាមមិនបាន ប្រហែលជាលោកមិនទៅកាន់សម្នាក់របស់អាចារ្យទៀតទេដឹង ព្រះថេរៈពោលថា យ៉ាងនោះឯងលោកម្ចាស់ កាលកិលេសជាគ្រឿងជាប់ជំពាក់នៅមាន ខ្ញុំបានទៅហើយ តែឥឡូវនេះកិលេសជាគ្រឿងជាប់ជំពាក់ខ្ញុំកាត់បានហើយ ព្រោះដូច្នោះ ទើបខ្ញុំមិនទៅ ។

កិកុទាំងឡាយ ស្តាប់ចម្លើយនោះហើយយល់ថា កិកុនេះពោលមិនពិតព្យាករអរហត្តផល ដូច្នេះហើយ ទើបក្រាបទូលសេចក្តីនោះដល់ព្រះសាស្តា ។

ព្រះសាស្តាត្រាស់ថា ម្នាលកិកុទាំងឡាយ នង្គលកូដៈបុត្ររបស់តថាគតជាស់តឿនខ្លួនឯងដោយខ្លួនឯង ហើយទើបដល់ទីបំផុតនៃកិច្ចរបស់បព្វជិត ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ បានភាសិតព្រះគាថាទាំងនេះថា

អត្តនា ចោទយត្តានំ បដិមំសេតមត្តនា
សោ អត្តគុត្តោ សតិមា សុខំ ភិក្ខុ វិហាហិសិ ។
អត្តា ហិ អត្តនោ នាថោ អត្តាហិ អត្តនោ គតិ
តស្មា សញ្ញម អត្តានំ អស្សំ ភទ្រំវ វាណិជោ ។

អ្នកចូរជាស់តឿនខ្លួនឯងដោយខ្លួនឯង ចូរពិនិត្យខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះបើមានស្មារតី រក្សាខ្លួនទុកហើយ នឹងនៅជាសុខ ។ ពិតហើយ ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯងជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូរវាំងខ្លួន ដូចពាណិជវាំងសេះដ៏ល្អ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ចោទយត្តានំ** *សេចក្តីថា ចូរជាស់តឿនខ្លួនដោយខ្លួនឯង គឺចូរញុាំងខ្លួនឲ្យក្រាក់រឭកដោយខ្លួនឯង ។*

បទថា **បដិមំសេ** *គឺពិនិត្យមើលខ្លួនដោយខ្លួនឯង ។*

បទថា **សោ** *ជាដើម សេចក្តីថា ម្នាលភិក្ខុ បុគ្គលនោះកាលជាស់តឿនពិចារណាមើលខ្លួនយ៉ាងនោះ ជាបុគ្គលឈ្មោះថាគ្រប់គ្រងខ្លួនបាន ព្រោះភាពជាបុគ្គល មានខ្លួនគ្រប់គ្រងហើយដោយខ្លួនឯង ជាបុគ្គលឈ្មោះថា មានសតិ ព្រោះជាអ្នកមានសតិតាំងមាំហើយ នឹងនៅសប្បាយគ្រប់ឥរិយាបថ ។*

បទថា **នាថោ** *សេចក្តីថា ជាទីអាស្រ័យ គឺជាទីពំនាក់ ព្រោះបុគ្គលអាស្រ័យក្នុងអត្តភាពរបស់អ្នកដទៃ មិនអាចជាអ្នកធ្វើកុសលហើយ មានឋាន

សួគ៌ជាទីទៅខាងមុខ ឬជាអ្នកញុំាងមគ្គឲ្យចម្រើនហើយ ធ្វើផលឲ្យជាក់ច្បាស់បាន ព្រោះហេតុនោះ ទើបមានអធិប្បាយថា បុគ្គលដទៃណាគប្បីជាទីពឹងបាន ។

បទថា **តស្មា** ជាដើម សេចក្តីថា ហេតុដែលខ្លួនឯងជាគតិ គឺជាទីពំនាក់បានជល់ ជាសរណៈរបស់ខ្លួន ។

ឈ្មួញសេះ អាស្រ័យសេះដែលចម្រើន គឺសេះអាជានេយ្យនោះប្រាថ្នាលាភ ទើបវៀរចាកការគ្រាច់ទៅក្នុងទីមិនស្មើ គឺមិនសមគួរនៃសេះនោះឲ្យឆ្ងាតទឹក ឲ្យបរិភោគមួយថ្ងៃ ៣ ដង ឈ្មោះថា រក្សា គឺផ្គត់ផ្គង់ យ៉ាងណា សូម្បីអ្នក កាលការពារនូវការកើតឡើងនៃអកុសលដែលមិនទាន់កើត កម្ចាត់ទីកើតឡើងហើយ ព្រោះការមិនមានស្មារតី ឈ្មោះថា ជាអ្នករារាំង គឺគ្រប់គ្រងខ្លួន ដូច្នោះ កាលអ្នករក្សាខ្លួនបានយ៉ាងនេះ អ្នកនឹងសម្រេចគុណវិសេស ជាលោកិយផង ជាលោកុត្តរផង តាំងអំពីបឋមជ្ឈានជាដើមទៅ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ॥

រឿង ព្រះឆទ្ទលក្ខជត្ថេរ ចប់

រឿង ព្រះវក្កលិត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះវក្កលិត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ចាមោជ្ជពហុលោ ភិក្ខុ** ជាដើម ។

បានឮថា ព្រះវក្កលិត្ថេរនោះ កើតក្នុងត្រកូលព្រាហ្មណ៍ នាក្រុងសាវត្ថី ចម្រើនវ័យហើយ ឃើញព្រះតថាគតយាងចូលទៅដើម្បីបិណ្ឌបាត សម្ញឹងព្រះសរីរសម្បត្តិរបស់ព្រះសាស្តាហើយ មិនឆ្អែតដោយការឃើញព្រះសរីរសម្បត្តិ ទើបបព្វជ្ជាក្នុងសម្នាក់ព្រះសាស្តា ដោយតាំងចិត្តថា អញនឹងបានឃើញព្រះដ៏មានព្រះភាគជានិច្ចកាលដោយឧបាយនេះ ដូច្នេះហើយ ក៏ឈរក្នុងទីដែលខ្លួនឈរ ដែលអាចឃើញព្រះទសពលបាន លះកិច្ចវត្តទាំងឡាយ មានការស្វាធ្យាយ និងមនសិការកម្មដ្ឋានជាដើម ត្រាច់មើលព្រះសាស្តា ។

ព្រះសាស្តាទ្រង់រង់ចាំការចាស់ក្លានៃញាណរបស់លោក ទើបមិនត្រាស់អ្វីឡើយ លុះទ្រង់ជ្រាបថា ឥឡូវនេះ ញាណរបស់លោកចាស់ក្លាហើយ ទើបត្រាស់ឱវាទថា វក្កលិ ប្រយោជន៍អ្វីរបស់អ្នកដោយការមើលកាយស្អុយនេះ ម្នាលវក្កលិ បុគ្គលណាឃើញធម៌ បុគ្គលនោះ ឈ្មោះថា ឃើញតថាគត បុគ្គលណាឃើញតថាគត បុគ្គលនោះ ឈ្មោះថា ឃើញធម៌ ។

ព្រះវក្កលិនោះ កាលព្រះសាស្តាទូន្មានហើយយ៉ាងនោះ ក៏មិនអាចលះនូវការមើលព្រះសាស្តាទៅក្នុងទីដទៃបានឡើយ ។ កាលនោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា ភិក្ខុនេះមិនបាននូវការសង្វេគ នឹងមិនបានត្រាស់ដឹង កាលវស្សូបនាយិកសម័យជិតចូលមកហើយ ទើបយាងទៅកាន់ក្រុងរាជគ្រឹះ ក្នុង

ថ្ងៃចូលវស្សា ទ្រង់បណ្តេញព្រះវក្កលិដោយព្រះតម្រាស់ថា វក្កលិ ចូរអ្នកចៀសចេញទៅ ព្រះថេរៈគិតថា ព្រះសាស្តាមិនត្រាស់ជាមួយអញ មិនអាចតាំងនៅក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តាបាន អស់ត្រើមាស ទើបគិតថា ប្រយោជន៍អ្វីរបស់អញដោយជីវិត អញនឹងឲ្យខ្លួនធ្លាក់ពីលើភ្នំចុះ ដូច្នេះហើយ ទើបឡើងទៅកាន់ភ្នំគិជ្ឈកូដ ។ ព្រះសាស្តា ទ្រង់ជ្រាបការហត់នឿយរបស់ព្រះថេរៈហើយ ទ្រង់ព្រះតម្រិះថា កិក្ខុនេះបើមិនបាននូវការលួងលោមអំពីសម្នាក់របស់តថាគត គប្បីញុំាងឧបនិស្សយនៃមគ្គ និងផលឲ្យវិនាស ទើបទ្រង់បញ្ជូនព្រះរស្មីទៅហើយ ដើម្បីបង្ហាញព្រះកាយឲ្យប្រាកដ ។

លំដាប់នោះ តាំងអំពីកាលលោកឃើញព្រះសាស្តាហើយ សេចក្តីសោកសូម្បីច្រើនដល់ម៉្លោះ ក៏បាត់ទៅហើយ ។ ព្រះសាស្តា ហាក់ដូចជាញុំាងស្រះដែលវិងស្ងួតឲ្យពេញដោយទឹក ដើម្បីទ្រង់ញុំាងបីតិ និងបាមោជ្ជដ៏មានកម្លាំងឲ្យកើតដល់ព្រះថេរៈ ទើបត្រាស់ព្រះគាថានេះថា

ចាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។

ភិក្ខុអ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា រមែងបាននូវបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះថា ភិក្ខុអ្នកច្រើនដោយបាមោជ្ជ ដោយ

ប្រក្រតី រមែងបណ្តុះនូវសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា កិកូនោះជ្រះថ្លាយ៉ាងនោះ គប្បីសម្រេចព្រះនិព្វានក្នុងព្រះពុទ្ធសាសនា ដែលបានឈ្មោះថា សន្តបទ ជាទីចូលទៅស្ងប់សង្ខារជាសុខ ។ ព្រះសាស្តាកាលត្រាស់ព្រះគាថានេះហើយ ទ្រង់លាព្រះហស្ត បានត្រាស់ព្រះគាថាទាំងនេះ ដល់ព្រះវក្កលិត្ថេរថា

មកចុះវក្កលិ អ្នកកុំខ្លាច ចូរសម្លឹងមើលតថាគត តថាគតនឹងលើកអ្នកឡើង ដូចបុគ្គលលើកដីរដែលលិចក្នុងកក់ឡើងដូច្នោះ មកចុះវក្កលិ ចូរអ្នកកុំខ្លាច ចូរអ្នកសម្លឹងតថាគត តថាគតនឹងលើកអ្នកឡើង ដូចបុគ្គលដែលជួយព្រះចន្ទ ដែលត្រូវរាហូចាប់ ដូច្នោះ ។

កាលញាំងបីតិយ៉ាងខ្លាំងក្លា ឲ្យកើតឡើងហើយថា អញបានឃើញព្រះទសពលហើយ ទ្រង់ត្រាស់ហៅអញថា មកចុះ ទើបគិតថា អញគប្បីទៅតាមផ្លូវណាហ្ន៎ កាលមិនឃើញផ្លូវជាទីទៅ ទើបហោះឡើងទៅក្នុងអាកាស ក្នុងទីចំពោះព្រះភក្ត្រព្រះទសពល កាលជើងទីមួយតាំងនៅត្រង់ភ្នំនោះឯង នឹកដល់ព្រះគាថា ដែលព្រះសាស្តាត្រាស់ហើយ សង្កត់បីតិបានក្នុងអាកាសនោះឯង សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទាទាំងឡាយហើយ ថ្វាយបង្គំព្រះតថាគតនោះឯង បានចុះមកឈរក្នុងសម្នាក់ព្រះសាស្តាហើយ ។

ក្នុងកាលតមក ព្រះសាស្តា ទ្រង់តាំងលោកទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាសទ្ធាធិមុត្ត ដូច្នេះឯង ។

រឿងព្រះវក្កលិត្ថេរ ចប់

រឿង សុមនសាមណេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងបុព្វារាម ទ្រង់ប្រារព្ធសុមនសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ មារេ** ជាដើម ។

អនុបុព្វីកថា ក្នុងរឿងនោះ មានដូចតទៅនេះ

សេចក្តីពិស្តារថា ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ កុលបុត្រម្នាក់ ឃើញព្រះសាស្តាទ្រង់តាំងភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈ លើសភិក្ខុទាំងឡាយខាងមានទិព្វចក្ខុ ក្នុងកណ្តាលបរិស័ទ ៤ ប្រាថ្នាសម្បត្តិនោះទើបនិមន្តព្រះសាស្តា ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ហើយតាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គគប្បីជាកំពូលជាងភិក្ខុទាំងឡាយអ្នកមានទិព្វចក្ខុ ក្នុងព្រះសាសនារបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគត ។

ព្រះសាស្តាទ្រង់ប្រមើលមើលអស់សេនកប្ប ទ្រង់ជ្រាបការសម្រេចនៃសេចក្តីប្រាថ្នារបស់កុលបុត្រនោះហើយ ទើបទ្រង់ព្យាករថា ក្នុងទីបំផុតនៃសេនកប្បបន្ទាប់អំពីកប្បនេះ អ្នកនឹងបានជាភិក្ខុឈ្មោះអនុរុទ្ធត្ថេរ ជាកំពូលជាងភិក្ខុទាំងឡាយខាងទិព្វចក្ខុ ក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមគោតម ។ កុលបុត្រស្តាប់ពាក្យព្យាករនោះហើយ សម្គាល់សម្បត្តិនោះហាក់ដូចជាបានក្នុងថ្ងៃស្អែក ។ កាលព្រះសាស្តាបរិនិព្វានហើយ ទើបសូរការបរិកម្មដើម្បីបានទិព្វចក្ខុ ពួកភិក្ខុឲ្យធ្វើគោមដើមច្រើនពាន់ដើម ព័ទ្ធជុំវិញព្រះស្តូបមាស ដែលមានកម្ពស់ ៧ យោជន៍ ហើយឲ្យធ្វើការបូជាដោយប្រទីប ចុតិអំពីអត្តភាពនោះហើយកើតក្នុង

ទេវលោក អន្ទោលទៅក្នុងទេវលោក និងមនុស្សលោកអស់មួយសែនកប្ប ក្នុងកប្បនេះ កើតក្នុងត្រកូលជនទុគ៌ត ក្នុងក្រុងពារាណសី អាស្រ័យសុមន-សេដ្ឋី ជាអ្នកជញ្ជូនស្មៅរបស់សេដ្ឋីនោះចិញ្ចឹមជីវិត ។ បុរសនោះបានឈ្មោះ ថា អន្ធការៈ សូម្បីសុមនសេដ្ឋី ក៏ថ្វាយមហាទានក្នុងព្រះនគរនោះអស់កាល ជានិច្ច ។

ថ្ងៃមួយ ព្រះបច្ចេកពុទ្ធព្រះនាមថា ឧបរិដ្ឋៈ ចេញអំពីនិរោធសមាបត្តិ ត្រង់ភ្នំគន្ធមាទន៍ហើយគិតថា ថ្ងៃនេះអាត្មាអញនឹងធ្វើសេចក្តីអនុគ្រោះដល់អ្នក ណាហ្ន៎ ជ្រាបថា ថ្ងៃនេះការដែលអាត្មាអញធ្វើសេចក្តីអនុគ្រោះដល់បុរសឈ្មោះ អន្ធការៈគួរ ឥឡូវនេះ បុរសនោះវែកស្មៅចេញអំពីព្រៃហើយនឹងមកផ្ទះ ដូច្នេះ ហើយ ទើបកាន់យកបាត្រ និងចីវរទៅដោយឫទ្ធិ ប្រាកដចំពោះមុខអន្ធការៈ ។ កាលអន្ធការៈឃើញព្រះបច្ចេកពុទ្ធ មានបាត្រទទេក្នុងដៃហើយសួរថា បពិត្រ លោកម្ចាស់ លោកម្ចាស់បានកិក្ខាខ្វះដៃឬទេ កាលព្រះបច្ចេកពុទ្ធតបថា នែ អ្នកមានបុណ្យច្រើន អាត្មានឹងបាន ទើបពិតថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់មេត្តារង់ចាំបន្តិចចុះ ដូច្នេះហើយ ក៏ទុកអម្រែកស្មៅ រត់ទៅ កាន់ផ្ទះ ដោយរហ័ស សួរភរិយាថា នែនាង កត្តចំណែកដែលនាងទុកដើម្បី ខ្ញុំ តើមានដែរឬទេ កាលនាងឆ្លើយថា មានអ្នក ទើបត្រឡប់មកដោយរហ័ស ទទួលបាត្ររបស់ព្រះបច្ចេកពុទ្ធទៅកាន់ផ្ទះ ដោយគិតថា កាលអញប្រាថ្នា ដើម្បីឲ្យ ទេយ្យធម៌មិនមាន កាលទេយ្យធម៌មាន អញមិនបានបដិគ្គាហក តែថ្ងៃនេះ បដិគ្គាហកក៏អញជួបហើយ ទេយ្យធម៌របស់អញក៏មាន ជាលាភ

របស់អញហ្នឹ ឲ្យចាក់កត្តចុះក្នុងជាត្រ ហើយនាំត្រឡប់មកជាក់ក្នុងដៃរបស់ព្រះបច្ចេកពុទ្ធ តាំងសេចក្តីប្រាថ្នាថា ដោយទាននេះ ភាពជាអ្នកក្រីក្រ កុំបីមានដល់ខ្ញុំឡើយ ពាក្យថា មិនមាន កុំបីមានឡើយ ក្នុងភពតូចភពធំ ។

បពិត្រលោកម្ចាស់ ខ្ញុំគប្បីរួចផុតចាកការចិញ្ចឹមជីវិតខ្វះខាតបែបនេះ មិនគប្បីបានឮពាក្យថា មិនមានឡើយ ។

ព្រះបច្ចេកពុទ្ធធ្វើអនុមោទនាថា សូមសេចក្តីប្រាថ្នារបស់អ្នក សម្រេចយ៉ាងនោះចុះ ដូច្នេះហើយ ក៏ចៀសចេញទៅ ។

ទេវតាដែលអាស្រ័យត្រង់សេ្វតច្ឆត្ររបស់សុមនសេដ្ឋីពោលថា

គួរត្រេកអរពិតហ្នឹ ទាននេះជាទានដ៏កំពូល អន្នការៈតម្កល់ទុកល្អហើយក្នុងព្រះឧបរិដ្ឋបច្ចេកពុទ្ធ ដូច្នេះហើយ បានឲ្យសាធុការ ៣ ដង ។

គ្រានោះ សេដ្ឋីពោលនឹងទេវតានោះថា អ្នកមិនឃើញយើងឲ្យទានជានិច្ចអស់កាលមានប្រមាណប៉ុណ្ណេះទេឬ ទេវតាពោលថា ខ្ញុំប្រាថ្នាទានរបស់លោកហើយ ឲ្យសាធុការក៏មិនមែន តែសាធុការនេះ ខ្ញុំឲ្យប្រព្រឹត្តទៅហើយ ព្រោះសេចក្តីជ្រះថ្លាក្នុងបិណ្ឌបាត ដែលអន្នការៈប្រគេនហើយ ដល់ព្រះឧបរិដ្ឋបច្ចេកពុទ្ធ ។

សេដ្ឋីនោះគិតថា គួរអស្ចារ្យហ្នឹ អញឲ្យទានអស់កាលមានប្រមាណប៉ុណ្ណេះ ក៏មិនអាចឲ្យទេវតាឲ្យទួវសាធុការបាន អន្នការៈ អាស្រ័យអញរស់នៅ គង់ឲ្យទេវតាធ្វើសាធុការដោយបិណ្ឌបាតម្តងប៉ុណ្ណោះ អញនឹងធ្វើវត្តុដែលសមគួរក្នុងទានរបស់អន្នការៈ ហើយធ្វើបិណ្ឌបាតនោះឲ្យជារបស់អញ ដូច្នេះ

ហើយ ទើបឲ្យហៅអន្នការៈមកសួរថា ថ្ងៃនេះឯងបានឲ្យអ្វីដល់អ្នកណាដែរឬទេ អន្នការៈពោលថា បពិត្រលោកម្ចាស់ ថ្ងៃនេះខ្ញុំប្រគេនភត្តាហារដល់ព្រះឧបវិដ្ឋបច្ចេកពុទ្ធ សេដ្ឋីពោលថា ណ្ហើយចុះបាចូរឯងយកកហាបណៈ ហើយឲ្យបិណ្ឌបាតនោះដល់យើងចុះ អន្នការៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំឲ្យមិនបានទេ ។ សេដ្ឋីនោះ ទ្បើងតម្លៃឲ្យរហូតដល់មួយពាន់ ចំណែកអន្នការៈ ក៏មិនបានឲ្យសូម្បីទ្រព្យមួយពាន់ ។ លំដាប់នោះ សេដ្ឋីពោលថា អ្នកដ៏ចម្រើនសេចក្តីនោះលើកទុកចុះ បើឯងមិនឲ្យបិណ្ឌបាត ចូរកាន់យកទ្រព្យមួយពាន់ហើយឲ្យចំណែកបុណ្យចុះ អន្នការៈពោលថា ខ្ញុំប្រឹក្សាជាមួយព្រះបច្ចេកពុទ្ធហើយ ទើបដឹងបាន ប្រញាប់រត់ទៅទាន់ព្រះបច្ចេកពុទ្ធហើយសួរថា បពិត្រលោកម្ចាស់ សុមនសេដ្ឋីឲ្យទ្រព្យមួយពាន់ ហើយសូមចំណែកបុណ្យក្នុងបិណ្ឌបាតរបស់លោកម្ចាស់ តើខ្ញុំត្រូវធ្វើដូចម្តេច ។

ពេលនោះព្រះបច្ចេកពុទ្ធ នាំឧបមាមកប្រៀបធៀបដល់បុរសនោះថា នែអ្នក ប្រទីបក្នុងផ្ទះមួយខ្នង ក្នុងស្រុកដែលមានត្រកូលមួយរយ គប្បីឆេះទ្បើងពួកជនដ៏សេស យកប្រេងរបស់ខ្លួនជ្រលក់ប្រឆេះហើយគប្បីទៅអុជបន្ត ហើយកាន់យក ពន្លឺប្រទីបដើមបុគ្គលគប្បីពោលថាមានឬមិនមាន ។ អន្នការៈពោលថា ពន្លឺរមែងមានច្រើនជាង ព្រះបច្ចេកពុទ្ធពោលថា ដូច្នោះឯងបណ្ឌិត ទោះជាបបរមួយវែក ឬភិក្ខាមួយវែកក្តី កាលបុគ្គលឲ្យចំណែកបុណ្យក្នុងបិណ្ឌបាតរបស់ខ្លួនដល់អ្នកដទៃ ឲ្យដល់មនុស្សប៉ុនណា បុណ្យទាំងនោះរមែងចម្រើនឯអ្នកបានឲ្យបិណ្ឌបាតមួយចំណែកប៉ុណ្ណោះ តែកាលអ្នកឲ្យចំណែកបុណ្យ

ជល់សេដ្ឋី បិណ្ឌបាត ឈ្មោះថា ពីរចំណែក មួយចំណែកជារបស់អ្នក មួយចំណែកជារបស់សេដ្ឋី អន្នការៈទទួលថា សាធុ ហើយថ្វាយបង្គំព្រះបច្ចេក-ពុទ្ធ ទៅកាន់សម្នាក់សេដ្ឋីពោលថា សូមលោកម្ចាស់ទទួលយកនូវចំណែកបុណ្យចុះ សេដ្ឋីពោលថា បើដូច្នោះ ចូរអ្នកទទួលយកកហាបណៈទាំងនេះ អន្នការៈពោលថា ខ្ញុំមិនបានលក់បិណ្ឌបាត ខ្ញុំឲ្យចំណែកបុណ្យដល់លោកម្ចាស់ដោយសទ្ធា សេដ្ឋីពោលថា អ្នកឲ្យដោយសទ្ធា ខ្ញុំក៏បូជាគុណរបស់អ្នកដោយសទ្ធា ចូរទទួលយកចុះ ម្យ៉ាងទៀត ចាប់តាំងអំពីនេះទៅ អ្នកកុំធ្វើការដោយដៃរបស់ខ្លួន ចូរសង់ផ្ទះក្បែរផ្លូវថ្មីចុះ ចូរកាន់យកវត្ថុគ្រប់យ៉ាង ដែលអ្នកត្រូវការអំពីសម្នាក់របស់ខ្ញុំ ។

បិណ្ឌបាតដែលបុគ្គលថ្វាយដល់អ្នកចេញអំពីនិរោធ រមែងឲ្យផលក្នុងថ្ងៃនោះឯង ព្រោះដូច្នោះ សូម្បីព្រះរាជាទ្រង់ស្តាប់ការប្រព្រឹត្តទៅនោះហើយ ទើបត្រាស់ឲ្យហៅអន្នការៈមក ហើយទ្រង់ទទួលចំណែកបុណ្យ ព្រះរាជទានភោគៈច្រើន ហើយត្រាស់ឲ្យព្រះរាជទានតំណែងសេដ្ឋីដល់អន្នការៈ ។

អន្នការៈនោះ បានជាសម្ងាញ់របស់សុមនសេដ្ឋី ធ្វើបុណ្យទាំងឡាយដរាបដល់អស់ជីវិត ចុតិអំពីអត្តភាពនោះហើយកើតក្នុងទេវលោក អន្ទោលទៅក្នុងទេវលោក និងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុងព្រះរាជវាំងរបស់ស្តេចសក្យៈ ព្រះនាមអមិតោទនៈ ក្នុងនគរកបិលពស្តុ ព្រះញាតិទាំង-ឡាយថ្វាយព្រះនាមដល់ព្រះកុមារនោះថា អនុរុទ្ធ ។ កុមារនោះ ជាព្រះកនិដ្ឋ-ភាតារបស់មហានាមសក្យៈ ជាឱរសរបស់ម្ចាស់មានៃព្រះសាស្តា បានជា

សុខមាលជាតិយ៉ាងក្រៃលែង ជាអ្នកមានបុណ្យច្រើន ។

បានឮថា ថ្ងៃមួយ កាលកូត្រ ៦ អង្គលេងឃ្លី យកនំសម្រាប់ក្នាល់គ្នា ព្រះអនុរុទ្ធចាញ់ ទើបបញ្ជូនដំណឹងទៅកាន់សម្នាក់របស់ព្រះមាតា ដើម្បីនំ ព្រះមាតាយកភាជនៈធំជាក់នំពេញហើយបញ្ជូនមកឲ្យ ព្រះអនុរុទ្ធសោយនំ ហើយ ទ្រង់លេងចាញ់ទៀត ក៏បញ្ជូនដំណឹងទៅយ៉ាងនោះឯង ។

កាលមនុស្សនាំនំមកយ៉ាងនេះអស់ ៣ ដង លើកទី ៤ មាតាបញ្ជូនដំណឹងទៅថា ឥឡូវនេះ នំមិនមាន ព្រះអនុរុទ្ធទ្រង់ស្តាប់ពាក្យរបស់មាតានោះហើយ ធ្វើសេចក្តីសម្គាល់ថា នំឈ្មោះមិនមាន នឹងមានក្នុងឥឡូវនេះ ព្រោះបទថា មិនមាន ជាបទដែលខ្លួនមិនធ្លាប់ឮហើយ ទើបទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា ចូរឯងទៅយកនំមិនមានមក ។ កាលនោះ មាតារបស់ព្រះកុមារ កាលអ្នកបម្រើទូលថា បពិត្រព្រះនាង សូមព្រះនាងឲ្យនំមិនមាន ទើបព្រះនាងត្រិះរិះថា ពាក្យថា មិនមាន កូនរបស់អញ មិនធ្លាប់ឮមកហើយ អញគប្បីឲ្យកូនរបស់អញដឹងភាពដែលមិនមាននោះដូចម្តេចហ្ន៎ ទើបព្រះនាងលាងថាសមាស គ្របដោយថាសមាស ជន្លៃបញ្ជូនទៅថា ទៅចុះបា ចូរបាឲ្យថាសមាសនេះដល់កូនរបស់យើង ។

ខណៈនោះ ទេវតាទាំងឡាយ ដែលជាអ្នករក្សាន្តគតិតថា ព្រះអនុរុទ្ធរបស់ពួកយើង ប្រគេនកត្តជាចំណែកខ្លួនដល់ព្រះបច្ចេកពុទ្ធព្រះនាមថាឧបរិដ្ឋៈ ហើយតាំងសេចក្តីប្រាថ្នាថា ខ្ញុំមិនគប្បីបានឮពាក្យថាមិនមាន កាលនៅជាអ្នកវៃកស្មៅឈ្មោះអន្ធការៈ ។ បើអញដឹងសេចក្តីនោះហើយ គប្បីប្រើយកន្តើយ

សោត ក្បាលរបស់អញនឹងបែកជា ៧ ភាគ ទើបធ្វើថាសឲ្យពេញដោយនំទិព្វទាំងឡាយហើយ ។ បុរសនោះនាំថាសមកទុកក្នុងសម្នាក់របស់សក្យៈទាំងនោះហើយបើក ក្លិនរបស់នំទិព្វទាំងនោះ ក៏ផ្សាយទៅពេញព្រះនគរ កាលនំគ្រាន់តែស្គុចសក្យៈទាំងនោះជាក់ក្នុងព្រះឱស្ឋ ក្លិននោះបានផ្សាយទៅកាន់សរសៃសម្រាប់ទទួលរសទាំង ៧ ពាន់ តាំងនៅហើយ ។

ព្រះអនុរុទ្ធទ្រង់ត្រិះរិះថា ពីមុនព្រះមាតាប្រហែលជាមិនស្រឡាញ់អញព្រោះក្នុងកាលជទៃទ្រង់មិនធ្លាប់ធ្វើនំមិនមានឲ្យដល់អញ ។ កុមារនោះទៅហើយទូលនឹងមាតាយ៉ាងនេះថា បពិត្រព្រះមាតា ខ្ញុំមិនជាទីស្រឡាញ់របស់ទ្រង់ឬ ព្រះមាតាពោលថា នែបា កូននិយាយអ្វី បាជាទីស្រឡាញ់ក្រៃលែងរបស់មាតា ក្រៃលែងជាងកែវភ្នែកទាំងគូ ក្រៃលែងជាងសាច់បេះដូង ព្រះអនុរុទ្ធពោលថា បពិត្រព្រះមាតា បើខ្ញុំជាទីស្រឡាញ់របស់ទ្រង់សោត ព្រោះហេតុអ្វីក្នុងកាលមុន ទើបមាតាមិនប្រទាននំមិនមានបែបនេះដល់ខ្ញុំ ព្រះនាងត្រាស់សួរបុរសនោះថា នែបា តើមានអ្វីកើតក្នុងថាសនោះឬ បុរសនោះពោលថា បពិត្រព្រះនាង មាន ថាសនោះពេញដោយនំទាំងឡាយ នំបែបនោះ ទូលបង្គំមិនធ្លាប់ឃើញឡើយ ។ ព្រះនាងត្រិះរិះថា កូនរបស់អញបានធ្វើបុណ្យទុកហើយ នំទិព្វដែលជារបស់ទេវតាទាំងឡាយ បញ្ជូនឲ្យទៅឲ្យបុត្ររបស់អញ ។ ព្រះអនុរុទ្ធក៏ទូលនឹងព្រះមាតាថា បពិត្រព្រះមាតា នំបែបនេះ ខ្ញុំមិនធ្លាប់សោយឡើយ តាំងអំពីថ្ងៃនេះទៅ សូមព្រះមាតាធ្វើនំមិនមាននេះប៉ុណ្ណោះដល់ខ្ញុំ ។

តាំងពីកាលនោះមក ព្រះនាងលាងថាសមាសហើយ គ្របដោយថាស

ជនៃបញ្ជូនទៅក្នុងពេលដែលព្រះអនុរុទ្ធពោលថា ខ្ញុំត្រូវការបរិភោគនំ ។ ទេវតាទាំងឡាយ រមែងញុំាងថាសឲ្យពេញ ។ ព្រះកុមារនោះ កាលនៅក្នុងរាជវាំង មិនបានជ្រាបពាក្យថាមិនមានដោយប្រការយ៉ាងនេះសោយតែនំទិព្វទាំងនោះ ។

កាលឱរសរបស់សក្យៈ បួសតាមលំដាប់ត្រកូល ដើម្បីជាបរិវារបស់ព្រះសាស្តា កាលព្រះបាទមហានាមសក្យៈត្រាស់ថា នែបា ក្នុងត្រកូលរបស់ពួកយើង បុគ្គលណាម្នាក់ដែលបួសហើយមិនមាន ឯង ឬខ្ញុំគួរបួស អនុរុទ្ធត្រាស់ថា ខ្ញុំជាសុខុមាលជាតិក្រៃលែង មិនអាចបួសបានទេ មហានាមពោលថា បើដូច្នេះ ចូរឯងរៀនការងារចុះ បងនឹងបួស អនុរុទ្ធពោលថា ឈ្មោះថាការងារនោះដូចម្តេច ។ ពិតហើយ ព្រះអនុរុទ្ធរមែងមិនដឹងទីកើតឡើងនៃកត្តនឹងជ្រាបការងារបានដូចម្តេច ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនោះ ។

ថ្ងៃមួយ សក្យៈ ៣ អង្គ គឺអនុរុទ្ធ កទ្ទិយៈ កិម្ពិលៈប្រឹក្សាគ្នាថា ឈ្មោះថា កត្តុ កើតក្នុងទីណា បណ្តាសក្យៈទាំង ៣ អង្គនោះ កិម្ពិលៈត្រាស់ថា កត្តុ កើតឡើងក្នុងជង្រុក បានឮថា ថ្ងៃមួយ កិម្ពិលៈនោះ បានឃើញស្រូវគេជញ្ជូនជាក់ក្នុងជង្រុក ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនោះដោយសម្គាល់ថា កត្តុរមែងកើតឡើងក្នុងជង្រុក ។ កាលណោះ កទ្ទិយៈពោលនឹងកិម្ពិលៈថា ឯងមិនដឹង ដូច្នេះហើយ ទើបត្រាស់ថា ធម្មតាកត្តុ គឺកើតឡើងក្នុងឆ្នាំងបាយ បានឮថា ថ្ងៃមួយ កទ្ទិយៈនោះ ឃើញជនទាំងឡាយដួសកត្តុចេញអំពីឆ្នាំងបាយ ហើយធ្វើសេចក្តីសម្គាល់ថា កត្តុនោះ កើតក្នុងឆ្នាំងនោះឯង ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនោះ ។

ព្រះអនុរុទ្ធត្រាស់នឹងស្តេចទាំងពីរអង្គថា ឯងទាំងពីរក៏មិនដឹង ហើយត្រាស់ថា កត្តកើតឡើងក្នុងថាសមាសធំកម្ពស់មួយហត្ថ បានឮថា ព្រះអនុរុទ្ធមិនធ្លាប់ឃើញគេបុកស្រូវ មិនធ្លាប់ឃើញគេដាំបាយ ឃើញតែកត្តដែលគេដួសទុកក្នុងថាសមាសហើយ តម្កល់ទុកចំពោះមុខប៉ុណ្ណោះ ព្រោះដូច្នោះ ទើបធ្វើសេចក្តីសម្គាល់ថា កត្តនោះ រមែងកើតឡើងក្នុងថាសនោះឯង ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនោះ ។ កុលបុត្រមានបុណ្យច្រើន មិនដឹងទីកើតនៃកត្តយ៉ាងនោះ នឹងដឹងការងារទាំងឡាយបានដូចម្តេច ។

ព្រះអនុរុទ្ធនោះ បានស្តាប់របៀបធ្វើការងារទាំងឡាយ ដែលបងប្រុសប្រាប់ដោយនយជាដើមថា អនុរុទ្ធមក បងនឹងបង្រៀនដើម្បីនឹងគ្រប់គ្រងផ្ទះ ដល់ឯងដែលជាអ្នកគ្រប់គ្រងផ្ទះ ជាបឋមត្រូវក្អួរស្រែដូច្នេះ ជារបស់មិនមានទីបំផុត ហើយទូលលាព្រះមាតាថា សេចក្តីត្រូវការដោយការគ្រប់គ្រងផ្ទះរបស់ខ្ញុំមិនមាន ហើយយាងចេញទៅ មួយអន្ទើដោយព្រះឱរសរបស់សក្យៈ ៥ អង្គ មានភទ្ទិយៈជាប្រធាន ចូលទៅគាល់ព្រះសាស្តាត្រង់អនុបិយម្តវន ទ្រង់ផ្នួស ហើយ កាលទ្រង់ផ្នួសហើយ ព្រះអនុរុទ្ធជាអ្នកបដិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា ៣ ដោយលំដាប់ ជាអ្នកអង្គុយលើអាសនៈមួយ អាចឃើញលោក-ធាតុមួយពាន់បានដោយទិព្វចក្ខុ ដូចផ្លែកន្ធតព្រៃ ដែលបុគ្គលដាក់លើបាតដៃដូច្នោះ ទើបបន្ទឺឧទានថា

ខ្ញុំព្រួកបាននូវបុព្វេនិវាស ទិព្វចក្ខុខ្ញុំក៏ជម្រះហើយ ខ្ញុំជាអ្នកបានវិជ្ជា ៣ ជាអ្នកដល់នូវឫទ្ធិ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។

ព្រះថេរៈពិចារណាថា អញធ្វើកម្មអ្វីហ្ន៎ ទើបបានសម្បត្តិនេះ បានជ្រាបថា បានតាំងនូវសេចក្តីប្រាថ្នាទៀបបាទមូល របស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ហើយជ្រាបបន្តទៀតថា អាត្មាអញអន្ទោលទៅក្នុងសង្សារអស់កាលឈ្មោះនោះ អាស្រ័យសុមនសេដ្ឋីក្នុងក្រុងពារាណសីចំពោះមជីវិតឈ្មោះអន្ធការៈ ដូច្នេះហើយ ពោលថា

ក្នុងកាលមុន ខ្ញុំឈ្មោះអន្ធការៈ ជាជនទុគ៌ត ជាអ្នកវែកស្មៅ បានប្រគេនបិណ្ឌបាតដល់ព្រះឧបរិដ្ឋបច្ចេកពុទ្ធ ជាអ្នកមានយស ។

កាលនោះ ព្រះថេរៈបរិវិតក្កថា សុមនសេដ្ឋីសម្លាញ់របស់អញ បានឲ្យកហាបណៈហើយ ទទួលយកចំណែកបុណ្យអំពីបិណ្ឌបាត ដែលអាត្មាអញប្រគេនដល់ព្រះឧបរិដ្ឋបច្ចេកពុទ្ធក្នុងកាលនោះ ឥឡូវនេះកើតក្នុងទីណាហ្ន៎ ក៏បានឃើញសេដ្ឋីនោះថា កើតក្នុងស្រុកឈ្មោះមុណ្ឌនិគម ត្រង់ជើងភ្នំក្បែរព្រៃភ្លើងនេះ ឧបាសកឈ្មោះមហាមុណ្ឌៈ ក្នុងមុណ្ឌនិគមនោះមានកូនប្រុសពីរនាក់ គឺមហាសុមនៈ ១ ចូឡសុមនៈ ១ ក្នុងកូនទាំងពីរនោះ សុមនសេដ្ឋីកើតជាចូឡសុមនៈ កាលឃើញហើយគិតថា បើអាត្មាអញទៅក្នុងទីនោះ ឧបការៈនឹងមានឬហ្ន៎ លោកពិចារណាបានឃើញហេតុនេះថា កាលអញទៅទីនោះ ចូឡ-សុមនៈនោះមានអាយុ ៧ ឆ្នាំប៉ុណ្ណោះនឹងចេញបួស នឹងសម្រេចអរហត្តក្នុងពេលកោរសក់ស្រេចនោះឯង ។ កាលឃើញហើយ រដូវក្តៀងជិតចូលមកដល់ ទើបទៅតាមអាកាសចុះត្រង់ទ្វារស្រុក ។ ចំណែកមហាមុណ្ឌឧបាសក ជាអ្នកស្និទ្ធស្នាលរបស់ព្រះថេរៈក្នុងកាលមុនដូចគ្នា ឃើញព្រះថេរៈឃ្លាំចីវរក្នុងពេល

បិណ្ឌបាត ទើបពោលនឹងមហាសុមនៈជាកូនថា នែបា ព្រះអនុរុទ្ធត្ថេរ របស់យើងនិមន្តមកហើយ ចូរបាទៅទទួលបាត្រឲ្យទាន់ពេលដែលអ្នកដទៃមិនទាន់ទទួលបាត្រលោកទៅ ឪពុកនឹងឲ្យគេក្រាលអាសនៈ ។ មហាសុមនៈបានធ្វើយ៉ាងនោះហើយ ឧបាសកអង្គាសព្រះថេរៈខាងក្នុងដោយគោរពហើយ ទទួលប្តេជ្ញាដើម្បីការនៅចាំវស្សាអស់ត្រីមាស ព្រះថេរៈទទួលនិមន្តហើយ ។

គ្រានោះ ឧបាសកបដិបត្តិព្រះថេរៈអស់ត្រីមាស ដូចបដិបត្តិមួយថ្ងៃនោះឯង ក្នុងថ្ងៃមហាបវារណា ទើបនាំត្រៃចីវរ និងអាហារវត្ថុដែលមានទឹកតិចប្រេង អង្គាជាដើមមកហើយ ជាក់ទៀបបាតជើងរបស់ព្រះថេរៈពោលថា សូមលោកម្ចាស់ទទួលចុះ ។ ព្រះថេរៈពោលថា កុំឡើយឧបាសក សេចក្តីត្រូវការដោយវត្ថុនេះរបស់អាត្មាមិនមាន ឧបាសកពោលថា បពិត្រលោកម្ចាស់នេះឈ្មោះថាវស្សាវាសិកលាភ សូមលោកម្ចាស់ទទួលវត្ថុនេះចុះ ព្រះថេរៈពោលថា កុំឡើយឧបាសក ឧបាសកពោលថា បពិត្រលោកម្ចាស់ ហេតុអ្វីទើបលោកម្ចាស់មិនទទួល ព្រះថេរៈពោលថា សាមណេរដែលជាកប្បិយការកក្នុងសម្នាក់របស់អាត្មាក៏មិនមាន ឧបាសកពោលថា បើយ៉ាងនោះមហាសុមនៈជាកូនរបស់ខ្ញុំនឹងជាសាមណេរ ព្រះថេរៈពោលថា ឧបាសក សេចក្តីត្រូវការដោយមហាសុមនៈរបស់អាត្មាមិនមាន ឧបាសកពោលថា បពិត្រលោកម្ចាស់ បើដូច្នោះសូមលោកម្ចាស់ឲ្យចូឡសុមនៈបួសចុះ ព្រះថេរៈទទួលថា សាធុ ហើយឲ្យចូឡសុមនៈបួស ។ ចូឡសុមនៈសម្រេចអរហត្តក្នុងពេលកោរសក់ស្រេចនោះឯង ។ ព្រះថេរៈនៅក្នុងទីនោះជាមួយចូឡសុមនសាមណេរនោះប្រមាណកន្លះ

ខែហើយ លាពួកញាតិរបស់លោកថា ពួកអាត្មានឹងគាល់ព្រះសាស្តា ដូច្នេះហើយ បានទៅតាមអាកាស ចុះត្រង់តូបដែលតាំងនៅក្នុងព្រៃ នាហិមវន្តប្បទេស ។

ព្រះថេរ: តាមប្រក្រតីជាអ្នកប្រារព្ធសេចក្តីព្យាយាម កាលលោកកំពុងចង្ក្រមក្នុងទីនោះ យប់ដំបូង និងយប់បន្ទាប់មក ខ្យល់ក្នុងផ្ទៃតាំងឡើងហើយ ក្នុងកាលនោះ សាមណេរយើញព្រះថេរ:លំបាក ទើបសាកសួរថា បពិត្រលោកម្ចាស់ រោគអ្វីចាក់ដោតលោកម្ចាស់ ព្រះថេរ:ពោលថា ខ្យល់សៀតផ្ទៃកើតឡើងដល់ខ្ញុំហើយ សាមណេរពោលថា ក្នុងកាលដទៃខ្យល់សៀតផ្ទៃធ្លាប់កើតឡើងឬ ព្រះថេរ:ពោលថា អើអាវុសោ សាមណេរពោលថា ការសប្បាយរមែងមានដោយអ្វី ព្រះថេរ:ពោលថា កាលខ្ញុំបានទឹកអំពីអនោតត្តស្រះផឹក ការសប្បាយរមែងមានអាវុសោ ។ សាមណេរពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ ខ្ញុំនឹងទៅយកមក ព្រះថេរ:ពោលថា លោកអាចនាំមកបានឬ សាមណេរពោលថា អាចលោកម្ចាស់ ព្រះថេរ:ពោលថា បើដូច្នោះ នាគរាជឈ្មោះបន្នក: ក្នុងអនោតត្តស្រះស្គាល់ខ្ញុំ ចូរលោកប្រាប់ដល់នាគរាជនោះ រួចហើយនាំទឹកមួយបំពង់មក ដើម្បីប្រយោជន៍ដល់ការប្រកបថ្នាំចុះ សាមណេរទទួលថា សាធុ ហើយថ្វាយបង្គំខបជ្ឈាយ៍ ហោះទៅកាន់អាកាសដែលមានចម្វាយផ្លូវ ៥០០ យោជន៍ហើយ ។

ថ្ងៃនោះ នាគរាជមានអ្នករបាំចោមរោមហើយ ប្រាថ្នានឹងលេងទឹក នាគ-រាជនោះ លុះយើញសាមណេរកំពុងទៅប៉ុណ្ណោះក៏ក្រោធហើយគិតថា សមណ: ត្រងោលនេះ រោយធូលីដែលជាប់នឹងបាតជើងលើអំបែងក្បាលរបស់អញ

សមណៈត្រង៉ោលនេះ មកហើយដើម្បីទឹកក្នុងអនោតត្តស្រះ ឥឡូវនេះ អញនឹងមិនឲ្យទឹកដល់លោក ដូច្នេះហើយ ដេកបិទអនោតត្តស្រះ ដែលមានប្រមាណ ៥០ យោជន៍ដោយពពារ ដូចបិទឆ្នាំងបាយដោយថាសធំ ដូច្នោះ ។ សាមណេរសម្លឹងមើលអាការរបស់នាគរាជហើយ ដឹងថា នាគនេះ ក្រោធហើយ ទើបពោលគាថាថា

នាគរាជ អ្នកជាបុគ្គលមានតេជៈខ្លាំងក្លា មានកម្លាំងច្រើន ចូរអ្នកស្តាប់ពាក្យខ្ញុំចុះ ចូរឲ្យទឹកផឹកដល់ខ្ញុំ ខ្ញុំមកហើយដើម្បីប្រយោជន៍ដល់ទឹកសម្រាប់ផ្ងើថ្នាំ ។ នាគរាជស្តាប់គាថានោះហើយ ពោលគាថានេះថា

ស្ទឹងធំឈ្មោះគង្គាត្រង់ទិសបូព៌ រមែងហូរទៅកាន់មហាសមុទ្រ សូមលោកនាំទឹកផឹកអំពីស្ទឹងគង្គានោះទៅចុះ ។

សាមណេរស្តាប់ពាក្យនោះហើយគិតថា ស្តេចនាគនេះមិនឲ្យតាមសេចក្តីប្រាថ្នារបស់អញ អាត្មាអញនឹងប្រើកម្លាំងឲ្យនាគនេះដឹងអានុភាពធំ អញនឹងសង្កត់ស្តេចនាគនេះហើយយកទឹកទៅ ដូច្នេះហើយ ពោលថា មហារាជ ព្រះឧបជ្ឈាយ៍ឲ្យខ្ញុំនាំទឹកផឹកអំពីអនោតត្តស្រះប៉ុណ្ណោះ ព្រោះហេតុនោះ ទើបខ្ញុំនាំទឹកផឹកនេះតែម្យ៉ាងទៅ ចូរលោកចៀសចេញ កុំឃាត់ខ្ញុំទៀយ ដូច្នេះហើយ ពោលគាថានេះថា

ខ្ញុំនឹងនាំទឹកផឹកអំពីអនោតត្តស្រះនេះប៉ុណ្ណោះ ខ្ញុំជាបុគ្គលមានសេចក្តីត្រូវការដោយទឹកផឹកនេះប៉ុណ្ណោះ បើថាមពល និងកម្លាំងមានសោត ចូរនាគរាជបិទស្រះចុះ ។ កាលនោះ ស្តេចនាគពោលថា នែសាមណេរ បើលោកក្លាហាន

ជាកូនប្រុសសោត ខ្ញុំពេញចិត្តនឹងពាក្យរបស់លោក សូមអញ្ជើញលោកនាំទីករបស់ខ្ញុំទៅចុះ ។

លំដាប់នោះ សាមណេរឆ្លើយនឹងស្តេចនាគថា មហារាជ ខ្ញុំនឹងនាំទៅយ៉ាងនោះ កាលស្តេចនាគពោលថា បើលោកអាចក៏ចូរនាំទៅចុះ ទទួលប្តេជ្ញាអស់វារៈ ៣ ដងថា បើដូច្នោះ ចូរលោកជឹងដោយល្អចុះ ហើយគិតថា ការដែលអញសម្តែងអានុភាពរបស់ព្រះពុទ្ធសាសនា ហើយយកទឹកទៅវិមែងគួរបានទៅកាន់សម្នាក់របស់ពួកអាកាសដ្ឋកទេវតាមុន ទេវតាទាំងនោះមកថ្វាយបង្គំ ហើយពោលថា មានរឿងអ្វីលោកម្ចាស់ ហើយនាំគ្នាឈរ ។

សាមណេរពោលថា សង្គ្រាមរបស់អាត្មា និងបន្ទុកនាគរាជនឹងមានត្រង់ផ្ទៃអនោតត្តស្រះនេះ សូមពួកលោកទៅកាន់ទីនោះហើយ មើលនូវការឈ្នះ និងការចាញ់ ។ សាមណេរទៅរកស្តេចចតុលោកបាល និងសក្កទេវរាជ ស្តេចសុយាម ស្តេចសន្តុសិត ស្តេចសុនិម្មិត និងស្តេចវសវត្តី ហើយប្រាប់សេចក្តីនោះដោយទំនងនោះឯង ។ បន្ទាប់អំពីនោះ សាមណេរទៅដោយលំដាប់រហូតដល់ព្រហ្មលោក កាលព្រហ្មទាំងឡាយក្នុងទីនោះៗ មកថ្វាយបង្គំ ហើយឈរសួរថា មានរឿងអ្វីលោកម្ចាស់ ទើបប្រាប់សេចក្តីនោះ ។

សាមណេរ ប្រាប់ក្នុងទីគ្រប់កន្លែងមួយរំពេច រៀវតែអសញ្ញិសត្ត និងអរូបព្រហ្មដោយអាការយ៉ាងនេះ សូម្បីទេវតាគ្រប់ពួក ស្តាប់ពាក្យលោកហើយ ប្រជុំគ្នាពេញអាកាសមិនមានចន្លោះ ត្រង់អនោតត្តស្រះ ដូចលម្អិតនៃនំដែលបុគ្គលដាក់ក្នុងនាឡិ ដូច្នោះ ។

កាលពួកទេវតាប្រជុំគ្នាហើយ សាមណេរឈរក្នុងអាកាស ពោលនឹងស្តេចនាគថា

នាគរាជ អ្នកជាបុគ្គលមានតេជះខ្លាំងក្លា មានកម្លាំងច្រើន ចូរអ្នកស្តាប់ពាក្យខ្ញុំ សូមអ្នកឲ្យភ្អមទឹកផឹកដល់ខ្ញុំ ខ្ញុំមកដើម្បីត្រូវការទឹកផ្ងើថ្នាំ ពេលនោះនាគរាជពោលថា

សាមណេរ បើលោកក្លាហាន ជាកូនប្រុសសោត ខ្ញុំពេញចិត្តនឹងពាក្យរបស់លោក សូមលោកនាំទឹកផឹករបស់ខ្ញុំទៅចុះ ។

សាមណេរនោះទទួលពាក្យប្តេជ្ញារបស់នាគរាជ ៣ ដងហើយ ឈរក្នុងអាកាសនោះឯង និម្មិតអត្តភាពជាព្រហ្មប្រមាណ ១២ យោជន៍ ហើយទម្លាក់ខ្លួនពីលើអាកាស ជាន់ត្រង់ពពាររបស់ស្តេចនាគ សង្កត់ឲ្យផ្កាប់មុខចុះហើយ រំពេចនោះឯង កាលសាមណេរជាន់ពពាររបស់ស្តេចនាគប៉ុណ្ណោះ ពពារស្តេចនាគបានរួញទៅសល់ប្រមាណប៉ុនវែក ដូចស្បែកស្រស់ដែលបុរសមានកម្លាំងជាន់ហើយ ដូច្នោះ ។ ក្នុងទីដែលផុតចាកពពាររបស់ស្តេចនាគមក ទៀទឹកប្រមាណ ប៉ុនដើមត្នោតក៏បាញ់ទៅឯលើ សាមណេរញ៉ាំងបំពង់ទឹកឲ្យពេញក្នុងអាកាសនោះឯង ពួកទេវតាបានឲ្យសាធុការហើយ ។

នាគរាជខ្មាស ក្រោធចំពោះសាមណេរហើយ ភ្នែកទាំងពីររបស់នាគរាជនោះមានពណ៌ដូចផ្កាច្បា ស្តេចនាគគិតថា សមណៈត្រង៉ោលនេះឲ្យពួកទេវតាប្រជុំគ្នាហើយ កាន់យកទឹកផឹក ធ្វើអញឲ្យខ្មាសហើយ អញនឹងចាប់លោកលូកដៃចូលក្នុងមាត់ហើយ ច្របាច់បេះដូងរបស់លោក ឬចាប់ជើងរបស់លោក

ហើយគ្រវែងទៅត្រើយស្ទឹងម្ខាង ដូច្នេះហើយ ដេញតាមសាមណេរដោយសម្លុះដ៏រហ័ស តែមិនអាចទាន់សាមណេរឡើយ ។ សាមណេរមកហើយ ជាក់ទឹកផឹកទុកក្នុងដៃព្រះឧបជ្ឈាយ៍ ពិតថា សូមលោកម្ចាស់ធាន់ចុះ ។

ស្តេចនាគក៏មកតាមក្រោយពោលថា បពិត្រព្រះអនុរុទ្ធ សាមណេរកាន់យកទឹកដែលខ្ញុំមិនបានឲ្យមក សូមលោកម្ចាស់កុំធាន់ ព្រះថេរៈសួរថា នែសាមណេរ បានឮថា សេចក្តីនោះយ៉ាងនោះឬ សាមណេរពោលថា សូមលោកម្ចាស់និមន្តធាន់ចុះ ទឹកផឹកនេះស្តេចនាគឲ្យហើយ ទើបខ្ញុំនាំមក ។ ព្រះថេរៈដឹងថា ឈ្មោះថា ការពោលពាក្យកុហករបស់សាមណេរ ដែលជាព្រះខីណាស្រព មិនមាន ទើបធាន់ទឹកហើយ អាពាធក៏ស្ងប់ក្នុងខណៈនោះឯង ។ នាគរាជពោលនឹងព្រះថេរៈទៀតថា បពិត្រលោកម្ចាស់ ខ្ញុំជាបុគ្គលដែលសាមណេរឲ្យពួកទេវតាទាំងអស់ប្រជុំគ្នា ធ្វើឲ្យខ្វាសហើយ ខ្ញុំនឹងហែកហទយៈរបស់លោក ឬនឹងចាប់លោកត្រង់ជើង គ្រវែងទៅកាន់ត្រើយស្ទឹងម្ខាង ព្រះថេរៈពោលថា មហារាជ សាមណេរមានអានុភាពច្រើន អ្នកមិនអាចប្រយុទ្ធជាមួយសាមណេរបានឡើយ ចូរអ្នកឲ្យសាមណេរអត់ទោសហើយទៅវិញចុះ ។

ស្តេចនាគ ដឹងអានុភាពរបស់សាមណេរឯង តែដេញមក ព្រោះការខ្វាស ។ លំដាប់នោះ ស្តេចនាគឲ្យសាមណេរនោះ អត់ទោសតាមពាក្យរបស់ព្រះថេរៈ ធ្វើនូវការពេញចិត្តជាមិត្តភាព ទើបពោលថា តាំងអំពីកាលនេះទៅ បើសេចក្តីត្រូវការដោយទឹកក្នុងអនោតត្តស្រះមាន កិច្ចដោយការមកនៃលោកម្ចាស់ មិនមាន សូមលោកម្ចាស់បញ្ជូនដំណឹងដល់ខ្ញុំ ខ្ញុំនឹងនាំទឹកមក

ប្រគេនឯង ដូច្នេះហើយ ចៀសចេញទៅ សូម្បីព្រះថេរៈក៏នាំសាមណេរទៅ ហើយ ។

ព្រះសាស្តា ទ្រង់ជ្រាបការមករបស់ព្រះថេរៈហើយ ប្រថាប់គង់ទតការមករបស់ព្រះថេរៈលើប្រាសាទរបស់មិគារមាតា ។ សូម្បីពួកភិក្ខុក៏ឃើញព្រះថេរៈកំពុងមក ក្រោកទៅទទួល ទទួលបាត្រ និងចីវរ ។

គ្រានោះ ភិក្ខុពួកខ្លះសូបសាមណេរត្រង់ក្បាលខ្លះ ចាប់ត្រចៀកទាំងពីរខ្លះ ដើមដៃខ្លះ អង្រែនខ្លះ ពោលថា នែសាមណេរ លោកមិនអផ្សុកទេឬ ។ ព្រះសាស្តាទតឃើញកិរិយារបស់ភិក្ខុទាំងនោះហើយ ទ្រង់ត្រិះរិះថា កម្មរបស់ភិក្ខុទាំងនេះគ្រោតគ្រោតពិត ភិក្ខុទាំងនេះចាប់សាមណេរ ដូចចាប់អាសិរពិសត្រង់ក ពួកភិក្ខុទាំងនេះមិនដឹងអានុភាពរបស់សាមណេរឡើយ ថ្ងៃនេះសមគួរតថាគតនឹងធ្វើគុណរបស់សុមនសាមណេរឲ្យប្រាកដ ។ ព្រះថេរៈក៏មកថ្វាយបង្គំព្រះសាស្តាហើយ ។

ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈ ហើយហៅព្រះអានន្ទត្ថេរមកថា អានន្ទ តថាគតមានបំណងនឹងលាងជើងទាំងពីរ ដោយទឹកក្នុងអនោតត្តស្រះ ចូរអ្នកឲ្យក្អមដល់សាមណេរឲ្យនាំទឹកមកចុះ ព្រះថេរៈឲ្យសាមណេរប្រមាណ ៥០០ ក្នុងវិហារប្រជុំគ្នាហើយ ។

បណ្តាសាមណេរទាំងនោះ សុមនសាមណេរបួសថ្មីជាងសាមណេរទាំងពួង ។ ព្រះថេរៈពោលនឹងសាមណេរចាស់ជាងគេបង្អស់ថា នែសាមណេរ ព្រះសាស្តាមានបំណងលាងព្រះបាទទាំងគូ ដោយទឹកក្នុងអនោតត្តស្រះ លោក

កាន់ក្អមទឹកទៅនាំទឹកមកចុះ ។ សាមណេរនោះមិនជ្រាបថ្នាដោយពោលថា ខ្ញុំមិនអាច ព្រះថេរៈសួរសាមណេរទាំងឡាយដ៏សេសដោយលំដាប់ សាមណេរទាំងនោះ ក៏ពោលដោះខ្លួនយ៉ាងនោះឯង ។

មានពាក្យសួរថា បណ្តាសាមណេរទាំងនោះ សាមណេរជាព្រះខីណាស្រពមិនមានឬ ឆ្លើយថា មាន តែសាមណេរទាំងនោះមិនជ្រាបថ្នាដោយគិតឃើញថា កម្រងផ្កានេះ ព្រះសាស្តាទ្រង់មិនចងដើម្បីពួកយើង ទ្រង់ចងដើម្បីសុមនសាមណេរមួយអង្គប៉ុណ្ណោះ ។ តែពួកសាមណេរដែលជាបុថុជ្ជន មិនជ្រាបថ្នាទៅ ក៏ព្រោះភាពដែលខ្លួនជាអ្នកមិនអាចនោះឯង ក្នុងទីបំផុត កាលវារៈជល់សុមនសាមណេរ ព្រះថេរៈពោលថា សាមណេរ ព្រះសាស្តាមានបំណងលាងព្រះបាទទាំងគូ ដោយទឹកក្នុងអនោតត្តស្រះ ចូរអ្នកកាន់យកក្អមទឹកទៅជងទឹកមក សុមនសាមណេរនោះពិតថា កាលព្រះសាស្តាទ្រង់ឲ្យនាំមក ខ្ញុំនឹងនាំមក ដូច្នេះហើយ ថ្វាយបង្គំព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ បានឮថា ទ្រង់ឲ្យខ្ញុំព្រះអង្គនាំទឹកមកអំពីអនោតត្តស្រះឬ ព្រះសាស្តាត្រាស់ថា ម្នាលសុមនៈ ពិតហើយ សុមនសាមណេរនោះយកដៃចាប់ក្អមធំមួយ ដែលជាក់ទឹកបាន ៦០ ក្អម ក្នុងបណ្តាក្អមសម្រាប់សេនាសនៈ ដែលធ្វើអំពីមាស ដែលនាងវិសាខាសាង កាន់ទៅដោយគិតថា សេចក្តីត្រូវការរបស់អញដោយក្អមដែលអញលើកឡើងជាក់លើស្មាមិនមាន ប្រញាប់ហោះឡើងទៅកាន់អាកាស បែរមុខទៅកាន់ហិមវន្តប្បទេស ។

នាគរាជឃើញសាមណេរកំពុងមកអំពីចម្ងាយ ទើបទទួលលីភ្លុមដោយស្មា ពោលថា បពិត្រលោកម្ចាស់ បើអ្នកបម្រើដូចខ្ញុំមាន ព្រោះហេតុអ្វី ទើបលោកម្ចាស់មកឯង បើសេចក្តីត្រូវការទឹកមាន ហេតុអ្វីលោកម្ចាស់មិនបញ្ជូនជំណឹងមក ដូច្នេះហើយ យកភ្លុមដងទឹកលីដោយស្មាពោលថា សូមលោកម្ចាស់ និមន្តទៅមុនចុះ ខ្ញុំនឹងនាំទៅ សាមណេរពោលថា មហារាជចូរលោកឈប់ចុះ ខ្ញុំឯងដែលព្រះសម្ចាសម្ពុទ្ធប្រើមក ដូច្នេះ ឲ្យស្តេចនាគត្រឡប់ហើយ យកដៃចាប់ត្រង់កណ្តាប់មាត់ឆ្នាំង ហោះមកតាមអាកាស ។

លំដាប់នោះ ព្រះសាស្តាទ្រង់សម្លឹងមើលសាមណេរដែលកំពុងត្រឡប់មក ហៅពួកភិក្ខុមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នកមើលលីលារបស់សាមណេរ ដែលល្អដូចស្តេចហង្សក្នុងអាកាសដូច្នោះ ។ សាមណេរជាក់ភ្លុមទឹកហើយ ថ្វាយបង្គំព្រះសាស្តាឈរក្នុងចំណែកម្ខាង ។ លំដាប់នោះ ព្រះសាស្តាត្រាស់ថា សុមនៈអ្នកមានអាយុប៉ុន្មាន សាមណេរក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមានអាយុ ៧ ឆ្នាំ ព្រះសាស្តាត្រាស់ថា សុមនៈ បើដូច្នោះតាំងអំពីនេះទៅ ចូរអ្នកជាភិក្ខុចុះ ដូច្នេះហើយ បានប្រទានទាយជ្ឈឧបសម្បទា ។

បានឮថា សាមណេរអាយុ ៧ ឆ្នាំពីរូបប៉ុណ្ណោះ ដែលបានឧបសម្បទា គឺសុមនសាមណេរនេះមួយរូប និងសោឋកសាមណេរមួយរូប ។ កាលសុមន-សាមណេរឧបសម្បទាហើយយ៉ាងនោះ ពួកភិក្ខុសន្ធនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ កម្មនេះ គួរអស្ចារ្យ អានុភាពរបស់សាមណេរតូចបែបនេះ ក៏មានអានុភាពបែបនេះ ពួកយើងមិនធ្លាប់ឃើញឡើយ ក្នុងកាលមុនអំពីនេះ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលពួកលោកក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនារបស់តថាគត បុគ្គលទោះជាក្មេងបដិបត្តិប្រពៃហើយ រមែងបានសម្បត្តិបែបនេះដូចគ្នា កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យោ ហវេ ឧហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ
សោ មំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

ភិក្ខុណាទៅកំលោះ ប្រឹងប្រែងក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងញ៉ាំងលោកនេះឲ្យភ្លឺស្វាងបាន ដូចព្រះចន្ទ្រដែលរះផុតអំពីពពក ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យុញ្ជតិ** *បានដល់ ប្រឹងប្រែង គឺព្យាយាម ។*

បទថា **បភាសេតិ** *ជាដើម សេចក្តីថា ភិក្ខុនោះរមែងញ៉ាំងលោក មានខន្ធលោកជាដើមឲ្យភ្លឺស្វាងបាន គឺរមែងធ្វើឲ្យមានពន្លឺតែមួយ ដោយញាណដែលសម្បយុត្តដោយអរហត្តមគ្គរបស់ខ្លួន ដូចព្រះចន្ទ្រដែលផុតចាកគ្រឿងបិទបាំង មានពពកជាដើម ដូច្នោះ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងសុមនសាមណេរ ចប់

ភិក្ខុវគ្គទី ២៥ ចប់

សុត្តន្តបិដក

ធម្មបទគាថា ព្រាហ្មណវគ្គទី ២៦

[៣៦] ម្នាលព្រាហ្មណ៍ អ្នកចូរប្រឹងកាត់តណ្ហាដូចខ្សែទឹក ចូរបន្ទោបង់កាមទាំងឡាយចេញ ម្នាលព្រាហ្មណ៍ អ្នកស្គាល់ច្បាស់នូវការអស់សង្ខារទាំងឡាយហើយ ឈ្មោះថា ជាអ្នកដឹងព្រះនិព្វាន ដែលបច្ច័យតាក់តែងមិនបាន ។

កាលណា ព្រាហ្មណ៍អ្នកដល់ត្រើយ ក្នុងធម៌ពីរប្រការ គឺសមថធម៌ និងវិបស្សនាធម៌ ក្នុងកាលណោះ កិលេស គ្រឿងប្រកបសត្វទុកទាំងអស់ របស់ព្រាហ្មណ៍ អ្នកដឹងនោះ រមែងដល់នូវការតាំងនៅមិនបាន ។ ត្រើយក្តី ទីមិនមែនត្រើយក្តី ត្រើយ និងទីមិនមែនត្រើយក្តី មិនមានដល់បុគ្គលណា (សេចក្តីប្រកាន់អាយតន:មិនមានដល់បុគ្គលណា) តថាគតហៅបុគ្គលនោះ ដែលជាអ្នកមានសេចក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកប្រាសចាកកិលេស ថាជាព្រាហ្មណ៍ ។ តថាគតហៅបុគ្គលអ្នកចម្រើនឈាន មានធូលី គឺកាមអស់ហើយ អ្នកអង្គុយនៅឯកឯង អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈ ដល់នូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ដោយលំដាប់ហើយនោះ ថាជាព្រាហ្មណ៍ ។

ព្រះអាទិត្យរុងរឿងក្នុងវេលាថ្ងៃ ព្រះចន្ទ្រុងរឿងក្នុងវេលាយប់ ក្សត្រប្រដាប់ពេញយសហើយ រមែងរុងរឿង សមណព្រាហ្មណ៍ជាអ្នកមានឈាន រមែងរុងរឿង ឯព្រះពុទ្ធ រមែងរុងរឿងដោយតេជៈរហូតថ្ងៃ និងយប់ទាំងអស់ ។

អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះថា ព្រាហ្មណ៍ អ្នកដែលតថាគតហៅថា សមណៈ ព្រោះការប្រព្រឹត្តរម្ងាប់ អ្នកដែលបណ្តេញមន្ទិលនៃខ្លួន ហេតុនោះ ទើបតថាគតហៅថា បព្វជិត ។

ព្រាហ្មណ៍ មិនគប្បីប្រហារព្រាហ្មណ៍ទេ (ចំណែក) ព្រាហ្មណ៍ (ដែលត្រូវគេប្រហារហើយ) មិនគប្បីចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍ ដែលប្រហារព្រាហ្មណ៍ ព្រាហ្មណ៍ណា ចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍នោះ ក្រៃលែងជាងនោះទៅទៀត ។

ការហាមឃាត់ចិត្ត ចាកអារម្មណ៍ជាទីស្រឡាញ់ របស់ព្រាហ្មណ៍នោះ មិនមែនប្រសើរបន្តិចបន្តួចទេ ចិត្តដែលគិតបៀតបៀនគេ ងាកចេញចាកវត្ថុណាៗ សេចក្តីទុក្ខព្រោះវត្ថុនោះៗ ក៏រម្ងាប់ទៅបាន ។

អំពើអាក្រក់ដោយទ្វារកាយ ទ្វារវាចា ទ្វារចិត្ត របស់បុគ្គលណា មិនមានទេ តថាគតហៅបុគ្គល ដែលបានសង្រួមដោយឋានទាំង ៣ នោះថា ជាព្រាហ្មណ៍ ។

បុគ្គលចេះធម៌អាថ៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយ អំពីសម្នាក់គ្រូណា គប្បីនមស្ការគ្រូនោះ ដោយគោរព ដូចព្រាហ្មណ៍ដែលគោរពការបូជាភ្លើង ដូច្នោះដែរ ។

បុគ្គលដែលឈ្មោះថាព្រាហ្មណ៍ ព្រោះផ្នងសក់ក៏មិនមែន ព្រោះគោត្រក៏មិនមែន ព្រោះជាតិក៏មិនមែន សច្ចៈផង ធម៌ផង មានក្នុងបុគ្គលណា

បុគ្គលនោះ ឈ្មោះថា អ្នកស្នាតផង បុគ្គលនោះ ឈ្មោះថា ព្រាហ្មណ៍ផង ។ នែអ្នកអប្បញ្ញាអើយ អ្នកមានប្រយោជន៍អ្វី ដោយការទុកផ្ដងសក់ អ្នកមានប្រយោជន៍អ្វី ដោយការទ្រទ្រង់សំពត់ស្បែកខ្លា បើសន្ដានខាងក្នុងរបស់អ្នកសឹងសាំវញ្ជាំដោយរាគាទិក្កិលេស អ្នកឈ្មោះថា ជុសខាត់តែកាយខាងក្រៅទេ ។

តថាគតហៅបុគ្គលអ្នកទ្រទ្រង់សំពត់បង្សុកូល មានកាយស្គម មានខ្លួនរវាមដោយសរសៃ ជាបុគ្គលឯកឯង ចម្រើនឈានក្នុងព្រៃនោះ ថាជាព្រាហ្មណ៍ ។ តថាគតនឹងហៅអ្នកកើតអំពីកំណើត អ្នកកើតក្នុងផ្ទៃនៃព្រាហ្មណី ជាមាតា ថាជាព្រាហ្មណ៍ក៏ទេ បុគ្គលនោះ គ្រាន់តែបាននាមថាភោវាទី (អ្នកពោលថា ចម្រើន) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេស គ្រឿងកង្វល់នៅហើយ តថាគតហៅបុគ្គលអ្នកមិនមានកិលេសគ្រឿងកង្វល់ អ្នកមិនមានសេចក្ដីប្រកាន់មាំនោះឯង ថាជាព្រាហ្មណ៍ ។

បុគ្គលណា កាត់សំយោជន:ទាំងអស់បាន មិនតក់ស្លុត តថាគតហៅបុគ្គលនោះ ដែលគ្មានកិលេសជាគ្រឿងចំពាក់ អ្នកវួចស្រឡះចាកកិលេស ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលដែលកាត់សេចក្ដីក្រោធ ដូចពួរផង កាត់តណ្ហា ដូចព្រ័ត្រផង កាត់ទិដ្ឋិ ៦២ ដូចទី-ត ព្រមទាំងអនុសយ ដូចអ្នកដើរតាមផង អ្នកមានអវិជ្ជា ដូចសសរខឿនជកចោលហើយ អ្នកត្រាស់ដឹងសច្ច: ៤ នោះឯង ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនប្រទូស្ត អត់សង្កត់ពាក្យជេរផង ការបៀតបៀន និង ការចងផងបាន ទើបតថាគតហៅបុគ្គលដែលមានខន្តិជាពល មានខន្តិជាវេហ៍ ពលនោះឯង ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល ដែលមិនមានសេចក្តីក្រោធ មានធុតង្គវត្ត មាន ចតុប្បារិសុទ្ធិសីល មិនមានតណ្ហាគ្រឿងប៉ោងចិត្ត មានឥន្ទ្រិយទូន្មានហើយ មានសរីរៈស្ថិតនៅ ក្នុងទីបំផុតនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មានចិត្តមិនបានជាប់នៅក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹក ឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជា ព្រាហ្មណ៍ ។

បុគ្គលណា ក្នុងសាសនានេះឯង ដឹងច្បាស់នូវការអស់ទុក្ខរបស់ខ្លួន តថាគតហៅបុគ្គលនោះ ដែលមានខន្ធភារៈ ដាក់ចុះហើយ ដែលរួចស្រឡះ ចាកកិលេសទាំងឡាយ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលអ្នកមានប្រជ្ញាជ្រៅ មានប្រជ្ញាជាគ្រឿងទម្លាយ កិលេស អ្នកឈ្លាសក្នុងផ្លូវ និងមិនមែនផ្លូវ បានសម្រេចប្រយោជន៍ ដ៏ ខ្ពង់ខ្ពស់នោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល ដែលមិនច្រឡំជោយជនទាំងឡាយ ២ ពួក គឺ គ្រហស្ថ ១ បព្វជិត ១ ជាអ្នកគ្រាច់ទៅជោយមិនមានសេចក្តីអាល័យ មាន សេចក្តីប្រាថ្នាតិចនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងឡាយ ដែលនៅតក់ស្លុតក្តី

ដែលមាំមួន គឺមិនមានតក់ស្លុតក្តី មិនបៀតបៀនដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលអ្នកដែលមិនខឹង ចំពោះពួកជនដែលខឹងហើយ អ្នករលត់ចំពោះពួកជន ដែលមានអាជ្ញាក្នុងខ្លួន អ្នកមិនមានសេចក្តីប្រកាន់ចំពោះពួកជន ដែលមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

រាគៈ ទោសៈ មានៈ និងមក្ខៈ ដែលបុគ្គលណា បានជម្រុះចេញហើយ ដូចគ្រាប់ស្ពៃដែលជ្រុះចុះ អំពីចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។ បុគ្គលណា ពោលពាក្យមិនអាក្រក់ ពាក្យជាហេតុឲ្យដឹងសេចក្តីបាន ជាពាក្យពិត ជាពាក្យដែលមិនធ្វើអ្នកណាឲ្យទាស់ចិត្ត តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនកាន់យករបស់វែង ឬខ្លី តូច ឬធំ ល្អ ឬអាក្រក់ ដែលគេមិនបានឲ្យហើយក្នុងលោកនេះ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

អ្នកណា មិនមានសេចក្តីប្រាថ្នា ក្នុងលោកនេះផង ក្នុងលោកខាងមុខផង តថាគតហៅបុគ្គលនោះ ដែលមិនមានសេចក្តីប្រាថ្នា ដែលផុតស្រឡះចាកកិលេស ថាជាព្រាហ្មណ៍ ។

អ្នកណា មិនមានសេចក្តីអាល័យ គឺតណ្ហា មិនមានសេចក្តីសង្ស័យក្នុងអ្វីសោះ ព្រោះដឹងច្បាស់ធម៌ តថាគតហៅបុគ្គលនោះ ដែលមានចិត្តចុះស៊ប់កាន់ព្រះនិព្វាន ដែលមានព្រះអរហត្តផលដល់ហើយ ដោយលំដាប់ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យ និងបាបទាំងពីរ និងកិលេស ជាគ្រឿងជំពាក់ (មានរាគៈជាដើម) ចេញហើយ តថាគតហៅបុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តីសោក មានធូលី គឺកិលេសអស់ហើយ ជាអ្នក បរិសុទ្ធ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល ដែលមិនមានសេចក្តីសៅហ្មង ដូចព្រះចន្ទ្រជ្រះថ្លា ចាកមន្ទិល ជាអ្នកបរិសុទ្ធ មានចិត្តជ្រះថ្លា មិនកកស្អុក អស់សេចក្តី ត្រេកអរក្នុងភពហើយនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា កន្ទងផ្លូវវាង គឺរាគៈ និងកក់ដែលគេឆ្លងបានដោយកម្រ គឺកិលេស និងសង្សារវដ្ត និងមោហៈទាំងនេះបាន ជាអ្នកឆ្លងអន្ទង់ទាំង ៤ បានដល់ត្រើយ គឺព្រះនិព្វាន ជាអ្នកមានឈាន មិនញាប់ញ័រដោយតណ្ហា មិន មានសេចក្តីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថាគតហៅ បុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ក្នុងលោកនេះ បានលះបង់កាមទាំងឡាយ ជាអ្នកមិនមាន ផ្ទះ គេចចេញចាកកាមបាន តថាគតហៅបុគ្គលនោះ ដែលអស់កាមភព ហើយ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ក្នុងលោកនេះ បានលះបង់តណ្ហាហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហាបាន តថាគតហៅបុគ្គល ដែលអស់តណ្ហា និងភព ហើយនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា លះកិលេសជាគ្រឿងប្រកប ដែលជារបស់មនុស្ស កន្ទង

កិលេសជាគ្រឿងប្រកប ដែលជារបស់ទិព្វបានហើយ តថាគតហៅបុគ្គលដែលផុតស្រឡះ ចាកកិលេសជាគ្រឿងប្រកបទាំងពួងនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល ដែលលះបង់សេចក្តីត្រេកអរក្នុងកាមគុណ និងមិនត្រេកអរក្នុងកិរិយានៅក្នុងព្រៃ ជាអ្នកមានចិត្តត្រជាក់មិនមានឧបក្កិលេសគ្របសង្កត់លោកទាំងពួង មានសេចក្តីព្យាយាមនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ជីងច្បាស់ចុតិ និងបដិសន្ធិរបស់ពួកសត្វ ដោយអាការទាំងពួងបាន តថាគតហៅបុគ្គលដែលជាអ្នកមិនជាប់នៅក្នុងកាម អ្នកមានជំណើរល្អ ដោយសេចក្តីប្រតិបត្តិ អ្នកត្រាស់ដឹងនូវសច្ចៈ ៤ នោះ ថាជាព្រាហ្មណ៍ ។

ទេវតា គន្ធព្វ និងពួកមនុស្សទាំងឡាយ មិនដឹងគតិរបស់បុគ្គលណា តថាគតហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្តនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនមានសេចក្តីកង្វល់ ក្នុងកាលមុនផង ក្នុងកាលជាខាងក្រោយផង ក្នុងកាលជាកណ្តាលផង តថាគតហៅបុគ្គល ដែលជាអ្នកមិនមានកង្វល់ មិនមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅវីរបុរស អ្នកអង់អាច អ្នកប្រសើរ អ្នកស្វែងរកគុណដ៏ធំ ឈ្នះមារ មិនមានកិលេសជាគ្រឿងញាប់ញ័រ ឆ្លងលាងកិលេស ត្រាស់ដឹងសច្ចៈនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ដ៏ងច្បាស់ខន្ធបញ្ចកៈ ដែលខួនធ្លាប់នៅអាស្រ័យ ក្នុងកាលមុនផង ឃើញច្បាស់ស្ថានសួគ៌ និងអបាយភូមិផង មួយទៀត បានសម្រេចធម៌ជាគ្រឿងអស់ជាតិ ជាអ្នកជ្រាជ្រ ស្រេចកិច្ចហើយ ព្រោះអភិញ្ញា តថាគតហៅបុគ្គល ដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ចប់សព្វគ្រប់ហើយនោះ ថាជាព្រាហ្មណ៍ ។

ព្រាហ្មណវគ្គទី ២៦ ចប់

ឧទ្ទាននៃធម្មបទគាថាគឺ

[៣៧] សម្តែងពីយមកវគ្គ ១ អប្បមាទវគ្គ ១ ចិត្តវគ្គ ១ បុប្ផវគ្គ ១ ពាលវគ្គ ១ បណ្ឌិតវគ្គ ១ អរហន្តវគ្គ ១ សហស្សវគ្គ ១ បាបវគ្គ ១ ទណ្ឌវគ្គ ១ ត្រូវជា ១០ វគ្គ ។

ជរាវគ្គ ១ អត្តវគ្គ ១ លោកវគ្គ ១ ពុទ្ធវគ្គ ១ សុខវគ្គ ១ បិយវគ្គ ១ កោធវគ្គ ១ មលវគ្គ ១ ធម្មដ្ឋវគ្គ ១ មគ្គវគ្គ ១ រួបនឹងវគ្គខាងដើមត្រូវជា ២០ វគ្គ ។

បកិណ្ណកវគ្គ ១ និរយវគ្គ ១ នាគវគ្គ ១ តណ្ហាវគ្គ ១ ភិក្ខុវគ្គ ១ ព្រាហ្មណវគ្គ ១ បូករួមត្រូវជា ២៦ វគ្គ ដែលព្រះអាទិច្ចពន្ធុទ្រង់សម្តែងទុកហើយ ។ ក្នុងយមកវគ្គ មាន ២០ គាថា ក្នុងអប្បមាទវគ្គ មាន ១២ គាថា ក្នុងចិត្តវគ្គ មាន ១១ គាថា ក្នុងបុប្ផវគ្គ មាន ១៦ គាថា ក្នុងពាលវគ្គ

មាន ១៧ គាថា ក្នុងបណ្ឌិតវគ្គ មាន ១៤ គាថា ក្នុងអរហន្តវគ្គ មាន ១០ គាថា ក្នុងសហស្សវគ្គ មាន ១៦ គាថា ក្នុងបាបវគ្គ មាន ១៣ គាថា ក្នុងទណ្ឌវគ្គ មាន ១៧ គាថា ក្នុងជរាវគ្គ មាន ១១ គាថា ក្នុងអត្តវគ្គ មាន ១២ គាថា ក្នុងលោកវគ្គ មាន ១ គាថា ក្នុងពុទ្ធវគ្គ មាន ១៦ គាថា ក្នុងសុខវគ្គ និងបិយវគ្គ មាន ១២ គាថាដូចគ្នា ក្នុងកោធវគ្គ មាន ១៤ គាថា ក្នុងមលវគ្គ មាន ២១ គាថា ក្នុងធម្មដ្ឋវគ្គ មាន ១៧ គាថា ក្នុងមគ្គវគ្គ មាន ១៦ គាថា ក្នុងបកិណ្ណកវគ្គ មាន ១៦ គាថា ក្នុងនិរយវគ្គ និងនាគវគ្គ មាន ១៤ គាថាដូចគ្នា ក្នុងតណ្ហាវគ្គ មាន ២២ គាថា ក្នុងភិក្ខុវគ្គ មាន ២៣ គាថា ក្នុងព្រាហ្មណវគ្គដ៏ឧត្តម មាន ៤០ គាថា ។ ៤២៣ គាថាដទៃទៀត ព្រះអាទិច្ចពន្ធុទ្រង់សម្តែងទុកហើយ ក្នុងធម្មបទនិបាត ។

ធម្មបទ ចប់

អដ្ឋកថា

ព្រាហ្មណវគ្គទី ២៦

រឿង ព្រាហ្មណ៍មានសេចក្តីជ្រះថ្លាច្រើន

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ មានសេចក្តីជ្រះថ្លាច្រើន ត្រាស់ព្រះធម្មទេសនានេះថា **ឯវំ សោតំ បវត្តម្ហ** *ជាដើម ។*

បានឮថា ព្រាហ្មណ៍នោះ ស្តាប់ព្រះធម្មទេសនារបស់ព្រះដ៏មានព្រះភាគហើយ មានចិត្តជ្រះថ្លា ផ្តើមតាំងនិច្ចភត្តដើម្បីភិក្ខុមានប្រមាណ ១៦ រូប ក្នុងផ្ទះរបស់ខ្លួន ទទួលបាត្រក្នុងពេលភិក្ខុទាំងឡាយមកហើយ ពោលថា សូមព្រះអរហន្តទាំងឡាយនិមន្តមក សូមព្រះអរហន្តទាំងឡាយនិមន្តគង់ ។ កាលពោលពាក្យណាមួយ ក៏ពោលពាក្យប្រកបចំពោះដោយវាទៈថា ព្រះអរហន្តប៉ុណ្ណោះ បណ្តាភិក្ខុទាំងនោះ ភិក្ខុជាបុថុជ្ជនគិតថា ព្រាហ្មណ៍នេះសម្គាល់ក្នុងពួកយើងថាជាព្រះអរហន្ត ភិក្ខុដែលជាព្រះខីណាស្រពគិតថា ព្រាហ្មណ៍ជីងកាពដែលពួកយើងជាព្រះខីណាស្រព ភិក្ខុទាំងឡាយនោះ ប្រព្រឹត្តរង្កៀសយ៉ាងនេះ ទើបមិនទៅកាន់ផ្ទះរបស់ព្រាហ្មណ៍នោះ គាត់ទោមនស្សគិតថា ហេតុអ្វីហ្ន៎ ទើបលោកម្ចាស់មិននិមន្តមក ទៅកាន់វិហារថ្វាយបង្គំព្រះសាស្តា ក្រាបទូលសេចក្តីនោះ ព្រះសាស្តាត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ត្រាស់សួរថា ម្នាលភិក្ខុ

ទាំងឡាយ សេចក្តីនោះដូចម្តេច កាលភិក្ខុទាំងនោះក្រាបទូលសេចក្តីនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកត្រេកអរនឹងវាទៈថាជាព្រះអរហន្ត ឬ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនត្រេកអរទេ ព្រះសាស្តាត្រាស់ថា បើដូច្នោះ ពាក្យនោះ គ្រាន់តែជាពាក្យពោលដោយការជ្រះថ្លារបស់មនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវអាបត្តិព្រោះការពោលដោយសេចក្តីជ្រះថ្លាឡើយ ម្យ៉ាងទៀត សេចក្តីស្រឡាញ់ក្នុងព្រះអរហន្តទាំង-ឡាយរបស់ព្រាហ្មណ៍ មានប្រមាណក្រៃលែង ហេតុនោះសូម្បីពួកអ្នកកាត់ក្រែសេតណ្ហា ហើយសម្រេចអរហត្តនោះឯងគួរ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ឆិន្ទ សោតំ បរក្កម្ម កាមេ បនុទ ព្រាហ្មណ
សង្ខារានំ ខយំ ញត្វា អកតញ្ញូសិ ព្រាហ្មណ ។

ម្នាលព្រាហ្មណ៍ ចូរអ្នកទំប្រើងកាត់តណ្ហាដូចខ្សែទឹក ចូរបន្ទោបង់កាមទាំងឡាយចេញ ម្នាលព្រាហ្មណ៍ អ្នកស្គាល់ច្បាស់នូវការអស់សង្ខារទាំងឡាយហើយ ឈ្មោះថា ជាអ្នកដឹងនូវព្រះនិព្វាន ដែលបច្ច័យតាក់តែងមិនបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បរក្កម្ម** *ជាដើម សេចក្តីថា ឈ្មោះថាក្រែសេតណ្ហា បុគ្គលណាម្នាក់មិនអាចកាត់បាន ដោយសេចក្តីព្យាយាម មានប្រមាណតិច ហេតុនោះ ចូរអ្នកព្យាយាមកាត់ក្រែសេនោះ ដោយការប្រឹងប្រែង*

ដ៏ធំ ដែលសម្បយុត្តដោយញាណ គឺចូរបន្ទោបង់ បានដល់ ចូរបណ្តេញកាម ទាំងពីរចុះ ។

បទថា **ព្រាហ្មណោ** *នោះ ជាពាក្យហៅព្រះខីណាស្រពទាំងឡាយ ។*

បទថា **សង្ខារានំ** *សេចក្តីថា ដឹងនូវការអស់ទៅនៃខន្ធ ៥ ។*

បទថា **អកតញ្ញូ** *សេចក្តីថា កាលបើដូច្នោះ អ្នកជាបុគ្គលឈ្មោះថា អកតញ្ញូ ព្រោះដឹងនូវព្រះនិព្វាន ដែលធម៌ណាមួយ បណ្តាលោកធាតុទាំង-ឡាយ មានមាសជាដើមធ្វើមិនបាន ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងព្រាហ្មណ៍មានសេចក្តីជ្រះថ្លាច្រើន ចប់

រឿង ភិក្ខុច្រើនរូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **យថា ទ្វយេសុ ធម្មេសុ** ជាដើម ។

ថ្ងៃមួយ ភិក្ខុនៅក្នុងទិសប្រមាណ ៣០ រូប មកថ្វាយបង្គំព្រះសាស្តា ហើយ អង្គុយ ។ ព្រះសារីបុត្តត្ថេរ ឃើញឧបនិស្សយនៃព្រះអរហត្តរបស់ភិក្ខុទាំងនោះហើយ ចូលទៅគាល់ព្រះសាស្តា ឈរទូលសួរបញ្ហានេះថា បពិត្រព្រះអង្គ ធម៌ទាំងឡាយដែលទ្រង់ត្រាស់ហៅថា ធម៌ ២ ប្រការ ធម៌ ២ ប្រការដូច្នោះ តើធម៌ ២ ប្រការនេះ ដូចម្តេចហ្ន៎ ។

ពេលនោះ ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្ត សមថៈ និង វិបស្សនា ហៅថា ធម៌ ២ ប្រការ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

យថា ទ្វយេសុ ធម្មេសុ ចារគ្គ ហោតិ ព្រាហ្មណោ
អថស្ស សព្វេ សំយោគា អត្ថំ គច្ឆន្តិ ជានតោ ។

កាលណា ព្រាហ្មណ៍អ្នកដល់ត្រើយ ក្នុងធម៌ ២ ប្រការ គឺ សមថធម៌ និងវិបស្សនាធម៌ ក្នុងកាលនោះ កិលេសជាគ្រឿងប្រកបសត្វទុកទាំងអស់ របស់ព្រាហ្មណ៍អ្នកដឹងនោះ រមែងដល់នូវការតាំងនៅមិនបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យថា** ជាដើម សេចក្តីថា ក្នុងកាលណា ព្រះខីណាស្រពនោះ ជាអ្នកដល់នូវត្រើយក្នុងធម៌ គឺសមថៈ និងវិបស្សនា

ដែលតាំងនៅដោយចំណែក ២ ដោយអំណាចនៃការដល់នូវត្រើយ គឺអកិញ្ចាជាដើម ក្នុងកាលនោះ កិលេសជាគ្រឿងប្រកបទាំងឡាយ មានកិលេសទាំងពួងជាគ្រឿងប្រកប គឺកាមជាដើម ដែលអាចប្រកបក្នុងវដ្តៈរបស់ព្រះខីណាស្រពនោះ ជាអ្នកដឹងយ៉ាងនេះ រមែងដល់នូវការតាំងនៅមិនបាន គឺកាលអស់ទៅ ។ ក្នុងកាលចប់ទេសនា ភិក្ខុទាំងឡាយនោះ តាំងនៅក្នុងអរហត្តហើយ ដូច្នេះឯង ។

រឿង ភិក្ខុច្រើនរូប ចប់

រឿង មារ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមារ ត្រាស់ព្រះធម្មទេសនានេះថា **យស្ស ចារំ អចារំ វា** *ជាដើម ។*

បានឮថា ថ្ងៃមួយ មារនោះកាឡាខ្លួនជាបុរសម្នាក់ ចូលទៅគាល់ព្រះសាស្តា ហើយទូលសួរថា បពិត្រព្រះអង្គ ទីដែលទ្រង់ត្រាស់ថា ត្រើយៗ អ្វីហ្ន៎ ឈ្មោះថា ត្រើយនោះ ព្រះសាស្តាទ្រង់ជ្រាបថា នេះជាមារ ទើបត្រាស់ថា ម្នាលមារមានចិត្តបាប ប្រយោជន៍អ្វីរបស់អ្នកដោយត្រើយ ត្រើយនោះ បុគ្គលទាំងឡាយ ដែលមានរាគៈទៅច្រាសហើយគប្បីដល់ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

យស្ស ចារំ អចារំ វា ចារាចារំ ឧ វិជ្ជតិ
វីតទ្ទរំ វិសញ្ញុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

ត្រើយក្តី មិនមែនត្រើយក្តី ត្រើយ និងទីមិនមែនត្រើយក្តី មិនមានដល់បុគ្គលណា (សេចក្តីប្រកាន់អាយតន: មិនមានដល់បុគ្គលណា) តថាគតហៅបុគ្គលនោះ ដែលជាអ្នកមានសេចក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកប្រាសចាកកិលេស ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

អាយតន:ដែលប្រព្រឹត្តទៅក្នុងខាងក្នុង ៦ ឈ្មោះថា **ចារំ** *ក្នុងព្រះគាថានោះ ។ អាយតន:ដែលមានខាងក្រៅ ៦ ឈ្មោះថា* **អចារំ ។** *អាយតន:ទាំងពីរនោះ ឈ្មោះថា* **ចារាចារំ ។**

បទថា **ឧ វិជ្ជតិ** *សេចក្តីថា ត្រើយ និងមិនមែនត្រើយទាំងអស់នោះ មិនមានដល់បុគ្គលណា ព្រោះការមិនមានការប្រកាន់ថា អញ ឬរបស់អញ តថាគតហៅបុគ្គលនោះ ដែលឈ្មោះថា មានសេចក្តីក្រវល់ក្រវាយទៅប្រាសហើយ ព្រោះដែលទៅប្រាសនៃសេចក្តីក្រវល់ក្រវាយ គឺកិលេសទាំងឡាយ បុគ្គលប្រាសចាកកិលេសទាំងពួងបានហើយ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងមារ ចប់

រឿង ព្រាហ្មណ៍ម្នាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ឈាយឺ** ជាដើម ។

បានឮថា ព្រាហ្មណ៍នោះគិតថា ព្រះសាស្តាហៅសាវ័ករបស់ព្រះអង្គថា ព្រាហ្មណ៍ ចំណែកអញក៏ជាព្រាហ្មណ៍ដោយជាតិ និងគោត្រ ការដែលព្រះអង្គ ត្រាស់ហៅអញយ៉ាងនោះដែរក៏គួរ គាត់ចូលទៅគាល់ព្រះសាស្តា ទូលសួរ សេចក្តីនោះហើយ ។

ព្រះសាស្តាត្រាស់ថា តថាគតមិនបានហៅបុគ្គលថាព្រាហ្មណ៍ដោយហេតុ ត្រឹមតែជាតិ និងគោត្រ តែតថាគតហៅបុគ្គលដែលសម្រេចប្រយោជន៍ដ៏ឧត្តម នោះប៉ុណ្ណោះ ថាជាព្រាហ្មណ៍ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ឈាយឺ វិរជមាសីនំ កតកិច្ចំ អនាសវំ
ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគតហៅបុគ្គលអ្នកចម្រើនឈាន មានធូលី គឺកាមអស់ហើយ អ្នកអង្គុយនៅឯកឯង អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈ ដល់នូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ដោយលំដាប់ហើយនោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឈាយឺ** ជាដើម សេចក្តីថា តថាគតហៅបុគ្គលដែលសម្ងីងដោយឈាន ២ យ៉ាង ដែលប្រាសចាកធូលី ដោយធូលី

គឺកាម នៅតែឯកឯងក្នុងព្រៃ ឈ្មោះថា ជាអ្នកមានកិច្ចដែលធ្វើហើយ ព្រោះកិច្ច ១៦ ដែលខ្លួនធ្វើដោយមគ្គ ៤ ហើយ ឈ្មោះថា ជាអ្នកមិនមានអាសវៈ ព្រោះមិនមានអាសវៈទាំងឡាយ សម្រេចប្រយោជន៍ដ៏ខត្តម គឺអរហត្តហើយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាបានជាប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿងព្រាហ្មណ៍ម្នាក់ ចប់

រឿង ព្រះអានន្ទត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងប្រាសាទរបស់ខបាសិកាឈ្មោះមិគារមាតា ទ្រង់ប្រារព្ធព្រះអានន្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ធិរា តបតិ អាធិច្ចោ** ជាដើម ។

បានឣថា ក្នុងថ្ងៃមហាបវារណា ព្រះបាទបសេនទិកោសល ទ្រង់ប្រដាប់គ្រឿងរាជឥស្សរិយាភរណៈសព្វគ្រប់ ទ្រង់កាន់យកវត្ថុទាំងឡាយ មានគ្រឿងក្រអូបជាដើម បានយាងទៅកាន់វិហារហើយ ។

ខណៈនោះ ព្រះកាឡុទាយិត្ថេរអង្គុយចូលឈានខាងចុងបរិស័ទ ។ ពាក្យថា កាឡុទាយិត្ថេរនោះ ជាឈ្មោះរបស់លោកនោះឯង ។ សរីរៈរបស់លោក

មានពណ៌ដូចនិល ។ ក្នុងខណៈនោះ ព្រះចន្ទកំពុងរះ ព្រះអាទិត្យកំពុងអស្តង្គត ។ ព្រះអានន្ទគ្រោះសម្លឹងមើលរស្មីរបស់ព្រះអាទិត្យ ដែលកំពុងអស្តង្គត និងរបស់ព្រះចន្ទដែលកំពុងរះ ហើយសម្លឹងមើលព្រះសរីរកាសរបស់ព្រះរាជា សរីរកាសរបស់ព្រះថេរៈ និងព្រះសរីរកាសរបស់ព្រះតថាគត ។ ក្នុងជនទាំងនោះ ព្រះសាស្តារមែងរុងរឿងកន្ទងរស្មីទាំងពួង ។ ព្រះថេរៈថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា បពិត្រព្រះអង្គ ក្នុងថ្ងៃនេះ កាលខ្ញុំព្រះអង្គសម្លឹងមើលរស្មីទាំងនេះ រស្មីរបស់ព្រះអង្គប៉ុណ្ណោះ ខ្ញុំព្រះអង្គគាប់ចិត្ត ព្រោះថា សរីរៈរបស់ព្រះអង្គរមែងរុងរឿងកន្ទងរស្មីទាំងពួង ។

គ្រានោះ ព្រះសាស្តាត្រាស់ថា អានន្ទ ធម្មតាព្រះអាទិត្យ រមែងរុងរឿងក្នុងពេលថ្ងៃ ព្រះចន្ទ រមែងរុងរឿងក្នុងពេលយប់ ព្រះរាជា រមែងរុងរឿងក្នុងកាលប្រជាប់ហើយប៉ុណ្ណោះ ព្រះខីណាស្រពលះការច្រឡូកច្រឡំដោយពួកគណៈហើយ រមែងរុងរឿងខាងក្នុងសមាបត្តិប៉ុណ្ណោះ ចំណែកព្រះពុទ្ធ រមែងរុងរឿងដោយតេជៈ ៥ យ៉ាង ទាំងពេលយប់ ទាំងពេលថ្ងៃ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា
សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ
អថ សព្ពមហោរត្តឺ ពុទ្ធោ តបតិ តេជសា ។

ព្រះអាទិត្យរុងរឿងក្នុងពេលថ្ងៃ ព្រះចន្ទរុងរឿងក្នុងពេលយប់ ក្សត្រទ្រង់ប្រជាប់ពេញយសហើយ រមែងរុងរឿង សមណ-

ព្រាហ្មណ៍អ្នកមានឈានរមែងរុងរឿង ឯព្រះសម្ពុទ្ធរមែងរុងរឿងដោយតេជៈរហូត ថ្ងៃនិងយប់ទាំងអស់ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ទិវា តបតិ** *សេចក្តីថា ព្រះអាទិត្យរមែងរុងរឿងតែក្នុងពេលថ្ងៃ សូម្បីតែផ្លូវដែលព្រះអាទិត្យនោះទៅក្នុងពេលយប់ក៏មិនភ្លឺរកជ ។*

បទថា **ចន្ទិមា** *សេចក្តីថា សូម្បីព្រះចន្ទដែលផុតហើយចាកពពកជាដើមក៏រុងរឿងចំពោះក្នុងពេលយប់ មិនមែនរុងរឿងក្នុងពេលថ្ងៃឡើយ ។*

បទថា **សន្នទ្ធោ** *សេចក្តីថា ព្រះរាជាទ្រទ្រង់ប្រដាប់ដោយគ្រឿងអាភរណៈទាំងពួងដ៏វិចិត្រ ដោយមាស និងកែវមណី មានសេនាប្រកបដោយអង្គ ៤ ចោមរោមហើយប៉ុណ្ណោះរមែងរុងរឿង ព្រះរាជាប្រថាប់នៅដោយភេទដែលបុគ្គលមិនដឹង គឺបន្ទំខ្លួន មិនរុងរឿងឡើយ ។*

បទថា **ឈាយី** *សេចក្តីថា ចំណែកព្រះខីណាស្រព គេចចេញអំពីពួកហើយ សម្ងំគ្រាច់ទៅ ឈ្មោះថា រមែងរុងរឿង ។*

បទថា **តេជសា** *សេចក្តីថា ចំណែកព្រះសម្មាសម្ពុទ្ធ ទ្រង់គ្របសង្កត់តេជៈនៃការទ្រុស្តសីល ដោយតេជៈ គឺសីល តេជៈនៃគុណាថោកថយ ដោយតេជៈ គឺគុណ តេជៈនៃបញ្ញាថោកថយ ដោយតេជៈ គឺបញ្ញា តេជៈនៃវត្ថុដែលមិនមែនជាបុណ្យ ដោយតេជៈ គឺបុណ្យ តេជៈនៃអធម៌ ដោយតេជៈ គឺធម៌ រមែងរុងរឿងដោយតេជៈ ៥ យ៉ាងនេះអស់កាលជានិច្ចនោះឯង ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះអានន្ទត្ថេរ ចប់

រឿង បព្វជិតមួយរូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបព្វជិតមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **ពាហិតចាចោ** *ជាដើម ។*

បានឮថា ព្រាហ្មណ៍ម្នាក់បួសហើយដោយការបួសក្នុងលទ្ធិខាងក្រៅ គិតថា ព្រះសមណគោតមហៅសាវ័ករបស់ព្រះអង្គថា បព្វជិត ចំណែកអ្នកក៏ជាបព្វជិត កាលដែលព្រះអង្គហៅអញយ៉ាងនោះដែរក៏គួរ ហើយចូលទៅគាល់ព្រះសាស្តា ទូលសួរសេចក្តីនោះ ។

ព្រះសាស្តាត្រាស់ថា តថាគតមិនមែនហៅថាបព្វជិតដោយហេតុត្រឹមតែប៉ុណ្ណេះទេ្បីយ ចំណែកបុគ្គលឈ្មោះថាជាបព្វជិត ព្រោះភាពដែលមន្ទិល គឺកិលេសទាំងឡាយដែលខ្លួនរៀបបានជាសមុច្ឆេទ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ពាហិតចាចោ ហិ ព្រាហ្មណោ សមចរិយា សមណោតិ វុច្ចតិ
បព្ភាជយមត្តនោ មលំ តស្មា បព្ភជិតោតិ វុច្ចតិ ។

អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះថា ព្រាហ្មណ៍ អ្នកដែលតថាគតហៅថា សមណៈ ព្រោះការប្រព្រឹត្តរម្ងាប់ អ្នកដែលបណ្តេញមន្ទិលនៃខ្លួន ហេតុនោះ ទើបតថាគតហៅថា បព្វជិត ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សមចរិយា** គឺព្រោះការប្រព្រឹត្តរម្ងាប់នូវអកុសលធម៌ទាំងពួង ។

បទថា **តស្មា** សេចក្តីថា បុគ្គលដែលព្រះសាស្តាត្រាស់ហៅថាព្រាហ្មណ៍ ព្រោះភាពជាអ្នកមានបាបបន្សាត់ហើយ ។ បុគ្គលដែលព្រះសាស្តាត្រាស់ហៅថា សមណៈ ព្រោះការប្រព្រឹត្តស្ងប់នូវអកុសលធម៌ទាំងឡាយ ហេតុនោះ បុគ្គលណាប្រព្រឹត្តបណ្តេញ គឺកម្ចាត់មន្ទិល មានរាគៈជាដើមរបស់ខ្លួន បុគ្គលនោះ ព្រះសាស្តាត្រាស់ហៅថា បព្វជិត ព្រោះការបណ្តេញនោះ ។

ក្នុងកាលចប់ទេសនា បព្វជិតនោះ តាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿងបព្វជិតមួយរូប ចប់

រឿង ព្រះសារីបុត្តត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ន ព្រាហ្មណាសฺ** ជាដើម ។

បានឮថា មនុស្សជាច្រើនក្នុងទីមួយកន្លែង ពោលគុណកថារបស់ព្រះថេរៈថា គួរសរសើរ លោកម្ចាស់របស់ពួកយើង ប្រកបដោយកម្លាំង គឺខន្តី កាលជនដទៃជេរក្តី ប្រហារក្តី សូម្បីត្រឹមតែការក្រោធ មិនមាន កាលនោះ ព្រាហ្មណ៍មិច្ឆាទិដ្ឋិម្នាក់សួរថា អ្នកណាមិនក្រោធ ពួកមនុស្សពោលថា ព្រះថេរៈរបស់ពួកខ្ញុំ ព្រាហ្មណ៍ពោលថា បុគ្គលធ្វើឲ្យលោកក្រោធមិនមានទេដឹង ពួកមនុស្សពោលថា នែព្រាហ្មណ៍ សេចក្តីនោះមិនមែនយ៉ាងនោះទេ្បីយ ព្រាហ្មណ៍ពោលថា បើដូច្នោះ ខ្ញុំនឹងធ្វើឲ្យលោកក្រោធ ពួកមនុស្សពោលថា បើអាចសោត ក៏ចូរធ្វើឲ្យលោកក្រោធចុះ ។

ព្រាហ្មណ៍នោះគិតថា ណ្ហើយចុះ អញនឹងដឹងកិច្ចដែលគួរធ្វើ ដូច្នេះហើយ ឃើញព្រះថេរៈចូលទៅដើម្បីភិក្ខា ទើបធ្វើដើរទៅអំពីខាងក្រោយ ឲ្យនូវការប្រហារដោយបាតដៃយ៉ាងខ្លាំងត្រង់កណ្តាលខ្នង ។

ព្រះថេរៈមិនបានគិតដល់ថា នេះជាអ្វីហ្ន៎ និមន្តទៅហើយ ។ ការក្តៅក្រហាយកើតឡើងពេញសរីរៈរបស់ព្រាហ្មណ៍ គាត់សង្វេគថា ឱ លោកម្ចាស់សម្បូរដោយគុណ ដូច្នេះហើយ ក្រាបចុះទៀបបាតជើងរបស់ព្រះថេរៈពោលថា សូមលោកម្ចាស់អត់ទោសដល់ខ្ញុំចុះ កាលព្រះថេរៈពោលថា តើមានរឿងអ្វី ទើបប្រាប់ថា ខ្ញុំប្រហារលោកម្ចាស់ដើម្បីល្បងមើល ព្រះថេរៈពោលថា

ណ្ហើយចុះ អាត្មាអត់ទោសឲ្យ ទើបព្រាហ្មណ៍ពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់អត់ទោសឲ្យខ្ញុំសោត សូមគង់ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំចុះ ដូច្នេះហើយ បានទទួលបាត្ររបស់ព្រះថេរៈ ចំណែកព្រះថេរៈឲ្យបាត្រហើយ ។ ព្រាហ្មណ៍នាំព្រះថេរៈទៅកាន់ផ្ទះអង្គាសហើយ ។

ពួកមនុស្សក្រោធហើយក៏គិតថា លោកម្ចាស់របស់ពួកយើងមិនមានទោស ត្រូវព្រាហ្មណ៍នេះប្រហារហើយ ការផុតចាកជំបងមិនមានដល់ព្រាហ្មណ៍នោះ ពួកយើងនឹងសម្លាប់វាចោលក្នុងទីនោះឯង ដូច្នេះហើយ មានជុំដី និងជំបងជាដើមក្នុងដៃ បានឈរជួបជុំគ្នាត្រង់ទ្វារផ្ទះរបស់ព្រាហ្មណ៍ ។

ព្រះថេរៈក្រោកឡើង បានឲ្យបាត្រក្នុងដៃរបស់ព្រាហ្មណ៍ ពួកមនុស្សបានឃើញព្រាហ្មណ៍នោះដើរទៅជាមួយព្រះថេរៈ ទើបពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលបាត្ររបស់លោកម្ចាស់ ហើយឲ្យព្រាហ្មណ៍ត្រឡប់ចុះ ព្រះថេរៈពោលថា នេះមានរឿងអ្វី ពួកមនុស្សពោលថា ព្រាហ្មណ៍ប្រហារលោកម្ចាស់ ពួកខ្ញុំនឹងដឹងកិច្ចដែលគួរធ្វើដល់គេ ព្រះថេរៈសួរថា ពួកអ្នកត្រូវព្រាហ្មណ៍នេះប្រហារ ឬអាត្មាត្រូវព្រាហ្មណ៍ប្រហារ ពួកមនុស្សពោលថា លោកម្ចាស់ត្រូវព្រាហ្មណ៍ប្រហារ ព្រះថេរៈពោលថា ព្រាហ្មណ៍នោះប្រហារអាត្មាហើយ បានសូមទោសហើយ ចូរពួកអ្នកត្រឡប់ចុះ បញ្ជូនពួកមនុស្សទៅហើយ ឲ្យព្រាហ្មណ៍ត្រឡប់ ហើយនិមន្តទៅកាន់វិហារនោះឯង ។

ភិក្ខុទាំងឡាយលើកទោសថា ហេតុអ្វី ព្រះសារីបុត្តត្ថេរត្រូវព្រាហ្មណ៍ប្រហារ នៅតែអង្គុយទទួលភិក្ខាក្នុងផ្ទះរបស់ព្រាហ្មណ៍នោះ និមន្តមកហើយ

ចាប់តាំងពីកាលដែលព្រះថេរៈ ត្រូវព្រាហ្មណ៍នោះប្រហារហើយ តទៅនេះ ព្រាហ្មណ៍នោះលែងខ្វាសចំពោះបុគ្គលណាម្នាក់ នឹងដើរវាយកិក្ខុទាំងឡាយ ដ៏សេស ។

ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយពាក្យដូចម្តេចហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយពាក្យឈ្មោះនេះ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ឈ្មោះថាប្រហារព្រាហ្មណ៍ មិនមាន តែព្រាហ្មណ៍ដែលជាសមណៈទោះជាត្រូវព្រាហ្មណ៍ជាគ្រហស្ថប្រហារ ឈ្មោះថា សេចក្តីក្រោធនោះ រមែងដល់នូវការដកខ្លីងបានដោយអនាគាមិមគ្គ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ បានភាសិតព្រះគាថាទាំងនេះថា

ន ព្រាហ្មណស្ស បហរេយ្យ ន ស្ស មុញ្ចេថ ព្រាហ្មណោ
ធិ ព្រាហ្មណស្ស ហន្តារំ តតោ ធិ យស្ស មុញ្ចតិ ។
ន ព្រាហ្មណស្សេតទកិញ្ចិ សេយ្យោ យទា និសេធោ មនសោ បិយេហិ
យតោ យតោ ហឹសមនោ និវត្តតិ តតោ តតោ សម្មតិមេវ ទុក្ខំ ។

ព្រាហ្មណ៍មិនគប្បីប្រហារព្រាហ្មណ៍ទេ (ចំណែក) ព្រាហ្មណ៍ (ដែលត្រូវគេប្រហារហើយ) មិនគប្បីចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍ដែលប្រហារព្រាហ្មណ៍ ព្រាហ្មណ៍ណាចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍នោះ ក្រៃលែងជាងនោះទៅទៀត ។ ការហាមឃាត់ចិត្តចាកអារម្មណ៍ ជាទីស្រឡាញ់របស់

ព្រាហ្មណ៍នោះ មិនមែនប្រសើរបន្តិចបន្តួចទេ ចិត្តដែលគិតបៀតបៀនគេ ងាកចេញចាកវត្ថុណាៗ សេចក្តីទុក្ខព្រោះវត្ថុនោះៗ ក៏រម្ងាប់ទៅបាន ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បមារេយ្យ** *សេចក្តីថា ព្រាហ្មណ៍ជាព្រះខីណាស្រពជឹងថា អាត្មាអញជាព្រះខីណាស្រព មិនគួរប្រហារដល់ព្រាហ្មណ៍ដែលជាព្រះខីណាស្រព ឬព្រាហ្មណ៍ដទៃ ។*

ពីរបទថា **ឆាស្ស មុញ្ចេ** *សេចក្តីថា ព្រាហ្មណ៍ខីណាស្រពនោះ ត្រូវគេប្រហារហើយ មិនគួរចងពៀរដល់បុគ្គលប្រហារ ហើយឈរនៅ គឺមិនគួរធ្វើសេចក្តីក្រោធក្នុងព្រាហ្មណ៍នោះ ។*

បទថា **ឯ ព្រាហ្មណាស្ស** *សេចក្តីថា តថាគតរមែងតិះដៀលព្រាហ្មណ៍ដែលប្រហារព្រាហ្មណ៍ជាខីណាស្រព ។*

បទថា **តតោ ឯ** *សេចក្តីថា បុគ្គលណាប្រហារតបនូវបុគ្គលដែលប្រហារ ឈ្មោះថា ចងពៀរក្នុងខាងលើរបស់បុគ្គលនោះ តថាគតតិះដៀលអ្នកចងពៀរនោះ ក្រៃលែងជាងអ្នកប្រហារនោះទៅទៀត ។*

ពីរបទថា **ឯតទកិញ្ចិ សេយ្យោ** *សេចក្តីថា ការមិនជេរតបនូវបុគ្គលដែលជេរ ឬការមិនប្រហារតបនូវបុគ្គលដែលប្រហារ របស់ព្រះខីណាស្រពណា ការមិនជេរតប ឬការមិនប្រហារតបនោះ រមែងជាការប្រសើរ មិនមែនតិច គឺមិនជាការប្រសើរមានប្រមាណតិច ដល់ព្រាហ្មណ៍ដែលជាខីណាស្រពនោះ ដែលពិត ជាការប្រសើរដែលមានប្រមាណក្រៃលែងនោះឯង ។*

បាទព្រះគាថាថា **យឆានិសេធោ មនសោ បិយេហិ** *សេចក្តីថា ការកើតឡើងនៃសេចក្តីក្រោធ ឈ្មោះថា អារម្មណ៍ជាទីស្រឡាញ់នៃចិត្ត របស់បុគ្គលដែលច្រើនដោយសេចក្តីក្រោធ បុគ្គលអ្នកក្រោធនោះ ទោះខុសក្នុងមាតាបិតាក្តី ក្នុងព្រះពុទ្ធជាដើមក្តី ក៏ព្រោះអារម្មណ៍ជាទីស្រឡាញ់ទាំងនោះ ហេតុនោះ ការសង្កត់សង្កិនចិត្តចាកអារម្មណ៍ ដែលជាទីស្រឡាញ់ទាំងនោះ គឺការសង្កត់សង្កិនចិត្តដែលកើតឡើងដោយអំណាចសេចក្តីក្រោធ របស់បុគ្គលដែលច្រើនដោយសេចក្តីក្រោធនោះ ការសង្កត់សង្កិននោះ រមែងជាការប្រសើរមិនមែនតិច ។*

ចិត្តដែលសម្បយុត្តដោយសេចក្តីក្រោធ ឈ្មោះថា **ហីនមនោ** *ចិត្តដែលសម្បយុត្តដោយសេចក្តីក្រោធរបស់បុគ្គលនោះ កាលដល់នូវការដកឡើងដោយអនាគាមិមគ្គ ឈ្មោះថា រមែងត្រឡប់បានចាកវត្ថុឯណានីមួយ ។*

ពីរបទថា **តតោ តតោ** *សេចក្តីថា វដ្តទុក្ខទាំងអស់ រមែងត្រឡប់បានព្រោះវត្ថុនោះៗ ឯង ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងព្រះសារីបុត្តស្ថេរ ចប់

រឿង ព្រះនាងមហាបជាបតិគោតមី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងមហា-បជាបតិគោតមី ត្រាស់ព្រះធម្មទេសនានេះថា **យស្ស កាយេន** ជាដើម ។

សេចក្តីពិស្តារថា ព្រះនាងមហាបជាបតិគោតមី មួយអន្លើដោយបរិវារ ទទួលគុរុធម៌ ៨ ប្រការដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តិហើយ ក្នុងកាលដែលរឿងមិនទាន់កើតឡើង ដូចបុរសអ្នកមានជាតិ ច្រើនដោយការប្រជាប់ ទទួលកម្រងផ្កាក្រអូបដោយសិរសា គឺត្បូង បានឧបសម្បទាហើយ ឧបជ្ឈាយ៍ ឬអាចារ្យដទៃរបស់ព្រះនាងមិនមាន ភិក្ខុទាំងឡាយ ប្រារព្ធព្រះថេរីដែលមាន ឧបសម្បទា ដែលបានហើយយ៉ាងនោះ សម័យដទៃក្រោយមក ក៏សន្មូនាគ្នា ថា អាចារ្យ និងឧបជ្ឈាយ៍របស់ព្រះនាងមហាបជាបតិគោតមីមិនប្រាកដ ព្រះ នាងកាន់យកសំពត់កាសាវៈទាំងឡាយ ដោយដៃរបស់ខ្លួនឯង ។

កាលពោលយ៉ាងនោះហើយ ភិក្ខុនីទាំងឡាយប្រព្រឹត្តរង្កៀស រមែងមិន ធ្វើឧបោសថ មិនធ្វើបវារណារួមជាមួយព្រះនាងឡើយ ភិក្ខុនីទាំងឡាយនោះ ទៅក្រាបទូលសេចក្តីនោះដល់ព្រះតថាគតហើយ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុនីទាំងនោះហើយ ទើបត្រាស់ថា គុរុធម៌ ៨ ប្រការ តថាគតឲ្យហើយដល់ព្រះនាងបជាបតិគោតមី តថាគតនេះ ឯងជាអាចារ្យ ជាឧបជ្ឈាយ៍របស់ព្រះនាង ឈ្មោះថា សេចក្តីរង្កៀសក្នុងព្រះ ខីណាស្រពទាំងឡាយ ជាអ្នកវៀរហើយចាកទុច្ចរិតទាំងឡាយ មានកាយទុច្ចរិត ជាដើមដែលអ្នកទាំងឡាយមិនគួរធ្វើ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌

ទើបត្រាស់ព្រះគាថានេះថា

យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កតំ
សំវុតំ តីហិ ឋានេហិ តមហំ ព្រូមិ ព្រាហ្មណំ ។

អំពើអាក្រក់ដោយទ្វារកាយ ទ្វារវាចា ទ្វារចិត្តរបស់បុគ្គលណាមិនមានទេ តថាគតហៅបុគ្គលដែលបានសង្រួមដោយឋានៈទាំង ៣ នោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

កម្មមានទោស គឺមានទោសជាផល ដែលញុំាងសត្វឲ្យប្រព្រឹត្តទៅក្នុងអបាយ ឈ្មោះថា **ទុក្កតំ** *ក្នុងព្រះគាថានោះ ។*

ពីរបទថា **តីហិ ឋានេហិ** *សេចក្តីថា តថាគតហៅបុគ្គលដែលមានទ្វារបិទហើយ ដើម្បីហាមការចូលទៅនៃទុច្ចរិតជាដើម ដោយហេតុ ៣ មានកាយជាដើមទាំងនោះ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះនាងមហាបជាបតិគោតមី ចប់

រឿង ព្រះសារីបុត្តត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យម្ហា ធម្មំ វិជានេយ្យ** ជាដើម ។

បានឮថា ព្រះសារីបុត្តនោះ ចាប់តាំងពីកាលដែលលោកស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះអស្សជិត្ថេរ ហើយសម្រេចសោតាបត្តិផល បានឮថា ព្រះថេរៈនៅក្នុងទិសណា ផ្គងអញ្ជលីទៅក្នុងទិសនោះ សិងបែរក្បាលទៅកាន់ទិសនោះឯង ។

ភិក្ខុទាំងឡាយពោលថា ព្រះសារីបុត្តជាមិច្ឆាទិដ្ឋិ សូម្បីថ្ងៃនេះក៏នៅតែសិងនមស្ការទិសទាំងឡាយ ដូច្នេះហើយ ក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ។

ព្រះសាស្តាត្រាស់ឲ្យហៅព្រះថេរៈមកហើយ ត្រាស់សួរថា ម្នាលសារីបុត្ត បានឮថា អ្នកដេកនមស្ការទិសទាំងឡាយពិតឬ កាលព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់ប៉ុណ្ណោះរមែងជ្រាបការគោរពទិស ឬមិនគោរពទិសទាំង-ឡាយរបស់ខ្ញុំព្រះអង្គ ដូច្នេះហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តមិនមែនគោរពទិសទាំងឡាយ តែព្រោះសារីបុត្តបានស្តាប់ធម៌អំពីសម្នាក់របស់អស្សជិ ហើយសម្រេចសោតាបត្តិផល ទើបដេកគោរពអាចារ្យរបស់ខ្លួន ព្រោះថា ភិក្ខុអាស្រ័យអាចារ្យណាត្រាស់ដឹងធម៌ ភិក្ខុនោះ គប្បីនមស្ការអាចារ្យនោះដោយគោរព ដូចព្រាហ្មណ៍នមស្ការភ្លើងដូច្នោះ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យម្ហា ធម្មំ វិជានេយ្យ សម្មាសម្ពុទ្ធទេសិតំ
សក្កច្ចំ តំ នមស្សេយ្យ អគ្គិហុត្តំវ ព្រាហ្មណោ ។

បុគ្គលចេះធម៌អាថ៌ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងហើយ អំពីសម្នាក់គ្រូណា គប្បីនមស្ការគ្រូនោះ ដោយគោរព ដូចព្រាហ្មណ៍ដែលគោរពការបូជាភ្លើងដូច្នោះដែរ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អគ្គិហុត្តំវ** *សេចក្តីថា បុគ្គលគប្បីដឹងច្បាស់នូវធម៌ដែលតថាគតប្រកាសហើយអំពីអាចារ្យណា គប្បីនមស្ការអាចារ្យនោះ ដោយគោរព ដូចព្រាហ្មណ៍នមស្ការការបូជាភ្លើងដោយគោរព ដោយការបម្រើដោយល្អ និងដោយកិច្ចទាំងឡាយ មានអញ្ជលីកម្មជាដើម ដូច្នោះ ។*

ក្នុងកាលចប់ទេសនា មហាជនបាននូវសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងព្រះសារីបុត្តត្ថេរ ចប់

រឿង ជដិលព្រាហ្មណ៍

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធជដិលព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ន ជដាហិ** ជាដើម ។

បានឮថា ជដិលព្រាហ្មណ៍នោះគិតថា អញកើតល្អហើយទាំងខាងមាតា ទាំងខាងបិតា ក្នុងត្រកូលព្រាហ្មណ៍ បើព្រះសមណគោតមហៅសាវ័កទាំង-ទ្បាយរបស់ព្រះអង្គថា ព្រាហ្មណ៍ ការដែលទ្រង់ត្រាស់ហៅអញយ៉ាងនោះដែរ ក៏គួរ ដូច្នេះហើយ ទើបទៅកាន់សម្នាក់ព្រះសាស្តា ទូលសួរសេចក្តីនោះ ។

គ្រានោះ ព្រះសាស្តាត្រាស់ទីឆ្ងព្រាហ្មណ៍នោះថា ម្នាលព្រាហ្មណ៍ តថាគតមិនហៅថា ព្រាហ្មណ៍ ព្រោះហេតុត្រឹមតែផ្ងសក់ មិនហៅដោយហេតុត្រឹមតែជាតិ និងគោត្រ តែតថាគតហៅបុគ្គលដែលមានសច្ចៈ ចាក់ធ្លុះហើយ ប៉ុណ្ណោះ ថាជាព្រាហ្មណ៍ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ន ជដាហិ ន គោតេហិ ន ជច្ចា ហោតិ ព្រាហ្មណោ
យម្ហិ សច្ចញ្ច ធម្មោ ច សោ សុចី សោ ច ព្រាហ្មណោ ។

បុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ ព្រោះផ្ងសក់ ក៏មិនមែន ព្រោះគោត្រ ក៏មិនមែន ព្រោះជាតិ ក៏មិនមែន សច្ចៈផង ធម៌ផង មានក្នុងបុគ្គលណា បុគ្គលនោះ ឈ្មោះថា អ្នកស្អាតផង បុគ្គលនោះ ឈ្មោះថា ព្រាហ្មណ៍ផង ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សច្ចំ** ជាដើម សេចក្តីថា សច្ចញ្ញាណដែល

ចាក់ផ្ទុះនូវសច្ចៈ ៤ យ៉ាងដោយអាការ ១៦ ហើយតាំងនៅ និងលោកុត្តរធម៌ ៩ មានក្នុងបុគ្គលណា បុគ្គលនោះ ជាអ្នកស្អាត និងជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ៨ដងព្រាហ្មណ៍ ចប់

រឿង កុហកព្រាហ្មណ៍

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងកូដាគារសាលា ទ្រង់ប្រារព្ធកុហកព្រាហ្មណ៍ ដែលមានវត្តដូចប្រពៃវម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **កិន្តេ** *ជាដើម ។*

បានឮថា ព្រាហ្មណ៍នោះឡើងដើមថ្ងាន់មួយដើម ជិតទ្វារនគរវេសាលី យកជើងទាំងពីរពាក់លើមែកឈើ សំយុងក្បាលចុះក្រោមពោលថា ចូរអ្នកទាំងឡាយឲ្យគោក្រហមមួយរយដល់យើង ចូរឲ្យកហាបណៈទាំងឡាយដល់យើង ចូរឲ្យទាសីដល់យើង បើអ្នកទាំងឡាយមិនឲ្យទេ យើងនឹងទម្លាក់ខ្លួនពីលើដើមថ្ងាន់នេះឲ្យស្លាប់ នឹងធ្វើព្រះនគរមិនឲ្យជាព្រះនគរ ។ ក្នុងកាលព្រះដ៏មានព្រះភាគយាងចូលទៅកាន់ព្រះនគរ ដែលមានពួកភិក្ខុចោមរោមហើយ ភិក្ខុទាំងឡាយឃើញព្រាហ្មណ៍នោះហើយ ក្នុងកាលដែលទ្រង់ចេញទៅ ក៏បានឃើញព្រាហ្មណ៍នោះ សំយុងក្បាលយ៉ាងនោះដូចគ្នា ចំណែកអ្នកនគរ

ត្រៃរិះថា ព្រាហ្មណ៍នេះ សំយុងយ៉ាងនេះតាំងអំពីព្រឹកគប្បីធ្លាក់ស្លាប់ ធ្វើនគរមិនឲ្យជានគរ ខ្លាចការលិចចុះនៃព្រះនគរ ទើបព្រមទទួលថា ពួកយើងនឹងឲ្យគ្រប់យ៉ាងតាមដែលព្រាហ្មណ៍សូម ហើយបានឲ្យព្រាហ្មណ៍បានចុះ ទទួលយកវបស់ទាំងពួងទៅ ។

ភិក្ខុទាំងឡាយ ឃើញព្រាហ្មណ៍ត្រាច់ទៅដូចមេគោក្បែរឧបចារៈនៃវិហារចាំបាន ក៏សួរថា នែព្រាហ្មណ៍ លោកបានទ្រព្យតាមប្រាថ្នាហើយឬ ព្រាហ្មណ៍ប្រាប់ថា ខ្ញុំបានហើយ ទើបក្រាបទូលរឿងនោះដល់ព្រះតថាគតខាងក្នុងវិហារ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍នោះជាចោរ ចោកបញ្ឆោតក្នុងកាលនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏ជាចោរចោកបញ្ឆោតហើយដូចគ្នា ឥឡូវនេះ ព្រាហ្មណ៍នោះចោកបានតែជនពាល តែក្នុងកាលមុនមិនអាចចោកបញ្ឆោតបណ្ឌិតបានឡើយ ដូច្នេះហើយ កាលភិក្ខុទាំងនោះទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល តាបសចោកបញ្ឆោតមួយរូប អាស្រ័យកាសិកគ្រាមមួយសម្រេចការនៅ ។ ត្រកូលមួយទំនុកបម្រុងតាបសនោះ គឺប្រគេនចំណែកមួយដល់តាបស អំពីរបស់គួរទំពា និងគួរបរិភោគដែលកើតឡើងហើយក្នុងពេលថ្ងៃ ដូចឲ្យដល់បុត្រវបស់ខ្លួន ទុកចំណែកដែលកើតក្នុងពេលល្ងាចប្រគេនក្នុងថ្ងៃទីពីរ ។

ថ្ងៃមួយ ត្រកូលនោះបានសាច់ទន្សាយក្នុងពេលល្ងាច ស្ងួរស្រេចជាប់ហើយទុកចំណែកមួយអំពីចំណែកនោះប្រគេនក្នុងថ្ងៃទីពីរ តាបសបរិភោគសាច់ហើយ

ត្រូវចំណង់ក្នុងរសគ្រប់សង្កត់ សួរថា នេះជាសាច់អ្វី លុះបានដឹងថា ជាសាច់ទន្សាង ដូច្នេះហើយ ត្រាច់ទៅដើម្បីកិក្ខា ទទួលយកសប្បិ ទឹកដោះជូរ និងគ្រឿងហឺរជាដើម ទៅកាន់បណ្ណសាលា ហើយទុកក្នុងចំណែកម្ខាង ។

ស្តេចទន្សាងនៅក្នុងដំបូកមួយ មិនឆ្ងាយអំពីបណ្ណសាលា ស្តេចទន្សាងចេញមកថ្វាយបង្គំតាបសតាមកាលសមគួរ ។ ក្នុងថ្ងៃនោះ តាបសនោះគិតថា អញនឹងសម្ងាប់ទន្សាងនេះ ដូច្នេះហើយ លាក់ដំបង អង្គុយធ្វើដូចដេកលក់ក្នុងទីជិតដំបូកនោះ ។ ស្តេចទន្សាងចេញអំពីដំបូកហើយ មកកាន់សម្នាក់តាបសកំណត់អាការបានហើយ ទើបត្រឡប់អំពីទីនោះដោយគិតថា ថ្ងៃនេះ អញមិនពេញចិត្តក្នុងអាការរបស់អាចារ្យ តាបសដឹងការត្រឡប់របស់ទន្សាងនោះហើយ គ្រវែងដំបងទៅដើម្បីបំណងសម្ងាប់ទន្សាងនោះ ដំបងខុសទៅ ស្តេចទន្សាងចូលកាន់ដំបូកហើយ អើតក្បាលចេញអំពីដំបូក ហើយមើលផ្លូវដែលមក ពោលនឹងតាបសថា

> *ទន្សាងពោធិសត្វនិយាយនឹងតាបសថា ខ្ញុំស្មានអ្នកថា ជាសមណៈ បានចូលទៅរកអ្នក ជាអ្នកមិនសង្រួម អ្នកនោះ ប្រហារខ្ញុំដោយដំបង ដូចមនុស្សមិនមែនជាសមណៈដែរ ។ ម្នាលតាបសកម្ចៅ ប្រយោជន៍អ្វី ដោយផ្ចង់សក់របស់អ្នក ប្រយោជន៍អ្វី ដោយស្បែកខ្លាឃ្មុំរបស់អ្នក ខាងក្នុងរបស់អ្នកសាំញ៉ាំដោយកិលេស អ្នកជ្រាសរំលីងតែសរីរៈខាងក្រៅ ។*

គ្រានោះ តាបសលួងលោមស្តេចទន្សាងនោះដោយទ្រព្យដែលមានរបស់

ខ្លួន ទើបពោលគាថានេះថា

នែទន្សង ឯងចូរមកណោះ ឯងត្រឡប់មកវិញ ចូរបរិភោគបាយស្រូវសាលីចុះ ប្រេង និងអំបិលរបស់អញក៏មាន ដីប្លីរបស់អញក៏មានច្រើន ។

ស្តេចទន្សងស្តាប់ពាក្យនោះហើយពោលថា លោកពោលដោយប្រការណា ភាពដែលខ្ញុំបំណងគេចទៅតែម្យ៉ាង រមែងមានដោយប្រការនោះ ដូច្នេះហើយ ពោលគាថានេះថា

ខ្ញុំនោះ នឹងចូលទៅរកជំបូកជម្រៅ ១០០ ជួរបុរស យ៉ាងក្រៃលែង ថ្វីបើអ្នកឯងមានប្រេង និងអំបិល ដីប្លីរបស់អ្នកមិនជាប្រយោជន៍ដល់ខ្ញុំឡើយ ។

កាលពោលយ៉ាងនោះហើយពោលបន្តថា ខ្ញុំបានធ្វើសេចក្តីសម្គាល់ក្នុងលោកថាជាសមណៈ អស់កាលមានប្រមាណប៉ុណ្ណោះ ឥឡូវនេះ លោកគ្រវែងជំបងទៅព្រោះបំណងនឹងប្រហារខ្ញុំ លោកមិនជាសមណៈតាំងអំពីកាលដែលគ្រវែងជំបងទៅហើយនោះឯង ប្រយោជន៍អ្វីដោយផ្នងសក់របស់បុគ្គលដែលមានបញ្ញាថោកថយដូចលោក ប្រយោជន៍អ្វីដោយស្បែកម្រឹគ ឈ្នោះអជិនៈទាំងក្រចក ព្រោះខាងក្នុងរបស់លោកសាំញ៉ាំ លោកជុសខាតតែខាងក្រៅតែម្យ៉ាងប៉ុណ្ណោះ ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ ទ្រង់ប្រជុំជាតកថា តាបសបោកបញ្ឆោតក្នុងកាលនោះ បានមកជាព្រាហ្មណ៍ ក្នុងកាលឥឡូវនេះ

ចំណែកស្តេចទន្សាង បានជាតថាគតនេះឯង កាលទ្រង់សម្តែងហេតុនៃតាបសនោះ ត្រូវទន្សាងដែលជាសត្វឈ្លាស សង្កត់សង្កិនក្នុងកាលនោះ ទើបត្រាស់ព្រះគាថានេះថា

កិន្តេ ជដាហិ ទុម្មេធ កិន្តេ អជិនសាដិយា
អព្ភន្តរន្តេ គហនំ ពាហិរំ បរិមជ្ជសិ ។

នែអ្នកអប្បញ្ញាអើយ អ្នកមានប្រយោជន៍អ្វីដោយការទុកផ្នួងសក់ អ្នកមានប្រយោជន៍អ្វីដោយការទ្រទ្រង់សំពត់ស្បែកខ្លា បើសន្តានខាងក្នុងរបស់អ្នក សឹងសាំវញ្ចុំដោយរាគាទិក្កិលេស អ្នក ឈ្មោះថា ជុសខាត់តែកាយខាងក្រៅទេ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **កិន្តេ ជដាហិ** *សេចក្តីថា នែអ្នកមានបញ្ញាថោកថយ ប្រយោជន៍អ្វីដោយជដាទាំងនេះ ដែលអ្នកចងល្អហើយ និងដោយសំពត់សាជក ដែលធ្វើដោយស្បែកម្រឹគឈ្មោះអជិនៈនេះ មួយអន្ទើដោយក្រចកដែលអ្នកស្បៀកហើយរបស់អ្នក ។*

បទថា **អព្ភន្តរំ** *សេចក្តីថា ខាងក្នុងរបស់អ្នកសាំវញ្ចុំដោយកិលេសមានរាគៈជាដើម អ្នកជុសខាត់តែខាងក្រៅ ដូចលាមកដំរី លាមកសេះ រលោងតែខាងក្រៅតែម្យ៉ាង ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង កុមារកព្រាហ្មណ៍ ចប់

រឿង កិសាគោតមី

លំនាំដើម

ព្រះសាស្តា កាលគង់នៅត្រង់ភ្នំគិជ្ឈកូដ ទ្រង់ប្រារព្ធនាងកិសាគោតមី ត្រាស់ព្រះធម្មទេសនានេះថា **បំសុកូលធរំ** ជាដើម ។

បានឮថា ក្នុងកាលនោះ សក្កទេវរាជចូលគាល់ព្រះសាស្តា មួយអន្ទឹង ដោយទេវបរិស័ទ ក្នុងទីបំផុតនៃបឋមយាម ថ្វាយបង្គំហើយប្រថាប់គង់ ទ្រង់ស្តាប់ធម្មកថា ដែលជាទីតាំងនៃសេចក្តីរឭកដល់ ក្នុងចំណែកម្នាង ។

ក្នុងខណៈនោះ នាងកិសាគោតមីគិតថា អញនឹងគាល់ព្រះសាស្តា ហោះតាមអាកាសហើយ ឃើញសក្កទេវរាជ ទើបត្រឡប់ទៅ ។ សក្កទេវរាជ ទត ឃើញនាងដែលថ្វាយបង្គំហើយត្រឡប់ទៅ ទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ កិកុនីនោះឈ្មោះអ្វី មកឃើញទ្រង់ហើយក៏ត្រឡប់ ព្រះសាស្តាត្រាស់ថា មហាបពិត្រ កិកុនីនោះឈ្មោះកិសាគោតមី ជាធីតារបស់តថាគត ជាកំពូលនៃព្រះថេរីខាងទ្រទ្រង់សំពត់បង្សុកូលទាំងឡាយដូច្នេះ ត្រាស់ព្រះគាថានេះថា

បំសុក្កូលធរំ ជន្តុំ កិសទ្ធមនិសន្តតំ
ឯកំ វនស្មឹ ឈាយន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅបុគ្គលអ្នកទ្រទ្រង់សំពត់បង្សុកូល មានកាយស្គម មានខ្លួនរវាមដោយសរសៃ ជាបុគ្គលឯកឯង ចម្រើនឈានក្នុងព្រៃនោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កិសំ** *សេចក្តីថា ជនទាំងឡាយដែលទ្រទ្រង់សំពត់បង្សុកូល បំពេញបដិបទាសមគួរដល់ខ្លួន រមែងជាអ្នកមានសាច់ និងឈាមតិច ជាបុគ្គលមានខ្លួនរវាមដោយសរសៃ ហេតុនោះ ទើបព្រះសាស្តាត្រាស់យ៉ាងនោះ ។*

ពីរបទថា **ឯកំ វនស្មឹ** *សេចក្តីថា តថាគតរមែងហៅបុគ្គលដែលសម្ងឹងជាអ្នកនៅតែឯងក្នុងទីស្ងាត់នោះ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង កិសាគោតមី ចប់

រឿង ព្រាហ្មណ៍ម្នាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ន ចាហំ** ជាដើម ។

បានឮថា ព្រាហ្មណ៍នោះគិតថា ព្រះសមណគោតមត្រាស់ហៅសាវ័ក ទាំងឡាយរបស់ព្រះអង្គថា ព្រាហ្មណ៍ ចំណែកអញ ជាអ្នកកើតក្នុងកំណើត ព្រាហ្មណ៍ កាលដែលទ្រង់ត្រាស់ហៅអញយ៉ាងនោះដែរមែងគួរ ដូច្នេះហើយ ចូលគាល់ព្រះសាស្តា ទូលសួរសេចក្តីនោះ ។ លំដាប់នោះ ព្រះសាស្តាត្រាស់ ថា ម្នាលព្រាហ្មណ៍ តថាគតមិនហៅថាព្រាហ្មណ៍ដោយហេតុគ្រាន់តែកើតក្នុង កំណើតព្រាហ្មណ៍ប៉ុណ្ណោះទេ ចំណែកបុគ្គលណា មិនមានកិលេសជាគ្រឿង កង្វល់ មិនប្រកាន់មាំ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ន ចាហំ ព្រាហ្មណំ ព្រូមិ យោនិជំ មត្តិសម្ភវំ
ភោវាទិ នាម សោ ហោតិ ស វេ ហោតិ សកិញ្ចនោ
អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត នឹងហៅអ្នកកើតអំពីកំណើត អ្នកកើតក្នុងផ្ទៃនៃ ព្រាហ្មណីជាមាតា ថាជាព្រាហ្មណ៍ក៏ទេ បុគ្គលនោះ គ្រាន់តែបាន នាមថា ភោវាទី (អ្នកពោលថាចម្រើន) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេសគ្រឿងកង្វល់នៅឡើយ តថាគតហៅបុគ្គល អ្នកមិនមានកិលេសគ្រឿងកង្វល់ អ្នកមិនមានសេចក្តីប្រកាន់មាំ

នោះឯង ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យោនិជំ** *បានដល់ ជាអ្នកកើតហើយអំពីកំណើត ។*

បទថា **មត្តិសម្ភវ** *សេចក្តីថា អ្នកកើតហើយក្នុងផ្ទៃ ដែលជារបស់មាននៃមាតា ដែលជាព្រាហ្មណី ។*

បទថា **ភោវាទិ** *សេចក្តីថា បុគ្គលនោះដើរពោលថា អ្នកចម្រើន អ្នកចម្រើន ក្នុងពាក្យដែលហៅគ្នាជាដើមរមែងជាបុគ្គលឈ្មោះថា ភោវាទិ បុគ្គលនោះ នៅជាបុគ្គលមានកិលេសគ្រឿងកង្វល់ ដោយកិលេសជាគ្រឿងកង្វល់ទាំងឡាយ មានរាគៈជាដើម តែតថាគតហៅអ្នកមិនមានកិលេសគ្រឿងកង្វល់ដោយកិលេសទាំងឡាយ មានរាគៈជាដើម ដែលមិនប្រកាន់មាំដោយឧបាទាន ៤ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់មហាជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង ព្រាហ្មណ៍ម្នាក់ ចប់

រឿង ឧគ្គសេន

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសេដ្ឋីបុត្រឈ្មោះ ឧគ្គសេន ត្រាស់ព្រះធម្មទេសនានេះថា **សព្វសំយោជនំ** ជាដើម ។

រឿងខ្ញុំបានឲ្យពិស្តារហើយ ក្នុងអត្ថនៃព្រះគាថាថា **មុញ្ច បុរេ មុញ្ច បញ្ឆតោ** ជាដើមនោះឯង ។

ក្នុងកាលនោះ ព្រះសាស្តាកាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ព្រះឧគ្គសេនតែងពោលថាខ្ញុំមិនខ្លាច ប្រហែលជាចង់ព្យាករអរហត្តផលដោយពាក្យមិនពិត ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចគ្នានឹងបុត្រតថាគត មានសំយោជនៈកាត់បានហើយ មិនខ្លាចទៀយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

សព្វសំយោជនំ ឆេត្វា យោ វេ ន បរិតស្សតិ
សង្គាតិគំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា កាត់សញ្ញោជនៈទាំងអស់បាន មិនតក់ស្លុត តថាគតហៅ បុគ្គលនោះ ដែលគ្មានកិលេសជាគ្រឿងចំពាក់ អ្នកកន្លងស្រឡះចាកកិលេស ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សព្វសំយោជនំ** បានដល់ សំយោជនៈ ១០ យ៉ាង ។ បទថា **ន បរិតស្សតិ** បានដល់ រមែងមិនខ្លាចព្រោះតណ្ហា ។

បទថា **តមហំ** *កាត់បទជា* **តំ អហំ** *សេចក្តីថា តថាគតហៅបុគ្គលនោះ ដែលឈ្មោះថាឈានកន្ធង់នូវកិលេស ដែលជាគ្រឿងជាប់ជំពាក់ ព្រោះភាពដែលកិលេស គ្រឿងជាប់ជំពាក់ទាំងឡាយ មានរាគៈជាដើម ដែលកន្ធង់បានហើយ ជាបុគ្គលឈ្មោះថា ធ្វើឲ្យប្រាសបានហើយ ព្រោះមិនមានសំយោជនៈ ៤ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ឧគ្គសេន ចប់

រឿង ព្រាហ្មណ៍ពីរនាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ពីរនាក់ ត្រាស់ព្រះធម្មទេសនានេះថា **ឆេត្វា ឆេ្ន** *ជាដើម ។*

បានឮថា ព្រាហ្មណ៍ពីរនាក់នោះ ម្នាក់មានគោឈ្មោះចូឡរោហិត ម្នាក់ទៀត មានគោឈ្មោះមហារោហិត ។

ថ្ងៃមួយ ព្រាហ្មណ៍ទាំងពីរប្រកែកគ្នាថា គោរបស់អ្នករឹងប៉ឹង ឬគោរបស់ខ្ញុំរឹងប៉ឹង ដូច្នេះហើយ ប្រកែកគ្នាថា ប្រយោជន៍អ្វីរបស់យើងទាំងឡាយដោយការប្រកែកគ្នា យើងប្រណាំងគ្នាហើយនឹងដឹង ទើបដាក់រនេះឲ្យពេញដោយ

ខ្សាច់ ត្រង់ស្ទឹងអចិរវតី ហើយទឹមគោ ។

ក្នុងខណៈនោះ សូម្បីភិក្ខុទាំងឡាយក៏បានទៅហើយក្នុងទីនោះដើម្បីស្រង់ទឹក ព្រាហ្មណ៍ទាំងឡាយប្រណាំងគោគ្នាហើយ រនេះបានឈប់ស្ងៀម ឯព្រ័ត្រ និងខ្សែទាំងឡាយជាប់ហើយ ។

ភិក្ខុទាំងឡាយឃើញហើយ ទៅកាន់វិហារក្រាបទូលសេចក្តីនោះដល់ព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រ័ត្រ និងខ្សែនោះគ្រាន់តែជារបស់ខាងក្រៅ បុគ្គលណាក៏កាត់ព្រ័ត្រ និងខ្សែទាំងនោះបាន ឯភិក្ខុកាត់ព្រ័ត្រ គឺសេចក្តីក្រោធ កាត់ខ្សែ គឺតណ្ហា ដែលប្រព្រឹត្តទៅខាងក្នុង គួរជូចេះហើយ ត្រាស់ព្រះគាថានេះថា

ឆេត្វា នទ្ធឹ វរត្តញ្ច សន្ទានំ សហនុក្កមំ
ឧក្ខិត្តបលិឃំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅបុគ្គលដែលកាត់សេចក្តីក្រោធ ដូចពួរផង កាត់តណ្ហា ដូចព្រ័ត្រផង កាត់ទិដ្ឋិ ៦២ ដូចទី-ត ព្រមទាំងអនុសយ ដូចអ្នកដើរតាមផង អ្នកមានអវិជ្ជា ដូចសសរខឿនដកចោលហើយ អ្នកត្រាស់ដឹងសច្ចៈ ៤ នោះឯង ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **នទ្ធឹ** *បានដល់ សេចក្តីក្រោធដែលប្រព្រឹត្តទៅដោយភាពជាគ្រឿងចងរឹតតែ ។*

បទថា **វនត្ថំ** *បានដល់ តណ្ហាដែលប្រព្រឹត្តទៅដោយភាពជាគ្រឿងចង ។*

បានព្រះគាថាថា **សង្គានំ សហានុក្កមំ** *ជាដើម សេចក្តីថា តថាគតហៅបុគ្គលដែលកាត់គ្រឿង-ត គឺទិដ្ឋិ ៦២ ដែលប្រកបដោយខ្សែ គឺអនុសយទាំងពួងតាំងនៅហើយ ជាបុគ្គលឈ្មោះថា មានសសរខឿនដកខ្ទឹងហើយ ព្រោះសសរខឿន គឺអវិជ្ជា ជារបស់ដកខ្ទឹងហើយ បុគ្គលឈ្មោះថា ដឹងហើយ ព្រោះដឹងសច្ចៈ ៤ នោះ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា ភិក្ខុ ៥០០ រូបតាំងនៅក្នុងអរហត្តផលហើយ ទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង ព្រាហ្មណ៍ពីរនាក់ ចប់

រឿង អក្កោសកភារទ្វាជព្រាហ្មណ៍

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធអក្កោសកភារទ្វាជព្រាហ្មណ៍ ត្រាស់ព្រះធម្មទេសនានេះថា **អក្កោសំ** *ជាដើម ។*

សេចក្តីពិស្តារថា នាងព្រាហ្មណីឈ្មោះធនញ្ជានី ជាភរិយារបស់ភារទ្វាជព្រាហ្មណ៍ ដែលជាបងប្រុសរបស់អក្កោសកភារទ្វាជព្រាហ្មណ៍ បានជាព្រះសោបន្នហើយ ។ នាងកណ្តាស់ក្តី ក្អកក្តី ភ្លាត់ជើងក្តី តែងបន្ទឹងទានថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ថ្ងៃមួយ ក្នុងពេលដែលអង្គាសព្រាហ្មណ៍ នាងភ្ញាក់ហើយ បន្ទឹខទាន យ៉ាងនោះឯងដោយសំឡេងខ្លាំង ព្រាហ្មណ៍ក្រោធហើយពោលថា ស្រីថោកទាបនេះ ភ្ញាក់ហើយក្នុងទីណាមួយ រមែងពោលសរសើរសមណៈក្បាលត្រងោលនោះ គ្រប់ទីកន្លែង ដូច្នេះហើយ ពោលបន្តថា ស្រីថោកទាបឥឡូវនេះ អញនឹងទៅលើកវាទៈជាមួយសាស្តារបស់ហង ។

លំដាប់នោះ នាងពោលនឹងព្រាហ្មណ៍ថា អញ្ជើញចុះព្រាហ្មណ៍ ខ្ញុំមិនឃើញបុគ្គលដែលអាចលើកវាទៈ ចំពោះព្រះដ៏មានព្រះភាគអង្គនោះបាន អើបើទៅហើយ សូមទូលសួរបញ្ហានឹងព្រះសាស្តាផង ។ ព្រាហ្មណ៍ចូលទៅកាន់សម្នាក់ព្រះសាស្តា មិនថ្វាយបង្គំ ឈរក្នុងចំណែកម្ខាងហើយ កាលនឹងទូលសួរបញ្ហា ទើបពោលគាថានេះថា

> បុគ្គលកាត់បង់នូវអ្វី ទើបដេកជាសុខ បុគ្គលកាត់បង់នូវអ្វី ទើបមិនសោកសៅ បពិត្រព្រះគោតម ព្រះអង្គពេញព្រះហឫទ័យនឹងសម្ងាប់ធម៌ណាដែលជាធម៌ឯក ។

លំដាប់នោះ ព្រះសាស្តា ទ្រង់ព្យាករបញ្ហាជាមួយព្រាហ្មណ៍ ទើបត្រាស់ព្រះគាថានេះថា

> បុគ្គលកាត់បង់នូវសេចក្តីក្រោធ ទើបដេកជាសុខ បុគ្គលកាត់បង់នូវសេចក្តីក្រោធ ទើបមិនសោកសៅ ម្នាលព្រាហ្មណ៍ ពួកព្រះអរិយៈ តែងសរសើរនូវការសម្ងាប់សេចក្តីក្រោធ ដែលមានឫសជាពិស មានចុងដ៏ផ្អែម ព្រោះថា បុគ្គលកាត់បង់នូវ

សេចក្តីក្រោធនោះបានហើយ ទើបមិនសោកសៅ ។

ព្រាហ្មណ៍ជ្រះថ្លាក្នុងព្រះសាស្តា បួសហើយ សម្រេចអរហត្ត ។ គ្រានោះ អក្កោសកភារទ្វាជព្រាហ្មណ៍ ឮនប្រុសរបស់ព្រាហ្មណ៍ បានដំណឹងថា បងប្រុសរបស់ខ្ញុំនបួសហើយក៏ក្រោធ ទើបមកជេរព្រះសាស្តាដោយវាចាគ្រោតគ្រាត មិនមែនវាចាសប្បុរស សូម្បីព្រាហ្មណ៍នោះ ក៏ត្រូវព្រះសាស្តាឲ្យសិក្សាហើយ ដោយឧបមាអំពីរបស់គួរទំពាជាដើម ដល់ក្រៀវទាំងឡាយជ្រះថ្លាក្នុងព្រះសាស្តា បួសហើយ សម្រេចអរហត្ត ។

ឮនប្រុសទាំងពីររបស់ព្រាហ្មណ៍ដទៃទៀត គឺសុន្ទរិកភារទ្វាជៈ ពិលង្គ-កភារទ្វាជៈ ជេរព្រះសាស្តាដូចគ្នា កាលព្រះសាស្តាទ្រង់ទូន្មានបួសហើយ សម្រេចអរហត្ត ។

ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំង-ឡាយ គុណរបស់ព្រះពុទ្ធគួរអស្ចារ្យហ្ន៎ កាលព្រាហ្មណ៍បងឮនទាំង ៤ ជេរព្រះដ៏មានព្រះភាគមិនត្រាស់ពាក្យណាមួយ ត្រឡប់បានជាទីពឹងនៃព្រាហ្មណ៍ទាំងនោះទៀត ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាដូចម្តេច កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្នោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនប្រទូស្ត ក្នុងជនទាំងឡាយដែលជាអ្នកប្រទូស្ត ព្រោះតថាគតប្រកបដោយកម្លាំង គឺខន្តី រមែងជាទីពឹងរបស់មហាជនដោយពិត ដូច្នេះហើយ ត្រាស់

ព្រះគាថានេះថា

អក្កោសំ វធពន្ធញ្ច　　អទុដ្ឋោ យោ តិតិក្ខតិ
ខន្តិពលំ ពលានីកំ　　តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា មិនប្រទូស្ត អត់សង្កត់ពាក្យជេរផង ការបៀតបៀន និងការចងផងបាន ទើបតថាគតហៅបុគ្គល ដែលមានខន្តីជាពល មានខន្តីជាវេហ៍ពលនោះឯង ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អទុដ្ឋោ** *ជាដើម សេចក្តីថា បុគ្គលណាជាអ្នកមានចិត្តមិនក្រោធ អត់សង្កត់នូវពាក្យជេរ និងពាក្យបរិភាសដោយអក្កោសវត្ថុ ១០ និងការវាយដោយបាតដៃជាដើម និងការចងដោយគ្រឿងចងមានខ្នោះជាដើម តថាគតហៅបុគ្គលនោះ គឺបុគ្គលបែបនោះ ដែលឈ្មោះថាមានកម្លាំង គឺខន្តី ព្រោះជាអ្នកប្រកបដោយកម្លាំង គឺខន្តី បុគ្គលឈ្មោះថាមានវេហ៍ពល ព្រោះជាអ្នកប្រកបដោយកម្លាំង គឺខន្តីដែលជាពួក ព្រោះកើតឡើងរឿយៗ នោះឯង ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងអក្កោសកភារទ្វាជព្រាហ្មណ៍ ចប់

រឿង ព្រះសារីបុត្តត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អក្កោធនំ** ជាដើម ។

បានឮថា ក្នុងកាលនោះ ព្រះថេរៈត្រាច់ទៅបិណ្ឌបាតជាមួយភិក្ខុ ៥០០ រូប បានទៅកាន់ទ្វារផ្ទះរបស់មាតាក្នុងស្រុកនាលកៈ ។ គ្រានោះ នាងនិមន្តឲ្យលោកគង់ហើយ អង្គាសហើយ ជេរថា បពិត្រលោកម្ចាស់ លោកមិនបានរបស់ទំពាដែលជាសំណល់ និងទឹកដែលជាសំណល់ ក៏សមគួរនឹងបរិភោគទឹកបាយដែលជាប់នៅនឹងបាតត្រឡោកក្នុងផ្ទះរបស់អ្នកជនៃ លោកលះបង់ទ្រព្យ ៨០ កោដិបួសបាន លោកឲ្យខ្ញុំវិនាសហើយ ឥឡូវនេះ សូមលោកបរិភោគចុះ ។ នាងថ្វាយកត្តបណ្តើរដល់ភិក្ខុទាំងឡាយ ពោលថា កូនរបស់ខ្ញុំត្រូវលោកទាំងឡាយធ្វើឲ្យជាអ្នកបម្រើរបស់ខ្លួនហើយ ឥឡូវនេះ សូមពួកលោកបរិភោគចុះ ព្រះថេរៈទទួលភិក្ខាហើយ បានទៅកាន់វិហារនោះឯង ។ គ្រានោះ ព្រះរាហុលអើពើនឹងព្រះសាស្តាដោយបិណ្ឌបាតហើយ ។ ពេលនោះ ព្រះសាស្តាត្រាស់ថា រាហុល ពួកអ្នកទៅក្នុងទីណា រាហុលពោលថា បពិត្រព្រះអង្គ ទៅកាន់ស្រុករបស់យាយ ព្រះសាស្តាត្រាស់ថា ឧបជ្ឈាយ៍របស់អ្នកត្រូវយាយពោលដូចម្តេច រាហុលពោលថា បពិត្រព្រះអង្គ ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គត្រូវយាយជេរហើយ ព្រះសាស្តាត្រាស់ថា ឧបជ្ឈាយ៍របស់អ្នកត្រូវយាយជេរដូចម្តេច ព្រះរាហុលពោលថា លោកយាយជេរដោយពាក្យឈ្មោះនេះ ព្រះសាស្តាត្រាស់ថា ចំណែកឧបជ្ឈាយ៍របស់អ្នកពោល

ដូចម្តេច រាហុលពោលថា លោកមិនពោលដូចម្តេចទេឬ ។

ភិក្ខុទាំងឡាយ ស្តាប់ពាក្យនោះហើយ សន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ គុណទាំងឡាយរបស់ព្រះសារីបុត្ត គួរអស្ចារ្យហ្ន៎ កាលមាតារបស់លោកជេរយ៉ាងនោះ សូម្បីត្រឹមតែក្រោធ ក៏មិនមានឡើយ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយកថាដូចម្តេចហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រពទាំងឡាយ ជាអ្នកមិនក្រោធឡើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អក្កោធនំ វតវន្តំ សីលវន្តំ អនុស្សុទំ
ទន្តំ អន្តិមសារីរំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅបុគ្គលដែលមិនមានសេចក្តីក្រោធ មានធុតង្គវត្ត មានចតុប្បារិសុទ្ធិសីល មិនមានតណ្ហា ជាគ្រឿងរបាំងចិត្ត មានឥន្ទ្រិយទូន្មានហើយ មានសរីរៈស្ថិតនៅក្នុងទីបំផុតនោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **វតវន្តំ** ជាដើម សេចក្តីថា តថាគតហៅបុគ្គលប្រកបដោយវត្ត គឺធុតង្គ ដែលមានសីលដោយចតុបារិសុទ្ធិសីល ៤ ឈ្មោះថា មិនមានតណ្ហាជាគ្រឿងប៉ោងខ្ពើង ព្រោះមិនមានគ្រឿងប៉ោងខ្ពើង គឺតណ្ហា បុគ្គលឈ្មោះថាទូន្មានហើយ ព្រោះទូន្មានឥន្ទ្រិយ ៦ ដែល

ឈ្មោះថា មានសរីរៈក្នុងទីបំផុត ព្រោះអត្តភាពតាំងនៅក្នុងទំបំផុតនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះសារីបុត្តត្ថេរ ចប់

រឿង ឧប្បលវណ្ណាថេរី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងឧប្បលវណ្ណាថេរី ត្រាស់ព្រះធម្មទេសនានេះថា **អារិ ចោក្ខរបត្តេវ** *ជាដើម ។*

រឿងខ្ញុំឲ្យពិស្តារហើយ ក្នុងអដ្ឋកថានៃព្រះគាថាថា **មធុវា មញ្ញតិ ពាលោ** *ជាដើម ។*

ពិតហើយ ក្នុងទីនោះ ខ្ញុំពោលថា ដោយសម័យដទៃទៀត មហាជនសន្ទនាក្នុងរោងធម្មសភាថា សូម្បីព្រះខីណាស្រព ប្រហែលជានៅតែសេពកាម ហេតុអ្វីទើងមិនសេព ព្រោះលោកទាំងនោះ មិនមែនឈើពុក មិនមែនដំបូក នៅមានសាច់ស្រស់ និងសរីរៈស្រស់នោះឯង ហេតុនោះ សូម្បីព្រះខីណាស្រពទាំងនោះ គង់ត្រេកអរក្នុងកាមសុខ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់

មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ខីណាស្រពទាំង-ឡាយ មិនត្រេកអរនូវកាមសុខ មិនសេពកាម ដូចតំណក់ទឹកដែលធ្លាក់លើស្វឹកឈូករមែងមិនជាប់ មិនជក់នៅ រមែងរមៀលធ្លាក់ទៅនោះឯង យ៉ាងណា ម្យ៉ាងទៀត ដូចគ្រាប់ស្ពៃ រមែងមិនជាប់ មិនតាំងនៅលើចុងដែកស្រួច រមែងរមៀលចុះទៅនោះឯង យ៉ាងណា សូម្បីកាមទាំងពីរយ៉ាង រមែងមិនជាប់ មិនតាំងនៅក្នុងចិត្តរបស់ព្រះខីណាស្រពដូច្នោះ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថាក្នុងព្រាហ្មណវគ្គនេះថា

យាវិ ចោក្ករបត្តេវ អារគ្គេរិវ សាសបោ
យោ ន លិម្បតិ កាមេសុ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា មានចិត្តមិនបានជាប់នៅក្នុងកាមទាំងឡាយ ដូចទឹកលើស្វឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **យោ ន លិម្បតិ** ជាដើម សេចក្តីថា បុគ្គលណា រមែងមិនជាប់ក្នុងកាមទាំងពីរយ៉ាងក្នុងខាងក្នុង គឺមិនតាំងនៅក្នុងកាមនោះយ៉ាងនេះឯង តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រាហ្មណ៍ម្នាក់

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **យោ ធុក្ខស្ស** ជាដើម ។

បានឲ្យថា ទាសៈម្នាក់របស់ព្រាហ្មណ៍នោះ កាលសិក្ខាបទព្រះសាស្តាទ្រង់មិនទាន់បញ្ញត្តិ គេចទៅបួសសម្រេចអរហត្តហើយ ។ ព្រាហ្មណ៍រកមិនឃើញក្នុងថ្ងៃមួយ ជួបលោកកំពុងចូលទៅបិណ្ឌបាតជាមួយព្រះសាស្តា ត្រង់រវាងទ្វារ បានទាញចីវរយ៉ាងមាំ ព្រះសាស្តាយាងត្រឡប់ត្រាស់សួរថា ម្នាលព្រាហ្មណ៍ តើមានរឿងអ្វី ព្រាហ្មណ៍ពោលថា បពិត្រព្រះគោតម ភិក្ខុនេះជាខ្ញុំបម្រើរបស់ខ្ញុំព្រះអង្ត ។ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ ភិក្ខុនោះមានភារៈដាក់ចុះហើយ ។

កាលព្រះសាស្តាត្រាស់ថា ជាអ្នកមានភារៈដាក់ចុះហើយ ព្រាហ្មណ៍ កំណត់បានថា ជាព្រះអរហន្ត ហេតុនោះ កាលព្រាហ្មណ៍ក្រាបទូលទៀតថា បពិត្រព្រះគោតមយ៉ាងនោះឬ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ ត្រឹមត្រូវហើយ ភិក្ខុនោះជាបុគ្គលមានភារៈដាក់ចុះហើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

យោ ធុក្ខស្ស បជានាតិ ឥធេវ ខយមត្តនោ
បណ្ណភារំ វិសញ្ញុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ក្នុងសាសនានេះឯង ដឹងច្បាស់នូវការអស់ទុក្ខ
របស់ខ្លួន តថាគតហៅបុគ្គលនោះ ដែលមានខន្ធភារៈដាក់ចុះ

ហើយ ដែលរួចស្រឡះចាកកិលេសទាំងឡាយ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទុក្ខស្ស** បានដល់ ខន្ធទុក្ខ ។

បទថា **បណ្ណភារំ** ជាដើម សេចក្តីថា តថាគតហៅបុគ្គលមានភារៈ គឺខន្ធដែលដាក់ចុះហើយ ដែលបន្សាត់បានហើយចាកយោគៈ ៤ ឬកិលេសទាំងពួងនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់មហាជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿង ព្រាហ្មណ៍ម្នាក់ ចប់

រឿង ខេមាភិក្ខុនី

លំនាំដើម

ព្រះសាស្តា កាលគង់នៅត្រង់ក្នុងគិជ្ឈកូដ ទ្រង់ប្រារព្ធព្រះនាងខេមាភិក្ខុនី ត្រាស់ព្រះធម្មទេសនានេះថា **គម្ភីរបញ្ញំ** ជាដើម ។

សេចក្តីពិស្តារថា ក្នុងថ្ងៃមួយ សក្កទេវរាជយាងមកជាមួយទេវបរិស័ទក្នុងវាងនៃបឋមយាម ប្រថាប់គង់ស្តាប់ធម្មកថា ដែលជាទីតាំងនៃការរឭកដល់ ក្នុងសម្នាក់របស់ព្រះសាស្តា ។

ខណៈនោះ ព្រះនាងខេមាកិក្ខុនីមកដោយត្រិះរិះថានឹងគាល់ព្រះសាស្តា ឃើញសក្កទេវរាជហើយ ឈរក្នុងអាកាសនោះឯង ថ្វាយបង្គំព្រះសាស្តាហើយ ក៏ត្រឡប់ទៅ ។

សក្កទេវរាជទតឃើញព្រះនាងខេមាហើយ ទូលសួរថា បពិត្រព្រះអគ្គកិក្ខុនីនោះឈ្មោះអ្វី មកឈរក្នុងអាកាសនោះឯង ថ្វាយបង្គំហើយត្រឡប់ទៅ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ កិក្ខុនីនោះជាធីតារបស់តថាគត ឈ្មោះខេមា ដែលជាអ្នកមានបញ្ញាច្រើន ឈ្វាសក្នុងផ្លូវ និងមិនមែនផ្លូវ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

គម្ភីរបញ្ញំ មេធាវឹ មគ្គាមគ្គស្ស កោវិទំ
ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅបុគ្គលអ្នកមានប្រាជ្ញាជ្រៅ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស អ្នកឈ្វាសក្នុងផ្លូវ និងមិនមែនផ្លូវ បានសម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់នោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **គម្ភីរបញ្ញំ** *ជាដើម សេចក្តីថា តថាគតហៅបុគ្គលដែលប្រកបដោយបញ្ញា ដែលប្រព្រឹត្តទៅក្នុងធម៌ទាំងឡាយ មានខន្ធជាដើមដ៏ជ្រាលជ្រៅ ជាអ្នកប្រាជ្ញ ប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ បុគ្គលឈ្មោះថា ឈ្វាសក្នុងផ្លូវ និងមិនមែនផ្លូវ ព្រោះភាពជាអ្នកឈ្វាសក្នុងផ្លូវ និងមិនមែនផ្លូវយ៉ាងនេះ គឺនេះជាផ្លូវនៃទុគ្គតិ នេះជាផ្លូវនៃសុគតិ នេះជាផ្លូវនៃព្រះ*

និព្វាន នេះមិនមែនផ្លូវ បុគ្គលសម្រេចប្រយោជន៍ដ៏ឧត្តម ពោល គឺព្រះអរហត្តនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ខេមាភិក្ខុនី ចប់

រឿង ព្រះតិស្សត្ថេរអ្នកដេកក្នុងញែកភ្នំ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះតិស្សត្ថេរ ដែលនៅក្នុងញែកភ្នំ ត្រាស់ព្រះធម្មទេសនានេះថា **អសំសដ្ឋំ** *ជាដើម ។*

បានឮថា ព្រះថេរៈនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ចូលកាន់ព្រៃ សម្លឹងរកសេនាសនៈជាទីសប្បាយ ដល់ញែកភ្នំមួយកន្លែង ក្នុងខណៈដែលលោកដល់នោះឯង ចិត្តរបស់លោកបានដល់កាពជាធម្មជាតតែមួយហើយ លោកគិតថា បើអញនៅក្នុងទីនេះនឹងអាចឲ្យកិច្ចរបស់បព្វជិតសម្រេចបាន ។

ទេវតាដែលអាស្រ័យនៅក្នុងគុហានោះគិតថា កិក្ខុមានសីលមកហើយ កាលដែលអញនៅក្នុងទីជាមួយគ្នានឹងកិក្ខុនេះ លំបាក កិក្ខុនេះនឹងនៅអស់រាត្រីមួយប៉ុណ្ណោះ ក៏នឹងចេញទៅ ទើបពកួនទាំងឡាយចេញទៅ ។

ក្នុងថ្ងៃស្អែកទៀង ព្រះថេរៈចូលទៅកាន់គោចរគ្រាមអំពីព្រលឹមដើម្បីបិណ្ឌបាត កាលនោះ ឧបាសិកាម្នាក់ឃើញលោកហើយ បាននូវការស្រឡាញ់ដូចកូន និមន្តឲ្យគង់ក្នុងផ្ទះឲ្យធាន់ហើយ អង្វរដើម្បីឲ្យអាស្រ័យខ្លួនអស់កាល ៣ ខែ លោកក៏ទទួលដោយគិតថា អាត្មាអញអាស្រ័យឧបាសិកានេះ អាចធ្វើនូវការលោសចេញចាកកិលេសបាន ដូច្នេះហើយ បានទៅកាន់គុហានោះឯង ។

ទេវតាឃើញលោកកំពុងដើរមក គិតថា ព្រះថេរៈនេះពិតជាបុគ្គលណាម្នាក់និមន្តពិត លោកនឹងទៅក្នុងថ្ងៃស្អែកនេះ ឬខានស្អែកនេះ ។

កន្លះខែកន្លងទៅហើយយ៉ាងនេះ ទេវតាគិតថា ភិក្ខុនេះពិតជានៅក្នុងទីនេះពិតៗ ខាងក្នុងរដូវក្តៀង ការដែលអញ និងកូនតូចទាំងឡាយ នៅក្នុងទីតែមួយនឹងអ្នកមានសីល ជាការធ្វើបានលំបាក ការភ្ជាំងភ្ជាត់ក្នុងសីលរបស់ភិក្ខុនេះមានដែរឬទេហ្ន៎ ដូច្នេះហើយ សម្លឹងមើលដោយទិព្វចក្ខុ ក៏មិនឃើញការភ្ជាំងភ្ជាត់ក្នុងសីលរបស់លោក តាំងអំពីឧបសម្បទាមក ទើបគិតថា សីលរបស់លោកបរិសុទ្ធ អញនឹងធ្វើហេតុណាមួយនោះឯង ឲ្យនូវការវិនាសកើតឡើងដល់លោក ដូច្នេះហើយ ទើបចូលទៅសណ្ឋិតក្នុងសរីរៈកូនច្បងរបស់ឧបាសិកា ក្នុងត្រកូលឧបដ្ឋាក មួលកហើយ ភ្លែកទាំងពីររបស់កុមារនោះបញ្ឆេះហើយ ទឹកមាត់ហូរចេញអំពីមាត់ ឧបាសិកាឃើញបុត្រនោះហើយ ស្រែកថា តើមានរឿងអ្វី ។

គ្រានោះ ទេវតាមានរូបមិនប្រាកដ ពោលនឹងឧបាសិកានោះយ៉ាងនេះថា កូននោះយើងចាប់ហើយ យើងមិនត្រូវការដោយពលីកម្ម តែចូរអ្នកសូមឈើ

អែមនឹងព្រះថេរៈ ដែលចូលដល់ត្រកូលរបស់អ្នក ហើយយកឈើអែមនោះ ចៀននឹងប្រេងហើយ ចូរឲ្យដល់បុត្រនេះដោយវិធីនគ្គុចុះ កាលបើធ្វើយ៉ាងនេះ ទើបយើងលែងបុត្រនេះ ។

ឧបាសិកាពោលថា បុត្រនោះចូរវិនាស ឬស្លាប់ក៏ដោយចុះ ខ្ញុំមិនអាចសូមឈើអែមនឹងព្រះថេរៈបានទេ្បីយ ទេវតាពោលថា បើមិនអាចសូមឈើអែមសោត ចូរអ្នកជ្រាប់ដើម្បីដាក់លម្អិតហិង្គុក្នុងច្រមុះបុត្រនោះចុះ ។

ឧបាសិកាពោលថា ខ្ញុំមិនអាចពោលពាក្យយ៉ាងនេះបាន ទេវតាពោលថា បើយ៉ាងនោះ ចូរអ្នកធ្វើទឹកលាងជើងរបស់ព្រះថេរៈនោះ ស្រោចលើក្បាលកូនចុះ ។ ឧបាសិកាពោលថា ខ្ញុំអាចធ្វើសេចក្តីនេះបាន និមន្តឲ្យព្រះថេរៈមកតាមកាលគង់ហើយ ថ្វាយយាគូ និងរបស់ទំពា លាងជើងរបស់ព្រះថេរៈក្នុងរោងភត្ត ត្រង់យកទឹកហើយ ពិតឲ្យជ្រាបថា បពិត្រលោកម្ចាស់ ខ្ញុំនឹងស្រោចទឹកនេះលើក្បាលរបស់ក្មេង ព្រះថេរៈអនុញ្ញាតថា ចូរស្រោចចុះ បានធ្វើយ៉ាងនោះហើយ ។ ទេវតាលែងកុមារនោះក្នុងខណៈនោះឯង ហើយបានទៅឈរត្រង់ទ្វារគុហា ។

ព្រះថេរៈ ក្នុងវេលាស្រេចភត្តកិច្ច ក្រោកចាកអាសនៈ ស្វាធ្យាយអាការ ៣២ នោះឯង ព្រោះលោកមិនលះបង់កម្មដ្ឋាន ចៀសចេញទៅហើយ ។ ក្នុងកាលលោកមកដល់ទ្វារគុហា ទេវតាពោលនឹងលោកថា គ្រូធំ សូមលោកកុំចូលក្នុងទីនេះ លោកឈរក្នុងទីនោះឯង ពោលថា អ្នកជាអ្នកណា ទេវតាពោលថា ខ្ញុំជាទេវតាអាស្រ័យនៅក្នុងទីនេះ ព្រះថេរៈគិតថា អញធ្វើវេជ្ជកម្ម

មានឬហ្ន៎ ដូច្នេះហើយ ពិនិត្យមើល ចាប់តាំងពីឧបសម្បទាមក ក៏មិនឃើញ ការសៅហ្មង ពព្រុស ពពាល ក្នុងសីលរបស់ខ្លួន ទើបពោលថា ខ្ញុំមិន ឃើញទីដែលខ្ញុំធ្វើវេជ្ជកម្មឡើយ អ្នកពោលយ៉ាងនោះ ព្រោះហេតុអ្វី ទេវតា ពោលថា លោកមើលមិនឃើញឬ ព្រះថេរៈពោលថា អើ ខ្ញុំមិនឃើញ ទេវតា ពោលថា បើយ៉ាងនោះ ខ្ញុំនឹងប្រាប់ដល់លោក ព្រះថេរៈពោលថា អញ្ជើញ អ្នកប្រាប់ចុះ ទេវតាពោលថា ការនិយាយវត្ថុដែលឆ្ងាយ ចូរស្ងៀមចុះ ក្នុងថ្ងៃ នេះឯង លោកស្រោចទឹកលាងជើងលើក្បាលដល់កូនរបស់ឧបដ្ឋាក ដែលត្រូវ អមនុស្សស្រណុតហើយ តើមែនឬទេ ព្រះថេរៈពោលថា អើ ខ្ញុំស្រោច ទេវតា ពោលថា នុ៎ះជាអ្វី លោកមិនឃើញឬ ព្រះថេរៈពោលថា អ្នកបំណងហេតុ នោះឬ ទេវតាពោលថា ខ្ញុំពោលបំណងហេតុនោះឯង ព្រះថេរៈគិតថា ឱហ្ន៎ ខ្លួនអាត្មាអញ ប្រពៃហើយ អញប្រព្រឹត្តសមគួរដល់សាសនាហើយ សូម្បីតែ ទេវតាក៏មិនបានឃើញការសៅហ្មង ឬពព្រុស ពពាល ក្នុងចតុប្បារិសុទ្ធ-សីលរបស់អញ បានឃើញត្រឹមតែទឹកលាងជើង ដែលអញស្រោចហើយ លើក្បាលទារក ។ បីតិដ៏មានកម្លាំង ប្រារព្ធសីលកើតឡើងហើយដល់លោក លោកសង្កត់បីតិដ៏មានកម្លាំងហើយ មិនធ្វើនូវការលើកជើងឡើង សម្រេច អរហត្តក្នុងទីនោះឯង ហើយពោលថា អ្នកប្រទូស្តសមណៈដែលបរិសុទ្ធដូចខ្ញុំ អ្នកកុំនៅក្នុងព្រៃនេះ អ្នកនោះឯង ចូរចេញទៅ កាលទូន្មានទេវតា ទើបបន្ទឹ ឧទានថា

ការនៅរបស់ខ្ញុំបរិសុទ្ធហើយហ្ន៎ អ្នកកុំប្រទូស្តខ្ញុំដែលមិនមានមន្ទិល ជាអ្នកមានតបៈបរិសុទ្ធហើយ ចូរអ្នកចេញអំពីព្រៃធំនេះចុះ ។

លោកនៅក្នុងទីនោះឯងអស់ ៣ ខែ ចេញវស្សាហើយទៅកាន់សម្នាក់ព្រះសាស្តា ត្រូវភិក្ខុទាំងឡាយសួរថា អាវុសោ កិច្ចនៃបព្វជិតលោកធ្វើដល់ទីបំផុតហើយឬ ទើបប្រាប់រឿងទាំងអស់នោះ ចាប់តាំងពីការនៅចាំវស្សាក្នុងគុហានោះដល់ភិក្ខុទាំងឡាយ កាលភិក្ខុទាំងឡាយពោលថា អាវុសោ លោកត្រូវទេវតាពោលយ៉ាងនោះ មិនក្រោធទេឬ ក៏ពោលថា ខ្ញុំមិនក្រោធទេ ។

ភិក្ខុទាំងឡាយក្រាបទូលរឿងនោះដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុនេះព្យាករអរហត្តផល ត្រូវទេវតាពោលពាក្យឈ្នានេះ ពោលថា ខ្ញុំមិនក្រោធទេ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កូនរបស់តថាគតមិនក្រោធឡើយ ព្រោះឈ្នានថាការជាប់ជំពាក់ដោយគ្រហស្ថ ឬបព្វជិតទាំងឡាយ រមែងមិនមានដល់បុត្ររបស់តថាគតនោះ បុត្ររបស់តថាគតនោះ មិនជាប់ជំពាក់ ជាអ្នកប្រាថ្នាតិច សន្តោស ដូច្នេះហើយ កាលនឹងសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

អសំសដ្ឋំ គហដ្ឋេហិ អនាគារេហិ ចូភយំ
អនោកសារឹ អប្បិច្ឆំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅបុគ្គលដែលមិនច្រឡំដោយជនទាំងឡាយ ២ ពួក គឺគ្រហស្ថ ១ បព្វជិត ១ ជាអ្នកត្រាច់ទៅដោយមិនមាន

សេចក្តីអាល័យ មានសេចក្តីប្រាថ្នាតិចនោះថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អសំសដ្ឋំ** *សេចក្តីថា ឈ្មោះថា មិនជាប់ជំពាក់ ព្រោះការមិនមានការជាប់ជំពាក់ដោយការមើល ការស្តាប់ ការសន្ទនា ការបរិភោគ និងដោយកាយ ។*

បទថា **ឧភយំ** *បានដល់ មិនជាប់ជំពាក់ដោយជន ២ ពួក គឺគ្រហស្ថ ១ បព្វជិត ១ ។*

បទថា **អនោកសារឺ** *បានដល់ ជាអ្នកមិនអាល័យត្រាច់ទៅ អធិប្បាយថា តថាគតហៅបុគ្គលនោះ គឺបុគ្គលបែបនោះ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងព្រះតិស្សត្ថេរអ្នកនៅក្នុងញ្ជែកភ្នំ ចប់

រឿង ភិក្ខុមួយរូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **ឯធាយ** *ជាដើម ។*

បានឮថា ភិក្ខុនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ព្យាយាមនៅព្រៃ សម្រេចអរហត្តហើយគិតថា អញនឹងក្រាបទូលគុណដែលខ្លួនបានហើយដល់ព្រះសាស្តា ទើបចេញអំពីព្រៃនោះ ។

គ្រានោះ ស្រីម្នាក់ក្នុងស្រុកមួយធ្វើការវិវាទគ្នាជាមួយស្វាមី កាលស្វាមីនោះចេញទៅខាងក្រៅ គិតថា អញនឹងទៅកាន់ផ្ទះត្រកូល ទើបធ្វើដំណើរទៅជួបភិក្ខុនោះក្នុងរវាងផ្លូវគិតថា អញនឹងអាស្រ័យព្រះថេរៈនេះទៅ ទើបដើរតាមក្រោយ តែព្រះថេរៈមិនឃើញនាង ។

គ្រានោះ ប្តីដើរមកកាន់ផ្ទះមិនឃើញភរិយា គិតថា នាងទៅកាន់ផ្ទះនៃត្រកូលហើយដេញតាមទៅ ជួបហើយគិតថា ស្រីនេះម្នាក់ឯងមិនអាចដើរឆ្លងព្រៃនេះបាន នាងអាស្រ័យអ្វីហ្ន៎ទើបទៅបាន ដូច្នេះហើយ ពិនិត្យមើលក៏ឃើញព្រះថេរៈ គិតថា ព្រះថេរៈនេះជាអ្នកនាំស្រីនេះចេញទៅហើយ ទើបសម្លុតព្រះថេរៈ ។ កាលនោះ ទើបស្រីនោះពោលនឹងស្វាមីថា នែអ្នក លោកម្ចាស់មិនបានឃើញ មិនបានហៅខ្ញុំឡើយ អ្នកកុំស្តីថាពាក្យណាមួយជាមួយលោកម្ចាស់ឡើយ ។

ប្តីនោះមានសេចក្តីក្រោធពោលថា នាងមិនជ្រាបបុគ្គលដែលនាំនាងទៅដល់អញឬ អញនឹងធ្វើកម្មដែលសមគួរដល់កិក្ខុនេះ ជំនួសខ្លួននាងឲ្យបាន ។

ដោយការអាឃាតក្នុងស្រី ទើបវាយព្រះថេរៈ ហើយនាំស្រីនោះត្រឡប់ ។

សរីរៈរបស់ព្រះថេរៈប៉ោងឡើងហើយ ក្នុងកាលព្រះថេរៈមកកាន់វិហារ ភិក្ខុទាំងឡាយនាំគ្នាច្របាច់សរីរៈ ឃើញពកហើយសួរថា នេះអ្វី លោកច្រាប់សេចក្តីនោះដល់ភិក្ខុទាំងនោះ ។

លុំជាប់នោះ ពួកភិក្ខុសួរថា អាវុសោ កាលបុរសនោះប្រហារយ៉ាងនោះ លោកបាននពោលពាក្យអ្វី ឬសេចក្តីក្រោធកើតឡើងដល់លោកដែរឬទេ ព្រះថេរៈពោលថា អាវុសោទាំងឡាយ សេចក្តីក្រោធមិនកើតឡើងដល់ខ្ញុំទេ ។

ភិក្ខុទាំងនោះ ទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលសេចក្តីនោះហើយ ទូលថា បពិត្រព្រះអង្គ ភិក្ខុនោះកាលខ្ញុំព្រះអង្គពោលថា សេចក្តីក្រោធកើតឡើងដល់លោកដែរឬទេ លោកពោលថា អាវុសោទាំងឡាយ សេចក្តីក្រោធមិនកើតឡើងដល់ខ្ញុំឡើយ ភិក្ខុនោះពោលពាក្យមិនពិត ព្យាករអរហត្តផល ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រពទាំងឡាយ មានអជ្ជាជាក់ចុះហើយ ព្រះខីណាស្រពទាំងនោះ រមែងមិនធ្វើសេចក្តីក្រោធក្នុងជនទាំងឡាយ ជាអ្នកសូម្បីមានអ្នកប្រហារ ដូច្នេះហើយ ត្រាស់គាថានេះថា

ឯធាយ ឧណ្ហំ ភូតេសុ តសេសុ ថាវរេសុ ច
យោ ន ហន្តិ ន ឃាតេតិ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ជាក់ចុះនូវអជ្ជា ក្នុងសត្វទាំងឡាយ ដែលនៅតក់ស្លុតក្តី ដែលមាំមួន គឺមិនមានតក់ស្លុតក្តី មិនបៀតបៀន

ដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **និធាយ** បានដល់ ដាក់ហើយ គឺដាក់ចុះហើយ ។

ពីរបទថា **តសេសុ ថាវរេសុ ច** សេចក្តីថា បុគ្គលឈ្មោះថាតក់ស្តូត ព្រោះការតក់ស្តូតដោយអំណាចនៃតណ្ហា និងបុគ្គលឈ្មោះថាមាំទាំ ព្រោះជាអ្នកមាំទាំដោយការមិនមាននៃតណ្ហា ។

ពីរបទថា **យោ ន ហញ្ញតិ** ជាដើម សេចក្តីថា បុគ្គលណា ឈ្មោះថាមានអាជ្ញាដាក់ចុះហើយ ព្រោះភាពជាអ្នកមានបដិឃៈទៅប្រាសហើយ ក្នុងសត្វទាំងពួងយ៉ាងនេះ រមែងមិនសម្លាប់ឯង មិនប្រើឲ្យអ្នកដទៃសម្លាប់នូវសត្វណាមួយទៀយ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងភិក្ខុមួយរូប ចប់

រឿង សាមណេរ

លំនាំដើម

ព្រះសាស្តា កាលគង់ក្នុងវត្តជេតពន ទ្រង់ប្រោរព្ធសាមណេរទាំងឡាយ ត្រាស់ព្រះធម្មទេសនានេះថា **អវិរុទ្ធំ** ជាដើម ។

បានឮថា ព្រាហ្មណ៍ម្នាក់ រៀបចំខនេ្ទសកត្តដើម្បីភិក្ខុ ៤ រូប ពោលនឹងព្រាហ្មណ៍ថា នែព្រាហ្មណ៍ សូមអ្នកទៅវិហារ ហើយនាំព្រាហ្មណ៍ចាស់ ៤ អង្គមក ព្រាហ្មណ៍ទៅកាន់វិហារហើយពោលថា សូមលោកម្ចាស់ទាំងឡាយ ឲ្យព្រាហ្មណ៍ ៤ អង្គដល់ខ្ញុំ ។

ព្រះថេរៈបានឲ្យសាមណេរជាខីណាស្រព ៤ រូប ដែលមានអាយុ ៧ ឆ្នាំ គឺសង្កិច្ចសាមណេរ បណ្ឌិតសាមណេរ សោបាកសាមណេរ រេវត-សាមណេរ ដល់ព្រាហ្មណ៍នោះ ។

ព្រាហ្មណ៍រៀបចំអាសនៈទាំងឡាយដែលមានតម្លៃច្រើន ឃើញសាមណេរ ហើយក្រោធ ឆេវឆាវ ដូចអំបិលដែលបុគ្គលជាក់ក្នុងភ្លើងពោលថា អ្នកទៅវិហារហើយ នាំកូនក្មេង ៤ នាក់ ដូចជាចៅរបស់ខ្លួន ដែលមិនសមគួរមកហើយ ទើបមិនឲ្យសាមណេរទាំងនោះគង់លើអាសនៈទាំងនោះ ជាក់តាំងទាបៗ ហើយពោលថា សូមលោកទាំងឡាយអង្គុយលើតាំងទាំងនោះ ពោលថា នែព្រាហ្មណ៍ ចូរអ្នកទៅជ្រើសរើសព្រាហ្មណ៍ចាស់ហើយនាំមក ។

ព្រាហ្មណ៍ទៅកាន់វិហារ ជួបព្រះសារីបុត្តត្ថេរហើយ ពិតថា មកចុះ យើងនឹងទៅផ្ទះរបស់យើងទាំងឡាយ ដូច្នេះហើយ នាំមក ព្រះថេរៈមក ឃើញសាមណេរទាំងឡាយហើយសួរថា ព្រាហ្មណ៍ទាំងនេះ បានកត្តហើយឬ

កាលព្រាហ្មណ៍ឆ្លើយថា មិនទាន់បានទេ ទើបជ្រាបភាពដែលគេរៀបចំកត្តជើម្បីព្រាហ្មណ៍ ៤ អង្គនោះ ពោលថា ចូរពួកអ្នកនាំបាត្រវបស់យើងមក ហើយទទួលបាត្រ ចៀសចេញទៅ ។

ព្រាហ្មណីសួរថា ព្រាហ្មណ៍នេះពោលអ្វី កាលព្រាហ្មណ៍ឆ្លើយថា លោកពោលថា ព្រាហ្មណ៍ដែលអង្គុយនោះបានអាហារមុនទើបគួរ ចូរនាំបាត្រអាត្មាមក ទទួលយកបាត្រវបស់ខ្លួនហើយទៅ ទើបព្រាហ្មណីពោលថា ព្រះថេរៈនោះ ប្រហែលជាមិនបំណងនឹងឆាន់ ចូរប្រញាប់ទៅជ្រើសរើសព្រាហ្មណ៍ដទៃនាំមក ព្រាហ្មណ៍ទៅជួបព្រះមហាមោគ្គល្លានត្ថេរ ក៏ពោលយ៉ាងនោះដូចគ្នា នាំមកហើយ លោកឃើញសាមណេរទាំងឡាយហើយ ពោលយ៉ាងនោះដូចគ្នា ហើយទទួលបាត្រ ចៀសចេញទៅ ។

លំដាប់នោះ ព្រាហ្មណីពោលនឹងព្រាហ្មណ៍នោះថា ព្រាហ្មណ៍ទាំងនោះជាអ្នកមិនបំណងដើម្បីឆាន់ទេដឹង ចូរអ្នកទៅកាន់រោងស្វាធ្យាយរបស់ព្រាហ្មណ៍ នាំព្រាហ្មណ៍ចាស់ម្នាក់មក ។

សាមណេរទាំងឡាយ មិនបានវត្តុណាមួយតាំងពីព្រឹក ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់អង្គុយហើយ ។ គ្រានោះ អាសនៈរបស់ព្រះឥន្ទ្រ សម្តែងអាការក្តៅហើយ ព្រោះតេជៈនៃគុណរបស់សាមណេរទាំងនោះ ។ សក្កទេវរាជទ្រង់ពិចារណា ក៏ជ្រាបភាពដែលសាមណេរទាំងនោះ អង្គុយស្រេកឃ្លានតាំងអំពីព្រឹក ទ្រង់ព្រះតម្រិះថា ការដែលអញទៅក្នុងទីនោះគួរ ទើបកាឡាខ្លួនជាព្រាហ្មណ៍ចាស់ជរា ប្រថាប់អង្គុយលើអាសនៈដ៏ប្រសើររបស់ព្រាហ្មណ៍

ទាំងឡាយ ក្នុងរោងស្វាធ្យាយរបស់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍ឃើញសក្កៈនោះហើយគិតថា គ្រានេះ ព្រាហ្មណីរបស់អញនឹងពេញចិត្ត ពោលថា មកលោក ពួកយើងទៅកាន់ផ្ទះ បាននាំសក្កៈទៅកាន់ផ្ទះហើយ ។

ព្រាហ្មណីគ្រាន់តែឃើញសក្កៈប៉ុណ្ណោះ មានចិត្តត្រេកអរហើយ លាតកម្រាលលើអាសនៈពីរជាន់ក្នុងទីតែមួយពោលថា សូមលោកអញ្ជើញអង្គុយលើកម្រាលនេះចុះ ។

សក្កៈយាងចូលទៅកាន់ផ្ទះ ហើយថ្វាយបង្គំសាមណេរទាំង ៤ ដោយបញ្ចង្គប្រតិស្ឋានហើយ ទើបប្រថាប់គង់ដោយបល្ល័ង្ក ដែលជាអាសនៈខាងចុងនៃសាមណេរទាំងនោះ ។

គ្រានោះ ព្រាហ្មណីឃើញសក្កៈហើយពោលនឹងព្រាហ្មណ៍ថា លំបាកហ្ន៎ ព្រាហ្មណ៍ដែលអ្នកនាំមកហើយ ជាព្រាហ្មណ៍ឆ្កួត ព្រាហ្មណ៍នោះ ថ្វាយបង្គំសាមណេរដែលស្រករនឹងចៅរបស់ខ្លួន ប្រយោជន៍អ្វីដោយព្រាហ្មណ៍នេះ ចូរលោកបណ្តេញព្រាហ្មណ៍នេះចេញទៅ ព្រាហ្មណ៍កាឡាខ្លួននោះ ត្រូវគេចាប់ត្រង់កខ្ទះ ត្រង់ដៃខ្ទះ ត្រង់ក្លៀកខ្ទះទាញចេញទៅ ក៏មិនច្រេះថ្នាន់នឹងក្រោកឡើង ។ លំដាប់នោះ ព្រាហ្មណីពោលនឹងព្រាហ្មណ៍ជាប្តីថា មកព្រាហ្មណ៍ ចូរអ្នកចាប់ដៃម្ខាង ខ្ញុំចាប់ដៃម្ខាង ទាំងពីរនាក់ចាប់ត្រង់ដៃទាំងពីរហើយវាយត្រង់ខ្នង នាំគ្នាអូសទៅខាងក្រៅទ្វារផ្ទះហើយ ។

ចំណែកសក្កទេវរាជ ក៏បាត់ពីទីនោះ មកប្រថាប់គង់ក្នុងទីដើមនោះឯង គ្រវីដៃហើយ ។ ព្រាហ្មណ៍ប្តីប្រពន្ធនោះ ត្រឡប់មកឃើញសក្កៈនោះប្រថាប់

គង់ដូចដើម ស្រែកដោយសេចក្តីខ្លាច ហើយលែងទៅ ។ ខណៈនោះ សក្ក-ទេវរាជ ឲ្យព្រាហ្មណ៍ជ្រាបភាពដែលទ្រង់ជាសក្កៈហើយ ។

លំដាប់នោះ ប្តីប្រពន្ធទាំងពីរ បានថ្វាយអាហារដល់សាមណេរទាំងនោះ ហើយ ជនទាំង ៥ ទទួលអាហារហើយ មួយរូបទម្លាយមណ្ឌលហោងជាង ហោះទៅ មួយរូបទម្លាយដំបូលខាងមុខហោះទៅ មួយរូបទម្លាយដំបូលខាង ក្រោយហោះទៅ មួយរូបមុជចូលក្នុងផែនដី ចំណែកសក្កទេវរាជ ទៅដោយ ផ្លូវមួយ ជនទាំង ៥ បានទៅកាន់ទីទាំង ៥ ដោយប្រការដូច្នេះ ។

ចាប់តាំងពីកាលនោះមក បានឮថា ផ្ទះនោះ ឈ្មោះថាផ្ទះប្រហោង ៥ ។ ក្នុងកាលដែលសាមណេរទៅកាន់វិហារ ភិក្ខុទាំងឡាយ សួរសាមណេរ ទាំងឡាយថា អាវុសោទាំងឡាយ រឿងនេះដូចម្តេច ។

ពួកសាមណេរប្រាប់ថា សូមលោកម្ចាស់ទាំងឡាយ កុំសួរពួកខ្ញុំ ចាប់តាំងពីកាលដែលព្រាហ្មណ៍ឃើញពួកខ្ញុំហើយ ព្រាហ្មណីត្រូវសេចក្តីក្រោធគ្រប សង្កត់ មិនឲ្យពួកខ្ញុំអង្គុយលើអាសនៈដែលតាក់តែង ហើយពោលថា ចូរអ្នក នាំព្រាហ្មណ៍ចាស់មកឲ្យឆាប់ ឧបជ្ឈាយ៍របស់ពួកខ្ញុំ ឃើញពួកខ្ញុំហើយពោល ថា ពួកព្រាហ្មណ៍ដែលអង្គុយទាំងនេះបានអាហារមុនគួរ បានយកបាត្រមក ហើយ ចេញទៅ ។

កាលព្រាហ្មណីពោលថា ចូរអ្នកនាំព្រាហ្មណ៍ចាស់ដទៃមក ព្រាហ្មណ៍ នាំព្រះមោគ្គល្លានត្ថេរមកហើយ លោកឃើញពួកខ្ញុំ ក៏ពោលយ៉ាងនោះដូចគ្នា ហើយចៀសចេញទៅ ពេលនោះ ព្រាហ្មណីពោលថា ព្រាហ្មណ៍ទាំងនេះ មិន

បំណងនឹងធាន់ ចូរអ្នកទៅនាំព្រាហ្មណ៍ចាស់ម្នាក់ អំពីរោងស្វាធ្យាយរបស់ព្រាហ្មណ៍មកចុះ ហើយបញ្ជូនព្រាហ្មណ៍ទៅ ព្រាហ្មណ៍នោះ ទៅត្រង់រោងស្វាធ្យាយនោះហើយ នាំសក្កៈកាឡាខ្លួនជាព្រាហ្មណ៍មក ក្នុងកាលដែលសក្កៈនោះយាងមកហើយ ទើបប្តីប្រពន្ធទាំងពីរឲ្យអាហារដល់ពួកខ្ញុំ ភិក្ខុទាំងឡាយសួរថា ពួកលោកមិនក្រោធជាមួយព្រាហ្មណ៍ដែលធ្វើយ៉ាងនោះទេឬ សាមណេរពោលថា ពួកខ្ញុំមិនក្រោធទេ ភិក្ខុទាំងឡាយស្តាប់ពាក្យនោះហើយ ក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ សាមណេរទាំងនេះពោលពាក្យមិនពិតថា ពួកខ្ញុំមិនក្រោធ ជាការព្យាករអរហត្តផល ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រពទាំង-ឡាយ រមែងមិនចង្អៀតចង្អល់ក្នុងជនទាំងឡាយ ដែលជាអ្នកខឹងក្រោធហើយ ដូច្នេះហើយ ត្រាស់គាថានេះថា

អវិរុទ្ធំ វិរុទ្ធេសុ អត្តទណ្ឌេសុ និព្ពុតំ
សាទានេសុ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគតហៅពួកអ្នកដែលមិនខឹង ចំពោះពួកជនដែលខឹងហើយ អ្នករម្ងាប់ចំពោះពួកជន ដែលមានអាជ្ញាក្នុងខ្លួន អ្នកមិនមានសេចក្តីប្រកាន់ចំពោះពួកជន ដែលមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អវិរុទ្ធំ** *ជាដើម សេចក្តីថា តថាគតរមែង*

ហៅបុគ្គលនោះ គឺបែបនោះ ដែលឈ្មោះថាមិនចង្អៀតចង្អល់ ព្រោះការមិនមានអាឃាតក្នុងពួកលោកិយមហាជន ដែលជាអ្នកចង្អៀតចង្អល់ហើយដោយអំណាចនៃសេចក្តីអាឃាត ជាអ្នកឈ្មោះថារម្ងាប់បាន គឺមានអាជ្ញាជាក់ចុះហើយក្នុងជនទាំងឡាយ ដែលឈ្មោះថាមានអាជ្ញាក្នុងខ្លួន ព្រោះភាពដែលបុគ្គលនោះជាបុគ្គលមិនវៀរចាកការឲ្យនូវការប្រហារជនដទៃ ក្នុងកាលដំបង ឬសស្ត្រា ក្នុងដៃសូម្បីមិនមាន ជាបុគ្គលឈ្មោះថា មិនប្រកាន់មាំ ព្រោះមិនមានការប្រកាន់នោះក្នុងជនទាំងឡាយ ជាបុគ្គលឈ្មោះថាមានការប្រកាន់មាំ ព្រោះការប្រកាន់ក្នុងខន្ធ ៥ ថាអញ ថារបស់អញ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង សាមណេរ ចប់

រឿង ព្រះមហាបន្តកត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះមហាបន្តកត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យស្ស រាគោ ច** *ជាដើម ។*

សេចក្តីពិស្តារថា ព្រះមហាបន្តក:នោះ បណ្តេញព្រះចូឡបន្តក: ដែលមិនអាចធ្វើ គឺទន្ទេញមួយគាថាឲ្យស្ទាត់ជំនាញបាន អស់កាល ៤ ខែ ចេញអំពីវិហារ ដោយពាក្យថា លោកមានអត្តភាពក្នុងព្រះសាសនា ទាំងជាអ្នកវិនាសចាកកោគ:របស់គ្រហស្ថ ប្រយោជន៍អ្វីរបស់លោក ដោយការនៅក្នុងវិហារនេះ ចូរអ្នកចេញអំពីវិហារនេះ ហើយបើកទ្វារ ។

ភិក្ខុទាំងឡាយសន្ទនាគ្នាថា អាវុសោទាំងឡាយ កម្មឈ្មោះនេះព្រះមហាបន្តក:បានធ្វើ ប្រហែលជាសេចក្តីក្រោធ កើតឡើងដល់ព្រះខីណាស្រពទាំងឡាយ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយពាក្យអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ដោយពាក្យឈ្មោះនេះ ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កិលេសទាំងឡាយ មានរាគ:ជាដើម មិនមានដល់ព្រះខីណាស្រពទាំងឡាយ តែបុត្ររបស់តថាគតធ្វើកម្មនោះ ព្រោះភាពដែលខ្លួនជាអ្នកប្រាថ្នាអត្តខាងមុខ ព្រោះជាអ្នកប្រាថ្នាធម៌ខាងមុខ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

យស្ស រាគោ ច ទោសោ ច មានោ មក្ខោ ច ឆាតិតោ

សាសវោរិវ អារគ្គា តមហំ ព្រូមិ ព្រាហ្មណំ ។

រាគៈ ទោសៈ មានៈ និងមក្ខៈដែលបុគ្គលណាបានជម្រុះចេញហើយ ដូចគ្រាប់ស្ពៃដែលជ្រុះចុះអំពីចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អារគ្គា** *ជាដើម សេចក្តីថា កិលេសទាំងឡាយ មានរាគៈជាដើមនោះ និងមក្ខៈ ដែលមានការលុបគុណអ្នកដទៃជាលក្ខណៈនេះ បុគ្គលណាឲ្យធ្លាក់ទៅហើយ ដូចគ្រាប់ស្ពៃធ្លាក់អំពីចុងដែកស្រួចដូច្នោះ កិលេសទាំងនោះរមែងមិនតាំងនៅក្នុងចិត្ត ដូចគ្រាប់ស្ពៃមិនជាប់ត្រង់ចុងដែកស្រួច ដូច្នោះ ។ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងព្រះមហាបន្ថកត្ថេរ ចប់

រឿង ព្រះបិលិន្ទវច្ឆត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបិលិន្ទវច្ឆត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អកក្កសំ** ជាដើម ។

បានឮថា ព្រះបិលិន្ទវច្ឆៈនោះ ពោលពាក្យជាដើមថា អ្នកថោកទាប ចូរមក អ្នកថោកទាប ចូរទៅ រមែងហៅទាំងគ្រហស្ថ ទាំងបព្វជិតដោយវាទៈថា អ្នកថោកទាបទាំងអស់ ។

ថ្ងៃមួយ ភិក្ខុជាច្រើនក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ព្រះបិលិន្ទវច្ឆៈ រមែងហៅភិក្ខុទាំងឡាយដោយវាទៈថា ជនថោកទាប ។

ព្រះសាស្តាឲ្យហៅព្រះថេរៈមកហើយ ត្រាស់សួរថា ម្នាលបិលិន្ទវច្ឆៈ បានឮថា អ្នកហៅភិក្ខុទាំងឡាយដោយវាទៈថា អ្នកថោកទាបឬ កាលព្រះថេរៈក្រាបទូលថា យ៉ាងនោះឯងព្រះអង្គ ទើបទ្រង់ធ្វើបុព្វេនុវាសរបស់ព្រះបិលិន្ទវច្ឆៈនោះក្នុងព្រះហឫទ័យហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំលើកទោសដល់ភិក្ខុឈ្មោះបិលិន្ទវច្ឆៈឡើយ ម្នាលភិក្ខុទាំងឡាយ វច្ឆៈមិនមានទោសខាងក្នុង ហៅភិក្ខុទាំងឡាយដោយពាក្យថា អ្នកថោកទាបឡើយ ម្នាលភិក្ខុទាំងឡាយ ជាតិទាំងឡាយ ៥០០ របស់ភិក្ខុឈ្មោះវច្ឆៈ មិនលាយឡំគ្នា (គឺព្រាហ្មណ៍ ៥០០ ជាតិជាប់គ្នា) ទាំងអស់នោះ កើតហើយក្នុងត្រកូលព្រាហ្មណ៍ ក្នុងកាលខាងក្រោយ វាទៈថោកទាបនោះ វច្ឆៈហៅមកហើយអស់កាលយូរ ជាពាក្យទ្រគោះចោះចោកជនដទៃ ជាពាក្យមិនពីរោះ ជាពាក្យគ្រោតគ្រោតនោះឯង ឈ្មោះថា មិនមានដល់ព្រះខីណាស្រព ព្រោះថាបុត្រ

របស់តថាគតពោលយ៉ាងនោះដោយអំណាចនៃការធ្លាប់ កាលទ្រង់សម្តែងធម៌ទើប ត្រាស់ព្រះគាថានេះថា

អកក្កសំ វិញ្ញាបនឹ គិរំ សច្ចំ ឧទីរយេ
យាយ នាភិសជេ កញ្ចិ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ពោលពាក្យមិនអាក្រក់ ពាក្យជាហេតុឲ្យដឹងសេចក្តីបាន ជាពាក្យពិត ជាពាក្យដែលមិនធ្វើអ្នកណាឲ្យទាស់ចិត្ត តថាគតហៅបុគ្គលនោះថា ជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អកក្កសំ** *បានដល់ ពាក្យមិនគ្រោតគ្រាត ។ បទថា* **វិញ្ញាបនឹ** *បានដល់ ឲ្យដឹងអត្ថគ្នាបាន ។ បទថា* **សច្ចំ** *បានដល់ ជាអត្ថដែលពិត ។ បទថា* **នាភិសជេ** *ជាដើម សេចក្តីថា បុគ្គលមិនគប្បីញុំងបុគ្គលដទៃឲ្យជាប់ជំពាក់ ដោយអំណាចនៃការឲ្យបុគ្គលនោះក្រោធ ដោយពាក្យណាមួយ ។ ធម្មតាព្រះខីណាស្រព គប្បីពោលពាក្យបែបនោះឯង ហេតុនោះទើបតថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះបិលិន្ទវច្ឆត្ថេរ ចប់

រឿង ភិក្ខុមួយរូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **យោធ ធីឃំ** ជាដើម ។

បានឮមកថា ព្រាហ្មណ៍មិច្ឆាទិដ្ឋិម្នាក់ក្នុងក្រុងសាវត្ថី ដោះសំពត់សាដកសម្រាប់ដណ្តប់ដាក់ក្នុងចំណែកម្ខាង ព្រោះខ្លាចធំក្ងិនខ្លួន អង្គុយបែរមុខចេញមកខាងក្រៅទ្វារផ្ទះ ។

លំដាប់នោះ ព្រះខីណាស្រពមួយរូបធ្វើកត្តកិច្ចហើយ កំពុងដើរទៅកាន់វិហារ ឃើញសំពត់សាដកនោះហើយ សម្លឹងមើលឆ្វេងស្តាំ កាលមិនឃើញបុគ្គលណាម្នាក់ ទើបគិតថា សំពត់សាដកនេះមិនមានម្ចាស់ ហើយអធិដ្ឋានជាសំពត់បង្សុកូល កាន់យកហើយ ។

ខណៈនោះ ព្រាហ្មណ៍ឃើញហើយ ជេរបណ្តើរ ចូលទៅរកបណ្តើរថា សមណៈត្រង៉ោល លោកកាន់យកសំពត់សាដកខ្ញុំធ្វើអ្វី ព្រះខីណាស្រពពោលថា ព្រាហ្មណ៍ នុ៎ះសំពត់សាដករបស់អ្នកឬ ព្រាហ្មណ៍ពោលថា អើសមណៈ ព្រះខីណាស្រពពោលថា អាត្មាមិនឃើញបុគ្គលណាម្នាក់ ទើបកាន់យកសំពត់សាដកនោះ ដោយសម្គាល់ថា ជាសំពត់បង្សុកូល ចូរអ្នកទទួលយកសំពត់សាដកនោះចុះ ឲ្យដល់ព្រាហ្មណ៍នោះហើយទៅកាន់វិហារ ប្រាប់សេចក្តីនោះដល់ភិក្ខុទាំងឡាយ ។

លំដាប់នោះ ភិក្ខុទាំងឡាយស្តាប់ពាក្យរបស់លោកហើយ ក៏ធ្វើនូវការចំអក ទើបពោលថា អាវុសោ សំពត់សាដកវែង ឬខ្លី គ្រោតគ្រាត ឬល្អិតហ្មត់

ព្រះខីណាស្រពពោលថា អាវុសោទាំងឡាយ សំពត់សាដកវែង ឬខ្លី គ្រោត គ្រោត ឬល្អិតក៏ដោយចុះ ការអាល័យក្នុងសំពត់សាដកនោះរបស់ខ្ញុំមិនមាន ខ្ញុំកាន់យកដោយសម្គាល់ថា ជាសំពត់បង្សុកូលទេតើ ។

ភិក្ខុទាំងឡាយស្តាប់ពាក្យនោះហើយ ក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុនោះពោលពាក្យមិនពិត ព្យាករអរហត្តផល ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះពោលពាក្យពិត ធម្មតាព្រះខីណាស្រពទាំងឡាយ មិនកាន់យករបស់អ្នកដទៃ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

យោធ ទីឃំ វ រស្សំ វា អណុំ ថូលំ សុភាសុភំ
លោកេ អទិន្នំ នាទិយតិ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា មិនកាន់យករបស់វែង ឬខ្លី តូច ឬធំ ល្អ ឬអាក្រក់ ដែលគេមិនបានឲ្យហើយ ក្នុងលោកនេះ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះដូច្នេះថា បុគ្គលណា រមែងមិនកាន់យកទ្រព្យវែង ឬខ្លី បណ្តាវត្ថុទាំងឡាយ មានសំពត់សាដក និងគ្រឿងប្រដាប់ជាដើម តូច ឬធំ បណ្តាវត្ថុទាំងឡាយ មានកែវមណី និងកែវមុក្តាជាដើម ស្អាត ឬមិនស្អាត ដោយអំណាចនៃវត្ថុមានតម្លៃច្រើន និងមានតម្លៃតិច ដែលបុគ្គលដទៃហួងហែងហើយ ក្នុងលោកនេះ តថាគតហៅបុគ្គលនោះ ថាជា

ព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ភិក្ខុមួយរូប ចប់

រឿង ព្រះសារីបុត្តត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អាសា យស្ស** *ជាដើម ។*

បានឮថា ព្រះថេរៈមានភិក្ខុ ៥០០ ជាបរិវារ ទៅកាន់វិហារមួយកន្លែងក្នុងជនបទ ហើយចាំវស្សា ។

មនុស្សទាំងឡាយ ឃើញព្រះថេរៈហើយ ត្រៀមសំពត់ចំណាំវស្សាជាច្រើន ។ ព្រះថេរៈបវារណាហើយ កាលសំពត់ចំណាំវស្សាទាំងពួងមិនទាន់ដល់ (លំដាប់លោក) នោះឯង កាលទៅកាន់សម្នាក់ព្រះសាស្តា ផ្តាំភិក្ខុទាំងឡាយថា បើសំពត់ចំណាំវស្សា ដែលមនុស្សទាំងឡាយនាំមកហើយដើម្បីភិក្ខុកំលោះ និងសាមណេរទាំងឡាយ ពួកលោកទទួល ហើយបញ្ជូនមក ឬរក្សាទុកហើយ គប្បីឲ្យដំណឹងមក ។ ព្រះថេរៈកាលពោលយ៉ាងនោះហើយ បានទៅកាន់សម្នាក់ព្រះសាស្តា ។

ភិក្ខុទាំងឡាយសន្ទនាគ្នាថា សូម្បីថ្ងៃនេះ តណ្ហារបស់ព្រះសារីបុត្តត្ថេរប្រហែលជានៅមាន ពិតហើយ ព្រះថេរៈផ្តាំដល់ភិក្ខុទាំងឡាយថា កាលពួកមនុស្សប្រគេនសំពត់ចំណាំវស្សាហើយ ពួកលោកគប្បីបញ្ជូនសំពត់ចំណាំវស្សាមកដល់ពួកសទ្ធិវិហារិករបស់ខ្លួន ឬទុកជាក់ហើយ គប្បីឲ្យដំណឹងមកដូច្នេះហើយ ទើបចេញដំណើរមក ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តណ្ហារមែងមិនមានដល់បុត្រតថាគត តែសារីបុត្តពោលយ៉ាងនោះ ដោយគិតថាការវិនាសចាកបុណ្យរបស់ពួកមនុស្ស និងវិនាសចាកលាភ ដែលប្រកបដោយធម៌របស់ភិក្ខុកំលោះ និងសាមណេរទាំងឡាយ កុំបីមានឡើយដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អាសា យស្ស ន វិជ្ជន្តិ អស្មឹ លោកេ បរម្ហិ ច
និរាសយំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

អ្នកណា មិនមានសេចក្តីប្រាថ្នាក្នុងលោកនេះផង ក្នុងលោកខាងមុខផង តថាគតហៅបុគ្គលនោះ ដែលមិនមានសេចក្តីប្រាថ្នា ដែលផុតស្រឡះចាកកិលេស ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

តណ្ហា ឈ្មោះថា **អាសា** *ក្នុងព្រះគាថានោះ ។ បទថា* **និរាសាសំ**

បានដល់ មិនមានតណ្ហា ។ បទថា **វិសំយុត្តំ** *សេចក្តីថា តថាគតហៅបុគ្គលដែលផុតស្រឡះបានហើយចាកកិលេសទាំងពួងនោះ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះសារីបុត្តត្ថេរ ចប់

រឿង ព្រះមហាមោគ្គល្លានត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះមោគ្គល្លានត្រាស់ព្រះធម្មទេសនានេះថា **យស្សាលយា** *ជាដើម ។*

រឿងដូចគ្នានឹងរឿងមុននោះឯង តែក្នុងរឿងនេះ ព្រះសាស្តាត្រាស់ភាពដែលព្រះមោគ្គល្លានត្ថេរ ជាបុគ្គលមិនមានតណ្ហា ហើយត្រាស់ព្រះគាថានេះថា

យស្សាលយា ន វិជ្ជន្តិ អញ្ញាយ អកថង្កថី
អមតោគធំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

អ្នកណា មិនមានសេចក្តីអាល័យ គឺតណ្ហា មិនមានសេចក្តីសង្ស័យក្នុងអ្វីសោះ ព្រោះដឹងច្បាស់ធម៌ តថាគតហៅបុគ្គលនោះ ដែលមានចិត្តចុះស៊ប់កាន់ព្រះនិព្វាន ដែលមានព្រះអរហត្តផលដល់ហើយដោយលំដាប់ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

តណ្ហា ឈ្មោះថា អាលយ ក្នុងព្រះគាថានេះ ។

បាទព្រះគាថាថា **អញ្ញាយ អកថង្កថី** សេចក្តីថា បុគ្គលជីឆវត្ត ៨ តាមសេចក្តីពិតហើយ ជាអ្នកមិនមានសេចក្តីសង្ស័យ ដោយសេចក្តីសង្ស័យដែលមានវត្ថុ ៨ ។

បាទព្រះគាថាថា **អមតោគធំ អនុប្បត្តំ** សេចក្តីថា តថាគតហៅបុគ្គលនោះ ដែលចុះស៊ប់កាន់ព្រះនិព្វាន ឈ្មោះអមតៈ តាមសម្រេចហើយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ॥

រឿងព្រះមហាមោគ្គល្លានត្ថេរ ចប់

រឿង ព្រះវេតន្តេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងបុព្វារាម ទ្រង់ប្រារព្ធព្រះវេតន្តេរ ត្រាស់ព្រះធម្មទេសនានេះថា **យោធ បុញ្ញញ្ច** *ជាដើម ។*

រឿងខ្ញុំឲ្យពិស្តារហើយ ក្នុងអដ្ឋកថានៃព្រះគាថាថា **គាមេ វា យទិ វា រញ្ញេ** *ជាដើមហើយនោះឯង ។*

ពិតហើយ ក្នុងរឿងនោះខ្ញុំពោលថា ស្អែកឡើងភិក្ខុទាំងឡាយសន្ទនាគ្នាថា គួរអស្ចារ្យ សាមណេរមានលាភ គួរអស្ចារ្យ សាមណេរមានបុណ្យ មួយរូប សាងផ្ទះកំពូល ៥០០ ដើម្បីភិក្ខុ ៥០០ រូបបាន ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុណ្យ រមែងមិនមានដល់បុត្រវេស់តថាគត ជាប ក៏មិនមាន បុណ្យជាបទាំងពីរ ភិក្ខុនោះលះបង់ហើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

យោធ បុញ្ញញ្ច ចាបញ្ច ឧភោ សង្គិ ឧបច្ចគា
អសោកំ វិរជំ សុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យ និងជាបទាំងពីរ និងកិលេសជាគ្រឿងជំពាក់ (មានរាគៈជាដើម) ចេញហើយ តថាគតហៅបុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តីសោក មានធូលី គឺកិលេសអស់ហើយ ជាអ្នកបរិសុទ្ធ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឧភោ** សេចក្តីថា លះបុណ្យ និងបាបទាំងពីរ ។

បទថា **សង្គិំ** បានដល់ កិលេសជាគ្រឿងជាប់ជំពាក់ មានរាគៈជាដើម ។

បទថា **ឧបញ្ញគា** បានដល់ ឈានកន្លងហើយ អធិប្បាយថា តថាគតហៅបុគ្គល ដែលឈ្មោះថាមិនមានសេចក្តីសោក ព្រោះមិនមានសេចក្តីសោកដែលមានវដ្តៈជាមូល ដែលឈ្មោះថាមានធូលីទៅប្រាសហើយ ព្រោះមិនមានធូលី គឺរាគៈជាដើមខាងក្នុង បុគ្គលឈ្មោះថាបរិសុទ្ធហើយ ព្រោះជាអ្នកមិនមានឧបក្កិលេសនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះវេតន្តេរ ចប់

រឿង ព្រះចន្ទាភត្តេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះចន្ទាភត្តេរ ត្រាស់ព្រះធម្មទេសនានេះថា **ចន្ទំវ** ជាដើម ។

អនុបុព្វីកថាក្នុងរឿងរបស់ព្រះចន្ទាភត្តេរដូចតទៅនេះថា បានឮថា ក្នុងអតីតកាល ឈ្មួញក្នុងក្រុងពារាណសីម្នាក់គិតថា អញទៅកាន់បច្ចន្តជនបទ ហើយនាំចន្ទន៍ក្រហមមក ជញ្ជូនយកវត្ថុជាច្រើនមានសំពត់ និងគ្រឿងអាភរណៈជាដើម ទៅកាន់បច្ចន្តជនបទដោយរទេះ ៥០០ កាន់យកទីសម្រាកក្នុងទីជិតទ្វារស្រុកហើយ សួរក្មេងឃ្វាលគោក្នុងព្រៃថា មនុស្សណាម្នាក់ក្នុងស្រុកនេះ ធ្វើការងារក្បែរជើងភ្នំមានដែរឬ ពួកក្មេងឃ្វាលគោពោលថា មាន ឈ្មួញពោលថា មនុស្សនោះឈ្មោះអ្វី ក្មេងឃ្វាលគោប្រាប់ថា មនុស្សនោះឈ្មោះនោះ ។

ឈ្មួញសួរថា ភរិយា ឬកូនរបស់គាត់ឈ្មោះអ្វី ពួកក្មេងឃ្វាលគោប្រាប់ថា គាត់មានឈ្មោះយ៉ាងនេះៗ ឈ្មួញពោលថា ផ្ទះរបស់គាត់នៅទីណា ពួកក្មេងឃ្វាលគោប្រាប់ថា ផ្ទះរបស់គាត់នៅក្នុងទីឈ្មោះនោះ ឈ្មួញនោះអង្គុយលើយានតូចដែលជាសប្បាយ ទៅកាន់ទ្វារផ្ទះរបស់បុរសនោះតាមសញ្ញាដែលពួកក្មេងទាំងនោះឲ្យហើយ ចុះអំពីយានចូលទៅកាន់ផ្ទះហើយ ហៅស្រីឈ្មោះនោះ ស្រីនោះគិតថា បុគ្គលនេះជាញាតិរបស់អញណាម្នាក់ ទើបមកដោយរហ័ស បានក្រាលអាសនៈ ។

ឈ្មួញនោះអង្គុយលើអាសនៈនោះហើយ ប្រារព្ធឈ្មោះសួរថា សម្លាញ់

របស់ខ្ញុំទៅណា ស្រីនោះឆ្លើយថា គាត់ទៅកាន់ព្រៃហើយ ឈ្មួញប្រាប្តឈ្មោះរបស់មនុស្សទាំងពួងសួរថា កូនប្រុសរបស់ខ្ញុំឈ្មោះនោះ កូនស្រីរបស់ខ្ញុំឈ្មោះនោះទៅណា ដូច្នេះហើយ ពោលថា អ្នកគប្បីឲ្យសំពត់ និងគ្រឿងអាភរណៈទាំងនេះដល់ជនទាំងនោះ ក្នុងពេលដែលសម្លាញ់របស់ខ្ញុំត្រឡប់មកហើយអំពីព្រៃ នាងគប្បីឲ្យសំពត់ និងគ្រឿងអាភរណៈនេះ ហើយបានឲ្យវត្ថុទាំងនោះ ។ នាងធ្វើសក្ការៈក្រៃលែងដល់ឈ្មួញហើយ ក្នុងកាលដែលប្តីមក ទើបពោលថា នែអ្នក បុគ្គលនេះតាំងអំពីគាត់ចូលមកហើយ ប្រាប្តឈ្មោះរបស់ជនទាំងពួងហើយ ឲ្យវត្ថុនេះ និងវត្ថុនេះ ចំណែកប្តីរបស់ស្រីនោះ ក៏ធ្វើកិច្ចដែលគួរធ្វើដល់ឈ្មួញនោះ ។

ក្នុងពេលល្ងាច ឈ្មួញនោះអង្គុយលើទីដេកសួរថា សម្លាញ់ អ្នកត្រាច់ទៅត្រង់ជើងភ្នំ ធ្លាប់ឃើញអ្វីច្រើន បុរសម្ចាស់ផ្ទះពោលថា ខ្ញុំមិនបានឃើញអ្វីដទៃ ឃើញតែដើមឈើប្រភេទនេះ ដែលមានមែកពណ៌ក្រហមច្រើន ឈ្មួញពោលថា ដើមឈើប្រភេទនេះមានច្រើនឬ ម្ចាស់ទីកន្លែងពោលថា មានច្រើន ឈ្មួញពោលថា បើដូច្នោះ ចូរអ្នកបង្ហាញដើមឈើនោះដល់ខ្ញុំ ដូច្នេះហើយ ទៅជាមួយបុរសនោះ កាប់ចន្ទន៍ក្រហមផ្ទុកពេញរទេះ ៥០០ ហើយ ។ កាលធ្វើដំណើរមកពោលនឹងបុរសនោះថា សម្លាញ់ ផ្ទះរបស់ខ្ញុំនៅក្នុងទីឈ្មោះនោះ ក្នុងក្រុងពារាណសី អ្នកគប្បីមកកាន់សម្លាក់របស់ខ្ញុំ សព្វកាល តាមកាល ខ្ញុំមិនត្រូវការដោយគ្រឿងបណ្ណាការដទៃ អ្នកគប្បីនាំមកចំពោះតែដើមឈើមានមែកក្រហមប៉ុណ្ណោះ កាលបុរសនោះទទួលថា សាធុហើយ កាលមកកាន់

សម្ងាញ់របស់ឈ្មួញនោះ សព្វកាល តាមកាល រមែងនាំមកតែដើមចន្ទន៍ ក្រហមប៉ុណ្ណោះ សូម្បីឈ្មួញនោះ ក៏ឲ្យទ្រព្យច្រើនដល់បុរសនោះ ។

សម័យដទៃក្រោយមក កាលព្រះកស្សបទសពលបរិនិព្វានហើយ កាលព្រះស្តូបមាស គេបានប្រតិស្ឋានហើយ បុរសនោះ បានផ្ទុកចន្ទន៍ក្រហមជាច្រើន ទៅកាន់ក្រុងពារាណសី ។

កាលនោះ ឈ្មួញនោះជាសម្ងាញ់របស់បុរសនោះ ឲ្យបុកដើមចន្ទន៍ជាច្រើនជាក់ពេញថាសហើយពោលថា សម្ងាញ់ ចូរមកពួកយើងទៅកាន់ទីសាងចេតិយ ទម្រាំបាយឆ្អិនសឹមត្រឡប់ បាននាំបុរសនោះទៅក្នុងទីនោះ ធ្វើការបូជាដោយលម្អិតចន្ទន៍ហើយ ។

សម្ងាញ់អ្នកបច្ចន្តជនបទរបស់បុរសនោះ បានសាងមណ្ឌលនៃព្រះចន្ទដោយខ្វឹមចន្ទន៍ ក្នុងបន្ទប់នៃចេតិយ បុព្វកម្មរបស់គាត់មានប្រមាណប៉ុណ្ណោះ ។

បុរសនោះចុតិអំពីអត្តភាពនោះហើយ កើតក្នុងទេវលោក ញុំាងពុទ្ធន្តរមួយឲ្យអស់ហើយក្នុងទេវលោកនោះ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណមហាសាលក្នុងក្រុងរាជគ្រឹះ ។ រស្មីដូចគ្នានឹងមណ្ឌលព្រះចន្ទ តាំងទ្បើងអំពីផ្ទៃរបស់កុមារនោះ ព្រោះហេតុនោះ ទើបពួកញាតិជាក់ឈ្មោះថា ចន្ទាកៈ បានឮថា នុ៎ះជាផលនៃការធ្វើមណ្ឌលនៃព្រះចន្ទក្នុងព្រះចេតិយរបស់បុរសនោះ ។

ព្រាហ្មណ៍ទាំងទ្បាយគិតថា ពួកយើងអាចនាំយកព្រាហ្មណ៍នេះទៅរកស៊ីក្នុងលោកបាន ដូច្នេះហើយ ឲ្យគាត់អង្គុយលើយានតូច ដើរប្រកាសថា អ្នក

ណាយកដៃស្ទាបសរីរៈរបស់ចន្ទាកព្រាហ្មណ៍នេះ បុគ្គលនោះនឹងបានឥស្សរិយ-
សម្បត្តិបែបនេះ ។ មនុស្សទាំងឡាយឲ្យទ្រព្យមួយរយខ្លះ មួយពាន់ខ្លះ មួយ
សែនខ្លះនោះឯង ទើបបានយកដៃស្ទាបសរីរៈរបស់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍
ទាំងនោះត្រាច់ទៅរឿយៗ យ៉ាងនេះ ដល់ក្រុងសាវត្ថីដោយលំដាប់ កាន់យក
ទីសម្រាកត្រង់ចន្លោះនគរ និងវត្តជេតពនហើយ ។

អរិយសាវកប្រមាណ ៥ កោដិ ក្នុងក្រុងសាវត្ថីថ្វាយទានក្នុងកាលមុន
នៃភត្តហើយ ក្នុងកាលក្រោយភត្ត មានដៃកាន់គ្រឿងក្រអូប និងកម្រងផ្កា
សំពត់ និងកេសជ្ជៈជាដើម ដើម្បីទៅស្តាប់ធម៌ ។ ព្រាហ្មណ៍ទាំងឡាយឃើញ
អរិយសាវកទាំងនោះហើយ សួរថា អ្នកទាំងឡាយនាំគ្នាទៅណា អរិយសាវក
ពោលថា ពួកយើងទៅកាន់សម្នាក់របស់ព្រះសាស្តាដើម្បីស្តាប់ធម៌ ។ ពួក
ព្រាហ្មណ៍ពោលថា មកអ្នកទាំងឡាយ អ្នកទៅក្នុងទីនោះហើយ នឹងធ្វើអ្វី
អានុភាពដូចគ្នានឹងអានុភាពរបស់ចន្ទាកព្រាហ្មណ៍នៃពួកខ្ញុំ មិនមាន ព្រោះថា
ជនទាំងឡាយស្ទាបសរីរៈរបស់ចន្ទាកព្រាហ្មណ៍នោះ រមែងបានសម្បត្តិឈ្មោះ
នេះ ចូរអ្នកទាំងឡាយមក ចូរមើលចន្ទាកព្រាហ្មណ៍នោះ ។

អរិយសាវកទាំងនោះពោលថា ឈ្មោះថាអានុភាពរបស់ចន្ទាកព្រាហ្មណ៍
របស់អ្នកទាំងឡាយដូចម្តេច ព្រះសាស្តារបស់ពួកយើងប៉ុណ្ណោះមានអានុភាព
ច្រើន ។ អរិយសាវក និងពួកព្រាហ្មណ៍ទាំងនោះ មិនអាចញុំាងគ្នានិងគ្នាឲ្យ
យល់ព្រមបាន ទើបពោលថា ពួកយើងទៅវិហារហើយនឹងដឹងអានុភាពរបស់
ចន្ទាកព្រាហ្មណ៍ ឬព្រះសាស្តារបស់ពួកយើង ដូច្នេះហើយ បាននាំចន្ទាក-

ព្រាហ្មណ៍នោះទៅកាន់វិហារហើយ ។

ព្រះសាស្តា កាលចន្ទាកព្រាហ្មណ៍នោះ ចូលទៅកាន់សម្នាក់របស់ព្រះអង្គ ទ្រង់បានធ្វើរស្មីដូចព្រះចន្ទឲ្យជាត់ទៅ ចន្ទាកព្រាហ្មណ៍នោះដូចគ្នានឹងក្អែកដែលនៅក្នុងកញ្ជើផេះ ក្នុងសម្នាក់របស់ព្រះសាស្តា ។

គ្រានោះ ទើបព្រាហ្មណ៍ទាំងឡាយ នាំគាត់ទៅក្នុងចំណែកម្ខាង រស្មីក៏មានដូចមុន ព្រាហ្មណ៍ក៏នាំមកកាន់សម្នាក់ព្រះសាស្តាទៀត រស្មីក៏ជាត់ទៅយ៉ាងនោះដូចគ្នា ចន្ទាកព្រាហ្មណ៍ទៅហើយយ៉ាងនោះអស់ ៣ ដង ឃើញរស្មីជាត់ទៅ ទើបគិតថា បុគ្គលនេះប្រហែលជាចេះមន្ត ធ្វើរស្មីឲ្យជាត់ទៅ ទើបទូលសួរព្រះសាស្តាថា ទ្រង់ចេះមន្តជាគ្រឿងជាត់ទៅនៃរស្មីឬហ្ន៎ ព្រះសាស្តាត្រាស់ថា អើ តថាគតចេះ ចន្ទាកៈទូលថា បើដូច្នោះ សូមទ្រង់ប្រទានដល់ខ្ញុំព្រះអង្គផង ព្រះសាស្តាត្រាស់ថា តថាគតមិនអាចឲ្យដល់បុគ្គលដែលមិនបួស ។ ចន្ទាកព្រាហ្មណ៍ពោលនឹងពួកព្រាហ្មណ៍ថា កាលខ្ញុំរៀនមន្តនោះហើយ ខ្ញុំនឹងជាបុគ្គលប្រសើរក្នុងជម្ពូទ្វីបទាំងមូល ចូរពួកអ្នករង់ចាំក្នុងទីនេះសិន ខ្ញុំនឹងបួសរៀនមន្ត ២-៣ ថ្ងៃប៉ុណ្ណោះ ។

គាត់ទូលសូមបព្វជ្ជានឹងព្រះសាស្តា បានឧបសម្បទាហើយ ។ គ្រានោះ ទើបព្រះសាស្តាត្រាស់ប្រាប់អាការ ៣២ ដល់ចន្ទាកភិក្ខុនោះ ព្រះថេរៈទូលសួរថា នេះជាអ្វី ព្រះសាស្តាត្រាស់ថា នេះជាបរិកម្មនៃមន្ត អ្នកគួរស្វាធ្យាយ ។ ពួកព្រាហ្មណ៍ មកក្នុងចន្លោះៗ ហើយសួរថា លោកម្ចាស់រៀនមន្តបានហើយឬ ព្រះចន្ទាកៈពោលថា នៅទេ អាត្មាកំពុងរៀន ។ លោកសម្រេចអរហត្តក្នុង

កាល ២-៣ ថ្ងៃប៉ុណ្ណោះ ក្នុងពេលដែលពួកព្រាហ្មណ៍មកសួរហើយពោលថា អ្នកទាំងឡាយទៅចុះ ឥឡូវនេះ អាត្មាជាបុគ្គលមានធម៌ជា គ្រឿងមិនទៅ ហើយ ។

ភិក្ខុទាំងឡាយក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុនេះពោលពាក្យមិនពិត រមែងព្យាករអរហត្តផល ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ចន្ទាភៈបុត្ររបស់តថាគតមានអាសវៈអស់ហើយ រមែងពោលតែពាក្យពិតប៉ុណ្ណោះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ចន្ទំវ វិមលំ សុទ្ធំ វិប្បសន្នមលាវិលំ
នន្ទិភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅបុគ្គលដែលមិនមានសេចក្តីសៅហ្មង ដូចព្រះចន្ទ្រាសចាកមន្ទិល ជាអ្នកបរិសុទ្ធ មានចិត្តថ្លា មិនកកស្អុក អស់សេចក្តីត្រេកអរក្នុងភពហើយនោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **វិមលំ** *បានដល់ រឿរហើយចាកមន្ទិល មានពពកជាដើម ។ បទថា* **សុទ្ធំ** *បានដល់ មិនមានឧបក្កិលេស ។*

បទថា **វិប្បសន្នំ** *បានដល់ មានចិត្តផូរផង់ហើយ ។ បទថា* **អនាវិលំ** *បានដល់ រឿរហើយចាកមន្ទិល មានកិលេសជាដើម ។*

បទថា **នន្ទិភវបរិក្ខីណំ** *សេចក្តីថា តថាគតហៅបុគ្គលដែលមានតណ្ហា*

ក្នុងភពទាំង ៣ អស់ហើយនោះថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះចង្ការកត្ថេរ ចប់

រឿង ព្រះសីវលិត្ថេរ

លំនាំដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យនៅក្រុងកុណ្ឌិកាលិយនគរ ប្រថាប់នៅក្នុងព្រៃ ឈ្មោះកុណ្ឌធាន ទ្រង់ប្រារព្ធព្រះសីវលិត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោមំ** *ជាដើម ។*

សេចក្តីពិស្តារថា សម័យមួយ ធីតារបស់កោលិយវង្ស ព្រះនាមថា សុប្បវាសា ព្រះនាងទ្រង់គភ៌អស់ ៧ ឆ្នាំ មានគភ៌វង្វេងអស់ ៧ ថ្ងៃ ត្រូវទុក្ខវេទនាដ៏ខ្លាំងក្លា ក្តៅក្រហាយពាល់ត្រូវហើយ ព្រះនាងអត់ធន់ក្នុងទុក្ខនោះដោយវិតក្ក ៣ គឺព្រះដ៏មានព្រះភាគអង្គណា ទ្រង់សម្តែងធម៌ដើម្បីលះទុក្ខនៃរូបនេះឯង ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹងឯងដោយប្រពៃហ្ន៎ ១ ព្រះសង្ឃសាវ័កណា បដិបត្តិដើម្បីលះទុក្ខនៃរូបនេះឯង ព្រះសង្ឃសាវ័កនោះរបស់ព្រះដ៏មានព្រះភាគអង្គនោះ ជាអ្នកបដិបត្តិល្អហើយហ្ន៎ ១ ទុក្ខបែបនេះ មិនមានក្នុងព្រះនិព្វានណា ព្រះនិព្វាននោះជាសុខហ្ន៎ ១ ដូច្នេះហើយ ព្រះនាងបញ្ជូន

ស្វាមីទៅកាន់សម្នាក់ព្រះសាស្តា កាលព្រះស្វាមីនោះ ក្រាបទូលនូវការថ្វាយ បង្គំដល់ព្រះសាស្តា តាមពាក្យរបស់ព្រះនាងហើយ ក្នុងខណៈដែលព្រះដ៏មាន ព្រះភាគត្រាស់ថា ព្រះធីតាកោលិយវង្ស ព្រះនាមសុប្បវាសា ចូរមាន សេចក្តីសុខ កុំបីមានរោគ ប្រសូតឱរសដោយមិនមានរោគចុះ ដូច្នេះនោះឯង ជាអ្នកសប្បាយ ប្រាសចាករោគ ប្រសូតព្រះឱរសមិនមានរោគហើយ ព្រះ នាងនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយបានថ្វាយមហាទានអស់ ៧ ថ្ងៃ ។

ឱរសរបស់ព្រះនាងកាន់យកធម្មក្រក ត្រងទឹកថ្វាយសង្ឃបាន ចាប់តាំង ពីថ្ងៃដែលកើតហើយ ។ ក្នុងកាលតមក ព្រះឱរសនោះ ចេញបព្វជ្ជាហើយ សម្រេចអរហត្ត ។

ថ្ងៃមួយ ពួកភិក្ខុសនូនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ចូរពួកលោកមើល ភិក្ខុដល់ព្រមដោយឧបនិស្សយនៃអរហត្តបែបនេះ គង់ សោយទុក្ខក្នុងផ្ទៃមាតាអស់កាលមានប្រមាណប៉ុណ្ណេះ នឹងពោលថ្វីដល់ជន ដទៃ ទុក្ខជាច្រើនហ្នឹ ដែលភិក្ខុនេះដកចោលហើយ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់ មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្នឹ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគត ផុតទុក្ខប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ ធ្វើព្រះនិញានឲ្យជាក់ច្បាស់ហើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

យោមំ បលិបថំ ទុគ្គំ សំសារំ មោហមច្ចគា
តិណ្ណោ ចារគតោ ឈាយី អនេជោ អកថង្កថី
អនុបាទាយ និព្ពុតោ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា កន្លងផ្លូវវាង គឺរាគៈ និងកក់ ដែលគេឆ្លងបានដោយកម្រ គឺកិលេស និងសង្សារវដ្ត និងមោហៈទាំងនេះបាន ជាអ្នកឆ្លងអន្ទង់ទាំង ៤ បាន ដល់ត្រើយ គឺព្រះនិព្វាន ជាអ្នកមានឈាន មិនញាប់ញ័រដោយតណ្ហា មិនមានសេចក្តីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះដូច្នេះថា ភិក្ខុណាកន្លងនូវផ្លូវ គឺរាគៈ កក់ គឺកិលេស សង្សារវដ្ត និងមោហៈ ដែលមិនឲ្យចាក់ផ្ទុះអរិយសច្ច ៤ នេះទៅហើយ ជាអ្នកឆ្លងឱឃៈទាំង ៤ បាន ដល់ត្រើយហើយដោយលំដាប់ មានប្រក្រតីសម្ងឹងឈាន ២ យ៉ាង ឈ្មោះថា មិនមានកិលេសជាគ្រឿងញាប់ញ័រ ព្រោះមិនមានតណ្ហា ។ ឈ្មោះថា មិនមានសេចក្តីសង្ស័យជាហេតុនឹងពោលបាន ព្រោះមិនមានវាចាដើម្បីពោលថាដូចម្តេច ឈ្មោះថា មិនប្រកាន់មាំហើយ ព្រោះមិនមានឧបាទាន ឈ្មោះថា រម្ងាប់ហើយ ព្រោះការរលត់ទៅនៃកិលេស តថាគតហៅភិក្ខុនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

រឿង ព្រះសីវលិត្ថេរ ចប់

រឿង ព្រះសុន្ទរសមុទ្ទត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសុន្ទរសមុទ្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោធ កាមេ** ជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថី កុលបុត្រម្នាក់ឈ្មោះសុន្ទរសមុទ្ទកុមារ កើតក្នុងត្រកូលធំ មានសម្បត្តិ ៤០ កោដិ ។

ថ្ងៃមួយ ឃើញមហាជន មានគ្រឿងក្រអូប និងកម្រងផ្កាក្នុងដៃជាដើម ទៅកាន់វត្តជេតពនដើម្បីស្តាប់ធម៌ ក្នុងកាលខាងក្រោយភត្ត ទើបសួរថា ពួកលោកនាំគ្នាទៅណា កាលមហាជនទាំងនោះប្រាប់ថា ពួកយើងទៅកាន់សម្នាក់ព្រះសាស្តា ដើម្បីប្រយោជន៍ដល់ការស្តាប់ធម៌ ក៏ពោលថា ខ្ញុំក៏ទៅដែរ ហើយទៅជាមួយនឹងមហាជនទាំងនោះ អង្គុយខាងចុងបរិស័ទ ។

ព្រះសាស្តាទ្រង់ជ្រាបអាធ្យាស្រ័យរបស់កុមារ ទើបទ្រង់សម្តែងអនុបុព្វី-កថា កុមារគិតថា បុគ្គលដែលគ្រប់គ្រងផ្ទះ មិនអាចប្រព្រឹត្តព្រហ្មចរិយៈឲ្យដូចជាសង្ខ៍ដែលគេខាត់ហើយបាន អាស្រ័យកថារបស់ព្រះសាស្តា មានឧស្សាហៈ

កើតហើយក្នុងបព្វជ្ជា កាលបរិស័ទចៀសចេញទៅហើយ ទើបទូលសូមបព្វជ្ជានឹងព្រះសាស្តា លុះបានឮថា ព្រះតថាគតទាំងឡាយមិនឲ្យកុលបុត្រដែលមាតាបិតាមិនទាន់អនុញ្ញាតបួស ទើបចូលទៅកាន់ផ្ទះ ញុាំងមាតាបិតាឲ្យអនុញ្ញាតដោយសេចក្តីព្យាយាមច្រើន ដូចកុលបុត្រឈ្មោះរដ្ឋបាលជាដើម បានបព្វជ្ជាឧបសម្បទាក្នុងសម្នាក់ព្រះសាស្តាហើយ គិតថា ប្រយោជន៍អ្វីរបស់អញដោយការនៅក្នុងទីនេះ ទើបចេញអំពីក្រុងសាវត្ថី ទៅកាន់ក្រុងរាជគ្រឹះ ត្រាច់បិណ្ឌបាត ញុាំងកាលឲ្យកន្លងទៅហើយ ។

ថ្ងៃមួយ មាតាបិតារបស់ព្រះសុន្ទរសមុទ្ទត្ថេរនោះ ឃើញពួកកុមារដែលជាសម្ងាញ់របស់លោក កំពុងលេងដោយសិរីសម្បត្តិដ៏ធំ ក្នុងថ្ងៃមហោស្រពមួយក្នុងក្រុងសាវត្ថី ឃំរៀបរាប់ថា ការលេងនេះ កូនរបស់អញបានដោយលំបាក ។

ក្នុងខណៈនោះ ស្រីពេស្យាម្នាក់ទៅកាន់ត្រកូលនោះ ឃើញមាតារបស់ព្រះសុន្ទរសមុទ្ទត្ថេរនោះកំពុងអង្គុយយំ ទើបសួរថា បពិត្រអ្នកម៉ែ ព្រោះហេតុអ្វីទើបអ្នកម៉ែយំ ម្តាយរបស់ព្រះសុន្ទរសមុទ្ទត្ថេរពោលថា ខ្ញុំនឹកដល់កូនទើបយំ ស្រីពេស្យាពោលថា កូននោះនៅឯណា ស្រីនោះពោលថា បួសក្នុងសម្នាក់ភិក្ខុទាំងឡាយ ស្រីពេស្យាពោលថា បើឲ្យលោកសឹកមិនគួរឬ មាតាព្រះសុន្ទរសមុទ្ទត្ថេរនោះពោលថា គួរ តែលោកមិនជ្រាបថាសឹក លោកចេញអំពីក្រុងសាវត្ថីនេះ ទៅកាន់ក្រុងរាជគ្រឹះ ។ ស្រីពេស្យាពោលថា បើខ្ញុំឲ្យលោកសឹកបាន អ្នកម៉ែគប្បីធ្វើដូចម្តេចដល់ខ្ញុំ មាតាព្រះសុន្ទរសមុទ្ទត្ថេរនោះពោលថា

ខ្ញុំគប្បីឲ្យនាងជាម្ចាស់នៃទ្រព្យរបស់ត្រកូលនេះ ស្រីពេស្សាពោលថា បើដូច្នោះ សូមអ្នកម៉ែឲ្យឈ្នួលដល់ខ្ញុំ កាន់យកឈ្នួលហើយ ទៅកាន់ក្រុងរាជគ្រឹះដោយបរិវារធំ កំណត់វិថីដែលលោកត្រាច់បិណ្ឌបាតបានហើយ កាន់យកផ្ទះដែលជាទីសម្រាកមួយក្នុងទីនោះ ។ តាក់តែងអាហារដ៏ប្រណីតអំពីព្រលឹម ហើយថ្វាយភិក្ខា ក្នុងពេលព្រះថេរៈចូលទៅបិណ្ឌបាត ដោយកាលកន្លងទៅ ២-៣ ថ្ងៃ នាងក៏និមន្តថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់គង់ក្នុងទីនេះឯង ធ្វើភត្តកិច្ច ហើយទទួលយកបាត្រ លោកឲ្យបាត្រហើយ ។

គ្រានោះ ស្រីពេស្សានោះអង្គាសព្រះថេរៈដោយអាហារដ៏ប្រណីត ជ្រាប់ថា បពិត្រលោកម្ចាស់ ការត្រាច់បិណ្ឌបាតក្នុងទីនេះឯងងាយស្រួលល្អ និមន្តឲ្យព្រះថេរៈគង់ធាន់ត្រង់យ៉ាមុខ ២-៣ ថ្ងៃហើយ យកនំលួងលោមពួកក្មេងហើយពោលថា ពួកឯងចូរមកក្នុងពេលដែលព្រះថេរៈមកហើយ សូម្បីខ្ញុំហាម ឯងគប្បីមកក្នុងទីនេះ ហើយជាចជូលីឲ្យហុយឡើង ។

ស្អែកឡើង ពេលព្រះថេរៈធាន់ ពួកក្មេងទាំងនោះ សូម្បីត្រូវស្រីនោះឃាត់ ក៏នៅតែជាចជីឲ្យហុយឡើង ។

ស្អែកឡើង ស្រីពេស្សាជ្រាប់ថា ពួកក្មេងសូម្បីខ្ញុំឃាត់ក៏មិនស្តាប់ពាក្យរបស់ខ្ញុំ នៅតែជាចជីនោះឲ្យហុយឡើងក្នុងទីនេះបាន សូមលោកម្ចាស់គង់ខាងក្នុងផ្ទះចុះ ឲ្យលោកគង់ខាងក្នុងហើយ និមន្តឲ្យធាន់ ២-៣ ថ្ងៃ នាងប្រមូលក្មេងមកទៀតពោលថា ពួកឯងសូម្បីខ្ញុំឃាត់ គប្បីធ្វើសំឡេងអឺងកងក្នុងពេលដែលព្រះថេរៈធាន់ ក្មេងទាំងនោះធ្វើយ៉ាងនោះហើយ ។

ស្អែកឡើងនាងពោលថា បពិត្រលោកម្ចាស់ ក្នុងទីនេះសំឡេងអឺងកងពន់ពេក ពួកក្មេងសូម្បីខ្ញុំហាម ក៏មិនស្តាប់ពាក្យរបស់ខ្ញុំ សូមលោកម្ចាស់គង់ក្នុងប្រាសាទខាងលើចុះ ។ កាលព្រះថេរៈទទួលនិមន្តហើយ ធ្វើព្រះថេរៈទុកខាងមុខ កាលឡើងទៅកាន់ប្រាសាទ បិទទ្វារទាំងឡាយបណ្តើរៗ ឡើងទៅកាន់ប្រាសាទ ។

ព្រះថេរៈ សូម្បីជាអ្នកត្រាច់បិណ្ឌបាតតាមលំដាប់ច្រកជាវត្តយ៉ាងឧក្រិដ្ឋ ត្រូវចំណង់ក្នុងរសចងហើយ ទើបឡើងទៅកាន់ប្រាសាទជាន់ទី ៧ តាមពាក្យរបស់នាង ។

នាងឲ្យព្រះថេរៈគង់ហើយ សម្តែងមាយារបស់ស្រី លីលារបស់ស្រីដែលមកហើយយ៉ាងនេះថា ធ្វើមុខឲ្យស្រស់ថ្លា បានឮថា ស្រីរមែងទាក់បុរសដោយហានៈ ៤០ គឺកាច់រាង ១ បន្ទន់ខ្លួន ១ កែក្រាយ ១ ក្រអឹមក្រអៀម ១ យកក្រចកផ្ចាត់ក្រចក ១ យកជើងជាន់ជើង ១ យកកំណាត់ឈើគូសផែនដី ១ លើកកូនក្មេងដោយខ្លួនឯង ១ ឲ្យកូនក្មេងលើកខ្លួនវិញ ១ លេងកូនក្មេងដោយខ្លួនឯង ១ ញ៉ាំងកូនក្មេងឲ្យលេង ១ ថើបកូនក្មេងដោយខ្លួនឯង ១ ញ៉ាំងកូនក្មេងឲ្យថើបវិញ ១ សុំខ្លួនឯង ១ ញ៉ាំងកូនក្មេងឲ្យសុំ ១ ឲ្យវត្ថុទៅកូនក្មេង ១ សុំលួងលោមយកមកវិញ ១ ធ្វើត្រាប់តាមក្មេងដែលវាធ្វើ ១ និយាយខ្ចាំង ១ និយាយតិច ១ និយាយបើកចំហមាត់ ១ និយាយលាក់លៀម ១ ធ្វើនូវនិមិត្តដោយការរាំ ច្រៀង ប្រគំ យំរាប់រៀប ម្ជុកម្ជាក់ ស្អិតស្អាង ១ សើចភ្នាកភ្នាយ ១ សម្ងីងសម្ងក់ ១ ញាក់ចង្កេះ ១ ញ៉ាំងទ្រព្យ

កំបាំងឲ្យកម្រើក ១ បើកបង្ហាញក្លៀ ១ បិទក្លៀទៅវិញ ១ បង្ហាញដោះ ១ បង្ហាញក្លៀក ១ បង្ហាញផ្ចិត ១ មិចភ្នែក ១ ញាក់ចញ្ចើម ១ ខាំបបូរមាត់ ១ លៀនអណ្តាត ១ ច្បូតសំពត់ ១ ស្លៀកសំពត់វិញ ១ រំសាយសក់ ១ បួងសក់វិញ ១ ឈរខាងមុខព្រះថេរៈនោះហើយ ពោលគាថានេះថា

> ស្រីពេស្យា មានជើងជ្រលក់ហើយដោយទឹកលក្ខ ពាក់ទ្រនាប់ជើង ពោលថា លោកម្ចាស់ជាកំលោះសម្រាប់ខ្ញុំ សូម្បីខ្ញុំជាក្រមុំសម្រាប់លោកម្ចាស់ សូម្បីយើងទាំងពីរចាស់ហើយ មានឈើច្រត់ចោះទៅខាងមុខហើយ សឹមបួស ។

គ្រានោះ មហាសង្វេគកើតដល់ព្រះថេរៈថា ឱហ្ន៎ កម្មដែលអញមិនពិចារណាហើយធ្វើ ធ្ងន់ហ្ន៎ ខណៈនោះ ព្រះសាស្តាប្រថាប់គង់ក្នុងវត្តជេតពន ចម្ងាយ ៤៥ យោជន៍នោះឯង ទ្រង់ឃើញហេតុនោះហើយ ទើបធ្វើការញញឹមឲ្យប្រាកដ ។

លំដាប់នោះ ព្រះអានន្ទត្ថេរទូលសួរថា បពិត្រព្រះអង្គ អ្វីហ្ន៎ ជាហេតុ អ្វីហ្ន៎ ជាបច្ច័យនៃការធ្វើញញឹមឲ្យប្រាកដ ព្រះសាស្តាត្រាស់ អានន្ទ សង្គ្រាមរបស់កិកុឈ្មោះសុន្ទរសមុទ្ទ និងស្រីផ្កាមាសកំពុងប្រព្រឹត្តទៅលើប្រាសាទ ៧ ជាន់ ក្នុងក្រុងរាជគ្រឹះ ព្រះអានន្ទទូលសួរថា បពិត្រព្រះអង្គ ជ័យជម្នះនឹងមានដល់អ្នកណា បរាជ័យនឹងមានដល់អ្នកណា ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ការឈ្នះនឹងមានដល់សុន្ទរសមុទ្ទ ការចាញ់នឹងមានដល់ស្រីផ្កាមាសដូច្នេះហើយ ទ្រង់ប្រកាសការឈ្នះរបស់ព្រះថេរៈ ប្រថាប់គង់ក្នុងវត្តជេតពន

នោះឯង ទ្រង់ផ្សាយព្រះវស្សីទៅត្រាស់ថា ម្នាលភិក្ខុ ចូរអ្នកអស់អាល័យ លះនូវកាមទាំងពីរចេញ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

យោធ កាមេ បហន្ត្វាន អនាគារោ បរិព្វជេ
កាមភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ក្នុងលោកនេះ បានលះបង់កាមទាំងឡាយ ជាអ្នកមិនមានផ្ទះ គេចចេញចាកកាមបាន តថាគតហៅបុគ្គលនោះ ដែលអស់កាមភពហើយ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះដូច្នេះថា បុគ្គលណា លះកាមទាំងពីរក្នុងលោកនេះហើយ ជាអ្នកមិនមានផ្ទះ វៀរចេញបានហើយ តថាគតហៅបុគ្គលនោះ ដែលមានកាមអស់ហើយ និងមានភពអស់ហើយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ព្រះថេរៈសម្រេចអរហត្ត ហោះទៅក្នុងអាកាស ដោយកម្លាំងនៃឫទ្ធិ ទម្លុះមណ្ឌលហោជាងចេញទៅហើយ សរសើរព្រះសរីរៈរបស់ព្រះសាស្តានោះឯង មកថ្វាយបង្គំព្រះសាស្តាហើយ ។

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ព្រះសុន្ទរសមុទ្តេរ អាស្រ័យរសដែលគប្បីដឹងដោយអណ្តាត ស្ទើរនឹងពូចការណ៍តែព្រះសាស្តាជាទីពឹងរបស់លោក ។

ព្រះសាស្តា ទ្រង់ស្តាប់កថានោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាទីពឹងរបស់សុន្ទរសមុទ្តនោះ តែក្នុងឥឡូវនេះ ក៏មិនមែន សូម្បីក្នុង

កាលមុន តថាគតក៏ជាទីពឹងរបស់សុន្ធរសមុទ្ទនោះ ដែលជាប់ក្នុងរសតណ្ហា ហើយដូចគ្នា កាលភិក្ខុទាំងនោះអារាធនាហើយ ទ្រង់នាំអតីតនិទានមកដើម្បីប្រកាសសេចក្តីនោះ ទ្រង់ញុំាងវាតមិគជាតកឲ្យពិស្តារថា

ឆន្ទរាគៈដោយអាវាសទាំងឡាយ ឬដោយការស្និទ្ធស្នាលទាំងឡាយ ជាសភាវៈលាមកជាងឆន្ទរាគៈ ដោយរសទាំងឡាយ មិនមានទេ ឧយ្យានបាលឈ្មោះសញ្ជ័យ បាននាំសត្វឈ្លូសដែលអាស្រ័យនៅ ព្រៃស្បាត មកកាន់អំណាច (របស់ខ្លួន) បាន ព្រោះតែរសទាំងឡាយ ។

ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ម្រឹគស្នាន់ក្នុងកាលណោះ បានមកជាសុន្ធរសមុទ្ទ ចំណែកមហាមាត្យរបស់ព្រះរាជា ដែលពោលគាថានេះហើយ បានដោះលែងម្រឹគនោះទៅ គឺតថាគតនេះឯង ។

រឿង ព្រះសុន្ធរសមុទ្ទត្ថេរ ចប់

-ក្នុងបិដកខ្មែរថា ព្រះរាជាជាអ្នកពោល ។

រឿង ព្រះជោតិកត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះជោតិកត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោធ តណ្ហំ** ជាដើម ។

អនុពួកថាក្នុងរឿងនោះ មានដូចតទៅនេះ ក្នុងអតីតកាល កុដុម្ពិកៈ ២ នាក់បងប្អូនក្នុងក្រុងពារាណសី ញ៉ាំងជនឲ្យធ្វើចម្ការអំពៅជាច្រើន ។ ថ្ងៃមួយ ប្អូនប្រុសទៅចម្ការអំពៅ គិតថា អញនឹងឲ្យអំពៅមួយដើមដល់បងប្រុសមួយដើមជារបស់អញ ហើយចងអំពៅទាំងពីរក្នុងទីដែលកាប់ហើយ ដើម្បីកុំឲ្យរសហូរចេញ កាន់យកហើយ ។

បានឮថា ក្នុងកាលណោះ កិច្ចដោយការគាបអំពៅដោយគ្រឿងយន្ត មិនមាន ក្នុងពេលអំពៅដែលគេកាត់ត្រង់ចុង ឬគល់ហើយលើកឡើង រសរមែងហូរចេញឯង ដូចទឹកហូរចេញអំពីធម្មក្រក ដូច្នោះ ។ ក្នុងពេលដែលបុរសនោះកាន់អំពៅអំពីចម្ការដើរមក ព្រះបច្ចេកពុទ្ធនៅត្រង់ភ្នំគន្ធមាទន៍ ចេញអំពីសមាបត្តិហើយ ពិចារណាថា ថ្ងៃនេះ អាត្មានឹងធ្វើការអនុគ្រោះដល់អ្នកណាហ្ន៎ ឃើញបុរសនោះនៅក្នុងសំណាញ់ញាណ និងជ្រាបភាពដែលបុរសនោះ ជាអ្នកអាចធ្វើការសង្គ្រោះបាន ទើបកាន់យកបាត្រ និងចីវរ ហើយមកដោយឫទ្ធិ ឈរអំពីខាងមុខបុរសនោះ ។

បុរសនោះឃើញព្រះបច្ចេកពុទ្ធ មានចិត្តជ្រះថ្លា ទើបលាសំពត់ដណ្តប់លើប្រទេសដែលខ្ពស់ជាង ហើយនិមន្តឲ្យព្រះបច្ចេកពុទ្ធគង់ដោយពាក្យថា សូមនិមន្តគង់ទីនេះចុះ សូមលោកម្ចាស់បង្អោនបាត្រមកចុះ បានស្រាយចំណង

ដែលចងអំពៅ ដាក់លើបាត្រ រសហូរចេញពេញបាត្រហើយ កាលព្រះបច្ចេកពុទ្ធធាន់រសនោះហើយ គាត់គិតថា ល្អហ្ន៉ៃ លោកម្ចាស់របស់អញធាន់រស បើបងប្រុសរបស់អញទារតម្លៃ អញនឹងឲ្យតម្លៃ បើឲ្យអញនាំចំណែកបុណ្យមក អញនឹងឲ្យចំណែកបុណ្យ ហើយពោលថា សូមលោកម្ចាស់បង្អោនបាត្រមកចុះ ហើយ ស្រាយអំពៅ ដើមទី ២ ប្រគេនរស ។

បុរសនោះគិតកន្ទងមានប្រមាណប៉ុណ្ណោះថា បងប្រុសរបស់អញនឹងនាំអំពៅដទៃអំពីចម្ការមកទំពាស៊ី ។ ចំណែកព្រះបច្ចេកពុទ្ធ ប្រាថ្នានឹងចែករសនោះដល់ព្រះបច្ចេកពុទ្ធដទៃ ព្រោះលោកធាន់រសអំពៅដើមដំបូងនោះ ទើបទទួលប៉ុណ្ណោះ ហើយគង់ស្ងៀម ។ បុរសនោះ ជ្រាបអាការរបស់លោកហើយ ទើបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន តាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ រសដ៏ប្រសើរនេះ ដែលខ្ញុំថ្វាយហើយ ដោយផលនៃរសដ៏ប្រសើរនេះ ខ្ញុំគប្បីសោយសម្បត្តិក្នុងទេវលោក និងមនុស្សលោក ក្នុងទីបំផុតគប្បីសម្រេចធម៌ ដែលលោកម្ចាស់សម្រេចហើយនោះឯង ។ ព្រះបច្ចេកពុទ្ធក៏ពោលថា សេចក្តីប្រាថ្នាដែលអ្នកតម្កល់ទុកហើយ ចូរសម្រេចយ៉ាងនោះ ហើយធ្វើអនុមោទនាដោយគាថា ២ ថា **ឥច្ឆិតំ បត្ថិតំ តុយ្ហំ** ជាដើម ហើយអធិដ្ឋានដោយអាការដែលបុរសនោះឃើញបាន ហោះទៅកាន់ភ្នំគន្ធមាទន៍តាមអាកាស ហើយបានប្រគេនរសអំពៅដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ បុរសនោះឃើញបាដិហារ្យនោះហើយ ទៅកាន់សម្នាក់បងប្រុស កាលបងប្រុសសួរថា ឯងទៅណា ទើបប្រាប់ថា ខ្ញុំទៅមើលចម្ការអំពៅ ត្រូវបងប្រុសពោលថា ប្រយោជន៍អ្វីដោយ

បុគ្គលដូចឯងទៅចម្ការអំពៅ ឯងគួរកាន់យកអំពៅមួយដើម ឬពីរដើមមក មិនមែនឬ ក៏ឆ្លើយថា ខ្ញុំកាន់យកមកពីរដើម តែខ្ញុំឃើញព្រះបច្ចេកពុទ្ធមួយអង្គ ទើបប្រគេនអំពៅរបស់ខ្ញុំ ហើយប្រគេនទាំងអំពៅរបស់បង ដោយគិតថា អញនឹងឲ្យតម្លៃ ឬចំណែកបុណ្យ តែបងទទួលយកតម្លៃ ឬចំណែកបុណ្យ បងប្រុសពោលថា ព្រះបច្ចេកពុទ្ធធ្វើដូចម្តេច ប្អូនប្រុសពោលថា លោកធាន់រសអំពៅខ្ញុំហើយ ក៏កាន់យករសអំពៅរបស់បង ទៅកាន់ក្នុងគន្ធមាទន៍តាមអាកាស ហើយចែកដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ។

បងប្រុសនោះ កាលប្អូនកំពុងពោលនោះឯង មានសរីរៈដែលបីតិពាល់ត្រូវហើយ មិនមានចន្លោះ បានធ្វើសេចក្តីជ្រាបថា ការសម្រេចធម៌ដែលព្រះបច្ចេកពុទ្ធនោះឃើញហើយនោះឯង គប្បីមានដល់អញ ប្អូនប្រុសជ្រាបថាសម្បត្តិ ៣ យ៉ាង បងប្រុសជ្រាបថាអរហត្ត ដោយប្រការដូច្នេះ នេះជាបុព្វកម្មរបស់ជនទាំងពីរ ។

ជនទាំងពីរនោះ តាំងនៅដល់អស់អាយុហើយ ចុតិចាកអត្តភាពនោះ កើតក្នុងទេវលោក ញុំាងពុទ្ធន្តរមួយឲ្យអស់ទៅ ក្នុងវេលាជនទាំងពីរនោះ ទៅកាន់ទេវលោកនោះឯង ព្រះសម្មាសម្ពុទ្ធព្រះនាមវិបស្សី កើតឡើងហើយក្នុងលោក ។

បងប្អូនទាំងពីរនោះ ឃ្លាតចាកទេវលោកហើយ បងប្រុសនៅតែជាបងប្រុស ប្អូនប្រុសនៅតែជាប្អូនប្រុស បដិសន្ធិក្នុងត្រកូលមួយនាពន្ធុមតីនគរ ។

បណ្តាក្មេងទាំងពីរនោះ មាតាបិតាបានដាក់ឈ្មោះកូនច្បងថា សេនៈ ប្អូន

ថា អបរាជិតៈ ។ កាលបងប្អូនទាំងពីរកំពុងប្រមូលកំណប់ទ្រព្យ ក្នុងវេលាធំហើយ សេនកុដុម្ភិកៈ បានស្តាប់សេចក្តីប្រកាសក្នុងពន្ធុមតីនគរ របស់ឧបាសកដែលឃោសនាថា ពុទ្ធរ័តន៍កើតឡើងហើយក្នុងលោក ធម្មរ័តន៍កើតឡើងហើយ ក្នុងលោក សង្ឃរ័តន៍កើតឡើងហើយ ក្នុងលោក ចូរពួកអ្នកឲ្យទាន ចូរធ្វើបុណ្យទាំងឡាយ ថ្ងៃនេះជាថ្ងៃតិថីទី ១៤ ថ្ងៃនេះជាតិថីទី ១៥ ចូរពួកអ្នកធ្វើឧបោសថ ចូរស្តាប់ធម៌ ឃើញមហាជនថ្វាយទានក្នុងកាលមុនភត្តហើយ ទៅស្តាប់ធម៌ក្នុងកាលក្រោយភត្ត ទើបសួរថា ពួកអ្នកទៅណា កាលមហាជនប្រាប់ថា ពួកយើងទៅកាន់សម្នាក់ព្រះសាស្តា ដើម្បីស្តាប់ធម៌ ទើបពោលថា ខ្ញុំក៏នឹងទៅ ហើយទៅព្រមជាមួយជនទាំងនោះ អង្គុយខាងចុងបរិស័ទ ។

ព្រះសាស្តា ទ្រង់ជ្រាបអាធ្យាស្រ័យរបស់កុលបុត្រនោះ ទើបត្រាស់អនុបុព្វីកថា បុរសនោះស្តាប់ធម៌របស់ព្រះសាស្តាហើយ កើតឧស្សាហៈក្នុងបព្វជ្ជា ទើបទូលសូមបព្វជ្ជានឹងព្រះសាស្តា ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរថា ពួកញាតិដែលអ្នកគប្បីលាមានដែរឬទេ សេនកុដុម្ភិកៈពោលថា មានព្រះអង្គ ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ ចូរអ្នកទៅលាហើយសឹមមក ។

កុមារទៅកាន់សម្នាក់របស់ប្អូនប្រុសហើយពោលថា ទ្រព្យសម្បត្តិណាមានក្នុងត្រកូលនេះ ទ្រព្យសម្បត្តិទាំងអស់នោះ ចូរជារបស់ឯងចុះ ប្អូនប្រុសពោលថា ចុះបងវិញ សេនកុដុម្ភិកៈពោលថា ខ្ញុំនឹងបួសក្នុងសម្នាក់របស់ព្រះ

សាស្តា ប្អូនប្រុសពោលថា បងនិយាយអ្វី ខ្ញុំកាលមាតាស្លាប់ហើយ ក៏បានបងដូចជាមាតា កាលបិតាស្លាប់ហើយ ក៏បានបងដូចជាបិតា ត្រកូលនេះមានភោគៈច្រើន បងតាំងនៅក្នុងផ្ទះនេះឯងក៏អាចធ្វើបុណ្យបាន បងកុំធ្វើយ៉ាងនោះ សេនកុដុម្ពិកៈពោលថា ខ្ញុំស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តាហើយ ខ្ញុំតាំងនៅក្នុងកណ្តាលផ្ទះមិនអាចបំពេញធម៌នោះបាន ខ្ញុំនឹងបួសឲ្យបាន ចូរឯងត្រឡប់ចុះ ។ សេនៈញ្ញុាំងប្អូនប្រុសឲ្យត្រឡប់ដោយអាការយ៉ាងនោះហើយ បានចូលកាន់បព្វជ្ជាឧបសម្បទាក្នុងសម្នាក់ព្រះសាស្តាហើយ ក្នុងកាលមិនយូរប៉ុន្មានក៏សម្រេចអរហត្ត ។ ចំណែកប្អូនប្រុសគិតថា អញនឹងធ្វើសក្ការៈដល់បព្វជិតដែលជាបងប្រុស ទើបថ្វាយទានដល់ភិក្ខុសង្ឆ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ថ្វាយបង្គំបងប្រុសហើយពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ធ្វើនូវការរលាស់ចេញចាកភពនៃខ្លួនបានហើយ ចំណែកខ្ញុំ ជាអ្នកជាប់ជំពាក់ដោយកាមគុណ ៥ មិនអាចចេញបួសបាន សូមលោកម្ចាស់ប្រាប់បុញ្ញកម្មដ៏ធំដែលសមគួរដល់ខ្ញុំដែលតាំងនៅក្នុងផ្ទះនេះឯង ។ លំដាប់នោះ ព្រះថេរៈពោលនឹងប្អូនប្រុសនោះថា សាធុ ឯងជាបណ្ឌិត ចូរឯងសាងព្រះគន្ធកុដិ សម្រាប់ព្រះសាស្តាចុះ ។

ប្អូនប្រុសនោះទទួលថា សាធុ ហើយញ្ញុាំងជនឲ្យនាំឈើផ្សេងៗ មកហើយឲ្យចាំងដើម្បីប្រយោជន៍ដល់ទព្វសម្ភារៈទាំងឡាយ មានសសរជាដើម ឲ្យធ្វើសសរទាំងអស់ដាំដោយកែវ ៧ ប្រការ គឺមួយដើមដាំដោយមាស មួយដើមដាំដោយប្រាក់ មួយដើមដាំដោយកែវមណីជាដើម ហើយឲ្យសាងព្រះគន្ធកុដិ

ដោយសសរទាំងនោះ ឲ្យប្រក់ដោយក្បឿងសម្រាប់ប្រក់ រំលេចដោយកែវ ៧ ប្រការដូចគ្នា ។

ក្នុងពេលសាងព្រះគន្ធកុដិនោះឯង ក្ងួយប្រុសឈ្មោះអបរាជិតៈ ដែលមានឈ្មោះដូចខ្លួននោះឯង ចូលទៅរកអបរាជិតកុដុម្ពិកៈនោះហើយ ពោលថា ខ្ញុំនឹងសាង សូមលោកឲ្យចំណែកបុណ្យដល់ខ្ញុំចុះ បុរសនោះពោលថា នែបាខ្ញុំមិនឲ្យ ខ្ញុំនឹងសាងមិនឲ្យទូទៅដល់ជនដទៃ ។

ក្ងួយប្រុសនោះ អង្វរជាច្រើន កាលមិនបានចំណែកបុណ្យ ទើបគិតថា ការដែលអញបានកុញ្ជរសាលាខាងមុខព្រះគន្ធកុដិ គួរ ដូច្នេះហើយ ទើបសាងកុញ្ជរសាលាដែលសម្រេចដោយកែវ ៩ ប្រការ ។ បុរសនោះបានមកជាមេណ្ឌកសេដ្ឋី ក្នុងពុទ្ធុប្បាទកាលនេះ ។

ក្នុងបន្ទះបង្ហួចធំ ៣ បន្ទះដែលសម្រេចដោយកែវ ៧ ប្រការមានហើយក្នុងព្រះគន្ធកុដិ អបរាជិតគហបតី ឲ្យសាងស្រះបោក្ខរណី ៣ ដែលបូកលាបដោយបាយអាងក្រោម ត្រង់សន្ទះបង្ហួចទាំងនោះឲ្យពេញដោយគន្ធជាតិ ៤ យ៉ាង ហើយឲ្យដាំដើមផ្កាដែលមានពណ៌ ៥ ឲ្យសំយុងបណ្តាកែវ ៧ ប្រការ កែវដែលគួរដល់ការសំយុង បានកាន់យកកែវក្រៅអំពីនេះ ទាំងអស់នោះឯង រោយជុំវិញព្រះគន្ធកុដិ ស្មើក្បាលជង្គង់ ញ៉ាំងបរិវេណឲ្យពេញហើយ ។

គហបតីឈ្មោះអបរាជិតៈ ញ៉ាំងព្រះគន្ធកុដិឲ្យសម្រេច ដោយអាការយ៉ាងនេះហើយ ទើបចូលទៅរកព្រះថេរៈដែលជាបងប្រុសសាកសួរថា បពិត្រលោកម្ចាស់ ព្រះគន្ធកុដិសម្រេចហើយ ខ្ញុំទន្ទឹងការប្រើប្រាស់ព្រះគន្ធកុដិនោះ

បានឮថា បុណ្យជាច្រើនរមែងមានព្រោះការប្រើប្រាស់ ។

ព្រះថេរៈនោះ ចូលទៅគាល់ព្រះសាស្តាក្រាបទូលថា បពិត្រព្រះអង្គ បានឮថា កុដុម្ពិកៈនេះឲ្យសាងព្រះគន្ធកុដិដើម្បីព្រះអង្គ ឥឡូវនេះ កុដុម្ពិកៈនោះទន្ទឹងការប្រើប្រាស់ ។ ព្រះសាស្តាក្រោកចាកអាសនៈហើយ យាងទៅកាន់ទីចំពោះមុខព្រះគន្ធកុដិ ទតគំនរវតនៈដែលរោយជុំវិញព្រះគន្ធកុដិ បានប្រថាប់ឈរហើយត្រង់ខ្ទោងទ្វារ កាលកុដុម្ពិកៈនោះក្រាបទូលថា បពិត្រព្រះអង្គ ការរក្សាទីងមានដល់ខ្ញុំព្រះអង្គឯង សូមទ្រង់យាងចូលចុះ ព្រះសាស្តាបានយាងចូលហើយ ។

កុដុម្ពិកៈ ក៏តាំងការរក្សាដោយជុំវិញ បញ្ជាមនុស្សទាំងឡាយថា នែបាបុរពួកអ្នកហាមជនទាំងឡាយ ដែលកាន់យកវតនៈដោយថ្នក់ ឬដោយល្អីនិងស្បោងជាដើមទៅ តែកុំហាមជនដែលកាន់យកដោយដៃ ខាងក្នុងនគរ ក៏ឲ្យប្រាប់ថា វតនៈ ៧ ប្រការ ខ្ញុំរោយហើយត្រង់បរិវេណព្រះគន្ធកុដិ មនុស្សក្រីក្រទាំងឡាយដែលស្តាប់ធម៌ ក្នុងសម្នាក់ព្រះសាស្តាហើយទៅ ចូរកាន់យកពេញដៃទាំងពីរ មនុស្សទាំងឡាយដល់នូវសេចក្តីសុខហើយ ក៏ចូរកាន់យកដោយដៃនោះឯង ។

បានឮថា គាត់គិតយ៉ាងនេះថា ជនទាំងឡាយអ្នកមានសទ្ធា បំណងនឹងស្តាប់ធម៌មុន ទើបទៅនោះឯង ចំណែកអ្នកមិនមានសទ្ធា ទៅដោយការចង់បានក្នុងទ្រព្យ ស្តាប់ធម៌ហើយនឹងផុតចាកទុក្ខបាន ព្រោះហេតុនោះ ទើបគាត់ឲ្យប្រាប់យ៉ាងនោះ ដើម្បីសង្គ្រោះជន ។

មហាជនកាន់យករតនៈទាំងឡាយ តាមកំណត់ដែលគេជ្រាប់ហើយនោះឯង កាលរតនៈដែលគេរោយម្តងអស់ហើយ ទើបឲ្យរោយរឿយៗ ស្មើក្បាលជង្គង់អស់ ៣ ជង ។ ម្យ៉ាងទៀត គាត់ដាក់កែវមណីដែលមានតម្លៃមិនមានប្រមាណប៉ុនផ្ទៃខ្ពឹក ទៀបបាទមូលរបស់ព្រះសាស្តា ។

បានឮថា គាត់បានគិតយ៉ាងនេះថា ឈ្មោះថាការឆ្អែតនឹងមិនមានដល់ជនទាំងឡាយ ដែលសម្លឹងមើលរស្មីនៃកែវមណី មួយអន្ទៀដោយរស្មីដែលមានពណ៌ដូចមាស ដែលផ្សាយចេញអំពីសរីរៈរបស់ព្រះសាស្តា ព្រោះដូច្នោះទើបគាត់ធ្វើយ៉ាងនោះ សូម្បីមហាជនក៏មើលមិនឆ្អែតឡើយ ។

សម័យថ្ងៃមួយ ព្រាហ្មណ៍មិច្ឆាទិដ្ឋិម្នាក់គិតថា បានឮថា កែវមណីមានតម្លៃច្រើន ដែលកុដុម្ពិកៈនោះដាក់ទៀបបាទមូលនៃព្រះសាស្តា អញនឹងលួចកែវមណីនោះ ទើបទៅកាន់វិហារ ចូលទៅចន្លោះមហាជនដែលមកហើយដើម្បីថ្វាយបង្គំព្រះសាស្តា ។ កុដុម្ពិកៈកំណត់បានថា ព្រាហ្មណ៍នេះមានបំណងនឹងកាន់យកកែវមណី ដោយអាការនៃការចូលទៅរបស់ព្រាហ្មណ៍នោះឯង ទើបគិតថា ឱហ្ន៎ ព្រាហ្មណ៍មិនគួរកាន់យក សូម្បីព្រាហ្មណ៍នោះ ជាក់ដៃទៀបបាទមូលហាក់ដូចថ្វាយបង្គំព្រះសាស្តា កាន់យកកែវមណីលាក់ក្នុងប្រមូរសំពត់ចៀសចេញទៅហើយ ។ កុដុម្ពិកៈមិនអាចញុំងចិត្តឲ្យជ្រះថ្លាក្នុងព្រាហ្មណ៍នោះបាន ។ ក្នុងកាលចប់ធម្មកថា កុដុម្ពិកៈនោះចូលទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ រតនៈ ៧ ប្រការ ខ្ញុំព្រះអង្គរោយជុំវិញព្រះគន្ធកុដិអស់ ៣ ជង ដោយជួរត្រឹមក្បាលជង្គង់ កាលជនទាំងឡាយកាន់យករតនៈទាំងនោះ

ឈ្មោះថាការអាឃាតមិនមានដល់ខ្ញុំព្រះអង្គឡើយ ចិត្តរីឯរីតែជ្រះថ្លារឿយៗ តែថ្ងៃនេះខ្ញុំព្រះអង្គគិតថា ឱហ្ន៎ ព្រាហ្មណ៍នេះមិនគួរកាន់យកកែវមណី កាលព្រាហ្មណ៍នោះ កាន់យកកែវមណីទៅហើយ ទើបមិនអាចញ៉ាំងចិត្តឲ្យជ្រះថ្លាបាន ។

ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់កុដុម្ពិកៈនោះហើយត្រាស់ថា ឧបាសក អ្នកមិនអាចធ្វើរបស់មាននៃខ្លួន ឲ្យជារបស់ដែលជនដទៃ គប្បីនាំទៅមិនបាន មិនមែនឬ ដូច្នេះហើយ ទ្រង់បានប្រទានន័យហើយ ។ កុដុម្ពិកៈនោះតាំងនៅក្នុងន័យដែលព្រះសាស្តាប្រទានហើយ ថ្វាយបង្គំព្រះសាស្តា បានធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ ព្រះរាជាក្តី ចោរក្តី ទោះបីរាប់រយ ឈ្មោះថាអាចកាន់យកកំណប់នៃខ្ញុំព្រះអង្គ សូម្បីត្រឹមតែអំបោះជាយសំពត់ កុំបីមានតាំងអំពីថ្ងៃនេះជាដើមទៅ ភ្លើងក៏កុំឆេះទ្រព្យខ្ញុំព្រះអង្គឡើយ ទឹកក៏កុំលិច ។ ព្រះមានព្រះភាគទ្រង់ធ្វើអនុមោទនាដល់កុដុម្ពិកៈនោះថា សេចក្តីប្រាថ្នាដែលអ្នកប្រាថ្នាយ៉ាងនោះ ចូរសម្រេចចុះ ។ កុដុម្ពិកៈនោះ កាលធ្វើការឆ្លងព្រះគន្ធកុដិ ថ្វាយមហាទានដល់ភិក្ខុ ៦៨ សែនអង្គ ខាងក្នុងវិហារនោះឯង អស់កាល ៩ ខែ ក្នុងកាលជាទីបំផុត បានថ្វាយត្រៃចីវរដល់ភិក្ខុគ្រប់រូប ។ សំពត់សាដកសម្រាប់ចីវររបស់ភិក្ខុបួសថ្មីក្នុងសង្ឃ មានតម្លៃដល់មួយពាន់ ។

កុដុម្ពិកៈនោះ ធ្វើបុណ្យទាំងឡាយ ដរាបដល់អស់អាយុយ៉ាងនេះហើយ ចុតិចាកអត្តភាពនោះកើតក្នុងទេវលោក អន្តោលទៅក្នុងទេវលោក និងមនុស្សលោក អស់កាលមានប្រមាណប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុង

ត្រកូលសេដ្ឋីមួយក្នុងក្រុងរាជគ្រឹះ នៅក្នុងផ្ទៃមាតាអស់ ៩ ខែកន្ទះ ។ ក្នុងថ្ងៃដែលកុដុម្ពិកៈកើត អាវុធទាំងឡាយក្នុងនគរទាំងមូលភ្ជឹរុងរឿងហើយ អាភរណៈទាំងឡាយ ដែលពាក់ត្រង់កាយជនទាំងពួងភ្ជឹរុងរឿងបញ្ចេញរស្មីហើយ ព្រះនគររុងរឿងជាសភាពតែមួយ សេដ្ឋីក៏បានទៅកាន់ទីបម្រើព្រះរាជាអំពីព្រលឹមកាលនោះ ព្រះរាជាត្រាស់សួរសេដ្ឋីនោះថា ថ្ងៃនេះសញ្ជាវុធទាំងឡាយ រុងរឿងហើយ ព្រះនគរក៏រុងរឿងតែមួយ អ្នកដឹងហេតុក្នុងរឿងនេះដែរឬទេ សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំដឹង ព្រះរាជាត្រាស់សួរថា តើដោយហេតុអ្វី សេដ្ឋីពោលថា ទាសៈរបស់ព្រះអង្គកើតក្នុងផ្ទះរបស់ទូលបង្គំ ការរុងរឿងនោះ មានហើយដោយតេជះនៃបុណ្យរបស់ទារកនោះឯង ព្រះរាជាត្រាស់ថា ទារកនោះជាចោរទេដឹង សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព សេចក្តីនោះមិនមាន សត្វមានបុណ្យបានធ្វើអភិនីហារមកហើយ ។ ព្រះរាជាទ្រង់តាំងទ្រព្យថ្ងៃចិញ្ចឹម មួយថ្ងៃមួយពាន់ ដោយព្រះតម្រាស់ថា បើដូច្នោះ អ្នកចិញ្ចឹមទារកនោះឲ្យល្អ ទើបគួរ នេះជាថ្ងៃទឹកដោះសម្រាប់ទារកនោះ ក្នុងថ្ងៃតាំងឈ្មោះ ទើបជនទាំងឡាយឲ្យឈ្មោះថាជោតិកៈនោះឯង ព្រោះព្រះនគរទាំងមូលរុងរឿងតែមួយ ។

សម័យតមកក្នុងកាលដែលកុមារនោះធំហើយ កាលផ្ទៃដីដែលគេជម្រះដើម្បីសង់ផ្ទះ សក្កៈពិភពសម្តែងអាការក្តៅហើយ ។ សក្កៈទ្រង់ពិចារណាថា ហេតុអ្វីហ្នឹ ទ្រង់ជ្រាបថាជនទាំងឡាយកំពុងសាងផ្ទះដើម្បីជោតិកៈ ទ្រង់ត្រិះរិះថា ជោតិកៈនេះ នឹងមិននៅក្នុងផ្ទះដែលជនទាំងនោះធ្វើហើយ អញគួរទៅក្នុង

ទីនោះ ហើយទ្រង់យាងទៅទីនោះដោយភេទជាជាងឈើគ្រាស់ថា ពួកអ្នកធ្វើអ្វី ពួកជនពោលថា ពួកខ្ញុំជម្រះទីដើម្បីសង់ផ្ទះសម្រាប់ជោតិកៈ សក្កទេវរាជគ្រាស់ថា ចូរពួកអ្នកចៀសចេញទៅ ជោតិកៈនេះ មិននៅក្នុងផ្ទះដែលពួកអ្នកធ្វើ ហើយទ្រង់ទតមើលភូមិប្រទេសប្រមាណ ១៦ ករីស ភូមិប្រទេសនោះក្លាយជាផ្ទៃដីដែលស្មើក្នុងរំពេចនោះឯង ដូចមណ្ឌលកសិណ ហើយទ្រង់ត្រិះរិះទៀតថា ចូរប្រាសាទ ៧ ជាន់សម្រេចដោយកែវ ៧ ប្រការ ព្រែកផែនដីផុសឡើងក្នុងទីនេះ ហើយទតមើលប្រាសាទ ឃើញប្រាសាទបែបនោះផុសឡើងក្នុងខណៈនោះឯង ។ សក្កទេវរាជត្រិះរិះទៀតថា ចូរកំពែង ៧ ជាន់សម្រេចដោយកែវ ៧ ប្រការ ផុសឡើងជុំវិញប្រាសាទនេះ ហើយទតមើលកំពែងបែបនោះផុសឡើងហើយ ។ កាលនោះ សក្កៈត្រិះរិះថា ចូរដើមកប្បព្រឹក្សទាំងឡាយ ផុសឡើងក្នុងទីបំផុតជុំវិញកំពែងទាំងនោះ ហើយទតមើលដើមកប្បព្រឹក្សទាំងឡាយបែបនោះ ផុសឡើងហើយ សក្កៈត្រិះរិះថា កំណាប់ទ្រព្យ ៤ រណ្តៅ ចូរផុសឡើងត្រង់ជ្រុងទាំង ៤ នៃប្រាសាទ ហើយទតមើលវត្ថុគ្រប់យ៉ាង មានយ៉ាងនោះដូចគ្នា ។

បណ្តាកំណាប់ទ្រព្យទាំងឡាយ កំណាប់មួយ មានប្រមាណមួយយោជន៍ កំណាប់មួយមានប្រមាណ ៣ គាវុត កំណាប់មួយ មានប្រមាណកន្លះយោជន៍ កំណាប់មួយមានប្រមាណ ១ គាវុត ។ ត្រង់ខ្វោងទ្វារទាំង ៧ យក្ខ ៧ នាក់ធ្វើការរក្សាហើយ ក្នុងខ្វោងទ្វារទីមួយ យក្ខឈ្មោះយមមោលី មួយអន្លើដោយយក្ខមួយពាន់ ជាបរិវារបស់ខ្លួន ធ្វើការរក្សាហើយ ត្រង់ខ្វោងទ្វារទី ២

យក្ខឈ្មោះឧប្បល មួយអន្ទើដោយយក្ខជាបរិវារ ២ ពាន់ធ្វើការរក្សាហើយ ត្រង់ខ្ញោងទ្វារទី ៣ យក្ខឈ្មោះវជិរៈ មួយអន្ទើដោយយក្ខដែលជាបរិវារ ៣ ពាន់ ធ្វើការរក្សាហើយ ត្រង់ខ្ញោងទ្វារទី ៤ យក្ខឈ្មោះវជិរពាហុ មួយអន្ទើដោយយក្ខជាបរិវារ ៤ ពាន់ ធ្វើការរក្សាហើយ ត្រង់ខ្ញោងទ្វារទី ៥ យក្ខឈ្មោះសកជៈ មួយអន្ទើដោយយក្ខជាបរិវារ ៥ ពាន់រក្សាហើយ ត្រង់ខ្ញោងទ្វារទី ៦ យក្ខឈ្មោះសកជត្តៈ មួយអន្ទើដោយយក្ខដែលជាបរិវារ ៦ ពាន់រក្សាហើយ ត្រង់ខ្ញោងទ្វារទី ៧ យក្ខឈ្មោះទិសាមុខៈ មួយអន្ទើដោយយក្ខជាបរិវារ ៧ ពាន់ រក្សាហើយ ។ ទាំងខាងក្នុង និងខាងក្រៅនៃប្រាសាទ មានការរក្សាយ៉ាងមាំទាំហើយ ដោយប្រការដូច្នេះ ។

ព្រះរាជាព្រះនាមពិម្ពិសារ ទ្រង់ឮថាប្រាសាទ ៧ ជាន់ សម្រេចដោយកែវ ៧ ប្រការ ផុសឡើងហើយដើម្បីជោតិកៈ កំពែង ៧ ជាន់ ខ្ញោងទ្វារ ៧ កំណាប់ទ្រព្យ ៤ ផុសឡើងហើយជុំចគ្នា ទ្រង់បញ្ជូនឆត្រតំណែងសេដ្ឋីទៅឲ្យហើយ កុមារបានឈ្មោះថា ជោតិកសេដ្ឋី ស្រីដែលមានបុញ្ញកម្មបានធ្វើហើយជាមួយជោតិកសេដ្ឋីនោះ កើតហើយក្នុងឧត្តរកុរុទ្វីប ។

កាលនោះ ទេវតានាំនាងមកអំពីឧត្តរកុរុទ្វីបនោះហើយ ឲ្យអង្គុយក្នុងបន្ទប់ដ៏មានសិរី ។ ស្រីនោះកាលមក កាន់យកនាឡិអង្គរ ១ និងដុំថ្មដែលមានពន្លឺ ៣ ដុំមក កត្តរបស់ជនទាំងពីរនោះ មានហើយដោយនាឡិអង្គរនោះឯងរហូតអស់ជីវិត ។

បានឮថា បើជនទាំងនោះបំណងនឹងញុំាងរនេះមួយរយ ឲ្យពេញដោយ

អង្គរ រទេះមួយរយក៏គង់ជ្រាកដជានាឡិ ដែលពេញដោយអង្គរនោះឯង ក្នុងពេលចម្អិនភត្ត ជនទាំងនោះដាក់អង្គរក្នុងឆ្នាំង ហើយដាក់ខាងលើដុំថ្មនោះ ដុំថ្មក៏ឆេះឡើងខណៈនោះឯង កាលភត្តឆ្អិនហើយរមែងរលត់ទៅ ពួកជននោះដឹងថាភត្តឆ្អិនហើយដោយសញ្ញានោះឯង ។ ក្នុងពេលស្រូបរបស់ដែលគួរស្រូបាដើមក៏នយនេះដូចគ្នា ។ ជនទាំងពីររមែងចម្អិនអាហារដោយថ្មដែលឆេះឯងដោយអាការយ៉ាងនេះ ជនទាំងនោះ រមែងនៅដោយពន្ធីនៃតែវមណី មិនស្គាល់ពន្ធីរបស់ភ្លើង ឬប្រទីបឡើយ ។

បានឮថា សម្បត្តិរបស់ជោតិកសេដ្ឋីបែបនោះ បានជ្រាកដពេញជម្ពូទ្វីបទាំងមូលហើយ មហាជនទើមរទេះជាដើមមកដើម្បីមើល ។

ជោតិកសេដ្ឋី ឲ្យចម្អិនភត្តដោយស្រូវសាលី ដែលនាំមកអំពីឧត្តរកុរុទ្វីប ហើយឲ្យដល់ជនទាំងឡាយដែលមកហើយប្រាប់ថា ចូរជនទាំងឡាយកាន់យកសំពត់ ចូរកាន់យកគ្រឿងប្រដាប់អំពីដើមកប្បព្រឹក្សទាំងឡាយ ហើយឲ្យបើកមាត់រណ្តៅទ្រព្យ មានប្រមាណ ១ គាវុត ហើយប្រាប់ថា ចូរជនទាំងឡាយកាន់យកទ្រព្យល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ។ កាលជនទាំងឡាយនៅក្នុងជម្ពូទ្វីបទាំងមូលកាន់យកទ្រព្យទៅ មាត់នៃកំណប់ទ្រព្យ មិនបានស្រកចុះសូម្បីត្រឹមមួយធ្នាប់ ។ បានឮថា នុ៎ះជាផលនៃវតនៈដែលគាត់រោយ ធ្វើឲ្យជាខ្សាច់ក្នុងបរិវេណព្រះគន្ធកុដិ ។

កាលមហាជនកាន់យកអាករណៈ និងទ្រព្យតាមប្រាថ្នាទៅយ៉ាងនោះ ព្រះបាទពិម្ពិសារ មានបំណងនឹងទតប្រាសាទរបស់ជោតិកសេដ្ឋីនោះ កាលមហា-

ជនមក ទើបមិនបានឱកាស ។ ក្នុងកាលតមក កាលពួកមនុស្សថ្វយចុះ ព្រោះកាន់យកវត្តាករណៈ និងទ្រព្យតាមសេចក្តីត្រូវការទៅហើយ ទើបព្រះរាជាត្រាស់នឹងបិតារបស់ជោតិកៈថា យើងមានបំណងនឹងទតប្រាសាទកូនរបស់អ្នក ឪពុកជោតិកៈនោះក្រាបទូលថា សាធុ ព្រះសម្មតិទេព ហើយទៅប្រាប់ដល់កូនថា នែបា ព្រះរាជាបំណងនឹងទតប្រាសាទរបស់ឯង ជោតិកៈពោលថា សាធុ លោកឪពុក សូមទ្រង់យាងមកចុះ ។

ព្រះរាជាបានយាងទៅក្នុងទីនោះ មួយអន្ទើដោយរាជបរិវារជាច្រើន ។ ទាសីចោសសម្អាតសំរាមត្រង់ខ្ញោងទ្វារទីមួយ បានថ្វាយដៃដល់ព្រះរាជា ព្រះរាជាទ្រង់ខ្មាសដោយសម្គាល់ថា ជាភរិយារបស់សេដ្ឋី ទ្រង់មិនជាក់ព្រះហស្តត្រង់ដៃរបស់នាង ។ព្រះរាជាទ្រង់សម្គាល់ទាសីក្នុងខ្ញោងទ្វារដ៏សេសទាំងឡាយថាជាភរិយារបស់សេដ្ឋីយ៉ាងនោះ ទើបទ្រង់មិនជាក់ព្រះហស្ត ត្រង់ដៃរបស់ទាសីទាំងនោះ ។

ជោតិកសេដ្ឋីមកទូលព្រះរាជា ថ្វាយបង្គំហើយ នៅអំពីខាងខ្នងក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់យាងខាងមុខចុះ ផែនដីដែលប្រជាប់ដោយកែវមណី រមែងប្រាកដដល់ព្រះរាជា ដូចជ្រោះជម្រៅមួយរយជួរបុរសព្រះរាជាសម្គាល់ថា ជោតិកៈនេះជីកអណ្តូង ដើម្បីចាប់ទ្រង់ ទើបមិនអាចយាងទៅបាន ។

ជោតិកៈក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះមិនមែនអណ្តូង សូមទ្រង់យាងមកខាងក្រោយទូលបង្គំចុះ ហើយនាំដំណើរព្រះរាជា ។

ព្រះរាជាទ្រង់ជាន់ក្នុងទីដែលជោតិកៈនោះជាន់ហើយ ទ្រង់ទតប្រាសាទ តាំងអំពីជាន់ក្រោមរហូតដល់ជាន់លើ ។ ក្នុងកាលនោះ ព្រះរាជកុមារព្រះនាម អជាតសត្តុ ទ្រង់ចាប់អង្គុលីរបស់ព្រះបិតាយាងទៅ ទ្រង់ព្រះតម្រិះថា ឱ បិតារបស់អញជាអន្ធពាល គបហតីគង់នៅក្នុងប្រាសាទ ដែលធ្វើដោយកែវ ៧ ប្រការ បិតារបស់អញសូម្បីជាព្រះរាជា គង់ប្រថាប់នៅក្នុងព្រះរាជមន្ទីរ ដែលធ្វើដោយឈើ ឥឡូវនេះ បើអញបានជាព្រះរាជាហើយ នឹងមិនឲ្យគហបតីនេះ នៅក្នុងប្រាសាទនេះ ។ កាលព្រះរាជាកំពុងឡើងកាន់ប្រាសាទជាន់ខាងលើនោះឯង ជាពេលសោយព្រះក្រយាហារព្រឹក ព្រះរាជាត្រាស់ហៅសេដ្ឋីមកត្រាស់ថា សេដ្ឋី ពួកយើងនឹងបរិភោគអាហារព្រឹកក្នុងទីនេះឯង សេដ្ឋីពោលថា បពិត្រព្រះសម្មតិទេព ទូលបង្គំក៏ជ្រាប ព្រះក្រយាហារសម្រាប់ព្រះសម្មតិ-ទេព ទូលបង្គំបានត្រៀមហើយ ។

ព្រះរាជាទ្រង់ស្រង់ដោយទឹកក្រអូប ១៦ ភ្នម ហើយប្រថាប់គង់លើបល្ល័ង្ក ដែលជាទីអង្គុយរបស់សេដ្ឋីនោះឯង ដែលគេតាក់តែងហើយក្នុងមណ្ឌប ជាទីអង្គុយរបស់សេដ្ឋី ដែលធ្វើដោយកែវ ។

គ្រានោះ ពួកបុរសថ្វាយទឹកសម្រាប់លាងព្រះហស្តដល់ព្រះរាជា ហើយជូនសុបាយសអំពីកាជនៈនោះ ដែលមានតម្លៃមួយសែនជាក់ត្រង់ព្រះភក្ត្រ ព្រះរាជាទ្រង់ផ្តើមនឹងសោយដោយសម្គាល់ថាជាកោជន សេដ្ឋីក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះមិនមែនកោជន នេះជាបាយសសើម ពួកបុរសជូនកោជនជាក់កាជនៈជំទៃ ហើយជាក់លើកាជនៈមុន ។ បានឮថា ការបរិភោគកោជន

នោះ ដោយកម្តៅដែលផ្សាយទ្បើង អំពីភាជនៈបាយសសើមនោះ ជាហេតុនាំមកនូវការសប្បាយ ។ ព្រះរាជាកាលសោយភោជន ដែលមានរសឆ្ងាញ់ទ្រង់មិនដឹងប្រមាណ ។ លំដាប់នោះ សេដ្ឋីថ្វាយបង្គំព្រះរាជាហើយ ផ្គងអញ្ជលី ក្រាបទូលថា បពិត្រព្រះអង្គ សោយប៉ុណ្ណោះល្មម ទ្រង់មិនអាចឲ្យភោជនដែលកៃ្រលែងជាងនេះរលាយបានទ្បើយ ។ ពេលនោះ ព្រះរាជាត្រាស់ថា គហបតី អ្នកទើសទាល់ឬ ទើបនិយាយដល់ភត្តរបស់ខ្ជូន សេដ្ឋីទូលថា បពិត្រព្រះអង្គ មិនមែនដូច្នោះទ្បើយ ព្រោះភត្តដើម្បីពួកពលរបស់ព្រះអង្គទាំងអស់ ក៏បែបនេះឯង សម្ង ក៏សម្ងនេះ តែខ្ញុំព្រះអង្គខ្វាចចំពោះការវិនាសយស ព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី សេដ្ឋីទូលថា បើហេតុត្រឹមតែធ្ងន់នៃព្រះកាយ គប្បីមានដល់ព្រះសម្មតិទេពសោត ទូលបង្គំខ្វាចចំពោះពាក្យថាម្សិលមិញនេះ ព្រះរាជាសោយក្នុងផ្ទះរបស់សេដ្ឋី សេដ្ឋីគង់នឹងធ្វើអ្វីមួយថ្វាយពិត ព្រះរាជាត្រាស់ថា បើយ៉ាងនោះ ចូរនាំភត្តទៅ ហើយយកទឹកមក ។ ក្នុងពេលស្រេចភត្តកិច្ចរបស់ព្រះរាជា រាជបរិវារទាំងអស់ក៏បរិភោគភត្តនោះឯង ។

ព្រះរាជាប្រថាប់គង់សនួនាប្រាវព្ធដល់សេចក្តីសុខ ត្រាស់ហៅសេដ្ឋីមកហើយត្រាស់ថា ភរិយារបស់អ្នកក្នុងផ្ទះនេះមិនមានឬ សេដ្ឋីទូលថា បពិត្រព្រះអង្គ មាន ព្រះរាជាត្រាស់ថា នាងនៅឯណា សេដ្ឋីទូលថា នាងអង្គុយក្នុងបនូប់ដ៏មានសិរី មិនដឹងថា ព្រះសម្មតិទេពយាងមកទេ ។

ព្រះរាជា មួយអន្ទើដោយរាជបរិវារ យាងមកអំពីព្រលឹមក៏ពិត តែនាងក៏មិនដឹងថា ទ្រង់យាងមក ។ លំដាប់នោះ សេដ្ឋីដឹងថា ព្រះរាជាមានបំណង

ទតកវិយោរបស់ខ្លួន ទើបចូលទៅកាន់សម្នាក់របស់នាងហើយប្រាប់ថា ព្រះរាជាយាងមកហើយ ការដែលនាងគាល់ព្រះរាជាមិនគួរឬ ។

កំពុងដេកនោះឯងនាងពោលថា នែអ្នក ឈ្មោះថាព្រះរាជានោះដូចម្តេច កាលសេដ្ឋីប្រាប់ថា ជនដែលជាធំរបស់ពួកយើង ឈ្មោះថាព្រះរាជា ទើបប្រាប់ភាពដែលខ្លួនជាអ្នកមានចិត្តមិនត្រេកអរពោលថា ពួកយើងសូម្បីបុគ្គលជាធំ ឈ្មោះថា ធ្វើបុញ្ញកម្មទាំងឡាយមិនល្អហ្ន៎ ពួកយើងធ្វើបុញ្ញកម្មទាំងឡាយដោយមិនមានសទ្ធា ទើបដល់នូវសម្បត្តិកើតហើយក្នុងទីរបស់ជនដទៃ ដែលជាធំ ទានជារបស់ដែលយើងទាំងឡាយមិនជឿហើយឲ្យពិត នេះជាផលរបស់ទាននោះ ហើយពោលថា នែអ្នក ឥឡូវនេះ ខ្ញុំនឹងធ្វើដូចម្តេច សេដ្ឋីពោលថា ចូរនាងកាន់យកផ្ងិតស្វឹកត្នោត មកបក់ថ្វាយព្រះរាជា កាលនាងកាន់ផ្ងិតស្វឹកត្នោតមកបក់ថ្វាយព្រះរាជា ខ្យល់ក្លិននៃព្រះកូសាសម្រាប់ជូតសីសៈរបស់ព្រះរាជា បានជួលមកបះក្អែករបស់នាង ។ លំដាប់នោះ តំណក់នៃទឹកភ្នែកហូរចេញអំពីភ្នែករបស់នាង ព្រះរាជាទតឃើញអាការនោះ ទើបត្រាស់នឹងសេដ្ឋីថា មហាសេដ្ឋី ធម្មតាមាតុគ្រាមមានការជឿងតិច ប្រហែលជាយំព្រោះខ្លាចថា ព្រះរាជាគប្បីកាន់យកសម្បត្តិរបស់ប្តីអញ ចូរអ្នកលួងលោមនាង យើងមិនត្រូវការដោយសម្បត្តិរបស់អ្នកទេ សេដ្ឋីពោលថា បពិត្រព្រះសម្មតិទេព នាងមិនបានយំ ព្រះរាជាត្រាស់ថា បើដូច្នោះ ទុំះជាអ្វី សេដ្ឋីទូលថា ទឹកភ្នែករបស់នាងហូរចេញមកហើយ ព្រោះចំហាយក្លិននៃព្រះកូសាសម្រាប់ជូតរបស់ព្រះអង្គ ព្រោះថា ភរិយារបស់ទូលបង្គំនេះមិនធ្លាប់ឃើញ

ពន្ធីប្រទីប ពន្ធីភ្លើង រមែងបរិភោគ អគ្គិយ និងជេក ដោយពន្ធីរបស់កែវមណី ប៉ុណ្ណោះ ចំណែកព្រះសម្មតិទេព នឹងប្រថាប់គង់ដោយពន្ធីនៃប្រទីប ព្រះរាជាត្រាស់ថា ត្រូវហើយសេដ្ឋី សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព បើដូច្នោះ ចាប់ពីថ្ងៃនេះទៅ សូមទ្រង់ប្រថាប់គង់ ដោយពន្ធីនៃកែវមណី ហើយថ្វាយកែវមណីដែលមានតម្លៃកាត់ថ្លៃមិនបាន ទំហំប្រមាណប៉ុនផ្ទៃឪឡឹក ។

ព្រះរាជាទតប្រាសាទហើយត្រាស់ថា សម្បត្តិរបស់ជោតិកៈ ច្រើនពិតហើយយ៉ាងត្រឡប់ទៅ នេះជារឿងកើតឡើងរបស់ជោតិកៈមានប្រមាណប៉ុណ្ណោះសិន ។

ឥឡូវនេះ គប្បីជ្រាបការកើតឡើងរបស់ព្រះថេរៈ ឈ្មោះជដិល

សេចក្តីពិស្តារថា ក្នុងក្រុងពារាណសី មានធីតារបស់សេដ្ឋីម្នាក់ មានរូបស្អាត មាតាបិតាឲ្យស្រីបម្រើម្នាក់ដើម្បីរក្សាក្នុងពេលមានអាយុ ១៥-១៦ ឆ្នាំ ឲ្យនៅក្នុងបន្ទប់ដ៏មានសិរី លើប្រាសាទជាន់ទី ៧ ។

ថ្ងៃមួយ ពិទ្យាធរម្នាក់ កំពុងហោះទៅតាមអាកាស ឃើញនាងកំពុងបើកបង្អួចមើលមកខាងក្រៅ កើតសេចក្តីស្នេហា ទើបចូលទៅតាមបង្អួច ហើយធ្វើសេចក្តីស្និទ្ធស្នាលជាមួយនាង ។ អាស្រ័យការនៅរួមគ្នាជាមួយពិទ្យាធរនោះ គភ៌ក៏តាំងឡើងហើយក្នុងកាលមិនយូរឡើយ ។

លំដាប់នោះ ស្រីបម្រើនោះឃើញដូច្នោះហើយទើបពោលថា អ្នកនាងម្ចាស់ តើនេះជាអ្វី នាងប្រាប់ថា សេចក្តីនេះចូរលើកទុក នាងកុំប្រាប់ដល់អ្នកណាឡើយ ទាសីនៅស្ងៀមព្រោះខ្លាច លុះកន្លងទៅ ១០ ខែ កាលនាងប្រសូត

បុត្រហើយ ឲ្យស្រីបម្រើនាំកាជនៈថ្មីមក ដាក់ក្មេងនោះដេកក្នុងកាជនៈហើយ បិទកាជនៈនោះ ដាក់កម្រងផ្កាខាងលើ ប្រាប់ស្រីអ្នកបម្រើថា ចូរនាងយកក្បាលទូលកាជនៈទៅបណ្តែតក្នុងស្ទឹងគង្គា បើត្រូវអ្នកណាសួរថា នេះអ្វី គប្បីប្រាប់ថា នេះជាពលីកម្មរបស់ម្ចាស់ខ្ញុំ ស្រីបម្រើនោះបានធ្វើយ៉ាងនោះ ។

ស្រីពីរនាក់កំពុងដួតទឹកខាងក្រោមខ្សែទឹក ឃើញកាជនៈនោះ ត្រូវទឹកបន្សាត់មក ស្រីម្នាក់ពោលថា កាជនៈនេះជារបស់ខ្ញុំ ស្រីម្នាក់ពោលថា វត្ថុដែលមានខាងក្នុងកាជនៈនោះជារបស់ខ្ញុំ កាលកាជនៈអណ្តែតមកជល់ហើយ ទើបចាប់កាជនៈនោះយកមកលើគោក បើកមើលឃើញទារក ស្រីម្នាក់ពោលថា ក្មេងជារបស់ខ្ញុំនោះឯង ព្រោះខ្ញុំពោលថា កាជនៈជារបស់ខ្ញុំ ស្រីម្នាក់ពោលថាក្មេងជារបស់ខ្ញុំ ព្រោះខ្ញុំពោលថា វត្ថុដែលនៅខាងក្នុងកាជនៈជារបស់ខ្ញុំ ។

ស្រីទាំងពីរប្រកែកគ្នា នាំគ្នាទៅកាន់សាលាវិនិច្ឆ័យហើយ ប្រាប់សេចក្តីនោះ កាលពួកអមាត្យវិនិច្ឆ័យមិនបាន ទើបបញ្ជូនទៅកាន់សម្នាក់ព្រះរាជា ។

ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ស្រីទាំងពីរនោះ ទើបត្រាស់ថា ចូរនាងយកក្មេង ចូរនាងយកកាជនៈ ។

ស្រីដែលបានក្មេង ជាឧបដ្ឋាយិការបស់ព្រះមហាកច្ចាយនត្ថេរ ព្រោះហេតុនោះ ទើបស្រីនោះចិញ្ចឹមទារកនោះ ដោយគិតថា នឹងឲ្យក្មេងនេះបួស ក្នុងសម្នាក់របស់ព្រះថេរៈ ។

សក់របស់ក្មេងនោះ បានរួញក្រញាញ់ ព្រោះមន្ទិលនៃគក់ដែលគេលាងមិនស្អាតក្នុងទីដែលក្មេងនោះកើត ព្រោះហេតុនោះ ទើបជនទាំងឡាយដាក់

ឈ្មោះថា ជដិលនោះឯង ។

ក្នុងកាលដែលកុមារដើរបាន ព្រះថេរៈចូលទៅកាន់ផ្ទះនោះដើម្បីបិណ្ឌបាត ឧបាសិកានិមន្តព្រះថេរៈឲ្យគង់ ហើយប្រគេនអាហារ ។ ព្រះថេរៈឃើញក្មេង ទើបសួរថា ឧបាសិកា នាងមានកូនឬ ឧបាសិកាប្រាប់ថា ករុណាលោកម្ចាស់ ខ្ញុំចិញ្ចឹមក្មេងនេះ ដោយបំណងថា នឹងឲ្យបួសក្នុងសម្នាក់របស់លោកម្ចាស់ សូមលោកម្ចាស់ឲ្យក្មេងនេះបួសចុះ ដូច្នេះ បានប្រគេនហើយ ព្រះថេរៈ ទទួលថា សាធុ ហើយនាំក្មេងនោះទៅ ប្រមើលមើលថា បុញ្ញកម្មដែលនឹង សោយសម្បត្តិរបស់គ្រហស្ថនៃក្មេងនេះមានឬហ្ន៎ ឃើញថា សត្វនេះមានបុណ្យ ច្រើន នឹងសោយសម្បត្តិធំ ក្មេងនេះនៅតូចពេក សូម្បីញ្ញាណក៏មិនទាន់ចាស់ ក្លាដោយជុំវិញ ទើបនាំក្មេងនោះទៅកាន់ផ្ទះរបស់ឧបដ្ឋាកម្នាក់ នៅក្នុងនគរ តក្កសិលា ឧបដ្ឋាកនោះ ថ្វាយបង្គំព្រះថេរៈហើយឈរ ឃើញក្មេងនោះហើយ សួរថា លោកម្ចាស់បានក្មេងឬ ព្រះថេរៈឆ្លើយថា អើឧបាសក កុមារនេះនឹង បួស តែនៅក្មេងពេក ចូរឲ្យនៅក្នុងសម្នាក់របស់អ្នកចុះ ។ ឧបាសកនោះ ទទួលថា សាធុ ហើយតាំងទុកក្នុងឋានៈជាកូន ថែរក្សាហើយ ។

ទំនិញក្នុងផ្ទះរបស់ឧបាសកនោះ ជារបស់ដែលសន្សំទុកហើយអស់ ១២ ឆ្នាំ គាត់ចូលកាន់ចន្លោះនៃស្រុក នាំយកទំនិញទាំងអស់ទៅកាន់ផ្សារ ឲ្យកុមារ នោះអង្គុយក្នុងផ្សារហើយ ប្រាប់តម្លៃទំនិញនោះៗ ហើយពោលថា អ្នកគប្បី កាន់យកទ្រព្យដែលមានប្រមាណប៉ុណ្ណេះហើយសឹមឲ្យវត្ថុនេះ និងវត្ថុនេះ ដូច្នេះ ហើយចៀសចេញទៅ ។ ក្នុងថ្ងៃនោះ ទេវតាអ្នករក្សានគរ ធ្វើឲ្យជនមានសេចក្តី

ត្រូវការដោយវត្ថុ ដោយហោចសូម្បីត្រឹមតែមេួស និងជីរ ឲ្យបែរមុខទៅកាន់ផ្សារបស់ក្មេងប៉ុណ្ណោះ ក្មេងនោះលក់ទំនិញដែលសន្សំមកអស់ ១២ ឆ្នាំក្នុងមួយថ្ងៃប៉ុណ្ណោះ កុដុម្ពិកៈនោះមកមិនឃើញរបស់អ្វីមួយក្នុងផ្សារ ទើបពោលថា នែបា ទំនិញទាំងអស់ បាឲ្យវិនាសហើយឬ ។

កុមារឆ្លើយថា ខ្ញុំមិនបានឲ្យវិនាសទេ្បីយ ខ្ញុំលក់ទំនិញទាំងអស់តាមនយ័ដែលពុកប្រាប់ហើយនោះឯង នេះជាថ្លៃរបស់ទំនិញឈ្នោះនោះ នេះជាតម្លៃរបស់ទំនិញឈ្នោះនោះ ។ កុដុម្ពិកៈត្រេកអរគិតថា បុរសដែលមានតម្លៃកាត់ថ្លៃមិនបាន នឹងរស់នៅក្នុងទីណាមួយបាន ទើបឲ្យកូនស្រីដែលចម្រើនវ័យហើយក្នុងផ្ទះរបស់ខ្លួនដល់កុមារនោះ ប្រាប់ពួកបុរសថា ចូរពួកអ្នកសាងផ្ទះដល់កូនយើង កាលផ្ទះធ្វើស្រេចហើយ ទើបប្រាប់ថា ចូរពួកអ្នកទៅ ចូរនៅក្នុងផ្ទះរបស់ខ្លួន ។

កាលនោះ ក្នុងពេលដែលជដិលកុមារនោះចូលទៅកាន់ផ្ទះ កាលធរណីទ្វារត្រូវកុមារជាន់ហើយដោយជើងម្ខាង ក្អំមាសប្រមាណ ៨០ ហត្ថ បានជ្រែកផែនដីផុសឡើងខាងក្រោយផ្ទះ ។

ព្រះរាជាឮថា ក្អំមាសជ្រែកផែនដីផុសឡើង កែ្បរផ្ទះរបស់ជដិលកុមារ ទើបបញ្ជូនឆត្រសម្រាប់សេដ្ឋី ទៅប្រទានដល់កុមារនោះ គាត់បានឈ្មោះថា ជដិលសេដ្ឋី ក្រោយមក គាត់មានកូនប្រុស ៣ នាក់ ។

គាត់ញុំាងចិត្តឲ្យកើតឡើងក្នុងការបួសក្នុងពេលដែលបុត្រទាំងនោះចម្រើនវ័យហើយ គិតថា បើត្រកូលសេដ្ឋីណាមានកោគៈស្មើអញសោត កូនទាំង-

ឡាយក៏នឹងឲ្យបួសបាន បើមិនមានសោត កូនទាំងឡាយនឹងមិនឲ្យ ក្នុងជម្ពូទ្វីប ត្រកូលដែលមានភោគៈ ស្មើនឹងយើងទាំងឡាយមានឬហ្ន៎ ទើបឲ្យជាងធ្វើឥដ្ឋ សម្រេចដោយមាស ជងជន្លួញដែលសម្រេចដោយមាស និងស្បែកជើងដែល សម្រេចដោយមាសដើម្បីពិសោធមើល ឲ្យក្នុងដៃរបស់បុរសទាំងឡាយហើយ បញ្ជូនទៅថា ចូរពួកអ្នកទៅ ចូរកាន់ឥដ្ឋដែលសម្រេចដោយមាសជាដើមនេះ ធ្វើដូចជាមើលអ្វីមួយនោះឯង ត្រាច់ទៅក្នុងជម្ពូទ្វីប ដឹងភាពដែលត្រកូលសេដ្ឋី មានភោគៈស្មើយើង មានឬមិនមានហើយចូរមក បុរសនោះត្រាច់ចារិកទៅដល់ ភទ្ទិយនគរ ។

គ្រានោះ មេណ្ឌកសេដ្ឋីឃើញបុរសទាំងនោះហើយសួរថា បាទាំងឡាយ ពួកអ្នកត្រាច់ទៅធ្វើអ្វី កាលពួកបុរសជ្រាប់ថា ពួកខ្ញុំដើរមើលរបស់អ្វីមួយ ។ ដឹងថា កិច្ចដោយការកាន់ឥដ្ឋដែលសម្រេចដោយមាសជាដើម ទាំងនេះត្រាច់ ទៅដើម្បីមើលវត្ថុណាមួយនោះឯងរបស់បុរសទាំងនេះ រមែងមិនមាន បុរស ទាំងនេះដើរសើបមើលសេដ្ឋី ទើបពោលថា បាទាំងឡាយ ចូរពួកអ្នកទៅមើល ខាងក្រោយផ្ទះរបស់ខ្ញុំ ។

បុរសទាំងនោះ ឃើញពពែមាសទាំងឡាយមានប្រការដូចពោលហើយ ខាងដើមមានទំហំប៉ុនៗ ជីរី សេះ និងគោឧសភៈ យកខ្នងទាល់ខ្នង ជ្រែក ផែនដី ផុសឡើងក្នុងទីប្រមាណ ៨ ករីស ក្រោយផ្ទះនោះហើយ ត្រាច់ទៅ ក្នុងចន្លោះៗ ពពែទាំងនោះ ហើយចេញទៅ ។

លំដាប់នោះ សេដ្ឋីសួរបុរសទាំងនោះថា នែបាទាំងឡាយ ពួកអ្នកត្រាច់

ទៅមើលបុគ្គលណា បុគ្គលនោះពួកអ្នកឃើញហើយឬ កាលពួកបុរសពោលថា ឃើញហើយលោកម្ចាស់ ទើបបញ្ជូនទៅហើយពោលថា បើយ៉ាងនោះ ចូរពួកអ្នកទៅ ។

បុរសទាំងនោះ ទៅអំពីទីនោះហើយ កាលសេដ្ឋីរបស់ខ្លួនពោលថា ជាទាំងឡាយ ត្រកូលសេដ្ឋីមានភោគៈស្មើយើងទាំងឡាយ ពួកអ្នកឃើញហើយឬ ជនទាំងនោះប្រាប់ថា លោកម្ចាស់មានអ្វីប៉ុណ្ណឹង សម្បត្តិបែបនេះ របស់មេណ្ឌកសេដ្ឋីមាន ក្នុងកទ្ទិយនគរ ហើយប្រាប់រឿងរ៉ាវទាំងអស់ ។

សេដ្ឋីស្តាប់ពាក្យនោះហើយ ជាអ្នកមានចិត្តត្រេកអរគិតថា ត្រកូលសេដ្ឋីអញបានជីងមួយត្រកូលហើយ ត្រកូលសេដ្ឋីដទៃទៀតមានឬហ្ន៎ ហើយឲ្យសំពត់កម្ពលដែលមានតម្លៃមួយសែនបញ្ជូនទៅថា ជាទាំងឡាយ ចូរពួកអ្នកទៅ ចូរស្វែងរកត្រកូលសេដ្ឋីដទៃ ។ ពួកបុរសទៅកាន់ក្រុងរាជគ្រឹះហើយ ធ្វើគំនរឧស ក្នុងទីមិនឆ្ងាយអំពីផ្ទះរបស់ជោតិកសេដ្ឋី ដុតភ្លើងហើយ ឈរ ។ ក្នុងពេលពួកជនសួរថា តើអ្នកធ្វើអ្វី ក៏ប្រាប់ថា កាលពួកខ្ញុំលក់សំពត់កម្ពលដែលមានតម្លៃច្រើននេះ មិនមានអ្នកទិញ ពួកខ្ញុំនឹងកាន់ដើរទៅក៏ខ្លាចចោរព្រោះហេតុនោះ ទើបពួកខ្ញុំដុតចោលហើយ សឹមទៅ ។

គ្រានោះ ជោតិកសេដ្ឋីឃើញជនទាំងនោះ សួរថា ពួកអ្នកធ្វើអ្វី ស្តាប់សេចក្តីនោះហើយ ឲ្យហៅមកសួរថា សំពត់កម្ពលមានតម្លៃប៉ុន្មាន កាលជនទាំងនោះប្រាប់ថា មានតម្លៃមួយសែន ទើបប្រាប់ថា ចូរពួកអ្នកឲ្យសំពត់នេះដល់ទាសីដែលបោសសំរាមត្រង់ខ្ញោងទ្វារ ហើយបញ្ជូនឲ្យក្នុងដៃរបស់ពួក

ជននោះឯង ទាសីទទួលសំពត់កម្ពលហើយ ស្រែកយំ ទៅកាន់សម្នាក់របស់ម្ចាស់ប្រាប់ថា បពិត្រលោកម្ចាស់ បើកំហុសមាន សូមប្រហារខ្ញុំចុះ មិនគួរឬចុះហេតុអ្វី ទើបឲ្យសំពត់កម្ពលសាច់អន់យ៉ាងនេះដល់ខ្ញុំ ខ្ញុំនឹងស្បៃកឬដណ្តប់សំពត់កម្ពលនេះបានដូចម្តេច ។

ជោតិកសេដ្ឋីពោលថា យើងមិនមែនឲ្យនាងដើម្បីប្រយោជន៍ដល់ការស្បៃក ឬការដណ្តប់ឡើយ យើងបញ្ជូនសំពត់កម្ពលនេះទៅឲ្យនាង ដើម្បីឲ្យនាងបត់ ហើយជាក់ក្នុងជិតជំណេករបស់នាង ក្នុងកាលដេក ជួតជើងដែលលាងហើយ ដោយទឹកក្រអូបទេតើ នាងមិនអាចធ្វើកិច្ចនោះបានឬ ទាសីពោលថា បើដូច្នោះ ខ្ញុំអាចធ្វើកិច្ចនោះបាន ទើបទទួលយកទៅ ។

ចំណែកបុរសនោះ ឃើញហេតុនោះហើយ ទើបទៅកាន់សម្នាក់សេដ្ឋីរបស់ខ្លួន កាលសេដ្ឋីពោលថា ចូរទាំងឡាយ ត្រកូលនៃសេដ្ឋីពួកអ្នកឃើញហើយឬ ក៏ប្រាប់ថា បពិត្រលោកម្ចាស់ លោកម្ចាស់មានអ្វីប៉ុណ្ណឹង សម្បត្តិបែបនេះរបស់សេដ្ឋីឈ្មោះជោតិក: ក៏មានក្នុងក្រុងរាជគ្រឹះ ទើបប្រាប់សម្បត្តិក្នុងផ្ទះទាំងអស់ ហើយប្រាប់រឿងវានោះ ។

សេដ្ឋីស្តាប់ពាក្យរបស់បុរសទាំងនោះហើយ មានចិត្តត្រេកអរ គិតថា ឥឡូវនេះ អញនឹងបានបួស ទើបទៅកាន់សម្នាក់ព្រះរាជាក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមានបំណងនឹងបួស ព្រះរាជាត្រាស់ថា សាធុ ចូរលោកសេដ្ឋីបួសចុះ ។

សេដ្ឋីនោះ ទៅកាន់ផ្ទះហើយ ហៅកូនទាំងឡាយមកហើយ ទុកជាក់ចប

ដែលមានជង្ឃជាមាស ផ្ទៃជាពេជ្រ ក្នុងដៃរបស់កូនច្បងហើយពោលថា នែបា ចូរបាជីកមាសអំពីភ្នំខាងក្រោយផ្ទះ កូនច្បងនោះ យកចបទៅកាប់ភ្នំមាស ពេលកាប់ភ្នំមាសនោះ ដួចកាប់ថ្មជា ដួច្នោះ ។ សេដ្ឋីទទួលចបអំពីដៃរបស់ កូនប្រុសច្បងនោះ ឲ្យក្នុងដៃកូនកណ្តាល សូម្បីកូនកណ្តាលនោះកាប់ភ្នំមាស ពេលកាប់នោះ ដួចកាប់ថ្មជាដួច្នោះ ។ លំដាប់នោះ ទើបសេដ្ឋីបញ្ជូនចបនោះ ជាក់ក្នុងដៃកូនពៅ កាលកូនពៅនោះទទួលយកចបនោះកាប់ ពេលដែលកាប់ នោះ ដួចកាប់ដីឥដ្ឋដែលគេគរ ដួច្នោះ ។

លំដាប់នោះ ទើបសេដ្ឋីពោលនឹងកូនប្រុសពៅថា មកបា ឪពុកនឹងឲ្យ ទ្រព្យប្រមាណប៉ុណ្ណោះ ហើយហៅកូនច្បងទាំងពីរមកប្រាប់ថា ភ្នំមាសនេះមិន កើតសម្រាប់ពួកឯង កើតដើម្បីឪពុក និងកូនពៅ ចូរពួកអ្នកប្រើប្រាស់រួមគ្នា ជាមួយបួនប្រុសចុះ ។ សួរថា ព្រោះហេតុអ្វី ទើបភ្នំនោះកើតឡើងដើម្បីឪពុក និងកូនពៅប៉ុណ្ណោះ ព្រោះហេតុអ្វី ទើបជជិលសេដ្ឋី ត្រូវគេបណ្តេតក្នុងទឹក ក្នុងពេលដែលកើតហើយ ឆ្លើយថា ព្រោះកម្មដែលខ្លួនធ្វើហើយនោះឯង ។

សេចក្តីពិស្តារ កាលមហាជនកំពុងសាងព្រះចេតិយរបស់ព្រះកស្សប-សម្មាសម្ពុទ្ធ ព្រះខីណាស្រពមួយអង្គ ទៅកាន់ចេតិយដ្ឋាន សម្លឹងមើលហើយ សួរថា ជាទាំងឡាយ ព្រោះហេតុអ្វី ទើបមុខខាងទិសឧត្តរនៃចេតិយ មិន សាងឡើយ មហាជនពោលថា មាសមិនគ្រប់គ្រាន់ ព្រះខីណាស្រពពោល ថា អាត្មានឹងចូលទៅខាងក្នុងស្រុកហើយបបួល ចូរពួកអ្នកធ្វើកម្មដោយ អើពើចុះ ។ លោកពោលយ៉ាងនោះហើយ ចូលទៅកាន់ព្រះនគរ បបួល

មហាជនថា ញោមស្រី ញោមប្រុសទាំងឡាយ មាសត្រង់មុខនៃព្រះចេតិយ របស់ពួកយើង មិនគ្រប់គ្រាន់ ចូរពួកអ្នកជីងមាសចុះ បានទៅកាន់ត្រកូល នៃជាងមាសហើយ ចំណែកជាងមាស កំពុងឈ្លោះជាមួយភរិយាក្នុងខណៈ នោះឯង ។ គ្រានោះ ព្រះថេរៈពោលថា មាស សម្រាប់មុខព្រះចេតិយ ដែលអ្នកទាំងឡាយទទួល មិនគ្រប់គ្រាន់ ការដែលអ្នកជីងមាសនោះ គួរ ជាងមាសពោលដោយសេចក្តីក្រោធចំពោះភរិយាថា ចូរលោកបោះព្រះសាស្តា របស់លោក ចូលក្នុងទឹក ហើយទៅចុះ ។ លំដាប់នោះ ទើបនាងពោលថា អ្នកធ្វើកម្មដ៏រហ័សក្រៃលែង អ្នកខឹងនឹងខ្ញុំ គួរជេរ ឬគួរវាយខ្ញុំប៉ុណ្ណោះ ហេតុ អ្វី ទើបធ្វើពៀរក្នុងព្រះពុទ្ធទាំងឡាយ ទាំងដែលជាអតីត អនាគត និង បច្ចុប្បន្នទៅវិញ រំពេចនោះឯង ជាងមាសដល់នូវសេចក្តីសង្វេគហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់អត់ទោសដល់ខ្ញុំ ហើយក្រាប ចុះទៀបបាតជើងរបស់ព្រះថេរៈ។ ពោលថា នែញោម ញោមមិនបានថាអ្វីជា មួយអាត្មាឡើយ ចូរញុំាងព្រះសាស្តាឲ្យអត់ទោសចុះ ។

ជាងមាសពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងធ្វើដូចម្តេច ទើបឲ្យព្រះ សាស្តាអត់ទោសបាន ព្រះថេរៈពោលថា ចូរអ្នកធ្វើផើងផ្តាមាស ៣ ផើងទុក ខាងក្នុងទីបញ្ចុះព្រះធាតុ ហើយជាអ្នកមានសំពត់សើម មានសក់សើម ញុំាង ព្រះសាស្តាឲ្យអត់ទោសចុះ ជាងមាសទទួលថា សាធុ កាលធ្វើផើងផ្តាមាស បានហៅកូនច្បងក្នុងបណ្តាកូន ៣ នាក់មកហើយ ពោលថា មកបា ឪពុក បានពោលពាក្យនឹងព្រះសាស្តា ដោយពាក្យជាពៀរវេរ ព្រោះដូច្នោះ ឪពុក

នឹងធ្វើផ្តាទាំងនេះជាក់ក្នុងទីបញ្ចុះព្រះធាតុ ឲ្យព្រះសាស្តាអត់ទោស សូម្បីបា ក៏ចូរជាសម្ងាញ់របស់ឪពុក ។ កូនប្រុសច្បងក្រាបថ្វាយបង្គំថា ខ្ញុំមិនបានឲ្យពុកពោលនូវពាក្យដែលជាពៀរវេរាទេ សូមពុកធ្វើខ្លួនឯងចុះ ហើយមិនក្រាថ្វាធ្វើជាងមាស ហៅកូនកណ្តាលមកហើយ ពោលដូចគ្នាយ៉ាងនោះ សូម្បីកូនកណ្តាលនោះ ក៏ពោលដូចគ្នាយ៉ាងនោះ ហើយមិនក្រាថ្វានឹងធ្វើ ទើបជាងមាសឲ្យហៅកូនពៅមកហើយ ពោលយ៉ាងនោះ កូនពៅគិតថា ធម្មតាកិច្ចដែលកើតឡើងដល់បិតា រមែងជាការៈរបស់បុត្រ ទើបជាសម្ងាញ់របស់បិតា បានធ្វើផ្តាទាំងឡាយហើយ ។ ជាងមាសញុំាងផើងផ្តាទំហំ ១ ចំអាម ៣ ផើងឲ្យសម្រេចហើយជាក់ក្នុងទីបញ្ចុះព្រះធាតុ មានសំពត់សើម មានសក់សើម ញុំាងព្រះសាស្តាឲ្យអត់ទោសហើយ ។ ជាងមាសត្រូវគេចោះក្នុងទឹកឲ្យអណ្តែតទៅអស់កាល ៧ ជង ដោយប្រការដូច្នេះ ។

អត្តភាពរបស់គាត់ តាំងនៅហើយក្នុងទីបំផុតនេះ ក៏ត្រូវគេចោះទៅក្នុងទឹក ព្រោះផលរបស់កម្មនោះដូចគ្នា ។ ចំណែកបុត្ររបស់គាត់ ២ នាក់ មិនក្រាថ្វាជាសម្ងាញ់ក្នុងកាលធ្វើផ្តាមាស ទើបភ្នំមាសមិនកើតសម្រាប់កូនទាំងពីរនោះ តែកើតសម្រាប់កូនពៅ ព្រោះភាពដែលគេធ្វើផ្តាមាសរួមគ្នានឹងឪពុក ។

សេដ្ឋីនោះទូន្មានបុត្រហើយ បួសក្នុសម្នាក់ព្រះសាស្តា សម្រេចអរហត្តក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

សម័យជនៃក្រោយមក ព្រះសាស្តាគ្រាច់ចារិកទៅជើម្បីបិណ្ឌបាត មួយអន្ទើដោយភិក្ខុ ៥០០ រូប បានទៅកាន់ទ្វារផ្ទះកូនទាំងឡាយរបស់សេដ្ឋីនោះ

កូនទាំងនោះ បានថ្វាយភិក្ខាហារដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អស់កាលកន្លះខែ ភិក្ខុទាំងឡាយសន្ទនាក្នុងរោងធម្មសភាថា អាវុសោជដិល ក្នុងថ្ងៃនេះ ចំណង់ក្នុងភ្នំមាសប្រមាណ ៨០ ហត្ថ និងកូនទាំងឡាយរបស់លោកមានឬ ជដិលភិក្ខុពោលថា អាវុសោ តណ្ហា ឬមានះក្នុងភ្នំមាស និងកូនទាំងនោះរបស់ខ្ញុំមិនមាន ។ ទើបភិក្ខុទាំងនោះពោលថា ជដិលត្ថេរនេះ ពោលមិនពិត ព្យាករអរហត្តផល ។ ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តណ្ហា ឬមានះក្នុងភ្នំមាស និងបុត្រទាំងនោះរបស់បុត្រតថាគតមិនមាន ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យោធ តណ្ហំ បហន្ត្វាន អនាគារោ បរិព្វជេ
តណ្ហាភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ក្នុងលោកនេះ បានលះបង់តណ្ហាហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហាបាន តថាគតហៅបុគ្គលដែលអស់តណ្ហា និងភពហើយនោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះថា បុគ្គលណាលះតណ្ហា ដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ ក្នុងលោកនេះចេញបាន ជាអ្នកមិននៅគ្រប់គ្រងផ្ទះ ឈ្មោះថាជាអ្នកមិនមានផ្ទះ វៀរចេញបាន តថាគតហៅបុគ្គលឈ្មោះថា មានតណ្ហានិងភពអស់ហើយ ព្រោះភាពដែលតណ្ហា និងភព ជារបស់អស់ហើយនោះ

ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។

ចំណែកព្រះបាទអជាតសត្តុកុមារ សេពគប់នឹងទេវទត្ត ផ្តាច់ព្រះជន្មព្រះបិតា តាំងនៅក្នុងរាជសម្បត្តិហើយ ទ្រង់ព្រះតម្រិះថា អញនឹងកាន់យកប្រាសាទរបស់ជោតិកសេដ្ឋី ទើបទ្រង់ត្រៀមការច្បាំង ហើយយាងចេញទៅ លុះទតឃើញព្រះធាយា គឺស្រែមោលរបស់ព្រះអង្គ មួយអន្ទើដោយបរិវារត្រង់កំពែងកែវ យល់ថា គហបតី ជាអ្នកត្រៀមការច្បាំង ត្រៀមពលចេញមកហើយ ទើបទ្រង់មិនអាចយាងចូលបាន ។

ក្នុងថ្ងៃនោះ សេដ្ឋីជាអ្នករក្សាឧបោសថ បរិភោគអាហារអំពីព្រលឹមទៅកាន់វិហារ អង្គុយស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ។ ចំណែកយក្ខឈ្មោះយមមោលី ដែលរក្សាត្រង់ខ្ញោងទ្វារទីមួយ ឃើញព្រះបាទអជាតសត្តុនោះ ទើបសួរថា ទ្រង់យាងទៅណា ហើយកម្ចាត់ព្រះបាទអជាតសត្តុ មួយអន្ទើដោយរាជបរិវារ ដេញតាមទៅក្នុងទិសតូច និងទិសធំទាំងឡាយ ព្រះរាជាបានយាងទៅកាន់វិហារដូចគ្នា ។

គ្រានោះ សេដ្ឋីឃើញព្រះរាជាទើបទូលថា បពិត្រព្រះអង្គ តើមានរឿងអ្វី បានក្រោកចាកអាសនៈឈរហើយ ព្រះរាជាត្រាស់ថា គហបតី អ្នកបញ្ជូនពួកបុរសរបស់អ្នកថា ចូរច្បាំងជាមួយយើង ហើយមកក្នុងទីនេះអង្គុយធ្វើដូចស្តាប់ធម៌ឬ សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព ទ្រង់យាងទៅដើម្បីដណ្តើម

យកផ្ទះរបស់ទូលបង្គំពិតមែនឬ ព្រះរាជាត្រាស់ថា អើ យើងទៅ សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព សូម្បីព្រះរាជារាប់ពាន់ ក៏មិនអាចដណ្តើមយកផ្ទះទូលបង្គំបាន ព្រោះទូលបង្គំមិនប្រាថ្នា ព្រះរាជាក្រោធថា អ្នកជាព្រះរាជាឬ សេដ្ឋីទូលថា ទូលបង្គំមិនជាព្រះរាជា តែព្រះរាជាក្តី ចោរក្តី មិនអាចកាន់យកសូម្បីអំបោះត្រង់ជាយសំពត់ដែលជារបស់ទូលបង្គំបានឡើយ បើទូលបង្គំមិនប្រាថ្នាឲ្យ ព្រះរាជាត្រាស់ថា យើងនឹងកាន់យកតាមគាប់ចិត្តរបស់អ្នកបានដូចម្តេច សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព បើយ៉ាងនោះ ចិញ្ចៀន ២០ វង់នេះ ដែលមានក្នុងម្រាមដៃទាំង ១០ របស់ទូលបង្គំ ទូលបង្គំមិនថ្វាយចិញ្ចៀនទាំងនេះដល់ទ្រង់ បើទ្រង់អាចសោត សូមទ្រង់កាន់យកចុះ ។ ព្រះរាជានោះប្រថាប់គង់ច្រហោងលើផែនដី កាលនឹងលោត រមែងលោតទៅកាន់ទី ១៨ ហត្ថ បើប្រថាប់ឈរ កាលនឹងលោត រមែងលោតទៅក្នុងទី ៨០ ហត្ថ ។ ព្រះរាជាទ្រង់មានកម្លាំងច្រើនយ៉ាងនេះ ទ្រង់លោតទៅមកខាងនោះខាងនេះ ក៏មិនអាចដោះនូវចិញ្ចៀនមួយបាន ។

លំដាប់នោះ សេដ្ឋីក្រាបទូលនឹងព្រះរាជាថា បពិត្រព្រះសម្មតិទេព សូមទ្រង់លាសំពត់សាដក ហើយបានធ្វើម្រាមទាំងឡាយឲ្យត្រង់ ចិញ្ចៀនទាំង ២០ របូតចេញហើយ ។ លំដាប់នោះ សេដ្ឋីក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព បុគ្គលណាម្នាក់ មិនអាចកាន់យកសម្បត្តិ ដែលជារបស់ទូលបង្គំដោយអាការយ៉ាងនោះបាន បើទូលបង្គំមិនប្រាថ្នាឲ្យ ដូច្នេះហើយ កើតនូវសេចក្តីសង្វេគ ព្រោះកិរិយារបស់ព្រះរាជា ទើបក្រាបទូលថា បពិត្រព្រះ

សម្មតិទេព សូមទ្រង់អនុញ្ញាតដើម្បីការបួសដល់ទូលបង្គំ ព្រះរាជាទ្រង់ព្រះតម្រិះថា កាលសេដ្ឋីនេះបួសហើយ អញនឹងដណ្តឹមប្រាសាទបានងាយ ទើបត្រាស់ថា ចូរបួសចុះ ដោយការត្រាស់ត្រឹមតែម្តងប៉ុណ្ណោះ សេដ្ឋីនោះ បួសក្នុងសម្នាក់ព្រះសាស្តាហើយ ក្នុងកាលមិនយូរ ក៏បានសម្រេចអរហត្ត ឈ្មោះថា ជោតិកត្ថេរ ។

ក្នុងខណៈដែលសម្រេចអរហត្តហើយនោះឯង សម្បត្តិទាំងអស់នោះក៏អន្តរធានទៅ ពួកទេវតាក៏នាំកវិយោរបស់សេដ្ឋីនោះ ដែលមានឈ្មោះថា សតុលកាយា ទៅកាន់ឧត្តរកុរុទ្វីបវិញ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយហៅជោតិកៈនោះមកហើយ សួរថា អាវុសោជោតិកៈ តណ្ហាក្នុងប្រាសាទ ឬក្នុងស្រីនោះរបស់លោក នៅមានឬ កាលលោកជ្រាបច់ថា មិនមានឡើយអាវុសោ ទើបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ជោតិកត្ថេរនេះពោលមិនពិត ព្យាករអរហត្តផល ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតមិនមានតណ្ហាក្នុងប្រាសាទ ឬក្នុងស្រីទាំងនោះឡើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

បុគ្គលណាក្នុងលោកនេះ បានលះបង់តណ្ហាហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហាបាន តថាគតហៅបុគ្គលដែលអស់តណ្ហា និងកពហើយនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ភិក្ខុធ្លាប់ជាអ្នករកាំមួយរូប

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុមួយរូបធ្លាប់ជាអ្នករបាំ ត្រាស់ព្រះធម្មទេសនានេះថា **ហិត្វា មានុសកំ** ជាដើម ។

បានឮថា អ្នករបាំនោះត្រាច់លេងកីឡា គឺការរាំមួយប្រភេទ ស្តាប់ធម្ម-កថារបស់ព្រះសាស្តា បួសហើយសម្រេចអរហត្ត កាលភិក្ខុនោះកំពុងចូលទៅបិណ្ឌបាតជាមួយភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ភិក្ខុទាំងឡាយបានឃើញកូនរបស់អ្នករបាំម្នាក់កំពុងលេង ទើបសួរថា អាវុសោ បុត្ររបស់អ្នករបាំនោះលេងកីឡាដែលលោកលេងហើយ លោកមានការជាប់ជំពាក់ក្នុងកីឡាប្រភេទនេះដែរឬហ្ន៎ កាលភិក្ខុនោះឆ្លើយថា មិនមាន ទើបពោលថា អាវុសោ ភិក្ខុនេះពោលមិនពិត ព្យាករអរហត្តផល ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតឈានកន្ធងកិលេស ជាគ្រឿងប្រកបទាំងពួងបានហើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ហិត្វា មានុសកំ យោគំ ទិព្វំ យោគំ ឧបច្ចគា
សព្វយោគវិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា លះកិលេសជាគ្រឿងប្រកប ដែលជារបស់មនុស្ស កន្ធងកិលេសជាគ្រឿងប្រកប ដែលជារបស់ទិព្វបានហើយ តថាគតហៅបុគ្គលដែលផុតស្រឡះចាកកិលេសជាគ្រឿងប្រកបទាំងពួងនោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **មានុសកំ យោគំ** បានដល់ អាយុនិងកាមគុណទាំង ៥ ដែលជារបស់មនុស្ស ក្នុងកិលេសជាគ្រឿងប្រកបដែលជាទិព្វ ក៏នយនេះដូចគ្នា ។

បទថា **ឧបច្ចគា** ជាដើម សេចក្តីថា បុគ្គលណាលះកិលេសជាគ្រឿងប្រកប ដែលជារបស់មនុស្ស ឈានកន្លងកិលេសគ្រឿងប្រកបដែលជាទិព្វបានហើយ តថាគតហៅបុគ្គលនោះដែលផុតស្រឡះចាកកិលេស ជាគ្រឿងប្រកប ៤ យ៉ាងបានហើយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ॥

រឿង ភិក្ខុធ្លាប់ជាអ្នកវាំមួយរូប ចប់

រឿង ភិក្ខុធ្លាប់ជាអ្នករចាំមួយរូបទៀត

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុដែលធ្លាប់ជាអ្នករចាំ ដូចគ្នានឹងភិក្ខុរូបទីមួយ ទើបត្រាស់ព្រះធម្មទេសនានេះថា **ហិត្វា រតឺ** ជាដើម ។

រឿងដូចគ្នានឹងរឿងមុននោះឯង តែក្នុងរឿងនេះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតលះសេចក្តីត្រេកអរ និងមិនត្រេកអរបានហើយតាំងនៅ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ហិត្វា រតឺ អរតិញ្ច សីតិភូតំ និរូបធឹ
សព្វលោកាភិភុំ វីរំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគតហៅបុគ្គល ដែលលះបង់សេចក្តីត្រេកអរក្នុងកាមគុណ និងមិនត្រេកអរក្នុងកិរិយានៅក្នុងព្រៃ ជាអ្នកមានចិត្តត្រជាក់ មិនមានឧបក្កិលេស គ្របសង្កត់លោកទាំងពួង មានសេចក្តីព្យាយាមនោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **រតឺ** បានដល់ សេចក្តីត្រេកអរក្នុងកាមគុណ ៥ ។

បទថា **អរតឺ** បានដល់ បុគ្គលមិនត្រេកអរក្នុងការនៅព្រៃ ។

បទថា **សីតិភូតំ** បានដល់ ជាអ្នករម្ងាប់ហើយ ។

បទថា **និរូបធឹ** បានដល់ អ្នកមិនមានឧបធិ គឺកិលេស ។

បទថា **វីរំ** *សេចក្តីថា តថាគតហៅបុគ្គលដែលគ្របសង្កត់ខន្ធលោកទាំងអស់បានហើយ តាំងនៅ ជាអ្នកមានសេចក្តីក្សៀវក្សាខ្លាំងនោះ គឺបែបនោះថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ភិក្ខុធ្លាប់ជាអ្នករចាំមួយរូបទៀត ចប់

រឿង ព្រះវង្គីសត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះវង្គីសត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ចុតិ យោ វេទិ** *ជាដើម ។*

បានឮថា ព្រាហ្មណ៍ក្នុងក្រុងរាជគ្រឹះម្នាក់ឈ្មោះវង្គីសៈ ជាអ្នកគោះលលាដ៍ក្បាលរបស់ពួកមនុស្សដែលស្លាប់ហើយដឹងបានថា នេះជាក្បាលរបស់បុគ្គលដែលកើតក្នុងនរក នេះជាក្បាលរបស់បុគ្គលដែលកើតក្នុងកំណើតតិរច្ឆាន នេះជាក្បាលរបស់បុគ្គលដែលកើតក្នុងបិត្តិវិស័យ នេះជាក្បាលរបស់បុគ្គលដែលកើតក្នុងមនុស្សលោក នេះជាក្បាលរបស់បុគ្គលដែលកើតក្នុងទេវលោក ។

ពួកព្រាហ្មណ៍គិតថា ពួកយើងអាស្រ័យវង្គីសព្រាហ្មណ៍នេះ ក៏អាចរកស៊ីក្នុងលោកបាន ទើបឲ្យស្បែកសំពត់ក្រហម ២ ផ្ទាំង ហើយនាំគ្រាច់ទៅក្នុង

ជនបទ ពោលនឹងពួកមនុស្សថា ព្រាហ្មណ៍ឈ្មោះវង្គីសៈ គោះលលាដ៍ក្បាលរបស់ពួកមនុស្សដែលស្លាប់ហើយក៏ដឹងទីកើត ចូរពួកអ្នកសួរដល់ទីដែលពួកញាតិរបស់ខ្លួនកើតហើយចុះ ។

ពួកមនុស្សឲ្យកហាបណៈ ១០ ខ្ទះ ២០ ខ្ទះ ១០០ ខ្ទះ តាមកម្លាំងហើយទើបសួរដល់ពួកញាតិដែលកើតហើយ ។ ព្រាហ្មណ៍ទាំងនោះដល់ក្រុងសាវត្ថីដោយលំដាប់ហើយ កាន់យកទីសម្រាកក្នុងទីមិនឆ្ងាយអំពីវត្តជេតពន ពួកជនទាំងនោះឃើញមហាជនបរិភោគអាហារព្រឹកហើយ មានដៃកាន់គ្រឿងក្រអូបនិងកម្រងផ្កាជាដើម កំពុងដើរទៅដើម្បីស្តាប់ធម៌ ទើបសួរថា ពួកអ្នកទៅណា កាលមហាជនប្រាប់ថា ទៅកាន់វិហារដើម្បីស្តាប់ធម៌ ទើបពោលថា ពួកអ្នកទៅក្នុងទីនោះធ្វើអ្វី បុគ្គលដែលប្រៀបស្មើនឹងវង្គីសព្រាហ្មណ៍របស់ពួកយើង មិនមាន វង្គីសៈគោះលលាដ៍ក្បាលរបស់ពួកមនុស្សដែលស្លាប់ហើយដឹងទីកើតបាន ចូរពួកអ្នកសួរដល់ទីដែលពួកញាតិកើតចុះ ។

មនុស្សទាំងនោះពោលថា វង្គីសៈដឹងអ្វី បុគ្គលដែលប្រៀបផ្ទឹមនឹងព្រះសាស្តារបស់ពួកយើងមិនមាន ។ កាលពួកព្រាហ្មណ៍ក្រៅអំពីនេះពោលថា បុគ្គលដែលផ្ទឹមនឹងវង្គីសៈមិនមាន ក៏ប្រកែកគ្នាហើយពោលថា មក ឥឡូវនេះពួកយើងនឹងដឹងថា វង្គីសៈរបស់ពួកអ្នក ឬព្រះសាស្តារបស់ពួកយើង មានការដឹង ហើយបាននាំព្រាហ្មណ៍ទាំងនោះទៅកាន់វិហារ ។

ព្រះសាស្តាទ្រង់ជ្រាបថាជនទាំងនោះមក ទើបត្រាស់ឲ្យនាំលលាដ៍ក្បាល ៥ មក គឺលលាដ៍ក្បាលសត្វដែលកើតក្នុងឋាន: ៤ គឺក្នុងនរក ក្នុងកំណើត

តិរច្ឆាន ក្នុងមនុស្សលោក ក្នុងទេវលោក និងលលាដ៍របស់ព្រះខីណាស្រពគ្រាស់ឲ្យតម្រៀបតាមលំដាប់ ។ ក្នុងពេលដែលវង្គីសៈមកហើយ ទើបគ្រាស់សួរវង្គីសៈថា បានឮថា អ្នកគោះលលាដ៍ក្បាលហើយ ដឹងទីកើតរបស់សត្វទាំងឡាយដែលស្លាប់ហើយឬ វង្គីសៈទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គអាចដឹងបាន ព្រះសាស្តាគ្រាស់ថា នេះលលាដ៍ក្បាលរបស់អ្នកណា វង្គីសៈគោះហើយ ទូលថា របស់សត្វដែលកើតក្នុងនរក ។ លំដាប់នោះ ព្រះសាស្តាប្រទានសាធុការថា សាធុ ទើបគ្រាស់សួរដល់លលាដ៍ក្បាលទាំង ៣ ក្រៅអំពីនេះ ក្នុងខណៈដែលព្រាហ្មណ៍ក្រាបទូលហើយមិនខុស ក៏ប្រទានសាធុការយ៉ាងនោះ ទើបទ្រង់បង្ហាញលលាដ៍ក្បាលទី ៥ គ្រាស់សួរថា នេះលលាដ៍ក្បាលរបស់អ្នកណា ព្រាហ្មណ៍គោះហើយ មិនដឹងទីកើត ។ ពេលនោះព្រះសាស្តាគ្រាស់នឹងព្រាហ្មណ៍ថា វង្គីសៈ អ្នកមិនដឹងឬ កាលព្រាហ្មណ៍ក្រាបទូលថា ខ្ញុំព្រះអង្គមិនដឹង ទើបគ្រាស់ថា តថាគតដឹង វង្គីសៈពោលថា ទ្រង់ជ្រាបដោយអ្វី ព្រះសាស្តាគ្រាស់ថា ជ្រាបដោយកម្លាំងមន្ត ។

លំដាប់នោះ វង្គីសៈទូលអង្វរថា សូមទ្រង់ប្រទានមន្តនេះដល់ខ្ញុំព្រះអង្គ ព្រះសាស្តាគ្រាស់ថា តថាគតមិនអាចឲ្យមន្តដល់បុគ្គលដែលមិនបានបួស ។

ព្រាហ្មណ៍គិតថា កាលអញរៀនមន្តនេះហើយ អញនឹងបានជាបុគ្គលប្រសើរក្នុងជម្ពូទ្វីបទាំងមូល ទើបបញ្ជូនព្រាហ្មណ៍ទាំងនោះទៅដោយពាក្យថា ចូរពួកអ្នកនៅក្នុងទីនេះឯងអស់ ២-៣ ថ្ងៃ ខ្ញុំនឹងបួស ហើយបានបំពេញបព្វជ្ជាឧបសម្បទាក្នុងសម្នាក់ព្រះសាស្តា ជាអ្នកមានឈ្មោះថា វង្គីសត្ថេរ ។

លំដាប់នោះ ព្រះសាស្តាប្រទានកម្មដ្ឋាន មានអាការ ៣២ ជាអារម្មណ៍ដល់លោកហើយ ត្រាស់ថា ចូរអ្នកស្វាធ្យាយបរិកម្មនៃមន្ត ។

វិទ្ធីសត្តេរកំពុងស្វាធ្យាយមន្ត ត្រូវពួកព្រាហ្មណ៍សួរក្នុងចន្លោះៗ ថា លោកម្ចាស់រៀនមន្តបានហើយឬ ទើបប្រាប់ថា ចូរពួកអ្នកបង្អង់សិន អាត្មាកំពុងរៀន ក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចអរហត្ត ។ ព្រាហ្មណ៍ទាំងឡាយសួរទៀត ទើបពោលថា អាវុសោ ឥឡូវនេះ ខ្ញុំមិនគួរទៅ ពួកភិក្ខុស្តាប់ពាក្យនោះហើយ ទើបក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ វិទ្ធីសត្តេរនេះ ព្យាករអរហត្តផល ដោយពាក្យមិនពិត ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំពោលយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ បុត្ររបស់តថាគតឈ្វាសក្នុងការចុតិ និងបដិសន្ធិហើយ ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

ចុតឹ យោ វេទិ សត្តានំ ឧបបត្តិញ្ច សព្វសោ
អសត្តំ សុគតំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។
យស្ស គតឹ ន ជានន្តិ ទេវា គន្ធព្វមានុសា
ខីណាសវំ អរហន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ជីងច្បាស់ចុតិ និងបដិសន្ធិរបស់ពួកសត្វ ដោយអាការទាំងពួងបាន តថាគតហៅបុគ្គល ដែលជាអ្នកមិនជាប់នៅក្នុងកាម អ្នកមានដំណើរល្អ ដោយសេចក្តីប្រតិបត្តិ អ្នកត្រាស់ជីងនូវសច្ចៈ ៤ នោះ ថាជាព្រាហ្មណ៍ ។

ទេវតា គន្ធព្វ និងពួកមនុស្សទាំងឡាយ មិនដឹងគតិរបស់បុគ្គលណា តថាគតហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្តនោះថា ជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **យោ ឥធ** *ជាដើម សេចក្តីថា បុគ្គលណា ដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ដោយប្រការទាំងពួងយ៉ាងជាក់ច្បាស់ តថាគតហៅបុគ្គលនោះ ដែលឈ្មោះថា មិនជាប់ជំពាក់ ព្រោះភាពជាអ្នកមិនជាប់ជំពាក់ ឈ្មោះថា ទៅល្អហើយ ព្រោះភាពជាអ្នកទៅល្អហើយក្នុងកិច្ចបដិបត្តិ ឈ្មោះថា ជាអ្នកដឹងហើយ ព្រោះភាពជាអ្នកដឹងសច្ចៈទាំង ៤ ថាជាព្រាហ្មណ៍ ។*

បទថា **យស្ស** *ជាដើម សេចក្តីថា ទេវតាជាដើមនោះមិនដឹងគតិរបស់បុគ្គលណា តថាគតហៅបុគ្គលដែលឈ្មោះថាមានអាសវៈអស់ហើយ ព្រោះភាពដែលអាសវៈទាំងឡាយអស់ហើយ ឈ្មោះថាជាអ្នកឆ្ងាយចាកកិលេស ព្រោះភាពជាអ្នកឆ្ងាយចាកកិលេសទាំងឡាយ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះវង្គីសត្ថេរ ចប់

រឿង ព្រះនាងធម្មទិន្នាថេរី

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុនីឈ្មោះធម្ម-ទិន្នាថេរី ត្រាស់ព្រះធម្មទេសនានេះថា **យស្សូ ឃុរេ ច** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ក្នុងកាលដែលនាងនៅជាគ្រហស្ថ វិសាខ-ឧបាសកជាស្វាមី ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា សម្រេចអនាគាមិ-ផលហើយ គិតថា ការដែលអញឲ្យធម្មទិន្នាទទួលទ្រព្យសម្បត្តិទាំងពួង គួរក្នុងកាលមុនអំពីនោះ ឧបាសកនោះកាលមក ឃើញនាងធម្មទិន្នាកំពុងឈរមើលត្រង់មាត់បង្អួច រមែងធ្វើការញញឹម តែក្នុងថ្ងៃនោះ មិនសម្លឹងមើលនាង ដែលឈរត្រង់បង្អួចឡើយ បានទៅហើយ ។

នាងគិតថា តើមានរឿងអ្វីហ្ន៎ ហើយគិតទៀតថា សេចក្តីនោះចូរលើកទុក អញនឹងដឹងក្នុងពេលបរិភោគ ហើយនាំកត្តចូលទៅក្នុងពេលបរិភោគ ។ ក្នុងថ្ងៃដទៃ ឧបាសកពោលថា មក យើងនឹងបរិភោគជាមួយគ្នា តែក្នុងថ្ងៃនោះជាអ្នកអង្គុយស្ងៀមបរិភោគហើយ នាងគិតថា ប្តីគង់នឹងក្រោធដោយហេតុណាមួយពិតប្រាកដ ។

គ្រានោះ វិសាខឧបាសក ហៅនាងក្នុងពេលអង្គុយតាមសប្បាយមក ហើយពោលថា ធម្មទិន្នា ចូរនាងទទួលទ្រព្យសម្បត្តិទាំងពួងក្នុងផ្ទះនេះចុះ នាងគិតថា ធម្មតាមនុស្សទាំងឡាយដែលក្រោធហើយ រមែងមិនឲ្យអ្នកណាទទួលទ្រព្យសម្បត្តិ តើមានរឿងអ្វីហ្ន៎ ទើបពោលថា ចុះអ្នកវិញ ឧបាសកពោលថា ចាប់អំពីថ្ងៃនេះទៅ ខ្ញុំមិនចាត់ចែងការងារណាមួយ ធម្មទិន្នាពោលថា អ្នកណា

នឹងទទួលទឹកមាត់ដែលអ្នកស្តោះចោល កាលបើដូច្នោះ សូមអ្នកអនុញ្ញាតការបួសដល់ខ្ញុំចុះ ។

ឧបាសកទទួលថា សាធុ នាំនាងទៅកាន់សម្នាក់ភិក្ខុនីដោយសក្ការៈធំឲ្យបួសហើយ នាងបានឧបសម្បទាហើយ បានឈ្មោះថា ធម្មទិន្នាថេរី ។

នាងទៅកាន់ជនបទជាមួយភិក្ខុនីទាំងឡាយ ព្រោះជាអ្នកបំណងវិវេកកាលនៅក្នុងជនបទនោះ មិនយូរប៉ុន្មានក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ត្រឡប់មកកាន់ក្រុងរាជគ្រឹះវិញ ដោយគិតថា ឥឡូវនេះ ពួកជនដែលជាញាតិអាស្រ័យអញហើយ នឹងធ្វើបុណ្យទាំងឡាយ ។

ឧបាសកបានជ្រាបភាពដែលព្រះថេរីមកហើយគិតថា ព្រះថេរីមកព្រោះហេតុអ្វីហ្ន៎ ទើបទៅកាន់សម្នាក់ភិក្ខុនី ថ្វាយបង្គំព្រះថេរីហើយអង្គុយក្នុងចំណែកម្ខាងគិតថា កាលដែលអញពោលថា បពិត្រអ្នកនាងម្ចាស់ នាងអផ្សុកឬ ដូច្នេះក៏ជាការមិនគួរ អញសួរបញ្ហាមួយ ជាមួយព្រះថេរីនោះ ហើយសួរបញ្ហាក្នុងសោតាបត្តិមគ្គ ព្រះថេរីឆ្លើយបញ្ហានោះបាន ឧបាសកសួរបញ្ហាក្នុងអរហត្តមគ្គដ៏សេសដោយឧបាយនោះឯង កាលព្រះថេរីនោះពោលក្នុងវេលាបញ្ហា ដែលឧបាសកនោះសួរឈានកន្ធវិស័យថា អាវុសោវិសាខៈ អ្នកកន្ធវិស័យទៅហើយហើយពោលថា បើអ្នកចង់ជីវិតគប្បីចូលគាល់ព្រះសាស្តា ហើយទូលសួរបញ្ហានោះ ថ្វាយបង្គំព្រះថេរីហើយក្រោកចាកអាសនៈ ទៅកាន់សម្នាក់ព្រះសាស្តាក្រាបទូលការសន្ទនាប្រាស្រ័យទាំងអស់នោះ ជល់ព្រះដ៏មានព្រះភាគ ។

ព្រះសាស្តាត្រាស់ថា ធម្មទិន្នាធីតារបស់តថាគតពោលល្អហើយ ទោះបី

តថាគត កាលឆ្លើយបញ្ហានោះ ក៏គប្បីឆ្លើយយ៉ាងនោះដូចគ្នា ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

យស្ស បុរេ ច បច្ឆា ច មជ្ឈេ ច នត្ថិ កិញ្ចនំ
អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា មិនមានសេចក្តីកង្វល់ក្នុងកាលមុនផង ក្នុងកាលជាខាងក្រោយផង ក្នុងកាលជាកណ្តាលផង តថាគតហៅបុគ្គលដែលជាអ្នកមិនមានកង្វល់ មិនមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បុរេ** *សេចក្តីថា ក្នុងខន្ធទាំងឡាយដែលជាអតីត ។ បទថា* **បច្ឆា** *គឺក្នុងខន្ធទាំងឡាយដែលជាអនាគត ។ បទថា* **មជ្ឈេ** *បានដល់ ខន្ធទាំងឡាយដែលជាបច្ចុប្បន្ន ។*

ពីរបទថា **នត្ថិ កិញ្ចនំ** *ជាដើម សេចក្តីថា ការកង្វល់ ពោល គឺការប្រកាន់ដោយតណ្ហាក្នុងហេតុទាំង ៣ នោះរបស់បុគ្គលណាមាន តថាគតហៅបុគ្គលនោះ ដែលមិនមានសេចក្តីកង្វល់ដោយកិលេសជាគ្រឿងកង្វល់ គឺរាគៈជាដើម ដែលឈ្មោះថាមិនមានការប្រកាន់មាំ ព្រោះមិនមានការប្រកាន់មាំក្នុងអ្វីមួយ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះអង្គុលីមាលត្ថេរ

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះអង្គុលីមាលត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ឧសភំ** ជាដើម ។

រឿងខ្ញុំបានពោលហើយ ក្នុងកាលពណ៌នាកថាថា **ន វ កធរិយា ទេវលោកំ វជន្តិ** ជាដើមនោះឯង ។

ពិតហើយ ក្នុងទីនោះ ខ្ញុំពោលថា ភិក្ខុទាំងឡាយសួរព្រះអង្គុលីមាលថា អាវុសោ លោកយើញជំរីកាចឈរបាំងធត្រហើយ មិនខ្លាចឬហ្នឹ ព្រះអង្គុលីមាលធ្លើយថា អាវុសោ ខ្ញុំមិនខ្លាចទេ ភិក្ខុទាំងនោះ ក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ ព្រះអង្គុលីមាលព្យាករព្រះអរហត្តដោយពាក្យមិនពិត ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អង្គុលីមាលបុត្ររបស់តថាគត មិនខ្លាច ព្រោះថា ភិក្ខុទាំងឡាយដូចគ្នានឹងបុត្ររបស់តថាគត ជាអ្នកអង់អាចបំផុត ក្នុងរវាងព្រះខីណាស្រពដែលអង់អាចទាំងឡាយ មិនខ្លាចដូច្នេះហើយ ត្រាស់ព្រះគាថានេះ ក្នុងព្រាហ្មណវគ្គថា

ឧសភំ បវរំ វីរំ **មហេសឹ វិជិតាវិនំ**
អនេជំ ន្ហាតកំ ពុទ្ធំ **តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត ហៅវីរបុរស អ្នកអង់អាច អ្នកប្រសើរ អ្នកស្វែងរកគុណដ៏ធំ ឈ្នះមារ មិនមានកិលេសជាគ្រឿងញាប់ញ័រ ងូតលាងកិលេស ត្រាស់ដឹងសច្ចៈនោះថា ជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះថា តថាគតហៅបុគ្គលនោះ គឺបែបនោះ ដែលឈ្មោះថា **ឧសភំ** *ព្រោះដូចគ្នានឹងគោឧសភៈ ដោយអត្ថថា ជាអ្នកមិនតក់ស្លុត ឈ្មោះថា* **បវរំ** *ព្រោះឧត្តម ឈ្មោះថា* **វីរំ** *ព្រោះដល់ព្រមដោយភាពជាអ្នកក្លាហាន ឈ្មោះថា* **មហេសឺ** *ព្រោះភាពជាអ្នកស្វែងរកគុណដ៏ធំ មានសីលក្ខន្ធជាដើម ឈ្មោះថា* **វិជិតាវិនំ** *ព្រោះភាពដែលមានទាំង ៣ ដែលខ្លួនឈ្នះហើយ ឈ្មោះថា* **ន្ហាតកំ** *ព្រោះភាពជាអ្នកមានកិលេសលាងហើយ ឈ្មោះថា* **ពុទ្ធំ** *ព្រោះភាពជាអ្នកដឹងសច្ចៈ ៤ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងព្រះអង្គុលីមាលត្ថេរ ចប់

រឿង ទេវហិតព្រាហ្មណ៍

លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហារបស់ទេវ-ហិតព្រាហ្មណ៍ ត្រាស់ព្រះធម្មទេសនានេះថា **ឃុញ្ជេនិវាសំ** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ ព្រះសាស្តាទ្រង់អាពាធ ដោយព្រះវាយោកម្រើក ទ្រង់បញ្ជូនព្រះឧបវានត្ថេរ ទៅកាន់សម្នាក់របស់ទេវហិត-ព្រាហ្មណ៍ ដើម្បីទឹកក្តៅ ។ ព្រះថេរៈទៅប្រាប់ភាពដែលព្រះសាស្តាទ្រង់អាពាធ ហើយសូមទឹកក្តៅ ។

ព្រាហ្មណ៍ស្តាប់ពាក្យនោះហើយ ជាអ្នកមានចិត្តត្រេកអរគិតថា ការដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បញ្ជូនព្រះឧបវានត្ថេរមកកាន់សម្នាក់របស់អញ ដើម្បីទឹកក្តៅ ជាលាភរបស់អញហ្ន៎ ទើបឲ្យបុរសកាន់យកអម្រែកទឹកក្តៅ និងកញ្ចប់ស្ករអំពៅ ប្រគេនដល់ព្រះឧបវានត្ថេរ ។

ព្រះថេរៈ ឲ្យជនកាន់យកទឹកក្តៅជាដើមនោះទៅកាន់វិហារ ក្រាបទូលព្រះសាស្តាឲ្យទ្រង់ស្រង់ដោយទឹកក្តៅហើយ រំលាយស្ករអំពៅដោយទឹកក្តៅ ថ្វាយដល់ព្រះសាស្តា ។ ក្នុងខណៈនោះឯង អាពាធរបស់ព្រះសាស្តាក៏ស្ងប់រម្ងាប់ ។ ព្រាហ្មណ៍គិតថា ទេយ្យធម៌របស់អញ ឲ្យដល់អ្នកណាហ្ន៎ ទើបមានផលច្រើន អញនឹងទូលសួរព្រះសាស្តា ព្រាហ្មណ៍នោះ ទៅកាន់សម្នាក់ព្រះដ៏មានព្រះភាគហើយ កាលនឹងទូលសួរសេចក្តីនោះ ទើបពោលគាថាថា

បុគ្គលគួរឲ្យទេយ្យធម៌ដល់បុគ្គលណា ទេយ្យវត្ថុដែលបុគ្គលឲ្យដល់បុគ្គលណា ទើបមានផលច្រើន ទក្ខិណារបស់បុគ្គលដែលបូជាដូចម្តេច នឹងសម្រេចបានដូចម្តេច ។

លំដាប់នោះ ព្រះសាស្តាត្រាស់ថា ទេយ្យវត្ថុដែលបុគ្គលឲ្យហើយដល់ព្រាហ្មណ៍បែបនេះរមែងមានផលច្រើន ដូច្នេះហើយ កាលទ្រង់ប្រកាសបុគ្គលដែលជាព្រាហ្មណ៍ ដល់ព្រាហ្មណ៍នោះ ទើបត្រាស់ព្រះគាថានេះថា

បុព្វេនិវាសំ យោ វេទិ សគ្គាចាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ អភិញ្ញា វោសិតោ មុនិ
សព្វវោសិតវោសានំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ដឹងច្បាស់នូវខន្ធបញ្ចកៈ ដែលខ្លួនធ្លាប់នៅអាស្រ័យក្នុងកាលមុនផង ឃើញច្បាស់ស្ថានសួគ៌ និងអបាយ-ភូមិផង មួយទៀត បានសម្រេចធម៌ជាគ្រឿងអស់ជាតិ ជាអ្នកប្រាជ្ញ ស្រេចកិច្ចហើយ ព្រោះអភិញ្ញា តថាគតហៅបុគ្គលដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ចប់សព្វគ្រប់ហើយនោះថាជាព្រាហ្មណ៍ ។

សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះថា បុគ្គលណាដឹងខន្ធដែលអាស្រ័យនៅពីមុនយ៉ាងជាក់ច្បាស់ ឃើញស្ថានសួគ៌ មានទេវលោក ២៦ ជាន់ និងអបាយ ៤ ដោយទិព្វចក្ខុ ម្យ៉ាងទៀត សម្រេចអរហត្ត ពោល គឺការអស់ទៅនៃជាតិ

សម្រេចកិច្ចហើយ ព្រោះដឹងក្រៃលែងនូវធម៌ដែលគួរដឹងក្រៃលែង កំណត់ដឹងធម៌ដែលគួរកំណត់ដឹង លះធម៌ដែលគួរលះ ធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ គឺសម្រេចព្រះនិព្វាន ឬសម្រេចព្រហ្មចរិយៈដែលខ្ជួននៅចប់ហើយ ឈ្មោះថា ជាមុនី ជាអ្នកសម្រេចការៈនៃបុគ្គលអ្នកដឹងដោយបញ្ញាដែលជាហេតុអស់ទៅនៃអាសវៈ តថាគតហៅបុគ្គលនោះ ដែលឈ្មោះថាមានព្រហ្មចរិយៈនៅចប់ហើយ ព្រោះភាពជាអ្នកនៅចប់ព្រហ្មចរិយៈ ដែលជាទីបំផុតនៃកិលេសទាំងមូល គឺអរហត្តមគ្គញ្ញាណ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ចំណែកព្រាហ្មណ៍ មានចិត្តជ្រះថ្លាហើយ តាំងនៅក្នុងសរណៈទាំងឡាយ ប្រកាសភាពជាឧបាសកហើយ ដូច្នេះឯង ។

រឿងទេវហិតព្រាហ្មណ៍ ចប់

ព្រាហ្មណវគ្គ ចប់

វគ្គទី ២៦ ចប់

វគ្គដែលមានក្នុងគាថាធម្មបទ គឺ

យមកវគ្គ ១ អប្បមាទវគ្គ ១ ចិត្តវគ្គ ១ បុប្ផវគ្គ ១ ពាលវគ្គ ១ បណ្ឌិតវគ្គ ១ អរហន្តវគ្គ ១ សហស្សវគ្គ ១ បាបវគ្គ ១ ទណ្ឌវគ្គ ១ ជរាវគ្គ ១ អត្តវគ្គ ១ លោកវគ្គ ១ ពុទ្ធវគ្គ ១ សុខវគ្គ ១ បិយវគ្គ ១ កោធវគ្គ ១ មលវគ្គ ១ ធម្មដ្ឋវគ្គ ១ មគ្គវគ្គ ១ រួមជា ២០ វគ្គ បកិណ្ណកវគ្គ ១ និរយវគ្គ ១ នាគវគ្គ ១ តណ្ហាវគ្គ ១ ភិក្ខុវគ្គ ១ ព្រាហ្មណវគ្គ ១ រួមទីង ២០ វគ្គខាង ដើមជា ២៦ វគ្គ ដែលព្រះពុទ្ធទ្រង់មានផៅពង្សដូចព្រះអាទិត្យ ទ្រង់សម្តែង ហើយក្នុងយមកវគ្គ មាន ២០ គាថា អប្បមាទវគ្គមាន ១២ គាថា ចិត្តវគ្គ មាន ១១ គាថា បុប្ផវគ្គ មាន ១៦ គាថា ពាលវគ្គ មាន ១៧ គាថា បណ្ឌិតវគ្គ មាន ១៤ គាថា អរហន្តវគ្គ មាន ១០ គាថា សហស្សវគ្គ មាន ១៦ គាថា ក្នុងបាបវគ្គ មាន ១៣ គាថា ក្នុងទណ្ឌវគ្គ មាន ១៧ គាថា ក្នុងជរាវគ្គ មាន ១១ គាថា ក្នុងអត្តវគ្គ មាន ១២ គាថា ក្នុងលោកវគ្គ មាន ១២ គាថា ក្នុងពុទ្ធវគ្គ មាន ១៦ គាថា ក្នុងសុខវគ្គ និងបិយវគ្គ មួយវគ្គមាន ១២ គាថា ក្នុងកោធវគ្គ មាន ១៤ គាថា ក្នុងមលវគ្គ មាន ២១ គាថា ក្នុងធម្មដ្ឋវគ្គ មាន ១៧ គាថា ក្នុងមគ្គវគ្គ មាន ១៦ គាថា ក្នុងបកិណ្ណកវគ្គ មាន ១៦ គាថា ក្នុងនិរយវគ្គ និងនាគវគ្គ មួយវគ្គ មាន ១៤ គាថា ក្នុងតណ្ហាវគ្គ មាន ២២ គាថា ក្នុងភិក្ខុវគ្គ មាន ២៣ គាថា ក្នុងព្រាហ្មណវគ្គ ដែលជាវគ្គចុងក្រោយ មាន ៤០ គាថា ៤២៣ គាថា ដែលព្រះពុទ្ធមានផៅពង្សនៃព្រះអាទិត្យ ទ្រង់សម្តែងក្នុងនិបាតធម្មបទ ។

គាថាធម្មបទ ចប់

សរុបរឿង

អដ្ឋកថានៃធម្មបទមានប្រមាណ ៧២ ភាណវារ ដែលខ្ញុំប្រកាស មាន រឿង ២៩៩ រឿង គឺក្នុងយមកវគ្គ ដែលជាវគ្គដំបូងនៃវគ្គទាំងពួង មាន ១៤ រឿង ក្នុងអប្បមាទវគ្គ ៩ រឿង ក្នុងចិត្តវគ្គ ៩ រឿង ក្នុងបុប្ផវគ្គ ១២ រឿង ក្នុងពាលវគ្គ ១៥ រឿង ក្នុងបណ្ឌិតវគ្គ ១១ រឿង ក្នុងអរហន្តវគ្គ ១០ រឿង ក្នុងសហស្សវគ្គ ១៤ រឿង ក្នុងបាបវគ្គ ១២ រឿង ក្នុងទណ្ឌវគ្គ ១១ រឿង ក្នុងជរាវគ្គ ៩ រឿង ក្នុងអត្តវគ្គ ១០ រឿង ក្នុងលោកវគ្គ ១១ រឿង ក្នុងពុទ្ធវគ្គ ៩ រឿង ក្នុងសុខវគ្គ ៨ រឿង ក្នុងបិយវគ្គ ៩ រឿង ក្នុងកោធវគ្គ ៨ រឿង ក្នុងមលវគ្គ ១២ រឿង ក្នុងធម្មដ្ឋវគ្គ ១០ រឿង ក្នុងមគ្គវគ្គ ១០ រឿង ក្នុងបកិណ្ណកវគ្គ ៩ រឿង ក្នុងនិរយវគ្គ ៩ រឿង ក្នុងនាគវគ្គ ៨ រឿង ក្នុងតណ្ហាវគ្គ ១២ រឿង ក្នុងភិក្ខុវគ្គ ១២ រឿង ក្នុងព្រាហ្មណវគ្គ ៣៩ រឿង ជានរចនាល្មមសមគួរដោយអំណាចមិនសង្ខេបពេក មិនពិស្តារពេក ចប់ហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

ធម្មបទដ្ឋកថា ចប់

ពាក្យឧទ្ទិស

ធម្មបទដ៏កំពូល ដែលព្រះដ៏មានព្រះភាគអង្គណា ដែលជាធម្មរាជាទ្រង់សម្រេចហើយ ព្រះគាថាពួកណាក្នុងព្រះធម្មបទ មានប្រមាណ ៤២៣ គាថា តាំងខ្ទើងហើយក្នុងរឿង ២៩៩ រឿង ដែលព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ស្វែងរកគុណធំ ទ្រង់ញុំាងសច្ចៈទាំង ៤ ឲ្យជាក់ច្បាស់ ទ្រង់កាសិតហើយ ខ្ញុំជាអ្នកនៅក្នុងប្រាសាទរបស់ព្រះបាទសិរិកូដ ក្នុងវិហារអធិរាជ ដែលមានព្រះកតញ្ញូត្រាស់ឲ្យសាងហើយ រៀបរៀងអដ្ឋកថានេះ នៃព្រះគាថាទាំងនោះ ឲ្យដល់ព្រមដោយអត្ថ និងព្យញ្ជនៈ ឲ្យអស់មន្ទិលដោយល្អ តាមព្រះបាលីមានប្រមាណ ៧២ ភាណវារ ដើម្បីប្រយោជន៍ និងដើម្បីអនុគ្រោះដល់លោក ព្រោះភាពដែលខ្ញុំជាអ្នកប្រាថ្នាដើម្បីការតាំងមាំ នៃព្រះសទ្ធម្មរបស់ព្រះលោកនាថ បានសម្រេចកុសលណាហើយ ដោយអំណាចកុសលនោះ សូមតម្រិះដែលជាកុសលទាំងពួង ចូរឲ្យផលដែលគួរប្រាថ្នា សម្រេចដល់សត្វទាំងពួង ដោយប្រការដូច្នេះ ។

គុណាព្រះពុទ្ធឃោសាចារ្យ

ព្រះថេរៈទ្រទ្រង់នូវឈ្មោះ ដែលគ្រូទាំងឡាយឲ្យហើយថា **ពុទ្ធឃោសៈ** ជាអ្នកប្រដាប់ដោយសទ្ធា ប្រាជ្ញា និងសេចក្តីព្យាយាមបរិសុទ្ធក្រៃលែង មានគុណសមុទយៈ មានសីល អាចារ ភាពជាអ្នកស្មោះត្រង់ និងភាពជាអ្នកទន់ភ្លន់ជាដើមដល់ព្រមហើយ អាចឈមចុះក្នុងការកាន់យកលទ្ធិរបស់ខ្លួន និងលទ្ធិដទៃ ប្រកបដោយការឈ្វាសនៃបញ្ញា ប្រកាសញ្ញាណដែលមិនទើសទាក់ក្នុងសត្ថុសាសនៈ មានបរិយត្តិធម៌ គឺព្រះត្រៃបិដក មួយអន្ទើដោយអដ្ឋកថា ជាអ្នកជំនាញក្នុងវេយ្យាករណ៍ ជាអ្នកប្រកបដោយគន្ថនៃពាក្យពីរោះក្រៃលែង ដែលបន្ទឹចេញបានស្រួល ដែលញុំងករណសម្បត្តិឲ្យកើត ជាអ្នកមានប្រក្រតីពោលត្រឹមត្រូវ ស្ទាត់ជំនាញ ប្រសើរក្នុងពាក្យពោល ជាមហាកវី ជាអ្នកប្រដាប់វង្សរបស់ព្រះថេរៈទាំងឡាយ ដែលនៅក្នុងមហាវិហារដោយប្រក្រតី ជាបុគ្គលប្រៀបដូចប្រទីបក្នុងវង្សរបស់ព្រះថេរៈ ដែលមានការដឹងមិនទើសទាក់ ក្នុងឧត្តរិមនុស្សធម្ម ដែលប្រដាប់ដោយគុណ មានអភិញ្ញា ៦ និងបដិសម្ភិទា ៤ ជាដើម មានការដឹងបរិបូណ៌ បរិសុទ្ធ រៀបរៀងអត្ថវណ្ណនានៃព្រះធម៌នេះហើយ ។

សុត្តន្តបិដក ខុទ្ទកនិកាយ

ឧទាន

សូមនមស្ការ ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធ អង្គនោះ

ពោធិវគ្គទី ១

បឋមពោធិសូត្រ

[៣៨] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ បានគ្រាស់ជីងជាដំបូង ទ្រង់គង់នៅក្បែរគល់ពោធិព្រឹក្ស ទៀបឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។*

សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ដោយបល្ល័ង្កតែមួយ សោយវិមុត្តិសុខអស់មួយសប្តាហ៍ (៧ ថ្ងៃ) ។ លុះអំណឹះសប្តាហ៍នោះហើយ ព្រះមានព្រះភាគ ទ្រង់ចេញអំពីសមាធិនោះ ទ្រង់រំពឹងក្នុងព្រះហប្ញទ័យចំពោះបដិច្ចសមុប្បាទធម៌ ជាអនុលោម គឺពិចារណាបណ្តាយ អស់រាត្រីបឋមយាម ដោយប្រពៃថា កាលបើបច្ច័យនេះមាន ផលនេះក៏មាន ផលនេះរមែងកើតឡើង ព្រោះការកើតឡើងនៃបច្ច័យនេះ គឺសង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈ កើតមាន ព្រោះនាមរូបជាបច្ច័យ

ផស្សៈ កើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ក៏រមែងកើតព្រម ការកើតឡើងនៃកងទុក្ខទាំងអស់នោះ រមែងមានយ៉ាងនេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺនូវឧទាននេះ ក្នុងវេលានោះថា

> *ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាម ញុាំងកិលេសឲ្យក្តៅ អ្នកជុតបង់នូវកិលេស ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយ ទាំងពួងរបស់ព្រាហ្មណ៍នោះ រមែងអស់ទៅ ក្នុងកាលនោះ ព្រោះដឹងច្បាស់នូវធម៌ ព្រមទាំងហេតុ ។*
>
> *សូត្រទី ១ ។*

អដ្ឋកថា

ខុទ្ទកនិកាយ ឈ្មោះ បរមត្ថទីបនី

អធិប្បាយ ខុទ្ទាន

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

បឋមភាគ

ខ្ញុំសូមនមស្ការព្រះលោកនាថ ដែលប្រកបដោយព្រះមហាករុណា ជាអ្នកដល់នូវត្រើយសាគរ គឺញេយ្យធម៌ ទ្រង់សម្តែងធម៌ដ៏ល្អិតជ្រាលជ្រៅ មានន័យដ៏វិចិត្រ ។

ខ្ញុំសូមនមស្ការព្រះធម៌ដ៏ឧត្តម ដែលព្រះសម្មាសម្ពុទ្ធទ្រង់បូជាហើយ ដែល ជាហេតុនាំសត្វ ដែលដល់ព្រមដោយវិជ្ជា និងចរណៈ ចេញចាកលោក ។

ខ្ញុំសូមនមស្ការព្រះអរិយសង្ឃ ដែលសម្បូរដោយសីលគុណជាដើម តាំងនៅក្នុងមគ្គ និងផល ជាបុញ្ញក្ខេត្តដ៏កំពូល ។ បុណ្យណា ដែលកើតអំពីការថ្វាយបង្គំព្រះរតនត្រ័យ សូមឲ្យខ្ញុំព្រះករុណាជាបុគ្គលមានអន្តរាយ ដែលតេជៈនៃបុណ្យកម្ចាត់ហើយ ក្នុងទីគ្រប់អន្លើ ។

ព្រះមហេសី អ្នកស្វែងរកនូវប្រយោជន៍ ទ្រង់សម្តែងឧទានណា ដោយ

និទាននោះៗ ដោយអបទានដ៏បរិសុទ្ធ ព្រះធម្មសង្គាហកាចារ្យ កាលលើកឧទានទាំងអស់នោះមក ជាពួកតែមួយ ហើយចងក្រង ឲ្យឈ្មោះថា ឧទាន ដែលជាគ្រឿងសម្តែងសេចក្តីសង្វេគ និងជាមោជ្ជ ក្នុងធម៌របស់ព្រះជិនស្រី ប្រជាប់ដោយគាថា ដែលមានសោមនស្សញ្ញាណជាសមុដ្ឋាន ។

ខ្ញុំធ្វើកិច្ចពណ៌នាអត្ថនៃឧទាននោះ ធ្វើបានដោយលំបាក ព្រោះត្រូវប្រើញាណដ៏ជ្រាលជ្រៅ ឈមចុះក៏ពិត តែទោះជាដូច្នោះ ព្រោះសត្ថុសាសន៍មួយអន្ទើដោយសំវណ្ណនាគង់នៅ ការវិនិច្ឆ័យរបស់បុព្វចារ្យអ្នកសីហឡ ក៏គង់នៅជួចគ្នា ដូច្នោះ ទើបខ្ញុំទាញយកសត្ថុសាសន៍នោះ ឈមចុះកាន់និកាយទាំង ៥ អាស្រ័យនយបុរាណអដ្ឋកថាដ៏បរិសុទ្ធល្អ មិនលាយឡំគ្នា ទាញយកលទ្ធិរបស់ព្រះមហាថេរៈដែលនៅក្នុងមហាវិហារវៀរអត្ថដែលជាន់គ្នាជដែលៗចេញ សម្តែងតែអដ្ឋកថាឧទាន តាមកម្លាំងឲ្យល្អ ដូច្នោះ ខ្ញុំសង្ឃឹមការតាំងមាំនៃព្រះសទ្ធម្ម ចែកអត្ថនៃឧទាន សូមសាធុជនទាំងឡាយ ទទួលយកដោយល្អហោង ។

បណ្តាបទទាំងនោះ បទថា **ឧទានំ** *សេចក្តីថា ឈ្មោះថា ឧទាន ដោយអត្ថជូចម្តេច ដោយអត្ថបន្ទឺចេញ ។ ដែលឈ្មោះថា* **ឧទាន** *នេះ គឺអ្វី គឺការបន្ទឺដែលតាំងឡើងដោយកម្លាំងរបស់បីតិ ។ ឧបមាដូចវត្តុដែលគប្បីរាប់ មានប្រេងជាដើម យ៉ាងណា មិនអាចរាប់យកប្រមាណបាន រមែងហូរទៅ វត្តុនោះ ហៅថា* **អាសេក** *គឺហូរចុះ ម្យ៉ាងទៀត ខ្សែទឹកណាមិនអាចដក់ក្នុងអូរតែងហូរទៅ ខ្សែទឹកនោះ ហៅថា* **ឱឃ** *គឺជំនន់ទឹក យ៉ាងណា វត្តុណាដែល*

តាំងឡើងដោយកម្លាំងបីតិ ផ្សាយទៅដោយកម្លាំងវិតក្ក មិនអាចតាំងនៅក្នុងហទយៈបាន ក៏ដូច្នោះ ការបន្ទឺចេញជ័រវិសេសនោះ ជារបស់ក្រៃលែង តាំងនៅខាងក្នុងមិនបាន ចេញទៅខាងក្រៅតាមរបើទ្វារ មិនអាចដើម្បីនឹងទុកនៅ ហៅថា **ឧទាន** *អាការនេះ រមែងបានដោយអំណាចសេចក្តីសង្វេគក្នុងធម៌ ។*

ឧទាននេះ ទីខ្លះប្រព្រឹត្តទៅដោយអំណាចចង់ជាគាថា ទីខ្លះ ប្រព្រឹត្តទៅដោយអំណាចវាចា ។ លក្ខណៈឧទានឯណា ដែលលោកពោលក្នុងអដ្ឋកថាទាក់ទងដោយគាថា ដែលសម្រេចមកអំពីសោមនស្សញ្ញាណនោះ ពោលដោយចំណែកច្រើន ។ ដោយច្រើន ឧទាន លោកពោលដោយការចង់ជាគាថា និងតាំងឡើងដោយអំណាចបីតិ និងសោមនស្ស ។ តែឧទានក្រៅអំពីនេះ រមែងបានក្នុងប្រយោគជាដើមថា **អត្ថិ ភិក្ខវេ តទាយតនំ យត្ថ នេវ បឋវី ន អាចោ** *ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះ រមែងមានពិត ដីមិនមាន ទឹកមិនមាន ... និងបានក្នុងប្រយោគជាដើមថា* **សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឹសតិ** *បុគ្គលណា កាលស្វែងរកសេចក្តីសុខ ដើម្បីខ្លួនហើយបៀតបៀនពួកសត្វ អ្នកប្រាថ្នាសេចក្តីសុខដោយដំបង ... និងបានក្នុងប្រយោគជាដើមថា* **សចេ ភាយថ ទុក្ខស្ស សចេ នោ ទុក្ខមប្បិយំ** *បើអ្នកទាំងឡាយ ខ្លាចសេចក្តីទុក្ខ បើសេចក្តីទុក្ខ មិនជាទីស្រឡាញ់របស់អ្នកទាំង-ឡាយទេ ... ។ ឧទាននោះ ដូចពោលមកនេះជាដើម មាន ៣ យ៉ាង គឺជាសព្វញ្ញុពុទ្ធភាសិត ១ ជាបច្ចេកពុទ្ធភាសិត ១ ជាសាវកភាសិត ១ ក្នុង ៣ យ៉ាងនោះ បច្ចេកពុទ្ធភាសិត មកក្នុងខគ្គវិសាណសូត្រ ដោយន័យជាដើមថា*

បុគ្គលជាក់អាជ្ញាចោលចេញ ចំពោះពួកសត្វទាំងអស់ មិនបានបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ មិនគប្បីប្រាថ្នានូវបុត្រ តើគប្បីត្រូវការសម្ងាញ់អំពីណា គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ឯសាវកភាសិត មកក្នុងថេរគាថា ដោយនយជាដើមថា

រាគៈទាំងពួង ខ្ញុំលះចោលហើយ ទោសៈទាំងពួង ខ្ញុំក៏ដកចោលហើយ មោហៈទាំងពួងរបស់ខ្ញុំ ក៏ប្រាសចេញហើយ ខ្ញុំជាបុគ្គលត្រជាក់រលត់ទុក្ខហើយ ដូច្នេះ ។

និងមកក្នុងថេរីគាថាដូច្នេះថា

ខ្ញុំជាអ្នកសង្រួមដោយកាយ ដោយវាចា ដោយចិត្ត បានដកតណ្ហាព្រមទាំងឫស (ឬព្រមទាំងអវិជ្ជា) ជាអ្នកមានចិត្តត្រជាក់ សម្រេចអនុបាទិសេសនិព្វានធាតុ ដូច្នេះ ។

ឧទានទាំងនោះ ជាឧទានរបស់ព្រះថេរៈ និងព្រះថេរីទាំងនោះតែម្យ៉ាងក៏មិនមែន ដោយពិត ជាប្រកែទសីហនាទក៏មាន ឧទានដែលទេវតា មានសក្កទេវរាជជាដើមភាសិត មានពាក្យជាដើមថា **អហោ ធានំ បរមធានំ កស្សបេ សុប្បតិដ្ឋិតំ ។** *និងឧទានដែលមនុស្សទាំងឡាយ មានសោណទណ្ឌព្រាហ្មណ៍ជាដើមភាសិត មានពាក្យជាដើមថា* **ឧមោ តស្ស ភគវតោ** *ជាឧទានដែលលើកឡើងកាន់សង្គីតិទាំង ៣ ដង ឧទានទាំងនោះ មិនបំណងយកក្នុងទីនេះ ។ ភាសិតទាំងឡាយណា ដែលព្រះសម្មាសម្ពុទ្ធត្រាស់ចំពោះ*

ព្រះអង្គឯង ជាពុទ្ធវចនៈ និងកាសិតពួកណា ដែលព្រះមានព្រះភាគ ទ្រង់សំដៅយក កាលទ្រង់ចែកសម្តែងបរិយត្តិធម៌ចេញជា ៩ យ៉ាង ដែលត្រាស់ថា ឧទានកាសិតនោះឯង ព្រះធម្មសង្គាហកាចារ្យចង់ក្រងថា **ឧទាន ។** *ឧទាននោះឯង ក្នុងទីនេះ កាន់យកដោយភាពជាវត្ថុដែលគប្បីពណ៌នា ។*

ឯគាថាណាដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយគាថា មានជាដើមថា **អនេកជាតិសំសារំ** *ដែលប្រព្រឹត្តទៅដោយអំណាចឧទាន ត្រង់មណ្ឌលនៃពោធិព្រឹក្ស និងគាថាឧទាន ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយរាប់សែនអង្គមិនលះចោល តែក្នុងកាលតមក គាថាទាំងនោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយមិនបានចង់ក្រងក្នុងឧទានបាលី ចង់ក្រងទុកក្នុងធម្មបទ ព្រោះព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដល់ភិក្ខុដែលជាធម្មកណ្ឋគារិក ។ ពាក្យឧទានថា* **អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ** *ជាដូច្នេះ ដែលព្រះមានព្រះភាគ ត្រាស់ឲ្យមានសំឡេងកងរំពង អាចប្រកាសដល់ទេវតា និងមនុស្សទាំងឡាយ ក្នុងម៉ឺនលោកធាតុនោះ ជាហេតុកើតអំពីការពិចារណាដល់សេចក្តីលំបាករបស់ទ្រង់ មានផល ព្រោះអរិយមគ្គ តាមដែលទ្រង់សម្តែងដែលជាចំណែកមួយរបស់ធម៌ដែលទ្រង់សម្រេច ជាមគ្គដែលព្រះថេរៈសម្រេចមុនជាងសាវ័កទាំងពួង ក្នុងបណ្តាសាវ័កទាំងឡាយ ក្នុងកាលចប់ទេសនា ព្រះធម្មចក្កប្បវត្តនសូត្រ និងជាហេតុកើតអំពីការពិចារណាសម្បដិបត្តិរបស់ភិក្ខុទាំងពួង ក្នុងបឋមពោធិកាល ត្រឹមតែជាឧទានដែលកើតអំពីបីតិ និងសោមនស្ស ដូចពាក្យជាដើមថា សម័យមួយ ភិក្ខុទាំងឡាយធ្វើឲ្យ*

តថាគតត្រេកអរហ្នឹ មិនជាពាក្យប្រកាសការប្រព្រឹត្តទៅ ឬវិលត្រឡប់មក ដូចពាក្យជាដើមថា **យទា ហវេ ចាតុភវន្តិ ធម្មា** *ធម៌ទាំងឡាយ ប្រាកដ ដល់ព្រាហ្មណ៍អ្នកមានព្យាយាមដុត ញ៉ាំងកិលេសឲ្យក្តៅ អ្នកដុតបង់នូវ កិលេស ក្នុងកាលណា ព្រោះដូច្នោះ មិនគប្បីឃើញថា ព្រះធម្មសង្គាហ-កាចារ្យចង់ក្រងទុកក្នុងឧទានបាលី ។*

ឧទាននេះ ទាក់ទងក្នុងសុត្តន្តបិដក ក្នុងបណ្តាបិដក ៣ គឺវិនយបិដក សុត្តន្តបិដក អភិធម្មបិដក ទាក់ទងក្នុងខុទ្ទកនិកាយ ក្នុងបណ្តានិកាយ ៥ គឺ ទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ និងខុទ្ទកនិកាយ សង្គ្រោះចូលក្នុងឧទាន ក្នុងបណ្តាសត្ថុសាសន:មានអង្គ ៩ គឺសុត្ត: គេយ្យ: វេយ្យាករណ: គាថា ឧទាន ឥតិវុត្តក: ជាតក អព្ភូតធម្ម និងវេទល្ល សង្គ្រោះ ចូលក្នុងធម្មក្ខន្ធបន្តិចបន្តួច ក្នុងបណ្តាធម្មក្ខន្ធ ៨៤០០០ ធម្មក្ខន្ធ ដែលព្រះ-ធម្មភណ្ឌាគារិកប្តេជ្ញាយ៉ាងនេះថា

ខ្ញុំរៀនអំពីព្រះពុទ្ធ ៨២០០០ ធម្មក្ខន្ធ អំពីភិក្ខុ ២០០០ ធម្មក្ខន្ធ រួមជា ៨៤០០០ ធម្មក្ខន្ធ ។

ពោលដោយវគ្គមាន ៨ វគ្គ គឺពោធិវគ្គ មុច្ចលិន្ទវគ្គ នន្ទវគ្គ មេឃិយ-វគ្គ មហាវគ្គ ជច្ចន្ធវគ្គ ចូឡវគ្គ បាដលិគាមិយវគ្គ ។ ពោលដោយសូត្រ សង្គ្រោះជា ៨០ សូត្រ ។ ពោលដោយគាថា សង្គ្រោះជាឧទានគាថា ៩៥ គាថា ពោលដោយភាណវារ ប្រមាណ ៩ កន្ទះភាណវារ ។ ពោលដោយ អនុសន្ធិ មាន ១ អនុសន្ធិ គឺបុច្ឆានុសន្ធិ ក្នុងពោធិសូត្រទាំងឡាយ ។ ក្នុង

សុប្បពុទ្ធសូត្រ មាន ២ អនុសន្ធិ គឺបុច្ឆានុសន្ធិ និងយថានុសន្ធិ ។ ក្នុងសូត្រដ៏សេស មានអនុសន្ធិតែ ១ ដោយអំណាចយថានុសន្ធិ តែអជ្ឈាសយានុសន្ធិមិនមានក្នុងទីនេះ ។ មានការសង្គ្រោះអនុសន្ធិ ៨១ ដោយប្រការទាំងពួង ដោយប្រការដូច្នេះ ។ ពោលដោយបទ មាន ២១១០០ បទ ។ ពោលដោយបាទគាថា មាន ៨៤២៣ គាថា ។ ពោលដោយអក្ខរៈ មាន ៦៧៣៨២ អក្ខរៈ ព្រោះហេតុនោះ ទើបលោកពោលពាក្យនេះថា

> *ឧទាន ពោលដោយសង្ខេប លោកប្រកាសថា មាន ៨០ សូត្រ ៨ វគ្គ ៩៥ គាថា ចំណែកភាណវារពោលដោយប្រមាណ មានប្រមាណ ៩ ភាណវារកន្លះ មានអនុសន្ធិ ៨១ បុគ្គលមានបញ្ញាឃើញប្រចក្ស សម្តែងបទឧទានទាំងនេះ គណនាបាន ២១១០០ បទ ។*

តែកាលពោលដោយបទគាថា លោកសម្តែង ៨៤២៣ បាទគាថា ប្រកាសអក្ខរៈ ៦៧៣៨២ អក្ខរៈ ដូច្នេះ ។

បណ្តាវគ្គទាំង ៨ នៃឧទាននោះ មានពោធិវគ្គជាខាងដើម ។ បណ្តាសូត្រ មានពោធិសូត្រ ជាសូត្រទី ១ ពោធិសូត្រនោះ មាននិទានដែលព្រះអានន្ទពោលក្នុងគ្រាមហាសង្គីតិទី ១ មានពាក្យជាដើមថា **ឯវម្មេ សុតំ** *ដូច្នេះជាខាងដើម ។ មហាសង្គីតិខាងដើមនោះ លើកទៅងកាន់តន្តិកាសាក្នុងវិនយបិដកនោះឯង ក្នុងទីនេះ កថាមគ្គដែលគួរពោល ដើម្បីការឈ្វាសក្នុងនិទាននោះ លោកក៏ពោលក្នុងអដ្ឋកថាទីឃនិកាយ ឈ្មោះ* **សុមង្គលវិលាសិនី**

នោះឯង ព្រោះដូច្នោះ គប្បីជ្រាបដោយនយដូចពោលក្នុងអដ្ឋកថា ឈ្មោះ **សុមង្គលវិលាសិនី** នោះចុះ ។

បឋមភាណវារៈ ចប់

អធិប្បាយ ពោធិវគ្គទី ១

បឋមពោធិសូត្រ

[៣៨] ក្នុងពោធិសូត្រនេះ ពាក្យថា **ឯវម្មេ សុតំ** ជាដើម ត្រឹមតែជានិទាន ។ បណ្តាបទទាំងនោះ សព្ទថា **ឯវំ** ជានិបាត ។ បទថា **មេ** ជាដើម ជានាមបទ ។ បទថា **វិ** ក្នុងបទថា **ឧរុវេលាយំ វិហរតិ** នេះ ជាបទឧបសគ្គ ។ បទថា **ហរតិ** ជាបទអាខ្យាត ។ ការចែកបទទាំងអស់គប្បីជ្រាបដោយនយនេះជាលំដាប់ដំបូង ។ តែកាលពោលដោយអត្ថ **ឯវំ** ជាលំដាប់ដំបូង មានអត្ថច្រើន ប្រភេទដូចជាឧបមា គឺប្រៀបធៀប ឧបទេស គឺណែនាំ សម្បហំសនៈ គឺលើកសរសើរ គរហាណៈ គឺតិះដៀល វចន-សម្បដិគ្គហាណៈ គឺទទួលពាក្យ អាការ គឺអាការ និទស្សនៈ គឺឧទាហរណ៍ អវធារណៈ គឺរាំងសេចក្តីជនៃ បុច្ឆា គឺសួរ **ឥមត្ថ** គឺអត្ថនៃ **ឥទំ** សព្ទ និងបរិមាណ គឺប្រមាណជាដើម ។

ពិតហើយ **ឯវំ** សព្ទនោះ មកក្នុងឧបមា ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **ឯវំ ជាតេន មច្ចេន កត្តព្ពំ កុសលំ ពហុំ** កុសលដែលសត្វកើត

មកហើយ គួរធ្វើឲ្យច្រើនយ៉ាងនោះ ដូច្នេះ ។

មកក្នុងឧបទេស ដូចក្នុងប្រយោគជាដើមថា **ឯវន្តេ អភិក្កមិតព្ពំ ឯវំ បដិក្កមិតព្ពំ** *អ្នកត្រូវឈានដើរទៅមុខយ៉ាងនេះ អ្នកត្រូវថយក្រោយយ៉ាងនេះ ដូច្នេះ ។*

មកក្នុងសម្បហំសន គឺលើកសរសើរ ដូចក្នុងប្រយោគជាដើមថា **ឯវមេតំ ភគវា ឯវមេតំ សុគត** *បពិត្រព្រះដ៏មានព្រះភាគ ហេតុនុ៎ះ យ៉ាងនេះហើយ បពិត្រព្រះសុគត ហេតុនុ៎ះ យ៉ាងនេះហើយ ដូច្នេះ ។*

មកក្នុងគរហណៈ គឺការតិះដៀល ដូចក្នុងប្រយោគជាដើមថា **ឯវមេវ បនាយំ វសលី យស្មឺ វា តស្មឺ វា តស្ស មុណ្ឌកស្ស វណ្ណំ ភាសតិ** *មេចង្រៃនេះ ធ្លាប់តែអីចឹងៗ ហ៊ានពោលសរសើរសមណៈត្រង់ោលក្នុងទីផ្តេសផ្តាស ដូច្នេះ ។*

មកក្នុងវចនសម្បដិគ្គហៈ គឺការទទួលពាក្យ ដូចក្នុងប្រយោគជាដើមថា **ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ** *ភិក្ខុទទួលពាក្យនៃព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ដូច្នេះ ។*

មកក្នុងអាការ ដូចក្នុងប្រយោគជាដើមថា **ឯវំ ឥមា ខោ អហំ ភន្តេ ភគវតោ ធម្មំ ទេសិតំ អាជានាមិ** *ខ្ញុំបានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយក៏យ៉ាងនោះដែរ ដូច្នេះ ។*

មកក្នុងនិទស្សនៈ គឺឧទាហរណ៍ ដូចក្នុងប្រយោគជាដើមថា **ឯហិ ត្វំ មាណវក យេន សមណោ អានន្ទោ ។បេ។ អនុកម្បំ ឧបាទាយ** *ម្នាល*

មាណព ចូរឯងមកនេះ ចូរឯងទៅរកព្រះសមណៈឈ្មោះអានន្ទ លុះចូលទៅជល់ហើយ ចូរសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន មានកម្លាំងនៅជាសុខសប្បាយ នីឯងព្រះសមណៈឈ្មោះអានន្ទ តាមពាក្យរបស់អញថា សុភមាណពជាកូនគោទេយ្យព្រាហ្មណ៍ផ្តាំឲ្យសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន និងកម្លាំង និងអាការនៅជាសុខសប្បាយ ចំពោះព្រះអានន្ទដ៏ចម្រើន រួចហើយ ចូរឯងនិមន្តថា សូមលោកម្ចាស់អានន្ទ អាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តមកកាន់ទីលំនៅរបស់សុភមាណព ជាកូនគោទេយ្យព្រាហ្មណ៍ឲ្យទាន ដូច្នេះ ។

មកក្នុងអវធារណៈ គឺរាំងសេចក្តីដទៃ ដូចក្នុងប្រយោគជាដើមថា **តំ កិំ មញ្ញថ កាលាមា ។បេ។ ឯវំ នោ ឯត្ថ ហោតិ** *ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្តេច ធម៌នេះ ជាកុសល ឬជាអកុសល ។ ជាអកុសល ព្រះអង្គ ។ ជាធម៌ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ ។ ជាធម៌ប្រកបដោយទោស ព្រះអង្គ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬអ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ព្រះអង្គ ។ ធម៌ទាំងនេះដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ឬមិនប្រព្រឹត្តទៅទេ ឬក៏ក្នុងដំណើរនោះ ដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះ ដែលបុគ្គលសមាទានបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ យើងខ្ញុំក៏យល់ក្នុងដំណើរនោះដូច្នោះដែរ ដូច្នេះ ។*

មកក្នុងបុច្ឆា គឺពាក្យសួរ ដូចក្នុងប្រយោគជាដើមថា **ឯវំ សុ តេ សុន-ហាតា សុវិលិត្តា កប្បិតកេសមស្ឆ អាមុត្តមាលាភរណា ។បេ។ សាច-រិយកោតិ ។** ឥសីទាំងនោះបានងូតទឹកដ៏ស្អាត លាបស្រឡាបដោយគ្រឿងក្រអូបសាយល្អ មានសក់ និងពុកមាត់កាត់ស្រេចហើយ ពាក់កម្រងផ្កា និងគ្រឿងប្រដាប់ ស្លៀកសំពត់ស ជាអ្នកធ្មែតស្ពប់ស្ពល់ មានគេផ្គាប់ផ្គុនបម្រើដោយកាមគុណ ៥ ដូចជាខ្ជូនអ្នក ព្រមទាំងអាចារ្យ ក្នុងកាលឥឡូវនេះយ៉ាងនេះដែរឬ ។

មកក្នុងឥទមត្ត គឺអត្ថនៃ **ឥធំ** សព្ទ ដូចក្នុងប្រយោគជាដើមថា **ឯវំ-គតានិ បុថុសិប្បាតនានិ** ពុំនោះសោត សិប្ប:សម្រាប់បង្ហើតផល មានប្រមាណច្រើនឯណានីមួយដទៃទៀត និងដូចប្រយោគមួយទៀតថា **ឯវំវិធោ ឯវមាការោ** អាការនេះ មានប្រការយ៉ាងនេះ ដូច្នេះ ។ ពិតហើយ ពាក្យថា **គត** មានការហៅថា ប្រការ ។ ពាក្យថា **វិធាការ** ក៏ដូចគ្នា ។ ពិតហើយ សត្វលោកពោល **គត** សព្ទ ដែលប្រកបនឹង **វិធ** សព្ទ ក្នុងអត្ថថា ប្រការ ។

មកក្នុងបរិមាណ គឺប្រមាណ ដូចក្នុងប្រយោគជាដើមថា **ឯវំ លហុបរិ-វត្តំ ឯវមាយុបរិយន្តោ** មានការផ្ទាស់ប្តូររហ័សជាប្រមាណ មានការអស់អាយុជាប្រមាណ ដូច្នេះ ។

ដោយ **ឯវំ** សព្ទ ក្នុងពាក្យថា **ឯវំ វិតក្ពិតំ នោ តុម្ហេហិ ឯវមាយុ-បរិយន្តោ ។ ឯវំ** សព្ទដែលឈ្មោះថា មានអាការជាអត្ថប៉ុណ្ណោះ ព្រោះពោលអាការសួរ និងអាការប្រមាណមិនមែនឬ មិនមែន ព្រោះមានសេចក្តីប្លែកគ្នា

ឯវំ *សព្ទក្នុងទីនេះ ប្រាប់ត្រឹមអាការ លោកបំណងយកថា មានអាការជាអត្ថ តែ* **ឯវំ** *សព្ទ ក្នុងពាក្យជាដើមថា* **ឯវំ ៣ប្យា ទោ** *ប្រាប់ការប្លែកគ្នានៃអាការ* **ឯវំ** *សព្ទទាំងនេះ ដែលឈ្មោះថា ប្រាប់ការប្លែកគ្នានៃអាការ ព្រោះប្រាប់អាការ នៃពាក្យសួរ និងអាការនៃប្រមាណ ព្រោះអធិប្បាយយ៉ាងនេះ ឧទាហរណ៍ ជាដើមថា សត្វកើតមកដូច្នោះ ទើបនឹងត្រូវ ។ ក្នុងសេចក្តីនោះមានអធិប្បាយ ដូច្នេះ សត្វ ឈ្មោះថា មច្ចៈ ព្រោះគប្បីស្លាប់ជាសភាវៈ ត្រូវតែបំពេញបុណ្យ ឲ្យច្រើន ដូចគំនរផ្កា ព្រោះគួរដល់ហានៈ ដែលជាគំនរផ្កា ក្នុងគាថានេះថា*

យថាបិ បុប្ផរាសិម្ហា កយិរា មាលាគុណេ ពហូ
ឯវំ ជាតេន មច្ចេន កត្តព្ពំ កុសលំ ពហុំ ។

មាលាការ ចេះធ្វើសំណុំនៃកម្រងផ្កាអំពីគំនរនៃផ្កា (ផ្សេងៗ គ្នា) ឲ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើនយ៉ាងនោះ ។

ព្រោះតាំងឡើងចាកហេតុនៃការបំពេញបុណ្យ មានទានជាដើម មានកើតក្នុងមនុស្ស ការគប់រកសប្បុរស ការស្តាប់ព្រះសទ្ធម្ម ការធ្វើទុកក្នុងចិត្ត ដោយឧបាយ និងការសម្លឹងដោយកោគៈជាដើម ព្រោះប្រកបដោយគុណ វិសេស មានការស្អាត និងមានភ្ញៀនក្រអូបជាដើម ព្រោះដូច្នោះ កាលពោល ដោយមិនប្លែកគ្នា និងមានគំនរផ្កា និងសំណុំផ្កាជាគ្រឿងប្រៀបធៀប ។ ការប្រៀបធៀបគំនរផ្កាទាំងនោះ លោកពោលដោយកំណត់មិនពិតប្រាកដដោយ **យថា** *សព្ទ ពោលដោយកំណត់ពិតប្រាកដ ដោយ* **ឯវំ** *សព្ទទៀត ។ ឯការ*

ប្រៀបធៀបនោះ កាលកំណត់ចុះទៅដោយអត្ថ ក៏ត្រឹមតែជាឧបមាប៉ុណ្ណោះ ព្រោះដូច្នោះ ទើបលោកពោលថា **ឧបមាយំ អាគតោ** *មកក្នុងឧបមាដូច្នេះ ។*

ម្យ៉ាងទៀត អាការ គឺការដឹកនាំក្នុងការដល់ព្រមដោយមារយាទដ៏សមគួរដល់សមណៈ ដែលលោកទូន្មានដោយន័យជាដើមថា គប្បីឈានទៅយ៉ាងនេះ គឺដោយអាការនេះ ពោលដោយអត្ថ គឺឧបទេសនោះឯង ព្រោះហេតុនោះ ទើបលោកពោលថា **ឃរំ** *សព្ទ មកក្នុងឧបទេស ក្នុងប្រយោគជាដើមថា អ្នកត្រូវឈានដើរទៅមុខយ៉ាងនេះ អ្នកត្រូវថយក្រោយយ៉ាងនេះ ដូច្នេះ ។*

ក្នុងពាក្យថា **ឃរមេ តំ ភគវា ឃរមេ តំ សុគត** *នេះ គប្បីជ្រាបដោយន័យដែលពោលថា ការសើច គឺការធ្វើនូវការសប្បាយចិត្ត បានដល់ ការត្រេកអរដោយប្រការនៃគុណ ដែលមានក្នុងសេចក្តី ដែលបុគ្គលដឹងអត្ថតាមដែលព្រះមានព្រះភាគត្រាស់ហើយ មិនធ្វើឲ្យឃ្លៀងឃ្លាត ។ ក្នុងពាក្យថា* **ឃរមេវ បធាយំ** *នេះ គប្បីជ្រាបដោយន័យដែលពោលហើយថា ជាអាការនៃការតិះដៀល ។ អាការ គឺការតិះដៀលនោះ រមែងដឹងបានថា លោកប្រកាសដោយ* **ឃរំ** *សព្ទ ក្នុងទីនេះ ដោយប្រៀបធៀបជាមួយ* **ទុំសន** *សព្ទ សម្តែងថា មេចង្រៃជាដើម ។ គប្បីជ្រាបថា អាការ គឺការប្រៀបធៀប លោកពោលដោយប្រៀបធៀបសព្ទ មាន* **បុព្វរាសិ** *សព្ទជាដើម ដែលលោកពោលដោយឧបមាជាដើម ដូចក្នុងអាការតិះដៀលនេះ ។*

ដោយពាក្យថា **ឃញ្ច វាចេហិ** *នេះ លោកពោលថា អាការ គឺការពោលដែលគប្បីពោលក្នុងឥឡូវនេះថា ខ្ញុំពោលអាការយ៉ាងណា ចូរអ្នកពោលនឹង*

សមណៈអានន្ទដោយអាការយ៉ាងនោះ លោកសម្តែងនៃ ដោយ **ឯវំ** *សព្ទ នោះ ទើបមាននិទស្សនៈជាអត្ថ ។*

ក្នុងបទថា **ឯវំ នោ** *នេះ ព្រោះកាលតាំងនូវពាក្យសួរថា មិនមែនយ៉ាងនោះឬ ឬថា ក្នុងសេចក្តីនោះដូចម្តេច ដោយអំណាចការកាន់យកតាមការអនុមតិ ដើម្បីឲ្យដឹងការធ្លាក់ចុះដោយភាវៈដែលធ្វើតាមដែលពោលហើយនោះ នាំវត្ថុដែលមិនជាប្រយោជន៍ និងទុក្ខមកឲ្យ ទើបឆ្លើយថា ក្នុងសេចក្តីនោះមិនដូច្នោះទេ្បីយ ការសន្និដ្ឋានអាការ ដូច្នោះ រមែងដឹងបានថា លោកឲ្យជាក់ច្បាស់ហើយ ដោយ* **ឯវំ** *សព្ទ អាការដែលប្រព្រឹត្តទៅដើម្បីមិនមែនប្រយោជន៍ដើម្បីទុក្ខនៃធម៌ទាំងនោះ កាលកំណត់ពិតប្រាកដ មានអវធារណៈជាអត្ថ ព្រោះដូច្នោះ ទើបលោកពោលថា* **ឯវំ** *សព្ទ មកក្នុងអវធារណៈ ក្នុងប្រយោគជាដើមថា* **ឯវំ នោ ឯត្ថ ហោតិ** *ក្នុងសេចក្តីនេះ ។*

លោកពោលដល់ **ឯវំ** *សព្ទទាំងនោះ ដែលចង្អុលដល់ការប្លែកគ្នានៃអាការយ៉ាងនោះថា មានអត្ថឧបមាជាដើម ព្រោះមានការប្រព្រឹត្តទៅ ដោយអត្ថវិសេស មានឧបមាជាដើម ។* **ឯវំ** *សព្ទ ក្នុងពាក្យថា* **ឯវម្ភន្តេ** *នោះ មានការទទួលពាក្យជាអត្ថ ព្រោះភិក្ខុទាំងឡាយ ដែលប្រកបក្នុងការជាក់ចិត្តដោយល្អនូវការស្តាប់ធម៌ ពោលដោយអំណាចការដឹងចំពោះនូវភាវៈដែលខ្ជនតាំងនៅក្នុងធម៌នោះ ព្រោះហេតុនោះ ទើបលោកអធិប្បាយថា បទថា* **ឯវម្ភន្តេ** *បានដល់* **សាធុ ភន្តេ សុដ្ឋុ ភន្តេ** *ដូច្នេះ ។ ក្នុងទីនេះ* **ឯវំ** *សព្ទ នេះ គប្បីឃើញថា ចុះក្នុងអត្ថថា អាការ និទស្សនៈ និងអវធារណៈ ។*

ក្នុង ៣ យ៉ាងនោះ ដោយ **ឃរំ** *សព្ទ មានអាការជាអត្ត ព្រះថេរៈសម្តែងអត្តនេះថា បុគ្គលណាអាចដឹងព្រះតម្រាស់របស់ព្រះមានព្រះភាគនោះ ដោយប្រការទាំងពួង ដែលមានន័យផ្សេងៗ ដែលល្អិត កើតអំពីអធ្យាស្រ័យជាអនេក សម្បូរដោយអត្ត និងព្យញ្ជនៈ មានបាជិហារ្យផ្សេងៗ ជ្រៅដោយធម៌ អត្ថ ទេសនា និងបដិវេធដែលមកប្រាកដតាមសោតវិញ្ញាណ ព្រោះសមគួរដល់កាសាវៀងៗ ខ្លួន នៃសព្វសត្វ ។ ខ្ញុំធ្វើសេចក្តីបំណង ដើម្បីស្តាប់ឲ្យកើត ដោយប្រការទាំងពួង ក៏បានស្តាប់មកហើយយ៉ាងនេះ គឺខ្ញុំក៏បានស្តាប់មកហើយ ដោយអាការឯណានីមួយ ។*

ក្នុងទីនេះ មានន័យផ្សេងៗ ដោយប្រភេទអារម្មណ៍ជាដើម ពោល គឺ ឯកត្តន័យ នានត្តន័យ អព្យាបារន័យ ឯវិធម្មតាន័យ និងពោល គឺនន្ទិយាវដ្តន័យ តិបុក្ខលន័យ សីហវិក្កីលិតន័យ ទិសាលោចនន័យ និងអង្គុសន័យ ឈ្មោះថា នានាន័យ ។ ម្យ៉ាងទៀត នយទាំងឡាយ មានបាលីជាគតិ ។ នយទាំងនោះ ឈ្មោះថា នានានយ ព្រោះមានប្រការផ្សេងៗ ដោយអំណាចបញ្ញត្តិ អនុប្បញ្ញត្តិជាដើម ដោយនយដែលជាចំណែកនៃសង្គិលេសជាដើម និងនយដែលជាលោកិយជាដើម និងនយដែលលាយគ្នាទាំង ២ នោះ ដោយអំណាចកុសលជាដើម ដោយអំណាចខន្ធជាដើម ដោយអំណាចសង្គហៈជាដើម ដោយអំណាចសមយវិមុត្តិជាដើម ដោយអំណាចថបនៈជាដើម ដោយអំណាចកុសលមូលជាដើម និងដោយអំណាចតិកបដ្ឋានជាដើម ។ ឈ្មោះថា ល្អិត ដោយន័យផ្សេងៗ ព្រោះល្អិតសុខុមដោយន័យទាំងនោះ ។

អាសយៈនោះឯង ឈ្មោះថា អជ្ឈាស្រ័យ ។ អជ្ឈាស្រ័យនោះ មានច្រើនយ៉ាង ដោយការផ្សេងគ្នានៃភាវៈ មានភាពជារបស់ទៀងជាដើម និង ដោយការផ្សេងគ្នានៃភាពដែលសត្វ មានកិលេសដូចធូលីក្នុងភ្នែកតិចជាដើម ឬមានបែបជាអនេកជាដើមថា អជ្ឈាស្រ័យរបស់ខ្លួនជាដើម ឈ្មោះថា អនេកជ្ឈាសយៈៗ នោះ ឈ្មោះថា អនេកជ្ឈាសយសមុដ្ឋាន ព្រោះមាន សមុដ្ឋានជាហេតុកើតឡើង ។

ឈ្មោះថា សម្បវរដោយអត្ថ និងព្យញ្ជនៈ ព្រោះប្រកបដោយបទនៃអត្ថ ៦ យ៉ាង គឺសង្កាសនៈ (ដូចគ្នា) បកាសនៈ គឺប្រកាស វិវរណៈ គឺលម្អិត សេចក្តី វិភជនៈ គឺចែក ឧត្តានីករណៈ គឺធ្វើឲ្យរាក់ និងបញ្ញត្តិ គឺឈ្មោះ និងប្រកបដោយបទនៃព្យញ្ជនៈ ៦ យ៉ាង គឺអក្ខរៈ បទព្យញ្ជនៈ អាការ និរុត្តិ និងនិទ្ទេសនៃសម្បត្តិរបស់អត្តនៃសីលជាដើម និងសម្បត្តិនៃព្យញ្ជនៈ ដែលធ្វើនូវការជាក់ច្បាស់នៃអត្ថ មានសីលជាដើមនោះ ។

ឈ្មោះថា មានបាដិហារ្យផ្សេងៗ ព្រោះមានបាដិហារ្យផ្សេងៗ ឬច្រើន ដោយការផ្សេងគ្នានៃឥទ្ធិប្បាដិហារ្យ អាទេសនាបាដិហារ្យ និងអនុសាសនី-បាដិហារ្យ និងដោយការផ្សេងគ្នានៃអារម្មណ៍ជាដើមរបស់បាដិហារ្យណាមួយ បណ្តាបាដិហារ្យទាំងនោះ ។ ក្នុងសេចក្តីនោះ មានអត្ថថា ឈ្មោះថា បាដិហារ្យ ព្រោះកម្ចាត់ធម៌ដែលជាសត្រូវ គឺព្រោះកម្ចាត់កិលេស មានរាគៈជាដើមដែល ជាសត្រូវ គប្បីកម្ចាត់មិនមានដល់ព្រះមានព្រះភាគ ។ កាលចិត្តប្រាសចាក ឧបក្កិលេស ប្រកបដោយគុណ ៨ ប្រការ កម្ចាត់បង់នូវធម៌ដែលជាសត្រូវ

បានហើយ ជាដំហរ្យសម្តែងឫទ្ធិបាន សម្រាប់បុថុជ្ជន ក៏នៅប្រព្រឹត្តទៅបាន ព្រោះដូច្នោះ កាលពោលដោយវោហារដែលប្រព្រឹត្តទៅ ក្នុងការសម្តែងឫទ្ធិនោះ ទើបមិនអាចនឹងពោលបានថា ជាដំហរ្យក្នុងទីនេះ ។ បើព្រះមានព្រះភាគប្រកបដោយព្រះមហាករុណា នៅមានកិលេស ដែលនៅក្នុងវេនេយ្យសត្វ ជាសត្រូវសោត ព្រោះកម្ចាត់កិលេសដែលជាសត្រូវនោះបាន ទើបហៅថា ជាដំហរ្យ កាលបើដូច្នោះ ទើបសេចក្តីនោះ ត្រឹមត្រូវ ។

ម្យ៉ាងទៀត ពួកតិរ្ថិយជាសត្រូវចំពោះព្រះមានព្រះភាគ និងព្រះសាសនា ព្រោះកម្ចាត់ពួកតិរ្ថិយនោះបាន ទើបហៅថា ជាដំហរ្យ ។ ពិតហើយ តិរ្ថិយទាំងនោះ ត្រូវទ្រង់កម្ចាត់ គឺបណ្តេញចេញដោយឥទ្ធិប្បាដិហរ្យ និងអាទេសនាជាដំហរ្យ និងអនុសាសនីជាដំហរ្យ ដោយអំណាចការកម្ចាត់ទិដ្ឋិ និងដោយមិនមានសមត្ថភាពក្នុងការប្រកាសទិដ្ឋិ ។ ម្យ៉ាងទៀត សព្ទថា **បដិ** *នេះ រមែងឲ្យដឹងអត្ថរបស់សព្ទថា* **បច្ចា** *នេះ ដូច* **បដិ** *ក្នុងប្រយោគជាដើមថា* **តស្មឹ បដិបវិដ្ឋម្ហិ អញ្ញោ អាគច្ឆតិ ព្រាហ្មណោ** *កាលព្រាហ្មណ៍នោះចូលទៅ ទើបព្រាហ្មណ៍ម្នាក់ទៀតមក ។ ព្រោះដូច្នោះ កាលចិត្តតាំងមាំ ប្រាសចាកឧបក្កិលេស បុគ្គលធ្វើកិច្ចហើយ គប្បីនាំទៅ គឺឲ្យប្រព្រឹត្តទៅក្នុងកាលខាងក្រោយ ព្រោះហេតុនោះ ទើបឈ្មោះថា ជាដំហរ្យ ។ ម្យ៉ាងទៀត កាលឧបក្កិលេសរបស់ខ្លួន ត្រូវមគ្គដែលសម្បយុត្តដោយឈានទី ៤ កម្ចាត់ហើយ ការកម្ចាត់ខាងក្រោយ ឈ្មោះថា ជាដំហរ្យ ។ ម្យ៉ាងទៀត ឥទ្ធិប្បាដិហរ្យ អាទេសនាជាដំហរ្យ និងអនុសាសនីជាដំហរ្យ ដែលប្រាសចាកឧបក្កិលេស*

សម្រេច កិច្ចហើយ គប្បីឲ្យប្រព្រឹត្តទៅទៀត ដើម្បីជាប្រយោជន៍ដល់សត្វ ម្យ៉ាងទៀត កាលឧបក្កិលេសរបស់ខ្លួនត្រូវកម្ចាត់ហើយ ការកម្ចាត់ឧបក្កិលេស ក្នុងសន្តាននៃបុគ្គលដទៃក៏មាន ព្រោះដូច្នោះ ទើបឈ្មោះថា មានបាដិហារ្យ ។ បាដិហារ្យនោះឯង ជាបាដិហារ្យ ។ ម្យ៉ាងទៀត កាលពោលដោយបាដិហារ្យ បាដិហារ្យតែម្យ៉ាងដែលមានក្នុងពួកនៃឥទ្ធិបាដិហារ្យ អាទេសនាបាដិហារ្យ និង អនុសាសនីបាដិហារ្យ លោកហៅថា បាដិហារ្យ ។ ម្យ៉ាងទៀត ឈានទី ៤ និងមគ្គ ឈ្មោះថា បាដិហារ្យ ព្រោះកម្ចាត់ធម៌ដែលជាសត្រូវ ។ គប្បីជ្រាបអត្ថថា បាដិហារ្យ ព្រោះកើតក្នុងឈានទី ៤ និងមគ្គនោះ ឬជានិមិត្តក្នុងឈានទី ៤ និងមគ្គនោះ ឬមកអំពីឈានទី ៤ និងមគ្គនោះ ដូច្នេះ ។

ព្រោះការរឭកដោយធម៌ អត្ថ ទេសនា និងបដិវេធ ពោល គឺបែបផែន អត្ថ ទេសនា និងការត្រាស់ដឹង ឈ្មោះរបស់បែបផែនជាដើមនោះ ឬពោល គឺហេតុ និងផល ដែលកើតមកអំពីហេតុ ទាំងហេតុ ទាំងផល បញ្ញត្តិ និង បដិវេធ ដែលជាការៈ ដែលសត្វមិនបានសាងសន្សំកុសលសម្ភារៈ មិនមាន ទីពឹង និងសូង់ដឹងបានលំបាក ដូចមហាសមុទ្រដែលសត្វទាំងឡាយ មាន ទន្សាយជាដើម មិនអាចសូង់ដឹង ព្រោះដូច្នោះ ព្រះតម្រាស់របស់ព្រះមានព្រះ ភាគ ឈ្មោះថា ជ្រៅដោយធម៌ អត្ថ ទេសនា និងបដិវេធ ព្រោះប្រកបដោយ ការៈដែលជ្រៅ ៤ ប្រការនោះ ។

ការប្រកាសធម្មទេសនា របស់ព្រះមានព្រះភាគតែម្យ៉ាងប៉ុណ្ណោះ ប្រព្រឹត្ត ទៅក្នុងមួយខណៈ រមែងគួរកាន់យកបាន មិនមុន មិនក្រោយ ដោយភាសា

រៀងៗ ខ្លួន នៃសត្វទាំងឡាយ ដែលមានភាសាផ្សេងៗ គ្នា ។ ពិតហើយ ពុទ្ធានុភាពនៃព្រះពុទ្ធទាំងឡាយ ជាអចិន្ត្យៃយ្យ ព្រោះហេតុនោះ គប្បីជ្រាបថា ប្រោកជតាមសោតប្បសាទរបស់សព្វសត្វដោយសមគួរដល់ភាសារៀងៗ ខ្លួន ។

ដោយ **ឯវំ** *សព្ទ មាននិទស្សនៈជាអត្ថ ព្រះថេរៈកាលនឹងដោះខ្លួនថា ខ្ញុំ មិនមែនព្រះសយម្ភូ ព្រះសូត្រនេះ ខ្ញុំមិនបានធ្វើឲ្យជាក់ច្បាស់ឯង ទើបសម្តែង លម្អិតសូត្រទាំងមូលដែលគប្បីពោលក្នុងឥទ្បវនេះថា ខ្ញុំបានស្តាប់បទហើយ យ៉ាងនេះ គឺសូម្បីខ្ញុំក៏បានស្តាប់មកហើយយ៉ាងនេះ ។*

ដោយ **ឯវំ** *សព្ទ ដែលមានអវធារណៈជាអត្ថ ព្រះថេរៈកាលសម្តែង កម្លាំងនៃការទ្រទ្រង់ចាំរបស់ខ្លួនដោយសមគួរដល់ភាវៈ ដែលព្រះមានព្រះភាគ ទ្រង់សរសើរយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុដែលជាសាវក របស់តថាគត អានន្ទជាកំពូលនៃភិក្ខុដែលជាពហុសូត ដែលមានគតិ មានសតិ មានធិតិ និងដែលជាឧបដ្ឋាក និងពាក្យដែលព្រះធម្មសេនាបតីសារីបុត្រ សរសើរយ៉ាងនេះថា ព្រះអានន្ទ ជាអ្នកឈ្លាសក្នុងអត្ថ ឈ្លាសក្នុងធម៌ ឈ្លាសក្នុងព្យញ្ជនៈ ឈ្លាសក្នុងនិរុត្តិ ឈ្លាសក្នុងអក្ខរៈខាងដើម និងខាងចុង ទើបឲ្យពួកសត្វកើតនូវបំណង ដើម្បីស្តាប់ថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ហើយព្រះសូត្រទាំងអស់នោះឯង ពោលដោយអត្ថ ឬព្យញ្ជនៈ មិនលើស មិនខ្វះជាងគ្នា កាលបើដូច្នោះ ទើបមិនគប្បីឃើញដោយប្រការដទៃ ។ បទថា* **អញ្ញថា** *គឺដោយប្រការដទៃ ចាកអាការដែលបានស្តាប់មកហើយ ចំពោះ ព្រះកត្តុរបស់ព្រះសាស្តា តែមិនមែនដោយប្រការដទៃ ចាកអាការដែលព្រះ*

មានព្រះភាគទ្រង់សម្តែងហើយ ពិតហើយ ទេសនារបស់ព្រះមានព្រះភាគ មានអានុភាពជាអចិន្តេយ្យ ។ ទេសនានោះ បុគ្គលណាម្នាក់មិនអាចដឹងបាន ដោយអាការទាំងពួង ព្រោះដូច្នោះ ទើបលោកពោលអត្ថនេះដូច្នេះឯង ។ ពិតហើយ កម្លាំងនៃការទ្រទ្រង់ចាំ គឺការមិនខុសភ្លាំងភ្លាត់ចាកអាការដែលបានស្តាប់មកហើយនោះឯង ។

មេ *សព្ទ ប្រាកដក្នុងអត្ថទាំង ៣ ។ ពិតហើយ* **មេ** *សព្ទនោះ មានអត្ថថា* **មយា** *ដូចក្នុងប្រយោគជាដើមថា* **គាថាភិគីតម្នេអភោជនេយ្យំ** *ភោជនដែលតថាគតពោលហើយដោយគាថា (ច្រៀង) ជាវត្ថុមិនគួរដល់ការបរិភោគទេ ដូច្នេះ ។*

មេ *សព្ទ មានអត្ថថា* **មយ្ហំ** *ដូចក្នុងប្រយោគជាដើមថា* **សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ** *បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអារាធនា សូមព្រះមានព្រះភាគសម្តែងធម៌ដោយសង្ខេបដល់ខ្ញុំ ដូច្នេះ ។*

មេ *សព្ទ មានអត្ថថា* **មម** *ដូចក្នុងប្រយោគជាដើមថា* **ធម្មទាយាទា មេ ភិក្ខវេ ភវថ** *ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយយកធម៌របស់តថាគតជាមត៌កចុះ ដូច្នេះ ។ តែ* **មេ** *សព្ទក្នុងទីនេះ ប្រើក្នុងអត្ថ ២ យ៉ាង គឺ* **មយា សុតំ** *និង* **មម សុតំ**។

តែក្នុងទីនេះ **មេ** *សព្ទទាំង ៣ យ៉ាង រមែងប្រាកដក្នុង ១ អត្ថប៉ុណ្ណោះ ព្រោះប្រព្រឹត្តទៅក្នុងសន្តានរបស់ខ្លួន ពោល គឺកើតចំពោះក្នុងខ្លួន ដែលគប្បីពោលយ៉ាងនេះថា សការៈណា មិនជារបស់ដទៃ សការៈនោះគឺអត្តា ក៏ពិត*

តែក៏ដឹងបានមួយរំពេចថា ការផ្សងគ្នានៃអត្ថនេះ ពោល គឺការពិសេសនៃ ករណៈ និងសម្បទានជាដើម ។ ព្រោះដូច្នោះ គប្បីឃើញថា **មេ** *សព្ទ លោកពោលថា ច្រាកដក្នុងអត្ថ ៣ យ៉ាង ។*

សុត *សព្ទ ក្នុងបទថា* **សុតំ** *នេះ មានឧបសគ្គផង មិនមានឧបសគ្គ ផង មានប្រភេទនៃអត្ថដ៏ច្រើន ដូចជា* **គមន វិសុត កិលិន្ន ឧបចិត អនុយោគ សោតវិញ្ញេយ្យ សោតទ្វារានុសារវិញ្ញាត** *ជាដើម ។ ពិត ហើយ ឧបសគ្គ រមែងធ្វើកិរិយាឲ្យវិសេសទ្បើងក៏ពិត តែបើមានឧបសគ្គ* **សុត** *សព្ទនោះឯង ក៏ចង្អុលដល់អត្ថនោះ ព្រោះបញ្ជូនដល់អត្ថ ព្រោះដូច្នោះ ក្នុងការពន្យ្រលសេចក្តីនៃ* **សុត** *សព្ទ ដែលមិនមានឧបសគ្គ ទោះកាន់យក* **សុត** *មានឧបសគ្គក៏មិនខុស ។*

ក្នុងពាក្យថា **សុតំ** *នោះ* **សុត** *សព្ទ មានអត្ថថា* **គមន** *ដូចក្នុង ប្រយោគជាដើមថា* **សេនាយ បសុតោ** *ទៅហើយដោយសេនា ដូច្នេះ ។*

សុត *សព្ទ មានអត្ថថា* **វិសុតធម៌** *ដូចក្នុងប្រយោគជាដើមថា* **សុត-ធម្មស្ស បសន្នោ** *បុគ្គលមានធម៌ស្តាប់ហើយបានឃើញច្បាស់ ដូច្នេះ ។*

សុត *សព្ទ មានអត្ថថា* **កិលេសនេ កិលិន្នា កិលិន្នស្ស** *ដូចក្នុង ប្រយោគជាដើមថា* **អវស្សុតា អវស្សុតស្ស** *(សុទ្ធរីនន្ទាជាម្ចាស់) មាន តម្រេក មិនគួរនឹងត្រេកអរឲ្យបុរសបុគ្គល ដែលមានតម្រេក ... ដូច្នេះ ។*

សុត *សព្ទ មានអត្ថថា* **ឧបចិត** *ដូចក្នុង ប្រយោគជាដើម* **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ** *បុណ្យ ឈ្មោះថា បានសន្សំ មិនមែនតិចឡើយ*

ដូច្នេះ ។

សុត *សព្ទ មានអត្ថថា* **ឈានានុយុត្តា** *(* **អនុយោគ** *) ដូចក្នុងប្រយោគជាដើមថា* **យេ ឈានបសុតា ធីរា** *អ្នកប្រាជ្ញឯណា ជាអ្នកប្រកបរឿយៗ (ខ្ជាប់ខ្ជួយ) ក្នុងឈាន ដូច្នេះ ។*

សុត *សព្ទ មានអត្ថថា* **សោតវិញ្ញេយ្យ** *ដូចក្នុងប្រយោគជាដើមថា* **ឥដ្ឋំ សុតំ មុតំ** *រូបដែលឃើញ សំឡេងដែលបានឮ អារម្មណ៍ដែលដឹង ដូច្នេះ ។*

សុត *សព្ទ មានអត្ថថា* **សោតទ្វារានុសារវិញ្ញាត** *ដូចក្នុងប្រយោគជាដើមថា* **សុតធរោ សុតសន្និចយោ** *(កិកុក្នុងសាសនានេះ) ជាអ្នកទ្រទ្រង់នូវពុទ្ធវចន: សន្សំនូវពុទ្ធវចន: ដូច្នេះ ។*

តែក្នុងទីនេះ **សុត** *សព្ទនោះ មានអត្ថថា* **ឧបធារិតំ** *ដែលលោកទ្រទ្រង់ ឬ* **ឧបធារណាំ** *ការទ្រទ្រង់តាមក្រសែនៃសោតទ្វារ ពិតហើយ កាល* **មេ** *សព្ទ មាន* **មាយា** *សព្ទជាអត្ថ សេចក្តីថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ គឺទ្រទ្រង់តាមក្រសែនៃសោតទ្វារ ដូច្នេះ ទើបគួរ ។ កាល* **មេ** *សព្ទ មាន* **មម** *សព្ទជាអត្ថ សេចក្តីថា ការស្តាប់របស់ខ្ញុំយ៉ាងនេះ គឺការទ្រទ្រង់ចាំតាមក្រសែនៃសោតទ្វារ ដូច្នេះ ទើបនឹងត្រូវ ។*

បណ្តាបទទាំង ៣ តាមដែលពោលមកនោះ ព្រោះហេតុដែល **ឃ** *សព្ទ ប្រើប្រៀបធៀបនឹង* **សុត** *សព្ទ គប្បីបញ្ជូនដល់កិរិយា គឺការស្តាប់ ដូច្នោះបទថា* **ឃ** *ជាពាក្យសម្តែងលម្អិតដល់កិច្ចនៃវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុង*

សោតទ្វារ មានសោតវិញ្ញាណ និងសម្បដិច្ឆន្នជាដើម និងនៃវិញ្ញាណដែលប្រព្រឹត្តទៅតាមមនោទ្វារ ដែលវិញ្ញាណខាងសោតទ្វារនោះនាំមក ។

បទថា **មេ** *ជាបទសម្តែងលម្អិតដល់បុគ្គលអ្នកដល់ព្រមដោយវិញ្ញាណដូចពោលហើយ ។ ពិតហើយ ពាក្យ គឺវាចាដែលជាបយោគគ្រប់ពាក្យប្រកបដោយអត្ថនៃ* **ឃរំ** *អក្ខរៈនោះឯង ព្រោះពាក្យទាំងនោះ មានអវធារណៈជាផល ។ បទថា* **សុតំ** *ជាបទសម្តែងលម្អិតដល់ការកាន់យកដែលមិនលើស មិនខ្វះ និងមិនវិបរិតចាកការបដិសេធ ការមិនបានឮ ។ ដូចការស្តាប់ គួរពោលថា* **សុតមេវ** *យ៉ាងណា ការស្តាប់នោះ ក៏ដូច្នោះ ជាការស្តាប់ត្រឹមត្រូវ គឺជាការកាន់យកមិនខ្វះ មិនលើស និងមិនវិបរិត ម្យ៉ាងទៀត សំឡេងដែលចង្អុលដល់អត្ថ ដោយឆ្លុះបញ្ចាំងដល់អត្ថក្នុងលំដាប់នៃសំឡេង ព្រោះហេតុនោះ ក្នុងចំណែកនេះ ព្រោះ* **សុត** *សព្ទនេះ មានអត្ថដែលលោកពោលដូច្នេះថា* **អសុតំ ន ហោតិ** *ប្រែថា ការបានឮមិនមាន ដូច្នោះ ទើបបទថា* **សុតំ** *ជាបទសម្តែងលម្អិតដល់ការកាន់យកមិនខ្វះ មិនលើស មិនវិបរិត ដោយបដិសេធការៈដែលមិនបានឮ ។ ព្រះថេរៈអធិប្បាយពាក្យនេះ ដូច្នេះ ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ខ្ញុំមិនបានឃើញ ខ្ញុំមិនធ្វើឲ្យជាក់ច្បាស់ដោយសយម្ភូញាណ ឬខ្ញុំមិនបានមកដោយប្រការដទៃ ។ ម្យ៉ាងទៀត ខ្ញុំបានស្តាប់មកហើយនោះឯង ការស្តាប់នោះឯង ជាការស្តាប់ប្រពៃពិត ។ ម្យ៉ាងទៀត ក្នុង* **ឃរំ** *សព្ទ ដែលមានអវធារណៈជាអត្ថ ក៏មានអត្ថយោជនា គឺការប្រកបសេចក្តីដូចពោលមកនេះ ។* **សុត** *សព្ទ ដែលសម្តីងដល់ ឃរំ សព្ទនោះ*

មានអត្ថពិតប្រាកដ ព្រោះដូច្នោះ **សុតៈ** *សព្ទ ដែលចង្អុលដល់* **ឃ្រាំ** *សព្ទ នោះ គប្បីជ្រាបថា បដិសេធការៈដែលមិនបានឮ និងជាការសម្តែងលម្អិត ដល់ការកាន់យកមិនខ្វះ មិនលើស និងមិនវិបរិត ដូច្នោះ គប្បីឃើញថា លោកធ្វើអត្ថយោជនានៃសព្ទទាំង ៣ ដោយអំណាចនៃការស្តាប់ ហេតុនៃការស្តាប់ និងការប្រកួតគ្នានៃការស្តាប់ ។*

ម្យ៉ាងទៀត បទថា **ឃ្រាំ** *ជាការប្រកាសការៈនៃវិញ្ញាណវិថីដែលប្រព្រឹត្ត ទៅតាមក្រសៃនៃសោតវិញ្ញាណនោះ ប្រព្រឹត្តទៅក្នុងអារម្មណ៍ ដោយប្រការ ផ្សេងៗ ដោយការកាន់យកអត្ត និងព្យញ្ជនៈផ្សេងៗ ព្រោះធ្វើអធិប្បាយថា* **ឃ្រាំ** *សព្ទ មានអាការជាអត្ត ។ បទថា* **មេ** *ជាបទប្រកាសអត្ត ។ បទថា* **សុតំ** *ជាបទប្រកាសធម៌ ព្រោះវិញ្ញាណវិថីតាមដែលពោលហើយ មានបរិយត្តិធម៌ ជាអារម្មណ៍ ។ ពិតហើយ ក្នុងសេចក្តីនេះ មានសេចក្តីសង្ខេបដូចតទៅនេះថា ខ្ញុំមិនបានធ្វើកិច្ចដទៃ តែធ្វើកិច្ចនេះ ធម៌នេះ ខ្ញុំបានស្តាប់ហើយដោយវិញ្ញាណ-វិថីដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ ដោយប្រការផ្សេងៗ ដែលជាតួហេតុ ។*

ម្យ៉ាងទៀត បទថា **ឃ្រាំ** *ជាការប្រកាសអត្តដែលគប្បីសម្តែងលម្អិត ព្រោះអធិប្បាយថា* **ឃ្រាំ** *សព្ទ មានទិស្សន៍ជាអត្ត ព្រោះត្រូវសម្តែងលម្អិត អត្តដែលគួរសម្តែងលម្អិត ។ ព្រោះដូច្នោះ ព្រះសូត្រទាំងមូលគប្បីជ្រាបថា កាន់យកហើយដោយ* **ឃ្រាំ** *សព្ទ ។ បទថា* **មេ** *ជាការប្រកាសបុគ្គល ។ បទថា* **សុតំ** *ជាការប្រកាសកិច្ចរបស់បុគ្គល ។ ពិតហើយ កិរិយាដែល ស្តាប់ កាលបានដោយ* **សុតៈ** *សព្ទ រមែងបានដោយសោតវិញ្ញាណចិត្ត*

ហើយក្នុងសេចក្តីនោះ រមែងបាននូវការបញ្ញត្តិដល់បុគ្គល តែក្នុងវត្ថុដែលទាក់ទងដោយធម៌ ដែលវៀរចាកការបញ្ញត្តិដល់បុគ្គល រមែងមិនបានកិរិយា គឺការស្តាប់ ។ **សុតៈ** *សព្ទនេះ មានអត្ថដោយសង្ខេបដូច្នេះថា ខ្ញុំនឹងសម្តែងលម្អិតព្រះសូត្រណា ព្រះសូត្រនោះ ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។*

ម្យ៉ាងទៀត បទថា **ឯវំ** *ជាបទសម្តែងអាការផ្សេងៗ នៃចិត្តសន្តានដែលទាញយកអត្ថ និងព្យញ្ជនៈផ្សេងៗ ដោយការប្រព្រឹត្តទៅនៃអារម្មណ៍ផ្សេងៗ ព្រោះអធិប្បាយថា* **ឯវំ** *សព្ទ មានអាការជាអត្ថនោះឯង ។ ពិតហើយ ការបញ្ញត្តិអាការថា* **ឯវំ** *នេះ ព្រោះអាស្រ័យអាការនៃការប្រព្រឹត្តទៅនោះៗ នៃធម៌ទាំងឡាយ ហើយទើបបញ្ញត្តឡើងជាសភាវៈ ។ បទថា* **មេ** *ជាការសម្តែងដល់កត្តុ គឺអ្នកធ្វើ ។ បទថា* **សុតំ** *ជាការសម្តែងដល់អារម្មណ៍ ។ ពិតហើយធម៌ដែលគួរស្តាប់ ជាទីតាំងនៃការប្រព្រឹត្តទៅដោយអំណាចនៃកិរិយា គឺការស្តាប់របស់បុគ្គលដែលធ្វើកិរិយា គឺការស្តាប់ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា សម្តែងនូវការយល់ព្រម នៃការទទួលអារម្មណ៍របស់អ្នកធ្វើ ដែលដល់ព្រមដោយកិរិយា គឺការស្តាប់នោះ ដោយចិត្តសន្តានដែលប្រព្រឹត្តទៅដោយប្រការផ្សេងៗ ។*

ម្យ៉ាងទៀត បទថា **ឯវំ** *សម្តែងកិច្ចរបស់បុគ្គល ។ ពិតហើយ* **ឯវំ** *សព្ទ មានការប្រកាសនិទស្សនៈ ឬអវធារណៈ ដែលមានអាការកាន់យកធម៌ដែលបានស្តាប់ហើយជាសភាវៈ ជាការសម្តែងលម្អិតដល់កិច្ចរបស់បុគ្គល ដោយភាវៈនៃការកាន់យកបញ្ញត្តិថាបុគ្គល ព្រោះការទ្រល់ទ្វាយក្នុងធម៌នៃការ*

ទ្រទ្រង់អាការនោះជាដើម ។ បទថា **សុតំ** *សម្តែងនៃកិច្ចរបស់វិញ្ញាណ ។ ពិតហើយ កិរិយា គឺការស្តាប់របស់អ្នកមានវាទៈថាបុគ្គល មិនសំដៅដល់វិញ្ញាណ ក៏មិនមែន ។ បទថា* **មេ** *ជាការសម្តែងដល់បុគ្គលដែលប្រកបដោយកិច្ចទាំង ២ ។ ពិតហើយ ការប្រព្រឹត្តទៅនៃសព្ទថា* **មេ** *ជាអារម្មណ៍វិសេសនៃសព្ទដោយចំណែកមួយប៉ុណ្ណោះ ឯកិច្ចរបស់វិញ្ញាណ ក៏គប្បីប្រជុំចុះក្នុងទីនោះឯង ។ ឯសេចក្តីសង្ខេបក្នុងសេចក្តីនេះ មានដូច្នេះថា ខ្ញុំបានស្តាប់មកហើយ ដោយវោហារនៃចំណែកកិច្ច ដែលបុគ្គលដល់ព្រមដោយសោត-វិញ្ញាណកិច្ចបានហើយដោយអំណាចវិញ្ញាណ ។*

ម្យ៉ាងទៀត បទថា **ឯវំ** *និង* **មេ** *ឈ្មោះថា អវិជ្ជមានប្បញ្ញត្តិ បញ្ញត្តិក្នុងវត្ថុដែលមិនមាន ដោយអំណាចសច្ចិកត្ថបរមត្ថ ។ ព្រោះប្រយោជន៍ទាំងពួងដែលគប្បីសម្រេចដោយសទ្ធា ចាំបាច់បដិបត្តិដោយមុខនៃបញ្ញត្តិប៉ុណ្ណោះ ឈ្មោះថា ជាការខុសភ្លាំងភ្លាត់នៃបញ្ញត្តិទាំងពួង និងក្នុងបញ្ញត្តិ ៦ មានវិជ្ជ-មានប្បញ្ញត្តិជាដើម ព្រោះដូច្នោះ អត្តដែលមិនពិតឯណា ដូចរបស់បញ្ឆោតមានមាយា និងថ្លៃបណ្តើរកូនជាដើម និងអត្ត មិនមែនឧត្តម ដូចគប្បីកាន់យកដោយអាការដែលស្តាប់តាមគ្នាមកជាដើម ក៏មិនមែន អត្តនោះ មានសភាវៈជាបរមត្ថ មានរូបារម្មណ៍ សទ្ទារម្មណ៍ និងរសារម្មណ៍ជាដើម និងមានការបែកធ្លាយ ការសោយអារម្មណ៍ជាដើម រមែងមានដោយសច្ចិកត្ថ-បរមត្ថ អត្ត គឺអាការជាដើមដែលពោលថា* **ឯវំ** *និង* **មេ** *មានភាវៈមិនមែនបរមត្ថ កាលមិនចូលជាមួយសច្ចិកត្ថបរមត្ថ ឈ្មោះថា អវិជ្ជមានប្បញ្ញត្តិ*

ព្រោះដូច្នោះ វត្ថុដែលលោកទាំងឡាយ បាននិទ្ទេសថា **ឃរំ** *ឬ* **មេ** *នីងមាន ដោយបរមត្ថបានដូចម្តេច ។ បទថា* **សុតំ** *បានដល់ វិជ្ជមានប្បញ្ញត្តិ បញ្ញត្តិ ដែលមាន ពិតហើយ វត្ថុណាមួយ ដែលបានដោយសោតវិញ្ញាណនោះ ដោយបរមត្ថ ឈ្មោះថា វិជ្ជមានប្បញ្ញត្តិ នោះឯង ។*

ម្យ៉ាងទៀត បទថា **ឃរំ** *ជា ឧបាទាយប្បញ្ញត្តិ ដោយអាស្រ័យធម៌ ដែលមកប្រាកដតាមសោតទ្វារ ហើយទាញយកអាការ គឺការទ្រទ្រង់ចាំនូវធម៌ ទាំងនោះជាដើម ។ បទថា* **មេ** *ជា ឧបាទាយប្បញ្ញត្តិ ព្រោះចាំបាច់ត្រូវ ពោលអាស្រ័យខន្ធ ដែលទាក់ទងក្នុងសន្តតិដ៏វិសេស ដោយការប្រកបគ្នានៃ ការធ្វើជាដើម ។ បទថា* **សុតំ** *ឈ្មោះថា ឧបនិធានបញ្ញត្តិ ព្រោះចូលទៅ កាន់យកទិដ្ឋិជាដើម ។ បញ្ញត្តិថា* **សុត** *សូម្បីប្រព្រឹត្តទៅក្នុងសទ្ទាយតនៈ ដែលវៀរចាកសការៈ មានរូបដែលឃើញហើយជាដើម ចាំបាច់ពោលទាញ យករូបដែលឃើញជាដើម ព្រោះមិនសម្ងីនរូបដែលឃើញហើយ អារម្មណ៍ ដែលដឹងហើយ និងធម៌ដែលដឹងច្បាស់ហើយ ក៏ដឹងច្បាស់ថា វត្ថុនោះខ្ញុំស្តាប់ ហើយ ដូចក្នុងវោហារទី ២-៣ ជាដើម ចាំបាច់ពោលកាន់យកទី ១ ជាដើម បទថា* **សុតំ** *ក្នុងពាក្យថា* **អសុតំ ន ហោតិ** *នេះ មានអត្ថដែលលោក ពោលត្រឹមប៉ុណ្ណោះឯង ។*

ក្នុងពាក្យទាំងនោះ ដោយពាក្យថា **ឃរំ** *ព្រះថេរៈសម្តែងដល់ការមិន ភ្លេចស្មារតី ។ ពិតហើយ ការប្រកបគ្នាដោយប្រការនៃព្រះសូត្រដែលខ្លួនដឹង ច្បាស់ហើយ ព្រះអានន្ទកាន់យកក្នុងពាក្យថា* **ឃរំ** *នេះ ឈ្មោះថា ព្រះអានន្ទ*

សម្តែងដល់ការមិនភ្ជាប់ភ្ជាំងដល់ **ឯវ** សព្ទនោះ ។ ពិតហើយ បុគ្គលដែលមិនមានស្មារតី មិនអាចចាក់ធ្លុះដោយប្រការផ្សេងៗ លោកសម្តែងប្រការផ្សេងៗ និងប្រការដែលដឹងបានលំបាក ដោយអំណាចបច្ចយាការថា ព្រះសូត្រ ។ ដោយពាក្យថា **សុតំ** លោកសម្តែងដល់ការមិនវង្វេងក្នុងរឿងដែលបានស្តាប់មកហើយ ព្រោះអាការនៃរឿងដែលបានស្តាប់មកហើយ លោកសម្តែងតាមសេចក្តីពិត ព្រះសូត្រដែលបានស្តាប់មកហើយភ្ជាចទៅវិញ បុគ្គលនោះ រមែងប្តេជ្ញាមិនបានថា ខ្ញុំបានស្តាប់មកហើយក្នុងកាលដទៃ ដូច្នោះ ពាក្យសម្រេចនៃបញ្ញាក្នុងកាលក្រៃលែងជាងនោះ រមែងមានដោយការមិនវង្វេងរបស់ព្រះថេរ: គឺមិនវង្វេង ឬដោយបញ្ញានោះឯងដែលកើតអំពីការស្តាប់ការសម្រេចនៃសតិ រមែងមានដោយការមិនវង្វេងដូចគ្នា ។ គប្បីជ្រាបអធិប្បាយក្នុងពាក្យនោះថា សតិដែលមានបញ្ញាជាប្រធាន អាចហាមសេចក្តីដទៃដោយព្យញ្ជន: ពិតហើយ អាការរបស់ព្យញ្ជន: ដែលគប្បីដឹងច្បាស់ ចាក់ធ្លុះ ជាអាការមិនជ្រៅពេក ការទ្រទ្រង់ចាំនូវសុត: តាមដែលបានស្តាប់មក ទើបជាករណីយកិច្ចក្នុងសេចក្តីនោះ ព្រោះដូច្នោះ ទើបសតិមានការខ្ចល់ខ្ចាយក្រៃលែងជាង ចំណែកបញ្ញាជាតួគុណក្នុងការព្យាយាមរបស់សតិនោះ ព្រោះអធិប្បាយថា ជាប្រធានរបស់បញ្ញា ។ គប្បីជ្រាបភាពដែលបញ្ញាមានសតិជាប្រធានអាចចាក់ធ្លុះនូវអត្ថបាន ។ ពិតហើយ អាការដែលគប្បីចាក់ធ្លុះបាន ជាអាការជ្រាលជ្រៅ ព្រោះដូច្នោះ ទើបបញ្ញា មានសេចក្តីព្យាយាមក្រៃលែង ចំណែកសតិជាតួគុណក្នុងសេចក្តីព្យាយាមរបស់បញ្ញានោះ ព្រោះអធិប្បាយថា ជាតួ

នាំនៃសតិ ។ គប្បីជ្រាបសេចក្តីសម្រេចនៃភាពជាធម្មកណ្ហាគារិក ដោយ អំណាចការតាមរក្សាឃ្លាំងធម៌ដែលសម្បូរដោយអត្ថ និងព្យញ្ជនៈ ព្រោះប្រកប ដោយអំណាចនៃសតិ និងបញ្ញាទាំង ២ នោះ ។

ម្យ៉ាងទៀត លោកសម្តែងយោនិសោមនសិការដោយពាក្យថា **ឱរំ** *ឯ សេចក្តីសម្រេចដែលមិនវិបរិតនៃអត្ថរបស់អាការ និទស្សនៈ និងអវធារណៈ ដែលពោលដោយបទថា* **ឱរំ** *នោះ ធ្លុះបញ្ចាំងដល់ការចាក់ធ្លុះ មានប្រការ ផ្សេងៗ ដែលនឹងពោលខាងមុខ ព្រោះមានធម៌ជាអារម្មណ៍ ។ ពិតហើយ ការ ចាក់ធ្លុះដោយប្រការផ្សេងៗ ដោយយោនិសោមនសិការ មិនមាន ។ លោក សម្តែងដល់ការមិនរាយមាយ ដោយពាក្យថា* **សុតំ** ។ *ការស្តាប់ព្រះសូត្រ ដែលពោល ដែលចាត់ជាបករណ៍ ដោយអំណាចពាក្យសួរជាដើមថា បឋម-ពោធិសូត្រ លោកពោលក្នុងទីណា វៀរការតាំងមាំចេញហើយ រមែងមិន មាន ព្រោះចិត្តរាយមាយ ពិតហើយ បុគ្គលមានចិត្តរាយមាយ ទោះបីបុគ្គល នោះពោលដោយសម្បត្តិគ្រប់យ៉ាង ក៏ពោលថា ខ្ញុំមិនបានឮ សូមអ្នកនិយាយ ជាថ្មី ។ ដោយការដាក់ចិត្តដោយឧបាយក្នុងសេចក្តីនេះ រមែងញ៉ាំងអត្ត-សម្មាបណិធិ និងបុព្វេកតបុញ្ញតាឲ្យសម្រេច ព្រោះបុគ្គលដែលមិនបានតម្កល់ ខ្លួនប្រពៃ និងមិនបានធ្វើបុណ្យក្នុងកាលមុន មិនមានយោនិសោមនសិការ នោះ ។ ព្រោះការមិនរាយមាយ រមែងឲ្យសម្រេចការស្តាប់ព្រះសទ្ធម្ម និង ការគប់រកសប្បុរស ព្រោះបុគ្គលដែលមិនបានស្តាប់ និងមិនសេពគប់សប្បុរស មិនមានយោនិសោមនសិការនោះ ដឹងថា បុគ្គលមានចិត្តរាយមាយ មិនអាច*

ស្តាប់បាន និងបុគ្គលដែលមិនសេពគប់សប្បុរស ក៏មិនមានការបានស្តាប់ឡើយ ។

នយម្យ៉ាងទៀត លោកពោលថា នុ៎ះជាការសម្តែងលម្អិតចិត្តសន្តានដែលកាន់យកអត្ត និងព្យញ្ជនៈផ្សេងៗ ដោយការប្រព្រឹត្តទៅ ដោយប្រការផ្សេងៗ ព្រោះចិត្តសន្តាននោះ គឺអាការដែលចម្រើនយ៉ាងនេះ ជាគ្រឿងធ្វើប្រយោជន៍ អនុគ្រោះរបស់អ្នកជនៃឲ្យបរិបូណ៌គ្រប់យ៉ាង ដោយការឈមចុះកាន់សាសនសម្បត្តិទាំងមូល ដោយការកំណត់ប្រភេទអត្ត និងព្យញ្ជនៈនៃព្រះតម្រាស់របស់ព្រះមានព្រះភាគ រមែងមិនមានដល់បុគ្គល ដែលមិនតម្កល់ខ្លួនប្រពៃ ឬបុគ្គលដែលមិនបានធ្វើបុណ្យក្នុងកាលមុន ដូច្នោះ ដោយអាការដែលចម្រើនថា **ឃ** *នេះ ព្រះថេរៈសម្តែងចក្កសម្បត្តិ ២ ខាងក្រោយរបស់ខ្លួន ដោយការប្រកបការស្តាប់ថា* **សុតំ** *ព្រះថេរៈសម្តែងចក្កសម្បត្តិ ២ ប្រការដំបូង ។ សេចក្តីពិត បុគ្គលនៅក្នុងបទេសដែលមិនសមគួរ ឬវៀរចាកការសេពគប់សប្បុរស រមែងមិនមានការស្តាប់ ។ ដូច្នោះ សេចក្តីបរិសុទ្ធនៃអធ្យាស្រ័យរបស់ព្រះថេរៈ រមែងសម្រេចដោយការសម្រេចនៃចក្ក ២ ខាងក្រោយ ។ បុគ្គលដែលតាំងខ្លួនទុកដោយប្រពៃ និងបុគ្គលបានបំពេញបុណ្យក្នុងកាលមុន រមែងជាអ្នកមានអធ្យាស្រ័យបរិសុទ្ធ ព្រោះកិលេសដែលជាហេតុមិនបរិសុទ្ធនោះនៅឆ្ងាយ ។ ហេតុនោះ ទើបលោកពោលថា* **សម្មា-បណិហិតំ ចិត្តំ សេយ្យសោ នំ កតោ កយេ** *ចិត្តដែលតាំងទុកប្រពៃ គប្បីធ្វើបុគ្គលឲ្យប្រសើរជាងនោះ និងថា ម្នាលអានន្ទ អ្នកជាបុគ្គលបានធ្វើបុណ្យ*

ហើយ ចូរប្រកបសេចក្តីព្យាយាម អ្នកនឹងជាបុគ្គលមិនមានអាសវៈ ដោយ ធាប់រួសរាន់ ។ សេចក្តីសម្រេចនៃការប្រកប ព្រោះការសម្រេចនៃចក្ក ២ ខាងដើម ។ ការប្រកបដ៏បរិសុទ្ធ រមែងមានដោយការដើរតាមទិដ្ឋានុគតិនៃ សាធុជន ដោយការនៅក្នុងបទេសដ៏សមគួរ និងដោយការគប់រកសប្បុរស ។ ការសម្រេចដោយភាពជាអ្នកជំនាញក្នុងអធិគម រមែងមានដោយសេចក្តីបរិសុទ្ធ នៃអធ្យាស្រ័យនោះ ព្រោះខ្លួនបានជម្រះកាប់ឆ្ការសង្កិលេស គឺតណ្ហា និងទិដ្ឋិ ក្នុងកាលមុនរៀបរយហើយ ការសម្រេចដោយការជំនាញក្នុងអាគម រមែង មានដោយសេចក្តីបរិសុទ្ធនៃការប្រកប ។ ពិតហើយ បុគ្គលមានកាយបយោគ និងវចីបយោគបរិសុទ្ធហើយ ឈ្មោះថា មានចិត្តមិនរាយមាយ ព្រោះមិនមាន ការក្តៅក្រហាយ រមែងជាអ្នកឈ្វាសក្នុងបរិយត្តិ ។ ដូច្នោះ ពាក្យរបស់អ្នក បរិសុទ្ធដោយការប្រកប និងអធ្យាស្រ័យ ជាអ្នកសម្បូរដោយអាគម និងអធិគម ទើបគួរជាខាងដើមនៃព្រះតម្រាស់របស់ព្រះមានព្រះភាគ ដូចអរុណោទ័យជា បុព្វនិមិត្តនៃព្រះអាទិត្យរះឡើង និងដូចយោនិសោមនសិការ ជាបុព្វនិមិត្តនៃ កុសលកម្ម ព្រោះដូច្នោះ ព្រះអានន្ទ កាលនឹងតាំងនិទានក្នុងឋាន:ដ៏សមគួរ ទើបពោលពាក្យជាដើមថា **ឯវម្មេ សុតំ។**

ម្យ៉ាងទៀត ព្រះអានន្ទសម្តែងការ:នៃសម្បត្តិ គឺអត្តប្បដិសម្ភិទា និង បដិភាណប្បដិសម្ភិទារបស់ខ្លួន ដោយពាក្យដែលសម្តែងដល់ការដឹងច្បាស់ ដោយប្រការផ្សេងៗ ដោយនយដូចពោលហើយ ក្នុងកាលមុន ដោយពាក្យ ថា **ឯវំ** *នេះ ។ សម្តែងសការ: គឺសម្បត្តិនៃធម្មប្បដិសម្ភិទា និងនិរុត្តិប្បដិ-*

សម្ដិទា ដោយការប្រៀបធៀប **ឯវំ** *សព្ទ ឬដោយពាក្យដែលសម្ដែងដល់ការចាក់ធ្លុះប្រកេទដែលគួរស្ដាប់ ដោយការសម្ដឹងពាក្យដែលនឹងពោលដល់ ដោយពាក្យថា* **សុតំ** *នេះ ។ ព្រះថេរៈកាលនឹងពោលដល់ពាក្យដែលសម្ដែងយោនិសោមនសិការថា* **ឯវំ** *នេះ ដោយនយដូចពោលហើយ ទើបសម្ដែងថា ធម៌ទាំងនេះ ខ្ញុំសម្ដឹងដោយចិត្ត ចាក់ធ្លុះដោយល្អ ដោយទិដ្ឋិ ។ ពិតហើយ បរិយត្តិធម៌ ខ្ញុំសម្ដឹងដោយចិត្ត ដោយនយជាដើមថា សីលត្រាស់ក្នុងទីនេះ សមាធិត្រាស់ក្នុងទីនេះ បញ្ញាត្រាស់ក្នុងទីនេះ អនុសន្ធិក្នុងទីនេះ មានប្រមាណប៉ុណ្ណេះ កំណត់ចាក់ធ្លុះដោយល្អ នូវរូបធម៌ និងអរូបធម៌ ដែលត្រាស់ក្នុងទីនោះ។ ដោយនយជាដើមថា រូបមានដូច្នេះ រូបមានប្រមាណប៉ុណ្ណេះ ដោយទិដ្ឋិដែលប្រកបដោយការត្រិះរិះតាមអាការដែលបានស្ដាប់មក ជាការអត់ធន់ចំពោះការសម្ដឹងធម៌ ឬពោល គឺញាតប្បរិញ្ញា រមែងនាំហិតសុខដល់ខ្លួន និងដល់អ្នកដទៃ ។ ព្រះថេរៈកាលនឹងពោលពាក្យដែលសម្ដែងដល់ការប្រកបក្នុងការស្ដាប់ថា* **សុតំ** *នេះ ទើបសម្ដែងថា ធម៌ជាច្រើន ខ្ញុំបានស្ដាប់ហើយ ទ្រទ្រង់ចាំហើយ វត់មាត់ហើយ ។ ពិតហើយ ការស្ដាប់ ការទ្រទ្រង់ចាំ ការសន្សំព្រះបរិយត្តិធម៌ ទាក់ទងដោយការផ្ទៀងសោតៈស្ដាប់ ដោយបទទាំង ២ នោះ ព្រះថេរៈកាលសម្ដែងសេចក្ដីបរិបូណ៌នៃអត្ថ និងព្យញ្ជនៈ ដោយភាពជាធម៌ដែលទ្រង់ត្រាស់ល្អហើយ ឈ្មោះថា ឲ្យកើតការអើពើក្នុងការស្ដាប់ ។ ពិតហើយ បុគ្គលដែលមិនបានស្ដាប់ធម៌ ដែលសម្បូរដោយអត្ថ និងព្យញ្ជនៈ ដោយអើពើ រមែងជាបុគ្គលឆ្ងាយចាកប្រយោជន៍ដ៏ក្រៃលែង ព្រោះដូច្នោះ គប្បី*

ឲ្យកើតការអើពើមុន ហើយទើបស្តាប់ធម៌ដោយគោរព ។

ដោយពាក្យទាំងអស់ថា **ឯវម្មេ សុតំ** *នេះ ព្រះអានន្ទកាលមិនទ្រទ្រង់ចាំធម្មវិនัយដែលព្រះតថាគត ទ្រង់ប្រកាសហើយសម្រាប់ខ្លួន រមែងឈានទៅកាន់ភូមិអសប្បុរស កាលប្តេជ្ញាខ្លួនថាជាសាវក ឈ្មោះថា ឈានចុះកាន់ភូមិសប្បុរស ម្យ៉ាងទៀត ឈ្មោះថា រមែងធ្វើចិត្តឲ្យចេញចាកអសទ្ធម្ម និងធ្វើចិត្តឲ្យតាំងនៅក្នុងព្រះសទ្ធម្ម ។ ព្រះថេរៈកាលសម្តែងថា សូត្រនេះ ខ្ញុំស្តាប់មកហើយទាំងអស់ ទាំងជាព្រះតម្រាស់របស់ព្រះមានព្រះភាគអង្គនោះឯង ឈ្មោះថា រមែងដោះខ្លួនអាងដល់ព្រះសាស្តា កាន់យកព្រះតម្រាស់របស់ព្រះជិនស្រី ឲ្យបែបផែននៃធម៌ប្រតិស្ឋាន ។ ម្យ៉ាងទៀត កាលមិនប្តេជ្ញាថា ខ្លួនឲ្យកើតឡើងឯង ដោយពាក្យថា* **ឯវម្មេ សុតំ** *កាលនឹងបើកផ្លូវពាក្យដែលស្តាប់មកពីមុន ទើបគិតថា ពាក្យនេះ ខ្ញុំបានទទួលមកចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគអង្គនោះ ជាអ្នកក្លៀវក្លាដោយវេសារជ្ជញាណ ៤ ដែលទ្រទ្រង់នូវទសពលញ្ញាណ ដែលតាំងនៅក្នុងឋានៈអ្នកអង់អាច អ្នកបន្ទឹសីហនាទ អ្នកឧត្តុង្គឧត្តមជាងសត្វ ជាធម្មិស្សរៈ ជាធម្មរាជា ជាអធិបតីក្នុងធម៌ ជាប្រទីបនៃធម៌ដែលជាធម្មសរណៈ ជាចក្រពត្តិនៃព្រះសទ្ធម្មដ៏ប្រសើរ បុគ្គលគ្រាស់ដឹងដោយប្រពៃ និងដឹងដោយព្រះអង្គឯង ក្នុងសេចក្តីនេះ អាត្មាអញមិនគួរធ្វើការងឿងឆ្ងល់ ឬការសង្ស័យក្នុងអត្ថ ធម៌ បទ ឬព្យញ្ជនៈ ធ្វើកាពជាអ្នកមិនមានសទ្ធាក្នុងធម៌នៃទេវតា និងមនុស្សទាំងពួងឲ្យវិនាស ឲ្យកើតសទ្ធាសម្បទាឡើង ព្រោះហេតុនោះ ទើបលោកពោល*

ពាក្យនេះថា

វិនាសយតិ អស្សទ្ធំ　　សទ្ធំ វឌ្ឍតិ សាសនេ

ឯវម្មេ　សុតមិច្ចេវំ　　វទំ គោតមសាវកោ។

សាវ័កវបស់ព្រះគោតម　កាលពោលពាក្យយ៉ាងនេះថា

ឯវម្មេ　សុតំ *រមែងឈ្មោះថា ញុំាងការមិនមានសទ្ធាឲ្យ*

វិនាស ញុំាងសទ្ធាឲ្យចម្រើនក្នុងព្រះសាសនា ។

បទថា **ឯកំ** *ជាការសម្តែងលម្អិតកំណត់ការរាប់ ។ ពិតហើយ* **ឯក** *សព្ទនេះ ប្រាកដក្នុងអត្ថថា* **អញ្ញ សេដ្ឋ អសហាយ** *និងសង្ខ្យាជាដើម ។*

ពិតហើយ **ឯក** *សព្ទនេះ ប្រាកដក្នុងអត្ថថា* **អញ្ញ** *គឺជនៃ ដូចក្នុងប្រយោគជាដើមថា* **សស្សតោ អត្តា ច លោកោ ច ឥច្ចេវ សច្ចំ មោឃមញ្ញន្តិ ឥត្តេកេ អភិវាទន្តិ** *បុគ្គលមួយពួកពោលអះអាងដូច្នេះថា ខ្លួននិងលោក ទៀង វត្តុនេះប៉ុណ្ណោះពិត វត្តុដទៃទេ ដូច្នេះ ។*

ប្រាកដក្នុងអត្ថថា **សេដ្ឋ** *គឺប្រសើរបំផុត ដូចក្នុងប្រយោគជាដើមថា* **ចេតសោ ឯកោធិភាវំ** *ការមានចិត្តឯក ផុសឡើង ដូច្នេះ ។*

ប្រាកដក្នុងអត្ថថា **អសហាយ** *គឺមិនមានសម្ងាញ់ ដូចក្នុងប្រយោគជាដើមថា* **ឯកោ វូបកដ្ឋោ** *ម្នាក់ឯងចៀសចេញហើយ ដូច្នេះ ។*

ប្រាកដក្នុងអត្ថថា សង្ខ្យា គឺការរាប់ ដូចក្នុងប្រយោគជាដើមថា **ឯកោ ខោ ភិក្ខវេ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ** *ម្នាលភិក្ខុទាំងឡាយ ខណៈ និងសម័យនៃការនៅ ប្រព្រឹត្តព្រហ្មចារ្យ មានតែមួយ ។*

ក្នុងទីនេះ គប្បីឃើញថា ប្រើក្នុងការរាប់នោះឯង ។ ព្រោះហេតុនោះ ទើបលោកពោលថា បទថា **ឯកំ** *ជាការសម្តែងកំណត់ការរាប់ ។ បទថា* **សមយំ** *ជាបទសម្តែងវេលាដែលកំណត់ បទថា* **ឯកំ សមយំ** *ជាការសម្តែងពេលដែលមិនកំណត់ពិតប្រាកដ ។ ក្នុងពាក្យថា* **ឯកំ សមយំ** *នោះ* **សមយ** *សព្ទ ប្រើក្នុងអត្ថ ៩ យ៉ាង គឺ* **សមវាយ** *គឺការព្រមព្រៀង ១ ខណៈ ១ កាល ១* **សមូហ** *គឺប្រជុំ ១ ហេតុ ១ ទិដ្ឋិ ១* **បដិលាភ** *គឺការបានចំពោះ ១ បហាន ១ បដិវេធ ១ ។*

ពិតហើយ **សមយ** *សព្ទនោះ មានអត្ថថា ព្រមព្រៀង ដូចក្នុងប្រយោគជាដើមថា* **អប្បេវ នាម សេបិ ឧបសង្កមេយ្យាម កាលញ្ច សមយញ្ច ឧចានាយ** *បើដូច្នោះ ចាំយើងពិចារណានូវកាល និងសម័យ (កាលព្រមព្រៀម) សិនហើយ សឹមទៅក្នុងថ្ងៃស្អែក ។ អធិប្បាយថា បានកាលសមគួរ និងការព្រមព្រៀងនៃបច្ចយ ព្រោះដូច្នោះ គប្បីជ្រាបបច្ចយសមវាយ គឺការព្រមព្រៀងនៃបច្ចយ ដូច្នេះ ។*

មានអត្ថថា **ខណៈ** *ដូចក្នុងប្រយោគជាដើមថា* **អយំ ភិក្ខវេ ឯកោ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ** *ម្នាលភិក្ខុទាំងឡាយ នេះជាខណៈ និងសម័យនៃការនៅ ប្រព្រឹត្តព្រហ្មចារ្យតែមួយ ដូច្នេះ ។ អធិប្បាយថា ឱកាស ពិតហើយ ឱកាសរបស់មគ្គព្រហ្មចរិយៈ មានការកើតឡើងនៃព្រះតថាគតជាដើម ព្រោះជាហេតុឲ្យបានមគ្គព្រហ្មចរិយៈនោះជាបច្ចយ អធិប្បាយថា សម័យ គឺខណៈ លោកហៅថា ខណៈ និងសម័យនោះតែ*

មួយនោះឯង ។

មានអត្ថថា **កាល** ដូចក្នុងប្រយោគជាដើមថា **ឧណ្ហសមយោ បរិឌ្ឍា-ហសមយោ** សម័យក្តៅ សម័យ (កាល) ស្អុះស្អាប់ ដូច្នេះ ។

មានអត្ថថា **សមុហ** គឺប្រជុំ ដូចក្នុងប្រយោគជាដើមថា **មហាសមយោ បវនស្មឹ** ថ្ងៃនេះជាថ្ងៃប្រជុំធំ ក្នុងដងព្រៃធំ ។ ពិតហើយ បទថា **មហា-សមយោ** សេចក្តីថា ជាទីប្រជុំធំនៃភិក្ខុ និងទេវតាទាំងឡាយ ។

មានអត្ថថា **ហេតុ** ដូចក្នុងប្រយោគជាដើមថា **សមយោបិ ខោ តេ ភទ្ទាលិ ។បេ។ សមយោ អប្បដិវិទ្ធោ អហោសិ ។** ម្នាលភទ្ទាលិ អ្នកមិនបានដឹងហេតុថា ព្រះមានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី តែព្រះមានព្រះភាគ គង់ដឹងអាត្មាអញថា ភិក្ខុឈ្មោះភទ្ទាលិ មិនបានបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តាដូច្នេះទ្បើយ ម្នាលភទ្ទាលិ នេះឯងជាហេតុដែលអ្នកមិនបានដឹង ពិតហើយ ហេតុនៃសិក្ខាបទ លោកបំណងយកថា ជា **សមយ** ក្នុងទីនេះ ។

មានអត្ថថា **ទិដ្ឋិ** ដូចក្នុងប្រយោគជាដើមថា **តេន ខោ បន សមយេន ឧគ្គាហមានោ បរិញ្ញាជកោ សមណមុណ្ឌិកាបុត្តោ សមយប្បវាទកេ តិណ្ឌុកាចីរេ ឯកសាលកេ មល្ទិកាយ អារាមេ បដិវសតិ** សម័យនោះឯង បរិញ្ញជកឈ្មោះឧគ្គាហមានះ ជាសមណមុណ្ឌិកាបុត្រ អាស្រ័យនៅក្នុងអារាមរបស់ព្រះនាងមល្ទកាទេវី ដែលមានសាលាមួយ មានជួរដើមទន្ទាប់ ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវទិដ្ឋិ (លទ្ធិ) ។ ពិតហើយ តិរ្ថិយទាំង-

ទ្បាយ អង្គុយត្រង់អាវមដែលមានសាលាមួយខ្នងនោះ ជ្រាប់សម័យ ពោល គឺទិដ្ឋិរៀងៗ ខ្លួន ព្រោះដូច្នោះ អាវមរបស់បរិព្វាជកនោះ លោក ហៅថា ជាទីបង្រៀនទិដ្ឋិ ។

មានអត្ថថា **បដិលាភ** *គឺការបានចំពោះ ដូចក្នុងប្រយោគជាដើមថា*

ឯដ្ឋេ ធម្មេ ច យោ អត្តោ យោ ចត្តោ សម្បរាយកោ
អត្តាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ ។

បណ្ឌិត ជាអ្នកមិនប្រមាទ តែងបានចំពោះប្រយោជន៍ទាំងពីរ គឺ ប្រយោជន៍ណា ក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ណា ដែលមានក្នុង បរលោកក្តី ធីរជន ឈ្មោះថា បណ្ឌិត ព្រោះការបានចំពោះ នូវប្រយោជន៍ទាំងពីរនោះ ។

ពិតហើយ បទថា **អត្តាភិសមយា** *សេចក្តីថា ព្រោះបានប្រយោជន៍ ទាំង ២ នោះ ។*

មានអត្ថថា **បហាន** *គឺការលះ ដូចក្នុងប្រយោគជាដើមថា* **សម្មា មានាភិសមយាអន្តមកាសិ ទុក្ខស្ស** *ធ្វើនូវទីបំផុតកងទុក្ខ ដោយហេតុដែល បានលះបង់នូវមានះចោលដោយប្រពៃ ។*

អភិសម័យ ឈ្មោះថា **បហាន** *ក្នុងពាក្យថា* **អធិការណា** *គឺការធ្វើ ឲ្យក្រៃលែង* **សមយ** *គឺការលះ* **វូបសម** *គឺការចូលទៅស្ងប់ **អបគម** គឺការទៅជ្រាស ។*

មានអត្ថថា **បដិវេធ** *គឺការចាក់ធ្លុះ ដូចក្នុងប្រយោគជាដើមថា* **ទុក្ខស្ស**

បីឋ្យនដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ អភិសមយដ្ឋោ ទុក្ខ មានអត្ថថា បៀតបៀន មានបច្ចយតាក់តែង ធ្វើឲ្យក្តៅក្រហាយ ប្រែប្រួល និងគួរចាក់ធ្លុះ ។ ពិតហើយ ការចាក់ធ្លុះ ឈ្មោះថា **អភិសមយ** ព្រោះចាំបាច់ត្រូវចាក់ធ្លុះ ។ អត្ថ គឺអភិសម័យ ឈ្មោះថា **អភិសមយត្ត** ព្រោះហេតុនោះ ទុក្ខ មានការបៀតបៀនជាដើម លោកពោលសង្គ្រោះជាមួយគ្នា ព្រោះចាំបាច់ត្រូវចាក់ធ្លុះ ។ ម្យ៉ាងទៀត អត្ថដែលជាអារម្មណ៍នៃអភិសម័យ គឺការចាក់ធ្លុះ ឈ្មោះថា **អភិសមយត្ត** ព្រោះហេតុនោះ ការបៀតបៀនជាដើមនោះឯង ទើបលោកពោលយ៉ាងនោះ ដោយភាពតែមួយ ។ ក្នុងអត្ថទាំងនោះ ទុក្ខសច្ច បៀតបៀនបុគ្គលដែលជល់ព្រមដោយទុក្ខសច្ចនោះ គឺធ្វើឲ្យចម្រើនមិនបាន ឈ្មោះថា បៀតបៀន ។ ការដុតរោល គឺការក្តៅក្រហាយដោយអំណាចទុក្ខ និងភាពជាទុក្ខជាដើម ឈ្មោះថា ការក្តៅក្រហាយ ។

ក្នុងសេចក្តីនេះ សម័យ ឈ្មោះថា **សមវាយ** ព្រោះសេចក្តីសម្រេច ព្រោះមានហេតុដែលមានការធ្វើរួមគ្នា ប្រព្រឹត្តព្រមគ្នា គឺព្រមព្រៀងគ្នា ។ សម័យ ឈ្មោះថា **ឱសរ** ព្រោះជាទីព្រមព្រៀងគ្នា គឺមកព្រមគ្នានៃមគ្គ-ព្រហ្មចរិយៈ ដោយបុគ្គលដែលទ្រទ្រង់ នូវមគ្គព្រហ្មចរិយៈនោះ ។ សម័យ ឈ្មោះថា **កាល** ព្រោះជាទីទៅព្រមគ្នា ឬជាហេតុទៅព្រមគ្នានៃសត្វ ឬនៃសភាវធម៌ ដោយខណៈ មានឧប្បាទក្ខណៈជាដើម ឬដោយសម្បយុត្តធម៌មានសហជាតធម៌ជាដើម ។ ពិតហើយ បើពោលដោយអត្ថ កាល មិនមានពិតដោយសភាវៈ គ្រាន់តែប្រព្រឹត្តទៅតាមធម៌ លោកហៅដោយការ

សមគួរដែលសម្រេចមកត្រឹមតែការត្រិះរិះ នៃការប្រព្រឹត្តទៅរបស់ធម៌ ដូច អធិករណៈ និង ករណសាធនៈ ដូច្នេះ សម័យ ឈ្មោះថា **សមុទា** *ព្រោះ ទៅ គឺប្រព្រឹត្តទៅ ព្រោះការតាំងនៅនៃអវយវៈទាំងឡាយស្មើគ្នា ឬព្រមគ្នា ដូចការប្រជុំ ។ ពិតហើយ ការតាំងចុះព្រមគ្នានៃអវយវៈនោះឯង ឈ្មោះថា* **សមុទា** *គឺការប្រជុំ សម័យ ឈ្មោះថា* **ហេតុ** *ព្រោះជាទីទៅ គឺកើតឡើង ប្រព្រឹត្តទៅនៃផល ក្នុងកាលមានការប្រជុំនៃបច្ច័យទាំងអស់ ដូចសមុទយៈជា ដែនកើតឡើងនោះឯង សម័យ ឈ្មោះថា* **ឋិដ្ឋិ** *ព្រោះទៅព្រមគ្នា គឺជាប់ទាក់ ទងគ្នាដោយការៈជាសំយោជនៈ ប្រព្រឹត្តទៅក្នុងអារម្មណ៍របស់ខ្លួន ។ ម្យ៉ាង ទៀត ព្រោះជាគ្រឿងប្រកបដោយការៈប្រកាន់មាំ គឺប្រព្រឹត្តទៅតាមការ ប្រកាន់មាំនៃសត្វទាំងឡាយ ពិតហើយ សត្វទាំងឡាយ ត្រូវទិដ្ឋិសំយោជនៈ ចងយ៉ាងស្អិតនោះឯង។ សម័យ ឈ្មោះថា* **បដិលាភ** *ព្រោះការប្រជុំ ការជួប ការប្រមូលចុះ សម័យ ឈ្មោះថា* **បហាន** *ព្រោះលះបង់ទៅ សាបសូន្យទៅ ប្រាសទៅ ។ ម្យ៉ាងទៀត សម័យ ឈ្មោះថា* **អភិសមយ** *ព្រោះជាសម័យ ក្រៃលែងដោយការលះបានជាច់ខាត ដូចអភិធម្ម ដូច្នេះ ។ ឈ្មោះថា* **អភិសមយ** *ព្រោះគប្បីដល់ គឺគប្បីសម្រេចដោយញាណចំពោះមុខ បាន ដល់ ឈមចុះដល់សការៈនៃធម៌ដែលមិនប្រែប្រួល ។ ឈ្មោះថា* **អភិ-សមយ** *ព្រោះទៅ គឺសម្រេចនូវការត្រាស់ដឹងដោយការៈចំពោះមុខ គឺដោយ ប្រពៃ បានដល់ ការឈមចុះកាន់សការៈតាមសេចក្តីពិតនៃធម៌ ។ គប្បីជ្រាប ការប្រព្រឹត្តទៅនៃ* **សមយ** *សព្ទ ក្នុងអត្តនោះៗ ដោយអាការយ៉ាងនេះ ។*

គប្បីជ្រាបហេតុនៃការពង្រីកអត្ថនៃ **សមយ** *សព្ទ បន្ថែម* **អភិសមយ** *សព្ទចូលដោយនយដូចពោលហើយនោះឯង ។ តែក្នុងទីនេះ* **សមយ** *សព្ទ ឈ្មោះថា មានកាលជាអត្ថ ព្រោះអត្ថទាំង ៩ មានសមយៈជាដើមមិនមាន គប្បីជ្រាប* **សមយ** *សព្ទនោះថាជា កាល ក្នុងការៈនៃពាក្យផ្តើមរបស់ទេសនា ដូចជាទីកន្លែងអ្នកសម្តែង និងបរិស័ទជាដើម ព្រោះលោកបំណងយកកាលថាជាសម័យក្នុងទីនេះ ដូច្នោះ ទើបព្រះថេរៈសម្តែងថា សម័យមួយ បណ្តាសម័យដែលជាប្រភេទនៃកាល ដូចជាឆ្នាំ រដូវ ខែ កន្លះខែ កណ្តាលយប់ កណ្តាលថ្ងៃ ពេលព្រឹក ថ្ងៃត្រង់ ល្ងាច បឋមយាម មជ្ឈិមយាម បច្ឆិមយាម និងមួយរំពេចជាដើម ។*

បើមានពាក្យសួរជ្រៀតចូលមកថា ព្រោះហេតុអ្វី ក្នុងទីនេះ ទើបលោកសម្តែងលម្អិតដល់កាល ដោយមិនកំណត់ពិតប្រាកដនោះឯង ហើយកំណត់សម្តែងលម្អិតដោយរដូវ និងឆ្នាំជាដើមក៏មិនមែន ។ ឆ្លើយថា បណ្តាសម័យមានឆ្នាំជាដើមនោះ សូត្រណាមួយដែលលោកពោលក្នុងឆ្នាំ រដូវ ខែ បក្ខ ឯ រាត្រី ឬចំណែកថ្ងៃណាមួយ ទាំងអស់នោះ ព្រះថេរៈដឹងច្បាស់ហើយ គឺប្រើបញ្ញាកំណត់ដោយល្អហើយ ។ ព្រោះហេតុដែលលោកពោលហើយយ៉ាងនេះថា ខ្ញុំបានស្តាប់ហើយយ៉ាងនេះ ក្នុងឆ្នាំនោះ រដូវនោះ បក្ខនោះ ចំណែករាត្រី ឬចំណែកថ្ងៃនោះ បុគ្គលណាម្នាក់ មិនអាចចាំបាន សម្តែងឯង ឬឲ្យអ្នកដទៃសម្តែង បានដោយងាយឡើយ ទាំងត្រូវពោលច្រើន ដូច្នោះ ទើបលោកប្រជុំអត្ថនោះដោយ បទមួយប៉ុណ្ណោះ ហើយពោលថា **ឯកំ សមយំ**

ដូច្នេះ ។

ម្យ៉ាងទៀត ព្រះថេរៈសម្តែងថា សម័យមួយ ពោល គឺសម័យសម្តែងធម៌ បណ្តាសម័យទាំងនេះ ដែលមានប្រភេទនៃកាលច្រើននោះឯង ដែលជាការប្រកាសយ៉ាងក្រៃលែងក្នុងពួកទេវតា និងមនុស្ស សម្រាប់ព្រះមានព្រះភាគមានជាអាទិ៍យ៉ាងនេះថា

សម័យដែលទ្រង់ចុះកាន់គភ៌ សម័យប្រសូត សម័យសង្វេគ សម័យទ្រង់ចេញអភិនេស្ក្រមណ៍ សម័យទ្រង់ធ្វើទុក្ករកិរិយា សម័យឈ្នះមារ សម័យត្រាស់ដឹងអភិសម្ពោធិញ្ញាណ សម័យប្រថាប់ជាផាសុកក្នុងបច្ចុប្បន្ន សម័យសម្តែងធម៌ និងសម័យបរិនិព្វាន ។

ម្យ៉ាងទៀត ព្រះថេរៈពោលថា សម័យមួយ សំដៅយកសម័យណាមួយ បណ្តាសម័យទាំងនេះ គឺសម័យបំពេញកិច្ចនៃព្រះបញ្ញាគុណ និងព្រះករុណាគុណ គឺសម័យបំពេញកិច្ចនៃព្រះករុណាគុណ ។ ក្នុងសម័យបំពេញប្រយោជន៍ចំណែកព្រះអង្គ និងប្រយោជន៍អ្នកដទៃ គឺសម័យបំពេញនូវប្រយោជន៍អ្នកដទៃ ។ ក្នុងសម័យព្រះករណីយកិច្ចទាំង ២ សម្រាប់បុគ្គលប្រជុំគ្នា គឺសម័យសម្តែងធម្មកថា ។ ក្នុងសម័យសម្តែងធម៌ និងបដិបត្តិធម៌ គឺសម័យសម្តែងធម៌ ។

សួរថា ព្រោះហេតុអ្វី ក្នុងសុត្តន្តបិដកនេះ លោកធ្វើនិទ្ទេសដោយទុតិយាវិភត្តិ ក្នុងអត្ថនៃអច្ចន្តសំយោគថា **ឯកំ សមយំ** *មិនធ្វើដូចដែលលោកធ្វើនិទ្ទេសដោយសត្តមីវិភត្តិ ក្នុងអភិធម្មថា* **យស្មឹ សមយេ កាមាវចរំ កុសលំ**

ចិត្តំ ឧប្បន្នំ ហោតិ ជួរច្នេះ និងក្នុងសុត្តបទដទៃចាកអភិធម្មនេះថា **យស្មឹ សមយេ ភិក្ខវេ ភិក្ខុ វិវេច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ** ជួរច្នេះ ក្នុងព្រះវិនយ លោកធ្វើនិទ្ទេសដោយតតិយាវិភត្តិថា **តេន សមយេន ពុទ្ធោ ភគវា** ជួរច្នេះ ។ ឆ្លើយថា ព្រោះក្នុងព្រះអភិធម្ម និងព្រះវិនយនោះ មានអត្ថយ៉ាងនោះ តែក្នុងព្រះសូត្រនេះមានអត្ថដទៃ ។ ពិតហើយ ក្នុងបិដកទាំង ៣ នោះ អត្ថនៃអធិករណសាធន ពោល គឺអាធារ និងវិសយ ក្នុងអភិធម្មបិដក និងក្នុងសុត្តន្តបិដក ក្រៅអំពីអភិធម្មបិដក និងអត្ថនៃលក្ខណៈ នៃការៈដោយការៈ ពោល គឺលក្ខណៈនៃកិរិយាជដទៃ ដោយកិរិយារមែងមាន ។ ពិតហើយ សមយដែលមានកាលជាអត្ថ និងមានសមុហៈជាអត្ថ ចាត់ជាអធិករណៈ ។ ម្យ៉ាងទៀត កាលនៃធម៌ មានផស្សៈជាដើម តាមដែលពោលហើយក្នុងអត្ថទាំង ២ នោះ មិនមានដោយបរមត្ថ ព្រោះត្រឹមតែជាការប្រព្រឹត្តទៅនៃសភាវធម៌ ក៏ជ្រាកដដល់ការៈនៃអាធារ ព្រោះធម៌ដែលប្រព្រឹត្តទៅក្នុងខណៈនោះ មិនមានក្នុងកាលមុន និងដទៃអំពីនោះ ដូចប្រយោគជាដើមថា **បុព្វណ្ហេ ជាតោ** កើតក្នុងពេលព្រឹក **សាយណ្ហេ ជាតោ** កើតក្នុងពេលល្ងាច អត្ថថា សមុហៈ ផុតចាកចំណែកប្រកប សូម្បីមិនមានដោយបរមត្ថ ក៏រមែងជ្រាកដដោយការៈនៃអាធារបស់ចំណែកប្រកបទាំងឡាយ ដោយរូបសម្រេចត្រឹមតែការត្រិះរិះ ដូចក្នុងប្រយោគជាដើមថា មែកត្រង់ដើមឈើ ជាយដំណើបតាំងឡើងត្រង់គំនរជាយដំណើប ។ កាមាវចរកុសលចិត្ត រមែងកើតក្នុងកាលណា និងក្នុងក្រុមធម៌ណា សូម្បីសម្បយុត្តធម៌ មានផស្សៈជាដើម

រមែងមានក្នុងកាលនោះ និងក្រុមធម៌នោះឯង ។ ក្នុងសេចក្តីនោះ មានអធិប្បាយត្រឹមប៉ុណ្ណោះ ។ ម្យ៉ាងទៀត សភាវធម៌ មានផស្សៈជាដើមដែលពោលក្នុងអភិធម្មនោះ លោកកំណត់ដោយភាវៈនៃ ***សមយ*** *សព្ទ ពោលគឺខណសមវាយ និងហេតុ ។ ដូចលោកកំណត់កិរិយាទៅដោយការ ធ្វើការរឹតទឹកដោះគោ ក្នុងពាក្យថា កាលមេគោត្រូវរឹតទឹកដោះហើយ នាយគោបាលក៏ទៅ កាលមេគោមានទឹកដោះ នាយគោបាលក៏មក យ៉ាងណា ក្នុងព្រះអភិធម្មក៏មានន័យយ៉ាងនោះ កាលពោលថា* ***យស្មឺ សមយេ*** *ជាការដែលយល់អត្ថដូច្នេះថា សម្រាប់បរមត្ថ និងវៀរសត្វក៏មិនបាន ទីងមិនមានសត្វក៏មិនបាន ព្រោះដូច្នោះ* ***សមយ*** *សព្ទ លោកកំណត់កិរិយា គឺឧប្បាទក្ខណៈនៃចិត្ត និងកិរិយា គឺការសោយសភាវធម៌ មានផស្សៈជាដើម ដោយមិនមានកិរិយានៃសត្វ ។ ម្យ៉ាងទៀត កាលសម័យណា កាលខណៈទី ៩ ណា កាលហេតុមាន យោនិសោមនសិការជាដើមណា ឬកាលការដល់ព្រមនៃបច្ច័យណាមាន កាមាវចរកុសលចិត្តរមែងកើតឡើង សូម្បីសភាវធម៌ មានផស្សៈជាដើម ក៏មានក្នុងសម័យនោះ ក្នុងខណៈនោះ ក្នុងហេតុនោះ និងក្នុងការដល់ព្រមនៃបច្ច័យនោះឯង ព្រោះដូច្នោះ ទើបធ្វើនិទ្ទេសដោយសត្តមីវិភត្តដើម្បីផ្តុះបញ្ចាំងនូវអត្ថនោះ ។*

ឯក្នុងព្រះវិនយ ***សមយ*** *សព្ទ ដែលមានហេតុជាអត្ថ ដូចក្នុងប្រយោគជាដើមថា បុគ្គលរមែងនៅព្រោះហេតុនៃបាយ ព្រោះហេតុនៃការអញ្ជើញ និងមានករណៈជាអត្ថ ដូចក្នុងប្រយោគជាដើមថា បុគ្គលរមែងកាប់ដោយពូថៅ*

រមែងជីកដោយចប ។ ពិតហើយ សម័យក្នុងការបញ្ញត្តិសិក្ខាបទឯណា សូម្បីព្រះធម្មសេនាបតីជាដើម ក៏យល់បានលំបាក សម័យនោះ ជាករណៈ និងជាហេតុ ព្រះមានព្រះភាគទ្រង់ជ្រាបការកន្ទងល្មើស ទើបទ្រង់ប្រជុំភិក្ខុសង្ឃសាកសួរ និងតិះដៀល បុគ្គលដែលជាដើមហេតុ កាលទ្រង់បញ្ញត្តសិក្ខាបទ ដោយមិនកន្ទងកាល ពោល គឺសម័យដែលប្រព្រឹត្តនូវរឿងនោះ និងមិនសម្ដឹងដល់ហេតុនៃការបញ្ញត្តិសិក្ខាបទ ដូចបញ្ញត្តតតិយបារាជិកជាដើម ហើយប្រថាប់នៅក្នុងទីនោះៗ ព្រោះដូច្នោះ ទើបធ្វើនិទ្ទេសដោយតតិយាវិភត្តិក្នុងព្រះវិនយ ដើម្បីឆ្លុះបញ្ចាំងអត្ថនោះ ។ តែ **សមយ** *សព្ទ ដែលមានអច្ចន្តសំយោគជាអត្ថ រមែងមានក្នុងទីនេះ និងក្នុងទីដទៃ ដែលមានកំណើតយ៉ាងនេះ ។ ពិតហើយ ក្នុងសម័យណា ឧទាននេះ កើតព្រមដោយហេតុដែលជាសមុដ្ឋាន ព្រះមានព្រះភាគគង់ប្រថាប់ដោយការពិចារណាធម៌ ដែលមានអរិយវិហារធម៌ជាប្រធាន អស់សម័យនោះ ដោយចំណែកមួយ ព្រោះដូច្នោះ ទើបធ្វើនិទ្ទេសដោយទុតិយាវិភត្តិ ក្នុងព្រះសូត្រនេះ ដើម្បីឆ្លុះបញ្ចាំងអត្ថនៃឧបយោគ ដូចក្នុងប្រយោគជាដើមថា* **មាសំ អជ្ឈេតិ** *រមែងស្វាធ្យាយអស់ខែ ។*

ដោយហេតុនោះ ទើបលោកពោលពាក្យនេះថា

តំ តំ អត្ថមបេក្ខិត្វា ភុម្មេន ករណេន ច
អញ្ញត្រ សមយោ វុត្តោ ឧបយោគេន សោ ឥធ ។

ព្រះអានន្ទពិចារណាដល់អត្ថនោះៗ ហើយពោល **សមយ** *សព្ទ ក្នុងសុត្តន្តបិដក និងអភិធម្មបិដក ដោយសត្តមីវិភត្តិ*

និងតតិយាវិភត្តិ **សមយ** *សព្ទនោះ ព្រះឧបាលីពោល ក្នុងវិនយបិដកនោះ ដោយទុតិយាវិភត្តិ ។*

ចំណែកបុរាណាចារ្យទាំងឡាយ បានពណ៌នាថា និទ្ទេសនោះ ជាការផ្សេងគ្នាត្រឹមតែរៀហារថា **យស្មឹ សមយេ** *ឬ* **តេន សមយេន** *ឬ* **ឯកំ សមយំ** *មានអត្ថជាសត្តមីវិភត្តិគ្រប់ៗ បទ ព្រោះដូច្នោះ សូម្បីលោកពោលថា* **ឯកំ សមយំ** *ក៏គប្បីជ្រាបថា* **ឯកស្មឹ សមយេ** *ដូច្នេះ ។*

បទថា **ភគវា** *ជាពាក្យសំដៅដល់គ្រូ ។ ពិតហើយ សត្វលោក ហៅគ្រូថា* **ភគវា** *។ ព្រះមានព្រះភាគអង្គនោះ ជាគ្រូនៃសព្វសត្វ ព្រោះជាបុគ្គលវិសេសដោយគុណទាំងពួង ព្រោះដូច្នោះ ទើបបណ្ឌិតថ្វាយព្រះនាមថា* **ភគវា** *សូម្បីបុរាណាចារ្យទាំងឡាយក៏ពោលថា*

ភគវាតិ វចនំ សេដ្ឋំ ភគវាតិ វចនមុត្តមំ
គរុគារវយុត្តោ សោ ភគវា តេន វុច្ចតិ ។

ពាក្យថា **ភគវា** *ជាពាក្យប្រសើរបំផុត ពាក្យថា* **ភគវា** *ជាពាក្យឧត្តមបំផុត ព្រះមានព្រះភាគអង្គនោះ ជាអ្នកគួរដល់ការគោរព ដោយហេតុជាគ្រូ ព្រោះដូច្នោះ ទើបបណ្ឌិតថ្វាយព្រះនាមទ្រង់ថា* **ភគវា** *ដូច្នេះ ។*

ក្នុងពាក្យទាំងនោះ ពាក្យពោលថា ប្រសើរបំផុត លោកពោលថា **សេដ្ឋ** *ព្រោះដល់ព្រមដោយគុណដ៏ប្រសើរ ។ ម្យ៉ាងទៀត អត្ថ ឈ្មោះថា* **វចន** *ព្រោះបុគ្គលនោះពោល ។ បទថា* **ភគវាតិ វចនំ សេដ្ឋំ** *សេចក្តីថា អត្ថ*

ដែលគួរពោលដោយពាក្យថា **ភគវា** *នេះ ជាអត្ថប្រសើរ សូម្បីក្នុងពាក្យថា* **ភគវាតិ វចនមុត្តមំ** *នេះ គប្បីជ្រាបអត្ថដោយនយដូចពោលហើយនោះ ។ បទថា* **គារវយុត្តោ** *បានដល់ ឈ្មោះថា ប្រកបដោយភាពជាគ្រូ ព្រោះប្រកបដោយគុណក្នុងហាន:ជាគ្រូ ឬឈ្មោះថា ប្រកបដោយសេចក្តីគោរព ព្រោះមានករុណា ហាន:ជាគ្រូជាពិសេស* **ភគវា** *នេះ គប្បីជ្រាបថា ជាឈ្មោះរបស់បុគ្គលវិសេសដោយគុណដែលខត្តុង្គខត្តមជាងសត្វ និងគួរគោរពដោយហាន:ជាគ្រូ ម្យ៉ាងទៀត គប្បីជ្រាបអត្ថនៃបទថា* **ភគវា** *ដូចមកក្នុងនិទ្ទេសថា*

ភគី ភជី ភាគី វិភត្តវា ៨តិ

អកាសិ ភគ្គន្តិ គរូតិ ភាគ្យវា

ពហូហិ ញាយេហិ សុភាវិតត្តនោ

ភវន្តគោ សោ ភគវាតិ វុច្ចតិ ។

ព្រះមានព្រះភាគអង្គនោះ បណ្ឌិតថ្វាយព្រះនាមថា **ភគវា** *ព្រោះទ្រង់ជាអ្នកមានជោគ ជាអ្នកសេពទីស្ងាត់ ជាអ្នកមានចំណែកដែលគួរទទួលបច្ច័យ ជាអ្នកចែក បានធ្វើការកាច់នូវភគធម៌ ជាគ្រូ ជាអ្នកមានបុណ្យបារមី ជាអ្នកអប់រំព្រះអង្គយ៉ាងល្អ ដោយញាយធម៌ដ៏ច្រើន និងជាបុគ្គលដល់ទីបំផុតភព ។ និងដោយអំណាចនៃគាថានេះថា*

ភាគ្យវា ភគ្គវា យុត្តោ ភគេហិ ច វិភត្តវា
ភត្តវា វន្តគមនោ ភវេសុ ភគវា តតោ ។

ព្រះមានព្រះភាគ បណ្ឌិតថ្វាយព្រះនាមថា **ភគវា** *ព្រោះជាអ្នកមានភាគ្យ ជាអ្នកកាច់បំបាក់នូវកិលេស ជាអ្នកប្រកបដោយភគធម៌ ជាអ្នកចែក ជាអ្នកសេពគប់ និងជាអ្នកខ្ជាក់ការទៅនៃភពចេញបាន ។*

អត្ថនៃបទថា **ភគវា** *នោះ លោកពោលក្នុងវិសុទ្ធិមគ្គ ដោយអាការទាំងពួង ព្រោះដូច្នោះ គប្បីជ្រាបតាមនយដែលពោលក្នុងវិសុទ្ធិមគ្គនោះ ។*

ម្យ៉ាងទៀត ឈ្មោះថា **ភគវា** *ព្រោះជួបនូវភាគធម៌ ឬខ្ជាក់ចោលនូវភគធម៌ ។ ពិតហើយ ព្រះតថាគត រមែងគប់រក សមាគម សេព ធ្វើឲ្យច្រើននូវបារមីធម៌ មានទាន និងសីលជាដើម និងឧត្តរិមនុស្សធម៌ មានឈាន និងវិមោក្ខជាដើម ព្រោះដូច្នោះ ទើបឈ្មោះថា* **ភគវា** *ម្យ៉ាងទៀត ឈ្មោះថា* **ភគវា** *ព្រោះសេពគប់ គឺប្រាថ្នាក្រៃលែងនូវធម៌ទាំងនោះឯងថា ធ្វើម្តេចហ្ន៎ ធម៌ទាំងនេះ គប្បីកើតឡើងក្នុងសន្តានរបស់វេនេយ្យសត្វ ។ ម្យ៉ាងទៀត ឈ្មោះថា* **ភគវា** *ព្រោះខ្ជាក់ គឺខ្ជាក់ចេញនូវភាពជាធំ និងយស ពោល គឺភគធម៌ មិនអាល័យ ខ្ជាល់ចោលហើយ ដូចបុគ្គលខ្ជាក់នូវទឹកមាត់ចោលដូច្នោះ ។ ពិតហើយ ព្រះតថាគត សម្គាល់សិរីរាជសម្បត្តិ នៃស្តេចចក្រពត្តិដែលនៅក្នុងព្រះហស្ត ភាពជាធំក្នុងទ្វីបទាំង ៤ ឬភាពជាធំក្នុងទេវលោក និងយសដ៏រុងរឿង ដោយរតនៈ ៧ យ៉ាង ជាទីអាស្រ័យនៃចក្កពត្តិសម្បត្តិថា*

ដូចត្រាវក្លីងឆេះ ទ្រង់មិនអាល័យ ទ្រង់លះបង់ យាងចេញមហាភិនេស្ក្រមិ ត្រាស់ដឹងដោយប្រពៃ ដោយព្រះអង្គឯង នូវសម្មាសម្ពោធិញ្ញាណ ព្រោះដូច្នោះ ទើបបណ្ឌិតថ្វាយព្រះនាមថា **ភគវា** *ព្រោះខ្ចាក់ចោលនូវភគធម៌ មានសិរីទាំងនេះជាដើម ។ ឈ្មោះថា* **ភគា** *ព្រោះទៅ គឺទៅព្រមជាមួយនក្ខត្ត-ឫក្ស គឺ* **ភា** *ទាំងនោះ គឺជាការស្អាតដែលអាស្រ័យលោក ដែលជាទីទទួលទ្រទ្រង់ ដូចជាភ្នំសិនេរុ ភ្នំយុគន្ធរ ឧត្តរកុរុទ្វីប និងព្រៃហិមពាន្តជាដើម ព្រោះជាទីតាំងនៅអស់កប្ប ។ ព្រះមានព្រះភាគ ទ្រង់ខ្ចាក់ គឺលះភគធម៌ទាំងនោះ ដោយការលះឆន្ទរាគៈ ដែលទាក់ទងជាមួយភគធម៌នោះ ព្រោះឈានកន្ទងការនៅរបស់សត្វ ដែលអាស្រ័យនៅក្នុងលោកនោះឯង កាលបើដូច្នោះ ក៏គប្បីជ្រាបអត្ថនៃបទថា* **ភគវា** *ដោយនយជាដើមយ៉ាងនេះថា ឈ្មោះថា* **ភគវា** *ព្រោះខ្ចាក់ចោលនូវ ភគធម៌ ។*

ដោយហេតុមានប្រមាណប៉ុណ្ណេះ បណ្តាពាក្យទាំងនោះ ដោយពាក្យថា **ឯវម្មេ សុតំ** *ព្រះថេរៈ កាលពោលធម៌តាមដែលស្តាប់មក ទើបធ្វើសរីរៈនៃធម៌របស់ព្រះមានព្រះភាគឲ្យប្រាកដច្បាស់ ព្រោះដូច្នោះ ទើបព្រះថេរៈលួងលោមជនដែលនឿយណាយ ដោយការមិនបានគាល់ព្រះសាស្តា ឲ្យបានធូរស្បើយថា មិនមែនតែបាវចនា គឺធម្មវិន័យដែលព្រះសាស្តាបរិនិព្វានទៅហើយនេះ ជាសាស្តារបស់ពួកអ្នកឡើយ ។ សមដូចព្រះតម្រាស់ ដែលត្រាស់ថា*

ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែង
ហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណឹះឥត

អំពីតថាគតទៅ ធម៌ និងវិនัយនោះ ជាគ្រូរបស់អ្នក ទាំងឡាយ ។

ដោយពាក្យថា **ឯកំ សមយំ ភគវា** *នេះ ព្រះថេរៈ កាលសម្តែងថា ក្នុងសម័យនោះ ព្រះមានព្រះភាគ ទ្រង់មិនគង់ព្រះជន្មនៅ ទើបលើកឧទាហរណ៍ ការបរិនិព្វានដោយរូបកាយ ដោយហេតុនោះ ព្រះថេរៈ ឲ្យជនដែលស្រេវឹងដោយសេចក្តីស្រេវឹងក្នុងជីវិតសង្វេគ និងឲ្យកើតឧស្សាហ៍ក្នុងព្រះសទ្ធម្ម ថា ព្រះមានព្រះភាគអង្គនោះ ទ្រង់សម្តែងធម៌មានច្រើនយ៉ាង ដូច្នេះ ទ្រទ្រង់នូវទសពលញ្ញាណ មានព្រះកាយស្មើដោយសីរពេជ្រ ទ្រង់បរិនិព្វានហើយ អ្នកជំទែគប្បីឲ្យកើតសេចក្តីជ្រាបក្នុងជីវិត ។*

ម្យ៉ាងទៀត កាលពោលថា **ឯវំ** *ទើបសម្តែងអាងយកទេសនាសម្បត្តិ ព្រោះព្រះសូត្រទាំងមូលដែលពោលសម្តែងអាងដល់បទថា* **ឯវំ** *ដូច្នេះ ដោយបទថា* **មេ សុតំ** *នេះ ព្រះថេរៈសម្តែងសាវកសម្បត្តិ និងសវនសម្បត្តិ ព្រោះសម្តែងដល់ការៈដែលបុគ្គលសម្រេចបដិសម្ភិទាជាកណ្ហាគារិក ដែលព្រះមានព្រះភាគទ្រង់ស្តាបនាក្នុងតំណែងឯតទគ្គៈ ក្នុងឋានៈទាំង ៥ ស្តាប់មកហើយ និងព្រោះសម្តែងសេចក្តីនេះថា ព្រះសូត្រនោះឯង ខ្ញុំបានស្តាប់មកហើយ មិនមែនមិនបានស្តាប់ទេ និងមិនមែននាំបន្តៗ គ្នាមកប៉ុណ្ណោះទេឬយ ។ ដោយបទថា* **ឯកំ សមយំ** *នេះ ព្រះថេរៈសម្តែងដល់កាលសម្បត្តិ ព្រោះសម្តែងដល់ការៈដែលស្តាប់ដោយពុទ្ធុប្បាទកាល ត្រូវនឹងសម័យដែលព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅត្រង់តំបន់ឧរុវេលា ។ កាលសម្បទា មានពុទ្ធុប្បាទកាល*

ដែលជាទីក្រៃលែង ។ ដោយបទថា **ភគវា** *នេះ ព្រះថេរៈសម្តែងដល់ទេស-កសម្បត្តិ ព្រោះសម្តែងដល់ភាវៈដែលទ្រង់ជាបុគ្គលវិសេស ដោយគុណដ៏ឧត្តមជាងសត្វ និងជាគ្រូ ។*

បទថា **ឧរុវេលាយំ** *បានដល់ ជិតគំនរខ្សាច់ធំ អធិប្បាយថា ត្រង់គំនរខ្សាច់ធំ ម្យ៉ាងទៀត ខ្សាច់លោកហៅថា ឧរុ ។ ព្រំដែន លោកហៅថា វេលា ។ គប្បីឃើញអត្ថក្នុងពាក្យនេះយ៉ាងនេះថា ខ្សាច់ដែលគេនាំមកព្រោះប្រព្រឹត្តកន្លងព្រំដែន ឈ្មោះថា ឧរុវេលា ។*

បានឮថា ក្នុងអតីតកាល កាលព្រះពុទ្ធមិនទាន់កើតឡើង តាបស ១ ម៉ឺននាក់នៅក្នុងប្រទេសនោះ ធ្វើកតិកាវត្តថា កាយកម្ម និងវចីកម្ម រមែងប្រាកដដល់ជនដទៃ ឯមនោកម្មមិនប្រាកដឡើយ ព្រោះដូច្នោះ បុគ្គលណាត្រិះរិះដល់មិច្ឆាវិតក្ក បុគ្គលនោះឈ្មោះថា ចោទខ្លួនឯងដោយខ្លួនឯង ចូរប្រើកន្ទោងវាល់ខ្សាច់មកចាក់ក្នុងទីនេះ នេះជាទណ្ឌកម្មរបស់បុគ្គលនោះ ។ បន្ទាប់អំពីនោះ បុគ្គលណាត្រិះរិះដល់វិតក្កនោះ បុគ្គលនោះ នឹងនាំខ្សាច់មកដោយកន្ទោងស្មើកឈើ ហើយចាក់ក្នុងទីនោះ ។ កាលបើដូច្នោះ ទើបកើតជាគំនរខ្សាច់ធំដោយលំដាប់ក្នុងទីនោះ ។ បន្ទាប់អំពីនោះ បច្ចិមាជនតាជន ព័ទ្ធគំនរខ្សាច់ធំនោះ សាងជាចេតិយដ្ឋាន លោកសំដៅយកទីនោះ ទើបលោកពោលដូច្នេះថា បទថា **ឧរុវេលាយំ** *បានដល់ ជិតគំនរខ្សាច់ធំ គប្បីឃើញសេចក្តីថា ត្រង់គំនរខ្សាច់ធំ ។*

បទថា **វិហរតិ** *ជាបទសម្តែងការដល់ព្រមដោយវិហារធម៌ណាមួយ*

បណ្តាឥរិយាបថវិហារ ទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ ។ ដោយមិនប្លែកគ្នា ។ តែក្នុងទីនេះ បទថា **វិហរតិ** *គប្បីជ្រាបថា ជាបទសម្តែងការប្រកបឥរិយាបថ ពោល គឺការអង្គុយក្នុងបណ្តាឥរិយាបថ ដូចជាឈរ ការអង្គុយ ការដើរ និងការដេក ។ ម្យ៉ាងទៀត បទថា* **វិហរតិ** *នោះ គប្បីជ្រាបថា សម្តែងការដល់ព្រមនៃអរិយវិហារ ក្នុងឥរិយាបថទាំងនោះ ព្រោះបុគ្គលកាត់នូវសេចក្តីលំបាកក្នុងឥរិយាបថ ដោយឥរិយាបថមួយ ហើយនាំអត្តភាពទៅ គឺឲ្យប្រព្រឹត្តទៅដោយមិនទ្រុឌទ្រោម ព្រោះដូច្នោះ ក្នុងទីនេះ គប្បីជ្រាបអត្ថនៃបទថា* **វិហរតិ** *ដោយឥរិយាបថវិហារ ។ ព្រោះព្រះមានព្រះភាគទ្រង់នាំទៅ ទ្រង់នាំចូលទៅ ទ្រង់នាំចូលទៅជិត បានដល់ ឲ្យកើតហិតប្រយោជន៍ច្រើនប្រការដល់សត្វទាំងឡាយ ដោយទិព្វវិហារជាដើម ព្រោះដូច្នោះ កាលពោលដោយទិព្វវិហារជាដើម គប្បីជ្រាបអត្ថយ៉ាងនេះថា នាំទៅផ្សេងៗ ។*

បទថា **ឆដ្ឋា** *សេចក្តីថា ឈ្មោះថា* **ឆទី** *ព្រោះហូរ គឺហូរទៅ ។ ការហូរទៅរបស់ស្ទឹងនោះ អធិប្បាយថា ស្ទឹងដែលហូរទៅ ។ បទថា* **នេរញ្ជរាយ** *សេចក្តីថា ទឹករបស់ស្ទឹងនោះមិនមានទោស ព្រោះដូច្នោះ កាលគួរនឹងពោល* **នេលំឥលាយ** *ពោលភ្ងាត់ថា* **នេរញ្ជរាយ** *ព្រោះផ្លាស់ **ល** អក្ខរៈ ឲ្យជា **រ** អក្ខរៈ អធិប្បាយថា ទឹកវៀរចាកទោស មានភក់ សាវាយ និងចកជាដើម ។ អាចារ្យពួកខ្លះពោលថា គួរពោលថា* **និលឥលាយ** *ពោលភ្ងាត់ថា* **នេរញ្ជរាយ** *ម្យ៉ាងទៀត ឈ្មោះនោះឯងគប្បីជ្រាបថា ជាឈ្មោះរបស់ទឹកនោះ ដើម្បីសម្តែង*

ស្ថានទីដែលព្រះមានព្រះភាគប្រថាប់នៅក្បែរច្រាំងស្ទឹងនោះ ទើបលោកពោលថា **ពោធិរុក្ខមូលេ** *ដូច្នេះ ។*

ក្នុងបទថា **ពោធិរុក្ខមូលេ** *នោះ មគ្គញ្ញាណ ហៅថា* **ពោធិ** *ក្នុងប្រយោគនេះថា* **ចតុមគ្គេសុ ញាណំ** *ប្រែថា ញាណក្នុងមគ្គទាំង ៤ លោកហៅថា* **ពោធិ** *ដូច្នេះ ។ សព្វញ្ញុតញ្ញាណ ហៅថា* **ពោធិ** *ដូចក្នុងប្រយោគនេះថា* **បបញ្ចាតិ ពោធឺ វរភូរិ មេធសោ** *ប្រែថា តថាគតនោះ មានប្រាជ្ញាដ៏ប្រសើរប្រៀបដូចផែនដី និងបានដល់ពោធិញ្ញាណដ៏ខ្ពង់ខ្ពស់ មានចំណែកដ៏ប្រសើរក្នុងផ្លូវប្រាជ្ញា ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់សម្រេចពោធិទាំង ២ យ៉ាងនេះ ត្រង់ដើមឈើនោះ ព្រោះហេតុនោះ សូម្បីដើមឈើនោះ ក៏បានឈ្មោះថា* **ពោធិព្រឹក្ស** *ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា* **ពោធិ** *ព្រោះត្រាស់ដឹងពោជ្ឈង្គ ៧ សូម្បីដើមឈើ ក៏បានឈ្មោះថា* **ពោធិព្រឹក្ស** *ព្រោះព្រះអង្គកាលត្រាស់ដឹង ចាំបាច់អាស្រ័យដើមឈើនោះ ។ នៃពោធិព្រឹក្សនោះ ។*

បទថា **មូលេ** *ប្រែថា ទីជិត ។ ពិតហើយ សព្ទថា* **មូល** *នេះ ប្រាកដត្រង់មូល គឺឫសគល់ ដូចក្នុងប្រយោគជាដើមថា* **មូលានិ ឧទ្ធរេយ្យ អគ្គមសោ ឧសីរនាឡិមត្តានិបិ** *ក៏រម្ងើឫសគល់ ដោយហោចទៅ សូម្បីប៉ុនចម្រៀកស្បូវភ្លាំង (ក៏មិនឲ្យសល់) ដូច្នេះ ។*

ប្រាកដក្នុងហេតុដែលមិនទូទៅ ក្នុងប្រយោគជាដើមថា **លោភោ អកុសលមូលំ** *លោភៈជាឫសគល់នៃអកុសល ដូច្នេះ ។*

ប្រាកដក្នុងទីជិត ដូចក្នុងប្រយោគជាដើមថា **យោ ច មជ្ឈន្ហិកេ កាលេ**

ឆាយា ឌរតិ និវាតេ បណ្ណានិ បតន្តិ ឯត្តាវតា រុក្ខមូលំ ក្នុងពេលថ្ងៃត្រង់ស្រមោលដើមឈើផ្សាយទៅត្រឹមណា ក្នុងពេលស្ងប់ខ្យល់ ស្លឹកឈើជ្រុះត្រឹមណា ទីដែលស្រមោលផ្សាយទៅ និងទីដែលស្លឹកឈើជ្រុះនោះ ហៅថាទីជិតគល់ឈើ ដូច្នេះ ។

មូល សព្ទ ក្នុងទីនេះ ក៏បំណងយកក្នុងទីជិត ដូច្នោះ គប្បីឃើញអត្ថនេះយ៉ាងនេះថា ត្រង់គល់ គឺទីជិតពោធិព្រឹក្ស ។ បទថា **បឋមាភិសម្ពុទ្ធោ** បានដល់ ជាបុគ្គលត្រាស់ដឹងក្រៃលែងគ្រាដំបូង អធិប្បាយថា មុនបង្អស់ ។

ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះ ព្រះថេរៈដែលជាភណ្ឌាគារិក កាលផ្តើមតាំងពាក្យផ្តើមនៃខទានទេសនា ទើបជាការប្រកាសសម្តែងអាងដល់កាល ប្រទេស និងជាអ្នកសម្តែងដល់កាល និងបទេស មួយអន្ទើ ដោយគុណវិសេស ។

ក្នុងសេចក្តីនេះ មានអ្នកចោទសួរថា ព្រោះហេតុអ្វី កាលធ្វើសង្គាយនាព្រះធម្មវិនយ ទើបពោលដល់ពាក្យផ្តើម ។ គួរធ្វើការរួបរួមចំពោះព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ហើយ មិនមែនឬ ។ ឆ្លើយថា ដើម្បីឲ្យព្រះធម្មទេសនាដល់ព្រមដោយការតាំងមាំ មិនញាប់ញ័រ និងជាទីតាំងនៃសទ្ធា ។ ពិតហើយ ទេសនាដែលតាំងដោយបន្តគ្នាមកដោយកាល ប្រទេសអ្នកសម្តែង និងវត្ថុជាដើម តាំងនៅអស់កាល មិនញាប់ញ័រ និងជាទីតាំងនៃសទ្ធា ដូចការវិនិច្ឆ័យបញ្ញត្តិដែលពាក់ព័ន្ធដោយប្រទេស កាលអ្នកធ្វើហេតុ និងនិមិត្ត ព្រោះហេតុនោះឯង កាលព្រះមហាកស្សប ធ្វើការសួរក្នុងប្រទេស

ជាដើម មានពាក្យថា អានន្ទ ព្រះមានព្រះភាគត្រាស់ឧទានដំបូង ក្នុងទីណា ព្រះអានន្ទជាធម្មភណ្ឌាគារិក កាលធ្វើការវិសជ្ជនាបញ្ហាទាំងនោះ ទើបពោលពាក្យផ្តើមនៃឧទាន ដោយន័យជាដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។

ម្យ៉ាងទៀត លោកពោលដល់ពាក្យផ្តើមជាការប្រកាសសត្ថុសម្បត្តិ គឺសម្បត្តិនៃព្រះសាស្តា ។ ការសម្រេចជាព្រះពុទ្ធរមែងមាន ព្រោះព្រះមានព្រះភាគដ៏ជាតថាគត មិនមានការរចនា ការអនុមាន ការរៀននិកាយ និងការគិតគ្នេរ ។ ដ្បិតថា ព្រះសម្មាសម្ពុទ្ធ មិនមានការរចនាមុនជាដើម ព្រោះទ្រង់មានប្រមាណជាឯកក្នុងញេយ្យធម៌ ព្រោះទ្រង់បានបំពេញព្រះញាណដែលមិនមានបច្ច័យណាមួយ រារាំងក្នុងទីគ្រប់អន្ទើ ។ ការសម្រេចជាព្រះឧណាស្រព រមែងមាន ព្រោះមិនមានការជាប់ជំពាក់ក្នុងអាចរិយមុដ្ឋិ គឺភាពស្រពិចស្រពិល ធម្មមច្ចរិយៈ គឺការកំណាញ់ធម៌ ពាក្យប្រៀនប្រដៅ និងសាវ៉ក ព្រោះថា បុគ្គលអស់អាសវៈដោយប្រការទាំងពួង ក្នុងទីណាមួយ ក៏មិនមានអាចរិយមុដ្ឋិជាដើម ព្រោះដូច្នោះ បុគ្គលដែលបរិសុទ្ធល្អ ធ្វើការអនុគ្រោះដល់ពួកសត្ត ។ ដូច្នោះ ការសម្រេចក្នុងវេសារជ្ជញ្ញាណ ២ ឣាងដើម រមែងមានដោយការបរិសុទ្ធ និងបរិសុទ្ធល្អ ដែលឆ្ទុះបញ្ចាំងដល់ការមិនមានអវិជ្ជា និងតណ្ហា ដែលប្រទូស្តទិដ្ឋិសម្បត្តិ គឺសីលសម្បត្តិ ដែលជាទោសក្នុងការសម្តែង និងប្រាកដច្បាស់ ដោយញាណសម្បទា និងបហានសម្បទា ម្យ៉ាងទៀត ការសម្រេចវេសារជ្ជញ្ញណ ២ ឣាងចុង រមែងមានព្រោះសម្រេចដោយការមិនមានការវង្វេងក្នុងអន្តរាយិកធម៌ និងនិយ្យានិកធម៌

នោះឯង ។ ការប្រកបដោយវេសារជ្ជញ្ញាណ ៤ នៃព្រះមានព្រះភាគ និងការបំពេញប្រយោជន៍ចំណែកព្រះអង្គ និងប្រយោជន៍ចំណែកអ្នកដទៃ ជាការប្រកាសហើយ ដោយពាក្យផ្តើម ព្រោះសម្តែងព្រះធម្មទេសនា ដោយបដិភាណដែលកើតឡើងតាមហានៈ ដោយសមគួរដល់អធ្យាស្រ័យរបស់បរិស័ទដែលប្រជុំគ្នាក្នុងទីនោះៗ ។ តែក្នុងទីនេះ គប្បីប្រកបសេចក្តីថា ដោយការប្រកាសការសោយវិមុត្តិសុខ និងមនសិការដល់បដិច្ចសមុប្បាទ ។ ព្រោះដូច្នោះ ទើបព្រះអានន្ទពោលថា ពោលពាក្យផ្តើមដើម្បីប្រកាសសត្ថុសម្បត្តិ ។

ម៉្យាងទៀត ពោលពាក្យផ្តើមដើម្បីប្រកាសសាសនសម្បត្តិ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់បំពេញកិច្ចទាំងពួង ដែលកំណត់ដោយព្រះបញ្ញាគុណ និងព្រះករុណាគុណ មិនមានបដិបទាដែលឥតប្រយោជន៍ ឬច្បាច្បាប្រយោជន៍ផ្ទាល់ព្រះអង្គ ។ ព្រោះដូច្នោះ កាយកម្ម វចីកម្ម និងមនោកម្មទាំងមូលរបស់ព្រះសម្មាសម្ពុទ្ធ ដែលជាអ្នកបំពេញប្រយោជន៍ទាំងពួង ដែលប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់អ្នកដទៃតែម្យ៉ាង ដែលត្រាស់តាមការប្រព្រឹត្តទៅ ឈ្មោះថា **សាសនា** *ព្រោះតាមបង្រៀនសត្វទាំងឡាយតាមសមគួរ ដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ មិនមែនជាពាក្យរចនារបស់កវី ពុទ្ធចរិយានេះ លោកប្រកាសតាមសមគួរដោយពាក្យផ្តើមក្នុងទីនោះៗ មួយអន្ទើដោយកាលទេសៈ អ្នកសម្តែង និងប្រទេស ។ តែក្នុងទីនេះ គប្បីប្រកបថា ដោយការសោយវិមុត្តិសុខក្នុងការត្រាស់ដឹងក្រៃលែង និងដោយមនសិការបដិច្ចសមុប្បាទ ។ ព្រោះហេតុនោះ ទើបលោកពោលថា*

ពោលពាក្យផ្តើមដើម្បីប្រកាសសាសនសម្បត្តិ ម្យ៉ាងទៀត ការពោលពាក្យផ្តើម ដើម្បីសម្តែងភាវៈដែលព្រះសាសនាជាប្រមាណ ដោយការប្រកាសភាវៈដែលព្រះសាស្តាជាប្រមាណ ។ និងការសម្តែងភាវៈ ដែលព្រះសាសនាជាប្រមាណនោះ គប្បីជ្រាបតាមក្រសែនយ័ដែលពោលមកហើយខាងដើម ។

ពិតហើយ ដោយពាក្យថា **ភគវា** *នេះ ជាការប្រកាសសេចក្តីដោយប្រការទាំងពួង ដោយការសម្តែងដល់ការលះមន្ទិល គឺកិលេសទាំងពួង មានរាគៈ ទោសៈ មោហៈជាដើម និងការលះទោស មានទុច្ចរិតជាដើម ដោយការសម្តែងភាពដែលព្រះតថាគត ជាបុគ្គលឧត្តមជាងសព្វសត្វ និងដោយការសម្តែងដល់ការប្រកបដោយគុណវិសេស មានព្រះបញ្ញាគុណ និងព្រះករុណាគុណជាដើម ដែលមិនទូទៅដល់អ្នកដទៃ ព្រោះដូច្នោះ ទើបពាក្យនេះជាពាក្យសម្តែងត្រឹមតែជាប្រធាននៃការប្រកបពាក្យផ្តើមក្នុងសេចក្តីនេះ ។*

គប្បីជ្រាបពាក្យដែលលោកផ្តើមថា **ឃវម្ម សុតំ** *រហូតដល់ពាក្យថា* **ឥមំ ឧទានំ ឧទានេសិ** *នេះជាពាក្យផ្តើមរបស់ឧទាននេះ ។ ពិតហើយ ពាក្យនោះជាពាក្យដែលព្រះសង្គីតិកាចារ្យពោលក្នុងគ្រាសង្គាយនា ដើម្បីប្រកាសកិច្ចបដិបត្តិផ្លូវកាយ និងផ្លូវចិត្តរបស់ព្រះមានព្រះភាគអង្គនោះ ចាប់តាំងអំពីដើមតាមដែលទ្រង់បដិបត្តិមក រហូតដល់បន្ទឹឧទាននេះ ។ សួរថា ពាក្យថា* **ឥមស្មឹ សតិ ឥទំ ហោតិ** *ជាដើម គួរជាពាក្យរបស់ព្រះមានព្រះភាគប៉ុណ្ណោះ ព្រោះអ្នកដទៃក្រៅអំពីព្រះសាស្តាហើយ មិនអាចនឹងសម្តែងបដិច្ចសមុប្បាទបានមិនមែនឬ ។ ឆ្លើយថា សេចក្តីនោះពិត ដូចព្រះមានព្រះភាគទ្រង់ធ្វើបដិច្ច-*

សមុប្បាទក្នុងព្រះហឫទ័យ ដោយការពិចារណាសភាវធម៌ត្រង់មណ្ឌលពោធិ-ព្រឹក្ស យ៉ាងណា ព្រះធម្មសង្គាហកមហាថេរៈទាំងឡាយ សង្គាយនាពាក្យផ្តើមនៃឧទាននេះ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងក្នុងបដិច្ចសមុប្បាទ និងសីហនាទសូត្រជាដើម ដើម្បីបណ្តុះសត្វដែលជាផៅពង្សអ្នកគួរត្រាស់ដឹងបដិច្ចសមុប្បាទនោះ និងត្រាស់មនសិការដល់បដិច្ចសមុប្បាទ ឲ្យជាអត្ថុប្បត្តិហេតុ ដោយអំណាចនៃការធ្វើតាមអាការនៃព្រះតម្រាស់ ដែលទ្រង់សម្តែង ព្រោះហេតុនោះ គប្បីយល់ព្រមក្នុងសេចក្តីនេះថា ពាក្យដែលពោលជាពាក្យរបស់ព្រះសង្គីតិកាចារ្យនោះឯង ក្នុងសូត្រដទៃក្រៅអំពីនេះក៏ដូចគ្នា ។

ក្នុងសេចក្តីនេះ គប្បីជ្រាបសុត្តនិក្ខេបបទ គឺការតាំងព្រះសូត្រ ៤ ប្រការ គឺកើតដោយអធ្យាស្រ័យរបស់ខ្លួន ១ កើតដោយអធ្យាស្រ័យរបស់អ្នកដទៃ ១ កើតដោយអំណាចពាក្យសួរ ១ កើតដោយការកើតរឿងឡើង ១ ។ ព្រះសូត្រច្រើនរយ ច្រើនពាន់ ក៏មិនកន្ទងភាវៈ ១៦ យ៉ាង ដោយបដ្ឋានន័យ មានសង្គិលេសភាគិយន័យជាដើម យ៉ាងណា ព្រះសូត្រទាំងអស់នោះ ក៏ដូច្នោះ មិនកន្ទងភាវៈ ៤ ប្រការ ដោយសុត្តនិក្ខេបន័យ មានអត្តជ្ឈាសយន័យ (អធ្យាស្រ័យរបស់ខ្លួន) ជាដើម ។ ក្នុងសេចក្តីនេះ ការតាំងព្រះសូត្រដែលកើតដោយអធ្យាស្រ័យរបស់ខ្លួន និងកើតដោយអត្ថុប្បត្តិហេតុ រមែងមានប្រភេទនៃការទាក់ទងនឹងទីកើត ដោយអធ្យាស្រ័យរបស់អ្នកដទៃ និងដែលកើតដោយអំណាចពាក្យសួរ ព្រោះកើតដោយអនុសន្ធិនៃអធ្យាស្រ័យ និងអនុសន្ធិនៃពាក្យសួរក៏ពិត តែការតាំងព្រះសូត្រដែលកើតអំពីអធ្យាស្រ័យ

របស់ខ្លួន និងដែលកើតដោយការកើតរឿងឡើង ទើបមិនមានការទាក់ទងដល់គ្នានិងគ្នា ព្រោះដូច្នោះ ទើបបដ្ឋានន័យ មិនមានចំណែកសេសសល់ឡើយ ។ ម្យ៉ាងទៀត លោកពោលថា សុត្តនិក្ខេប ៤ ដោយអំណាចមូលនិក្ខេបនៃនិក្ខេបដ៏សេសមាន ព្រោះឈមចុះខាងក្នុងនៃបដ្ឋានន័យនោះ ។

ក្នុងសេចក្តីនោះ មានវចនត្ថៈដូចតទៅនេះ ការតាំងចុះ ឈ្មោះថា និក្ខេប និក្ខេបនៃព្រះសូត្រ ឈ្មោះថា សុត្តនិក្ខេប អធិប្បាយថា សុត្តទេសនា ម្យ៉ាងទៀត ឈ្មោះថា និក្ខេប ព្រោះចូលទៅតាំងទុក និក្ខេប គឺព្រះសូត្រ ឈ្មោះថា សុត្តនិក្ខេប ។ អធ្យាស្រ័យរបស់ខ្លួន ឈ្មោះថា អត្តជ្ឈាសយ សុត្តនិក្ខេបនោះ ឈ្មោះថា អត្តជ្ឈាសយ ព្រោះមានអធ្យាស្រ័យនៃខ្លួនជាហេតុ ។ ម្យ៉ាងទៀត ឈ្មោះថា អត្តជ្ឈាសយ ព្រោះមានខ្លួនជាអធ្យាស្រ័យ ។ សូម្បីក្នុងអធ្យាស្រ័យរបស់អ្នកជនៃ ក៏មានន័យដូចគ្នា ។ អំណាចនៃពាក្យសួរ ឈ្មោះថា បុច្ឆាវសៈ សុត្តនិក្ខេបនោះ ឈ្មោះថា បុច្ឆាសិក ព្រោះមានអំណាចនៃពាក្យសួរ ។ ការកើតឡើងនៃអត្ថដែលជារឿងនៃសុត្តទេសនា ឈ្មោះថា អត្ថុប្បត្តិ សុត្តនិក្ខេប ឈ្មោះថា អត្ថុប្បត្តិក ព្រោះមានការកើតរឿងឡើង ។ ម្យ៉ាងទៀត អត្ថុប្បត្តិនោះឯង ឈ្មោះថា អត្ថុប្បត្តិក ។ ម្យ៉ាងទៀត ឈ្មោះថា និក្ខេប ព្រោះជាហេតុនៃការតាំងព្រះសូត្រ គឺអធ្យាស្រ័យរបស់ខ្លួនជាដើម ។ ឯក្នុងការកំណត់អត្ថនេះ គប្បីជ្រាបអត្ថក្នុងសេចក្តីនេះយ៉ាងនេះថា អធ្យាស្រ័យនៃខ្លួន ឈ្មោះថា អត្តជ្ឈាសយ អធ្យាស្រ័យរបស់អ្នកជនៃ ឈ្មោះថា បរជ្ឈាសយ ។ ឈ្មោះថា បុច្ឆា ព្រោះអ្នកជនៃសួរ គឺរឿងដែលត្រូវសួរ ។

ពាក្យរបស់បុគ្គលទទួលធម៌ ដែលប្រព្រឹត្តទៅដោយពាក្យសួរ ឈ្មោះថា បុច្ឆាវសៈ បុច្ឆាវសៈនោះឯង លោកពោលជាបុំលិង្គថា បុច្ឆាវសិកោ ដោយបំណងដល់សព្ទថា និក្ខេប ។ ម្យ៉ាងទៀត អត្ថុប្បត្តិនោះឯង ឈ្មោះថា អត្ថុប្បត្តិក ។

ក្នុងសេចក្តីនេះ មានពាក្យសួរជ្រៀតចូលមកថា ព្រោះមិនជ្រាបជាដល់ហេតុ មានការចាស់ក្លាំនៃឥន្ទ្រិយជាដើមរបស់អ្នកដទៃ ទើបគួរមានការៈនៃសុត្តនិក្ខេបមួយផ្នែករបស់អត្ថជ្ឈាសយ ព្រោះប្រកាសទេសនា ដើម្បីតាំងបែបផែននៃធម៌តាមអធ្យាស្រ័យរបស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះ ឯសុត្តនិក្ខេបដែលកើតដោយអធ្យាស្រ័យរបស់អ្នកដទៃ និងដែលកើតដោយពាក្យសួរ ប្រព្រឹត្តទៅក្នុងការកើតឡើងនៃអធ្យាស្រ័យ និងពាក្យសួររបស់អ្នកដទៃដែលជាហេតុឲ្យប្រកាសធម្មទេសនាដូចម្តេច ទើបមិនខុស ក្នុងការកើតរឿងឡើង ឬថា កាលសុត្តនិក្ខេប ដែលកើតឡើងដោយអំណាចពាក្យសួរ និងដែលកើតដោយការកើតរឿងឡើង ប្រព្រឹត្តទៅដោយអនុលោមតាមអធ្យាស្រ័យរបស់អ្នកដទៃដូចម្តេច ទើបមិនខុសក្នុងអធ្យាស្រ័យរបស់អ្នកដទៃ សេចក្តីនោះមិនចាំបាច់សាកសួរ ។ ព្រោះលោកកាន់យកការកើតឡើង ដែលជាហេតុនៃព្រះសូត្រ ដែលផុតចាកអកិនីហារ និងការសាកសួរជាដើម និងការវិនិច្ឆ័យជាដើមរបស់អ្នកដទៃ ព្រោះជាអត្ថុប្បត្តិហេតុ ទើបកាន់យកសុត្តនិក្ខេប ដែលកើតដោយអធ្យាស្រ័យរបស់អ្នកដទៃ និងដែលកើតដោយអំណាចពាក្យសួរក្នុងចំណែកមួយដោយឡែក ។ ពិតហើយ ហេតុក្នុងការសម្តែងគុណ និងទោស និងការ

កើតឡើងនៃអាមិស នៃព្រហ្មជាលសូត្រ និងធម្មទាយាទសូត្រជាដើម លោកហៅថា អត្តុប្បត្តិ គឺហេតុកើតរឿងឡើង ។ រឿងពាក្យសួរបស់អ្នកជនៃចេញអត្តដែលលោកសម្តែងចំពោះអធ្យាស្រ័យឲ្យជានិមិត្តនេះ ច្រាកជថា បវជ្ជាសយ គឺកើតអំពីអធ្យាស្រ័យរបស់អ្នកជនៃ ដែលលោកសម្តែងដោយអំណាចពាក្យសួរ នេះច្រាកជថា បុច្ឆាវសក កើតដោយអំណាចពាក្យសួរ ។

ក្នុងនិក្ខេប ៤ យ៉ាងនោះ ខុទានទាំងនេះ គឺពោធិសូត្រ ៣ សូត្រ មានបឋមពោធិសូត្រជាដើម មុចលិន្ទសូត្រ អាយុសង្ខារោសជ្ជនសូត្រ បច្ចវេក្ខណសូត្រ និងបបញ្ចសញ្ញាសូត្រ ចាត់ជាអត្តជ្ឈាសយនិក្ខេប ។ ខុទានទាំងនេះ គឺហុំហុំកសូត្រ ព្រាហ្មណជាតិកសូត្រ ពាហិយសូត្រ ចាត់ជាបុច្ឆាវសិកនិក្ខេប ខុទានទាំងនេះ គឺរាជសូត្រ សក្ការសូត្រ ខុច្ឆាទនសូត្រ បិណ្ឌបាតកសូត្រ សិប្បសូត្រ គោបាលកសូត្រ សុនូរិកាសូត្រ មាតុសូត្រ សង្ឃភេទសូត្រ ខុទបានសូត្រ តថាគតុប្បាទសូត្រ មោនេយ្យសូត្រ បាដលិគាមិយសូត្រ និងទព្វសូត្រ ២ សូត្រ ចាត់ជាអត្តុប្បត្តិកនិក្ខេប ។ ខុទានទាំងនេះ គឺបាលិលេយ្យសូត្រ បិយសូត្រ នាគសមាលសូត្រ និងវិសាខាសូត្រ ជាអត្តជ្ឈាសយនិក្ខេបផង បវជ្ជាសយនិក្ខេបផង សូត្រដ៏សេសទៀត ៥១ សូត្រ ចាត់ជាបវជ្ជាសយនិក្ខេប គប្បីជ្រាបការប្លែកគ្នានៃនិក្ខេបនៃខុទានទាំងនោះដោយអំណាចអត្តជ្ឈាសយនិក្ខេបជាដើម ដោយប្រការដូច្នេះ ។

ក្នុងទីនេះ ខុទានពួកណា ព្រះមានព្រះភាគត្រាស់ចំពោះមុខភិក្ខុទាំងឡាយ ខុទានទាំងនោះ ជាព្រះសូត្រតាមដែលត្រាស់ ភិក្ខុទាំងនោះទន្ទេញ

វត់មាត់ សម្ដីងបានដោយចិត្ត ត្រាស់ដល់ព្រះធម្មកណ្ហាគារិក ឯឧទានទាំង-ទ្បាយណា ព្រះមានព្រះភាគមិនបានត្រាស់ចំពោះមុខភិក្ខុទាំងទ្បាយ ឧទានទាំងនោះ ខាងក្រោយ ព្រះមានព្រះភាគបានត្រាស់ដល់ព្រះធម្មកណ្ហាគារិកទៀត ។ គប្បីជ្រាបថា ឧទានទាំងអស់ដូចពោលមកនេះ ព្រះអានន្ទចាំបានទ្រទ្រង់ទាំងអស់ និងប្រាប់ដល់ភិក្ខុទាំងទ្បាយ ខាងក្រោយមក បានលើកឡើងកាន់សង្គាយនាថា ឧទាននោះឯង ក្នុងគ្រាធ្វើមហាសង្គាយនាលើកទី ១ ។

បទថា **តេន សមយេន** *ក្នុងបទជាដើមថា* **តេន ខោ បន សមយេន** *ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភត្តិ ។ បទថា* **ខោ បន** *ជានិបាត អធិប្បាយថា* **តស្មឹ សមយេ** *ប្រែថា ក្នុងសម័យនោះ ។ សួរថា ក្នុងសម័យណា ឆ្លើយថា សម័យណា ព្រះមានព្រះភាគ ត្រាស់ដឹងគ្រាដំបូង ប្រថាប់នៅត្រង់មណ្ឌលពោធិព្រឹក្សក្បែរស្ទឹងនេរញ្ជរា ក្នុងតំបន់ឧរុវេលាបទេស ដរាបណា គឺក្នុងសម័យនោះ ។ បទថា* **សត្តាហំ** *ប្រែថា ៧ ថ្ងៃ គឺមួយសប្ដាហ៍ ។ បទថា* **សត្តាហំ** *នេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃអច្ចន្តសំយោគ ប្រែថា រហូត ។ ព្រោះព្រះមានព្រះភាគ ទ្រង់ពួនសំងំដោយសុខ ដែលកើតអំពីផលសមាបត្តិ ដោយចំណែកមួយ ដោយមិនជាប់ខ្សែអស់មួយសប្ដាហ៍នោះដូច្នោះ ទើបលោកពោលទុតិយាវិភត្តិ ដោយអំណាចអច្ចន្តសំយោគថា* **សត្តាហំ** *ប្រែថា អស់មួយសប្ដាហ៍ ។ បទថា* **ឯកបល្លង្កេន** *សេចក្ដីថា ដោយភ្នែនមួយប៉ុណ្ណោះ ទ្រង់មិនបានក្រោកឡើង សូម្បីត្រឹមតែម្ដងឡើយ តាំងអំពីកាលដែលប្រថាប់គង់លើវជិរាសនៈ ដែលជាអបរាជិតបល្ល័ង្កដ៏ប្រសើរ*

ក្នុងកាលព្រះអាទិត្យមិនទាន់អស្តង្គត ក្នុងថ្ងៃវិសាខបុណ្ណមី ។ បទថា **វិមុត្តិ-សុខំ បដិសំវេទី** *សេចក្តីថា ទ្រង់ប្រថាប់គង់សោយវិមុត្តិសុខ គឺសុខដែលកើតអំពីផលសមាបត្តិ ។*

បណ្តាបទទាំងនោះ បទថា **វិមុត្តិ** *បានដល់ វិមុត្តិ ៥ គឺតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និស្សរណវិមុត្តិ បណ្តាវិមុត្តិ ៥ នោះ ការរួចផុត ដោយផុតចាកធម៌ដែលជាសត្រូវនោះៗ ដោយអង្គនោះៗ មានការបរិច្ចាគទេយ្យធម៌ជាដើម និងដោយអង្គនៃវិបស្សនា មានការកំណត់នាមរូបជាដើម ជារបស់នីឝអង្គនោះៗ នៅប្រព្រឹត្តទៅដោយមិនមានការវិនាសចាត់ជាបហាន ការលះ គឺការរួចផុតចាកមច្ឆរិយៈ និងលោភៈជាដើមដោយទាន ចាកបាណាតិបាតជាដើមដោយសីល ចាកសក្កាយទិដ្ឋិដោយកំណត់នាមរូប ចាកទិដ្ឋិដែលមិនមានហេតុ និងមានហេតុ មិនស្មើគ្នា ដោយការកំណត់បច្ចយ និងធម៌ដែលមិនមែនបច្ចយ ចាកភាពជាបុគ្គលសង្ស័យ ដោយការឆ្លងផុតសេចក្តីសង្ស័យ ដែលជាចំណែកជនៃរបស់នាមរូបនោះឯង ចាកការប្រកាន់ថាជាអញ ថាជារបស់អញ ដោយការពិចារណាដល់រូបកលាបៈ ចាកការសម្គាល់ធម៌ដែលមិនមែនមគ្គថាជាមគ្គ ដោយការកំណត់ថា មគ្គ និងមិនមែនមគ្គ ចាកឧច្ឆេទទិដ្ឋិ ដោយការឃើញការកើតនៃនាមរូប ចាកសស្សតទិដ្ឋិ ដោយការឃើញការរលត់រូប និងនាម ចាកការសម្គាល់ក្នុងវត្ថុដែលជាភ័យថាមិនជាភ័យ ដោយការឃើញថាជាភ័យ ចាកសេចក្តីសម្គាល់ថា គួរត្រេកអរ ដោយការឃើញថាជាទោស ចាកការសម្គាល់រូបថា គួរត្រេកអរ ដោយការ*

ឃើញរួបថា គួរនឿយណាយ ចាកកាពជាអ្នកប្រាថ្នាដើម្បីរួចផុត ដោយមុញ្ចិ-តុកម្យតាញ្ញាណ គឺការប្រាថ្នាដើម្បីនឹងរួចផុត ចាកការមិនព្រងើយ ដោយឧបេក្ខាញ្ញាណ ចាកការៈដែលជាបដិលោមក្នុងធម្មដ្ឋិតិ និងព្រះនិព្វាន ដោយអនុលោមញ្ញាណ និងផុតចាកការៈ មានសង្ខារជានិមិត្ត ដោយគោត្រភូញ្ញាណ នេះឈ្មោះថា តទង្គវិមុត្តិ ។ ម្យ៉ាងទៀត ការរួចផុតដែលសម្គាល់ ដោយការមិនកើតឡើងនៃនីវរណៈ មានកាមច្ឆន្ទនីវរណៈជាដើម និងបច្ចនិកធម៌ ធម៌ដែលជាសត្រូវ មានវិតក្កជាដើម ដោយសមាធិ មានឧបចារសមាធិ និងអប្បនាសមាធិ ជរាបណាសមាធិនោះ នៅប្រព្រឹត្តទៅដោយមិនវិនាស នេះឈ្មោះថា វិក្ខម្ភនវិមុត្តិ ។

ការរួចផុត ដោយអំណាចសមុច្ឆេទប្បហាន ដោយការៈដែលកើតឡើងមិនបាន ដោយឥតសេសសល់ទៀត នៃការប្រកាន់ដោយកិលេសខាងសមុទយៈ ដែលពោលដោយន័យជាដើមថា **ទិដ្ឋិគតានំ បហាយ** *ព្រោះលះទិដ្ឋិ សមគួរក្នុងសន្តានៃព្រះអរិយៈ ដែលតាំងនៅក្នុងមគ្គនោះៗ ព្រោះលោកធ្វើអរិយមគ្គ ៤ ឲ្យកើត នេះឈ្មោះថា សមុច្ឆេទវិមុត្តិ ។*

ការៈដែលកិលេសស្ងប់រម្ងាប់ទៅ ក្នុងខណៈនៃផលចិត្ត នេះឈ្មោះថា បដិបស្សទ្ធិវិមុត្តិ ។ ចិត្តដែលរួចផុតចាកសង្ខារទាំងពួង ឈ្មោះថា ព្រះនិព្វាន ព្រោះរលាស់សង្ខតធម៌ទាំងពួង នេះឈ្មោះថា និស្សរណវិមុត្តិ ។ តែក្នុងទីនេះ លោកបំណងយកការរួចផុតដោយអំណាចនៃផលចិត្ត របស់ព្រះមានព្រះភាគដែលមាននិព្វានជាអារម្មណ៍ ។ ដោយហេតុនោះ ទើបលោកពោលថា បទថា

វិមុត្តិសុខំ បដិសំវេទី *សេចក្តីថា ជាអ្នកប្រថាប់គង់សោយវិមុត្តិសុខ គឺសុខកើតពីផលសមាបត្តិ ។*

បទថា **វិមុត្តំ** *បានដល់ ការៈដែលចិត្តរួចផុត ដោយអំណាចសេចក្តីស្ងប់រម្ងាប់ឧបធិក្កិលេស ។ ម្យ៉ាងទៀត គប្បីជ្រាបចិត្តនោះឯង ថារួចផុតហើយយ៉ាងនោះ ។ សុខដែលកើត ឬសម្បយុត្តដោយវិមុត្តិសុខនោះ ឈ្មោះថា វិមុត្តិសុខក្នុងទីនេះ ។ សូម្បីឧបេក្ខា ក៏គប្បីជ្រាបថា ជាសុខដូចគ្នា ព្រោះព្រះបាលីថា* **យាយំ ភន្តេ ឧបេក្ខា សន្តេ សុខេ វុត្តា ភគវតា** *បពិត្រលោកម្ចាស់ ឧបេក្ខានេះ ព្រះមានព្រះភាគ ត្រាស់ក្នុងកាលសុខមាន ។ សមដូចពាក្យដែលលោកពោលក្នុងអដ្ឋកថា សម្មោហវិនោទនីថា* **ឧបេក្ខា បន សន្តត្តា សុខមិច្ចេវ ភាសិតា ឧបេក្ខា** *លោកពោលថា សុខដូចគ្នា ព្រោះមានសេចក្តីស្ងប់ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ចូលអរហត្តសមាបត្តិដែលប្រកបដោយឈានទី ៤ មិនចូលសមាបត្តិដទៃ ។ ម្យ៉ាងទៀត ការចូលទៅស្ងប់សង្ខារទុក្ខ លោកហៅថា សុខ ដូចក្នុងប្រយោគជាដើមថា* **តេសំ វូបសមោ សុខោ** *ការចូលទៅស្ងប់សង្ខារ ជាសុខ យ៉ាងណា ព្រោះបដិបស្សទ្ធិវិមុត្តិ ដែលបានក្នុងអគ្គផល ព្រោះជាការស្ងប់កិលេស និងទុក្ខទាំងមូល គប្បីជ្រាបថា សុខក្នុងទីនេះ ដូច្នោះ ។*

ការៈដែលកិលេសរម្ងាប់ទៅក្នុងខណៈនៃផលចិត្ត នេះឈ្មោះថា បដិបស្សទ្ធិវិមុត្តិ ។ ចិត្តដែលរួចផុតចាកសង្ខារទាំងពួង ឈ្មោះថា ព្រះនិព្វាន ព្រោះលះបង់សង្ខតធម៌ទាំងពួង នេះឈ្មោះថា និស្សរណវិមុត្តិ ។ តែក្នុងទីនេះ លោក

បំណងយកការរួចផុត ដោយអំណាចនៃផលចិត្តរបស់ព្រះមានព្រះភាគ ដែលមានព្រះនិព្វានជាអារម្មណ៍ ។ ដោយហេតុនោះ ទើបលោកពោលថា បទថា **សុខប្បដិសំវេទី** *សេចក្តីថា ជាអ្នកប្រថាប់គង់សោយវិមុត្តិសុខ គឺសុខកើតដល់ផលសមាបត្តិ ។*

វិមុត្តិសុខនេះ មាន ២ យ៉ាង ដោយការចែកការប្រព្រឹត្តទៅរបស់ផល-ចិត្ត គឺក្នុងមគ្គវិថី ១ ក្នុងកាលជវៃ ១ ។ ផលចិត្ត ៣-២ ខណៈ ដែលមានព្រះនិព្វានជាអារម្មណ៍ដែលជាផលរបស់វិមុត្តិសុខនោះ។ រមែងកើតឡើងក្នុងលំដាប់អរិយមគ្គនីមួយៗ ព្រោះលោកុត្តរកុសល មានវិបាកក្នុងលំដាប់ ក្នុងគ្រាដែលអនុលោមចិត្ត ២ ដួង កើតក្នុងជវនវារៈដែលអរិយមគ្គកើតឡើង ចិត្តដួងទី ៣ ចាត់ជាគោត្រភូចិត្ត ចិត្តដួងទី ៤ ចាត់ជាមគ្គចិត្ត បន្ទាប់អំពីនោះទៅជាផលចិត្ត ៣ ដួង ។ តែក្នុងទីនេះ ដែលអនុលោមចិត្តកើតឡើង ៣ ដួង ចិត្តដួងទី ៤ ជាគោត្រភូចិត្ត ដួងទី ៥ ជាមគ្គចិត្ត បន្ទាប់អំពីនោះទៅជាផលចិត្ត ២ ដួង ។ ចិត្តដួងទី ៤-៥ រមែងប្រព្រឹត្តទៅដោយអំណាចអប្បនា ដោយប្រការដូច្នេះ ។ បន្ទាប់អំពីនោះ ប្រព្រឹត្តទៅមិនបាន ព្រោះជិតចំពោះភវង្គចិត្ត តែអាចារ្យពួកខ្លះពោលថា សូម្បីចិត្តដួងទី ៦ ក៏ជាអប្បនា ។ ពាក្យនោះលោកជំទាស់ ក្នុងអដ្ឋកថាហើយ ។ គប្បីជ្រាបផលចិត្តក្នុងមគ្គវិថី ដោយប្រការដូច្នេះ តែផលចិត្តក្នុងកាលជវៃ រមែងប្រព្រឹត្តទៅដោយផលសមាបត្តិដែលកើតឡើង ដល់បុគ្គលដែលចេញចាកនិរោធសមាបត្តិ លោកសង្គ្រោះដោយផលសមាបត្តិនោះឯង ផលសមាបត្តិនោះ ពោលដោយអត្ថ ជាវិបាក

នៃលោកុត្តរកុសលចិត្ត ដែលមានព្រះនិព្វានជាអារម្មណ៍ គប្បីជ្រាបថា ជាអប្បនា ។

សួរថា ផលសមាបត្តិនោះ បុគ្គលពួកណាចូលបាន បុគ្គលពួកណាចូលមិនបាន ។ ឆ្លើយថា បុថុជ្ជនទាំងអស់ចូលមិនបាន ព្រោះមិនទាន់បានសម្រេច ម្យ៉ាងទៀត ព្រះអរិយៈថ្នាក់ទាបក៏ដូចគ្នា ចូលផលសមាបត្តិថ្នាក់ខ្ពស់មិនបាន សូម្បីព្រះអរិយៈថ្នាក់ខ្ពស់ ក៏មិនចូលផលសមាបត្តិថ្នាក់ទាបដូចគ្នា ព្រោះលោកស្ងប់រម្ងាប់ ដោយការចូលដល់ភាពជាបុគ្គលដទៃ ។ ព្រះអរិយៈនោះៗ រមែងចូលផលសមាបត្តិវៀងៗ ខ្លួនប៉ុណ្ណោះ ។ តែអាចារ្យពួកខ្លះពោលថា ព្រះសោតាបន្នបុគ្គល និងព្រះសកទាគាមិបុគ្គល មិនចូលផល-សមាបត្តិ ព្រះអរិយៈជាន់ខ្ពស់ ២ ពួកប៉ុណ្ណោះ រមែងចូលបាន ព្រោះលោកធ្វើឲ្យបរិបូណ៌ក្នុងសមាធិ សេចក្តីនោះមិនជាហេតុ ព្រោះសូម្បីបុថុជ្ជន ក៏ចូលលោកិយសមាធិដែលខ្លួនបាន ម្យ៉ាងទៀត នឹងពោលថ្វី ដោយការគិតដល់ហេតុក្នុងសេចក្តីនេះ សមដូចលោកពោលក្នុងបដិសម្ភិទាថា សង្ខារុបេក្ខា ១០ កើតឡើងដោយអំណាចវិបស្សនា តើដូចម្តេច ។ គោត្រភូធម៌ ១០ ដូចម្តេចខ្លះ កើតឡើងដោយអំណាចវិបស្សនា ។ ក្នុងការស្រាយបញ្ហា ដូចពោលនេះ លោកពោលដល់ការចូលផលសមាបត្តិ របស់ព្រះអរិយៈទាំងនោះថា ដើម្បីជាប្រយោជន៍ដល់សោតាបត្តិផលសមាបត្តិ ដើម្បីជាប្រយោជន៍ដល់សកទាគាមិផលសមាបត្តិ ។ ព្រោះដូច្នោះ ទើបសម្រេចក្នុងសេចក្តីនេះថា ព្រះអរិយៈទាំងពួង រមែងចូលផលសមាបត្តិ វៀងៗ ខ្លួន ។

សួរថា ព្រោះហេតុអ្វី ទើបព្រះអរិយៈទាំងនោះចូលសមាបត្តិ ។ ឆ្លើយថា ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ។ ឧបមាដូចព្រះរាជាទាំងឡាយសោយសុខក្នុងរាជសម្បត្តិ ទេវតាទាំងឡាយសោយទិព្វសុខ យ៉ាងណា ព្រះអរិយៈទាំងឡាយ ក៏ដូច្នោះ រមែងកំណត់កាលថា អញនឹងសោយលោកុត្តរសុខ ទើបចូលផលសមាបត្តិ ក្នុងខណៈដែលត្រូវការ ។

សួរថា ផលសមាបត្តិនោះ ចូលដូចម្តេច ឈប់ដូចម្តេច ចេញដូចម្តេច ឆ្លើយថា ជាបឋម ការចូលផលសមាបត្តិនោះ មាន ២ យ៉ាង គឺមិនមនសិការអារម្មណ៍ដទៃអំពីព្រះនិព្វាន និងមនសិការដល់ព្រះនិព្វាន ដូចលោកពោលថា

ម្នាលអាវុសោ (ការចូល) អនិមិត្តាចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ២ គឺការមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្តទុកដាក់ចំពោះនិព្វានធាតុដែលប្រាសចាកអារម្មណ៍ ១ ។

ក្នុងទីនេះ មានលំដាប់ការចូលផលសមាបត្តិដូចតទៅនេះ ព្រះអរិយ-សាវ័កដែលត្រូវការផលសមាបត្តិ ទៅក្នុងទីកំបាំង ពួនសំងំ គប្បីពិចារណាសង្ខារដោយខន្ធយព្វយញ្ញាណជាដើម ។ បើលោកមានវិបស្សនាញាណដោយលំដាប់ ដែលប្រព្រឹត្តទៅយ៉ាងនេះ ចិត្តតែងជាអប្បនាក្នុងនិរោធ ដោយអំណាចផលសមាបត្តិ ក្នុងលំដាប់គោត្រភូញាណ មានសង្ខារជាអារម្មណ៍ ។ ផលចិត្តប៉ុណ្ណោះកើត មគ្គចិត្តមិនកើតដល់ព្រះសេក្ខបុគ្គល ព្រោះលោកបានបង្អោនទៅក្នុងផលសមាបត្តិ ឯអាចារ្យពួកណាពោលថា ព្រះសោតាបន្នគិតថា នឹងចូលផលសមាបត្តិរបស់ខ្លួនហើយ ចម្រើនវិបស្សនា នឹងបានជាព្រះសកទាគាមី

ហើយព្រះសកទាគាមីគិតថា អញនឹងចូលផលសមាបត្តិរបស់ខ្លួន ហើយចម្រើនវិបស្សនា នឹងបានជាអនាគាមី ដូច្នេះ អាចារ្យទាំងនោះ គប្បីត្រូវតាំថា កាលបើដូច្នោះ ព្រះអនាគាមីក៏នឹងជាព្រះអរហន្ត ។ ព្រះអរហន្តក៏នឹងជាព្រះបច្ចេកពុទ្ធ ព្រះបច្ចេកពុទ្ធក៏នឹងជាព្រះសម្មាសម្ពុទ្ធ ដូច្នេះ ព្រោះដូច្នោះ ទើបវិបស្សនា ឲ្យសម្រេចប្រយោជន៍ តាមការត្រេកអរក្នុងចិត្តសន្តានតាមអធ្យាស្រ័យ ដោយហេតុនោះ សម្រាប់ព្រះសេក្ខបុគ្គល ក៏កើតតែផលចិត្តដូចគ្នា មគ្គចិត្តមិនកើតឡើយ ។ បើលោកសម្រេចមគ្គចិត្តដែលសម្បយុត្តដោយបឋមជ្ឈានសោត ផលចិត្តដែលសម្បយុត្តដោយបឋមជ្ឈានប៉ុណ្ណោះកើតឡើងដល់លោក បើលោកសម្រេចមគ្គចិត្ត ដែលសម្បយុត្តដោយឈានណាមួយ ក្នុងបណ្តាទុតិយជ្ឈានជាដើមសោត ផលចិត្តដែលសម្បយុត្តដោយឈានណាមួយ ក្នុងបណ្តាទុតិយជ្ឈានជាដើម ក៏រមែងកើត ។

សួរថា ព្រោះហេតុអ្វី ទើបក្នុងទីនេះ គោត្រភូញាណមិនមាននិព្វានជាអារម្មណ៍ ដូចញាណដែលជាបុរេចារិករបស់មគ្គញាណ ។ ឆ្លើយថា ព្រោះផលញាណ មិនជានិយ្យានិកធម៌ ។ សេចក្តីពិត ធម៌ គឺអរិយមគ្គប៉ុណ្ណោះជានិយ្យានិកធម៌ ។ សមដូចពាក្យដែលលោកពោលថា ពួកធម៌ជានិយ្យានិក (ធម៌នាំសត្វឲ្យរួចចាកវដ្តៈ) តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្ននេះ ពួកធម៌ជានិយ្យានិក ។[1] ដូច្នោះ ញាណដែលជាអនន្តរប្បច្ច័យនៃសភាវធម៌ដែលជានិយ្យានិកដោយចំណែកមួយ ដែលប្រព្រឹត្តទៅដោយសភាវៈ ដែល

១- បិ.៧៩ ទំ.២២០ ។

ចេញចាកទាំង ២ ចំណែក គប្បីចេញចាកនិមិត្តបាន ព្រោះដូច្នោះ ទើប គោត្រភូញាណនោះ មានព្រះនិព្វានជាអារម្មណ៍ត្រឹមត្រូវ ញាណដែលជា បុរេចារិករបស់ផលញាណ ដែលមានសភាវៈមិនចេញទៅ ព្រោះជានិយ្យា-និកធម៌ ព្រោះមិនកាត់កិលេស ដែលកំពុងប្រព្រឹត្តទៅ ព្រោះជាវិបាករបស់ អរិយមគ្គនោះ ព្រោះបានចម្រើនមគ្គ ជួនកាល មានព្រះនិព្វានជាអារម្មណ៍ ក៏មិនត្រូវ មិនគួរ ព្រោះអនុលោមញ្ញាណទាំង ២ ចំណែក មានអាការមិន ស្មើគ្នា ។ ពិតហើយ អនុលោមញ្ញាណក្នុងអរិយមគ្គវិថី ដែលដល់នូវការ បរិបូណ៌យ៉ាងឧត្រិដ្ឋ ដោយលោកិយញ្ញាណដែលជាគ្រឿងទម្លាយគំនរលោភៈ ជាដើមដ៏ច្រើន ដែលមិនធ្លាប់ចាក់ធ្លុះបានយ៉ាងល្អ កើតឡើងអនុលោមដល់ មគ្គញ្ញាណ ឯក្នុងផលសមាបត្តិវិថី អនុលោមញ្ញាណទាំងនោះ មិនមានការ ខ្វល់ខ្វាយក្នុងអរិយមគ្គវិថីនោះ ព្រោះកាត់កិលេសនោះៗ បានជាសមុច្ឆេទ កើតត្រឹមតែបរិកម្មនៃការដល់ព្រមដោយសុខ ដែលកើតអំពីផលសមាបត្តិ របស់ព្រះអរិយៈទាំងឡាយតែម្យ៉ាង ព្រោះដូច្នោះ ទើបអនុលោមញ្ញាណ ទាំងនោះ មិនមានការចេញចាកបច្ចយណាមួយ ព្រោះញាណក្នុងទីបំផុតនៃ អនុលោមញ្ញាណទាំងនោះ ដែលមានសង្ខារជានិមិត្ត គប្បីមានព្រះនិព្វាន ជាអារម្មណ៍ ចាកការចេញអំពីសមាបត្តិ ព្រោះធ្វើពាក្យ អធិប្បាយដូច្នេះថា កាលសេក្ខបុគ្គលពិចារណាសង្ខារទាំងឡាយ ដោយឧទយព្វយញ្ញាណជាដើម ដើម្បីនឹងប្រើផលសមាបត្តិរបស់ខ្លួន ផលចិត្តប៉ុណ្ណោះ កើតឡើងក្នុងលំដាប់ វិបស្សនាញាណ មគ្គមិនកើត ។ ដូច្នោះ អត្ថដូចពោលមកនេះឯង ទើបជា

ការបរិបូរហើយ ។ គប្បីជ្រាបការចូលផលសមាបត្តិដូចពោលមកយ៉ាងនេះ ។

ផលសមាបត្តិនោះ មានការតាំងនៅដោយអាការ ៣ យ៉ាង ព្រោះព្រះបាលីថា ម្នាលអាវុសោ បច្ចយដែលឲ្យអនិមិត្តាចេតោវិមុត្តិតាំងនៅបានយូរ មាន ៣ ប្រការ គឺការមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្តទុកដាក់ចំពោះព្រះនិព្វានធាតុដែលប្រាសចាកអារម្មណ៍ ១ ការបានតាក់តែងទុកពីខាងដើម ១ ដូច្នេះ ។ ក្នុង ៣ យ៉ាងនោះ ពាក្យថា ការបានតាក់តែងអំពីខាងដើម បានដល់ ការកំណត់កាល ក្នុងកាលមុនចូលសមាបត្តិ ។ ផលសមាបត្តិនោះ មិនមានការចេញដរាបណា មិនទាន់ដល់កាលកំណត់នោះ ព្រោះលោកកំណត់ថា នឹងចេញក្នុងពេលឈ្មោះនោះ ។

ម្យ៉ាងទៀត ផលសមាបត្តិនោះ រមែងមានការចេញទៅ ដោយអាការ ២ យ៉ាង ព្រោះព្រះបាលីថា ម្នាលអាវុសោ បច្ចយនៃការចេញចាកអនិមិត្តា-ចេតោវិមុត្តិ មាន ២ ប្រការ គឺការយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការមិនយកចិត្តទុកដាក់ចំពោះនិព្វានធាតុដែលមិនមានអារម្មណ៍ ១ ដូច្នេះ ។ ក្នុង ២ យ៉ាងនោះ ពាក្យថា ការយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង បានដល់ រូបនិមិត្ត វេទនានិមិត្ត សញ្ញានិមិត្ត សង្ខារនិមិត្ត និងវិញ្ញាណនិមិត្ត ។ ព្រះយោគាវចរមិនមនសិការរួមគ្នានូវនិមិត្តទាំងនោះ ក៏ពិត តែលោកពោលយ៉ាងនោះ ដោយការរួមនិមិត្តទាំងពួង ព្រោះដូច្នោះ អារម្មណ៍របស់ភវង្គចិត្តឯណា មានការចេញចាកផលសមាបត្តិ រមែងមាន ដោយមនសិការដល់អារម្មណ៍នោះៗ គប្បីជ្រាបការចេញចាកផលសមាបត្តិនោះ ដោយប្រការ

យ៉ាងនេះ ។ លោកពោលថា **វិមុត្តិសុខំ បដិសំវេទី** *ដូច្នេះ សំដៅយកការចូល ការតាំងនៅ និងការចេញចាកផលសមាបត្តិ ដូចពោលមកនេះ ន៎ុះចាត់ជាអរហត្តផល ដែលរម្ងាប់សេចក្តីក្រវល់ក្រវាយ មានអមតៈជាអារម្មណ៍ ជាសុខ ប្រាសចាកអាមិស ស្ងប់ ជាសាមញ្ញផលដ៏ឧត្តម ព្រោះហេតុនោះ ទើបលោកពោលថា បទថា* **វិមុត្តិសុខំ បដិសំវេទី** *បានដល់ គង់ប្រថាប់សោយវិមុត្តិ គឺផល សមាបត្តិសុខ ។*

សព្ទថា **អថ** *ជានិបាត ចុះក្នុងអត្ថនៃអធិការ ។ សព្ទថា* **ឱ** *ជានិបាត ចុះក្នុងអត្ថនៃបទបូរណៈ គឺធ្វើបទឲ្យពេញ ។ ក្នុងសព្ទថា* **អថឱ** *នោះ ដោយសព្ទថា* **អថ** *ដែលមានអធិការជាអត្ថនេះ លោកសម្តែងដល់អធិការ គឺការកិច្ចដទៃចាកការសោយវិមុត្តិសុខ ។ សួរថា អធិការដទៃនោះ គឺអ្វី ។ ឆ្លើយថា គឺការធ្វើមនសិការដល់បដិច្ចសមុប្បាទ ។ ម្យ៉ាងទៀត សព្ទថា* **អថ** *ជានិបាត ចុះក្នុងអត្ថនេះថា បច្ឆា គឺខាងក្រោយ ។ ដោយហេតុនោះ ទើបសព្ទថា* **អថ** *នោះ ន៎ុះបញ្ជាំងអត្ថដែលកំពុងពោលថា ដោយកន្លងទៅ ៧ ថ្ងៃ នោះ ។ បទថា* **តស្ស សត្តាហស្ស** *បានដល់ អង្គុយពត់ភ្នែន ៧ ថ្ងៃ ។ បទថា* **អច្ចយេន** *ប្រែថា ប្រាសទៅ ។ បទថា* **តម្ហា សមាធិម្ហា** *បានដល់ចាកសមាធិដែលសម្បយុត្តដោយអរហត្តផល ។ តែក្នុងទីនេះ អាចារ្យពួកខ្លះពន្រីកសប្តាហ៍ទាំងនោះឲ្យពិស្តារចេញទៅថា គប្បីសម្តែង ៧ សប្តាហ៍ រៀងទៅដោយលំដាប់ ។ ខ្ញុំនឹងពណ៌នាសប្តាហ៍ទាំងនោះខាងមុខ ដោយគន្លងនៃការសម្តែងដែលមិនខុសក្បាំងក្បាត់ ក្នុងឧទានបាលីនេះ ដោយខន្ធកបាឋៈ ។*

បទថា **រត្តិយា** *ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថដែលសម្ពន្ធដោយចំណែកផ្សេងៗ នៃរាត្រី ។ បទថា* **បឋមំ** *ជាទុតិយាវិមុត្តិ ចុះក្នុងអត្ថអច្ចន្តសំយោគ ប្រែថា រហូត ។ ពិតហើយ ព្រះមានព្រះភាគទ្រង់ប្រកបដោយមនសិការនោះ អស់បឋមយាមនៃរាត្រីនោះ ។*

បទថា **បដិច្ចសមុប្បាទំ** *បានដល់ បច្ចយធម៌ ។ ពិតហើយ បច្ចយធម៌ មានអវិជ្ជាជាដើម ឈ្មោះថា បដិច្ចសមុប្បាទ ។ បើមានពាក្យសួរជ្រៀតចូលមកថា សេចក្តីនេះ គប្បីដឹងបានដូចម្តេច ។ ឆ្លើយថា ដឹងបាន ព្រោះព្រះ-តម្រាស់របស់ព្រះមានព្រះភាគ ។ ពិតហើយ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ទើបជាតិនេះជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ចយនៃជរាមរណៈ ។បេ។ នោះ ជាបច្ចយនៃសង្ខារ គឺអវិជ្ជា ។ រួមសេចក្តីថា បច្ចយធម៌ មានអវិជ្ជាជាដើម ជាតួហេតុ ដូចលោកពោលថា បច្ចយ ១២ គឺបដិច្ចសមុប្បាទ ១២ ។*

ក្នុងសេចក្តីនោះ មានវចនត្ថៈដូចតទៅនេះ ឈ្មោះថា បដិច្ចសមុប្បាទ ព្រោះអាស្រ័យ គឺបែរមុខដល់គ្នានិងគ្នា មិនបដិសេធការព្រមព្រៀងនៃហេតុ ឲ្យបច្ចយដល់គ្នានិងគ្នាកើតឡើង ។ ម្យ៉ាងទៀត ការអាស្រ័យបច្ចយដែលគួរជាបច្ចយ ដែលត្រូវអាស្រ័យគ្នាប្រព្រឹត្តទៅ ទើបកើតឡើងសម្ពន្ធគ្នា ដោយមិនវៀរបច្ចយនោះ ឈ្មោះថា បដិច្ចសមុប្បាទ ។ ក្នុងពាក្យថា បដិច្ច-សមុប្បាទនេះ បានដល់ ហេតុដែលប្រកបដោយការអាចក្នុងការឲ្យកើតផល ដែលនឹងដឹងបានដោយពាក្យដែលមានការកើតឡើងព្រមជាហេតុជិត មិនគប្បី

ជ្រោបត្រឹមតែអាស្រ័យគ្នាកើតឡើង ។

ម្យ៉ាងទៀត បច្ចយ ឈ្មោះថា **បដិច្ច** *ព្រោះគួរអាស្រ័យចំពោះបណ្ឌិត ។ ឈ្មោះថា* **សមុប្បាទ** *ព្រោះឲ្យកើតឡើងដោយប្រពៃ ឬដោយខ្លួនឯង បដិច្ចនោះផង សមុប្បាទនោះផង ឈ្មោះថា* **បដិច្চសមុប្បាទ** *គប្បីជ្រាបសេចក្តីក្នុងរឿងបដិច្ចសមុប្បាទនេះ ដោយប្រការដូចពោលមកនេះ ។*

បទថា **អនុលោមំ** *បានដល់ បច្ចយាការ មានអវិជ្ជាជាដើម ដែលលោកពោលដោយនយជាដើមថា* **អវិជ្ជាបច្চយា សង្ខារា** *ព្រោះអវិជ្ជាជាបច្ចយទើបកើតមានសង្ខារ ។ លោកហៅថា* **អនុលោម** *ព្រោះធ្វើកិច្ចដែលខ្លួនគួរធ្វើ ។ ម្យ៉ាងទៀត ឈ្មោះថា* **អនុលោម** *ព្រោះលោកពោលតាំងអំពីដើមរហូតដល់ទីបំផុត ឬព្រោះអនុលោមតាមការប្រព្រឹត្តទៅ ។ នូវអនុលោមនោះ ។*

បទថា **សាធុកំ មនសាកាសិ** *បានដល់ ធ្វើទុកក្នុងចិត្តដោយគោរព ។ អធិប្បាយថា បច្ចយធម៌ណាមួយ ជាបច្ចយដល់បច្ចុប្បន្នធម៌ណាមួយ ដោយភាពជាបច្ចយ មានហេតុប្បច្ចយជាដើម ដោយប្រការណាមួយ ព្រះមានព្រះភាគទ្រង់ធ្វើធម៌ទាំងអស់នោះទុកក្នុងព្រះហឫទ័យមិនឲ្យវិបរិត មិនឲ្យស្រេកចុះ ដោយទ្រង់ពិចារណាមិនឲ្យសេសសល់ ។ ដើម្បីសម្តែងប្រការដែលព្រះមានព្រះភាគទ្រង់មនសិការបដិច្ចសមុប្បាទ ជាអនុលោមដោយសង្ខេបសិន ទើបពោលពាក្យជាដើមថា* **ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ** *ជួរចុះ ។*

បណ្តាបទទាំងនោះ បទថា **ឥតិ** *ស្មើគ្នានឹង* **ឯវំ** *អធិប្បាយថា ដោយ*

ប្រការនេះ ។ បទថា **ឥមស្មឹ សតិ ឥទំ ហោតិ** *សេចក្តីថា កាលបច្ចយ មានអវិជ្ជាជាដើមនេះមាន ផល មានសង្ខារជាដើមនេះក៏មាន ។ បទថា* **ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ** *សេចក្តីថា ព្រោះបច្ចយ មានអវិជ្ជាជាដើមនេះកើត ទើបផល មានសង្ខារជាដើមកើតឡើង ។*

បទថា **ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** *សេចក្តីថា ព្រោះត្រាស់ការមិនមានសង្ខារជាដើម ក្នុងកាលអវិជ្ជាជាដើមមិនមាន ក្នុងទុតិយពោធិសូត្រ និងត្រាស់ការរលត់សង្ខារជាដើម ក្នុងកាលអវិជ្ជាជាដើមរលត់ ក្នុងតតិយពោធិសូត្រ ឈ្មោះថា ទ្រង់សម្តែងការកំណត់លក្ខណៈនៃបច្ចយខាងដើមនេះ កាលបច្ចយ មានអវិជ្ជាជាដើមនេះ មានន៏ះឯង មិនមែនមិនមាន ។ ព្រោះអវិជ្ជាជាដើមកើតន៏ះឯង មិនមែនមិនកើត ។ ព្រោះរលត់ន៏ះឯង មិនមែនមិនរលត់ ។ ព្រោះហេតុដូច្នេះ គប្បីឃើញថា លក្ខណៈន៏ះ ជាការកំណត់ឈមចុះខាងក្នុង ត្រាស់ទុកក្នុងទីនេះ សម្រាប់បដិច្ចសមុប្បាទ ។ ម្យ៉ាងទៀត បទថា* **និរោធោ** *បានដល់ ការមិនកើតឡើង គឺការមិនប្រព្រឹត្តតទៅ ព្រោះសម្រេចការប្រាសចាកបច្ចយ មានអវិជ្ជាជាដើម ។ សមដូចលោកពោលថា* **អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** *ព្រោះការរលត់ដោយឥតសេសសល់នូវអវិជ្ជា ទើបសង្ខាររលត់ ។*

ដោយពាក្យថា **ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** *នោះ លោកសម្តែងសេចក្តីនេះថា ការមិនរលត់ ឈ្មោះថា ការកើត ការកើតនោះ ក្នុងទីនេះ លោកហៅថា* **អត្ថិភាវោ** *ភាវៈដែលមាន ដូច្នេះក៏មាន ។ ពិតហើយ*

លក្ខណៈថា **ឥមស្មឹ សតិ ឥទំ ហោតិ** *នេះឯង កាលពោលដោយបរិយាយ ដទៃបទដំបូង ជាការប្លែកអំពីបទចុង ។ ដែលពោលថា* **ឥមស្ស ឧប្បាទា ឥទំ ឧប្បជ្ជតិ** *ព្រោះដូច្នោះ ដែលលោកពោលថា* **ឥមស្មឹ សតិ** *សំដៅដល់ការៈដែលទ្រង់នៅប៉ុណ្ណោះ ក៏មិនមែន ។ ដោយពិត រមែងឲ្យឃើញថា មិនមែនការៈដែលនឹងរលត់ដោយមគ្គ ។ ព្រោះហេតុកាលពោលដល់និទ្ទេសនៃលក្ខណៈ ដែលលើកឡើងសម្តែងជា ២ យ៉ាង គឺ* **ឥមស្មឹ អសតិ ឥទំ ន ហោតិ** *និង* **ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** *ដូច្នេះ ទើបពោលចំពោះការរលត់ ដោយនយជាដើមថា* **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារ-និរោធោ** *ដូច្នោះ ទើបជាការសម្តែងថា ការមិនមាន គឺការរលត់ រមែងមានការខុសចាកការមិនមាន គឺការមិនរលត់ ។ ដោយហេតុនោះ ទើបលោកសម្តែងការកើតឲ្យប្លែកជាមួយការមាន ពោល គឺការមិនរលត់ ។ ព្រោះហេតុនោះ ក្នុងទីនេះ ទើបលោកមិនបំណងយក សេចក្តីថា ត្រឹមតែការមាន ជាការកើតឡើងដោយពិត លោកធ្វើឲ្យជាក់ច្បាស់ដល់អត្ថនេះថា ការមិនមាន គឺការមិនរលត់ ។ កាលបើដូច្នោះ ការពោលដល់លក្ខណៈទាំង ២ នោះ គប្បីជ្រាបថា មានប្រយោជន៍ ព្រោះជាលក្ខណៈដែលគប្បីឲ្យប្លែក ដោយការប្លែកនៃគ្នានិងគ្នា ។*

សួរថា ឈ្មោះថា **អនិរោធ** *ដែលហៅថា* **អត្តភាវៈ** *និង* **ឧប្បាទ** *នេះ គឺអ្វី ឆ្លើយថា គឺការៈដែលមិនលះ ១ ការៈដែលគួរបន្តែមផល ដោយមិនលះបង់ការៈដែលគួរដល់ផល ដែលមិនទាន់កើត ១ ការៈដែលអកុសលធម៌*

ដែលគប្បីលះនោះ ដែលអរិយមគ្គមិនទាន់ដកឡើង ១ ការៈដែលសំយោជនៈក្នុងកុសលធម៌ និងអព្យាកតធម៌ ដែលមិនចាំបាច់លះ សម្រាប់បុគ្គលដែលមានអាសវៈមិនទាន់អស់ទៅ និងមិនទាន់លះបាន ១ ។ ពិតហើយ ការប្រព្រឹត្តទៅនៃខន្ធទាំងមូល ឈ្មោះថា បដិច្ចសមុប្បាទ ព្រោះការៈដែលមានអនុសយមិនទាន់ដកឡើងបាន សមដូចព្រះតម្រាស់ថា

> *ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលដែលអវិជ្ជាណា បិទបាំងផង ដែលតណ្ហាណាប្រកបផង ទើបកាយនេះកើតឡើង បុគ្គលពាលមិនបានលះបង់ អវិជ្ជានោះផង មិនទាន់អស់តណ្ហានោះផង ដំណើរនុ៎ះ តើព្រោះហេតុដូចម្តេច ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលពាល មិនបានប្រព្រឹត្តមគ្គព្រហ្មចរិយៈ ដើម្បីការអស់នៃទុក្ខ ដោយប្រពៃទេព្រោះហេតុនោះ បុគ្គលពាលលុះបែកធ្លាយរាងកាយទៅហើយ ក៏ចូលទៅចាប់បដិសន្ធិកាយ (ផ្សេងទៀត) កាលបុគ្គលពាលនោះ ចូលទៅចាប់បដិសន្ធិ-កាយ (ផ្សេងទៀត) រមែងមិនរួចស្រឡះចាកជាតិ ជរា មរណៈ ... ។*

ព្រោះអវិជ្ជារបស់បុគ្គលដែលអស់សំយោជនៈហើយមិនមាន ទើបសង្ខារមិនមាន ព្រោះតណ្ហា និងឧបាទានមិនមាន ទើបឧបាទាន និងភពមិនមាន ព្រោះហេតុនោះ ទើបវដ្តៈជ្រុកជាការកាត់ផ្តាច់ ។ ដោយហេតុនោះ ទើបលោកពោលពាក្យជាដើមថា

ម្នាលផគ្គុន ឯការរលត់នៃផស្សៈ ព្រោះការរលត់ឥតមានសេស សល់ នៃផស្សាយតនៈទាំង ៦ ការរលត់នៃវេទនា ព្រោះការរលត់នៃផស្សៈ ការរលត់នៃតណ្ហា ព្រោះការរលត់នៃវេទនា ... ដូច្នេះ ។

ពិតហើយ តាំងពីសម្រេចអរហត្តមគ្គ មកទល់គ្នានឹងបរិនិព្វាន អាយតនៈ ៦ ជាដើម មិនប្រព្រឹត្តទៅក៏មិនមែន ។ ដោយពិត លោកពោលដល់និរោធ ព្រោះភាវៈដែលមិនមាន ភាវៈដែលគួរពោលនិរោធសព្វ ភាវៈដែលអស់សំយោជនៈ ។ ម្យ៉ាងទៀត កម្មដែលធ្វើយូរ រាប់ថា មានតាមគួរដល់ផល ព្រោះផលមិនទាន់កើត និងព្រោះមិនទាន់លះអាហារ គឺមិនមែនផលដែលកើតហើយ ទាំងមិនមែនលះអាហារហើយ ។ ភាវៈដែលបច្ចុយជាហេតុកើតផល មានអវិជ្ជា និងសង្ខារជាដើម ជាបច្ចុយគួរដល់ផល ដោយន័យដូចពោលហើយនោះឯង គប្បីជ្រាបថា **អនិរោធ** *គឺមិនរលត់ ។ ព្រោះបច្ចុយដែលឲ្យកើតផលយ៉ាងនោះ មិនទាន់រលត់ រៀរហេតុណាចេញ ផលមិនកើតហេតុនោះ មានអតីតហេតុជាដើម ដែលលោកពោលដោយពាក្យថា* **ឥមស្មឹ សតិ** *នេះ ព្រោះហេតុនោះឯង ការកើតឡើងនៃបច្ចុយ មិនពាល់ត្រូវដល់ការមិនប្រព្រឹត្តរបស់បុគ្គលដែល មិននៅចប់ព្រហ្មចរិយៈ លោកពោលថា* **ឥមស្ស ឧប្បាទា** *ដោយការមិនត្រឡប់មក ដោយមិនពឹងផ្អែកដល់ប្រភេទរបស់កាល ។ ម្យ៉ាងទៀត ក្នុងការដល់ព្រមនៃបច្ចុយដ៏សេស ភាវៈដែលបច្ចុយមិនមានក៏ដូចមាន និងពោលថ្វីដល់បច្ចុយដែលមាន ដែលជាបច្ចុយ*

បំណងឲ្យកើតផលនោះ លោកហៅថា **ឥមស្ស ឧប្បាទា។** *ពិតហើយ ផលរមែងកើតអំពីហេតុនោះ ព្រោះហេតុនោះ ទើបឈ្មោះថា* **តជាតុ** *បានដល់ហេតុដែលកើតឡើង ដោយការៈដែលឲ្យកើតផល ដែលឈ្មោះថា កើតឡើងហើយ ។ ហេតុ ទោះបីមិនមាន ក៏ឈ្មោះថា* **តជាតុ** *ព្រោះដូច្នោះ ការៈដែលជា* **តជាតុ** *គប្បីជ្រាបថា* **ឧប្បាទ។**

បណ្តាបទទាំងនោះ ដោយបទថា **សតិ** *នេះ ព្រះថេរៈកាលពោលដល់ការៈដែលជាបច្ច័យដោយត្រឹមតែការៈដែលមាន ទើបសម្តែងភាពដែលបដិច្ច-សមុប្បាទមិនត្រូវខ្វល់ខ្វាយ ។ បទថា* **ឧប្បាទា** *នេះ ព្រះថេរៈ កាលនឹងសម្តែងការកើតឡើងជាធម្មតា និងការៈដែលមិនប្រព្រឹត្តទៅសព្វកាល និងការៈដែលប្រាថ្នាចំពោះការកើតផល ទើបសម្តែងដល់ការៈដែលបដិច្ចសមុប្បាទជាអនិច្ចតា ។ ព្រះថេរៈសម្តែងដល់បដិច្ចសមុប្បាទជាហេតុ ជាសមុទយៈ ជាជាតិ និងជាដែនកើត ដែលសម្រេចដោយសត្តមីវិភត្តិ និងបញ្ចមីវិភត្តិ ដែលប្រើក្នុងអត្ថនៃហេតុ ដោយពាក្យថា* **សតិ ន អសតិ ឧប្បាទា ន និរោធា** *ក្នុងកាលវត្តនេះមាន គឺមិនមានក៏មិនមែន ព្រោះវត្តនេះកើត គឺរលត់ក៏មិនមែន ។ លោកកំណត់ការៈនៃផលដែលមាន ដោយមិនវៀរចាកហេតុ ព្រោះការៈនៃសត្តមីវិភត្តិ ចុះក្នុងអត្ថនៃហេតុ គប្បីជ្រាបការប្រព្រឹត្តទៅក្នុងហេតុនោះ ដូចពាក្យថា ក្នុងកាលមនុស្សមិនមានទ្រព្យ មិនធ្វើទ្រព្យឲ្យកើតឡើង ការក្រើនរឹតតែក្រ និងពាក្យថា ក្នុងកាលស្រូវសម្បូរ ក៏កើតអាហារល្អឡើង ។ ទោះបីបញ្ចមីវិភត្តិ ក៏ចុះក្នុងអត្ថនៃហេតុ ឈ្មោះថា ប្រព្រឹត្តទៅបានក្នុងដែន*

កើត និងក្នុងភាពប្រក្រតីរបស់ផល ដូចពាក្យថា អំពីកលល: ជាអព្ទុទ: អំពីអព្ទុទ: ជាបេសិ និងពាក្យថា ស្ទឹងគង្គាកើតអំពីភ្នំហិមពាន្ត ស្រះកើតអំពីស្ទឹងសរភូ ។ ព្រោះអវិជ្ជាជាដើមមាន ទើបលោកកំណត់ភាវ:នៃផលមានសង្ខារជាដើម ព្រោះភាវ:ដែលមិនវៀរចាកអវិជ្ជាជាដើមនោះ និងផលមានសង្ខារជាដើម កើតអំពីបច្ចយ មានអវិជ្ជាជាដើម និងដែលបច្ចយ មានអវិជ្ជាជាដើមតាំងឡើង ព្រោះដូច្នោះ ទើបបច្ចយ មានអវិជ្ជាជាដើមនោះ ជាដែនកើត និងជាប្រក្រតីរបស់ផល មានសង្ខារជាដើមនោះ ព្រោះដូច្នោះ ដើម្បីទ្រង់សម្តែងអត្ថនោះ ទើបលោកធ្វើនិទ្ទេសសត្តមីវិភត្តិ និងបញ្ចមីវិភត្តិ ក្នុងអត្ថនៃហេតុថា **ឥមស្មឹ សតិ ឥមស្ស ឧប្បាធា** ព្រោះវត្ថុនេះមាន ព្រោះវត្ថុនេះកើត ។

ព្រោះក្នុងសេចក្តីនេះ បដិច្ចសមុប្បាទដែលលើកឡើង សម្តែងដោយសង្ខេបថា **ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្ស្ប្បាធា ឥទំ ឧប្បជ្ជតិ** មាននិទ្ទេសជាដើមថា **អវិជ្ជាបច្ចយា សង្ខារា** ដូច្នោះ ភាវ:ដែលមាន និងការកើតឡើង តាមដែលពោលហើយ រមែងដឹងបានថា ជាបច្ចយនៃបច្ចយុប្បន្នធម៌នោះៗ ។ ពិតហើយ ភាវ:ដែលជាបច្ចយដទៃ មិនមាន ព្រោះលះអត្ថិភាវ: និងឧប្បាទ ពោល គឺការមិនរលត់ ការមិនត្រឡប់ជាសភាវ: ឬការតាំងនៅនៃសមុទយ: គឺការកើតដែលលោកពោល ដោយពាក្យដែលកំណត់ពិតប្រាកដខាងក្នុងថា **សតិឯវ ឆាសតិ ឧប្បាធា ឯវ ឆ ឆិរោធា** ដូច្នេះ ព្រោះដូច្នោះ គប្បីជ្រាបថា ភាវ:ដែលមាន និងឧប្បាទដូចពោល

ហើយ ជាតួបច្ចយ ។ សូម្បីបច្ចយ ២៤ មានហេតុប្បច្ចយជាដើម ដែលមកក្នុងបជ្ជាន គប្បីជ្រាបថា ជាបច្ចយពិសេសនៃបច្ចយនោះឯង ។

ដូច្នោះ ដើម្បីសម្តែងប្រការដែលព្រះអង្គទ្រង់មនសិការដល់អនុលោម-បដិចសមុប្បាទដោយពិស្តារ ទើបត្រាស់ពាក្យជាដើមថា **យទិទំ អវិជ្ជា-បច្ចយា សង្ខារា** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **យទិទំ** *ជានិបាត ។ បទថា* **យទិទំ** *នោះ មានអត្ថថា* **យោ អយំ ។** *ក្នុងបទថា* **អវិជ្ជាបច្ចយា** *ជាដើម មានវិនិច្ឆយដូចតទៅនេះ ឈ្មោះថា* **អវិជ្ជា** *ព្រោះជួបនូវវត្ថុមិនគួរជួប មានកាយទុច្ចរិតជាដើម ។ ឈ្មោះថា* **អវិជ្ជា** *ព្រោះមិនជួបវត្ថុដែលគួរជួប មានកាយសុចរិតជាដើម ។ ឈ្មោះថា* **អវិជ្ជា** *ព្រោះធ្វើសភាវៈនៃធម៌ដែលមិនវិបរិតមិនឲ្យដឹងច្បាស់ ។ ឈ្មោះថា* **អវិជ្ជា** *ព្រោះញុំាងសត្វឲ្យសុះទៅក្នុងភពជាដើម ក្នុងសង្សារដែលវៀរចាកទីបំផុត ។ ឈ្មោះថា* **អវិជ្ជា** *ព្រោះសុះទៅក្នុងវត្ថុដែលមិនមាន មិនសុះទៅក្នុងវត្ថុដែលមាន ។ ម្យ៉ាងទៀត ឈ្មោះថា* **អវិជ្ជា** *ព្រោះជាបដិបក្ខចំពោះវិជ្ជា ។ អវិជ្ជានោះ គប្បីជ្រាបថា មាន ៤ យ៉ាង ដោយន័យថា* **ទុក្ខេ អញ្ញាណំ** *គឺការមិនដឹងទុក្ខជាដើម។ ឈ្មោះថា* **បច្ចយ** *ព្រោះអាស្រ័យទៅ គឺកើតឡើង និងប្រព្រឹត្តទៅ មិនវៀរផល ។ ម្យ៉ាងទៀត ធម៌ ដែលមានការឧបការៈជាអត្ត ឈ្មោះថា* **បច្ចយ ។** *អវិជ្ជានោះផង ជាបច្ចយផង ព្រោះហេតុនោះ ទើបឈ្មោះថា មានអវិជ្ជា ជាបច្ចយ ។ ព្រោះមានអវិជ្ជាជាបច្ចយនោះ ។ ឈ្មោះថា* **សង្ខារ** *ព្រោះតាក់តែង បានដល់*

កុសលចេតនា និងអកុសលចេតនាខាងលោកិយ កុសល និងអកុសល-ចេតនានោះ គប្បីជ្រាបថា មាន ៣ យ៉ាង គឺបុញ្ញាភិសង្ខារ ១ អបុញ្ញា-ភិសង្ខារ ១ អានេញ្ជាភិសង្ខារ ១ ។ ឈ្មោះថា **វិញ្ញាណ** *ព្រោះដឹងច្បាស់ ។ វិញ្ញាណនោះ មាន ៣២ គឺ (ឬអហេតុកវិបាក ១៥ មហាវិបាក ៨ មហគ្គតវិបាក ៩) ដោយអំណាចវិបាកវិញ្ញាណដែលជាលោកិយ ។ ឈ្មោះថា* **នាម** *ព្រោះបង្អោនទៅ បានដល់ នាមក្ខន្ធ ៣ មានវេទនាជាដើម ។ ឈ្មោះថា* **រូប** *ព្រោះអត្ថថា បែកធ្លាយទៅ បានដល់ ភូតរូប ៤ និងឧបាទា-យរូប ២៤ មានចក្ខុបសាទរូបជាដើម ។ ឈ្មោះថា* **អាយតន** *ព្រោះជាទីត និងនាំសត្វទៅកាន់សង្សារទុក្ខ។ ឈ្មោះថា* **ផស្ស** *ព្រោះពាល់ត្រូវ ។ ឈ្មោះថា* **វេទនា** *ព្រោះសោយអារម្មណ៍ ។ ទាំង ២ នោះ ពោលដោយទ្វារមាន ៦ ពោលដោយវិបាក មាន ៣៦ ។ ឈ្មោះថា* **តណ្ហា** *ព្រោះតក់ស្លុត ។ តណ្ហានោះ ដោយសង្ខេបមាន ៣ មានកាមតណ្ហាជាដើម និងដោយពិស្តារ មាន ១០៨ ។ ឈ្មោះថា* **ឧបាទាន** *ព្រោះប្រកាន់មាំ ឧបាទាននោះមាន ៤ យ៉ាង មានកាមុបាទានជាដើម ។ ឈ្មោះថា* **ភព** *ព្រោះមាន និងមិនមាន ភពនោះ មាន ២ យ៉ាង ដោយចែកជាកម្មភព និងឧបបត្តិភព ។ ការកើត ឈ្មោះថា* **ជាតិ** *ការគ្រាំគ្រា ឈ្មោះថា* **ជរា** *។ ឈ្មោះថា* **មរណ** *ព្រោះជាហេតុស្លាប់នៃសត្វ ។ ការសោយសោក ឈ្មោះថា* **សោក** *ការយំរៀបរាប់ ឈ្មោះថា* **បរិទេវ** *ឈ្មោះថា* **ទុក្ខ** *ព្រោះអត់ធន់បានដោយលំបាក ។ ម្យ៉ាងទៀត ឈ្មោះថា* **ទុក្ខ** *ព្រោះមាន ២ ខណៈ គឺទុក្ខក្នុងខណៈកើត និងទុក្ខ*

ក្នុងខណៈតាំងនៅ ។ ភាវៈនៃការខូចចិត្ត ឈ្មោះថា **ទោមនស្ស** *។ ការចង្អៀតចង្អល់ តានតឹង ឈ្មោះថា* **ឧបាយាស** *។ បទថា* **សម្ភវន្តិ** *ប្រែថា រមែងកើតឡើង ។ សេចក្តីពិត មិនមែនប្រកបដោយបទ មានសោកជាដើម តែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត គប្បីប្រកបបទថា* **សម្ភវន្តិ** *ជាមួយនឹងបទទាំងអស់ ។ កាលបើដូច្នេះ ឈ្មោះថា សម្តែងការកំណត់បច្ចុយធម៌ និងបច្ចុប្បន្នធម៌ ដោយពាក្យថា* **អវិជ្ជាបច្ចយា សង្ខារា សម្ភវន្តិ** *។ ក្នុងបទទាំងពួង ក៏មានន័យនេះ ។*

ក្នុងធម៌ទាំងនោះ អវិជ្ជា មានការមិនដឹងជាលក្ខណៈ មានការវង្វេងជាកិច្ច មានការបិទបាំងជាអាការប្រាកដ មានអាសវៈជាហេតុជិត ។ សង្ខារ មានការតាក់តែងជាលក្ខណៈ មានការប្រមូលមកជាកិច្ច មានការចាត់ចែងជាអាការប្រាកដ មានអវិជ្ជាជាហេតុជិត ។ វិញ្ញាណមានការដឹងច្បាស់ជាលក្ខណៈ មានភាពជាប្រធានជាកិច្ច មានបដិសន្ធិជាអាការប្រាកដ មានសង្ខារជាហេតុជិត ឬមានវត្ថុ និងអារម្មណ៍ជាហេតុជិត ។ នាម មានការបង្គោនទៅជាលក្ខណៈ មានសម្បយោគជាកិច្ច មិនមានការបែកចាកគ្នាជាអាការប្រាកដ មានវិញ្ញាណជាហេតុជិត ។ រូបមានការបែកធ្លាយទៅជាលក្ខណៈ មានការមិនដឹងអារម្មណ៍ជាកិច្ច មានភាវៈជាសម្បយោគជាអាការប្រាកដ មានវិញ្ញាណជាហេតុជិត ។ សឡាយតនៈ មានការតជាលក្ខណៈ មានការឃើញជាដើមជាកិច្ច មានភាពជាវត្ថុ និងទ្វារជាអាការប្រាកដ មាននាមរូបជាហេតុជិត ។ ផស្សៈ មានការពាល់ត្រូវជាលក្ខណៈ មានការប៉ះទង្គិចជាកិច្ច មានការប្រជុំជាអាការ

ប្រាកដ មានសឡាយតនៈជាហេតុជិត ។ វេទនា មានការសោយជាលក្ខណៈ មានការបរិភោគរសនៃអារម្មណ៍ជាកិច្ច មានសុខ និងទុក្ខជាអាការប្រាកដ មានផស្សៈជាហេតុជិត ។ តណ្ហា មានភាពជាតួហេតុជាលក្ខណៈ មានការត្រេកអរជាកិច្ច មានការមិនឆ្អែតជាអាការប្រាកដ មានវេទនាជាហេតុជិត ។ ឧបាទាន មានការប្រកាន់មាំជាលក្ខណៈ មានការមិនលែងជាកិច្ច មានទិដ្ឋិ គឺការប្រកាន់មាំដោយអំណាចតណ្ហាជាអាការប្រាកដ មានតណ្ហាជាហេតុជិត ។ ភព មានកម្ម និងផលនៃកម្មជាលក្ខណៈ មានការកើត និងការឲ្យកើតជាកិច្ច មានកុសល អកុសល និងអព្យាកតៈជាអាការប្រាកដ មានឧបាទានជាហេតុជិត ។ ជាតិ មានការកើតមុនក្នុងភពនោះៗ ជាលក្ខណៈ មានការពង្រីកចេញទៅជាកិច្ច មានការកើតក្នុងភពនេះចាកអតីតភពជាអាការប្រាកដ មានការវិចិត្រនៃទុក្ខជាហេតុជិត ។ ជរា មានការចាស់នៃខន្ធជាលក្ខណៈ មានការនាំចូលទៅរកសេចក្តីស្លាប់ជាកិច្ច មានការធ្វើនូវភាពជាកំលោះ ក្រមុំ ឲ្យវិនាសជាអាការប្រាកដ ។ មរណៈ មានចុតិជាលក្ខណៈ មានការព្រាត់ប្រាសជាកិច្ច មានការនៅប្រាសចាកគតិជាអាការប្រាកដ ។ សោក មានការឆាបឆេះខាងក្នុងជាលក្ខណៈ មានការក្រៀមក្រំចិត្តជាកិច្ច មានការសោយសោកជាប់ជាអាការប្រាកដ ។ បរិទេវៈ មានការរៀបរាប់ជាលក្ខណៈ មានការប្រារព្ធដល់គុណ និងទោសជាកិច្ច មានសេចក្តីសង្រ្តែងសង្រ្តែជាអាការប្រាកដ ។ ទុក្ខ មានការបៀតបៀនកាយជាលក្ខណៈ មានការទុព្វលផ្លូវកាយ និងទាញយកទោមនស្សមកជាកិច្ច មានអាពាធផ្លូវកាយជាអាការប្រាកដ ។ ទោមនស្ស

មានការបៀតបៀនចិត្តជាលក្ខណៈ មានការចង្អៀតចង្អល់ចិត្តជាកិច្ច មានព្យាធិផ្ទុំចិត្តជាអាការប្រាកដ ។ ឧបាយាសមានការដុតរោលចិត្តជាលក្ខណៈ មានការតានតឹងជាកិច្ច មានការប្រាសចាកការត្រេកអរចិត្តជាអាការប្រាកដ ។ បច្ចុយធម៌ មានអវិជ្ជាជាដើមទាំងនោះ គប្បីជ្រាបដោយលក្ខណៈជាដើមដោយប្រការយ៉ាងនេះឯង ។ ក្នុងទីនេះ សេចក្តីសង្ខេបមានប្រមាណប៉ុណ្ណេះ ។ ឯសេចក្តីពិស្តារ បុគ្គលប្រាថ្នាវិនិច្ឆ័យដែលសម្បូរដោយប្រការទាំងពួង គប្បីរកមើលក្នុងអដ្ឋកថាវិភង្គ ឈ្មោះសម្មោហវិនោទនី ។

បទថា **ឃនំ** *ជាបទសម្តែងលម្អិតដល់នយដែលបានសម្តែងមកហើយ ។ ដោយបទថា* **ឃនំ** *នោះ លោកសម្តែងដោយហេតុ មានអវិជ្ជាជាដើមនោះឯង មិនមែនដោយហេតុ មានការនិម្មិតរបស់បុគ្គលជាធំជាដើម ។ បទថា* **ឯតស្ស** *បានដល់ តាមដែលពោលហើយ ។ បទថា* **កេវលស្ស** *បានដល់ មិនលាយឡំ ឬសុទ្ធៗ ។ បទថា* **ទុក្ខក្ខន្ធស្ស** *បានដល់ ប្រជុំ មិនមែនរបស់សត្វ មិនមែនរបស់ជីវៈ និងរបស់សុខជាដើម ។ បទថា* **សមុទយោ ហោតិ** *បានដល់ កើតទ្បើង គឺកើតព្រម ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ដឹងច្បាស់នូវអត្ថតាមដែលពោលថា គំនរទុក្ខ មានសង្ខារជាដើម រមែងកើតដោយអវិជ្ជាជាដើម ដោយអាការទាំងពួង ។ បទថា* **តាយំ វេលាយំ** *បានដល់ ក្នុងវេលាដែលដឹងច្បាស់អត្ថនោះ ។ បទថា* **ឥមំ ឧទានំ ឧទានេសិ** *សេចក្តីថា បន្ទឺឧទាននេះ ដែលសម្តែងអានុភាពការដឹងហេតុ និងធម៌ដែលកើតអំពីហេតុ ក្នុងកាលដឹងច្បាស់នូវផល*

នោះ ដែលជាសមុដ្ឋាននៃញាណដែលសម្បយុត្តដោយសោមនស្សថា **យទា ហវេ ចាតុភវន្តិ** *ជាដើម អធិប្បាយថា បន្ទឹព្រះវាចាដែលជាទីពេញព្រះហឫទ័យ ។*

ឧទាននោះ មានអធិប្បាយដូច្នេះថា បទថា **យទា** *ប្រែថា ក្នុងកាលណា ។ សពួថា* **ហវេ** *ជានិបាត ចុះក្នុងអត្ថនេះថា* **ព្យត្តំ** *គឺជាក់ច្បាស់ ។ តែអាចារ្យពួកខ្លះពោលអធិប្បាយថា សពួថា* **ហវេ** *ប្រែថា ក្នុងសង្គ្រាម គឺការច្បាំង ។ លោកអាចារ្យទាំងនោះ មានបំណងថា ក្នុងសម័យច្បាំងនឹងកិលេសមារដោយព្រះបាលីថា ចូរពួកអ្នកប្រើអាវុធ គឺបញ្ញាច្បាំងនឹងមារ ។ បទថា* **ចាតុភវន្តិ** *ប្រែថា កើតទ្បើង ។ បទថា* **ធម្មា** *បានដល់ ពោធិបក្ខិយ-ធម៌ ដែលឲ្យសម្រេចការចាក់ធ្លុះបច្ចយាការដោយអនុលោម ។ ម្យ៉ាងទៀត បទថា* **ចាតុភវន្តិ** *បានដល់ ប្រកាស គឺជាក់ច្បាស់ ប្រាកដដោយការត្រាស់ដឹង ។ បទថា* **ធម្មា** *បានដល់ ធម៌ គឺអរិយសច្ច ៤ ។* **អាតាប** *ហៅថា សេចក្តីព្យាយាម ព្រោះអត្ថថា ធ្វើកិលេសឲ្យក្តៅ ។ បទថា* **អាតាបិនោ** *បានដល់ មានសេចក្តីព្យាយាម គឺសម្មប្បធាន ។ បទថា* **ឈាយិនោ** *បានដល់ សម្ប៉ីងដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ។ បទថា* **ព្រាហ្មណស្ស** *បានដល់ ព្រះខីណាស្រពដែលបន្សាត់នូវបាប ។ បទថា* **អថស្ស កង្ខា វបយន្តិ សព្ពា** *សេចក្តីថា កាលព្រាហ្មណ៍មានធម៌ប្រាកដយ៉ាងនេះហើយ ការសង្ស័យក្នុងបច្ចយាការ ដែលត្រាស់ដោយនយជាដើមថា ព្រះមានព្រះភាគបានត្រាស់ថា* **នោ កល្លោ បញ្ហោ** *បញ្ហាមិនសមគួរ ដើម្បី*

ឆ្លើយនូវពាក្យសួរថា **កោ ឆុទ្ធោ ភន្តេ ជុសតិ** *បពិត្រព្រះអង្គ អ្នកណាហ្ន៎ អ្នកពាល់ត្រូវ ដោយនយជាដើមថា ព្រះមានព្រះភាគត្រាស់ថា* **ឆោ កល្យោ បញ្ញោ** *ដើម្បីឆ្លើយសំណួរថា* **កតមំ ឆុទ្ធោ ភន្តេ ជរាមរណំ កស្ស ច បនិទំ ជរាមរណំ** *បពិត្រព្រះអង្គដ៏ចម្រើន ជរា និងមរណៈដូចម្តេច ជរា និងមរណៈនេះជារបស់អ្នកណា សេចក្តីសង្ស័យ ១៦ ដែលមកដោយនយជាដើមថា* **អហោសឺ ឆុទ្ធោ អហំ អតីតមទ្ធានំ** *ក្នុងអតីតកាល ខ្ញុំមានហើយឬហ្ន៎ ព្រោះមិនទាន់ចាក់ធ្លុះនូវបច្ចយាការនោះឯង សេចក្តីសង្ស័យទាំងអស់នោះ រមែងបាត់ទៅ ប្រាសទៅ រលត់ទៅ ។ ព្រោះហេតុអ្វី ព្រោះដឹងទូទៅដល់ធម៌ មួយអន្ទើនឹងហេតុ អធិប្បាយថា ព្រោះដឹងច្បាស់ ដឹងទូទៅដល់ការចាក់ធ្លុះនូវធម៌ គឺគំនរទុក្ខទាំងមូល មានសង្ខារជាដើមនេះ មួយអន្ទើដោយហេតុ មានអវិជ្ជាជាដើម ។*

កាលណាពោធិបក្ខិយធម៌ ឬចតុសច្ចធម៌ប្រាកដឡើង ឬជាក់ច្បាស់ដល់ព្រាហ្មណ៍នោះ ក្នុងវិបស្សនាញាណ និងមគ្គញ្ញាណ ។ ក្នុងញាណ ២ យ៉ាងនោះ គប្បីជ្រាបវិបស្សនាញាណមុន ។ ធម៌ទាំងឡាយ មានសតិជាដើម ដែលសម្បយុត្តដោយវិបស្សនាញាណ ហើយវិបស្សនាញាណ ការលះសុភសញ្ញាជាដើម ដោយអំណាចតទង្គប្បហាន ក្នុងអារម្មណ៍របស់ខ្លួន ទើបកើតឡើងជាចំណែកៗ ដោយអនុបស្សនា មានកាយានុបស្សនាជាដើម ។ តែក្នុងខណៈមគ្គ ធម៌ទាំងនោះ កាលទាញយកព្រះនិព្វាន និងធម៌ដែលជាបដិបក្ខ ដោយសមុច្ឆេទប្បហាន កើតឡើងតែម្តងប៉ុណ្ណោះ សម្រេចការចាក់ធ្លុះ

មិនវង្វេងក្នុងអរិយសច្ចទាំង៤ ។ ក្នុងសេចក្តីនេះគប្បីជ្រាបថា ពោធិបក្ខិយធម៌ ប្រាកដដោយអត្ថថា កើតឡើង ដោយប្រការដូច្នេះ ។ គប្បីជ្រាបថា អរិយ-សច្ចធម៌ ចំណែកលោកិយប្រាកដ ដោយជាអារម្មណ៍នៃវិបស្សនា ក្នុងខណៈវិបស្សនា គប្បីជ្រាបថា អរិយសច្ចធម៌ចំណែកលោកុត្តរប្រាកដ ដោយភាវៈដែលបង្អោនទៅក្នុងលោកុត្តរធម៌នោះ គប្បីជ្រាបថា និរោធសច្ចប្រាកដ ដោយការត្រាស់ដឹងអារម្មណ៍ក្នុងខណៈមគ្គ និងគប្បីជ្រាបថា ទាំងអស់ប្រាកដ ដោយអត្ថថា ជាក់ច្បាស់ ប្រាកដច្បាស់ ដោយការត្រាស់ដឹងកិច្ច ។

ដូច្នោះ ព្រះមានព្រះភាគ កាលធម៌ទាំងអស់ប្រាកដដល់ព្រះញាណ របស់ព្រះអង្គ ដោយអាការទាំងពួង ទ្រង់ពិចារណាបច្ចយាការនោះ ព្រោះ បច្ចយាការ ជាសភាវៈល្អិតជ្រាលជ្រៅ ដែលយើញបានលំបាក ព្រោះទ្រង់ ធ្វើការចងចិត្តក្នុងវិបស្សនាដោយមុខ គឺបដិច្ចសមុប្បាទ ទ្រង់កើតសោមនស្ស ដ៏ខ្លាំងក្លា ទើបទ្រង់បន្ទឺឧទានក្នុងសេចក្តីនេះ សម្តែងដល់អានុភាពនៃការ ត្រាស់ដឹងព្រម នូវបច្ចយាការរបស់ព្រះអង្គនោះ ដោយជាបច្ច័យ កាត់នូវ បដិបក្ខធម៌ជាសមុច្ឆេទ ។

ព្រះបាលីថា **អយម្ឯ ឧទានោ វុត្តោ ភគវតា ឥតិ មេ សុតំ** នេះ ប្រាកដក្នុងគម្ពីរក្នុងទីខ្លះប៉ុណ្ណោះ ។ បណ្តាបទទាំងនោះ **ឯ** សព្ទ ក្នុងបទថា **អយម្ឯ** ជាសម្បិណ្ឌនត្ថ ដូចក្នុងប្រយោគថា **ឥទម្ឯ ពុទ្ធេ រតនំ បណីតំ អយម្ឯ ទារាជិកោ ហោតិ** នេះ ជារតនៈដ៏ប្រណីតក្នុងព្រះពុទ្ធ ភិក្ខុនេះ ត្រូវអាបត្តិបារាជិក ។ ព្រោះហេតុនោះ **ឯ** សព្ទនោះ រមែងប្រមូលពាក្យមុនៗ

មក **វុត្ត** *សព្ទ ក្នុងពាក្យថា* **វុត្តោ** *នេះ ប្រាកដក្នុងពាក្យជាដើមថា* **កេសោហារណា ១ វបន ១ វាបសមីករណា ១ ជីវិតវុត្តិ ១ បមុត្តភាវ ១ ចារបនភាវេនបវត្តិត ១ អជ្ឈេន ១ កថន ១ ។**

ពិតហើយ **វុត្ត** *សព្ទនោះ មកក្នុង* **កេសោហារណា** *គឺការកោរសក់ ដូចក្នុងប្រយោគជាដើមថា* **កាបទិកោ នាម មាណវោ ឧហារេ វុត្តសិរោ** *មាណពកំលោះម្នាក់ ឈ្មោះកាបទិក: មានក្បាលកោរ ១ ដូច្នេះ ។ មកក្នុង* **វបន** *គឺការព្រោះពូជ ដូចក្នុងប្រយោគជាដើមថា*

គាវោ តស្ស បជាយន្តិ ខេត្តេ វុត្តំ វិរូហតិ
វុត្តានំ ផលមស្នាតិ យោ មិត្តានំ ន ទុព្ភតិ ។

បុគ្គលណា មិនប្រទូស្តមិត្តទាំងឡាយ គោទាំងឡាយរបស់បុគ្គលនោះ សម្រាលកូនដោយស្រួល ពូជដែលបុគ្គលនោះ សាបព្រោះក្នុងស្រែ រមែងដុះដាល បុគ្គលនោះរមែងបរិភោគផ្លែនៃពូជទាំងឡាយ ដែលខ្លួនសាបព្រោះហើយ ។

មកក្នុង **វាបសមីករណា** *គឺការធ្វើពូជដែលព្រោះឲ្យស្មើគ្នា ដោយប្រើរនាស់ជាដើម ក្នុងប្រយោគជាដើមថា* **នោ ច នោ បដិវុត្តំ** *ពូជដែលព្រោះមិនស្មើគ្នា ដូច្នេះ ។ មកក្នុង* **ជីវិតវុត្តិ** *គឺការចិញ្ចឹមជីវិត ដូចក្នុងប្រយោគជាដើមថា* **បណ្ណាលោមោ បរទត្តវុត្តោ មិគភូតេន ចេតសា វិហរាមិ** *ជាមនុស្សសម្ថបភោម ចិញ្ចឹមជីវិតដោយចតុប្បច្ចយ ដែលបុគ្គលដទៃឲ្យ មានចិត្តដូចជាពួកសត្វម្រឹគ ដូច្នេះ ។ មកក្នុង* **បមុត្តភាវ** *គឺការជ្រុះចាកទន*

ដូចក្នុងប្រយោគជាដើមថា **បណ្ឌុបលាសោ ពន្ធនា បវុត្តោ អភព្វោ ហរិតត្តាយ** *ធម្មតាស្លឹកឈើទុំដែលជ្រុះចាកទងហើយ មិនអាចត្រឡប់ទៅជាមានពណ៌ខៀវវិញបាន ដូច្នេះ ។ មកក្នុង* **ចារចនភាវេនបវត្តិត** *គឺការប្រព្រឹត្តទៅដោយជ្រាប់តគ្នា ដូចក្នុងប្រយោគជាដើមថា* **តីតំ បវុត្តំ សមិហិតំ** *ដែលពួកឥសីណាបាន (ស្វាធ្យាយ) មកហើយ បានសូធ្យមកហើយ បានសន្សំមកច្រើនហើយ ។ មកក្នុង* **អជ្ឈេន** *គឺការអញ្ជើញ ដូចក្នុងប្រយោគជាដើមថា* **វុត្តោ គុណោ វុត្តោ បរាយនោ** *ការអញ្ជើញជាគុណ ការអញ្ជើញជាការវិនាស ។ មកក្នុង* **កថន** *គឺការពោល ដូចក្នុងប្រយោគជាដើមថា* **វុត្តំ ខោ បនេតំ ភគវតា ធម្មបាយាធា មេ ភិក្ខវេ ភវថ មា អាមិសបាយាធ** *ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងកាលឥឡូវនេះ អ្នកទាំងឡាយ ចូរយកធម៌របស់តថាគត ជាមតិក កុំយកអាមិសជាមតិកឡើយ ។ ក្នុងទីនេះ គប្បីឃើញថា* **វុត្ត** *សព្ទ ប្រើក្នុងការពោលប៉ុណ្ណោះ អធិប្បាយថា ត្រាស់ឧទាននេះដោយព្រះតម្រាស់នោះ សព្ទថា* **ឥតិ** *ស្មើគ្នានឹង* **វាំ ។** *អត្ថនៃបទទាំង ២ ថា* **មេ សុតំ** *បានពោលក្នុងអដ្ឋកថានិទាន ដោយអាការទាំងពួងនោះឯង ។ ពិតហើយក្នុងកាលមុន អត្ថទាំង ២ នៃបទថា* **វាម្មេ សុតំ** *បានពោលដោយអំណាច*

ពាក្យផ្តើម ក្នុងទីនេះ ពោលទៀតថា **ឥតិ មេ សុតំ** *ដោយអំណាចពាក្យចុងក្រោយ ។ ពោលត្រួតជល់អត្ថដែលពោលហើយនោះឯង ឈ្មោះថា* **និគមៈ** *គឺពាក្យចុងក្រោយ ។ ការលើកអត្ថនៃ* **ឥតិ** *សព្ទ ដូចក្នុងពាក្យថា* **ឯវម្មេ សុតំ** *នេះ ព្រោះ* **ឥតិ** *សព្ទ មានអត្ថស្មើដោយ* **ឯវំ** *សព្ទ និងការប្រកបសេចក្តីនៃ* **ឥតិ** *សព្ទ ខ្ញុំប្រកាសហើយ ក្នុងឥតិវុត្តកវណ្ណនានោះឯង ព្រោះហេតុនោះ គប្បីជ្រាបដោយនយតាមដែលពោលហើយ ក្នុងអដ្ឋកថានោះចុះ ដូច្នេះ ៗ*

អដ្ឋកថា បឋមពោធិសូត្រ ចប់

សុត្តន្តបិដក

ឧតិយពោធិសូត្រ

[៣៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គ្រាស់ដីងជាដំបូង ទ្រង់គង់នៅក្បែរគល់ពោធិព្រឹក្ស ទៀបឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ដោយបល្ល័ង្កតែមួយ សោយវិមុត្តិសុខអស់មួយសប្តាហ៍ ។ លុះអំណើះសប្តាហ៍នោះហើយ ទើបព្រះមានព្រះភាគ ទ្រង់ចេញអំពីសមាធិនោះ ហើយទ្រង់រឭកក្នុងព្រះហឫទ័យចំពោះបដិច្ចសមុប្បាទធម៌ ជាបដិលោម គឺពិចារណាច្រាសឡើងអស់មជ្ឈិមយាមនៃរាត្រី ដោយប្រពៃថា កាលបើបច្ច័យនេះមិនមាន ផលនេះក៏មិនមាន ផលនេះរមែងរលត់ទៅ ព្រោះការរលត់ទៅនៃបច្ច័យនេះ គឺការរលត់ទៅនៃសង្ខារ ព្រោះរលត់អវិជ្ជា ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់សង្ខារ ការរលត់ទៅនៃនាមរូប ព្រោះរលត់វិញ្ញាណ ការរលត់ទៅនៃសឡាយតនៈ ព្រោះរលត់នាមរូប ការរលត់ទៅផស្សៈ ព្រោះរលត់សឡាយតនៈ ការរលត់ទៅនៃវេទនា ព្រោះរលត់ផស្សៈ ការរលត់ទៅនៃតណ្ហា ព្រោះរលត់វេទនា ការរលត់ទៅនៃឧបាទាន ព្រោះរលត់តណ្ហា ការរលត់ទៅនៃភព ព្រោះរលត់ឧបាទាន ការរលត់ទៅនៃជាតិ ព្រោះរលត់ភព ជរាមរណៈរលត់ទៅព្រម ព្រោះរលត់ជាតិ សោក បរិទេវៈ ទុក្ខ ទោមនស្ស

ឧបាយាស ក៏រមែងរលត់ សេចក្តីរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាម ញុាំងកិលេសឲ្យក្តៅ អ្នកជុតបង់កិលេស ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួង របស់ព្រាហ្មណ៍នោះ រមែងអស់ទៅក្នុងកាលនោះ ព្រោះបានដឹងច្បាស់នូវព្រះនិព្វានជាទីអស់ទៅ នៃបច្ច័យទាំងឡាយ ។ សូត្រទី ២ ។

អដ្ឋកថា

ទុតិយពោធិសូត្រ

ទុតិយពោធិសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះថា

[៣៩] បទថា **បដិលោមំ** សេចក្តីថា បច្ចយាការ មានអវិជ្ជាជាដើមដែលពោលដោយនយជាដើមថា ព្រោះអវិជ្ជារលត់ ទើបសង្ខារលត់ ដូច្នេះ កាលរលត់ដោយការរលត់ ដោយមិនកើតឡើង ទើបលោកហៅថា **បដិលោម** ព្រោះមិនធ្វើកិច្ចដែលខ្លួនគួរធ្វើ ម្យ៉ាងទៀត ឈ្មោះថា **បដិលោម** ព្រោះបញ្ឈោសប្រព្រឹត្តទៅ ព្រោះមិនពោលដល់ តាំងអំពីទីបំផុត ឬត្រង់កណ្តាល រហូតដល់ខាងដើម ក្នុងទីនេះ ភាពដែលបច្ចយាការ ជាបដិលោម ដោយសេចក្តីជំទែអំពីនេះ ទើបមិនត្រូវ ។ ម្យ៉ាងទៀត បទថា **បដិលោម** ជាការសម្តែងការវនបុំសកលិង្គ ដូចក្នុងប្រយោគជាដើមថា **វិសមំ ចន្ទិម-សុរិយា បរិវត្តន្តិ** ព្រះចន្ទ និងព្រះអាទិត្យគោចរទៅមិនស្មើ ។ បទថា **ឥមស្មឹ អសតិ ឥទំ ន ហោតិ** សេចក្តីថា កាលបច្ច័យ មានអវិជ្ជាជាដើមមិនមាន គឺត្រូវមគ្គលះហើយ ផល មានសង្ខារជាដើម ក៏មិនមាន គឺប្រព្រឹត្តទៅមិនបាន ។ បទថា **ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** សេចក្តីថា ព្រោះបច្ច័យ មានអវិជ្ជាជាដើមនេះរលត់ គឺព្រោះមគ្គឲ្យដល់នូវភាពជាធម្មជាតមិនកើតឡើងជាសភាវៈ ទើបផល មានសង្ខារជាដើមនេះ រលត់ គឺមិនប្រព្រឹត្តទៅ ។ ក្នុងសេចក្តីនេះ គប្បីជ្រាបថា លោកសម្តែងលក្ខណៈដែលកំណត់ចុះខាងក្នុងជាដើមថា កាលបច្ច័យ មានអវិជ្ជាជាដើមនេះមិនមាន ព្រោះ

បច្ចយ មានអវិជ្ជាជាដើមនេះរលត់ គឺមិនកើត ដូចលោកសម្តែងលក្ខណៈដែលកំណត់ចុះជាដើមថា កាលបច្ចយ មានអវិជ្ជាជាដើមនេះមាន គឺមិនមែនមិនមាន ព្រោះបច្ចយ គឺអវិជ្ជាជាដើមនៅកើតទ្បើង គឺមិនរលត់ ដូចក្នុងពាក្យនេះថា កាលបច្ចយ មានអវិជ្ជាជាដើមនេះមាន ផល មានសង្ខារជាដើមនេះក៏មាន ព្រោះបច្ចយ មានអវិជ្ជាជាដើមនេះកើត ផល មានសង្ខារជាដើមនេះក៏កើត ។ ក្នុងទីនេះ ពាក្យដ៏សេស ដែលគប្បីពោល គប្បីពោលតាមន័យដែលពោលក្នុងអដ្ឋកថាបឋមពោធិសូត្រ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រការដែលទ្រង់ធ្វើបដិច្ចសមុប្បាទដោយបដិលោមក្នុងព្រះហឫទ័យ ដូចពណ៌នាមក ដូច្នេះ ដោយសង្ខេបហើយ ឥឡូវនេះ ដើម្បីសម្តែងដោយពិស្តារ ទើបត្រាស់ពាក្យជាដើមថា **អវិជ្ជានិរោធា សង្ខារនិរោធោ** *ព្រោះអវិជ្ជារលត់ ទើបសង្ខាររលត់ ។*

បណ្តាបទទាំងនោះ បទថា **អវិជ្ជានិរោធា** *សេចក្តីថា ព្រោះអវិជ្ជារលត់ជាសមុច្ឆេទ ដោយអរិយមគ្គ អធិប្បាយថា ព្រោះអវិជ្ជា ត្រូវអរហត្តមគ្គដកទ្បើងបានជាសមុច្ឆេទ ដោយការប្រហារអនុសយ ។ បើអវិជ្ជា កាលត្រូវមគ្គខាងក្រោមលះបាន រមែងលះបានចំពោះ ដោយអំណាចដកទ្បើងបានដោយចំណែកមួយក៏ពិត តែក៏លះមិនបានជាសមុច្ឆេទ ។ អវិជ្ជាដែលនាំសត្វទៅកាន់អបាយ ត្រូវបឋមមគ្គលះបាន អវិជ្ជាដែលជាបច្ចយឲ្យកើតក្នុងលោកនេះនិងក្នុងភូមិដែលមិនមែនរបស់ព្រះអរិយៈទាំងអស់ ដែលមគ្គទី ២-៣ លះបានតាមលំដាប់ មិនមែនលះកិលេសក្រៅអំពីនេះបានទេ ។ ពិតហើយ អវិជ្ជា*

នោះ អរហត្តមគ្គប៉ុណ្ណោះ លះបានជាសមុច្ឆេទ ។ បទថា **សង្ខារនិរោធោ** *សេចក្តីថា រមែងរលត់ ដោយសង្ខារមិនកើតឡើង ។ ដើម្បីសម្តែងថា ព្រោះសង្ខាររលត់ទៅយ៉ាងនេះ ទើបវិញ្ញាណរលត់ និងព្រោះវិញ្ញាណជាដើមរលត់ នាមរូបជាដើមក៏រលត់ដូចគ្នា ទើបលោកពោលពាក្យជាដើមថា ព្រោះសង្ខាររលត់ ទើបវិញ្ញាណរលត់ ហើយពោលថា គំនរទុក្ខទាំងអស់នេះ រមែងរលត់ទៅ ដោយប្រការដូច្នេះ ។ ក្នុងពាក្យទាំងនោះ ពាក្យដែលគួរពោល មានន័យដូចពោលហើយខាងដើមនោះឯង ។*

ម្យ៉ាងទៀត ក្នុងទីនេះ ព្រោះអវិជ្ជារលត់ ទើបសង្ខាររលត់ ព្រោះសង្ខាររលត់ ទើបវិញ្ញាណរលត់ ព្រោះដូច្នោះ ទើបជាការពោលគំនរទុក្ខទាំងអស់រលត់ទៅដោយឥតសេសសល់ ដោយហេតុមានប្រមាណប៉ុណ្ណោះក៏ពិត ទោះជាដូច្នោះ ដើម្បីសម្តែងសេចក្តីនេះ ក្នុងអនុលោមថា បច្ចុប្បន្នធម៌ណាមួយដែលមិនទាន់រលត់ទៅ គឺនៅប្រព្រឹត្តទៅ ព្រោះបច្ចយធម៌ណាមួយមាន ទើបលោកពោលថា **អវិជ្ជាបច្ចយា សង្ខារា ។បេ។ សមុទយោ ហោតិ** *ដូច្នេះយ៉ាងណា ដើម្បីសម្តែងថា បច្ចុប្បន្នធម៌នោះៗ រមែងរលត់ គឺមិនប្រព្រឹត្តទៅ ព្រោះបច្ចយធម៌នោះៗ មិនមាន ដោយជាបដិបក្ខចំពោះបច្ចុប្បន្នធម៌នោះ ទើបលោកពោលក្នុងទីនេះថា* **អវិជ្ជានិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ វិញ្ញាណនិរោធា នាមរូបនិរោធោ ។បេ។ ទុក្ខក្ខន្ធស្ស-និរោធោ ហោតិ** *ដូច្នេះ ។ តែមិនបានពោលដើម្បីសម្តែងការរលត់កងទុក្ខដែលទាក់ទងក្នុងកាល ៣ ដូចក្នុងអនុលោម គប្បីជ្រាបការប្លែកគ្នានេះថា*

ពិតហើយ កាលមិនមានអរិយមគ្គភាវនា នៃកងទុក្ខដែលជាអនាគត លោកបំណងយកការរលត់កងទុក្ខដែលគួរនឹងកើត ដោយអរិយមគ្គភាវនា ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ជីងអត្តនេះដែលលោកពោលថា កងទុក្ខ មានសង្ខារជាដើមរមែងរលត់ដោយអំណាចអវិជ្ជារលត់ជាដើម ដោយអាការទាំងពួង ។ បទថា* **ឥមំ ឧទានំ ឧទានេសិ** *សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ដែលសម្តែងអានុភាពនៃការឈមចុះក្នុងការអស់បច្ច័យ មានអវិជ្ជាជាដើម ដែលប្រកាសយ៉ាងនេះថា ព្រោះអវិជ្ជារលត់ ទើបសង្ខារលត់ ក្នុងកាលជីងច្បាស់អត្តនោះ ។*

ក្នុងសេចក្តីនោះ មានសេចក្តីសង្ខេបដូចតទៅនេះថា ព្រោះហេតុដែលទ្រង់ជីងច្បាស់ទូទៅ ចាក់ធ្លុះនូវការអស់ទៅ ពោល គឺការរលត់មិនកើតឡើងនៃបច្ចយធម៌ មានអវិជ្ជាជាដើម ដូច្នោះ ពោធិបក្ខិយធម៌ ឬចតុសច្ចធម៌ មានប្រការដូចពោលហើយ ប្រាកដកើតឡើង ឬជាក់ច្បាស់ដល់ព្រាហ្មណ៍នោះ ដែលមានព្យាយាមសម្ងីង ដោយនយដូចពោលហើយ ពេលនោះ ការសង្ស័យ មានប្រភេទដូចពោលហើយក្នុងកាលមុន គប្បីកើតឡើង ព្រោះមិនជីងច្បាស់នូវការរលត់បច្ច័យ ដោយប្រពៃ ទាំងអស់នោះ រមែងបាត់ទៅ គឺរលត់ទៅ ។ ពាក្យជ័សេស មានន័យដូចពោលហើយខាងដើមនោះឯង ॥

អដ្ឋកថាឧទានិយពោធិសូត្រ ចប់

សុត្តន្តបិដក

តតិយពោធិសូត្រ

[៤០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ បានគ្រាស់ដីងជាដំបូង ទ្រង់គង់នៅក្បែរគល់ពោធិព្រឹក្ស ទៀបឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ដោយបល្ល័ង្កតែមួយ សោយវិមុត្តិសុខ អស់មួយសប្តាហ៍ ។ លុះអំណើះសប្តាហ៍នោះហើយ ទើបព្រះមានព្រះភាគ ទ្រង់ចេញអំពីសមាធិនោះ ហើយទ្រង់រំពឹងក្នុងព្រះហឫទ័យ ចំពោះបដិច្ចសមុប្បាទធម៌ ជាអនុលោម និងបដិលោម អស់រាត្រីបច្ឆិមយាម ដោយប្រពៃថា កាលបើបច្ច័យនេះមានផលនេះក៏មាន ផលនេះ រមែងកើតឡើង ព្រោះកើតឡើងនៃបច្ច័យនេះ កាលបើបច្ច័យនេះមិនមាន ផលនេះក៏មិនមាន ផលនេះរលត់ទៅ ព្រោះរលត់ទៅនៃបច្ច័យនេះ គឺសង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរា-មរណៈកើតមានព្រម ព្រោះជាតិជាបច្ច័យ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាស ក៏រមែងកើតមាន ។ ការកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែង

មានយ៉ាងនេះឯង ។ ការរលត់ទៅនៃសង្ខារ ព្រោះរលត់អវិជ្ជាឥតមានសេសសល់ ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់សង្ខារ ការរលត់ទៅនៃនាមរូប ព្រោះរលត់វិញ្ញាណ ការរលត់ទៅនៃសឡាយតនៈ ព្រោះរលត់នាមរូប ការរលត់ទៅនៃផស្សៈ ព្រោះរលត់សឡាយតនៈ ការរលត់ទៅនៃវេទនា ព្រោះរលត់ផស្សៈ ការរលត់ទៅនៃតណ្ហា ព្រោះរលត់វេទនា ការរលត់ទៅនៃឧបាទាន ព្រោះរលត់តណ្ហា ការរលត់ទៅនៃភព ព្រោះរលត់ឧបាទាន ការរលត់ទៅនៃជាតិ ព្រោះរលត់ភព ជរាមរណៈរលត់ព្រម ព្រោះរលត់ជាតិ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាស ក៏រមែងរលត់ទៅ ។ សេចក្តីរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះឯង ។ លុះព្រះមានព្រះភាគជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបបន្ទឺនូវឧទាននេះ ក្នុងវេលានោះថា

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាមញុាំងកិលេសឲ្យក្តៅ អ្នកជុតបង់នូវកិលេស ក្នុងកាលណា ព្រាហ្មណ៍នោះ រមែងកម្ចាត់បង់នូវមារ ព្រមទាំងសេនាមារ ស្ថិតនៅក្នុងកាលនោះ បីដូចព្រះអាទិត្យរះឡើង ធ្វើអាកាសឲ្យរុងរឿង ដោយរស្មីរបស់ខ្លួន កម្ចាត់បង់នូវឥន្ធឺត ស្ថិតនៅ ដូច្នោះឯង ។ សូត្រទី ៣ ។

អដ្ឋកថា

តតិយពោធិសូត្រ

តតិយពោធិសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

[៤០] បទថា **អនុលោមបដិលោមំ** បានដល់ អនុលោម និង បដិលោម អធិប្បាយថា ដោយអំណាចអនុលោមតាមដែលពោលហើយ និងដោយអំណាចបដិលោម ។ មានពាក្យសួរថា លោកពោលការប្រព្រឹត្ត ទៅរបស់មនសិការ ក្នុងបដិច្ចសមុប្បាទក្នុងសូត្រទាំង ២ ដោយអនុលោម និងបដិលោមក្នុងកាលមុនមិនមែនឬ ព្រោះហេតុអ្វី ក្នុងទីនេះ ទើបលោក ពោលការប្រព្រឹត្តទៅរបស់មនសិការ ដោយអំណាចសូត្រនោះទៀត ។ ឆ្លើយ ថា ព្រោះប្រកាសមនសិការក្នុងបដិច្ចសមុប្បាទដល់វារៈទី ៣ ដោយអំណាច សូត្រទាំង ២ នោះ ។ សួរថា លោកប្រកាសមនសិការដោយសូត្រទាំង ២ ដូចម្តេច ព្រោះអ្នកណាម្នាក់ មិនអាចប្រកាសមនសិការបដិច្ចសមុប្បាទដោយ អនុលោម និងបដិលោម មិនមុន មិនក្រោយ ។ ឆ្លើយថា សេចក្តីនោះ មិនគប្បីឃើញយ៉ាងនោះថា ទ្រង់មនសិការដល់អនុលោម និងបដិលោមទាំង ២ នោះរួមគ្នា ដោយពិត ទ្រង់មនសិការជាវារៈ ។ ពិតហើយ ព្រះមាន ព្រះភាគ ទ្រង់មនសិការដល់បដិច្ចសមុប្បាទដោយអនុលោមមុន ហើយទ្រង់ បន្ទឹ្ធនដំបូង ដែលសមគួរដល់មនសិការនោះ ។ គ្រាទី ២ ទ្រង់មនសិការ ដល់បដិច្ចសមុប្បាទនោះដោយបដិលោម ហើយទ្រង់បន្ទឹ្ធនដែលសមគួរ ដល់មនសិការនោះដូចគ្នា ។ ឯគ្រាទី ៣ ទ្រង់មនសិការដល់អនុលោម

បដិលោម ដោយអំណាចមនសិការ ជាអនុលោមដោយកាល ជាបដិលោម ដោយកាល ។ ដោយហេតុនោះ ទើបលោកពោលថា បទថា **អនុលោម-បដិលោមំ** *បានដល់ អនុលោម និងបដិលោម ដោយអំណាចអនុលោម បដិលោម តាមដែលពោលហើយ ។ ដោយពាក្យនេះ ជាការប្រកាសតាមដែលមនសិការស្តាត់ជំនាញមានកម្លាំង និងភាពជំនាញ ។ តែក្នុងទីនេះ គប្បីជ្រាបវិភាគនៃអនុលោម និងបដិលោមទាំងនោះ ដោយអំណាចចំណែកខាងដើមដែលប្រព្រឹត្តទៅយ៉ាងនេះថា តថាគតមនសិការដល់អនុលោម មនសិការដល់បដិលោម មនសិការដល់អនុលោមបដិលោម ។*

បណ្តាបទទាំងនោះ បទថា **អវិជ្ជាយត្វេវ** *កាត់បទជា* **អវិជ្ជាយ តុ ឯវ** *បទថា* **អសេសវិរាគនិរោធា** *បានដល់ ព្រោះរលត់ដោយមិនសេសសល់ ដោយមគ្គ ពោល គឺវិរាគធម៌ អធិប្បាយថា ជាការលះដោយមិនកើតឡើង ដោយអរហត្តមគ្គដោយឥតសេសសល់ ។ បទថា* **សង្ខារនិរោធោ** *បានដល់ រលត់សង្ខារទាំងពួង ដោយមិនកើតឡើង ដោយឥតសេសសល់ ។ ពិតហើយ សង្ខារពួកខ្លះរលត់ដោយមគ្គ ៣ ខាងក្រោម ពួកខ្លះមិនរលត់ ព្រោះអវិជ្ជារលត់នៅមានចំណែកសេសសល់ ។ តែសង្ខារពួកខ្លះ មិនរលត់មិនមាន ព្រោះអរហត្តមគ្គ រំលត់អវិជ្ជាមិនឲ្យសេសសល់ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ជីងច្បាស់នូវអត្ថនេះ ដោយអាការទាំងពួង ដែលលោកពោលដោយអំណាចអវិជ្ជាជាដើម កងទុក្ខ មានសង្ខារជាដើមកើត ព្រោះអវិជ្ជាជាដើមកើត កងទុក្ខ មានសង្ខារជាដើមរលត់ ព្រោះ*

អវិជ្ជាជាដើមរលត់ ។ បទថា **ឥមំ ឧឆានំ ឧឆានេសិ** *សេចក្តីថា ទ្រង់បន្ទឹ ឧទាននេះ មានប្រការដូចពោលហើយ ដែលសម្តែងអានុភាពអរិយមគ្គនោះ ដែលជាហេតុឲ្យដឹងច្បាស់ដល់អត្ថ ពោល គឺការកើត និងការរលត់កងទុក្ខ ដោយអំណាចកិច្ច និងការធ្វើឲ្យជាអារម្មណ៍ ។*

ក្នុងសេចក្តីនោះ មានសេចក្តីសង្ខេបដូចតទៅនេះ កាលណា ធម៌ទាំង-ទ្បាយប្រាកដដល់ព្រាហ្មណ៍ ជាអ្នកមានព្យាយាមសម្លឹង កាលនោះ ព្រាហ្មណ៍នោះ រមែងកម្ចាត់នូវមារ និងសេនាមារចេញបាន ដោយពោធិបក្ខិយធម៌ ដែលកើតឡើងទាំងនោះ ឬដោយអរិយមគ្គ ដែលជាហេតុប្រាកដនៃចតុ-សច្ចធម៌ ។ បទថា **វិធូបយំ តិដ្ឋតិ មារសេនំ** *សេចក្តីថា កម្ចាត់ ធ្វើឲ្យវិនាស ទម្លាយមារ មួយអន្ទើដោយសេនា មានប្រការដូចពោលហើយ ដោយនយជាដើមថា កាមទាំងនោះ ជាកងទ័ពទី ១ តាំងនៅ ។ សួរថា សេចក្តីនេះដូចម្តេច ។ ឆ្លើយថា ដូចព្រះអាទិត្យធ្វើអាកាសឲ្យភ្លឺ អធិប្បាយថា ព្រះអាទិត្យគោចរឡើង ធ្វើអាកាសឲ្យភ្លឺដោយរស្មីរបស់ខ្លួន ហើយកម្ចាត់ងងឹត គោចរទៅ យ៉ាងណា ព្រាហ្មណ៍ដែលជាខីណាស្រព ក៏ដូច្នោះ ចាក់ផ្ទុះនូវសច្ចធម៌ ដោយធម៌ទាំងនោះ ឬដោយមគ្គនោះ ឈ្មោះថា កម្ចាត់មារ និងសេនាចេញបាន ។*

ក្នុងយាមទាំង ៣ ព្រះមានព្រះភាគត្រាស់ឧទានទាំង ៣ នេះ ដែលប្រកាសអានុភាពនៃការដឹងច្បាស់ នូវបច្ចយាការ ក្នុងយាមទី ១ ការសម្រេចនូវការអស់បច្ច័យក្នុងយាមទី ២ និងការសម្រេចអរិយមគ្គ ក្នុងយាមទី ៣ ដោយ

ប្រការដូច្នេះ ។ សួរថា ក្នុងរាត្រីណា ។ ឆ្លើយថា ក្នុងរាត្រីទី ៧ នៃការត្រាស់ដឹងអភិសម្ពោធិញ្ញាណ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់រឭកដល់បុព្វ-និវាសញ្ញាណក្នុងយាមដើមនៃរាត្រីវិសាខបុណ្ណមី ទ្រង់ជម្រះទិព្វចក្ខុញ្ញាណក្នុងមជ្ឈិមយាម ទ្រង់ញុំាងព្រះញាណចុះក្នុងបដិច្ចសមុប្បាទ ក្នុងបច្ឆិមយាម ទ្រង់ពិចារណាសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយនយផ្សេងៗ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ អរុណនឹងរះឡើង ក៏បានសម្រេចព្រះសម្មាសម្ពោធិញ្ញាណ ។ ក្នុងលំដាប់ដែលកើតព្រះសព្វញ្ញុតញ្ញាណ អរុណក៏រះឡើង ។ គ្រានោះ ទ្រង់នៅបង្គងមួយសប្តាហ៍នាមណ្ឌលពោធិព្រឹក្ស ដោយភ្នែនមួយនោះឯង កាលដល់រាត្រីនៃបាដិបទ គឺថ្ងៃ ១ រោច ទ្រង់ធ្វើមនសិការដល់បដិច្ចសមុប្បាទ ដោយនយដែលពោលហើយ ក្នុងយាមទាំង ៣ ហើយទ្រង់បន្ទឺឧទាននេះ តាមលំដាប់ ។

តែព្រោះមកក្នុងខន្ធកៈទាំង ៣ វារៈថា ទ្រង់មនសិការដល់បដិច្ចសមុប្បាទជាអនុលោម បដិលោម ទើបលោកពោលក្នុងអដ្ឋកថាខន្ធកៈថា ព្រះមានព្រះភាគទ្រង់ធ្វើមនសិការយ៉ាងនេះក្នុងយាមទាំង ៣ ហើយទ្រង់បន្ទឺឧទានទាំងនេះ យ៉ាងនេះ គឺឧទានទី ១ ដោយអំណាចពិចារណាបច្ចយាការ ឧទានទី ២ ដោយអំណាចពិចារណាព្រះនិព្វាន ឧទានទី ៣ ដោយអំណាចការពិចារណា

មគ្គ ។ ពាក្យនោះ ក៏មិនខុស ។

ពិតហើយ ព្រះមានព្រះភាគ ទ្រង់ពិចារណាធម៌ក្នុងរវាងខាងក្នុងសប្តាហ៍ទាំង ៦ ដ៏សេស រៀរសប្តាហ៍ដែលប្រថាប់នៅត្រង់រតនឃរចេតិយ ដោយច្រើន ទ្រង់សោយវិមុត្តិសុខ ។ តែក្នុងសប្តាហ៍ដែលប្រថាប់ក្នុងរតនឃរចេតិយ ទ្រង់នៅប្រថាប់ដោយការពិចារណាព្រះអភិធម្មប៉ុណ្ណោះឯង ។

តតិយពោធិសូត្រ ចប់

សុត្តន្តបិដក

ហុំហុំកសូត្រ

[៤១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គ្រាស់ដីងជាដំបូង ទ្រង់គង់នៅក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរាក្នុងឧរុវេលាប្រទេស ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅដោយបល្ល័ង្កតែមួយ សោយវិមុត្តិសុខអស់មួយសប្តាហ៍ ។ លុះកន្លងសប្តាហ៍នោះហើយ ទើបព្រះមានព្រះភាគ ទ្រង់ចេញអំពីសមាធិនោះ ។ គ្រានោះ ព្រាហ្មណ៍ម្នាក់ ជាហុំហុំកជាតិកៈ (មានជាតិជាអ្នកធ្វើសំឡេងគំរាមថា ហុំ ហុំ) ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួរឫកហើយ ក៏ស្ថិតក្នុងទីសមគួរ ។ លុះព្រាហ្មណ៍នោះ ស្ថិតនៅក្នុងទីសមគួរហើយ ក៏ទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលដែលហៅថា ព្រាហ្មណ៍ ដោយហេតុដូចម្តេច មួយទៀត ធម៌អ្វីខ្លះ សម្រាប់ធ្វើបុគ្គលឲ្យជាព្រាហ្មណ៍ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវបញ្ហានុ៎ះហើយ ទើបបន្ទឺនូវឧទាននេះ ក្នុងវេលានោះថា

> ព្រាហ្មណ៍ណា មានបាបធម៌បរិបូណ៌តចោលហើយ មានសំឡេងគំរាមថា ហុំហុំ លះចោលហើយ មានទឹកចត់ គឺរាគាទិក្កិលេសលះចោលហើយ មានចិត្តសង្រួមហើយ ចេះចប់នូវវេទ គឺមគ្គញ្ញាណទាំង ៤ មានមគ្គព្រហ្មចរិយធម៌អប់រំហើយ មួយ

ទៀត ព្រាហ្មណ៍ណា មិនមានគំនរ គឺរាគាទិក្កិលេស ក្នុង អារម្មណ៍បន្តិចបន្តួច ក្នុងលោកសន្និវាស ព្រាហ្មណ៍នោះ ទើប គួរនឹងហៅខ្លួនថាជាព្រាហ្មណ៍ ដោយធម៌បាន ។ សូត្រទី ៤ ។

អដ្ឋកថា

ហុំហុំកសូត្រ

ហុំហុំកសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

[៤១] បទថា **អជ្ឌាលនិគ្រោធេ** សេចក្តីថា បានឣថា អ្នកចិញ្ចឹមពពែ ទាំងឡាយ បានទៅអង្គុយត្រង់ម្លប់ដើមជ្រៃនោះ ព្រោះដូច្នោះ ទើបដើមជ្រៃ នោះ ឈ្មោះថា អជបាលនិគ្រោធនោះឯង ។ តែអាចារ្យពួកខ្លះ ពោលថា ព្រោះបុរាណព្រាហ្មណ៍ មិនអាចទនេ្ទញវេទទាំងឡាយក្នុងទីនោះបាន ទើបធ្វើ ទីអាស្រ័យនៅ ដែលប្រកបដោយរបង ហើយនាំគ្នានៅ ដូច្នោះ ទើបដើម ឈើនោះ បានឈ្មោះថា អជបាលនិគ្រោធ ។ ក្នុងសេចក្តីនោះ មានវចនត្ថ: ដូចតទៅនេះថា ឈ្មោះថា **អជ្ឌា** ព្រោះរាយមន្តមិនបាន អធិប្បាយថា ស្វាធ្យាយមន្តមិនបាន ។ ឈ្មោះថា **អជ្ឌាល** ព្រោះជាទីកាន់ គឺស្នាក់ អាស្រ័យនៅរបស់អ្នករាយមន្តមិនបាន អាចារ្យពួកខ្លះពោលថា ព្រោះដើម ឈើនោះ បិទបាំងរក្សាពួកពពែ ដែលចូលទៅនៅក្នុងពេលថ្ងៃត្រង់ ដោយ

ម្ចប់របស់ខ្លួន ដូច្នោះ ទើបបានឈ្មោះថា **អជបាល** *គឺដើមឈើរក្សាពពែ ។ ន៎ុះជាឈ្មោះរបស់ដើមឈើនោះគ្រប់ឈ្មោះ ។ ត្រង់ទីជិតដើមឈើនោះ ។ ពិតហើយ បទថា* **អជបាលនិគ្រោធេ** *នេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ។*

បទថា **វិមុត្តិសុខំ បដិសំវេទី** *សេចក្តីថា កាលទ្រង់ពិចារណាធម៌ត្រង់អជបាលនិគ្រោធនោះ គង់ប្រថាប់សោយវិមុត្តិសុខ ។ ដើមឈើនោះ នៅខាងកើតនៃពោធិព្រឹក្ស ។ បទថា* **សត្តាហំ** *នេះ មិនមែនសប្តាហ៍ជាប់នឹងសប្តាហ៍ដែលទ្រង់គង់ពត់ព្រះភ្នែននោះទេ ។ ពិតហើយ ព្រះមានព្រះភាគទ្រង់សម្ងំនៅក្នុងទីជិតពោធិព្រឹក្សនោះឯង អស់ ៣ សប្តាហ៍ ខាងក្រៅសប្តាហ៍ដែលទ្រង់ពត់ព្រះភ្នែន ។ ក្នុងសេចក្តីនោះ មានអនុបុព្វីកថាដូចតទៅនេះ*

បានឮថា ព្រះមានព្រះភាគ ទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណហើយ ប្រថាប់គង់ពត់ភ្នែនអស់មួយសប្តាហ៍ ពួកទេវតាកើតសេចក្តីសង្វ័យឡើងថា ព្រះមានព្រះភាគទ្រង់មិនយាងចេញ ធម៌ដែលធ្វើភាពជាព្រះពុទ្ធដទៃ នៅមានទៀតឬហ្ន៎ ។ ក្នុងថ្ងៃទី ៨ ព្រះមានព្រះភាគ ទ្រង់ចេញអំពីសមាបត្តិ ទ្រង់ជ្រាបការសង្វ័យរបស់ទេវតា ទើបហោះទៅកាន់អាកាសដើម្បីកម្ចាត់សេចក្តីសង្វ័យនៃទេវតាទាំងនោះ ហើយសម្តែងយមកប្បាដិហារ្យ ប្រថាប់ឈរត្រង់ទិសឧត្តរ ឆៀងទៅទិសខាងកើត ឆៀងនឹងបល្ល័ង្ក ទ្រង់បើកព្រះនេត្រមើលបល្ល័ង្ក និងពោធិព្រឹក្ស ដែលជាទីសម្រេចផលនៃព្រះបារមី ដែលទ្រង់សន្សំមកអស់ ៤ អសង្ខ្យេយ្យ និង ១ សែនកប្ប ទ្រង់គង់នៅអស់មួយសប្តាហ៍ ទើបទីនោះឯង បានឈ្មោះថា **អនិមិសចេតិយ** ។ *គ្រានោះ ព្រះ*

មានព្រះភាគ ទ្រង់ចង្ក្រមត្រង់រតនចង្ក្រម ដែលកាត់អំពីទិសខាងកើត ទៅទិសខាងលិច ចន្លោះពោធិបល្ល័ង្ក និងទីប្រថាប់ឈរនោះ ទ្រង់ចង្ក្រមអស់មួយសប្តាហ៍ ទើបទីនោះ ឈ្មោះថា **រតនចង្កមចេតិយ។** *ត្រង់ទិសខាងលិចអំពីទីនោះ ទេវតានិម្មិតផ្ទះកែវ ទ្រង់ប្រថាប់គង់ពត់ភ្នែនក្នុងផ្ទះកែវនោះ ទ្រង់ពិចារណាអភិធម្មបិដក ដែលជាសមន្តប្បដ្ឋាន អនន្តនយដោយពិសេស ទ្រង់នៅគង់សម្ងំមួយសប្តាហ៍ ទីនោះ ឈ្មោះថា* **រតនឃរចេតិយ។** *ទ្រង់គង់សម្ងំ ៤ សប្តាហ៍ក្នុងទីជិតពោធិព្រឹក្ស ដោយអាការយ៉ាងនេះ ។ ក្នុងសប្តាហ៍ទី ៥ ទ្រង់យាងចេញអំពីពោធិព្រឹក្ស ទៅកាន់អជបាលនិគ្រោធ ទ្រង់ប្រថាប់ពត់ភ្នែន នាមណ្ឌលអជបាលនិគ្រោធនោះ ។*

បទថា **តម្ហា សមាធិម្ហា វុដ្ឋាសិ** *សេចក្តីថា ចេញចាកសមាធិ គឺផល-សមាបត្តិនោះ តាមដែលបានកំណត់ ។ កាលព្រះមានព្រះភាគ ចេញអំពីសមាបត្តិហើយ គង់ប្រថាប់ក្នុងទីនោះយ៉ាងនេះ ព្រាហ្មណ៍ម្នាក់មកអកទ្រង់ទូលសួរបញ្ហា ដោយហេតុនោះ ទើបលោកពោលពាក្យជាដើមថា* **អថខោ អញ្ញតរោ។**

បណ្តាបទទាំងនោះ បទថា **អញ្ញតរោ** *បានដល់ ព្រាហ្មណ៍ម្នាក់ មិនមានកេរ្តិ៍ឈ្មោះ មិនប្រាកដនាម និងគោត្រ ។ បទថា* **ហុំហុំកជាតិកោ** *សេចក្តីថា បានឮថា ព្រាហ្មណ៍នោះ ជាទិដ្ឋមង្គលិក មានមានះខ្លាំងក្លា ឃើញវត្តុគ្រប់យ៉ាង ដែលមានកំណើតថោកទាប ស្អប់ខ្ពើម ដើរពោល* **ហុំ ហុំ** *ដោយអំណាចមានះ និងសេចក្តីក្រោធ ។ ព្រោះដូច្នោះ ទើបគេហៅព្រាហ្មណ៍*

នោះថា **ហុំហុំកជាតិក** *ជាលីថា* **ហុហុក្កជាតិកោ** *ដូច្នេះក៏មាន ។ បទថា* **ព្រាហ្មណោ** *បានដល់ ជាព្រាហ្មណ៍ដោយកំណើត ។*

បទថា **យេន ភគវា** *សេចក្តីថា ព្រះមានព្រះភាគគង់ប្រថាប់នៅក្នុងទិសណា ។ ពាក្យថា* **យេន** *នេះ ជាតតិយាវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ ដែលទេវតា និងមនុស្សគប្បីចូលទៅគាល់ដោយទិសណា ព្រាហ្មណ៍ក៏ចូលទៅគាល់ដោយទិសនោះ ។ ម្យ៉ាងទៀត បទថា* **យេន** *ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃហេតុ អធិប្បាយថា ព្រះមានព្រះភាគ ដែលទេវតា និងមនុស្សគប្បីចូលទៅគាល់ ព្រោះហេតុណា ព្រាហ្មណ៍ក៏ចូលទៅគាល់ ព្រោះហេតុនោះ ។ ព្រោះហេតុអ្វី ទើបត្រូវចូលគាល់ព្រះមានព្រះភាគ ព្រោះទេវតា និងមនុស្សទាំងឡាយ មានចិត្តរសាប់រសល់ ព្រោះត្រូវព្យាធិ គឺកិលេសផ្សេងៗ គ្របសង្កត់ ទើបចូលទៅគាល់ព្រះមានព្រះភាគ ដោយហេតុ មានការស្តាប់ធម៌ និងសួរបញ្ហាជាដើម ដើម្បីព្យាបាលព្យាធិ គឺកិលេស ដូចពេទ្យមានអានុភាព ដែលមហាជនមានកាយរសាប់រសល់ ព្រោះត្រូវរោគ និងទុក្ខ មានប្រការផ្សេងៗ ហៀតហៀន ទើបចូលទៅរក ដើម្បីព្យាបាល ដោយហេតុនោះ ព្រាហ្មណ៍នេះបំណងនឹងកាត់សេចក្តីសង្ស័យរបស់ខ្លួន ទើបចូលទៅគាល់ ។*

បទថា **ឧបសង្កមិត្វា** *ជាបទសម្តែងចុងក្រោយនៃការចូលគាល់ ។ ម្យ៉ាងទៀត សេចក្តីថា ចូលទៅកាន់ទីជិតព្រះមានព្រះភាគ ចាកទីដែលចូលទៅគាល់ បទថា* **សម្មោទិ** *បានដល់ ត្រេកអរជានិច្ច ឬដោយប្រពៃ ។ ព្រះមានព្រះភាគ*

ទ្រង់បានត្រេកអរ ដែលព្រាហ្មណ៍ឲ្យប្រព្រឹត្តទៅ ឯព្រាហ្មណ៍វិញ ក៏ជាអ្នកត្រេកអរដែលព្រះមានព្រះភាគឲ្យប្រព្រឹត្តទៅ ដោយការធ្វើបដិសណ្ឋារៈជាដើមថា អ្នកដ៏ចម្រើន លួមអត់ធន់បានឬ លួមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានឬ ។

បទថា **សម្មោទនីយំ** *បានដល់ គួរដល់ការត្រេកអរ គឺសមគួរដល់ការឲ្យកើតការត្រេកអរ ។ បទថា* **កថំ** *បានដល់ ចរចាប្រាស្រ័យគ្នា ។ បទថា* **សារាណីយំ** *បានដល់ គួរឮក គឺដែលមនុស្សល្អគប្បីឲ្យប្រព្រឹត្តទៅ ឬគប្បីគិតក្នុងកាលដទៃ ។ បទថា* **វីតិសារេត្វា** *ប្រែថា ឲ្យសម្រេច ។ បទថា* **ឯកមន្តំ** *ជាបទសម្តែងការនៅបុំសកលិង្គ ។ អធិប្បាយថា ក្នុងទីមួយ គឺក្នុងចំណែកមួយ វៀរទោសនៃការអង្គុយ ៦ យ៉ាង មានការអង្គុយចំអំពីមុខជាដើម ។ បទថា* **ឯតទវោច** *សេចក្តីថា ព្រះមានព្រះភាគត្រាស់ពាក្យនេះ គឺពាក្យដែលគប្បីត្រាស់ក្នុងឥឡូវនេះ មានជាដើមថា* **កិត្តាវតា ឧទោ ។**

បណ្តាបទទាំងនោះ បទថា **កិត្តាវតា** *ប្រែថា ដោយប្រមាណប៉ុណ្ណា បទថា* **ឧ** *ជានិបាត ប្រើក្នុងអត្ថថា សង្ស័យ ។ បទថា* **ឱ** *ជានិបាត ប្រើក្នុងអត្ថថា ធ្វើបទឲ្យពេញ ។ បទថា* **ភោ** *ជាអាលបនៈ គឺហៅជាតិរបស់ព្រាហ្មណ៍ ។ សមដូចពាក្យដែលលោកពោលថា ព្រាហ្មណ៍នោះ ឈ្មោះថា* **ភោវាទី** *ព្រាហ្មណ៍នោះឯងជាអ្នកនៅមានកិលេសដែលជាគ្រឿងកង្វល់ ។*

ព្រាហ្មណ៍ហៅព្រះមានព្រះភាគ ដោយគោត្រថា **គោតម ។** *សួរថា ព្រោះហេតុអ្វី ព្រាហ្មណ៍នេះ ទើបតែមកដល់ ជ្រាបគោត្ររបស់ព្រះមានព្រះ*

ភាគ ។ ឆ្លើយថា ព្រាហ្មណ៍នេះ មិនមែនមកដល់ត្រឹមតែឥឡូវនេះទេ ទ្រង់យោងត្រាច់ទៅជាមួយបញ្ចវគ្គិយដែលឧបដ្ឋាក ក្នុងកាលបំពេញព្យាយាម ៦ វស្សាក្តី ក្រោយមក ទ្រង់លះវត្តនោះ ត្រាច់បិណ្ឌបាតមួយអង្គឯង មិនមានសម្ងាញ់ជាគម្រប់ ២ ក្នុងឧរុវេលាសេនានិគមក្តី ព្រាហ្មណ៍នោះ ធ្លាប់ឃើញនិងធ្លាប់សាសង ។ ព្រោះហេតុនោះ ទើបព្រាហ្មណ៍នឹកឃើញដល់គោត្រនៃព្រះមានព្រះភាគ ដែលបញ្ចវគ្គិយរាប់អានក្នុងកាលមុន ទើបបានហៅព្រះមានព្រះភាគ ដោយព្រះគោត្រថា **ភោ គោតម ។** *ម្យ៉ាងទៀត ចាប់តាំងអំពីកាលដែលព្រះមានព្រះភាគ ទ្រង់ចេញមហានិនេស្ក្រមណ៍ ត្រង់ស៊ីងអនោមានទី ទ្រង់ប្រោកជជួចព្រះចន្ទ និងព្រះអាទិត្យ គេជីងទូទៅថា ព្រះសមណគោតម មិនចាំបាច់ត្រិះរិះហេតុ ក្នុងការជីងគោត្ររបស់ព្រះមានព្រះភាគ ។*

បទថា **ព្រាហ្មណាការណា** *សេចក្តីថា ឈ្មោះថា* **ព្រាហ្មណាការណា** *ព្រោះធ្វើភាពជាព្រាហ្មណ៍ អធិប្បាយថា ធ្វើភាវៈថា ជាព្រាហ្មណ៍ ។ ក្នុងពាក្យនោះ ដោយពាក្យថា* **កិត្តាវតា** *នេះ ព្រាហ្មណ៍ទូលសួរដល់បរិមាណនៃធម៌ដែលជាហេតុឲ្យកើតជាព្រាហ្មណ៍ ។ ដោយបទថា* **កតមេ** *នេះ ទូលសួរដល់ការសរុបធម៌ទាំងនោះ ។ បទថា* **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជីងច្បាស់សេចក្តីនេះ ដែលជាចំណុចកំពូលនៃបញ្ហាដែលព្រាហ្មណ៍នោះទូលសួរ ទើបទ្រង់បន្ទឺឧទាននេះក្នុងពេលនោះ ។ តែទ្រង់មិនបានសម្តែងធម៌ដល់ព្រាហ្មណ៍នោះ ។ ព្រោះហេតុអ្វី ព្រោះព្រាហ្មណ៍មិនទាន់ជាទីអាចទទួលព្រះធម្មទេសនាបាន ។ ពិតហើយ ព្រាហ្មណ៍នោះបានស្តាប់គាថានេះហើយ ក៏មិន*

មែនត្រាស់ដឹងទ្បើយ ។ ការប្រកាសពុទ្ធគុណដល់ឧបកាជីវក ក៏ដូចគ្នានឹងការ ប្រកាសដល់ព្រាហ្មណ៍នេះ ។ ពិតហើយ ព្រះតម្រាស់ដែលព្រះមានព្រះភាគ ត្រាស់ក្នុងចំណែកខាងដើម មុនការប្រកាសព្រះធម្មចក្រ ព្រោះជាចំណែកនៃ វាសនាដល់បុគ្គលដទៃដែលបានស្តាប់ ដូចឲ្យសរណ:ដល់តបុស្ស: និងភល្លិក: ពាណិជ្ជ ២ នាក់បងប្អូន មិនមែនជាចំណែកនៃព្រះសេក្ខ: និងមិនមែនជា ចំណែកនៃការត្រាស់ដឹង ។ ពិតហើយ សេចក្តីនោះ ជាធម្មតា ។

បណ្តាបទទាំងនោះ បទថា **យោ ព្រាហ្មណោ** សេចក្តីថា បុគ្គលណា ឈ្មោះថា ជាព្រាហ្មណ៍ ព្រោះបន្សាត់បាបធម៌បាន ជាអ្នកប្រកបដោយបាបធម៌ មានការគំរាមថា **ហុំ ហុំ** ដូចទឹកមួត់ជាដើម ។ ព្រោះជាទិដ្ឋិមង្គលិក នៅ ប្តេជ្ញាខ្លួនថាជាព្រាហ្មណ៍ ដោយត្រឹមតែជាតិតែម្យ៉ាងក៏មិនមែន បុគ្គលនោះ ឈ្មោះថាព្រាហ្មណ៍ ព្រោះបន្សាត់បាបធម៌បាន ឈ្មោះថា ប្រាសចាកកិលេស ដែលសម្ថុតអ្នកដទៃថា **ហុំ ហុំ** ព្រោះលះកិលេសដែលគំរាមអ្នកដទៃថា **ហុំ ហុំ** បាន ឈ្មោះថា មិនមានកិលេសដូចទឹកមួត់ ព្រោះមិនមានកិលេសដូចទឹក មួត់ មានរាគ:ជាដើម ឈ្មោះថា មានសេចក្តីព្យាយាមជាសភាវ: ព្រោះមាន ចិត្តប្រកបដោយភាវនានុយោគ ឬឈ្មោះថា សង្រួមខ្លួនហើយ ព្រោះមានចិត្ត សង្រួមហើយ ដោយសីលសំវរ: ឈ្មោះថា ដល់ទីបំផុតនៃវេទ ព្រោះដល់

ទីបំផុត គឺព្រះនិព្វាន ដែលជាទីបំផុតសង្ខារ ឬទីបំផុតនៃវេទ ដោយវេទទាំង-
ទ្វាយ ពោល គឺមគ្គញ្ញាណ ៤ ។ ឈ្មោះថា នៅចប់ព្រហ្មចរិយៈហើយ ព្រោះ
នៅចប់មគ្គព្រហ្មចរិយៈ ។ បុគ្គលដែលពោលវាទៈថា ជាព្រាហ្មណ៍ដោយធម៌
គឺពោលវាទៈថា ជាព្រាហ្មណ៍ដោយធម៌ គឺដោយប្រពៃនោះ បុគ្គលមិនមាន
កិលេសជាគ្រឿងប៉ោងខ្ពើងទាំងនេះ បានដល់ កិលេសជាគ្រឿងប៉ោងខ្ពើង
គឺរាគៈ ទោសៈ មោហៈ មានៈ និងទិដ្ឋិ ក្នុងទីណាមួយ គឺក្នុងអារម្មណ៍ ១
ក្នុងលោកសន្និវាសទាំងមូល អធិប្បាយថា លះបានដោយឥតសល់ ។

អដ្ឋកថាហាំហាំកសូត្រ ចប់

សុត្តន្តបិដក

ជេរសូត្រ

[៤២] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុផង ព្រះមហាមោគ្គល្លានដ៏មានអាយុផង ព្រះមហាកស្សប:ដ៏មានអាយុផង ព្រះមហាកច្ចាន:ដ៏មានអាយុផង ព្រះមហាកោដ្ឋិត:ដ៏មានអាយុផង ព្រះមហាកប្បិនដ៏មានអាយុផង ព្រះមហាចុន្ទដ៏មានអាយុផង ព្រះអនុរុទ្ធដ៏មានអាយុផង ព្រះរេវត:ដ៏មានអាយុផង ព្រះនន្ទដ៏មានអាយុផង ចូលទៅគាល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ក៏បានទតឃើញពួកលោកដ៏មានអាយុ អម្បាលនោះ ដែលកំពុងដើរមកអំពីឆ្ងាយ លុះឃើញហើយ បានត្រាស់ប្រាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍ទាំងនុ៎ះ កំពុងដើរមក ម្នាលភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍ទាំងនុ៎ះ កំពុងដើរមក ។ កាលបើព្រះមានព្រះភាគ សម្តែងយ៉ាងនេះហើយ ភិក្ខុមួយរូប មានជាតិជាព្រាហ្មណ៍ បានទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ ដោយហេតុដូចម្តេច មួយទៀត ធម៌ដូចម្តេចខ្លះ ដែលធ្វើបុគ្គលឲ្យជាព្រាហ្មណ៍ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវបញ្ហានុ៎ះហើយ ទើបបន្ទឺនូវឧទាននេះក្នុងវេលានោះថា

បុគ្គលណា បានបណ្តេញចោលនូវធម៌ដ៏លាមក មានស្មារតីប្រព្រឹត្តទៅគ្រប់កាល ជាអ្នកអស់សំយោជន: (ត្រាស់ដឹងនូវសច្ចធម៌) បុគ្គលនោះឯង ឈ្មោះថា ព្រាហ្មណ៍ក្នុងលោក ។ សូត្រទី ៥ ។

អដ្ឋកថា

ថេរសូត្រ

ថេរសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ

[៤២] បទថា **សាវត្ថិយំ** គឺជិតនគរមានឈ្មោះយ៉ាងនេះ ។ ពិតហើយ នគរនោះ លោកហៅថា សាវត្ថី ព្រោះសាងក្នុងទីលំនៅរបស់ឥសីឈ្មោះ **សវត្ថ:** ដូចក្រុងកាកន្ទិ ហៅថា **មាកន្ទី** អ្នកអក្ខរសាស្ត្រជីឆយ៉ាងនេះជាលំដាប់ដំបូង ចំណែកអដ្ឋកថាទាំងឡាយពោលថា ឈ្មោះថា **សាវត្ថី** ព្រោះមានគ្រឿងឧបភោគបរិភោគ គ្រប់ប្រភេទសម្រាប់មនុស្ស កាលត្រូវសួរថា ក្នុងទីនេះ មានវត្ថុណាមួយ ក្នុងការប្រកបជាពួក ទើបហៅថា **សាវត្ថី** ។ ឆ្លើយថា ព្រោះអាស្រ័យពាក្យថា **សព្ពមត្ថិ** វត្ថុទាំងអស់មាន ដូច្នេះ ។

គ្រឿងឧបករណ៍ទាំងអស់ មានព្រម ដោយប្រការទាំងពួង ក្នុងក្រុងសាវត្ថី ព្រោះអាស្រ័យការដល់ព្រមទាំងពួង ទើបហៅថា **សាវត្ថី** ដូច្នេះ ។ ជិតក្រុងសាវត្ថីនោះ ។ បទថា **សាវត្ថិយំ** នេះ ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថជាជិត ។ បទថា **ជេតវនេ** សេចក្តីថា ឈ្មោះថា **ជេត** ព្រោះឈ្នះសត្រូវរបស់ខ្លួន ។ ម្យ៉ាងទៀត ឈ្មោះថា **ជេត** ព្រោះប្រសូតក្នុងកាលព្រះរាជាឈ្នះពួកជនដែលជាសត្រូវ ។ ម្យ៉ាងទៀត ឈ្មោះថា **ជេត** ព្រោះតាំងឈ្មោះយ៉ាងនោះ ព្រោះត្រូវការឲ្យជាមង្គល ។ ឈ្មោះថា **វន** ព្រោះគប់រក អធិប្បាយថា ធ្វើនូវភក្តីក្នុងខ្លួនឲ្យកើតដល់សត្វទាំងឡាយ ដោយគុណសម្បត្តិរបស់ខ្លួន ម្យ៉ាងទៀត ឈ្មោះថា **វន** ព្រោះហៅ អធិប្បាយថា ហាក់ដូចហៅសត្វ

ទាំងឡាយថា ចូរពួកអ្នកប្រើប្រាស់ខ្ញុំ ដោយការបញ្ចេញសំឡេងរបស់វិហគៈ មានតារៀជាដើម ដោយការស្រែវឹង ដោយការត្រែកត្រអាលដោយផ្តា និង គ្រឿងក្រអូបច្រើនប្រភេទដោយដៃ គឺស្លឹកខ្ទឹរបស់មែកឈើ ដែលខ្យល់ ត្រសៀកៗ បក់មក ។ អារាមរបស់ព្រះអង្គម្ចាស់ជេត ឈ្មោះថា **ជេតវន។** *ពិតហើយ សួននោះ ព្រះរាជកុមារព្រះនាមថា* **ជេត** *ទ្រង់ដាំឲ្យចម្រើន និង រក្សា ព្រះអង្គម្ចាស់ជេតនោះឯង ជាម្ចាស់របស់ឧទ្យាននោះ ព្រោះដូច្នោះ ទើបឧទ្យាននោះ ឈ្មោះថា* **ជេតវន។** *ក្នុងឧទ្យានឈ្មោះថា* **ជេតវន** *នោះ ។*

បទថា **អនាថបិណ្ឌិកស្ស អារាមេ** *សេចក្តីថា មហាសេដ្ឋីឈ្មោះសុទត្តៈ ព្រោះមាតាបិតាជាក់ឈ្មោះឲ្យ តែសេដ្ឋីនោះឲ្យដុំបាយដល់មនុស្សអនាថាអស់ កាលជានិច្ច ព្រោះមានសេចក្តីសម្រេចក្នុងវត្ថុដែលបំណងគ្រប់ប្រការ ព្រោះ ប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ និងព្រោះដល់ព្រមដោយគុណ មាន ករុណាជាដើម ព្រោះដូច្នោះ ទើបហៅថា* **អនាថបិណ្ឌិក ។** *ឈ្មោះថា* **អារាម** *ព្រោះជាទីត្រេកអរបស់សត្វ គឺអ្នកបួសដោយពិសេស អធិប្បាយថា អ្នក មកអំពីទីនោះៗ រមែងត្រេកត្រអាលមិននឿយណាយ ដោយលម្អរបស់ផ្តា និង ផ្លែជាដើម និងដោយការសម្បូរ នៃអង្គរបស់សេនាសនៈ ៥ មានមិនធ្លាយ ពេក មិនជិតពេកជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា* **អារាម** *ព្រោះនាំមនុស្ស ដែលទៅក្នុងទីនោះៗ មកត្រេកអរចំពោះជាមួយខ្លួនដោយសម្បត្តិ មានប្រការ ដូចពោលហើយ ។ ពិតហើយ អារាមនោះ អនាថបិណ្ឌិកគហបតី ប្រើ ប្រាក់ ១៨ កោដិ ទិញមកអំពីដៃរបស់ព្រះរាជកុមារព្រះនាមជេត ដោយការ*

យកប្រាក់រាប់កោដិក្រាល ប្រើប្រាក់ ១៨ កោដិសាងសេនាសនៈ ១៨ កោដិ ឆ្លងវិហារឲ្យសម្រេច ហើយវេរថ្វាយសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយបរិច្ចាគប្រាក់ ៥៤ កោដិ ដោយប្រការយ៉ាងនេះ ព្រោះដូច្នោះ ទើបហៅថា អារាមរបស់អនាថបិណ្ឌិកគហបតី ។ ក្នុងអារាមរបស់អនាថបិណ្ឌិកសេដ្ឋី នោះ ។

ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **ជេតវនេ** *ជាពាក្យប្រារព្ធដល់ម្ចាស់ដើម ។ ពាក្យថា* **អនាថបិណ្ឌិកស្ស អារាមេ** *ជាពាក្យប្រារព្ធដល់ម្ចាស់ក្រោយ ។ ពាក្យទាំង ២ មានអត្ថ ឲ្យកាន់យកជាបែបផែនតទៅរបស់បុគ្គលត្រូវការបុណ្យ ដោយការសម្តែងការបរិច្ចាគជាពិសេសរបស់លោកទាំង ២ ។ បើពោលដោយការសាងខ្ងោងទ្វារ និងប្រាសាទ ត្រង់វត្តជេតពននោះ ព្រះអង្គម្ចាស់ជេត ទ្រង់បរិច្ចាគប្រាក់ ១៨ កោដិ ដែលបានមកអំពីការលក់ទីកន្លែង និងដើមឈើ មានតម្លៃច្រើនកោដិ ហើយអនាថបិណ្ឌិកគហបតីបរិច្ចាគ ៥៤ កោដិ ។ ដូច្នោះ ព្រះអានន្ទដែលជាភណ្ឌាគារិក កាលសម្តែងថា បុគ្គលត្រូវការបុណ្យ រមែងធ្វើបុណ្យយ៉ាងនេះ ដោយការប្រារព្ធដល់ការបរិច្ចាគរបស់ជនទាំង ២ នោះ ទើបដឹកនាំបុគ្គលដែលត្រូវការបុណ្យដទៃ ដោយការប្រព្រឹត្តតាមលំអានរបស់លោកទាំង ២ នោះឯង ។*

ក្នុងសេចក្តីនោះ គប្បីមានពាក្យសួរជ្រៀតចូលមកថា ជាបឋម បើព្រះមានព្រះភាគប្រថាប់នៅក្នុងក្រុងសាវត្ថី មិនគួរពោលថា ក្នុងវត្តជេតពន បើប្រថាប់នៅក្នុងវត្តជេតពន មិនគួរពោលថា ក្នុងក្រុងសាវត្ថី ព្រោះបុគ្គលណា

ម្នាក់ មិនអាចនៅក្នុងទី ២ កន្លែងក្នុងពេលតែមួយ ឆ្លើយថា សេចក្តីនោះ មិនគួរយើញយ៉ាងនោះ ខ្ញុំបានពោលហើយមិនមែនឬថា បទថា **សាវត្ថិយំ** *នេះជាសត្តមីវិភត្តិ ប្រើក្នុងអត្ថថា ជិត ។ ព្រោះដូច្នោះ កាលទ្រង់ប្រថាប់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ទើបលោកពោលថា* **សាវត្ថិយំ វិហរតិ ជេតវនេ ។** *ពិតហើយ ពាក្យថា* **សាវត្ថី** *មានការសម្តែងគោចរគ្រាមរបស់ព្រះមានព្រះភាគអង្គនោះជាអត្ថ ។ ពាក្យជ័សេស មានការសម្តែងទីកន្លែងដ៏សមគួរដល់បព្វជិត ជាអត្ថនោះឯង ។*

បទថា **អាយស្មា** *ក្នុងពាក្យជាដើមថា* **អាយស្មា ច សារិបុត្តោ** *ជាពាក្យសម្តែងដល់សេចក្តីស្រឡាញ់ ។* **ច** *សព្ទ ជាសមុច្ចយត្ថ ។ ឈ្មោះថា* **សារីបុត្ត** *ព្រោះជាកូនរបស់ព្រាហ្មណី ឈ្មោះរូបសារី ។ ពាក្យថា* **មហា-មោគ្គល្លានោ** *ជាពាក្យសម្តែងដល់ការបូជា ។ សេចក្តីពិត ឈ្មោះមហា-មោគ្គល្លាន ព្រោះព្រះមោគ្គល្លានជាធំដោយគុណវិសេស ។ បទថា* **វេរញ្ជោ** *បានដល់ ព្រះខទិរវេតៈ មិនមែនកង្វាវេតៈទេ្លយ ។ ពិតហើយ ថ្ងៃមួយ ព្រះមានព្រះភាគ ចោមរោមដោយមហាភិក្ខុសង្ឃ ដូចព្រះចន្ទអណ្តែតនាកណ្តាលអាកាស ប្រថាប់សម្តែងធម៌ គឺសច្ចៈ ៤ កណ្តាលបរិស័ទ ៤ ដូចប្រាសាទមាស ដែលព័ទ្ធដោយវាំងននពណ៌ក្រហម និងដូចភ្នំមាសព័ទ្ធដោយជលធារពណ៌ទឹកប្រាក់ ដូចស្តេចហង្សធតរដ្ឋ ចោមរោមដោយហង្ស ៩ ម៉ឺន ដូចស្តេចចក្រពត្តិរៃហាមដោយចតុរង្គិនីសេនា ដ៏រុងរឿងដោយរតនៈ ៧ ក្រោនោះ អគ្គសាវក និងព្រះមហាសាវកទាំងនេះ បានចូលទៅគាល់ ដើម្បីថ្វាយ*

បង្គំព្រះយុគលបាទរបស់ព្រះមានព្រះភាគ ។

បទថា **ភិក្ខូ អាមន្តេសិ** *សេចក្តីថា ទ្រង់សម្តែងព្រះសាវ័កទាំងនោះ ដែលកំពុងមក ត្រាស់នឹងភិក្ខុដែលអង្គុយចោមរោមទ្រង់ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ឃើញជនទាំងនោះ ដែលសម្បូរដោយគុណ មានសីល សមាធិ និងបញ្ញាជាដើម ដែលប្រកបដោយសេចក្តីស្ងប់ក្រៃលែង ប្រកបដោយសម្បត្តិ គឺមារយាទយ៉ាងក្រៃលែង កំពុងចូលមកគាល់ ទ្រង់មានព្រះហឫទ័យជ្រះថ្លា ដើម្បីប្រោរព្ធគុណវិសេសរបស់ព្រះសាវ័កទាំងនោះ ទើបត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍ទាំងនុ៎ះ កំពុងដើរមក ម្នាលភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍ទាំងនុ៎ះ កំពុងដើរមក ។ ពាក្យនោះ ទ្រង់ត្រាស់ដោយសេចក្តីជ្រះថ្លា និងត្រាស់ដោយការសរសើរដូច្នេះ ក៏ត្រឹមត្រូវ ។ បទថា* **ឍវំ វុត្តេ** *សេចក្តីថា កាលព្រះមានព្រះភាគត្រាស់ថា ព្រាហ្មណ៍សំដៅយកជនទាំងនោះ ដោយប្រការដូច្នេះ ។ បទថា* **អញ្ញតរោ** *បានដល់ភិក្ខុមួយរូប ដែលមិនជ្រុកជដោយឈ្មោះ និងគោត្រ អង្គុយនៅក្នុងបរិស័ទនោះ ។ បទថា* **ព្រាហ្មណជាតិកោ** *ប្រែថា ជាអ្នកកើតក្នុងត្រកូលព្រាហ្មណ៍ ។ ពិតហើយ ភិក្ខុនោះបួសអំពីត្រកូលព្រាហ្មណមហាសាល ដែលមានភោគៈច្រើន ។ បានឮថា ភិក្ខុនោះ មានគំនិតយ៉ាងនេះថា សត្វលោកទាំងនេះពោលថា បុគ្គលជាព្រាហ្មណ៍ ដោយឧភតោសុជាតិ និងសម្រេចការសិក្សា មកអំពីលទ្ធិព្រាហ្មណ៍ មិនមែនជាព្រាហ្មណ៍ដោយប្រការដទៃ តែព្រះមានព្រះភាគត្រាស់ហៅជនទាំងនោះថា ជាព្រាហ្មណ៍ ណ្ហើយចុះ អញនឹងទូលសួរដល់*

លក្ខណៈនៃភាពជាព្រាហ្មណ៍ ជាមួយនឹងព្រះមានព្រះភាគ ។ ពិតហើយ ក្នុងគ្រានោះ ព្រះមានព្រះភាគបានត្រាស់ដល់ព្រះថេរៈនោះថា ព្រាហ្មណ៍ សំដៅយកសេចក្តីនោះឯង ។ ពិតហើយ រូបវិគ្គហៈនៃជាតិព្រាហ្មណ៍ថា ឈ្មោះថា ព្រាហ្មណ៍ ព្រោះជាអ្នកស្វាធ្យាយមន្ត ។ ឯព្រះអរិយៈ ឈ្មោះថា ព្រាហ្មណ៍ ព្រោះជាអ្នកបន្សាត់បាប ។ សមដូចពាក្យដែលលោកពោលថា ឈ្មោះថា **ព្រាហ្មណ៍** *ព្រោះជាអ្នកបន្សាត់បាប ហៅថា* **សមណៈ** *ព្រោះជាអ្នកប្រព្រឹត្តស្ងប់ តែលោកពោលថា ជាអ្នកបន្សាត់នូវបាបធម៌ ។*

បទថា **ឯតមត្ថំ វិទិត្វា** *បានដល់ ជ្រាបអត្ថនៃ* **ព្រាហ្មណា** *សព្វនោះ ដែលដល់នូវភាពជាកំពូលដោយបរមត្ថ ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ដែលសម្តែងភាពជាព្រាហ្មណ៍ដោយបរមត្ថ ។ បណ្តាបទទាំងនោះ បទថា* **ពាហិត្វា** *បានដល់ ធ្វើទុកខាងក្រៅ គឺនាំចេញចាកសន្តានរបស់ខ្លួន អធិប្បាយថា លះដោយសមុច្ឆេទប្បហាន ។ បទថា* **ចាបកេ ធម្មេ** *ប្រែថា ធម៌ដ៏លាមក អធិប្បាយថា ពោលដោយទុច្ចរិត បានដល់ ទុច្ចរិត ៣ ពោលដោយចិត្តុប្បាទ បានដល់ អកុសលចិត្តុប្បាទ ១២ ពោលដោយកម្មបថ បានដល់ អកុសលកម្មបថ ១០ ។ ពោលដោយប្រភេទនៃបវត្តិ បានដល់ អកុសលធម៌ទាំងអស់ ចែកជាច្រើនប្រភេទ ។ បទថា* **យេ ចរន្តិ សធា សតា** *សេចក្តីថា ជនពួកណា មានសតិ គឺជាអ្នកមានសតិដោយធម៌ជាគ្រឿងនៅ គឺសតិ ៦ ក្នុងអារម្មណ៍ ៦ មានរូបជាដើមអស់កាលទាំងពួង ព្រោះជាបុគ្គលដល់នូវការបរិបូណ៌ដោយសតិ រមែងត្រាច់ទៅដោយ*

ឥរិយាបថទាំង ៤ ។ ក្នុងទីនេះ សូម្បីសម្បជញ្ញៈ គប្បីជ្រាបថា លោកកាន់យកដោយ **សតិ** *សព្វនោះឯង ។ បទថា* **ខីណាសញ្ញោជនា** *បានដល់ឈ្មោះថា អស់សញ្ញោជនៈទាំងពួង ព្រោះកាត់សញ្ញោជនៈ ១០ បានជាសមុច្ឆេទដោយមគ្គទាំង ៤ ។ បទថា* **ពុទ្ធា** *គឺឈ្មោះថា* **ពុទ្ធ** *ព្រោះត្រាស់ដឹងសច្ចៈ ៤ ពុទ្ធទាំងនោះ មាន ៣ ប្រភេទ គឺសាវកពុទ្ធ បច្ចេកពុទ្ធ និងសម្មាសម្ពុទ្ធ ។ បណ្តាពុទ្ធទាំង ៣ នោះ ក្នុងទីនេះ សំដៅយកសាវកពុទ្ធ ។ បទថា* **តេ វៃ លោកស្មិំ ព្រាហ្មណា** *សេចក្តីថា ពុទ្ធទាំងនោះ កើតដោយអរិយជាតិ ក្នុងធម្ម ពោល គឺព្រាហ្មណ៍ ។ ព្រោះអត្ថថា ជាបុគ្គលប្រសើរ ឬជាបុត្រ គឺឱរសរបស់ព្រះមានព្រះភាគ ដែលជាព្រាហ្មណ៍ ព្រោះដូច្នោះ បើពោលដោយបរមត្ថ ក៏ឈ្មោះថា ព្រាហ្មណ៍ក្នុងសត្វលោកនេះ អធិប្បាយថា មិនមែនជាព្រាហ្មណ៍ ដោយហេតុនៃជាតិ និងគោត្រ ឬមិនមែនជាព្រាហ្មណ៍ដោយហេតុត្រឹមតែទ្រទ្រង់ជដាជាដើម ។ ក្នុងសូត្រទាំង ២ នេះ ធម៌ដែលធ្វើភាពជាព្រាហ្មណ៍ ទ្រង់ត្រាស់ឲ្យដល់អរហត្ត ដោយប្រការដូច្នេះ តែគប្បីជ្រាបការផ្សេងគ្នានៃទេសនា ដោយការត្រាស់ផ្សេងៗ គ្នា ដោយទេសនាវិលាស ព្រោះពួកសត្វ មានអធ្យាស្រ័យផ្សេងគ្នា ។*

អដ្ឋកថាថេរសូត្រ ចប់

សុត្តន្តបិដក

មហាកស្សបសូត្រ

[៤៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមហាកស្សប:ដ៏មានអាយុ គង់នៅក្នុងបិប្ផលិគុហា ជាអ្នកមានអាពាធ ប្រកបដោយទុក្ខឈឺធ្ងន់ ។ លុះក្នុងសម័យខាងក្រោយមក ព្រះមហាកស្សប:ដ៏មានអាយុ សះស្បើយចាកអាពាធនោះ ។ លុះព្រះមហា-កស្សប:សះស្បើយចាកអាពាធនោះហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ មានតែអាត្មាអញចូលទៅបិណ្ឌបាត ឯក្រុងរាជគ្រឹះចុះ ។ សម័យនោះឯង ពួកទេវតាចំនួន ៥០០ ប្រឹងខ្វិឃ្មាត បម្រុងឲ្យព្រះមហាកស្សប:ដ៏មានអាយុ បានបិណ្ឌបាត ។ គ្រានោះ ព្រះមហាកស្សប:ដ៏មានអាយុ បានហាមឃាត់ពួកទេវតាទាំង ៥០០ នោះ ហើយស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ រួចចូលទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ តាមច្រកផ្លូវរបស់មនុស្សក្រមុត់មនុស្សកំព្រា និងជាងតម្បាញ ក្នុងបុព្វណ្ហសម័យ ។ ព្រះមានព្រះភាគ បានឃើញព្រះមហាកស្សប:ដ៏មានអាយុ កំពុងដើរបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ តាមច្រករបស់មនុស្សក្រមុត់ មនុស្សកំព្រា និងជាងតម្បាញ ។ លុះព្រះមានព្រះភាគ បានជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបបន្លឺនូវឧទាននេះ ក្នុងវេលានោះថា

បុគ្គលដែលជាអ្នកមិនចិញ្ចឹមអ្នកដទៃ អ្នកជឿជាក់ច្បាស់ អ្នកទូន្មានខ្លួន តាំងនៅក្នុងធម៌មានទ្វីម អ្នកអស់អាសវៈ អ្នកមានទោសៈខ្ជាក់ចោល តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។ សូត្រទី ៦ ។

អដ្ឋកថា

មហាកស្សបសូត្រ

មហាកស្សបសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ

[៤៣] បទថា **រាជគហេ** បានដល់ ជិតនគរដែលមានឈ្មោះយ៉ាងនេះ ។ ពិតហើយ នគរនោះ ហៅថា រាជគ្រឹះ ព្រោះព្រះបាទមហាមន្ធាតុនិងព្រះបាទមហាគោវិន្ទជាដើមគ្រប់គ្រង អាចារ្យខ្លះពណ៌នាសេចក្តីនេះ ដោយប្រការដទៃ មានជាដើមថា ឈ្មោះថា **រាជគ្រឹះ** ព្រោះជាផ្ទះរបស់ព្រះរាជាដែលសត្រូវណាម្នាក់គ្របសង្កត់បានដោយលំបាក ។ លោកអាចារ្យទាំងនោះនិងមានប្រយោជន៍អ្វី ។ ពាក្យថា **រាជគ្រឹះ** នោះ ជាឈ្មោះនៃនគរនោះ ។ នគររាជគ្រឹះនោះ ជាក្រុងនៅក្នុងសម័យពុទ្ធកាល និងសម័យស្តេចចក្រពត្តិក្នុងកាលជដទៃ ជាក្រុងដែលគេបោះបង់ ពួកយក្សគ្រប់គ្រង ក្លាយជាលំនៅរបស់ពួកយក្សទាំងនោះ ។ ពាក្យថា **វេឡុវនំ** ក្នុងពាក្យថា **វេឡុវនេ កលន្ទកនិវាបេ** ជាឈ្មោះរបស់វិហារនោះ ។ បានឮថា វត្តវេឡុវននោះ ព័ទ្ធ

ដោយកំពែងកម្ពស់ ១៨ ហត្ថ ប្រដាប់ដោយមហាគន្ធកុដិ ជាទីគង់ប្រថាប់
របស់ព្រះមានព្រះភាគ និងដោយវត្ថុជទៃ មានប្រាសាទ កុដិ ទីសម្ងំ មណ្ឌប
ទីចង្រ្កម និងខ្ញោងទ្វារជាដើម ខាងក្រៅ ព័ទ្ធដោយគុម្ពឫស្សី មានពណ៌ខៀវ
គួរជាទីត្រេកអរ ព្រោះដូច្នោះ ទើបឈ្មោះថា **វេឡុវនៈ** *។ និងហៅថា*
កលន្ទកនិវាបៈ *ព្រោះជាទីឲ្យចំណីដល់ពួកសត្វកង្កែន បានឮថា សម័យមុន*
ព្រះរាជាមួយអង្គ ទ្រង់ប្រពាសព្រះរាជឧទ្យាននោះ ទ្រង់ស្រវឹងទឹកចណ្ឌ ទើប
ផ្ទំក្នុងពេលថ្ងៃ ឯបរិវារបស់ព្រះរាជានោះ គិតថា ព្រះរាជាផ្ទំលក់ហើយ
ត្រូវលួងលោមដោយផ្កា និងផ្លែឈើ ទើបចៀសចេញទៅក្នុងទិស និងផ្លូវ
ផ្សេងៗ ។ គ្រានោះ ពស់វែកលូនចេញអំពីព្រង់ឈើមួយដើមស្រង់ក្លិន លូន
មកឱកព្រះរាជា ។ រុក្ខទេវតាឃើញដូច្នោះ ទើបគិតថា អញនឹងជួយជីវិត
ព្រះរាជា ទើបកាឡាខ្លួនជាកង្កែន ស្រែកក្បែរព្រះកាណ៌ ព្រះរាជាទ្រង់ភ្ញាក់
អំពីផ្ទំ ពស់ក៏លូនត្រឡប់ទៅ ។ ព្រះរាជាទ្រង់ឃើញដូច្នោះ ទើបទ្រង់ព្រះ
តម្រិះថា កង្កែននេះឲ្យជីវិតដល់អញ ទើបទ្រង់ឲ្យគេឲ្យចំណីដល់ពួកកង្កែន
ក្នុងទីនោះ ទ្រង់ប្រកាសឲ្យអភ័យ ព្រោះដូច្នោះ តាំងអំពីនោះមក ទើបទីនោះ
ឈ្មោះថា **កលន្ទកនិវាបៈ** *ពាក្យថា* **កលន្ទក** *ជាឈ្មោះរបស់ពួកកង្កែន ។*
ក្នុងវត្តវេឡុវន កលន្ទកនិវាបនោះ ។

បទថា **មហាកស្សបោ** *សេចក្តីថា ឈ្មោះថា មហាកស្សបៈ ព្រោះព្រះ*
កស្សបៈជាធំ ហេតុប្រកបដោយគុណធំ មានសីលក្ខន្ធជាដើម ។ ម្យ៉ាងទៀត
ព្រះមហាថេរៈអង្គនេះ ហៅថា មហាកស្សបៈ ព្រោះប្រៀបធៀបនឹងព្រះកុមារ-

កស្សបៈ ។ បទថា **បិប្ផលិគុហាយំ** *សេចក្តីថា បានឮថា ជិតទ្វារគុហានោះ មានដើមជីប្ចីមួយដើម ព្រោះដូច្នោះ ទើបគុហានោះប្រាកដឈ្មោះថា បិប្ផលិ-គុហា ។ ត្រង់បិប្ផលិគុហានោះ ។ បទថា* **អាពាធិកោ** *សេចក្តីថា ឈ្មោះថា អាពាធិក ព្រោះមានអាពាធជូន់ អធិប្បាយថា មានជំងឺ ។ បទថា* **ទុក្ខិតោ** *សេចក្តីថា ឈ្មោះថា ទុក្ខ ព្រោះកើតទុក្ខដែលអាស្រ័យកាយ អធិប្បាយថា ជួបនូវទុក្ខ ។ បទថា* **ពាឡ្ហគិលានោ** *បានដល់ ជាអ្នកមានជំងឺធ្ងន់ ។ តែ ព្រះមហាកស្សបៈ មានសតិសម្បជញ្ញៈ អត់សង្កត់នូវជំងឺនោះបាន ។ កាល ព្រះមានព្រះភាគ ទ្រង់ជ្រាបហេតុនោះរបស់លោក ទើបយាងទៅក្នុងទីនោះ ត្រាស់ពោជ្ឈង្គបរិត្ត ។ ដោយពោជ្ឈង្គបរិត្តនោះឯង ទើបព្រះថេរៈជាសះ ស្បើយអំពីអាពាធនោះ ។ សមដូចព្រះតម្រាស់ត្រាស់ក្នុងពោជ្ឈង្គសំយុត្តថា*

> *សម័យនោះឯង ព្រះមហាកស្សបៈដ៏មានអាយុ គង់នៅក្នុង បិប្ផលិគុហា លោកមានអាពាធ ជល់នូវសេចក្តីទុក្ខ មានជំងឺជា ទម្ងន់ ។*
>
> *គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំ ក្នុង សាយណ្ហសម័យ ទ្រង់ចូលទៅរកព្រះមហាកស្សបៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈដែលគេក្រាល ។ លុះព្រះដ៏មានព្រះភាគ គង់ហើយ ទ្រង់មានព្រះពុទ្ធដីកា នឹង ព្រះមហាកស្សបៈដ៏មានអាយុដូច្នេះថា ម្នាលកស្សបៈ សរីរយន្ត របស់អ្នក លួមអត់ធន់បានខ្លះដែរឬ លួមឲ្យប្រព្រឹត្តទៅបានដែរ*

ឬ ទុក្ខវេទនាជូរចយ មិនចម្រើនឡើង មានតែស្រោកស្រាន្តទៅ មិនរីតឡើងទេឬ ។

បពិត្រព្រះអង្គដ៏ចម្រើន សរីរយន្តរបស់ខ្ញុំព្រះអង្គ មិនល្មមអត់ធន់បានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គ ក្អៀវក្អាខ្លាំងណាស់ មិនជូរចយទេ មានតែរីតឡើង មិនស្រោកស្រាន្តទេ ។

ម្នាលកស្សបៈ ពោជ្ឈង្គទាំង ៧ នេះ ដែលតថាគតសម្តែងប្រពៃហើយ បានចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ តែងប្រព្រឹត្តទៅដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹងដើម្បីនិព្វាន ។ ពោជ្ឈង្គទាំង ៧ តើអ្វីខ្លះ ។

ម្នាលកស្សបៈ សតិសម្ពោជ្ឈង្គដែលតថាគតបានសម្តែង ច្រាប់ប្រពៃហើយ ចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ តែងប្រព្រឹត្តទៅដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។បទ។ ម្នាលកស្សបៈ ឧបេក្ខាសម្ពោជ្ឈង្គ ដែលតថាគតសម្តែងច្រាប់ប្រពៃហើយ ចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ តែងប្រព្រឹត្តទៅដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។

ម្នាលកស្សបៈ ពោជ្ឈង្គទាំង ៧ នេះឯង ដែលតថាគតសម្តែងច្រាប់ប្រពៃហើយ ចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ តែងប្រព្រឹត្តទៅដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។

បពិត្រព្រះដ៏មានព្រះភាគ ពិតមែនហើយ ពោជ្ឈង្គទាំង៧ឱ្យ
បពិត្រព្រះសុគត ពិតមែនហើយ ពោជ្ឈង្គទាំង៧ឱ្យ ។
លុះព្រះដ៏មានព្រះភាគបានត្រាស់ធម៌នេះចប់ហើយ ។
ព្រះមហាកស្សប:ដ៏មានអាយុ ក៏ត្រេកអរចំពោះភាសិតរបស់
ព្រះដ៏មានព្រះភាគ ។ ឯព្រះមហាកស្សប:ដ៏មានអាយុ ក៏បានជា
សះស្បើយចាកអាពាធនោះ មួយទៀត អាពាធនោះ ក៏ព្រះ
មហាកស្សប:ដ៏មានអាយុ បានលះបង់យ៉ាងនោះហើយ ។

ព្រោះហេតុនោះ ទើបលោកពោលថា **អថខោ អាយស្មា មហា-កស្សបោ អបរេន សមយេន តម្ហា អាពាធា វុដ្ឋាសិ** *សម័យតមក ព្រះមហាកស្សប: ក៏ជាសះស្បើយអំពីជំងឺនោះ ។*

បទថា **ឯតទវោចុំ** *សេចក្តីថា ព្រះមហាកស្សប:ឆាន់បិណ្ឌបាតដែល សន្ទិវិហារិកនាំទៅប្រគេន ក្នុងថ្ងៃមានជំងឺក្នុងកាលមុន បាននៅក្នុងវិហារនោះ ឯង កាលលោកជាអំពីអាពាធនោះហើយ មានបរិវិតក្កនេះថា ធ្វើម្តេចហ្ន៎ អាត្មាគប្បីត្រាច់ទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ។ បទថា* **បញ្ចមត្តានិ ទេវតា សតានិ** *បានដល់ ស្រីទេពអប្សរដែលមានជើង៥ដូចជើងព្រាប ប្រមាណ ៥០០ ដែលបម្រើសក្កទេវរាជ ។ បទថា* **ឧស្សុក្កំ អាបន្នានិ ហោន្តិ** *សេចក្តីថា ស្រីទេពអប្សរទាំងនោះ គិតនឹងថ្វាយបិណ្ឌបាតដល់ ព្រះថេរ: ទើបត្រៀមបិណ្ឌបាត ៥០០ សម្រាប់ ជាក់ក្នុងភាជន៍មាស ទៅឈរ ក្នុងរវាងផ្លូវ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលបិណ្ឌបាត*

នេះ សូមសង្គ្រោះពួកខ្ញុំ ខ្វល់ខ្វាយក្នុងការប្រគេនបិណ្ឌបាត ដោយហេតុនោះ ទើបលោកពោលថា **អាយស្មតោ មហាកស្សបស្ស បិណ្ឌចាតប្បដិ-លាភាយ** *ដើម្បីឲ្យព្រះមហាកស្សបៈទទួលបិណ្ឌបាត ។*

បានឮថា សក្កទេវរាជជ្រាបការប្រព្រឹត្តទៅនៃចិត្តរបស់ព្រះថេរៈ ទើបបញ្ជូនទេពអប្សរទាំងនោះទៅ ដោយព្រះតម្រាស់ថា ពួកនាងចូរទៅថ្វាយបិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរ ធ្វើឲ្យជាទីពឹងរបស់ខ្លួន ។ សេចក្តីពិត សក្ក-ទេវរាជនោះ មានការត្រិះរិះយ៉ាងនេះថា បណ្តាស្រីទេពអប្សរទាំងនេះដែលទៅដល់ ជួនកាល ព្រះថេរៈគប្បីទទួលបិណ្ឌបាតអំពីដៃរបស់ស្រីទេពអប្សរត្រឹមតែម្នាក់ សេចក្តីនោះនឹងជាប្រយោជន៍ និងសេចក្តីសុខដល់នាងអស់កាលយូរ ព្រះថេរៈឃាត់ទេពអប្សរដែលកំពុងពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ ទទួលបិណ្ឌបាតរបស់ខ្ញុំ សូមលោកម្ចាស់ ទទួលបិណ្ឌបាតរបស់ខ្ញុំ ហើយពោលថា ពួកនាងបានធ្វើបុណ្យទុកហើយ មានភោគៈច្រើន ចូរចៀសចេញទៅ អាត្មានឹងសង្គ្រោះដល់មនុស្សក្រីក្រ ហើយទើបឃាត់ម្តងទៀតដល់ទេពអប្សរដែលកំពុងពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ កុំធ្វើពួកខ្ញុំឲ្យវិនាសឡើយ សូមសង្គ្រោះពួកខ្ញុំចុះ ទើបផ្ចាត់ម្រាមដៃពោលពាក្យដដែលជាមួយទេពអប្សរដែលមិនជ្រាបថានឹងចៀសចេញទៅ ដែលកំពុងអង្វរថា ពួកនាងមិនស្គាល់ប្រមាណខ្លួនឯង ចូរចៀសចេញទៅ ។ ទេពអប្សរទាំងនោះ បានឮសំឡេងផ្ចាត់ម្រាមដៃរបស់ព្រះថេរៈ កាលមិនអាចតាំងនៅបាន ទើបគេចទៅកាន់ទេវលោកវិញ ។ ព្រោះហេតុនោះ ទើបលោកពោលថា

បញ្ចមត្តានិ ទោតាសតានិ បដិក្កិបិត្វា ដូច្នេះ ។

បទថា **បុព្ពណ្ហសមយំ** *បានដល់ សម័យមួយ គឺពេលមួយ នាពេលព្រឹក ។ បទថា* **និវាសេត្វា** *សេចក្តីថា ស្បៃកដណ្តប់យ៉ាងខ្ជាប់ខ្ជួន ដោយការផ្ចាស់ប្តូរគ្រឿងស្បៃកដណ្តប់ក្នុងវិហារ ។ បទថា* **បត្តចីវរមាទាយ** *សេចក្តីថា ដណ្តប់ចីវរ ហើយកាន់បាត្រ ។ បទថា* **បិណ្ឌាយ បាវិសិ** *បានដល់ ចូលទៅបិណ្ឌបាត ។*

បទថា **ឧលិទ្ធវិសិខា** *បានដល់ ទីកដីដែលជាលំនៅរបស់ជនក្រីក្រ ។ បទថា* **កបណវិសិខា** *បានដល់ លំនៅរបស់អ្នកក្រីក្រ ព្រោះដល់នូវការអស់ភោគៈ ។ បទថា* **បេសការវិសិខា** *បានដល់ លំនៅរបស់ជាងតម្បាញ ។*

បទថា **អទ្ទសា ខោ ភគវា** *សេចក្តីថា ព្រះមានព្រះភាគ ទ្រង់បានឃើញដូចម្តេច ព្រះមានព្រះភាគទ្រង់ត្រិះរិះថា កស្សបៈ បុត្រតថាគត ប្រាសចាកអាពាធហើយ កំពុងធ្វើអ្វីហ្ន៎ ទ្រង់ប្រថាប់គង់ក្នុងវត្តវេឡុវនោះឯង បានឃើញដោយទិព្វចក្ខុ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបអត្ថដែលព្រះមហាកស្សបៈឃាត់បិណ្ឌបាតជាទិព្វ មានសូបៈ និងព្យញ្ជនៈច្រើន ដែលស្រីទេពអប្សរ ៥ រយ នាំទៅប្រគេន ហើយពោលដល់បដិបទាក្នុងការសង្គ្រោះមនុស្សក្រីក្រ ។*

បទថា **ឥមំ ឧទានំ** *បានដល់ ទ្រង់បន្ទឺឧទាននេះ ដែលសម្តែងអានុភាពនៃការមិនញាប់ញ័ររបស់ព្រះខីណាស្រព ដោយសម្តែងភាពជាអ្នកប្រាថ្នាតិចជាប្រធាន ។*

បណ្តាបទទាំងនោះ បទថា **អនញ្ញោសិ** *សេចក្តីថា ឈ្មោះថា* **អញ្ញ-ោសិ** *ព្រោះចិញ្ចឹមអ្នកដទៃ ដែលមិនចិញ្ចឹមអ្នកដទៃ ឈ្មោះថា* **អនញ្ញោសិ** *អធិប្បាយថា មិនមានសម្ងាញ់ជាគម្រប់ ២ គឺជាបុគ្គលឯក ព្រោះមិនមានអ្នកដទៃ ដែលខ្លួនត្រូវចិញ្ចឹម ។ ដោយពាក្យនោះ លោកសម្តែងដល់ព្រះថេរៈដែលជាអ្នកចិញ្ចឹមងាយ ។ ពិតហើយ ព្រះថេរៈចិញ្ចឹមចំពោះខ្លួន ដោយចីវរគ្រឿងរក្សាកាយ ដោយបិណ្ឌបាតគ្រឿងរក្សាផ្ទៃ ឈ្មោះថា ជាអ្នកប្រាថ្នាតិចក្រៃលែង ។ មិនចិញ្ចឹមបុគ្គលដទៃណាម្នាក់ ក្នុងបណ្តាញាតិមិត្តជាដើម ព្រោះជាអ្នកមិនជាប់ក្នុងអារម្មណ៍ណាមួយ ។ ម្យ៉ាងទៀត ឈ្មោះថា* **អនញ្ញោសិ** *ព្រោះមិនមានការៈដែលខ្លួនត្រូវអ្នកដទៃណាម្នាក់ចិញ្ចឹម ។ សេចក្តីពិត អ្នកដែលមានបច្ចយ ៤ ទាក់ទងក្នុងទាយកដែលឲ្យបច្ចយប៉ុណ្ណោះ មិនឈ្មោះថា* **អនញ្ញោសិ** *ព្រោះមានការប្រព្រឹត្តទាក់ទងនឹងមនុស្សម្នាក់ ។ ឯព្រះថេរៈអាស្រ័យកម្លាំងស្មង គ្រាច់បិណ្ឌបាត ដោយនយដូចពោលក្នុងគាថាជាដើមថា* **យថាបិ ភមរោ បុប្ផំ** *ជាអ្នកថ្នឹកក្នុងត្រកូលទាំងឡាយជានិច្ច ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយអាហារ ដែលច្របល់គ្នា ។ ពិតហើយ ព្រះមានព្រះភាគទ្រង់សរសើរបុគ្គលនោះ ដោយបដិបទាដែលប្រៀបដូចព្រះចន្ទ ។ បទថា* **អញ្ញាតំ** *ប្រែថា មានកេរ្តិ៍ឈ្មោះប្រាកដ គឺមានកិត្តិយសផ្សាយទៅដោយគុណតាមសេចក្តីពិត ។ ម្យ៉ាងទៀត ឈ្មោះថា មានកេរ្តិ៍ឈ្មោះប្រាកដ ព្រោះជាអ្នកប្រាថ្នាតិច សន្តោស ដោយការៈដែលមិនចិញ្ចឹមអ្នកដទៃនោះឯង ។ ម្យ៉ាងទៀត បទថា* **អញ្ញាតំ** *ឈ្មោះថា អ្នកដទៃមិនស្គាល់ ដោយឲ្យអ្នកដទៃស្គាល់*

ខ្ជូន ព្រោះមិនប្រាថ្នាលាភសក្ការ: និងកេរ្តិ៍ឈ្មោះ ព្រោះលះតណ្ហាបានហើយ ដោយប្រការទាំងពួង ។ សេចក្តីពិត បុគ្គលដែលមិនទាន់ប្រាសចាកតណ្ហា មានការប្រាថ្នាលាមក រមែងឲ្យអ្នកដទៃស្គាល់ខ្ជូន ដោយបំណងនូវការលើកតម្កើង ដោយការបោកបញ្ឆោត ។ បទថា **ធន្តំ** សេចក្តីថា ទូន្មានខ្ជូនហើយ ព្រោះអត្ថថា ទូន្មានខ្ជូនយ៉ាងឧក្រិដ្ឋ ក្នុងឥន្ទ្រិយទាំងឡាយ ដោយអំណាចឆឡង្គុបេក្ខា គឺឧបេក្ខាមានអង្គ ៦ ។ បទថា **សារេ បតិដ្ឋិតំ** បានដល់ តាំងចុះក្នុងវិមុត្តិសារ: ឬតាំងនៅក្នុងសីលសារ:ជាដើម ដែលមានសីលក្ខន្ធ ជារបស់ព្រះអសេក្ខ:ជាដើម ។

បទថា **ខីណាសវំ វន្តទោសំ** សេចក្តីថា ឈ្មោះថា ខីណាសវ: ព្រោះលះអាសវ: ៤ មានកាមាសវ:ជាដើមបានដោយឥតសេសសល់ បន្ទាប់អំពីនោះឯង ឈ្មោះថា **វន្តទោស** ព្រោះខ្ជាក់ចោលនូវទោស មានរាគ:ជាដើមបាន ដោយប្រការទាំងពួង ។ បទថា **តមហំ ព្រូមិ ព្រាហ្មណំ** សេចក្តីថា តថាគតហៅបុគ្គលនោះ គឺបុគ្គលដែលជាព្រាហ្មណ៍ដោយបរមត្ថ ដែលមានគុណតាមដែលពោលហើយថា ជាព្រាហ្មណ៍ ។ ក្នុងទីនេះ គប្បីជ្រាបការផ្សងគ្នានៃទេសនា ដោយន័យដូចពោលហើយខាងដើមនោះឯង ។

អដ្ឋកថាកស្សបសូត្រ ចប់

សុត្តន្តបិដក

ចារ៉ាសូត្រ

[៤៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងអជកលាបកចេតិយ ជាលំនៅនៃអជកលាបកយក្ស ជិតក្រុងបាវា ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីវាល នៅវេលារាត្រីងងឹតអព្ធ ទាំងភ្លៀង ក៏កំពុងរលឹមស្រិបៗ ។ លំដាប់នោះ អជកលាបកយក្ស មានបំណងនឹងធ្វើព្រះមានព្រះភាគឲ្យខ្លាច តក់ស្លុតព្រឺព្រឺងរោមបានចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏មានសម្តីគំហកបន្ទាច ធ្វើសំឡេងសន្ធាប់ខ្លាំងៗ អស់វារៈ ៣ ដង ជិតព្រះមានព្រះភាគថា នែព្រះសមណៈ នុ៎ះន៏បិសាច (ឈរខាងមុខ) ចំពោះលោកហើយ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបបន្ទឺឧទាននេះ ក្នុងវេលានោះថា

កាលណា បុគ្គលណាដល់ត្រើយក្នុងសកធម៌ទាំងឡាយ ក្នុងកាលនោះ បុគ្គលនោះ ឈ្មោះថា ព្រាហ្មណ៍ រមែងគ្របសង្កត់នូវបីសាចផង នូវសំឡេងសន្ធាប់ផងយ៉ាងនេះ ក្នុងកាលនោះ ។ សូត្រទី ៧ ។

អដ្ឋកថា

ចាវាសូត្រ

ចាវាសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ

[៤៤] បទថា **ចាវាយំ** បានដល់ ជិតក្រុងរបស់មល្លក្សត្រ ដែលមានឈ្មោះយ៉ាងនោះ ។ បទថា **អជកលាបកេ ចេតិយេ** បានដល់ ក្នុងទីដែលពួកមនុស្សកោតក្រែង ដែលបានឈ្មោះថា **អជកលាប** ព្រោះយក្ខឈ្មោះអជកលាបៈគ្រប់គ្រង ។ បានឮថា យក្ខនោះទទួលពលីកម្ម ដោយកោជ្ជាសនៃពពែ ដោយការចងពពែឲ្យជាក្រុមៗ មិនមែនទទួលដោយប្រការដទៃទេ ព្រោះដូច្នោះ ទើបប្រាកដឈ្មោះថា **អជកលាបកយក្ខ** ។ តែអាចារ្យពួកខ្លះពោលថា ឈ្មោះថា **អជកលាបកយក្ខ** ព្រោះញុំាងពួកមនុស្សឲ្យស្រែកដូចពពែ បានឮថា ក្នុងពេលពួកមនុស្សនាំពលីកម្មទៅ បូជាដល់អជកលាបកយក្ខ ត្រូវស្រែកដូចសំឡេងពពែ ហើយនាំពលីកម្មចូលទៅ យក្ខនោះក៏ត្រេកអរ ព្រោះដូច្នោះ ទើបគេហៅថា **អជកលាបកយក្ខ** ។ យក្ខនោះសម្បូរដោយអានុភាពរឹងត្អឹង កាច នៅអាស្រ័យទីនោះ ព្រោះដូច្នោះ ទើបពួកមនុស្សធ្វើទីនោះឲ្យជាទីគោរព កោតក្រែង នាំពលីកម្មចូលទៅសព្វកាល ព្រោះហេតុនោះ ទើបលោកពោលថា **អជកលាបយក្ខេ ចេតិយេ** ។ បទថា **អជកលាបកស្ស យក្ខស្ស ភវនេ** បានដល់ ដែលជាវិមានរបស់យក្ខនោះ ។

បានឮថា ក្នុងគ្រានោះ ព្រះសាស្តាបំណងនឹងទូន្មានយក្ខនោះក្នុងពេលល្ងាច ទ្រង់យាងទៅមួយព្រះអង្គឯង មិនមានសម្ងាញ់ជាគម្រប់ ២ ទ្រង់កាន់

ជាត្រ និងចីវរ ហើយយាងទៅកាន់ទ្វារលំនៅរបស់អជកលាបកយក្ខ ។ ទើប ទ្រង់សុំអ្នកយាមទ្វារយក្ខនោះ ដើម្បីចូលទៅកាន់លំនៅ ។ អ្នកយាមទ្វារទូល ថា បពិត្រព្រះអង្គដ៏ចម្រើន អជកលាបកយក្ខ ជាបុគ្គលគ្រោតគ្រោត មិនធ្វើ សេចក្តីគោរពសមណៈ ឬព្រាហ្មណ៍ ព្រោះដូច្នោះ សូមទ្រង់ជ្រាបចុះ តែខ្ញុំ ព្រះអង្គមិនជ្រាប់ដល់យក្ខនោះ មិនសមគួរ ហើយរួតរះទៅកាន់លំនៅរបស់ អជកលាបកយក្ខ ដែលទៅកាន់សមាគមយក្ខ ក្នុងខណៈនោះឯង ។ ព្រះ សាស្តាយាងចូលទៅខាងក្នុងលំនៅ ហើយប្រថាប់គង់លើបញ្ញត្តាសនៈ ក្នុង មណ្ឌប ជាទីអង្គុយរបស់អជកលាបកយក្ខ ។ ពួកស្នំយក្ខចូលទៅគាល់ព្រះ សាស្តាថ្វាយបង្គំ ហើយបានឈរក្នុងចំណែកម្ខាង ។ ព្រះសាស្តាបានសម្តែង ធម្មីកថាដែលគួរដល់កាល ដល់ស្នំយក្ខទាំងនោះ ។ ដោយហេតុនោះ ទើប លោកពោលថា ប្រថាប់នៅត្រង់អជកលាបកចេតិយ ដែលជាលំនៅរបស់ អជកលាបកយក្ខ ជិតក្រុងជាវា ។

សម័យនោះ សាតាគីរយក្ខ និងហេមវតាយក្ខ បានទៅកាន់សមាគម យក្ខតាមអាកាសខាងលើលំនៅរបស់អជកលាបកយក្ខ កាលទៅមិនរួច ទើប អាវជ្ជនៈថា មានហេតុអ្វីហ្ន៎ បានឃើញព្រះសាស្តា គង់ប្រថាប់ក្នុងលំនៅនៃ អជកលាបកយក្ខ ទើបចូលទៅក្នុងទីនោះ ថ្វាយបង្គំព្រះមានព្រះភាគហើយ ទូលលាថា ខ្ញុំព្រះអង្គទៅកាន់ទីប្រជុំយក្ខ ធ្វើប្រទក្សិណ ហើយចៀសចេញ ទៅ ឃើញអជកលាបកយក្ខ ក្នុងទីប្រជុំយក្ខ ទើបសម្តែងសេចក្តីត្រេកអរថា នៃអជកលាបកៈ ព្រះមានព្រះភាគជាអគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោក

គង់ប្រថាប់ក្នុងលំនៅរបស់អ្នក នេះជាលាភរបស់អ្នក ចូរអ្នកទៅគាល់ព្រះមានព្រះភាគ ស្តាប់ធម៌ចុះ ។ អជកលាបកយក្ខនោះ បានស្តាប់ពាក្យរបស់សាតាគិរិយក្ខ និងហេមវតាយក្ខហើយ គិតថា យក្ខទាំងនេះបានជ្រាប់អញថា សមណៈត្រង៉ោល អង្គុយត្រង់លំនៅរបស់អញ ត្រូវសេចក្តីក្រោធគ្របសង្កត់ គិតថា ថ្ងៃនេះ អញនឹងធ្វើសង្គ្រាមជាមួយសមណៈនោះ កាលយក្ខឈប់ប្រជុំ ទើបក្រោកឡើងអំពីទីនោះ យកជើងស្តាំជាន់កំពូលភ្នំប្រមាណ ៦០ យោជន៍ កំពូលភ្នំនោះ ក៏បែកជា ២ ចំណែក ។ ពាក្យដែលគួរពោលក្នុងទីនេះ គប្បីជ្រាបដោយនយក្នុងអដ្ឋកថា អាឡវកសូត្រនោះឯង ។

ពិតហើយ សមាគមរបស់អជកលាបកយក្ខ ក៏ដូចសមាគមរបស់អាឡវកយក្ខនោះឯង តែវៀរការសាកសួរបញ្ហា ការដោះស្រាយបញ្ហា និងការយាងចេញអំពីលំនៅ និងការចូលទៅ ៣ ដង ។ លុះអជកលាបកយក្ខមកដល់ប៉ុណ្ណោះ ក៏គិតថា អញនឹងដេញសមណៈនោះ ដោយក្លៀងទាំងនេះ ទើបធ្វើក្លៀង ៩ ប្រភេទ មានវាតមណ្ឌលជាដើម ឲ្យតាំងឡើង កាលមិនអាចធ្វើត្រឹមតែជាយថាវរបស់ព្រះមានព្រះភាគឲ្យកម្រើក ដោយព្យុះទាំងនោះបាន ក៏និម្មិតពួកកូតដែលមានរូបគួរខ្លាចក្រៃលែង កាន់គ្រឿងប្រហារច្រើនប្រភេទ ចូលទៅរកព្រះមានព្រះភាគ មួយអន្ទើដោយពួកកូតទាំងនោះត្រាច់ទៅជុំវិញ សូម្បីធ្វើអាការប្លែកៗ មានប្រការផ្សេងៗ មួយយប់ទល់ភ្លឺ ក៏មិនអាចធ្វើឲ្យព្រះមានព្រះភាគ ឃ្លាតចាកទីប្រថាប់គង់ សូម្បីត្រឹមមួយចម្រៀកសក់ ក៏នេះដោយអំណាចសេចក្តីក្រោធតែម្យ៉ាងថា សមណៈនេះ មិនជ្រាប់

អញ្ញសោះ ចូលទៅអង្គុយត្រង់លំនៅរបស់អញ ។ កាលព្រះមានព្រះភាគ ទ្រង់ជ្រាបការប្រព្រឹត្តទៅនៃចិត្តរបស់យក្ខនោះ ទើបទ្រង់ព្រះតម្រិះថា បុគ្គលលាបប្រមាត់ត្រង់ច្រមុះឆ្កែ កាលបើដូច្នេះ ឆ្កែនោះ រឹងរឹតតែកាចក្រៃលែងឡើង យ៉ាងណា យក្ខនេះក៏ដូច្នោះដូចគ្នា កាលតថាគតអង្គុយក្នុងទីនេះ ក៏ក្រោធក្រៃលែង ដូច្នោះ តថាគតគប្បីចេញទៅខាងក្រៅ ហើយទ្រង់ក៏ចេញអំពីលំនៅ ប្រថាប់គង់ក្នុងទីវាល ដោយហេតុនោះ ទើបលោកពោលថា គ្រានោះឯង ព្រះមានព្រះភាគ គង់ប្រថាប់ក្នុងទីវាល ក្នុងពេលងងឹតនៃរាត្រីដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រត្តន្ធការតិមិសាយំ** *ប្រែថា ក្នុងងងឹតនៃរាត្រី អធិប្បាយថា ក្នុងការងងឹតខ្លាំង រៀរការកើតនៃចក្ខុវិញ្ញាណ ។ បានឮថា ក្នុងពេលនោះ ងងឹតប្រកបដោយអង្គ ៤ កើតឡើង ។ បទថា* **ឧរោ** *បានដល់ មេឃញ៉ាំងតំណក់ទឹកគ្រាប់តូចៗ ឲ្យធ្លាក់ចុះ ។ លំដាប់នោះ យក្ខគិតថា អញនឹងឲ្យសមណៈនេះគេចទៅដោយការភ័យខ្លាចនឹងសំឡេងនេះ ទើបចូលទៅកាន់ទីជិតព្រះមានព្រះភាគ ហើយធ្វើសំឡេងដែលគួរខ្លាច ដោយន័យជាដើមថា* **អក្កុល អក្កុល** *ដោយហេតុនោះ ទើបលោកពោលពាក្យជាដើមថា* **អថខោ អជកលាបកោ** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **ភយំ** *បានដល់ ការភ័យខ្លាចនៃចិត្ត ។ បទថា* **ជម្ភិតត្តំ** *បានដល់ ភាវៈដែលសរីរៈស្រៀវខ្លាច មានការរើងក្ងៀ ។ បទថា* **លោមហំសំ** *បានដល់ ភាវៈដែលព្រឺរោម ។ ដោយបទទាំង ៣ លោកសម្តែង*

ចំពោះការកើតសេចក្តីខ្លាច ។ បទថា **ឧបសង្កមិ** *សួរថា ព្រោះហេតុអ្វី យក្ខនេះមានបំណងយ៉ាងនេះ ចូលទៅរកបានធ្វើអាការប្លែក ដែលខ្លួនធ្វើក្នុងកាលមុន មិនមែនឬ ។ ឆ្លើយថា បានធ្វើក៏ពិត តែយក្ខសម្គាល់ថា អញមិនអាចធ្វើអ្វីដល់សមណៈ ដែលប្រថាប់ខាងក្នុងលំនៅក្នុងទីដែលមិនមានភ័យ ក្នុងទីដែលមាំទាំ ឥឡូវនេះ អញអាចឲ្យសមណៈដែលនៅខាងក្រៅភ័យខ្លាចយ៉ាងនេះហើយ គេចទៅ ទើបចូលទៅរកព្រះមានព្រះភាគអង្គនោះ ។ សេចក្តីពិត យក្ខនេះសម្គាល់ទីលំនៅរបស់ខ្លួនថា មាំទាំ និងសម្គាល់ថា សមណៈនេះមិនខ្លាច ព្រោះនៅក្នុងលំនៅរបស់ខ្លួន ។*

បទថា **តិក្ខត្តុំ អក្កោសោ បក្កោសោតិ អក្កុសបក្កុសិកំ អកាសិ** *សេចក្តីថា យក្ខបានធ្វើសំឡេងបែបនេះថា* **អក្កោសោ បក្កោសោ** *៣ ដង ដើម្បីឲ្យទ្រង់ខ្លាច ។ សេចក្តីពិត នេះជាសំឡេងធ្វើតាម ព្រោះថា ពេលនោះ យក្ខនោះ ហាក់ដូចជាបុគ្គលវិសេស លើកភ្នំសិនេរុ និងដូចក្រឡប់មហាព្រឹថពី ឲ្យលាន់នូវសំឡេង ដូចសំឡេងអសនីបាតរាប់រយធ្លាក់ចុះមកដោយខណៈតែមួយ ធំ ដូចសំឡេងគ្រហឹមរបស់ដីរប្រចាំទិស ដែលរួមគ្នាជាហ្វូង ក្នុងទីតែមួយ ហើយស្រែក ដូចសំឡេងសីហនាទរបស់កេសរសីហៈ ដូចសំឡេង* **ហុំ ហុំ** *របស់ពួកយក្ខ ដូចសំឡេងខ្លាំងរបស់កូតបិសាច ដូចសំឡេងទះដៃរបស់ពួកអសុរដូចសំឡេងរំពងនៃវជិរ ដែលស្តេចទេវរាជគ្រវែងមក ដូចសំឡេងរំពងរបស់មហាព្យុះ ដែលតាំងនៅអស់មួយកប្ប ជាសំឡេងញាំញី និងគ្របសង្កត់សំឡេងដទៃៗ ព្រោះជាសំឡេងជ្រៅ ធំទូលាយ និងធ្វើការភ័យខ្លាចឲ្យ*

ជល់ខ្លួន និងដូចសំឡេងដែលជាភ័យចំពោះមុខដ៏ក្រៃលែង ហាក់ដូចពុះបេះដូងនៃពួកបុថុជ្ជន ព្រោះសំឡេងដែលបន្លឺចេញ ដោយគិតថា អញនឹងឲ្យសមណៈនេះខ្លាច ដោយសំឡេងនេះ ហើយគេចទៅ ភ្នំក៏បែកជាបំណែករមៀលចុះមកស្ទឹកឈើ ផ្លែឈើ ផ្កាឈើ និងគុម្ពវល្លិ៍ទាំងអស់ ដែលនៅតាមដើមក្នុងព្រៃក៏ជ្រុះចុះ ភ្នំហិមពាន្តទំហំ ៣ ពាន់យោជន៍ក៏រង្គើញាប់ញ័រ កក្រើកទៅដោយច្រើន សូម្បីពួកទេវតា តាំងពីភុម្មទេវតាជាដើមទៅ មានការភ័យខ្លាចតក់ស្លុតព្រឺរោម ព្រឺស្បែកទាំងអស់ នឹងពោលទៅថ្វី ដល់ពួកមនុស្ស និងសត្វដែលមានជើង ២ និងជើង ៤ ការតក់ស្លុតច្រើន ហាក់ដូចជាមហាប្រឹថពីស្រុតកោលាហល បានកើតឡើងក្នុងជម្ពូទ្វីបទាំងមូល ។ ឯព្រះមានព្រះភាគ ទ្រង់មិនបានសម្គាល់សំឡេងនោះ ថាជាអ្វីឡើយ ទ្រង់គង់ប្រថាប់ស្ងៀម ទ្រង់អធិដ្ឋានថា ដោយហេតុនេះ អន្តរាយកុំបីមានដល់សត្វណាមួយឡើយ ។

ព្រោះហេតុដែលសំឡេងនោះ មកប្រាកដតាមសោតទ្វារបស់សត្វទាំងឡាយ ដោយអាការយ៉ាងនេះថា **អក្កុល បក្កុល** *ដូច្នោះ ទើបលោកអាចារ្យលើកឡើងកាន់សង្គហៈថា យក្ខបានបន្លឺសំឡេងថា* **អក្កុល បក្កុល** *ដោយអធិប្បាយថា ឈ្មោះថា* **អក្កុល បក្កុល** *ព្រោះធ្វើតាមសំឡេងនោះ និងថា ការបន្លឺសំឡេងថា* **អក្កុល បក្កុល** *មាននៅក្នុងការដែលយក្ខបន្លឺសំឡេងកងរំពងនោះ ។ តែអាចារ្យពួកខ្លះពោលថា យក្ខបន្លឺសំឡេងតាមភាសានេះថា* **អក្កុល បក្កុល** *ដោយឈ្មោះម្យ៉ាងទៀត ពីរបទថា* **អាកុល ព្យាកុល** *ដូចពាក្យថា* **ឯក ឯកក** ។ *ព្រោះហេតុដែល* **អា** *អក្ខរៈ ដែល*

កើតគ្រាតែមួយ មានជាដើមថា **អាកុល** *ព្រោះកើត ដោយការកើតគ្រាជំបូងនោះឯង និងធ្វើ* **អា** *អក្ខរៈនោះឲ្យមានសំឡេងខ្លី ដោយចុះ* **ក** *អាគមដូច្នេះ ។ តែដែលកើត ២ វារៈ ជា* **បក្កុល** *ឯ* **កុល** *សព្ទ ក្នុងទីនេះ ជាបរិយាយរបស់ជាតិ ដូចក្នុងប្រយោគថា* **កោលំកោល** *ជាដើម និងការប្រកបសព្ទ ជាការផ្ទាស់បំណងដែលលោកពោលហេតុនោះ បទទី ១ លោកពោលដល់ជលាពុជកំណើត មានសីហៈ និងព្យគ្ឃៈ (ខ្លា) ជាដើម ។ បទទី ២ ពោលដល់អណ្ឌជកំណើត មានពស់ និងពស់វែកជាដើម ព្រោះដូច្នោះ អាចារ្យពួកជទៃពោលថា យក្ខសម្តែងបទនេះ ដោយ ២ បទថា* **អហន្តេ ជីវិតហារកោ** *ខ្ញុំនាំជីវិតរបស់អ្នកទៅ ដូចសីហៈជាដើម និងពស់ជាដើម ។ តែអាចារ្យមួយពួកទៀត ពោលជាបាលីថា* **អក្កុល ភក្កុល** *ហើយពោលអត្ថរបស់ ២ បទនោះថា ដែលឈ្មោះថា* **អក្កុល** *ព្រោះទៅ គឺប្រព្រឹត្តទៅ ដើម្បីទម្លាយឲ្យអស់ទៅ ឲ្យវិនាសទៅ ដែលឈ្មោះថា* **ភក្កុល** *ព្រោះទៅដើម្បីស៊ី គឺទំពាស៊ី អត្ថនោះ គឺអ្វី គឺបុគ្គលណាម្នាក់ មានយក្ខ អារក្ខទឹក បិសាច សីហៈ និងខ្លាជាដើមណាមួយ ដែលជាអ្នកនាំសេចក្តីវិនាសមកឲ្យដល់ពួកមនុស្ស ក្នុងទីនេះ គប្បីជ្រាបអធិប្បាយអត្ថដោយន័យ ដូចពោលហើយខាងដើមនោះឯង ។*

បទថា **ឯសោ តេ សមណ បិសាចោ** *សេចក្តីថា យក្ខនិម្មិតរូបគួរខ្លាចធំ គួរស្បើម ឈរត្រង់ព្រះភក្ត្រព្រះមានព្រះភាគ ពោលសំដៅដល់ខ្លួនថា សមណៈ បិសាចដែលស៊ីសាច់ប្រាកដដល់អ្នកហើយ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ដឹងការប្លែកនេះ ដែលឃុំឲ្យប្រព្រឹត្តទៅតាមផ្លូវកាយ និងវាចា និងដឹងភាពដែលខ្លួនអស់ឧបក្កិលេសក្នុងលោកធម៌ ជាហេតុនៃអាការដែលឃុំនោះសង្កត់សង្កិនមិនបាន ដោយអាការទាំងពួង បទថា* **តាយំ វេលាយំ** *បានដល់ ពេលដែលធ្វើអាការប្លែកនោះ ។ បទថា* **ឥមំ ឧទានំ ឧទានេសិ** *សេចក្តីថា មិនគិតដល់អាការប្លែកនោះ ទ្រង់បន្ទឺឧទាននេះ ដែលសម្តែងធម្មានុភាព មានការមិនអាវជ្ជនៈដល់អាការប្លែកនោះជាហេតុ ។*

បណ្តាបទទាំងនោះ បទថា **យទា សកេសុ ធម្មេសុ** *បានដល់ ធម៌ គឺឧបាទានក្ខន្ធ ៥ ពោល គឺអត្តភាពរបស់ខ្លួនក្នុងកាលណា ។ បទថា* **ចារគ្គូ** *សេចក្តីថា ជាអ្នកដល់នូវត្រើយនៃការបរិបូណ៌នៃបរិញ្ញាភិសមយ ។ បន្ទាប់អំពីនោះឯង បុគ្គលដល់ត្រើយដោយការបរិបូណ៌នៃបហានាភិសមយ សច្ឆិកិរិយាភិសមយ និងភាវនាភិសមយក្នុងសមុទយៈ ជាហេតុនៃឧបាទានក្ខន្ធទាំងនោះ ក្នុងនិរោធដែលមានលក្ខណៈមិនទៅតាមសមុទយៈនោះ និងក្នុងនិរោធគាមិនីបដិបទា ។ បទថា* **ហោតិ ព្រាហ្មណោ** *សេចក្តីថា ឈ្មោះថាជាព្រាហ្មណ៍ ព្រោះជាបុគ្គលបន្សាត់នូវបាបដោយអាការទាំងពួង ដោយប្រការដូច្នេះ ។ សេចក្តីពិត ការត្រាស់ដឹងសច្ចៈ ៤ រមែងមានដោយការឈមចុះកាន់អត្តភាពរបស់ខ្លួន ដោយប្រការទាំងពួង ។ សមដូចពាក្យដែលលោកពោលជាដើមថា*

តថាគតសម្តែងនូវលោក គឺទុក្ខសច្ចផង នូវហេតុជាទីកើតឡើងនៃលោក គឺសមុទយសច្ចផង នូវទីរលត់នៃលោក គឺនិរោធសច្ចផង នូវបដិបទាជាហេតុទៅកាន់ទីរលត់នៃលោក គឺមគ្គសច្ចផង ក្នុង អត្តភាពប្រមាណមួយព្យាម ដែលប្រកបដោយសញ្ញា ប្រកបដោយចិត្តនេះទេតើ ។

ម្យ៉ាងទៀត បទថា **សកេសុ ឆម្មេសុ** បានដល់ ក្នុងធម៌របស់ខ្លួន ឈ្មោះថា ធម៌របស់ខ្លួន បានដល់ ធម៌ មានសីលជាដើម របស់បុគ្គលដែលស្រឡាញ់ខ្លួន ។ ពិតហើយ ភោទានធម៌ មានសីល សមាធិ បញ្ញា និងវិមុត្តិជាដើម ឈ្មោះថា ធម៌របស់មនុស្ស គឺរបស់ខ្លួន ព្រោះញុំាងហិតសុខឲ្យបរិបូណ៌ដោយចំណែកមួយ មិនជាធម៌របស់អ្នកដទៃ ដូចសង្កិលេសធម៌ដែលនាំសេចក្តីវិនាសមកឲ្យ ។ បទថា **ចារគ្គ** បានដល់ ដល់នូវត្រើយ គឺទីបំផុត សេចក្តីបរិបូណ៌នៃធម៌ មានសីលជាដើមនោះ ។ ក្នុងធម៌ទាំងនោះ ដំបូង ឈ្មោះថា សីល មាន ២ យ៉ាង គឺលោកិយសីល ១ លោកុត្តរសីល ១ ។ ក្នុងសីលទាំងនោះ លោកិយសីល ជាសីលខាងដើម សីលខាងដើមនោះ ពោលដោយសង្ខេប មាន ៤ យ៉ាង មានជាតិមោក្ខសំវរសីលជាដើម តែពោលដោយពិស្តារ មានច្រើនប្រភេទ ។ លោកុត្តរសីល មាន ២ យ៉ាង គឺមគ្គសីល ១ ផលសីល ១ ។ តែពោលដោយអត្ថ បានដល់ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ។ សមាធិ និងបញ្ញា មាន ២ យ៉ាង ជាលោកិយ ១ ជាលោកុត្តរ ១ ដូចសីលដែរ ។ សមាធិ ២ យ៉ាងនោះ លោកិយ-សមាធិ បានដល់ សមាបត្តិ ៨ មួយអន្ទើដោយឧបចារៈ លោកុត្តរសមាធិ

បានដល់ សមាធិដែលទាក់ទងក្នុងមគ្គ ។ ឯបញ្ញាដែលជាលោកិយ បានដល់ សុតមយបញ្ញា ចិន្តាមយបញ្ញា និងភាវនាមយបញ្ញា ដែលនៅមានអាសវៈ ឯលោកុត្តរបញ្ញា បានដល់ បញ្ញាដែលសម្បយុត្តដោយមគ្គ និងផល ។ ឈ្មោះថា វិមុត្តិ បានដល់ ផលវិមុត្តិ និងនិព្វាន ។ ព្រោះដូច្នោះទើបវិមុត្តិនោះ ជាលោកុត្តរតែម្យ៉ាង ។ វិមុត្តិញ្ញាណទស្សនៈ ជាលោកិយតែម្យ៉ាង វិមុត្តិញ្ញាណទស្សនៈនោះ មាន ១៩ យ៉ាង ព្រោះជាបច្ចវេក្ខ-ណញ្ញាណ ។ ឈ្មោះថា ជាអ្នកដល់ត្រើយ គឺទីបំផុត ព្រោះសេចក្តីបរិបូណ៌នៃធម៌ មានសីលជាដើមទាំងនេះ ដែលកើតឡើងដោយឥតសេសសល់ ព្រោះសម្រេចអរហត្ត ក្នុងសន្តានរបស់ខ្លួន ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះទើបឈ្មោះថា ដល់ត្រើយក្នុងធម៌របស់ខ្លួន ។ ម្យ៉ាងទៀត ឈ្មោះថា ដល់ត្រើយក្នុងសីល ព្រោះសម្រេចសោតាបត្តិផល ។ ពិតហើយ សោតាបន្ននោះ លោកហៅថា ធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ។ ក្នុងទីនេះ ព្រះសកទាគាមី ឈ្មោះថា លោកកាន់យកដោយសោតាបន្នសព្វជួចគ្នា ឈ្មោះថា ជាអ្នកដល់ត្រើយក្នុងសមាធិ ព្រោះសម្រេចអនាគាមិផល ។ ពិតហើយ ព្រះអនាគាមីនោះ លោកហៅថា ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ឈ្មោះថា ជាអ្នកដល់ត្រើយក្នុងធម៌ ៣ ក្រៅអំពីនេះ ព្រោះសម្រេចអរហត្តផល ។ ពិតហើយ ព្រះអរហន្ត ឈ្មោះថា ជាអ្នកដល់នូវត្រើយក្នុងបញ្ញាវិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈ ព្រោះសម្រេចចេតោវិមុត្តិ ដែលជាអកុប្បធម៌ដ៏កំពូលដោយការដល់នូវភាពបរិបូណ៌ ដោយបញ្ញា និងព្រោះដល់ទីបំផុតនៃបច្ចវេក្ខ-

ណញ្ញាណ ឈ្មោះថា ជាអ្នកដល់នូវត្រើយក្នុងធម៌របស់ខ្លួន ក្នុងកាលណា តាមដែលពោលហើយ ព្រោះសម្រេចកិច្ច ១៦ យ៉ាង មានបរិញ្ញាកិច្ចជាដើម ដោយមគ្គ ៤ ក្នុងអរិយសច្ច ៤ ដោយប្រការទាំងពួង ។ បទថា **ហោតិ ព្រាហ្មណោ** *សេចក្តីថា ក្នុងកាលនោះ បុគ្គលនោះ ឈ្មោះថា ជាព្រាហ្មណ៍ ដោយបរមត្ថ ព្រោះជាអ្នកបន្សាត់បាបធម៌ចេញបាន ។ បទថា* **អថ ឱតំ បិសាចញ្ច បក្កុលញ្ចាតិ វត្តតិ** *សេចក្តីថា ម្នាលអជកលាបក: ក្នុងកាលខាងក្រោយអំពីដល់ត្រើយដែលពោលហើយនោះ បុគ្គលមិនកន្ទង គឺឈានកន្ទងគ្របសង្កត់ មិនខ្លាចបិសាចដែលមកស៊ីសាច់ ដែលអ្នកសម្តែងហើយនោះ និងសំឡេង* **អក្កុល ពក្កុល** *ដែលតាំងឡើង ឲ្យកើតសេចក្តីខ្លាច ។*

គាថានេះ លោកពោលសរសើរចំពោះអរហត្ត ។ គ្រានោះ អជក-លាបកយក្ខឃើញការមាំទាំនោះ ព្រោះព្រះមានព្រះភាគ ទ្រង់មិនញាប់ញ័រ សូម្បីការខ្លាចដែលមានភ័យកើតចំពោះមុខបែបនោះ ដែលខ្លួនធ្វើហើយ ក៏មានចិត្តជ្រះថ្លាថា សមណៈនេះជាមនុស្សអស្ចារ្យហ្ន៎ កាលប្រកាសដល់សទ្ធាដែលជារបស់បុថុជ្ជនតាំងមាំក្នុងខ្លួន ទើបប្រកាសភាពជាឧបាសក ចំពោះព្រះភក្ត្រព្រះសាស្តា ។

អដ្ឋកថាចារ្យាសូត្រ ចប់

សុត្តន្តបិដក

សង្គាមជិសូត្រ

[៤៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះ ព្រះសង្គាមជិដ៏មានអាយុ បានទៅនគរសាវត្ថី ដើម្បីជួបព្រះមានព្រះភាគ ។ ឯបុរាណទុតិយិកា របស់ព្រះសង្គាមជិដ៏មានអាយុ បានឮដំណឹងថា អើ ឮថា ព្រះសង្គាមជិ មកដល់នគរសាវត្ថីហើយ ។ នាងនោះបាននាំទារកទៅឯវត្តជេតពន ។ សម័យនោះ ព្រះសង្គាមជិដ៏មានអាយុ កំពុងអង្គុយនៅក្នុងវេលាថ្ងៃ កែ្បរគល់ឈើមួយដើម ។ លំដាប់នោះ បុរាណទុតិយិការបស់ព្រះសង្គាមជិដ៏មានអាយុ បានចូលទៅរកព្រះសង្គាមជិដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះសង្គាមជិដ៏មានអាយុថា បពិត្រសមណៈ សូមលោកចិញ្ចឹមខ្ញុំ ទាំងកូនតូចផង ។ និមិត្តតែបុរាណទុតិយិកានោះ ពោលយ៉ាងនេះហើយ ព្រះសង្គាមជិដ៏មានអាយុនៅស្ងៀម ។ បុរាណទុតិយិការបស់ព្រះសង្គាមជិដ៏មានអាយុ បានពោលនឹងព្រះសង្គាមជិដ៏មានអាយុជាគម្រប់ ២ ដង យ៉ាងនេះទៀតថា បពិត្រសមណៈ សូមលោកចិញ្ចឹមខ្ញុំ ទាំងកូនតូចផង ។ ព្រះសង្គាមជិដ៏មានអាយុ នៅស្ងៀមអស់វារៈ ២ ដង ។ បុរាណទុតិយិការបស់ព្រះសង្គាមជិដ៏មានអាយុ ក៏ទទូចនិយាយនឹងព្រះសង្គាមជិដ៏មានអាយុជាគម្រប់ ៣ ដងថា បពិត្រសមណៈ សូមលោកចិញ្ចឹមខ្ញុំ ទាំងកូនតូចផង ។ ព្រះសង្គាមជិដ៏មានអាយុ ក៏នៅស្ងៀមអស់វារៈ ៣ ។ លំដាប់នោះ បុរាណ-

ទុតិយិការបស់ព្រះសង្គ្រាមជិដ៏មានអាយុ បានយកទារកតូចនោះ ទៅជាក់អំពីមុខព្រះសង្គ្រាមជិដ៏មានអាយុ រួចនិយាយថា បពិត្រសមណៈ នេះជាកូនប្រុសរបស់លោក លោកចិញ្ចឹមវាផង៦ចុះ រួចហើយក៏ដើរចេញទៅ ។ ឯព្រះសង្គ្រាមជិដ៏មានអាយុ មិនរមិលមើល មិនហៅរកនូវកូនតូចនោះសោះ ។ លំដាប់នោះ បុរាណទុតិយិការបស់ព្រះសង្គ្រាមជិដ៏មានអាយុ កាលដើរចេញទៅ មិនឆ្ងាយប៉ុន្មាន ក៏ងាកមើលមកឃើញព្រះសង្គ្រាមជិដ៏មានអាយុ ដែលមិនរមិលមើល មិនហៅរកកូនតូចនោះសោះ ស្ត្រីនោះលុះឃើញហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា សមណៈនេះ មិនត្រូវការដោយកូនប្រុសទេតើ ។ បុរាណទុតិយិកានោះ ក៏ត្រឡប់អំពីទីនោះ មកយកកូនតូចនោះវិញ ដើរចេញទៅ ។ ព្រះមានព្រះភាគ បានទតឃើញនូវអាការដ៏ប្លែកប៉ែបយ៉ាងនេះ នៃបុរាណទុតិយិការបស់ព្រះសង្គ្រាមជិដ៏មានអាយុ ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្ទងចក្ខុរបស់មនុស្សធម្មតា ។ លុះព្រះមានព្រះភាគ ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបបន្ទឺនូវឧទាននេះ ក្នុងវេលានោះថា

> កិក្ខុណា មិនត្រេកត្រអាលនឹងស្ត្រីដែលមករក មិនស្តាយស្ត្រីដែលគេចចេញទៅ តថាគតហៅបុគ្គលនោះថា ជាព្រាហ្មណ៍ ដូចជាកិក្ខុឈ្មោះ សង្គ្រាមជិ ដែលរួចស្រឡះហើយចាកគ្រឿងជាប់ គឺ កិលេស ។ សូត្រទី ៨ ។

អដ្ឋកថា

សង្គាមជិសូត្រ

សង្គាមជិសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ

[៤៥] *បទថា* **សង្គាមជិ** *បានដល់ មានឈ្មោះយ៉ាងនេះ ។ ពិត*
ហើយ លោកមានអាយុអង្គនោះ ជាកូនរបស់សេដ្ឋី មានសម្បត្តិច្រើនម្នាក់
ក្នុងក្រុងសាវត្ថី វេលាចម្រើនវ័យ មាតា បិតា ឲ្យមានគ្រួសារដោយសមគួរ ។
ប្រគល់ទ្រព្យសម្បត្តិឲ្យ ឲ្យនៅគ្រប់គ្រងផ្ទះ ថ្ងៃមួយ គាត់ឃើញឧបាសកក្នុង
ក្រុងសាវត្ថី កំពុងថ្វាយទាន សមាទានសីលអំពីព្រលឹម ស្បៀកសំពត់ស
កាន់គ្រឿងក្រអូប និងផ្កាជាដើម ឆ្ពោះមុខទៅកាន់វត្តជេតពន ដើម្បីស្តាប់ធម៌
ក្នុងពេលល្ងាច ទើបសួរថា អ្នកទាំងឡាយទៅណា ។ កាលជនទាំងនោះ
ឆ្លើយថា ទៅសម្នាក់ព្រះសាស្តាក្នុងវត្តជេតពន ដើម្បីស្តាប់ធម៌ ទើបពោល
ថា បើដូច្នោះ ខ្ញុំក៏នឹងទៅ ទើបទៅជាមួយជនទាំងនោះ ។ សម័យនោះឯង
ព្រះមានព្រះភាគ ប្រថាប់គង់លើបវរពុទ្ធាសនៈ ដែលគេរៀបចំក្នុងមណ្ឌប
សម្រាប់ស្តាប់ព្រះសទ្ធម្ម សម្តែងធម៌ក្នុងកណ្តាលបរិស័ទ ៤ ដូចកេសរ-
សីហៈបន្ទឺសីហនាទក្នុងគុហាមាស ។ សម័យនោះឯង ឧបាសកទាំងនោះ
ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយនាចំណែកម្ខាង ។ ឯសង្គាមជិកុលបុត្រ
អង្គុយស្តាប់ធម៌ចុងបរិស័ទនោះ ព្រះមានព្រះភាគត្រាស់អនុបុព្វីកថា ប្រកាស
សច្ចៈ ៤ ក្នុងពេលចប់សច្ចៈ សត្វច្រើនពាន់បានត្រាស់ដឹងធម៌ ។ ឯសង្គាម-
ជិកុលបុត្រ ក៏សម្រេចសោតាបត្តិផល កាលបរិស័ទចេញទៅហើយ ចូល

ទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ទូលសូមបព្វជ្ជាថា បពិត្រព្រះមានព្រះភាគ សូមទ្រង់ឲ្យខ្ញុំព្រះអង្គបួសចុះ ព្រះមានព្រះភាគត្រាស់សួរថា មាតា បិតាអនុញ្ញាតឲ្យអ្នកបព្វជ្ជាហើយឬ ។ បុរសនោះក្រាបទូលថា មិនទាន់អនុញ្ញាតទេ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលសង្គាមជិ ព្រះតថាគតទាំងឡាយ មិនបំបួសកុលបុត្រ ដែលមាតាបិតាមិនអនុញ្ញាតឡើយ ។ សង្គាមជិទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ នឹងធ្វើដោយមាតាបិតាអនុញ្ញាតឲ្យខ្ញុំព្រះអង្គបួស ដូច្នេះហើយ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ចូលទៅរកមាតា បិតា ពោលថា លោកឪពុក អ្នកម្តាយ សូមអនុញ្ញាតឲ្យខ្ញុំបួសចុះ ។ បន្ទាប់អំពីនោះ គប្បីជ្រាបតាមន័យដែលពោលមកហើយ ក្នុងរដ្ឋបាលសូត្រ ។ គ្រានោះ គាត់ប្តេជ្ញាថា បួសហើយនឹងបង្ហាញខ្លួន កាលមាតាបិតាអនុញ្ញាតហើយ ចូលទៅគាល់ព្រះមានព្រះភាគ ទូលសូមបព្វជ្ជា ។ ហើយគាត់ក៏បានបព្វជ្ជាឧបសម្បទា ក្នុងសម្នាក់ព្រះមានព្រះភាគ ។ កាលលោកឧបសម្បទាបានមិនយូរ ក៏ព្យាយាមដើម្បីសម្រេចមគ្គខ្ពស់ឡើងៗ នៅចាំវស្សាក្នុងអរញ្ញវាសមួយកន្លែង បានអភិញ្ញា ៦ ចេញវស្សាហើយ ទៅកាន់ក្រុងសាវត្ថី គាល់ព្រះមានព្រះភាគ និងដោះពាក្យប្តេជ្ញាមាតាបិតា ។ ហេតុនោះ ទើបលោកពោលថា **តេន ខោ បន សមយេន អាយស្មា សង្គាមជិ សាវត្ថឹ អនុប្បត្តោ ហោតិ** *ដូច្នេះ ។*

ព្រះសង្គាមជិនោះ ត្រាច់បិណ្ឌបាតក្នុងជួរគាម ត្រឡប់អំពីបិណ្ឌបាត ខាងក្រោយភត្ត ចូលទៅកាន់វត្តជេតពន គាល់ព្រះមានព្រះភាគ ព្រះអង្គក៏បានធ្វើ

បដិសណ្ឋារៈ ហើយព្យាករអរហត្តផល ថ្វាយបង្គំព្រះមានព្រះភាគទៀត ហើយ ធ្វើប្រទក្សិណ ចេញទៅអង្គុយសម្រាកពេលថ្ងៃ ត្រង់គល់ឈើមួយកន្លែង ។ លំដាប់នោះ មាតាបិតា និងញាតិមិត្តរបស់លោកដឹងថា លោកនិមន្តមក ក៏ត្រេកអរ រីករាយ បានដឹងថា ព្រះសង្គ្រាមជិមកក្នុងទីនេះ ទើបប្រញាប់ទៅកាន់វិហារ រកមើល ឃើញលោកអង្គុយក្នុងទីនោះ ចូលទៅរក ធ្វើបដិសណ្ឋារៈ ហើយអង្វរថា ព្រះរាជា កុំបីរឹបជាន់សម្បត្តិរបស់បុគ្គលដែលមិនមានបុត្រ ទាយាទ គប្បីបានទទួល សូមចាលះបង់បព្វជ្ជា សឹកចុះ ព្រះថេរៈស្តាប់ដូច្នោះ ហើយ គិតថា ជនទាំងនេះ មិនដឹងថា អាត្មាអញ មិនត្រូវការដោយកាមទាំងឡាយ ប្រាថ្នាឲ្យជាប់នៅក្នុងកាមប៉ុណ្ណោះ ដូចបុគ្គលវែកលាមក ត្រូវការលាមក ដូច្នោះ បុគ្គលណាម្នាក់ មិនអាចឲ្យជនទាំងនេះយល់ធម្មកថាបាន ទើបអង្គុយ ធ្វើហាក់មិនឮ មនុស្សទាំងនោះ អង្វរដោយប្រការផ្សេងៗ ឃើញលោកមិនជឿពាក្យរបស់ខ្លួន ទើបទៅផ្ទះ ប្រាប់ភរិយារបស់លោក មួយអន្ទើដោយបុត្រ និងបរិវារ ពោលថា ពួកយើង ទោះបីអង្វរផ្សេងៗ ក៏យកចិត្តលោកមិនបាន ទើបនាំគ្នាមក ចូរនាងអង្វរកស្តារបស់នាង ឲ្យយល់ព្រមដោយឃើញដល់បុត្រ បានឮថា កាលនាងតាំងគភ៌ ព្រះថេរៈចេញបួស ។ នាងទទួលពាក្យហើយ ទើបបាននាំក្មេង មួយអន្ទើដោយបរិវារច្រើន ទៅកាន់វត្តជេតពន ដែលលោកសំដៅពោលពាក្យជាដើមថា **អសេ្សាសិ ខោ អាយស្មតោ សង្គ្រាមជិស្ស** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **បុរាណទុតិយិកា** *សេចក្តីថា កាលមុន គឺ*

ក្នុងកាលជាគ្រហស្ថ នាងបានជាភរិយាចាស់ ដោយជាគូបម្រើ អធិប្បាយថា ជាភរិយា ។ ដោយពាក្យថា **អយ្យោ** កាលនឹងពោលថា អយ្យបុត្រ តែ ពោលដោយវោហារដែលសមគួរដល់បព្វជិត ។ សព្ទថា **កិរ** ជានិបាត ប្រើ ក្នុង **អនុស្សវនត្ថ** គឺបានឲមក ។ គប្បីជ្រាបសម្ពន្ធថា បានឲថា កាលលោក មកដល់ ។ បទថា **ទុទ្ទបុត្តំ ហិ សមណ ចោស មំ** សេចក្តីថា នាងពោល ថា លោកម្ចាស់ចោលខ្ញុំកំពុងតាំងគភិ ហើយបួស ឥឡូវនេះ ខ្ញុំមានកូនតូច ការដែលលោកម្ចាស់បោះបង់ខ្ញុំបែបនោះ ហើយធ្វើសមណធម៌ មិនសមគួរ ព្រោះដូច្នោះ សមណ: សូមលោកម្ចាស់ចិញ្ចឹមខ្ញុំ ដែលមានបុត្រជាសម្ងាញ់ គម្រប់ ២ ដោយអាហារ និងគ្រឿងស្លៀកដណ្តប់ជាដើម ។ ឯព្រះសង្តាមជិ សង្រួមឥន្ទ្រិយ មិនសម្ងឹងមើលផង មិនចរចាជាមួយនាងផង ។ ដោយហេតុ នោះ ទើបលោកពោលថា **ឯវំ វុត្តេ អាយស្មា សង្តាមជិ តុណ្ហី អហោសិ** ដូច្នេះ ។

នាងពោលដូច្នោះអស់ ៣ ដង ឃើញលោកអង្គុយស្ងៀមតែម្យ៉ាង ទើប សម្គាល់ថា ឈ្មោះថា ពួកបុរស មិនអាល័យក្នុងភរិយា តែគង់អាល័យក្នុង បុត្រ ការស្រឡាញ់ក្នុងបុត្រជ្រួតជ្រាបដល់ខួរក្នុងឆ្អឹងរបស់បិតា ដូច្នោះ លោក គង់នៅក្នុងអំណាចរបស់ខ្ញុំ ព្រោះស្រឡាញ់កូន ទើបដាក់កូនលើភ្លៅរបស់ ព្រះថេរ: ហើយចៀសចេញទៅចំណែកម្ខាង ពោលថា សមណ: នេះកូន របស់លោក សូមចិញ្ចឹមចុះ ហើយទៅឆ្ងាយបន្តិច បានឲថា នាងមិនអាច ឈរចំពោះមុខលោក ដោយតេជះសមណ: ។ សូម្បីកូនតូច ព្រះថេរ:ក៏មិន

មើលផង មិនពោលផង ពេលនោះ នាងជាស្ត្រីឈរនៅក្នុងទីមិនឆ្ងាយ ប៉ែរ មុខសម្ងឹងមើលដឹងអាការព្រះថេរ: ត្រឡប់មកបីកូន ដោយគិតថា សមណ: នេះ មិនត្រូវការកូន រូចក៏ចៀសចេញទៅ ហេតុនោះ ទើបលោកពោលពាក្យ ជាដើមថា **អថ ខោ អាយស្មតោ សង្តាមជិស្ស បុរាណទុតិយិកា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុត្តេនបិ** សេចក្តីថា សមណ:នេះ មិន ត្រូវការបុត្រដែលកើតអំពីទ្រូងខ្លួនឯង អធិប្បាយថា នឹងពោលថ្ងីដល់អ្នកដទៃ នោះ ។

ឈ្មោះថា **ទិព្ព** ក្នុងបទថា **ទិព្ពេន** នេះ ព្រោះដូចជាទិព្ព ពិតហើយ ទេវតាទាំងឡាយមានចក្ខុបសាទជាទិព្ព ដែលកើតអំពីកម្មមិនប្រឡាក់ដោយទឹក ប្រមាត់ សេម្ហ: និងឈាមជាដើម អាចទទួលអារម្មណ៍បានក្នុងទីឆ្ងាយ ។ អភិញ្ញាចក្ខុនេះ កើតអំពីចតុត្ថជ្ឈានសមាធិ កាលបើដូច្នោះ ហេតុនោះ ទើប ឈ្មោះថា ជាទិព្ព ព្រោះដូចជារបស់ទិព្ព ។ ម្យ៉ាងទៀត ឈ្មោះថា **ទិព្ព** ព្រោះ បានដោយការអាស្រ័យទិព្ពវិហារធម៌ ។ ម្យ៉ាងទៀត ឈ្មោះថា **ទិព្ព** ព្រោះ មានការរុងរឿងច្រើន ឬមានគតិធំដោយទិព្ពនោះ ។ បទថា **វិសុទ្ធេន** បាន ដល់ ឈ្មោះថា បរិសុទ្ធដោយល្អ ព្រោះប្រាសចាកសង្កិលេស មាននីវរណ: ជាដើម បទថា **អតិក្ពន្តមានុសកេន** បានដល់ កន្ងងវិស័យរបស់ពួក មនុស្ស ។ បទថា **ឥមំ ឯវ្ហបំ វិប្ឆការំ** សេចក្តីថា មានសេចក្តីប្ជែកនេះ គឺយ៉ាងនេះ បានដល់ កិរិយាដែលខុសរូប ពោល គឺដាក់បុត្រលើភ្ជៅ ដែល មិនសមគួរ ក្នុងពួកបព្ជិត តាមដែលពោលហើយ ។

បទថា **ឯតមត្ថំ** *សេចក្តីថា ដឹងអត្ថនេះ ពោល គឺការដែលព្រះសង្ឃាមជិ អស់នូវសេចក្តីអាល័យក្នុងសត្វគ្រប់ពួក មានបុត្រ និងភរិយាជាដើម ដោយ អាការទាំងពួង ។ បទថា* **ឥមំ ឧទានំ ឧទានេសិ** *សេចក្តីថា ទ្រង់បន្លឺឧទាន នេះ គឺដែលសម្តែងអានុភាពរបស់សង្ឃាមជិនោះ ជាបុគ្គលមាំទាំក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើម ។*

បទថា **អាយន្តិ** *អធិប្បាយថា ភរិយាចាស់ដែលកំពុងមក ។ បទថា* **នាភិនន្ទតិ** *សេចក្តីថា មិនត្រេកអរ មិនរីករាយថា នាងនីងមកមើលអញ ។ បទថា* **បក្កមន្តិ** *សេចក្តីថា ដែលឃើញហើយទៅ ដោយគិតថា បុគ្គលនេះ មិនជាប់ជំពាក់ក្នុងអញទេឬយ ។ បទថា* **ន សោចតិ** *បានដល់ មិនដល់នូវ ការក្តៅក្រហាយចិត្ត ។*

តែដើម្បីសម្តែងហេតុ ដែលព្រះថេរៈមិនត្រេកអរ មិនសោយសោក យ៉ាងនេះ ទើបពោលពាក្យជាដើមថា **សង្ឃោ សង្ឃាមជី មុត្តំ** *ជាអ្នកឈ្នះដល់ ការរួចផុតចាកធម៌ដែលជាគ្រឿងជាប់ជំពាក់ ។*

បណ្តាបទទាំងនោះ បទថា **សង្ឃោ** *សេចក្តីថា ភិក្ខុដែលឈ្មោះថា សង្ឃាមជិ ជាអ្នករួចផុតចាកធម៌ជាគ្រឿងជាប់ជំពាក់ ៥ យ៉ាង គឺគ្រឿងជាប់ ជំពាក់ មានរាគៈ ទោសៈ មោហៈ មានះ និងទិដ្ឋិ ដោយសមុច្ឆេទវិមុត្តិ និង បដិបស្សទ្ធិវិមុត្តិ ។ បទថា* **តមហំ ព្រូមិ ព្រាហ្មណំ** *សេចក្តីថា តថាគតហៅ បុគ្គលនោះ គឺជាអ្នកដល់នូវភាពមាំទាំ ដែលអស់អាសវៈថា ជាព្រាហ្មណ៍ ព្រោះជាអ្នកបន្សាត់បាប ដោយប្រការទាំងពួង ។*

សុត្តន្តបិដក

៨ដិលសូត្រ

[៤៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងគយាសីសប្រទេស ទៀបទន្លេគយា ។ សម័យនោះឯង ពួកជដិលច្រើនរូប នាំគ្នាងើបខ្លះ មុជខ្លះ ងើបមុជៗ ខ្លះ ស្រោចខ្លួនខ្លះ បំពក់ភ្លើងខ្លះ ទៀបកំពង់ឈ្នោះគយា ក្នុងសម័យជាទីធ្លាក់ចុះនៃទឹកសន្សើមរវាង ៨ ថ្ងៃ ក្នុងវេលារាត្រីដ៏ត្រជាក់នៃហេមន្តរដូវ ដោយសេចក្តីគិតយើញថា សេចក្តីបរិសុទ្ធដោយអំពើនេះ ។ ព្រះមានព្រះភាគ ក៏បានយើញពួកជដិលជាច្រើនទាំងនោះ ដែលកំពុងងើបខ្លះ មុជខ្លះ ងើបមុជៗ ខ្លះ ស្រោចខ្លួនខ្លះ បំពក់ភ្លើងខ្លះ ទៀបកំពង់ឈ្នោះគយា ក្នុងសម័យជាទីធ្លាក់ចុះនៃទឹកសន្សើមរវាង ៨ ថ្ងៃ ក្នុងវេលារាត្រីដ៏ត្រជាក់នៃហេមន្តរដូវ ដោយសេចក្តីគិតយើញថា សេចក្តីបរិសុទ្ធដោយអំពើនេះ ។ លុះព្រះមានព្រះភាគ បានជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបបន្ទឺនូវឧទាននេះក្នុងវេលានោះថា

បុគ្គលមិនមែនស្អាតព្រោះទឹកទេ អ្នកផងច្រើនគ្នា រមែងងូតទឹកនោះដែរ សច្ចៈ ១ ធម្មៈ ១ (មាននៅ) ក្នុងបុគ្គលណា បុគ្គលនោះ ទើបឈ្មោះថា ជាអ្នកស្អាតផង ឈ្មោះថា ជាព្រាហ្មណ៍ផង ។ សូត្រទី ៩ ។

អដ្ឋកថា

៨ដិលសូត្រ

ជដិលសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ

[៤៦] ពាក្យថា **គយា** ក្នុងបទថា **គយាយំ** នេះ គេហៅថា ស្រុកខ្លះ កំពង់ខ្លះ ។ ពិតហើយ ព្រះមានព្រះភាគ កាលប្រថាប់នៅក្នុងទីមិនឆ្ងាយអំពីគយាគាម ហៅថា ប្រថាប់នៅជិតស្រុកគយា ។ កាលប្រថាប់នៅក្នុងទីមិនឆ្ងាយអំពីកំពង់គយា ក៏ហៅថា ប្រថាប់នៅក្បែរកំពង់គយាដូចគ្នា ។ ពិតហើយ ក្នុងពាក្យថា **គយាតិត្ថំ** គឺស្រែក្តី ស្ទឹងក្តី ទោះបីមាននៅក្នុងទីមិនឆ្ងាយស្រុក ឈ្មោះថា **គយា** ។ ទាំង ២ យ៉ាងនោះ លោកិយមហាជនតែងហៅថា កំពង់ជាទីបន្សាត់បាប ។ បទថា **គយាសីសេ** សេចក្តីថា ក្នុងទីនោះ មានភ្នំមួយ ឈ្មោះគយាសីសៈ មានកំពូលស្រេជៀងក្បាលដំរី ជាទីដែលមានថ្មជាដូចពោងដំរី ជាឱកាសល្មមភិក្ខុ ១០០០ រូបនៅបាន ព្រះមានព្រះភាគក៏គង់ប្រថាប់នៅទីនោះ ព្រោះហេតុនោះ ទើបលោកពោលថា **គយាយំ វិហរតិ គយាសីសេ** ។

បទថា **៨ដិលា** បានដល់ ពួកតាបស ។ ពិតហើយ តាបសទាំងនោះ ហៅថា ជដិលក្នុងទីនេះ ព្រោះជាអ្នកទ្រទ្រង់ជដា ។ បទថា **អន្តរដ្ឋកេ ហិមចាតសមយេ** សេចក្តីថា ក្នុងកាលសន្សើមធ្លាក់ មានប្រមាណ ៨ ថ្ងៃ គឺក្នុងទីបំផុតនៃខែមាឃ ដែលជាខាងក្នុងហិមន្តរដូវ ៤ ថ្ងៃ ក្នុងថ្ងៃដើមនៃខែផល្គុន ៤ ថ្ងៃ ។ បទថា **គយាយំ ឧម្មុជ្ជន្តិ** សេចក្តីថា បុគ្គលពួកខ្លះ មុជ

ចុះទាំងខ្លួនជំបួង ក្នុងទឹកដែលសន្ធតគ្នាថា ជាកំពង់ទឹកនោះ បន្ទាប់អំពីនោះ ក៏ផុសឡើង ហែលទៅ ។ បទថា **និមុជ្ជតិ** *សេចក្តីថា មុជចុះក្នុងទឹកត្រឹមក្បាល ។ បទថា* **ឧម្មុជ្ជនិម្មុជ្ជម្បិ ករោតិ** *សេចក្តីថា ធ្វើការផុសឡើង មុជចុះរឿយៗ ។ ពិតហើយ ក្នុងការធ្វើនោះ មនុស្សពួកខ្លះ មានការយើញយ៉ាងនេះថា ដោយការផុសឡើងតែម្តងប៉ុណ្ណោះ ជាវត្តបរិសុទ្ធចាកបាប ទើបមនុស្សទាំងនោះ ធ្វើចំពោះការផុសឡើងប៉ុណ្ណោះ ហើយក៏ទៅ ។ តែការផុសឡើង មិនមានក្នុងរវាងការមុជចុះ ព្រោះហេតុនោះ ទើបជនទាំងនោះ ធ្វើត្រឹមតែការមុជចុះ ដោយមិនវៀរ ឯជនដែលមានការយើញយ៉ាងនេះថា ដោយការមុជចុះតែម្តងប៉ុណ្ណោះ ទើបជាការបរិសុទ្ធចាកបាប ទើបមុជចុះចំពោះតែម្តង ធ្វើត្រឹមតែការផុសឡើង ដោយមិនវៀរ តាមន័យដែលពោលហើយនោះឯង ហើយក៏ចៀសចេញទៅ ។*

ឯជនដែលមានការយើញយ៉ាងនេះថា ដោយការមុជចុះត្រង់កំពង់នោះឯង មានការបរិសុទ្ធចាកបាប ទើបមុជចុះត្រង់កំពង់នោះ អត់ជង្អើមឲ្យអស់ជីវិត ក្នុងទីនោះឯង ដូចលិចចូលក្នុងផ្នែរខ្សាច់ ។ ជនមួយពួកទៀត មានការយើញយ៉ាងនេះថា ក្នុងការធ្វើការផុសឡើង មុជចុះរឿយៗ ហើយទើបងូតជាការបរិសុទ្ធចាកបាប ទើបជនទាំងនោះ ធ្វើការផុសឡើង និងមុជចុះ សព្វកាល ។ លោកសំដៅយកមនុស្សទាំងនោះ ទើបពោលថា ងើបឡើងខ្លះមុជចុះខ្លះ ផុសឡើងផង មុជចុះផងខ្លះ ។ ក្នុងសេចក្តីនេះ ការផុសឡើង ត្រូវមានការមុជចុះមុនក៏ពិត តែជនដែលធ្វើការមុជចុះ មានតិចតួច ជនដែលធ្វើ

ការផុសឡើង និងការមុជចុះ ផុសឡើងទាំង ២ មានច្រើន ព្រោះដូច្នោះ ដើម្បីសម្តែងការៈដែលជនទាំងនោះនៅខាងចំណែកច្រើន ទើបពោលការផុសឡើងមុន ។ ម្យ៉ាងទៀត ពាក្យថា **ជដិលា** ក៏ដូចគ្នា លោកពោលក៏ព្រោះពួកជដិលជាចំណែកខាងច្រើន ម្យ៉ាងទៀត ពួកព្រាហ្មណ៍ ទោះក្បាលត្រងោលឬទុកជុក ជាអ្នកត្រូវការសេចក្តីបរិសុទ្ធដោយទឹក រមែងធ្វើយ៉ាងនោះ ត្រង់កំពង់នោះ ក្នុងកាលនោះ ។

បទថា **ឱសិញ្ចន្តិ** សេចក្តីថា ពួកខ្លះ យកដៃក្បង់ទឹកក្នុងស្រះ ហើយស្រោចក្បាល និងដងខ្លួនរបស់ខ្លួន មួយពួកទៀត យកក្អមដងទឹក ឈរត្រង់មាត់ច្រាំង ហើយធ្វើយ៉ាងនោះ ។ បទថា **អគ្គិំ ជុហន្តិ** សេចក្តីថា ពួកខ្លះចាត់ចែងវេទិកាត្រង់មាត់ស្ទឹងគយា ហើយនាំគ្រឿងឧបករណ៍ បូជាដោយឧស និងស្បូវក្តាំងជាដើមចូលទៅបូជាភ្លើង គឺបម្រើភ្លើង ។ បទថា **ឥមិនា សុទ្ធិ** សេចក្តីថា ពួកខ្លះ ជាអ្នកមានការយើញយ៉ាងនេះថា សេចក្តីបរិសុទ្ធចាកមន្ទិលគឺបាប បានដល់ ការបន្សាត់បាប ឬការបរិសុទ្ធចាកសង្សារ រមែងមានដោយការមុជចុះជាដើមក្នុងស្ទឹងគយា និងដោយការបម្រើភ្លើងនេះ ។ ក្នុងទីនេះ ការមុជចុះជាដើម គប្បីឃើញថា លោកពោលត្រឹមតែជាគំរូ ។

បណ្តាមនុស្សទាំងនោះ ពួកខ្លះ នៅក្នុងទឹក ពួកខ្លះ ធ្វើអញ្ជលីទឹក ពួកខ្លះ ឈរក្នុងទឹក ហើយបែរតាមព្រះចន្ទ ព្រះអាទិត្យ ពួកខ្លះ អានធនូ មានសាវិត្តិធនូជាដើមរាប់ពាន់ដង ពួកខ្លះ រាយវិជ្ជា ដោយន័យជាដើមថា **ឥន្ទ-អាគច្ឆ** ប្រែថា សូមព្រះឥន្ទ្រមកចុះ ពួកខ្លះ ធ្វើមហកម្ម ។ កាលធ្វើយ៉ាង

នេះ ពួកខ្លះ ចុះ ពួកខ្លះ ឡើង ពួកខ្លះ ឡើងមកហើយ ធ្វើការលាងជម្រះឲ្យ ស្អាត ពួកខ្លះ ឈរនៅក្នុងទឹក ពួកខ្លះ ត្រូវងាបៀតបៀន ទើបសម្តែងកិរិយា មានប្រការផ្សេងៗ ជាដើម មានយ៉ាងនេះ ដូចជាដេញពិណ ដែលធ្វើដោយ ភ្កុកជីរជាដើម ។ ម្យ៉ាងទៀត ព្រោះពួកទាំងនោះ កាលធ្វើកិរិយាចម្លែកបែប នេះ ក៏ធ្វើចំពោះការមុជចុះ និងផុសឡើងជាដើមក្នុងទឹកនោះប៉ុណ្ណោះ ដូច្នោះ ទើបលោកធ្វើហេតុទាំងអស់នោះ នៅក្នុងការមុជចុះ និងផុសឡើងប៉ុណ្ណោះ ទើបលោកពោលពាក្យជាដើមថា **ឧម្មុជ្ជនិមិ ។**

កាលសំឡេង **អាកុល ព្យាកុល** *កំពុងរំពងក្នុងទីនោះយ៉ាងនេះ ព្រះដ៏ មានព្រះភាគប្រថាប់ឈរនៅលើកំពូលភ្នំ ទ្រង់ស្តាប់សំឡេងកោលាហលនៃ ពួកមនុស្សទាំងនោះ ទើបទ្រង់ពិចារណាមើលថា នេះហេតុអ្វីហ្ន៎ ទ្រង់បាន ឃើញកិរិយាប្លែកៗ លោកសំដៅយកសេចក្តីនោះ ទើបបានពោលដូច្នេះថា* **អច្ឆរា ខោ ភគវា ។បេ។ ឥមិនា សុទ្ធិ** *ពាក្យនោះ មានអត្ថដូច ពោលហើយនោះឯង ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ដឹងច្បាស់សេចក្តីនោះ គឺការ ដែលមនុស្សទាំងនោះ ទាញយកផ្លូវមិនបរិសុទ្ធ មានការចុះទឹកជាដើមថា ជា ផ្លូវបរិសុទ្ធ និងការដែលព្រះអង្គជ្រាបក្នុងផ្លូវបរិសុទ្ធ មានសច្ចៈជាដើមថា មិន ខុសភ្លាំងភ្លាត់ ដោយអាការទាំងពួង ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់ បន្ទឺឧទាននេះ គឺដែលសម្តែងភាពមិនជាផ្លូវបរិសុទ្ធ ដោយការបរិសុទ្ធព្រោះទឹក និងសម្តែងដល់ធម៌ មានសច្ចៈជាដើម ជាផ្លូវបរិសុទ្ធតាមសេចក្តីពិត ។*

បណ្តាបទទាំងនោះ បទថា **ឧឧកេន** *ក្នុងពាក្យថា* **ឯ ឧឧកេន សុចិ ហោតិ** *នេះ បានដល់ ដោយការផុសទ្បើងចាកទឹកជាដើម ក្នុងទីនេះ ការផុសទ្បើងអំពីទឹក លោកពោលថា* **ឧឧកំ** *គឺទឹក ព្រោះលុបបទចុង ដូចឧទាហរណ៍ថា* **រូបភវោ រូបំ** *រូប គឺរូបភព ។ ម្យ៉ាងទៀត បទថា* **ឧឧកេន** *សេចក្តីថា ការស្អាតដោយទឹក មានកិរិយាផុសទ្បើងជាដើម មិនឈ្មោះថា ជាការបរិសុទ្ធរបស់សត្វទ្បើយ ។ ម្យ៉ាងទៀត បទថា* **សុចិ** *សេចក្តីថា សេចក្តីបរិសុទ្ធដោយទឹកតាមដែលពោលហើយនោះ មិនជាសត្វ ឈ្មោះថា ជាអ្នកបរិសុទ្ធចាកមន្ទិល គឺបាប ។ ព្រោះហេតុអ្វី ព្រោះជនជាច្រើនងូតទឹកនេះ ។ ព្រោះបើឈ្មោះថា ការបរិសុទ្ធចាកបាប គប្បីមានព្រោះការចុះទឹកជាដើម តាមដែលពោលហើយសោត ជនជាច្រើនក៏និងនាំគ្នាងូតទឹកនេះ គឺមនុស្សដែលធ្វើកម្មអាក្រក់ មានមាតុឃាតជាដើម និងសត្វដទៃ មានគោ ក្របីជាដើម ដោយហោចត្រី និងអណ្តើក ក៏នាំគ្នាងូតទឹកនេះ មនុស្ស និងសត្វទាំងអស់នោះ ក៏និងបរិសុទ្ធចាកបាបទៅហើយដែរ តែសេចក្តីនោះ មិនមែនដូច្នោះទ្បើយ ។ ព្រោះហេតុអ្វី ព្រោះការងូតទឹក មិនជាបដិបក្ខចំពោះហេតុនៃបាប ។ វត្ថុណាធ្វើវត្ថុណាឲ្យវិនាសទៅបាន វត្ថុនោះ ក៏ជាបដិបក្ខចំពោះវត្ថុនោះ ដូចពន្លឺ ជាបដិបក្ខចំពោះឆ្ងឹត និងវិជ្ជា ជាបដិបក្ខចំពោះអវិជ្ជា ការងូតទឹកមិនជាបដិបក្ខចំពោះបាបទេ ព្រោះដូច្នោះ ទើបគួរជ្ជាក់ចុះក្នុងសេចក្តីនេះថា ការស្អាត តែងមិនមានព្រោះទឹក ។ ដើម្បីសម្តែងធម៌ដែលជាហេតុធ្វើឲ្យស្អាត ទើបពោលពាក្យជាដើមថា* **យម្ហិ សច្ចញ្ច** *ជួច្នេះ ។*

បណ្តាបទទាំងនោះ បទថា **យម្ហិ** *បានដល់ ក្នុងបុគ្គលណា ។ បទថា* **សច្ចំ** *បានដល់ វចីសច្ច និងវិរតិសច្ច ។ ម្យ៉ាងទៀត បទថា* **សច្ចំ** *បានដល់ ញាណសច្ច និងបរមត្ថសច្ច ។ បទថា* **ធម្មោ** *បានដល់ ធម៌ គឺអរិយមគ្គ និងធម៌ គឺផលចិត្ត ។ ធម៌ទាំងអស់នោះ រមែងបានក្នុងបុគ្គលណា ។ បទថា* **សោ សុចី សោ ច ព្រាហ្មណោ** *សេចក្តីថា បុគ្គលនោះ គឺព្រះអរិយបុគ្គល ដោយពិសេស បានដល់ ព្រះខីណាស្រព ឈ្មោះថា ជាអ្នកស្អាត និងឈ្មោះថា ជាព្រហ្មណ៍ ព្រោះជាបុគ្គលបរិសុទ្ធ ដោយឥតសេសសល់ ។ ព្រោះហេតុអ្វី ទើបក្នុងសេចក្តីនេះ លោកចែកសច្ចៈ កាន់យកធម៌ ព្រោះសច្ចៈមានឧបការៈច្រើន ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់បានប្រកាសគុណនៃសច្ចៈ ក្នុងសុត្តបទជាច្រើន ដោយនយជាដើមថា ពាក្យពិត ជាពាក្យមិនស្វាប់ សច្ចៈនេះឯង ប្រសើរជាងរសទាំងពួង ។ បណ្ឌិតទាំងឡាយ ពោលបុគ្គលអ្នកតាំងនៅក្នុងសច្ចៈ ជាអ្នកដឹងអត្ថ និងធម៌ ថាជាសប្បុរស និងថាជាសមណព្រាហ្មណ៍ដែលតាំងនៅក្នុងសច្ចៈ ។ ប្រកាសទោសរបស់ធម៌ ដែលផ្ទុយគ្នា និងសច្ចៈដោយនយជាដើមថា សត្វដែលពោលកុហក កន្ទងនូវធម៌ឯកចោល និងពាក្យថា បុគ្គលពោលពាក្យមិនពិត រមែងចូលដល់នរកដូច្នេះ ។*

អដ្ឋកថា ៨ដិលសូត្រ ចប់

សុត្តន្តបិដក

ពាហិយសូត្រ

[៤៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អានាថបិណ្ឌិកសេដ្ឋី ។ សម័យនោះឯង ពាហិយទារុចីរិយបុរស (អ្នកស្លៀកដណ្តប់សំពត់សម្បកឈើ ឈ្មោះ ពាហិយៈ) អាស្រ័យនៅទៀបឆ្នេរសមុទ្រ ឈ្មោះសុប្បារកៈ ជាអ្នកដែលគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បានន្តវចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ កាលពាហិយទារុចីរិយ-បុរស ពួនសម្ងំក្នុងទីស្ងាត់ ស្រាប់តែមានសេចក្តីត្រិះរិះ កើតឡើងក្នុងចិត្ត យ៉ាងនេះថា ពួកជនណាមួយក្នុងលោក ជាព្រះអរហន្ត ឬសម្រេចអរហត្ត-មគ្គ បណ្តាអរហន្តទាំងនេះ ខ្ញុំនឹងជាអរហន្តមួយអង្គដែរ ។ លំដាប់នោះ ទេវតាដែលជាសាលោហិតអំពីដើម របស់ពាហិយទារុចីរិយបុរស ជាអ្នក អនុគ្រោះ ប្រាថ្នាប្រយោជន៍ បានដឹងច្បាស់នូវសេចក្តីត្រិះរិះក្នុងចិត្ត ដោយ ចិត្តរបស់ពាហិយទារុចីរិយបុរស បានចូលទៅរកពាហិយទារុចីរិយបុរស លុះ ចូលទៅដល់ហើយ ក៏និយាយនឹងពាហិយទារុចីរិយបុរសយ៉ាងនេះថា នែ ពាហិយៈ អ្នកមិនមែនជាព្រះអរហន្តទេ ទាំងមិនទាន់សម្រេចព្រះអរហន្តទេ ខ្ញុំនអ្នកមិនមានបដិបទា ដែលនាំឲ្យបានជាព្រះអរហន្ត ឬសម្រេចអរហត្តមគ្គ ទេ ។ ពាហិយទារុចីរិយសួរថា បើដូច្នោះ ក្នុងកាលឥឡូវនេះ ក្នុងលោក ព្រមទាំងទេវលោក តើជនណា ជាអរហន្ត ឬបានសម្រេចអរហត្តមគ្គ មាន

ដែរឬ ។ ទេវតាឆ្លើយថា ម្នាលពាហិយៈ មាន ខាងជនបទឯជើង មានក្រុង មួយឈ្មោះសាវត្ថី ឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គ នោះ ទ្រង់គង់នៅក្នុងក្រុងសាវត្ថីនោះ ។ ម្នាលពាហិយៈ ព្រះមានព្រះភាគ អង្គនោះឯង ជាព្រះអរហន្តផង ទ្រង់សម្តែងធម៌ ដើម្បីអរហត្តផង ។ លំដាប់ នោះ ពាហិយទារុចីរិយបុរស ដែលទេវតានោះ ធ្វើឲ្យតក់ស្លុត ក៏ស្រាប់តែ គេចចេញអំពីឆ្នេរសមុទ្រ ឈ្មោះសុប្បារកៈ ក្នុងខណៈនោះភ្លាម ដោយការ នៅតែក្នុងផ្លូវទាំងពួង អស់មួយយប់ ក៏បានទៅដល់ព្រះមានព្រះភាគ ដែល កំពុងគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

[៤៨] សម័យនោះ គាប់ជួនភិក្ខុច្រើនរូប កំពុងដើរចង្រ្កម ក្នុងទី វាល ។ លំដាប់នោះ ពាហិយទារុចីរិយបុរស ក៏ឆៀងចូលទៅរកពួកភិក្ខុ លុះចូលទៅដល់ហើយ ក៏បានសួរភិក្ខុទាំងនោះដូច្នេះថា បពិត្រលោកដ៏ ចម្រើនទាំងឡាយ ឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធគង់នៅ ទីណា យើងមានបំណងនឹងចូលទៅ ដើម្បីជួបព្រះមានព្រះភាគ ជាអរហន្ត-សម្មាសម្ពុទ្ធអង្គនោះ ។ ពួកភិក្ខុតបថា ម្នាលពាហិយៈ ព្រះមានព្រះភាគចូល កាន់ចន្លោះភូមិ ដើម្បីបិណ្ឌបាតទៅហើយ ។ លំដាប់នោះ ពាហិយទារុចី-រិយបុរស ក៏មានដំណើរម្នីម្នាចេញពីវត្តជេតពន ចូលទៅនគរសាវត្ថី បាន ឃើញព្រះមានព្រះភាគ កំពុងនិមន្តបិណ្ឌបាតក្នុងក្រុងសាវត្ថី ជាទីនាំមកនូវ សេចក្តីជ្រះថ្លា គួរជ្រះថ្លា មានឥន្ទ្រិយស្ងប់ មានព្រះហឫទ័យស្ងប់ ទ្រង់បាន ដល់នូវការហាត់ពត់ និងការស្ងប់រម្ងាប់ដ៏ឧត្តម ទ្រង់បានទូន្មាន គ្រប់គ្រង

សង្រ្ខមឥន្ទ្រិយ ជាពុទ្ធនាគ គឺជាព្រះពុទ្ធដ៏ប្រសើរ លុះឃើញហើយ ក៏ចូលទៅរកព្រះមានព្រះភាគ មានសិរ្សឱនចុះទៀបព្រះបាទនៃព្រះមានព្រះភាគ ហើយអារាធនាព្រះមានព្រះភាគនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់រាត្រីដ៏វែង ដល់ខ្ញុំព្រះអង្គឲ្យទាន ។

[៤៩] កាលពាហិយទារុចីរិយបុរស អារាធនាយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពាហិយទារុចីរិយបុរសដូច្នេះថា ម្នាលពាហិយៈ ឈប់សិន កាលនេះ ជាកាលមិនគួរ ដ្បិតតថាគតចូលទៅកាន់ចន្លោះភូមិ បិណ្ឌបាត ។ ពាហិយទារុចីរិយបុរស ទូលព្រះមានព្រះភាគជាគម្រប់ ២ ដង យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដំណើរប្រព្រឹត្តទៅនៃជីវិតន្តរាយរបស់ព្រះមានព្រះភាគ ឬជីវិតន្តរាយរបស់ខ្ញុំព្រះអង្គ ដឹងបានដោយក្រណាស់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្តែងធម៌ ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់រាត្រីដ៏វែង ដល់ខ្ញុំព្រះអង្គឲ្យទាន ។ ព្រះមានព្រះភាគ បានត្រាស់នឹងទារុចីរិយ-បុរស អស់វារៈ ២ ដង យ៉ាងនេះថា ម្នាលពាហិយៈ ឈប់សិន កាលនេះ ជាកាលមិនគួរ ដ្បិតតថាគតចូលទៅកាន់ចន្លោះភូមិ បិណ្ឌបាតសិន ។ ពាហិយទារុចីរិយបុរស ទូលព្រះមានព្រះភាគ អស់វារៈ ៣ ដង យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដំណើរប្រព្រឹត្តទៅនៃជីវិតន្តរាយរបស់ព្រះមានព្រះភាគ ឬជីវិតន្តរាយរបស់ខ្ញុំព្រះអង្គ ដឹងបានដោយក្រណាស់ បពិត្រព្រះ

អង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្តែងធម៌ ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់រាត្រីវែងដល់ខ្ញុំព្រះអង្គឲ្យទាន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកត្រូវសិក្សាយ៉ាងនេះថា រូបារម្មណ៍ដែលអ្នកឃើញហើយ គ្រាន់តែជារូបារម្មណ៍ដែលឃើញហើយ សទ្ទារម្មណ៍ដែលអ្នកឮហើយ គ្រាន់តែជាសទ្ទារម្មណ៍ដែលអ្នកឮហើយ គន្ធៈ រសៈ ផោដ្ឋព្វារម្មណ៍ដែលប៉ះពាល់ហើយ គ្រាន់តែជាអារម្មណ៍ដែលប៉ះពាល់ហើយ ធម្មារម្មណ៍ដែលអ្នកដឹងហើយ គ្រាន់តែជាធម្មារម្មណ៍ដែលដឹងហើយ ម្នាលពាហិយៈ អ្នកគប្បីសិក្សាយ៉ាងនេះឯង ។ ម្នាលពាហិយៈ រូបារម្មណ៍ដែលអ្នកឃើញហើយ គ្រាន់តែជារូបារម្មណ៍ដែលឃើញហើយ សទ្ទារម្មណ៍ដែលអ្នកឮហើយ គ្រាន់តែជាសទ្ទារម្មណ៍ដែលឮហើយ គន្ធៈ រសៈ ផោដ្ឋព្វារម្មណ៍ដែលអ្នកប៉ះពាល់ហើយ គ្រាន់តែជាអារម្មណ៍ដែលប៉ះពាល់ហើយ ធម្មារម្មណ៍ដែលអ្នកដឹងហើយ គ្រាន់តែជាធម្មារម្មណ៍ដែលដឹងហើយ ព្រោះហេតុណា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកនឹងលែងមាន ម្នាលពាហិយៈ អ្នកនឹងលែងមាន ព្រោះហេតុណា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកនឹងមិនមានក្នុងភពនេះ និងភពមុខ នឹងមិនមានក្នុងចន្លោះនៃលោកទាំង ២ នេះឯងជាទីបំផុតនៃទុក្ខ ។ គ្រានោះ ចិត្តនៃពាហិយទារុចីរិយបុរស ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនមានឧបាទាន ក្នុងខណៈនោះឯង ដោយធម្មទេសនាសង្ខេប របស់ព្រះមានព្រះភាគនេះ ។ លុះព្រះមានព្រះភាគ ទ្រង់ប្រទានពាហិយទារុចីរិយបុរស ដោយឱវាទ

សង្ខេបនេះហើយ ស្តេចចៀសចេញទៅ ។

[៥០] កាលដែលព្រះមានព្រះភាគ ស្តេចចេញផុតទៅមិនយូរប៉ុន្មាន មេគោមានកូនខ្ចី បុះផ្ដួលពាហិយទារុចីរិយបុរស ឲ្យដាច់ចាកជីវិតទៅ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាច់បិណ្ឌបាតក្នុងនគរសាវត្ថី រួចត្រឡប់អំពីបិណ្ឌបាត វេលាខាងក្រោយភត្ត ចេញអំពីនគរជាមួយភិក្ខុច្រើនរូប បានទតឃើញពាហិយទារុចីរិយបុរសធ្វើមរណភាព លុះទតឃើញហើយ ទើបត្រាស់ប្រាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរយកសរីរៈពាហិយទារុចីរិយបុរស លើកដាក់លើគ្រែនាំទៅដុតផង ធ្វើស្តូបដល់សរីរៈនោះផង ម្នាលភិក្ខុទាំងឡាយ (ព្រោះថា) សព្រហ្មចារីរបស់អ្នកទាំង-ឡាយ ធ្វើមរណភាពហើយ ។ ពួកភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយលើកសរីរៈ ពាហិយទារុចីរិ-យបុរសដាក់លើគ្រែតូចនាំទៅរម្ងាយ ទាំងធ្វើស្តូបដល់សរីរៈនោះ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ បានទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សរីរៈពាហិយទារុចីរិយបុរស រម្ងាយហើយ ទាំងស្តូបសម្រាប់បញ្ចុះសរីរៈនោះក៏ធ្វើហើយ គតិរបស់គាត់ តើដូចម្តេច ដំណើរក្នុងលោកខាងមុខ តើដូចម្តេច ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ពាហិយទារុចីរិយបុរស ជាបណ្ឌិត បានប្រតិបត្តិធម៌គួរដល់ព្រះនិព្វាន ហើយ មិនបៀតបៀនតថាគត ព្រោះហេតុសម្តែងធម៌ទេ ម្នាលភិក្ខុទាំងឡាយ

ពាហិយទារុចីរិយបុរស បរិនិព្វានហើយ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបបន្ទឺនូវឧទាននេះ ក្នុងវេលានោះថា

ទឹក ដី ភ្លើង ខ្យល់ រមែងមិនតាំងនៅក្នុងនិព្វានជាតុណា ពួកផ្កាយ មាននាមថា សុក្កៈ (មានពន្លឺ) រមែងមិនភ្លឺ ទាំងព្រះអាទិត្យក៏មិនរុងរឿង ក្នុងនិព្វានជាតុនោះ ព្រះចន្ទ្រក៏មិនមានពន្លឺ ក្នុងនិព្វានជាតុនោះ ទាំងងងឹតក៏មិនមាន ក្នុងនិព្វានជាតុនោះទេ ព្រាហ្មណ៍មាននាមថាមុនី ព្រោះមានប្បដិបត្តិ ដឹងច្បាស់នូវព្រះនិព្វានដោយខ្លួនឯង ក្នុងកាលណា រមែងរួចចាករូបផង អរូបផង សុខទុក្ខផង ក្នុងកាលនោះ ។ សូត្រទី ១០ ។

ពោធិវគ្គទី ១ ចប់

ឧទ្ទាននៃពោធិវគ្គនោះ គឺ

និយាយអំពីព្រះមានព្រះភាគ គង់ក្រោមពោធិព្រឹក្ស ៣ លើក ព្រះមានព្រះភាគគង់ក្រោមដើមអជបាលនិក្រោធ ១ ព្រះថេរៈច្រើនអង្គ ១ ព្រះមហាកស្សបៈ ១ ព្រះមានព្រះភាគគង់នៅជិតក្រុងចាវា ១ ព្រះសង្គាមជិត្តៃរ ១ ពួកជដិល ១ ពាហិយទារុចីរិយបុរស ១ រួមទាំងអស់ជា ១០ រឿង ។

អដ្ឋកថា

ពាហិយសូត្រ

សូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ

[៤៧] *បទថា* **ពាហិយោ** *ជាឈ្មោះរបស់លោក ។ បទថា* **ទារុចីរិយោ** *បានដល់ សំពត់ដែលក្រងធ្វើដោយសម្បកឈើ ។ បទថា* **សុប្បារកេ** *បានដល់ នៅត្រង់កំពង់ឈ្មោះយ៉ាងនោះ ។ ពាហិយៈនេះជានរណា ហេតុអ្វី ទើបជាអ្នកស្លៀកសំពត់ដែលក្រងដោយសម្បកឈើ ហេតុអ្វី ទើបនៅត្រង់កំពង់ សុប្បារកៈ ។*

ក្នុងសេចក្តីនេះ មានអនុបុព្វីកថាដូចតទៅនេះ

បានឮថា ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមបទុមុត្តរៈ ក្នុងទីបំផុតមួយសែនកប្ប អំពីកទុកប្បនេះ កុលបុត្រម្នាក់កំពុងស្តាប់ធម្មទេសនារបស់ព្រះទសពល ត្រង់ហង្សវតីនគរ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈនៃពួកភិក្ខុ ដែលជាទិដ្ឋាភិញ្ញា គិតថា ធ្វើម្តេចហ្ន៎ ក្នុងអនាគត អញនឹងបួសក្នុងព្រះសាសនារបស់ព្រះសម្មាសម្ពុទ្ធបែបនេះ ហើយគប្បីជាបុគ្គលដែលព្រះសាស្តាស្ថាបនាទុកក្នុងតំណែងឯតទគ្គៈ ដូចភិក្ខុរូបនេះដូច្នេះ បានប្រាថ្នាតំណែងនោះ ទើបបំពេញបុញ្ញាធិការដែលសមគួរដល់តំណែងនោះ បំពេញបុណ្យដរាបដល់អស់ជីវិត មានស្ថានសួគ៌ជាទីទៅខាងមុខ អន្ទោលទៅក្នុងទេវតា និងមនុស្ស បួសក្នុងសាសនារបស់ព្រះកស្សបទសពល មានសីលបរិបូណ៌ បំពេញសមណធម៌ ដល់នូវការអស់ជីវិត កើត

ក្នុងទេវលោក នៅក្នុងទេវលោកអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុងផ្ទះមានត្រកូល ក្នុងពាហិយរដ្ឋ ជនទាំងឡាយស្គាល់គាត់ថា ជាពាហិយ: ព្រោះកើតក្នុងពាហិយរដ្ឋ ។ គាត់ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ យកសំពៅដឹកទំនិញជាច្រើន ធ្វើដំណើរទៅកាន់មហាសមុទ្រ ត្រឡប់ទៅ ត្រឡប់មក សម្រេចបំណង ៧ ដង ទើបត្រឡប់មកនគរបស់ខ្លួន លើកទី ៨ គិតទៅកាន់សុវណ្ណភូមិ ទើបជញ្ជូនទំនិញ ហើយចេញសំពៅ ។ សំពៅអណ្តែតក្នុងមហាសមុទ្រ មិនទាន់ដល់ទឹកដីដែលប្រាថ្នាក៏បែកធ្លាយ ត្រង់មហាសមុទ្រ មហាជនបានជាចំណីរបស់ត្រី និងអណ្តើក ឯពាហិយ: គោងបន្ទះក្តារមួយបន្ទះ ហែលឆ្លង ត្រូវកម្លាំងរលករុញច្រានបន្តិចម្តងៗ ក្នុងថ្ងៃទី ៧ ក៏ដល់ច្រាំង ក្បែរកំពង់សុប្បារក: ។ គាត់ដេកត្រង់ច្រាំងសមុទ្រ ដោយរូបកាយដូចកាលកើត ព្រោះសំពត់អណ្តែតទៅក្នុងសមុទ្រ បន្ទោបង់សេចក្តីក្រវល់ក្រវាយ បានត្រឹមតែល្មមដកដង្ហើមស្រួល ក្រោកឡើងចូលទៅកាន់គុម្ពឈើ ដោយការខ្មាសអៀន មិនឃើញរបស់ណាមួយ ត្រឹមតែជាគ្រឿងបិទបាំងនូវការខ្មាស ទើបកាច់មែករាក់ យកសម្បកចងធ្វើជាគ្រឿងស្លៀកដណ្តប់បិទបាំងកាយ ។ តែអាចារ្យពួកខ្លះពោលថា ចោះបន្ទះក្តារ យកសម្បកឈើដោតធ្វើជាគ្រឿងស្លៀកដណ្តប់ បិទបាំងកាយ លោកក៏ប្រាកដឈ្មោះថា ទារុចីរិយ: ព្រោះទ្រទ្រង់សំពត់ ដែលធ្វើដោយឈើ និងឈ្មោះថា ពាហិយ:តាមឈ្មោះកំណើត ដោយប្រការទាំងពួង ដោយប្រការដូច្នេះ ។

លោកកាន់អំបែងមួយ ត្រាច់សូមដុំបាយត្រង់កំពង់សុប្បារក: ដោយ

ទំនងដូចពោលហើយ ពួកមនុស្សឃើញគាត់ ទើបពោលថា បើព្រះអរហន្ត
មានក្នុងលោកសោត លោកគង់មានសភាពយ៉ាងនេះ លោកម្ចាស់អង្គនេះ
កាន់យកសំពត់ដែលគេឲ្យ ឬមិនកាន់យក ព្រោះការប្រាថ្នាតិច ដូច្នេះ ទើប
សាកល្បងបង្អោនសំពត់មកអំពីទីផ្សេងៗ ចូលទៅ ។ គាត់គិតថា បើអញ
មិនមកដោយទំនងនេះសោត ជនទាំងនេះ មិនគប្បីជ្រះថ្លាទីងអញ បើដូច្នោះ
អញគប្បីហាមសំពត់ទាំងនេះ នៅដោយទំនងនេះឯង កាលបើដូច្នេះ លាភ
សក្ការៈ នឹងកើតឡើងដល់អញ ។ គាត់គិតយ៉ាងនេះហើយ តាំងនៅក្នុង
ហានៈជាអ្នកឱកបញ្ឆោត មិនទទួលសំពត់ ។ ពួកមនុស្សគិតថា គួរអស្ចារ្យ
លោកម្ចាស់អង្គនេះប្រាថ្នាតិចពិត ទើបមានចិត្តជ្រះថ្លា ដោយប្រមាណក្រៃលែង
ធ្វើសក្ការៈ និងសមានដ៏ច្រើន ។ ចំណែកលោកបរិភោគអាហារហើយ បាន
ទៅកាន់ទេវស្ថានមួយកន្លែង ក្នុងទីមិនឆ្ងាយ ។ មហាជន ក៏ទៅជាមួយលោក
ដូចគ្នា បានជួសជុលទេវស្ថាននោះឲ្យ គាត់គិតថា មនុស្សទាំងនេះជ្រះថ្លា
ក្នុងហានៈត្រឹមតែអញស្បៀកសំពត់ក្រង ទើបនាំគ្នាធ្វើសក្ការៈ និងរាប់អាន
យ៉ាងនេះ អញគួរមានការប្រព្រឹត្តដ៏ខ្ពង់ខ្ពស់សម្រាប់មនុស្សទាំងនេះ ទើបជា
អ្នកមានបរិក្ខារតិចតួច ជាអ្នកប្រាថ្នាតិច ។ ឯគាត់ កាលត្រូវមនុស្សទាំងនោះ
លើកតម្កើងថា ជាព្រះអរហន្ត ក៏សម្គាល់ខ្លួនថា ជាព្រះអរហន្ត ម្យ៉ាងទៀត
ការធ្វើសក្ការៈ គោរព ក៏ចម្រើនក្រៃលែងឡើងៗ ហើយលោកក៏មានបច្ច័យ
ច្រើនឡើងៗ ព្រោះហេតុនោះ ទើបលោកពោលពាក្យជាដើមថា សម័យ
នោះឯង ពាហិយទារុចីរិយបុរស (អ្នកស្បៀកដណ្តប់សំពត់សម្បកឈើ

ឈ្មោះពាហិយៈ) អាស្រ័យនៅទៀបឆ្នេរសមុទ្រ ឈ្មោះសុប្បារកៈ ជាអ្នក ដែលគេធ្វើសក្ការៈ គោរព រាប់អាន ។

បណ្តាបទទាំងនោះ បទថា **សក្ការោ** *សេចក្តីថា ជាបុគ្គលដែលមហាជន ធ្វើសក្ការៈ ដោយការទំនុកបម្រុង ដោយសេចក្តីគោរព គឺអើពើ ។ បទថា* **គរុការោ** *សេចក្តីថា ដែលមហាជនធ្វើឲ្យធ្ងន់ ដោយការធ្វើឲ្យធ្ងន់ ដូចឆត្រ ថ្ម ដោយបំណងថា ជាអ្នកប្រកបដោយគុណវិសេស ។ បទថា* **មានិការោ** *សេចក្តីថា ជាបុគ្គលដែលមហាជនរាប់អាន ដោយការលើកតម្កើងដោយ ទឹកចិត្ត ។*

បទថា **បូជិការោ** *សេចក្តីថា ដែលមហាជនបូជាហើយ ដោយការបូជា ដោយការធ្វើសក្ការៈ មានផ្កា និងគ្រឿងក្រអូបជាដើម ។ បទថា* **អបចិការោ** *បានដល់ ដែលមហាជនកោតក្រែងហើយ ដោយការឲ្យផ្លូវ និងការនាំអាសនៈ មកជាដើម ដោយចិត្តជ្រះថ្លាក្រៃលែង ។ បទថា* **លាភី ចីវរ ។បេ។ បរិក្ខារានំ** *សេចក្តីថា ជាអ្នកបាន ដោយការបានបច្ច័យ ៤ មានចីវរជាដើមដ៏ ប្រណីត ដែលមហាជននាំចូលទៅក្រៃលែង ។ ម្យ៉ាងទៀត បទថា* **សក្ការោ** *បានដល់ បានទទួលសក្ការៈ ។ បទថា* **គរុការោ** *បានដល់ បានទទួលសេចក្តី គោរព ។ បទថា* **មានិការោ** *បានដល់ ដែលមហាជនរាប់អានច្រើន និងមាន ចិត្តស្រឡាញ់ច្រើន ។ បទថា* **បូជិការោ** *បានដល់ ដែលមហាជនបូជាហើយ ដោយការបូជាដ៏ក្រៃលែងដោយបច្ច័យ ៤ ។ បទថា* **អបចិការោ** *សេចក្តីថា បានទទួលការឱនលំទោន ។ ពិតហើយ ជនទាំងឡាយរមែងធ្វើសក្ការៈដោយ*

បច្ច័យ ៤ តាក់តែងយ៉ាងល្អ ធ្វើឲ្យប្រណីតក្រៃលែង ឲ្យដល់បុគ្គលណា បុគ្គលនោះ ឈ្មោះថា **សក្ការោ** ។ *មនុស្សទាំងឡាយធ្វើនូវការគោរពឲ្យជ្រុកជហើយ ប្រគល់ឲ្យក្នុងបុគ្គលណា បុគ្គលនោះឈ្មោះថា* **គរុកោ** ។ *ជនទាំងឡាយរមែងមានចិត្តប្រព្រឹត្តស្រឡាញ់ និងរាប់អានច្រើននូវបុគ្គលណា បុគ្គលនោះឈ្មោះថា* **មានិតោ** ។ *ជនទាំងឡាយធ្វើវត្ថុទាំងអស់នោះ ដោយការបូជាដល់បុគ្គលណា បុគ្គលនោះឈ្មោះថា* **បូជិតោ** ។ *ជនទាំងឡាយ រមែងធ្វើការបង្អោនយ៉ាងក្រៃលែង ដោយការអភិវាទ ការទទួល និងអញ្ជលីកម្មជាដើមដល់បុគ្គលណា បុគ្គលនោះឈ្មោះថា* **អបចិតោ** ។ *មនុស្សទាំងនោះ បានធ្វើវត្ថុគ្រប់យ៉ាងដល់ពាហិយៈ ដោយហេតុនោះ ទើបលោកពោលពាក្យជាដើមថា ព្រះពាហិយទារុចីរិយៈ ដែលគេធ្វើសក្ការៈហើយ អាស្រ័យនៅត្រង់កំពង់សុប្បារកៈ ។ ក្នុងទីនេះ ព្រះពាហិយទារុចីរិយៈ កាលមិនទទួលចីវរ គេក៏ពោលថា ជាអ្នកបានចីវរដូចគ្នា ដោយការបង្អោនចូលទៅថា មកចុះ សូមទទួលសំពត់នេះ ។ បទថា* **រហោគតស្ស** *បានដល់ នៅក្នុងទីកំបាំង ។ បទថា* **បដិសល្លីនស្ស** *បានដល់ ជាបុគ្គលម្នាក់ឯង ។ កាលត្រូវពួកមនុស្សជាច្រើនពោលថា អ្នកជាព្រះអរហន្ត គាត់ក៏កើតបរិវិតក្ក គឺកើតការត្រិះរិះខុស ដោយអាការដែលពោលក្នុងឥទ្ធិវរនេះ ។ សួរថា កើតបរិវិតក្កដូចម្តេច ។ ឆ្លើយថា កើតបរិវិតក្កឡើងថា មនុស្សពួកណាម្នាក់ ទោះជាព្រះអរហន្ត ឬបុគ្គលដែលសម្រេចអរហត្តមគ្គក្នុងលោក អាត្មាអញ ក៏ជាបុគ្គលម្នាក់ ក្នុងចំនួនព្រះអរហន្ត ឬបុគ្គលសម្រេចអរហត្តមគ្គនោះ សេចក្តីនោះមានអធិប្បាយ*

ដូច្នេះ ជនពួកណាឈ្មោះថា ព្រះអរហន្ត ព្រោះកម្ចាត់សត្រូវ គឺកិលេសក្នុងលោកនេះ និងព្រោះជាអ្នកគួរបូជា និងសក្ការៈជាដើម ឬបុគ្គលពួកណាឈ្មោះថា សម្រេចអរហត្តមគ្គ ព្រោះសម្លាប់សត្រូវ គឺកិលេសទាំងនោះ បណ្តាមនុស្សទាំងនោះ អាត្មាអញ ក៏ជាបុគ្គលម្នាក់ដែរ ។

បទថា **ចោរាណសាសាលោហិតា** *បានដល់ ទេវតាដែលបំពេញសមណធម្មរួមគ្នា ដូចមិត្តភក្តិរួមសាលោហិតគ្នាក្នុងកាលមុន ។ តែអាចារ្យពួកខ្លះពោលថា បទថា* **បុរាណសាសាលោហិតា** *បានដល់ ទេវតាមួយអង្គដែលជាមាតារួមសាលោហិតក្នុងកាលមុន គឺក្នុងភពជទៃ ។ ក្នុងអដ្ឋកថា លោកបដិសេធពាក្យនោះ បានកាន់យកអត្ថជំបូងប៉ុណ្ណោះ ។*

បានឮថា ក្នុងកាលមុន ក្នុងសាសនារបស់ព្រះកស្សបទសពលវិនាសសាបសូន្យទៅ ភិក្ខុ ៧ រូបឃើញប្រការដែលប្លែកនៃសហធម្មិក មានសាមណេរជាដើម កើតនូវសេចក្តីសង្វេគ គិតថា សាសនាមិនទាន់អន្តរធានដរាបណាយើងគប្បីធ្វើទីពឹងដល់ខ្លួនដរាបនោះ ទើបថ្វាយបង្គំសុវណ្ណចេតិយ ហើយចូលព្រៃ ឃើញភ្នំមួយ ទើបពោលថា បុគ្គលមានសេចក្តីអាល័យក្នុងជីវិត ចូរត្រឡប់ បុគ្គលមិនមានសេចក្តីអាល័យ ចូរឡើងភ្នំនេះ ហើយនាំគ្នាចងជណ្តើរឡើងភ្នំនោះទាំងអស់គ្នា ហើយច្រានជណ្តើរចោល ធ្វើសមណធម៌ បណ្តាភិក្ខុទាំងនោះ ព្រះសង្ឃត្តេរសម្រេចអរហត្ត ដោយកន្ទងទៅមួយរាត្រីប៉ុណ្ណោះ លោកនាំបិណ្ឌបាតមកអំពីឧត្តរកុរុទ្វីប ហើយពោលនឹងភិក្ខុទាំងនោះថា អាវុសោទាំងឡាយ ចូរធាន់បិណ្ឌបាតអំពីទីនេះចុះ ។ ភិក្ខុទាំងនោះពោលថា បពិត្រ

លោកម្ចាស់ លោកម្ចាស់បានធ្វើយ៉ាងនេះដោយអានុភាពរបស់ខ្ញុន បើពួកខ្ញុំ ញ្ញុំងគុណវិសេស ឲ្យកើតឡើងបានដូចលោកម្ចាស់សោត ខ្ញុំក៏នឹងនាំមក ធាន់ឯងនោះឯង ទើបមិនប្រាថ្នា ដូច្នោះ តាំងអំពីថ្ងៃទី ២ ទៅ ព្រះថេរៈទី ២ ក៏បានសម្រេចនូវអនាគាមិផល ។ លោកក៏កាន់យកបិណ្ឌបាតយ៉ាងនោះ ទៅ កាន់ទីនោះហើយ និមន្តភិក្ខុក្រៅអំពីនេះឲ្យធាន់ ។ ឯភិក្ខុទាំងនោះក៏បដិសេធ យ៉ាងនោះឯង ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុដែលសម្រេចអរហត្ត ក៏បរិនិញ្ចាន ទៅ ។ ព្រះអនាគាមីក៏ទៅកើតក្នុងជាន់សុទ្ធាវាស ។ ឯព្រះថេរៈ ៥ រូបក្រៅ អំពីនេះ សូម្បីព្យាយាម ក៏មិនអាចធ្វើគុណវិសេសឲ្យកើតឡើងបាន ភិក្ខុទាំង នោះ កាលមិនអាចធ្វើបាន ក៏ស្តាំងស្តមស្ងាប់ក្នុងទីនោះ ហើយកើតក្នុង ទេវលោក ត្រាច់ទៅក្នុងទេវលោកនោះឯង អស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទ-កាលនេះ បានចុតិអំពីទេវលោក កើតក្នុងផ្ទះមានត្រកូលនោះៗ ។ បណ្តា មនុស្សទាំងនោះ ម្នាក់បានជាព្រះរាជា ព្រះនាមបុក្កុសៈ ម្នាក់ទៀត បានជា កុមារកស្សបៈ ម្នាក់បានជាទព្វមល្ងបុត្រ ម្នាក់បានជាសភិយបរិព្វាជក ម្នាក់ បានជាពាហិយទារុចីរិយៈ ។ បណ្តាមនុស្សទាំងនោះ ព្រះអនាគាមីកើតឡើង ក្នុងព្រហ្មលោក ដែលលោកសំដៅយក ពោលពាក្យនេះថា **បុរាណ-សាលោហិតា ទេវតា** គឺទេវតាដែលជាសាលោហិតអំពីដើម ដូច្នេះ ។ ពិតហើយ ទេវតាបុត្រ ក៏ហៅថា ទេវតា ព្រោះអធិប្បាយថា ទេវតា គឺទេវៈ ដូចទេពធីតា ដូចក្នុងប្រយោគជាដើមថា **អថ ទោ អញ្ញតរា ទេវតា** គ្រានោះឯង ទេវតាមួយអង្ត ។ តែក្នុងទីនេះ ព្រហ្ម លោកបំណងយកថា

ជាទេវតា ។ កាលព្រហ្មនោះសម្ងំមើលសម្បត្តិហើយ អាវជ្ជនៈដល់ទីដែលខ្លួនមក ក្នុងលំដាប់ដែលកើតក្នុងព្រហ្មលោកនោះឯង ការដែលពួកជនទាំង ៧ ឡើងភ្នំធ្វើសមណធម្មិក្តី ភាពដែលខ្លួនសម្រេចអនាគាមិផល ហើយកើតក្នុងព្រហ្មលោកក្តី ជ្រាកជហើយ ព្រហ្មនោះពិចារណាថា ជនទាំង ៥ កើតក្នុងទីណាហ្ន៎ ដឹងថា ជនទាំងនោះ កើតក្នុងទេវលោកជាន់កាមាវចរ ក្នុងកាលតមក តាមកាលដ៏សមគួរ បានពិចារណាមើលបវត្តិរបស់ជនទាំងនោះថា ជនទាំងនោះ ធ្វើអ្វីហ្ន៎ ។ តែក្នុងពេលនេះ កាលរំពឹងថា ពួកជនទាំងនោះនៅទីណាហ្ន៎ ទើបបានឃើញពាហិយៈ អាស្រ័យកំពង់សុប្បារកៈ ស្បៃកសំពត់ក្រងដោយសម្បកឈើ ចិញ្ចឹមជីវិតដោយការបោកបញ្ឆោត គិតថា ក្នុងកាលមុន បុគ្គលនេះ មួយអន្ទៀដោយអាត្មាអញ ចងជណ្តើរឡើងភ្នំ ធ្វើសមណធម៌ មិនអាល័យក្នុងជីវិត ព្រោះប្រព្រឹត្តតឹងរ៉ឹងក្រៃលែង សូម្បីព្រះអរហន្តនាំបិណ្ឌបាតមកឲ្យឆាន់ ក៏មិនឆាន់ ឥឡូវនេះ បំណងឲ្យគេលើកតម្កើង មិនមែនជាព្រះអរហន្តសោះ ក៏គង់ប្តេជ្ញាខ្លួនថា ជាព្រះអរហន្ត មានការប្រាថ្នាលាភសក្ការៈ និងកេរ្តិ៍ឈ្មោះ ទាំងមិនដឹងថា ព្រះទសពលកើតឡើងហើយ ណ្ហើយចុះ អញនឹងធ្វើបុគ្គលនេះឲ្យសង្វេគ ហើយឲ្យដឹងថា ព្រះពុទ្ធកើតឡើងហើយ ។ រំពេចនោះឯង ទើបចុះអំពីព្រហ្មលោក ជ្រាកជចំពោះមុខព្រះទារុចីរិយៈ ត្រង់កំពង់សុប្បារកៈ ក្នុងកណ្តាលយប់ ព្រះពាហិយៈឃើញពន្លឺក្នុងលំនៅរបស់ខ្លួន ទើបគិតថា នេះ ហេតុអ្វីហ្ន៎ បានចេញទៅខាងក្រៅ ពិនិត្យមើល ឃើញមហាព្រហ្មនៅលើអាកាស ទើបផ្គងអញ្ជលីសួរថា

លោកជានរណា លំដាប់នោះ ព្រហ្មបានពោលដល់លោកថា ខ្ញុំជាសម្លាញ់របស់អ្នក គ្រានោះ ខ្ញុំសម្រេចអនាគាមិផល កើតក្នុងព្រហ្មលោក តែអ្នកមិនអាចធ្វើគុណវិសេសណាមួយឲ្យកើតបាន ពេលនោះ អ្នកធ្វើកាលកិរិយាទាំងនៅជាបុថុជ្ជន អន្ទោលទៅ ឥឡូវនេះ ទ្រទ្រង់កេទជាតិវិយ មិនមែនជាព្រះអរហន្ត ប្រកាន់លទ្ធិថា យើងជាព្រះអរហន្ត ខ្ញុំដឹងដូច្នេះ ទើបមក នែពាហិយៈ អ្នកមិនមែនជាព្រះអរហន្តទេ ចូរលះបង់ទិដ្ឋិដ៏លាមកបែបនោះចេញ អ្នកកុំប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ដើម្បីទុក្ខអស់កាលយូរឡើយ ព្រះសម្មាសម្ពុទ្ធ ទ្រង់កើតឡើងហើយក្នុងលោក សេចក្តីពិត ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះអរហន្ត ចូលទៅគាល់ទ្រង់ចុះ ។ ដោយហេតុនោះ ទើបលោកពោលពាក្យជាដើមថា គ្រានោះឯង ទេវតាដែលជាសាលោហិតអំពីដើមរបស់ពាហិយទារុចិរិយបុរស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនុកម្បិកោ** បានដល់ មានប្រក្រតីអនុគ្រោះ គឺជាអ្នកក្រែលែងដោយករុណា ។ បទថា **អត្តកាមោ** បានដល់ជាអ្នកប្រាថ្នាប្រយោជន៍ គឺជាអ្នកក្រែលែងដោយមេត្តា ។ ក្នុងទីនេះ ដោយបទដំបូង លោកសម្តែងដល់ភាពដែលទេវតានោះ បំណងនឹងបំបាត់ទុក្ខរបស់ពាហិយៈ ដោយបទក្រោយ សម្តែងដល់ការនាំប្រយោជន៍ចូលទៅ ។ បទថា **ចេតសា** បានដល់ ដោយចិត្តរបស់ខ្លួន ។ ក្នុងទីនេះ គប្បីជ្រាបថា លោកកាន់យកចេតោបរិយញ្ញាណ ដោយលើកចិត្តឡើងជាប្រធាន ។ បទថា **ចេតោបរិវិតក្កំ** បានដល់ ការប្រព្រឹត្តទៅនៃចិត្តរបស់លោក ។ បទថា

អញ្ញាយ ប្រែថា ដឹងហើយ ។ បទថា **តេនុបសង្កមិ** សេចក្តីថា បុរសមានកម្លាំងបត់ដៃ ឬលាចេញ យ៉ាងណា ព្រហ្មអន្តរធានអំពីព្រហ្មលោក មកប្រាកដចំពោះមុខពាហិយៈ ក៏ដូច្នោះដូចគ្នា ។ បទថា **ឯតទវោច** សេចក្តីថា ព្រហ្មបានពោលពាក្យនេះ គឺពាក្យដែលពោលក្នុងឥទ្ធិវនេះជាដើមថា នែពាហិយៈ អ្នកមិនមែនជាព្រះអរហន្តទេ ដូច្នេះ ព្រះពាហិយៈ ត្រូវមិច្ឆាបរិ-វិតក្កដែលប្រព្រឹត្តទៅជាដើមថា បុគ្គលណាម្នាក់ នឹងជាព្រះអរហន្តឬ ដូច្នេះដូចចាប់ចោរ ព្រមទាំងកស្តុតាង ។ បទថា **នេវ ខោ ត្វំ ពាហិយ អរហា** នេះ ព្រហ្មបដិសេធថា ពាហិយៈ មិនមែនព្រះអរិយបុគ្គលក្នុងកាលនោះ ។ ដោយបទថា **នាបិ អរហត្តមគ្គំ វា សមាបន្នោ** នេះ សម្តែងថា ព្រះពាហិយៈនៅជាសេក្ខបុគ្គល ។ ដោយបទទាំង ២ នោះ សម្តែងថា ព្រះពាហិយៈមិនមែនព្រះអរិយបុគ្គលឡើយ ។ ដោយពាក្យថា **សាបិ តេ បដិបទា ឆត្តិ យាយ ត្វំ អរហា វា អស្សសិ អរហត្តមគ្គំ វា សមាបន្នោ** នេះ ព្រហ្មបដិសេធថា ពាហិយៈត្រឹមតែជាកល្យាណបុថុជ្ជន ។ បណ្តាបទទាំងនោះ បទថា **បដិបទា** បានដល់ វិសុទ្ធិ ៦ ទាងដើម មានសីលវិសុទ្ធិជាដើម ។ ដែលឈ្មោះថា បដិបទា ព្រោះជាគ្រឿងប្រព្រឹត្តទៅក្នុងអរិយមគ្គ ។ បទថា **អស្សសិ** ប្រែថា គប្បីសម្រេច ។ សួរថា ការសម្គាល់ខ្លួនថាជាព្រះអរហន្តនេះ កើតឡើងដល់លោក ព្រោះអាស្រ័យអ្វី ។ ឆ្លើយថា អាចារ្យពួកខ្លះពោលថា ការសម្គាល់ខ្លួនថា ជាព្រះអរហន្តកើតឡើងដល់លោក ព្រោះលោកកម្ចាត់កិលេសបានដោយតទង្គប្បហាន ព្រោះបានសាងបុញ្ញាធិការអស់

កាលយូរ ដោយភាពដែលលោកជាអ្នកប្រាថ្នាតិច សន្តោស និងជាអ្នកជុសខាត់ ។ តែអាចារ្យមួយពួកពោលថា ពាហិយៈ បានចតុត្ថជ្ឈាន មានបឋមជ្ឈានជាដើម ព្រោះដូច្នោះ ទើបការសម្គាល់ខ្លួនថា ជាព្រះអរហន្តកើតឡើងដល់លោក ព្រោះកិលេសមិនកើតឡើង ដោយវិក្ខម្ភនប្បហាន ។ ទាំង ២ យ៉ាងនោះ ត្រឹមតែជាមតិរបស់កេចិអាចារ្យប៉ុណ្ណោះ ព្រោះមកក្នុងអដ្ឋកថាថា លោកមានបំណងតែការលើកតម្កើង និងលោកមិនប្រាថ្នាលាភសក្ការៈ និងការសរសើរ ព្រោះដូច្នោះ គប្បីជ្រាបក្នុងសេចក្តីនេះ ដោយនយដូចពោលហើយនោះឯង ។

លំដាប់នោះ ព្រះពាហិយៈសម្លឹងមើលមហាព្រហ្មដែលឈរលើអាកាស ទើបគិតថា ឱ! កាលដែលអញយល់ថាជាព្រះអរហន្ត ជាកម្មធ្ងន់ពិត ព្រហ្មនេះពោលថា បដិបទាជាគ្រឿងសម្រេចអរហត្ត ក៏មិនមានដល់អ្នក បុគ្គលដែលជាព្រះអរហន្តក្នុងលោកមានឬហ្ន៎ ។ លំដាប់នោះ ទើបសួរមហាព្រហ្មនោះ ដោយហេតុនោះ ទើបលោកពោលថា **អថ កេ ចរហិ សទេវតេ លោកេ អរហន្តោ វា អរហត្តមគ្គំ វា សម្មាបន្នា។**

បណ្តាបទទាំងនោះ សព្ទថា **អថ** *ជានិបាត ប្រើក្នុងអត្ថផ្តើមពាក្យសួរ ។ បទថា* **កេ ចរហិ** *កែជា* **កេ ឯតរហិ ។** *បទថា* **លោកេ** *បានដល់ ក្នុងឱកាសលោក ក្នុងសេចក្តីនេះ មានពាក្យអធិប្បាយដូចតទៅនេះ សម័យនោះ ក្នុងផ្ទៃជម្ពូទ្វីបទាំងមូល ដែលជាទីទទួលទ្រ ឥឡូវនេះ ព្រះអរហន្ត ឬបុគ្គលសម្រេចអរហត្តមគ្គ មាននៅក្នុងទីណា ដែលជាទីពួកយើងចូលទៅរកលោក*

ទាំងនោះ តាំងនៅក្នុងឱវាទរបស់លោកហើយ នឹងផុតចាកទុក្ខ ។

បទថា **ឧត្តរេសុ** *លោកពោលសំដៅយកទិសខាងកើត ឆៀងខាងជើង ចាកកំពង់សុប្បារកៈ ។ បទថា* **អរហំ** *បានដល់ ឈ្មោះថា ជាព្រះអរហន្ត ព្រោះជាអ្នកនៅឆ្ងាយអំពីកិលេស ។ ពិតហើយ ព្រះអរហន្តនោះ ឈ្មោះថា ជាអ្នកនៅឆ្ងាយ គឺតាំងនៅក្នុងទីឆ្ងាយចាកកិលេសទាំងពួង ។ ឈ្មោះថា ព្រះអរហន្ត ព្រោះកម្ចាត់កិលេស ព្រមទាំងវាសនាដោយមគ្គ ឬសម្ងាប់កិលេសជួចសត្រូវបាន ។ ពិតហើយ សត្រូវ គឺកិលេសទាំងឡាយ ដែលព្រះមានព្រះភាគសម្ងាប់ គឺដកហើយដោយអរហត្តមគ្គដោយឥតសេសសល់ ។ ម្យ៉ាងទៀត ឈ្មោះថា ជាព្រះអរហន្ត ព្រោះកាច់បំបាក់នូវកាំ គឺកិលេសបាន ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ឈរលើផែនដី គឺសីល ដោយព្រះឃុគលបាទ គឺវីរិយៈ ទ្រង់ប្រើព្រះហស្ត គឺសទ្ធា ចាប់ពូថៅ គឺបញ្ញាដែលជាហេតុធ្វើកម្ម ឲ្យអស់ ហើយទ្រង់ប្រហារ គឺកម្ចាត់ទាំងអស់នៃសង្ឃារចក្រ ដែលមានដុំ សម្រេចដោយអវិជ្ជា ភព និងតណ្ហា មានបុញ្ញាភិសង្ខារជាដើម ជាកម្ម មានជរា និងមរណៈជាខ្នងកង់ ស៊កដោយក្លៅ ដែលសម្រេចដោយអាសវៈ សមុទយៈ ប្រកបចូលក្នុងរថ គឺភព ៣ ដែលប្រព្រឹត្តទៅអស់កាល មិនមានខាងដើម ។ ម្យ៉ាងទៀត ឈ្មោះថា ព្រះអរហន្ត ព្រោះជាបុគ្គលគួរ ។ ពិតហើយ ព្រះមានព្រះភាគ រមែងគួរដល់បច្ចយ មានចីវរជាដើមដ៏ក្រៃលែង និងបូជាពិសេស ព្រោះទ្រង់ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរក្នុងលោក ព្រមទាំងទេវលោក ។ ម្យ៉ាងទៀត ឈ្មោះថា ព្រះអរហន្ត ព្រោះមិនធ្វើបាបក្នុងទី

កំចាំង ពិតហើយ ព្រះតថាគត លោកហៅថា ព្រះអរហន្ត ព្រោះមិនមានការកំចាំងក្នុងការធ្វើបាប ដោយកិលេសលាមក មិនមាន ។ ព្រោះទ្រង់ដកនូវកិលេស មានរាគៈជាដើមបាន ដោយប្រការទាំងពួង ។

ឈ្មោះថា **សម្មាសម្ពុទ្ធ** *ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹងក្រៃលែងនូវធម៌ដែលគួរដឹងក្រៃលែង នូវធម៌ដែលគួរកំណត់ដឹង ដោយជាធម៌ដែលគួរកំណត់ដឹង នូវធម៌ដែលគួរលះ ដោយភាពជាធម៌ដែលគួរលះ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ដោយជាធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរចម្រើន ដោយភាពជាធម៌ដែលគួរចម្រើន ។ សមដូចព្រះតម្រាស់ដែលបានត្រាស់ក្នុងសុត្តនិបាតថា*

អភិញ្ញេយ្យំ អភិញ្ញាតំ ភាវេតព្វញ្ច ភាវិតំ
បហាតព្ពំ បហីនម្ម តស្មា ពុទ្ធោស្មិ ព្រាហ្មណា។

វិជ្ជា និងវិមុត្តិ ដែលគប្បីដឹងច្បាស់ តថាគតដឹងច្បាស់ហើយ មគ្គសច្ចដែលគប្បីចម្រើន តថាគតបានចម្រើនហើយ សមុទយសច្ចដែលគប្បីលះ តថាគតលះបង់ហើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ ទើបតថាគត ឈ្មោះថា ពុទ្ធៈ ។

ម្យ៉ាងទៀត គប្បីណែនាំអត្ថនេះដោយធម៌ពួក ៣ និងពួក ២ ទាំងពួងជាដើម ដោយនយជាដើមថា ធម៌ ឈ្មោះថា ជាកុសល ព្រោះមិនមានទោស មានសុខជាផល ធម៌ ឈ្មោះថា ជាអកុសល ព្រោះមានទោស មានទុក្ខជា

ផល ។ ក្នុងសេចក្តីនេះ មានសេចក្តីសង្ខេបដូច្នេះ ឈ្មោះថា **សម្មាសម្ពុទ្ធ** *ព្រោះត្រាស់ដឹងក្រៃលែងនូវធម៌ទាំងពួង ដោយអាការទាំងពួង ដោយសយម្ភូ-ញ្ញាណ ដែលមិនវិបរិត ដោយប្រការដូច្នេះ ។ ឯសេចក្តីពិស្តារ គប្បីជ្រាប ដោយន័យដែលមកក្នុងវិសុទ្ធិមគ្គនោះ ។*

បទថា **អរហត្តាយ** *បានដល់ ដើម្បីបានអរហត្តផល ។ បទថា* **ធម្មំ ទេសេតិ** *សេចក្តីថា រមែងអាង គឺសម្តែងធម៌ គឺបដិបទា មានសីលជាដើម ដែលគួរដល់គុណពិសេស មានលម្អក្នុងបទដើមជាដើម ឬធម៌ គឺសមថៈ និង វិបស្សនា ដែលសមគួរដល់អធ្យាស្រ័យរបស់វិនេយ្យសត្វនោះឯង ។ បទ ថា* **សំវេជនីយោ** *សេចក្តីថា ឲ្យដល់នូវការសង្វេគក្នុងចិត្តថា អ្នកដ៏ចម្រើន គួរ តិះដៀលពិតហ្ន៎ ភាពជាបុថុជ្ជនដែលជាហេតុឲ្យអាត្មាអញ មិនជាព្រះអរហន្ត សម្គាល់ថាជាព្រះអរហន្ត និងមិនដឹងព្រះសម្មាសម្ពុទ្ធទ្រង់កើតឡើងក្នុងលោក ទ្រង់សម្តែងធម៌ ឯការរស់នៅដឹងបានលំបាក ការស្លាប់ក៏ដឹងបានលំបាក ។ អធិប្បាយថា មានចិត្តសង្វេគដោយអាការតាមដែលពោលហើយ ដោយពាក្យ របស់ទេវតា ។ បទថា* **តាវទេវ** *ប្រែថា ក្នុងខណៈនោះឯង ។ បទថា* **សុប្បារកា បក្កាមិ** *សេចក្តីថា ព្រោះមានហទយៈដែលបីតិមានព្រះពុទ្ធជា អារម្មណ៍កើតឡើង ព្រោះបានឮព្រះនាមថា* **ពុទ្ធោ** *និងត្រូវសេចក្តីសង្វេគ ជាស់តឿន ទើបបានចេញអំពីកំពង់សុប្បារកៈ ចៀសចេញទៅ បែរមុខឆ្ពោះ ក្រុងសាវត្ថី ។ បទថា* **សព្ពត្ថ ឯការត្តិបរិហារេន** *សេចក្តីថា បានទៅដោយ មួយរាត្រីក្នុងផ្លូវទាំងពួង ។ ពិតហើយ ក្រុងសាវត្ថី មានចម្ងាយអំពីកំពង់*

សុប្បារកៈ ១២០ យោជន៍ តែព្រះពាហិយៈនេះ បានទៅក្រុងសាវត្ថីនោះដោយមួយរាត្រី អស់រយៈកាលផ្លូវប៉ុណ្ណោះ ។ លោកដល់ក្រុងសាវត្ថីក្នុងថ្ងៃដែលចេញចាកកំពង់សុប្បារកៈនោះឯង ។ សួរថា ហេតុអ្វី ទើបព្រះពាហិយៈនេះទៅបានយ៉ាងនោះ ។ ឆ្លើយថា ព្រោះអានុភាពរបស់ទេវតា ។ អាចារ្យពួកខ្លះពោលថា ព្រោះពុទ្ធានុភាពក៏មាន ជាការសម្តែងអធិប្បាយដូច្នេះថា ព្រោះលោកពោលថា ដោយមួយរាត្រី ក្នុងទីគ្រប់អន្ទឹ និងព្រោះចម្ងាយផ្លូវ ១២០ យោជន៍ លោកមិនឲ្យអរុណទី ២ តាំងឡើង ក្នុងពេលដែលខ្លួននៅកណ្តាលរាត្រីក្នុងគាមនិគម និងរាជធានី ទើបទៅដល់ក្រុងសាវត្ថី ដោយមួយរាត្រីក្នុងទីគ្រប់កន្លែង ។ សេចក្តីនេះ មិនគប្បីឃើញយ៉ាងនេះថា លោកនៅក្នុងរវាងផ្លូវនោះ អស់ត្រឹមមួយរាត្រី ព្រោះបំណងយកសេចក្តីនេះថា ដោយមួយរាត្រី ក្នុងផ្លូវ ១២០ យោជន៍ ក្នុងថ្ងៃចុងក្រោយ ពេលល្ងាច ទើបដល់ក្រុងសាវត្ថី ។

ឯព្រះមានព្រះភាគ ជ្រាបថា ពាហិយៈមកដល់ ទ្រង់ព្រះតម្រិះថា ជំបូងឥន្ទ្រិយរបស់ពាហិយៈ មិនទាន់ចាស់ក្លា តែក្នុងពេលមួយរំពេចទៀត នឹងដល់នូវភាពចាស់ក្លា ដូច្នេះហើយ ទ្រង់រង់ចាំឲ្យពាហិយៈមានឥន្ទ្រិយចាស់ក្លា ទើបចោមរោមដោយមហាភិក្ខុសង្ឃ ទ្រង់យាងបិណ្ឌបាតក្នុងក្រុងសាវត្ថី ក្នុងខណៈនោះ ។ ពាហិយៈចូលទៅកាន់វត្តជេតពន ឃើញភិក្ខុជាច្រើន ឆាន់ភត្តាហារព្រឹក ហើយចង្រ្កមនៅក្នុងអព្ភោកាស ដើម្បីបន្ទយនូវការវិលច្រអូសផ្លូវកាយ ទើបសួរថា ឥឡូវនេះ ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធ គង់

នៅទីណា ។ ភិក្ខុទាំងឡាយពោលថា ម្នាលពាហិយៈ ព្រះមានព្រះភាគ ចូលកាន់ចន្លោះភូមិដើម្បីបិណ្ឌបាតទៅហើយ ។ ហើយសួរថា អ្នកមកពីទីណា គាត់ឆ្លើយថា មកអំពីកំពង់សុប្បារកៈ ។ ភិក្ខុទាំងឡាយពោលថា អ្នកមកអំពីឆ្ងាយ ចូរអង្គុយសិន ចូរលាងជើង លាបប្រេង ហើយសម្រាកបន្តិច ទម្រាំទ្រង់ត្រឡប់មក ក៏នឹងឃើញព្រះសាស្តា ។ ព្រះពាហិយៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនដឹងអន្តរាយនៃជីវិតរបស់ខ្លួន ដោយថ្ងៃតិចតួច ខ្ញុំមិនឈរ មិនអង្គុយឃ្លេកក្នុងទីណាឡើយ មកអស់ចម្ងាយផ្លូវ ១២០ យោជន៍ លុះគាល់ព្រះសាស្តាហើយ ទើបសម្រាក ទើបប្រញាប់ទៅកាន់ក្រុងសាវត្ថី ឃើញព្រះមានព្រះភាគ រុងរឿងដោយពុទ្ធសិរី ដែលប្រៀបមិនបាន ដោយហេតុនោះ ទើបលោកពោលថា សម័យនោះឯង គាប់ជួនភិក្ខុច្រើនរូបកំពុងចង្រ្កមក្នុងទីវាល ។ លំដាប់នោះឯង ពាហិយទារុចីរិយបុរស ក៏ឆៀងចូលទៅរកពួកភិក្ខុ ដូច្នេះជាដើម ។

[៤៨] *បណ្តាបទទាំងនោះ បទថា* **កហំ** *កាត់បទជា* **កត្ត** *ប្រែថា ទីណា សព្ទថា* **នុ** *ប្រើក្នុងអត្ថថា សង្ស័យ ។ សព្ទថា* **វោ** *ប្រើក្នុងអត្ថថា ធ្វើបទឲ្យពេញ អធិប្បាយថា ក្នុងប្រទេសណាហ្ន៎ ។ បទថា* **ឧសฺสุกามฺหา** *ប្រែថា ជាអ្នកប្រាថ្នានឹងឃើញ ។ លោកសម្តែងថា ខ្ញុំប្រាថ្នានឹងគាល់ នឹងចូលទៅជិតព្រះមានព្រះភាគនោះ ដូចបុគ្គលខ្វាក់ ប្រាថ្នាចក្ខុបសាទ ដូចមនុស្សថ្លង់ ប្រាថ្នាសោតប្បសាទ ដូចមនុស្សគ្រុ ប្រាថ្នាការពោលឲ្យដឹងរឿង ក៏ដូចមនុស្សមានដៃ-ជើងវិកល ប្រាថ្នាដៃ-ជើង ដូចមនុស្សក្រីក្រ ប្រាថ្នា*

ទ្រព្យសម្បត្តិ ដូចអ្នកដើរផ្លូវឆ្ងាយ ប្រាថ្នាផុតភ័យ ដូចបុគ្គលត្រូវរោគគ្របសង្កត់ ប្រាថ្នាការមិនមានរោគ ដូចមនុស្សលិចទូកក្នុងមហាសមុទ្រ ប្រាថ្នាក្បូនធំ ដូច្នោះ ។ បទថា **តរមានរូបោ** *បានដល់ ជាអ្នកមានអាការប្រញាប់ប្រញាល់ ឬមានការសង្រ្គោះ ដែលគួរសរសើរ ។*

បទថា **ចាសាធិកំ** *សេចក្តីថា នាំមកនូវការជ្រះថ្លាដោយជុំវិញ ដល់ជនដែលទ្រហឹងក្នុងការឃើញព្រះរូបកាយ ព្រោះភាពសម្បូរ ដោយលម្អនៃសរីរៈរបស់ទ្រង់ ដែលនាំមកនូវការជ្រះថ្លាមកដោយជុំវិញ ដែលប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ អនុព្យញ្ជនៈ ៨០ ព្រះរស្មីមួយព្យាម និងព្រះកេតុមាលា ដែលបញ្ចេញលើព្រះសីសៈ ។ បទថា* **បសាទនីយំ** *សេចក្តីថា ជាទីតាំងនៃការជ្រះថ្លា សមគួរនឹងជ្រះថ្លា ឬគួរដល់ការជ្រះថ្លារបស់បុគ្គលមានបញ្ញាឃើញប្រចក្ស ព្រោះធម្មកាយសម្បត្តិ ដែលប្រកបដោយចំនួនព្រះគុណ មិនមានប្រមាណ មានទសពលញ្ញាណ ១០ វេសារជ្ជញ្ញាណ ៤ អសាធារណញ្ញាណ ៦ អាវេណិយពុទ្ធធម្ម ១៨ ជាដើម ។ បទថា* **សន្តិន្ទ្រិយំ** *បានដល់ ឥន្ទ្រិយ ៥ ដែលស្ងប់រម្ងាប់ ព្រោះប្រាសចាកការញាប់ញ័រក្នុងឥន្ទ្រិយ ៥ មានចក្ខុន្ទ្រិយជាដើម ។ បទថា* **សន្តមានសំ** *បានដល់ មានចិត្តស្ងប់រម្ងាប់ ព្រោះចូលដល់ភាវៈដែលមនិន្ទ្រិយទី ៦ អស់នូវព្យសន៍ ។ បទថា* **ឧត្តមទមថសមថមនុប្បត្តំ** *សេចក្តីថា ដល់ដោយលំដាប់ គឺសម្រេចការហ្វឹកហាត់ និងស្ងាត់ដ៏ឧត្តម ពោល គឺបញ្ញាវិមុត្តិ និងចេតោវិមុត្តិ ដែលជាលោកុត្តរតាំងនៅ ។ បទថា* **ឧត្តំ** *សេចក្តីថា ឈ្មោះថា ទូន្មានកាយ*

ព្រោះមានកាយសមាចារបរិសុទ្ធល្អ ព្រោះមិនមានការលេងដោយមិនមានការរពិសដៃ-ជើងជាដើម ។ បទថា **គុត្តំ** សេចក្តីថា ឈ្មោះថា ឃុំគ្រងវាចា ព្រោះមានវចីសមាចារបរិសុទ្ធ និងព្រោះមិនមានការលេង ដោយមិនមានវាចាឥតប្រយោជន៍ជាដើម ។ បទថា **យតិន្ទ្រិយំ** បានដល់ ឈ្មោះថា មានឥន្ទ្រិយសង្រួមហើយ ដោយការប្រកបប្ចទ្ធិ ដែលជារបស់អរិយ: ព្រោះមានមនោសមាចារបរិសុទ្ធដោយល្អ និងដោយអំណាចមនិន្ទ្រិយ ព្រោះមានការព្រងើយក្នុងការមិនខ្ចល់ខ្ចាយ និងការមិនពិចារណា ។ បទថា **ឆាតំ** សេចក្តីថា ឈ្មោះថា ជាបុគ្គលប្រសើរ ព្រោះហេតុទាំងនេះ គឺការមិនលុះអំណាចឆន្ទាគតិជាដើម កិលេសមានរាគ:ជាដើម ដែលលះបានហើយ មិនត្រឡប់កើតទៀត គឺមិនវិលត្រឡប់មក បាបណាមួយ ក៏មិនធ្វើដោយប្រការទាំងពួង និងមិនទៅកាន់ភពថ្មី ។

ដោយបទថា **ចាសាធិកំ** នេះ ក្នុងអធិការនេះ លោកសម្តែងដល់ការសំខាន់របស់ព្រះមានព្រះភាគដោយរូបកាយ ។ ដោយបទថា **ចាសាធនីយំ** នេះ សម្តែងដល់ការសំខាន់របស់ព្រះមានព្រះភាគដោយធម្មកាយ ដោយបទជាដើមថា **សន្ទិន្ទ្រិយំ** នេះ សម្តែងដល់ការសំខាន់ក្នុងព្រះគុណដ៏សេស ។ ព្រោះហេតុនោះ គប្បីជ្រាបថា លោកប្រកាសសេចក្តីសំខាន់របស់ព្រះមានព្រះភាគដល់ពួកសត្វដោយឥតសេសសល់ ក្នុងលោកសន្និវាស ដែលកាន់យកប្រមាណ ៤ ពួក ។

ព្រះពាហិយ: បានឃើញព្រះមានព្រះភាគយ៉ាងនោះ កំពុងយាងទៅតាម

ផ្លូវ ត្រែកអរថា យូរពិតហ្ន៎ ទើបអញបានឃើញព្រះមានព្រះភាគដ៏មានសិរី ដែលបីតិ ៥ ប្រការពោលត្រូវសព្វកាល កែវភ្នែកក៏នៅស្ងៀម ព្រោះបីតីជ្រួតជ្រាប បង្អោនសរីរៈចុះ តាំងអំពីទីដែលបានឃើញហើយ ក៏ចុះកាន់កណ្តាលរស្មីព្រះវរកាយរបស់ព្រះមានព្រះភាគ លិចចូលក្នុងរស្មីនោះ ចូលទៅជិតព្រះមានព្រះភាគ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ច្របាច់ព្រះយុគលបាទព្រះដ៏មានព្រះភាគ ជញ្ជក់ព្រះបាទបណ្តើរ ក្រាបទូលបណ្តើរថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់ខ្ញុំព្រះអង្គចុះ ។ ព្រោះហេតុនោះ ទើបលោកពោលថា មានសិរ្សឱនចុះទៀបព្រះបាទនៃព្រះមានព្រះភាគ ហើយអារាធនាព្រះមានព្រះភាគនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់រាត្រីដ៏វែង ដល់ខ្ញុំព្រះអង្គឲ្យទាន ។

បណ្តាបទទាំងនោះ បទថា **សុគតោ** *សេចក្តីថា ឈ្មោះថា* **សុគត** *ព្រោះយាងទៅដោយល្អ គឺយាងទៅកាន់ទីល្អ យាងទៅដោយប្រពៃ មានវាចាប្រពៃ ។ ពិតហើយ ការទៅ លោកហៅថា* **គត** *ការទៅនោះរបស់ព្រះមានព្រះភាគស្អាត គឺបរិសុទ្ធមិនមានទោស ។ សួរថា ការទៅ គឺអ្វី ។ ឆ្លើយថា គឺអរិយមគ្គ ។ ពិតហើយ ព្រះមានព្រះភាគនោះ យាងទៅកាន់ទិសក្សេម មិនជាប់ជំពាក់ ដោយការទៅនោះ ។ សូម្បីអ្នកដទៃ ទ្រង់ក៏ឲ្យប្រព្រឹត្តទៅដែរ ព្រោះដួងច្នោះ ទើបឈ្មោះថា* **សុគត** *ព្រោះយាងទៅស្អាត ។*

ទ្រង់យាងទៅកាន់ទីដែលល្អ គឺអមតនិព្វាន ព្រោះដូច្នោះ ទើបឈ្មោះថា **សុគត** *ព្រោះយាងទៅកាន់ទីល្អ ។ ទ្រង់ឈ្មោះថា* **សុគត** *ព្រោះយាងទៅប្រពៃ មិនវិលត្រឡប់មកកាន់កិលេស ដែលទ្រង់សម្លាប់ដោយមគ្គនោះៗ ។ សមដូចព្រះតម្រាស់ ដែលត្រាស់ក្នុងចូឡនិទ្ទេសថា*

> *កិលេសទាំងឡាយណា ដែលព្រះអង្គលះហើយ ដោយសោតា-បត្តិមគ្គ ព្រះអង្គមិនមក មិនបែរមក មិនត្រឡប់មកកាន់កិលេសទាំងនោះវិញ កិលេសទាំងឡាយណា ដែលព្រះអង្គលះហើយ ដោយសកទាគាមិមគ្គ អនាគាមិមគ្គ ព្រះអង្គមិនមក មិនបែរមក មិនត្រឡប់មកកាន់កិលេសទាំងនោះវិញ កិលេសទាំងឡាយណា ដែលព្រះអង្គលះហើយ ដោយអរហត្តមគ្គ ព្រះអង្គមិនមក មិនបែរមក មិនត្រឡប់កាន់កិលេសទាំងនោះវិញទេ ព្រះនាមថា* **សុគត** *ព្រោះព្រះមានព្រះភាគមិនមក យ៉ាងនេះឯង ដូច្នេះ ។*

ម្យ៉ាងទៀត ពាក្យថា យាងទៅដោយល្អ សេចក្តីថា ព្រោះយាងទៅគឺប្រព្រឹត្តទៅដោយល្អ ដោយសម្មាបដិបត្តិ ក្នុងការកំណត់ទាំង ៣ យ៉ាង ។ ពិតហើយ ឈ្មោះថា **សុគត** *ព្រោះយាងទៅដោយប្រពៃ ដោយអាការយ៉ាងនេះថា ទ្រង់សម្រេចទីបំផុតនូវញោតត្ថចរិយា លោកត្ថចរិយា ពុទ្ធត្ថចរិយា ដោយសម្មាបដិបត្តិ ដែលបរិបូណ៌ដោយបារមី ៣០ ចាប់តាំងអំពីបាទមូលរបស់ព្រះទីបង្ករសម្ពុទ្ធ ដរាបមកដល់ពោធិមណ្ឌល ទ្រង់ធ្វើឲ្យច្រើនចំពោះហិតសុខដល់លោកទាំងពួង បន្ទាប់អំពីនោះ ទើបយាងទៅ គឺប្រព្រឹត្តទៅ*

ដោយភាពជាធំក្នុងធម៌ដែលទ្រង់សម្រេចក្នុងអរិយសច្ច ៤ ដោយមជ្ឈិមា-បដិបទា ពោល គឺពោជ្ឈង្គភាវនាដ៏កំពូល មិនជាប់ជំពាក់ក្នុងអន្តធម៌ទាំងនេះ គឺសស្សទិដ្ឋិ ឧច្ឆេទទិដ្ឋិ កាមសុខល្លិកានុយោគ អត្តកិលមថានុយោគ និង ដោយសម្មាបដិបត្តិ ដែលមិនមែនវិសយក្នុងសត្វទាំងពួង ។ ព្រះមានព្រះភាគ ត្រាស់ដោយប្រពៃ គឺត្រាស់វាចាចំពោះទីគួរ ក្នុងឋាន:ដ៏គួរ ព្រោះហេតុនោះ ទើបឈ្មោះថា **សុគត ។** *សមដូចព្រះតម្រាស់ ដែលត្រាស់ក្នុងមជ្ឈិមនិកាយ ទេវទហសូត្រថា*

> *ជាអ្នកនិយាយពាក្យក្នុងកាលគួរ និយាយពាក្យពិត និយាយពាក្យ មានប្រយោជន៍ និយាយធម៌ និយាយវិន័យ ជាអ្នកនិយាយសម្តី ដែលគួរតម្កល់ទុកក្នុងហឫទ័យ ជាពាក្យប្រកបដោយគ្រឿងអាង ជាពាក្យមានកំណត់ ជាពាក្យប្រកបដោយប្រយោជន៍តាមកាលគួរ ដូច្នេះ ។*

និងត្រាស់ក្នុងមជ្ឈិមនិកាយ អភយរាជកុមារសូត្រទៀតថា

> *តថាគតដឹងនូវវាចាណា ដែលមិនពិត មិនទៀង មិនប្រកបដោយ ប្រយោជន៍ វាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ ជនទាំងឡាយដទៃផង តថាគតក៏មិនពោលវាចានោះជាដើម ។*

ឈ្មោះថា **សុគត** *ព្រោះត្រាស់ប្រពៃ ដោយប្រការដូច្នេះ ។ បទថា* **យំ មមស្ស ឧីយរត្តំ ហិតាយ សុខាយ** *សេចក្តីថា ការសម្តែងអាងដល់កម្មណា គប្បីប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់ឈាន និងវិមោក្ខជាដើម*

និងដើម្បីសុខ និងដើម្បីសម្រេចឈាន និងវិមោក្ខជាដើមនោះ ដល់ខ្ញុំព្រះអង្គ អស់កាលយូរ ។

[៤៩] *បទថា* **អកាលោ ខោ តាវ** *សេចក្តីថា ម្នាលពាហិយៈ មិនមែនកាល ដើម្បីសម្តែងធម៌ដល់អ្នក អធិប្បាយថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ មិនមានកាលក្នុងការបដិបត្តិប្រយោជន៍ដល់ពួកសត្វ ព្រោះព្រះមានព្រះភាគ ជាកាលវាទី ។ ក្នុងពាក្យថា* **កាលោ** *នេះ បំណងយកកាលដែលវេនេយ្យសត្វ មានឥន្ទ្រិយចាស់ក្លា ។ ជ្បិតថា ព្រោះក្នុងខណៈនោះ ជីងបានលំបាក ឥន្ទ្រិយទាំងឡាយរបស់ព្រះពាហិយៈចាស់ក្លា និងមិនចាស់ក្លា ដូច្នោះ ទើបព្រះមានព្រះភាគមិនត្រាស់ទេសនានោះ កាលទ្រង់អាងដល់ហេតុ ទ្រង់ប្រថាប់ឈរត្រង់រវាងផ្លូវ ទើបត្រាស់ថា* **អន្តរឃរំ បវិដ្ឋម្ហា** *ដូច្នេះ ។ បទថា* **ទុដ្ឋានំ** *ប្រែថា គប្បីជីងបានលំបាក ។ ដោយបទថា* **ជីវិតន្តរាយានំ** *ព្រះពាហិយៈបំណងនឹងពោលថា ការប្រព្រឹត្តទៅ ឬមិនប្រព្រឹត្តទៅនៃធម៌ ដែលធ្វើអន្តរាយចំពោះជីវិត ទើបពោលថា* **ជីវិតន្តរាយានំ** *ដូច្នេះ ដោយអំណាចការវិលវល់ ។ ពិតហើយ ជីវិត គឺការប្រព្រឹត្តទៅទាក់ទងដោយបច្ច័យដ៏ច្រើន និងអន្តរាយចំពោះជីវិតនោះ ក៏មានច្រើន ។ សមដូចព្រះតម្រាស់ក្នុងមជ្ឈិមនិកាយ ភទ្ទេករត្តសូត្រថា*

អច្ចេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា ។

នរណានឹងជឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាច្រើននោះ មិនមានឡើយ ដូច្នេះ ។

ព្រោះហេតុអ្វី ទើបព្រះពាហិយៈនេះ បំណងតែអន្តរាយជីវិតប៉ុណ្ណោះ ដែលជាលំដាប់ដំបូង ។ អាចារ្យពួកខ្លះឆ្លើយថា ព្រោះលោកជឹងពីអារម្មណ៍ដែលជានិមិត្ត ឬឈ្វាសក្នុងវត្តុដែលខ្លួនមិនឃើញ ។ អាចារ្យមួយពួកទៀតពោលថា ព្រោះលោកបានឮអន្តរាយជីវិត ក្នុងសម្នាក់របស់ទេវតា ។ លោកត្រូវឧបនិស្សយសម្បត្តិជាស់តឿន ទើបពោលយ៉ាងនោះ ព្រោះជាបុគ្គលមានភពចុងក្រោយ ពិតហើយ លោកទាំងនោះមិនសម្រេចអរហត្ត ទើបមិនអស់ជីវិត ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ មានព្រះបំណងសម្តែងធម៌ដល់លោកនោះឯង ទើបហាមអស់វារៈ ២ ដង បានឮថា ទ្រង់មានព្រះតម្រិះយ៉ាងនេះថា តាំងអំពីកាលដែលពាហិយៈនេះឃើញតថាគត សរីរៈទាំងមូលដែលបីតិពាល់ត្រូវមិនដាច់ខ្សែ កម្លាំងបីតិខ្លាំងក្លា ទើបស្តាប់ធម៌ហើយ មិនអាចចាក់ធ្លុះបាន ទើបទ្រង់ឃាត់ ដរាបដល់មជ្ឈត្តុបេក្ខាតាំងនៅ សូម្បីសេចក្តីក្រវល់ក្រវាយក្នុងកាយរបស់លោកក៏មានកម្លាំង ព្រោះលោកមកកាន់ផ្លូវអស់ចម្ងាយ ១២០ យោជន៍ លោករម្ងាប់សេចក្តីក្រវល់ក្រវាយសិនព្រោះហេតុនោះ ទើបទ្រង់បដិសេធអស់វារៈ ២ ដង ។ តែអាចារ្យពួកខ្លះពោលថា ព្រះមានព្រះភាគទ្រង់ធ្វើយ៉ាងនោះ ដើម្បីឲ្យកើតសេចក្តីអើពើ ក្នុងការស្តាប់ធម៌ ។ តែព្រះអង្គត្រូវអាពាធនាអស់ ៣ ដង ទ្រង់ឃើញមជ្ឈត្តុបេក្ខា

ជាគ្រឿងរម្ងាប់សេចក្តីក្រវល់ក្រវាយ និងអន្តរាយជីវិតដែលជ្រុកជដល់លោក ទ្រង់ត្រិះរិះថា ឥឡូវនេះ ជាកាលដើម្បីសម្តែងធម៌ ទើបផ្តើមសម្តែងធម៌ដោយ នយជាដើមថា **តស្មាតិហ តេ** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **តស្មា** *សេចក្តីថា ព្រោះលោកជាបុគ្គល កើតសេចក្តីខ្វល់ខ្វាយ អង្វរតថាគតក្រៃលែង ឬព្រោះលោកពោលថា អន្តរាយនៃជីវិតដ៏ងបានលំបាក ឥន្ទ្រិយរបស់លោកចាស់ក្លាហើយ ។ សព្ទ ថា* **តិហ** *ត្រឹមតែជានិបាត ។ បទថា* **តេ** *ប្រែថា ដែលលោក ។ ដោយ ពាក្យថា* **ឯវំ** *នេះ ត្រាស់ដល់អាការដែលពោលក្នុងឥឡូវនេះ ។ បទថា* **សិក្ខិតព្វំ** *សេចក្តីថា គប្បីធ្វើការសិក្សាដោយសិក្ខាបទទាំង ៣ មានអធិ-សីលសិក្ខាជាដើម ។*

កាលទ្រង់សម្តែងអាការដែលគប្បីសិក្សា ទើបត្រាស់ពាក្យជាដើមថា **ឯដ្ឋេ ឯដ្ឋមត្តំ ភវិស្សតិ** *រូបារម្មណ៍ដែលអ្នកឃើញហើយគ្រាន់តែជារូប-រម្មណ៍ដែលឃើញហើយ ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **ឯដ្ឋេ ឯដ្ឋមត្តំ** *បានដល់ ត្រឹមតែការឃើញ រូបាយតនៈដោយចក្ខុវិញ្ញាណ អធិប្បាយថា អ្នកគប្បីសិក្សាថា ចក្ខុវិញ្ញាណ ឃើញនូវរូបក្នុងរូបប៉ុណ្ណោះ មិនឃើញសភាវលក្ខណៈ មានអនិច្ចលក្ខណៈជា ដើមឡើយ យ៉ាងណា រូបដ៏សេស ត្រឹមតែជាការឃើញ ដោយវិញ្ញាណដែល ប្រព្រឹត្តទៅតាមចក្ខុទ្វារប៉ុណ្ណោះ ។ ម្យ៉ាងទៀត អធិប្បាយថា ការដឹងច្បាស់ នូវរូបក្នុងរូបដោយចក្ខុវិញ្ញាណ ឈ្មោះថា ឃើញរូបក្នុងរូបដែលឃើញ ។ បទ*

ថា **មត្តំ** ប្រែថា ប្រមាណ ។ ប្រមាណនៃរូបនេះដែលឃើញហើយ ព្រោះដូច្នោះ ទើបឈ្មោះថា **ឯិដ្ឋមត្តំ** អធិប្បាយថា ចិត្តត្រឹមតែជាចក្ខុវិញ្ញាណជាប្រមាណប៉ុណ្ណោះ ។ លោកអធិប្បាយថា ចក្ខុវិញ្ញាណ រមែងមិនត្រេកអរ អាក់អន់ រង្វេងក្នុងរូបដែលមកប្រាកដ យ៉ាងណា អញនឹងតាំងជវនចិត្ត ដោយប្រមាណនៃចក្ខុវិញ្ញាណ យ៉ាងនេះថា ជវនចិត្តរបស់អញ ត្រឹមតែជាចក្ខុវិញ្ញាណប៉ុណ្ណោះ ព្រោះវៀរចាកភាគៈជាដើម ។ ម្យ៉ាងទៀត រូបដែលចក្ខុវិញ្ញាណឃើញ ឈ្មោះថា **ឯិដ្ឋ។** ចិត្ត ៣ ដួង គឺសម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត និងវោដ្ឋព្វនចិត្តដែលកើតឡើងយ៉ាងនោះឯង ឈ្មោះថា **ឯិដ្ឋមត្ត។** គប្បីជ្រាបក្នុងសេចក្តីនេះយ៉ាងនេះថា ចិត្ត ៣ ដួងនេះ មិនត្រេកអរ មិនអាក់អន់ មិនរង្វេង យ៉ាងណា កាលរូបមកប្រាកដ អញក៏នឹងដឹកនាំចិត្តឲ្យកើតឡើងដោយប្រមាណសម្បដិច្ឆន្នចិត្តជាដើមនោះឯង អញមិនឲ្យឈានកន្លងប្រមាណនោះកើតឡើង ដោយតម្រេកជាដើម ដូច្នោះ ។ ក្នុងសុតៈ និងមុតៈ ក៏នយនេះដូចគ្នា ។ បទថា **មុតំ** គប្បីជ្រាបគន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈ និងដោយវិញ្ញាណ ដែលមានគន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈនោះជាអារម្មណ៍ ។ ក្នុងពាក្យថា **វិញ្ញាតេ វិញ្ញាតមត្តំ** នេះ មានវិនិច្ឆ័យដូច្នេះ ឈ្មោះថា **វិញ្ញាត** បានដល់ អារម្មណ៍ដែលមនោទ្វារវជ្ជនចិត្តជំនឿចប្បាស់ហើយ ។ កាលជំនឿចប្បាស់អារម្មណ៍នោះ ក៏ឈ្មោះថា មនោទ្វារវជ្ជនចិត្តជំនឿចប្បាស់ហើយ ហេតុនោះ ទើបឈ្មោះថា មានអាវជ្ជនចិត្តជាប្រមាណ ។ ក្នុងសេចក្តីនេះ មានអធិប្បាយដូច្នេះថា អាវជ្ជនចិត្ត រមែងមិន

ត្រេកអរ មិនអាក់អន់ មិនវង្វេង យ៉ាងណា អញនឹងផ្អាកចិត្តដោយប្រមាណ នៃអាវជ្ជនចិត្តប៉ុណ្ណោះ មិនឲ្យកើតឡើងដោយតម្រេកជាដើម ដូច្នោះ ។ បទ ថា **ឯវញ្ហិ តេ ពាហិយ សិក្ខិតព្ពំ** *សេចក្តីថា ម្នាលពាហិយៈ អ្នកគប្បី សិក្សាដោយអនុលោមសិក្ខាទាំង ៣ ដោយបដិបទានេះយ៉ាងនេះ ។*

ដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់ចែកអារម្មណ៍ដែលផ្សេងគ្នាដោយ ប្រភេទអារម្មណ៍ ៦ មួយអន្ទើដោយវិញ្ញាណកាយ ៦ ដោយសង្ខេប និងតាម គាប់ចិត្តរបស់ពាហិយៈ ដោយវិបស្សនា ដោយកោដ្ឋាសទាំង ៤ មានរូបដែល ខ្លួនឃើញហើយជាដើមហើយ ទើបទ្រង់សម្តែងញាតប្បវិញ្ញា និងតីរណប្ប-វិញ្ញាក្នុងសេចក្តីនោះដល់លោក ។ សេចក្តីនេះដូចម្តេច ព្រោះថា ក្នុងសេចក្តី នេះ រូបារម្មណ៍ ឈ្មោះថា **ទិដ្ឋ** *ព្រោះអត្ថថា ដែលចក្ខុវិញ្ញាណគប្បីឃើញ ។ ឯចក្ខុវិញ្ញាណ មួយអន្ទើដោយវិញ្ញាណដែលប្រព្រឹត្តទៅតាមចក្ខុទ្វារនោះ ឈ្មោះ ថា* **ទិដ្ឋ** *ព្រោះអត្ថថា ឃើញ ។ ទាំង ២ យ៉ាងនោះ ត្រឹមតែជាធម៌ដែល ប្រព្រឹត្តទៅតាមបច្ច័យប៉ុណ្ណោះ ។ ក្នុងសេចក្តីនេះ បុគ្គលណាម្នាក់ ធ្វើឯងក្តី ឲ្យអ្នកដទៃធ្វើក្តី មិនមាន ។ ពិតហើយ ក្នុងសេចក្តីនេះ មានអធិប្បាយ ដូច្នេះថា ចក្ខុវិញ្ញាណនោះ ឈ្មោះថា មិនទៀង ព្រោះមានហើយ បែរជាមិន មាន ឈ្មោះថា ជាទុក្ខ ព្រោះត្រូវការកើតឡើង និងការរលត់ទៅបៀតបៀន ឈ្មោះថា ជាអនត្តា ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ហេតុនោះ ក្នុងសេចក្តីនេះ ចាត់ជាឱកាសរបស់ធម៌ មានតម្រេកជាដើម នៃបណ្ឌិតបាន អំពីណា ។*

គប្បីជ្រាបវិនិច្ឆ័យក្នុងសុត:ជាដើមថា ឥទ្ធូវនេះ ដើម្បីនឹងសម្តែងបហានប្បវិញ្ញោ មួយអន្ទើដោយមូលខាងលើដល់បណ្ឌិត ដែលតាំងនៅក្នុងញាតប្បវិញ្ញោ និងតីរណប្បវិញ្ញោ ទើបផ្តើមពាក្យជាដើមថា **យតោ ខោ តេ ពាហិយ** *ជូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **យតោ** *បានដល់ ក្នុងកាលណា ឬព្រោះហេតុណា ។ បទថា* **តេ** *បានដល់ **តវ** ប្រែថា ដល់លោក ។ បទថា* **តតោ** *បានដល់ ក្នុងកាលនោះ ឬព្រោះហេតុនោះ ។ បទថា* **តេន** *សេចក្តីថា ដោយរូបដែលលោកគប្បីឃើញជាដើម ឬដោយកិលេស មានរាគ:ជាដើម ដែលទាក់ទងដោយរូបដែលលោកឃើញហើយជាដើម ។ ទ្រង់ត្រាស់ពាក្យនេះថា ម្នាលពាហិយៈ ក្នុងកាលណា ឬព្រោះហេតុណា ត្រឹមតែរូបដែលអ្នកឃើញហើយជាដើម នឹងមានដល់បុគ្គលដែលបដិបត្តិតាមវិធី ដែលតថាគតពោលហើយ ក្នុងរូបដែលឃើញហើយជាដើម ដោយការសូងចុះនូវសភាវ:ដែលមិនវិបរិត ក្នុងកាលនោះ ឬព្រោះហេតុនោះ អ្នកនឹងមិនមានដោយកិលេស មានរាគ:ជាដើម ដែលទាក់ទងដោយរូប ដែលអ្នកឃើញហើយជាដើម អ្នកនឹងមិនជាបុគ្គលត្រេកត្រអាល អាក់អន់ ឬវង្វេង ឬនឹងមិនជាបុគ្គលទាក់ទងដោយរូប ដែលអ្នកឃើញហើយជាដើមនោះ ព្រោះលះរាគ:ជាដើមបានហើយ ។ បទថា* **តតោ តំ ពាហិយ ន តត្ថ** *សេចក្តីថា ក្នុងកាលណា ឬព្រោះហេតុណា អ្នកនឹងជាបុគ្គលច្រាសចាកតម្រេក ព្រោះរាគ:នោះ អាក់អន់ ព្រោះទោស: ឬវង្វេង ព្រោះមោហៈ ក្នុងកាលនោះ*

ឬព្រោះហេតុនោះ អ្នកនឹងមិនមានក្នុងរូប ដែលឃើញហើយជាដើមនោះ ឬ កាលរូបនោះដែលឃើញហើយ ឬសំឡេង និងអារម្មណ៍ដែលដឹងហើយ អ្នក នឹងមិនជាបុគ្គលជាប់ជំពាក់ តាំងនៅដោយតណ្ហា មានៈ និងទិដ្ឋិថា នុ៎ះរបស់ អញ អញជារបស់នោះ នុ៎ះជាខ្លួនរបស់អញ ។ ដោយពាក្យមានប្រមាណ ប៉ុណ្ណេះ ទ្រង់ឲ្យបហានប្បរិញ្ញាដល់ទីបំផុតហើយ សម្តែងនូវភូមិ ។ បទថា **តតោ តំ ពាហិយ នេវិធ ន ហុរំ ន ឧភយមន្តរេន** *សេចក្តីថា ម្នាលពាហិយៈ ក្នុងកាលណា អ្នកនឹងមិនជាបុគ្គលទាក់ទងក្នុងរូបដែលឃើញ ហើយជាដើមនោះ ដោយកិលេស មានរាគៈជាដើម ក្នុងកាលនោះ អ្នកនឹង មិនមានក្នុងលោកនេះ ក្នុងលោកខាងមុខ និងលោកទាំង ២ ។ បទថា* **ឯសេវន្តោ ទុក្ខស្ស** *សេចក្តីថា ពិតហើយ ក្នុងសេចក្តីនេះ មានអធិប្បាយ ត្រឹមប៉ុណ្ណេះថា ទីបំផុតដែនកំណត់ និងការវិលវល់នៃកិលេសទុក្ខ និងវដ្តទុក្ខ ប៉ុណ្ណេះ ។ អាចារ្យពួកណា កាន់យកបទថា* **ឧភយមន្តរេន** *ហើយ ទើប ប្រាថ្នា ឈ្មោះថា រវាងភព ពាក្យរបស់អាចារ្យទាំងនោះ ខុស ។ ពិតហើយ ភាវៈរវាងភព លោកជំទាស់ហើយ ក្នុងព្រះអភិធម្មនោះឯង ។ ពាក្យថា* **អន្តរេន** *ជាការសម្តែងវិកប្បដទៃ ។ ព្រោះហេតុនោះ ក្នុងសេចក្តីនេះ មាន អធិប្បាយដូច្នេះថា វិកប្បដទៃមិនមានក្នុងលោកនេះ លោកខាងមុខ ឬលោក ទាំង ២ ម្យ៉ាងទៀត ពាក្យថា* **អន្តរេន** *ជាការសម្តែងភាវៈមិនមានវិកប្បដទៃ ។ ពាក្យនោះ មានអធិប្បាយដូច្នេះថា ទីតាំងដទៃមិនមាន ក្នុងលោកនេះ លោក ខាងមុខ សូម្បីរវាងភពក៏មិនមាន អាចារ្យពួកណា កាន់យកដោយមិនមែន*

*ឧបាយប្រាជ្ញា នូវអត្តសុត្តបទទាំងនេះថា អន្តរាបរិនិព្វាយី និងថា សម្ភវេសី ហើយពោលថា កពដនៃទៅមានដូចគ្នា អាចារ្យទាំងនោះ ព្រោះត្រូវជំទាស់ថា អត្តសុត្តបទដើមថា ឈ្មោះថា អន្តរាបរិនិព្វានយី ព្រោះមិនរំលងពាក់កណ្តាលអាយុក្នុងភូមិនោះ មានអវិហាព្រហ្មជាដើម ហើយបរិនិព្វាន ដោយកិលេសបរិនិព្វានដោយឥតសេសសល់ ព្រោះសម្រេចអរហត្តមគ្គក្នុងរវាង មិនមានក្នុងកពដនៃទេឬយ និងត្រូវជំទាស់អត្តសុត្តបទក្រោយថា សត្វពួកណា នឹងមិនជាយ៉ាងនោះ សត្វទាំងនោះ នឹងជាបុគ្គលអស់អាសវៈ មានក្នុងកពមុន អធិប្បាយថា ឈ្មោះថា **សម្ភវេសី** ព្រោះស្វែងរកកពថ្មី ផ្ទុយគ្នានឹងអន្តរាបរិនិព្វាយីបុគ្គលនោះ និងឈ្មោះថា សេក្ខបុថុជ្ជន ព្រោះលះកវសំយោជនៈមិនបាន ម្យ៉ាងទៀត បណ្តាកំណើត ៤ អណ្ឌជសត្វ និងជលាពុជសត្វ មិនទាន់ទម្លាយសម្បកស៊ុត ឬសា្បនជរាបណា ឈ្មោះថា **សម្ភវេសី** ជរាបនោះ សត្វដែលចេញពីសម្បក ស៊ុត និងសា្បន ឈ្មោះថា **ភូត** សំសេទជសត្វ និងឱបបាតិកសត្វ ឈ្មោះថា សម្ភវេសី ក្នុងខណៈចិត្តជួងជំបូង តាំងអំពីខណៈចិត្តជួងទី ២ ទៅ ឈ្មោះថា **ភូត** ម្យ៉ាងទៀត សត្វទាំងឡាយកើតដោយឥរិយាបថណា មិនទាន់ដល់ឥរិយាបថជនៃជរាបណា នៅឈ្មោះថាជាសម្ភវេសីជរាបនោះ បន្ទាប់អំពីនោះ គឺប្តូរឥរិយាបថ ឈ្មោះថា **ភូត** ព្រោះហេតុនោះ ទើបលោកជំទាស់ថា មិនមាន ដូច្នេះ កាលមានអត្តដែលអនុលោមតាមបាលីត្រង់ៗ និងជាប្រយោជន៍បានដោយអត្តដែលកំណត់ដោយកពដនៃ ដែលមិនអាចពង្រីកបាន ។ អាចារ្យពួកណា ពោលយុត្តិថា យើញ

ធម៌ ដែលប្រព្រឹត្តទៅដោយការបន្តប្រាកដក្នុងចំណែកជនៃមិនជាច់ខ្សែ សេចក្តីនោះ គប្បីប្រាកដក្នុងការបន្តនៃអវិញ្ញាណកទ្រព្យ មានស្រូវជាដើម យ៉ាងណា ក្នុងការបន្តនៃសវិញ្ញាណកសង្ខារ ក៏គប្បីប្រាកដក្នុងចំណែកជនៃ ដោយមិនជាច់ខ្សែយ៉ាងនោះ ម្យ៉ាងទៀត ន័យនេះ រមែងសមក្នុងកាល មានភពជនៃមិនមែនដោយប្រការជនៃឡើយ ព្រោះហេតុនោះ បុគ្គលមានឫទ្ធិ សម្រេចនូវការជំនាញផ្លូវចិត្ត អធិដ្ឋានកាយឲ្យប្រព្រឹត្តទៅតាមចិត្ត គប្បីជំទាស់យុត្តិដោយការចេញចាកព្រហ្មលោក មកកាន់លោកនេះ ឬចាកលោកនេះ ទៅកាន់ព្រហ្មលោកខណៈជាមួយគ្នា បើប្រាថ្នាការប្រព្រឹត្តទៅរបស់ធម៌ក្នុងចំណែកដែលមិនជាច់ខ្សែក្នុងទីគ្រប់ស្ថានសោត បើលោកអ្នកមានឫទ្ធិទាំងឡាយគប្បីមានឥទ្ធិ វិសយជាអចិន្តេយ្យសោត ពាក្យនោះ គប្បីស្មើគ្នាក្នុងទីនេះ ព្រោះព្រះបាលីថា **កម្មវិបាកោ អចិន្តិយោ** *ផលរបស់កម្មជាអចិន្តេយ្យ ព្រោះហេតុនោះ ពាក្យនោះ ត្រឹមតែជាមតិរបស់អាចារ្យទាំងនោះប៉ុណ្ណោះ ព្រោះថា សភាវធម៌ មានភាពជាអចិន្តេយ្យ សភាវធម៌ទាំងនោះ ទីខ្លះ ទើបប្រាកដក្នុងចំណែកដោយបច្ច័យ ទីខ្លះ ប្រាកដដោយចំណែកមិនជាច់ខ្សែ ។ ពិតហើយ របស់ដែលកើតឡើងព្រោះបច្ច័យ មានឧបមាដូចសំឡេងរំពងជាដើម រមែងកើតប្រាកដក្នុងចំណែកមួយ មានចំណែកនៃកញ្ចក់ និងក្អមជាដើមចាកបច្ច័យមានសំឡេងរំពងខាងមុខជាដើម ។ ព្រោះហេតុនោះ ទើបមិនគប្បីបង្អោនវត្ថុទាំងអស់ ក្នុងទីគ្រប់អន្លើ ដូច្នេះ ។ ក្នុងសេចក្តីនេះ មានសេចក្តីសង្ខេបប៉ុណ្ណោះ ។ ឯសេចក្តីពិស្តារ មានការពិចារណារឿងរបស់ភពជនៃ ដែលឲ្យ*

សម្រេចឧទាហរណ៍ជាដើមនៃឧបមា គប្បីមើលក្នុងដីកាកថាវត្ថុប្បករណ៍ចុះ ។ ឯអាចារ្យមួយពួកទៀតពោលថា បទថា **ឥធ** *លោកពោលសំដៅយកកាមភព ។ បទថា* **ហុរំ** *ពោលសំដៅយកអរូបភព ។ បទថា* **ឧភយ-មន្តរេន** *ពោលសំដៅយករូបភព អាចារ្យពួកជទៃពោលថា បទថា* **ឥធ** *បានដល់ អាយតនៈខាងក្នុង ។ បទថា* **ហុរំ** *បានដល់ អាយតនៈខាងក្រៅ ។ បទថា* **ឧភយមន្តរេន** *បានដល់ ចិត្ត និងចេតសិក ។ ម្យ៉ាងទៀត អាចារ្យមួយពួកពោលថា បទថា* **ឥធ** *ពោលថា បច្ចុយធម៌ ។ បទថា* **ហុរំ** *ពោលថា បច្ចុប្បន្នធម៌ គឺធម៌កើតអំពីបច្ចុយ ។ បទថា* **ឧភយមន្តរេន** *ពោលថា បញ្ញត្តិធម៌ ពាក្យទាំងអស់ មិនមានក្នុងអដ្ឋកថា ។ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ គប្បីសង្គ្រោះដោយអាការ ៤ ដោយរូបដែលចក្ខុ-វិញ្ញាណឃើញហើយជាដើម ដោយពាក្យជាដើមថា* **ឯត្ថេ ឯដ្ឋមត្តំ ភវិស្សតិ** *កាលចក្ខុវិញ្ញាណឃើញរូប ក៏ត្រឹមតែជាការឃើញយ៉ាងនេះសិន ក្នុងធម៌ទាំងនោះ លោកសម្តែងដល់អសុភកាវនា ទុក្ខានុបស្សនា អនិច្ចានុបស្សនា និងអនត្តានុបស្សនាដោយមុខ គឺការវៀរចាកការប្រកាន់ថា ស្អាត ជាសុខ ជារបស់ទៀង និងជាតួខ្លួន ។ បើពោលដោយសង្ខេប លោកពោលវិបស្សនា និងវិសុទ្ធិខាងក្រោម ។ ដោយពាក្យថា* **តតោ តុំ ពាហិយ ន តេន** *នេះ ត្រាស់ដល់មគ្គ ព្រោះបំណងយកការកាត់ផ្តាច់នូវកិលេស មានរាគៈជាដើមជាច់ជាសមុច្ឆេទ ។ ដោយពាក្យថា* **តតោ តុំ ពាហិយ ន តត្ត** *នេះ ត្រាស់ដល់ផលចិត្ត ។ ដោយពាក្យថា* **នេវិធ** *ជាដើម គប្បីឃើញថា ត្រាស់ដល់*

អនុបាទិសេសនិព្វានធាតុ ។ ព្រោះហេតុនោះ ទើបលោកពោលថា **អថខោ ពាហិយស្ស ។បេ។ អាសវេហិ ចិត្តំ វិមុច្ចិ** *ដូច្នេះ ។*

ចិត្តរបស់ពាហិយៈ រួចផុតចាកអាសវៈ ដោយការសម្តែងបទសង្ខេបនេះ ។ បទថា **តាវតោ** *បានដល់ ក្នុងខណៈនោះឯង មិនមែនកាលដទៃទេ ។ បទថា* **អនុចានាយ** *ប្រែថា មិនប្រកាន់មាំ ។ បទថា* **អាសវេហិ** *សេចក្តីថា ចាកកាមភពៈជាដើមដែលមានឈ្មោះថា អាសវៈ ព្រោះហូរទៅ គឺប្រព្រឹត្តទៅចាកភវគ្គព្រហ្ម រហូតដល់គោត្រភូ និងដួចគ្រឿងត្រាំ មានសុភជាដើម ដោយអត្ថថា ត្រាំយូរ ។ បទថា* **វិមុច្ចិ** *សេចក្តីថា រួចផុត គឺរលាស់ចេញចាកកាមភពៈជាដើម ដោយសមុច្ឆេទវិមុត្តិ និងបដិបស្សទ្ធិវិមុត្តិ ។*

ព្រះពាហិយៈនោះ គ្រាន់តែស្តាប់ធម៌ របស់ព្រះសាស្តាប៉ុណ្ណោះ ជម្រះសីលឲ្យបរិសុទ្ធ អាស្រ័យសមាធិចិត្តតាមដែលបានហើយ ផ្តើមវិបស្សនាជាវិប្បាកញ្ញាបុគ្គល ឲ្យអាសវៈទាំងពួងអស់ទៅ សម្រេចអរហត្ត មួយអន្ទឹងឯងបដិសម្ភិទាខណៈនោះឯង ។ លោកកាត់កិលេស ដួចក្រសែទឹកក្នុងសង្ឃារធ្វើទីបំផុតនៃវដ្តទុក្ខ ទ្រទ្រង់នូវកាយចុងក្រោយ ត្រូវធម្មតាប្រព្រឹត្តទៅដោយបច្ចវេក្ខណញ្ញាណ ១៩ ជាស់តឿន ទើបទូលសួរជាមួយព្រះមានព្រះភាគ ព្រះសាស្តាត្រាស់សួរថា អ្នកមានបាត្រ និងចីវរបរិបូណ៌ហើយឬ ក៏ក្រាបទូលថា មិនទាន់បរិបូណ៌ឡើយ ព្រះអង្គ គ្រានោះ ព្រះសាស្តាត្រាស់នឹងពាហិយៈថា បើដូច្នោះ ចូរអ្នកស្វែងរកបាត្រ និងចីវរ ដូច្នេះហើយ ទ្រង់ចៀសចេញទៅ ។ ព្រោះហេតុនោះ ទើបលោកពោលថា **អថ ខោ ភគវា ។បេ។**

បក្ពាមិ ដូច្នេះ ។

បានឣថា ពាហិយៈនោះ កាលធ្វើសមណធម៌អស់ ២ ម៉ឺនឆ្នាំ នៅក្នុងសាសនារបស់ព្រះកស្សបទសពល គិតថា ធម្មតាភិក្ខុ កាលខ្លួនបានបច្ចុយហើយ ធ្វើទានតាមសមគួរ ឆាន់ដោយខ្លួន ទើបគួរ ដូច្នេះហើយ មិនធ្វើការសង្ត្រោះដោយបាត្រ ឬចីវរដល់ភិក្ខុមួយរូប ហេតុនោះ ទើបលោកមិនមានឧបនិស្សុយឯហិភិក្ខុឧបសម្បទា ។ តែអាចារ្យពួកខ្លះពោលថា បានឣថា លោកជាចោរក្នុងចន្លោះព្រះពុទ្ធ ចងធ្នូ តាំងខ្លួនជាចោរក្នុងព្រៃ យើញព្រះបច្ចេកពុទ្ធមួយអង្គ ព្រោះការចង់បានបាត្រ និងចីវរ ទើបប្រើធ្នូបាញ់ព្រះបច្ចេកពុទ្ធ រួចកាន់យកទៅ ដោយហេតុនោះ បាត្រ និងចីវរដែលសម្រេចដោយឬទ្ធិ មិនកើតដល់លោក ព្រះសាស្តាទ្រង់ជ្រាបដូច្នោះហើយ ទើបមិនបានប្រទានបព្វជ្ជាដោយឯហិភិក្ខុ ។ លោកកំពុងស្វែងរកបាត្រ និងចីវរ មេគោមួយ រត់មកដោយសម្ចុះដ៏រហ័ស វ៉ធលោកឲ្យអស់ជីវិត ទើបលោកពោលថា **អថ ខោ អចិរប្បក្ពន្ទស្ស ភគវតោ ពាហិយំ ទារុចីរិយំ គាវី តរុណវច្ឆា អធិ-បតិត្វា ជីវិតា វោរោបេសិ** កាលដែលព្រះមានព្រះភាគ ទ្រង់ចេញផុតទៅមិនយូរប៉ុន្មាន មេគោមានកូនខ្ចី បុះផ្ពួលពាហិយទារុចីរិយបុរស ឲ្យដាច់ចាកជីវិតទៅ ។

[៥០] បណ្តាបទទាំងនោះ បទថា **អចិរប្បក្ពន្ទស្ស** ប្រែថា ព្រះមានព្រះភាគ ចៀសចេញទៅមិនយូរ ។ បទថា **គាវី តរុណវច្ឆា** បានដល់យក្ខិនី កាឡាខ្លួនជាមេគោកូនខ្ចី ។ បទថា **អធិបតិត្វា** បានដល់ បុះ គឺ

ញាំញី ។ បទថា **ជីវិតា វោរោបេសិ** *សេចក្តីថា មេគោនោះឲ្យកើតចិត្តចង់ពៀរឡើង ដោយហេតុត្រឹមតែបានឃើញ ព្រោះបានទួរការអាឃាតក្នុងអត្តភាពមុន ទើបយកស្នែងជល់ឲ្យអស់ជីវិត ។*

ព្រះសាស្តា បិណ្ឌបាតហើយ សោយស្រេចហើយ មួយអន្ទើដោយភិក្ខុជាច្រើន ទ្រង់ចេញអំពីព្រះនគរ ទតឃើញព្រះពាហិយៈដួលត្រង់គំនរសំរាម ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកឈរត្រង់ទ្វារផ្ទះមួយខ្នង នាំគ្នាយកក្រែមក នាំសរីរៈនេះទៅអំពីនគរ ធ្វើឈាបនកិច្ចសាងស្តូប ។ ភិក្ខុទាំងឡាយបានធ្វើយ៉ាងនោះ ។ កាលធ្វើហើយ ទៅកាន់វិហារគាល់ព្រះសាស្តាក្រាបទូលកិច្ចដែលខ្លួនធ្វើហើយ ទើបទូលសួរដល់អភិសម្បរាយភពរបស់ពាហិយៈ ។ សម័យនោះ ទើបព្រះមានព្រះភាគ ត្រាស់ដល់ភិក្ខុនោះថា ពាហិយៈបរិនិព្វានហើយ ។ ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះពាហិយទារុចីរិយៈ សម្រេចអរហត្តហើយឬ លោកសម្រេចអរហត្តទីណា សូមទ្រង់ត្រាស់ប្រាប់ចុះ ។ កាលព្រះសាស្តាត្រាស់ថា ក្នុងខណៈដែលស្តាប់ធម៌របស់តថាគត ទើបពួកភិក្ខុទូលថា ទ្រង់សម្តែងធម៌ដល់លោកក្នុងពេលណា ។ ព្រះសាស្តាត្រាស់ថា កាលតថាគតកំពុងបិណ្ឌបាត ឈរនៅក្នុងរវាងផ្លូវថ្ងៃនេះឯង ។ ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលទ្រង់ឈរត្រាស់ក្នុងរវាងផ្លូវ មានប្រមាណតិចណាស់ លោកធ្វើគុណវិសេសឲ្យកើតដោយហេតុ មានប្រមាណប៉ុណ្ណេះបានដូចម្តេច ព្រះសាស្តាកាលទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ អ្នកកុំ

ប្រមាណក្នុងធម៌របស់តថាគតថា មានតិច ឬច្រើន ទោះបីគាថាច្រើនពាន់តែមិនប្រកបដោយប្រយោជន៍ មិនប្រសើរទេ ឯបទគាថា សូម្បីតែមួយបទដែលប្រកបដោយប្រយោជន៍ប្រសើរជាង ទើបត្រាស់គាថាក្នុងធម្មបទថា

សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា
ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

បើគាថា សូម្បី ១ ពាន់ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថានោះ ពុំប្រសើរឡើយ អ្នកណា ស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ដូច្នេះ ។

កាលទ្រង់សម្តែងថា អ្នកជាបុគ្គលគួរដល់ការបូជាដោយហេតុត្រឹមតែបរិនិព្វានតែម្យ៉ាងក៏មិនមែន ដោយពិត ជាបុគ្គលសមគួរដល់ការបូជា ដោយការៈដ៏លើសជាងកិក្ខុសាវ័ករបស់តថាគត ទាងទិប្បាកិញ្ញា ទើបទ្រង់ស្តាបនាលោកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុសាវ័ក ដែលជាទិប្បាកិញ្ញា ពាហិយទារុចីរិយៈជាកំពូល ដែលលោកសំដៅយកពោលថា **អថ ខោ ភគវា សាវត្ថិយំ បិណ្ឌាយ ចរិត្វា ។បេ។ បរិនិព្ពុតោ ភិក្ខវេ ពាហិយោ ទារុចីរិយោ** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **បច្ឆាភត្តំ** *បានដល់ ក្រោយអំពីសោយព្រះក្រយាហារស្រេចហើយ ។ បទថា* **បិណ្ឌចារិកប្បដិក្កន្តោ** *បានដល់ ទ្រង់ត្រឡប់អំពីបិណ្ឌបាត ។ សូម្បីទាំង ២ បទ លោកក៏អធិប្បាយថា សោយ*

ព្រះក្រយាហារស្រេចហើយ ។ បទថា **និយ្យាតុំ** *សេចក្តីថា នាំចេញទៅខាងក្រៅព្រះនគរ ។ បទថា* **ឈាបេថ** *ប្រែថា ចូរធ្វើឈាបនកិច្ច ។ បទថា* **ថូបញ្ចស្ស ការេថ** *សេចក្តីថា ចូរនាំសរីរធាតុរបស់ពាហិយៈមកសាងចេតិយបញ្ចុះ ។ ក្នុងសេចក្តីនោះ ទ្រង់ត្រាស់ហេតុដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សព្រហ្មចារីរបស់ពួកអ្នកបរិនិព្វានហើយ សេចក្តីនោះ មានអធិប្បាយថា ព្រះពាហិយៈនោះបានប្រព្រឹត្តធម៌ គឺបដិបត្តិអធិសីលជាដើម ដែលពួកអ្នកប្រព្រឹត្តហើយ និងកំពុងប្រព្រឹត្ត ដែលឈ្មោះថា* **ព្រហ្ម** *ព្រោះអត្ថថា ប្រសើរ បានប្រសើរស្មើនឹងពួកអ្នក ព្រោះហេតុនោះ ទើបឈ្មោះថា* **សព្រហ្មចារី** *បានធ្វើកាលកិរិយាហើយ តាមប្រក្រតីនៃមរណកាល ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ចូរពួកអ្នកយកគ្រែ សែងសរីរៈរបស់ពាហិយៈទៅធ្វើឈាបនកិច្ច និងសាងស្តូបបញ្ចុះ ។ បទថា* **តស្ស កា គតិ** *សេចក្តីថា បណ្តាគតិទាំង ៥ លោកមានគតិ ឧបបត្តិភពដូចម្តេច ។ ម្យ៉ាងទៀត បទថា* **គតិ** *ប្រែថា កើតឡើង អធិប្បាយថា គតិរបស់លោកធ្លាក់ចុះដូចម្តេច ជាព្រះអរិយៈ ឬជាបុថុជ្ជន ។ បទថា* **អភិសម្បរាយោ** *បានដល់ លោកលះទៅហើយ កើតក្នុងភព ឬរលត់ក្នុងភព ។ ពោលដោយអត្ថ ទ្រង់ប្រកាសថា លោកបរិនិព្វានដោយការត្រាស់ឲ្យសាងស្តូបក៏ពិត តែភិក្ខុដែលមិនដឹងដោយហេតុប្រមាណប៉ុណ្ណោះ ក៏ទូលសួរថា គតិរបស់លោកដូចម្តេច ឬដែលបំណងឲ្យធ្វើ ឲ្យប្រាកដ ទើបទូលសួរព្រះមានព្រះភាគយ៉ាងនោះ ។*

បទថា **បណ្ឌិតោ** *សេចក្តីថា ឈ្មោះថា* **បណ្ឌិត** *ព្រោះទៅ គឺប្រព្រឹត្ត*

ទៅ បានដល់ ប្រព្រឹត្តទៅដោយបញ្ញា ឈ្មោះថា **បណ្ឌ** *ព្រោះសម្រេចដោយបញ្ញា ដែលសម្បយុត្តដោយអរហត្តមគ្គ ។ បទថា* **បច្ចាឌិ** *ប្រែថា ប្រព្រឹត្តទៅហើយ ។ បទថា* **ធម្មស្ស** *បានដល់ លោកុត្តរធម៌ ។ បទថា* **អនុធម្មំ** *បានដល់ ធម៌ គឺបដិបទា មានសីលវិសុទ្ធិជាដើម ។ ម្យ៉ាងទៀត បទថា* **ធម្មស្ស** *បានដល់ និព្វានធម៌ ។ បទថា* **អនុធម្មំ** *បានដល់ ធម៌ គឺអរិយមគ្គ និងអរិយផល ។ បទថា* **ន ច មំ ធម្មាធិការណា** *សេចក្តីថា ហេតុនៃការសម្តែងធម៌ មិនធ្វើឲ្យតថាគតលំបាក ព្រោះបដិបត្តិតាមដែលទ្រង់ប្រៀនប្រដៅ ។ ពិតហើយ លោកស្តាប់ធម៌ ឬរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តា មិនបដិបត្តិធម៌ តាមដែលទ្រង់ប្រៀនប្រដៅ ឈ្មោះថា ធ្វើព្រះសាស្តាឲ្យទ្រង់លំបាក ដែលលោកបំណង ពោលក្នុងមជ្ឈិមនិកាយ ជាសរាសិសូត្រថា*

វិហឹសសញ្ញី ខគុណំ ន ភាសឺ ធម្មំ បណីតំ មនុជេសុ ព្រហ្មេតិ ។

ម្នាលព្រហ្ម តថាគត មានសេចក្តីសម្គាល់ក្នុងការនាំឲ្យលំបាកកាយ និងវាចា បានជាមិនសម្តែងធម៌ដ៏ឧត្តម ដែលតថាគតស្ទាត់ហើយ ក្នុងពួកមនុស្សទាំងឡាយ ដូច្នេះ ។

ម្យ៉ាងទៀត បទថា **ន ច មំ ធម្មាធិការណា** *សេចក្តីថា ជាហេតុនៃធម៌នេះក៏មិនមែន ។ លោកអធិប្បាយពាក្យនេះថា ឈ្មោះថា មិនធ្វើតថាគតឲ្យលំបាក ព្រោះបដិបត្តិសាសនធម៌របស់តថាគតនេះដោយល្អ ដែលជាហេតុនាំសត្វចេញចាកវដ្តទុក្ខ ។ បុគ្គលបដិបត្តិអាក្រក់ ទម្លាយសាសនធម៌ ឈ្មោះថា ឲ្យការប្រហារសរីរៈ គឺធម៌របស់ព្រះសាស្តា ។ តែព្រះពាហិយៈនេះ ធ្វើ*

សម្មាបដិបត្តិឲ្យដល់ទីបំផុតហើយ បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា **បរិនិព្វុតោ ភិក្ខវេ ពាហិយោ ឋានុ-ចីរិយោ ។**

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបថា ព្រះពាហិយត្តេរបរិ-និព្វាន ដោយអនុបាទិសេសនិព្វានធាតុ គតិរបស់ព្រះខីណាស្រពទាំងឡាយ ដែលបរិនិព្វានហើយនោះ បុគ្គលជាច្រើនដងបានលំបាក ដោយអាការទាំង ពួង ។ បទថា* **ឥមំ ឧទានំ** *បានដល់ ទ្រង់បន្ទឺឧទានដែលសម្តែងអានុភាពនៃ ការបរិនិព្វានដែលមិនប្រតិស្ឋានហើយនេះ ។ បណ្តាបទទាំងនោះ បទថា* **យត្ថ** *សេចក្តីថា អាបោធាតុ បឋវីធាតុ តេជោធាតុ និងវាយោធាតុ មិនឈមចុះ គឺមិនប្រតិស្ឋានក្នុងនិព្វានធាតុណា ព្រោះហេតុអ្វី ព្រោះព្រះនិព្វាន មានសភាវៈ ជាអសង្ខតធម៌ ។ ពិតហើយ វត្ថុតិចតួច នៃសង្ខតធម៌ មិនមានក្នុងព្រះ និព្វាននោះ ។ បទថា* **សុក្កា** *សេចក្តីថា ផ្កាយព្រះគ្រោះ និងផ្កាយនក្ខត្តឫក្ស ដែលបានឈ្មោះថា* **សុក្ក** *ព្រោះមានពន្លឺពណ៌ស មិនរុងរឿង គឺមិនភ្លឺស្វាង ។ បទថា* **អាធិច្ចោ ឆប្បកាសតិ** *សេចក្តីថា សូម្បីព្រះអាទិត្យដែលអាចផ្សាយ ពន្លឺ មួយខណៈ ៣ ទ្វីប ក៏មិនផ្សាយពន្លឺដោយអំណាចរស្មី ។ បទថា* **ឆ តត្ត ចន្ទិមា ភាតិ** *សេចក្តីថា កាលព្រះអាទិត្យមានរស្មីខ្លាំងក្លា ព្រះចន្ទមាន រស្មីត្រជាក់ គួរបូលចិត្ត ក៏មិនរុងរឿង ព្រោះកម្ចាត់រស្មីត្រចះត្រចង់របស់ខ្លួន ព្រោះមិនមានក្នុងព្រះនិព្វាននោះ ទ្រង់ត្រាស់ថា* **តមោ តត្ត ឆ វិជ្ជតិ** *ងងឹត មិនមានក្នុងព្រះនិព្វាននោះ ដូច្នេះ ទ្រង់សំដៅយកសេចក្តីសង្ស័យថា បើព្រះ*

ចន្ទ និងព្រះអាទិត្យមិនមានក្នុងព្រះនិព្វាននោះ ព្រះនិព្វាននោះ គប្បីងងឹតតែម្យ៉ាង ដូចលោកន្តរនរក ។ ពិតហើយ កាលរូបមាន ការងងឹតក៏មាន ។ បទថា **យតា ច អត្តនាវេទិ មុនិ មោនេន ព្រាហ្មណោ** *សេចក្តីថា ព្រាហ្មណ៍ជាព្រះអរិយសាវក ដែលបានឈ្មោះថា* **មុនិ** *ព្រោះប្រកបដោយមគ្គញ្ញាណ ដែលបានឈ្មោះថា* **មោន** *ព្រោះដឹងសច្ចៈ ៤ និងប្រកបដោយមោនេយ្យ-ប្បដិបទាផ្លូវកាយជាដើម លះអាការ មានការស្តាប់តៗ គ្នាមកជាដើមដោយខ្លួន គឺខ្លួនឯង ។ ក្នុងខណៈអរហត្តមគ្គ ក្នុងកាលណា គឺក្នុងកាលណា ដោយបដិវេធញ្ញាណ ពោល គឺមានៈនោះឯង និងដឹង គឺដឹងច្បាស់នូវព្រះនិព្វាន ធ្វើប្រចក្សដល់ខ្លួន ។ បាឋៈថា* **អវេទិ** *ដូច្នេះក៏មាន ។ អធិប្បាយថា បានដឹងទូទៅ ។ សព្ទថា* **អថ** *ក្នុងបទថា* **អថ រូបា អរូបា ច សុខទុក្ខា បមុច្ចតិ** *ប្រែថា ខាងក្រោយអំពីការត្រាស់ដឹងព្រះនិព្វាននោះ ។ បទថា* **រូបា** *បានដល់ រូបធម៌ ។ ដោយបទថា* **រូបា** *នោះ ឈ្មោះថា លោកកាន់យកបញ្ចវោការភព និងឯកវោការភព ។ បទថា* **អរូបា** *បានដល់ អរូបធម៌ ។ ដោយបទថា* **អរូបា** *នោះ ឈ្មោះថា លោកកាន់យកអរូបភព ព្រោះមិនលាយឡំជាមួយរូប ដែលហៅថា ចតុវោការភពក៏មាន ។ បទថា* **សុខទុក្ខា** *សេចក្តីថា ចាកវដ្តៈ ដែលមានទាំងសុខ និងទុក្ខ ដែលកើតឡើងក្នុងទីសព្វ*

អន្ទឺ ។

ម្យ៉ាងទៀត បទថា **រូបា** *បានដល់ ព្រោះបដិសន្ធិក្នុងរូបលោក ។ បទថា* **អរូបា** *បានដល់ ព្រោះបដិសន្ធិក្នុងអរូបលោក ។ បទថា* **សុខុក្ខា** *បានដល់ ព្រោះបដិសន្ធិក្នុងកាមាវចរភូមិ ពិតហើយ កាមភព មានទាំងសុខនិងទុក្ខលាយឡំគ្នា ។ ព្រាហ្មណ៍នោះរមែងផុតចាកវដ្តៈទាំងអស់នោះ ដោយឥតសេសសល់ ដោយប្រការដូច្នេះឯង ។*

សូម្បី ២ គាថា ព្រះមានព្រះភាគទ្រង់សម្តែងថា ព្រះនិព្វានបែបនេះ ជាគតិនៃពាហិយៈ ដែលជាបុត្ររបស់តថាគត ។

អដ្ឋកថាពាហិយសូត្រ ចប់

អធិប្បាយពោធិវគ្គទី ១ ចប់

សុត្តន្តបិដក

ឧទាន មុចលិន្ទវគ្គទី ២

មុចលិន្ទសូត្រ

[៥១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទើបបានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅទៀបមុចលិន្ទ (រាំងអន្ទក់) ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ សម័យនោះឯង ព្រះមានព្រះភាគទ្រង់គង់ដោយបល្ល័ង្កតែមួយ សោយវិមុត្តិសុខអស់ ១ សប្តាហ៍ ។ សម័យនោះ បណ្តាលមានភ្លៀងធំ ពុំជួកាលកើតឡើង ។ ភ្លៀងរលឹមមួយសប្តាហ៍ មានមេឃត្រជាក់ទូទឹមស្រអាប់ ។ លំដាប់នោះ មុចលិន្ទនាគរាជចេញពីលំនៅរបស់ខ្លួនហើយ ពែនព័ទ្ធព្រះកាយនៃព្រះមានព្រះភាគដោយក្អែន ៧ ជុំ ហើយបើកពពារដ៏ធំ ជាំងអំពីខាងលើព្រះសិរ្សព្រះមានព្រះភាគ ដោយគិតថា រង្គាកុំបីប៉ះពាល់ព្រះមានព្រះភាគ កម្តៅកុំបីប៉ះពាល់ព្រះមានព្រះភាគ សម្ផស្សរបស់ មូស ខ្យល់ កម្តៅថ្ងៃ ពស់តូច ពស់ធំ ក៏កុំបីបៀតបៀនព្រះមានព្រះភាគឡើយ ។ លុះកន្លងសប្តាហ៍នោះហើយ ព្រះមានព្រះភាគ ទ្រង់ចេញអំពីសមាធិនោះ ។ លំដាប់នោះ មុចលិន្ទនាគរាជដឹងថា ភ្លៀងរាំងហើយមានពពកស្រឡះហើយ ក៏រំសាយក្អែន ចាកព្រះកាយនៃព្រះមានព្រះភាគ និម្មិតកេទរបស់ខ្លួន (ជាកេទមាណព) ឈរប្រណម្យអញ្ជលី នមស្ការព្រះមានព្រះភាគ ពីខាងទីចំពោះព្រះភក្ត្រព្រះអង្គ ។ លុះព្រះមានព្រះភាគទ្រង់បានជ្រាបច្បាស់សេចក្តីនោះហើយ ទ្រង់បន្ទឺនូវឧទាននេះ ក្នុងវេលានោះថា

វិវេករបស់បុគ្គលអ្នកត្រេកអរ (ដោយមគ្គញ្ញាណ) មានធម៌ស្តាប់ ហើយបានឃើញច្បាស់ (ដោយ ញាណចក្ខុ) នាំមកនូវសុខ ការមិនបៀតបៀនគ្នា និងការសង្រួម ក្នុងសត្វទាំងឡាយ ជាសុខក្នុងលោក ការប្រាសចាកតម្រេក ការប្រព្រឹត្តកន្លងកាមទាំង-ឡាយ ជាសុខក្នុងលោក កិរិយាកម្ចាត់បង់នូវអស្មិ-មានៈ ដំណើរនុ៎ះ ឈ្មោះថា ជាសុខយ៉ាងក្រៃលែង ។

សូត្រទី ១ ។

អដ្ឋកថា

មុច្ចលិន្ទវគ្គទី ២

មុច្ចលិន្ទសូត្រ

មុច្ចលិន្ទសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ

[៥១] *ដើមរាំងអន្ទក់ លោកហៅថា* **មុច្ចលិន្ទ** *ក្នុងពាក្យថា* **មុច្ចលិន្ទ-មូលេ** *នេះ មុច្ចលិន្ទនោះ លោកហៅថា* **និច្ចុល** *ដូច្នេះក៏មាន ។ ក្នុងទីជិតមុច្ចលិន្ទនោះ ។ តែអាចារ្យពួកខ្លះពោលថា បទថា* **មុចលោ** *ជាឈ្មោះរបស់ដើមឈើនោះ ។ តែបទថា* **មុចលោ** *នោះ លោកពោលថា មុច្ចលិន្ទ ព្រោះជាដើមឈើធំបំផុតក្នុងព្រៃ ។*

បទថា **មហាអកាលមេឃោ** *បានដល់ មហាមេឃដែលកើតឡើង ក្នុងកាលដែលមិនទាន់ដល់រដូវភ្លៀង ។ ពិតហើយ មហាកាលមេឃនោះ កើតឡើងក្នុងផ្ទៃចក្រវាលទាំងមូល ក្នុងខែចុងក្រោយរបស់គិម្ហរដូវ ។ បទថា* **សត្តាហវទ្ធលិកា** *សេចក្តីថា កាលមហាអកាលមេឃនោះ កើតឡើងហើយមានភ្លៀងធ្លាក់មិនដាច់អស់ ៧ ថ្ងៃ ។ បទថា* **សីតវាតទុទ្ទិនី** *សេចក្តីថា ភ្លៀងធ្លាក់ជោកជាំអស់ ៧ ថ្ងៃនោះ បានឈ្មោះថា* **ទុទ្ទិនី** *ព្រោះជាថ្ងៃដែលខ្យល់រងា លាយដោយតំណក់ភ្លៀងវិលទៅដោយជុំវិញ បៀតបៀនហើយ ។*

បទថា **មុច្ចលិង្គោ នាម នាគរាជា** *បានដល់ ស្តេចនាគមានអានុភាពច្រើន កើតឡើងក្នុងនាគពិភពខាងក្រោមបាតស្រះបោក្ខរណី ជិតដើមមុច្ចលិន្ទនោះឯង ។ បទថា* **សកភវនា** *ប្រែថា ចេញពីពិភពនាគរបស់ខ្លួន ។ បទថា*

សត្តក្ខត្តុំ ភោគេហិ បរិក្ខិបិត្វា *សេចក្តីថា យកវង្វែលនៃរាងកាយរបស់ខ្លួន ព័ទ្ធជុំវិញកាយរបស់ព្រះមានព្រះភាគ ៧ ជុំ ។ បទថា* **ឧបរិមុទ្ធនិ មហន្តំ ផណំ វិហាច្ឆុ** *សេចក្តីថា បើកពពារធំរបស់ខ្លួន លើចំណែកព្រះសីសៈរបស់ព្រះមានព្រះភាគ ។ បាឋៈថា* **ផណំ ករិត្វា** *ដូច្នេះក៏មាន ។ អត្ថក៏ដូចគ្នានោះឯង ។*

បានឮថា ស្តេចនាគនោះ មានការគិតយ៉ាងនេះថា ព្រះមានព្រះភាគ គង់ប្រថាប់នៅត្រង់គល់ឈើកែវពិភពរបស់អញ ហើយក្លៀងក៏ធ្លាក់ជោកជាំអស់ ៧ ថ្ងៃនេះ នៅប្រព្រឹត្តទៅនៅឡើយ អញគួរបានជាទីសម្រាករបស់ព្រះអង្គ ។ ស្តេចនាគនោះ កាលមិនអាចនិម្មិតប្រាសាទដែលសម្រេចដោយរតនៈ ៧ ក៏គិតថា បើអញធ្វើយ៉ាងនេះ នឹងឈ្មោះថា មិនបានយកកាយឲ្យជាសារៈ អញនឹងធ្វើសេចក្តីខ្វល់ខ្វាយផ្លូវកាយដល់ព្រះទសពល ទើបនិម្មិតកាយឲ្យធំ ព័ទ្ធជុំវិញព្រះសាស្តា ៧ ជុំ ហើយបើកពពារខាងលើ ។ លោកពោលក្នុងអដ្ឋកថាខន្ធកៈថា ខាងក្នុងរង្វង់ ទំហំប៉ុនបន្ទប់កណ្តាគារ ក្នុងលោហប្រាសាទ តែក្នុងអដ្ឋកថាមជ្ឈិមនិកាយ លោកពោលថា មានទំហំប៉ុនផ្នែកខាងក្រោមនៃលោហប្រាសាទ ។ បានឮថា ស្តេចនាគមានអធ្យាស្រ័យដូច្នេះថា ព្រះសាស្តាប្រថាប់នៅដោយឥរិយាបថដែលទ្រង់ប្រាថ្នា ។ ឯព្រះមានព្រះភាគគង់ប្រថាប់ដូចដើមនោះឯង សម្លឹងអស់មួយសប្តាហ៍ ។ ក្នុងទីនោះ បានដូចជាកូដាគារមានបង្អួចបិទជិត ទ្វារមានគន្លឹះជិតល្អ ។ ពាក្យជាដើមថា **មា ភគវន្តំ សីតំ** *ជាពាក្យសម្តែងហេតុដែលស្តេចនាគនោះធ្វើយ៉ាងនោះ ។ ពិតហើយ ស្តេចនាគ*

នោះគិតថា សូមរងា ក្តៅ សម្ផស្សនៃរបោមជាដើម កុំបៀតបៀនព្រះដ៏មានព្រះភាគឡើយ ទើបធ្វើយ៉ាងនោះ ។ ក្នុងការធ្វើនោះ ការក្តៅរមែងមិនមានព្រោះភ្លៀងធ្លាក់អស់ ៧ ថ្ងៃ ពិតហើយ តែទោះជាយ៉ាងនោះ បើភ្លៀងជាច់គ្រាប់ម្តងម្តាល កម្តៅក៏នឹងមាន ការក្តៅនោះ ក៏កុំបៀតបៀនឡើយ ព្រោះដូច្នោះ ទើបស្តេចនាគនោះ គិតយ៉ាងនោះ ក៏គួរហើយ តែក្នុងសេចក្តីនេះ អាចារ្យពួកខ្លះពោលថា សពូថា **ឧណ្ហា** ជាការប្រារព្ធដល់ហេតុក្នុងការយករង្វែលព័ទ្ធឲ្យបរិបូណ៌ទូលំទូលាយ ។ កាលធ្វើរង្វង់តូចពេក កម្តៅកើតអំពីសរីរៈស្តេចនាគ គប្បីបៀតបៀនព្រះមានព្រះភាគ តែបើធ្វើរង្វង់ធំពេក ការក្តៅបែបនោះ ក៏បៀតបៀនមិនបាន ព្រោះដូច្នោះ ទើបស្តេចនាគបានធ្វើដូច្នោះ ។

បទថា **ទិធុំ** បានដល់ ស្រឡះ ។ អធិប្បាយថា ឈ្នោះថា នៅឆ្វាយ ព្រោះប្រាសចាកពពក ។ បទថា **ទិគតពលាហកំ** ប្រែថា ប្រាសចាកពពក បទថា **ទេវំ** បានដល់ អាកាស ។ បទថា **ទិធិត្វា** បានដល់ ដឹងថា ឥឡូវនេះ អាកាសប្រាសចាកពពក ព្រះមានព្រះភាគ មិនមានអន្តរាយអំពីវិរោធិ-ប្បច្ចយ មានរងាជាដើម ។ បទថា **ទិធិវេឋេត្វា** ប្រែថា រំសាយនូវរង្វែលហើយ ។ បទថា **សកវណ្ណំ** បានដល់ រូបនាគរបស់ខ្លួន ។ បទថា **បដិ-សំហរិត្វា** បានដល់ ឲ្យអន្តរធានទៅហើយ ។ បទថា **មាណវកវណ្ណំ** បានដល់ រូបកុមារតូច ។

បទថា **ឯតមត្ថំ** សេចក្តីថា ដឹងសេចក្តីនេះដោយអាការទាំងពួង ។ សេចក្តីសុខប៉ុណ្ណោះ រមែងមានក្នុងទីមួយកន្លែងដល់បុគ្គលដែលសោយសុខ

ដែលកើតអំពីវិវេក ។ បទថា **ឥមំ ឧទានំ** *សេចក្តីថា រមែងបន្លឺឧទាននេះ ដែលសម្តែងដល់អានុភាពនៃសេចក្តីសុខ ដែលកើតអំពីវិវេក ។ បណ្តាបទទាំងនោះ បទថា* **សុខោ វិវេកោ** *បានដល់ ឧបធិវិវេក ពោល គឺព្រះនិព្វាន ជាហេតុនាំមកនូវសេចក្តីសុខ ។ បទថា* **តុដ្ឋស្ស** *បានដល់ ដែលត្រេកអរដោយសន្តោស ក្នុងចតុមគ្គញ្ញាណ ។ បទថា* **សុតធម្មស្ស** *បានដល់ មានធម៌ដែលទ្រង់ប្រកាសហើយ គឺប្រាកដហើយ ។ បទថា* **បស្សតោ** *បានដល់ ជាអ្នកឃើញវិវេកនោះ ។ ឬវត្ថុដែលឈ្មោះថា គប្បីឃើញយ៉ាងណាមួយ ដោយបញ្ញាចក្ខុដែលសម្រេចដោយកម្លាំងនៃសេចក្តីព្យាយាមរបស់ខ្លួន ។ បទថា* **អព្យាបជ្ឈំ** *បានដល់ ភាវៈមិនកម្រើក ។ ដោយបទថា* **អព្យាបជ្ឈំ** *នោះ ទ្រង់សម្តែងដល់ចំណែកខាងដើម មានមេត្តាជាអារម្មណ៍ ។ បទថា* **ចាណាភូតេសុ សំយមោ** *សេចក្តីថា ការសង្រួមក្នុងសត្វទាំងឡាយ គឺការមិនបៀតបៀន ជាហេតុនាំមកនូវសេចក្តីសុខ ។ ដោយបទថា* **ចាណាភូតេសុ សំយមោ** *នេះ ទ្រង់សម្តែងដល់ចំណែកខាងដើម ដែលមានករុណាជាអារម្មណ៍ ។ បទថា* **សុខា វិរាគតា លោកេ** *សេចក្តីថា សូម្បីភាពជាបុគ្គលប្រាសចាកវាគៈ ជាហេតុនាំមកនូវសេចក្តីសុខក្នុងលោក ។ សួរថា ដូចអ្វី ឆ្លើយថា ព្រោះកន្ទងកាមភពទាំងឡាយបាន អធិប្បាយថា ភាពជាបុគ្គលប្រាសចាកវាគៈ ដែលលោកហៅថា ការឆ្លងផុតចាកកាមទាំងឡាយ ជាហេតុនាំមកនូវសេចក្តីសុខ ។ ដោយពាក្យថា* **កាមានំ សមតិក្កមោ** *នេះ ទ្រង់ត្រាស់សំដៅយកអនាគាមិមគ្គ ។ ដោយពាក្យថា* **អស្មិមានស្ស វិនយោ**

នេះ ទ្រង់ត្រាស់សំដៅយកអរហត្ត ។ ពិតហើយ អរហត្ត ទ្រង់ត្រាស់ថា **អស្ថិមានស្ស បដិប្បស្សទ្ធិវិនយោ** *ការកម្ចាត់អស្ថិមាននេះ ដោយបដិប្បស្សទ្ធិ ។ ឈ្មោះថា សេចក្តីសុខដែលក្រៃលែងជាងនេះ មិនមាន ។ ព្រោះហេតុនោះ ទើបត្រាស់ថា* **ឯតំ វេ បរមំ សុខំ** *បទនេះឯង ជាសុខដ៏ក្រៃលែង ។ ព្រះអង្គទ្រង់កាន់យកកំពូលនៃទេសនា ដោយព្រះអរហត្ត ដោយប្រការដូច្នេះឯង ។*

អដ្ឋកថា មុច្ចលិន្ទសូត្រ ចប់

សុត្តន្តបិដក

រាជសូត្រ

[៥២] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុច្រើនរូបត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត អង្គុយជួបជុំគ្នា ក្នុងឧបដ្ឋានសាលា អន្តរកថានេះកើតឡើងថា ម្នាលអាវុសោទាំងឡាយ បណ្តាព្រះរាជាទាំង ២ ព្រះអង្គនេះ គឺព្រះរាជាព្រះនាមមាគធសេនិយពិម្ពិសារ និងព្រះរាជាព្រះនាមបសេនទិកោសល ព្រះរាជាអង្គណាហ្ន៎ ដែលមានទ្រព្យច្រើន មានកោគៈច្រើន មានឃ្លាំងច្រើន មានរដ្ឋចម្រុះច្រើន មានពាហនៈច្រើន មានពលច្រើន មានឫទ្ធិច្រើន មានអានុភាព*

ច្រើនជាង ។ ឥឡូវនេះ អន្តរភកថារបស់ភិក្ខុទាំងនោះ ក៏ផ្អាកឈប់នៅ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ក៏យាងចូលទៅឯឧបដ្ឋានសាលា លុះទ្រង់ចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគទ្រង់គង់ហើយ ទើបត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ អង្គុយជួបជុំគ្នាដោយការនិយាយអ្វី ក្នុងកាលឥឡូវនេះ មួយទៀត អន្តរភកថាជួចម្តេច ដែលអ្នកទាំង-ឡាយផ្អាកទុក ពួកភិក្ខុទាំងនោះទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលពួកយើងខ្ញុំទាំងឡាយ ត្រឡប់អំពីបិណ្ឌបាត វេលាខាងក្រោយភត្ត ក្នុងក្រុងសាវត្ថីនេះ ហើយអង្គុយជួបជុំគ្នា ក្នុងឧបដ្ឋានសាលា មានអន្តរភកថានេះកើតឡើងថា ម្នាលអាវុសោទាំងឡាយ បណ្តាព្រះរាជា ២ ព្រះអង្គនេះ គឺព្រះរាជាព្រះនាមមាគធសេនិយពិម្ពិសារ និងព្រះរាជាព្រះនាមបសេនទិកោសលព្រះរាជាអង្គណាហ្ន៎ ដែលមានទ្រព្យច្រើន មានកោគៈច្រើន មានឃ្លាំងច្រើន មានរដ្ឋចម្រុះច្រើន មានពាហនៈច្រើន មានពលច្រើន មានឫទ្ធិច្រើន មានអានុភាពច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន អន្តរភកថានេះឯង ដែលយើងខ្ញុំទាំងឡាយផ្អាកទុក ក៏ស្រាប់តែព្រះមានព្រះភាគ ស្តេចយាងមកដល់ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលអ្នកទាំងឡាយនិយាយពាក្យបែបនេះ ដំណើរនុ៎ះ មិនមែនជាកិច្ចដ៏គួរដល់អ្នកទាំងឡាយ ដែលជាកុលបុត្តចេញចាកផ្ទះ ចូលកាន់ផ្នួសដោយសទ្ធាទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កាលដែលជួបជុំគ្នា ដើម្បីធ្វើកិច្ច ២ យ៉ាង គឺការពោលជាធម៌ ១

ភាពស្ងប់ស្ងៀមដ៏ប្រសើរ ១ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទ្រង់បន្ទឺនូវឧទាននេះ ក្នុងវេលានោះថា

កាមសុខណា ក្នុងលោកក្តី ទិព្វសុខណាក្តី សេចក្តីសុខទាំងនោះ មិនដល់នូវចំណិតមួយ ក្នុងចំណែក ១៦ នៃសេចក្តីសុខ ព្រោះការអស់តណ្ហាទេ ។ សូត្រទី ២ ។

អដ្ឋកថា

រាជសូត្រ

រាជសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ

[៥២] *បទថា* **សម្ពហុលានំ** *សេចក្តីថា ដោយភេហារនៃព្រះវិន័យ ភិក្ខុ ៣ រូប ហៅថា* **សម្ពហុលា** *ច្រើនជាងនោះ ហៅថា* **សង្ឃ ។** *តែដោយភេហារនៃព្រះសូត្រ មនុស្ស ៣ នាក់ ហៅថា ៣ នាក់នោះឯង ច្រើនជាងនោះ ហៅថា* **សម្ពហុលា ។** *ព្រោះដូច្នោះ សូម្បីក្នុងទីនេះ ពោលដោយភេហារព្រះសូត្រ គប្បីជ្រាបថា* **សម្ពហុលា ។** *បទថា* **ឧបដ្ឋានសាលាយំ** *បានដល់ ក្នុងមណ្ឌបដែលជាទីប្រជុំស្តាប់ធម៌ ។ ពិតហើយ ធម្មសភានោះ លោកហៅថា* **ឧបដ្ឋានសាលា** *ព្រោះជាទីដែលពួកភិក្ខុទាំងឡាយធ្វើឧបដ្ឋាកព្រះតថាគត ដែលយាងមកសម្តែងធម៌ ។ ម្យ៉ាងទៀត សាលាក្តី មណ្ឌបក្តី*

ជាទីដែលកិក្ខុវិនិច្ឆ័យវិនិយ សម្តែងធម៌ ប្រជុំធម្មសាកច្ឆា និងជាទីចូលទៅប្រជុំតាមប្រក្រតី ដោយការប្រជុំ លោកក៏ហៅថា **ឧបដ្ឋានសាលា** *ដូចគ្នា ។ ពិតហើយ ក្នុងទីនោះ ឈ្មោះថា ព្រះអង្គទ្រង់បញ្ញត្តព្រះពុទ្ធសាសនាជានិច្ចនោះឯង ។ ពិតហើយ សេចក្តីនេះ ជាការប្រព្រឹត្តរបស់ពួកកិក្ខុ ក្នុងសម័យដែលព្រះពុទ្ធគង់ធរមាននៅ ។ បទថា* **សន្និសិន្នានំ** *បានដល់ អង្គុយប្រជុំដោយការអង្គុយ ។ បទថា* **សន្និបតិតានំ** *បានដល់ ដែលប្រជុំគ្នា ដោយមកអំពីទីនោះៗ ហើយប្រជុំ ។ ម្យ៉ាងទៀត អ្នកប្រជុំ ដោយបំណងយកព្រះពុទ្ធសាសនាជាគោល ហើយអង្គុយប្រជុំគ្នាដោយគោរព ដើម្បីឲ្យកើតការអើពើ ដូចប្រជុំចំពោះព្រះភក្ត្រព្រះសាស្តា គឺព្រោះមានអធ្យាស្រ័យស្មើគ្នា ទើបប្រជុំតាមអធ្យាស្រ័យនៃគ្នានិងគ្នា និងដោយការចុះសម្រុងគ្នាដោយល្អ ដោយប្រពៃ ។ ដោយបទថា* **អយំ** *លោកសម្តែងដល់ពាក្យដែលកំពុងពោល ក្នុងខណៈនេះ ។ បទថា* **អន្តរាកថា** *បានដល់ ពាក្យឯណានីមួយ គឺពាក្យណាមួយក្នុងរវាងកិច្ច មានមនសិការកម្មដ្ឋាន ខន្ធទេស និងការសាកសួរជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា អន្តរាកថា ព្រោះប្រព្រឹត្តទៅក្នុងរវាងនៃសុគតោវាទ ដែលបានក្នុងពេលថ្ងៃត្រង់ និងក្នុងរវាងការស្តាប់ធម៌ ដែលគប្បីបានក្នុងពេលល្ងាច ។ ម្យ៉ាងទៀត ឈ្មោះថា អន្តរាកថា ព្រោះជាកថាណាមួយ គឺណាមួយដែលប្រព្រឹត្តទៅក្នុងរវាងនៃសមណសមាចារនោះឯង ។ បទថា* **ឧឌ្ឌាហិ** *ប្រែថា កើតឡើងហើយ ។*

បទថា **ឥមេសំ ទ្វិន្នំ រាជូនំ** *ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនិទ្ធារណៈ ។ ក្នុង*

ពាក្យថា **មហាទ្ធនតរោ វា** *ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា មានទ្រព្យច្រើន ព្រោះបុគ្គលនោះមានទ្រព្យច្រើន ពោល គឺសន្សំរតន:ទាំង ៧ កប់ទុកក្នុងផែនដី ឈ្មោះថា* **មហាទ្ធនតរោ** *ព្រោះបណ្តាព្រះរាជាទាំង ២ អង្គ អង្គនេះមានទ្រព្យច្រើនក្រៃលែង ។* **វា** *សព្ទ ជាវិកប្បត្ថ ។ ក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ ឯការថ្លែកគ្នាមានដូច្នេះ ឈ្មោះថា* **មហា-ភោគោ** *ព្រោះបុគ្គលនោះ មានភោគ:ច្រើន គឺមានគ្រឿងបរិភោគច្រើន ដោយមានទុនទ្រព្យជាគ្រឿងប្រើប្រាស់ជានិច្ច ឈ្មោះថា* **មហាភោគោ** *ព្រោះមានឃ្លាំងច្រើន ដោយមានចំណូលរាល់ថ្ងៃ ។ ឯអាចារ្យមួយពួកទៀតពោលថា ទ្រព្យដែលជាទីហួងហែង មានកែវមណី ទ្រព្យដែលជាសារ: ទ្រព្យដែលកើតអំពីក្រមរ ទ្រព្យដែលកើតអំពីគុម្ពឈើជាដើម ដែលនាំចំណូលបានរាល់ថ្ងៃ ទ្រព្យនោះឯង គេរក្សានៅក្នុងបន្ទប់ ដែលជាសារ:ជាដើម ឈ្មោះថា* **កោស ។** *កែវមណី ២៤ គឺវជិរ មហានីល ឥន្ទនិល មកិត ពិទូរ្យ បទុមរាគ: គឺកែវទទឹម បុស្សរាគ: គឺកែវបុស្សរាគ កក្កេតន: ផុលាក: វិមល: លោហិតង្ក: ផលិក បវាឡ ជោតិរស គោមុត្តក: គោមេទក: សោគន្ធិក: មុក្តា សង្ខ អញ្ជនមូល: រាជាវដ្ដ: អមតង្សក: សស្សក: និងព្រាហ្មណី ឈ្មោះថា មណី ។ លោហ: ៧ ប្រភេទ និងកហាបណ: ឈ្មោះថា ទ្រព្យជាសារ: ។ វត្ថុផ្សេងៗ មានទីដេក គ្រឿងស្បៀកដណ្តប់ និងសំពត់ក្រហមជាដើម ឈ្មោះថា* **ជេត្តុ ។** *រុក្ខជាតិផ្សេងៗ មានខ្ញីមចន្ទន៍ ក្រស្នា ស្បូវភ្លាំង ក្ងាំពាក់ និងកប៊ូរជាដើម ឈ្មោះថា គុម្ព ។ ក្នុងបទទាំងនោះ ដោយ* **អាធិ**

សព្ព ដែលជាបទដំបូង លោកសង្គ្រោះវត្ថុទាំងអស់ ជាគ្រឿងឧបភោគ បរិភោគរបស់ពួកសត្វ តាំងអំពីប្រភេទធញ្ញជាតិ មានបុព្វណ្ណជាតិ ដូចជា ស្រូវសាលីជាដើម និងអបរណ្ណជាតិ មានសណ្តែកបាយ និងសណ្តែកវាជ-មាសជាដើម ។ ឈ្មោះថា **មហាវិជិត** *ព្រោះលោកមានដែន គឺប្រទេស ធំទូលាយ ។ ឈ្មោះថា* **មហាវាហន** *ព្រោះលោកមានពាហនៈច្រើន មាន ដំរី និងសេះជាដើម ។ ឈ្មោះថា* **មហាពល** *ព្រោះលោកមានកម្លាំងកងទ័ព និងកម្លាំងកាយច្រើន ។ ឈ្មោះថា* **មហិទ្ធិក** *ព្រោះលោកមានឫទ្ធិច្រើន ដែលសម្រេចដោយបុញ្ញកម្ម ពោល គឺការសម្រេចតាមបំណង ។ ឈ្មោះថា* **មហានុភាវ** *ព្រោះលោកមានអានុភាពច្រើន ពោល គឺតេជៈ ការឧស្សាហ៍ មន្ត ភាពជាធំ និងសមត្ថភាព ។ បណ្តាបទទាំងនោះ ដោយបទដើមដែល ព្រះរាជាទាំងនោះទ្រង់ប្រកាស អាយសម្បទា គឺការដល់ព្រមដោយចំណូល ដោយបទទី ២ ប្រកាសដល់ការសម្បូរ ដោយគ្រឿងឧបករណ៍ដ៏វិចិត្រ ដោយបទទី ៣ ប្រកាសដល់សេចក្តីសម្បូរដោយទ្រព្យសម្បត្តិ ដោយបទទី ៤ ប្រកាសដល់ការសម្បូរដោយជនបទ ដោយបទទី ៥ ប្រកាសដល់ការ សម្បូរដោយយានពាហនៈ ដោយបទទី ៦ ប្រកាសអត្តសម្បត្តិ និងបរិវារ-សម្បត្តិ ដោយបទទី ៧ ប្រកាសដល់បុញ្ញសម្បត្តិ ដោយបទទី ៨ ប្រកាស ដល់ភាពជាអ្នកមានអំណាច ។ ព្រោះហេតុនោះ បកតិសម្បទា ដែលព្រះ រាជាគប្បីប្រាថ្នាទាំង ៧ យ៉ាង គឺសាមិសម្បត្តិ អមាត្យសម្បត្តិ សេនា-សម្បត្តិ រដ្ឋសម្បត្តិ វិភវសម្បត្តិ មិត្តសម្បត្តិ និងទុគ្គតសម្បត្តិ ទាំងអស់នោះ*

គប្បីជ្រាបថា លោកសម្តែងហើយតាមសមគួរ ។ ឈ្មោះថា **រាជា** ព្រោះធ្វើឲ្យបរិសទ្ទ្រេកអរ ដោយសង្គហវត្ថុ ៤ មានទានជាដើម ។ ឈ្មោះថា **មាគធោ** ព្រោះទ្រង់ជាឥស្សរៈនៃអ្នកមគធៈ ។ ឈ្មោះថា **សេនិយោ** ព្រោះប្រកបដោយកងទ័ពធំ ឬព្រោះមានគោត្រទាក់ទងមកអំពីមេទ័ព ។ មាសលោកហៅថា **ពិម្ពិ** ព្រោះដូច្នោះ ទើបឈ្មោះថា **ពិម្ពិសារ** ព្រោះមានពណ៌ដូចមាសដែលជាសារៈ ។ ឯអាចារ្យមួយពួកទៀតពោលថា ព្រះរាជានោះមានឈ្មោះយ៉ាងនោះឯង ។ ឈ្មោះថា **បសេនទិ** ព្រោះឈ្នះបច្ចាមិត្រ គឺកងទ័ពដែលជាបរបក្ខ ។ ឈ្មោះថា **កោសល** ព្រោះទ្រង់ជាអធិបតីនៃកោសលរដ្ឋ ។ សព្ទថា **ចរហិ** ក្នុងបទថា **អយញ្ចរហិ** នេះ ត្រឹមតែជានិបាត ។ បទថា **វិប្បកតា** ប្រែថា មិនទាន់អស់ទៅ អធិប្បាយថា អន្តរាកថានៃភិក្ខុទាំងនោះ មិនទាន់ចប់ ។

បទថា **សាយណ្ហសមយំ** គឺសម័យមួយ ក្នុងពេលល្ងាច ។ បទថា **បដិសល្លានា វុដ្ឋិតោ** សេចក្តីថា ចេញចាកអារម្មណ៍ មានរូបជាដើមនោះៗ ចាកការរក្សាចិត្ត ចាកផលសមាបត្តិ ពោល គឺការពួនសម្ងំតាមកាលកំណត់ ។

ពិតហើយ ក្នុងវេលាព្រឹក ព្រះមានព្រះភាគ ចោមរោមដោយពួកភិក្ខុសង្ឃ យាងចូលទៅកាន់ក្រុងសាវត្ថី សោយព្រះក្រយាហារ ដែលពួកភិក្ខុចាត់បិណ្ឌបាត ដែលខ្លួនបានមកដោយល្អថ្វាយ ទ្រង់ចេញអំពីក្រុងសាវត្ថី មួយអន្ទើដោយភិក្ខុទាំងឡាយហើយ ទ្រង់ចូលព្រះវិហារ ប្រថាប់ត្រង់មុខព្រះគន្ធកុដិ ទ្រង់ប្រទានសុគតោវាទ តាមដែលលើកឡើងសម្តែងដល់ភិក្ខុទាំងឡាយ

ដែលមកឈរហើយ កាលភិក្ខុទាំងនោះទៅកាន់ទីសម្រាកពេលថ្ងៃ មានគល់ឈើក្នុងព្រៃជាដើម ទើបយាងចូលព្រះគន្ធកុដិ ពួនសម្ងំអស់ចំណែកនៃថ្ងៃ ដែលកើតអំពីផលសមាបត្តិ ហើយទ្រង់ចេញអំពីផលសមាបត្តិ តាមកាលដែលកំណត់ ទ្រង់ព្រះតម្រិះថា បរិស័ទ ៤ រង់ចាំតថាគត ចូលទៅអង្គុយពេញវិហារទាំងមូល ឥឡូវនេះ ដល់កាលដែលតថាគត ចូលទៅកាន់ធម្ម-សភាមណ្ឌល ដើម្បីសម្តែងធម៌ ដូច្នេះហើយ ទើបទ្រង់ក្រោកចាកអាសនៈ ចេញអំពីព្រះគន្ធកុដិ ដ៏ក្រអូបឈ្ងុយឈ្ងប់ ដូចកេសរសីហរាជ ចេញអំពីគុហាមាស មានព្រះដំណើរយាងយាស រុងរឿងដោយព្រះវរកាយ ដែលមិនគ្រែលង ដូចជ័រដ៏ប្រសើរចុះប្រេង ចូលកាន់ហ្វូង ដូច្នោះ ទ្រង់ធ្វើវិហារទាំងមូលឲ្យមានពន្លឺតែមួយ ដោយរូបកាយសម្បត្តិ ដែលរុងរឿងដោយមហាបុរិសលក្ខណៈ ៣២ ប្រដាប់ដោយអនុព្យញ្ជនៈ ៨០ ប្រកបដោយលម្អ ចោមរោមដោយព្រះរស្មីប្រមាណមួយព្យាម ប្រដាប់ដោយព្រះកេតុមាលដ៏ភ្លឺថ្លា ចែងចាំងដោយឆព្ណរង្សី ខៀវ លឿង ក្រហម ស ហង្សុធ និងពណ៌ផ្សេង មានអានុភាពជាអចិន្ត្រៃយ្យ ប្រកបដោយពុទ្ធលីលា គ្មានអ្វីផ្ទឹម ទ្រង់ចូលទៅកាន់ឧបដ្ឋានសាលា ដោយហេតុនោះ ទើបលោកពោលថា **អថខោ ភគវា ។បេ។ តេនុបសង្កមិ ។**

ព្រះមានព្រះភាគ កាលយាងចូលទៅយ៉ាងនោះហើយ ទ្រង់ឃើញភិក្ខុទាំងនោះសម្តែងវត្តស្ងប់ស្ងាត់ ទ្រង់ព្រះតម្រិះថា បើតថាគតមិនពោល ភិក្ខុទាំងនេះ ក៏មិនពោល សូម្បីតែការគិត រហូតអស់អាយុកប្ប ព្រោះគោរពក្នុង

តថាគត ដើម្បីផ្តើមរឿងឡើង ទើបត្រាស់ពាក្យជាដើមថា **កាយ ឆុត្ត ភិក្ខវេ** *ជួច្នេះ ។*

បណ្តាបទទាំងនោះ បទថា **កាយ ឆុត្ត** *កែជា* **កតមាយ ឆុ ភវេ** *ប្រែថា ពួកអ្នកសន្ទនាអំពីរឿងអ្វីហ្ន៎ ។ ជាលីថា* **កាយ ឆោត្ត** *ជួច្នេះក៏មានឯសេចក្តីក៏ដូចគ្នា ។ អាចារ្យពួកខ្លះពោលថា* **កាយ ឆ្ងេត្ត** *ជួច្នេះក៏មាន ។ ជាលីនោះ មានសេចក្តីថា* **កតមាយ ឆុ ឍត្ត។** *ក្នុងសេចក្តីនោះ មានសេចក្តីសង្ខេបដូចតទៅនេះ ព្រះមានព្រះភាគទ្រង់បវារណា ដោយការបវារណារបស់ព្រះសព្វញ្ញុយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយសន្ទនាគ្នាក្នុងទីនេះ ដោយរឿងអ្វីហ្ន៎ រឿងរបស់ពួកអ្នកប្រព្រឹត្តទៅមិនទាន់ចប់ ព្រោះការមកបស់តថាគតជាហេតុ ពួកអ្នកគប្បីឲ្យរឿងនោះចប់ចុះ ។*

បទថា **ឆ ឆ្ងេតំ** *កាត់បទជា* **ឆ ឆោ ឍតំ** *ម្យ៉ាងទៀត ជាឋ:ក៏យ៉ាងនេះដូចគ្នា ។ អាចារ្យពួកខ្លះពោលថា* **ឆ ឆោតំ** *ជួច្នេះក៏មាន មានការចែកបទថា* **ឆ ឆោ ឍតំ** *ជួច្នេះដូចគ្នា ។ បទថា* **កុលបុត្តានំ** *បានដល់ កុលបុត្រដែលមានមារយាទប្រចាំជាតិ ។ បទថា* **សទ្ធា** *បានដល់ ដោយសទ្ធា គឺដោយជឿកម្ម និងផលនៃកម្ម និងដោយការជឿព្រះរតនត្រ័យ ។ បទថា* **អគារស្មា** *ប្រែថា ចាកផ្ទះ អធិប្បាយថា ចាកភាពជាគ្រហស្ថ ។ បទថា* **អនគារិយំ** *ប្រែថា ការចេញបព្វជ្ជា ។ បទថា* **បព្វជិតានំ** *បានដល់ ដែលចូលដល់ ។ បទថា* **យំ** *ជាកិរិយាបរាមាស ក្នុងសេចក្តីនោះ មានបទយោជនាដូចតទៅនេះ ព្រះមានព្រះភាគ ទ្រង់បដិសេធប្រការដែលមិនសមគួរបស់បព្វជិត*

ដែលនៅប្រជុំគ្នាយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនមែនត្រូវព្រះរាជាបង្គាប់ មិនមែនត្រូវពួកចោរបង្គាប់ មិនមែនមានក្តី ព្រោះបំណុល មិនមែនដើម្បីចិញ្ចឹមជីវិត ទើបបួស ដោយពិតនោះ ពួកអ្នកចេញចាកផ្ទះ បួសក្នុងសាសនារបស់តថាគតដោយសទ្ធា ឥឡូវនេះ ពួកអ្នកពោលតិរច្ឆានកថាទាក់ទងដោយព្រះរាជាបែបនេះ ការដែលអ្នកពោលរឿងបែបនោះ មិនសមគួរដល់ពួកអ្នកឡើយ ឥឡូវនេះ កាលទ្រង់អនុញ្ញាតបដិបទា ដែលសមគួរដល់ភិក្ខុទាំងនោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កិច្ច ២ យ៉ាង ដែលពួកអ្នកប្រជុំគ្នាគប្បីធ្វើ គឺពោលធម្មីកថា ឬជាអ្នកស្ងៀមដូចព្រះអរិយៈ ។

បណ្តាបទទាំងនោះ បទថា **តេ** *ប្រែថា របស់ពួកអ្នក ។ បទថា* **តេ** *នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃកត្តុ គឺអ្នកធ្វើ សំដៅដល់បទថា* **ករណីយំ** *ព្រោះដូច្នោះ ទើបបទថា* **តេ** *ប្រែថា ដែលអ្នកទាំងឡាយ ។ បទថា* **ទ្វយំ ករណីយំ** *បានដល់ គប្បីធ្វើ ២ យ៉ាង ។ បទថា* **ធម្មីកថា** *បានដល់ ពាក្យដែលមិនច្រាសចាកធម៌ គឺសច្ចៈ ៤ អធិប្បាយថា ធម្មទេសនាដែលសម្តែងដល់ការប្រព្រឹត្តទៅ គឺទុក្ខសច្ច និងការមិនត្រឡប់ គឺនិរោធសច្ច ។ ធម្មកថាពោល គឺកថាវត្ថុ ១០ ជាឯកទេសរបស់ធម្មទេសនានោះឯង ។ បទថា* **អរិយោ** *សេចក្តីថា ឈ្មោះថា អរិយៈ ព្រោះនាំប្រយោជន៍មកយ៉ាងពិត ។ ម្យ៉ាងទៀតឈ្មោះថា* **អរិយៈ** *ព្រោះជាបុគ្គលបរិសុទ្ធ គឺឧត្តម ។ បទថា* **តុណ្ហីភាវោ** *គឺការមិនពោល ដែលជាតួសមថភាវនា និងវិបស្សនាភាវនា ។ តែអាចារ្យមួយពួកពោលថា ទុតិយជ្ឈាន ជាការស្ងប់ដ៏ប្រសើរ ព្រោះជាបដិបក្ខចំពោះ*

វចីសង្ខារ ។ អាចារ្យមួយពួកទៀតពោលថា ចតុត្ថជ្ឈានជាការស្ងប់ដ៏ប្រសើរក្នុងទីនេះ មានអធិប្បាយដូច្នេះថា ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ពួកអ្នកមានកាយស្ងប់ក្នុងសុញ្ញាគារ ដើម្បីចម្រើនចិត្តវិវេក បើប្រជុំគ្នាម្តងម្កាល កាលពួកអ្នកប្រជុំគ្នាយ៉ាងនេះ គប្បីឲ្យធម្មកថាដែលទាក់ទងដោយអនិច្ចលក្ខណៈជាដើម នៃសភាវធម៌ មានខន្ធជាដើមប្រព្រឹត្តទៅ ដោយជាឧបការៈដល់គ្នានិងគ្នា តាមន័យដែលពោលថា រមែងបានស្តាប់វត្ថុដែលមិនធ្លាប់ស្តាប់ ឬរមែងធ្វើវត្ថុដែលបានស្តាប់ហើយ ឲ្យរឹងរឹតតែយល់ច្បាស់ ឬគប្បីនៅដោយឈានសមាបត្តិ ដើម្បីមិនបៀតបៀនគ្នានិងគ្នា ។

បណ្តាកវណីទាំង ២ នោះ ដោយកវណីដំបូង ទ្រង់សម្តែងឧបាយដែលជាហេតុឈមចុះក្នុងព្រះសាសនា សម្រាប់បុគ្គលដែលមិនទាន់បានឈមចុះ ដោយកវណីក្រោយ ទ្រង់សម្តែងឧបាយជាគ្រឿងរលាស់ចេញចាកសង្សារ សម្រាប់បុគ្គលដែលឈមចុះហើយ ឬដោយកវណីដំបូង ទ្រង់ដឹកនាំក្នុងភាពជាអ្នកជំនាញក្នុងអាគម គឺព្រះសូត្រ ឯកវណីក្រោយ ទ្រង់ទូន្មានក្នុងភាពជាបុគ្គលជំនាញក្នុងអធិគម គឺមគ្គផលដែលគប្បីសម្រេច ។ ម្យ៉ាងទៀត ដោយកវណីទី ១ ទ្រង់សម្តែងដល់ហេតុ ដែលសម្ធាទិដ្ឋិកើតឡើងលើកទី ១ ដោយកវណីទី ២ ទ្រង់សម្តែងដល់ហេតុដែលសម្ធាទិដ្ឋិកើតឡើងលើកទី ២ សមដូចព្រះតម្រាស់ដែលត្រាស់ក្នុងអង្គុត្តរនិកាយទុកនិបាតថា

> ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ២ យ៉ាងនេះ ជាបច្ច័យដើម្បីនាំឲ្យសម្ធាទិដ្ឋិកើតឡើង ។ ធម៌ ២ យ៉ាង តើដូចម្តេច ។

គឺសូរសំឡេង អំពីសម្នាក់អ្នកដទៃ (ការស្តាប់ព្រះសទ្ធម្ម) ១

យោនិសោមនសិការ ១ ។

ម្យ៉ាងទៀត ដោយការណីដំបូង ទ្រង់ប្រកាសមូលនៃសម្មាទិដ្ឋិខាងលោកិយ ។ ដោយការណីក្រោយ ទ្រង់សម្តែងដល់មូលនៃសម្មាទិដ្ឋិចំណែកលោកុត្តរ គប្បីជ្រាបអត្ថយោជនាដោយន័យជាដើមដូចពោលមក ដូច្នេះ ។

បទថា **ឯតមត្តំ វិធិត្វា** សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងដល់សេចក្តីនេះថា សម្បត្តិ មានឈានជាដើមនៅស្ងប់ជាង និងប្រណីតជាងសម្បត្តិដែលគួរប្រាថ្នាដែលភិក្ខុទាំងនោះប្រារព្ធដល់ ។ បទថា **ឥមំ ឧធានំ** សេចក្តីថា ទ្រង់បន្ទឺឧទានដែលសម្តែងអានុភាពរបស់សុខ ដែលកើតអំពីអរិយវិហារនេះ ។

បណ្តាបទទាំងនោះ សព្ទថា **លោក** ក្នុងបទថា **យញ្ច កាមសុខំ លោកេ** នេះ មកក្នុងសង្ខារជាដើមថា ខន្ធលោក អាយតនលោក ធាតុ-លោក ។ មកក្នុងឧកាសជាដើមថា ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយ ដើរបំភ្ងឺទិសទាំងឡាយ ឲ្យភ្ងឺបានត្រឹមណា លោក គឺចក្រវាលទាំងមួយពាន់ ក៏កំណត់ត្រឹមនោះ អំណាចរបស់អ្នកប្រព្រឹត្តទៅបានតែត្រឹមចក្រវាលមួយពាន់ន៉ុះ ។ ក្នុងសត្វទាំងឡាយ មានពាក្យថា ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញហើយ ។ ក្នុងទីនេះ គប្បីជ្រាបសព្ទថា **លោក** ក្នុងអត្ថថា សត្វលោក និងឧកាសលោក ។ បានដល់ក្នុងលោកនេះ ខាងក្រោមចាប់អំពីអវីចីឡើងមក ខាងលើចាប់អំពីរូបព្រហ្មចុះ

មក សុខដែលសហគត:ដោយកាមកើតឡើង ព្រោះអាស្រ័យវត្ថុកាម និង កិលេសកាម ។ បទថា **យញ្ចិទំ ឥន្ទ្រិយំ សុខំ** *សេចក្តីថា សុខដែលជាទិព្វ និងសុខដែលកើតអំពីរូបសម្បត្តិរបស់ព្រហ្ម និងរបស់មនុស្សដែលបានដោយ ទិព្វវិហារនេះ ។ បទថា* **តណ្ហាក្ខយសុខស្ស** *សេចក្តីថា សុខដែលកើតអំពី ផលសមាបត្តិ ដែលប្រព្រឹត្តទៅ ព្រោះការធ្វើព្រះនិព្វាន ដែលតណ្ហាមកដល់ ហើយ អស់ទៅជាអារម្មណ៍ និងព្រោះស្ងប់រម្ងាប់តណ្ហាចេញបាន ឈ្មោះថា សុខដែលកើតអំពីការអស់តណ្ហា នៃសុខដែលកើតអំពីការអស់តណ្ហានោះ ។ បទថា* **ឯតេ** *ជាបទសម្តែងលម្អិតលិង្គវិបល្លាស ។ អធិប្បាយថា* **ឯតានិ សុខានិ** *ប្រែថា សុខទាំងនេះ ។ អាចារ្យពួកខ្លះ ទាញយកសុខទាំង ២ ដោយ ជាសុខសាមញ្ញ ទូទៅ ហើយពោលថា* **ឯតំ ។** *គប្បីមានបាឋៈរបស់កេចិ-អាចារ្យទាំងនោះថា* **កលំ ឧគ្ឃតិ ។**

បទថា **សោឡសឹ** *ប្រែថា ជាទីពេញរបស់ ១៦ ចំណែក ។ ក្នុង សេចក្តីនេះ មានសេចក្តីសង្ខេបដូចតទៅនេះ*

កាមសុខដែលកើតក្នុងកាមលោកទាំង ១១ ប្រការ គឺសុខរបស់មនុស្ស ក្នុងមនុស្សលោកទាំងអស់ ចាប់តាំងអំពីសុខរបស់ស្តេចចក្រពត្តិ សុខដែល នាគ និងគ្រុឌ សោយក្នុងស្ថាននាគ និងស្ថានគ្រុឌជាដើម និងកាមសុខ ៦ យ៉ាងក្នុងទេវលោក មានជាន់ចាតុម្មហារាជិកាជាដើម និងសុខដែលកើតអំពី លោកិយជ្ឈានដែលបានឈ្មោះថា **ឥន្ទ្រិយំ** *គឺទិព្វ ព្រោះកើតក្នុងទេវតាជាន់ រូបាវចរ និងអរូបាវចរ ក្នុងរូបជ្ឈាន និងអរូបជ្ឈាន ដែលជាទិព្វវិហារ សុខ*

ទាំង ២ យ៉ាងនោះ ក៏មិនដល់មួយចម្រៀក ពោល គឺចំណែកមួយ ដែលបាន ក្នុងការគុណឲ្យជា ១៦ ចំណែក យកត្រឹមតែ ១ ចំណែកអំពីចំណែក ១៦ នោះ ដោយចែកសុខដែលកើតអំពីផលសមាបត្តិ ពោល គឺសុខដែលកើតអំពីការ អស់តណ្ហា ឲ្យជា ១៦ ចំណែក ។

កិច្ចពណ៌នាអត្តនេះ លោកពោលដោយការស្មើគ្នានៃផលសមាបត្តិ ព្រោះ ធម៌ជាទីអស់តណ្ហា មកក្នុងព្រះបាលីដោយមិនប្លែកគ្នា ។ លោកិយសុខ មិន ដល់មួយចម្រៀកនៃសុខ ដែលកើតអំពីផលសមាបត្តិមួយឡើយ សមដូច ពាក្យដែលលោកពោលក្នុងធម្មបទថា

សោតាបត្តិផល ជាគុណជាតិដ៏ប្រសើរ ជាងភាពនៃឯករាជ្យលើផែន ដីផង ជាងដំណើរទៅកាន់ស្ថានសួគ៌ផង ជាងភាពជាធំ ក្នុងលោក ទាំងមូលផង ។

ក្នុងសោតាបត្តិសំយុត្តក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពិតមែនថា ស្តេច ចក្រពត្តិ សោយរាជសម្បត្តិ មានសភាពជាឥស្សរៈ ជាធំជាងទ្វីបទាំង ៤ លុះ បែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ រមែងទៅកើតក្នុងសុគតិសួគ៌ ទេវលោក ជាមួយនឹងពួកទេវតាក្នុងស្ថានតាវត្តិង្ស ។ ទេវបុត្រនោះ មានពួក ស្រីអប្សរចោមរោម ក្នុងនន្ទនវនឧទ្យាន ក្នុងស្ថានតាវត្តិង្សនោះ ទ្រង់ឆ្អែត ស្កប់ស្កល់មូលមិត្តដោយកាមគុណទាំង ៥ ជាទិព្វ ។ បើទេវបុត្រនោះ មិន បានប្រកបដោយធម៌ ៤ យ៉ាង ។ ទេវបុត្រនោះ ក៏គង់មិនរួចស្រឡះចាកនរក មិនរួចស្រឡះចាកកំណើតតិរច្ឆាន មិនរួចស្រឡះចាកប្រេតវិសយ មិនរួច

ស្រឡះចាកអសុរកាយបានឡើយ ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវក រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយកោជនជាពំនូត ដែលបានមកដោយកម្លាំងកំភួនជើង ប្រើប្រាស់នូវសំពត់គ្មានជាយក៏ពិតមែនហើយ ។ តែថា អរិយសាវកនោះ ប្រកបដោយធម៌ ៤ យ៉ាង ។ ទើបអរិយសាវកនោះ រួចស្រឡះចាកនរក រួចស្រឡះចាកកំណើតតិរច្ឆាន រួចស្រឡះចាកប្រេតវិសយ រួចស្រឡះចាកអសុរកាយបាន ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ។បេ។ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ខ្ចាក់ចោលនូវត្រៃគព លែងវិលត្រឡប់មកកើតទៀត ១ ។ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះធម៌ថា ព្រះបរិយត្តិធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ ។បេ។ ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងច្បាស់ក្នុងចិត្តនៃខ្លួន ១ ។ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះសង្ឃថា ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដោយប្រពៃ ។បេ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ១ ។ ប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះ មិនពព្រុស មិនពពាល ជាសីលជានា ដែលអ្នកប្រាជ្ញគប្បីសរសើរ មិនបានប៉ះពាល់ (ដោយតណ្ហា និងទិដ្ឋិ) ប្រព្រឹត្តទៅព្រមដើម្បីសមាធិ ១ ។ អរិយសាវកជាអ្នកប្រកបដោយធម៌ទាំង ៤ យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ការដែលបាននូវទ្វីបទាំង ៤ ហើយនឹងការដែលបាននូវធម៌ទាំង ៤ ឯការបាននូវទ្វីបទាំង ៤ មិនដល់នូវចំណិតដែលចែកជាចំណែក ១៦ ដងនៃការបាននូវធម៌ទាំង ៤ ឡើយ ។

ព្រះមានព្រះភាគ ទ្រង់ចែកលោកិយសុខ ថាក្រៃលែង ថាប្រព្រឹត្តទៅដោយសេចក្តីល្អក្រៃលែង ទ្រង់ចែកចំពោះលោកុត្តរសុខ ថាកំពូល ថាល្អក្រៃលែង ក្នុងទីគ្រប់ស្ថាន ដោយប្រការដូច្នេះ ។

អដ្ឋកថា រាជសូត្រធី ២ ចប់

សុត្តន្តបិដក

ឧណ្ឌសូត្រ

[៥៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកកុមារច្រើននាក់ នាំគ្នាបៀតបៀនពស់នឹងដំបង ត្រង់ទីជាចន្លោះនៃក្រុងសាវត្ថី នឹងវត្តជេតពន ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ក្នុងបុព្វណ្ហ-សម័យ ។ ព្រះមានព្រះភាគ បានទតឃើញពួកកុមារច្រើននាក់ទាំងនោះ កំពុងតែបៀតបៀនពស់នឹងដំបង ត្រង់ទីជាចន្លោះនៃក្រុងសាវត្ថី នឹងវត្តជេតពន ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៉ះហើយ ទើបទ្រង់បន្ទឺនូវ

ឧទាននេះ ក្នុងវេលានោះឯង

បុគ្គលណា កាលស្វែងរកសេចក្តីសុខដើម្បីខ្លួន ហើយបៀតបៀនពួកសត្វ អ្នកប្រាថ្នាសេចក្តីសុខដោយដំបង បុគ្គលនោះ លុះលះលោកនេះទៅ រមែងមិនបានសេចក្តីសុខឡើយ ។

បុគ្គលណា កាលស្វែងរកសេចក្តីសុខដើម្បីខ្លួន មិនបៀតបៀនពួកសត្វ អ្នកប្រាថ្នាសេចក្តីសុខ ដោយដំបង បុគ្គលនោះ លុះលះលោកនេះទៅ តែងបានសេចក្តីសុខ ។ សូត្រទី ៣ ។

អដ្ឋកថា

ទណ្ឌសូត្រ

ទណ្ឌសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

[៥៣] បទថា **កុមារកា** បានដល់ ក្មេងទាំងឡាយ ។ **អន្តរា** សព្ទក្នុងពាក្យថា **អន្តរា ច សាវត្ថឹ អន្តរា ច ជេតវនំ** នេះ មកក្នុងហេតុ ក្នុងប្រយោគជាដើមថា **តឧនន្តរំ កោ ជានេយ្យ អញ្ញត្រ តថាគតេន** លំដាប់តអំពីនោះមក អ្នកណាគប្បីដឹងបាននូវហេតុនោះកើត លើកលែងតែព្រះតថាគតចេញ ។ និងក្នុងប្រយោគមួយទៀតថា **ជនា សង្គម្ម មន្តេន្តិ មញ្ច តញ្ច កិមន្តរំ** ជនទាំងឡាយ មកប្រជុំនិយាយគ្នាទៀបឆ្នេរស្ទឹងទាំងឡាយផង ... ហើយនិយាយចំពោះខ្ញុំផង ចំពោះលោកផង តើព្រោះហេតុអ្វី ។ មក

ក្នុងខណ: ដូចក្នុងប្រយោគជាដើមថា **ភន្តេ អញ្ញតរា ឥត្តី វិជ្ជន្តរិកាយ ភាជនំ ធោវន្តិ** បពិត្រព្រះអង្គដ៏ចម្រើន ស្រីម្នាក់កំពុងលាងភាជន: បានឃើញខ្ញុំព្រះអង្គក្នុងពេលមានផ្ទេកបន្ទោរ ។ មកក្នុងចិត្ត ដូចក្នុងប្រយោគជាដើមថា **យស្ស្ន្តរតោ ន សន្តិ កោធា** សេចក្តីក្រោធ មិនមានក្នុងចិត្ត របស់បុគ្គលណា ។ មានអត្ថថា ត្រង់កណ្តាល ដូចក្នុងប្រយោគជាដើមថា **អន្តរា វោសានមាធាធិ** ដល់នូវការផ្អាកនូវសេចក្តីព្យាយាមក្នុងចន្ទោះ (ត្រង់កណ្តាល) ។ មានអត្ថថា ចន្ទោះ ដូចក្នុងប្រយោគជាដើមថា **អបិចាយំ ភិក្ខវេ តថោធាធ្ធិន្នំ មហានិរយានំ អន្តរិកាយអាគច្ឆតិ** ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែ ស្ទឹងតបោទានេះ ហូរមកតាមចន្ទោះនៃមហានរកទាំងពីរ ។ ក្នុងទីនេះ សព្ទថា **អន្តរា** គប្បីជ្រាបថា ប្រើក្នុងអត្ថថា ចន្ទោះ ព្រោះដូច្នោះ គប្បីជ្រាបអត្ថក្នុង **អន្តរា** សព្ទនេះ យ៉ាងនេះថា ក្នុងចន្ទោះក្រុងសាវត្ថី និងវត្តជេតពន ។ ព្រោះប្រកបដោយ **អន្តរា** សព្ទ ទើបក្នុងទីនេះ ជាទុតិយាវិភត្តិថា **អន្តរា ច សាវត្ថឹ អន្តរា ច ជេតវនំ** ចន្ទោះក្រុងសាវត្ថី និងជេតពនមហាវិហារ ។ ក្នុងទីដូច្នេះ អ្នកអក្ខរសាស្ត្រទាំងឡាយ ប្រកប **អន្តរា** សព្ទមួយប៉ុណ្ណោះថា **អន្តរា គាមញ្ច នធិញ្ច គច្ឆតិ** ក្នុងចន្ទោះស្រុកនិងចន្ទោះស្ទឹង ។ **អន្តរា** សព្ទ ជាការដែលត្រូវប្រកបជាមួយបទទី ២ តែក្នុងទីនេះ លោកប្រកបហើយ ។

បទថា **អហឹ ឧណ្ហេន ហានន្តិ** សេចក្តីថា ពួកក្មេងដេញតាមពស់វែកដែលបានទទួលនូវការស្រេកឃ្ងាន កំពុងលូនចេញអំពីរូង ស្វែងរកចំណី ប្រើ

ជំបង់វាយ ។ សម័យនោះ ព្រះមានព្រះភាគ កំពុងយាងបិណ្ឌបាតកាត់តាមក្រុងសាវត្ថី ឃើញក្មេងទាំងនោះក្នុងវាំងចន្ទោះផ្លូវយកជំបង់វាយពស់ ទើបត្រាស់សួរថា ម្នាលកុមារទាំងឡាយ ព្រោះហេតុអ្វី ទើបអ្នកយកជំបង់វាយពស់នេះ កុមារក្រាបទូលថា បពិត្រព្រះអង្គ ព្រោះខ្លាចវាចឹក ទើបទ្រង់កើតធម្មសង្វេគឡើងថា ពួកក្មេងទាំងនេះ គិតធ្វើសេចក្តីសុខក្នុងខ្លួន ទើបវាយពស់នេះ នឹងសោយទុក្ខក្នុងទីដែលខ្លួនកើត ក្មេងទាំងនេះ ឈ្មោសក្នុងការវៀចវេរ ព្រោះភាពល្ងង់ខ្លៅ ព្រោះហេតុនោះឯង ទើបទ្រង់បន្ទឺឧទាន ដោយធម្មសង្វេគ ។ ព្រោះហេតុនោះ ទើបលោកពោលពាក្យជាដើមថា **អថ ខោ ភគវា** *ជួបច្នេះ ។*

បណ្តាបទទាំងនោះ បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា អាចារ្យមួយពួក ពណ៌នាយ៉ាងនេះថា ទ្រង់ជ្រាបអត្ថនេះថា ពួកក្មេងទាំងនេះ ធ្វើសេចក្តីទុក្ខឲ្យដល់អ្នកដទៃ ដើម្បីសេចក្តីសុខរបស់ខ្លួន ខ្លួនឯងនឹងមិនបានទទួលសេចក្តីសុខក្នុងលោកខាងមុខ ។ ការដែលជនដទៃជាអ្នកបដិបត្តិអាក្រក់ស្វែងរកសេចក្តីសុខ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីទុក្ខក្នុងអនាគត សម្រាប់អ្នកបដិបត្តិល្អ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសុខដោយចំណែកមួយ ព្រោះដូច្នោះ ទើបអាចារ្យទាំងឡាយពោលថា ព្រះសាស្តា ទ្រង់បន្ទឺឧទាននេះ ដោយទ្រង់សោមនស្សថា បុគ្គលដែលផុតចាកការបៀតបៀនបុគ្គលដទៃ ជាអ្នកមានសេចក្តីសុខដោយពិតនោះឯង ឈ្មោះថា ជាការស្នងឱវាទរបស់តថាគត ឯអាចារ្យមួយពួកទៀតពោលថា ព្រះអង្គទ្រង់ជ្រាបការបៀតបៀនអ្នកដទៃ*

ដែលពួកក្មេងទាំងនោះឲ្យប្រព្រឹត្តទៅយ៉ាងនេះ ដោយមានទោសដោយប្រការទាំងពួង ទើបទ្រង់បន្ទឹមទាននេះ ដើម្បីប្រកាសទោស និងអានិសង្សតាមលំដាប់នៃការបៀតបៀនអ្នកដទៃ និងការអនុគ្រោះអ្នកដទៃ ។

បណ្តាបទទាំងនោះ បទថា **សុខកាមានិ** *បានដល់ ជាអ្នកជាប់នៅក្នុងសេចក្តីសុខ ព្រោះប្រាថ្នាសុខដើម្បីខ្លួនដោយចំណែកមួយប៉ុណ្ណោះ ។ បទថា* **ភូតានិ** *បែបថា សត្វមានជីវិតទាំងឡាយ ។ បទថា* **ទណ្ឌេន** *ក្នុងពាក្យថា* **យោ ទណ្ឌេន វិហឹសតិ** *នេះ ត្រឹមតែជាទេសនា អធិប្បាយថា ដោយកំណាត់ឈើ ឬដោយគ្រឿងប្រហារផ្សេងៗ ដូចជា ដុំដី សស្ត្រា និងការប្រហារដោយដៃជាដើម ។ ម្យ៉ាងទៀត បទថា* **ទណ្ឌេន** *បានដល់ ដោយការដាក់ទោស ។ លោកអធិប្បាយដូច្នេះថា បុគ្គលណាបៀតបៀនសត្វទាំងពួង ប្រាថ្នាសេចក្តីសុខ ធ្វើឲ្យលំបាក បានទទួលសេចក្តីទុក្ខ ដោយអាជ្ញាណាមួយ ក្នុងបណ្តាអាជ្ញាទាំងនេះ គឺអាជ្ញាផ្លូវវាចា ដូចជា ជេរដល់ជាតិជាដើម អាជ្ញាផ្លូវកាយ ដូចជា វាយ តប់ កាប់ជាដើម ដោយដៃ ដំបង និងសស្ត្រាជាដើម ឬអាជ្ញាដោយទ្រព្យ ដូចជា ពិន័យ ១០០-១០០០ ជាដើម ។ បទថា* **អត្តនោ សុខមេសានោ បេច្ច សោ ន លភតេ សុខំ** *សេចក្តីថា បុគ្គលនោះ កាលស្វែងរក គិតគ្នេរ ប្រាថ្នាសុខដើម្បីខ្លួន លះលោកនេះទៅហើយ រមែងមិនបានទទួលសេចក្តីសុខទាំង ៣ ប្រការ គឺមនុស្សសុខ ទិព្វសុខ និព្វានសុខ ក្នុងលោកខាងមុខដោយពិត រមែងបានទទួលតែសេចក្តីទុក្ខ ដោយអាជ្ញានោះ ។*

បទថា **បេច្ច សោ លភតេ សុខំ** *សេចក្តីថា បុគ្គលណា ដល់ព្រម

ដោយខន្តី មេត្តា និងករុណា គិតថា អាត្មាអញប្រាថ្នាសុខ ស្អប់ខ្ពើមទុក្ខ យ៉ាងណា សូម្បីសត្វទាំងពួងក៏ដូច្នោះ ទើបតាំងនៅក្នុងសម្បត្តិវិតជាដើម មិនបៀតបៀន មិនធ្វើសត្វទាំងពួងឲ្យលំបាក ដោយអាជ្ញាណាមួយ តាមន័យដែលពោលហើយ បុគ្គលនោះ ជាមនុស្សក្នុងបរលោក រមែងបានទទួលសុខរបស់មនុស្ស ជាទេវតា រមែងបានទទួលទិព្វសុខ កាលឆ្លងសុខទាំង ២ នោះទៅ រមែងបានទទួលសេចក្តីសុខក្នុងព្រះនិព្វាន ។ ក្នុងទីនេះ ដើម្បីសម្តែងថា ព្រោះបុគ្គលបៃបនោះ បានអប់រំយ៉ាងពិតប្រាកដ សេចក្តីសុខនោះ ហាក់បីដូចកើតឡើងចំពោះមុខ ទើបទ្រង់ពោលថា **លភតេ** ដូច្នេះ ។ សូម្បីក្នុងគាថាដើម ក៏នយនេះដូចគ្នា ។

អដ្ឋកថា ឧណ្ហស្សត្រធី ៣ ចប់

សុត្តន្តបិដក

សក្ការសូត្រ

[៥៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ គេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារជាប្រក្រតី ។ សូម្បីភិក្ខុសង្ឃ ក៏គេធ្វើសក្ការៈ គោរព រាប់អាន បូជា

កោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិ-ក្ខារដែរ ។ ចំណែកពួកបរិព្វាជក អន្យតិ្ថរិយ គេមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា មិនកោតក្រែង មិនបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាប្រក្រតីឡើយ ។ គ្រានោះឯង ពួកបរិ-ព្វាជក អន្យតិ្ថរិយ កាលធន់ទ្រាំនឹងសក្ការៈ ចំពោះព្រះមានព្រះភាគ និងភិក្ខុ-សង្ឃមិនបាន លុះឃើញពួកភិក្ខុ ក្នុងស្រុកក្តី ក្នុងព្រៃក្តី ក៏ជេរប្រទេច ខឹង ចាក់រុក ដោយសម្តីទ្រគោះ ជារបស់អស្បុរស ។ លំដាប់នោះឯង ពួកភិក្ខុ ច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំ ព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទី សមគួរហើយ ក៏ទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រះមានព្រះភាគ មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជ-បរិក្ខារ ។ ទាំងភិក្ខុសង្ឃ ក៏គេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារជាប្រក្រតីដែរ ។ ចំណែកខាងពួកបរិព្វាជក អន្យតិ្ថរិយ គេមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា មិនកោតក្រែង មិនបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារជាប្រក្រតី ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះឯង ពួកបរិព្វាជក អន្យតិ្ថរិយទាំងនោះ ការធន់ទ្រាំនឹងសក្ការៈ ចំពោះព្រះ-មានព្រះភាគ និងភិក្ខុសង្ឃមិនបាន លុះឃើញពួកភិក្ខុសង្ឃ ក្នុងស្រុកក្តី ក្នុង

ព្រៃក្តី ក៏ជេរប្រទេច ខឹង ចាក់រុក ដោយវាចាទ្រគោះ ជារបស់អស្បុរស ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

អ្នកទាំងឡាយ ដែលសុខ និងទុក្ខ ប៉ះពាល់ហើយ នោះនៅក្នុងស្រុក ឬព្រៃ មិនត្រូវក្តៅក្រហាយ អំពីខ្លួន ឬអំពីអ្នកដទៃឡើយ ផស្សធម៌ទាំង-ឡាយ រមែងប៉ះពាល់ត្រូវបាន ព្រោះអាស្រ័យឧបធិ កាលបើឧបធិមិនមាន ផស្សធម៌ទាំងឡាយ ប៉ះពាល់ត្រូវដូចម្តេចបាន ។ សូត្រទី ៤ ។

អដ្ឋកថា

សក្ការសូត្រ

សក្ការសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

[៥៤] *បទថា* **តេន ខោ បន សមយេន ភគវា សក្ការោ ហោតិ** *សេចក្តីថា ព្រះមានព្រះភាគ ជាបុគ្គលដែលទេវតា និងមនុស្សធ្វើសក្ការៈដោយគ្រឿងសក្ការៈជាដើម ដែលចម្រើនក្រៃលែងឡើងៗ ។ ដែលជាផលនៃបុញ្ញសម្ភារ និងគុណវិសេសដែលទ្រង់បំពេញមក ៤ អសង្ខ្យេយ្យ និងមួយសែនកប្ប បីដូចកើតនូវសេចក្តីឧស្សាហ៍ឡើងថា ខាងមុខអំពីនេះ អាត្មាអញមិនមានឱកាស ពិតហើយ បារមីទាំងពួង ហាក់ដូចប្រជុំគ្នាថា នឹងឲ្យវិបាកក្នុងអត្តភាពមួយ ទើបបណ្តាលឲ្យជំនន់ទឹកធំ គឺលាភសក្ការៈ កើត*

ឡើងដល់ព្រះមានព្រះភាគ ដូចភ្លៀងធំធ្លាក់ជាគួៗ តាំងឡើងគ្រប់ទិស ធ្វើឲ្យ កើតជំនន់ធំ ដូច្នោះ ។ បន្ទាប់អំពីនោះ ក្សត្រ និងព្រាហ្មណ៍ជាដើម កាន់ ជាយ ទឹក សំពត់ យាន ផ្ការម្រង គ្រឿងក្រអូប និងគ្រឿងលាបជាដើម មកវកព្រះមានព្រះភាគថា ព្រះសម្ពុទ្ធ ព្រះមានព្រះភាគ ព្រះទេវទេព ព្រះ នរាសភៈ ព្រះបុរិសសីហៈ ប្រថាប់នៅទីណា ទើបយកវរទេះ ១០០ ផ្គុក បច្ច័យទាំងឡាយមក កាលមិនទាន់បានឱកាស ទើបយកទូកវរទេះទល់គ្នានឹង ទូកវរទេះ ក្នុងទីប្រមាណមួយគាវុតដោយជុំវិញ ស្នាក់នៅ និងជាប់តាមទៅ ដូចអន្ធកព្រាហ្មណ៍ និងវិនូព្រាហ្មណ៍ជាដើម ។ ពាក្យទាំងអស់នោះ គប្បី ជ្រាបដោយនយដែលពោលមកក្នុងខន្ធកៈ និងក្នុងសូត្រនោះៗ កើតដល់ភិក្ខុ សង្ឃ ដូចកើតដល់ព្រះមានព្រះភាគនោះឯង ។ សមដូចព្រះតម្រាស់ត្រាស់ ថា ម្នាលចុន្ទ ឥឡូវនេះ ទោះជាសង្ឃក្តី គណៈក្តី របស់តថាគតកើតឡើង ក្នុងលោកហើយ ។ ម្នាលចុន្ទ តថាគតជ្រើសរើសមិនឃើញ សង្ឃដទៃ សូម្បីមួយពួក ដែលដល់នូវលាភដ៏ប្រសើរ និងយសដ៏ប្រសើរយ៉ាងនេះ ឲ្យ ដូចជាភិក្ខុសង្ឃ (ក្នុងសាសនានេះ) ឡើយ ។ លាភសក្ការៈនេះ កើត ឡើងដល់ព្រះមានព្រះភាគ និងភិក្ខុសង្ឃ មិនមានប្រមាណ ដូចជំនន់ស្ទឹងធំ ២ ខ្សែ ហូរមក ជួបគ្នាតែមួយខ្សែ ដូច្នេះ ។ ដោយហេតុនោះ ទើបលោក ពោលថា សម័យនោះឯង ព្រះមានព្រះភាគ គេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារជាប្រក្រតី ។ សូម្បីភិក្ខុសង្ឃ ក៏គេធ្វើសក្ការៈ គោរព រាប់អាន

បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ-
ភេសជ្ជបរិក្ខារដែរ ។

ឯតិរ្ថិយទាំងឡាយ បុគ្គលណាម្នាក់ ក៏មិនធ្វើសក្ការៈ មិនគោរព ព្រោះ
ជាអ្នកមិនបានធ្វើបុណ្យក្នុងកាលមុន និងជាអ្នកបដិបត្តិខុស ពោលដោយ
ពិសេសតាមពុទ្ធុប្បាទកាល ជាអ្នកមានសេចក្តីល្អវិបត្តិ អស់ន្ទូវស្មី តេជៈ
សាបសូន្យលាភសក្ការៈ ដូចជា អំពិលអំពេក ក្នុងកាលព្រះអាទិត្យ រះឡើង
ដូច្នោះ ។ ជនទាំងនោះ អត់ធន់នឹងលាភសក្ការៈ របស់ព្រះមានព្រះភាគ និង
ភិក្ខុសង្ឃមិនបាន ត្រូវសេចក្តីឫស្សាគ្រប់សង្កត់ ទើបពោលឡើងថា យើង
និងជេរប្រទេចជនទាំងនេះ ដោយផរុសវាចា យ៉ាងនេះហើយ ដេញឲ្យគេច
ទៅ តាំងខ្លួនជាសត្រូវ គ្រាច់ជេរបរិភាសភិក្ខុទាំងឡាយ ក្នុងទីនោះៗ ដោយ
ហេតុនោះ ទើបលោកពោលថា បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះឯង ពួក
បរិព្វាជកអន្យតិរ្ថិយទាំងនោះ កាលធន់ទ្រាំនឹងសក្ការៈ ចំពោះព្រះមានព្រះភាគ
និងភិក្ខុសង្ឃមិនបាន លុះឃើញពួកភិក្ខុសង្ឃ ក្នុងស្រុកក្តី ក្នុងព្រៃក្តី ក៏ជេរ
ប្រទេច ខឹង ចាក់រុក ដោយវាចាទ្រគោះ ជារបស់អស្បុរស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសព្ភាហិ** សេចក្តីថា ដោយផរុសវាចា
ដែលមិនសមគួរក្នុងសភា គឺមិនគួរក្នុងទីជំនុំសាធុជន ក្នុងទីប្រជុំ អធិប្បាយថា
ដោយវាចាអាក្រក់គ្រោតគ្រោត ។ បទថា **ផរុសាហិ** បានដល់ ដោយវាចា
គ្រោតគ្រោត គឺកាត់បង់នូវសេចក្តីស្រឡាញ់ ។ បទថា **អក្កោសន្តិ** បានដល់
ជេរដោយអក្កោសវត្ថុ មានជាតិជាដើម ។ បទថា **បរិភាសន្តិ** បានដល់

គំរាមឲ្យកើតការខ្លាច ដោយជម្ងោះ ។ បទថា **ភោសេន្តិ** *សេចក្តីថា ឲ្យកើតនូវការក្រេវក្រោធ តាមកម្ចាត់ ដូចក្រេវក្រោធដល់អ្នកដទៃ ។ បទថា* **វិភោ-សេន្តិ** *សេចក្តីថា រមែងបៀតបៀន គឺធ្វើនូវការមិនសប្បាយចិត្ត ដោយអាការផ្សេងៗ ។ សួរថា ហេតុអ្វី ទើបជនទាំងនេះនាំគ្នាធ្វើការជេរជាដើមឲ្យកើតក្នុងព្រះមានព្រះភាគ និងភិក្ខុសង្ឃ ដែលជាទីតាំងនៃសេចក្តីជ្រះថ្លាដោយជុំវិញ ។*

ឆ្លើយថា ជនទាំងនោះ ជាអ្នកមានចិត្តខិងអាក់អន់ ព្រោះខ្លួនវិនាសលាភសក្ការៈ ព្រោះព្រះមានព្រះភាគ ទ្រង់កើតឡើងក្នុងលោក ទើបធ្វើឧបាយដ៏កនាំនាងសន្ធរិកាបរិព្វាជិកា ឲ្យប្រកាសទោសរបស់ព្រះសាស្តា និងភិក្ខុទាំងឡាយ ហើយធ្វើការជេរជាដើម ដូចបុគ្គលជីកដីក្លាត់ ជួលទៅ និងដូចមនុស្សធ្វើការតិះដៀលឲ្យកើតក្នុងកែវពិទូរ្យ ដែលមិនគួរឲ្យតិះដៀល ដូច្នោះ ។ រឿងរបស់នាងសន្ធរិកាបរិព្វាជិកានេះ នឹងមានច្បាស់ក្នុងបាលី សុន្ធរិកាសូត្រខាងមុខនោះឯង ។ ព្រោះហេតុនោះ ពាក្យដែលគួរពោលក្នុងទីនេះ ខ្ញុំនឹងពណ៌នាក្នុងសុន្ធរិកាសូត្រនោះឯង ។ ភិក្ខុទាំងឡាយ ចូលទៅគាល់ព្រះមានព្រះភាគ ហើយក្រាបទូលរឿងនោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា គ្រានោះឯង ភិក្ខុជាច្រើន ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។បេ។ បៀតបៀន ។ ពាក្យនោះ មានអត្ថដូចពោលហើយនោះឯង ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងដល់កិច្ចបដិបត្តិខុសរបស់ពួកតិរ្ថិយដែលត្រូវឥស្សាគ្របសង្កត់ ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ដែលសម្តែងដល់នូវភាពជាបុគ្គលមាំទាំ*

ក្នុងប្រការដែលខុស ដែលពួកតិរ្ថិយទាំងនោះធ្វើ និងក្នុងប្រការដែលជនដទៃ អ្នកមានចិត្តជ្រះថ្លាធ្វើ ។

បណ្តាបទទាំងនោះ បទថា **តាមេ អរញ្ញេ សុខទុក្ខជុជ្ឈោ** សេចក្តីថា បុគ្គលត្រូវសុខ និងទុក្ខពាល់ត្រូវហើយ គឺសោយសុខ និងទុក្ខក្នុងទីណាមួយ ទោះជាក្នុងស្រុក ឬក្នុងព្រៃ ឬដល់ព្រមដោយហេតុនៃសុខ និងទុក្ខទាំងនោះ។ បទថា **នេវត្ថតោ នោ បរតោ ឧហេថ** សេចក្តីថា ពួកអ្នកកុំតាំងសុខ និងទុក្ខនោះ ទាំងចាកខ្លួន ទាំងចាកអ្នកដទៃទ្បើយថា អញបានទទួលសុខ បានទទួលទុក្ខ សុខរបស់អញ ទុក្ខរបស់អញ និងថា សុខទុក្ខនេះអ្នកដទៃឲ្យកើតដល់អញ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះក្នុងខន្ធបញ្ចកៈនេះ មិនមានវត្ថុណាមួយ ថាជាអញ ថាជារបស់អញ ថាជាអ្នកដទៃ ថាជារបស់អ្នកដទៃ តែចំពោះសង្ខារតែម្យ៉ាងប៉ុណ្ណោះ កើតទ្បើងតាមបច្ចុយបែកធ្លាយទៅគ្រប់ខណៈ ។ ក្នុងទីនេះ សពួថា **សុខ** និង **ទុក្ខ** ជាកំពូលនៃទេសនា ។ គប្បីជ្រាបអត្ថនៃលោកធម៌ទាំងអស់ ។

ដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ប្រកាសសុញ្ញតដែលមានចំណុច ៤ គឺ ពាក្យថា **នាហំ ក្វចនិ** ព្រះយោគាវចរនេះមិនយើញតួខ្លួន មានក្នុងទីណាមួយទ្បើយ ១ ពាក្យថា **កស្ឯចិ កិញ្ចនតស្មឹ** មិនយើញតួខ្លួន របស់ខ្លួន ដែលគប្បីនាំចូលទៅក្នុងភាពជាអ្វីមួយនៃបុគ្គលណាម្នាក់ ១ ពាក្យថា **ន ច មម ខ្វចនិ** មិនយើញតួខ្លួនរបស់ខ្លួនក្នុងទីណាមួយ ១ ពាក្យថា **កត្ថចិ កិញ្ចន-តត្ថិ** មិនយើញតួខ្លួនរបស់បុគ្គលដទៃ ដែលមានទៅក្នុងទីណាមួយ ១ ឥទ្បូវ

នេះ ទ្រង់សម្តែងហេតុនៃការមិនតាំងមាំអំពីខ្លួន និងអំពីអ្នកដទៃនោះ ។

បទថា **ផុសន្តិ ផស្សា ឧបធឹ បដិច្ច** *សេចក្តីថា ឈ្មោះថា ផស្សៈ ដែលជាគ្រឿងឲ្យនូវសុខ-ទុក្ខនេះ អាស្រ័យឧបធិ ពោល គឺខន្ធបញ្ចកៈ តែងពាល់ត្រូវអារម្មណ៍តាមដែលជារបស់ខ្លួន ក្នុងឧបធិនោះមាន គឺប្រព្រឹត្តទៅក្នុងឧបធិនោះឯង ។ ពិតហើយ អទុក្ខមសុខវេទនា សង្គ្រោះចូលក្នុងសុខដូចគ្នា ព្រោះមានការៈស្ងប់ ។ ព្រោះដូច្នោះ ទើបលោកពណ៌នាអត្តនេះដោយផស្សៈ ២ យ៉ាងនោះឯង ។ ដើម្បីសម្តែងប្រការដែលផស្សៈទាំងនោះ មិនពាល់ត្រូវ ទើបលោកពោលថា* **និរូបធឹ កេន ផុសេយ្យុំ ផស្សា** *កាលបើឧបធិមិនមានផស្សធម៌ទាំងឡាយ ប៉ះពាល់ត្រូវដូចម្តេចបាន ។ ពិតហើយ កាលឧបធិ គឺខន្ធ មិនមានដោយប្រការទាំងពួង ព្រោះហេតុអ្វី ទើបផស្សៈទាំងនោះ គប្បីពាល់ត្រូវ ។ ព្រោះថា ហេតុនោះមិនមាន ។ បើអ្នកទាំងឡាយមិនប្រាថ្នាសុខ និងទុក្ខដែលកើតព្រោះការជេរជាដើមសោត ពួកអ្នកគប្បីធ្វើសេចក្តីព្យាយាមក្នុងការមិនមានឧបធិ ដោយប្រការទាំងពួងនោះឯង ។ គាថាបានចប់ដោយអនុបាទិសេសនិព្វានធាតុ ។ ត្រាស់វដ្តៈ និងវិវដ្តៈដោយឧបាទាននេះ ដោយប្រការដូច្នេះ ॥*

អដ្ឋកថាសក្ការសូត្រទី ៤ ចប់

សុត្តន្តបិដក

ឧបាសកសូត្រ

[៥៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឧបាសកម្នាក់ នៅក្នុងស្រុកឥច្ឆានង្គលៈ បានទៅដល់នគរសាវត្ថី ដោយកិច្ចនីមួយ ។ លុះឧបាសកនោះ បានសម្រេចកិច្ចនោះស្រេចក្នុងនគរសាវត្ថីហើយ ក៏ឆៀងចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះឧបាសកនោះ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាលឧបាសក ខ្លួនអ្នកធ្វើហេតុជាទំនង ដើម្បីមកទីនេះយូរអង្វែងហើយ ។ ឧបាសកនោះទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គប្រឹងនឹងចូលមកគាល់ព្រះមានព្រះភាគជាយូរហើយ ប៉ុន្តែ ខ្ញុំព្រះអង្គជាអ្នកទ្វល់ទ្វាយមិនជាច់ ដោយកិច្ចការនីមួយ ទើបមិនអាចឆ្លៀតចូលមកគាល់ព្រះមានព្រះភាគបានសោះ ។ លុះព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> *កិលេសគ្រឿងទ្វល់ទ្វាយណាមួយ មិនមានដល់បុគ្គលអ្នកមានធម៌ពិចារណាហើយ ជាពហុស្សូត នុ៎ះឯងជាសុខ អ្នកចូរមើលបុគ្គលអ្នកប្រកបដោយកង្វល់ កំពុងតែលំបាកចំពោះអ្នកផង ច្រើនតែមានសភាពជាប់ជំពាក់ចំពោះអ្នកផង ។ សូត្រទី ៥ ។*

អដ្ឋកថា

ឧចាសកសូត្រ

ឧបាសកសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ

[៥៥] បទថា **ឥច្ឆានង្គលកោ** សេចក្តីថា ស្រុកព្រាហ្មណ៍មួយ ក្នុងដែនកោសល ដែលបានឈ្មោះថា ឥច្ឆានង្គល ។ ឈ្មោះថា ឥច្ឆានង្គល ព្រោះនៅអាស្រ័យ ក្នុងស្រុកព្រាហ្មណ៍នោះ ឬព្រោះកើត គឺមានក្នុងស្រុកព្រាហ្មណ៍នោះ ។ បទថា **ឧចាសកោ** សេចក្តីថា ឈ្មោះថា ឧបាសក ព្រោះជាអ្នកប្រកាសការៈ ដែលខ្លួនជាឧបាសក ក្នុងសម្នាក់របស់ព្រះមានព្រះភាគ ដោយត្រៃសរណគមន៍ ជាអ្នកកាន់យកសិក្ខាបទ ៥ ជាពុទ្ធមាមកៈ ធម្មមាមកៈ សង្ឃមាមកៈ ។ បទថា **កេនចិទេវ ករណីយេន** សេចក្តីថា ដោយករណីយកិច្ចឯណាមួយ មានការជម្រះឲ្យបរិសុទ្ធយ៉ាងក្រៃលែងជាដើម ដែលបុគ្គលទ្រទ្រង់ គប្បីធ្វើ ។ បទថា **តីរេត្វា** ប្រែថា ឲ្យសម្រេច ។ បានឮថា ឧបាសកនោះធ្លាប់ចូលគាល់ អង្គុយជិតព្រះមានព្រះភាគជានិច្ចកាល ។ គាត់មិនបានគាល់ព្រះសាស្តា ព្រោះមានកិច្ចច្រើន អស់ ២-៣ ថ្ងៃ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ចិរស្សំ ខោ ត្វំ ឧចាសក ឥមំ បរិ-យាយមកាសិ យទិទំ ឥធាគមនាយ** ម្នាលឧបាសក ខ្លួនអ្នកធ្វើហេតុជាទំនង ដើម្បីមកទីនេះ ជាយូរអង្វែងហើយ ។

បណ្តាបទទាំងនោះ បទថា **ចិរស្សំ** ប្រែថា ដោយកាលយូរ ។ បទថា **បរិយាយំ** ប្រែថា គ្រាមួយ ។ សព្ទថា **យទិទំ** ជានិបាត ។ សេចក្តីថា

យោ អយំ ។ *លោកអធិប្បាយពាក្យនេះថា អ្នកធ្វើវារៈ ដែលធ្វើក្នុងថ្ងៃនេះ ដោយកាលយូរ គឺធ្វើឲ្យយឺតយូរ ដោយការមកក្នុងទីនេះ គឺក្នុងសម្នាក់របស់តថាគតនេះ ។ បទថា* **ចិរប្បដិកាមាំ** *កែជា* **ចិរប្បដិកោ អមាំ** *ភ្ជាប់សេចក្តីថា ខ្ញុំព្រះអង្គបំណងចូលគាល់អស់កាលយូរហើយ ។ បទថា* **កេមាិចិ កេមាិចិ** *ប្រែថា កិច្ចតូច កិច្ចធំ ។ ម្យ៉ាងទៀត បទថា* **កេមាិចិ** *បានដល់កិច្ចឯណានីមួយ ។ ក្នុងសេចក្តីនោះ ទ្រង់សម្តែងដល់ការអើពើ ។ ពិតហើយ កាលគាត់ជ្រះថ្លាក្រៃលែងក្នុងព្រះសាស្តា មិនមានការអើពើក្នុងរឿងដទៃ ដូចក្នុងការចូលគាល់ និងការស្តាប់ធម៌របស់ព្រះសាស្តា ។ បទថា* **កិច្ចករណីយេហិ** *សេចក្តីថា វត្ថុដែលត្រូវធ្វើពិត ក្នុងការគាល់ជាដើមនេះ ចាត់ជាកិច្ច ក្រៅអំពីនេះ ចាត់ជាករណី ។ ម្យ៉ាងទៀត វត្ថុដែលត្រូវធ្វើមុន ហៅថា កិច្ច វត្ថុដែលត្រូវធ្វើក្រោយ ហៅថា ករណី ។ ម្យ៉ាងទៀត វត្ថុតិចតួច ហៅថា កិច្ច វត្ថុធំ ហៅថា ករណី ។ បទថា* **ព្យាវដោ** *ប្រែថា ខ្វល់ខ្វាយ ។ បទថា* **ឯវាមាំ** *សេចក្តីថា ខ្ញុំព្រះអង្គមិនអាចចូលគាល់ដោយអាការយ៉ាងនេះ គឺដោយប្រការនេះ អធិប្បាយថា មិនអាចចូលគាល់ដោយមិនគោរពជាដើម ។*

បទថា **ឯតមត្តំ វិឯិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងនូវសេចក្តីនេះថា អន្តរាយនៃកុសលរមែងមាន ព្រោះភាពដែលពួកសត្វ មានការខ្វល់ខ្វាយក្នុងកិច្ច ដោយមានការកង្វល់ក្នុងកាលព្រះពុទ្ធកើតឡើង និងក្នុងកាលបានជាមនុស្សដែលរកបានលំបាក មិនមានអន្តរាយនៃកុសល ចំពោះការមិនមាននូវការកង្វល់ឡើយ ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្ទឺ*

ឧទាននេះ ដែលសម្តែងដល់សេចក្តីនោះឯង ។

បណ្តាបទទាំងនោះ បទថា **សុខំ វត តស្ស ន ហោតិ កិញ្ចិ** *សេចក្តីថា ក្នុងវត្តមានរូបជាដើម វត្ថុណានីមួយ រមែងមិនមាន គឺមិនមាន បានដល់មិនប្រាកដដល់បុគ្គលណា ដោយការៈដែលកំណត់ដោយតណ្ហាថា នេះរបស់អញ បុគ្គលនោះ រមែងមានសុខពិត អធិប្បាយថា មានសេចក្តីសុខ គួរអស្ចារ្យនោះឯង បាឋៈថា* **ន ហោសិ** *ដូច្នេះក៏មាន ។ គប្បីជ្រាបអត្ថនោះដោយភាពជាអតីតកាល ។ តែអាចារ្យពួកខ្លះពណ៌នាអត្ថនៃបទថា* **ន ហោតិ កិញ្ចិ** *ដូច្នេះថា កិលេសជាគ្រឿងកង្វល់ មានរាគៈជាដើម រមែងមិនមានដល់បុគ្គលណា ។ ពាក្យនោះ មិនល្អ ព្រោះមកក្នុងទេសនាដោយការកំណត់ធម៌ ។ ដោយពាក្យថា កិលេសជាគ្រឿងកង្វល់ មានរាគៈជាដើម លោកពោលត្រឹមតែពាក្យសមគួរប៉ុណ្ណោះ ក្នុងកាលមានការរួបរួមធម៌គួរកំណត់ ។ ម្យ៉ាងទៀត អធិប្បាយថា បុគ្គលណាមិនមានកិលេសជាគ្រឿងកង្វល់ គឺគ្រឿងជាប់ជំពាក់ណាមួយ សូម្បីតិចតួច ព្រោះមិនមានកិលេសជាគ្រឿងកង្វល់ មានរាគៈជាដើមនោះឯង សេចក្តីនោះរបស់បុគ្គលនោះ ដែលមិនមានកិលេសជាគ្រឿងកង្វល់ឈ្មោះថា ជាសេចក្តីសុខពិត គឺជាសេចក្តីសុខគួរអស្ចារ្យ ព្រោះជាបច្ច័យនៃសេចក្តីសុខ បើសួរថា កិលេសជាគ្រឿងកង្វល់ មិនមានដល់បុគ្គលណាដូច្នេះ ទើបទ្រង់ត្រាស់ថា* **សង្ខាតធម្មស្ស ពហុស្សុតស្ស** *ដូច្នេះ បុគ្គលណាមានធម៌ដែលត្រូវជ្រាប់ហើយ គឺមានកិច្ចដែលត្រូវធ្វើហើយ ព្រោះសម្រេចកិច្ច ១៦ យ៉ាង ពោល គឺមគ្គទាំង ៤ ឈ្មោះថា ជាពហុសូត ព្រោះដឹងពហុសច្ច

ជាក់ច្បាស់ ចាកធម៌នោះឯងនៃបុគ្គលនោះ ។

ដូច្នោះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងអានិសង្សក្នុងការមិនមានកិលេសជាគ្រឿងកង្វល់ឯណានីមួយហើយ ទើបសម្តែងទោសក្នុងការមានកិលេសជាគ្រឿងកង្វល់ណាមួយ ទើបត្រាស់ពាក្យជាដើមថា **សកិញ្ចនំ បស្ស** ដូច្នេះ ។

ពាក្យនោះ មានន័យដូចពោលតទៅនេះ ព្រះសាស្តា ទ្រង់ដល់នូវធម្ម-សង្វេគហើយ ទើបត្រាស់នឹងចិត្តរបស់ទ្រង់ថា ចូរអ្នកមើលបុគ្គល ឈ្មោះថាមានកិលេសជាគ្រឿងកង្វល់ ព្រោះមានកិលេសជាគ្រឿងកង្វល់ មានរាគៈជាដើម និងកិលេសជាគ្រឿងកង្វល់ គឺអាមិស ក្តៅក្រហាយ គឺដល់នូវការចង្អៀតចង្អល់ដោយកិចូតូច-ធំ ព្រោះហេតុនៃការស្វែងរក និងរក្សាកាមដែលបានហើយ និងមិនទាន់បាន ព្រោះភាពជាបុគ្គលមានកិលេសជាគ្រឿងកង្វល់នោះឯង និងដោយអំណាចការប្រកាន់ ថាអញ ថារបស់អញ ដូច្នេះ ។ បទថា **ជនោ ជនស្មឹ បដិពជ្ជរូចោ** សេចក្តីថា ខ្លួនឯងជាជនដទៃ ជាអ្នកមានសភាវៈទាក់ទងជាមួយជនដទៃ ដោយអំណាចតណ្ហាថា អាត្មាអញជារបស់បុគ្គលនេះ បុគ្គលនេះជារបស់អញ ទើបក្តៅក្រហាយ គឺដល់នូវការចង្អៀតចង្អល់ ។ បាឬៈថា **បដិពជ្ជចិត្តោ** ដូច្នេះក៏មាន ។ សេចក្តីនេះ គប្បីសម្តែងដោយសុត្តបទជាដើមថា

បុត្តា មត្តិ ធនមត្តិ ឥតិ ពាលោ វិហញ្ញតិ
អត្តា ហិ អត្តនោ នត្តិ កុតោ បុត្តា កុតោ ធនំ ។

ជនពាល តែងព្រួយលំបាក ដោយសេចក្តីសម្គាល់ថា កូន ទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន ចំណង់បើកូនទាំងឡាយនឹងរាប់ថា មានអំពីណាបាន ទ្រព្យនឹងរាប់ថា មានអំពីណាបាន ។

អដ្ឋកថា ឧបាសកសូត្រទី ៥ ចប់

សុត្តន្តបិដក

គពិ្ភនីសូត្រ

[៥៦] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង នាងមាណវិកានៅក្មេង ជាប្រពន្ធបរិព្វាជកម្នាក់ ជាស្ត្រីមានគភ៌ ជិតសម្រាលកូន ។ លំដាប់នោះ នាងបរិព្វាជិកានោះ បាននិយាយនឹងបរិព្វាជកយ៉ាងនេះថា នែព្រាហ្មណ៍ អ្នកចូរទៅនាំមកនូវប្រេងដែលជាប្រយោជន៍ដល់ខ្ញុំសម្រាប់សម្រាលកូន ។ កាលបើនាងបរិព្វាជិកា និយាយយ៉ាងនេះហើយ បរិព្វាជកនោះ ក៏និយាយនឹងនាងបរិព្វាជិកានេះវិញថា ចុះអញនាំយកប្រេងពីណាមកឲ្យនាង ។ នាងបរិព្វាជិកានោះ បាននិយាយនឹងបរិព្វាជកនោះ ជា*

គម្រប់ពីរដងយ៉ាងនេះថា ម្នាលព្រាហ្មណ៍ អ្នកចូរទៅនាំប្រេង ដែលជាប្រយោជន៍ដល់ខ្ញុំ សម្រាប់សម្រាលកូន ។ បរិព្វាជកនោះ បាននិយាយនឹងនាងបរិព្វាជិកានោះ ជាគម្រប់ពីរដង យ៉ាងនេះថា ចុះអញនាំយកប្រេងពីណាមកឲ្យនាង ។

នាងបរិព្វាជិកានោះ បាននិយាយនឹងបរិព្វាជកនោះជាគម្រប់បីដង យ៉ាងនេះថា ម្នាលព្រាហ្មណ៍ អ្នកចូរទៅនាំយកប្រេង ដែលជាប្រយោជន៍ដល់ខ្ញុំ សម្រាប់សម្រាលកូន ។

[៥៧] សម័យនោះឯង ព្រះរាជាបសេនទិកោសល ទ្រង់ប្រទានឲ្យសមណៈ ឬព្រាហ្មណ៍ ធាន់សប្បិ ឬប្រេង ក្នុងឃ្លាំងត្រឹម ១ ឆ្នែត មិនទ្រង់ប្រទានឲ្យនាំចេញបានទេ ។ គ្រានោះឯង បរិព្វាជកនោះ មានសេចក្តីត្រិះរិះថា ចំណែកតែព្រះរាជាព្រះនាមបសេនទិកោសល ទ្រង់ប្រទានឲ្យសមណៈ ឬព្រាហ្មណ៍ធាន់សប្បិ ឬប្រេង ក្នុងឃ្លាំងត្រឹម ១ ឆ្នែត មិនទ្រង់ប្រទានឲ្យនាំចេញបានទេ បើដូច្នោះ មានតែអាត្មាអញ នឹងទៅឯឃ្លាំងព្រះរាជា ព្រះនាមបសេនទិកោសល ក្រេបផឹកប្រេងជរាបជល់ឆ្នែត ហើយមកផ្ទះវិញ សឹមរើឲ្យ ដើម្បីជាប្រយោជន៍ដល់ប្រពន្ធនេះ សម្រាប់សម្រាលកូន ។ លំដាប់នោះ បរិព្វាជកនោះ ទៅឯឃ្លាំងព្រះរាជា ព្រះនាមបសេនទិកោសលហើយ ក្រេបផឹកនូវប្រេង ជរាបជល់ឆ្នែតមកផ្ទះវិញ ក៏មិនអាចនឹងរើប្រេង ឲ្យចេញមកខាងលើ ទាំងមិនអាចធ្វើឲ្យធ្លាក់ចុះទៅខាងក្រោមបាន ។

បរិព្វាជកនោះ ត្រូវទុក្ខវេទនា ដ៏ក្លៀវក្លា ខ្លាចផ្សា ពាល់ត្រូវ ក៏បម្រះ

ននៀលទៅមក ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ សព្វរចូលទៅបិណ្ឌបាត ឯក្រុងសាវត្ថី ក្នុងបុព្វណ្ហសម័យ ។ ព្រះមានព្រះភាគ បានទតឃើញបរិព្វាជកនោះ កំពុងត្រូវទុក្ខវេទនា ដ៏ក្លៀវក្លា ខ្លោចផ្សា ពាល់ត្រូវ កំពុងបម្រះននៀលទៅមក ។ លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ឥហ្មុ ជនទាំងឡាយណា មិនមានកិលេសជាគ្រឿងកង្វល់ ជននោះ រមែងមានសេចក្តីសុខ មួយទៀត ជនទាំងឡាយណា មិនមានកង្វល់ ជនទាំងនោះ ឈ្មោះថា ដល់នូវវេទ គឺអរហត្តមគ្គញ្ញាណ អ្នកចូរមើលពួកជន ដែលប្រកបដោយកង្វល់ កំពុងលំបាក (ដោយទុក្ខ) អ្នកផង (ច្រើនតែ) មានចិត្តជំពាក់ចំពោះអ្នកផង ។ សូត្រទី ៦ ។

អដ្ឋកថា

គព្ភិនីសូត្រ

គព្ភិនីសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ

[៥៦] *បទថា* **អញ្ញតរស្ស បរិព្វាជកស្ស** *បានដល់ របស់កុដុម្ពិក-បរិព្វាជកម្នាក់ ។ បទថា* **ឧមារា** *ប្រែថា ជាកំលោះក្រមុំ ។ បទថា* **មាណវិកា** *ជាវោហារហៅកូនស្រីរបស់ព្រាហ្មណ៍ ។ បទថា* **បជាបតី** *ប្រែថា ភរិយា ។ បទថា* **គព្ភិនី** *ប្រែថា មានគភ៌ ។ បទថា* **ឧបវិជញ្ញា** *ភ្ជាប់សេចក្តីថា ជាអ្នកមានពេលប្រសូតជ្រាកជថា ថ្ងៃនេះ ស្អែកនេះ ។ បានឮថា បរិព្វាជកនោះ មានជាតិជាព្រាហ្មណ៍ មានភរិយាតាំងនៅត្រង់អាស្រម ឈ្មោះ ភទ្ទបត្តៈ ព្រោះហេតុនោះ ទើបមនុស្សហៅគាត់ដែលមានភរិយាដោយវោហារថា បរិព្វាជក ។ ឯភរិយារបស់គាត់ គេហៅថា ព្រាហ្មណី ព្រោះមានជាតិជាព្រាហ្មណ៍ ។ បទថា* **តេលំ** *បានដល់ ប្រេងល្ង ។ ក្នុងសេចក្តីនេះថា ដោយវត្ថុ មានប្រេងល្ងជាប្រធាន ទើបនាងប្រាប់ថា ចូរអ្នកនាំយកវត្ថុដែលស្រីប្រសូតកូនត្រូវការដើម្បីបំបាត់ទុក្ខ ក្នុងពេលប្រសូតទាំងអស់ មានសប្បិ និងអំបិលជាដើមមក ។ បទថា* **យំ មេ វិជាតាយ ភវិស្សតិ** *សេចក្តីថា វត្ថុណា មានប្រេងជាដើម ជាឧបការៈដល់ខ្ញុំ ដែលជាអ្នកមានគភ៌ប្រសូត ។ បាឋៈថា* **បរិព្វាជិកាយ** *ដូច្នេះក៏មាន ។ បទថា* **កុតោ** *ប្រែថា ចាកទីណា អធិប្បាយថា គប្បីនាំប្រេងជាដើមមកអំពីណា ទោះជាត្រកូលញាតិ-មិត្រទីនោះ មិនមានដល់យើង ។ បទថា* **តេលំ អាហរាមិ** *លោកពោលឲ្យជាបច្ចុប្បន្នកាល ព្រោះជិតកាលដែលជាបច្ចុប្បន្ន ដោយអត្ថថា នឹងនាំប្រេងមក ។*

[៥៧] **វា** សព្ទ ក្នុងបទថា **សមណស្ស វា** ក្តី **ព្រាហ្មណស្ស វា** ក្តី **សប្ឋិស្ស វា** ក្តី **តេលស្ស វា** ក្តី ក៏ជាសមុច្ចយត្ថ ដូចក្នុងប្រយោគ ជាដើមថា **អត្តិតោ វា ឧធកតោ វា មិថុភេធា វា** ។ បទថា **សប្ឋិស្ស វា តេលស្ស វា** ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថបឋមាវិភត្តិ ។ អធិប្បាយថា សប្ឋិ និងប្រេង ដែលគេឲ្យផឹកតាមដែលត្រូវការ ។ ឯអាចារ្យមួយពួកទៀតពោលថា បទថា **សប្ឋិស្ស វា តេលស្ស វា** ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថថា ចំណែកតិចតួច និងវត្ថុដែលមានចំណែកតិច ពិតហើយ ចំណែកតិចតួចរបស់សប្ឋិ និងប្រេង ក្នុងទីនេះ លោកហៅដោយសព្ទតាមដែលត្រូវការ ។ បទថា **នោ នីហរតុំ** សេចក្តីថា គេមិនឲ្យប្រើភាជន: ឬដៃនាំយកទៅខាងក្រៅ ។ បទថា **ឧច្ចធ្ទិត្វាន** បានដល់ រើអៀងចេញ ។ ភ្ជាប់សេចក្តីថា ធ្វើម្តេចហ្នឹ អញគប្បីរើអៀងចេញ ។ បានញ្ចថា បរិព្វាជកនោះ មានគំនិតយ៉ាងនេះថា អញនឹងទៅកាន់ឃ្លាំងរបស់ព្រះរាជា ផឹកប្រេងឲ្យបានត្រឹម-ក ហើយមកផ្ទះ រើអៀងដាក់ក្នុងភាជន:មួយ រួចលើកដាក់លើជើងច្រាន វត្ថុ របស់ដែលលាយដោយប្រមាត់ និងស្លេស្មជាដើម ភ្លើងនឹងឆេះ តែអញនឹងយកតែប្រេងទៅប្រើក្នុងការងាររបស់បរិព្វាជិកានេះ ។

បទថា **ឧធ្ទំ កាតុំ** បានដល់ ដើម្បីនាំទ្បើងខាងលើ ដោយការរើអៀងចេញ ។ បទថា **ន បន អធោ** សេចក្តីថា មិនអាចនាំចេញខាងក្រោម ដោយការបន្ទោបង់ ។ ពិតហើយ បរិព្វាជកនោះ ផឹកដោយគិតថា នឹងរើវត្ថុដែលអាត្មាអញផឹកចូលទៅច្រើន ចេញអំពីមាត់ខ្លួនឯង កាលវត្ថុដែលផឹកចូលទៅ

មិនចេញមក ព្រោះមិនជាប្រយោជន៍ដល់ក្រពះ មិនជីង ឬមិនបានវត្ថុដែលគួររើអៀង និងបន្ទោបង់ចេញបាន បានទទួលទុក្ខវេទនាតែម្យ៉ាង ទើបបម្រះនៀលទៅមក ។ បទថា **ទុក្ខាហិ** *ប្រែថា មានទុក្ខ ។ បទថា* **តិប្បាហិ** *បានដល់ ច្រើន ឬខ្លាំងក្លា ។ បទថា* **ឱរាហិ** *បានដល់ ខ្លាំងក្លា ។ បទថា* **កដុកាហិ** *បានដល់ ទារុណ ព្រោះជារបស់មិនគួរប្រាថ្នាយ៉ាងក្រៃលែង ។ បទថា* **អាវដ្ដតិ** *សេចក្តីថា កាលមិនដេកនៅក្នុងទីតែមួយ ប្រមៀលកាយរបស់ខ្លួនទៅខាងនោះខាងនេះ ឈ្មោះថា បម្រះនៀលទៅ ។ បទថា* **បរិ-វដ្ដតិ** *សេចក្តីថា ជាអ្នកដេកនៅក្នុងទីមួយកន្លែង កាលរលាស់អវយវៈតូចធំទៅដោយជុំវិញ ឈ្មោះថា* **បរិវដ្ដតិ** ។ *ម្យ៉ាងទៀត កាលវិលទៅត្រង់មុខ ឈ្មោះថា* **អាវដ្ដតិ** *កាលវិលទៅជុំវិញ ឈ្មោះថា* **បរិវដ្ដតិ** ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា កាលទ្រង់ជ្រាបដោយប្រការទាំងពួងដល់សេចក្តីនេះថា ការកើតទុក្ខបែបនេះ ព្រោះបរិភោគដោយមិនពិចារណានៃបុគ្គលដែលមានកិលេសជាគ្រឿងកង្វល់មាន តែសម្រាប់បុគ្គលមិនមានកិលេសជាគ្រឿងកង្វល់ រមែងមិនមានទុក្ខនេះ ដោយប្រការទាំងពួង ដូច្នេះហើយ ទើបទ្រង់បន្ទឺឧទាននេះ ដែលប្រកាសសេចក្តីនោះ ។ បណ្តាបទទាំងនោះ បទថា* **សុខិនោ វត** *សេចក្តីថា សប្បុរសទាំងឡាយ មានសេចក្តីសុខហ្ន៎ ។ សួរថា សប្បុរសទាំងនោះ គឺសប្បុរសពួកណា ឆ្លើយថា គឺពួកដែលមិនមានកិលេសជាគ្រឿងកង្វល់ ដែលឈ្មោះថា* **អកិញ្ចន** *ព្រោះមិនមានកិលេសជាគ្រឿងកង្វល់ មានរាគៈជាដើម និងកិលេសជាគ្រឿងកង្វល់ក្នុងវត្ថុដែលហួងហែង*

ទើបទ្រង់ត្រាស់ថា **វេឧគុនោ ហិ ជនា អកិញ្ចនា** *ជនទាំងឡាយណា មិនមានកង្វល់ ជនទាំងនោះ ឈ្មោះថា ដល់នូវវេទ គឺអរហត្តមគ្គញ្ញាណ ។ បុគ្គល ឈ្មោះថា* **វេឧគូ** *ព្រោះដល់ គឺសម្រេចវេទ ពោល គឺអរិយ-មគ្គញ្ញាណ ឬដល់ គឺសម្រេចព្រះនិព្វានដោយវេទនោះ ។ អរិយជនទាំងនោះ គឺបុគ្គលដែលអស់អាសវៈ ឈ្មោះថា* **អកិញ្ចន** *ព្រោះកាត់កិលេសជាគ្រឿងកង្វល់ មានរាគៈជាដើមបានជាសមុច្ឆេទ ដោយអរហត្តមគ្គ ។ កាលកិលេសជាគ្រឿងកង្វល់ មានរាគៈជាដើមមិនមាន កិលេសជាគ្រឿងកង្វល់ក្នុងវត្ថុដែលហួងហែង នឹងមានអំពីណា ។*

ព្រះមានព្រះភាគ កាលទ្រង់សរសើរបុគ្គលដែលជាព្រះអរហន្ត ដោយបុព្វភាគនៃគាថាយ៉ាងនេះហើយ កាលទ្រង់តិះដៀលអន្ធបុថុជ្ជន ដោយអបរ-ភាគនៃគាថា ទើបត្រាស់ពាក្យជាដើមថា **សកិញ្ចនំ បស្ស ។** *ពាក្យនោះមានអត្ថដូចពោលហើយ ក្នុងសូត្រដំបូងនោះឯង ដោយគាថានេះ ទ្រង់ត្រាស់វដ្តៈផង វិវដ្តៈផង ដូចពណ៌នាមក ដូច្នេះ ៗ*

អដ្ឋកថា គព្ភិនីសូត្រទី ៦ ចប់

សុត្តន្តបិដក

ឯកបុត្តសូត្រ

[៥៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឧបាសកម្នាក់ មានកូនប្រុសតូចមួយ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ធ្វើមរណភាព ។ គ្រានោះឯង ពួកឧបាសកច្រើននាក់ មានសំពត់ទទឹក មានសក់ទទឹក ចូលទៅគាល់ព្រះមានព្រះភាគទាំងថ្ងៃ ហើយថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះឧបាសកទាំងនោះ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ត្រាស់សួរយ៉ាងនេះថា ម្នាលឧបាសកទាំងឡាយ ដូចម្តេចហ្ន៎ បានជាអ្នកទាំងឡាយ មានសំពត់ទទឹក មានសក់ទទឹក ចូលមកក្នុងទីនេះទាំងថ្ងៃ ។ កាលបើព្រះមានព្រះភាគត្រាស់សួរ យ៉ាងនេះហើយ ឧបាសកនោះ បានទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះមានព្រះភាគ កូនប្រុសតូចមួយរបស់ខ្ញុំព្រះអង្គ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ធ្វើមរណភាពទៅ បានជាពួកខ្ញុំព្រះអង្គ មានសំពត់ទទឹក មានសក់ទទឹក ចូលមកក្នុងទីនេះទាំងថ្ងៃ ។ លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ពួកទេវតា និងពួកមនុស្សជាច្រើន ជាប់ជំពាក់ដោយការត្រេក-ត្រអាលក្នុងរូប ជាទីស្រឡាញ់ ជាអ្នកមានសេចក្តីទុក្ខ និងសេចក្តីសោកសួទ្យ លុះក្នុងអំណាចមច្ចុរាជ ។ ពួកជនណា មិនធ្វេសប្រហែសទាំងថ្ងៃ ទាំងយប់ លះបង់រូបជាទីស្រឡាញ់ ពួកជននោះ

ឯង ឈ្មោះថា គាស់រម្លើង ឬ ធ្វើមិនអោយសេសសល់នូវទុក្ខ ជានុយនៃមច្ចុ ដែលកន្ទង់បានដោយក្រ ។ សូត្រទី ៧ ។

អដ្ឋកថា

ឯកបុត្តសូត្រ

ឯកបុត្តសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ

[៥៨] បទថា **ឯកបុត្តកោ** *ប្រែថា កូនម្នាក់ កូននោះ ឈ្មោះថា* **ឯកបុត្តក** *ព្រោះអត្តថា ដែលគេអនុគ្រោះ ។ ឈ្មោះថា* **បិយោ** *ព្រោះអត្តថា ដែលគេស្រឡាញ់ ឈ្មោះថា* **មនាបោ** *ព្រោះអត្តថា ជាទីត្រេកអរ ។ ម្យ៉ាងទៀត ឈ្មោះថា* **បិយោ** *ព្រោះអត្តថា គួរសរសើរ ព្រោះសម្បូរដោយលម្អនៃរាងកាយ ឈ្មោះថា* **មនាបោ** *ព្រោះជាអ្នកមានកល្យាណធម៌ ព្រោះសម្បូរដោយសីល និងអាចារ ។ ឈ្មោះថា* **កាលេ** *ព្រោះធ្វើសត្វឲ្យអស់ទៅ បានដល់ មរណៈ ។ ឈ្មោះថា* **កាលង្កតោ** *ព្រោះធ្វើ គឺដល់កាលៈនោះ ។ ម្យ៉ាងទៀត ឈ្មោះថា* **កាលង្កតោ** *ព្រោះកាលៈ គឺមច្ចុ ធ្វើហើយ គឺវិនាសទៅហើយ បានដល់ ដល់នូវការមិនឃើញ អធិប្បាយថា ស្លាប់ ។*

បទថា **សម្ពហុលា ឧបាសកា** *សេចក្តីថា ឧបាសកអ្នកក្រុងសាវត្ថីជាច្រើន ទៅតាមក្រោយឧបាសកដែលត្រូវកូនស្លាប់ រហូតដល់ប៉ាធា មួយអន្ទឹងដោយសេចក្តីសោក ឲ្យធ្វើឈាបនកិច្ចសពហើយ ក៏ត្រឡប់ទៅ ចុះទឹកទាំង*

សម្លៀកបំពាក់នោះឯង ជ្រមុជក្បាល ពួតសំពត់ មិនទាន់ស្ងួតនៅឡើយ ស្លៀកសំពត់មួយផ្ទាំង ធ្វើធ្លៀងស្មាម្ខាង ឲ្យឧបាសកនោះនាំមុខ គិតនឹងស្តាប់ធម៌ដែលជាហេតុបន្ទោបង់នូវសេចក្តីសោក ក្នុងសម្នាក់ព្រះសាស្តា ទើបចូលទៅគាល់ព្រះសាស្តា ។ ដោយហេតុនោះ ទើបលោកពោលពាក្យជាដើមថា **អល្លកេសោ** មានសក់សើមដោយទឹក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អល្លវត្ថោ** ប្រែថា មានសំពត់សើមដោយទឹក ។ បទថា **ឯកាឯកវស្សេ** ប្រែថា កណ្តាលថ្ងៃត្រង់ អធិប្បាយថា ពេលថ្ងៃត្រង់ ។ ព្រោះព្រះតថាគតទាំងឡាយ ទ្រង់ជ្រាបហើយ ត្រាស់សួរក៏មាន ទ្រង់ជ្រាបហើយ មិនត្រាស់សួរក៏មាន ។ ទ្រង់ដឹងពេលត្រាស់សួរក៏មាន ទ្រង់ដឹងពេល មិនត្រាស់សួរក៏មាន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបនោះឯង កាលត្រាស់សួរដើម្បីតាំងរឿងឡើង ទើបត្រាស់ពាក្យជាដើមថា **កិន្នុ ខោ តុម្ហេ ឧបាសកា** ម្នាលឧបាសកទាំងឡាយ ដូចម្តេចហ្ន៎ បានជាអ្នកទាំងឡាយ ដូច្នេះ ។

ព្រះតម្រាស់នោះ មានអត្ថដូច្នេះថា ម្នាលឧបាសកទាំងឡាយ ក្នុងថ្ងៃជាទៃ។ ពួកអ្នកកាលមកកាន់សម្នាក់របស់តថាគត ស្លៀកសំពត់ស្ងួត ហើយស្អាត មកក្នុងវេលាល្ងាច តែថ្ងៃនេះ មានសំពត់សើម សក់សើម មកក្នុងទីនេះទាំងថ្ងៃត្រង់ ព្រោះហេតុអ្វីហ្ន៎ ។ បទថា **តេន មយំ** សេចក្តីថា ព្រោះហេតុនោះ ទើបខ្ញុំព្រះអង្គទាំងឡាយមានសភាពដូច្នោះ ព្រោះត្រូវសេចក្តីសោកដ៏ខ្លាំងក្លាគ្របសង្កត់ ព្រោះការក្តៅក្រហាយចិត្ត ដែលកើតអំពីការព្រាត់ប្រាស

ចាកបុត្រ ទើបបានមកគាល់ក្នុងទីនេះ ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ជ្រាបដោយប្រការទាំងពួងដល់រឿងនេះថា សការវត្ថុ មានសោក ទុក្ខ និងទោមនស្ស ជាដើម មានវត្ថុជាទីស្រឡាញ់ជាដែនកើត កាលវត្ថុដែលមិនជាទីស្រឡាញ់ មិនមាន សេចក្តីសោកជាដើមនោះ ក៏មិនមានដោយប្រការទាំងពួង ទើបទ្រង់បន្ទឺឧទាននេះ ដើម្បីប្រកាសអត្ថនោះ ។*

បណ្តាបទទាំងនោះ បទថា **បិយរូបសាទគធិតាសេ** *សេចក្តីថា ជាប់គឺមានចិត្តប្រតិព័ទ្ធក្នុងសការៈដែលជាទីស្រឡាញ់ មានរូបក្ខន្ធជាដើម ដោយការត្រេកអរក្នុងសុខវេទនា ។ បទថា* **គធិតាសេ** *សំដៅយក* **គធិតា** *នោះឯង ម្យ៉ាងទៀត សព្ទថា* **សេ** *ត្រឹមតែជានិបាត ។ ចក្ខុបសាទជាដើម និងបិយជន មានបុត្រ និងភរិយាជាដើម ឈ្មោះថា* **បិយរូប** ។ *សមដូចពាក្យដែលលោកពោលក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេសថា អារម្មណ៍ដូចម្តេច មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ។ ចក្ខុ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ។បេ។ សេចក្តីប្រាថ្នាក្នុងធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរក្នុងលោក ដូច្នេះ ។ និងដូចព្រះតម្រាស់ក្នុងខុទ្ទកនិកាយ សុត្តនិបាតថា*

មួយទៀត ជនណា ជាប់ជំពាក់នឹងស្រែចម្ការ កន្លែង
ប្រាក់ គោ សេះ និងបុរសជាខ្ញុំ ពួកស្ត្រី ពួកផៅពង្ស
និងកាមជ័រច្រើន ពួកកិលេសយ៉ាងខ្សោយ រមែងគ្រប

សង្កត់ជននោះ អន្តរាយទាំងឡាយ ញាំញីជននោះ
តពីនេះទៅ ទុក្ខនឹងជាប់ជននោះ ដូចជាទឹកហូរចូលទូក
ដែលបែកធ្លាយ ។

ព្រោះហេតុនោះ បុគ្គលជាប់ជំពាក់ងប់ជ្រប់ អធិប្បាយថា ពាល់ត្រូវ ដោយការត្រេកអរក្នុងបិយរូបទាំងនោះ ។ ដើម្បីឆ្លើយនូវសំណួរថា ជនទាំងនោះ គឺនរណាដែលជាប់នៅក្នុងបិយរូប សាតរូប ទើបទ្រង់សម្តែងជនទាំងនោះថា **ទេវកាយា បុថុមនុស្សា ច** *គឺពួកទេពនិកាយ និងមនុស្សជាច្រើនបានដល់ ពួកទេវតាជាច្រើន មានទេវតាជាន់ចាតុម្មហារាជិកាជាដើម និងមនុស្សជាច្រើន មានអ្នកជម្ពូទ្វីបជាដើម ។ បទថា* **អឃាវិនោ** *បានដល់ ដែលមានទុក្ខតាមផ្លូវកាយ និងចិត្ត ។ បទថា* **បរិដុន្នា** *បានដល់ ជាអ្នកវិនាសចាកសម្បត្តិ មានភាពជាកំលោះក្រមុំ និងការមិនមានរោគជាដើម ព្រោះការវិបត្តិនៃជរា និងរោគជាដើម គប្បីជ្រាបសេចក្តីនោះ តាមដែលបានក្នុងទេវតា និងមនុស្សទាំងឡាយ ។ ម្យ៉ាងទៀត ទេវតាទាំងឡាយដល់ព្រមដោយសុខ ដោយចំណែកមួយ មិនមានទុក្ខ ជរា និងរោគក៏ពិត តែទេវតាទាំងនោះ លោកក៏ហៅថា ជាអ្នកមានទុក្ខ និងជាអ្នកមានសេចក្តីវិនាស ព្រោះមិនមានការផុតចាកទុក្ខនោះឯងជាធម្មតា ។ ម្យ៉ាងទៀត គប្បីជ្រាបការកើត មានទុក្ខជាដើមនៃទេវតាទាំងនោះ ដោយអំណាចការកើតឡើងនៃបុព្វនិមិត្ត បដិច្ចុប្បជរា និងរោគផ្លូវចិត្ត ។ បទថា* **មច្ចុរាជស្ស វសំ គច្ឆន្តិ** *សេចក្តីថា ជនទាំងនោះទៅកាន់អំណាច គឺដៃនៃសេចក្តីស្លាប់ ពោល គឺមច្ចុរាជ ព្រោះមានធាតុ ៣*

ជាធំ ព្រោះកើតក្នុងគភ៌រៀយៗ ព្រោះមិនទាន់លះតណ្ហា មានបិយវត្ថុជា អារម្មណ៍បាន ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងវដ្តៈ ដោយហេតុមានប្រមាណ ប៉ុណ្ណេះហើយ ឥឡូវនេះ ទើបសម្តែងវិវដ្តៈ ដោយន័យជាដើមថា **យេ ច កិលា** *ជួច្នេះ ។*

បណ្តាបទទាំងនោះ បទថា **យេ ច កិលា ច រត្តា ច អប្បមត្តា** *សេចក្តីថា បុគ្គលដែលជាអ្នកមិនប្រមាទយ៉ាងមាំទាំ រមែងបំពេញអប្បមាទប្បដិបទាទាំងពេលថ្ងៃ និងពេលយប់ ដោយន័យដូចពោលហើយជាដើមថា ជម្រះចិត្តឲ្យបរិសុទ្ធចាកធម៌ ដែលជាគ្រឿងរារាំង ដោយការចង្រ្កម និងការអង្គុយអស់ថ្ងៃជាដើម ។ បទថា* **ឆហាត្តិ បិយរូបំ** *សេចក្តីថា ចូរខ្ចល់ខ្វាយក្នុងកម្មដ្ឋានភាវនាដែលសម្បយុត្តដោយសច្ចៈ ៤ លះបិយរូប គឺបិយវត្ថុ មានចក្ខុបសាទជាដើម ដែលកើតអំពីសត្វ និងសង្ខារដែលជាទីស្រឡាញ់ ដោយការលះឆន្ទរាគ ដែលទាក់ទងជាមួយបិយរូបនោះ ព្រោះសម្រេចអរិយមគ្គ ។ បទថា* **តេ ច ឱឃន្តិ អយម្ហលំ មច្ចុនោ អាមិសំ ទុរតិវត្តំ** *សេចក្តីថា ព្រះអរិយ-បុគ្គលទាំងនោះ ប្រើចប គឺ អរិយមគ្គញ្ញាណជីកនូវតណ្ហា មួយអន្ទើដោយអវិជ្ជាដែលជាមូលនៃទុក្ខ គឺវដ្តទុក្ខ ឈ្មោះថា ជាអាមិស ព្រោះមច្ចុ គឺមរណៈពាល់ត្រូវ ឈ្មោះថា កន្ទងបានលំបាក ព្រោះសមណព្រាហ្មណ៍មួយពួកណាក្រៅសាសនានេះ មិនអាចត្រឡប់បាន គឺជកឫសឡើង ធ្វើមិនឲ្យសេសសល់សូម្បីតែវត្ថុតិចតួច សេចក្តីនេះ គប្បីឲ្យពិស្តារដោយសុត្តបទជាដើមថា*

អប្បមាណោ អមតំ បថំ បមាណោ មច្ចុនោ បថំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា ។

សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថា មិនស្លាប់ ជនទាំងឡាយ ដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។

អដ្ឋកថា ឯកបុត្តសូត្រទី ៧ ចប់

សុត្តន្តបិដក

សុប្បវាសាសូត្រ

[៥៩] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកុណ្ឌិដ្ឋានវន ទៀបក្រុងកុណ្ឌិយា ។ សម័យនោះឯង កោលិយ-ធីតា នាមសុប្បវាសា ទ្រទ្រង់គភ៌អស់ ៧ ឆ្នាំ មានគភ៌លំបាកអស់ ៧ ថ្ងៃ ។ កោលិយធីតានោះ លុះត្រូវទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សា ប៉ះពាល់ អត់ទ្រាំ ដោយការត្រិះរិះ ៣ យ៉ាងថា ឱហ្ន៎ ព្រះមានព្រះភាគ ព្រះអង្គនោះ ត្រាស់ដឹងញុំាយ្យធម៌ចំពោះព្រះអង្គឯង ដោយប្រពៃ ព្រោះទ្រង់សម្តែងធម៌ ដើម្បីលះបង់ទុក្ខបែបនេះ ១ ឱហ្ន៎ ព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគអង្គនោះ លោកប្រតិបត្តិប្រពៃ ព្រោះលោកប្រតិបត្តិហើយ ដើម្បីលះបង់ទុក្ខបែបនេះ ១*

ឱហ្ន៎ ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ព្រោះមិនមានទុក្ខបៃបនេះឡើយ ១ ។

[៦០] *គ្រានោះ កោលិយធីតា នាមសុប្បវាសា បានហៅស្វាមីមក ប្រាប់ថា បពិត្រព្រះអយ្យបុត្ត សូមព្រះអង្គមក សូមព្រះអង្គចូលទៅគាល់ ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ សូមថ្វាយបង្គំព្រះបាទានៃព្រះមាន ព្រះភាគ ដោយសិរ្ស សូមព្រះអង្គទូលសួរនូវការមិនមានអាពាធ មិនមាន ទុក្ខ មានកម្លាំងក្រោកឡើងរហ័ស និងការនៅសប្បាយ តាមពាក្យរបស់ខ្ញុំ ម្ចាស់ថា បពិត្រព្រះអង្គដ៏ចម្រើន កោលិយធីតា នាមសុប្បវាសា ថ្វាយបង្គំ ព្រះបាទានៃព្រះមានព្រះភាគ ដោយសិរ្ស ទូលសួរនូវការមិនមានអាពាធ មិនមានទុក្ខ មានកម្លាំងក្រោកឡើងរហ័ស និងការនៅសប្បាយ មួយទៀត សូមព្រះអង្គទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កោលិយធីតា នាម សុប្បវាសា ទ្រទ្រង់គភ៌អស់ ៧ ឆ្នាំ មានគភ៌លំបាកអស់ ៧ ថ្ងៃ ព្រះនាង ត្រូវទុក្ខវេទនាដ៏ក្លាខ្លាំង ខ្ចោចផ្សា ពាល់ត្រូវហើយ អត់ទ្រាំដោយការត្រិះរិះ ៣ យ៉ាងថា ឱហ្ន៎ ព្រះមានព្រះភាគ ព្រះអង្គនោះ ត្រាស់ដឹងញេយ្យធម៌ ចំពោះព្រះអង្គឯង ដោយប្រពៃ ព្រោះទ្រង់សម្តែងធម៌ ដើម្បីឲ្យលះបង់ទុក្ខ បៃបនេះ ១ ឱហ្ន៎ ព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគ ព្រះអង្គនោះ ប្រតិបត្តិប្រពៃ ព្រោះលោកប្រតិបត្តិហើយ ដើម្បីលះបង់ទុក្ខបៃបនេះ ១ ឱហ្ន៎ ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ព្រោះមិនមានទុក្ខបៃបនេះឡើយ ១ ។ កោលិយរាជបុត្ត (ជាស្វាមី) បានទទួលស្តាប់ពាក្យកោលិយធីតា នាម សុប្បវាសាថា ប្រសើរហើយ រួចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅ*

ដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីសមគួរ ។ លុះកោលិ-
យរាជបុត្ត គង់ក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះ
ថា បពិត្រព្រះអង្គដ៏ចម្រើន កោលិយធីតា នាមសុប្បវាសា ថ្វាយបង្គំព្រះ
បាទានៃព្រះមានព្រះភាគ ដោយសិរ្ស ទូលសួរការមិនមានអាពាធ មិនមាន
ទុក្ខ មានកម្លាំងក្រោកឡើងរហ័ស និងការនៅជាសុខសប្បាយ រួចនិយាយ
ផ្តាំយ៉ាងនេះថា កោលិយធីតា នាមសុប្បវាសា ទ្រទ្រង់គភ៌អស់ ៧ ឆ្នាំ មាន
គភ៌លំបាកអស់ ៧ ថ្ងៃ នាងត្រូវទុក្ខវេទនាដ៏ក្លាខ្លាំង ខ្ជោចផ្សា អត់ទ្រាំដោយ
ការត្រិះរិះ ៣ យ៉ាងថា ឱហ្ន៎ ព្រះមានព្រះភាគ ព្រះអង្គនោះ គ្រាស់ដឹង
ញេយ្យធម៌ចំពោះព្រះអង្គឯងដោយប្រពៃ ព្រោះព្រះអង្គទ្រង់សម្តែងធម៌ដើម្បី
លះបង់ទុក្ខបែបនេះ ១ ឱហ្ន៎ ព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគអង្គនោះ
ប្រតិបត្តិប្រពៃ ព្រោះលោកប្រតិបត្តិហើយ ដើម្បីលះបង់ទុក្ខបែបនេះ ១
ឱហ្ន៎ ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ព្រោះមិនមានទុក្ខបែបនេះទេឬយ ១ ។
ព្រះមានព្រះភាគ ទ្រង់គ្រាស់ថា សូមឲ្យកោលិយធីតា នាមសុប្បវាសា បាន
សេចក្តីសុខ សូមកុំឲ្យមានរោគ ប្រសូតបុត្តកុំឲ្យមានរោគ ។ ឯកោលិយធីតា
នាមសុប្បវាសា ក៏បានសេចក្តីសុខ ឥតមានរោគ ប្រសូតបុត្តក៏ឥតមានរោគ
ជំណាលនឹងព្រះពុទ្ធដីកាព្រះមានព្រះភាគ ។ កោលិយរាជបុត្តនោះ ត្រេកអរ
អនុមោទនាភាសិតរបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រោក
ចាកអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ រួចធ្វើប្រទក្សិណ ហើយយាង
សំដៅមកកាន់គេហដ្ឋានព្រះអង្គវិញ ។ កោលិយរាជបុត្តនោះ បានឃើញ

កោលិយធីតានាមសុប្បវាសា បានសេចក្តីសុខ មិនមានរោគ ប្រសូតបុត្ត មិនមានរោគ លុះកោលិយរាជបុត្តនោះបានឃើញហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អស្ចារ្យណាស់ ឱហ្ន៎ ចម្លែកណាស់តើ ព្រះតថាគតមានឫទ្ធិច្រើន មានអានុភាពច្រើនមែន មិនគួរបើកោលិយធីតា នាមសុប្បវាសានេះ បានសេចក្តីសុខ មិនមានរោគ ប្រសូតបុត្តមិនមានរោគ ដំណាលគ្នានឹងព្រះពុទ្ធដីការបស់ព្រះមានព្រះភាគសោះ កោលិយរាជបុត្ត មានចិត្តត្រេកអរវីករាយ កើតបីតិសោមនស្ស ។

[៦១] *គ្រានោះ កោលិយធីតា នាមសុប្បវាសា ហៅស្វាមីមកថា បពិត្រព្រះអយ្យបុត្ត សូមព្រះអង្គមក សូមព្រះអង្គចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគដោយសិរ្ស តាមពាក្យរបស់ខ្ញុំម្ចាស់ថា បពិត្រព្រះអង្គដ៏ចម្រើន កោលិយ-ធីតា នាមសុប្បវាសា ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយសិរ្ស រួចសូមព្រះអង្គក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កោលិយធីតា នាមសុប្បវាសា ទ្រទ្រង់គភ៌អស់ ៧ ឆ្នាំ មានគភ៌លំបាកអស់ ៧ ថ្ងៃ ឥឡូវនេះ នាងបានសេចក្តីសុខ មិនមានរោគ ប្រសូតបុត្តមិនមានរោគ នាងនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយភត្តអស់ ៧ ថ្ងៃ បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទ្រង់ទទួលភត្ត ៧ ថ្ងៃ របស់កោលិយធីតា នាមសុប្បវាសា ។ កោលិយរាជបុត្តនោះ ទទួលស្តាប់ពាក្យកោលិយធីតា នាមសុប្បវាសាថា ប្រសើរហើយ រួចចូល*

ទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីសមគួរ ។ លុះកោលិយរាជបុត្តនោះ គង់ក្នុងទីសមគួរហើយ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កោលិយ-ធីតា នាមសុប្បវាសា ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយសិរ្ស មួយទៀតនាងក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កោលិយធីតា នាមសុប្បវាសា ទ្រទ្រង់គភ៌អស់ ៧ ឆ្នាំ មានគភ៌លំបាកអស់ ៧ ថ្ងៃ ឥឡូវនេះ នាងបានសេចក្តីសុខ មិនមានរោគ ប្រសូតបុត្តមិនមានរោគ នាងនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយភត្តអស់ ៧ ថ្ងៃ បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទ្រង់ទទួលភត្ត ៧ ថ្ងៃ របស់កោលិយធីតា នាមសុប្បវាសាឲ្យទាន ។

[៦២] សម័យនោះឯង ឧបាសកម្នាក់ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយភត្តក្នុងថ្ងៃស្អែក ។ ឧបាសកនោះ ជាឧបដ្ឋាករបស់ព្រះមហាមោគ្គល្លានដ៏មានអាយុ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់ព្រះមហាមោគ្គល្លានដ៏មានអាយុថា ម្នាលមោគ្គល្លាន អ្នកចូរមក អ្នកចូលទៅរកឧបាសកនោះ លុះចូលទៅដល់ហើយ ចូរនិយាយនឹងឧបាសកនោះយ៉ាងនេះថា ម្នាលអាវុសោ កោលិយធីតា នាមសុប្បវាសា ទ្រទ្រង់គភ៌អស់ ៧ ឆ្នាំ មានគភ៌លំបាកអស់ ៧ ថ្ងៃ ឥឡូវនេះ នាងមានសេចក្តីសុខ មិនមានរោគ ប្រសូតបុត្តឥតមានរោគ នាងនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយភត្តអស់ ៧ ថ្ងៃ សូមឲ្យកោលិយធីតា នាមសុប្បវាសា ធ្វើភត្ត ៧ ថ្ងៃ

សិនចុះ ខ្លួនអ្នកចាំធ្វើក្រោយ ព្រោះឧបាសកនោះ ជាឧបដ្ឋាករបស់លោក ស្រាប់ហើយ ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ រួចចូលទៅរកឧបាសកនោះ លុះចូលទៅដល់ហើយ ក៏និយាយនឹងឧបាសកនោះ យ៉ាងនេះថា ម្នាលអាវុសោ កោលិយធីតា នាមសុប្បវាសា ទ្រទ្រង់គភ៌អស់ ៧ ឆ្នាំ មានគភ៌លំបាកអស់ ៧ ថ្ងៃ ឥឡូវនេះ នាងមានសេចក្តីសុខ មិនមានរោគ ប្រសូតបុត្តឥតមានរោគ នាងនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយភត្តអស់ ៧ ថ្ងៃ សូមឲ្យកោលិយធីតា នាមសុប្បវាសា ធ្វើភត្ត ៧ ថ្ងៃសិនចុះ ខ្លួនអ្នកនឹងធ្វើក្រោយ ។ ឧបាសកនោះនិយាយថា បពិត្រលោកដ៏ចម្រើន បើព្រះមហា-មោគ្គល្លានជាម្ចាស់ធានា ចំពោះធម៌ ៣ យ៉ាង គឺកោគៈ ១ ជីវិត ១ សទ្ធា ១ សូមឲ្យកោលិយធីតា នាមសុប្បវាសា ធ្វើភត្ត ៧ ថ្ងៃសិនចុះ ខ្លួនខ្ញុំធ្វើក្រោយ ។ ព្រះមហាមោគ្គល្លាន ពោលថា ម្នាលអាវុសោ ខ្លួនអាត្មាធានាឲ្យអ្នកតែធម៌ ២ យ៉ាង គឺកោគៈ ១ ជីវិត ១ ឯខ្លួនអ្នកត្រូវតែធានាសទ្ធាខ្លួនឯងចុះ ។ ឧបាសកនោះនិយាយថា បពិត្រលោកដ៏ចម្រើន បើព្រះមហា-មោគ្គល្លានដ៏មានអាយុ ធានាចំពោះតែធម៌ ២ យ៉ាង គឺកោគៈ ១ ជីវិត ១ សូមឲ្យកោលិយធីតា នាមសុប្បវាសា ធ្វើភត្ត ៧ ថ្ងៃសិនចុះ ខ្លួនខ្ញុំចាំធ្វើក្រោយ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានពន្យល់ឧបាសកនោះហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបាន

ពន្យល់ឧបាសកនោះហើយ សូមឲ្យកោលិយធីតា នាមសុប្បវាសា ធ្វើកត្ត ៧ ថ្ងៃសិនចុះ ឧបាសកនោះ ចាំធ្វើខាងក្រោយ ។ លំដាប់នោះ កោលិយធីតា នាមសុប្បវាសា អង្គាសកិក្ខុសង្ឃ មានព្រះពុទ្ធប្រធានអស់ ៧ ថ្ងៃ ឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ឧត្តម ដោយដៃខ្លួនឯង គ្រាន់តែហាមឃាត់រួចហើយ ឲ្យទាវកនោះ ថ្វាយបង្គំព្រះមានព្រះភាគ និងភិក្ខុសង្ឃ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ បានសួរទាវកនោះ យ៉ាងនេះថា ម្នាលទាវក កាលអ្នកនៅក្នុងភគ៌ា ល្មមអត់ទ្រាំបានដែរឬ ល្មមប្រព្រឹត្តទៅបានដែរឬ មិនមានទុក្ខតិចតួចទេឬ ។ ទាវកនោះទូលតបថា បពិត្រព្រះសារីបុត្តដ៏ចម្រើន ខ្ញុំព្រះករុណា ល្មមអត់ទ្រាំបានមកពីណា ល្មមប្រព្រឹត្តទៅបានមកពីណា (ព្រោះ) ខ្ញុំនៅក្នុងផ្ទៃប្រឡាក់ដោយឈាមអស់ ៧ ឆ្នាំមកហើយ ។ លំដាប់នោះ កោលិយធីតា នាមសុប្បវាសា មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្ស ដោយសេចក្តីនឹកគោតថា បុត្តអាត្មាអញ ចេះប្រឹក្សាជាមួយព្រះធម្មសេនាបតីបាន ។ លំដាប់នោះ ព្រះមានព្រះភាគ បានជ្រាបថា កោលិយធីតា នាមសុប្បវាសា មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្សហើយ ទើបត្រាស់នឹងកោលិយធីតា នាមសុប្បវាសា យ៉ាងនេះថា ម្នាលនាងសុប្បវាសា នាងចង់បានបុត្តដទៃបែបនេះតទៅទៀតដែរឬ ។ កោលិយធីតា នាមសុប្បវាសាទូលថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន ខ្ញុំម្ចាស់ចង់បានបុត្តដទៃបែបនេះ ៧ នាក់ទៀត ។ លុះព្រះមានព្រភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបបន្ទឺនូវឧទាននេះ ក្នុងវេលានោះថា

អារម្មណ៍មិនជាទីត្រេកអរ មិនជាទីស្រឡាញ់ អារម្មណ៍ជាទុក្ខ រមែងគ្របសង្កត់នូវបុគ្គលអ្នកប្រមាទ ដោយសភាពជាទីត្រេកអរ ដោយសភាពជាទីស្រឡាញ់ ដោយសភាពនៃសេចក្តីសុខ ។

សូត្រទី ៨ ។

អដ្ឋកថា

សុប្បវាសាសូត្រ

សុប្បវាសាសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ

[៥៩] *បទថា* **កុណ្ឌិយាយំ** *បានដល់ ជិតនគរបស់ស្តេចកោលិយៈ មានឈ្មោះយ៉ាងនោះ ។ បទថា* **កុណ្ឌធានវនេ** *បានដល់ ក្នុងព្រៃឈ្មោះកុណ្ឌធាន មិនឆ្ងាយអំពីនគរនោះ ។*

ក្នុងអតីតកាល បានឮមកថា យក្ខមួយរូប ឈ្មោះកុណ្ឌៈ នៅអាស្រ័យត្រង់ជង្រៃនោះ យក្ខនោះចូលចិត្តពលីកម្មដែលលាយដោយកន្ទក់ និងលាជព្រោះដូច្នោះ ទើបជនទាំងឡាយនាំពលីកម្មទាំងនោះចូលទៅក្នុងទីនោះ ដល់យក្ខនោះ ដោយហេតុនោះ ទើបជង្រៃនោះប្រាកដឈ្មោះថា កុណ្ឌធានវន ។ ក្នុងទីមិនឆ្ងាយជង្រៃនោះ មានស្រីម្ចាស់ស្រុកម្នាក់ នាងក៏ត្រូវហៅថា កុណ្ឌិយា ព្រោះនៅអាស្រ័យក្នុងទីដែលជាអាណាខេត្តរបស់យក្ខ និងព្រោះ

ត្រវយក្ខនោះគ្រប់គ្រង ។ ក្នុងគ្រាតមក ព្រះបាទកោលិយៈបានសាងនគរ ឡើងក្នុងទីនោះ ។ សូម្បីនគរនោះ គេក៏ហៅថា កុណ្ឌិយាដូចមុននោះឯង ក្នុងព្រៃនោះ ពួកស្តេចកោលិយៈបានសាងវិហារ ដើម្បីជាទីប្រថាប់ និងជាលំនៅរបស់ព្រះមានព្រះភាគ និងភិក្ខុសង្ឃ ។ ក្នុងជង្ឃព្រៃនោះ ក៏ប្រាកដថា កុណ្ឌធានវនដូចគ្នា ។ សម័យនោះ ព្រះមានព្រះភាគ ទ្រង់ចារិកទៅកាន់ជនបទ ដល់វិហារនោះហើយ គង់ប្រថាប់ក្នុងទីនោះឯង ព្រោះហេតុនោះ ទើបលោកពោលថា **ឯកំ សមយំ ភគវា កុណ្ឌិយាយំ វិហរតិ កុណ្ឌិដ្ឋានវនេ** *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកុណ្ឌិដ្ឋានវន ទៀបក្រុងកុណ្ឌិយា ។ បទថា* **សុប្បវាសា** *ជាឈ្មោះរបស់ឧបាសិកានោះ ។ បទថា* **កោលិយធីតា** *បានដល់ ជារាជបុត្រីរបស់ស្តេចកោលិយៈ ។*

រាជបុត្រីនោះ ជាអគ្គឧបដ្ឋាយិការបស់ព្រះមានព្រះភាគ ទ្រង់ស្ថាបនាក្នុងឯតទគ្គៈ កំពូលលើសសាវិកាទាំងឡាយ ខាងឲ្យរបស់ប្រណីត ។ ជាព្រះអរិយសាវិកាសោតាបន្ន ។ វត្ថុឯណានីមួយ ទោះជារបស់ទំពា របស់បរិភោគ ឬភេសជ្ជៈ ដែលសមគួរដល់ព្រះមានព្រះភាគ មិនមានស្រីដទៃ គប្បីចាត់ចែងក្នុងនោះ វត្ថុទាំងអស់នោះ នាងប្រើបញ្ជារបស់ខ្លួនប៉ុណ្ណោះ ចាត់ចែងហើយនឹងបង្អោនចូលទៅថ្វាយដោយគោរព ។ នាងបានថ្វាយសង្ឃភត្ត និងជាដិបុគ្គលិកភត្ត ៨០០ សម្រាប់ រាល់ៗ ថ្ងៃ បុគ្គលណាម្នាក់ ទោះជាភិក្ខុ ឬភិក្ខុនី ចូលទៅបិណ្ឌបាតកាន់ត្រកូលនោះ មិនមានដៃទទេឡើយ ។ ព្រះនាងមានការបរិច្ចាគយ៉ាងជាច់ខាត មានដៃស្អាត ត្រេកអរក្នុងការលះបង់ គួរដល់

ការសូម ត្រែកអរក្នុងទានដែលឲ្យ ដោយប្រការដូច្នេះ ។ សាវកពោធិសត្វ ដែលមានកពពុងក្រោយ បានធ្វើបុញ្ញាធិការក្នុងកាលមុន បានបដិសន្ធិក្នុងផ្ទៃ របស់នាង ។ ដោយបាបកម្មយ៉ាងនោះឯង នាងក្បាគភ៌អស់ ៧ ឆ្នាំ មាន គភ៌វង្វេងអស់ ៧ ថ្ងៃ ព្រោះហេតុនោះ ទើបលោកពោលថា **សត្ត វស្សានិ គព្ភំ ធារេតិ សត្តាហំ មុទ្ធគ្គា** *ព្រះនាងទ្រទ្រង់គភ៌អស់ ៧ ឆ្នាំ មាន គភ៌វង្វេង ៧ ថ្ងៃ ។*

បណ្តាបទទាំងនោះ បទថា **សត្ត វស្សានិ** *ប្រែថា ដល់ ៧ ឆ្នាំ ។ ពាក្យថា* **សត្ត វស្សានិ** *នេះ ជាទុតិយាវិភត្តិ ប្រើក្នុងអច្ចន្តសំយោគ ប្រែថា រហូត ។ បទថា* **គព្ភំ ធារេតិ** *ប្រែថា ទ្រទ្រង់នូវគភ៌ អធិប្បាយថា មានគភ៌ ។ បទថា* **សត្តាហំ មុទ្ធគ្គា** *បានដល់ មានគភ៌វង្វេង គឺប្រសូតមិនរួចអស់ ៧ ថ្ងៃ ព្រោះថា គភ៌ចាស់ពេញទំហឹង ពេលប្រសូត ខ្យល់កម្មជវាត ធ្វើឲ្យ វិលត្រឡប់ទៅមក យកជើងឡើងខាងលើ ក្បាលចុះក្រោម ឆ្ពោះមកកាន់ ទ្វារប្រសូត ។*

សត្វនោះចេញទៅខាងក្រៅ មិនទើសទាក់ក្នុងទីណាមួយ ដោយប្រការ ដូច្នេះ តែកាលវិបត្តិ ក៏នឹងដេកទទឹងទ្វារប្រសូត ដោយការវិលត្រឡប់ខុស ប្រក្រតី ឬទ្វារប្រសូតបិទឯងនោះឯង ។ សត្វនោះ ព្រោះខ្យល់កម្មជវាតក្នុង គភ៌នោះបក់ត្រឡប់ទៅមក ទើបហៅថា មានគភ៌វង្វេង ព្រោះនាងប្រព្រឹត្ត ទៅយ៉ាងនោះ ៧ ថ្ងៃ ។ ព្រោះហេតុនោះ ទើបលោកពោលថា **សត្តាហំ មុទ្ធគ្គា** *ដូច្នេះ ។ សត្វដែលកើតក្នុងគភ៌នេះ គឺព្រះសីវលិត្ថេរ ។ សួរថា*

ព្រោះហេតុអ្វី ទើបលោកនៅជាទុក្ខក្នុងគភ៌អស់ ៧ ឆ្នាំ ដល់នូវភាពជាអ្នកវង្វេងគភ៌អស់ ៧ ថ្ងៃ សូម្បីព្រះមាតារបស់លោក ជាអរិយសាវិកា សោតាបន្ន ក៏បានសោយទុក្ខយ៉ាងនោះដូចគ្នា ខ្ញុំនឹងធ្វើយដូចតទៅនេះ

ក្នុងអតីតកាល កាលព្រះបាទកាសី គ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ស្តេចកោសលមួយអង្គ ទ្រង់កែនកងពលធំ មកដណ្តើមក្រុងពារាណសី ទ្រង់ផ្តាច់ព្រះជន្មព្រះរាជានោះ បានស្ថាបនាព្រះអគ្គមហេសីរបស់ព្រះរាជាអង្គនោះ ឲ្យជាអគ្គមហេសីរបស់ព្រះអង្គ ។ ចំណែកព្រះឱរសរបស់ព្រះបាទពារាណសី ក្នុងពេលព្រះបិតាអស់ព្រះជន្ម ទើបគេចចេញទៅតាមទ្វារបង្ហូរទឹក ប្រមូលញាតិមិត្រ និងពួកអមាត្យរបស់ព្រះអង្គក្នុងទីតែមួយ រួមកម្លាំងដោយលំដាប់ ហើយយោងមកកាន់ក្រុងពារាណសី តាំងបន្ទាយក្នុងទីមិនឆ្ងាយ ទ្រង់បញ្ជូនរាជសាសន៍ដល់ស្តេចអង្គនោះថា ទ្រង់ឲ្យរាជសម្បត្តិ ឬច្បាំង ។ ព្រះមាតាបានស្តាប់សាសន៍របស់ព្រះរាជកុមារហើយ ទើបបញ្ជូនរាជសាសន៍ទៅថា មិនមានការច្បាំង កូនត្រូវកាត់ផ្តាច់ការចេញចូលគ្រប់ទិស ព័ទ្ធក្រុងពារាណសី បន្ទាប់អំពីនោះ ពួកមនុស្សក្នុងក្រុងលំបាក ព្រោះអស់សម្បកឈើ ទឹក និងអាហារ នឹងចាប់ព្រះរាជាមកថ្វាយ កូនមិនចាំបាច់ច្បាំងឡើយ ។ ព្រះរាជ-កុមារបានស្តាប់សាសន៍របស់មាតាហើយ កាលរក្សាទ្វារធំទាំង ៤ ទើបព័ទ្ធនគរអស់ ៧ ឆ្នាំ ពួកមនុស្សក្នុងក្រុង នាំគ្នាចេញតាមទ្វារតូច យកបន្លែ និងទឹកជាដើម មកធ្វើកិច្ចគ្រប់យ៉ាង ។

គ្រានោះ ព្រះមាតារបស់ព្រះរាជកុមារទ្រង់ដឹងរឿងនោះហើយ ទើបបញ្ជូន

ព្រះរាជសាសន៍ដល់ព្រះឱរសថា កូនល្ងង់ខ្លៅ មិនដឹងឧបាយ ពួកអ្នកចូរទៅប្រាប់ដល់កូនយើងនោះថា ចូរបិទទ្វារគូច ។ ព្រះរាជកុមារទ្រង់ស្តាប់ព្រះរាជសាសន៍របស់ព្រះមាតា ទើបទ្រង់ធ្វើយ៉ាងនោះអស់ ៧ ថ្ងៃ អ្នកនគរកាលចេញទៅខាងក្រៅមិនបាន ក្នុងថ្ងៃទី ៧ ទើបយកសិរីសោរបស់ព្រះរាជា ទៅប្រគល់ដល់ព្រះរាជកុមារៗ បានយាងចូលក្រុង ជណ្តើមរាជសម្បត្តិ ព្រោះផលកម្មដែលព័ទ្ធនគរអស់ ៧ ឆ្នាំ ក្នុងគ្រានោះ ឥឡូវនេះ ទើបទ្រង់នៅក្នុងលោហិតកុម្ភី គឺព្រះគភ៌របស់មាតា ៧ ថ្ងៃ ។ តែព្រោះព័ទ្ធព្រះនគរ ៧ ថ្ងៃ ដោយតឹងរ៉ឹងបំផុត ទើបដល់នូវភាពជាអ្នកវង្វេងគភ៌អស់ ៧ ថ្ងៃ ។ ឯក្នុងអដ្ឋកថាជាតក លោកពោលថា ព្រោះផលកម្មដែលព័ទ្ធនគរអស់ ៧ ថ្ងៃ ទើបទ្រង់នៅក្នុងលោហិតកុម្ភីអស់ ៧ ឆ្នាំ ដល់នូវភាពជាអ្នកវង្វេងគភ៌ អស់ ៧ ថ្ងៃ ។ ព្រះថេរៈជាកំពូលដោយលាភ ព្រោះអានុភាពដែលថ្វាយមហាទាន ហើយតាំងសេចក្តីប្រាថ្នាទៀបបាទមូល នៃព្រះបទុមុត្តរសម្មាសម្ពុទ្ធថា ខ្ញុំព្រះអង្គសូមជាបុគ្គលក្រៃលែងដោយលាភ និងបានថ្វាយទឹកអំពៅ និងទធិដែលមានតម្លៃ ១០០០ កហាបណៈជាមួយអ្នកនគរ ហើយបានតាំងសេចក្តីប្រាថ្នាក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី ។ ឯព្រះនាងសុប្បវាសា ទ្រទ្រង់នូវគភ៌អស់ ៧ ឆ្នាំ វង្វេងគភ៌អស់ ៧ ថ្ងៃ ព្រោះបញ្ជូនសាសន៍ទៅថា ចូរបាព័ទ្ធព្រះនគរ ។ ព្រះមាតា និងបុត្រទាំងនោះ បានសោយទុក្ខបែបនេះ សមគួរដល់កម្មរបស់ខ្លួន ដោយប្រការដូច្នេះ ។

បទថា **តីហិ វិតក្កេហិ** *សេចក្តីថា ដោយសម្មាវិតក្ក ៣ ដែលទាក់ទង*

ដោយការរឲកដល់គុណព្រះរតនត្រ័យ ។ បទថា **អធិវាសេតិ** សេចក្តីថា អត់ធន់ចំពោះទុក្ខដែលកើតឡើង ព្រោះជាអ្នកវង្វេងគភិ ។ សេចក្តីពិត ព្រោះនាងរឲកដល់ភាពដែលព្រះមានព្រះភាគ ត្រាស់ដឹងប្រពៃដោយព្រះអង្គឯង កិចូបដិបត្តិល្អរបស់ព្រះអរិយសង្ឆ និងព្រះនិព្វាន ជាគ្រឿងរលាស់ចេញចាកទុក្ខ ទើបអត់ធន់ សង្កត់នូវទុក្ខដែលកើតឡើងដល់ខ្លួន មិនធ្វើទុកក្នុងចិត្តនោះឯង ។ ព្រោះហេតុនោះ ទើបលោកពោលថា **តីហិ វិតក្ពេហិ អធិវាសេតិ** ដូច្នេះ ។

បទ មានបទជាដើមថា **សម្មាសម្ពុទ្ធោ វត** ត្រឹមតែជាបទសម្តែងអាការដែលវិតក្កទាំងនោះកើតឡើង ។ ពាក្យនោះ មានអធិប្បាយដូច្នេះថា ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា ជានាថនៃលោក ព្រោះមានភាពជាបុគ្គលមានភាគ្យធម៌ជាដើម ឈ្មោះថា **ពុទ្ធ** ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ គឺមិនវិបរិតដោយព្រះអង្គឯង គឺដោយព្រះអង្គឯង ព្រះមានព្រះភាគអង្គនោះ ត្រាស់ធម៌ដើម្បីលះវដ្តទុក្ខទាំងមូលបែបនេះ ដែលអញបានទទួលក្នុងឥឡូវនេះ និងដែលមានការកើតយ៉ាងនេះណាមួយ និងដើម្បីរលត់មិនកើតឡើង ដោយឥតសេសសល់ ត្រាស់ធម៌ដែលមិនខុស មិនផ្ទុយតាមសេចក្តីពិត ការដែលព្រះសាស្តាសម្រេចព្រះសម្មាសម្ពោធិញ្ញាណ ព្រោះទ្រង់សម្តែងធម៌មិនខុស ទ្រង់មានពួកនៃអរិយបុគ្គល ៨ បានឈ្មោះថា សាវកសង្ឆ ព្រោះកើតក្នុងទីជិតនៃការស្តាប់ធម៌របស់ព្រះមានព្រះភាគ ទ្រង់មានព្រះគុណតាមដែលពោលមកហើយ និងកើតរួមដោយភាពជាអ្នកមានសីល និងទិដ្ឋិស្មើគ្នា ដែល

*ជាអរិយសង្ឃអ្នកបដិបត្តិប្រពៃ ដើរតាមបដិបទាដែលជាហេតុមិនត្រឡប់ គឺព្រះនិព្វាន ដើម្បីលះវដ្តទុក្ខបែបនេះ គឺដូច្នេះ និងដើម្បីរម្ងាប់ គឺមិនកើតឡើងនៃទុក្ខ តែងមិនបានទទួលវដ្តទុក្ខ ដូច្នេះ ក្នុងព្រះនិព្វានដែលជាគ្រឿងរលាស់សង្ខតធម៌ទាំងពួង ដែលជាសុខហ្ន៎ សុខណ្ណហ្ន៎ ។ ក្នុងទីនេះ បុគ្គលកំពុងបដិបត្តិ លោកក៏ពោលថា បដិបត្តិហើយដូចគ្នា ព្រោះកិច្ចបដិបត្តិមិនត្រឡប់ ។ ម្យ៉ាងទៀត សព្ទថា **បដិបន្ន** គប្បីជ្រាបថា ជាអត្តបច្ចុប្បន្ន ដូចសព្ទថា **ឧប្បន្ន** ។ ដោយហេតុនោះឯង ទើបលោកពោលថា ឈ្មោះថា អ្នកបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ដូច្នេះ ។*

[៦០] *បទថា* **សាមិកំ** *បានដល់ ព្រះរាជឱរសរបស់ស្តេចកោលិយៈ ដែលជាស្វាមីរបស់ព្រះនាង ។ បទថា* **អាមន្តេសិ** *ប្រែថា បានត្រាស់ហើយ ។ បទថា* **មម វចនេន ភគវតោ ចាទេ សិរសា វន្ទាហិ** *សេចក្តីថា ចូរថ្វាយបង្គំដោយសិរសា គឺត្បូងរបស់អ្នកនូវព្រះយុគលបាទរបស់ព្រះសាស្តា ដែលមានសិរីដូចផ្កាបទុមរីក ដែលប្រដាប់ដោយចក្កលក្ខណៈ តាមពាក្យរបស់ខ្ញុំអធិប្បាយថា ចូរធ្វើអភិវាទដោយសិរសា គឺត្បូង ។ បទថា* **អាពាធោ** *ក្នុងពាក្យជាដើមថា* **អប្បាពាធំ** *លោកពោលដល់វេទនាដែលមិនត្រូវចំណែកគ្នា ដែលកើតឡើងហើយក្នុងចំណែកមួយ ក៏កាន់យកសរីរៈទាំងមូល ដូចកាន់យកដោយបន្ទះដែក ។ បទថា* **អាតង្កោ** *បានដល់ រោគដែលធ្វើជីវិតឲ្យថមថយ ម្យ៉ាងទៀត រោគដែលគប្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ឈ្មោះថា* **អាតង្ក** *រោគក្រៅអំពីនេះ ឈ្មោះថា* **អាពាធ** ។ *ម្យ៉ាងទៀត រោគតូចតាច*

ឈ្មោះថា **អាតង្ក** *រោគខ្លាំងក្លា ឈ្មោះថា* **អាពាធ** ។ *តែអាចារ្យពួកខ្លះ ពោលថា រោគដែលកើតខាងក្នុង ឈ្មោះថា* **អាពាធ** *រោគដែលកើតខាងក្រៅ ឈ្មោះថា* **អាតង្ក** ។ *ព្រះនាងត្រាស់ថា សូមទ្រង់ទូលសួរដល់ការមិនមានរោគទាំង ២ យ៉ាងនោះ ។ ឈ្មោះថា ការកើតឡើងនៃជំងឺនោះឯង ជាការៈធ្ងន់ កាយមិនមានកម្លាំង ព្រោះហេតុនោះ ទើបព្រះនាងត្រាស់ថា សូមទ្រង់ទូលសួរដល់ហានៈនៃរាងកាយស្រាល និងមានកម្លាំង ពោល គឺការប្តូរឥរិយាបថបានរហ័ស ព្រោះមិនមានជំងឺ ។ បទថា* **ផាសុវិហារំ** *សេចក្តីថា ព្រះនាងត្រាស់ថា សូមទូលសួរដល់ការនៅជាផាសុកក្នុងឥរិយាបថទាំង ៤ ពោល គឺឈរ អង្គុយ ដើរ និងដេក ។ លំដាប់នោះ ព្រះនាងកាលសម្តែងអាការទូលសួរព្រះអង្គ ទើបត្រាស់ពាក្យជាដើមថា* **សុប្បវាសា ភន្តេ** *ជូច្នេះ ។ ដោយពាក្យថា* **ឯវញ្ច វនេថិ** *លោកសម្តែងដល់អាការដែលគប្បីទូលក្នុងឥទ្ធរនេះ ។*

បទថា **បរមំ** *ជាការទទួលពាក្យឆ្ងើយ ។ ដោយបទថា* **បរមំ** *នោះទ្រង់សម្តែងថា សាធុ ខ្ញុំនឹងបដិបត្តិតាមដែលនាងពោល ។ បទថា* **កោលិយ-បុត្តោ** *បានដល់ ព្រះរាជឱរសរបស់ស្តេចកោលិយៈ ដែលជាស្វាមីរបស់ព្រះនាងសុប្បវាសា ។*

ដោយបទថា **សុខិនី ហោតុ** *ព្រះសាស្តាទ្រង់ជាអគ្គទក្ខិណេយ្យបុគ្គលក្នុងលោក មួយអន្ទើដោយទេវលោក ទ្រង់ទទួលពាក្យថ្វាយបង្គំរបស់ព្រះរាជបុត្រ ដែលព្រះនាងសុប្បវាសាបញ្ជូនមកពេលនោះ ទើបទ្រង់ប្រកាសការ*

នាំសេចក្តីសុខចូលទៅក្នុងទីដែលព្រះពុទ្ធទ្រង់ធ្លាប់បំពេញ ជាហេតុឲ្យកើតមេត្តាវិហារធម៌របស់ព្រះអង្គដល់ព្រះនាងសុប្បវាសានោះ ដោយសាមញ្ញទូទៅ លុះទ្រង់សម្តែងការនាំសេចក្តីសុខចូលទៅដល់ព្រះនាង និងព្រះឱរសទៀត ដោយការបដិសេធការបានទទួលទុក្ខ ដែលមានការវិបត្តិគកិជាមូលជាប្រធាន ទើបត្រាស់ថា **សុខិនី អរោគា អរោគំ បុត្តំ វិជាយតុ** *ចូរកោលិយធីតា នាមសុប្បវាសា មានសេចក្តីសុខ ចូរកុំឲ្យមានរោគ ប្រសូតបុត្តកុំឲ្យមានរោគ ។ បទថា* **សហ វជនា** *បានដល់ ជំណាលគ្នានឹងព្រះតម្រាស់របស់ព្រះមានព្រះភាគនោះឯង ក្នុងគ្រាដែលព្រះមានព្រះភាគត្រាស់ដូច្នោះនោះឯង កម្មនោះក៏ដល់នូវការអស់ទៅ ព្រះសាស្តាទ្រង់ប្រមើលមើលថា កម្មនោះ អស់ទៅហើយ ទើបត្រាស់យ៉ាងនោះ ។ ឯអាចារ្យមួយពួកទៀតពោលថា បើមិនត្រាស់យ៉ាងនោះសោត បន្តអំពីនោះ សេចក្តីទុក្ខនោះ នឹងជាប់តាមព្រះនាងទៅអស់កាលតិចតួច តែព្រោះព្រះមានព្រះភាគត្រាស់ថា ចូរនាងមានសេចក្តីសុខ មិនមានរោគ និងប្រសូតព្រះឱរសដែលមិនមានរោគចុះ ដូច្នោះ ជំណាលគ្នានឹងព្រះតម្រាស់របស់ព្រះមានព្រះភាគនោះឯង គកិនោះ ក៏ជ្រុសចាកការឈឺចាប់ ប្រសូតដោយងាយស្រួលនោះឯង ។ ព្រះមាតា និងព្រះឱរសទាំង ២ នោះ មានសួស្តី ដោយប្រការដូច្នេះ សេចក្តីពិត ពុទ្ធានុភាពរបស់ព្រះពុទ្ធទាំងឡាយ ជាអចិន្តេយ្យ ប្រៀបដូចនាងបជាបតីដល់នូវភាពឆ្ងួត ព្រោះសេចក្តីសោក ដែលកើតអំពីសត្វ និងសង្ខារជាទីស្រឡាញ់ មានការរូបដូចពេលកើត (អាក្រាត) ត្រាច់ពោលថា*

ឧភោ បុត្តា កាលកតា បន្តេ មយ្ហំ បតី មតោ

មាតា បិតា ច ភាតា ច ឯកចិតកស្មឹ ឈាយរេ។

កូនទាំង ២ ក៏ស្លាប់ ប្តីរបស់ខ្ញុំក៏ស្លាប់ត្រង់កណ្តាលអធ្ងន់

មាតា បិតា និងបងប្រុស គេដុតក្នុងជើងភ្នំតែមួយ ។

ក្នុងខណៈដែលព្រះមានព្រះភាគត្រាស់ថា ម្នាលប្អូនស្រី ចូរនាងបាននូវស្មារតីឡើងនោះឯង ការឆ្កួតក៏បាត់ទៅ យ៉ាងណា សូម្បីនាងសុប្បិយោឧបាសិកាក៏ដូចគ្នា កាលមិនអាចឲ្យដំបៅធំដែលខ្លួនឯងធ្វើ ត្រង់ភ្លៅរបស់ខ្លួនជាសះស្បើយ ទើបដេកលើគ្រែ កាលដំបៅជាជាប្រក្រតីក្នុងខណៈដែលទ្រង់ត្រាស់ថា ចូរនាងមកថ្វាយបង្គំតថាគតចុះ ខ្លួនឯងក៏ទៅថ្វាយបង្គំព្រះមានព្រះភាគ សរុបសេចក្តីថា រឿងមានជាដើមដូចពោលនេះ គប្បីលើកឡើងពោលក្នុងទីនេះឯង ។

បទថា **ឯវំ ភន្តេ** *សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនោះ ដូចព្រះតម្រាស់ដែលព្រះមានព្រះភាគ កាលទ្រង់បំណងនូវការដែលព្រះនាង មួយអន្ទើនឹងព្រះឱរសមិនមានរោគ ទើបត្រាស់ថា ចូរនាងមានសេចក្តីសុខ ប្រាសចាករោគ ប្រសូតព្រះឱរសប្រាសចាករោគនោះឯង ។ អធិប្បាយថា ក្នុងកាលណាមួយ ព្រះតម្រាស់ព្រះមានព្រះភាគ មិនប្រព្រឹត្តទៅដទៃឡើយ ។ ចំណែកអាចារ្យពួកខ្លះពោលថា* **ឯវមត្តុ** *ប្រែថា ចូរសម្រេចយ៉ាងនោះចុះ អាចារ្យមួយពួកទៀត នាំយកអត្ថនៃបទថា* **ហោតុ** *ចូរសម្រេចចុះ មកពណ៌នា ។ បទថា* **អភិនន្ទិត្វា** *សេចក្តីថា ត្រេកអរចំពោះព្រះកក្រ ដោយ*

បានទទួលបីតិ និងសោមនស្ស ក្នុងកាលព្រះមានព្រះភាគ មានព្រះសូរសៀង មានព្រះតម្រាស់ផ្អែមល្អែម ដូចសំឡេងសត្វកវិក ដែលកំពុងត្រាស់នោះឯង ។ បទថា **អនុមោទិត្វា** *សេចក្តីថា បន្ទាប់អំពីនោះ ក៏ធ្វើឲ្យកើតការត្រេកអរ គឺត្រេកអរដោយចិត្ត ហើយអនុមោទនាដោយវាចា ឬត្រេកអរដោយការសម្បូរនៃព្រះតម្រាស់ ហើយត្រេកអរតាម ដោយការសម្បូរនៃប្រយោជន៍ ។ បទថា* **សកំ ឃរំ បច្ចាយាសិ** *បានដល់ ទ្រង់យាងត្រឡប់អំពីដំណាក់របស់ព្រះអង្គ ។ លោកអាចារ្យអ្នកស្វាធ្យាយ សូធ្យថា* **យេន សកំ ឃរំ** *គឺពោលបទថា* **តេន** *ព្រោះ* **យ ត** *ភ្ជាប់គ្នា តែទោះជាដូច្នោះ គប្បីប្រកបបាលីដ៏សេសថា* **បដិយាយិត្វា** *ប្រែថា ត្រឡប់ ។ បទថា* **វិជាតំ** *បានដល់ ប្រសូត អធិប្បាយថា កើតកូន ។ បទថា* **អច្ឆរិយំ** *សេចក្តីថា ឈ្មោះថា គួរអស្ចារ្យ ព្រោះមិនមានជានិច្ច ដូចមនុស្សក្អែកខ្វាក់ខ្លឹងភ្នំ ។ អត្ថនៃសព្ទមានប្រមាណប៉ុណ្ណេះ ។ តែក្នុងអដ្ឋកថាពោលថា ឈ្មោះថា គួរអស្ចារ្យ ព្រោះគួរដល់ការទះដៃ អធិប្បាយថា គួរដល់ការផ្គាត់ម្រាមដៃ ។ សព្ទថា* **វត** *ប្រើក្នុង* **សម្ភាវន** *អធិប្បាយថា គួរអស្ចារ្យពិត ។ បទថា* **ភោ** *ជាពាក្យហៅធម្មតា ។ ឈ្មោះថា* **អព្ភូត** *ព្រោះមិនធ្លាប់មាន ។*

បទថា **តថាគតស្ស** *សេចក្តីថា ព្រះមានព្រះភាគ ឈ្មោះថា តថាគត ដោយហេតុ ៨ ប្រការ គឺឈ្មោះថា តថាគត ព្រោះទ្រង់យាងមកយ៉ាងនោះ ឈ្មោះថា តថាគត ព្រោះយាងទៅយ៉ាងនោះ ឈ្មោះថា តថាគត ព្រោះយាងមកកាន់លក្ខណៈដែលពិត ឈ្មោះថា តថាគត ព្រោះត្រាស់ដឹងប្រពៃនូវ*

ធម៌ពិតតាមសេចក្តីពិត ឈ្មោះថា តថាគត ព្រោះទ្រង់ឃើញធម៌ដែលពិត ឈ្មោះថា តថាគត ព្រោះមានព្រះតម្រាស់ពិត ឈ្មោះថា តថាគត ព្រោះទ្រង់ធ្វើយ៉ាងនោះ ឈ្មោះថា តថាគត ព្រោះអត្ថថា គ្របសង្កត់នូវសត្វទាំងពួង ។

សួរថា ហេតុអ្វី ទើបព្រះមានព្រះភាគ ឈ្មោះថា តថាគត ព្រោះទ្រង់យាងមកយ៉ាងនោះ ឆ្លើយថា ព្រះសម្មាសម្ពុទ្ធទាំងឡាយក្នុងកាលមុន ដែលជល់នូវការខ្វល់ខ្វាយ ព្រោះយាងមកដើម្បីជាប្រយោជន៍ដល់លោកទាំងពួង អធិប្បាយដូចម្តេច អធិប្បាយថា ព្រះមានព្រះភាគអង្គនេះ យាងមកដោយអភិនីហារ ៨ ប្រការ ដែលជាគ្រឿងយាងមករបស់ព្រះមានព្រះភាគទាំងឡាយនោះ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគអង្គនោះ ទ្រង់បំពេញបារមី ៣០ គឺទ្រង់បំពេញទានបារមី សីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី ឧបេក្ខាបារមី រួមបារមីទាំងនេះ ចាត់ជាបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ ទ្រង់បរិច្ចាគមហាបរិច្ចាគ ៥ និងទ្រង់បំពេញបុព្វបយោគ បុព្វចរិយា ការត្រាស់ធម្មទេសនា និងញាតត្ថចរិយាជាដើម ហើយទ្រង់ដល់នូវទីបំផុតនៃពុទ្ធចរិយាយាងមកហើយ ដោយប្រការណា ព្រះមានព្រះភាគអង្គនោះ ក៏យាងមកដោយប្រការនោះ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់បំពេញសតិប្បដ្ឋាន ៤ ។បេ។ អរិយមគ្គមានអង្គ ៨ យាងមកដោយប្រការណា ព្រះមានព្រះភាគអង្គនេះក៏យាងមក ដោយប្រការនោះ។ ឈ្មោះថា តថាគត ព្រោះយាងមក

យ៉ាងនោះ ដោយប្រការដូច្នេះ ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា តថាគត ព្រោះយាងទៅដោយប្រការនោះដូចម្តេច ឆ្លើយថា ព្រះមានព្រះភាគទាំងឡាយ ទ្រង់កើតឡើងក្នុងមនោះឯង ប្រថាប់ឈរដោយព្រះយុគលបាទទាំង ២ បែរព្រះភក្ត្រទៅទិសឧត្តរ យាងទៅបាន ៧ ជំហាន កាលទេវតាជាំងស្វេតច្ឆត្រ ទ្រង់សម្លឹងមើលគ្រប់ទិស ទ្រង់បន្ទឺនូវអាសភិវាចា ហើយព្រះមានព្រះភាគអង្គនោះ កាលប្រកាសដល់ភាពដែលទ្រង់ជាអ្នកចម្រើនបំផុត និងប្រសើរបំផុតក្នុងលោក ទើបមានការយាងទៅយ៉ាងពិត មិនខុស ព្រោះជាបុព្វនិមិត្តនៃការសម្រេចគុណវិសេសដ៏ច្រើន ដោយប្រការណា ព្រះមានព្រះភាគអង្គនោះ ក៏យាងទៅដោយប្រការនោះ ហើយការយាងទៅរបស់ទ្រង់នោះ ជាការយាងទៅដោយពិត មិនខុស ព្រោះជាបុព្វនិមិត្ត នៃការសម្រេចគុណវិសេសទាំងនោះដូចគ្នា ។ ឈ្មោះថា តថាគត ព្រោះយាងទៅដោយប្រការនោះយ៉ាងនេះ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគទាំងឡាយនោះ ទ្រង់លះកាមច្ឆន្ទៈដោយនេក្ខម្មៈ ហើយយាងទៅ លះព្យាបាទដោយមិនព្យាបាទ លះថីនមិទ្ធៈដោយអាលោក-សញ្ញា លះឧទ្ធច្ចកុក្កុច្ចៈដោយការមិនរាយមាយ លះវិចិកិច្ឆាដោយការកំណត់ធម៌ យាងទៅទម្លាយអវិជ្ជាដោយព្រះញាណ បន្ទោបង់នូវការមិនត្រេកអរដោយបាមោជ្ជ លះធម៌ដែលជាបដិបក្ខនោះៗ ដោយសមាបត្តិ ៨ ដោយមហាវិបស្សនា ១៨ និងដោយអរិយមគ្គ ៤ យាងទៅ យ៉ាងណា សូម្បីព្រះមានព្រះភាគក៏យាងទៅយ៉ាងនោះ ឈ្មោះថា តថាគត ព្រោះយាងទៅដោយ

ប្រការនោះ ដោយប្រការដូច្នេះ ។

ឈ្មោះថា តថាគត ព្រោះយោងមកកាន់លក្ខណៈពិតដូចម្តេច ឆ្លើយថា ឈ្មោះថា តថាគត ព្រោះទ្រង់មានញាណគតិ យាងមកដល់ គឺសម្រេចមិនខុសក្លាំងក្លាត់នូវលក្ខណៈដែលពិត មិនខុស មិនប្រែប្រួលទៅជាដទៃ មានធម៌នោះៗ ជាសភាវៈ មួយអន្លើដោយកិច្ចជាលក្ខណៈយ៉ាងនេះ គឺបឋវីធាតុមានការរឹងជាលក្ខណៈ អាបោធាតុមានការហូរទៅជាលក្ខណៈ តេជោធាតុមានការក្តៅជាលក្ខណៈ វាយោធាតុមានការបក់កម្រើកជាលក្ខណៈ អាកាសធាតុមានការពាល់ត្រូវមិនបានជាលក្ខណៈ រូបមានការប្រែប្រួលជាលក្ខណៈ វេទនាមានការសោយជាលក្ខណៈ សញ្ញាមានការចាំជាលក្ខណៈ សង្ខារមានការតាក់តែងជាលក្ខណៈ វិញ្ញាណមានការដឹងច្បាស់ជាលក្ខណៈ រួមសេចក្តីថា បានដល់ ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ឥន្ទ្រិយ ២២ សច្ចៈ ៤ បច្ចយាការ ១២ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ វិសុទ្ធិ ៧ និងនិព្វាន ១ ឈ្មោះថា តថាគត ព្រោះយាងមកកាន់លក្ខណៈពិត ដោយប្រការដូច្នេះ ។

ឈ្មោះថា តថាគត ព្រោះត្រាស់ដឹងប្រពៃក្រៃលែងនូវធម៌ពិតតាមសេចក្តីពិតដូចម្តេច គឺឈ្មោះថា ធម៌ពិត បានដល់ អរិយសច្ច ៤ សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ យ៉ាងនេះ ជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ធម្មជាត ៤ គឺអ្វីខ្លះ ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះជាទុក្ខ នុ៎ះជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយ

ទៅជារបស់ដទៃទៀតឡើយ ដូច្នេះជាដើម ។ សេចក្តីពិស្តារហើយ ។ ព្រះមានព្រះភាគ ត្រាស់ដឹងក្រៃលែងនូវអរិយសច្ចទាំង ៤ នោះ ព្រោះដូច្នោះ ទើបឈ្មោះថា តថាគត ព្រោះត្រាស់ដឹងអរិយសច្ច ៤ នោះ យ៉ាងពិត ។ ម្យ៉ាងទៀត អត្តដែលជរា និងមរណៈកើត និងប្រព្រឹត្តទៅព្រោះជាតិជាបច្ច័យ ជាសភាវៈពិត មិនខុស មិនក្លាយទៅជាដទៃ ។បេ។ អត្តដែលសង្ខារកើត និងប្រព្រឹត្តទៅព្រោះអវិជ្ជាជាបច្ច័យ ជាសភាវៈពិត មិនខុស មិនវិបរិត អត្តដែលអវិជ្ជាជាបច្ច័យនៃសង្ខារក៏ដូចគ្នា ។បេ។ អត្តដែលជាតិជាបច្ច័យនៃជរា និងមរណៈក៏ដូចគ្នា ជាសភាវៈពិត មិនខុស មិនក្លាយទៅជាដទៃ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹងនូវធម៌ទាំងអស់នោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគព្រះនាមថា តថាគត ព្រោះជាអ្នកត្រាស់ដឹងក្រៃលែងនូវអរិយសច្ច ៤ យ៉ាងដោយពិត ។ ពិតហើយ **គត** *សព្ទ ក្នុងបទថា* **តថាគតោ** *នេះ មានអត្តថា ត្រាស់ដឹងក្រៃលែង ។ ឈ្មោះថា តថាគត ព្រោះត្រាស់ដឹងធម៌ពិតតាមសេចក្តីពិត ដោយប្រការដូច្នេះ ។*

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** *ព្រោះទ្រង់មានប្រក្រតីឃើញអារម្មណ៍ដែលពិតដូចម្តេច ឆ្លើយថា អារម្មណ៍ណា ដែលឈ្មោះថារូបារម្មណ៍ ដែលមកប្រាកដក្នុងចក្ខុទ្វាររបស់សត្វទាំងឡាយ មិនមានប្រមាណ មានទាំងក្នុងលោក និងទាំងទេវលោក ។បេ។ ក្នុងពួកសត្វ ព្រមទាំងទេវលោក និងមនុស្ស ក្នុងលោកធាតុមិនមានប្រមាណ អារម្មណ៍នោះ ព្រះមានព្រះភាគទ្រង់ដឹង គឺទ្រង់ឃើញ ដោយអាការទាំងអស់ ។*

*អារម្មណ៍នោះ ព្រះមានព្រះភាគ ទ្រង់ដឹង និងទ្រង់ឃើញយ៉ាងនេះ ចែកចេញទៅតាមឈ្មោះជាអនេក តាមវារៈ ១៣ វារៈ តាមនយ ៥២ នយ ដោយនយជាដើមថា រូប គឺរូបាយតនៈនោះដូចម្តេច ។ រូបណាដែលអាស្រ័យមហាភូតរូប ៤ ជារូបដែលមានវណ្ណៈ គឺពណ៌ មើលឃើញបាន ពាល់ត្រូវបានជារូបពណ៌ខៀវ ជារូបពណ៌លឿង ដោយអំណាចជារូបដែលគួរជ្រាបថ្នា និងមិនគួរជ្រាបថ្នាជាដើម ដោយអំណាចដែលនឹងបានក្នុងរូបដែលបានឃើញ សំឡេងដែលបានឮ ក្លិន រស ផោដ្ឋព្វៈដែលបានជ្រាប និងធម្មារម្មណ៍ដែលបានដឹងច្បាស់ រមែងជារបស់ពិតនោះឯង មិនប្រែប្រួល ។ ក្នុងសទ្ទារម្មណ៍ជាដើមដែលមកប្រាកដក្នុងសោតទ្វារជាដើម ក៏នយនេះ ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដែលពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សជ័សេស ឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ត្រាច់រង្គាត់រកអារម្មណ៍នោះ តថាគតបានដឹងជាក់ស្តែងហើយដោយសាវចិត្ត ព្រោះហេតុនោះ បានជាគេហៅថា តថាគត ។ ឈ្មោះថា តថាគត ព្រោះទ្រង់ឃើញពិតដោយប្រការដូច្នេះ ។ បទថា **តថាគតោ** គប្បីជ្រាបថា ជាបទប្រើក្នុងអត្ថថា ទ្រង់ឃើញពិត ។*

ឈ្មោះថា តថាគត ព្រោះមានវាទៈពិតដូចម្តេច គឺព្រះមានព្រះភាគត្រាស់ដឹងដ៏ក្រៃលែងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងចំណែកនៃរាត្រីណា

ហើយ ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងរាត្រីណា រវាងនេះ មានកាលប្រមាណ ៤៥ ព្រះវស្សា ព្រះមានព្រះភាគត្រាស់សុត្តៈ និងគេយ្យៈ ជាដើមណា ទាំងអស់នោះ បរិសុទ្ធបរិបូណ៌ កម្ចាត់នូវការស្រវឹង ព្រោះរាគៈ ជាដើមបាន ដូចគ្នាតែមួយពិត មិនខុស ។ ដោយហេតុនោះ ទើបទ្រង់ត្រាស់ ថា ម្នាលចុន្ទ តថាគតត្រាស់ដឹងនូវសម្មាសម្ពោធិដ៏ប្រសើរ ក្នុងវេលាយប់ ណាផង បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងវេលាយប់ណាផង រមែងសម្តែងហៅ ចង្អុលបង្ហាញនូវហេតុណា ក្នុងចន្លោះនុ៎ះ ហេតុទាំងអស់ នោះ សុទ្ធតែពិត មិនមែនត្រឡប់ទៅជាដទៃឡើយ ហេតុដូច្នោះហើយ បាន ជាគេហៅថា ព្រះតថាគត ។ **គត** *សព្ទ ក្នុងបទថា* **តថាគតោ** *នេះ មាន អត្ថថា* **គឧ** *ប្រែថា ត្រាស់ ។ ឈ្មោះថា តថាគត ព្រោះមានវាទៈពិត ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត* **អាគឧឧ** *គឺ* **អាគឧ** *អធិប្បាយថា ត្រាស់ ។ ក្នុងបទនេះ គប្បីជ្រាបបទសម្រេចរូប យ៉ាងនេះថា ឈ្មោះថា តថាគត ព្រោះផ្លាស់* **ឧ** *អក្ខរៈ ជា* **ត** *អក្ខរៈ ព្រោះអត្ថថា ទ្រង់មាន ព្រះតម្រាស់យ៉ាងពិត គឺមិនប្រែប្រួល ។*

ឈ្មោះថា តថាគត ព្រោះទ្រង់ធ្វើយ៉ាងនោះដូចម្តេច គឺសេចក្តីពិត ព្រះ កាយរបស់ព្រះមានព្រះភាគ ស្របតាមព្រះវាចា ព្រះវាចាស្របតាមកាយ ព្រោះដូច្នោះ ទើបទ្រង់ជា **យថាវាទី តថាការី** *គឺត្រាស់យ៉ាងណា ធ្វើយ៉ាង នោះ និងជា* **យថាការី តថាវាទី** *គឺទ្រង់ធ្វើយ៉ាងណា ត្រាស់យ៉ាងនោះ អធិប្បាយថា វាចាក្តី ព្រះកាយរបស់ទ្រង់ក្តី យ៉ាងនោះ រមែងមានដោយ*

ប្រការណា ទ្រង់ប្រព្រឹត្តទៅ គឺប្រព្រឹត្តទៅដោយប្រការនោះ ។ ម្យ៉ាងទៀត ព្រះកាយប្រព្រឹត្តទៅយ៉ាងណា ព្រះវាចាក៏ត្រាស់ទៅ គឺប្រព្រឹត្តទៅយ៉ាងនោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា តថាគត ។ ដោយហេតុនោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ពោលយ៉ាងនោះ រួមសេចក្តីថា ទ្រង់ជា **យថាវាទី តថាការី** និង **យថាការី តថាវាទី** ព្រោះដូច្នោះ ទើបហៅថា តថាគត ។ ឈ្មោះថា តថាគត ព្រោះធ្វើយ៉ាងនោះ ដោយប្រការដូច្នេះ ។

ឈ្មោះថា តថាគត ព្រោះអត្ថថា គ្របសង្កត់ដូចម្តេច គឺព្រះអង្គ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ធ្វើភវគ្គព្រហ្មខាងលើ រហូតដល់អវីចីមហានរកខាងក្រោម ត្រង់ទទឹង ក៏ទ្រង់គ្របសង្កត់សព្វសត្វក្នុងលោកធាតុ មិនមានប្រមាណ ដោយសីលខ្លះ សមាធិខ្លះ បញ្ញាខ្លះ វិមុត្តិខ្លះ វិមុត្តិញ្ញាណ-ទស្សនៈខ្លះ ទ្រង់ថ្លឹងមិនបាន ប្រមាណមិនបានដោយពិត ទ្រង់ជាបុគ្គលដែលបុគ្គលណាម្នាក់ ថ្លឹងមិនបាន ប្រមាណមិនបាន ជាទេវតា ក្រៃលែងជាងទេវតា ជាសក្កៈក្រៃលែងជាងសក្កៈ ជាព្រហ្មក្រៃលែងជាងព្រហ្ម ជាបុគ្គលឧត្តមជាងសព្វសត្វ ។ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកគ្របសង្កត់ អង់អាច ជាអ្នកឃើញពិត មានអំណាចគ្របសង្កត់លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសបាន ហេតុនោះ បានជាគេហៅថា តថាគត ។ ក្នុងសេចក្តីនោះ មាន

បទសម្រេចរូបដូចតទៅនេះ ព្រះតម្រាស់របស់ព្រះអង្គ ដូចឱសថវិសេស ជានដល់ ទេសនាវិលាស និងការសន្សំបុណ្យ ដោយហេតុនោះ ទើបទ្រង់ គ្រប់សង្កត់បុគ្គលដែលជាបរប្បវាទទាំងអស់ និងលោក ព្រមទាំងទេវលោក ដូចពេទ្យដែលមានអានុភាពច្រើន ប្រើថ្នាំទិព្វ បង្ក្រាបពស់ទាំងឡាយ ព្រោះ ហេតុនោះ ទើបថ្វាយព្រះនាមថា តថាគត ព្រោះផ្លាស់ **ឧ** *អក្ខរៈឲ្យជា* **ត** *អក្ខរៈ ដោយអត្ថថា ទ្រង់មានព្រះតម្រាស់ពិត មិនប្រែប្រួល តាមដែលពោល មកហើយ ព្រោះគ្រប់សង្កត់សព្វសត្វបាន ។ ឈ្មោះថា តថាគត ព្រោះអត្ថ ថា គ្រប់សង្កត់សព្វសត្វ ដោយប្រការដូច្នេះ ។*

ម្យ៉ាងទៀត ឈ្មោះថា តថាគត ព្រោះយាងទៅ ដោយប្រការនោះ ។ ឈ្មោះថា តថាគត ព្រោះយាងទៅដោយពិត ។ ក្នុងបទថា **តថាគតោ** *នោះ ឈ្មោះថា តថាគត ព្រោះយាងជល់ គឺសម្រេចលោកទាំងមូលដោយពិត ដោយតីរណប្បរិញ្ញា ឈ្មោះថា តថាគត ព្រោះយាងទៅ គឺឈានកន្ទងលោក-សមុទយៈដោយពិត ដោយបហានប្បរិញ្ញា ។ ឈ្មោះថា តថាគត ព្រោះយាង ជល់ គឺសម្រេចលោកនិរោធដោយពិត ដោយសច្ឆិកិរិយា ឈ្មោះថា តថាគត ព្រោះយាងទៅ គឺបដិបត្តិលោកនិរោធគាមិនីបដិបទាដោយពិត ។ សមដូច ព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោក (គឺ ទុក្ខសច្ច) តថាគតបានត្រាស់ដឹងហើយ តថាគតផុតចាកលោក (គឺទុក្ខ-សច្ច) ហើយ ម្នាលភិក្ខុទាំងឡាយ លោកសមុទយៈ តថាគតបានត្រាស់ ដឹងហើយ លោកសមុទយៈ តថាគតបានលះបង់ហើយ ម្នាលភិក្ខុទាំងឡាយ*

លោកនិរោធ តថាគតបានត្រាស់ដឹងហើយ លោកនិរោធ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធគាមិនីបដិបទា តថាគតបានត្រាស់ដឹងហើយ លោកនិរោធគាមិនីបដិបទា តថាគតបានចម្រើនហើយ ព្រោះដូច្នោះ ទើបបានទទួលព្រះនាមថា **តថាគត។**

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះហេតុ ៨ ប្រការដទៃទៀត គឺឈ្មោះថា តថាគត ព្រោះយាងមកដោយប្រការនោះ ១ ឈ្មោះថា តថាគត ព្រោះយាងទៅដោយប្រការនោះ ១ ឈ្មោះថា តថាគត ព្រោះមកដល់សច្ចៈយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះយាងទៅយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះមានប្រការយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះមានការប្រព្រឹត្តទៅដោយប្រការយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះត្រាស់ដោយព្រះញាណយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះភាវៈដែលយាងទៅយ៉ាងនោះ ១ ។

ឈ្មោះថា តថាគត ព្រោះយាងមកដោយប្រការនោះដូចម្តេច គឺព្រះមានព្រះភាគ កាលជាសុមេធតាបស បំពេញអភិនីហារដែលប្រកបដោយអង្គ ៨ ប្រការ ទៀបបាទមូលរបស់ព្រះទសពល ព្រះនាមទីបង្กរ ដូចដែលលោកពោលយ៉ាងនេះថា

មនុស្សត្តំ លិង្គសម្បត្តិ ហេតុ សត្ថារទស្សនំ
បព្វជ្ជា គុណសម្បត្តិ អធិការោ ឆន្ទតា
អដ្ឋធម្មសមោធានា អភិនីហារោ សមិជ្ឈតិ។

អភិនីហារមែងសម្រេច ព្រោះសមោធានធម៌ ៨ ប្រការ គឺភាពជាមនុស្ស ១ ភាពជាអ្នកសម្បូរដោយភេទ ១ ហេតុ ១ ការបានឃើញព្រះសាស្តា ១ ការចេញបព្វជ្ជា ១ ការសម្បូរដោយគុណធម៌ ១ បុញ្ញាធិការ ១ ភាពជាអ្នកមានឆន្ទៈ ១ ។

ទ្រង់ប្រកាសមហាប្តេជ្ញាថា អាត្មាអញឆ្លងនូវលោក ព្រមទាំងទេវលោក បានហើយ និងញុំាងសត្វឲ្យឆ្លង អាត្មាអញរួចផុតហើយ និងញុំាងសត្វឲ្យរួចផុត អាត្មាអញទូន្មានខ្លួនហើយ និងទូន្មានអ្នកដទៃ អាត្មាអញស្ងប់ហើយ និងឲ្យអ្នកដទៃស្ងប់ អាត្មាអញធូរស្បើយចិត្តហើយ និងឲ្យអ្នកដទៃធូរស្បើយ អាត្មាអញបរិនិព្វានហើយ និងឲ្យអ្នកដទៃបរិនិព្វាន អាត្មាអញត្រាស់ដឹងហើយ និងឲ្យអ្នកដទៃត្រាស់ដឹង សមដូចព្រះតម្រាស់ត្រាស់ថា

ប្រយោជន៍អ្វីអាត្មាអញជាបុរស សម្តែងកម្ចាំងឆ្លងទៅម្នាក់ឯង អាត្មាអញគួរជល់នូវសព្វញ្ញុតញ្ញាណ ចម្ងងមនុស្ស-លោក ព្រមទាំងទេវលោក ។

អាត្មាអញ នឹងបានជល់នូវសព្វញ្ញុតញ្ញាណ ចម្ងងប្រជុំជនច្រើន ដោយអធិការនេះ ដែលអាត្មាអញធ្វើចំពោះព្រះពុទ្ធជាបុរសខ្ពង់ខ្ពស់ ។ តថាគតនឹងកាត់ខ្សែសង្សារ កម្ចាត់បង់ភពទាំង ៣ ឡើងជិះលើនាវា គឺធម៌ នឹងចម្ងងមនុស្សលោក ព្រមទាំងទេវលោក ដូច្នេះ ។

ព្រះមានព្រះភាគ ជាលោកនាថ កាលគ្រាស់មហាប្តេជ្ញានេះ ដែលជាហេតុនៃការត្រិះរិះពិចារណា និងការសមាទានពួកធម៌ ធ្វើភាពជាពុទ្ធៈទាំងអស់ មិនឲ្យញាប់ញ័រ ព្រោះទ្រង់បំពេញបារមី ៣០ មានទានបារមីជាដើមបានយ៉ាងហ្មត់ចត់ ជាប់តគ្នាដោយគោរព ទ្រង់បរិច្ចាគមហាបរិច្ចាគ ៥ មានការបរិច្ចាគអវយវៈជាដើម ចម្រើនន្ទវអធិដ្ឋាន ៤ មានសច្ចាធិដ្ឋានជាដើម ទ្រង់បំពេញបុញ្ញសម្ភារ និងញាណសម្ភារ ទ្រង់ឲ្យបុព្វប្បយោគ បុព្វចរិយា ធម្មកថា និងញាតត្ថចរិយាជាដើម ឲ្យឧក្រិដ្ឋ ឲ្យពុទ្ធចរិយាដល់ទីបំផុតយ៉ាងក្រៃលែងអស់ ៤ អសង្ខ្យេយ្យ និងមួយសែនមហាកប្ប ទើបសម្រេចអនុត្តរសម្មាសម្ពោធិញ្ញាណ ដូច្នោះ ទើបមហាប្តេជ្ញារបស់ទ្រង់នោះឯងជារបស់ពិត មិនខុស មិនវិបរិត ការខុសភ្លាំងភ្លាត់របស់ទ្រង់ត្រឹមតែមួយចុងរោមទ្រាយមិនមាន ។ ពិតហើយ ព្រះសម្មាសម្ពុទ្ធ ២៤ អង្គ គឺព្រះទីបង្ករទសពល ព្រះកោណ្ឌញ្ញៈ ព្រះមង្គលៗបេៗ ព្រះមានព្រះភាគកស្សប ទ្រង់កើតឡើងដោយលំដាប់ ទ្រង់ព្យាករថា នឹងបានជាព្រះពុទ្ធ ទ្រង់បានទទួលព្យាករក្នុងសម្នាក់របស់ព្រះពុទ្ធ ២៤ ព្រះអង្គ ដោយប្រការដូច្នេះហើយ ទ្រង់បានទទួលអានិសង្សដែលព្រះពោធិសត្វបានបំពេញអភិនីហារ ដែលគប្បីបានទទួលនោះឯង យាងមកហើយ ព្រោះដូច្នោះ ទើបឈ្មោះថា តថាគត ព្រោះយាងមក គឺសម្រេចភាពជាអ្នកត្រាស់ដឹងក្រៃលែង ដោយមហាប្តេជ្ញាដែលត្រាស់នោះ ។ ឈ្មោះថា តថាគត ព្រោះយាងមក ដោយប្រការដូច្នោះ យ៉ាងនេះឯង ។

ឈ្មោះថា តថាគត ព្រោះយាងទៅ ដោយប្រការនោះដូចម្តេច គឺព្រះ-

លោកនាថ ទ្រង់ឃើញពួកសត្វដែលប្រព្រឹត្តទៅលំបាក ព្រោះទុក្ខធំ ទ្រង់មាន ព្រះមានសៈ ដែលព្រះមហាករុណាជាស់តឿនឡើងថា ពួកសត្វនោះមិនមាន អ្នកដទៃជាទីពឹង អាត្មាអញប៉ុណ្ណោះ ផុតចាកសង្សារទុក្ខនេះហើយ និងញុំង សត្វទាំងឡាយឲ្យផុតផង ទើបទ្រង់ធ្វើមហាអភិនីហារ ហើយទ្រង់ដល់នូវ ភាពឧស្សាហ៍ដែលឲ្យសម្រេចប្រយោជន៍ដល់លោកទាំងមូល តាមដែលទ្រង់ បានតាំងបណិធាន ទ្រង់មិនជាប់ជំពាក់ព្រះកាយ និងព្រះជន្មរបស់ព្រះអង្គ ទ្រង់បំពេញទុក្ករកិរិយា ដែលធ្វើបានលំបាក ធ្វើការសង្វេគនៃចិត្តឲ្យកើត ឡើង ដោយហេតុត្រឹមតែឮនៃជនដទៃ ទ្រង់ប្រព្រឹត្តទៅដោយបដិបទា ដើម្បី មហាពោធិញ្ញាណ ដែលមិនជាហានភាគិយ គឺចំណែកនៃការលះ សង្កិលេស-ភាគិយ គឺ ចំណែកនៃការសៅហ្មង និងឋិតិភាគិយ គឺចំណែកនៃការតាំងមាំ ដោយពិត ជាវិសេសភាគិយដ៏កំពូលពិត ទ្រង់សម្រេចពោធិសម្ភារដោយ លំដាប់ ទើបទ្រង់សម្រេចអភិសម្ពោធិញ្ញាណ ខាងមុខអំពីនោះ ទ្រង់មានព្រះ មានសៈដែលព្រះមហាករុណានោះឯងជាស់តឿន ទ្រង់លះការត្រេកអរ ក្នុង ការស្ងាត់ និងសេចក្តីសុខ ដែលកើតអំពីវិមោក្ខដ៏ស្ងប់ក្រៃលែង មិនត្រិះរិះដល់ ប្រការដែលមិនសមគួរ ដែលសត្វលោកដ៏ច្រើន មួយអន្លើដោយពាលជន ឲ្យកើតឡើង ទ្រង់សម្រេចពុទ្ធកិច្ចសព្វគ្រប់ ដោយការទូន្មានជនដែលគួរ ទូន្មាន ក្នុងសេចក្តីនោះ អាការដែលព្រះមានព្រះភាគ ញុំងមហាករុណាឲ្យ ធ្លាក់ចុះក្នុងពួកសត្វនោះ នឹងមានច្បាស់ខាងមុខ ។ ព្រះលោកនាថ ដ៏ជា សម្ពុទ្ធ មានព្រះមហាករុណាក្នុងសត្វទាំងឡាយ យ៉ាងណា ព្រះពោធិសត្វក៏

ដូច្នោះ ទ្រង់មានមហាករុណាក្នុងពួកសត្វ ក្នុងកាលបំពេញអភិនីហារជាដើម ព្រោះហេតុនោះ ទើបព្រះមហាករុណារបស់ព្រះអង្គ ឈ្មោះថា ពិត មិនខុស មិនក្លាយជាជំទៃ ព្រោះមានភាវៈស្មើគ្នា ក្នុងទីគ្រប់អន្លើ និងក្នុងកាល គ្រប់កាល ។ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា តថាគត ព្រោះយាងទៅ គឺ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដល់សត្វលោកទាំងមូល ដោយព្រះមហា-ករុណា ដែលពិត មានកិច្ចស្មើគ្នាក្នុងសព្វសត្វទាំងឡាយ ក្នុងកាលទាំង ៣ ។ ឈ្មោះថា តថាគត ព្រោះយាងទៅ ដោយប្រការនោះ យ៉ាងនេះ ។

ឈ្មោះថា តថាគត ព្រោះយាងមកដល់សច្ចៈពិតដូចម្តេច គឺឈ្មោះថា ពិត បានដល់ អរិយមគ្គញ្ញាណ ។ ពិតហើយ អរិយមគ្គញ្ញាណទាំងនោះ ឈ្មោះថា ពិត មិនខុស មិនក្លាយទៅជាជំទៃ ព្រោះមិនពោលលក្ខណៈរបស់សភាវធម៌ មួយអន្លើដោយកិច្ចឲ្យឃ្លៀងឃ្លាតនៃធម៌ គឺអរិយសច្ច ៤ ដែលជាបវត្តិ និវត្តិ និងហេតុទាំង ២ នោះ ជាគ្រឿងរួបរួមញ្ញេយ្យធម៌ទាំងមូល យ៉ាងនេះថា នេះទុក្ខ នេះទុក្ខសមុទយៈ នេះទុក្ខនិរោធ នេះទុក្ខនិរោធគាមិនី-បដិបទា នេះជាវិភាគនៃអរិយសច្ចទាំង ៤ ជាដើមថា ទុក្ខ មានអត្ថថា បៀត បៀន មានអត្ថថា ជាសង្ខតៈ មានអត្ថថា ធ្វើឲ្យក្តៅក្រហាយ មានអត្ថថា ប្រែប្រួល សមុទយសច្ច មានអត្ថថា ប្រមូលមក មានអត្ថថា ជាហេតុ មានអត្ថថា ប្រកបសត្វក្នុងភព មានអត្ថថា កង្វល់ និរោធសច្ច មានអត្ថថា ជាហេតុរលាស់ចេញ មានអត្ថថា ស្ងាត់ មានអត្ថថា ដែលបច្ច័យណាមួយ តាក់តែងមិនបាន មានអត្ថថា ជាអមតៈ មគ្គសច្ច មានអត្ថថា នាំសត្វចេញ

មានអត្ថថា ជាហេតុ មានអត្ថថា ជាទស្សនៈ មានអត្ថថា ជាអធិបតី ដើម្បីការប្រព្រឹត្តទៅនៃអាការដែលមិនខុស ពោល គឺត្រាស់ដឹងដោយមិនវង្វេងក្នុងធម៌នោះ ដែលបានដោយការកាត់ផ្តាច់នូវធម៌ ដែលជាបក្ខពួកនៃសង្កិលេស ដែលជាហេតុរារាំងនូវការឈមចុះក្នុងសភាវៈតាមសេចក្តីពិត ព្រះមានព្រះភាគទ្រង់មិនមានអ្នកដទៃណែនាំទ្រង់ឡើយ ទ្រង់មកជល់ គឺសម្រេចអរិយសច្ច ៤ ដោយព្រះអង្គឯង ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា តថាគត ព្រោះយាងមកជល់សច្ចៈដែលពិត ។

គប្បីជ្រាបជល់ភាវៈដែលពិតនៃព្រះញាណ ដែលបច្ចយណាមួយ មិនប៉ះខ្ចប់ក្នុងកាលទាំង ៣ បដិសម្ភិទាញាណ ៤ វេសារជ្ជញ្ញាណ ៤ ញាណដែលកំណត់គតិ ៥ អសាធារណញ្ញាណ ៦ ញាណដែលជាក់ច្បាស់ក្នុងពោជ្ឈង្គ ៧ ញាណដែលជាក់ច្បាស់ក្នុងមគ្គ ៨ ញាណក្នុងអនុបុព្វវិហារ-សមាបត្តិ ៩ និងទសពលញ្ញាណ ១០ នៃព្រះមានព្រះភាគជាក់ច្បាស់ ដូចមគ្គញ្ញាណ ដូច្នោះ ក្នុងសេចក្តីនោះ មានសេចក្តីជាក់ច្បាស់ដូចតទៅនេះថា ពិតហើយ គប្បីជ្រាបវត្តុណានីមួយ ទោះជាសភាវកិច្ច ឬការប្លែកគ្នាក្នុងការកំណត់ និងនាមគោត្រ ដែលទាក់ទងដោយខន្ធជាដើម ក្នុងខន្ធ អាយតនៈ និងធាតុដែលជាអតីត មានហីនធម៌ជាដើម នៃសត្វទាំងឡាយ ដែលមិនមានប្រមាណក្នុងលោកធាតុ ដែលប្រមាណមិនបាន ។ ញាណទាំងនេះ គឺព្រះញាណរបស់ព្រះមានព្រះភាគ ដែលមិនមានបច្ចយណាមួយប៉ះពាល់ ប្រព្រឹត្តទៅដោយប្រចក្ស ក្នុងទីទាំងពួង ក្នុងសេចក្តីវិសេសនៃវណ្ណៈ សណ្ឋាន កិន

រស និងផស្សៈជាដើមនៃធម៌ ដែលកើតព្រោះបច្ច័យ និងសេចក្តីវិសេសនៃបច្ច័យនោះៗ ក្នុងរូបធម៌ដែលមិនទាក់ទងដោយឥន្ទ្រិយដែលល្អិតក្រៃលែង ដែលនៅខាងក្រៅជញ្ជាំង ដែលនៅក្នុងទីធ្លាយ ដូចផ្លែកន្ធតព្រៃ នៅលើបាតដៃជូច្នោះ ។ ឯព្រះញាណ ដែលប្រព្រឹត្តទៅក្នុងអនាគត និងបច្ចុប្បន្នក៏ដូចគ្នា ឈ្មោះថា ព្រះញាណដែលមិនមានបច្ច័យណាមួយប៉ះពាល់ក្នុងកាលទាំង ៣ ។ ដូចលោកពោលក្នុងបដិសម្ភិទាមគ្គថា ញាណរបស់ព្រះពុទ្ធ មិនមានអ្វីរារាំងក្នុងអតីតកាល ញាណរបស់ព្រះពុទ្ធ មិនមានអ្វីរារាំងក្នុងអនាគតកាល ញាណរបស់ព្រះពុទ្ធ មិនមានអ្វីរារាំងក្នុងបច្ចុប្បន្នកាល ។ អរិយសច្ច ៤ នេះ ឈ្មោះថា ពិត មិនខុស មិនវិបរិត ព្រោះមិនបានត្រាស់លក្ខណៈនៃសភាវៈមួយអន្ទៅដោយកិច្ចនៃធម៌ក្នុងទីនោះៗ ឲ្យឃ្លៀងឃ្លាត ។ ព្រះមានព្រះភាគទ្រង់សម្រេចសច្ចៈ ៤ ដោយសយម្ភូញាណ ។ ឈ្មោះថា តថាគត ព្រោះយាងដល់សច្ចៈ ៤ យ៉ាងពិត ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិ-ប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ក្នុងបដិសម្ភិទា ៤ នោះ ញាណដែលដល់នូវការបែកធ្លាយក្នុងអត្ថ អាចធ្វើនូវការជាក់ច្បាស់ និងការកំណត់ព្រមដោយលក្ខណៈនៃប្រភេទរបស់អត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទា ។ ញាណដែលដល់នូវការបែកធ្លាយក្នុងធម៌ អាចធ្វើការជាក់ច្បាស់ និងការកំណត់ព្រមលក្ខណៈនៃប្រភេទរបស់ធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទា ញាណដែលដល់ការបែកធ្លាយ ក្នុងការសម្តែងភាសា អាចធ្វើនូវការជាក់ច្បាស់ និងការកំណត់

ព្រមដោយលក្ខណៈនៃប្រភេទរបស់កាសា ទើបឈ្មោះថា និរុត្តិប្បដិសម្ភិទា ញាណដែលដល់នូវការបែកធ្លាយក្នុងបដិភាណ អាចធ្វើការជាក់ច្បាស់ និង ការកំណត់ព្រមដោយលក្ខណៈប្រភេទរបស់បដិភាណ ឈ្មោះថា បដិភាណ-ប្បដិសម្ភិទា សមដូចព្រះតម្រាស់ដែលត្រាស់ក្នុងបដិសម្ភិទាវិភង្គថា សេចក្តី ដឹងក្នុងអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងធម៌ ឈ្មោះថា ធម្ម-ប្បដិសម្ភិទា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថ និងធម៌នោះ ឈ្មោះ ថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភា-ណប្បដិសម្ភិទា ។ ក្នុងញាណ ៤ យ៉ាងនោះ ពោលដោយសង្ខេប ផលដែល កើតមកអំពីហេតុ ឈ្មោះថា អត្ថ ព្រោះបុគ្គលគប្បីប្រព្រឹត្តទៅដើម្បីសម្រេច តាមក្រសែនៃហេតុ តែពោលដោយប្រភេទ ធម៌ទាំង ៥ គឺបច្ចុប្បន្នធម៌ណា មួយ និព្វាន អត្ថនៃភាសិត វិបាក និងកិរិយា ឈ្មោះថា អត្ថ ញាណដែល ដល់នូវការបែកធ្លាយក្នុងអត្ថនោះ នៃបុគ្គលដែលពិចារណាក្នុងអត្ថនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា ។ កាលពោលដោយសង្ខេប បច្ច័យ ឈ្មោះថា ធម៌ ។ ពិតហើយ បច្ច័យនោះ លោកហៅថា ធម៌ ព្រោះជាក់ច្បាស់ គឺឲ្យ នូវអត្ថនោះប្រព្រឹត្តទៅ និងឲ្យសម្រេច ។ តែបើពោលដោយប្រភេទ ធម៌ ៥ ប្រការ គឺហេតុដែលញុំងផលឲ្យកើតឡើងណាមួយ អរិយមគ្គ ភាសិត កុសលកម្ម និងអកុសលកម្ម ឈ្មោះថា ធម៌ដែលញាណដល់នូវការបែកធ្លាយ ក្នុងធម៌នោះ នៃបុគ្គលដែលពិចារណាធម៌នោះ ឈ្មោះថា ធម្មប្បដិសម្ភិទា ។ សមពិត ដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ថា សេចក្តីដឹងក្នុងទុក្ខ ឈ្មោះថា

អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងការកើតឡើងនៃទុក្ខ ឈ្មោះថា ធម្មប្បដិ-
សម្ភិទា សេចក្តីដឹងក្នុងការរលត់ទុក្ខ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹង
ក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ឈ្មោះថា ធម្មប្បដិសម្ភិទា ។

ម្យ៉ាងទៀត សេចក្តីដឹងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹង
ផលនៃហេតុ ឈ្មោះថា អត្ថប្បដិសម្ភិទា ។ ធម៌ទាំងឡាយណា កើតចម្រើន
លូតលាស់ ដុះដាល ចម្រុងចម្រើន កើតប្រាកដហើយ សេចក្តីដឹងក្នុងធម៌
ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា ធម៌ទាំងឡាយនោះ កើតចម្រើន
លូតលាស់ ដុះដាល ចម្រុងចម្រើន កើតប្រាកដហើយ អំពីធម៌ទាំងឡាយ
ណា សេចក្តីដឹងក្នុងធម៌ទាំងឡាយនោះ ឈ្មោះថា ធម្មប្បដិសម្ភិទា ។ ញាណ
ក្នុងជរា និងមរណៈ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងជរា និងមរណៈ
ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងការកើតឡើងនៃជរា និងមរណៈ
ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការរលត់នៃជរា និងមរណៈ ឈ្មោះ
ថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃជរា
និងមរណៈ ឈ្មោះថា ធម្មប្បដិសម្ភិទា ។ ញាណក្នុងជាតិ ភព ឧបាទាន
តណ្ហា វេទនា ផស្សៈ សឡាយតនៈ នាមរូប វិញ្ញាណ សង្ខារ ឈ្មោះថា
អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងការកើតឡើងនៃសង្ខារ ឈ្មោះថា ធម្មប្បដិ-
សម្ភិទា សេចក្តីដឹងក្នុងការរលត់នៃសង្ខារ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តី
ដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ឈ្មោះថា ធម្មប្បដិ-
សម្ភិទា ។ និងដូចព្រះតម្រាស់ថា ភិក្ខុក្នុងសាសនានេះ ដឹងនូវធម៌ គឺសុត្តៈ

គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្ល នេះ ឈ្មោះថា ធម្មប្បដិសម្ភិទា កិក្ខុនោះ ដឹងនូវសេចក្តីនៃភាសិតនោះៗ ថា នេះ សេចក្តីនៃភាសិតនេះ នេះ សេចក្តីនៃភាសិតនេះ នេះ ឈ្មោះថា អត្ថ-ប្បដិសម្ភិទា ។

ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរ-កុសល ច្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ជ្រាវឆ្ពនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន នេះ ពួកធម៌ជាកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយ នេះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា ។ សេចក្តីពិស្តារហើយ ។ សកាវនិរុត្តិ (ភាសាដើម) គឺអព្យភិចារវោហារ គឺពាក្យដែលមិនឃ្លៀងឃ្លាត អកិលាប (ការពោល) ក្នុងអត្ថ និងធម៌នេះ តាមភាសាដើមនៃសភាវៈសត្វ ដែលជាមគធភាសា ក្នុងការពោលភាសាដើមនោះ ឈ្មោះថា សកាវនិរុត្តិ នេះ មិនឈ្មោះថា សកាវនិរុត្តិទេឡើយ ញាណដែលដល់នូវការបែកធ្លាយ ដូច្នេះ ឈ្មោះថា និរុត្ត-ប្បដិសម្ភិទា ញាណដែលដល់នូវការបែកធ្លាយក្នុងញាណនោះ នៃកិក្ខុដែលពិចារណាការធ្វើញាណទាំងនោះឲ្យប្រព្រឹត្តទៅ ដោយកិច្ចនៃអារម្មណ៍យ៉ាងពិស្តារ ក្នុងញាណទាំងនោះ តាមដែលពោលហើយ ឲ្យជាអារម្មណ៍ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ ដូច្នោះ បដិសម្ភិទាញាណទាំង៤ នេះ ព្រះមាន

ព្រះភាគ ទ្រង់សម្រេចដោយព្រះអង្គឯង ទើបឈ្មោះថា ពិត មិនខុស មិនក្លាយទៅជាជនៃទ្បើយ ព្រោះប្រព្រឹត្តទៅដោយអាការមិនខុសប្លែក ដោយពោលមិនឲ្យឃ្លៀងឃ្លាត ក្នុងអារម្មណ៍របស់ខ្លួននោះៗ ដែលក្រៃលែងដោយអត្ថ និងធម៌ ។ ព្រះអង្គព្រះនាមថា តថាគត ព្រោះមកដល់សច្ចៈពិតដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ធម្មជាតឯណាមួយ ឈ្មោះថា **ញេយ្យ** *ទាំងអស់នោះ ព្រះមានព្រះភាគទ្រង់ជ្ញឹងហើយ ទ្រង់ឃើញហើយ ទ្រង់សម្រេចហើយ ទ្រង់ត្រាស់ដឹងចំពោះហើយ ដោយអាការទាំងពួង ។ ពិតហើយ ធម៌ដែលគួរដឹងក្រៃលែង ទ្រង់ត្រាស់ដឹងហើយ ដោយធម៌ដែលគួរដឹងក្រៃលែង ធម៌ដែលគួរកំណត់ដឹង ទ្រង់ត្រាស់ដឹងហើយ ព្រោះជាធម៌ដែលគួរកំណត់ដឹង ធម៌ដែលគួរលះ ទ្រង់ត្រាស់ដឹងហើយ ដោយជាធម៌ដែលគួរលះ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ទ្រង់ត្រាស់ដឹងហើយ ព្រោះជាធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ធម៌ដែលគួរចម្រើន ទ្រង់ត្រាស់ដឹងហើយ ថាជាធម៌ដែលគួរចម្រើន ព្រោះបុគ្គលណាម្នាក់ ជាសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី មិនអាចបដិសេធព្រះអង្គ ដោយប្រពៃតាមធម៌ថា ទ្រង់មិនបានត្រាស់ដឹងធម៌ឈ្មោះនេះទេ ។ ធម៌ឯណានីមួយ ឈ្មោះថា* **បហាតព្ព** *ធម៌ទាំងអស់នោះ ទ្រង់លះបានហើយ ត្រង់មណ្ឌលពោធិព្រឹក្សនោះឯង បានជាសមុច្ឆេទ មានការមិនកើតឡើងជាធម្មតា ករណីយកិច្ចដែលក្រៃលែងជាងការលះធម៌ដែលគួរលះនោះ មិនមាន ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះ ទ្រង់លះ ទ្រង់កាត់ផ្តាច់ ទ្រង់ដកបានជា*

សមុច្ឆេទនូវកិលេស ១៥០០ គឺលោភៈ ទោសៈ មោហៈ វិបរិតមនសិការ អហិរិកៈ អនោត្តប្បៈ ថីនៈ មិទ្ធៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ អកុសលមូល ៣ ទុច្ចរិត ៣ វិសម ៣ សញ្ញា ៣ មលៈ ៣ វិតក្ក ៣ បបញ្ចៈ ៣ អនេសនា ៣ តណ្ហា ៣ បរិយេសៈ ៤ អាសវៈ ៤ គន្ថៈ ៤ ឱឃៈ ៤ យោគៈ ៤ អគតិ ៤ តណ្ហុបាទាន ៤ អកិនន្ទនៈ ៥ នីវរណៈ ៥ ចេតោខីលៈ ៥ ចេតសោវិនិពន្ធ ៥ វិវាទមូល ៦ អនុសយ ៧ មិច្ឆត្ត ៨ អាឃាតវត្ថុ ៩ តណ្ហាមូលកៈ ៩ អកុសលកម្មបថ ១០ អនេសនា ២១ ទិដ្ឋិ ៦២ និងតណ្ហាវិបរិត ១០៨ ជាដើម មួយអន្ទើដោយវាសនា ព្រោះបុគ្គលណាម្នាក់ ជាសមណៈក្តី ព្រាហ្មណ៍ក្តី ព្រហ្មក្តី មិនអាចជំទាស់ព្រះអង្គបានដោយប្រពៃតាមធម៌ថា ឈ្មោះថា កិលេសទាំងនេះ ទ្រង់មិនទាន់លះបានទេ ។

ធម៌ទាំងនេះ មានប្រភេទ គឺកម្មវិបាក កិលេស ឧបវាទ និងអនាវីតកម្ម ព្រះមានព្រះភាគត្រាស់ថា ជាធម៌ឲ្យផលក្នុងលំដាប់ អាចឲ្យផលតាមលំដាប់ដោយចំណែកមួយ ដល់បុគ្គលដែលសេពនូវធម៌ទាំងនោះបាននោះឯង ព្រោះបុគ្គលណាម្នាក់ ទោះជាសមណៈក្តី ។បេ។ ព្រហ្មក្តី មិនអាចជំទាស់ព្រះអង្គបានដោយប្រពៃតាមធម៌ថា មិនអាចធ្វើអន្តរាយ ដល់អ្នកសេពនូវធម៌ទាំងនោះ ។

ឯនិយ្យានិកធម៌ដ៏កំពូល មានអរិយមគ្គជាអ្នកនាំមុខ មាន ៣៧ ប្រការ

ចែកជាពួកមាន ៧ រួមសីល សមាធិ បញ្ញា ដែលជាហេតុរលាស់ចេញចាកវដ្តទុក្ខបានជាសមុច្ឆេទ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយនោះ តែងនាំសត្វចេញចាកទុក្ខដោយពិតនោះឯង រមែងធ្វើអ្នកបដិបត្តិឲ្យផុតចាកទុក្ខបានដោយពិត ព្រោះបុគ្គលណាម្នាក់ ទោះជាសមណៈក្តី ។បេ។ ព្រហ្មក្តី ក៏មិនអាចបដិសេធព្រះអង្គបាន ដោយប្រពៃតាមធម៌ថា ធម៌ដែលទ្រង់សម្តែងថាជាធម៌នាំចេញចាកទុក្ខ មិននាំចេញចាកទុក្ខបានឡើយ ។ សមដូចទ្រង់ត្រាស់ថា ព្រះអង្គគ្រាន់តែប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងដោយប្រពៃ តែធម៌ទាំងនេះព្រះអង្គឥតបានត្រាស់ដឹងឡើយ ។ គប្បីជ្រាបសេចក្តីពិស្តារ (ក្នុងមជ្ឈិម-និកាយ មហាសីហនាទសូត្រ) ។ វេសារជ្ជញ្ញាណ ៤ ដូចពោលមកនេះនៃព្រះមានព្រះភាគ ប្រព្រឹត្តទៅដោយអាការមិនខុសប្លែក ឈ្មោះថា ពិត មិនខុស មិនក្លាយទៅជាជំនៃ ព្រោះដឹងនូវសេចក្តីវិសេសរបស់ញាណ បហាននិងទេសនារបស់ព្រះអង្គ ដោយការៈដែលមិនខុស ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះដល់នូវវេសារជ្ជញ្ញាណពិត ដោយប្រការដូច្នេះ ។

គតិ ៥ គឺនិរយគតិ តិរច្ឆានគតិ បេតគតិ មនុស្សគតិ និងទេវគតិ ។ ក្នុងគតិ ៥ នោះ មហានរក ៨ មានសញ្ជីវនរកជាដើម ឧស្សទនរក ១៦ មានកុក្កុលនរកជាដើម និងលោកន្តរនរក ទាំងអស់នេះ ឈ្មោះថា នរក ព្រោះអត្ថថា មិនមានសេចក្តីត្រេកអរ ដោយសការៈ ជាទុក្ខតែម្យ៉ាង ដោយពិត និងឈ្មោះថា គតិ ព្រោះសត្វគប្បីទៅតាមយថាកម្ម ព្រោះដូច្នោះ ទើបឈ្មោះថា និរយគតិ ។ សូម្បីផេះក្តៅ ទីដែលងងឹត និងទីដែលត្រជាក់បំផុត

ក៏សង្គ្រោះក្នុងនរកទាំងនេះជួបគ្នា ជង្ហឹ សត្វល្អិត ពស់ បក្សី ឆ្កែស្រុក ឆ្កែចចកជាដើម ឈ្មោះថា តិរច្ឆាន ព្រោះទៅដោយទទឹង គតិ គឺសត្វតិរច្ឆានទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា តិរច្ឆានគតិ ។ ឈ្មោះថា ប្រេត មានបរទត្តបជីវិប្រេត និងនិជ្ឈាមតណ្ហិកប្រេតជាដើម ព្រោះជាអ្នកមានសេចក្តីស្រេក និងសេចក្តីឃ្លានគ្របសង្កត់ ឈ្មោះថា ទៅ គឺច្រាសចាកសុខដែលល្អក្រៃលែង ព្រោះច្រើនដោយសេចក្តីទុក្ខ ព្រោះហេតុនោះ ទើបឈ្មោះថា ប្រេត គតិ គឺប្រេតទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា បេតគតិ សូម្បីពួកអសុរ មានកាឡកញ្ជិកាសុរជាដើម ក៏សង្គ្រោះចូលក្នុងប្រេតទាំងនោះដូចគ្នា អ្នកជម្ពូទ្វីប និងអ្នកមហាទ្វីបទាំង ៤ មួយអន្ទៅដោយអ្នកទ្វីបតូចៗ ឈ្មោះថា មនុស្ស ព្រោះជាអ្នកមានចិត្តខ្ពស់ គតិ គឺមនុស្សទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា មនុស្សគតិ ។ ពួកទេវតា ២៦ ជាន់ គឺរាប់តាំងអំពីចាតុម្មហារាជិកា ដល់ទេវតាដែលចូលដល់នេវសញ្ញានាសញ្ញាយតនជ្ឈានរមែងលេង គឺសោយសុខ រុងរឿងដោយអានុភាព គឺឫទ្ធិរបស់ខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថា ទេវៈ គតិ គឺទេវៈទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា ទេវគតិ ។

គតិទាំងនោះ ព្រោះហេតុដែលការវិសេសនៃឧបបត្តិភព ដែលកើតអំពីកម្មនោះៗ ដូច្នោះ កាលពោលដោយអត្ត បានដល់ វិបាកក្ខន្ធ និងកម្មជរូប ។ ក្នុងគតិទាំងនោះ ព្រះញាណរបស់ព្រះសាស្តា រមែងប្រព្រឹត្តទៅ ដោយហេតុៈ ដោយហេតុ ដោយការកំណត់ វិភាគហេតុ និងផល ដែលកើតអំពីហេតុ តាម

ហានៈនៃខ្លួនថា ធម្មតាគតិនេះ រមែងកើតអំពីកម្មឈ្មោះនេះ ។ និងពួកសត្វទាំងនេះ រមែងប្លែកផ្សេងគ្នាយ៉ាងនេះជាផ្នែកៗ ព្រោះបែកផ្សេងគ្នា ដោយវិការយ៉ាងនេះ ដោយបច្ចយវិសេសនៃកម្មនោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា ម្នាលសារីបុត្ត គតិនេះ មាន ៥ ប្រការ គតិ ៥ ប្រការ តើដូចម្តេច គឺនរក ១ កំណើតតិរច្ឆាន ១ បិត្តិវិស័យ ១ ពួកមនុស្ស ១ ពួកទេវតា ១ ។ ម្នាលសារីបុត្ត តថាគតស្គាល់នរកផង ស្គាល់ផ្លូវជាទីទៅកាន់នរកផង ស្គាល់សេចក្តីប្រតិបត្តិជាទីទៅកាន់នរកផង ឯបុគ្គលប្រតិបត្តិយ៉ាងណាហើយ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ព្រះញាណរបស់ព្រះមានព្រះភាគទាំងនោះ ឈ្មោះថា ពិត មិនខុស មិនវិបរិត ព្រោះត្រាស់ដល់ការប្រព្រឹត្តទៅនៃអាការដែលមិនខុសប្លែកក្នុងវិស័យនោះៗ មិនឲ្យឃ្លៀងឃ្លាត ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះមកដោយញាណទាំងនោះយ៉ាងពិត ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ឥន្ទ្រិយបរោបរិយត្តញ្ញាណ របស់ព្រះមានព្រះភាគ ដែលប្រព្រឹត្តទៅដោយអាការ ៥០ ដែលជាហេតុជាក់ច្បាស់ដោយពិសេសនៃភាពដែលសត្វមានកិលេស ដូចធូលីក្នុងភ្នែកតិច និងភាពដែលសត្វមានកិលេសដូចធូលីក្នុងភ្នែកច្រើន សមដូចទ្រង់ត្រាស់ថា ត្រង់ពាក្យថា មានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក គឺបុគ្គលដែលមានសទ្ធា ឈ្មោះថា អ្នកមានធូលីតិចក្នុងភ្នែក បុគ្គលដែលឥតសទ្ធា ឈ្មោះថា អ្នកមានធូលីច្រើនក្នុងភ្នែក

គប្បីជ្រាបសេចក្តីពិស្តារ (ក្នុងបដិសម្ភិទាមគ្គ) ។

អាសយានុសយញ្ញាណ របស់ព្រះមានព្រះភាគ ប្រព្រឹត្តទៅដោយការជាក់ច្បាស់តាមសេចក្តីពិតនៃអាសយៈ គឺការបំណងជាដើមរបស់ពួកសត្វ ដោយន័យជាដើមថា បុគ្គលនេះមានកិលេសដូចធូលីក្នុងភ្នែកតិច បុគ្គលនេះមានលទ្ធិជាសស្សតទិដ្ឋិ បុគ្គលនេះមានលទ្ធិជាឧច្ឆេទទិដ្ឋិ បុគ្គលនេះតាំងនៅក្នុងអនុលោមខន្តី បុគ្គលនេះតាំងនៅក្នុងយថាភូតញ្ញាណ បុគ្គលនេះមានអាសយៈ គឺអធ្យាស្រ័យក្នុងផ្លូវកាម មិនមានអធ្យាស្រ័យក្នុងផ្លូវនេក្ខម្មៈជាដើម បុគ្គលនេះមានអធ្យាស្រ័យក្នុងនេក្ខម្មៈ មិនមានអធ្យាស្រ័យក្នុងកាមជាដើម និងដោយន័យជាដើមថា កាមរាគរបស់បុគ្គលនោះ មានកម្លាំងខ្លាំងក្លា តែមិនមានបដិឃៈ បដិឃៈរបស់បុគ្គលនេះ មានកម្លាំងខ្លាំងក្លា តែមិនមានកាមរាគជាដើម និងដោយន័យជាដើមថា បុញ្ញាភិសង្ខារបស់បុគ្គលនេះក្រៃលែង តែមិនមានអបុញ្ញាភិសង្ខារ និងអនេញ្ជាភិសង្ខារ អបុញ្ញាភិសង្ខារបស់បុគ្គលនេះក្រៃលែង តែមិនមានបុញ្ញាភិសង្ខារ មិនមានអនេញ្ជាភិសង្ខារ អនេញ្ជាភិសង្ខារបស់បុគ្គលនេះក្រៃលែង តែមិនមានបុញ្ញាភិសង្ខារ មិនមានអបុញ្ញាភិសង្ខារ កាយសុចរិត វចីសុចរិត និងមនោសុចរិតរបស់បុគ្គលនេះក្រៃលែង បុគ្គលនេះមានអធិមុត្តិអាក្រក់ បុគ្គលនេះមានអធិមុត្តិប្រណីត បុគ្គលនេះប្រកបដោយកម្មាវរណៈ បុគ្គលនេះប្រកបដោយកិលេសាវរណៈ បុគ្គលនេះប្រកបដោយវិបាកាវរណៈ បុគ្គលនេះមិនប្រកបដោយកម្មាវរណៈ បុគ្គលនេះមិនប្រកបដោយកិលេសាវរណៈ បុគ្គលនេះមិនប្រកបដោយវិបាកាវរណៈ

ដែលទ្រង់សំដៅយក គ្រាស់ថា ព្រះតថាគតជ្រាបនូវអាសយធម៌ ជ្រាបនូវអនុសយធម៌ ជ្រាបនូវចរិត ជ្រាបនូវអធ្យាស្រ័យរបស់សត្វទាំងឡាយ ជ្រាបនូវពួកសត្វដែលមានភព្វ និងឥតភព្វ ក្នុងលោកនេះ (ញាណបែបនេះ ឈ្មោះថា សត្តាសយានុសយញ្ញាណរបស់ព្រះតថាគត) ដូច្នេះជាដើម ។

ម៉្យាងទៀត ឃមកប្បាដិហិរញ្ញាណ របស់ព្រះតថាគត តើដូចម្តេច ។ ព្រះតថាគតទ្រង់ធ្វើឃមកប្បាដិហារ្យ ដែលមិនទូទៅដល់ពួកសាវក ក្នុងលោកនេះ គឺគំនរភ្លើងចេញអំពីព្រះកាយខាងលើ ផ្ការទឹកចេញអំពីព្រះកាយខាងក្រោម គំនរភ្លើងចេញអំពីព្រះកាយខាងក្រោម ផ្ការទឹកចេញអំពីព្រះកាយខាងលើ គំនរភ្លើងចេញអំពីព្រះកាយខាងមុខ ផ្ការទឹកចេញអំពីព្រះកាយខាងក្រោយ គំនរភ្លើងចេញអំពីព្រះកាយខាងក្រោយ ផ្ការទឹកចេញអំពីព្រះកាយខាងមុខ គំនរភ្លើងចេញអំពីព្រះនេត្រខាងស្តាំ ផ្ការទឹកចេញអំពីព្រះនេត្រខាងឆ្វេង គំនរភ្លើងចេញអំពីព្រះនេត្រខាងឆ្វេង ផ្ការទឹកចេញអំពីព្រះនេត្រខាងស្តាំ គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ គំនរភ្លើងចេញអំពីរន្ធព្រះនាសិកាខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង គំនរភ្លើងចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាងស្តាំ គំនរភ្លើងចេញអំពីចង្ហួយព្រះអង្សាខាងស្តាំ ផ្ការទឹកចេញអំពីចង្ហួយព្រះអង្សាខាងឆ្វេង គំនរភ្លើងចេញអំពីចង្ហួយព្រះអង្សាខាងឆ្វេង ផ្ការទឹកចេញអំពីចង្ហួយព្រះអង្សាខាងស្តាំ គំនរភ្លើងចេញអំពីព្រះហស្តខាងស្តាំ ផ្ការទឹកចេញអំពីព្រះហស្ត

ខាងឆ្វេង គំនរភ្លើងចេញអំពីព្រះហស្តខាងឆ្វេង ធ្លាទឹកចេញអំពីព្រះហស្តខាងស្តាំ គំនរភ្លើងចេញអំពីខាងខាងស្តាំ ធ្លាទឹកចេញអំពីខាងខាងឆ្វេង គំនរភ្លើងចេញអំពីខាងខាងឆ្វេង ធ្លាទឹកចេញអំពីខាងខាងស្តាំ គំនរភ្លើងចេញអំពីព្រះបាទខាងស្តាំ ធ្លាទឹកចេញអំពីព្រះបាទខាងឆ្វេង គំនរភ្លើងចេញអំពីព្រះបាទខាងស្តាំ ធ្លាទឹកចេញអំពីព្រះបាទខាងឆ្វេង គំនរភ្លើងចេញអំពីព្រះបាទខាងឆ្វេង ធ្លាទឹកចេញអំពីព្រះបាទខាងស្តាំ គំនរភ្លើងចេញអំពីព្រះអង្គុលីមួយៗ ធ្លាទឹកចេញអំពីចន្លោះនៃព្រះអង្គុលី គំនរភ្លើងចេញអំពីចន្លោះនៃព្រះអង្គុលី ធ្លាទឹកចេញអំពីព្រះអង្គុលីមួយៗ គំនរភ្លើងចេញអំពីព្រះលោមាមួយៗ ធ្លាទឹកចេញអំពីព្រះលោមាមួយៗ គំនរភ្លើងចេញអំពីរណ្តៅព្រះលោមាមួយៗ ធ្លាទឹកចេញអំពីរណ្តៅព្រះលោមា ដែលទ្រង់បំណងត្រាស់ថា ព្រះតថាគតទ្រង់ធ្វើយមកប្បាដិហារ្យ ដែលមិនទូទៅដល់ពួកសាវក ក្នុងលោកនេះ គឺគំនរភ្លើងចេញអំពីព្រះកាយខាងលើ ធ្លាទឹកចេញអំពីព្រះកាយខាងក្រោម គំនរភ្លើងចេញអំពីព្រះកាយខាងក្រោម ធ្លាទឹកចេញអំពីព្រះកាយខាងលើ ដូច្នេះជាដើម ។

ម្យ៉ាងទៀត ព្រះមហាករុណាសមាបត្តិញ្ញាណ ដែលជាបច្ច័យឲ្យព្រះមានព្រះភាគផ្សាយព្រះមហាករុណា ដែលប្រព្រឹត្តទៅដោយនយផ្សេងៗ ដោយភាពដែលទ្រង់បំណងនឹងនាំពួកសត្វ ដែលត្រូវទុក្ខធម៌ជាច្រើន មានរាគៈជាដើម និងមានជាតិជាដើមបៀតបៀន ឲ្យចេញចាកទុក្ខធម៌ទាំងនោះ ដូចព្រះតម្រាស់ថា មហាករុណាសមាបត្តិញ្ញាណ របស់ព្រះតថាគត តើដូចម្តេច ។ កាលព្រះពុទ្ធមានព្រះភាគទាំងឡាយ ទ្រង់ឃើញដោយអាការច្រើន មហាករុណា

រមែងចុះស៊ប់ក្នុងពួកសត្វ គឺកាលព្រះពុទ្ធមានព្រះភាគទ្រង់ឃើញថា លោក-
សន្និវាស ត្រូវភ្លើងឆេះសព្វហើយ មហាកុណាចុះស៊ប់ក្នុងពួកសត្វ កាលព្រះ
ពុទ្ធមានព្រះភាគទ្រង់ឃើញថា លោកសន្និវាសមានសេចក្តីខ្វល់ខ្វាយ (ជានិច្ច)
ឯបេ ថាលោកសន្និវាសមានដំណើរទៅ (ជានិច្ច) ឯបេ ព្រះសម្ពុទ្ធមាន
ព្រះភាគទ្រង់ឃើញថា លោកសន្និវាសដើរទៅកាន់ផ្លូវខុស មហាកុណាក៏ចុះ
ស៊ប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគ ទ្រង់ឃើញថា សត្វលោក មិន
ទៀង ត្រូវជរានាំចូលទៅ (រកសេចក្តីស្លាប់) មហាកុណាក៏ចុះស៊ប់ក្នុងពួក
សត្វ កាលព្រះពុទ្ធមានព្រះភាគទ្រង់ឃើញថា សត្វលោកឥតមានទីពឹង ឥត
មានទីផ្អែក មហាកុណាក៏ចុះស៊ប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគទ្រង់
ឃើញថា សត្វលោកគ្មានអ្វីជារបស់ខ្លួន ត្រូវលះចោលរបស់ទាំងអស់ហើយ
ទៅ មហាកុណាក៏ចុះស៊ប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគទ្រង់ឃើញ
ថា សត្វលោកមានសេចក្តីខ្វះខាត មិនឆ្អែត ជាទាសៈនៃតណ្ហា មហាកុណា
ក៏ចុះស៊ប់ ក្នុងពួកសត្វ កាលព្រះពុទ្ធទ្រង់ឃើញថា លោកសន្និវាសឥតទីពឹង
ឯបេ កាលទ្រង់ឃើញថា លោកសន្និវាសឥតទីពួន ឯបេ ទ្រង់ឃើញថា
លោកសន្និវាស ឥតទីរឭក ឯបេ ទ្រង់ឃើញថា លោកសន្និវាស មិនមាន
វត្តជាទីរឭក ឯបេ ទ្រង់ឃើញថា សត្វលោកកំពុងរវើរវាយ មិនស្ងប់រម្ងាប់
ឯបេ ទ្រង់ឃើញថា លោកសន្និវាសប្រកបដោយសរមុតហើយ ដោយសរ
ផ្សែងៗ បុគ្គលដទៃទីមួយ ក្រៅពីតថាគតនឹងដកសរបស់លោកសន្និវាសនោះ
មិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសមានឆន្ទៈ គឺអវិជ្ជា ជាគ្រឿង

ភវាំង ជ្រាក់ចុះក្នុងទ្រូង គឺកិលេស បុគ្គលជនៃនីមួយ ជាអ្នកបង្ហាញនូវពន្លឺដល់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោក-សន្និវាស លុះក្នុងអំណាចអវិជ្ជា ជាអ្នកងងឹតងងុល ត្រូវអវិជ្ជារួបរឹត សាំញុំដូចអំបោះនៃជាងតម្បាញ ស្មុគស្មាញ ដូចអំបោះដែលជាងតម្បាញប្រឡាក់ដោយទឹកបាយ ដូចស្មៅយាប្ងន និងស្មៅដំណេកទន្សាយ មិនប្រព្រឹត្តកន្លងនូវអបាយ ទុគ្គតិ វិនិបាត និងសង្សារបានឡើយ ទ្រង់ឃើញថា លោកសន្និវាស ជាប់ដោយទោស គឺពិសនៃអវិជ្ជា ប្រកបដោយកំហុស គឺកិលេស ទ្រង់ឃើញថា លោកសន្និវាស ត្រូវភគៈ ទោសៈ មោហៈចាក់ស្រែះហើយ បុគ្គលជនៃនីមួយ ជាអ្នកដោះនូវបណ្តាញ របស់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសស៊កចុះក្នុងឃ្នាប គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាស ត្រូវបណ្តាញ គឺតណ្ហារួបរឹត ទ្រង់ឃើញថា លោក-សន្និវាស ត្រូវខ្សែតណ្ហាបន្សាត់ទៅហើយ ទ្រង់ឃើញថា លោកសន្និវាស ប្រកបហើយដោយចំណង គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាសត្រាំនៅក្នុងតម្រាំ គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាស ក្តៅដោយកម្តៅ គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាសក្តៅក្រហាយ ដោយសេចក្តីក្តៅក្រហាយ គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាសស៊កចុះក្នុងឃ្នាប គឺទិដ្ឋិ ទ្រង់ឃើញថា លោកសន្និវាស ត្រូវបណ្តាញ គឺទិដ្ឋិរួបរឹតហើយ ទ្រង់ឃើញថា លោក-សន្និវាស ត្រូវខ្សែទិដ្ឋិបន្សាត់ទៅ ទ្រង់ឃើញថា លោកសន្និវាស ប្រកបដោយគ្រឿងប្រកប គឺទិដ្ឋិ ទ្រង់ឃើញថា លោកសន្និវាសត្រាំនៅក្នុងតម្រាំ គឺទិដ្ឋិ

ទ្រង់ឃើញថា លោកសន្និវាសក្តៅដោយកម្តៅ គឺទិដ្ឋិ ទ្រង់ឃើញថា លោក-
សន្និវាសក្តៅក្រហាយ ដោយសេចក្តីក្តៅក្រហាយ គឺទិដ្ឋិ ទ្រង់ឃើញថា
លោកសន្និវាសប្រកបដោយជាតិជានិច្ច ។បេ។ ទ្រង់ឃើញថា លោកសន្និវាស
ត្រាំក្នុងជរា ។បេ។ ទ្រង់ឃើញថា លោកសន្និវាសត្រូវព្យាធិគ្របសង្កត់ហើយ
។បេ។ ទ្រង់ឃើញថា លោកសន្និវាសត្រូវមរណៈបៀតបៀន ។បេ។ ទ្រង់ឃើញ
ថា លោកសន្និវាសមានទុក្ខធ្លាក់ត្រូវហើយ ទ្រង់ឃើញថា លោកសន្និវាសត្រូវ
តណ្ហាទាក់ជាប់ហើយ ទ្រង់ឃើញថា លោកសន្និវាសស្រោបហើយ ដោយ
កំពែង គឺជរា ទ្រង់ឃើញថា លោកសន្និវាសត្រូវអន្ទាក់គឺមច្ចុរីតួរត ទ្រង់ឃើញ
ថា លោកសន្និវាសជាប់ដោយចំណងច្រើន គឺចំណងរាគៈ ចំណងទោសៈ
ចំណងមោហៈ ចំណងមានៈ ចំណងទិដ្ឋិ ចំណងកិលេស ចំណងទុច្ចរិត បុគ្គល
ដទៃនីមួយជាអ្នកស្រាយនូវចំណងរបស់លោកសន្និវាសនោះ ក្រៅពីតថាគតមិន
មានឡើយ ទ្រង់ឃើញថា លោកសន្និវាសដើរទៅកាន់ទីចង្អៀតខ្លាំង បុគ្គលដទៃ
នីមួយ ជាអ្នកបង្ហាញនូវពន្ធដល់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមាន
ឡើយ ទ្រង់ឃើញថា លោកសន្និវាសមានកង្វល់ ដោយកង្វល់ច្រើន បុគ្គល
ដទៃនីមួយ ជាអ្នកកាត់នូវកង្វល់របស់លោកសន្និវាសនោះ ក្រៅពីតថាគតមិន
មានឡើយ ។បេ។ ទ្រង់ឃើញថា លោកសន្និវាសធ្លាក់ចុះក្នុងជ្រោះធំ បុគ្គល
ដទៃនីមួយ ជាអ្នកស្រង់លោកសន្និវាសនោះ ឲ្យរួចពីជ្រោះក្រៅពីតថាគតមិន
មានឡើយ ទ្រង់ឃើញថា លោកសន្និវាសដើរទៅកាន់ផ្លូវលំបាកខ្លាំង បុគ្គល
ដទៃនីមួយ ជាអ្នកចម្ងឹងលោកសន្និវាសនោះ ឲ្យឆ្លងផ្លូវលំបាក ក្រៅពីតថាគត

មិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសដើរទៅក្នុងមហាសង្សារ បុគ្គលជនៃទីមួយ ជាអ្នកស្រាយលោកសន្និវាសនោះ ឲ្យរួចចាកសង្សារ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសវិលវល់នៅក្នុងផ្លូវកម្រខ្លាំង បុគ្គលជនៃទីមួយ ជាអ្នកស្រង់លោកសន្និវាសនោះ ឲ្យរួចចាកផ្លូវកម្រ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសលិចចុះក្នុងល្បាប់ជ្រៅ ត្រូវភ្លើងគឺរាគៈ ភ្លើង គឺទោសៈ ភ្លើង គឺមោហៈ និងជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាស ញាំញីហើយ បុគ្គលជនៃទីមួយ ជាអ្នកលត់ភ្លើងរបស់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសអណ្តែតឡើង ឥតមានទីពឹងជានិច្ច មានអាជ្ញាត្រូវហើយធ្វើតាមតែអាជ្ញានោះ រមែងលំបាក ទ្រង់ឃើញថា លោកសន្និវាសជាប់ចំណងវដ្តៈ ប្រាកដក្នុងទីសម្រាប់សម្លាប់ បុគ្គលជនៃទីមួយ ជាអ្នកស្រាយចំណងឲ្យដល់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោក-សន្និវាសឥតមានទីពំនាក់ ដល់នូវភាពគួរអាណិតក្រៃពេក បុគ្គលជនៃទីមួយ ជាអ្នកជួយស្រោចស្រង់លោកសន្និវាសនោះ ក្រៅពីតថាគត មិនមានឡើយ ។បេ។ ទ្រង់ឃើញថា លោកសន្និវាសត្រូវសេចក្តីទុក្ខចាក់ជោតហើយ ត្រូវសេចក្តីទុក្ខបៀតបៀនហើយអស់កាលយូរ ទ្រង់ឃើញថា លោកសន្និវាសជាប់ចំពាក់ជានិច្ច ស្រែកឃ្លានជានិច្ច ។បេ។ ទ្រង់ឃើញថា លោកសន្និវាសខ្វាក់ ឥតមានចក្ខុ ទ្រង់ឃើញថា លោកសន្និវាសមានភ្នែកវិនាសហើយ ឥតមានអ្នកដឹកដៃ ទ្រង់ឃើញថា លោកសន្និវាសស្ទុះទៅកាន់ផ្លូវខុស ដើរខុស

ផ្លូវ បុគ្គលដទៃនីមួយ ជាអ្នកនាំលោកសន្និវាសនោះ ឲ្យដើរទៅកាន់ផ្លូវដ៏ប្រសើរ ក្រៅពីតថាគត មិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសសុះទៅក្នុងជំនន់ធំ បុគ្គលដទៃនីមួយ ជាអ្នកស្រង់នូវលោកសន្និវាសនោះ អំពីជំនន់ ក្រៅពីតថាគត មិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាស ត្រូវទិដ្ឋិទាំងពីររួបរឹត ទ្រង់ឃើញថា លោកសន្និវាសប្រតិបត្តិខុស ព្រោះទុច្ចរិតទាំង ៣ ទ្រង់ឃើញថា លោកសន្និវាសពេញដោយយោគធម៌ ប្រកបដោយយោគធម៌ទាំង ៤ ទ្រង់ឃើញថា លោកសន្និវាសចាក់ស្រែះហើយ ដោយគន្ថកិលេសទាំង ៤ ទ្រង់ឃើញថា លោកសន្និវាសប្រកាន់មាំដោយឧបាទានទាំង ៤ ទ្រង់ឃើញថា លោកសន្និវាសឡើងកាន់គតិទាំង ៥ ទ្រង់ឃើញថា លោកសន្និវាស រមែងត្រេកអរដោយកាមគុណទាំង ៥ ទ្រង់ឃើញថា លោក-សន្និវាស ត្រូវនីវរណៈទាំង ៥ គ្របសង្កត់ហើយ ទ្រង់ឃើញថា លោក-សន្និវាស រមែងវិវាទដោយវិវាទមូលទាំង ៦ ទ្រង់ឃើញថា លោកសន្និវាស រមែងត្រេកអរដោយតណ្ហា កាយទាំង ៦ ទ្រង់ឃើញថា លោកសន្និវាស ត្រូវទិដ្ឋិទាំង ៦ រួបរឹតហើយ ទ្រង់ឃើញថា លោកសន្និវាស ត្រាំនៅហើយដោយតម្រាំទាំង ៧ ទ្រង់ ឃើញថា លោកសន្និវាសប្រកបហើយ ដោយសំយោជនៈទាំង ៧ ទ្រង់ឃើញថា លោកសន្និវាស ប៉ាន់ឡើងហើយដោយមានៈទាំង ៧ ទ្រង់ឃើញថា លោកសន្និវាស វិលវល់តាមលោកធម៌ទាំង ៨ ទ្រង់ឃើញថា លោកសន្និវាសទៀងដោយមិច្ឆត្តធម៌ទាំង ៨ ទ្រង់ឃើញថា លោកសន្និវាស រមែងប្រទូស្តដោយទោសសម្រាប់បុរស ៨ ទ្រង់ឃើញ

ថា លោកសន្និវាស ចងគំនុំដោយអាឃាតវត្ថុទាំង ៩ ទ្រង់ឃើញថា លោក-សន្និវាសប៉ោងឡើងដោយមានះទាំង ៩ ទ្រង់ឃើញថា លោកសន្និវាសរមែងត្រេកអរ ដោយតណ្ហាមូលកធម៌ទាំង ៩ ទ្រង់ឃើញថា លោកសន្និវាសរមែងសៅហ្មងដោយកិលេសវត្ថុទាំង ១០ ទ្រង់ឃើញថា លោកសន្និវាស ចងគំនុំដោយអាឃាតវត្ថុទាំង ១០ ទ្រង់ឃើញថា លោកសន្និវាសប្រកបព្រមហើយដោយអកុសលកម្មបថទាំង ១០ ទ្រង់ឃើញថា លោកសន្និវាសប្រកបដោយសញ្ញោជនៈទាំង ១០ ទ្រង់ឃើញថា លោកសន្និវាសទៀងដោយមិច្ឆត្តធម៌ទាំង ១០ ទ្រង់ឃើញថា លោកសន្និវាសប្រកបហើយ ដោយមិច្ឆាទិដ្ឋិមានវត្ថុ ១០ ទ្រង់ឃើញថា លោកសន្និវាសប្រកបហើយដោយសក្កាយទិដ្ឋិមានវត្ថុ ១០ ព្រះពុទ្ធមានព្រះភាគទាំងឡាយទ្រង់ឃើញថា លោកសន្និវាស ត្រូវបបញ្ចធម៌ គឺតណ្ហាទាំង ១០៨ ឲ្យឃឺតយូរហើយ មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ ព្រះពុទ្ធមានព្រះភាគទាំងឡាយទ្រង់ឃើញថា លោកសន្និវាស ត្រូវទិដ្ឋិទាំង ៦២ រួបរឹតហើយ មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ ព្រះពុទ្ធមានព្រះភាគទាំងឡាយទ្រង់ឃើញថា តថាគតឆ្លងរួចហើយ ឯសត្វលោកមិនទាន់ឆ្លងនៅឡើយ តថាគតរួចហើយ ឯសត្វលោកមិនទាន់រួចនៅឡើយ តថាគតហ្វឹកហ្វឺនហើយ ឯសត្វលោកមិនទាន់ហ្វឹកហ្វឺននៅឡើយ តថាគតស្ងប់ហើយ ឯសត្វលោកមិនទាន់ស្ងប់នៅឡើយ តថាគតសប្បាយចិត្តហើយ ឯសត្វលោកមិនទាន់សប្បាយចិត្តនៅឡើយ តថាគតរលត់កិលេសហើយ ឯសត្វលោកមិនទាន់រលត់កិលេសនៅឡើយ តថាគតឆ្លងហើយ ដើម្បីចម្ងង (សត្វលោក) តថាគតរួចហើយ

ដើម្បីញុំាងសត្វលោកឲ្យរួច តថាគតហ្វឹកហ្វឺនហើយ ដើម្បីហ្វឹកហ្វឺនសត្វលោក តថាគតស្ងប់រម្ងាប់ហើយ ដើម្បីញុំាងសត្វលោកឲ្យស្ងប់រម្ងាប់ តថាគតសប្បាយចិត្តហើយ ដើម្បីញុំាងសត្វលោកឲ្យសប្បាយចិត្ត តថាគតរលត់កិលេសហើយ ដើម្បីញុំាងសត្វលោកឲ្យរលត់កិលេស មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ នេះឈ្មោះថា មហាករុណាសមាបត្តិញ្ញាណ របស់ព្រះតថាគត ។ ទ្រង់ធ្វើការចែកដោយអាការ ៨៩ យ៉ាង ដោយប្រការដូច្នេះ ។

សព្វញ្ញុតញ្ញាណ របស់ព្រះតថាគត តើដូចម្តេច ។ ព្រះតថាគត ទ្រង់ជ្រាបសង្ខតធម៌ និងអសង្ខតធម៌ទាំងអស់ មិនមានសេសសល់ ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះ មិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វ នូវហេតុជាអនាគតហេតុនោះ ឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះ មិនមានហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវហេតុជាអតីត ហេតុនោះ ឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះ មិនមាន ហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវហេតុជាបច្ចុប្បន្ន ហេតុនោះ ឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ ភ្នែក និងរូប (យ៉ាងណា) ព្រះតថាគតទ្រង់ជ្រាបសព្វនូវធម៌នោះយ៉ាងនោះដែរ ហេតុនោះ ឈ្មោះ ថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ ត្រចៀក និងសំឡេង ។បេ។ ច្រមុះ និងក្លិន

អណ្តាត និងវស កាយ និងសម្ផស្ស ចិត្ត និងធម្មារម្មណ៍ យ៉ាងណា ព្រះតថាគតទ្រង់ជ្រាបសព្វទ្ធវធម៌នោះទាំងអស់យ៉ាងនោះដែរ ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ ។ គប្បីជ្រាបសេចក្តីពិស្តារ (ក្នុងបដិសម្ភិទាមគ្គ) ។

អសាធារណញ្ញាណ ៦ របស់ព្រះមានព្រះភាគទាំងនេះ ឈ្មោះថា ពិត មិនខុស មិនវិបរិត ព្រោះមិនពោលអារម្មណ៍របស់ខ្លួនឲ្យឃ្លៀងឃ្លាត ដោយប្រព្រឹត្តទៅតាមអាការដែលមិនខុសប្លែក ដោយប្រការដូច្នេះ ព្រោះហេតុនេះទើបព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះមកដល់ញាណដែលពិត ។

ម្យ៉ាងទៀត ព្រះញាណដែលប្រកាសសម្ពោជ្ឈង្គ របស់ព្រះមានព្រះភាគដែលប្រព្រឹត្តទៅដោយអាការផ្សេងៗ យ៉ាងនេះថា កាលពោលដោយសរុបយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គមាន ៧ គឺសតិសម្ពោជ្ឈង្គ ធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ បីតិសម្ពោជ្ឈង្គ បស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ ឧបេក្ខាសម្ពោជ្ឈង្គ កាលពោលដោយសាមញ្ញលក្ខណៈ យ៉ាងនេះថា ធម្មសាមគ្គីនេះ មានសតិជាដើម ដែលជាបដិបក្ខចំពោះឧបទ្ទវច្រើនប្រការ មានការរួញរា ការរាយមាយ ការតាំងមាំ សេចក្តីព្យាយាម កាមសុខល្លិកានុយោគ អត្តកិលមថានុយោគ និងការប្រកាន់មាំដោយឧច្ឆេទទិដ្ឋិ និងសស្សតទិដ្ឋិ ដែលកើតក្នុងខណៈនៃលោកុត្តរមគ្គ ព្រះអរិយសាវ័ករមែងក្រាក់ គឺរមែងក្រោកឡើងចាកកិលេសនិទ្រា ឬជាអ្នកដឹងច្បាស់នូវសច្ចៈ

៤ ឬធ្វើឲ្យជាក់ច្បាស់ចំពោះព្រះនិព្វាន ដោយធម្មសាមគ្គីណា ធម្មសាមគ្គី នោះ លោកហៅថា **ពោធិ** *ឈ្មោះថា* **ពោជ្ឈង្គ** *ព្រោះជាអង្គនៃធម្មសាមគ្គី ជាគ្រឿងត្រាស់ដឹងនោះ ម្យ៉ាងទៀត ព្រះអរិយសាវក លោកហៅថា* **ពោធិ** *ព្រោះធ្វើអត្ថវិគ្គហៈថា ព្រោះត្រាស់ដឹងដោយធម្មសាមគ្គី ដូចដែលពោលហើយ ឈ្មោះថា* **ពោជ្ឈង្គ** *ព្រោះជាអង្គនៃព្រះអរិយសាវក ដែលត្រាស់ដឹងនូវធម្ម-សាមគ្គីនោះ កាលពោលលក្ខណៈពិសេសយ៉ាងនេះថា សតិសម្ពោជ្ឈង្គមាន ការប្រាកដជាលក្ខណៈ ធម្មវិចយសម្ពោជ្ឈង្គ មានការឆ្លុះបញ្ចាំងជាលក្ខណៈ វីរិយសម្ពោជ្ឈង្គ មានការផ្គងជាលក្ខណៈ បីតិសម្ពោជ្ឈង្គ មានការផ្សាយទៅជាលក្ខណៈ បស្សទ្ធិសម្ពោជ្ឈង្គ មានការស្ងប់ជាលក្ខណៈ សមាធិ-សម្ពោជ្ឈង្គ មានការមិនរាយមាយជាលក្ខណៈ ឧបេក្ខាសម្ពោជ្ឈង្គ មានការពិចារណាជាលក្ខណៈ កាលពោលដោយការសម្តែងការប្រព្រឹត្តទៅក្នុងខណៈជាមួយគ្នា ដោយជាឧបការៈដល់គ្នានិងគ្នានៃសម្ពោជ្ឈង្គ ៧ ដោយនយជាដើមថា ក្នុងពោជ្ឈង្គទាំង ៧ នោះ សតិសម្ពោជ្ឈង្គដូចម្តេច បណ្តាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងបញ្ញាខ្ជាប់ខ្ជួនដ៏ប្រសើរ ជាអ្នករឭក នឹកឃើញនូវអំពើដែលខ្លួន ឬអ្នកដទៃធ្វើហើយ អស់កាលយូរក្តី នូវពាក្យដែលខ្លួន ឬអ្នកដទៃនិយាយហើយ អស់កាលយូរក្តីនេះ ហៅថា* **សតិសម្ពោជ្ឈង្គ** *កាលពោលដោយការសម្តែងការប្រព្រឹត្តទៅ ដោយការចែកអារម្មណ៍នៃពោជ្ឈង្គទាំងនោះ ដោយនយជាដើមថា បណ្តាសម្ពោជ្ឈង្គទាំងនោះ សតិ-*

សម្ពោជ្ឈង្គ តើដូចម្តេច ។ សតិក្នុងធម៌ទាំងឡាយខាងក្នុងក៏មាន សតិក្នុងធម៌ទាំងឡាយខាងក្រៅក៏មាន ។ កាលពោលដោយវិធីការនា ដោយនយជាដើម ថា បណ្តាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើនន្ទូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យន្ទូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យន្ទូវការប្រាសចាកតម្រេក អាស្រ័យន្ទូវនិរោធ ជាគ្រឿងឈមទៅកាន់ការលះ ។ កាលពោលដោយវិភាគនយ មាន ៩៦០០០ នយ ដោយនយជាដើមថា ពោជ្ឈង្គ ៧ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ បណ្តាធម៌ទាំងនោះ ពោជ្ឈង្គ ៧ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់ន្ទូវការមិនសន្សំ (ន្ទូវកិលេសវដ្ត) ដើម្បីលះន្ទូវទិដ្ឋិទាំងឡាយ ដើម្បីដល់ន្ទូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ពោជ្ឈង្គ ៧ យ៉ាង គឺសតិ-សម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ក៏កើតមាន ។ ក្នុងពោជ្ឈង្គទាំង ៧ នោះ សតិសម្ពោជ្ឈង្គដូចម្តេច សតិ គឺអនុស្សតិ ឈ្មោះថា ពិត មិនខុស មិនវិបរិត ព្រោះមិនពោលអត្ថនោះៗ ឲ្យឃ្លៀងឃ្លាត ព្រោះហេតុនេះ ទើបព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះមកដល់ញាណដែលពិត ។

ម្យ៉ាងទៀត ព្រះញាណដែលធ្វើអរិយមគ្គឲ្យជាក់ច្បាស់របស់ព្រះមាន-ព្រះភាគ ដែលប្រព្រឹត្តទៅដោយអាការច្រើនយ៉ាងនេះថា កាលពោលដោយ

សរុប យ៉ាងនេះថា បណ្ដាអរិយសច្ចទាំង ៤ នោះ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចៈតើដូចម្ដេច ។ មគ្គដ៏ប្រសើរមានអង្គ ៨ ប្រការនេះឯង ។ មគ្គដ៏ប្រសើរមានអង្គ ៨ ប្រការតើដូចម្ដេច ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ បើពោលដោយសាមញ្ញលក្ខណៈយ៉ាងនេះថា ឈ្មោះថា **អរិយ** *ព្រោះឆ្ងាយចាកកិលេសទាំងពួង ព្រោះធ្វើភាពជាព្រះអរិយៈ និងព្រោះឲ្យបានអរិយផល ឈ្មោះថា មានអង្គ ៨ ព្រោះមាន ៨ យ៉ាង និងព្រោះជាហេតុឲ្យសម្រេចព្រះនិព្វានដោយចំណែកមួយ ឈ្មោះថា* **មគ្គ** *ព្រោះសម្លាប់កិលេស ដល់នូវព្រះនិព្វាន ឬបុគ្គលត្រូវការព្រះនិព្វានគប្បីស្វែងរក ឬខ្លួនឯងស្វែងរកព្រះនិព្វាន កាលពោលដោយលក្ខណៈពិសេសយ៉ាងនេះថា សម្មាទិដ្ឋិ មានការឃើញប្រពៃជាលក្ខណៈ សម្មាសង្កប្ប មានការលើកសម្បយុត្តធម៌ទ្បើងកាន់អារម្មណ៍ដោយប្រពៃជាលក្ខណៈ សម្មាវាចា មានការកំណត់ដោយប្រពៃជាលក្ខណៈ សម្មាកម្មន្តៈ មានការឧស្សាហ៍ដោយប្រពៃជាលក្ខណៈ សម្មាអាជីវៈ មានការផ្ទេរផង់ជាលក្ខណៈ សម្មាវាយាមៈ មានការផ្គងដោយប្រពៃជាលក្ខណៈ សម្មាសតិ មានការប្រាកដដោយប្រពៃជាលក្ខណៈ សម្មាសមាធិ មានការមិនរាយមាយដោយប្រពៃជាលក្ខណៈ កាលពោលដោយការចែកកិច្ចយ៉ាងនេះថា សម្មាទិដ្ឋិលះមិច្ឆាទិដ្ឋិ និងកិលេសជាច្រើន ដែលជាសត្រូវដល់ខ្លួនធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ឃើញសម្បយុត្តធម៌ដោយមិនវង្វេង ព្រោះកម្ចាត់មោហៈ ដែលបិទបាំងព្រះនិព្វាននោះ ម្យ៉ាងទៀត សូម្បីសម្មាសង្កប្ប ក៏លះមិច្ឆាសង្កប្បជាដើម ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ និងធ្វើការលើកសម្បយុត្តធម៌*

ទ្បើងកាន់អារម្មណ៍ដោយប្រពៃ ការកំណត់ ការឧស្សាហ៍ ការផ្ទេរផង់ ការផ្គង ការប្រាកដ និងការតាំងមាំនៃសហជាតធម៌ កាលពោលដោយវិភាគ ការប្រព្រឹត្តទៅក្នុងចំណែកខាងដើម និងចំណែកខាងចុងយ៉ាងនេះថា សម្មាទិដ្ឋិ មានខណៈផ្សេងៗ គ្នាក្នុងខាងដើម មានទុក្ខជាដើមជាអារម្មណ៍ជាផ្នែកៗ ក្នុងខណៈមគ្គ ចិត្តមានខណៈ ១ ធ្វើព្រះនិព្វាននោះឯងឲ្យជាអារម្មណ៍ថា ដោយកិច្ច បានឈ្មោះ ៤ យ៉ាង មានជាដើមថា ញាណក្នុងទុក្ខ សូម្បីសម្មាសង្កប្ប ជាដើម ក៏មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នាក្នុងខាងដើម ក្នុងខណៈមគ្គចិត្តមានខណៈ ១ មានអារម្មណ៍ ១ ក្នុងធម៌ទាំងនោះ សម្មាសង្កប្ប ពោលដោយកិច្ច បានឈ្មោះ ៣ យ៉ាងជាដើមថា នេក្ខម្មសង្កប្ប ធម៌ ៣ យ៉ាង មានសម្មាវាចាជាដើមខាងដើម ជាវិរតិក៏មាន ជាចេតនាក៏មាន ព្រោះមានវិភាគថា មុសាវាទាវេរមណីជាដើម ក្នុងខណៈមគ្គជាវិរតិតែម្យ៉ាង សម្មាវាយាមៈ និងសម្មាសតិ ពោលដោយកិច្ច បានឈ្មោះ ៤ យ៉ាង គឺសម្មប្បធាន ៤ សតិប្បដ្ឋាន ៤ ឯសម្មាសមាធិ សូម្បីក្នុងខណៈមគ្គ ក៏មានការផ្សេងគ្នា ដោយអំណាចឈាន មានបឋមជ្ឈានជាដើម ពោលដោយវិធីការនា ដោយនយជាដើមថា បណ្តាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើនសម្មាទិដ្ឋិ ដែលអាស្រ័យវិវេក ពោលដោយការចែកនយ មាន ៨៤០០០ នយ ដោយនយជាដើមថា បណ្តាធម៌ទាំងនោះ មគ្គមានអង្គ ៨ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនទូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេស-

វដ្ត) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្វាត់ចាកកាមទាំង-ឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ មគ្គមានអង្គ ៨ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិក៏កើតមាន ។ ញាណទាំងអស់នោះ ឈ្មោះថា ពិត មិនខុស មិនវិបរិត ព្រោះមិនពោលអត្ថឲ្យឃ្លៀងឃ្លាត ព្រោះហេតុនេះ ទើបព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះយាងមកដល់ញាណដែលពិត ។

ម្យ៉ាងទៀត ញាណរបស់ព្រះមានព្រះភាគ ដែលប្រព្រឹត្តទៅក្នុងអនុបុព្ធ-វិហារសមាបត្តិ ដោយអត្ថថា គប្បីចម្រើន និងដោយអត្ថថា គប្បីចូលតាមលំដាប់ទាំងនោះ គឺបឋមជ្ឈានសមាបត្តិ ១ និរោធសមាបត្តិ ១ ដោយអំណាចការឲ្យសម្រេច និងការពិចារណាជាដើម និងដោយការប្រកបតាមសមគួរ ឈ្មោះថា ពិត មិនខុស មិនវិបរិត ព្រោះសម្រេចប្រយោជន៍ដោយញាណនោះ ។ ម្យ៉ាងទៀត ទសពលញ្ញាណរបស់ព្រះមានព្រះភាគទាំងនេះ គឺការដឹងហេតុ និងមិនមែនហេតុនៃផលនោះៗ ដែលមិនខុសប្លែកដូច្នេះថា នេះជាឋានៈនៃផលនេះ នេះមិនមែនឋានៈនៃផលនេះ ១ ការដឹងលំដាប់វិបាកតាមសេចក្តីពិត ដោយឥតសេសសល់នៃការកាន់យកកម្ម មានអតីតកាលជាដើមរបស់ពួកសត្វនោះៗ ១ ការដឹងដល់កម្ម និងការចែកកម្មដែលមានអាសវៈផង មិនមានអាសវៈផង តាមសេចក្តីពិតថា នេះបដិបទាជាគ្រឿងនាំសត្វទៅកាន់នរក ។បេ។ នេះបដិបទាជាគ្រឿងនាំសត្វទៅកាន់ព្រះនិព្វានរបស់សត្វនោះៗ ក្នុងខណៈធ្វើកម្មនោះឯង ១ ការដឹងនូវការផ្សេងគ្នានៃធាតុតាមសេចក្តីពិត ដោយ

ន័យជាដើមថា ព្រោះធាតុឈ្មោះនេះក្រាស់ ការពិសេសនេះកើតទ្បើង ក្នុងកាលទាក់ទងជាមួយធម៌នេះរបស់លោកនោះ ដែលមានសភាវៈនៃខន្ធ និងអាយតនៈជាច្រើន ទាំងដែលជាឧបាទិន្នក និងអនុបាទិន្នកជាដើម និងមានសភាវៈផ្សេងៗ គ្នា ១ ការដឹងដល់អធ្យាស្រ័យ និងអធិមុត្តិដែលថោកទាបជាដើមនៃសត្វទាំងឡាយដោយឥតសេសសល់ ១ ការដឹងឥន្ទ្រិយ មានសទ្ធិន្ទ្រិយជាដើមថា ចាស់ក្លា ឬទន់ខ្សោយ ១ ការដឹងដល់ភាពពិសេសនៃឈាន និងវិមោក្ខជាដើម មួយអន្ទើដោយកិលេសជាដើម ១ ការដឹងតំណនៃខន្ធ ដែលសត្វធ្លាប់នៅអាស្រ័យក្នុងកាលមុនដោយឥតសេសសល់ មួយអន្ទើដោយការជាប់ទាក់ទងដោយខន្ធនោះ ក្នុងជាតិដែលប្រមាណមិនបាន ១ ការដឹងចុតិ និងបដិសន្ធិ មួយអន្ទើដោយការចែកសត្វ មានថោកទាបជាដើម ១ ការដឹងសច្ចៈ ៤ ដោយន័យដូចពោលហើយខាងដើម ដោយន័យជាដើមថា នេះទុក្ខ ១ ឈ្មោះថា ពិត មិនខុស មិនវិបរិត ព្រោះប្រព្រឹត្តទៅតាមសេចក្តីពិត ដោយឈមចុះដល់អារម្មណ៍តាមដែលជារបស់ខ្លួន ដោយមិនខុសភ្លាំងភ្លាត់ និងដោយញុំាងប្រយោជន៍តាមដែលបំណងឲ្យសម្រេច សមដូចព្រះតម្រាស់ដែលត្រាស់ថា ព្រះតថាគតក្នុងលោកនេះ រមែងជ្រាបច្បាស់នូវហេតុតាមហេតុផង ជ្រាបច្បាស់នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង ដោយសេចក្តីជាក់លាក់ជាដើម ។ ព្រោះហេតុនេះ ទើបព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះមកដល់ព្រះញាណដែលពិត ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះមកដល់ គឺសម្រេច

ញាណដែលពិត ដោយអំណាចបញ្ញាពិសេស ដែលមិនទូទៅដល់អ្នកដទៃ មានប្រភេទមិនមានទីបំផុត និងមិនមានប្រមាណ មានញាណជាគ្រឿងធ្វើនូវការជាក់ច្បាស់នូវសតិប្បដ្ឋាន និងសម្មប្បធាន តាមដែលពោលមកហើយ ដូចទ្រង់សម្រេចដោយអំណាចព្រះញាណទាំងនេះ ព្រោះហេតុនេះ ទើបទ្រង់ព្រះនាមថា តថាគត ព្រោះមកដល់ព្រះញាណដែលពិត ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះយាងទៅដោយពិត ដូចម្តេច គឺការប្រសូតិ ការត្រាស់ដឹង ការបញ្ញត្តិព្រះធម្មវិនយ និងអនុបាទិសេសនិព្វានធាតុនោះ របស់ព្រះមានព្រះភាគអង្គនោះ ជាការពិត សួរថា លោកអធិប្បាយដូចម្តេច ឆ្លើយថា លោកអធិប្បាយថា ការត្រាស់ដឹងដែលព្រះលោកនាថទ្រង់ប្រាថ្នាចំពោះហើយ និងឲ្យប្រព្រឹត្តទៅហើយ ដើម្បីជាប្រយោជន៍ណា ឈ្មោះថា ពិត មិនខុស មិនវិបរិត ព្រោះឲ្យសម្រេចប្រយោជន៍នោះ ដោយចំណែកមួយ ព្រោះមិនពោលប្រយោជន៍នោះឲ្យឃ្លៀងឃ្លាត ព្រោះប្រព្រឹត្តទៅដើម្បីជាប្រយោជន៍មិនខុស ។ ពិតហើយ ព្រះមានព្រះភាគអង្គនេះ កាលនៅជាព្រះពោធិសត្វ ទ្រង់បំពេញហេតុទាំងពួងដើម្បីបានជាព្រះពុទ្ធ មានប្រភេទដូចពោលហើយ មានការបំពេញបារមី ៣០ ជាដើម ទ្រង់គាំងនៅក្នុងស្ថានតុសិត ទ្រង់ស្តាប់ពុទ្ធកោលាហល ដែលទេវតាក្នុងម៉ឺនចក្រវាលប្រជុំព្រមគ្នា ចូលទៅគាល់ ទូលអាយាចនាថា

ការោយន្តេ មហាវីរ ឧប្បជ្ជ មាតុ កុច្ឆិយំ

សទេវកំ តារយន្តោ ពុជ្ឈស្សុ អមតំ បទំ។

បពិត្រមហាវីរៈ នេះជាកាលសមគួរ សូមទ្រង់កើតឡើង ក្នុងព្រះគភ៌ព្រះមាតា ញុំាងលោកនេះ និងទេវលោកឲ្យឆ្លង ត្រាស់ដឹងនូវអមតបទ ដូច្នេះ ។

ទ្រង់កើតបុព្វនិមិត្តឡើង ប្រមើលមើលមហាវិលោកនៈ ៥ ប្រការ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ អញនឹងកើតជាមនុស្ស ត្រាស់ដឹងចំពោះក្នុងថ្ងៃអាសាឡ្ហបុណ្ណមី បដិសន្ធិក្នុងព្រះគភ៌របស់ព្រះនាងមហាមាយាទេវី ក្នុងសក្យ-រាជត្រកូល ដែលទេវតា និងមនុស្សថែរក្សា ដោយការថែរក្សាដ៏ក្រៃលែង អស់ ១០ ខែ ក្នុងវេលាបច្ចូសសម័យវិសាខបុណ្ណមី ទើបប្រសូត ។

ក្នុងខណៈដែលទ្រង់ប្រសូត ប្រាកដបុព្វនិមិត្ត ៣២ ប្រការ ដូចក្នុងខណៈដែលទ្រង់បដិសន្ធិ ។ ពិតហើយ លោកធាតុមួយម៉ឺននេះញាប់ញ័រកក្រើកលាន់ខ្ទរខ្ទា រស្មីមិនមានប្រមាណផ្សាយទៅក្នុងម៉ឺនចក្រវាល មនុស្សខ្វាក់ពីកំណើតក៏បាននូវចក្ខុ ដូចបុគ្គលប្រាថ្នានឹងមើលព្រះរូបរបស់ព្រះអង្គ មនុស្សថ្លង់បានឮសំឡេង មនុស្ស-គក៏ចរចាបាន មនុស្សគមក៏ដើរត្រង់ មនុស្សខ្វិនក៏ដើរទៅបាន សត្វទាំងពួងដែលត្រូវចងក៏រួចចាកចំណង មានខ្នោះជាដើម ភ្លើងក្នុងនរកទាំងអស់ក៏រលត់ ការស្រែកឃ្លានក្នុងបេតវិសយក៏ស្ងប់ ពួកសត្វតិរច្ឆានមិនមានភ័យ រោគរបស់សត្វក៏ស្ងប់ទៅ សព្វសត្វនាំគ្នាពោលវាចាជាទីស្រឡាញ់ សេះស្រែកដោយអាការពីរោះ ពួកដំរីនាំគ្នាគ្រហឹម តន្ត្រីទាំងពួងបន្លឺសំឡេងមួយបែបៗ គ្រឿងអាភរណៈដែលពាក់ក្នុងដៃជាដើមដែល

ពាក់ក្នុងដៃរបស់ពួកមនុស្ស មិនទង្គិចគ្នាឡើយ ក៏មានសំឡេងដោយអាការពីរោះ ទិសទាំងអស់ភ្លឺស្វាង ខ្យល់ត្រជាក់បក់ត្រសៀកៗ ឲ្យពួកសត្វបានទទួលនូវសេចក្តីសុខ ភ្លៀងធ្លាក់ពុំជួរកាល ទឹកខ្ពុរឡើងអំពីផែនដីហូរទៅ ហូរបក្សីមិនហើរទៅក្នុងអាកាស ស្មឹងក៏ឈប់ហូរ ទឹកក្នុងមហាសមុទ្រមានរសឆ្ងាញ់ កាលព្រះអាទិត្យប្រាសចាកការអ័ពួអួកំពុងប្រាកដនោះឯង ពន្លឺក្នុងអាកាសក៏ភ្លឺស្វាង ទេវតាទាំងពួងមិនមានសេសសល់ និងសត្វនរកទាំងពួងវៀរទេវតាជាន់រូបាវចរ បានប្រាកដរូបរាង ដើមឈើ ជញ្ជាំងផ្ទះ ទ្វារផ្ទះ និងក្តំថ្មជាដើម មិនមានការបិទរាំង ពួកសត្វមិនមានការចុតិ និងបដិសន្ធិក្នុងទិព្វផ្សាយឡើងក្រអូបឈ្ងុយ លុបនូវក្លិនមិនគួរប្រាថ្នាទាំងអស់ចេញបាន ដើមឈើចេញផ្កាផ្លែទាំងអស់ដេរជាស មហាសមុទ្រមានផ្ទៃដេរជាសដោយផ្កាបទុមដែលមានពណ៌ ៥ មានប្រយោជន៍ ក្នុងទីគ្រប់ស្ថាននោះឯង បុព្វជាតិទាំងឡាយដែលកើតលើគោកក្តី ក្នុងទឹកជាដើមក្តី រីកស្គុសស្គាយ បណ្តាដើមឈើទាំងឡាយ ខន្ធបទុមក៏រីកស្គុសស្គាយ ត្រង់ដើម សាខាបទុមក៏រីកស្គុសស្គាយត្រង់មែក លតាបទុមក៏រីកស្គុសស្គាយត្រង់វល្លិ ជុះទម្ងុះផ្ទាំងថ្មលើផ្ទៃផែនដី ត្រួតជាជាន់ៗ ៧ ជាន់ ឈ្មោះថា ទណ្ឌបទុមក្នុងអាកាសក៏កើតផ្កាបទុមសំយុងចុះមក ភ្លៀងផ្កាធ្លាក់ដោយទូទៅ ក្នុងអាកាសមានតន្ត្រីទិព្វបន្លឺឡើង លោកធាតុទាំងមូល មានបែបផែនតែមួយ មានផ្ទៃតវាលវិជនីបក់ ក្រអូបដោយក្លិនផ្កា និងផ្សែងក្រអូប ដល់នូវភាពដ៏ប្រសើរក្រៃលែង ដូចក្រុមមាលាដែលតម្រៀប ដូចគំនរមាលាដែលគេខ្ចប់ចង និងដូចអាសនៈផ្កាដែលគេ

ប្រជាប់តាក់តែង ។ បុព្វនិមិត្តទាំងនោះ បានជានិមិត្តនៃបុគ្គលដែលសម្រេចធម្មវិសេសជាអនេក ដែលសម្រេចធម៌ជាន់ខ្ពស់ ការកើតចំពោះនេះ ប្រជាប់ដោយការជ្រាកដដែលគួរអស្ចារ្យច្រើនយ៉ាងនេះឯង ជាប្រយោជន៍ដែលទ្រង់តាំងទៅដោយចំពោះ បានឈ្មោះថា ពិត មិនខុស មិនវិបរិត ព្រោះសម្រេចយ៉ាងពិតនៃអភិសម្ពោធិញ្ញាណនោះ ។

ម្យ៉ាងទៀត សត្វទាំងឡាយណា ជាពុទ្ធវេនេយ្យ ជាផៅពង្សនៃសត្វដែលនឹងត្រាស់ដឹងទាំងអស់នោះ ព្រះមានព្រះភាគ ទ្រង់ទូន្មានដោយព្រះអង្គឯងយ៉ាងឧក្រិដ្ឋ ។ ឯសត្វទាំងឡាយណា ជាសាវកវេនេយ្យ និងជាធម្ម-វេនេយ្យ សត្វទាំងនោះ កាលសាវកជាដើមប្រៀនប្រដៅហើយ រមែងដល់និងដល់នូវការនាំទៅឲ្យវិសេសបាន ។ ដើម្បីជាប្រយោជន៍ណា ព្រះមានព្រះភាគ ទ្រង់ប្រាថ្នាចំពោះអភិសម្ពោធិញ្ញាណ ព្រោះឲ្យប្រយោជន៍នោះសម្រេចដោយពិត ព្រះអភិសម្ពោធិញ្ញាណ ទើបជាគុណពិត មិនខុស មិនវិបរិត ។

ម្យ៉ាងទៀត សការៈណាមួយ នៃញេយ្យធម៌ណាមួយ ដែលសត្វគប្បីត្រាស់ដឹងសការៈនោះៗ ឈ្មោះថា ដែលព្រះមានព្រះភាគត្រាស់ដឹងក្រៃលែងហើយ ដោយឥតសេសសល់ ដោយមិនខុស ដោយញាណរបស់ព្រះអង្គទាក់ទងដោយហេតុត្រឹមតែទ្រង់អាវជ្ជនៈដល់ ដូចផ្លែកន្ធតព្រៃដែលជាក់លើបាតដៃ ព្រោះហេតុនេះ ទើបអភិសម្ពោធិញ្ញាណរបស់ព្រះអង្គ ឈ្មោះថា ពិត មិនខុស មិនក្លាយជារបស់ដទៃ ។ ម្យ៉ាងទៀត កាលព្រះមានព្រះភាគ ទ្រង់ពិចារណាមើលប្រការនៃធម៌ទាំងនោះ ដែលគប្បីសម្តែងដោយប្រការនោះៗ និង

អធ្យាស្រ័យ អនុស័យ ចរិយា និងអធិមុត្តិរបស់សត្វនោះៗ ដោយប្រពៃនោះឯង ទ្រង់មិនលះធម្មតា មិនកន្ទងន័យរបស់បញ្ញត្តិ និងហេតុត្រឹមតែបញ្ញត្តិធ្វើធម្មតាឲ្យជាក់ច្បាស់ ទ្រង់អនុសាសន៍តាមការខុស តាមអធ្យាស្រ័យ និងតាមធម៌ ទើបទ្រង់នាំវេនេយ្យសត្វឲ្យសម្រេចអរិយភូមិ ។ សូម្បីទ្រង់បញ្ញត្តព្រះធម្មវិនយរបស់ព្រះអង្គ ក៏ឈ្មោះថា ពិត មិនខុស មិនក្លាយជាជនៃព្រោះប្រយោជន៍នោះសម្រេច ព្រោះប្រព្រឹត្តទៅតាមសេចក្តីពិត ។ ម្យ៉ាងទៀត អមតមហានិព្វានធាតុដែលព្រះមានព្រះភាគទ្រង់សម្រេចហើយដោយលំដាប់ ដែលផុតចាកសភាវៈនៃរូប មានបឋវីធាតុជាដើម និងភាវៈនៃអរូបមានផស្សៈ និងវេទនាជាដើម ឈ្មោះថា កន្ទងបង់នូវសភាវៈនៃលោក ព្រោះមិនមានភាវៈ គឺការបោកបញ្ឆោត ឈ្មោះថា មិនមានបច្ចយណាមួយធ្វើឲ្យភ្លឺស្វាង ព្រោះប្រាសចាកងងឹត ឈ្មោះថា ប្រាសចាកភាវៈនៃគតិជាដើម ព្រោះមិនមានឱកាសនោះឯង មិនមានទីតាំងអាស្រ័យ មិនមានអារម្មណ៍ លោកហៅថា អនុបាទិសេស ព្រោះឧបាទិ ពោល គឺខន្ធត្រឹមតែជាចំណែកសេសសល់មិនមាន ដែលទ្រង់សំដៅយកត្រាស់ថា

> ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះ រមែងមានពិត ដីមិនមាន ទឹកមិនមាន ភ្លើងមិនមាន ខ្យល់មិនមាន អាកាសានញ្ចាយនៈមិនមាន វិញ្ញាណញ្ចាយតនៈមិនមាន អាកិញ្ចញ្ញាយតនៈមិនមាន នេវសញ្ញានាសញ្ញាយតនៈមិនមាន លោកនេះមិនមាន លោកមុខមិនមាន ព្រះចន្ទ និងព្រះអាទិត្យ ទាំង ២ ក៏មិនមាន

ក្នុងព្រះនិព្វានណា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលព្រះនិព្វាននោះថា មិនមានដំណើរមក មិនមានដំណើរទៅ មិនមានការតាំងនៅ មិនមានការច្យុត មិនមានការកើត មិនមានទីជាទីតាំង មិនប្រព្រឹត្តទៅ មិនមានអារម្មណ៍ ព្រះនិព្វាននោះ ជាទីបំផុតនៃទុក្ខតែម្យ៉ាង ដូច្នេះ ។

អមតមហានិព្វានធាតុនោះ ដល់នូវការរម្ងាប់សូន្យនៃឧបាទានក្ខន្ធទាំងអស់ ជាសភាវៈស្ងប់នូវសង្ខារ ជាសភាវៈលះបង់នូវឧបាទិក្កិលេសទាំងពួង ជាទីស្ងប់ទុក្ខទាំងពួង ជាទីដកនូវសេចក្តីអាល័យទាំងពួង ជាទីកាត់ផ្តាច់នូវវដ្តៈទាំងពួង ទីនោះ ស្ងប់ពិត ប្រណីតពិតជាលក្ខណៈ ព្រោះដូច្នោះ ទើបអមត-មហានិព្វាននោះ ឈ្មោះថា ពិត មិនខុស មិនវិបរិត ព្រោះមិនពោលសភាវៈតាមសេចក្តីពិត ឲ្យឃ្លៀងឃ្លាតក្នុងកាលណាមួយ ។ ទ្រង់ឈ្មោះថា តថាគត ព្រោះយាងទៅ ទ្រង់ចូលដល់ សម្រេច ប្រព្រឹត្តទៅ យាងដល់ដោយពិតនូវអមតមហានិព្វានធាតុនោះ មានអភិជាតិជាដើម ដោយប្រការដូច្នេះ ។ ព្រោះហេតុនេះ ទើបព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះស្ងប់ទៅដោយពិត ។

ទ្រង់ឈ្មោះថា តថាគត ព្រោះមានការពិតដូចម្តេច គឺព្រះសម្មាសម្ពុទ្ធទាំងឡាយក្នុងកាលមុន មានសភាពយ៉ាងណា ព្រះមានព្រះភាគអង្គនោះ ក៏មានសភាពយ៉ាងនោះ សេចក្តីនេះ លោកអធិប្បាយដូចម្តេច ដោយសង្ខេប លោកពោលដូច្នេះថា ព្រះមានព្រះភាគអង្គនោះ មានប្រការយ៉ាងណា គឺទ្រង់

បរិបូណ៌ដោយមគ្គសីល ផលសីល លោកិយ លោកុត្តរសីលទាំងអស់ មគ្គសមាធិ ផលសមាធិ លោកិយ លោកុត្តរសមាធិទាំងពួង ដោយមគ្គប្បញ្ញា ផលប្បញ្ញា ដោយលោកិយ លោកុត្តរប្បញ្ញាទាំងពួង ដោយផលសមាបត្តិវិហារ ២ លាន ៤ សែនកោដិ ដែលទ្រង់ប្រើជាប្រចាំ ដោយតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និស្សរណវិមុត្តិ ដូច្នេះ តែកាលពោលដោយពិស្តារ ដោយគុណនៃព្រះសព្វញ្ញុទាំងមូល ដែលមានអានុភាពជាអាចិន្តេយ្យ មានគុណដែលមិនមានទីបំផុត ព្រះមានព្រះភាគក៏មានប្រការយ៉ាងនោះ ។

សេចក្តីពិត ព្រះសម្មាសម្ពុទ្ធទាំងពួង គប្បីមានការផ្សេងគ្នា ៥ ប្រការ គឺផ្សេងគ្នាដោយអាយុ ១ ការផ្សេងគ្នានៃប្រមាណព្រះសរីរៈ ១ ការផ្សេងគ្នានៃត្រកូល ១ ការផ្សេងគ្នានៃការបំពេញទុក្ករកិរិយា ១ ផ្សេងគ្នានៃព្រះរស្មី ១ ។ តែក្នុងវិសុទ្ធិ មានសីលវិសុទ្ធិជាដើម ក្នុងកិច្ចបដិបត្តិសមថៈ និងវិបស្សនា ក្នុងព្រះគុណដែលទ្រង់ត្រាស់ដឹង មិនមានហេតុណាមួយដែលធ្វើឲ្យផ្សេងគ្នាឡើយ ។ ដោយពិត ព្រះមានព្រះភាគទាំងឡាយនោះ មិនវិសេសជាងគ្នានិងគ្នា ដូចមាសដែលបាក់ត្រង់កណ្តាល ព្រោះហេតុនោះ ព្រោះសម្មាសម្ពុទ្ធក្នុងកាលមុន មានប្រការយ៉ាងណា ព្រះមានព្រះភាគនៃយើងនេះ ក៏មានប្រការយ៉ាងនោះ ព្រោះហេតុនេះ ទើបទ្រង់ព្រះនាមថា តថាគត ព្រោះមានប្រការយ៉ាងនោះ ។ ក្នុងទីនេះ **គត** *សព្ទ មាន* **៧ជ** *សព្ទជាអត្ថ ។ ពិតហើយ សត្វលោកពោល* **គត** *សព្ទដែលប្រកបដោយ* **៧ជ** *សព្ទមានប្រការ*

ជាអត្ត ។

ទ្រង់ព្រះនាមថា តថាគត ព្រោះប្រព្រឹត្តទៅដោយប្រការនោះដូចម្តេច គឺ ទ្រង់ព្រះនាមថា តថាគត ព្រោះមានការប្រព្រឹត្តទៅតាមព្រះកាយ ព្រះវាចា និងព្រះហឫទ័យដែលទៅ ជាទីទៅ ជាការយាងទៅ ដោយប្រការតាមដែល ពេញព្រះហឫទ័យ ព្រោះមិនមានការប៉ះពាល់ក្នុងអ្វីមួយ នៃការប្រព្រឹត្តទៅ ផ្លូវព្រះកាយជាដើមរបស់ព្រះមានព្រះភាគ ព្រោះទ្រង់ប្រកបដោយឥទ្ធានុភាព ដែលមិនទូទៅដល់អ្នកដទៃ ព្រោះសម្រេចបារមីដ៏កំពូលនៃបដិសម្ភិទា មាន អត្ថប្បដិសម្ភិទាជាដើម និងហេតុដែលទ្រង់បានទទួលអនាវរណញ្ញាណ ព្រោះ ហេតុយ៉ាងនេះ ទើបទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់យាងទៅដោយ ប្រការនោះ ។

*ទ្រង់ព្រះនាមថា តថាគត ព្រោះមិនប្រាសចាកព្រះញាណដែលពិតដូច ម្តេច គឺទ្រង់ឈ្មោះថា **អគត** ព្រោះមិនមានការទៅ ពោល គឺការប្រព្រឹត្តទៅ ដែលជាសត្រូវចំពោះព្រះញាណ ក្នុងការសន្សំពោធិសម្ភារ ។ ការដែល ព្រះអង្គមិនប្រាសចាកព្រះញាណនោះ ឈ្មោះថា តថាគត ព្រោះមិនប្រាសចាក ព្រះញាណដែលប្រព្រឹត្តទៅដោយនយ មានការពិចារណាទោស និងអានិសង្ស ជាដើម ដោយមិនខុសប្លែកក្នុងធម៌ មានការកំណាញ់ និងទានបារមីជាដើម ។ ម្យ៉ាងទៀត ព្រះអង្គឈ្មោះថា **អគត** ព្រោះមិនមានការយាងទៅ ការទៅក្នុង គតិ ៥ ពោល គឺការប្រព្រឹត្តទៅនៃអភិសង្ខារ គឺកិលេស ពោល គឺការ ប្រព្រឹត្តទៅនៃខន្ធនោះឯង ការៈដែលទ្រង់មិនទៅនោះ ដោយទ្រង់សម្រេច*

សឧបាទិសេសនិព្វាន និងអនុបាទិសេសនិព្វាន ដោយអរិយមគ្គញ្ញាណយ៉ាងពិត ព្រោះហេតុយ៉ាងនេះ ទើបព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះមិនទៅប្រាសចាកព្រះញាណដែលពិត ។

ទ្រង់ព្រះនាមថា តថាគត ព្រោះមានការៈប្រព្រឹត្តទៅដោយពិតដូចម្តេច គឺបទថា **តថាគតការេន** *បានដល់ ដោយសការៈ ដែលទ្រង់យាងទៅដោយពិត អធិប្បាយថា ការៈដែលទ្រង់យាងទៅដោយពិត មាន ។ សួរថា ព្រះមានព្រះភាគដែលគេថ្វាយព្រះនាមថា* **តថាគត** *ព្រោះភាពដែលទ្រង់យាងទៅ ដោយពិតនោះ គឺអ្វី ឆ្លើយថា គឺព្រះសទ្ធម្ម ។ ពិតហើយ ព្រះសទ្ធម្មលំជាប់ដំបូង គឺអរិយមគ្គ អធិប្បាយថា ទ្រង់យាងទៅដោយប្រការដែលទ្រង់ដកនូវកិលេសជាបដិបក្ខបានដោយសមុច្ឆេទ ដោយកម្លាំង គឺសមថៈ និងវិបស្សនា ដែលជាគូគ្នា ទើបទ្រង់សម្រេចដោយសមុច្ឆេទប្បហាន បានដល់ផលធម៌ដែលទ្រង់ទៅ គឺប្រព្រឹត្តទៅដោយប្រការដែលទ្រង់សម្រេចដោយបដិបស្សទ្ធិប្បហាន តាមសមគួរដល់មគ្គ ។ ឯនិព្វានធម៌ដែលព្រះពុទ្ធជាដើមទ្រង់យាងដល់ គឺធ្វើឲ្យជាក់ច្បាស់ដោយប្រការដែលទ្រង់យាងដល់ គឺត្រាស់ដឹងដោយបញ្ញា ដែលសម្រេចដោយការស្ងប់ទុក្ខក្នុងវដ្តៈទាំងមូល ព្រោះដូច្នោះ ទើបឈ្មោះថា តថាគត សូម្បីបរិយត្តិធម៌ ក៏ឈ្មោះថា តថាគត ព្រោះព្រះមានព្រះភាគនៃយើង ទ្រង់យាងទៅ គឺត្រាស់ បានដល់ ប្រកាសដោយប្រការដែលព្រះបរិយត្តិធម៌នោះ ដែលព្រះពុទ្ធក្នុងកាលមុន ទ្រង់ប្រកាសឲ្យសមគួរដល់អធ្យាស្រ័យជាដើមរបស់វេនេយ្យសត្វ ដោយសុត្តៈ និងគេយ្យៈ*

ជាដើម និងដោយការប្រកាស ការប្រព្រឹត្តទៅជាដើម ។ ឈ្មោះថា តថាគត ព្រោះសាវ័កបស់ព្រះមានព្រះភាគប្រព្រឹត្តទៅ គឺដើរតាមដោយប្រការដែល ព្រះបរិយត្តិធម៌នោះ ព្រះមានព្រះភាគទ្រង់សម្តែងហើយ ព្រោះហេតុយ៉ាងនេះ ទើបព្រះសទ្ធម្មទាំងអស់ ឈ្មោះថា តថាគត ដែលប្រព្រឹត្តទៅដោយពិត ។ ព្រោះហេតុនោះ ទើបសក្កទេវរាជត្រាស់ថា យើងទាំងឡាយ សូមនមស្ការ នូវព្រះធម៌ដែលមានមកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមមានសិរីសួស្តី ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់មានព្រះសទ្ធម្មនោះ ។ ម្យ៉ាងទៀត ព្រះធម៌យ៉ាងណា សូម្បីព្រះអរិយសង្ឃ ក៏យ៉ាងនោះ ឈ្មោះថា តថាគត ព្រោះប្រព្រឹត្តទៅ ដោយប្រការដែលអ្នក បដិបត្តិដើម្បីជាប្រយោជន៍ដល់ខ្លួន និងដើម្បីជាប្រយោជន៍ដល់អ្នកដទៃបំពេញ បដិបទា គឺសមថៈ និងវិបស្សនាដែលជាចំណែកខាងដើមឲ្យបរិសុទ្ធដោយល្អ ជាខាងមុខហើយ ទើបសម្រេចដោយមគ្គនោះៗ ។ ម្យ៉ាងទៀត ឈ្មោះថា តថាគត ព្រោះត្រាស់ដឹង និងព្រោះត្រាស់ដោយប្រការដែលសច្ចៈ និងបដិច្ច-សមុប្បាទជាដើម ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយហេតុនោះ ទើបសក្កទេវរាជត្រាស់ថា យើងទាំងឡាយ សូមនមស្ការ នូវព្រះសង្ឃដែលមានមកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមមានសិរីសួស្តី ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ជាបុគ្គល មានសង្ឃនោះជាសាវ័ក ។ ព្រោះហេតុយ៉ាងនេះ ទើបទ្រង់ព្រះនាមថា តថាគត ព្រោះមានការៈប្រព្រឹត្តទៅដោយពិតនោះឯង ។

បទថា **តថាគត** *នេះ ត្រឹមតែជាប្រធានក្នុងការសម្តែងការៈដែលព្រះតថាគតទ្រង់យាងទៅដោយពិតនោះឯង ។ ព្រះតថាគតប៉ុណ្ណោះគប្បីពណ៌នាសេចក្តីដែលព្រះតថាគតប្រព្រឹត្តទៅដោយពិត ។ ពិតហើយ បទថា* **តថាគត** *នេះ មានអត្ថច្រើន មានគតិច្រើន មានអារម្មណ៍ច្រើន ។ ព្រះធម្មកថិកនាំព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកនៃតថាគតបទនោះមក ដូចអប្បមាទបទដោយសមគួរ ដោយការៈមានប្រយោជន៍ បុគ្គលណាម្នាក់ មិនគួរពោលថា ព្រះធម្មកថិករសាត់ទៅខុសកំពង់ឡើយ ។ ក្នុងសេចក្តីនោះ លោកពោលពាក្យជាគាថាថា*

ព្រះមុនីទាំងឡាយ ក្នុងកាលមុន ជាអ្នកស្វែងរកគុណធំ មកដល់ភាពជាព្រះសព្វញ្ញូក្នុងលោកនេះ ដោយប្រការណា សូម្បីព្រះសក្យមុនី ក៏យាងមក ដោយប្រការនោះ ព្រោះហេតុនោះ ទើបព្រះសក្យមុនីដ៏មានចក្ខុ សត្វលោកថ្វាយព្រះនាមថា តថាគត ។

ព្រះជិនស្រីទាំងឡាយ ទ្រង់លះមន្ទិល គឺកិលេស មានកាមជាដើមបានជាសមុច្ឆេទ ដោយសមាធិ និងបញ្ញាហើយ ទើបប្រព្រឹត្តទៅ ដោយប្រការណា ព្រះសក្យមុនីក្នុងកាលមុន ទ្រង់ទ្រទ្រង់ទុកនូវភាពរុងរឿង យាងទៅដោយប្រការនោះ ព្រោះដូច្នោះ ទើបសត្វលោកថ្វាយព្រះនាមថា តថាគត ។

ម្យ៉ាងទៀត ព្រះជិនស្រីយាងដល់ព្រមនូវលក្ខណៈនៃធាតុ និងអាយតនៈជាដើម ដែលពិត ដោយចែកសការៈ សាមញ្ញ និងវិភាគ ដោយព្រះសយម្ភូញាណ ព្រោះដូច្នោះ ទើបព្រះសក្យៈដ៏ប្រសើរ សត្វលោកថ្វាយព្រះ

នាមថា តថាគត ។

សច្ចៈដែលពិត និងឥទប្បច្ចយតាដែលពិត ដែលអ្នកដទៃឲ្យប្រព្រឹត្ត ទៅមិនបាន ដែលព្រះតថាគត មានសមន្តចក្ខុទ្រង់ប្រកាសហើយ ដោយនយ ដោយប្រការទាំងពួង ព្រោះដូច្នោះ ទើបព្រះជិនស្រីយាងទៅដោយពិត សត្វ លោកថ្វាយព្រះនាមថា តថាគត ។

ព្រះជិនស្រី ទ្រង់ឃើញដោយពិត ក្នុងលោកធាតុ មានប្រមាណមិន មែនតិច ក្នុងអារម្មណ៍ មានរូបាយតនៈជាដើម មានសភាពជ័រវិចិត្រ ព្រោះ ដូច្នោះ ទើបព្រះសមន្តចក្ខុ សត្វលោកថ្វាយព្រះនាមថា តថាគត ។

ម្យ៉ាងទៀត ព្រោះទ្រង់សម្តែងធម៌យ៉ាងពិត ឬទ្រង់ធ្វើព្រះអង្គឲ្យសមគួរ ដល់ធម៌នោះ ទ្រង់គ្របសង្កត់សត្វលោក ដោយព្រះគុណទាំងឡាយ ព្រោះ ហេតុនោះ ទើបព្រះលោកនាយក សត្វលោកថ្វាយព្រះនាមថា តថាគត ។

ម្យ៉ាងទៀត ទ្រង់ត្រាស់ដឹងដោយបរិញ្ញាដែលពិត ដោយប្រការទាំងពួង ទ្រង់ឆ្លងលោក ដល់នូវការរម្ងាប់ ដោយការធ្វើឲ្យប្រចក្ស ទ្រង់ដល់អរិយមគ្គ ដូច្នោះ ទើបទ្រង់ព្រះនាមថា តថាគត ។

ម្យ៉ាងទៀត ព្រោះទ្រង់ប្រកបដោយប្រយោជន៍ ដល់សត្វលោក ទ្រង់ ប្តេជ្ញាយ៉ាងពិត ដោយប្រការទាំងពួង ទ្រង់ជាលោកនាថ ដោយព្រះករុណា ដោយប្រការទាំងពួង យាងទៅ ព្រោះហេតុនោះ ទើបព្រះជិនស្រី សត្វ លោកថ្វាយព្រះនាមថា តថាគត ។

ទ្រង់កើតឡើងអំពីអកិជាតិយ៉ាងពិត ព្រោះទ្រង់ពិចារណាអារម្មណ៍តាម

ពិត ដូច្នោះ ទើបសត្វលោកថ្វាយព្រះនាមថា តថាគត ។ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ធ្វើប្រយោជន៍នោះឲ្យសម្រេច ។

ព្រះមហេសី ក្នុងកាលមុននោះ មានសភាពយ៉ាងណា សូម្បីព្រះមានព្រះភាគអង្គនេះ ក៏មានសភាពយ៉ាងនោះតាមពេញព្រះហឫទ័យ ព្រោះទ្រង់ជាអគ្គបុគ្គល សត្វលោកថ្វាយព្រះនាមថា តថាគត ព្រោះមានព្រះហឫទ័យប្រព្រឹត្តទៅ តាមព្រះវាចាដែលទ្រង់ប្រកាស ។

ក្នុងជាតិមុនៗ ព្រោះទ្រង់មិនទៅចាកធម៌ ដែលជាសត្រូវចំពោះពោធិ-សម្ភារ ការទៅក្នុងសង្សារ ក៏មិនមានដល់ព្រះអង្គ សង្សារនេះ មិនមានដល់ព្រះតថាគត ដែលជានាថ ទ្រង់ឃើញទីបំផុតភព ព្រោះដូច្នោះ ទ្រង់មិនច្រាសចាកញាណដែលពិត ទើបសត្វលោកថ្វាយព្រះនាមថា តថាគត ។

ព្រះធម៌ដ៏ប្រសើរ ដែលព្រះមហេសីត្រាស់ ដោយប្រការដែលលះមន្ទិល ដែលគួរលះ ព្រោះដូច្នោះ ទើបព្រះធម៌នោះ ឈ្មោះថា តថាគត ។ ព្រះអរិយសង្ឃរបស់ព្រះសាស្តា ឈ្មោះថា តថាគត ព្រោះជាអ្នកដល់ព្រមដោយព្រះធម៌ដ៏ប្រសើរនោះ ។

បទថា **មហិទ្ធិកតា** *សេចក្តីថា ការប្រកបដោយមហិទ្ធិឫទ្ធិ ពោល គឺ ភាពជាអ្នកញុំងសេចក្តីប្រាថ្នាជនៃឲ្យសម្រេច ដោយអានុភាពនៃធម៌ ព្រោះមានការជំនាញផ្លូវចិត្ត និងប្រកបដោយឫទ្ធិផ្សេងៗ យ៉ាងក្រៃលែង ទើបឈ្មោះថា* **មហិទ្ធិកតា** ។ *ការប្រកបដោយតេជៈនៃបុណ្យដ៏រុងរឿងក្រៃលែង ជាហេតុឲ្យសម្រេចប្រយោជន៍តាមប្រាថ្នា នៅឆ្ងាយក្រៃលែងអំពីសត្រូវ ដែល*

កើតមកអស់កាលយូរ ឈ្មោះថា **មហាឧក្កាវតា។** *សព្ទថា* **យត្រ** *ជានិបាត ចុះក្នុងអត្ថបឋមាវិភត្តិ ដែលញុំងភាពអស្ចារ្យ ការសរសើរ ការក្រាក់ផ្តើល ការត្រេកអរឲ្យសម្រេច ។ បទថា* **វិជាយិស្សតិ** *ជាពាក្យចង្អុលដល់អនាគតកាល ព្រោះប្រកបដោយបទថា* **យត្រ** *នោះ ។ តែអត្ថ ប្រើក្នុងអត្ថអតីត-កាលប៉ុណ្ណោះ ។ ក្នុងសេចក្តីនេះ មានអធិប្បាយដូចតទៅនេះថា ពិតហើយ ឈ្មោះថា ព្រះនាងសុប្បវាសានេះ លិចចុះក្នុងកងទុក្ខ ជួបនូវសេចក្តីលំបាកបែបនោះ ដំណាលគ្នានឹងពេលដែលព្រះមានព្រះភាគត្រាស់នោះឯង ទើបមានសេចក្តីសុខ មិនមានរោគ ប្រសូតព្រះឱរស ប្រាសចាករោគ ។ បទថា* **អត្តមនោ** *ប្រែថា មានចិត្តជារបស់ខ្លួន ។ អធិប្បាយថា មានចិត្តប្រាសចាកកិលេស ព្រោះជ្រះថ្លាក្នុងព្រះមានព្រះភាគ ។ ពិតហើយ ចិត្តដែលត្រូវកិលេសចោមរោមបុគ្គលណា មិនអាចពោលថា មានចិត្តជារបស់ខ្លួនឡើយ ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ។ ម្យ៉ាងទៀត បទថា* **អត្តមនោ** *បានដល់ មានចិត្តដែលបីតិ និងសោមនស្សពាល់ត្រូវហើយ ។ បទថា* **បមុទិតោ** *ប្រែថា ប្រកបដោយបាមោជ្ជ ។ បទថា* **បីតិសោមនស្សជាតោ** *ប្រែថា កើតបីតិ និងសោមនស្សដ៏ខ្លាំងក្លា ។*

[៦១] *បទថា* **អថ** *ប្រែថា ខាងក្រោយ គឺកន្លងទៅ ២ ឬ ៣ ថ្ងៃអំពីនោះ ។ បទថា* **សត្តភត្តានិ** *បានដល់ កត្តដែលគប្បីថ្វាយក្នុង ៧ ថ្ងៃ ។*

[៦២] *បទថា* **ស្វាតនាយ** *សេចក្តីថា ដើម្បីបុណ្យដែលនឹងមានក្នុងថ្ងៃស្អែកនេះ គឺដើម្បីបុណ្យដែលនឹងមានក្នុងថ្ងៃស្អែកនេះ ដោយការថ្វាយ*

ទាន និងដោយការចូលទៅអង្គុយជិតព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ។ បទ
ថា **អថខោ ភគវា អាយស្មន្តំ មហាមោគ្គល្លានំ អាមន្តេសិ** *សួរថា ព្រោះ*
ហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ហៅ ។ ឆ្លើយថា ដើម្បីរក្សាការជ្រះថ្លា
របស់ព្រះស្វាមីនៃព្រះនាងសុប្បវាសា ។ ព្រះនាងសុប្បវាសា ជាបុគ្គលមាន
ការជ្រះថ្លាមិនលម្អៀង ។ តែការរក្សាការជ្រះថ្លារបស់ឧបាសក ជានាទីរបស់
ព្រះមហាមោគ្គល្លានត្ថេរ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា គេជាឧបដ្ឋាក
របស់អ្នក ។

បណ្តាបទទាំងនោះ បទថា **តុយ្ហេសោ** *កាត់បទជា* **តុយ្ហំ ឯសោ ។**
ដោយបទថា **តិណ្ណំ ធម្មានំ បដិភោគោ** *លោកសម្តែងថា បើព្រះមហា*
មោគ្គល្លានធានា គឺជាអ្នករ៉ាប់រង ដើម្បីមិនឲ្យធម៌ ៣ ប្រការ មានភោគៈជា
ដើមរបស់ខ្ញុំសាបសូន្យ គឺវិនាស គឺបើលោកម្ចាស់ជីងថា ៧ ថ្ងៃ បន្ទាប់អំពី
ថ្ងៃនេះទៅ ខ្ញុំអាចឲ្យទានបាន ។ ឯព្រះថេរៈឃើញការមិនមានអន្តរាយនៃ
ភោគៈ និងជីវិតរបស់ឧបាសកក្នុងថ្ងៃទាំងនោះ ទើបពោលថា ម្នាលអាវុសោ
ខ្លួនអាត្មាជានាឲ្យអ្នកតែធម៌ទាំង ២ យ៉ាង គឺភោគៈ ១ ជីវិត ១ ។ តែសទ្ធា
ជាគុណជាតទាក់ទងនៅក្នុងចិត្តរបស់ឧបាសកនោះ ព្រោះហេតុនោះ ព្រះថេរៈ
កាលធ្វើឲ្យជាការៈរបស់ឧបាសកប៉ុណ្ណោះ ទើបពោលថា ឯខ្លួនរបស់អ្នកត្រូវ
តែជានាសទ្ធាខ្លួនឯងចុះ ។ ម្យ៉ាងទៀត ឧបាសកនោះ ជាអ្នកឃើញសច្ចៈ
ហើយ កាពដែលសទ្ធារបស់ឧបាសកនោះប្រែប្រួលទៅជាដទៃ រមែងមិនមាន
ព្រោះហេតុនោះ ទើបព្រះថេរៈពោលយ៉ាងនោះ ។ ព្រោះហេតុនោះឯង ទើប

ព្រះមានព្រះភាគត្រាស់ថា ចូរអ្នកឲ្យឧបាសកយល់ព្រមថា ខ្លួនអ្នកនឹងធ្វើក្រោយ ។ ចំណែកឧបាសកប្រាប្តាសេចក្តីចម្រើន ដោយការគោរពក្នុងព្រះសាស្តា និងព្រះថេរៈ និងដោយបុណ្យរបស់ព្រះនាងសុប្បវាសា ដែលជាអ្នកមានសេចក្តីសុខ ទើបយល់ព្រមថា សូមឲ្យកោលិយធីតា ព្រះនាមសុប្ប-វាសា ធ្វើភត្ត ៧ ថ្ងៃសិនចុះ ខ្លួនខ្ញុំចាំធ្វើក្រោយ ។

បទថា **តញ្ច ធារកំ** *សេចក្តីថា ចាប់តាំងអំពីថ្ងៃប្រសូតហើយ កន្លងទៅដល់ថ្ងៃទី ១១ បន្ទាប់អំពីនោះ ទើបឲ្យភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឆាន់ ៧ ថ្ងៃ ហើយទើបឲ្យទារកមានអាយុ ៧ ខួបនោះ ថ្វាយបង្គំព្រះមានព្រះភាគ និងនមស្ការភិក្ខុសង្ឃ ក្នុងថ្ងៃទី ៧ ។ បទថា* **សត្ត មេ វស្សានិ** *ប្រែថា ខ្ញុំមានអាយុ ៧ ឆ្នាំ ។ បទថា* **វស្សានិ** *នេះជាទុតិយាវិភត្តិ ប្រើក្នុងអត្ថថា អច្ចន្តសំយោគ ប្រែថា រហូត ។ ពាក្យថា* **លោហិតកុម្ភិយំ វុត្ថានិ** *លោកពោលសំដៅយកទុក្ខដែលខ្លួននៅក្នុងគភ៌របស់មាតា ។ បទថា* **អញ្ញានិបិ ឍវ្ហថានិ សត្ត បុត្តានិ** *សេចក្តីថា កាលគួរនឹងពោលថា* **អញ្ញេបិ ឍវ្ហបេ សត្ត បុត្តេ** *លោកពោលដោយលិង្គវិបល្លាសថា* **ឍវ្ហថានិ ។** *អធិប្បាយថា នូវបុត្រដែលកើតឡើង បានទទួលទុក្ខយ៉ាងខ្លាំងក្លា ព្រោះនៅក្នុងគភ៌ ៧ ឆ្នាំ និងព្រោះវង្វេងគភ៌ ៧ ថ្ងៃ ដោយប្រការដូច្នេះ ។ ដោយពាក្យនោះ លោកសម្តែងថា មាតុគ្រាមទាំងឡាយ មិនឆ្អែតព្រោះការចង់បានកូន ព្រោះមាតុ-គ្រាមជាអ្នកចង់បានកូន ។*

បទថា **ឯតមត្តំ វិនិគ្ឃា** *សេចក្តីថា ទ្រង់ជ្រាបអត្តនេះ ដែលព្រះនាង*

ពោលដោយការចង់បានបុត្រ ព្រោះរួមទុក្ខយ៉ាងខ្លាំងក្លា ដែលប្រព្រឹត្តទៅដោយការទ្រទ្រង់នូវគភ៌ជាដើមអស់ ៧ ឆ្នាំ ៧ ថ្ងៃ ចូលក្នុងបទតែមួយ ដោយបទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់បន្ទឺឧទាននេះ សម្តែងការៈ គឺកន្ទងបុគ្គលដែលប្រមាទដោយអាការដែលគួរជ្រាបថ្នា ទើបធ្វើប្រយោជន៍ក្នុងការលះស្នេហាដោយតណ្ហា ដូចបុគ្គលដែលស្រវឹងដោយសុខតាមផ្លូវចិត្ត ដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **អសាតំ** បានដល់ មិនឆ្ងាញ់ មិនល្អ មិនគួរជ្រាបថ្នា ។ បទថា **សាតរូបេន** ប្រែថា មានសការៈគួរជ្រាបថ្នា ។ បទថា **បិយរូបេន** ប្រែថា មានការៈដែលគួរស្រឡាញ់ ។ បទថា **សុខរូបេន** បានដល់ មានការៈជាសុខ ។ លោកអធិប្បាយពាក្យនេះថា ព្រោះហេតុដែលសង្ខារប្រព្រឹត្តទៅក្នុងវដ្តៈទាំងមូល មិនគួរត្រេកអរ មិនគួរស្រឡាញ់ ជាទុក្ខពិត ប្រាកដដូចគួរជ្រាបថ្នា គួរស្រឡាញ់ ជាសុខ ព្រោះធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ ព្រោះលះវិបល្លាសមិនបាន រមែងកន្ទង គ្របសង្កត់លិចលង់បុគ្គលអ្នកប្រមាទ ព្រោះប្រាសចាកស្មារតី ដូច្នោះ ទុក្ខដែលមិនគួរត្រេកអរ មិនគួរជ្រាបថ្នាបែបនោះ រមែងលិចលង់ព្រះនាងសុប្បវាសានេះ ៧ ជងទៀត ដោយទុក្ខដែលមានចំណែកប្រៀបដូចសេចក្តីសុខជាដើម គឺដោយវដ្តទុក្ខដែលកើតអំពីសេចក្តីស្រឡាញ់ គឺបុត្រ ។

អដ្ឋកថាសុប្បវាសាសូត្រទី ៨ ចប់

សុត្តន្តបិដក

វិសាខាសូត្រ

[៦៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទនៃមិគារមាតា ក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង ប្រយោជន៍ណាមួយ របស់នាងវិសាខាមិគារមាតា ជាប្រយោជន៍ជាប់ទាក់ទងនឹងព្រះបាទបសេនទិកោសល ។ ព្រះបាទបសេនទិកោសល ទ្រង់មិនពិចារណាប្រយោជន៍នោះ តាមបំណងឡើយ ។ គ្រានោះ នាងវិសាខាមិគារមាតា ចូលទៅគាល់ព្រះមានព្រះភាគ ទាំងថ្ងៃក្តៅ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលនាងវិសាខា នាងមកអំពីណា ទាំងថ្ងៃក្តៅម្ល៉េះ ។ នាងវិសាខាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រយោជន៍នីមួយ របស់ខ្ញុំព្រះអង្គក្នុងទីនេះ ជាប្រយោជន៍ជាប់ទាក់ទងនឹងព្រះបាទបសេនទិកោសល ព្រះបាទបសេនទិកោសលទ្រង់មិនពិចារណាប្រយោជន៍នោះ តាមបំណងឡើយ ។ លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

(ប្រយោជន៍ណាមួយ) ដែលនៅក្នុងអំណាចនៃជនដទៃទាំងអស់
នាំមកនូវទុក្ខ ឥស្សរភាពទាំងអស់ នាំមកនូវសុខ សត្វទាំងឡាយ
ដែលជ្រមុជទៅក្នុងហេតុនៃទុក្ខទូទៅ តែងនឿយព្រួយព្រោះកិលេស

ជាគ្រឿងប្រកបទាំងឡាយ សត្វកន្ទងបានដោយក្រ ។ សូត្រទី ៩ ។

អដ្ឋកថា

វិសាខាសូត្រ

វិសាខាសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ

[៦៣] *បទថា* **បុព្វារាមេ** *បានដល់ ក្នុងអារាមដែលសាងឡើងក្នុងទិដូចឧត្តមទេវវិហារនៃអនុរាធបុរី ក្នុងទិសខាងកើតនៃក្រុងសាវត្ថី ។ បទថា* **មិគារមាតុបាសាទេ** *ប្រែថា ក្នុងប្រាសាទរបស់មិគារមាតា ។ ក្នុងសេចក្តីនោះ មានអនុបុព្វីកថាដូចតទៅនេះ*

ក្នុងអតីតកាល ក្នុងទីបំផុតមួយសែនកប្ប ឧបាសិកាម្នាក់ ឃើញព្រះទសពលព្រះនាមបទុមុត្តរៈ ទ្រង់ស្ថាបនាឧបាសិកាម្នាក់ ទុកក្នុងតំណែងអគ្គ-ឧបដ្ឋាយិការបស់ព្រះអង្គ ទើបទូលនិមន្តព្រះមានព្រះភាគ ថ្វាយទានដល់ភិក្ខុមួយសែន មានព្រះពុទ្ធជាប្រធាន ធ្វើការនមស្ការចំពោះព្រះមានព្រះភាគ រួចតាំងសេចក្តីប្រាថ្នាថា ក្នុងអនាគត សូមឲ្យខ្ញុំម្ចាស់បានជាឧបដ្ឋាយិការបស់ព្រះសម្ពុទ្ធ ដូចគ្នានឹងព្រះអង្គ ។ នាងអន្ទោលទៅក្នុងទេវតា និងមនុស្ស អស់មួយសែនកប្ប ក្នុងកាលនៃព្រះមានព្រះភាគរបស់យើង ទើបបដិសន្ធិក្នុងគភ៌របស់សុមនទេវី ក្នុងគេហាសនៈរបស់ធនញ្ជយសេដ្ឋី ដែលជាបុត្ររបស់មេណ្ឌកសេដ្ឋី ក្នុងកទ្ទិយនគរ ក្នុងពេលដែលនាងកើត ជនទាំងឡាយបានឲ្យ

ឈ្មោះនាងថា **វិសាខា។** *ក្នុងគ្រាដែលព្រះមានព្រះភាគ យាងទៅកន្លែងនាងមួយអន្លើដោយទាហិកា ៥០០ ទៅទទួលព្រះមានព្រះភាគ បានជាព្រះ-សោតាបន្ន ព្រោះការបានគាល់ដំបូងនោះឯង ។*

ខាងក្រោយមក នាងទៅកាន់គេហាសនៈរបស់បុណ្ណវឌ្ឍនកុមារ ដែលជាបុត្ររបស់មិគារសេដ្ឋី ក្នុងក្រុងសាវត្ថី មិគារសេដ្ឋីដែលជាឪពុកក្មេក តាំងនាងទុកក្នុងឋានៈជាមាតា ដោយជាអ្នកមានឧបការៈក្នុងគេហាសនៈនោះ ព្រោះដូច្នោះ ទើបគេឲ្យឈ្មោះថា មិគារមាតា នាងលះគ្រឿងប្រដាប់ឈ្មោះមហា-លតារបស់ខ្លួន ដោយប្រើទ្រព្យ ៩ កោដិសាងប្រាសាទ ប្រដាប់ដោយបន្ទប់ ១០០០ គឺខាងលើ ៥០០ បន្ទប់ ខាងក្រោម ៥០០ បន្ទប់ ក្នុងផែ្ទដីប្រមាណមួយកវីស ដើម្បីជាទីគង់ប្រថាប់របស់ព្រះមានព្រះភាគ និងភិក្ខុសង្ឃ ដោយហេតុនោះ ទើបលោកពោលថា ក្នុងប្រាសាទនៃមិគារមាតា ។

បទថា **កោចិទេវ អត្ថោ** *ប្រែថា ប្រយោជន៍ឯណានីមួយ ។ បទថា* **រញ្ញោ** *ប្រែថា ព្រះរាជា ។ បទថា* **បដិពាទ្ធោ** *ប្រែថា ទាក់ទងដល់គ្នានិងគ្នា ។ ពួកញាតិរបស់នាងវិសាខាបញ្ជូនរបស់ដូច្នោះ ដែលវិចិត្រដោយកែវមណី និងកែវមុក្តាជាដើមពីត្រកូលញាតិទៅដើម្បីជាបណ្ណាការដល់នាង ទ្រព្យនោះគ្រាន់តែដល់ទ្វារក្រុង ទើបពួកគយដកពន្ធក្នុងទីនោះ តែមិនដកឲ្យសមគួរដល់ទ្រព្យនោះ ដកហួសប្រមាណ ។ នាងវិសាខាបានស្តាប់ដូច្នោះ បំណងនឹងទូលសេចក្តីនោះដល់ព្រះរាជា ទើបបានទៅកាន់ព្រះរាជនិវេសន៍ មួយអន្លើដោយបរិវារតាមសមគួរ ខណៈនោះ ព្រះរាជា មួយអន្លើដោយព្រះនាងមល្លិកាទេវី*

បានយាងទៅខាងក្នុងព្រះដំណាក់ នាងវិសាខា កាលមិនបានឱកាស ទើបគិត ថា អញនឹងបានក្នុងឥឡូវនេះ អញនឹងបានក្នុងឥឡូវនេះ ជាអ្នកកាត់នូវការ បរិភោគអាហារ ព្រោះកន្ធងពេលបរិភោគ ទើបចៀសចេញទៅ ។ នាងទៅ យ៉ាងនេះអស់ ២-៣ ថ្ងៃ ក៏មិនបានឱកាសឡើយ ។ ដូច្នោះ ព្រះរាជាសូម្បី គេមិនក្រាបទូលឲ្យទ្រង់ជ្រាប ក៏ហៅថា ព្រះអង្គមិនញ្ចាំងប្រយោជន៍ឲ្យសម្រេច តាមបំណង ព្រោះមិនបានឱកាស ដែលនឹងធ្វើការវិនិច្ឆ័យសេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **យថាធិប្បាយំ** ប្រែថា តាមគួរដល់បំណង បទថា **ន តីរេតិ** ប្រែថា មិនទាន់យល់ព្រម ។ ពិតហើយ មហាឧបាសិកា មានបំណងនឹងថ្វាយសួយ ដែលទាក់ទងនឹងព្រះរាជាដល់ព្រះរាជា ហើយលះ នូវរបស់ទាំងនេះ ព្រោះបំណងនោះ ព្រះរាជាមិនទាន់បានពិចារណា ព្រោះ ព្រះអង្គមិនទាន់បានឃើញឡើយ ។ សពូថា **ហន្ទ** ជានិបាត ប្រើក្នុងអត្ថថា លះបង់ ។ បទថា **ធិវាធិវស្ស** ប្រែថា ក្នុងពេលថ្ងៃ អធិប្បាយថា ក្នុង ពេលថ្ងៃត្រង់ ។ មហាឧបាសិកា កាលសម្តែងសេចក្តីនេះថា ខ្ញុំម្ចាស់ទៅកាន់ ទ្វារព្រះរាជនិវេសន៍ ២-៣ ថ្ងៃ ក្នុងពេលថ្ងៃ ដោយការណីយកិច្ចឯណានីមួយ ចូលទៅរកដោយឥតប្រយោជន៍នោះឯង ព្រោះសេចក្តីនោះមិនទាន់យល់ព្រម តែការចូលទៅគាល់ព្រះមានព្រះភាគប៉ុណ្ណោះ មានប្រយោជន៍ ព្រោះជាហេតុ ឲ្យបាននូវទស្សនានុត្តរិយៈជាដើម ព្រោះហេតុនោះ ទើបខ្ញុំម្ចាស់មកក្នុងទីនេះ ក្នុងពេលនេះ ដូច្នេះ ទើបក្រាបទូលពាក្យជាដើមថា **ឥធ មេ ភន្តេ ។**

បទថា **ឯតមត្ថំ** សេចក្តីថា ទ្រង់ជ្រាបសេចក្តីនេះ ពោល គឺការសម្រេច

បំណងដោយទាក់ទងនឹងអ្នកដទៃ ។ ដោយបទថា **ឥមំ ឧទានំ** *ព្រះមានព្រះភាគទ្រង់បន្ទឺឧទាននេះ ដែលសម្តែងទោស និងអានិសង្សក្នុងការប្រព្រឹត្តទៅ ដែលអាស្រ័យអ្នកដទៃ និងមិនអាស្រ័យអ្នកដទៃ ។*

បណ្តាបទទាំងនោះ បទថា **សព្ពំ បរវសំ ទុក្ខំ** *សេចក្តីថា អត្ថ គឺប្រយោជន៍ឯណានីមួយ ដែលប្រព្រឹត្តទៅក្នុងអំណាចនៃអ្នកដទៃ គឺទាក់ទងនឹងអ្នកដទៃ ឈ្មោះថា ជាទុក្ខ គឺនាំទុក្ខមកឲ្យ ព្រោះមិនអាចសម្រេចតាមសេចក្តីប្រាថ្នានៃខ្លួន ។ បទថា* **សព្ពំ ឥស្សរិយំ សុខំ** *សេចក្តីថា ភាពជាធំមាន ២ យ៉ាង គឺជាលោកិយ ១ លោកុត្តរ ១ ។ ក្នុងបទ ២ យ៉ាងនោះ ភាពជាធំខាងលោកិយ មានភាពជាធំនៃព្រះរាជាជាដើម និងភាពជាធំនៃចិត្តដែលកើតអំពីឈាន និងអភិញ្ញាខាងលោកិយ ភាពជាធំខាងលោកុត្តរ បានដល់ ភាពជាធំនៃនិរោធ ដែលមានការសម្រេចមគ្គ និងផលជានិមិត្ត ។ ក្នុងភាពជាធំទាំងនោះ ភាពជាធំក្នុងមនុស្ស ដែលមានភាពជាស្តេចចក្រពត្តិជាទីបំផុត ១ ភាពជាធំ ជាអធិបតីក្នុងពួកទេវតានោះៗ នៃសក្កទេវរាជជាដើម ១ ទាំង ២ យ៉ាងនេះ ទើបឈ្មោះថា ជាសុខ ព្រោះមានសុខជានិមិត្ត ដោយសម្រេចតាមសេចក្តីប្រាថ្នា ដោយអានុភាពនៃកម្ម តែមិនឈ្មោះថា ជាសុខយ៉ាងពិត ដោយប្រការទាំងពួងឡើយ ព្រោះជាទុក្ខ ដោយមានការប្រែប្រួលទៅ ។ ម្យ៉ាងទៀត ភាពជាធំផ្លូវចិត្ត ដែលកើតអំពីលោកិយជ្ឈានជាដើម ឈ្មោះថា មិនជាសុខយ៉ាងពិតឡើយ ព្រោះមានការមិនទៀងជាទីបំផុត ។ ឯភាពជាធំនៃនិរោធប៉ុណ្ណោះ ឈ្មោះថា មានភាពជាសុខយ៉ាងពិត ព្រោះមិន*

ញាប់ញ័រដោយលោកធម៌ និងព្រោះមិនមានការវិលត្រឡប់ជាសភាវៈ ។ ក្នុងទីនេះ ព្រះសាស្តាទ្រង់សំដែងយកសុខតាមផ្លូវចិត្ត ដែលបានដោយមិនទាក់ទងនឹងវត្ថុជនៃ ក្នុងទីគ្រប់ស្ថាននោះឯង ទើបត្រាស់ថា **សព្វំ ឥស្សរិយំ សុខំ** *ភាពជាធំទាំងពួង នាំមកនូវសេចក្តីសុខ ។*

បទថា **សាធារណោ វិយាញ្ញន្តិ** *នេះ ជាបទលម្អិតនៃបទនេះថា* **សព្វំ បរវសំ ទុក្ខំ** *ប្រយោជន៍ណាមួយ ដែលនៅក្នុងអំណាចនៃអ្នកជនៃទាំងអស់ នាំមកនូវទុក្ខ ។ ក្នុងសេចក្តីនេះ មានអធិប្បាយដូច្នេះថា កាលប្រយោជន៍ទូទៅ ដែលគប្បីឲ្យសម្រេចមាន សត្វទាំងនេះ ឈ្មោះថា ក្តៅក្រហាយ គឺជល់នូវការចង្អៀតចង្អល់ លំបាក ព្រោះមិនសម្រេចតាមបំណង ព្រោះប្រយោជន៍នោះទាក់ទងដោយអ្នកជនៃ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកិលេសជាគ្រឿងប្រកប កន្ទងបានដោយលំបាក អធិប្បាយថា ព្រោះកាមយោគៈ ភវយោគៈ ទិដ្ឋិយោគៈ និងអវិជ្ជាយោគៈ ដែលបុគ្គលឲ្យកើតមានអស់កាលមិនមានទីបំផុតខាងដើម ឈ្មោះថា កន្ទងបានដោយលំបាក ព្រោះបុគ្គលមិនបានសន្សំកុសលសម្ភារមក មិនអាចនឹងលះបាន ក្នុងយោគៈជាដើមនោះ ទិដ្ឋិយោគៈ ដែលបុគ្គលគប្បីកន្ទងបានដោយបឋមមគ្គ គឺសោតាបត្តិមគ្គ កាមយោគៈ ដែលបុគ្គលគប្បីកន្ទងបានដោយមគ្គទី ៣ គឺអនាគាមិមគ្គ យោគៈក្រៅអំពីនេះ បុគ្គលគប្បីកន្ទងបានដោយអគ្គមគ្គ ។ ដូច្នោះ ទើបយោគៈទាំងនោះ ឈ្មោះថា កន្ទងទៅបានលំបាក ព្រោះអរិយមគ្គទាំងឡាយ សម្រេចបានលំបាក ព្រោះដូច្នោះ ទើបសត្វទាំងឡាយ ឈ្មោះថា*

ក្តៅក្រហាយព្រោះហេតុដែលមិនបានវត្ថុ ដែលប្រាថ្នាដោយអំណាចកាមយោគៈ ជាដើម អធិប្បាយថា កាលភាពជាធំនៃចិត្ត និងភាពជាធំនៃនិរោធ មាន ក្នុងកាលណាមួយ ការចង្អៀតចង្អល់ ក៏កើតមិនបាន ។

ម្យ៉ាងទៀត បទថា **សព្ពំ បរវសំ** *សេចក្តីថា ប្រយោជន៍ ពោល គឺការ ប្រព្រឹត្តទៅរបស់ខ្លួន ទាក់ទងដោយបុគ្គលដទៃ និងអ្នកដទៃទាក់ទងនឹងខ្លួន ទាំងអស់នោះ ឈ្មោះថា ជាហេតុនាំទុក្ខមកឲ្យ ព្រោះមានការមិនទៀងជា សភាវៈ ។ សមដូចពាក្យដែលលោកពោលថា វត្ថុណាមិនទៀង វត្ថុនោះជា ទុក្ខ ។ បទថា* **សព្ពំ ឥស្សរិយំ** *សេចក្តីថា ព្រះនិព្វាន ដែលជាទីរលាស់ចេញ ចាកសង្ខតធម៌ទាំងពួង ដែលបានឈ្មោះថា ឥស្សរិយៈ ព្រោះជាទីតាំងនៃភាព ជាធំ ទាំងអស់នោះ ចែកជាសឧបាទិសេសនិព្វានជាដើម ឈ្មោះថា នាំមក នូវសេចក្តីសុខ ។ សមដូចព្រះតម្រាស់ថា* **និព្វានំ បរមំ សុខំ** *ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។ បទថា* **សាធារណោ** *សេចក្តីថា កាលកំណត់ទុក្ខ និងសុខបានយ៉ាងនេះ សត្វទាំងនេះរមែងក្តៅក្រហាយ លិចចុះក្នុងហេតុនៃទុក្ខ ដែលទូទៅដល់ទុក្ខដ៏ច្រើន ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះកិលេស ជាគ្រឿងប្រកបកន្ទងបានលំបាក អធិប្បាយថា ព្រោះកាមយោគៈជាដើមនោះ ជាហេតុឲ្យលិចចុះក្នុងទុក្ខទាំងពួង ដែលកន្ទងបានលំបាក ដូច្នោះ វិសាខា សូម្បីនាងប្រាថ្នាប្រយោជន៍ ដែលទាក់ទងនឹងអ្នកដទៃ កាលមិនបានក៏ក្តៅ ក្រហាយ ។*

អដ្ឋកថា វិសាខាសូត្រទី ៩ ចប់

សុត្តន្តបិដក

កាឡិគោភទ្ទិយសូត្រ

[៦៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តអម្ពវន ទៀបក្រុងអនុប្បិយា ។ សម័យនោះ ព្រះកទ្ទិយៈដ៏មានអាយុ ជាបុត្តនាងសាកិយានី ឈ្មោះកាឡិគោធា ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្ទឺនូវឧទានរឿយៗ ថា ឱហ្ន៎ សុខអ្ហូម្ល៎ះ ឱហ្ន៎ សុខអ្ហូម្ល៎ះ ។ ពួកភិក្ខុជាច្រើនរូប បានឮថា ព្រះកទ្ទិយៈដ៏មានអាយុ ជាបុត្តនៃនាងសាកិយានី ឈ្មោះកាឡិគោធា ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្ទឺនូវឧទានរឿយៗ ថា ឱហ្ន៎ សុខ អ្ហូម្ល៎ះ ឱហ្ន៎ សុខអ្ហូម្ល៎ះ ដូច្នេះដែរ ។ លុះភិក្ខុទាំងនោះបានឮហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ព្រះកទ្ទិយៈដ៏មានអាយុ ជាបុត្តនាងសាកិយានី ឈ្មោះកាឡិគោធា ប្រាកដជាអផ្សុកនឹងប្រព្រឹត្តព្រហ្មចរិយធម៌ដោយពិត ព្រះកទ្ទិយៈដ៏មានអាយុនោះ នឹកឃើញសេចក្តីសុខក្នុងរាជ្យរបស់លោក កាលនៅជាគ្រហស្ថអំពីដើម ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្ទឺឧទានរឿយៗ ថា ឱហ្ន៎ សុខអ្ហូម្ល៎ះ ឱហ្ន៎ សុខអ្ហូម្ល៎ះ ។ លំដាប់នោះ ពួកភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះកទ្ទិយៈដ៏មានអាយុ ជាបុត្តនាងសាកិយានី ឈ្មោះកាឡិគោធា ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្ទឺឧទាន

រឿយៗ ថា ឱហ្ន៎ សុខអ្វីម្ល៉េះ ឱហ្ន៎ សុខអ្វីម្ល៉េះ ព្រះកទ្ទិយៈជាបុត្តនាង សាកិយានី ឈ្មោះកាឡិគោធា ប្រាកដជាអផ្សុកនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ដោយពិត ។បេ។ ឱហ្ន៎ សុខអ្វីម្ល៉េះ ។

[៦៥] *គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុ ១ រូប ហើយបង្គាប់ថា ម្នាលភិក្ខុ អ្នកចូរមក ចូរហៅកទ្ទិយភិក្ខុតាមពាក្យតថាគត ថា នែអាវុសោកទ្ទិយៈ ព្រះសាស្តាទ្រង់ឲ្យហៅអ្នក ។ ភិក្ខុនោះ ទទួល ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ រួចចូលទៅរកព្រះ កទ្ទិយៈដ៏មានអាយុ ជាបុត្តនាងសាកិយានី ឈ្មោះកាឡិគោធា លុះចូលទៅ ដល់ហើយ ក៏និយាយនឹងព្រះកទ្ទិយៈដ៏មានអាយុ ជាបុត្តនាងសាកិយានី ឈ្មោះកាឡិគោធាថា នែអាវុសោ កទ្ទិយៈ ព្រះសាស្តាត្រាស់ហៅអ្នក ព្រះ កទ្ទិយៈដ៏មានអាយុ ជាបុត្តនាងសាកិយានី ឈ្មោះកាឡិគោធា បានទទួល ពាក្យភិក្ខុនោះថា អើ អាវុសោ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះ ចូលទៅដល់ហើយ ក្រាបថ្វាយបង្គំនូវព្រះមានព្រះភាគ ហើយអង្គុយក្នុងទី សមគួរ ។ លុះព្រះកទ្ទិយៈដ៏មានអាយុ ជាបុត្តនាងសាកិយានី ឈ្មោះ កាឡិគោធា អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលកទ្ទិយៈ បានឮថា អ្នក ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុង ផ្ទះស្ងាត់ក្តី តែងបន្ទឺឧទានរឿយៗ ថា ឱហ្ន៎ សុខអ្វីម្ល៉េះ ឱហ្ន៎ សុខអ្វីម្ល៉េះ ដូច្នេះមែនឬ ។ ព្រះកទ្ទិយៈក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ម្នាលព្រះ កទ្ទិយៈ អ្នកពិចារណាឃើញអំណាចប្រយោជន៍ដូចម្តេច បានជាចូលទៅនៅ*

ក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្ទឺឧទានរឿយៗ ថា ឱហ្ន៎ សុខអ្ហីម្ល៎ះ ឱហ្ន៎ សុខអ្ហីម្ល៎ះ ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលពីដើម ខ្ញុំព្រះអង្គនៅជាគ្រហស្ថ សោយសុខក្នុងរាជ្យ ការរក្សាខាងក្នុងព្រះរាជវាំង គេបានចាត់ចែងល្អហើយ ការរក្សាខាងក្រៅព្រះរាជវាំង គេក៏ចាត់ចែងល្អហើយ ការរក្សាខាងក្នុងនគរ គេចាត់ចែងល្អហើយ ការរក្សាខាងក្រៅនគរ គេចាត់ចែងល្អហើយ ការរក្សាក្នុងជនបទ គេចាត់ចែងល្អហើយ ការរក្សាខាងក្រៅជនបទ គេចាត់ចែងល្អហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះឯង ដែលគេរក្សាគ្រប់គ្រងយ៉ាងនេះហើយ ក៏នៅតែភ័យក្លាក់ផ្អើលរង្គៀស តក់ស្លុត បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គតែម្នាក់ឯងទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ក៏លែងភ័យ លែងក្លាក់ផ្អើល លែងតក់ស្លុតហើយ ជាអ្នកមានការខ្វល់ខ្វាយតិច ឥតព្រឺព្រួចរោម ចិញ្ចឹមជីវិតដោយបច្ច័យដែលអ្នកដទៃឲ្យ នៅដោយមានចិត្តដូចជាពួកម្រឹគ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញអំណាចប្រយោជន៍នេះហើយ ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្ទឺឧទានរឿយៗ ថា ឱហ្ន៎ សុខអ្ហីម្ល៎ះ ឱហ្ន៎ សុខអ្ហីម្ល៎ះ ដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនេះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

សេចក្តីក្រោធ មិនមានក្នុងចិត្តរបស់បុគ្គលណា បុគ្គលនោះ ឈ្មោះ
ថា កន្ទងផុតនូវសេចក្តីចម្រើន និងសេចក្តីវិនាស ទេវតាទាំងឡាយ

កម្រនឹងបានឃើញបុគ្គលដែលជ្រាសចាកភ័យ បានប្រកបដោយសេចក្តីសុខ ឥតសោកនោះឡើយ ។ សូត្រទី ១០ ។

មុច្ចលិន្ទវគ្គទី ២ ចប់

ឧទ្ទាននៃមុច្ចលិន្ទវគ្គនោះ គឺ

និយាយអំពីព្រះមានព្រះភាគ គង់ទៀបគល់រាំង ១ អំពីព្រះរាជា ១ អំពីការវាយពស់ដោយដំបង ១ អំពីគ្រឿងសក្ការៈ ១ អំពីឥច្ឆានង្គលកឧបាសក ១ អំពីប្រពន្ធព្រាហ្មណ៍មានគភ៌ ១ អំពីកូនតូច ១ អំពីកោលិយធីតា ឈ្មោះសុប្បវាសា ១ អំពីនាងវិសាខា ១ អំពីព្រះកុទ្ទិយត្ថេរ (ជាបុត្ត) នាងសាកិយានី ឈ្មោះកាឡិគោធា ១ ។

អដ្ឋកថា

កាឡិគោភទ្ទិយសូត្រ

កាឡិគោភទ្ទិយសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ

[៦៤] *បទថា* **អនុបិយាយំ** *បានដល់ ជិតព្រះនគរដែលមានឈ្មោះយ៉ាងនេះ ។ បទថា* **អម្ពវនេ** *សេចក្តីថា ក្នុងទីមិនឆ្ងាយអំពីនគរនោះ ស្តេចមល្លៈទាំងឡាយ មានចម្ការស្វាយមួយកន្លែង ក្នុងចម្ការស្វាយនោះ ស្តេចមល្លៈទាំងឡាយ បានសាងវិហារថ្វាយដល់ព្រះមានព្រះភាគ វិហារនោះ គេហៅថា* **អម្ពវន ។** *ព្រះមានព្រះភាគទ្រង់ធ្វើអនុបិយនគរឲ្យជាគោចរគ្រាមគង់ប្រថាប់ក្នុងអម្ពវនៈនោះ ព្រោះហេតុនោះ ទើបលោកពោលថា* **អនុបិយាយំ វិហរតិ អម្ពវនេ ។** *បទថា* **ភទ្ទិយោ** *ជាឈ្មោះនៃព្រះថេរៈនោះ ។ បទថា* **កាឡិគោធាយ បុត្តោ** *សេចក្តីថា សក្យរាជទេវីសាកិយានី ព្រះនាមថា កាឡិគោធា ជាព្រះអរិយសាវិកា សម្រេចអរិយផល យល់ក្នុងសាសនាជាក់ច្បាស់ហើយ ព្រះថេរៈនេះជាបុត្ររបស់ព្រះនាង ។ បព្វជ្ជាវិធីរបស់ព្រះថេរៈនោះ មកក្នុងខន្ធកៈនោះឯង ។ ព្រះថេរៈនោះ កាលបព្វជ្ជាហើយ ផ្តើមតាំងវិបស្សនា មិនយូរប៉ុន្មាន ក៏បានអភិញ្ញា ៦ លោកសមាទានប្រព្រឹត្តធុតង្គទាំង ១៣ ។ ព្រះមានព្រះភាគ ទ្រង់ស្តាបនាលោកក្នុងឯតទគ្គៈ ក្នុងផ្នែកមានត្រកូលខ្ពស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងបណ្តាភិក្ខុសាវ័ករបស់តថាគតដែលមានត្រកូលខ្ពស់ ស្តេចនឹងបុត្ររបស់ព្រះនាងកាឡិគោធា ឈ្មោះថា ភទ្ទិយៈ លោកជាភិក្ខុមួយរូបក្នុងចំនួនអសីតិមហាសាវ័ក ។*

បទថា **សុញ្ញាគារគតោ** *លោកពោលថា វៀរស្រុក និងឧបចារស្រុក ក្រៅអំពីនោះ ឈ្មោះថា ព្រៃ វៀរព្រៃ និងគល់ឈើចេញ ទីនៅអាស្រ័យជាទៃ មានញាកក្តុំជាដើម ដែលសមគួរដល់បព្វជិត លោកបំណងយកថាសុញ្ញាគារ ក្នុងទីនេះ ព្រោះមិនអ៊ូអរដោយពួកមហាជន ។ ម្យ៉ាងទៀត ឃ្លាំងឯណាមួយ ដែលស្ងាត់ ក៏គប្បីជ្រាបថា ជាសុញ្ញាគារ ព្រោះមិនមានសំឡេងដែលជា សត្រូវចំពោះឈាន ។ ដែលចូលដល់សុញ្ញាគារនោះ ។ បទថា* **អភិក្កមាំ** *ប្រែថា ច្រើនយ៉ាង ។ បទថា* **ឧឆានំ ឧឆានេសិ** *សេចក្តីថា ព្រោះលោកដ៏ មានអាយុអង្គនោះ សម្រាកពេលថ្ងៃក្តី សម្រាកពេលយប់ក្តី ដោយច្រើន ឲ្យកាលឆ្លងទៅដោយសុខ ដែលកើតអំពីផលសមាបត្តិ និងសុខដែលកើត អំពីនិរោធ ដូច្នោះ លោកសំដៅយកសុខនោះ ទើបស្អប់ខ្ពើមសុខក្នុងរាជ-សម្បត្តិ ដែលប្រកបដោយភ័យ មានសេចក្តីក្តៅក្រហាយ ដែលខ្លួនធ្លាប់ សោយក្នុងកាលមុន ទើបបន្ទឺដល់សុខ ដែលសម្បយុត្តដោយសោមនស្ស មានញាណជាសមុដ្ឋាន មានបីតិជាសមុដ្ឋានថា ឱហ្ន៎ សុខអ្វីម្ល៉េះ ឱហ្ន៎ សុខ អ្វីម្ល៉េះ ដូច្នេះ ។*

បទថា **សុត្វាន តេសំ ឯតទហោសិ** *សេចក្តីថា ភិក្ខុជាច្រើន កាល បានស្តាប់ឧទានរបស់លោកដែលបន្ទឺថា ឱហ្ន៎ សុខអ្វីម្ល៉េះ ឱហ្ន៎ សុខអ្វីម្ល៉េះ ក៏មានបរិវិតក្កដូច្នេះថា អាវុសោនេះ នឿយណាយក្នុងព្រហ្មចរិយៈដោយឥត សង្ស័យ ។ ពិតហើយ ភិក្ខុទាំងនោះជាបុថុជ្ជន កាលមិនដឹងឧទានដែល សំដៅដល់សុខ កើតអំពីវិវេករបស់លោកដ៏មានអាយុនោះ ទើបមើលងាយ*

យ៉ាងនោះ ដោយហេតុនោះ ទើបលោកពោលពាក្យថា **ឯសវ្ហសយំ** *ដូច្នេះ ជាដើម ។*

បណ្តាបទទាំងនោះ បទថា **ឯសវ្ហសយំ** *គឺដោយឥតសង្ស័យ អធិប្បាយ ថា ដោយពិតប្រាកដ ។ អាចារ្យពួកខ្លះពោលបាលីជាដើមថា* **យំ សោ បុព្ពេ អគារិយភូតោ សមានោ** *ប្រែថា លោកជាអ្នកគ្រប់គ្រងផ្ទះក្នុងកាលមុន សោយសុខណា ហើយពណ៌នាអត្ថដោយពាក្យដ៏សេសថា* **អនុភវិ** *ប្រែថា សោយ អាចារ្យមួយពួកទៀតពោលថា* **យំស ។** *តែបាលីជា* **យំស បុព្ពេ អគារិយភូតស្ស ។** *ក្នុងបទទាំងនោះ បទថា* **យំស** *កាត់ជាបទ* **យំ អស្ស** *ព្រោះលុប* **អ** *អក្សរ និង* **ស** *អក្សរ ដោយអំណាចសន្ធិ ដូចក្នុងប្រយោគ ជាដើមថា* **ឃវំស តេ** *និងថា* **បុប្ផំសា ឧប្បជ្ជតិ ។** *គប្បីជ្រាបអត្ថនៃពាក្យ នោះដូចតទៅនេះ ព្រះកទ្ទិយៈនោះ ក្នុងកាលមុនបួស ជាគ្រហស្ថ អ្នកគ្រប់ គ្រងផ្ទះ សោយសុខក្នុងរាជសម្បត្តិណា ។ បទថា* **សោ តមនុស្សរមានោ** *សេចក្តីថា ឥឡូវនេះ លោកនឹកដល់សុខនោះ ដោយសេចក្តីអផ្សុក ។*

បទថា **តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ** *សេចក្តីថា ភិក្ខុជាច្រើនទាំងនោះ តាំងនៅក្នុងការពោលអួត ទើបបានក្រាបទូលពាក្យនេះដល់ព្រះមានព្រះភាគ ដោយបំណងនឹងអនុគ្រោះលោក មិនមែនបំណងនឹងលើកទោស ។*

[៦៥] បទថា **អញ្ញតរំ** *បានដល់ ភិក្ខុមួយរូបដែលមិនប្រាកដនាម និងគោត្រ ។ បទថា* **អាមន្តេសិ** *បានដល់ មានបំណងនឹងឲ្យភិក្ខុទាំងនោះ យល់ ទើបទ្រង់គ្រាស់ប្រាប់ ។ បទថា* **ឃវំ** *បានដល់ ក្នុងការទទួលព្រះ*

តម្រាស់ អធិប្បាយថា ខ្ញុំព្រះអង្គសូមព្រះវិវេកាស ។ បទថា **ឃរំ** *បានដល់ ដោយការប្តេជ្ញាទៀត ។ បទថា* **អភិក្ខណំ អហោ សុខំ អហោ សុខន្តិ ឥមំ ឧទានំ ឧទានេសិ** *សេចក្តីថា ទទួលឧទានរបស់ខ្លួនថា សេចក្តីនោះពិតដូច្នោះ គឺដូចប្រការដែលភិក្ខុទាំងនោះពោល ។ បទថា* **កឹ បន ត្វំ ភន្តេ យ** *សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់សួរ ទ្រង់មិនជ្រាបចិត្តរបស់លោកឬ ។ ឆ្លើយថា ទ្រង់មិនជ្រាបក៏មិនមែន ព្រោះហេតុនោះឯង ទើបទ្រង់ត្រាស់សួរ ដើម្បីឲ្យពោលរឿងនោះ ហើយឲ្យភិក្ខុទាំងនោះយល់ព្រម ។ សមដូចពាក្យដែលលោកពោលជាដើមថា ព្រះតថាគតទាំងឡាយ ដឹង ត្រាស់សួរក៏មាន ដឹង មិនត្រាស់សួរក៏មាន ។ បទថា* **អត្ថវសំ** *ប្រែថា ហេតុ ។*

បទថា **អន្តេបុរេ** *បានដល់ ខាងក្នុងព្រះរាជដំណាក់ដែលជាសញ្ជរបស់អ្នករាជវាំង ដែលជាទីទ្រង់ស្រង់ ទ្រង់សោយ និងទ្រង់ផ្ទំជាដើមរបស់ព្រះរាជា ។ បទថា* **រក្ខា សុសំវិហិតា** *បានដល់ គ្រប់គ្រងដែលពួករាជ-បុរសធ្វើការរក្សាយ៉ាងតឹងរឹង បានចាត់ចែងដោយជុំវិញយ៉ាងល្អ ។ បទថា* **ពហិបិ អន្តេបុរេ** *បានដល់ ក្នុងរាជដំណាក់ដែលជាខាងក្រៅអំពីខាងក្នុងនៃព្រះរាជវាំង មានសំយោបសម្រាប់រង់ចាំជាដើម ។ បទថា* **ឃរំ រក្ខិតោ គោបិតោ សន្តោ** *សេចក្តីថា ខ្ញុំព្រះអង្គនោះ ជាបុគ្គលដែលរាជបុរសច្រើនរយរក្សា ថែទាំ ដើម្បីការមិនមានភ័យ ដើម្បីការនៅជាផាសុករបស់ខ្ញុំព្រះអង្គឯង ដោយការរៀបចំការរក្សាការពារ និងគ្រប់គ្រងយ៉ាងល្អ ក្នុងទីច្រើនកន្លែង ទាំងខាងក្នុង និងខាងក្រៅព្រះដំណាក់រាជធានី រាជអាណាខេត្ត*

ដោយប្រការយ៉ាងនេះ ។ បទថា **ភីតោ** *ជាដើម ជាវេវចនៈនៃគ្នានិងគ្នា ។ ម្យ៉ាងទៀត បទថា* **ភីតោ** *បានដល់ ដែលរាជសត្រូវក្លាចក្រែង ។ បទថា* **ឧព្វិគ្គោ** *បានដល់ ជាអ្នកភ័យ ខ្លាច តក់ស្លុត ដោយសេចក្តីភ័យដែលកើតអំពីការបះបោរតាមប្រក្រតី ក្នុងរាជសីមាអាណាចក្រ ។ បទថា* **ឧស្សង្កី** *បានដល់ សង្ស័យក្នុងខាងមុខ ដោយការមិនទុកចិត្តក្នុងទីគ្រប់កន្លែង និងដោយការចំបែងដល់កិច្ច និងករណីយកិច្ចនោះ ព្រោះពាក្យពោលថា ធម្មតា ព្រះរាជា មិនគួរទុកចិត្តគ្រប់កាលឡើយ ។ បទថា* **ឧត្រាសី** *បានដល់ តក់ស្លុត ដោយការតក់ស្លុតដែលអាចធ្វើឲ្យកើតការញ័រខ្លួនដែលកើតឡើងថា ក្នុងកាលខ្លះ ការវិនាសគប្បីមានដល់អាត្មាអញ ដោយមិនដឹងខ្លួនឡើយ ព្រោះមនុស្សជិតស្និទ្ធ ។ អាចារ្យពួកខ្លះពោលថា* **ឧត្រាសោ** *ដូច្នេះក៏មាន ។ បទថា* **វិហាសឹ** *បានដល់ អាត្មាអញ ជាបុគ្គលយ៉ាងនេះ ។*

បទថា **ឯតរហិ** *បានដល់ ឥឡូវនេះ រាប់តាំងអំពីពេលដែលបួសមក ។ បទថា* **ឯកោ** *បានដល់ មិនមានសម្ងាញ់ ដោយបទថា* **ឯកោ** *នោះ លោកពោលដល់ភាពជាបុគ្គលមានខ្លួនចៀសចេញហើយ ។ គប្បីជ្រាបអត្ថនៃបទថា* **អភីតោ** *ជាដើម ដោយបរិយាយផ្ទុយគ្នានឹងពាក្យដែលពោលមកហើយ ។ លោកសម្តែងដល់ចិត្តវិវេក ដោយពាក្យជាដើមថា ការដែលអ្នកមិនមានការភ័យខ្លាចជាដើម ព្រោះមិនមានការកំណត់ត្រង់និមិត្ត មានភ័យជាដើម និងភ័យគឺកិលេស ដែលមានការកំណត់នោះជានិមិត្ត ។ បទថា* **អប្បោស្សុក្កោ** *បានដល់ ជ្រាសចាកសេចក្តីខ្វល់ខ្វាយក្នុងការគ្រប់គ្រងរាងកាយ ។ បទថា* **បន្ន-**

លោភោ បានដល់ មិនមានការព្រឺរោមព្រឺស្បែក ព្រោះមិនមានការភ័យខ្លាច ដែលធ្វើឲ្យកើតការព្រឺរោមជាដើមឡើយ ។ ដោយបទទាំង ២ លោកសម្តែងដល់ការនៅដោយសិរី ។ បទថា **បរេនុត្តោ** សេចក្តីថា ប្រព្រឹត្តទៅដោយចីវរជាដើមដែលអ្នកដទៃឲ្យ ដោយបទនោះ លោកសម្តែងដល់ការវៀរចាកហេតុនៃភ័យជាសមុច្ឆេទ ដោយមុខ គឺការមិនមានការជាប់ជំពាក់ដោយប្រការទាំងពួង ។ បទថា **មិគភូតេន ចេតសា** បានដល់ មានចិត្តកើតដូចម្រឹគ ព្រោះនៅដោយធូរស្បើយចិត្ត ។ ពិតហើយ ម្រឹគនៅក្នុងព្រៃដែលជាទឹកដីមិនមានមនុស្ស ទោះឈរ អង្គុយ ដេក ក៏ល្អែល្អើយចិត្ត ព្រោះឈានទៅតាមការប្រាថ្នា គ្រាច់ទៅដោយមិនជាប់ជំពាក់ លោកសម្តែងថា ខ្ញុំក៏នៅយ៉ាងនោះ ។ សមដូចព្រះបច្ចេកពុទ្ធគ្រាស់ថា

> ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណីតាមចំណង់ចិត្ត
> បាន យ៉ាងណា វិញ្ញូជន កាលបើឃើញសេរីភាព (យ៉ាងនោះ)
> គប្បីគ្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បទថា **ឥមំ ខោ អហំ ភន្តេ អត្ថវសំ** សេចក្តីថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គកាលពិចារណាឃើញហេតុ គឺសុខដែលកើតអំពីវិវេកនិងសុខដែលកើតអំពីផលសមាបត្តិដ៏កំពូលនេះប៉ុណ្ណោះ ទើបបន្ទឺឧទានថា ឱហ្ន៎ សុខអ្វីម្ល៉ះ ឱហ្ន៎ សុខអ្វីម្ល៉ះ ។

បទថា **ឯតមត្ថំ** សេចក្តីថា ទ្រង់ជ្រាបគ្រប់ប្រការដល់សេចក្តីនេះ ពោលគឺសុខដែលកើតអំពីវិវេក ដែលកន្ទងវិស័យបុថុជ្ជនរបស់ព្រះកទ្ទិយត្ថេរ ។

បណ្តាបទទាំងនោះ បទថា **យស្សន្តរតោ ន សន្តិ កោចា** សេចក្តីថា

កិលេស មានរាគៈជាដើម ឈ្មោះថា ធ្វើចិត្តឲ្យកម្រើក ព្រោះជាហេតុធ្វើចិត្ត ឲ្យផ្សាយទ្បើងតាមកាល សេចក្តីក្រោធមានច្រើនប្រភេទ មានអាយាតវត្ថុជា ដើម រមែងមិនមានអំពីខាងក្នុង គឺក្នុងចិត្តរបស់ខ្លួន ចាកចិត្តរបស់ព្រះអរិយ-បុគ្គល ឈ្មោះថា រមែងមិនមាន ព្រោះព្រះអរិយបុគ្គលលះបានដោយមគ្ត ។ ពិតហើយ **អន្ត**រ សពួនេះ ប្រាកដក្នុងហេតុ ដូចក្នុងប្រយោគជាដើមថា **ជនា សន្ត្ថម្ម មន្តេន្តិ មញ្ញ តញ្ញ កិមន្ត**រំ ជនទាំងឡាយ មកប្រជុំនិយាយគ្នា ទៀបធ្នេរស្ទឹងទាំងឡាយផង ... ហើយនិយាយចំពោះខ្ញុំផង ចំពោះលោកផង តើព្រោះហេតុអ្វី ។ ប្រាកដត្រង់កណ្តាល ដូចក្នុងប្រយោគជាដើមថា **អន្ត-រដ្ឋកាសុ ហិមចាតសមយេ** ក្នុងសម័យមានទឹកសន្សើមធ្លាក់ចុះខ្លាំង ប្រហែល ជា ៨ រាត្រីក្នុងចន្លោះខែទាំងពីរ ។ ប្រាកដត្រង់ក្នុង រវាង ដូចក្នុងប្រយោគ ជាដើមថា **អន្ត**រា **ច សាវត្ថឹ អន្ត**រា **ច ជេតវនំ** រវាង ក្រុងសាវត្ថី និងរវាងជេតពនមហាវិហារ ។ ប្រាកដក្នុង ចិត្ត ដូចក្នុងប្រយោគជាដើមថា **ភយមន្ត**រតោ **ជាតំ** ភ័យកើតហើយក្នុងចិត្ត ដូច្នេះ ។ សូម្បីក្នុងទីនេះ គប្បីឃើញ **អន្ត**រ សពួ ប្រើក្នុងចិត្តប៉ុណ្ណោះ ដោយហេតុនោះ ទើបលោក ពោលថា **អន្ត**រតោ **អត្ត**នោ **ចិត្ត** ចាកចិត្ត គឺក្នុងចិត្តរបស់ខ្លួន ។

បទថា **ឥតិ ភាវាភវតញ្ញ វីតិវត្តោ** សេចក្តីថា សម្បត្តិ ឈ្មោះថា **ភ**រ វិបត្តិ ឈ្មោះថា **អភ**រ ។ ម្យ៉ាងទៀត សេចក្តីចម្រើន ឈ្មោះថា **ភ**រ សេចក្តីវិនាស ឈ្មោះថា **អភ**រ ។ ម្យ៉ាងទៀត បុណ្យ ឈ្មោះថា **ភ**រ បាប ឈ្មោះថា **អភ**រ ។ ម្យ៉ាងទៀត សុគតិ ឈ្មោះថា **ភ**រ ទុគ្គតិ ឈ្មោះថា

អភវ ។ ម្យ៉ាងទៀត ភពតូច ឈ្មោះថា **ភវ** ភពធំ ឈ្មោះថា **អភវ ។** ដូច្នោះ ទើបលោកហៅថា ជា **ភវាភវ** គឺ **ភវ** និង **អភវ** មានប្រការជាអនេក គឺសម្បត្តិ វិបត្តិ ការចម្រើន ការវិនាស ការទៀង ការដាច់ សូន្យ បុណ្យ បាប សុគតិ ទុគ្គតិ និងឧបបត្តិភពតូច-ធំ ។ ព្រះអរិយបុគ្គលឆ្ងងផុត គឺឈានកន្ងងនូវសេចក្តីក្រោធនោះ និងភព អភព ដូចពោលមកក្នុងន័យនោះៗ តាមសេចក្តីពិត ដោយអរិយមគ្គទាំង ៤ ។ គប្បីផ្ទាស់វិភត្តិទៅតាមអត្ត ។ បទថា **តំ វិតតភយំ** សេចក្តីថា នូវព្រះខីណាស្រពនោះ គឺបែបនោះ ដែលប្រកបដោយគុណដូចពោលហើយ ឈ្មោះថា **វិតតភយំ** ព្រោះប្រាសចាកហេតុនៃភ័យ ដោយមិនមានការកម្រើកនៃចិត្ត និងដោយការឈានកន្ងងភវាភវ: ដូចពោលហើយ ។ ឈ្មោះថា **សុខំ** ដោយសុខដែលកើតអំពីវិវេក និងសុខដែលកើតអំពីមគ្គចិត្ត និងផលចិត្ត ។ ឈ្មោះថា **អសោកំ** ព្រោះប្រាសចាកភ័យនោះឯង ។ បទថា **ឧវា នានុភវន្តិ ឧស្សនាយ** សេចក្តីថា ឧបបត្តិទេពទាំងអស់ រៀរបុគ្គលសម្រេចមគ្គ សូម្បីព្យាយាមក៏មិនអាច មិនមានសមត្ថភាព ដើម្បីនឹងយើញ គឺសម្ងឹងយើញ ដោយការយើញ ដោយការត្រាច់ទៅនៃចិត្ត នឹងពោលថ្ងីដល់ពួកមនុស្សនោះ ។ សូម្បីព្រះសេក្ខ:ទាំងឡាយ ក៏មិនដឹងការប្រព្រឹត្តទៅនៃចិត្តរបស់ព្រះអរហន្តបានដូចបុថុជ្ជនមិនដឹងការប្រព្រឹត្តទៅនៃចិត្តរបស់ព្រះសេក្ខ:នោះឯង ។

អដ្ឋកថាកាឡិតោធាភឡិយសូត្រទី ១០ ចប់

អដ្ឋកថាមុចូលិន្ទវគ្គទី ២ ចប់

សុត្តន្តបិដក

ឧទាន ឯក្ខវគ្គទី ៣

កម្មសូត្រ

[៦៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុ ១ រូប អង្គុយពែនភ្នែនក្នុងទីជិតនៃព្រះមានព្រះភាគ ហើយតាំងកាយត្រង់ អត់ទ្រាំទុក្ខវេទនា ដ៏ក្លាខ្លាំង ខ្លោចផ្សា ដែលកើតអំពីផលនៃកម្មចាស់ មានស្មារតី មានសេចក្តីដឹងខ្លួន មិនលំបាក ។ ព្រះមានព្រះភាគ បានទតឃើញភិក្ខុនោះ អង្គុយពែនភ្នែនក្នុងទីជិតនៃព្រះអង្គ តាំងកាយត្រង់ អត់ទ្រាំទុក្ខវេទនា ដ៏ក្លាខ្លាំង ខ្លោចផ្សា ដែលកើតអំពីផលនៃកម្មចាស់ មានស្មារតី មានសេចក្តីដឹងខ្លួន មិនលំបាក ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> ភិក្ខុអ្នកលះបង់កម្មទាំងពួង កម្ចាត់បង់នូវធូលី គឺកិលេស ដែលខ្លួនធ្លាប់ធ្វើក្នុងកាលមុន មិនមានសេចក្តីប្រកាន់ថា អញ ស្ងៀតនៅនឹងធឹង សេចក្តីត្រូវការ ដើម្បីហៅរកអ្នកផងឲ្យជួយ មិនមានទៀយ ។ សូត្រទី ១ ចប់ ។

អដ្ឋកថា

ឆក្កវគ្គទី ៣

កម្មសូត្រ

កម្មសូត្រទី ១ នៃឆក្កវគ្គទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

[៦៦] *បទថា* **អញ្ញតរោ ភិក្ខុ** *បានដល់ ភិក្ខុដែលជាខីណាស្រពមួយរូបដែលមិនប្រាកដនាម និងគោត្រ ។*

បានឮថា ភិក្ខុនោះជាកុលបុត្រ អ្នកក្រុងរាជគ្រឹះ ដែលព្រះមហាមោគ្គ-ល្លានឲ្យសង្វេគហើយ ឃើញទោសក្នុងសង្សារ ទើបបួសនៅក្នុងសម្នាក់ព្រះសាស្តា ជម្រះសីលឲ្យបរិសុទ្ធ កាន់យកកម្មដ្ឋានដែលសម្បយុត្តដោយសច្ចៈ ៤ មិនយូរប៉ុន្មាន បានបំពេញវិបស្សនាសម្រេចអរហត្ត ។ ក្រោយមក លោកមានអាពាធជ័ធ្ងន់ ។ លោកសម្ងំនៅដោយការពិចារណា ពិតហើយ ធម្មតាព្រះខីណាស្រព មិនមានទុក្ខផ្លូវចិត្ត តែទុក្ខផ្លូវកាយមានដូចគ្នា ។ ថ្ងៃមួយ កាលព្រះសាស្តាកំពុងសម្តែងធម៌ លោកអត់ធន់នូវទុក្ខ អង្គុយពត់ភ្នែន ក្នុងទីមិនឆ្ងាយ ព្រោះហេតុនោះ ទើបលោកពោលពាក្យជាដើមថា **ភគវតោ អវិទូរេ និសិន្នោ ហោតិ** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **បល្លង្កំ** *ប្រែថា អង្គុយពត់ភ្នែន ។ បទថា* **អាភុជិត្វា** *ប្រែថា ពត់ ។ បទថា* **ឧជុំ កាយំ បណិធាយ** *សេចក្តីថា លោកតាំងកាយខាងលើឲ្យត្រង់ ហើយឲ្យឆ្អឹងខ្នង ១៨ កំណាត់ត្រួតលើគ្នា ។ កាលលោកអង្គុយយ៉ាងនេះ សៀក សាច់ សរសៃ មិនតឹង ព្រោះដូច្នោះ*

ទើបលោកអង្គុយយ៉ាងនោះ ។ បទថា **បុរាណកម្មវិបាកជំ** *ប្រែថា កើតដោយវិបាកនៃកម្មដែលធ្វើហើយក្នុងកាលមុន ។ ម្យ៉ាងទៀត កើតដោយភាពជាចំណែកមួយនៃកម្មនោះ ក្នុងកាលវិបាករបស់កម្មចាស់ ដែលមានអាការជាសុខ និងទុក្ខ កើតជាវិបាកវដ្ត សេចក្តីនោះ គឺអ្វី គឺទុក្ខ ។ ដោយពាក្យថា* **បុរាណកម្មវិបាកជំ** *នេះ លោកសម្តែងដល់អាពាធនោះ មានកម្មជាសមុដ្ឋាន ទើបហាមភាពដែលកម្មកើតអំពីការប្រែប្រួលរដូវជាដើម ដែលទទួលនូវការឈឺថ្កាត់ ។ បទថា* **ទុក្ខំ** *បានដល់ ទុក្ខដែលបុថុជ្ជនមិនអាចអត់ធន់បាន ។ បទថា* **តិប្បំ** *ប្រែថា ខ្លាំងក្លា ឬធ្ងន់ ព្រោះគ្របសង្កត់ប្រព្រឹត្តទៅ ។ បទថា* **ខរំ** *ប្រែថា ខ្លាំងក្លា ។ បទថា* **កដុកំ** *ប្រែថា មិនមានផាសុក ។ បទថា* **អធិវាសេន្តោ** *ប្រែថា សម្ងំ គឺអត់ធ្មត់ អត់ធន់ដ៏កំពូល ។ បទថា* **សតោ សម្បជានោ** *បានដល់ មានសតិ គឺមានសម្បជញ្ញៈ ដោយអំណាចសតិ និងសម្បជញ្ញៈ ដែលជាគ្រឿងកំណត់វេទនា ។ លោកអធិប្បាយពាក្យនេះថា ធម្មតា វេទនានេះ ឈ្មោះថា មិនទៀង ព្រោះអត្ថថា មានហើយ ត្រឡប់ជាមិនមាន ឈ្មោះថា បដិច្ចសមុប្បន្ន ព្រោះអាស្រ័យបច្ច័យ មានអារម្មណ៍ដែលមិនគួរជ្រុះថ្នាជាដើមកើតឡើង ឈ្មោះថា មានការអស់ មានការវិនាស មានការជ្រុះសាក ព្រោះមានការកើតឡើងហើយ បែកធ្លាយទៅជាចំណែកមួយដោយសភាវៈ ព្រោះដួច្នោះ ទើបឈ្មោះថា* **សតោ** *គឺមានសតិ ព្រោះជាបុគ្គលធ្វើសតិ ដោយកំណត់វេទនាថា ជាអនិច្ចតា គឺការមិនទៀង និងឈ្មោះថា ជាអ្នកមានសម្បជញ្ញៈ ព្រោះចាក់ជ្រុះនូវសភាវៈដែលមិនប្រែប្រួល ។*

ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកមានសតិ ព្រោះមានសតិប្រាកដដោយល្អក្នុងកាយ វេទនា ចិត្ត និងធម៌ ក្នុងទីគ្រប់អន្លើ ដោយដល់នូវភាពជាបុគ្គលបរិបូណ៌ដោយសតិ ឈ្មោះថា **សម្បជានោ** *ព្រោះជាអ្នកកំណត់សង្ខារដោយដល់នូវភាពបរិបូណ៌ដោយបញ្ញា ដោយប្រការដូច្នេះ ។ បទថា* **អវិ-ហញ្ញមានោ** *សេចក្តីថា មិនក្តៅក្រហាយដូចអន្ធបុថុជ្ជន ដោយន័យដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង កាលបើទុក្ខធម៌ពាល់ត្រូវ រមែងសោយសោក លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវការវង្វេង ងេងងោង ដូច្នេះ ។ មិនឲ្យទុក្ខផ្សព្វចិត្តកើតឡើង ព្រោះដកឡើងបានដោយមគ្គនោះឯង អត់សង្កត់នូវទុក្ខក្នុងរាងកាយ ដែលកើតអំពីវិបាកនៃកម្មតែម្យ៉ាង ដូចបុគ្គលអង្គុយចូលសមាបត្តិ ។ បទថា* **អទ្ទសា** *សេចក្តីថា ទ្រង់ឃើញភិក្ខុនោះអង្គុយយ៉ាងនោះ ដោយអធិវាសនខន្តី ។*

បទថា **ឯតមត្ថំ** *សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងដល់អត្ថនេះ ពោល គឺព្រះខីណាស្រពមិនត្រូវលោកធម៌បួកលាប ដែលជាហេតុឲ្យដល់នូវការមិនខ្វល់ខ្វាយ ដើម្បីឲ្យគ្រូពេទ្យព្យាបាល ដូច្នោះ ។ ដោយបទថា* **ឥមំ ឧទានំ** *ទ្រង់បន្ទឺឧទាននេះ ដែលជាការជាក់ច្បាស់នៃសង្ខតធម៌ ដែលដល់នូវការមិនចង្អៀតចង្អល់ដោយទុក្ខធម៌ឯណានីមួយ ។*

បណ្តាបទទាំងនោះ បទថា **សព្ពកម្មក្ខយាសម្ប** *បានដល់ ជាអ្នកលះកម្មទាំងអស់បានហើយ ។ ពិតហើយ ចាប់តាំងអំពីកាលដែលអរហត្តមគ្គកើតឡើង កុសលកម្ម និងអកុសលកម្មទាំងពួង ឈ្មោះថា ព្រះអរហន្តលះបាន*

ហើយ ព្រោះមិនអាចឲ្យបដិសន្ធិបាន ដែលជាហេតុឲ្យហៅអរិយមគ្គញ្ញាណថា ធ្វើការអស់ទៅនៃកម្ម ។ បទថា **ភិក្ខុនោ** *បានដល់ ឈ្មោះថា ជាភិក្ខុ ព្រោះទម្លាយកិលេស ។ បទថា* **ឆឌ្ឍមានស្ស បុរេកតំ រជំ** *សេចក្តីថា ទុក្ខ-វេទនីយកម្មដែលបានឈ្មោះថា* **រជំ** *ព្រោះលាយដោយកិលេស ដូចធូលី មានរាគៈជាដើម ដែលបានធ្វើហើយក្នុងកាលមុនអំពីសម្រេចអរហត្ត ដែលកម្ចាត់ គឺកម្ចាត់ទុក្ខវេទនីយកម្មនោះ ដោយការសោយវិបាក ខាងមុខអំពីការសម្រេចអរហត្ត រមែងមិនកើតកិរិយាដែលមានទោសឡើយ កិរិយាដែលមិនមានទោស ត្រឹមតែជាកិរិយាប៉ុណ្ណោះ ព្រោះមិនឲ្យផល កាត់នូវឫសនៃភពបានជាសមុច្ឆេទ ដូចផ្កាមិនអាចឲ្យផ្លែ ព្រោះត្រូវឫសជាច់ ដូច្នោះ ។*

បទថា **អមមស្ស** *សេចក្តីថា ឈ្មោះថា មិនប្រកាន់ថា អញ គឺវៀរចាកមមង្ការ ព្រោះមិនមានការប្រកាន់ថា របស់អញ ក្នុងអារម្មណ៍ណាមួយ មានរូបារម្មណ៍ជាដើម ។ ព្រោះបុគ្គលមានមមង្ការ រមែងឲ្យគ្រូពេទ្យជាដើមរក្សាពាងកាយ ព្រោះការស្រឡាញ់ខ្លួន ឯព្រះអរហន្ត មិនមានមមង្ការ ព្រោះដូច្នោះ ទើបលោកព្រងើយក្នុងការប្រណិប័តន៍ពាងកាយ ។ បទថា* **ឋិតស្ស** *បានដល់ ឆ្លងឱឃៈទាំង ៤ ហើយនៅលើគោក គឺព្រះនិព្វាន ឬតាំងនៅដោយមិនមានការត្រាច់ទៅដោយអំណាចបដិសន្ធិ ។ ពិតហើយ ព្រះសេក្ខៈ និងបុថុជ្ជន ឈ្មោះថា រមែងត្រាច់ទៅ ដោយអំណាចចុតិ និងបដិសន្ធិ ព្រោះលោកលះកិលេស និងអភិសង្ខារមិនទាន់បាន ព្រះអរហន្ត លោកហៅថា* **ឋិតោ** *គឺអ្នកតាំងនៅ ព្រោះមិនមានចុតិ និងបដិសន្ធិនោះ ។ ម្យ៉ាងទៀត*

បានដល់ បុគ្គលដែលតាំងនៅក្នុងអរិយធម៌ ១០ ប្រការ ពោល គឺព្រះខីណាស្រព ។ បទថា **តាទិនោ** *បានដល់ ជាអ្នកប្រកបដោយអរិយឫទ្ធិ ៥ ប្រការ ដែលលោកពោលដោយន័យជាដើមថា ជាបុគ្គលមានការសម្គាល់ក្នុងវត្ថុដែលគួរខ្ពើមថា ជាវត្ថុមិនគួរខ្ពើម និងប្រកបដោយឧបេក្ខាមានអង្គ ៦ ដែលមិនញាប់ញ័រដោយលោកធម៌ ៨ ឈ្មោះថា* **តាទិនោ** *ព្រោះជាអ្នកមាំទាំ ពោល គឺភាពជាបុគ្គលដូចគ្នាក្នុងឥដ្ឋារម្មណ៍ជាដើម ។ បទថា* **អត្ថោ ឧត្តិ ជនំ លបេតវេ** *សេចក្តីថា មិនមានប្រយោជន៍ដែលនឹងពោល គឺពោលនឹងជនថា អ្នកទាំងឡាយ ចូរតាក់តែងកេសជ្ជៈជាដើមដល់អាត្មា ព្រោះមិនមានសេចក្តីអាល័យក្នុងរាងកាយ ។ ពិតហើយ អធ្យាស្រ័យរបស់ព្រះខីណាស្រព មានដូច្នេះថា កាយនេះបែកទៅឯង ដូចស្លឹកឈើពណ៌លឿងជ្រុះចាកទង ដូច្នោះ សមដូចពាក្យដែលលោកពោលពោលក្នុងថេរគាថាថា*

អាត្មា មិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ អាត្មារង់ចាំតែកាលនឹងបរិនិព្វាន ដូចជាអ្នកស៊ីឈ្នួល ទន្ទឹងតែអស់ថ្ងៃ ដូច្នោះ ។

ម្យ៉ាងទៀត ព្រះខីណាស្រព មិនត្រូវការដើម្បីនឹងសម្តែងនិមិត្តណាមួយ ហើយពោលនឹងជនថា ព្រះមានព្រះភាគត្រូវការអ្វី គឺដើម្បីឲ្យជននិយាយដោយការនិមន្តដោយបច្ច័យទាំងឡាយ ព្រោះលោកជកនូវមិច្ឆាជីវៈនោះចេញបាន ដោយមគ្គចិត្តនោះឯង ។

ដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់ប្រកាសហេតុក្នុងការឲ្យព្យាបាលព្រះ

ថេរ: សម្រាប់ពួកជនដែលគិតថា ជាប្រយោជន៍អ្វី ទើបព្រះថេរ:នេះឲ្យហ្នឹ
ព្យាបាលរោគរបស់ខ្លួនហើយ អង្គុយក្នុងទីមិនឆ្ងាយអំពីព្រះមានព្រះភាគ ។

អដ្ឋកថាកម្មសូត្រទី ១ ចប់

សុត្តន្តបិដក

នន្ទសូត្រ

[៦៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះនន្ទដ៏មានអាយុ ជាព្រះអនុជ ជាបុត្តព្រះមាតុច្ចានៃព្រះមានព្រះភាគ និយាយប្រាប់ពួកភិក្ខុច្រើនរូបយ៉ាងនេះថា ម្នាលអាវុសោទាំង-ឡាយ ខ្ញុំមិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយ:ទេ ខ្ញុំមិនអាចនឹងទ្រទ្រង់ព្រហ្ម-ចរិយ:បានទេ ខ្ញុំមុខជានឹងពោលលាសិក្ខា ត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ លំដាប់នោះ ភិក្ខុ ១ រូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនន្ទដ៏មានអាយុ ជាព្រះអនុជ និងជាបុត្តព្រះមាតុច្ចានៃព្រះមានព្រះភាគ បាននិយាយប្រាប់ពួកភិក្ខុច្រើនរូបយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយធម៌ទេ ខ្ញុំមិនអាចទ្រទ្រង់

ព្រហ្មចរិយធម៌បានទេ ខ្ញុំមុខជានឹងពោលលាសិក្ខា ត្រឡប់ទៅកាន់កេទថោក ទាបវិញ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុ ១ រូបមកថា ម្នាលភិក្ខុ អ្នកចូរមក ចូរហៅនន្ទភិក្ខុ តាមពាក្យតថាគតថា ម្នាលអាវុសោ នន្ទ ព្រះសាស្តាទ្រង់ត្រាស់ហៅអ្នក ។ ភិក្ខុនោះទទួលស្តាប់ព្រះពុទ្ធដីកាព្រះ មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយចូលទៅរកព្រះនន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះនន្ទដ៏មានអាយុ ដូច្នេះថា ម្នាល អាវុសោ នន្ទ ព្រះសាស្តាទ្រង់ត្រាស់ហៅអ្នក ។ ព្រះនន្ទដ៏មានអាយុ ទទួល ពាក្យភិក្ខុនោះថា អើអាវុសោ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះ ចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះនន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ ត្រាស់ដូច្នេះថា ម្នាលនន្ទ បានឮថា អ្នកបាននិយាយប្រាប់ពួកភិក្ខុច្រើនរូប យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនត្រេកអរ ។បេ។ ខ្ញុំមុខជានឹង ត្រឡប់ទៅកាន់កេទដ៏ថោកទាបវិញដូច្នេះ ពិតមែនឬ ។ ព្រះនន្ទក្រាបទូលថា ព្រះករុណាព្រះអង្គ ពិតមែន ។ ម្នាលនន្ទ ព្រោះហេតុអ្វី បានជាអ្នកមិន ត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយៈ មិនអាចទ្រទ្រង់ព្រហ្មចរិយៈ នឹងពោលលា សិក្ខា ត្រឡប់ទៅកាន់កេទដ៏ថោកទាបវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន កាល ដែលខ្ញុំព្រះអង្គចេញមកអំពីផ្ទះ នាងសាកិយានីជនបទកល្យាណី កំពុងតែ ស្ទិតស្ទាងសក់បានពាក់កណ្តាល បានស្រែកផ្តាំខ្ញុំព្រះអង្គដូច្នេះថា បពិត្រព្រះ អយ្យបុត្ត សូមទ្រង់ត្រឡប់មកវិញឆាប់ៗ ណា៎ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំ

ព្រះអង្គនោះ រឭកឃើញពាក្យនោះ បានជាមិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយៈ មិនអាចទ្រទ្រង់ព្រហ្មចរិយៈបាន នឹងពោលសិក្ខា ត្រឡប់ទៅកាន់កេទថោកទាបវិញ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចាប់ព្រះនន្ទដ៏មានអាយុត្រង់ដើមដៃ ហើយបាត់អំពីវត្តជេតពន ទៅប្រាកដឯស្ថានតាវត្តិង្សទេវលោក ដូចជាបុរសមានកម្លាំងលាដៃដែលបត់ ឬបត់ដៃដែលលា ដូច្នោះ ។

[៦៨] សម័យនោះឯង ពួកស្ត្រីទេពអប្សរ ចំនួន ៥០០ រូប មានសម្បុរដូចសម្បុរជើងព្រាប បានមកគាល់បម្រើព្រះឥន្ទ្រ ជាស្តេចទេវតា ។ លំដាប់នោះ ព្រះមានព្រះភាគ បានត្រាស់ហៅព្រះនន្ទដ៏មានអាយុថា ម្នាលនន្ទ អ្នកឃើញពួកស្ត្រីទេពអប្សរចំនួន ៥០០ រូប ដែលមានសម្បុរដូចជាសម្បុរជើងព្រាបនេះដែរឬ ។ ព្រះនន្ទក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ម្នាលនន្ទ អ្នកសម្គាល់ហេតុនោះដូចម្តេច នាងសាកិយានីជនបទកល្យាណី នឹងពួកស្ត្រីទេពអប្សរ ចំនួន ៥០០ រូប ដែលមានសម្បុរដូចជាសម្បុរជើងព្រាបនេះ តើស្ត្រីណាមានរូបល្អជាង គួរមិលមើលជាង គួរជ្រះថ្លាជាង ។ បពិត្រព្រះអង្គដ៏ចម្រើន មេស្វាមានរោមរេច កំបុតស្វិតត្រចៀក និងច្រមុះយ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន នាងសាកិយានីជនបទកល្យាណី បើប្រៀបធៀបនឹងពួកស្ត្រីទេពអប្សរ ទាំង ៥០០ រូបនេះ មិនដល់នូវការរាប់ មិនបានមួយចំណិត ទាំងមិនគួរនឹងប្រៀបផ្ទឹមទេ ប្រហែលគ្នានឹងមេស្វានោះក៏យ៉ាងនោះដែរ កាលបើយ៉ាងនេះ ពួកស្ត្រីទេពអប្សរទាំង ៥០០ រូបនេះ មានរូបល្អជាងផង គួរមិលមើលជាងផង គួរជ្រះថ្លាជាងផង ។ ម្នាលនន្ទ

ចូរអ្នកត្រេកអរចុះ ម្នាលនន្ទ ចូរអ្នកត្រេកអរចុះ តថាគតជាអ្នកជានា ឲ្យអ្នក បានពួកស្ត្រីទេពអប្សរទាំង ៥០០ រូប ដែលមានសម្បុរដូចជាសម្បុរជើង ព្រាប ។ បពិត្រព្រះអង្គដ៏ចម្រើន បើព្រះមានព្រះភាគ ជានាឲ្យខ្ញុំព្រះអង្គ បានពួកស្ត្រីទេពអប្សរ ៥០០ រូប ដែលមានសម្បុរដូចសម្បុរជើងព្រាប បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងត្រេកអរក្នុងព្រហ្មចរិយធម៌ ។ លំដាប់ នោះ ព្រះមានព្រះភាគ ទ្រង់ចាប់នន្ទកិក្ខុដ៏មានអាយុ ត្រង់ដើមដៃ ហើយបាត់ អំពីតាវត្តិង្សទេវលោក មកប្រាកដនាវត្តជេតពន ដូចជាបុរសមានកម្លាំងលា ដៃដែលបត់ ឬបត់ដៃដែលលាដូច្នោះឯង ។ ពួកភិក្ខុបានឮថា ព្រះនន្ទដ៏មាន អាយុ ជាព្រះអនុជ ជាបុត្តព្រះមាតុច្ឆានៃព្រះមានព្រះភាគ ប្រព្រឹត្តព្រហ្មចរិយៈ ព្រោះហេតុ (ចង់បាន) នូវពួកស្ត្រីទេពអប្សរ បានឮថា ព្រះមានព្រះភាគ ជាអ្នកជានា ឲ្យលោកបានពួកស្ត្រីទេពអប្សរទាំង ៥០០ រូប ដែលមាន សម្បុរដូចជាសម្បុរជើងព្រាប ។

[៦៩] *លំដាប់នោះ ពួកភិក្ខុជាសម្ភាញ់ព្រះនន្ទដ៏មានអាយុ តែងហៅ រកព្រះនន្ទដ៏មានអាយុ ដោយពាក្យថា ព្រះនន្ទជាអ្នកស៊ីឈ្នួលផង ដោយ ពាក្យថា ព្រះនន្ទ គឺព្រះមានព្រះភាគជួលហើយផង បានឮថា ព្រះនន្ទដ៏មាន អាយុ ជាអ្នកស៊ីឈ្នួល បានឮថា ព្រះនន្ទដ៏មានអាយុ ព្រះមានព្រះភាគជួល ហើយ ប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះហេតុតែពួកស្ត្រីទេពអប្សរ បានឮថា ព្រះមានព្រះភាគ ទ្រង់ជានាឲ្យលោកបានពួកស្ត្រីទេពអប្សរទាំង ៥០០ រូប ដែលមានសម្បុរដូចជាសម្បុរជើងព្រាប ។ លំដាប់នោះ ព្រះនន្ទដ៏មានអាយុ*

នៀយណាយ ធុញទ្រាន់ ជិនឆ្អន់នឹងពាក្យរបស់ពួកភិក្ខុជាសម្ភាញ់ ដែលនិយាយថា លោកជាអ្នកស៊ីឈ្នួលផង នឹងពាក្យថា លោក គឺព្រះមានព្រះភាគជួលហើយផង ក៏គេចចេញទៅតែម្នាក់ឯង មិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្ចាត់កិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន ពួកកុលបុត្តដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីអនុត្តរ-គុណណា មិនយូរប៉ុន្មាន លោកក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចអនុត្តរគុណនោះ មានព្រហ្មចរិយៈជាទីបំផុត ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងបច្ចុប្បន្ន ក៏បានដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចារ្យយៈ អាត្មាអញបានប្រព្រឹត្តចប់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនា-កិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអហន្តទាំងឡាយ ព្រះនន្ទដ៏មានអាយុ ក៏ជាព្រះអរហន្ត ១ រូបដែរ ។

[៧០] លំដាប់នោះឯង ទេវតាមួយអង្គ កាលវេលាវាត្រីបឋមយាមកន្ទងទៅហើយ មានរស្មីរុងរឿង ញុំាងវត្តជេតពនជុំវិញទាំងអស់ឲ្យភ្លឺស្វាងហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយស្ថិតក្នុងទីសមគួរ ។ លុះទេវតានោះ ឈរក្នុងទីសមគួរហើយ ក៏បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនន្ទដ៏មានអាយុ ជាព្រះអនុជ ជាបុត្តព្រះមាតុច្ឆានៃព្រះមានព្រះភាគ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងបច្ចុប្បន្ន

ហើយ ។ ញាណក៏កើតដល់ព្រះមានព្រះភាគ ដូច្នេះថា នន្ទកិក្ខុ បានធ្វើឲ្យ ជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះ អស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងបច្ចុប្បន្នមែន ។ លុះកន្លងរាត្រីនោះហើយ ព្រះនន្ទដ៏មានអាយុ ក៏បានចូលទៅគាល់ព្រះមាន ព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទី សមគួរ ។ លុះព្រះនន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាប ទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ ជានាឲ្យខ្ញុំព្រះអង្គ បានពួកស្ត្រីទេពអប្សរទាំង ៥០០ រូប មានសម្បុរដូចជា សម្បុរជើងព្រាប ដោយការប្តេជ្ញាណា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំ ព្រះអង្គបានរួចចាកការប្តេជ្ញានុ៎ះ នឹងព្រះមានព្រះភាគហើយ ។ ព្រះមានព្រះ ភាគទ្រង់ត្រាស់ថា ម្នាលនន្ទ ទោះបីតថាគត ក៏បានកំណត់ដឹងចិត្តរបស់អ្នក ដោយចិត្តថា នន្ទកិក្ខុ បានធ្វើឲ្យជាក់ច្បាស់ សម្រេចចេតោវិមុត្តិ និងបញ្ញា-វិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញា ដ៏ឧត្តមខ្លួនឯង ក្នុងបច្ចុប្បន្នដែរ ទាំងទេវតា ក៏បានប្រាប់សេចក្តីនុ៎ះ ដល់ តថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនន្ទជាព្រះអនុជ ជាបុត្តព្រះមាតុច្ឆានៃ ព្រះមានព្រះភាគ បានធ្វើឲ្យជាក់ច្បាស់សម្រេចចោតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ម្នាលនន្ទ ចិត្តរបស់អ្នកផុតស្រឡះចាកអាសវៈទាំង-ឡាយ ព្រោះមិនមានសេចក្តីប្រកាន់ ក្នុងកាលណា ឯតថាគត ក៏ផុតស្រឡះ

ចាកការប្តេជ្ញានុ៎ះ ក្នុងកាលនោះដែរ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ភិក្ខុណា បានឆ្លងកន្លង គឺកាម បានញាំញីបង្វា គឺកាម ភិក្ខុនោះ បានដល់នូវការអស់មោហៈ រមែងមិនញាប់ញ័រព្រោះសុខ និងទុក្ខឡើយ ។ សូត្រទី ២ ។

អដ្ឋកថា

ឧរុវេលសូត្រ

នន្ទសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ

[៦៧] *បទថា* **ឧរុវេលោ** *ជាឈ្មោះនៃព្រៃនោះ ។ ពិតហើយ ព្រៃនោះ បានឈ្មោះថា ឧរុ ព្រោះមាតាបិតា បរិវារជន និងញាតិទាំងអស់កើតនូវការត្រេកអរ ព្រោះលោកប្រកបដោយលក្ខណៈនៃស្តេចចក្រពត្តិ ។ បទថា* **ភគវតោ ភាតា** *ឈ្មោះថា ជាប្អូនប្រុស ព្រោះជាឱរសរួមព្រះបិតាជាមួយព្រះមានព្រះភាគ ។ ពិតហើយ មិនមានព្រះឱរសដែលកើតរួមផ្ទៃជាមួយនឹងព្រះមានព្រះភាគ ដោយហេតុនោះ ទើបពោលថា* **មាតុច្ឆាបុត្តោ** *អធិប្បាយថា ជាឱរសរបស់ព្រះមាតុច្ឆា ។ ព្រោះថា លោកជាឱរសរបស់ម្តាយមីង ឈ្មោះថា មហាបជាបតិគោតមី ។ បទថា* **អនភិរតោ** *កាត់បទជា* **ន អភិរតោ** *ប្រែថា មិនត្រេកអរក្រៃលែង ។ បទថា* **ព្រហ្មចរិយំ** *បាន*

ដល់ ការប្រព្រឹត្តដូចព្រហ្ម គឺប្រសើរបំផុត មានទីអង្គុយតែមួយ ទីដេក តែមួយ វៀរមេថុនធម្ម ។ បទថា **សង្ឃារេតុំ** *បានដល់ ដើម្បីញុំាងចិត្តដួង ដំបូង រហូតដល់ចិត្តដួងចុងក្រោយឲ្យប្រព្រឹត្តទៅ គឺឲ្យប្រព្រឹត្តទៅដោយប្រពៃ គឺបរិបូណ៌បរិសុទ្ធ ។ ក្នុងសេចក្តីនេះ គប្បីជ្រាបសង្គហៈ គឺការសង្គ្រោះ មគ្គព្រហ្មចរិយៈ ដោយបទថា* **ព្រហ្មចរិយ** *បទទី ២ ។ បទថា* **សិក្ខំ បច្ចក្ខាយ** *សេចក្តីថា ហាម គឺលះបង់សិក្ខា ៣ ដែលសមាទានព្រមជាមួយ ភាពជាភិក្ខុការៈ ក្នុងពេលឧបសម្បទាដែលមិនតាំងឡើង ដោយការៈដែល គួរកើត ។ បទថា* **ហីនាយ** *ប្រែថា ដើម្បីភាពជាគ្រហស្ថ ។ បទថា* **អាវត្តិស្សាមិ** *បានដល់ នឹងត្រឡប់ទៅ សួរថា ព្រោះហេតុអ្វី ទើបលោក ក្រាបទូលយ៉ាងនោះ ក្នុងសេចក្តីនោះ មានអនុបុព្វីកថាដូចតទៅនេះ*

ព្រះមានព្រះភាគ ទ្រង់ប្រកាសព្រះធម្មចក្រដ៏បវរ ហើយយាងទៅក្រុង រាជគ្រឹះ គង់ប្រថាប់នៅក្នុងវត្តវេឡុវនមហាវិហារ ដែលព្រះកាឡុទាយិត្ថេរទៅ ក្រោយគេបង្អស់ ក្នុងបណ្តាទូត ១០ នាក់ ដែលមានបរិវារ ១០០០ ដែល ព្រះបាទសុទ្ធោទនមហារាជ ទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា ចូរពួកអ្នកនាំ បុត្រមកបង្ហាញដល់ខ្ញុំ សម្រេចព្រះអរហត្ត មួយអន្លើដោយបរិវារ សម្រេច ព្រះអរហត្តហើយ ដឹងកាលយាងទៅរបស់ព្រះមានព្រះភាគ បានពណ៌នាផ្លូវ ទូលអារាធនាដើម្បីយាងទៅកាន់ជាតិភូមិ ចោមរោមដោយព្រះខីណាស្រព ២ ម៉ឺន យាងដល់ក្រុងកបិលពស្តុ ធ្វើភ្លៀងបោកព័ន្ធឲ្យធ្លាក់ក្នុងសមាគមព្រះញាតិ ជាអត្ថុប្បត្តិហេតុ ហើយទ្រង់សម្តែងវេស្សន្តរជាតក ថ្ងៃស្អែកឡើង ទ្រង់យាង

ទៅបិណ្ឌបាត ទ្រង់ញុាំងព្រះបិតាឲ្យតាំងនៅក្នុងសោតាបត្តិផល ដោយព្រះគាថាថា **ឧត្តិដ្ឋេ នប្បមជ្ជេយ្យ** មិនគប្បីប្រមាទក្នុងដុំបាយ ដែលបុគ្គលគប្បីក្រោកឡើងទទួល ហើយយាងទៅកាន់ព្រះរាជនិវេសន៍ ទ្រង់ឲ្យព្រះនាងមហាបជាបតីតាំងនៅក្នុងសោតាបត្តិផល ទ្រង់ឲ្យព្រះរាជាតាំងនៅក្នុងសកទាគាមិផល ដោយព្រះគាថាថា **ធម្មញ្ចរេ** គឺគប្បីប្រព្រឹត្តធម៌ជាដើម ។

ក្នុងកាលស្រេចភត្តកិច្ច ទ្រង់អាស្រ័យកិច្ចពណ៌នាគុណរបស់រាហុលមាតា ត្រាស់ចន្ទកិន្នរីជាតក ក្នុងថ្ងៃទី ៣ ក្នុងថ្ងៃវិវាហមង្គល ព្រះញាតិយាងទ្រង់ចូលកាន់ព្រះដំណាក់ ដើម្បីអភិសេកនន្ទកុមារកំពុងប្រព្រឹត្តទៅ ទ្រង់ក៏យាងចូលទៅបិណ្ឌបាត ប្រទានបាត្រក្នុងដៃនន្ទកុមារ ត្រាស់មង្គលហើយ ទ្រង់យាងចេញទៅ ទ្រង់មិនទទួលបាត្រអំពីដៃរបស់នន្ទកុមារឡើយ ។ ឯនន្ទកុមារដោយការគោរពក្នុងព្រះតថាគត ទើបមិនអាចទូលថា សូមទ្រង់ទទួលបាត្រវិញចុះ តែគិតយ៉ាងនេះថា ព្រះសាស្តាទ្រង់នឹងទទួលបាត្រត្រង់ក្បាលជណ្តើរក្នុងទីនោះទ្រង់មិនទទួល ។ ឯនន្ទកុមារក៏គិតថា ទ្រង់នឹងទទួលត្រង់ជើងជណ្តើរ ។ ក្នុងទីនោះ ព្រះសាស្តាក៏ទ្រង់មិនទទួល ។ នន្ទកុមារគិតថា ទ្រង់នឹងទទួលត្រង់លានព្រះរាជវាំង ។ ក្នុងទីនោះ ព្រះសាស្តាក៏មិនទទួល ។ ព្រះរាជកុមារប្រាថ្នាយាងត្រឡប់ តែទៅដោយការមិនពេញចិត្ត ដោយសេចក្តីគោរព ទើបមិនអាចទូលថា សូមទ្រង់ទទួលបាត្រចុះ គ្រាន់តែគិតថា ព្រះសាស្តាទ្រង់នឹងទទួលក្នុងទីនេះ ទ្រង់នឹងទទួលក្នុងទីនេះ ។ គ្រានោះ ស្រីដទៃឃើញអាការនោះហើយ ទើបប្រាប់ដល់នាងជនបទកល្យាណីថា បពិត្រព្រះ

នាង ព្រះមានព្រះភាគ ទ្រង់នាំនន្ទកុមារយាងទៅហើយ ទ្រង់ពិតជាពង្រាត់នន្ទកុមារអំពីព្រះនាង ។ នាងជនបទកល្យាណីនោះ មកទាំងមានទឹកភ្នែកហូរ មានសក់បួងបានពាក់កណ្តាល រួតរះឡើងកាន់ប្រាសាទ ឈរត្រង់មាត់បង្អួច ទូលថា បពិត្រអយ្យបុត្រ សូមទ្រង់ប្រញាប់យាងត្រឡប់ ។ ពាក្យរបស់នាងនោះ ហាក់បីដូចជាក់ទៅតាំងនៅក្នុងហទយៈរបស់នន្ទកុមារនោះ ។ សូម្បីព្រះសាស្តាទ្រង់ក៏មិនទទួលបាត្រអំពីដៃនន្ទកុមារនោះឡើយ ទ្រង់នាំនន្ទកុមារនោះទៅកាន់វិហារ ហើយត្រាស់ថា នន្ទ អ្នកបួសឬទេ នន្ទនោះ ដោយសេចក្តីគោរពក្នុងព្រះពុទ្ធ ទើបមិនទូលថា មិនបួស បែរជាទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងបួស ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នេះ អ្នកទាំងឡាយ ចូរឲ្យនន្ទបួសចុះ ទើបយាងទៅកាន់ក្រុងកបិលពស្តុក្នុងថ្ងៃទី ៣ ទ្រង់ឲ្យនន្ទកុមារបួសហើយ ។ ក្នុងថ្ងៃទី ៧ ព្រះសាស្តាឲ្យព្រះរាហុលកុមារដែលព្រះមាតាតាក់តែងបញ្ជូនទៅដោយព្រះតម្រាស់ថា បពិត្រសមណៈ សូមទ្រង់ប្រទានទ្រព្យមត៌កដល់ខ្ញុំចុះ ដូច្នេះហើយ មកកាន់អារាមជាមួយព្រះអង្គ ឲ្យបព្វជ្ជាហើយ ស្អែកឡើង ទើបត្រាស់មហាធម្មបាលជាតកឲ្យព្រះរាជា គឺព្រះបាទសុទ្ធោទនៈតាំងនៅក្នុងអនាគាមិផល ។

ព្រះមានព្រះភាគ ទ្រង់ឲ្យព្រះនាងមហាបជាបតី តាំងនៅក្នុងសោតាបត្តិផល ទ្រង់ឲ្យព្រះបិតាតាំងនៅក្នុងផល ៣ ទ្រង់ចោមរោមដោយភិក្ខុសង្ឃ យាងទៅកាន់ក្រុងរាជគ្រឹះទៀត បន្ទាប់អំពីនោះ បានទទួលប្តេជ្ញា ដែលអនាថបិណ្ឌិកអារាធនា ដើម្បីយាងមកកាន់ក្រុងសាវត្ថី កាលវត្តជេតពនធ្វើស្រេច

ហើយ ក៏យាងទៅប្រថាប់ក្នុងទីនោះ ដោយប្រការដូច្នេះ ។ កាលព្រះសាស្តា គង់ប្រថាប់នៅក្នុងវត្តជេតពន ដោយអាការយ៉ាងនេះ ព្រះនន្ទបួសដោយមិនពេញព្រះហឫទ័យ មិនឃើញទោសក្នុងកាម លោភរឭកដល់ពាក្យដែលនាងជនបទកល្យាណីពោល កើតនូវសេចក្តីអផ្សុក ប្រាប់ការមិនត្រេកអរដល់ភិក្ខុទាំងឡាយហើយ ។ ដោយហេតុនោះ ទើបលោកពោលថា **តេន ខោ បន សមយេន អាយស្មា នន្ទោ ។បេ។ ហីនាយាវត្តិស្សាមិ** *ដូច្នេះ ។*

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគឲ្យនន្ទបួសយ៉ាងនោះ ឆ្លើយថា ព្រោះព្រះសាស្តា ជាអ្នកឈ្វាសក្នុងការដឹកនាំវិនេយ្យសត្វ ដោយបំណងថា តថាគតនឹងសម្តែងទោស ទើបមិនឲ្យនន្ទស្វាត់ចាកកាមទាំងឡាយបាន លុះឲ្យបួសហើយ ទើបឲ្យស្វាត់ចាកកាមនោះដោយឧបាយ ញុំាងគុណវិសេសខាងលើឲ្យកើតឡើង កាលបើដូច្នោះ ទើបឲ្យនន្ទនោះបួសសិន ។ បទថា **សាកិយានី** *បានដល់ ធីតានៃស្តេចសក្យៈ ។ បទថា* **ជនបទកល្យាណី** *ប្រែថា ស្រីស្អាតប្រចាំជនបទ ជាអ្នកល្អដោយរូប មិនមានទោសក្នុងវាងកាយ ៦ យ៉ាង ប្រកបដោយលម្អ ៥ ព្រោះនាងមិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិនសពេក កន្ទងបង់នូវពណ៌សម្បុរបស់មនុស្ស តែមិនដល់ពណ៌សម្បុរបស់ទេវតា ដូច្នោះ ទើបឈ្មោះថា រៀរទោសក្នុងវាងកាយ ៦ ប្រកបដោយលម្អទាំងឡាយ គឺលម្អស្បែក លម្អសាច់ លម្អក្រចក ឬលម្អសក់ លម្អឆ្អឹង និងលម្អវ័យ ។ បណ្តាលម្អទាំងនោះ ស្បែករមែងធ្វើនូវពន្លឺក្នុងទីប្រមាណ ១០-១២ ហត្ថ ដោយពន្លឺដែលចេញអំពីសរីរៈ*

របស់ខ្លួន មានសម្បុរស្បែកស្មើដោយផ្កាប្រយង្គ ឬស្មើដោយមាស នេះ ឈ្មោះថា លម្អស្បែក ។ ឯដៃទាំង ២ ជើងទាំង ២ បបូរមាត់របស់នាង ដូច គ្នានឹងកែវប្រពាល និងសំពត់កម្ពលក្រហម ហាក់បីដូចលាបដោយទឹកលវ៉ា នេះឈ្មោះថា លម្អសាច់ ។ ឯក្រចកទាំង ២០ ក្នុងទីដែលផុតអំពីសាច់ ដូច គ្នានឹងធ្នាវទឹកដោះ ក្នុងទីដែលមិនផុតអំពីសាច់ ហាក់បីដូចលាបដោយទឹកលវ៉ា នេះឈ្មោះថា លម្អក្រចក ។ ធ្មេញទាំង ៣២ រាបស្មើ ដូចគ្នានឹងជួរនៃកែវ ប្រពាលដ៏សបរិសុទ្ធ រមែងប្រាកដដូចកម្រងពេជ្រ នេះឈ្មោះថា លម្អធ្មេញ ។ នាងមានអាយុ ១២០ ឆ្នាំ ដូចគ្នានឹងស្រីអាយុ ១៦ ឆ្នាំ មិនមានសក់ស្កូវ នេះឈ្មោះថា លម្អវ័យ ។ នាងជាបុគ្គលមានលម្អប្រកបដោយគុណសម្បត្តិ បែបនេះ ដោយហេតុនោះ ទើបឈ្មោះថា ជនបទកល្យាណី គឺស្រីស្អាត ក្នុងជនបទ ។

បទថា **ឃរា និក្ខមន្តស្ស** *ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថអនាទរ អធិប្បាយ ថា កាលចេញចាកផ្ទះ ។ អាចារ្យពួកខ្លះពោលថា* **ឃរា និក្ខមន្តិ** *ដូច្នេះក៏ មាន ។ បទថា* **ឧបឌ្ឍលិទ្ធិតេហិ កេសេហិ** *ជាតតិយាវិភត្តិ ប្រើក្នុងលក្ខណៈ ឥត្ថម្ភូត អធិប្បាយថា នាងមានចុងសក់ ធ ។ អាចារ្យពួកខ្លះពោលថា* **អឌ្ឍលិទ្ធិតេហិ** *ដូច្នេះក៏មាន ។ ពាក្យថា* **ឧលិទ្ធិតំ** *ជាការធ្វើសក់ឲ្យតាំងនៅ ដូចជាពពាវពស់ អាចារ្យពួកខ្លះពោលថា* **អឌ្ឍការវិធានំ** *ដូច្នេះក៏មាន ។ បទថា* **អបលោកេត្វា** *បានដល់ សម្ងឹងមើលដោយភ្នែកដែលខ្ទុះបញ្ចាំងដល់ ការជ្រួតជ្រាបទៅនៃរសស្នេហា ដូចគ្រឿងចង ។ បទថា* **មំ ភន្តេ** *សេចក្តីថា*

កាលមុន នាងក៏បានពោលថា **មំ ឯតទវោច** ព្រោះនាងមានចិត្តវិលវល់ ដោយការអផ្សុក ។ បទថា **តុវដំ** ប្រែថា រហ័ស ។ បទថា **តមនុស្សរ-មានោ** សេចក្តីថា ព្រះនន្ទរឲកដល់ពាក្យរបស់នាង ឬពាក្យដែលប្រកប ដោយអាការរបស់នាងនោះ ។

ព្រះមានព្រះភាគ កាលទ្រង់ស្តាប់ពាក្យរបស់ន្ទនោះហើយ ទ្រង់ព្រះ-តម្រិះរម្ងាប់រាគៈរបស់ន្ទដោយឧបាយ កាលនាំព្រះន្ទនោះទៅកាន់តាវត្តិង្ស-ភព ដោយកម្ងាំងឫទ្ធិ ទើបទ្រង់បង្ហាញស្ងាញីមួយក្បាល មានត្រចៀក ច្រមុះ និងកន្ទុយដាច់ អង្គុយលើដង្គត់ដែលត្រូវភ្លើងឆេះ ក្នុងស្រែដែលត្រូវភ្លើងឆេះ មួយកន្លែង ក្នុងរវាងផ្ទូវ ទ្រង់នាំទៅកាន់តាវត្តិង្សភព ។ តែក្នុងព្រះបាលី ព្រះ សាស្តាត្រាស់ហាក់ដូចទៅកាន់តាវត្តិង្សភពតែម្តងប៉ុណ្ណោះ មិនត្រាស់ការទៅ នោះ ត្រាស់សំដៅយកភពតាវត្តិង្ស ។ ពិតហើយ ព្រះសាស្តា កាលយាង ទៅនោះឯង ទ្រង់បង្ហាញស្ងានោះដល់ព្រះន្ទ ក្នុងរវាងផ្ទូវ ។ កាលបើដូច្នោះ ការសម្តែងការបត់ដៃជាដើមដូចម្តេច ការសម្តែងនោះ គួរកាន់យកថា ជាការ សម្តែងការអន្ទរធានទៅ ។ ព្រះសាស្តា ទ្រង់នាំព្រះន្ទទៅកាន់ភពតាវត្តិង្ស ដោយប្រការយ៉ាងនោះហើយ ទ្រង់បង្ហាញស្រីទេពអប្សរ ៥០០ ដែលមាន ជើងដូចជើងព្រាប ដែលមកកាន់ទីបម្រើសក្តទេវរាជ ឈរថ្វាយបង្គំព្រះសាស្តា ហើយត្រាស់សួរការប្លែកគ្នា ដោយប្រៀបធៀបរូបសម្បត្តិស្រីទេពអប្សរ ៥០០ នឹងនាងជនបទកល្យាណី ។ ព្រោះហេតុនោះ ទើបលោកពោលថា **អថទោ ភគវា អាយស្មន្តំ ន្ទំ ពាហាយ គហេត្វា ។បេ។ កកុដទាធានិ** បណ្តាបទ

ទាំងនោះ បទថា **ពាហាយ គហេត្វា** ប្រែថា ដូចចាប់ដើមដៃ ។

ពិតហើយ ក្នុងពេលនោះ ព្រះមានព្រះភាគទ្រង់សម្តែងឥទ្ធាភិសង្ខារ ដូចព្រះនន្ទត្រូវព្រះមានព្រះភាគចាប់ដើមដៃនាំទៅ ដូច្នោះ ។ ក្នុងកាលនោះ បើព្រះមានព្រះភាគ ទ្រង់ប្រាថ្នាឲ្យព្រះនន្ទយើញ ឬចូលទៅកាន់ទេវលោក ជាន់តាវត្តិង្ស ទ្រង់គប្បីបង្ហាញទេវលោកនោះដល់ព្រះនន្ទ ដែលកំពុងអង្គុយនោះឯង ដូចក្នុងកាលដែលទ្រង់សម្តែងឬទ្ធិបើកលោក ឬគប្បីបញ្ជូនន្ទនោះឯងទៅក្នុងទេវលោកដោយឬទ្ធិ ព្រោះហេតុដើម្បីកាន់យកដោយងាយដល់ភាវ: នៃអត្តភាពមនុស្ស ដែលជារបស់ស្មោកគ្រោក គូរខ្ពើម ជាងអត្តភាពដែលជាទិព្ធ ទ្រង់បំណងនឹងបង្ហាញស្ងានោះ ក្នុងរវាងផ្លូវ ដល់ព្រះនន្ទ និងទ្រង់មានបំណងបង្ហាញឲ្យព្រះនន្ទកាន់យកសិរីសម្បត្តិ និងភាវសម្បត្តិក្នុងទេវលោកដូច្នោះ ទើបទ្រង់នាំព្រះនន្ទទៅក្នុងទេវលោកនោះ ។ ដោយអាការយ៉ាងនេះ ព្រះនន្ទក៏នឹងមានសេចក្តីត្រេកអរក្រៃលែង ជាពិសេស ក្នុងការនៅប្រព្រឹត្តព្រហ្មចរិយ: ដើម្បីសម្បត្តិនេះឯង ។

[៦៨] បទថា **ឥកុដទាធានិ** សេចក្តីថា មានជើងដូចជើងព្រាបព្រោះមានពណ៌ក្រហម ។ បានឮថា ទេពអប្សរទាំងនោះមានជើងប្រណីតបែបនោះ ព្រោះបានប្រគេនប្រេងសម្រាប់លាបជើងដល់សាវ័ករបស់ព្រះមានព្រះភាគ ព្រះនាមកស្សប ។

បទថា **បស្សសិ នោ** កាត់បទជា **បស្សសិ នុ ។** បទថា **អភិរូបតរា** ប្រែថា មានរូបវិសេសជាង ។ បទថា **ឧស្សនីយតរា** សេចក្តីថា ឈ្មោះថា

គួរសរសើរជាង ព្រោះអត្ថថា ធ្វើបុគ្គលដែលសម្ងឹងមើលអស់ថ្ងៃក៏មិនធ្មែត ។ បទថា **ចាសាធិកតរា** បានដល់ នាំមកនូវការសរសើរដោយទូទៅ ព្រោះមានអវយវៈគ្រប់ចំណែក ។

ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់ឲ្យព្រះនន្ទដែលមានចិត្តសើមដោយរាគៈឃើញស្រីទេពអប្សរ ធ្វើយថា ដើម្បីនាំកិលេសរបស់ព្រះនន្ទចេញដោយងាយស្រួលនោះឯង ។ គប្បីជ្រាបថា ដូចពេទ្យអ្នកឈ្ងាស ព្យាបាលបុគ្គលដែលមានទោសច្រើន ជាបឋម ជម្រះទោស ដោយការផឹកប្រេងជាដើម ក្រោយមក ទើបនាំចេញនូវកម្អួត និងការបញ្ចុះបានដោយងាយ យ៉ាងណា ព្រះមានព្រះភាគ ទ្រង់ឈ្ងាសក្នុងការទូន្មានវេនេយ្យសត្វក៏ដូច្នោះ ទ្រង់បង្ហាញស្រីទេពអប្សរដល់ព្រះនន្ទ ដែលមានរាគៈក្រាស់ ឲ្យអស់ទោស ទ្រង់បំណងនឹងនាំព្រះនន្ទចេញជាសមុច្ឆេទដោយភេសជ្ជៈ គឺអរិយមគ្គ ។

បទថា **បលុដ្ឋមក្ពជី** បានដល់ ស្វាញី មានខ្ជូន និងអវយវៈដូចត្រូវភ្ជីងធេះ ។ បទថា **ឯវមេវ ខោ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ស្វាញីដែលកំបុតត្រចៀក និងច្រមុះ ដែលទ្រង់បង្ហាញដល់ខ្ញុំព្រះអង្គនោះ ប្រៀបដូចនាងជនបទកល្យាណី យ៉ាងណា នាងជនបទកល្យាណីប្រៀបនឹងស្រីទេពអប្សរ ៥០០ នេះ ក៏ដូច្នោះដូចគ្នា ។ បទថា **បញ្ចន្នំ អច្ឆរាសតានំ** ជាធដ្ឋីវិភត្តិ ប្រើក្នុងអត្ថទុតិយាវិភត្តិ សេចក្តីថា នូវស្រីទេពអប្សរ ៥០០ ។ ម្យ៉ាងទៀត បទថា **បញ្ចន្នំ អច្ឆរាសតានំ** នេះ ជាធដ្ឋីវិភត្តិ ប្រើក្នុងអត្ថដែលភ្ជាប់ជាមួយអវយវៈ ។ ដោយពាក្យនោះ មានអធិប្បាយថា ប្រៀបរូបសម្បត្តិនៃ

ស្រីទេពអប្សរ ៥០០ ។ បទថា **ឧបនិធាយ** *បានដល់ តាំងនៅក្នុងទីជិតគ្នា អធិប្បាយថា ប្រៀបធៀបគ្នា ។ បទថា* **សង្ខ្យំ** *បានដល់ ការរាប់ ឬបែងចែក ថា ស្រី ។ បទថា* **កលភាគំ** *ប្រែថា ចំណែកនៃចម្រៀក ។ កាលចែក ១ ចម្រៀកជា ១៦ ដង ហើយកាន់យកចំណែកទី ១៦ នោះ ហើយរាប់ដោយ ១៦ ចំណែក ក្នុង ១៦ ចំណែកនោះ ១ ចំណែក លោកបំណងយកថា ចំណែកនៃចម្រៀក ។ លោកពោលថា មិនចូលដល់ចំណែកនៃចម្រៀកនោះ បទថា* **ឧបនិធិ** *បានដល់ ទុកក្នុងទីជិតគ្នា ដោយកាន់យកការប្រៀបធៀបថា ស្រីនេះ និងស្រីនេះ ។*

ព្រហ្មចរិយៈដែលព្រះនន្ទមិនត្រេកអរនោះ បានពោលហើយ និងប្រាកដក្នុងកាលមុន ព្រោះដូច្នោះ ដើម្បីមិនអាស្រ័យសេចក្តីនោះ ទើបឲ្យលោកកើតនូវសេចក្តីអើពើក្នុងសេចក្តីត្រេកអរក្រៃលែងក្នុងព្រហ្មចរិយៈនោះ ទើបត្រាស់ត្រួតពាក្យថា ម្នាលនន្ទ ចូរអ្នកត្រេកអរចុះ ម្នាលនន្ទ ចូរអ្នកត្រេកអរចុះ ដូច្នេះ ។ បទថា **អហំ តេ ថាដិភោគោ** *សេចក្តីថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទ្រង់ប្រាថ្នាឲ្យព្រះនន្ទនៅប្រព្រឹត្តព្រហ្មចរិយៈ ទើបទ្រង់បានទទួលជានាមិនឲ្យព្រះនន្ទនៅប្រព្រឹត្តព្រហ្មចរិយៈព្រោះព្រះអង្គ ដើម្បីនឹងធ្វើអារម្មណ៍ដែលព្រះនន្ទមានតម្រេកជាប់ស្និត ហើយឲ្យឈានទៅក្នុងអារម្មណ៍ថ្មី ទើបអាចឲ្យលះបានងាយ ព្រោះហេតុនោះ ទើបទ្រង់ជានា ។ ក្នុងអនុបុព្វីកថា មានកថាប្រារព្ធសួរជាគ្រឿងចង្អុលដល់អត្ថនេះ ។ បទថា* **អស្សោសុំ** *បានដល់ ភិក្ខុទាំងឡាយបានស្តាប់មកដូចម្តេច ព្រោះក្នុងពេលនោះ ព្រះមានព្រះភាគ*

កាលនន្ទសម្តែងវត្តហើយ ទើបទៅកាន់ទីសម្រាកពេលថ្ងៃរបស់ខ្លួន ត្រាស់រឿងនោះដល់ភិក្ខុដែលមកឧបដ្ឋាក មានព្រះបំណងនឹងនាំនូវតម្រេករបស់ព្រះនន្ទ ក្នុងអារម្មណ៍ដែលធ្លាប់ស្និទ្ធស្នាល ដោយអារម្មណ៍ដែលគ្រាច់មកហើយ ទើបនាំចេញទៅ និងធ្វើអារម្មណ៍នោះឲ្យជាហេតុ ក្នុងមគ្គព្រហ្មចរិយៈ ដូចបុរសដែលឈ្វាស យកស្មៀតមួយ ចោះបញ្ចូនស្មៀតមួយ ដែលមិនទាន់ចេញ ឲ្យចេញទៅ ហើយយកដៃជាដើមចាប់ស្មៀតនោះអង្រៀកទាញចេញ ទើបទ្រង់ត្រាស់ថា មកចុះភិក្ខុទាំងឡាយ ពួកអ្នក ចូរហៅនន្ទភិក្ខុដោយវាទៈជាកូនឈ្នួល និងដោយវាទៈថា ភិក្ខុដែលត្រូវលោះមក ។ ភិក្ខុទាំងឡាយបានក្រាបទូលយ៉ាងនោះ ។ ឯអាចារ្យពួកខ្លះពោលថា ព្រះមានព្រះភាគ ទ្រង់សម្តែងឥន្ទ្រិយសង្វរ ដូចដែលភិក្ខុទាំងឡាយដឹងនូវសេចក្តីនោះ ។

[៦៩] *បទថា* **ភតកវាទេន** *ប្រែថា ដោយវាទៈថា កូនឈ្នួល ។ បុគ្គលណា ធ្វើការងារដើម្បីឈ្នួល បុគ្គលនោះ ហៅថា កូនឈ្នួល ។ ព្រះនន្ទនេះប្រព្រឹត្តព្រហ្មចរិយៈ ដែលមានការនៅរួមជាមួយស្រីទេពអប្សរជាហេតុ ទើបហាក់ដូចកូនឈ្នួល ព្រោះដូច្នោះ ទើបត្រាស់ថា* **ភតកវាទេន** *ដូច្នេះ ។ បទថា* **ឧបក្ខិតកវាទេន** *សេចក្តីថា បុគ្គលណាទិញអ្វីដោយកហាបណៈជាដើម អ្នកនោះ គេហៅថា ជាបុគ្គលត្រូវលោះមក សូម្បីព្រះនន្ទ ក៏ទិញព្រហ្មចរិយៈរបស់ខ្លួន ព្រោះហេតុនៃស្រីទេពអប្សរ ព្រោះដូច្នោះ ទើបភិក្ខុទាំងឡាយ ហៅព្រះនន្ទដោយពាក្យយ៉ាងនេះថា ជាបុគ្គលត្រូវលោះមក ។ ម្យ៉ាងទៀត ព្រះនន្ទ ញុំាងជីវិត ពោល គឺការប្រព្រឹត្តព្រហ្មចរិយៈឲ្យប្រព្រឹត្តទៅ*

ដោយថ្លៃឈ្នួល ពោល គឺការនៅរួមជាមួយស្រីទេពអប្សរតាមព្រះតម្រាស់របស់ព្រះមានព្រះភាគ ហាក់ដូចព្រះអង្គទ្រង់ចិញ្ចឹម ដោយការញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅដោយថ្លៃឈ្នួលនោះ ព្រោះដូច្នោះ ទើបគេហៅថា ជាបុគ្គលដែលព្រះមានព្រះភាគ ទ្រង់ចិញ្ចឹម ។ ម្យ៉ាងទៀត លោកធ្វើនូវការលក់ ពោល គឺការនៅរួមជាមួយស្រីទេពអប្សរ ឲ្យជាវត្ថុដែលខ្លួនគប្បីទាញយក ហើយតាំងនៅក្នុងព្រះតម្រាស់របស់ព្រះមានព្រះភាគ ទើបហាក់ដូចជាព្រះមានព្រះភាគទ្រង់លោះមក ដោយការលក់នោះ ព្រោះដូច្នោះ ទើបលោកហៅថា ជាបុគ្គលដែលព្រះមានព្រះភាគ ទ្រង់លោះមក ។

បទថា **អដ្ឋិយមានោ** *បានដល់ ត្រូវបៀតបៀន គឺបានទទួលនូវសេចក្តីលំបាក ។ បទថា* **ហរាយមានោ** *បានដល់ ខ្វាស ។ បទថា* **ជិគុច្ឆមនោ** *បានដល់ តិះដៀលថា ជារបស់គួរខ្ពើម ។ បទថា* **ឃកោ** *ប្រែថា មិនមានសម្ងាញ់ ។ បទថា* **វូបកដ្ឋោ** *សេចក្តីថា មានកាយ និងចិត្តស្ងាត់ហើយចាកវត្ថុកាម និងកិលេសកាម ។ បទថា* **អប្បមត្តោ** *បានដល់ មិនលះសតិក្នុងកម្មដ្ឋាន ។ បទថា* **អាតាបី** *បានដល់ ឈ្មោះថា ញ៉ាំងកិលេសឲ្យក្តៅ ព្រោះឲ្យក្តៅក្រហាយ ដោយសេចក្តីព្យាយាមផ្លូវកាយ និងសេចក្តីព្យាយាមផ្លូវចិត្ត ឈ្មោះថា* **អាតាប** *ព្រោះញ៉ាំងកិលេសឲ្យក្តៅទូទៅ បានដល់ សេចក្តីព្យាយាម ។ បទថា* **បហិតត្តោ** *ប្រែថា មានកាយបញ្ជូនទៅហើយ គឺមានអត្តភាពលះបង់ហើយ ដោយមិនអាល័យក្នុងកាយ និងជីវិត ឬមានចិត្តបញ្ជូនទៅហើយក្នុងព្រះនិព្វាន ។ បទថា* **ឆថិរសេ្សវ** *បានដល់ មិនយូរប៉ុន្មានអំពី*

ការផ្តើមកម្មដ្ឋាន ។ បទថា **យស្សត្តាយ** *កាត់បទជា* **យស្ស អត្តាយ ។** *បទថា* **កុលបុត្តា** *បានដល់ កុលបុត្រ ២ ពួក គឺកុលបុត្រដោយកំណើត ១ កុលបុត្រដោយមារយាទ ១ តែព្រះនន្ទនេះ ជាកុលបុត្រទាំង ២ ចំណែក ។ បទថា* **សម្មទេវ** *បានដល់ ដោយហេតុ និងដោយការណ៍ ។ បទថា* **អគារស្មា** *ប្រែថា ចាកផ្ទះ ។ បទថា* **អនគារិយំ** *បានដល់ ការចេញបព្វជ្ជា ។ ពិតហើយ កម្ម មានកសិកម្ម និងពាណិជកម្មជាដើមជាប្រយោជន៍ដល់ផ្ទះ ព្រោះដូច្នោះ ទើបឈ្មោះថា* **អគារិយ ។** *កម្មនោះ មិនមានក្នុងបព្វជ្ជានេះ ព្រោះដូច្នោះ ទើបបព្វជ្ជា ឈ្មោះថា* **អនគារិយ ។** *បទថា* **បព្វជន្តិ** *ប្រែថា ចូលដល់ ។ បទថា* **តទនុត្តរំ** *កាត់ជា* **តំ អនុត្តរំ ។** *បទថា* **ព្រហ្មចរិយ-បរិយោសានំ** *បានដល់ អរហត្តផល ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។ ពិតហើយ កុលបុត្រទាំងឡាយ រមែងបួសក្នុងព្រះសាសនាដើម្បីជាប្រយោជន៍ដល់អរហត្តផលនោះ ។ បទថា* **ឯដ្ឋេវ ធម្មេ** *គឺក្នុងអត្តភាពនោះឯង ។ បទថា* **សយំ អភិញ្ញា សច្ឆិកត្វា** *សេចក្តីថា ធ្វើឲ្យប្រចក្សដោយបញ្ញាខ្លួនឯងនោះឯង អធិប្បាយថា ដឹងដោយមិនមានអ្នកដទៃជាហេតុ ។ បទថា* **ឧបសម្បជ្ជ វិហាសិ** *បានដល់ ដល់ ឬសម្រេច ។ លោកសម្តែងបច្ចវេក្ខណភូមិ ដោយពាក្យនេះថា ក៏បានដឹងច្បាស់ថា ជាតិអស់ហើយ ។បេ។ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។*

បណ្តាបទទាំងនោះ បទថា **ខីណា ជាតិ** *បានដល់ ជាបឋមជាតិ ដែលជាអតីតរបស់ព្រះនន្ទនោះ អស់ទៅក៏មិនមែន ព្រោះអស់ទៅក្នុងអតីតហើយ*

*ជាតិក្នុងអនាគតរបស់លោក អស់ទៅហើយក៏មិនមែន ព្រោះមិនទាន់មកទាំង ក្នុងអតីត និងបច្ចុប្បន្ន ជាតិដែលជាបច្ចុប្បន្នរបស់លោកអស់ទៅហើយក៏មិន មែន ព្រោះនៅមាន ។ ម្យ៉ាងទៀត ជាតិណា មានខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ក្នុងឯកវោការភព ចតុវោការភព និងបញ្ចវោការភពគប្បីកើតឡើង ព្រោះ មិនទាន់ចម្រើនមគ្គ ជាតិនោះ ឈ្មោះថា អស់ទៅហើយ ព្រោះដល់នូវការមិន កើតឡើងជាធម្មតា ដែលបានចម្រើនមគ្គហើយ ។ ព្រះខន្ធនោះ ពិចារណា ដល់កិលេសដែលលះហើយ ដោយមគ្គភាវនា ទើបដឹងក្រៃលែងដល់ជាតិ នោះ ដោយការដឹងថា សូម្បីមានកម្ម ក៏មិនមានបដិសន្ធិតទៅ ព្រោះមិន មានកិលេស ។ បទថា **វុសិតំ** ប្រែថា នៅហើយ គឺនៅចប់ហើយ បានដល់ ធ្វើហើយ ប្រព្រឹត្តហើយ អធិប្បាយថា សម្រេចហើយ ។ បទថា **ព្រហ្ម-ចរិយំ** បានដល់ មគ្គព្រហ្មចរិយៈ ។ ព្រះសេក្ខៈ ៧ ពួក រួមនឹងកល្យាណ-បុថុជ្ជន ឈ្មោះថា កំពុងនៅព្រហ្មចរិយៈ ព្រះខីណាស្រព ឈ្មោះថា នៅចប់ ព្រហ្មចរិយៈហើយ ។ ព្រោះដូច្នោះ ទើបព្រះខន្ធនោះ កាលពិចារណាការ នៅព្រហ្មចរិយៈរបស់ខ្លួន ទើបដឹងច្បាស់ថា ព្រហ្មចរិយៈ ខ្ញុំនៅចប់ហើយ ។ បទថា **កតំ ករណីយំ** សេចក្តីថា ឲ្យកិច្ច ១៦ យ៉ាងសម្រេចដោយ បរិញ្ញាកិច្ច បហានកិច្ច សច្ឆិកិរិយាកិច្ច និងភាវនាកិច្ច ក្នុងសច្ចៈ ៤ ដោយមគ្គ ៤ ។ ពិតហើយ កល្យាណបុថុជ្ជនជាដើម ឈ្មោះថា កំពុងធ្វើកិច្ចនោះ ។ ព្រះខីណាស្រព ឈ្មោះថា ធ្វើករណីយកិច្ចស្រេចហើយ ។ ព្រោះហេតុនោះ ព្រះខន្ធ កាលពិចារណាករណីយកិច្ចរបស់ខ្លួន ទើបដឹងច្បាស់ថា ករណីយកិច្ច*

ធ្វើហើយ ។ បទថា **ឆាឃរំ ឥត្តត្តាយ** *សេចក្តីថា ដឹងច្បាស់ថា ឥឡូវនេះ អាត្មាអញមិនមានភាពជាយ៉ាងនេះតទៅ គឺដើម្បីកិច្ច ១៦ យ៉ាងនេះ ឬដើម្បីចម្រើននូវការអស់កិលេស ។ ម្យ៉ាងទៀត បទថា* **ឆាឃរំ ឥត្តត្តាយ** *សេចក្តីថា ដឹងច្បាស់ថា ខន្ធសន្តានតទៅអំពីភាពយ៉ាងនេះ គឺអំពីខន្ធសន្តានដែលជាបច្ចុប្បន្ននេះ គឺដែលមានប្រការដូចពោលនេះ មិនមានដល់ខ្ញុំ តែខន្ធទាំង ៥ នេះ ខ្ញុំកំណត់ដឹងហើយ តាំងនៅ ដូចដើមឈើដែលមានឫសជាប់ហើយ ខន្ធទាំង ៥ នោះ នឹងរលត់ គឺដល់នូវការមិនមានបញ្ញត្តិ ព្រោះរលត់ចរមកចិត្ត ដូចភ្លើងរលត់ ព្រោះមិនមានកំញ្ជឹម ដូច្នោះ ។ បទថា* **អញ្ញតរោ** *បានដល់ព្រះនន្ទ ជាបុគ្គលម្នាក់ និងបានជាព្រះមហាសាវ័កមួយរូប ក្នុងអរហន្តសាវ័ករបស់ ព្រះមានព្រះភាគ ។*

[៧០] *បទថា* **អញ្ញតរា ទេវតា** *បានដល់ ព្រហ្មទេវតាមួយអង្គ ដែលសម្រេចមគ្គ ។ ពិតហើយ ព្រហ្មទេវតានោះដឹងច្បាស់នូវអារម្មណ៍នៃព្រះអសេក្ខៈ ព្រោះខ្លួនឯងជាព្រះអសេក្ខៈ ។ ព្រះអសេក្ខៈទាំងឡាយ រមែងដឹងអារម្មណ៍របស់ព្រះសេក្ខៈនោះៗ បាន ។ ឯបុថុជ្ជន រមែងដឹងចំពោះអារម្មណ៍បុថុជ្ជនរបស់ខ្លួនប៉ុណ្ណោះ ។ បទថា* **អភិក្កន្តាយ រត្តិយា** *បានដល់ រាត្រីកន្លងទៅ អធិប្បាយថា កាលមជ្ឈិមយាមកន្លងទៅ ។ បទថា* **អភិក្កន្ត-វណ្ណា** *ប្រែថា មានវណ្ណៈរុងរឿងក្រៃលែង ។ បទថា* **កេវលកប្បំ** *បានដល់ ដោយជុំវិញ មិនមានចំណែកសេសសល់ ។ បទថា* **ឱភាសេត្វា** *បានដល់ ធ្វើវត្តជេតពនឲ្យមានពន្លឺតែមួយ ដោយរស្មីរបស់ខ្លួន ដូចព្រះចន្ទ និងព្រះ*

អាទិត្យ ។ បទថា **តេនុបសង្កមិ** *សេចក្តីថា ព្រហ្មនោះដឹងថា ព្រះនន្ទ សម្រេចអរហត្តហើយ ទើបកើតបីតិសោមនស្ស ចូលគាល់ដោយបំណងថា នឹងក្រាបទូលសេចក្តីនោះ ដល់ព្រះមានព្រះភាគ ។*

ក្នុងបទថា **អាសវានំ ខយា** *នេះ មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា* **អាសវ** *ព្រោះអត្ថថា ហូរទៅ អធិប្បាយថា ប្រព្រឹត្តទៅតាមចក្ខុទ្វារជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា* **អាសវ** *ព្រោះអត្ថថា ហូរទៅរហូតដល់គោត្រភូ ឬដល់ភវគ្គព្រហ្ម អធិប្បាយថា ធ្វើធម៌ទាំងនេះ និងឱកាសនេះ ឲ្យនៅខាងក្នុង ហូរទៅ ។ ឈ្មោះថា* **អាសវ** *ព្រោះអត្ថថា ដូចទឹកត្រាំ មានសុរាជាដើម ព្រោះត្រាំយូរ ។ គប្បីជ្រាបភាពដែលអាសវៈទាំងនោះត្រាំនៅយូរ ដោយព្រះតម្រាស់ជាដើមថា ម្នាលភិក្ខុទាំងឡាយ ចំណុចខាងដើមរបស់អវិជ្ជា មិនប្រាកដ ។ ម្យ៉ាងទៀត ឈ្មោះថា* **អាសវ** *ព្រោះអត្ថថា ដល់ គឺជួបនូវសង្សារទុក្ខដែលវែងឆ្ងាយ ។ ក្នុងសេចក្តីនេះ អត្តជើម រមែងគួរក្នុងកិលេស អត្តក្រោយ រមែងគួរ (ក្នុងកិលេសផង) ក្នុងកម្មផង ។ មិនមែនតែកម្មក្កិលេសតែម្យ៉ាងប៉ុណ្ណោះទេ ដែលឈ្មោះថា* **អាសវ** *ដោយពិតនោះ ឧបទ្ទវមានប្រការផ្សេងៗ ក៏ឈ្មោះថា* **អាសវ** *។ ពិតហើយ កិលេសដែលជាវិវាទមូលមកដោយឈ្មោះ ឈ្មោះថា* **អាសវ** *ក្នុងព្រះតម្រាស់នេះថា ម្នាលចុន្ទ តថាគតមិនសម្តែងធម៌ ដើម្បីរាល់នូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នតែមួយយ៉ាងដល់ពួកអ្នកទេ ។ កម្មដែលប្រព្រឹត្តទៅក្នុងភូមិ ៣ និងអកុសលកម្មទាំងអស់ មកដោយឈ្មោះ ឈ្មោះថា* **អាសវ** *ក្នុងពាក្យជា*

គាថានេះថា

តថាគតគប្បីកើតជាទេវតា ឬកើតជាគន្ធព្វ ត្រាច់ទៅតាមអាកាស ព្រោះអាសវៈណាក្តី គប្បីដល់នូវភាពនៃខ្លួនជាយក្ខ និងជួបប្រទះនូវភាពនៃខ្លួនជាមនុស្ស ព្រោះអាសវៈណាក្តី អាសវៈទាំងអស់នោះរបស់តថាគតអស់ហើយ បានកម្ចាត់បង់ហើយ ធ្វើឲ្យរបូតចំណងហើយ ។

ឧបទ្វមានប្រការផ្សេងៗ មានការបៀតបៀនអ្នកដទៃ ការក្តៅក្រហាយការសម្ងាប់ និងការចងជាដើម ដែលជាអបាយទុក្ខទាំងនោះ ឈ្មោះថា **អាសវ** *ព្រោះបាលីថា ដើម្បីរារាំងអសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកម្ចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ។ មកក្នុងព្រះវិនយ (នេះ) ដោយចំណែក ២ គឺដើម្បីការពារនូវអាសវៈដែលជាបច្ចុប្បន្ន ដើម្បីកម្ចាត់អាសវៈដែលប្រព្រឹត្តទៅក្នុងភពខាងមុខ ។ មកក្នុងសឡាយតនសូត្រ ដោយចំណែក ៣ ម្នាលអាវុសោ អាសវៈ ៣ យ៉ាង គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ និងមកក្នុងសុត្តន្តដទៃក៏ដូចគ្នា ។ ក្នុងអភិធម្ម អាសវៈ ៣ នោះឯង មាន ៤ ដោយបន្ថែមទិដ្ឋាសវៈ ។ ក្នុងនិព្ពេធិកបរិយាយសូត្រ មាន ៥ យ៉ាង ដោយព្រះតម្រាស់ជាដើមថា ម្នាលភិក្ខុទាំងឡាយ អាសវៈទាំង-ឡាយ នាំសត្វឲ្យទៅនរកក៏មាន ។ ក្នុងឆក្កនិបាត មាន ៦ យ៉ាង ដោយនយជាដើម ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ គប្បីលះដោយការសង្រួមក៏មាន ។ ក្នុងសព្វាសវសំវរសូត្រ អាសវៈទាំងនោះឯង រួមជាមួយ*

ទស្សនបហាតព្វធម៌ មកជា ៧ យ៉ាង តែក្នុងទីនេះ គប្បីជ្រាបអាសវៈ ៤ តាមន័យដែលមកក្នុងអភិធម្ម ។ ក្នុងបទថា **ឲយា** *នេះ ត្រាស់ការប្លែកផ្សេងគ្នានៃអាសវៈ មួយអន្ទើដោយកិច្ច ថាជាអាសវក្ខយៈ ដូចក្នុងប្រយោគជាដើមថា ការអស់ទៅ ការបែកទៅ ការទម្លាយទៅនៃអាសវៈណា ដូច្នេះ ។ ត្រាស់ការមិនកើតឡើងតទៅនៃអាសវៈ ថាជាអាសវក្ខយៈ ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការអស់ទៅនៃអាសវធម៌ទាំងឡាយរបស់បុគ្គលអ្នកជឹង អ្នកឃើញ ... ដូច្នេះ ។ ត្រាស់មគ្គចិត្តថា អាសវក្ខយៈ ដូចក្នុងប្រយោគជាដើមថា*

> *កាលបើសេក្ខបុគ្គល កំពុងសិក្សា ត្រាច់ទៅតាមផ្លូវដ៏ត្រង់ ញាណទី ១ ក្នុងការអស់ទៅនៃអាសវៈ (ក៏កើតមាន) ត អំពីនោះទៅ អរហត្តមគ្គញាណដ៏ប្រសើរ (ក៏កើតឡើង) ។*

ត្រាស់ផលចិត្តថា ជាអាសវក្ខយៈ ដូចក្នុងប្រយោគជាដើមថា តថាគតហៅបព្វជិតនោះថាជាសមណៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដូច្នេះ ។ ត្រាស់ព្រះនិព្វានថា អាសវក្ខយៈ ដូចក្នុងប្រយោគជាដើមថា

> *កាលបុគ្គលគយយ្ហាំមើលទោស របស់បុគ្គលដទៃជាប្រក្រតី មានការសម្គាល់ហេតុក្នុងការពោលទោស (អ្នកដទៃ) ជានិច្ច ជាប្រក្រតី អាសវៈទាំងឡាយរបស់បុគ្គលនោះ តែងចម្រើនបុគ្គលនោះ ឈ្មោះថា ស្ថិតនៅឆ្ងាយអំពីធម៌ ជាគ្រឿងអស់អាសវៈ ។*

តែក្នុងទីនេះ ត្រាស់ការអស់ទៅនៃអាសវៈដោយចំណែកមួយ គឺការមិនកើតឡើងនៃអាសវៈ ឬមគ្គចិត្តថា អាសវក្ខយៈ ។

បទថា **អនាសវំ** បានដល់ ដែលលះអាសវៈ ដោយប្រការទាំងពួងដោយបដិបស្សទ្ធិសម្ពោជ្ឈង្គ ។ បទថា **ចេតោវិមុត្តឹ** បានដល់ សមាធិដែលសម្បយុត្តដោយអរហត្តផល ។ បទថា **បញ្ញាវិមុត្តឹ** បានដល់ បញ្ញាដែលសម្បយុត្តដោយអរហត្តផល ។ ពាក្យទាំង ២ មានអត្ថសម្តែងភាវៈដែលសមថៈ និងវិបស្សនាទាក់ទងគ្នាជាគូ ក្នុងផលចិត្ត ដូចក្នុងមគ្គចិត្ត ។ បទថា **ញាណំ** បានដល់ ព្រះសព្វញ្ញុតញ្ញាណ ។

ក្នុងលំដាប់ពាក្យរបស់ទេវតានោះឯង កាលព្រះមានព្រះភាគ ទ្រង់ពិចារណាថា យ៉ាងនោះឬហ្នឹ ញាណក៏កើតឡើងថា ន្ទូធ្វើឲ្យជាក់ច្បាស់ន្ទូវអរហត្តហើយ ពិតហើយ ព្រះន្ទូត្រូវភិក្ខុដែលជាសម្ងាញ់ចំអកចំអន់ ដូច្នោះ ទើបកើតសង្វេគឡើងថា ការដែលអាត្មាអញបួសក្នុងព្រះធម្មវិន័យ ដែលព្រះតថាគតត្រាស់ល្អហើយយ៉ាងនេះ បានធ្វើព្រះសាស្តាឲ្យជាអ្នកធានា ដើម្បីបានស្រីទេពអប្សរនោះ អាត្មាអញ ឈ្មោះថា ធ្វើកម្មធ្ងន់ហ្នឹ ទើបចូលទៅតាំងហិរិនិងឧត្តប្ប: ព្យាយាម សម្រេចព្រះអរហត្តហើយ គិតថា ធ្វើម្តេចហ្នឹ អាត្មាអញគប្បីឲ្យព្រះមានព្រះភាគផុតអំពីការធានា ។ លោកចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលបំណងរបស់ខ្ជូនដល់ព្រះសាស្តា ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ អាយស្មា ឆន្ទោ ។បេ។ ឯតស្មា បដិស្សវា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បដិស្សវា** សេចក្តីថា ចាកការទទួលធានា

គឺចាកប្តេជ្ញាថា តថាគតជាអ្នកធានាដើម្បីឲ្យបានស្រីទេពអប្សរ ។

លំដាប់នោះ ព្រះមានព្រះភាគត្រាស់ដល់លោកថា ព្រោះហេតុដែលតថាគតដឹងសេចក្តីនេះថា អ្នកត្រេកអរក្នុងអរហត្តផល ទាំងទេវតាក៏ប្រាប់ដល់តថាគត ដូច្នោះ ទើបតថាគត មិនត្រូវអ្នកឲ្យផុតចាកការធានា ក្នុងឥឡូវនេះ ព្រោះអ្នកផុតហើយ ដោយការសម្រេចអរហត្តនោះឯង ។ ដោយហេតុនោះ ទើបលោកពោលថា **យទេវទោ តេ ឆន្ទ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យទេវ** កាត់បទជា **យទា ឯវ ។** បទថា **តេ** កែជា **តវ** ប្រែថា របស់អ្នក ។ បទថា **មុត្តោ** ប្រែថា ផុតហើយ លោកអធិប្បាយដូច្នេះថា ក្នុងកាលណា ចិត្តរបស់អ្នកផុតចាកអាសវ: ក្នុងកាលនោះ គឺក្នុងលំដាប់នោះឯង តថាគតផុតចាកការធានានោះ ។ ឯព្រះនន្ទ ក្នុងកាលចម្រើនវិបស្សនានោះឯង កើតនូវឧស្សាហ៍ឡើងថា អាត្មាអញ នឹងសង្កត់ការមិនសង្រួមឥន្ទ្រិយ ដែលអាត្មាអញអាស្រ័យដល់ប្រការដែលប្លែកនេះប៉ុណ្ណោះ ដោយល្អ មានហិរិ និងឱត្តប្ប:យ៉ាងចាស់ក្លា និងបានដល់បដិបទាយ៉ាងឧក្រិដ្ឋ ក្នុងឥន្ទ្រិយសំវរ: ព្រោះបានធ្វើបុញ្ញាធិការក្នុងរឿងនោះ សមដូចព្រះតម្រាស់ដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើនន្ទភិក្ខុរមិលមើលទៅទិសខាងកើតលុះតែប្រមូលនូវហេតុទាំងអស់ដោយចិត្ត ទើបនន្ទភិក្ខុរមិលមើលនូវទិសខាងកើត ដោយគំនិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោម-នស្ស នឹងមិនជាប់តាមអាត្មាអញ ដែលកំពុងរមិលមើលទិសខាងកើតយ៉ាងនេះ ។ ព្រោះហេតុនោះ ទើបក្នុងសាសនានេះ នន្ទភិក្ខុឈ្មោះថា ជាអ្នកមាន

សេចក្តីដឹងខ្លួន ក្នុងការគ្រប់គ្រងទ្វារនោះ ។ ម្នាលភិក្ខុទាំងឡាយ បើនន្ទុភិក្ខុ រមិលមើលទិសខាងលិច រមិលមើលទិសខាងជើង រមិលមើលទិសខាងត្បូង ងើយមើលទៅទិសខាងលើ ឧនមើលទិសខាងក្រោម ងាកមើលទៅទិសជា លំដាប់ លុះតែប្រមូលនូវហេតុទាំងអស់ ដោយចិត្ត ទើបនន្ទុភិក្ខុងាកមើលនូវ ទិសជាលំដាប់ ដោយគំនិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និង ទោមនស្ស នឹងមិនជាប់តាមអាត្មាអញ ដែលកំពុងងាកមើលទិសជាលំដាប់ ។ ព្រោះហេតុនោះ ទើបក្នុងសាសនានេះ នន្ទុភិក្ខុ ឈ្មោះថា ជាអ្នកមានសេចក្តី ដឹងខ្លួន ក្នុងការគ្រប់គ្រងទ្វារយ៉ាងនេះ ។ ដោយហេតុនោះ ទើបព្រះសាស្តា ស្តាបនានន្ទុនោះក្នុងឯតគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុសាវករបស់ តថាគតដែលជាអ្នកគ្រប់គ្រង់ទ្វារក្នុងឥន្ទ្រិយទាំងឡាយ ស្រេចលើនន្ទុ ។

បទថា **ឯតមត្តំ វិធិត្វា** សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងដល់ សេចក្តីនោះ ពោល គឺការដែលព្រះនន្ទុធ្វើអាសវៈទាំងពួងឲ្យអស់ ហើយ ដល់នូវភាពជាអ្នកមាំទាំក្នុងលោកធម៌ មានសុខជាដើម ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ដែលប្រកាសសេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **យស្ស តិណ្ណោ កាមបង្កោ** សេចក្តីថា ភក់ គឺទិដ្ឋិទាំងអស់ដែលព្រះអរិយបុគ្គលណាឆ្លងហើយ ដោយស្ពាន គឺអរិយមគ្គ ឬភក់ គឺសង្សារនោះឯង ដែលព្រះអរិយបុគ្គលបានឆ្លងហើយ ដោយការដល់ នូវត្រើយ គឺព្រះនិព្វាន ។ បទថា **មន្ទិតោ កាមកណ្តកោ** សេចក្តីថា កិលេសកាមទាំងអស់ គឺថា បន្ទា គឺកាមទាំងអស់ដែលបានឈ្មោះថា **កាម-**

កណ្ហកេ ព្រោះចាក់ដោតនូវពួកសត្វ ដែលព្រះអរិយបុគ្គលញាំញីហើយ គឺកាច់ហើយ ទម្លាយហើយ ដោយឥតសេសសល់ ដោយជំពង គឺអរហត្ត-មគ្គញ្ញាណ ។ បទថា **មោហក្ខយំ អនុប្បត្តោ** សេចក្តីថា ព្រះនន្ទជាបុគ្គលយ៉ាងនេះ សម្រេចនូវការអស់មោហៈ ដោយធម្មសម្មោហៈទាំងអស់ មានទុក្ខជាដើមជាអារម្មណ៍ឲ្យអស់ទៅ គឺសម្រេចអរហត្តផល និងព្រះនិព្វាន ។ បទថា **សុខទុក្ខេសុ ន វេធតិ សភិក្ខុ** សេចក្តីថា ភិក្ខុទម្លាយកិលេសនោះ រមែងមិនញាប់ញ័រ មិនកម្រើកក្នុងសុខដែលកើតឡើង ព្រោះជួបនូវឥដ្ឋារម្មណ៍ និងក្នុងទុក្ខដែលកើតឡើង ព្រោះជួបនឹងអនិដ្ឋារម្មណ៍ គឺមិនដល់នូវការប្រែប្រួលនៃចិត្ត ដែលមានសុខទុក្ខនោះជាហេតុ ។ បទថា **សុខទុក្ខេសុ** នេះ ត្រឹមតែជាទេសនា គប្បីជ្រាបថា ព្រះនន្ទមិនញាប់ញ័រក្នុងលោកធម៌ទាំងអស់ ។

អដ្ឋកថា ឆន្ទសូត្រទី ២ ចប់

សុត្តន្តបិដក

យសោជសូត្រ

[៧១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុចំនួន ៥០០ រូប មានព្រះយសោជៈជាប្រធាន បាននិមន្តទៅគរសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគ ។ ពួកអាគន្តុកភិក្ខុទាំងនោះ កាល

និយាយសំណេះសំណាលជាមួយនឹងពួកនេវាសិកភិក្ខុ ឲ្យក្រាលសេនាសនៈទុកជាក់ជាត្រចីវរ ក៏មានសំឡេងកងរំពង មានសំឡេងខ្លាំង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទជ័មានអាយុមកថា ម្នាលអានន្ទ សូរសំឡេងកងរំពង សូរសំឡេងខ្លាំង ទំនងដូចព្រានសំណាញ់ ក្នុងកាលចាប់ត្រី តើជាសំឡេងអ្វី ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុ ៥០០ រូប មានព្រះយសោជៈជាប្រធានទុំៈ បានមកដល់នគរសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគ ពួកអាគន្តុកភិក្ខុទាំងនោះ កាលនិយាយសំណេះសំណាលជាមួយនឹងពួកនេវាសិកភិក្ខុឲ្យក្រាលសេនាសនៈ ទុកជាក់ជាត្រចីវរ ក៏មានសំឡេងកងរំពង មានសំឡេងខ្លាំង ។ ម្នាលអានន្ទ បើដូច្នោះ ចូរអ្នកទៅហៅពួកភិក្ខុទាំងនោះ តាមពាក្យតថាគតថា ព្រះសាស្តាត្រាស់ហៅលោកដ៏មានអាយុទាំងឡាយ ។ ព្រះអានន្ទជ័មានអាយុ បានទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយចូលទៅរកពួកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ និយាយនឹងពួកភិក្ខុទាំងនោះថា ព្រះសាស្តាត្រាស់ហៅលោកដ៏មានអាយុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលពាក្យព្រះអានន្ទជ័មានអាយុថា អើអាវុសោ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ដូចម្តេច បានជាអ្នកទាំងឡាយមានសំឡេងកងរំពង មានសំឡេងខ្លាំង ទំនងដូចជាពួកព្រានសំណាញ់ ក្នុងកាលចាប់ត្រី ។

[៧២] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះយសោជ:ដ៏មានអាយុ ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុ ៥០០ រូបនេះ មកកាន់នគរសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគ អាគន្ពុកភិក្ខុទាំងនោះ កាលនិយាយសំណេះសំណាល ជាមួយនឹងពួកនេវាសិកភិក្ខុ ឲ្យក្រាលសេនាសន: ទុកដាក់បាត្រចីវរ ក៏មានសំឡេងកងរំពង មានសំឡេងខ្លាំង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរទៅតថាគតបណ្តេញអ្នកទាំងឡាយ អ្នកទាំងឡាយ មិនត្រូវនៅក្នុងសម្នាក់តថាគតទេ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រោកចាកអាសន:ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ រួចទុកដាក់សេនាសន: យកបាត្រចីវរ ហើយចៀសចេញទៅកាន់ចារិកក្នុងដែនវជ្ជី កាលត្រាច់ទៅកាន់ចារិក ក្នុងដែនវជ្ជីតាមលំដាប់ បានចូលទៅឯស្ទឹងវគ្គុមុទា លុះចូលទៅដល់ហើយ ក៏ធ្វើខ្ទមស្ថឹកនៅចាំវស្សា ប្របឆ្នេរស្ទឹងឈ្មោះវគ្គុមុទា ។

[៧៣] លំដាប់នោះ ព្រះយសោជ:ដ៏មានអាយុ នៅចាំវស្សាហើយ ក៏ហៅពួកភិក្ខុមកថា ម្នាលអាវុសោទាំងឡាយ យើងទាំងឡាយត្រូវព្រះមានព្រះភាគ ព្រះអង្គជាអ្នកប្រាថ្នាសេចក្តីចម្រើន ស្វែងរកប្រយោជន៍ ព្រះអង្គអនុគ្រោះ អាស្រ័យសេចក្តីអនុគ្រោះ ទ្រង់បណ្តេញហើយ ម្នាលអាវុសោ ព្រះមានព្រះភាគ គប្បីប្រាថ្នាប្រយោជន៍ ចំពោះពួកយើង កាលនៅដោយការប្រព្រឹត្តយ៉ាងណា ពួកយើងគួរសម្រេចការនៅ ដោយការប្រព្រឹត្តយ៉ាងនោះ

ចុះ ។ ពួកភិក្ខុទាំងនោះ ទទួលពាក្យព្រះយសោជៈដ៏មានអាយុថា អើ អាវុសោ ។ លំដាប់នោះ ពួកភិក្ខុទាំងនោះ ក៏ចៀសចេញទៅ មិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន លុះដល់ខាងក្នុងវស្សានោះ ក៏ធ្វើឲ្យជាក់ច្បាស់នូវត្រៃវិជ្ជទាំងអស់គ្នា ។

[៧៤] គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងសាវត្ថី តាមសមគួរដល់អព្យាស្រ័យហើយ ស្តេចចៀសចេញទៅកាន់ចារិក ក្នុងក្រុងវេសាលី កាលគ្រាច់ទៅកាន់ចារិក តាមលំដាប់ បានទៅដល់ក្រុងវេសាលី ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលីនោះ ។ លំដាប់នោះ ព្រះមានព្រះភាគ កំណត់ចិត្តពួកភិក្ខុ អ្នកនៅប្របង្គេរស្ទឹងវគ្គុមុទាដោយព្រះហឫទ័យ ហើយធ្វើទុកក្នុងព្រះហឫទ័យ គ្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ពួកភិក្ខុអ្នកនៅប្របង្គេរស្ទឹងវគ្គុមុទា នៅក្នុងទិសណា ម្នាលអានន្ទ ទិសនុ៎ះឯង ដូចជាមានពន្លឺដល់តថាគត ម្នាលអានន្ទ ទិសនុ៎ះឯង ដូចជាមានរស្មីដល់តថាគត ភិក្ខុទាំងនោះ តថាគតមិនមែនស្អប់ខ្ពើម នឹងទៅរកទេ តថាគតមិនមែនស្អប់ខ្ពើម នឹងធ្វើទុកក្នុងចិត្តទេ ម្នាលអានន្ទ គួរអ្នកបញ្ជូនទូតទៅក្នុងសម្នាក់ពួកភិក្ខុ អ្នកនៅប្របង្គេរស្ទឹងវគ្គុមុទា ដោយពាក្យថា ព្រះសាស្តាត្រាស់ហៅលោកដ៏មានអាយុទាំងឡាយ ព្រះសាស្តាចង់ជួបលោកដ៏មានអាយុទាំងឡាយ ។ ព្រះអានន្ទដ៏មានអាយុ បានទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះកុរុណាព្រះអង្គ ហើយចូលទៅរកភិក្ខុ

១ រូប លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងភិក្ខុនោះថា ម្នាលអាវុសោ អ្នកចូរមក អ្នកចូរទៅរកពួកភិក្ខុអ្នកនៅប្រុបន្ឆេរស្ទឹងវគ្គុមុទា លុះចូលទៅដល់ហើយ ចូរនិយាយប្រាប់ពួកភិក្ខុអ្នកនៅប្រុបន្ឆេរស្ទឹងវគ្គុមុទាយ៉ាងនេះថា ព្រះសាស្តា ទ្រង់ត្រាស់ហៅលោកដ៏មានអាយុទាំងឡាយ ព្រះសាស្តាចង់ជួបនឹងលោកដ៏មានអាយុទាំងឡាយ ។ ភិក្ខុនោះ បានទទួលពាក្យព្រះអានន្ទដ៏មានអាយុថា អើអាវុសោ ហើយក៏ស្រាប់តែបាត់អំពីកូដាគារសាលា នាមហាវន ទៅប្រាកដក្នុងទីចំពោះមុខភិក្ខុទាំងនោះ ប្រុបន្ឆេរស្ទឹងវគ្គុមុទា ដូចជាបុរសមានកម្លាំង លាដៃដែលបត់ ឬបត់ដៃដែលលា ដូច្នោះ ។ លំដាប់នោះ ភិក្ខុនោះ បាននិយាយប្រាប់ពួកភិក្ខុ អ្នកនៅប្រុបន្ឆេរស្ទឹងវគ្គុមុទាថា ព្រះសាស្តា ទ្រង់ត្រាស់ហៅលោកដ៏មានអាយុទាំងឡាយ ព្រះសាស្តា ចង់ជួបនឹងលោកដ៏មានអាយុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលពាក្យភិក្ខុនោះថា អើអាវុសោ ហើយក៏ទុកដាក់សេនាសនៈ កាន់យកបាត្រចីវរ រួចស្រាប់តែបាត់អំពីឆ្ងេរស្ទឹងវគ្គុមុទា មកប្រាកដក្នុងទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ក្នុងកូដាគារសាលា នាមហាវន ដូចជាបុរសមានកម្លាំងលាដៃដែលបត់ ឬបត់ដៃដែលលា ដូច្នោះ ។

[៧៥] សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ដោយសមាធិ មិនកម្រើក ។ លំដាប់នោះ ពួកភិក្ខុទាំងនោះមានសេចក្តីត្រិះរិះថា ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់គង់នៅដោយវិហារធម៌ ដូចម្តេចហ្ន៎ ។ លំដាប់នោះ ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះថា ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់គង់នៅដោយ

វិហារធម៌ ដ៏មិនកម្រើក ។ ភិក្ខុទាំងអស់ ក៏អង្គុយដោយសមាធិ ដ៏មិនកម្រើកដែរ ។ គ្រាកាលដែលរាត្រីអស់ទៅ បឋមយាមកន្លងហើយ ព្រះអានន្ទដ៏មានអាយុ ក្រោកចាកអាសនៈធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ រួចក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន រាត្រីកន្លងហើយ បឋមយាមកន្លងហើយ ពួកអាគន្តុកភិក្ខុអង្គុយយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលសំណេះសំណាលនឹងពួកអាគន្តុកភិក្ខុ ។ កាលដែលព្រះអានន្ទក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់នៅស្ងៀម ។ លុះរាត្រីអស់ទៅ មជ្ឈិម-យាមកន្លងហើយ ព្រះអានន្ទដ៏មានអាយុ ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ រួចក្រាបបង្គំទូលព្រះមានព្រះភាគ អស់វារៈជាគម្រប់ ២ ថា បពិត្រព្រះអង្គដ៏ចម្រើន រាត្រីអស់ទៅ មជ្ឈិមយាមកន្លងហើយ ពួកអាគន្តុកភិក្ខុអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូល សំណេះសំណាលនឹងពួកអាគន្តុកភិក្ខុ ។ ព្រះមានព្រះភាគទ្រង់ស្ងៀម អស់វារៈជាគម្រប់ ២ ។ កាលដែលរាត្រីអស់ទៅ បច្ឆិមយាមកន្លងទៅ អរុណក៏រះឡើង រាត្រីក៏ប្រាកដដូចជាមានមុខស្រស់ ព្រះអានន្ទដ៏មានអាយុ ក៏ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ រួចក្រាបបង្គំទូលព្រះមានព្រះភាគ អស់វារៈជាគម្រប់ ៣ ថា បពិត្រព្រះអង្គដ៏ចម្រើន រាត្រីអស់ទៅ បច្ឆិមយាមកន្លងទៅ អរុណក៏រះហើយ រាត្រីក៏ប្រាកដដូចជាមាន

មុខស្រស់ ពួកអាគន្តុកភិក្ខុ អង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូល សំណេះសំណាលនឹងពួកអាគន្តុក-ភិក្ខុ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចេញចាកសមាធិនោះហើយ ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាលអានន្ទ ប្រសិនបើអ្នកដឹង អ្នកមិនិយាយពាក្យទាំងប៉ុណ្ណោះទេ ម្នាលអានន្ទ (ព្រោះថា) តថាគតផង ពួកភិក្ខុ ៥០០ រូបនេះផង ទាំងអស់គ្នា សុទ្ធតែអង្គុយនៅដោយសមាធិមិនកម្រើក ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាន នេះក្នុងវេលានោះថា

> *បន្ទា គឺកាម កិរិយាជេរ ការសម្លាប់ និងការចង ដែល បុគ្គលណាឈ្នះហើយ បុគ្គលនោះ ឈ្មោះថា មិនញាប់ញ័រ ស្ថិតនៅដូចភ្នំ បុគ្គលនោះ ឈ្មោះថា ភិក្ខុ រមែងមិន ញាប់ញ័រ ព្រោះសុខ និងទុក្ខ ឡើយ ។ សូត្រទី ៣ ។*

អដ្ឋកថា

យសោជសូត្រ

យសោជសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

[៧១] *បទថា* **យសោជោ** *ក្នុងពាក្យថា* **យសោជប្បមុខានិ** *នេះ ជាឈ្មោះនៃព្រះថេរៈនោះ ។ ភិក្ខុ ៥០០ រូបនោះ លោកពោលថា មានយសោជភិក្ខុជាប្រធាន ព្រោះបួសធ្វើព្រះយសោជៈឲ្យជាប្រធាន និងព្រោះត្រាច់ទៅជាមួយគ្នា ។ ភិក្ខុទាំងនោះ មានការប្រកបបុញ្ញកម្មក្នុងកាលមុន ដូចតទៅនេះ*

បានឮថា ក្នុងអតីតកាល ក្នុងសាសនារបស់ព្រះកស្សបទសពល មានភិក្ខុនៅព្រៃមួយរូបនៅក្នុងកុដិប្រក់ដោយស្លឹកឈើ កសាងត្រង់ថ្ងាជា ក្នុងព្រៃ ។ សម័យនោះ ចោរ ៥០០ ធ្វើការប្លន់អ្នកស្រុកជាដើមចិញ្ចឹមជីវិត ដោយចោរកម្ម កាលធ្វើចោរកម្ម ត្រូវពួកមនុស្សក្នុងជនបទ នាំគ្នាដេញតាម គេចចូលទៅកាន់ព្រៃ មិនឃើញអ្វីក្នុងទីនោះ ទោះជាព្រៃស្តុក ឬទីគប្បីអាស្រ័យ ឃើញភិក្ខុនោះអង្គុយលើផ្ទាំងថ្ម ក្នុងទីមិនឆ្ងាយ ទើបថ្វាយបង្គំ ប្រាប់រឿងនោះ អង្វរថា សូមលោកម្ចាស់ជាទីពឹងជល់ពួកខ្ញុំចុះ ។ ព្រះថេរៈពោលថា ទីពឹងដទៃដូចជាសីល របស់ពួកអ្នកមិនមាន ចូរសមាទានសីល ៥ ទាំងអស់គ្នាចុះ ។ ចោរទាំងនោះទទួលពាក្យរបស់លោកហើយ ទទួលសីល ។ ព្រះថេរៈពោលថា អ្នកតាំងនៅក្នុងសីលហើយ សូមជីវិតរបស់ខ្លួនវិនាសទៅ ក៏កុំខឹងក្រោធ ដួចច្នេះហើយ ទើបប្រាប់វិធីឧបមាដោយរណា ។ ចោរទាំងនោះទទួលថា សាធុ ។ លំដាប់នោះ អ្នកជនបទទាំងនោះ ទៅកាន់ទីនោះ

រកមើលក្នុងទីផ្សេងៗ ជួបពួកចោរទាំងនោះ ក៏សម្លាប់ទាំងអស់ ចោរទាំងនោះមិនបានធ្វើត្រឹមតែការអាក់អន់ក្នុងជនទាំងនោះ មិនបានជាច់សីល ស្លាប់ទៅកើតក្នុងទេវលោកជាន់កាមាវចរ ។ មេចោរជាជាប្រធាន បានជាទេវបុត្រជាប្រធាន ឯចោរដទៃក្រៅអំពីនោះ បានជាបរិវារបស់ទេវបុត្រ ដែលជាប្រធាននោះឯង ។ ទេវបុត្រទាំងនោះ អន្ទោលទៅមក អស់មួយពុទ្ធន្តរក្នុងទេវលោក ក្នុងកាលព្រះមានព្រះភាគនៃយើង ចុតិអំពីទេវលោកហើយ ទេវបុត្រដែលជាប្រធាន កើតជាកូនអ្នកប្រមង់ដែលជាមេស្រុក ក្នុងត្រកូល ៥០០ នាក្បែរវត្តគ្រាម ក្បែរទ្វារក្រុងសាវត្ថី ។ គេឲ្យឈ្មោះថា យសោជៈ ។ ឯទេវបុត្រក្រៅអំពីនោះ កើតជាកូនអ្នកប្រមង់ដទៃៗ ។ ដោយបុព្វសន្និវាសមនុស្សទាំងនោះបានជាសម្លាញ់លេងធូលីជាមួយគ្នា ធំឡើងដោយលំដាប់ យសោជៈបានជាប្រធានក្នុងជនទាំងនោះ ។ ពួកគេរួមគ្នាកាន់សំណាញ់ចាប់ត្រីក្នុងស្ទឹង និងក្នុងបឹងជាដើម ។ ថ្ងៃមួយ កាលបង់សំណាញ់ក្នុងស្ទឹងអចិរវតី ត្រីពណ៌មាសជាប់សំណាញ់ អ្នកប្រមង់ទាំងអស់ ឃើញដូច្នោះ នាំគ្នាត្រេកអរថា កូនៗ របស់ពួកយើង កាលចាប់ត្រី ចាប់បានត្រីមាស ។ ពេលនោះ សម្លាញ់ទាំង ៥០០ នាក់ បានជាក់ត្រីក្នុងទូក សែងទូកទៅបង្ហាញជល់ព្រះរាជា ។ ព្រះរាជាទ្រង់ឃើញដូច្នោះ ទ្រង់ព្រះតម្រិះថា ព្រះមានព្រះភាគទ្រង់ជ្រាបហេតុដែលត្រីនេះជាមាស ទើបចាប់ត្រីនោះ ទៅបង្ហាញជល់ព្រះមានព្រះភាគ ។ ព្រះសាស្តាត្រាស់ថា ត្រីនេះ ក្នុងកាលសាសនារបស់ព្រះសម្មាសម្ពុទ្ធកស្សបវិនាសទៅ ជាអ្នកបួសបដិបត្តិខុស ធ្វើសាសនាឲ្យសាប

សូន្យ កើតក្នុងនរក ឆេះក្នុងនរកនោះអស់មួយពុទ្ធន្តរ ចុតិអំពីអត្តភាពនោះ កើតជាត្រីក្នុងស្ទឹងអចិរវតី ដូច្នេះហើយ ទើបទ្រង់ឲ្យត្រីនោះឯង និយាយដល់ភាពដែលខ្លួន ម្តាយ បង្ស្រី កើតក្នុងនរក ព្រះថេរៈដែលជាបង្ប្រុស បរិនិព្វានហើយ ទើបទ្រង់សម្តែងកបិលសូត្រ ព្រោះកើតរឿងនេះឡើង កូនរបស់អ្នកប្រមង់ទាំង ៥០០ នោះ ស្តាប់ទេសនារបស់ព្រះសាស្តាហើយ កើតនូវសេចក្តីសង្វេគ បព្វជ្ជាឧបសម្បទាក្នុងសម្នាក់ព្រះមានព្រះភាគ នៅដោយការស្ងាត់ ហើយមកគាល់ព្រះមានព្រះភាគ ។ ដោយហេតុនោះ ទើបលោកពោលថា **តេន ខោ បន សមយេន យសោជប្បមុខានិ បញ្ចមត្តានិ ភិក្ខុសតានិ** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **តេន** *កាត់បទជា* **តេ ឥន។** *បទថា* **នេវាសិកេហិ** *បានដល់ ដែលនៅប្រចាំ ។ បទថា* **បដិសម្ភោទមានា** *សេចក្តីថា កាលភិក្ខុម្ចាស់កន្លែងធ្វើការប្រាស្រ័យដោយបដិសណ្ឋារៈ មានពាក្យជាដើមថា លោកប្រព្រឹត្តទៅបានដែរឬ កាលប្រាស្រ័យទៀត ទើបប្រាស្រ័យនឹងភិក្ខុដែលជាម្ចាស់អាវាសនោះ ដោយន័យជាដើមថា ល្មមប្រព្រឹត្តទៅបាន ។ បទថា* **សេនាសនានិ បញ្ញាបយមានា** *សេចក្តីថា សួរដល់សេនាសនៈដែលដល់លំដាប់អាចារ្យ ឧបជ្ឈាយ៍ និងដល់ខ្លួន មួយអន្ទើដោយភិក្ខុដែលជាម្ចាស់អាវាសទាំងនោះ នាំគ្នាចាត់ចែងសេនាសនៈដល់ភិក្ខុទាំងនោះថា នេះសម្រាប់អាចារ្យរបស់លោក នេះសម្រាប់ឧបជ្ឈាយ៍របស់លោក នេះសម្រាប់ពួកលោក ហើយខ្លួនឯងទៅក្នុងទីនោះ បើកទ្វារ និងបង្អួច ជញ្ជួតគ្រែ តាំង និងកន្លែ

ផែងជាដើមចេញមកក្រោល ហើយរៀបចំតាមដែលតាំងនៅដូចកាលមុន ។

បទថា **បត្តចីវរានិ បដិសាមយមានា** *សេចក្តីថា ឲ្យទុកជាក់សមណ-បរិក្ខារ ដោយពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទុកជាក់ជាត្រចីវរ កាជនៈ តម្រងទឹក និងឈើច្រត់របស់ខ្ញុំនេះ ។ បទថា* **ឧច្ចា-សទ្ទា មហាសទ្ទា** *សេចក្តីថា កិកូដែលឈ្មោះថា មានសំឡេងខ្លាំង ព្រោះអត្ថថា មានសំឡេងខ្ពស់ ព្រោះបញ្ចេញសំឡេង* **អ** *អក្ខរៈ ឲ្យជា* **អា** *អក្ខរៈ ។ កិកូដែលឈ្មោះថា មានសំឡេងធំ ព្រោះអត្ថថា ផ្សាយទៅដោយជុំវិញ ។ បទថា* **កេវដ្តា មញ្ញេ មច្ឆវិលោបេ** *បានដល់ ក្នុងការដណ្តើមត្រីដូចអ្នកប្រមង់ ។ លោកសម្តែងថា កិកូទាំងនោះដូចអ្នកប្រមង់ចាប់ត្រី បានឈ្មោះថា* **កេវដ្ត** *ព្រោះវិលវល់ក្នុងទឹក គឺប្រព្រឹត្តទៅដើម្បីចាប់ត្រី បង់សំណាញ់ក្នុងទឹកដើម្បីចាប់ត្រី មានសំឡេងអឺងកង ដោយន័យជាដើមថា ចូល ឬមិនចូល ចាប់បាន ឬចាប់មិនបាន និងដូចអ្នកប្រមង់ទាំងនោះ កាលមហាជននាំគ្នាទៅក្នុងទីដែលគេដាក់ត្រែកត្រីជាដើម ហើយដណ្តើមគ្នា ពោលពាក្យជាដើមថា ពួកអ្នកឲ្យត្រីមួយដល់ខ្ញុំ ចូរឲ្យត្រីមួយចង្កោមនេះដល់ខ្ញុំ ឲ្យដល់អ្នកនោះធំ ឲ្យដល់ខ្ញុំតូច ដូច្នេះ និងឈ្មោះថា ជាអ្នកមានសំឡេងអឺងកង ដោយការបដិសេធជាដើមរបស់ជនទាំងនោះ ។*

បទថា **តេតេ** *កាត់បទជា* **តេ ឯតេ ។** *បទថា* **កិន្តុ** *កែជា* **កិស្ស ន្តុ** *អធិប្បាយថា* **កិមត្ថំ ន្តុ** *ប្រែថា ដើម្បីហេតុអ្វីហ្ន៎ ។ បទថា* **តេមេ** *កាត់បទជា* **តេ ឥមេ ។**

[៧២] បទថា **បណាមេមិ** ប្រែថា នាំចេញ ។ បទថា **តេ** កែជា **តេ តុម្ហេ** ប្រែថា លោកទាំងនោះ ។ បទថា **ឯវេ មម សន្តិកេ វត្តព្ពំ** សេចក្តីថា ពួកអ្នកកុំនៅក្នុងសម្នាក់តថាគត ។ ទ្រង់សម្តែងថា ភិក្ខុពួកណា មកកាន់ទីប្រថាប់របស់ព្រះពុទ្ធដូចតថាគត ធ្វើសំឡេងខ្លាំងយ៉ាងនេះ នៅតាមធម្មតារបស់ខ្លួន នឹងធ្វើឲ្យសមគួរដូចម្តេច បុគ្គលដូចពួកអ្នក មិនមានកិច្ចដែលនឹងនៅក្នុងសម្នាក់របស់តថាគត ដូច្នេះ ។

បណ្តាភិក្ខុទាំងនោះ ដែលព្រះមានព្រះភាគទ្រង់បណាមយ៉ាងនេះ សូម្បីត្រឹមតែមួយរូប ក៏មិនមានពាក្យឆ្លើយឆ្លងថា បពិត្រព្រះមានព្រះភាគ ទ្រង់បណ្តេញខ្ញុំព្រះអង្គដោយហេតុត្រឹមតែសំឡេងខ្លាំង ឬមិនឲ្យពាក្យណាមួយដទៃព្រោះគោរពក្នុងព្រះពុទ្ធ ភិក្ខុទាំងអស់ កាលទទួលព្រះតម្រាស់របស់ព្រះមានព្រះភាគ ទើបក្រាបទូលថា ករុណាព្រះអង្គ ហើយនាំគ្នាចៀសចេញទៅ ភិក្ខុទាំងនោះ មិនមានការគិតយ៉ាងនេះថា ពួកយើងគាល់ព្រះសាស្តា ស្តាប់ធម៌និងនៅក្នុងសម្នាក់ព្រះសាស្តា ព្រោះដូច្នោះ ទើបនាំគ្នាមក តែពួកយើងមកកាន់សម្នាក់ព្រះសាស្តា ដែលជាគ្រូបែបនេះ ធ្វើសំឡេងខ្លាំង នេះជាទោសរបស់ពួកយើងប៉ុណ្ណោះ ពួកយើងត្រូវបណ្តេញព្រោះទោស យើងមិនបាននៅក្នុងសម្នាក់ព្រះសាស្តា មិនបានសរសើរព្រះរូបដែលមានពណ៌ដូចមាស ដែលនាំមកនូវការជ្រះថ្លាដោយជុំវិញ មិនបានស្តាប់ធម៌ដែលទ្រង់សម្តែង ដោយព្រះសូរសៀងដ៏ពីរោះ ។ ភិក្ខុទាំងនោះ កើតនូវការតូចចិត្តយ៉ាងខ្លាំង ហើយនាំគ្នាចៀសចេញទៅ ។

បទថា **សំសារមេត្វា** *បានដល់ គ្រប់សង្កត់ដោយល្អ ។ បទថា* **វជ្ជី** *បានដល់ ជនបទដែលមានឈ្មោះយ៉ាងនោះ ។ សូម្បីជនបទមួយ ដែលជាទីប្រថាប់របស់ព្រះរាជកុមារ អ្នកជនបទឈ្មោះថាវជ្ជី ទើបគេហៅថាវជ្ជីនោះឯង ដោយគ្រាមភាសា ។ ព្រោះហេតុនោះ ទើបលោកពោលថា* **វជ្ជីសុ** *ដូច្នេះ ។ ស៊ីឯមួយទៀតដែលសន្មតគ្នាថា ជាបុណ្យនៃសត្វលោក មានឈ្មោះយ៉ាងនេះថា* **វគ្គុមុទា ។** *បាលីថា* **វគ្គមុទា** *ដូច្នេះក៏មាន ។*

[៧៣] *បទថា* **អត្តកាមេន** *បានដល់ ប្រាថ្នាតែប្រយោជន៍ប៉ុណ្ណោះ មិនសំដៅការប្រកបណាមួយ ។ បទថា* **ហិតេសិនា** *បានដល់ ប្រាថ្នានូវប្រយោជន៍ គឺមានប្រក្រតីស្វែងរកប្រយោជន៍ ពោល គឺអត្ត ឬដែលជាហេតុនៃប្រយោជន៍នោះថា សាវ័ករបស់តថាគត គប្បីរួចផុតចាកវដ្តទុក្ខ ព្រោះហេតុអ្វី ព្រោះហេតុនោះឯង ទើបទ្រង់ឈ្មោះថា ជាអ្នកអនុគ្រោះ ព្រោះអនុគ្រោះតាមសម្នាក់នៃវេនេយ្យសត្វ សូម្បីក្នុងទីឆ្ងាយ មិនគិតដល់សេចក្តីលំបាកផ្លូវកាយឡើយ អាត្មាអញត្រូវបណ្តេញ ព្រោះអាស្រ័យសេចក្តីអនុគ្រោះ មិនមែនបណ្តេញព្រោះបំណងសេចក្តីខ្វល់ខ្វាយជាដើមរបស់ខ្លួន ។ ព្រោះព្រះមានព្រះភាគ ទ្រង់ជួនក្នុងធម៌ ទ្រង់បណ្តេញ ព្រោះហេតុធ្វើសំឡេងខ្លាំង ទើបគួរបូជាដោយសម្មាបដិបត្តិប៉ុណ្ណោះ ដូច្នោះ អាវុសោ ណ្ហើយចុះ យើងសម្រេចការនៅយ៉ាងនេះ គឺយើងបំពេញអបណ្ណកបដិបទា ដោយការប្រកបសតិសម្បជញ្ញៈក្នុងទីគ្រប់អន្ទឿ ធ្វើកម្មដ្ឋានតាមដែលកំណត់ឲ្យដល់ទីបំផុត ឈ្មោះថា សម្រេច គឺនៅដោយឥរិយាបថវិហារទាំង ៤ ។ បទថា*

យថា ឆោ វិហារតំ សេចក្តីថា កាលអាត្មាអញនៅដោយប្រការណា ព្រះមានព្រះភាគ គប្បីជាបុគ្គលមានព្រះហឫទ័យត្រេកអរ គឺដែលពួកយើងគប្បីឲ្យទ្រង់ជ្រោសជ្រាណ ដោយសម្មាបដិបត្តិបូជា ។

បទថា **តេនេវន្តរាវស្សេន** បានដល់ មិនហួសថ្ងៃមហាបវារណាខាងក្នុងវស្សានោះឯង ។ បទថា **តិស្សោ វិជ្ជា សច្ឆាកំសុ** សេចក្តីថា ភិក្ខុ ៥០០ នោះឯង បានធ្វើឲ្យជាក់ច្បាស់ដល់ខ្លួននូវវិជ្ជា ៣ គឺបុព្វេនិវាសានុស្សតិញ្ញាណ ១ ទិព្វចក្ខុញ្ញាណ ១ អាសវក្ខយញ្ញាណ ១ ព្រោះអត្ថថា ចាក់ផ្ទុះនូវខន្ធដែលធ្លាប់នៅអាស្រ័យក្នុងកាលមុន និងខន្ធ គឺមោហៈ ដែលជាគ្រឿងបិទបាំង ។ ក្នុងទីនេះ ទ្រង់លើកវិជ្ជា ៣ ឡើងសម្តែង ដោយសម្តែងដល់ការដែលភិក្ខុទាំងនោះសម្រេច ដើម្បីសម្តែងថា បណ្តាលោកិយអភិញ្ញា អភិញ្ញា ២ នេះប៉ុណ្ណោះមានឧបការៈច្រើនដល់អាសវក្ខយញ្ញាណ ឯទិព្វសោតញ្ញាណ ចេតោបរិយ-ញ្ញាណ និងឥទ្ធិវិធញ្ញាណ មិនដូច្នោះឡើយ ។ ពិតហើយ ក្នុងវេរញ្ជសូត្រ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការដែលព្រះអង្គទ្រង់សម្រេចដល់វេរញ្ជ-ព្រាហ្មណ៍ ទើបទ្រង់សម្តែងវិជ្ជា ៣ ប៉ុណ្ណោះ ព្រោះមិនមានទិព្វសោតញ្ញាណជាដើម ។ កាលបើដូច្នេះ ទើបទ្រង់មិនលើកទិព្វសោតញ្ញាណជាដើម ដែលមានសម្តែងដល់ភិក្ខុទាំងនោះ ព្រោះភិក្ខុទាំងនោះមានអភិញ្ញា ៦ ។ ព្រោះធ្វើអធិប្បាយដូចពោលមកនេះ ទើបទ្រង់ត្រាស់ដល់ការប្រើឫទ្ធិរបស់ភិក្ខុទាំងនោះថា ភិក្ខុទាំងនោះបាត់ទៅក្នុងច្រាំងស្ទឹងវគ្គុមុទា មកប្រាកដចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ក្នុងកូដាគារសាលា ។

[៧៤] បទថា **យថាភិរន្តំ** បានដល់ តាមគាប់ព្រះហឫទ័យ គឺព្រះអធ្យាស្រ័យ ។ ពិតហើយ ធម្មតាព្រះពុទ្ធទាំងឡាយ ដែលប្រថាប់នៅក្នុងទីមួយកន្លែង រមែងមិនមានការត្រេកអរ ព្រោះអាស្រ័យការវិបត្តិនៃម្ចប់ និងទឹក ឬសេនាសនៈ ដែលមិនជាទីសប្បាយ ឬភាពដែលមនុស្សមិនមានសទ្ធាជាដើម សូម្បីការប្រថាប់នៅយូរ ដោយទ្រង់ព្រះតម្រិះថានៅជាសុក ព្រោះការបរិបូណ៌ ក៏មិនមានដល់ព្រះពុទ្ធទាំងឡាយ ។ កាលព្រះមានព្រះភាគប្រថាប់នៅក្នុងទីណា មនុស្សទាំងឡាយក្នុងទីនោះ តាំងនៅក្នុងសរណៈ សមាទានសីល បព្វជ្ជា ឬសម្រេចសោតាបត្តិមគ្គជាដើម ទើបព្រះសាស្តាគង់ប្រថាប់ ដើម្បីមនុស្សទាំងនោះ តាំងនៅក្នុងសម្បត្តិទាំងនោះ កាលមិនមានសម្បត្តិនោះទេ ទ្រង់ក៏យាងចៀសចេញទៅ ។ ក្នុងកាលនោះ ទ្រង់មិនមានពុទ្ធកិច្ចដែលគប្បីធ្វើក្នុងក្រុងសាវត្ថី ។ ព្រោះហេតុនោះ ទើបលោកពោលថា គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងសាវត្ថី តាមសមគួរដល់អធ្យាស្រ័យហើយ ស្តេចចៀសចេញទៅកាន់ចារិក ក្នុងក្រុងវេសាលី ។

បទថា **ចារិកញ្ញមាគោ** បានដល់ ទ្រង់យាងទៅដោយផ្លូវឆ្ងាយ ។ ឈ្មោះថា ការចារិករបស់ព្រះមានព្រះភាគ មាន ២ យ៉ាង គឺយាងចារិកទៅដោយប្រញាប់ ១ យាងចារិកទៅដោយមិនប្រញាប់ ១ ។ ក្នុងចារិក ២ យ៉ាងនោះ ការដែលទ្រង់ឃើញពោធនេយ្យបុគ្គលក្នុងទីឆ្ងាយ ក៏ប្រញាប់យាងទៅដើម្បីឲ្យបុគ្គលនោះត្រាស់ដឹង ឈ្មោះថា ចារិកទៅដោយប្រញាប់ ។ ការយាងទៅដោយប្រញាប់នោះ គប្បីឃើញក្នុងការទទួលព្រះមហាកស្សបៈជាដើម ។

ចំណែកការយាងចារិកទៅអនុគ្រោះសត្វលោក ដោយការគ្រាច់បិណ្ឌបាតជាដើមដោយផ្លូវមួយយោជន៍ កន្លះយោជន៍រៀងរាល់ថ្ងៃ តាមលំដាប់គាមនិគមនិងរាជធានី នេះឈ្មោះថា ចារិកទៅដោយមិនប្រញាប់ ។ ការចារិកទៅដោយមិនប្រញាប់នេះ លោកបំណងយកក្នុងទីនេះ ។ បទថា **តជ្ជាសិ** *កែជា* **តេន អាសិ** *ឬ* **តំ អាសិ** *គឺយាងទៅ អធិប្បាយថា យាងទៅដោយប្រការនោះ ។ បទថា* **តត្រ** *បានដល់ ជិតក្រុងវេសាលីនោះ ។ បទថា* **សុទំ** *ត្រឹមតែជានិបាត ។ បទថា* **វេសាលិយំ** *បានដល់ នគរបស់ពួកស្តេចលិច្ឆវី ដែលបានឈ្មោះថា* **វេសាលី** *ព្រោះជាទីក្រុងដែលពង្រីកឲ្យទូលំទូលាយអស់វារៈ ៣ ដង ។ បទថា* **មហាវនេ** *សេចក្តីថា ឈ្មោះថា មហាវន បានដល់ព្រៃដែលកើតឯង មិនមានអ្នកណាដាំ ជាព្រៃធំ មានដែនកំណត់ ។ ព្រៃមហាវន ជិតក្រុងកបិលពស្តុ ជាព្រៃមិនមានដែនកំណត់ ទាក់ទងជាមួយនឹងព្រៃហិមពាន្ត រហូតទល់មហាសមុទ្រ ។ ព្រៃមហាវននេះ មិនមែនដូច្នោះទេ ។ ឈ្មោះថា មហាវន ព្រោះជាព្រៃធំ មានដែនកំណត់ ។ បទថា* **កូដាគារសាលាយំ** *សេចក្តីថា ក្នុងអារាមដែលសាងឧទ្ទិសព្រះមានព្រះភាគក្នុងព្រៃមហាវននោះ ព្រះគន្ធកុដិរបស់ព្រះមានព្រះភាគ សម្បូរដោយអាការទាំងពួង សាងដោយប្រក់ដំបូលជារង្វង់មូល មានទ្រង់ទ្រាយស្រដៀងសត្វហង្ស ដោយមានកូដាគារនៅខាងក្នុង ឈ្មោះថា* **កូដាគារសាលា ។** *ក្នុងកូដាគារសាលានោះ ។ បទថា* **វគ្គុមុទាតីរិយានំ** *បានដល់ នៅច្រាំងស្ទឹងវគ្គុមុទា ។ បទថា* **ចេតសា ចេតោ បរិច្ច មនសិការិត្វា** *សេចក្តីថា ទ្រង់*

មនសិការកំណត់ចិត្តរបស់ភិក្ខុទាំងនោះ ដោយព្រះហឫទ័យរបស់ព្រះអង្គ ។ អធិប្បាយថា ទ្រង់ជ្រាបគុណវិសេសដែលភិក្ខុនោះសម្រេច ដោយចេតោ-បរិយញ្ញាណ ឬសព្វញ្ញុតញ្ញាណ ។

បទថា **អាលោកជាតា វិយ** *ប្រែថា ដូចកើតពន្លឺ ។ ក្រៅអំពីនោះជាវេវចនៈនៃបទថា* **អាលោកជាតា** *នោះដូចគ្នា ។ អធិប្បាយថា ដូចពន្លឺព្រះចន្ទ ១០០០ ដួង និងព្រះអាទិត្យ ១០០០ ដួង ។ ព្រោះហេតុដែលភិក្ខុ ៥០០ ដែលមានព្រះយសោជៈជាប្រធាននោះ ជាបុគ្គលភ្លឺស្វាង ព្រោះកម្ចាត់ងងឹតគឺអវិជ្ជាដោយប្រការទាំងពួង ។ ដូច្នោះ ទើបព្រះមានព្រះភាគទ្រង់សរសើរភិក្ខុទាំងនោះ ដោយការអាងដល់កិច្ចពណ៌នាគុណ ក្នុងទីដែលភិក្ខុទាំងនោះស្ថិតនៅ ដោយនយជាដើមថា អានន្ទ ទិសនោះ ហាក់ដូចជាពន្លឺរបស់តថាគត ។ ដោយហេតុនោះ ទើបលោកពោលថា* **យស្សុំ ទិសាយំ វគ្គុមុទា-តីរិយា ភិក្ខូ វិហរន្តិ** *ពួកភិក្ខុអ្នកនៅប្របង្អេរស្ទឹងវគ្គុមុទា នៅក្នុងទិសណា ។*

បទថា **អប្បដិក្កូលា** *ប្រែថា មិនគួរខ្ពើម អធិប្បាយថា គួរពេញចិត្ត គួរជាទីត្រេកអរនៃចិត្ត ។ ពិតហើយ ទឹកដីដែលបុគ្គលអ្នកស្វែងរកគុណធំដែលសម្បូរដោយគុណ មានសីលជាដើមរស់នៅនោះ មានអាការដូចទីខ្ពស់ទីទាប មិនរាបស្មើក៏ពិត តែទីនោះ ជាទីគាប់ចិត្ត ជាទីត្រេកអរនៃចិត្តនោះឯង ។ សមដូចព្រះតម្រាស់ដែលត្រាស់ថា*

> *ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី*
> *ទីទាបក្តី ទីទួលក្តី ទីនោះឯង ជាភូមិគួរត្រេកអរ ។*

បទថា **បហិណេយ្យាសិ** *ប្រែថា គប្បីបញ្ជូនទៅ ។ បទថា* **សត្ថា អាយស្មន្តានំ ឧស្សនកាមោ** *នេះ ជាបទសម្តែងដល់អាការដែលបញ្ជូនទៅ ក្នុងសម្នាក់នៃភិក្ខុទាំងនោះ ដូច្នោះ ព្រះមានព្រះភាគ ទ្រង់ឃើញប្រយោជន៍ ដែលទ្រង់បណ្តេញភិក្ខុទាំងនោះដល់ទីបំផុត មានព្រះហឫទ័យត្រេកអរ ទើបត្រាស់ប្រាប់បំណងដែលនឹងឃើញភិក្ខុទាំងនោះដល់ព្រះថេរៈ ។ បានឮថា ទ្រង់មានព្រះតម្រិះយ៉ាងនេះថា តថាគតបណ្តេញភិក្ខុទាំងនេះ ព្រោះធ្វើសំឡែងខ្លាំង កាលបើដូច្នោះ ភិក្ខុទាំងនោះក៏ត្រូវអានន្ទៈចោទសួរ ដូចសេះអាជានេយ្យដ៏ប្រសើរ រាយដោយគ្នាង បានទទួលនូវការសង្វេគហើយ ចូលទៅកាន់ព្រៃ ដើម្បីឲ្យតថាគតប្រោសប្រាណ ព្យាយាម ធ្វើឲ្យជាក់ច្បាស់នូវអរហត្តដោយឆាប់រួសរាន់ ។ ឥឡូវនេះ ទ្រង់ឃើញភិក្ខុទាំងនោះសម្រេចអរហត្ត មានព្រះហឫទ័យត្រេកអរ ដោយការសម្រេចអរហត្តនោះ មានបំណងនឹងឃើញភិក្ខុទាំងនោះ ទើបទ្រង់បញ្ជាព្រះអានន្ទដែលជាធម្មភណ្ឌាគារិកយ៉ាងនោះ ។ បទថា* **សោ ភិក្ខុ** *បានដល់ ភិក្ខុមួយរូបដែលបានអភិញ្ញា ៦ ត្រូវព្រះអានន្ទប្រាប់ដូច្នោះ ។ បទថា* **បមុខេ** *ប្រែថា ក្នុងទីចំពោះមុខ ។*

[៧៥] *បទថា* **អានេញ្ជសមាធិនា** *បានដល់ ដោយសមាធិដែលសម្បយុត្តដោយអរហត្តផល មានចតុត្ថជ្ឈានជាបាទ ។ អាចារ្យមួយពួកពោលថា មានអរូបជ្ឈានជាបាទដូច្នេះក៏មាន ។ បាលីថា* **អានេញ្ជសមាធិនា** *ដោយសមាធិដែលមិនញាប់ញ័រ ដូច្នេះក៏មាន ។ ព្រោះហេតុអ្វី ព្រះមានព្រះភាគ កាលទ្រង់ជ្រាបការមករបស់ភិក្ខុទាំងនោះ ទ្រង់មិនធ្វើបដិ-*

សណ្ហាវៈ ទ្រង់ចូលសមាបត្តិតែម្យ៉ាង ដើម្បីឲ្យភិក្ខុទាំងនោះដឹងថា ទ្រង់ចូលសមាបត្តិ ទើបចូលដែរ ដើម្បីសម្តែងការនៅរួមរបស់ភិក្ខុទាំងនោះ ដែលទ្រង់បណ្តេញក្នុងកាលមុនថា ស្មើនឹងព្រះអង្គក្នុងកាលឥឡូវនេះ ដើម្បីសម្តែងអានុភាព និងដើម្បីសម្តែងការព្យាករណ៍អរហត្តផល ដោយការបន្ទឹព្រះវាចា ។ អាចារ្យពួកខ្លះពោលថា ដើម្បីទ្រង់ធ្វើបដិសណ្ហារៈដែលមិនទូទៅដល់អ្នកដទៃ ដោយធ្វើសេចក្តីសុខដ៏កំពូលឲ្យកើតឡើងដល់ភិក្ខុទាំងនោះ ដែលទ្រង់បណ្តេញក្នុងកាលមុន ឥឡូវនេះ មកកាន់សម្នាក់របស់ព្រះអង្គ ។ លោកទាំងនោះជ្រាបព្រះអធ្យាស្រ័យរបស់ព្រះមានព្រះភាគ ទើបចូលសមាបត្តិនោះឯង ។ ព្រោះហេតុនោះ ទើបលោកពោលថា **កតមេន នុ ខោ ភគវា វិហារេន ឯតរហិ វិហរតិ** *ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់គង់នៅដោយវិហារធម៌ដូចម្តេចហ្ន៎ ។*

ក្នុងទីនេះ រូបាវចរចតុត្ថជ្ឈានដល់នូវការមិនញាប់ញ័រ ព្រោះប្រកបដោយភោទានធម៌ ១៦ ប្រការ មានការមិនស្រុតចុះជាដើម ដែលជាមូលនៃឫទ្ធិ ព្រោះធម៌ជាសត្រូវ មានកោសជ្ជៈជាដើមនៅឆ្ងាយ លោកហៅថា **អានេញ្ជ** *ព្រោះអត្ថថា ខ្ជួនឯងក៏មិនញាប់ញ័រ សមដូចពាក្យដែលលោកពោលក្នុងបដិសម្ភិទាមគ្គថា*

> *ឫទ្ធិ មានមូល ១៦ តើដូចម្តេច ។ ចិត្តដែលមិនទ្រោម រមែងមិនញាប់ញ័រក្នុងការខ្ជិលច្រអូស ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ (ទុកជាមូល) ១ ចិត្តដែលមិនជ៉ាងឡើង រមែង*

មិនញាប់ញ័រក្នុងសេចក្តីរវើរវាយ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ (ទុកជាមូល) ១ ចិត្តដែលមិនទន់ទោរ រមែងមិនញាប់ញ័រក្នុងរាគៈ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមិនបង្អោន រមែងមិនញាប់ញ័រក្នុងព្យាបាទ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមិនអាស្រ័យ រមែងមិនញាប់ញ័រក្នុងទិដ្ឋិ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមិនជាប់ជំពាក់ រមែងមិនញាប់ញ័រក្នុងឆន្ទរាគ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលផុតស្រឡះ រមែងមិនញាប់ញ័រក្នុងកាមរាគ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលគ្មានគ្រឿងប្រកប រមែងមិនញាប់ញ័រក្នុងកិលេស ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលគ្មានភ្លឺ គឺកិលេស រមែងមិនញាប់ញ័រក្នុងភ្លឺ គឺកិលេស ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានអារម្មណ៍តែមួយ រមែងមិនញាប់ញ័រក្នុងកិលេសមានសភាពផ្សេងៗ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានសទ្ធាថែរក្សា រមែងមិនញាប់ញ័រក្នុងវត្តុមិនគួរជឿ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានវីរិយៈថែរក្សា រមែងមិនញាប់ញ័រក្នុងការខ្ជិលច្រអូស ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានសតិថែរក្សា រមែងមិនញាប់ញ័រក្នុងប្រមាទ ហេតុនោះ ឈ្មោះថា ចិត្ត

មិនញាប់ញ័រ ១ ចិត្តដែលមានសមាធិថែរក្សា រមែងមិនញាប់ញ័រក្នុងសេចក្តីរាយមាយ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានបញ្ញាថែរក្សា រមែងមិនញាប់ញ័រក្នុងអវិជ្ជា ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលភ្ញីស្វាង រមែងមិនញាប់ញ័រក្នុងឆន្ទរាគ គឺអវិជ្ជា ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ។

ម្យ៉ាងទៀត បុរាណាចារ្យទាំងឡាយពោលថា ការបញ្ញត្តិឈានទាំង ៥ នេះថា ជាអនេញ្ជៈ គឺរូបាវចរចតុត្ថជ្ឈានប៉ុណ្ណោះ ដែលប្រព្រឹត្តទៅដោយអំណាចការចម្រើននូវការខ្ជាក់ចោលនូវរូប ១ អរូបាវចរជ្ឈាន ៤ ដែលប្រព្រឹត្តទៅដោយចែកតាមអារម្មណ៍ ។ បណ្តាឈានទាំងនោះ អរហត្តផល-សមាបត្តិដែលធ្វើឈានឯណានីមួយឲ្យជាបាទ ហើយទើបចូល ឈ្មោះថា អនេញ្ជសមាធិ ។

បទថា **អភិក្កន្តាយ** *ប្រែថា កន្លងទៅហើយ ។ បទថា* **និក្ខន្តេ** *ប្រែថា ឆ្លងទៅហើយ អធិប្បាយថា ប្រាសទៅហើយ ។ បទថា* **តុណ្ហី អហោសិ** *សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ជាអ្នកស្ងៀមដោយតុណ្ហីភាព ដ៏ប្រសើរ ។ បទថា* **ឧទ្ធស្តេ អរុណេ** *ប្រែថា កាលអរុណរះឡើង ឈ្មោះថា អរុណបានដល់ ពន្លឺដែលចាំងឡើងមុនព្រះអាទិត្យរះនោះឯង ក្នុងបុរត្ថិមទិស ។ បទថា* **ឆដ្ឋិមុទិយា** *សេចក្តីថា កាលរាត្រីកើតហើយ ភ្ញីស្វាងហើយ ដូចពន្លឺនៃអរុណដែលជាប្រធាន ក្នុងការធ្វើពួកសត្វដែលអាស្រ័យពន្លឺព្រះអាទិត្យ ឲ្យ*

ត្រេកអរ ព្រោះអរុណនៃរាត្រីរះឡើងនោះឯង ។

បទថា **តម្ហា សមាធិម្ហា វុដ្ឋហិត្វា** *សេចក្តីថា ចេញចាកអនេញ្ជ-សមាធិ គឺចេញអំពីផលសមាបត្តិដែលសម្បយុត្តដោយអរហត្តផលនោះ តាមកាលដែលកំណត់ ។ បទថា* **សចេ ខោ ត្វំ អានន្ទ ជានេយ្យាសិ** *សេចក្តីថា ម្នាលអានន្ទ បើអ្នកគប្បីដឹងយ៉ាងនេះថា ព្រះមានព្រះភាគ និងភិក្ខុទាំងនោះ សម្ងំនៅដោយសុខ ដែលកើតអំពីសមាបត្តិឈ្មោះនេះ អស់កាលមានប្រមាណប៉ុណ្ណេះសោត ។ ដោយបទថា* **ឯត្តកម្បិ តេ ន ឧប្បដិកាសេយ្យ** *ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា ការជាក់ច្បាស់ ដែលប្រាកដដល់អ្នក ៣ ដង ដោយនយជាដើមថា រាត្រីអស់ទៅហើយ ព្រះអង្គ ដូច្នេះ ដែលសំដៅការប្រាស្រ័យដែលជាចំណែកលោកិយ មានប្រមាណត្រឹមប៉ុណ្ណេះ ក៏មិនប្រាកដដល់អ្នក ។ ម្នាលអានន្ទ ព្រោះហេតុដែលអ្នកជាសេក្ខបុគ្គល មិនជឹងសមាបត្តិវិហារធម៌ដែលជារបស់ព្រះអសេក្ខៈ ដូច្នោះ ទើបអ្នកដល់នូវការខ្វល់ខ្វាយ ដែលនឹងឲ្យតថាគតធ្វើការប្រាស្រ័យ ដែលជាចំណែកលោកិយដល់ភិក្ខុទាំងនេះ ។ តែតថាគត មួយអន្ទើដោយភិក្ខុទាំងនេះ សម្ងំអស់រាត្រីទាំង ៣ យាម ដោយការប្រាស្រ័យដែលជាលោកុត្តរនោះឯង ទើបត្រាស់ថា* **អហាវ្យានន្ទ ឥមានិ ច បញ្ច ភិក្ខុសតានិ សព្វេ អានេញ្ជសមាធិនា និសិន្នម្ហា** *ម្នាលអានន្ទ (ព្រោះថា) តថាគតផង ពួកភិក្ខុ ៥០០ រូបនេះផងទាំងអស់គ្នា សុទ្ធតែអង្គុយនៅដោយអានេញ្ជសមាធិមិនកម្រើក ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួង*

ដល់នូវអត្ត គឺភាពដែលភិក្ខុទាំងនោះ មានការជំនាញ ពោល គឺអាចក្នុង ការចូលអានេញ្ជសមាបត្តិជាមួយព្រះអង្គ ។ បទថា **ឥមំ ឥទានំ** *សេចក្តីថា ទ្រង់បន្ទឹខទាននេះ ដែលសម្តែងដល់ភាវៈដែលភិក្ខុទាំងនោះ ជាអ្នកសម្រេច ក្នុងការលះរាគៈជាដើមបានជាសមុច្ឆេទ ។*

បណ្តាបទទាំងនោះ បទថា **យស្ស ឯតោ កាមកណ្ហាកោ** *សេចក្តីថា កាម គឺកិលេស ឈ្មោះថា ជាបន្ទា ព្រោះអត្តថា ដែលចាក់ធ្លុះនូវធម៌ជា បដិបក្ខចំពោះកុសលធម៌ ដែលជាហេតុឲ្យព្រះអរិយបុគ្គលឈ្នះ គឺលះបានជា សមុច្ឆេទ ដោយពាក្យនោះ ព្រះអង្គទ្រង់សម្តែងដល់ភាវៈ ដែលព្រះអរិយ-បុគ្គលនោះ មិនមានសេចក្តីត្រេកអរ ។ បាលីថា* **កាមកណ្ហាកោ** *ដូច្នេះ ក៏មាន ។ ព្រះបាលីនោះ មានអធិប្បាយដូច្នេះថា បន្ទាក្នុងស្រុក បានដល់ វត្ថុកាមទាំងអស់ដែលជាទីតាំងនៃបន្ទា ដែលព្រះអរិយបុគ្គលណាឈ្នះហើយ ព្រោះដូច្នោះ ការឈ្នះរបស់ព្រះអរិយបុគ្គលនោះ គប្បីជ្រាបដោយការលះ ឆន្ទរាគ ដែលទាក់ទងដោយវត្ថុកាមនោះ ដោយពាក្យនោះ ទ្រង់ត្រាស់ដល់ អនាគាមិមគ្គនៃភិក្ខុទាំងនោះ ភ្ជាប់សេចក្តីថា ការជេរដែលព្រះអរិយបុគ្គល ឈ្នះហើយ ក្នុងបទថា* **វធោ ច ពន្ធនញ្ច** *នេះ ក៏នយនេះដូចគ្នា ។ ក្នុងការ ជេរជាដើមនោះ ទ្រង់សម្តែងការមិនមានវិចិទុច្ចរិត ដោយការឈ្នះការជេរ ទ្រង់សម្តែងការមិនមានកាយទុច្ចរិតដោយធម៌ក្រៅអំពីនេះ ។ ដោយពាក្យនោះ ទ្រង់ត្រាស់មគ្គទី ៣ ដោយការលះព្យាបាទ ដែលមានការជេរជាដើមនោះជា និមិត្តបានដោយសមុច្ឆេទ ។ ម្យ៉ាងទៀត ទ្រង់ត្រាស់ដល់មគ្គទី ៣ ដោយការ*

ត្រាស់ដល់ជ័យជម្នះ (មាន) ការជេរជាដើម ។ ការសង្កត់នូវការជេរជាដើមបានជាសមុច្ឆេទ ទ្រង់ប្រកាសក្នុងមគ្គទី ៣ នោះ ។ សូម្បីបទទាំង ២ ក៏ទ្រង់សម្តែងដល់កាពដែលភិក្ខុទាំងនោះ មិនមានការអាក់អន់ ។ បទថា **បញ្ហតោ វិយ សោ ឋិតោ អនេជោ** *សេចក្តីថា អន្តរាយ គឺកិលេសដែលជាតួញាប់ញ័រ លោកហៅថា* **ឯជា** *ឈ្មោះថា* **អនេជា** *ព្រោះមិនមានកិលេសដែលនៅសល់ ជាហេតុឲ្យញាប់ញ័រតាំងនៅ គឺដូចគ្នានឹងថ្មភ្នំតាន់ ព្រោះមិនញាប់ញ័រដោយកិលេសទាំងពួង និងដោយខ្យល់ គឺការពោលទ្រគោះរបស់អ្នកដទៃ ព្រោះមិនមានការញាប់ញ័រនោះឯង ។ បទថា* **សុខ-ទុក្ខេសុ ន វេធតិ ស ភិក្ខុ** *សេចក្តីថា ភិក្ខុនោះ គឺភិក្ខុដែលទម្លាយកិលេសហើយ រមែងមិនញាប់ញ័រ ដែលមានសុខ និងទុក្ខជាហេតុ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបសេចក្តីដោយន័យដូចពោលហើយខាងដើមនោះឯង ។*

ព្រះមានព្រះភាគ ទ្រង់សំដៅដល់កាពជាអ្នកមាំទាំ ដោយការសម្រេចអរហត្តរបស់ភិក្ខុទាំងនោះ ទើបទ្រង់បន្ទឺឧទាន ដែលមានបុគ្គលឯកជាទីតាំងដោយប្រការដូច្នេះឯង ॥

អដ្ឋកថាយសោជសុត្តនិ ៣ ចប់

សុត្តន្តបិដក

សារិបុត្តសូត្រ

[๗๖] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ អង្គុយពែនភ្នែន តម្រង់កាយ ផ្ចង់ស្មារតីឆ្ពោះមុខទៅរកកម្មដ្ឋាន ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញព្រះសារីបុត្តដ៏មានអាយុ អង្គុយពែនភ្នែន តម្រង់កាយ ផ្ចង់ស្មារតីឆ្ពោះមុខទៅរកកម្មដ្ឋាន ក្នុងទីជិតនៃព្រះអង្គ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ភ្នំជាវិការនៃថ្ម មិនកម្រើកញាប់ញ័រ តាំងនៅស៊ប់ យ៉ាងណា
កិក្ខុដែលអស់មោហៈហើយ រមែងមិនញាប់ញ័រ ដូចភ្នំយ៉ាងនោះ
ដែរ ។ សូត្រទី ๔ ។

អដ្ឋកថា

សារិបុត្តសូត្រ

សារិបុត្តសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

[៧៦] *បទថា* **បរិមុខំ សតិ ឧបដ្ឋបេត្វា** *សេចក្តីថា តាំងសតិឲ្យមានមុខចំពោះអារម្មណ៍ គឺតាំងសតិក្នុងទីចំពោះមុខ ។ ពិតហើយ ព្រះមានព្រះភាគត្រាស់ក្នុងវិភង្គថា ការរឭក ការនឹកឃើញ ។បេ។ សេចក្តីរឭកត្រូវណា នេះហៅថា សតិ សតិនេះ ដែលបុគ្គលតម្កល់ទុកហើយ តាំងទុកល្អហើយ ត្រង់ទីបំផុតនៃច្រមុះក្តី ត្រង់និមិត្តនៃមាត់ក្តី ព្រោះហេតុនោះ ទើបពោលថា តម្កល់សតិឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ដោយហេតុនោះ ទើបលោកពោលថា* **បរិមុខំ សតិ ឧបដ្ឋបេត្វា ។** *ម្យ៉ាងទៀត បទថា* **បរិ** *មានអត្ថថា កំណត់ ។ បទថា* **មុខំ** *មានអត្ថថា នាំចេញ ។ បទថា* **សតិ** *មានអត្ថថា ប្រាកដ ។ ដោយហេតុនេះ ទើបលោកពោលថា* **បរិមុខំ សតិ ។** *ក្នុងទីនេះ គប្បីជ្រាបអត្ថដោយនយដូចពោលហើយ ក្នុងបដិសម្ភិទា ដោយប្រការដូច្នេះ ។ ក្នុងសេចក្តីនោះ មានសេចក្តីសង្ខេបដូចតទៅនេះ បទថា* **និយ្យានំ** *ក្នុងបទថា* **បរិគ្គហិតនិយ្យានសតិ កត្វា** *(**បរិគ្គហិត** ប្រែថា កំណត់ ជាអត្ថរបស់ **បរិ** សព្ទ ពាក្យថា **និយ្យាន** ប្រែថា នាំចេញ ជាអត្ថរបស់សព្ទថា **មុខំ**) នេះ គប្បីឃើញអារម្មណ៍ដែលសតិឈមចុះ ។ ក្នុងសេចក្តីនេះ សេចក្តីខាងដើម និងសេចក្តីខាងចុង គប្បីឃើញសតិគ្រប់គ្រងនូវអារម្មណ៍បានទាំងអស់ ក្រៅអំពីនោះ គប្បីឃើញការប្រមូលចំណែកខាង*

ដើមរបស់សមាបត្តិ ។ ម្យ៉ាងទៀត ឈាន លោកហៅថា សតិ ដោយលើកសតិទ្បើងជាប្រធាន ដូចក្នុងប្រយោគជាដើមថា **យេ កាយគតាសតឹ បរិ-ភុញ្ជន្តិ** *ភិក្ខុណាបរិភោគកាយគតាសតិ ។ សួរថា ឈាននោះដូចម្តេច ឆ្លើយថា បានដល់ ឈានដែលសម្បយុត្តដោយអរហត្តផល ដែលធ្វើរូបាវចរ-ចតុត្ថជ្ឈានឲ្យជាបាទ ហើយទើបចូល ។ សួរថា ឈាននោះ គប្បីដឹងបានដូចម្តេច ឆ្លើយថា ព្រះមានព្រះភាគ កាលទ្រង់ប្រកាសភាពដែលព្រះថេរៈមិនញាប់ញ័រ មួយអន្ទើដោយគុណវិសេស ព្រោះប្រកបដោយអានេញ្ជសមាធិ និងភាពដែលព្រះថេរៈនោះ ជាបុគ្គលដែលបុគ្គលណាម្នាក់ ឲ្យញាប់ញ័រមិនបាន ដោយប្រៀបធៀបនឹងភ្នំ ទើបទ្រង់បន្ទឺឧទាននេះ ព្រោះហេតុនោះ រមែងដឹងអត្ថនេះបាន ដោយគាថានោះឯង ។ នេះមិនមែនព្រះថេរៈ អង្គុយដើម្បីចាក់ផ្ទុះសច្ចៈ ដោយពិត អង្គុយដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ។ ពិតហើយ ក្នុងកាលមុននោះឯង កាលព្រះមានព្រះភាគទ្រង់សម្តែងធម៌ដល់ ទីឃនខ-បរិព្វាជកជាក្មួយរបស់ព្រះថេរៈ ត្រង់គុហាសូករខាតា ព្រះមហាថេរៈដល់នូវទីបំផុតកិច្ចនៃការចាក់ផ្ទុះសច្ចៈ ។*

បទថា **ឯតមត្ថំ** *សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងដល់អត្ថនេះ ពោល គឺភាពដែលព្រះថេរៈមិនមានអ្វីឲ្យញាប់ញ័របាន ព្រោះប្រកបដោយអានេញ្ជសមាធិ និងព្រោះដល់នូវភាពជាតាទិបុគ្គល ទើបទ្រង់បន្ទឺឧទាននេះ ប្រកាសសេចក្តីនោះ ។*

បណ្តាបទទាំងនោះ បទថា **យថាបិ បព្វតោ សេលោ** *សេចក្តីថា ដូចថ្ម*

ភ្នំតាន់ ជាថ្មវាន ឬមិនមែនជាភ្នំដី ។ បទថា **អចលោ សុប្បតិដ្ឋិតោ** *សេចក្តីថា មានឫសតាំងនៅដោយល្អ មិនកម្រើក មិនញាប់ញ័រដោយខ្យល់ តាមប្រក្រតី ។ បទថា* **ឯវំ មោហក្ខយា ភិក្ខុ បញ្ចោរ ន វេធតិ** *សេចក្តីថា ភិក្ខុ ឈ្មោះថា លះអកុសលទាំងពួងបាន ព្រោះលះមោហៈបានជាសមុច្ឆេទ និងព្រោះលះអកុសលទាំងពួង មានមោហៈជាមូល រមែងមិនញាប់ញ័រ គឺមិនញាប់ញ័រដោយលោកធម៌ ដូចភ្នំមិនញាប់ញ័រដោយខ្យល់តាមប្រក្រតី ។ ម្យ៉ាងទៀត ព្រោះព្រះនិព្វាន និងព្រះអរហត្ត លោកហៅថា* **មោហក្ខយ** *ដូច្នោះ ទើបភិក្ខុនោះ ឈ្មោះថា តាំងនៅដោយល្អហើយ ក្នុងអរិយសច្ច ៤ ព្រោះសម្រេចព្រះនិព្វាន និងព្រះអរហត្ត ព្រោះអស់ទៅនៃមោហៈ ក្នុងកាលដែលមិនចូលសមាបត្តិ ក៏មិនញាប់ញ័រ ដោយហេតុណាមួយ ដូចភ្នំ ដូចពោលហើយ អធិប្បាយថា នឹងពោលទៅថ្មី ក្នុងពេលចូលសមាបត្តិនោះ ៗ*

អដ្ឋកថាសារិបុត្តសូត្រទី ៤ ចប់

សុត្តន្តបិដក

កោលិតសូត្រ

[៧៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមហាមោគ្គល្លានដ៏មានអាយុ អង្គុយពែនភ្នែន ក្នុងទីជិតនៃព្រះមានព្រះភាគ ហើយតម្រង់កាយ មានកាយគតាសតិតម្កល់ស៊ប់ក្នុងសន្តាន ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញព្រះមហាមោគ្គល្លានដ៏មានអាយុ អង្គុយពែនភ្នែន តម្រង់កាយ មានកាយគតាសតិតម្កល់ស៊ប់ក្នុងសន្តាន ក្នុងទីជិតនៃព្រះអង្គ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ភិក្ខុតាំងស៊ប់នូវកាយគតាសតិ ហើយបានសង្រួម ក្នុងទ្វារទាំង ៦ ដែលជាហេតុនៃផស្សៈ មានចិត្តតាំងមាំជានិច្ច គប្បីដឹងព្រះនិព្វានចំពោះខ្លួន ។ សូត្រទី ៥ ។

អដ្ឋកថា

កោលិតសូត្រ

កោលិតសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ

[៧៧] *បទថា* **កាយគតាយ សតិយា** *សេចក្តីថា មានសតិទៅក្នុងកាយ គឺមានកាយជាអារម្មណ៍ ដោយអំណាចកាយានុបស្សនា ។ បទថា* **សតិយា** *នេះ ជាតតិយាវិភត្តិ ប្រើក្នុងលក្ខណៈឥត្ថម្ភូត ។ ខាងក្នុងខ្លួនឈ្មោះថា អជ្ឈត្ត ក្នុងបទថា* **អជ្ឈត្តំ** *នេះ ។ ព្រោះដូច្នោះ ទើបមានអត្ថថា ក្នុងខ្លួន គឺក្នុងសន្តានរបស់ខ្លួន ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថនៃបទថា* **អជ្ឈត្តំ** *ថា* **គោចរជ្ឈត្តំ** *ព្រោះលោកបំណងយកប្រជុំចំណែកទាំង ៣២ មានសក់ជាដើម ដែលជាតួកម្មដ្ឋាន ថាកាយក្នុងទីនេះ ។ បទថា* **សុប្បតិដ្ឋិតាយ** *សេចក្តីថា ប្រាកដដោយល្អក្នុងកាយ ដែលជាខាងក្នុងខ្លួន ឬដែលជាខាងក្នុងអារម្មណ៍ ។ សួរថា សតិដែលលោកពោលថា ប្រាកដដោយល្អខាងក្នុងខ្លួន គឺអ្វី ។ ឆ្លើយថា គឺសតិដែលប្រាកដក្នុងកាយ ដោយអំណាចឧបចារៈ និងអប្បនានៃព្រះយោគីដែលជាអ្នកញ៉ាំងបដិកូលមនសិការ ឲ្យប្រព្រឹត្តទៅក្នុងអាការ ៣២ មានសក់ជាដើម ដែលជាខាងក្នុង ដែលព្រះមានព្រះភាគត្រាស់ថា កាយ ដោយន័យជាដើមថា សក់ រោម មាននៅក្នុងកាយនេះ លោកហៅថា* **កាយគតាសតិ ។** *កាយគតាសតិនេះ យ៉ាងណា សតិដែលប្រាកដក្នុងកាយ ដោយអំណាចឧបចារៈ និងអប្បនា តាមគួរនៃព្រះយោគី ដែលញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅ ដោយអំណាចសតិសម្បជញ្ញៈក្នុងអានាបាន*

និងឥរិយាបថ ៤ និងដោយអំណាចឧទ្ធុមាតកអសុភ និងវិនីលកអសុភ ជាដើម ក៏ហៅថា កាយគតាសតិ ដូច្នោះ ក្នុងទីនេះ កាយគតាសតិខាងក្នុងខ្លួន កំណត់ធាតុទាំង ៤ មានបឋវីធាតុជាដើម ដោយអាការឯណានីមួយ គឺ ដោយអាការ ១ ក្នុងអាការ ៤ មានសសម្ភារសន្ធៃបជាដើម ប្រាកដដោយអាការកំណត់អនិច្ចលក្ខណៈជាដើមនៃធាតុទាំងនោះ ជាសតិដែលសម្បយុត្ត ដោយវិបស្សនា លោកបំណងយកថា កាយគតាសតិ ។ ព្រះថេរៈឃើញច្បាស់យ៉ាងនោះ ទើបអង្គុយចូលផលសមាបត្តិរបស់ខ្លួនប៉ុណ្ណោះ ។ ក្នុងទីនេះ ភាពដែលអត្ថនៃព្រះគាថានេះ ជីងច្បាស់បានយ៉ាងនោះ គប្បីប្រកបតាមគន្ថន័យដែលពោល ដោយន័យថា **ន ចាយំ និសជ្ជា** *ប្រែថា ការអង្គុយនេះមិនមែន ... ដូច្នេះជាដើម ។*

បទថា **ឯតមត្ថំ** *សេចក្តីថា ទ្រង់ជ្រាបអត្ថនេះ ពោល គឺការដែលព្រះថេរៈចម្រើនវិបស្សនាក្នុងកាយានុបស្សនាសតិប្បដ្ឋាន ដោយការកំណត់ធាតុ ៤ ជាប្រធាន ទើបចូលផលសមាបត្តិ ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្លឺឧទាននេះ ដែលសម្តែងការសម្រេចព្រះនិព្វានដោយសតិប្បដ្ឋានភាវនា ។*

បណ្តាបទទាំងនោះ បទថា **សតិ កាយគតា ឧបដ្ឋិតា** *សេចក្តីថា សតិ មានលក្ខណៈដូចពោលហើយក្នុងកាលមុន ឈ្មោះថា លះធម៌ដែលជាបដិបក្ខចេញបាន ព្រោះដល់នូវភាវៈ ដែលជួយក្នុងការធ្វើកិច្ចរបស់សមាធិ វីរិយៈ និងបញ្ញា ដែលមានសទ្ធាជាប្រធានឲ្យសម្រេចកិច្ចរបស់ខ្លួន បន្ទាប់អំពីនោះ គ្រាន់តែជាលម្អដ៏ខ្ជាំងក្លានោះឯង ចូលទៅកំណត់សភាវៈដែលមិនខុស*

ប្លែក ដោយអំណាចកាយសំវរៈតាមដែលពោលហើយ និងដោយអំណាចការប្រមូលអត្តទុកតែមួយតាំងនៅ ។ ដោយពាក្យនេះ ទ្រង់សម្តែងដល់សតិដែលទៅមកៗ ជាមួយបញ្ញាដែលកំណត់បច្ចយទាំងឡាយ ដោយការកំណត់ធាតុ ៤ ពោល គឺកាយ និងឧបាទារូបដែលអាស្រ័យធាតុ ៤ នោះ បន្ទាប់អំពីនោះ ទើបប្រព្រឹត្តទៅដោយអំណាចការកំណត់បច្ចយទាំងនោះ ជាអនិច្ច-លក្ខណៈជាដើម ម្យ៉ាងទៀត កាលពោលដោយលើកសតិឡើងជាប្រធានទើបទ្រង់សម្តែងចំពោះការបន្តគ្នាមកនៃបញ្ញាដែលទាក់ទងក្នុងបរិញ្ញា ៣ ដែលសម្បយុត្តដោយសតិនោះ ។ បទថា **ជសុ ជសញ្ញាយតនេសុ សំវុតោ** *សេចក្តីថា ព្រះយោគីដែលប្រកបដោយភាពជាអ្នកមានសតិជ្រុតជក្នុងកាយតាមដែលពោលហើយ ទើបបដិសេធការប្រព្រឹត្តទៅនៃបញ្ញា ព្រោះកាលទៅចម្រើនកាយានុបស្សនា ក្នុងទ្វារទាំង ៦ មានចក្ខុទ្វារជាដើម ដែលជាហេតុនៃផស្សៈ អកិរិយាជាដើម ដែលគួរនឹងកើត ក៏កើតឡើង កាលនឹងរារាំងអកិរិយាជាដើមនោះ ទើបត្រាស់ហៅថា ជាអ្នកសង្រួមក្នុងទ្វារ ៦ មានចក្ខុទ្វារជាដើមនោះ ។ ដោយពាក្យនោះ ទ្រង់សម្តែងដល់ញាណសំវរៈ ។*

បទថា **សត្តំ ភិក្ខុ សមាហិតោ** *សេចក្តីថា ភិក្ខុមានសតិជ្រុតជហើយយ៉ាងនោះ និងសង្រួមហើយក្នុងទ្វារទាំងពួង មិនបណ្តោយចិត្តទៅក្នុងអារម្មណ៍ដ៏ច្រើន ពិចារណាដោយអនិច្ចលក្ខណៈជាដើម ចម្រើនវិបស្សនា កាលញាណចាស់ក្លា កំពុងប្រព្រឹត្តទៅ ក៏មានចិត្តតាំងមាំដោយសមាធិ ដែលសម្បយុត្តដោយវិបស្សនា ប្រព្រឹត្តទៅជាប់តគ្នា មិនដាច់ខ្សោះឯង តាំងពី*

លំដាប់អនុលោមញាណ រហូតដល់កើតគោត្រភូញាណ ។ បទថា **ផញ្ញោ និព្វានមត្តនោ** *សេចក្តីថា ព្រះនិព្វានដែលជាអសង្ខតធាតុ នាំមកនូវសេចក្តីសុខយ៉ាងពិត ដោយជាអារម្មណ៍ដ៏កំពូលដល់មគ្គញាណ និងផលញាណ ដែលបានបញ្ញត្តិថា អត្តា ព្រោះមិនជាអារម្មណ៍របស់បុថុជ្ជនដទៃ ដោយហោចសូម្បីតែយល់សប្តិ តែព្រោះជាផ្នែកមួយនៃមគ្គញាណ និងផលញាណនោះៗ របស់ព្រះអរិយៈទាំងឡាយ និងព្រោះដូចគ្នានឹងអត្តា ទើបហៅថា* **អត្តនោ** *គឺ របស់ខ្លួន គប្បីដឹង គឺគប្បីជ្រាបនូវព្រះនិព្វាននោះ អធិប្បាយថា គប្បីដឹងច្បាស់ គឺគប្បីឲ្យជាក់ច្បាស់ដោយមគ្គញាណ និងផលញាណទាំងឡាយ ។ ដោយពាក្យនោះ ទ្រង់សម្តែងដល់ភាពដែលព្រះអរិយៈទាំងឡាយ មានចិត្តបង្អោនទៅក្នុងព្រះនិព្វាន ។ ពិតហើយ ព្រះអរិយៈទាំងឡាយ រមែងនៅសូម្បីក្នុងពេលដែលអធិចិត្តប្រព្រឹត្តទៅ ក៏នៅដោយការៈដែលបង្អោនទៅក្នុងព្រះនិព្វានដោយចំណែកមួយប៉ុណ្ណោះ ។ ក្នុងទីនេះ សតិ ប្រព្រឹត្តទៅក្នុងកាយជ្រាកជ ដល់ភិក្ខុណា ភិក្ខុនោះសង្រ្គមហើយក្នុងផស្សាយតនៈ ៦ បន្ទាប់អំពីនោះ ក៏មានចិត្តតាំងមាំរឿយៗ គប្បីដឹងព្រះនិព្វានរបស់ខ្លួន ដោយការធ្វើឲ្យប្រចក្សដល់ខ្លួន គប្បីជ្រាបការភ្ជាប់បទនៃគាថាយ៉ាងនេះ ដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ជាធម្មរាជា ទ្រង់សម្តែងផ្លូវជាគ្រឿងនាំចេញនៃភិក្ខុមួយរូបដោយមុខ គឺកាយានុបស្សនាសតិប្បដ្ឋាន រហូតដល់អរហត្ត ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ដោយបទថា* **សតិ កាយគតា ឧបដ្ឋិតា** *នេះ ទ្រង់សម្តែងដល់កាយានុបស្សនាសតិប្បដ្ឋាន ។ បទថា* **ឆសុ ផស្សាយតនេសុ**

សំវុតោ *សេចក្តីថា ឈ្មោះថា ផស្សាយតនៈ ព្រោះជាទីមកបន្ត គឺជាហេតុនៃផស្សៈ ក្នុងផស្សាយតនៈទាំងនោះ ។ ឈ្មោះថា សង្រួមហើយ ព្រោះតណ្ហាជាដើម មិនប្រព្រឹត្តទៅក្នុងវេទនា ៦ មានចក្ខុសម្ផស្សជាវេទនាជាដើម ដែលមានផស្សៈជាហេតុ គឺកើតឡើងព្រោះផស្សៈជាបច្ច័យ ដោយពាក្យនោះ ទ្រង់សម្តែងដល់វេទានុបស្សនាសតិប្បដ្ឋាន ។ បទថា* **សត្តំ ភិក្ខុ សមាហិតោ** *សេចក្តីថា ភិក្ខុ ឈ្មោះថា តាំងមាំជាប់តអស់កាលជានិច្ច មិនមានចន្លោះ ព្រោះមិនមានការរាយមាយ ភិក្ខុនេះ ឈ្មោះថា ជាអ្នកមិនរាយមាយ ព្រោះដល់ទីបំផុត ដោយសតិប្បដ្ឋានភាវនា ដោយប្រការទាំងពួង ។ ពិតហើយ កាលលោកពិចារណា កំណត់បានជាសមុច្ឆេទនោះឯង ក្នុងឧបាទានក្ខន្ធ ៥ មានកាលជាអតីតជាដើមនោះឯង ។ ដោយពាក្យនេះ ទ្រង់សម្តែងដល់សតិប្បដ្ឋានដ៏សេស ។ បទថា* **ជញ្ញា និព្វានមត្តនោ** *សេចក្តីថា ភិក្ខុដែលទម្លាយកិលេស ដល់នូវទីបំផុតនៃសតិប្បដ្ឋានភាវនាទាំង ៤ តាំងនៅដោយអាការយ៉ាងនេះ ខ្លួនឯងនោះឯង គប្បីដឹងកិលេសនិព្វានរបស់ខ្លួន ដោយបច្ចវេក្ខណញ្ញាណ ។*

ម្យ៉ាងទៀត ដោយបទថា **សតិ កាយគតា ឧបដ្ឋិតា** *នេះ ទ្រង់សម្តែងដល់កាពដែលព្រះថេរៈជាបុគ្គលបរិបូណ៌ដោយសតិ ដោយការសម្តែងដល់ការកំណត់ដឹងតាមសភាវៈ និងកាយរបស់ខ្លួន និងរបស់អ្នកដទៃ ។ ដោយបទថា* **ឆសុ ផស្សាយតនេសុ សំវុតោ** *នេះ ទ្រង់សម្តែងដល់ការដែលព្រះថេរៈដល់នូវភាពសម្បូរដោយបញ្ញា ដែលប្រកាសដល់សម្បជញ្ញៈ ដោយ*

អំណាចនៃការនៅដោយភាពស្ងប់ជាដើម ដែលសម្តែងដល់ការសង្រួមយ៉ាងពិត ក្នុងទ្វារ ៦ មានចក្ខុទ្វារជាដើម ។ ដោយបទថា **សត្តំ ភិក្ខុ សមាហិតោ** *នេះ ទ្រង់សម្តែងអនុបុព្វវិហារសមាបត្តិ ៩ ដោយសម្តែងដល់ភាពជាបុគ្គលច្រើនដោយសមាបត្តិ ។ ភិក្ខុដែលនៅយ៉ាងនេះ គប្បីដឹងនិព្វានរបស់ខ្លួន គឺគប្បីដឹង គប្បីគិតដល់អនុបាទិសេសនិព្វានធាតុ របស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះ ព្រោះមិនមានករណីយកិច្ចដ៏ក្រៃលែង ព្រោះធ្វើកិច្ចស្រេចហើយ អធិប្បាយថា កិច្ចដទៃដែលលោកគប្បីគិតក៏មិនមាន ៗ*

អដ្ឋកថា កោលិតសូត្រទី ៥ ចប់

សុត្តន្តបិដក

បិលិន្ទវច្ឆសូត្រ

[៧៨] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះបិលិន្ទវច្ឆដ៏មានអាយុ តែងហៅរកភិក្ខុទាំងឡាយដោយពាក្យអសុរោះ ។ គ្រានោះ ពួកភិក្ខុច្រើនរូប បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបិលិន្ទវច្ឆដ៏មានអាយុ ហៅរកភិក្ខុដោយពាក្យ*

អសុរោះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុ ១ រូបមក ថា ម្នាលភិក្ខុ អ្នកចូរមក អ្នកចូរហៅបិលិន្ទវច្ឆភិក្ខុមក តាមពាក្យតថាគតថា នែអាវុសោ វច្ឆៈ ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ ភិក្ខុនោះបានទទួល ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយចូលទៅរក បិលិន្ទវច្ឆភិក្ខុដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយប្រាប់បិលិន្ទវច្ឆដ៏ មានអាយុដូច្នេះថា នែអាវុសោ ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ បិលិន្ទវច្ឆ ដ៏មានអាយុ ទទួលពាក្យភិក្ខុនោះថា អើអាវុសោ ហើយក៏ចូលទៅគាល់ព្រះ មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយ ក្នុងទីសមគួរ ។ លុះបិលិន្ទវច្ឆដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះ មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលបិលិន្ទវច្ឆ បានឮថា អ្នកហៅរកពួកភិក្ខុ ដោយពាក្យអសុរោះ ពិតមែនឬ ។ បិលិន្ទវច្ឆបានក្រាបទូលថា បពិត្រព្រះអង្គ ដ៏ចម្រើន ពិតមែន ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ធ្វើទុកក្នុងព្រះ ហប្ញទ័យ នូវបុព្វេនិវាសរបស់បិលិន្ទវច្ឆដ៏មានអាយុ ហើយត្រាស់ហៅភិក្ខុ ទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំពោលទោសវច្ឆភិក្ខុ ឡើយ ម្នាលភិក្ខុទាំងឡាយ វច្ឆភិក្ខុ មិនមែនជាអ្នកមានទោសចិត្ត ហើយ ហៅរកពួកភិក្ខុដោយពាក្យអសុរោះទេ ម្នាលភិក្ខុទាំងឡាយ វច្ឆភិក្ខុធ្លាប់កើត ក្នុងត្រកូលព្រាហ្មណ៍ ច្រឡំបល់គ្នាអស់ ៥០០ ជាតិមកហើយ វច្ឆភិក្ខុនោះ ធ្លាប់សន្សំពាក្យអសុរោះនោះ អស់កាលជាអង្វែងមកហើយ ហេតុនោះ ទើប វច្ឆភិក្ខុនេះ តែងហៅរកពួកភិក្ខុដោយពាក្យអសុរោះ ។ លុះព្រះមានព្រះភាគ

ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

មាយា (ការបិទបាំងទោសខ្លួន) និងមានះ (សេចក្តីប្រកាន់) មិនប្រព្រឹត្តទៅ ក្នុងបុគ្គលណា ឬក៏បុគ្គលណា អស់សេចក្តីលោភ មិនប្រកាន់ថា របស់អញ មិនមានសេចក្តីប្រាថ្នា បន្ទោបង់សេចក្តីក្រោធ មានចិត្តត្រជាក់ បុគ្គលនោះ ហៅថា ព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថាភិក្ខុក៏បាន ។ សូត្រទី ៦ ។

អដ្ឋកថា

បិលិន្ទវច្ឆសូត្រ

បិលិន្ទវច្ឆសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ

[៧៨] *បទថា* **បិលិន្ទវច្ឆោ** *សេចក្តីថា បិលិន្ទ ជាឈ្មោះរបស់ព្រះថេរៈ ជនទាំងឡាយស្គាល់ព្រះថេរៈបានដោយគោត្រថា វច្ឆៈ ។ បទថា* **វសលវាឧេន សមុទាចរតិ** *សេចក្តីថា ព្រះថេរៈរមែងពោល រមែងហៅភិក្ខុទាំងឡាយ ដោយវាទៈថា អ្នកថោកទាប ដោយន័យជាដើមថា មកចុះអ្នកថោកទាប ទៅចុះអ្នកថោកទាប ។ បទថា* **សម្ពហុលា ភិក្ខូ** *ប្រែថា ភិក្ខុជាច្រើន ។ ភិក្ខុទាំងនោះឃើញព្រះថេរៈហៅដូច្នោះ កាលមិនដឹងថា ព្រះថេរៈជាព្រះអរហន្ត ពោលយ៉ាងនោះ ព្រោះមិនទាន់លះវាសនាបាន ទើបគិតថា*

ព្រះថេរៈនេះ ប្រហែលជាប្រទូស្ត ទើបហៅយ៉ាងនេះ មានបំណងនឹងពោលអួត ទើបក្រាបទូលដល់ព្រះមានព្រះភាគ ដើម្បីឲ្យចេញចាកភាពជាបុគ្គលប្រទូស្តនោះ ។ ដោយហេតុនោះ ទើបលោកពោលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ ហៅរកពួកភិក្ខុដោយពាក្យអសុរោះ ។

ចំណែកកេចិអាចារ្យពោលថា ភិក្ខុទាំងឡាយចាំព្រះថេរៈនេះបានថា ជាព្រះអរហន្ត គិតថា ព្រះថេរៈនេះហៅភិក្ខុទាំងឡាយយ៉ាងនេះ ដោយពាក្យគ្រោតគ្រោត ឧត្តរិមនុស្សធម៌ក្នុងព្រះថេរៈនេះ ប្រហែលជាមិនមានទេដឹង ដូច្នេះមិនដឹងការហៅយ៉ាងនោះរបស់លោក ដោយអំណាចវាសនា និងមិនជឿថា លោកជាព្រះអរិយៈ ទើបសម្គាល់ក្នុងការសម្ដឹងទោស បានក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ បំណងនឹងប្រកាសថា ព្រះថេរៈមិនមានការប្រទូស្ត ទើបត្រាស់ឲ្យភិក្ខុមួយរូបហៅលោកមក ហើយត្រាស់ដល់លោកចំពោះមុខថា ភិក្ខុនេះហៅយ៉ាងនោះ ព្រោះធ្លាប់មកក្នុងកាលមុន មិនមានបំណងក្នុងការពោលពាក្យគ្រោតគ្រោតឡើយ ដោយហេតុនោះ ទើបលោកពោលថា លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុមួយរូបមកដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **បុព្វេនិវាសំ មនសិការិត្វា** *សេចក្ដីថា ព្រះសាស្ដាកាលត្រាស់សួរព្រះថេរៈថា ម្នាលវច្ឆៈ បានឮថា អ្នកហៅភិក្ខុទាំងឡាយដោយពាក្យថា អ្នកថោកទាបពិតឬ កាលព្រះថេរៈក្រាបទូលថា យ៉ាងនោះឯង ព្រះអង្គ ទើបទ្រង់រំពឹងថា វច្ឆៈនេះមិនលះបង់វាទៈថា ថោកទាប ព្រោះវាសនា*

ដ៏សៅហ្មង ក្នុងអត្តភាពដែលជាអតីត វច្ឆៈបានកើតក្នុងជាតិព្រាហ្មណ៍ឬហ្ន៎ ទើបមនសិការដល់ខន្ធសន្តានដែលលោកធ្លាប់នៅក្នុងអតីតជាតិ ដែលជាលំនៅនៃខន្ធក្នុងកាលមុនរបស់ព្រះថេរៈ ដោយបុព្វេនិវាសញ្ញាណ និងសព្វញ្ញុតញ្ញាណ គឺធ្វើទុកក្នុងព្រះហឫទ័យរបស់ព្រះអង្គ ដោយធ្វើឲ្យប្រហែកឬដូចផ្លែកន្ធតព្រៃដែលជាក់លើបាតដៃ ។ បទថា **ភិក្ខូ អាមន្តេសិ** *សេចក្តីថា ត្រាស់ហៅដើម្បីឲ្យភិក្ខុទាំងនោះយល់ព្រម ដោយហេតុនោះ ទើបលោកពោលថា* **មា ខោ តុម្ហេ ភិក្ខវេ** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ សព្ទថា **មា** *ជានិបាត ប្រើក្នុងអត្ថថា បដិសេធ ។* **មា** *សព្ទនោះ ភ្ជាប់នឹងបទថា* **ឧជ្ឈាយិត្ថ** *នេះ ។ បទថា* **មា ឧជ្ឈាយិត្ថ** *សេចក្តីថា ពួកអ្នកកុំគិត គឺសម្លឹងទៅកាន់ផ្លូវខាងក្រោម ។ បទថា* **វច្ឆស្ស ភិក្ខុនោ** *ជាចតុត្ថីវិភត្តិ ព្រោះការសម្លឹងទោស ជាការច្រណែន ។*

ឥឡូវនេះ កាលទ្រង់សម្តែងហេតុក្នុងការដែលលោកមិនគួរសម្លឹងទោស ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វច្ឆភិក្ខុ មិនមែនជាអ្នកមានទោសចិត្ត ហើយហៅរកពួកភិក្ខុ ដោយពាក្យអសុរោះទេ ។ ព្រះតម្រាស់នោះ មានអត្ថដូច្នេះថា ម្នាលភិក្ខុទាំងឡាយ វច្ឆៈនេះ មិនប្រទូស្ត មិនមានចិត្តប្រទូស្ត មិនមានចិត្តត្រូវទោសៈព្យាបាទ ប្រទូស្ត ហៅភិក្ខុទាំងឡាយ ដោយវាទៈថា អ្នកចោកទាបឡើយ វច្ឆៈដកព្យាបាទ បានដោយមគ្គនោះឯង ។ កាលទ្រង់សម្តែងហេតុដែលសម្រេចមកអំពីជាតិមុន នៃការហៅដូច្នោះរបស់លោក ក្នុងកាលលោកមិនមានបំណងប្រទូស្ត ដោយប្រការយ៉ាងនេះ ទើបត្រាស់ថា

វច្ឆសប្ប ភិក្ខវេ ដូច្នេះ ជាដើម ។

បណ្តាបទទាំងនោះ បទថា **អញ្ញោកិណ្ណានិ** *បានដល់ មិនលាយឡំ គឺមិនមានលំដាប់ឃាំង ដោយលំដាប់នៃជាតិ មានឧត្តិយជាតិជាដើម ។ បទថា* **បញ្ច ជាតិសតានិ ព្រាហ្មណាកុលេ បច្ចាជាតានិ** *សេចក្តីថា វច្ឆៈបានកើតចំពោះក្នុងត្រកូលព្រាហ្មណ៍ តាមលំដាប់ជាតិទាំងអស់ដល់ទៅ ៥០០ ជាតិ ។ បទថា* **សោ តស្ស វសលាទោ ធីឃរត្តំ សមុទាចិណ្ណោ** *សេចក្តីថា វាទៈថា អ្នកថោកទាប របស់វច្ឆកិក្ខុនោះ ដែលលោកសូម្បីជាព្រះខីណាស្រព ក៏នៅប្រព្រឹត្តក្នុងឥឡូវនេះ ជាវាទៈដែលលោកសន្សំ ប្រព្រឹត្តមកអស់កាលយូរ ព្រោះលោកកើតជាព្រាហ្មណ៍អស់កាលប្រមាណ ៥០០ ជាតិ ដោយលើកឡើងខាងលើ រាប់អំពីជាតិនេះទៅ ។ ពិតហើយ ព្រាហ្មណ៍ទាំងឡាយ ជាបុគ្គលរឹងត្អឹង ដោយមានៈដែលសម្រេចមកអំពីជាតិ ទើបហៅអ្នកដទៃដោយវាទៈថា អ្នកថោកទាប ។ អាចារ្យពួកខ្លះពោលថា* **អដ្ឋាចិណ្ណោ** *ដូច្នេះក៏មាន ។ សេចក្តីក៏ដូច្នោះដូចគ្នា ។ បទថា* **តេន** *សេចក្តីថា ដោយការៈដែលលោកធ្លាប់តែប្រព្រឹត្តមកដូច្នោះអស់កាលយូរ ដោយពាក្យនោះ ទ្រង់សម្តែងថា ជាហេតុ គឺជាវាសនានៃការហៅដូច្នោះរបស់លោក ។ ឈ្មោះថា វាសនានេះ គឺអ្វី ។ អាចារ្យពួកខ្លះពោលថា គឺអធិមុត្តិ ហាក់បីដូចជាសមត្ថភាពដែលកិលេស ដែលលោកអប់រំមក រកទីបំផុតខាងដើមមិនបាន ។ ជាប់នៅក្នុងសន្តាន ជាហេតុនៃការប្រព្រឹត្តទៅ ដូចការប្រព្រឹត្តរបស់បុគ្គលដែលនៅមានកិលេសក្នុងសន្តាន របស់លោកដែលវៀរចាកកិលេស*

បានហើយ ។ ពោលដោយការលះកិលេសជាគ្រឿងរារាំងញេយ្យធម៌ ដោយការសម្លាប់នៃអកិនីហារ ហេតុនៃការប្រព្រឹត្តនេះ មិនមានក្នុងសន្តានរបស់ព្រះមានព្រះភាគ ដែលលះកិលេសបានហើយ តែនៅមានក្នុងខន្ធសន្តានរបស់ព្រះសាវក និងព្រះបច្ចេកពុទ្ធ ដែលនៅលះកិលេសយ៉ាងនោះមិនទាន់បានព្រោះព្រះតថាគតប៉ុណ្ណោះ ទ្រង់ឃើញអនាវរណញ្ញាណ ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបអត្ថនេះ ពោល គឺការមិនមានបំណងអាក្រក់ ក្នុងកាលព្រះបិលិន្ទវច្ឆៈហៅអ្នកជទៃថា អ្នកថោកទាប ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ដែលប្រកាសការសម្រេចអរហត្តផលរបស់លោក ។*

បទថា **យម្ហិ ន មាយា វត្តតិ ន មានោ** *សេចក្តីថា មាយា មានលក្ខណៈបិទបាំងទោសដែលមាន មានៈ មានលក្ខណៈប៉ោងឡើង ដែលប្រព្រឹត្តទៅដោយការលើកតម្កើង ដោយនយជាដើមថា អាត្មាអញជាបុគ្គលប្រសើរ ដូច្នេះ រមែងមិននៅក្នុងព្រះអរិយបុគ្គលណា គឺមិនប្រព្រឹត្តទៅ មិនកើតឡើង ព្រោះលោកជកបានហើយដោយមគ្គចិត្ត ។ បទថា* **យោ ទីឃ-លោភោ អមមោ និរាសោ** *សេចក្តីថា បុគ្គលណា ឈ្មោះថា ជ្រាសចាកលោកៈ ព្រោះជ្រាសចាកលោកៈ ដែលមានលក្ខណៈទាញយកនូវអារម្មណ៍ដោយប្រការទាំងពួង ដែលប្រព្រឹត្តទៅដោយបរិយាយនៃកិលេស មានរាគៈជាដើម ឈ្មោះថា មិនប្រកាន់ថា ជារបស់អញ គឺមិនហួងហែង ព្រោះមិនមានការប្រកាន់ក្នុងអារម្មណ៍ មានរូបជាដើមឯណាមួយថា ជារបស់អញនោះ*

ឯង ឈ្មោះថា អស់នូវសេចក្តីប្រាថ្នា ព្រោះមិនប្រាថ្នាភពជាដើមដែលជាអនាគត ។ បទថា **បន្ទុណ្ណាកោធោ** *សេចក្តីថា ឈ្មោះថា កម្ចាត់សេចក្តីក្រោធបានហើយ គឺដកអាឃាតបានហើយ ព្រោះលះសេចក្តីក្រោធ ដែលមានលក្ខណៈអាក់អន់ ដោយប្រការទាំងពួង ដោយអំណាចអនាគាមិមគ្គ ។ បទថា* **អភិនិព្ពុតត្តោ** *សេចក្តីថា បុគ្គលណា មានចិត្តត្រជាក់ល្អ គឺត្រជាក់ដោយការរលត់ ដោយឥតសេសសល់ ដោយប្រការទាំងពួង ព្រោះដកនូវមាយា មានះ លោភៈ និងកោធៈបាន ព្រោះលះធម៌ដែលជាចំណែកនៃសង្កិលេសទាំងពួងបានជាសមុច្ឆេទ ដោយភាពដែលសង្កិលេសទាំងនោះតាំងនៅក្នុងខណៈតែមួយ ជាមួយនឹងមាយាជាដើម ។ បទថា* **សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ** *សេចក្តីថា បុគ្គលនោះ គឺជាបុគ្គលបែបនោះ ជាព្រះខីណាស្រព ឈ្មោះថា ព្រាហ្មណ៍ ព្រោះជាអ្នកបន្សាត់បាប ដោយប្រការទាំងពួង ។ បុគ្គលនោះឯង ឈ្មោះថា សមណៈ ព្រោះជាអ្នកបន្សាត់បាប និងជាអ្នកប្រព្រឹត្តទៅស្មើ បុគ្គលនោះឯង ឈ្មោះថា ភិក្ខុ ព្រោះជាអ្នកទម្លាយកិលេស ដោយប្រការទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ វច្ឆៈ ជាបុគ្គលយ៉ាងនោះឯង គប្បីជាអ្នកប្រាថ្នាអាក្រក់ ធ្វើកាយកម្មជាដើមណាមួយ ឲ្យប្រព្រឹត្តទៅដូចម្តេច ។ វច្ឆៈរមែងហៅដោយវាទៈថា អ្នកថោកទាប ព្រោះលះវាសនាមិនទាន់បាននោះឯង ។*

អដ្ឋកថាបិលិន្ទវច្ឆ ចប់

សុត្តន្តបិដក

មហាកស្សបសូត្រ

[៧៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យ នោះឯង ព្រះមហាកស្សប:ដ៏មានអាយុ នៅក្នុងបិប្ផលិគុហា អង្គុយដោយ ភ្នែនតែមួយ ចូលសមាធិណាមួយ អស់ ៧ ថ្ងៃ លុះកន្លង ៧ ថ្ងៃនោះហើយ ព្រះមហាកស្សប:ដ៏មានអាយុ ក៏ចេញអំពីសមាធិនោះ ។ កាលដែលព្រះ មហាកស្សប:ដ៏មានអាយុ ចេញអំពីសមាធិនោះហើយ មានសេចក្តីត្រិះរិះ យ៉ាងនេះ បើដូច្នោះ គួរតែអាត្មាអញចូលទៅបិណ្ឌបាត ឯក្រុងរាជគ្រឹះចុះ ។ សម័យនោះឯង ពួកទេវតាចំនួន ៥០០ អង្គ ដល់នូវការខ្វល់ខ្វាយ ដើម្បី ប្រគេនបិណ្ឌបាតចំពោះព្រះមហាកស្សប:ដ៏មានអាយុ ។ លំដាប់នោះ ព្រះ មហាកស្សប:ដ៏មានអាយុ ហាមឃាត់ពួកទេវតាទាំង ៥០០ អង្គនោះហើយ ស្បៃកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅ បិណ្ឌបាត ឯក្រុងរាជគ្រឹះ ។

[៨០] សម័យនោះឯង សក្ក:ជាធំជាងពួកទេវតា មានប្រាថ្នាដើម្បី ប្រគេនបិណ្ឌបាត ចំពោះមហាកស្សប:ដ៏មានអាយុ បាននិម្មិតភេទខ្លួនជាជាង តម្បាញ កំពុងត្បាញនូវតម្បាញ ។ ឯអសុរកញ្ញាឈ្មោះសុជាតា ក៏ការ អម្បាះឲ្យពេញខ្នារ ។ គ្រានោះ ព្រះមហាកស្សប:ដ៏មានអាយុ កំពុងត្រាច់ បិណ្ឌបាតសព្វច្រក ក្នុងក្រុងរាជគ្រឹះ បានចូលទៅកាន់លំនៅរបស់ទេវរាជ ឈ្មោះសក្ក: ជាធំជាងពួកទេវតា ។ សក្ក:ជាធំជាងពួកទេវតា បានឃើញ

ព្រះមហាកស្សប:ដ៏មានអាយុ កំពុងតែនិមន្តមកអំពីចម្ងាយ លុះបានឃើញ ហើយ ក៏ចេញអំពីផ្ទះទៅ ទទួលយកបាត្រអំពីព្រះហស្ត ចូលទៅកាន់ផ្ទះ ដួសបាយអំពីឆ្នាំង ដាក់ឲ្យពេញបាត្រ រួចប្រគេន ចំពោះព្រះមហាកស្សប: ដ៏មានអាយុ ។ បិណ្ឌបាតនោះ មានសម្ងប្រើនមុខ មានម្ហូបក្រៀមប្រើនមុខ ។ លំដាប់នោះ ព្រះមហាកស្សប:ដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា សត្វ នេះជាអ្វីហ្ន៎ បានជាមានឥទ្ធានុភាព មានសភាពយ៉ាងនេះ ។ លំដាប់នោះ ព្រះមហាកស្សប:ដ៏មានអាយុ មានសេចក្តីត្រិះរិះ ដូច្នេះទៀតថា ឱហ្ន៎ សក្ក: ជាធំជាងពួកទេវតា ទេតើ ។ លុះព្រះមហាកស្សប:ដ៏មានអាយុ បានដឹង ច្បាស់ដូច្នេះហើយ និយាយនឹងសក្ក:ជាធំជាងទេវតាថា បពិត្រកោសិយ: ព្រះអង្គបានធ្វើអំពើនេះហើយ ក្រោយទៅ ព្រះអង្គកុំធ្វើអំពើយ៉ាងនេះទៀត ឡើយ ។ បពិត្រព្រះកស្សប:ដ៏ចម្រើន យើងខ្ញុំក៏មានសេចក្តីត្រូវការដោយ បុណ្យដែរ យើងខ្ញុំគួរធ្វើបុណ្យបានដែរ ។ លំដាប់នោះ សក្ក:ជាធំជាងពួក ទេវតា ថ្វាយបង្គំព្រះមហាកស្សប:ដ៏មានអាយុ រួចធ្វើប្រទក្សិណ ហើយ ហោះទៅឯអាកាស បន្លឺនូវឧទាន ក្នុងអាកាសជាទីវាលអស់វារៈ ៣ ដងថា

ឱហ្ន៎ ទានដែលអាត្មាអញបានតម្កល់ទុកល្អហើយ ក្នុងព្រះមហា-
កស្សប: ហៅពេញជាទានឧត្តម ឱហ្ន៎ ទានដែលអាត្មាអញ បាន
តម្កល់ទុកល្អហើយ ក្នុងព្រះមហាកស្សប: ហៅពេញជាទានឧត្តម ។

[៨១] *ព្រះមានព្រះភាគ ទ្រង់បានឮឧទានដោយទិព្វសោតធាតុដ៏បរិ-សុទ្ធ កន្លងបងសោតធាតុរបស់មនុស្សធម្មតា ដែលសក្ក: ជាធំជាងពួកទេវតា*

កំពុងហោះទៅកាន់វេហាស៍ ហើយបន្ទឺអស់វារៈ ៣ ដង ក្នុងអាកាស ជាទីវាលថា

ឱហ្ន៎ ទានដែលអាត្មាអញបានតម្កល់ទុកល្អហើយ ក្នុងព្រះមហាកស្សបៈ ហៅពេញជាទានដ៏ឧត្តម ឱហ្ន៎ ទានដែលអាត្មាអញ បានតម្កល់ទុកល្អហើយ ក្នុងព្រះមហាកស្សបៈ ហៅពេញជាទានដ៏ឧត្តម ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ទេវតាទាំងឡាយ រមែងស្រឡាញ់ភិក្ខុ អ្នកប្រព្រឹត្តបិណ្ឌបាតជាវត្ត អ្នកចិញ្ចឹមតែខ្លួន មិនចិញ្ចឹមបុគ្គលដទៃ ជាអ្នកនឹងធឹងស្ងប់រម្ងាប់ មានស្មារតី គ្រប់កាល ។ សូត្រទី ៧ ។

អដ្ឋកថា

មហាកស្សបសូត្រ

មហាកស្សបសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ

[៧៩] ក្នុងពាក្យថា **សត្តាហំ ឯកបល្លង្កេន និសិន្នោ អញ្ញតរំ សមាធឹ សមាបជ្ជិត្វា** *នេះ ជាបឋម កេចិអាចារ្យពោលថា សមាធិដែលសម្បយុត្តដោយអរហត្តផល លោកបំណងយកថា សមាធិណាមួយ ក្នុងសូត្រនេះ ។*

ព្រះមហាកស្សបៈនោះ ចូលសមាធិនោះច្រើន ដើម្បីនៅជាសុខ ក្នុងបច្ចុប្បន្ន នឹងអាចនៅសម្ងំអស់ ៧ ថ្ងៃ ដោយផលសមាបត្តិ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ស្តាបនាលោកទុកក្នុងឋានៈស្មើជាមួយព្រះអង្គ ក្នុងឧត្តរិមនុស្ស-ធម៌ មានអនុបុព្វវិហារ ៩ និងអភិញ្ញា ៦ ជាដើម ដោយនយក្នុងសំយុត្ត-និកាយ និទានវគ្គជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគត ប្រាថ្នាដរាបណា ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន ។បេ។ ម្នាលភិក្ខុទាំងឡាយ តថាគត ប្រាថ្នាដរាបណា ក៏បាននូវឥទ្ធិវិធៈជាច្រើនបែប ។បេ។ ធ្វើអំណាចឲ្យប្រព្រឹត្តដោយកាយ រហូតដល់ព្រហ្មលោកនាយដរាបនោះដែរ ។ ក្នុងទីនេះ មិនគួរពោលថា កាលបើដូច្នោះ ព្រះថេរៈគប្បីធ្វើសូម្បីយមកប្បាដិហារ្យបាន ព្រោះលោកបំណងយកឈានជាដើម ដែលទូទៅដល់សាវ័កប៉ុណ្ណោះ ។

ឯបុរាណាចារ្យពោលថា បទថា **អញ្ញតរំ សមាធឹ សមាបជ្ជិត្វា** *បានដល់ ចូលនិរោធសមាបត្តិ ។ សួរថា សេចក្តីនេះដូចម្តេច ទើបនិរោធសមាបត្តិលោកពោលថា សមាធិ ។ ឆ្លើយថា ព្រោះអត្ថថា តាំងមាំ ។ អត្ថថា ការតាំងមាំនេះ គឺអ្វី គឺព្រោះនិរោធសមាបត្តិ ជាគុណធម៌មិនញាប់ញ័រ ដោយធម៌ដែលជាសត្រូវ ព្រោះជាធម៌ដែលគប្បីតាំងមាំដោយប្រពៃ គឺព្រះអរហន្ត ឬព្រះអនាគាមី ដែលដល់នូវការជំនាញក្នុងឋានៈដែលពោលហើយ បំណងយ៉ាងនោះ គប្បីតាំងមាំ ការមិនប្រព្រឹត្តទៅ (គឺនិរោធសមាបត្តិ) ដោយប្រពៃនោះឯង នៃការបន្តរបស់ចិត្ត និងចេតសិកអស់កាល តាមដែលបំណង*

ដោយការសម្រេច ដោយពល ២ គឺសមថពល វិបស្សនាពល ដោយ ញាណចរិយា ១៦ ញាណ ១៦ នេះ គឺអនិច្ចានុបស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា និព្វិទានុបស្សនា វិរាគានុបស្សនា និរោធានុបស្សនា បដិ-និស្សគ្គានុបស្សនា វិវដ្ដានុបស្សនា មគ្គញ្ញាណ ៤ ផលញ្ញាណ ៤ ដោយ សមាធិចរិយា ៩ គឺសមាធិ ៩ មានបឋមជ្ឈានសមាធិជាដើម និងឧបចារ-សមាធិនៃសមាធិ ៨ នោះ ដែលរួមចូលគ្នាតែមួយ ដោយការស្ងប់រម្ងាប់នូវ សង្ខារ ៣ ក្នុងធម៌នោះៗ គឺកាយសង្ខារ វចីសង្ខារ ចិត្តសង្ខារ ការដែល និរោធសមាបត្តិនោះ គប្បីតាំងមាំយ៉ាងនោះ ឈ្មោះថា អត្តនៃការតាំងមាំក្នុង ទីនេះ ដោយហេតុនោះ វិហារធម៌នេះ ទើបលោកពោលថា សមាធិ ព្រោះ អត្ថថា មិនរាយមាយ ។ ដោយហេតុនេះ អត្តនៃការចូលនិរោធសមាធិនោះ គប្បីជ្រាបថា លោកពោលហើយ ។ ពិតហើយ ក្នុងបដិសម្ភិទាមគ្គ លោក សំដៅយកនិរោធសមាបត្តិនេះ សួរថា សេចក្តីនេះដូចម្តេច ឈ្មោះថា ញាណ ក្នុងសញ្ញានិរោធសមាបត្តិ ព្រោះប្រកបដោយពល ២ ព្រោះស្ងប់រម្ងាប់សង្ខារ ៣ ព្រោះញាណចរិយា ១៦ ព្រោះសមាធិចរិយា ៩ ព្រោះភាពជាអ្នកជំនាញ ដូច្នេះហើយ ទើបពោលថា ពាក្យថា **ទ្វីហិ ៣លេហិ** *បានដល់ ពល ២ គឺ សមថពល វិបស្សនាពល គប្បីជ្រាបសេចក្តីពិស្តារតទៅ កថាពោលអំពី និរោធសមាបត្តិ លោកពណ៌នាហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ។ ព្រោះហេតុ អ្វី ព្រះថេរៈនេះមិនចូលផលសមាបត្តិ តែចូលនិរោធសមាបត្តិ ព្រោះអនុគ្រោះ ពួកសត្វ ។ ពិតហើយ ព្រះមហាថេរៈនេះប្រើសមាបត្តិបានទាំងអស់ តែ*

ដោយច្រើន លោកចូលនិរោធសមាបត្តិ ព្រោះអនុគ្រោះសត្វ ។ ព្រោះកាលលោកចូលនិរោធសមាបត្តិនោះហើយ ចេញមក សក្ការៈមានប្រមាណតិចដែលសត្វធ្វើ រមែងមានផលច្រើន មានអានិសង្សច្រើន ជាពិសេសនោះឯង ។ បទថា **វុដ្ឋាសិ** *បានដល់ ចេញ ដោយអរហត្តផលចិត្តកើតឡើង ។ ពិតហើយ បុគ្គលចូលនិរោធសមាបត្តិ បើជាព្រះអរហន្ត រមែងឈ្មោះថា ចេញដោយអរហត្តផលកើតឡើង បើជាព្រះអនាគាមី រមែងឈ្មោះថា ចេញដោយអនាគាមិផលកើតឡើង ។*

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា សម័យនោះឯង សក្កទេវរាជមានបំណងនឹងប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបៈដូចតទៅ ហេតុអ្វី ទើបសក្កទេវរាជ មានបំណងប្រគេនដល់លោក ទេពធីតាដែលលោកពោលថា មានប្រមាណ ៥០០ នោះ ជាបរិចារិការបស់សក្កទេវរាជ នាងមានជើងដូចជើងព្រាប សក្កទេវរាជធ្វើឲ្យបញ្ជូនទៅដោយព្រះតម្រាស់ថា លោកម្ចាស់មហាកស្សបៈ ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ចូរពួកនាងទៅថ្វាយដល់មហាថេរៈ ទើបចូលទៅរក ហើយឈរបំណងនឹងប្រគេនអាហារទិព្វ ត្រូវព្រះថេរៈឃាត់ ទើបត្រឡប់ទៅកាន់ទេវលោកវិញ ។ ឥឡូវនេះ គិតដល់ការឃាត់អំពីមុន ទើបគិតថា ព្រះថេរៈនឹងទទួលក្នុងកាលខ្លះ មានបំណងនឹងថ្វាយទានដល់ព្រះថេរៈ ដែលចេញអំពីសមាបត្តិ ទើបមិនក្រាបទូលឲ្យសក្កៈទ្រង់ជ្រាប នាំគ្នាមកឯង បង្អោនកោជនដែលជាទិព្វចូលទៅប្រគេន ត្រូវព្រះថេរៈឃាត់ ដោយន័យមុនដូចគ្នា ទើបត្រឡប់ទៅកាន់ទេវលោក ត្រូវសក្កៈត្រាស់សួរថា ពួក

នាងនាំគ្នាទៅណាមកណា ទើបក្រាបទូលសេចក្តីនោះ សក្កទេវរាជក៏សួរថា ពួកនាងប្រគេនបិណ្ឌបាតដល់ព្រះថេរៈហើយឬ ទើបទូលថា លោកមិនព្រមថ្នាំនឹងទទួល សក្កទេវរាជត្រាស់សួរថា លោកពោលដូចម្តេច ទើបទូលថា បពិត្រទេវៈ លោកពោលថា នឹងសង្គ្រោះអ្នកក្រីក្រ សក្កៈសួរថា ពួកនាងទៅដោយអាការដូចម្តេច ទើបទូលថា ទៅដោយអាការនេះឯង សក្កទេវរាជត្រាស់ថា បុគ្គលដូចពួកនាង នឹងប្រគេនបិណ្ឌបាតដល់ព្រះថេរៈបានដូចម្តេច មានបំណងនឹងថ្វាយដោយព្រះអង្គឯង ទើបកាឡាខ្លួនជាជាងតម្បាញចាស់ជរា ធ្មេញបាក់សក់ស្កូវ ខ្នងកោង ធ្វើនាងសុជាតាអសុរធីតា ឲ្យជាស្រីចាស់នោះដូចគ្នា រួចនិម្មិតវិថីនៃអ្នកតម្បាញមួយខ្សែ កំពុងរវៃអំបោះ នាងសុជាតាធ្វើអំបោះឲ្យពេញខ្នារ ។ ព្រោះហេតុនោះ ទើបលោកពោលថា **តេន ខោ បន សមយេន សក្កោ ទេវានមិន្ទោ ។បេ។ តសរំ ឃរេសិ** *ជាដើម ។*

[៨០] *បណ្តាបទទាំងនោះ បទថា* **តន្តំ វិនាតិ** *បានដល់ សក្កទេវរាជក្លែងធ្វើជាតម្បាញសំពត់ ។ បទថា* **តសរំ ឃរេតិ** *បានដល់ នាងសុជាតាក្លែងធ្វើដូចរវៃអំបោះ ។ បទថា* **យេន សក្កស្ស ទេវានមិន្ទស្ស និវេសនំ តេនុបសង្កមិ** *សេចក្តីថា ព្រះថេរៈស្លៀកស្បង់ ហើយកាន់បាត្រ និងចីវរ និមន្តតម្រង់ទៅកាន់នគរ ដោយបំណងថា នឹងសង្គ្រោះអ្នកក្រីក្រ ទើបនិមន្តទៅតាមផ្លូវជាងតម្បាញ ដែលសក្កទេវរាជនិម្មិត ខាងក្រៅព្រះនគរ សម្លឹងមើលបានឃើញខ្ទមចាស់ រយើករយាក ហើយស្វាមីភរិយាទាំង ២ ដែលមានរូបរាង ដូចពោលហើយ កំពុងតម្បាញនៅក្នុងខ្ទមនោះ កាលឃើញហើយ គិតថា*

ពីរនាក់ប្តីប្រពន្ធនេះ ចាស់ម្ល៉ះហើយ ក៏នៅធ្វើការ ក្នុងក្រុងនេះ ប្រហែលជាមិនមានមនុស្សដែលក្រីក្រជាងប្តីប្រពន្ធពីរនាក់នេះទៀយ អាត្មាអញនឹងទទួលរបស់ដែលប្តីប្រពន្ធនេះឲ្យ សូម្បីតែជ្រក់ សង្គ្រោះប្តីប្រពន្ធនេះ ទើបលោកនិមន្តទៅកាន់ផ្ទះរបស់ប្តីប្រពន្ធនោះ ។ សក្កទេវរាជឃើញព្រះថេរៈកំពុងនិមន្តមក ទើបត្រាស់នឹងនាងសុជាតាថា នែនាង លោកម្ចាស់របស់យើងកំពុងនិមន្តមក ចូរនាងអង្គុយស្ងៀម ធ្វើដូចជាមិនឃើញ ខ្ញុំនឹងធ្វើល្បិចមួយជួរខណៈហើយសឹមប្រគេនបិណ្ឌបាត ។ ព្រះថេរៈបានទៅឈរត្រង់ទ្វារផ្ទះ ។ ឯប្តីប្រពន្ធនោះ ធ្វើជាមិនឃើញ ធ្វើតែការងារបស់ខ្លួនតែម្យ៉ាង រង់ចាំពេលបន្តិច ។ គ្រានោះ សក្កៈប្រាប់ថា មើលទៅដូចព្រះថេរៈមួយរូបឈរនៅត្រង់ទ្វារ នាងចូរពិចារណាមើលចុះ នាងទូលថា សូមព្រះអង្គទៅពិចារណាមើលចុះ ។ សក្កៈចេញអំពីផ្ទះ ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន យកដៃទាំង ២ ច្រត់ក្បាលជង្គង់ក្រោកឡើង សួរថា លោកម្ចាស់ ជាព្រះថេរៈរូបណាហ្ន៎ ទើបថយទៅបន្តិច ហើយត្រាស់ថា ភ្នែករបស់ខ្ញុំងងឹត ទើបយកដៃបាំងថ្ងាសហើយផ្ទៀងមើល រួចត្រាស់ថា ឱហ្ន៎ ព្រះមហាកស្សបត្ថេរ លោកម្ចាស់របស់ខ្ញុំ មកកាន់ទ្វារទូរបស់ខ្ញុំយូរហើយ ក្នុងផ្ទះមានអ្វីខ្លះឬ ។ នាងសុជាតាធ្វើជាបង្អែបង្អង់បន្តិច ហើយឲ្យចម្លើយថា មានអ្នក ។ សក្កៈត្រាស់ថា បពិត្រលោកម្ចាស់ លោកម្ចាស់កុំគិតថា សៅហ្មង ឬប្រណីតឡើយ សូមសង្គ្រោះញោមចុះ ដូច្នេះហើយ ទើបទទួលបាត្រ ។ ព្រះថេរៈកាលឲ្យបាត្រ គិតថា អាត្មាអញ គួរសង្គ្រោះមនុស្សក្រីក្រចាស់ជរានេះឯង ។ សក្កៈនោះចូលទៅ

ខាងក្នុង ដួសបាយក្នុងឆ្នាំង ដាក់ពេញបាត្រ ហើយដាក់ក្នុងដៃព្រះថេរៈ ។ ដោយហេតុនោះ ទើបលោកពោលថា សក្កៈជាធំជាងពួកទេវតា បានឃើញព្រះមហាកស្សបៈដ៏មានអាយុ ។បេ។ រួចប្រគេន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បឃិយា** *ប្រែថា អំពីឆ្នាំងបាយ ។ បាលីថា* **ឃដិឱឝនំ** *ដូច្នេះក៏មាន ។ អាចារ្យពួកខ្លះ ពោលអត្ថនៃបាលីនោះថា ឈ្មោះថា បាយក្នុងឆ្នាំង បានដល់ អាហារពិសេសសម្រាំងរបស់ពួកទេវតា ។ បទថា* **ឧទ្ធរិត្វា** *បានដល់ លើកឡើងចាកភាជនៈណាមួយ ។ អាហារនោះឯង មានសូបៈច្រើន ក្នុងកាលដាក់ចូលក្នុងបាត្រ ហើយដាក់ក្នុងដៃព្រះថេរៈ ប្រាកដដូចអាហារអន់ៗ ដែលសម្រេចដល់មនុស្សអនាថា តែអាហារនោះគ្រាន់តែដាក់ក្នុងដៃ បានតាំងនៅដោយសភាវៈដូចរបស់ទិព្វសម្រាប់ខ្លួន ។ បទថា* **អនេកសូទោ** *បានដល់ សូបៈច្រើនយ៉ាង ដោយសូបៈ មានសណ្តែកបាយ និងសណ្តែករាជមាសជាដើម និងដោយប្រភេទរបស់ទំពាច្រើន ។ បទថា* **អនេកព្យញ្ជនោ** *បានដល់ សម្ភវត្តវិកង្គច្រើនប្រភេទ ។ បទថា* **អនេក-រសសូបព្យញ្ជនោ** *សេចក្តីថា មានសូបៈ និងព្យញ្ជនៈ មានរសដ៏ប្រសើរផ្សេងៗ ដែលប្រកាសដល់រសដើម មានអង្ឃែមជាដើម និងរសដែលលាយគ្នាដោយសូបៈ និងព្យញ្ជនៈជាច្រើន ។*

បានឮថា បិណ្ឌបាតនោះ ក្នុងពេលដាក់ក្នុងដៃរបស់ព្រះថេរៈ ក្រអូបទៅដោយក្លិនទិព្វរបស់ខ្លួនពេញក្រុងរាជគ្រឹះ ។ លំដាប់នោះ ព្រះថេរៈគិតថា បុរសនេះមានសក្តិតូច តែបិណ្ឌបាតប្រណីតពន់ពេក ដូចភោជនរបស់សក្ក-

ទេវរាជ នេះជានរណាហ្ន៎ ។ គ្រានោះ ព្រះថេរៈដ៏ឆ្ងាយថា ជាសក្កទេវរាជ ទើបពោលថា នែកោសិយៈ ហេតុអ្វីទ្រង់ដណ្តើមសម្បត្តិអ្នកក្រីក្រ អ្នកធ្វើកម្មធ្ងន់ហើយ ថ្ងៃនេះ អ្នកក្រីក្រណាឲ្យទានដល់អាត្មាហើយ គប្បីបានតំណែងសេនាបតី ឬតំណែងសេដ្ឋី ។ សក្កៈពោលថា អ្នកដែលក្រីក្រជាងខ្ញុំមានឬ ព្រះថេរៈពោលថា ព្រះអង្គសោយរាជសម្បត្តិក្នុងទេវលោក ជាមនុស្សក្រីក្រដូចម្តេច សក្កៈពោលថា សេចក្តីនោះ ឈ្មោះថា យ៉ាងនោះឯងលោកម្ចាស់ ខ្ញុំបានធ្វើសុចរិតកម្ម ក្នុងកាលព្រះពុទ្ធមិនទាន់កើតឡើង តែលុះពុទ្ធុប្បាទ-កាលប្រព្រឹត្តទៅ ទេវបុត្រ ៣ អង្គ គឺចូឡរថទេវបុត្រ មហារថទេវបុត្រ អនេកវណ្ណទេវបុត្រ ធ្វើបុញ្ញកម្មហើយ កើតក្នុងទីជិតខ្ញុំ មានតេជៈច្រើនជាងខ្ញុំ កាលទេវបុត្រទាំងនោះគិតនឹងលេងនក្ខត្តឫក្ស ទើបនាំអ្នកបម្រើចុះកាន់វិថី ឯខ្ញុំគេចចូលក្នុងប្រាសាទ ព្រោះតេជៈអំពីសរីរៈរបស់ទេវបុត្រទាំងនោះ គ្របជាប់សរីរៈរបស់ខ្ញុំ តេជៈអំពីសរីរៈរបស់ខ្ញុំ មិនបានគ្របសង្កត់សរីរៈរបស់ទេវបុត្រទាំងនោះឡើយ អ្នកណាជាអ្នកក្រីក្រជាងខ្ញុំនោះ ។ ព្រះថេរៈពោលថា កាលបើដូច្នោះ តាំងអំពីនេះទៅ ទ្រង់កុំបោកបញ្ឆោតយ៉ាងនេះ ហើយថ្វាយទានដល់អាត្មាឡើយ ។ សក្កៈត្រាស់ថា បើខ្ញុំបោកបញ្ឆោតថ្វាយទានដល់លោកម្ចាស់ ខ្ញុំនឹងមានកុសល ឬក៏មិនមាន ។ ព្រះថេរៈពោលថា មានអាវុសោ ។ សក្កៈត្រាស់ថា កាលបើដូច្នោះ ឈ្មោះថា ការធ្វើកុសលជានាទីរបស់ខ្ញុំ ដូច្នេះហើយ ទើបនមស្ការព្រះថេរៈ នាំនាងសុជាតាធ្វើប្រទក្សិណព្រះថេរៈ ហើយហោះទៅ បន្ទឹងទាន ៣ ដងថា គួរអស្ចារ្យ ទានខ្ញុំតាំងទុកល្អហើយ

ក្នុងព្រះកស្សបៈ ជាទានដ៏ប្រសើរ ។ ដោយហេតុនោះ ទើបលោកពោលថា **អថខោ អាយស្មតោ មហាកស្សបស្ស ឯតទហោសិ** *ដូច្នេះ ។*

ព្រះមហាកស្សបៈហៅសក្កទេវរាជស្តេចទេវតាដោយគោត្រថា កោសិយ ក្នុងព្រះបាលីនោះ ។ បទថា **បុញ្ញេន អត្តោ** *ប្រែថា ប្រកបដោយបុណ្យ ។ បទថា* **អត្តិ** *ជាបាលីដ៏សេស ។ បទថា* **វេហាសំ អព្ភុគ្គច្ឆា** *សេចក្តីថា ហោះទ្បើងអំពីផែនដី ។ អាចារ្យពួកខ្លះពោលថា បទថា* **អាកាសេ អន្តលិក្ខេ** *គឺក្នុងអាកាសដែលជាទីឃើញរូបក្នុងចន្លោះ ដោយបរិយាយសព្ទ គឺអាកាស ។ ម្យ៉ាងទៀត លោកពោលដោយពិសេសថា ក្នុងអាកាស ពោល គឺដែលឃើញរូបក្នុងចន្លោះ មិនមែនក្នុងអាកាសដែលបើកកសិណជាដើមឡើយ ។ សព្ទថា* **អហោ** *ក្នុងបទថា* **អហោ ទានំ** *នេះ ជានិបាត ប្រើក្នុងអត្ថថា គួរអស្ចារ្យ ។*

ពិតហើយ សក្កទេវរាជស្តេចទេវតា កើតព្រះហឫទ័យគួរអស្ចារ្យថា ព្រោះហេតុដែលអាត្មាអញ ធ្វើនូវការកោតក្រែងដោយដៃរបស់ខ្លួន ដោយគោរព ដល់ព្រះមហាកស្សបត្ថេរ ដែលចេញអំពីនិរោធសមាបត្តិ ហើយធ្វើសម្មាទិដ្ឋិមិនឲ្យផ្ទាស់ប្តូរ មិនឲ្យប៉ះទង្គិចអ្នកដទៃដោយកាល ទើបឲ្យទានដោយកោជនជាទិព្វ ដូច្នេះ ព្រោះខ្ញុំជាអ្នកប្រកបដោយសម្បត្តិ ៣ ប្រការ គឺខេត្តសម្បត្តិ ទេយ្យសម្បត្តិ និងចិត្តសម្បត្តិ ទើបបំពេញទានដែលសម្បូរដោយអង្គទាំងពួងហ្នឹង ក្នុងគ្រានោះ កាលនឹងបង្ហូរចេញនូវបីតិ និងសោមនស្សដែលនៅខាងក្នុងព្រះហឫទ័យរបស់ព្រះអង្គ ទើបពោលថា **អហោ ទានំ** *ទាន*

គួរអស្ចារ្យ កាលទ្រង់ប្រកាសថា ទាននោះ ជាទានឧត្តម និងថា ជាខេត្ត ដោយនយដូចពោលហើយ ទើបទ្រង់បន្ទឺឧទានថា **បរមទានំ កស្សបេ សុបតិដ្ឋិតំ** *ជាដូច្នេះ ។*

កាលសក្កៈទ្រង់បន្ទឺឧទានយ៉ាងនេះ ព្រះមានព្រះភាគប្រថាប់នៅឯវិហារនោះឯង ទ្រង់ស្តាប់សំឡេងដោយទិព្វសោត ហើយត្រាស់ដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកឃើញទេ សក្កទេវរាជស្តេចទៅតាទ្រង់បន្ទឺឧទាន ហើយហោះទៅ ភិក្ខុទាំងនោះទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន សក្កៈនោះទ្រង់ធ្វើអ្វី ទើបត្រាស់ថា ទ្រង់ថ្វាយទានដល់កស្សបៈ បុត្ររបស់តថាគត ព្រោះហេតុនោះឯង ទ្រង់ពេញព្រះហឫទ័យ ទើបបន្ទឺឧទាន ។ ដោយហេតុនោះ ទើបពោលពាក្យជាដើមថា ព្រះមានព្រះភាគ ទ្រង់បានឮឧទានដោយទិព្វសោតធាតុ ជាដូច្នេះ ។

[៨១] *បណ្តាបទទាំងនោះ បទថា* **ទិព្វាយ សោតធាតុយា** *សេចក្តីថា ឈ្មោះថា ទិព្វ ព្រោះដូចគ្នានឹងរបស់ទិព្វ ។ ពិតហើយ ទិព្វបសាទ-សោតធាតុដែលកើតដោយសុចរិតកម្មរបស់ពួកទេវតា មិនប្រឡាក់ប្រឡូសដោយរបស់មិនស្អាត មានទឹកប្រមាត់ ស្លេស្ម និងឈាមជាដើម អាចទទួលអារម្មណ៍ក្នុងទីឆ្ងាយបាន ព្រោះប្រាសចាកឧបក្កិលេស ។ សូម្បីសោតធាតុសម្រេចដោយញាណ ដែលកើតអំពីកម្លាំងនៃសេចក្តីព្យាយាមការនារបស់ព្រះមានព្រះភាគអង្គនេះក៏ដូចគ្នា ហេតុនោះ ឈ្មោះថា ទិព្វ ព្រោះដូចគ្នានឹងរបស់ទិព្វ ។ ម្យ៉ាងទៀត ឈ្មោះថា ទិព្វ ព្រោះបានដោយអំណាចទិព្វ-*

វិហារធម៌ និងព្រោះខ្លួនឯងអាស្រ័យទិព្វវិហារ ឈ្មោះថា សោតធាតុ ព្រោះអត្ថថា ស្តាប់ និងអត្ថថា ទ្រទ្រង់នៅតាមសភាវៈ ។ ឈ្មោះថា សោតធាតុ ព្រោះដូចគ្នានឹងសោតធាតុ ដោយធ្វើកិច្ចរបស់សោតធាតុ ។ ដោយសោត-ធាតុដែលជាទិព្វនោះ ។ បទថា **វិសុទ្ធាយ** *បានដល់ បរិសុទ្ធ គឺផុតចាកឧបក្កិលេស ។ បទថា* **អតិក្កន្តមានុសិកាយ** *សេចក្តីថា កន្លងបង់នូវឧបចារៈមនុស្ស ឈានកន្លងនូវមំសសោតធាតុរបស់មនុស្ស ដោយការស្តាប់សំឡេងតាំងនៅ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបសេចក្តីនេះថា ទេវតាក្តី មនុស្សក្តី កើតការអើពើ ប្រព្រឹត្តស្រឡាញ់យ៉ាងក្រៃលែងនូវបុរសដែលល្អកំពូល តាំងនៅក្នុងគុណវិសេស ដោយសម្មាបដិបត្តិហើយ ទើបទ្រង់បន្លឺនូវឧទាននេះ ដែលសម្តែងសេចក្តីនោះ ។*

ក្នុងអត្ថនោះ បុគ្គលឈ្មោះថា **បិណ្ឌចារិក** *ព្រោះសមាទានធុតង្គ ពោលគឺអង្គភិក្ខុដែលត្រាច់បិណ្ឌបាតជាវត្ត ហើយទើបបំពេញធុតង្គនោះ ។ សួរថា ព្រះគាថានេះត្រាស់ធ្វើព្រះមហាកស្សបៈឲ្យជាហេតុ និងព្រះថេរៈដែលជាកំពូលជាងធុតវាទភិក្ខុទាំងអស់ ដែលទ្រទ្រង់នូវធុតង្គ ១៣ មិនមែនឬ ព្រោះហេតុអ្វី ទើបព្រះថេរៈត្រូវប្រារព្ធធុតង្គតែមួយប៉ុណ្ណោះ ឆ្លើយថា នេះជាការសម្តែងក្នុងអត្ថប្បត្តិហេតុ ។ ម្យ៉ាងទៀត នេះត្រឹមតែជាទេសនា ។ ដោយពាក្យនេះគប្បីជ្រាបថា ត្រាស់ធុតង្គទាំងអស់ ដល់ព្រះថេរៈនោះ ដោយលើកទេសនាឡើងជាប្រធាន ។ ម្យ៉ាងទៀត ដើម្បីប្រកាសបដិបទា ដ៏កំពូលក្នុងព្រះថេរៈ*

នោះ មិនធ្វើបិណ្ឌបាតិកវត្តទាំងអស់ឲ្យជាប់ ព្រោះលោកប្រាថ្នាតិចក្រៃលែង និងអនុគ្រោះចំពោះត្រកូល ទើបពោលថា **បិណ្ឌបាតិកស្ស** *ដោយនយដូចពោលហើយ ដោយគាថាជាដើមថា* **យថាបិ ភមរោ បុប្ផំ** *ដូច្នេះ ។ បទថា* **បិណ្ឌបាតិកស្ស** *ជាចតុត្ថីវិភត្តិ សំដៅដល់បទថា* **បិហាយន្តិ** *។ បទថា* **បិណ្ឌបាតិកស្ស** *នោះ គប្បីឃើញថា ប្រើក្នុងអត្ថទុតិយាវិភត្តិ ។ បទថា* **អត្តភរស្ស** *សេចក្តីថា ជាអ្នកចិញ្ចឹមចំពោះខ្លួនប៉ុណ្ណោះ ដោយបច្ច័យ ៤ ដែលតិចតួច មិនមានទោស និងរកបានងាយ ដែលលោកពោលយ៉ាងនេះថា បច្ច័យទាំងនោះតិចផង រកបានងាយផង មិនមានទោសផង ។ បទថា* **អនញ្ញោសិនោ** *សេចក្តីថា ឈ្មោះថា មិនចិញ្ចឹមអ្នកដទៃ ព្រោះមិនមានការខ្វល់ខ្វាយដែលនឹងចិញ្ចឹមអ្នកដទៃ មានអន្តេវាសិកជាដើម ដោយការសង្គ្រោះដោយអាមិស ។ ដោយបទទាំង ២ ទ្រង់សម្តែងការប្រព្រឹត្តស្រាលព្រមភាពជាអ្នកចិញ្ចឹមងាយ និងភាពជាអ្នកសន្តោសយ៉ាងក្រៃលែងរបស់ព្រះមហាកស្សបៈ ព្រោះលោកគ្រាច់ទៅដោយចីវរជាគ្រឿងបរិហារកាយ និងបិណ្ឌបាត ជាគ្រឿងបរិហារផ្ទៃ ។ ម្យ៉ាងទៀត បទថា* **អត្តភរស្ស** *សេចក្តីថា ឈ្មោះថា ជាអ្នកចិញ្ចឹមខ្លួន ព្រោះចិញ្ចឹមខ្លួនម្នាក់ប៉ុណ្ណោះ ពោល គឺអត្តភាព ដោយពោលថា ចិញ្ចឹមខ្លួនមួយមាត់ មិនមែនចិញ្ចឹមអ្នកដទៃអំពីការងារនេះទេ ។ បន្ទាប់អំពីនោះឯង ឈ្មោះថា មិនចិញ្ចឹមអ្នកដទៃ ព្រោះមិនមានអ្នកដទៃដែលខ្លួនគប្បីស្តាប់សំឡេង ។ ភិក្ខុនោះជាអ្នកចិញ្ចឹមខ្លួន មិនចិញ្ចឹមអ្នកដទៃ ។ បទទាំង ២ ទ្រង់សម្តែងដល់ការមិនប្រកាន់តទៅ ព្រោះលោកជាព្រះខីណាស្រព ។*

បទថា **ឧភា បិហាយន្តិ ។បេ។ សតីមតោ** *សេចក្តីថា ទេវៈ មានសក្កៈជាដើម រមែងស្រឡាញ់ គឺរមែងប្រាថ្នាព្រះនិណាស្រពនោះ ឈ្មោះថា ចូលទៅស្ងប់ដោយបដិបស្សទ្ធិ ព្រោះចូលទៅស្ងប់ការក្រវល់ក្រវាយ និងការក្តៅក្រហាយដែលកើតអំពីកិលេសទាំងពួង ដោយសម្រេចអរហត្តផល ឈ្មោះថា ជាអ្នកមានសតិ ព្រោះជាអ្នកមានសតិអស់កាលជានិច្ច ដោយដល់នូវការបរិបូណ៌ដោយសតិ បន្ទាប់អំពីនោះ ដល់នូវលក្ខណៈជាបុគ្គលមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើម គឺញុំាងនូវការរាប់រានដ៏ច្រើនឲ្យកើត ទើបកើតការអើពើក្នុងគុណវិសេសរបស់លោក មានសីលជាដើម និងពោលទៅថ្វីដល់មនុស្សនោះ ។*

អដ្ឋកថា មហាកស្សបសូត្រទី ៧ ចប់

សុត្តន្តបិដក

បិណ្ឌបាតសូត្រ

[៨២] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុច្រើនរូប ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាជាខាងក្រោយភត្ត ហើយអង្គុយជួបជុំគ្នា ក្នុងរោងឈ្មោះកវេរិមណ្ឌល ក៏កើតអន្តរាកថានេះឡើងថា ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត កាល*

ត្រាច់ទៅបិណ្ឌបាត តែងបានឃើញរូបទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយ ភ្នែកមួយជង្ហ មួយកាល បានឮសំឡេងទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយ ត្រចៀក មួយជង្ហ មួយកាល បានធុំក្លិនទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយ ច្រមុះ មួយជង្ហ មួយកាល បានទទួលរសទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយ អណ្តាត មួយជង្ហ មួយកាល បានប៉ះពាល់ផ្សព្វទាំងឡាយ ដែលជាទីគាប់ ចិត្ត ដោយកាយ មួយជង្ហ មួយកាល ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នក ប្រព្រឹត្តបិណ្ឌបាត មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ត្រាច់ទៅបិណ្ឌបាត ម្នាលអាវុសោទាំងឡាយ ណ្ហើយចុះ ពួកយើង ចូរជា អ្នកប្រព្រឹត្តបិណ្ឌបាត ពួកយើងនឹងបានឃើញរូបទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយភ្នែក មួយជង្ហ មួយកាលផង ពួកយើងនឹងបានឮសំឡេងទាំងឡាយ ដែលជាទីគាប់ចិត្តដោយត្រចៀក មួយជង្ហ មួយកាលផង ពួកយើងនឹងបានធុំ ក្លិនទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយច្រមុះ មួយជង្ហ មួយកាលផង ពួក យើងនឹងបានទទួលរសទាំងឡាយ ដែលជាទីគាប់ចិត្តដោយអណ្តាត មួយជង្ហ មួយកាលផង ពួកយើងនឹងបានប៉ះពាល់ផ្សព្វទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយកាយ មួយជង្ហ មួយកាលផង ពួកយើងនឹងមានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ត្រាច់ទៅបិណ្ឌបាតផង ។ ឯអន្តរភកថានេះ ពួក ភិក្ខុទាំងនោះ ក៏ពុំទាន់ធ្វើឲ្យចប់ស្រេចនៅឡើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញចាកការសម្ងំ ក្នុងផលសមាបត្តិ ក្នុងសាយណ្ហសម័យ ហើយទ្រង់ ចូលទៅកាន់រោង ឈ្មោះកវេរិមណ្ឌល លុះទ្រង់ចូលទៅដល់ហើយ ក៏គង់

លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេច ហើយ ទើបត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នក ទាំងឡាយ អង្គុយប្រជុំគ្នាដោយកថាដូចម្តេច អន្តរាកថាដូចម្តេច ដែលអ្នក ទាំងឡាយធ្វើមិនទាន់ចប់ ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះអង្គ ដ៏ចម្រើន កាលពួកខ្ញុំព្រះអង្គ ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយ ភត្ត ហើយអង្គុយប្រជុំគ្នា ក្នុងរោងឈ្មោះកវរិមណ្ឌលនេះ អន្តរាកថានេះ កើតឡើងថា ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត កាលត្រាច់ ទៅបិណ្ឌបាត តែងបានឃើញរូបទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយភ្នែក មួយជង មួយកាល បានឮសំឡេងទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយ ត្រចៀក មួយជង មួយកាល បានធុំក្លិនទាំងឡាយ ដែលជាទីគាប់ចិត្តដោយ ច្រមុះ មួយជង មួយកាល បានទទួលរសទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយអណ្តាត មួយជង មួយកាល បានប៉ះពាល់ផ្សព្វទាំងឡាយ ដែលជាទី គាប់ចិត្ត ដោយកាយ មួយជង មួយកាល ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុ អ្នកប្រព្រឹត្តបិណ្ឌបាត មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ត្រាច់ទៅបិណ្ឌបាត ម្នាលអាវុសោភិក្ខុទាំងឡាយ ណ្ហើយចុះ ពួកយើងត្រូវជា អ្នកប្រព្រឹត្តបិណ្ឌបាតផង ពួកយើងនឹងបានឃើញរូបទាំងឡាយ ដែលជាទី គាប់ចិត្តដោយភ្នែក មួយជង មួយកាលផង ពួកយើងនឹងបានឮសំឡេង ទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយត្រចៀក មួយជង មួយកាលផង ពួក យើងនឹងបានធុំក្លិនទាំងឡាយ ដែលជាទីគាប់ចិត្តដោយច្រមុះ មួយជង មួយ

កាលផង ពួកយើងនឹងបានទទួលរសទាំងឡាយ ដែលជាទីគាប់ចិត្តដោយអណ្តាត មួយជង មួយកាលផង ពួកយើងនឹងបានប៉ះពាល់ផ្សព្វទាំងឡាយដែលជាទីគាប់ចិត្តដោយកាយ មួយជង មួយកាលផង ពួកយើងនឹងមានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ត្រាច់ទៅបិណ្ឌបាតផង បពិត្រព្រះអង្គដ៏ចម្រើន អន្តរាកថានេះហើយ ដែលពួកខ្ញុំព្រះអង្គ ធ្វើមិនទាន់ចប់ស្រេចនៅឡើយ ស្រាប់តែព្រះមានព្រះភាគ ទ្រង់ស្តេចមកដល់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ពោលកថា មានសភាពយ៉ាងនេះ មិនសមគួរដល់អ្នកទាំងឡាយ ដែលជាកុលបុត្តចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធាឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កាលបើបានប្រជុំគ្នា គួរធ្វើអំពើ ២ យ៉ាង គឺធម្មីកថា ១ អរិយតុណ្ហីភាព ១ ។ លុះព្រះមានព្រះភាគទ្រង់បានជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> ទេវតាទាំងឡាយ តែងស្រឡាញ់ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត អ្នកចិញ្ចឹមតែខ្លួន មិនចិញ្ចឹមបុគ្គលដទៃ ជាអ្នកនឹងធឹង ប្រសិនបើ (ភិក្ខុនោះ) មិនអាស្រ័យនូវការសរសើរ គឺកិត្តិសព្ទ ទេ (សេចក្តីសរសើរ រមែងមានក្នុងទីចំពោះមុខ ឬកំបាំងមុខមិនខាន) ។ សូត្រទី ៨ ។

អដ្ឋកថា

បិណ្ឌបាតសូត្រ

បិណ្ឌបាតសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ

[៨២] បទថា **បច្ឆាភត្តំ** សេចក្តីថា ពេលខាងក្នុងថ្ងៃត្រង់របស់ភិក្ខុ ដែលសមាទានឯកាសនិកង្គធុតង្គ និងខលុបច្ឆាកត្តិធុតង្គ ដែលឆាន់អាហារព្រឹកហើយ ក៏បច្ឆាកត្តដូចគ្នា ។ តែក្នុងទីនេះ ខាងក្រោយអំពីឆាន់អាហារតាមប្រក្រតីនោះឯង គប្បីជ្រាបថា ជាបច្ឆាកត្តិ ។ បទថា **បិណ្ឌចាតបដិក្កន្តានំ** សេចក្តីថា បុគ្គលត្រឡប់អំពីបិណ្ឌបាត គឺត្រឡប់អំពីស្វែងរកបិណ្ឌបាតហើយត្រឡប់ពីបិណ្ឌបាតហើយនោះ ដោយធ្វើកត្តកិច្ចឲ្យសម្រេច ។ បទថា **ការេរិ** ក្នុងបទថា **ការេរិមណ្ឌលមាឡេ** ជាឈ្មោះរបស់ដើមថ្ងាន់ ។ បានឮថា ដើមថ្ងាន់នោះ នៅខាងក្នុងវាងមណ្ឌប និងព្រះគន្ធកុដិ ដោយហេតុនោះ សូម្បីព្រះគន្ធកុដិ ក៏លោកហៅថា **ការេរិកុដិកា** ។ មណ្ឌបក្តី សាលាក្តី លោកហៅថា **ការេរិមណ្ឌលមាឡ** គឺរោងមូលជិតដើមថ្ងាន់ ។ ព្រោះហេតុអ្វី ក្នុងរោងមូល ពោល គឺសាលាសម្រាប់អង្គុយដែលសាងទុកមិនឆ្ងាយអំពីដើមថ្ងាន់នោះ ។ អាចារ្យពួកខ្លះ ពោលដល់ដំបូលដែលប្រក់ដោយស្មៅ និងស្លឹកឈើ ក្បឿងមិនលិច ថាជារោងមូល ។ អាចារ្យមួយពួកទៀតពោលថា មណ្ឌបដែលប្រក់ដោយវល្លិ មានវល្លិអតិមុត្តកជាដើម ឈ្មោះថា រោងមូល ។ បទថា **កាលេន កាលំ** បានដល់ ក្នុងវាង ម្តងម្កាល អធិប្បាយថា ក្នុងសម័យនោះៗ ។ បទថា **មនាបិកេ** ប្រែថា គួរជាទីត្រេកអរ អធិប្បាយថា

បិយរូបដែលគួរជ្រាបថ្នា ។ ភាពជាឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ គប្បីកាន់យក ដោយអំណាចបុគ្គល និងដោយអំណាចទ្វារ ។ ពិតហើយ ភាពជាឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍នោះ គេសន្មតថា ជាវត្ថុគួរជ្រាបថ្នារបស់បុគ្គលពួកខ្លះ មិនគួរជ្រាបថ្នារបស់បុគ្គលពួកខ្លះ សន្មតថា មិនគួរជ្រាបថ្នារបស់បុគ្គលពួកខ្លះ គួរជ្រាបថ្នារបស់បុគ្គលពួកខ្លះ ។ ម្យ៉ាងទៀត គួរជ្រាបថ្នារបស់ទ្វារ ១ មិនគួរជ្រាបថ្នារបស់ទ្វារ ១ ។ តែក្នុងទីនេះ គប្បីជ្រាបវិនិច្ឆ័យដោយអំណាចវិបាក ពិតហើយ កុសលវិបាក គួរជ្រាបថ្នាដោយចំណែកមួយ អកុសលវិបាក មិនគួរជ្រាបថ្នាឡើយ ។ បទថា **ចក្ខុទ្វារេ បសដ្ឋិតុំ** *សេចក្តីថា ភិក្ខុទៅកាន់ស្រុកដើម្បីបិណ្ឌបាត កាលពួកឧបាសកនិមន្តឲ្យចូលទៅកាន់ផ្ទះ នាំអាសនៈ និងពិតាន ចូលទៅ ដើម្បីធ្វើការបូជា សក្ការៈ បានឃើញរូបដែលគួរត្រេកអរ ពោលគឺរូបដែលរុងរឿងដោយលម្អផ្សេងៗ និងរូបដែលមានវិញ្ញាណគ្រប់គ្រងជនៃដោយវិញ្ញាណដែលប្រព្រឹត្តទៅតាមចក្ខុទ្វារ ។ បទថា* **សទ្ទេ** *សេចក្តីថា ភិក្ខុចូលទៅកាន់ផ្ទះឥស្សរជន បានឮសំឡេងច្រៀង និងប្រគំ ដែលគេលេងដើម្បីឥស្សរជនទាំងនោះ ក៏ដូច្នោះដូចគ្នា ។ បទថា* **គន្ធេ** *សេចក្តីថា ដើម្បីហិតក្លិនមានក្លិនផ្កា និងក្លិនផ្សែងក្រអូបជាដើម ដែលបុគ្គលទាំងនោះបង្អោននាំចូលទៅ ដោយបូជា និងសក្ការៈដូចគ្នា ។ បទថា* **រសេ** *សេចក្តីថា ដើម្បីភ្លក្សរសជ៏ប្រសើរផ្សេងៗ ដោយការបរិភោគអាហារដែលជនទាំងនោះប្រគេន ។ បទថា* **ផោដ្ឋព្ពេ** *សេចក្តីថា ដើម្បីពាល់ត្រូវផោដ្ឋព្វារម្មណ៍ជាសុខសម្ផស្ស ក្នុងការអង្គុយលើអាសនៈមានតម្លៃច្រើន ដែលគេក្រាល ។ កាលទ្រង់ប្រារព្ធ*

ដល់ការបាននូវឥដ្ឋារម្មណ៍ ដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ ដូចពោលមកហើយ នេះ ឥឡូវនេះ ដើម្បីសម្តែងការបាននូវឥដ្ឋារម្មណ៍ដែលប្រព្រឹត្តទៅតាមមនោទ្វារ ទើបត្រាស់ពាក្យជាដើមថា **សក្ការោ** *ជួច្នេះ ។ ពាក្យនោះ មានអត្ថដូចពោលហើយខាងដើមនោះឯង ។*

សួរថា នយនេះសម្រាប់ភិក្ខុដែលមិនសមាទានបិណ្ឌបាតជាវត្ត រមែងមិនបានឬ ។ ឆ្លើយថា បាន ។ ពិតហើយ ក្នុងពេលដែលភិក្ខុទាំងនោះចូលទៅកាន់ស្រុកដើម្បីនិមន្តនភត្ត និងសលាកភត្តជាដើម ឧបាសកទាំងឡាយជាអ្នកមានសម្បត្តិច្រើន រមែងធ្វើសក្ការៈ និងសមានដូច្នោះដូចគ្នា តែក្នុងសេចក្តីនោះ មិនពិតប្រាកដឡើយ ឯសម្រាប់ភិក្ខុដែលត្រាច់បិណ្ឌបាតជាវត្តពិតប្រាកដក្នុងកាលនោះ ។ ភិក្ខុទាំងនោះឃើញបុគ្គលនោះកំពុងធ្វើការបូជា និងសក្ការៈក្នុងទីនោះ តាំងនៅក្នុងផ្លូវមិនជាទីរលាស់ចេញចាកទុក្ខ ព្រោះជ្រួតក្នុងសក្ការៈទើបពោលយ៉ាងនោះ ដោយអនុយោនិសោមនសិការ ។ ដោយហេតុនោះឯង ទើបលោកពោលពាក្យជាដើមថា **ហន្ទាវុសោ មយម្បិ បិណ្ឌចារិកា ភោម** *ប្រែថា ណ្ហើយចុះ ពួកយើងនឹងជាអ្នកសមាទានការត្រាច់បិណ្ឌបាតជាវត្ត ។*

បណ្តាបទទាំងនោះ សព្ទថា **ហន្ទ** *ជានិបាត ប្រើក្នុងអត្ថថា លះបង់ ។ បទថា* **លច្ឆាម** *ប្រែថា នឹងបាន ។ បទថា* **តេឆុបសង្កមិ** *សេចក្តីថា ទ្រង់ប្រថាប់គង់ក្នុងព្រះគន្ធកុដិ មានភ្លឹនក្រអូបនោះ ទ្រង់ស្តាប់ការចរចាជ្រុះស្រ័យរបស់ភិក្ខុទាំងនោះ ទើបចូលទៅកាន់ភេងមូល ដោយព្រះបំណងថា ភិក្ខុទាំងនេះបួសក្នុងសាសនារបស់ព្រះពុទ្ធដូចតថាគត សូម្បីនៅក្នុងវិហារជាមួយនឹង*

តថាគត ក៏នៅតែប្រើប្រាស់ពាក្យដោយអយោនិសោមនសិការយ៉ាងនេះ មិនប្រព្រឹត្តក្នុងការដុសខាត់ ណ្ហើយចុះ តថាគតនឹងហាមភិក្ខុនោះ ចាកហេតុនោះ ហើយប្រកបក្នុងធម៌ ដែលជាគ្រឿងដុសខាត់ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

បទថា **ឯតមត្តំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបអត្តនេះថា សូម្បីទេវតាទាំងឡាយ រមែងស្រឡាញ់ចំពោះភិក្ខុដែលត្រាច់បិណ្ឌបាតជាវត្ត ដើម្បីកម្ចាត់កិលេស ដើម្បីធ្វើតណ្ហាឲ្យរីងស្ងួត ដោយធម៌ជាគ្រឿងដុសខាត់ គឺប្រាថ្នាតិចនិងសន្តោស កើតនូវការអើពើក្នុងកិច្ចបដិបត្តិ ប្រព្រឹត្តស្រឡាញ់ចំពោះលោកមិនប្រព្រឹត្តស្រឡាញ់បុគ្គលដទៃក្រៅអំពីនេះ ដូច្នេះហើយ ទើបទ្រង់បន្ទឺឧទាននេះ ដើម្បីសម្តែងសេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **ឆោ ចេ សទ្ធសិលោកនិស្បិតោ** សេចក្តីថា បើមិនចង់បានអាស្រ័យការសរសើរ ពោល គឺសំឡេងដែលជនដទៃសរសើរ ដោយន័យជាដើមថា គួរអស្ចារ្យ លោកម្ចាស់ជាអ្នកប្រាថ្នាតិច សន្តោស មានការប្រព្រឹត្តដុសខាត់ក្រៃលែង ។ ម្យ៉ាងទៀត កិត្តិសព្ទ បានដល់ ការយោសនាសរសើរគុណចំពោះមុខ លើកតម្កើង បានដល់ លើកតម្កើង ក្នុងទីកំបាំងមុខ ឬភាពជាបុគ្គលមានយសផ្សាយទៅ ។ ពាក្យដ៏សេស មានន័យដូចពោលក្នុងសូត្រដែលជាលំដាប់នោះឯង ។

អដ្ឋកថា បិណ្ឌចាតសូត្រទី ៨ ចប់

សុត្តន្តបិដក

សិប្បសូត្រ

[៨៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុច្រើនរូប កាលត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត អង្គុយប្រជុំគ្នាក្នុងរោងសម្រាប់អង្គុយ អន្តរកថានេះកើតឡើងថា ម្នាលអាវុសោទាំងឡាយ អ្នកណាហ្ន៎ ជឿនលូវសិល្បៈ អ្នកណាជាអ្នកសិក្សាសិល្បៈអ្វី បណ្តាសិល្បៈទាំងឡាយ សិល្បៈណាប្រសើរជាង ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុពួកខ្លះ និយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងជីវប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងសេះប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងរថប្រសើរជាង ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងធ្នូប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងអាវុធប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងដៃទេប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងការវាយប់ប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងការវាយប់បូកប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងការសរសេរប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងកាព្យ

ប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងគម្ពីរលោកាយតនៈប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងវិជ្ជាទាយស្រែប្រសើរជាង ។ ឯអន្តរ-កថានេះ ពួកភិក្ខុទាំងនោះ ធ្វើពុំទាន់ចប់ស្រេចនៅឡើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញចាកការសម្ងំ ក្នុងសាយណ្ហសម័យ ហើយស្តេចចូលទៅកាន់រោងជាទីអង្គុយ រួចគង់លើអាសនៈដែលគេក្រាលថ្វាយ លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយ ទើបត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយ អង្គុយប្រជុំគ្នា ដោយកថាដូចម្តេច អន្តរកថាដូចម្តេច ដែលអ្នកទាំងឡាយធ្វើមិនទាន់ចប់ស្រេចនៅឡើយ ។ ពួកភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលពួកខ្ញុំព្រះអង្គត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ហើយអង្គុយប្រជុំគ្នា ក្នុងរោងសម្រាប់អង្គុយនេះ អន្តរកថាកើតឡើងថា ម្នាលអាវុសោទាំងឡាយ អ្នកណាហ្ន៎ ជំងសិល្បៈ អ្នកណាជាអ្នកសិក្សាសិល្បៈអ្វី បណ្តាសិល្បៈទាំងឡាយ សិល្បៈណាប្រសើរជាង ។ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈជំរីប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងសេះប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងរថប្រសើរជាង ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងធ្នូប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈ

ទាំងឡាយ សិល្បៈក្នុងអាវុធប្រសើរជាង ។ ពួកភិក្ខុខ្លះ និយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងដៃទប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងការរាប់ ជាលំដាប់ប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងការរាប់បូកប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងការសរសេរ ប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងកាព្យ ប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងគម្ពីរលោកាយតនៈ ប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងវិជ្ជាទាយស្រែ ប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចម្រើន អត្ថុប្បត្តិកថានេះហើយ ដែលពួកខ្ញុំព្រះអង្គ ធ្វើពុំទាន់ចប់ស្រេចនៅឡើយ ស្រាប់តែព្រះមានព្រះភាគ ទ្រង់ស្តេចមកជល់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយពោលកថាមានសភាពបែបនេះ មិនសមគួរដល់អ្នកទាំងឡាយ ដែលជាកុលបុត្រចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដោយសទ្ធាទេ ។ ម្នាលភិក្ខុទាំងឡាយ កាលអ្នកទាំងឡាយប្រជុំគ្នា គួរធ្វើអំពើ ២ យ៉ាង គឺធម្មីកថា ឬ អរិយតុណ្ហីភាព ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

បុគ្គលណា ជាអ្នកមិនចិញ្ចឹមជីវិត ដោយសិល្បៈ ជាអ្នក
ប្រព្រឹត្តស្រាល ប្រាថ្នាប្រយោជន៍ដល់ជនដទៃ សង្រួមឥន្ទ្រិយ

មានចិត្តផុតស្រឡះចាកអាសវៈទាំងពួង មិនមានទីនៅនៃតណ្ហា មិនមានសេចក្តីប្រកាន់ថា របស់អញមិនមានសេចក្តីប្រាថ្នា ជានសម្ងាប់មារហើយ ចរទៅម្នាក់ឯង បុគ្គលនោះ ឈ្មោះថា ភិក្ខុ ។ សូត្រទី ៩ ។

អដ្ឋកថា

សិប្បសូត្រ

សិប្បសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ

[៨៣] *បទថា* **កោ ឆុ ខោ អាវុសោ សិប្បំ ជានាតិ** *សេចក្តីថា អាវុសោ កាលពួកយើងប្រជុំគ្នាក្នុងទីនេះ បុគ្គលណាហ្ន៎ ទើងជីងច្បាស់នូវអាជីវៈណាមួយ ដែលមានជីវិតជាហេតុ ដែលបានឈ្មោះថា សិប្បៈ ព្រោះអត្ថថា ត្រូវសិក្សា ។ បទថា* **កោ កឺ សិប្បំ សិក្ខី** *សេចក្តីថា បុគ្គលណាចូលទៅរកត្រកូលអាចារ្យ ដែលល្បីល្បាញក្នុងសិប្បៈអស់កាលយូរហើយ សិក្សាសិប្បៈណាមួយ បណ្តាសិប្បៈ មានសិប្បៈដ៏រជាដើម ដោយគន្ធងដែលរៀន និងដោយគន្ធងបដិបត្តិ ។ បទថា* **កតរំ សិប្បំ សិប្បានំ អគ្គំ** *សេចក្តីថា សិប្បៈប្រភេទណាជាកំពូល គឺប្រសើរជាងសិប្បៈទាំងពួង ដោយមិនថោកថយ មានផលច្រើន និងសម្រេចបានមិនលំបាក អធិប្បាយថា បុគ្គលអាស្រ័យសិប្បៈណាហើយ អាចរស់នៅបានងាយ ។ បទថា* **តត្តេកច្ចេ**

សេចក្តីថា បណ្តាភិក្ខុទាំងនោះ ពួកខ្លះ ដែលចេញបួសអំពីត្រកូលនាយ ហត្ថាចារ្យនោះ ។ បទថា **ឯវមាហំសុ** *សេចក្តីថា លោកទាំងនោះបានពោលយ៉ាងនោះ បន្ទាប់អំពីនេះទៅ ក្នុងទីដែលពោលថា* **ឯកេ** *ក៏នយនេះដូចគ្នា ។ បទថា* **ហត្ថិសិប្បំ** *សេចក្តីថា សិប្បៈគ្រប់យ៉ាង មានការចាប់ដី ការបង្វឹក ការបរ ការជិះ ការរក្សារោគជាដើម ដែលចាំបាច់ត្រូវធ្វើ លោកបំណងយកថា ជាសិប្បៈក្នុងការបង្វឹកដីក្នុងទីនេះ ។ ក្នុងពាក្យថា* **អស្សសិប្បំ** *នេះ ក៏នយនេះដូចគ្នា ។ ឯសិប្បៈ គឺការបររថ គប្បីជ្រាបដោយវិធីហ្វឹកហាត់ និងបរទៅជាដើមរបស់អ្នកបររថ និងដោយការប្រកបរថ ។ បទថា* **ធនុសិប្បំ** *បានដល់ សិប្បៈនៃនាយខ្មាន់ធ្នូដែលហៅថា អ្នកខ្មាន់ធ្នូ ។ បទថា* **ថរុសិប្បំ** *បានដល់ សិប្បៈខាងអាវុធដ៏សេស ។ បទថា* **មុទ្ទាសិប្បំ** *បានដល់ សិប្បៈក្នុងការរាប់មេដៃ ។ បទថា* **គណនាសិប្បំ** *បានដល់ សិប្បៈក្នុងការរាប់មិនជាច់រយៈ ។ បទថា* **សង្ខានសិប្បំ** *បានដល់ សិប្បៈក្នុងការរាប់ជាដុំដោយការបូក និងការដកជាដើម ។ បុគ្គលដែលពោលស្ទាត់ជំនាញក្នុងសិប្បៈនោះ គ្រាន់តែឃើញដើមឈើក៏រាប់បានថា ដើមឈើនេះ មានស្លឹកប៉ុណ្ណេះ ។ បទថា* **លេខាសិប្បំ** *បានដល់ សិប្បៈក្នុងការសរសេរអក្សរដោយអាការផ្សេងៗ ឬក្នុងការគូរ ។ បទថា* **កាវេយ្យសិប្បំ** *សេចក្តីថា សិប្បៈ គឺការតែងកាព្យនៃកវី ៤ ពួក មានចិន្តកវីជាដើម ដោយការគិតរបស់ខ្លួន ដោយការស្តាប់ដែលបានមកអំពីអ្នកដទៃ ដោយប្រយោជន៍យ៉ាងនេះថា វត្តុនេះមានប្រយោជន៍ អញនឹងប្រកបវត្តុនេះយ៉ាងនេះ ឬដោយការ*

ឃើញកាព្យណាមួយ ហើយកើតបដិភាណាទ្បើងក្នុងហាន:ថា អញនឹងតែង កាព្យឲ្យដូចគ្នានឹងកាព្យនោះ ។ សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ កវីមាន ៤ ពួក គឺចិន្តកវី ១ សុតកវី ១ អត្ថកវី ១ បដិ-ភាណកវី ១ ។ បទថា **លោកាយតនសិប្បំ** *សេចក្តីថា សិប្ប:ក្នុងវិតណ្ឌ-សាស្ត្រដែលបដិសេធបរលោក និងនិព្វាន ប្រព្រឹត្តទៅ ដោយនយជាដើមថា ក្អែកស ព្រោះឆ្អឹងស កុកក្រហម ព្រោះឈាមក្រហម ។ បទថា* **ឥត្ត-វិជ្ជាសិប្បំ** *សេចក្តីថា សិប្ប:ក្នុងនីតិសាស្ត្រ មានការរក្សាស្តេចជាដើម ។ បានឮថា សិប្ប:ទាំង ១២ នេះ ឈ្មោះថា មហាសិប្ប: ទើបពោលក្នុងទីនេះថា* **សិប្បានំ អគ្គំ** *ដូច្នេះ ។*

បទថា **ឯតមត្តំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងនូវ ការមិនរលាស់ចេញចាកទុក្ខ ដើម្បីប្រយោជន៍ដល់ការរស់នៅនៃសិប្បាយតន: ទាំងពួងនេះ តែក៏ទ្រង់ជ្រាបការមិនរលាស់ចេញនៃភាពបរិសុទ្ធ មានសីល ជាដើម និងភាពជាភិក្ខុនៃបុគ្គលដល់ព្រមដោយសីលជាដើមនោះ ទើបទ្រង់ បន្ទឹងទាននេះ ដែលប្រកាសអត្តនោះ ។*

បណ្តាបទទាំងនោះ បទថា **អសិប្បជីវី** *សេចក្តីថា ឈ្មោះថា អសិប្បជីវី ព្រោះអត្ថថា មិនទៅអាស្រ័យសិប្ប:ណាមួយចិញ្ចឹមជីវិត ព្រោះការសង្ឃឹម ក្នុងបច្ច័យក្រៀមស្ងួតទៅ ដោយសង្កត់តណ្ហាឧប្បាទាន ៤ ឲ្យនៅឆ្ងាយ ។ ដោយ ពាក្យនេះ ទ្រង់សម្តែងដល់អាជីវបារិសុទ្ធិសីល ។ បទថា* **លហុ** *បានដល់ ឈ្មោះថា ស្រាល គឺមិនមានសម្ភារ:ច្រើន ព្រោះមានកិច្ចតិច និងមានការ*

ប្រព្រឹត្តស្រោលព្រម ។ ដោយពាក្យនេះ ទ្រង់សម្តែងដល់ភាពជាអ្នកចិញ្ចឹមងាយ ដែលសម្រេចដោយការសន្តោសក្នុងបច្ច័យ ៤ ។ បទថា **អត្តកាមោ** *សេចក្តីថា ឈ្មោះថា* **អត្តកាម** *ព្រោះអត្តថា ស្រឡាញ់ គឺប្រាថ្នាចំពោះប្រយោជន៍របស់លោក ព្រមទាំងទេវលោកប៉ុណ្ណោះ ។ ដោយពាក្យនេះ ទ្រង់សម្តែងដល់ជាតិមោក្ខសំវរសីល ព្រោះប្រកាសដល់ការវៀរវត្ថុដែលមិនមែនប្រយោជន៍ដល់សត្វទាំងឡាយ ព្រោះសម្តែងដល់ការវៀរនូវសេចក្តីវិនាសមានជាណាតិជាតជាដើម ។ បទថា* **យតិន្ទ្រិយោ** *សេចក្តីថា ឈ្មោះថា មានឥន្ទ្រិយសង្រួមហើយ ព្រោះសង្រួមឥន្ទ្រិយ ៦ មានចក្ខុន្ទ្រិយជាដើម ដោយមិនឲ្យអកុសលធម៌ មានអវិជ្ជាជាដើមកើតឡើង ។ ដោយពាក្យនេះ ត្រាស់ដល់ឥន្ទ្រិយសំវរៈ ។ បទថា* **សព្ពធិ វិប្បមុត្តោ** *សេចក្តីថា ជាអ្នកមានសីលបរិសុទ្ធល្អយ៉ាងនេះ តាំងមាំនៅក្នុងការសន្តោសដោយបច្ច័យ ៤ កំណត់នាមរូប មួយអន្ទើដោយបច្ច័យ ពិចារណាសង្ខារដោយលក្ខណៈ មានអនិច្ចលក្ខណៈជាដើម បំពេញវិបស្សនា បន្ទាប់អំពីនោះ ក៏ឈ្មោះថា ជាអ្នករួចផុតក្នុងធម៌ទាំងពួង គឺក្នុងភូមិទាំងពួង មានកពជាដើម ព្រោះលះសំយោជនៈបានដោយអរិយមគ្គ ៤ ដែលប្រព្រឹត្តទៅតាមលំដាប់ ។*

បទថា **អនោកសារី អមមោ និរាសោ** *សេចក្តីថា ឈ្មោះថា* **អនោកសារី** *ព្រោះមិនមានការផ្សាយទៅនៃតណ្ហាក្នុងអាយតនៈទាំង ៦ ពោល គឺឱកាស គឺទីក ព្រោះរួចផុតហើយក្នុងធម៌ទាំងពួងដូច្នោះឯង ឈ្មោះថា* **អមម** *ព្រោះមិនមានមមង្ការក្នុងអារម្មណ៍ណាមួយ មានរូបាទិអារម្មណ៍ជាដើម ឈ្មោះថា*

និរាស ព្រោះមិនមានការសង្ឃឹម ដោយប្រការទាំងពួង ។ បទថា **ហិត្វា មានំ ឯកចរោ ស ភិក្ខុ** សេចក្តីថា ភិក្ខុនោះជាបុគ្គលយ៉ាងនោះ លះមានះបានមិនសេសសល់ ជំណាលគ្នានឹងពេលដែលបានសម្រេចអរហត្តមគ្គនោះ ឯង ទើបមិនច្រឡូកច្រឡំដោយពួកគណៈ ដូចភិក្ខុទាំងនេះ ជាបុគ្គលម្នាក់ឯងត្រាច់ទៅ ក្នុងឥរិយាបថទាំងពួង ព្រោះបំណងការស្វាត់ និងវៀរចាកសម្ងាញ់គឺតណ្ហា បុគ្គលនោះដោយបរមត្ថ ឈ្មោះថា ភិក្ខុ ព្រោះទម្ងាយកិលេសដោយប្រការទាំងពួង ។ ក្នុងទីនេះ ត្រាស់ដល់គុណដែលជាលោកិយ ដោយន័យជាដើមថា **អសិប្បជីវី** បុគ្គលមិនអាស្រ័យសិប្បៈចិញ្ចឹមជីវិត ដោយពាក្យជាដើមថា **សព្វធិ វិប្បមុត្តោ** ត្រាស់ដល់គុណដែលជាលោកុត្តរ ។ ក្នុងពាក្យនោះ ទ្រង់សម្តែងថា ធម៌នេះសម្រាប់បុគ្គលតាំងនៅក្នុងភាពជាអ្នកមិនអាស្រ័យសិប្បៈចិញ្ចឹមជីវិតជាដើមប៉ុណ្ណោះ មិនមែនជារបស់អ្នកអាស្រ័យសិប្បៈចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះដូច្នោះ ចូរពួកអ្នកវៀរចាកការកាន់យកក្នុងសិប្បៈថាជាសារៈ ហើយសិក្សាក្នុងអធិសីលជាដើមប៉ុណ្ណោះ ។

អដ្ឋកថាសិប្បសូត្រទី ៩ ចប់

សុត្តន្តបិដក

លោកសូត្រ

[៨៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទើបនឹងត្រាស់ដឹងជាជំបូង ទ្រង់គង់នៅទៀបគល់ពោធិព្រឹក្ស ប្របង្អែរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ដោយព្រះភ្នែនតែមួយ សោយវិមុត្តិសុខអស់ ៧ ថ្ងៃ ។ លុះកន្លង ៧ ថ្ងៃនោះទៅហើយ ព្រះមានព្រះភាគ ទ្រង់ចេញចាកសមាធិនោះ ហើយប្រមើលមើលសត្វលោក ដោយពុទ្ធចក្ខុ ។ កាលព្រះមានព្រះភាគ ទ្រង់ប្រមើលមើលដោយពុទ្ធចក្ខុ ទ្រង់បានឃើញពួកសត្វដែលកំពុងក្តៅអន្ទះសាដោយគ្រឿងក្តៅជាអនេកផង កំពុងឆេះរោលរាល ដោយគ្រឿងឆេះរោលរាលជាអនេកផង ដែលកើតអំពីរាគៈខ្លះ កើតអំពីទោសៈខ្លះ កើតអំពីមោហៈខ្លះ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

សត្វលោកនេះ មានសេចក្តីក្តៅអន្ទះសា ត្រូវផស្សៈគ្របសង្កត់ហើយ រមែងពោលនូវខន្ធបញ្ចកៈ ដែលមានរោគថាជាខ្លួន ព្រោះថា សម្គាល់ឃើញដោយអាការណា ខន្ធបញ្ចកៈនោះ រមែងប្រែក្លាយទៅចាកអាការនោះ សត្វលោកជាប់ជំពាក់ក្នុងភព ត្រូវភពគ្របសង្កត់ មានការប្រែក្លាយជាធម្មតា តែងត្រេកត្រអាលនឹងភព ។ សត្វត្រេកអរនឹងរបស់ណា របស់នោះ ជាភ័យ ខ្លាចចំពោះរបស់ណា របស់នោះ ជាទុក្ខ មានតែបុគ្គលប្រព្រឹត្តមគ្គ-

ព្រហ្មចរិយនេះ ទើបលះបង់កពបាន ។ ពួកសមណៈ ឬព្រាហ្មណ៍ ណាមួយ ពោលនូវការរួចចាកកពដោយកព (សស្សតទិដ្ឋិ) ពួកសមណៈ ឬព្រាហ្មណ៍ទាំងអស់នោះ តថាគតពោលថា មិនផុតស្រឡះចាកកពឡើយ ។ មួយទៀត ពួកសមណៈ ឬព្រាហ្មណ៍ ណាមួយ ពោលនូវការរលាស់ចាកកពដោយវិកព (ឧច្ឆេទទិដ្ឋិ) ពួកសមណៈ ឬព្រាហ្មណ៍ទាំងអស់នោះ តថាគតពោលថា មិនរលាស់ចេញចាកកពបានឡើយ ។ ព្រោះថា ទុក្ខនេះ កើតមានព្រោះអាស្រ័យឧបធិទាំងពួង ការកើតទុក្ខមិនមាន ព្រោះអស់ឧបាទានទាំងពួង ។ អ្នកចូរមើលលោកនេះចុះ ពួកសត្វក្តី អ្នកត្រេកអរក្នុងពួកសត្វក្តី ដែលអវិជ្ជាដ៏ក្រាស់ គ្របសង្កត់ហើយ មិនរួចស្រឡះ (ចាកទុក្ខ) បានឡើយ ។ ព្រោះថា កពណាមួយ ក្នុងទីទាំងពួង គ្រប់ទិសទាំងអស់ កពទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានការប្រែប្រួលជាធម្មតា ។ កាលបើបុគ្គលឃើញហេតុនុ៎ះ ដោយប្រជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះហើយ រមែងលះបង់កវគណ្ហា មិនត្រេកត្រអាលចំពោះវិកវ-គណ្ហាឡើយ ។ ការប្រាសចាកតម្រេក និងការរលត់មិនសល់ ព្រោះអស់តណ្ហាទាំងឡាយ ដោយសព្វគ្រប់ ឈ្មោះថា និព្វាន កពថ្មីក៏មិនមានដល់ភិក្ខុនោះ អ្នករលត់ហើយ ព្រោះមិនមានឧបាទាន ។ ភិក្ខុនោះ បានគ្របសង្កត់មារ ទាំងឈ្នះសង្គ្រាម ជា

អ្នកនឹងជឹង កន្ទងកពទាំងអស់បាន ។ សូត្រទី ១០ ។

នន្ទវគ្គទី ៣ ចប់

ឧទ្ទាននៃនន្ទវគ្គនោះ គឺ

និយាយអំពីផលនៃកម្មចាស់ ១ ព្រះនន្ទ ១ ព្រះយសោជៈ ១ ព្រះសារីបុត្ត ១ ព្រះកោលិតៈ (មោគ្គល្លាន) ១ ព្រះបិលិន្ទវច្ឆៈ ១ ព្រះកស្សបៈ ១ ពួកភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត ១ សិល្បៈ ១ សត្វលោក ១ រួមទាំងអស់ត្រូវជា ១០ ។

អដ្ឋកថា

លោកសូត្រ

លោកសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ

[៨៤] *អាសយានុសយញ្ញាណ និងឥន្ទ្រិយបរោបរិយត្តិញ្ញាណ ឈ្មោះថា ពុទ្ធចក្ខុ ក្នុងពាក្យថា* **ពុទ្ធចក្ខុនា** *នេះ ។ សមដូចលោកពោលពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ កាលតថាគត កំពុងប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ក៏បានឃើញនូវពួកសត្វដែលមានធូលីតិចក្នុងភ្នែក (ខ្លះ) មានធូលីច្រើនក្នុងភ្នែក (ខ្លះ) មានឥន្ទ្រិយក្លៀវក្លា (ខ្លះ) មាន*

ឥន្ទ្រិយទន់ ។ បទថា **លោកំ** *បានដល់ លោក ៣ គឺឱកាសលោក ១ សង្ខារលោក ១ សត្វលោក ១ ។ ក្នុងលោកទាំង ៣ នោះ ឱកាសលោក ត្រាស់ក្នុងប្រយោគជាដើមថា*

ព្រះអង្គត្រាស់ថា ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយ ដើរបំភ្លឺទិសទាំងឡាយ ឲ្យភ្លឺបានត្រឹមណា លោក គឺចក្រវាលទាំងមួយពាន់ក៏កំណត់ត្រឹមនោះ អំណាចរបស់អ្នកប្រព្រឹត្តទៅបាន តែត្រឹមចក្រវាលមួយពាន់ន៎ុះ ។

សង្ខារលោក ត្រាស់ក្នុងប្រយោគជាដើមថា លោក ១ បានដល់ ពួកសត្វទាំងអស់ដែលតាំងនៅបានដោយអាហារ លោក ២ បានដល់ នាម ១ រូប ១ លោក ៣ បានដល់ វេទនា ៣ លោក ៤ បានដល់អាហារ ៤ លោក ៥ បានដល់ ឧបាទានក្ខន្ធ ៥ លោក ៦ បានដល់ អាយតនៈខាងក្នុង ៦ លោក ៧ បានដល់ ទីតាំងនៃវិញ្ញាណ ៧ លោក ៨ បានដល់ លោកធម៌ ៨ លោក ៩ បានដល់ ទីនៅរបស់សត្វ ៩ លោក ១០ បានដល់ អាយតនៈទាំង ១០ លោក ១២ បានដល់ អាយតនៈ ១២ លោក ១៨ បានដល់ ធាតុ ១៨ ។ សត្វលោក ត្រាស់ក្នុងប្រយោគជាដើមថា លោកទៀង លោកមិនទៀង ។ ក្នុងទីនេះ គប្បីជ្រាបសត្វលោក ។ បណ្តាលោកទាំងនោះ លោក ពោល គឺចក្រវាល ឈ្មោះថា ឱកាសលោក ព្រោះអត្ថថា ឃើញ គឺប្រាកដដោយអាការវិចិត្រ ។ សង្ខារ ឈ្មោះថា លោក ព្រោះអត្ថថា ទ្រុឌ ទ្រោម គឺបែកធ្លាយ ឈ្មោះថា សត្វលោក ព្រោះអត្ថថា ជាទីមើលបុណ្យ

និងបាប និងផលនៃបុណ្យ និងបាប ។ ព្រះមានព្រះភាគ ទ្រង់អនុគ្រោះក្នុងសត្វទាំងនោះ ដោយមហាករុណា មានព្រះបំណងឲ្យសត្វទាំងនោះផុតចាកសង្សារទុក្ខ ទើបប្រមើលមើលសត្វលោក ព្រះអង្គទ្រង់ប្រមើលមើលក្នុងសប្តាហ៍ណា ឆ្លើយថា ក្នុងសប្តាហ៍ទី ១ ។ ពិតហើយ ក្នុងទីបំផុតនៃបច្ឆិមយាម ក្នុងថ្ងៃចុងក្រោយនៃចុងសប្តាហ៍ ទ្រង់ចូលសមាធិ ព្រះមានព្រះភាគទ្រង់បន្ទឺឧទាន សម្តែងអានុភាពនៃអរិយមគ្គនេះថា

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាម ញាំងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេស ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួងរបស់ព្រាហ្មណ៍នោះ រមែងអស់ទៅ ក្នុងកាលនោះ ព្រោះដឹងច្បាស់នូវធម៌ព្រមទាំងហេតុ ដូច្នេះ ។

ទើបប្រមើលមើលសត្វលោកថា ជាបឋម តថាគតប្រើទូក គឺធម៌នេះឆ្លងអន្ទង់ទឹកធំ គឺសង្សារ ដែលឆ្លងទៅបានដោយលំបាកយ៉ាងនេះ ទើបឈរត្រង់ច្រាំង គឺព្រះនិព្វាន ណ្ហើយចុះ ឥឡូវនេះ សូម្បីសត្វលោក តថាគតក៏នឹងឲ្យឆ្លងដែរ សត្វលោកដូចម្តេចហ្ន៎ ដូច្នេះ ។ លោកពោលសំដៅថា កន្លង ៧ ថ្ងៃ បន្ទាប់អំពីថ្ងៃនោះទៅ ព្រះមានព្រះភាគចេញចាកសមាធិនោះ ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភោលោកេសិ** *សេចក្តីថា ទ្រង់ឃើញដោយអាការផ្សេងៗ គឺការធ្វើឲ្យប្រចក្សដោយញាណរបស់ព្រះអង្គ ដូចផ្លែកន្ធពៃ ដែលដាក់លើបាតដៃ ។ បទ មានបទថា* **អនេកេហិ សន្តាបេហិ**

ជាបទសម្តែងអាការមើលងាយ ។ បទថា **អនេកេហិ សន្តាបេហិ** *បានដល់ ដោយសេចក្តីទុក្ខជាអនេក ។ ពិតហើយ ទុក្ខ លោកហៅថា* **សន្តាប** *ព្រោះអត្ថថា ធ្វើឲ្យក្តៅ ដូចលោកពោលថា ទុក្ខ មានអត្ថថា បៀតបៀន មានអត្ថថា តាក់តែង មានអត្ថថា ធ្វើឲ្យក្តៅ មានអត្ថថា ប្រែប្រួល ទុក្ខនោះ មានអត្ថច្រើនប្រការ ដោយអំណាចទុក្ខទុក្ខជាដើម និងដោយអំណាចជាតិជាដើម ។ ដោយហេតុនោះ ទើបលោកពោលថា* **អនេកេហិ សន្តាបេហិ** *បុគ្គលក្តៅក្រហាយ គឺត្រូវទុក្ខជាច្រើនគ្របសង្កត់បៀតបៀន ។ បទថា* **បរិឌ្ឌាហេហិ** *ប្រែថា ដោយការក្តៅក្រហាយ ។ បទថា* **បរិឌយ្ហមានេ** *បានដល់ ត្រូវភ្លើងដុតដោយជុំវិញ ដូចកំពុង ។ បទថា* **រាគគ្គិនា** *បានដល់ កើតអំពីរាគៈ ។ ក្នុងបទជ័សេស ក៏មានន័យដូច្នេះ ពិតហើយ កិលេស មានរាគៈជាដើម រមែងកើតក្នុងសន្តានណា រមែងបៀតបៀនសន្តាននោះ ដូចកំពុងដុត ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភ្លើង ៣ កង គឺរាគគ្គិ ១ ទោសគ្គិ ១ មោហគ្គិ ១ ។ ព្រោះភ្លើងទាំងនោះ ធ្វើចិត្ត និងកាយឲ្យសៅហ្មង ដូច្នោះ ទើបហៅថា កិលេស ។ ក្នុងបទទាំងនេះ ដោយបទថា* **បរិឌយ្ហមានេ** *នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងដល់កិលេស មានរាគៈជាដើម ជាបវត្តិទុក្ខ និងភាពដែលសត្វត្រូវបវត្តិទុក្ខនោះគ្របសង្កត់ ។ ម្យ៉ាងទៀត ដោយបទថា* **សន្តប្បមានេ** *នេះ ទ្រង់សម្តែងដល់ភាពដែលសត្វទាំងនោះជាទុក្ខគ្រប់កាល និងជាអ្នកមានអន្តរាយមិនជាប់ ព្រោះទុក្ខនោះ ។*

ពិតហើយ ព្រះមានព្រះភាគប្រថាប់លើអបរាជិតល្ង្ហ នាមណ្ឌល

ពោធិព្រឹក្សក្នុងបឋមយាម ទ្រង់រញកដល់បុព្វេនិវាសញ្ញាណ ក្នុងមជ្ឈិមយាម ទ្រង់ជម្រះទិព្វចក្ខុ ក្នុងបច្ចិមយាម ទ្រង់ញ្ជាំងញាណឲ្យឈមចុះក្នុងបដិច្ច-សមុប្បាទ ទ្រង់ដឹងក្រៃលែងនូវវដ្តទុក្ខ ដែលមានកិលេសជាមូល ទ្រង់ពិចា-រណាកំណត់សង្ខារ ចម្រើនវិបស្សនាដោយលំដាប់ ទ្រង់កម្ចាត់កិលេសឲ្យ ប្រាសទៅ ត្រាស់ដឹងក្រៃលែង ដោយព្រះអង្គឯង ដោយការសម្រេចអរិយ-មគ្គ ព្រោះទ្រង់លះកិលេសបានជាសមុច្ចេទ ក្នុងលំដាប់បច្ចវេក្ខណញ្ញាណ ហើយទើបទ្រង់បន្ទឺខទានថា **អនេកជាតិសង្សារំ** ដូច្នេះជាដើម ដែលសម្តែង ដល់ភាពដែលទ្រង់អស់វដ្តទុក្ខ ដែលព្រះពុទ្ធគ្រប់អង្គទ្រង់មិនដែលលះបង់ គង់ប្រថាប់ពត់ភ្នែន សោយវិមុត្តិសុខអស់ ៧ ថ្ងៃ ក្នុងយាម ៣ នៃរាត្រីទី ៧ ទ្រង់បន្ទឺខទាន ៣ យ៉ាង ដោយន័យដូចពោលហើយ ក្នុងលំដាប់នៃខទានទី ៣ ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញថា វដ្តទុក្ខរបស់ សត្វទាំងអស់នេះ មានកិលេសជាមូល ឈ្មោះថា កិលេសទាំងនេះ ជាបវត្តិ-ទុក្ខ គឺទុក្ខក្នុងបច្ចុប្បន្ន និងជាហេតុនៃទុក្ខតទៅ ព្រោះដូច្នោះ ទើបសត្វទាំង នេះក្តៅក្រហាយ រាលរាល ព្រោះកិលេសទាំងនោះ ដោយហេតុនោះ ទើប លោកពោលថា **អឌ្ឍសា ទោ ភគវា ។បេ។ មោហជេហិបិ** ដូច្នេះ ។

បទថា **ឯតមត្តំ វិជិត្វា** សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួង ដល់ នូវភាពដែលសត្វលោក ក្តៅក្រហាយ រាលរាល ដូចពោលហើយ គ្រប សង្កត់ ។ បទថា **ឧជានំ ឧជានេសិ** សេចក្តីថា ទ្រង់បន្ទឺមហាខទាននេះ ដែល ប្រកាសដល់ការរលាស់ឥតសេសសល់ នូវការក្តៅក្រហាយ រាលរាល

ទាំងពួង ។

បណ្តាបទទាំងនោះ បទថា **អយំ លោកោ សន្តាបជាតោ** *សេចក្តីថា សត្វលោកទាំងអស់ កើតក្តៅក្រហាយ ព្រោះជរា រោគ និងមរណៈ ព្រោះការវិកវរផ្សេងៗ និងព្រោះការចាមរោមនៃកិលេស អធិប្បាយថា ត្រូវទុក្ខផ្លូវកាយ និងផ្លូវចិត្តដែលកើតឡើងហើយគ្របសង្កត់ ។ បទថា* **ផស្សបរេតោ** *សេចក្តីថា បុគ្គលត្រូវទុក្ខសម្ផស្សជាអនេកនោះឯងគ្របសង្កត់ គឺបៀតបៀនម្យ៉ាងទៀត បទថា* **ផស្សបរេតោ** *សេចក្តីថា ដែលត្រូវផស្សៈទាំង ៦ ជាបច្ច័យដល់ទុក្ខវេទនា ៣ ពោល គឺសុខវេទនាជាដើមគ្របសង្កត់ គឺជាប់ជំពាក់ដោយការប្រព្រឹត្តទៅក្នុងអារម្មណ៍នោះៗ តាមទ្វារនោះៗ ។ បទថា* **រោគំ វទតិ អត្តតោ** *សេចក្តីថា សត្វលោក កាលមិនដឹងតាមសេចក្តីពិតដល់រោគទុក្ខ ឬបញ្ចក្ខន្ធ ពោល គឺវេទនាដែលកើតឡើង ព្រោះផស្សៈជាបច្ច័យ តែងពោលដោយអត្តាថា អញបានទទួលសុខ ទទួលទុក្ខ ដោយអំណាចការយល់ខុស ដោយអំណាចសម្គាល់ថាជាអញ ។ អាចារ្យពួកខ្លះពោលថា* **អត្តនោ** *ដូច្នេះក៏មាន ។ ពាក្យនោះ មានអធិប្បាយដូច្នេះថា សត្វលោកនេះ ត្រូវទុក្ខធម៌ណាមួយគ្របសង្កត់ កាលមិនអាចអត់ធន់បាន ព្រោះមិនបានចម្រើនអត្តា ទើបកន្ទក់កន្ទេញ ដោយន័យជាដើមថា ឱ ទុក្ខ ទុក្ខបែបនេះ ចូរកុំបីមានដល់ខ្លួនរបស់អញ ទើបពោលដល់រោគរបស់ខ្លួនតែម្យ៉ាង តែមិនបដិបត្តិដើម្បីលះរោគនោះ ។ ម្យ៉ាងទៀត សត្វលោក កាលមិនដឹងតាមពិតនូវទុក្ខ តាមដែលពោលហើយនោះ ទើបពោលថា របស់ខ្លួន ដោយសម្គាល់ថា ជារបស់អញ*

គឺបន្ទឹរាថាថា នេះរបស់អញ ដោយអំណាចតណ្ហាគាហៈ គឺការប្រកាន់ដោយអំណាចតណ្ហា ។

បទថា **យេន ហិ មញ្ញតិ** *សេចក្តីថា សត្វលោក កាលពោលបញ្ចក្ខន្ធដែលជាតួរោគនេះ ដោយភាពជាខ្លួន ឬរបស់ខ្លួន ដោយអាការយ៉ាងនេះ ទើបសម្គាល់ដោយទិដ្ឋិ មានៈ និងតណ្ហា ដោយប្រការដែលជាហេតុ មានរូប និងវេទនាជាដើមណា ឬដោយប្រការ មានភាពជារបស់ទៀងជាដើមណា ។ បទថា* **តតោ តំ ហោតិ អញ្ញថា** *សេចក្តីថា បញ្ចក្ខន្ធដែលជាវត្ថុនៃការសម្គាល់នោះ រមែងកើតដោយប្រការដទៃអំពីអាការដែលខ្លួនកំណត់នោះ និងជាការប្រកាន់ថា ខ្លួន ក្នុងវត្ថុដែលមិនមែនខ្លួន អធិប្បាយថា មិនធ្វើនូវអហង្ការ និងមមង្ការឲ្យសម្រេច ។ ព្រោះមិនអាចឲ្យនៅក្នុងអំណាចបាន ។ ម្យ៉ាងទៀត បទថា* **តតោ** *សេចក្តីថា បញ្ចក្ខន្ធនោះ ដែលបុគ្គលសម្គាល់ថា ទៀងជាដើម រមែងកើតដោយប្រការដទៃ គឺជាសភាវៈមិនទៀងជាដើមនោះឯង ព្រោះភាវៈត្រឹមតែការសម្គាល់នោះ ការសម្គាល់មិនអាចធ្វើភាវៈ ឬលក្ខណៈ ឲ្យទៅជាដទៃបាន ។*

បទថា **អញ្ញថាភាវី ភវសត្តោ** *សេចក្តីថា សត្វលោក ជាប់ជំពាក់ក្នុងសេចក្តីចម្រើន ក្នុងហិតសុខដែលមិនទាន់កើត សូម្បីគិតតាមការពេញចិត្ត ដោយអំណាចសញ្ញា ក៏មានភាពជដទៃអំពីសញ្ញានោះ ដោយបដិបត្តិខុស មានតែវត្ថុដែលឥតប្រយោជន៍ និងជាទុក្ខ ជួបតែការចង្អៀតចង្អល់តែម្យ៉ាង ។ បទថា* **ភវមេវាភិនន្ទតិ** *សេចក្តីថា កាលបើយ៉ាងនោះ ក៏គង់ត្រេកអរ គឺប្រាថ្នា*

ភព គឺការចម្រើនដែលមិនមាន ដែលខ្ជួនកំណត់ដោយការសម្គាល់ខុសនោះ ប៉ុណ្ណោះ ។ ម្យ៉ាងទៀត បទថា **អញ្ញថាភាវី** *សេចក្តីថា មានភាពដទៃដោយខ្ជួនឯងចាកអាការដែលកំណត់ដោយការសម្គាល់ ដោយនយជាដើមថា អត្តារបស់អញទៀង តែជារបស់មិនទៀង មិនស្ថិតស្ថេរ ។ បទថា* **ភវសង្ខោ** *សេចក្តីថា សត្វលោកជាប់ជំពាក់ ងប់ជ្រប់ ព្រោះភវតណ្ហា ក្នុងកាមភពជាដើម ។ បទថា* **ភវមេវាភិនន្ទតិ** *សេចក្តីថា ប្រកាន់ភពដែលមានសភាវៈមិនទៀងនោះឯង ដោយជារបស់ទៀង ហើយត្រេកអរ ដោយការសម្គាល់បង្អោនទៅក្នុងភពនោះឯង ដោយការត្រេកអរក្នុងភព ដោយអំណាចតណ្ហានិងទិដ្ឋិ គឺមិននឿយណាយក្នុងភពនោះ ។ បទថា* **យទភិនន្ទតិ តំ ភយំ** *សេចក្តីថា ភព គឺសេចក្តីចម្រើន ឬភព មានកាមជាដើមដែលសត្វលោកត្រេកអរនោះ ឈ្មោះថា ជាភ័យ ព្រោះអត្ថថា គួរខ្លាចក្រែងលែង ដោយជាហេតុកើតភព ព្រោះមានសភាវៈប្រែប្រួល មានមិនទៀងជាដើម និងព្រោះត្រូវសេចក្តីវិនាសច្រើនប្រការជាប់តាម ។ បទថា* **យស្ស ភាយតិ** *សេចក្តីថា ជរា និងមរណៈជាដើម ដែលជាហេតុឲ្យសត្វលោកខ្លាចនោះ ចាត់ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខ និងព្រោះជាតួទុក្ខ ។ ម្យ៉ាងទៀត បទថា* **យស្ស ភាយតិ** *សេចក្តីថា សត្វលោករមែងខ្លាចចំពោះការសេពណា ព្រោះការត្រេកអរក្នុងភព ការសេព ពោល គឺការជាប់សូន្យ (ខច្ឆេទទិដ្ឋិ) នោះ និងការខ្លាចអំពីការសេពនោះ រាប់ថាជាទុក្ខ គឺមានសភាវៈជាទុក្ខនោះឯង ព្រោះជាទីតាំងនៃទុក្ខ និងព្រោះទុក្ខ មានជាតិទុក្ខជាដើម មិនប្រែប្រួលទៅជា*

ជនៃ ។ ម្យ៉ាងទៀត បទថា **យស្ស ភយតិ តំ ទុក្ខំ** *សេចក្តីថា ការខ្វាច ដែលសត្វលោកមិនដឹងនូវការលាស់ចេញ នូវអនិច្ចលក្ខណៈជាដើម ដែលខ្លួនខ្វាចនោះ ជាទុក្ខ គឺនាំទុក្ខមកឲ្យ ។*

ព្រះមានព្រះភាគ កាលទ្រង់សម្តែងវដ្ដៈ ដោយហេតុមានប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ ដើម្បីនឹងសម្តែងវិវដ្ដៈ ទើបត្រាស់ថា មានតែបុគ្គលប្រព្រឹត្តមគ្គព្រហ្មចរិយៈនេះ ទើបលះបង់ភពបាន ។

បណ្តាបទទាំងនោះ បទថា **ភវិប្បហានាយ** *បានដល់ ដើម្បីលះកាមភពជាដើម ។ សព្ទថា* **នោ** *ប្រើក្នុងអត្ថអវធារណៈ គឺហាមសេចក្តីជនៃ ។ សព្ទថា* **បន** *ជានិបាត ប្រើក្នុងអត្ថបទបូរណៈ ធ្វើឲ្យពេញបទ ។ បទថា* **ឥធ** *ជាបទពោលចំពោះទីជិត ។ បទថា* **ព្រហ្មចរិយំ** *បានដល់មគ្គព្រហ្មចរិយៈ ។ បទថា* **វុស្សតិ** *ប្រែថា រមែងបំពេញ ។ លោកអធិប្បាយពាក្យនេះថា មគ្គព្រហ្មចរិយៈដែលប្រកបដោយអង្គ ៨ នេះ សង្គ្រោះដោយខន្ធ ៣ មានសីលក្ខន្ធជាដើម តថាគតប្រព្រឹត្តវត្តុដែលធ្វើបានលំបាកក្រៃលែង បំពេញបារមីមក អស់ ៤ អសង្ខ្យៃ កប្បមួយសែនកប្ប ហើយជាន់ក្បាលមារទាំង ៣ ត្រង់មណ្ឌលពោធិព្រឹក្សបានសម្រេចហើយ ទើបប្រព្រឹត្តបំពេញដើម្បីប្រយោជន៍ដល់ការលះជាសមុច្ឆេទ ដោយការលះហេតុកើតនៃកាមភពជាដើម ដោយចំណែកមួយ ។*

ព្រះមានព្រះភាគ កាលទ្រង់សម្តែងអរិយមគ្គ ដែលជាហេតុនាំសត្វចេញចាកទុក្ខដោយពិត ដោយប្រការដូច្នេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងដល់

ការមិនមានមគ្គដទៃ ក្រៅអំពីអរិយមគ្គនោះ ទើបត្រាស់ពាក្យជាដើមថា **យេ ហិ កេចិ** *ជួច្នេះ ។*

បណ្តាបទទាំងនោះ បទថា **យេ** *ជាបទសម្តែងលម្អិតការមិនពិតប្រាកដ ពាក្យថា* **ហិ** *ត្រឹមតែជានិបាត ។ បទថា* **កេចិ** *បានដល់ ពួកខ្លះ ។ ដោយបទទាំង ២ លោកកាន់យកបុគ្គលដែលមានវាទៈយ៉ាងនោះ ដែលមានទិដ្ឋិជាគតិ ដោយមិនកំណត់ពិតប្រាកដ ។ បទថា* **សមណា** *បានដល់ ជាសមណៈដោយត្រឹមតែចូលទៅបួស មិនមែនដោយការស្ងប់បាប ។ បទថា* **ព្រាហ្មណា** *បានដល់ ដោយហេតុត្រឹមតែកំណើត មិនមែនជាអ្នកបន្សាត់បាប* **វា** *សព្ទជាវិកប្បដ្ឋ ។ បទថា* **ភវេន ភវស្ស វិប្បមោក្ខមាហំសុ** *សេចក្តីថា សមណព្រាហ្មណ៍ពួកខ្លះ ពោលការរួចផុតចាកភពទាំងពួង គឺការបរិសុទ្ធចាកសង្សារដោយកាមភព ឬរូបភព ។ សួរថា សមណព្រាហ្មណ៍ពួកណា ពោលយ៉ាងនេះ ។ ឆ្លើយថា ពួកដែលពោលដល់និព្វានក្នុងបច្ចុប្បន្ន ។ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកខ្លះពោលថា អត្តាដែលដល់ព្រមដោយកាមគុណ ៥ យ៉ាងខ្ជាស់ រមែងដល់នូវការរម្ងាប់ (និព្វាន) យ៉ាងក្រៃលែងក្នុងបច្ចុប្បន្ន ។ ពួកខ្លះពោលថា បណ្តាឈានចំណែកបួរជាវចរ អត្តាដែលដល់ព្រមដោយបឋមជ្ឈាន ។បេ។ ពួកខ្លះពោលថា អត្តាដែលដល់ព្រមដោយចតុត្ថជ្ឈាន តែងដល់នូវព្រះនិព្វានយ៉ាងក្រៃលែងក្នុងបច្ចុប្បន្ន ។ ដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈ ឬព្រាហ្មណ៍ មានពាក្យយ៉ាងនេះ មានសេចក្តីយល់ឃើញយ៉ាងនេះថា នែអ្នកដ៏ចម្រើន កាល

ណាបើខ្ជនេះឆ្អែតស្កប់ស្កល់ ឲ្យគេបម្រើដោយកាមគុណ ៥ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះឯង ទើបខ្ជនេះឈ្មោះថា ជាអត្តភាពដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថា ជាគុណជាតយ៉ាងក្រៃលែង ។ គប្បីជ្រាបសេចក្តីពិស្តារ (ក្នុងមជ្ឈិមនិកាយ ព្រាហ្មជាលសូត្រ) ។

កេចិអាចារ្យទាំងនោះពោលថា ព្រោះហេតុដែលការស្វែងរកកាម ជាដើម ដើម្បីខ្ជ នឹងមិនមានដល់បុគ្គលដែលដល់ព្រមដោយសុខជាដើម ដូចឈើង ដែលឆ្អែតហើយ ព្រោះបីតឈាមពេញទំហឹង មិនមានការស្រេកឃាម កាលមិនមានការស្វែងរកកាម កពក៏មិនមានដូចគ្នា ន័យនេះគួរបានដល់បុគ្គលតាំងនៅក្នុងកពណាមួយ ការរួចផុតចាកកពទាំងពួង រមែងមានដោយកពនោះៗ ដូច្នោះ ទើបត្រាស់ថា សមណព្រាហ្មណ៍ទាំងឡាយ ពោលការរួចផុតចាកកពដោយកព ដូច្នេះ ។ សូម្បីបុគ្គលដែលមានលទ្ធិថា បុគ្គលពាល និងបណ្ឌិត អន្ទោលទៅអស់កាលប៉ុណ្ណោះ តាំងនៅក្នុងកពចុងក្រោយ នឹងរួចផុតចាកសង្សារ ឈ្មោះថា ពោលការរួចផុតចាកកពដោយកព ។ សមដូចព្រះតម្រាស់ថា ជនពាលក្តី ជនជាបណ្ឌិតក្តី អន្ទោលទៅ ត្រាច់រង្គាត់ទៅ (ក្នុងវដ្តសង្សារ) អស់កាលចំនួន ៨ លាន ៤ សែនមហាកប្ប ហើយនឹងធ្វើនូវទីបំផុតនៃទុក្ខបាន[1] ដូច្នេះ ។ ម្យ៉ាងទៀត បទថា **ភវេន** បានដល់ភវទិដ្ឋិ ។ សស្សតទិដ្ឋិ លោកហៅថា ភវទិដ្ឋិ ព្រោះប្រព្រឹត្តទៅដោយអត្ថថា កើតមាន គឺតាំងនៅជាប់តគ្នា ក្នុងទីនេះ ភវទិដ្ឋិនោះឯង លោកហៅ

-១ បិ. ៣៤ ទំ. ១២៦ ។

ថា **ភព** *ដូចក្នុងប្រយោគថា* **ភវតណ្ហា** *ដោយលុបបទខាងចុង ។ កាលពោលដោយអំណាចទិដ្ឋិ សមណព្រាហ្មណ៍ពួកខ្លះ រមែងសម្គាល់ភពពិសេសប៉ុណ្ណោះ ដែលមានសភាវៈទៀងជាដើម ថាជាការរួចផុតចាកភព ព្រោះមានការប្រព្រឹត្តទៅស្ងប់កិលេស និងព្រោះអាយុរស់នៅបានយូរ ដូចពាក្យព្រាហ្មពោលថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ធម្មតាស្ថានព្រហ្មនេះ ជាទីទៀង ជាទីស្ថិតស្ថេរ មាននៅសព្វកាល មិនធ្លុះធ្លាយ មិនឃ្លៀងឃ្លាត ... ។ សមណ-ព្រាហ្មណ៍ទាំងនោះឯង ជាអ្នកប្រកាន់ខុស ផ្ទុយគ្នា មានការឃើញក្នុងវត្ថុដែលមិនមែនជាគ្រឿងរលាស់ចេញ ថាជាគ្រឿងរលាស់ចេញ ការរួចផុតចាកភព នឹងមានអំពីណា ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ពួកសមណៈ ឬព្រាហ្មណ៍ទាំងអស់នោះ តថាគតពោលថា មិនរលាស់ចេញចាកភពបានឡើយ ។*

បទថា **វិភវេន** *ប្រែថា ដោយការដាច់សូន្យ គឺឧច្ឆេទទិដ្ឋិ ។ បទថា* **ភវស្ស និស្សរណមាហំសុ** *សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះពោលការប្រាសទៅ ការចេញទៅអំពីភពទាំងពួង ថាជាសង្ឃារសុទ្ធិ ព្រោះសមណ-ព្រាហ្មណ៍ កាលមិនដឹងវាទៈនៃបុគ្គលដែលពោលថា ការរួចផុតវិសេសចាកភពដោយភព រមែងប្តេជ្ញាការរលាស់ចេញចាកទុក្ខ ដោយការកាត់ផ្តាច់ចាកភព ។*

ម្យ៉ាងទៀត បទថា **វិភវេន** *បានដល់ ឧច្ឆេទទិដ្ឋិ ។ ឧច្ឆេទទិដ្ឋិ លោកពោលថា* **វិភវ** *ដោយនយដូចពោលហើយ ព្រោះប្រព្រឹត្តទៅដោយអត្ថថា*

អត្តា និងលោកមិនមាន គឺវិនាសជាច់សូន្យ ។ ពិតហើយ សត្វទាំងឡាយ រមែងបង្អោនទៅដោយឧច្ឆេទទិដ្ឋិ ហើយកើតក្នុងភពនោះៗ ជាច់សូន្យទៅ ។ ឧច្ឆេទទិដ្ឋិនោះឯង ជាសង្ឃាវសុទ្ធិ ព្រោះហេតុនោះ ទើបសត្វទាំងនោះ ឈ្មោះថា ឧច្ឆេទវាទ គឺមានវាទៈថាជាច់សូន្យ ។ សមដូចព្រះតម្រាស់ថា នែអ្នកដ៏ចម្រើន ខ្ញុំនេះមានរូប ប្រកបដោយមហាភូតរូប ៤ ។បេ។ ហើយចូលទៅកាន់នេវសញ្ញានាសញ្ញាយតនភព មានអារម្មណ៍ថា នេះជាធម្មជាតស្ងប់ នេះជាធម្មជាតឧត្តម អ្នកមិនដឹង មិនឃើញ នូវខ្ញុំនណា ឯខ្ញុំទើបដឹង ទើបឃើញនូវខ្ញុំនោះ នែអ្នកដ៏ចម្រើន ខ្ញុំនេះឯង លុះកាយបែកធ្លាយទៅកាលណា រមែងជាច់សូន្យ រមែងវិនាសខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀតឡើយ នែអ្នកដ៏ចម្រើន ខ្ញុំនេះឈ្មោះថា ជាសកាវៈជាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណេះឯង ដូច្នេះ ។ ម្យ៉ាងទៀត ត្រាស់ថា បពិត្រមហារាជ ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច មិនមានផល ។បេ។ ជនពាលក្តី ជនជាបណ្ឌិតក្តី លុះបែកធ្លាយរាងកាយទៅ រមែងជាច់សូន្យបាត់ទៅ មិនកើតទៀត ខាងមុខអំពីសេចក្តីស្លាប់ឡើយ ដូច្នេះ ។ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រកាន់ខុសផ្ទុយគ្នាយ៉ាងនេះ តើរលាស់ចេញចាកភពបានអំពីណា ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា តថាគតពោលថា ពួកសមណព្រាហ្មណ៍ទាំងអស់នោះ តថាគតពោលថា មិនរលាស់ចេញចាកភពទៅបានឡើយ ។ ព្រោះសត្វលោក មិនទាន់បានដកនូវកិលេសដ៏សេស ឲ្យអស់ដោយអរិយមគ្គភាវនា ក្នុងកាលណា

មួយ ក៏មិនបានរួចផុត ដោយការរលាស់ចេញចាកភព ។ ពិតហើយ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកជ្ងាក់ទៅក្នុងអន្តជមិទាំង ២ ថា មាន និង មិនមាន ព្រោះមិនជីងតាមសេចក្តីពិត ទើបអន្ទះអន្ទែង បម្រះនទៀល ព្រោះ តណ្ហា និងទិដ្ឋិ ព្រោះបុគ្គលទាំងនោះ មានទិដ្ឋិជាគតិ វង្វេងក្នុងហេតុនៃការ ប្រព្រឹត្តទៅ គឺសមុទយៈ ត្រូវគ្រឿងចង គឺតណ្ហាលាមត្រង់សសរ គឺទស្សនៈ ដែលខុសផ្ទុយគ្នា ដែលកប់យ៉ាងណែនត្រង់ផែនដី គឺសក្កាយទិដ្ឋិ រមែងមិន លះទីដែលចងទៅបាន ដូចឆ្កែដែលលាមដោយចំណង សមណព្រាហ្មណ៍ ទាំងនោះ នឹងមានការរួចផុតអំពីណា ។

ព្រះសាស្តា កាលទ្រង់សម្តែងថា សមណព្រាហ្មណ៍ពួកណា មិនជាប់ ជំពាក់ដោយអន្តជមិ ២ យ៉ាងនោះ ព្រោះមិនវង្វេងក្នុងបវត្តិជាដើម ដោយ ជាក់ច្បាស់ក្នុងសច្ចៈទាំង ៤ រមែងឡើងកាន់មជ្ឈិមប្បដិបទា សមណព្រាហ្មណ៍ ទាំងនោះឯង នឹងមានការរួចផុត នឹងការរលាស់ចេញទៅចាកភពបាន ទើប ត្រាស់ថា **ឧបធិ** *ជួច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **ឧបធី** *បានដល់ ខន្ធូបធិជាដើម ។ សព្ទថា* **ហិ** *ត្រឹមតែជានិបាត ។ បទថា* **បដិច្ច** *ប្រែថា អាស្រ័យ គឺធ្វើឲ្យជាទី អាស្រ័យ ។ បទថា* **ទុក្ខំ** *បានដល់ ទុក្ខ មានជាតិទុក្ខជាដើម ។ លោក អធិប្បាយដូចម្តេច លោកអធិប្បាយថា សត្វទាំងនេះ មានទិដ្ឋិជាគតិ សម្គាល់ ថា រួចផុតក្នុងទីណា ពួកគេក៏បានជួបនូវឧបធិ គឺខន្ធ កិលេស និងអភិសង្ខារ ក្នុងទីនោះ សត្វលោកនោះ រលាស់ចេញចាកទុក្ខបានអំពីណា ព្រោះអភិសង្ខារ*

កើតមាន ក្នុងទីដែលកិលេសកើតមាន ទើបការបន្តនៃភពមិនដាច់ខ្សែ ព្រោះ ជួច្នោះ ទើបវដ្តទុក្ខមិនរលត់ ។ ដោយហេតុនោះ ទើបលោកពោលថា ព្រោះ ថា ទុក្ខនេះ កើតមាន ព្រោះអាស្រ័យឧបធិទាំងពួង ។

ឥឡូវនេះ ដើម្បីសម្តែងហេតុជាគ្រឿងរលាស់ចេកចាកទុក្ខ ទើបត្រាស់ ថា ការកើតទុក្ខមិនមាន ព្រោះអស់ឧបាទានទាំងពួង ។

បណ្តាបទទាំងនោះ បទថា **សព្ពុបាទានក្ខយា** *សេចក្តីថា ព្រោះលះ បានជាសមុច្ឆេទនូវឧបាទានទាំងអស់ ៤ យ៉ាង គឺកាមុបាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន អត្តវាទុបាទាន ដោយការសម្រេចអរិយមគ្គ ។ ក្នុងឧបាទាន ទាំង ៤ នោះ ឧបាទាន ៣ គឺទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្ត-វាទុបាទាន ១ សោតាបត្តិមគ្គឲ្យអស់ទៅ គឺដល់នូវការមិនកើតឡើងជា ធម្មតា ។ គប្បីជ្រាបថា កាមុបាទានដែលញុំាងសត្វឲ្យទៅអបាយ មគ្គទី ១ ឲ្យអស់ទៅ ដែលជាកាមរាគៈយ៉ាងគ្រោតគ្រាត មគ្គទី ២ ឲ្យអស់ទៅ កាមរាគៈ និងព្យាបាទយ៉ាងល្អិត មគ្គទី ៣ ឲ្យអស់ទៅ ។ ការលះរូបរាគៈ អរូបរាគៈ មគ្គទី ៤ ឲ្យអស់ទៅ រួមសេចក្តីថា ឧបាទានដែលមគ្គទាំង ៤ ឲ្យអស់ទៅ គឺដល់នូវការមិនកើតឡើងជាធម្មតា ។ បទថា* **ឆត្តិ ទុក្ខស្ស សម្ភវោ** *សេចក្តីថា ព្រោះឧបាទានអស់ទៅដោយប្រការទាំងពួងយ៉ាងនេះ គឺ ព្រោះព្រៃស្តុក គឺកិលេសទាំងអស់ ដែលរួមនៅក្នុងឋាន:ជាមួយគ្នានឹង ឧបាទាននោះ មិនកើតឡើង វដ្តទុក្ខ មានប្រមាណតិច ក៏មិនកើត គឺមិន ប្រាកដ ។*

ព្រះមានព្រះភាគ កាលទ្រង់សម្តែងបវត្តិ គឺទុក្ខសច្ច និងនិវត្តិ គឺនិរោធ-សច្ច មួយអន្ទើដោយហេតុ ដូចពណ៌នាមកដូច្នេះហើយ កាលទ្រង់សម្តែងថា សត្វលោក កាលមិនដឹងន័យនេះ ក៏ងើបក្បាលអំពីវដ្ត:មិនបាន ទើបត្រាស់ពាក្យជាដើមថា **លោកមិមំ បស្ស**។

បណ្តាបទទាំងនោះ បទថា **លោកមិមំ បស្ស** សេចក្តីថា ព្រះមានព្រះភាគ កាលទ្រង់ដឹកនាំក្នុងការធ្វើការពិចារណាមើល ទើបត្រាស់ហៅដល់ព្រះអង្គថា ចូរមើលលោកនេះ ព្រោះទ្រង់ចូលដល់ភាវវិស័យនៃលោកដោយប្រចក្ស ដោយពុទ្ធចក្ខុ ។ បទថា **បុថុ** ប្រែថា ច្រើន ។ ម្យ៉ាងទៀត បទថា **បុថុ** ប្រែថា ជាពួកៗ ។ បទថា **អវិជ្ជា បរេតា** សេចក្តីថា ត្រូវអវិជ្ជាបិទបាំងសច្ច: ៤ គ្របសង្កត់ ។ ទើបត្រាស់ដោយន័យជាដើមថា ការមិនដឹងក្នុងទុក្ខ ។ បទថា **ភូតា** ប្រែថា កើតហើយ គឺកើតឡើងហើយ ព្រោះកម្ម និងកិលេស ។ បទថា **ភូតរតា** សេចក្តីថា ត្រេកអរក្រៃលែងដោយតណ្ហាក្នុងសត្វទាំងឡាយ គឺក្នុងសត្វដទៃ ដោយសម្គាល់ថា បិតា មាតា បុត្រ និងភរិយាជាដើម ឬក្នុងភូត គឺបញ្ចក្ខន្ធ ដោយកំណត់ថា ជាស្ត្រី បុរសជាដើម ដោយភាវ:ថា ទៀងជាដើម និងដោយការប្រកាន់ថា ខ្លួន និងមានក្នុងខ្លួន ដោយមិនឈមចុះក្នុងសភាវ:នៃបញ្ចក្ខន្ធថា មិនទៀង មិនស្អាត ជាទុក្ខ និងជាអនត្តា ។ បទថា **ភវា អបរិមុត្តា** សេចក្តីថា មិនរួចផុតចាកភព ចាកសង្សារ ដោយការប្រកាន់ ដោយអំណាចតណ្ហា និងទិដ្ឋិដូចពោលហើយ ។

ក្នុងបទទាំងនោះ បទថា **លោកមិមំ** នេះ លំដាប់ដំបូង កាលទ្រង់នាំ

ពួកសត្វទាំងអស់ចូលក្រុមតែមួយ ដោយការៈស្មើគ្នាមុន ទើបត្រាស់សម្តែងសពួ ដោយមិនចំពោះ ដោយឯកវចនៈ ហើយទ្រង់ប្រកាសអានុភាពនៃពុទ្ធ-ចក្ខុញ្ញាណរបស់ទ្រង់ថា សត្វលោកនេះ មានការផ្សេងគ្នាច្រើនប្រភេទ ដោយភព កំណើត គតិ ឋិតិ និងសត្តាវាសជាដើម និងដោយពួកសត្វនោះៗ ជាដើម ក្នុងភពជាដើមនោះ តថាគតរំពឹងមើលមួយបែបៗ ទើបធ្វើប្រភេទវចនៈទៀត ហើយទ្រង់សម្តែងសពួដោយចំពោះជាពហុវចនៈ ដោយព្រះតម្រាស់ជាដើមថា ពួកសត្វក្តី អ្នកត្រេកអរក្នុងពួកសត្វក្តី ដែលអវិជ្ជាដ៏ក្រាស់គ្របសង្កត់ហើយ ។ កាលធ្វើពាក្យអធិប្បាយដូចពោលមកនេះហើយ ធ្វើឲ្យជាទុតិយាវិភត្តិថា **លោកមិមំ** *និទ្ទេសដែលជាបឋមាវិភត្តិពហុវចនៈ ដោយព្រះបាលីថា* **អវិជ្ជាយ បរេតោ** *ជាដើម ក៏ជាការមិនខុស ព្រោះមានពាក្យផ្សេងគ្នា តែកាលពោលដោយបំណងឲ្យជាពាក្យតែមួយ ទើបអាចារ្យពួកខ្លះពោលថា ភូតដែលអវិជ្ជាគ្របសង្កត់ ត្រេកអរក្នុងភូត មិនផុតចាកភពបាន ។ តែបាលីបុរាណពោលដោយការផ្សេងគ្នានៃវិភត្តិប៉ុណ្ណោះ ។*

ឥឡូវនេះ កាលនឹងសម្តែងវិបស្សនាវិថី ដែលជាគោចររបស់ព្រះពុទ្ធមិនជាវិសយនៃតិរ្ថិយ ដែលជាឧបាយឲ្យផុតចាកភពទាំងអស់ ទើបត្រាស់ពាក្យជាដើមថា **យេ ហិ កេចិ** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **យេ ហិ កេចិ ភវា** *សេចក្តីថា ភពពួកណានីមួយដែលមានអាយុវែង ឬមានអាយុមួយជួរខណៈ ដែលមានប្រភេទផ្សេងគ្នា ដោយចែកជាកាមភពជាដើម សញ្ញីភពជាដើម និងឯកវោការភព*

ជាដើម ដែលសន្មតថា មានផាសុក ដែលផ្សេងគ្នាដោយសារៈ និងវៀរចាក ផាសុក ។ បទថា **សព្ពធិ** *បានដល់ ក្នុងទីទាំងពួង ដោយវិភាគជាដើមថា ខាងលើ ខាងក្រោម ខាងទទឹង ។ បទថា* **សព្ពត្តតាយ** *បានដល់ ដោយ ភាវៈទាំងពួង មានសួគ៌ អបាយ និងមនុស្សជាដើម ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា* **សព្ពេ តេ** *ជាដើមដូចតទៅនេះ*

កពទាំងអស់នោះ មានរូប និងវេទនាជាដើមជាធម្មតា ឈ្មោះថា មិនទៀង ព្រោះអត្ថថា មានហើយ ត្រឡប់ទៅជាមិនមាន ។ ឈ្មោះថា ជាទុក្ខ ព្រោះត្រូវការកើត និងការរលត់បៀតបៀន ។ ឈ្មោះថា មានការប្រែប្រួល ទៅជាធម្មតា ព្រោះត្រូវប្រែប្រួលទៅដោយហេតុ ២ ប្រការ គឺជរា និង មរណៈ ។ **ឥតិ** *សព្ទ មានអាទិជាអត្ថ ឬប្រការជាអត្ថ ។ គឺអ្វី គឺដោយ* **ឥតិ** *សព្ទនោះ ទ្រង់សង្គ្រោះដោយអនត្តលក្ខណៈ ហើយត្រាស់ថា ឈ្មោះ ថា អនត្តា ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ឬឈ្មោះថា អនត្តា ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ព្រោះមានការប្រែប្រួលទៅជាធម្មតា ។ សត្វ លោកពិចារណាឃើញបញ្ចក្ខន្ធនេះ ពោល គឺកពតាមសេចក្តីពិត គឺមិនប្រែ ប្រួលដោយបញ្ញាដ៏ប្រពៃ គឺដោយញាណដ៏ប្រពៃ បានដល់ ដោយបញ្ញាដែល សម្បយុត្តដោយមគ្គ ដែលប្រកបដោយវិបស្សនា គឺចាក់ធ្លុះដោយបរិញ្ញាអភិ- សមយជាដើម ទើបលះតណ្ហាក្នុងកព ដែលប្រព្រឹត្តទៅដោយនយជាដើមថា កពទៀង ដោយប្រការដូច្នេះ គឺដោយអាការចាក់ធ្លុះលក្ខណៈ ៣ គឺរម្ងាប់បាន ជាសមុច្ឆេទ មួយអន្ទើដោយការសម្រេចអរហត្តមគ្គនោះឯង រមែងមិនត្រេកអរ*

គឺរមែងមិនប្រាថ្នាវិភវ: គឺការដាច់សូន្យ ព្រោះលះខច្ចេទទិដ្ឋិបាន ដោយប្រការទាំងពួង ។ ព្រោះការអស់ទៅ គឺព្រោះលះតណ្ហា ១០៨ ប្រភេទ មានកាម-តណ្ហាជាដើម និងមានប្រភេទមិនមានទីបំផុត ដោយវិភាគជាដើមរបស់សត្វលោក ដែលជាអ្នករស់នៅយ៉ាងនោះ ដោយអាការទាំងពួង គឺដោយប្រការទាំងពួង ការរម្ងត់ ដោយមិនកើតឡើងនៃធម៌ដែលជាចំណែកនៃសង្កិលេសទាំងមូល ដែលរួមនៅក្នុងឋាន:ជាមួយតណ្ហានោះ ដោយមិនសេសសល់ គឺដោយសមុច្ចេទ ដោយធម៌ជាគ្រឿងខ្ជាក់ចោល គឺដោយអរិយមគ្គនោះពោល គឺព្រះនិព្វាន ។

កាលទ្រង់សម្តែងសខបាទិសេសនិព្វាន ដោយការលះតណ្ហាជាប្រធានដូចពណ៌នាមកដូច្នេះ ឥឡូវនេះ កាលទ្រង់សម្តែងអនុបាទិសេសនិព្វាន ទើបត្រាស់គាថាថា **តស្ស និព្ពុតស្ស** ដូច្នេះជាដើម ។

ពាក្យដែលជាគាថានោះ មានអធិប្បាយដូច្នេះថា ព្រោះភិក្ខុដែលជាខីណាស្រព ទម្ងាយកិលេសដោយន័យដូចពោលហើយ រលត់ដោយឥតសេសសស់ ដោយកិលេសបរិនិព្វាន ព្រោះអស់តណ្ហា ដោយប្រការទាំងពួង មិនមានខបាទាន គឺអស់ខបាទាន ឬព្រោះមិនប្រកាន់មាំ ដោយកិលេស-មារ និងអភិសង្ខារមារ ទើបភពថ្មីមិនមាន គឺមិនមានខបបត្តិភព ដោយការបដិសន្ធិតទៅ ភិក្ខុបែបនោះគ្របសង្កត់មារបាន គឺក្នុងខណ:អរិយមគ្គ គ្របសង្កត់កិលេសមារ អភិសង្ខារមារ និងទេវបុត្តមារ ក្នុងខណ:ចរិមកចិត្ត ចិត្តចុងក្រោយ គឺអរហត្តមគ្គ គ្របសង្កត់ខន្ធមារ និងមច្ចុមារបាន សេចក្តីថា

លោកគ្របសង្កត់មារទាំង ៥ បាន គឺឲ្យចាញ់ បានដល់ ធ្វើឲ្យអស់ព្យសន៍ ដោយការមិនឲ្យដើបក្បាលឡើងបានទៀត ព្រោះលោកឈ្នះសង្គ្រាមដែលពួកមារធ្វើឲ្យកើតក្នុងទីនោះៗ ដោយប្រការដូច្នេះ លោកឈ្មោះថា ឈ្នះសង្គ្រាម ឈ្មោះថា ជាអ្នកមិនញាប់ញ័រ គឺជាព្រះអរហន្ត ព្រោះដល់នូវលក្ខណៈនៃភាពជាតាទិបុគ្គល ព្រោះមិនមានវិការក្នុងអារម្មណ៍ទាំងពួង មានឥដ្ឋារម្មណ៍ជាដើម ឈ្មោះថា ឈានកន្ទង គឺឈានកន្ទងដោយល្អនូវភពទាំងពួង គឺភពទាំងអស់ មានប្រភេទតាមដែលពោលហើយ មិនរាប់ចូលក្នុងទីណាមួយដោយពិត ជាបុគ្គលបញ្ញត្តិមិនបាន ខាងមុខអំពីបរិនិព្វានទៅ ដូចភ្លើងអស់កំញម ដូច្នោះ ។ ព្រះមានព្រះភាគ ទ្រង់កាន់យកនូវកំពូលនៃអនុបាទិ-សេសនិព្វានធាតុ ទើបឲ្យមហាឧទាននេះបញ្ចប់ ដោយប្រការដូច្នេះ ។

អដ្ឋកថាលោកសូត្រទី ១០ ចប់

ឆន្ទវគ្គទី ៣ ចប់

សុត្តន្តបិដក

ខុទ្ទាន មេឃិយវគ្គទី ៤

មេឃិយសូត្រ

[៨៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបចាលិកបព៌ត ជិតក្រុងចាលិកា ។ សម័យនោះឯង ព្រះមេឃិយៈដ៏មានអាយុ ជាអ្នកបម្រើព្រះមានព្រះភាគ ។ គ្រានោះ ព្រះមេឃិយៈដ៏មានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចស្ថិតនៅក្នុងទីសមគួរ ។ លុះព្រះមេឃិយៈដ៏មានអាយុ ស្ថិតនៅក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចង់ចូលទៅបិណ្ឌបាត ក្នុងជន្តុគ្រាម ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលមេឃិយៈ អ្នកចូរសម្គាល់នូវកាលដែលគួរនឹងទៅ ក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ ស្បៃកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាតឯជន្តុគ្រាម ។ លុះត្រាច់ទៅបិណ្ឌបាត ក្នុងជន្តុគ្រាម រួចត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្តវិញហើយ ចូលទៅឯឆ្នេរស្ទឹងកិមិកាឡា លុះចូលទៅដល់ហើយ ក៏ដើរទៅដើរមក សម្រាកស្មងប្របឆ្នេរស្ទឹងកិមិកាឡា បានឃើញព្រៃស្វាយគួរជាទីជ្រះថ្លា គួររីករាយ លុះព្រះមេឃិយៈដ៏មានអាយុ បានឃើញហើយ ក៏មានសេចក្តីត្រិះរិះថា ឱហ្ន៎ ព្រៃស្វាយនេះ គួរជាទីជ្រះថ្លា គួររីករាយ ឱហ្ន៎ ព្រៃស្វាយនេះ សមគួរដល់ការព្យាយាម របស់កុលបុត្តអ្នកត្រូវការ

ដោយព្យាយាម ប្រសិនបើព្រះមានព្រះភាគ ទ្រង់អនុញ្ញាតដល់អាត្មាអញ គួរអាត្មាអញមកឯព្រៃស្វាយនេះ ដើម្បីប្រកបព្យាយាម ។ លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះមេឃិយៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ ខ្ញុំព្រះអង្គស្បៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យហើយ ចូលទៅបិណ្ឌបាត ក្នុងជន្តុគ្រាម លុះត្រាច់ទៅបិណ្ឌបាត ក្នុងជន្តុគ្រាម រួចត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្តវិញហើយ ចូលទៅឯឆ្នេរស្ទឹងកិមិកាឡា លុះចូលទៅដល់ហើយ ក៏ដើរទៅដើរមក សម្រាកស្មងប្របឆ្នេរស្ទឹងកិមិកាឡា បានឃើញព្រៃស្វាយ គួរជាទីជ្រះថ្លា គួរពីកពាយ លុះខ្ញុំព្រះអង្គបានឃើញហើយ ក៏មានសេចក្តីត្រិះរិះថា ឱហ្ន៎ ព្រៃស្វាយនេះ គួរជាទីជ្រះថ្លា គួរជាទីពីកពាយ ឱហ្ន៎ ព្រៃស្វាយនេះ សមគួរដល់ការព្យាយាមរបស់កុលបុត្ត អ្នកត្រូវការដោយព្យាយាម ប្រសិនបើព្រះមានព្រះភាគ ទ្រង់អនុញ្ញាតដល់អាត្មាអញ អាត្មាអញគួរមកព្រៃស្វាយនេះ ដើម្បីប្រកបព្យាយាម ។ បពិត្រព្រះអង្គដ៏ចម្រើន បើព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គ គួរខ្ញុំព្រះអង្គ ទៅឯព្រៃស្វាយ ដើម្បីប្រកបព្យាយាម ។

[៨៦] កាលព្រះមេឃិយៈដ៏មានអាយុ ក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះមេឃិយៈដ៏មានអាយុថា ម្នាលមេឃិយៈ អ្នកចូររង់ចាំសិន តថាគតនៅតែម្នាក់ឯងទេ ចាំកិក្ខុឯទៀតណាមួយមកសិន ។ ព្រះ

មេឃិយៈដ៏មានអាយុ នៅតែក្រាបទូលព្រះមានព្រះភាគ ជាគម្រប់ ២ ដង ទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ មិនមានកិច្ចតិចតួច ដែលត្រូវធ្វើតទៅទៀតឡើយ ទាំងមិនមានការសន្សំកិច្ចដែលទ្រង់ធ្វើស្រេចហើយ ឲ្យចម្រើនឡើងទៀតទេ បពិត្រព្រះអង្គដ៏ចម្រើន ឯខ្ញុំព្រះអង្គនៅមានកិច្ចដែលត្រូវធ្វើតទៅទៀត ទាំងនៅមានការសន្សំកិច្ច ដែលខ្ញុំព្រះអង្គធ្វើហើយ ឲ្យចម្រើនឡើងទៀត បពិត្រព្រះអង្គដ៏ចម្រើន បើព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គ គួរខ្ញុំព្រះអង្គទៅឯព្រៃស្វាយនោះ ដើម្បីប្រកបព្យាយាម ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះមេឃិយៈដ៏មានអាយុ ជាគម្រប់ ២ ដង ទៀតថា ម្នាលមេឃិយៈ អ្នកចូររង់ចាំបន្តិចសិន តថាគតនៅតែម្នាក់ឯងទេ ចាំភិក្ខុឯទៀតណាមួយមកសិន ។ ព្រះមេឃិយៈដ៏មានអាយុ នៅតែក្រាបទូលព្រះមានព្រះភាគ ជាគម្រប់ ៣ ដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ មិនមានកិច្ចតិចតួច ដែលត្រូវធ្វើតទៅទៀតឡើយ ទាំងមិនមានការសន្សំកិច្ចដែលទ្រង់ធ្វើស្រេចហើយ ឲ្យចម្រើនឡើងទៀត បពិត្រព្រះអង្គដ៏ចម្រើន ឯខ្ញុំព្រះអង្គនៅមានកិច្ច ដែលត្រូវធ្វើតទៅទៀត ទាំងនៅមានការសន្សំកិច្ច ដែលខ្ញុំព្រះអង្គធ្វើហើយ ឲ្យចម្រើនឡើងទៀត បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គ គួរខ្ញុំព្រះអង្គទៅឯព្រៃស្វាយនោះ ដើម្បីប្រកបព្យាយាម ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលមេឃិយៈ តថាគតគប្បីនិយាយនឹងអ្នក កាលនិយាយថា ព្យាយាមដូច្នេះ ដូចម្តេចបាន ម្នាលមេឃិយៈ អ្នកចូរសម្គាល់នូវកាលដែលគួរនឹងទៅ

ក្នុងកាលឥឡូវនេះចុះ ។

[៨៧] លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ បានក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចធ្វើប្រទក្សិណ ហើយចូលទៅកាន់ព្រៃស្វាយនោះ លុះចូលទៅដល់ហើយ ក៏លុកចូលទៅក្នុងព្រៃស្វាយនោះ រួចអង្គុយសម្រាកនៅវេលាថ្ងៃ ប្រហែលឈើមួយដើម ។ កាលដែលព្រះមេឃិយៈដ៏មានអាយុ នៅសម្រាកក្នុងព្រៃស្វាយនោះ អកុសលវិតក្កដ៏លាមក ៣ យ៉ាង គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហឹសាវិតក្ក ១ ផុសផុលឡើងរឿយៗ ។ លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ មានសេចក្តីត្រិះរិះថា ឱហ្ន៎ អស្ចារ្យណាស់ ឱហ្ន៎ ចម្លែកណាស់ អម្បាលអាត្មាអញ ជាអ្នកចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា នៅតែមានអកុសលវិតក្ក ដ៏លាមក ៣ យ៉ាងនោះ គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហឹសាវិតក្ក ១ គ្របសង្កត់បាន ។ លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ ចេញចាកទីសម្ងំក្នុងសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះមេឃិយៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ កាលដែលខ្ញុំព្រះអង្គកំពុងនៅក្នុងព្រៃស្វាយនោះ អកុសលវិតក្កដ៏លាមក ៣ យ៉ាង គឺកាមវិតក្ក ១ ព្យាបាទ-វិតក្ក ១ វិហឹសាវិតក្ក ១ ផុសផុលឡើងរឿយៗ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះមានសេចក្តីត្រិះរិះថា ឱហ្ន៎ អស្ចារ្យណាស់ ឱហ្ន៎ ចម្លែកណាស់

អម្បាលអាត្មាអញ ជាអ្នកចេញចាកផ្ទះទៅកាន់ផ្នួសដោយសទ្ធា នៅតែមានអកុសលវិតក្កដ៏លាមក ៣ យ៉ាង គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហឹសាវិតក្ក ១ គ្របសង្កត់បាន ។

[៨៨] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមេឃិយៈ ធម៌ ៥ យ៉ាង ប្រព្រឹត្តទៅ ដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ ម្នាលមេឃិយៈ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានមិត្តល្អ បែរទៅរកមិត្តល្អ ។ ម្នាលមេឃិយៈ នេះជាធម៌ទី ១ ប្រព្រឹត្តទៅ ដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកមានសីល សង្រួមហើយដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈ និងគោចរ ជាអ្នកឃើញភ័យ ក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលមេឃិយៈ នេះជាធម៌ទី ២ ប្រព្រឹត្តទៅ ដើម្បីធ្វើនូវចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ គឺអប្បិច្ឆកថា ១ សន្តុដ្ឋិកថា ១ បវិវេកកថា ១ អសំសគ្គកថា ១ វីរិយារម្ភកថា ១ សីលកថា ១ សមាធិកថា ១ បញ្ញាកថា ១ វិមុត្តិកថា ១ វិមុត្តិញាណទស្សនកថា ១ ដែលជាកថាផូរផង់ ជាទីសប្បាយទូលាយចិត្ត ប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ ម្នាល

មេយិយ: នេះជាធម៌ទី ៣ ប្រព្រឹត្តទៅ ដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេយិយ: មួយទៀត ភិក្ខុជាអ្នកប្រារព្ធ ព្យាយាម ដើម្បីលះអកុសលធម៌ទាំងឡាយ ដើម្បីញ្ចុាំងកុសលធម៌ទាំង-ឡាយឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងមាំមួន មិនដាក់ធុរ:ក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលមេយិយ: នេះជាធម៌ទី ៤ ប្រព្រឹត្តទៅ ដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេយិយ: មួយទៀត ភិក្ខុមានបញ្ញា ប្រកបដោយបញ្ញា ជាគ្រឿងដឹងការកើតឡើង និងសូន្យទៅ ជាប្រាជ្ញាដ៏ប្រសើរ ជាគ្រឿងទម្លុះទម្លាយកិលេសប្រព្រឹត្តទៅ ដើម្បីអស់ទុក្ខដោយប្រពៃ ។ ម្នាលមេយិយ: នេះជាធម៌ទី ៥ ប្រព្រឹត្តទៅ ដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេយិយ: ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លា ឲ្យចាស់ក្លាបាន ។ ម្នាលមេយិយ: គុណជាតន៉ុះ រមែងកើតប្រាកដ ដល់ភិក្ខុដែលមានមិត្តល្អ មានសម្លាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកមានសីល សង្រួមហើយ ដោយការសង្រួមក្នុងបាតិមោក្ខ-សំវរ: បរិបូណ៌ដោយអាចារ: និងគោចរ ជាអ្នកឃើញភ័យ ក្នុងទោសទាំង-ឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលមេយិយ: គុណជាតន៉ុះ រមែងកើតប្រាកដ ដល់ភិក្ខុដែលមានមិត្តល្អ មានសម្លាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ គឺអប្បិច្ឆកថា

១ សន្តុដ្ឋិកថា ១ បវិវេកកថា ១ អសំសគ្គកថា ១ វីរិយារម្ភកថា ១ សីលកថា ១ សមាធិកថា ១ បញ្ញាកថា ១ វិមុត្តិកថា ១ វិមុត្តិញ្ញាណ-ទស្សនកថា ១ ដែលជាកថាផូរផង់ ជាទីសប្បាយ ទូលាយចិត្ត ប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ម្នាលមេឃិយៈ គុណជាតនុ៎ះ រមែងកើតប្រាកដ ដល់ភិក្ខុដែលមានមិត្តល្អ មានសម្លាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់អកុសលធម៌ទាំងឡាយ ដើម្បីញុំាងកុសលធម៌ទាំងឡាយ ឲ្យកើតឡើង មានកម្លាំង មានសេចក្តីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលមេឃិយៈ គុណជាតនុ៎ះ រមែងមានប្រាកដ ដល់ភិក្ខុដែលមានមិត្តល្អ មានសម្លាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាជាគ្រឿងដឹងនូវការកើតឡើង និងសូន្យទៅជាប្រាជ្ញាដ៏ប្រសើរ អាចទម្លុះទម្លាយកិលេស ប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃ ។

[៨៩] *ម្នាលមេឃិយៈ មួយទៀត ភិក្ខុនោះ តាំងនៅក្នុងធម៌ ៥ យ៉ាងនេះហើយ ត្រូវចម្រើនធម៌ ៤ យ៉ាងតទៅទៀត គឺចម្រើនអសុភ ដើម្បីលះរាគៈ ១ ចម្រើនមេត្តា ដើម្បីលះព្យាបាទ ១ ចម្រើនអានាបានស្សតិ ដើម្បីផ្តាច់បង់វិតក្ក ១ ចម្រើនអនិច្ចសញ្ញា ដើម្បីដកអស្មិមានៈ ១ ។ ម្នាលមេឃិយៈ ព្រោះថា កាលភិក្ខុមានសេចក្តីសម្គាល់ថា មិនទៀងហើយ សេចក្តី*

សម្គាល់ថា មិនមែនខ្លួន រមែងតាំងនៅ (ក្នុងចិត្ត) ភិក្ខុដែលមានសេចក្តីសម្គាល់ថា មិនមែនខ្លួន រមែងដល់នូវការដកអស្មិមានៈ ឈ្មោះថា ដល់និព្វានក្នុងបច្ចុប្បន្ន ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺខទាននេះ ក្នុងវេលានោះថា

> *វិតក្កទាំងឡាយ ដ៏ថោកទាប វិតក្កទាំងឡាយ ដ៏ល្អិត ដែលចិត្តប្រព្រឹត្តទៅតាមហើយ ធ្វើចិត្តឲ្យច្នៃងកន្ទ្រើង បុគ្គលមិនដឹងច្បាស់សេចក្តីត្រិះរិះនៃចិត្តទាំងនុ៎ះទេ ជាអ្នកមានចិត្តក្លាក់ផ្អើល សុះទៅសុះមក កាន់អារម្មណ៍ផ្សេងៗ ។ ឯអ្នកប្រាជ្ញដឹងច្បាស់សេចក្តីត្រិះរិះ នៃចិត្តទាំងនុ៎ះហើយ ជាអ្នកមានព្យាយាម ជាគ្រឿងជុតបំផ្ងាញកិលេស មានស្មារតី បិទខ្ទប់វិតក្កទាំងឡាយ ដែលចិត្តប្រព្រឹត្តទៅតាម ហើយធ្វើចិត្តឲ្យច្នៃងកន្ទ្រើង លះបង់វិតក្កទាំងនុ៎ះ មិនឲ្យសេសសល់ ។ សូត្រទី ១ ។*

អដ្ឋកថា

មេឃិយវគ្គទី ៤

មេឃិយសូត្រ

មេឃិយសូត្រទី ១ នៃមេឃិយវគ្គទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

[៨៥] *បទថា* **ចាលិកាយំ** *បានដល់ ជិតក្រុងឈ្មោះយ៉ាងនេះ ។ បានឮថា ហួសទ្វារនោះទៅ មានភក់កម្រើកដោយជុំវិញ ។ ព្រោះនៅជិតភក់ដែលកម្រើក ទើបនគរនោះប្រាកដដល់អ្នកដែលមើល ដូចកំពុងកម្រើក ព្រោះដូច្នោះ ទើបនគរនោះ គេហៅថា* **ចាលិកា** ។ *បទថា* **ចាលិកេ បព្វតេ** *សេចក្តីថា ក្នុងទីជិតនគរនោះ មានភ្នំមួយ ភ្នំនោះក៏ប្រាកដដល់អ្នកមើល ហាក់ដូចជាញ័រដែរ ក្នុងថ្ងៃឧបោសថខាងរនោច ព្រោះភ្នំនោះសស្មុទ្ធ ទើបភ្នំនោះហៅថា ចាលិកបព្វត ។ ជនទាំងឡាយបាននាំគ្នាសាងវិហារធំក្នុងទីនោះ ថ្វាយដល់ព្រះមានព្រះភាគ ។ ក្នុងកាលនោះ ព្រះមានព្រះភាគ ទ្រង់បានធ្វើនគរនោះ ឲ្យជាគោចរគ្រាម ប្រថាប់នៅក្នុងវិហារ ក្បែរចាលិកបព្វតនោះ ដោយហេតុនោះ ទើបលោកពោលថា ទ្រង់គង់នៅទៀបចាលិកបព្វត ជិតក្រុងចាលិកា ។*

បទថា **មេឃិយោ** *ជាឈ្មោះរបស់ព្រះថេរៈនោះ ។ បទថា* **ឧបដ្ឋាកោ ហោតិ** *បានដល់ ជាអ្នកបម្រើ ។ ពិតហើយ ក្នុងបឋមពោធិកាល ព្រះមានព្រះភាគមិនមានឧបដ្ឋាកជាប្រចាំឡើយ ជួនកាលមានព្រះនាគសមាលៈ ជួនកាលមានព្រះនាគិតៈ ជួនកាលព្រះឧបវាណ ជួនកាលព្រះសុនក្ខត្តៈ ។ ជួន*

កាលព្រះចុន្ទសមណុទ្ទេស ជួនកាលព្រះសាគតៈ ជួនកាលព្រះមេឃិយៈ ។ ក្នុងគ្រានោះ ព្រះមេឃិយត្ថេរនោះឯងជាឧបដ្ឋាក ។ ដោយហេតុនោះ ទើបលោកពោលថា សម័យនោះឯង ព្រះមេឃិយៈជាឧបដ្ឋាកព្រះមានព្រះភាគ ។

បទថា **ជន្តុគាមំ** *បានដល់ វិហារនោះឯង មានគោចរគ្រាមជាទៃដែលមានយ៉ាងនោះ ។ បាលីថា* **ជន្តុគាមំ** *ដូច្នេះក៏មាន ។ បទថា* **កិមិកាឆ្បាយ** *បានដល់ នៃស្ទឹងដែលបានឈ្មោះថា* **កិមិកាឆ្បា** *ព្រោះមានសត្វល្អិតពណ្ណច្រើន ។ បទថា* **ជង្ឃាវិហារំ** *សេចក្តីថា ត្រាច់ទៅដើម្បីបន្ទោបង់នូវការហត់នឿយ ដែលកើតត្រង់ស្មង ព្រោះអង្គុយយូរ ។ បទថា* **ចាសាធិកំ** *សេចក្តីថា ឈ្មោះថា ជ្រះថ្លា ព្រោះនាំការជ្រះថ្លាមកដល់អ្នកឃើញ ព្រោះមានជើមឈើមិនធ្លាយ និងមានស្លឹកមូលល្អ ។ ឈ្មោះថា* **មនុញ្ញំ**[1] *ព្រោះមានមូលល្អ និងព្រោះមានភូមិភាគគួរជាទីត្រេកអរ ។ ឈ្មោះថា* **រមណីយំ** *ព្រោះធ្វើចិត្តឲ្យរីករាយ ដោយអត្ថថា ធ្វើអ្នកចូលទៅខាងក្នុង ឲ្យកើតបីតិសោមនស្ស ។ បទថា* **អលំ** *ប្រែថា អាច ឬប្រែថា គួរ ក៏បាន ។ បទថា* **បធានត្តិកស្ស** *បានដល់ ជាអ្នកមានការអប់រំព្យាយាម ។ បទថា* **បធានាយ** *បានដល់ ដោយការធ្វើសមណធម៌ ។ បទថា* **អាគន្តុយ្យាហំ** *កាត់បទជា* **អាគន្តុយ្យំ អហំ** *។ បានឮថា កាលមុន ទីនោះជាព្រះរាជឧទ្យាន ដែលព្រះថេរៈធ្លាប់ជាព្រះរាជា គ្រប់គ្រងមក ៥០០ ជាតិតាមលំដាប់ ដោយហេតុនោះ ទើបចិត្តរបស់ព្រះថេរៈបង្អោនទៅដើម្បីនៅក្នុងទីនោះ ក្នុងខណៈគ្រាន់*

-បទនេះ បិដកខ្មែរ មិនមាន ។

តែបានឃើញប៉ុណ្ណោះ ។

[៨៦] *បទថា* **អាគមេហិ តាវ** *សេចក្តីថា ព្រះសាស្តា កាលទ្រង់ស្តាប់ពាក្យរបស់ព្រះថេរៈហើយ កាលទ្រង់ពិចារណា ទើបទ្រង់ជ្រាបថា ញាណរបស់លោកមិនទាន់ចាស់ក្លា ទើបត្រាស់ហាមយ៉ាងនេះ ។ ដើម្បីឲ្យលោកកើតចិត្តទន់ភ្លន់ឡើងថា កាលបើដូច្នេះ ព្រះថេរៈនេះទៅហើយ កាលកម្មមិនទាន់សម្រេច ក៏មិនសង្វេយ និងត្រឡប់មក ដោយអំណាចការស្រឡាញ់ ទើបត្រាស់ពាក្យនេះថា តថាគតនៅតែម្នាក់ឯងទេ ។ បទថា* **យាវ អញ្ញោបិ កោចិ ភិក្ខុ អាគច្ឆតិ** *សេចក្តីថា ចូរអ្នកបង្អង់សិន ទម្រាំភិក្ខុណាមួយមកកាន់សម្នាក់តថាគត ។ បាលីថា* **កោចិ ភិក្ខុ ឯស្សតិ** *ភិក្ខុណាមួយ និងប្រែកដូច្នេះក៏មាន ។ អាចារ្យពួកខ្លះពោលថា* **អាគច្ឆតុ ។** *ពួកខ្លះពោលថា* **ឯស្សតុ** *ដូចគ្នា ។ បទថា* **ឆត្តំ កិញ្ចិ ឧត្តរិ ករណីយំ** *សេចក្តីថា ព្រោះទ្រង់ធ្វើកិច្ច ១៦ មានបរិញ្ញាកិច្ចជាដើម ក្នុងសច្ចៈ ៤ ដោយមគ្គ ៤ ឬព្រោះទ្រង់សម្រេចអភិសម្ពោធិញ្ញាណ ឈ្មោះថា ករណីយកិច្ចដទៃដែលក្រៃលែងជាងនោះ មិនមាន ។ បទថា* **ឆត្តំ កតស្ស វា បដិចយោ** *សេចក្តីថា កិច្ចដែលទ្រង់ធ្វើស្រេចហើយ ក៏មិនចាំបាច់សន្សំតទៅក្តី ។ ដល់មគ្គដែលទ្រង់ឲ្យកើតតទៅ ឬកិលេសដែលទ្រង់លះបានហើយ មិនមានកិច្ចដែលលះបង់ទៀត ។ បទថា* **អត្ថិ កតស្ស បដិចយោ** *សេចក្តីថា ព្រោះខ្ញុំព្រះអង្គមិនទាន់សម្រេចអរិយមគ្គ ទើបខ្ញុំព្រះអង្គចាំបាច់សន្សំ ពោល គឺចម្រើនតទៅដើម្បីធម៌ មានសីលជាដើម ដែលសម្រេចក្នុងសន្តានរបស់ខ្ញុំព្រះអង្គ ។ បទ*

ថា **បធានន្តិ ទោ មេឃិយ វទមានំ កិន្តិ វទេយ្យាម** សេចក្តីថា តថាគត មិនពោលឈ្មោះអ្វីមួយដទៃជាមួយអ្នក ដែលកំពុងពោលថា នឹងធ្វើសមណ-ធម៌នោះ ។

[៨៦] បទថា **ឧវាវិហារំ និសីឧិ** សេចក្តីថា ព្រះថេរៈអង្គុយសម្រាកក្នុងពេលថ្ងៃ ។ ព្រះថេរៈអង្គុយ ក៏អង្គុយលើផ្ទាំងសិលាមង្គល ដែលកាលមុនធ្លាប់ជាព្រះរាជា ៥០០ ជាតិតាមលំដាប់ ទ្រង់លេងក្នុងព្រះរាជឧទ្យានចោមរោមដោយស្រីស្នំផ្សេងៗ ។ តែកាលលោកអង្គុយហើយ ភាវៈនៃសមណៈហាក់ដូចជាបាត់ទៅ ហាក់ដូចជាប្រែភេទក្លាយជាព្រះរាជា ចោមរោមដោយបរិវារស្រីស្នំ អង្គុយលើបល្ល័ង្កដែលមានតម្លៃច្រើន ខាងក្រោមស្វេតច្ឆត្រ ។ កាលលោកត្រេកអរក្នុងសម្បត្តិនោះ កាមវិតក្កក៏កើតឡើង ។ ខណៈនោះ លោកបានឃើញហាក់ដូចជាចោរ ២ នាក់ ដែលគេចាប់មក មួយអន្ទើដោយភស្តុតាង គេនាំមកឈរចំពោះមុខ ក្នុងចោរ ២ នាក់នោះ ព្យាបាទវិតក្កកើតឡើង ដោយអំណាចការបញ្ជាឲ្យសម្លាប់ចោរម្នាក់ វិហិង្សាវិតក្កកើតឡើងដោយអំណាចការបញ្ជាឲ្យចងចោរម្នាក់ ។ កាលបើដូច្នោះ លោកបានជាអ្នកចោមរោមដេរដាសដោយអកុសលវិតក្ក ដូចដើមឈើធំ ត្រូវចោមរោមដោយវល្ជិ និងដូចសម្បុកឃ្ចុំ ចោមរោមដោយឃ្ចុំ ដូច្នោះ ។ លោកសំដៅយកអាការនោះ ទើបពោលថា **អថ្ថទោ អាយស្មតោ មេឃិយស្ស** ដូច្នេះជាដើម ។

បានព្ថថា ពាក្យថា **អច្ឆរិយំ វត ភោ** នេះ ឈ្មោះថា អស្ចារ្យក្នុងការតិះដៀល ដូចព្រះអានន្ទឃើញព្រះមានព្រះភាគ មានព្រះសរីរៈប្រែប្រួលទៅ

*ព្រោះមានស្នាមជ្រីវជ្រួញ ទើបទូលថា គួរអស្ចារ្យណាស់ ព្រះអង្គ រឿងមិនធ្លាប់មាន ... ។ តែអាចារ្យមួយពួកទៀតពោលថា សម័យនោះ កាមវិតក្កកើតឡើងដល់លោកដោយអំណាចលោភៈក្នុងផ្កា ផ្លែឈើ និងត្រួយឈើជាដើម ព្យាបាទវិតក្កកើតឡើង ព្រោះបានឮសំឡេងបក្សីដែលស្រែកខ្ទាំង វិហិង្សាវិតក្កកើតឡើង ព្រោះបំណងឃាត់បក្សីទាំងនោះ ដោយដុំដីជាដើម កាមវិតក្កកើតឡើង ព្រោះប្រាថ្នាក្នុងទីនោះថា អញនឹងនៅក្នុងទីនេះឯង ព្យាបាទវិតក្កកើតឡើង ព្រោះបានឃើញព្រានព្រៃទាំងឡាយ ក្នុងទីនោះៗ ហើយមានចិត្តប្រទូស្តក្នុងព្រានព្រៃទាំងនោះ វិហិង្សាវិតក្កកើតឡើង ព្រោះបំណងបៀតបៀនព្រានព្រៃទាំងនោះ ដូច្នេះក៏មាន ។ ការដែលមិច្ឆាវិតក្កកើតឡើង ដល់លោកយ៉ាងណាមួយនោះឯង ជាហេតុគួរអស្ចារ្យ ។ បទថា **អច្ឆាសត្តា** ប្រែថា តាមជាប់ជំពាក់ គឺជេរជាស ។ ការនិយាយច្រើនក្នុងភាពជាបុគ្គលម្នាក់ឯង ក៏ប្រាកដ ទាំងក្នុងខ្លួន និងក្នុងគ្រួ ។ បាលីថា **អច្ឆាសត្តោ** ដូច្នេះក៏មាន ។*

បទថា **យេន ភគវា តេនុបសង្កមិ** *សេចក្តីថា ព្រះថេរៈស្អែកស្អុះទៅដោយមិច្ឆាវិតក្កយ៉ាងនេះ មិនអាចធ្វើកម្មដ្ឋានឲ្យជាសប្បាយ ទើបកំណត់ថា ព្រះមានព្រះភាគ ទ្រង់ឃើញកាលវែង បានឃើញហេតុដែលគួរអស្ចារ្យនេះហ្ន៎ ទើបទ្រង់ហាម គិតថា អញនឹងក្រាបទូលហេតុនេះ ដល់ព្រះទសពល ទើបក្រោកឡើងចាកអាសនៈដែលអង្គុយ ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ស្រេចហើយ បានក្រាបទូលរឿងរបស់ខ្លួន ដោយន័យជាដើមថា* **៥ឆ មយ្ហំ ភន្តេ** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **យេភុយ្យេន** *បានដល់ ច្រើនជង គឺរឿយៗ។ បទថា* **ចាបលា** *ប្រែថា លាមក ។ បទថា* **អកុសលា** *ប្រែថា កើតអំពីអកុសល ។ ម្យ៉ាងទៀត ឈ្មោះថា* **ចាបលា** *ព្រោះអត្ថថា នាំសត្វឲ្យដល់ទុគ្គតិ ឈ្មោះថា* **អកុសលា** *ព្រោះជាសត្រូវចំពោះកុសល ។ ឈ្មោះថា* **វិតក្កោ** *ព្រោះត្រិះរិះ គឺគិត បានដល់ លើកចិត្តទ្បើងកាន់អារម្មណ៍ ។ វិតក្ក ដែលកើតព្រមនឹងកាម ឈ្មោះថា កាមវិតក្ក អធិប្បាយថា វិតក្កដែលសម្បយុត្តដោយកិលេសកាម មានវត្ថុកាមជាអារម្មណ៍ វិតក្កដែលកើតព្រមនឹងព្យាបាទ ឈ្មោះថា ព្យាបាទវិតក្ក វិតក្កដែលកើតព្រមដោយវិហិង្សា ឈ្មោះថា វិហិង្សាវិតក្ក ក្នុងវិតក្កទាំងនោះ ធម៌ដែលជាសត្រូវចំពោះនេក្ខម្ម: ដែលប្រព្រឹត្តទៅដោយអំណាចការត្រេកអរក្នុងកាម ឈ្មោះថា កាមវិតក្ក ធម៌ដែលជាសត្រូវចំពោះមេត្តា ដែលប្រព្រឹត្តទៅដោយអំណាចការប្រទូស្ត ដល់សត្វទាំងឡាយ ដោយគិតថា ចូរឲ្យសត្វទាំងនេះក្តៅក្រហាយចុះ ចូរវិនាសចុះ ឬកុំបីមាន ឈ្មោះថា ព្យាបាទវិតក្ក ធម៌ដែលជាសត្រូវចំពោះករុណា ដែលប្រព្រឹត្តទៅដោយអំណាចភាពជាបុគ្គល ដែលបំណងនឹងបៀតបៀនសត្វដោយបហរណាវត្ថុ មានបាតដៃ ដុំដី និងដំបងជាដើម ឈ្មោះថា វិហិង្សា-វិតក្ក ។*

ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យលោកទៅក្នុងទីនោះ ព្រោះទ្រង់អនុញ្ញាតដោយទ្រង់ព្រះតម្រិះថា មេឃិយៈនេះ សូម្បីតថាគតមិនអនុញ្ញាត ក៏គង់លះបង់តថាគតទៅ ហើយមេឃិយៈ នឹងមានការគិតដទៃថា

ប្រហែលជាព្រះមានព្រះភាគ មិនអនុញ្ញាតឲ្យអញទៅ ព្រោះបំណងឲ្យអញជាអ្នកប្រតិបត្តិ សេចក្តីនោះគប្បីប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខអស់កាលយូរដល់មេឃិយៈ ។

កាលលោកអង្គុយក្រាបទូលរឿងរ៉ាវរបស់ខ្លួនយ៉ាងនេះ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ដែលជាសប្បាយដល់លោក ទើបត្រាស់ពាក្យជាដើមថា ម្នាលមេឃិយៈ ធម៌ ៥ យ៉ាង ប្រព្រឹត្តទៅ ដើម្បីធ្វើចេតោវិមុត្តិដែលមិនទាន់ចាស់ក្លា ឲ្យចាស់ក្លាបាន ដូច្នេះ ។

[៨៨] *បណ្តាបទទាំងនោះ បទថា* **អបរិបក្កាយ** *ប្រែថា មិនទាន់ដល់នូវការចាស់ក្លា ។ បទថា* **ចេតោវិមុត្តិយា** *បានដល់ ចិត្តរួចផុតអំពីកិលេស ។ ពិតហើយ ខាងដើម ចិត្តរមែងរួចផុតចាកកិលេស ដោយតទង្គ-វិមុត្តិ និងវិក្ខម្ភនវិមុត្តិ ខាងក្រោយ រមែងរួចផុតដោយសមុច្ឆេទវិមុត្តិ និងបដិបស្សទ្ធិវិមុត្តិ វិមុត្តិនេះ ខ្ញុំពោលពិស្តារហើយខាងដើមនោះឯង ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបដោយនយតាមដែលពោលហើយ ក្នុងអធិការដែលពោលអំពីវិមុត្តិនោះ ។ ក្នុងសេចក្តីនោះ កាលលោកបន្ទុំ គឺបណ្តុះអធ្យាស្រ័យឲ្យក្លាក់រឭក ដោយធម៌ជាគ្រឿងបន្ទុំវិមុត្តិ កាលវិបស្សនាកាន់យកបន្ទប់មគ្គដល់នូវភាពចាស់ក្លា ចេតោវិមុត្តិ ឈ្មោះថា ចាស់ក្លា កាលវិបស្សនាមិនទាន់កាន់យកបន្ទប់មគ្គ ឈ្មោះថា មិនទាន់ចាស់ក្លា ។ ធម៌ជាគ្រឿងអប់រំបន្ទុំវិមុត្តិដូចម្តេច គឺគប្បីជ្រាបធម៌ ១៥ យ៉ាង ដោយធ្វើសទ្ធិន្ទ្រិយជាដើមឲ្យបរិសុទ្ធ សមដូចលោកពោលក្នុងបដិសម្ភិទាមគ្គថា*

សទ្ធិន្ទ្រិយ បរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលឥតសទ្ធា ១ សេព គប់ គប់រក ចូលទៅអង្គុយជិត បុគ្គលដែលមានសទ្ធា ១ ពិចារណាព្រះសូត្រដែលជាទីជ្រះថ្លា ១ ។

វីរិយិន្ទ្រិយ បរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលខ្ជិលច្រអូស ១ សេព គប់ គប់រក ចូលទៅអង្គុយជិត បុគ្គលដែលមានសេចក្តីព្យាយាម ១ ពិចារណាសម្មប្បធាន ១ ។

សតិន្ទ្រិយ បរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលភ្លេចស្មារតី ១ សេព គប់ គប់រក ចូលទៅអង្គុយជិត បុគ្គលដែលមានស្មារតីតម្កល់មាំ ១ ពិចារណាសតិប្បដ្ឋាន ១ ។

សមាធិន្ទ្រិយ បរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលមានចិត្តមិននឹងធឹង ១ សេព គប់ គប់រក ចូលទៅអង្គុយជិត បុគ្គលដែលមានចិត្តនឹងធឹង ១ ពិចារណាឈាន និងវិមោក្ខ ១ ។

បញ្ញិន្ទ្រិយ បរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលអប្បឥតបញ្ញា ១ សេព គប់ គប់រក ចូលទៅអង្គុយជិត បុគ្គលដែលមានបញ្ញា ១ ពិចារណានូវញាណចរិយាដ៏ជ្រៅ ១ នេះឯង ឥន្ទ្រិយទាំង ៥ បរិសុទ្ធដោយអាការ ១៥ នេះ ដូច្នេះ ។

ធម៌ ១៥ ប្រការដទៃទៀត ជាគ្រឿងបន្ទុំវិមុត្តិ គឺឥន្ទ្រិយ ៥ មានសទ្ធាជាដើម សញ្ញា ជាចំណែកនៃការត្រាស់ដឹងទាំង ៥ គឺអនិច្ចសញ្ញា ទុក្ខសញ្ញា អនត្តាសញ្ញា បហានសញ្ញា វិរាគសញ្ញា ភាពជាអ្នកមានកល្យាណមិត្រ

សង្រ្គមក្នុងសីល ជាអ្នកជុសខាត់ក្រៃលែង ការប្រារព្ធសេចក្តីព្យាយាម បញ្ញា ដែលប្រព្រឹត្តទៅក្នុងចំណែកនៃការត្រាស់ដឹង ។

បណ្តាធម៌ទាំងនោះ ព្រះសាស្តាទ្រង់ជាអ្នកឈ្វាសក្នុងការដឹកនាំវ៉ៃនេយ្យ-បុគ្គល កាលទ្រង់សម្តែងធម៌ដែលជាគ្រឿងបន្ទុំវិមុត្តិ មានកល្យាណមិត្រជាដើមក្នុងទីនេះ តាមអធ្យាស្រ័យរបស់ព្រះមេឃិយត្ថេរ បុគ្គលដែលគួរដឹកនាំ ទើបត្រាស់ថា ធម៌ទាំងនេះរមែងប្រព្រឹត្តទៅ ដើម្បីការចាស់ក្លា កាលឲ្យធម៌ទាំងនោះពិស្តារ ទើបត្រាស់ពាក្យជាដើមថា ម្នាលមេឃិយៈ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានមិត្តល្អ បែរទៅរកមិត្តល្អ ។

បណ្តាបទទាំងនោះ បទថា **កល្យាណមិត្តោ** *សេចក្តីថា ឈ្មោះថាកល្យាណមិត្រ ព្រោះមានមិត្រល្អ គឺចម្រើន ប្រសើរ ។ បុគ្គលដែលមានមិត្រសម្បូរដោយសីលគុណជាដើម មានឧបការៈដោយអាការទាំងពួងយ៉ាងនេះ គឺបំបាត់ទុក្ខ សាងនូវហិតប្រយោជន៍ ឈ្មោះថា កល្យាណមិត្រពិត ។ ឈ្មោះថា* **កល្យាណសហាយោ**[1] *ព្រោះទៅ គឺប្រព្រឹត្តទៅជាមួយដោយកល្យាណបុគ្គល តាមដែលពោលហើយនោះឯង គឺមិនប្រព្រឹត្តទៅប្រាសចាកកល្យាណមិត្តបុគ្គលទាំងនោះ ។ ឈ្មោះថា* **កល្យាណសម្បវង្កោ** *ព្រោះប្រព្រឹត្តទៅដោយការៈ ដែលបង្អោនទៅតាមផ្លូវចិត្ត និងកាយ ក្នុងកល្យាណ-បុគ្គលនោះឯង ។ ដោយ ៣ បទ រមែងញុំាងនូវការអើពើឲ្យកើតឡើង ក្នុងការសេពគប់កល្យាណមិត្រ ។*

-បិដកខ្មែរ មិនមានបទនេះ ។

ក្នុងសេចក្តីនោះ កល្យាណមិត្រមានលក្ខណៈដូចតទៅនេះ កល្យាណមិត្រក្នុងព្រះសាសនានេះ ជាអ្នកជល់ព្រមដោយសទ្ធា សីល សុតៈ ចាគៈ វិរិយៈ សតិ សមាធិ និងបញ្ញា ។ ក្នុងលក្ខណៈកល្យាណមិត្រនោះ បុគ្គលមានសទ្ធាសម្បត្តិ រមែងជឿបញ្ជាត្រាស់ដឹងរបស់ព្រះតថាគត កម្ម និងផលនៃកម្ម មិនលះបង់ការស្វែងរកប្រយោជន៍ដល់ពួកសត្វ ដែលជាហេតុនៃសម្មាសម្ពោធិញ្ញាណ ដោយការជឿនោះ មានសីលសម្បត្តិជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព សរសើរ ជាអ្នកចោទ ជាអ្នកតិះដៀលបាប ជាអ្នកពោលក្នុងការអត់ធន់ចំពោះពាក្យរបស់សព្រហ្មចារីទាំងឡាយ មានសុតសម្បត្តិ រមែងធ្វើពាក្យដែលជ្រៅ ទាក់ទងដោយសច្ចៈ និងបដិច្ចសមុប្បាទជាដើម មានចាគសម្បត្តិ រមែងជាអ្នកមានការជ្រាបថ្នាតិច សន្តោស គាប់ចិត្តក្នុងទីស្ងាត់ មិនច្រឡូកច្រឡំដោយពួកគណៈ មានវិរិយសម្បត្តិ រមែងជាអ្នកផ្តើមសេចក្តីព្យាយាម ដើម្បីបដិបត្តិប្រយោជន៍ដល់សត្វទាំងឡាយ មានសតិសម្បត្តិ តែងមានសតិតាំងមាំ មានសមាធិសម្បត្តិ រមែងជាអ្នកមានចិត្តមិនរាយមាយ មានចិត្តជាសមាធិ មានបញ្ញាសម្បត្តិ រមែងដឹងសភាវៈដែលមិនខុស ។ បុគ្គលនោះ ជាអ្នកជល់ព្រមដោយគតិធម៌ ដែលជាកុសលដោយសតិ ដឹងវត្ថុដែលមានប្រយោជន៍ និងមិនមានប្រយោជន៍ នៃសត្វទាំងឡាយ តាមសេចក្តីពិតដោយបញ្ញា ជាអ្នកមានចិត្តក្នុងកុសលធម៌ទាំងនោះដោយសមាធិ រមែងបៀតបៀនសត្វទាំងឡាយចាកវត្ថុដែលមិនជាប្រយោជន៍ ហើយនាំចូលទៅក្នុងវត្ថុដែលជាប្រយោជន៍ ដោយវិរិយៈ ។ ដោយហេតុនោះ ទើបលោកពោលក្នុង

អដ្ឋកថានិកាយ សត្តកនិបាតថា

កិកូជាអ្នក (ធ្វើខ្លួន) ឲ្យជាទីស្រឡាញ់ផង គួរគោរពផង គួរសរសើរផង ឧស្សាហ៍ប្រៀនប្រដៅផង អត់ធន់ចំពោះពាក្យផង ជាអ្នកនិយាយពាក្យជ្រៅផង ទាំងមិនដឹកនាំក្នុងហេតុដែលមិនគួរផង ... ។

បទថា **អយំ បឋមោ ធម្មោ បរិហាកាយ សំវត្តតិ** *សេចក្តីថា ធម៌ដែលមិនមានទោសនេះ ពោល គឺភាពជាអ្នកមានមិត្រល្អ ឈ្មោះថា ជាទី ១ ព្រោះជាខាងដើមនៃព្រហ្មចរិយាវាស និងព្រោះត្រាស់ជាបឋមក្នុងធម៌ ៥ ប្រការនេះ ដោយមានឧបការៈច្រើនដល់កុសលធម៌ទាំងពួង និងដោយភាពជាប្រធាន រមែងប្រព្រឹត្តទៅដើម្បីការចាស់ក្លានៃចេតោវិមុត្តិ ដោយធ្វើសទ្ធាជាដើមដែលមិនបរិសុទ្ធ ឲ្យបរិសុទ្ធ ។ ក្នុងទីនេះ ភាពដែលកល្យាណមិត្រមានឧបការៈច្រើន និងជាប្រធាន គប្បីជ្រាបដោយសុត្តបទជាដើមថា ម្នាលអានន្ទ អ្នកកុំនិយាយយ៉ាងនេះឡើយ ឯភាពនៃបុគ្គលអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន នេះចាត់ជាមគ្គព្រហ្មចរិយៈទាំងមូល ទ្រង់បដិសេធព្រះអានន្ទ ដែលជាឃ្លាំងធម៌ ដែលពោលថា បពិត្រព្រះអង្គដ៏ចម្រើន ភាពនៃបុគ្គលអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន នេះជាគុណពាក់កណ្តាល របស់មគ្គព្រហ្មចរិយៈនេះ អស់ភារៈ ២ ដងថា* **មា ហេវំ អានន្ទ** *ប្រែថា ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ ។*

បទថា **បុន ចបរំ** ប្រែថា ធម៌ដទៃទៅមានតទៅទៀត ។ ក្នុងបទថា **សីលវា** នេះ មានវិនិច្ឆ័យដូចតទៅនេះ ដែលឈ្មោះថា សីល ព្រោះអត្ថដូចម្តេច ដែលឈ្មោះថា សីល ព្រោះអត្ថថា តាំងមាំ ។ ដែលឈ្មោះថា តាំងមាំ គឺអ្វី គឺតម្កល់មាំដោយល្អ អធិប្បាយថា ភាពដែលកាយកម្មជាដើម សព្វគ្គិសម ព្រោះភាពជាបុគ្គលមានសីលល្អ ។ ម្យ៉ាងទៀត ជាទីទ្រទ្រង់ អធិប្បាយថា ជាទីទ្រទ្រង់ដោយភាពជាទីតាំងនៃកុសលធម៌ មានឈានជាដើម ព្រោះដូច្នោះ ទើបឈ្មោះថា សីល ព្រោះទទួល ឬទ្រទ្រង់ ។ នេះជាអត្ថនៃសីល ដោយន័យនៃលក្ខណៈរបស់សព្វជាលំដាប់ដំបូង ។ តែអាចារ្យមួយពួកទៀត ពណ៌នាអត្ថដោយនិរុត្តិន័យថា អត្ថនៃសីល មានអត្ថថា ក្បាល មានអត្ថថា ត្រជាក់ មានអត្ថថា តាំងមាំ មានអត្ថថា សង្រួម ។ សីលនេះ មានជាមួយបុគ្គលនោះដោយគ្រប់គ្រាន់ ឬដោយល្អបំផុត ព្រោះដូច្នោះ ទើបឈ្មោះថា **សីលវា** គឺជាអ្នកមានសីល អធិប្បាយថា ជាអ្នកបរិបូណ៌ដោយសីល ។

ម្យ៉ាងទៀត ដើម្បីនឹងសម្តែងប្រការដែលបុគ្គលជាអ្នកមានសីល បរិបូណ៌ដោយសីល ទើបត្រាស់ពាក្យជាដើមថា **ចាតិមោក្ខសំវរសំវុតោ** ជូចេ្នះ ។

អធិប្បាយពាក្យថា ចាតិមោក្ខ

បណ្តាបទទាំងនោះ បទថា **ចាតិមោក្ខំ** បានដល់ សីលក្នុងសិក្ខាបទ ។ ពិតហើយ សីលក្នុងសិក្ខាបទនោះ ឈ្មោះថា **ចាតិមោក្ខ** ព្រោះអត្ថថា ធ្វើបុគ្គលដែលព្យាយាមរក្សាសីលសិក្ខាបទនោះឲ្យផុតចាកទុក្ខ មានទុក្ខក្នុងអបាយ

ជាដើម ។ ការរាំង ឈ្មោះថា **សំវរ** *បានដល់ ការមិនកន្លងល្មើសតាមកាយ និងវាចា ។* **សំវរ** *គឺបាតិមោក្ខ ឈ្មោះថា* **ចាតិមោក្ខសំវរ ។** *កិក្ខុដែលសង្រួម គឺមានកាយ និងវាចាបិទដោយបាតិមោក្ខសំវរៈនោះ ទើបឈ្មោះថា សង្រួមដោយបាតិមោក្ខសំវរៈ នេះជាការសម្តែងភាវៈដែលកិក្ខុនោះតាំងនៅក្នុងសីលនោះ ។ បទថា* **វិហរតិ** *ជាបទសម្តែងភាវៈដែលកិក្ខុដល់ព្រមដោយការនៅដ៏សមគួរ ដោយបាតិមោក្ខសំវរៈនោះ ។ បទថា* **អាចារ-គោចរសម្បន្នោ** *ជាបទសម្តែងដល់ធម៌ដែលមានឧបការៈដល់បាតិមោក្ខសំវរៈថ្នាក់ទាប និងដល់សេចក្តីព្យាយាម ដើម្បីគុណវិសេសខាងលើ ។ បទថា* **អណុមត្តេសុ វជ្ជេសុ ភយទស្សាវី** *ជាបទសម្តែងភាវៈដែលកិក្ខុមិនឃ្លាតចាកបាតិមោក្ខសំវរសីលជាធម្មតា ។ បទថា* **សមាទាយ** *ជាបទសម្តែងការកាន់យកសិក្ខាបទ ដោយមិនមានចំណែកសល់ ។ បទថា* **សិក្ខតិ** *ជាបទសម្តែងភាវៈដែលកិក្ខុដល់ព្រមដោយការសិក្សា ។ បទថា* **សិក្ខាបទេសុ** *ជាបទសម្តែងធម៌ដែលគួរសិក្សា ។*

ម្យ៉ាងទៀត ឈ្មោះថា **ចាតិ** *ព្រោះមានប្រក្រតីធ្លាក់ទៅក្នុងអបាយច្រើនជង ព្រោះកិលេសខ្លាំងក្លា ព្រោះធ្វើសេចក្តីអាក្រក់បានងាយ និងព្រោះការធ្វើបុណ្យបានលំបាក បានដល់ បុថុជ្ជន ។ ម្យ៉ាងទៀត ឈ្មោះថា* **ចាតិ** *ព្រោះត្រូវកម្លាំងកម្មបន្សាត់ទៅក្នុងភពជាដើម ដោយភាវៈមិនទៀង និងមានប្រក្រតីទៅដោយការវិលវល់ ដោយកំណត់មិនបាន ដូចប្រដាប់យោងទឹក ដូចឆ្នាំងយន្ត ។ ម្យ៉ាងទៀត ឈ្មោះថា* **ចាតិ** *ព្រោះមានប្រក្រតីធ្លាក់ទៅនៃអត្តភាព*

ក្នុងសត្តនិកាយនោះៗ ដោយអំណាចមរណៈ ឬសន្តានរបស់សត្វ គឺចិត្តនោះឯង ។ ឈ្មោះថា **ចាតិមោក្ខ** ព្រោះធ្លាក់ទៅផុតអំពីសង្សារទុក្ខ ។ សត្វដែលហៅថា **វិមុត្តិ** ព្រោះចិត្តរួចផុត ។ សមដូចពាក្យដែលលោកពោលថា **ចិត្តភាវនាយ សត្តា វិសុជ្ឈន្តិ** សត្វមានចិត្តផូរផង់ រមែងបរិសុទ្ធ និងពោលថា **អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តំ** ចិត្តរួចផុតចាកអាសវៈ ព្រោះមិនប្រកាន់មាំ ។ ម្យ៉ាងទៀត ឈ្មោះថា **ចាតិ** ព្រោះធ្លាក់ទៅ គឺទៅ បានដល់ប្រព្រឹត្តទៅក្នុងសង្សារ ដោយហេតុ មានអវិជ្ជាជាដើម សមដូចលោកពោលថា ទីបំផុតខាងដើមរបស់សត្វទាំងឡាយ ដែលមានអវិជ្ជាជារនាំង មានតណ្ហាជាចំណង អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ។ ធម៌ ឈ្មោះថា **ចាតិមោក្ខ** ព្រោះជាហេតុឲ្យសត្វធ្លាក់ទៅនោះ ផុតចាកសង្កិលេស ៣ មានតណ្ហាជាដើម ។ គប្បីជ្រាបការសម្រេចសមាស ដូចការសម្រេចពាក្យជាដើមថា **តណ្ហាកាលោ។**

ម្យ៉ាងទៀត ឈ្មោះថា **ចាតិ** ព្រោះធ្វើសត្វឲ្យធ្លាក់ទៅ គឺឲ្យធ្លាក់ទៅមិនសល់អំពីទុក្ខ បានដល់ ចិត្ត ។ សមដូចលោកពោលថា ចិត្តតែងនាំសត្វលោកទៅ ចិត្តតែងកើចកន្ត្រាក់សត្វលោកទៅ ។ ឈ្មោះថា **ចាតិមោក្ខ** ព្រោះជាគ្រឿងធ្វើសត្វដែលធ្លាក់ទៅនោះ ឲ្យផុតទៅអំពីទុក្ខ ។ ម្យ៉ាងទៀត ឈ្មោះថា **ចាតិ** ព្រោះជាគ្រឿងធ្លាក់ទៅក្នុងអបាយទុក្ខ និងសង្សារទុក្ខរបស់សត្វ បានដល់ សង្កិលេស មានតណ្ហាជាដើម ។ សមដូចលោកពោលថា តណ្ហាតែងញាំងបុរសឲ្យកើត និងពោលថា បុរសមានតណ្ហាជាគម្រប់ពីរ

ឈ្មោះថា **ចាតិមោក្ខ** *ព្រោះផុតអំពីការធ្លាក់ទៅចាកតណ្ហា និងសង្កិលេស នោះ ។ ម្យ៉ាងទៀត ឈ្មោះថា* **ចាតិ** *ព្រោះជាទីធ្លាក់ទៅនៃសត្វ បានដល់ អាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ សមដូចលោកពោលថា សត្វលោកកើតឡើងព្រោះវត្ថុ ៦ ធ្វើសេចក្តីស្និទ្ធស្នាលព្រោះវត្ថុ ៦ ។ ឈ្មោះ ថា* **ចាតិមោក្ខ** *ព្រោះផុតអំពីការធ្លាក់ទៅ ពោល គឺអាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ នោះ ។ ម្យ៉ាងទៀត ឈ្មោះថា* **ចាតិ** *គឺសង្ឃរ ព្រោះមានការធ្លាក់ទៅ គឺការធ្វើឲ្យធ្លាក់ទៅ ឈ្មោះថា* **ចាតិមោក្ខ** *ព្រោះផុត ចាកសង្ឃរនោះ ។*

ម្យ៉ាងទៀត ព្រះមានព្រះភាគ ជាធម្មិស្សរៈ សត្វលោកថ្វាយព្រះនាម ថា **បតិ** *ព្រោះជាអធិបតីនៃលោកទាំងពួង ។ ឈ្មោះថា* **មោក្ខ** *ព្រោះជា គ្រឿងរួចផុតរបស់សត្វ ។ ឈ្មោះថា* **បតិមោក្ខ** *ព្រោះជាគ្រឿងរួចផុតនៃ ព្រះមានព្រះភាគ ដែលបានឈ្មោះថា* **បតិ** *ព្រោះទ្រង់បញ្ញត្តិ ។ បតិមោក្ខ នោះឯង ជាបាតិមោក្ខ ។ ម្យ៉ាងទៀត ឈ្មោះថា* **បតិមោក្ខ** *ព្រោះព្រះមាន ព្រះភាគអង្គនោះ ឈ្មោះថា ជាធំ ដោយអត្ថថា មានគុណទាំងពួងឧត្តមដែល មានគុណនោះជាមូល និងឈ្មោះថា ជាអ្នករួចផុត ដោយអត្ថតាមដែលពោល ហើយ ។ បតិមោក្ខនោះឯង ជាបាតិមោក្ខ ។ សមដូចពាក្យដែលលោកពោល ថា ពាក្យថា* **ចាតិមោក្ខ** *នេះ ជាមុខ និងជាប្រមុខ ។ គប្បីជ្រាបសេចក្តី ពិស្តារដូចតទៅនេះ*

ម្យ៉ាងទៀត សព្ទថា **ប** *ប្រើក្នុងអត្ថថា* **បការ** *សព្ទថា* **អតិ** *ជានិបាត

ប្រើក្នុងអត្ថថា អច្ចន្ត ។ ព្រោះដូច្នោះ ទើបឈ្មោះថា **ចាតិមោក្ខ** ព្រោះកន្ទង ផុតចំណែកគ្រប់ប្រការ ។ ពិតហើយ សីលនោះឈ្មោះថា ជាតិមោក្ខ ព្រោះ តួសីលធ្វើឲ្យរួចផុតបានពិត ដោយតទង្គវិមុត្តិ ដែលប្រកបដោយសមាធិ និង បញ្ញា ធ្វើឲ្យរួចផុតបានពិត ដោយអំណាចវិក្ខម្ភនវិមុត្តិ និងសមុច្ឆេទវិមុត្តិ ។ ម្យ៉ាងទៀត ឈ្មោះថា **ចាតិមោក្ខ** ព្រោះរួចផុតចំពោះ អធិប្បាយថា រួចផុត ចាកវីតិក្កមទោសនោះៗ ដោយចំពោះ ។ បតិមោក្ខនោះឯង ជាជាតិមោក្ខ ។ ឬថា និព្វាន ឈ្មោះថា **មោក្ខ។** ឈ្មោះថា **បតិមោក្ខ** ព្រោះប្រៀបផៀបនឹង **មោក្ខ** នោះ ។ ពិតហើយ សីលសំវរៈ ជាហេតុធ្វើព្រះនិព្វានឲ្យកើត ដូច ព្រះអាទិត្យធ្វើអរុណឲ្យកើត និងមានចំណែកប្រៀបដូចព្រះនិព្វាននោះ ព្រោះ ធ្វើកិលេសឲ្យរលត់តាមសមគួរ ។ បតិមោក្ខនោះឯង ជាជាតិមោក្ខ ។ ម្យ៉ាង ទៀត ឈ្មោះថា បតិមោក្ខ ព្រោះប្រែប្រួលទៅ គឺធ្វើទុក្ខឲ្យផុតទៅ ។ បតិ-មោក្ខនោះឯង ជាជាតិមោក្ខ ក្នុងសេចក្តីនេះ គប្បីជ្រាបតាមសព្ទថា **ចាតិ-មោក្ខ** ប៉ុណ្ណោះ យ៉ាងនេះ ដោយប្រការដូច្នេះ ។

ឈ្មោះថា **សំវរ** ព្រោះជាគ្រឿងរារាំង ។ **សំវរ** គឺជាតិមោក្ខ ឈ្មោះថា **ចាតិមោក្ខសំវរ** ។ តែបើពោលដោយអត្ថ បានដល់ វៀរចាកទោសដែល គប្បីឈានកន្ទងនោះៗ និងចេតនា ។ ភិក្ខុដែលចូលដល់ប្រកបដោយជាតិ-មោក្ខសំវរៈនោះ លោកហៅថា ជាអ្នកសង្រួមដោយជាតិមោក្ខសំវរៈ ។ សម ដូចទ្រង់ត្រាស់ក្នុងគម្ពីរវិភង្គថា ពាក្យថា ជាអ្នកសង្រួម គឺជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រមដោយ

ការសង្រ្គមក្នុងបាតិមោក្ខនេះ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកសង្រ្គមក្នុងបាតិមោក្ខសំវរៈ ។

បទថា **វិហរតិ** *សេចក្តីថា រមែងនៅ គឺផ្សាស់ប្តូរ បានដល់ ផ្សាស់ប្តូរដោយឥរិយាបថវិហារ ។*

បទថា **អាចារគោចរសម្បន្នោ** *សេចក្តីថា ឈ្មោះថា ដល់ព្រមដោយអាចារ និងគោចរ ព្រោះវៀរអនាចារទាំងពួង ព្រោះមិនធ្វើមិច្ឆាជីវៈ មានការឲ្យឫស្សីជាដើម និងការឆ្នាំឆ្គងកាយជាដើម ហើយប្រកបដោយអាចារសម្បត្តិដែលសមគួរដល់ភិក្ខុ ដែលត្រាស់យ៉ាងនេះថា ការមិនកន្ទងល្មើសតាមកាយ តាមវាចា និងទាំងតាមកាយ ទាំងតាមវាចា និងវៀរចាកអគោចរ មានលំនៅស្រីពេស្យាជាដើម ហើយប្រកបដោយគោចរ ពោល គឺដែលសមគួរចូលទៅបិណ្ឌបាតជាដើម ។*

ម្យ៉ាងទៀត ភិក្ខុណា មានសេចក្តីគោរពកោតក្រែងក្នុងព្រះសាស្តា មានការគោរពកោតក្រែងក្នុងសព្រហ្មចារី ដល់ព្រមដោយហិរិឱត្តប្បៈ ស្បៃកជណ្តប់រៀបរយ មានការឈានទៅមុខ ឈានថយក្រោយ មើលទៅមុខ ក្រឡេកមើលឆ្វេងស្តាំ បត់ លាត គួរជ្រះថ្លា សម្បូរដោយឥរិយាបថ គ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ស្គាល់ប្រមាណក្នុងភោជន ដល់ព្រមដោយសេចក្តីព្យាយាម ប្រកបដោយសតិ និងសម្បជញ្ញៈ ជាអ្នកប្រាថ្នាតិច សន្តោស ពេញចិត្តក្នុងទីស្ងាត់ មិនច្រឡូកច្រឡំដោយពួកគណៈ ធ្វើសេចក្តីគោរពក្នុងអភិសមាចារិកវត្ត ច្រើនដោយការគោរព និងកោតក្រែង ភិក្ខុនេះ លោកហៅថា សម្បូរដោយ

អាចារ ។

ឯគោចរមាន ៣ យ៉ាង គឺឧបនិស្សយគោចរ ១ អារក្ខគោចរ ១ ឧប-
និពន្ធគោចរ ១ ក្នុងគោចរ ៣ យ៉ាងនោះ ភិក្ខុណាប្រកបដោយគុណ គឺកថា-
វត្ថុ ១០ មានកល្យាណមិត្តជួចពោលហើយ ដែលអាស្រ័យហើយ រមែង
បានស្តាប់នូវធម៌ដែលមិនធ្លាប់ស្តាប់ រមែងធ្វើធម៌ដែលធ្លាប់ស្តាប់ហើយ ឲ្យ
ផូរផង់ កាត់សេចក្តីសង្ស័យចេញបាន ធ្វើទិដ្ឋិឲ្យត្រង់ ធ្វើចិត្តឲ្យជ្រះថ្លា កាល
សិក្សាតាម រមែងចម្រើនដោយសទ្ធា ដោយសីល ដោយសុតៈ ដោយចាគៈ
និងដោយបញ្ញា នេះលោកហៅថា ឧបនិស្សយគោចរ ។ ភិក្ខុណាចូលទៅកាន់
ចន្លោះស្រុក ដើរទៅតាមវិថី មានភ្នែកជាក់ចុះ សម្លឹងមើលមួយជួរនឹម ដើរ
សង្រួមចក្ខុន្ទ្រិយទៅ មិនដើរមើលពលដំរី មិនដើរមើលពលសេះ មិនដើរ
មើលពលរថ មិនដើរមើលពលថ្មើរជើង មិនដើរមើលស្រី មិនដើរមើល
ប្រុស មិនងើយមើល មិនឱនមើល មិនក្រឡេកមើល តាមទិសតូច-ធំ នេះ
លោកហៅថា អារក្ខគោចរ ។ ឯឧបនិពន្ធគោចរ បានដល់ សតិប្បដ្ឋាន ៤
ដែលជាទីភិក្ខុគួរចូលទៅចងចិត្តរបស់ខ្លួន ។ សមដូចព្រះមានព្រះភាគត្រាស់
ថា ម្នាលភិក្ខុទាំងឡាយ ចុះទីជាទីគោចររបស់ភិក្ខុ ជារំដែននៃបិតារបស់ខ្លួន
តើដូចម្តេច ។ គឺសតិប្បដ្ឋានទាំង ៤ នេះឯង ដូច្នេះ ។ ក្នុងគោចរ ៣ យ៉ាង
នោះ ព្រោះឧបនិស្សយគោចរ លោកពោលហើយ ក្នុងទីនេះ គប្បីជ្រាប
គោចរ ២ យ៉ាងក្រៅអំពីនោះ ។ ភិក្ខុនោះ ឈ្មោះថា បរិបូរដោយអាចារ
និងគោចរ ព្រោះប្រកបដោយអាចារសម្បត្តិតាមដែលពោលហើយ និង

គោចរសម្បត្តិនេះ ដោយប្រការដូច្នេះ ។

បទថា **អណុមត្តេសុ វជ្ជេសុ ភយទស្សាវី** *សេចក្តីថា ជាអ្នកមានប្រក្រតីឃើញភ័យក្នុងទោស មានសេក្ខិយសិក្ខាបទ ដែលកិក្ខុមិនគ្រែងត្រូវអាបត្តិ និង អកុសលចិត្តុប្បាទជាដើម ឈ្មោះថា មានប្រមាណតិច ព្រោះមានប្រមាណតិចតួច ។ ពិតហើយ កិក្ខុណាឃើញទោសមានប្រមាណតិច ធ្វើឲ្យដូចភ្នំសិនេរុដែលមានកម្ពស់ ១ សែន ៦ ម៉ឺន ៨ ពាន់យោជន៍ ឯកិក្ខុណាឃើញអាបត្តិត្រឹមតែទុព្ភាសិត ដែលជាអាបត្តិស្រាលជាងអាបត្តិទាំងពួង ធ្វើឲ្យដូចអាបត្តិបារាជិក កិក្ខុនេះឈ្មោះថា មានប្រក្រតីឃើញភ័យក្នុងទោស មានប្រមាណតិច ។ បទថា* **សមាទាយ សិក្ខតិ សិក្ខាបទេសុ** *សេចក្តីថា កិក្ខុទាញយកសិក្ខាបទដែលគួរសិក្សាណាមួយ ក្នុងសិក្ខាបទទាំងអស់ ដោយមិនមានចំណែកសល់ ដោយប្រការទាំងពួង សិក្សា អធិប្បាយថា រមែងប្រព្រឹត្ត គឺធ្វើឲ្យបរិបូណ៌ដោយប្រពៃ ។*

បទថា **អភិសល្លេខិកា** *បានដល់ ជាអ្នកមានប្រក្រតីដុសខាត់កិលេសយ៉ាងតឹងរ៉ឹង គឺជាបុគ្គលសមគួរដើម្បីលះកិលេសទាំងនោះ ដោយធ្វើឲ្យស្រាលស្តើង ។ បទថា* **ចេតោវិវរណសប្បាយា** *បានដល់ ឃើញសប្បាយរបស់សមថៈ និងវិបស្សនា ពោល គឺបើកចិត្ត ដោយធ្វើនីវរណៈដែលជាតួបិទបាំងចិត្តឲ្យធ្លាយ សមថៈ និងវិបស្សនានោះឯងជាសប្បាយ គឺជាឧបការៈដល់ការបើកចិត្ត ឬការធ្វើចិត្តនោះឯងឲ្យប្រាកដ ហេតុដូច្នោះ ទើបឈ្មោះថា* **ចេតោ-វិវរណសប្បាយា** *ជាសប្បាយក្នុងការបើកចិត្ត ។*

ឥទ្ធូវនេះ កាលនឹងសម្តែងហេតុ ជាគ្រឿងនាំមកនូវការនឿយណាយជាដើម ដែលជាកថាជុំសខាត់កិលេស និងជាសប្បាយក្នុងការបើកចិត្ត ទើបត្រាស់ពាក្យជាដើមថា **ឯកន្តនិព្ពិទាយ** *ជូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **ឯកន្តនិព្ពិទាយ** *បានដល់ ដើម្បីនឿយណាយចាកវដ្តទុក្ខដោយពិតនោះឯង ។ បទថា* **វិរាគាយ ឯរោធាយ** *បានដល់ដើម្បីប្រាសចាកតម្រេក និងដើម្បីរម្ងាប់វដ្តទុក្ខនោះឯង ។ បទថា* **ឧបសមាយ** *បានដល់ ដើម្បីស្ងប់កិលេសទាំងពួង ។ បទថា* **អភិញ្ញាយ** *បានដល់ ដើម្បីដឹងត្រៃលក្ខណ៍នូវធម៌ដែលគួរដឹងត្រៃលក្ខណ៍ទាំងអស់ ។ បទថា* **សម្ពោធាយ** *បានដល់ ដើម្បីត្រាស់ដឹងមគ្គចិត្ត ៤ ។ បទថា* **និព្ពានាយ** *បានដល់ ដើម្បីអនុបាទិសេសនិព្វានធាតុ ។ បណ្តាបទទាំងនោះ ត្រាស់វិបស្សនា ដោយ ៣ បទខាងដើម ។ ត្រាស់មគ្គដោយបទទាំង ២ ត្រាស់និព្វានដោយបទទាំង ២ លោកសម្តែងថា ឧត្តរិមនុស្សធម្មទាំងអស់នេះ ផ្តើមអំពីសមថៈ និងវិបស្សនារហូតដល់និព្វានជាទីបំផុត រមែងកើតមានដល់បុគ្គលដែលបាននូវកថាវត្ថុ ១០ ។*

ឥទ្ធូវនេះ កាលទ្រង់ចែកកថានោះ ទើបត្រាស់ពាក្យជាដើមថា **អប្បិច្ឆកថា** *ជូច្នេះ ។*

កថាវត្ថុ ១០

បណ្តាបទទាំងនោះ បទថា **អប្បិច្ឆោ** *ប្រែថា ជាអ្នកមិនប្រាថ្នា ។ កថានៃអប្បិច្ឆនោះ ឈ្មោះថា* **អប្បិច្ឆកថា** *ឬកថាដែលទាក់ទងដោយភាពជាអ្នក*

ប្រាថ្នាតិច ឈ្មោះថា **អប្បិច្ឆកថា ។** *ក្នុងទីនេះ ពោលដោយអំណាចសេចក្តីប្រាថ្នា មានបុគ្គល ៤ ពួក គឺ* **អត្រិច្ឆោ** *បុគ្គលប្រាថ្នាក្រៃលែងឧឡឹងៗ ១* **ចាមិច្ឆោ** *បុគ្គលប្រាថ្នាលាមក ១* **មហិច្ឆោ** *បុគ្គលប្រាថ្នាច្រើន ១* **អប្បិច្ឆោ** *បុគ្គលប្រាថ្នាតិច ១ ។ ក្នុងបុគ្គល ៤ ពួកនោះ បុគ្គលមិនឆ្អែតដោយលាភតាមដែលខ្លួនបានមក ប្រាថ្នាក្រៃលែងឧឡឹងៗ ឈ្មោះថា* **អត្រិច្ឆ** *ដែលលោកពោលហើយក្នុងមិត្តវិន្ទកជាតកថា*

> *អ្នកចេញអំពីវេមានិកប្រេត ៤ នាក់ទៅ ក៏បាននូវវេមានិកប្រេត ៨ នាក់ (ចេញ) អំពីវេមានិកប្រេត ៨ នាក់ទៅ ក៏បាននូវវេមានិកប្រេត ១៦ នាក់ (ចេញ) អំពីវេមានិកប្រេត ១៦ នាក់ទៅ ក៏បាននូវវេមានិកប្រេត ៣២ នាក់ អ្នកកាលប្រាថ្នាខ្លាំងពេកទើបមកប្រទះនឹងចក្ក ចំណែកខាងចក្ក ក៏វិលកិនអំបែងក្បាលរបស់សត្វ ដែលត្រូវសេចក្តីច្រណែនបៀតបៀន ដូច្នេះ ។*

និងដែលត្រាស់ក្នុងអសិតាកុជាតកថា បុគ្គលមានសេចក្តីប្រាថ្នាលើសលុប រមែងសាបសូន្យចាកប្រយោជន៍ ព្រោះលោភហួសហេតុផង ព្រោះសេចក្តីស្រើឯក្នុងការចង់បានហួសហេតុផង ... ដូច្នេះ ។ បុគ្គលមានបំណងក្នុងការសរសើរគុណដែលមិនមាន ឈ្មោះថា ប្រាថ្នាលាមក ព្រោះត្រូវការក្នុងលាភសក្ការៈ និងសំឡេងសរសើរ ដែលលោកសំដៅយក ពោលក្នុងខុទ្ទកវិភង្គថា បណ្តាធម៌ទាំងនោះ ការកុហក តើដូចម្តេច ។ ការប្រុងប្រៀបខាងដើម អាការប្រុងប្រៀប ការរៀបចំនូវឥរិយាបថ ការធ្វើមុខស្រពោន ការ

មានមុខស្រពោន ការធ្វើគេឲ្យស្ងើច អាការធ្វើគេឲ្យស្ងើច ភាពនៃសេចក្តីធ្វើគេឲ្យស្ងើច ដោយការសេពនូវបច្ច័យក្តី ដោយការខ្ជឹបខ្ជែវក្តី របស់កិកុអ្នកអាស្រ័យលាភសក្ការៈ និងការសរសើរ ... ដូច្នេះ ។ ដែលមានបំណងក្នុងការសរសើរគុណដែលមាន និងមិនដឹងប្រមាណក្នុងការទទួល ឈ្មោះថា ជាអ្នកប្រាថ្នាច្រើន ដែលលោកសំដៅយក ពោលក្នុងខុទ្ទកវិភង្គថា បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា ប្រាថ្នាថា ចូរជនដឹងនូវអញ ថាជាអ្នកមានសទ្ធា ជាអ្នកទ្រុស្តសីល ប្រាថ្នាថា ចូរជនដឹងនូវអញ ថាជាអ្នកមានសីល ... ដូច្នេះ ។ ពិតហើយ សូម្បីម្តាយបង្កើត ក៏មិនអាចនឹងយកចិត្តបុគ្គលនោះបាន ដោយហេតុនោះ ទើបលោកពោលពាក្យនេះថា

> បុគ្គលណា ឲ្យបច្ច័យដ៏ច្រើន ពេញរនេះ ក៏មិនញុំាងសភាវៈ ៣ គឺគំនរភ្លើង ១ មហាសមុទ្រ ១ បុគ្គលប្រាថ្នាច្រើន ១ ឲ្យឆ្អែតបានឡើយ ។

បុគ្គលវៀរទោស មានភាពជាអ្នកប្រាថ្នាច្រើនជាដើមនេះឲ្យឆ្ងាយ ហើយមានបំណងលាក់គុណដែលមាន និងស្គាល់ប្រមាណក្នុងការទទួល ឈ្មោះថាជាអ្នកប្រាថ្នាតិច ព្រោះបុគ្គលប្រាថ្នានឹងចិទគុណដែលមានក្នុងខ្លួន ទោះបីមានសទ្ធាក៏មិនប្រាថ្នាថា សូមបុគ្គលស្គាល់អាត្មាអញ ថាជាអ្នកមានសទ្ធា ទោះបីមានសីល មានសុតៈច្រើន គាប់ចិត្តក្នុងទីស្ងាត់ ប្រារព្ធសេចក្តីព្យាយាម មានសតិតាំងមាំ មានចិត្តជាសមាធិ មានបញ្ញា ក៏មិនប្រាថ្នាថា សូមបុគ្គលស្គាល់អាត្មាអញ ថាជាអ្នកមានបញ្ញា ។

បុគ្គលប្រាថ្នាតិចនេះ មាន ៤ ពួក គឺប្រាថ្នាតិចក្នុងបច្ច័យ ១ ប្រាថ្នាតិចក្នុងធុតង្គ ១ ប្រាថ្នាតិចក្នុងបរិយត្តិ ១ ប្រាថ្នាតិចក្នុងអធិគម ១ ក្នុង ៤ ពួកនោះ បុគ្គលប្រាថ្នាតិចក្នុងបច្ច័យ ៤ ពិនិត្យមើលអ្នកឲ្យបច្ច័យ ទេយ្យធម៌និងកម្លាំងរបស់ខ្លួន បើទេយ្យធម៌មានច្រើន ទាយកប្រាថ្នានឹងឲ្យតិច ក៏ទទួលតែបន្តិច ដោយអំណាចទាយក ។ បើទេយ្យធម៌មានតិច ទាយកប្រាថ្នានឹងឲ្យច្រើន ក៏ទទួលតែបន្តិច ដោយអំណាចទេយ្យធម៌ ។ បើទេយ្យធម៌មានច្រើនផង ទាយកប្រាថ្នានឹងឲ្យច្រើនផង គួរដឹងកម្លាំងរបស់ខ្លួន ហើយទទួលតែល្មមប្រមាណប៉ុណ្ណោះ កិក្ខុបែបនេះរមែងធ្វើលាភ ដែលមិនទាន់កើតឲ្យកើតឡើង រមែងធ្វើលាភដែលកើតឡើងហើយ ឲ្យស្ថិតស្ថេរ ញុំាងចិត្តទាយកទាំងឡាយឲ្យត្រេកអរ ជាអ្នកមិនបំណងឲ្យដឹងថា ការសមាទានធុតង្គដែលមានក្នុងខ្លួនឈ្មោះថា ប្រាថ្នាតិចក្នុងធុតង្គ ។ បុគ្គលណា មិនប្រាថ្នាឲ្យអ្នកដទៃដឹងថាខ្លួនជាពហូសូត បុគ្គលនេះឈ្មោះថា ជាអ្នកប្រាថ្នាតិចក្នុងបរិយត្តិ ។ ឯបុគ្គលណាជាព្រះអរិយបុគ្គលថ្នាក់សោតាបន្នជាដើមណាមួយ ក៏មិនប្រាថ្នាឲ្យសព្រហ្មចារីដឹងថា ខ្លួនជាព្រះសោតាបន្នជាដើម បុគ្គលនេះឈ្មោះថា ជាអ្នកប្រាថ្នាតិចក្នុងអធិគម ។ កថាដែលប្រព្រឹត្តទៅដោយអំណាចនៃការប្រកាសទោស និងអានិសង្ស មានអាការជាអនេក និងដោយអំណាចប្រកាសទោសរបស់ឥច្ឆាចារ ដែលមានភាពជាបុគ្គលប្រាថ្នាច្រើនជាដើម ជាបដិបក្ខចំពោះការប្រាថ្នាតិចនោះ មួយអន្ទើដោយវិធី មានការចង្អុលដល់សេចក្តីត្រេកអរ ក្នុងការប្រាថ្នាតិចនៃបុគ្គលអ្នកប្រាថ្នាតិចនេះ ឈ្មោះថា កថាពោលដោយការប្រាថ្នាតិច ដោយ

ប្រការដូច្នេះ ។

សន្តុដ្ឋិកថា

បទថា **សន្តុដ្ឋិ** *ក្នុងពាក្យថា* **សន្តុដ្ឋិកថា** *នេះ បានដល់ ការត្រេកអរ រៀងៗ ខ្លួន គឺដោយរបស់ដែលខ្លួនបានមក ឈ្មោះថា សន្តុដ្ឋិ ។ ម្យ៉ាងទៀត ការលះសេចក្តីប្រាថ្នាក្នុងបច្ច័យដែលមិនស្មើ ហើយត្រេកអរក្នុងបច្ច័យដែលស្មើ ឈ្មោះថា សន្តុដ្ឋិ ។ ម្យ៉ាងទៀត សេចក្តីត្រេកអរដោយរបស់ដែលមានគឺប្រាកដ ឈ្មោះថា សន្តុដ្ឋិ ។ សមដូចពាក្យដែលលោកពោលថា*

> *បុគ្គលមិនសោកស្តាយ ដល់របស់ដែលជាអតីត មិនកន្ទក់កន្ទេញ ដល់របស់ដែលជាអនាគត ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយរបស់ជាបច្ចុប្បន្ន លោកហៅថា ជាអ្នកសន្តោស ។*

ម្យ៉ាងទៀត សេចក្តីត្រេកអរដោយបច្ច័យ ដោយវិធីដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ដោយញ្ញាយធម៌ ដោយប្រពៃ ឈ្មោះថា សន្តុដ្ឋិ ដោយអត្ថ បានដល់ សន្តោសក្នុងបច្ច័យតាមមានតាមបាន ។ សន្តោសនោះ មាន ១២ យ៉ាង ១២ យ៉ាងនោះ ដូចម្តេចខ្លះ គឺសន្តោសដោយចីវរ មាន ៣ យ៉ាង គឺយថាលាភសន្តោស ១ យថាពលសន្តោស ១ យថាសារុប្បសន្តោស ១ ។ សន្តោសក្នុងបិណ្ឌបាតជាដើមក៏ដូចគ្នា ។

ក្នុងសន្តោសទាំងនោះ មានសេចក្តីអធិប្បាយដោយប្រការដូចតទៅនេះ ភិក្ខុក្នុងធម្មវិនយនេះ បានចីវរល្អក្តី មិនល្អក្តី លោកញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរនោះឯង មិនប្រាថ្នាចីវរដទៃ ទោះបីបានក៏មិនទទួល អាការនៃ

ភិក្ខុនោះ ឈ្មោះថា យថាលាភសន្តោសក្នុងចីវរ ។ តែកាលលោកទុព្វលភាព តាមប្រក្រតី ឬត្រូវជំងឺតម្កាត់គ្របសង្កត់ លោកដណ្តប់ចីវរធ្ងន់ រមែងលំបាក លោកប្តូរចីវរធ្ងន់នោះជាមួយភិក្ខុដែលរាប់អានគ្នា ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយចីវរស្រាល ក៏ឈ្មោះថា ជាអ្នកសន្តោសពិត អាការរបស់ភិក្ខុនេះ ឈ្មោះថា យថាលាភសន្តោសក្នុងចីវរ ។ ភិក្ខុមួយរូបទៀត បានចីវរមានតម្លៃច្រើនផ្ាំងណាមួយ មានចីវរធ្វើអំពីសូត្រជាដើម គិតថា ចីវរនេះសមគួរដល់ព្រះថេរៈ ដែលជាអ្នកបួសយូរ នេះសមគួរដល់ព្រះថេរៈដែលជាពហុសូត នេះសមគួរដល់ព្រះថេរៈដែលមានជំងឺ នេះសមគួរដល់ព្រះថេរៈ ដែលមានលាភតិច ទើបប្រគេនដល់ព្រះថេរៈទាំងនោះ ហើយស្វែងរកសំពត់ ដែលមានជាយអំពីគំនរសំរាមជាដើមដោយខ្លួនឯង ធ្វើសង្ឃាដី ឬទទួលចីវរចាស់របស់លោកទាំងនោះ មកស្ឡៀកដណ្តប់ ក៏ចាត់ថា ជាអ្នកសន្តោសដោយពិត អាការរបស់ភិក្ខុនោះ ឈ្មោះថា យថាសារុប្បសន្តោសក្នុងចីវរ ។ ម្យ៉ាងទៀត ភិក្ខុក្នុងធម្មវិនយនេះ បានបិណ្ឌបាតដែលអន់ក្តី ប្រណីតក្តី លោកញុំាងអត្ត-ភាពឲ្យប្រព្រឹត្តទៅ ដោយបិណ្ឌបាតនោះឯង មិនប្រាថ្នាបិណ្ឌបាតជាទៃ ទោះបីបានក៏មិនទទួល អាការរបស់ភិក្ខុនេះ ឈ្មោះថា យថាលាភសន្តោសក្នុងបិណ្ឌបាត ។ កាលលោកមានជំងឺតម្កាត់ បរិភោគបិណ្ឌបាតដែលអន់ៗ ដែលជារបស់ស្វែងតាមប្រក្រតី ឬស្វែងចំពោះជំងឺ ដល់នូវភាពជាបុគ្គលមានរោគធ្ងន់ លោកប្រគេនដល់ភិក្ខុដែលរាប់អានគ្នា បរិភោគភោជនដែលជាសប្បាយ អំពីដៃរបស់ភិក្ខុដែលរាប់អានគ្នានោះ ធ្វើសមណធម៌ ក៏ឈ្មោះថា ជាអ្នក

សន្តោសពិត អាការរបស់ភិក្ខុនោះ ឈ្មោះថា យថាពលសន្តោសក្នុងបិណ្ឌ-
បាត ។ ភិក្ខុមួយរូបទៀត បានបិណ្ឌបាតប្រណីត គិតថា បិណ្ឌបាតនេះ
សមគួរដល់ព្រះថេរៈដែលបួសយូរជាដើម ប្រគេនដល់ព្រះថេរៈទាំងនោះ ដូច
ចីវរដែរ ឬកាន់យកបាត្រ ដែលជារបស់ព្រះថេរៈទាំងនោះ ត្រាច់ទៅបិណ្ឌ-
បាតដោយខ្លួនឯង ហើយឆាន់អាហារលាយ ឈ្មោះថា ជាអ្នកសន្តោសពិត
អាការរបស់ភិក្ខុនោះ ឈ្មោះថា យថាសារុប្បសន្តោសក្នុងបិណ្ឌបាត ។ សេនា-
សនៈដែលដល់ភិក្ខុក្នុងធម្មវិនយនេះ ទោះជាទីពេញចិត្ត ឬមិនពេញចិត្តក្តី
ដោយហោច ខ្មួមដែលប្រក់ដោយស្មៅក្តី កម្រាលស្មៅក្តី លោកត្រេកអរ
ដោយសេនាសនៈនោះឯង ឬសេនាសនៈជនៃដែលល្អជាង ដែលមកដល់
តាមក្រោយក៏មិនទទួល អាការរបស់ភិក្ខុនោះ ឈ្មោះថា យថាលាភសន្តោស
ក្នុងសេនាសនៈ ។ កាលលោកអាពាធ មានរាងកាយទុព្វល បាននូវសេនា-
សនៈ ដែលស្វែងតាមប្រក្រតី ឬស្វែងដល់ជំងឺ កាលនៅក៏មិនមានជាសុក
លោកឲ្យសេនាសនៈនោះដល់ភិក្ខុដែលលោកពេញចិត្ត ហើយក្នុងសេនាសនៈ
ដែលជាសប្បាយរបស់ភិក្ខុនោះ ធ្វើសមណធម៌ ក៏រាប់ថា ជាអ្នកសន្តោស
ពិត អាការរបស់ភិក្ខុនោះ ឈ្មោះថា យថាពលសន្តោស ក្នុងសេនាសនៈ ។
ភិក្ខុមួយរូបទៀត មិនទទួលសេនាសនៈល្អ សូម្បីដល់លំដាប់លោក ដោយ
គិតថា សេនាសនៈនេះ ជារបស់ប្រណីត ជាទីតាំងនៃសេចក្តីប្រមាទ ឬបាន
សេនាសនៈប្រណីត មានគុហា មណ្ឌប និងកូដាគារជាដើម ព្រោះលោក
មានបុណ្យច្រើន លោកប្រគេនសេនាសនៈ ទាំងនោះដល់ព្រះថេរៈដែលបួស

យូរជាដើម ដូចជាចីវរជាដើម ទោះបីនៅក្នុងទីណាមួយ ក៏ឈ្មោះថា ជាអ្នក សន្តោសដោយពិត អាការរបស់ភិក្ខុនោះ ឈ្មោះថា យថាសារុប្បសន្តោស ក្នុងសេនាសនៈ ។

ម្យ៉ាងទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានភេសជ្ជៈថាកថយក្តី ប្រណីតក្តី លោកត្រេកអរដោយភេសជ្ជៈនោះឯង មិនប្រាថ្នាភេសជ្ជៈដទៃ ទោះបីបានក៏ មិនទទួល អាការរបស់ភិក្ខុនោះ ឈ្មោះថា យថាលាភសន្តោសក្នុងគិលាន-ប្បច្ចយ ។ កាលលោកត្រូវការប្រេង បានទឹកអំពៅ លោកប្រគេនទឹកអំពៅ នោះដល់ភិក្ខុដែលលោកពេញចិត្ត ធ្វើភេសជ្ជៈដោយប្រេង ដែលបានមកអំពី ដៃរបស់ភិក្ខុ ដែលលោកពេញចិត្តនោះ ធ្វើសមណធម៌ ក៏ចាត់ថា ជាអ្នក សន្តោសពិត អាការរបស់ភិក្ខុនោះ ឈ្មោះថា យថាពលសន្តោសក្នុងគិលាន-ប្បច្ចយ ។ ភិក្ខុមួយរូបទៀតមានបុណ្យច្រើន បានភេសជ្ជដែលប្រណីត មាន ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើមច្រើន លោកឲ្យភេសជ្ជៈនោះដល់ព្រះថេរៈ ដែលបួសយូរជាដើម ដូចចីវរដែរ ប្រកបភេសជ្ជៈ ដោយវត្ថុណាមួយ ដែល ខ្លួនបានមកអំពីព្រះថេរៈទាំងនោះ ក៏ឈ្មោះថា ជាអ្នកសន្តោសពិត ចំណែក ភិក្ខុណា ជាក់សម៉ត្រាំដោយទឹកមូត្រក្នុងភាជនៈមួយ ជាក់ចតុមធុរសនៅក្នុង ភាជនៈមួយ កាលអ្នកដទៃពោលថា វត្ថុណាដែលលោកម្ចាស់ត្រូវការ សូម យកចុះ បើរោគរបស់លោករម្ងាប់ទៅដោយភេសជ្ជៈណាមួយ បណ្តាភេសជ្ជៈ ទាំងនោះ លោករឭកដល់ព្រះតម្រាស់ថា ឈ្មោះថា សម៉ត្រាំដោយទឹកមូត្រ នេះ បណ្ឌិតទាំងឡាយ មានព្រះសម្ពុទ្ធជាដើមសរសើរហើយ បព្វជ្ជាអាស្រ័យ

កេសជ្ជៈដែលត្រាំដោយទឹកមូត្រ អ្នកគប្បីធ្វើនូវឧស្សាហ៍ក្នុងសេចក្តីនោះដរាបដល់អស់ជីវិតចុះ ទើបឃាត់ចតុមធុរស ប្រកបកេសជ្ជៈសម៉ែត្រាំដោយទឹកមូត្រ ឈ្មោះថា ជាអ្នកសន្តោសយ៉ាងក្រៃលែង អាការបស់ភិក្ខុនោះ ឈ្មោះថា យថាសុប្បសន្តោសក្នុងគិលានប្បច្ចយ ។ សន្តោសទាំងអស់ មានប្រកែនដូចពោលហើយ ហៅថា **សន្តុដ្ឋី** *។ ដោយហេតុនោះ ទើបលោកពោលថា ដោយអត្ថ គឺឥតវិតរប្បច្ចយសន្តោស គឺសន្តោសដោយបច្ចយតាមមានតាមបាន ។ កថាដែលប្រព្រឹត្តទៅ ដោយការប្រកាសអានិសង្សរបស់សន្តុដ្ឋិនោះ មួយអន្ទើដោយវិធីទូន្មានជាដើម និងដោយអំណាចប្រកាសទោសរបស់ភិក្ខុដែលធ្លាក់នៅក្នុងការចង់បាន មានការប្រុងប្រាច្រើនជាដើម ដែលជាបដិបក្ខចំពោះការសន្តោសនោះ ឈ្មោះថា* **សន្តុដ្ឋិកថា** *។ ក្នុងកថាដទៃអំពីនេះ ក៏នយនេះដូចគ្នា ។ ខ្ញុំពោលត្រឹមតែការប្លែកគ្នាប៉ុណ្ណោះ ។*

វិវេក *ក្នុងបទថា* **វិវេកកថា** *នេះ មាន ៣ យ៉ាង គឺកាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក ១ ក្នុង ៣ យ៉ាងនោះ ភិក្ខុលះការនៅច្រឡូកច្រឡំដោយពួក ហើយជាអ្នកស្ងាត់ក្នុងកិច្ចទាំងពួង គ្រប់ឥរិយាបថយ៉ាងនេះ គឺរូប ១ ដើរ រូប ១ ឈរ រូប ១ អង្គុយ រូប ១ ដេក រូប ១ ចូលស្រុកបិណ្ឌបាត រូប ១ ត្រឡប់ រូប ១ ឈានទៅមុខ រូប ១ អធិដ្ឋានទីចង្រ្កម រូប ១ ត្រាច់ទៅ រូប ១ នៅ ឈ្មោះថា កាយវិវេក ។ ម្យ៉ាងទៀត សមាបត្តិ ៨ ឈ្មោះថា ចិត្តវិវេក ព្រះនិព្វាន ឈ្មោះថា ឧបធិវិវេក សមដូចពាក្យដែលលោកពោលក្នុងខុទ្ទកនិកាយ មហានិទ្ទេសថា*

កាយវិវេក សម្រាប់អ្នកមានកាយគេចចេញ (ចាកពួក) អ្នក ត្រេកអរ ចំពោះនេក្ខម្មៈ ចិត្តវិវេក សម្រាប់អ្នកមានចិត្តបរិសុទ្ធ អ្នកដល់សេចក្តីផូរផង់ ដ៏ក្រៃលែង ឯឧបធិវិវេក សម្រាប់បុគ្គល មិនមានឧបធិ អ្នកដល់នូវវិសង្ខារ គឺព្រះនិព្វាន ដូច្នេះ ។

ចាត់ជាឧបធិវិវេក វិវេកនោះឯង គឺបវិវេក ។ កថាដែលទាក់ទងដោយ ការស្ងាត់ ឈ្មោះថា បវិវេកកថា ។

សំសគ្គា *ក្នុងបទថា* **អសំសគ្គកថា** *នេះ មាន ៥ យ៉ាង គឺសរីរ-សំសគ្គៈ ១ ទស្សនសំសគ្គៈ ១ សមុល្លបនសំសគ្គៈ ១ សម្ភោគសំសគ្គៈ ១ កាយសំសគ្គៈ ១ ក្នុង ៥ យ៉ាងនោះ ភិក្ខុរូបខ្លះក្នុងធម្មវិនយនេះ បានឮថា ស្រីក្នុងស្រុក ឬនិគមឈ្មោះថា មានរូបស្អាត គួរសរសើរ គួរជ្រះថ្លា ប្រកបដោយភាពជាអ្នកមានសម្បុរកាយល្អក្រៃលែង លោកបានឮដូច្នោះហើយ មានចិត្តរសាត់ទៅ ផ្សាយទៅ មិនអាចតាំងនៅក្នុងព្រហ្មចរិយៈបាន ទើបលាសិក្ខា ជាគ្រហស្ថ ការស្និទ្ធស្នាលដោយកិលេសកើតឡើង ដោយបានស្តាប់វិសភាគារម្មណ៍ ដោយអាការយ៉ាងនេះ ឈ្មោះថា* **សវនសំសគ្គ** ។ *ភិក្ខុមិនបានស្តាប់ដូច្នោះឡើយ លោកឃើញស្រីស្អាតឯង គួរមើល គួរជ្រះថ្លា ប្រកបដោយសម្បុរកាយល្អក្រៃលែង លោកគ្រាន់តែឃើញប៉ុណ្ណោះ មានចិត្តអណ្តែតទៅ ផ្សាយទៅ មិនអាចតាំងនៅក្នុងព្រហ្មចរិយៈបាន ទើបលាសិក្ខាជាគ្រហស្ថ ការស្និទ្ធស្នាលដោយកិលេស ដែលកើតឡើង ដោយបានឃើញវិសភាគា-រម្មណ៍ ដោយអាការយ៉ាងនេះ ឈ្មោះថា* **ទស្សនសំសគ្គ** ។ *ព្រោះបានឃើញ*

ការស្និទ្ធស្នាលដោយកិលេសកើតឡើង ដោយការចរចាប្រាស្រ័យគ្នានិងគ្នា ឈ្មោះថា **សមុល្លបនសំសគ្គ** ដោយការចរចាប្រាស្រ័យនេះឯង ទើបចាត់ចូលជាមួយនឹងការចំអកចំអន់ក៏បាន ។ ព្រោះវត្ថុណាមួយជារបស់ខ្លួន ដែលឲ្យក្តី មិនឲ្យក្តី ដល់មាតុគ្រាម ការស្និទ្ធស្នាលដោយកិលេសកើតឡើងដោយការឲ្យវត្ថុដែលមានតម្លៃ ដែលខ្លួនឲ្យជាដើម ឈ្មោះថា **សម្ភោគសំសគ្គ** ការស្និទ្ធស្នាលដោយកិលេសកើតឡើង ដោយការចាប់ដៃមាតុគ្រាមជាដើម ឈ្មោះថា **កាយសំសគ្គ** ។ ភាពដែលភិក្ខុលះនូវការច្រឡូកច្រឡំដោយគ្រហស្ថ ដែលមិនប្រព្រឹត្តទៅតាមអនុលោម និងការច្រឡូកច្រឡំដែលជាហេតុកើតកិលេស ជាមួយសព្រហ្មចារីទាំងឡាយ ដែលលោកពោលក្នុងសំយុត្តនិកាយ ខន្ធវារវៈ យ៉ាងនេះថា

> ភិក្ខុខ្លះ ក្នុងសាសនានេះ ជាអ្នកច្រឡូកច្រឡំដោយពួកគ្រហស្ថ មានសេចក្តីរីករាយជាមួយគ្នា មានសេចក្តីសោកជាមួយគ្នា កាលបើពួកគ្រហស្ថបានសេចក្តីសុខ ក៏បានសេចក្តីសុខផង កាលបើពួកគ្រហស្ថបានសេចក្តីទុក្ខ ក៏បានសេចក្តីទុក្ខផង កាលបើពួកគ្រហស្ថទាំងនោះ មានកិច្ចការដែលត្រូវធ្វើកើតឡើង ជួយខ្វល់ខ្វាយក្នុងកិច្ចទាំងនោះដោយខ្លួនឯង ដូច្នេះ ។

ទាំងអស់ចេញបាន ចូលទៅតាំងចំពោះនូវធម៌ទាំងពួង គឺការសង្វេគក្នុងសង្ឃារដែលមាំទាំ ជាងការសម្គាល់ក្នុងវត្ថុដែលមានសង្ខារ ថាជាភ័យយ៉ាងខ្លាំងក្លា ការសម្គាល់ក្នុងរាងកាយ ថាជារបស់បដិកូល មានហិរិ និង

ឱត្តប្បៈ មានការខ្ចីមអកុសលទាំងអស់ ដែលជាប្រធាន មានសតិ និង សម្បជញ្ញៈក្នុងការធ្វើគ្រប់យ៉ាង ហើយមិនមានការជាប់ជំពាក់ក្នុងធម៌ទាំងពួង ដូចតំណក់ទឹកមិនជាប់លើស្លឹកឈូក ដូច្នោះ ឈ្មោះថា **អសំសគ្គ** *ព្រោះជា បដិបក្ខចំពោះសំសគ្គៈទាំងពួង កថាដែលទាក់ទងដោយអសំសគ្គៈ ឈ្មោះថា* **អសំសគ្គកថា** ។

ក្នុងបទថា **វីរិយារម្ភកថា** *នេះ មានវិនិច្ឆ័យដូចតទៅនេះ ការៈនៃបុគ្គល អង់អាច ឬកម្មនៃបុគ្គលអង់អាច ព្រោះដូច្នោះ ទើបឈ្មោះថា* **វីរិយ** *ម្យ៉ាង ទៀត ឈ្មោះថា* **វីរិយ** *ព្រោះបុគ្គលគប្បីប្រព្រឹត្តទៅ គឺគប្បីឲ្យទៅតាមវិធី សេចក្តីព្យាយាមនោះ គឺការផ្តើមដើម្បីលះអកុសលធម៌ និងឲ្យកុសលធម៌ កើតឡើង ឈ្មោះថា* **វីរិយារម្ភ** *គឺការប្រារព្ធព្យាយាម ។ វីរិយារម្ភៈនោះ មាន ២ យ៉ាង គឺប្រព្រឹត្តទៅតាមផ្លូវកាយ ១ ប្រព្រឹត្តទៅផ្លូវចិត្ត ១ មាន ៣ យ៉ាង គឺអារម្ភធាតុ ១ និក្កមធាតុ ១ បរក្កមធាតុ ១ មាន ៤ យ៉ាង ដោយ អំណាចសម្មប្បធាន ៤ ។ វីរិយារម្ភៈទាំងអស់នោះ គប្បីជ្រាបដោយអំណាច សេចក្តីប្រារព្ធព្យាយាមយ៉ាងនេះ នៃកិក្ខុដែលមិនឲ្យកិលេសកើតឡើងក្នុង ពេលដើរ ឲ្យនៅដល់ពេលឈរ ដែលកើតក្នុងពេលឈរ មិនឲ្យនៅដល់ ពេលអង្គុយ ដែលកើតឡើងក្នុងពេលអង្គុយ មិនឲ្យនៅដល់ពេលដេក តែង សង្កត់ដោយកម្លាំងនៃសេចក្តីព្យាយាម មិនឲ្យកិលេសងើបក្បាលឡើងបាន ក្នុងឥរិយាបថនោះៗ ដូចបុគ្គលយកឈើដែលមានលក្ខណៈដូចជើងពពែ សង្កត់ក្បាលពស់វែក និងដូចយកដាវដ៏មុតកាត់កសត្រូវ ដូច្នោះ ។ កថា*

ដែលទាក់ទងដោយវីរិយារម្ភនោះ ឈ្មោះថា **វីរិយារម្ភកថា** ។

សីល *ក្នុងបទថា* **សីលកថា** *ជាដើម មាន ២ យ៉ាង គឺលោកិយសីល ១ លោកុត្តរសីល ១ ក្នុងសីល ២ យ៉ាងនោះ លោកិយសីល បានដល់ ចារិសុទ្ធិសីល ៤ មានបាតិមោក្ខសំវរសីលជាដើម ។ លោកុត្តរសីល បាន ដល់ មគ្គសីល និងផលសីល ។ ម្យ៉ាងទៀត សមាបត្តិ ៨ មួយអន្ទើដោយ ឧបចារៈដែលជាបាទនៃវិបស្សនា ឈ្មោះថា* **លោកិយសមាធិ** *ក្នុងទីនេះ សមាធិដែលសម្បយុត្តដោយមគ្គ ឈ្មោះថា* **លោកុត្តរសមាធិ** ។ *ឯបញ្ញា ក៏ដូចគ្នា ដែលសម្រេចដោយការស្តាប់ សម្រេចដោយការគិត ដែលសម្ប-យុត្តដោយឈាន និងវិបស្សនាញាណ ចាត់ជា* **លោកិយបញ្ញា** *តែក្នុងទី នេះ បើពោលដោយពិសេស គប្បីកាន់យកវិបស្សនាបញ្ញា ។ បញ្ញាដែល សម្បយុត្តដោយមគ្គ និងផល ចាត់ជា* **លោកុត្តរបញ្ញា** ។ *សូម្បីវិមុត្តិ ក៏ បានដល់វិមុត្តិដែលសម្បយុត្តដោយអរិយផល និងនិព្វាន ។ ឯអាចារ្យមួយ ពួកទៀត ពណ៌នាក្នុងសេចក្តីនេះ ដោយអំណាចតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ និង សមុច្ឆេទវិមុត្តិ ។ សូម្បីវិមុត្តិញាណទស្សនៈ ក៏បានដល់បច្ចវេក្ខណញាណ ១៩ ។ កថាដែលប្រព្រឹត្តទៅដោយអំណាចការប្រកាសទោស និងអានិសង្ស មានអាការជាអនេកនៃគុណ មានសីលជាដើមនេះ មួយអន្ទើដោយវិធី មាន ការចង្អុលបង្ហាញជាដើម និងដោយអំណាចការប្រកាសទោស នៃភាពជាអ្នក ទ្រុស្តសីលជាដើម ដែលជាសត្រូវចំពោះគុណ មានសីលជាដើមនោះ ឬកថា ដែលទាក់ទងដោយអានិសង្ស និងទោសរបស់សីលនោះ ឈ្មោះថា កថា*

ពោលដោយសីលជាដើម ។

ក្នុងទីនេះ ព្រោះព្រះបាលីជាដើមថា ភិក្ខុជាអ្នកប្រាថ្នាតិចដោយខ្លួនឯងផង ធ្វើកថា មានការប្រាថ្នាតិចដល់អ្នកដទៃផង ឈ្មោះថា ជាអ្នកសន្តោសដោយចីវរតាមមានតាមបានផង ប្រកាសគុណនៃការសន្តោសដោយចីវរតាមមានតាមបានផង កថាបែបនោះ ដែលភិក្ខុប្រកបដោយគុណ មានភាពជាអ្នកប្រាថ្នាតិចជាដើមដោយខ្លួនឯង គប្បីឲ្យទោសប្រព្រឹត្តទៅតាមអធ្យាស្រ័យ អនុគ្រោះដល់អ្នកដទៃ ដើម្បីជាប្រយោជន៍ដល់ការប្រាថ្នាតិច និងសន្តោសនោះ ដែលលោកពោលដោយពិសេស ដោយភាពជាអ្នកជុសខាត់យ៉ាងក្រៃលែងជាដើម ក្នុងទីនេះ គប្បីជ្រាបថា កថាពោលដោយការប្រាថ្នាតិចជាដើម ។ ពិតហើយ កថារបស់អ្នកធ្វើនោះឯង រមែងធ្វើប្រយោជន៍តាមដែលបំណងឲ្យសម្រេចដោយពិសេស សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលមេយិយ: គុណជាតន៉ុះ រមែងកើតប្រាកដដល់ភិក្ខុដែលមានមិត្តល្អ មានសម្លាញ់ល្អ បែរទៅរកមិត្តល្អ ។បេ។ បានដោយមិនលំបាក ។ បទថា **ឯវ្ហទាយ** បានដល់ បែបនេះ គឺតាមដែលពោលហើយ ។ បទថា **ឆិកាមលាភី** សេចក្តីថា ជាអ្នកបានតាមប្រាថ្នា គឺបានតាមគាប់ចិត្ត បានដល់ បានដោយស្រួល ដើម្បីស្តាប់និងពិចារណាកថាទាំងនេះសព្វកាល ។ បទថា **អកិច្ចលាភី** បានដល់ ជាអ្នកបានដោយមិនលំបាក ។ បទថា **អកសិរលាភី** បានដល់ ជាអ្នកបានដោយបរិបូណ៌ ។

បទថា **អារទ្ធវីរយោ** បានដល់ ផ្តងសេចក្តីព្យាយាម ។ បទថា **អកុ-**

សលានំ ធម្មានំ បហានាយ បានដល់ ដើម្បីលះបាបធម៌ដែលឈ្មោះថា អកុសល ព្រោះអត្ថថា កើតអំពីការមិនឈ្វាស ។ បទថា **កុសលានំ ធម្មានំ** បានដល់ ធម៌ដែលសម្បយុត្តដោយមគ្គ និងផល មួយអន្ទើដោយវិបស្សនា ឈ្មោះថា **កុសល** ព្រោះអត្ថថា កាត់នូវបាបធម៌ដែលបណ្ឌិតស្អប់ខ្ពើមជាដើម និងព្រោះអត្ថថា មិនមានទោស ។ បទថា **ឧបសម្បទាយ** បានដល់ ឲ្យដល់ព្រម គឺឲ្យកើតឡើងក្នុងសន្តានខ្លួន ។ បទថា **ថាមវា** បានដល់ ជាអ្នកប្រកបដោយកម្ចាំងសេចក្តីព្យាយាម ពោល គឺឧស្សាហ៍ ។ បទថា **ទឡ្ហ-បរក្ពមោ** បានដល់ មានសេចក្តីព្យាយាមមាំ គឺមានសេចក្តីព្យាយាមមិនធូរថយ ។ បទថា **និក្ខិត្តធុរោ** បានដល់ មិនដាក់ធុរ: គឺមានសេចក្តីព្យាយាមមិនធូរថយ ។

បទថា **បញ្ញវា** បានដល់ ជាអ្នកមានបញ្ញា ដោយបញ្ញាដែលសម្បយុត្តដោយវិបស្សនា ។ បទថា **ឧទយត្ថគាមិនិយា** បានដល់ ចាក់ធ្ទុះដោយការកើតឡើង និងការរលត់ទៅនៃបញ្ចក្ខន្ធ ។ បទថា **អរិយាយ** បានដល់ ឆ្វាយ គឺតាំងនៅឆ្វាយអំពីកិលេស ដោយអំណាចវិក្ខម្ភនវិមុត្តិ គឺប្រាសចាកទោស ។ បទថា **និព្វេធិកាយ** ប្រែថា ជាចំណែកនៃការត្រាស់ដឹង ។ បទថា **សម្មា-ទុក្ខក្ខយគាមិនិយា** បានដល់ សម្រេចដោយប្រពៃ គឺដោយហេតុ ដោយន័យនូវអរិយមគ្គ ដែលបានឈ្មោះថា **ទុក្ខក្ខយ** ព្រោះធ្វើវដ្តទុក្ខឲ្យអស់ទៅ ។

ក្នុងធម៌ ៥ ប្រការនេះ សីល វីរិយ: និងបញ្ញា ជាអង្គខាងក្នុង ធម៌ ២ ក្រៅអំពីនេះ ជាអង្គខាងក្រៅសម្រាប់ព្រះយោគី តែព្រះយោគីក៏នៅប្រាថ្នាធម៌

៤ ប្រការក្រៅអំពីនោះ ដោយជាទីអាស្រ័យនៃកល្យាណមិត្រនោះឯង ។ ក្នុងទីនេះ ព្រះសាស្តា កាលទ្រង់សម្តែងថា កល្យាណមិត្រនោះឯង ជាអ្នកមានឧបការៈច្រើន ទើបទ្រង់បន្តែមព្រះធម្មទេសនា ដោយនយជាដើមថា មេឃិយៈ សេចក្តីនេះ ភិក្ខុមានកល្យាណមិត្រ គប្បីប្រាថ្នាបាន ។

បណ្តាបទទាំងនោះ បទថា **ចាដិកង្ខំ** *ប្រែថា គប្បីប្រាថ្នាដោយចំណែកមួយ អធិប្បាយថា មានការៈពិត ។ បទថា* **យំ** *ជាកិរិយាបរាមាស ។ លោកអធិប្បាយពាក្យនេះថា ក្នុងពាក្យថា* **សីលវា ភវិស្សតិ** *នេះ មានអធិប្បាយថា ភិក្ខុដែលមានកល្យាណមិត្រ មានសីល គឺសម្បូរដោយសីលនោះ គប្បីប្រាថ្នាបាន ព្រោះភិក្ខុនោះ ជាអ្នកសម្បូរដោយសីល គឺជាអ្នកមានការៈពិត ប្រាកដ ព្រោះដឹកនាំអ្នកក្នុងសេចក្តីនោះដោយពិតនោះឯង ។ ក្នុងពាក្យថា* **ចាតិមោក្ខសំវរសំវុតោ វិហរិស្សតិ** *ជួបច្នេះជាដើម ក៏នយនេះដូចគ្នា ។*

ព្រះមានព្រះភាគ ទ្រង់សម្តែងសាសនសម្បត្តិទាំងមូល ដោយភាពជាអ្នកមានកល្យាណមិត្រជាដើម តែព្រះមេឃិយៈ មិនអើពើនឹងព្រះតម្រាស់របស់ព្រះអង្គ ដែលជាកល្យាណមិត្រ ដ៏ឧត្តុង្គឧត្តមក្នុងលោក ព្រមទាំងទេវលោក ហើយចូលទៅកាន់ជង្ឃព្រៃនោះ ជល់នូវបការដែលប្លែកនោះ ឥឡូវនេះ ទើបទ្រង់ប្រកាសភាវនានយជល់លោក ដែលកើតការអើពើក្នុងជង្ឃព្រៃនោះ ព្រោះលោកត្រូវកាមវិតក្កជាដើមប្រទូស្តក្នុងកាលមុន និងព្រោះកាមវិតក្កជាដើមនោះជាសត្រូវដោយត្រង់ ទើបកម្មដ្ឋានមិនសម្រេចជល់លោក បន្ទាប់ពីនោះ កាលត្រាស់ប្រាប់កម្មដ្ឋាននៃអរហត្ត ទើបត្រាស់ពាក្យជាដើមថា ម្នាលមេឃិយៈ

មួយទៀត ភិក្ខុនោះ តាំងនៅក្នុងធម៌ ៥ យ៉ាងនេះហើយ ត្រូវចម្រើនធម៌ ៤ យ៉ាងតទៅទៀត ដូច្នេះ ។

[៨៩] បណ្តាបទទាំងនោះ បទថា **តេន** *បានដល់ ប្រកបដោយគុណមានសីលជាដើមតាមដែលពោលហើយ ដោយមានកល្យាណមិត្រជាទីអាស្រ័យយ៉ាងនេះ ។ ដោយហេតុនោះឯង ទើបត្រាស់ថា តាំងនៅក្នុងធម៌ទាំង ៥ ប្រការនេះជាដើម ។ បទថា* **ឧត្តរិ** *សេចក្តីថា បើអន្តរាយ មានរាគៈជាដើម គប្បីកើតឡើងដល់បុគ្គលប្រារព្ធតុណ្ហីភាវនា ដើម្បីជម្រះអន្តរាយទាំងនោះឲ្យបរិសុទ្ធ ខាងមុខអំពីនោះ គប្បីចម្រើន គឺធ្វើឲ្យកើត ព្រោះកពូននូវធម៌ ៤ ប្រការនោះ ។ បទថា* **អសុភា** *បានដល់ ចម្រើនអសុភកម្មដ្ឋានណាមួយតាមសមគួរ ក្នុងបណ្តាអសុភកម្មដ្ឋាន ក្នុងឯកទេសមួយ ។ បទថា* **រាគស្ស បហានាយ** *បានដល់ ដើម្បីលះនូវកាមរាគៈ បណ្ឌិតគប្បីប្រកាសអត្ថនេះ ដោយឧបមាដូចបុគ្គលច្រូតស្រូវសាលី ពិតហើយ បុរសម្នាក់កាន់កណ្តៀវច្រូតស្រូវសាលីក្នុងស្រែ តាំងអំពីទីបំផុតទៅ កាលពួកគោហែករបងចូលទៅ គាត់ក៏ដាក់កណ្តៀវ កាន់ដំបងដេញគោឲ្យចេញទៅដោយផ្លូវនោះឯង រួចធ្វើរបងវិញ កាន់យកកណ្តៀវច្រូតស្រូវទៀត ក្នុងឧបមានោះ ព្រះពុទ្ធសាសនា គប្បីឃើញដូចស្រូវសាលី ព្រះយោគាវចរ គប្បីឃើញដូចអ្នកច្រូតស្រូវ មគ្គប្បញ្ញា គប្បីឃើញដូចកណ្តៀវ កាលធ្វើកម្មក្នុងវិបស្សនា ដូចពេលច្រូត អសុភកម្មដ្ឋានដូចដំបង សំវរៈដូចរបង ការដែលរាគៈកើតឡើង ព្រោះអាស្រ័យការប្រមាទ ដោយមិនពិចារណាទាន់ ដូចគោទាំងឡាយ*

ទម្លាយរបង់ចូលទៅ គ្រាដែលសង្កត់រាគៈដោយអសុភកម្មដ្ឋាន ហើយផ្តើមធ្វើកម្មក្នុងវិបស្សនាទៀត គប្បីឃើញដូចបុគ្គលដែលច្រូតជាក់កណ្តៀវចុះ កាន់ជំបង់ដេញគោឲ្យចេញទៅតាមផ្លូវ ដែលចូលមកនោះឯង ធ្វើរបង់ឲ្យដូចដើម ហើយច្រូតស្រូវ តាំងអំពីទីដែលខ្ជួនឈរនោះទៀត ក្នុងសេចក្តីនេះ មានការប្រៀបធៀបឧបមាដូចពោលមកនេះ ។ ទ្រង់សំដៅយកភាវនាវិធី ដូចពោលមកនេះ ទើបត្រាស់ថា គប្បីចម្រើនអសុភ ដើម្បីលះរាគៈ ។

បទថា **មេត្តា** *បានដល់ កម្មដ្ឋានមានមេត្តាជាអារម្មណ៍ ។ បទថា* **ព្យាចាទស្ស បហានាយ** *បានដល់ ដើម្បីលះសេចក្តីក្រោធដែលកើតឡើងដោយនយដូចពោលហើយនោះឯង ។ បទថា* **អានាចានសុត្តតិ** *បានដល់ អានាបានសុត្តដែលមានវត្ថុ ១៦ ។ បទថា* **វិតក្កុបច្ឆេទាយ** *បានដល់ ដើម្បីកាត់បង់នូវវិតក្កដែលកើតឡើងហើយ ដោយនយដូចពោលហើយនោះឯង ។ បទថា* **អស្មិមានសមុគ្ឃាតាយ** *បានដល់ ដើម្បីដកនូវមានៈ ៩ យ៉ាង ដែលកើតថា អញមាន ។ បទថា* **អនិច្ចសញ្ញិនោ** *បានដល់ ដែលមានសេចក្តីសម្គាល់ថា មិនទៀង ដោយអនិច្ចានុបស្សនាដែលប្រព្រឹត្តទៅថា សង្ខារទាំងពួង ឈ្មោះថា មិនទៀង ព្រោះមានហើយ ត្រឡប់ជាមិនមាន ព្រោះមានការកើតឡើង និងរលត់ទៅជាទីបំផុត ព្រោះមានការបែកធ្លាយ ព្រោះប្រព្រឹត្តទៅមួយជួរខណៈ ព្រោះបដិសេធភាពជារបស់ទៀង ។ បទថា* **អនត្តសញ្ញា សណ្ឋាតិ** *បានដល់ អនត្តសញ្ញា ពោល គឺអនត្តានុបស្សនាដែលប្រព្រឹត្តទៅយ៉ាងនេះថា ធម៌ទាំងពួង ឈ្មោះថា ជាអនត្តា ព្រោះមិន*

មានខ្វីមសារ ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ព្រោះជារបស់ដទៃ ព្រោះទំនេរ ព្រោះទទេ ព្រោះសូន្យ ព្រោះមិនតាំងនៅ គឺមិនតាំងមាំនៅក្នុងចិត្ត ។ ពិតហើយ កាលយើញអនិច្ចលក្ខណៈដែលឈ្មោះថា យើញអនត្តលក្ខណៈដូចគ្នា ។ បណ្តាលក្ខណៈទាំង ៣ កាលយើញលក្ខណៈ ១ ក៏ឈ្មោះថាយើញលក្ខណៈ ២ យ៉ាងក្រៅអំពីនេះដូចគ្នា ។ ដោយហេតុនោះ ទើបត្រាស់ថា ម្នាលមេយិយៈ ព្រោះថា កាលភិក្ខុមានសេចក្តីសម្គាល់ថា មិនទៀងហើយ សេចក្តីសម្គាល់ថា មិនមែនខ្លួន រមែងតាំងនៅ ដូច្នេះ ។ កាលយើញអនត្តលក្ខណៈ មានះដែលកើតឡើងថា អញមាន ឈ្មោះថា លះបានផងនោះឯង ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា ជាអ្នកមានសេចក្តីសម្គាល់ក្នុងសង្ខារថាជាអនត្តា រមែងដល់នូវការដកអស្មិមានះចេញបាន ។ បទថា **ឧដ្ឋេវ ធម្មេ និព្វានំ** សេចក្តីថា រមែងសម្រេចព្រះនិព្វាន ដែលមិនមានបច្ចុយក្នុងបច្ចុប្បន្ននេះឯង គឺក្នុងអត្តភាពនេះឯង ។ ក្នុងទីនេះ សេចក្តីសង្ខេបមានប្រមាណប៉ុណ្ណេះ តែបើពោលដោយនយពិស្តារនៃភាវនា ដែលពោលដោយអសុភកម្មដ្ឋានជាដើម គប្បីពិនិត្យមើលដោយនយដែលពោលហើយក្នុងគម្ពីរវិសុទ្ធិមគ្គឯណោះចុះ ។

បទថា **ឯតមត្ថំ វិឧិត្វា** សេចក្តីថា ទ្រង់ជ្រាបសេចក្តីនេះ ពោល គឺការដែលព្រះមេយិយៈត្រូវពួកចោរ គឺមិច្ចាវិតក្កប្ងន់ភណ្ឌៈ គឺកុសល ។ បទថា **ឥមំ ឧឧានំ** សេចក្តីថា ទ្រង់បន្ទឺឧទាននេះដែលសម្តែងទោសក្នុងការមិនបន្ទោបង់កាមវិតក្កជាដើម និងអានិសង្សក្នុងការបន្ទោបង់កាមវិតក្កជាដើម ។

បណ្តាបទទាំងនោះ បទថា **ខុទ្ទា** *បានដល់ អាក្រក់ គឺលាមក ។ បទថា* **វិតក្កា** *បានដល់ បាបវិតក្ក ៣ មានកាមវិតក្កជាដើម ។ អកុសលវិតក្កទាំងនោះ លោកហៅថាខុទ្ទៈក្នុងទីនេះ ព្រោះត្រូវវិតក្កទាំងពួង ធ្វើឲ្យអាក្រក់ដូចក្នុងប្រយោគជាដើមថា មិនគប្បីប្រព្រឹត្តអាក្រក់ ។ បទថា* **សុខុមា** *លោកបំណងយកការត្រិះរិះដោយលាភជាដើម ។ វិតក្កទាំងនេះ គឺញាតិវិតក្ក ជនបទវិតក្ក អមរាវិតក្ក (ត្រិះរិះដល់ទេវតា) បរានុទ្ទយតាបដិសំយុត្តវិតក្ក (ការត្រិះរិះដែលទាក់ទងនឹងការអាណិតអាសូរអ្នកដទៃ) លាភសក្কារ-សិលោកបដិសំយុត្តវិតក្ក (ការត្រិះរិះដែលទាក់ទងដោយលាភសក្কារៈ) អនវញ្ញត្តិបដិសំយុត្តវិតក្ក (ការត្រិះរិះដែលទាក់ទងនឹងការមិនមើលងាយ) រមែងមិនខ្វាំងក្នា ដូចកាមវិតក្កជាដើម ព្រោះដូច្នោះ ទើបលោកពោលថា វិតក្កល្អិត ព្រោះមានសភាវៈមិនគ្រោតគ្រាត ។ បទថា* **អនុគតា** *បានដល់ អនុវត្តទៅតាមចិត្ត ។ ពិតហើយ កាលវិតក្កកើតឡើង ចិត្តក៏ទៅតាមវិតក្កនោះឯង ព្រោះលើកវិតក្កនោះឡើងកាន់អារម្មណ៍ ។ បាលីថា* **អនុគ្គតា** *ដូច្នេះក៏មាន សេចក្តីថា* **អនុដ្ឋិតា** *គឺមិនតាំងមាំ ។ បទថា* **មនសោ ឧព្ពិលាបោ** *ប្រែថា ធ្វើចិត្តឲ្យរាយមាយ ។ បទថា* **ឃតេ អវិទ្ធា មនសោ វិតក្កេ** *សេចក្តីថា មិនដឹងតាមសេចក្តីពិតនូវមនោវិតក្ក មានកាមវិតក្កជាដើមទាំងនោះ ដោយញាតប្បរិញ្ញា តីរណប្បរិញ្ញា និងបហានប្បរិញ្ញា ។ ដោយរលាស់ចេញចាកទោស គឺសេចក្តីត្រេកអរ ។ បទថា* **ហុរា ហុរំ ធាវតិ ភន្តចិត្តោ** *សេចក្តីថា ឈ្មោះថា មានចិត្តមិនតាំងមាំ ព្រោះមិនទាន់លះមិច្ឆាវិតក្កបាន ទើបសុះ*

ទៅ គឺវិលទៅមក ដោយអំណាចការត្រេកអរជាដើម ក្នុងអារម្មណ៍នោះៗ ដោយន័យជាដើមថា ជួនកាលក្នុងរូបារម្មណ៍ ជួនកាលក្នុងសទ្ទារម្មណ៍ ម្យ៉ាងទៀត បទថា **ហុរា ហុរំ ធាវតិ ភន្តចិត្តោ** *សេចក្តីថា មានចិត្តវិលទៅ ដោយអំណាចអវិជ្ជា និងតណ្ហា ដែលមានវិតក្កនោះជាហេតុ ព្រោះមិនទាន់កំណត់បាន ទើបស្ទុះទៅ គឺអន្ទោលទៅមក ដោយចុតិ និងបដិសន្ធិអំពីលោកនេះទៅកាន់លោកខាងមុខ ។ បទថា* **ឯតេ ច វិទ្ធា មនសោ វិតក្កេ** *សេចក្តីថា តែជីងតាមសេចក្តីពិត ដោយការត្រេកអរជាដើមនូវមនោវិតក្ក មានកាមវិតក្កជាដើម មានប្រភេទតាមដែលពោលហើយនោះ ។ បទថា* **អាតា-បិយោ** *សេចក្តីថា មានសេចក្តីព្យាយាម ។ បទថា* **សំវរតិ** *ប្រែថា រមែងបិទ ។ បទថា* **សតិមា** *ប្រែថា សម្បូរដោយសតិ ។ បទថា* **អនុគ្គតេ** *បានដល់ មិនកើតឡើង ដោយអំណាចការបានដោយលំបាក ។ លោកអធិប្បាយពាក្យនេះថា ជីងមនោវិតក្ក មានកាមវិតក្កជាដើម មានប្រការដូចពោលហើយនោះថាជាការវាយមាយនៃចិត្ត ព្រោះជាហេតុធ្វើចិត្តឲ្យវាយមាយ គឺជីងដោយប្រពៃនោះឯង ដោយមគ្គប្បញ្ញា ដែលប្រកបដោយវិបស្សនាញាណ ឈ្មោះថា ជាអ្នកមានសេចក្តីព្យាយាម មានសតិ ព្រោះមានសម្មាវាយាម និងសម្មាសតិ ដែលមានមគ្គប្បញ្ញានោះជាសម្ភារៈ បិទមនោវិតក្កទាំងនោះ ដែលគួរនឹងកើតតទៅ មិនឲ្យកើត គឺមិនឲ្យផុសឡើងក្នុងខណៈមគ្គ ដោយអរិយមគ្គភាវនា គឺរាំងដោយញាណសំវរៈ បានដល់ កាត់នូវការប្រាកដនៃវិតក្កទាំងនោះ ។ ព្រះអរិយសាវ័កដែលមានសភាពយ៉ាងនោះ ឈ្មោះថា* **ពុទ្ធ**

ព្រោះដឹងសច្ចៈទាំង ៤ លះជាច់ គឺកាត់ផ្តាច់កាមវិតក្កទាំងនោះជាដើម ដោយមិនសេសសល់ គឺមិនមានចំណែកសល់ ព្រោះសម្រេចអរហត្ត ។ ក្នុងបទនេះ អាចារ្យពួកខ្លះពោលថា **អនុគតេ** *ដូច្នេះក៏មាន សេចក្តីនៃបទ* **អនុគតេ** *នោះ បានពោលខាងដើមហើយ ។*

អដ្ឋកថា មេឃិយសូត្រទី ១ ចប់

សុត្តន្តបិដក

ខុទ្ទកសូត្រ

[៩០] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងសាលវនឧទ្យាន របស់មល្លក្សត្រិយ៍ ជាទីប្រព្រឹត្តចូលទៅជិតក្រុងកុសិនារា ។ សម័យនោះឯង ពួកភិក្ខុច្រើនរូប នៅក្នុងតូបដែលគេធ្វើក្នុងព្រៃ ក្នុងទីជិតព្រះមានព្រះភាគ ជាអ្នកមានចិត្តអណ្តែតអណ្តូង លើកកម្ពស់ មានចិត្តឃ្វេងឃ្វាង មានមាត់រឹង មានសម្តីផ្តេសផ្តាស ភ្លេចស្មារតី មិនដឹងខ្លួន មិនបានតាំងចិត្តមាំមួន មានចិត្តក្អាក់ផ្អើល មានឥន្ទ្រិយជ្រុលជ (មិនសង្រួមឥន្ទ្រិយ) ។ ព្រះមានព្រះភាគ ទ្រង់បានទតឃើញពួកភិក្ខុច្រើនរូបនោះ នៅក្នុងតូបដែលគេធ្វើក្នុងព្រៃ ក្នុងទីជិតព្រះអង្គ មានចិត្តអណ្តែតអណ្តូង ជាអ្នកលើកកម្ពស់ មានចិត្តឃ្វេងឃ្វាង មានមាត់រឹង មានសម្តីផ្តេសផ្តាស ភ្លេចស្មារតី មិនដឹងខ្លួន មិនបានតាំងចិត្តមាំមួន មានចិត្តក្អាក់ផ្អើល មាន*

ឥន្ទ្រិយដ៏ប្រាកដ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៉ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> បុគ្គលមានវិញ្ញាណកាយទាំង ៦ មិនរក្សាផង ជាមិច្ចាទិដ្ឋិផង ដែលបីនមិទ្ធ: គ្របសង្កត់ផង រមែងដល់នូវអំណាចនៃមារ ។ ព្រោះហេតុនោះ ភិក្ខុជាអ្នកមានចិត្តរក្សាហើយ មានសេចក្តីត្រិះរិះ ត្រូវជាអារម្មណ៍ មានសម្មាទិដ្ឋិប្រព្រឹត្តទៅក្នុងខាងមុខ ដឹងការ កើតឡើង និងសូន្យទៅបាន គ្របសង្កត់នូវបីន: និងមិទ្ធ:ហើយ គប្បីលះបង់គតិអាក្រក់ទាំងពួង ។ សូត្រទី ២ ។

អដ្ឋកថា

ឧទ្ធតសូត្រ

ឧទ្ធតសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ

[៩០] បទថា **កុសិនារាយំ** បានដល់ ជិតនគរបស់ស្តេចមល្ល: ឈ្មោះថា **កុសិនារា** ។ បទថា **ឧបវត្តនេ មល្លានំ សាលវនេ** សេចក្តីថា ឧទ្យាននៃនគរកុសិនារាមានទៅក្នុងទិសទក្សិណ និងទិសបស្ចិម ដូចជូបារាម នៃអនុរាធបុរី ។ ផ្លូវចេញអំពីជូបារាមទៅកាន់នគរ ដោយទ្វារទិសទក្សិណ ត្រង់ទៅទិសខាងកើត វិលត្រឡប់មកខាងទិសឧត្តរ យ៉ាងណា ជួរនៃព្រៃ សាលព្រឹក្ស ចេញពីឧទ្យានត្រង់ទៅទិសខាងកើត បត់ទៅទិសខាងជើង

ព្រោះដូច្នោះ ទើបគេហៅថា **ឧបវត្តន** *គឺទីវិលវង់ ។ ក្នុងសាលវនៃរបស់ស្តេចមល្លៈដែលជាទីវិលវង់នោះ ។ បទថា* **អរញ្ញេកុដិកាយំ** *បានដល់ ខ្ទមដែលសាងក្នុងទីដែលដេរជាសទៅដោយដើមឈើ និងគុម្ពឈើ នៅមិនឆ្ងាយចាកដើមសាលព្រឹក្ស ដែលលោកសំដៅយក ពោលថា* **អរញ្ញេកុដិកាយំ វិហរន្តិ ។** *កិក្ខុទាំងនោះវៀរការពិចារណា មានសេចក្តីព្យាយាមធូរថយ នៅដោយសេចក្តីប្រមាទ ។ ដោយហេតុនោះ ទើបលោកពោលថា* **ឧទ្ធតា** *ដូច្នេះជាដើម ។*

ក្នុងកិក្ខុទាំងនោះ កិក្ខុឈ្មោះថា **ឧទ្ធត** *ព្រោះមានចិត្តមិនស្ងប់ ព្រោះច្រើនទៅដោយឧទ្ធច្ចៈ ។ មានៈ ឈ្មោះថា* **ឩឡ** *ព្រោះដូចដើមបបុស ព្រោះជារបស់ទទេ ។ កិក្ខុឈ្មោះថា* **ឧទ្ធឩឡ** *ព្រោះមាន* **ឩឡ** *ពោល គឺមានៈខ្ពស់អធិប្បាយថា មានមានៈខ្ពស់ទទេ ។ ឈ្មោះថា* **ចបល** *ព្រោះប្រកប ឬច្រើនទៅដោយការញាប់ញ័រ មានជាត្រ និងចីវរជាដើម ។ ឈ្មោះថា* **មុខរ** *ព្រោះមានមាត់រឹង ព្រោះមានវាចាគ្រោតគ្រាត ។ ឈ្មោះថា* **វិកិណ្ណវាចា** *ព្រោះមានវាចាផ្តេសផ្តាស គឺវាចាឥតប្រយោជន៍ ព្រោះច្រើនទៅដោយតិរច្ឆានកថា ឈ្មោះថា* **មុដ្ឋស្សតិ** *ព្រោះមិនមានស្មារតី ។ អធិប្បាយថា វៀរចាកសតិ គឺនៅដោយសេចក្តីប្រមាទ ។ ឈ្មោះថា* **អសម្បជាន** *ព្រោះមិនមានសម្ប-ជញ្ញៈ ដោយប្រការទាំងពួង ។ ឈ្មោះថា* **អសមាហិត** *ព្រោះមានចិត្តមិនតាំងមាំ ដោយមិនមានការតាំងមាំនៃចិត្ត អស់កាល មានការជជែកជាប្រមាណ។ឈ្មោះថា* **វិព្ភន្តចិត្ត** *ព្រោះមានចំណែកប្រៀបដូចម្រឹគ (ទន្សាយ)*

ផ្អើលផ្ទៃញ្ជៅ ព្រោះមានការឡេះឡោះជាសភាវ: ។ ឈ្មោះថា **ចាកតិន្ទ្រិយ** ព្រោះជាបុគ្គលមិនសង្រួម ដោយមិនសង្រួមឥន្ទ្រិយ មានមនិន្ទ្រិយជាគម្រប់ ៦ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបថា ភិក្ខុទាំងនោះនៅដោយការប្រមាទ ដោយអំណាចឧទ្ធច្ចៈជាដើម ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ដែលប្រកាសទោស និងអានិសង្សតាមលំដាប់ ក្នុងការនៅដោយសេចក្តីប្រមាទ និងនៅដោយការមិនប្រមាទ ។

បណ្តាបទទាំងនោះ បទថា **អរក្ខិតេន** សេចក្តីថា ឈ្មោះថា មិនគ្រប់គ្រង ព្រោះមិនមានសតិជាគ្រឿងរក្សា ។ បទថា **កាយេន** បានដល់ ដោយកាយវិញ្ញាណ ៦ ។ ក៏ព្រោះឃើញរូបដោយចក្ខុវិញ្ញាណហើយ មិនប្រើសតិរក្សានៃវិញ្ញាណ ដោយឲ្យអភិជ្ឈាជាដើមកើត ដោយការកាន់យកនិមិត្ត និងអនុព្យញ្ជនៈក្នុងរូបនោះ សូម្បីក្នុងសោតវិញ្ញាណក៏នយនេះដូចគ្នា ទ្រង់ត្រាស់ថា **អរក្ខិតេន កាយេន** សំដៅដល់ ភាពដែលភិក្ខុមិនរក្សាវិញ្ញាណកាយ ៦ ដោយអាការយ៉ាងនេះ ។ តែអាចារ្យពួកខ្លះពោលអត្ថថា **កាយេន** ដូច្នេះគប្បីប្រកបសតិដោយអត្ថយោជនា របស់អាចារ្យពួកខ្លះនោះ ដោយនយដូចពោលហើយនោះឯង ។ អាចារ្យមួយពួកទៀតពោលថា **អរក្ខិតេន ចិត្តេន** ។ អត្ថរបស់អាចារ្យមួយពួកនោះ ក៏នយនេះដូចគ្នា ។ បទថា **មិច្ឆាទិដ្ឋិហតេន** បានដល់ ការប្រកាន់ថាទៀងជាដើម ប្រទូស្តហើយ ។ បទថា **ថីនមិទ្ធាភិ-ភូតេន** សេចក្តីថា ត្រូវថីនៈដែលមានភាពនៃចិត្តមិនគួរដល់ការងារជាលក្ខណៈ

និងត្រូវមិទ្ធៈ មានភាពដែលកាយមិនគួរដល់ការងារជាលក្ខណៈ គ្របសង្កត់ហើយ ភ្ជាប់សេចក្តីថា ដោយកាយនោះ ឬដោយចិត្តនោះ ។ បទថា **វសំ មារស្ស គច្ឆតិ** *សេចក្តីថា ចូលដល់អំណាច គឺភាពដែលខ្លួនត្រូវមារទាំងអស់ មានកិលេសមារទាំងអស់ធ្វើតាមប្រាថ្នា អធិប្បាយថា មិនកន្លងវិស័យរបស់មារទាំងនោះទៅបាន ។*

ពិតហើយ ដោយព្រះគាថានេះ ព្រះមានព្រះភាគទ្រង់សម្តែងវដ្តៈដោយជាប្រធាន គឺទ្រង់តិះដៀលភិក្ខុទាំងនោះ ដោយសេចក្តីប្រមាទថា ភិក្ខុពួកណាមិនរក្សាចិត្តដោយប្រការទាំងពួង ព្រោះមិនមានសតិជាគ្រឿងរក្សា ដែលកាន់យកការស្វែងរកខុស ដោយនយថា ទៀងជាដើម ដោយអយោនិសោផុសឡើង ព្រោះមិនមានបញ្ញាដែលជាហេតុនៃយោនិសោមនសិការ ព្រោះហេតុនោះឯង ទើបភិក្ខុទាំងនោះឈ្មោះថា ត្រូវកោសជ្ជៈគ្របសង្កត់ ព្រោះមិនមានវីរិយារម្ភៈក្នុងការបំពេញកុសល ដែលងើបក្បាលឡើងអំពីវដ្តៈបាន ដូច្នេះ ដើម្បីទ្រង់សម្តែងវិវដ្តៈ ទើបត្រាស់គាថាទី ២ ថា **តស្មា រក្ខិតចិត្តស្ស** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **តស្មា រក្ខិតចិត្តស្ស** *សេចក្តីថា ព្រោះហេតុដែលភិក្ខុមិនរក្សាចិត្ត ត្រូវមារធ្វើតាមបំណង ទើបនៅក្នុងសង្សារប៉ុណ្ណោះដូច្នោះ ភិក្ខុគប្បីជាអ្នករក្សាចិត្ត ដោយការរក្សា គឺគ្រប់គ្រងឥន្ទ្រិយទាំងឡាយមានមនិន្ទ្រិយជាគម្រប់ ៦ ដោយសតិសំវរៈ ។ ព្រោះកាលលោករក្សាចិត្តបានហើយ ឈ្មោះថា រក្សាឥន្ទ្រិយ មានចក្ខុន្ទ្រិយជាដើមបានផងដែរ ។ បទ*

ថា **សម្មាសង្កប្បគោចរោ** សេចក្តីថា ព្រោះភិក្ខុមានមិច្ឆាសង្កប្បជាអារម្មណ៍ ទើបត្រិះរិះដោយមិនមែនឧបាយ កាន់យកមិច្ឆាទស្សនៈផ្សេងៗ មានចិត្តដែលមិច្ឆាទិដ្ឋិកម្ចាត់ហើយ ជាបុគ្គលត្រូវមារធ្វើតាមប្រាថ្នា ដូច្នោះ កាលធ្វើកម្មដោយយោនិសោមនសិការ គប្បីជាអ្នកមានសេចក្តីត្រិះរិះប្រពៃ មានការត្រិះរិះក្នុងការចេញចាកកាមជាដើមជាអារម្មណ៍ គប្បីធ្វើតាមតម្រិះត្រូវ ដែលសម្បយុត្តដោយឈានជាដើមប៉ុណ្ណោះឲ្យជាហេតុ ដែលប្រព្រឹត្តទៅនៃចិត្តរបស់ខ្លួន ។ បទថា **សម្មាទិដ្ឋិបុរេក្ខារោ** សេចក្តីថា ភិក្ខុដែលកម្ចាត់មិច្ឆាទស្សនៈដោយភាពជាអ្នកមានសម្មាសង្កប្បជាអារម្មណ៍ គប្បីបំណងធ្វើសម្មាទិដ្ឋិដែលមានសេចក្តីល្អ ដែលសត្វមានកម្មជារបស់ខ្លួនជាខាងមុខជាលក្ខណៈ ហើយបន្តអំពីនោះ មានយថាភូតញាណទស្សនៈជាលក្ខណៈ ទើបខ្វល់ខ្វាយប្រកបក្នុងសីល និងសមាធិ ដោយន័យដូចពោលហើយក្នុងកាលមុននោះឯង ផ្តើមវិបស្សនា ពិចារណាសង្ខារ ដឹងនូវការកើត និងការរលត់នៃសង្ខារ កំណត់ការកើត និងការរលត់ ក្នុងឧបាទានក្ខន្ធ ៥ ដោយអាការ ៥០ សម្រេចខយញ្ញាណ បន្ទាប់អំពីនោះ ទើបបំពេញវិបស្សនាដោយអំណាចកង្ខាវិតរណវិសុទ្ធិ-ញាណជាដើម ទាញយកអរិយមគ្គ បានដោយលំដាប់ ឈ្មោះថាជាភិក្ខុអ្នកគ្របសង្កត់ថីនមិទ្ធៈ លះទុគ្គតិទាំងពួងបាន ដោយអរហត្តមគ្គ ។ ដោយអាការយ៉ាងនេះ លោកឈ្មោះថា ជាភិក្ខុវិណាស្រព ទម្លាយកិលេស ដោយប្រការទាំងពួង ព្រោះលះកិលេស ដែលមគ្គខាងក្រោមគប្បីសម្លាប់បាន ព្រោះកាត់ផ្តាច់នូវថីនមិទ្ធៈ ដែលកើតក្នុងចិត្តុប្បាទ ដែលសម្បយុត្តដោយ

លោកៈ ប្រកបដោយទិដ្ឋិ ដោយអរហត្តមគ្គដែលខ្ជួនសម្រេច បន្ទាប់អំពីនោះ ទើបលះកិលេស មានមានះជាដើម ដែលរួមនៅក្នុងឋានៈតែមួយជាមួយនឹងលោកៈនោះ ព្រោះកាត់មូលនៃភពបានជាសមុច្ឆេទ ទើបឈ្មោះថា លះ គឺ លះដាច់នូវគតិទាំងពួង ពោល គឺទុគ្គតិ ព្រោះប្រកបដោយភាពជាទុក្ខ ៣ ប្រការ អធិប្បាយថា គប្បីតាំងនៅក្នុងចំណែកជនៃគតិទាំងនោះ គឺក្នុងព្រះនិព្វាន ។

អដ្ឋកថា ខុទ្ទកសូត្រទី ២ ចប់

សុត្តន្តបិដក

គោចាលសូត្រ

[៩១] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ស្តេចទៅកាន់ចារិកក្នុងកោសលជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើនរូប ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់គេចចេញអំពីផ្លូវ ហើយចូលទៅរកម្លប់ឈើ ១ ដើម លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាបថ្វាយ ។ លំដាប់នោះ នាយគោបាលម្នាក់ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះនាយគោបាលនោះ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់សម្តែងពន្យល់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ គ្រានោះ*

នាយគោបាលនោះ លុះព្រះមានព្រះភាគ ទ្រង់សម្តែងពន្យល់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក្រាបបង្គំទូលព្រះមានព្រះភាគ ថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ទទួលភត្តរបស់ខ្ញុំ ព្រះអង្គ ក្នុងថ្ងៃស្អែក ជាមួយនឹងភិក្ខុសង្ឃ ។ ព្រះមានព្រះភាគ ទ្រង់ទទួល ដោយតុណ្ហីភាព ។ លុះនាយគោបាលនោះ បានដឹងថា ព្រះមានព្រះភាគ ទ្រង់ទទួលហើយ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើ ប្រទក្សិណ រួចចៀសចេញទៅ ។ លំដាប់នោះ នាយគោបាលនោះ លុះកន្លង រាត្រីនោះហើយ បានឲ្យមនុស្សតាក់តែងអប្បោទកជាយាស (ជាយាសមាន ទឹកតិច) និងទឹកដោះថ្លាដ៏ថ្មីជាច្រើន ក្នុងលំនៅរបស់ខ្លួន ហើយឲ្យមនុស្ស ទៅក្រាបទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលល្មមហើយ ទាំងភត្តសោត ក៏ស្រេចហើយ ។ លំដាប់នោះ ព្រះមាន ព្រះភាគ ទ្រង់ស្បង់ ប្រដាប់ចាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយយាង ចូលទៅកាន់លំនៅរបស់នាយគោបាលនោះ ជាមួយភិក្ខុសង្ឃ លុះយាងទៅ ដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លំដាប់នោះ នាយ គោបាលនោះ អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយអប្បោទក-ជាយាស និងទឹកដោះថ្លាដ៏ថ្មី ឲ្យឆាន់ឆ្អែតស្កប់ស្កល់ ត្រាតែហាមឃាត់ដោយ ដៃខ្លួនឯង ។ លំដាប់នោះ នាយគោបាលនោះ លុះព្រះមានព្រះភាគ ទ្រង់ សោយស្រេច លែងលូកព្រះហស្តក្នុងបាត្រទៀតហើយ ក៏កាន់យកអាសនៈ ដ៏ទាបមួយ អង្គុយក្នុងទីសមគួរ ។ លុះនាយគោបាលនោះ អង្គុយក្នុងទីសមគួរ

ហើយ ព្រះមានព្រះភាគ ទ្រង់សម្តែងពន្យល់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយយធម្មីកថា រួចទ្រង់ក្រោកចាកអាសនៈ យាងចេញទៅ ។

[៩២] *គ្រាកាលដែលព្រះមានព្រះភាគ ស្តេចចេញទៅមិនយូរប៉ុន្មាន ស្រាប់តែមានបុរសម្នាក់ ផ្តាច់ជីវិតនាយគោបាលនោះ ត្រង់ចន្លោះព្រំប្រទល់ស្រុក ។ លំដាប់នោះ ពួកភិក្ខុច្រើនរូប បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន នាយគោបាលណា ដែលបានអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយអប្បោទកបាយាស និងទឹកដោះថ្លាដ៏ប្លី ឲ្យឆាន់ឆ្អែតស្កប់ស្កល់ ត្រាតែហាមឃាត់ដោយដៃខ្លួនឯង ក្នុងថ្ងៃនេះ បពិត្រព្រះអង្គដ៏ចម្រើន បានឮថា នាយគោបាលនោះ មានបុរសម្នាក់ផ្តាច់ជីវិត ត្រង់ចន្លោះព្រំប្រទល់ស្រុកទៅហើយ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា*

> *ចោរបានឃើញចោរផងគ្នា ឬក៏បុគ្គលមានពៀរ ឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើសេចក្តីវិនាសណា ចិត្តដែលបុគ្គលតម្កល់ខុសហើយ រមែងធ្វើបុគ្គលនោះ ឲ្យលាមកលើសជាងសេចក្តីវិនាសនោះទៅទៀត ។ សូត្រទី ៣ ។*

អដ្ឋកថា

គោចាលសូត្រ

គោបាលសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

[៩១] បទថា **កោសលេសុ** សេចក្តីថា ព្រះរាជកុមារអ្នកជនបទ ឈ្មោះថា **កោសល** ។ ជនបទមួយកន្លែងដែលជាលំនៅរបស់រាជកុមារ ទាំងនោះ ក៏ហៅថា **កោសល** ដូចគ្នា ។ ក្នុងកោសលជនបទនោះ ។ បទថា **ចារិកំចរតិ** បានដល់ យាងចារិកទៅក្នុងជនបទ ដោយយាងទៅមិនប្រញាប់ប្រញាល់ ។ បទថា **មហតា** សេចក្តីថា ឈ្មោះថា ធំ ព្រោះធំដោយគុណខ្លះ ឈ្មោះថា ធំ ព្រោះធំដោយចំនួន ព្រោះកំណត់រាប់មិនបានខ្លះ ។ បទថា **ភិក្ខុសង្ឃេន** បានដល់ ដោយពួកសមណៈដែលស្មើគ្នាដោយទិដ្ឋិ និងសីល ។ បទថា **សទ្ធឹ** ប្រែថា ជាមួយគ្នា ។ បទថា **មគ្គា ឯក្កម្ម** ប្រែថា គេចចេញអំពីផ្លូវ ។ បទថា **អញ្ញតរំ រុក្ខមូលំ** បានដល់ មូល ពោល គឺក្បែរដើមឈើធំ មានស្លឹកខៀវក្រាស់ មានម្លប់ត្រជាក់ ។ បទថា **អញ្ញតរោ គោចាលកោ** សេចក្តីថា អ្នកឃ្វាលគោម្នាក់ឈ្មោះនន្ទ ។ បានឮថា នន្ទនោះ ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានកោគៈច្រើន រក្សាហ្វូងគោរបស់អនាថបិណ្ឌិកសេដ្ឋី គេចពីការពិន័យរបស់ព្រះរាជា ដោយបន្ទំជាអ្នកឃ្វាលគោ រក្សាទ្រព្យរបស់ខ្លួន ដូចកេណិយជដិលចៀសវាងការពិន័យ ដោយបព្វជ្ជាភេទ ដូច្នោះ ។ គាត់កាន់យកបញ្ជូគោរសតាមកាល មកកាន់សម្នាក់របស់មហាសេដ្ឋី ហើយប្រគល់ឲ្យ រួចទៅកាន់សម្នាក់ព្រះសាស្តា ជួបព្រះ

សាស្តា ស្តាប់ធម៌ អារាធនាព្រះសាស្តាដើម្បីយាងមកកាន់លំនៅរបស់ខ្លួន ។ ព្រះសាស្តា ទ្រង់រង់ចាំការចាស់ក្លាំនៃញាណរបស់គាត់នោះឯង ក្រោយមក ទ្រង់ចោមរោមដោយមហាភិក្ខុសង្ឃ យាងចារិកទៅក្នុងជនបទ ជិងថា ឥឡូវ នេះ គាត់មានញាណចាស់ក្លាហើយ ទើបយាងចុះអំពីផ្លូវ មិនឆ្ងាយអំពីទី លំនៅរបស់គាត់ គង់ប្រថាប់ត្រង់គល់ឈើមួយដើម រង់ចាំការមករបស់គាត់ ឯនន្ទជិងថា ព្រះសាស្តាយាងចារិកមកក្នុងជនបទនេះ ទើបត្រេកអររីករាយ ទៅគាល់ព្រះសាស្តា ថ្វាយបង្គំ កាលព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈហើយ អង្គុយក្នុងចំណែកម្ខាង ។ លំដាប់នោះ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់គាត់ ។ នន្ទតាំងនៅក្នុងសោតាបត្តិផលហើយ អារាធនាព្រះមានព្រះភាគ ដើម្បីថ្វាយ បាយាសអស់កាល ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើ អនុមោទនា ហើយយាងចៀសចេញទៅ ដោយហេតុនោះ ទើបលោកពោល ថា លុះនាយគោបាលនោះ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ សម្តែងពន្យល់ឲ្យកាន់យក ។បេ។ រួចទ្រង់ក្រោកចាកអាសនៈយាងចេញទៅ ។

បណ្តាបទទាំងនោះ បទថា **សន្ទស្សេសិ** *សេចក្តីថា កាលទ្រង់សម្តែងធម៌ មានកុសលជាដើម វិបាករបស់កម្ម លោកនេះ និងលោកខាងមុខដោយប្រចក្ស ដោយនយជាដើមថា ធម៌ទាំងនេះជាកុសល ធម៌ទាំងនេះជាអកុសល ក្នុងកាលចប់អនុបុព្វីកថា ទើបទ្រង់ចង្អុលបង្ហាញអរិយសច្ច ៤ ។ បទថា* **សមាទបេសិ** *សេចក្តីថា ឲ្យបុរសនោះកាន់យកធម៌ មានសីលជាដើមដោយប្រពៃ គឺឲ្យនន្ទតាំងនៅក្នុងធម៌ មានសីលជាដើមនោះ ដោយនយជាដើមថា*

ដើម្បីសម្រេចសច្ចៈ អ្នកគប្បីឲ្យធម៌ទាំងនេះកើតឡើងក្នុងខ្លួន ។ បទថា **សមុត្តេជេសិ** *សេចក្តីថា ទ្រង់ឲ្យធម៌ទាំងនោះ ដែលសមាទានហើយ អប់រំដោយលំដាប់ ដែលជាចំណែកនៃធម៌គ្រឿងត្រាស់ដឹងមានការរឹងប៉ឹង និងល្អប្រសើរ ឲ្យអាចហ៊ានដោយប្រពៃ គឺឲ្យរុងរឿងដោយប្រពៃនោះឯង ដោយប្រការដែលនាំមកនូវអរិយមគ្គ ដោយឆាប់រួសរាន់ ។ បទថា* **សម្បហំសេសិ** *សេចក្តីថា ទ្រង់ឲ្យក្សៀវក្សាដោយល្អ ដោយធ្វើចិត្តឲ្យផូរផង់ហើយ ដោយការសម្តែងការៈនៃការនា មានគុណវិសេសទាំងខាងដើម និងខាងចុង ។ ម៉្យាងទៀត ក្នុងសេចក្តីនេះ គប្បីជ្រាបការចង្អុលបង្ហាញដោយបន្ទោបង់នូវសម្មោហៈក្នុងធម៌ដែលមានទោស និងមិនមានទោស និងក្នុងសច្ចៈ មានទុក្ខសច្ចជាដើម ការឲ្យសមាទាន ដោយការបន្ទោបង់នូវសេចក្តីប្រមាទក្នុងសម្មាបដិបត្តិ ការឲ្យអាចហ៊ាន ដោយការបន្ទោបង់ការរួញរានៃចិត្ត និងការត្រេកអរដោយការសម្រេចសម្មាបដិបត្តិ ។ ដោយអាការយ៉ាងនេះ លោកគប្បីតាំងនៅក្នុងសោតាបត្តិផល ដោយសាមុក្កង្សិកធម្មទេសនារបស់ព្រះមានព្រះភាគ ។ បទថា* **អធិវាសេសិ** *សេចក្តីថា ព្រះមានព្រះភាគ ដែលនាយគោបាលនោះជាអ្នកមានសច្ចៈឃើញហើយ ទូលអាពាធនាដោយនយជាដើមថា សូមព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តរបស់ខ្ញុំព្រះអង្គចុះ ទ្រង់មិនធ្វើអង្គ គឺកាយ និងវាចាឲ្យញាប់ញ័រ ទ្រង់ទទួល គឺត្រេកអរ ដោយព្រះហឫទ័យនោះឯង ដោយហេតុនោះឯង ទើបលោកពោលថា* **តុណ្ហីភាវេន។**

បទថា **អបេក្ខាឧកថាយាសំ** *ប្រែថា ជាយាសមានទឹកតិច ។ បទថា*

បដិយាទាបេត្វា ប្រែថា ចាត់ចែង គឺប្រុងប្រៀប ។ បទថា **ឆវញ្ច សប្បឺ** បានដល់ យកនវនីតមកចម្អិនឲ្យរាវ និងឲ្យជាសប្បិក្នុងខណៈនោះឯង ។ បទថា **សហត្ថា** សេចក្តីថា កើតនូវការអើពើអង្គាសដោយដៃខ្លួនឯង ។ បទថា **សន្តប្បេសិ** សេចក្តីថា ឲ្យសោយកោជនដែលរៀបចំ ។ បទថា **សម្បវារេសិ** បានដល់ ទ្រង់ហាមដោយវាចាថា ល្មមហើយៗ ។ បទថា **ភុត្តាវឺ** បានដល់ កិច្ច គឺការសោយព្រះក្រយាហារ ។ បទថា **ឱនីតបត្តបាណឺ** បានដល់ ដកព្រះហស្តចេញអំពីបាត្រ ។ បាឋៈថា **ឱនតបត្តបាណឺ** ដូច្នេះក៏មាន សេចក្តីថា លាងព្រះហស្តក្នុងបាត្រ ។ បទថា **ឯកំ** ប្រែថា មិនខ្ពស់ ។ ការកាន់យកអាសនៈដែលមិនខ្ពស់ ហើយអង្គុយលើអាសនៈនោះឯង ជាបែបបទរបស់អ្នកនៅក្នុងអរិយបទេស គាត់អង្គុយក្នុងទីជិតអាសនៈ ដែលធ្វើដោយបន្ទះក្តារ ដែលរៀបចំជាឧបចារៈក្នុងសម្នាក់ព្រះសាស្តា ។ បទថា **ធម្មិយា កថាយ** ជាដើម ត្រាស់សំដៅយកអនុមោទនាដែលទ្រង់ធ្វើក្នុងថ្ងៃទី ៧ ។ បានឮថា នន្ទអារាធនាព្រះមានព្រះភាគ និងភិក្ខុដែលនៅក្នុងទីនោះ អស់ ៧ ថ្ងៃ ហើយបំពេញមហាទាន ។ ក្នុងថ្ងៃទី ៧ បានថ្វាយមធុបាយាសដែលមានទឹកតិច ។ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាហើយ ចៀសចេញទៅ ព្រោះនន្ទមិនមានញាណចាស់ក្លា ដើម្បីបានមគ្គជាន់លើ ក្នុងអត្តភាពនោះ ។

[៩១] បទថា **សីមន្តរិកាយ** បានដល់ ក្នុងរវាងដែន គឺក្នុងរវាងស្រុកនោះ ។ បានឮថា ពួកអ្នកស្រុកអាស្រ័យស្រះមួយកន្លែង បានធ្វើការទាស់ទែងជាមួយនន្ទ នន្ទសង្កត់ពួកអ្នកស្រុកនោះហើយ កាន់កាប់ស្រះនោះ ។

ព្រោះហេតុនោះ ទើបបុរសម្នាក់ចង អាយាត ប្រើព្រួញបាញ់សម្លាប់នន្ទដែលកាន់បាត្ររបស់ព្រះសាស្តា ជូនដំណើរទៅឆ្ងាយ កាលទ្រង់ត្រាស់ថា នែឧបាសក ចូរអ្នកត្រឡប់ចុះ ទើបនន្ទថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ និងធ្វើអញ្ជលីភិក្ខុសង្ឆ ហើយផ្គងអញ្ជលីដ៏រុងរឿង ដែលប្រជុំដោយម្រាម ១០ រហូតដល់ផុតកន្ទុយភ្នែក ហើយត្រឡប់ទៅតែម្នាក់ឯង ក្នុងអរញ្ញបទេសក្នុងចន្លោះស្រុកទាំង ២ ។ ដោយហេតុនោះ ទើបលោកពោលថា **អចី-រប្ឈក្ពន្ធស្ឆ ។បេ។ ហោរោបេសិ** ជូច្នេះ ។

ភិក្ខុទាំងឡាយ ដែលយឺតយូរ ដោយការណីឯណាមួយ ទៅឯក្រោយ យើញនន្ទគោបាលស្លាប់ ជូច្នោះ ទើបក្រាបទូលសេចក្តីនោះដល់ព្រះមានព្រះភាគ ជូចលោកពោលថា **អថ ខោ សម្ពហុលា ភិក្ខូ** ជូច្នេះជាដើម ។

បទថា **ឯតមត្តំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបអត្តនេះថា ព្រោះបុរសដែលសម្លាប់នន្ទអរិយសាវក ដែលសម្ឃូរដោយទិដ្ឋិ ឧល់ឧាយតែនឹងអនន្ត-រិយកម្ម ដែលមិនមែនជាបុណ្យ ជូច្នោះ ចិត្តដែលតម្ពល់ឧសរបស់សត្វទាំងនេះ រមែងធ្វើកម្មដ៏ឧាំងក្លាជាងកម្មរបស់ចោរ និងអ្នកដែលមានពៀរ គប្បីធ្វើដល់គ្នា ជូច្នេះហើយ ទើបទ្រង់បន្ទឺឧទាននេះ ដែលសម្តែងសេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **ឧសោ ឧសំ** សេចក្តីថា ចោរបានយើញផងគ្នា គឺចោរយើញចោរ ។ បាលីដ៏សេសថា **ឧស្ឆា** គប្បីនាំមកភ្ជាប់ជាមួយគ្នា ។ បទថា **យន្តំ ឥយិរា** បានដល់ គប្បីធ្វើនូវការវឹកវរឲ្យដល់ចោរ ឬអ្នកដែលមានពៀរនោះ ។ ក្នុងបទទី ២ ក៏នយនេះដូចគ្នា ។ ទើបលោក

អធិប្បាយដូច្នេះថា ចោរដែលបំណងប្រទូសរ៉ាយមិត្រណាមួយ ខុសក្នុងវិញ្ញាណកទ្រព្យ និងអវិញ្ញាណកទ្រព្យ មានបុត្រ ភរិយា ស្រែ ចម្ការ គោ និងក្របីជាដើមរបស់ចោរម្នាក់ ខ្លួនខុសចំពោះចោរណា ឃើញចោរនោះខុសក្នុងខ្លួនយ៉ាងនោះឯង ឬបុគ្គលមានពៀរ ឃើញបុគ្គលមានពៀរ ដោយហេតុណាមួយ គប្បីធ្វើការវឹកវរដល់បុគ្គលមានពៀរនោះ ឬគប្បីបៀតបៀនបុត្រ និងភរិយា ឬគប្បីសម្លាប់បំបាត់ជីវិត ព្រោះខ្លួនជាបុគ្គលយោរយៅ ចិត្តដែលឈ្មោះថា តម្កល់ខុស ព្រោះតម្កល់ខុសក្នុងអកុសលកម្មបថ ១០ គប្បីធ្វើបុគ្គលនោះឲ្យអាក្រក់ជាងនោះ គឺគប្បីធ្វើបុរសនោះឲ្យអាក្រក់ជាងនោះ ។ សេចក្តីពិត ចោរ ឬបុគ្គលមានពៀរ មានប្រការដូចពោលហើយ គប្បីធ្វើទុក្ខឲ្យកើតខ្លឹងដល់ចោរ ឬបុគ្គលមានពៀរ ឬធ្វើចោរ និងបុគ្គលមានពៀរឲ្យអស់ជីវិតក្នុងអត្តភាពនេះប៉ុណ្ណោះ ឯចិត្តដែលតម្កល់ខុសក្នុងអកុសលកម្មបថ ១០ នេះ រមែងធ្វើបុគ្គលនោះឲ្យវឹកវរក្នុងបច្ចុប្បន្ននេះឯង រមែងបន្សាត់ទៅក្នុងអបាយ ៤ មិនឲ្យងើបក្បាលខ្លឹងបានក្នុងសែនអត្តភាព ៗ

អដ្ឋកថាគោចាលសូត្រទី ៣ ចប់

សុត្តន្តបិដក

ជុណ្ហសូត្រ

[៩៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ និងព្រះមហាមោគ្គល្លានដ៏មានអាយុ នៅក្នុងវត្តកបោតកន្ទរ ។ សម័យនោះ ព្រះសារីបុត្តដ៏មានអាយុ មានសក់ទើបកោរថ្មីៗ អង្គុយក្នុងទីវាល ចូលកាន់សមាធិណាមួយ ក្នុងរាត្រីខាងខ្នើត ។

[៩៤] សម័យនោះ មានយក្ស ២ នាក់ ជាសម្លាញ់នឹងគ្នា មកអំពីទិសខាងជើង ទៅទិសខាងត្បូង ដោយកិច្ចណាមួយ ។ យក្សទាំងនោះ បានឃើញព្រះសារីបុត្តដ៏មានអាយុ មានសក់ទើបកោរថ្មីៗ អង្គុយក្នុងទីវាល ក្នុងរាត្រីខាងខ្នើត លុះយក្សម្នាក់បានឃើញហើយ និយាយប្រាប់យក្សម្នាក់ទៀតថា ម្នាលសម្លាញ់ ចិត្តរបស់ខ្ញុំកើតប្រាកដ ដើម្បីប្រហារក្បាលសមណៈនេះ។ កាលបើយក្សម្នាក់ និយាយយ៉ាងនេះហើយ យក្សនោះក៏និយាយទៅនឹងយក្សម្នាក់ទៀតនោះថា កុំសម្លាញ់ អ្នកកុំប្រហារសមណៈឡើយ ម្នាលសម្លាញ់ សមណៈនោះ មានគុណដ៏លើសលុប មានឫទ្ធិច្រើន មានអានុភាពច្រើន ។ យក្សម្នាក់នោះ បាននិយាយនឹងយក្សនោះ ជាគម្រប់ ២ ដងទៀតថា ម្នាលសម្លាញ់ ចិត្តរបស់ខ្ញុំកើតប្រាកដ ដើម្បីប្រហារក្បាលសមណៈនេះ ។ យក្សនោះ និយាយទៅនឹងយក្សម្នាក់ទៀតនោះ ជាគម្រប់ ២ ទៀតថា កុំសម្លាញ់ អ្នកកុំប្រហារសមណៈឡើយ ម្នាលសម្លាញ់ សមណៈនោះមានគុណដ៏លើសលុប មានឫទ្ធិច្រើន មានអានុភាពច្រើន ។ យក្សម្នាក់នោះ និយាយទៅនឹង

*យក្សនោះ ជាគម្រប់ ៣ ដងទៀតថា ម្នាលសម្ងាញ់ ចិត្តរបស់ខ្ញុំកើតជ្រាកជ
ដើម្បីប្រហារក្បាលសមណៈនេះ ។ យក្សនោះនិយាយទៅនឹងយក្សម្នាក់ទៀត
នោះ ជាគម្រប់ ៣ ដងទៀតថា កុំសម្ងាញ់ អ្នកកុំប្រហារសមណៈឡើយ
ម្នាលសម្ងាញ់ សមណៈនោះមានគុណដ៏លើសលុប មានឫទ្ធិច្រើន មាន
អានុភាពច្រើន ។ លំដាប់នោះ យក្សម្នាក់នោះ មិនអើពើនឹងយក្សនោះឡើយ
ហើយប្រហារចំព្រះសិរ្សព្រះសារីបុត្តត្ថេរដ៏មានអាយុ ។ មានសេចក្តីតំណាល
ថា យក្សនោះអាចពន្ធិចដីរីមានកម្ពស់ ៧ ហត្ថ ឬ ៨ ហត្ថ (ឲ្យស្រុត
ទៅក្នុងផែនដី) ក៏បាន អាចធ្វើកំពូលភ្នំធំ ឲ្យបែបខ្ទេចខ្ទីក៏បាន ដោយការ
ប្រហារនោះ ។ លំដាប់នោះ ស្រាប់តែយក្សនោះពោលថា ខ្ញុំក្តៅណាស់
ដូច្នេះហើយ ធ្លាក់ទៅកាន់មហានរក ត្រង់ទីនោះឯង ។*

[៩៥] *ព្រះមហាមោគ្គល្លានដ៏មានអាយុ បានឃើញយក្សនោះ កំពុង
ប្រហារចំព្រះសិរ្ស ព្រះសារីបុត្តដ៏មានអាយុ ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្ទង
ចក្ខុរបស់មនុស្សធម្មតា លុះឃើញហើយ ក៏ចូលទៅរកព្រះសារីបុត្តដ៏មាន
អាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះសារីបុត្តដ៏មានអាយុថា
ម្នាលអាវុសោ លោកលួមអត់ធន់បានដែរឬ លួមប្រព្រឹត្តទៅបានដែរឬ មិន
មានសេចក្តីទុក្ខតិចតួចទេឬ ។ ព្រះសារីបុត្តដ៏មានអាយុ ប្រាប់ថា ម្នាល
អាវុសោមោគ្គល្លាន ខ្ញុំលួមអត់ធន់បាន ម្នាលអាវុសោមោគ្គល្លាន ខ្ញុំលួម
ប្រព្រឹត្តទៅបាន តែថា មានសេចក្តីទុក្ខបន្តិច ត្រង់ក្បាលរបស់ខ្ញុំ ។ ម្នាល
អាវុសោសារីបុត្ត អស្ចារ្យណាស់ ម្នាលអាវុសោសារីបុត្ត ចម្លែកណាស់*

ព្រោះថា សារីបុត្តដ៏មានអាយុ មានឬទ្ធិច្រើន មានអានុភាពច្រើន ។ ម្នាលអាវុសោសារីបុត្ត ក្នុងទីនេះ មានយក្សមួយ ប្រហារចំព្រះសិរ្សនៃលោក (ការប្រហារនោះ) ពេញជាការប្រហារខ្លាំង ឯយក្សនោះអាចពន្ធិចដំរីមានកម្ពស់ ៧ ហត្ថ ឬ ៨ ហត្ថ (ឲ្យស្រុតទៅក្នុងផែនដីបាន) អាចធ្វើកំពូលភ្នំធំឲ្យបែកខ្ទេចខ្ទីបាន ដោយការប្រការនោះ ។ ហេតុអ្វីក៏ព្រះសារីបុត្តដ៏មានអាយុនិយាយយ៉ាងនេះថា ម្នាលអាវុសោមោគ្គល្លាន ខ្ញុំល្មមអត់ធន់បាន ម្នាលអាវុសោមោគ្គល្លាន ខ្ញុំល្មមប្រព្រឹត្តទៅបាន តែថា មានសេចក្តីទុក្ខបន្ធិចត្រង់ក្បាលរបស់ខ្ញុំ ។ ម្នាលអាវុសោមោគ្គល្លាន អស្ចារ្យណាស់ ម្នាលអាវុសោមោគ្គល្លាន ចម្លែកណាស់ ព្រោះថា មហាមោគ្គល្លានដ៏អាយុ មានឬទ្ធិច្រើន មានអានុភាពច្រើន មើលយក្សយើញបាន ចំណែកខាងយើងមិនយើញ សូម្បីបិសាច ដែលអាស្រ័យនឹងអាចម៍ដីសោះឡើយ ។

[៩៦] ព្រះមានព្រះភាគ ទ្រង់ព្រះសណ្តាប់ពាក្យចរចា មានសភាពយ៉ាងនេះ របស់ព្រះមហានាគត្ថេរទាំង ២ អង្គនោះ ដោយទិព្វសោតធាតុដ៏បរិសុទ្ធ កន្ធងសោតធាតុរបស់មនុស្សធម្មតា ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីន៉ុះហើយ ទើបបន្ធឹឧទាននេះ ក្នុងវេលានោះថា

> ចិត្តរបស់បុគ្គលណា មានឧបមាដោយថ្មតាន់ នៅនឹង មិនញាប់ញ័រ ប្រាសចាកតម្រេក ក្នុងហេតុគួរវីការាយទាំងឡាយ មិនក្រោធ ក្នុងវត្ថុគួរក្រោធ ចិត្តដែលបុគ្គលណា បានចម្រើនយ៉ាងនេះហើយ សេចក្តីទុក្ខនឹងមានមកដល់បុគ្គលនោះអំពីណាបាន ។ សូត្រទី ៤ ។

អដ្ឋកថា

ជុណ្ហសូត្រ

ជុណ្ហសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

[៩៣] បទថា **កកោតកន្តរាយំ** បានដល់ ក្នុងវិហារមានឈ្មោះយ៉ាងនោះ ។ បានឮថា ក្នុងកាលមុនសត្វព្រាបជាច្រើននៅក្នុងញកភ្នំនោះ ។ ដោយហេតុនោះ ទើបញកភ្នំនោះ គេហៅថា **កកោតកន្តរា** ។ ខាងក្រោយ គេសាងវិហារក្នុងទីនោះ ក៏នៅប្រាកដឈ្មោះថា កកោតកន្តរានោះឯង ។ ដោយហេតុនោះ ទើបលោកពោលថា **កកោតកន្តរាយំ** ។ ត្រង់វិហារនោះ ។

បទថា **ជុណ្ហាយ រត្តិយា** បានដល់ ក្នុងរាត្រីសុក្កបក្ខ ។ បទថា **ឆវោ-អាមិតេហិ កេសេហិ** បានដល់ មានសក់ដែលកោរមិនយូរ ពាក្យថា **កេសេហិ** នេះ ជាតតិយាវិភត្តិ ប្រើក្នុងលក្ខណៈឥត្ថម្ភូត ។ បទថា **អព្ភោកាសេ** បានដល់ ទីទួលកណ្តាលវាលដែលមិនមានគ្រឿងប្រក់ ឬគ្រឿងបាំង ។ ក្នុងព្រះថេរៈទាំងនោះ ព្រះសារីបុត្រមានពណ៌ដូចមាស ព្រះមហាមោគ្គល្លាន មានពណ៌ដូចផ្កាឧប្បលខៀវ ព្រះមហាថេរៈទាំង ២ អង្គនោះ ជាជាតិព្រាហ្មណ៍ ដោយចំពោះ សម្បូរដោយអភិនីហារអស់មួយអសង្ខ្យៃ និងមួយសែនកប្ប សម្រេចអភិញ្ញា ៦ និងបដិសម្ភិទា ៤ ជាព្រះខីណាស្រពធំ បាននូវសមាបត្តិគ្រប់យ៉ាង ដល់ទីបំផុតនូវសាវកបារមីញាណ ៦៧ ប្រការ ធ្វើកកោតកន្តរ-វិហារមួយកន្លែង ឲ្យភ្លឺស្វាងរុងរឿង ដូចរាជសីហ៍ ២ នៅក្នុងគុហាមាសតែមួយ ដូចខ្លាធំ ២ ចុះកាន់ទីរលាស់កាយជាមួយគ្នា ដូចស្តេចដំរីឆទ្ទន្ត ២

ចូលកាន់ព្រៃសាលវ័ន ដែលមានផ្ការីកស្គុសស្គាយជាមួយគ្នា ដូចស្តេចគ្រុឌ ២ នៅក្នុងសិម្ពលីវ័នជាមួយគ្នា ដូចស្តេចវេស្សវណ ២ អង្គ ឡើងកាន់យាន សម្រាប់នាំមនុស្សក្នុងយានតែមួយ ដូចសក្កទេវរាជ ២ អង្គ ប្រថាប់លើ បណ្ដុកម្ពលសិលាសនៈតែមួយ ដូចស្តេចមហាព្រហ្ម ២ អង្គ នៅក្នុងវិមាន តែមួយ ដូចព្រះចន្ទ ២ វង់ និងព្រះអាទិត្យ ២ វង់ នៅក្នុងលម្ហតែមួយ ដូច្នោះ ។ ក្នុងព្រះថេរៈទាំងនោះ ព្រះមហាមោគ្គល្លានបានអង្គុយស្ងៀម ឯ ព្រះសារីបុត្រចូលសមាបត្តិ ។ ដោយហេតុនោះ ទើបលោកពោលថា **អញ្ញតរំ សមាធិ សមាបជ្ជិត្វា** *ដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **អញ្ញតរំ សមាធិ** *បានដល់ ឧបេក្ខាព្រហ្ម-វិហារសមាបត្តិ ។ អាចារ្យពួកខ្លះពោលថា សញ្ញាវេទយិតនិរោធសមាបត្តិ ។ ឯអាចារ្យមួយពួកទៀតពោលថា ចូលផលសមាបត្តិដែលមានអរូបជ្ឈានជាបាទ ។ ពិតហើយ សមាបត្តិទាំង ៣ នេះ ជាសមាបត្តិដែលអាចរក្សាកាយក្នុងសមាបត្តិទាំងនោះ ការកើតដោយបរិយាយនៃសមាធិរបស់និរោធសមាបត្តិ បានពោលខាងដើមហើយនោះឯង ។ តែអាចារ្យទាំងឡាយពណ៌នាសមាបត្តិចុងក្រោយប៉ុណ្ណោះ ។*

[៩៤] *បទថា* **ឧត្តរាយ ទិសាយ ទក្ខិណាទិសំ គច្ឆន្តិ** *សេចក្ដីថា ទៅកាន់សមាគមយក្ខក្នុងឧត្តរទិស ហើយទៅទក្ខិណទិស ដើម្បីទៅកាន់កន្លែងរបស់ខ្លួន ។ បទថា* **បដិភាតិ មំ** *បានដល់ ចិត្តរបស់អាត្មាអញប្រាកដ ។ ពិតហើយ បទថា* **មំ** *ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថឆដ្ឋីវិភត្តិ ព្រោះប្រកបដោយ*

បដិ *សព្ទ សេចក្តីថា ចិត្តរបស់ខ្ញុំកើតឡើងដើម្បីនឹងវាយសីសៈព្រះថេរៈនេះ ។ បានឮថា យក្ខនោះចងអាឃាតព្រះថេរៈមកតាំងអំពីជាតិមុន ព្រោះហេតុនោះ ទើបគ្រាន់តែឃើញព្រះថេរៈ មានចិត្តប្រទូស្តបែបនោះ ។ ឯយក្ខដែលជាសម្លាញ់ ជាអ្នកមានបញ្ញា ព្រោះដូច្នោះ កាលហាមយក្ខនោះ ទើបពោលពាក្យជាដើមថា កុំសម្លាញ់ អ្នកកុំប្រហារសមណៈឡើយ ។*

បណ្តាបទទាំងនោះ បទថា **មា អាសាឧទេសិ** *បានដល់ កុំព្យាយាម អធិប្បាយថា ចូរកុំប្រហារ ។ បទថា* **ឧឡ្ឆាភោ** *សេចក្តីថា ប្រកបដោយគុណ មានសីលជាដើមដ៏ក្រៃលែង គឺប្រសើរបំផុត ។ បទថា* **អនាធិយិត្វា** *សេចក្តីថា មិនធ្វើនូវការអើពើ គឺមិនជឿពាក្យរបស់យក្ខជាសម្លាញ់នោះ ។ ព្រោះហេតុយក្ខមិនជឿពាក្យរបស់យក្ខសម្លាញ់នោះ ទើបឈ្មោះថា មិនអើពើនឹងយក្ខនោះ ដូច្នោះ ទើបលោកពោលថា* **តំ យក្ខំ អនាធិយិត្វា ។** *បទថា* **សីសេ បហារំ អទាសិ** *សេចក្តីថា ធ្វើសេចក្តីឧស្សាហ៍ឲ្យកើតដោយកម្លាំងទាំងអស់ ឈរនៅលើអាកាសនោះឯង វាយត្រង់សីសៈ អធិប្បាយថា យកដៃវាយត្រង់សីសៈ ។*

[៩៥] *បទថា* **តាវ មហា** *សេចក្តីថា បានប្រហារយ៉ាងធ្ងន់បែបនោះ ដោយកម្លាំងដ៏មហិមា ។ បទថា* **តេន បហារេន** *បានដល់ ដោយការប្រហារនោះដែលជាតួហេតុ ។ បទថា* **សត្តរតនំ** *បានដល់ ៧ ហត្ថ ដោយហត្ថរបស់មជ្ឈិមបុរស ។ បទថា* **សោ** *បានដល់ យក្ខ ។ បទថា* **ឆាគំ** *បានដល់ ស្តេចដំរី ។ បទថា* **ឱសាឧយ្យ** *បានដល់ គប្បីឲ្យលិចចុះ*

គឺគប្បីឲ្យស្រុតចូលក្នុងផែនដី ជាប៉ះថា **ឱសារេយ្យ** *គប្បីឲ្យប្រជុំចុះដូច្នេះ ក៏មាន អធិប្បាយថា គប្បីធ្វើឲ្យបែកល្អិត ។ បទថា* **អឌ្ឍដ្ឋមរតនំ** *សេចក្តីថា ជាទីពេញនៃវត្ថុ ៨ មួយអន្ទើដោយកន្ទុះ ព្រោះដូច្នោះ ទើបឈ្មោះថា ជាគម្រប់ ៨ ដោយកន្ទុះ ។ ហត្ថទី ៨ ទាំងកន្ទុះ ជាទំហំរបស់ដីរនោះ ហេតុនោះ ដីរនោះមានទំហំ ៧ ហត្ថ កន្ទុះ ដែលដីរនោះ មានទំហំ ៨ ហត្ថកន្ទុះ ។ បទថា* **មហន្តំ បព្ភតក្ខន្ធំ** *បានដល់ កំពូលភ្នំទំហំប្រមាណប៉ុនកំពូលភ្នំកៃលាស ។ បទថា* **បទាលេយ្យ** *បានដល់ គប្បីទម្លាយដោយអាការឲ្យជាបំណែក ភ្ជាប់សេចក្តីថា ឲ្យលិចចុះទៅខ្លះ ឲ្យបែកទៅខ្លះ ។*

ក្នុងខណៈនោះឯង ការក្តៅក្រហាយធំកើតឡើងក្នុងសរីរៈរបស់យក្ខនោះ យក្ខនោះក្តៅក្រហាយដោយវេទនា មិនអាចស្ថិតនៅក្នុងអាកាសបាន ទើបធ្លាក់ចុះត្រង់ផែនដី ។ ខណៈនោះឯង មហាប្រឹថពីកម្រាស់ ២ សែន ៤ ម៉ឺន យោជន៍ ទ្រស្តេចភ្នំកម្ពស់ ១ សែន ៦ ម៉ឺន ៨ ពាន់យោជន៍ មិនអាចទ្រសត្វអាក្រក់នោះបាន ទើបបើកប្រហោងឲ្យអណ្តាតភ្លើងផុសឡើងមកអំពីអវីចីមហានរក លេបត្របាក់យកយក្ខដែលកំពុងសុបសៅនោះឯង យក្ខនោះកន្ទក់កន្ទេញធ្លាក់ទៅ ។ ដោយហេតុនោះ ទើបលោកពោលថា លំដាប់នោះ ស្រាប់តែយក្ខនោះពោលថា ខ្ញុំក្តៅណាស់ ដូច្នេះហើយ ក៏ធ្លាក់ទៅកាន់មហានរក ត្រង់ទីនោះឯង ។

បណ្តាបទទាំងនោះ បទថា **អបតាសិ** *បានដល់ បានធ្លាក់ទៅហើយ ។ សួរថា យក្ខនោះធ្លាក់នរកទាំងអត្តភាពនោះឯងឬ ។ ឆ្លើយថា មិនមែនទេ តែ*

ក្នុងទីនេះ ព្រោះកម្លាំងនៃបាបកម្មដែលឲ្យផលក្នុងបច្ចុប្បន្ន ទើបយក្ខសោយទុក្ខដ៏ខ្លាំងក្លា ក្នុងអត្តភាពជាយក្ខ ។ ម្យ៉ាងទៀត ព្រោះឧបបជ្ជវេទនីយកម្មដែលជាអនន្តរិយកម្ម ទើបយក្ខកើតក្នុងនរកបន្ទាប់ពីចុតិ តែរាងកាយរបស់ព្រះថេរៈដែលត្រូវកម្លាំងនៃសមាបត្តិឧបការៈ ទើបមិនមានវិការអ្វីឡើយ ។ សេចក្តីពិត យក្ខប្រហារលោកក្នុងកាលដែលលោកមិនទាន់ចេញអំពីសមាបត្តិ ព្រះមហាមោគ្គល្លានឃើញយក្ខនោះប្រហារយ៉ាងនោះ ដោយទិព្វចក្ខុ ទើបចូលទៅរកព្រះធម្មសេនាបតី ព្រមគ្នានឹងពេលដែលលោកចូលទៅរកនោះឯង ព្រះធម្មសេនាបតី ក៏ចេញពីសមាបត្តិ ។ ក្នុងគ្រានោះ ទើបព្រះមហាមោគ្គល្លានសួរដល់ការមើលងាយនោះ ជាមួយព្រះធម្មសេនាបតី ឯព្រះធម្មសេនាបតីក៏ព្យាករដល់លោក ។ ដោយហេតុនោះ ទើបលោកពោលថា លុះឃើញហើយ ។បេ។ តែថា មានសេចក្តីទុក្ខបន្តិច ត្រង់ក្បាលរបស់ខ្ញុំ ។

[៩៥] *បណ្តាបទទាំងនោះ បទថា* **ថោកំ ទុក្ខំ** *សេចក្តីថា ក្បាលរបស់ខ្ញុំជាទុក្ខ គឺបានទទួលទុក្ខតិចតួច គឺមានប្រមាណតិចតួច ដូចគ្នានឹងបន្តក់ទៀន ពិតហើយ ក្បាលជាទីតាំងនៃទុក្ខ លោកហៅថា មានទុក្ខ ចារីថា* **សីសេ ថោកំ ទុក្ខំ** *ជាទុក្ខតិចតួចត្រង់ក្បាល ដូច្នេះក៏មាន ។ សួរថា កាលសរីរៈត្រូវកម្លាំងនៃសមាបត្តិឧបការៈ សីសៈរបស់ព្រះថេរៈ ជាទុក្ខតិចតួចដូចម្តេច ។ ឆ្លើយថា ព្រោះលោកទើបតែចេញអំពីសមាបត្តិ ពិតហើយ ទុក្ខមិនប្រាកដក្នុងសមាបត្តិ ដូចមូសជាដើមប្រាកដដល់អ្នកដេកលក់ គឺប្រាកដតិចតួចដល់អ្នកភ្ញាក់ឡើង ព្រោះទាក់ទងដោយកាយ ។ កាលព្រះមហាមោគ្គ-*

ល្ងានកើតនូវការអស្ចារ្យឡើងថា ឈ្មោះថា វិការមិនមានក្នុងរាងកាយដែល ត្រូវយក្ខមានកម្លាំងច្រើនប្រហារ ដោយពេញកម្លាំងបែបនោះ ប្រកាសភាព ដែលព្រះធម្មសេនាបតីមានអានុភាពច្រើន ដោយន័យជាដើមថា គួរអស្ចារ្យ ហ្ន៎ សារីបុត្រ ។ ឯព្រះធម្មសេនាបតីសម្តែងភាពដែលខ្លួនលះបានជាសមុច្ឆេទ នូវមន្ទិលមានឥស្សា និងអហង្ការជាដើម ដោយប្រការថា ខ្លួនមានអានុភាព ច្រើនដល់ព្រះមោគ្គល្ងាននោះ ដោយន័យជាដើមថា ម្នាលអាវុសោមោគ្គល្ងាន អស្ចារ្យណាស់ ម្នាលអាវុសោមោគ្គល្ងាន ចម្លែកណាស់ ។ បទថា **បំសុ-បិសាចកម្បិ ន បស្សាម** *សេចក្តីថា ខ្ញុំមិនឃើញសូម្បីត្រឹមតែខ្ទុះប្រេត ដែលត្រាច់ទៅតាមគំនរសំរាមជាដើម ។ ដូច្នោះ ព្រះមហាថេរៈជាកំពូលនៃ បុគ្គលប្រាថ្នាមគ្គផល ទើបបានពោលសំដៅដល់ការមិនឃើញប្រេតទាំងនោះ ព្រោះមិនបានពិចារណាដល់ក្នុងកាលនោះ ។ ដោយហេតុនោះឯង ទើបលោក ពោលថា* **ឯតរហិ ។** *ព្រះមានព្រះភាគ ប្រថាប់នៅត្រង់វត្តវេឡុវ័ន ស្តាប់ ចរចានេះនៃអគ្គសាវ័កទាំង ២ ដោយទិព្វសោតញ្ញាណ ។ ដោយហេតុនោះ ទើបលោកពោលថា* **អស្សោសិ ខោ ភគវា** *ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថដូចពោលទុកហើយនោះឯង ។*

[៩៦] *បទថា* **ឯតមត្ថំ វិទិត្វា** *បានដល់ ទ្រង់ជ្រាបភាពដែលព្រះ សារីបុត្រជាអ្នកប្រកបដោយកម្លាំងនៃសមាបត្តិ មានឥទ្ធានុភាពច្រើន ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្ទឺឧទាននេះ សម្តែងដល់ការដែលព្រះសារីបុត្រ នោះឯង ដល់នូវភាពជាបុគ្គលនឹងធឹង ។*

បណ្តាបទទាំងនោះ បទថា **យស្ស សេលូបមំ ចិត្តំ ឋិតំ ឆានុបកម្បតិ** *សេចក្តីថា ចិត្តរបស់ព្រះខីណាស្រពណា ឧបមាដូចថ្មកំ ដែលជាវិការនៃថ្ម សុទ្ធ ក្រាស់ តាំងនៅដោយភាពជាវសី ព្រោះមិនមានកិលេសជាគ្រឿងលំអៀងទាំងអស់ រមែងមិនញាប់ញ័រ គឺរមែងមិនកម្រើកដោយលោកធម៌ទាំងពួង ។*

ឥឡូវនេះ កាលទ្រង់សម្តែងអាការដែលព្រះខីណាស្រពនោះ មិនមានការញាប់ញ័រ មួយអន្ទើដោយហេតុ ទើបត្រាស់ពាក្យជាដើមថា **វិរត្តំ។**

បណ្តាបទទាំងនោះ បទថា **វិរត្តំ រជនីយេសុ** *សេចក្តីថា ដែលច្រាសចាកសេចក្តីត្រេកអរក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាហេតុកើតរាគៈ ដែលជាទីតាំងនៃការត្រេកអរ ដោយអរិយមគ្គ គឺវិរាគធម៌ អធិប្បាយថា កាត់នូវរាគៈបានជាសមុច្ឆេទ ដោយប្រការទាំងពួង ដោយធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ ។ បទថា* **កោបនេយ្យេ** *សេចក្តីថា រមែងមិនក្រោធ គឺរមែងមិនអាក់អន់ បានដល់ មិនដល់នូវអាការដែលខុសប្លែក ក្នុងអាឃាតវត្ថុទាំងអស់ ដែលជាទីតាំងនៃការអាក់អន់ ។ បទថា* **យស្សេវំ ភាវិតំ ចិត្តំ** *សេចក្តីថា ចិត្តដែលព្រះអរិយបុគ្គលដែលពោលហើយណា អប់រំហើយដោយភាវៈដែលនាំមកនូវភាពជាអ្នកនឹងធឹង ដោយអាការយ៉ាងនេះ គឺដោយនយដូចពោលហើយ ។ បទថា* **កុតោ តំ ទុក្ខមេស្សតិ** *សេចក្តីថា ទុក្ខនឹងចូលដល់នូវខត្តមបុគ្គលនោះបានអំពីណា គឺអំពីសត្វ ឬសង្ខារ អធិប្បាយថា បុគ្គលបែបនោះ មិនមានទុក្ខ ៗ*

អដ្ឋកថាជុណ្ហសូត្រទី ៤ ចប់

សុត្តន្តបិដក

ជាគសូត្រ

[៧៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងយោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅច្រឡូកច្រឡំដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ស្តេច អមាត្យធំរបស់ស្តេច តិរ្ថិយ និងពួកសាវ័ករបស់តិរ្ថិយ ព្រះមានព្រះភាគ ទ្រង់គង់នៅច្រឡូកច្រឡំជាទុក្ខ មិនសប្បាយឡើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់មានសេចក្តីត្រិះរិះថា ឥឡូវនេះ តថាគតនៅច្រឡូកច្រឡំដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ស្តេច អមាត្យធំរបស់ស្តេច តិរ្ថិយ និងពួកសាវ័ករបស់តិរ្ថិយ តថាគតនៅច្រឡូកច្រឡំជាទុក្ខ មិនសប្បាយ បើដូច្នោះ គួរតែតថាគត គេចចេញអំពីពួកហើយ នៅតែម្នាក់ឯង ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាត ក្នុងក្រុងកោសម្ពី ។ លុះព្រះមានព្រះភាគ ត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងកោសម្ពី ត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលខាងក្រោយភត្ត ហើយទុកជាក់សេនាសនៈដោយព្រះអង្គឯង ហើយប្រដាប់បាត្រចីវរ មិនបានលាឧបជ្ឈាក មិនបានប្រាប់ភិក្ខុសង្ឃ តែមួយអង្គឯង ឥតមានភិក្ខុជាគម្រប់ ២ ទ្រង់យាងទៅកាន់ចារិក នៃបាលិលេយ្យកប្រទេស កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ បានដល់បាលិលេយ្យកប្រទេស ។

[៧៨] បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្រោមម្លប់ភទ្ទសាល-ព្រឹក្ស ក្នុងដងព្រៃឈ្មោះរក្ខិតៈ ជិតបាលិលេយ្យកប្រទេសនោះ ។ មានដំរី

ដ៏ប្រសើរ ១ នៅច្រឡូកច្រឡំដោយពួកជំរីឈ្មោល ជំរីញី ជំរីស្ទាវ និងកូន ជំរី ហើយស៊ីស្មៅ ដែលពួកជំរីទាំងនោះ ច្រឹបចុងហើយផង ពួកជំរីទាំងនោះ ស៊ីនូវមែកឈើបាក់ ដែលជំរីដ៏ប្រសើរនោះបំបាក់ចុះហើយផង ឯជំរីដ៏ប្រសើរ ក៏ផឹកទឹកទាំងឡាយដ៏ល្អក់ផង កាលបើជំរីដ៏ប្រសើរដើរចុះឡើងកំពង់ទឹក ពួក មេជំរីក៏ដើរត្រដុសកាយផង ជំរីដ៏ប្រសើរ នៅច្រឡូកច្រឡំជាទុក្ខ មិន សប្បាយឡើយ ។ លំដាប់នោះ ជំរីដ៏ប្រសើរនោះ មានសេចក្តីត្រិះរិះថា ឥឡូវនេះ អញនៅច្រឡូកច្រឡំដោយពួកជំរីឈ្មោល ជំរីញី ជំរីស្ទាវ និងកូន ជំរី ហើយស៊ីស្មៅ ដែលពួកជំរីទាំងនោះ ច្រឹបចុងហើយផង ពួកជំរីទាំងនោះ ស៊ីមែកឈើបាក់ ដែលអញកាច់បំបាក់ហើយផង អញផឹកទឹកទាំងឡាយដ៏ ល្អក់ផង កាលបើអញដើរចុះឡើងកំពង់ទឹក ពួកមេជំរីដើរត្រដុសកាយផង អញនៅច្រឡូកច្រឡំជាទុក្ខ មិនសប្បាយ បើដូច្នោះ គួរអញគេចចេញពី ហ្វូងនៅម្នាក់ឯងវិញចុះ ។ លំដាប់នោះ ជំរីដ៏ប្រសើរនោះ ដើរគេចចេញពី ហ្វូង ហើយចូលទៅរកព្រះមានព្រះភាគ ដែលទ្រង់គង់នៅក្រោមម្លប់ភទ្ទ-សាលព្រឹក្ស ក្នុងដងព្រៃឈ្មោះរក្ខិត: ជិតបាលិលេយ្យកប្រទេស លុះចូល ទៅដល់ហើយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រទេសណា បានញ្ញថា ជំរីដ៏ប្រសើរនោះ ក៏ធ្វើប្រទេសនោះ មិនឲ្យមានស្មៅស្រស់ ទាំងតម្ពល់ទឹក ធាន់ ទឹកប្រើ ថ្វាយព្រះមានព្រះភាគ ដោយប្រមោយ ។

[៩៩] គ្រានោះ ព្រះមានព្រះភាគ ទ្រង់យាងទៅសម្ងំ ក្នុងទីស្ងាត់ ទ្រង់មានព្រះហឬទ័យបរិវិតក្តកើតឡើងយ៉ាងនេះថា កាលមុន តថាគតបាន

នៅច្រឡូកច្រឡំដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ស្តេច អមាត្យធំ របស់ស្តេច តិរ្ថិយ និងពួកសាវ័ករបស់តិរ្ថិយ តថាគតនៅច្រឡូកច្រឡំជាទុក្ខ មិនសប្បាយឡើយ ។ ឥឡូវនេះ តថាគត មិនបាននៅច្រឡូកច្រឡំ ដោយពួក ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ស្តេច អមាត្យធំរបស់ស្តេច តិរ្ថិយ និងពួក សាវ័ករបស់តិរ្ថិយឡើយ តថាគតមិនបាននៅច្រឡូកច្រឡំ ក៏បានសេចក្តីសុខ សប្បាយ ។ ជីវជីវប្រសើរនោះ មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា កាលមុន អញបាននៅច្រឡូកច្រឡំដោយពួកជីវឈ្មោល ជីវញ្ជើ ជីវស្ងួត និងកូនជីវ តូចៗ ហើយអញបានស៊ីស្មៅទាំងឡាយ ដែលពួកជីវទាំងនោះ ច្រឹបចុង ហើយផង ពួកជីវទាំងនោះ ស៊ីមែកឈើបាក់ ដែលអញកាច់បំបាក់ហើយផង អញបានផឹកទឹកទាំងឡាយដ៏ល្អក់ផង កាលបើអញ ដើរចុះឡើងកំពង់ទឹក ពួក មេជីវដើរត្រជុសកាយផង អញនៅច្រឡូកច្រឡំជាទុក្ខ មិនសប្បាយឡើយ ។ ឥឡូវនេះ អញមិននៅច្រឡូកច្រឡំដោយពួកជីវឈ្មោល ជីវញ្ជើ ជីវស្ងួត និង កូនជីវ ហើយស៊ីស្មៅទាំងឡាយ ដែលពួកជីវទាំងនោះ មិនបានច្រឹបចុង ហើយផង ពួកជីវទាំងនោះ ក៏មិនស៊ីមែកឈើបាក់ ដែលអញកាច់បំបាក់ផង អញផឹកទឹកទាំងឡាយមិនល្អក់ផង កាលបើអញដើរចុះឡើងកំពង់ទឹក ពួក មេជីវក៏មិនដើរត្រជុសកាយផង អញមិននៅច្រឡូកច្រឡំ ក៏បានសេចក្តីសុខ សប្បាយ ។ លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់សេចក្តីស្ងប់ស្ងាត់ របស់ព្រះអង្គ និងបានជ្រាបច្បាស់បវិតក្ក ក្នុងចិត្តរបស់ជីវជីវប្រសើរនោះ ដោយព្រះហឫទ័យនៃព្រះអង្គហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ចិត្តរបស់ហត្ថិនាគ មានភ្ជុកផទន្ទាំន៉ុះ ស្មើនឹងចិត្តរបស់ពុទ្ធនាគដែរ ព្រោះហត្ថិនាគតែម្នាក់ឯង ត្រេកអរក្នុងព្រៃដែរ ។ សូត្រទី ៥ ។

អដ្ឋកថា

ឆាគសូត្រ

នាគសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ

[៩៧] *បទថា* **កោសម្ពិយំ** *សេចក្តីថា ជិតនគរដែលមានឈ្មោះយ៉ាងនេះថា* **កោសម្ពី** *ព្រោះសាងក្នុងទីដែលកុសមឥសីរស់នៅ ។ បទថា* **ឃោសិតារាមេ** *បានដល់ ក្នុងអារាមដែលឃោសិតសេដ្ឋីសាង ។ បទថា* **ភគវា អាកិណ្ណោ វិហរតិ** *បានដល់ ព្រះមានព្រះភាគ ទ្រង់បានទទួលការចង្អៀតចង្អល់ប្រថាប់នៅ ។ សួរថា ព្រះមានព្រះភាគ មានការចង្អៀតចង្អល់ ឬមានការច្រឡូកច្រឡំឬ ។ ឆ្លើយថា មិនមាន ព្រោះបុគ្គលណាម្នាក់មិនអាចចូលគាល់ព្រះមានព្រះភាគដោយមិនប្រាថ្នា ។ ពិតហើយ ព្រះសម្ពុទ្ធទាំងឡាយ គេចូលគាល់បានដោយបានលំបាក ព្រោះទ្រង់មិនជាប់ជំពាក់ក្នុងទីទាំងពួង ។ ព្រះមានព្រះភាគ ទ្រង់អាស្រ័យសេចក្តីអនុគ្រោះពួកសត្ត ដោយទ្រង់ស្វែងរកប្រយោជន៍ ដើម្បីនឹងស្រង់ពួកសត្ត្ចចេញអំពីឧយ: ៤ ដោយ*

សមគួរដល់ប្តេជ្ញាថា តថាគតរួចផុតហើយ និងឲ្យពួកសត្វរួចផុតផង ទើបទ្រង់ទទួលឲ្យបរិស័ទទាំង ៨ ចូលកាន់សម្នាក់របស់ព្រះអង្គ សព្វកាល ។ ព្រះអង្គ កាលព្រះមហាករុណាជាស់តឿន ជាកាលញ្ជូ យាងទៅក្នុងបរិស័ទនោះ ។ សេចក្តីនេះ ព្រះពុទ្ធគ្រប់ព្រះអង្គធ្លាប់ប្រព្រឹត្តមក ។ នេះលោកបំណងថា ការនៅប្រទ្បូកប្រទ្បាំក្នុងទីនេះ ។

តែក្នុងទីនេះ កាលភិក្ខុអ្នកក្រុងកោសម្ពី ឈ្លោះទាស់ទែងគ្នា ព្រះសាស្តាទ្រង់នាំរឿងរបស់ព្រះបាទកោសលព្រះនាមថា ទីឃីតិមកប្រទានជាឱវាទដោយនយជាដើមថា ពៀរក្នុងកាលណាម្នាក់ ក្នុងលោកនេះ រមែងមិនស្ងប់ដោយពៀរ ថ្ងៃនោះ កាលភិក្ខុទាំងនោះធ្វើនូវជម្លោះនោះឯង មួយយប់ទល់ភ្លឺ ។ ក្នុងថ្ងៃទី ២ ព្រះមានព្រះភាគត្រាស់រឿងនោះដដែលទៀត ។ សូម្បីក្នុងថ្ងៃនោះ ភិក្ខុទាំងនោះក៏ឈ្លោះគ្នានោះឯង រហូតទល់ភ្លឺ ។ ក្នុងថ្ងៃទី ៣ ព្រះមានព្រះភាគទ្រង់សម្តែងរឿងនោះដូចគ្នា ។ លំដាប់នោះ ភិក្ខុមួយរូប ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទ្រលំទ្វាយតិចចុះ សូមប្រកបដោយការនៅជាសុខក្នុងបច្ចុប្បន្នចុះ ពួកខ្ញុំព្រះអង្គនឹងប្រាកដដោយជម្លោះទាស់តែង ការប្រកួតប្រកាន់ និងដោយវិវាទនេះ ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា មោឃបុរសទាំងនេះ មានចិត្ត ត្រូវជម្លោះជាដើមគ្របសង្កត់ហើយ ឥឡូវនេះ តថាគតមិនអាចឲ្យភិក្ខុទាំងនេះចុះសម្រុងគ្នាបាន ក្នុងទីនេះ មិនមានបុគ្គលណាចុះចាញ់នរណា បើដូច្នោះ គប្បីគ្រាច់ទៅតែឯង កាលបើដូច្នោះ ភិក្ខុទាំងនេះ នឹងឈប់ទាស់ទែងគ្នា ព្រោះធ្វើការនៅក្នុងវិហារកន្លែងជាមួយភិក្ខុ

ដែលទាស់ទែងគ្នាទាំងនេះ និងការដែលពួកឧបាសកជាដើមចូលទៅគាល់ ដោយមិនមានអ្នកទូន្មានឲ្យរស់នៅច្រឡូកច្រឡំ ដោយប្រការដូច្នេះ ទើបលោកពោលថា **តេន ខោ បន សមយេន ភគវា អាកិណ្ណោ វិហរតិ** *ប្រែថា សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅច្រឡូកច្រឡំ ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **ទុក្ខំ** *បានដល់ មិនមែនសុខ អធិប្បាយថា មិនគួរប្រុងថ្នា ព្រោះមានចិត្តមិនគួរត្រេកអរ ។ ដោយហេតុនោះឯង ទើបលោកពោលថា* **ន ផាសុ វិហរាមិ** *។ បទថា* **វូបកដ្ឋោ** *ប្រែថា ចៀសចេញ គឺនៅក្នុងទីឆ្ងាយ ។*

ព្រះមានព្រះភាគ កាលទ្រង់ព្រះតម្រិះយ៉ាងនេះហើយ ទើបទ្រង់ជម្រះព្រះវរកាយអំពីព្រលឹម ទ្រង់ត្រាច់បិណ្ឌបាតក្នុងក្រុងកោសម្ពី មិនលាបុគ្គលណាម្នាក់ យាងទៅតែមួយអង្គឯង មិនមានសម្ងាញ់ ប្រថាប់គង់នៅត្រង់គល់ កទូសាល នាព្រៃបាលិលេយ្យកៈ ក្នុងកោសលរដ្ឋ ។ ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ ភគវា បុព្ពណ្ហសមយំ ។បេ។ កទ្ទុសាលម្ហូលេ** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **សាមំ** *ប្រែថា ដោយព្រះអង្គឯង ។ បទថា* **សំសាមេត្វា** *ប្រែថា គ្រប សង្កត់ ។ គប្បីនាំបទថា* **សាមំ** *មកប្រកបចូលក្នុងបទថា* **បត្តចីវរមាទាយ** *នេះ ។ បទថា* **ឧបដ្ឋាកេ** *បានដល់ មិនបានលាពួកឧបដ្ឋាក មានយោសិតសេដ្ឋី អ្នកក្រុងកោសម្ពី និងព្រះអានន្ទដែលជាឧបដ្ឋាកក្នុងវិហារជាដើម ។*

កាលព្រះសាស្តាយាងទៅហើយយ៉ាងនេះ ភិក្ខុ ៥០០ រូប ពោលនឹងព្រះអានន្ទថា អាវុសោ អានន្ទ ព្រះសាស្តាយាងទៅតែមួយព្រះអង្គឯង ពួកយើងនឹងជាប់តាម ។ ព្រះអានន្ទឃាត់ថា អាវុសោ ក្នុងពេលដែលព្រះមានព្រះភាគទ្រង់ជាក់សេនាសនៈដោយព្រះអង្គឯង ហើយទ្រង់កាន់បាត្រ និងចីវរ មិនលាឧបដ្ឋាក មិនប្រាប់ភិក្ខុសង្ឃ យាងទៅមិនមានសម្ងាញ់ យាងទៅដោយមួយព្រះអង្គឯង ជាអធ្យាស្រ័យរបស់ព្រះមានព្រះភាគ ធម្មតាសាវក គួរបដិបត្តិឲ្យសមគួរដល់ព្រះអធ្យាស្រ័យរបស់ព្រះសាស្តា ព្រោះដូច្នោះ មិនគួរតាមព្រះមានព្រះភាគទៅក្នុងថ្ងៃនេះ ដូច្នេះ សូម្បីខ្លួនឯងក៏មិនទៅតាម ។ បទថា **អនុបុព្ពេន** *ប្រែថា ដោយលំដាប់ ។*

ព្រះសាស្តាយាងចារិកទៅតាមលំដាប់គាម និងនិគម ទ្រង់ព្រះតម្រិះថា តថាគតនឹងសួរសុខទុក្ខភិក្ខុដែលនៅម្នាក់ឯងមុន ដូច្នេះហើយ ទើបយាងទៅកាន់ពាលកលោណកាគាម ហើយទ្រង់សម្តែងអានិសង្ស ក្នុងការគ្រាច់ទៅម្នាក់ឯង ដល់ព្រះភគ្គត្តេរ ក្នុងទីនោះ រហូតបច្ឆាភត្ត និងអស់រាត្រី ៣ យាម ស្អែកឡើង ទ្រង់មានព្រះភគ្គត្តេរជាបច្ឆាសមណៈ យាងទៅបិណ្ឌបាត ឲ្យព្រះភគ្គត្តេរត្រឡប់ក្នុងទីត្រង់នោះឯង ហើយទ្រង់ព្រះតម្រិះថា នឹងសួរសុខទុក្ខកុលបុត្រទាំង ៣ ដែលនៅព្រមព្រៀងគ្នា ទើបយាងទៅកាន់បាចីនវង្សមិគទាយវន ហើយទ្រង់សម្តែងអានិសង្ស ដែលកុលបុត្រទាំងនោះនៅដោយព្រមព្រៀងគ្នាមួយយប់ទល់ភ្លឺ ទ្រង់ឲ្យកុលបុត្រទាំងនោះត្រឡប់ក្នុងទីត្រង់នោះឯង យាងដល់បាលិលេយ្យគាមតែមួយព្រះអង្គឯង ។ អ្នកបាលិលេយ្យគាមនាំគ្នា

ទទួល ថ្វាយទានដល់ព្រះមានព្រះភាគ ហើយសាងបណ្ណសាលា ថ្វាយដល់ព្រះមានព្រះភាគ ក្នុងដងព្រៃរក្ខិតវន ដែលនៅមិនឆ្ងាយអំពីបាលិលេយ្យគាម ហើយទូលអារាធនា ឲ្យទ្រង់គង់ប្រថាប់ ដោយពាក្យថា សូមព្រះមានព្រះភាគ ប្រថាប់គង់ទីនេះចុះ ។ ក្នុងរក្ខិតវននោះ មានដើមសាលព្រឹក្សមួយ គួរជាទីត្រេកអរ មានឈ្មោះថា ភទ្ទសាល ។ ព្រះមានព្រះភាគ ទ្រង់អាស្រ័យស្រុកនោះ គង់ប្រថាប់នាគល់ឈើនោះ ជិតបណ្ណសាលា ក្នុងដងព្រៃ ។ ដោយហេតុនោះ ទើបលោកពោលថា **ចាលិលេយ្យកេ វិហរតិ រក្ខិតវនសណ្ឌេ ភទ្ទសាលមូលេ** ដូច្នេះជាដើម ។

[៩៨] បទថា **ហត្ថិនាគោ** បានដល់ ស្តេចដំរី គឺមេហ្ទូង ។ បទថា **ហត្ថិកលភេហិ** ប្រែថា កូនដំរី ។ បទថា **ហត្ថិច្ឆាបេហិ** បានដល់ កូនដំរីជំទង់ ដែលនៅបៅដោះមេនៅឡើយ គេហៅថា **ភិឌ្ឌា** ដូច្នេះក៏មាន ។ បទថា **ធិន្នគ្គានិ** សេចក្តីថា ទំពាស៊ីស្មៅដែលមិនមានចុង គឺដង្គត់ស្មៅដែលសល់អំពីដំរីទាំងនោះជាដើម ដែលស៊ីមុនហើយ ។ បទថា **ឱភគ្គោភគ្គំ** បានដល់ រុក្ខាវយវ: គឺមែកឈើដែលស្តេចដំរីនោះកាច់បំបាក់អំពីទីខ្ពស់ ។ បទថា **អស្ស សាខាភង្គំ** សេចក្តីថា ដំរីនោះទំពាស៊ីរុក្ខាវយវ: គឺមែកឈើដែលជារបស់ស្តេចដំរីនោះ ។

បទថា **អាវិលានិ** សេចក្តីថា រមែងផឹកទឹកដែលល្អក់ គឺដែលលាយដោយភក់ ព្រោះត្រូវដំរីនោះចុះទៅផឹកមុន ទើបធ្វើឲ្យល្អក់ ។ បទថា **ឱគាហា** ប្រែថា អំពីកំពង់ ។ បាលីថា **ឱគាហំ** ដូច្នេះក៏មាន ។ បទថា **អស្ស** ប្រកប

ជាមួយ **ហត្ថិនាគស្ស ។** *បទថា* **ឧបនិយ្យំសន្តិយោ** *ប្រែថា ជ្រៀតបៀត ។ ស្តេចដំរីនោះ សូម្បីត្រូវពួកដំរីជ្រៀតបៀត ក៏មិនក្រោធ ព្រោះខ្លួនមានចិត្តទូលាយ ដោយហេតុនោះ ទើបដំរីញីទាំងនោះ នាំគ្នាជ្រៀតបៀតស្តេចដំរីនោះឯង ។ បទថា* **យូថា** *ប្រែថា ចាកហ្វូងដំរី ។*

បទថា **យេន ភគវា តេនុបសង្កមិ** *សេចក្តីថា បានឮថា ស្តេចដំរីនោះ នឿយណាយក្នុងហ្វូង ទើបចូលទៅកាន់ដងព្រៃនោះ ឃើញព្រះមានព្រះភាគក្នុងទីនោះ ជាសត្វមានចិត្តត្រជាក់ ដូចយកទឹក ១០០០ ក្អម មកលត់សេចក្តីក្រវល់ក្រវាយ កាលមានចិត្តជ្រះថ្លា បាននៅក្នុងសម្នាក់របស់ព្រះមានព្រះភាគ ។ តាំងអំពីនោះមក ស្តេចដំរីនោះក៏តាំងនៅក្នុងកិច្ចបដិបត្តិ យកមែកឈើបោសជុំវិញដើមកទូសាល និងបណ្ណសាលា ឲ្យប្រាសចាករបស់ពណ៌ខៀវ ថ្វាយទឹកក្តុរព្រះឱស្ឋ នាំទឹកសម្រាប់ស្រង់មកថ្វាយ ថ្វាយឈើជម្រះព្រះទន្តដល់ព្រះមានព្រះភាគ នាំផ្លែឈើមានរសឆ្ងាញ់មកអំពីព្រៃហើយ ថ្វាយដល់ព្រះសាស្តា ។ ព្រះសាស្តា ទ្រង់សោយផ្លែឈើទាំងនោះ ដោយហេតុនោះ ទើបលោកពោលថា បានឮថា ដំរីដ៏ប្រសើរនោះ ក៏ធ្វើប្រទេសនោះ មិនឲ្យមានស្មៅស្រស់ ទាំងតម្កល់ទឹកឆាន់ ទឹកប្រើ ថ្វាយព្រះមានព្រះភាគដោយប្រមោយ ដូច្នេះជាដើម ។ ស្តេចដំរីនោះ យកប្រមោយជញ្ជួនខ្សមកកួតគ្នា និងគ្នាឲ្យកើតជាភ្លើង ធ្វើឲ្យឆេះ ធ្វើជុំថ្មក្នុងទីនោះឲ្យក្តៅ យកឈើឆ្កឹះជុំថ្មនោះមកទម្លាក់ក្នុងទឹក ដឹងថា ទឹកក្តៅហើយ ទើបចូលទៅក្នុងសម្នាក់របស់ព្រះមានព្រះភាគ ហើយឈរ ព្រះសាស្តាទ្រង់ជ្រាបថា ស្តេចដំរីប្រាថ្នា ទើបសម*

នឹងចិត្តដ៏ប្រសើរ គឺសមនឹងចិត្តរបស់ទ្រង់ ព្រោះពាក្យអធិប្បាយនឹងឲ្យ តថាគតស្រង់ទឹក ទើបយាងទៅក្នុងទីនោះ ហើយធ្វើការស្រង់ទឹក សូម្បីក្នុងទឹកធាន់ក៏នយនេះដូចគ្នា ឯទឹកធាន់នោះ កើតនូវការត្រជាក់ឡើងហើយ ក៏ចូលទៅគាល់ដែលលោកសំដៅ ពោលថា ស្តេចដ៏រៀបចំតម្កល់ទឹកធាន់ ទឹកប្រើប្រាស់ថ្វាយព្រះមានព្រះភាគ ដោយប្រមោយ ។

[៩៩] *បទជាដើមថា* **អថ ខោ ភគវតោ រហោគតស្ស** *ជាបទសម្តែងការដែលមហានាគទាំង ២ ពិចារណាដល់សេចក្តីសុខ ដែលកើតអំពីវិវេក ។ ពាក្យនោះ មានអត្ថដូចពោលហើយនោះឯង ។*

បទថា **អត្តនោ ច បវិវេកំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបកាយវិវេកដែលបានដោយការមិនច្រឡូកច្រឡំ ដោយចំណែកណាមួយ ។ ឯចិត្តវិវេក និងឧបធិវិវេក រមែងមានដល់ព្រះមានព្រះភាគគ្រប់កាលនោះឯង ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ដែលសម្តែងដល់ភាពដែលទ្រង់ និងស្តេចដ៏រីមានអធ្យាស្រ័យស្មើគ្នា ក្នុងការត្រេកអរក្រៃលែងក្នុងការស្ងាត់ ។*

ក្នុងសេចក្តីនោះ មានសេចក្តីសង្ខេបដូចតទៅនេះថា ចិត្តរបស់ស្តេចដ៏រីដែលមានភ្នក់ងទន្ទាំនេះ គឺមានភ្នក់ងដូចចន្ទោលរថ សមគ្នា គឺប្រៀបធៀបគ្នាបានជាមួយចិត្តដ៏ប្រសើររបស់ព្រះពុទ្ធដ៏ប្រសើរ ។ បើមានពាក្យសួរជ្រៀតចូលមកថា សមគ្នាបានដូចម្តេច ។ ឆ្លើយថា ព្រោះជាបុគ្គលតែឯង ត្រេកអរនៅក្នុងព្រៃ អធិប្បាយថា ព្រោះព្រះពុទ្ធដ៏ប្រសើរទ្រង់ត្រិះរិះថា កាលមុនតថាគតច្រឡូកច្រឡំ ដូច្នេះ ទើបទ្រង់រង្គៀសការនៅច្រឡូកច្រឡំក្នុងកាលមុន

កាល ទ្រង់ចម្រើនវិវេក ឥឡូវនេះ ទើបជាបុគ្គលម្នាក់ឯង គឺមិនមានសម្ងាញ់ ត្រេកអរ គឺអភិរមក្នុងព្រៃ គឺក្នុងជង្ឃព្រៃ យ៉ាងណា សូម្បីស្តេចដំរីនេះ ក៏ដូច្នោះ កាលមុន រង្គៀសក្នុងការនៅច្រឡូកច្រឡំជាមួយពួកដំរីជាដើម កាលចម្រើនវិវេក ឥឡូវនេះ ទើបជាដំរីឯក គឺមិនមានសម្ងាញ់ជាទីត្រេកអរ រីករាយម្នាក់ឯងក្នុងព្រៃ ដូច្នោះ ចិត្តនៃស្តេចដំរីដូចពោលមកនេះ ទើបដូចគ្នានឹងការត្រេកអរក្នុងឯកីភាព ។

អដ្ឋកថា នាគសូត្រទី ៥ ចប់

សុត្តន្តបិដក

បិណ្ឌោលភារទ្វាជសូត្រ

[១០០] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះបិណ្ឌោលភារទ្វាជៈដ៏មានអាយុ ជាអ្នកប្រព្រឹត្តអារញ្ញក-ធុតង្គ បិណ្ឌបាតិកធុតង្គ បង្សុកូលិកធុតង្គ និងតេចីវរិកធុតង្គ ជាអ្នកប្រាថ្នាតិច មានសេចក្តីសន្តោស មានសេចក្តីស្ងប់ស្ងាត់ មិននៅលាយឡំដោយពួក ប្រារព្ធព្យាយាម ជាអ្នកពោលពាក្យជាគ្រឿងកម្ចាត់បង់កិលេស ប្រកបរឿយៗ នូវអធិចិត្ត អង្គុយផ្គត់ភ្នែន តម្រង់កាយត្រង់ ក្នុងទីជិតព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ទតឃើញបិណ្ឌោលភារទ្វាជៈដ៏មានអាយុ ជាអ្នកប្រព្រឹត្ត*

អារញ្ញកធុតង្គ បិណ្ឌបាតិកធុតង្គ បង្សុកូលិកធុតង្គ និងតេចីវរិកធុតង្គ ជាអ្នក ប្រាថ្នាតិច មានសេចក្តីសន្តោស មានសេចក្តីស្ងប់ស្ងាត់ មិននៅលាយឡំ ដោយពួក ប្រារព្ធព្យាយាម ជាអ្នកពោលពាក្យជាគ្រឿងកម្ចាត់បង់កិលេស ប្រកបរឿយៗ នូវអធិចិត្ត អង្គុយផ្គត់ភ្នែន តម្រង់កាយត្រង់ ក្នុងទីជិតព្រះ អង្គ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់ បន្ទឺឧទាននេះ ក្នុងវេលានោះថា

កិរិយាមិនតិះដៀល ១ កិរិយាមិនបៀតបៀនគេ ១ កិរិយា សង្រួមក្នុងបាតិមោក្ខ ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ ១ ទីដេកទីអង្គុយដ៏ស្ងាត់ ១ កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត ១ នុ៎ះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។ សូត្រទី ៦ ។

អដ្ឋកថា

បិណ្ឌោលភារទ្វាជសូត្រ

បិណ្ឌោលភារទ្វាជសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះថា

[១០០] បទថា **បិណ្ឌោលភារទ្វាជោ** សេចក្តីថា ឈ្មោះថា បិណ្ឌោល ព្រោះ បួសស្វែងរកដុំបាយ ។

បានឮថា លោកជាព្រាហ្មណ៍វិនាសនូវភោគៈ ឃើញលាភសក្ការៈជាច្រើនរបស់ភិក្ខុសង្ឃ ទើបចង់បួសដើម្បីដុំបាយ ។ លោកកាន់អំបែងធំសម្គាល់ ថាជាបាត្រ ហុតបបរពេញអំបែង បរិភោគកត្តុ បរិភោគនំ និងរបស់ទំពា ។ លំដាប់នោះ ពួកភិក្ខុក្រាបទូលភាពដែលលោកជាអ្នកបរិភោគច្រើនដល់ព្រះសាស្តា ។ ទើបព្រះសាស្តាទ្រង់មិនអនុញ្ញាតឲ្យលោកប្រើស្មៅកបាត្រ ។ ទើបលោកផ្តាប់បាត្រលើត្រែគ កាលលោកញាត់បាត្រ និងកាលទាញចេញមក កន្ទុងយូរទៅ អំបែងនោះក៏សឹក ព្រោះការប្រជ្រៀតនៅសល់ត្រឹមតែបាយមួយនាឡិប៉ុណ្ណោះ លំដាប់នោះ ទើបពួកភិក្ខុក្រាបទូលដល់ព្រះសាស្តា ។ ចំណែកតមក ទើបព្រះសាស្តាឲ្យលោកមានស្មៅកបាត្រ ។ សម័យក្រោយមក ព្រះថេរៈចម្រើនឥន្ទ្រិយ តាំងនៅក្នុងអរហត្តផល ។ ដូច្នោះ ទើបគេហៅលោកថា បិណ្ឌោល ព្រោះកាលមុនលោកស្វែងរកដុំបាយដោយគោត្រ ហៅថា ភារទ្វាជៈ ព្រោះរួមសពួទាំង ២ ចូលគ្នា ទើបហៅថា បិណ្ឌោល-ភារទ្វាជៈ ។

បទថា **អរញ្ញកោ** សេចក្តីថា ឈ្មោះថា **អរញ្ញក** ព្រោះលោកនៅក្នុង

ព្រៃ ដោយហាមសេនាសនៈស្រុកចេញ ។ បទថា **អរញ្ញកោ** *នេះ ជាឈ្មោះរបស់ភិក្ខុដែលសមាទានអរញ្ញិកធុតង្គ ។ ម្យ៉ាងទៀត ការធ្លាក់ចុះនៃដុំអាមិសគឺកិក្ខាហារ ឈ្មោះថា បិណ្ឌបាត ។ អធិប្បាយថា ដុំបាយដែលអ្នកដទៃឲ្យធ្លាក់ចុះក្នុងបាត្រ ។ ភិក្ខុឈ្មោះថា បិណ្ឌបាតិក ព្រោះស្វែងរកបិណ្ឌបាត គឺចូលទៅស្វែងរកក្នុងត្រកូលនោះៗ ។ ម្យ៉ាងទៀត ឈ្មោះថា* **បិណ្ឌចារី** *ព្រោះមានការធ្លាក់ទៅ គឺត្រាច់ទៅដើម្បីបិណ្ឌជាវត្ត ។* **បិណ្ឌចារី** *នោះឯង ជា* **បិណ្ឌចារិកៈ** *។ សំពត់ ឈ្មោះថា* **បំសុកូល** *ព្រោះដូចជាប្រឡាក់ប្រឡូសដោយធូលី ព្រោះអត្ថថា ហុយឡើង ព្រោះតាំងនៅលើធូលី ។ ក្នុងទីមានគំនរសំរាមជាដើម ។ ម្យ៉ាងទៀត សំពត់ ឈ្មោះថា* **បំសុកូល** *ព្រោះទៅ គឺដល់នូវភាពជារបស់គួរខ្ពើម ដូចធូលី ការទ្រទ្រង់សំពត់បង្សុកូល ឈ្មោះថា* **បំសុកូល** *។ ការទ្រទ្រង់សំពត់បង្សុកូលនោះ ជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ ភិក្ខុនោះ ឈ្មោះថា* **បំសុកូលិកៈ** *។ ចីវរ ៣ គឺសង្ឃាដី ឧត្តរាសង្គ និងអន្តរវាសក ឈ្មោះថា ចីវរ ៣ ។ ការទ្រទ្រង់ចីវរ ៣ ឈ្មោះថា* **តិចីវរៈ** *។ ការទ្រទ្រង់ត្រៃចីវរនោះ ជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ ទើបភិក្ខុនោះ ឈ្មោះថា* **តេចីវរិកៈ** *។ អត្ថនៃបទថា* **អប្បិច្ឆោ** *ជាដើម ខ្ញុំបានពោលហើយ (ក្នុងកាថាវត្ថុ ១០) ខាងដើមនោះឯង ។*

បុគ្គលកម្ចាត់កិលេស លោកហៅថា **ធុត** *ក្នុងបទថា* **ធុតវាទោ** *។ ម្យ៉ាងទៀត ធម៌ជាគ្រឿងកម្ចាត់កិលេស លោកហៅថា* **ធុត** *។ ក្នុង ២ យ៉ាងនោះ ភិក្ខុឈ្មោះថា មានធុតៈ តែមិនមានធុតវាទក៏មាន មិនមានធុតៈ តែមាន*

ធុតវាទក៏មាន មិនមានធុតៈផង មិនមានទាំងធុតវាទផងក៏មាន មានធុតៈផង មានធុតវាទផងក៏មាន គប្បីជ្រាបធុតៈដូចពោលមកនេះ ។ ក្នុង ៤ យ៉ាងនោះ ភិក្ខុណា សមាទាន ប្រព្រឹត្តធម៌ដោយខ្លួនឯង មិនដឹកនាំអ្នកដទៃ ព្រោះការប្រព្រឹត្តសមាទានធុតធម៌នោះ នេះជាធុតៈពួកទី ១ ។ ឯភិក្ខុណា មិនប្រព្រឹត្តសមាទានធុតធម៌ដោយខ្លួនឯង តែដឹកនាំអ្នកដទៃ នេះឈ្មោះថា ជាធុតធម៌ទី ២ ។ ភិក្ខុណា វៀរទាំង ២ នេះចេញ ជាធុតៈទី ៣ ។ ឯភិក្ខុណា សម្បូរដោយធុតៈទាំង ២ នេះ ឈ្មោះថា ជាធុតៈទី ៤ ព្រះបិណ្ឌាលការទ្វាជៈក៏ដូច្នោះ ។ ដោយហេតុនោះ ទើបលោកពោលថា **ធុតវាទ** ។ នេះជានិទ្ទេស ពោលដោយសមាស ដែលលោកបង្រួញសព្ទមួយ បន្សល់ទុកនូវសព្ទមួយ ដូចពាក្យថា **នាមញ្ច រូបញ្ច នាមរូបញ្ច នាមរូបំ** ប្រែថា នាម ១ រូប ១ នាមរូប ១ ជានាមរូប ។

ក្នុងបទថា **អធិចិត្តមនុយុត្តោ** នេះ មានវិនិច្ឆ័យដូចតទៅនេះ គប្បីជ្រាបភាពដែលចិត្តជាអធិចិត្ត ព្រោះប្រកបដោយសមាបត្តិ ៨ ឬប្រកបដោយអរហត្តផលសមាបត្តិ ។ តែក្នុងទីនោះ គប្បីជ្រាបថា អរហត្តផលចិត្ត ។ សមាធិក្នុងសមាបត្តិនោះឯង ឈ្មោះថា **អធិចិត្ត** ។ តែក្នុងទីនេះ គប្បីជ្រាបថាជាអរហត្តផលសមាធិ ។ តែអាចារ្យពួកខ្លះលើកពុទ្ធដីកាឡើងពោលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលព្យាយាមប្រកបអធិចិត្ត គប្បីមនសិការដល់និមិត្ត ៣ តាមកាល ព្រោះដូច្នោះ ចិត្តដែលប្រកបដោយសមថៈ និងវិបស្សនា លោកបំណងក្នុងទីនេះថាជាអធិចិត្ត ដូចក្នុងអធិចិត្តសូត្រនេះ ។ ពាក្យដែលលើក

មកអាងនោះ មិនប្រពៃ ។ គប្បីកាន់យកក្នុងពាក្យមុននោះឯង ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងនូវអត្ថនេះ ពោល គឺការប្រកបអធិចិត្តដែលសម្បូរដោយការអធិដ្ឋានបរិក្ខារ និងការមិនខ្វះខាតរបស់ព្រះបិណ្ឌាលការទ្វាជៈ ។ កាលទ្រង់សម្តែងថា ការប្រកបអធិចិត្ត គឺការតាំងមាំនៃសាសនារបស់តថាគត ទើបទ្រង់បន្ទឺឧទាននេះ ដោយប្រការដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **អន្ធបរាធោ** *បានដល់ មិនចូលទៅប្រទូស្តចំពោះបុគ្គលណាម្នាក់ដោយវាចា ។ បទថា* **អន្ធបឃាតោ** *បានដល់ មិនធ្វើការទ្រគោះបោះបោកចំពោះបុគ្គលណាម្នាក់ ។ អត្ថនៃបទថា* **ចាតិមោក្ខេ** *ក្នុងបទថា* **ចាតិមោក្ខេ** *នេះ លោកពោលដោយប្រការផ្សេងៗ ខាងដើម ។ ធម៌ដែលមានការមិនកន្ទងល្មើសអាបត្តិ ៧ កង ក្នុងបាតិមោក្ខនោះជាលក្ខណៈ ឈ្មោះថា* **សំវរ** *គឺការស្គាល់ប្រមាណ ដោយអំណាចការទទួល និងការបរិភោគ ឈ្មោះថា* **មត្តញ្ញុតា ។** *បទថា* **បត្តញ្ច សយនាសនំ** *បានដល់ទីដេក និងទីអង្គុយដ៏ស្ងាត់ គឺវៀរការជាប់តគ្នា ។ បទថា* **អធិចិត្តេ ច អាយោគោ** *បានដល់ ប្រកបការនាដើម្បីសម្រេចសមាបត្តិ ៨ ។ ម្យ៉ាងទៀត បទថា* **អន្ធបរាធោ** *បានដល់ មិនពោលពាក្យអាក្រក់ចំពោះបុគ្គលណាម្នាក់ឡើយ ។ ដោយហេតុនោះ ទើបលោកសង្គ្រោះសីលដែលប្រព្រឹត្តទៅតាមផ្លូវវាចាទាំងអស់ ។ បទថា* **អន្ធបឃាតោ** *បានដល់ មិនធ្វើការទ្រគោះបោះបោកចំពោះបុគ្គលណា គឺមិនបៀតបៀនអ្នកដទៃដោយកាយ ។ ដោយហេតុនោះ*

ទើបលោកសង្គ្រោះសីល ដែលប្រព្រឹត្តទៅតាមផ្លូវកាយទាំងអស់ ដើម្បីទ្រទ្រង់សម្តែងសីលទាំង ២ ដែលឈមចុះខាងក្នុងសាសនារបស់ព្រះពុទ្ធទាំងអស់ ទើបត្រាស់ថា **ចាតិមោក្ខេ ច សំវរោ** *ជួបច្នេះ ច សព្ទ ត្រឹមតែជានិបាត ។ បទថា* **ចាតិមោក្ខេ ច សំវរោ** *សេចក្តីថា ការមិនប្រទូស្ត ព្រោះការមិនចូលទៅប្រទូស្ត ដែលជាហេតុសង្រួមក្នុងបាតិមោក្ខ ។ ម្យ៉ាងទៀត បទថា* **ចាតិមោក្ខេ** *ជាសត្តមីវិភត្តិ ប្រើក្នុងអត្តអធិករណៈ ។ សំវរៈជាទីអាស្រ័យក្នុងបាតិមោក្ខ ។ សួរថា សំវរៈនោះ គឺអ្វី ។ ឆ្លើយថា គឺការមិនចូលទៅប្រទូស្ត ការមិនប្រទូស្ត ។ ពិតហើយ ក្នុងពេលឧបសម្បទា កាលពោលដោយមិនប្លែកគ្នា បាតិមោក្ខសីល ឈ្មោះថា ភិក្ខុសមាទានហើយ កាលភិក្ខុតាំងនៅក្នុងបាតិមោក្ខនោះ បន្ទាប់ពីនោះ សំវរៈ រមែងមានដោយអំណាចការមិនប្រទូស្តដោយវាចា និងការមិនប្រទូស្តដោយកាយសំវរៈនោះ លោកហៅថា ការមិនប្រទូស្តដោយវាចា និងការមិនប្រទូស្តដោយកាយ ។ ម្យ៉ាងទៀត បទថា* **ចាតិមោក្ខេ** *ជាសត្តមីវិភត្តិ ប្រើក្នុងអត្តថា គប្បីឲ្យសម្រេច ដូចពាក្យថា ការមិនស្ងប់នៃចិត្ត មានអយោនិសោមនសិការជាហេតុជិត ។ អធិប្បាយថា ការមិនប្រទូស្តដោយវាចា ការមិនប្រទូស្តដោយកាយ ដែលបាតិមោក្ខគប្បីឲ្យសម្រេច គឺការប្រទូស្តដោយវាចា និងការប្រទូស្តដោយកាយ សង្គ្រោះចូលក្នុងបាតិមោក្ខសំវរៈដូចគ្នា ។ ដោយពាក្យថា* **សំវរោ ច** *នេះ សព្ទនៃ* **សំវរ** *ទាំង ៤ នេះ គឺសតិសំវរៈ ១ ញាណសំវរៈ ១ ខន្តិសំវរៈ ១ វិរិយសំវរៈ ១ សំវរៈ ៤ នេះ មានការធ្វើបាតិមោក្ខឲ្យសម្រេច ។ បទថា* **មត្តញ្ញុតា ច**

ភត្តស្មឹ បានដល់ ភាពជាបុគ្គលដ៏ឯកប្រមាណក្នុងភោជន ដោយអំណាចការស្វែងរក ការទទួល ការបរិភោគ និងការលះបង់ ។ បទថា **បន្តញ្ច សយនាសនំ** បានដល់ ទីដេក និងទីអង្គុយដ៏ស្ងាត់ មានដងព្រៃ និងគល់ឈើជាដើម ដែលអនុគ្រោះដល់ការវនា ។ បទថា **ចិត្តេ ច អាយោគោ** សេចក្តីថា កាលធ្វើអរហត្តផលចិត្ត ពោល គឺឈ្មោះថា អធិចិត្ត ព្រោះជាចិត្តក្រៃលែង គឺព្រោះឧត្តមជាងចិត្តទាំងពួងឲ្យសម្រេច សេចក្តីព្យាយាមតែងមានដោយអំណាចសមថការវនា និងវិបស្សនាការវនា ដើម្បីធ្វើអរហត្តផលចិត្តនោះឲ្យសម្រេច ។ បទថា **ឯតំ ពុទ្ធាន សាសនំ** សេចក្តីថា កាលមិនប្រទូស្តដោយវាចាជល់អ្នកដទៃ ១ ការមិនប្រទូស្តដោយកាយជល់អ្នកដទៃ ១ ការសង្រួមក្នុងបាតិមោក្ខ ១ ការស្គាល់ប្រមាណក្នុងការស្វែងរក និងការទទួលជាដើម ១ ការនៅក្នុងទីស្ងាត់ ១ ការប្រកបរឿយៗ នូវអធិចិត្តតាមដែលពោលហើយ ១ នេះជាពាក្យប្រៀនប្រដៅ គឺជាឱវាទ អធិប្បាយថា ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ សិក្ខា ៣ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ហើយដោយព្រះគាថានេះ ដោយប្រការដូច្នេះ ៗ

អដ្ឋកថា បិណ្ឌាលការទ្វាទសសូត្រទី ៦ ចប់

សុត្តន្តបិដក

សារិបុត្តសូត្រ

[១០១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ ជាអ្នកមានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោស មានសេចក្តីស្ងប់ស្ងាត់ មិននៅលាយឡំដោយពួក ប្រារព្ធព្យាយាម ប្រកបរឿយៗ នូវអធិចិត្ត អង្គុយផ្គត់ភ្នែន តម្រង់កាយត្រង់ ក្នុងទីជិតព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញព្រះសារីបុត្តដ៏មានអាយុ ជាអ្នកមានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោស មានសេចក្តីស្ងប់ស្ងាត់ មិននៅលាយឡំដោយពួក ប្រារព្ធព្យាយាម ប្រកបរឿយៗ នូវអធិចិត្ត អង្គុយផ្គត់ភ្នែន តម្រង់កាយត្រង់ ក្នុងទីជិតព្រះអង្គ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> *សេចក្តីសោកទាំងឡាយ រមែងមិនកើតមាន ដល់បុគ្គលមាន អធិចិត្ត មិនប្រមាទ ជាអ្នកដឹង ជាអ្នកសិក្សា ក្នុងផ្លូវនៃការដឹង ទាំងឡាយ គឺអរហត្តផលញ្ញាណ មានចិត្តមិនញាប់ញ័រ ជាអ្នក ឆ្លាតឆ្លង ជាអ្នកស្ងប់ មានស្មារតីគ្រប់កាល ។ សូត្រទី ៧ ។*

អដ្ឋកថា

សារិបុត្តសូត្រ

[១០១] ពាក្យដែលមិនបានពោលក្នុងកាលមុន មិនមានក្នុងសូត្រទី ៧ នេះ ។ ក្នុងគាថា គប្បីជ្រាបសេចក្តីដូចតទៅនេះ បទថា **អធិចេតសោ** ប្រែថា ជាអ្នកមានអធិចិត្ត ។ អធិប្បាយថា ដែលប្រកបដោយអរហត្តផល ចិត្តដែលក្រៃលែង ជាងចិត្តទាំងពួង ។ បទថា **អប្បមជ្ជតោ** ប្រែថា ដែលមិនប្រមាទ លោកអធិប្បាយថា ដែលប្រកបដោយការធ្វើ ប្រព្រឹត្តទៅជាប់តក្នុងធម៌ ដែលមិនមានទោស ដោយការមិនប្រមាទ ។ បទថា **មុនិនោ** សេចក្តីថា ព្រះខីណាស្រព ឈ្មោះថា មុនី ព្រោះដឹងនូវលោកទាំង ២ យ៉ាងនេះថា ព្រោះជាអ្នកដឹងនូវលោកទាំង ២ លោកហៅថា មុនី ឬព្រោះប្រកបដោយញាណ ពោល គឺបញ្ញាដែលសម្បយុត្តដោយ អរហត្តផលនោះ លោកហៅថា **មោនេ។** ដល់ព្រះមុនីនោះ ។ បទថា **មោនបថេសុ សិក្ខតោ** សេចក្តីថា ដែលសិក្សាក្នុងពោធិបក្ខិយធម៌ ៣៧ ប្រការ ឬក្នុងសិក្ខា ៣ ដែលជាផ្លូវនៃមោនៈ ពោល គឺអរហត្តមគ្គញាណ ។ ពាក្យនេះ លោកពោលសំដៅយកបដិបទា ដែលជាចំណែកខាងដើម ។ ពិតហើយ បុគ្គលសម្រេចការសិក្សា ឈ្មោះថា ព្រះអរហន្ត ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងទីនេះថា ដល់ព្រះមុនីដែលសម្រេចការសិក្សា ដូចពោលមកនេះ គឺដល់នូវភាពជាមុនីដោយការសិក្សានេះ ។ ព្រោះសេចក្តីនោះឯង ដូច្នោះ អត្ថនៃបទទាំង ៣ នេះ យ៉ាងនេះ គឺរបស់បុគ្គលដែលមានអធិចិត្ត គឺមគ្គចិត្ត ផលចិត្តខាងក្រោម បុគ្គលមិន

ប្រមាទ ដោយការមិនប្រមាទក្នុងកិច្ចបដិបត្តិដែលទាក់ទងដោយការត្រាស់ដឹង សច្ចៈ ៤ ឈ្មោះថា ជាមុនី ព្រោះប្រកបដោយមគ្គញ្ញាណ រមែងសមពិត ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថនៃហេតុរបស់បទថា **អប្បមជ្ជតោ ច សិក្ខតោ** *ថា ឈ្មោះថា មានអធិចិត្ត ព្រោះមិនប្រមាទ និងព្រោះការសិក្សា ។ បទថា* **សោកា ន ភវន្តិ តាទិនោ** *សេចក្តីថា ការសោកស្តាយ គឺការក្រៀមក្រំចិត្ត ដែលមានការព្រាត់ប្រាសចាកវត្ថុ ដែលគួរប្រាថ្នាជាដើមជាទីតាំង រមែងមិនមានខាងក្នុងនៃបុគ្គលនឹងធឹង គឺរបស់មុនី ដែលជាខីណាស្រព ។ ម្យ៉ាងទៀត ក្នុងបទថា* **តាទិនោ** *នេះ មានអធិប្បាយដូច្នេះថា ការសោយសោក រមែងមិនមានដល់មុនីបែបនេះ ដែលប្រកបដោយលក្ខណៈនៃភាពជាបុគ្គលនឹងធឹង ។ បទថា* **ឧបសន្តស្ស** *បានដល់ ជាអ្នកស្ងប់រម្ងាប់ ព្រោះស្ងប់កិលេស មានរាគៈជាដើមបានជាសមុច្ឆេទ ។ បទថា* **សទា សតីមតោ** *បានដល់ មិនវៀរសតិអស់កាលជានិច្ច ។ ក្នុងទីនេះ បទថា* **អធិចេតសោ** *នេះ គប្បីជ្រាបថា លោកបំណងយកអធិចិត្តសិក្ខា ។ បទថា* **អប្បមជ្ជតោ** *នេះ លោកបំណងយកអធិសីលសិក្ខា ។ បទថា* **មុនិនោ មោនបថេសុ សិក្ខតោ** *នេះ លោកបំណងយកអធិបញ្ញាសិក្ខា ។ ម្យ៉ាងទៀត ដោយបទថា* **មុនិនោ** *នេះ លោកបំណងយកអធិបញ្ញាសិក្ខា ។ ដោយបទថា* **មោនបថេសុ សិក្ខតោ** *នេះ លោកបំណងយកបដិបទាដែលជាចំណែកខាងដើម នៃលោកុត្តរសិក្ខាទាំងនោះ ។ បទថា* **សោកា ន ភវន្តិ** *ជាដើម គប្បីជ្រាបថា លោកប្រកាសអានិសង្សនៃការបំពេញសិក្ខា ។ ពាក្យដ៏សេស មានន័យដូចពោលហើយ*

នោះឯង ។

អដ្ឋកថា សារិបុត្តសូត្រទី ៧ ចប់

សុត្តន្តបិដក

សុន្ទរីសូត្រ

[១០២] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ទ្រង់បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជ-បរិក្ខារ ជាប្រក្រតី ។ សូម្បីភិក្ខុសង្ឃ ក៏មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារ ជាប្រក្រតីដែរ ។ ឯពួកបរិព្វាជក ជាអន្យតិ្ថរិយ មិនមានគេធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា មិនកោតក្រែង មិនបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាប្រក្រតីឡើយ ។*

[១០៣] *គ្រានោះ ពួកបរិព្វាជក ជាអន្យតិ្ថរិយ អត់ធន់មិនបានន្ទូវ សក្ការៈ របស់ព្រះមានព្រះភាគ និងភិក្ខុសង្ឃ ចូលទៅរកនាងបរិព្វាជិកា ឈ្មោះសុន្ទរី លុះចូលទៅដល់ហើយ ក៏និយាយនឹងនាងបរិព្វាជិកាឈ្មោះ សុន្ទរីថា នែបួនស្រី នាងអាចធ្វើប្រយោជន៍ដល់ពួកញាតិបានឬទេ ។ នាង*

បរិព្វាជិកាឈ្មោះសុន្ទរីសួរថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំព្រះករុណា ត្រូវ ធ្វើដូចម្តេច អំពើដូចម្តេច ដែលខ្ញុំអាចធ្វើបាន សូម្បីជីវិតក៏ខ្ញុំហ៊ានលះបង់ ដើម្បីជាប្រយោជន៍ដល់ពួកញាតិដែរ ។ ម្នាលប្អូនស្រី បើដូច្នោះ នាងចូល ទៅកាន់វត្តជេតពន ឲ្យព្រួយៗ ។ នាងបរិព្វាជិការឈ្មោះសុន្ទរី បានទទួល ពាក្យបរិព្វាជក ជាអន្យត្ថិរិយទាំងនោះថា ព្រះករុណាលោកម្ចាស់ ហើយទៅ កាន់វត្តជេតពនព្រួយៗ ។ កាលណាបរិព្វាជក ជាអន្យត្ថិរិយទាំងនោះ បាន ដឹងថា ជនច្រើនបានឃើញនាងបរិព្វាជិកាឈ្មោះសុន្ទរី ទៅកាន់វត្តជេតពន ព្រួយៗ ហើយ ក៏សម្លាប់នាងនោះឲ្យដាច់ចាកជីវិត ហើយកប់ក្នុងរណ្តៅ ស្នាមក្លោះ នៃវត្តជេតពននោះឯង ក្នុងកាលណោះ រួចចូលទៅគាល់ព្រះបាទ សេនទិកោសល លុះចូលទៅដល់ហើយ ក៏ថ្វាយព្រះពរព្រះបាទបសេនទិ-កោសលថា បពិត្រមហារាជ នាងបរិព្វាជិកាណាឈ្មោះសុន្ទរី នាងបរិព្វាជិកា នោះ មិនប្រាកដដល់ពួកអាគ្នាកាពសោះ ។ ព្រះរាជា ទ្រង់មានព្រះបន្ទូល សួរថា ចុះលោកទាំងឡាយ មានសង្ស័យក្នុងទីណាខ្លះ ។ បពិត្រមហារាជ ពួកអាគ្នាកាពមានសង្ស័យ ក្នុងវត្តជេតពន ។ បើដូច្នោះ ចូរលោកទាំងឡាយ គន់រកក្នុងវត្តជេតពនចុះ ។ លំដាប់នោះ បរិព្វាជកជាអន្យត្ថិរិយទាំងនោះ គយគន់មើលវត្តជេតពន ហើយក៏គាស់ឡើង (នូវសាកសព) ដែលបាន កប់ទុកហើយ អំពីរណ្តៅស្នាមក្លោះ ហើយលើកដាក់លើគ្រែតូច នាំចូលទៅ កាន់ក្រុងសាវត្ថី ហើយចេញពីច្រកមួយ ចូលទៅកាន់ច្រកមួយ ចេញពីផ្លូវ ត្រឡែងកែងមួយ ចូលទៅកាន់ផ្លូវត្រឡែងកែងមួយ ហើយប្រើពួកមនុស្សឲ្យ

លើកទោសថា នែម្ចាស់ទាំងឡាយ អ្នកទាំងឡាយ ចូរមើលអំពើរបស់ពួក សមណៈ ជាសក្យបុត្តិយ៍ចុះ ពួកសមណៈជាសក្យបុត្តិយ៍នេះ ជាបុគ្គល មិនអៀនខ្មាស ទ្រុស្តសីល មានធម៌លាមក ជាអ្នកនិយាយពាក្យកុហក ប្រព្រឹត្តធម៌មិនប្រសើរ ។ មិនគួរបើពួកសមណៈជាសក្យបុត្តិយ៍នេះ មកប្តេជ្ញាខ្លួនថា ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រព្រឹត្តធម៌ដ៏ប្រសើរ ពោលពាក្យពិត មានសីល មានកល្យាណធម៌សោះ ភាពជាសមណៈ គឺជាអ្នករម្ងាប់បាប មិនមានដល់ពួកសមណៈនេះទេ្បីយ ភាពជាអ្នកប្រសើរ គឺជាអ្នកបន្សាត់បាប មិនមានដល់ពួកសមណៈនេះទេ្បីយ ភាពជាសមណៈ របស់ពួកសមណៈនេះ សាបសូន្យហើយ ភាពជាអ្នកប្រសើររបស់ពួកសមណៈនេះ សាបសូន្យហើយ ភាពជាសមណៈ នឹងមានដល់ពួកសមណៈនេះ អំពីហេតុដូចម្តេច ភាពជាអ្នកប្រសើរ នឹងមានដល់ពួកសមណៈ អំពីហេតុដូចម្តេច ពួកសមណៈនេះ ច្រាសចាកភាពជាសមណៈ ពួកសមណៈនេះ ច្រាសចាកភាពជាអ្នកប្រសើរហើយ ។ មិនគួរបើបុរសនឹងធ្វើកិច្ចរបស់បុរស (មេថុនកិច្ច) ហើយមកធ្វើស្រីឲ្យដាច់ចាកជីវិតសោះ ។

[១០៤] *សម័យនោះឯង ពួកមនុស្សក្នុងក្រុងសាវត្ថី បានឃើញពួកភិក្ខុ ហើយនាំគ្នាជេរ ប្រទេចផ្តាសា បៀតបៀនដោយសម្តីទ្រគោះ ជារបស់អសប្បុរសថា ពួកសមណៈជាសក្យបុត្តិយ៍នេះ ជាអ្នកមិនអៀនខ្មាស ទ្រុស្ត-សីល មានធម៌លាមក ជាអ្នកនិយាយពាក្យកុហក ប្រព្រឹត្តធម៌មិនប្រសើរ ។ មិនគួរបើ ពួកសមណៈទាំងនោះ មកប្តេជ្ញាខ្លួនថា ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្ត*

ស្មើ ប្រព្រឹត្តដ៏ប្រសើរ ពោលពាក្យពិត មានសីល មានកល្យាណធម៌ សោះ ភាពជាសមណៈ គឺជាអ្នករម្ងាប់បាប មិនមានដល់សមណៈទាំងនេះ ឡើយ ភាពជាអ្នកប្រសើរ គឺជាអ្នកបន្សាត់បាប មិនមានដល់សមណៈទាំង នេះឡើយ ភាពជាសមណៈ របស់សមណៈនេះ សាបសូន្យហើយ ភាពជា អ្នកប្រសើររបស់សមណៈទាំងនេះ សាបសូន្យហើយ ភាពជាសមណៈ និង មានដល់សមណៈទាំងនេះ អំពីហេតុដូចម្តេច ភាពជាអ្នកប្រសើរ និងមាន ដល់ពួកសមណៈនេះ អំពីហេតុដូចម្តេច សមណៈទាំងនេះ ប្រាសចាកភាព ជាសមណៈហើយ សមណៈទាំងនេះ ប្រាសចាកភាពជាអ្នកប្រសើរហើយ ។ មិនគួរបើ បុរសនឹងធ្វើកិច្ចរបស់បុរស (មេថុនកិច្ច) ហើយមកធ្វើស្រីឲ្យ ដាច់ចាកជីវិតសោះ ។

[១០៥] គ្រានោះ ពួកភិក្ខុច្រើនរូប បានស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ លុះ ភិក្ខុទាំងនោះ ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ហើយត្រឡប់មកអំពីបិណ្ឌ-បាត ក្នុងកាលខាងក្រោយភត្ត រួចចូលទៅគាល់ព្រះមានព្រះភាគ លុះចូល ទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះ ភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពាក្យមនុស្សក្នុងក្រុងសាវត្ថី បានឃើញ ពួកភិក្ខុហើយ (នាំគ្នា) ជេរប្រទេច ផ្តាសា បៀតបៀនដោយសម្តីទ្រគោះ ជារបស់អសប្បុរសថា ពួកសមណៈជាសក្យបុត្តិយ៍នេះ ជាបុគ្គលមិនអៀន

ខ្មាស ទ្រុស្តសីល មានធម៌លាមក ពោលពាក្យកុហក ប្រព្រឹត្តធម៌មិនប្រសើរ ។ ពួកសមណៈទាំងនេះ មិនគួរបើមកប្តេជ្ញាខ្លួនថា ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រព្រឹត្តធម៌ប្រសើរ ពោលពាក្យពិត មានសីល មានកល្យាណធម៌សោះ ភាពជាសមណៈ គឺជាអ្នករម្ងាប់បាប មិនមានដល់ពួកសមណៈទាំងនេះ ភាពជាអ្នកប្រសើរ គឺជាអ្នកបន្សាត់បាប មិនមានដល់សមណៈទាំងនេះ ភាពជាសមណៈរបស់សមណៈទាំងនេះ សាបសូន្យហើយ ភាពជាអ្នកប្រសើររបស់សមណៈទាំងនេះ សាបសូន្យហើយ ភាពជាសមណៈនឹងមានដល់សមណៈទាំងនេះ អំពីហេតុដូចម្តេច ភាពជាអ្នកប្រសើរ នឹងមានដល់សមណៈទាំងនេះ អំពីហេតុដូចម្តេច សមណៈទាំងនេះ ប្រាសចាកភាពជាសមណៈហើយ សមណៈទាំងនេះ ប្រាសចាកភាពជាអ្នកប្រសើរហើយ ។ មិនគួរបើ បុរសនឹងធ្វើកិច្ចរបស់បុរស (មេថុនកិច្ច) ហើយមកធ្វើស្រីឲ្យដាច់ចាកជីវិតសោះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំឡេង (ពោលទោស) នុ៎ះ នឹងមិនស្ថិតនៅយូរឡើយ ស្ថិតនៅបានតែត្រឹម ៧ ថ្ងៃប៉ុណ្ណោះ លុះកន្លងហួស ៧ ថ្ងៃហើយ គង់នឹងបាត់ទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ បើជួបច្បោះ ពួកមនុស្សណា បានឃើញពួកភិក្ខុហើយ ជេរប្រទេច ផ្តាសា បៀតបៀនដោយសម្តីទ្រគោះ ជារបស់អសប្បុរសអ្នកទាំងឡាយ ចូរម្ងឹកពួកមនុស្សទាំងនោះ ដោយគាថានេះថា

អ្នកនិយាយកុហក ឬអ្នកណាធ្វើហើយ និយាយថា ខ្ញុំមិនធ្វើទេ រមែងចូលទៅកាន់នរក បុគ្គលទាំង ២ នោះ ជាអ្នក

កើតអំពីមនុស្ស មានកម្មដ៏ថោកទាប លុះលះលោកនេះ
ទៅហើយ ជាអ្នកស្មើគ្នា ក្នុងលោកខាងមុខ ។

[១០៦] *លំដាប់នោះ ភិក្ខុទាំងនោះ បានរៀនគាថានេះ ក្នុងសម្នាក់*
នៃព្រះមានព្រះភាគ ពួកមនុស្សណា ដែលបានឃើញពួកភិក្ខុហើយ ជេរ
ប្រទេច ផ្តាសា បៀតបៀនដោយសម្តីទ្រគោះ ជារបស់អសប្បុរស ក៏រម្ងឹក
មនុស្សទាំងនោះ ដោយគាថានេះថា

បុគ្គលអ្នកនិយាយកុហក ឬអ្នកណាធ្វើហើយ និយាយថា
ខ្ញុំមិនធ្វើទេ រមែងចូលទៅកាន់នរក បុគ្គលទាំង ២ ពួក
នោះ ជាអ្នកកើតអំពីមនុស្ស មានកម្មដ៏ថោកទាប លុះលះ
លោកនេះទៅហើយ ជាអ្នកស្មើគ្នា ក្នុងលោកខាងមុខ ។

[១០៧] *មនុស្សទាំងឡាយ ក៏មានសេចក្តីត្រិះរិះថា ពួកសមណៈជា*
សក្យបុត្តិយ៍នេះ ជាអ្នកមិនធ្វើទេ អំពើអាក្រក់ សមណៈទាំងនេះ មិនបាន
ធ្វើទេ ពួកសមណៈនេះ ជាសក្យបុត្តិយ៍ ។ សំឡេងនោះ មិនបានស្ងិតនៅ
យូរឡើយ សំឡេងនុ៎ះ ស្ងិតនៅបានតែត្រឹម ៧ ថ្ងៃប៉ុណ្ណោះ លុះកន្លង ៧
ថ្ងៃហើយ ក៏សាបសូន្យទៅ ។ គ្រានោះ ពួកភិក្ខុច្រើនរូប បានចូលទៅគាល់
ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយ
ក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូល
ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គ
ដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ បាន

ត្រាស់ព្រះពុទ្ធដីកានេះប្រាកដមែនថា ម្នាលភិក្ខុទាំងឡាយ សំឡេងនុ៎ះ នឹងមិនស្ថិតនៅយូរឡើយ លុះកន្លង ៧ ថ្ងៃហើយ នឹងសាបសូន្យទៅ បពិត្រព្រះអង្គដ៏ចម្រើន សំឡេងនុ៎ះ សូន្យបាត់ទៅហើយ ។ លុះព្រះមានព្រះភាគទ្រង់បានជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ពួកជនអ្នកមិនសង្រួម តែងចាក់ដោតគេដោយវាចា ដូចជា (ទាហានតទល់) កាលចាក់ដំរី ដែលទៅកាន់សង្គ្រាម ដោយសរទាំងឡាយ ភិក្ខុបានឮពាក្យអាក្រក់ ដែលពួកជនដទៃពោលហើយ ជាអ្នកមានចិត្តមិនប្រទូស្ត ហើយគប្បីអត់ទ្រាំបាន ។ សូត្រទី ៨ ។

អដ្ឋកថា

សុន្ទរីសូត្រ

សុន្ទរីសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ

[១០២-១០៤] *អត្ថនៃបទជាដើមថា* **សក្ការោ** *ខ្ញុំបានពោលខាងដើមនោះឯង ។ បទថា* **អសហមានា** *ប្រែថា អត់ធន់មិនបាន ។ អធិប្បាយថា អាក់អន់ ក្លាប់សេចក្តីថា អត់ធន់នឹងសក្ការៈរបស់ភិក្ខុសង្ឃមិនបាន ។ បទថា* **សុន្ទរី** *ជាឈ្មោះរបស់ស្ត្រីនោះ ។*

បានឮថា ក្នុងពេលនោះ បណ្តាបរិព្វាជិកាទាំងអស់ នាងជាអ្នកមានរូប

ស្អាត គួរសរសើរ គួរជ្រះថ្លា ប្រកបដោយពណ៌សម្បុរកាយយ៉ាងក្រៃលែង ហេតុនោះឯង ទើបឈ្មោះថា **សុឆ្ឌី** ។ នាងមិនទាន់ឆ្លងវ័យក្រមុំនៅឡើយ មិនដាក់ចិត្តក្នុងការប្រព្រឹត្ត ។ ព្រោះហេតុនោះ ទើបតិន្ទិយទាំងនោះបញ្ជូននាងទៅក្នុងបាបកម្ម ។ ពិតហើយ តិន្ទិយទាំងនោះវិនាសលាភសក្ការៈទៅឯង តាំងពីកាលដែលព្រះពុទ្ធកើតឡើង ឃើញលាភ និងសក្ការៈមិនមានប្រមាណ ប្រព្រឹត្តទៅដល់ព្រះមានព្រះភាគ និងភិក្ខុសង្ឆ ដោយន័យដែលមកហើយ ក្នុងអដ្ឋកថាអក្កោសកសូត្រខាងដើម ទើបនាំគ្នាច្រណែន ប្រឹក្សាគ្នាថា ចាប់តាំងពីព្រះសមណគោតមកើតឡើងហើយ ពួកយើងនាំគ្នាវិនាស សាបសូន្យ លាភ សក្ការៈ បុគ្គលណាម្នាក់មិនដឹងថា ពួកយើងមាន ព្រោះអាស្រ័យ ហេតុអ្វីហ្នឹ ទើបសត្វលោកនាំគ្នាជ្រះថ្លាក្រៃលែង ក្នុងព្រះសមណគោតម នាំ សក្ការៈចូលទៅថ្វាយដ៏ច្រើន ។ ក្នុងបណ្តាតិន្ទិយទាំងនោះ តិន្ទិយម្នាក់ថ្លែងឡើងថា ព្រះសមណគោតមប្រសូតក្នុងត្រកូលខ្ពស់ ទ្រង់ប្រសូតតាមបវេណី របស់មហាសម្មតិរាជដែលមិនលាយឡំ ។ តិន្ទិយម្នាក់ទៀតពោលឡើងថា ក្នុងកំណើតនៃត្រកូលវង្ស ទ្រង់មានហេតុគួរអស្ចារ្យប្រាកដច្រើន ។ តិន្ទិយម្នាក់ទៀត ពោលថា ព្រះបាទទាំងគួរបស់ព្រះអង្ត ដែលនាំចូលទៅថ្វាយបង្គំ កាលទេវិលតាបស បែរជាទៅតាំងនៅត្រង់ជជារបស់ទេវិលតាបសនោះ ។ បុរសម្នាក់ទៀត ពោលឡើងថា ក្នុងវប្សមង្គល កាលទ្រង់ផ្ទំត្រង់ម្លប់ព្រីង សូម្បីថ្ងៃត្រង់កន្ធងទៅហើយ ស្រមោលនៃដើមព្រីងតាំងនៅ មិនជ្រេទៅឡើយ ។ តិន្ទិយម្នាក់និយាយឡើងថា ទ្រង់មានរូបស្អាត គួរសរសើរ គួរ

ជ្រះថ្លា ព្រោះសម្ឃូរដោយទ្រង់ទ្រាយ តិរ្ថិយម្នាក់ពោលឡើងថា ព្រះអង្គទត យើញនិមិត្ត គឺមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងបព្វជិត ទ្រង់ កើតសង្វេគ ទ្រង់លះចក្រពត្តិរាជនឹងមកដល់ហើយ ទ្រង់បព្វជ្ជា ពួកតិរ្ថិយមិន ដឹងបុញ្ញសម្ភាររបស់ព្រះមានព្រះភាគ ដែលមិនទូទៅដល់អ្នកដទៃ ដែលទ្រង់ ធ្លាប់សន្សំមក អស់កាលប្រមាណមិនបាន ។ សល្លេខបដិបទា មិនមានអ្វី ប្រៀប សូម្បីបារមីដ៏ខត្តម និងពុទ្ធានុភាព មានញាណសម្បទា និងបហាន-សម្បទាជាដើមដ៏កំពូល ទើបប្រារព្ធដល់ហេតុ ដែលព្រះមានព្រះភាគជាទី រាប់អានច្រើននោះៗ តាមដែលខ្ជូនបានយើញ បានព្ឋមក ទើបស្វែងរកហេតុ ដែលទ្រង់មិនជាទីរាប់អាន កាលរកមិនយើញ ទើបគិតថា ព្រោះហេតុអ្វីហ្នឹ ពួកយើងគប្បីធ្វើការវិនាសយសឲ្យកើត និងធ្វើលាភ សក្ការៈរបស់ព្រះ សមណគោតមឲ្យសាបសូន្យ ។ បណ្តាតិរ្ថិយទាំងនោះ បុរសម្នាក់មានគំនិត មុតស្រួច ខ្ជាក់ប្រយោគយ៉ាងនេះថា អ្នកដ៏ចម្រើន ធម្មតាសត្វទាំងឡាយ ដែលមិនជាប់ជំពាក់ក្នុងសេចក្តីសុខ ដែលកើតអំពីមាតុគ្រាម តែងមិនមាន ក្នុងសត្វលោកនេះ ព្រះសមណគោតមនេះ មានរូបស្អាតដូចទេវតា កំលោះ គួរបានមាតុគ្រាម ដែលមានរូបរាងស្មើខ្ជូនមកនែបនិត្យ ប៉ើមិនភិសម័យ ខាងបរិស័ទ គប្បីសង្ស័យ ណ្ហើយចុះ ពួកយើងបញ្ជូននាងសុន្ទរីបរិព្វាជិកា ទៅ ដោយប្រការដែលការវិនាសកិត្តិសព្ទរបស់ព្រះគោតម នឹងផ្សាយទៅក្នុង ផ្ទៃប្រឹថពី ។

ឯតិរ្ថិយក្រៅអំពីនេះ បានស្តាប់ដូច្នោះ គិតថា រឿងនេះ អ្នកគិតត្រូវពិត

កាលយើងធ្វើយ៉ាងនេះ ព្រះសមណគោតមក៏មានព្រះហឫទ័យរីករាយ ដោយកិត្តិសព្ទ មិនអាចងើបសីសៈឡើងបាន ក៏និងគេចទៅដោយអាការណាមួយដូច្នេះហើយ ទើបមានអធ្យាស្រ័យដូចគ្នាទាំងអស់ នាំគ្នាទៅរកនាងសុន្ទរីដើម្បីបញ្ជូននាងទៅ ។ នាងឃើញតិរ្ថិយទាំងនោះ ទើបពោលថា ហេតុអ្វី ទើបលោក មកព្រមគ្នាយ៉ាងនេះ ពួកតិរ្ថិយទាំងឡាយ ធ្វើអាការមិននិយាយគ្នាអង្គុយក្នុងទីកំបាំងខាងចុងអារាម នាងក៏ទៅក្នុងទីនោះ ពោលហើយពោលទៀត ក៏មិនមានអ្នកណាឆ្លើយ ទើបសួរថា ខ្ញុំមានកំហុសអ្វីចំពោះលោក ហេតុអ្វី ទើបមិនឆ្លើយដល់ខ្ញុំ ពួកតិរ្ថិយសាកសួរថា នាងព្រងើយកន្តើយយើងត្រូវបៀតបៀន នាងដឹងឬទេ នាងសុន្ទរីសួរថា អ្នកណាបៀតបៀនពួកលោក ពួកតិរ្ថិយឆ្លើយថា ព្រះសមណគោតមបៀតបៀនពួកយើង ធ្វើយើងឲ្យវិនាសលាភសក្ការៈ នាងមិនដឹងទេឬ ។ កាលនាងសួរថា តើខ្ញុំធ្វើដូចម្តេចក្នុងសេចក្តីនោះ ទើបពោលថា បើដូច្នោះ ចូរនាងទៅជិតវត្តជេតពនរៀយៗគប្បីនិយាយយ៉ាងនេះ និងយ៉ាងនេះដល់មហាជន ឯនាងទទួលថា សាធុ ដោយហេតុនោះ ទើបលោកពោលថា គ្រានោះ ពួកបរិព្វាជក ជាអន្យតិរ្ថិយអត់ធន់មិនបាន នូវសក្ការៈរបស់ព្រះមានព្រះភាគ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឧស្សហាមិ** *ប្រែថា រមែងអាច ។ បទថា* **អត្តំ** *បានដល់ ប្រយោជន៍ ឬកិច្ច ។ បទថា* **ករ្យាហំ** *កាត់បទជា* **កឹ អហំ** *ប្រែថា យើងនឹងធ្វើដូចម្តេច ។*

ព្រោះតិរ្ថិយទាំងនោះ មិនមែនជាញាតិរបស់នាង តែក៏ដូចជាញាតិ ដើម្បី

សង្គ្រោះនាងដោយហេតុត្រឹមសម្ពន្ធគ្នាក្នុងការបួស ទើបពោលថា នែប្អូនស្រី នាងអាចធ្វើប្រយោជន៍ដល់ពួកញាតិបានឬ ។ ព្រោះដូច្នោះ នាងក៏គង់ជាប់ជំពាក់ដូចវល្លិរុំជើង ទើបពោលថា សូម្បីជីវិតក៏ខ្ញុំហ៊ានលះបង់ ដើម្បីជាប្រយោជន៍ ដល់ពួកញាតិដែរ ។ បទថា **តេនហិ** *សេចក្តីថា ពួកតិរ្ថិយពោលថា ព្រោះនាងពោលថា សូម្បីជីវិតរបស់ខ្ញុំក៏លះបាន ដើម្បីជាប្រយោជន៍ដល់ពួកលោក នាងតាំងនៅក្នុងបឋមវ័យ មានរូបស្អាត ស្រស់បស់ ដូច្នោះ គប្បីធ្វើប្រការដែលព្រះសមណគោតម នឹងកើតនូវការខូចកិត្តិសព្ទ ព្រោះអាស្រ័យនាង ដូច្នេះហើយ ទើបបញ្ជូនទៅ ដោយពាក្យថា ចូលទៅកាន់វត្តជេតពនរឿយៗ ឯនាងជាបុគ្គលល្ងង់ ដូចបំណងនឹងលេងខ្សែដែលជោតផ្កា ដែលគេព្យួរត្រង់ធ្នេញរណា ដូចចាប់ប្រមោយជីរចុះប្រេង និងដូចឈរបែរមុខចូលទៅរកសេចក្តីស្លាប់ ទើបទទួលពាក្យរបស់តិរ្ថិយ ហើយកាន់យកផ្កា គ្រឿងក្រអូប គ្រឿងលាប ស្វាមួ និងគ្រឿងអប់មុខជាដើម ក្នុងកាលដែលមហាជន ស្តាប់ធម្មទេសនារបស់ព្រះសាស្តាហើយ ចូលទៅកាន់ព្រះនគរ នាងបែរមុខទៅកាន់វត្តជេតពន ត្រូវគេសួរថា តើនាងទៅណា ទើបឆ្លើយថា ទៅកាន់សម្នាក់ព្រះសមណគោតម ព្រោះខ្ញុំនៅក្នុងព្រះគន្ធកុដិជាមួយព្រះសមណគោតមនោះ ដូច្នេះហើយ ទើបនៅក្នុងអាវាសរបស់តិរ្ថិយមួយកន្លែង លុះព្រលឹមឡើង ក៏ធៀងចូលកាន់ផ្លូវវត្តជេតពន បែរមុខមកព្រះនគរ ត្រូវគេសួរថា នែសុន្ទរី នាងមកពីណា ទើបឆ្លើយថា ខ្ញុំនៅក្នុងព្រះគន្ធកុដិជាមួយព្រះសមណគោតម ឲ្យទ្រង់អភិរម្យត្រេកអរដោយកិលេសហើយ*

ទើបមក ។ ដោយហេតុនោះ ទើបលោកពោលថា នាងបរិព្វាជិកាឈ្មោះ សុន្ទរី បានទទួលពាក្យបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះថា ព្រះករុណាលោកម្ចាស់ ហើយទៅកាន់វត្តជេតពនញយៗ ។ កន្លទៅ ២-៣ ថ្ងៃ ទើបពួកតិរ្ថិយឲ្យឈ្នួលដល់ពួកអ្នកលេង ហើយពោលថា ពួកអ្នកចូរទៅសម្លាប់នាងសុន្ទរី ហើយកប់ក្នុងគំនរសំរាម មិនឆ្ងាយអំពីព្រះគន្ធកុដិរបស់ព្រះសមណគោតម ហើយចូរមក ។ ពួកអ្នកលេងក៏បានធ្វើយ៉ាងនោះ ។ លំដាប់នោះ ពួកតិរ្ថិយធ្វើនូវការធោឡា ទើបក្រាបទូលដល់ព្រះរាជាៗ ត្រាស់សួរថា ពួកអ្នកសង្សយក្នុងទីណា ទើបក្រាបទូលថា ច្រើនថ្ងៃមកនេះ នាងនៅក្នុងវត្តជេតពន ពួកទូលបង្គំ មិនជ្រាបរឿងរបស់នាងក្នុងទីនោះ ព្រះរាជាទ្រង់អនុញ្ញាតថា បើដូច្នោះ ពួកអ្នកចូរទៅស្វែងរកនាងត្រង់វត្តជេតពននោះចុះ ទើបនាំពួកឧបដ្ឋាករបស់ខ្លួន ទៅកាន់វត្តជេពន ធ្វើអាការដូចជាស្វែងរក កាយគំនរសំរាមហើយលើកសរីរៈរបស់នាងឡើងកាន់គ្រែ សែងទៅកាន់ព្រះនគរ ហើយក្រាបទូលដល់ព្រះរាជាថា ពួកសាវ័ករបស់ព្រះសមណគោតម គិតបិទបាំងកម្មអាក្រក់ដែលគ្រូខ្លួនធ្វើ ទើបនាំគ្នាសម្លាប់នាងសុន្ទរី ហើយកប់ក្នុងគំនរសំរាម ។ ឯព្រះរាជាទ្រង់មិនពិចារណា ទើបបញ្ជាថា បើដូច្នោះ ពួកអ្នកចូរគ្រាច់ទៅកាន់ព្រះនគរ ។ ពួកតិរ្ថិយទាំងនោះ ដើរពោលក្នុងវិថីពេញព្រះនគរ មានពាក្យជាដើមថា អ្នកទាំងឡាយ ចូរមើលកម្មអាក្រក់ របស់ពួកសមណ-សក្យបុត្រិយ៍ចុះ ហើយក៏បានទៅកាន់ទ្វារព្រះរាជនិវេសន៍ទៀត ព្រះរាជាត្រាស់ឲ្យលើកសពនាងសុន្ទរីឡើងកាន់គ្រែ ហើយរក្សាទុកក្នុងព្រៃខ្មោច ។

អ្នកក្រុងសាវត្ថី រៀវព្រះអរិយសាវ័កចេញ ពោលពាក្យជាដើមថា ពួកអ្នក ចូរមើលកម្មអាក្រក់របស់សមណសក្យបុត្តិយ៍ចុះ ដូច្នេះហើយ ដើរដេរពួក ភិក្ខុ ទាំងក្នុងក្រុង ទាំងក្រៅក្រុង ដោយហេតុនោះ ទើបលោកពោលថា កាលណាបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ បានដឹងថា ជនច្រើនបានឃើញ នាងបរិព្វាជិកា ឈ្មោះសុន្ទរី ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អញ្ញឹសុ** *ប្រែថា ដឹងហើយ ។ បទថា* **ទិដ្ឋា** *ប្រែថា ឃើញដោយពិសេស អធិប្បាយថា នាងទៅមកៗ កាន់វត្ត ជេតពន ដែលឃើញដោយពិសេស គឺឃើញច្រើនគ្នា ។ បទថា* **បរិក្ខាក្ខយេ** *បានដល់ គូទឹកវែង ។ បទថា* **យា សា មហារាជ សុន្ទរី** *សេចក្តីថា មហា បពិត្រ នាងសុន្ទរីបរិព្វាជិកាដែលប្រាកដ គឺប្រាកដជាប្រាស់ថា សុន្ទរី ព្រោះ នាងមានរូបស្អាតក្នុងក្រុងនេះ ។ បទថា* **សា នោ ន ទិស្សតិ** *សេចក្តីថា នាងជាទីស្រឡាញ់ដូចកែវភ្នែក និងជីវិតរបស់ទូលបង្គំ ឥឡូវនេះ មិនប្រាកដ។ បទថា* **យថានិក្ខិត្តំ** *សេចក្តីថា តាមដែលខ្លួនបញ្ជាពួកបុរសឲ្យទុកខាងក្នុង គំនរសំរាម ។ ជាលីថា* **យថា និខាតំ** *(តាមដែលកប់) ដូច្នេះក៏មាន អធិប្បាយថា កប់ក្នុងផែនដី ។*

បទថា **រថិយាយ រថិយំ** *ប្រែថា អំពីផ្លូវនេះទៅកាន់ផ្លូវនោះ ។ ច្រក ដែលមិនទាល់ ហៅថា* **រថិយំ។** *ច្រកដែលបែកជា ៣ ឈ្មោះថា* **សិង្ឃាដកំ។** *បទថា* **អលជ្ជិនោ** *ប្រែថា មិនខ្មាស អធិប្បាយថា រៀរចាកសេចក្តីរង្កៀស ក្នុងបាប ។ បទថា* **ទុស្សីលា** *ប្រែថា មិនមានសីល ។ បទថា* **ចាបធម្មា**

បានដល់ មានសភាវៈលាមក គឺមានការប្រព្រឹត្តអាក្រក់ ។ បទថា **មុសា-វាទិនោ** *បានដល់ ជាបុគ្គលទ្រុស្តសីល ជាបុគ្គលអ្នកនិយាយកុហក ព្រោះច្រើនដោយការពោលឡេះឡោះថា ខ្ញុំជាអ្នកមានសីល ។ បទថា* **អព្រហ្ម-ចារិនោ** *បានដល់ ជាអ្នកប្រព្រឹត្តមិនប្រសើរ ព្រោះសេពមេថុន ។ ពួកតិរ្ថិយពោលមើលងាយថា ពួកនេះឯង ។ បទថា* **ធម្មចារិនោ** *បានដល់ ជាអ្នកប្រព្រឹត្តកុសលធម៌ ។ បទថា* **សមចារិនោ** *បានដល់ ប្រព្រឹត្តស្មើក្នុងកាយកម្មជាដើម បទថា* **កល្យាណធម្មា** *បានដល់ បុគ្គលមានសភាវៈដែលស្អាតក្លាប់សេចក្តីថា ឈ្មោះថា ជីងចំពោះ ។ ពាក្យថា* **បដិជានិស្សន្តិ** *ក្នុងព្រះបាលីនេះ ជាពាក្យសបញ្ជាក់ដល់អនាគតកាល ព្រោះប្រកបដោយនាមសព្ទ ។ ភាពជាសមណៈ ឈ្មោះថា* **សាមញ្ញ** *បានដល់ ភាពជាអ្នកស្ងប់ចាកបាប ។ ភាពជាអ្នកមានធម៌ដ៏ប្រសើរ ឈ្មោះថា* **ព្រហ្មញ្ញ** *បានដល់ ភាពជាអ្នកបន្សាត់បាប ។ បទថា* **កុតោ** *ប្រែថា ដោយហេតុណាមួយ ។ បទថា* **អបគតា** *ប្រែថា ទៅប្រាសហើយ គឺរលាស់ចេញហើយ ។ ដោយពាក្យថា* **បុរិសកិច្ចំ** *លោកអាចារ្យពោលសំដៅដល់ការសេពមេថុន ។ លំដាប់នោះ ពួកភិក្ខុក្រាបទូលរឿងនោះដល់ព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ពួកអ្នកក៏ចូរឆ្លើយនឹងមនុស្សទាំងនោះ ដោយគាថានេះ ទើបត្រាស់ថា* **អភូតវាទី** *ជាដើម ។ ដែលលោកពោលថា គ្រានោះ ពួកភិក្ខុជាច្រើនរូប ។បេ។ បុគ្គលទាំងពីរនោះ ជាអ្នកកើតអំពីមនុស្សមានកម្មដ៏ថោកទាបលះលោកនេះទៅហើយ ជាអ្នកស្មើគ្នាក្នុងលោកខាងមុខ ។*

ព្រះសាស្តា ទ្រង់ជ្រាបការសម្រេចនៃការវិនាសយសនោះ ដោយព្រះ-សព្វញ្ញុតញ្ញាណ កាលទ្រង់លួងលោមភិក្ខុទាំងឡាយ ទើបត្រាស់ពាក្យនេះក្នុងព្រះបាលីនោះថា ម្នាលភិក្ខុទាំងឡាយ សំឡេងនេះ មិននៅយូរឡើយ ។

[១០៥] ក្នុងគាថា មានវិនិច្ឆ័យដូចតទៅនេះថា បទថា **អភូតវាទិ** *បានដល់ មិនឃើញទោសរបស់អ្នកដទៃឡើយ ពោលមុសាវាទ ពោលចំពោះអ្នកដទៃដោយពាក្យមិនពិត គឺមិនប្រាកដ ។ បទថា* **យោ វាបិ កត្វា** *សេចក្តីថា ឬថា បុគ្គលធ្វើកម្មអាក្រក់ហើយ ពោលថា ខ្ញុំមិនបានធ្វើកម្មអាក្រក់នេះទេ ។ បទថា* **បេច្ច សមា ភវន្តិ** *សេចក្តីថា ជនទាំង ២ ពួកនោះ ចាកលោកនេះទៅកាន់បរលោក ជាអ្នកមានគតិស្មើគ្នា ដោយការចូលដល់នរក ។ ពិតហើយ គតិរបស់ជនទាំងនោះឯងនៅកំណត់ តែអាយុកំណត់មិនបាន ។ ព្រោះថា បុគ្គលធ្វើកម្មអាក្រក់ច្រើន ឆេះក្នុងនរកអស់កាលយូរ ធ្វើកម្មអាក្រក់តិច ឆេះត្រឹមតិចតួចប៉ុណ្ណោះ ព្រោះជនទាំង ២ មានកម្មលាមកនោះឯងជួច្នោះ ទើបលោកពោលថា* **និហីនកម្មា មនុជា បរត្ថ** *ជាដើម ។ បទថា* **បរត្ថ** *នេះ ភ្ជាប់នឹងបទថា* **បេច្ច** *ខាងមុខ អធិប្បាយថា ជាអ្នកមានកម្មដ៏លាមកទាំងនោះ នឹងទៅក្នុងលោកខាងមុខ គឺទៅអំពីលោកនេះ ជាអ្នកស្មើគ្នាក្នុងលោកខាងមុខ ។*

[១០៦-១០៧] បទថា **បរិយាបុណិត្វា** *បានដល់ រៀនហើយ ។*

បទថា **អកាវកា** *បានដល់ ជាអ្នកមិនធ្វើនូវកំហុស ។ បទថា* **ឆយិ-មេហិ កតំ** *សេចក្តីថា បានឮថា ពួកមនុស្សទាំងនោះ មានការគិតយ៉ាងនេះ*

ថា ព្រះសមណសក្យបុត្តិយ៍ មិនបានធ្វើកម្មអាក្រក់ តាមដែលពួកតិរ្ថិយដើរ ឃោសនាពេញព្រះនគរដោយពិត ព្រោះតិរ្ថិយទាំងនេះពោលដោយផរុសវាចា ដែលមិនមែនសប្បុរសយ៉ាងនេះ ក៏មិនសម្តែងអាការដែលប្លែកណាមួយ ទាំងមិនលះខន្តិ និងសោរច្ចៈ គ្រាន់តែពោលផ្តាសាតាមធម៌តែម្យ៉ាងប៉ុណ្ណោះថា បុគ្គលពោលពាក្យមិនពិត រមែងធ្លាក់នរក សមណសក្យបុត្តិយ៍ទាំងនេះ ពោលផ្តាសាពួកយើងដែលមិនពិចារណាហើយ ពោលទោស និយាយដូចជាក់បណ្តាសា ។ ម្យ៉ាងទៀត ពោលផ្តាសាថា អ្នកណាធ្វើ តែពោលថា មិនធ្វើ អធិប្បាយថា សមណៈទាំងនេះធ្វើសម្បថដល់ពួកយើង ដើម្បីឲ្យដឹងថា ខ្លួនមិនបានធ្វើ ។ ឯសេចក្តីត្រេកអរ ឈមចុះដោយពុទ្ធានុភាពក្នុងលំដាប់ មួយអន្ទើដោយការស្តាប់ព្រះគាថា ដែលព្រះមានព្រះភាគ ត្រាស់ដល់ពួកមនុស្សទាំងនោះ ។ សេចក្តីសង្វេគកើតឡើងហើយថា រឿងនេះ ពួកយើងមិនបានឃើញដោយប្រចក្ស ធម្មតារឿងដែលបានឮហើយ រមែងពិតខ្លះ មិនពិតខ្លះ ។ ពិតហើយ ពួកតិរ្ថិយទាំងនោះប្រាថ្នាវត្ថុដែលមិនជាប្រយោជន៍ និងមិនជាឧបការៈដល់សមណៈទាំងនេះ ព្រោះដូច្នោះ ពួកយើងមិនគប្បីពោលរឿងនេះដោយជឿពួកគេ ព្រោះថា សមណៈទាំងឡាយ ដឹងបានលំបាក ។ ចាប់តាំងអំពីនោះ ពួកមនុស្សក៏វៀរចាកការពោលទោសនោះ ។

ឯព្រះរាជា បញ្ជាពួករាជបុរសដើម្បីស៊ើបដល់បុគ្គលដែលសម្ងាប់នាងសុន្ទរី ។ សម័យនោះឯង ពួកអ្នកលេងទាំងនោះ យកកហាបណៈទាំងនោះទិញស្រាផឹក បង្អួតជម្លោះ ។ បណ្តាអ្នកលេងទាំងនោះ បុរសម្នាក់និយាយ

នឹងបុរសម្នាក់ថា ឯងសម្លាប់នាងសុន្ទរី ដោយការវាយឲ្យស្លាប់ ហើយកប់ក្នុងគំនរសំរាម យកកហាបណៈដែលបានអំពីការស៊ីឈ្នួលនោះ ទិញស្រោមជើកជើកចុះអាសម្លាញ់ ។ ពួករាជបុរសបានឮដូច្នោះហើយ ទើបចាប់ពួកអ្នកលេងទាំងនោះ ថ្វាយដល់ព្រះរាជា ព្រះរាជាត្រាស់សួរពួកអ្នកលេងទាំងនោះថា ពួកអ្នកសម្លាប់នាងសុន្ទរីឬ ។ ពួកអ្នកលេងទូលថា បពិត្រព្រះអង្គ ទូលបង្គំសម្លាប់ ។ ព្រះរាជាត្រាស់សួរថា អ្នកណាជួលពួកអ្នកឲ្យសម្លាប់ ។ ពួកអ្នកលេងក្រាបទូលថា បពិត្រព្រះអង្គ គឺពួកតិរ្ថិយ ។ ព្រះរាជា ត្រាស់ឲ្យហៅពួកតិរ្ថិយមកហើយ ទើបឲ្យទទួលជីងរឿងនោះ ហើយទ្រង់បញ្ជាថា ពួកអ្នកចូរត្រាច់ទៅពេញព្រះនគរ និយាយយ៉ាងនេះថា ពួកខ្ញុំមានបំណងនឹងលើកទោសព្រះសមណគោតម ទើបបានសម្លាប់នាងសុន្ទរីនេះ ព្រះគោតមមិនមានទោស សាវ័ករបស់ព្រះគោតមក៏មិនមានទោស ពួកខ្ញុំប៉ុណ្ណោះមានទោស ។ តិរ្ថិយទាំងនោះ បានធ្វើយ៉ាងនោះ ។ មហាជនជឿយ៉ាងពិតប្រាកដ ហើយនាំគ្នាតិះដៀលពួកតិរ្ថិយ ។ ពួកតិរ្ថិយបានទទួលទោសទណ្ឌ ព្រោះសម្លាប់មនុស្ស ចាប់តាំងអំពីនោះមក ព្រះពុទ្ធ និងព្រះភិក្ខុសង្ឃ មានសក្ការៈ និងការគោរពរាប់អានសន្ធឹកសន្ធាប់ហួសប្រមាណ ។ ពួកភិក្ខុកើតអស្ចារ្យក្នុងចិត្ត ទើបចូលទៅគាល់ព្រះមានព្រះភាគ ហើយប្រកាសការត្រេកអររបស់ខ្លួនឲ្យទ្រង់ជ្រាប ។ ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ សម្ពហុលា ភិក្ខូ ។បេ។ អន្តរហិតោ ភវេ្ត សោ សទ្ទោ** *ជួច្នេះជាដើម ។*

ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគមិនត្រាស់ប្រាប់ដល់ពួកភិក្ខុថា នេះ

ជាការធ្វើរបស់ពួកតិរ្ថិយ ។ ឆ្លើយថា ព្រោះការប្រាប់ដល់អរិយសាវ័កមុន មិនមានប្រយោជន៍ទ្បើយ តែក្នុងពួកបុថុជ្ជនមិនគ្រាស់ប្រាប់ ដោយទ្រង់ព្រះតម្រិះថា កម្មរបស់ពួកជនដែលមិនជឿនោះ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ដើម្បីទុក្ខអស់កាលយូរ ។ ម្យ៉ាងទៀត ការដែលគ្រាស់ប្រាប់រឿងនេះ ដែលមិនទាន់មកដល់ ដែលព្រះពុទ្ធទាំងឡាយ ទ្រង់មិនធ្លាប់ប្រព្រឹត្តមកទ្បើយ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ប្រកាសបក្ខពួកនៃសង្កិលេស ចំពោះទ្រង់សម្តែងមកដោយលំដាប់ ។ បុគ្គលណាម្នាក់ មិនអាចនឹងឲ្យឱកាសដែលខ្លួនធ្វើកម្មហើយ វិលត្រឡប់មកបាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ប្រថាប់គង់ពិចារណាមើលនូវការពោលទោស និងហេតុនៃការពោលទោសដោយឧបេក្ខា សមដូចព្រះតម្រាស់ដែលត្រាស់ថា

> *បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលស្ថិតនៅហើយ គប្បីរួចចាកបាបកម្មបាននោះ មិនដែលមានទ្បើយ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងដល់រឿងនេះថា កាលពោលដោយការកាត់បង់នូវសេចក្តីស្រឡាញ់ ពាក្យអាក្រក់ដែលពាលជនឲ្យប្រព្រឹត្តទៅហើយ ឈ្មោះថាជាការអត់ធន់បានលំបាកសម្រាប់ធីរជន ដែលប្រកបដោយកម្លាំងនៃខន្តី រមែងមិនមាន ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ដែលប្រកាសកម្លាំងនៃអធិវាសនខន្តី ។*

បណ្តាបទទាំងនោះ បទថា **តុឆ្តិ វាចាយ ជនា អសញ្ញតា សរេហិ សង្គ្រាមគតំវ កុញ្ជរំ** *សេចក្តីថា ពួកពាលជន ឈ្មោះថា មិនសង្រួម គឺដែលជីកនាំមិនបាន ព្រោះមិនមានសំវរៈណាមួយ មានកាយសំវរៈជាដើម រមែងចាក់ធ្លុះ គឺចាក់ធ្លុះដោយលំពែង គឺវាចា ដូចទាហានដែលជាសត្រូវ ចាក់នូវជ័រកុញ្ជរ គឺជ័រដ៏ប្រសើរចូលក្នុងសង្គ្រាម គឺក្នុងសមរភូមិដោយព្រួញដែលលាបដោយថ្នាំពិស ។ នេះជាសភាវៈរបស់ពាលជនទាំងនោះ ។ បទថា* **សុត្វាន វាក្យំ ជរុសំ ឧទីរិតំ អធិវាសយេ ភិក្ខុ អនុទ្ធចិត្តោ** *សេចក្តីថា ភិក្ខុជម្រះនូវពាក្យ គឺពាក្យគ្រោតគ្រាតដែលពាលជននោះបន្ទឺ គឺពោល បានដល់ ឲ្យប្រព្រឹត្តទៅដោយអំណាចការប៉ះខូចនូវសេចក្តីស្រឡាញ់ដែលមិនពិត ដោយសេចក្តីពិត រឭកដល់ឱវាទដែលឧបមាដោយវណ្ណៈរបស់ព្រះតថាគត ដែលមានចិត្តមិនប្រទូស្ត សូម្បីតិចតួច ជាអ្នកមានប្រក្រតីឃើញភ័យក្នុងសង្សារថា នេះមានសង្សារជាសភាវៈ គប្បីអត់ធន់ គឺគប្បីតាំងនៅក្នុងអធិវាសនខន្តី ។ ក្នុងសេចក្តីនេះ មានអ្នកចោទសួរថា ព្រះសាស្តាមានបុញ្ញសម្ភារដ៏បរិបូណ៌ ដែលទ្រង់សន្សំមកដោយគោរព អស់កាលប្រមាណមិនបាន ទ្រង់បានទទួលការពោលទោសដែលមិនពិត ដែលខ្ពាំងក្លាដល់ម្ល៉េះ នុ៎ះជាកម្មអ្វី ខ្ញុំនឹងធ្វើយតទៅ*

ព្រះមានព្រះភាគអង្គនោះ ធ្លាប់ជាព្រះពោធិសត្វក្នុងអតីតជាតិ ជាអ្នកលេង ឈ្មោះថា មុនាឡិ សេពតែមិត្រអាក្រក់ ច្រើនទៅដោយអយោនិសោមនសិការ ។ ថ្ងៃមួយ ឃើញព្រះបច្ចេកពុទ្ធព្រះនាមសុរភី កំពុងដណ្តប់ចីវរដើម្បីចូលទៅបិណ្ឌបាតក្នុងព្រះនគរ ។ ក្នុងសម័យនោះ ស្រីម្នាក់ដើរទៅមិន

ឆ្ងាយអំពីព្រះបច្ចេកពុទ្ធ អ្នកលេងនោះពោលទោសថា សមណៈនេះ មិនមែនជាអ្នកប្រព្រឹត្តព្រហ្មចរិយៈ ដោយកម្មនោះ ទើបធ្លាក់ក្នុងនរកច្រើនសែនឆ្នាំ ព្រោះសេសនៃវិបាកកម្មនោះឯង បានជាព្រះពុទ្ធក្នុងកាលឥឡូវនេះ ក៏ត្រូវពោលទោស ព្រោះហេតុនៃនាងសុន្ទរី ក្នុងសេចក្តីនេះ យ៉ាងណា ទុក្ខមានការពោលជាដើម ដែលស្រីធ្វើអាការប្លែក មាននាងចិញ្ចមាណវិកាជាដើម ឲ្យប្រព្រឹត្តទៅហើយដល់ព្រះមានព្រះភាគ ទាំងអស់នោះ ជាវិបាកដែលសល់អំពីកម្ម ដែលទ្រង់ធ្វើហើយក្នុងកាលមុន ទើបហៅថា **កម្មបិលោតិក** *សមដូចព្រះតម្រាស់ដែលត្រាស់ក្នុងអបទានថា*

> *ព្រះលោកនាយក មានភិក្ខុសង្ឃច្រើន ចោមរោម ទ្រង់គង់លើផ្ទៃនៃថ្ម ជាទីរកវាយ ជិតស្រះអនោតត្ត រុងរឿងដោយរតនៈផ្សេងៗ ក្នុងចន្លោះនៃព្រៃ មានកិនផ្កាផ្សេងៗ ទ្រង់ព្យាករនូវបុព្វកម្ម របស់ព្រះអង្គ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវអំពើរបស់តថាគត ដែលបានធ្វើទុកមកហើយ ដូចតទៅនេះ តថាគតបានឃើញនូវភិក្ខុមួយរូបនៅក្នុងព្រៃ ហើយបានប្រគេនកំណាត់សំពត់ ។ ក្នុងកាលនោះ តថាគតបានប្រាថ្នា ជាព្រះសម្ពុទ្ធ ជាដំបូង ដើម្បីការត្រាស់ដឹង ឯសេចក្តីប្រាថ្នានោះ ក៏ឲ្យផលក្នុងការបានត្រាស់ជាព្រះពុទ្ធ ដោយអំណាចនៃបិលោតិកម្ម ។ ក្នុងកាលមុន តថាគត កើតជានាយគោបាល កៀងមេគោទៅ*

កាន់ទីគោចរ បានឃើញមេគោ កំពុងផឹកទឹកល្អក់ ហើយ ដេញចេញ ។ ដោយវិបាកនៃកម្មនោះ ក្នុងបច្ឆិមភពនេះ តថាគតស្រែកទឹក ហើយមិនបានផឹក ដូចសេចក្តីប្រាថ្នា ។ កាលភពមុន ក្នុងជាតិជទៃ តថាគតជាអ្នកលេង ឈ្មោះ បុនាលិ បានពោលបង្កាច់នូវព្រះបច្ចេកពុទ្ធ ព្រះនាមសុរភី ព្រះអង្គជាបុគ្គលមិនប្រទូស្តឡើយ ។ ដោយវិបាកនៃកម្មនោះ តថាគតអន្ទោលទៅក្នុងនរក អស់កាលជ័យូរ រងទុក្ខវេទនា អស់ពាន់នៃឆ្នាំជ័ច្រើន ។ ដោយសំណល់នៃកម្មនោះ ក្នុង បច្ឆិមភពនេះ តថាគតបាននូវការពោលបង្កាច់ ព្រោះហេតុ នៃនាងសុន្ទរិកា ។ មួយទៀត តថាគតពោលបង្កាច់សាវ័ក ឈ្មោះនន្ទ របស់ព្រះពុទ្ធ ទ្រង់គ្របសង្កត់ នូវសត្វលោក ទាំងពួង តថាគតបានអន្ទោលទៅក្នុងនរក អស់កាលជ័យូរ ព្រោះការពោលបង្កាច់ នូវសាវ័កនោះ ។ តថាគតបាន អន្ទោលទៅក្នុងនរក អស់កាលជ័យូរ ចំនួនមួយហ្មឺនឆ្នាំ លុះ តថាគត បានមកជាមនុស្ស ក៏បាននូវការពោលបង្កាច់ជា ច្រើន ។ ដោយសំណល់នៃកម្មនោះ នាងចិញ្ចមានវិកាមក ពោលបង្កាច់តថាគត ក្នុងប្រជុំជន ដោយពាក្យមិនពិត ។ តថាគតកើតជាព្រាហ្មណ៍ តែងជាអ្នកចេះមន្ត មានគេធ្វើ សក្ការបូជា បង្ហាញមន្តដល់មាណព ៥០០ នាក់ក្នុងព្រៃធំ ។

ឥសីកិម: បានអភិញ្ញា ៥ មានឫទ្ធិច្រើន មកក្នុងទីនោះ តថាគត បានឃើញឥសីនោះ លោកជាអ្នកមិនប្រទូស្តនិមន្តមក ក៏បានពោលបង្គាប់ ។ លំដាប់នោះ តថាគតនិយាយនឹងពួកសិស្សថា ឥសីនេះ ជាអ្នកបរិភោគកាម កាលតថាគតនិយាយប្រាប់ ឯពួកមាណព ក៏បានរីករាយតាម ។ លំដាប់នោះ មាណពទាំងអស់ គ្រាច់ទៅសូមក្នុងត្រកូលតូចធំ និយាយប្រាប់មហាជនថា ឥសីនេះ ជាអ្នកបរិភោគកាម ។ ដោយវិបាកនៃកម្មនោះ ភិក្ខុទាំងអស់ចំនួន ៥០០ នេះ ក៏បានទទួលការពោលបង្គាប់ ព្រោះហេតុនៃនាងសុន្ទរិកា ។ កាលកាលមុន តថាគតសម្លាប់បងប្រុសម្នាក់ មានមាតាផ្សេងគ្នា ព្រោះហេតុនៃទ្រព្យ ហើយបោះចោលទៅក្នុងជ្រោះភ្នំឲ្យប៉ះនឹងថ្ម ។ ដោយវិបាកនៃកម្មនោះ ទេវទត្តបានប្រមៀលថ្ម ដុំថ្មក៏រមៀលមកប៉ះអង្គុដ្ឋបាទ (មេជើង) នៃតថាគត ។ កាលពីជាតិមុន តថាគតជាទាវក កំពុងលេងក្នុងផ្លូវធំ បានឃើញព្រះបច្ចេកពុទ្ធ ក៏ជុតព្រៃទាំងមូល ក្បែរផ្លូវ ។ ដោយវិបាកនៃកម្មនោះ ក្នុងបច្ឆិមភពនេះ ទេវទត្តក៏ប្រើខ្នាន់ធ្នូ ឲ្យសម្លាប់តថាគត ។ កាលពីជាតិមុន តថាគតកើតជាហ្វូងដីរ បានបរដីរបំព្រេចព្រះបច្ចេកមុនីដ៏ឧត្តម ព្រះអង្គកំពុងគ្រាច់ទៅដើម្បីបិណ្ឌបាត ។ ដោយវិបាកនៃកម្មនោះ ដីរនាឡាគិរីចុះប្រេង

កាច ចូលមកព្រេចតថាគតក្នុងគិរិព្វជបុរីដ៏ប្រសើរ (រាជ-គហៈ) ។ តថាគតកើតជាស្តេច ឈ្មោះបត្តិកៈ បានយកលំពែងសម្លាប់បុរសទាំងឡាយ ដោយវិបាកនៃកម្មនោះ តថាគត ឆេះក្នុងភ្លើងនរកក្លាខ្លាំង ។ ដោយសំណល់នៃកម្មនោះ ក្នុងកាលឥឡូវនេះ កម្មវិបាកនោះ ក៏ធ្វើឲ្យរបកស្បែកជើងទាំងអស់ របស់តថាគត ព្រោះថា កម្មនៅតែមិនទាន់វិនាស ។ តថាគតកើតជាទាវកនៃព្រានត្រី ក្នុងកេវដ្តគ្រាមបានឃើញពួកជនអ្នកសម្លាប់ត្រី ក៏កើតសោមនស្ស ។ ដោយវិបាកនៃកម្មនោះ ស្តេចវិជជុកៈសម្លាប់ពួកសក្យៈ ក្នុងកាលណា ទុក្ខក្នុងក្បាលក៏មានដល់តថាគត (ក្នុងកាលនោះ) ព្រោះពួកសក្យៈ ត្រូវគេសម្លាប់ ។ តថាគតបានពោលផ្តន្ទានូវពួកសាវ័កក្នុងសាសនា នៃព្រះពុទ្ធព្រះនាមផុស្សៈថា ចូរលោកទាំងឡាយ ទំពាស៊ី បរិភោគ នូវបាយដំណើបចុះ កុំបរិភោគនូវបាយស្រូវសាលីឡើយ ។ ដោយវិបាកនៃកម្មនោះ ក្នុងកាលនោះ តថាគតនៅក្នុងស្រុកវេរញ្ជា ព្រាហ្មណ៍និមន្តឲ្យឆាន់តែបាយដំណើបអស់ ៣ ខែ ។ តថាគតបានហាមឃាត់កូនអ្នកចំបាប់ ក្នុងកាលដែលគ្មានព្រះពុទ្ធត្រាស់ ដោយវិបាកនៃកម្មនោះ ជំងឺខ្នងក៏កើតឡើងដល់តថាគត ។ តថាគតកើតជាពេទ្យ បានដាក់ថ្នាំបញ្ចុះសេដ្ឋីបុត្ត ដោយវិបាកនៃកម្ម

នោះ ជំងឺចុះឈាមក៏កើតឡើងដល់តថាគត ។ ក្នុងកពមួយ នោះ តថាគតកើតជាជោតិបាល បានផ្ទួញ់ផ្ទាល់ព្រះសុគត ព្រះនាមកស្សបៈថា ព្រោះអ្វីក៏ថាត្រាស់ដឹងពោធិញ្ញាណជាទីផ្ទរផង់ គេរកបានដោយកម្រៃក្រៃលែង ។ ដោយវិបាកនៃកម្មនោះ តថាគតប្រព្រឹត្តទុក្ករកិរិយាជាច្រើន ក្នុងឧរុវេល-ប្រទេសអស់ ៦ វស្សា ទើបបានត្រាស់ដឹងឡើង ។ តថាគត មិនបានទូវពោធិញ្ញាណដ៏ឧត្តម ដោយផ្លូវនុ៎ះទេ តថាគត ហេតុតែបុព្វកម្មនោះ ជាស់តឿន ក៏ស្វែងរកតាមផ្លូវខុស ។ តថាគតមានបុណ្យ និងជាបអស់រលីងហើយ បានវៀរបង់ នូវកម្ដៅទាំងពួង មិនមានសេចក្ដីសោក មិនមានសេចក្ដី ចង្អៀតចង្អល់ មិនមានអាសវៈ នឹងបរិនិព្វាន ។ ព្រះជិនស្រី ទ្រង់ដល់នូវអភិញ្ញា និងពលទាំងពួង បានព្យាករដោយ សេចក្ដីពិស្តារ ដល់ភិក្ខុសង្ឃ ជិតមហាស្រះឈ្មោះអនោតត្ត ដូចរៀបរាប់មកនេះឯង ॥

អដ្ឋកថា សុន្ទរីសូត្រទី ៨ ចប់

សុត្តន្តបិដក

ឧបសេនវង្គន្តបុត្តសូត្រ

[១០៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះឧបសេនវង្គន្តបុត្តដ៏មានអាយុ ទៅក្នុងទីស្ងាត់ហើយសម្ងំនៅ មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា ឱហ្ន៎ អញពេញជាមានលាភ ឱហ្ន៎ អញពេញជាបានល្អ (ព្រោះ) ព្រះមានព្រះភាគ ជាគ្រូអញ ព្រះអង្គជាព្រះអរហន្ត-សម្មាសម្ពុទ្ធផង អញក៏បានចេញចាកផ្ទះចូលទៅកាន់ផ្នួស ក្នុងធម្មវិន័យដែលព្រះមានព្រះភាគ ត្រាស់ទុកដោយប្រពៃផង ពួកសព្រហ្មចារីរបស់អញជាអ្នកមានសីល មានកល្យាណធម៌ផង អញជាអ្នកធ្វើឲ្យពេញលេញ ក្នុងសីលទាំងឡាយផង អ្នកមានចិត្តតាំងមាំល្អ មានចិត្តមូលនឹងក្នុងអារម្មណ៍តែមួយផង ជាអរហន្តខីណាស្រពផង អ្នកមានឫទ្ធិច្រើន មានអានុភាពច្រើនផង រស់នៅក៏ចម្រើន ស្លាប់ក៏ចម្រើន ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់សេចក្តីត្រិះរិះ ក្នុងចិត្តរបស់ព្រះឧបសេនវង្គន្តបុត្តដ៏មានអាយុដោយព្រះហឫទ័យរបស់ព្រះអង្គហើយ ទើបទ្រង់បន្ទឺឧទាននេះក្នុងវេលានោះថា

ជីវិតរបស់បុគ្គលណា មិនក្តៅក្រហាយ បុគ្គលនោះ រមែងមិនសោក ក្នុងកាលជិតស្លាប់ ប្រសិនបើអ្នកប្រាជ្ញនោះឯង បានឃើញបទ គឺព្រះនិព្វាន រមែងមិនសោក ក្នុងកណ្តាលពួកអ្នកសោកឡើយ ។

ភិក្ខុបានគាស់រម្លើងតណ្ហា ក្នុងភព មានចិត្តស្ងប់ មានជាតិសង្សារអស់ហើយ ភពថ្មីទៀត មិនមានដល់ភិក្ខុហើយ ។ សូត្រទី ៩ ។

អដ្ឋកថា

ឧបសេនវង្គន្តបុត្តសូត្រ

ឧបសេនវង្គន្តបុត្តសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ

[១០៨] បទថា **ឧបសេនោ** ក្នុងបទថា **ឧបសេនស្ស** នេះ ជាឈ្មោះរបស់ព្រះថេរៈ ។ ព្រោះលោកជាបុត្ររបស់វង្គន្តព្រាហ្មណ៍ ទើបគេហៅថា វង្គន្តបុត្រ ។

សេចក្តីពិស្តារថា ព្រះថេរៈនេះ ជាប្អូនប្រុសរបស់ព្រះសារីបុត្រ បួសក្នុងព្រះសាសនា កាលទ្រង់មិនទាន់បញ្ញត្តសិក្ខាបទ ឧបសម្បទាបាន ២ វស្សា ធ្វើជាឧបជ្ឈាយ៍ បានបំបួសភិក្ខុមួយរូប នាំភិក្ខុនោះទៅឧបដ្ឋាកព្រះមានព្រះភាគ ត្រូវព្រះមានព្រះភាគត្រាស់សួរ ដឹងថា ភិក្ខុនោះ ជាសទ្ធិវិហារិករបស់លោកហើយ ទ្រង់តិះដៀលដោយនយដែលមកក្នុងខន្ធកៈថា ម្នាលមោឃបុរស អ្នកវិលមក ដើម្បីភាពជាអ្នកប្រាថ្នាច្រើន គឺទាក់ទងដោយគណៈ ជាអ្នកមានចិត្តសង្វេគ ដូចសេះដែលវាយដោយត្មោង ទើបកើតឧស្សាហ៍ឡើងថា ឥឡូវនេះ អញអាស្រ័យបរិស័ទ ត្រូវព្រះមានព្រះភាគទ្រង់តិះដៀល ក៏ព្រោះអាស្រ័យបរិស័ទដូចគ្នា ទើបបានទទួលការសរសើរ ដូច្នេះហើយ ទើបសមាទានធុតធម៌ទាំងអស់ ផ្តើមចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានអភិញ្ញា ៦ សម្រេចបដិសម្ភិទា ជាព្រះមហាខីណាស្រព ឲ្យនិស្សិតរបស់ខ្លួនទ្រទ្រង់ធុតង្គដូចគ្នា មួយអន្ទើដោយនិស្សិតទាំងនោះ ចូលទៅគាល់ព្រះមានព្រះភាគ បានទទួលការសរសើរអំពីសម្ពាក់របស់ព្រះមានព្រះភាគ ទាក់ទងដោយបរិស័ទ

ដោយន័យដែលមកហើយ ក្នុងសន្ទតសិក្ខាបទថា ម្នាលឧបសេន បរិស័ទ
របស់អ្នកគួរជ្រះថ្លា ទើបទ្រង់ស្ថាបនាក្នុងឯតទគ្គ:ថា ម្នាលភិក្ខុទាំងឡាយ
ពួកភិក្ខុអ្នកមានសេចក្តីជ្រះថ្លាគ្រប់គ្រាន់ ស្រេចនឹងឧបសេនវង្គន្តបុត្ត ប្រសើរ
ជាងគេ ក្នុងបណ្តាមហាសាវ័ក ៨០ រូប ក៏មានមួយរូប នៅក្នុងនោះដែរ ។
ថ្ងៃមួយ លោកត្រឡប់អំពីបិណ្ឌបាត ក្រោយបច្ចាភត្ត កាលពួកអន្តេវាសិក
ទៅកាន់ទីសម្រាកពេលថ្ងៃរៀងៗ ខ្លួន ទើបកាន់យកទឹកអំពីឆ្នាំងលាងជើង រួច
លាបខ្លួនឲ្យត្រជាក់ លាតកម្រាលស្បែកអង្គុយសម្រាកក្នុងពេលថ្ងៃ ពិចា-
រណាគុណរបស់ខ្លួន ។ ពួកនិស្សិតរបស់លោកច្រើនរយច្រើនពាន់ នាំគ្នា
ទំនុកបម្រុងលោកមិនដាច់ ។ លោកបញ្ជូនមនសិការ ឆ្ពោះគុណរបស់ព្រះ
មានព្រះភាគថា ដំបូង គុណរបស់សាវ័កនៃព្រះតថាគត គង់មានប្រមាណ
ដល់ម្ដែ: ចំណង់បើគុណរបស់ព្រះសាស្តា តើក្រៃលែងយ៉ាងណាទៅហ្នឹ ។
ពួកនិស្សិតទាំងនោះ ច្រើនពាន់កោដិ នាំគ្នាទំនុកបម្រុងលោកតាមសមគួរដល់
កម្លាំងញាណ លោករពូកដល់ព្រះគុណរបស់ព្រះសាស្តា ដែលសមគួរដល់
ការ:ដែលប្រាកដច្បាស់ ដោយន័យជាដើមថា ព្រះសាស្តានៃយើង ទ្រង់មាន
សីលយ៉ាងនេះ មានធម៌យ៉ាងនេះ មានបញ្ញាយ៉ាងនេះ មានវិមុត្តិយ៉ាងនេះ និង
ដោយន័យជាដើមថា **ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ** បន្ទាប់អំពី
នោះ រពូកដល់ធម្មគុណ ដោយន័យជាដើមថា **ស្វាក្ខាតោ ភគវតា ធម្មោ**
និងគុណរបស់អរិយសង្ឆ ដោយន័យជាដើមថា **សុប្បដិបន្នោ ភគវតោ**
សាវកសង្ឆោ កាលគុណព្រះរតនត្រ័យប្រាកដច្បាស់ ដោយអាការយ៉ាងនេះ

ទើបព្រះមហាថេរ: មានចិត្តត្រេកអរ អង្គុយសោយបីតិ និងសោមនស្សដ៏ ឧឡារ មានរៅការ មានអាការជាអនេក ។ កាលសម្តែងដល់សេចក្តីនោះ ទើបលោកពោលពាក្យជាដើមថា គ្រានោះឯង ព្រះឧបសេនវង្គន្តបុត្តដ៏មានអាយុ ទៅក្នុងទីស្ងាត់ហើយ សម្ងំនៅ ។

បណ្តាបទទាំងនោះ បទថា **រហោគតស្ស** ប្រែថា នៅក្នុងទីស្ងាត់ ។ បទថា **បដិសល្លីនស្ស** ចានដល់ ជាបុគ្គលឯកោ ។ បទថា **ឯវំ ចេតសោ បរិវិតក្ពោ ឧទបាទិ** សេចក្តីថា ការត្រិះរិះនៃចិត្តដែលមានអាការដូចពោលក្នុងឥឡូវនេះ កើតឡើងហើយដោយអាការយ៉ាងនេះ ។ បទថា **លាភា វត មេ** សេចក្តីថា ការបានអត្តភាពជាមនុស្ស ការកើតឡើងនៃព្រះពុទ្ធ ការមានសទ្ធា និងការសម្រេចមគ្គផលជាដើមនោះ ចាត់ជាលាភរបស់អាត្មាអញ ដែលគួរអស្ចារ្យពិតហ្នឹ ។ បទថា **សុលទ្ធំ វត មេ** សេចក្តីថា ការសម្រេចបព្វជ្ជា-ឧបសម្បទា និងការចូលទៅអង្គុយជិតព្រះរតនត្រ័យជាដើម តថាគតបានហើយ ក្នុងព្រះសាសនារបស់ព្រះមានព្រះភាគនេះ អាត្មាអញបានល្អហើយហ្នឹ ។ លោកពោលហេតុនោះ ដោយន័យជាដើមថា **សត្តា ច មេ** ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សត្តា ច មេ** ជាដើមនោះ ឈ្មោះថា **សត្តា** ព្រោះទូន្មានពួកសត្វតាមសមគួរ ដោយប្រយោជន៍ក្នុងភពនេះ ប្រយោជន៍ក្នុងភពខាងមុខ និងបរមត្ថប្រយោជន៍ ។ ឈ្មោះថា **ភគវា** ព្រោះមានភាពជាបុគ្គលមានភាគធម៌ជាដើម ។ ឈ្មោះថា **អរហំ** ព្រោះជាអ្នកឆ្ងាយចាកកិលេសទាំងឡាយ ១ ព្រោះជាអ្នកកម្ចាត់នូវកាំនៃសង្សារចក្រ ១ ព្រោះកម្ចាត់សត្រូវ

គឺកិលេស ១ ព្រោះជាបុគ្គលសមគួរដល់សក្ការៈ មានបច្ច័យជាដើម ១ ព្រោះមិនធ្វើបាបក្នុងទីស្ងាត់ ១ ឈ្មោះថា **សម្មាសម្ពុទ្ធោ** *ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ក្នុងទីនេះ មានសេចក្តីសង្ខេបប្រមាណប៉ុណ្ណេះ[1] ។ បទថា* **សុវាក្ខាតេ** *ប្រែថា ត្រាស់ល្អហើយ គឺ ត្រាស់នាំសត្វចេញចាកទុក្ខដោយចំណែក ១ ។ បទថា* **ធម្មវិនយេ** *បានដល់ បាវចនៈ ។ ពិតហើយ បាវចនៈនោះ លោកហៅថា ធម្មវិនយ ព្រោះទ្រទ្រង់នូវបុគ្គលបដិបត្តិតាមពាក្យប្រៀនប្រដៅ មិនឲ្យធ្លាក់ទៅក្នុងសង្សារទុក្ខ ព្រោះកម្ចាត់កិលេស មានរាគៈជាដើម ។ បទថា* **ព្រហ្មចារិនោ** *សេចក្តីថា ឈ្មោះថា* **ព្រហ្មចារី** *ព្រោះប្រព្រឹត្ត គឺបដិបត្តិស្មើនូវសាសនា គឺព្រហ្ម ព្រោះអត្ថថា ប្រសើរ បានដល់ អរិយមគ្គសច្ចរបស់ព្រះមានព្រះភាគ ។ បទថា* **សីលវន្តោ** *បានដល់ ជាអ្នកមានសីល គឺសីលក្នុងមគ្គ និងសីលក្នុងផល ។ បទថា* **កល្យាណធម្មា** *សេចក្តីថា ឈ្មោះថា កល្យាណធម៌ ព្រោះមានធម៌ស្អាតដូចជា សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈ ដោយពាក្យនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងបដិបទាដែលល្អដល់ព្រះសង្ឃ ។ ដោយបទថា* **សីលេសុ ចម្ហិ បរិបូរិការី** *នេះ ព្រះមានព្រះភាគត្រាស់ថា សូម្បីតថាគតបួសហើយ ក៏មិនបានពោលតិរច្ឆានកថា ជាអ្នកច្រើនទៅដោយសេចក្តីព្យាយាមដ៏មាំទាំ ដោយពិត តថាគតបំពេញសីលទាំង ៤ មានបាតិមោក្ខសំវរសីលជាដើម មិនឲ្យដាច់ មិនឲ្យធ្លុះ មិនឲ្យពពាល មិនឲ្យពព្រុស ឲ្យជាទេយ្យ ឲ្យជាសីល*

---

[1]សេចក្តីពិស្តារសូមរកមើលក្នុងពុទ្ធានុស្សតិនិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គឯណោះចុះ ។

ដែលវិញ្ញូជនសរសើរ ឲ្យជាសីលដែលតណ្ហា និងទិដ្ឋិពាល់ត្រូវមិនបាន ឲ្យ សម្រេចចំពោះអរិយមគ្គប៉ុណ្ណោះ ។ ដោយពាក្យនេះ ទ្រង់សម្តែងដល់ការ ជល់ព្រមដោយអរិយផលទាំង ២ របស់ព្រះអង្គ ។ ពិតហើយ ព្រះសោតា-បន្ន និងព្រះសកទាគាមី ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ។ បទថា **សុសមាហិតោ ចម្ហិ ឯកគ្គចិត្តោ** *សេចក្តីថា តថាគតជាអ្នកមានចិត្តតាំងមាំ ដោយសមាធិ មានឧបចារៈ និងអប្បនា និងជាអ្នកមានចិត្តមិនរាយមាយ ដោយប្រការទាំងពួង ។ ដោយពាក្យ គឺភាពជាបុគ្គលធ្វើឲ្យបរិបូណ៌ ក្នុង សមាធិនេះ ទ្រង់សម្តែងដល់ការជល់ព្រម ដោយអរិយផលទី ៣ របស់ព្រះ អង្គ ។ ពិតហើយ ព្រះអនាគាមីជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ។ បទថា* **អរហា ចម្ហិ ខីណាសវោ** *សេចក្តីថា តថាគតជាបុគ្គលឈ្មោះថា ខីណាស្រព ព្រោះអាសវៈ មានកាមាសវៈជាដើមអស់ទៅ ដោយប្រការទាំងពួង ដោយ ហេតុនោះឯង ទើបតថាគតជាបុគ្គលឈ្មោះថា អស់កិលេសជាគ្រឿងចង់សត្វ ក្នុងភព និងឈ្មោះថា ជាព្រះអរហន្ត ព្រោះជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរក្នុង លោក និងទេវលោក ។ ដោយពាក្យនេះ ទ្រង់សម្តែងដល់ភាពដែលព្រះអង្គ ធ្វើករណីយកិច្ចខ្លះហើយ ។ បទថា* **មហិទ្ធិកោ ចម្ហិ មហានុភាវោ** *សេចក្តី ថា តថាគតឈ្មោះថា ជាអ្នកមានឫទ្ធិច្រើន ព្រោះប្រកបដោយភាពជាបុគ្គល មានជំនាញច្រើនក្នុងឫទ្ធិ មានការអធិដ្ឋាន និងមានការធ្វើអាការផ្សេងៗ ជា ដើម និងឈ្មោះថា មានអានុភាពច្រើន ព្រោះដល់ព្រមដោយបុញ្ញានុភាព និង គុណានុភាពដ៏ឱឡារ ។ ដោយពាក្យនេះ ទ្រង់សម្តែងដល់ការប្រកបដោយ*

លោកិយអភិញ្ញា និងអនុបុព្វវិហារសមាបត្តិ ៩ របស់ព្រះអង្គ ។ ពិតហើយ សាវ័កឈ្មោះថា ជាអរិយៈ ព្រោះជាអ្នកជំនាញក្នុងអភិញ្ញាទាំងឡាយ ឈ្មោះថា មានឫទ្ធិច្រើន ព្រោះញុំាងវត្ថុតាមដែលខ្លួនប្រាថ្នាឲ្យសម្រេច និងឈ្មោះថា មានអានុភាពច្រើន ព្រោះជម្រះសន្តានឲ្យបរិសុទ្ធ ដោយឧបនិស្សយសម្បត្តិក្នុងកាលមុន និងដោយវិហារសមាបត្តិផ្សេងៗ បទថា **ភទ្ទកំ មេ ជីវិតំ** *សេចក្តីថា កាយនេះរបស់តថាគត ប្រកបដោយគុណ មានសីលយ៉ាងនេះជាដើម តាំងនៅជរាបណា ប្រយោជន៍នោះឯង ក៏ចម្រើនដល់ពួកសត្វជរាបនោះ សូម្បីជីវិតរបស់តថាគត ក៏ឈ្មោះថា ចម្រើនល្អ ព្រោះថា ជាបុញ្ញក្ខេត្ត ដោយបទថា* **ភទ្ទកំ មរណំ** *នេះ ទ្រង់សម្តែងដល់ភាពជាតាទិបុគ្គល ក្នុងអត្ថទាំង ២ ថា បើបញ្ចក្ខន្ធនេះរលត់ទៅក្នុងថ្ងៃនេះ ឬក្នុងខណៈនេះឯង ដូចភ្លើងអស់កំញ្ជឹម ដូច្នោះ សូម្បីមរណៈ គឺបរិនិព្វានដែលមិនមានបដិសន្ធិរបស់តថាគតនោះ ក៏ឈ្មោះថា ជាការល្អ ដូច្នោះ ទើបព្រះមហាថេរៈត្រិះរិះដល់ភាពដែលខ្លួនមានសោមនស្សយ៉ាងឱឡារ ដោយការរាប់អានច្រើនក្នុងធម៌ និងដោយការសោយបីតិដែលកើតអំពីធម៌ ព្រោះខ្លួនលះនូវកាពក្រាស់ទៅដោយមានះក្នុងសោមនស្សមិនទាន់បាន ។*

ព្រះសាស្តា ប្រថាប់គង់នៅក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ជ្រាបរឿងនោះដោយព្រះសព្វញ្ញុតញ្ញាណ ទើបបន្ទឺឧទាននេះ ដែលប្រកាសភាពជាបុគ្គលនឹងធ៌ងរបស់លោកទាំងក្នុងជីវិត និងមរណៈ ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ ភគវា ។បេ។ ឧទានេសិ** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **យំ ជីវិតំ ន តបតិ** *សេចក្តីថា ជីវិតរមែងធ្វើបុគ្គលដែលជាព្រះខីណាស្រព មិនឲ្យក្តៅក្រហាយ គឺមិនឲ្យលំបាក ព្រោះការកើតឡើងនៃខន្ធតទៅ មិនមានដោយប្រការទាំងពួង ។ ម្យ៉ាងទៀត ជីវិតដែលជាបច្ចុប្បន្ននោះឯង រមែងមិនបៀតបៀន ព្រោះប្រកបដោយសតិសម្បជញ្ញៈ ក្នុងទីគ្រប់អន្ទឿ ព្រោះដល់នូវភាពបរិបូណ៌ដោយសតិបញ្ញា ព្រោះជីវិតនោះជាសង្ខតធម៌ ដោយប្រការទាំងពួង ។ ពិតហើយ អន្ធបុថុជ្ជនដែលសេពគប់បាបមិត្រ ច្រើនទៅដោយអយោនិសោមនសិការ មិនបំពេញកុសល មិនបំពេញបុណ្យ រមែងក្តៅក្រហាយដោយការក្តៅក្រហាយ មានក្តៅក្រហាយថា អញមិនបានធ្វើកម្មល្អហ្ន៎ជាជើម ព្រោះហេតុនោះ ទើបជីវិតរបស់បុគ្គលនោះធ្វើឲ្យបុគ្គលនោះក្តៅក្រហាយ ។ ឯបុគ្គលក្រៅអំពីនេះ ដែលមិនធ្វើបាប ធ្វើតែបុណ្យ ឬព្រះសេក្ខៈ ៧ ពួក និងកល្យាណបុថុជ្ជន រមែងមិនក្តៅក្រហាយដោយការក្តៅក្រហាយខាងក្រោយ ព្រោះវៀរចាកធម៌ជាទីតាំងនៃសេចក្តីក្តៅក្រហាយ ព្រោះប្រកបដោយធម៌ ដែលមិនជាទីតាំងនៃការក្តៅក្រហាយ ព្រោះដូច្នោះ ទើបជីវិតរបស់បុគ្គលទាំងនោះ មិនក្តៅក្រហាយ ។ ឯក្នុងព្រះខីណាស្រព មិនចាំបាច់ពោលឡើយ ព្រោះហេតុនោះ ទើបលោកចង់អត្តវណ្ណនាដោយអំណាចបវត្តិទុក្ខ ។ បទថា* **មរណន្តេ ន សោចតិ** *សេចក្តីថា ក្នុងទីបំផុត គឺក្នុងទីបំផុតដោយជុំវិញ ពោល គឺមរណៈ ក្នុងកាលជិតស្លាប់ បុគ្គលនោះរមែងមិនសោយសោក ព្រោះដកសេចក្តីសោកឡើងបាន ដោយអនាគាមិមគ្គនោះឯង ។ បទថា* **សវេ និដ្ឋបនោ ធីរោ សោលសមជ្ឈេ ន សោចតិ**

សេចក្តីថា បុគ្គលនោះឈ្មោះថា ឃើញនូវបទ ព្រោះឃើញបទធម៌ ៤ មាន អនកិរិយាជាដើម ឬឃើញព្រះនិព្វាននោះឯង ឈ្មោះថា ជាអ្នកប្រាជ្ញ គឺព្រះខីណាស្រព ព្រោះដល់ព្រមដោយបញ្ញា សូម្បីតាំងនៅត្រង់កណ្តាលពួកសត្វ ដែលមិនទាន់ប្រាសចាកវាគៈ ដែលបានឈ្មោះថា សោក ព្រោះមានសោក ជាធម៌ ឬក្នុងកណ្តាលនៃលោកធម៌ ដែលជាហេតុនៃសេចក្តីសោក រមែងមិនសោយសោក ។

ឥឡូវនេះ ដើម្បីសម្តែងភាពដែលភិក្ខុនោះ មិនមានហេតុនៃសេចក្តីសោក ដោយប្រការទាំងពួង ទើបត្រាស់ពាក្យជាដើមថា **ឧច្ឆិន្នភវតណ្ហស្ស** *ជាដូច្នេះ ។ ក្នុងពាក្យថា* **ឧច្ឆិន្នភវតណ្ហស្ស** *នោះ មានវិនិច្ឆ័យដូចតទៅនេះ ភវតណ្ហា ដែលបុគ្គលណាកាត់ដាច់ហើយ ដោយប្រការទាំងពួង ដោយអរហត្តមគ្គ បុគ្គលនោះ ឈ្មោះថា មានភវតណ្ហាកាត់ផ្តាច់ហើយ ។ ភិក្ខុនោះ គឺភិក្ខុដែលជាព្រះខីណាស្រព ឈ្មោះថា ជាអ្នកមានចិត្តស្ងប់ ព្រោះស្ងប់កិលេសដ៏សេសបានជាសមុច្ឆេទ ។ បទថា* **វិក្ខីណោ ជាតិសំសារោ** *សេចក្តីថា សង្សារ មានការកើតជាដើម ដែលមានលក្ខណៈដូចពោលហើយថា លំដាប់នៃខន្ធ ធាតុ អាយតនៈ ប្រព្រឹត្តទៅមិនដាច់ លោកហៅថា សង្សារ ដូច្នេះ អស់ហើយដោយពិសេស ។ ព្រោះហេតុអ្វី ព្រោះកពថ្មីរបស់ភិក្ខុនោះមិនមាន អធិប្បាយថា ព្រោះព្រះអរិយបុគ្គលនោះ គឺបែបនោះ មិនកើតតទៅទៀត ដូច្នោះ ទើបសង្សារ គឺការកើតរបស់លោកអស់ទៅ ។ ព្រោះហេតុអ្វី ទើបលោកមិនកើតទៀត គួរពោលទៀតថា ព្រោះលោកកាត់ភវតណ្ហាបានជាសមុច្ឆេទ និងជា*

បុគ្គលមានចិត្តស្ងប់ ។ ម្យ៉ាងទៀត គប្បីប្រកបសេចក្តីថា សង្ឃារ គឺជាតិអស់ហើយ ព្រោះហេតុនោះឯង ទើបលោកមិនកើតទៀត ។

អដ្ឋកថា ឧបសេនវង្គន្តបុត្តសូត្រទី ៩ ចប់

សុត្តន្តបិដក

សារិបុត្តសូត្រ

[១០៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ អង្គុយផ្គត់ភ្នែក តម្រង់កាយត្រង់ ពិចារណាការរម្ងាប់របស់ខ្លួន ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញព្រះសារីបុត្តដ៏មានអាយុ អង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ ពិចារណាការស្ងប់រម្ងាប់របស់ខ្លួន ក្នុងទីជិតព្រះអង្គ ។ លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ភិក្ខុអ្នកមានចិត្តស្ងប់រម្ងាប់ បានកាត់ផ្តាច់តណ្ហាសម្រាប់នាំទៅ (កាន់កព) មានជាតិសំសារអស់ហើយ ភិក្ខុនោះ បានផុតហើយចាកចំណងនៃមារ ។ សូត្រីទី ១០ ។

មេឃិយវគ្គទី ៤ ចប់

ឧទ្ទាននៃមេឃិយវគ្គនោះ គឺ

និយាយអំពីរឿងព្រះមេឃិយៈ ១ ពួកភិក្ខុដែលមានចិត្តអណ្តែតអណ្តូង ១ នាយគោបាល ១ ព្រះសារីបុត្តអង្គុយក្នុងទីវាលក្នុងរាត្រីខាងខ្នើត ១ ពុទ្ធនាគ និងហត្ថិនាគ ១ ជាគម្រប់ ៥ ព្រះបិណ្ឌាលការទ្វាជៈ ១ ព្រះសារីបុត្ត ១ នាងបរិព្វាជិកាឈ្មោះសុន្ទរី ១ ជាគម្រប់ ៨ ព្រះឧបសេនវង្គន្តបុត្ត ១ ព្រះសារីបុត្ត ១ រួមទាំងអស់នោះ ត្រូវជា១០ ។

អដ្ឋកថា

សារិបុត្តសូត្រ

សារិបុត្តសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ

[១០៩] *បទថា* **អត្តនោ ឧបសមំ** *សេចក្តីថា ការស្ងប់កិលេសរបស់ខ្លួនបានជាសមុច្ឆេទ ដោយអរហត្តមគ្គ ដែលជាហេតុនៃការសម្រេចទីបំផុតសាវកបារមីញាណ ។*

ព្រះសារីបុត្រឃើញប្រចក្សនូវការក្តៅក្រហាយ ការក្រវល់ក្រវាយ ការរោលរាល និងសេចក្តីទុក្ខដែលកើតអំពីកិលេស មានរាគៈជាដើម និងទុក្ខមានជាតិ ជរា ព្យាធិ មរណៈ សោក និងបរិទេវៈជាដើម មានអភិសង្ខារ គឺអភិសង្ខារជាហេតុនៃពួកសត្វដែលមិនទាន់ស្ងប់កិលេស ហើយពិចារណាទុក្ខមានវដ្តៈជាមូលនៃសត្វទាំងនោះ ទាំងក្នុងអតីត និងអនាគត ផ្សាយកុណ្ឌា

រឭកដល់ទុក្ខ មានប្រមាណមិនតិច ដែលខ្លួនធ្លាប់សោយ ក្នុងកាលជាបុថុជ្ជន ឬដែលមានកិលេសជាហេតុ ទើបពិចារណារឿយៗ នូវការស្ងប់កិលេសរបស់ខ្លួនថា កិលេសដែលជាហេតុនៃទុក្ខជាច្រើនឈ្មោះនេះ ឥឡូវនេះ អាត្មាអញលះបានជាសមុច្ឆេទហើយ ។ ម្យ៉ាងទៀត កាលពិចារណារមែងពិចារណាដល់ការស្ងប់កិលេសដោយពិត ដោយមគ្គញ្ញាណនោះៗ ថា កិលេសមានប្រមាណប៉ុណ្ណេះស្ងប់ហើយ ដោយសោតាបត្តិមគ្គ ប្រមាណប៉ុណ្ណេះស្ងប់ហើយដោយសកទាគាមិមគ្គ ប្រមាណប៉ុណ្ណេះស្ងប់ហើយដោយអរហត្តមគ្គ ។ ដោយហេតុនោះ ទើបលោកពោលថា **អត្តនោ ឧបសមំ បច្ចវេក្ខមនោ** *ដូច្នេះជាដើម អាចារ្យមួយពួកទៀតពោលថា ព្រះថេរៈចូលអរហត្តផលសមាបត្តិ ពិចារណាសមាបត្តិនោះហើយ ពិចារណាសេចក្តីស្ងប់រឿយៗ យ៉ាងនេះថា ការៈដែលឧបសមនេះ មានការស្ងប់ប្រណីត ព្រោះជាអារម្មណ៍នៃអសង្ខត-ធាតុ ដែលមានការស្ងប់ដោយឥតសេសសល់ ព្រោះស្ងប់កិលេសដោយប្រពៃដោយខ្លួនឯង ។ អាចារ្យពួកជទៃពោលថា ក្នុងទីនេះ អរហត្តផលដែលកើតក្នុងទីបំផុតនៃការស្ងប់កិលេសបានជាសមុច្ឆេទ ឈ្មោះថា* **ឧបសម** *លោកអង្គុយពិចារណាឧបសមនោះ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងដល់អត្ថ គឺការពិចារណាការលះកិលេស ដែលជាហេតុឲ្យព្រះសារីបុត្រមានបញ្ញាច្រើនជាដើម មិនទូទៅដល់សាវកជទៃ ក្នុងបណ្តាសាវកទាំងពួង ឬអរហត្ត-ផល ដែលពោលដោយបរិយាយនៃឧបសម ទើបទ្រង់បន្ទឺឧទាននេះ ដែល*

សម្តែងអានុភាពរបស់ឧបសមនោះ ។

បណ្តាបទទាំងនោះ បទថា **ឧបសន្តសន្តចិត្តស្ស** *សេចក្តីថា ឈ្មោះថា ជាអ្នកមានចិត្តស្ងប់រម្ងាប់ ព្រោះលោកជាអ្នកមានចិត្តស្ងប់រម្ងាប់នោះឯង ។ ពិតហើយ ចិត្តឈ្មោះថា ចូលទៅស្ងប់ ព្រោះកិលេសចូលទៅស្ងប់ ដោយសង្កត់សង្កិនបានដោយសមាបត្តិ ទើបលោកមិនពោលថា* **ឧបសន្តសន្តំ** *ប្រែថា ស្ងប់រម្ងាប់ដោយប្រការទាំងពួង ព្រោះឧបសមនោះ មិនទាន់ស្ងប់ដោយឥតសេសសល់ ព្រោះមិនដូចគ្នានឹងការស្ងប់ដោយអរហត្តមគ្គ ។ ឯចិត្តរបស់បុគ្គលដែលឈ្មោះថា ព្រះអរហន្ត ព្រោះលោកកាត់កិលេសបានជាសមុច្ឆេទនោះឯង ជាកិលេសដែលស្ងប់ដោយមគ្គខាងក្រោម ដែលសម្បយុត្តដោយសមថៈ និងវិបស្សនា ដោយជាការៈមិនចាំបាច់ស្ងប់កិលេសទៀត ទើបលោកហៅថា ស្ងប់រម្ងាប់ ព្រោះស្ងប់បានដោយឥតសេសសល់ ។*

ព្រោះហេតុនោះ ទើបលោកពោលថា ឈ្មោះថា មានចិត្តស្ងប់រម្ងាប់ ព្រោះលោកមានចិត្តស្ងប់រម្ងាប់នោះឯង ។ ម្យ៉ាងទៀត ឧបសម លោកហៅថា **ឧបសន្ត។** *ព្រោះដូច្នោះ បទថា* **ឧបសន្តសន្តចិត្តស្ស** *ទើបសំដៅសេចក្តីថា ជាអ្នកមានចិត្តស្ងប់ ដោយចូលទៅស្ងប់យ៉ាងក្រៃលែង ។ ម្យ៉ាងទៀត ព្រះសាស្តា កាលទ្រង់សម្តែងថា កាលព្រឹណាស្រពទាំងអស់ស្ងប់កិលេសបានជាសមុច្ឆេទ តែការស្ងប់កិលេសរបស់ព្រះធម្មសេនាបតី នៅមានពិសេសដែលជាហេតុដល់ទីបំផុតនៃសាវកបារមីញ្ញាណ មិនទូទៅដល់សាវកដទៃ ក្នុងបណ្តាសាវកទាំងឡាយ ទើបត្រាស់ឲ្យពិសេស ដោយ* **ឧបសន្ត** *សព្ទថា*

ឧបសន្តសន្តចិត្តស្ស។

ក្នុងសេចក្តីនោះ មានអធិប្បាយដូចតទៅនេះថា ចិត្តស្ងប់យ៉ាងក្រៃលែង គឺចិត្តមាំទាំ ឈ្មោះថា **ឧបសន្ត** គឺចិត្តដែលស្ងប់រម្ងាប់ដោយឧបសន្តចិត្តនោះឯង ឈ្មោះថា **ឧបសន្តសន្តចិត្ត។** ចិត្តរបស់លោកបែបនោះ ពាក្យទាំងអស់ដូចគ្នានឹងពាក្យដែលមានក្នុងកាលមុននោះឯង ។ ពិតហើយ ទើបព្រះមានព្រះភាគត្រាស់សរសើរព្រះសារីបុត្រនោះអនេកបរិយាយ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រមានបញ្ញាច្រើន មានបញ្ញាក្រាស់ មានបញ្ញាក្អៀវក្អា មានបញ្ញារហ័ស មានបញ្ញាមុត មានបញ្ញាជាហេតុត្រាស់ដឹង ។ បទថា **នេត្តិច្ឆិន្នស្ស** សេចក្តីថា ភវតណ្ហា លោកហៅថា **នេត្តិ** ព្រោះនាំសង្សារវដ្តទៅ ។ ឈ្មោះថា ជាអ្នកមាននេត្តិច្ឆន្ន ព្រោះលោកកាត់នេត្តិបានជាសមុច្ឆេទបានហើយ ។ របស់លោកអ្នកដែលមាននេត្តិជាច់ហើយនោះ អធិប្បាយថា ដែលលះតណ្ហាបានហើយ ។ បទថា **មុត្តោ សោ មារពន្ធនា** សេចក្តីថា បុគ្គលនោះ គឺបុគ្គលបែបនោះ បានដល់ បុគ្គលដែលមានកិលេសជាគ្រឿងទាក់សត្វទុកក្នុងភពទាំងមូលហើយ រួចផុតហើយចាកគ្រឿងនៃមារទាំងពួង លោកមិនមានកិច្ចដែលត្រូវធ្វើ ព្រោះលោកផុតចាកគ្រឿងចងនៃមារ ព្រោះដូច្នោះ ទើបព្រះធម្មសេនាបតីពិចារណាសេចក្តីស្ងប់របស់ខ្លួន ។ ពាក្យដ៏សេសមានន័យដូចបានពោលហើយនោះឯង ។

អដ្ឋកថា សារីបុត្តសូត្រទី ៩ ចប់

មេឃិយវគ្គទី ៤ ចប់

សុត្តន្តបិដក

ឧទានសោណត្ថេរវគ្គទី ៥

រាជសូត្រ

[១១០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុង វត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះ ព្រះបាទបសេនទិកោសល គង់នៅខាងលើប្រាសាទដ៏ប្រសើរ ជាមួយនឹងព្រះនាងមល្លិកាទេវី ។ គ្រានោះ ព្រះរាជាបសេនទិកោសល ទ្រង់សួរព្រះនាងមល្លិកាទេវីថា ម្នាលនាងមល្លិកា ចុះបុគ្គលដទៃណាមួយ ជាទីស្រឡាញ់ ជាងខ្លួននៃនាងមានដែរឬ ។ បពិត្រមហារាជ បុគ្គលដទៃណាមួយ ជាទីស្រឡាញ់ ជាងខ្លួនរបស់ខ្ញុំម្ចាស់ មិនមានទេ បពិត្រមហារាជ ចុះបុគ្គលដទៃណាមួយ ជាទីស្រឡាញ់ ជាងខ្លួនព្រះអង្គមានដែរឬ ។ ម្នាលនាងមល្លិកា បុគ្គលដទៃណាមួយ ជាទីស្រឡាញ់ ជាងខ្លួននៃយើង មិនមានទេ ។ លំដាប់នោះ ព្រះរាជាបសេនទិកោសល ទ្រង់យាងចុះអំពីប្រាសាទហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះព្រះរាជាបសេនទិកោសល គង់ក្នុងទីសមគួរហើយ ក៏តំណាលសេចក្តីនេះទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ ខ្ញុំព្រះអង្គនៅខាងលើប្រាសាទដ៏ប្រសើរជាមួយនឹងនាងមល្លិកាទេវី ហើយសួរនាងមល្លិកាទេវីថា ម្នាលនាងមល្លិកា ចុះបុគ្គលដទៃណាមួយ ជាទីស្រឡាញ់ជាងខ្លួននៃនាង មានដែរឬ លុះខ្ញុំព្រះអង្គ

សួរយ៉ាងនេះហើយ ទើបនាងមល្លិកាទេវីតបថា បពិត្រមហារាជ បុគ្គលដទៃណាមួយ ជាទីស្រឡាញ់ ជាងខ្លួនរបស់ខ្ញុំម្ចាស់ មិនមានទេ បពិត្រមហារាជ បុគ្គលដទៃណាមួយ ជាទីស្រឡាញ់ ជាងខ្លួនព្រះអង្គមានដែរឬ បពិត្រព្រះអង្គដ៏ចម្រើន លុះនាងមល្លិកាទេវី សួរយ៉ាងនេះរួចហើយ ខ្ញុំព្រះអង្គឆ្លើយនឹងនាងមល្លិកាទេវីថា ម្នាលនាងមល្លិកា បុគ្គលដទៃណាមួយ ជាទីស្រឡាញ់ជាងខ្លួននៃយើង មិនមានទេ ។ គ្រានោះ ព្រះមានព្រះភាគ ជ្រាបសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> បុគ្គលមានចិត្តរំពឹងរក គ្រប់ទិស ក៏មិនបានបុគ្គលជាទីស្រឡាញ់ជាងខ្លួន ក្នុងទីណាឡើយ ចំណែកខ្លួននោះ ទើបជាទីស្រឡាញ់ ច្រើនជាងបុគ្គលដទៃ យ៉ាងនេះ ព្រោះហេតុនោះ បុគ្គលអ្នកស្រឡាញ់ខ្លួន មិនត្រូវបៀតបៀនបុគ្គលដទៃឡើយ ។ សូត្រទី ១ ។

អដ្ឋកថា

មហាវគ្គទី ៥

រាជសូត្រ

រាជសូត្រទី ១ នៃមហាវគ្គទី ៥ មានវិនិច្ឆ័យដូចតទៅនេះ

[១១០] *បទថា* **មល្លិកាយ ទេវិយា សទ្ធឹ** *សេចក្តីថា ជាមួយព្រះមហេសីរបស់ព្រះអង្គព្រះនាមមល្លិកា ។ បទថា* **ឧបរិបាសាទវរគតោ** *បានដល់ ជាន់ខាងលើប្រាសាទដ៏ប្រសើរ ។ បទថា* **កោចញ្ញោ អត្តនា បិយតរោ** *សេចក្តីថា បុគ្គលដទៃណាម្នាក់ ដែលនាងគប្បីស្រឡាញ់ក្រៃលែងជាងខ្លួនមានឬ ។*

ព្រោះហេតុអ្វី ទើបព្រះរាជាត្រាស់សួរ ។ ព្រោះព្រះនាងមល្លិកានេះ ជាកូនស្រីនាយមាលាការក្រីក្រក្នុងក្រុងសាវត្ថី ថ្ងៃមួយ ទិញនំមកអំពីផ្សារ ទៅកាន់សួនផ្កា គិតថា នឹងបរិភោគ ទើបដើរទៅជួបព្រះមានព្រះភាគ ចោមរោមដោយភិក្ខុកំពុងចូលទៅបិណ្ឌបាត និមន្តបញ្ជូនសង្ឃមក មានចិត្តជ្រះថ្លា បានថ្វាយនំនោះដល់ព្រះមានព្រះភាគ ។ ព្រះសាស្តាទ្រង់សម្តែងអាការគង់ប្រថាប់បៃបនោះ ។ ព្រះអានន្ទត្ថេរបានក្រាលចីវរថ្វាយ ព្រះមានព្រះភាគគង់ប្រថាប់ក្នុងទីនោះ ទ្រង់សោយនំនោះហើយ ខ្ជុរព្រះឱស្ឋ ទ្រង់ធ្វើការញញឹមឲ្យប្រាកដ ព្រះថេរៈទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន វិបាកនៃការថ្វាយទានរបស់ស្រីនេះដូចម្តេច ។ ព្រះមានព្រះភាគត្រាស់ថា អានន្ទ ថ្ងៃនេះ នាងបានឲ្យកោជនដល់តថាគតមុនគេ ថ្ងៃនេះឯង នាងនឹងបានជាអគ្គមហេសីជាទីស្រឡាញ់ ជា

ទីប្រោសប្រាណនៃព្រះបាទកោសល ។ ក្នុងថ្ងៃនោះឯង ព្រះរាជាច្បាំងជាមួយក្សត្រិយក្នុងកាសិគាម ចាញ់សង្គ្រាម គេចចូលមកកាន់ក្រុង ទន្ទឹងរង់ចាំពួកពលមក ទើបយាងចូលទៅកាន់សួនផ្កានោះ ។ នាងមល្លិកានោះ ឃើញព្រះរាជាយាងមក ទើបប្រណិបត្តន៍ព្រះរាជា។ ទ្រង់ពេញព្រះហឫទ័យក្នុងប្រណិបត្តន៍របស់នាង ហើយបញ្ជាឲ្យហៅបិតាមក ទ្រង់ប្រទានឥស្សរិយយសដ៏ច្រើន ហើយឲ្យនាំនាងចូលមកខាងក្នុងព្រះរាជវាំង ទ្រង់ស្ថាបនាក្នុងតំណែងអគ្គមហេសី ។ ថ្ងៃមួយ ព្រះរាជាទ្រង់ត្រិះរិះថា អញនឹងឲ្យឥស្សរិយយសដ៏ច្រើនដល់នាង បើអញសួរនាងថា អ្នកណាជាទីស្រឡាញ់របស់នាង ហើយនាងទូលថា បពិត្រព្រះអង្គ ទ្រង់ជាទីស្រឡាញ់ខ្ញុំ ហើយនឹងសាកសួរអញ កាលបើដូច្នោះ អញនឹងឆ្លើយដល់នាងថា នាងប៉ុណ្ណោះជាទីស្រឡាញ់របស់ខ្ញុំ ។ ដូច្នោះហើយ ព្រះរាជាកាលទ្រង់ធ្វើសម្មោទនីយ ដើម្បីឲ្យកើតសេចក្តីស្និទ្ធស្នាលជាមួយនាងហើយ ទើបត្រាស់សួរ ។ ព្រះទេវីជាបណ្ឌិត និងជាឧបដ្ឋាយិការបស់ព្រះពុទ្ធ ជាឧបដ្ឋាយិការបស់សង្ឃ ទ្រង់ត្រិះរិះថា បញ្ហានេះមិនគួរយល់មុខ ក្រាបទូលព្រះរាជា កាលទូលតាមសេចក្តីពិតនោះឯង ទើបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់មិនមានអ្នកដទៃជាទីស្រឡាញ់ជាងខ្លួនឡើយ ព្រះទេវីត្រាស់ហើយ បំណងនឹងធ្វើអត្តដែលខ្លួនលើកឡើងឲ្យជាក់ច្បាស់ដល់ព្រះរាជាដោយឧបាយ ទើបទូលសួរព្រះរាជា ដូចព្រះរាជាត្រាស់សួរថា បពិត្រព្រះអង្គ ទ្រង់មានអ្នកដទៃជាទីស្រឡាញ់ជាងខ្លួនឬ ។ ឯព្រះរាជាមិនអាចចាប់សេចក្តីបាន ព្រោះព្រះទេវីត្រាស់ដោយលក្ខណៈ មួយអន្ទើដោយកិច្ច សូម្បី

ទ្រង់ក៏ត្រាស់ដោយលក្ខណៈ ព្រមទាំងកិច្ច ទើបត្រាស់អះអាងដូចព្រះទេវី ត្រាស់អះអាង ។

កាលត្រាស់បញ្ជាក់ហើយ ព្រោះភាពដែលទ្រង់មានបញ្ញាទន់ ទើបព្រះតម្រិះថា អញជាស្តេច ជាធំក្នុងផែនដី គ្រប់គ្រងមណ្ឌលប្រឹថពីធំ ការអះអាងថា អញមិនឃើញអ្នកដទៃដែលជាទីស្រឡាញ់ក្រៃលែងជាងខ្លួន ដូច្នេះ មិនសមគួរដល់អញឡើយ តែស្រីនេះ ជាស្រីតូចតាច មានជាតិថោកថយ អញតាំងក្នុងតំណែងខ្ពស់ ក៏គង់មិនស្រឡាញ់អញដែលជាប្តីយ៉ាងពិត ហ៊ានពោលចំពោះមុខអញថា ខ្លួនប៉ុណ្ណោះជាទីស្រឡាញ់ខ្លួន ដូច្នេះហើយ ទើបមិនពេញព្រះហឫទ័យ នឹកស្មានថា នាងស្រឡាញ់ព្រះរតនត្រ័យច្រើនជាង ។ ព្រះទេវីក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់ប្រាថ្នាសុខក្នុងស្ថានសួគ៌ និងសុខក្នុងមគ្គដើម្បីខ្លួន សូម្បីព្រះរតនត្រ័យ ខ្ញុំម្ចាស់ក៏ស្រឡាញ់ ព្រោះដូច្នោះ ទើបខ្លួននោះឯងជាទីស្រឡាញ់របស់ខ្ញុំម្ចាស់ ។ សត្វលោកទាំងអស់ស្រឡាញ់អ្នកដទៃ ក៏ដើម្បីប្រយោជន៍ខ្លួនឯងប៉ុណ្ណោះ កាលប្រាថ្នាបុត្រក៏ប្រាថ្នាថា បុត្រនេះនឹងចិញ្ចឹមអញ ក្នុងកាលអញចាស់ កាលប្រាថ្នាធីតា ក៏ប្រាថ្នាថា ត្រកូលនៃអញនឹងចម្រើនឡើង កាលប្រាថ្នាភរិយា ក៏ប្រាថ្នាថា នឹងបម្រើបាតជើងអញ កាលប្រាថ្នាអ្នកដទៃ ជាញាតិក្តី ជាមិត្រក្តី ក៏ប្រាថ្នាទាក់ទងដោយកិច្ចនោះៗដូច្នោះ ទើបសត្វលោកជាអ្នកឃើញតែប្រយោជន៍ខ្លួនតែប៉ុណ្ណោះ ទើបស្រឡាញ់អ្នកដទៃ រួមសេចក្តីថា ព្រះទេវីមានបំណងយ៉ាងនេះឯង ។

សម័យនោះ ព្រះរាជាទ្រង់ព្រះតម្រិះថា នាងមល្លិកានេះ ជាស្រីឈ្លាស

ជាបណ្ឌិត មុតស្រួចដោយបញ្ញា ពោលថា ខ្លួននោះឯងជាទីស្រឡាញ់ក្រៃលែង របស់ខ្លួន សូម្បីខ្លួនរបស់អញនោះឯង ក៏ប្រាកដជា ជាទីស្រឡាញ់ ណ្ហើយចុះ អញនឹងក្រាបទូលរឿងនេះដល់ព្រះសាស្តា អញនឹងចាំនាងទុកតាមដែលព្រះសាស្តាទ្រង់ព្យាករដល់អញ ។ កាលទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបយាងទៅគាល់ព្រះសាស្តាក្រាបទូលសេចក្តីនោះ ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ រាជា បសេនទិកោសលោ ។បេ។ បិយតរោ** *ជួច្នេះជាដើម ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ព្រះសាស្តាទ្រង់ជ្រាបដោយប្រការទាំងពួងនូវសេចក្តីនេះ គឺដែលព្រះរាជាត្រាស់ថា សព្វសត្វក្នុងលោក ដែលមានខ្លួនជាទីស្រឡាញ់ក្រៃលែងរបស់ខ្លួន ទើបបន្ទឹមនេះ សម្តែងដល់សេចក្តីនោះ ។*

បណ្តាបទទាំងនោះ បទថា **សព្វា ទិសា អនុបរិគម្ម ចេតសា** *សេចក្តីថា បញ្ជូនចិត្តទៅ ដោយអំណាចការស្វែងរកទាំង ១០ ទិស ។ បទថា* **នេវជ្ឈគា បិយតរមត្តនា ក្វចិ** *សេចក្តីថា បុគ្គលខ្លះមានសេចក្តីឧស្សាហ៍យ៉ាងខ្លាំងក្លា ហើយស្វែងរកបុគ្គលដទៃ ដែលជាទីស្រឡាញ់ក្រៃលែងដល់ខ្លួន មិនជួប គឺមិនប្រទះក្នុងទីណាមួយ គឺក្នុងគ្រប់ទិស ។ បទថា* **ឯវំ បិយោ បុថុ អត្តា បរេសំ** *សេចក្តីថា សត្វទាំងឡាយនោះ មានខ្លួនជាទីស្រឡាញ់ច្រើន គឺជាពួកៗ យ៉ាងនោះ គឺរកបុគ្គលណាម្នាក់ដែលជាទីស្រឡាញ់ក្រៃលែងជាងខ្លួនមិនបាន ។ បទថា* **តស្មា ន ហឹំសេ បរមត្តកាមោ** *សេចក្តីថា ព្រោះសត្វទាំងអស់ គឺស្រឡាញ់សុខ ស្អប់ទុក្ខយ៉ាងនេះ ដូច្នោះ បុគ្គលស្រឡាញ់*

ខ្លួន កាលប្រាថ្នាហិតសុខដើម្បីខ្លួន ទើបមិនបៀតបៀន មិនសម្លាប់សត្វដទៃ ដោយហោចស្រមោចខ្មៅ-ក្រហមផង មិនបៀតបៀនដោយហរណវត្តុ មានបាតដៃ ដុំដី និងកំណាត់ឈើជាដើម ពិតហើយ កាលខ្លួនធ្វើទុក្ខឲ្យដល់អ្នកដទៃ ទុក្ខនោះហាក់ដូចជាឈានចេញមកអំពីកម្មដែលខ្លួនធ្វើហើយនោះ នឹងប្រាកដក្នុងកាលជិតស្លាប់ សេចក្តីនេះ ជាធម្មតារបស់កម្មនោះឯង ៗ

អដ្ឋកថា រាជសូត្រទី ១ ចប់

សុត្តន្តបិដក

អប្បាយុកាសូត្រ

[១១១] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមាតារបស់ព្រះមានព្រះភាគ មានព្រះជន្មាយុតិចណាស់ កាលព្រះមានព្រះភាគ ប្រសូតិបាន ៧ ថ្ងៃ ព្រះមាតារបស់ព្រះអង្គ ទ្រង់សោយព្រះវិលា-*

លំយ ទៅកើតក្នុងទេវនិកាយ ឯស្ថានតុសិត ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ ជំណើរនុ៎ះ មែនហើយ ម្នាលអានន្ទ ជំណើរនុ៎ះ មែនហើយ ម្នាលអានន្ទ ព្រោះថា ព្រះមាតារបស់ពោធិសត្វទាំងឡាយ តែងមានព្រះជន្មាយុតិច កាលព្រះពោធិសត្វទាំងឡាយ ទ្រង់ប្រសូតិបាន ៧ ថ្ងៃ ព្រះមាតារបស់ព្រះពោធិសត្វទាំងឡាយ ក៏សោយព្រះវិលាលំយ ហើយទៅកើតក្នុងទេវនិយាយ ឯស្ថានតុសិត (ជាធម្មតា) ។ គ្រានោះ ព្រះមានព្រះភាគ ជ្រាបសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ពួកសត្វណាមួយ ដែលកើតហើយក្តី នឹងកើត (ក្នុងអនាគត) ក្តី ពួកសត្វទាំងអស់នោះ នឹងលះបង់នូវរាងកាយ ទៅកាន់ (បរលោក) ដូចគ្នា បណ្ឌិតអ្នកឈ្វាសដឹងច្បាស់សេចក្តីសាបសូន្យ ទាំងអស់នោះហើយ គួរជាអ្នកមានព្យាយាម ប្រព្រឹត្តព្រហ្មចរិយធម៌ ។ សូត្រទី២ ។

អដ្ឋកថា

អប្បាយុកាសូត្រ

អប្បាយុកាសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ

[១១១] *ពាក្យថា* **អច្ឆរិយំ ភន្តេ** *នេះ គប្បីជ្រាបភាពអស្ចារ្យដែលគួរតិះដៀល ដូចក្នុងមេឃិយសូត្រ ។ បទថា* **យាវ អប្បាយុកា** *ប្រែថា មានអាយុតិចជាងបណា អធិប្បាយថា មានជីវិតតិចតួច ។ បទថា* **សត្តាហ-ជាតេ** *សេចក្តីថា ប្រសូត ១ សប្តាហ៍។ ឈ្មោះថា* **សត្តាហជាត** *ក្នុងកាលទ្រង់ប្រសូតបាន ៧ ថ្ងៃ អធិប្បាយថា ក្នុងថ្ងៃទី ៧ ដែលទ្រង់ប្រសូត ។ បទថា* **តុសិតំ កាយំ ឧបបជ្ជិ** *សេចក្តីថា ចូលដល់ទេពនិកាយជាន់តុសិត ដោយបដិសន្ធិ ។*

បានឮថា ថ្ងៃមួយ ខាងក្រោយភត្ត ព្រះថេរៈអង្គុយសម្រាកពេលថ្ងៃ ពិចារណាដល់ព្រះរូបរបស់ព្រះមានព្រះភាគ ដែលប្រដាប់ដោយព្រះលក្ខណៈ និងព្រះអនុព្យញ្ជនៈ មានព្រះរូបល្អឆ្អះ ជាទស្សនានុត្តរិយៈ ហើយទើបគិតថា គួរអស្ចារ្យ ព្រះពុទ្ធទាំងឡាយដល់ព្រមទៅដោយព្រះរូបកាយគួរសរសើរ នាំមកនូវការជ្រះថ្លាដោយជុំវិញ គួរត្រេកអរក្នុងចិត្ត ដូច្នេះហើយ ទើបសោយបីតិ និងសោមនស្សយ៉ាងក្រៃលែង ទើបគិតយ៉ាងនេះថា ធម្មតាម្តាយបង្កើតទោះមានបុត្ររូបរាងមិនល្អ ក៏នៅតែមានការពេញចិត្ត ដូចគ្នានឹងបុត្រដែលមានរូបល្អ ដូច្នោះ បើព្រះនាងមហាមាយាទេវីជាពុទ្ធមាតា គង់ព្រះជន្មនៅសោត នាងក៏គប្បីកើតបីតិសោមនស្ស ព្រោះបានឃើញព្រះរូបរបស់ព្រះមាន

ព្រះភាគ ហេតុអ្វីហ្ន៎ កាលទ្រង់ប្រសូតបាន ៧ ថ្ងៃ ព្រះទេវីមហាមាយាមាតា ទ្រង់សោយព្រះវិលាល័យ ជាការវិនាសយ៉ាងធំកន្តង ។ កាលគិតយ៉ាងនេះ ហើយ ទើបចូលគាល់ព្រះមានព្រះភាគ ក្រាបទូលបវិតក្តរបស់ខ្លួន កាលនឹងតិះដៀលការសោយព្រះវិលាល័យរបស់ព្រះនាង ទើបក្រាបទូលពាក្យជាដើមថា **អច្ឆរិយំ ភន្តេ។**

តែអាចារ្យពួកខ្លះពោលថា ព្រះនាងមហាបជាបតិគោតមី ទោះសូមអង្វរដើម្បីបួសជាមួយព្រះមានព្រះភាគ ដោយការប្រាថ្នាក្រៃលែង ក៏ត្រូវឃាត់ តែអាត្មាអញ ទូលសូមដោយឧបាយហើយ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតការបួស និងឧបសម្បទា ដោយការទទួលគរុធម៌ ៨ ប្រការ ព្រះនាងទទួលធម៌ទាំងនោះហើយ បានបព្វជ្ជាឧបសម្បទា ហើយទើបកើតបរិស័ទទី ៣ នៃព្រះមានព្រះភាគ បានជាបច្ចយជល់បរិស័ទទី ៤ បើព្រះមហាមាយាទេវីព្រះជននីរបស់ព្រះមានព្រះភាគ គង់ព្រះជន្មនៅសោត កាលបើដូច្នេះ ក្សត្រិយានីទាំង ២ នេះរួមគ្នា គប្បីធ្វើសាសនានេះឲ្យចម្រើន ព្រោះការរាប់អានក្នុងព្រះមាតាច្រើន ព្រះមានព្រះភាគគប្បីទ្រង់អនុញ្ញាតការបួស និងឧបសម្បទាក្នុងព្រះសាសនាជល់មាតុគ្រាមដោយងាយនោះឯង តែព្រោះព្រះនាងមានព្រះ-ជន្មាយុតិច ហេតុនោះ ទើបសម្រេចបានលំបាក ដោយអធិប្បាយដូចពោលនេះ ទើបព្រះថេរៈក្រាបទូលពាក្យជាដើមថា **អច្ឆរិយំ ភន្តេ** *ក្នុងសម្នាក់របស់ព្រះមានព្រះភាគ ប្រការនោះមិនមែនជាហេតុ ។ ពិតហើយ ព្រះមានព្រះភាគកាលទ្រង់អនុញ្ញាតការបួសក្នុងសាសនា របស់ព្រះអង្គជល់ព្រះមាតា ឬជល់*

មាតុគ្រាមដទៃ ទើបទ្រង់អនុញ្ញាតឲ្យរឹងប៉ឹងនោះឯង មិនមែនអនុញ្ញាតដោយធូរលុង ព្រោះទ្រង់មានព្រះបំណងឲ្យសាសនា តាំងនៅបានយូរអង្វែង ។

ឯអាចារ្យមួយពួកទៀតពោលថា ព្រះថេរៈមនសិការដល់ពុទ្ធគុណ មិនមានទីបំផុត មិនមានប្រមាណ ដែលមិនទូទៅដល់អ្នកដទៃ មានព្រះទស-ពលញ្ញាណ និងចតុវេសារជ្ជញ្ញាណជាដើម ទើបកើតការអស្ចារ្យឡើងថា ព្រះពុទ្ធមាតាថែរក្សាព្រះសាស្តា ដែលជាអគ្គបុគ្គលក្នុងលោក ដែលមានអានុភាពច្រើនដល់ម៉្លេះក្នុងព្រះគភ៌ អស់ ១០ ខែ និងជាបរិចារិការបស់បុគ្គលណា ព្រោះដូច្នោះ ទើបសេចក្តីនេះមិនសមគួរ ព្រោះដូច្នោះ ការដែលព្រះមានព្រះភាគប្រសូតបាន ៧ ថ្ងៃ ពុទ្ធមាតាសោយព្រះវិលាល័យ និងកាលសោយព្រះវិលាល័យហើយ ព្រះនាងកើតក្នុងជាន់តុសិត នេះជាការសមគួរដល់ព្រះគុណនៃព្រះសាស្តាយ៉ាងពិត កាលក្រាបទូលបវិតក្ក ដែលកើតឡើងដល់ខ្លួននោះ ដល់ព្រះមានព្រះភាគ ទើបបានពោលពាក្យជាដើមថា **អច្ឆរិយំ ភន្តេ** *ដូច្នេះ ។*

ព្រះសាស្តា កាលទ្រង់សម្តែងព្រះពោធិសត្វប្រសូតបាន ៧ ថ្ងៃ ព្រះមាតារបស់ព្រះពោធិសត្វក៏សោយព្រះវិលាល័យ ចាត់ជាការសម្រេចដោយធម្មតា ទើបត្រាស់ពាក្យជាដើមថា **ឯវមេតំ អានន្ទ។** *ឯធម្មតានេះ គប្បីជ្រាបដោយអំណាចដែលព្រះពោធិសត្វគ្រប់អង្គ ធ្លាប់ប្រព្រឹត្តជាអាចិណ្ណវត្តជានិច្ចមក ព្រោះព្រះពោធិសត្វគ្រប់អង្គ ទ្រង់បំពេញព្រះបារមីហើយ កើតឡើងក្នុងស្ថានតុសិតនោះ ដរាបដល់អស់អាយុ កាលអស់អាយុ ដែលទេវតាក្នុងម៉ឺនចក្រវាលប្រជុំ*

គ្នា ទូលអារាធនាដើម្បីឲ្យទ្រង់បដិសន្ធិក្នុងមនុស្សលោក ដើម្បីអភិសម្ពោ-ធិញ្ញាណ ទើបប្រមើលមើលប្រមាណអាយុរបស់ព្រះពុទ្ធមាតា ប្រមើលមើលកាល ទ្វីប ប្រទេស និងត្រកូលហើយ ទើបបដិសន្ធិ យ៉ាងណា ព្រះមានព្រះភាគអង្គនេះ ជាព្រះពោធិសត្វ តាំងនៅក្នុងស្ថានតុសិត ក៏ដូច្នោះដូចគ្នា ទ្រង់ប្រមើលមើលមហាវិលោកនៈ ៥ ប្រការ ទ្រង់កំណត់ប្រមាណអាយុរបស់ព្រះពុទ្ធមាតា ១០ ខែ ៧ ថ្ងៃ ទ្រង់ជ្រាបថា នេះជាពេលដែលអាត្មាអញបដិសន្ធិដូច្នេះ អញគួរបដិសន្ធិ ដូច្នេះហើយ ទើបទ្រង់បដិសន្ធិ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អប្បាយុកា ហិ អានន្ទ ពោធិ-សត្តមាតរោ ហោន្តិ** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **កាលំ ករោន្តិ** *សេចក្តីថា ធ្វើកាលដោយអស់ទៅនៃអាយុតាមដែលពោលហើយនោះឯង មិនមែនព្រោះមានការប្រសូតិជាបច្ច័យ ។ ពិតហើយ ទីដែលព្រះពោធិសត្វនៅក្នុងអត្តភាពចុងក្រោយ ដូចជាខឿនព្រះចេតិយ មិនមែនជាទីដែលអ្នកជំនៃប្រើប្រាស់ បុគ្គលណាម្នាក់មិនអាចដកព្រះមាតារបស់ព្រះពោធិសត្វចេញ ហើយតាំងស្រីជំនៃក្នុងតំណែងអគ្គមហេសី ។ ត្រឹមប៉ុណ្ណោះឯង ចាត់ជាប្រមាណអាយុរបស់ព្រះពោធិសត្វព្រោះដូច្នោះ ទើបបានធ្វើកាលកិរិយាក្នុងពេលនោះ ។ ព្រះមហាពោធិសត្វទាំងឡាយសំដៅដល់សេចក្តីនេះឯង ទើបធ្វើមហាវិលោកនៈ ៥ ប្រការ ។ សួរថា ព្រះមាតារបស់ព្រះពោធិសត្វធ្វើកាលកិរិយាក្នុងវ័យណា ។ ឆ្លើយថា ក្នុងមជ្ឈិមវ័យ ។ ពិតហើយ ក្នុងបឋមវ័យ សត្វទាំងឡាយ មានឆន្ទរាគៈ*

ខ្លាំងក្លាក្នុងអត្តភាព ព្រោះដូច្នោះ ស្រីទាំងឡាយតាំងគភ៌ក្នុងកាលនោះដោយច្រើន មិនអាចតាមរក្សាគភ៌បាន ។ បើបដិសន្ធិបានសោត សត្វដែលកើតក្នុងគភ៌ក៏នឹងលំបាកច្រើន ។ កាលកន្លងទៅ ២ ចំណែករបស់មជ្ឈិមវ័យទៅហើយ ក្នុងចំណែកទី ៣ គភ៌ក៏បរិសុទ្ធ ក្មេងដែលកើតក្នុងគភ៌ដែលបរិសុទ្ធនឹងមិនមានរោគ ព្រោះដូច្នោះ ទើបមាតារបស់ព្រះពោធិសត្វទទួលនូវការសម្បូរក្នុងបឋមវ័យ ប្រសូតក្នុងចំណែកទី ៣ នៃមជ្ឈិមវ័យ ហើយសោយវិលាល័យ ។

បទថា **ឯតមត្ថំ វិឯក្ខា** *សេចក្តីថា ទ្រង់ជ្រាបថា អាយុក្នុងអត្តភាពនៃមាតាព្រះពោធិសត្វ និងសព្វសត្វដទៃ មានសេចក្តីស្លាប់ជាទីបំផុត ទើបទ្រង់បន្ទឺឧទាននេះ ដែលសម្តែងដល់សេចក្តីឧស្សាហ៍ ក្នុងកិច្ចបដិបត្តិដែលមិនមានទោសដោយមុខ ដែលសម្តែងដល់អត្តនោះយ៉ាងជាក់ច្បាស់ ។*

បណ្តាបទទាំងនោះ បទថា **យេ កេចិ** *ជាបទសម្តែងអត្ត ដែលមិនពិតប្រាកដ ។ បទថា* **ភូតា** *ប្រែថា កើតហើយ ។ បទថា* **ភវិស្សន្តិ** *ប្រែថា នឹងកើតក្នុងអនាគត ។* **វា** *សព្ទ ជាវិកប្បត្ថ ។* **អបិ** *សព្ទ ជាសម្បិណ្ឌនត្ថ ដោយ* **អបិ** *សព្ទនោះ លោកសង្គ្រោះយកសព្ទដែលកំពុងកើតឡើង ។ ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះ លោកកំណត់កាន់យកពួកសត្វដែលទាក់ទងក្នុងបដិសន្ធិ ដោយអំណាចកាល មានអតីតកាលជាដើម ដោយមិនមានចំណែកសល់ ។ ម្យ៉ាងទៀត គប្បីសេយ្យកសត្វដែលកើតក្នុងគភ៌ តាំងអំពីចេញចាកគភ៌ ឈ្មោះថា* **ភូតា** *មុនអំពីនោះ ឈ្មោះថា* **សម្ភវេសី** *។ ពួក*

សំសេទជៈ និងឱបបាតិកៈ ក្រោយអំពីបដិសន្ធិចិត្តទៅ ឈ្មោះថា **ភូត** *មុនអំពីនោះ ឈ្មោះថា* **សម្ភវេសី** *ទាក់ទងដោយភពដែលគប្បីបដិសន្ធិ ។ ម្យ៉ាងទៀត សត្វទាំងអស់ ឈ្មោះថា* **ភូត** *ទាក់ទងដោយបច្ចុប្បន្នភព ឈ្មោះថា* **សម្ភវេសី** *ទាក់ទងដោយភពថ្មីក្នុងអនាគត ។ បុគ្គលអស់អាសវៈ ឈ្មោះថា* **ភូត** *ពិតហើយ លោកដែលអស់អាសវៈទាំងនោះ កើតហើយប៉ុណ្ណោះ ក៏មិនកើតតទៅទៀត ។ សត្វជនៃក្រៅអំពីអ្នកអស់អាសវៈទាំងនោះ ឈ្មោះថា* **សម្ភវេសី** *(សត្វដែលកំពុងស្វែងរកទីកើត) ។ បទថា* **សព្ពេ គមិស្សន្តិ បមាយ ឥមំ** *សេចក្តីថា សត្វទាំងពួង មានសត្វដួចពោលហើយ នឹងផ្សេងគ្នាច្រើនប្រភេទ ដោយភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងសត្តាវាសជាដើម នឹងលះ គឺចោលរាងកាយ គឺសរីរៈរបស់ខ្លួនទៅកាន់បរលោក ឯព្រះអសេក្ខបុគ្គលទៅព្រះនិព្វាន ។ ក្នុងសេចក្តីនេះ លោកសម្តែងថា បុគ្គលណាម្នាក់ ឈ្មោះថា មិនមានចុតិជាធម្មតា មិនមាន ។ បទថា* **តំ សព្ពញ្ញឺ កុសលោ វិធិញ្ញា** *សេចក្តីថា លោកអ្នកឈ្វាស គឺបណ្ឌិត ជ្រាបនូវការវិនាស គឺការសូន្យទៅ បានដល់ ការស្លាប់របស់សព្វសត្វនោះ ឬជ្រាបដល់ការសាបសូន្យ គឺសេចក្តីវិនាស បានដល់ ការទ្រុឌទ្រោម នៃសព្វសត្វទាំងអស់នោះ ដោយអំណាចមរណានុស្សតិ ឬដោយអំណាចមនសិការដល់ព្រះត្រៃលក្ខណ៍ មានអនិច្ចតាជាដើម ។ បទថា* **អាតាបិយោ ព្រហ្មចរិយំ ចរេយ្យ** *សេចក្តីថា កាលបំពេញវិបស្សនា ឈ្មោះថា មានសេចក្តីព្យាយាម ព្រោះប្រកបដោយសេចក្តីព្យាយាម គឺសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ឈ្មោះថា ប្រារព្ធ*

ព្យាយាមដោយអំណាចសម្មប្បធាន ៤ គប្បីប្រព្រឹត្ត គឺបដិបត្តិមគ្គព្រហ្មចរិយៈ ដែលជាឧបាយជាគ្រឿងឈានកន្លងបង់នូវមរណៈ ដោយឥតសល់ ។

អដ្ឋកថា អប្បាយុកាសូត្រទី ២ ចប់

សុត្តន្តបិដក

សុប្បពុទ្ធកុដ្ឋិសូត្រ

[១១២] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង មនុស្សឃ្លង់ម្នាក់ ជាមនុស្សកម្សត់ មនុស្សកំព្រា មនុស្សថោកទាប ឈ្មោះសុប្បពុទ្ធ នៅក្នុងក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមានព្រះភាគ មានបរិសទ្យច្រើនគាល់ជុំវិញ កំពុងគង់សម្តែងធម៌ ។ សុប្បពុទ្ធកុដ្ឋិ បានឃើញអំពីចម្ងាយ នូវពួកមហាជនប្រជុំគ្នា លុះឃើញហើយ គាត់មានសេចក្តីត្រិះរិះថា គេនឹងចែកខាទនីយៈ ឬភោជនីយាហារណាមួយ ក្នុងទីនេះដោយឥតសង្ស័យ បើដូច្នោះ អញនឹងចូលទៅរកពួកមហាជន ដោយគិតថា ធ្វើម្តេចទៅហ្ន៎ អញនឹងបានខាទនីយៈ ឬភោជនីយាហារណាមួយក្នុងទីនុ៎ះ ។ លំដាប់នោះ សុប្បពុទ្ធកុដ្ឋិ ចូលសំដៅទៅរកពួកមហាជន សុប្បពុទ្ធកុដ្ឋិបានឃើញព្រះមានព្រះភាគ ដែលបរិសទ្យជាច្រើនគាល់ជុំវិញ កំពុងគង់សម្តែងធម៌ លុះឃើញហើយ គាត់ក៏មានសេចក្តីត្រិះរិះដូច្នេះថា ឱហ្ន៎ គេមិនចែកខាទនីយៈ ឬ*

កោជនីយាហារណាមួយ ក្នុងទីនេះទេ ព្រះសមណៈគោតមនេះ ទ្រង់សម្តែងធម៌ ក្នុងកណ្តាលបរិសទ្យ បើដូច្នោះ គួរតែអាត្មាអញស្តាប់ធម៌ដែរ គាត់ក៏អង្គុយក្នុងទីសមគួរ ក្នុងទីនោះ គិតថា អាត្មាអញនឹងស្តាប់ធម៌ដែរ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ធ្វើទុកក្នុងព្រះហឫទ័យកំណត់ចិត្តបរិសទ្យទាំងអស់ ដោយព្រះហឫទ័យថា នរណាហ្ន៎ គួរត្រាស់ដឹងធម៌ក្នុងទីនេះបាន ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញសុប្បពុទ្ធកុដ្ឋិ ដែលអង្គុយក្នុងបរិសទ្យនោះ លុះទ្រង់ឃើញហើយ ព្រះមានព្រះភាគ ត្រិះរិះថា សុប្បពុទ្ធកុដ្ឋិនេះឯង គួរដើម្បីដឹងធម៌បានក្នុងទីនេះ ទើបទ្រង់សម្តែងអនុបុព្វីកថា ប្រារព្ធសុប្បពុទ្ធកុដ្ឋិ គឺទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា ទោសដ៏លាមកសៅហ្មង នៃកាមគុណ និងអានិសង្សក្នុងការចេញបួស ។ ព្រះមានព្រះភាគ ជ្រាបថា សុប្បពុទ្ធកុដ្ឋិ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តខ្ពស់ឡើង មានចិត្តជ្រះថ្លា ក្នុងកាលណាហើយ ទ្រង់ប្រកាសធម៌ទេសនាដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសម្តែងព្រះអង្គឯង គឺសម្តែងទុក្ខ-សមុទយៈ និរោធ និងមគ្គ ក្នុងកាលនោះ ។ ធម្មចក្ខុប្រាសចាកធូលី ប្រាសចាកមន្ទិលកើតឡើងដល់សុប្បពុទ្ធកុដ្ឋិ ក្នុងទីអង្គុយនោះថា ធម្មជាតិណាមួយដែលកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា ដូច្នេះ ដូចសំពត់សស្អាតប្រាសចាកពណ៌ខ្មៅ គួរទទួលគ្រឿងជ្រលក់បានដោយប្រពៃ យ៉ាងដូច្នោះឯង ។

[១១៣] គ្រានោះ សុប្បពុទ្ធកុដ្ឋិឃើញធម៌ហើយ បានធម៌ហើយ ដឹង

ធម៌ហើយ ចុះកាន់ធម៌ស៊ប់ហើយ ឆ្ងន់សេចក្តីសង្ស័យ ប្រាសចាកសេចក្តី ងឿងឆ្ងល់ ដល់នូវភាពក្លៀវក្លា មិនជឿបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា ហើយក្រោកចាកទីអង្គុយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះសុប្ប-ពុទ្ធកុដ្ឋិ អង្គុយក្នុងទីសមគួរហើយ សរសើរព្រះមានព្រះភាគថា បពិត្រ ព្រះអង្គដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទេសនាដែលព្រះមានព្រះភាគសម្តែងហើយ ដោយ អនេកបរិយាយ ដូចបុរសផ្ងារបស់ដែលផ្កាប់ ឬបើករបស់ដែលបិទបាំង ពុំនោះ ដូចគេប្រាប់ផ្លូវដល់អ្នកវង្វេង ពុំនោះ ដូចគេទ្រោលប្រទីបប្រេងក្នុងទី ងងឹត ដោយគិតថា ពួកអ្នកមានភ្នែកឃើញរូបទាំងឡាយ ដូច្នោះឯង បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនុ៎ះ សូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង សូមព្រះមានព្រះភាគ ចាំទុកខ្ញុំព្រះអង្គថាជាឧបាសក ដល់សរណៈស្មើដោយជីវិត តាំងពីថ្ងៃនេះរៀងទៅ ។ គ្រានោះ សុប្បពុទ្ធកុដ្ឋិ ដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ត្រេកអរ រីករាយ នឹងភាសិតរបស់ព្រះមានព្រះភាគ ទើបក្រោកចាកទីអង្គុយ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណចៀស ចេញទៅ ។ គ្រានោះ គោមេមានកូនខ្ចី មកបុះសុប្បពុទ្ធកុដ្ឋិ ដែលទើបនឹង ចេញទៅមិនយូរប៉ុន្មាន ឲ្យដាច់ចាកជីវិត ។ គ្រានោះ ភិក្ខុច្រើនរូប ចូលទៅ គាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ

អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សុប្បពុទ្ធកុដ្ឋិ ដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ឲ្យកាន់យក ឲ្យអង់អាច ឲ្យរីករាយដោយធម្មីកថា (ឥឡូវនេះ) សុប្បពុទ្ធកុដ្ឋិនោះស្លាប់ហើយ គតិរបស់គាត់ តើដូចម្តេច បរលោករបស់គាត់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សុប្បពុទ្ធកុដ្ឋិ ជាបណ្ឌិត បានដឹងធម៌សមគួរតាមធម៌ហើយ មិនបៀតបៀនតថាគត ព្រោះហេតុនៃការសម្តែងធម៌ទៀតទេ ម្នាលភិក្ខុទាំងឡាយ សុប្បពុទ្ធកុដ្ឋិ ជាសោតាបន្នបុគ្គល មានសណ្តាប់ធ្នាប់មិនធ្លាក់ចុះ មានគតិទៀងទាត់ មានសម្ពោធិធម៌ ប្រព្រឹត្តទៅខាងមុខ ព្រោះអស់ទៅនៃសញ្ញោជនធម៌ ៣ ប្រការ ។

[១១៤] កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះ ភិក្ខុ ១ រូប ទូលសួរព្រះមានព្រះភាគទៀតថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យសុប្បពុទ្ធកុដ្ឋិ ជាមនុស្សកម្សត់ ជាមនុស្សកំព្រា ជាមនុស្សថោកទាប ។ ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ សុប្បពុទ្ធកុដ្ឋិ កើតជាសេដ្ឋីបុត្ត ក្នុងក្រុងរាជគ្រឹះនេះឯង សេដ្ឋីបុត្តនោះ ចេញទៅកាន់ឧទ្យានភូមិ បានឃើញព្រះតគរសិខីបច្ចេកពុទ្ធ ដែលកំពុងត្រាច់ទៅបិណ្ឌបាតក្នុងក្រុង លុះឃើញហើយ ទើបសេដ្ឋីបុត្តនោះគិតថា សមណៈគំលង់នេះ ដើរធ្វើអ្វីហើយ ស្តោះទឹកមាត់ ធ្វើដោយអាការពេបជ្រាយ ហើយចៀសចេញទៅ ។ ដោយផលនៃកម្មនោះ សេដ្ឋីបុត្តនោះ ក៏ទៅកើតនៅក្នុងនរក អស់ឆ្នាំជាច្រើន គឺអស់រយនៃឆ្នាំជាច្រើន អស់ពាន់នៃឆ្នាំ និងសែននៃឆ្នាំជាច្រើន ដោយ

សំណល់នៃផលកម្មនោះ ទើបគាត់កើតមកជាមនុស្សក្រមឃ្លត់ មនុស្សកំព្រា មនុស្សថោកទាប ក្នុងក្រុងរាជគ្រឹះនេះឯង សុប្បពុទ្ធកុដ្ឋិនោះ បានអាស្រ័យធម្មវិនិយ ដែលព្រះតថាគតសម្តែងហើយ កាន់យកសទ្ធាដោយប្រពៃ កាន់យកសីលដោយប្រពៃ កាន់យកសុតៈដោយប្រពៃ កាន់យកចាគៈដោយប្រពៃ កាន់យកបញ្ញាដោយប្រពៃ សុប្បពុទ្ធកុដ្ឋិនោះ លុះអាស្រ័យធម្មវិនិយ ដែលតថាគតសម្តែងហើយ ក៏កាន់យកសទ្ធាដោយប្រពៃ កាន់យកសីលដោយប្រពៃ កាន់យកសុតៈដោយប្រពៃ កាន់យកចាគៈដោយប្រពៃ កាន់យកបញ្ញាដោយប្រពៃ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតឯសុគតិ សួគ៌ទេវ-លោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ទេវបុត្តនោះ ក៏រុងរឿងកន្ធងលើសពួកទេវតាឯទៀត ក្នុងទីនោះ ដោយពណ៌សម្បុរផង ដោយយសបរិវារផង។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះក្នុងវេលានោះថា

បណ្ឌិតគប្បីវៀរស្រឡះកម្មដ៏លាមក ក្នុងជីវលោកចេញ
ដូចបុរសមានចក្ខុ វៀរស្រឡះទីមិនស្មើ ក្នុងកាលដែលដើរទៅ ។ សូត្រទី ៣ ។

អដ្ឋកថា

សុប្បពុទ្ធកុដ្ឋិសូត្រ

សុប្បពុទ្ធកុដ្ឋិសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

[១១២] *បទថា* **រាជគហេ សុប្បពុទ្ធោ នាម កុដ្ឋី អហោសិ** *សេចក្តីថា បុរសម្នាក់ ឈ្មោះសុប្បពុទ្ធ នៅក្នុងក្រុងរាជគ្រឹះ ។ គាត់មានរោគឃ្លង់ បៀតបៀនយ៉ាងធ្ងន់ ។ បទថា* **មនុស្សឧឡិទ្ធោ** *សេចក្តីថា ជាអ្នកក្រីក្រជាង គេបង្អស់ ក្នុងបណ្តាមនុស្សក្នុងក្រុងរាជគ្រឹះ ។ គាត់ដេរកំណាត់សំពត់ចាស់ៗ ដែលពួកមនុស្សចោលត្រង់គំនរសំរាម ឬត្រង់របងជាដើមស្បៃកដណ្តប់ ។ កាន់អំបែងទៅតាមផ្ទះ អាស្រ័យបាយក្តាំង និងកត្តា ដែលជាសំណល់ចិញ្ចឹមជីវិត សូម្បីរបស់នោះ ក៏គាត់មិនបានតាមសេចក្តីត្រូវការ ព្រោះកម្មដែលខ្លួនធ្វើក្នុងកាលមុន ។ ដោយហេតុនោះ ទើបលោកពោលថា ជាមនុស្សក្រីក្រ ។ បទថា* **មនុស្សកបណោ** *បានដល់ ក្នុងបណ្តាមនុស្សដែលដល់នូវភាពកំព្រាយ៉ាងក្រៃលែង ។ បទថា* **មនុស្សវ្រាកោ** *បានដល់ មនុស្សកម្សត់ ព្រោះត្រូវមនុស្សគេះដៀល និងមើលងាយ ។ បទថា* **មហតិយា បរិសាយ** *សេចក្តីថា ដោយភិក្ខុបរិស័ទ និងឧបាសកបរិស័ទជាច្រើន ។*

បានឮថា ថ្ងៃមួយ ព្រះមានព្រះភាគ ចោមរោមដោយភិក្ខុសង្ឃ ចូលទៅបិណ្ឌបាតកាន់ក្រុងរាជគ្រឹះ ទ្រង់សោយបិណ្ឌបាត ដែលពួកភិក្ខុបានមកដោយល្អ ទ្រង់ត្រឡប់អំពីបិណ្ឌបាត ខាងក្រោយភត្ត ចោមរោមដោយភិក្ខុតិចតួច ទ្រង់ចេញវង្វាំការមកបរបស់ឧបាសកដែលថ្វាយទាន និងភិក្ខុដ៏សេស បាន

ប្រថាប់ឈរក្នុងទីដែលគួរជាទីត្រេកអរមួយកន្លែង ខាងក្នុងនគរនោះឯង ។ រំពេចនោះ ភិក្ខុទាំងឡាយមកអំពីទីនោះ នាំគ្នាចោមរោមព្រះមានព្រះភាគ ។ ឯ ឧបាសកទាំងឡាយចូលទៅគាល់ព្រះមានព្រះភាគ ដោយបំណងថា នឹងស្តាប់ អនុមោទនា ថ្វាយបង្គំហើយត្រឡប់មក ។ មានការប្រជុំធំឡើងហើយ ។ ទ្រង់សម្តែងអាការគង់ ។ ក្នុងខណៈនោះឯង ភិក្ខុទាំងឡាយក្រាលអាសនៈដ៏ សមគួរដល់ទ្រង់ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ធ្វើបទេសទាំងមូលនោះ ឲ្យភ្លឺស្វាងដោយព្រះរូប ដែលប្រៀបមិនបាន ដែលរុងរឿងដោយមហាបុរិស-លក្ខណៈ ៣២ ប្រការ ដែលប្រដាប់ដោយអនុព្យញ្ជនៈ ៨០ ប្រការដ៏រុងរឿង ចោមរោមទៅដោយរស្មីមួយព្យាម ផ្សាយពុទ្ធរស្មីដែលមានពណ៌ ៦ គឺខៀវ លឿង ក្រហម ស ហង្សធាតុ និងពណ៌ផ្កែក ចោមរោមទៅដោយពួកភិក្ខុ ដូចព្រះចន្ទពេញវង់ ចោមរោមដោយពួកផ្កាយ គង់ប្រថាប់លើបវរពុទ្ធាសនៈ ដែលរៀបចំ ទ្រង់បន្ទឺសីហនាទ ដូចកេសរសីហៈ នាផ្នែមនោសិលា ទ្រង់ សម្តែងធម៌ដោយព្រះសូរសៀងដូចសំឡេងព្រហ្មដ៏ពីរោះ ដូចជាសំឡេងសត្វ ករវិក ។

ឯភិក្ខុទាំងឡាយ ដែលជាអ្នកប្រាថ្នាតិច សន្តោស គាប់ចិត្តក្នុងទីស្ងាត់ មិនច្រឡូកច្រឡំ ប្រារព្ធសេចក្តីព្យាយាម មានចិត្តជាសមាធិ ពេញចិត្តនឹង ទូន្មានខ្លួន ជាអ្នកតិះដៀលបាប ជាអ្នកប្រៀនប្រដៅ អត់ធន់ចំពោះពាក្យ សម្បូរ ដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈ ។ ជណ្តប់បង្សុ-កូលចីវរ ពណ៌ដូចពពក ចោមរោមព្រះមានព្រះភាគ ដូចដំរីត្រកូលគន្ធៈ ពាក់

នូវក្រោះដោយល្អ ផ្ទៀងនូវសោតៈ ស្តាប់នូវព្រះធម្មទេសនា ។ ឯឧបាសកទាំងឡាយ ជណ្តប់សំពត់រៀបរយ មានឧត្តរាសង្គស្អាត ក្នុងពេលព្រឹក ញុំាងមហាទានឲ្យប្រព្រឹត្តទៅ បូជាព្រះមានព្រះភាគដោយសក្ការៈ មានផ្កាកម្រងនិងគ្រឿងក្រអូបជាដើម ថ្វាយបង្គំ ហើយសម្តែងអាការថ្វាយបង្គំកិក្ខុសង្ឃ ចោមរោមព្រះមានព្រះភាគ និងកិក្ខុសង្ឃ សង្រួមដៃ និងជើង ផ្ទៀងនូវសោតៈ ស្តាប់ធម៌ដោយគោរព ដោយហេតុនោះ ទើបលោកពោលថា សម័យនោះឯង ព្រះមានព្រះភាគ មានបរិស័ទច្រើនគាល់ជុំវិញ កំពុងគង់សម្តែងធម៌ ដូច្នេះជាដើម ។

សុប្បពុទ្ធត្រូវភាពទុព្វលគឺសេចក្តីស្រេកឃ្លានគ្របសង្កត់ទើបត្រាច់ស្វែងរកអាហារឆ្ងាច់ចន្ទោះវិថី ឃើញមហាជនប្រជុំគ្នាអំពីចម្ងាយ កើតសេចក្តីត្រេកអរឡើងថា មហាជនទាំងនេះ ប្រជុំគ្នាដោយរឿងអ្វីហ្ន៎ ប្រហែលជាទីនោះ គេចែកអាហារដោយពិត បើដូច្នោះ អញទៅក្នុងទីនោះ គ្រាន់ទឹងបានវត្តុណាមួយជារបស់ទំពាក្តី របស់ស៊ីក្តី ដូច្នេះហើយ ទើបទៅទីនោះ បានឃើញព្រះមានព្រះភាគ ទ្រង់គួរជ្រះថ្លា គួរសរសើរ ដល់នូវការស្ងប់ ដោយការទូន្មានខ្លួនដ៏ខ្ពង់ខ្ពស់ ទ្រង់ទូន្មានហើយ គ្រប់គ្រងហើយ ប្រកបដោយឥន្ទ្រិយដែលសង្រួមហើយ ចោមរោមទៅដោយបរិស័ទសម្តែងធម៌នោះ កាលឃើញហើយ ដោយឧបនិស្សយសម្បត្តិចាស់ក្លា ដែលប្រកបហើយក្នុងជាតិមុនជាស់តឿន ទើបគិតថា បើដូច្នោះ អញក៏គួរស្តាប់ធម៌ ដូច្នេះហើយ ទើបអង្គុយខាងចុងបរិស័ទ ទើបលោកពោលថា សុប្បពុទ្ធកុដ្ឋិបានឃើញព្រះមាន

ព្រះភាគ ។បេ។ គាត់ក៏អង្គុយក្នុងទីសមគួរក្នុងទីនោះ គិតថា អាត្មាអញស្តាប់ធម៌ដែរ ដូច្នេះជាដើម ។

បទថា **សព្ភាវន្តំ** *ប្រែថា មានបុគ្គលគ្រប់ពួក គឺមានបុគ្គលគ្រប់ពួក មានបុគ្គលអាក្រក់ជាដើម ។ ក្នុងសេចក្តីនោះមានអធិប្បាយថា មិនសល់ សូម្បីបុគ្គលណាម្នាក់ អាចារ្យពួកខ្លះពោលថា* **សព្ភវន្តំ** *ដូច្នេះក៏មាន ។ បទថា* **ចេតសា** *សេចក្តីថា ដោយព្រះហឫទ័យដែលប្រកបដោយពុទ្ធចក្ខុ ។ ពិតហើយ លោកសម្តែងព្រះញាណដោយលើកចិត្តឡើងជាប្រធាន ព្រោះដូច្នោះទើបមានអធិប្បាយថា ដោយអាសយានុសយញ្ញាណ និងឥន្ទ្រិយបរោបរិ-យត្តិញ្ញាណ ។ បទថា* **ចេតោ បរិច្ច មនសាកាសិ** *សេចក្តីថា ទ្រង់កំណត់ចិត្តរបស់បរិស័ទនោះចំពោះបុគ្គល ហើយទ្រង់ធ្វើទុកក្នុងព្រះហឫទ័យ គឺទ្រង់ប្រមើលមើលជនទាំងនោះ ។ បទថា* **ភព្ពោ ធម្មំ វិញ្ញាតុំ** *សេចក្តីថា ជាអ្នកអាច គឺដល់ព្រមដោយឧបនិស្សយ ដើម្បីសម្រេចធម៌ គឺមគ្គ និងផល ។ បទថា* **ឯតទហោសិ** *សេចក្តីថា ព្រះមានព្រះភាគទ្រង់មានព្រះតម្រិះដូច្នេះថា សុប្បពុទ្ធនោះ ធ្វើខុសក្នុងព្រះបច្ចេកពុទ្ធព្រះនាមតគរសិខី ទើបមានសភាពដូច្នេះ តែសុប្បពុទ្ធក៏គង់មានឧបនិស្សយនៃមគ្គ និងផល រុងរឿងខាងក្នុងនោះឯង ដូចដុំមាសត្រូវធូលីបិទបាំង ព្រោះដូច្នោះ ទើបសុប្បពុទ្ធគួរដឹងច្បាស់ ។ ដោយហេតុនោះ ទើបត្រាស់ថា សុប្បពុទ្ធកុដ្ឋិនេះឯង គួរដើម្បីដឹងធម៌បានក្នុងទីនេះ ដូច្នេះជាដើម ។*

បទថា **អនុបុព្ពិកថំ** *បានដល់ កថាតាមលំដាប់យ៉ាងនេះថា សីលក្នុង*

លំជាប់ទាន សួគ៌ក្នុងលំជាប់សីល មគ្គក្នុងលំជាប់នៃសួគ៌ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់សម្តែងការត្រេកអរ មួយអន្ទើដោយហេតុ បន្ទាប់អំពីនោះ ទ្រង់ប្រកាសទោសដោយនយផ្សេងៗ ដើម្បីឲ្យពួកសត្វបាននូវវិវេក ទើបសម្តែងវិវដ្ត ដោយប្រកាសគុណនៃនេក្ខម្មៈជាប្រធានរបស់ពួកសត្វ ដែលមានហឫទ័យសង្វេគ ព្រោះការស្តាប់ទោស ។

បទថា **ទានកថំ** បានដល់ កថាដែលទាក់ទងដោយគុណរបស់ទាន មានយ៉ាងនេះថា ឈ្មោះថា ទាននេះ ជាហេតុនៃសេចក្តីសុខ ជាមូលនៃសម្បត្តិ ជាទីតាំងនៃភោគៈ ជាទីពឹងពួន ជាទីសម្ងំ ជាគតិ ជាទីទៅខាងមុខរបស់សត្វ ដែលប្រព្រឹត្តទៅតាមផ្លូវដែលមិនស្មើ ទីពឹង ទីពុំនាក់ ទីតោង ទីជ្រកកោន ទីពួន ទីទៅ ទីទៅខាងមុខ ដូចគ្នានឹងទាននេះ មិនមាន ក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី ។ ពិតហើយ ទាននេះ ដូចគ្នានឹងអាសនៈសីហៈ ដែលសម្រេចដោយកែវ ព្រោះអត្ថថា ជាទីពឹង ដូចគ្នានឹងមហាប្រឹថពី ព្រោះអត្ថថា ជាទីពុំនាក់ ដូចគ្នានឹងខ្សែសម្រាប់តោង ព្រោះអត្ថថា ជាគ្រឿងតោង ដូចគ្នានឹងនាវា ព្រោះអត្ថថា ជាទីឆ្លងនូវទុក្ខ ជាអ្នកក្លាហានក្នុងសង្គ្រាម ព្រោះអត្ថថា ជាទីធ្ងន់ចិត្ត ដូចនគរដែលព័ទ្ធដោយគូទឹកជុំវិញ ព្រោះអត្ថថា ជាទីការពារភ័យជុំវិញ ដូចផ្ទាំងភ្នក ព្រោះអត្ថថា មិនត្រូវមន្ទិល គឺសេចក្តីកំណាញ់ ជាដើមបូកលាប ដូចភ្លើង ព្រោះអត្ថថា ជុតនូវមន្ទិល គឺសេចក្តីកំណាញ់ជាដើមនោះ ដូចអាសិរពិស ព្រោះអត្ថថា ត្រេកអរបានលំបាក ដូចរាជសីហ៍ ព្រោះអត្ថថា មិនតក់ស្លុត ដូចដំរី ព្រោះអត្ថថា ទ្រទ្រង់នូវកម្លាំង ដូចគោ

ឧសភពណ៌ាស ព្រោះអត្ថថា ដែលសត្វលោកសន្មតថា ជាមង្គលដ៏ក្រៃលែង ដូចស្តេចសេះវលាហក ព្រោះអត្ថថា នាំទៅដល់ភូមិស្ថានដែលផុតភ័យ ពិតហើយ ទានរមែងឲ្យសិរីរាជសម្បត្តិក្នុងលោក ឲ្យនូវចក្រពត្តិសម្បត្តិ សក្ក-សម្បត្តិ មារសម្បត្តិ ព្រហ្មសម្បត្តិ សាវកបារមីញ្ញាណ បច្ចេកពោធិញ្ញាណ និងឲ្យនូវសម្មាសម្ពោធិញ្ញាណ ព្រោះបុគ្គលឲ្យទាន អាចនឹងសមាទានសីល ដូច្នោះ ទើបទ្រង់សម្តែងសីលកថាក្នុងលំដាប់នៃទានកថា ។

បទថា **សីលកថំ** *បានដល់ កថាដែលទាក់ទងដោយគុណនៃសីល មានពាក្យជាដើមថា ឈ្មោះថា សីលនេះ ជាទីពឹង ជាទីពុំនាក់ ជាទីតោង ជាទីជ្រកកោន ជាទីពួន ជាគតិ ជាទីទៅខាងមុខរបស់សត្វទាំងឡាយ ពិតហើយ ទីពឹង ទីពុំនាក់ ទីតោង ទីជ្រកកោន ទីពួន ទីទៅ ទីទៅខាងមុខរបស់សម្បត្តិក្នុងលោកនេះ និងលោកខាងមុខ ដូចគ្នានឹងសីល មិនមាន គ្រឿងប្រដាប់ដូចគ្នានឹងសីល ផ្កា ដូចគ្នានឹងផ្កា គឺសីល ក្លិន ដូចគ្នានឹងក្លិន គឺសីល មិនមាន ពិតហើយ សត្វលោក មួយអន្លើដោយទេវតា សម្លឹងមើលបុគ្គលដែលប្រដាប់ដោយគ្រឿងអលង្ការ គឺសីល បុគ្គលទ្រទ្រង់នូវផ្កា គឺសីល លាបនូវគ្រឿងក្រអូប គឺសីល រមែងមិនដល់នូវការឆ្អែត ដើម្បីទ្រង់សម្តែងថា បុគ្គលបាននូវស្ថានសួគ៌នោះ ក៏ព្រោះអាស្រ័យសីលនេះ ដូច្នេះ ហើយទើបទ្រង់សម្តែងសគ្គកថាទុកក្នុងលំដាប់នៃសីល ។*

បទថា **សគ្គកថំ** *បានដល់ កថាដែលទាក់ទងដោយគុណនៃស្ថានសួគ៌ មានពាក្យថា ឈ្មោះថា ស្ថានសួគ៌ ជាវត្ថុដែលគួរប្រាថ្នា គួរស្រឡាញ់ គួរ*

ពេញចិត្ត រមែងបាននូវការត្រេកអរក្នុងស្ថានសួគ៌នោះជានិច្ច គឺរមែងបាននូវសម្បត្តិជានិច្ច បានដល់ ទេវតាជាន់ចាតុម្មហារាជ រមែងបានទិព្វសុខ ទិព្វ-សម្បត្តិ ដល់ទៅ ៩ លានឆ្នាំ ទេវតាជាន់តាវត្តិង្ស រមែងបានដល់ទៅ ៣ កោដិ ៦ លានឆ្នាំ ពិតហើយ កាលព្រះពុទ្ធសម្តែងសគ្គសម្បត្តិ ព្រះឱស្ឋមិនគ្រប់គ្រាន់សម្រាប់ត្រាស់ឡើយ ។ សមដូចព្រះតម្រាស់ជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតតប្បីសម្តែងសគ្គកថា ដោយអនេកបរិយាយ ។ ព្រះមានព្រះភាគ កាលទ្រង់លួងលោមដោយកថា សម្តែងសេចក្តីត្រេកអរព្រមដោយហេតុដូចពណ៌នាមកយ៉ាងនេះ ទើបសម្តែងថា សូម្បីស្ថានសួគ៌នេះមិនទៀង មិនស្ថិតស្ថេរ មិនគួរធ្វើសេចក្តីត្រេកអរ ដោយអំណាចការពេញចិត្តក្នុងស្ថានសួគ៌នោះ ប្រៀបដូចបុគ្គលប្រជាប់តាក់តែងជ័រ ហើយកាត់ប្រមោយរបស់ជ័រនោះទៀត ទើបទ្រង់សម្តែងទោស គឺការថោកថយ ការសៅហ្មងរបស់កាមទាំងឡាយ ដោយន័យជាដើមថា កាមទាំងឡាយ មានសុខតិចមានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនោះមានច្រើនក្រៃពេក ។

បណ្តាបទទាំងនោះ បទថា **អាទីនវំ** ប្រែថា ទោស ។ បទថា **ឱការំ** បានដល់ មានការអាក្រក់ជាសភាវៈ អធិប្បាយថា ពួកបុគ្គលមិនប្រសើរ គប្បីសេព ពួកបុគ្គលប្រសើរ មិនគប្បីសេព ទើបឈ្មោះថា មានការអាក្រក់ជាសភាវៈ ។ បទថា **សង្ខិលេសំ** សេចក្តីថា ព្រោះកាមទាំងនោះ ទើបសត្វទាំងឡាយមានសេចក្តីសៅហ្មងក្នុងសង្សារ ។ ព្រោះហេតុនោះឯង ទើបទ្រង់

ត្រាស់ថា ឱហ្ន៎ ! សត្វទាំងឡាយសៅហ្មងហ្ន៎ ។ កាលទ្រង់ឲ្យខ្ជាចដោយ ទោសនៃកាមយ៉ាងនេះហើយ ទើបទ្រង់ប្រកាសអានិសង្សក្នុងនេក្ខម្មៈ គឺការ សម្តែងគុណរបស់បព្វជ្ជា និងគុណក្នុងឈានជាដើម ។

បទថា **កល្យចិត្តំ** *ជាដើម បានដល់ ចិត្តដែលគួរដល់ការងារ គឺចិត្ត ដែលជាទីតាំងនៃការងារ អធិប្បាយថា ជាចិត្តដែលសមគួរដល់ការងារ ដោយ ចូលដល់ភាវៈដែលទទួលទេសនា ដែលទ្រង់ប្រកាសខាងក្រោម និងទេសនា ខាងលើ ព្រោះប្រាសចាកទោសនៃចិត្ត មានភាពជាអ្នកមិនមានសទ្ធាជាដើម ។ ភ្ជាប់សេចក្តីថា ក្នុងគ្រាដែលព្រះមានព្រះភាគទ្រង់ជ្រាបថា សុប្បពុទ្ធកុដ្ឋិនោះ មានចិត្តទន់ ព្រោះប្រាសចាកកិលេស មានទិដ្ឋិ និងមានះជាដើម មានចិត្ត ប្រាសចាកនីវរណៈ ព្រោះប្រាសចាកនីវរណៈ មានកាមច្ឆន្ទនីវរណៈជាដើម ជាអ្នកមានចិត្តរីក ព្រោះប្រកបដោយបីតិ និងជាមោជ្ឈយ៉ាងក្រៃលែង ក្នុង សម្មាបដិបត្តិ និងមានចិត្តផូរផង់ ព្រោះបរិបូណ៌ដោយសទ្ធាក្នុងសម្មាបដិបត្តិ នោះ ។ ម៉្យាងទៀត បទថា* **កល្យចិត្តំ** *បានដល់ ចិត្តមិនមានរោគ ព្រោះ ប្រាសចាកកាមច្ឆន្ទនីវរណៈ ។ បទថា* **មុទុចិត្តំ** *បានដល់ ចិត្តមិនរឹងត្អឹង ដោយអំណាចមេត្តា ព្រោះប្រាសចាកព្យាបាទ ។ បទថា* **វិនីវរណចិត្តំ** *បានដល់ ចិត្តដែលមិនត្រូវរារាំង ព្រោះមិនរាយមាយ ដោយប្រាសចាកឧទ្ធច្ចៈ និងកុក្កុច្ចនីវរណៈ ។ បទថា* **ឧទគ្គចិត្តំ** *បានដល់ ចិត្តមិនរួញរា ដោយ អំណាចផ្គង ដោយប្រាសចាកថីនមិទ្ធនីវរណៈ ។ បទថា* **បសន្នចិត្តំ** *បានដល់ ចិត្តដែលបង្អោនទៅក្នុងសម្មាបដិបត្តិ ដោយប្រាសចាកវិចិកិច្ឆានីវរណៈ ។*

សព្ទថា **អថ** *ប្រែថា ខាងក្រោយ ។ បទថា* **សាមុក្កំសិកា** *បានដល់ ទេសនាដែលទ្រង់សម្តែងឯង គឺទ្រង់លើកឡើងសម្តែងដោយព្រះអង្គឯង បានដល់ ទ្រង់ឃើញឯង ដោយព្រះសយម្ភូញាណ អធិប្បាយថា មិនទូទៅដល់ជនដទៃ ។ សួរថា ទេសនានោះឈ្មោះអ្វី ។ ឆ្លើយថា ឈ្មោះអរិយសច្ច-ទេសនា ។ ដោយហេតុនោះឯង ទើបទ្រង់ត្រាស់ថា ទុក្ខសមុទយ និរោធ និង មគ្គក្នុងកាលនោះ ។ ក្នុងសេចក្តីនេះ ជាការសម្តែងសច្ចៈដោយសរុប ។ ព្រោះ ដូច្នោះ ទើបក្នុងទីនេះគួរសម្តែងអរិយសច្ច ។ អរិយសច្ចទាំងនោះ កាល ពោលដោយអាការទាំងពួង គឺដោយពិស្តារ លោកពោលហើយ ក្នុងគម្ពីរ វិសុទ្ធិមគ្គ ព្រោះដូច្នោះ គប្បីជ្រាបដោយនយដែលពោលហើយ ក្នុងគម្ពីរ វិសុទ្ធិមគ្គនោះឯង ។*

ព្រះមានព្រះភាគ ទ្រង់សម្តែងការលះកិលេស និងការញុំាងអរិយមគ្គឲ្យ កើតឡើងដល់សុប្បពុទ្ធ ដោយអំណាចឧបមា ដោយពាក្យថា **សេយ្យថាបិ** *ដូច្នេះជាដើម ។ បទថា* **អបគតកាឡកំ** *ប្រែថា ប្រាសចាកធម៌ចំណែកខ្មៅ ។ បទថា* **សម្មទេវ** *ប្រែថា ដោយល្អនោះឯង ។ បទថា* **រជនំ** *បានដល់ ទឹក ជ្រលក់ មានពណ៌ខៀវ លឿង ក្រហម និងហង្សបាទជាដើម ។ បទថា* **បដិគ្គណ្ហេយ្យ** *ប្រែថា គប្បីទទួល គឺគប្បីជាសំពត់ដែលផូរផង់ ។ បទថា* **តស្មីយេវ អាសនេ** *បានដល់ ក្នុងទីអង្គុយនោះឯង ។ ដោយពាក្យនេះ ឈ្មោះថា ទ្រង់សម្តែងដល់ភាពដែលសុប្បពុទ្ធកុដិនោះ មានការឃើញច្បាស់ បានរហ័ស មានបញ្ញាមុតស្រួច និងជាសុខាបដិបទាទិប្បាភិញ្ញាបុគ្គល ។ បទ*

ថា **វិរជំ វិតមលំ** *សេចក្តីថា ឈ្មោះថា ប្រាសចាកធូលី ព្រោះមិនមានធូលី គឺរាគៈជាដើម ដែលជាហេតុនាំសត្វទៅកាន់អបាយ ឈ្មោះថា ប្រាសចាកមន្ទិល ព្រោះប្រាសចាកមន្ទិល គឺទិដ្ឋិ និងវិចិកិច្ឆា មិនមានចំណែកសល់ឡើយ ។ ម្យ៉ាងទៀត ឈ្មោះថា ប្រាសចាកធូលី ព្រោះមិនមានធូលី គឺកិលេស ដែលសោតាបត្តិមគ្គគប្បីសម្លាប់ ឈ្មោះថា ប្រាសចាកមន្ទិល ព្រោះប្រាសចាកភាពជាអ្នកទ្រុស្តសីល ៥ ។ បទថា* **ធម្មចក្ខុំ** *លោកសំដៅដល់សោតាបត្តិផល ។ ដើម្បីទ្រង់សម្តែងការកើតឡើងនៃធម្មចក្ខុនោះ ទើបត្រាស់ថា របស់ឯណានីមួយ មានការកើតឡើងជាធម្មតា របស់នោះសុទ្ធតែមានការរលត់ទៅជាធម្មតា ។ ធម្មតា ចក្ខុនោះ សូម្បីធ្វើនិរោធឲ្យជាអារម្មណ៍ហើយ ក៏ចាក់ធ្លុះនូវសង្ខតធម៌ ដោយអំណាចកិច្ចនោះឯងកើតឡើង ។ ក្នុងសេចក្តីនោះ មានការប្រៀបធៀបឧបមាដូចតទៅនេះ ចិត្តគប្បីឃើញដូចសំពត់ ភាវៈដែលចិត្តសៅហ្មងដោយមន្ទិល មានរាគៈជាដើម គប្បីឃើញដូចភាវៈដែលសំពត់ប្រឡាក់ដោយមន្ទិល ដែលហុយមកជូថ្នោះ អនុបុព្វីកថា គប្បីឃើញដូចបន្ទះក្តារសម្រាប់ជោកគក់ សទ្ធា គប្បីឃើញដូចទឹក ការប្រើទឹក គឺសទ្ធាជ្រលក់ឲ្យសើម ហើយប្រើសតិ សមាធិ និងបញ្ញា ធ្វើទោសៈឲ្យថយចុះ ហើយប្រារព្ធព្យាយាម ជម្រះចិត្តឲ្យស្អាត ដោយវិធី មានសុតៈជាដើម គប្បីឃើញដូចការយកទឹកត្រាំសំពត់ឲ្យសើម ហើយប្រើទឹកក្សុងគោម័យជូសត្រង់ទីប្រឡាក់ ព្រោះការប្រកបនោះ ។ អរិយមគ្គ គប្បីឃើញដូចទឹកជ្រលក់ ។ ការជម្រះចិត្តដែលសង្ខត់កិលេសបានហើយ ឲ្យផូរផង់ដោយមគ្គ គប្បីឃើញ*

ដូចសំពត់ដែលស្អាតផូរផង់ ដោយការជោក និងជ្រលក់នោះ ដូច្នោះ ។

សុប្បពុទ្ធអង្គុយត្រង់ចុងបរិស័ទ ស្តាប់ព្រះធម្មទេសនា សម្រេចសោតាបត្តិផលយ៉ាងនេះហើយ មានបំណងនឹងក្រាបទូលដល់គុណដែលខ្លួនបានទទួលដល់ព្រះសាស្តា កាលមិនអាចឈមចុះកាន់កណ្តាលបរិស័ទបាន ក្នុងកាលដែលមហាជនថ្វាយបង្គំព្រះសាស្តា ហើយតាមជួនដំណើរព្រះសាស្តានាំគ្នាត្រឡប់ កាលព្រះមានព្រះភាគយាងទៅកាន់ព្រះវិហារ សូម្បីខ្លួនឯង ក៏បានទៅកាន់វិហារដែរ ។ គ្រានោះ សក្កទេវរាជទ្រង់ជ្រាបថា សុប្បពុទ្ធកុដិនេះមានបំណងនឹងប្រកាសគុណ ដែលខ្លួនទទួលក្នុងព្រះសាសនារបស់ព្រះសាស្តា ឲ្យប្រាកដ គិតនឹងសាកល្បង ទើបយាងទៅប្រថាប់នៅក្នុងអាកាស បានត្រាស់ពាក្យនេះថា សុប្បពុទ្ធ អ្នកជាបុគ្គលក្រីក្រ ជាបុគ្គលកំព្រា ជាជនទុគ៌ត ខ្ញុំនឹងឲ្យទ្រព្យ មិនមានប្រមាណដល់អ្នក តែចូរអ្នកពោលថា ព្រះពុទ្ធមិនមែនព្រះពុទ្ធ ព្រះធម៌មិនមែនព្រះធម៌ ព្រះសង្ឃមិនមែនព្រះសង្ឃ ខ្ញុំលះបង់ព្រះពុទ្ធ ខ្ញុំលះបង់ព្រះធម៌ ខ្ញុំលះបង់ព្រះសង្ឃ ។ លំដាប់នោះ ទើបសុប្បពុទ្ធពោលនឹងសក្កៈនោះថា អ្នកជានរណា ព្រះឥន្ទ្រឆ្លើយថា ខ្ញុំជាសក្កទេវរាជ សុប្បពុទ្ធកុដ្ឋិពោលថា នែបុគ្គលអន្ធពាល មិនមានខ្មាស អ្នកពោលពាក្យដែលមិនគួរពោលយ៉ាងនេះ មិនគួរពោលជាមួយខ្ញុំឡើយ ម្យ៉ាងទៀត ព្រោះហេតុអ្វី ទើបអ្នកនិយាយជាមួយខ្ញុំថា ជាមនុស្សក្រីក្រ ទុគ៌ត កំព្រា ខ្ញុំជាឱរសរបស់ព្រះលោកនាថមិនមែនឬ ខ្ញុំមិនក្រីក្រ មិនកំព្រា ពិតហើយ ខ្ញុំបានទទួលសេចក្តីសុខយ៉ាងក្រៃលែង ជាអ្នកមានទ្រព្យច្រើន ដូច្នេះហើយ ទើបលោកពោលក្នុង

អង្គុត្តរនិកាយ សត្តកនិបាតថា

ទ្រព្យ គឺសទ្ធា ទ្រព្យ គឺសីល ទ្រព្យ គឺហិរិ ទ្រព្យ គឺឱត្តប្បៈ ទ្រព្យ គឺសុតៈ ទ្រព្យ គឺចាគៈ ទ្រព្យ គឺបញ្ញាជាគម្រប់ ៧ បុគ្គលណា ទោះស្ត្រីក្តី បុរសក្តី មានទ្រព្យទាំងនេះ អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថា ជាអ្នកមិនទ័លក្រ ការរស់នៅរបស់បុគ្គលនោះ មិនសោះសូន្យឡើយ ដូច្នេះ ។

ដូច្នោះ ខ្ញុំឈ្មោះថា មានអរិយទ្រព្យ ៧ ប្រការ ព្រោះបុគ្គលដែលមានអរិយទ្រព្យទាំងនេះ ព្រះពុទ្ធ ឬព្រះបច្ចេកពុទ្ធមិនត្រាស់ហៅថា ជាមនុស្សក្រីក្រឡើយ ។ សក្កទេវរាជស្តាប់ពាក្យរបស់សុប្បពុទ្ធហើយ ទើបជាត់ខ្ជួនក្នុងរវាងផ្លូវនោះឯង យាងទៅគាល់ព្រះសាស្តា ក្រាបទូលពាក្យទាំងអស់នោះជល់ព្រះសាស្តា ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់នឹងសក្កៈថា ម្នាលសក្កៈ ទេវតាដូចអ្នកវាប់រយ រាប់ពាន់ ក៏មិនអាចឲ្យសុប្បពុទ្ធកុដ្ឋិពោលថា ព្រះពុទ្ធមិនមែនព្រះពុទ្ធ ព្រះធម៌មិនមែនព្រះធម៌ ព្រះសង្ឃមិនមែនព្រះសង្ឃ សូម្បីសុប្បពុទ្ធកុដ្ឋិក៏ទៅគាល់ព្រះសាស្តាៗ ទ្រង់ធ្វើបដិសណ្ឋារៈហើយ ទើបក្រាបទូលជល់គុណដែលខ្លួនបានទទួល ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ សុប្បពុទ្ធោ កុដ្ឋិ ទិដ្ឋធម្មោ បត្តធម្មោ** *ដូច្នេះជាដើម ។*

[๑๑๓] *បណ្តាបទទាំងនោះ បទថា* **ទិដ្ឋធម្មោ** *សេចក្តីថា ឈ្មោះថាជាអ្នកឃើញធម៌ ព្រោះឃើញអរិយសច្ចធម៌ ។ ក្នុងបទដ៏សេស ក៏នយនេះដូចគ្នា ។ បណ្តាបទទាំងនោះ* **ធម្ម** *សព្ទ ក្នុងបទថា* **ទិដ្ឋធម្មោ** *នេះ សំដៅ*

ដល់ពាក្យសាមញ្ញ ឈ្មោះថា ទស្សនៈដទៃអំពីញាណទស្សនៈ ក៏នៅមាន ព្រោះហេតុនោះ ទស្សនៈនោះលោកហៅថា **បត្តធម្មោ** *ដើម្បីសម្តែងនិវត្តនៈ គឺនិរោធសច្ច ។ ការសម្រេចដទៃអំពីញាណសម្បត្តិ ក៏នៅមាន ព្រោះហេតុនោះ ទើបលោកហៅថា* **វិទិតធម្មោ** *គឺអ្នកឃើញច្បាស់នូវធម៌ ដើម្បីឲ្យប្លែកទៅអំពីញាណទស្សនៈនោះ ។ ភាពជាអ្នកដឹងច្បាស់នូវធម៌នេះ ចាត់ជាចំណែកមួយក្នុងធម៌ទាំងឡាយ ព្រោះដូច្នោះ ដើម្បីសម្តែងភាពជាអ្នកដឹងច្បាស់នូវធម៌នោះដោយគ្រប់ចំណែក ទើបលោកពោលថា* **បរិយោគាឡ្ហ-ធម្មោ** *គឺអ្នកឈមចុះដល់ធម៌ ។ ព្រោះហេតុនោះ ទើបទ្រង់សម្តែងចំពោះការត្រាស់ដឹងសច្ចៈតាមដែលពោលហើយ ដល់បុគ្គលនោះ ។ ពិតហើយ មគ្គញ្ញាណឲ្យសម្រេចបរិញ្ញាកិច្ចជាដើម ដោយអំណាចការត្រាស់ដឹងលើកទី ១ ឈ្មោះថា ឈមចុះកាន់ញេយ្យធម៌គ្រប់ចំណែកដោយជុំវិញ មិនមែនប្រើញាណដទៃក្រៅអំពីមគ្គញ្ញាណនោះ ។ ដោយហេតុនោះ ទើបលោកពោលថា* **ឯដ្ឋោ អរិយសច្ច ធម្មោ ឯតេនាតិ ឯដ្ឋធម្មោ** *ដូច្នេះជាដើម ។ ព្រោះហេតុនោះឯង ទើបលោកពោលពាក្យជាដើមថា* **តិណ្ណាវិចិកិច្ឆោ** *គឺអ្នកឆ្លងសេចក្តីសង្ស័យបានហើយ ដូច្នេះ ។*

ក្នុងធម៌ទាំងនោះ បុគ្គលឈ្មោះថា **តិណ្ណាវិចិកិច្ឆោ** *ព្រោះឆ្លងសេចក្តីសង្ស័យ មានវត្ថុ ១៦ ប្រការ និងមានវត្ថុ ៨ ប្រការ ដូចគ្នានឹងផ្លូវកន្តារដែលមានភ័យ ។ ក្នុងបណ្តាធម៌ មានបវត្តិ (ទុក្ខសច្ច) ជាដើម ចាកធម៌នោះឯង ឈ្មោះថា* **វិគតកថង្កថោ** *ព្រោះប្រាសចាក គឺកាត់នូវការ*

សង្ស័យ ដែលប្រព្រឹត្តទៅយ៉ាងនេះថា អញបានកើតយ៉ាងនេះឬហ្ន៎ ។ ឈ្មោះ ថា **វេសារជ្ជប្បត្តោ** *ព្រោះដល់នូវភាពអង់អាច គឺការៈនៃបុគ្គលអង់អាច បានដល់ ភាពជាអ្នកជំនាញ និងលះបាបធម៌ ដែលធ្វើភាពមិនក្លៀវក្លា និង ព្រោះតាំងនៅដោយល្អក្នុងគុណ មានសីលជាដើម ដែលជាសត្រូវចំពោះ បាបធម៌នោះ ។ ឈ្មោះថា* **អបរប្បច្ចយោ** *ព្រោះមិនមានអ្នកដទៃឧបការៈ គឺមិនបានប្រព្រឹត្តក្នុងសាសនានេះ ដោយជឿចំពោះអ្នកដទៃ ។ ក្នុងពាក្យថា* **អភិក្ខណំ ភន្តេ** *ជាដើម មានវិនិច្ឆ័យដូចតទៅនេះ* **អភិក្ខណ** *សព្ទនេះ ប្រាកដ ក្នុងអត្ថច្រើនយ៉ាង មានអត្ថថា អស់ទៅ ល្អ រុងរឿង និងអនុមោទនា ក្រៃលែងជាដើមដោយពិត តែក្នុងទីនេះ គប្បីឃើញ* **អភិក្ខណ** *សព្ទ ប្រើក្នុង អត្ថថា អនុមោទនាក្រៃលែង ។ ដោយហេតុនោះឯង ទើប* **អភិក្ខណ** *សព្ទ នោះ លោកពោលដល់ទៅ ២ ដង គឺដោយការជ្រះថ្លា ១ ដោយការ សរសើរ ១ ។ អធិប្បាយថា សាធុ សាធុ ព្រះអង្គ ។ ម្យ៉ាងទៀត បទថា* **អភិក្ខណំ** *ប្រែថា គួរស្រឡាញ់ គួរជ្រះថ្លា គួរពេញចិត្តក្រៃលែង អធិប្បាយ ថា ល្អក្រៃលែង ។ ក្នុង ២ សព្ទនោះ សុប្បពុទ្ធកុដ្ឋិសរសើរទេសនារបស់ ព្រះមានព្រះភាគ ដោយ* **អភិក្ខណ** *សព្ទ ១ សរសើរការជ្រះថ្លារបស់ខ្លួន ដោយ* **អភិក្ខណ** *សព្ទ ១ ទៀត ។ ពិតហើយ ក្នុងសេចក្តីនោះ មាន អធិប្បាយដូចតទៅនេះ ព្រះធម្មទេសនានៃព្រះមានព្រះភាគជាក់ច្បាស់ពន់ពេក ការជ្រះថ្លារបស់ខ្ញុំព្រះអង្គ ព្រោះអាស្រ័យធម្មទេសនារបស់ព្រះមានព្រះភាគ ជាក់ច្បាស់ពន់ពេក ។ ម្យ៉ាងទៀត សុប្បពុទ្ធកុដ្ឋិពោលបទសរសើរព្រះ*

តម្រាស់របស់ព្រះមានព្រះភាគប៉ុណ្ណោះថា ជាក់ច្បាស់ពន់ពេក ដោយឲ្យ ទោសៈវិនាសទៅ ជាក់ច្បាស់ពន់ពេក ដោយសម្រេចនូវគុណ ជាក់ច្បាស់ ពន់ពេក ដោយនាំមកនូវសទ្ធា ដោយឲ្យកើតបញ្ញា មួយអន្ទើដោយអត្ថ មួយ អន្ទើដោយព្យញ្ជនៈ ដោយបទដ៏ងាយ ដោយអត្ថដ៏ជ្រាលជ្រៅ ពីរោះដល់ ត្រចៀក ដោយចាប់ចិត្ត ដោយមិនលើកខ្ជួន ដោយមិនសង្កត់សង្កិនអ្នកដទៃ ដោយត្រជាក់ព្រោះករុណា ដោយការផ្សព្វផង់នៃបញ្ញា ដោយជួបនូវអារម្មណ៍ ដោយជកចំពោះការញ៉ាំញ៉ី ជាសុខដល់អ្នកស្តាប់ ជាប្រយោជន៍ដល់អ្នក ពិចារណា បន្តាប់អំពីនោះ ទើបសរសើរចំពោះទេសនា ដោយឧបមា ៤ យ៉ាង ។

បណ្តាបទទាំងនោះ បទថា **ឯកុទ្ធដិតំ** *បានដល់ ផ្តាប់ ឬមានមាត់ចុះ ក្រោម ។ បទថា* **ឧក្កុជ្ជេយ្យ** *បានដល់ គប្បីផ្ងារឡើង ។ បទថា* **បដិច្ឆន្នំ** *បានដល់ បិទដោយស្មៅ និងស្លឹកឈើជាដើម ។ បទថា* **វិវរេយ្យ** *ប្រែថា គប្បីបើក ។ បទថា* **មូឡ្ហស្ស** *បានដល់ ដែលវង្វេងទិស ។ បទថា* **មគ្គំ អាចិក្ខេយ្យ** *សេចក្តីថា ចាប់ដៃហើយ ចង្អុលផ្លូវថា នុ៎ះផ្លូវ ។ បទថា* **អន្ធការេ** *បានដល់ ក្នុងទីងងឹតប្រកបដោយអង្គ ៨ នេះជាអត្ថជាបឋម ។ ឯ ការប្រកបអធិប្បាយ មានដូចតទៅនេះ ព្រះមានព្រះភាគ កាលឲ្យអាត្មាអញ បែរមុខចេញអំពីព្រះសទ្ធម្ម ធ្លាក់នៅក្នុងអសទ្ធម្ម ហើយឲ្យចេញអំពីអសទ្ធម្ម ដូចបុគ្គលណាម្នាក់ ផ្ងារភាជនៈដែលផ្តាប់ ដូច្នោះ ទ្រង់បើកព្រះសាសនាដែល ស្មុក គឺមិច្ឆាទិដ្ឋិបិទបាំង តាំងអំពីព្រះសាសនារបស់ព្រះមានព្រះភាគព្រះនាម*

កស្សបៈអន្តរធានទៅ ដូចបុគ្គលបើកភាជនៈដែលបិទ ដូច្នោះ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវស្ថានសួគ៌ និងព្រះនិព្វានដល់អាត្មាអញ ដែលដើរទៅក្នុងផ្លូវអាក្រក់ផ្លូវខុស ដូចបុគ្គលប្រាប់ផ្លូវដល់មនុស្សដែលវង្វេង ដូច្នោះ កាលលិចចុះក្នុងងងឹត គឺមោហៈ មិនឃើញរូបរតនៈ មានពុទ្ធរតនៈជាដើម ទើបទ្រង់ប្រកាសធម៌ដោយអនេកបរិយាយ ព្រោះប្រកាសដោយនយផ្សេងៗ ដោយទ្រទ្រង់នូវពន្លឺនៃទេសនា ដែលកម្ចាត់ងងឹត គឺមោហៈ ដែលជាតួបិទបាំងរតនៈ មានពុទ្ធរតនៈជាដើម ដូចបុគ្គលអុជប្រទីបក្នុងទីងងឹត ដូច្នោះ ។ កាលសរសើរទេសនាយ៉ាងនេះហើយ មានចិត្តជ្រះថ្លាក្នុងព្រះរតនត្រ័យ ដោយទេសនានោះ កាលធ្វើអាការជ្រះថ្លា ទើបពោលពាក្យជាដើមថា **ឯសាហំ** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **ឯសាហំ** *កាត់បទថា* **ឯសោ អហំ។** *បទថា* **ភគវន្តំ សរណំ គច្ឆាមិ** *សេចក្តីថា ខ្ញុំព្រះអង្គសូមដល់ សូមសេពគប់ សូមជិង ឬសូមឈមចុះនូវព្រះមានព្រះភាគ ដោយបំណងនេះថា ព្រះមានព្រះភាគជាសរណៈ ជាទីពឹងក្នុងខាងមុខ ជាទីកម្ចាត់ទុក្ខ ជាទីទ្រទ្រង់នូវប្រយោជន៍របស់ខ្ញុំព្រះអង្គ ។ ពិតហើយ គតិ ជាអត្ថនៃភាពទាំងឡាយណា ដល់នូវពុទ្ធិជាអត្ថនៃធាតុទាំងនោះ ។ បទថា* **ធម្មំ** *សេចក្តីថា ឈ្មោះថា ធម៌ ព្រោះទ្រទ្រង់នូវបុគ្គលដែលសម្រេចមគ្គ ដែលធ្វើឲ្យជាក់ច្បាស់នូវនិព្វាន អ្នកបដិបត្តិតាមដែលទ្រង់ប្រៀនប្រដៅ មិនឲ្យធ្លាក់ទៅក្នុងអបាយ ៤ ព្រះធម៌នោះ ដោយអត្ថ គឺអរិយមគ្គ និងព្រះនិព្វាននោះឯង ។ សមដូចព្រះតម្រាស់ដែលត្រាស់ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាតថា ម្នាលភិក្ខុទាំងឡាយ ពួកសង្ឃតធម៌ ធម៌ដែល*

បច្ចយតាក់តែងទាំងប៉ុន្មាន មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ប្រាកដជាប្រសើរជាងពួកសង្ខតធម៌ទាំងនោះ ។ និងថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មានជាសង្ខតធម៌ក្តី អសង្ខតធម៌ក្តី វិរាគធម៌ប្រាកដជាប្រសើរជាងពួកធម៌ទាំងនោះ ដូច្នេះ ។ មិនត្រឹមតែអរិយមគ្គ និងព្រះនិព្វានតែម្យ៉ាងប៉ុណ្ណោះទេ ដែលតថាគតពោលថា ប្រសើរ សូម្បីព្រះបរិយត្តិធម៌ មួយអន្ទើដោយអរិយផល តថាគតក៏ពោលថា ប្រសើរ ដូចគ្នា ។ សមដូចព្រះតម្រាស់ដែលត្រាស់ក្នុងខុទ្ទកនិកាយ វិមានវត្ថុថា

វិរាគវិរាគមនេញ្ជមសោកំ ធម្មសង្ខតមប្បដិក្កូលំ មធុរមិមំ បគុណាំ សុវិភត្តំ ធម្មមិមំ សរណាត្ថមុបេហិ ។

អ្នកចូរដល់នូវធម៌ ដែលប្រាសចាករាគៈ (អរិយមគ្គ) មិនរំភើប មិនមានសោក (អរិយផល) ជាសង្ខារធម៌ដែលបច្ចយប្រជុំតាក់តែងមិនបាន ជាធម៌មិនគួរខ្ពើម ជាធម៌ដ៏ពីរោះ ដ៏ល្អិត ដែលលោកចែកត្រឹមត្រូវហើយ ដើម្បីជាសរណៈចុះ ដូច្នេះ ។

ពិតហើយ ក្នុងគាថានេះ មគ្គ ត្រាស់ថា ជាធម៌ គឺខ្លាក់ចោលនូវរាគៈ ។ បទថា **អនេជមសោកំ** បានដល់ អរិយផល ។ បទថា **អសង្ខតំ** បានដល់ ព្រះនិព្វាន ។ ដោយពាក្យថា **អប្បដិក្កូលំ មធុរមិមំ បគុណាំ សុវិភត្តំ** នេះ ទ្រង់បំណងដល់ព្រះបរិយត្តិធម៌ ។

បទថា **ភិក្ខុសង្ឃំ** បានដល់ ពួកនៃព្រះអរិយបុគ្គល ៨ ដែលប្រៀបធៀបគ្នា ដោយការស្មើគ្នា ដោយទិដ្ឋិ និងសីល ។ ដោយលំដាប់ពាក្យមាន

ប្រមាណប៉ុណ្ណោះ សុប្បពុទ្ធកុដ្ឋិបានប្រកាសដល់ត្រៃសរណាគមន៍ ។

បទថា **អជ្ជតគ្គេ** *ក្នុងពាក្យថា* **ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ ចាណុបេតំ សរណំ គតំ** *នេះ ប្រែថា តាំងអំពីថ្ងៃនេះជាដើមទៅ ។ បាលីថា* **អជ្ជគ្គេ** *ដូច្នេះក៏មាន ។* **គ** *អក្សរៈ ក្នុងបទថា* **អជ្ជគ្គ** *នេះ ធ្វើនូវការភ្ជាប់បទ សេចក្តីថា* **អជ្ជ អគ្គេ អជ្ជ អាធិ កត្វា** *ប្រែថា ក្នុងទីបំផុតថ្ងៃនេះ គឺតាំងអំពីថ្ងៃនេះជាដើមទៅ ។ បទថា* **ចាណុបេតំ** *បានដល់ ប្រកបដោយខ្យល់ដង្ហើមចេញ-ចូល អធិប្បាយថា ជីវិតរបស់ខ្ញុំព្រះអង្គរស់នៅដរាបណាសូមព្រះមានព្រះភាគ ទ្រង់ចាំ គឺជីវិតខ្ញុំព្រះអង្គថា ជាអ្នកចូលដល់ គឺដល់សរណៈដោយត្រៃសរណាគមន៍ ដែលមិនទូទៅដល់សាស្តាដទៃ បុគ្គលឈ្មោះថា ឧបាសក គឺកប្បិយការកៈ ព្រោះចូលដល់ព្រះរតនត្រ័យដរាបនោះ ។ ការដល់សរណាគមន៍របស់សុប្បពុទ្ធនេះសម្រេចហើយ ដោយការសម្រេចអរិយ-មគ្គនោះឯង តែកាលធ្វើអធ្យាស្រ័យរបស់ខ្លួនឲ្យជាក់ច្បាស់ ទើបក្រាបទូលយ៉ាងនោះ ។*

បទថា **ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា** *សេចក្តីថា កាលមានចិត្តត្រេកអរចំពោះព្រះតម្រាស់នៃព្រះមានព្រះភាគហើយ កាលនឹងប្រកាសថា ខ្លួនត្រេកអរក្នុងព្រះតម្រាស់នោះឯង ទើបអនុមោទនាដោយវាចា ដោយន័យដូចពោលហើយ ។ បទថា* **អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ** *សេចក្តីថា កាលថ្វាយបង្គំព្រះមានព្រះភាគនោះ ដោយបញ្ចង្គប្រតិស្ឋានហើយ ធ្វើប្រទក្សិណ ៣ ជុំ មានចិត្តបង្អោនទៅក្នុងគុណរបស់ព្រះសាស្តា សម្ដែងមើល*

បណ្តើរ ផ្តងអញ្ជលីបណ្តើរ នមស្ការព្រះមានព្រះភាគនោះឯង រហូតដាច់កន្ទុយភ្នែក ទើបចៀសចេញទៅ ។ សុប្បពុទ្ធកុដ្ឋិចៀសចេញទៅ ដែលមានម្រាមដៃ-ម្រាមជើងកំបុត ព្រោះត្រូវរោគឃ្លង់បៀតបៀន មានខ្លួនប្រឡាក់លាមក មានរបស់មិនស្អាតហូរចេញពេញខ្លួន ត្រូវបូសបៀតបៀន មិនស្អាត មានក្លិនស្អុយ គួរខ្ពើមរអើមក្រៃពេក ដល់នូវភាពជាបុគ្គលគួរកុណាក្រៃលែង ត្រូវមេគោកូនខ្ចី ដែលត្រូវបាបកម្មចូលទៅកាត់ផ្តាច់ឲ្យប្រព្រឹត្តទៅដើម្បីមានអាយុតិច ដែលខ្លួនបានសន្សំហើយជាស់តឿន កាលបុញ្ញកម្មឲ្យប្រព្រឹត្តទៅដើម្បីស្តានសួគ៌បានឱកាស ហាក់ដូចសេចក្តីប្រាថ្នាកើតឡើងថា កាយនេះ មិនសមគួរជាទីទ្រទ្រង់អរិយធម៌ដ៏ប្រណីតក្រៃលែង ដែលស្ងប់ពិតដូច្នេះ រំងឲ្យដួល ស្ងាប់ទៅ ។ ដោយហេតុនោះ ទើបលោកពោលថា គ្រានោះ មេគោកូនខ្ចី មកបុះសុប្បពុទ្ធកុដ្ឋិដែលទើបនឹងចេញទៅមិនយូរប៉ុន្មាន ឲ្យដាច់ចាកជីវិត ដូច្នេះជាដើម ។

បានឮថា ក្នុងអតីតកាល សុប្បពុទ្ធកុដ្ឋិនោះ ជាកូនសេដ្ឋីម្នាក់ កំពុងលេងជាមួយនឹងសេដ្ឋីបុត្រ ៣ នាក់ ជាសម្ងាញ់របស់ខ្លួន នាំស្រីនគរសោកិនីទៅកាន់ឧទ្យាន សោយសម្បត្តិអស់មួយថ្ងៃ កាលព្រះអាទិត្យលិចទៅ បានពោលពាក្យនេះនឹងសម្ងាញ់ទាំងឡាយថា មាសជាច្រើន ដល់ទៅ ១០០០ កហាបណៈ និងគ្រឿងប្រដាប់មានតម្លៃច្រើន ដែលមានក្នុងដៃរបស់ស្រីនេះក្នុងទីនេះ មិនមានអ្នកដទៃ ហើយក៏ជាពេលព្រលប់ផងដែរ ណ្ហើយចុះ ពួកយើងនាំគ្នាសម្លាប់ស្រីនេះឲ្យស្ងាប់ហើយ កាន់យកទ្រព្យទាំងអស់ទៅ ។ ជន

ទាំង ៤ នាក់នោះ មានអធ្យាស្រ័យតែមួយ ទើបចូលទៅដើម្បីសម្លាប់ស្រីនោះ ។ ស្រីនោះកាលត្រូវជនទាំងនោះសម្លាប់ បានតាំងសេចក្តីប្រាថ្នាថា ជនទាំងនេះមិនមានហិរិ គ្មានករុណា ធ្វើសន្តវៈដោយអំណាចកិលេសជាមួយនឹងអញហើយ សម្លាប់អញដែលមិនមានកំហុស ព្រោះចំណង់ក្នុងទ្រព្យតែម្យ៉ាង ជនទាំងនេះសម្លាប់អញម្តង ឯអញសូមកើតជាយក្ខិនី ក៏អាចសម្លាប់ជនទាំងនេះបានច្រើនដង ដូច្នេះហើយ ក៏ស្លាប់ទៅ ។ បានឮថា មនុស្សទាំងនោះ ម្នាក់បានជាកុលបុត្រ ឈ្មោះបុក្កុសៈ ម្នាក់ជាពាហិយទារុចីរិយៈ ម្នាក់ជាតម្ពទាឋិកៈ អ្នកសម្លាប់ចោរ និងម្នាក់ទៀតជាសុប្បពុទ្ធកុដ្ឋិ ។ ក្នុងច្រើនរយអត្តភាព ជនទាំង ៤ នេះ នាងកើតជាមេគោក្នុងកំណើតយក្ខផ្តាច់ជីវិតជនទាំងនោះ ។ ដោយវិបាកវបស់កម្មនោះ អ្នកទាំងនោះដល់នូវការស្លាប់ក្នុងរវាងអត្តភាពនោះៗ ។ សុប្បពុទ្ធកុដ្ឋិស្លាប់ដោយទាន់ហន់ ដោយអាការយ៉ាងនេះ ។ ដោយហេតុនោះ ទើបលោកពោលថា **អថខោ អចិរប្បក្កន្តំ ។បេ។ ភោភោ-បេសិ** *ដូច្នេះជាដើម ។*

សម័យនោះឯង ភិក្ខុច្រើនរូបក្រាបទូលដំណឹងមរណភាពរបស់សុប្បពុទ្ធកុដ្ឋិ ដល់ព្រះមានព្រះភាគហើយ ទើបទូលសួរដល់ភពខាងមុខ ។ ព្រះមានព្រះភាគទ្រង់ព្រាសព្យាករហើយ ។ ដោយហេតុនោះ ទើបលោកពោលថា **អថខោ សម្ពហុលា ភិក្ខូ** *ជាដើម ។*

បណ្តាបទទាំងនោះ បទថា **តិណ្ណំ សញ្ញោជនានំ បរិក្ខយា** *សេចក្តីថា ព្រោះការលះដោយសមុច្ឆេទនូវគ្រឿងចងក្នុងភព ៣ នេះ គឺសក្កាយទិដ្ឋិ វិចិកិច្ឆា*

និងសីលព្វតបរាមាស ។ បទថា **សោតាបន្នោ** *បានដល់ បុគ្គលសម្រេចអរិយមគ្គ ពោល គឺក្រៃសែដំបូង ។ សមដូចពាក្យដែលលោកពោលថា ម្នាលសារីបុត្ត គេតែងពោលថា សោតៈៗ ដូច្នេះ ម្នាលសារីបុត្ត ចុះសោតៈ តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាសោតៈ ដូច្នេះជាដើម ។ បទថា* **អវិនិបាតធម្មោ** *ប្រែថា មិនមានការធ្លាក់ចុះជាធម្មតា ឈ្មោះថា ជាអ្នកមានការមិនធ្លាក់ចុះជាធម្មតា ព្រោះលោកមិនមានការធ្លាក់ចុះជាធម្មតា អធិប្បាយថា មិនមានការធ្លាក់ទៅដោយអំណាចការកើតក្នុងអបាយ ៤ ជាសភាវៈ ។ បទថា* **និយតោ** *បានដល់ ពិតប្រាកដដោយធម្មនិយាម គឺដោយកំណត់ពិតប្រាកដ ។ បទថា* **សម្ពោធិបរាយនោ** *សេចក្តីថា ជាអ្នកត្រាស់ដឹងខាងមុខ ព្រោះការត្រាស់ដឹង ពោល គឺមគ្គ ៣ ខាងលើ គប្បីជាទីទៅ ជាគតិ ជាទីពឹងក្នុងខាងមុខ គឺដែលខ្លួនគប្បីសម្រេចពិត ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគសម្តែងសេចក្តីនេះថា កាលមានពាក្យសួរថា គតិរបស់គាត់នោះដូចម្តេច បរលោករបស់គាត់នោះដូចម្តេច ក៏ត្រាស់ថា គតិរបស់សុប្បពុទ្ធចម្រើនពិត មិនវិនាស ។ តែគតិមិនសម្បូរ ព្រោះកម្មនោះ ។ ព្រះអង្គទ្រង់ជាធម្មរាជា ទ្រង់មានព្រះបំណងនឹងប្រកាសសេចក្តីនេះ ដែលទាក់ទងដោយការបន្តនៃពាក្យសួរ ទើបបានភាសិតសេចក្តីមានប្រមាណប៉ុណ្ណេះឯង ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ឃើញថា កាលតថាគតពោលពាក្យមានប្រមាណប៉ុណ្ណេះ បណ្តាបុគ្គលមានសតិដោយជុំវិញប៉ុណ្ណេះ ភិក្ខុមួយរូបដែលឈ្វាសក្នុងអនុសន្ធិ នឹងសួរដល់ហេតុ*

ថា សុប្បពុទ្ធកើតរោគឃ្លង់ ជាអ្នកក្រីក្រ និងជាមនុស្សកំព្រា កាលបើដូច្នោះ តថាគតនឹងប្រកាសហេតុនោះរបស់សុប្បពុទ្ធ ដោយការបន្តនៃពាក្យសួរនោះ ហើយបញ្ចប់ទេសនា ដោយហេតុនោះឯង ទើបត្រាស់ថា **ឃវំ វុត្តេ អញ្ញតរោ ភិក្ខុ** *ដូច្នេះជាដើម ។*

[๑๑๔] *បណ្តាបទទាំងនោះ បទថា* **ហេតុ** *បានដល់ ហេតុដែលមិនទូទៅ ឯហេតុដែលទូទៅ បានដល់ បច្ច័យ ។ ហេតុទាំង ๒ យ៉ាងនេះ មានសេចក្តីប្លែកគ្នា ដូច្នេះ ។ បទថា* **យេន** *បានដល់ ដោយហេតុ និងដោយបច្ច័យណា ។ បទថា* **ភូតបុព្វំ** *បានដល់ ហេតុដែលធ្លាប់កើតហើយ ។ ដើម្បីសម្តែងភាពដែលហេតុកើតក្នុងអតីតកាល ទើបលោកពោលពាក្យថា* **សុប្បពុទ្ធោ** *ដូច្នេះជាដើម ។*

សួរថា ហេតុកើតឡើងក្នុងកាលណា ខ្ញុំនឹងឆ្លើយថា បានឮថា ក្នុងអតីតកាល កាលព្រះតថាគតមិនទាន់កើតឡើង កុលធីតាម្នាក់ ក្នុងស្រុកមួយកន្លែង រក្សាស្រែជុំវិញក្រុងពារាណសី នាងឃើញព្រះបច្চេកពុទ្ធមួយរូប មានចិត្តជ្រះថ្លា ទើបប្រគេនផ្កាបទុមមួយ មួយអន្ទៀដោយលាជ ๕๐๐ ដល់ព្រះបច្চេកពុទ្ធនោះហើយ តាំងសេចក្តីប្រាថ្នាឲ្យបានបុត្រ ๕๐๐ ។ ក្នុងខណៈនោះឯង ព្រានម្រឹគ ๕๐๐ ក៏ប្រគេនសាច់ដែលមានរសឆ្ងាញ់ ដល់ព្រះបច្চេកពុទ្ធ រួចប្រាថ្នាថា ពួកខ្ញុំគប្បីជាកូនរបស់នាង ហើយពួកខ្ញុំគប្បីបានទួវគុណវិសេសដែលលោកម្ចាស់បានទទួលហើយ ។ នាងតាំងនៅដរាបដល់អស់អាយុហើយ កើតក្នុងទេវលោក ចុតិអំពីទេវលោកនោះហើយ កើតក្នុងត្រកូលឈូក ក្នុង

ស្រះដែលកើតឯងមួយកន្លែង ។ តាបសម្នាក់បានឃើញ ទើបយកទៅចិញ្ចឹម ។ កាលនាងដើរទៅ ផ្កាឈូកទាំងឡាយ ក៏ផុសឡើងអំពីផែនដីគ្រប់ៗ ជំហាន ។ ព្រោនព្រៃម្នាក់បានឃើញ ទើបក្រាបទូលដល់ព្រះបាទពារាណសី ។ ព្រះរាជាទ្រង់បញ្ជាឲ្យនាំមកហើយ តាំងជាអគ្គមហេសី ។ នាងមានគភ៌ហើយ មហាបទុមកុមារនៅក្នុងផ្ទៃរបស់នាង ឯកុមារដ៏សេស អាស្រ័យមន្ទិលគភ៌កើតឡើង ។ ព្រះរាជកុមារទាំងនោះ ចម្រើនវ័យហើយ នាំគ្នាលេងក្នុងស្រះឈូកក្នុងព្រះរាជឧទ្យាន អង្គុយក្នុងផ្កាឈូកម្នាក់មួយផ្កា មានញាណចាស់ក្លា ផ្តើមតាំងនូវការអស់ទៅ និងសូន្យ ទៅក្នុងសង្ខារទាំងឡាយ ហើយសម្រេចបច្ចេកពោធិញ្ញាណ ។ ព្រះបច្ចេកពុទ្ធទាំងនោះ មានគាថាព្យាករថា

> *អ្នកចូរមើលស្លឹក និងត្របកបរបស់ផ្កាឈូកដែលកើតឡើងក្នុងស្រះ រីកហើយក៏ដេរដាសទៅដោយពួកភមរ ជារបស់មិនទៀង លុះឃើញការមិនទៀងនោះហើយ គប្បីជាអ្នកត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។*

ព្រះបច្ចេកពុទ្ធព្រះនាមថា តគរសិខីនៅក្នុងចំណោមព្រះបច្ចេកពុទ្ធ ៥០០ អង្គនោះ ដែលសម្រេចបច្ចេកពោធិញ្ញាណយ៉ាងនោះ ចូលនិរោធសមាបត្តិអស់ ៧ ថ្ងៃ ត្រង់ញកភ្នំនន្ទមូលកៈ ក្នុងគន្ធមាទនបព៌ត កន្លងទៅ ៧ ថ្ងៃ ទើបចេញអំពីនិរោធ ហោះទៅចុះត្រង់ឥសិគិលិបព៌ត ក្នុងពេលព្រឹក គ្រងស្បង់ចីវរ កាន់បាត្រ និងចីវរ ហើយទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ។ ក្នុងសម័យនោះ ក្នុងក្រុងរាជគ្រឹះ មានកូនសេដ្ឋីម្នាក់ មួយអន្ទៅដោយបរិវារធំ

ចេញអំពីព្រះនគរ ដើម្បីលេងកីឡាក្នុងឧទ្យាន ជួបព្រះបច្ចេកពុទ្ធព្រះនាមថា តគរសិខី គិតថា អ្នកណានេះ ក្បាលត្រងោល ដណ្តប់កាសាវកស្ត្រ ប្រហែលជាមនុស្សមានរោគឃ្លង់ យកសំពត់របស់មនុស្សរោគឃ្លង់ដណ្តប់រាងកាយទៅយ៉ាងនោះ ដូច្នេះហើយ ទើបស្តោះទឹកមាត់ចៀសចេញទៅផ្លូវខាងឆ្វេង ដែលលោកពោលថា **សុប្បពុទ្ធោ កុដ្ឋី ឥមស្មីយេវ រាជគហេ ។បេ។ បក្កាមិ** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **ក្វាយំ** *កាត់បទជា* **កោ អយំ** *គឺខ្ញុំពោលដោយការសង្កត់សង្កិន ។ បាលីថា* **កោវាយំ** *ដូច្នេះក៏មាន ។ ដោយបទថា* **កុដ្ឋិ** *បុគ្គលនោះពោលដល់លោកដែលមិនកើតរោគឃ្លង់ ជាអ្នកស្វែងរកគុណធំនោះឯងថា កើតរោគឃ្លង់ ឲ្យដល់នូវអក្កោសវត្ថុ ។ បទថា* **កុដ្ឋិចីវរេន**[1] *ប្រែថា ដោយចីវរបស់មនុស្សរោគឃ្លង់ លោកសម្តែងថា សូម្បីព្រះបច្ចេកពុទ្ធនេះ ក៏ដូចមនុស្សកើតឃ្លង់ ដោយច្រើន ដែលកាន់យកសំពត់ណាមួយមកដណ្តប់ ដើម្បីការពារនូវរបួស មូសជាដើម និងដើម្បីការពាររោគ ។ ម្យ៉ាងទៀត ព្រោះហេតុដែលលោកទ្រទ្រង់សំពត់បង្សុកូលចីវរ ទើបបុរសនោះមើលងាយថា ដូចរាងកាយរបស់មនុស្សកើតឃ្លង់ ព្រោះសំពត់បំណះ មានពណ៌ច្រើនយ៉ាង ទើបពោលថា* **កុដ្ឋិចីវរេន** *ដូច្នេះ ។ បទថា* **ឯដ្ឋហិត្វា** *បានដល់ ស្តោះទឹកមាត់ ។ បទថា* **អបព្យាមតោ ករិត្វា** *សេចក្តីថា បណ្ឌិត*

-១ បទនេះ ជាពាក្យរបស់ព្រះអដ្ឋកថា ដែលពោលថា ដោយសំពត់របស់មនុស្សរោគឃ្លង់ មិនមែនជាពាក្យក្នុងបិដកទេ ។

ទាំងឡាយឃើញព្រះបច្ចេកពុទ្ធដែលមានសភាពដូច្នោះ ថ្វាយបង្គំហើយ ធ្វើប្រទក្សិណ តែបុរសរោគឃ្លង់នោះ ដើរទៅខាងឆ្វេងព្រះបច្ចេកពុទ្ធនោះ គឺឲ្យលោកនៅខាងឆ្វេងដៃខ្លួន ដើរទៅដោយការមើលងាយ ព្រោះខ្លួនមិនមែនជាវិញ្ញូជន ។ បាឋៈថា **អបរាមតោ** *ដូច្នេះក៏មាន ។ បទថា* **តស្ស កម្មស្ស** *បានដល់ កម្មអាក្រក់ដែលប្រព្រឹត្តទៅដោយការមើលងាយព្រះបច្ចេកពុទ្ធតគរ-សិខីថា អ្នកណានេះកើតរោគឃ្លង់ ហើយទើបស្ពោះទឹកមាត់ចៀសចេញទៅដោយផ្លូវខាងឆ្វេង ។ បទថា* **និរយេ បចិត្ត** *បានដល់ បុគ្គលនោះ ត្រូវភ្លើងនរកដុតកម្ចាច ។ អាចារ្យពួកខ្លះពោលថា* **បចិត្វា និរយគ្គិនា** *ដូច្នេះក៏មាន បទថា* **តស្សេវ កម្មស្ស វិបាកាវសេសេន** *បានដល់ បដិសន្ធិក្នុងនរកដោយកម្មណា កម្មនោះរមែងមិនឲ្យផលក្នុងមនុស្សលោក ម្យ៉ាងទៀត វេទនារបស់បុគ្គលនោះដែលប្រព្រឹត្តទៅក្នុងខណៈផ្សេងគ្នា ប្រព្រឹត្តទៅដោយអំណាចកិច្ចបដិបត្តិខុសក្នុងព្រះបច្ចេកពុទ្ធ ក្នុងកាលនោះ ជាកម្មឲ្យផលក្នុងភពបន្តទៅ គ្រាវិបាកកម្មឲ្យបដិសន្ធិជាតិហេតុកៈ ក្នុងពួកមនុស្ស ព្រោះបុញ្ញកម្ម ដើរតួនាទីឲ្យផលក្នុងភពដទៃៗនោះឯង តែឲ្យដល់នូវភាពជាមនុស្សរោគឃ្លង់ ជាមនុស្សទុគ៌ត និងជាបុគ្គលដែលគួរអាសូរក្រៃពេកក្នុងបវត្តិកាល ដែលលោកសំដៅពោលថា ដោយសេសសល់កម្មនោះឯង ដោយអំណាចភាពជាកម្មដែលមានចំណែកស្មើគ្នា ។ ពិតហើយ ការបញ្ញត្តិកម្មនោះ ប្រាកដហើយក្នុងលោកនេះដូចការបញ្ញត្តិនោះឯងថា វត្ថុដែលមានរសល្វីងប៉ុណ្ណោះជាឱសថ ។ គ្រាទ្រង់ឆ្លើយបញ្ហា ដែលភិក្ខុនោះទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុអ្វីហ្ន៎ដូច្នេះ*

ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណោះ ឥឡូវនេះ ដើម្បីនឹងឆ្លើយបញ្ហាដែលកិកូទាំងឡាយសួរក្នុងកាលមុនថា លោកមានគតិដូចម្តេច ក្នុងភពខាងមុខ លោកកើតដូចម្តេច ទើបត្រាស់ពាក្យជាដើមថា **សោ តថាគតប្បវេទិតំ ធម្មវិនយំ** *ជួបច្នេះ ។*

បណ្តាបទទាំងនោះ បទថា **តថាគតប្បវេទិតំ** *សេចក្តីថា ឈ្មោះថា* **តថាគតប្បវេទិតំ** *ព្រោះព្រះតថាគត គឺព្រះមានព្រះភាគទ្រង់សម្តែងហើយ ត្រាស់ហើយ ទ្រង់ប្រកាសហើយ ។ បទថា* **អាគម្ម** *បានដល់ សម្រេចម្យ៉ាងទៀត បទថា* **អាគម្ម** *ព្រោះអាស្រ័យហើយ ទើបជឿ ។ បាឋៈថា* **តថាគតប្បវេទិតេ ធម្មវិនយេ** *ជួបច្នេះក៏មាន ។ បទថា* **សទ្ធំ សមាធិយិ** *សេចក្តីថា បុគ្គលនោះកាន់យកដោយប្រពៃនូវសទ្ធាទាំង ២ យ៉ាង គឺសទ្ធាដែលជាបុព្វភាគ ដែលជាទីអាស្រ័យនៃព្រះរតនត្រ័យថា ព្រះមានព្រះភាគត្រាស់ដឹងដោយប្រពៃ និងដោយព្រះអង្គឯង ១ ព្រះធម៌ដែលព្រះមានព្រះភាគត្រាស់ល្អហើយ ១ ព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគ លោកបដិបត្តិល្អហើយ ១ និងសទ្ធាដែលជាលោកុត្តរ អធិប្បាយថា កាន់យករហូតអស់នូវភព ដែលមិនត្រូវកាន់យកទៀត គឺធ្វើឲ្យកើតឡើងក្នុងចិត្តសន្តានរបស់ខ្លួន សូម្បីក្នុងបទជាដើមថា* **សីលំ សមាធិយិ** *ក៏មាននយ័នេះដូចគ្នា ។ បទថា* **សីលំ** *បានដល់ សីលដែលសម្បយុត្តដោយមគ្គចិត្ត និងដែលសម្បយុត្តដោយផលចិត្ត មួយអន្ទើដោយសីលដែលជាចំណែកខាងដើម ។ បទថា* **សុតំ** *បានដល់ សុតៈទាំង ២ យ៉ាង គឺភាពជាអ្នកមានបរិយត្តិធម៌ដែលស្តាប់ហើយច្រើន*

១ ភាពជាអ្នកមានបដិវេធដែលស្តាប់ហើយច្រើន ១ ពិតហើយ សូម្បីបរិយត្តិ-ធម៌ មានប្រការតាមដែលសាវ័កទាំងឡាយបានហើយ ដោយការចាក់ធ្លុះសច្ចៈក្នុងវេលាស្តាប់ធម៌ លោកក៏បានស្តាប់ហើយ ទ្រទ្រង់ចាំហើយ បានសន្សំហើយ បានសម្ងឹងដោយចិត្តហើយ និងបានចាក់ធ្លុះដោយល្អ ដោយទិដ្ឋិ ។ បទថា **ចាគំ** *បានដល់ ចាគៈ ពោល គឺការលះបង់នូវអភិសង្ខារ គឺកិលេសដែលបឋមមគ្គគប្បីសម្លាប់ ជាហេតុឲ្យព្រះអរិយសាវ័កទាំងឡាយ ជាអ្នកលះបង់ជាច់ខាត ក្នុងទេយ្យធម៌ មានដៃលាងស្អាត ត្រេកអរក្នុងការលះបង់ បទថា* **បញ្ញំ** *បានដល់ បញ្ញាដែលសម្បយុត្តដោយមគ្គចិត្ត និងបញ្ញាដែលសម្បយុត្តដោយផលចិត្ត មួយអន្ទើដោយវិបស្សនាបញ្ញា ។*

បទថា **កាយស្ស ភេទា** *បានដល់ ព្រោះលះខន្ធដែលមានចិត្តគ្រប់គ្រង បទថា* **បរម្មរណា** *បានដល់ អំពីការកាន់យកខន្ធដែលកើតចំពោះក្នុងខណៈនោះ ។ ម្យ៉ាងទៀត បទថា* **កាយស្ស ភេទា** *បានដល់ ព្រោះជីវិតិន្ទ្រិយដាច់ទៅ បទថា* **បរម្មរណា** *បានដល់ ខាងមុខអំពីចុតិចិត្ត ។ ដោយបទទាំង ៣ គឺ* **សុគតឺ សគ្គំ លោកំ** *លោកពោលដល់ទេវលោកប៉ុណ្ណោះ ។ ពិតហើយទេវលោកនោះ ឈ្មោះថា* **សុគតិ** *ព្រោះជាគតិល្អ ព្រោះស្អាតដោយសម្បត្តិទាំងឡាយ ។ ឈ្មោះថា* **សគ្គ** *ព្រោះល្អដោយអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ម្យ៉ាងទៀត ហៅថា* **លោក** *ព្រោះឃើញតែសេចក្តីសុខគ្រប់កាល ឬហៅថា* **លោក** *ព្រោះបែកធ្លាយ ឬវិនាស ។ បទថា* **ឧបបជ្ជោ** *បានដល់ ចូលដល់ដោយបដិសន្ធិ ។ បទថា* **សហាព្យតំ** *បានដល់ ភាពជា*

សម្ងាញ់ ។ តែអត្ថនៃពាក្យមានដូច្នេះថា ឈ្មោះថា **សហាឮ** *ព្រោះអត្ថថា ទៅ គឺប្រព្រឹត្តទៅ បានដល់ នៅរួមគ្នា គឺ* **សហាត្តាយី** *ប្រែថា ឈររួមគ្នា ឬ* **សហាសិ** *ប្រែថា នៅរួមគ្នា ។ ការៈនៃ* **សហាឮ** *ឈ្មោះថា* **សហាឮតា។** *បទថា* **អតិរោចតិ** *បានដល់ ឈ្មោះថា រុងរឿង ព្រោះកន្ទងបង់ ឬរុងរឿង ព្រោះគ្របសង្កត់ ។ បទថា* **វណ្ណេន** *បានដល់ សម្បុរដោយរូប ។ បទថា* **យសសា** *ប្រែថា ដោយបរិវារ ពិតហើយ សុប្បពុទ្ធលះបង់រូបកាយ មានប្រការដូចពោលក្នុងលោកនេះ ហើយបានអត្តភាពជាទិព្វតាមដែលពោលហើយ មួយអន្ទើដោយបរិវារដ៏ច្រើន ដោយខណៈចិត្ត ១ ដួចបុគ្គលលះបង់ភាជនៈដីដែលប្រឡាក់របស់មិនស្អាតផង គ្រាំគ្រាផង ហើយកាន់យកភាជនៈមាសជម្ពូនុទដ៏បរិសុទ្ធ វិចិត្រដោយរតនៈច្រើនប្រការ គ្របដណ្តប់ដោយសំណាញ់រស្មីដ៏ភ្លឺផ្លេក ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងនូវទោសក្នុងការមិនវៀរចាកបាប និងអានិសង្សក្នុងការវៀរចាកបាបនេះ ទើបទ្រង់បន្ទឺឧទាននេះ ដើម្បីប្រកាសនូវសេចក្តីនោះ ។*

ឧទាននោះ មានសេចក្តីសង្ខេបដូចតទៅនេះ បុរសដែលមានចក្ខុ កាលសេចក្តីព្យាយាម គឺការព្យាយាមផ្លូវកាយមាន គឺប្រព្រឹត្តទៅក្នុងរាងកាយតែងវៀរទីដែលមិនស្មើ មានជ្រោះជាដើម ឬរូបដែលមិនស្មើ មានរូបដំរី រូបសេះ រូបពស់ រូបមាន់ និងរូបគោជាដើម ព្រោះមានការកាចជាសភាវៈយ៉ាងណា បណ្ឌិត គឺបុរសអ្នកមានបញ្ញាក្នុងជីវលោក គឺក្នុងសត្វលោកនេះ

ក៏ដូច្នោះ កាលដឹងនូវប្រយោជន៍របស់ខ្លួន ព្រោះភាពជាអ្នកមានបញ្ញានោះ គប្បីវៀរបាបទាំងឡាយ គឺទុច្ចរិតលាមក អធិប្បាយថា កាលបើដូច្នេះ មិនគប្បីដល់ដោយប្រការដែលសុប្បពុទ្ធនេះ មិនវៀរបាបក្នុងព្រះបច្ចេកពុទ្ធឈ្មោះតគរសិខី ហើយដល់នូវការវិកវរធំ ។ ម្យ៉ាងទៀត អធិប្បាយថា សុប្ប-ពុទ្ធកុដ្ឋិអាស្រ័យធម្មទេសនារបស់តថាគត ឥឡូវនេះ ដល់នូវសេចក្តីសង្វេគ វៀរនូវបាបទាំងឡាយ សម្រេចនូវគុណវិសេសយ៉ាងក្រៃលែង យ៉ាងណា ទោះបីអ្នកដទៃ ក៏ដូច្នោះ កាលត្រូវការសម្រេចគុណវិសេសដ៏ក្រៃលែង គប្បីវៀរនូវបាប ។

អដ្ឋកថា សុប្បពុទ្ធកុដ្ឋិសូត្រទី ៣ ចប់

សុត្តន្តបិដក

កុមារកសូត្រ

[១១៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកកុមារច្រើនកំពុងចាប់ត្រី ក្នុងចន្លោះក្រុងសាវត្ថី និងវត្តជេតពន ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរ ក្នុងវេលាព្រឹក ហើយចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញនូវពួកកុមារច្រើននាក់ទាំងនោះ កំពុងចាប់ត្រីក្នុង

ចន្ទោះក្រុងសាវត្ថី និងវត្តជេតពន លុះឃើញហើយ ទើបទ្រង់ឆៀងចូលទៅរកពួកកុមារទាំងនោះ លុះចូលទៅដល់ហើយ ទ្រង់សួរពួកកុមារទាំងនោះថា ម្នាលកុមារទាំងឡាយ អ្នកទាំងឡាយ ខ្លាចសេចក្តីទុក្ខឬ សេចក្តីទុក្ខ មិនជាទីស្រឡាញ់របស់អ្នកទាំងឡាយទេឬ ព្រះករុណាព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ ខ្លាចសេចក្តីទុក្ខដែរ សេចក្តីទុក្ខមិនជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គទាំងឡាយទេ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានេះថា

បើអ្នកទាំងឡាយ ខ្លាចសេចក្តីទុក្ខ បើសេចក្តីទុក្ខ មិនជាទីស្រឡាញ់ របស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ កុំធ្វើបាបកម្ម ក្នុងទីវាល ឬក្នុងទីកំបាំងឡើយ ប្រសិនបើ អ្នកទាំងឡាយនឹងធ្វើ ឬកំពុងធ្វើបាបកម្ម សូម្បីអ្នកទាំងឡាយ គេចរត់ទៅ ក៏មិនរួចចាកទុក្ខឡើយ ។ សូត្រទី៤ ។

អដ្ឋកថា

កុមារកសូត្រ

កុមារកសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

[១១៥] *បទថា* **កុមារកោ** *ប្រែថា បុរសជំទង់ តែក្នុងទីនេះ មនុស្សជំទង់ ដែលជីឯសេចក្តីរបស់សុភាសិត និងទុព្ភាសិត លោកបំណងថា* **កុមារក** ។ *ពិតហើយ សត្វទាំងនេះ ចាប់តាំងអំពីថ្ងៃដែលកើតមកហួតដល់អាយុ ១៥ លោកហៅថា* **កុមារក** *និងហៅថា* **ពាល** *បន្ទាប់អំពីនោះ មានអាយុ ២០ លោកហៅថា* **កំលោះ ក្រមុំ** ។ *បទថា* **មច្ឆកេ ពាឆេត្តិ** *សេចក្តីថា ក្មេងជំទង់ទាំងនោះ ក្នុងរដូវប្រាំង កាលទឹកក្នុងស្រះមួយកន្លែងក្បែរផ្លូវរីងស្ងួតហើយ ក៏នាំគ្នាជាបចទឹកដែលជក់នៅក្នុងរណ្តៅ ចាប់ និងសម្លាប់ត្រីតូចៗ ដោយបំណងថា អញនឹងអាំងស៊ី ។ បទថា* **តេឧបសង្ក្រមិ** *សេចក្តីថា ទ្រង់ចៀសចេញពីផ្លូវ ចូលទៅកាន់ស្រះទឹកតូចមួយ ហើយឈរប្រថាប់ ព្រោះហេតុនោះ ទើបលោកពោលថា* **ឧបសង្ក្រមិ** ។ *ព្រោះហេតុអ្វី ទើបទ្រង់ចូលទៅរក ព្រោះដើម្បីឲ្យក្មេងទាំងនោះ កើតទុវិសេចក្តីស្និទ្ធស្នាលជាមួយទ្រង់ ទើបចូលទៅរក ។ សព្ទថា* **ភោ** *ក្នុងពាក្យនេះថា* **ភាយថ ភោ** *ត្រឹមតែជានិបាត ។ បទថា* **ទុក្ខស្ស** *ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថបញ្ចមីវិភត្តិ អធិប្បាយថា* **ទុក្ខស្មា** *គឺចាកទុក្ខ ។ ដោយបទថា* **អប្បិយំ ភោ ទុក្ខំ** *ទ្រង់ត្រាស់សួរថា ទុក្ខដែលកើតក្នុងរាងកាយរបស់ពួកអ្នកមិនជាទីស្រឡាញ់ មិនគួរប្រាថ្នា មិនមែនឬ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងនូវអត្ថនេះថា សត្វទាំងនេះ មិនប្រាថ្នាទុក្ខដើម្បីខ្លួន តែបដិបត្តិហេតុនៃទុក្ខ ដោយអត្ថ ជាការដែលឈ្មោះថា ប្រាថ្នាទុក្ខនោះឯង ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ដែលរារាំងការធ្វើអាក្រក់ និងប្រកាសទោសនៃការធ្វើអាក្រក់ ។*

ឧទាននោះ មានអត្ថដូចតទៅនេះ បើទុក្ខដែលនឹងឲ្យប្រព្រឹត្តទៅក្នុងអបាយទាំងមូល និងដោយភាពជាអ្នកមានអាយុខ្លី និងភាពជាអ្នកមានចំណែកអាក្រក់នៃមនុស្សជាដើមក្នុងសុគតិ ជាធម្មជាតិមិនគួរស្រឡាញ់ មិនគួរប្រាថ្នាសម្រាប់ពួកអ្នក បើពួកអ្នកខ្លាចទុក្ខនោះសោត ពួកអ្នកកុំធ្វើ គឺកុំសាងនូវកម្មអាក្រក់ គឺបាបកម្ម សូម្បីមានប្រមាណតិចតួចឡើយ ប្រកេទបាណាតិបាតជាដើម ផ្លូវកាយ និងផ្លូវវាចា ទាំងក្នុងទីវាល គឺមិនបិទបាំង ព្រោះប្រាកដដល់អ្នកដទៃ និងប្រកេទអកិរិយាជាដើម ព្រោះក្នុងមនោទ្វារក្នុងទីកំបាំងក្តី ដោយមិនប្រាកដដល់អ្នកដទៃ បើអ្នកធ្វើកម្មនោះ ឥឡូវនេះ ឬនឹងធ្វើក្នុងអនាគតសោត ទុក្ខដែលជាផលនៃកម្មនោះ ក្នុងអបាយ ៤ មាននរកជាដើម និងក្នុងមនុស្សទាំងឡាយ នឹងមិនជាប់តាមពួកយើង ដែលគេចទៅក្នុងទីផ្សេងៗ ដោយបំណងដូចពោលមកនេះ ទោះបីពួកអ្នកហោះគេច គឺប្រាថ្នានឹងគេចទៅ ក៏មិនរួច គឺមិនផុតចាកទុក្ខនោះទៅបានឡើយ លោកសម្តែងថា នឹងឲ្យផលក្នុងកាលការដល់ព្រមនៃបច្ចុប្បន្នដទៃ មានគតិ និងកាលជាដើមនោះឯង ។ អាចារ្យពួកខ្លះពោលថា **បលាយនេ** *ដូច្នេះក៏មាន សេចក្តីថា កាលការទៅ គឺការ*

ចៀសទៅក្នុងទីណាមួយមាន ដោយន័យដូចពោលមកហើយ សេចក្តីនេះគប្បីសម្តែងដោយគាថានេះថា បុគ្គលធ្វើកម្មអាក្រក់ ទោះជាគេចទៅក្នុងអាកាស ឬកណ្តាលសមុទ្រ ។បេ។ រមែងមិនផុតចាកកម្មអាក្រក់នោះទៅបានឡើយ ។

អដ្ឋកថាកុមារកសូត្រធី ៤ ចប់

សុត្តន្តបិដក

ឧចោសថសូត្រ

[១១៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងប្រាសាទមិគារមាតាក្នុងបុព្វារាម ទៀបក្រុងសាវត្ថី ។ សម័យនោះឯង នាថ្ងៃឧបោសថនោះ ព្រះមានព្រះភាគ មានភិក្ខុសង្ឆចោមរោមទ្រង់គង់ក្នុងរោងឧបាសថនោះ ។ លុះវេលារាត្រីបឋមយាម កន្ងទៅហើយ ព្រះអានន្ទដ៏មានអាយុ ក្រោកចាកអាសនៈ ធ្វើចីវរធៀងស្មាម្ខាង ប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសេចក្តីនុ៉ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីបឋមយាមកន្ងហើយ ភិក្ខុសង្ឆអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់សម្តែងបាតិមោក្ខដល់ពួកភិក្ខុ ។ កាលព្រះអានន្ទក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាក៏គង់ស្ងៀម ។ កាលរាត្រីមជ្ឈិមយាមកន្ងហើយ ព្រះអានន្ទដ៏មានអាយុ ក៏ក្រោកចាកអាសនៈ ធ្វើចីវរធៀងស្មាម្ខាង ប្រណម្យ

អញ្ជលី ចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគអស់វារៈ ២ ដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីមជ្ឈិមយាមកន្លងហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងបាតិមោក្ខដល់ពួកភិក្ខុទាំងឡាយ ។ ព្រះមានព្រះភាគ ក៏ទ្រង់គង់ស្ងៀមអស់វារៈ ២ ដង ។ លុះវេលារាត្រីបច្ឆិម-យាមកន្លងហើយ រាត្រីក៏ជ្រាកជដូចជាមានមុខស្រស់ ក្នុងវេលាដែលអរុណារះឡើង ព្រះអានន្ទដ៏មានអាយុ ក៏ក្រោកចាកអាសនៈធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគជាគម្រប់ ៣ ដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ រាត្រីបច្ឆិមយាមកន្លងហើយ អរុណារះហើយ រាត្រីក៏ជ្រាកជដូចមានមុខស្រស់ហើយ ភិក្ខុសង្ឃអង្គុយរង់ចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងបាតិមោក្ខដល់ពួកភិក្ខុ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ បរិសទ្យមិនបរិសុទ្ធទេ ។ គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ត្រិះរិះថា ព្រះមានព្រះភាគទ្រង់សំដៅបុគ្គលណាហ្ន៎ បានជាទ្រង់ត្រាស់ថា ម្នាលអានន្ទ បរិសទ្យមិនបរិសុទ្ធយ៉ាងនេះ ទើបព្រះមហាមោគ្គល្លានដ៏មានអាយុ សូងមើលចិត្តដោយចិត្តរបស់លោក ហើយធ្វើទុកក្នុងចិត្ត ចំពោះភិក្ខុសង្ឃទាំងអស់ ។ លុះព្រះមហាមោគ្គល្លានដ៏មានអាយុ បានឃើញបុគ្គលទ្រុស្តសីលនោះ មានធម៌លាមក មានមារយាទមិនល្អ គួរឲ្យរង្កៀស មានអំពើអាក្រក់បិទបាំងទុក មិនមែនជាសមណៈ តែប្តេជ្ញាថា ខ្លួនជាសមណៈ

មិនប្រព្រឹត្តធម៌ដ៏ប្រសើរ តែប្តេជ្ញាថា ខ្លួនជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយខាងក្នុង មានចិត្តជោកដោយរាគៈ ក៏ខ្វក់ដូចសំរាម អង្គុយក្នុងកណ្តាលភិក្ខុសង្ឃ លុះឃើញហើយ ក្រោកចាកអាសនៈ ចូលទៅរកបុគ្គលនោះ លុះចូលទៅដល់ហើយ ក៏និយាយនឹងបុគ្គលនោះថា នែអាវុសោ អ្នកចូរក្រោកចេញ ជ្បិតព្រះមានព្រះភាគ ទ្រង់ឃើញអ្នកហើយ អ្នកលែងបាននៅរួមជាមួយនឹងពួកភិក្ខុហើយ ។ លំដាប់នោះ បុគ្គលនោះក៏នៅស្ងៀម ។ ព្រះមហាមោគ្គល្លានដ៏មានអាយុនោះ បាននិយាយនឹងបុគ្គលនោះ ជាគម្រប់ ២ ដងថា នែអាវុសោ អ្នកចូរក្រោកចេញ ជ្បិតព្រះមានព្រះភាគ ទ្រង់ឃើញអ្នកហើយ អ្នកលែងបាននៅរួមជាមួយនឹងពួកភិក្ខុហើយ ។ បុគ្គលនោះ នៅស្ងៀមអស់វារៈ ២ ដងទៀត ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បាននិយាយនឹងបុគ្គលនោះ ជាគម្រប់ ៣ ដងថា នែអាវុសោ អ្នកចូរក្រោកចេញ ជ្បិតព្រះមានព្រះភាគ ទ្រង់ឃើញអ្នកហើយ អ្នកលែងបាននៅរួមជាមួយនឹងពួកភិក្ខុហើយ ។ បុគ្គលនោះ ក៏នៅស្ងៀម អស់វារៈជាគម្រប់ ៣ ដង ។ តពីនោះមក ព្រះមហាមោគ្គល្លានដ៏មានអាយុ ចាប់ដើមដៃបុគ្គលនោះ ទាញចេញទៅខាងក្រៅស៊ុមទ្វារ ហើយស៊កឱនសន្ទះ និងរនុកទ្វារ រួចចូលមករកព្រះមានព្រះភាគវិញ លុះចូលទៅដល់ហើយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលនោះ ខ្ញុំព្រះអង្គបានបណ្តេញឲ្យចេញទៅហើយ ឥឡូវនេះ បរិសុទ្ធបរិសុទ្ធហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់សម្តែងបាតិមោក្ខដល់ពួកភិក្ខុឲ្យទាន ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន គួរអស្ចារ្យណាស់ ម្នាលមោគ្គល្លាន ចម្លែកណាស់ មោឃបុរសនោះ មិនសមបើនឹងក្រាញនៅបង្អន់ទាល់តែគេចាប់ទាញដៃសោះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងឈប់ធ្វើឧបោសថ សម្តែងបាតិមោក្ខ អំពីកាលនេះ ម្នាលភិក្ខុទាំងឡាយ លំជាប់អំពីនេះ អ្នកទាំងឡាយ ធ្វើឧបោសថ សម្តែងបាតិមោក្ខចុះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើឧបោសថ សម្តែងបាតិមោក្ខ ដល់បរិស័ទដែលមិនបរិសុទ្ធដោយហេតុណាជំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ។

[១១៧] ម្នាលភិក្ខុទាំងឡាយ ក្នុងមហាសមុទ្រ មានធម្មតាដែលអស្ចារ្យ កើតចម្លែក ៨ យ៉ាងនេះ ដែលពួកអសុរឃើញហើយរីករាយ ក្នុងមហាសមុទ្រ ។ ធម្មតាអស្ចារ្យ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ មហាសមុទ្រមានទំនាបដោយលំជាប់ មានទីជម្រាលដោយលំជាប់ មានទីទេរដោយលំជាប់ មិនមែនចោទជ្រៅស្រឡះទៅតែម្តង ដូចជាអណ្តូងទេ ម្នាលភិក្ខុទាំងឡាយ ឯមហាសមុទ្រ ដែលមានទំនាបដោយលំជាប់ មានទីជម្រាលដោយលំជាប់ មានទីទេរដោយលំជាប់ មិនមែនចោតជ្រៅស្រឡះទៅតែម្តង ដូចជាអណ្តូងដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាអស្ចារ្យ កើតចម្លែកទី ១ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយតែងរីករាយក្នុងមហាសមុទ្រ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាសមុទ្រ មានទឹកតាំងនៅនឹងជា

ធម្មតា មិនដែលឡើង ឬជោរហួសច្រាំងទៅបានទេ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ ដែលមានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង ឬជោរហួសច្រាំងទៅបាន ដោយធម្មតាណា ម្នាលភិក្ខុ ទាំងនេះជាធម្មតា អស្ចារ្យ កើតចម្លែកទី ២ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយក្នុងមហាសមុទ្រ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាសមុទ្រមិនដែលមានសាកសពស្លាប់នៅរួមបានទេ បើសាកសពស្លាប់ណា មានក្នុងមហាសមុទ្រ រលកតែងបន្សាត់សាកសពស្លាប់នោះ ទៅរកច្រាំង ផាត់ឡើងទៅលើគោកមួយរំពេច ម្នាលភិក្ខុទាំងឡាយ ឯមហាសមុទ្រ មិនដែលមានសាកសព ស្លាប់នៅរួមបាន បើសាកសពស្លាប់ណា មានក្នុងមហាសមុទ្រ រលកតែងបន្សាត់សាកសពស្លាប់នោះ ទៅរកច្រាំង ផាត់ឡើងទៅលើគោកមួយរំពេច ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតា អស្ចារ្យ កើតចម្លែកទី ៣ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយក្នុងមហាសមុទ្រ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ទន្លេធំៗ ទាំងឡាយណាមួយ ដូចទន្លេគង្គា យមុនា អចិរវតី សរភូ មហី ទន្លេទាំងនោះ កាលបើហូរទៅដល់មហាសមុទ្រហើយ តែងលះបង់នាម និងគោត្រដើម (របស់ខ្លួន) ដល់នូវកិរិយារាប់បញ្ចូលថា មហាសមុទ្រតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ទន្លេធំៗ ទាំងឡាយណាមួយ ដូចជាទន្លេគង្គា យមុនា អចិរវតី សរភូ មហី ទន្លេទាំងនោះ កាលបើហូរទៅដល់មហាសមុទ្រហើយ តែងលះបង់នាម និង

គោត្រជើម (របស់ខ្លួន) ដល់នូវកិរិយារាប់បញ្ចូលថា មហាសមុទ្រតែម្យ៉ាង ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតា អស្ចារ្យ កើតចម្រែកទី ៤ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ទឹកទន្លេទាំងឡាយណាមួយ ក្នុងលោក ដែលហូរគគាច ទៅរកមហាសមុទ្រក្តី ធារទឹកភ្លៀងទាំងឡាយណា ដែលធ្លាក់ចុះមកចាកអាកាសក្តី មហាសមុទ្រ ក៏មិនប្រាកដជាស្រេក ឬពេញដោយទឹកទន្លេ និងធារទឹកភ្លៀងនោះឡើយ ម្នាលភិក្ខុទាំងឡាយ ទឹកទន្លេទាំងឡាយណាមួយ ក្នុងលោក ដែលហូរទៅរកមហាសមុទ្រក្តី ធារទឹកភ្លៀងទាំងឡាយណា ដែលហូរធ្លាក់ចុះមកចាកអាកាសក្តី មហាសមុទ្រក៏មិនប្រាកដជាស្រេក ឬពេញដោយទឹកទន្លេ និងធារទឹកភ្លៀងទាំងនោះ ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតា អស្ចារ្យ កើតចម្រែកទី ៥ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាសមុទ្រមានរសតែមួយ គឺរសប្រៃ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រមានរសតែមួយ គឺរសប្រៃ ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតា អស្ចារ្យ កើតចម្រែកទី ៦ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាសមុទ្រមានរតនៈច្រើនយ៉ាង មិនមែនមានរតនៈតែម្យ៉ាងទេ ឯរតនៈទាំងនេះ ដែលមានក្នុងមហាសមុទ្រនោះ គឺ

កែវមុក្តា កែវមណី កែវពៃទូរ្យ សង្ខ សិលា កែវប្រពាល ប្រាក់ មាស កែវក្រហម (តម្បូងទទឹម) និងកែវមរកត ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ មានរតន:ច្រើនយ៉ាង មិនមែនមានរតន:តែម្យ៉ាងទេ ឯរតន:ទាំងនេះ ដែលមាននៅក្នុងមហាសមុទ្រនោះ គឺកែវមុក្តា កែវមណី កែវពៃទូរ្យ សង្ខ សិលា កែវប្រពាល ប្រាក់ មាស កែវក្រហម និងកែវមរកត ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតា អស្ចារ្យ ដែលកើតចម្លែកទី ៧ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាសមុទ្រ ជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើន ពួកសត្វធំៗ ទាំងនេះ ក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គល: ឈ្មោះតិមិតិមិង្គល: និងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព ១ រយយោជន៍ខ្លះ មានអត្តភាព ២ រយយោជន៍ខ្លះ មានអត្តភាព ៣ រយយោជន៍ខ្លះ មានអត្តភាព ៤ រយយោជន៍ខ្លះ មានអត្តភាព ៥ រយយោជន៍ខ្លះ តែងនៅក្នុងមហាសមុទ្រ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ ជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើន ពួកសត្វធំទាំងនេះ ក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គល: ឈ្មោះតិមិតិមិង្គល: និងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព ១ រយយោជន៍ខ្លះ មានអត្តភាព ២ រយយោជន៍ខ្លះ មានអត្តភាព ៣ រយយោជន៍ខ្លះ មានអត្តភាព ៤ រយយោជន៍ខ្លះ មានអត្តភាព ៥ រយយោជន៍ខ្លះ តែងនៅក្នុងមហាសមុទ្រ ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតា អស្ចារ្យ ដែលកើតចម្លែកទី ៨ ក្នុង

មហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។ ម្នាលភិក្ខុទាំងឡាយ ធម្មតា អស្ចារ្យ ដែលកើតចម្រែកទាំង ៨ ប្រការនេះ តែងមានក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

[១១៨] ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានសភាពអស្ចារ្យ ដែលកើតចម្រែក ៨ ប្រការ ដែលភិក្ខុទាំងឡាយឃើញហើយ តែងត្រេកអរ រីករាយ ក្នុងធម្មវិន័យនេះ ដូចមហាសមុទ្រដែរ ។ សភាពអស្ចារ្យ ដែលកើតចម្រែក ៨ ប្រការ តើដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងអរហត្តផលតែម្តងទេ ដូចជាមហាសមុទ្រ ដែលមានទីទំនាបដោយលំដាប់ មានទីជម្រាលដោយលំដាប់ មានទីទេរដោយលំដាប់ មិនមែនចោតជ្រៅស្រឡះទៅតែម្តង ដូចអណ្តូងទេ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ តែងមានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងអរហត្តផលតែម្តងដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពអស្ចារ្យ ដែលកើតចម្រែកទី ១ ក្នុងធម្មវិន័យនេះ ដែលភិក្ខុទាំងឡាយឃើញហើយ តែងត្រេកអរក្នុងធម្មវិន័យនេះ ។

ម្នាលភិក្ខុទាំងឡាយ សិក្ខាបទណា ដែលតថាគតបានបញ្ញត្តិដល់សាវក

ទាំងឡាយហើយ ពួកសាវ័កនៃតថាគត សូម្បីមានហេតុដល់ជីវិត ក៏មិនហ៊ាន ប្រព្រឹត្តកន្លងសិក្ខាបទឡើយ ដូចមហាសមុទ្រដែលមានទឹកនៅនឹងជាធម្មតា មិនដែលខ្ជើង ឬជោរហួសច្រាំងទៅបាន ដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ សិក្ខាបទណា ដែលតថាគតបានបញ្ញត្តិដល់សាវ័កទាំងឡាយហើយ ពួកសាវ័កនៃតថាគត សូម្បីមានហេតុដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះ ដោយសភាពណា នេះជាសភាពអស្ចារ្យ ដែលកើតចម្រើនទី ២ ក្នុងធម្ម-វិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរក្នុងធម្មវិន័យនេះ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលណាជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនស្អាត គួរឲ្យរង្កៀស មានអំពើអាក្រក់បិទបាំងទុក មិនមែនជាសមណៈ តែប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ តែប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ សុយទាងក្នុង មានចិត្តជោកជាយ រាគៈ កខ្វក់ដូចសំរាម សង្ឃមិននៅរួមជាមួយបុគ្គលនោះទេ សង្ឃប្រជុំគ្នានាំ យកបុគ្គលនោះចេញមួយរំពេច បុគ្គលនោះ បើទុកជាអង្គុយនៅក្នុងកណ្តាលភិក្ខុសង្ឃពិតមែន ប៉ុន្តែបុគ្គលនោះ ឈ្មោះថា នៅឆ្ងាយអំពីសង្ឃ ចំណែកសង្ឃក៏ឈ្មោះថា នៅឆ្ងាយអំពីបុគ្គលនោះ ដូចមហាសមុទ្រ មិននៅរួមជាមួយសាកសពស្លាប់ទេ បើសាកសពស្លាប់ណាមួយ ដែលមានក្នុងមហាសមុទ្រ មហាសមុទ្រតែងបន្សាត់សាកសពនោះ ទៅរកច្រាំង ផាត់ខ្ជើងទៅលើគោកមួយរំពេច ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនស្អាត គួរឲ្យរង្កៀស បិទបាំងអំពីអាក្រក់

ទុក មិនមែនជាសមណៈ តែប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនជាអ្នកប្រព្រឹត្ត ធម៌ដ៏ប្រសើរ តែប្តេជ្ញាខ្លួនថាជាអ្នក ប្រព្រឹត្តធម៌ដ៏ប្រសើរ ស្មុយខាងក្នុង មាន ចិត្តជោកដោយរាគៈ កខ្វក់ដូចសំរាម សង្ឃមិននៅរួមជាមួយបុគ្គលនោះ សង្ឃតែងប្រជុំគ្នានាំយកបុគ្គលនោះចេញមួយរំពេច បុគ្គលនោះ បើទុកជា អង្គុយនៅក្នុងកណ្តាលភិក្ខុសង្ឃពិតមែន ប៉ុន្តែបុគ្គលនោះ ឈ្មោះថា នៅឆ្ងាយ អំពីសង្ឃ ចំណែកខាងសង្ឃ ក៏ឈ្មោះថា នៅឆ្ងាយអំពីបុគ្គលនោះ ដោយ សភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពអស្ចារ្យ ដែលកើតចម្ងៃកទី ៣ ក្នុងធម្មវិន័យនេះ ដែលភិក្ខុទាំងឡាយ ឃើញហើយ តែងត្រេកអរ ក្នុង ធម្មវិន័យនេះ ។

ម្នាលភិក្ខុទាំងឡាយ វណ្ណៈ ៤ ពួកនេះ គឺខត្តិយៈ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ វណ្ណៈទាំងនោះ ចេញចាកផ្ទះមកបួសក្នុងធម្មវិន័យ ដែលតថាគត សម្តែងហើយ រមែងលះបង់នាម និងគោត្រដើម (របស់ខ្លួន) ហើយដល់ នូវកិរិយាហាប់បញ្ចូលថាជាសមណសក្យបុត្តិយ៍តែម្យ៉ាង ដូចទន្លេធំៗ ទាំងឡាយ គឺទន្លេគង្គា យមុនា អចិរវតី សរភូ មហី ទន្លេទាំងនោះ កាលបើហូរទៅដល់ មហាសមុទ្រហើយ តែងលះបង់នាម និងគោត្រដើម (របស់ខ្លួន) ហើយ ដល់នូវកិរិយាហាប់បញ្ចូលថាជាមហាសមុទ្រតែម្យ៉ាង ដូច្នេះឯង ម្នាលភិក្ខុទាំង ឡាយ វណ្ណៈទាំង ៤ ពួក គឺ ខត្តិយៈ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ វណ្ណៈ ទាំងនោះ ចេញចាកផ្ទះមកបួសក្នុងធម្មវិន័យ ដែលតថាគតសម្តែងហើយ ក៏ រមែងលះបង់នាម និងគោត្រដើម (របស់ខ្លួន) ហើយដល់នូវកិរិយាហាប់

បញ្ចូលថាជាសមណសក្យបុត្តិយ៍តែម្យ៉ាង ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពអស្ចារ្យ ដែលកើតចម្ងៃកទី ៤ ក្នុងធម្មវិនយនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរក្នុងធម្មវិនយនេះ ។

ម្នាលភិក្ខុទាំងឡាយ ទោះបីពួកភិក្ខុច្រើនរូប បរិនិព្វានដោយអនុបាទិ-សេសនិព្វានធាតុ និព្វានធាតុក៏មិនប្រាកដថា ខ្វះ ឬពេញ ដោយភិក្ខុទាំងនោះឡើយ ម្នាលភិក្ខុទាំងឡាយ ដូចជាទឹកទន្លេទាំងឡាយណាមួយ ក្នុងលោកហូរស្រោចចុះទៅកាន់មហាសមុទ្រក្តី ធារទឹកភ្លៀទាំងឡាយណា ដែលធ្លាក់ចុះមកចាកអាកាសក្តី មហាសមុទ្រក៏មិនប្រាកដថា ជាស្រេក ឬពេញដោយទឹកនោះ ដូច្នេះឯង ម្នាលភិក្ខុទាំងឡាយ ទុកជាពួកភិក្ខុច្រើនរូបបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ និព្វានធាតុក៏មិនប្រាកដថា ខ្វះ ឬពេញដោយភិក្ខុទាំងនោះ ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពអស្ចារ្យ ដែលកើតចម្ងៃកទី ៥ ក្នុងធម្មវិនយនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិនយនេះ ។

ម្នាលភិក្ខុទាំងឡាយ ធម្មវិនយនេះ មានរសតែមួយ គឺវិមុត្តិរស ដូចមហាសមុទ្រ មានរសតែមួយ គឺរសប្រៃ ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ធម្មវិនយនេះ មានរសតែមួយ គឺវិមុត្តិរស ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពអស្ចារ្យ ដែលកើតចម្ងៃកទី ៦ ក្នុងធម្មវិនយនេះ ដែល ពួកភិក្ខុឃើញហើយ តែងត្រេកអរក្នុងធម្មវិនយនេះ ។

ម្នាលភិក្ខុទាំងឡាយ ធម្មវិនយនេះ មានរតនៈច្រើនយ៉ាង មិនមែនមាន

ត្រឹមតែមួយប៉ុណ្ណោះទេ រតនៈនេះក្នុងធម្មវិន័យនោះ គឺសតិប្បដ្ឋាន ៤ សម្ម-ប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ និងមគ្គប្រកប ដោយអង្គ ៨ ដ៏ប្រសើរ ដូចមហាសមុទ្រ ដែលមានរតនៈច្រើនយ៉ាង មិន មែនមានតែមួយទេ រតនៈទាំងនេះ ក្នុងមហាសមុទ្រនោះ គឺកែវមុក្តា កែវ មណី កែវពៃទូរ្យ សង្ខ សិលា កែវប្រពាល ប្រាក់ មាស កែវក្រហម និង កែវមរកត ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះ មានរតនៈច្រើន យ៉ាង មិនមែនមានត្រឹមតែមួយទេ រតនៈទាំងនេះ ក្នុងធម្មវិន័យនោះ គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ និងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដោយសភាពណា នេះជាសភាព អស្ចារ្យ ដែលកើតចម្រើនទី ៧ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះ ជាទីអាស្រ័យនៃពួកបុគ្គលធំៗ ជា ច្រើន បុគ្គលទាំងនេះ ក្នុងធម្មវិន័យនោះ គឺសោតាបន្នបុគ្គល និងបុគ្គលអ្នក ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់សោតាបត្តិផល សកទាគាមិបុគ្គល និងបុគ្គល អ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់សកទាគាមិផល អនាគាមិបុគ្គល និង បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់អនាគាមិផល ព្រះអរហន្ត និង បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់អរហត្តផល ដូចជាមហាសមុទ្រ ជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើន ឯពួកសត្វទាំងនេះ ក្នុងមហាសមុទ្រ នោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គលៈ ឈ្មោះតិមិតិមិង្គលៈ និងពួកអសុរ

នាគ គន្ធព្វ ដែលមានអត្តភាព ១ រយយោជន៍ខ្លះ មានអត្តភាព ២ រយយោជន៍ខ្លះ មានអត្តភាព ៣ រយយោជន៍ខ្លះ មានអត្តភាព ៤ រយយោជន៍ខ្លះ មានអត្តភាព ៥ រយយោជន៍ខ្លះ ដែលមាននៅក្នុងមហាសុទ្រ ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ធម្មវិនយនេះ ជាទីនៅអាស្រ័យនៃពួកបុគ្គលធំៗ ជាច្រើនបុគ្គលទាំងនេះ ក្នុងធម្មវិនយនោះ គឺសោតាបន្នបុគ្គល និងបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់សោតាបត្តិផល សកទាគាមិបុគ្គល និងបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់សកទាគាមិផល អនាគាមិបុគ្គល និងបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់អនាគាមិផល ព្រះអរហន្ត និងបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់អរហត្តផល ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពអស្ចារ្យ ដែលកើតចម្រែកទី ៨ ក្នុងធម្មវិនយនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិនយនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហើយដែលហៅថា សភាពអស្ចារ្យ ដែលកើតចម្រែក ៨ ប្រការ ក្នុងធម្មវិនយនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិនយនេះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> ភិក្ខុត្រូវអាបត្តិហើយ បិទបាំងអាបត្តិទុក រមែងត្រូវអាបត្តិប្លឹជនៃទៀត ភិក្ខុត្រូវអាបត្តិហើយ បើកអាបត្តិ មិនត្រូវអាបត្តិជនៃទៀត ព្រោះហេតុនោះ ភិក្ខុ (ណាមួយ) ត្រូវអាបត្តិដែលបិទបាំងហើយ ភិក្ខុ (នោះ) ត្រូវតែបើក

អាបត្តិចេញ កាលបើយ៉ាងនេះ ទើបមិនត្រូវអាបត្តិនោះ ទៀត ។ សូត្រទី ៥ ។

អដ្ឋកថា

ឧចោសថសូត្រ

ឧបោសថសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ

[១១៦] *បទថា* **តទហុ** *បានដល់ ក្នុងថ្ងៃនោះ គឺក្នុងពេលថ្ងៃនោះ ។ ក្នុងពាក្យថា* **ឧចោសថេ** *មានវិនិច្ឆ័យដូចតទៅនេះ ថ្ងៃ ឈ្មោះថា ឧបោសថ ព្រោះជាទីចូលទៅរក្សារបស់មនុស្សទាំងឡាយ ។ ពាក្យថា ចូលទៅរក្សា សេចក្តីថា ជាអ្នកចូលទៅរក្សាដោយសីល ឬដោយការអត់អាហារ ។ ពិត ហើយ សព្ទថា* **ឧចោសថ** *នេះ មកក្នុងសីល ដូចក្នុងប្រយោគជាដើមថា* **អដ្ឋង្គសមន្នាគតំ ឧចោសថំ ឧបវសិត្វា** *(ស្ត្រី ឬបុរសពួកខ្លះ) ក្នុងលោកនេះ រក្សានូវឧបោសថប្រកបដោយអង្គ ៨ ដូច្នេះ ។ មកក្នុងវិនយកម្ម មាន ជាតិមោក្ខនិទ្ទេសជាដើម ដូចក្នុងប្រយោគជាដើមថា* **ឧចោសថោ វា បវា-រណា វា** *ឧបោសថក្តី បវារណាក្តី ដូច្នេះ ។ មកក្នុង* **ឧបវាស** *ដូចក្នុង ប្រយោគជាដើមថា* **គោចាលកុចោសថោ និគ្គណ្ឋចោសថោ** *ឧបោសថ របស់គង្វាលគោ ១ ឧបោសថរបស់និគ្គណ្ឋ ១ ដូច្នេះ ។ មកក្នុងបញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា* **ឧចោសថោ ឆាម ឆាគរាជា** *ស្តេចដំរីឈ្មោះ*

ឧបោសថ ដូច្នេះ ។ មកក្នុងថ្ងៃ ដូចក្នុងប្រយោគជាដើមថា **អដ្ឋមោសថោ បណ្ណរសោ** *ថ្ងៃទី ១៥ នេះ ជាថ្ងៃឧបោសថ ដូច្នេះ ។ ក្នុងទីនេះ គប្បីឃើញថា មកក្នុងថ្ងៃនោះឯង ។ ព្រោះដូច្នោះ បទថា* **តទហុបោសថេ** *សេចក្តីថា ក្នុងថ្ងៃដែលជាថ្ងៃឧបោសថនោះ ។ បទថា* **និសិន្នោ ហោតិ** *សេចក្តីថា ទ្រង់ចោមរោមទៅដោយមហាភិក្ខុសង្ឃ គង់ប្រថាប់ដើម្បីទ្រង់សម្តែងឱវាទ-ប្បាតិមោក្ខ ។ កាលទ្រង់គង់ប្រថាប់ហើយ ទ្រង់ប្រមើលមើលចិត្តរបស់ភិក្ខុទាំងនោះ ទ្រង់ឃើញបុគ្គលទ្រុស្តសីលមួយរូប ទ្រង់ព្រះតម្រិះថា តថាគតនឹងសម្តែងបាតិមោក្ខ ក្នុងកាលបុគ្គលនេះ អង្គុយក្នុងទីនោះឯង ក្បាលរបស់បុគ្គលនោះ នឹងបែកជា ៧ ចម្រៀក ដូច្នេះហើយ ទើបទ្រង់តុណ្ហីភាព ដើម្បីអនុគ្រោះភិក្ខុនោះ ។ ក្នុងទីនេះ បទថា* **ឧទ្ទេ្ទ អរុណេ** *សេចក្តីថា កាលជល់អរុណរះ ព្រះថេរៈអាវជនាព្រះមានព្រះភាគ ទ្រង់សម្តែងបាតិមោក្ខ ដោយពាក្យថា សូមព្រះមានព្រះភាគ ទ្រង់សម្តែងបាតិមោក្ខជល់ភិក្ខុទាំងឡាយចុះ ព្រោះក្នុងពេលនោះ ទ្រង់មិនបានបញ្ញត្តិសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគួរធ្វើឧបោសថ ក្នុងថ្ងៃដែលមិនមែនឧបោសថ ។ បទថា* **អបរិសុទ្ធា អានន្ទ បរិសា** *សេចក្តីថា ព្រោះទ្រង់ត្រាស់ព្រះថេរៈអាវជនា ឲ្យទ្រង់សម្តែងព្រះបាតិមោក្ខ អស់ ៣ ដង កាលនឹងត្រាស់ហេតុការណ៍ដែលទ្រង់មិនសម្តែង មិនត្រាស់ថា បុគ្គលនោះមិនបរិសុទ្ធ តែត្រាស់ថា អានន្ទ បរិសទ្ទមិនបរិសុទ្ធ ។ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគឲ្យយាម ៣ នៃរាត្រីកន្លងទៅយ៉ាងនោះ ព្រោះតាំងអំពីនោះ ទ្រង់មានព្រះបំណងមិនសម្តែង*

ឱវាទបាតិមោក្ខ ដើម្បីធ្វើវត្តនៃការមិនសម្តែងនោះឲ្យប្រាកដ ។

បទថា **អទ្ទសា** *បានដល់ បានឃើញដូចម្តេច ។ ព្រះថេរៈកំណត់ដឹងចិត្តរបស់ភិក្ខុទាំងឡាយក្នុងបរិស័ទនោះ ដោយចេតោបរិយញ្ញាណរបស់ខ្លួន ទើបឃើញចិត្ត គឺភាពជាអ្នកទ្រុស្តសីលនៃមោឃបុរសនោះ ។ កាលឃើញចិត្តហើយ ក៏ឈ្មោះថា ឃើញបុគ្គលដែលដល់ព្រមដោយចិត្តនោះ ដូច្នោះ ទើបលោកពោលពាក្យជាដើមថា ព្រះមហាមោគ្គល្លានបានឃើញហើយនូវបុគ្គលទ្រុស្តសីលនោះ ដូចបុគ្គលដែលបានចេតោបរិយញ្ញាណ រមែងដឹងចិត្តរបស់បុគ្គលដទៃ ដែលប្រព្រឹត្តទៅក្នុង ៧ ថ្ងៃក្នុងអនាគត យ៉ាងណា សូម្បីក្នុងអតីត ក៏ដូច្នោះដូចគ្នា ។ បទថា* **ទុស្សីលំ** *ប្រែថា ជាអ្នកទ្រុស្តសីល អធិប្បាយថា ដែលវៀចាកសីល ។ បទថា* **ចាបជ្ឈំ** *បានដល់ ដែលមានធម៌ដ៏លាមកជាសភាវៈ ព្រោះមានអធ្យាស្រ័យអាក្រក់ ព្រោះជាអ្នកទ្រុស្តសីលនោះឯង ។*

បទថា **អសុចឹ** *បានដល់ ឈ្មោះថា ជាអ្នកមិនស្អាត ព្រោះប្រកបដោយកម្មជាដើមដែលមិនបរិសុទ្ធ ។ បទថា* **សង្កស្សរសមាចារំ** *សេចក្តីថា ឈ្មោះថា ជាអ្នកមានសមាចារដែលគប្បីរំពៃដោយសេចក្តីរង្កៀស ព្រោះអ្នកដទៃឃើញកម្មដែលមិនសមគួរណាមួយហើយ រង្កៀសយ៉ាងនេះថា នេះប្រហែលជាកម្មដែលបុគ្គលនេះធ្វើហើយ ម្យ៉ាងទៀត ព្រោះបានឃើញភិក្ខុទាំងឡាយប្រឹក្សាគ្នា ដោយករណីយកិច្ចឯណានីមួយ អ្នកមានសមាចារដែលគប្បីរំពៃ ដោយការរង្កៀសរបស់ខ្លួនឯងថា ភិក្ខុទាំងនេះ ជឿកម្មដែលអញ

ធ្វើ ទើបប្រឹក្សាគ្នាទេដឹងហ្ន៎ ។

ឈ្មោះថា **បដិបន្នកម្មន្តំ** *ព្រោះលោកមានការងារបិទបាំងទុក ដោយការធ្វើកម្មដែលគប្បីបិទបាំង ព្រោះជាកម្មដែលគប្បីខ្មាស ។ ឈ្មោះថា* **អស្សមណាំ** *ព្រោះមិនមែនសមណៈ ព្រោះទ្រទ្រង់នូវភេទនៃសមណៈដែលគួរខ្ពើម ។ ឈ្មោះថា* **សមណាបដិញ្ញំ** *ក្នុងការពោលថា សមណៈ មានចំនួនប៉ុន្មាន ក្នុងការចាប់ស្លាកជាដើម និងក្នុងប្តេជ្ញាខ្លួនថា សូម្បីខ្ញុំក៏ជាសមណៈ ។ ឈ្មោះថា* **អព្រហ្មចារី** *ព្រោះជាអ្នកមានការប្រព្រឹត្តមិនប្រសើរ ។ ឈ្មោះថា* **ព្រហ្មចារិបដិញ្ញំ** *ព្រោះបុគ្គលមិនមែនជាព្រហ្មចារី ឃើញសព្រហ្មចារីដទៃស្មៀកដណ្តប់រៀបរយ ឱបបាត្ររៀបរយ កំពុងត្រាច់បិណ្ឌបាត ក្នុងគាម និងនិគមជាដើមចិញ្ចឹមជីវិត សូម្បីខ្លួនឯង ក៏បដិបត្តិដោយអាការបែបនោះ និងប្រាកដក្នុងថ្ងៃឧបោសថជាដើម ហាក់ដូចឲ្យនូវប្តេជ្ញាថា សូម្បីខ្ញុំក៏ជាព្រហ្មចារី ។ ឈ្មោះថា* **អន្តោបូតឹ** *ព្រោះកម្មខូច គឺសីលវិបត្តិ ចូលទៅខាងក្នុង ។ ឈ្មោះថា* **អវស្សុតំ** *ព្រោះទន្ទឹកដោយកិលេសជាគ្រឿងហូរចេញ មានរាគៈជាដើមតាមទ្វារ ៦ ។ ឈ្មោះថា* **កសម្ពុកជាតំ** *ព្រោះមានសំរាម គឺរាគៈជាដើម និងត្រូវអ្នកមានសីលទាំងឡាយបោះចោល ។ បទថា* **មជ្ឈេ ភិក្ខុ-សង្ឃស្ស និសិន្នំ** *សេចក្តីថា ដែលអង្គុយក្នុងខាងក្នុងភិក្ខុសង្ឃ ហាក់ដូចទាក់ទងក្នុងសង្ឃ ។ បទថា* **ឱដ្ឋោសិ** *សេចក្តីថា ជាបុគ្គលដែលព្រះមានព្រះភាគទ្រង់ឃើញហើយថា បុគ្គលនេះ មិនមែនជាភិក្ខុតាមប្រក្រតី ។ ក្នុងសេចក្តីនេះ គប្បីឃើញការប្រកបបទយ៉ាងនេះថា ព្រោះព្រះមានព្រះភាគទ្រង់ឃើញ*

ដូច្នោះ បុគ្គលនោះ គឺបុគ្គលមិនមានធម៌ ជាគ្រឿងនៅរួមដោយកម្មជាមួយ នឹងភិក្ខុទាំងឡាយ ព្រោះលោកមិនមានធម៌ ជាគ្រឿងនៅរួមនោះ ដូច្នោះ ចូរអ្នកក្រោកឡើងចុះអាវុសោ ។ បទថា **តតិយម្ឃិ ទោ សោ បុគ្គលោ តុណ្ហី អហោសិ** សេចក្តីថា បុគ្គលនោះ ជាអ្នកនៅស្ងៀមដោយបំណងថា ព្រះថេរ: ពោលរឿយៗ ក៏នឹងនៀយណាយ ឈប់ឯង ឬថា ឥឡូវនេះ អញនឹងដឹងកិច្ចបដិបត្តិរបស់ភិក្ខុទាំងនេះ ។ បទថា **ពាហាយំ គហេត្វា** សេចក្តីថា បុគ្គលទ្រុស្តសីលនោះ ដែលព្រះមានព្រះភាគ និងអាត្មាអញឃើញតាមសេចក្តីពិតហើយ ឯអញក៏ពោលថា ចូរលោកក្រោកឡើងអស់វារ: ៣ ដងក៏មិនក្រោកឡើង ទើបចាប់ត្រង់ដើមដៃបុគ្គលទ្រុស្តសីលនោះ ដោយគិតថា ឥឡូវនេះ ជាពេលដែលទាញចេញទៅ អន្តរាយនៃឧបោសថកុំមានដល់សង្ឆឡើយ ក៏ចាប់យ៉ាងនោះហើយ ។ បទថា **ពហិទ្វារកោដ្ឋកា និក្ខាមេត្វា** សេចក្តីថា ទើបឲ្យចេញទៅខាងក្រៅខ្លោងទ្វារ គឺចេញអំពីទ្វារសាលា ។ បទថា **ពហិ** ជាបទសម្តែងដល់ទីដែលទាញចេញទៅ ។ ម្យ៉ាងទៀត បទថា **ពហិទ្វារកោដ្ឋកា** សេចក្តីថា ឲ្យចេញទៅខាងក្រៅខ្លោងទ្វារ មិនមែនឲ្យចេញទៅខាងក្នុងខ្លោងទ្វារឡើយ អធិប្បាយថា ធ្វើឲ្យនៅខាងក្រៅវិហារ ដោយប្រការទាំង ២ ដោយប្រការដូច្នេះ ។ បទថា **សុចិយដិកំ ទត្វា** សេចក្តីថា ប្រើរនុកទ្វារ និងគន្លឹះខាងលើ អធិប្បាយថា រារាំងដោយល្អ ។ ដោយបទថា **យាវ ពាហាគហណាបិ ឆាម** នេះ លោកសម្តែងថា ក៏ព្រោះបានស្តាប់ព្រះតម្រាស់ថា ម្នាលអានន្ទ បរិស័ទមិនបរិសុទ្ធ ដូច្នេះ កាលបើដូច្នោះ លោក

គប្បីចៀសចេញទៅ កាលមិនចៀសចេញទៅយ៉ាងនោះ មោយបុរសនោះ នឹងរង់ចាំរហូតដល់ចាប់ដើមដៃដឹកចេញទៅ ដូច្នោះ ទើបសេចក្តីនេះ គួរអស្ចារ្យ គប្បីជ្រាបថា សេចក្តីនេះ ក៏ជាការអស្ចារ្យដែលគួរតិះដៀលនោះឯង ។

សម័យនោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ ចម្រូងចម្រាសកើតឡើងក្នុងភិក្ខុសង្ឆហើយ ពួកបុគ្គលមិនបរិសុទ្ធ មកកាន់ឧបោសថ ព្រះតថាគតទាំងឡាយ មិនសម្តែងឧបោសថដល់បរិស័ទដែលមិនបរិសុទ្ធ កាលមិនសម្តែងឧបោសថៗ របស់ភិក្ខុក៏ដាច់ បើដូច្នោះ តាំងអំពីនេះទៅ តថាគតគប្បីអនុញ្ញាតបាតិមោក្ខុទ្ទេសដល់ភិក្ខុទាំងឡាយ កាលទ្រង់ព្រះតម្រិះយ៉ាងនេះហើយ ទើបទ្រង់អនុញ្ញាតបាតិមោក្ខុទ្ទេសដល់ភិក្ខុទាំងឡាយ ។ ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ ភគវា ។បេ។ ចាតិមោក្ខំ ឧទ្ទិសេយ្យាថ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ ដោយបទថា **នជានាហំ** នេះ ភ្ជាប់ដោយ **ន** អក្ខរៈ ចំពោះបទថា ឥឡូវនេះ តថាគតនឹងមិនធ្វើឧបោសថ នឹងមិនសូធ្យបាតិមោក្ខ។

បាតិមោក្ខមាន ២ យ៉ាង គឺអាណាបាតិមោក្ខ ១ ឱវាទប្បាតិមោក្ខ ១ ។ ក្នុង ២ យ៉ាងនេះ ពាក្យមានពាក្យថា **សុណាតុ មេ ភន្តេ** ជាដើម ឈ្មោះថា អាណាបាតិមោក្ខ ។ អាណាបាតិមោក្ខប៉ុណ្ណោះ សាវកទាំងឡាយសូធ្យរៀងរាល់កន្លះខែ ព្រះពុទ្ធទាំងឡាយមិនសូធ្យឡើយ ។ គាថាទាំង ៣ គឺ **ទន្តិបរមំ ។បេ។ សព្វចាបស្ស អករណំ ។បេ។ អនូបវាទោ អនូបឃាតោ ។បេ។ ឯតំ ពុទ្ធាន សាសនំ** ដូច្នេះ ឈ្មោះថា ឱវាទប្បាតិមោក្ខ ។ ឱវាទ-

ប្បាតិមោក្ខនោះ ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះសម្តែង សាវ័កមិនសម្តែងឡើយ ។ ដោយកន្លងទៅ ៦ វស្សា ទើបទ្រង់សម្តែង ។ ពិតហើយ ក្នុងកាលដែលព្រះពុទ្ធមានព្រះជន្មាយុវែង នៅទ្រទ្រង់ ឯបាតិមោក្ខុទ្ទេសនេះសម្រាប់ព្រះពុទ្ធដែលមានព្រះជន្មខ្លី ក្នុងបឋមពោធិកាលប៉ុណ្ណោះ ឯបាតិមោក្ខុទ្ទេសនេះ បន្ទាប់អំពីនោះទៅ ក៏ជាដរៃ ។ បាតិមោក្ខនោះឯង ចំពោះភិក្ខុទាំងឡាយប៉ុណ្ណោះសូធ្យ ព្រះពុទ្ធទាំងឡាយមិនសូធ្យឡើយ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគនៃយើងទាំងឡាយ ទ្រង់សម្តែងឱ្យទាបាតិមោក្ខត្រឹម ២០ វស្សា លុះឃើញអន្តរាយកើតឡើង បន្ទាប់អំពីនោះ ទ្រង់ក៏លែងសម្តែង ។

បទថា **អដ្ឋានំ** *ប្រែថា ហេតុដែលមិនសមគួរ ។ បទថា* **អនវកាសោ** *ជាវេវចនៈនៃហេតុដែលមិនសមគួរនោះដូចគ្នា ពិតហើយ ហេតុ លោកហៅថា* **ឋាន** *ព្រោះជាទីតាំងនៅនៃផល ហេតុមានការប្រព្រឹត្តទៅទាក់ទងនឹងផលនោះឯង យ៉ាងណា ហេតុដែលមិនសមគួរនោះ លោកហៅថា* **អនវកាសោ** *ដូច្នេះក៏មាន ដូច្នោះឯង ។ បទថា* **យំ** *ជាកិរិយាបរាមាស ។ បទថា* **យំ** *នោះ គប្បីប្រកបដោយនយដែលពោលហើយខាងដើមនោះឯង ។*

[๑๑๗] *សួរថា ក្នុងបទថា* **អដ្ឋិមេ ភិក្ខវេ មហាសមុទ្ទេ** *នេះ មានអនុសន្ធិដូចម្តេច ។ ឆ្លើយថា ការមិនសម្តែងបាតិមោក្ខជាប់បរិសទ្ធដែលមិនបរិសុទ្ធ ដែលព្រះមានព្រះភាគត្រាស់ហើយនោះ ចាត់ជាអច្ឆរិយាព្ភូតធម៌ក្នុងធម្មវិនយនេះ ព្រោះដូច្នោះ ព្រះសាស្តាមានបំណងនឹងចែកសម្តែងការមិនសូធ្យបាតិមោក្ខនោះ មួយអន្ទើដោយអច្ឆរិយាព្ភូតធម៌ ៧ ប្រការ ក្រៅអំពីនេះ*

លំជាប់ដំបូង កាលទ្រង់សម្តែងអច្ឆរិយពួតធម៌ ៨ ប្រការ ក្នុងមហាសមុទ្រ ដោយភាពជាឧបមាដល់ភិក្ខុទាំងនោះ ទើបត្រាស់ពាក្យជាដើមថា **អដ្ឋិមេ ភិក្ខវេ មហាសមុទ្ទេ** *ដូច្នេះ ។*

បទថា **អសុរា** *សេចក្តីថា ឈ្មោះថា* **អសុរ** *ព្រោះមិនលេង គឺមិនត្រេកអរ បានដល់ មិនរុងរឿងដូចទេវតា ។ ម្យ៉ាងទៀត ទេវតា ឈ្មោះថា* **អសុរ** *ព្រោះជាសត្រូវចំពោះទេវតាដែលជាសុរៈទាំងនោះ បានដល់ ទេវតាឲ្យនូវការប្រហារដល់ព្រះបាទវេបចិត្តិអសុរជាដើម ។ កពរបស់អសុរទាំងនោះ មានក្នុងចំណែកខាងក្រោមនៃភ្នំសិនេរុ ។ ទេវតាទាំងនោះ កំពុងចូល និងចេញក្នុងកពនៃអសុរនោះៗ និម្មិតមណ្ឌបជាដើមនាជើងភ្នំសិនេរុ សោយសុខ ។ ព្រោះឃើញគុណទាំងនេះ ដោយការត្រេកអរក្រៃលែងរបស់ទេវតាទាំងនោះ ក្នុងកពនោះ ព្រោះដូច្នោះ ទើបលោកពោលថា ដែលពួកអសុរឃើញហើយ រីករាយក្នុងមហាសមុទ្រ ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **អភិរមន្តិ** *ប្រែថា រមែងជួបនូវការត្រេកអរ អធិប្បាយថា មិននឿយណាយ ។ បទទាំងឡាយ មានជាដើមថា* **អនុបុព្ព-និន្នោ** *ជាវេវចនៈនៃភាពជាទីជម្រេលតាមលំជាប់នោះឯង ។*

បទថា **នាយតកេនេវ បថាគោ** *សេចក្តីថា មិនមែនជ្រោះអំពីមុនមកទេ ដូចបឹងធំដែលមានលំជាប់ ។ ពិតហើយ ចាប់តាំងអំពីមាត់ច្រាំងទៅ ជាចំណែកដែលជ្រៅ ១ អង្គុលី ២ អង្គុលី ១ ចំអាម ១ ហត្ថ ១ សសរ ១ ឧសភ កន្ទះគាវុត ១ គាវុត និង ១ យោជន៍ជាដើម ជ្រៅទៅៗ រហូតដល់*

៨៤០០០ យោជន៍ ក្នុងជើងភ្នំសិនេរុបពិត លោកសម្តែងដូច្នេះ ។ បទថា **ឋិតឆម្មោ** *បានដល់ មានការតាំងនៅជាសភាវៈ គឺមានការតាំងចុះជាសភាវៈ ។ បទថា* **មតេន កុណាបេន** *បានដល់ ដោយសាកសពដ៏រឺ និងសាកសពសេះ ជាដើមណានីមួយ ។ បទថា* **វាហោតិ** *ប្រែថា អណ្តែតទៅ ។ បទថា* **ថលំ ឧស្សាទេតិ** *សេចក្តីថា បន្សាត់ឡើងលើគោក ដោយរលកបក់ម្តងប៉ុណ្ណោះ ដូចយកដៃចាប់ចោះទៅ ដូច្នោះ ។ បទថា* **គង្គា យមុនា** *សេចក្តីថា ស្ទឹងដែលហូរចេញអំពីទិសខាងត្បូងនៃអនោតត្តស្រះ ចាត់ជាស្ទឹង ៥ ខ្សែ ដល់នូវការរាប់ ៥ ខ្សែ មានស្ទឹងគង្គាជាដើម ក្នុងទីដែលហូរទៅ ។*

ក្នុងសេចក្តីនោះ មានកថាសម្តែងការកើតឡើង តាំងអំពីដើមនៃស្ទឹង ៥ ខ្សែនេះ ដូចតទៅនេះ ពិតហើយ ជម្ពូទ្វីបនេះ មានទំហំមួយម៉ឺនយោជន៍ ។ ក្នុងជម្ពូទ្វីបនោះ ផ្ទៃដីប្រមាណ ៤០០០ យោជន៍ ត្រូវទឹកច្រោះ ដល់នូវការរាប់ថាជាសមុទ្រ ពួកមនុស្សអាស្រ័យនៅក្នុងផ្ទៃដីប្រមាណ ៣០០០ យោជន៍ ។ ភ្នំហិមពាន្តស៊ីផ្ទៃដីអស់ប្រមាណ ៣០០០ យោជន៍ កម្ពស់ ៥០០ យោជន៍ ប្រជាប់ទៅដោយកំពូល ៨៤០០០ វិចិត្រទៅដោយស្ទឹង ៥ ខ្សែ ដែលហូរមកដោយជុំវិញ ជាទីដែលពោលដោយបណ្តាយ ទទឹង និងជម្រៅ មានប្រមាណ ៥០ យោជន៍ វាស់ដោយបរិមាត្រប្រមាណ ១៥០ យោជន៍ ដែលជាទីតាំងនៅនៃស្រះធំ ៧ គឺអនោតត្តស្រះ ១ កណ្ណមុណ្ឌៈ ១ រថការៈ ១ ឆទ្ទន្តៈ ១ កុណាលៈ ១ មន្ទាកិនី ១ សីហប្បបាតៈ ១ ។ ក្នុងស្រះធំ ៧ នោះ អនោតត្តស្រះហ៊ុមព័ទ្ធដោយភ្នំ ៥ គឺភ្នំសុទស្សនៈ ១ ភ្នំចិត្តៈ ១ ភ្នំ

កាឡៈ ១ ភ្នំគន្ធមាទន៍ ១ ភ្នំកៃលាស ១ ។ កំពូលភ្នំ ៥ នោះ ភ្នំសុទស្សនៈ ជាវិការនៃមាស កម្ពស់ ៣០០ យោជន៍ ខាងក្នុងកោង មានទ្រង់ទ្រាយដូចចំពុះក្អែកព័ទ្ធស្រះនោះ កំពូលភ្នំចិត្តៈ សម្រេចដោយកែវ ៧ ប្រការ កំពូលភ្នំកាឡៈសម្រេចហើយដោយផ្កាអញ្ចន កំពូលភ្នំគន្ធមាទន៍សម្រេចដោយកែវមកិត ខាងក្នុងមានពណ៌ដូចសណ្តែកបាយ ភ្លឺរុងរឿងដូចរងើកភ្លើង ក្នុងថ្ងៃឧបោសថខាងរនោច ដេរជាសទៅដោយឱសថច្រើនប្រការ ច្រើនទៅដោយកូន ១០ យ៉ាង គឺកូនឫសឈើ កូនខ្ចីមឈើ កូនស្រាយឈើ កូនសម្បកឈើ កូនក្រមុំឈើ កូនដើមឈើ កូនរសឈើ កូនផ្កាឈើ កូនផ្លែឈើ និងកូនស្វាយឈើ ។ កំពូលភ្នំកៃលាសសម្រេចដោយថ្មកំ ។ កំពូលភ្នំទាំងអស់នោះ មានទ្រង់ទ្រាយស្មើគ្នានឹងភ្នំសុទស្សនៈ ព័ទ្ធស្រះនោះ ។ ក្នុងកំពូលភ្នំទាំងនោះ ភ្លៀងធ្លាក់ដោយទេវានុភាព ទឹកហូរដោយនាគានុភាព ។ ទឹកទាំងអស់នោះ ហូរចូលកាន់អនោតត្តស្រះប៉ុណ្ណោះ ព្រះចន្ទ និងព្រះទិត្យគោចរឆៀងទៅទិសខាងត្បូង ឬទិសខាងជើង ធ្វើពន្លឺក្នុងទីនោះដោយរវាងនៃភ្នំ តែមិនគោចរទៅដោយត្រង់ឡើយ ដោយហេតុនោះឯង ស្រះនោះ ឈ្មោះថាអនោតត្តៈ គឺមិនត្រូវពន្លឺ ក្នុងអនោតត្តស្រះនោះ ដេរជាសដោយមនោសិលា មិនមានត្រី និងអណ្តើក ដូចកែវផលិកប្រាសចាកមន្ទិល មិនល្អក់ កើតអំពីកម្មនោះឯង ជាកំពង់សម្រាប់ងូតរបស់ពួកសត្វដែលប្រើទឹកនោះ ជាទីដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវក ឥសីអ្នកមានឫទ្ធិ ធ្វើការងូតជាដើម ។ ឯទេវតា និងយក្ខជាដើម នាំគ្នាលេងទឹក ។ ក្នុងទិសទាំង ៤ នៃអនោតត្ត-

ស្រះនោះ មានទឹកហូរចេញ ៤ ច្រក គឺច្រករាជសីហ៍ ច្រកដំរី ច្រកសេះ និងច្រកគោឧសភ ជាហេតុឲ្យផ្លូវទឹក ៤ ហូរទៅ ។ ត្រង់ច្រាំងច្រកដែលហូរចេញទៅតាមច្រករាជសីហ៍ មានកេសរសីហៈជាច្រើន ។ ច្រកដំរី ច្រកសេះ ច្រកគោឧសភក៏ដូចគ្នា ។ ទឹកដែលហូរចេញច្រកទិសខាងកើត ប្រទក្សិណអនោតត្តស្រះ ៣ ជុំ មិនជួបនឹងស្មៅ ៣ ខ្សែក្រៅអំពីនេះទេ ហូរទៅកាត់ទឹកដីរបស់អមនុស្ស ខាងកើតភ្នំហិមពាន្តនោះឯង ហូរទៅកាន់មហាសមុទ្រ ឯច្រកទឹកទិសខាងលិច ខាងជើង ប្រទក្សិណយ៉ាងនោះដូចគ្នា ហូរឆ្លងទឹកដីអមនុស្ស ទៅទិសខាងលិច និងទិសខាងជើងដូចគ្នា រួចធ្លាក់ទៅក្នុងមហា-សមុទ្រ ឯច្រកទឹកទិសខាងត្បូង ប្រទក្សិណជុំវិញអនោតត្តស្រះនោះ ៣ ជុំ ហូរទៅទិសខាងត្បូង លើថ្មជានោះឯង បាន ៦០ យោជន៍ ប៉ះភ្នំក៏បាញ់ឡើងលើ ជាធ្លាទឹកប្រមាណ ៣ គាវុតដោយជុំវិញ ហោះទៅតាមអាកាសចម្ងាយ ៦០ យោជន៍ ក៏ធ្លាក់ចុះត្រង់ថ្មជា ឈ្មោះតិយគ្គលៈ[1] ថ្មជាបែកព្រោះកម្លាំងទឹក ។ ក្នុងទីនោះកើតជាស្រះបោក្ខរណី ឈ្មោះតិយគ្គលៈ មានប្រមាណ ៥០ យោជន៍ ។ ទម្ងុះថ្ម ច្រាំងស្រះបោក្ខរណី ហូរលើថ្មទៅបាន ៦០ យោជន៍ បន្ទាប់អំពីនោះ ទម្ងុះផែនដី ជាឧម្មគ្គហូរទៅ ៦០ យោជន៍ ប៉ះនឹងភ្នំមួយ ឈ្មោះវិជ្ឈៈ ហើយបែកជាស្មៅ ៥ ខ្សែ ដូចគ្នានឹងម្រាមដៃ ។ ក្នុងទីដែលហូរប្រទក្សិណអនោតត្តស្រះ ហៅថា អាវដ្តគង្គា ។ ក្នុងទីដែលហូរលើថ្មប្រមាណ ៦០ យោជន៍ ហៅថា កណ្ណគង្គា ក្នុងទីដែលទឹកហោះទៅ

-១ ក្នុងទីខ្លះ ជាតិយង្គឡ ។

តាមអាកាសប្រមាណ ៦០ យោជន៍ ហៅថា អាកាសគង្គា ក្នុងទីដែលទឹកធ្លាក់លើថ្មដាឈ្មោះតិយគ្គល: ទំហំប្រមាណ ៥០ យោជន៍ ហៅថា តិយគ្គ-លបោក្ខរណី ។ ក្នុងទីដែលទឹកហូរទម្លុះច្រាំងស្រះ លើថ្មដាទៅប្រមាណ ៦០ យោជន៍ ហៅថា ពហលគង្គា ។ ក្នុងទីដែលហូរក្រោមដីជាឧម្មង្គប្រមាណ ៦០ យោជន៍ ហៅថា ឧម្មង្គគង្គា ។ ក្នុងទីដែលប៉ះភ្នំវិជ្ឈ: បែកជាស្ទឹង ៥ ខ្សែគឺស្ទឹងគង្គា ១ យមុនា ១ អចិរវតី ១ សរភូ ១ មហី ១ ។ ស្ទឹង ៥ ខ្សែនេះ គប្បីជ្រាបថា ហូរចេញមកអំពីភ្នំហិមពាន្ត ។ បណ្តាបទទាំងនោះ បទថា **នធី និន្នគា** ដូច្នេះជាដើម ចាត់ជាគោត្រ ។ ពាក្យថា **គង្គា យមុនា** ដូច្នេះជាដើម ចាត់ជាឈ្មោះ ។

បទថា **សវន្តិយោ** បានដល់ ស្ទឹងធំ ឬស្ទឹងតូចប្រភេទណាមួយ ដែលហូរទៅធ្លាយ ។ បទថា **អប្បេន្តិ** ប្រែថា ហូរទៅ គឺហូររួមគ្នាទៅ ។ បទថា **ធារា** បានដល់ ភ្លៀង ។ បទថា **ឃូរត្តំ** ប្រែថា ទឹកភ្លៀងដក់ពេញ ។ ពិតហើយ មហាសមុទ្រ ជាធម្មតាដូចតទៅនេះ បុគ្គលណាម្នាក់ មិនអាចពោលមហាសមុទ្រនោះថា ក្នុងពេលនេះភ្លៀងធ្លាក់តិច ពួកយើងកាន់យកនេសា-ទុបករណ៍ មានសំណាញ់ និងលបជាដើម ដាក់ត្រី និងអណ្តើក ឬថា ក្នុងពេលនេះ មានភ្លៀងច្រើនពេក ពួកយើងមិនបានទីកន្លែងដែលជាទីតម្រង់ខ្នងពិតហើយ តាំងអំពីបឋមកប្បមក ភ្លៀងធ្លាក់ដក់រហូតទល់គ្នានឹងភ្នំសិនេរុ បន្តអំពីនោះ ទឹកសូម្បីប្រមាណមួយអង្គុលី ក៏ហូរចុះខាងក្រោម មិនហូរឡើងលើឡើយ ។

បទថា **ឯកវរសោ** *បានដល់ មានវរសមិនលាយឡំ គឺវរសតែមួយ ។ បទថា* **មុត្តា** *បានដល់ កែវមុក្តាច្រើនប្រភេទ មានតូច ធំ មូល និងវែងជាដើម បទថា* **មណិ** *បានដល់ កែវមណីច្រើនប្រភេទ មានមណីក្រហម និងមណីខៀវជាដើម ។ បទថា* **វេឡុរិយោ** *បានដល់ កែវពិទូរ្យច្រើនប្រភេទ ដោយសណ្ឋាន មានពណ៌ដូចដើមឫស្សី និងពណ៌ដូចផ្កាច្រេសជាដើម ។ បទថា* **សង្ខោ** *បានដល់ សង្ខ៍ច្រើនប្រភេទ មានសង្ខ៍ទក្ខិណាវដ្ដ សង្ខ៍មាស និងសង្ខ៍សម្រាប់ផ្លុំជាដើម ។ បទថា* **សិលា** *បានដល់ ថ្មច្រើនប្រភេទ ដូចជាសិលាស សិលាខ្មៅ និងសិលាពណ៌ដូចសណ្ដែកបាយជាដើម ។ បទថា* **បវាឡំ** *បានដល់ កែវប្រវាលច្រើនប្រភេទ មានតូច មានធំ ក្រហមខ្ចី ក្រហមចាស់ជាដើម ។ បទថា* **លោហិតង្កំ** *បានដល់ កែវទទឹមច្រើនប្រភេទ មានបទុម-វគៈជាដើម ។ បទថា* **មសារគល្លំ** *បានដល់ កែវមរកត ។ អាចារ្យពួកខ្លះពោលថា* **ចិត្តជលិកំ** *កែវផលិកដ៏វិចិត្រដូច្នេះក៏មាន ។*

បទថា **មហាតំ ភូតានំ** *បានដល់ សត្វធំ ។ ត្រី ៣ ប្រភេទ គឺត្រីតិមិ ១ ត្រីតិមិង្គលៈ ១ ត្រីតិមិតិមិង្គលៈ ១ ត្រីដែលអាចស៊ីត្រីតិមិ ឈ្មោះតិមិង្គលៈ ត្រីដែលអាចស៊ីត្រីតិមិ និងត្រីតិមិង្គលៈ ឈ្មោះតិមិតិមិង្គលៈ ។ បទថា* **នាគា** *បានដល់ នាគដែលនៅលើរលកខ្លះ នាគដែលនៅក្នុងវិមានខ្លះ ។*

[๑๑๘] *ដោយបទថា* **ឯវមេវ ខោ** *ព្រះសាស្ដាទ្រង់អាចសម្ដែងចែកអច្ឆរិយពួតធម៌ ១៦ ខ្លះ ៣២ ខ្លះ ក្រៃលែងជាងនេះខ្លះ ក្នុងព្រះធម្មវិន័យ*

នេះ តែកាលទ្រង់ចែកធម៌ដែលគួរឧបមាទាំងនោះ ត្រឹម ៨ យ៉ាង ដោយ សមគួរដល់អត្ត ដែលកាន់យកដោយភាពជាឧបមាក្នុងខណៈនោះ ទើប ត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានសភាព អស្ចារ្យ ដែលកើតចម្លែកទាំង ៨ ប្រការ ដូច្នេះ ។ ក្នុងធម៌ទាំងនោះ លោក កាន់យកសិក្ខា ៣ ដោយអនុបុព្វសិក្ខា គឺការសិក្សាទៅតាមលំដាប់។ ធុតធម៌ ១៣ កាន់យកដោយអនុបុព្វកិរិយា គឺការធ្វើទៅតាមលំដាប់ ។ អនុបស្សនា ៧ មហាវិបស្សនា ១៨ ការចែកអារម្មណ៍ ៣៨ និងពោធិបក្ខិយធម៌ ៣៧ លោកកាន់យកដោយអនុបុព្វបដិបទា កិច្ចបដិបត្តិទៅតាមលំដាប់ ។ បទថា **ឆាយតកេនេវ អញ្ញោបដិវេធោ** *សេចក្តីថា ធម្មតាការមិនធ្វើសីលជាដើម ឲ្យបរិបូណ៌ តាំងអំពីដើមមក ហើយចាក់ធ្លុះអរហត្ត មិនមាន ដូចការកើត ឡើងនៃមណ្ឌុកទេវបុត្រ ដូច្នោះ ឯការធ្វើសីល សមាធិ និងបញ្ញាឲ្យបរិបូណ៌ ទៅតាមលំដាប់មុនហើយ ទើបសម្រេចអរហត្ត មាន ។*

ដោយបទថា **មម សាវកា** *ទ្រង់ត្រាស់សំដៅដល់ព្រះអរិយបុគ្គល មាន សោតាបន្នជាដើម ។ បទថា* **ន សំវិសតិ** *បានដល់ មិនធ្វើសង្ស័យ ដោយ អំណាចឧបោសថកម្មជាដើម ។ បទថា* **ឧក្ខិបតិ** *ប្រែថា ប្រាននចេញទៅ ។ បទថា* **អារកា វ** *បានដល់ ក្នុងទីឆ្ងាយនោះឯង ។ បទថា* **ន តេន និព្ពានធាតុយា ឧនត្តំ វា បូរត្តំ វា** *សេចក្តីថា បុគ្គលណាម្នាក់ មិនអាច និងពោលថា កាលកប្បមិនទាន់អស់ទៅ ព្រះពុទ្ធទាំងឡាយ ទ្រង់មិនទាន់ កើតឡើង សូម្បីសត្វមួយ ក៏មិនអាចបរិនិព្វានបានឡើយ ក្នុងកាលនោះ ក៏*

មិនអាចពោលថា និព្វានជាតុទទេឡើយ តែក្នុងពុទ្ធកាល សត្វទាំងឡាយ រាប់មិនអស់ ក្នុងសមាគមនីមួយៗ ក៏នាំគ្នាត្រេកអរក្នុងអមតធម៌ ក្នុងកាលនោះ បុគ្គលណាម្នាក់ ក៏មិនអាចពោលបានថា និព្វានជាតុពេញឡើយ ។ បទថា **វិមុត្តិរសោ** *ប្រែថា មានការរួចផុតចាកកិលេសជារស ។ ពិតហើយ សាសនសម្បត្តិទាំងមូល រមែងតាំងនៅត្រឹមតែចិត្តរួចផុតចាកអាសវៈទាំង-ឡាយ ព្រោះមិនប្រកាន់មាំ ។*

បទថា **រតនានិ** *សេចក្តីថា ឈ្មោះថា* **រតន** *ព្រោះអត្ថថា ឲ្យកើតនូវការត្រេកអរ ។ ពិតហើយ កាលចម្រើនសតិបដ្ឋានជាដើម មានបីតិ និងបាមោជ្ជ មានប្រមាណមិនតិច រមែងកើតក្នុងចំណែកខាងដើម ។ ក្នុងចំណែកខាងចុង មិនចាំបាច់ពោលដល់ឡើយ សមដូចព្រះតម្រាស់ត្រាស់ក្នុងខុទ្ទក-និកាយ ធម្មបទថា*

> *ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធទាំងឡាយក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះ រមែងបាននូវបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអតមធម៌របស់បណ្ឌិត អ្នកដឹងនូវធម៌ទាំងឡាយ ។*

បីតិ និងបាមោជ្ជ ដែលមានលោកិយវតនៈជាហេតុ រមែងមិនដល់ចំណែកនៃចម្រៀករបស់អមតធម៌នោះ អត្តជូចពោលមកនេះ លោកសម្តែងខាងដើមហើយ ម្យ៉ាងទៀត លោកពោលថា

> *វត្តុដែលធម្មជាតធ្វើឲ្យវិចិត្រ មានតម្លៃច្រើន មិនមានអ្វី*

ប្រៀប ឃើញបានដោយកម្រ ជាគ្រឿងប្រើប្រាស់របស់
សត្វដែលមិនថោកថយ លោកហៅថា **រតន ។**

ឈ្មោះថា **រតន** *រមែងមានដោយភាវៈ ដែលធម្មតាធ្វើឲ្យវិចិត្រជាដើម សោត តែសតិប្បដ្ឋានជាដើមនោះឯង ក៏ជារតនៈបាន ព្រោះជារបស់មានពិតពិតហើយ ភាវៈនៃសតិប្បដ្ឋានជាដើមនោះ ជាអានុភាពនៃពោធិបក្ខិយធម៌ ព្រោះជាហេតុជិត ដែលធ្វើឲ្យសាវ័កសម្រេចសាវកបារមីញ្ញាណ ព្រះបច្ចេក-ពុទ្ធសម្រេចបច្ចេកពោធិញ្ញាណ ព្រះសម្មាសម្ពុទ្ធសម្រេចសម្មាសម្ពោធិញ្ញាណ ពិតហើយ ហេតុដែលបន្តគ្នាមក ជាឧបនិស្សយនៃទានជាដើម សេចក្តីថា សតិប្បដ្ឋានជារតនៈ ជាធម៌ល្អក្រៃលែងនៃពោធិបក្ខិយធម៌ ព្រោះអត្ថថា ធ្វើឲ្យកើតនូវការត្រេកអរ និងព្រោះអត្ថថា ជារបស់ដែលធម្មជាតធ្វើឲ្យវិចិត្រ ។ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា ក្នុងធម៌ទាំងនោះ រតនៈទាំងនេះ គឺ សតិប្បដ្ឋាន ៤ ។*

បណ្តាធម៌ទាំងនោះ ឈ្មោះថា **បដ្ឋាន** *ព្រោះអត្ថថា ឈមចុះប្រាកដក្នុងអារម្មណ៍ កម្ម ផ្តើមដំបូង គឺសតិ ឈ្មោះថា* **សតិប្បដ្ឋាន ។** *ព្រោះអារម្មណ៍មាន ៤ យ៉ាង ដោយអំណាចកាយជាដើម ទើបលោកពោលថា សតិប្បដ្ឋាន ៤ ។ ពិតហើយ សតិប្បដ្ឋានទាំង ៤ នោះ លោកចែកចេញជាកាយានុ-បស្សនាជាដើម ព្រោះលះនូវការសម្គាល់ក្នុងកាយថាស្អាត វេទនាថាជាសុខ ចិត្តថាជារបស់ទៀង ក្នុងធម៌ថាជាអត្តា និងព្រោះប្រកាន់ក្នុងកាយ ថាជាវត្ថុមិនស្អាត ក្នុងវេទនា ថាជាទុក្ខ ក្នុងចិត្តថាជារបស់មិនទៀង និងធម៌ ថាជា*

អនត្តា ។

ឈ្មោះថា **សម្មប្បធាន** *ព្រោះជាហេតុឲ្យព្រះយោគី ផ្តើមចម្រើនដោយប្រពៃ ឬថា ខ្លួនឯងផ្តើមចម្រើនដោយប្រពៃ ឬការផ្តើមចម្រើនដែលបណ្ឌិតសរសើរ ឬជារបស់ល្អ ។ ម្យ៉ាងទៀត ឈ្មោះថា សម្មប្បធាន ព្រោះជាហេតុឲ្យបុគ្គលធ្វើនូវសេចក្តីព្យាយាមដោយប្រពៃនោះឯង ពាក្យថា សម្មប្បធាននេះជាឈ្មោះរបស់វីរិយៈ ។ សម្មប្បធាន គឺសេចក្តីព្យាយាមនោះ ក៏ហៅថា សម្មប្បធាន ៤ ព្រោះធ្វើកិច្ច ៤ យ៉ាង គឺមិនឲ្យអកុសលធម៌ ដែលមិនទាន់កើត មិនឲ្យកើតឡើង ១ លះអកុសលធម៌ដែលកើតឡើង ១ ធ្វើកុសលធម៌ដែលមិនទាន់កើត ឲ្យកើតឡើង ១ ធ្វើកុសលធម៌ដែលកើតឡើងហើយ ឲ្យចម្រើន ១ ។*

ឈ្មោះថា **ឥទ្ធិ** *ព្រោះអត្ថថា ឲ្យសម្រេច អធិប្បាយថា សម្រេច គឺបាននូវផល ។ ម្យ៉ាងទៀត ឈ្មោះថា* **ឥទ្ធិ** *ព្រោះជាហេតុសម្រេច គឺសម្រេចចម្រើនដល់ភាពខុតុង្គខុតុមដល់សត្វទាំងឡាយ ដោយអត្ថជំបូង* **ចាន** *គឺការសម្រេច ឈ្មោះថា* **ឥទ្ធិចាន** *អធិប្បាយថា ចំណែកនៃសេចក្តីសម្រេច ។ ដោយអត្ថទី ២* **ចាន** *គឺទីតាំង បានដល់ ឧបាយជាគ្រឿងសម្រេច ដល់នូវការសម្រេច ព្រោះហេតុនោះ ទើបឈ្មោះថា* **ឥទ្ធិចាន** *។ ពិតហើយ សត្វទាំងឡាយរមែងដល់ គឺចាក់ផ្ទុះនូវសេចក្តីសម្រេច ពោល គឺគុណវិសេសក្រៃលែងឡើង ដោយឥទ្ធិបាទនោះ ។ ឥទ្ធិបាទនោះ លោកហៅថា ឥទ្ធិបាទ ៤ ព្រោះធ្វើអធិបតីធម៌ ៤ មានឆន្ទាធិបតីជាដើមឲ្យជាធុរៈ គឺឲ្យជាធំកើត*

ឡើង ។

បទថា **បញ្ចិន្ទ្រិយានិ** *បានដល់ ឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើម ក្នុង ឥន្ទ្រិយ ៥ នោះ សទ្ធា ឈ្មោះថា* **ឥន្ទ្រិយ** *ព្រោះគ្របសង្កត់ភាពជាបុគ្គល មិនមានសទ្ធា ហើយធ្វើឲ្យជាធំក្នុងលក្ខណៈនៃការជឿ ។ បញ្ញា ឈ្មោះថា ឥន្ទ្រិយ ព្រោះគ្របសង្កត់កោសជ្ជ ហើយធ្វើឲ្យជាធំក្នុងលក្ខណៈនៃការផ្គង គ្របសង្កត់នូវបមាទៈ ហើយធ្វើឲ្យជាធំ ក្នុងលក្ខណៈប្រាកដ ការគ្របសង្កត់នូវការរាយមាយ ហើយធ្វើឲ្យជាធំ ក្នុងលក្ខណៈនៃការមិនរាយមាយ ការគ្របសង្កត់នូវការមិនដឹង ហើយធ្វើភាពជាធំ ក្នុងលក្ខណៈនៃទស្សនៈ ឥន្ទ្រិយ ៥ នោះឯង គប្បីជ្រាបថា ជាពល ព្រោះភាពជាធម្មជាតមាំទាំ ក្នុងសម្បយុត្តធម៌ទាំងឡាយ ដោយអត្ថថា មិនញាប់ញ័រ ដោយការមិនមានសទ្ធាជាដើម គ្របសង្កត់មិនបាន ។*

បទថា **សត្ត ពោជ្ឈង្គា** *សេចក្តីថា ពោជ្ឈង្គ ព្រោះអត្ថថា ជាអង្គនៃធម្មសាមគ្គីជាគ្រឿងត្រាស់ដឹង ឬរបស់បុគ្គលអ្នកត្រាស់ដឹង ។ អរិយសាវ័ករមែងត្រាស់ដឹង គឺចេញចាកកិលេសនិទ្រា គឺចាក់ធ្លុះអរិយសច្ច ៤ ឬធ្វើឲ្យជាក់ច្បាស់ចំពោះព្រះនិព្វាន ដោយធម្មសាមគ្គីណា ពោល គឺសតិធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខាដែលជាបដិបក្ខចំពោះអន្តរាយជាអនេក ដូចការតាំងនៅ និងការប្រមូលមកនូវការរួញរា និងការរាយមាយ ការប្រកបក្នុងកាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ និងការប្រកាន់មាំក្នុងឧច្ឆេទទិដ្ឋិ និងសស្សតទិដ្ឋិជាដើម ដែលកើតឡើងក្នុងខណៈលោកុត្តរមគ្គ*

ព្រោះហេតុនោះ ធម្មសាមគ្គីនោះ លោកហៅថា ពោធិ ឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃពោធិ ពោល គឺធម្មសាមគ្គីនោះ ដូចអង្គនៃឈាន និងអង្គនៃមគ្គជាដើម ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃព្រះអរិយសាវ័កដែលត្រាស់ដឹង ដែលហៅថា ពោធិ ព្រោះវិគ្គហៈថា ត្រាស់ដឹងដោយធម្មសាមគ្គី មានប្រការដូចពោលហើយ ដូចអង្គរបស់សេនា និងអង្គរបស់រថជាដើម ។ ដោយហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា ឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃបុគ្គលត្រាស់ដឹង គប្បីជ្រាបអត្ថនៃពោជ្ឈង្គ ដោយនយជាដើមថា ឈ្មោះថា ពោជ្ឈង្គ ព្រោះប្រព្រឹត្តទៅដើម្បីធម្មសាមគ្គី គឺគ្រឿងត្រាស់ដឹងដូច្នេះ ។

បទថា **អរិយោ អដ្ឋង្គិកោ មគ្គោ** *សេចក្តីថា ឈ្មោះថា អរិយៈ ព្រោះធ្វើយចាកកិលេសដែលមគ្គនោះៗ គប្បីសម្លាប់ ព្រោះធ្វើភាពជាព្រះអរិយៈ និងព្រោះឲ្យបានអរិយផល ។ ឈ្មោះថា អដ្ឋង្គិក ព្រោះមគ្គនោះមានអង្គ ៨ មានសម្មាទិដ្ឋិជាដើម ។ ម្យ៉ាងទៀត អង្គ ៨ នោះឯង ឈ្មោះថា អដ្ឋង្គិក ។ ឈ្មោះថា មគ្គ ព្រោះសម្លាប់កិលេសទាំងឡាយឲ្យងាប់ទៅ ឬព្រោះបុគ្គលត្រូវព្រះនិព្វានស្វែងរក ឬខ្លួនឯងស្វែងរកព្រះនិព្វាន ។ គប្បីជ្រាបការចែកអត្ថនៃសតិប្បដ្ឋានជាដើមទាំងនោះយ៉ាងនេះ ដោយប្រការដូច្នេះ ។*

បទថា **សោតាបន្នោ** *បានដល់ ព្រះអរិយបុគ្គលដែលដល់ គឺសម្រេចក្រៃសែ ពោល គឺមគ្គតាំងនៅ អធិប្បាយថា ដែលតាំងនៅក្នុងសោតាបត្តិ-ផល ។ បទថា* **សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ** *បានដល់ ព្រះ*

អរិយបុគ្គល ដែលតាំងនៅក្នុងបឋមមគ្គ ដែលកំពុងបដិបត្តិ ដើម្បីធ្វើសោតា-បត្តិផលឲ្យជាក់ច្បាស់ដល់ខ្លួន ដែលហៅព្រះអរិយបុគ្គលទី ៨ ដូច្នេះក៏មាន ។ បទថា **សកទាគាមី** *បានដល់ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងផលទី ២ និងដែលមកកាន់លោកនេះតែម្តងប៉ុណ្ណោះដោយបដិសន្ធិ ។ បទថា* **អនាគាមី** *បានដល់ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងផលទី ៣ ដែលមានប្រក្រតីមិនមកកាន់កាមលោកដោយបដិសន្ធិ ។ ការចែកអរិយបុគ្គល មានសទ្ធានុសារី ១ ធម្មានុសារី ១ ឯកពីជី ១ ជាដើម ជាប្រភេទនៃព្រះអរិយបុគ្គលទាំងនោះឯង ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបការពោល គឺការមិនមានធម៌ជាគ្រឿងនៅរួមគ្នាជាមួយបុគ្គលទុស្សសីល ដូចសាកសពសត្វដែលស្លាប់ក្នុងធម្មវិន័យរបស់ព្រះអង្គនេះ ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្លឺឧទាននេះ ដែលសម្តែងហេតុនៃការចែកបុគ្គល ដែលមិនគួរនៅរួម និងបុគ្គលដែលគួរនៅរួម ។*

បណ្តាបទទាំងនោះ បទថា **ឆន្នមតិវស្សតិ** *សេចក្តីថា កិក្ខុត្រូវអាបត្តិហើយបិទបាំង រមែងត្រូវអាបត្តិដទៃជាថ្មីទៀត រមែងត្រូវអាបត្តិច្រើនឡើងភ្លៀង គឺអាបត្តិ បានដល់ ភ្លៀង គឺកិលេស រមែងលិចស្រោចច្រើនឡើងយ៉ាងនេះ ដោយប្រការដូច្នេះ ។ បទថា* **វិវដំ នាតិវស្សតិ** *សេចក្តីថា កិក្ខុត្រូវអាបត្តិហើយ មិនបិទបាំងអាបត្តិនោះ បើកផ្សារ ប្រកាស ដើម្បីសព្រហ្មចារីសម្តែង ចេញចាកអាបត្តិតាមធម៌តាមវិន័យ មិនត្រូវអាបត្តិដទៃជាថ្មី ព្រោះ*

ហេតុនោះ ភ្លៀង គឺអាបត្តិ ភ្លៀង គឺកិលេស ដែលកិក្ខុនោះបើកផ្ទារហើយ រមែងមិនលិចស្រោចទៀត ព្រោះសេចក្តីនោះយ៉ាងនោះ ដូច្នោះ លោកទាំង-ឡាយគប្បីបើក គឺប្រកាសអាបត្តិដែលបិទ គឺដែលបិទជាំង ។ បទថា **ឯវន្តំ ឆាតិវស្សតិ** *សេចក្តីថា កាលបើដូច្នោះ ភ្លៀង គឺកិលេស រមែងមិនទម្លាយអត្តភាព ហើយលិចស្រោច គឺមិនសើមបុគ្គលដែលត្រូវអាបត្តិនោះ ។ អធិប្បាយថា បុគ្គលនោះមិនត្រូវកិលេសលិចស្រោចយ៉ាងនោះ ជាអ្នកមានសីលបរិសុទ្ធ មានចិត្តមាំ ផ្តើមតាំងវិបស្សនា ពិចារណា រមែងសម្រេចដល់ព្រះនិព្វានដោយលំដាប់ ។*

អដ្ឋកថា ឧទោសថសូត្រទី ៥ ចប់

សុត្តន្តបិដក

សោណសូត្រ

[១១៩] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមហាកច្ចាន:ដ៏មានអាយុ គង់នៅលើភ្នំឈ្មោះបវត្ត: ទៀបក្រុងឈ្មោះកុរុរឃរ: ក្នុងអវន្តិជនបទ ។ សម័យនោះ ឧបាសកឈ្មោះសោណកុដិកណ្ណ: ជាឧបដ្ឋាករបស់ព្រះមហាកច្ចាន:ដ៏មានអាយុ ។ វេលានោះ ឧបាសកឈ្មោះសោណកុដិកណ្ណ:នៅក្នុងទីស្ងាត់ ពួនសម្ងំ កើតសេចក្តី*

ត្រិះរិះក្នុងចិត្តយ៉ាងនេះថា លោកម្ចាស់មហាកច្ចាន: សម្តែងធម៌ដោយអាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នោះឲ្យបរិបូណ៌ បរិសុទ្ធពេញលេញ ដូចជាសង្ខ៍ដែលដុសខាត់ហើយ (ដោយអាការនោះ) បានឡើយ បើដូច្នោះ មានតែអញ កោរសក់ និងពុកមាត់ហើយ ស្បៀកជណ្តប់សំពត់កាសាយ: ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ គ្រានោះ ឧបាសកឈ្មោះសោណកុដិកណ្ណ: ចូលទៅរកព្រះមហាកច្ចាន:ដ៏មានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមហាកច្ចាន:ដ៏មានអាយុហើយ អង្គុយក្នុងទីសមគួរ លុះឧបាសកឈ្មោះសោណកុដិកណ្ណ:អង្គុយក្នុងទីសមគួរហើយ បាននិយាយពាក្យនេះ នឹងមហាកច្ចាន:ដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងទីនេះ ខ្ញុំព្រះករុណានៅក្នុងទីស្ងាត់ ពួនសម្ងំ កើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា លោកម្ចាស់មហាកច្ចាន: សម្តែងធម៌ដោយអាការណា បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះឲ្យបរិបូណ៌ បរិសុទ្ធ ពេញលេញ ដូចជាសង្ខ៍ដែលដុសខាត់ហើយ (ដោយអាការនោះ) បានឡើយ បើដូច្នោះ មានតែអញ កោរសក់ និងពុកមាត់ហើយស្បៀកជណ្តប់សំពត់កាសាយ: ចេញចាកផ្ទះចូលទៅកាន់ផ្នួស បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មហាកច្ចាន:បំបួសខ្ញុំឲ្យទាន ។

[១២០] លុះឧបាសក និយាយយ៉ាងនេះហើយ ទើបមហាកច្ចាន:ដ៏មានអាយុ ពោលតបនឹងឧបាសក ឈ្មោះសោណកុដិកណ្ណ:ដូច្នេះថា នែសោណ: ព្រហ្មចរិយ: មានការបរិភោគភត្ត តែមួយពេល មានការដេកនៅ

តែម្នាក់ឯង ជាបជាល់អស់មួយជីវិត កម្របុគ្គលនឹងធ្វើបាន នៃសោណៈ ណ្ហើយចុះ អ្នកនៅជាគ្រហស្ថ ក្នុងទីនោះបណ្តើរសិនចុះ ចូរប្រកបតាមពាក្យ ប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រហ្មចរិយៈ មានការបរិភោគកត្ត តែមួយពេល មានការដេកនៅតែម្នាក់ឯង សមគួរតាមកាលចុះ ។ លំដាប់ នោះ ការប្រុងប្រៀបនឹងបួសរបស់ឧបាសកឈ្មោះសោណកុដិកណ្ណៈ ក៏អាក់ ខានទៅ ។ ឧបាសកសោណកុដិកណ្ណៈ នៅក្នុងទីស្ងាត់ ពួនសម្ងំ កើតសេចក្តី ត្រិះរិះក្នុងចិត្តអស់វារៈ ២ ដងថា លោកម្ចាស់មហាកច្ចានៈ សម្តែងធម៌ដោយ អាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ នេះឲ្យបរិបូណ៌ បរិសុទ្ធ ពេញលេញ ដូចជាសង្ខ ដែលជូសខាត់ហើយ (ដោយអាការនោះ) បានឡើយ បើដូច្នោះ មានតែអញកោរសក់ និងពុក មាត់ ហើយស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ ឧបាសកឈ្មោះសោណកុដិកណ្ណៈ ចូលទៅរកមហាកច្ចានៈដ៏មានអាយុ លុះ ចូលទៅដល់ហើយ ថ្វាយបង្គំមហាកច្ចានៈដ៏មានអាយុ ហើយអង្គុយក្នុងទី សមគួរ អស់វារៈ ២ ដង ។ លុះឧបាសកឈ្មោះសោណកុដិកណ្ណៈអង្គុយ ក្នុងទីសមគួរហើយ ពិតថេរោចាមមហាកច្ចានៈដ៏មានអាយុ ដូច្នេះថា បពិត្រ លោកម្ចាស់ដ៏ចម្រើន អម្បាញ់មិញនេះ ខ្ញុំនៅក្នុងទីស្ងាត់ ពួនសម្ងំ កើត សេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា លោកម្ចាស់មហាកច្ចានៈសម្តែងធម៌ដោយ អាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ នេះ ឲ្យបរិបូណ៌ បរិសុទ្ធ ពេញលេញ ដូចជាសង្ខដែលជូសខាត់ហើយ

(ដោយអាការនោះ) បានឡើយ បើដូច្នោះ មានតែអញ កោរសក់ និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ហើយចេញចាកផ្ទះចូលទៅកាន់ផ្នួសបពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មហាកច្ចានៈ បំបួសខ្ញុំឲ្យទាន ។ ព្រះមហាកច្ចានៈដ៏មានអាយុ និយាយថ្កោះ ឧបាសកឈ្មោះសោណកុដិកណ្ណៈ អស់វារៈ ២ ដងថា នែសោណៈ ព្រហ្មចរិយៈ មានការបរិភោគភត្តតែមួយពេល មានការដេកនៅតែម្នាក់ឯង ដរាបដល់អស់ជីវិត កម្របុគ្គលធ្វើបាន នែសោណៈ ណ្ហើយចុះ អ្នកនៅជាគ្រហស្ថក្នុងទីនេះបណ្តើរសិនចុះ ចូរប្រកបតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រហ្មចរិយៈ មានការបរិភោគភត្តតែមួយពេល មានការដេកនៅតែម្នាក់ឯង សមគួរដល់កាលចុះ ។ ការប្រុងប្រៀបនឹងបួសរបស់ឧបាសកឈ្មោះសោណកុដិកណ្ណៈ ក៏អាក់ខានទៅ អស់វារៈ ២ ដង ឧបាសកឈ្មោះសោណកុដិកណ្ណៈ នៅក្នុងទីស្ងាត់ពួនសម្ងំកើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះ អស់វារៈ ៣ ដងថា លោកម្ចាស់មហា-កច្ចានៈ សម្តែងធម៌ដោយអាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ឲ្យបរិបូណ៌ បរិសុទ្ធ ពេញលេញ ដូចជាសង្ខ័ដែលជូតសខាត់ហើយ (ដោយអាការនោះ) បានឡើយ បើដូច្នោះ មានតែអញ កោរសក់ និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ ឧបាសកឈ្មោះសោណកុដិកណ្ណៈ ចូលទៅរកមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំមហាកច្ចានៈដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ជាគម្រប់ ៣ ដង ។ លុះឧបាសក

ឈ្មោះសោណកុដិកណ្ណៈ អង្គុយក្នុងទីសមគួរហើយ ពិតថេរោចាមហាកច្ចានៈ ដ៏មានអាយុដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន អម្បាញ់មិញនេះ ខ្ញុំនៅក្នុងទីស្ងាត់ ពួនសម្ងំ កើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា លោកម្ចាស់មហាកច្ចានៈ សម្តែងធម៌ដោយអាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះឲ្យបរិបូណ៌ បរិសុទ្ធ ពេញលេញ ដូចជាសង្ខ ដែលជូតខាត់ហើយ (ដោយអាការនោះ) បានឡើយ បើដូច្នោះ មានតែអញ កោរសក់ និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មហាកច្ចានៈ បំបួសខ្ញុំឲ្យទាន ។ លំដាប់នោះ ព្រះមហាកច្ចាន:ដ៏មានអាយុ ក៏បំបួសឧបាសក ឈ្មោះសោណកុដិកណ្ណៈ (ក្នុងកាលនោះ) ។

[១២១] *សម័យនោះឯង អវន្តិទក្ខិណាបថជនបទ មានភិក្ខុតិច ។ វេលានោះ ព្រះមហាកច្ចាន:ដ៏មានអាយុ ក៏ប្រជុំភិក្ខុសង្ឃទសវគ្គ អំពីគាមនិគមនោះៗ ដោយកាលកន្លងទៅ ៣ ឆ្នាំ ដោយក្រលំបាក ហើយឲ្យសោណៈដ៏មានអាយុ បានឧបសម្បទា ។ គ្រានោះ ព្រះសោណ:ដ៏មានអាយុ នៅចាំវស្សារួចហើយ នៅក្នុងទីស្ងាត់ ពួនសម្ងំ កើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា អញមិនដែលឃើញព្រះមានព្រះភាគអង្គនោះ ក្នុងទីចំពោះមុខសោះ អញគ្រាន់តែឮថា ព្រះមានព្រះភាគ ព្រះអង្គនោះ ទ្រង់មានសភាពដូច្នេះខ្លះៗ ប្រសិនបើព្រះឧបជ្ឈាយ៍អនុញ្ញាតអញៗ គួរតែទៅគាល់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។ លំដាប់នោះ ព្រះសោណ:ដ៏មានអាយុ*

ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ចូលទៅរកព្រះមហាកច្ចាន:ដ៏មានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមហាកច្ចាន:ដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសោណ:ដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ និយាយពាក្យនេះនឹងមហាកច្ចាន:ដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន អម្បាញ់មិញនេះ ខ្ញុំព្រះករុណានៅក្នុងទីស្ងាត់ ពួនសម្ងំ កើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា អញមិនដែលឃើញព្រះមានព្រះភាគព្រះអង្គនោះ ក្នុងទីចំពោះមុខសោះ អញគ្រាន់តែឮថា ព្រះមានព្រះភាគ ព្រះអង្គនោះ មានសភាពដូច្នេះខ្លះៗ ប្រសិនបើ ព្រះឧបជ្ឈាយ៍អនុញ្ញាតអញៗ គួរតែទៅគាល់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។ ព្រះមហាកច្ចាន:ដ៏មានអាយុ តបថា នែសោណ: ប្រពៃណាស់ ប្រពៃណាស់ ម្នាលសោណ: លោកចូរទៅគាល់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះចុះ ម្នាលសោណ: លោកនឹងឃើញព្រះមានព្រះភាគនោះ ជាទីជ្រះថ្លា គួរឲ្យជ្រះថ្លា មានឥន្ទ្រិយស្ងប់ មានព្រះហឫទ័យស្ងប់ ដល់នូវការស្ងប់ និងការទូន្មានដ៏ឧត្តម បានទូន្មាន គ្រប់គ្រង មានឥន្ទ្រិយសង្រួមហើយ ជាព្រះពុទ្ធដ៏ប្រសើរ លុះឃើញហើយ ចូរថ្វាយបង្គំព្រះបាទារបស់ព្រះមានព្រះភាគ ដោយត្បូងតាមពាក្យបណ្តាំរបស់ខ្ញុំ លោកចូរសួរសេចក្តីមិនមានអាពាធ មិនមានទុក្ខ ការក្រោកឡើងដោយរហ័សរហួន កម្លាំងកាយ និងការនៅជាសុខសប្បាយផង ។ សោណកិក្ខុដ៏មានអាយុទទួលថា ព្រះករុណាលោកម្ចាស់ ហើយត្រេកអរ រីករាយ នឹងការសិតរបស់មហាកច្ចាន:ដ៏មានអាយុ ហើយក្រោកចាក

អាសនៈ ថ្វាយបង្គំព្រះមហាកច្ចានៈដ៏មានអាយុ ធ្វើប្រទក្សិណ ទុកជាក់ សេនាសនៈ កាន់យកបាត្រចីវរហើយ ចេញទៅកាន់ចារិកក្នុងក្រុងសាវត្ថី កាលត្រាច់ទៅកាន់ចារិកតាមលំដាប់ សំដៅទៅឯក្រុងសាវត្ថី នាវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះ សោណកិកុដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះមាន ព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហាកច្ចានៈដ៏មានអាយុ ជាឧបជ្ឈាយ៍ នៃខ្ញុំព្រះអង្គ ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយត្បូង សួរសេចក្តី មិនមានអាពាធ មិនមានទុក្ខ ការក្រោកឡើងរហ័សរហួន កម្លាំងកាយ និង ការនៅជាសុខសប្បាយផង ។ ព្រះមានព្រះភាគ ទ្រង់សួរថា ម្នាលកិកុ អ្នក គួរអត់ធន់បានដែរឬ គួរឲ្យប្រព្រឹត្តទៅបានដែរឬ អ្នកមកតាមផ្លូវ កាន់ផ្លូវ ឆ្ងាយ មិនលំបាកទេឬ ទាំងមិនលំបាកដោយចង្ហាន់ទេឬ ។ បពិត្រព្រះមានព្រះ ភាគ គួរអត់ធន់បាន បពិត្រព្រះមានព្រះភាគ គួរឲ្យប្រព្រឹត្តទៅបាន បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមកតាមផ្លូវកាន់ផ្លូវឆ្ងាយ មិនលំបាកទេ ទាំងមិន លំបាកដោយចង្ហាន់បិណ្ឌបាតឡើយ ។

[១២២] *គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅអានន្ទដ៏មាន អាយុមកថា ម្នាលអានន្ទ អ្នកចូរក្រាលសេនាសនៈ សម្រាប់អាគន្តុកកិកុនេះ ផងចុះ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីត្រិះរិះថា ព្រះមាន ព្រះភាគទ្រង់បង្គាប់អញ ឲ្យក្រាលអាសនៈសម្រាប់កិកុណា ដោយព្រះពុទ្ធ-*

ដីកាថា អ្នកចូរក្រាលសេនាសនៈ សម្រាប់អាគន្តុកភិក្ខុនេះផងចុះ ព្រះមានព្រះភាគ ប៉ងនឹងគង់នៅក្នុងលំនៅមួយ ជាមួយនឹងភិក្ខុនោះ ព្រះមានព្រះភាគទ្រង់ប៉ងនឹងគង់នៅក្នុងលំនៅមួយ ជាមួយនឹងសោណភិក្ខុដ៏មានអាយុ ។ ព្រះមានព្រះភាគ ទ្រង់ប្រថាប់ក្នុងលំនៅណា អានន្ទក៏ក្រាលសេនាសនៈសម្រាប់សោណភិក្ខុដ៏មានអាយុ ក្នុងលំនៅនោះដែរ ។ លុះជាប់នោះ ព្រះមានព្រះភាគទ្រង់ផ្ទំនៅក្នុងទីវាល អស់រយៈយប់ជ្រៅ លុះកន្លងវេលាហើយ ក៏លាងព្រះបាទហើយចូលទៅកាន់វិហារ ។ ឯសោណភិក្ខុដ៏មានអាយុ ក៏សិងក្នុងទីវាល អស់រយៈយប់ជ្រៅ លុះកន្លងវេលាទៅហើយ ក៏លាងជើង ហើយចូលទៅកាន់វិហារដែរ ។ លុះជាប់នោះ ព្រះមានព្រះភាគ ទ្រង់តើនឡើងក្នុងបច្ចូសសមัยនៃរាត្រីត្រាស់បង្គាប់ព្រះសោណៈដ៏មានអាយុថា ម្នាលភិក្ខុ កាលសម្តែងធម៌នឹងប្រោកដដល់លោក ។ ព្រះសោណៈដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយសម្តែងព្រះសូត្រ ១៦ ក្នុងអដ្ឋកវគ្គទាំងអស់ ដោយសំឡេង (បទសរភញ្ញ) ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់សរសើរព្រះសោណភិក្ខុដ៏មានអាយុ ក្នុងទីបំផុតនៃការសម្តែង ដោយសំឡេងថា ម្នាលភិក្ខុ ពីរោះណាស់ ម្នាលភិក្ខុ សូត្រដែលមានក្នុងអដ្ឋកវគ្គ អ្នករៀនល្អហើយ យកចិត្តទុកដាក់ល្អហើយ ចាំស្ទាត់ហើយ អ្នកជាភិក្ខុប្រកបដោយវាចាដ៏ពីរោះ ក្បោះក្បាយ ជាវាចាមិនមានទោស អាចញុំងបុគ្គលដទៃ ឲ្យដឹងច្បាស់សេចក្តីបាន ម្នាលភិក្ខុ អ្នកមានវស្សាប៉ុន្មាន ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទើបនឹងបានមួយវស្សា ។

ម្នាលភិក្ខុ ហេតុអ្វីក៏អ្នកធ្វើឲ្យយូរយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ទោស ក្នុងកាមគុណ ខ្ញុំព្រះអង្គឃើញយូរហើយដែរ តែថា ធម្មតា ឃរាវាស ជាធម៌ចង្អៀត មានកិច្ចច្រើន មានការងារច្រើន ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនោះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

អរិយៈឃើញទោស ក្នុងសង្ខារលោក ជាធម៌ដែលគ្មានឧបធិហើយ រមែងមិនត្រេកអរក្នុងបាប (ដូច) បុគ្គលស្អាត មិនត្រេកអរក្នុងវត្ថុអាក្រក់ ។ សូត្រទី ៦ ។

អដ្ឋកថា

សោណាសូត្រ

សោណាសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ

[១១៩] *បទថា* **អវន្តីសុ** *បានដល់ ក្នុងអវន្តីរដ្ឋ ។ បទថា* **កុរុឃរេ** *បានដល់ នគរដែលមានឈ្មោះយ៉ាងនោះ ។ បទថា* **បវត្តេ បព្វតេ** *បានដល់ ភ្នំដែលឈ្មោះថា* **បវត្ត** ។ *អាចារ្យពួកខ្លះពោលថា* **បថាតេ** *ដូច្នេះក៏មាន ។ បទថា* **សោណោ ឧបាសកោ កុដិកណ្ណោ** *សេចក្តីថា ដោយឈ្មោះ ឈ្មោះថា សោណៈ ឈ្មោះថា ឧបាសក ព្រោះប្រកាសភាពជាឧបាសក ដោយដល់សរណៈ ៣ ព្រោះទ្រទ្រង់នូវគ្រឿងប្រដាប់ត្រចៀកតម្កៃមួយកោដិ គួរហៅថា កោដិកណ្ណៈ តែគេស្គាល់ច្រើនថា កុដិកណ្ណៈ អធិប្បាយ*

ថា សោណៈជាក្មួយស្អ ។

សោណឧបាសកនោះ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះកច្ចានៈ ជ្រះថ្លា ក្រៃលែងក្នុងព្រះសាសនា តាំងនៅក្នុងសរណៈ និងសីល ទើបឲ្យសាងវិហារ ក្នុងទីដែលសម្បូរដោយម្ជប់ និងទឹក ក្បែរបវត្តបពិត ហើយនិមន្តព្រះថេរៈឲ្យ នៅក្នុងវិហារនោះ ទំនុកបម្រុងដោយបច្ច័យ ៤ ដោយហេតុនោះ ទើបលោក ពោលថា ជាឧបដ្ឋាករបស់ព្រះមហាកច្ចានៈ ។

គាត់ចូលទៅកាន់ទីទំនុកបម្រុងរបស់ព្រះថេរៈ តាមកាលដែលគួរ ហើយ ព្រះថេរៈក៏បានសម្តែងធម៌ដល់ឧបាសកនោះ ដោយហេតុនោះ ទើបគាត់មាន សេចក្តីសង្វេគច្រើន កើតនូវឧស្សាហ៍ក្នុងការប្រព្រឹត្តធម៌ ។ សម័យមួយ ឧបាសកទៅនគរឧជ្ជេនីជាមួយក្រុមរទេះ ដើម្បីលក់ដូរ កាលសម្រាករទេះក្នុង រវាងផ្លូវ ព្រោះធុញនឹងមនុស្សអ៊ូអរ ទើបគេចទៅជេកក្នុងទីបំផុតនាចំណែក ម្ខាង ។ ក្នុងពេលជិតភ្លឺ ក្រុមរទេះក៏ក្រោកទៅ សូម្បីមនុស្សម្នាក់ ក៏មិនដាស់ ឲ្យសោណឧបាសកភ្ញាក់ មនុស្សទាំងអស់មិនបាននឹកដល់ នាំគ្នាទៅ ។ កាល រាត្រីអស់ហើយ គាត់ភ្ញាក់ពីជេក ហើយក្រោកឡើង មិនឃើញបុគ្គលណា ម្នាក់ ទើបកាន់យកផ្លូវដែលក្រុមរទេះទៅនោះឯង កាលធ្វើដំណើរយូរទៅ ក៏ គេចចូលទៅសម្រាកត្រង់ដើមជ្រៃមួយដើម ។ ក្នុងដើមជ្រៃនោះ គាត់បាន ឃើញបុរសម្នាក់ មានរាងកាយធំខុសធម្មតាផង គួរខ្ពើមផង កំពុងទំពាស៊ី សាច់របស់ខ្លួន ដែលជ្រុះអំពីឆ្អឹង កាលឃើញហើយ ទើបសួរថា អ្នកជា នរណា ។ បុរសនោះឆ្លើយថា នែអ្នក ខ្ញុំជាប្រេត ។ សោណៈសួរថា ហេតុ

អ្វី ទើបអ្នកធ្វើយ៉ាងនេះ ។ បុរសនោះឆ្លើយថា ព្រោះកម្មរបស់ខ្ញុំ ។ សោណៈ ពោលថា កម្មនោះ ដូចម្តេច ។ ប្រេតពោលថា ពីជាតិមុន ខ្ញុំជាឈ្មួញកោង នៅក្នុងក្រុងភារុកច្ឆនគរ បោកបញ្ឆោតយករបស់អ្នកដទៃ ដើម្បីចិញ្ចឹមជីវិត កាលសមណៈចូលទៅបិណ្ឌបាតក៏ជេរថា ចូរទំពាស៊ីសាច់របស់ពួកអាចុះ ព្រោះកម្មនោះ ទើបខ្ញុំសោយទុក្ខក្នុងឥឡូវនេះ ។ សោណឧបាសកបានស្តាប់ ដូច្នោះ បាននូវសេចក្តីសង្វេគពន់ពេក បន្ទាប់អំពីនោះ កាលដើរទៅជួបពួក ប្រេត ២ នាក់ មានឈាមខ្ទៅហូរចេញអំពីមាត់ ទើបសួរដូចមុននោះឯង ។ ឯប្រេតទាំងនោះ បានប្រាប់កម្មរបស់ខ្លួន ដល់សោណៈនោះ ។

បានឮថា ក្នុងកាលនៅជាកុមារ ប្រេតទាំងនោះ ចិញ្ចឹមជីវិតដោយការ លក់ដូរក្នុងភារុកច្ឆនគរ ។ កាលមាតារបស់ខ្លួននិមន្តព្រះខីណាស្រពទាំងឡាយ មកឆាន់ ទើបទៅកាន់ផ្ទះ ហើយជេរថា ហេតុអ្វី ទើបម៉ែឲ្យទ្រព្យរបស់ពួក យើងដល់ពួកសមណៈ សូមឲ្យឈាមខ្ទៅ ហូរចេញអំពីមាត់របស់ពួកសមណៈ ដែលបរិភោគភោជនដែលម៉ែឲ្យហើយចុះ ។ ដោយកម្មនោះ ទើបកើងទាំង នោះធ្លាក់ក្នុងនរក ហើយកើតក្នុងកំណើតប្រេត ដោយសេសនៃវិបាកកម្មនោះ ទើបសោយទុក្ខនេះក្នុងកាលនោះ ។

សោណឧបាសកស្តាប់ពាក្យនោះ កើតនូវសេចក្តីសង្វេគពន់ពេក ទៅ កាន់ក្រុងឧជ្ជេនី ពិនិត្យមើលការងារដែលខ្លួនគប្បីធ្វើនោះហើយ ទើបត្រឡប់ មកកាន់ផ្ទះប្រចាំត្រកូល ចូលទៅកព្រះថេរៈ បានទទួលបដិសណ្ឋារៈហើយ ទើបប្រាប់សេចក្តីនោះដល់ព្រះថេរៈ ។ ឯព្រះថេរៈកាលប្រកាសទោសក្នុងការ

កើតទុក្ខ និងអានិសង្សក្នុងការលត់ទុក្ខដល់សោណឧបាសកនោះ ទើបសម្តែងធម៌ ។ គាត់ថ្វាយបង្គំព្រះថេរ: ហើយទៅកាន់ផ្ទះ រួចបរិភោគអាហារពេលល្ងាច ហើយទើបដេក កាលលក់មួយភាំងប៉ុណ្ណោះ ក៏ភ្ញាក់ឡើង អង្គុយត្រង់ដំណេកហើយ ផ្តើមពិចារណាធម៌តាមដែលខ្លួនបានស្តាប់មក កាលគាត់ពិចារណាធម៌នោះ និងរញកដល់អត្តភាពរបស់ប្រេតទាំងនោះ សង្ខារទុក្ខប្រាកដជារបស់គួរខ្លាចក្រែលែង ចិត្តក៏បង្អោនទៅក្នុងបព្វជ្ជា ។ កាលរាត្រីអស់ហើយ គាត់ងូតទឹកស្អាតបាត ចូលទៅរកព្រះថេរ: ប្រាប់អធ្យាស្រ័យរបស់ខ្លួនឲ្យដឹង ហើយសូមបព្វជ្ជា ។ ដោយហេតុនោះ ទើបលោកពោលថាវេលានោះ ឧបាសកឈ្មោះសោណកុដិកណ្ណ: នៅក្នុងទីស្ងាត់ ពួនសម្ងំ ។បេ។ សូមលោកម្ចាស់មហាកច្ចាន: បំបួសខ្ញុំឲ្យទាន ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទជាដើមថា **យថា យថា** មានសេចក្តីសង្ខេបដូចដូច្នេះ ព្រះមហាកច្ចាន: សម្តែង ប្រាប់ បញ្ញត្ត ផ្តើម បើកផ្លារ ចែក ធ្វើឲ្យរាក់ ប្រកាសនូវធម៌ដោយប្រការណាមួយ កាលខ្ញុំ (សោណ:) ពិចារណានូវអាការនោះ។ រមែងប្រាកដយ៉ាងនេះថា ព្រហ្មចរិយ: គឺសិក្ខា ៣ ដែលគប្បីប្រព្រឹត្តឲ្យបរិសុទ្ធដោយចំណែកមួយ ដោយរក្សាមិនឲ្យដាច់ សូម្បីមួយថ្ងៃ រហូតដល់ចិត្តចុងក្រោយ គឺចុតិចិត្តឲ្យបរិសុទ្ធដោយចំណែកមួយ ដោយមិនធ្វើឲ្យមានមន្ទិល ដោយមន្ទិល គឺកិលេស សូម្បីត្រឹមតែមួយថ្ងៃ រហូតដល់ចិត្តចុងក្រោយ ឲ្យដូចគ្នានឹងស័ង្ខដែលខាត់ល្អហើយ គឺប្រៀបដូចស័ង្ខដែលជម្រះស្អាតល្អ ព្រហ្មចរិយ:នេះ ដែលបុគ្គលនៅគ្រប់គ្រងផ្ទះ គឺនៅក្នុងផ្ទះ

និងប្រព្រឹត្តឲ្យបរិបូណ៌ដោយចំណែកមួយ ។បេ។ មិនមែនធ្វើបានងាយ បើដូច្នោះ អញគប្បីផ្តាច់ គឺគប្បីកោរសក់ និងពុកមាត់ ហើយបិទបាំង គឺដណ្តប់សំពត់ ឈ្មោះកាសាវកស្ត្រ ជ្រលក់ដោយទឹកមូតរ គឺសំពត់ដែលគួរដល់បុគ្គលប្រព្រឹត្តព្រហ្មចរិយៈ ចេញចាកផ្ទះ ហើយបួស ជាអ្នកមិនមានផ្ទះ ។ ព្រោះហេតុដែលកម្ម មានកសិកម្ម និងពាណិជ្ជកម្មជាដើម ដែលជាប្រយោជន៍ដល់ផ្ទះ លោកហៅថា **អគារិយំ** *ហើយ អគារិយៈនោះមិនមានក្នុងបព្វជ្ជា ព្រោះដូច្នោះ ទើបបព្វជ្ជា ឈ្មោះថា* **អនគារិយ** *គឺកម្មមិនជាប្រយោជន៍ដល់ផ្ទះ អធិប្បាយថា អញគប្បីចេញ គឺគប្បីចូលដល់ បានដល់គប្បីបដិបត្តិកម្មដែលមិនជាប្រយោជន៍ដល់ផ្ទះ គឺបព្វជ្ជានោះ សោណឧបាសកប្រាប់ដល់ហេតុដែលខ្នត្រិះរិះក្នុងទីកំបាំង ដោយអាការយ៉ាងនេះដល់ព្រះថេរៈ ហើយ មានបំណងនឹងបដិបត្តិតាមនោះ ទើបប្រាប់ថា សូមលោកម្ចាស់មហាកច្ចានៈ ឲ្យខ្ញុំបួសចុះ ចំណែកព្រះថេរៈពិចារណាថា ញាណរបស់ឧបាសក មិនទាន់ចាស់ក្លា ទើបវង់ចាំការចាស់ក្លានៃញាណ ឃាត់នូវការពេញចិត្តក្នុងបព្វជ្ជា ដោយនយជាដើមថា កម្របុគ្គលធ្វើបាន ដូច្នេះ ។*

[១២០] *បណ្តាបទទាំងនោះ បទថា* **ឯកភត្តំ** *នេះ លោកពោលសំដៅដល់ការវៀរចាកការបរិភោគក្នុងវេលាវិកាល ដែលពោលយ៉ាងនេះថា ភិក្ខុជាអ្នកធាន់ម្តង វៀរចាកតម្រេក វៀរចាកការបរិភោគក្នុងវេលាវិកាល ។ បទថា* **ឯកសេយ្យំ** *បានដល់ ដេកមិនមានសម្ងាញ់ ។ ក្នុងពាក្យថា* **ឯក-សេយ្យំ** *នេះ កាលប្រាថ្នាដល់ការដេកជាប្រធាន ទើបលោកសម្តែងកាយវិវេក*

ក្នុងឥរិយាបថទាំង ៤ ដែលពោលហើយ ដោយនយជាដើមថា ឈរម្នាក់ឯង ដើរម្នាក់ឯង អង្គុយម្នាក់ឯង ដូច្នេះ មិនមែនសម្តែងត្រឹមតែជាបុគ្គលម្នាក់ឯងដេក ។ បទថា **ព្រហ្មចរិយំ** *បានដល់ ព្រហ្មចរិយៈ គឺវៀរចាកមេថុន ឬសាសនព្រហ្មចរិយៈ គឺការប្រកបរឿយៗ នូវត្រៃសិក្ខា ។ បទថា* **ឥច្ឆ** *ជានិបាត ក្នុងចោទនត្ថ ។ បទថា* **តត្ថេវ** *បានដល់ ក្នុងផ្ទះនោះឯង ។ បទថា* **ពុទ្ធសាសនំ អនុយុញ្ជ** *សេចក្តីថា ចូរប្រកបរឿយៗ នូវសីលមានអង្គ ៥ មានអង្គ ៨ និងមានអង្គ ១០ មានការកំណត់ជានិច្ចសីល និងឧបោសថ-សីលជាដើម និងសមាធិភាវនា និងបញ្ញាភាវនា ដែលសមគួរដល់សីល ។ ពិតហើយ ព្រហ្មចរិយៈនេះ ដែលឧបាសកគប្បីប្រព្រឹត្តរឿយៗ ក្នុងចំណែកខាងដើម ឈ្មោះថា ព្រះពុទ្ធសាសនា ដោយហេតុនោះ ទើបលោកពោលថា ព្រហ្មចរិយៈ មានការបរិភោគកត្តតែមួយពេល មានការដេកតែម្នាក់ឯង ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **កាលយុត្តំ** *សេចក្តីថា ប្រកបដោយកាលពោល គឺថ្ងៃ ១៤ , ១៥ , ៨ និងថ្ងៃបាដិហារិយបក្ខ ។ ម្យ៉ាងទៀត អាត្មាអញគប្បីអាចអស់កាលដ៏គួរ គឺដែលសមគួរដល់បុគ្គលដែលប្រកបរឿយៗ ក្នុងកាលតាមដែលពោលហើយ អធិប្បាយថា មិនមែនបួសសព្វកាល ។ ពាក្យទាំងអស់ លោកពោលដើម្បីឲ្យសមគួរក្នុងសម្មាបដិបត្តិ ព្រោះកាមទាំងឡាយលះបានលំបាក ព្រោះញាណរបស់ឧបាសកមិនទាន់ចាស់ក្លា មិនមែនពោលដើម្បីឃាត់ការពេញចិត្តក្នុងបព្វជ្ជា ។*

បទថា **បព្ភជ្ជាភិសង្ខារោ** *បានដល់ ផ្តើម គឺឧស្សាហ៍ដើម្បីបព្វជ្ជា ។ បទថា* **បដិប្បស្សម្ភិ** *សេចក្តីថា រម្ងាប់ទៅ ព្រោះឥន្ទ្រិយមិនទាន់ចាស់ក្លា និង ព្រោះការសង្វែគមិនទាន់ចាស់ក្លា ។ ការបួសរបស់ឧបាសករម្ងាប់ទៅក៏ពិត តែលោកក៏នៅតាំងនៅតាមវិថីដែលព្រះថេរៈប្រាប់ ហើយចូលទៅរកព្រះថេរៈ តាមកាលដ៏សមគួរ ហើយអង្គុយជិតស្តាប់ធម៌ ។ ចិត្តរបស់លោក កើតឡើង ក្នុងការបួសគ្រាទី ២ ដោយនយដូចពោលហើយនោះឯង ។ លោកប្រាប់ ដល់ព្រះថេរៈឲ្យជ្រាប សូម្បីគ្រាទី ២ ព្រះថេរៈក៏ហាម តែក្នុងវារៈទី ៣ ព្រះ ថេរៈដឹងថា គាត់មានញាណចាស់ក្លាហើយ ឥឡូវនេះ ជាពេលដែលនឹងឲ្យ ឧបាសកបួស ។ ព្រះថេរៈឲ្យឧបាសកបួសហើយ ស្វែងរកគណៈកន្ធង់ទៅ បាន ៣ ឆ្នាំ ទើបឲ្យឧបសម្បទា ដូចលោកពោលថា* **ទុតិយម្បិ ខោ សោណោ ។បេ។ ឧបសម្បាទេសិ** *ដូច្នេះជាដើម ។*

[๑๒๑] *បណ្តាបទទាំងនោះ បទថា* **អឌ្ឍភិក្ខុកោ** *ប្រែថា មានភិក្ខុ ២-៣ រូប ។ បានឮថា ក្នុងកាលនោះ ភិក្ខុទាំងឡាយ ដោយច្រើននៅក្នុង មជ្ឈិមប្រទេសប៉ុណ្ណោះ ។ ព្រោះដូច្នោះ ទើបក្នុងទីនោះ មានភិក្ខុ ២-៣ រូបប៉ុណ្ណោះ ។ ភិក្ខុទាំងនោះចែកគ្នានៅយ៉ាងនេះ គឺក្នុងនិគមមួយមានមួយរូប ក្នុងនិគមមួយមានពីររូប ។ បទថា* **កិច្ឆេន** *ប្រែថា ដោយលំបាក ។ បទថា* **កសិរេន** *ប្រែថា ដោយកម្រ ។ បទថា* **តតោ តតោ** *បានដល់ ចាកគាម និងនិគមជាដើមនោះៗ ។ ពិតហើយ កាលព្រះថេរៈនាំភិក្ខុ ២-៣ រូបមក បណ្តាភិក្ខុដទៃដែលនាំមកមុន ក៏នាំគ្នាចៀសចេញទៅ ដោយករណីយកិច្ច*

ឯណានីមួយ គ្រោងចំាកាលបន្តិចបន្តួច ហើយនាំភិក្ខុទាំងនោះត្រឡប់មកទៀត ឯភិក្ខុក្រៅអំពីនេះ ក៏ចៀសចេញទៅ ការប្រជុំដោយការនាំមករឿយៗយ៉ាងនេះ មានដោយកាលយូរនោះឯង ។ ក្នុងកាលនោះ ព្រះថេរៈបាននៅតែមួយរូប ។ បទថា **ឧសវគ្គំ ភិក្ខុសង្ឃំ សន្និចាតេត្វា** *សេចក្តីថា ក្នុងកាលនោះ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឧបសម្បទា ដោយសង្ឃទសវគ្គប៉ុណ្ណោះ ក្នុងបច្ចន្តប្បទេស ។ ពិតហើយ ព្រះមានព្រះភាគ ត្រូវព្រះថេរៈទូលដល់ហេតុឧបសម្បទានេះ ទើបទ្រង់អនុញ្ញាតឧបសម្បទា ក្នុងបច្ចន្តប្បទេស ដោយសង្ឃបញ្ចវគ្គ ។ ដោយហេតុនោះ ទើបលោកពោលថា* **តិណ្ណំ វស្សានំ ។បេ។ សន្និចាតេត្វា** *ជួច្នេះជាដើម ។*

បទថា **វស្សំ វុដ្ឋសុទ្ធ** *បានដល់ ដែលឧបសម្បទាហើយ ចូលវស្សាខាងដើម ហើយចេញ ។ បទថា* **ឯតិសោ ច ឯតិសោ ច** *សេចក្តីថា ព្រះមានព្រះភាគ អញ្ជបានស្តាប់មកថា បែបនេះ បែបនេះ គឺទ្រង់ប្រកបដោយនាមកាយសម្បត្តិ និងរូបកាយសម្បត្តិបែបនេះ និងប្រកបដោយធម្មកាយសម្បត្តិបែបនេះ ដោយពាក្យថា* **ឯ ខោ មេ សោ ភគវា សម្មុខា ឯដ្ឋោ** *នេះ អាចារ្យទាំងឡាយសំដៅយកភាពជាបុថុជ្ជនប៉ុណ្ណោះ ពោលថា សោណៈមានបំណងនឹងគាល់ព្រះមានព្រះភាគ តែខាងក្រោយ លោកនៅក្នុងព្រះគន្ធកុដិជាមួយព្រះសាស្តា ក្នុងពេលទៀបភ្លឺ ព្រះសាស្តាទ្រង់និមន្ត ទើបធ្វើទុកក្នុងចិត្ត ឲ្យមានប្រយោជន៍ដល់ព្រះសូត្រ ១៦ ជា ៨ វគ្គ ចំពោះព្រះភក្ត្រព្រះសាស្តា ហើយប្រមូលមកទុកក្នុងចិត្តទាំងអស់ ជាអ្នកជីងច្បាស់នូវអត្ថ និងធម៌ កាល*

និងពោល ជាអ្នកមានចិត្តជាសមាធិដោយមុខ គឺបាមោជ្ជដែលកើតអំពីធម៌ ក្នុងពេលចប់សរភញ្ញ ផ្តើមចម្រើនវិបស្សនា ពិចារណាសង្ខារ សម្រេចអរហត្ត ដោយលំដាប់ ក៏ដើម្បីជាប្រយោជន៍នេះប៉ុណ្ណោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ឲ្យលោកនៅក្នុងព្រះគន្ធកុដិជាមួយទ្រង់ ។ ឯអាចារ្យពួកខ្លះពោលថា ពាក្យថា អញមិនទាន់បានឃើញព្រះមានព្រះភាគចំពោះមុខ ដូច្នេះ លោកពោលសំដៅយកការឃើញរូបកាយប៉ុណ្ណោះ ។ ពិតហើយ ព្រះសោណៈគ្រាន់តែបួសហើយ រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះថេរៈ ព្យាយាម ក៏មិនទាន់បានឧបសម្បទាផង ក៏បានជាព្រះសោតាបន្ន កាលឧបសម្បទាហើយ គិតថា ឧបាសកទាំងឡាយក៏ជាព្រះសោតាបន្ន ឯអាត្មាអញក៏ជាសោតាបន្ន សេចក្តីនេះ គិតធ្វើអ្វី ទើបចម្រើនវិបស្សនា ដើម្បីមគ្គជាន់ខ្ពស់ បានអភិញ្ញា ៦ ខាងក្នុងវស្សានោះឯង ហើយបវារណាដោយវិសុទ្ធិបវារណា ព្រោះឃើញអរិយ-សច្ច ទើបឈ្មោះថា លោកបានឃើញធម្មកាយរបស់ព្រះមានព្រះភាគ សមដូចទ្រង់ត្រាស់ថា

ម្នាលវក្កលិ បុគ្គលណាឃើញធម៌ បុគ្គលនោះឈ្មោះថា ឃើញតថាគត បុគ្គលណាឃើញតថាគត បុគ្គលនោះឈ្មោះថាឃើញធម៌ ។ ព្រោះដូច្នោះ ទើបការឃើញធម្មកាយ សម្រេចដល់លោកមុននោះឯង កាលបវារណាហើយ លោកមានបំណងនឹងឃើញរូបកាយ ។ បាលីថា **សចេមំ ឧបជ្ឈាយោ អនុជានាតិ** *បើឧបជ្ឈាយ៍អនុញ្ញាតខ្ញុំសោតដូច្នេះក៏មាន ។ តែអ្នកវចនាពោលថា* **ភន្តេ។** *ម្យ៉ាងទៀត បាលីថា* **សាធុ សាធុ អាវុសោ សោណ តញ្ច ត្វំ**

អាវុសោ សោណ សាធុ សាធុ សោណ: អ្នកចូរទៅចុះ ដូច្នេះក៏មាន ។ តែពាក្យថា **មា អាវុសោ** មិនមានក្នុងគម្ពីរច្បាប់ខ្ងះទ្បើយ ។ ម្យ៉ាងទៀត បទថា **ឯវមាវុសោ** បាលីថា **ទោ អាយស្មា សោណោ** ដូច្នេះក៏មាន ។ ពិតហើយ រាទ:ថា អាវុសោ នោះឯង ពួកភិក្ខុធ្លាប់ប្រព្រឹត្តហៅគ្នានិងគ្នាមក ក្នុងកាលដែលព្រះមានព្រះភាគទ្រង់គង់ព្រះជន្ទនៅ ។ អត្ថនៃបទជាដើមថា **ភគវន្តំ ចាសាធិកំ** ខ្ញុំបានពោលហើយខាងដើមនោះឯង ។

បទថា **កច្ចិ ភិក្ខុ ទមនីយំ** សេចក្តីថា ម្នាលភិក្ខុ យន្ត គឺសរីរ:របស់អ្នក មានចក្រ ៤ មានទ្វារ ៩ អ្នកអត់ធន់បានដែរឬ ។ គឺអ្នកអាចអត់ធន់ គឺអត់ធន់បរិហារបានឬ បានដល់ ភារ: គឺទុក្ខមិនគ្របសង្កត់អ្នកឬ ។ បទថា **កច្ចិ យាបនីយំ** សេចក្តីថា អ្នកអាចញ្ចាំងអត្តភាពឲ្យប្រព្រឹត្តទៅ គឺឲ្យដំណើរទៅក្នុងកិច្ចនោះៗ បានដែរឬ អ្នកមិនសម្តែងអន្តរាយណាមួយឬ ។ បទថា **កច្ចិសិ អប្បកិលមថេន** សេចក្តីថា អ្នកមកអស់ផ្លូវឆ្ងាយ មានប្រមាណ ប៉ុណ្ណេះ ដោយមិនលំបាកទេឬ ។

[១២២] បទថា **ឯតទហោសិ** សេចក្តីថា ព្រះអានន្ទ កាលអនុ-សរណ:ដល់ពុទ្ធចរិយាគុណ ទើបបានពោលពាក្យនេះក្នុងឥទ្ឈូវនេះ ដោយ នយជាដើមថា **យស្ស ទោ មំ ភគវា** នេះ បានជាពាក្យដែលលោកគិតមក ជាអាចិណ្ណវត្ត ។ បទថា **ឯកវិហារេ** បានដល់ ក្នុងព្រះគន្ធកុដិជាមួយគ្នា ។ ពិតហើយ ព្រះគន្ធកុដិក្នុងទីនេះ លោកបំណងដល់វិហារ ។ បទថា **វត្ថុំ** ប្រែថា ដើម្បីនៅ ។

ក្នុងបទថា **ឯសជ្ឈាយ វីតិនាមេត្វា** *នេះ មានវិនិច្ឆ័យដូចតទៅនេះ អាចារ្យពួកខ្លះពោលថា ព្រោះព្រះមានព្រះភាគ កាលទ្រង់ធ្វើបដិសណ្ឋារៈក្នុងការចូលសមាបត្តិជល់ព្រះសោណៈ ទ្រង់ចូលសមាបត្តិទាំងអស់ ដែលទូទៅជល់ព្រះសាវក ដោយអនុលោម និងបដិលោម អស់រាត្រីដ៏ច្រើន ។បេ។ រួចទើបយាងចូលទៅកាន់វិហារ ដូច្នោះ ។ ឯព្រះសោណៈជ្រាបបំណងរបស់ព្រះមានព្រះភាគ ទើបចូលសមាបត្តិទាំងអស់ដែលសមគួរជល់ព្រះបំណងនោះ អស់រាត្រីជាច្រើន ។បេ។ ហើយចូលកាន់វិហារ ។ កាលចូលទៅហើយ ព្រះមានព្រះភាគទ្រង់អនុញ្ញាត សូម្បីព្រះសោណៈក៏ធ្វើចីវរឲ្យជាករណីយកិច្ចខាងក្រៅ (ដោះចីវរ) ហើយសម្ងំដោយការអង្គុយក្បែរព្រះបាទរបស់ព្រះមានព្រះភាគ ។ បទថា* **អជ្ឈេសិ** *បានជល់ ទ្រង់ត្រាស់ប្រាប់ ។ បទថា* **ឯតំ ភិក្ខុ ធម្មោ ភាសិតុំ** *បានជល់ ម្នាលភិក្ខុ ការពោលធម៌ចូរប្រាកដដល់អ្នក គឺចូរមកក្នុងមុខ គឺញាណរបស់អ្នក អធិប្បាយថា ចូរពោលធម៌តាមដែលបានស្តាប់មក តាមដែលបានរៀនមក ។*

បទថា **សោឡស អដ្ឋកវគ្គិកានិ** *បានជល់ សូត្រ ១៦ សូត្រ មានកាមសូត្រជាដើម ដែលចែកជាវគ្គមាន ៨ បទថា* **សវនេ អភណិ** *បានជល់ បានពោលដោយសំឡេងពីរោះទៅតាមសូត្រ អធិប្បាយថា ពោលដោយសរភញ្ញ ។ បទថា* **សរភញ្ញបរិយោសានេ** *បានជល់ ក្នុងការពោលសំឡេងខ្ពស់ឲ្យចប់ ។ បទថា* **សុគ្គហិតានិ** *បានជល់ រៀនសូត្រដោយប្រពៃ ។ បទថា* **សុមនសិកតានិ** *បានជល់ ជាក់ចិត្តដោយល្អ ។ បុគ្គលពួកខ្លះ ក្នុង*

កាលរៀនសូត្រ រៀនដោយប្រពៃ ក្រោយមក ក្នុងពេលធ្វើទុកក្នុងចិត្តដោយការស្វាធ្យាយជាដើម ក៏ពោលព្យញ្ជនៈឲ្យខុសទៅ ឬធ្វើបទមុខ បទក្រោយឲ្យខុសភ្លាំងភ្លាត់ ព្រះសោណៈនេះ មិនមែនដូច្នោះទេ តែព្រះសោណៈនេះជាក់ចិត្តតាមដែលរៀនមក ដោយប្រពៃនោះឯង ។ ដោយហេតុនោះ ទើបលោកពោលថា បទថា **សុមនសិកតានិ** *បានដល់ ជាក់ចិត្តដោយល្អ ។ បទថា* **សុបធារិតានិ** *បានដល់ ដោយអត្ថ លោកក៏ទ្រទ្រង់ចាំល្អហើយ ។ កាលលោកទ្រទ្រង់ចាំអត្ថល្អហើយ ក៏អាចសូធ្យបាលីបានយ៉ាងត្រឹមត្រូវ ។ បទថា* **កល្យាណិយាសិ វាចាយ សមង្គាគតោ** *សេចក្តីថា លោកជាអ្នកប្រកបដោយវាចារបស់អ្នកក្រុង បរិបូណ៌ដោយបទ និងព្យញ្ជនៈដ៏មូលពីរោះ ដោយការពោលតាមវិធីនៃសិថិល និងធនិតជាដើម ។ បទថា* **វិសដ្ឋាយ** *ប្រែថា រួចផុត ។ ដោយពាក្យនោះ លោកសម្តែងដល់ភាពដែលលោកជាអ្នកមានវាទៈថា រួចផុត ។ បទថា* **អនេលគឡាយ** *សេចក្តីថា ទោស លោកហៅថា* **ឯល** *ទោសនៃវាចានោះមិនហូរចេញទៅ ហេតុនោះ ទើបវាចានោះឈ្មោះថា* **អនេលគឡា** *អធិប្បាយថា វាចានោះមិនមានទោស ។ ម្យ៉ាងទៀត បទថា* **អនេលគឡាយ** *សេចក្តីថា ដោយវាចាដែលមិនមានទោស និងមិនឃ្យៀងឃ្យាត ឈ្មោះថា វាចាមិនមានទោស អធិប្បាយថា មានបទ និងព្យញ្ជនៈមិនឃ្យៀងឃ្យាត គឺមានបទ និងព្យញ្ជនៈមិនជាច់ ។ ពិតហើយ ទើបព្រះមានព្រះភាគ ទ្រង់ស្តាបនាលោកក្នុងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកពោលពាក្យពីរោះ ដែលជាសាវ័ករបស់តថាគត ស្រេច*

នឹងសោណកុដិកណ្ណៈ ប្រសើរជាងគេ ។ បទថា **អត្តស្ស វិញ្ញាបនិយា** *សេចក្តីថា ដោយវាចាដែលអាចឲ្យដឹងច្បាស់ អត្តតាមបំណង ។*

បទថា **កតិវស្សោ** *សេចក្តីថា បានឮថា លោកតាំងនៅក្នុងចំណែកទី ៣ នៃមជ្ឈិមវ័យ សម្បូរដោយអាកប្បកិរិយាពិត រមែងប្រាកដដល់ជនដទៃ ដូចបព្វជិតដែលបួសយូរ ដែលព្រះមានព្រះភាគត្រាស់សួរសុំជៀដល់លោក។ អាចារ្យពួកខ្លះពោលថា សេចក្តីនោះ មិនមែនហេតុ កាលបើដូច្នោះ លោកសមគួរនឹងសោយសុខដែលកើតអំពីសមាធិ តែព្រោះហេតុអ្វី ទើបលោកដល់នូវសេចក្តីប្រមាទអស់កាលមានប្រមាណប៉ុណ្ណោះ ព្រោះហេតុនោះ ដើម្បីប្រកបសេចក្តីនេះទៀត ទើបព្រះសាស្តាសួរលោកថា អ្នកមានវស្សាប៉ុន្មាន ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ហេតុអ្វីក៏អ្នកធ្វើឲ្យយឺតយូរយ៉ាងនេះ ។*

បណ្តាបទទាំងនោះ បទថា **កិស្ស** *ប្រែថា ព្រោះហេតុអ្វី ។ បទថា* **ឃរំ ចិរំ អកាសិ** *ប្រែថា ប្រព្រឹត្តយឺតយូរ អធិប្បាយថា ព្រោះហេតុអ្វី ទើបអ្នកមិនចូលដល់បព្វជ្ជា នៅក្នុងផ្ទះអស់កាលយូរដល់ម្ល៉េះ ។ បទថា* **ចិរំ ឯជ្ឈោ មេ** *បានដល់ ខ្ញុំព្រះអង្គបានឃើញទោសក្នុងកាមទាំងឡាយមកយូរ គឺដោយកាលយូរ ។ បទថា* **កាមេសុ** *បានដល់ ក្នុងកិលេសកាម និងវត្ថុកាម ។ បទថា* **អាទីនវោ** *ប្រែថា ទោស ។ បទថា* **អបិច** *សេចក្តីថា កាលខ្ញុំព្រះអង្គឃើញទោសក្នុងកាមទាំងឡាយ ដោយប្រការណាមួយ ខ្ញុំព្រះអង្គមិនអាចចេញចាកការគ្រប់គ្រងផ្ទះ។ ព្រោះហេតុអ្វី ព្រោះការគ្រប់គ្រងផ្ទះចង្អៀតចង្អល់*

គឺការៈនៃការគ្រប់គ្រងផ្ទះ មានកិច្ចធំ-តូច កិច្ចខ្ពស់-ទាបចូលមកពាក់ព័ន្ធ ។ ដោយហេតុនោះឯង ទើបលោកពោលថា **ពហុកិច្ចោ ពហុករណីយោ** *មានកិច្ចច្រើន មានករណីច្រើន ដូច្នេះជាដើម ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងនូវអត្ថនេះថា ចិត្តនៃបុគ្គលដែលឃើញទោសក្នុងកាមទាំងឡាយតាមសេចក្តីពិត សូម្បីយឺតយូរ ក៏មិនសុះទៅ គឺមិនរមៀលធ្លាក់ទៅដោយពិតនោះឯង ដូចតំណក់ទឹកលើស្លឹកឈូក ដូច្នោះ ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្លឺឧទាននេះ ដែលសម្តែងដល់អត្ថនេះថា លោកកាលជ្រាបបវត្តិ និងនិវត្តិ ដោយប្រពៃនោះឯង រមែងមិនត្រេកអរក្នុងបវត្តិកាល និងក្នុងកាលខ្លះ ដែលមានបវត្តិកាល និងនិវត្តិនោះជានិមិត្ត ។*

បណ្តាបទទាំងនោះ បទថា **ឥស្សា អាទីនវំ លោកេ** *សេចក្តីថា ឃើញអាទីនវ គឺទោស ដោយចក្ខុ គឺបញ្ញា ក្នុងសង្ខារលោកទាំងអស់ ដោយន័យថា មិនទៀង ជាទុក្ខ មានការប្រែប្រួលទៅជាធម្មតាដូច្នេះ ដោយពាក្យនេះទ្រង់សម្តែងដល់វិបស្សនាវារៈ ។ បទថា* **ញត្វា ធម្មំ និរូបធឹ** *សេចក្តីថា ដឹងការមិនមានឧបធិ គឺនិព្វានធម៌ ព្រោះលះបង់ឧបធិទាំងពួងមិនជាប់ គឺធ្វើអមត-ធម៌ ពោល គឺវិវេកដែលជាគ្រឿងរលាស់ទុក្ខឲ្យជាក់ច្បាស់ ចាក់ធ្លុះដោយមគ្គញ្ញាណតាមសេចក្តីពិត ។ គប្បីឃើញហេតុ និងអត្ថនៃបទទាំងនេះថា* **ឥស្សា ញត្វា** *ដូចក្នុងប្រយោគជាដើមថា ព្រោះផឹកទធិ ទើបមានកម្លាំង ព្រោះឃើញរាជសីហ៍ ទើបខ្លាច ព្រោះឃើញដោយបញ្ញា ទើបអាសវៈអស់ទៅ ។ បទថា*

អរិយោ ន រមតិ ចាបេ សេចក្តីថា សប្បុរស ឈ្មោះថា អរិយៈ ព្រោះឆ្ងាយចាកកិលេស រមែងមិនត្រេកអរក្នុងបាប សូម្បីមានប្រមាណតិច ។ ព្រោះហេតុអ្វី ព្រោះមនុស្សល្អ រមែងមិនត្រេកអរក្នុងបាប អធិប្បាយថា បុគ្គលបរិសុទ្ធ ព្រោះមានកាយសមាចារបរិសុទ្ធដោយល្អ រមែងមិនត្រេកអរ គឺមិនត្រេកអរក្នុងបាប គឺក្នុងសង្កិលេសធម៌ ដូចស្តេចហង្ស មិនត្រេកអរក្នុងទីស្មោកគ្រោក ដូច្នោះ ។ បាលីថា **ចាបេ ន មរតី សុចិ** បុគ្គលអាក្រក់ មិនត្រេកអរក្នុងរបស់ស្អាត ដូច្នេះក៏មាន ។ ពាក្យនោះ មានអធិប្បាយដូចតទៅ បុគ្គលបាប គឺមនុស្សអាក្រក់ រមែងមិនត្រេកអរក្នុងរបស់ស្អាត គឺរបស់មិនមានទោស មានសេចក្តីផូរផង់ជាសភាវៈ ដោយពិត ត្រេកអរតែរបស់មិនស្អាត គឺសង្កិលេសធម៌ប៉ុណ្ណោះ ដូចជ្រូកស្រុកជាដើម ត្រេកអរក្នុងទីដែលស្មោកគ្រោកប៉ុណ្ណោះ ព្រោះដូច្នោះ ទើបទ្រង់ប្តូរទេសនាដោយធម៌ដែលជាបដិបក្ខដល់គ្នានិងគ្នា ។

កាលព្រះមានព្រះភាគ ទ្រង់បន្ទឺឧទានយ៉ាងនេះហើយ ព្រះសោណៈក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះសាស្តា ទូលសូមវត្ថុ ៥ ប្រការ មានឧបសម្បទាជាដើម មួយអន្ទើដោយសង្ឃបពួកក្នុងបច្ចន្តប្បទេស តាមពាក្យឧបជ្ឈាយ៍របស់ខ្លួន ។ ឯសេចក្តីដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតទាំងអស់ គប្បីជ្រាបដោយនយដែលពោលមកហើយ ក្នុងខន្ធកៈចុះ ៗ

អដ្ឋកថា សោណាសូត្រទី ៦ ចប់

សុត្តន្តបិដក

កង្ខារេវតសូត្រ

[១២៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះកង្ខារេវតៈដ៏មានអាយុ អង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ហើយ រំពឹងនូវកង្ខាវិតរណវិសុទ្ធិ (សេចក្តីបរិសុទ្ធព្រោះឆ្លងនូវសេចក្តីសង្ស័យ) របស់ខ្លួន ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគក៏ទតឃើញព្រះកង្ខារេវតៈដ៏មានអាយុ កំពុងអង្គុយផ្គត់ភ្នែន កម្រង់កាយឲ្យត្រង់ហើយ រំពឹងនូវកង្ខាវិតរណវិសុទ្ធិរបស់ខ្លួន ក្នុងទីជិតនៃព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> *សេចក្តីសង្ស័យទាំងឡាយណាមួយ ក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី ដែលបុគ្គលគប្បីដឹង ក្នុងអត្តភាពរបស់ខ្លួនឬ ឬគប្បីដឹងក្នុងអត្តភាពរបស់បុគ្គលដទៃ បុគ្គលអ្នកមានឈាន មានព្យាយាម កាលប្រព្រឹត្តព្រហ្មចរិយធម៌ រមែងលះបង់នូវសេចក្តីសង្ស័យទាំងអស់នោះបាន ។ សូត្រទី ៧ ។*

អដ្ឋកថា

កង្ខាវេតសូត្រ

កង្ខាវេតសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ

[១២៣] *បទថា* **វេរញ្ជោ** *ជាឈ្មោះរបស់ព្រះថេរៈនោះ ។ ពិតហើយ ព្រះថេរៈនោះ បានបព្វជ្ជាឧបសម្បទាក្នុងព្រះសាសនា ហើយជាអ្នកមានសីល មានកល្យាណធម៌ តែលោកច្រើនដោយសេចក្តីសង្ស័យ ពោល គឺ សេចក្តីរង្គៀសក្នុងព្រះវិនัยជាដើមថា សណ្តែកបាយជាអកប្បិយ រមែងមិនគួរដើម្បីបរិភោគ ស្ករអំពៅដែលជាអកប្បិយ រមែងមិនគួរបរិភោគ ។ ដោយហេតុនោះ ទើបលោកប្រាកដឈ្មោះថា កង្ខាវេតៈ ។ ក្រោយមក លោករៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តា ព្យាយាមធ្វើឲ្យជាក់ច្បាស់នូវអភិញ្ញា ៦ សម្ងំនៅដោយសុខដែលកើតអំពីឈាន និងសុខដែលកើតអំពីផលចិត្ត ។ តែដោយច្រើន លោកពិចារណាអរិយមគ្គដែលខ្លួនសម្រេចហើយធ្វើឲ្យជ្រួន ។ ដោយហេតុនោះ ទើបលោកពោលថា រំពឹងនូវកង្ខាវិតរណវិសុទ្ធិ (សេចក្តីបរិសុទ្ធព្រោះឆ្លងនូវសេចក្តីសង្ស័យ) របស់ខ្លួន ដូច្នេះជាដើម ។*

ពិតហើយ បញ្ហាដែលសម្បយុត្តដោយមគ្គក្នុងទីនេះ លោកបំណងយកថា ជាកង្ខាវិតរណវិសុទ្ធិនេះ ព្រោះឆ្លង គឺឈានកន្លងសេចក្តីសង្ស័យទាំងពួងដោយមិនមានចំណែកសេសសល់ គឺការសង្ស័យមានវត្ថុ ១៦ ដែលប្រព្រឹត្តទៅដោយនัยជាដើមថា អតីតកាលដែលយូរ អញមានហើយឬហ្ន៎ សេចក្តីសង្ស័យមានវត្ថុ ៨ ដែលលោកពោលទុកយ៉ាងនេះថា រមែងសង្ស័យក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។បេ។ រមែងសង្ស័យក្នុងបដិច្ចសមុប្បន្នធម៌ និងពោលថ្វីដល់

សេចក្តីសង្ស័យក្រៅអំពីនេះ និងព្រោះសេចក្តីបរិសុទ្ធដោយចំណែកមួយចាក កិលេសជនៃ ដែលខ្លួនគប្បីលះ ។ អាវុសោរូបនេះ ព្រោះលោកមានសេចក្តី សង្ស័យជាប្រក្រតីអស់កាលជ័យូរ ទើបអង្គុយពិចារណាអរិយមគ្គ ដែលខ្លួន សម្រេចហើយនោះឲ្យឆ្ងន់ថា អញលះសេចក្តីសង្ស័យទាំងនេះបានជាសមុច្ឆេទ ដោយអាស្រ័យមគ្គធម៌នេះ មិនមែនអង្គុយពិចារណាឃើញនាមរូប មួយអន្ទឹ ដោយបច្ចយ ព្រោះឆ្ងន់នូវការសង្ស័យបាន មានការមិនទៀងជាទីបំផុត ។

បទថា **ឯតមត្តំ វិឆិក្ខា** *សេចក្តីថា ទ្រង់ជ្រាបអត្តនេះ គឺការឆ្ងងសេចក្តី សង្ស័យនៃអរិយមគ្គបានជាសមុច្ឆេទ ហើយទើបទ្រង់បន្ទឺឧទាននេះ ដែល សម្តែងដល់សេចក្តីនោះ ។*

បណ្តាបទទាំងនោះ បទថា **យាកាចិ កង្ខា ឥធ វា ហុរំ វា** *សេចក្តីថា សេចក្តីសង្ស័យក្នុងអត្តភាពនេះ គឺអត្តភាពដែលជាបច្ចុប្បន្ននេះ ដែលកើត ឡើងដោយនយជាដើមថា អញកើតឬហ្ន៎ ឬថា អញមិនកើតហ្ន៎ ឬក្នុងអត្ត-ភាពជនៃ គឺក្នុងអត្តភាពដែលជាអតីត និងអនាគត ដែលកើតឡើងដោយនយ ជាដើមថា អតីតកាលជ័យូរ អញមានហើយឬហ្ន៎ ។ បទថា* **សកាវេឌិយា វា បរវេឌិយា វា** *សេចក្តីថា សេចក្តីសង្ស័យនោះ គឺការងឿងឆ្ងល់ណា មួយ ក្នុងការដឹងរបស់ខ្លួនដែលគប្បីបាន គឺដែលប្រព្រឹត្តទៅដោយជាអារម្មណ៍ ក្នុងអត្តភាពរបស់ខ្លួនយ៉ាងនេះ គឺដោយនយដូចពោលហើយ ឬក្នុងការដឹង របស់អ្នកជនៃ ដែលគប្បីបានក្នុងអត្តភាពរបស់អ្នកជនៃ គឺដែលគប្បីបាន បាន ដល់ ដែលប្រព្រឹត្តទៅក្នុងអត្តភាពដ៏ឧត្តម ដោយនយជាដើមថា ជាព្រះពុទ្ធ*

ឬហ្ន៎ ឬថា មិនមែនជាព្រះពុទ្ធ ។ បទថា **ឈាយិនោ តា បជហន្តិ សព្ពា អាតាបិនោ ព្រហ្មចរិយំ ចរន្តា** *សេចក្តីថា បុគ្គលណា ឈ្មោះថា ជាអ្នកសម្ងីឈាន ដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ចម្រើនវិបស្សនា ឈ្មោះថា មានសេចក្តីព្យាយាម ព្រោះបរិបូណ៌ដោយសម្មប្បធាន ៤ កំពុងប្រព្រឹត្ត គឺបានទទួលមគ្គព្រហ្មចរិយៈ ដែលតាំងនៅក្នុងបឋមមគ្គ មានសទ្ធានុសារីបុគ្គលជាដើម រមែងលះ គឺរមែងកាត់ផ្តាច់នូវសេចក្តីសង្ស័យទាំងពួងនោះ ក្នុងខណៈនៃមគ្គ បន្ទាប់អំពីនោះ ឈ្មោះថា បុគ្គលទាំងនោះលះនូវសេចក្តីសង្ស័យទាំងឡាយចេញបាន ។ ព្រោះដូច្នោះ ទើបមានអធិប្បាយថា ការលះសេចក្តីសង្ស័យទាំងនោះដទៃអំពីនេះបានជាសមុច្ឆេទ មិនមាន ។*

ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សរសើរការសម្រេចអរិយមគ្គរបស់កង្ខាវេតៈដោយឈានមុខ គឺដោយលើកឈានឡើងជាប្រធាន ទើបទ្រង់បន្ថែមទាន ដោយអំណាចការសរសើរ ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគទ្រង់ស្តាបនាលោកក្នុងឯតទគ្គៈ ដោយភាពជាអ្នកមានឈានថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកបានឈាន ដែលជាសាវ័ករបស់តថាគត ស្រេចនឹងកង្ខាវេតៈ ប្រសើរជាងគេ ។

អដ្ឋកថា កង្ខាវេតសុត្តនិ ៧ ចប់

សុត្តន្តបិដក

អានន្ទសូត្រ

[១២៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះអានន្ទដ៏មានអាយុ ស្បៃកស្បង់ប្រដាប់បាត្រ និងចីវរ ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ក្នុងវេលាបុព្វណ្ហសម័យ ក្នុងឧបោសថថ្ងៃនោះ ។ ទេវទត្តបានឃើញនូវព្រះអានន្ទដ៏មានអាយុ កំពុងត្រាច់ទៅបិណ្ឌ-បាត ក្នុងក្រុងរាជគ្រឹះ លុះឃើញហើយ ចូលសំដៅមករកព្រះអានន្ទដ៏មានអាយុ លុះចូលមកដល់ហើយ ក៏និយាយនឹងព្រះអានន្ទដ៏មានអាយុយ៉ាងនេះថា នែអាវុសោ អានន្ទ តាំងពីថ្ងៃនេះជាដើមទៅ ខ្ញុំវៀរព្រះមានព្រះភាគ វៀរភិក្ខុសង្ឃហើយ នឹងធ្វើឧបោសថ និងសង្ឃកម្មទាំងឡាយ (ដាច់ដោយខ្លួន) ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ លុះត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ ខ្ញុំព្រះអង្គស្បៃកស្បង់ ប្រដាប់បាត្រចីវរ ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ក្នុងបុព្វណ្ហសម័យ បពិត្រព្រះអង្គដ៏ចម្រើន ទេវទត្តក៏បានឃើញខ្ញុំព្រះអង្គ កំពុងត្រាច់ទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត លុះឃើញហើយ ក៏ឆៀងចូលមករកខ្ញុំព្រះអង្គ លុះចូលមកហើយ និយាយនឹងខ្ញុំព្រះអង្គ

ថា នែអាវុសោអានន្ទ តាំងពីថ្ងៃនេះជាដើមទៅ ខ្ញុំវៀរព្រះមានព្រះភាគ វៀរភិក្ខុសង្ឃហើយ នឹងធ្វើឧបោសថ និងសង្ឃកម្មទាំងឡាយ (ជាច់ដោយខ្លួន) បពិត្រព្រះអង្គដ៏ចម្រើន ទេវទត្តនឹងបំបែកសង្ឃក្នុងថ្ងៃនេះ នឹងធ្វើឧបោសថ ឬសង្ឃកម្មទាំងឡាយ (ជាច់ដោយខ្លួន) ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

អំពើល្អ មនុស្សល្អ ធ្វើបានដោយងាយ អំពើល្អ មនុស្សអាក្រក់ ធ្វើបានដោយកម្រ អំពើអាក្រក់ មនុស្សអាក្រក់ ធ្វើបានដោយងាយ អំពើអាក្រក់ ពួកព្រះអរិយៈ ធ្វើបានដោយកម្រ ។ សូត្រទី ៨ ។

អដ្ឋកថា

អានន្ទសូត្រ

អានន្ទសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ

[១២៤] *បទថា* **អាយស្មន្តំ អានន្ទំ ឯតទវោច** *សេចក្តីថា ទេវទត្តជីកនាំក្នុងការសម្លាប់ ឲ្យលែងជីវនាឡាគីរី ប្រមៀលឬ កាលមិនអាចធ្វើសេចក្តីវិនាសដល់ព្រះមានព្រះភាគ ទើបពោលពាក្យជាដើមថា* **អជ្ជតគ្គេ** *ប្រែថា តាំងអំពីថ្ងៃនេះជាដើមទៅ ដោយបំណងនឹងបំបែកសង្ឃ ធ្វើនូវការទម្ងាយចក្រ ។ បទថា* **អញ្ញត្រេវ ភគវតា** *ប្រែថា បែកពីព្រះមានព្រះភាគ អធិប្បាយថា មិនធ្វើឲ្យជាព្រះសាស្តា ។ បទថា* **អញ្ញត្រ ភិក្ខុសង្ឃា** *ប្រែថា*

បែកពីភិក្ខុសង្ឃប៉ុណ្ណោះ ។ បទថា **ឧបោសថំ ករិស្សាមិ សង្ឃកម្មានិ ច** សេចក្តីថា និងបំបែកភិក្ខុសង្ឃដែលធ្វើតាមឱវាទរបស់ព្រះមានព្រះភាគ ធ្វើឧបោសថ និងសង្ឃកម្មមួយផ្នែក ជាមួយភិក្ខុដែលយល់ស្របតាមខ្លួន ។ បទថា **នេវជ្ជត្តា សង្ឃំ ភិន្ទិស្សតិ** សេចក្តីថា ថ្ងៃនេះ ទេវទត្តនឹងបំបែកសង្ឃជា ២ ចំណែកដោយពិត ព្រោះទេវទត្តត្រៀមគ្នីគ្នា ធ្វើការបំបែកទាំងអស់ហើយ ពិតហើយ កាលទេវទត្តសម្តែងវត្ថុណាមួយ ក្នុងបណ្តាវត្ថុជាគ្រឿងធ្វើឲ្យបែកជាដើមថា សម្តែងអធម៌ ថាជាធម៌ ហើយឲ្យយល់ព្រមថា ពួកអ្នកចូរកាន់យកវត្ថុនេះ ចូរគាប់ចិត្តក្នុងវត្ថុនេះ ដោយហេតុនោះៗ ហើយឲ្យចាប់ស្វាកបំបែក ធ្វើសង្ឃកម្ម សង្ឃ ឈ្មោះថា ត្រូវបំបែកហើយ ។

សមដូចព្រះតម្រាស់ដែលត្រាស់ក្នុងបរិវារថា ម្នាលឧបាលិ សង្ឃបែកគ្នា ដោយអាការ ៥ អាការ ៥ តើដូចម្តេច គឺដោយកម្ម (មានអបលោកនកម្មជាដើម) ១ ដោយឧទ្ទេស (មាននិទានុទ្ទេសជាដើម) ១ ដោយសម្តែងភេទកវត្ថុ ១៨ យ៉ាង ១ ដោយអនុសាវនៈ គឺសូត្របញ្ជាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន ១ ដោយប្រគល់ស្វាក ១ ។

បណ្តាបទទាំងនោះ ពាក្យថា **កម្ម** បានដល់ ដោយកម្មឯណានីមួយក្នុងបណ្តាកម្ម ៤ យ៉ាង មានអបលោកនកម្មជាដើម ។ ពាក្យថា **ឧទ្ទេស** បានដល់ ដោយឧទ្ទេសណាមួយ ក្នុងបណ្តាបាតិមោក្ខុទ្ទេស ៥ យ៉ាង ។ ពាក្យថា **សម្តែង** បានដល់ សម្តែងដល់វត្ថុជាគ្រឿងធ្វើទុវការប្រៈឆា ១៨ យ៉ាង មានការសម្តែងវត្ថុដែលមិនជាធម៌ ថាជាធម៌ជាដើម ដោយឧប្បត្តិទាំង

នោះ ។ ពាក្យថា **អនុសាវនៈ** *សេចក្តីថា ដោយការបន្ទឺវាចាប្រកាសក្បែរត្រចៀក ដោយនយ័ជាដើមថា ពួកអ្នករមែងជីងមិនមែនឬថា ខ្ញុំបួសមកអំពីត្រកូលខ្ពស់ ឬថា ជាពហូសូត គួរឬ ពួកលោកកើតនូវការគិតថា ឈ្មោះថាមនុស្សដូចខ្ញុំ គប្បីឲ្យកាន់យកក្រៅធម៌ ក្រៅវិនយ ខ្ញុំមិនខ្វាចអបាយឬ ។ ពាក្យថា* **ប្រគល់ស្វាក** *សេចក្តីថា ដោយការសូធ្យប្រកាសយ៉ាងនេះហើយ ទើបឧបការៈការគិតរបស់ភិក្ខុទាំងនោះ ធ្វើឲ្យមានការមិនវិលត្រឡប់ជាសការៈ ហើយចាប់ស្វាកដោយពាក្យថា ពួកលោក ចូរចាប់ស្វាកនេះ ។ ក្នុងអាការទាំងនេះ កម្ម ឬឧទ្ទេសប៉ុណ្ណោះ រមែងជាសំខាន់ ឯការដឹកនាំ ការសូធ្យប្រកាស និងការឲ្យចាប់ស្វាក ជាចំណែកខាងដើម ។ ពិតហើយ កាលលោកបបួលដោយការសម្តែងវត្ថុ ១៨ ហើយសូធ្យប្រកាស ដើម្បីឲ្យកើតការត្រេកអរក្នុងការបបួលនោះហើយ ទើបឲ្យចាប់ស្វាក សង្ឃក៏ឈ្មោះថាមិនទាន់បែកគ្នា តែកាលភិក្ខុ ៤ រូប ឬច្រើនជាងនោះ នាំគ្នាចាប់ស្វាក ហើយនាំគ្នាធ្វើឧទ្ទេស ឬកម្មបែកគ្នា ដោយអាការយ៉ាងនេះ សង្ឃ ឈ្មោះថា បែកហើយ ។ ឯទេវទត្តគ្រាន់តែឲ្យចំណែកខាងដើមនៃសង្ឃភេទទាំងអស់សម្រេចហើយ ក៏គិតថា ថ្ងៃនេះ អាត្មាអញនឹងធ្វើឧបោសថ និងសង្ឃកម្មចំពោះចំណែកមួយ ទើបពោលពាក្យជាដើមថា* **អជ្ជតគ្គេ** *ជួបច្នេះ ។ ដោយហេតុនោះ ទើបព្រះអានន្ទក្រាបទូលថា ថ្ងៃនេះ ទេវទត្តនឹងបំបែកសង្ឃ ជួបច្នេះជាដើម ។ ព្រោះយើងទាំងឡាយ បានពោលហើយថា ព្រោះទេវទត្តត្រៀមគ្នីគ្នា ធ្វើការបំបែកទាំងអស់ហើយ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងនូវសង្ឃភេទកម្ម ដែលជាផ្លូវឲ្យកើតក្នុងអវីចីមហានរក តាំងនៅអស់កប្ប កែមិនបាន ដែលទេវទត្តភិក្ខុឲ្យកើតឡើងនេះ ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្លឺឧទាននេះ ដែលប្រកាសអត្ថនេះថា បុគ្គលដែលឈ្វាស មុតស្រួចល្អ ទាក់ទងដោយជាសប្បុរសបដិបត្តិត្រូវចំណែកគ្នាក្នុងកុសល និងជាអសប្បុរសបដិបត្តិមិនត្រូវចំណែកគ្នាក្នុងចំណែកកុសលតាមលំដាប់ ។*

បណ្តាបទទាំងនោះ បទថា **សុករំ សាធុនា សាធុ** *សេចក្តីថា ឈ្មោះថា មនុស្សល្អ ព្រោះញុំាងប្រយោជន៍ខ្លួន និងប្រយោជន៍សង្គមឲ្យសម្រេចបានដល់ ជាអ្នកបដិបត្តិប្រពៃ កម្មល្អ គឺសុចរិតកម្ម ចម្រើន ដែលនាំមកនូវប្រយោជន៍ដល់ខ្លួន និងសង្គម ដែលបុគ្គលល្អនោះ គឺសាវក មានព្រះសារីបុត្រជាដើម ព្រះបច្ចេកសម្ពុទ្ធ ព្រះសម្មាសម្ពុទ្ធ ឬលោកិយសាធុជនដទៃ ធ្វើបានដោយងាយ គឺអាចធ្វើបានដោយងាយ ។ បទថា* **សាធុ ចាបេន ទុក្ករំ** *សេចក្តីថា កម្មល្អ មានលក្ខណៈដូចពោលហើយនោះឯង ដែលមនុស្សអាក្រក់ គឺបាបបុគ្គល មានទេវទត្តភិក្ខុជាដើម ធ្វើបានលំបាក គឺមិនអាចធ្វើបាន អធិប្បាយថា មិនអាចធ្វើកម្មល្អនោះបាន ។ បទថា* **ចាបំ ចាបេន សុករំ** *សេចក្តីថា កម្មអាក្រក់ គឺកម្មមិនល្អ បានដល់ កម្មដែលនាំសេចក្តីវិនាសមកឲ្យដល់ខ្លួនផង ដល់សង្គមផង ដែលបុគ្គលអាក្រក់ គឺបាបបុគ្គលធ្វើបានងាយ គឺអាចធ្វើបានដោយងាយ ។ បទថា* **ចាបមរិយេហិ ទុក្ករំ** *សេចក្តីថា ចំណែកកម្មអាក្រក់នោះៗ ដែលព្រះអរិយៈទាំងឡាយ គឺដែល*

បណ្ឌិត មានព្រះពុទ្ធជាដើមធ្វើបានលំបាក គឺមិនមានការត្រេកអរជាដើមកើត ព្រះសាស្តាទ្រង់សម្តែងថា ព្រះអរិយបុគ្គលទាំងនោះ ជាបុគ្គលសម្ងាប់កិលេសដូចស្ថានបានហើយ ។

អដ្ឋកថា អានន្ទសូត្រទី ៨ ចប់

សុត្តន្តបិដក

សង្គាយមានសូត្រ

[១២៥] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងដែនកោសល ជាមួយភិក្ខុសង្ឃច្រើនរូប ។ សម័យនោះ មាណពច្រើននាក់ (ក្មេងៗ) មានសភាពជាអ្នកនិយាយកោកកាក ដើរមកក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ បានឃើញពួកមាណពច្រើននាក់ ដែលកំពុងនិយាយកោកកាក ដើរមកជិតព្រះអង្គ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា*

បុគ្គលល្ងង់ខ្លៅ មានសម្តីធ្វើហាក់ដូចជាសម្តីបណ្ឌិត ពោលវាចាជាវិសម័យ (នៃវាចាព្រះអរិយៈ) ប្រាថ្នានូវការហើបមាត់និយាយចាក់បណ្តោយ ដរាបណា (វាក៏ហាមាត់និយាយ ដរាបនោះ) វាចាដែលបុគ្គលល្ងង់ខ្លៅណា នាំមកនិយាយ បុគ្គល

ល្ងង់ខ្វៅនោះ មិនដឹងច្បាស់វាចានោះទេ ។ សូត្រទី ៩ ។

អដ្ឋកថា

សទ្ធាយមានសូត្រ

សទ្ធាយមានសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ

[១២៥] បទថា **មាណវកា** បានដល់ កំលោះ គឺតាំងនៅក្នុងបឋមវ័យ គឺវ័យកំលោះ ។ កូនព្រាហ្មណ៍ លោកបំណងយកក្នុងទីនេះ ។ បទថា **សធាយមានរូចា** នេះ លោកពោលសំដៅយកពាក្យដែលកើតអំពីការ អះអាង អធិប្បាយថា ពោលបញ្ជាក់ចំពោះបុគ្គលដទៃ និងជាអ្នកមានប្រក្រតី ពោលពាក្យនោះ ។ ក្នុងសេចក្តីនោះ មានអត្ថនៃពាក្យដូចតទៅនេះ ។ កាលគួរនឹងពោលថា **សធយមានា** ព្រោះវិគ្គហៈថា ការពោលពាក្យគួរខ្ពើម ឈ្មោះថា **សធ** ពោលពាក្យគួរខ្ពើមនោះ ទើបពោលថា **សធាយមានា** ព្រោះធ្វើឲ្យជាទីយៈ ។ ម្យ៉ាងទៀត បន្ទាប់អំពីនោះ ទើបពោលថា **សធាយ-មានរូចា** ព្រោះមានសភាវៈយ៉ាងនោះ ។ បាលីថា **សទ្ធាយមានរូចា** ដូច្នេះ ក៏មាន អធិប្បាយថា ធ្វើសំឡេងអឺងកង គឺធ្វើសំឡេងខ្ទាំង ។ បទថា **ភគវតោ អវិទូរេ អតិក្ពមន្តិ** សេចក្តីថា ពោលពាក្យដែលធ្លាប់មាត់នោះៗ ធ្លងទៅក្នុងវិស័យនៃការស្តាប់របស់ព្រះមានព្រះភាគ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបអត្ថនេះ គឺទ្រង់ជ្រាបថា

មនុស្សទាំងនោះមិនសង្រ្គមវាចា ទើបទ្រង់បន្ទឺឧទាននេះ ដែលសម្តែងអត្ថនោះ ដោយឋម្មសង្វេគ ។

បណ្តាបទទាំងនោះ បទថា **បរិមុដ្ឋា** *ប្រែថា បុគ្គលល្ងង់ខ្លៅ គឺមិនមានស្មារតី ។ បទថា* **បណ្ឌិតាភាសា** *សេចក្តីថា បណ្ឌិតក្លែងក្លាយ ព្រោះបន្ទឺវាចាថា ខ្ញុំនោះឯង ដឹងក្នុងអត្ថនោះៗ ដោយយល់ថា អ្នកដទៃណានឹងដឹងពួកខ្ញុំប៉ុណ្ណោះ ដឹងក្នុងអត្ថនេះ ។ បទថា* **វាចាគោចរភាណិនោ** *សេចក្តីថា វាចាប៉ុណ្ណោះជាគោចរ គឺជាអារម្មណ៍របស់ជនពួកណា ជនទាំងនោះ ឈ្មោះថា មានការពោលវាចាជាអារម្មណ៍ ឈ្មោះថា ជាអ្នកមានប្រក្រតីពោលវាចាជាទីតាំងប៉ុណ្ណោះ ព្រោះមិនកំណត់ដឹងនូវអត្ថ ។ ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកមានប្រក្រតីពោលវាចាជាអារម្មណ៍ ព្រោះពោលមុសាវាទ ដែលមិនជាអារម្មណ៍របស់វាចា គឺមិនមែនជាអារម្មណ៍នៃវាចារបស់ព្រះអរិយៈ ។ ម្យ៉ាងទៀត លោកធ្វើរស្សៈ* **អា** *អក្ខរៈ ឲ្យជា* **អ** *អក្ខរៈ ក្នុងបទថា* **គោចរភាណិនោ** *នេះ ។ បុគ្គលច្រើនដោយការពោល មានវាចាជាអារម្មណ៍ មិនមែននិយាយមានសតិបដ្ឋានជាអារម្មណ៍ ។ ពោលដូចម្តេច គឺពោលយឺតយ៉ាវតាមប្រាថ្នា បានដល់ ពោលទៅតាមមាត់ដែលធ្លាប់ពោល អធិប្បាយថា ធ្វើមុខក្រញូវ ព្រោះមិនគោរពក្នុងអ្នកដទៃ និងព្រោះមិនជួបអារម្មណ៍ខ្លួន ។ ម្យ៉ាងទៀត អធិប្បាយថា ពោលតែវាចាជាអារម្មណ៍ប៉ុណ្ណោះ គឺខ្លួនឯងក៏មិនដឹងដល់បទពោល ក៏ពោលទៅ អធិប្បាយថា ព្រោះហេតុនោះឯង ទើបពោលយឺតយ៉ាវតាមប្រាថ្នា គឺមិនគិតដល់ពាក្យដែលជាហេតុឲ្យសម្រេច ប្រាថ្នាត្រឹម*

តែពោលទៅតាមមាត់របស់ខ្លួន ។ បទថា **យេន នីតា ន តំ វិទ្ទូ** *សេចក្តីថា បុគ្គលដែលមិនដឹង គឺខ្ជិលល្ងង់ ត្រូវបុគ្គលមិនមានស្មារតីជាដើមដឹកនាំ តែក្នុងការៈដែលមិនមែនជាហិរិ និងការៈដែលសម្គាល់ថា ខ្លួនជាបណ្ឌិតប៉ុណ្ណោះ ពោលបានដូច្នេះ ដោយហេតុណា រមែងមិនដឹងនូវហេតុនោះរបស់ខ្លួនដែលពោលយ៉ាងនោះ ។*

អដ្ឋកថា សច្ចាយមានសូត្រទី ៩ ចប់

សុត្តន្តបិដក

ចូឡបន្តកសូត្រ

[១២៦] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះ ព្រះចូឡបន្តក:ដ៏មានអាយុ អង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងសតិ (ចំពោះកម្មដ្ឋាន) ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ បានឃើញចូឡបន្តក:ដ៏មានអាយុ កំពុងអង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងសតិក្នុងទីជិតនៃព្រះមានព្រះភាគ ។ លុះព្រះមានព្រះភាគជ្រាបច្បាស់សេចក្តីនុ៎ះ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា*

ភិក្ខុមានកាយខ្ជាប់ខ្ជួន មានចិត្តខ្ជាប់ខ្ជួន ទោះបីឈរ អង្គុយ ឬដេក តែងតម្កល់សតិនុ៎ះ ភិក្ខុនោះ គប្បីបានគុណវិសេសមានទីបំផុតខាង

ដើម លុះបានគុណវិសេសមានទីបំផុតខាងដើមហើយ ក៏ដល់នូវ
ការមិនជួបប្រទះមច្ចុរាជ ។ សូត្រទី ១០ ។

សោណត្ថេរវគ្គទី ៥ ចប់

ឧទ្ទាននៃសោណត្ថេរវគ្គនោះគឺ

និយាយអំពីព្រះបាទបសេនទិកោសល ១ ពុទ្ធមាតាមានព្រះជន្មាយុ
តិច ១ សុប្បពុទ្ធកុដ្ឋិ ១ ពួកកុមារ ១ ឧបោសថ ១ សោណ-
កុដិកណ្ណៈ ១ កង្ខារេវតៈ ១ ព្រះអានន្ទ ១ មាណពច្រើននាក់
មានវាចាកោកកាក ១ ចូឡបន្ថកភិក្ខុ ១ ។

អដ្ឋកថា

ចូឡបន្ថកសូត្រ

ចូឡបន្ថកសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ

[១២៦] *បទថា* **ចូឡបន្ថកោ** *សេចក្តីថា ក្នុងកាលជាខាងក្រោយ*
អាវុសោរូបនេះ ប្រាកដឈ្មោះថា ចូឡបន្ថកៈនោះឯង ដោយបានវោហារក្នុង
កាលដែលខ្លួននៅជាកំលោះ ព្រោះជាប្អូនប្រុសរបស់ព្រះមហាបន្ថកៈ និងកើត
កណ្តាលអង្ឃ័ន តែពោលដោយគុណវិសេស លោកសម្រេចអភិញ្ញា ៦ បែក
ធ្វើយនូវបដិសម្ភិទា និងជាព្រះថេរៈមួយអង្គក្នុងអសីតិមហាសាវក ដែលព្រះ

មានព្រះភាគ ទ្រង់ស្តាបនាក្នុងតំណែងឯតទគ្គៈ ២ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកនិមិត្តកាយ សម្រេចតាមចិត្តបាន ដែលជាសាវ័ករបស់តថាគត ស្រេចនឹងចូឡបន្ថកៈប្រសើរជាងគេ ។ ពួកភិក្ខុអ្នកឈ្វាសក្នុងការបើកចិត្ត ស្រេចនឹងចូឡបន្ថកៈ ។

ថ្ងៃមួយ ក្នុងពេលក្រោយភត្ត លោកត្រឡប់មកអំពីបិណ្ឌបាត អង្គុយសម្រាក ក្នុងទីសម្រាកពេលថ្ងៃរបស់ខ្លួន នៅសម្ងំដោយសមាបត្តិផ្សេងៗ អស់មួយថ្ងៃ លុះវេលាល្ងាច កាលពួកឧបាសកមិនទាន់មកស្តាប់ធម៌ កាលព្រះដ៏មានព្រះភាគយាងចូលទៅកាន់កណ្តាលវិហារ ប្រថាប់គង់ក្នុងព្រះគន្ធកុដិ លោកគិតថា មិនមែនកាលដែលគួរចូលទៅឧបដ្ឋាកព្រះមានព្រះភាគ ទើបអង្គុយពត់ភ្នែកក្នុងទីបំផុតនាចំណែកម្ខាង មុខព្រះគន្ធកុដិ ។ ដោយហេតុនោះ ទើបលោកពោលថា សម័យនោះ ព្រះចូឡបន្ថកៈដ៏មានអាយុ អង្គុយផ្គត់ភ្នែនតម្រង់កាយឲ្យត្រង់ តាំងសតិ (ចំពោះកម្មដ្ឋាន) ក្នុងទីជិតនៃព្រះមានព្រះភាគដូច្នេះ ។ ពិតហើយ ក្នុងពេលនោះ លោកកំណត់កាលហើយ អង្គុយចូលសមាបត្តិ ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបអត្ថនេះ គឺព្រះចូឡបន្ថកៈតាំងកាយ និងចិត្តដោយប្រពៃ ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្លឺឧទាននេះ ដែលប្រកាសសេចក្តីប្រាកដក្នុងការសម្រេចគុណវិសេស ដែលមានអនុបាទាបរិនិព្វានជាទីបំផុតរបស់ភិក្ខុដទៃ ដែលមានកាយស្ងប់ ដែលមានសតិប្រាកដ ក្នុងឥរិយាបថទាំងពួង ដែលមានចិត្តជាសមាធិ ។*

បណ្តាបទទាំងនោះ បទថា **ឋិតេន កាយេន** *សេចក្តីថា ជាអ្នកមានកាយគ្រប់ចំណែក តាំងនៅដោយមិនញាប់ញ័រ ពោល គឺភាពជាអ្នកមិនមានវិការដោយសង្ខេបថា មានចោបនកាយ ដែលឈ្មោះថា តាំងទុកប្រពៃ ព្រោះលះគឺមិនធ្វើអសំវរៈតាមកាយទ្វារ ម្យ៉ាងទៀត មានកាយដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ ដែលឈ្មោះថា តាំងទុកដោយល្អ ព្រោះធ្វើឥន្ទ្រិយ មានចក្ខុន្ទ្រិយជាដើមឲ្យអស់ព្យសន៍ ឬមានកវជកាយដែលឈ្មោះថា តាំងនៅដោយការមិនប្រែប្រួល ព្រោះមិនមានការឆ្គាំឆ្គងដៃជាដើម ព្រោះសង្រ្គមដៃ និងជើងបានហើយ ។ ដោយពាក្យនោះ ទ្រង់សម្តែងដល់ការបរិសុទ្ធនៃសីលរបស់លោក។ បទថា* **កាយេន** *នេះ ជាតតិយាវិភត្តិ ប្រើក្នុងលក្ខណៈឥត្ថម្ភូត ។ ដោយពាក្យថា* **ឋិតេន ចេតសា** *នេះ ទ្រង់សម្តែងការជាប់ព្រមនៃសមាធិ ដោយសម្តែងដល់ការតាំងមាំនៃចិត្ត ។ ពិតហើយ សមាធិ លោកហៅថា ការតាំងមាំនៃចិត្ត ។ ព្រោះដូច្នោះ កាលភាពដែលចិត្តមានអារម្មណ៍តែមួយ ដោយអំណាចសមថៈ ឬដោយអំណាចវិបស្សនា ចិត្ត ឈ្មោះថា តាំងនៅ ដោយចូលដល់ភាវៈដែលចិត្តជាឯក ផុសទ្បើងក្នុងអារម្មណ៍ មិនមែនតាំងនៅដោយប្រការដទៃ ។*

ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា ការតាំងនៅ គឺការតាំងមាំនូវកាយនិងចិត្តតាមដែលពោលហើយនេះ ចាំបាច់គ្រប់ៗ កាល គ្រប់ៗ ឥរិយាបថ ទើបត្រាស់ថា ទោះបីឈរ អង្គុយ ឬដេក ដូច្នេះជាដើម ។

វា *សព្ទ ក្នុងបាទព្រះគាថានោះ មានអត្ថមិនពិតប្រាកដ ។ ព្រោះ* **វា**

សព្ទ សម្តែងដល់អត្តនេះថា ឈរក្តី អង្គុយក្តី ដេកក្តី ឬថា ជាឥរិយាបថ ដទៃអំពីនោះ ព្រោះដូច្នោះ ការចង្រ្កម គប្បីជ្រាបថា ក៏លោកសង្គ្រោះយកក្នុងទីនេះ ។ បទថា **ឯតំ សតឹ ភិក្ខុ អធិដ្ឋហានោ** *សេចក្តីថា ភិក្ខុតាំងទុកគឺតម្កល់នូវចិត្តឲ្យស្ងាត់ជំនាញ ឲ្យប្រពៃ គួរដល់ការងារដោយល្អ ដោយអំណាចការស្ងប់កាយ និងចិត្ត ដោយការអធិដ្ឋានដល់សេចក្តីសុខ ដែលមិនមានទោស ដែលបានមកព្រោះធ្វើកាយ និងចិត្ត មិនឲ្យរសាប់រសល់ ដោយការស្ងប់កាយ និងចិត្តយ៉ាងគ្រោតគ្រាត មិនចាំបាច់ពោលដល់បុគ្គលមានសមាចារដែលបរិសុទ្ធ គប្បីចម្រើនវិបស្សនា និងឲ្យកម្មដ្ឋានដល់ទីបំផុត ដោយសតិណា កិក្ខុគ្រប់គ្រងសតិនោះឯង ដែលមានឧបការៈច្រើនខាងដើម កណ្តាល និងទីបំផុតនៃការប្រកបកម្មដ្ឋាន គ្រប់គ្រងក្នុងកិច្ចនោះៗ តាំងអំពីជម្រះសីលឲ្យបរិសុទ្ធ រហូតដល់សម្រេចគុណវិសេស ។ បទថា* **លភេថ បុព្វាបរិយំ វិសេសំ** *សេចក្តីថា លោកមានចិត្តដែលសតិគ្រប់គ្រងហើយយ៉ាងនេះ ចម្រើន ធ្វើឲ្យច្រើន ធ្វើឲ្យកើនឡើងនូវកម្មដ្ឋាន ឲ្យក្រៃលែងឡើង គប្បីបានគុណវិសេសដែលក្រៃលែង និងក្រៃលែងជាង ដែលមានខាងដើមផង ខាងចុងផង គឺដែលប្រព្រឹត្តទៅខាងដើម និងខាងចុង ។*

ក្នុងពាក្យនោះ គុណវិសេសដែលជាចំណែកខាងដើម និងចំណែកខាងចុង មាន ២ យ៉ាង គឺសមថៈ ១ វិបស្សនា ១ ។ ក្នុងគុណវិសេស ២ យ៉ាងនោះ គុណវិសេសដែលប្រព្រឹត្តទៅ ដោយអំណាចសមថៈ បានដល់ភាពជាអ្នកជំនាញតាំងអំពីកើតនិមិត្តឡើង រហូតដល់នេវសញ្ញានាសញ្ញា-

យតនជ្ឈាន គុណវិសេសចំណែកកាវនាដែលប្រព្រឹត្តទៅយ៉ាងនោះ បានដល់គុណវិសេសដែលជាចំណែកខាងដើម និងជាចំណែកខាងចុង ។ តែកាលពោលដោយគុណវិសេស ដែលប្រព្រឹត្តទៅដោយអំណាចវិបស្សនា បានដល់គុណវិសេស ចំណែកកាវនាដែលប្រព្រឹត្តទៅដោយកំណត់រូបធម៌ របស់បុគ្គលដែលប្រកាន់មាំ ដោយលើកឬបឡើងជាប្រធាន ចំណែករបស់បុគ្គលដែលប្រកាន់មាំក្រៅអំពីនេះ ប្រព្រឹត្តទៅ តាំងអំពីកំណត់ធម៌ក្រៅអំពីនេះ រហូតដល់សម្រេចអរហត្ត ឈ្មោះថា គុណវិសេសដែលប្រព្រឹត្តទៅក្នុងចំណែកខាងដើម និងចំណែកខាងចុង ។ គុណវិសេសនេះឯង លោកបំណងយកក្នុងទីនេះ ។

បទថា **លទ្ធាន បុព្វាបរិយំ វិសេសំ** *សេចក្តីថា បានសម្រេចបារមីដ៏ឧត្តម គឺព្រះអរហត្ត ក្នុងគុណវិសេសដែលជាចំណែកខាងដើម និងចំណែកខាងចុង ។ បទថា* **អនុស្សវំ មច្ចុរាជស្ស គច្ឆេ** *សេចក្តីថា គប្បីដល់នូវទីដែលមច្ចុមិនឃើញ គឺទីដែលមិនជាអារម្មណ៍ ព្រោះឈានកន្លងនូវភព ៣ ដែលជាអារម្មណ៍របស់មរណៈ ពោល គឺមច្ចុរាជ ព្រោះគ្រប់សង្កត់សព្វសត្វដោយអំណាចការចូលទៅកាត់ផ្តាច់នូវជីវិត ។*

ពាក្យដែលខ្ញុំមិនបានពោលក្នុងវគ្គនេះ មានន័យដូចពោលហើយអំពីខាងដើមនោះឯង ។

អដ្ឋកថា ចូឡបន្តកសូត្រទី ១០ ចប់

សោណត្ថេរវគ្គទី ៥ ចប់

សុត្តន្តបិដក

ឧធានជច្ចន្ធវគ្គទី ៦

អាយុសមឧសជ្ជនសូត្រ

[១២៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ៉ន ជិតក្រុងវេសាលី ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរ ចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាត ក្នុងបុព្វណ្ហសម័យ ព្រះអង្គកាលត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងវេសាលី ត្រឡប់អំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយភត្ត ក៏ត្រាស់ប្រាប់អានន្ទដ៏មានអាយុថា នែអានន្ទ អ្នកចូរយកនិសីទន: យើងនឹងចូលទៅឯបាវាលចេតិយ ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ ព្រះអានន្ទដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយកាន់យកនិសីទន:ទៅតាមក្រោយ នៃព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់យាងចូលទៅឯបាវាលចេតិយ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសន:ដែលព្រះអានន្ទក្រាល លុះព្រះមានព្រះភាគទ្រង់គង់ស៊ប់ហើយ ទើបទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា នែអានន្ទ ទីក្រុងវេសាលី គួរជាទីត្រេកអរ ឧទេនចេតិយ គួរជាទីត្រេកអរ គោតមកចេតិយ ជាទីត្រេកអរ សត្តម្ពចេតិយ ជាទីត្រេកអរ ពហុបុត្តចេតិយ ជាទីត្រេកអរ សារន្ទចេតិយ ជាទីត្រេកអរ បវាលចេតិយ ជាទីត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ យ៉ាង ដែលបុគ្គលណាមួយចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ ធ្វើឲ្យដូចជា

យានហើយ ធ្វើឲ្យជាទីតាំងហើយ អធិដ្ឋានហើយ សន្សំហើយ ប្រារព្ធល្អ ហើយ បុគ្គលនោះ កាលបើប្រាថ្នានឹងឋិតនៅអស់អាយុកប្ប ឬលើសពីអាយុ កប្បទៅក៏បាន ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ តថាគតចម្រើនហើយ ធ្វើឲ្យ រឿយៗ ហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ អធិដ្ឋានហើយ សន្សំហើយ ប្រារព្ធល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ កាលប្រាថ្នានឹង ឋិតនៅអស់អាយុកប្ប ឬលើសអំពីអាយុកប្បទៅក៏បាន ។

[១២៨] កាលដែលព្រះមានព្រះភាគ ធ្វើនិមិត្តដ៏ឱឡារិក ធ្វើឱកាស ដ៏ឱឡារិក យ៉ាងនេះ ព្រះអានន្ទដ៏មានអាយុ មិនអាចនឹងយល់បាន ទាំងមិន បានអារាធនា នូវព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គ ឋិត នៅអស់អាយុកប្ប សូមព្រះសុគតឋិតនៅអស់អាយុកប្ប ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ និងសេចក្តីសុខដល់ទេវតា និងមនុស្ស ទាំងឡាយ ដូច្នេះទ្បើយ ព្រោះត្រូវមារគ្របសង្កត់ចិត្ត ។ ព្រះមានព្រះភាគ ត្រាស់នឹងព្រះអានន្ទដ៏មានអាយុជាគម្រប់ ២ ដងថា ម្នាលអានន្ទ ក្រុងវេសាលី គួរជាទីត្រេកអរ ឧទេនចេតិយ ជាទីត្រេកអរ គោតមកចេតិយ ជាទីត្រេកអរ សត្តម្ពចេតិយ ជាទីត្រេកអរ ពហុបុត្តចេតិយ ជាទីត្រេកអរ សារន្ទូចេតិយ ជាទីត្រេកអរ បាលចេតិយ ជាទីត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទ ៤ ដែល បុគ្គលណាចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើ ឲ្យជាទីតាំងហើយ អធិដ្ឋានហើយ សន្សំហើយ ប្រារព្ធល្អហើយ បុគ្គលនោះ

កាលក្រោថ្នា នឹងឋិតនៅអស់អាយុកប្ប ឬលើសពីអាយុកប្បក៏បាន ម្នាលអានន្ទ ឥទ្ធិបាទ ៤ ដែលព្រះតថាគតចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ អធិដ្ឋានហើយ សន្សំហើយ ប្រារព្ធល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ កាលក្រោថ្នា នឹងឋិតនៅអស់អាយុកប្ប ឬលើសពីអាយុកប្បទៅក៏បាន ។ កាលព្រះមានព្រះភាគ ធ្វើនិមិត្តដ៏ឱឡារិក ធ្វើឱកាសដ៏ឱឡារិក យ៉ាងនេះ ព្រះអានន្ទដ៏មានអាយុ មិនអាចយល់បាន ទាំងមិនបានអារាធនា ព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គឋិតនៅអស់អាយុកប្ប សូមព្រះសុគតឋិតនៅអស់អាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយឲ្យទាន ដូច្នេះឡើយ ព្រោះត្រូវមារគ្របសង្កត់ចិត្ត ។ ព្រះមានព្រះភាគ ត្រាស់នឹងព្រះអានន្ទដ៏មានអាយុ ជាគម្រប់ ៣ ដងថា ម្នាលអានន្ទ ក្រុងវេសាលី គួរជាទីត្រេកអរ ឧទេនចេតិយ ជាទីត្រេកអរ គោតមកចេតិយ ជាទីត្រេកអរ សត្តម្ពចេតិយ ជាទីត្រេកអរ ពហុបុត្តចេតិយ ជាទីត្រេកអរ សារន្ទចេតិយ ជាទីត្រេកអរ បវាលចេតិយ ជាទីត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ ដែលបុគ្គលណាចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ អធិដ្ឋានហើយ សន្សំហើយ ប្រារព្ធល្អហើយ បុគ្គលនោះ កាលក្រោថ្នា នឹងឋិតនៅអស់អាយុកប្ប ឬលើសពីអាយុកប្បទៅក៏បាន ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤

ដែលតថាគតចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ អធិដ្ឋានហើយ សន្សំហើយ ប្រារព្ធល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ កាលប្រាថ្នានឹងឋិតនៅអស់អាយុកប្ប ឬលើសអំពីអាយុ-កប្បទៅក៏បាន ។ លុះព្រះមានព្រះភាគ ធ្វើនិមិត្តដ៏ឱឡារិក ធ្វើឱកាសដ៏ឱឡារិក យ៉ាងនេះ ព្រះអានន្ទដ៏មានអាយុ មិនអាចយល់បាន ទាំងមិនបានអារាធនាព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គ ឋិតនៅអស់អាយុកប្ប សូមព្រះសុគត ឋិតនៅអស់អាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់ទេវតា និងមនុស្ស ទាំងឡាយ ឲ្យទាន ដូច្នេះឡើយ ព្រោះត្រូវមារគ្របសង្កត់ចិត្ត ។

[១២៩] គ្រានោះ ព្រះមានព្រះភាគ ត្រាស់នឹងព្រះអានន្ទដ៏មានអាយុ ថា ម្នាលអានន្ទ អ្នកចូរទៅ អ្នកចូរសម្គាល់កាលដែលគួរទៅ ក្នុងកាលឥឡូវ នេះចុះ ។ ព្រះអានន្ទដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមាន ព្រះភាគថា ព្រះកុរុណាព្រះអង្គ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះ មានព្រះភាគ ធ្វើប្រទក្សិណហើយ អង្គុយទៀបគល់ឈើមួយដើម ជិតព្រះ មានព្រះភាគ ។

[១៣០] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចេញទៅមិនយូរប៉ុន្មាន មារ ចិត្តបាប ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឋិតនៅក្នុងទី ដ៏សមគួរ ។ លុះមារចិត្តបាប ឋិតនៅក្នុងទីសមគួរហើយ ទើបពោលពាក្យ

នេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់បរិនិព្វាន ក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វាន បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ កាលនេះ ជាកាលគួរបរិនិព្វាន របស់ព្រះមានព្រះភាគ ហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគ បានត្រាស់វាចា នេះហើយថា នែមារចិត្តបាប ពួកភិក្ខុជាសាវ័ករបស់តថាគត ដែលឈ្លាសវៃ បានបទ ក្លៀវក្លា ប្រាថ្នាការក្សេមចាកយោគៈ ជាពហុស្សុត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួរ រៀនយកវាទៈនៃអាចារ្យរបស់ខ្លួន ហើយនឹងប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អ សម្តែងធម៌ប្រកបដោយបាដិហារ្យ (គ្រឿងអាង) នៅមិនមានជរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វានជរាបនោះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកភិក្ខុជាសាវ័ករបស់ព្រះមានព្រះភាគ ឈ្លាសវៃ បានបទ ក្លៀវក្លា ប្រាថ្នាការក្សេមចាកយោគៈ ជាពហុស្សុត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួរ រៀនយកវាទៈនៃអាចារ្យរបស់ខ្លួនហើយ ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់បរិនិព្វាន ក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិ-

និព្វាន បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ កាលនេះ ជាកាលគួរបរិនិព្វាន របស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគត្រាស់វាចានេះហើយថា ម្នាលមារចិត្តបាប ពួកភិក្ខុនីជាសាវិការបស់តថាគត ឈ្លាសវៃ បានបទ ក្លៀវក្លា ប្រាថ្នាសេចក្តីក្សេមចាកយោគៈ ជាពហុស្សុត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួរ រៀនយកវាទៈនៃអាចារ្យរបស់ខ្លួន ហើយនឹងប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យវាក់ បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនគួរសង្កត់សង្កិនដោយល្អ សម្តែងធម៌ ប្រកបដោយបាដិហារ្យ នៅមិនទាន់មានជរាបណា តថាគតនឹងមិនទាន់បរិនិព្វាន ជរាបនោះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកភិក្ខុនី ជាសាវិការបស់ព្រះមានព្រះភាគ ឈ្លាសវៃ បានបទ ក្លៀវក្លា ប្រាថ្នាសេចក្តីក្សេមចាកយោគៈ ជាពហុស្សុត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួរ រៀនយកវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យវាក់ បានសង្កត់សង្កិនបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់បរិនិព្វាន ក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វាន បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ កាលនេះ ជាកាលគួរបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះ

ថា ព្រះមានព្រះភាគ ទ្រង់ត្រាស់វាចានេះហើយថា នែមារចិត្តបាប ពួកឧបាសក ជាសាវ័ករបស់តថាគត ឈ្មោះសៃ បានបទ ក្លៀវក្លា ប្រាថ្នាសេចក្តីក្សេម ចាកយោគៈ ជាពហុស្សុត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិ ដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួរ បានរៀនយកវាទៈនៃ អាចារ្យរបស់ខ្លួន ហើយទន្ទឹងជ្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យ រាក់ បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួន សង្កត់សង្កិនបានដោយល្អ សម្តែងធម៌ ប្រកបដោយបាដិហារ្យ នៅមិនទាន់ មានជរាបណា តថាគតនឹងមិនទាន់បរិនិព្វានជរាបនោះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកឧបាសក ជាសាវ័ករបស់ព្រះមានព្រះភាគ ឈ្មោះសៃ បានបទ ក្លៀវក្លា ប្រាថ្នាសេចក្តីក្សេមចាកយោគៈ ជាពហុស្សុត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួរ បានរៀនយកវាទៈនៃអាចារ្យរបស់ខ្លួន ហើយជ្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យ ជាកិច្ចដែលខ្លួនសង្កត់សង្កិនបានដោយល្អ ហើយសម្តែងធម៌ប្រកបដោយ បាដិហារ្យ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ បរិនិព្វានក្នុងកាល ឥឡូវនេះសូមព្រះសុគត បរិនិព្វាន បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ កាល នេះ ជាកាលគួរបរិនិព្វាន របស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ ចម្រើន ព្រោះថា ព្រះមានព្រះភាគ ទ្រង់ត្រាស់វាចានេះហើយថា ម្នាលមារ ចិត្តបាប ពួកឧបាសិកាជាសាវិការបស់តថាគត ឈ្មោះសៃ បានបទ ក្លៀវក្លា

ប្រាថ្នាសេចក្តីក្សេមចាកយោគៈ ទ្រទ្រង់ធម៌ ជាពហុស្សុត ប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួរ រៀនយកវាទៈនៃអាចារ្យរបស់ខ្លួន ហើយនឹងប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ជាសង្គត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនសង្គត់សង្កិនបានដោយល្អ សម្តែង ធម៌ប្រកបដោយបាដិហារ្យ ដរាបណា តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកឧបាសិកាជាសាវិការបស់ព្រះមានព្រះភាគ ឈ្មោះសៃ បានបទក្កៀវក្កា ប្រាថ្នាសេចក្តីក្សេមចាកយោគៈ ទ្រទ្រង់ធម៌ ជាពហុស្សុត ប្រព្រឹត្តធម៌ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រតិបត្តិតាមធម៌ដ៏សមគួរ រៀនយកវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្តតាំងទុក បើក ចែក ធ្វើឲ្យរាក់ ជាសង្គត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនសង្គត់សង្កិនបានដោយល្អ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ បរិនិព្វានក្នុងកាលឥឡូវនេះ សូមព្រះសុគត បរិនិព្វាន បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ កាលនេះ ជាកាលគួរបរិនិព្វាន របស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគ ទ្រង់ត្រាស់វាចានេះហើយថា ម្នាលមារចិត្តបាប ព្រហ្មចរិយធម៌ របស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន ផ្សព្វផ្សាយទូលាយ ដ៏ធំច្រើនគ្នា ក្រាស់ក្រែល ដរាបណា ទាំងពួកទេវតា និងមនុស្ស សម្តែងបានដោយប្រពៃ ដរាបណា តថាគតនឹងមិនទាន់បរិនិព្វាន ដរាបនោះ

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រហ្មចរិយធម៌ របស់ព្រះមានព្រះភាគ ខ្ជាប់ខ្ជួន ផ្សព្វផ្សាយ ទូលាយ ដ៏ងច្រើនគ្នា ក្រាស់ក្រែលហើយ ទាំងពួកទេវតា និងមនុស្ស ក៏សម្តែងបានដោយប្រពៃ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វាន សូមព្រះសុគត បរិនិព្វាន បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ កាលនេះ ជាកាលគួរបរិនិព្វាន របស់ព្រះមានព្រះភាគហើយ ។

[១៣១] កាលបើមារ ទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់តបនឹងមារចិត្តបាបថា ម្នាលមារចិត្តបាប ចូរអ្នកកុំមានសេចក្តីខ្វល់ខ្វាយចុះ ការបរិនិព្វាន របស់តថាគតមិនយូរប៉ុន្មានទេ អំណើះទៅ ៣ ខែទៀត អំពីខែនេះ តថាគតនឹងបរិនិព្វាន ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានសតិសម្បជញ្ញៈ ដាក់អាយុសង្ខារ នាបាវាលចេតិយ ។ លុះព្រះមានព្រះភាគ ទ្រង់ដាក់អាយុសង្ខារហើយ មហាប្រឹថពីកក្រើក គួរឲ្យខ្លាច ព្រឺព្រួចរោមទាំងផ្គរកំលាន់ឮខ្ទឹង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ព្រះពុទ្ធ ជាអ្នកប្រាជ្ញ បានលះបង់កុសលចិត្ត ដែលគួរថ្លឹងបាន និងថ្លឹងមិនបានផង កិលេសជាដែនកើតផង សង្ខារប្រព្រឹត្តទៅក្នុងភពផង ទ្រង់ត្រេកអរក្នុងខាងក្នុង មានព្រះហឫទ័យតាំងមាំហើយ បានទម្លាយ បណ្តាញ គឺកិលេសដែលមានខ្ជួន ជាដែនកើត ដូចជាគ្រឿងក្រោះ (របស់ទាហាន) ។ សូត្រទី ១ ។

អដ្ឋកថា

ជច្ចន្ធវគ្គទី ៦

អាយុសមឧសជ្ជនសូត្រ

អាយុសមឧសជ្ជនសូត្រទី ១ នៃជច្ចន្ធវគ្គទី ៦ មានវិនិច្ឆ័យដូច្នេះ

[១២៧] *បទបាលីជាដើមថា* **វសាលិយំ** *មានអត្ថដូចពោលហើយ ខាងដើមនោះឯង ។ បទថា* **វសាលឹ បិណ្ឌាយ ចាវិសិ** *សេចក្តីថា ព្រះអង្គ ទ្រង់ចូលទៅក្នុងកាលណា ក្នុងកាលដែលទ្រង់ចេញអំពីឧក្កាចេលវិហារ ហើយយាងទៅកាន់ក្រុងវេសាលី ។*

សេចក្តីពិស្តារថា ព្រះមានព្រះភាគ ទ្រង់ចាំវស្សាក្នុងវេឡុវគ្រាម ហើយ យាងចេញអំពីវេឡុវគ្រាមនោះ ដល់ក្រុងសាវត្ថីដោយលំដាប់ ហើយប្រថាប់ នៅក្នុងវត្តជេតពន ។ ក្នុងកាលនោះ ព្រះធម្មសេនាបតីរំពឹងមើលអាយុសង្ខារ របស់ខ្លួន ដឹងថា នៅបាន ៧ ថ្ងៃប៉ុណ្ណោះ ទើបសូមអនុញ្ញាតព្រះមានព្រះភាគ ទៅកាន់នាលកគ្រាម ឲ្យម្តាយតាំងនៅក្នុងសោតាបត្តិផល ហើយបរិនិព្វាន ក្នុងទីនោះ ។ ព្រះសាស្តាទ្រង់កាន់យកធាតុ របស់ព្រះធម្មសេនាបតី ដែល ព្រះចុនូនាំមកហើយ ឲ្យសាងចេតិយ ជាទីបញ្ចុះព្រះធាតុ ចោមរោមទៅ ដោយមហាភិក្ខុសង្ឆ យាងទៅកាន់ក្រុងរាជគ្រឹះ ។ ក្នុងកាលទៅកាន់ក្រុង រាជគ្រឹះនោះ ព្រះមហាមោគ្គល្លានបរិនិព្វានហើយ ព្រះមានព្រះភាគ ទ្រង់កាន់ យកធាតុព្រះមហាមោគ្គល្លាននោះ ហើយឲ្យសាងជាចេតិយ ហើយយាង ចេញអំពីក្រុងរាជគ្រឹះ ទៅកាន់ឧក្កាចេលវិហារតាមលំដាប់ ។ ក្នុងទីនោះ

ចោមរោមទៅដោយភិក្ខុសង្ឃ អង្គុយត្រង់ស្ទឹងគង្គា សម្តែងធម៌ ទាក់ទង ដោយបរិនិព្វានរបស់អគ្គសាវ័កទាំង ២ ចេញអំពីឧក្កាចេលវិហារ ហើយ យាងទៅកាន់ក្រុងវេសាលី ។ ព្រះមានព្រះភាគ យាងទៅយ៉ាងនោះ ទើប លោកពោលថា ទ្រង់ស្បង់ប្រដាប់បាតចីវរ ចូលទៅកាន់ក្រុងវេសាលី ដើម្បី បិណ្ឌបាត ក្នុងបុព្វណ្ហសម័យ ។ ដោយហេតុនោះ ទើបលោកពោលថា ទ្រង់យាងចេញអំពីឧក្កាចេលវិហារហើយ យាងទៅកាន់ក្រុងវេសាលី ដូច្នេះ ជាដើម ។

ក្នុងបទថា **និសីទនំ** *នេះ លោកបំណងយកកំណាត់ស្បែក ។ បទថា* **ចាបាលចេតិយំ** *សេចក្តីថា ក្នុងទីដែលយក្ខឈ្មោះចាបាល នៅអាស្រ័យក្នុង កាលមុន ប្រាកដជា* **ចាបាលចេតិយ** *។ សូម្បីវិហារដែលគេសាងថ្វាយព្រះ មានព្រះភាគក្នុងទីនោះ ក៏គេហៅថា* **ចាបាលចេតិយ** *ដោយគ្រាមភាសា របស់អ្នកស្រុកក្នុងទីនោះ ។ ក្នុងបទថា* **ពហុបុត្តំ** *ជាដើម ក៏នយនេះ ដូចគ្នា ។ បទថា* **សត្តម្ពំ** *សេចក្តីថា បានឮថា ព្រះរាជកុមារី ៧ អង្គ ព្រះ រាជធីតារបស់ព្រះបាទកាសី ព្រះនាមកិកិ កើតនូវសេចក្តីសង្វេគ ចេញអំពី ក្រុងរាជគ្រឹះ ផ្តើមតាំងសេចក្តីព្យាយាមក្នុងទីណា ទីនោះ ជនទាំងឡាយ នាំ គ្នាហៅថា* **សត្តម្ពចេតិយ** *។ បទថា* **ពហុបុត្តំ** *សេចក្តីថា ពួកមនុស្សជា ច្រើនប្រាថ្នាបុត្រជាមួយទេវតា ដែលអាស្រ័យនៅត្រង់ដើមជ្រៃមួយ ដែលមាន ឫសច្រើន ព្រោះអាស្រ័យហេតុនោះ ទើបទីនោះប្រាកដឈ្មោះថា* **ពហុបុត្ត-ចេតិយ** *។ បទថា* **សារន្ធំ** *បានដល់ ទីដែលយក្ខឈ្មោះថា សារន្ធៈអាស្រ័យ*

នៅ ដូច្នោះ ទីទាំងអស់នោះឯង គេហៅដោយវោហារថា **ចេតិយ** ព្រោះទេវតាគ្រប់គ្រងមុនពុទ្ធកាល ។ កាលសាងវិហារថ្វាយព្រះមានព្រះភាគ ជនទាំង-ឡាយក៏នៅចាំបានយ៉ាងនោះដូចគ្នា ។ ក្នុងបទថា **មរណីយា** នេះ គប្បីជ្រាបថា ក្រុងវេសាលី ជាទីគួរត្រេកអរ ព្រោះសម្បូរដោយភូមិភាគ ដេរដាសដោយបុគ្គល មានបច្ចុ័យរកបានងាយ ជាលំដាប់ដំបូង ។ ឯវិហារទាំងឡាយគប្បីជ្រាបថា ជាទីគួរត្រេកអរ ព្រោះមិនជិត មិនឆ្ងាយអំពីព្រះនគរ សម្បូរដោយគមនាគមន៍ ព្រោះជាលំនៅដែលមិនចង្អៀត សម្បូរដោយម្ងប់ និងទឹកនិងជាទីដែលសមគួរដល់ការស្វាត់ ។ អត្ថនៃបទថា **ឥទ្ធិចាធ** ក្នុងបទថា **ចាត្តារោ ឥទ្ធិចាធា** នេះ លោកពោលហើយខាងដើមនោះឯង ។ បទថា **ភាវិតា** ប្រែថា បានចម្រើនហើយ ។ បទថា **ពហុលីកតា** បានដល់ ធ្វើរឿយៗ ។ បទថា **យានីកតា** បានដល់ ធ្វើឲ្យដូចជាយានដែលទឹមហើយ ។ បទថា **វត្ថុកតា** បានដល់ ធ្វើឲ្យដូចជាវត្ថុ ព្រោះអត្ថថា ជាទីតាំងអាស្រ័យ ។ បទថា **អនុដ្ឋិតា** ប្រែថា តាំងមាំហើយ ។ បទថា **បរិចិតា** បានដល់ សន្សំដោយជុំវិញ គឺចម្រើនដោយល្អ ។ បទថា **សុសមារទ្ធា** បានដល់ ប្រារព្ធដោយល្អ គឺឲ្យសម្រេចដោយប្រពៃយ៉ាងក្រៃលែង ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដោយមិនកំណត់ ដោយប្រការដូច្នេះហើយ កាលនឹងកំណត់សម្តែងទៀត ទើបត្រាស់ពាក្យជាដើមថា **តថា-គតស្ស ខោ** ដូច្នេះ ។

ក្នុងបទទាំងនេះ បទថា **កប្បំ** បានដល់ អាយុកប្ប ។ បទថា **តិដ្ឋេយ្យ**

បានដល់ គប្បីតាំងនៅ គឺគប្បីទ្រទ្រង់ទុកនូវប្រមាណនៃអាយុរបស់មនុស្ស ក្នុងកាលនោះឲ្យបរិបូណ៌ ។ បទថា **កប្បាវសេសំ វា** *សេចក្តីថា ក្រៃលែងជាងរយឆ្នាំ ដែលពោលថា* **អឍ្ឍំ វា ភិយ្យោ** *ដូច្នេះជាដើម ។*

ចំណែកព្រះមហាសិវត្ថេរ ពោលថា ដែលឈ្មោះថា សំឡេងគ្រហឹម ក្នុងទីដែលមិនគួរ រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយ ដូចកាលទ្រង់សង្កត់វេទនាទៀបបរិនិព្វានដែលកើតឡើងក្នុងវេឡុវគ្រាម អស់ ១០ ខែ យ៉ាងណា ក៏ទ្រង់ចូលសមាបត្តិនោះរឿយៗ ហើយសង្កត់បានដល់ទៅ ១០ ខែ គប្បីតាំងនៅរហូតកន្ទុយកប្បនេះ ដូច្នោះ ។ សួរថា ព្រោះហេតុអ្វី ទើបទ្រង់មិនតាំងនៅ ។ ឆ្លើយថា ព្រោះឈ្មោះថា រាងកាយដែលមានចិត្តគ្រប់គ្រង ត្រូវទុក្ខវេទនា មានធម្មតាជាក់ជាដើមចូលមកគ្របសង្កត់ ឯព្រះពុទ្ធទាំងឡាយមិនដល់នូវភាវៈនៃទុក្ខវេទនា មានធម្មតាជាក់ជាដើមឡើយ រមែងបរិនិព្វានក្នុងកាលដែលជនច្រើននាំគ្នាស្រឡាញ់ពេញចិត្ត ក្នុងចំណែកព្រះជន្មាយុចំណែកទី ៥ កាលអគ្គសាវក និងមហាសាវកត្រាស់ដឹងតាមព្រះពុទ្ធបរិនិព្វានហើយ គប្បីតាំងនៅមួយអន្តរ មិនមានបរិវារ ឬមានកិក្ខុកំលោះ និងសាមណេរជាបរិវារក្តី បន្ទាប់អំពីនោះ គប្បីដល់នូវភាពជាបុគ្គលត្រូវមើលងាយថា គួរសង្វេគ បរិស័ទរបស់ព្រះពុទ្ធទាំងឡាយ ព្រោះដូច្នោះ ទើបមិនតាំងនៅ ។ កាលលោកពោលយ៉ាងនោះ តែទ្រង់ក៏ត្រូវហៅថា មិនតាំងនៅ ។ ពាក្យថា **អាយុកប្បោ** *នេះឯង លោកបានកំណត់ក្នុងអដ្ឋកថាហើយ ។*

[๑๒๘] *បទថា* **ឱឡារិកេ ឯមិត្តេ** *បានដល់ ឲ្យសញ្ញាគ្រោតគ្រោត*

កើតឡើង ។ ពិតហើយ ការប្រើសញ្ញាគ្រោតគ្រោតកើតឡើងនេះ គឺការអង្វរការតាំងនៅអស់កប្បទាំងមូលថា សូមព្រះមានព្រះភាគ តាំងនៅអស់កប្ប គឺជាការប្រកាសភាពជាអ្នកអាចតាំងនៅអស់កប្ប ដោយអានុភាពនៃការចម្រើនឥទ្ធិបាទ ៤ របស់ខ្លួន ដោយការអាងសេចក្តីជនៃ ដោយនយជាដើមថា ម្នាលអានន្ទ ឥទ្ធិបាទ ៤ បុគ្គលណាម្នាក់អប់រំហើយ ដូច្នេះ ។ បទថា **ទិភាសេ** *គឺក្នុងព្រះតម្រាស់ដែលប្រាកដ ។ ពិតហើយ ព្រះតម្រាស់ដែលប្រាកដនេះ គឺការលះពាក្យបរិយាយដោយអមហើយ ទើបទ្រង់ប្រកាសបំណងរបស់ទ្រង់ដោយត្រង់នោះឯង ។*

បទថា **ពហុជនហិតាយ** *បានដល់ ដើម្បីជាប្រយោជន៍ដល់មហាជន ។ បទថា* **ពហុជនសុខាយ** *បានដល់ ដើម្បីសេចក្តីសុខដល់មហាជន ។ បទថា* **លោកានុកម្បាយ** *បានដល់ ព្រោះអាស្រ័យសេចក្តីអនុគ្រោះដល់សត្វលោក ដល់សត្វលោកណាខ្លះ គឺដល់បុគ្គលដែលស្តាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ហើយចាក់ធ្លុះ គឺផឹកនូវអមតៈ ។ ពិតហើយ ព្រហ្ម ១៨ កោដិ មានព្រះអញ្ញាកោណ្ឌញ្ញៈជាប្រធាន ចាក់ធ្លុះនូវធម៌ដោយទេសនា ធម្មចក្កប្ប-វត្តនសូត្ររបស់ព្រះមានព្រះភាគ ។ សត្វដែលចាក់ធ្លុះនូវធម៌ រហូតដល់ជីកនាំនូវសុកទូបរិព្វាជក ដោយប្រការយ៉ាងនេះរាប់មិនបាន ។ ពួកសត្វដែលបានត្រាស់ដឹងក្នុងកាលដែលទ្រង់សម្តែងព្រះសូត្រទាំង ៤ នេះ គឺមហាសមយ-សូត្រ មង្គលសូត្រ ចូឡរាហុលោវាទសូត្រ និងសមចិត្តសូត្រ មិនមានដែនកំណត់ ទីដែលកើតមានដល់ព្រះមានព្រះភាគ ដើម្បីទ្រង់អនុគ្រោះសត្វលោក*

មិនមានប្រមាណនេះ លោកពោលដោយបំណងថា សូម្បីក្នុងអនាគត ក៏នឹងមានយ៉ាងនេះ ។ បទថា **ទេវមនុស្សានំ** *សេចក្តីថា ស្តានទីរមែងមានដល់ព្រះដ៏មានព្រះភាគ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន សូម្បីសត្វដ៏សេស មានឧគ និងគ្រុឌជាដើមក៏មាន ។ ដើម្បីសម្តែងភព្វបុគ្គលដែលជាសហេតុកបដិសន្ធិ ដោយធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផល ទើបត្រាស់ហើយយ៉ាងនោះ អធិប្បាយថា ព្រោះដូច្នោះ ទើបព្រះមានព្រះភាគគង់ព្រះជន្មនៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់សត្វជនៃ ។ បណ្តាបទទាំងនោះ បទថា* **អត្ថាយ** *បានដល់ ដើម្បីជាប្រយោជន៍ដល់សម្បត្តិក្នុងលោកនេះ ។ បទថា* **ហិតាយ** *បានដល់ ដើម្បីជាប្រយោជន៍ ដែលជាហេតុនៃសម្បត្តិក្នុងលោកខាងមុខ ។ បទថា* **សុខាយ** *បានដល់ ដើម្បីជាប្រយោជន៍ដល់សេចក្តីសុខក្នុងព្រះនិព្វាន ។ សព្ទថា* **ហិត** *និង* **សុខ** *ជាអាការដំបូង គប្បីជ្រាបដោយទូទៅដល់ហិតសុខទាំងពួង ។*

បទថា **តំ** *ក្នុងបទថា* **យថាតំ មាវេន បរិយុដ្ឋិតចិត្តោ** *នេះ ត្រឹមតែជានិបាត អធិប្បាយថា បុថុជ្ជនជនៃពួកខ្លះ ដែលត្រូវមារបណ្តាលចិត្ត គឺត្រូវមារគ្របសង្កត់ចិត្ត មិនអាចដឹងច្បាស់បាន យ៉ាងណា អានន្ទក៏ដូច្នោះដូចគ្នា មិនអាចដឹងច្បាស់បាន ។ ពិតហើយ មាររមែងគ្របសង្កត់ចិត្តរបស់បុគ្គលដែលមិនទាន់លះវិបល្លាសខ្លះបាន ។ ឯក្នុងបុគ្គលដែលមិនទាន់លះវិបល្លាស ១២ យ៉ាង ដោយប្រការទាំងពួងមិនទាន់បាន នឹងពោលទៅថ្វី ព្រោះព្រះថេរៈ*

លះវិបល្លាស ៤ មិនទាន់បាន ដូច្នោះ ទើបចិត្តរបស់លោកត្រូវមារគ្របសង្កត់ ។ សួរថា មារកាលគ្របសង្កត់ចិត្ត ធ្វើដូចម្តេច ។ ឆ្លើយថា សម្តែងរូបារម្មណ៍ដែលគួរខ្ជាប ឬឲ្យបានឮសទ្ទារម្មណ៍ដែលគួរខ្ជាប ។ បន្ទាប់អំពីនោះ សត្វទាំងឡាយ បានឃើញ ឬបានឮអារម្មណ៍ដែលគួរខ្ជាបនោះហើយ ក្លេចស្មារតី ហាមាត់ មារលូកដៃចូលតាមមាត់របស់សត្វទាំងនោះ ហើយច្របាច់បេះដូង បន្ទាប់អំពីនោះ សត្វក៏ដល់នូវវិសញ្ញី គឺសន្លប់ ។ ឯមារមិនអាចស៊កដៃចូលតាមមាត់ព្រះអានន្ទបានឡើយ តែសម្តែងអារម្មណ៍ដែលគួរខ្ជាបបាន ព្រះថេរៈនោះបានឃើញដូច្នេះហើយ ទើបមិនជឿចម្បាស់នូវនិមិត្តឱកាស ។ ព្រះមានព្រះភាគ ក៏ទ្រង់ជ្រាបប្រយោជន៍អ្វី ទើបត្រាស់ហៅអស់ភារៈ ៣ ដង ។ ឆ្លើយថា គឺតទៅខាងមុខ ដើម្បីធ្វើសេចក្តីសោកឲ្យធូរស្បើយ ដោយលើកទោសឡើងថា សេចក្តីនោះ ជាការធ្វើមិនល្អរបស់លោក សេចក្តីនោះ ជាកំហុសរបស់លោក ក្នុងកាលលោកអារាធនាថា សូមព្រះមានព្រះភាគ ទ្រង់គង់ព្រះជន្មនៅចុះ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ឃើញថា អានន្ទនេះមានចិត្តស្និទ្ធស្នាលក្នុងតថាគតពន់ពេក តទៅខាងមុខ អានន្ទបានស្តាប់ហេតុផែនដីកម្រើក និងការដាក់អាយុសង្ខារ និងអារាធនាឲ្យតថាគត តាំងនៅអស់កាលយូរ កាលបើដូច្នោះ តថាគតនឹងឲ្យទោសធ្លាក់លើអំបែងក្បាលរបស់អានន្ទប៉ុណ្ណោះថា ព្រោះហេតុអ្វី ទើបអ្នកមិនអារាធនាមុន ។ ព្រោះទោសរបស់ខ្លួន សត្វទាំងឡាយក៏មិនក្តៅក្រហាយ ដូច្នោះ ។ ព្រោះហេតុនោះ សេចក្តីសោករបស់អានន្ទនឹងស្រាកស្រាន្ត ។

[១២៩] បទថា **គច្ឆ ត្វំ អានន្ទ** សេចក្តីថា ព្រោះហេតុដែលអ្នកមកក្នុងទីនេះ ដើម្បីសម្រាកពេលថ្ងៃ ដូច្នោះ ម្នាលអានន្ទ អ្នកទៅចុះ ទៅកាន់ទីដែលខ្លួនគាប់ចិត្តដើម្បីសម្រាកពេលថ្ងៃ ដោយហេតុនោះឯង ទើបទ្រង់ត្រាស់ថា អ្នកចូរទៅ អ្នកចូរសម្គាល់កាលដែលគួរទៅ ក្នុងកាលឥឡូវនេះចុះ ដូច្នេះជាដើម ។

[១៣០] ក្នុងបទថា **មារោ ចាបិមា** នេះ មានវិគ្គហៈដូចតទៅនេះ ឈ្មោះថា មារ ព្រោះប្រកបពួកសត្វឲ្យនៅក្នុងសេចក្តីវិនាស ធ្វើឲ្យស្លាប់ ។ បទថា **ចាបិមា** នេះ ជាវេវចនៈនៃបទថា **មារ** នោះឯង ។ ពិតហើយ មារនោះ លោកហៅថា **ចាបិមា** ព្រោះប្រកបដោយធម៌ចំណែកអាក្រក់ ។ បទថា **ភាសិតា ខោ បនេសា** សេចក្តីថា ពិតហើយ មារនេះ កាលព្រះមានព្រះភាគប្រថាប់នៅត្រង់ដើមអជបាលនិគ្រោធ កន្លងទៅ ៧ ថ្ងៃ ក្នុងមណ្ឌលពោធិព្រឹក្ស ធីតាទាំង៣ឱ្យរបស់ខ្លួន នាំគ្នាមក ត្រេកអ្នាត់សេចក្តីប្រាថ្នាចេញ ហើយក៏នាំគ្នាទៅ មានគិតថា ឧបាយនេះប្រើបាន ទើបមកពោលថា បពិត្រព្រះមានព្រះភាគ ទ្រង់បំពេញបារមីមក ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ ព្រះអង្គសម្រេចហើយដោយលំដាប់ សព្វញ្ញុតញ្ញាណព្រះអង្គក៏ត្រាស់ដឹងហើយ ទ្រង់មានប្រយោជន៍អ្វីដោយការនៅក្នុងលោក ដូច្នេះហើយ ទើបទូលអារាធនាថា សូមព្រះមានព្រះភាគ ទ្រង់បរិនិព្វាន ក្នុងកាលឥឡូវនេះ សូមព្រះសុគត បរិនិព្វាន ។ ឯព្រះមានព្រះភាគត្រាស់ហាមមារនោះជាដើមថា តថាគតនឹងមិនទាន់បរិនិព្វានទេ ដូច្នេះ ដែលលោកបំណងពោល

ក្នុងឥទ្ធរនេះថា **ភាសិតា ខោ បន** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **វិយត្តា** បានដល់ ជាអ្នកជំនាញ ដោយការសម្រេចអរិយមគ្គ ។ បទថា **វិនីតា** បានដល់ ដែលបានទទួលការណែនាំដោយការកម្ចាត់កិលេសយ៉ាងនោះឯង ។ បទថា **វិសារទា** បានដល់ ដែលដល់នូវការក្លៀវក្លា ព្រោះការលះទិដ្ឋិ និងវិចិកិច្ឆាជាដើមដែលធ្វើនូវតម្រេក ។ បទថា **ពហុស្សុតា** សេចក្តីថា ឈ្មោះថា ជាពហុសូត ព្រោះមានព្រះពុទ្ធ-វចនៈច្រើន ដោយអំណាចបិដក ៣ ។ ឈ្មោះថា **ធម្មធរា** ព្រោះទ្រទ្រង់នូវធម៌នោះៗ ឯង ។ ម្យ៉ាងទៀត បទថា **ពហុស្សុតា** បានដល់ ព្រោះមានបរិយត្តិដែលស្តាប់ហើយច្រើន និងព្រោះមានបដិវេធដែលស្តាប់ហើយច្រើន ។ គប្បីជ្រាបអត្ថក្នុងបទថា **ធម្មធរា** នេះ ដោយអាការយ៉ាងនេះថា ឈ្មោះថា **ធម្មធរា** ព្រោះទ្រទ្រង់នូវព្រះបរិយត្តិធម៌ និងបដិវេធធម៌ ។ បទថា **ធម្មានុធម្មប្បដិបន្នា** បានដល់ ដែលបដិបត្តិវិបស្សនាធម៌ ដែលជាធម៌សមគួរដល់អរិយធម៌ ។ បទថា **សាមីចិប្បដិបន្នា** បានដល់ ដែលបដិបត្តិបដិបទាតៗ គ្នាមក ដោយវិសុទ្ធិដែលសមគួរដល់ញាណទស្សនវិសុទ្ធិ ។ បទថា **អនុធម្មចារិនោ** បានដល់ ដែលមានប្រក្រតីប្រព្រឹត្តធម៌ មានការប្រាថ្នាតិចជាដើមដែលជុំសខាត់ក្រៃលែង គឺដែលសមគួរដល់បដិបទានោះ ។ បទថា **សកំ អាចរិយកំ** បានដល់ នូវអាចរិយវាទរបស់ខ្លួន ។ បទថា **អាចិក្ខិស្សន្តិ** បានដល់ នឹងសម្តែងតែខាងដើម អធិប្បាយថា នឹងឲ្យអ្នកដទៃរៀនសូត្រ ដោយទំនងដែលខ្លួនរៀនមក ។ បទថា **ទេសេស្សន្តិ** បានដល់ នឹងប្រាប់ អធិប្បាយ

ថា នឹងជ្រាប់បាលីដោយប្រពៃ ។ បទថា **បញ្ញាបេស្សន្តិ** *ប្រែថា នឹងឲ្យដឹងច្បាស់ អធិប្បាយថា នឹងប្រកាស ។ បទថា* **បដ្ឋបេស្សន្តិ** *ប្រែថា នឹងតាំងទុកដោយប្រការទាំងឡាយ ។ បទថា* **វិវរិស្សន្តិ** *ប្រែថា នឹងធ្វើការបើកផ្ទារ ។ បទថា* **វិភជិស្សន្តិ** *ប្រែថា នឹងធ្វើការចែក ។ បទថា* **ឧត្តានី ករិស្សន្តិ** *បានដល់ នឹងធ្វើអត្ថដែលមិនវាក់ គឺដែលជ្រៅឲ្យវាក់ឡើង គឺឲ្យប្រាកដ ។ បទថា* **សហេតុនេ** *បានដល់ ដោយពាក្យដែលប្រព្រឹត្តទៅជាមួយហេតុ គឺដែលប្រព្រឹត្តទៅដោយការណ៍ ។ បទថា* **សប្បាដិហារិយំ** *បានដល់ ធ្វើរហូតឲ្យចេញចាកទុក្ខ ។ បទថា* **ធម្មំ ទេសេស្សន្តិ** *សេចក្តីថា នឹងញុំាងពួកសត្វឲ្យត្រាស់ដឹង គឺនឹងប្រកាសលោកុត្តរធម៌ ៩ ក្នុងបទទាំងនោះ ដោយបទ ៦ បទ មានពាក្យថា* **បញ្ញាបេស្សន្តិ** *លោកសម្តែងដល់បទដែលជាអត្ថ ៦ បទ ។ ដោយ ២ បទខាងដើម លោកសម្តែងដល់បទដែលជាព្យញ្ជនៈ ៦ បទ ។ ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះ ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ឈ្មោះថា ទ្រង់សង្គ្រោះសម្តែងដោយនយនៃវណ្ណនា ។ សមដូចពាក្យដែលលោកពោលក្នុងនេត្តិបករណ៍ថា បទ ១២ ចាត់ជាសូត្រ សូត្រទាំងអស់នោះជាព្យញ្ជនៈ ១ ជាអត្ថ ១ ។*

បទថា **ព្រហ្មចរិយំ** *បានដល់ សាសនព្រហ្មចរិយៈទាំងមូល ដែលសង្គ្រោះដោយត្រៃសិក្ខា ។ បទថា* **ឥទ្ធំ** *បានដល់ សម្រេចដោយញុំាងឈានឲ្យកើតឡើង ។ បទថា* **ផីតំ** *បានដល់ ដល់នូវសេចក្តីចម្រើន គឺឲ្យផលច្រើន ព្រោះដល់ព្រមដោយអភិញ្ញា ។ បទថា* **វិត្ថារិកំ** *បានដល់ ទូលំទូលាយ*

ដោយការប្រតិស្ឋាននៅក្នុងទិសភាគនោះៗ ។ បទថា **ពហុជញ្ញំ** *បានដល់ ជនច្រើនតែងដឹង គឺដឹងទាំងអស់ ដោយអំណាចការគ្រាស់ដឹងរបស់ជនច្រើន បទថា* **បុថុភូតំ** *បានដល់ ដល់នូវការក្រាស់ដោយអាការទាំងពួង ។ សេចក្តីនេះដូចម្តេច គឺជារាបដែលទេវតា និងមនុស្សប្រកាសល្អហើយ អធិប្បាយថា ទេវតា និងមនុស្សដែលមានជាតិនៃវិញ្ញាជនមានប្រមាណប៉ុនណា ទេវតា និងមនុស្សទាំងនោះប្រកាសល្អហើយ ។*

[១៣១] បទថា **អប្បោស្សុក្កោ** *បានដល់ អស់នូវការឧស្សាហ៍ គឺប្រាសចាកការហួងហែង ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលមារមានចិត្តបាបតាំងអំពី ៧ សប្តាហ៍កន្លងទៅ អ្នកត្រាច់ស្រែកថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់បរិនិព្វានក្នុងឥឡូវនេះចុះ សូមព្រះសុគតបរិនិព្វានក្នុងឥឡូវនេះចុះ ឥឡូវនេះ តាំងអំពីថ្ងៃនេះទៅ ចូរអ្នកប្រាសចាកសេចក្តីព្យាយាមចុះ ចូរកុំធ្វើនូវសេចក្តីព្យាយាមឲ្យតថាគតបរិនិព្វានឡើយ ។*

បទថា **សតោ សម្បជានោ អាយុសង្ខារំ ឱស្សជ្ជិ** *សេចក្តីថា ទ្រង់ត្រិះរិះដោយសតិ ហើយកំណត់ដោយញាណ ដាក់ គឺលះនូវអាយុសង្ខារ ។ ក្នុងការដាក់អាយុសង្ខារនោះ ព្រះមានព្រះភាគ ទ្រង់មិនបានដាក់អាយុសង្ខារដូចយកដៃគ្រវែងដុំដី តែទ្រង់កើតព្រះតម្រិះឡើងថា អស់កាលត្រឹម ៣ ខែ ប៉ុណ្ណោះ តថាគតនឹងចូលសមាបត្តិ ក្រោយអំពីនោះនឹងមិនចូល ដែលលោកបំណងពោលថា ព្រះអង្គទ្រង់ដាក់ហើយ ។ បាលីថា* **ភោសជ្ជិ** *ដូច្នេះក៏មាន ។*

ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគអាចតាំងនៅអស់កប្ប ឬលើសកប្ប

ទើបមិនតាំងនៅអស់កាលប្រមាណប៉ុណ្ណោះ ទ្រង់ជាក់អាយុសង្ខារតាមដែលមានទូលអាពាធនាដើម្បីឲ្យបរិនិព្វាន ព្រោះព្រះមានព្រះភាគ មិនបានជាក់អាយុសង្ខារតាមមានអាពាធនា និងមិនជាក់អាយុសង្ខារតាមព្រះថេរៈសំណូមពរឡើយ តែក្រោយអំពី ៣ ខែទៅ ទ្រង់ជាក់អាយុសង្ខារ ព្រោះពុទ្ធវេនេយ្យមិនមាន ធម្មតាការតាំងនៅនៃព្រះពុទ្ធទាំងឡាយ ក៏ដើម្បីដឹកនាំវេនេយ្យសត្វ កាលវេនេយ្យជនមិនមាន ព្រះមានព្រះភាគទាំងឡាយ នឹងតាំងនៅដោយហេតុអ្វី បើទ្រង់គប្បីបរិនិព្វាន តាមដែលមានអាពាធនា ក៏គប្បីបរិនិព្វានអំពីមុននោះឯង ។ ម្យ៉ាងទៀត លោកពោលសេចក្តីនេះថា ពិតហើយ ត្រង់ពោធិមណ្ឌល មារក៏អាពាធនាហើយ ដល់នូវការធ្វើនិមិត្តឱកាស ក៏ដើម្បីធ្វើសេចក្តីសោករបស់ព្រះថេរៈឲ្យស្រាកស្រាន្ត ។ ម្យ៉ាងទៀត ការធ្វើនិមិត្ត-ឱកាស ក៏ដើម្បីសម្តែងកម្លាំងរបស់ព្រះពុទ្ធ ។ ព្រះមានព្រះភាគទាំងឡាយដែលមានអានុភាពច្រើនយ៉ាងនេះ សូម្បីតាំងនៅ ក៏តាំងនៅតាមគាប់ព្រះហឫទ័យរបស់ព្រះអង្គប៉ុណ្ណោះ ។ កាលបរិនិព្វាន ក៏រមែងបរិនិព្វានតាមការពេញព្រះហឫទ័យរបស់ព្រះអង្គដូចគ្នា ។

បទថា **មហាភូមិចាលោ** *បានដល់ ផែនដីកម្រើកយ៉ាងធំ ។ បានឮថា ក្នុងកាលនោះ លោកធាតុមួយម៉ឺនញាប់ញ័រហើយ ។ បទថា* **ភីសនកោ** *ប្រែថា ឲ្យកើតការតក់ស្លុត ។ បទថា* **ទេវទុន្ទភិយោ ច ផលឹសុ** *សេចក្តីថា ស្គរទិព្វក៏បន្ទឺឡើង មេឃក៏លាន់កងរំពង ផ្គរបន្ទោរពុំជួកាល ក៏វាសឆ្ងៀលធ្ងាត់ អធិប្បាយថា ភ្លៀងធ្លាក់មួយរយៈ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ដឹងអាការទាំងពួងដល់អត្តនេះ ពោល គឺសេចក្តីវិសេសនៃសង្ខារ និងវិសង្ខារ ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្ទឺឧទានសម្តែងនូវការដែលព្រះអង្គទ្រង់លះសង្ខារមិនមានសេសសល់ ហើយដល់នូវវិសង្ខារ ។*

ព្រោះហេតុអ្វី ទើបទ្រង់បន្ទឺឧទាន ព្រោះឈ្មោះថា បុគ្គលណាម្នាក់ គប្បីពោលថា ព្រះអង្គត្រូវមារជាប់តាមអំពីខាងក្រោយ ហើយបៀតបៀនថា សូមទ្រង់បរិនិព្វានចុះ សូមទ្រង់បរិនិព្វានចុះ ទើបទ្រង់លះអាយុសង្ខារ ព្រោះខ្លាចមារ ។ ដើម្បីសម្តែងសេចក្តីនេះថា មារនោះកុំមានឱកាស ព្រោះធម្មតាបុគ្គលពោល រមែងមិនមានការបន្ទឺឧទាន ទើបព្រះអដ្ឋកថាចារ្យពោលក្នុងអដ្ឋកថាថា ទ្រង់បន្ទឺឧទានដែលកើតអំពីបីតិ ។ ព្រោះពុទ្ធកិច្ចនឹងសម្រេច ដោយកាលត្រឹម ៣ ខែប៉ុណ្ណោះ កាលទ្រង់ឃើញថា តថាគតបរិហារការៈ គឺទុក្ខនេះមកអស់កាលយូរយ៉ាងនេះ មិនយូរប៉ុន្មានក៏នឹងជាក់ចុះ ដូច្នេះ បីតិ និងបាមោជ្ជដ៏ក្រៃលែង កើតឡើងដោយពិចារណាគុណនៃព្រះនិព្វាន មើលទៅគួរនឹងពោលថា ទ្រង់បន្ទឺដោយកម្លាំងបីតិ ។ ពិតហើយ ព្រះសាស្តាទ្រង់បង្អោនទៅក្នុងវិសង្ខារ គឺមានព្រះនិព្វានជាអធ្យាស្រ័យដោយចំណែកមួយ ទើបទ្រង់តាំងនៅក្នុងលោកអស់កាលយូរ ដើម្បីជាប្រយោជន៍ដល់សត្វ ដោយព្រះមហាករុណា ដូចតាំងនៅដោយកម្លាំង ។ ពិតហើយ ទ្រង់ប្រើសមាបត្តិប្រមាណ ២ លាន ៤ សែនកោដិវាល់ថ្ងៃ ឥឡូវនេះ ទ្រង់បែរមុខចំពោះព្រះនិព្វាន ព្រោះអធិការដែលប្រកបដោយមហាករុណាសម្រេចហើយ ទើបសោយបីតិ និង

សោមនស្សដ៏ក្រៃលែង ព្រោះហេតុនោះឯង ទើបរស្មីនៃព្រះរូបរបស់ព្រះមានព្រះភាគផូរផង់ បរិសុទ្ធ ក្តីថាជាពិសេស សូម្បីក្នុងថ្ងៃរម្ងាប់ខន្ធបរិនិព្វាន ដូចគ្នាក្នុងថ្ងៃរម្ងាប់កិលេស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះគាថា មានដូចតទៅនេះ កាមាវចរកម្ម ឈ្មោះថា **តុល** *ព្រោះថ្លឹងបាន គឺកំណត់បានដោយការៈប្រចក្សដល់ឆ្កែស្រុក និងឆ្កែចចកជាដើម ។ មហគ្គតកម្ម ឈ្មោះថា* **អតុល** *ព្រោះថ្លឹងមិនបាន ឬព្រោះមិនមានលោកិយកម្មដទៃដែលថ្លឹងបាន គឺប្រៀបផ្ទឹម ។ កាមាវចរកម្ម ឬរូបាវចរកម្ម ឈ្មោះថា* **តុល** *អរូបាវចរកម្ម ឈ្មោះថា* **អតុល** *ម៉្យាងទៀត កម្មដែលមានវិបាកតិច ឈ្មោះ* **តុល** *ដែលមានវិបាកច្រើន ឈ្មោះ* **អតុល** *។ បទថា* **សម្ភវំ** *សេចក្តីថា ជាហេតុនៃការកើត គឺធ្វើបដិសន្ធិឲ្យកើត ។ បទថា* **ភវសង្ខារំ** *បានដល់ ធ្វើសង្ខារក្នុងភពថ្មីឲ្យកើត ។ បទថា* **អវស្សជ្ជិ** *បានដល់ លែង ។ បទថា* **មុនិ** *បានដល់ ពុទ្ធមុនី ។ បទថា* **អជ្ឈត្តរតោ** *ប្រែថា ត្រេកអរខាងក្នុងខ្លួន ។ បទថា* **សមាហិតោ** *បានដល់ មានចិត្តជាសមាធិ ដោយឧបចារសមាធិ និងអប្បនាសមាធិ ។ បទថា* **អភិន្ទិ កវចមិវ** *សេចក្តីថា បែកធ្លាយទៅ ដូចគ្នានឹងទាហានទម្លាយក្រោះ ដូច្នោះ ។ បទថា* **អត្តសម្ភវំ** *បានដល់ កិលេសដែលកើតក្នុងខ្លួន លោកអធិប្បាយថា មុនីលែងនូវលោកិយកម្ម ពោល គឺកម្មដែលថ្លឹងបាន និងថ្លឹងមិនបាន ដែលបានឈ្មោះថា* **សម្ភវ** *ព្រោះអត្ថថា មានវិបាក និងបានឈ្មោះថា* **ភវសង្ខារ** *ព្រោះអត្ថថា តាក់តែងភព និងជាអ្នកត្រេកអរខាងក្នុង មានចិត្តជាសមាធិ បាន*

ទម្លាយកិលេសដែលមានខ្ជួនជាដែនកើត ដូចទាហានធំ ទម្លាយក្រោះក្នុង សមរភូមិ ដូច្នោះ ។

ម្យ៉ាងទៀត បទថា **តុលំ** *បានដល់ ថ្លឹង គឺពិចារណា ។ បទថា* **អតុព្ភុសម្ភវំ** *បានដល់ ព្រះនិព្វាន និងកព ។ បទថា* **ភវសង្ខារំ** *បានដល់ កម្ម ដែលនាំសត្វទៅកាន់កព ។ បទថា* **អវស្សជ្ជិ មុនិ** *សេចក្តីថា ព្រះពុទ្ធមុនី ទ្រង់ពិចារណាដោយនយជាដើមថា បញ្ចក្ខន្ធមិនទៀង ការរម្ងាប់បញ្ចក្ខន្ធ គឺ ព្រះនិព្វានទៀង ទ្រង់ឃើញទោសក្នុងកព និងអានិសង្សក្នុងព្រះនិព្វាន ទ្រង់ លែងនូវសង្ខារកម្ម ដែលជាមូលនៃខន្ធទាំងឡាយនោះ ដោយអរិយមគ្គ ដែល ធ្វើការអស់ទៅនៃកម្ម ដែលលោកពោលយ៉ាងនេះថា រមែងប្រព្រឹត្តទៅដើម្បី ការអស់កម្ម ។ សេចក្តីនេះដូចម្តេច គឺលោកត្រេកអរខាងក្នុង មានចិត្តជា សមាធិ បានទម្លាយកិលេសដែលកើតក្នុងខ្ជួន ដូចទាហានទម្លាយក្រោះ លោកត្រេកអរក្នុងខាងក្នុងដោយវិបស្សនា មានចិត្តជាសមាធិដោយសមថៈ រួមសេចក្តីថា លោកទម្លាយកិលេសទាំងអស់ ដែលរួបរឹតអត្តភាព ដែលបាន ឈ្មោះថា* **អត្តសម្ភវ** *ព្រោះកើតក្នុងខ្ជួនដោយកម្លាំងនៃសមថៈ និងវិបស្សនា តាំងអំពីចំណែកខាងដើម ដូចទាហានទម្លាយក្រោះ ដូច្នោះ កាលមិនមាន កិលេស ឈ្មោះថា លះបង់កម្មបានជាសមុច្ឆេទ ព្រោះមិនមានបដិសន្ធិ ។ លោកលះកម្ម ព្រោះលះកិលេស ដោយប្រការដូច្នេះ ។ ដូច្នោះ ព្រះមាន ព្រះភាគ ទ្រង់ជាក់សង្ខារក្នុងកព នាមណ្ឌលពោធិព្រឹក្សនោះឯង សូម្បីញុំង អត្តភាពឲ្យប្រព្រឹត្តទៅដោយគ្រឿងជួសជុល គឺសមាបត្តិ ដូចធ្វើរនេះចាស់ឲ្យ*

ទៅដោយគ្រឿងអបសូប ទើបទ្រង់ដាក់អាយុសង្ខារ ដោយធ្វើព្រះហឬទ័យឲ្យ
កើតឡើងថា បន្ទាប់អំពីនេះទៅ ៣ ខែ តថាគតនឹងមិនឲ្យនូវគ្រឿងជួលជុល
គឺសមាបត្តិដល់សង្ខារនេះ ដូច្នេះ ។

អដ្ឋកថា អាយុសមឱសជ្ជនសូត្រទី ១ ចប់

សុត្តន្តបិដក

បដិសល្ខានសូត្រ

[១៣២] ខ្ញុំបានស្តាប់មកយ៉ាងនេះ សម័យមួយ ព្រះមានព្រះភាគ គង់
ក្នុងមិគារមាតុប្រាសាទ នាវត្តបុព្វារាម ទៀបក្រុងសាវត្ថី ។ សម័យនោះឯង
ព្រះមានព្រះភាគ ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយទ្រង់គង់ព្ជដ៏
ខាងក្រៅខ្វោងទ្វារ ។ គ្រានោះ ព្រះបាទបសេនទិកោសល ចូលទៅគាល់
ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ គង់នៅ
ក្នុងទីសមគួរ ។ សម័យនោះឯង ពួកជដិល ៧ នាក់ ពួកនិគ្រន្ថ ៧ នាក់
ពួកអចេល ៧ នាក់ ពួកឯកសាដក ៧ នាក់ ពួកបរិព្វាជក ៧ នាក់ សុទ្ធ
តែមានរោមព្ជដ៏ក្លៀក ទ្រុបទ្រុល និងក្រចកវែងៗ នាំយកអម្រែកមានប្រការ
ផ្សងៗ ដើរចូលមកក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះបាទបសេនទិកោ-
សល ទ្រង់ទតឃើញពួកអ្នកបួសទាំងនោះ គឺពួកជដិល ៧ នាក់ ពួកនិគ្រន្ថ
៧ នាក់ ពួកអចេល ៧ នាក់ ពួកឯកសាដក ៧ នាក់ ពួកបរិព្វាជក ៧

នាក់ សុទ្ធតែមានរោម ព្ងដ៏ក្បៀក ទ្រុបទ្រុល និងក្រចកវែងៗ នាំយកអម្រែក មានប្រការផ្សេងៗ ហើយដើរចូលមកក្នុងទីជិតនៃព្រះមានព្រះភាគ លុះទ្រង់ ទតឃើញហើយ ទើបក្រោកចាកអាសនៈ ធ្វើសំពត់ឆៀងស្មាម្ខាង ហើយ លុតមណ្ឌលជង្គង់ខាងស្តាំចុះលើប្រឹថពី ប្រណម្យអញ្ជលី ចំពោះពួកអ្នក បួសទាំងនោះ គឺជដិល ៧ នាក់ និគ្រន្ថ ៧ នាក់ អចេល ៧ នាក់ ឯកសាដក ៧ នាក់ បរិព្វាជក ៧ នាក់នោះ ហើយប្រកាសនាម (របស់ព្រះអង្គ) អស់វារៈ ៣ ដងថា បពិត្រលោកដ៏ចម្រើន ខ្ញុំជាស្តេចឈ្មោះបសេនទិកោ-សល បពិត្រលោកចម្រើន ខ្ញុំជាស្តេចឈ្មោះបសេនទិកោសល ។ គ្រានោះ កាលពួកអ្នកបួសទាំងនោះ គឺជដិល ៧ នាក់ និគ្រន្ថ ៧ នាក់ អចេល ៧ នាក់ ឯកសាដក ៧ នាក់ បរិព្វាជក ៧ នាក់ ចេញទៅមិនយូរប៉ុន្មាន ទើបព្រះ-បាទបសេនទិកោសល ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិ-កោសល ស្តេចគង់នៅក្នុងទីសមគួរហើយ ទើបបង្គំទូលសេចក្តីនុ៎ះ ចំពោះ ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពួកអ្នកបួសណា ជាព្រះអរហន្ត ឬបានសម្រេចអរហត្តមគ្គក្នុងលោក បណ្តាអ្នកបួសទាំងនោះ ជាព្រះអរហន្ត មួយដែរឬ ។

[១៣៣] បពិត្រមហារាជ ដំណើរដែលថា បុគ្គលនេះជាព្រះអរហន្ត ឬបុគ្គលនេះ បានសម្រេចអរហត្តមគ្គនោះ ព្រះអង្គជាគ្រហស្ថ ជាអ្នកបរិភោគ កាម គ្រប់គ្រងសយនៈដែលចង្អៀតដោយបុត្ត ប្រើប្រាស់កាសិកពស្ត្រ និង

លម្អិតខ្វីមចន្ទន៍ ទ្រទ្រង់កម្រងផ្កា និងគ្រឿងប្រអូប គ្រឿងលាបផ្សេងៗ ត្រេកអរចំពោះមាសប្រាក់ ជីងបានដោយក្រណាស់ ។ បពិត្រមហារាជ សីល ត្រូវបុគ្គលជីងដោយការនៅរួមគ្នា សីលនោះឯង គេជីងបានដោយកាលវែង មិនមែនជីងបានដោយកាលបន្តិចបន្តួចទេ កាលកំណត់ក្នុងចិត្ត ទើបអាចជីងបាន កាលបើមិនបានកំណត់ក្នុងចិត្ត មិនងាយជីងបាន អ្នកជាបណ្ឌិត ទើបអាចជីងបាន ជនពាលមិនងាយជីងបានទេ ។ បពិត្រមហារាជ សេចក្តីស្អាត ត្រូវបុគ្គលជីងបាន ដោយការនិយាយឆ្លើយឆ្លង ទាំងសេចក្តីស្អាតនោះឯង គេជីងបានដោយកាលវែង មិនមែនជីងដោយកាលបន្តិចបន្តួចទេ កាលកំណត់ក្នុងចិត្ត ទើបអាចជីងបាន កាលបើមិនបានកំណត់ក្នុងចិត្ត មិនងាយជីងបានទេ អ្នកជាបណ្ឌិត ទើបអាចជីងបាន ជនពាលមិនងាយជីងបានទេ ។ បពិត្រមហារាជ កម្ចាំងញាណ ត្រូវបុគ្គលជីងបាន ក្នុងវេលាមានអន្តរាយ ទាំងកម្ចាំងញាណនោះឯង ត្រូវជីងដោយកាលវែង មិនមែនជីងដោយកាលបន្តិចបន្តួចទេ កាលកំណត់ក្នុងចិត្ត ទើបអាចជីងបាន កាលបើមិនបានកំណត់ក្នុងចិត្ត មិនងាយជីងបានទេ អ្នកជាបណ្ឌិត ទើបអាចជីងបាន ជនពាលមិនងាយជីងបានទេ ។ បពិត្រមហារាជ បញ្ញាត្រូវបុគ្គលជីងបាន ដោយការសាកច្ចា ទាំងបញ្ញានោះឯង ត្រូវជីងដោយកាលវែង មិនមែនជីងដោយកាលបន្តិចបន្តួចទេ កាលកំណត់ក្នុងចិត្ត ទើបអាចជីងបាន កាលបើមិនបានកំណត់ក្នុងចិត្ត មិនងាយជីងបានទេ អ្នកជាបណ្ឌិត ទើបអាចជីងបាន ជនពាលមិនងាយជីងបានទេ ។

[១៣៤] បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏

ចម្រើន ចម្អែកណាស់ ត្រង់ដែលព្រះមានព្រះភាគ សម្តែងដោយប្រពៃថា បពិត្រមហារាជ ដំណើរដែលថា បុគ្គលនេះ ជាព្រះអរហន្ត ឬបុគ្គលនេះ បានសម្រេចអរហត្តមគ្គនោះ ព្រះអង្គជាគ្រហស្ថ ជាអ្នកបរិភោគកាម គ្រប់គ្រងសយនៈដែលចង្អៀតដោយបុត្ត ប្រើប្រាស់កាសិកពស្ត្រ និងលម្អិតខ្ចីមចន្ទន៍ ទ្រទ្រង់កម្រងផ្កា និងគ្រឿងប្រអូប គ្រឿងលាបផ្សេងៗ ត្រេកអរចំពោះមាស ប្រាក់ ជីងបានដោយក្រណាស់ ។ បពិត្រមហារាជ សីលត្រូវបុគ្គលជីងបានដោយការនៅរួមគ្នា ទាំងសីលនោះឯង គេជីងបានដោយកាលវែង មិនមែនជីងបាន ដោយកាលបន្តិចបន្តួចទេ កាលកំណត់ក្នុងចិត្ត ទើបជីងបាន កាលបើមិនកំណត់ក្នុងចិត្ត មិនងាយជីងបានទេ អ្នកជាបណ្ឌិត ទើបអាចជីងបាន ជនពាល មិនងាយជីងបានទេ ។ បពិត្រមហារាជ សេចក្តីស្អាត ត្រូវបុគ្គលជីងបាន ដោយការនិយាយឆ្លើយឆ្លង ទាំងសេចក្តីស្អាតនោះឯង គេជីងដោយកាលវែង មិនមែនជីង ដោយកាលបន្តិចបន្តួចទេ កាលកំណត់ក្នុងចិត្ត ទើបអាចជីងបាន កាលបើមិនកំណត់ក្នុងចិត្ត មិនងាយជីងបានទេ អ្នកជាបណ្ឌិត ទើបអាចជីងបាន ជនពាល មិនងាយជីងបានទេ ។ បពិត្រមហារាជ កម្លាំងញាណ ត្រូវបុគ្គលជីងបាន ក្នុងវេលាមានអន្តរាយ ទាំងកម្លាំងញាណនោះឯង ត្រូវជីងដោយកាលវែង មិនមែនជីងដោយកាលបន្តិចបន្តួចទេ កាលកំណត់ក្នុងចិត្ត ទើបអាចជីងបាន កាលបើមិនបានកំណត់ក្នុងចិត្ត មិនងាយជីងបានទេ អ្នកជាបណ្ឌិត ទើបអាចជីងបាន ជនពាលមិនងាយជីងបានទេ ។ បពិត្រមហារាជ បញ្ញាត្រូវបុគ្គលជីងបាន ដោយការ

សាកច្ឆា ទាំងបញ្ញានោះឯង ត្រូវដឹងដោយកាលវែង មិនមែនដឹង ដោយកាលបន្តិចបន្តួចទេ កាលកំណត់ក្នុងចិត្ត ទើបអាចដឹងបាន កាលបើមិនកំណត់ក្នុងចិត្ត មិនងាយដឹងបានទេ អ្នកជាបណ្ឌិត ទើបអាចដឹងបាន ជនពាលមិនងាយដឹងបានទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកបុរសរបស់ខ្ញុំព្រះអង្គទាំងនុ៎ះដូចជាចោរ ដើរតត្រុក ត្រួតត្រាជនបទ ពួកបុរសទាំងនោះមកត្រួតត្រាមុន ខ្ញុំព្រះអង្គនឹងមក ត្រួតត្រាខាងក្រោយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកបុរសទាំងនោះ បណ្តែត បន្សាត់បង់ធូលី និងមន្ទិលនោះចេញ ហើយងូតទឹក លាបស្រឡាបដោយល្អ កោរសក់ និងពុកមាត់ ស្លៀកពាក់សំពត់ពណិស ឆ្អែតស្កប់ស្កល់ មូលមិត្ត បម្រើដោយកាមគុណ ៥ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺ ខទាននេះក្នុងវេលានោះថា

> បុគ្គលមិនគប្បីប្រឹងប្រែង ក្នុងអំពើលាមកទាំងពួងទេ បុគ្គលមិនគប្បីជាបុរសនៃបុគ្គលដទៃ មិនគប្បីរស់នៅព្រោះអាស្រ័យអ្នកដទៃ មិនគប្បីប្រព្រឹត្តធម៌ (ដើម្បីលាភ) ដូចការជួញប្រែទេ ។ សូត្រទី ២ ។

អដ្ឋកថា

បដិសល្លានសូត្រ

បដិសល្លានសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ

[១៣២] បទថា **ពហិទ្វារកោដ្ឋកេ** បានដល់ ខាងក្រៅខ្លោងទ្វារប្រាសាទ មិនមែនខាងក្រៅខ្លោងទ្វារវិហារ ។ បានឮថា ប្រាសាទនោះដូចគ្នានឹងលោហប្រាសាទ ដោយជុំវិញព័ទ្ធកំពែង ដែលសមគួរដល់ខ្លោងទ្វារទាំង ៤ ។ ក្នុងមួយប្រាសាទ ខាងក្រៅខ្លោងទ្វារទិសខាងកើត ក្នុងបណ្តាទ្វារទាំងនោះ ទ្រង់ប្រថាប់គង់លើបវរពុទ្ធាសនៈដែលផ្ចិតផ្ចង់ ទ្រង់សម្លឹងមើលលោកធាតុទិសខាងកើត ។

បទថា **ជដិលា** បានដល់ អ្នកទ្រទ្រង់កេសជាតាបសមានផ្នួងសក់ ។ បទថា **និគ្គន្ថា** បានដល់ អ្នកទ្រទ្រង់រូបនិគ្រន្ថ ស្បៀកសំពត់ស ។ បទថា **ឯកសាដកា** បានដល់ ជាអ្នកយកកំណាត់សំពត់ចាស់មួយផ្ទាំងចងដៃ បិទបាំងផ្នែកខាងមុខនៃរាងកាយ ដោយសំពត់ចាស់ដទៃនោះ ត្រាច់ទៅ ដូចពួកនិគ្រន្ថ ដែលមានសំពត់មួយផ្ទាំង ។ បទថា **បវុដ្ឋកេចូឡលោមា** បានដល់ ជាអ្នកមានរោមក្លៀកជុះហើយ ក្រចកជុះហើយ និងរោមក្រៅអំពីនោះក៏ជុះហើយ អធិប្បាយថា រោមក្លៀកជាដើមវែង និងក្រចកវែង ។ បទថា **នានាវិធមានាយ** សេចក្តីថា ប្រើសម្រែកផ្សេងៗ រែកគ្រឿងបរិក្ខារបស់បព្វជិតមានប្រការផ្សេងៗ ។ បទថា **អន្ទរេ អតិក្កមន្តិ** សេចក្តីថា ចូលទៅកាន់ព្រះនគរដោយផ្លូវមិនឆ្ងាយអំពីព្រះវិហារ ។ បទថា **រាជាហំ ភន្តេ បសេនទិ-**

កោសលោ *សេចក្តីថា ព្រះបាទបសេនទិកោសល ទ្រង់ប្រកាសថា លោកដ៏ចម្រើន ខ្ញុំជាព្រះរាជា ឈ្មោះបសេបទិកោសល ចូរលោកទាំងឡាយជ្រាបនូវឈ្មោះរបស់ខ្ញុំ ។ សួរថា ព្រោះហេតុអ្វី ព្រះរាជាប្រថាប់នៅក្នុងសម្នាក់អគ្គ-បុគ្គលក្នុងលោក ហើយផ្គងអញ្ជលីដល់អ្នកអាក្រាត មិនមានសិរីបែបនេះ ។ ឆ្លើយថា ដើម្បីទ្រង់សង្គ្រោះ ។ ពិតហើយ ព្រះបាទបសេនទិកោសល មានព្រះតម្រិះយ៉ាងនេះថា បើអញមិនធ្វើហេតុមានប្រមាណប៉ុណ្ណេះដល់ជនពួកនេះទេ ជនពួកនេះ ក៏នឹងគិតថា ពួកយើងលះកូន និងប្រពន្ធ ស៊ី និងដេកលំបាកជាដើម ដើម្បីជាប្រយោជន៍ដល់ព្រះរាជានេះៗ ទ្រង់មិនធ្វើត្រឹមតែការកោតក្រែង ពួកយើង ព្រោះកាលទ្រង់ធ្វើការកោតក្រែងជាដើមនោះ ពួកមនុស្សនឹងមិនជឿពួកយើងថា ជាពួកចារបុរស និងយល់ថា យើងជាបព្វជិត ពិតប្រយោជន៍អ្វីដោយការប្រាប់សេចក្តីពិតដល់ព្រះរាជានេះ ទើបបិទបាំងវត្ថុដែលខ្លួនឃើញ និងបានឮមក មិនប្រាប់ តែបើទ្រង់ធ្វើយ៉ាងនេះ ជនទាំងនោះនឹងប្រាប់ដោយមិនបិទបាំង ។ ម្យ៉ាងទៀត ដើម្បីជីវិតអធ្យាស្រ័យរបស់ព្រះសាស្តា ទើបព្រះរាជាធ្វើយ៉ាងនោះ ។ បានឮថា ព្រះរាជា កាលចូលទៅគាល់ព្រះមានព្រះភាគ ទ្រង់ក៏មិនជឿសម្មាសម្ពោធិញ្ញាណអស់កាលតិចតួច ។ ដោយហេតុនោះ ទើបព្រះរាជាមានព្រះតម្រិះយ៉ាងនេះថា បើព្រះមានព្រះភាគទ្រង់ជីវិតហេតុទាំងពួងសោត កាលអញធ្វើសេចក្តីកោតក្រែងចំពោះជនទាំងនេះ ហើយពោលថា ជនទាំងនេះជាព្រះអរហន្ត ក៏មិនគប្បីយល់ព្រម បើព្រះសាស្តាទ្រង់យល់ព្រមតាមអញ ទ្រង់ជាព្រះសព្វញ្ញុបានអំពីណា ។ ព្រះរាជាទ្រង់ធ្វើ*

យ៉ាងនោះ ដើម្បីទ្រង់ជ្រាបអធ្យាស្រ័យរបស់ព្រះសាស្តា ដោយប្រការដូច្នេះ ។ តែព្រះមានព្រះភាគទ្រង់ជ្រាបថា កាលតថាគតពោលត្រង់ៗ ថា ជនទាំងនេះមិនមែនសមណៈ ជាចារបុរស បើព្រះរាជាជឿសោត ឯមហាជនកាលមិនដឹងសេចក្តីនោះ ក៏នឹងមិនគប្បីជឿ ទើបពោលថា ព្រះសមណគោតមត្រាស់ពាក្យណាមួយ រហូតដល់រត់ព្រះឱស្ឋថា ព្រះរាជាស្តាប់ពាក្យរបស់ព្រះអង្គ សេចក្តីនោះ គប្បីប្រព្រឹត្តទៅដើម្បីមិនមែនប្រយោជន៍ ដើម្បីទុក្ខអស់កាលយូរជល់មហាជននោះ ទាំងអាចិកំចាំងរបស់ព្រះរាជាគប្បីបើកឡើង ព្រះរាជានឹងត្រាស់ថា ជនទាំងនោះជាចារបុរសដោយព្រះអង្គឯង ទើបត្រាស់ពាក្យជាដើមថា សេចក្តីនោះដឹងបានលំបាក ។

[๑๓๔] *បណ្តាបទទាំងនោះ បទថា* **បុត្តសម្ពាធសយនំ** *បានដល់ទ្រង់ផ្ងើជ្រៀតបៀតជាមួយព្រះឱរស និងព្រះមហេសី ។ ក្នុងការនេះ លោកសម្តែងដល់ការកំណត់យកព្រះមហេសី ដោយលើកព្រះឱរសឡើងជាប្រធាន ។ លោកសម្តែងដល់ការដែលចិត្តរបស់ជនទាំងនោះសៅហ្មង ដោយត្រូវសេចក្តីសោក មានរាគៈជាដើមគ្របសង្កត់ ដោយភាពដែលព្រះរាជាមានចិត្តជាប់ជំពាក់ក្នុងបុត្រ និងភរិយា ។ ដោយបទថា* **កាមភោគិនោ** *នេះ លោកសម្តែងដល់ត្រូវរាគៈគ្របសង្កត់ ។ ដោយបទទាំង ២ សម្តែងដល់ភាពដែលជនទាំងនោះ មានចិត្តរាយមាយ ។ បទថា* **កាសិកចន្ទនំ** *បានដល់ លម្អិតចន្ទន៍ ។ ម្យ៉ាងទៀត បានដល់ សំពត់ដែលធ្វើក្នុងដែនកាសី និងខ្លឹមចន្ទន៍ ។ បទថា* **មាលាគន្ធវិលេបនំ** *បានដល់ ទ្រទ្រង់នូវកម្រងផ្កា ដើម្បីពណ៌ និង*

ក្ខិន នូវគ្រឿងក្រអូប ដើម្បីក្រអូប នូវគ្រឿងលាប ដើម្បីស្បែកស្អាត ។ បទ ថា **ជាតរូបរជតំ** *បានដល់ មាស និងទ្រព្យដ៏សេស ។ បទថា* **សាធិ-យន្តេន** *បានដល់ ទទួល ។ បទទាំងអស់ ក៏ប្រកាសដល់ភាពដែលជន ទាំងនោះ ជាប់នៅក្នុងកាមនោះឯង ។*

បទថា **សំវាសេន** *បានដល់ ដោយការនៅរួម ។ បទថា* **សីលំ វេទិតព្ពំ** *សេចក្តីថា ដែលនៅរួម គឺនៅរួមក្នុងទីតែមួយ គប្បីជ្រាបថា បុគ្គលនេះ ជា អ្នកមានសីល ឬជាអ្នកទ្រុស្តសីល ។ បទថា* **តញ្ហេ ខោ ឆិយេន អទ្ធុនា ន ឥត្តរេន** *សេចក្តីថា សីលនោះ គប្បីជ្រាបដោយកាលយូរ មិនគប្បីជ្រាប ដោយកាលដែលគប្បីមាន គប្បីកើត ។ ពិតហើយ ក្នុងថ្ងៃតិចតួច បុគ្គល ណាម្នាក់ អាចសម្តែងជាបុគ្គលមានអាការសង្រួម និងអាការសង្រួមឥន្ទ្រិយ បទថា* **មនសិករោតា ខោ អមនសិករោតា** *សេចក្តីថា សីលនោះ បុគ្គល ជាក់ចិត្ត គឺពិចារណាថា អញនឹងកំណត់សីលរបស់បុគ្គលនោះ អាចដឹងបាន បុគ្គលក្រៅអំពីនេះ មិនអាចដឹងបានឡើយ ។ បទថា* **បញ្ញាវតា** *សេចក្តីថា សីលនោះ ព្រោះអ្នកមានបញ្ញា គឺបណ្ឌិតអាចដឹងបាន ។ ព្រោះបុគ្គលល្ងង់ ខ្លៅជាក់ចិត្ត ក៏មិនអាចដឹង ។ បទថា* **សំវោហារេន** *ប្រែថា ដោយការ ពោល ។ ពិតហើយ ពាណិជ្ជកម្ម ឈ្មោះថា វោហារ ដូចក្នុងប្រយោគថា*

មនុស្សណាមួយចិញ្ចឹមជីវិតដោយការជួញ ម្នាលវាសេដ្ឋ អ្នកចូរ ដឹងយ៉ាងនេះថា អ្នកនោះជាពាណិជ្ជ មិនមែនព្រាហ្មណ៍ទេ ដូច្នេះ ។

ចេតនា ឈ្មោះថា វោហារ ដូចក្នុងប្រយោគថា ម្នាលភិក្ខុទាំងឡាយ

អរិយវោហារ (វោហារដ៏ប្រសើរ) នេះ មាន ៨ យ៉ាង ... ម្នាលភិក្ខុទាំងឡាយ អនរិយវោហារ (វោហារមិនប្រសើរ) នេះ មាន ៨ យ៉ាង ដូច្នេះ ។ បញ្ញត្តិ ឈ្មោះថា វោហារ ដូចក្នុងប្រយោគថា **សង្ខា សមញ្ញា បញ្ញត្តិ វោហារោ** *ការរាប់ ការដឹង ដោយប្រពៃ ការតាំង ការនិយាយ... ។ ពាក្យសម្តី ឈ្មោះថា វោហារ ដូចក្នុងប្រយោគជាដើមថា* **វោហារមត្តេន សោ វោហារេយ្យ** *ហើយនិយាយតាមតែវោហារប៉ុណ្ណោះ ។ ក្នុងទីនេះ លោកបំណងយកវោហារ គឺពាក្យសម្តីនោះឯង ។ ពិតហើយ ការពោលចំពោះមុខនៃបុគ្គលខ្លះ រមែងមិនស្មើនឹងពាក្យដែលពោលក្រោយខ្នង ហើយពាក្យដែលពោលក្រោយខ្នង មិនស្មើនឹងពាក្យដែលពោលចំពោះមុខ ពាក្យដែលពោលមុនក៏ដូចគ្នា មិនស្មើនឹងពាក្យដែលពោលក្រោយ និងពាក្យដែលពោលក្រោយក៏មិនស្មើនឹងពាក្យដែលពោលមុន បុគ្គលនោះ កាលពោលនោះឯង បុគ្គលណាម្នាក់ អាចដឹងបានថា បុគ្គលនោះមិនស្អាត ។ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសថា សម្រាប់បុគ្គលដែលមានការស្អាតជាប្រក្រតី បទដែលពោលមុន រមែងសមគ្នានឹងបទដែលពោលក្រោយ ឯបទដែលពោលក្រោយ រមែងសមគ្នានឹងបទដែលពោលមុន បទដែលពោលចំពោះមុខ រមែងសមគ្នានឹងបទដែលពោលទីកំពាំងមុខ បទដែលពោលទីកំពាំងមុខ រមែងសមគ្នានឹងបទដែលពោលចំពោះមុខ ។ ព្រោះដូច្នោះ បុគ្គលដែលពោល ទើបអាចដឹងបានថា បុគ្គលនេះជាបុគ្គលស្អាត ទើបត្រាស់ពាក្យជាដើមថា បពិត្រមហារាជ សេចក្តីស្អាតត្រូវបុគ្គលដឹងបាន ដោយការនិយាយឆ្លើយឆ្លង ដូច្នេះ ។*

បទថា **ថាមោ** បានដល់ កម្លាំងនៃញាណ ។ បុគ្គលដែលមិនមានកម្លាំងនៃញាណ រមែងមិនសម្លឹងឃើញវត្ថុដែលគួរកាន់យក គឺកិច្ចដែលគួរធ្វើក្នុងកាលអន្តរាយកើតឡើង ទើបត្រាច់ទៅ ដូចចូលផ្ទះដែលមិនមានទ្វារ ។ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា បពិត្រមហារាជ កម្លាំងញាណ ត្រូវបុគ្គលដឹងបាន ក្នុងវេលាមានអន្តរាយ ដូច្នេះជាដើម ។

បទថា **សាកច្ឆាយ** ប្រែថា ដោយការសន្ទនា ។ ពិតហើយ ពាក្យនៃបុគ្គលមានបញ្ញាថោកថយ រមែងអណ្តែតទៅ ដូចវូក្នុងទឹក ។ សម្រាប់បុគ្គលមានបញ្ញា កាលពោល រមែងមានបដិភាណ មិនមានទីបំផុត ។ ពិតហើយត្រី គេដឹងបានថា ខ្លួនធំ ឬខ្លួនតូច ក៏ដោយទឹកដែលព្រួចឡើងនោះឯង ។

ដូច្នោះ ព្រះមានព្រះភាគមិនបានត្រាស់ដល់បុគ្គលទាំងនោះ ដល់ព្រះរាជាដោយត្រង់ថា ជនពួកនេះ ... ទើបប្រកាសឧបាយជាហេតុឲ្យដល់នូវព្រះអរហន្ត ឬមិនមែនព្រះអរហន្ត ។ ព្រះរាជាទ្រង់ជ្រាបដូច្នោះហើយ មានការជ្រះថ្លាក្រៃលែងក្នុងព្រះសព្វញ្ញុតញ្ញាណ និងទេសនាវិលាសរបស់ព្រះមានព្រះភាគ ទើបទ្រង់ប្រកាសសេចក្តីជ្រះថ្លារបស់ទ្រង់ ដោយន័យជាដើមថា បពិត្រព្រះអង្គចម្រើន អស្ចារ្យណាស់ ។ ឥឡូវនេះ កាលត្រាស់ប្រាប់មនុស្សទាំងនោះ ដល់ព្រះសាស្តាតាមសេចក្តីពិត ទើបត្រាស់ពាក្យជាដើម បពិត្រព្រះអង្គចម្រើន ពួកបុរសរបស់ខ្ញុំព្រះអង្គទាំងនុ៉ះ ដូចជាចោរ ដូច្នេះ ។

[១៣៤] បណ្តាបទទាំងនោះ បទថា **ចោរា** សេចក្តីថា បុគ្គលដែលមិនបានជាបព្វជិត បរិភោគជុំបាយរបស់អ្នកដែន ដោយរូបភាពរបស់បព្វជិត

ព្រោះជាអ្នកបិទបាំងកម្មអាក្រក់ ។ បទថា **ឧចរកា** ប្រែថា អ្នកស្រីបការ ពិតហើយ ពួកចោរ កាលត្រាច់ទៅតាមកំពូលភ្នំ ក៏ឈ្មោះថា ជាអ្នកស្រីបការ ដូចគ្នា ព្រោះមានកម្មថោកទាប ។ ម្យ៉ាងទៀត បទថា **ឧចរកា** បានដល់ ជាចារបុរស ។ បទថា **ឧចរិត្វា** បានដល់ ត្រាច់ពិចារណា ស្រីបអង្កេត អធិប្បាយថា ដឹងរឿងនោះៗ ក្នុងទីនោះៗ បទថា **ឧសារិស្សាមិ** ប្រែថា នឹងប្រព្រឹត្តទៅ អធិប្បាយថា នឹងធ្វើ ។ បទថា **រជោជល្ជំ** បានដល់ ធូលី និងមន្ទិល ។ បទថា **បវាហេត្វា** បានដល់ កម្ចាត់ គឺជម្រះឲ្យស្អាត ។ បទថា **កប្បិតកេសមស្សុ** បានដល់ ឲ្យជាងកាត់សក់កោរពុកមាត់ តាមវិធី ដែលពោលហើយ ក្នុងអលង្ការសាស្ត្រ ។ បទថា **កាមគុណេហិ** បានដល់ ចំណែកនៃកាម ឬគ្រឿងចង គឺកាម ។ បទថា **សមប្បិតា** បានដល់ ជាប់ ជំពាក់ដោយល្អ ។ បទថា **សមង្គីភូតា** បានដល់ ព្រមព្រៀង ។ បទថា **បរិចារិស្សន្តិ** បានដល់ ឲ្យឥន្ទ្រិយត្រាច់ទៅដោយជុំវិញ ឬនឹងលែង ។

បទថា **ឯតមត្តំ វិធិត្វា** សេចក្តីថា ទ្រង់ជ្រាបសេចក្តីនេះ ពោល គឺការ ដែលរាជបុរសទាំងនោះ ជាអ្នកបោកបញ្ជោតលោក ដោយភេទបព្វជិត ព្រោះ ហេតុនៃផ្ទៃរបស់ខ្លួន ។ បទថា **ឥមំ ឧធានំ** បានដល់ ទ្រង់បន្ទឺឧទាននេះ ដែលប្រកាសដល់ការហាមនូវសេចក្តីខុស និងជាអ្នកបោកបញ្ជោតលោក ។

បណ្តាបទទាំងនោះ បទថា **ន វាយមេយ្យ សព្វត្ត** សេចក្តីថា បព្វជិត មិនគប្បីព្យាយាម គឺមិនគប្បីធ្វើសេចក្តីព្យាយាមខ្ងល់ខ្ងាយ ក្នុងការធ្វើអាក្រក់ ទាំងអស់ មានភាពជាទូត និងការស្រីបអង្កេតជាដើម ដូចរាជបុរសទាំងនេះ

អធិប្បាយថា មិនគប្បីធ្វើសេចក្តីព្យាយាមក្នុងកម្មណាមួយឡើយ គប្បីព្យាយាមចំពោះបុណ្យ សូម្បីមានប្រមាណតិចប៉ុណ្ណោះ ។ បទថា **នាញ្ញស្ស បុរិសោ សិយា** *បានដល់ មិនគប្បីបម្រើអ្នកដទៃដោយរូបភាពបព្វជិត ព្រោះហេតុអ្វី ព្រោះត្រូវធ្វើកម្មអាក្រក់ មានចារបុរសជាដើម ដែលមានសភាពបែបនេះ ។ បទថា* **នាញ្ញំ និស្សាយ ជីវេយ្យ** *បានដល់ ជាអ្នកមិនអាស្រ័យបុគ្គលដទៃ មានឥស្សរជនជាដើម មានការគិតយ៉ាងនេះថា សុខទុក្ខរបស់អញទាក់ទងដោយបុគ្គលនោះ ដូច្នេះហើយ ចិញ្ចឹមជីវិត គឺជាអ្នកមានខ្លួនជាទីពឹង ជាទីអាស្រ័យ កុំមានអ្នកដទៃជាទីពឹង ទីអាស្រ័យឡើយ ។ ម្យ៉ាងទៀត មិនគប្បីអាស្រ័យអកុសលកម្មដទៃចិញ្ចឹមជីវិតឡើយ ព្រោះឈ្មោះថា អ្នកដទៃជាហេតុនាំមកនូវសេចក្តីវិនាស ។ បទថា* **ធម្មេន ន វណ្ណីចរេ** *សេចក្តីថា មិនគប្បីសម្តែងធម៌ដើម្បីទ្រព្យ ។ ព្រោះសម្តែងដល់ជនដទៃ ដោយហេតុនៃទ្រព្យជាដើម រមែងឈ្មោះថា នាំធម៌ទៅលក់ ។ កុំគ្រាចយកធម៌ទៅធ្វើការលក់ដូរយ៉ាងនោះ ។ ម្យ៉ាងទៀត បុគ្គលធ្វើកម្ម មានចារបុរសជាដើម ដូចបុរសរបស់ព្រះបាទកោសល ធ្វើនូវការស៊ើបអង្កេតដើម្បីប្រយោជន៍ដល់ទ្រព្យជាដើម តាំងនៅតាមកិច្ច មានការសមាទានបព្វជ្ជាភេទជាដើម ដោយមិនឲ្យអ្នកដទៃសង្ស័យ ឈ្មោះថា នាំធម៌មកលក់ ។ ឯបុគ្គលណាប្រព្រឹត្តព្រហ្មចរិយៈ បរិសុទ្ធក្នុងសាសនានេះ ក៏ប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីប្រាថ្នាទេវនិកាយណាមួយ បុគ្គលនោះ ក៏ឈ្មោះថា នាំធម៌មកលក់ អធិប្បាយថា មិនគប្បីប្រព្រឹត្ត គឺមិនគប្បីធ្វើការជួញដូរធម៌យ៉ាងនេះ ។*

សុត្តន្តបិដក

អាហុសូត្រ

[១៣៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ កំពុងគង់ពិចារណា ពួកអកុសលធម៌ដ៏លាមកច្រើនប្រការ ដែលទ្រង់លះហើយផង ពួកកុសលធម៌ច្រើនប្រការ ដែលបរិបូណ៌ដោយការចម្រើនផង ។ លុះព្រះមានព្រះភាគជ្រាបពួកអកុសលធម៌ដ៏លាមកច្រើនប្រការ ដែលព្រះអង្គលះហើយផង ពួកកុសលធម៌ច្រើនប្រការ ដែលបរិបូណ៌ដោយការចម្រើនផង ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> ពួកកិលេស មានរាគៈជាដើម ធ្លាប់មានហើយ ក្នុងកាលមុន ពួកកិលេសណាមួយ របស់តថាគត មិនបានមានហើយ ក្នុងខណៈនៃមគ្គញ្ញាណនោះទេ អរិយមគ្គមិនធ្លាប់មានហើយ ក្នុងកាលមុន អរិយមគ្គ ក៏បានមានហើយ ក្នុងកាលណោះ ពួកកិលេស មិនបានមានក្នុងកាល (ជាអតីត) ផង មិនមានក្នុងកាល (ជាអនាគត) ផង មិនមានក្នុងកាលជាបច្ចុប្បន្នផង (ដល់តថាគត) ។
>
> សូត្រទី ៣ ។

អដ្ឋកថា

អាហុសូត្រ

អាហុសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

[១៣៥] *បទថា* **អត្តនោ អនេកេ ចាបកេ អកុសលេ ធម្មេ បហីនេ** *សេចក្តីថា ព្រះមានព្រះភាគទ្រង់ពិចារណាកិលេស ១៥០០ ដែលប្រព្រឹត្តទៅមិនមានខាងដើមក្នុងសន្តានរបស់ទ្រង់ មានលោភៈ ទោសៈ មោហៈ វិបរិតមនសិការ អហិរិកៈ អនោត្តប្បៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ តណ្ហា អវិជ្ជា អកុសលមូល ៣ ទុច្ចរិត ៣ សង្កិលេស ៣ មន្ទិល ៣ វិសមសញ្ញា ៣ វិតក្ក ៣ បបញ្ចៈ ៣ វិបល្លាស ៤ អាសវៈ ៤ ឱឃៈ ៤ យោគៈ ៤ គន្ថៈ ៤ អគតិ ៤ តណ្ហុប្បាទាន ៤ ចេតោខីលៈ ៥ ចេតោវិនិពន្ធៈ ៥ នីវរណៈ ៥ អភិនន្ទនៈ ៥ វិវាទមូល ៦ តណ្ហាកាយ ៦ អនុសយ ៧ មិច្ឆត្តៈ ៨ តណ្ហាមូលកៈ ៩ អកុសលកម្មបថ ១០ ទិដ្ឋិ ៦២ និងតណ្ហាវិបរិត ១០៨ ជាដើម ជាប្រភេទក្តី ធម៌ដែលអាក្រក់លាមកជាអនេក ដែលឈ្មោះថា ជាអកុសល ព្រោះអត្ថថា កើតអំពីការមិនឈ្លាសសូម្បីដែលកើតរួមជាមួយកិលេស ១៥០០ នោះក្តី ដែលទ្រង់លះហើយ គឺលះដាច់ហើយដោយអរិយមគ្គ ត្រង់មណ្ឌលពោធិព្រឹក្សនោះឯង ព្រមដោយវាសនា គឺទ្រង់ពិចារណាតាមលំដាប់បទថា កិលេសនេះ អាត្មាអញលះបានហើយ កិលេសនេះ អញលះបានហើយ ដូច្នេះ ។*

បទថា **អនេកេ ច កុសលេ ធម្មេ** *បានដល់ ទ្រង់គង់ពិចារណាកុសល*

គឺធម៌ដែលមិនមានទោសរបស់ព្រះអង្គជាអនេក មានសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ មគ្គ ៤ ផល ៤ បដិសម្ភិទា ៤ ញាណជាគ្រឿងកំណត់កំណើត ៤ អរិយវង្ស ៤ វេសារជ្ជញ្ញាណ ៤ អង្គជាទីតាំងនៃសេចក្តីព្យាយាម ៥ សម្មាសមាធិមានអង្គ ៥ សម្មាសមាធិដែលប្រកបដោយញាណ ៥ ឥន្ទ្រិយ ៥ ពល ៥ និស្សារណីយធាតុ ៥ វិមុត្តាយតនញ្ញាណ ៥ វិមុត្តិបរិបាចនីយសញ្ញា ៥ អនុស្សតិដ្ឋាន ៦ គារវៈ ៦ និស្សារណីយធាតុ ៦ សត្តវិហារធម៌ ៦ អនុត្តរិយៈ ៦ និព្វេធភាគិយសញ្ញា ៦ អភិញ្ញា ៦ អសាធារណញ្ញាណ ៦ អបរិហានិយធម៌ ៧ អរិយទ្រព្យ ៧ ពោជ្ឈង្គ ៧ សប្បុរិសធម៌ ៧ និជ្ជរវត្ថុ ៧ សញ្ញា ៧ ទក្ខិណេយ្យបុគ្គលទេសនា ៧ ខីណាសវពលទេសនា ៧ បញ្ចាបដិលាភហេតុទេសនា ៨ សម្មត្តៈ ៨ លោកធម្មាតិក្កមៈ ៨ អារព្ភវត្ថុ ៨ អក្ខណទេសនា ៨ មហាបុរិសវិតក្ក ៨ អភិភាយតនទេសនា ៨ វិមោក្ខ ៨ ធម៌ដែលមានយោនិសោមនសិការជាមូល ៩ អង្គនៃធម៌ជាទីតាំងនៃសេចក្តីព្យាយាមដ៏បរិសុទ្ធ ៩ សត្តាវាសទេសនា ៩ អឃាតបដិវិនយទេសនា ៩ សញ្ញា ៩ នានត្ត ៩ អនុបុព្វវិហារ ៩ នាថករណធម៌ ១០ កសិណាយតនៈ ១០ កុសលកម្មបថ ១០ សម្មត្តៈ ១០ អរិយវាស ១០ អសេក្ខធម៌ ១០ តថាគតពល ១០ អានិសង្សនៃមេត្តា ១១ អាការនៃចក្រ ១២ ធុតង្គ ១៣ ពុទ្ធញ្ញាណ ១៤ វិមុត្តិបរិបាចនីយធម៌ ១៥ អានាបានស្សតិ ១៦ អបរន្តបនីយធម៌ ១៦ មហាវិបស្សនា ១៨ ពុទ្ធធម៌ ១៨ បច្ចវេក្ខណញ្ញាណ ១៩

ញាណវត្ថុ ៤៤ ឧទយព្វយញ្ញាណ ៥០ កុសលធម៌ជាង ៥០ ញាណវត្ថុ ៧៧ សមាបត្តិ មហាវជិរញ្ញាណ ២៤០០០០០ កោដិ បច្ចវេក្ខណាទេសនាញាណដែលជាវិស័យនៃសមន្តប្បដ្ឋាន ដែលមានន័យមិនមានទីបំផុត ញាណដែលប្រកាសអធ្យាស្រ័យជាដើមរបស់សត្វទាំងឡាយ ដែលមិនមានទីបំផុតក្នុងលោកធាតុមិនមានទីបំផុត ដូចគ្នានឹងការដល់ហើយ នូវសេចក្តីចម្រើនបរិបូណ៌នៃការបំពេញបារមី និងការចម្រើនមគ្គ អស់កាលមិនមានទីបំផុត ធ្វើពុទ្ធគុណដែលបែរមុខចំពោះមនសិការ ឲ្យជាវគ្គៗ គឺឲ្យជាគំនរៗ ដោយអំណាចព្រះទ័យថា ធម៌ដែលមិនមានទោសទាំងនេះ មាននៅក្នុងព្រះតថាគត ធម៌ដែលមិនមានទោសទាំងនេះ មាននៅក្នុងព្រះតថាគត ។ ធម៌ទាំងនោះអាចមនសិការបាន ដោយមានការសម្តែងនៅសល់នោះឯង មិនអាចមនសិការបានទាំងអស់ ។ ពុទ្ធគុណទាំងអស់ សូម្បីព្រះមានព្រះភាគ ក៏មិនអាចមនសិការតាមលំដាប់បទបានសព្វគ្រប់ ព្រោះជាធម៌មិនមានទីបំផុត មិនមានប្រមាណ សមដូចព្រះតម្រាស់ត្រាស់ថា

> *សូម្បីព្រះពុទ្ធដូចគ្នា ពណ៌នាគុណរបស់ព្រះពុទ្ធដូចគ្នា មិនត្រាស់ធម៌ដទៃ សូម្បីអស់មួយកប្ប កប្បក៏គប្បីអស់ទៅ គុណរបស់ព្រះតថាគតទាំងឡាយ ក៏មិនអស់ឡើយ ។*

និងព្រះតម្រាស់មួយកន្លែងទៀតថា

> *បុគ្គលមិនអាចរាប់ឈ្មោះព្រះមហេសី ដោយព្រះគុណដែលមាន គប្បីលើកព្រះនាមឡើងដោយព្រះគុណ សូម្បីរាប់ពាន់ព្រះនាម ។*

ក្នុងកាលនោះ ព្រះមានព្រះភាគ យាងត្រឡប់អំពីបិណ្ឌបាតខាងក្រោយ ភត្ត ទ្រង់ចូលព្រះវិហារ ប្រថាប់ឈរត្រង់យ៉ាមុខព្រះគន្ធកុដិ កាលកិក្ខុទាំង-ឡាយ សម្តែងវត្ត ហើយចៀសចេញទៅ ទើបយាងចូលមហាគន្ធកុដិ គង់ប្រថាប់លើបវរពុទ្ធាសនៈដែលរៀបចំ ញាណដែលវិស័យនៃអតីតរបស់ព្រះអង្គ ទៅ ។ លំដាប់នោះ អតីតជាតិរបស់ព្រះអង្គមិនមានទីបំផុត ប្រាកដច្បាស់ សព្វកាលមិនមានចន្លោះ ។ ទ្រង់បញ្ជូនញាណចារ ដែលមានកិលេសជា អារម្មណ៍ថា កិលេសទាំងនេះជាមូលនៃខន្ធទុក្ខដ៏ធំកន្ធង ទ្រង់ពិចារណាកិលេស ទាំងនោះតាមលំដាប់ដោយមុខ គឺបហាន កាលពិចារណាអរិយមគ្គ មួយ អន្ទើដោយអាការ និងបរិវាស ព្រមទាំងឧទ្ទេស ដែលធ្វើការលះកិលេស ទាំងនោះទៀតថា កិលេសទាំងនេះហ្ន៎ តថាគតលះបានជាសមុច្ឆេទហើយ ដោយល្អ ទើបទ្រង់ធ្វើក្នុងព្រះហឫទ័យនូវធម៌ដែលមិនមានទោស មានសីល ជាដើមរបស់ព្រះអង្គ ដែលមានប្រភេទមិនមានទីបំផុត ដោយហេតុនោះ ទើប លោកពោលថា សម័យនោះឯង ព្រះមានព្រះភាគ កំពុងគង់ពិចារណាពួក អកុសលធម៌ដ៏លាមកច្រើនប្រការ ដែលទ្រង់លះហើយផង ពួកកុសលធម៌ ច្រើនប្រការ ដែលបរិបូណ៌ដោយការចម្រើនផង ដូច្នេះ ។ កាលទ្រង់ពិចា-រណាយ៉ាងនេះហើយ ទើបទ្រង់បន្ទឺឧទាននេះ ដែលសម្តែងដល់បីតិ និង បាមោជ្ជដែលកើតឡើងហើយ ។

បណ្តាបទទាំងនោះ បទថា **អហុ បុព្វេ** *សេចក្តីថា មុនអំពីកើតអរ-ហត្តមគ្គញ្ញាណ ពួកកិលេស មានរាគៈទាំងអស់នេះជាដើម មានក្នុងសន្តាន*

របស់តថាគតហើយ ក្នុងពួកកិលេសនេះ កិលេសណាមួយ មិនមានក៏មិន មែន ។ បទថា **តធា ឆាហុ** សេចក្តីថា ក្នុងកាលនោះ គឺពេលនោះ បានដល់ ក្នុងខណៈអរិយមគ្គ ពួកកិលេសមិនមាន គឺមិនមានទ្បើយ ។ ក្នុងពួកកិលេសនោះ កិលេសសូម្បីមានប្រមាណតិច ឈ្មោះថា តថាគតមិនទាន់ បានលះក្នុងខណៈអរិយមគ្គ រមែងមិនមាន ។ អាចារ្យពួកខ្ងះពោលថា **តតោ ឆាហុ** ដូច្នេះក៏មាន អធិប្បាយថា បន្ទាប់អំពីខណៈនៃអរិយមគ្គនោះ កិលេសមិនមានទ្បើយ ។ បទថា **ឆាហុ បុព្វេ** សេចក្តីថា ធម៌ដែលមិនមានទោសមិនមានប្រមាណរបស់តថាគតនេះ ឥទ្បូវនេះ តថាគតបានជួបបរិបូណ៌ហើយ ដោយកាវនា ធម៌ដែលមិនមានទោសនោះ ក្នុងកាលមុនអំពីខណៈអរិយមគ្គ មិនមានទ្បើយ ។ បទថា **តធា អហុ** សេចក្តីថា អរហត្តមគ្គញ្ញាណ កើតទ្បើងដល់តថាគតក្នុងកាលណា ក្នុងកាលនោះ ធម៌ដែលមិនមានទោសទាំងអស់ មានហើយដល់តថាគត ។ ពិតហើយ គុណនៃព្រះសព្វញ្ញូទាំងអស់ មួយអន្ទើដោយការសម្រេចអរហត្តមគ្គ រមែងនៅក្នុងកណ្តាប់ដៃរបស់ព្រះពុទ្ធ ទាំងឡាយនោះឯង ។ បទថា **ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ** សេចក្តីថា ធម៌ដែលមិនមានទោស គឺអរិយមគ្គនោះ កើតទ្បើងហើយក្នុងបទេសដែលផូរផង់នៃពោធិញ្ញាណរបស់តថាគត ដែលជាហេតុឲ្យតថាគតលះកិលេសទាំងអស់បានជាសមុច្ចេទ ។ អរិយមគ្គនោះ មុនអំពីខណៈមគ្គ មិនមាន នឹងមិនមានដល់តថាគតទ្បើយ យ៉ាងណា សូម្បីអរិយមគ្គនេះក៏ដូច្នោះ នឹងមិនមាន គឺនឹងមិនកើតក្នុងអនាគត ដូចកិលេសទាំងនោះ ព្រោះមិនមាន

កិលេសដែលខ្ជួនត្រូវលះ សូម្បីក្នុងឥឡូវនេះ គឺក្នុងបច្ចុប្បន្នក៏មិនមាន គឺមិនកើត ព្រោះមិនមានកិច្ចដែលខ្ជួនត្រូវធ្វើ ។ ព្រោះអរិយមគ្គមិនប្រព្រឹត្តទៅច្រើនជង ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា រមែងមិនដល់ត្រើយ ២ ជង ។

គ្រានោះ ព្រះមានព្រះភាគ កាលទ្រង់ពិចារណាដល់អកុសលធម៌ដែលទ្រង់លះបានជាសមុច្ឆេទ ក្នុងសន្តានរបស់ព្រះអង្គ ដោយអរិយមគ្គ និងធម៌ដែលមិនមានទោស មិនមានប្រមាណដែលដល់នូវសេចក្តីបរិសុទ្ធដោយការនា ទើបទ្រង់បន្ទឺឧទានដែលកើតដោយកម្លាំងបីតិ ដែលបង្អោនចូលមកក្នុងខ្ជួន ។ ដោយគាថាដើម ត្រាស់ដល់វេសារជ្ជញ្ញាណខាងដើមទាំង ២ ប៉ុណ្ណោះ វេសារជ្ជញ្ញាណ ២ ខាងក្រោយ ឈ្មោះថា ទ្រង់ប្រកាសហើយនោះឯង ព្រោះប្រកាសដល់សម្មាសម្ពោធិញ្ញាណនោះឯង ៗ

អដ្ឋកថាអាហុសូត្រទី ៣ ចប់

សុត្តន្តបិដក

បឋមកិរិយសូត្រ

[១៣៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកសមណព្រាហ្មណ៍ បរិព្វាជកច្រើនគ្នា អស្រ័យនៅក្នុងក្រុងសាវត្ថី មានលទ្ធិផ្សេងៗ មានទិដ្ឋិផ្សេងៗ មានសេចក្តីគាប់ចិត្តផ្សេងៗ មានសេចក្តីចូលចិត្តផ្សេងៗ អាស្រ័យទិដ្ឋិនិស្សយផ្សេងៗ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកមិនទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកមានទីបំផុត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកមិនមានទីបំផុត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ជីវិតនោះ គឺសរីរៈនោះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ជីវិតដទៃ សរីរៈដទៃ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា សត្វស្លាប់ទៅ កើតទៀត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។

សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា សត្វ ស្លាប់ទៅ មិនកើតទៀត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា សត្វស្លាប់ ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យ សោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មាន ទិដ្ឋិយ៉ាងនេះថា សត្វស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍ ទាំងនោះ មានសេចក្តីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង ចាក់ដោតគ្នានិងគ្នា ដោយលំពែង គឺមាត់ថា យ៉ាងនេះ ធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ មិន មែនធម៌ យ៉ាងនេះធម៌ ។

[១៣៧] *គ្រានោះ ពួកភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ។ លុះត្រាច់ ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាង ក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយ បង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយ ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ ចម្រើន ក្នុងទីឯណោះ ពួកសមណព្រាហ្មណ៍ បរិព្វាជកច្រើនគ្នា អាស្រ័យ នៅក្នុងក្រុងសាវត្ថី មានលទ្ធិផ្សេងៗ មានទិដ្ឋិផ្សេងៗ មានសេចក្តីគាប់ចិត្ត ផ្សេងៗ មានសេចក្តីចូលចិត្តផ្សេងៗ អាស្រ័យទិដ្ឋិនិស្សយផ្សេងៗ ។ សមណ-*

ព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោក ទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោក មិនទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកមានទីបំផុត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកមិនមានទីបំផុត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ជីវិតនោះ គឺសរីរៈនោះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ជីវិតដទៃ សរីរៈដទៃ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា សត្វស្លាប់ទៅកើតទៀត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា សត្វស្លាប់ទៅ មិនកើតទៀត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា សត្វស្លាប់ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា សត្វស្លាប់ទៅ កើតទៀត

ក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះពិត ពាក្យជាទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីប្រកួតប្រកាន់ ជម្លោះទាស់ទែង ចាក់ជោតគ្នានិងគ្នា ដោយលំពែង គឺមាត់ថា យ៉ាងនេះ ធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ ធម៌ ។ ម្នាលភិក្ខុទាំង-ឡាយ ពួកអន្យតិរ្ថិយបរិព្វាជក ដូចជាមនុស្សខ្វាក់ មើលមិនឃើញ មិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈមិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌ ។ អន្យតិរ្ថិយបរិព្វាជកទាំងនោះ កាលបើមិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈមិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌ហើយ ក៏មានសេចក្តីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង ចាក់ជោតគ្នានិងគ្នា ដោយលំពែង គឺមាត់ថា យ៉ាងនេះ ធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះធម៌ ។

[១៣៨] ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ មានព្រះរាជាមួយអង្គក្នុងក្រុងសាវត្ថីនេះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះរាជានោះ ទ្រង់ហៅបុរសម្នាក់មកត្រាស់បង្គាប់ថា នែបុរសដ៏ចម្រើន ចូរអ្នកមកអាយ ចូរអ្នកទៅ ប្រមូលពួកមនុស្សខ្វាក់ពីកំណើត ដែលមានក្នុងក្រុងសាវត្ថីទាំងប៉ុន្មាន ឲ្យមកជួបជុំគ្នាទាំងអស់ ក្នុងទីជាមួយគ្នា ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះទទួលព្រះរាជបញ្ជា របស់ព្រះរាជានោះថា ព្រះករុណាថ្លៃពិសេស ហើយប្រមូលពួកមនុស្សខ្វាក់ពីកំណើត ដែលមានក្នុងក្រុងសាវត្ថីទាំងប៉ុន្មានមកទាំងអស់ ហើយចូលគាល់ព្រះរាជាអង្គនោះ លុះចូលទៅដល់ ក្រាបបង្គំទូលព្រះ

រាជាអង្គនោះថា បពិត្រព្រះសម្មតិទេព ពួកមនុស្សខ្ងាក់ពីកំណើត ដែលមានក្នុងក្រុងសាវត្ថីទាំងប៉ុន្មាន ខ្ញុំព្រះអង្គបានឲ្យមកជួបជុំគ្នាទាំងអស់ហើយ ។ ព្រះរាជាត្រាស់ថា ម្នាលនាយ បើដូច្នោះ ចូរអ្នកបង្ហាញជីរីដល់ពួកមនុស្សខ្ងាក់ពីកំណើត ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះទទួលព្រះរាជបញ្ជារបស់ព្រះរាជានោះថា ព្រះករុណាថ្ងៃវិសេស ហើយក៏បង្ហាញជីរីដល់មនុស្សខ្ងាក់ពីកំណើតទាំងឡាយ គឺបង្ហាញក្បាលជីរីដល់ពួកមនុស្សខ្ងាក់ពីកំណើតខ្ងះថា នែមនុស្សខ្ងាក់ពីកំណើតទាំងឡាយ ជីរីបែបនេះ ។ បង្ហាញត្រចៀកជីរី ដល់ពួកមនុស្សខ្ងាក់អំពីកំណើតខ្ងះថា នែមនុស្សខ្ងាក់ពីកំណើតទាំងឡាយ ជីរីបែបនេះ ។ បង្ហាញភ្ជុកជីរី ដល់ពួកមនុស្សខ្ងាក់ពីកំណើតខ្ងះថា នែមនុស្សខ្ងាក់ពីកំណើតទាំងឡាយ ជីរីបែបនេះ ។ បង្ហាញប្រមោយជីរី ដល់ពួកមនុស្សខ្ងាក់ពីកំណើតខ្ងះថា នែមនុស្សខ្ងាក់ពីកំណើតទាំងឡាយ ជីរីបែបនេះ ។ បង្ហាញខ្ជូនជីរី ដល់ពួកមនុស្សខ្ងាក់ពីកំណើតខ្ងះថា នែមនុស្សខ្ងាក់ពីកំណើតទាំងឡាយ ជីរីបែបនេះ ។ បង្ហាញជើងជីរី ដល់ពួកមនុស្សខ្ងាក់ពីកំណើតខ្ងះថា នែមនុស្សខ្ងាក់ពីកំណើតទាំងឡាយ ជីរីបែបនេះ ។ បង្ហាញខ្នងជីរី ដល់ពួកមនុស្សខ្ងាក់អំពីកំណើតខ្ងះថា នែមនុស្សខ្ងាក់ពីកំណើតទាំងឡាយ ជីរីបែបនេះ ។ បង្ហាញកន្ទុយជីរី ដល់ពួកមនុស្សខ្ងាក់ពីកំណើតខ្ងះថា នែមនុស្សខ្ងាក់ពីកំណើតទាំង-ឡាយ ជីរីបែបនេះ ។ បង្ហាញរោមកន្ទុយជីរី ដល់ពួកមនុស្សខ្ងាក់ពីកំណើតខ្ងះថា នែមនុស្សខ្ងាក់ពីកំណើតទាំងឡាយ ជីរីបែបនេះ ។ ម្នាលភិក្ខុទាំង-ឡាយ លុះបុរសនោះបង្ហាញជីរី ដល់ពួកមនុស្សខ្ងាក់ពីកំណើតរួចហើយ ក៏ចូល

ទៅគាល់ព្រះរាជាអង្គនោះ លុះចូលទៅដល់ ក្រាបបង្គំទូលព្រះរាជាអង្គនោះ ថា បពិត្រព្រះសម្មតិទេព មនុស្សខ្វាក់ពីកំណើតទាំងនោះ បានឃើញដីរ ច្បាស់លាស់ហើយ សូមព្រះអង្គសម្គាល់កាលគួរនឹងស្តេចទៅក្នុងកាលឥឡូវ នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ ឯព្រះរាជាអង្គនោះ ទ្រង់ចូលទៅរកមនុស្ស ខ្វាក់ពីកំណើតទាំងនោះ លុះចូលទៅដល់ ត្រាស់ព្រះរាជឱង្ការទៅនឹងមនុស្ស ខ្វាក់ពីកំណើតទាំងនោះថា នែមនុស្សខ្វាក់ពីកំណើតទាំងឡាយ អ្នកទាំង-ឡាយ បានឃើញដីរហើយឬ ។ ពួកមនុស្សខ្វាក់ពីកំណើត ទ្រើយតបព្រះ រាជឱង្ការថា ព្រះករុណាថ្លៃវិសេស ។ ព្រះរាជាត្រាស់ថា នែមនុស្សខ្វាក់ពី កំណើតទាំងឡាយ អ្នកទាំងឡាយនិយាយថា ដីរ យើងទាំងឡាយបានឃើញ ហើយ តើដីរដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ពីកំណើតណា ដែលបានឃើញក្បាលដីរ មនុស្សទាំងនោះ និយាយយ៉ាងនេះថា បពិត្រព្រះ សម្មតិទេព ដីរនេះដូចក្អម ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ពីកំណើត ណា ដែលបានឃើញស្វឹកត្រចៀកដីរ មនុស្សទាំងនោះ និយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ដីរនេះ ដូចចង្អេរ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្ស ខ្វាក់ពីកំណើតណា ដែលបានឃើញភ្លុកដីរ មនុស្សទាំងនោះ និយាយយ៉ាង នេះថា បពិត្រព្រះសម្មតិទេព ដីរនេះ ដូចផាល ។ ម្នាលភិក្ខុទាំងឡាយ ពួក មនុស្សខ្វាក់ពីកំណើតណា ដែលបានឃើញប្រមោយដីរ មនុស្សទាំងនោះ និយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ដីរនេះ ដូចយាមនង្គ័ល ។ ម្នាល ភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ពីកំណើតណា ដែលបានឃើញខ្នងដីរ មនុស្ស

ទាំងនោះ និយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ជំរីនេះ ដូចដោកស្រូវ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ពីកំណើតណាដែលបានឃើញជើងជំរី មនុស្សទាំងនោះ និយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ជំរីនេះ ដូចសសរ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ពីកំណើតណា ដែលបានឃើញខ្នងជំរី មនុស្សទាំងនោះ និយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ជំរីនេះ ដូចតា្បល់ក្តឿង ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ពីកំណើតណាដែលបានឃើញកន្ទុយជំរី មនុស្សទាំងនោះ និយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ជំរីនេះ ដូចអង្រែ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ពីកំណើតណា ដែលបានឃើញរោមកន្ទុយជំរី មនុស្សទាំងនោះ និយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ជំរីនេះ ដូចអម្បាស ។ មនុស្សខ្វាក់ពីកំណើតទាំងនោះ ក៏ជាល់តប់គ្នានិងគ្នាថា បែបនេះជំរី បែបនេះ មិនមែនជំរីទេ បែបនេះ មិនមែនជំរី បែបនេះ ទើបហៅថា ជំរី ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនោះ មានព្រះរាជហឫទ័យត្រេកអរ ដោយហេតុនោះឯង ម្នាលភិក្ខុទាំង-ឡាយ ពួកអន្យតិ្ថយបរិព្វាជក ដូចជាមនុស្សខ្វាក់មើលមិនឃើញ មិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈមិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌យ៉ាងនេះ កាលបើអន្យតិ្ថយបរិព្វាជកទាំងនោះ មិនស្គាល់ប្រ-យោជន៍ មិនស្គាល់សភាវៈមិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អត្តធម៌ហើយ ក៏មានសេចក្តីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង ចាក់ដោតគ្នានិងគ្នាដោយលំពែង គឺមាត់ថា យ៉ាងនេះ ធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាង

នេះ មិនមែនធម៌ យ៉ាងនេះ ធម៌ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

សមណព្រាហ្មណ៍មួយពួក រមែងជាប់ក្នុងពួកទិដ្ឋិ ដែលឥតខ្វីមសារទាំងនេះ ពួកជនអ្នកឃើញអវយវៈតែមួយៗ ទើបទាស់ទែងជជែកគ្នា ព្រោះអាស្រ័យនូវទិដ្ឋិនិស្សយនោះ ។ សូត្រទី ៤ ។

អដ្ឋកថា

បឋមកិរសូត្រ

បឋមកិរសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

[១៣៦] *ក្នុងបទថា* **នានាតិត្ថិយា សមណាព្រាហ្មណា បរិព្វាជកា** *នេះ មានវិគ្គហៈដូចតទៅនេះ ឈ្មោះថា* **តិត្ថំ** *ព្រោះជាហេតុឆ្លងឱឃសង្សារបានដល់ ផ្លូវជាទីទៅកាន់ព្រះនិព្វាន ។ តែក្នុងទីនេះទិដ្ឋិទស្សនៈ (ការឃើញគឺទិដ្ឋិ) ដែលពួកបុគ្គលមានទិដ្ឋិប្រកាន់ជាគតិ ដូច្នោះ ដោយវិបល្លាសដែលខុសប្លែក លោកបំណងយកថាជា* **តិត្ថំ** ។ *បុគ្គលប្រកបក្នុង* **តិត្ថំ** *មានអាការផ្សេងៗ មានការទៀងជាដើមនោះ ឈ្មោះថា* **នានាតិត្ថិយា** ។ *សមណៈអាក្រោត និងនិគ្គណ្ឋជាដើម មានកថកលាបព្រាហ្មណ៍ជាដើម និងបរិព្វាជកឈ្មោះបោក្ខរសាតិជាដើម ឈ្មោះថា សមណព្រាហ្មណ៍ និងបរិព្វាជក ។ សមណព្រាហ្មណ៍ និងបរិព្វាជកទាំងនោះ ដែលប្រកបក្នុង* **តិត្ថំ** *ផ្សេងៗ ដូច*

គ្នា ។ ឈ្មោះថា ទិដ្ឋិ ព្រោះជាគ្រឿងឃើញ ដោយនយជាដើមថា អត្តា ឬលោកទៀង ទិដ្ឋិនោះ រមែងឃើញឯង ទិដ្ឋិនោះ ត្រឹមតែការឃើញច្បាស់ ប៉ុណ្ណោះ ។ ពាក្យថា **និដ្ឋិ** *នេះ ជាឈ្មោះនៃការប្រកាន់ខុស ។ ទិដ្ឋិផ្សេងៗ មានច្រើនជាអនេក ដោយឃើញថា ទៀងជាដើមរបស់ជនទាំងនោះ មានហេតុនោះ ជនទាំងនោះ ឈ្មោះថា* **នានានិដ្ឋិកា** ។ *ការពេញចិត្តដោយឃើញថា ទៀងជាដើម ឈ្មោះថា* **ខន្តិ** *ការពេញចិត្ត ឈ្មោះថា* **រុចិ** *ដោយអត្ត បានដល់ ចិត្តវិបល្លាស និងសញ្ញាវិបល្លាស ដែលប្រព្រឹត្តទៅដោយនយជាដើមថា អត្តា និងលោក ទៀង ការពេញចិត្តផ្សេងៗ ដូច្នោះ នៃជនទាំងនោះ មានហេតុនោះ ទើបជនទាំងនោះ ឈ្មោះថា* **នានាខន្តិកា** ។ *ការពេញចិត្តរបស់ជនទាំងនោះ មានហេតុនោះ ជនទាំងនោះ មានឈ្មោះថា* **នានារុចិកា** ។ *ពិតហើយ ក្នុងចំណែកខាងដើម បុគ្គលដែលមានទិដ្ឋិជាគតិ រមែងធ្វើចិត្តឲ្យត្រេកអរ និងឲ្យពេញចិត្តដោយប្រការនោះ ខាងក្រោយប្រកាន់ថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទេ ។ ម្យ៉ាងទៀត ទិដ្ឋិ ពោលដោយការឃើញ ឈ្មោះថា* **ខន្តិ** *ពោលដោយការពេញចិត្ត ឈ្មោះថា* **រុចិ** *ដោយប្រការនោះៗ ដោយនយជាដើមថា លោកមិនទៀង លោកទៀង ។ ដោយបទទាំង ៣ ដូចពោលមកនេះ ទិដ្ឋិប៉ុណ្ណោះគប្បីជ្រាបអត្ថថា លោកពោលហើយ ។ បទថា* **នានានិដ្ឋិនិស្សយនិស្សិតា** *សេចក្តីថា អាស្រ័យ គឺជិតស្និទ្ធ ចូលដល់ទីអាស្រ័យ គឺទីតាំង បានដល់ ហេតុនៃទិដ្ឋិ មានប្រការផ្សេងៗ ដោយកំណត់ថា ទៀងជាដើម ឬទីអាស្រ័យ ពោល គឺទិដ្ឋិនោះឯង អធិប្បាយថា មិនលះ*

ទិដ្ឋិនោះតាំងនៅ ។ ព្រោះថា ទិដ្ឋិទាំងឡាយជាទីអាស្រ័យនៃការប្រកាន់របស់ពួកជន ដែលមានទិដ្ឋិជាគតិ ។

បទថា **សន្តិ** *ប្រែថា មាន គឺមានព្រម បានដល់ កើត ។ បទថា* **ឯកេ** *បានដល់ ពួកខ្លះ ។ បទថា* **សមណាព្រាហ្មណា** *សេចក្តីថា លោកកាន់យកយ៉ាងនេះ ឈ្មោះថា សមណៈ ព្រោះចូលដល់ការបួស ឈ្មោះថា ព្រាហ្មណ៍ ព្រោះជាតិកំណើត ។ ម្យ៉ាងទៀត បុគ្គលដែលសត្វលោកកាន់យកយ៉ាងនេះថា សមណៈ និងថា ព្រាហ្មណ៍ ។ បទថា* **ឯវំវាទិនោ** *បានដល់ បុគ្គលមានវាទៈយ៉ាងនេះថា បុគ្គលពោលយ៉ាងនេះ គឺដោយអាការដែលគប្បីពោលក្នុងឥទ្ធវារនេះ ។ ឈ្មោះថា* **ឯវំទិដ្ឋិនោ** *ព្រោះបុគ្គលទាំងនោះ មានទិដ្ឋិប្រព្រឹត្តទៅយ៉ាងនោះ គឺដោយអាការដែលគប្បីពោលក្នុងឥទ្ធវារនេះ ។ ក្នុងបទទាំងនោះ ដោយបទទី ២ លោកសម្តែងដល់ការកាន់យកខុសរបស់បុគ្គលដែលមានទិដ្ឋិជាគតិ ។ ដោយបទទី ១ លោកសម្តែងដល់ការពោលដោយឲ្យអ្នកជំទៃតាំងនៅក្នុងទិដ្ឋិនោះ តាមការប្រកាន់របស់ជនទាំងនោះ ។ បទថា* **លោកោ** *ក្នុងបទថា* **សស្សតោ លោកោ ឥទមេវ សច្চំ មោឃមញ្ញំ** *នេះ ជាអត្តា ។ ពិតហើយ អត្តានោះ លោកចំណាងយកថាជាលោក ព្រោះជាទីដែលបុគ្គលមានទិដ្ឋិជាគតិ ឃើញនូវបុណ្យបាប និងវិបាករបស់បុណ្យបាបនោះ ឬថា បុគ្គលប្រកបដោយភាពជាអ្នកធ្វើ រមែងឃើញឯង អធិប្បាយថា ការឃើញរបស់ពួកយើង ដែលថា លោកនេះទៀង មិនស្ងាប់ មាំទាំ ស្ថិតស្ថេរ នេះឯងជារបស់ពិត គឺមិនប្រែប្រួល ឯការឃើញដទៃថា លោកមិនទៀងជាដើម*

ទទេ គឺឧស ។ ដោយពាក្យនេះ ឈ្មោះថា លោកសម្តែងសស្សតវាទទាំង ៤ ។ បទថា **អសស្សតោ** ប្រែថា មិនទៀង អធិប្បាយថា មិនទៀង មិនស្ថិតស្ថេរ មានចុតិជាធម៌ ។ ដោយបទថា **អសស្សតោ** នេះ លោកសម្តែងឧច្ឆេទទិដ្ឋិ គឺការយើញថាដាច់សូន្យ ដោយបដិសេធភាវៈដែលលោកទៀងនោះឯង ព្រោះហេតុនោះ រមែងឈ្មោះថា សម្តែងឧច្ឆេទវាទទាំង ៧ ។ បទថា **អន្តវា** បានដល់ មានទីបំផុតវិលទៅដោយជុំវិញ មានប្រមាណកំណត់បាន អធិប្បាយថា មិនទៅរហូត ។ ដោយពាក្យនេះ ឈ្មោះថា លោកសម្តែងវាទៈ ដូចជាអត្តាមានសរីរៈជាប្រមាណ មានម្រាមមេដៃជាប្រមាណ មានអវយវៈជាប្រមាណ មានបរមាណុជាប្រមាណ ។ បទថា **អនន្តវា** ប្រែថា មិនមានទីបំផុត អធិប្បាយថា ទៅបានរហូត ។ ដោយពាក្យថា **អនន្តវា** នេះ ជាការសម្តែងវាទៈរបស់កបិលកាណព្រាហ្មណ៍ជាដើម ។

ដោយបទថា **តំ ជីវំ តំ សរីរំ** នេះ សមណៈ ឬព្រាហ្មណ៍ រមែងពិចារណាយើញជីវៈ និងសរីរៈ មិនជាគូគ្នាថា សរីរៈនោះឯង ជាវត្ថុ ពោលគឺ ជីវៈ វត្ថុ ពោល គឺជីវៈនោះឯង ជាសរីរៈ ។ ដោយបទនេះ ឈ្មោះថា លោកសម្តែងវាទៈនេះថា អត្តាដែលមានរូប ដូចវាទៈរបស់អាជីវក ។ ដោយបទថា **អញ្ញំ ជីវំ អញ្ញំ សរីរំ** នេះ លោកសម្តែងវាទៈថា អត្តាមិនមានរូប ។ បទថា **តថាគតោ** ក្នុងបទថា **ហោតិ តថាគតោ បរម្មរណា** នេះ បានដល់អត្តា ។ ពិតហើយ អត្តានោះ ទិដ្ឋិគតិកបុគ្គល ពោលថា តថាគត ព្រោះដល់នូវភាវៈដែលប្រព្រឹត្តទៅយ៉ាងនោះ ពោល គឺដែលធ្វើ និងដែលសោយ

ជាដើម ឬពោល គឺទៀង និងស្ថិតស្ថេរជាដើម អធិប្បាយថា ក្នុងទីនេះ អត្តានោះខាងមុខ គឺខាងក្រោយអំពីសេចក្តីស្លាប់ ព្រោះកាយបែកធ្លាយ រមែងមាន គឺមានប្រាកដ ។ ដោយពាក្យនេះ ដែលមានសស្សតវាទជាប្រធាន ឈ្មោះថា លោកសម្តែងសញ្ញីវាទ ១៦ អសញ្ញីវាទ ៨ និងនេវសញ្ញីនាសញ្ញីវាទ ៨ ។ បទថា **ន ហោតិ** *បានដល់ មិនមាន គឺមិនកើត ។ ដោយពាក្យនេះ លោកសម្តែងឧច្ឆេទវាទ ។ បទថា* **ហោតិ ច ន ច ហោតិ** *ប្រែថា មាន និងមិនមាន ។ ដោយពាក្យនេះ ឈ្មោះថា លោកសម្តែងសស្សតវាទណាមួយ និងអសញ្ញីវាទ ៧ ។ ដោយបទថា* **នេវ ហោតិ ន ន ហោតិ** *នេះ គប្បីជ្រាបថា លោកសម្តែងវាទៈបោះពាក្យ បោះសម្តី មិនឲ្យស្ងាប់ខ្លួន បានឮថា ទិដ្ឋិគតិកបុគ្គលទាំងនេះ មកអំពីទឹកដីផ្សេងៗ អាស្រ័យនៅក្នុងក្រុងសាវត្ថី គ្រាមួយ ប្រជុំគ្នាក្នុងទីប្រជុំ សម្តែងលទ្ធិ លើកតម្កើងវាទៈរបស់ខ្លួន សង្កត់សង្កិនវាទៈរបស់អ្នកដទៃ បានញុំាងវិវាទដល់គ្នានិងគ្នា ។ ដោយហេតុនោះ ទើបលោកពោលថា* **តេ ភណ្ឌនជាតា** *ដូច្នេះជាដើម ។*

ក្នុងវាទៈទាំងនោះ ចំណែកខាងដើមនៃជម្លោះ ឈ្មោះថា **ភណ្ឌន ។** *បទថា* **ភណ្ឌនជាតា** *ប្រែថា មានសេចក្តីប្រកួតប្រកាន់ ។ ការទាស់ទែងនោះឯង ឈ្មោះថា* **កលហៈ ។** *ម្យ៉ាងទៀត គប្បីឃើញការទាស់ទែង ព្រោះកម្ចាត់សំឡេងតិច ។ ឈ្មោះថា* **វិវាទាបន្នា** *ព្រោះដល់នូវវាទៈដែលខុសគ្នានិងគ្នា ។ លំពែង គឺមាត់ ព្រោះប៉ះខ្លប់ ទាំងសេចក្តីស្រឡាញ់ ព្រោះដូច្នោះ ទើបឈ្មោះថា* **មុខសត្តិ** *បានដល់ ផរុសវាចា ។ ពិតហើយ ហេតុ លោក*

ពោលថា ផលក៏មាន ព្រោះជិតគ្នានឹងហេតុ ដូចជិតគ្នានឹងផល ដែលលោកពោលថា ការកើតទ្បើងនៃព្រះពុទ្ធ នាំមកនូវសេចក្តីសុខ និងថា កម្មអាក្រក់ប្រាកដច្បាស់ ។ ចាក់ដោតដោយលំពែង គឺមាត់ទាំងនោះ ។ បទថា **ឯតិសោ ធម្មោ** *បានដល់ ធម៌ គឺសភាវៈដែលមិនខុស ដូច្នេះ គឺបែបនេះ ដូចខ្ញុំពោលថា លោកទៀង ។ បទថា* **នេតិសោ ធម្មោ** *បានដល់ ធម៌បែបនេះមិនមាន ។ ដូចលោកពោលថា លោកមិនទៀង ។ ដោយបទដ៏សេស គប្បីប្រកបយ៉ាងនេះ ។ វាទៈនៃពួកតិរ្ថិយនោះកើតប្រាកដពេញនគរ ។*

លំដាប់នោះ ភិក្ខុទាំងឡាយ ចូលទៅបិណ្ឌបាត កាន់ក្រុងសាវត្ថី បានស្តាប់ដូច្នោះ ទើបគិតថា មូលនៃពាក្យនេះមាន បើដូច្នោះ អាត្មាអញគប្បីក្រាបទូលរឿងនេះដល់ព្រះមានព្រះភាគ ធ្វើម្តេចហ្ន៎ អញគប្បីបានព្រះធម្មទេសនាដ៏សុខុមព្រោះអាស្រ័យរឿងនេះ ភិក្ខុទាំងនោះក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគក្នុងពេលសម្តែងធម៌ខាងក្រោយភត្ត ។ ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ សម្ពហុលា ភិក្ខូ** *ដូច្នេះជាដើម ព្រះមានព្រះភាគ កាលទ្រង់ស្តាប់ដូច្នេះហើយ កាលទ្រង់ប្រកាសការដែលពួកតិរ្ថិយមិនដឹងធម៌ តាមសេចក្តីពិត ទើបត្រាស់ថា* **អញ្ញតិត្ថិយា ភិក្ខវេ** *ដូច្នេះជាដើម ។*

[๑๓๘] *បណ្តាបទទាំងនោះ បទថា* **អន្ធា** *សេចក្តីថា ឈ្មោះថាបុគ្គលខ្វាក់ ព្រោះវៀរបញ្ញាចក្ខុ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា* **អចក្ខុកា** *ពិតហើយ បញ្ញាលោកហៅថា ចក្ខុក្នុងទីនេះ ពិតហើយ ទើបទ្រង់ត្រាស់ថា* **អត្តំ ន ជានន្តិ** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **អត្តំ ន ជានន្តិ**

សេចក្តីថា មិនដឹងប្រយោជន៍លោកនេះ និងប្រយោជន៍លោកខាងមុខ គឺមិនឈមចុះកាន់សេចក្តីចម្រើន លុតលាស់ក្នុងលោកនេះ និងលោកខាងមុខ នឹងពោលថ្វីដល់បរមត្ថប្រយោជន៍ គឺព្រះនិព្វាននោះ ។ ពិតហើយ ធម្មតាបុគ្គលវង្វេងក្នុងហេតុត្រឹមតែបវត្តិ គឺទុក្ខ និងជឹងនិវត្តិ គឺនិរោធបានដូចម្តេច ។ បទថា **អនត្ថំ ន ជានន្តិ** *សេចក្តីថា ជនទាំងនោះ រមែងដឹងប្រយោជន៍ដោយចំណែកណា រមែងមិនដឹងវត្ថុមិនជាប្រយោជន៍ចំណែកនោះ ព្រោះមិនដឹងធម៌ដូច្នោះ សូម្បីធម៌ក៏មិនដឹង ពិតហើយ ព្រោះការកាន់យកការស្វែងរកខុស ជនទាំងនោះ រមែងធ្វើកុសលធម៌ឲ្យជាអកុសលធម៌ខ្លះ ធ្វើអកុសលធម៌ឲ្យជាកុសលធម៌ខ្លះ ។ មិនមែនវង្វេងតែក្នុងធម៌ និងអធម៌តែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត សូម្បីក្នុងវិបាកនៃធម៌ និងអធម៌ ក៏វង្វេង ។ ពិតហើយ បុគ្គលទាំងនោះ សូម្បីកម្មក៏គង់ពោលឲ្យជាវិបាក សូម្បីវិបាកក៏ពោលឲ្យជាកម្ម ម្យ៉ាងទៀត រមែងមិនដឹងធម៌ គឺសភាវធម៌ខ្លះ រមែងមិនដឹងអធម៌ គឺមិនមែនសភាវធម៌ខ្លះ ។ បុគ្គលបែបនោះ រមែងប្រកាសសភាវធម៌ឲ្យជាអសភាវធម៌ និងប្រកាសអសភាវធម៌ ឲ្យជាសភាវធម៌ ។*

ព្រះមានព្រះភាគ កាលទ្រង់ប្រកាសថា តិរិយទាំងនោះដូចបុគ្គលខ្វាក់ ព្រោះខ្វះបញ្ញាចក្ខុ ដោយបានចំពោះនូវមោហៈ និងទិដ្ឋិ ដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីប្រកាសសេចក្តីនោះដោយឧបមា ដូចមនុស្សខ្វាក់អំពីកំណើត ទើបត្រាស់ថា **ភូតបុព្វំ ភិក្ខវេ** *ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា* **ភូតបុព្វំ** *បានដល់ មានហើយក្នុងកាលមុន គឺកើតហើយក្នុងអតីត-*

កាល ។ បទថា **អញ្ញតរោ រាជា អហោសិ** *សេចក្តីថា កាលមុន មានព្រះរាជាមួយអង្គ មិនប្រាកដនាម និងគោត្រក្នុងលោក ។ បទថា* **សោ រាជា អញ្ញតរំ បុរិសំ អាមន្តេសិ** *សេចក្តីថា បានឮថា ព្រះរាជាអង្គនោះ កាលទ្រង់ទតឃើញជំរឿរបស់ព្រះអង្គល្អក្រៃលែង មានរាងកាយបរិបូណ៌ មកកាន់ទីបម្រើ ទើបមានព្រះតម្រិះថា អ្នកដ៏ចម្រើន យាន គឺជំរឿដ៏ប្រសើរ គួរសរសើរហ្ន៎ ។ សម័យនោះ មនុស្សខ្វាក់អំពីកំណើតម្នាក់ ដើរមកតាមលានព្រះរាជវាំង ។ ព្រះរាជាទ្រង់ឃើញដូច្នោះ ទើបទ្រង់ព្រះតម្រិះថា មនុស្សខ្វាក់ទាំងនេះ មានសេចក្តីវិនាសយ៉ាងក្រៃលែង ដែលមិនបានឃើញជំរឿដ៏ប្រសើរបែបនេះ បើដូច្នោះ អញនឹងឲ្យមនុស្សខ្វាក់អំពីកំណើតដែលមានទាំងអស់ប្រជុំគ្នាក្នុងក្រុងសាវត្ថីនេះ ឲ្យយកដៃចាប់ម្នាក់មួយចំណែកៗ ហើយគប្បីស្តាប់ពាក្យរបស់មនុស្សខ្វាក់ទាំងនោះ ។ ព្រះរាជាមានព្រះហឫទ័យក្នុងការលេង ទើបបញ្ជាឲ្យរាជបុរសម្នាក់ ប្រជុំមនុស្សខ្វាក់ទាំងអស់ក្នុងក្រុងសាវត្ថី ហើយបានឲ្យសញ្ញាដល់រាជបុរសនោះថា អ្នកចូរធ្វើមនុស្សខ្វាក់ម្នាក់ៗ ពាល់ត្រូវអវយវៈរបស់ជំរឿមួយចំណែកៗ មានក្បាលជាដើម ហើយឲ្យកើតសញ្ញាឡើងថា ខ្ញុំឃើញជំរឿហើយ ។ រាជបុរសបានធ្វើយ៉ាងនោះ ។ គ្រានោះ ព្រះរាជាត្រាស់សួរមនុស្សខ្វាក់ទាំងនោះ ម្តងម្នាក់ៗ ថា នែអ្នក ជំរឿដូចម្តេច ។ មនុស្សខ្វាក់ទាំងនោះក្រាបទូលដល់អវយវៈ ដែលខ្លួនឃើញហើយថាជាជំរឿ ទើបបង្ហូរដៃម្ខាងថា ជំរឿដូច្នេះ ជំរឿមិនមែនដូច្នេះទេ យកដៃជាដើមប្រវាយប្រតប់គ្នាធ្វើកោលាហលយ៉ាងធំ ក្នុងលានព្រះរាជវាំង ឯព្រះរាជាមួយអន្ទៅដោយរាជ-

បរិវារ បានទតឃើញប្រការចម្លែកនោះរបស់មនុស្សខ្វាក់ទាំងនោះ មានផាសុក មានព្រះហឫទ័យរីករាយ ទ្រង់សើច ។ ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ ភិក្ខវេ សោ រាជា ។បេ។ អត្តមនោ អហោសិ** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **អម្ភោ** *ជាអាលបនៈ ។ បទថា* **យាវតិកា** *ប្រែថា មានប្រមាណប៉ុនណា ។ បទថា* **ជច្ចន្ធា** *ប្រែថា មនុស្សខ្វាក់អំពីកំណើត គឺមិនមានចក្ខុបសាទតាំងអំពីកំណើត ។ បទថា* **ឯកជ្ឈំ** *ប្រែថា ដូចគ្នាតែមួយ ។ បទថា* **ភណេ** *ជាការពោលដោយមិនរាប់អានច្រើន ។ បទថា* **ហត្ថី ឧស្សេហិ** *សេចក្តីថា ចូរសម្តែងដោយឲ្យដឹងដែលពោល ហើយដេក ។ ដំរីនោះដេកដោយមិនរើបម្រះ ព្រោះសិក្សាមកល្អហើយ ។*

ដោយបទថា **ឯដ្ឋោ នោ ហត្ថី** *មនុស្សខ្វាក់ពោលដោយយកដៃចាប់ពាល់ ដូចឃើញដោយភ្នែក ។ បុរសនោះ ឲ្យមនុស្សខ្វាក់ចាប់ក្បាល ព្រោះឲ្យដឹងថា ដំរីដូច្នេះ មនុស្សខ្វាក់អំពីកំណើត ដឹងថា ដំរីដូច្នោះឯង ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ដំរីនេះដូចក្អម ។ អត្ថនៃបទថា* **កុម្ភោ** *ប្រែថា ក្អម ។ បទថា* **ទីឃោ**[1] *បានដល់ តម្កល់សម្រាប់ព្យួរដែលធ្វើដោយភ្លុកដំរី ។ បទថា* **សោណ្ឌោ** *បានដល់ ប្រមោយ ។ បទថា* **ឧឡ្លិសា** *បានដល់ យាមនង្គ័ល ។ បទថា* **កាយោ** *បានដល់ ឆ្អឹងជំនីរ ។ បទថា* **កោដ្ឋោ** *ប្រែថា ដោកស្រូវ ។ បទថា* **ថាឧោ** *ប្រែថា ជើង ។ បទថា* **ថូណោ** *ប្រែថា សសរ ។ បទថា* **ឧត្តុដ្ឋំ** *បានដល់ ចំណែកខាងលើរបស់កន្ទុយ ។*

-១ បិដកខ្មែរជា ផាណោ ។

បទថា **វាលធិ** *បានដល់ ចំណែកខាងចុងនៃកន្ទុយ ។ បទថា* **មុដ្ឋីហិ សំសុម្ភីសុ** *បានដល់ ប្រើកណ្តាប់ដៃ គឺដាល់គ្នា ។ បទថា* **អត្តមនោ អហោសិ** *សេចក្តីថា ព្រោះទ្រង់មានប្រក្រតីលេង ។ ព្រះរាជានោះ ទ្រង់ពេញព្រះហឫទ័យ គឺមានការសប្បាយព្រះហឫទ័យ ព្រោះការឈ្លោះគ្នារបស់មនុស្សខ្វាក់អំពីកំណើតនោះ ។*

បទថា **ឱវមេវ ខោ** *ជាការប្រៀបធៀបដោយឧបមា ។ ការប្រៀបធៀបដោយឧបមានោះ មានអត្ថដូចតទៅនេះ ម្នាលភិក្ខុទាំងឡាយ មនុស្សខ្វាក់អំពីកំណើតទាំងនោះ មិនមានចក្ខុបសាទ ឃើញដោយចំណែក មិនឃើញដីរដោយចំណែកសព្វគ្រប់ កាលមិនដឹងវត្ថុដែលអ្នកដទៃឃើញ ដោយសម្គាល់ថា ដីរដូចអវយវៈដែលខ្លួនឃើញ ក៏ដល់នូវការឈ្លោះទាស់ទែងគ្នា យ៉ាងណា តិរ្ថិយទាំងនេះ ក៏ដូច្នោះដូចគ្នា សម្គាល់រូប វេទនាជាដើម ដែលជាចំណែកមួយនៃកាយរបស់ខ្លួន តាមដែលឃើញដោយទិដ្ឋិទស្សនៈរបស់ខ្លួនថា ជាអត្តា លើកទ្បើងកាន់ការៈថា ខ្លួននោះទៀងជាដើម ទើបទាស់ទែងគ្នា ដោយប្រកាន់ថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃមិនពិត ។ តែមិនដឹងដល់វត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ វត្ថុដែលជាធម៌ និងមិនជាធម៌តាមសេចក្តីពិត ព្រោះដូច្នោះ ទើបជាមនុស្សខ្វាក់មិនមានចក្ខុបសាទ មានចំណែកប្រៀបដូចមនុស្សខ្វាក់អំពីកំណើត ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួង ដល់នូវការដែលពួកតិរ្ថិយមិនដឹង មិនឃើញសភាវធម៌តាមសេចក្តីពិត ប្រកាន់ខុស*

តាមដែលឃើញ ដូចមនុស្សខ្វាក់អំពីកំណើតស្ទាបដំរី ដូច្នោះ និងដល់នូវការ វិវាទគ្នាក្នុងការដែលប្រកាន់ខុសនោះ ទើបទ្រង់បន្ទឺឧទាននេះ ដើម្បីសម្តែង សេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **ឥមេសុ កិរ សជ្ជន្តិ ឯកេ សមណ-ព្រាហ្មណា** *លោកសម្តែងថា បានឮថា បុគ្គលពួកខ្លះ ក្នុងលោកនេះ ឈ្មោះថា សមណៈ ព្រោះចូលដល់បព្វជ្ជា ឈ្មោះថា ព្រាហ្មណ៍ ព្រោះហេតុត្រឹមតែជាតិ រមែងជាប់ជំពាក់ដោយទន្ទឹយជាដើមថា នេះជារបស់អញ ដោយការត្រេកអរក្នុងទិដ្ឋិ ក្នុងទិដ្ឋិដែលមិនជាសារៈទាំងនេះប៉ុណ្ណោះ ដែលប្រព្រឹត្តទៅដោយទន្ទឹយជាដើមថា លោកទៀងជាដើម ឬដោយការត្រេកអរក្នុងតណ្ហា និងការត្រេកអរក្នុងទិដ្ឋិ ក្នុងឧបាទានក្ខន្ធ មានរូបជាដើម ដែលមិនទៀង ជាទុក្ខ មានការប្រែប្រួលទៅជាធម្មតាយ៉ាងនេះ គួរសង្វេគ ជនទាំងនេះមានការវង្វេង ។* **កិរ** *សព្ទ ក្នុងពាក្យថា* **ឥមេសុ កិរ ។បេ។ សជ្ជន្តិ** *នេះ ជាអរុចិសូចនត្ថៈ ឆ្លុះបញ្ចាំងនូវការមិនពេញចិត្ត ។ ដោយពាក្យនោះ ទ្រង់សម្តែងដល់ការមិនមានហេតុ ទាក់ទងក្នុងសេចក្តីនោះឯង មិនមែនជាប់ជំពាក់តែម្យ៉ាងប៉ុណ្ណោះ ដោយពិត ប្រកាន់ខុសនូវទិដ្ឋិនិស្សយនោះ គឺប្រណាំងប្រជែង បានដល់ វិវាទនូវគ្នានិងគ្នា ដោយការប្រកបតាមពាក្យដែលខុស ដោយទន្ទឹយជាដើមថា អ្នកមិនជ្ជឹងទូទៅដល់ធម្មវិន័យនេះទេ ខ្ញុំជ្ជឹងទូទៅដល់ធម្មវិន័យនេះ ។ បទថា* **ឆំ** *ក្នុងទីនេះ ត្រឹមតែជានិបាត ។ ម្យ៉ាងទៀត បទថា* **វិគ្គយ្ហ ឆំ** *សេចក្តីថា កាន់យកនូវទិដ្ឋិនិស្សយ ឬសក្កាយទិដ្ឋិនោះឯងឲ្យខុសគ្នានិងគ្នា ហើយវិវាទគ្នា*

គឺពោលឲ្យប្លែកចេញទៅ ដោយយើញថា ទៀងជាដើម ព្រោះមានការយើញ ខុសគ្នា គឺពោលកាន់យកតែវាទៈរបស់ខ្លួនប៉ុណ្ណោះឲ្យវិសេស គឺមិនឲ្យខុស ដូចអ្វី ដូចជនទាំងឡាយដែលយើញដោយចំណែកមួយ ។ អធិប្បាយថា មនុស្សខ្វាក់អំពីកំណើតទាំងនោះ យើញតែចំណែកនីមួយនៃដំរី ប្រកាន់ថា វត្ថុដែលខ្លួនពាល់ត្រូវនោះឯង គឺដំរី ទើបប្រកែកប្រណាំងគ្នា យ៉ាងណា ពាក្យឧបមេយ្យដែលញ្ចុាំងឧបមាឲ្យដល់ព្រមនេះក៏ដូច្នោះ ។ **៥៨** សពូ ក្នុង គាថានោះ គប្បីជ្រាបថា លោកសម្តែងថា លុបទៅហើយ ។

អដ្ឋកថាបឋមកិរសូត្រទី ៤ ចប់

សុត្តន្តបិដក

ទុតិយកិរសូត្រ

[១៣៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យ នោះឯង ពួកសមណព្រាហ្មណ៍ បរិព្វាជក ច្រើនគ្នា អាស្រ័យនៅក្នុងក្រុង សាវត្ថី មានលទ្ធិផ្សេងៗ មានទិដ្ឋិផ្សេងៗ មានសេចក្តីគាប់ចិត្តផ្សេងៗ មាន សេចក្តីចូលចិត្តផ្សេងៗ អាស្រ័យទិដ្ឋិនិស្សយផ្សេងៗ ។ សមណព្រាហ្មណ៍ មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយ

ពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មិនទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ទៀងខ្លះ មិនទៀងខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណ-ព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ទៀងក៏មិនមែន មិនទៀងក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ធ្វើដោយខ្លួនឯង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី អ្នកដទៃធ្វើ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ធ្វើដោយខ្លួនឯងខ្លះ អ្នកដទៃធ្វើខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ធ្វើដោយខ្លួនឯងក៏មិនមែន អ្នកដទៃធ្វើក៏មិនមែន អាស្រ័យបច្ចយកើតឡើង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ មិន

ទៀងទេ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណ-ព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ទៀងខ្លះ មិនទៀងខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ទៀងក៏មិនមែន មិនទៀងក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណ-ព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ធ្វើដោយខ្លួនឯង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ព្រោះអ្នកដទៃធ្វើ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ធ្វើដោយខ្លួនឯងខ្លះ អ្នកដទៃធ្វើខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ធ្វើដោយខ្លួនឯងក៏មិនមែន អ្នកដទៃធ្វើក៏មិនមែន អាស្រ័យបច្ច័យកើតឡើង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង ចាក់ដោតគ្នានិងគ្នា ដោយលំពែង គឺមាត់ថា យ៉ាងនេះ ធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ ធម៌ ។

[១៤០] *គ្រានោះ ពួកភិក្ខុច្រើនរូប ស្បៀកស្បង់ប្រដាប់បាត្រចីវរក្នុង វេលាបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ។ លុះភិក្ខុ ទាំងនោះ ត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ត្រឡប់អំពីបិណ្ឌបាត ក្នុង វេលាខាងក្រោយភត្ត ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំង នោះ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រ ព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ពួកសមណព្រាហ្មណ៍ បរិព្វាជក ច្រើនគ្នា អាស្រ័យនៅក្នុងក្រុងសាវត្ថី មានលទ្ធិផ្សេងៗ មានទិដ្ឋិផ្សេងៗ មានសេចក្តី គាប់ចិត្តផ្សេងៗ មានសេចក្តីចូលចិត្តផ្សេងៗ អាស្រ័យទិដ្ឋិនិស្សយផ្សេងៗ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោក ទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។បេ។ សមណ-ព្រាហ្មណ៍ទាំងនោះ មានសេចក្តីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង ចាក់ដោត គ្នានិងគ្នា ដោយលំពែង គឺមាត់ថា យ៉ាងនេះធម៌ យ៉ាងនេះមិនមែនធម៌ យ៉ាង នេះមិនមែនធម៌ យ៉ាងនេះធម៌ ។ ម្នាលភិក្ខុទាំងឡាយ ពួកអន្យតិ្ថយ បរិ-ព្វាជក ដូចជាមនុស្សខ្វាក់មើលមិនឃើញ មិនស្គាល់ប្រយោជន៍ មិនស្គាល់ សភាវៈមិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌ កាលបើអន្យ-តិ្ថយទាំងនោះ មិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈមិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌ហើយ ក៏មានសេចក្តីប្រកួត ប្រកាន់ ជម្លោះ ទាស់ទែង ចាក់ដោតគ្នានិងគ្នា ដោយលំពែង គឺមាត់ថា យ៉ាងនេះធម៌ យ៉ាង*

នេះមិនមែនធម៌ យ៉ាងនេះមិនមែនធម៌ យ៉ាងនេះធម៌ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីន៉ុះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

សមណព្រាហ្មណ៍ទាំងឡាយមួយពួក តែងជាប់ជំពាក់ ក្នុងទិដ្ឋិ-
និស្សយទាំងនេះ បើមិនទាន់បានដល់ព្រះនិព្វាន ជាទីពឹងនោះទេ
រមែងលិចចុះក្នុងកណ្តាលនៃអន្ទង់ គឺសង្សារ ។ សូត្រទី ៥ ។

អដ្ឋកថា

ទុតិយកិរសូត្រ

ទុតិយកិរសូត្រទី ៥ មានវិនិច្ឆយដូចតទៅនេះ

[១៣៩] បទថា **សស្សតោ អត្តា ច លោកោ ច** សេចក្តីថា ជនដទៃកាន់យករូបារម្មណ៍ជាដើមណាមួយ ថាជាអត្តា និងថាជាលោកហើយ កាន់យករូបារម្មណ៍ណាមួយ ថាទៀង ស្ថិតស្ថេរ ពោលយ៉ាងនោះ ដូចដែលពោលថា ជនទាំងឡាយ រមែងបញ្ញត្តរូបឲ្យជាអត្តា និងបញ្ញត្តលោក ថាជាអត្តា ជាលោកផង ទៀងផង បញ្ញត្តវេទនា ... សញ្ញា ... សង្ខារ ... វិញ្ញាណ ឲ្យជាអត្តា និងលោក ថាជាអត្តា ជាលោកផង ទៀងផង ។ ម្យ៉ាងទៀត បទថា **អត្តា** បានដល់ វត្ថុដែលប្រកាន់ថាជារបស់អញ ។ បទថា **លោកោ** បានដល់ វត្ថុដែលឈ្មោះថាជារបស់អញ លោកពោលថា មានក្នុងខ្លួន ។ ម្យ៉ាងទៀត បទថា **អត្តា** បានដល់ ខ្លួនឯង ។ បទថា **លោកោ** បានដល់

អ្នកដទៃ ។ ម្យ៉ាងទៀត បទថា **អត្តា** *បានដល់ ខន្ធ ១ ក្នុងបញ្ចុបាទានក្ខន្ធ ៥ ខន្ធក្រៅអំពីនោះ បានដល់ លោក ។ ម្យ៉ាងទៀត បទថា* **អត្តា** *បានដល់ ខន្ធសន្តានដែលមានវិញ្ញាណគ្រប់គ្រង ដែលមិនមានវិញ្ញាណគ្រប់គ្រង បានដល់ លោក ។ ជនទាំងឡាយ កាន់យករូបជាដើមនោះ ជា ២ ប្រការ តាមទស្សនៈថាអត្តា និងថាជាលោកយ៉ាងនេះហើយ កាន់យកទាំងអត្តា និងលោកនោះ ពោលថា ទៀង ស្ថិតស្ថេរ ពិតប្រាកដ ។ ដោយពាក្យនេះ លោកសម្តែងសស្សតវាទ ៤ ដោយពាក្យថា* **អសស្សតោ** *នេះ សម្តែងឧច្ឆេទវាទទាំង ៣ ។ បទថា* **សស្សតោ ច អសស្សតោ ច** *អធិប្បាយថា ដែលឈ្មោះថា ទៀង ព្រោះអត្តា និងលោកណាមួយទៀង ដែលឈ្មោះថា មិនទៀង ព្រោះអត្តា និងលោកណាមួយមិនទៀង ។ ម្យ៉ាងទៀត អត្តា និងលោកនោះឯង ជួនកាលទៀង ជួនកាលមិនទៀង ដូចរបស់បុគ្គលដែលឃើញខ្លួនជាគតិ គប្បីជ្រាបក្នុងសេចក្តីនេះយ៉ាងនេះថា* **សស្សតោ** *ប្រែថា ទៀង ។ ដោយបទថា* **សស្សតោ** *នេះ លោកសម្តែងដល់វាទៈថាទៀងណាមួយ ដោយប្រការទាំងពួង ។ ដោយបទថា* **នេវ សស្សតោ ន អសស្សតោ** *នេះ លោកសម្តែងដោយវាទៈ ដែលបោះពាក្យបោះសម្តីមិនឲ្យស្ទាប់ខ្លួន ។ ជនទាំងនោះ ឃើញទោសក្នុងសស្សតវាទ និងអសស្សតវាទ ពោលបណ្តោះបណ្តែទៅថា អត្តា និងលោកទៀងក៏មិនមែន មិនទៀងក៏មិនមែន ។ បទថា* **សយង្កតោ** *ប្រែថា ខ្លួនឯងសាងឡើង ។ ដូចអត្តារបស់ពួកសត្វនោះៗ បដិបត្តិធម៌សមគួរដល់ធម៌របស់ខ្លួន ហើយសោយសុខទុក្ខ យ៉ាងណា អត្តា*

ក៏យ៉ាងនោះ រមែងធ្វើអត្តា និងលោក ពោល គឺការកង្វល់ និងការជាប់ជំពាក់ ឲ្យជាគ្រឿងឧបភោគរបស់អត្តានោះ ជនទាំងនោះ មានលទ្ធិនេះ ដូចលទ្ធិអត្តា ថា និម្មិតឡើង ។ បទថា **បរដ្ឋតោ** *ប្រែថា មនុស្សជនៃសាងឡើង អធិប្បាយថា មនុស្សជនៃក្រៅអំពីខ្លួន និងជាឥស្សរជន បុរសក្តី ស្ត្រីក្តីសាង គឺនិម្មិតអត្តា និងលោកតាមកាល ឬតាមប្រក្រតី ។ បទថា* **សយដ្ឋតោ ច បរដ្ឋតោ ច** *សេចក្តីថា ព្រោះឥស្សរជនជាដើម គ្រានិម្មិតអត្តា និងលោក នឹងនិម្មិតដោយខ្លួនឯងតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន ដោយពិត ត្រូវបានហេតុ ដែលធ្វើរួមគ្នានៃធម៌ និងអធម៌នៃពួកសត្វនោះៗ ដូច្នោះ ទើបសត្វពួកខ្លះមាន លទ្ធិដូច្នេះថា អត្តា និងលោក ខ្លួនឯងសាងឡើង ឬអ្នកជនៃសាងឡើង ។ បទថា* **អសយដ្ឋារោ ច អបរដ្ឋារោ ច** *សេចក្តីថា ឈ្មោះថា* **អសយដ្ឋារ** *ព្រោះខ្លួនឯងមិនបានសាង ឈ្មោះថា* **អបរដ្ឋារ** *ព្រោះអ្នកជនៃមិនបានសាង ។ ព្រោះចុះនិគ្គហិតអាគម ទើបពោលថា* **អបរដ្ឋារោ ។** *បុគ្គលនេះឃើញ ទោសក្នុងប្រការដែលខ្លួន និងអ្នកជនៃសាង ទើបបដិសេធទាំង ២ យ៉ាង ។ ដើម្បីចៀសវាងនូវពាក្យសួរថា កាលបើដូច្នោះ អត្តា និងលោក កើតឡើង បានដូចម្តេច ទើបពោលឆ្លើយថា* **អធិច្ចសមុប្បន្នោ ។** *លោកសម្តែងអធិច្ច-សមុប្បន្នវាទថា កើតឡើងតាមសេចក្តីប្រាថ្នា គឺកើតឡើងដោយរៀរហេតុណាមួយ ។ ដោយពាក្យនោះ សង្គ្រោះហេតុកវាទចូលផង ។*

ឥឡូវនេះ កាលទ្រង់សម្តែងវាទៈនោះ របស់បុគ្គលដែលមានទិដ្ឋិជាគតិ ពោល គឺមានសុខ និងទុក្ខជាគុណ ឬជាគ្រឿងកង្វល់នៃអត្តានោះ ជារបស់

ទៀងជាដើម ដូចពោល កាន់យកអត្តា ទើបត្រាស់ពាក្យជាដើមថា **សព្ពេកេ សមណាព្រាហ្មណា** *ពាក្យនោះ មានន័យដូចពោលហើយ ។*

ក្នុងបទថា **ឯតមត្ថំ វិទិត្វា** *នេះ ព្រោះការប្រៀបដោយមនុស្សខ្វាក់អំពីកំណើត មិនមកក្នុងព្រះសូត្រនេះ ទើបលះសេចក្តីនោះ ហើយប្រកបសេចក្តីដោយន័យដែលពោលខាងដើមនោះឯង ។ ក្នុងគាថាក៏ដូចគ្នា ។ ក្នុងព្រះគាថាមានសេចក្តីប្លែកគ្នាត្រឹមប៉ុណ្ណោះថា មិនទាន់ដល់ព្រះនិព្វានដែលជាទីឈមចុះរមែងលិចចុះក្នុងចន្ទោះនោះឯង ។*

ពាក្យនេះ មានអធិប្បាយដូចតទៅនេះថា ទិដ្ឋិគតិកបុគ្គលទាំងឡាយជាប់នៅក្នុងទិដ្ឋិ គឺទិដ្ឋិនិស្សយ មិនទាន់ដល់ គឺមិនទាន់សម្រេចព្រះនិព្វាន ពោលគឺជាទីឈមចុះ ឬអរិយមគ្គដែលជាឧបាយ គ្រឿងសម្រេចព្រះនិព្វាននោះ ព្រោះជាត្រើយ ឬជាទីពឹងរបស់ទិដ្ឋិគតិកបុគ្គលទាំងនោះ ទើបលិចចុះ គឺលិចនៅក្នុងវាង គឺក្នុងកណ្តាលឱឃៈ ៤ មានកាមោឃៈជាដើម ឬអន្ធង់ទឹកធំ គឺសង្សារនោះឯង ។ អរិយមគ្គ និងព្រះនិព្វាន ឈ្មោះថា ធម៌ជាគ្រឿងឈមចុះ ព្រោះជាគ្រឿងឈមចុះ ឬជាទីតាំងអាស្រ័យ ។ ក្នុងទីនេះ ព្រោះរស្សៈ **ឱឃោធំ** *នោះឯង ទើបពោលថា* **ឱឃធំ** ។ *មានការចែកបទថា* **តំ ឱឃធំ** *ជា* **តមោឃធំ** ។

អដ្ឋកថាឧតិយកិរសូត្រទី ៥ ចប់

សុត្តន្តបិដក

តិត្តសូត្រ

[១៤១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកសមណព្រាហ្មណ៍ បរិព្វាជក ច្រើនគ្នា អាស្រ័យនៅក្នុងក្រុងសាវត្ថី មានលទ្ធិផ្សេងៗ មានទិដ្ឋិផ្សេងៗ មានសេចក្តីគាប់ចិត្តផ្សេងៗ មានសេចក្តីចូលចិត្តផ្សេងៗ អាស្រ័យទិដ្ឋិនិស្ស័យផ្សេងៗ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី ទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី មិនទៀងទេ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី ទៀងខ្លះ មិនទៀងខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណ-ព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី ទៀងក៏មិនមែន មិនទៀងក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី ធ្វើដោយខ្ញុំនឯង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី អ្នកដទៃធ្វើ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យ

សោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី ធ្វើដោយខ្លួនឯងខ្លះ អ្នកដទៃធ្វើខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី ធ្វើខ្លួនឯងក៏មិនមែន អ្នកដទៃធ្វើក៏មិនមែន អាស្រ័យបច្ចយកើតឡើង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី មានសុខ និងទុក្ខទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី មានសុខ និងទុក្ខមិនទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណ-ព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី មានសុខ និងទុក្ខ ទៀងខ្លះ មិនទៀងខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី មានសុខ និងទុក្ខ ទៀងក៏មិនមែន មិនទៀងក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណ-ព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី មានសុខ និងទុក្ខ ធ្វើដោយខ្លួនឯង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនក្តី លោកក្តី មានសុខ និងទុក្ខ អ្នកដទៃធ្វើ ពាក្យនេះពិត

ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ធ្វើដោយខ្លួនឯងខ្លះ អ្នកដទៃធ្វើខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ធ្វើដោយខ្លួនឯងក៏មិនមែន អ្នកដទៃធ្វើក៏មិនមែន អាស្រ័យបច្ចុប្បន្នកើតឡើង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីប្រកួតប្រកាន់ ជម្លោះ ទាស់ទែងចាក់ដោតគ្នានិងគ្នា ដោយលំពែង គឺមាត់ថា យ៉ាងនេះ ធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ ធម៌ ។

[១៤២] គ្រានោះ ពួកភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ។ លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ពួកសមណព្រាហ្មណ៍បរិព្វាជកច្រើនគ្នា អាស្រ័យនៅក្នុងក្រុងសាវត្ថី មានលទ្ធិផ្សេងៗ មានទិដ្ឋិផ្សេងៗ មានសេចក្តីគាប់ចិត្តផ្សេងៗ មានសេចក្តីចូលចិត្តផ្សេងៗ អាស្រ័យទិដ្ឋិនិស្សយផ្សេងៗ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តីទៀង ពាក្យនេះពិត

ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មិនទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ទៀងខ្លះ មិនទៀងខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ទៀងក៏មិនមែន មិនទៀងក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ធ្វើដោយខ្លួនឯង អ្នកដទៃធ្វើ ធ្វើដោយខ្លួនឯងខ្លះ អ្នកដទៃធ្វើខ្លះ មិនធ្វើដោយខ្លួនឯងខ្លះ អ្នកដទៃមិនធ្វើខ្លះ អាស្រ័យបច្ច័យកើតឡើង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខមិនទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណ-ព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ទៀងខ្លះ មិនទៀងខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ទៀងក៏មិនមែន មិនទៀង

ក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណ-ព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ធ្វើដោយខ្លួនឯង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ អ្នកដទៃធ្វើ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ធ្វើដោយខ្លួនឯងខ្លះ អ្នកដទៃធ្វើខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខ និងទុក្ខ ធ្វើដោយខ្លួនឯងក៏មាន អ្នកដទៃធ្វើក៏មាន អា-ស្រ័យបច្ចុ័យកើតឡើង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង ចាក់ដោតគ្នានិងគ្នា ដោយលំពែង គឺមាត់ថា យ៉ាងនេះ ធម៌ យ៉ាងនេះ មិន មែនធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ ធម៌ ។ ម្នាលភិក្ខុទាំងឡាយ ពួកអន្យតិរ្ថិយបរិព្វាជក ជាមនុស្សខ្វាក់មើលមិនឃើញ មិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈមិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌ កាល ពួកសមណព្រាហ្មណ៍ទាំងនោះ មិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈមិន មែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌ហើយ មានសេចក្តីប្រកួត ប្រកាន់ ជម្លោះ ទាស់ទែង ចាក់ដោតគ្នានិងគ្នាដោយលំពែង គឺមាត់ថា យ៉ាង

នេះ ធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ ធម៌ ។ លុះព្រះមានព្រះភាគ ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ពួកសមណព្រាហ្មណ៍មួយពួក មិនបានស្គាល់ប្រជុំពីរ នៃទិដ្ឋិនេះ ថា ពួកសត្វនេះ ខ្វល់ខ្វាយ ដោយអហង្ការទិដ្ឋិ ប្រកបដោយមមង្ការទិដ្ឋិ ទាំងមិនឃើញទិដ្ឋិនោះ ថាជាព្រួញទេ កាលបុគ្គលអាស្រ័យព្រួញ គឺទិដ្ឋិនុ៎ះ ហើយពិចារណាថា អាត្មាអញធ្វើ (នូវអរិយមគ្គ) ដូច្នេះ ក៏ទៅដែរ កាលបុគ្គលនោះ អាស្រ័យព្រួញគឺទិដ្ឋិនុ៎ះ ពិចារណាឃើញថា អ្នកជនៃធ្វើ (នូវអរិយមគ្គ) ដូច្នេះ ក៏ទៅដែរ ។ ពួកសត្វនេះ ប្រកបដោយមានះ ចាក់ស្រែះដោយមានះ ព័ន្ធព័ន្ធដោយមានះ ធ្វើការផ្ទុងផ្តើមក្នុងទិដ្ឋិទាំងឡាយ មិនអាចកន្ធងសង្សារបានឡើយ ។ សូត្រទី ៦ ។

អដ្ឋកថា

តិត្តសូត្រ

តិត្តសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ពាក្យទាំងអស់ មានន័យដូចពោលហើយខាងដើមនោះឯង ។

[១៤២] *ក្នុងពាក្យថា* **ឥមំ ឧធានំ** *នេះ គប្បីប្រកបសេចក្តីថា ព្រះមានព្រះភាគទ្រង់បន្ទឺឧទាននេះ ដែលសម្តែងដល់ការប្រព្រឹត្តទៅកន្ទង ព្រោះការមិនប្រព្រឹត្តទៅកន្ទងចាកសង្សារ តាមលំដាប់របស់បុគ្គលដែលឃើញក្នុងទិដ្ឋិ តណ្ហា និងមានះ ហើយវៀរទិដ្ឋិជាដើមនោះឲ្យឆ្ងាយ រួចពិចារណាសង្ខារតាមសេចក្តីពិត និងរបស់បុគ្គលប្រកាន់ខុស ព្រោះមិនឃើញទោសក្នុងសង្ខារទាំងនោះ មិនឃើញតាមសេចក្តីពិត ។*

បណ្តាបទទាំងនោះ បទថា **អហង្ការបសុតាយំ បជា** *សេចក្តីថា ពួកសត្វនេះ ដែលខ្ចល់ខ្ចាយ គឺប្រកបតាមអហង្ការ ពោល គឺអាត្មាអញសាងឯង ដូចពោលហើយយ៉ាងនេះថា អត្តា និងលោក អាត្មាអញសាងឯង បានដល់ ទិដ្ឋិដែលប្រព្រឹត្តទៅយ៉ាងនោះ គឺពួកសត្វដែលប្រកាន់ខុស ។ បទថា* **បរង្ការបសញ្ហិតា** *បានដល់ បុគ្គលប្រកបដោយបរង្ការ ព្រោះអាស្រ័យទិដ្ឋិថា អ្នកដទៃសាងដែលប្រព្រឹត្តទៅយ៉ាងនេះថា បុគ្គលដទៃ មានឥស្សរជនជាដើមសាងទាំងអស់ បានដល់ ដែលប្រកបដោយបរង្ការទិដ្ឋិនោះ ។ បទថា* **ឯតេកេ ឆាព្ភញ្ញំសុ** *សេចក្តីថា សមណៈ និងព្រាហ្មណ៍មួយពួក ជាបុគ្គលមានប្រក្រតីឃើញទោសក្នុងទិដ្ឋិ ២ យ៉ាងនោះ មិនតាមដឹងនូវទិដ្ឋិ ២ យ៉ាងនោះ សេចក្តី*

នេះដូចម្តេច គឺកាលសាងឯងបាន សត្វទាំងឡាយ ក៏គប្បីប្រាថ្នាសាងកាម ប៉ុណ្ណោះ បុគ្គលដែលមិនប្រាថ្នា មិនមាន ។ បុគ្គលណាម្នាក់ ទោះប្រាថ្នាទុក្ខ ដើម្បីខ្លួន នឹងមានវត្ថុដែលមិនត្រូវការ ក៏មិនមែន ព្រោះដូច្នោះ ទើបមិនជា អ្នកសាងឯង ។ សូម្បីអ្នកដទៃសាង បើមានឥស្សរជនជាហេតុ ឥស្សរជន នេះ គប្បីសាងដើម្បីខ្លួន ឬដើម្បីអ្នកដទៃ ។ ក្នុង ២ យ៉ាងនោះ បើសាង ដើម្បីខ្លួន ក៏គប្បីមិនមានកិច្ចដែលខ្លួនធ្វើ ព្រោះឲ្យកិច្ចដែលមិនទាន់សម្រេច ឲ្យសម្រេច បើសាងដើម្បីអ្នកដទៃ ក៏គប្បីឲ្យសម្រេចចំពោះហិតសុខដល់ជន ទាំងអស់ប៉ុណ្ណោះ វត្ថុដែលមិនជាប្រយោជន៍ និងជាទុក្ខ ក៏មិនសម្រេច ព្រោះ ដូច្នោះ ទើបអ្នកដទៃសាងមិនសម្រេច ដោយឥស្សរជន ។ បើហេតុដោយមិន ប្រាថ្នាអ្នកដទៃ ពោល គឺឥស្សរជនគប្បីមាន ដើម្បីការប្រព្រឹត្តទៅជានិច្ចនោះ ឯង ។ មិនគប្បីកើតឡើង ព្រោះការធ្វើ អ្នកទាំងអស់នោះឯង គប្បីកើត ឡើងរួមគ្នា ព្រោះហេតុតាំងទុករួមគ្នា ។ បើបុគ្គលនោះប្រាថ្នាហេតុ មានការ ធ្វើរួមគ្នាដទៃ សេចក្តីនោះឯងជាហេតុ ។ ប្រយោជន៍អ្វីដោយឥស្សរជនដែល កំណត់ដោយអំណាចក្នុងកិច្ចដែលមិនទាន់សម្រេច ។

បើអ្នកដទៃសាងឥស្សរជនជាហេតុ រមែងមិនសម្រេច យ៉ាងណា សូម្បី ខ្លួនសាង មានសត្វ បុរស បកតិព្រហ្ម និងកាលជាដើមជាហេតុ ក៏មិនសម្រេច ដូច្នោះដូចគ្នា ព្រោះជនទាំងនោះក៏មិនឲ្យសម្រេច និងព្រោះមិនផុតទុក្ខតាមដែល ពោលហើយ ដោយហេតុនោះ ទើបលោកពោលថា **ឯតទេកេ ឆាព្ភញ្ញំសុ ។** ជនទាំងឡាយណា មិនដឹងខ្លួនឯងសាង និងអ្នកដទៃសាង តាមដែលពោល

ហើយ រមែងបញ្ញត្តអត្តា និងលោក ដែលកើតឡើងឯងៗ ជនទាំងនោះមិនឃើញទិដ្ឋិនោះ ថាជាព្រួញ គឺសូម្បីបុគ្គលដែលមានវាទៈថា អត្តា និងលោក កើតឡើងឯងៗ មិនជឿតាមសេចក្តីពិត ព្រោះមិនកន្ទងផុតចាកការប្រកាន់ខុស ទើបមិនឃើញទិដ្ឋិនោះ ថាជាព្រួញ ព្រោះអត្តថា ចាក់ជោតដោយទុក្ខ ឲ្យកើតឡើងក្នុងអត្តា និងលោកនោះៗ ។ បទថា **ឯតញ្ច សល្លំ បដិគច្ច បស្សតោ** *សេចក្តីថា បុគ្គលណាផ្តើមបំពេញវិបស្សនា ពិចារណាឃើញឧបាទានក្ខន្ធទាំង ៥ ថា មិនទៀង ជាទុក្ខ ជាអនត្តា បុគ្គលនោះ រមែងពិចារណាឃើញបរិយត្តិ ទស្សនៈ ៣ យ៉ាងនេះ និងមិច្ឆាកិនិវេសន៍ជំទៃទាំងអស់ និងឧបាទានក្ខន្ធទាំង ៥ ដែលជាទីអាស្រ័យនៃធម៌ទាំងនោះ ដោយវិបស្សនាខាងដើមនោះឯង ថាជាព្រួញ ព្រោះចាក់ជោត និងព្រោះដកបានដោយកម្រ ។ កាលព្រះយោគីនោះឃើញយ៉ាងនេះ មិនមានការគិតថា អញសាងដោយចំណែកប៉ុណ្ណោះ ក្នុងខណៈអរិយមគ្គ ។ ព្រះយោគីនោះ មិនបានគិតថា បុគ្គលជំទៃសាងដោយប្រការដែលមិនជ្រាកជដល់លោកថា ខ្លួនសាងតែនឹងមានត្រឹមបដិច្ចសមុប្បន្នធម៌ ពោល គឺការមិនទៀងតែម្យ៉ាងប៉ុណ្ណោះ ។*

ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា សម្តែងដល់ភាពដែលបុគ្គលបដិបត្តិប្រពៃ មិនមានទិដ្ឋិ និងមានះ ដោយប្រការទាំងពួង ដោយពាក្យនោះ ជាការប្រកាសដល់ការកន្ទងផុតសង្សារ ដោយការសម្រេចដល់អរហត្ត ។ ឥឡូវនេះ ដើម្បីសម្តែងថា បុគ្គលដែលជាប់នៅក្នុងទិដ្ឋិ រមែងមិនអាចងើបក្បាលឡើងអំពីសង្សារបាន ទើបត្រាស់គាថាថា **មានុបេតា**

ជូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **មានុសេសា អយំ បជា** *សេចក្តីថា បជា គឺ ពួកសត្វ ពោល គឺទិដ្ឋិគតិកបុគ្គលទាំងអស់ចូលដល់ គឺប្រកបដោយមានៈ ដែលមានលក្ខណៈផ្ដងការកាន់យកវបស់ខ្លួនថា ទិដ្ឋិរបស់អញស្អាត ការកាន់ យករបស់អញស្អាត ។ បទថា* **មានគតា មានវិនិព្ភុតា** *សេចក្តីថា បន្ទាប់ អំពីនោះ ពួកសត្វទាំងនោះ ឈ្មោះថា មានគ្រឿងរួបរឹត គឺមានៈ មានគ្រឿង ចង គឺមានៈ ព្រោះមានៈកើតឡើងតៗ គ្នាមកនោះ រួបរឹត និងចងសន្ដានខ្លួន ព្រោះខ្លួនមិនទាន់លះបង់ទិដ្ឋិនោះ ។ បទថា* **ទិដ្ឋីសុ សារម្ភកថា សំសារំ ឆាតិវត្តតិ** *សេចក្តីថា មានសារម្ភកថាពោលដោយការប្រណាំងប្រជែង គឺ មានវិរោធកថា ពោលដោយការជំទាស់ក្នុងទិដ្ឋិរបស់ជនដទៃ ដោយការកាន់ យកទិដ្ឋិរបស់ខ្លួន ដោយការលើកខ្លួន សង្កត់អ្នកដទៃថា វត្តនេះប៉ុណ្ណោះពិត វត្តដទៃទេ វមែងមិនកន្លង គឺវមែងមិនផុតចាកសង្សារ ព្រោះមិនទាន់ ប្រហារអវិជ្ជា និងតណ្ហា ដែលនាំសត្វទៅកាន់សង្សារបាន ៕*

អដ្ឋកថាតិត្តសូត្រទី ៦ ចប់

សុត្តន្តបិដក

សុភូតិសូត្រ

[១៤៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសុភូតិដ៏មានអាយុ អង្គុយពែនភ្នែន តាំងកាយត្រង់ ចូលកាន់សមាធិ ដែលមិនមានវិតក្ក ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ បានទតឃើញព្រះសុភូតិដ៏មានអាយុ អង្គុយពែនភ្នែន តាំងកាយត្រង់ ចូលកាន់សមាធិ ដែលមិនមានវិតក្ក ក្នុងទីជិត ។ លុះព្រះមានព្រះភាគ ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> វិតក្កទាំងឡាយ ដែលអរិយបុគ្គលណា កម្ចាត់បង់ហើយ សម្រេចហើយដោយប្រពៃ ក្នុងសន្តាន ឥតមានសេសសល់ មិនសម្គាល់រូប ព្រោះកន្ទងការជាប់ជំពាក់នោះ អរិយបុគ្គលនោះ មិនដល់នូវជាតិ ព្រោះបានកន្ទងយោគធម៌ទាំង ៤ ហើយ ។ សូត្រទី ៧ ។

អដ្ឋកថា

សុភូតិសូត្រ

សុភូតិសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ

[១៤៣] បទថា **សុភូតិ** ជាឈ្មោះនៃព្រះថេរៈនោះ ។ ពិតហើយ ព្រះសុភូតិនោះ បានសាងអភិនីហារទៀបបាទមូល របស់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ កសាងបុញ្ញសម្ភារៈអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលធំ មានសម្បត្តិច្រើន ស្តាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគហើយ កើតនូវធម្មសង្វេគ ចេញចាកផ្ទះបួស ព្រោះបានសាងបុញ្ញាធិការ ព្យាយាមមិនយូរប៉ុន្មាន ក៏បាននូវអភិញ្ញា ៦ តែព្រោះដល់នូវបារមីខ្ពង់ខ្ពស់នៃព្រហ្មវិហារភាវនា ទើបព្រះមានព្រះភាគស្តាបនាក្នុងឯតទគ្គៈក្នុងការនៅដោយមិនមានកិលេសថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកនៅដោយឥតកិលេស ដែលជាសាវ័ករបស់តថាគត ស្រេចនឹងសុភូតិប្រសើរជាងគេ ។ ថ្ងៃមួយ ក្នុងវេលាល្ងាច លោកចេញអំពីទីសម្រាកពេលថ្ងៃ ចុះកាន់លានវិហារ ឃើញព្រះមានព្រះភាគកំពុងសម្តែងធម៌ កណ្តាលបរិស័ទ ៤ កំណត់កាលថា ពេលចប់ទេសនា អាត្មាអញនឹងក្រោកទៅថ្វាយបង្គំ ទើបគង់ចូលផលសមាបត្តិ ត្រង់ជើមឈើមួយកន្លែង មិនឆ្ងាយអំពីព្រះមានព្រះភាគ ព្រោះហេតុនោះ ទើបលោកពោលថា សម័យនោះឯង ព្រះសុភូតិដ៏មានអាយុ ។បេ។ ចូលកាន់សមាធិ ។

ក្នុងការចូលសមាបត្តិនោះ តាំងអំពីទុតិយជ្ឈានទៅ រូបាវចរសមាធិក្តី

អរូបាវចរសមាធិទាំងអស់ក្តី គឺអវិតក្កសមាធិនោះឯង ។ តែក្នុងទីនេះ អរ-ហត្តផលសមាធិ ដែលមានចតុត្ថជ្ឈានជាបាទ លោកបំណងយកថា អវិតក្ក-សមាធិ ។ មិច្ចាវិតក្កដែលទុតិយជ្ឈានជាដើមលះហើយ ចាត់ថា មិនទាន់លះ ល្អ ព្រោះមិនមានការលះជាសមុច្ចេទ ឯព្រះអរិយមគ្គនោះឯង ឈ្មោះថា លះ ដោយល្អ ព្រោះមិនមានកិច្ចដែលលះតទៅ ។ ព្រោះដូច្នោះ អរហត្តផល-សមាធិដែលជាទីបំផុតនៃអរហត្តមគ្ត ព្រោះកើតឡើងក្នុងទីបំផុតនៃការលះ មិច្ចាវិតក្កទាំងអស់ បើពោលដោយពិសេស គួរពោលថា អវិតក្កសមាធិ នឹងពោលថ្វីដល់ការមានចតុត្ថជ្ឈានជាបាទនោះ ព្រោះហេតុនោះ ទើបលោក ពោលថា ក្នុងទីនេះ អរហត្តផលសមាធិដែលមានចតុត្ថជ្ឈានជាបាទ លោក បំណងយកអវិតក្កសមាធិ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ដឹងដោយអាការទាំងពួងដល់ អត្ថនោះ ពោល គឺការដែលព្រះសុភូតិលះកិលេស គឺមិច្ចាវិតក្កទាំងអស់បាន ទើបទ្រង់បន្ទឺឧទាននេះ ដែលសម្តែងសេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **យស្ស វិតក្កា វិធូបិតា** សេចក្តីថា ព្រះ អរិយបុគ្គលណាកម្ចាត់មិច្ចាវិតក្កទាំងអស់ មានកាមវិតក្កជាដើម គឺធ្វើឲ្យស្ងប់ បានដល់ កាត់ផ្តាច់ដោយអរិយមគ្គញ្ញាណ ។ បទថា **អជ្ឈត្តំ សុវិកប្បិតា អសេសា** សេចក្តីថា កំណត់បានល្អ គឺកំណត់ដោយល្អ ដោយមិនសេស សល់ ដែលគួរកើតឡើងក្នុងសន្តានខ្លួន ពោល គឺខាងក្នុងខ្លួន អធិប្បាយថា កាត់ដោយល្អ ដោយមិនសេសសល់ធមិណាមួយ ។ បទថា **តំ** ក្នុងបទថា

តំ សង្ខមតិច្ច អរូបសញ្ញី នេះ ត្រឹមតែជានិបាត ។ ម្យ៉ាងទៀត **តំ** សព្ទ មានហេតុជាអត្ថ ព្រោះព្រះអរិយបុគ្គលកាត់មិច្ឆាវិតក្កបានជាសមុច្ឆេទ ដូច្នោះ ទើបព្រះអរិយបុគ្គលនោះ ឈ្មោះថា មានការសម្គាល់ក្នុងអរូប ដោយមគ្គ សញ្ញា និងផលសញ្ញា ដែលប្រព្រឹត្តទៅ ដោយធ្វើព្រះនិព្វាន ដែលបានឈ្មោះ ថា អរូប ឲ្យជាអារម្មណ៍ ព្រោះមិនមានសភាវៈនៃរូប និងមិនមានវិការ គឺ ការប្រែប្រួលក្នុងព្រះនិព្វាននោះ ឬព្រោះមិនមានហេតុនៃវិការ ព្រោះកន្ទងផុត គ្រឿងជាប់ជំពាក់ ៥ យ៉ាង មានគ្រឿងជាប់ជំពាក់ គឺរាគៈជាដើម ឬគ្រឿង ជាប់ជំពាក់ គឺកិលេសទាំងអស់ ។ បទថា **ចតុយោគាតិគតោ** បានដល់ ឈានកន្ទងនូវយោគៈ ៤ គឺកាមយោគៈ ភវយោគៈ ទិដ្ឋិយោគៈ និងអវិជ្ជា-យោគៈ ដោយមគ្គទាំង ៤ តាមសមគួរ ។ **ម** អក្សរ ក្នុងបទថា **ន ជាតុមេតិ** នេះ គ្រាន់តែជាការភ្ជាប់បទ ។ សេចក្តីថា រមែងមិនត្រឡប់មកដើម្បីកើតក្នុង ភពថ្មីដោយចំណែកមួយ គឺលោកមិនមានការកើតក្នុងភពថ្មីតទៅ ។ អាចារ្យ ខ្លះពោលថា **ន ជាតិ មេតិ** ដូច្នេះក៏មាន សេចក្តីក៏ដូច្នោះឯង ។ ដូច្នោះ ព្រះមានព្រះភាគ ទ្រង់ប្រោរព្ធធម៌ជាគ្រឿងនៅ គឺអហត្តផលសមាបត្តិ និង អនុបាទិសេសនិព្វានរបស់ព្រះសុភូតិ ទើបទ្រង់បន្ទឺឧទានដែលកើតអំពីកម្ចាំង បីតិ ៗ

អដ្ឋកថា សុភូតិសូត្រទី ៧ ចប់

សុត្តន្តបិដក

គណិកាសូត្រ

[២៤៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង មានមនុស្ស ២ ពួក ជាអ្នកមានតម្រេក មានចិត្តប្រតិព័ទ្ធនឹងស្រីផ្កាមាសម្នាក់ មានសេចក្តីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង ប្រហារគ្នានិងគ្នា ដោយដៃទាំងឡាយខ្លះ ប្រហារដោយដុំដីទាំងឡាយខ្លះ ប្រហារដោយដំបងទាំងឡាយខ្លះ ប្រហារដោយគ្រឿងសស្ត្រាទាំងឡាយខ្លះ ក្នុងទីនោះ មនុស្សទាំងនោះ ជល់សេចក្តីស្លាប់ខ្លះ ជល់សេចក្តីទុក្ខស្ទើរស្លាប់ខ្លះ ។ លំដាប់នោះ ពួកភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ ហើយត្រឡប់ពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងក្រុងរាជគ្រឹះនេះ មានមនុស្ស ២ ពួក មានតម្រេក មានចិត្តប្រតិព័ទ្ធនឹងស្រីផ្កាមាសម្នាក់ មានសេចក្តីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង ប្រហារគ្នានិងគ្នា ដោយដៃទាំងឡាយខ្លះ ប្រហារដោយដុំដីទាំងឡាយខ្លះ ប្រហារដោយដំបងទាំងឡាយខ្លះ ប្រហារដោយគ្រឿងសស្ត្រាទាំងឡាយខ្លះ ក្នុងទីនោះ មនុស្សទាំងនោះ ជល់សេចក្តីស្លាប់ខ្លះ

ដល់សេចក្តីទុក្ខស្ទើរស្ងាប់ខ្លះ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

អារម្មណ៍ណា ដែលបុគ្គលដល់ហើយក្តី អារម្មណ៍ណា ដែលបុគ្គលនឹងដល់ក្តី អារម្មណ៍ទាំង ២ នុ៎ះ រោយរាយដោយធូលី គឺរាគាទិក្កិលេសរបស់បុគ្គលអ្នកក្តៅក្រហាយ កាលសិក្សារឿយៗ ជនទាំងឡាយណា មានការសិក្សាជាខ្លឹម សីលពូតៈ ជីវិតព្រហ្មចរិយៈ និងការបម្រើជាខ្លឹម នេះជាផ្លូវលាមកទី ១ ។ ជនទាំងឡាយណា មានវាទៈយ៉ាងនេះថា ទោសក្នុងកាមទាំងឡាយមិនមានទេ នេះជាផ្លូវលាមកទី ២ ។ ផ្លូវលាមកទាំងពីរនុ៎ះ តែងចម្រើនដោយព្រៃស្មសាន គឺតណ្ហា និងអវិជ្ជា ព្រៃស្មសាន គឺតណ្ហា និងអវិជ្ជា តែងធ្វើទិដ្ឋិឲ្យចម្រើន ដោយប្រការដូច្នេះ ។ សមណព្រាហ្មណ៍មួយពួកតែងរួញរា មួយពួកតែងសុះទៅ ព្រោះមិនដឹងផ្លូវលាមកទាំងពីរនុ៎ះ ។ អរិយបុគ្គលទាំងឡាយណា ដឹងច្បាស់នូវផ្លូវលាមកទាំងពីរហើយ អរិយបុគ្គលទាំងនោះ មិនជ្រាក់ចុះក្នុងផ្លូវលាមកទាំងពីរនុ៎ះទេ ទាំងមិនបានសម្គាល់ខ្លួន ដោយការលះបង់ផ្លូវលាមកនោះឡើយ វដ្តរបស់ពួកអរិយបុគ្គលនោះ មិនមានដើម្បីបញ្ញត្តិទេ ។ សូត្រទី ៨ ។

អដ្ឋកថា

គណិកាសូត្រ

គណិកាសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ

[២៤៤] *បទថា* **ទ្វេ ឃុគា** *បានដល់ ២ គណៈ ។ បទថា* **អញ្ញតរិស្សា គណិកាយ** *បានដល់ ស្រីនគរសោភិនីម្នាក់ ។ បទថា* **សារត្តា** *ប្រែថា តម្រេកដោយល្អ ។ បទថា* **បដិពទ្ធចិត្តា** *ប្រែថា មានចិត្តជាប់ជំពាក់ដោយកិលេស ។*

បានឮថា ក្នុងក្រុងរាជគ្រឹះ ថ្ងៃមហោស្រពមួយ ពួកអ្នកលេងជាច្រើនដើរជាពួកៗ តែបុគ្គលម្នាក់នាំស្រីគណិកាម្នាក់ ចូលឧទ្យានលេងមហោស្រព ក្រោយអំពីនោះ ក្នុងថ្ងៃមហោស្រព អ្នកលេង ២-៣ នាក់ នាំស្រីគណិកានោះមកលេងមហោស្រព ។ សម័យថ្ងៃមួយ ពួកអ្នកលេងដទៃទៀត បំណងទីលេងមហោស្រពនោះដូចគ្នា កាលនាំស្រីគណិកាមក ទើបនាំស្រីគណិកាម្នាក់ ដែលពួកអ្នកលេងមុនធ្លាប់នាំមក ឯអ្នកលេងមុនឃើញជួច្នោះ ទើបពោលថា ស្រីនេះ នៅក្នុងការគ្រប់គ្រងរបស់ពួកយើង ឯពួកអ្នកលេងក្រោយក៏បានពោលយ៉ាងនោះដូចគ្នា ។ អ្នកលេង ២ ពួកនោះ បង្គន្ធូវជម្លោះថា បើជួច្នេះ ពួកយើងក៏គ្រប់គ្រងបាន ពួកយើងក៏គ្រប់គ្រងបាន ទើបវាយតប់គ្នាដោយកណ្តាប់ដៃជាដើម ដោយហេតុនោះ ទើបលោកពោលថា **តេន ខោ បន សមយេន រាជរោ ទ្វេ ឃុគា** *ជួច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **ឧបក្កមន្តិ** *ប្រែថា ប្រហារគ្នា ។ បទថា* **មរណម្បិ និគច្ឆន្តិ** *សេចក្តីថា ចូលដល់នូវការស្លាប់ ដោយការប្រហារគ្នា*

យ៉ាងខ្លាំងក្លា ។ ឯជនមួយពួកទៀត បានទទួលទុក្ខស្ទើរតែនឹងស្លាប់ គឺមានការស្លាប់ជាប្រមាណ ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងនូវតម្រេកក្នុងកាមទាំងឡាយនោះថា ជាមូលនៃវិវាទ និងជាមូលនៃសេចក្តីវិនាសទាំងពួង ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្លឺឧទាននេះ ដែលប្រកាសទោសក្នុងអន្តធម៌ ២ យ៉ាង និងអានិសង្សក្នុងមជ្ឈិមប្បដិបទា ។*

បណ្តាបទទាំងនោះ បទថា **យញ្ហ បត្តំ** *សេចក្តីថា បញ្ចកាមគុណ មានរូបជាដើមដែលបុគ្គលបានទទួល គឺដែលបុគ្គលធ្វើទិដ្ឋិខាងមុខ ឬមិនធ្វើទុកខាងមុខថា ទោសក្នុងកាមមិនមាន បានហើយ គឺសោយក្នុងឥឡូវនេះ ។ បទថា* **យញ្ហ បត្តញ្ច** *សេចក្តីថា កាមគុណណាដែលទិដ្ឋិគតិកបុគ្គលអាស្រ័យទិដ្ឋិថា កាមអញគប្បីបរិភោគ កាមអញគប្បីប្រើប្រាស់ កាមអញគប្បីសេព កាមអញគប្បីសេពចំពោះ បុគ្គលណាបរិភោគកាម បុគ្គលនោះឈ្មោះថា ធ្វើលោកឲ្យចម្រើន បុគ្គលណាធ្វើលោកឲ្យចម្រើន បុគ្គលនោះឈ្មោះថា ជួបនូវបុណ្យច្រើន ដូច្នេះហើយ គប្បីដល់ គប្បីសោយក្នុងអនាគត ដោយកម្មដែលខ្លួន មិនលះបង់ទិដ្ឋិនោះ ធ្វើ ។ បទថា* **ឧភយមេតំ រជានុកិណ្ណំ** *សេចក្តីថា កាមគុណទាំង ២ នោះ ដែលបុគ្គលដល់ហើយ នឹងគប្បីដល់ ដេរដាសដោយធូលី គឺរាគៈជាដើម ។ ពិតហើយ បុគ្គលកាលសោយវត្ថុកាម ដែលជួប រមែងឈ្មោះថា ដេរដាសដោយធូលី គឺរាគៈ ក្នុង ២ យ៉ាងនោះ កាលផលនៃចិត្តដែលសៅហ្មង មកដល់ក្នុងអនាគត ទើបឈ្មោះថា ដេរដាសដោយ*

ធូលី គឺទោសៈ ក្នុងកាលទោមនស្សកើតឡើង ដោយប្រការទាំង ២ ដែល ឈ្មោះថា ជេរជាសដោយធូលី គឺមោហៈ។ ដើម្បីនឹងឆ្លើយពាក្យសួរថា កាម ទាំង ២ នោះ ជេរជាសដោយធូលីដល់បុគ្គលណា ទើបត្រាស់ថា ដល់អ្នក ដែលរសាប់រសល់ ដែលសិក្សាតាម អធិប្បាយថា ដល់បុគ្គលដែលក្តៅ ក្រហាយព្រោះកិលេស ដោយអំណាចជ្រុលថ្នាកាម និងក្តៅក្រហាយព្រោះទុក្ខ ដោយផលនៃកិលេសនោះ ដែលសិក្សាកាមកិលេស និងផលរបស់កិលេស ដោយជ្រុលថ្នាការតបស្នងទាំង ២ យ៉ាង។ ម្យ៉ាងទៀត បទថា **យញ្ច បត្តព្វំ** *សេចក្តីថា កាមគុណណាដែលបុគ្គលដល់ហើយ ដោយអំណាចអចេលកវត្ត ជាដើម ឈ្មោះថា ញុំាងខ្លួនឲ្យក្តៅក្រហាយ។ បទថា* **យញ្ច បត្តព្វំ** *សេចក្តីថា កាមគុណណាជាផលដែលគប្បីដល់ក្នុងអបាយ ព្រោះហេតុនៃការសមា-ទានមិច្ឆាទិដ្ឋិកម្ម។ បទថា* **ឧភយមេតំ រជានុកិណ្ណាំ** *បានដល់ កាមគុណទាំង ២ នោះ ជេរជាសដោយធូលី គឺទុក្ខ។ បទថា* **អាតុរស្ស** *បានដល់ ដែលក្តៅក្រហាយព្រោះទុក្ខ ដោយការលំបាកផ្លូវកាយ។ បទថា* **អនុសិក្ខតោ** *បាន ដល់ ដែលសិក្សាតាមមិច្ឆាទិដ្ឋិ និងបុគ្គលដែលប្រកាន់មាំដោយមិច្ឆាទិដ្ឋិនោះ។*

បទថា **យេ ច សិក្ខាសារា** *សេចក្តីថា ពួកជនដែលគេហៅថា បរិសុទ្ធ ក្នុងសង្ឃដោយសីលវត្តនេះ ព្រោះកាន់យកសិក្ខា គឺសីលវត្តជាដើមដែល ខ្លួនកាន់យកជាសារៈ។ ដោយហេតុនោះ ទើបត្រាស់ថា សីលព្វតៈ ជីវិត ព្រហ្មចរិយៈ និងការបម្រើជាខ្ញីមជូច្នេះជាដើម។ ក្នុងសេចក្តីនោះ សិក្ខា ដែលបុគ្គលវៀរ រមែងមិនធ្វើ ចាត់ជាសីល ការប្រព្រឹត្តលំបាក ព្រោះត្រូវ*

បរិភោគតាមកាលជាដើម ចាត់ជាវត្ត ការរស់នៅដោយភាពជាអ្នកមានបន្ទែ ជាកិក្ខាជាដើម ចាត់ជាជីវិត មេថុនវិរតិ ចាត់ជាព្រហ្មចរិយៈ សីលវត្តទាំង នោះតាំងនៅរឿយៗ ចាត់ជាឧបដ្ឋាក ម្យ៉ាងទៀត ការប្រណិប័តន៍ព្រះខន្ធកុមារ និងព្រះឥសូរជាដើម ដោយការជ្រោះព្រំរបស់ភូតជាដើម ចាត់ជាការឧបដ្ឋាក ការបរិសុទ្ធក្នុងសង្ឃារ រមែងមានដោយសីលជាដើម តាមដែលពោលហើយ ទាំងនេះ ដោយអាការយ៉ាងនេះ ព្រោះហេតុនោះ សមណព្រាហ្មណ៍ទាំង-ឡាយ ដែលប្រកាន់សីលជាដើមនោះថាជាសារៈតាំងនៅ គប្បីជ្រាបថា ដែលមានការសិក្សាជាសារៈ មានសីល វត្ត ជីវិត ព្រហ្មចរិយៈ និងឧបដ្ឋាកជាសារៈ ។ បទថា **អយមេកោ អន្តោ** *សេចក្តីថា ចំណែកទីបំផុតនេះ គឺ ប្រកបខ្លួនឲ្យលំបាក ដោយការប្រកាន់សីលវត្ត ជាកិច្ចបដិបត្តិ ក្រៅគន្ថ មជ្ឈិមប្បដិបទា និងឈ្មោះថា ជាអន្តធម៌ ១ ព្រោះអត្ថថា ថោកទាប ។ បទ ថា* **អយំ ទុតិយោ អន្តោ** *សេចក្តីថា ការប្រកបខ្លួនឲ្យជាប់ជំពាក់ក្នុង កាមសុខ នេះចាត់ជាការធ្លាក់ចុះក្នុងកាមទាំងឡាយ ចាត់ជាអន្តធម៌ទី ២ ដោយន័យដូចពោលហើយ ។*

បទថា **ឥច្ចេតេ ទុភោ អន្តា** *បានដល់ អន្តធម៌ ២ យ៉ាង គឺកាម-សុខល្លិកានុយោគ ១ អត្តកិលមថានុយោគ ១ ។ ក្នុងទីបំផុតទាំង ២ នោះ ឈ្មោះថា អន្តធម៌ ព្រោះជាធម៌ថោកទាប ក្រៅគន្ថ ព្រោះបុគ្គលជាប់នៅក្នុង កាមគុណ ដែលដេរដាសដោយធូលី ដោយកិលេស និងទុក្ខ ដែលខ្លួនបាន ទទួលក្នុងបច្ចុប្បន្ន និងដែលគប្បីបានទទួលក្នុងអនាគត និងជាប់នៅក្នុងការ*

ធ្វើខ្លួនឲ្យក្តៅក្រហាយ ឈ្មោះថា ជាអ្នកសិក្សានូវការក្តៅក្រហាយ ព្រោះ
កិលេស និងទុក្ខ ព្រោះក្តៅក្រហាយដោយកិលេស និងទុក្ខ គប្បីប្រព្រឹត្តទៅ
ដោយខ្លួនឯង ។ បទថា **ឥជសិវឌ្ឍនា** បានដល់ ការពង្រីកខ្លួនរបស់តណ្ហា
និងអវិជ្ជា គឺកដសិ ព្រោះអត្ថថា អន្ទបុថុជ្ជនគប្បីសង្ឃឹមចំពោះ ។ បទថា
ឥជសិយោ ទិដ្ឋឹ វឌ្ឍន្តិ សេចក្តីថា តណ្ហា និងអវិជ្ជា ដែលឈ្មោះថាកដសិ
ទាំងនោះ តែងពង្រីកនូវទិដ្ឋិ មានប្រការផ្សេងៗ ។ ពិតហើយ បុគ្គលឃើញ
នូវការត្រេកអរក្នុងវត្ថុកាម បាននូវតណ្ហា និងអវិជ្ជាដែលជាហេតុធ្វើរួមគ្នានៃ
បុគ្គលដែលមិនអាចលះវត្ថុកាមនោះបាន ទើបឲ្យប្រកាន់នូវនត្ថិកទិដ្ឋិ អកិរិយ-
ទិដ្ឋិ និងអហេតុកទិដ្ឋិ ដោយន័យជាដើមថា ទានដែលបុគ្គលឲ្យហើយ មិន
មានផល ។ កាលបាននូវតណ្ហា និងអវិជ្ជាជាហេតុធ្វើរួមគ្នានៃបុគ្គលដែល
ប្រកបរឿយៗ នូវការធ្វើខ្លួនឲ្យក្តៅក្រហាយ រមែងឲ្យកាន់យកសីលវត្ត និង
ការប្រកាន់ខុស ដោយប្រាថ្នាសេចក្តីបរិសុទ្ធចំពោះខ្លួន ដោយន័យជាដើមថា
ការបរិសុទ្ធរមែងមានដោយសីល ការបរិសុទ្ធរមែងមានដោយវត្ត ដូច្នេះ ។
ភាវៈនៃសក្កាយទិដ្ឋិ ជាបច្ច័យដល់អន្ទបុថុជ្ជនទាំងនោះ រមែងប្រាកដច្បាស់
នោះឯង ។ គប្បីជ្រាបភាពដែលតណ្ហា និងអវិជ្ជា ជាគ្រឿងធ្វើឲ្យទិដ្ឋីរីកធំធាត់
ព្រោះចូលទៅអាស្រ័យអន្តធមិ ២ យ៉ាងដូចពោលមកនេះ ។ អាចារ្យពួកខ្លះ
ពោលថា បទថា **ឥជសិ** នេះ ជាឈ្មោះនៃខន្ធ ៥ អាចារ្យទាំងនោះ មាន
បំណងថា ការបរិសុទ្ធក្នុងសង្សារ រមែងមិនមានដោយអន្តធមិទាំង ២ នោះ
អន្តធមិទាំង ២ នោះ រមែងធ្វើឲ្យឧបាទានក្ខន្ធរីកធំធាត់ដោយចំណែកនោះ ។

តែអាចារ្យមួយពួកទៀត ពោលអត្ថនៃបទថា **កេជសិវឌ្ឍនា** *ថា ធ្វើឲ្យព្រៃ ខ្មោចចម្រើនដោយជរា និងមរណៈបន្តគ្នាមក ។ អាចារ្យទាំងនោះ ពោលចំពោះការមាន និងការមិនមាននៃអន្តធម៌ទាំង ២ ថា ជាហេតុនៃសេចក្តីបរិសុទ្ធក្នុងសង្សារប៉ុណ្ណោះ តែគប្បីពោលតណ្ហា និងអវិជ្ជា ដែលឈ្មោះថាកជសិ ជាគ្រឿងធ្វើឲ្យទិដ្ឋីរកចម្រើន ។*

បទថា **ឯតេ តេ ឧភោ អន្តេ អនភិញ្ញាយ** *សេចក្តីថា អន្ធបុថុជ្ជនទាំងនោះ ព្រោះមិនដឹងទីបំផុតទាំង ២ តាមដែលពោលហើយនេះ ព្រោះមិនដឹងគឺព្រោះការមិនដឹងយ៉ាងនេះថា អន្តធម៌ទាំងនេះ និងទាំងនេះ ដែលអន្ធបុថុជ្ជនប្រកាន់ហើយយ៉ាងនេះ តាំងមាំហើយយ៉ាងនេះ មានគតិយ៉ាងនេះ មានកពជាទីទៅខាងមុខយ៉ាងនេះ ។ គប្បីជ្រាបអត្ថនៃបទទាំងនោះថា ប្រើក្នុងអត្ថនៃហេតុដូចក្នុងប្រយោគជាដើមថា* **បញ្ញាយ ចស្ស ឯស្ស អាសវា បរិក្ខីណា** *អាសវៈរបស់បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញា ដូច្នេះ ។ បទថា* **ឱលីយន្តិ ឯកេ** *សេចក្តីថា បុគ្គលមួយពួកដល់នូវការរួញចូល ដោយអំណាចការប្រកបខ្ជិនក្នុងកាមសុខ ។ បទថា* **អតិធាវន្តិ ឯកេ** *សេចក្តីថា បុគ្គលពួកខ្លះឈានកន្លងដោយអំណាចការប្រកបខ្ជិនឲ្យលំបាក ។ ពិតហើយ បុគ្គលប្រកបដោយកាមសុខ ឈ្មោះថា រមែងលិចចុះ ព្រោះដល់នូវការរួញចូលអំពីសម្មាបដិបត្តិ ដោយអំណាចការខ្ជិលច្រអូស ដោយមិនបានធ្វើសេចក្តីព្យាយាម ។ ចំណែកបុគ្គលប្រកបក្នុងការធ្វើខ្ជិនឲ្យក្តៅក្រហាយ ការលះនូវការខ្ជិលច្រអូស ធ្វើការប្រារព្ធសេចក្តីព្យាយាមដោយមិនមែនឧបាយ ឈ្មោះ*

ថា រមែងស្ទុះទៅ ព្រោះកន្ធងនូវសម្ចាបដិបត្តិ ។ បទទាំង ២ នោះ ឈ្មោះ ថា រមែងស្ទុះទៅ ព្រោះមិនឃើញទោសក្នុងអន្តធម៌ ២ យ៉ាងនោះ ដោយ ហេតុនោះ ទើបលោកពោលថា ព្រោះមិនដឹងអន្តធម៌ទាំង ២ យ៉ាង ទើបពួក ខ្ញុះលិចចុះ ពួកខ្ញុះស្ទុះទៅ ដូច្នេះ ។ ក្នុងពាក្យនោះ គប្បីជ្រាបថា លិចចុះ ដោយការត្រេកអរក្នុងតណ្ហា ស្ទុះទៅដោយការត្រេកអរក្នុងទិដ្ឋិ ។

ម្យ៉ាងទៀត ពួកខ្ញុះ រមែងលិចចុះ ដោយអំណាចសស្សតទិដ្ឋិ ពួកខ្ញុះ រមែងស្ទុះទៅដោយអំណាចឧច្ឆេទទិដ្ឋិ ។ ពិតហើយ បុគ្គលពួកខ្ញុះ ជាអ្នក ប្រកបដោយការធ្វើខ្ជូនឲ្យក្តៅ ដោយអំណាចគោសីលជាដើម កាលប្រកាន់ ដោយសស្សតទិដ្ឋិថា អាត្មាជាទេវតា ឬជាទេវតាអង្គណានីមួយដោយសីល នេះ ដោយវត្តនេះ ដោយតបៈនេះ ឬដោយព្រហ្មចរិយៈនេះ អាត្មាអញនឹង ជាបុគ្គលទៀង ស្ថិតស្ថេរ ពិតប្រាកដ មានការមិនប្រែប្រួលជាធម្មតា តាំង នៅជាប់តជានិច្ចយ៉ាងនោះក្នុងទេវលោកនោះ ឈ្មោះថា លិចចុះក្នុងសង្សារ ។ ចំណែកពួកខ្ញុះប្រកបក្នុងកាមសុខ ប្រកាន់ដោយឧច្ឆេទទិដ្ឋិ ដែលអនុលោម តាមសស្សតទិដ្ឋិនោះ ដូចអ្នកបំពេញវត្តក្នុងលោក បំណងធ្វើវត្ថុណាមួយ រួច ធ្វើឥន្ទ្រិយឲ្យក្តៅ ឈ្មោះថា ស្ទុះទៅ ព្រោះស្វែងរកការដាច់សូន្យនៃវដ្តៈ ដោយ មិនជាឧបាយ ។ គប្បីជ្រាបការលិចចុះ និងការស្ទុះទៅ ដោយអំណាច សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ដោយអាការយ៉ាងនេះ ។

បទថា **យេន ច ទោ តេ អភិញ្ញាយ** សេចក្តីថា ព្រះអរិយបុគ្គលពួក ណា ដឹងនូវអន្តធម៌ ២ យ៉ាងតាមដែលពោលហើយនោះ ដោយញាណដ៏

វិសេស គឺមគ្គប្បញ្ញា ដែលប្រកបដោយវិបស្សនាថា អន្តធម៌ទាំងនេះ ដែលអន្ធបុថុជ្ជនប្រកាន់ហើយយ៉ាងនេះ តាំងមាំហើយយ៉ាងនេះ មានគតិយ៉ាងនេះ មានអភិសម្បរាយភពយ៉ាងនេះ បដិបត្តិដោយប្រពៃនូវមជ្ឈិមប្បដិបទា ដោយសម្មាបដិបត្តិនោះ ។ បទថា **តត្រ ច ឆាហោសុំ** *បានដល់ មិនបានធ្លាក់ចូលទៅក្នុងអន្តធម៌ទាំង ២ នោះ អធិប្បាយថា លះអន្តធម៌ទាំង ២ នោះ ។ បទថា* **តេន ច ឆាមញ្ញឹសុ** *សេចក្តីថា ព្រោះលះអន្តធម៌យ៉ាងនោះ ព្រះអរិយ-បុគ្គល មិនបានសម្គាល់ដោយតណ្ហា ទដ្ឋិ និងមានះ ដោយន័យជាដើមថា នេះជាការលះអន្តធម៌នៃអាត្មាអញ អញបានលះអន្តធម៌ ២ យ៉ាងហើយ ព្រោះការលះអន្តធម៌នេះ ទើបឈ្មោះថា ប្រសើរ ព្រោះលះនូវការសម្គាល់ទាំងពួងបានដោយប្រពៃនោះឯង ។ ក្នុងទីនេះ ព្រោះសំដៅព្រះអរិយបុគ្គលដែលតាំងនៅក្នុងអរហត្តផល ទើបប្រកាសទេសនានេះ ដោយអំណាចអតីតកាលថា មិនបានធ្លាក់ទៅក្នុងទីបំផុត ២ យ៉ាងនោះ និងមិនបានសម្គាល់ដោយការលះទីបំផុត ២ យ៉ាងនោះ កាលលោកបំណងយកខណៈនៃមគ្គ ក៏ចាំបាច់ពោលដល់ដោយអំណាចបច្ចុប្បន្នកាលដូចគ្នា ។ បទថា* **វដ្តំ តេសំ ឆត្តិ បញ្ញាបនាយ** *សេចក្តីថា ជនទាំងឡាយណា ជាបុរសដ៏ឧត្តម លះនូវការសម្គាល់ទាំងអស់ចេញបាន ដោយអាការយ៉ាងនេះ កាលលោកទាំងនោះបរិនិព្វាន ដោយមិនមានពូជសេសសល់ វដ្តៈទាំង ៣ គឺកម្មវដ្ត វិបាកវដ្ត និងកិលេសវដ្ត រមែងមិនមានដោយបញ្ញត្ត អធិប្បាយថា ក្រោយអំពីខន្ធដែលជាបច្ចុប្បន្នរលត់ទៅ ព្រះអរិយបុគ្គលទាំងនោះ ក៏ដល់នូវភាវៈមិនមាន*

បញ្ចត្ត ដូចភ្លើងដែលអស់កំញ្ជរលត់ទៅ ដូច្នោះ ។

អដ្ឋកថា គណិកាសូត្រទី ៨ ចប់

សុត្តន្តបិដក

ឧចាតិសូត្រ

[១៤៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ក្នុងទីវាល ក្នុងរាត្រីមានឆងឹតអ័ព្ទ មានគេអុជប្រទីបថ្វាយ ។ សម័យនោះឯង សត្វមមាចជាច្រើន ហើរឆ្អៀលឆ្អាត់ ជិតប្រទីបប្រេងនោះ ដល់សេចក្តីមិនចម្រើន គឺទុក្ខ ដល់សេចក្តីវិនាស គឺស្លាប់ ដល់សេចក្តីមិនចម្រើន និងសេចក្តីវិនាស ។ ព្រះមានព្រះភាគ ទ្រង់បានឃើញសត្វមមាចច្រើនទាំងនោះ ហើរឆ្អៀលឆ្អាត់ ជិតប្រទីបប្រេងទាំងនោះ ដល់សេចក្តីមិនចម្រើន ដល់សេចក្តីវិនាស ដល់សេចក្តីមិនចម្រើន និងសេចក្តីវិនាស ។ លុះព្រះមានព្រះភាគ បានជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

សមណព្រាហ្មណ៍ទាំងឡាយ មិនទាន់បានត្រាស់ដឹងសារធម៌
មានសីលជាដើម រមែងប្រកាន់មាំ តែងញ៉ាំងចំណងថ្មីៗ គឺ
តណ្ហា និងទិដ្ឋិឲ្យចម្រើន រមែងធ្លាក់ (ក្នុងភ្នក់ភ្លើង គឺកត ៣)

ដូចជាសត្វមមាច ដែលធ្លាក់ចូលក្នុងអណ្តាតភ្លើង សមណ-ព្រាហ្មណ៍មួយពួក ប្រកាន់មាំក្នុងរូបដែលឃើញ និងសំឡេងដែលខ្ជូនឮហើយ ។ សូត្រទី ៩ ។

អដ្ឋកថា

ឧចាតិសូត្រ

ឧបាតិសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ

[១៤៥] *បទថា* **រត្តន្ធការតិមិសាយំ** *បានដល់ ងងឹត ដោយការងងឹតស្ទុះក្នុងរាត្រី ។ ពិតហើយ រាត្រី សូម្បីក្នុងថ្ងៃ ១៥ កើត ភ្លឺស្វាង ដោយពន្លឺព្រះចន្ទខាងខ្នើត ឈ្មោះថា រៀរចាកងងឹត សូម្បីការងងឹត ក៏មិនគួរពោលថា ងងឹតក្នុងពេលថ្ងៃ ប្រាសចាកការសៅហ្មង ដោយពពកជាដើម ។ ពិតហើយ ការងងឹត លោកហៅថា* **តិមិសា ។** *ការងងឹតនេះ គឺថ្ងៃលិចកណ្តាលយប់ ភ្លៀងធ្លាក់ និងគ្របដណ្តប់ដោយពពក ដោយហេតុនោះ ទើបលោកពោលថា បទថា* **រត្តន្ធការតិមិសាយំ** *បានដល់ ការងងឹតដោយការងងឹតស្ទុះក្នុងរាត្រី ដូច្នេះ ។*

បទថា **អព្ភោកាសេ** *បានដល់ ក្នុងឱកាសដែលមិនបិទបាំង បានដល់ទីលានវិហារ ។ បទថា* **តេលប្បទីបេសុ ឈាយមានេសុ** *បានដល់ កាលប្រទីបឆេះសន្ធោសន្ធៅដោយប្រេង ។*

សួរថា រស្មីមួយព្យាមរបស់ព្រះសាស្តាតាមប្រក្រតីផ្សាយទៅ អស់ទីប្រមាណមួយព្យាម សង្កត់នូវពន្លឺព្រះចន្ទ និងព្រះអាទិត្យ ពន្លឺរបស់ព្រះពុទ្ធដែលក្រាស់ តាំងឡើងកម្ចាត់ងងឹត សូម្បីព្រះរស្មីនៃព្រះវរកាយ ក៏បញ្ចេញរស្មីដ៏ក្រាស់ មានពណ៌ ៦ មានពណ៌ខៀវ និងលឿងជាដើមតាមប្រក្រតីនោះ ឯង ទាំងធ្វើទីប្រមាណ ៨០ ហត្ថ ដោយជុំវិញឲ្យភ្លឺ កាលបើដូច្នោះ ក្នុងឱកាសដែលព្រះមានព្រះភាគគង់ប្រថាប់ មានពន្លឺតែមួយ ដូចគ្នានឹងពន្លឺរបស់ព្រះពុទ្ធនោះឯង មិនចាំបាច់មានកិច្ច គឺការអុជប្រទីប មិនមែនឬ ឆ្លើយថា មិនមានក៏ពិត តែឧបាសកត្រូវការបុណ្យ ក៏ត្រូវអុជប្រទីបរាល់ៗ ថ្ងៃ ដើម្បីធ្វើការបូជាព្រះមានព្រះភាគ និងភិក្ខុសង្ឃ ។ សមដូចពាក្យដែលលោកពោលក្នុងសាមញ្ញផលសូត្រថា នុ៉ះន៏ប្រទីបទាំងឡាយ ដែលគេអុជតាំងនៅក្នុងរោងមានសណ្ឋានមូល ដូច្នេះ ពាក្យថា **រត្តនូការមិតិសាយំ** នេះ លោកពោលដើម្បីប្រាវព្ធដល់សេចក្តីពិតរបស់រាត្រីនោះ តែមិនបានពោល ដោយឱកាសដែលព្រះមានព្រះភាគគង់ប្រថាប់ ជាភាវៈដែលងងឹតនោះឡើយ ។ ពិតហើយ ដើម្បីធ្វើការបូជាប៉ុណ្ណោះ សូម្បីកាលនោះ ពួកឧបាសកក៏អុជប្រទីប ។

ក្នុងថ្ងៃនោះ ឧបាសកអ្នកក្រុងសាវត្ថីជាច្រើន ជម្រះរាងកាយអំពីព្រលឹមទៅកាន់វិហារ សមាទានអង្គឧបោសថ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានចូលទៅកាន់ព្រះនគរ ឲ្យមហាទានប្រព្រឹត្តទៅហើយ ជូនព្រះមានព្រះភាគ និងភិក្ខុសង្ឃត្រឡប់ហើយ ទៅកាន់ផ្ទះរៀងៗ ខ្លួន ។ បរិភោគដោយខ្លួនឯង ស្លៀកសំពត់រៀបរយ មានឧត្តរាសង្គធៀងស្មាម្ខាង កាន់គ្រឿងក្រអូប និងកម្រងផ្កា

ជាដើម នាំគ្នាទៅកាន់វិហារ បូជាព្រះមានព្រះភាគ ជនពួកខ្លះ ចូលទៅរកភិក្ខុ ដែលខ្លួនគាប់ចិត្ត ពួកខ្លះជាក់ចិត្តដោយយោនិសោមនសិការ នៅសម្ងំអស់មួយ ថ្ងៃ ។ ក្នុងពេលល្ងាច ឧបាសកទាំងនោះ ក៏ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះដ៏ មានព្រះភាគ កាលព្រះសាស្តាគង់ប្រថាប់លើបវរពុទ្ធាសនៈ ដែលរៀបចំ ក្នុងទីវាល កែ្បរព្រះគន្ធកុដិ តាំងអំពីមណ្ឌបនៃធម្មសភា កាលភិក្ខុសង្ឃចូល ទៅគាល់ អង្គុយជិតព្រះមានព្រះភាគហើយ ដើម្បីជម្រះឧបោសថឲ្យស្អាត និង ដើម្បីចម្រើនទូវយោនិសោមនសិការ ទើបមិនត្រឡប់ទៅកាន់ព្រះនគរ បំណង នឹងនៅក្នុងវិហារប៉ុណ្ណោះ ទើបនៅសល់ ។ គ្រានោះ ឧបាសកទាំងនោះ អុជ ប្រទីបដែលធ្វើអំពីប្រេងជាច្រើន ដើម្បីបូជាព្រះសាស្តា និងភិក្ខុសង្ឃ ហើយ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ផ្គងអញ្ជលីដល់ភិក្ខុសង្ឃ អង្គុយ ក្នុងទីបំផុតនៃភិក្ខុសង្ឃ សន្ទនាគ្នាថា នែអាវុសោ ពួកតិរ្ថិយទាំងនេះ ប្រកាន់ ទូវទិដ្ឋិផ្សេងៗ កាលបើដូច្នោះ ពួកខ្លះពោលថា ទៀង ពួកខ្លះពោលថា មិន ទៀង មិនតាំងនៅក្នុងទិដ្ឋិណាមួយ មានឧច្ឆេទទិដ្ឋិជាដើម ដូចមនុស្សឆ្កួត សរសើរទូវទិដ្ឋិថ្មីៗ ថា វត្តុនេះពិត វត្តុដទៃទេ តិរ្ថិយទាំងនោះដែលប្រកាន់ យ៉ាងនោះ មានគតិដូចម្តេចហ្ន៎ អភិសម្បរាយភពរបស់ពួកគេ ដូចម្តេចហ្ន៎ ។ សម័យនោះ មមាចជាច្រើន កាលធ្លាក់ចុះ ក៏ធ្លាក់ចុះត្រង់ប្រទីបប្រេងប៉ុណ្ណោះ ដោយហេតុនោះ ទើបលោកពោលថា សម័យនោះឯង សត្វមមាចជាច្រើន ហើរឆ្ងៀលឆ្ងាត់ ជិតប្រទីបប្រេងនោះ ។

បណ្តាបទទាំងនោះ បទថា **អធិចាតកា** *ប្រែថា មមាច លោកពោលថា*

សលភា ដូច្នេះក៏មាន ។ ពិតហើយ មមាចទាំងនោះ លោកបំណងយកថា ជាអធិបាតកា ព្រោះធ្លាក់ចុះក្នុងអណ្តាតភ្លើង ។ បទថា **អថាតបរិថាតំ** ចែកជា **អថាតំ បរិថាតំ** អធិប្បាយថា ធ្លាក់ចុះទូទៅ ធ្លាក់ចុះជុំវិញ គឺវិលធ្លាក់ចុះត្រង់មុខ ហើយធ្លាក់ចុះ ។ អាចារ្យពួកខ្លះពោលថា ធ្លាក់ចុះដោយជុំវិញក្នុងផ្លូវដែលទៅមក ។ អធិប្បាយថា ក្នុងផ្លូវដែលមក កាលមានប្រទីបនៅក្នុងផ្លូវមករបស់ខ្លួន ក៏ធ្លាក់ចុះ ។ បទថា **អនយំ** ប្រែថា ការមិនចម្រើន គឺសេចក្តីទុក្ខ ។ បទថា **ព្យសនំ** ប្រែថា ការវិនាស ។ ពិតហើយ ដោយបទដើម លោកសម្តែងដល់ទុក្ខស្ទើរតែស្លាប់ បន្ទាប់ លោកសម្តែងដល់ការស្លាប់របស់មមាចទាំងនោះ ។ ក្នុងមមាចទាំងនោះ មមាចខ្លះស្លាប់ព្រមគ្នានឹងការធ្លាក់ចុះ មមាចខ្លះក៏ដល់នូវសេចក្តីទុក្ខស្ទើរស្លាប់ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបដល់ការដែលមមាចទាំង-ទ្បាយមិនដឹងប្រយោជន៍ខ្លួន ដល់នូវការវិនាស ឥតប្រយោជន៍ ដោយសេចក្តីព្យាយាមរបស់ខ្លួននេះ ទើបទ្រង់បន្ទឺខទាននេះ សម្តែងដល់ការវិនាសរបស់ទិដ្ឋិគតិកបុគ្គល ដោយការប្រកាន់ខុសដូចមមាច ដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **ឧចាតិធាវន្តិ ន សារមេន្តិ** សេចក្តីថា មិនដល់នូវធម៌ដែលជាសារៈ មានសីល សមាធិ បញ្ញា និងវិមុត្តិជាដើម គឺមិនដល់ដោយការត្រាស់ដឹងសច្ចៈ ៤ តែកាលធម៌ដែលជាសារៈ មួយអន្ទើដោយខបាយនោះ កំពុងតាំងនៅនោះឯង ពួកជនទាំងនោះ ដូចជាចូលដល់នូវធម៌ដែលជាសារៈនោះ ព្រោះប្រាថ្នាធម៌ដែលជាគ្រឿងរួចផុត រមែងស្ទុះទៅ គឺហួស

ទៅ ដោយទិដ្ឋិវិបល្លាស អធិប្បាយថា ប្រកាន់មាំក្នុងខបាទានក្ខន្ធ ៥ ថា ទៀង ស្អាត សុខ មានតួខ្លួន ។ បទថា **ឆវំ ឆវំ ពន្ធនំ ព្រូហយន្តិ** សេចក្តីថា កាលប្រកាន់យ៉ាងនោះ ឈ្មោះថា រមែងចម្រើន គឺដុះដាលនូវធម៌ដែលជាគ្រឿងចងថ្មីៗ ពោល គឺតណ្ហា និងទិដ្ឋិ ។ បទថា **បតន្តិ បដ្ឋោតមិវា-ធិចាតា ឧដ្ឋេ សុតេ ឥតិហោកេ និវិដ្ឋា** សេចក្តីថា សមណព្រាហ្មណ៍មួយពួកព្រោះត្រូវគ្រឿងចង គឺតណ្ហា និងទិដ្ឋិចងយ៉ាងនេះ ទើបប្រកាន់ក្នុងរូបារម្មណ៍ដែលខ្លួនឃើញ គឺក្នុងរូបារម្មណ៍ដែលខ្លួនឃើញដោយចក្ខុវិញ្ញាណរបស់ខ្លួន ឬដោយទិដ្ឋិទស្សនៈរបស់ខ្លួននោះឯង និងក្នុងសទ្ទារម្មណ៍ដែលខ្លួនបានឲមកដោយហេតុត្រឹមតែបានឲ បានស្តាប់មកប៉ុណ្ណោះថា ព្រោះហេតុនោះឯង ធម៌នេះ រមែងយ៉ាងនេះដោយពិត ប្រកាន់ដោយន័យជាដើមថា វត្ថុទាំងពួង ទៀងដោយការប្រកាន់ខុស ឬកាលមិនដឹងធម៌ជាហេតុរលាស់ចេញ ដែលជាប្រយោជន៍ដោយចំណែកមួយ រមែងធ្លាក់ទៅក្នុងរណ្តៅរងើកភ្លើងតែម្យ៉ាងពោល គឺភព ៣ ដែលភ្លើង ១១ កង មានរាគៈជាដើមឆេះហើយ ដូចមមាចទាំងនេះធ្លាក់ក្នុងអណ្តាតភ្លើងនេះ ដូច្នេះ អធិប្បាយថា ជនទាំងនោះ មិនអាចងើបក្បាលឡើងបានអំពីរណ្តៅរងើកភ្លើងទាំងនោះ ។

អដ្ឋកថាឧចាតិសូត្រធី ៩ ចប់

សុត្តន្តបិដក

ឧបបជ្ជន្តិសូត្រ

[១៤៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះតថាគតទាំងឡាយ ជាអរហន្ត-សម្មាសម្ពុទ្ធ មិនទាន់កើតក្នុងលោកជាបណា ពួកអន្យតិ្ថយបរិព្វាជក មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារជាបានោះ បពិត្រព្រះអង្គដ៏ចម្រើន កាលណាបើព្រះតថាគតទាំងឡាយ ជាអរហន្តសម្មាសម្ពុទ្ធ កើតឡើងក្នុងលោក ពួកអន្យតិ្ថយបរិព្វាជក ដែលមិនមានគេធ្វើសក្ការៈ មិនមានគេគោរព មិនមានគេរាប់អាន មិនមានគេបូជា មិនមានគេកោតក្រែង ទាំងមិនបានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ក្នុងកាលនោះឯង បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រះមានព្រះភាគ ព្រះអង្គមានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ទាំងភិក្ខុសង្ឃ (ក៏ដូច្នោះដែរ) ។ ម្នាលអានន្ទ ដំណើរនុ៎ះយ៉ាងនោះហើយ ម្នាលអានន្ទ ដំណើរនុ៎ះយ៉ាងនោះហើយ ម្នាលអានន្ទ ព្រះតថាគតទាំងឡាយ ជាអរហន្តសម្មាសម្ពុទ្ធ មិនទាន់កើតឡើង

ក្នុងលោកជាបណា ពួកអន្យតិ្ថយបរិព្វាជកទាំងឡាយ ដែលគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារជាបនោះដែរ ម្នាលអានន្ទ កាលណាបើ ព្រះតថាគតទាំងឡាយ ជាអរហន្តសម្មាសម្ពុទ្ធ កើតឡើងក្នុងលោក ពួកអន្យតិ្ថយបរិព្វាជក មិនមានគេធ្វើសក្ការៈ មិនមានគេគោរព មិនមានគេរាប់អាន មិនមានគេបូជា មិនមានគេកោតក្រែង ទាំងមិនបានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ក្នុងកាលនោះឡើយ ឥឡូវនេះ តថាគតដែលគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ទាំងភិក្ខុសង្ឃ (ក៏ដូច្នោះដែរ) ។ លុះព្រះមានព្រះភាគ បានជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ព្រះអាទិត្យ មិនទាន់រះឡើងជារាបណា សត្វអំពិលអំពែកនោះ ក៏រុងរឿងជារាបនោះ កាលបើព្រះអាទិត្យរះឡើង សត្វអំពិលអំពែក ក៏សាបសូន្យពន្លឺ មិនរុងរឿងទេ ។ ព្រះសម្មាសម្ពុទ្ធទាំងឡាយ មិនទាន់កើតឡើងក្នុងលោកជារាបណា សេចក្តីរុងរឿងរបស់ពួកអន្យតិ្ថយ (តែងមាន) ជារាបនោះ តិ្ថយទាំងឡាយ រមែងមិនស្អាត ទាំងពួកសាវក ក៏មាន

ទិដ្ឋិអាក្រក់ មិនស្អាត មិនគប្បីរួចចាកទុក្ខ
បានឡើយ ។ សូត្រទី ១០ ។

ជចុក្កនិបាតទី ៦ ចប់

ខុទ្ទកនៃជចុក្កនិបាតនោះគឺ

និយាយអំពីការដាក់អាយុសង្ខារ ១ អំពីព្រះ
មានព្រះភាគ ទ្រង់ចេញអំពីទីស្ងាត់ ១ អំពី
រាគាទិក្កិលេសមានហើយ ១ អំពីពួកសមណ-
ព្រាហ្មណ៍ទាស់ទែងគ្នា អាស្រ័យទិដ្ឋិ ១ អំពី
ពួកសមណព្រាហ្មណ៍មានលទ្ធិផ្សេងៗ ១ អំពី
ការជាប់នៅក្នុងទិដ្ឋិទាំងនោះ ១ អំពីសុភូតិជា
គម្រប់ជ្រុំពីរ ១ អំពីការត្រេកអរក្នុងស្រីផ្កាមាស
១ អំពីសត្វមាមាចគម្រប់ជ្រុំបួន ១ អំពីព្រះ
តថាគតទាំងឡាយ កើតឡើងក្នុងលោក ជា
គម្រប់ដប់ ១ ។

អដ្ឋកថា

ឧបបជ្ជន្តិសូត្រ

ឧបបជ្ជន្តិសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ

[១៤៦] បទថា **យាវកីវំ** ប្រែថា អស់កាលមានប្រមាណត្រឹមណា ។ បទថា **យតោ** សេចក្តីថា ក្នុងកាលណា គឺតាំងអំពីកាលណា ឬថា ក្នុងកាលណា ដោយបទថា **ឯវមេតំ អានន្ទ** ទ្រង់សម្តែងថា អានន្ទ បទដែលអ្នកពោលថា កាលតថាគតកើតឡើង លាភ និងសក្ការៈ រមែងចម្រើនក្រៃលែងដល់ព្រះតថាគត និងដល់សាវ័ករបស់តថាគតប៉ុណ្ណោះ ឯពួកតិរ្ថិយជាអ្នកអស់នូវតេជៈ អស់នូវស្មី វិនាសលាភ និងសក្ការៈនោះ រមែងយ៉ាងនោះ សេចក្តីនោះ មិនក្លាយទៅជាដទៃឡើយ ពិតហើយ កាលចក្កវត្តន៍របស់ស្តេចចក្រពត្តិជ្រាកដ សត្វលោកលះចក្កវត្តន៍ មិនធ្វើការបូជា សក្ការៈ និងការរាប់អាន ឲ្យប្រព្រឹត្តទៅក្នុងទីដទៃ តែសត្វលោកទាំងអស់ តែងធ្វើសក្ការៈ គោរព រាប់អាន បូជាចក្កវត្តន៍ប៉ុណ្ណោះ ដោយការៈទាំងពួង ដូច្នោះ សូម្បីវិបាកដែលជាគ្រឿងហូរចេញ ត្រឹមតែជាបុណ្យ ដែលហូរជូនទៅតាមវដ្តៈ ក៏គង់មានអានុភាពច្រើនដល់ម្ល៉ោះ នឹងពោលទៅថ្វីដល់ពុទ្ធវត្តន៍ ធម្មវត្តន៍ សង្ឃវត្តន៍ ដែលទ្រទ្រង់នូវគុណប្រមាណមិនបាន ដែលជាគ្រឿងឧបការៈដល់កម្ចាំងរបស់បុណ្យ ដែលឲ្យផលរហូតដល់ព្រះនិព្វាននោះ ។

ពិតហើយ ព្រះមានព្រះភាគ កាលទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណហើយទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរ កាលព្រះអរហន្ត ៦១ អង្គ កើតឡើង

ក្នុងលោកតាមលំដាប់ ទើបទ្រង់បញ្ជូនព្រះអរហន្ត ៦០ អង្គ ដើម្បីចារិកទៅ
តាមជនបទ ហើយទ្រង់យាងទៅកាន់ឧរុវេលាប្រទេស ឲ្យជដិល ១០០០ នាក់
មានឧរុវេលកស្សបៈជាប្រធាន តាំងនៅក្នុងអរហត្ត ទ្រង់ចោមរោមដោយព្រះ
អរហន្តទាំងនោះ យាងទៅប្រថាប់គង់ត្រង់ឧទ្យានត្នោតជំទង់ ធ្វើអ្នកដែនអង្គៈ
និងមគធៈ មានព្រះបាទពិម្ពិសារជាប្រធាន ប្រមាណបាន ១២០០០០ នាក់
ឲ្យឈមចុះក្នុងព្រះសាសនា ក្នុងកាលដែលទ្រង់ប្រថាប់នៅក្នុងក្រុងរាជគ្រឹះ ។
ចាប់តាំងអំពីនោះ លាភ និងសក្ការៈរបស់ពួកតិរ្ថិយ រមែងសាបសូន្យចុះនោះ
ឯង ដោយប្រការដែលលាភ និងសក្ការៈចម្រើនក្រៃលែងឡើងដល់ព្រះមាន
ព្រះភាគ និងភិក្ខុសង្ឆ ។ ថ្ងៃមួយ ព្រះអានន្ទអង្គុយក្នុងទីសម្រាកពេលថ្ងៃ
ពិចារណាដល់សម្មាបដិបត្តិរបស់ព្រះមានព្រះភាគ និងព្រះអរិយសង្ឆ កើត
បីតិ និងសោមនស្ស ទើបពិចារណាដល់បដិបទារបស់តិរ្ថិយទាំងនោះថា កិច្ច
បដិបត្តិរបស់ពួកតិរ្ថិយដូចម្តេចហ្នឹ ។ លំដាប់នោះ កិច្ចបដិបត្តិអាក្រក់ដោយ
ប្រការទាំងពួងរបស់ពួកតិរ្ថិយទាំងនោះ ប្រាកដហើយដល់ព្រះអានន្ទ ។ ព្រះ
អានន្ទគិតថា កាលព្រះមានព្រះភាគ ទ្រង់មានអានុភាពច្រើនដល់ម្ដៃ៉ះ ទ្រង់
សម្រេចព្រះបារមីដ៏ឧត្តម នៃឧបនិស្សយរបស់បុណ្យ និងសម្មាបដិបត្តិ កាល
ព្រះអរិយសង្ឆតាំងនៅ ពួកតិរ្ថិយទាំងនេះ បែរជាបដិបត្តិអាក្រក់ដល់ម្ដៃ៉ះ មិន
ធ្លាប់ធ្វើបុណ្យ ដូចមនុស្សកំព្រា មិនមានលាភ ជាបុគ្គលដែលគេធ្វើសក្ការៈ
ដូចម្តេច ទើបកើតសេចក្តីករុណា ក្នុងការវិនាសលាភ និងសក្ការៈរបស់ពួក
តិរ្ថិយឡើង បន្ទាប់អំពីនោះ ទើបក្រាបទូលបរិវិតក្ការបស់ខ្លួនដល់ព្រះមាន

ព្រះភាគ ដោយន័យជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះតថាគតទាំង-ទ្បាយ ជាអរហន្តសម្មាសម្ពុទ្ធ មិនទាន់កើតទ្បើងក្នុងលោកជាតបណា ។ ព្រះមានព្រះភាគមិនបានត្រាស់នឹងអានន្ទថា ម្នាលអានន្ទ អ្នកមានបវិតក្កខុសហើយ ដូច្នេះហើយ ទើបតម្រង់ព្រះសូរងទ្បើង ដូចគ្នានឹងជន្ទាប់មាស ទ្រង់ធ្វើព្រះភក្ត្រឲ្យឆ្អែតល្អ ដូចផ្កាឈូកវីក គួរជ្រះថ្លាពន់ពេក ទ្រង់សោមនស្សថា សេចក្តីនោះយ៉ាងនោះឯងអានន្ទ ហើយទ្រង់អនុលោមតាមពាក្យរបស់ព្រះអានន្ទ ដោយន័យជាដើមថា **យាវកីវញ្ច** *ដូច្នេះ ។ ដោយហេតុនោះ ទើបលោកពោលថា គ្រានោះ ព្រះអានន្ទដ៏មានអាយុ ។បេ។ ទាំងភិក្ខុសង្ឃ (ក៏ដូច្នោះដែរ) ដូច្នេះជាដើម ។*

កាលអត្តុប្បត្តិហេតុនោះកើតទ្បើង ទើបព្រះមានព្រះភាគត្រាស់ជាតិវុ-ជាតកថា ក្នុងអតីតកាល តថាគតមិនទាន់កើតទ្បើង ជនជាន់ទាបពួកខ្លះបានទូវការរាប់អានច្រើន តាំងអំពីតថាគតកើតហើយ តិរ្ថិយទាំងនោះ ក៏បានជាអ្នកវិនាសលាភសក្ការៈ ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងនូវអត្ថនេះថា ទិដ្ឋិគតិកបុគ្គលមានសក្ការៈ និងការរាប់អានអស់កាល ដែលព្រះសម្មាសម្ពុទ្ធមិនទាន់កើតទ្បើងក្នុងលោក តាំងអំពីកាលដែលព្រះសម្មាសម្ពុទ្ធកើតទ្បើងហើយ ពួកជនទាំងនោះ ក៏សាបសូន្យចាកលាភសក្ការៈ អស់នូវស្មៅ មិនមានតេជៈ ហើយពួកជនទាំងនោះ មិនផុតទុក្ខទៅបាន ព្រោះបដិបត្តិអាក្រក់ ទើបទ្រង់បន្ទឹងទាននេះដើម្បីសម្តែងសេចក្តីនោះ ។*

បណ្តាបទទាំងនោះ បទថា **ឱកាសតិ តាវ សោ កិមិ** *សេចក្តីថា អំពិលអំពែកនោះ នៅរុងរឿងបញ្ចេញពន្លឺដរាបនោះ ។ បទថា* **យាវ ន ឧណ្ហោមតិ បភង្ករោ** *សេចក្តីថា ព្រះអាទិត្យ ឈ្មោះថា បភង្ករ ព្រោះធ្វើឲ្យមានពន្លឺក្នុងខណៈតែមួយ ក្នុងមហាទ្វីបទាំង ៤ មិនទាន់ចែងចាំង គឺមិនទាន់រះឡើងដរាបណា ។ ពិតហើយ កាលព្រះអាទិត្យមិនទាន់រះឡើង ពួកអំពិលអំពែកក៏បានឱកាសបញ្ចេញនូវពន្លឺ ដូចគ្នានឹងផ្លែឈើមានបន្លា រមែងបញ្ចេញពន្លឺក្នុងទីងងឹត ។ បទថា* **វោរោចនម្ហិ ឧគ្គតេ ហាតប្បភោ ហោតិ ន ចាបិ ភាសតិ** *សេចក្តីថា កាលព្រះអាទិត្យដែលមានឈ្មោះវិរោចនៈ ព្រោះមានសការៈចែងចាំនូវពន្លឺ ដោយរស្មីផ្សាយចេញ ១០០០ ដួង កម្ចាត់កាពងងឹត ដោយជុំវិញហើយ អំពិលអំពែកក៏អស់រស្មី មិនមានតេជៈ មានពណ៌ខ្មៅ មិនភ្លឺ មិនចាំងពន្លឺ ដូចការងងឹតក្នុងរាត្រី ។ បទថា* **យាវ ឱកាសិតមេវ តិត្តិយានំ** *សេចក្តីថា អំពិលអំពែកនោះ មុនព្រះអាទិត្យរះឡើង រមែងមានពន្លឺ យ៉ាងណា ពួកតិរ្ថិយដែលបានឈ្មោះតក្កិកា ព្រោះកាន់យកនូវទិដ្ឋិ ដោយហេតុត្រឹមតែការត្រិះរិះកំណត់យកពន្លឺ គឺការចែងចាំងដោយតេជៈនៃលទ្ធិរបស់ខ្លួន ដរាបណា ព្រះសម្មាសម្ពុទ្ធមិនទាន់កើតឡើងក្នុងលោក ។ បទថា* **ន តក្កិកា សុជ្ឈន្តិ ន ចាបិ សាវកា** *សេចក្តីថា ក្នុងគ្រាដែលព្រះសម្មាសម្ពុទ្ធទ្រង់កើតឡើងក្នុងលោក ទិដ្ឋិគតិកបុគ្គលរមែងមិនបរិសុទ្ធ រមែងមិនស្អាត សូម្បីសាវករបស់ទិដ្ឋិគតិកបុគ្គលនោះ ក៏មិនស្អាត តែក៏ត្រូវកម្ចាត់រស្មី មិនប្រាកដ ដូចព្រួញដែលបាញ់ទៅក្នុងកណ្តាលយប់ ។ ម្យ៉ាងទៀត ព្រះសម្មាសម្ពុទ្ធ មិន*

ទាន់កើតឡើងក្នុងលោកដរាបណា ពួកតិរ្ថិយក៏នៅមានពន្ធឺតាមលទ្ធិរបស់ខ្លួន ក្រោយអំពីនោះ ក៏មិនមានពន្ធឺ ។ ព្រោះហេតុអ្វី ព្រោះពួកតិរ្ថិយមិនបរិសុទ្ធផង សាវ័ករបស់តិរ្ថិយក៏មិនបរិសុទ្ធផង ព្រោះពួកតិរ្ថិយទាំងនោះពោលធម្ម-វិន័យមិនល្អ មិនមានកិច្ចបដិបត្តិប្រពៃ រ័មេងមិនបរិសុទ្ធ ចាកសង្សារទៅបាន ព្រោះពាក្យប្រៀនប្រដៅ មិនជាគ្រឿងនាំចេញចាកទុក្ខ ។ ដោយហេតុនោះ ទើបត្រាស់ថា ក៏មានទិដ្ឋិអាក្រក់ មិនស្អាត មិនគប្បីរួចចាកទុក្ខបានឡើយ ។ ពិតហើយ ពួកតិរ្ថិយទាំងឡាយ ឈ្មោះថា មានទិដ្ឋិលាមក គឺមានទិដ្ឋិប្រកាន់ខុស បានដល់ មានការយើញខុស ព្រោះមិនមានលទ្ធិតាមសេចក្តីពិត មិន លះបង់ទិដ្ឋិនោះហើយ ក្នុងកាលណាមួយឡើយ ក៏មិនផុតចាកទុក្ខ ក្នុង សង្សារបានឡើយ ។

អដ្ឋកថាឧបបជ្ជន្តិសូត្រធី ៧០ ចប់

ជចូនូវគ្គធី ៦ ចប់

សុត្តន្តបិដក

ឧទាន ចូឡវគ្គទី ៧

ភទ្ទិយសូត្រ

[១៤៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ បានពន្យល់ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាច្រើនប្រការ ។ លំដាប់នោះ ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ដែលព្រះសារីបុត្តដ៏មានអាយុ ពន្យល់ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាច្រើនប្រការហើយ ចិត្តក៏រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ដែលព្រះសារីបុត្តដ៏មានអាយុពន្យល់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាច្រើនប្រការ ចិត្តក៏រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំហើយ ។ លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់សេចក្តីនុ៉ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> បុគ្គលរួចស្រឡះចាកសង្ខារទាំងពួង ក្នុងចំណែកខាងលើ គឺរូបធាតុ និងអរូបធាតុ ក្នុងចំណែកខាងក្រោម គឺកាមធាតុ មិនឃើញថា នេះជាអាត្មាអញ លុះរួចស្រឡះយ៉ាងនោះហើយ ក៏បានឆ្ងងអន្ទង់ (ទាំង ៤) ដែលខ្ជួនមិនធ្នាប់ឆ្ងង មិនប្រព្រឹត្តទៅដើម្បីភពថ្មីទៀតឡើយ ។ សូត្រទី ១ ។

អដ្ឋកថា

ចូឡវគ្គទី ៧

បឋមភទ្ទិយសូត្រ

បឋមភទ្ទិយសូត្រទី ១ នៃចូឡវគ្គទី ៧ មានវិនិច្ឆ័យដូចតទៅនេះ

[១៤៧] *បទថា* **ភទ្ទិយោ** *ក្នុងពាក្យថា* **លកុណ្ឌកភទ្ទិយំ** *នេះ ជាឈ្មោះរបស់លោកមានអាយុអង្គនោះ ។ ព្រោះលោកមានរូបវាងទាប ទើបគេស្គាល់លោកថា លកុណ្ឌកភទ្ទិយៈ ។*

បានឮមកថា លោកជាកុលបុត្រអ្នកក្រុងសាវត្ថី មានទ្រព្យច្រើន មានភោគៈច្រើន តែមានរូបវាងមិនគួរជ្រះថ្លា មានពណ៌សម្បុរមិនល្អ មិនគួរមើល ហើយទាបតឿ ។ ថ្ងៃមួយ កាលព្រះសាស្តាប្រថាប់នៅក្នុងវត្តជេតពន លោកមួយអន្ទើដោយឧបាសក ទៅកាន់វិហារ ស្តាប់ធម្មទេសនា បាននូវសទ្ធាបព្វជ្ជា និងឧបសម្បទាហើយ រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តា បំពេញវិបស្សនា សម្រេចសោតាបត្តិផលហើយ ក្នុងកាលនោះ ពួកភិក្ខុដែលជាសេក្ខបុគ្គលដោយច្រើន ចូលទៅរកព្រះសារីបុត្រ សូមកម្មដ្ឋាន សូមស្តាប់នូវធម្មទេសនា សូរបញ្ហាដើម្បីមគ្គខាងលើ ។ ព្រះសារីបុត្រកាលនឹងធ្វើបំណងនៃភិក្ខុទាំងនោះឲ្យបរិបូណ៌ ទើបសម្តែងធម៌ ប្រាប់កម្មដ្ឋាន និងដោះស្រាយប្រស្នា ។ ភិក្ខុទាំងនោះព្យាយាម ពួកខ្លះសម្រេចសកទាគាមិផល ពួកខ្លះសម្រេចអនាគាមិផល ពួកខ្លះសម្រេចអរហត្តផល ពួកខ្លះបាននូវវិជ្ជា ៣ ពួកខ្លះបាននូវអភិញ្ញា ៦ ពួកខ្លះបាននូវបដិសម្ភិទា ៤ ។ ឯព្រះលកុណ្ឌក-

ភទ្ទិយៈ ឃើញហេតុនោះហើយ ដល់នូវភាពជាសេក្ខបុគ្គល ក៏ស្គាល់កាល និងកំណត់ ទីដែលខ្ជិនខ្វះខាតក្នុងផ្លូវចិត្ត ចូលទៅរកព្រះធម្មសេនាបតី បានទទួលបដិសណ្ឋារៈហើយ និមន្តឲ្យសោកសម្តែងធម្មទេសនា ។ ឯព្រះធម្ម-សេនាបតីក៏បានសម្តែងធម៌ដ៏សមគួរដល់អធ្យាស្រ័យរបស់លោក ។ ដោយហេតុនោះ ទើបលោកពោលថា សម័យនោះឯង ព្រះសារីបុត្រដ៏អាយុ បានពន្យល់ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ច្រើនប្រការ ។

បណ្តាបទទាំងនោះ បទថា **អេកបរិយាយេន** *សេចក្តីថា ដោយហេតុច្រើនយ៉ាងនេះថា ព្រោះហេតុនេះ ទើបបញ្ចក្ខន្ធ ជារបស់មិនទៀង ព្រោះហេតុនេះ ទើបបញ្ចក្ខន្ធជាទុក្ខ ព្រោះហេតុនេះ ទើបបញ្ចក្ខន្ធជាអនត្តា ។ បទថា* **ធម្មិយា កថាយ** *បានដល់ ដោយធម្មីកថាដែលប្រកាសការកើត និងការរលត់ទៅជាដើមនៃឧបាទានក្ខន្ធ ៥ ។ បទថា* **សន្ទស្សេតិ** *បានដល់ សម្តែងដោយប្រពៃនូវលក្ខណៈ មានអនិច្ចលក្ខណៈជាដើមទាំងនោះឯង និងញាណមានឧទយព្វយញ្ញាណជាដើម គឺសម្តែងដោយប្រចក្ស ដូចយកដៃចាប់ ។ បទថា* **សមាទបេតិ** *សេចក្តីថា ឲ្យកាន់យកដោយប្រពៃនូវវិបស្សនា ដែលមានលក្ខណៈជាអារម្មណ៍ ក្នុងលក្ខណៈទាំងនោះ គឺឲ្យកាន់យកដោយប្រការដែលចិត្តប្រព្រឹត្តទៅតាមវិថី ។ បទថា* **សម្បហំសេតិ** *សេចក្តីថា កាលផ្តើមវិបស្សនា កាលឧទយព្វយញ្ញាណជាដើមនៃសង្ខារច្រាកដ លោករមែងញុំាងវិបស្សនាឲ្យឈមចុះកាន់វិថី ដែលជាខ្សែកណ្តាល ដោយអនុវត្តតាមពោជ្ឈង្គ ដោយការ*

ផ្តន ការសង្កត់ និងការពិចារណាតាមកាល ហើយញ្ចុំងវិបស្សនាចិត្តឲ្យកើតនូវការអាចហ៊ាន ដោយប្រពៃ គឺឲ្យផូរផង់ហើយ ដោយការធ្វើវិបស្សនាចិត្តឲ្យបរិសុទ្ធ ព្រោះធ្វើឥន្ទ្រិយឲ្យបរិសុទ្ធ ដូចវិបស្សនាញាណនាំមកនូវភាពជាធម្មជាតចាស់ក្លា ផូរផង់ ដូច្នោះ ។ បទថា **សម្ឋហំសេតិ** សេចក្តីថា រមែងញ្ចុំងចិត្តឲ្យត្រេកអរដោយប្រពៃ ឬឲ្យត្រេកអរដោយល្អ ដោយការត្រេកអរដែលបានមកដោយការចម្រើនវិបស្សនា ដែលឲ្យប្រព្រឹត្តទៅយ៉ាងនោះ ឲ្យប្រព្រឹត្តទៅដោយស្មើ ដោយកម្លាំងនៃភាវនា ដែលគប្បីបានខ្ពស់ក្រៃលែងឡើងទៅ ។ បទថា **អនុចាធាយ អាសវេហិ ចិត្តំ វិមុច្ចិ** សេចក្តីថា កាលលោកពិចារណាលក្ខណៈដែលពិត ញ្ចុំងញាណឲ្យប្រព្រឹត្តទៅតាមក្រសែទេសនាព្រោះលោកដល់នូវការចាស់ក្លានៃញាណ តាមអានុភាពទេសនានៃព្រះថេរ: និងព្រោះខ្ជូនសម្ឈូរដោយឧបនិស្សយ ដោយប្រការដែលព្រះធម្មសេនាបតីសម្តែងធម៌ ចិត្តរបស់លោកមិនប្រកាន់អាសវៈណាមួយ មានកាមាសវៈជាដើម រួចផុតដោយសមុច្ចេទតាមលំដាប់នៃមគ្ត អធិប្បាយថា ធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។

បទថា **ឯតមត្តំ វិធិត្វា** សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងនូវអត្តនេះ ពោល គឺព្រះលកុណ្ឌកភទ្ទិយៈត្រេកអរក្នុងអរហត្តផលហើយ ទើបបន្ទឺឧទាននេះ ដែលសម្តែងដល់សេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **ឧធុំ** បានដល់ ក្នុងរូបធាតុ និងអរូបធាតុ ។ បទថា **អធោ** ប្រែថា ក្នុងកាមធាតុ ។ បទថា **សព្វធិ** ប្រែថា ក្នុងសង្ខារទាំង

អស់ ។ បទថា **វិប្បមុត្តោ** *បានដល់ រួចផុតហើយ ដោយប្រការទាំងពួង ដោយវិក្ខម្ភនវិមុត្តិក្នុងចំណែកខាងដើម និងដោយសមុច្ឆេទវិមុត្តិ និងបដិ-បស្សទ្ធិវិមុត្តិ ក្នុងចំណែកខាងចុង ។ ក្នុងបទទាំងនោះ បទថា* **ឧច្ចំវិប្បមុត្តោ** *នេះ ទ្រង់សម្តែងដល់ការលះសំយោជន: ដែលជាចំណែកខាងលើ ៥ ។ បទថា* **អធោ វិប្បមុត្តោ** *នេះ ទ្រង់សម្តែងដល់ការលះសំយោជន:ដែលជាចំណែកខាងក្រោម ៥ ពាក្យថា* **សព្វធិ វិប្បមុត្តោ** *នេះ ទ្រង់សម្តែងដល់ការលះអកុសលទាំងពួងដ៏សេស ។ ម្យ៉ាងទៀត បទថា* **ឧច្ចំ** *ជាសព្ទសម្តែងអនាគតកាល ។ បទថា* **អធោ** *ជាសព្ទសម្តែងអតីតកាល ។ ដោយសព្ទទាំង ២ នោះឯង ជាការកាន់យកបច្ចុប្បន្នទ្វា ព្រោះទាក់ទងរវាងអតីតកាល និងអនាគតកាល ។ ក្នុងសព្ទទាំង ២ នោះ ដោយអនាគតកាលសព្ទ ជាការកាន់យកខន្ធ អាយតន: ធាតុ ដែលជាអនាគត ។ ក្នុងបទដ៏សេសក៏នយនេះដូចគ្នា ។ បទថា* **សព្វធិ** *បានដល់ ក្នុងភពទាំងពួង មានកាមភពជាដើម ។ មានពាក្យអធិប្បាយដូចតទៅនេះថា រួចផុតហើយក្នុងភពទាំងពួង ដែលសង្គ្រោះដោយកាលទាំង ៣ នេះ គឺអនាគតកាល អតីតកាល និងបច្ចុប្បន្នកាល ។ បទថា* **អយមហាស្មីតិ អធានុបស្សី** *សេចក្តីថា បុគ្គលណារួចផុតយ៉ាងនេះ បុគ្គលនោះរមែងមិនតាមឃើញក្នុងរូប វេទនាជាដើមយ៉ាងនេះ ដោយសម្គាល់ដោយអំណាចទិដ្ឋិ និងមានះថា អញជាធម៌ឈ្មោះនេះ អធិប្បាយថា បុគ្គលនោះមិនមានហេតុក្នុងទស្សន:ដូច្នោះ ។ ម្យ៉ាងទៀត បទថា* **អយមហាស្មីតិ អធានុបស្សី** *នេះ ជាបទសម្តែងឧបាយជាគ្រឿងសម្រេចវិមុត្តិតាមដែលពោល*

ហើយ ។ វិបស្សនាដែលជាវុដ្ឋានគាមិនី ដែលជាចំណែកខាងដើម ដែលធ្វើ នូវការមិនតាំងមាំដោយការសម្គាល់ ដែលមានសភាវៈ ដែលប្រព្រឹត្តទៅក្នុង សង្ខារ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលសង្គ្រោះដោយកាល ៣ ថា នុ៎ះ របស់អញ អញជារបស់នុ៎ះ នុ៎ះជាខ្លួនរបស់អញ ហើយកើតឡើងយ៉ាងនេះ ថា នុ៎ះមិនមែនរបស់អញ អញមិនមែនរបស់នុ៎ះ នុ៎ះមិនមែនខ្លួនរបស់អញ ដូច្នោះ វិបស្សនានោះ ជាបទដ្ឋាននៃវិមុត្តិ ។ បទថា **ឃវំ វិមុត្តោ ខុនតារិ ឳឃំ អតិណ្ណាបុព្វំ អបុនព្ភវាយ** *សេចក្តីថា ព្រះអរហន្តអ្នកឆ្លងផុតហើយ ដោយប្រការទាំងពួងចាកសំយោជនៈ ១០ និងចាកអកុសលទាំងពួង ដោយ ប្រការដូច្នេះ ។ ឈ្មោះថា ជាអ្នកឆ្លងឱឃៈ ៤ យ៉ាងនេះ គឺ កាមោឃៈ ១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១ ដែលខ្លួនមិនធ្លាប់ឆ្លង ដោយហោច សូម្បីយល់សប្តិក្នុងកាលមុន អំពីការសម្រេចអរិយមគ្គ ឬឆ្លង គឺឆ្លងផុតឱឃៈ ធំ គឺសង្ខារនោះឯង ដោយមិនមានភពថ្មី គឺដោយអនុបាទិសេសនិព្វានធាតុ អធិប្បាយថា ឆ្លងផុត តាំងនៅក្នុងត្រើយ ។*

អដ្ឋកថា បឋមភទ្ទិយសូត្រទី ១ ចប់

សុត្តន្តបិដក

ទុតិយភទ្ទិយសូត្រ

[១៤៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ សម្គាល់ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុថាជាសេក្ខៈ ក៏ពន្យល់ឲ្យយើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ច្រើនប្រការ មានប្រមាណដ៏ក្រៃលែង ។ កាលព្រះមានព្រះភាគ ទ្រង់បានយើញព្រះសារីបុត្តដ៏មានអាយុ សម្គាល់ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ថាជាសេក្ខៈ ក៏ពន្យល់ឲ្យយើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ច្រើនប្រការ មានប្រមាណដ៏ក្រៃលែង ។ លុះព្រះមានព្រះភាគ បានជ្រាបច្បាស់សេចក្តីនុ៉ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> បុគ្គលបានកាន់ផ្តាច់វដ្ត បានដល់ព្រះនិញ្ចាន មិនមានតណ្ហា
> ស្ទឹងរីងស្ងួត មិនហូរទៅ យ៉ាងណា កិលេសវដ្ត ដែល
> បុគ្គលកាត់ហើយ រមែងមិនប្រព្រឹត្តទៅ (យ៉ាងនោះដែរ)
> នេះជាទីបំផុតទុក្ខ ។ សូត្រទី ២ ។

អដ្ឋកថា

ទុតិយភទ្ទិយសូត្រ

ទុតិយភទ្ទិយសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ

[១៤៨] បទថា **សេក្ខោតិ មញ្ញមានោ** បានដល់ សម្គាល់ថា ព្រះភទ្ទិយៈនេះជាព្រះសេក្ខៈ ក្នុងពាក្យនោះ មានវចនត្ថៈដូចតទៅនេះ ឈ្មោះថា **សេក្ខៈ** ព្រោះត្រូវសិក្សា ។ សិក្សាអ្វី គឺសិក្សាអធិសីល អធិចិត្ត និង អធិបញ្ញា ។ ម្យ៉ាងទៀត ការសិក្សា ឈ្មោះថា **សិក្ខា** ការសិក្សានោះ ជាប្រក្រតីរបស់បុគ្គលនោះ ហេតុនោះ បុគ្គលនោះឈ្មោះថា ជាអ្នកមានការសិក្សា ។ ពិតហើយ បុគ្គលនោះឈ្មោះថា មានការសិក្សាជាប្រក្រតីដោយចំណែកមួយ ព្រោះមានការសិក្សាមិនទាន់ចប់ និងព្រោះបង្អោនចិត្តទៅក្នុងការសិក្សានោះ តែមិនមែនចប់ការសិក្សាដូចព្រះអសេក្ខៈ បុគ្គលរម្ងាប់ការខ្វល់ខ្វាយក្នុងការសិក្សានោះ ទាំងមិនមែនជាអ្នកលះនូវការសិក្សា ដូចជនច្រើនដែលមិនបង្អោនចិត្តទៅក្នុងការសិក្សានោះ ។ ម្យ៉ាងទៀត ឈ្មោះថា **សេក្ខៈ** ព្រោះកើតសិក្ខា ៣ ឬមានក្នុងសិក្ខា ៣ នោះ ដោយអរិយជាតិ ។

បទថា **ភិយ្យោសោ មត្តាយ** ប្រែថា ក្រៃលែងដោយប្រមាណ អធិប្បាយថា ក្រៃលែងហួសប្រមាណ ។

ពិតហើយ ព្រះលកុណ្ឌកភទ្ទិយៈអង្គុយនៅតាមប្រក្រតីនោះឯង សម្រេចនូវធម៌ជាគ្រឿងអស់ទៅនូវអាសវៈ ដោយឱវាទដ៏បួងតាមវិធីដូចពោលក្នុងសូត្រទី ១ ។ ឯព្រះធម្មសេនាបតី មិនជ្រាបការសម្រេចអរហត្តនោះរបស់

លោក ព្រោះមិនបានអាវជ្ជនៈដល់ សម្គាល់ថា នៅជាព្រះសេក្ខៈនៅឡើយ ដូចបុរសដែលមានចិត្តទូលាយ គេសូមបន្តិចក៏ឲ្យច្រើនដូច្នោះ រមែងសម្តែងធម៌ដើម្បីអស់អាសវៈ ដោយអនេកបរិយាយក្រៃលែងឡើងៗ នោះឯង ។ ឯព្រះលកុណ្ឌកភទ្ទិយៈ ក៏មិនបានគិតថា ឥឡូវនេះ អញធ្វើកិច្ចស្រេចហើយ នឹងមានប្រយោជន៍អ្វីដោយឱវាទនេះ ទើបស្តាប់ដោយគោរព ដូចក្នុងកាលមុន នោះឯង ព្រោះគោរពក្នុងព្រះសទ្ធម្ម ។ ព្រះមានព្រះភាគ ទ្រង់ឃើញដូច្នោះ គង់ប្រថាប់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ធ្វើឲ្យព្រះធម្មសេនាបតីជីងធម៌ដែលជាទីអស់ទៅនូវកិលេសរបស់លោក ដោយពុទ្ធានុភាព ទើបទ្រង់ចន្ទឹខទាននេះ ។ ដោយហេតុនោះ ទើបលោកពោលថា **តេន ខោ បន សមយេន** *ជាដើម ។*

ពាក្យដែលគប្បីពោលក្នុងសេចក្តីនោះ ខ្ញុំបានពោលហើយ ក្នុងអនន្តរ-សូត្រ (សូត្រដែលមិនចន្ទោះ) គឺសូត្រទី ១ នោះឯង ។

ក្នុងគាថា មានវិនិច្ឆ័យដូចតទៅនេះ បទថា **អច្ឆេច្ឆិ វដ្តំ** *សេចក្តីថា កាត់នូវកិលេសវដ្តបានជាសមុច្ឆេទ កាលកាត់កិលេសវដ្តបានហើយ ក៏ឈ្មោះថាកាត់កម្មវដ្តបានផងដែរ ។ តណ្ហា លោកហៅថា* **អាសា** *ព្រោះសង្ឃឹម ក្នុងពាក្យថា* **ឥច្ចាគា និរាសំ** *នេះ ព្រះនិព្វាន ឈ្មោះថា* **និរាស** *ព្រោះមិនមានសង្ឃឹម ឈ្មោះថា* **ឥច្ចាគា** *ព្រោះដល់ គឺសម្រេចនិព្វាន ដែលប្រាសចាកសេចក្តីសង្ឃឹមនោះដោយពិសេស ។ អធិប្បាយថា ព្រោះសម្រេចអរហត្តមគ្គហើយ ទើបឈ្មោះថា សម្រេចដោយវៀរចាកហេតុនៃការសម្រេចទៀត ។*

ព្រោះតណ្ហាជាហេតុកើតនៃទុក្ខ កិលេស ឈ្មោះថា លោកលះមិនទាន់បានដោយការលះនោះ រមែងមិនមាន ដូច្នោះ កាលនឹងសម្តែងការលះតណ្ហាឲ្យពិសេសដល់លោក ទើបត្រាស់ថា តណ្ហាដែលបុគ្គលឲ្យរីងស្ងួតហើយតែងមិនហូរទៅ ដូច្នេះជាដើម ។

ពាក្យនោះ មានអធិប្បាយដូចតទៅនេះ ស្ទឹង គឺតណ្ហាដែលបុគ្គលឲ្យរីងស្ងួត ដោយមិនមានចំណែកសល់ ដោយផ្លូវមគ្គញ្ញាណទី ៤ ឲ្យកើតឡើងដូចស្ទឹងធំរីងស្ងួតទៅ ព្រោះប្រាកដព្រះអាទិត្យដួងទី ៤ ក្នុងឥឡូវនេះ រមែងមិនហូរទៅ គឺតាំងអំពីនេះទៅ រមែងមិនប្រព្រឹត្តទៅ ។ តណ្ហា លោកហៅថា **សរិតា** *ដូចលោកពោលក្នុងធម្មបទថា សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្តីស្រឡាញ់ផង រមែងមានដល់សត្វ ... ដូច្នេះ ។*

និងព្រះតម្រាស់ថា តណ្ហាដែលផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ដូចវល្លិ ។ បទថា **ឆិន្នំ វដ្តំ ឧ វត្តតិ** *សេចក្តីថា វដ្តៈដែលកាត់ផ្តាច់ហើយ ដោយការកាត់ផ្តាច់កិលេសវដ្តយ៉ាងនេះ កម្មវដ្តដែលកាត់ផ្តាច់ដោយការឲ្យដល់ ឲ្យដល់នូវការមិនកើតឡើងជាសភាវៈ និងការមិនមានវិបាកជាសភាវៈ រមែងមិនប្រព្រឹត្តទៅ គឺរមែងមិនកើត ។ បទថា* **ឯសេវន្តោ ឧក្ខុស្ស** *សេចក្តីថា ការមិនប្រព្រឹត្តទៅនៃកម្មវដ្ត ព្រោះកិលេសវដ្តមិនមាន ដោយប្រការទាំងពួងនោះ គឺការមិនកើតឡើងនៃវិបាកវដ្តតទៅ ដោយចំណែកមួយ ដោយហោចជាដែនកំណត់ ជាភាវៈដែលវិលវល់នៃសង្សារទុក្ខទាំងមូល ។*

សុត្តន្តបិដក

បឋមកាមសូត្រ

[១៤៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យ នោះឯង ពួកមនុស្សក្នុងក្រុងសាវត្ថី ជាប់ជំពាក់ក្នុងកាមទាំងឡាយហួស វេលាដោយច្រើន ជាអ្នកត្រេកអរ ចង់បាន ជាប់ចិត្ត វង្វេង ងល់ងប់ ស្រវឹងខ្វាំងក្នុងកាមទាំងឡាយ ។ លំដាប់នោះ ពួកភិក្ខុជាច្រើនរូបស្ងៀក ស្បង់ ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាតក្នុង ក្រុងសាវត្ថី ។ លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីរួចហើយ ត្រឡប់ អំពីបិណ្ឌបាតវិញ ក្នុងវេលាខាងក្រោយភត្ត រួចចូលទៅគាល់ព្រះមាន ព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយក៏អង្គុយក្នុង ទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំ ទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សក្នុងក្រុងសាវត្ថី នេះ ជាប់ជំពាក់ក្នុងកាមទាំងឡាយ ហួសពេលដោយច្រើន ជាអ្នកត្រេកអរ ចង់បាន ជាប់ចិត្ត វង្វេង ងល់ងប់ ស្រវឹងខ្វាំងក្នុងកាមទាំងឡាយ ។ លុះព្រះ មានព្រះភាគ ទ្រង់ជ្រាបសេចក្តីន៉ុះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលា នោះថា

> ពួកបុគ្គលជាប់នៅក្នុងកាមទាំងឡាយ ឈ្មោះថា អ្នកជាប់
> នៅក្នុងគ្រឿងជាប់ជំពាក់ គឺកាម កាលបើមិនឃើញទោស

ក្នុងសំយោជនៈ ។

ឈ្មោះថា អ្នកជាប់នៅក្នុងគ្រឿងជាប់ជំពាក់ គឺសំយោជនៈ ធ្ងន់ អន្ទង់ដ៏ធំទូលាយ មិនបានដោយពិត ។ សូត្រទី ៣ ។

អដ្ឋកថា

បឋមកាមសូត្រ

បឋមកាមសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

[១៤៩] *បទថា* **កាមេសុ** *បានដល់ ក្នុងវត្ថុកាម ។ បទថា* **អតិវេលំ** *បានដល់ ហួសកាល ។ បទថា* **សត្តា** *បានដល់ សត្វ អធិប្បាយថា បុគ្គលជាប់ គឺជំពាក់ដោយមិនឃើញទោសដែលមាន រឭកដល់តែការត្រេកអរ ជាប់ជំពាក់ ព្រោះច្រើនទៅដោយអយោនិសោមនសិការ ។ បទថា* **រត្តា** *ឈ្មោះថា ត្រេកអរហើយ គឺតម្រេកហើយដោយឆន្ទរាគៈ ដែលជាគ្រឿងធ្វើចិត្តឲ្យប្រែប្រួល ដូចសំពត់ប្រែប្រួលទៅ ដោយការជ្រលក់ពណ៌ ដូច្នោះ ។ បទថា* **គិទ្ធា** *សេចក្តីថា ជាប់ គឺដល់នូវតម្រេក ដោយការសម្លឹងដែលមានការសង្ឃឹមជាសភាវៈ ។ បទថា* **គធិតា** *សេចក្តីថា ទាក់ទងក្នុងកាមនោះ ព្រោះភាវៈដែលដោះបានលំបាក ដូចក្រងទុក ។ បទថា* **មុច្ឆិតា** *សេចក្តីថា មិនមានកិច្ចដទៃ គឺដល់នូវការវង្វេងដោយអំណាចកិលេស ដូចបុគ្គលសន្លប់ ដូច្នោះ ។ បទថា* **អជ្ឈោបន្នា** *សេចក្តីថា លេបឲ្យសម្រេចតាំងនៅ ធ្វើឲ្យ*

ជួចវត្តុដែលមិនទូទៅដល់អ្នកដទៃ ។ បទថា **សម្ផុត្តកជាតា** *សេចក្តីថា ដល់នូវភាពជាអ្នកងប់ងល់ក្នុងកាមទាំងឡាយ គឺជាអ្នកស្រើងក្នុងសុខវេទនា មានប្រមាណតិច ។ ជាលីថា* **សម្ផោឧកជាតា** *ជួចេះក៏មាន អធិប្បាយថា កើតនូវការត្រេកអរ គឺកើតនូវការរីករាយចិត្ត ដោយបទទាំងអស់ លោកពោលដល់ភាពដែលជនទាំងនោះស្រើងដោយតណ្ហានោះឯង ក្នុងសូត្រនេះ ពាក្យដើម លោកពោលថា* **កាមេសុ** *ហើយពោលដដែលថា* **កាមេសុ** *ទៀត ក៏ដើម្បីសម្តែងថា សត្វទាំងនោះ មានចិត្តបង្អោនទៅក្នុងកាមនោះ ដោយពាក្យនោះ លោកសម្តែងថា សត្វទាំងនោះ ជាអ្នកដល់ព្រមដោយកាមគុណក្នុងគ្រប់ឥរិយាបថ ។*

បានឮមកថា សម័យនោះ វៀរព្រះអរិយសាវ័កចេញ អ្នកក្រុងសាវត្ថីទាំងអស់ឃោសនាដល់ការលេងមហោស្រព ត្រៀមផ្ទៃដីដែលលេងទៅតាមកម្លាំងសម្បត្តិដែលមាន ស៊ីផឹក បរិភោគកាមទាំងក្នុងទីវាល និងក្នុងទីកំបាំងបម្រើឥន្ទ្រិយ ដល់នូវការងប់ងល់ក្នុងកាមទាំងឡាយ ។ ពួកភិក្ខុទាំងឡាយនាំគ្នាត្រាច់បិណ្ឌបាតក្នុងក្រុងសាវត្ថី ឃើញមនុស្សក្នុងផ្ទះនោះៗ និងក្នុងសួនជាទីត្រេកអរជាដើម នាំគ្នាឃោសនាការលេងមហោស្រព មានចិត្តបង្អោនទៅក្នុងកាម បដិបត្តិយ៉ាងនោះ នាំគ្នាគិតថា អញទីងទៅវិហារ បានស្តាប់ធម្ម-ទេសនាដែលល្អិតសុខុម ជួចេះហើយ ទើបក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ សម្ពហុលា ភិក្ខូ ។បេ។ កាមេសុ វិហរន្តិ** *ជួចេះ ។*

បទថា **ឯតមត្ថំ វិចិត្វា** *សេចក្តីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំងពួង ដល់នូវភាពដែលមនុស្សទាំងនោះ មិនឃើញទោសក្នុងកាមទាំងឡាយ ដែលគួរខ្ជាច អត់ធន់មិនបាន និងមានផលក្តៅក្រហាយ មានទីលេងដែលគួរឹកពាយ មានការក្តៅក្រហាយច្រើន ដែលការវិនាសជាអនេកជាប់តាមចងនេះ ទើបទ្រង់បន្ទឺឧទាននេះ ដែលប្រកាសទោសនៃកាម និងកិលេស ។*

បណ្តាបទទាំងនោះ បទថា **កាមេសុ សត្តា** *សេចក្តីថា បុគ្គលតម្រេកស្រើង ជាប់ជំពាក់ មានចិត្តរាយមាយ ជាប់ ជាប់ជំពាក់ ប្រកបក្នុងវត្ថុកាមដោយកិលេសកាម ។ បទថា* **កាមសង្គសត្តា** *សេចក្តីថា ឈ្មោះថា ជាអ្នកជំពាក់ គឺមកជាប់ដោយគ្រឿងជាប់ គឺរាគៈ និងគ្រឿងជាប់ គឺទិដ្ឋិ មានះ ទោសៈ និងអវិជ្ជា ក្នុងវត្ថុកាម ដោយការជាប់ក្នុងកាមនោះឯង ។ បទថា* **សំយោជនេ វជ្ជមបស្សមានា** *សេចក្តីថា មិនឃើញទោស គឺទោសៈ បានដល់អាទីនវ ដែលឈ្មោះថា មានវដ្តទុក្ខជាមូលជាដើម ព្រោះមានប្រក្រតីឃើញតាមការត្រេកអរ ក្នុងធម៌ដែលជាគ្រឿងប្រកបសត្វក្នុងកិលេស មានកាមរាគៈជាដើម ដែលបានឈ្មោះថា សំយោជនៈ ព្រោះប្រកប គឺលាមនូវកម្មវដ្ត ដោយវិបាកវដ្ត ឬកពជាដើម ដោយកពជទៃជាដើម ឬសត្វទាំងឡាយដោយទុក្ខ ។ បទថា* **ន ហិ ជាតុ សំយោជនសង្គសត្តា ទុឃំ តរេយ្យុំ វិបុលំ មហន្តំ** *សេចក្តីថា សត្វទាំងឡាយដែលជាប់ជំពាក់ក្នុងធម៌ជាគ្រឿងជាប់ជំពាក់ ដែលមានសំយោជនៈជាសភាវៈ ព្រោះមិនមានការឃើញទោសយ៉ាងនេះ ឬជាប់ជំពាក់នៅក្នុងធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជា*

អារម្មណ៍នៃធម៌ជាគ្រឿងជាប់ជំពាក់ទាំងនោះ ដោយធម៌ជាគ្រឿងជាប់ជំពាក់ពោល គឺសំយោជនៈក្នុងកាលណាមួយ ក៏ឆ្ងងមិនបាននូវឱឃៈ មានកាមជាដើម ដែលឈ្មោះថា ទូលាយ ក្រាស់ និងធំ ឬឱឃៈ គឺសង្សារនោះឯង ព្រោះមានអារម្មណ៍ទូលាយ និងមិនមានកាលខាងដើម អធិប្បាយថា មិនគប្បីដល់ត្រើយនៃឱឃៈនោះ ដោយចំណែកមួយនោះឯង ។

អដ្ឋកថា បឋមកាមសូត្រទី ៣ ចប់

សុត្តន្តបិដក

ទុតិយកាមសូត្រ

[១៥០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកមនុស្សក្នុងក្រុងសាវត្ថី ជាប់នៅក្នុងកាមទាំងឡាយដោយច្រើន ជាអ្នកត្រេកអរ ចង់បាន ជាប់ចិត្ត វង្វេង ងល់ងប់ ងងឹត ស្រវឹងខ្ជាំង ក្នុងកាមទាំងឡាយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រ ចីវរហើយ ស្តេចចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញមនុស្សទាំងនោះ ក្នុងក្រុងសាវត្ថី ជាប់នៅក្នុងកាមទាំងឡាយ ជាច្រើន ចង់បាន ជាប់ចិត្ត វង្វេង ងល់ងប់ ងងឹត ស្រវឹងខ្ជាំង ក្នុងកាមទាំង-ឡាយ ។ លុះព្រះមានព្រះភាគ ជ្រាបច្បាស់សេចក្តីនុ៉ះហើយ ទើបទ្រង់បន្ទឺ

ឧទាននេះ ក្នុងវេលានោះឯង

ជនទាំងឡាយ ដែលងងឹត ព្រោះកាម ដែលបណ្តាញ គឺតណ្ហា រួបរឹត ត្រូវដំបូល គឺតណ្ហាបិទបាំង ជាប់នៅដោយកិលេសមារ ដូចជាពួកត្រីនៅក្នុងលប តែងដល់នូវជរានិងមរណៈ ដូចជាកូនគោនៅជៅដោះ តែងចូលទៅរកមេ ។ សូត្រទី ៤ ។

អដ្ឋកថា

ទុតិយកាមសូត្រ

ទុតិយកាមសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

[១៥០] *បទថា* **អដ្ឋីកតា** *សេចក្តីថា ឈ្មោះថា* **កាម** *ព្រោះធ្វើបុគ្គលមិនងងឹត ឲ្យងងឹត ដូចលោកពោលក្នុងឥតិវុត្តកៈថា*

បុគ្គលអ្នកលោភ ព្រោះមិនស្គាល់ប្រយោជន៍ បុគ្គលអ្នកលោភ ព្រោះមិនឃើញធម៌ សេចក្តីលោភ គ្របសង្កត់នរជន ក្នុងកាលណា សេចក្តីងងឹតជ្រាលជ្រៅ ក៏កើតឡើងក្នុងកាលនោះ ។

ព្រោះហេតុនោះ ទើបឈ្មោះថា **អដ្ឋីកតា** *ព្រោះត្រូវកាមគ្របសង្កត់បុគ្គលមិនងងឹត ឲ្យជាបុគ្គលងងឹត ។ ពាក្យដ៏សេសមានន័យដូចពោលហើយក្នុងសូត្រជាប់តគ្នានោះឯង ។ ក្នុងសូត្រនោះ ពួកភិក្ខុឃើញការប្រព្រឹត្តទៅនៃមនុស្ស ទើបក្រាបទូលដល់ព្រះមានព្រះភាគ ។ ក្នុងសូត្រនេះមានការប្លែកគ្នា

ប៉ុណ្ណោះថា ព្រះមានព្រះភាគ ទ្រង់ឃើញដោយព្រះអង្គឯងនោះឯង ។

ព្រះសាស្តាយាងចេញអំពីក្រុងសាវត្ថី ទៅកាន់វត្តជេតពន ក្នុងរវាងផ្លូវ ទ្រង់ទតឃើញត្រីជាច្រើន មិនអាចចូលកាន់លប ដែលពួកអ្នកប្រមង់ជាក់ ក្នុងស្ទឹងអចិរវតី ក្នុងកាលតមក ទ្រង់បានឃើញកូនគោ ដែលមិនទាន់ជាប់ ដោះ ជាប់តាមមេគោទៅ អើតកចូលទៅដើម្បីបៅដោះ បង្អោនមាត់ចូលទៅ ក្នុងចន្ទោះជើងមេ លំជាប់នោះ ព្រះមានព្រះភាគ យាងចូលទៅកាន់វិហារ លាងព្រះបាទទាំងទ្វេហើយ គង់ប្រថាប់លើបវរពុទ្ធាសន:ដែលគេបានផ្ចិតផ្ចង់ ទ្រង់កាន់យក ២ រឿង ខាងក្រោយជាឧបមារបស់រឿងមុន ទើបទ្រង់បន្ទឹ ឧទាននេះ ។

បណ្តាបទទាំងនោះ បទថា **កាមង្គា** *បានដល់ ធ្វើនូវការងងឹតក្នុងវត្ថុកាម ដោយកិលេស មិនឲ្យមើលឃើញ ។ បទថា* **ជាលសញ្ឆន្នា** *សេចក្តីថា ដេរដាស ជាប់ជំពាក់ បានដល់ ត្រូវតណ្ហាដូចសំណាញ់គ្របសង្កត់ ព្រោះ កើតឡើងបន្តទៅដោយភព អារម្មណ៍ខាងក្រោម និងខាងលើ ក្នុងអត្តភាព របស់ខ្លួន និងអ្នកដទៃ ក្នុងអាយតន:ខាងក្នុង និងខាងក្រៅ និងក្នុងធម៌ដែល អាស្រ័យអាយតន:ខាងក្នុង ខាងក្រៅនោះ មានធម៌ច្រើនប្រភេទ ដោយកាល មានអតីតកាលជាដើម និងនាំមកនូវអនត្តដល់បុគ្គលដែលលិចចុះខាងក្នុង ដូច ជំនន់ទឹកធំដែលព័ទ្ធដោយសំណាញ់ក្រឡាញឹក ។ បទថា* **តណ្ហា ឆទន-ជាឥតា** *បានដល់ ដែលគេបិទបាំង គឺបិទបាំងដោយគ្រឿងបិទបាំង គឺតណ្ហា ដូចទឹកដែលចកបិទ ដូច្នោះ ។ ដោយ ២ បទនេះ លោកសម្តែងដល់ការនាំ*

កុសលចិត្ត ដែលកាមច្ឆន្ទនីវរណៈរារាំង ។ បទថា **បមត្តពន្ធុនា ពន្ធ្ន** *បានដល់ បុគ្គលដែលកិលេសមារ និងទេវបុត្តមារចង ។ ពិតហើយ បុគ្គលដែលត្រូវកិលេសមារចងដោយអារម្មណ៍ណា ក៏ឈ្មោះថា ត្រូវទេវបុត្តមារចងដោយអារម្មណ៍នោះ ។ សមដូចពាក្យដែលលោកពោលក្នុងសំយុត្តនិកាយសគាថវគ្គថា*

អន្ទាក់ គឺរាគៈណា ដែលគ្រាច់ទៅលើអាកាស តែងតែប្រព្រឹត្តទៅក្នុងចិត្ត ខ្ញុំនឹងបៀតបៀនព្រះអង្គ ដោយអន្ទាក់នោះ បពិត្រព្រះសមណៈ ព្រះអង្គមិនរួច (ចាកវិស័យ) របស់ខ្ញុំឡើយ ។

បទទាំង ៣ គឺ **ឆមុចិ កណ្ហោ បមត្តពន្ធុ** *ជាឈ្មោះរបស់មារ ។ ព្រោះទេវបុត្តមារ ក៏ឈ្មោះថា* **បមត្តពន្ធុ** *ព្រោះចងសត្វអ្នកប្រមាទ ដោយសេចក្តីវិនាស ដូចកិលេសមារ ដូច្នោះ ។ អាចារ្យពួកខ្លះពោលថា* **បមត្តា ពន្ធនេ ពទ្ធ្ន** *ដូច្នេះក៏មាន ។*

បណ្តាបទទាំងនោះ បទថា **ពន្ធនេ** *សេចក្តីថា ក្នុងគ្រឿងចង គឺកាមគុណ បទថា* **ពទ្ធ្ន** *បានដល់ ដែលត្រូវកំណត់ ។ ប្រៀបដូចអ្វី ដូចត្រីក្នុងមាត់លប អធិប្បាយថា ត្រីទាំងឡាយចូលទៅកាន់មាត់លបដែលអ្នកប្រមង់ជាក់ជាត្រីដែលជាប់លប រមែងទៅ គឺដល់នូវសេចក្តីស្លាប់ យ៉ាងណា សត្វទាំងនេះក៏ដូច្នោះដូចគ្នា ត្រូវចងដោយចំណង គឺកាមគុណដែលមារជាក់ រមែងចូលដល់ជរា និងមរណៈនោះឯង ដូចកូនគោដែលមិនទាន់ជាប់ដោះ ជាប់តាមមេគោទៅ ដូច្នោះ អធិប្បាយថា ដូចកូនគោដែលមិនទាន់ជាប់ដោះ រមែងជាប់*

តាម គឺទៅតាមមេរបស់ខ្លួន មិនទៅតាមគោជទៃ យ៉ាងណា សត្វដែលត្រូវចងដោយគ្រឿងចង គឺមារ ក៏ដូច្នោះ កាលអនោ្ទាលទៅក្នុងសង្សារ រមែងជាប់តាម គឺទៅតាមមរណៈតែម្យ៉ាង មិនទៅតាមអមតមហានិញ្ចាន គឺការមិនស្លាប់ទ្បើយ ។

អដ្ឋកថាឧតិយកាមសូត្រទី ៤ ចប់

សុត្តន្តបិដក

លកុណ្ឌកភទ្ទិយសូត្រ

[១៥១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ អំពីខាងក្រោយៗ នៃពួកភិក្ខុជាច្រើន ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញ ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ មានរូបប្លែក មិនគួរជ្រះថ្លា ទាបកន្ត្ញ មានរូបគួរឲ្យភិក្ខុជាច្រើន ចាប់ពាល់លេង កំពុងដើរមកអំពីខាងក្រោយៗ នៃពួកភិក្ខុជាច្រើន អំពីចម្ងាយ លុះឃើញហើយ ទ្រង់ត្រាស់នឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញភិក្ខុន៉ុះដែលមានរូបប្លែក មិនគួរជ្រះថ្លា ទាបកន្ត្ញ មានរូបគួរឲ្យភិក្ខុជាច្រើន ចាប់ពាល់លេង កំពុងដើរមក អំពីខាងក្រោយៗ នៃពួកភិក្ខុជាច្រើន អំពីចម្ងាយដែរឬ ។ ភិក្ខុទាំងឡាយ ក្រាប

បង្គំទូលថា ព្រះកវុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនុ៎ះមានឫទ្ធិច្រើន មានអានុភាពច្រើន សមាបត្តិណាដែលភិក្ខុនោះមិនធ្លាប់បាន សមាបត្តិនោះ មិនមែនបុគ្គលបានដោយងាយទេ កុលបុត្តទាំងឡាយ ចេញចាកផ្ទះទៅបួសក្នុងផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ភិក្ខុនោះបានត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ បានដល់អនុត្តរធម៌នោះ មានព្រហ្មចរិយៈជាទីបំផុត ដោយខ្លួនឯង ក្នុងបច្ចុប្បន្នបាន ។ លុះព្រះមានព្រះភាគជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

រថ គឺអត្តភាព មានអវយវៈឥតទោស មានដំបូលស មានកាំតែមួយ រមែងប្រព្រឹត្តទៅបាន អ្នកចូរមើលអត្តភាព (នោះ) មានខ្សែ គឺតណ្ហាកាត់ហើយ មិនមានចំណង មិនមានទុក្ខ កំពុងដើរមក ។ សូត្រទី ៥ ។

អដ្ឋកថា

លកុណ្ឌកភទ្ទិយសូត្រ

លកុណ្ឌកភទ្ទិយសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ

[១៥១] *បទថា* **សម្ពហុលានំ ភិក្ខូនំ បិដ្ឋិតោ បិដ្ឋិតោ** *សេចក្តីថា ថ្ងៃមួយ ព្រះលកុណ្ឌកភទ្ទិយៈ មួយអន្ទើដោយភិក្ខុដ៏ច្រើន ត្រាច់បិណ្ឌបាតក្នុងចន្លោះស្រុក ឆាន់ភត្តាហារស្រេចហើយ លាងបាត្រដាក់ក្នុងស្លោក ស្ពាយត្រង់ស្មា បត់ចីវរ ពាក់ចីវរនោះត្រង់ស្មាឆ្វេង មានការឈានទៅ ឈានថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលឆ្វេង-ស្តាំ បត់ អង្កុញ លាតសណ្តូក គួរជ្រះថ្លា មានភ្នែកជាក់ចុះ សម្បូរដោយឥរិយាបថ ជួចប្រកាសនូវការសម្បូរដោយសតិ និងបញ្ញារបស់ខ្លួន តាំងសតិ និងសម្បជញ្ញៈ មានចិត្តជាសមាធិ ឈានទៅ កាលនឹងទៅតាមក្រោយភិក្ខុទាំងឡាយ មិនប្រឡាក់ប្រឡូសដោយភិក្ខុទាំងនោះ ។ ព្រោះហេតុអ្វី ព្រោះជាបុគ្គលដែលនៅដោយការមិនច្រឡូកច្រឡំ ។ ម្យ៉ាងទៀត បុថុជ្ជនទាំងឡាយរមែងមើលងាយរូបរបស់លោកថា គួរមើលងាយ ជាទីតាំងនៃការមើលងាយ ។ ព្រះថេរៈដឹងដូច្នោះ ទើបដើរទៅខាងក្រោយ ដោយគិតថា ភិក្ខុទាំងនេះ កុំបានទទួវបាបព្រោះអាស្រ័យអាត្មាអញឡើយ ។ ភិក្ខុទាំងនោះ និងព្រះថេរៈ ដល់ក្រុងសាវត្ថី ចូលទៅកាន់វិហារ គាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ដោយប្រការដូច្នេះ ។ ដោយហេតុនោះ ទើបលោកពោលថា* **តេន ខោ បន សមយេន អាយស្មា លកុណ្ឌកភទ្ទិយោ** *ជួច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **ធុញ្ញណ្ណំ** បានដល់ រូបគួរខ្ពើម ។ ដោយពាក្យនោះ លោកសម្តែងដល់ព្រះថេរ: មិនមានការដល់ព្រមដោយវណ្ណ: និងដល់ព្រមដោយទ្រង់ទ្រាយ ។ បទថា **ធុធូសឿកំ** ប្រែថា ឃើញហើយមិនគួរជ្រះថ្លា ។ ដោយបទនោះ សម្តែងដល់លោក មិនមានការបរិបូណ៌ដោយអនុព្យញ្ជន: និងការសម្ឃូរដោយអាការ ។ បទថា **ឧកោដិមកំ** ប្រែថា តឿ ដោយពាក្យនេះ ទ្រង់សម្តែងដល់ព្រះថេរ: មិនមានការសម្ឃូរដោយកម្ពស់ ។ បទថា **យេភុយ្យេន ភិក្ខូនំ បរិភូតរូបំ** បានដល់ មានរូបរាងដែលភិក្ខុបុថុជ្ជនទាំងឡាយមើលងាយ ។ ភិក្ខុបុថុជ្ជនពួកខ្លះ ដូចជាធព្វគ្គិយជាដើម កាលមិនដឹងគុណរបស់លោក ចាប់ស្ទាបអង្អែលត្រង់ដៃ និងស្លឹកត្រចៀកជាដើមលេង និងមើលងាយ ព្រះអរិយ: ឬកល្យាណបុថុជ្ជនមិនមើលងាយឡើយ ។

បទថា **ភិក្ខូ អាមន្តេសិ** សេចក្តីថា ត្រាស់ហៅភិក្ខុមកធ្វើអ្វី ។ ធ្វើយថាដើម្បីប្រកាសគុណរបស់ព្រះថេរ: ។ បានញ្ចថា ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះយ៉ាងនេះថា ភិក្ខុទាំងនេះមិនដឹងថា បុត្រតថាគត មានអានុភាពច្រើនព្រោះហេតុនោះ ទើបនាំគ្នាមើលងាយ សេចក្តីនោះនឹងប្រព្រឹត្តទៅដើម្បីវត្ថុមិនមែនប្រយោជន៍ ដើម្បីទុក្ខអស់កាលយូរដល់ភិក្ខុទាំងនោះ ណ្ហើយចុះ តថាគតនឹងប្រកាសគុណរបស់ភិក្ខុនេះ ដល់ភិក្ខុទាំងឡាយ ហើយនឹងដោះភទ្ទិយ:ឲ្យផុតអំពីការមើលងាយ ។

បទថា **បស្សថ នោ** ប្រែថា ពួកអ្នកចូរមើល ។ បទថា **ន ច សាសមាបត្តិ សុលភ្យចា យា តេន ភិក្ខុនា អសមាបន្នបុព្វា** សេចក្តីថា

ឈ្មោះថា សមាបត្តិណាមួយ ដែលទូទៅដល់សាវក មានប្រភេទយ៉ាងនេះ គឺរូបសមាបត្តិ អរូបសមាបត្តិ ព្រហ្មវិហារសមាបត្តិ និរោធសមាបត្តិ និង ផលសមាបត្តិ ក្នុងសមាបត្តិទាំងនោះ សមាបត្តិណាមួយ មិនមែនបានដោយ ងាយ គឺដោយលំបាក ។ លកុណ្ឌកភទ្ទិយភិក្ខុនោះ មិនធ្លាប់ចូលសមាបត្តិ នោះមិនមានឡើយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគកាលទ្រង់ប្រកាស ភាពដែលព្រះថេរៈនោះមានឫទ្ធិច្រើន ក្នុងពាក្យដែលត្រាស់ថា **មហិទ្ធិកោ មហានុភាវោ** *ឥឡូវនេះ ដើម្បីប្រកាសភាពដែលលោកមានអានុភាពច្រើន ទើបត្រាស់ពាក្យជាដើមថា* **យស្ស ចត្ថាយ** *ជួច្នេះ ។ ពាក្យនោះមានន័យដូច ពោលហើយ ខាងដើមនោះឯង ។*

ក្នុងពាក្យទាំងនោះ ដោយពាក្យថា **ឯសោ ភិក្ខវេ ភិក្ខុ** *ជាដើម ព្រះ មានព្រះភាគទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ មិនមែនភិក្ខុសាមញ្ញ បុគ្គលមិនគួរមើលងាយ ដោយហេតុត្រឹមតែជាអ្នកមានរូបគួរខ្ពើម មិនគួរមើល ជាមនុស្សតឿ ឬថា ដើរតាមក្រោយភិក្ខុទាំងឡាយ ដោយពិត ជាភិក្ខុមានឫទ្ធិ ច្រើន មានអានុភាពច្រើន សេចក្តីពិត វត្ថុណាមួយ ដែលសាវកគប្បីដល់ វត្ថុទាំងអស់នោះ ភិក្ខុនេះដល់ហើយដោយលំដាប់ ព្រោះដូច្នោះ ទើបធ្វើភិក្ខុ នោះឲ្យធ្ងន់ ដូចធត្រឫ ហើយទើបសម្ងំមើល សេចក្តីនោះនឹងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខអស់កាលយូរដល់អ្នកទាំងឡាយ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួង នូវ គំនរនៃគុណរបស់ព្រះលកុណ្ឌកភទ្ទិយៈ មានភាពជាអ្នកមានឫទ្ធិច្រើន មាន*

អានុភាពច្រើនជាដើមនេះ ទើបទ្រង់បន្ទឺឧទាននេះ ដែលសម្តែងសេចក្តីនោះ ។

ទោស លោកហៅថា **ឯល** *ក្នុងបទថា* **ឯលឆ្គោ** *នេះ ក្នុងព្រះគាថានេះ ។ ទោសនៃពាក្យនោះមិនមាន ហេតុនោះ ទើបពាក្យនោះ ឈ្មោះថា* **ឯលំ។ ឯល** *នោះ គឺអ្វី គឺសីលដែលបរិសុទ្ធដោយល្អ ។ ពិតហើយ សីលដែលបរិសុទ្ធដោយល្អនោះ លោកបំណងយកថា ជា* **ឯល** *ក្នុងព្រះគាថានេះ ព្រោះអត្ថថា មិនមានទោស ។ កិក្ខុឈ្មោះថា* **ឯលឆ្គ** *ព្រោះមានអង្គដែលជាប្រធានដែលមិនមានទោស ។ ភ្ជាប់សេចក្តីដោយពាក្យដែលលោកពោលដោយវថ ។ ព្រោះដូច្នោះ ជាអ្នកមានអង្គ គឺសីលដែលបរិសុទ្ធដោយល្អ ។ ពិតហើយ សីលដែលសម្បយុត្តដោយអរហត្តផល លោកបំណងយកក្នុងទីនេះ អត្តភាពដូចវថ ឈ្មោះថា* **សេតបច្ឆាឌោ** *ព្រោះមានដំបូលពណ៌ស ។ បទថា* **បច្ឆាឌោ** *បានដល់ សំពត់កម្ពលជាដើម ដែលក្រាលលើវថ ។ វថ គឺអត្តភាពនោះ មានពណ៌សក្តី មានពណ៌ក្រហមក្តី ខៀវក្តី ពណ៌ណាមួយ ព្រោះមានការៈសបរិសុទ្ធដោយល្អ តែក្នុងទីនេះ លោកពោលថា* **សេត-បច្ឆាឌោ** *មានដំបូលស ព្រោះអាស្រ័យការៈដែលបរិសុទ្ធដោយល្អ ព្រោះបំណងយកការរួចផុត ដោយអរហត្តផល ដូចឧបមាថា វថមានគ្រឿងបរិក្ខារពណ៌ស ។ កាំ ១ គឺសតិរបស់វថនោះមាន ហេតុនោះ វថនោះ ឈ្មោះថា មានកាំ ១ ។ បទថា* **វត្តតិ** *បានដល់ រមែងប្រព្រឹត្តទៅ ។ ដោយបទថា* **វថោ** *នេះ ទ្រង់ត្រាស់សំដៅដល់អត្តភាពរបស់ព្រះថេរៈ ។*

បទថា **អនីឃំ** *ប្រែថា មិនមានទុក្ខ អធិប្បាយថា វៀរចាកការកម្រើក*

នៃកិលេស ដូចយានដែលវៀរចាកការកម្រើក ដូច្នោះ ។ បទថា **អាយន្តំ** បានដល់ មកខាងក្រោយ គឺក្រោយភិក្ខុជាច្រើន ។ បទថា **ឯឡសោតំ** បានដល់ កាត់ក្រសែហើយ ។ ពិតហើយ ក្រសែនៃសប្បិ និងប្រេងជាដើមដែលលាបត្រង់ក្បាល ភ្លៅ និងជុំ ហូរទៅ គឺជ្រួតជ្រាបទៅ ដើម្បីឲ្យរថតាមប្រក្រតីស្ទុះទៅស្រួល ព្រោះដូច្នោះ ទើបរថនោះឈ្មោះថា មានក្រសែមិនជាប់ ។ តែរថនេះ ឈ្មោះថា ជាប់ក្រសែហើយ ព្រោះលះក្រសែកិលេស ៣៦ បានជាសមុច្ឆេទ ។ នូវរថដែលជាប់ក្រសែហើយនោះ ។ ឈ្មោះថា **អពន្ធនោ** ព្រោះរថនោះមិនមានចំណង ។ ពិតហើយ ចំណងទាំងឡាយរបស់រថ មានគ្រឿងប្រកប មួយអន្ទើដោយភ្លៅ រមែងមានច្រើន ដើម្បីធ្វើមិនឲ្យរថនោះរង្គោះរង្គើ ដោយហេតុនោះ ទើបរថនោះ ឈ្មោះថា មានគ្រឿងចង ។ តែរថនេះ ឈ្មោះថា មិនមានចំណង គឺសំយោជន:ទាំងពួងអស់ទៅ មិនមានសេសសល់ ។ នូវរថដែលមិនមានគ្រឿងចងនោះ ។ ព្រះមានព្រះភាគទ្រង់បានទទួលសោមនស្សដោយគុណរបស់ព្រះថេរៈ ទើបត្រាស់ហៅដោយព្រះតម្រាស់ថា ចូរមើល ។

ព្រះសាស្តាទ្រង់សម្តែងព្រះលកុណ្ឌកភទ្ទិយៈ ឲ្យជាអ្នកមានចក្រដោយល្អ ដោយលើកអរហត្តផលឡើងជាប្រធាន ឲ្យជាបុគ្គលមានវត្ថុកំពាំង ឆ្ងងផុតហើយដោយល្អ ដោយវិមុត្តិ ដែលសម្បយុត្តដោយអរហត្តផល ឲ្យជាបុគ្គលមានកំពាំងដោយល្អ ដោយសតិដែលតាំងមាំដោយល្អ ឲ្យជាអ្នកមិនកម្រើក ព្រោះកិលេសជាគ្រឿងកម្រើកមិនមាន ឲ្យជាអ្នកមិនមានកិលេសជាគ្រឿងលាប

ព្រោះគ្រឿងលាប គឺតណ្ហាមិនមាន ឲ្យជាបុគ្គលមិនមានកិលេសជាគ្រឿងចង ព្រោះមិនមានសំយោជនៈជាដើម ឲ្យដូចជារថទីមដោយសេះអាជានេយ្យ ដែលប្រកបដោយល្អហើយ ដែលមានគ្រឿងតាក់តែងល្អហើយ ។

អដ្ឋកថា លកុណ្ឌកភទ្ទិយសូត្រទី ៥ ចប់

សុត្តន្តបិដក

តណ្ហាក្ខយសូត្រ

[១៥២] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះអញ្ញាកោណ្ឌញ្ញៈជ៏មានអាយុ អង្គុយពែនភ្នែក តម្រង់កាយត្រង់ ក្នុងទីជិតនៃព្រះមានព្រះភាគ ហើយពិចារណា តណ្ហាសង្ខ្យ-វិមុត្តិ គឺ និព្វាន ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញ ព្រះអញ្ញាកោណ្ឌញ្ញៈជ៏មានអាយុ អង្គុយពែនភ្នែន តម្រង់កាយត្រង់ ក្នុងទីជិតហើយពិចារណា តណ្ហាសង្ខ្យវិមុត្តិ ។ លុះព្រះមានព្រះភាគ ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា*

ឫស គឺ អវិជ្ជា និងផែនដី គឺអាសវៈ មិនមានដល់
អរិយបុគ្គលណា ស្លឹក គឺ សេចក្តីស្រើង ក៏មិនមាន
វល្លិ គឺមានៈ នឹងមានមកអំពីណា បុគ្គលណានឹងគួរ

តិះដៀលនូវអរិយបុគ្គលនោះ ដែលជាអ្នកប្រាជ្ញ ផុតចាកចំណងបាន សូម្បីពួកទេវតា ក៏សរសើរបុគ្គលនោះ ទាំងព្រហ្មក៏សរសើរដែរ ។ សូត្រទី ៦ ។

អដ្ឋកថា

តណ្ហាក្ខយសូត្រ

តណ្ហក្ខយសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ

[១៥២] *បទថា* **កោណ្ឌញ្ញោ** *ក្នុងបទថា* **អញ្ញាសិកោណ្ឌញ្ញោ** *នេះ ជាឈ្មោះនៃព្រះថេរៈដែលមកដោយគោត្រ ។ ក្នុងបណ្តាសាវ័កទាំងឡាយ ព្រះថេរៈ ប្រាកដក្នុងព្រះសាសនាថា អញ្ញាកោណ្ឌញ្ញៈនោះឯង ដោយពាក្យឧទានដែលព្រះមានព្រះភាគត្រាស់ថា* **អញ្ញាសិ វត កោ កោណ្ឌញ្ញោ** *ព្រោះត្រាស់ដឹងអរិយសច្ច ៤ មុនសាវ័កទាំងអស់ ។*

បទថា **តណ្ហាសង្ខយវិមុត្តឹ** *ឈ្មោះថា ធម៌ជាទីអស់ទៅនៃតណ្ហា ព្រោះជាទីអស់តណ្ហា គឺជាទីដែលលះតណ្ហា បានដល់ ព្រះនិព្វាន ។ ការរួចផុត ព្រោះការអស់ទៅនៃតណ្ហានោះ ។ ម្យ៉ាងទៀត អរិយមគ្គ ឈ្មោះថា ធម៌ជាទីអស់ទៅនៃតណ្ហា ព្រោះជាហេតុអស់ គឺជាហេតុលះតណ្ហា ឈ្មោះថា* **តណ្ហាសង្ខយវិមុត្តិ** *ព្រោះមានវិមុត្តិជាផល ឬជាទីបំផុតនៃអរិយមគ្គ ដោយនិប្ប-*

វិយាយ បានដល់ សមាបត្តិដែលសម្បយុត្តដោយអរហត្តផល ។ ជាបុគ្គលអង្គុយពិចារណាសមាបត្តិ ដែលសម្បយុត្តដោយអរហត្តនោះ ។ ពិតហើយ ព្រះអញ្ញាកោណ្ឌញ្ញៈនេះចូលផលសមាបត្តិច្រើន ព្រោះដូច្នោះ សូម្បីក្នុងទីនេះ លោកក៏បានធ្វើយ៉ាងនេះ ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា កាលទ្រង់ជ្រាបការពិចារណាអរហត្តផលរបស់ព្រះអញ្ញាកោណ្ឌញ្ញៈហើយ ទើបទ្រង់បន្ទឺឧទាននេះ ដែលសម្តែងដល់សេចក្តីនោះ ។*

បណ្តាបទទាំងនោះ បទថា **យស្ស មូលំ ឆមា នត្ថិ** *សេចក្តីថា ព្រះអរិយបុគ្គលណាមិនមានអវិជ្ជាដូចជាឫសនៃដើមឈើ គឺអត្តភាព និងមិនមានផែនដី ពោល គឺអាសវៈ នីវរណៈ និងអយោនិសោមនសិការដែលជាទីតាំងអាស្រ័យនូវអវិជ្ជានោះឯង ព្រោះដកឡើងបានដោយអរហត្តមគ្គ ។ គប្បីជ្រាបសម្ពន្ធបទក្នុងបទថា* **បណ្ណា នត្ថិ កុតោ លតា** *នេះថា វល្លិមិនមាន ស្លឹក នឹងមានអំពីណា ។ អធិប្បាយថា សូម្បីវល្លិ ពោល គឺមែកធំ មែកតូច ជាដើម មានមានៈ និងអតិមានៈជាដើម រមែងមិនមាន ស្លឹក គឺមទៈ បមាទៈ មាយា និងសាឋេយ្យៈជាដើម នឹងមានអំពីណា ។ ម្យ៉ាងទៀត បទថា* **បណ្ណា នត្ថិ កុតោ លតា** *សេចក្តីថា កាលពន្លកដុះឡើង ស្លឹកឈើក៏កើតឡើងមុន ក្រោយមក លោកពោលតាំងឈ្មោះថា* **លតា** *គឺមែកធំ មែកតូច ។ ក្នុងពាក្យនោះ មូល គឺអវិជ្ជា និងកិលេស មានអាសវៈជាដើម ដែលជាទីតាំងអាស្រ័យរបស់មូល គឺអវិជ្ជានោះ រមែងមិនមានដល់ដើមឈើ គឺអត្តភាព*

ណា ដែលគួរដល់ការកើតឡើង ក្នុងកាលមិនមានការចម្រើនអរិយមគ្ត ព្រោះ
ចម្រើនអរិយមគ្តហើយ ។ ក្នុងទីនេះ ដោយ **មូល** សព្ទនោះឯង គប្បីជ្រាប
ថា លោកកាន់យក សូម្បីភាវៈដែលកម្មជាទីតាំងនៃពូជ ព្រោះជាហេតុនៃ
មូលនោះឯង ។ កាលពូជ គឺកម្មមិនមាន ពន្ធក គឺវិញ្ញាណដែលមានពូជ
គឺកម្ម ជាគ្រឿងសម្គាល់ និងស្ធឹក មែក មាននាមរូប សឡាយតនៈ ... ជា
ដើម ដែលមានពន្ធក គឺវិញ្ញាណជាគ្រឿងសម្គាល់ មិនមានការកើតឡើង
ឡើយ ។ ដោយហេតុនោះ ទើបលោកពោលថា ព្រះអរិយបុគ្គលណាមិន
មានអវិជ្ជាជាឬសគល់ មិនមាន វល្ធិ គឺមានះជាដើម ស្ធឹក គឺការស្រវឹង
ជាដើមនឹងមានអំពីណា ។ បទថា **តំ ធីរំ ពន្ធនា មុត្តំ** សេចក្តីថា នូវព្រះ
អរិយបុគ្គលនោះ ដែលឈ្មោះថា ធីរៈ ព្រោះឈ្នះមារ ដោយការប្រកប
សេចក្តីព្យាយម គឺសម្មប្បធាន ៤ ដែលផុតចាកគ្រឿងចង គឺអភិសង្ខារ
ដែលជាតួកិលេសទាំងអស់នោះឯង ។ បទថា **តំ** ក្នុងបទថា **កោ តំ
និន្ទិតុមរហតិ** នេះ ត្រឹមតែជានិបាត បុគ្គលណា មានជាតិនៃវិញ្ញូជន គួរ
និន្ទា តិះដៀលបុគ្គលដែលផុតចាកកិលេសទាំងពួង ដែលប្រកបដោយគុណ
ដ៏កំពូល មានសីលគុណជាដើម ដោយប្រការដូច្នេះ ព្រោះមិនមានការនិន្ទា
ជាគ្រឿងសម្គាល់នោះឯង ។ បទថា **ទេវាបិ នំ បសំសន្តិ** សេចក្តីថា
ដោយពិត ស្តេចទេវតាដឹងគុណវិសេស មានសក្តៈជាដើម ក៏រមែងសរសើរ
ដោយ **អបិ** សព្ទ សូម្បីមនុស្ស មានក្សត្រដែលជាបណ្ឌិតជាដើម ក៏រមែង
សរសើរក្រៃលែងឡើងទៀត សូម្បីព្រហ្ម ក៏សរសើរ គឺមហាព្រហ្មក្តី ព្រហ្មក្តី

នាគក្តី យក្ខក្តី គន្ធព្វជាដើមក្តី ជនដទៃក្តី ក៏រមែងសរសើរ គឺសរសើរជូចគ្នា ។

អដ្ឋកថា តណ្ហាក្ខយសូត្រទី ៦ ចប់

សុត្តន្តបិដក

បបញ្ចក្ខយសូត្រ

[១៥៣] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ពិចារណា ការលះបង់នូវការពិចារណាបបញ្ចសញ្ញា (សញ្ញាជាគ្រឿងយឺតយូរ) របស់ព្រះអង្គ ។ លុះព្រះមានព្រះភាគ ជ្រាបការលះបង់នូវការពិចារណា បបញ្ចសញ្ញារបស់ព្រះអង្គហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា*

> *បបញ្ចសញ្ញាក្តី ការមាំមួនក្តី មិនមានដល់បុគ្គលណា បុគ្គលនោះ ឈ្មោះថា បានកន្ទងកិលេសជាតិជាគ្រឿងតផង ជើងគុល គឺអវិជ្ជាផង មនុស្សលោក ព្រមទាំងទេវលោក ក៏មិនមើលងាយអ្នកប្រាជ្ញ ដែលគ្មានតណ្ហា ហើយប្រព្រឹត្តទៅដោយញាណនោះបានឡើយ ។ សូត្រទី ៧ ។*

អដ្ឋកថា

បបញ្ចក្ខយសូត្រ

បបញ្ចក្ខយសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ

[១៥៣] បទថា **បបញ្ចសញ្ញាសង្ខាបហានំ** សេចក្តីថា កិលេស ឈ្មោះថា ធម៌ជាគ្រឿងយឺតយូរ ព្រោះដែលកើតឡើងឯង ធ្វើឲ្យយឺតយូរ គឺ ពង្រីកនូវសន្តាននោះឲ្យទូលំទូលាយ បានដល់ ឲ្យតាំងនៅយូរដោយពិសេស បានដល់ រាគៈ ទោសៈ មោហៈ ទិដ្ឋិ និងមានះ ។ សមដូចពាក្យដែល លោកពោលថា រាគៈ ជាធម៌ធ្វើឲ្យយឺតយូរ ទោសៈ ជាធម៌ធ្វើឲ្យយឺតយូរ មោហៈ ជាធម៌ធ្វើឲ្យយឺតយូរ តណ្ហា ជាធម៌ធ្វើឲ្យយឺតយូរ ទិដ្ឋិ ជាធម៌ធ្វើ ឲ្យយឺតយូរ មានៈ ជាធម៌ធ្វើឲ្យយឺតយូរ ។ ម្យ៉ាងទៀត ធម៌ មានអត្ថថា សៅហ្មង ឈ្មោះថា អត្ថនៃធម៌ជាគ្រឿងយឺតយូរ ធម៌ មានអត្ថដូចសំរាម ឈ្មោះថា អត្ថនៃធម៌ជាគ្រឿងយឺតយូរ ។ ក្នុងបបញ្ចធម៌ទាំងនោះ សុភសញ្ញា ជាគ្រឿងសម្គាល់របស់បបញ្ចធម៌ គឺរាគៈ អាឃាតវត្ថុជាគ្រឿងសម្គាល់របស់ បបញ្ចធម៌ គឺទោសៈ អាសវៈជាគ្រឿងសម្គាល់របស់បបញ្ចធម៌ គឺមោហៈ វេទនាជាគ្រឿងសម្គាល់របស់បបញ្ចធម៌ គឺតណ្ហា សញ្ញា ជាគ្រឿងសម្គាល់ របស់បបញ្ចធម៌ គឺទិដ្ឋិ វិតក្ក ជាគ្រឿងសម្គាល់របស់បបញ្ចធម៌ គឺមានៈ ។ សញ្ញាដែលកើតព្រមជាមួយបបញ្ចធម៌ទាំងនោះ ឈ្មោះថា បបញ្ចសញ្ញា ។ ឯកាគៈ កោដ្ឋាសនៃបបញ្ចសញ្ញា ឈ្មោះថា ចំណែកនៃបបញ្ចសញ្ញា ពោល ដោយអត្ថ បានដល់ គំនរនៃកិលេស ដែលជាចំណែកនៃធម៌ ជាគ្រឿងយឺត យូរនោះ មួយអន្ទើដោយនិមិត្ត ។ ក្នុងទីនេះ សព្ទថា **សញ្ញា** រមែងមាន

ដោយបបញ្ចធម៌នោះ ជាហេតុដែលទូទៅដល់ចំណែកនោះៗ ។ សមដូចពាក្យដែលលោកពោលថា សេចក្តីពិត ចំណែកនៃបបញ្ចធម៌ មានសញ្ញាជាហេតុ ។ ការលះនូវចំណែកនៃបបញ្ចធម៌ទាំងនោះ ។ អធិប្បាយថា កាត់កិលេស មានរាគៈជាដើម ដោយមគ្គនោះៗ បានជាសមុច្ឆេទ ។

បានឮថា ក្នុងកាលនោះ ព្រះមានព្រះភាគ ទ្រង់ពិចារណាកិលេសដែលជាហេតុនៃសេចក្តីវិនាសក្នុងអតីតជាតិរបស់ព្រះអង្គ រាប់សែនកោដិ ដែលទ្រង់លះបាន មួយអន្ទើដោយវាសនា នាពោធិមណ្ឌល ដោយអរិយមគ្គក្នុងភពចុងក្រោយនេះ និងទ្រង់ឃើញសន្តានរបស់សត្វដែលដល់ព្រមទៅដោយកិលេសសៅហ្មងទៅដោយកិលេស មានរាគៈជាដើម ដែលដោះបានលំបាក ដូចឃ្លោកដែលពេញទៅដោយទឹកជ្រាយ ដូចភាជនៈដែលពេញទៅដោយតក្កៈ និងដូចកំណាត់សំពត់ចាស់ដែលជ្រលក់ដោយប្រេង ទើបទ្រង់កើតបីតិជាមោជ្ជឡើងថា កិលេសវដ្តនេះ ឈ្មោះថា ជាព្រៃស្តុកយ៉ាងនេះ ដែលកើតឡើងមិនមានទីបំផុតខាងដើម តថាគតលះបានហើយជាសមុច្ឆេទ ព្រោះលះហើយដោយល្អយ៉ាងគួរអស្ចារ្យ ទើបទ្រង់បន្លឺឧទាន ។ ដោយហេតុនោះ ទើបលោកពោលថា លុះព្រះមានព្រះភាគ ជ្រាបការលះបង់នូវការពិចារណាបបញ្ចសញ្ញារបស់ព្រះអង្គហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យស្ស បបញ្ចា ជិតិ ច ឯត្តិ** *សេចក្តីថា ព្រោះព្រះមានព្រះភាគ ទ្រង់សម្តែងចេញចំពោះព្រះអង្គឲ្យដូចអ្នកជនៃ ដូច្នោះ អគ្គបុគ្គលណា មិនមានធម៌ជាគ្រឿងយឺតយូរ ដែលមានលក្ខណៈដូចពោល*

ហើយ នីវរណមិនមានការតាំងចិត្តនៅក្នុងសង្ឃារ ដែលបបញ្ចធម៌ទាំងនោះសាង ទ្បើង ។ តែក្នុងនេត្តិ លោកពោលថា អនុសយ ឈ្មោះថា ធិតិ ។ ពិត ហើយ អនុសយ ក៏ជាមូលនៃការកើតក្នុងភព ។ បាលីថា **សត្តេ សង្ខារេ ឋបេតិ** *និងបាលីថា* **បបញ្ចដ្ឋិតិ** *ដូច្នេះក៏មាន ។ បាលីនោះមានអធិប្បាយ ដូច្នេះថា ការតាំងនៅ គឺការដែលបបញ្ចធម៌កំពុងប្រាកដ បានដល់ ដែលមិន ទាន់កាត់ផ្តាច់ដោយមគ្គ ឈ្មោះថា* **បបញ្ចដ្ឋិតិ ។** *ម្យ៉ាងទៀត ការតាំងនៅ នៃវដ្តៈ ព្រោះជាហេតុកើតទ្បើងនៃកុសល អកុសល និងវិបាកដ៏សេស គឺ បបញ្ចធម៌ ឈ្មោះថា* **បបញ្ចដ្ឋិតិ ។** *បបញ្ចដ្ឋិតិនោះ មិនមានដល់អគ្គបុគ្គល ណា ។ បទថា* **សង្ខានំ បលិឃញ្ច វីតិវត្តោ** *សេចក្តីថា បុគ្គលណាឈាន កន្ទងនូវតណ្ហា និងទិដ្ឋិ ដែលបានឈ្មោះថា* **សង្ខាន** *ព្រោះដូចជាទី-ត ព្រោះ អត្ថថា ជាគ្រឿងចង និងឈានកន្ទងអវិជ្ជា ពោល គឺជើងគុល ព្រោះដូច ជាជើងគុល ព្រោះរារាំងការចូលទៅកាន់នគរ គឺព្រះនិព្វាន គឺឈានកន្ទង ដោយពិសេស ដោយការលះកិលេស មួយអន្ទើដោយវាសនា ។ តែអាចារ្យ មួយពួកទៀត ពោលដោយសេចក្តីក្រោធថា* **សង្ខាន** *ពាក្យនោះ មិនគួរកាន់ យកធិតិនោះ លោកហៅថា ធ្វើហេតុឲ្យបុគ្គលដទៃជាប់ ។ បទថា* **តំ និត្តណ្ហំ មុនឹ ចរន្តំ** *សេចក្តីថា នូវព្រះអរិយបុគ្គលនោះ ឈ្មោះថា ជាអ្នកប្រាសចាក តណ្ហា ព្រោះមិនមានតណ្ហា ដោយប្រការទាំងពួង ។ ឈ្មោះថា មុនី ព្រោះ ដឹងនូវលោកទាំង ២ និងដឹងប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ឈ្មោះថា ត្រាច់ទៅដោយឥរិយាបថ ៤ ដោយការ ញុំាងសមាបត្តិផ្សេងៗ ឲ្យត្រាច់ទៅ*

និងដោយការញុាំងញាណ ដែលមិនទូទៅដល់ញាណជនៃឲ្យត្រាច់ទៅ ដើម្បីជាប្រយោជន៍ដល់សត្វទាំងពួង ដោយចំណែកមួយនោះឯង ។ បទថា **ជាវ-ជានាតិ សទេវកោបិ លោកោ** *សេចក្តីថា សត្វលោកដែលកើតមកដោយបញ្ញារបស់ខ្លួន ព្រមទាំងទេវលោក មួយអន្ទើដោយព្រហ្មក្នុងកាលណាមួយក៏មិនដឹង មិនបានសោយ ដោយពិត ធ្វើឲ្យជ្រួន ត្រេកអរក្នុងការបូជាសក្ការៈដោយគោរពថា បុគ្គលនេះប៉ុណ្ណោះជាបុគ្គលប្រសើរ ជាបុគ្គលឧត្តម អគ្គ-បុគ្គលក្រៃលែងក្នុងលោក ដូច្នេះឯង ។*

អដ្ឋកថា បបញ្ចក្ខយសូត្រទី ៧ ចប់

សុត្តន្តបិដក

មហាកច្ចានសូត្រ

[១៥៤] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមហាកច្ចានៈដ៏មានអាយុ អង្គុយពែនភ្នែន តម្រង់កាយត្រង់ ផ្ចង់ចិត្តទៅរកកាយគតាសតិ ឲ្យមានមុខឆ្ពោះទៅព្ជដ៏ខាងក្នុង ជិតព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញព្រះមហាកច្ចានៈដ៏មានអាយុ អង្គុយពែនភ្នែន តម្រង់កាយត្រង់ ផ្ចង់ចិត្តទៅរកកាយគតាសតិ ឲ្យមានមុខឆ្ពោះទៅព្ជដ៏ខាងក្នុង ក្នុងទីជិតហើយ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់*

សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

កាយគតាសតិ ដែលបុគ្គលណា តម្កល់រឿយៗ គ្រប់កាល (កាយគតាសតិនោះ) មិនមានដល់បុគ្គលនោះផង មិនមានដល់អាត្មាអញ (ក្នុងអតីតកាល) ផង នឹងមិនមានដល់អាត្មាអញ (ក្នុងអនាគត) ផង មិនមានដល់អាត្មាអញ (ក្នុងកាលឥឡូវនេះ) ផង បុគ្គលនោះ ឈ្មោះថា នៅដោយអនុបុព្វវិហារធម៌ គប្បីឆ្លងតណ្ហាជាពិស ក្នុងកាល (ទាំង ៣) ក្នុងភពទាំង ៣ នោះបាន ។ សូត្រទី ៨ ។

អដ្ឋកថា

មហាកច្ចានសូត្រ

មហាកច្ចានសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ

[១៥៤] **អជ្ឈត្ត** *សព្ទនេះ ក្នុងបទថា* **អជ្ឈត្តំ** *នេះ មកក្នុងអត្ថថា កើតខាងក្នុង ដូចក្នុងប្រយោគជាដើមថា* **ឆ អជ្ឈត្តិកានិ អាយតនានិ** *អាយតនៈខាងក្នុង ៦ ដូច្នេះ ។ មកក្នុងអត្ថថា កើតក្នុងខ្លួន ដូចក្នុងប្រយោគជាដើមថា* **អជ្ឈត្តា ធម្មា** *ធម៌ទាំងឡាយកើតក្នុងខ្លួន និងក្នុងប្រយោគមួយទៀតថា* **អជ្ឈត្តំ វា កាយេ កាយានុបស្សី** *ពិចារណានូវកាយក្នុងកាយដូច្នេះ ។*

មកក្នុងអត្ថថា ជាខាងក្នុងនៃអារម្មណ៍ ដូចក្នុងប្រយោគជាដើមថា **សព្ព-និមិត្តានំ អមនសិការា អជ្ឈត្តំ សុញ្ញតំ ឧបសម្បជ្ជ វិហរតិ** *ព្រោះមិនមនសិការដល់និមិត្តទាំងពួង ភិក្ខុចូលដល់សុញ្ញតដែលជាខាងក្នុង អធិប្បាយថា ក្នុងតំណែងដែលជាធំ ។ ពិតហើយ ផលសមាបត្តិ ឈ្មោះថា ជាឋានៈដ៏ធំនៃព្រះពុទ្ធទាំងឡាយ មកក្នុងអត្ថថា ជាខាងក្នុងនៃគោចរ ដូចក្នុងប្រយោគជាដើមថា* **តេនានន្ទ ភិក្ខុនា តស្មឹ យេវ បុរិមស្មឹ សមាធិនិមិត្តេ អជ្ឈត្តមេវ ចិត្តំ សណ្ឋបេតព្ពំ សន្និសាទេតព្ពំ ឯកោទិកាតព្ពំ សមាទហាតព្ពំ** *ម្នាលអានន្ទ ភិក្ខុនោះ ត្រូវតាំងចិត្ត ធ្វើចិត្តឲ្យជ្រះថ្លា ធ្វើចិត្តឲ្យស្ងប់ស្ងាត់ ធ្វើចិត្តឲ្យរីករាយខាងក្នុង ក្នុងសមាធិនិមិត្តពីមុននោះវិញ ។ ក្នុងទីនេះ អ្នកគប្បីឃើញថា មកក្នុងអត្ថថា មានគោចរជាខាងក្នុងនោះឯង ព្រោះដូច្នោះ ទើបលោកពោលថា បទថា* **អជ្ឈត្តំ** *បានដល់ ក្នុងអារម្មណ៍កម្មដ្ឋានដែលជាអារម្មណ៍ខាងក្នុង ។ បទថា* **បរិមុខំ** *ប្រែថា ចំពោះមុខ ។ បទថា* **សុបដ្ឋិតាយ** *បានដល់ មានសតិទៅក្នុងកាយ ដែលតាំងមាំដោយល្អ ។ ក្នុងទីនេះ លោកពោលដល់ឈាន ដោយលើកសតិទ្បើងជាប្រធាន ។ លោកអធិប្បាយដូច្នេះថា ភិក្ខុចូលឈានជាខាងក្នុង គឺដែលក្រៃលែងដែលខ្លួនបានដោយកាយានុបស្សនាសតិប្បដ្ឋាន ។*

ព្រះថេរៈនេះ កាលព្រះមានព្រះភាគប្រថាប់នៅក្នុងក្រុងសាវត្ថី ថ្ងៃមួយត្រាច់បិណ្ឌបាត ក្នុងក្រុងសាវត្ថី ត្រឡប់អំពីបិណ្ឌបាត ក្រោយបច្ឆាភត្ត ចូលទៅកាន់វិហារ សម្តែងវត្តដល់ព្រះមានព្រះភាគ អង្គុយសម្រាកក្នុងពេលថ្ងៃ

សម្ងំនៅដោយសមាធិផ្សេងៗ អស់ថ្ងៃ ក្នុងវេលាល្ងាច និមន្តទៅកាន់វិហារ
កាលព្រះមានព្រះភាគប្រថាប់គង់ត្រង់ព្រះគន្ធកុដិ ទើបគិតថា នេះមិនមែនជា
កាល ចូលគាល់ព្រះមានព្រះភាគ កំណត់កាលហើយ អង្គុយចូលសមាបត្តិ
ដូចពោលហើយ ត្រង់មណ្ឌលពោធិព្រឹក្ស មិនឆ្ងាយអំពីព្រះគន្ធកុដិ ព្រះ
សាស្តា គង់ប្រថាប់ក្នុងព្រះគន្ធកុដិនោះឯង ទតឃើញព្រះថេរៈអង្គុយយ៉ាង
នោះ ។ ដោយហេតុនោះ ទើបលោកពោលថា **តេន ខោ បន សមយេន
អាយស្មា មហាកច្ចានោ ។បេ។ សុបដ្ឋិតាយ** ដូច្នេះជាដើម ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួង
សូម្បីការដែលព្រះមហាកច្ចានត្ថេរ ចូលឈានដែលខ្ជួនសម្រេចដោយសតិ-
ប្បដ្ឋានភាវនាឲ្យជាបាទហើយ ទើបទ្រង់បន្ទឹឧទាននេះ ដែលសម្តែងដល់សេចក្តី
នោះ ។

បណ្តាបទទាំងនោះ បទថា **យស្ស សិយា សព្វទា សតិ សតតំ
កាយគតា ឧបដ្ឋិតា** សេចក្តីថា សតិដែលទៅហើយក្នុងកាយទាំង ២ យ៉ាង
ដោយការផ្សេងគ្នានៃនាម និងរូប គឺមានកាយជាអារម្មណ៍ គប្បីជាគុណជាតិ
ដែលភិក្ខុណាផ្តើមតម្កល់បំពេញវិបស្សនា ដោយអំណាចសេចក្តីព្យាយាម
ដែលប្រព្រឹត្តទៅជាប់តគ្នារឿយៗ មិនដាច់ ដោយពិចារណាលក្ខណៈ មាន
អនិចូលក្ខណៈជាដើមនៃឧបាទានក្ខន្ធ ៥ ក្នុងកាលទាំងអស់ ដោយចែកថ្ងៃ ១
ជា ៦ ចំណែក ។

បានញ្ចថា ព្រះមហាកច្ចានៈនេះញ្ចាំងឈានឲ្យកើតដោយកាយគតាសតិ-

កម្មដ្ឋានជាដំបូង ហើយធ្វើឈាននោះឲ្យជាបាទ តាំងវិបស្សនាដោយមុខ គឺ កាយានុបស្សនាសតិប្បដ្ឋាន ហើយសម្រេចអរហត្ត ។ ក្នុងកាលតមក ដោយ ច្រើនលោកចូលឈាននោះឯង ចេញហើយ ពិចារណាឃើញដោយប្រការ នោះឯង ហើយចូលផលសមាបត្តិ ។ ព្រះសាស្តាកាលទ្រង់សម្តែងវិធីដែល ជាហេតុឲ្យលោកសម្រេចអរហត្ត ទើបត្រាស់ថា បុគ្គលដែលមានសតិក្នុង កាលគ្រប់កាល គប្បីតាំងកាយគតាសតិជាប់តគ្នា ដើម្បីឲ្យអាការដែល កាយគតាសតិនោះប្រាកដជាក់ច្បាស់ ទើបត្រាស់ថា មិនមានដល់បុគ្គលនោះ ផង មិនមានដល់អាត្មាអញ (ក្នុងអតីតកាល) ផង នឹងមិនមានដល់អាត្មា អញ (ក្នុងអនាគត) ផង មិនមានដល់អាត្មាអញ (ក្នុងកាលឥឡូវនេះ) ផង ដូច្នេះ ។

សេចក្តីនោះ កាលពោលដោយពិចារណា គប្បីជ្រាបជា ២ ចំណែក គឺ ដោយចំណែកខាងដើម ១ ដោយខណៈពិចារណាមួយ ។

ក្នុង ២ យ៉ាងនោះ គប្បីជ្រាបដោយចំណែកខាងដើមមុន ។ បទថា **នោ ចស្ស នោ ច មេ សិយា** *សេចក្តីថា បើក្នុងអតីតកាល កិលេសកម្មរបស់ អាត្មាអញមិនគប្បីមានសោត ក្នុងកាលជាបច្ចុប្បន្ននេះ អត្តភាពនេះ ក៏មិន គប្បីមានដល់អញ គឺមិនគប្បីកើតដល់អញ ព្រោះកម្ម និងកិលេសមានដល់ អញក្នុងអតីតកាល ដូច្នោះ អត្តភាពរបស់អញក្នុងឥឡូវនេះ ដែលមានកម្ម-ក្លិសនោះជាគ្រឿងសម្គាល់ រមែងប្រព្រឹត្តទៅ ។ បទថា* **ន ភវិស្សតិ ន ច មេ ភវិស្សតិ** *សេចក្តីថា ក្នុងអត្តភាពនេះ ព្រោះប្រាសចាកធម៌ដែលជា*

បដិបក្ខនោះ ហើយកិលេសកម្ម នឹងមិនមាន គឺនឹងមិនកើតដល់អញ ហើយ វិបាកក្នុងអនាគតនឹងមិនមាន គឺនឹងមិនកើតដល់អញ ក្នុងកាលទាំង ៣ ដូច ពោលមកហើយនេះ ខន្ធបញ្ចក: គឺអត្តភាពរបស់អញ ដែលមានកម្មក្កិលេស ជាហេតុ មិនមែនមានបុគ្គលដែលធំក្រៃលែងជាដើមជាហេតុទ្បើយ ឈ្មោះថា លោកប្រកាសដល់នូវការឃើញនាម និងរូប ព្រមទាំងបច្ច័យថា របស់អញ យ៉ាងណា របស់សត្វទាំងពួង ក៏ដូច្នោះ ។

តែកាលពោលដោយពេលពិចារណា គប្បីជ្រាបសេចក្តីដូចតទៅនេះ

បទថា **នោ ចស្ស នោ ច មេ សិយា** *សេចក្តីថា ព្រោះបញ្ចក្ខន្ធនេះ ឈ្មោះថា មិនទៀង ព្រោះមានហើយ ត្រឡប់ជាមិនមាន ឈ្មោះថា ជាទុក្ខ ព្រោះអត្ថថា ត្រូវការកើត និងការរលត់គ្របសង្កត់រឿយៗ ឈ្មោះថា អនត្តា ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច កាលបើដូច្នោះ សភាវៈណាមួយ ដែលឈ្មោះថាអត្តានេះ ក្រៅអំពីបញ្ចក្ខន្ធក៏មិនមាន គឺមិនគប្បីមាន មិនគប្បី កើត កាលបើដូច្នោះ បញ្ចក្ខន្ធណាមួយ ដែលឈ្មោះថា ជារបស់អញ មិន គប្បីមានដល់អញ មិនកើតដល់អញ ។ ពិតហើយ កាលអត្តាមាន វត្ថុ ដែលកើតក្នុងខ្លួន ក៏គប្បីមាន ដូចនាមរូបនេះ ដែលកើតក្នុងខ្លួន និងសូន្យទៅ ក្នុងបច្ចុប្បន្ន ឬអតីត យ៉ាងណា សភាវៈណាមួយដែលឈ្មោះថា ជាអត្តា ដែលផុតអំពីខន្ធ ក៏ដូច្នោះ នឹងមិនមាន នឹងមិនកើតដល់អញ គឺនឹងមិនមាន នឹងមិនកើតដល់អញក្នុងអនាគត បន្ទាប់អំពីនោះ បញ្ចក្ខន្ធណាមួយ ដែលជា ទីតាំងនៃការកង្វល់ នឹងមិនមានដល់អញ គឺធម្មជាតណាមួយ ដែលកើតក្នុង*

ខ្លួន នឹងមិនមានដល់អញ សូម្បីក្នុងអនាគត ។ ដោយពាក្យនេះ ទ្រង់សម្តែងដល់ការមិនមានវត្ថុដែលគប្បីប្រកាន់ថាអញ និងគប្បីប្រកាន់ថា របស់អញ ព្រោះមិនមានក្នុងកាលទាំង ៣ ។ ដោយពាក្យនោះ ឈ្មោះថា ទ្រង់ប្រកាសសុញ្ញតា ៤ ចំណុច ។

បទថា **អនុបុព្ពវិហារី តត្ថ សោ** *សេចក្តីថា កាលព្រះយោគាវចរតាមឃើញការៈជារបស់ទទេ ដែលមានក្នុងខ្លួន ក្នុងសង្ខារនោះ ក្នុងកាលទាំង ៣ ដូចពណ៌នាមក ដូច្នេះ កាលវិបស្សនាញាណ មានឧទយព្វយញ្ញាណជាដើមកើតឡើងដោយលំដាប់ ឈ្មោះថា មានធម៌ជាគ្រឿងនៅដោយលំដាប់ ដោយអនុបុព្វវិបស្សនាវិហារធម៌ ។ បទថា* **ការលេនេវ តរេ វិសត្តិកំ** *សេចក្តីថា ព្រះយោគាវចរនោះ គឺបុគ្គលញុំាងវិបស្សនាឲ្យដល់ទីបំផុត តាំងនៅយ៉ាងនេះ ឈ្មោះថា គប្បីឆ្លងនូវតណ្ហា ពោល គឺតណ្ហាដែលផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ព្រោះបន្តវដ្ត: ៣ ទាំងមូល ដោយកាលដែលដល់នូវការចាស់ក្លា ដោយកាលដែលវុដ្ឋានគាមិនីវិបស្សនាបន្តដោយមគ្គ និងដោយកាល ដែលអរិយមគ្គកើតឡើង អធិប្បាយថា គប្បីឆ្លងទៅតាំងនៅក្នុងត្រើយនាយនៃតណ្ហានោះ ។*

ព្រះមានព្រះភាគ ទ្រង់បន្ទឹមទានដែលសម្តែងដល់ការដែលព្រះមហាកច្ចាន:សម្រេចអរហត្ត ដោយអាងដល់អរហត្តផល ដោយប្រការដូច្នេះ ॥

អដ្ឋកថាមហាកច្ចានសូត្រទី ៨ ចប់

សុត្តន្តបិដក

ឧធចានសូត្រ

[១៥៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិក ក្នុងដែនមល្ល: ជាមួយនឹងភិក្ខុសង្ឆជាច្រើនរូប ទ្រង់ចូលទៅដល់ព្រាហ្មណគ្រាមឈ្មោះ ថូន: របស់ពួកមល្លជន ។ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកថូន: បានឮហើយ (ក៏ប្រកាសប្រាប់គ្នា) ថា ម្នាលគ្នាយើង ឮថា សមណគោតម ជាសក្យបុត្ត ចេញចាកសក្យត្រកូល មកបួសហើយស្តេចមកកាន់ចារិក ក្នុងដែនមល្ល: ជាមួយនឹងភិក្ខុសង្ឆជាច្រើន បានមកដល់ថូនព្រាហ្មណគ្រាមហើយ ក៏នាំគ្នាយកស្មៅ និងអង្កាម ចាក់បំពេញអណ្តូងដរាបដល់មាត់ ដោយគិតថា កុំឲ្យសមណ:ត្រងោលទាំងនោះផឹកទឹកបាន ។

[១៥៦] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចៀសចេញអំពីផ្លូវ សំដៅទៅរកដើមឈើមួយដើម លុះចូលទៅដល់ ទ្រង់គង់លើអាសន: ដែលភិក្ខុក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ហើយ ទ្រង់ត្រាស់ប្រើអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅដងទឹកអំពីអណ្តូងនុ៉ះ មកឲ្យតថាគត ។ កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ អណ្តូងនោះ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកថូន: យកស្មៅ និងអង្កាម ចាក់បំពេញដរាបដល់មាត់ ដោយគិតថា កុំឲ្យសមណ:ត្រងោលទាំងនោះផឹកទឹកបាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រើព្រះអានន្ទដ៏មានអាយុ ជាគម្រប់ ២

ជង្ឃទៀតថា ម្នាលអានន្ទ អ្នកចូរទៅជង្ឃទឹកអំពីអណ្តូងនុ៎ះ មកឲ្យតថាគត ។ ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគ ជាគម្រប់ ២ ដងថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ អណ្តូងនោះ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកបូនៈ យកស្មៅ និងអង្ក្នាមចាក់បំពេញជរាបដល់មាត់ ដោយគិតថា កុំឲ្យសមណៈត្រង៉ោលទាំងនោះផឹកទឹកបាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រើព្រះអានន្ទដ៏មានអាយុ ជាគម្រប់ ៣ ដងទៀតថា ម្នាលអានន្ទ អ្នកចូរទៅជង្ឃទឹកអំពីអណ្តូងនុ៎ះ មកឲ្យតថាគត ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏កាន់ចាត្រដើរចូរទៅត្រង់អណ្តូងនោះ ។ កាលបើព្រះអានន្ទដ៏មានអាយុចូលទៅ ក៏ស្រាប់តែអណ្តូងខ្ពុរស្មៅ និងអង្ក្នាមទាំងអស់នោះ ចេញអំពីមាត់ ពេញពោរដោយទឹកថ្លា មិនល្អក់ ស្អាតជរាបដល់មាត់វិញ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា អើ អស្ចារ្យណាស់ហ្ន៎ អើ ចម្លែកណាស់ហ្ន៎ ព្រះតថាគត មានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះថា អណ្តូងនេះ កាលអាត្មាអញចូលទៅជិត ក៏ស្រាប់តែខ្ពុរស្មៅ និងអង្ក្នាមទាំងអស់នោះ ចេញអំពីមាត់ ទៅជាពេញពោរដោយទឹកថ្លា មិនល្អក់ ស្អាត ជរាបដល់មាត់ទៅវិញ ។ ព្រះអានន្ទដ៏មានអាយុ ក៏ជង្ឃទឹកដោយចាត្រ ហើយយកចូលទៅថ្វាយព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ ព្រោះព្រះតថាគត មានឫទ្ធិច្រើនមែន មានអានុភាពច្រើនមែន

បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា អណ្តូងនោះ កាលខ្ញុំព្រះអង្គចូលទៅជិត ក៏ស្រាប់តែខ្ទុះស្នៅ និងអង្កាមទាំងអស់នោះចេញអំពីមាត់ ពេញពោរដោយទឹកថ្លា មិនល្អក់ ស្អាតជរាបដល់មាត់ទៅវិញ សូមនិមន្តព្រះមានព្រះភាគ សោយទឹក សូមនិមន្តព្រះសុគត សោយទឹក ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះក្នុងវេលានោះថា

បុគ្គលគប្បីធ្វើអណ្តូងប្រយោជន៍អ្វី បើទឹកមាននៅ គ្រប់កាល
ហើយ តថាគត កាត់តណ្ហាតាំងពីឫសបានហើយ គប្បីត្រាច់
ទៅស្វែងរកទឹក ដូចម្តេចទៀត ។ សូត្រទី ៩ ។

អដ្ឋកថា

ឧឧចានសូត្រ

ឧទបានសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ

[១៥៥] បទថា **មល្លេសុ** សេចក្តីថា ជនបទមួយ ដែលជាទីនៅរបស់ព្រះរាជកុមារអ្នកជនបទ ឈ្មោះថា មល្ល: គេហៅថា មល្ល: ព្រោះដេរដាសក្នុងមល្លជនបទ ដែលផ្លូវលោកហៅថា មល្ល:នោះ ។ តែអាចារ្យពួកខ្លះពោលថា **មាលេសុ** ។ បទថា **ចារិកញ្ញមាឆោ** បានដល់ ទ្រង់យាងចារិកទៅក្នុងជនបទមណ្ឌលធំ ដោយយាងចារិកទៅមិនប្រញាប់ប្រញាល់ ។ បទថា **មហតា ភិក្ខុសង្ឃេន** បានដល់ ពួកមហាសមណ: ដែលកំណត់ចំនួន

មិនបាន ។ ពិតហើយ ក្នុងកាលនោះ ព្រះមានព្រះភាគ ចោមរោមទៅដោយ ភិក្ខុសង្ឃជាច្រើន បទថា **ថូណំ នាម មល្លានំ ព្រាហ្មណគ្គាមោ** *បានដល់ ស្រុកព្រាហ្មណ៍ ព្រោះមានព្រាហ្មណ៍ច្រើនដលឈ្មោះថា ថូនៈ ក្នុងមល្លបទេស ដែលជាទីតាំងនៃមជ្ឈិមប្រទេស ក្នុងទិសអាគ្នេយ៍ ។ បទថា* **តទវសរិ** *កាត់ បទជា* **តំ អវសរិ** *យាងទៅកាន់ស្រុកព្រាហ្មណ៍នោះ អធិប្បាយថា ទ្រង់ យាងទៅថូនគ្រាម ។*

បទថា **អស្សោសុំ** *ប្រែថា បានអង្គុយហើយ អធិប្បាយថា ដីងដោយ ក្រសែនៃសំឡេងយោសនាដែលមកប៉ះសោតទ្វារ ។ បទថា* **ខោ** *ជានិបាត ប្រើក្នុងអត្ថថា ធ្វើបទឲ្យពេញ ឬប្រើក្នុងអវធារណៈ គឺហាមសេចក្តីដទៃ ។ ២ យ៉ាងនោះ ដោយ* **ខោ** *សព្ទ ដែលមានអវធារណៈជាអត្ថ ប្រែថា បាន ស្តាប់ហើយ អធិប្បាយថា ព្រាហ្មណ៍ និងគហបតីអ្នកថូនគ្រាម មិនមាន អន្តរាយចំពោះការទៅ ។ ដោយ* **ខោ** *សព្ទ ដែលមានបទបូរណៈជាអត្ថ ត្រឹមតែជាបទ និងព្យញ្ជនៈពីរោះរណ្តំប៉ុណ្ណោះ ។ បទថា* **ថូណេយ្យកា** *ប្រែ ថា អ្នកដែនថូនគ្រាម ។ ក្នុងបទថា* **ព្រាហ្មណគហបតិកា** *នេះ មានវិនិច្ឆ័យ ដូចតទៅនេះ ឈ្មោះថា ព្រាហ្មណ៍ ព្រោះពោលពាក្យដ៏ប្រសើរ អធិប្បាយ ថា ស្វាធ្យាយមន្ត ។ ពិតហើយ បទថា* **ព្រាហ្មណា** *នេះ ជាវេវចនៈរបស់ ព្រាហ្មណ៍ដោយកំណើត ឯព្រះអរិយៈទាំងឡាយ លោកក៏ហៅថា ព្រាហ្មណ៍ ព្រោះជាអ្នកបន្សាត់បាប ។ ជនដែលគ្រប់គ្រងផ្ទះពួកណាមួយ រៀរក្សត្រ និង ព្រាហ្មណ៍ លោកហៅថា គហបតី តែបើពោលដោយពិសេស គេហៅថា*

វេស្សៈ ។ ព្រាហ្មណ៍ និងគហបតី ហៅថា ព្រាហ្មណគហបតី ។

ឥឡូវនេះ ដើម្បីប្រកាសភាពដែលព្រាហ្មណ៍ និងគហបតីនោះបានស្តាប់ ទើបលោកពោលថា **សមណោ ឱលុ ភោ គោតមោ** *ដូច្នេះជាដើម ។ ក្នុងពាក្យថា* **សមណោ ឱលុ ភោ គោតមោ** *នោះ ព្រះមានព្រះភាគ បណ្ឌិតគប្បីជ្រាបថា ជាសមណៈ ព្រោះស្ងប់នូវបាប ។ សមដូចពាក្យដែលលោកពោលក្នុងមជ្ឈិមនិកាយ មូលបណ្ណាសកៈថា អកុសលធម៌ទាំងឡាយ ដ៏លាមក ... ភិក្ខុនោះ បានរម្ងាប់ហើយ ដូច្នេះជាដើម ព្រះមានព្រះភាគ ទ្រង់ជាអ្នកស្ងប់បាបហើយ ដោយប្រការទាំងពួង ដោយអរិយមគ្គដ៏កំពូល ព្រោះទ្រង់សម្រេចគុណតាមសេចក្តីពិត ទើបបានឈ្មោះថា សមណៈ ។ បទថា* **ឱលុ** *ជានិបាត ប្រើក្នុងអនុស្សវនត្ថ ។ បទថា* **ភោ** *ត្រឹមតែពាក្យហៅដែលកើតមកអំពីកំណើតនៃជនជាតិព្រាហ្មណ៍ ។ សមដូចពាក្យដែលលោកពោលក្នុងធម្មបទថា បុគ្គលនោះ គ្រាន់តែបាននាមថា ភោវាទី (អ្នកពោលថា ចម្រើន) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេស គ្រឿងកង្វល់នៅឡើយ ។ បទថា* **គោតមោ** *ជាបទប្រារព្ធដល់ព្រះមានព្រះភាគដោយគោត្រ ព្រោះដូច្នោះ ក្នុងពាក្យថា* **សមណោ ឱលុ ភោ គោតមោ** *នេះ មានអត្ថដូច្នេះថា បានឮថា សមណគោតមដ៏ចម្រើន ។ បទថា* **សក្យបុត្តោ** *នេះ ជាបទសម្តែងដល់ការៈដែលព្រះមានព្រះភាគ មានត្រកូលខ្ពស់ ។ បទថា* **សក្យ-កុលា បព្វជិតោ** *ជាបទសម្តែងដល់ការៈដែលព្រះមានព្រះភាគ ទ្រង់ព្រះផ្នួសដោយសទ្ធា ។ លោកអធិប្បាយថា ទ្រង់មិនមានការវិនាសណាមួយ មក*

គ្របសន្តត់ ទ្រង់លះត្រកូល ដែលមិនមានការវិនាសទាំងមូលនោះឯង ទ្រង់ព្រះផ្ទួសដោយការជឿក្នុងការសម្រេច ដោយការចេញមហាភិនេស្ត្រមណ៍ បទថា **ឧជ្ជហាន់ តិណស្ស ច ភុសស្ស ច យាវ មុទតោ ឃូរេសុំ** សេចក្តីថា យកស្មៅ និងអង្ការមលុបអណ្តូងទឹកផឹកឲ្យពេញត្រឹមមាត់ អធិប្បាយថា ដាក់ស្មៅជាដើមចូលទៅហើយ បិទអណ្តូង ។ បានញ្ចថា ស្រុកនោះមានអណ្តូង ១ សម្រាប់ប្រើប្រាស់របស់ពួកព្រាហ្មណ៍ ជិតផ្លូវដែលព្រះមានព្រះភាគយាងមកខាងក្រៅ ។ ទីដែលមានអណ្តូង និងបឹងជាដើម គ្រប់កន្លែងក្នុងទីនោះ រៀរអណ្តូងទឹកនោះ ក្នុងគ្រានោះ រីងស្ងួតមិនមានទឹកឡើយ ។ គ្រានោះ អ្នកថូនគ្រាម មិនទាន់ជ្រះថ្លាក្នុងព្រះរតនត្រ័យនៅឡើយ ត្រូវសេចក្តីកំណាញ់ គ្របសន្តត់ ដឹងថា ព្រះមានព្រះភាគយាងមក នាំគ្នាគិតថា បើសមណគោតមចូលមកកាន់ស្រុកនេះ ២-៣ ថ្ងៃ នឹងធ្វើឲ្យជនទាំងអស់នេះ តាំងនៅក្នុងឧវាទរបស់ទ្រង់ បន្ទាប់អំពីនោះ ធមិរបស់ព្រាហ្មណ៍ក៏តាំងនៅមិនបាន ក៏នៅមិនសុខ ធ្វើដូចម្តេចដើម្បីមិនឲ្យព្រះមានព្រះភាគ ប្រថាប់នៅក្នុងទីនោះ ទើបប្រឹក្សាគ្នាថា ក្នុងស្រុកនេះ មិនមានអណ្តូងទឹកដទៃ ពួកយើងនឹងធ្វើអណ្តូងទឹកនោះមិនឲ្យជាទីសម្រាប់ប្រើប្រាស់ កាលបើដូច្នេះ ព្រះសមណគោតមព្រមទាំងសាវ័ក នឹងមិនចូលស្រុកនេះ ដូច្នេះហើយ ទើបឲ្យពួកអ្នកស្រុកទាំងអស់ដងទឹក ៧ ថ្ងៃឲ្យពេញពាងជាដើម ហើយយកស្មៅ និងអង្ការមលុបអណ្តូងនោះ ។ ដោយហេតុនោះ ទើបលោកពោលថា ក៏នាំគ្នាយកស្មៅ និងអង្ការមចាក់ពេញអណ្តូងដរាបដល់មាត់ ដោយគិតថា កុំឲ្យសមណៈត្រងោល

ទាំងនោះ ផឹកទឹកបាន ។

បណ្តាបទទាំងនោះ បទថា **មុណ្ឌកា សមណកា** *សេចក្តីថា គួរនឹងពោលបុគ្គលត្រង៉ោលថា បុគ្គលត្រង៉ោល និងពោលសមណៈថា សមណៈតែជនទាំងនោះ នាំគ្នាមើលងាយ ដោយបំណងសង្កត់សង្កិន ទើបពោលយ៉ាងនោះ បទថា* **មា** *ប្រើក្នុងអត្ថបដិសេធ អធិប្បាយថា កុំងូត កុំផឹក ។*

[១៥៦] បទថា **មគ្គា ឱក្កម្ម** *ប្រែថា ចៀសចេញអំពីផ្លូវ ។ បទថា* **ឯតម្ហ**[1] *បានដល់ ពោលសម្តែងចេញចំពោះអណ្តូងទឹកដែលជនទាំងនោះ ធ្វើយ៉ាងនោះប៉ុណ្ណោះ ។*

សួរថា ព្រះមានព្រះភាគ ទ្រង់មិនបានពិចារណាដល់ប្រការដែលប្លែកនៃពួកព្រាហ្មណ៍ទាំងនោះ ទើបត្រាស់យ៉ាងនេះថា អ្នកចូរនាំទឹកផឹកអំពីអណ្តូងនេះមក ឬថា ទ្រង់ពិចារណាហើយ ទើបជឹង ។ ឆ្លើយថា ទាំងដែលទ្រង់ជ្រាបនោះឯង ព្រះមានព្រះភាគ ទ្រង់ប្រកាសពុទ្ធានុភាពរបស់ព្រះអង្គទូន្មានព្រាហ្មណ៍ទាំងនោះ ដើម្បីធ្វើពួកជនទាំងនោះឲ្យអស់ព្យសន៍ ទើបត្រាស់យ៉ាងនោះ មិនមានបំណងនឹងឆាន់ទឹក ដោយហេតុនោះឯង ក្នុងទីនេះ ទ្រង់មិនត្រាស់ថា តថាគតស្រេកទឹក ដូចក្នុងមហាបរិនិព្វានសូត្រទេ ។ ព្រះភណ្ឌាគារិកកាលមិនជឹងព្រះអធ្យាស្រ័យរបស់ព្រះសាស្តា ក៏ក្រាបទូលប្រការចម្លែកដែលពួកអ្នកបួនគ្រាមធ្វើ ទើបក្រាបទូលថា **ឥទានិ សោ ភន្តេ** *ជូរច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **ឥទានិ** *ប្រែថា ឥឡូវនេះ អធិប្បាយថា ក្នុង*

-១ បិដកខ្មែរ ជា ឯតស្មា ។

កាលដែលពួកខ្ញុំព្រះអង្គមកដល់នោះឯង អាចារ្យពួកខ្លះ ពោលថា **ឯសោ ភន្តេ ឧទចាសោ** *ដូច្នេះក៏មាន ។*

ព្រះថេរៈបដិសេធអស់វារៈ ២ ដង ក្នុងគ្រាទី ៣ ទើបគិតថា ព្រះតថាគតទាំងឡាយ ទ្រង់មិនធ្វើការប្រើអស់វារៈ ៣ ដងឡើយ ទ្រង់ពិតជាឃើញកាលវែង ទ្រង់ពិតជាឃើញហេតុ ដូច្នេះហើយ ទើបកាន់ចាត្រៈបស់ព្រះមានព្រះភាគ ដែលទេវមហារាជថ្វាយ ហើយបាននៅកាន់អណ្តូងទឹក ។ កាលព្រះថេរៈកំពុងដើរទៅ ទឹកក្នុងអណ្តូងក៏បរិបូណ៌ ជន់ឡើង ហូរទៅដោយជុំវិញ ស្មៅ និងអង្កាមទាំងឡាយអណ្តែតទៅឯងនោះឯង ។ កាលទឹកដែលហូរទៅនោះជន់ឡើងខាងលើជលាល័យ មានស្រះបោក្ខរណីជាដើមទាំងអស់ក្នុងស្រុកនោះ ដែលរីងស្ងួត ក៏សម្បូរដោយទឹក គូ បឹង និងរណ្តៅជាដើមក៏ដូចគ្នា ។ ផ្ទៃដីនៃស្រុកទាំងអស់នោះ ត្រូវជំនន់ទឹកធំ មានដូចក្នុងកាលដែលភ្លៀងធ្លាក់ខ្លាំង ។ ផ្កាដែលកើតក្នុងទឹក មានផ្កាកោមុទ ឧប្បល បទុម និងបណ្ឌរិកជាដើម ផុសឡើងក្នុងជលាល័យនោះៗ រីកស្គុសស្គាយលើទឹក ។ បក្សីដែលអាស្រ័យទឹករស់នៅ មានហង្ស ក្រៀល ចាកក្រពាក ថ្ពុំ និងកុកជាដើម កាលភ្លៀងធ្លាក់ ក៏នាំគ្នាយំទ្រហឹងក្នុងទីនោះៗ អ្នកថូនគ្រាមឃើញអន្ទង់ទឹកនោះជន់ឡើងយ៉ាងនោះ ដេរដាសទៅដោយកម្ទួលទឹក និងរលកផុសឡើងជាពពុះ មានសោភណភាពតាំងនៅដោយជុំវិញ នាំគ្នាកើតអស្ចារ្យក្នុងចិត្ត មិនធ្លាប់មាន ទើបប្រឹក្សាព្រមគ្នាយ៉ាងនេះថា ពួកយើងព្យាយាមដើម្បីឲ្យសមណគោតមជាប់ទឹក តាំងអំពីកាលសមណគោតមនោះយាងមក

ជំនន់ទីញ្ជាំងនេះ ក៏ជន់ឡើងដល់ម្ល៉ះ ព្រះសមណាគោតមមានឥទ្ធានុភាពយ៉ាងនេះ មិនចាំបាច់សង្ឃ័យឡើយ ព្រោះព្រះសមណាគោតមនោះមានឫទ្ធិច្រើន មានអានុភាពច្រើន ។ ជំនន់ទឹកធំជន់ឡើងលិចស្រុករបស់យើង មិនមែនជាហាន:ឡើយ ណ្ហើយចុះ ពួកយើងនឹងចូលទៅរក ចូលទៅអង្គុយជិតព្រះសមណាគោតម សម្តែងទោសដែលខុសឆ្គងហើយ សូមខមាទោសជាមួយនឹងព្រះអង្គ ។

អ្នកបួនគ្រាមទាំងអស់ មានអធ្យាស្រ័យតែមួយជាពួកជាគណៈ ចេញពីស្រុក ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ពួកខ្លះថ្វាយបង្គំព្រះយុគលបាទនៃព្រះមានព្រះភាគ ដោយសិរសា គឺត្បូង ពួកខ្លះផ្គងអញ្ជលី ពួកខ្លះពោលពាក្យប្រាស្រ័យជាមួយព្រះមានព្រះភាគ ពួកខ្លះប្រកាសឈ្មោះនិងគោត្រ ពួកខ្លះអង្គុយស្ងៀម កាលធ្វើយ៉ាងនេះ ទើបអង្គុយក្នុងចំណែកម្ខាង ទាំងអស់គ្នា នាំគ្នាសម្តែងទោសថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គសូមប្រទានវារោកាស ពួកខ្ញុំព្រះអង្គបង្កការរាំងទឹកដល់ព្រះគោតម និងសាវ័កបានយកស្មៅ និងអង្ការមចាក់ក្នុងអណ្តូងទឹកនោះ អណ្តូងទឹកនោះ ទោះបីមិនមានចេតនា ក៏ដូចមានចេតនា ជាអ្នកដឹងគុណរបស់ព្រះគោតម ធ្វើស្មៅ និងអង្ការមទាំងអស់ឲ្យចេញទៅឯង ក្លាយជាអណ្តូងទឹកបរិសុទ្ធល្អ ក្នុងទីនេះ ទីដែលជក់ទឹកទាំងអស់ ពេញទៅដោយទឹកដ៏ច្រើន គួរជាទីត្រេកអរនៃចិត្ត សត្វទាំងឡាយ នាំគ្នាអាស្រ័យទឹកនោះចិញ្ចឹមជីវិត នាំគ្នាត្រេកអរ តែពួកខ្ញុំព្រះអង្គ ជាមនុស្ស ក៏មិនបានស្គាល់គុណរបស់ព្រះសមណាគោតម ទើបញុំាងនូវ

កម្មមិនសមគួរយ៉ាងនេះ សូមព្រះគោតមធ្វើអន្ទង់ទឹកធំនេះ កុំឲ្យលិចស្រុកនេះ ដល់ពួកខ្ញុំព្រះអង្គចុះ សូមព្រះគោតមអត់ទូវទោសតាមដែលខ្ញុំព្រះអង្គប្រព្រឹត្តកន្ទង ដោយការល្ងង់ខ្លៅ ដោយសេចក្តីអនុគ្រោះ ។ ឯព្រះមានព្រះភាគ ត្រាស់ថា ណ្ហើយចុះ តថាគតអត់ទូវទោសដែលពួកអ្នកប្រព្រឹត្តកន្ទងដោយសេចក្តីល្ងង់ខ្លៅ ដើម្បីសង្រួមតទៅ ដូច្នេះហើយ ទើបទ្រង់អត់ទូវទោសដែលប្រព្រឹត្តកន្ទងរបស់ជនទាំងនោះ ទ្រង់ជ្រាបថា ជនទាំងនោះ មានចិត្តជ្រះថ្លា ទើបទ្រង់សម្តែងធម៌តាមសមគួរដល់អធ្យាស្រ័យ ឲ្យក្រៃលែងឡើង ។ ពួកជនទាំងនោះ ស្តាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា តាំងនៅក្នុងគុណធម៌ មានសរណៈជាដើម ថ្វាយបង្គំព្រះមានព្រះភាគ ហើយធ្វើប្រទក្សិណ នាំគ្នាចៀសចេញទៅ ។ មុនពួកជនទាំងនោះមក ព្រះអានន្ទឃើញថ្ពាជិហារ្យនោះ កើតអស្ចារ្យក្នុងចិត្ត ព្រោះមិនធ្លាប់មានយកថ្ពាត្រជង់ទឹក បង្អោនចូលទៅថ្វាយព្រះមានព្រះភាគ ហើយក្រាបទូលរឿងនោះ ដោយហេតុនោះ ទើបលោកពោលពាក្យជាដើមថា **ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **មុខតោ ឱរមិត្វា** *សេចក្តីថា នាំយកស្មៅជាដើម ចេញទៅអំពីមាត់អណ្តូង ។ បទថា* **វិស្សន្ទេន្តោ មញ្ញេ** *សេចក្តីថា កាលមុន បុគ្គលត្រូវប្រើខ្សែវែង ជង់ទឹកអំពីអណ្តូង ក្នុងគ្រាព្រះថេរៈទទួលថ្ពាត្រ របស់ព្រះមានព្រះភាគ ហើយដើរទៅ ទឹកហូរចេញស្មើមាត់អណ្តូង តាំងនៅ ល្មមក្អែកផឹកបាន ។ ពាក្យនេះ លោកពោលសំដៅយកការកើតឡើង*

នៃទឹក ពេលដែលព្រះថេរៈដើរទៅ ក្រោយអំពីនោះ រណ្តៅទាំងអស់ ក្នុងស្រុកនោះ បានពេញទៅដោយទឹក ដោយនយដូចពោលហើយ ក្នុងកាលមុន ។ នេះជាការសម្រេចមិនមែនព្រោះការអធិដ្ឋានរបស់ព្រះពុទ្ធ មិនមែនប្រើអានុភាពរបស់ទេវតាទាំងឡាយទេ ដោយពិត តើតព្រោះបុញ្ញានុភាពរបស់ព្រះសាស្តា ដូចក្នុងការយោងអំពីក្រុងរាជគ្រឹះ ទៅកាន់ក្រុងវេសាលី ដើម្បីសម្តែងព្រះបរិត្ត ។ តែអាចារ្យពួកខ្លះពោលថា ដើម្បីឲ្យអ្នកចូនគ្រាមកើតសេចក្តីជ្រះថ្លា ក្នុងព្រះដ៏មានព្រះភាគ ទេវតាទាំងឡាយ ប្រាថ្នាប្រយោជន៍ដល់មនុស្សទាំងនោះផ្ទៃ ។ អាចារ្យមួយពួកទៀតពោលថា ស្តេចនាគដែលនៅខាងក្រោមអណ្តូងបានធ្វើយ៉ាងនោះ ។ ទាំងអស់ មិនមែនហេតុសមគួរឡើយ ព្រោះលោកសម្តែងការកើតឡើងនៃទឹក ដោយបុញ្ញានុភាពរបស់ព្រះសាស្តាប៉ុណ្ណោះ ។

បទថា **ឯតមត្តំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងនូវអត្តនេះ ពោល គឺការសម្រេចដែលខ្ជួនបំណង ដោយវៀរចាកការអធិដ្ឋាននោះ ទើបទ្រង់បន្ទឺឧទាននេះ ដែលសម្តែងដល់សេចក្តីនោះ ។*

បណ្តាបទទាំងនោះ បទថា **កឹ កយិរា ឧទចានេន អាចា ចេ យទិ សព្វទា សិយុំ** *សេចក្តីថា បើទឹកក្នុងទីគ្រប់អន្ទឺគប្បីមាន គឺគប្បីកើតដល់អណ្តូងទឹកណាអស់កាលទាំងពួង គឺបើអណ្តូងទឹកគប្បីទាក់ទងដោយហេតុត្រឹមតែការបំណង គឺអណ្តូងទឹកនោះ ក៏នឹងបានទឹកទាំងនោះ បុគ្គលគប្បីធ្វើអ្វី គឺគួរធ្វើអ្វីដោយអណ្តូងទឹកនោះ អធិប្បាយថា អណ្តូងទឹកមានប្រយោជន៍អ្វី ។*

បទថា **តណ្ហាយ មូលតោ ឆេត្វា កិស្ស បរិយេសនញ្ចរេ** សេចក្តីថា សត្វ ទាំងឡាយដែលមិនបានធ្វើបុណ្យ ត្រូវតណ្ហាដោតក្រង រមែងក្តៅក្រហាយ ព្រោះទុក្ខក្នុងការមិនបានវត្ថុដែលខ្លួនប្រាថ្នា ព្រះសព្វញ្ញូពុទ្ធដូចតថាគត កាត់ នូវឫស ឬគល់នៃតណ្ហានោះ ស្ថិតនៅ គប្បីស្វែងរកទឹក គឺស្វែងរកបច្ចុយ ដទៃ ដើម្បីហេតុអ្វី គឺព្រោះហេតុអ្វី ។ អាចារ្យពួកខ្លះពោលថា **មូលតោ ឆេត្តា** ដូច្នេះក៏មាន អធិប្បាយថា កាត់ឫសត្រង់គល់របស់តណ្ហានោះឯង ។ ម្យ៉ាងទៀត បទថា **មូលតោ ឆេត្តា** សេចក្តីថា កាត់តណ្ហាតាំងអំពីឫស លោកអធិប្បាយថា ទ្រង់មិនបានព្រះតម្រិះដល់បុញ្ញសម្ភារទាំងអស់ដែលមិន មានប្រមាណដើម្បីព្រះអង្គ ចាប់តាំងអំពីការប្រាថ្នាធំ ដែលជាមូលនៃ ពោធិញ្ញាណ ទ្រង់បំពេញដោយបង្អោនទៅដើម្បីជាប្រយោជន៍ដល់សត្វលោក តែប៉ុណ្ណោះ ទើបទ្រង់កាត់តណ្ហា មួយអន្ទើដោយឫស ទ្រង់ត្រាច់ស្វែងរកទឹក ដើម្បីអ្វី គឺព្រោះហេតុអ្វី ព្រោះបុគ្គលមានតណ្ហាជាតួហេតុ មិនមានការបាន វត្ថុដែលខ្លួនប្រាថ្នា តែអ្នកថូនគ្រាមទាំងនោះ ជាបុគ្គលខ្វាក់ ល្ងង់ខ្លៅ មិនដឹង ហេតុនេះ ទើបធ្វើយ៉ាងនេះឯង ។

អដ្ឋកថា ឧធមានសូត្រធី ៩ ចប់

សុត្តន្តបិដក

ឧឧេនសូត្រ

[១៥៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងយោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង កាល ព្រះបាទឧទេន ស្តេចទៅកាន់ឧទ្យាន មានភ្ញីងនេះខាងក្នុងព្រះរាជវាំង ពួក ស្ត្រីទាំង ៥០០ នាក់ មាននាងសាមាវតីជាប្រធាន ធ្វើមរណកាលទាំងអស់ ។ គ្រានោះ ពួកភិក្ខុជាច្រើន ស្បៃកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាតក្នុងក្រុងកោសម្ពី ។ លុះត្រាច់បិណ្ឌបាត ក្នុងក្រុងកោសម្ពី ហើយ ត្រឡប់អំពីបិណ្ឌបាតវិញ ក្នុងវេលាខាងក្រោយភត្ត ចូលទៅគាល់ ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយ អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ បាន ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ កាល ព្រះបាទឧទេន ទ្រង់ស្តេចទៅកាន់ឧទ្យាន មានភ្ញីងនេះខាងក្នុងព្រះរាជវាំង ពួកស្ត្រីទាំង ៥០០ នាក់ មាននាងសាមាវតីជាប្រធាន ធ្វើមរណកាល ទាំងអស់ បពិត្រព្រះអង្គដ៏ចម្រើន គតិរបស់ឧបាសិកាទាំងនោះ តើដូចម្តេច លោកខាងមុខ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាឧបាសិកាទាំងនុ៎ះ ឧបាសិកា ជាសោតាបន្នាក៏មាន ជាសកទាគាមិនីក៏មាន ជាអនាគាមិនីក៏មាន ម្នាលភិក្ខុទាំងឡាយ ឧបាសិកាទាំងអស់នោះ ដែលធ្វើកាលកិរិយា មិនមែន ឥតផលទេ ។ លុះព្រះមានព្រះភាគ ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់ បន្ទឺឧទាននេះ ក្នុងវេលានោះថា

សត្វលោក មានមោហៈជាចំណង ប្រាកដដូចជាមានរូបចម្រើន បុគ្គលពាលមានឧបធិក្កិលេសជាចំណងត្រូវងងឹតគឺអវិជ្ជាចោមរោមហើយ ប្រាកដដូចជាទៀងទាត់ សេចក្តីកង្វល់មានរាគៈជាដើម របស់បុគ្គលអ្នកពិចារណាឃើញច្បាស់ មិនមានទេ ។ សូត្រទី ១០ ។

ចូឡវគ្គទី ៧ ចប់

ឧទ្ទាននៃចូឡវគ្គនោះ គឺ

និយាយអំពីព្រះលកុណ្ឌកកទ្វិយៈ មាន ២ លើក អំពីពួកជនជាប់ក្នុងកាម មាន ២ លើក អំពីព្រះលកុណ្ឌក-កទ្វិយៈ ១ អំពីការអស់តណ្ហា ១ អំពីការអស់បបញ្ច-សញ្ញា ១ អំពីព្រះកច្ចានៈ ១ អំពីអណ្តូង ១ អំពីព្រះជាតខរទេន ១ ។

អដ្ឋកថា

ឧទេនសូត្រ

ឧទេនសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ

[១៥៧] បទថា **រញ្ញោ ឧទេនស្ស** បានដល់ ព្រះរាជាព្រះនាមឧទេន ដែលគេហៅថា ស្តេចវង្សីក៏មាន ។ បទថា **ឧយ្យានគតស្ស** បានដល់ យាងទៅកាន់ឧទ្យានដើម្បីប្រពាតក្នុងឧទ្យាននោះ ។ ពិតហើយ បទថា **ឧទេនស្ស** នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថអនាទរៈ ។ បទថា **ឧទេនស្ស** នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងសាមីសម្ពន្ធ មិនសំដៅដល់បទថា **អន្តេបុរំ** ទេ ។ បទថា **កាលកតានិ** បានដល់ ត្រូវភ្លើងឆេះស្ងាប់ហើយ ។ ក្នុងបទថា **សាមាវតីបមុខានិ** មានពាក្យជ្រៀតសួរចូលមកថា ព្រះនាងសាមាវតីនេះជានរណា ហេតុអ្វី ទើបត្រូវភ្លើងឆេះ ខ្ញុំនឹងឆ្លើយថា ធីតារបស់សេដ្ឋី ក្នុងក្រុងកោសម្ពី ដែលឃោសក-សេដ្ឋីតែងតាំងក្នុងតំណែងជាធីតា មានស្រី ៥០០ ជាបរិវារ ជាអគ្គមហេសីរបស់ព្រះបាទឧទេន ជាព្រះអរិយសាវិកា ច្រើនទៅដោយមេត្តាវិហារធម៌ ព្រះនាងព្រះនាមថា សាមាវតី ។ ក្នុងទីនេះ មានសេចក្តីសង្ខេបប្រមាណប៉ុណ្ណេះ បើពោលឲ្យពិស្តារ គប្បីជ្រាបឧប្បត្តិកថារបស់ព្រះនាងសាមាវតី តាំងអំពីដើមដល់ចប់ ក្នុងធម្មបទឯណោះចុះ ។ នាងមាគន្ទិយា ធីតារបស់មាគន្ទិយព្រាហ្មណ៍ ស្តាប់គាថាដែលព្រះមានព្រះភាគ ទ្រង់សម្តែងដល់មាតាបិតារបស់ខ្លួនថា

ព្រោះបានឃើញនាងតណ្ហា នាងអរតី និងនាងរាគា តថាគតមិនមានការ

ពេញចិត្តក្នុងមេថុនឡើយ ព្រោះបានឃើញសរីរៈរបស់កូនស្រីអ្នកដែលពេញ ដោយមូត្រ និងករីស តថាគតនឹងពេញចិត្តក្នុង (មេថុន) បានដូចម្តេច តថាគតមិនប្រាថ្នាពាល់ត្រូវសរីរៈនៃធីតារបស់អ្នក សូម្បីដោយជើង ដូច្នេះ ទើបចង់អាឃាតក្នុងព្រះសាស្តា ។ សម័យក្រោយមក ព្រះបាទឧទេន ទ្រង់ ស្តាបនាតំណែងមហេសី ជីងថា ព្រះមានព្រះភាគដល់ក្រុងកោសម្ពី និងជីង ថា ស្រី ៥០០ មាននាងសាមាវតីជាប្រធាន ជាឧបាសិកា ទើបគិតថា ព្រះ សមណគោតមមកកាន់នគរនេះ ឥឡូវនេះ អញនឹងជីងកិច្ចដែលគួរធ្វើដល់ ព្រះសមណគោតមនោះ មួយអន្ទើដោយស្រីដែលជាឧបដ្ឋាយិការបស់ សមណគោតមទាំងនោះ អញនឹងជីងកិច្ចដែលគួរធ្វើដល់ស្រីទាំងនេះ ដែល មានសាមាវតីជាប្រធាន ដូច្នេះ ព្យាយាមដើម្បីធ្វើសេចក្តីវិនាសដល់ព្រះសាស្តា និងដល់ស្រីទាំងនោះ ដោយអនេកបរិយាយ កាលមិនអាចធ្វើ ថ្ងៃមួយ ស្រប ពេលដែលព្រះរាជាយាងទៅលេងកីឡាក្នុងឧទ្យាន ទើបផ្ញើសារដល់ម្ចាស់មា សូមម្ចាស់មាឡើងកាន់ប្រាសាទរបស់នាងសាមាវតី បើកឃ្វាំងសំពត់ និង ឃ្វាំងប្រេង យកសំពត់ជ្រលក់ក្នុងក្រឡប្រេង ហើយរុំសសរ ឲ្យស្រីទាំង អស់នោះនៅរួមគ្នា បិទទ្វារ ជាក់គន្លឹះអំពីខាងក្រៅ យកភ្លើងឆួលជុតព្រះ ដំណាក់ ហើយចុះទៅ ។

ម្ចាស់មាស្តាប់ដូច្នោះ ទើបឡើងកាន់ប្រាសាទ បើកឃ្វាំង យកសំពត់ ជ្រលក់ប្រេង រុំសសរ ។ សម័យនោះឯង ស្រីទាំងឡាយ មាននាងសាមាវតី ជាប្រធាន ទើបចូលទៅរកមាគន្ធិយបុរសបណ្តើរ ពោលបណ្តើរថា ម្ចាស់មា

ធ្វើអ្វី មាគន្ទិយពោលថា នែនាងទាំងឡាយ ព្រះរាជាឲ្យយកសំពត់ជ្រលក់ប្រែងវុំសសរទាំងនេះ ដើម្បីធ្វើឲ្យមាំទាំ ឈ្មោះថា ក្នុងព្រះរាជដំណាក់ កម្មដែលប្រកបល្អ ប្រកបអាក្រក់ ជីងបានលំបាក ពួកនាងកុំនៅក្នុងសម្នាក់របស់ខ្ញុំឡើយ ដូច្នេះហើយ ទើបឲ្យស្រីដែលមកទាំងនោះ ចូលក្នុងបន្ទប់ ជាក់គន្លឹះខាងក្រៅ ជុតភ្លើង តាំងអំពីដើម ហើយចុះមក ។ ព្រះនាងបានឲ្យឱវាទដល់ស្រីទាំងនោះថា នែនាងទាំងឡាយ កាលយើងត្រាច់ទៅក្នុងសង្សារដែលជីងទីបំផុតមិនបាន អត្តភាពដែលត្រូវភ្លើងឆេះយ៉ាងនេះ កំណត់ដោយពុទ្ធញ្ញាណក៏ធ្វើបានដោយលំបាក ពួកនាងកុំប្រមាទឡើយ ។ ស្រីទាំងនោះ សម្រេចសោតាបត្តិផលក្នុងសម្នាក់នាងខុជ្ជុត្តរាអរិយសាវិកា ដែលជីងច្បាស់នូវពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ជាអ្នកស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ហើយសម្រេចផល និងដល់នូវសេក្ខប្បដិសម្ភិទា សម្តែងធម៌តាមទំនងដែលព្រះសាស្តាទ្រង់សម្តែងនោះឯង និងប្រកបសេចក្តីខ្វល់ខ្វាយ មនសិការកម្មដ្ឋានក្នុងលំដាប់ៗ កាលភ្លើងកំពុងឆេះព្រះរាជដំណាក់ មនសិការដល់វេទនាបរិគ្គហកម្មដ្ឋាន ពួកខ្លះសម្រេចទុតិយផល ពួកខ្លះសម្រេចតតិយផល ហើយធ្វើអនិច្ចកម្ម ។

គ្រានោះ ភិក្ខុទាំងឡាយកំពុងត្រាច់បិណ្ឌបាត ក្នុងក្រុងកោសម្ពី ក្រោយអំពីឆាន់កត្តាហារហើយ ទើបក្រាបទូលដល់ព្រះមានព្រះភាគ សួរដល់អភិសម្បរាយភពរបស់ស្រីទាំងនោះ ។ ព្រះមានព្រះភាគ បានត្រាស់ប្រាប់ការដែលស្រីទាំងនោះសម្រេចអរិយផលដល់ភិក្ខុទាំងឡាយ ។ ដោយហេតុនោះ

ទើបលោកពោលថា **តេន ខោ បន សមយេន រញ្ញោ ឧទេនស្ស ។បេ។ អនិបួលា កាលកតា។**

បណ្តាបទទាំងនោះ បទថា **អនិបួលា** *សេចក្តីថា ស្រីដែលអនិច្ចកម្ម មិនឥតផលឡើយ គឺសម្រេចសាមញ្ញផលនោះឯង ។ ឯស្រីទាំងនោះ បានទទួលផលដែលនាងសាមាវតីឲ្យឱវាទដោយគាថា ក្នុងសំយុត្តនិកាយ-សគាថវគ្គថា*

> *អ្នកទាំងឡាយ ចូរជ្រាវឮ ចូរប្រឹងប្រែង ចូរប្រកបព្យាយាម ក្នុងព្រះពុទ្ធសាសនា ចូរកម្ចាត់បង់សេនានៃមច្ចុ ដូចជាកុញ្ជរញ៉ាំញីផ្ទះបបុស អ្នកណាមិនប្រហែស ក្នុងធម្មវិន័យនេះ អ្នកនោះ នឹងលះបង់នូវជាតិសង្សារ ហើយធ្វើនូវទីបំផុតទុក្ខបាន ដូច្នេះ ។*

ទើបធ្វើមនសិការវេទនាបរិគ្គហកម្មដ្ឋាន បានឃើញច្បាស់ហើយសម្រេចផលទី ២-៣ ។ ឯនាងខុជ្ជុត្តរា ព្រោះមានអាយុនៅសល់ ព្រោះមិនបានធ្វើកម្មបែបនោះក្នុងកាលមុន បាននៅខាងក្រៅជ្រោងទាននោះ ។ អាចារ្យពួកខ្លះពោលថា នាងនៅចម្ងាយមួយយោជន៍ ។ លំដាប់នោះ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោ អរិយសាវិកាអនិច្ចកម្មបែបនោះ មិនគួរឡើយហ្ន៎ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ អម្បាញ់មិញនេះ ។ កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការស្លាប់របស់ស្រីទាំងនោះមិនគួរ ក្នុងអត្តភាពនេះសោត តែកម្មដែលពួកនាងធ្វើក្នុង

កាលមុននោះឯង ជាកម្មដែលសមគួរពិត ដែលពួកនាងបានទទួល ដូច្នេះ ហើយ កាលកិកុទាំងនោះទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ ក្នុងនគរ ពារាណសី ព្រះបច្ចេកពុទ្ធ ៨ រូប ឆាន់កត្តាហារជានិច្ច ក្នុងព្រះរាជនិវេសន៍ ស្រី ៥០០ នាក់ នាំគ្នាទំនុកបម្រុងព្រះបច្ចេកពុទ្ធទាំងនោះ ។ ក្នុងព្រះបច្ចេក-ពុទ្ធទាំង ៨ រូបនោះ ៧ រូបទៅកាន់ព្រៃហិមពាន្ត ។ ១ រូប អង្គុយចូល សមាបត្តិត្រង់គុម្ពស្មៅស៊ុមទ្រមួយកន្លែង ជិតមាត់ស្ទឹង ។ សម័យនោះ គ្រា ព្រះបច្ចេកពុទ្ធទៅហើយ ព្រះរាជាទ្រង់បំណងលេងទឹកជាមួយស្រីទាំងឡាយ នោះ ទើបយាងទៅ ស្រីទាំងនោះលេងទឹកក្នុងទីនោះអស់មួយថ្ងៃ ត្រូវឃាគ្របសង្កត់ បំណងនឹងអាំងភ្លើង ឈរជុំវិញគុម្ពស្មៅនោះ ខាងលើដេរដាសដោយស្មៅស្ងួត សម្គាល់ថា ជាគំនរស្មៅ ទើបដុតភ្លើង កាលស្មៅត្រូវភ្លើង រួចរលត់ ឃើញព្រះបច្ចេកពុទ្ធគិតថា ព្រះបច្ចេកពុទ្ធរបស់ព្រះរាជាត្រូវភ្លើងឆេះ ព្រះរាជាទ្រង់ជ្រោបរឿងនេះ នឹងធ្វើយើងឲ្យវិនាស យើងនឹងដុតលោកឲ្យស្រេច បាច់តែម្តង ដូច្នេះហើយ នាំគ្នាជញ្ជួនឧសមកអំពីទីផ្សេងៗ ធ្វើឲ្យជាគំនរអំពី លើព្រះបច្ចេកពុទ្ធ ដុតភ្លើង នាំគ្នាចៀសចេញទៅ ដោយយល់ថា ឥឡូវនេះ ព្រះបច្ចេកពុទ្ធនឹងឆេះខ្ទេចខ្ទីទៅហើយ ។ ស្រីទាំងនោះ ក្នុងកាលមុន មិនមាន ចេតនា តែឥឡូវនេះ នាំគ្នាចងដោយចំណងកម្ម ។ ខាងក្នុងសមាបត្តិ ទោះ បីស្រីទាំងនោះនាំគ្នាជញ្ជួនឧសមកវាប់ពាន់រនេះ ហើយដុតព្រះបច្ចេកពុទ្ធ ក៏មិន អាចឲ្យលោកមានអាការត្រឹមតែក្តៅបានឡើយ ។ ព្រោះដូច្នោះ ក្នុងថ្ងៃទី ៧

ព្រះបច្ចេកពុទ្ធបានក្រោកទៀងហើយ ទៅតាមសប្បាយ ។ ស្រីទាំងនោះ ព្រោះកម្មដែលនាងធ្វើ ទើបនេះក្នុងនរកច្រើនពាន់ឆ្នាំ ច្រើនសែនឆ្នាំ ព្រោះសេសវិបាកនៃកម្មនោះឯង ដំណាក់ត្រូវភ្លើងឆេះ ដោយទំនងនេះ នាងក៏ត្រូវភ្លើងឆេះអស់មួយរយអត្តភាព ។ នេះជាបុព្វកម្មរបស់ស្រីទាំងនោះ ។ ព្រោះស្រីទាំងនោះ ធ្វើឲ្យជាក់ច្បាស់នូវអរិយផលក្នុងអត្តភាពនេះ ទើបចូលទៅអង្គុយជិតព្រះរតនត្រ័យ ដូច្នោះ ក្នុងស្រីទាំងនោះ ស្រីដែលជាព្រះអនាគាមិនី កើតក្នុងសុទ្ធាវាស ក្រៅអំពីនោះ ពួកខ្លះ កើតក្នុងស្ថានតាវត្តិង្ស ពួកខ្លះ កើតក្នុងជាន់យាមា ពួកខ្លះ កើតក្នុងជាន់តុសិត ពួកខ្លះ កើតក្នុងនិម្មានរតី ពួកខ្លះ កើតក្នុងជាន់បរនិម្មិតវសវត្តី ។

ឯព្រះបាទឧទេន ទ្រង់ជ្រាបថា ដំណាក់របស់នាងសាមាវតីត្រូវភ្លើងឆេះ ទើបទ្រង់យាងមកដល់ទីនោះដោយប្រញាប់ កាលស្រីទាំងនោះ ត្រូវភ្លើងឆេះហើយនោះឯង ។ កាលយាងមក ទ្រង់បញ្ជាឲ្យមនុស្សលត់ភ្លើងត្រង់ដំណាក់ ទ្រង់កើតទោមនស្សដ៏ខ្លាំងក្លា ដឹងថា ព្រះនាងមាគន្ទិយាបង្កហេតុនោះដោយឧបាយ ព្រោះកម្មដែលនាងមាគន្ទិយាធ្វើខុសក្នុងអរិយសាវិកាជាសំគឿន ទើបឲ្យជាក់រាជអាជ្ញាដល់នាង មួយអន្ទើដោយពួកញាតិ ។ ព្រះនាងមាគន្ទិយា មួយអន្ទើដោយបរិវារ មិត្រ គ្នីគ្នា បានដល់នូវការវិនាសធំ ដោយប្រការដូច្នេះ ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងដល់ហេតុដែលស្រីទាំងនោះ មានព្រះនាងសាមាវតីជាប្រធាន ដល់នូវការវិនាស*

ក្នុងគំនរក្លីង និងនិមិត្តដែលនាងមាគន្ទិយា មួយអន្លើដោយមិត្រ និងបក្ខពួក ដល់នូវការវិនាស ដោយព្រះរាជអាជ្ញានេះ ទើបទ្រង់បន្លឺឧទាននេះ ដែល សម្តែងសេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **មោហសម្ពន្ធនោ លោកោ ភព្វរូចោវ ជិស្សតិ** សេចក្តីថា សត្វលោកណាក្នុងលោកនេះ ប្រាកដដូចបុគ្គលសមគួរពិត គឺដូច ជាបុគ្គលសម្ឃូរដោយហេតុ សត្វលោកនោះ មានមោហៈជាគ្រឿងចង គឺស្អេក ស្ពះដោយមោហៈ កាលមិនដឹងវត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ ដល់ខ្លួន ទើបមិនប្រព្រឹត្តទៅក្នុងវត្ថុដែលជាប្រយោជន៍ សន្សំតែវត្ថុដែលមិន មែនជាប្រយោជន៍ ដែលនាំសេចក្តីទុក្ខមកឲ្យ និងចម្រើននូវអកុសលដ៏ច្រើន ។ បាលីថា **ភវរូចោវ ជិស្សតិ** ដូច្នេះក៏មាន ។ បាលីនោះមានអធិប្បាយដូចត ទៅនេះ លោកនេះ មានមោហៈជាគ្រឿងចង គឺស្អេកស្ពះដោយមោហៈ ព្រោះ ហេតុនោះឯង ទើបខ្លួនរបស់សត្វលោកនោះ ប្រាកដដូចមានរូប គឺដូចមាន សកាវៈទៀង គឺប្រាកដដូចមិនចាស់ មិនស្លាប់ ដែលជាហេតុឲ្យធ្វើវត្ថុ ដែល មិនគួរធ្វើ មានបាណាតិបាតជាដើម ។ បទថា **ឧបធិពន្ធនោ ពាលោ តមសា បរិវារិតោ សស្សតោរិវ ទាយតិ** សេចក្តីថា មិនមែនតែសត្វលោក មាន មោហៈជាគ្រឿងចងតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត សត្វលោកល្ងង់ខ្លៅនេះ នៅមានឧបធិជាគ្រឿងចង ដែលការងងឹត គឺអវិជ្ជាចោមរោមហើយ លោក អធិប្បាយពាក្យនេះថា ព្រោះញាណដែលជាហេតុឲ្យបុគ្គលពិចារណាឃើញ កាម និងខន្ធដែលមិនខុសប្លែកថា មិនទៀង ជាទុក្ខ មានការប្រែប្រួលទៅជា

ធម្មតា ដូច្នេះមិនមាន ព្រោះបុថុជ្ជនល្ងង់ខ្លៅ ត្រូវងងឹត គឺអវិជ្ជា ចោមរោម គ្របជណ្តប់ដោយជុំវិញ ដូច្នោះ បុថុជ្ជនល្ងង់ខ្លៅនោះ មានឧបធិជាគ្រឿងចង ដោយឧបធិទាំងនេះ គឺកាមូបធិ កិលេសូបធិ ខន្ធូបធិ ព្រោះហេតុនោះ កាល បុគ្គលដែលមានឧបធិឃើញ រមែងប្រាកដដូចទៀង គឺរមែងប្រាកដថា មាន សភាវៈទៀង បានដល់ មានសព្វកាល ។ បាលីថា **អសស្សតិរេ ខាយតិ** *ដូច្នេះក៏មាន ។ បាលីនោះ មានអធិប្បាយដូចតទៅនេះថា ឧបធិនោះ រមែង ប្រាកដ អធិប្បាយថា ចូលទៅតាំង ដូចចំណែកមួយនៃលោក ដោយការ ប្រកាន់ខុសថា អត្តាមាន គឺកើតសព្វកាល និងថា អត្តាជទៃមិនទៀង គឺមាន ភាវៈមិនពិតប្រាកដ ។ ពិតហើយ រ អក្ខរៈ ធ្វើការតបទ ។ បទថា* **បស្សតោ នត្ថិ កិញ្ចនំ** *សេចក្តីថា បុគ្គលណាកំណត់សង្ខារទាំងឡាយ ពិចារណា ឃើញដោយលក្ខណៈ មានអនិច្ចលក្ខណៈជាដើម កាលបុគ្គលនោះឯង ឃើញ ដឹង ចាក់ធ្លុះតាមសេចក្តីពិត ដោយមគ្គប្បញ្ញា ដែលប្រកបដោយ វិបស្សនាបញ្ញា កិលេសជាគ្រឿងជាប់ជំពាក់ មានរាគៈជាដើម ដែលជាហេតុ ចងសត្វទុកក្នុងសង្ខារ រមែងមិនមាន អធិប្បាយថា សេចក្តីពិត កាលបុគ្គល មិនឃើញយ៉ាងនោះឯង គប្បីជាបុគ្គលត្រូវគ្រឿងចង មានអវិជ្ជា តណ្ហា និង ទិដ្ឋិជាដើម ចងក្នុងសង្ខារ ។*

អដ្ឋកថា ឧទេនសូត្រទី ១០ ចប់

ចូឡវគ្គទី ៧

សុត្តន្តបិដក

ឧទាន ចាដលិគ្គាមិយវគ្គទី ៨

បឋមនិព្វានសូត្រ

[១៥៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ពន្យល់ភិក្ខុទាំងឡាយ ឲ្យឃល់ច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ប្រកបដោយព្រះនិព្វាន ពួកភិក្ខុទាំងនោះបានធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវធម្មទេសនាទាំងអស់ដោយចិត្ត ផ្តង់ត្រចៀកស្តាប់ធម៌ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះ រមែងមានពិត ដីមិនមាន ទឹកមិនមាន ភ្លើងមិនមាន ខ្យល់មិនមាន អាកាសានញ្ចាយនៈមិនមាន វិញ្ញាណញ្ចាយតនៈមិនមាន អាកិញ្ចញ្ញាយតនៈមិនមាន នេវសញ្ញានាសញ្ញាយតនៈមិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន ព្រះចន្ទ និងព្រះអាទិត្យទាំងពីរក៏មិនមាន ក្នុងព្រះនិព្វានណា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលព្រះនិព្វាននោះថា មិនមានដំណើរមក មិនមានដំណើរទៅ មិនមានការតាំងនៅ មិនមានការច្យុត មិនមានការកើត មិនមានទីជាទីតាំង

មិនប្រព្រឹត្តទៅ មិនមានអារម្មណ៍ ព្រះនិព្វាននោះ ជាទីបំផុត
នៃទុក្ខតែម្យ៉ាង ។ សូត្រទី ១ ។

អដ្ឋកថា

ចាជលិគ្គាមិយវគ្គទី ៨

បឋមនិព្វានសូត្រ

បឋមនិព្វានសូត្រទី ១ នៃចាជលិគ្គាមិយវគ្គទី ៨ មានវិនិច្ឆ័យដូចេ្នះ

[១៥៨] *បទថា* **និព្វានប្បដិសំយុត្តាយ** *សេចក្តីថា អសង្ខតធាតុ ដែលអាស្រ័យអមតធាតុ ប្រព្រឹត្តទៅដោយអំណាចការប្រកាសឲ្យដឹង ។ បទថា* **ធម្មិយា កថាយ** *ប្រែថា ដោយធម្មទេសនា ។ បទថា* **សន្ទស្សេតិ** *បានដល់ សម្តែងដល់ព្រះនិព្វាន ដោយលក្ខណៈនៃសភាវៈ ព្រមដោយកិច្ច ។ បទថា* **សមាទបេតិ** *បានដល់ ឲ្យភិក្ខុទាំងនោះកាន់យកអត្តនោះឯង ។ បទថា* **សមុត្តេជេតិ** *បានដល់ កាលឲ្យនូវឧស្សាហ៍កើតក្នុងកាលកាន់យកនូវប្រយោជន៍នោះ ឈ្មោះថា រមែងឲ្យនូវកម្តៅ គឺឲ្យរុងរឿង ។ បទថា* **សម្ប-ហំសេតិ** *បានដល់ រមែងឲ្យត្រេកអរដោយគុណ គឺ ព្រះនិព្វាន ដោយជុំវិញនោះឯង គឺដោយប្រការទាំងពួង ។ ម្យ៉ាងទៀត បទថា* **សន្ទស្សេតិ** *សេចក្តីថា ទ្រង់សម្តែងដោយប្រពៃ ដែលសមគួរដល់អធ្យាស្រ័យរបស់ភិក្ខុទាំងនោះ*

ដោយប្រការទាំងពួង គឺដោយបរិយាយនោះៗ ដោយន័យជាដើមថា ធម៌ជាទីអស់តណ្ហា ជាទីខ្ជាក់ចោលនូវរាគៈ ជាទីរម្ងាប់ ជាគ្រឿងស្ងប់សង្ខារទាំងពួង ជាទីលះបង់ឧបធិទាំងពួងនោះ ។ បទថា **សមាទបេតិ** សេចក្តីថា ទ្រង់ធ្វើឲ្យភិក្ខុទាំងឡាយបង្អោនទៅ ជ្រុនទៅ ជម្រេលទៅក្នុងធម៌នោះ មួយអន្ទើដោយបដិបទាជាគ្រឿងត្រាស់ដឹង ឈ្មោះថា ទ្រង់ដឹកនាំ គឺ ឲ្យភិក្ខុកាន់យកដោយប្រពៃថា អ្នកគប្បីត្រាស់ដឹងនូវព្រះនិព្វាននោះ ដោយអរិយមគ្គនេះ ។ បទថា **សមុត្តេជេតិ** សេចក្តីថា ទ្រង់ធ្វើភិក្ខុទាំងនោះឲ្យអាចហ៊ាន ក្នុងការសម្រេចព្រះនិព្វាន ឬឲ្យធ្វើចិត្តផូរផង់ក្នុងព្រះនិព្វាននោះ ដោយព្រះតម្រាស់ថា ពួកអ្នកកុំដល់នូវសេចក្តីប្រមាទ គឺ ដល់នូវការឈប់ក្នុងចន្លោះ ក្នុងសម្មាបដិបត្តិថា ព្រះនិព្វាននេះធ្វើបានលំបាក មានសេចក្តីត្រេកអរបានលំបាក ព្រោះព្រះនិព្វាននេះ បុគ្គលសម្បុរទៅដោយឧបនិស្សយ មានសេចក្តីព្យាយាម មិនមែនធ្វើបានលំបាកឡើយ ព្រោះដូច្នោះ ពួកអ្នកគប្បីក្រោកឡើង ព្យាយាមដើម្បីបដិបទាដែលបរិសុទ្ធ មានសីលវិសុទ្ធិជាដើម ។ បទថា **សម្បហំសេតិ** សេចក្តីថា កាលទ្រង់ធ្វើចិត្តរបស់ភិក្ខុទាំងនោះឲ្យត្រេកអរ ឲ្យក្អៀវក្អា ដោយការប្រកាសអានិសង្សនៃព្រះនិព្វាន ដោយន័យជាដើមថា នេះជាធម៌ដែលបន្សាបស្រវឹង ជាទីកម្ចាត់នូវការស្រេកឃ្លាន ជាទីដកនូវអាល័យ និងដោយន័យជាដើមថា ធម៌នេះជាទីអស់រាគៈ ទោសៈ មោហៈ និងថា នេះជាអសង្ខតធម៌ និងថា អមតធម៌ សន្តិធម៌ ដូច្នេះ ឈ្មោះថា ញុំាងភិក្ខុឲ្យត្រេកអរ ឲ្យស្រោលចិត្ត ។ បទថា **តេ ច ភិក្ខូ អដ្ឋិកត្វា** សេចក្តីថា ភិក្ខុ

ទាំងឡាយកំណត់យ៉ាងនេះថា វត្ថុណាមួយមាន ប្រយោជន៍នេះរបស់ពួក យើង គួរសម្រេច និងជាបុគ្គលត្រូវការដោយទេសនានោះ ។ បទថា **មនសិកត្វា** *សេចក្តីថា ធ្វើទុកក្នុងចិត្ត មិនបញ្ជូនចិត្តទៅក្នុងទីដទៃ គឺ ធ្វើទេសនានោះឲ្យនៅក្នុងចិត្តរបស់ខ្លួនប៉ុណ្ណោះ ។ បទថា* **សព្វំ ចេតសោ សមន្នាហរិត្វា** *សេចក្តីថា នឹកដល់ទេសនាដោយចិត្តដែលជាប្រធានទាំងពួង តាំងអំពីដើមដល់ចប់ គឺធ្វើអាវជ្ជនៈឲ្យនៅក្នុងទេសនានោះឯង ។ ម្យ៉ាងទៀត បទថា* **សព្វំ ចេតសោ សមន្នាហរិត្វា** *សេចក្តីថា នាំមករឿយៗ ដោយប្រពៃ នូវទេសនាអំពីចិត្តទាំងអស់ ។ លោកអធិប្បាយដូច្នេះថា កាលបុគ្គលសម្តែង ធ្វើទេសនាដោយចិត្តណា មិនឲ្យទេសនាដែលប្រព្រឹត្តទៅចាកចិត្តទាំងពួង ចេញទៅខាងក្រៅ ហើយនាំមករឿយៗ ដោយប្រពៃ គឺមិនឲ្យខុសប្លែក រួច នាំចិត្តសន្តានរបស់ខ្លួនមកទ្រទ្រង់ដោយល្អ នូវទេសនា តាមដែលសម្តែង ហើយ ។ បទថា* **ឱហិតសោត្តា** *បានដល់ ផ្ទៀងនូវត្រចៀកស្តាប់ គឺតាំង សោតៈដោយល្អ ។ ម្យ៉ាងទៀត បទថា* **ឱហិតសោត្តា** *បានដល់ មាន សោតប្បសាទ មិនមានអ្វីបៀតបៀន ។ ពិតហើយ បុគ្គលកាលបាននូវ សោតប្បសាទ ដែលមិនមានអ្វីបៀតបៀននោះឯង ទើបមិនរាយមាយក្នុងការ ស្តាប់ ដូចសតិសំវរៈ គួរពោលបានថា ក្នុងចក្ខុន្ទ្រិយជាដើមខ្លះ សោតិន្ទ្រិយ ខ្លះ ។ ក្នុងទីនេះ ដោយបទទាំង ៤ មានបទថា* **អដ្ឋិកត្វា** *ជាដើម ទ្រង់ សម្តែងដល់ការដែលកិច្ចទាំងនោះ ស្តាប់ដោយគោរព ដោយសម្តែងនូវការ អើពើ ក្នុងការស្តាប់ ព្រោះមិនដទៃអំពីនោះ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងនូវការៈដែលភិក្ខុទាំងនោះ មានការអើពើក្នុងការស្តាប់ធម្មកថា ដែលទាក់ទងដោយព្រះនិព្វាននោះ ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ប្រកាសការៈដែលព្រះនិព្វានមានដោយបរមត្ថ ដោយមុខ គឺព្រះធម្មទេសនាដែលផុយគ្នាអំពីធម៌នោះ ។*

បណ្តាបទទាំងនោះ បទថា **អត្ថិ** *ប្រែថា មាន អធិប្បាយថា មានដោយបរមត្ថ ។ បទថា* **ភិក្ខវេ** *ជាពាក្យហៅភិក្ខុទាំងនោះ ។ សួរថា ការបន្ទឺដែលញុំាងបីតិ និងសោមនស្សឲ្យតាំងឡើងក្តី ដែលញុំាងធម្មសង្វេគឲ្យតាំងឡើងក្តី មិនជ្រាបជាប់បុគ្គលដែលទទួលធម៌ ឈ្មោះថា ឧទាន ឧទាននោះមកក្នុងសូត្រ មានប្រមាណប៉ុណ្ណេះដូច្នោះ ដូចគ្នាមិនមែនឬ ព្រោះហេតុអ្វី ទើបក្នុងទីនេះ ព្រះមានព្រះភាគ កាលទ្រង់បន្ទឺឧទាន ត្រាស់ហៅភិក្ខុទាំងនោះ ។ ឆ្លើយថា ព្រោះព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ជាប់ភិក្ខុទាំងនោះ ដែលទាក់ទងដោយព្រះនិព្វាន ដើម្បីឲ្យភិក្ខុទាំងនោះយល់ ទ្រង់កើតបីតិសោមនស្សឡើងដោយរឭកជាប់គុណព្រះនិព្វាន ទើបទ្រង់បន្ទឺឧទាន ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបបរិវិតក្កនៃចិត្តរបស់ភិក្ខុទាំងនោះថា សភាវធម៌ទាំងអស់ក្នុងព្រះសាសនានេះ រៀវព្រះនិព្វានដែលប្រព្រឹត្តទៅ ទាក់ទងនឹងបច្ចយប៉ុណ្ណោះកើតឡើងបាន បើប្រាសចាកបច្ចយ កើតមិនបានឡើយ តែនិព្វានធម៌នេះ កើតក្នុងបច្ចយណា នឹងមានបំណងឲ្យភិក្ខុទាំងនោះយល់ ទើបត្រាស់ពាក្យជាដើមថា* **ភិក្ខវេ តទាយតនំ** *ដូច្នេះ ។ គប្បីជ្រាបថា មិនមែនធ្វើឲ្យភិក្ខុទាំងនោះ ជាអ្នកទទួល*

ដោយចំណែកមួយប៉ុណ្ណោះឡើយ ។ បទថា **តទាយតនំ** *បានដល់ ហេតុនោះ ។* **ឧ** *អក្ខរៈ ជាសន្ធិ ។ ពិតហើយ ព្រះនិព្វាន លោកហៅថា អាយតនៈ ព្រោះអត្ថថា ជាហេតុ ព្រោះជាអារម្មណប្បច្ចុយដល់មគ្គញ្ញាណនិងផលញ្ញាណជាដើម ដូចរូបារម្មណ៍ជាដើម ជាអារម្មណប្បច្ចុយដល់ចក្ខុវិញ្ញាណជាដើម ។ ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណោះ ព្រះមានព្រះភាគទ្រង់ប្រកាសដល់អសង្ខតធាតុថា មានដោយបរមត្ថដល់កិក្ខុទាំងនោះ ។*

ក្នុងសេចក្តីនោះ មានន័យនៃធម៌ដូចតទៅនេះ ព្រោះសង្ខតធម៌មាន សូម្បីអសង្ខធាតុក៏មាន ព្រោះជាគូចំពោះសភាវធម៌ ដូចកាលទុក្ខមាន សុខជាគូនឹងទុក្ខនោះ មានដូចគ្នា យ៉ាងណា កាលក្តៅមាន ត្រជាក់ក៏មាន កាលបាបធម៌មាន កល្យាណធម៌ក៏មានដូចគ្នា ។ សមដូចពាក្យដែលលោកពោលថា

> *កាលបើទុក្ខមាន សុខក៏មាន យ៉ាងណា កាលបើភពមាន ការប្រាសចាកភព បុគ្គលគួរតែប្រាថ្នារក ក៏យ៉ាងនោះដែរ ។ កាលបើក្តៅមាន ត្រជាក់ជនៃក៏មាន យ៉ាងណា កាលបើភ្លើង ៣ ប្រការមាន ព្រះនិព្វានដែលបុគ្គលគួរប្រាថ្នា ក៏មានយ៉ាងនោះដែរដូច្នេះ ។*

ម្យ៉ាងទៀត ការលម្អិតសេចក្តីដល់ព្រះនិព្វានថា មានដោយបរមត្ថ និងមានច្បាស់ខាងមុខ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់អសង្ខតធាតុថា មានដោយបរមត្ថ មួយអន្ទើដោយសម្បត្តិ ដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងសភាវៈដែលព្រះនិព្វាននោះ មានដោយមុខ គឺការផូរផង់នៃធម៌

ដែលផ្ទុយគ្នាអំពីសង្ខតធាតុនោះ ទើបត្រាស់ពាក្យថា **យត្ថ នេវ បឋវី ន អាចោ** *ជួរច្នេះជាដើម ។*

ក្នុងសេចក្តីនោះ ព្រោះព្រះនិព្វានមានសភាវៈ ផ្ទុយគ្នាអំពីសង្ខារទាំងពួង មិនមានក្នុងបណ្តាសង្ខតធម៌ណាមួយ យ៉ាងណា ព្រះនិព្វាននោះ ក៏មិនមានសង្ខតធម៌ទាំងអស់ ដូច្នោះ ព្រោះសង្ខតធម៌ និងអសង្ខតធម៌រួមគ្នាមិនបាន ។ ក្នុងសេចក្តីនោះ មានការធ្វើអធិប្បាយអត្តដូចតទៅនេះ បឋវីធាតុ មានការរឹងជាលក្ខណៈ អាបោធាតុ មានការហូរទៅជាលក្ខណៈ តេជោធាតុ មានការក្តៅជាលក្ខណៈ វាយោធាតុ មានការកម្រើកជាលក្ខណៈ មិនមានក្នុងនិព្វានណា គឺអសង្ខតធាតុណា ដូច្នោះ ក្នុងធាតុទាំងនោះ បើពោលដោយការមិនមាននៃមហាភូតរូប ៤ ក៏ជាការពោលដល់ការមិនមាននៃឧបាទាយរូបទាំងអស់ ព្រោះអាស្រ័យមហាភូតរូបនោះ យ៉ាងណា កាមភព និងរូបភពក៏ដូច្នោះ ពោលថាមិនមានក្នុងព្រះនិព្វាននោះ សូម្បីតិចតួច ព្រោះមានការប្រព្រឹត្តទៅមិនទាក់ទងនឹងព្រះនិព្វាននោះ ព្រោះបញ្ចវោការភព ឬ ឯកវោការភព រៀរចាកការអាស្រ័យមហាភូតរូបហើយ មិនមាន ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងធម៌ដែលទាក់ទងក្នុងអរូបភព មិនមានក្នុងព្រះនិព្វាននោះ សូម្បីក្នុងកាលព្រះនិព្វាន មានសភាវៈជាអរូប គឺជានាម ទើបត្រាស់ពាក្យជាដើមថា **ន អាកាសានញ្ចាយតនំ ។បេ។ ន នេវសញ្ញានាសញ្ញាយតនំ** *ជួរច្នេះ ។*

បណ្តាបទទាំងនោះ បទថា **ន អាកាសានញ្ចាយតនំ** *សេចក្តីថា ចិត្តុប្បាទ*

ពោល គឺអាកាសានញ្ចយតនៈទាំង ៣ យ៉ាង មានកុសលចិត្ត វិបាកចិត្ត និង កិរិយាចិត្ត មួយអន្ទើដោយអារម្មណ៍ រមែងមិនមាន ។ ក្នុងបទដ៏សេស ក៏ មានន័យដូច្នេះដូចគ្នា ។

កាមលោក មិនមានក្នុងព្រះនិព្វានដោយអារម្មណ៍ សូម្បីឥធលោក និង បរលោក ក៏មិនមានក្នុងព្រះនិព្វាននោះ ដោយអារម្មណ៍នោះ ព្រោះហេតុនោះ ទើបលោកពោលថា លោកនេះមិនមាន លោកដទៃមិនមាន ដូច្នេះជាដើម ។

ពាក្យនោះ មានអធិប្បាយដូចតទៅនេះ ខន្ធលោកនេះ ដែលបានរៀហារ ថា យ៉ាងនេះ ជាបច្ចុប្បន្នធម៌ និងថា លោកនេះ និងខន្ធលោក ដែលបាន រៀហារថា លោកដទៃអំពីលោកនោះ បរលោក និងអភិសម្បរាយភព ទាំង ២ នោះ មិនមានក្នុងទីណា ។ បទថា **ន ឧភោ ចន្ទិមសុរិយា** *សេចក្តីថា ព្រោះហេតុដែល កាលរូបមាន ឈ្មោះថា ងងឹត ក៏គប្បីមាន និងកម្ចាត់ នូវការងងឹត ព្រះចន្ទ និងព្រះអាទិត្យគោចរទៅ តែរូបទាំងឡាយ មិនមាន ក្នុងទីណា ការងងឹតក្នុងទីនោះ ក៏មិនមាន ។ ម្យ៉ាងទៀត ការកម្ចាត់ងងឹត គឺ ព្រះចន្ទ និងព្រះអាទិត្យ ដូច្នោះ ព្រះចន្ទ និងព្រះអាទិត្យទាំង ២ រមែង មិនមានក្នុងព្រះនិព្វានណា ។ ដោយពាក្យនេះ ទ្រង់សម្តែងដល់ព្រះនិព្វាន មានការក្តីជាសភាវៈនោះឯង ។*

ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះ ព្រះធម្មរាជា កាលទ្រង់ប្រកាស អមតនិព្វាន ដែលមិនធ្លាប់មានក្នុងសង្សារ ដែលមិនមានទីបំផុតខាងដើម ដោយហោចត្រឹមតែយល់សប្តិ ជ្រៅដោយបរមត្ថ ឃើញបានលំបាកក្រៃលែង

ល្អិតសុខុម ប៉ាន់ស្មានមិនបាន ស្ងប់បំផុត ជាទីឲ្យផលចំពោះខ្លួន ប្រណីតពន់ពេកដល់កិក្ខុទាំងឡាយ ដែលមិនទាន់បានសម្រេច ទើបឲ្យកិក្ខុទាំងនោះកម្ចាត់នូវមោហៈជាដើម ព្រោះព្រះនិព្វាននោះ មាននោះឯង ដូចបាលីថា **អត្ថិ ភិក្ខវេ តទាយតនំ** *ជួរច្នេះជាដើម ទើបទ្រង់ប្រកាសព្រះនិព្វាននោះដោយមុខ គឺការមិនវង្វេងក្នុងធម៌ដទៃចាកព្រះនិព្វាននោះថា* **យត្ថ នេវ បឋវី ។បេ។ ន ឧភោ ចន្ទិមសុរិយា** *ជួរច្នេះជាដើម ។ ដោយពាក្យនោះ សម្តែងថា អសង្ខតធាតុមានសភាវៈផុយគ្នាអំពីសង្ខតធម៌ទាំងពួង មានបឋវីជាដើមថា ព្រះនិព្វាន ។ ដោយហេតុនោះឯង ទើបទ្រង់ត្រាស់ថា* **តត្រចាហំ ភិក្ខវេ នេវ អាគតឹ វទាមិ** *ជួរច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **តត្រ** *ប្រែថា ក្នុងនិព្វាននោះ ។* **អបិ** *សព្ទប្រើក្នុងអត្ថសមុច្ចយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលការមករបស់វត្ថុណាមួយ អំពីទីណាមួយ ដែលប្រព្រឹត្តទៅតាមសង្ខារ ព្រោះត្រឹមតែធម៌កើតក្នុងព្រះនិព្វាននោះតាមបច្ចយ ម្យ៉ាងទៀត តថាគតមិនពោលអាគតិ គឺការមកអំពីទីណាមួយ ក្នុងអាយតនៈ គឺព្រះនិព្វាននោះយ៉ាងនេះ ព្រោះព្រះនិព្វានមិនមានហានៈដែលគប្បីមក ។ បទថា* **ន គតឹ** *សេចក្តីថា តថាគតមិនពោលការទៅក្នុងទីណាមួយ ព្រោះហានៈដែលព្រះនិព្វាន គប្បីដល់មិនមាន ។ ព្រោះការមក និងការទៅនៃសត្វទាំងឡាយ រៀការធ្វើឲ្យជាអារម្មណ៍ដោយញាណមិនមានក្នុងព្រះនិព្វាននោះ ។ ម្យ៉ាងទៀត តថាគតមិនពោលដល់ឋិតិ ចុតិ និងឧប្បត្តិ ។ បាលីថា* **តទុភយំ** *ជួរច្នេះក៏មាន ។ អត្ថនៃព្រះបាលីនោះ*

មានដូច្នេះថា អាយតនៈនោះ ឈ្មោះថា មិនមានការមក ព្រោះជាហានៈដែលមិនគួរមក ដូចចេញអំពីចន្លោះស្រុកមកកាន់ចន្លោះស្រុក ។ ឈ្មោះថា មិនមានការទៅ ព្រោះមិនមានហានៈដែលគួរទៅ ឈ្មោះថា មិនមានឋិតិ ព្រោះមិនមានហានៈជាទីតាំងនៅ ដូចផែនដី និងភ្នំជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា មិនមានការកើត ព្រោះមិនមានបច្ច័យ ឈ្មោះថា មិនមានចុតិ ព្រោះមិនមានការស្លាប់ជាសភាវៈនោះ ។ តថាគតមិនពោលឋិតិ ចុតិ និងឧប្បត្តិ ព្រោះមិនមានការកើត និងការរលត់ និងព្រោះមិនមានការតាំងនៅ ដែលកំណត់ដោយការកើត និងការរលត់ទាំង ២ នោះ ។ ម្យ៉ាងទៀត ព្រះនិព្វាននោះ សុទ្ធតែឈ្មោះថា មិនតាំងនៅក្នុងទីណាមួយ ព្រោះមានសភាវៈជាអរូប និងព្រោះមិនមានបច្ច័យ ព្រោះហេតុនោះ ទើបឈ្មោះថា **អប្បតិដ្ឋំ** *។ ឈ្មោះថា* **អប្បវត្តំ** *ព្រោះមិនមានការប្រព្រឹត្តទៅព្រម និងព្រោះជាបដិបក្ខ ចំពោះការប្រព្រឹត្តទៅក្នុងព្រះនិព្វាននោះ ។ ឈ្មោះថា* **អារម្មណំ** *ព្រោះមិនមានអារម្មណ៍ណាមួយជាទីតោង និងព្រោះមិនត្រូវការអារម្មណ៍ឧបត្ថម្ភ ដូចសម្បយុត្តធម៌មានវេទនាជាដើម សូម្បីមានសភាវៈជាអរូប គឺជានាម ដូច្នោះ ទើបព្រះនិព្វាននោះ លោកពោលថា អាយតនៈ ។* **ឯវ** *សព្ទ គប្បីប្រកបចូលក្នុងបទទាំង ២ គឺ* **អប្បតិដ្ឋមេវ អប្បវត្តមេវ** *។ បទថា* **ឯសេវន្តោ ទុក្ខស្ស** *សេចក្តីថា ព្រះនិព្វានដែលមានលក្ខណៈ តាមដែលពោលហើយ ព្រះមានព្រះភាគត្រាស់សរសើរ ដោយពាក្យជាដើមថា* **អប្បតិដ្ឋំ** *ដូច្នេះនោះឯង ឈ្មោះថា ជាទីបំផុត គឺជាទីបំផុតនៃវដ្តទុក្ខទាំងអស់ ព្រោះបើមានការសម្រេច*

ព្រះនិព្វាន ទុក្ខទាំងអស់ក៏មិនមាន ព្រោះហេតុដូច្នោះ ទើបទ្រង់សម្តែងថា ព្រះនិព្វាននោះ មានសភាវៈដូច្នេះថា ជាទីបំផុតនៃទុក្ខតែម្យ៉ាង ។

អដ្ឋកថា បឋមនិព្វានសូត្រនី ១ ចប់

សុត្តន្តបិដក

ទុតិយនិព្វានសូត្រ

[១៥៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមាព្រះភាគ ទ្រង់ពន្យល់ភិក្ខុទាំងឡាយ ឲ្យយល់ច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ប្រកបដោយព្រះនិព្វាន ។ ភិក្ខុទាំងនោះ ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវធម្មទេសនាទាំងអស់ ដោយចិត្ត ផ្ងត់ត្រចៀកស្តាប់ធម៌ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> ធម្មតាព្រះនិព្វាន បុគ្គលឃើញបានដោយក្រ និព្វានសច្ច មិនមែនសម្រាប់ឃើញបានដោយងាយទេ កិលេសជាគ្រឿងកង្វល់រមែងមិនមានដល់បុគ្គល កាលដឹង កាលឃើញតណ្ហា ព្រោះត្រាស់ដឹង (នូវសច្ចៈ) ។ សូត្រទី ២ ។

អដ្ឋកថា

ទុតិយនិព្វានសូត្រ

ទុតិយនិព្វានសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ

[១៥៩] បទថា **តមំ ឧទានំ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់បន្ទឺឧទាននេះ សម្តែងដល់ការៈដែលព្រះនិព្វានឃើញបានលំបាក ព្រោះតាមប្រក្រតីជាគុណជាតិជ្រាលជ្រៅ ។

បណ្តាបទទាំងនោះ បទថា **ទុទ្ទសំ** សេចក្តីថា ព្រះនិព្វាន ឈ្មោះថាឃើញបានលំបាក ព្រោះបុគ្គលមិនអាចឃើញបាន ដោយគ្រឿងតាក់តែង គឺញាណដែលមិនធ្លាប់បានសន្សំអប់រំមក ព្រោះមានសភាវៈជ្រាលជ្រៅ និងព្រោះមានសភាវៈសុខុម ល្អិតក្រៃលែង ។ សមដូចព្រះតម្រាស់ដែលត្រាស់ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកថា ម្នាលមាគណ្ឌិយៈ អ្នកត្រូវដឹងនូវការមិនមានរោគ ត្រូវឃើញនូវព្រះនិព្វានដោយចក្ខុដ៏ប្រសើរណា ចក្ខុដ៏ប្រសើរនោះ របស់អ្នកមិនមានទេ ។ ទ្រង់ត្រាស់ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសកទៀតថា មួយទៀត ធម៌ណារម្ងាប់នូវសង្ខារទាំងពួង ជាគ្រឿងលះបង់នូវឧបធិគឺខន្ធ និងកិលេសទាំងពួង ជាទីអស់ទៅនៃតណ្ហា ជាទីនឿយណាយចាកវគៈ ជាទីរលត់ទុក្ខ គឺព្រះនិព្វានធម៌នេះ ជាហេតុដែលសត្វឃើញបានដោយកម្រដែរ ដូច្នេះជាដើម ។ បទថា **អឆតំ** សេចក្តីថា តណ្ហា ឈ្មោះថា **ឆត** ព្រោះបង្អោនទៅក្នុងអារម្មណ៍ មានរូបជាដើម និងក្នុងកព មានកាមកពជាដើម ព្រោះប្រព្រឹត្តទៅ ដោយការៈដែលបង្អោនទៅក្នុងអារម្មណ៍ និងកាមនោះ និង

ព្រោះសត្វទាំងឡាយ បង្អោនទៅក្នុងអារម្មណ៍ និងកាមភពជាដើមនោះ ។ ទើបព្រះនិព្វានឈ្មោះថា **អនត** *ព្រោះមិនជាទីដែលសត្វបង្អោនទៅ ។ អាចារ្យពួកខ្លះពោលថា* **អនន្តំ** *ដូច្នេះក៏មាន ។ អធិប្បាយថា ព្រះនិព្វាន ឈ្មោះថាវៀរចាកទីបំផុត គឺ មិនមានចុតិជាសភាវៈ ជាការរម្ងាប់ដោយឥតសេសសល់ បានដល់ ជាអមតៈ ព្រោះមានសភាវៈពិត ។ តែអាចារ្យពួកខ្លះពោលសេចក្តីនៃបទថា* **អនន្តំ** *ថាជា* **អប្បមាណំ** ។ *ក្នុងពាក្យទាំងនោះ ដោយពាក្យថា* **ទុទ្ទសំ** *នេះ ទ្រង់សម្តែងដល់ភាពដែលព្រះនិព្វាន សត្វគប្បីបានដោយលំបាកថា សត្វទាំងឡាយធ្វើព្រះនិព្វានដែលមិនមានបច្ច័យឲ្យសម្រេច មិនមែនធ្វើបានងាយឡើយ ព្រោះសត្វទាំងនោះ ត្រូវកិលេស មានរាគៈជាដើម ដែលធ្វើនូវបញ្ញាឲ្យទុព្វល ឲ្យមានមកអស់កាលយូរ ។ ដោយបទថា* **ន ហិ សច្ចំ សុទស្សនំ** *នេះ ទ្រង់ធ្វើសេចក្តីនោះឯងឲ្យច្បាស់ ។*

បណ្តាបទទាំងនោះ បទថា **សច្ចំ** *បានដល់ ព្រះនិព្វាន ។ ពិតហើយព្រះនិព្វាននោះ ឈ្មោះថា សច្ចៈ ព្រោះអត្ថថា មិនវិបរិត ព្រោះជាគុណជាតិស្ងប់ដោយពិតនោះឯង ព្រោះមិនមានសភាវៈដែលមិនស្ងប់ ដោយបរិយាយណាមួយ ព្រះនិព្វាននោះ ឈ្មោះថា មិនមែនឃើញបានងាយឡើយ គឺដែលបុគ្គលណាម្នាក់មិនគប្បីឃើញបានដោយងាយឡើយ ព្រោះដល់នូវការរួបរួមនូវបុញ្ញសម្ភារ និងញាណសម្ភារ មកអស់កាលយូរ ក៏គង់សម្រេចបានដោយលំបាកនោះឯង សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ក្នុងមជ្ឈិម-និកាយ មូលបណ្ណាសកថា ឥឡូវនេះ តថាគតមិនគួរសម្តែងធម៌ដែលតថាគត*

បានត្រាស់ដឹងដោយលំបាក ដូច្នេះ ។ បទថា **បដិវិទ្ធា តណ្ហាជានតោ បស្សតោ ឆត្តិ កិញ្ចនំ** *សេចក្តីថា បើនិរោធសច្ចនោះ បុគ្គលនឹងត្រាស់ដឹងដោយសច្ឆិកិរិយាកិសម័យ កាលពោលដោយវិសម័យ ដោយកិច្ច និង ដោយអារម្មណ៍ ក៏ត្រាស់ដឹងបានដោយការចាក់ធ្លុះអារម្មណ៍ និងការចាក់ធ្លុះ ដោយមិនវង្វេង ដូចទុក្ខសច្ចដែលត្រាស់ដឹងបានដោយបរិញ្ញាកិសម័យ និង មគ្គសច្ចដែលត្រាស់ដឹងបានដោយភាវនាកិសម័យ គឺការចាក់ធ្លុះដោយមិន វង្វេង ដោយអាការយ៉ាងនេះ ឈ្មោះថា ជីងច្បាស់នូវតណ្ហាដោយបហានា-កិសម័យ និងការមិនវង្វេង ។ កាលបុគ្គលឃើញសច្ចៈ ៤ ដោយបញ្ញាដែល សម្បយុត្តដោយអរិយមគ្គតាមសេចក្តីពិតយ៉ាងនេះ ឈ្មោះថា រមែងមិនមាន តណ្ហា ដែលជាហេតុនាំសត្វទៅក្នុងភពជាដើម កាលតណ្ហានោះមិនមាន កិលេសវដ្តៈទាំងអស់ក៏មិនមាន បន្ទាប់អំពីនោះ កម្មវដ្តៈ និងវិបាកវដ្តៈ ក៏ មិនមានដូចគ្នា ។*

ព្រះមានព្រះភាគ ទ្រង់ប្រកាសអានុភាពនៃអមតមហានិព្វាន ដែលជា ហេតុសូប់រម្ងាប់វដ្តទុក្ខបានជាសមុច្ឆេទ ដល់ភិក្ខុទាំងឡាយនោះ ដោយប្រការ ដូច្នេះ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ៕

អដ្ឋកថា ឧតិយឝិព្វានសូត្រទី ២ ចប់

សុត្តន្តបិដក

តតិយនិព្វានសូត្រ

[១៦០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុ ឲ្យឃល់ច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ប្រកបដោយព្រះនិព្វាន ។ ភិក្ខុទាំងនោះ ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវធម្មទេសនាទាំងអស់ ដោយចិត្ត ផ្ងត់ត្រចៀកស្តាប់ធម៌ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វាន ឈ្មោះថា អជាតៈ ឈ្មោះថា អភូតៈ ឈ្មោះថា អកតៈ ឈ្មោះថា អសង្ខតៈ មានច្រើនជ ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើព្រះនិព្វាននោះ ឈ្មោះថា អជាតៈ ឈ្មោះថា អភូតៈ ឈ្មោះថា អកតៈ ឈ្មោះថា អសង្ខតៈ មិនមានទេ ការរលាស់ចេញនូវកិលេស ដែលនាំឲ្យកើតមហាភូតរូប ដែលច្រើនជនូវហេតុ ដែលធ្វើនូវបច្ចុប្បន្ន ដែលតាក់តែងក្នុងលោកនេះ ក៏មិនច្រើនជ ។ ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វាន ឈ្មោះថា អជាតៈ ឈ្មោះថា អភូតៈ ឈ្មោះថា អកតៈ ឈ្មោះថា អសង្ខតៈ រមែងមានច្រើនជ ព្រោះហេតុណា ហេតុនោះ ការរលាស់ចេញនូវកិលេស ដែលនាំឲ្យកើតមហាភូតរូប ដ៏ច្រើនជនូវហេតុដែលគួរធ្វើនូវបច្ចុប្បន្នជាទីតាក់តែង ក៏រមែងច្រើនជ ។ សូត្រទី ៣ ។

អដ្ឋកថា

តតិយនិព្វានសូត្រ

តតិយ និព្វានសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

[១៦០] បទថា **អថខោ ភគវា ឯតមត្ថំ វិទិត្វា** សេចក្តីថា បានឮថា ក្នុងកាលនោះ កាលព្រះមានព្រះភាគ ទ្រង់ប្រកាសទោសក្នុងសង្ឃារដោយអនេកបរិយាយហើយ ទ្រង់សម្តែងព្រះធម្មទេសនា ដែលទាក់ទងដោយព្រះនិព្វាន ដោយការសម្តែងប្រៀបធៀបជាដើម ហើយភិក្ខុទាំងនោះមានការគិតដូច្នេះថា ព្រះមានព្រះភាគ ទ្រង់ប្រកាសសង្ឃារនេះ មួយអន្ទើដោយហេតុ មានអវិជ្ជាជាដើម ដែលឈ្មោះថា សហេតុកៈ តែមិនត្រាស់ដល់ហេតុណាមួយ នៃព្រះនិព្វានដែលជាហេតុស្ងប់សង្ឃារនោះ ព្រះនិព្វាននោះ ចាត់ជាអហេតុកៈៗ នោះ នឹងកើតបាន ព្រោះអត្តថា មានការធ្វើឲ្យជាក់ច្បាស់ នឹងមានអត្តដូចម្តេច លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបអត្តនេះ តាមដែលពោលហើយរបស់ភិក្ខុទាំងនោះ ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ព្រះអង្គទ្រង់បន្ទឺឧទាននេះ ដែលជាហេតុប្រកាសអមតមហានិព្វាន ដែលមានដោយបរមត្ថ ដើម្បីកម្ចាត់ការសង្ស័យរបស់ភិក្ខុទាំងនោះ និងដើម្បីកាច់បំបាក់មិច្ឆាវាទរបស់សមណព្រាហ្មណ៍ក្នុងលោកនេះ ដែលបដិបត្តិខុស ជាអ្នកមានទិដ្ឋិគតិក្រៅខាងក្រៅនោះឯង ដូចបុគ្គលដែលទាញលោកជាធំថា ពាក្យថា និព្វាន និព្វាន ត្រឹមតែជាគ្រឿងសម្រាប់និយាយគ្នាប៉ុណ្ណោះ តែសេចក្តីពិត កាលពោលដោយបរមត្ថ ឈ្មោះថា ព្រះនិព្វាន រមែងមិនមាន ព្រោះមិនមានការកើតជាសភាវៈ ។

បណ្តាបទទាំងនោះ បទថា **អជាតំ អភូតំ អកតំ អសង្ខតំ** *ទាំងអស់ ជាវេវចនៈនៃគ្នានិងគ្នា ម្យ៉ាងទៀត ព្រះនិព្វាន ឈ្មោះថា* **អជាត** *ព្រោះមិនកើត គឺមិនកើតឡើង ព្រោះការដល់ព្រមនៃហេតុ គឺការប្រជុំនៃហេតុ និងបច្ច័យ ដូចវេទនាជាដើម ឈ្មោះថា* **អភូត** *ព្រោះវៀរចាកហេតុ និងខ្ជួនឯងចេញ រមែងមិនមាន គឺ មិនប្រាកដ បានដល់ មិនកើត ឈ្មោះថា* **អកត** *ព្រោះមិនមានហេតុណាមួយសាងឡើង ព្រោះមិនកើត និងព្រោះមិនមានយ៉ាងនេះ។ ម្យ៉ាងទៀត ដើម្បីសម្តែងថា សង្ខតធម៌ មាននាមរូបជាដើម មានការកើត មានការសាងឡើងជាសភាវៈ ព្រះនិព្វានដែលមានអសង្ខតធម៌ ជាសភាវៈ មិនមែនដូច្នោះឡើយ ទើបត្រាស់ថា* **អសង្ខតំ** *ដូច្នេះ។ ម្យ៉ាងទៀត បើពោលដោយបដិលោម ត្រាស់ថា សង្ខតធម៌ ព្រោះត្រូវបច្ច័យអាស្រ័យគ្នា និងគ្នាសាងឲ្យមានឡើង។ ម្យ៉ាងទៀត លោកពោលថា ជាអសង្ខតៈ ព្រោះមិនមានបច្ច័យតាក់តែង គឺវៀរចាកលក្ខណៈដែលត្រូវបច្ច័យតាក់តែង។ កាលភាវៈដែលព្រះនិព្វានកើតឡើងដោយហេតុច្រើនយ៉ាងនេះ សម្រេចហើយ ដើម្បីសម្តែងថា ព្រះនិព្វានមិនមានបច្ច័យណាមួយតាក់តែងឡើង ដោយការរង្គៀសថា ព្រះនិព្វានគប្បីមានហេតុណាមួយតាក់តែងឬហ្ន៎ ទើបត្រាស់ថា* **អកតំ**។ *កាលព្រះនិព្វានមិនមានបច្ច័យយ៉ាងនេះ ដើម្បីឲ្យការរង្គៀសថា ព្រះនិព្វាននេះកើតឡើង ប្រាកដឡើងឯងឬហ្ន៎ ប្រព្រឹត្តទៅមិនបាន ទើបត្រាស់ថា* **អភូតំ**។ *ដើម្បីនឹងសម្តែងថា ព្រះនិព្វាននេះ មិនមានបច្ច័យប្រជុំ មិនបានតាក់តែងមិនមាននេះ នឹងមានបាន ព្រោះព្រះនិព្វាន មានការមិនកើតជាធម្មតា ដោយ*

ប្រការទាំងពួង ទើបត្រាស់ថា **អជានតំ** *បណ្ឌិតគប្បីជ្រាបភាពដែលបទទាំង ៤ នេះ មានប្រយោជន៍យ៉ាងនេះហើយ គប្បីជ្រាបថា ទ្រង់ប្រកាសថា ព្រះនិព្វាន មានដោយបរមត្ថ ដោយព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វាននេះមាន ។ ក្នុងព្រះសូត្រនេះ គប្បីជ្រាបហេតុក្នុងបទអាលបនថា* **ភិក្ខវេ** *ដោយនយដែលព្រះមានព្រះភាគ កាលទ្រង់បន្ទឺ ទើបត្រាស់ហើយខាងដើមនោះឯង ។*

ដូច្នោះ ព្រះសាស្តាកាលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានមិនកើត មិនមាន ដែលបច្ច័យណាមួយមិនប្រជុំ មិនតាក់តែង មាន កាលទ្រង់សម្តែងហេតុក្នុងបទនោះ ទើបត្រាស់ថា **នោ ចេ តំ ភិក្ខវេ** *ដូច្នេះជាដើម ។*

ព្រះបាលីនោះ មានសេចក្តីសង្ខេបដូចតទៅនេះ ម្នាលភិក្ខុទាំងឡាយ បើអសង្ខតធាតុ ដែលមានសភាវៈមិនកើតជាដើម នឹងមិនមានទេ ការរលាស់ចេញ គឺ សេចក្តីស្ងប់ដ៏ក្រៃលែង ដែលសង្ខតៈ ពោលគឺ ខន្ធ ៥ មានរូបជាដើម ដែលមានសភាវៈកើតឡើងជាដើម មិនគប្បីប្រាកដ គឺមិនគប្បីកើត មិនគប្បីមានក្នុងលោកនេះ ។ ពិតហើយ ធម៌ គឺ អរិយមគ្គ មានសម្មាទិដ្ឋិជាដើម ដែលធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ កើតឡើង រមែងកាត់កិលេស បានជាសមុច្ឆេទ ។ ដោយហេតុនោះ ក្នុងទីនេះ ការមិនប្រព្រឹត្តទៅ ការប្រាសទៅ ការរលាស់ចេញនៃវដ្តទុក្ខទាំងមូល រមែងប្រាកដ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ព្រះនិព្វានថា មាន ដោយភាវៈផ្ទុយគ្នា ឥឡូវនេះ ដើម្បីសម្តែងព្រះនិព្វាននោះដោយនយដែលអនុលោមតាម ទើបត្រាស់ពាក្យជាដើមថា **យស្មា ច ខោ** *ដូច្នេះ ។ ពាក្យនោះ មានអត្តជូច*

ពោលហើយនោះឯង ។ ក្នុងទីនេះ ព្រោះព្រះសម្មាសម្ពុទ្ធ កាលទ្រង់អនុគ្រោះ ដល់សត្វលោកទាំងអស់ ទើបទ្រង់សម្តែងនូវនិព្វានធាតុ មានប្រាកដ ដោយ បរមត្ថ ដោយសុត្តបទជាអនេកជាដើមថា ពួកធម៌មិនមានបច្ច័យ ពួកធម៌ឥត បច្ច័យតាក់តែង ។ ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះ មានពិត ជាមិន មាន ... ។ មួយទៀត ធម៌ណារម្ងាប់នូវសង្ខារទាំងពួង ជាគ្រឿងលះបង់ នូវឧបធិ គឺទន្ទ និងកិលេសទាំងពួង ធម៌នេះ ជាហេតុដែលសត្វ ... ឃើញ បានដោយកម្រដែរ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអសង្ខតធម៌ (ធម៌ដែលបច្ច័យតាក់តែងមិនបាន) ផង អសង្ខតគាមិមគ្គ (ផ្លូវជាដំណើរ ទៅកាន់អសង្ខតធម៌) ផង ដល់អ្នកទាំងឡាយ និងដោយសូត្រនេះថា ម្នាល ភិក្ខុទាំងឡាយ ព្រះនិព្វាន ឈ្មោះថា អជាតៈ ... ។ ដូច្នោះ បើវិញ្ញាណ ធ្វើឲ្យប្រចក្សក្នុងព្រះនិព្វាននោះសោត ក៏រមែងមិនមានសេចក្តីសង្ស័យ ឬ ការងឿងឆ្ងល់ឡើយ កាលបន្ទោបង់នូវការងឿងឆ្ងល់របស់បុគ្គលទាំងឡាយ ដែលមានការជឿក្នុងការទូន្មានអ្នកដទៃ ក្នុងសេចក្តីនេះ មានអធិប្បាយដូច តទៅនេះ ការរលាស់ចេញ ដែលជាបដិបក្ខចំពោះកាម និងអារម្មណ៍ មាន រូបជាដើម ដែលវិលត្រឡប់ គឺមានសភាវៈផុយគ្នាអំពីនោះ រមែងប្រាកដដោយ មុខ គឺការដកចេញអំពីទុក្ខ ឬព្រោះកំណត់ដឹង មានការពិចារណាដែល សមគួរ ព្រះនិព្វានដែលជាបដិបក្ខចំពោះសង្ខតធម៌ទាំងអស់ ដែលមាន សភាពជូច្នោះ គឺមានសភាវៈផុយអំពីនោះ គប្បីជាគ្រឿងរលាស់ចេញ ។ ព្រះនិព្វានដែលជាគ្រឿងរលាស់ចេញអំពីទុក្ខនោះ គឺអសង្ខតធាតុ ។ គប្បីជ្រាប

ឲ្យក្រៃលែងបន្តិចទៅទៀត ។ វិបស្សនាញាណក្តី អនុលោមញាណក្តី ដែលមានសង្ខតធម៌ជាអារម្មណ៍ រមែងមិនអាចលះកិលេសបានជាសមុច្ឆេទឡើយ ។ ម្យ៉ាងទៀត ញាណក្នុងបឋមជ្ឈានជាដើម ដែលមានសម្មតិសច្ចជាអារម្មណ៍ រមែងលះកិលេសបាន ដោយវិក្ខម្ភនប្បហានប៉ុណ្ណោះ មិនមែនលះដោយសមុច្ឆេទប្បហានឡើយ ដូច្នោះ អរិយមគ្គញាណ ដែលធ្វើនូវការលះកិលេសទាំងនោះបានជាសមុច្ឆេទ ក៏គប្បីជាអារម្មណ៍ដែលមានសភាវៈផុយគ្នាអំពីញាណទាំង ២ នោះ ព្រោះញាណដែលមានសង្ខតធម៌ជាអារម្មណ៍ និងមានសម្មតិ-សច្ចជាអារម្មណ៍ មិនអាចក្នុងការកាត់កិលេសបានជាសមុច្ឆេទ នោះឈ្មោះថា អសង្ខតធាតុ ។ ម្យ៉ាងទៀត ព្រះតម្រាស់ដែលឆ្ពុះបញ្ចាំងដល់បទនៃព្រះនិព្វាន ដែលមានដោយបរមត្ថ ព្រះមានព្រះភាគត្រាស់ថា ជាអត្ថដែលមិនវិបរិត ដូចបាលីថា ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានឈ្មោះថា អជាតៈ ឈ្មោះថា អភូតៈ ឈ្មោះថា អកតៈ ឈ្មោះថា អសង្ខតៈ មានច្រើនដង ។ ពិតហើយ ពាក្យដែលព្រះមានព្រះភាគត្រាស់ មានអត្ថមិនវិបរិត ដូចដែលត្រាស់ថា សង្ខារទាំងពួងមិនទៀង សង្ខារទាំងពួងជាទុក្ខ ធម៌ទាំងពួងជាអនត្តា ដូច្នេះ ។ ម្យ៉ាងទៀត **និព្វាន** *សព្ទ មានបរមត្ថជាអារម្មណ៍ តាមសេចក្តីពិត ក្នុងអារម្មណ៍ណាមួយ ព្រោះកើត មានការប្រព្រឹត្តទៅត្រឹមឧបចារៈ ដូចសព្ទថា* **សីមា** *ម្យ៉ាងទៀត គប្បីជ្រាបអសង្ខតធាតុថា មានដោយបរមត្ថ ដោយយុត្តិ ដោយនយយ៉ាងនេះជាដើមថា ព្រោះព្រះនិព្វាន មានសភាវៈផុតចាកធម៌ដែលមានភាវៈផុយគ្នានោះ ក្រៅអំពីនេះ ដូចបឋវីធាតុ ឬវេទនាចុះ ។*

សុត្តន្តបិដក

ចតុត្តនិព្វានសូត្រ

[១៦១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ប្រកបដោយព្រះនិព្វាន ។ ភិក្ខុទាំងនោះបានធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវធម្មទេសនាទាំងអស់ ដោយចិត្ត ផ្តង់ត្រចៀកស្តាប់ធម៌ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ការញាប់ញ័រ របស់បុគ្គលអ្នកអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) រមែងមាន ការញាប់ញ័រ របស់បុគ្គលអ្នកមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) មិនមាន កាលបើសេចក្តីញាប់ញ័រមិនមាន បស្សទ្ធិ (សេចក្តីស្ងប់) ក៏កើតមានឡើង កាលបើបស្សទ្ធិមាន តម្រេកក៏រមែងមិនមាន កាលបើតម្រេកមិនមាន ដំណើរមក និងដំណើរទៅ ក៏មិនមាន កាលបើដំណើរមក ដំណើរទៅមិនមាន ការច្យុត និងការកើត ក៏មិនមាន កាលបើការច្យុត និងការកើតមិនមាន ដំណើរទៅមក ក្នុងឥធលោក និងបរលោកក៏មិនមាន ទាំងមិនមានក្នុងរវាងនៃលោកទាំង ២ នេះជាទីបំផុតនៃទុក្ខ ។

សូត្រទី ៤ ។

អដ្ឋកថា

ចតុត្ថនិព្វានសូត្រ

ចតុត្ថនិព្វានសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

[១៦១] បទថា **អថខោ ភគវា ឯតមត្ថំ វិទិត្វា** សេចក្តីថា បានឮថា ក្នុងកាលនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងព្រះធម្មទេសនា ដែលទាក់ទងដោយព្រះនិព្វាន ដោយសម្តែងការប្រៀបធៀបជាដើម ដោយអនេក-បរិយាយហើយ ភិក្ខុទាំងនោះមានការគិតយ៉ាងនេះថា លំដាប់ដំបូង ព្រះមានព្រះភាគ កាលទ្រង់សម្តែងអានិសង្សដែលមានខន្ធ មានអាការជាអនេកនៃអមតមហានិព្វានធាតុ ទើបទ្រង់ប្រកាសអានុភាពនេះ ដែលមិនទូទៅដល់អ្នកដទៃ ។ តែមិនត្រាស់ឧបាយជាគ្រឿងសម្រេចអមតមហានិព្វានធាតុនោះ ពួកយើង កាលបដិបត្តិ គប្បីសម្រេចអមតមហានិព្វាននេះដូចម្តេចហ្ន៎ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបដោយអាការទាំងពួងនូវអត្ថ ពោល គឺ ការៈដែលភិក្ខុទាំងនោះ មាននូវបវិតក្ក តាមដែលពោលហើយនេះ ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ព្រះអង្គទ្រង់បន្ទឺឧទាននេះ ដែលប្រកាសដល់ការសម្រេចព្រះនិព្វាន ដោយការលះតណ្ហាមិនដាច់ ដោយអរិយមគ្គរបស់បុគ្គលដែលចម្រើនវិបស្សនា ដែលប្រព្រឹត្តទៅតាមវិថីចិត្ត មានកាយ និងចិត្តស្ងប់រម្ងាប់ ដែលមិនអាស្រ័យក្នុងអារម្មណ៍ណាមួយ ដោយអំណាចតណ្ហា ។

បណ្តាបទទាំងនោះ បទថា **និស្សិតស្ស ចលិតំ** សេចក្តីថា បុគ្គលដែលត្រូវតណ្ហា និងទិដ្ឋិចូលអាស្រ័យក្នុងសង្ខារ មានរូបជាដើម រមែងញាប់ញ័រ

គឺរមែងអនុះអនែង ព្រោះតណ្ហា និងទិដ្ឋិថា នុ៎ះជារបស់អញ នុ៎ះជាអត្តារបស់អញ ពិតហើយ កាលបុគ្គលលះតណ្ហា និងទិដ្ឋិមិនទាន់បាន កាលសុខវេទនាជាដើមកើតឡើង មិនអាចគ្របសង្កត់វេទនា មានសុខវេទនាទាំងនោះជាដើម មានចិត្តសន្តានកម្រើកញាប់ញ័រ អនុះអនែង ដែលនាំចេញហើយ ព្រោះឲ្យកុសលកើតឡើង ដោយអំណាចការប្រកាន់តណ្ហា និងទិដ្ឋិ ដោយនយជាដើមថា វេទនារបស់អញ អញសោយ ។ បទថា **អនិសង្ឋិតស្ស ចលិតំ ឯត្ថ** *សេចក្តីថា បុគ្គលណាប្រព្រឹត្តទៅតាមវិសុទ្ធិប្បដិបទា រមែងសង្កត់តណ្ហា និងទិដ្ឋិបានដោយសមថៈ និងវិបស្សនា រមែងពិចារណាឃើញសង្ខារដោយលក្ខណៈ មានអនិច្ចលក្ខណៈជាដើម បុគ្គលនោះ គឺបុគ្គលមិនត្រេកតណ្ហា និងទិដ្ឋិអាស្រ័យ រមែងមិនមានចិត្តញាប់ញ័រ រាយមាយ អនុះអនែង តាមដែលពោលហើយនោះ ព្រោះសង្កត់ហេតុបានដោយល្អហើយ ។ បទថា* **ចលិតេ អសតិ** *សេចក្តីថា កាលចិត្តមិនញាប់ញ័រតាមដែលពោលហើយ បុគ្គលនោះក៏ធ្វើចិត្តនោះឲ្យកើតនូវការទ្រុលទ្រាយក្នុងវិបស្សនា ដែលប្រព្រឹត្តទៅតាមវិថីចិត្ត ដោយការប្រកាន់តណ្ហា និងទិដ្ឋិកើតឡើងមិនបាន ។ បទថា* **បស្សទ្ធិ** *សេចក្តីថា បស្សទ្ធិទាំង ២ យ៉ាង ដែលចូលទៅស្ងប់កិលេស ដែលធ្វើនូវសេចក្តីក្រវល់ក្រវាយ កាយ និងចិត្ត ដែលកើតរួមជាមួយវិបស្សនាចិត្ត ។ បទថា* **បស្សទ្ធិយា សតិ ឯតិ ន ហោតិ** *សេចក្តីថា កាលបស្សទ្ធិដែលគួរដល់គុណវិសេសមុន និងក្រោយ មានលោកចម្រើនសមាធិ ដែលមានសេចក្តីសុខ មិនមានទោស ជាទីតាំងហើយ ទើបប្រកបសមថៈ និងវិបស្សនាឲ្យ*

ទាក់ទងគ្នាជាគូ ដោយធ្វើសមាធិនោះឲ្យរួមជាមួយវិបស្សនាហើយ ធ្វើកិលេស ឲ្យអស់ទៅជាបន្តៗ ដោយមគ្គ តណ្ហាដែលបានឈ្មោះថា **ឆតិ** *ព្រោះបង្អោន ទៅក្នុងកាមភពជាដើម មិនមានក្នុងខណៈនៃអរិយមគ្គដោយសមុច្ឆេទ អធិប្បាយថា មិនកើតឡើង ព្រោះមិនដល់នូវការកើតឡើងជាធម្មតា ។*

បទថា **ឆតិយា អសតិ** *សេចក្តីថា កាលមិនមានបរិយុដ្ឋានកិលេស គឺ ការអាល័យ និងការជាប់ក្នុងភពជាដើម ព្រោះលះតណ្ហាបានជាសមុច្ឆេទ ដោយអរិយមគ្គ ។ បទថា* **អាគតិគតិ ឆ ហោតិ** *សេចក្តីថា ការមក គឺ ការមកក្នុងលោកនេះ ដោយអំណាចបដិសន្ធិ ការទៅ គឺការទៅអំពីលោក នេះ កាន់បរលោក បានដល់ ការលះទៅដោយអំណាចចុតិ រមែងមិនមាន បានដល់ មិនកើត ។ បទថា* **អាគតិគតិយា អសតិ** *សេចក្តីថា កាល មិនមានការមក និងការទៅ ដោយន័យដូចពោលហើយ ។ បទថា* **ចុតូប-បាតោ ឆ ហោតិ** *សេចក្តីថា ការចុតិ និងបដិសន្ធិទៅមកៗ រមែងមិនមាន គឺរមែងមិនកើត ។ ពិតហើយ កាលមិនមានកិលេសវដ្តៈ កម្មវដ្តៈក៏ត្រូវកាត់ ផ្តាច់ទៅនោះឯង កាលកម្មវដ្តៈនោះដាច់ទៅ វិបាកវដ្តៈនឹងមានអំពីណា ដោយ ហេតុនោះឯង ទើបពោលថា កាលបើការច្យុត និងការកើត មិនមាន ដំណើរ ទៅមកក្នុងឥធលោក និងបរលោកក៏មិនមាន ដូច្នេះជាដើម ។ ពាក្យដែល គួរពោលក្នុងសេចក្តីនោះ ខ្ញុំបានពោលហើយដោយពិស្តារ ក្នុងពាហិយសូត្រ ខាងដើមនោះឯង ។ ព្រោះដូច្នោះ គប្បីជ្រាបអត្ថ ដោយន័យដូចពោលមក ហើយ ក្នុងពាហិយសូត្រនោះឯង ។*

ព្រះមានព្រះភាគ ទ្រង់ប្រកាសអានុភាពនៃអមតមហានិព្វាន ដែលជាហេតុស្ងប់ក្នុងវដ្ដៈបានដោយសមុច្ឆេទ ដោយសម្មាបដិបត្តិ ដល់ភិក្ខុទាំងនោះ ក្នុងព្រះសាសនានេះ ដោយប្រការដូច្នេះ ។

អដ្ឋកថា ចតុត្ថនិព្វានសូត្រទី ៤ ចប់

សុត្តន្តបិដក

ចុន្ទសូត្រ

[១៦២] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គ្រាច់ទៅកាន់ចារិក ក្នុងជនបទឈ្មោះមល្លៈ ជាមួយភិក្ខុសង្ឃច្រើនរូប បានដល់ក្រុងបាវា ។ បានឮថា ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ក្នុងសួនអម្ពវនៃរបស់ចុន្ទកម្មារបុត្ត (កូនជាងមាស) ទៀបក្រុងបាវា ។ ចុន្ទកម្មារបុត្ត បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់គ្រាច់មកកាន់ចារិក ក្នុងមល្លជនបទ ជាមួយភិក្ខុសង្ឃច្រើនរូប បានដល់ក្រុងបាវា ឥឡូវនេះ ទ្រង់គង់នៅក្នុងអម្ពវនៃរបស់អញ ទៀបក្រុងបាវា ។ គ្រានោះឯង ចុន្ទកម្មារបុត្ត ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយទីសមគួរ ។ លុះចុន្ទកម្មារបុត្ត អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ពន្យល់ ឲ្យឃល់ច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ។ លំដាប់នោះ ចុន្ទកម្មារបុត្ត ដែលព្រះមានព្រះភាគ

ឲ្យយល់ច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ គ្រានោះ ចុន្ទកម្មារបុត្ត ជ័ងច្បាស់ថា ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ ចៀសចេញទៅ ។ គ្រានោះ កាលរាត្រីនោះកន្លងហើយ ទើបចុន្ទកម្មារបុត្ត ឲ្យគេចាត់ចែកខាទនីយភោជនីយាហារ មានរសដ៏ឆ្ងាញ់ពិសា ព្រមទាំងសូករមទ្ទវៈដ៏ច្រើនក្នុងផ្ទះរបស់ខ្លួន ហើយឲ្យគេទៅក្រាបបង្គំទូលភត្តកាលដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់ជាត្រ និងចីវរ ក្នុងបុព្វណ្ហ-សម័យ ហើយស្តេចចូលទៅកាន់លំនៅនៃចុន្ទកម្មារបុត្ត ព្រមដោយភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ស៊ប់ហើយ ក៏ត្រាស់នឹងចុន្ទកម្មារបុត្តថា ម្នាលចុន្ទ សូករមទ្ទវៈណា ដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសតថាគត ដោយសូករមទ្ទវៈនោះចុះ ឯខាទនីយភោជនីយាហារណា ក្រៅពីនេះ ដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសចំពោះភិក្ខុសង្ឃ ដោយខាទនីយភោជនីយាហារនោះចុះ ។ ចុន្ទកម្មារបុត្ត ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយអង្គាសព្រះមានព្រះភាគ ដោយសូករមទ្ទវៈ ដែលខ្លួនតាក់តែង

ហើយ អង្គាសកិក្ខុសង្ឃ ដោយខាទនីយភោជនីយាហារដទៃ ដែលខ្ជួនតាក់តែងហើយ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងចុន្ទកម្មារបុត្តថា ម្នាលចុន្ទ សូករមទ្ទវៈណារបស់អ្នកដែលនៅសល់ អ្នកចូរកប់សូករមទ្ទវៈនោះក្នុងរណ្តៅចុះ ម្នាលចុន្ទ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជា សម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញបុគ្គលណាមួយ ដែលបរិភោគនូវសូករមទ្ទវៈនោះហើយ សូករមទ្ទវៈនោះ ដល់នូវការរលួចទៅ ដោយល្អទេ្បីយ វៀរលែងតែព្រះតថាគតចេញ ។ ចុន្ទកម្មារបុត្ត ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ស្រេចហើយ ក៏កប់សូករមទ្ទវៈដែលសល់នៅ ទៅក្នុងរណ្តៅ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងទីសមគួរ ។ លុះចុន្ទកម្មារបុត្ត អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ពន្យល់ ឲ្យឃល់ច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ហើយក្រោកចាកអាសនៈ ស្តេចចៀសចេញទៅ ។

[១៦៣] គ្រានោះ កាលព្រះមានព្រះភាគ ធាន់ភត្តរបស់ចុន្ទកម្មារបុត្ត រួចហើយ ព្រះអាពាធដ៏ខ្លាំង ក៏កើតទ្បឺង វេទនាដ៏ក្បៀវក្បា កើតអំពីលោហិតបក្ខន្ទិកាពាធ (អាពាធចុះព្រះលោហិត) ជិតដល់មរណៈក៏ប្រព្រឹត្តទៅ ។ បានឮថា ក្នុងទីនោះ ព្រះមានព្រះភាគ មានព្រះសតិ និងសម្បជញ្ញៈ មិនបានលំបាក ដោយទ្រង់អត់សង្កត់វេទនានោះបាន ។ វេលានោះឯង ព្រះមាន

ព្រះភាគ ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ មកយើងនឹងទៅឯនគរកុសិនារា ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះពុទ្ធដីកា ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ខ្ញុំបានឮថា ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់សោយភត្តរបស់ចុន្ទកម្មារបុត្ត ហើយទ្រង់មានព្រះអាពាធ ជាទម្ងន់ ជិតនឹងមរណៈ ។ ព្យាធិដ៏ខ្លាំងក្លា កើតដល់ព្រះសាស្តា ដែលសោយសូករមទ្ទវៈ ព្រះមានព្រះភាគ ទ្រង់ព្រះអាពាធចុះព្រះលោហិតរឿយៗ ទើបមានព្រះពុទ្ធតម្រាស់ថា តថាគតនឹងទៅកាន់ក្រុងកុសិនារា ។

[១៦៤] *គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចៀសចេញអំពីផ្លូវ ទ្រង់ចូលទៅកាន់ម្លប់ឈើមួយដើម លុះចូលទៅដល់ហើយ ទ្រង់ប្រើព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ ចូរអ្នកក្រាលសង្ឃាដិមានជាន់ ៤ ឲ្យតថាគតដោយធាប់ តថាគតល្វើតល្វែណាស់ តថាគតនឹងអង្គុយសិន ។ ព្រះអានន្ទដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រាលសង្ឃាដិមានជាន់ ៤ ថ្វាយ ។ ព្រះមានព្រះភាគ ក៏គង់លើអាសនៈ ដែលព្រះអានន្ទក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ គង់ស៊ប់ហើយ ទ្រង់ប្រើព្រះអានន្ទថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹក មកឲ្យតថាគតដោយធាប់ ម្នាលអានន្ទ តថាគតស្រេកទឹកណាស់ តថាគតនឹងផាន់ទឹកបន្តិច ។ កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទដ៏មានអាយុ ក៏ក្រាបថ្វាយបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏*

ចម្រើន អម្បាញ់មិញនេះ រនេះចំនួន ៥០០ បរឆ្ងែទៅហើយ ទឹកនោះតិច កង់រនេះ ក៏កិនល្អក់រឹតរហូរមក បពិត្រព្រះអង្គដ៏ចម្រើន កុកុជានទី នៅជិតនេះ មានទឹកថ្លា មានរសជាតិស្រួល មានទឹកត្រជាក់ មានទឹករងថ្លា មានកំពង់រាបទាប គួរជាទីរីករាយ ក្នុងស្ទឹងនោះ ព្រះមានព្រះភាគ នឹងសោយទឹកក៏បាន នឹងស្រង់ព្រះកាយឲ្យត្រជាក់ស្រួល ក៏បាន ។ ព្រះមានព្រះភាគ ត្រាស់ប្រើព្រះអានន្ទដ៏មានអាយុ ជាគម្រប់ ២ ដងទៀតថា ម្នាលអានន្ទ ចូរអ្នកដងទឹក មកឲ្យតថាគត ដោយឆាប់ ម្នាលអានន្ទ តថាគតស្រេកទឹកណាស់ តថាគតនឹងផាន់ ។ ព្រះអានន្ទដ៏មានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ជាគម្រប់ ២ ដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ រនេះចំនួន ៥០០ បរឆ្ងែទៅហើយ ទឹកនោះតិច កង់រនេះ កិនល្អក់រឹតរហូរមក បពិត្រព្រះអង្គដ៏ចម្រើន កុកុជានទី នៅជិតនេះ មានទឹកថ្លា មានរសជាតិស្រួល មានទឹកត្រជាក់ មានទឹករងថ្លា មានកំពង់រាបទាប គួរជាទីរីករាយ ក្នុងស្ទឹងនោះ ព្រះមានព្រះភាគ នឹងសោយក៏បាន នឹងស្រង់ព្រះកាយឲ្យត្រជាក់ ក៏បាន ។ ព្រះមានព្រះភាគ ត្រាស់ប្រើព្រះអានន្ទដ៏មានអាយុ ជាគម្រប់ ៣ ដងទៀតថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹក មកឲ្យតថាគត ដោយឆាប់ ម្នាលអានន្ទ តថាគតស្រេកទឹកណាស់ តថាគតនឹងផាន់ ។ ព្រះអានន្ទដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះកុរណាព្រះអង្គ ហើយក៏កាន់យកបាត្រ ដើរឆ្ពោះទៅឯស្ទឹងនោះ ។

[១៦៥] *គ្រានោះ ស្ទឹងដែលកង់រនេះបរឆ្ងែកាត់ មានទឹកតិច ល្អក់*

វឹកវរហូរមកនោះ កាលដែលព្រះអានន្ទដ៏មានអាយុ ចូលទៅដល់ ទឹកស្ទឹង ក៏ខ្វែរប្រែត្រឡប់ជាថ្លាស្អាត មិនល្អក់វឹកវរហូរមក ។ លំដាប់នោះ ព្រះអានន្ទ ដ៏មានអាយុ មានសេចក្តីត្រិះរិះថា យីអើ អស្ចារ្យណាស់ យីអើ ចម្លែកណាស់ ព្រះតថាគត មានឫទ្ធិច្រើន មានអានុភាពច្រើន ។ អម្បាញ់មិញ ស្ទឹងដែលកង់រនេះ បរឆ្ងែងកាត់ មានទឹកតិច ល្អក់វឹកវរហូរមកនេះ លុះដល់អាត្មាអញ ចូលមកដល់ ទឹកស្ទឹង ក៏ខ្វែរប្រែត្រឡប់ជាថ្លាស្អាត មិនល្អក់វឹកវរហូរមកវិញ ។ ព្រះអានន្ទ យកចាត្រទៅជង់ទឹក ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ ព្រះតថាគតមានឫទ្ធិច្រើន មានអានុភាពច្រើន ។ បពិត្រព្រះអង្គដ៏ចម្រើន ស្ទឹងនោះ កង់រនេះបរឆ្ងែងកាត់ មានទឹកតិច ល្អក់វឹកវរហូរមក កាលបើខ្ញុំព្រះអង្គចូលទៅដល់ ស្ទឹងក៏ខ្វែរប្រែត្រឡប់ជាថ្លាស្អាត មិនល្អក់វឹកវរទៅវិញ ។ សូមព្រះមានព្រះភាគ សោយទឹក សូមព្រះសុគត សោយទឹកចុះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សោយទឹកនោះឯង ។

[១៦៦] *គ្រានោះ ព្រះមានព្រះភាគ ទ្រង់យាងសំដៅទៅឯកុកុដានទី ជាមួយនឹងភិក្ខុសង្ឃច្រើនរូប លុះចូលទៅដល់ហើយ ក៏យាងចុះគាន់កុកុដានទី ទ្រង់ស្រង់ និងសោយស្រេចហើយ ទ្រង់ឡើងមក រួចយាងចូលទៅកាន់អម្ពវន លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងចុន្ទកៈដ៏មានអាយុថា ម្នាលចុន្ទកៈ អ្នកចូរក្រាលសង្ឃាដិមានជាន់ ៤ ឲ្យតថាគត ម្នាលចុន្ទកៈ តថាគត*

ល្អិតល្អែណាស់ តថាគតនឹងសិង ។ ចុន្ទកភិក្ខុដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រាលសង្ឃាដិ មានជាន់ ៤ ថ្វាយ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សម្រេចនូវសីហ-សេយ្យា ផ្អៀងទៅខាងស្តាំ ទ្រង់យកព្រះបាទ (ខាងឆ្វេង) ត្រួតលើព្រះបាទ (ខាងស្តាំ) ទ្រង់មានសតិសម្បជញ្ញៈ ធ្វើទុកក្នុងព្រះហឫទ័យ នូវឧដ្ឋានសញ្ញា ។ ចំណែកខាងចុន្ទកៈដ៏មានអាយុ ក៏អង្គុយនៅចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ក្នុងទីនោះដែរ ។

[១៦៧] ព្រះពុទ្ធ ទ្រង់យាងចុះទៅកាន់ស្ទឹងកុកុជា ដែលមានទឹកថ្លាឈ្វង មានទឹកត្រជាក់ រងថ្លា ព្រះតថាគត ជាសាស្តាចារ្យ មិនមានបុគ្គលប្រៀបផ្ទឹមបាន ក្នុងលោក ព្រះអង្គមានសេចក្តីលំបាកព្រះកាយ ទ្រង់ស្រេង សោយស្រេចហើយ ទើបយាងឡើងមក ព្រះសាស្តា មានភិក្ខុសង្ឃជាបរិវារ គង់នៅត្រង់កណ្តាល ។ ព្រះមានព្រះភាគ ជាសាស្តាស្វែងរកគុណធំ ញុំាងធម៌ទាំងឡាយឲ្យប្រព្រឹត្តទៅក្នុងលោកនេះ ហើយយាងមកកាន់អម្ពវន ។ ត្រាស់ហៅភិក្ខុ ឈ្មោះចុន្ទកៈថា អ្នកចូរក្រាលសង្ឃាដិ ៤ ជាន់ ឲ្យតថាគតចុះ តថាគតនឹងសិង ។ ចុន្ទកភិក្ខុនោះ កាលបើព្រះសាស្តា ព្រះអង្គមានព្រះហឫទ័យអប់រំ ទ្រង់ជាស់តឿនហើយ ក្រាលសង្ឃាដិ ៤ ជាន់ ដោយឆាប់រហ័ស ។ ព្រះសាស្តា មានព្រះកាយលំបាកក្រៃលែង ទ្រង់ផ្ទំ ចំណែកចុន្ទកភិក្ខុ

ក៏អង្គុយចំពោះព្រះភក្ត្រ ក្នុងទីនោះដែរ ។

[១៦៨] *គ្រានោះ ព្រះមានព្រះភាគ ត្រាស់ហៅព្រះអានន្ទដ៏មានអាយុ មកថា ម្នាលអានន្ទ បើមានបុគ្គលណាមួយ ញុំាងសេចក្តីក្តៅក្រហាយ ឲ្យកើតឡើង ដល់ចុន្ទកម្មារបុត្តថា ម្នាលអាវុសោចុន្ទ អ្នកឥតលាភ អ្នកបានធ្វើអំពើអាក្រក់ ព្រោះថា ព្រះតថាគត ទ្រង់សោយបិណ្ឌបាត របស់អ្នកជាទីបំផុត ហើយបរិនិព្វាន ។ ម្នាលអានន្ទ អ្នកត្រូវបន្ទោបង់ នូវសេចក្តីក្តៅក្រហាយនៃចុន្ទកម្មារបុត្ត យ៉ាងនេះថា ម្នាលអាវុសោចុន្ទ លាភរបស់អ្នកហើយ អ្នកបានល្អហើយ ព្រោះថា ព្រះតថាគត ទ្រង់សោយបិណ្ឌបាតរបស់អ្នកជាទីបំផុត ហើយបរិនិព្វាន ។ ម្នាលអាវុសោចុន្ទ ពាក្យនុ៎ះ អាត្មាបានស្តាប់ ចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ បានទទួលចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគថា បិណ្ឌបាត ២ នេះ មានផលស្មើៗ គ្នា មានវិបាកស្មើៗ គ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ជាងពួកបិណ្ឌបាតឯទៀត ។ បិណ្ឌបាត ២ តើដូចម្តេចខ្លះ គឺបិណ្ឌបាតដែលតថាគត ទ្រង់សោយហើយ ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិ ១ បិណ្ឌបាតដែលតថាគតសោយហើយ បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ១ បិណ្ឌបាតទាំង ២ នេះ មានផលស្មើៗ គ្នា មានវិបាកស្មើៗ គ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ជាងពួកបិណ្ឌបាតឯទៀត ។ កម្មដែលចុន្ទកម្មារបុត្តដ៏មានអាយុសន្សំហើយ ជាកម្មប្រព្រឹត្តទៅ ដើម្បីអាយុ កម្មដែលចុន្ទកម្មារ-បុត្តដ៏មានអាយុ សន្សំហើយ ជាកម្មប្រព្រឹត្តទៅ ដើម្បីពណ៌សម្បុរ កម្មដែល*

ចុន្ទកម្មារបុត្តដ៏មានអាយុ សន្សំហើយ ជាកម្មប្រព្រឹត្តទៅ ដើម្បីសេចក្តីសុខ កម្មដែលចុន្ទកម្មារបុត្តដ៏មានអាយុ សន្សំហើយ ជាកម្មប្រព្រឹត្តទៅ ដើម្បីសួគ៌ កម្មដែលចុន្ទកម្មារបុត្តដ៏មានអាយុ សន្សំហើយ ជាកម្មប្រព្រឹត្តទៅ ដើម្បីយស កម្មដែលចុន្ទកម្មារបុត្តដ៏មានអាយុ សន្សំហើយ ជាកម្មប្រព្រឹត្តទៅ ដើម្បីភាវៈជាធំ ។ ម្នាលអានន្ទ អ្នកត្រូវបន្ទោបង់នូវសេចក្តីក្តៅក្រហាយរបស់ចុន្ទ-កម្មារបុត្ត ចេញយ៉ាងនេះឯង ។ លំដាប់នោះ ព្រះមានព្រះភាគ ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> បុណ្យ រមែងចម្រើន ដល់បុគ្គលអ្នកឲ្យ បុគ្គលអ្នកសង្រួម រមែងមិនសន្សំទុកនូវពៀរទេ អ្នកឈ្លាស រមែងលះបង់កម្ម ដ៏លាមក បុគ្គលបរិនិព្វាន ព្រោះអស់ទៅនៃរាគៈ ទោសៈ មោហៈ ។ សូត្រទី ៥ ។

អដ្ឋកថា

ចុន្ទសូត្រ

ចុន្ទសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ

[១៦២] បទថា **មល្លេសុ** បានដល់ ក្នុងជនបទដែលមានឈ្មោះយ៉ាងនោះ ។ បទថា **មហតា ភិក្ខុសង្ឃេន** បានដល់ ឈ្មោះថា ធំ ព្រោះធំដោយគុណ និងធំដោយចំនួន ពិតហើយ ភិក្ខុសង្ឃនោះ ឈ្មោះថា ធំ ព្រោះ

ប្រកបដោយគុណវិសេស មានសីលជាដើម ព្រោះក្នុងបណ្តាភិក្ខុទាំងនោះ ភិក្ខុ ដែលក្រោមគេបង្អស់ ក៏ជាព្រះសោតាបន្ន ឈ្មោះថា ធំ ដោយអាការធំ ដោយចំនួន ព្រោះកំណត់ចំនួនមិនបាន ពិតហើយ តាំងអំពីកាលដាក់អាយុ សង្ខារ ភិក្ខុទាំងឡាយដែលមកហើយ មិនបានចៀសចេញទៅឡើយ ។ បទ ថា **ចុន្ទស្ស** *បានដល់ ដែលមានឈ្មោះយ៉ាងនោះ ។ បទថា* **កម្មារបុត្តស្ស** *បានដល់ កូននៃជាងមាស ។*

បានឮមកថា កូនរបស់ជាងមាសនោះ ជាមនុស្សស្តុកស្តម្ភ ជាកុដុម្ពិកៈ ធំ ជាព្រះសោតាបន្ន ដោយការឃើញព្រះសាស្តាលើកទី ១ នោះឯង រៀបចំ ព្រះគន្ធកុដិ ដែលគួរដល់ការគង់ប្រថាប់របស់ព្រះសាស្តា និងទីសម្រាកពេល ថ្ងៃ ពេលយប់ និងទីសម្រាកពេលថ្ងៃដល់ភិក្ខុសង្ឃ និងរៀបចំរោងធាន់ កុដិ មណ្ឌប និងទីចង្ក្រមដល់ភិក្ខុសង្ឃ ក្នុងចម្ការស្វាយរបស់ខ្លួន ហើយសាង វិហារដែលប្រកបដោយខ្ងោងទ្វារ ព័ទ្ធដោយកំពែង រៀបច្ចាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដែលលោកពោលថា បានឮថា ក្នុងទីនោះឯង ព្រះ មានព្រះភាគ ទ្រង់គង់ក្នុងសួនអម្ពវនៃរបស់នាយចុន្ទកម្មារបុត្ត (កូនជាង មាស) ទៀបក្រុងបាវានោះ ដូច្នេះ ។

បទថា **បដិយាទាបេត្វា** *សេចក្តីថា ឲ្យចាត់ចែង គឺឲ្យចម្អិន ។ បទថា* **សូរកមទ្ទវំ** *លោកពោលក្នុងមហាអដ្ឋកថាថា សាច់ជ្រូកទូទៅដែលមាន សាច់ខ្លីល្អ ។ តែអាចារ្យពួកខ្លះពោលថា បទថា* **សូរកមទ្ទវំ** *សេចក្តីថា មិន មែនសាច់ជ្រូក ជាទំពាំងឫស្សីដែលជ្រូកទាំងឡាយឈ្មុស ។ អាចារ្យពួកខ្លះ*

ទៀតពោលថា ជាផ្សិតដែលកើតក្នុងទីជ្រូកឈ្មុស ។ ឯអាចារ្យមួយពួកទៀតពោលថា អណ្តូងជាទីកើតរសមួយប្រភេទ ដែលបានឈ្មោះថា សូករមទ្ទវៈ ។ អាចារ្យមួយពួកទៀតពោលថា ចុន្ទកម្មារបុត្ត ស្តាប់ពាក្យនោះថា ថ្ងៃនេះ ព្រះមានព្រះភាគទ្រង់បរិនិព្វានហើយ គិតថា ធ្វើម្តេចហ្ន៎ ឲ្យព្រះមានព្រះភាគសោយសាច់ជ្រូកខ្ចីនេះហើយ គប្បីតាំងនៅអស់កាលយូរ ដូច្នេះហើយ ទើបបានថ្វាយ ដើម្បីបំណងឲ្យព្រះសាស្តាតាំងព្រះជន្មាយុនៅបានយូរ ។ បទថា **តេន មំ បរិវិស** *បានដល់ ឲ្យតថាគតសោយនូវសាច់ជ្រូកខ្ចីនោះ ។*

ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់យ៉ាងនោះ ព្រោះទ្រង់មានសេចក្តីករុណាដល់សត្វជទៃ ។ ហេតុនោះ ទ្រង់បានត្រាស់ហើយ ក្នុងព្រះបាលីនោះឯង ។ ដោយហេតុនោះ ឈ្មោះថា ទ្រង់សម្តែងថា គួរនឹងពោលយ៉ាងនោះ ព្រោះភិក្ខាគេនាំមកចំពោះ អ្នកជទៃមិនគួរបរិភោគ បានឮថា ទេវតាក្នុងទ្វីបធំទាំង ៤ ដែលមានទ្វីបតូច ២០០០ ជាបរិវារ ជាក់ឱជារសក្នុងសូករ-មទ្ទវៈនោះ ព្រោះដូច្នោះ បុគ្គលជទៃមិនអាចឲ្យសូករមទ្ទវៈនោះ រលាយបានងាយឡើយ ។ ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ដើម្បីដោះនូវការក្តៅក្រហាយរបស់អ្នកជទៃ ទើបទ្រង់បន្ទឺសីហនាទ ដោយន័យជាដើមថា ម្នាលចុន្ទ ក្នុងលោកព្រមទាំងទេវលោក ... តថាគតមិនឃើញបុគ្គលណាម្នាក់ដូច្នេះ ។ ពិតហើយ ដើម្បីដោះការពោលចោទរបស់អ្នកជទៃថា បានជាមិនឲ្យរបស់ដែលសល់អំពីខ្លួនបរិភោគដល់ភិក្ខុ មិនឲ្យដល់អ្នកជទៃ ឲ្យកប់ក្នុងអណ្តូង ធ្វើឲ្យវិនាស ដោយពាក្យថា ឱកាសនៃពាក្យនោះ ចូរកុំបីមានដូច្នេះ

ទើបទ្រង់បន្ទឺសីហនាទ ។

បណ្តាបទទាំងនោះ បទថា **សទេវកេ** *ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា* **សទេវកេ** *ព្រោះប្រព្រឹត្តទៅដោយទេវតាទាំងឡាយ ។ ឈ្មោះថា* **សមារកេ** *ព្រោះប្រព្រឹត្តទៅដោយមារ ។ ឈ្មោះថា* **សព្រហ្មកេ** *ព្រោះប្រព្រឹត្តទៅដោយព្រហ្ម ។ ឈ្មោះថា* **សស្សមណព្រាហ្មណិយា** *ព្រោះប្រព្រឹត្តទៅដោយសមណៈ និងព្រាហ្មណ៍ ។ ឈ្មោះថា* **បជាយ** *ព្រោះជាសត្វកើត ។ ឈ្មោះថា* **សទេវមនុស្សាយ** *ព្រោះប្រព្រឹត្តទៅដោយទេវតា និងមនុស្សទាំងឡាយ ។ ក្នុងលោកនោះ មួយអន្ទើដោយទេវលោក ។បេ។ ព្រមដោយទេវតា និងមនុស្ស ។ ក្នុងពាក្យទាំងនោះ ដោយពាក្យថា* **សទេវកេ** *សំដៅយកទេវតាជាន់កាមាវចរ ។ ដោយពាក្យថា* **សមារកេ** *សំដៅយកទេវតាកាមាវចរជាន់ទី ៦ ។ ពាក្យថា* **សព្រហ្មកេ** *សំដៅយកព្រហ្មជាន់ព្រហ្មកាយិកាជាដើម ។ ដោយពាក្យថា* **សស្សមណព្រាហ្មណិ** *សំដៅយកសមណៈដែលជាសត្រូវ និងព្រាហ្មណ៍ដែលជាសត្រូវចំពោះព្រះសាសនា និងសំដៅយកសមណៈដែលស្ងប់ជាប និងព្រាហ្មណ៍ដែលបន្សាត់បាប ។ ពាក្យថា* **បជា** *សំដៅយកសត្វលោក ។ ពាក្យថា* **សទេវមនុស្ស** *សំដៅយកទេវតាដោយសន្ទត និងមនុស្សដ៏សេស ។ ក្នុងបទទាំងនោះ ដោយ ៣ បទ គប្បីជ្រាបថា លោកកាន់យកសត្វលោក ដោយឱកាសលោក ដោយ ២ បទ គប្បីជ្រាបថា លោកកាន់យកសត្វលោក ដោយពួកសត្វ ។ គប្បីជ្រាបន័យមួយទៀតដូច្នេះ ពាក្យថា* **សទេវកេ** *លោកសំដៅយកទេវលោកជាន់អរូបាវចរ ។ ពាក្យថា*

សមារកេ *លោកសំដៅយកទេវលោកឆកាមាវចរ ។ ពាក្យថា* **សព្រហ្មកេ** *លោកសំដៅយកព្រហ្មលោកជាន់រូបាវចរ ។ ពាក្យថា* **សស្សមណ-ព្រាហ្មណិ** *ជាដើម គប្បីជ្រាបថា លោកសំដៅយកមនុស្សលោក មួយអន្ទើដោយទេវតាដោយសន្ថត ដោយអំណាចបរិស័ទ ៤ ឬគប្បីជ្រាបថា លោកសំដៅយកសត្វលោកដ៏សេស ។*

[១៦៣] *បទថា* **ភុត្តាវិស្ស** *បានដល់ អ្នកបរិភោគ ។ បទថា* **ឱរោ** *ប្រែថា គ្រោតគ្រោត ។ បទថា* **អាពាធោ** *បានដល់ រោគដែលមិនត្រូវចំណែកគ្នា ។ បទថា* **ពាឡ្ហា** *បានដល់ ខ្លាំងក្លា គឺជាទម្ងន់ ។ បទថា* **មរណន្តិកា** *បានដល់ ស្ទើរស្លាប់ គឺអាចនឹងឲ្យអ្នកឈឺដល់កាលជិតនឹងស្លាប់ ។ បទថា* **សតោ សម្បជានោ អធិវាសេតិ** *សេចក្តីថា តម្កល់សតិដោយល្អ កំណត់ដោយញាណ នៅសម្ងំ ។ បទថា* **អវិហញ្ញមានោ** *សេចក្តីថា មិនធ្វើឲ្យផ្លាស់ប្តូរទៅមក ដូចធម៌ដែលមិនបានកំណត់ ដោយអនុវត្តតាមវេទនា នៅសម្ងំ ដូចមិនត្រូវបៀតបៀន មិនបានទទួលសេចក្តីលំបាក ។*

ពិតហើយ វេទនាទាំងនោះ កើតឡើងដល់ព្រះមានព្រះភាគ ក្នុងស្រុកវេឡុវគ្រាមនោះឯង តែត្រូវកម្លាំងនៃសមាបត្តិសង្កត់ ទើបមិនកើតឡើង រហូតដល់ថ្ងៃបរិនិព្វាន ព្រោះឲ្យសមាបត្តិបង្អោនទៅចំពោះរាល់ៗ ថ្ងៃ ។ តែទ្រង់បំណងបរិនិព្វានក្នុងថ្ងៃនោះ ទើបមិនចូលសមាបត្តិ ដើម្បីឲ្យសត្វកើតនូវសេចក្តីសង្វេគថា ព្រះសាស្តាទ្រទ្រង់នូវកម្លាំងដ៏រឹមួយពាន់កោដិ មានកាយល្អដូចពេជ្រ មានបុញ្ញសម្ភារ សន្សំមកអស់កាលប្រមាណមិនបាន កាលភពនៅ

មាន វេទនាបែបនេះក៏រមែងប្រព្រឹត្តទៅ ទីងពោលទៅថ្វីដល់អម្បាលសត្វដទៃ នោះ ព្រោះហេតុនោះ ទើបវេទនាប្រព្រឹត្តទៅដ៏ខ្លាំងក្លា ។

បទថា **អាយាម** *ប្រែថា មកចុះ យើងនឹងទៅ ។*

ក្នុងកាលជាខាងក្រោយ ព្រះធម្មសង្គាហកាចារ្យបានតាំងគាថាថា **ចុទ្ទសន្នំ ភត្តំ ភុញ្ជិត្វា** *ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា* **ភុត្តស្ស ច សូករមទ្ទវេន** *សេចក្តីថា កើតទុក្ខវេទនាជាទុក្ខយ៉ាងខ្លាំងក្លាដល់ព្រះមានព្រះភាគ ដែលសោយ ព្រោះមិនមែនទ្រង់សោយព្រះក្រយាហារជាបច្ច័យ ។ ព្រោះបើ រោគដ៏ខ្លាំងក្លាដែលកើត គឺមានដល់ព្រះមានព្រះភាគ ដែលមិនបានសោយ អាហារហើយសោត តែព្រោះទ្រង់សោយព្រះក្រយាហារនោះ ទើបវេទនាធូរ ស្រាល ដោយហេតុនោះឯង ទើបទ្រង់មិនអាចយាងទៅបានដោយព្រះបាទ ហើយទ្រង់បន្ទឺសីហនាទ ឲ្យជាប្រយោជន៍ដែលទ្រង់បន្ទឺថា តថាគតមិនឃើញ បុគ្គលណាម្នាក់ ។បេ។ លើកលែងតែព្រះតថាគតចេញ ដូច្នេះ ។ ពិតហើយ ឈ្មោះថា សំឡេងគ្រហឹមក្នុងខណៈដែលមិនសមគួរ រមែងមិនមានដល់ ព្រះពុទ្ធទាំងឡាយឡើយ ។ ព្រោះហេតុដែលព្រះក្រយាហារ ដែលទ្រង់សោយ ហើយ មិនធ្វើវិការណាមួយឲ្យកើតដល់ព្រះមានព្រះភាគ ព្រះក្រយាហារដែល ជារបស់ស្វែង ដែលកម្មបានឱកាសហើយ ចូលទៅកាន់យក ស្ងប់ទៅ ដោយ ប្រមាណតិច ទើបធ្វើកម្លាំងឲ្យកើតឡើងក្នុងរាងកាយ ដែលជាហេតុឲ្យប្រ-យោជន៍ ៣ យ៉ាងតាមដែលពោលឲ្យសម្រេច ដូច្នោះ ទើបព្រះក្រយាហារ នោះដល់នូវការរលាយទៅ ដោយប្រពៃនោះឯង តែព្រោះវេទនា ស្ទើរស្ងាប់*

ដែលបុគ្គលណាម្នាក់មិនដឹង មិនជ្រាកដហើយ ទើបមានដូច្នេះឯង ។

បទថា **វិវិច្ចមានោ** *បានដល់ ចុះធ្លន់ដោយព្រះលោហិត ប្រព្រឹត្តទៅរឿយៗ ។ បទថា* **អវោច** *សេចក្តីថា ទ្រង់បានត្រាស់យ៉ាងនោះ ដើម្បីជាប្រយោជន៍ដល់បរិនិព្វានក្នុងទីដែលទ្រង់ប្រាថ្នា ។*

*សួរថា ព្រោះរោគកើតឡើងហើយយ៉ាងនេះ ទើបព្រះមានព្រះភាគយាងទៅកាន់ក្រុងកុសិនារ ព្រោះហេតុអ្វី ទើបទ្រង់មិនបរិនិព្វានក្នុងទីដទៃ ។ ឆ្លើយថា ព្រោះទ្រង់មិនអាចបរិនិព្វានក្នុងទីណាមួយក៏មិនមែន តែទ្រង់ព្រះតម្រិះយ៉ាងនេះថា បើតថាគតទៅកាន់ក្រុងកុសិនារ អត្តុប្បត្តិហេតុក្នុងការសម្តែងមហាសុទស្សនសូត្រក៏នឹងមាន សម្បត្តិណា ដូចគ្នានឹងសម្បត្តិ ដែលតថាគតគប្បីសោយក្នុងទេវលោក ដោយអត្តុប្បត្តិហេតុនោះ តថាគតបានសោយហើយក្នុងមនុស្សលោក តថាគតនឹងប្រជាប់សម្បត្តិនោះ ដោយការណារទាំង ២ ហើយ នឹងសម្តែងធម៌ មហាជនបានស្តាប់ហើយ នឹងសម្គាល់ដល់កុសលថា ខ្លួនគួរធ្វើ ក្នុងទីនោះ សុភទ្រក៏នឹងមកគាល់តថាគតសួរបញ្ហា ក្នុងទីបំផុតនៃការឆ្លើយបញ្ហា សុភទ្រនឹងតាំងនៅក្នុងសរណៈ បព្វជ្ជាឧបសម្បទា ហើយចម្រើនកម្មដ្ឋាន សម្រេចអរហត្ត ក្នុងកាលដែលតថាគតនៅមានជីវិតនោះឯង ជាបុគ្គល ឈ្មោះថា បច្ឆិមសាវក កាលតថាគតបរិនិព្វានក្នុងទីដទៃ ជម្ងឺក៏នឹងមានព្រោះធាតុជាហេតុ ឈាមនឹងហូរទៅដូចស្ទឹង តែកាលតថាគតបរិនិព្វានក្នុងនគរកុសិនារ ទោណព្រាហ្មណ៍នឹងរម្ងាប់វិវាទនោះ ចែកធាតុទាំងទ្វាយ ដូច្នេះ ព្រះមានព្រះភាគ កាលទ្រង់ឃើញហេតុ ៣ ប្រការដូចពោល

មកនេះ ទើបយាងទៅកាន់នគរកុសិនារា ដោយឧស្សាហ៍ធំ ។

[១៦៤] *សព្ទថា* **ឥដ្ឋ** *ជានិបាត ប្រើក្នុងចោទនត្ថៈ ។ បទថា* **កិលន្តោស្មិ** *សេចក្តីថា តថាគតជាអ្នកស្គមស្គាំង ។ ដោយបទនោះ ទ្រង់សម្តែងចំពោះវេទនាតាមដែលពោលហើយថា មានកម្លាំងខ្លាំងក្លានោះឯង ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់បានយាងទៅក្នុងកាលនោះ ដោយអានុភាពរបស់ព្រះអង្គ វេទនាដ៏ខ្លាំងក្លា មានសភាពក្តៅ ប្រព្រឹត្តទៅដោយប្រការដែលអ្នកដទៃ មិនអាចលើកជើងឡើងបាន ។*

ព្រោះហេតុនោះឯង ទើបទ្រង់ត្រាស់ថា តថាគតនឹងអង្គុយសិន ដូច្នេះ ។

បទថា **ឥធាធិ** *ប្រែថា ក្នុងកាលនោះ ។ បទថា* **លុទ្ធិតំ** *បានដល់ គួរខ្ពើម ដូចត្រូវជាន់ញាំញី ។ បទថា* **អាវិលំ** *ប្រែថា ល្អក់ ។ បទថា* **អច្ឆោទកា** *បានដល់ ទឹកដែលថ្លាតិច ។ បទថា* **សាតោទកា** *បានដល់ ទឹកដែលមានរសឆ្ងាញ់ ។ បទថា* **សីតោទកា** *បានដល់ ទឹកត្រជាក់ ។ បទថា* **សេតោទកា** *បានដល់ ទឹកច្រាសចាកកកក់ ។ ពិតហើយ ទឹកដោយសភាវៈមានពណ៌សតែក្លាយទៅជាដទៃ ដោយអំណាចទឹកន្លែង និងល្អក់ទៅដោយកកក់ ។ ស្ទឹងសូម្បីសមានខ្សាច់គ្រាប់ធំៗ ស្អាតជាច្រើន មានពណ៌ស ហូរទៅ ។ ដោយហេតុនោះ ទើបលោកពោលថា* **សេតោទកា** *គឺ ទឹកស ។ បទថា* **សុបតិត្ថា** *ប្រែថា កំពង់ល្អ ។ បទថា* **រមណីយា** *សេចក្តីថា ដែលបុគ្គលគប្បីត្រេកអរ ព្រោះជាចំណែកភូមិភាគដែលជាទីត្រេកអរនៃចិត្ត និងឈ្មោះថា ជាទីត្រេកអរនៃចិត្ត ព្រោះសម្បូរដោយទឹកតាមដែលពោលហើយ ។*

[១៦៦] បទថា **កិលញ្ជោស្មិ ចុន្ទ ឯបដ្ឋិសញ្ជាមិ** សេចក្តីថា ក្នុងបណ្តាត្រកូលដ៏វិ ១០ ដែលព្រះតថាគតត្រាស់យ៉ាងនេះថា

ត្រកូលដ៏វិ ១០ គឺកាឡាវក: ១ គង្គេយ្យ: ១ បណ្ឌរ: ១ តម្ព: ១ បិង្គល: ១ គន្ធ: ១ មង្គុល: ១ ហេម: ១ ឧបោសថ ១ និងឆទ្ទន្ត ១ ។

កម្លាំងនៃជីវធម្មតា ១០ ពោល គឺជីវត្រកូលកាឡាវក:តាមដែលពោលហើយយ៉ាងនេះ ស្មើនឹងកម្លាំងជីវត្រកូលគង្គេយ្យ: ១ សេចក្តីថា ដោយការគុណនឹង ១០ នៃជីវតាមប្រក្រតី កម្លាំងព្រះតថាគតដែលមានប្រមាណស្មើនឹងកម្លាំងជីវមួយពាន់កោដិនោះ ដល់នូវការអស់ទៅ ដូចទឹកដែលជាក់ក្នុងធម្មក្រកតាំងអំពីក្រោយភត្ត ក្នុងថ្ងៃនោះ ព្រះមានព្រះភាគយាងអំពីនគរបាវា ៣ គាវុត អំពីនគរកុសិនារា គង់ប្រថាប់ក្នុងរវាងផ្លូវនេះ ក្នុងទី ២៥ គាវុត ធ្វើឧស្សាហ៍ធំ ជល់នគរកុសិនារាក្នុងពេលព្រះអាទិត្យអស្តង្គត ។ ទ្រង់សម្តែងសេចក្តីនេះថា ឈ្មោះថា រោគ រមែងញាំញីបុគ្គលដែលមិនមានរោគទាំងអស់បាន ដោយប្រការដូច្នេះ ។ កាលនឹងត្រាស់ព្រះវាចាដែលធ្វើសេចក្តីសង្វេគដល់សត្វលោកព្រមទាំងទេវលោក ទើបត្រាស់ថា ចុន្ទ តថាគតល្អិតល្អែណាស់ តថាគតនិងសិង ដូច្នេះ ។

ការដេកក្នុងពាក្យថា **សីហសេយ្យំ** នេះ មាន ៤ យ៉ាង គឺការដេកនៃអ្នកបរិភោគកាម ១ ការដេករបស់ពួកប្រេត ១ ការដេករបស់ព្រះតថាគត ១ ការដេករបស់ពួកសីហ: ១ ។ បណ្តាការដេក ៤ យ៉ាងនោះ ការដេកដែលត្រាស់ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាតថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នក

បរិភោគកាម ច្រើនតែដេកផ្អៀងទៅខាងធ្វេង ។ នេះ ឈ្មោះថា ការដេក
របស់អ្នកបរិភោគកាម ។ ការដេកដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួក
ប្រេតច្រើនតែដេកផ្ទារ ។ នេះ ឈ្មោះថា ការដេករបស់ពួកប្រេត ។ ម្នាល
ភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។
ចូលកាន់ចតុត្ថជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា ដំណេកព្រះ
តថាគត ។ ការដេកដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សីហមិគរាជ
សម្រេចការដេកដោយខាងៗ ស្តាំ ... នេះឈ្មោះថា ការដេករបស់សីហ: ។
ពិតហើយ ការដេករបស់សីហ:នេះ ឈ្មោះថា ជាការដេកដ៏ខត្តម ព្រោះ
មានឥរិយាបថខ្ពស់ដោយតេជះ ។ ដោយហេតុនោះ ទើបលោកពោលថា
ទ្រង់សម្រេចនូវសីហសេយ្យា ផ្អៀងទៅខាងស្តាំ ដូច្នេះ ។

បទថា **ចាធេ ចាធំ** បានដល់ ត្រួតព្រះបាទធ្វេងលើព្រះបាទស្តាំ ។ បទ
ថា **អច្ចាធាយ** ប្រែថា ត្រួត គឺដាក់កជើងឲ្យខុសគ្នាបន្តិច ។ ពិតហើយ
កាល-កជើងចំត្រង់-កជើង ជង្គង់ចំត្រង់ជង្គង់ វេទនារមែងកើតឡើងរឿយៗ
ការដេករមែងមិនផាសុក ។ តែកាលដាក់កជើង ឲ្យខុសគ្នាបន្តិច វេទនារមែង
មិនកើត ការដេកក៏ផាសុក ។ ព្រោះដូច្នោះ ទើបទ្រង់ផ្ទំយ៉ាងនោះ ។

[១៦៧] គាថាទាំងនេះថា **គន្ត្វាន ពុទ្ធោ** ព្រះធម្មសង្គាហកាចារ្យ
ទាំងឡាយរចនាឡើងខាងក្រោយ ។ បណ្តាបទទាំងនោះ បទថា **នទិកំ** បាន
ដល់ នូវស្ទឹង ។ បទថា **អប្បដិមោធ លោកេ** បានដល់ មិនមានបុគ្គល
ប្រៀបក្នុងលោកនេះ គឺក្នុងលោក ព្រមទាំងទេវលោក ។ បទថា **ន្ហាត្វា ច**

បិវិត្វា ចុទកានិ បានដល់ ទ្រង់ស្រង់ ធ្វើឲ្យព្រះកាយត្រជាក់ ទ្រង់សោយទឹកហើយ ទ្បើងអំពីទឹក បានឮថា ក្នុងកាលនោះ កាលព្រះមានព្រះភាគទ្រង់ស្រង់ វត្តទាំងអស់ មានត្រី និងអណ្តើកខាងក្នុងស្ទឹង ទឹក ដងព្រៃត្រង់មាត់ច្រាំងទាំងសងខាង និងភូមិភាគទាំងអស់ មានពណ៌ដូចមាសនោះឯង ។

បទថា **បុរក្ខតោ** សេចក្តីថា ដែលលោក ព្រមទាំងទេវលោកធ្វើខាងមុខដោយការបូជា និងការរាប់អាន ព្រោះទ្រង់ជាគ្រូឧត្តមជាងសត្វពិសេសដោយគុណ ។ បទថា **ភិក្ខុគណាសប្ប មជ្ឈេ** ប្រែថា ក្នុងកណ្តាលនៃភិក្ខុសង្ឃ ។ ក្នុងកាលនោះ ភិក្ខុទាំងឡាយ ដឹងថា ព្រះមានព្រះភាគទ្រង់បានទទួលវេទនាពន់ប្រមាណ ទើបទៅចោមរោមដោយជុំវិញមិនឃ្លាត ។

បទថា **សត្ថា** សេចក្តីថា ឈ្មោះថា សាស្តា ព្រោះទ្រង់រាយនូវអនុ-សាសនីដល់ពួកសត្វ ដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ ។ បទថា **បវត្តា ភគវា ឥធ ធម្មេ** សេចក្តីថា ព្រះសាស្តា ឈ្មោះថា **ភគវា** ព្រោះជាបុគ្គលមានភាគធម៌ជាដើម ទ្រង់ប្រកាសសាសនធម៌ មានសីលជាដើម ក្នុងព្រះសាសនានេះ គឺទ្រង់ពន្រីកធម៌ ឬ ធម្មក្ខន្ធ ៨៤០០០ ព្រះធម្មក្ខន្ធ ឲ្យសាយកាយទៅ ។ បទថា **អម្ពវនំ** បានដល់ ចម្ការស្វាយ ជិតឆ្នេរស្ទឹងនោះឯង ។ បទថា **អាមន្តយិ ចុន្ទកំ** សេចក្តីថា បានឮថា ក្នុងខណៈនោះ ព្រះអានន្ទរវល់ពូតសំពត់ងូតទឹក ទើបយឺតយូរ ព្រះចុន្ទកត្ថេរបានទៅក្បែរ ព្រោះដូច្នោះ ទើបទ្រង់គ្រាស់ហៅមក ។ បទថា **បមុខេ និសីទិ** បានដល់ អង្គុយចំពោះព្រះភក្ត្រ របស់ព្រះសាស្តា

ដោយលើកវត្តឡើងជាប្រធាន ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះថា ព្រោះ ហេតុអ្វីហ្ន៎ ទើបព្រះសាស្តាត្រាស់ហៅដូច្នេះ ព្រះអានន្ទជាធម្មកណ្ឌាគារិក ក៏ មកដល់តាមលំដាប់ ។ កាលព្រះអានន្ទមកដល់តាមលំដាប់យ៉ាងនេះ ទើប ព្រះមានព្រះភាគហៅមក ។

[១៦៨] *បទថា* **ឧបជ្ឈាឧហោយ្យ** *ប្រែថា គប្បីឲ្យកើតឡើង អធិប្បាយ ថា បុគ្គលណាម្នាក់ ធ្វើនូវការក្តៅក្រហាយឲ្យកើតឡើងគប្បីមានខ្លះ ។ បទថា* **អលាភា** *សេចក្តីថា បុគ្គលដទៃឲ្យទាន ក៏ចាត់ថាជាលាភ ពោល គឺអានិសង្ស នៃទានក៏មិនមែន ។ បទថា* **ឧុលុទ្ធំ** *សេចក្តីថា ការបានអត្តភាពជាមនុស្ស ដែលបានដោយបុណ្យពិសេស ឈ្មោះថា ជាការបានដោយកម្រ ។ បទថា* **យស្ស្ស តេ** *កែជា* **យស្ស្ស តវ** *ប្រែថា របស់បុគ្គលណា ។ បុគ្គលនឹងដឹង បិណ្ឌបាតនោះថា ចម្អិនមិនឆ្អិន ឬជ្រាយពេក ។ ព្រះតថាគតទ្រង់សោយ បិណ្ឌបាតចុងក្រោយ ហេតុអ្វី ទើបបរិនិព្វាន ចាត់ជាទានដែលថ្វាយមិនល្អ ពិត ។ បទថា* **លាភា** *បានដល់ លាភ ពោល គឺអានិសង្សនៃទានដែល មានក្នុងបច្ចុប្បន្ន និងសម្បរាយភព ។ បទថា* **សុលទ្ធំ** *សេចក្តីថា ភាពជា មនុស្ស អ្នកបានល្អហើយ ។ បទថា* **សម្មុខា** *ប្រែថា ចំពោះមុខ មិនមែន បានឮមក អធិប្បាយថា មិនមែនដោយឮតៗ មក ។ បទថា* **មេតំ** *កាត់ជា* **មេ ឍតំ** *ឬ* **មយា ឍតំ** *ប្រែថា សេចក្តីនោះ តថាគតបានជ្រាបហើយ ។ បទថា* **ទ្វេមេ** *កាត់បទជា* **ទ្វេ ឥមេ** *ប្រែថា បិណ្ឌបាត ២ យ៉ាង ។ បទថា* **សមសមផលា** *បានដល់ មានផលស្មើគ្នាដោយអាការទាំងពួង ។ ព្រះតថាគត*

ទ្រង់សោយបិណ្ឌបាត ដែលនាងសុជាតាថ្វាយហើយ ទើបត្រាស់ដឹង ទាន នោះ ចាត់ជាទានក្នុងកាលដែលទ្រង់មិនទាន់លះកិលេស តែទានរបស់នាយ ចុន្ទនេះ ជាទានក្នុងកាលដែលទ្រង់អស់អាសវៈហើយ មិនមែនឬ ព្រោះហេតុ អ្វី ទើបទានទាំងនេះ មានផលស្មើគ្នា ។ ព្រោះបរិនិព្វានស្មើគ្នា ព្រោះមាន សមាបត្តិស្មើគ្នា ព្រោះមានការរឭកស្មើគ្នា ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់សោយបិណ្ឌបាតដែលនាងសុជាតាថ្វាយហើយ បរិនិព្វានដោយសឧបា-ទិសេសនិព្វានធាតុ ទ្រង់សោយបិណ្ឌបាតដែលនាយចុន្ទថ្វាយហើយ បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ រួមសេចក្តីថា ទានទាំងនោះ មានផលស្មើគ្នា ព្រោះមានការបរិនិព្វានស្មើគ្នា ។ ក្នុងថ្ងៃត្រាស់ដឹង ទ្រង់ចូលសមាបត្តិ ២ លាន ៤ សែនកោដិ ក្នុងថ្ងៃបរិនិព្វាន ទ្រង់ក៏ចូលសមាបត្តិមានប្រមាណ ប៉ុណ្ណោះ ទើបឈ្មោះថា មានផលស្មើគ្នា ព្រោះស្មើគ្នាដោយការចូលសមាបត្តិ ដោយប្រការដូច្នេះ ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគ ត្រាស់ក្នុង អង្គុត្តរនិកាយ ចតុក្កនិបាតថា ភិក្ខុកាលបរិភោគបិណ្ឌបាតរបស់ទាយកណា ... ចូលកាន់ចេតោសមាធិ ជាធម៌ប្រមាណមិនបាន អានិសង្សជាទីហូរមកនៃ បុណ្យ ជាទីហូរមកនៃកុសលរបស់ទាយកនោះ ក៏រមែងប្រមាណមិនបាន ដូច្នេះជាដើម ។ ក្នុងកាលបន្តបន្ទាប់មក នាងសុជាតាបានឮថា ទេវតានោះ មិន មែនវុក្ខទេវតា នុ៎ះជាព្រះពោធិសត្វ បានឮថា ព្រះពោធិសត្វបរិភោគបិណ្ឌ-បាតនោះហើយ ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ បានឮថា ព្រះពោធិ-សត្វនោះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះអស់ ៧ សប្តាហ៍

កាលនាងសុជាតាបានស្តាប់ពាក្យនេះហើយ រឭកថា ជាលាភរបស់អញហ្ន៎ ទើបកើតបីតិសោមនស្សដ៏ខ្លាំងក្លា ។ ក្នុងកាលតមក កាលនាយចុន្ទបានឮថា អញបានថ្វាយបិណ្ឌបាតចុងក្រោយ អញបានទទួលធម្មសីសៈ ព្រះសាស្តាទ្រង់សោយបិណ្ឌបាតរបស់អញហើយ បរិនិព្វានដោយអនុបាទិសេសនិព្វាន-ធាតុ ដែលទ្រង់ប្រាថ្នាក្រៃលែងអស់កាលយូរ ទើបរឭកថា ជាលាភរបស់អញហ្ន៎ ទើបកើតបីតិសោមនស្សដ៏ខ្លាំងក្លា ។ គប្បីជ្រាបថា បិណ្ឌបាតទាន ២ យ៉ាង ឈ្មោះថា មានផលស្មើគ្នា ព្រោះមានការរឭកស្មើគ្នាយ៉ាងនេះ ។

បទថា **អាយុសំវត្តនិកំ** *ប្រែថា ជាផ្លូវឲ្យអាយុវែង ។ បទថា* **ឧបចិតំ** *ប្រែថា សន្សំហើយ គឺឲ្យកើតហើយ ។ បទថា* **យសសំវត្តនិកំ** *ប្រែថា ជាផ្លូវឲ្យមានបរិវារ ។ បទថា* **អាធិបតេយ្យសំវត្តនិកំ** *ប្រែថា ជាផ្លូវនៃភាពជាបុគ្គលប្រសើរ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងនូវអត្ថទាំង ៣ យ៉ាង គឺភាពជាទានមានផលច្រើន ១ ភាពដែលព្រះអង្គទ្រង់ជាទក្ខិណេយ្យបុគ្គលដ៏កំពូល ដោយព្រះគុណ មានសីលជាដើម ១ អនុបាទា-បរិនិព្វាន ១ ហើយទើបបន្ទឺឧទាននេះ ដែលសម្តែងសេចក្តីនោះ ។*

បណ្តាបទទាំងនោះ បទថា **ឧឧតោ បុញ្ញំ បវឌ្ឍតិ** *សេចក្តីថា បុគ្គលអ្នកឲ្យទាន ឈ្មោះថា រមែងញុំាងនូវបុណ្យដែលសម្រេចដោយទាន ព្រោះដល់ព្រមដោយចិត្ត និងដល់ព្រមដោយទក្ខិណេយ្យបុគ្គល រមែងមានផលច្រើនជាង មានអានិសង្សច្រើនជាង ។ ម្យ៉ាងទៀត គប្បីជ្រាបអត្តក្នុងបទថា* **ឧឧតោ**

បុញ្ញំ បវឌ្ឍតិ នេះ យ៉ាងនេះថា ភិក្ខុដែលមិនច្រែនទៅដោយអាបត្តិ ក្នុងទីគ្រប់ស្ថាន រមែងអាចរក្សាសីលឲ្យបរិសុទ្ធល្អ ហើយបំពេញសមថៈ និងវិបស្សនាដោយលំដាប់ ព្រោះបុគ្គលបរិច្ចាគទេយ្យធម៌ រមែងធ្វើឲ្យច្រែនដោយចេតនាដែលជាគ្រឿងបរិច្ចាគ ព្រោះហេតុនោះ បុណ្យទាំង ៣ យ៉ាងនេះ មានទានជាដើម រមែងចម្រើនដល់បុគ្គលនោះ ។ បទថា **សញ្ញមតោ** បានដល់ដែលសង្រួមក្នុងសីល អធិប្បាយថា តាំងនៅក្នុងសំវរៈ ។ បទថា **វេរំ ន ចិយតិ** សេចក្តីថា ពៀរ ៥ យ៉ាង រមែងមិនកើត ។ ម្យ៉ាងទៀត បុគ្គលអ្នកមានសីល បរិសុទ្ធដោយសីល សង្រួមដោយកាយ វាចា និងចិត្ត ព្រោះអធិសីល មានអនោសៈជាប្រធាន រមែងមិនញុំាងពៀរដល់បុគ្គលណាម្នាក់ ព្រោះជាអ្នកច្រែនដោយខន្តី បុគ្គលនោះ ជាបុគ្គលឈ្មោះថា ញុំាងនូវពៀរអំពីណា ព្រោះដូច្នោះ បុគ្គលសង្រួម គឺបុគ្គលអ្នករារាំងប្រយ័ត្ននោះ រមែងមិនញុំាងនូវពៀរ ព្រោះមានការសង្រួម ។ បទថា **កុសលោ ច ជហាតិ ចាបកំ** សេចក្តីថា បុគ្គលអ្នកឈ្លាស គឺបុគ្គលសម្បូរដោយបញ្ញា តាំងនៅក្នុងសីល បរិសុទ្ធដោយល្អ កំណត់កម្មដ្ឋានដែលសមគួរដល់ខ្លួន ក្នុងអារម្មណ៍ ៣៨ ប្រការ រមែងញុំាងឈាន មានឧបចារៈ និងអប្បនាឲ្យសម្រេច ឈ្មោះថា លៈ គឺលះបង់អកុសល មានកាមច្ឆន្ទៈជាដើមដោយវិក្ខម្ភនប្បហាន បុគ្គលនោះធ្វើឈាននោះឯងឲ្យជាបាទ ធ្វើមចម្រើនទូវការអស់ទៅសូន្យទៅក្នុងសង្ខារទាំងឡាយ បំពេញវិបស្សនា ធ្វើវិបស្សនាឲ្យកើត រមែងលះអកុសលដ៏លាមកបានជាសមុច្ឆេទ ដោយអរិយមគ្គ ។

បទថា **រាគទោសមោហក្ខយា បរិនិព្ពុតោ** *សេចក្តីថា បុគ្គលនោះលះអកុសលដ៏លាមកយ៉ាងនេះហើយ បរិនិព្វានដោយការរម្ងាប់កិលេស មិនមានចំណែកសល់ ព្រោះអស់រាគៈជាដើម បន្ទាប់អំពីនោះ រមែងបរិនិព្វាន ដោយការរម្ងាប់ខន្ធ ។*

ព្រះមានព្រះភាគ ទ្រង់អាស្រ័យទក្ខិណាសម្បត្តិរបស់នាយចុន្ទ និងទ្រង់អាស្រ័យទក្ខិណេយ្យសម្បត្តិរបស់ទ្រង់ ទើបទ្រង់បន្ទឺឧទានដែលផ្សាយចេញដោយកម្លាំងនៃបីតិ ដោយប្រការដូច្នេះ ។

អដ្ឋកថា ចុន្ទសូត្រទី ៥ ចប់

សុត្តន្តបិដក

ចាជលិគាមិយសូត្រ

[១៦៩] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គ្រាច់ទៅកាន់ចារិក ក្នុងដែនមគធៈ ជាមួយនឹងភិក្ខុសង្ឃច្រើនរូប បានទៅដល់ចាជលិគ្រាម ។ ពួកឧបាសក ឧបាសិកា អ្នកចាជលិគ្រាម បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់ចារិក ក្នុងដែនមគធៈ ជាមួយនឹងភិក្ខុសង្ឃច្រើនរូប ឥឡូវនេះ យាងមកដល់ចាជលិគ្រាមហើយ ។ គ្រានោះឯង ពួកឧបាសក ឧបាសិកា អ្នកចាជលិគ្រាម ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ*

ក្នុងទីសមគួរ ។ លុះពួកឧបាសក ឧបាសិកា អ្នកបាដលិគ្រាម អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទទួលភោជនៈរបស់ពួកខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ គ្រានោះឯង ពួកឧបាសក ឧបាសិកា អ្នកបាដលិគ្រាម ដឹងច្បាស់ថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចូលទៅឯភោជនៈរបស់ខ្លួន លុះចូលទៅដល់ហើយ ក៏ក្រាលកម្រាលពេញក្នុងភោជនៈរបស់ខ្លួន តាក់តែងអាសនៈ តម្កល់ភាជន៍ទឹក លើកទៀនទូរប្រទីបប្រេងហើយ ចូលមកគាល់ព្រះមានព្រះភាគ លុះចូលមកដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយស្ថិតនៅក្នុងទីសមគួរ ។ លុះពួកឧបាសក ឧបាសិកា អ្នកបាដលិគ្រាម ស្ថិតនៅក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ភោជនៈរបស់ពួកខ្ញុំព្រះអង្គ បានក្រាលកម្រាលពេញហើយ អាសនៈបានតាក់តែងហើយ ភាជន៍ទឹកបានតម្កល់ហើយ ទាំងប្រទីបប្រេង ក៏បានលើកទៀនហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់សម្គាល់កាលគួរ ក្នុងកាលឥឡូវនេះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ជាមួយភិក្ខុសង្ឃ យាងទៅកាន់ភោជនៈរបស់ខ្លួន លុះចូលទៅដល់ហើយ ក៏លាងព្រះបាទា រួចចូលទៅកាន់ភោជនៈរបស់ខ្លួន ទ្រង់គង់បែរព្រះភក្ត្រទៅទិសខាងកើត ផ្អែកនឹងសសរកណ្តាល ។ ចំណែកខាងភិក្ខុសង្ឃ លាងជើងរួចហើយ ចូលទៅឯភោជនៈរបស់ខ្លួន អង្គុយបែរមុខទៅទិស

ខាងកើត ផ្អែកនឹងជញ្ជាំងខាងក្រោយ មានព្រះមានព្រះភាគពីខាងមុខ ។ ពួក ឧបាសក ឧបាសិកា អ្នកបាជលិគ្រាម លាងជើងរួចហើយ ចូលទៅឯវេឡុ សម្នាក់ អង្គុយបែរមុខទៅទិសខាងលិច ផ្អែកនឹងជញ្ជាំងខាងមុខ មានព្រះ មានព្រះភាគពីខាងមុខដែរ ។

[១៧០] *គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់ហៅពួកឧបាសក ឧបាសិកា អ្នកបាជលិគ្រាមមកថា ម្នាលគហបតីទាំងឡាយ ទោសនៃសីល-វិបត្តិ របស់បុគ្គលទុស្សីល មាន ៥ យ៉ាង ។ ទោស ៥ យ៉ាង តើដូច ម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលក្នុងលោកនេះ ជាអ្នកទុស្សីល វិបត្តិចាកសីល តែងជួលនូវសេចក្តីវិនាសភោគៈច្រើន ព្រោះមានសេចក្តី ប្រមាទជាហេតុ នេះជាទោសនៃសីលវិបត្តិ របស់បុគ្គលទុស្សីលទី ១ ។ ម្នាលគហបតីទាំងឡាយ មួយទៀត កិត្តិសព្ទដ៏អាក្រក់របស់បុគ្គលទុស្សីល វិបត្តិចាកសីល ផ្សាយទៅ នេះជាទោសនៃសីលវិបត្តិរបស់បុគ្គលទុស្សីល ទី ២ ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទុស្សីល វិបត្តិចាក សីល ចូលទៅរកបរិសទ្យណាៗ ទោះខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី រមែងមិនក្លៀវក្លា មានមុខឱនចុះ នេះ ជាទោសនៃសីលវិបត្តិ របស់បុគ្គលទុស្សីលទី ៣ ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទុស្សីល វិបត្តិចាកសីល តែងធ្វើមរណកាលទាំងវង្វេង នេះជាទោសនៃសីលវិបត្តិ របស់បុគ្គលទុស្សីលទី ៤ ។ ម្នាលគហបតី ទាំងឡាយ មួយទៀត បុគ្គលទុស្សីល វិបត្តិចាកសីល លុះបែកធ្លាយ*

រាងកាយ ស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក នេះជា
ទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តទី ៥ ។ ម្នាលគហបតីទាំងឡាយ
ទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីល មាន ៥ យ៉ាងនេះឯង ។ ម្នាល
គហបតីទាំងឡាយ អានិសង្សនៃសីលសម្បទា របស់បុគ្គលអ្នកមានសីល
នេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាល
គហបតីទាំងឡាយ ក្នុងលោកនេះ បុគ្គលមានសីល បរិបូណ៌ដោយសីល
តែងបានគំនរទ្រព្យច្រើន មានសេចក្តីមិនប្រមាទជាហេតុ នេះជាអានិសង្សនៃ
សីលសម្បទា របស់បុគ្គលមានសីលទី ១ ។ ម្នាលគហបតីទាំងឡាយ មួយ
ទៀត កិត្តិសព្ទដ៏ពីរោះរបស់បុគ្គលមានសីល បរិបូណ៌ដោយសីល តែង
ខ្ចរខ្ចាយទៅ នេះជាអានិសង្សនៃសីលសម្បទា របស់បុគ្គលមានសីលទី ២ ។
ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីល
ចូលទៅរកបរិសទ្យណាៗ ទោះជាខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី
គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី រមែងក្លៀវក្លា មិនមានមុខជិនចុះ នេះ
ជាអានិសង្សនៃសីលសម្បទា របស់បុគ្គលមានសីលទី ៣ ។ ម្នាលគហបតី
ទាំងឡាយ មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីល រមែងមិនធ្វើ
មរណកាលទាំងវង្វេង នេះជាអានិសង្សនៃសីលសម្បទា របស់បុគ្គលមាន
សីលទី ៤ ។ ម្នាលគហបតីទាំងឡាយ មួយវិញទៀត បុគ្គលមានសីល
បរិបូណ៌ដោយសីល លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើតក្នុង
សុគតិ សួគ៌ទេវលោក នេះជាអានិសង្សនៃសីលសម្បទា របស់បុគ្គលមាន

សីលទី ៥ ។ ម្នាលគហបតីទាំងឡាយ អានិសង្សនៃសីលសម្បទា របស់បុគ្គលមានសីល មាន ៥ យ៉ាងនេះឯង ។

[๑๗๑] *គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ញុំាងពួកឧបាសក ឧបាសិកា អ្នកជាដលិគ្រាម ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា អស់រាត្រីច្រើន ហើយទ្រង់បញ្ជូនថា ម្នាលគហបតីទាំងឡាយ រាត្រីក្តីហើយ អ្នកទាំងឡាយ ចូរសម្គាល់កាលគួរនឹងទៅ ក្នុងកាលឥឡូវនេះចុះ ។ គ្រានោះឯង ពួកឧបាសក ឧបាសិកា អ្នកជាដលិគ្រាម ត្រេកអរមរីករាយ ចំពោះភាសិតនៃព្រះមានព្រះភាគ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ចៀសចេញទៅ ។ លំដាប់នោះឯង ព្រះមានព្រះភាគ កាលពួកឧបាសក ឧបាសិកា អ្នកជាដលិគ្រាម ចៀសចេញទៅ មិនយូរប៉ុន្មាន ក៏យាងចូលទៅកាន់សុញ្ញាគារស្ថាន ។*

[๑๗๒] *សម័យនោះឯង មហាមាត្យក្នុងដែនមគធៈឈ្មោះសុនីធៈ និងវស្សការៈ កំពុងកសាងក្រុង ក្នុងប្រទេសជាដលិគ្រាម ដើម្បីការពារពួកស្តេចលិច្ឆវី នៅក្នុងដែនវជ្ជី ។ សម័យនោះឯង ពួកទេវតាជាច្រើនទាំងពាន់ កំណត់យកទីទាំងឡាយ ក្នុងជាដលិគ្រាម ។ ពួកទេវតាមានសក្តិធំ កំណត់យកទីទាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជា និងរាជមហាមាត្យទាំងឡាយ មានសក្តិធំ រមែងឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះដែរ ។ ពួកទេវតាមានសក្តិជាកណ្តាល កំណត់យកទីទាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជា និងរាជមហាមាត្យទាំងឡាយ មានសក្តិជាកណ្តាល*

ក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះដែរ ។ ពួកទេវតាមាន
សក្តិទាប កំណត់យកទីទាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជា និង
រាជមហាមាត្យទាំងឡាយ មានសក្តិទាបក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន
ក្នុងប្រទេសនោះដែរ ។ ព្រះមានព្រះភាគ មានទិព្វចក្ខុ ដ៏បរិសុទ្ធ កន្ទងបង់
ចក្ខុរបស់មនុស្សសាមញ្ញ ទ្រង់បានឃើញពួកទេវតាទាំងពាន់នោះ ដែលកំពុង
កំណត់យកទីទាំងឡាយ ក្នុងបាដលិគ្រាម ពួកទេវតាមានសក្តិធំ កំណត់យក
ទីទាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជា និងរាជមហាមាត្យទាំង-
ឡាយ មានសក្តិធំ ក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះ
ដែរ ។ ពួកទេវតាមានសក្តិជាកណ្តាល កំណត់យកទីទាំងឡាយ ក្នុងប្រទេស
ណា ចិត្តរបស់ព្រះរាជា និងរាជមហាមាត្យទាំងឡាយ មានសក្តិជាកណ្តាល
ក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះដែរ ។ ពួកទេវតាមាន
សក្តិទាប កំណត់យកទីទាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជា និង
មហាមាត្យទាំងឡាយ មានសក្តិទាប ក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុង
ប្រទេសនោះដែរ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់តើនឡើងក្នុងបច្ចូស-
សម័យ នៃរាត្រីនោះហើយ ត្រាស់សួរព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ
នរណាហ្ន៎ កំពុងកសាងក្រុង ក្នុងប្រទេសបាដលិគ្រាម ។ បពិត្រព្រះអង្គដ៏
ចម្រើន មហាមាត្យក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ កសាងក្រុង
ក្នុងបាដលិគ្រាម ដើម្បីការពារពួកស្តេចលិច្ឆវី ក្នុងដែនវជ្ជី ។ ម្នាលអានន្ទ
មហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ហាក់ដូចជាបាន

ប្រឹក្សាគ្នាជាមួយនឹងពួកទេវតា ក្នុងស្ថានតាវត្តិង្ស យ៉ាងណាមិញ ។ ម្នាលអានន្ទ មហាមាត្យក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ កសាងក្រុងបាដលិគ្រាម ដើម្បីការពារពួកស្តេចលិច្ឆវី ក្នុងដែនវជ្ជី ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ អម្បាញ់នេះ តថាគតមានទិព្វចក្ខុ ដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សសាមញ្ញ បានឃើញពួកទេវតាជាច្រើន ទាំងពាន់ កំពុងកំណត់យកទីទាំងឡាយ ក្នុងបាដលិគ្រាម ។ ពួកទេវតាមានសក្តិធំ កំណត់យកទីទាំង-ឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជា និងរាជមហាមាត្យ មានសក្តិធំ ក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះដែរ ។ ពួកទេវតាមានសក្តិជាកណ្តាល កំណត់យកទីទាំងឡាយក្នុងប្រទេសណា ចិត្តរបស់ព្រះរាជា និងរាជមហាមាត្យ មានសក្តិជាកណ្តាល ក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះដែរ ។ ពួកទេវតាមានសក្តិទាប កំណត់យកទីទាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជា និងរាជមហាមាត្យ មានសក្តិទាប ក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះដែរ ។ ម្នាលអានន្ទ ទីប្រជុំរបស់អរិយបុគ្គល ដែលមានទាំងប៉ុន្មាន ផ្លូវជំនួញ ដែលមានទាំងប៉ុន្មាន ក្រុងបាដលិបុត្តនេះ ជានគរដ៏ប្រសើរ និងជាកន្លែងធ្វាយបង្ហិចទ្រព្យ ។ ម្នាលអានន្ទ ក្រុងបាដលិបុត្ត មុខជានឹងមានសេចក្តីអន្តរាយ ៣ យ៉ាង គឺអន្តរាយអំពីភ្លើង ១ អំពីទឹក ១ អំពីការបែកចាកគ្នានិងគ្នា ១ ។

[១៧៣] គ្រានោះ មហាមាត្យក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តី

រីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួរឮកហើយ ទើបស្ថិតនៅក្នុងទីសមគួរ ។ លុះមហាមាត្យក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ស្ថិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគថា សូមព្រះគោតមដ៏ចម្រើន ទទួលភត្តរបស់ខ្ញុំព្រះអង្គទាំងឡាយ ដើម្បីឆាន់ក្នុងថ្ងៃនេះ ជាមួយនឹងភិក្ខុសង្ឃ ។ ព្រះមានព្រះភាគទ្រង់ទទួលដោយការៈស្ងៀម ។ លំដាប់នោះ មហាមាត្យក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ដឹងច្បាស់ថា ព្រះមានព្រះភាគទទួលនិមន្តន៍ហើយ ក៏ចូលទៅកាន់លំនៅរបស់ខ្លួន លុះចូលទៅដល់ហើយ ក៏តាក់តែងខាទនីយភោជនីយាហារដ៏ឧត្តមក្នុងលំនៅរបស់ខ្លួន ហើយក្រាបទូលភត្តកាលចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលនេះជាកាលគួរ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ យាងចូលទៅក្នុងលំនៅ របស់មហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ជាមួយនឹងភិក្ខុសង្ឃ លុះយាងចូលទៅដល់ហើយ គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លំដាប់នោះ មហាមាត្យក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ក៏អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដោយខាទនីយភោជនីយាហារដ៏ឧត្តម ឲ្យឆ្អែតស្កប់ស្កល់ដោយដៃខ្លួនឯង លុះត្រាតែហាមឃាត់ ។ លំដាប់នោះ មហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ដឹងថា ព្រះមានព្រះភាគ ទ្រង់ឆាន់រួចហើយ លែងលូកព្រះហស្តទៅក្នុងបាត្រ ក៏កាន់យកអាសនៈដ៏ទាបមួយ ហើយអង្គុយ

ក្នុងទីសមគួរ ។ កាលដែលមហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈ និង វស្សការៈ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់អនុមោទនា ដោយគាថានេះថា

មនុស្សជាបណ្ឌិតជាត សម្រេចការនៅក្នុងប្រទេសណា រមែង ញុាំង ពួកបុគ្គលអ្នកមានសីល សង្រួម ប្រព្រឹត្តធម៌ដ៏ប្រសើរ ឲ្យបរិភោគក្នុងប្រទេសនោះ ហើយបានឧទ្ទិសផលទក្ខិណាទាន ចំពោះទេវតាដែលនៅក្នុងប្រទេសនោះ ទេវតាទាំងនោះ ដែល បណ្ឌិតនោះបូជាហើយ រមែងបូជាគេវិញ ដែលរាប់អានហើយ រមែងរាប់អានគេវិញ តែងអនុគ្រោះបណ្ឌិតនោះ ព្រោះទក្ខិណា- នុប្បទាននោះ ដូចជាមាតាអនុគ្រោះបុត្រ ដែលកើតអំពីទ្រូង បុរសដែលទេវតាអនុគ្រោះហើយ តែងឃើញសេចក្តីចម្រើន សព្វកាល ។

[១៧៤] *គ្រានោះ ព្រះមានព្រះភាគ ទ្រង់អនុមោទនាដោយគាថា ទាំងនេះ ចំពោះមហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ រួច ហើយ ទ្រង់ក្រោកចាកអាសនៈ យាងចេញទៅ ។ សម័យនោះឯង មហា- មាត្យក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ដើរតាមក្រោយៗ នៃព្រះ មានព្រះភាគហើយ គិតថា ក្នុងថ្ងៃនេះ ព្រះសមណគោតម នឹងយាងចេញ ទៅតាមទ្វារណា ទ្វារនោះនឹងបានឈ្មោះថា គោតមទ្វារ ។ ព្រះអង្គនឹងឆ្លង ទន្លេគង្គាតាមកំពង់ណា កំពង់នោះ នឹងបានឈ្មោះថា គោតមតិត្ថៈ ។ លំដាប់*

នោះ ព្រះមានព្រះភាគ ទ្រង់យាងចេញទៅតាមទ្វារណា ទ្វារនោះ បាននឹ្មះ ថា គោតមទ្វារ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់យាងចូលទៅកាន់ ទន្លេគង្គា ។ សម័យនោះឯង ទន្លេគង្គាមានទឹកពេញប្រៀប ស្មើនឹងមាត់ច្រាំង ល្មមក្អែកឱនផឹកបាន ។ ពួកមនុស្សខ្លះ ស្វែងរកទូក ខ្លះស្វែងរកផៃ ខ្លះចង ក្បួន ប្រាថ្នាដើម្បីឆ្លង អំពីត្រើយខាងអាយ ទៅកាន់ត្រើយខាងនាយ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជាត់ព្រះអង្គអំពីត្រើយខាងអាយនៃទន្លេ គង្គា ទៅប្រាកដនៅត្រើយខាងនាយ ជាមួយនឹងភិក្ខុសង្ឃ ដូចបុរសមានកម្លាំង លាដៃ ដៃលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ដូច្នោះឯង ។ ព្រះមាន ព្រះភាគ បានឃើញពួកមនុស្សទាំងនោះ ខ្លះកំពុងស្វែងរកទូក ខ្លះកំពុងស្វែង រកផៃ ខ្លះកំពុងចងក្បួន ប្រាថ្នាដើម្បីឆ្លង អំពីត្រើយខាងអាយ ទៅកាន់ ត្រើយខាងនាយ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តី ន៎ុះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ពួកជនណា ឆ្លងទន្លេដ៏ជ្រៅទូលាយបាន ពួកជននោះឯង លុះតែធ្វើស្ពាន រំលងទំនាបទាំងឡាយ សេចក្តីពិតថា ជនធម្មតា តែងចងក្បួន ទើបឆ្លងទឹកបាន ចំណែកជន ជាអ្នកប្រាជ្ញទាំងឡាយ (មិនបាច់ក្បួន) ក៏ឆ្លងទៅបាន ។

សូត្រទី ៦ ។

អដ្ឋកថា

ចាជលិគាមិយសូត្រ

ចាជលិគាមិយសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ

[១៦៩] បទថា **មគធេសុ** ប្រែថា ក្នុងជែនមគធៈ ។ បទថា **មហាតា** សេចក្តីថា ក្នុងទីនេះ បានដល់ មហាភិក្ខុសង្ឃ ព្រោះធំដោយគុណខ្លះ ធំដោយការកំណត់ចំនួនមិនបានខ្លះ ។ បទថា **ចាជលិគ្គាមោ** បានដល់ តំបន់មួយ ក្នុងជែនមគធៈមានឈ្មោះយ៉ាងនេះ ។ បានឮថា ក្នុងថ្ងៃកសាងស្រុកនោះ ពន្លកច្រនៀង ២-៣ ពន្លក ក្នុងទីដែលបម្រុងសាងស្រុក បានដុះចេញអំពីផែនដី ។ ដោយហេតុនោះ ទើបជនទាំងឡាយ ហៅស្រុកនោះថា **ចាជ-លិគាម** ។ បទថា **តទវសរិ** បានដល់ ព្រះមានព្រះភាគ បានយាងទៅ គឺ បានយាងទៅដល់ចាជលិគ្រាមនោះ ។

ព្រះមានព្រះភាគ បានយាងទៅដល់ចាជលិគាមក្នុងកាលណា ។ ទ្រង់ឲ្យសាងចេតិយដើម្បីព្រះធម្មសេនាបតីក្នុងក្រុងសាវត្ថី ដោយន័យដូចពោលហើយខាងដើម ។ យាងចេញអំពីក្រុងសាវត្ថីនោះ ប្រថាប់នៅក្នុងក្រុងរាជគ្រឹះ ឲ្យសាងចេតិយដើម្បីព្រះមហាមោគ្គល្លាន ក្នុងក្រុងរាជគ្រឹះនោះ ។ ទ្រង់ចេញអំពីក្រុងរាជគ្រឹះនោះហើយ ប្រថាប់នៅត្រង់អម្ពលដ្ឋិវែន ហើយយាងចារិកទៅក្នុងជនបទ ដោយការចារិកមិនប្រញាប់ប្រញាល់ ទើបប្រថាប់សម្រាកមួយរាត្រីក្នុងទីនោះៗ ដើម្បីអនុគ្រោះសត្វលោក ទើបយាងដល់ចាជលិគ្រាមដោយលំដាប់ ។

បទថា **ចាដលិគ្គាមិយា** *បានដល់ ឧបាសកអ្នកបាដលិគាម ។ បានឮថា ឧបាសកទាំងនោះ ពួកខ្លះតាំងនៅក្នុងសរណៈ ពួកខ្លះតាំងនៅក្នុងសីល ពួកខ្លះតាំងនៅក្នុងសរណៈផង សីលផង ដោយការឃើញព្រះមានព្រះភាគលើកដំបូងនោះឯង ដោយហេតុនោះ ទើបលោកពោលថា ឧបាសក ឧបាសិកា អ្នកបាដលិគ្រាម ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ដូច្នេះ ។*

បានឮថា ក្នុងបាដលិគ្រាម ពួកមនុស្សរបស់ព្រះបាទអជាតសត្រូវ និងព្រះបាទលិច្ឆវីទាំងឡាយ នាំគ្នាទៅតាមកាលដ៏សមគួរ ដេញម្ចាស់ស្រុក ឲ្យចេញពីស្រុក ហើយនៅ ១ ខែខ្លះ កន្លះខែខ្លះ ។ ដោយហេតុនោះ ពួកអ្នកបាដលិគ្រាម ត្រូវបៀតបៀនជាប្រចាំ ទើបគិតថា ក្នុងកាលដែលមនុស្សទាំងនេះមក នឹងបានមានទីលំនៅ ដូច្នេះហើយ ទើបបាននាំគ្នាធ្វើសាលាមួយខ្នងធំកណ្តាលស្រុក ដែលល្មមគ្រប់គ្រាន់ដល់ការនៅរបស់មនុស្សទាំងអស់ ដោយមិនប្រជ្រៀតគ្នា គឺទីសម្រាប់ទុកទ្រព្យ របស់ឥស្សរជនមួយចំណែក ទីសម្រាប់នៅមួយចំណែក ទីសម្រាប់នៅរបស់អ្នកជំណើរដែលជាអាគន្តុក:មួយចំណែក ទីលំនៅរបស់មនុស្សកំព្រាអនាថាមួយចំណែក ទីលំនៅរបស់អ្នកជំងឺមួយផ្នែក ដូច្នេះ ។ សាលាមួយខ្នងនោះ មានឈ្មោះថា **អារាមថាគារ** *គឺអាគារសម្រាប់សម្រាកនោះឯង ។ ក្នុងថ្ងៃនោះ ការសាងសាលានោះក៏បានរួចស្រេច ។ អ្នកបាដលិគ្រាមទាំងនោះ នាំគ្នាទៅក្នុងទីនោះ ពិនិត្យមើលសាលានោះ តាំងអំពីខ្ងោងទ្វារដែលសម្រេចរៀបរយ ចាត់ចែងទុកដោយល្អ ដោយការងារឈើ*

ការងារកំបោរ និងការងារចិត្រកម្មជាដើម ដូចទេវវិមាន ហើយនាំគ្នាគិតថា អាវសថាគារនេះ ជាទីគួរត្រេកអរ ជារបស់សំណប់ក្រៃពេក អ្នកណាហ្ន៎នឹង បានប្រើប្រាស់មុន នឹងគប្បីប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខ ដល់ពួកយើងអស់កាលយូរ ។ ក្នុងខណៈនោះឯង ពួកជនទាំងនោះបានឮថា ព្រះមានព្រះភាគយាងចូលដល់ស្រុកនោះ ។ ដោយហេតុនោះ ទើបពួកជន ទាំងនោះកើតបីតិសោមនស្ស ធ្វើការសម្រេចថា ពួកយើងគួរនាំព្រះសាស្តា មក ព្រោះថា ទ្រង់យាងដល់លំនៅរបស់ពួកយើង ដោយព្រះអង្គឯងហើយ ថ្ងៃនេះ ពួកយើងនឹងឲ្យព្រះមានព្រះភាគប្រថាប់នៅក្នុងទីនេះ ហើយនឹងឲ្យព្រះ សាស្តាទ្រង់សោយមុន ភិក្ខុសង្ឃក៏ដូចគ្នា កាលភិក្ខុសង្ឃមកដល់ ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ក៏នឹងមកដល់ដូចគ្នា យើងនឹងឲ្យព្រះសាស្តាត្រាស់មង្គល សម្តែងធម៌ ដូច្នោះ កាលវតនៈ ៣ ប្រើប្រាស់ហើយ ខាងក្រោយមក ពួក យើង និងមនុស្សដទៃ ក៏ប្រើប្រាស់ កាលបើដូច្នោះ នឹងប្រព្រឹត្តទៅដើម្បីជា ប្រយោជន៍ និងសេចក្តីសុខដល់ពួកយើងអស់កាលយូរ ដូច្នេះហើយ ទើប ចូលទៅគាល់ព្រះមានព្រះភាគ ដើម្បីជាប្រយោជន៍នោះឯង ។ ព្រោះដូច្នោះ ទើបជនទាំងនោះក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ ទទួលអាវសថាគាររបស់ខ្ញុំព្រះអង្គទាំងឡាយចុះ ។

បទថា **យេន អាវសថាគារំ តេនុបសង្កមីសុ** *សេចក្តីថា អាវសថាគារ នោះ គេរៀបចំបដិបត្តិដោយល្អ ដូចទេវវិមាន ព្រោះសម្រេចរៀបរយដោយ ល្អ ក្នុងថ្ងៃនោះឯងដោយពិត តែក៏មិនទាន់បានតាក់តែងឲ្យសមគួរដល់ព្រះ-*

សម្ពុទ្ធ ពួកអ្នកបាដលិគ្រាមទាំងនោះ នាំគ្នាគិតថា ធម្មតាព្រះពុទ្ធទាំងឡាយ មានអធ្យាស្រ័យនៅព្រៃ មានព្រៃជាទីត្រេកអរ គប្បីនៅខាងក្នុងស្រុកក្តី មិននៅក្តី ដូច្នោះ ចាំពួកយើងដឹងថា ព្រះមានព្រះភាគទ្រង់ពេញព្រះហឫទ័យសឹមតាក់តែង ដូច្នេះហើយ ទើបនាំគ្នាទៅគាល់ព្រះមានព្រះភាគ ឥឡូវនេះបានឮថា ទ្រង់ពេញព្រះហឫទ័យ ទើបមានបំណងតាក់តែង ដូច្នោះ ទើបចូលទៅដល់អាវសថាគារ ។

បទថា **សព្វសន្ថរឺ អាវសថាគារំ សន្ថរិត្វា** *សេចក្តីថា អ្នកបាដលិគ្រាមទាំងនោះក្រាលកម្រាលក្នុងអាវសថាគារនោះ គឺក្រាលទាំងអស់នោះឯង ជាបឋម ទើបយកគោម័យស្រស់លាបផ្ទៃដែលបូកដោយធុយអ ដោយគិតថាធម្មតាគោម័យ រមែងប្រើបានក្នុងការងារមង្គលទាំងអស់ ដឹងថា ស្អុតហើយទើបលាបដោយគ្រឿងក្រអូប គឺគន្ធជាតិ ៤ ដោយមិនប្រាកដស្នាមជើងក្នុងទីដែលជាន់ ក្រាលកន្ទេលផែង មានពណ៌ផ្សេងៗ ខាងលើ ហើយលាតសំពត់រោមសត្វផ្ទាំងធំជាដើម ខាងលើកន្ទេលផែងទាំងនោះ ហើយក្រាលទីទំនេរទាំងអស់ ដែលគួរក្រាលដោយកម្រាល មានពណ៌ផ្សេងៗ មានកម្រាលដែលក្រាលលើខ្នងដំរីជាដើម ។ ដោយហេតុនោះ ទើបលោកពោលថា ក្រាលអាវសថាគារទាំងអស់ជាដើម ។*

ពិតហើយ ក្នុងចំណោមអាសនៈទាំងឡាយ ពួកជនទាំងនោះ តាក់តែងពុទ្ធាសនៈ មានតម្លៃច្រើន ផ្អែកសសរមង្គលជាលំដាប់ដំបូង ហើយក្រាលកម្រាលដែលទន់ គួរជាទីត្រេកអរនៃចិត្ត លើពុទ្ធាសនៈនោះហើយ ចាត់ចែង

ខ្នើយ មានពណ៌ក្រហមទាំងសងខាង ឃើញហើយគួរពេញចិត្ត ចងនូវពិតាន ដែលវិចិត្រដោយផ្កាយមាសផ្កាយប្រាក់ខាងលើ ប្រដាប់ដោយកម្រង គ្រឿងក្រអូប កម្រងផ្កា និងកម្រងស្លឹកឈើជាដើម ឲ្យចាំងសំណាញ់ផ្កាក្នុងទី ១២ ហត្ថដោយជុំវិញ យកវាំងននព័ទ្ធទីប្រមាណ ៣២ ហត្ថ ជាក់គ្រែដែលមានបង្អែក និងតាំងជាដើមដើម្បីភិក្ខុសង្ឃ ខាងក្រោយ ក្រាលកម្រាលពណ៌សខាងលើ ឲ្យសាងសាលាទិសខាងកើត ដែលសមគួរដល់ទីអង្គុយរបស់ខ្លួន ។ ដូចលោកពោលថា អាសនៈបានតាក់តែងហើយជាដើម ។

បទថា **ឧទកមណិកំ** *បានដល់ ក្អមទឹកដែលសម្រេចហើយដោយមាស និងកែវមណីដែលមានតម្លៃច្រើន គឺពាងទឹក ។ ព្រះមានព្រះភាគ និងភិក្ខុសង្ឃ នឹងលាងដៃជើង ខ្ពុរមាត់តាមការពេញចិត្តដោយប្រការដូច្នេះ ព្រោះដូច្នោះ ទើបពួកជនទាំងនោះដាក់ទឹកដែលមានពណ៌ដូចកែវមណីឲ្យពេញ ក្នុងទីនោះៗ ហើយដាក់ផ្តាច្រើនប្រភេទ និងលម្អិតសម្រាប់អប់ទឹក ដើម្បីប្រយោជន៍ដល់ការអប់ហើយ ក៏ឲ្យយកស្លឹកចេកគ្រប ដោយហេតុនោះ ទើបលោកពោលថា ភាជន៍ទឹកបានតម្កល់ហើយ ។*

បទថា **តេលប្បទីបំ អារោបេត្វា** *សេចក្តីថា ឲ្យដុតប្រទីបដែលធ្វើអំពីប្រេងសម្រេចដោយមាស និងប្រាក់ជាដើមក្នុងដៃរបស់រូបទាហាន និងរូបដែលឆ្លាក់ស្អាតជាដើម ដោយគប់ភ្លើងដែលមានជង សម្រេចដោយមាស និងប្រាក់ ។ ក្នុងពាក្យថា* **យេន ភគវា តេនុបសង្កមីសុ** *នេះ មានវិនិច្ឆ័យដូច្នេះ ឧបាសកអ្នកបាជលិគ្រាមទាំងនោះ មិនមែនចាត់ចែងតែអាវាសថាគារតែម្យ៉ាង*

ប៉ុណ្ណោះទេ ដោយពិត នៅរៀបចំវិថីក្នុងស្រុកទាំងមូលហើយ ហើយលើកទង់ទ្បើង តម្កល់កុម្ភទឹកដែលពេញ និងដើមចេកត្រង់ទ្វារស្រុក ឲ្យស្រុកទាំងមូល ដូចដេរដាសទៅដោយពួកផ្កាយ ដោយប្រទីប ឲ្យវាយស្គរ ប្រកាសថា ចូរឲ្យក្មេងដែលមិនទាន់ជាប់ដោះ ថ្មដោះ ឲ្យក្មេងធំៗ បរិភោគ ហើយចូលដេក កុំមានសំឡេងអឺងកង ថ្ងៃនេះ ព្រះសាស្តាប្រថាប់នៅក្នុងស្រុកមួយរាត្រី ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់មានបំណងទីដែលមានសំឡេងតិចដូច្នេះហើយ កាន់គប់ភ្លើងចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។

បទថា **អថ ខោ ភគវា បុព្ពណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន អាវសថាគារំ តេនុបសង្កមិ** *សេចក្តីថា បានឮថា កាលពួកអ្នកបាជលិគ្រាមទាំងនោះក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់សម្គាល់កាលដ៏សមគួរក្នុងឥឡូវនេះចុះ ព្រះមានព្រះភាគទ្រង់រៀបចំសំពត់ដែលជ្រលក់ហើយ ២ ជាន់ មានពណ៌ដូចផ្ការលួសផ្នង្រហម ដែលជ្រលក់ដោយទឹកមូត បិទបាំងដោយមណ្ឌល ៣ ដូចយកកន្ត្រៃកាត់ផ្តាំឈូក ទ្រង់ចងវត្តពន្ធចង្កេះ ដែលល្អដូចផ្ទៃកបន្ទោរ ដូចយកសង្ឃាដិមាសព័ទ្ធផ្តាបទុម ទ្រង់ដណ្តប់សំពត់បង្សុកូលចីវរដ៏ឧត្តមដែលជ្រលក់ល្អហើយ មានពណ៌ប្រៀបដូចដើមជ្រៃដែលទ្រង់កាន់យក ធ្វើក្តុំកណ្តាប់ចក្រវាល ក្តុំសិនេរុ ក្តុំយុគន្ធរ និងមហាប្រឹថពីទាំងមូលឲ្យញាប់ញ័រ ដូចយកសំពត់កម្ពលដណ្តប់ពោងដ៏រដូចរាយសំណាញ់កែវប្រពាល ត្រង់សសរមាសកម្ពស់ប្រមាណ ១០០ ហត្ថ ដូចដណ្តប់សំពត់កម្ពលក្រហម ត្រង់មហាសុវណ្ណចេតិយ ដូចពពកក្រហម*

បិទបាំងព្រះចន្ទក្នុងថ្ងៃពេញបូណ៌ ដែលកំពុងគោចរ ដូចស្រោចទឹកល័ខ លើកំពូលភ្នំមាស និងដូចយកសំណាញ់ផ្ទេកបន្ទោរ ព័ទ្ធកំពូលភ្នំចិត្រកូដ យាងចេញអំពីមណ្ឌបមាស ដែលទ្រង់ប្រថាប់គង់ ដូចព្រះចន្ទពេញវង់ និងដូចព្រះសុរិយោទ័យជះពន្លឺស្រទន់អំពីកំពូលភ្នំដោយជុំវិញ ដូចកេសរសីហៈចេញពីជងព្រៃ ។

លំដាប់នោះឯង រស្មីផ្សាយចេញអំពីព្រះកាយរបស់ទ្រង់ ដូចផ្ទេកបន្ទោរដែលវាសចេញអំពីស្រទាប់ពពក ហើយជះទៅលើដើមឈើ ដូចស្រោចដោយទឹកមាស ត្រង់ស្លឹក ផ្កា ផ្លែ មែក និងប្រគាប ដែលមានពណ៌លឿងដោយការស្រោចស្រព ។ ខណៈនោះឯង មហាភិក្ខុសង្ឃកាន់ចាត្រ និងចីវរវៀងៗ ខ្ជួន នាំគ្នាចោមរោមព្រះមានព្រះភាគ ។ ភិក្ខុទាំងនោះដែលឈរចោមរោមព្រះមានព្រះភាគ ដែលជាបុគ្គលដូច្នោះ គឺជាអ្នកប្រាថ្នាតិច សន្តោសស្ងាត់ មិនច្រឡូកច្រឡំដោយពួកគណៈដែលប្រារព្ធព្យាយាម ដែលជាអ្នកពោលប្រៀនប្រដៅ ជាអ្នកអត់ធន់ចំពោះពាក្យសម្តីដែលពោលជាសំតៀន ជាអ្នកតិះដៀលនូវបាប សម្បូរដោយសីល សមាធិ បញ្ញា វិមុត្តិ និងសម្បូរដោយវិមុត្តិញ្ញាណទស្សនៈ ។ ព្រះមានព្រះភាគ កាលភិក្ខុទាំងនោះចោមរោមហើយ រុងរឿងដូចមាស ដែលព័ទ្ធដោយសំពត់កម្ពលក្រហម ដូចព្រះចន្ទពេញវង់ ចោមរោមទៅដោយពួកផ្កាយ ដូចនាវាមាសនៅក្នុងគុម្ពឈូកក្រហម និងដូចប្រាសាទមាស ដែលព័ទ្ធទៅដោយវេទិកាវិចិត្រដោយកែវប្រពាល ។ ឯព្រះមហាថេរៈ មានព្រះមហាកស្សបៈជាប្រធាន ដែលមានរាគៈខ្ជាក់ចោល

ហើយ ដែលទម្លាយកិលេសហើយ ឆ្ការនូវកិលេស ដូចព្រៃស្តុក កាត់កិលេស ជាគ្រឿងចងបានហើយ មិនជាប់នៅក្នុងត្រកូល ឬគណៈ ដណ្តប់សំពត់បង្សុ-កូលចីវរ មានពណ៌ដូចពពក នាំគ្នាចោមរោម ដូចស្តេចដំរីពាក់នូវក្រោះកែវមណី ដូច្នោះ ។ ព្រះមានព្រះភាគ ទ្រង់ប្រាសចាកវាគៈ ដែលបុគ្គលប្រាសចាកវាគៈចោមរោម ទ្រង់ជាអ្នកប្រាសចាកទោសៈ ដែលបុគ្គលប្រាសចាកទោសៈចោមរោម ទ្រង់ជាអ្នកប្រាសចាកមោហៈ ដែលបុគ្គលប្រាសចាកមោហៈចោមរោម ទ្រង់ជាអ្នកប្រាសចាកតណ្ហា ដែលបុគ្គលប្រាសចាកតណ្ហាចោមរោម ទ្រង់ជាអ្នកប្រាសចាកកិលេស ដែលបុគ្គលប្រាសចាកកិលេសចោមរោម ទ្រង់ជាអ្នកត្រាស់ដឹងឯងហើយ ដែលបុគ្គលត្រាស់ដឹងតាមចោមរោម ដូចកេសរចោមរោមដោយត្របក ដូចសំណុំនៃផ្កាចោមរោមដោយកេសរ ដូចស្តេចដំរីឆទ្ទន្តចោមរោមដោយដំរី ៨០០០ ដូចស្តេចហង្សរាជតរដ្ឋៈចោមរោមដោយហង្ស ៩០០០០ ដូចស្តេចចក្រពត្តិចោមរោមដោយអង្គនៃសេនា ដូចសក្កទេវរាជចោមរោមដោយទេវតា ដូចហារិតមហាព្រហ្មចោមរោមដោយពួកព្រហ្ម ដូចព្រះចន្ទពេញវង់ចោមរោមដោយពួកផ្កាយ ទ្រង់យាងទៅតាមមាគ៌ាឆ្ពោះទៅកាន់បាដលិគ្រាម ដោយភេទជាព្រះពុទ្ធ ដែលមិនមានអ្វីប្រៀបដោយពុទ្ធវិលាស មិនមានប្រមាណ ។

លំដាប់នោះ ព្រះពុទ្ធរស្មីដ៏ក្រាស់ មានពណ៌ដូចមាស ផ្សាយចេញអំពីព្រះកាយខាងមុខរបស់ព្រះមានព្រះភាគអង្គនោះ រហូត ៨០ ហត្ថ ព្រះពុទ្ធ-រស្មី មានពណ៌ដូចមាស ផ្សាយចេញអំពីព្រះវរកាយខាងក្រោយ អំពីចំហៀង

ខាងស្តាំ អំពីចំហៀងខាងឆ្វេង ប្រមាណ ៨០ ហត្ថ ។ ព្រះពុទ្ធរស្មី មានពណ៌ខៀវចាស់ ដូចពណ៌ដែលចេញអំពីកសត្វក្ងោក ផ្សាយចេញអំពីផ្នងសក់ទាំងអស់ តាំងអំពីចុងសក់ខាងលើ អស់ទីប្រមាណ ៨០ ហត្ថ ក្នុងអាកាស រស្មីមានពណ៌ដូចកែវប្រពាល ផ្សាយចេញអំពីយុគលបាទទៅក្រោម អស់ទីប្រមាណ ៨០ ហត្ថ ក្នុងផែនដី ។ ព្រះពុទ្ធរស្មីពណ៌ស ផ្សាយចេញអំពីព្រះទន្ត ចេញអំពីព្រះនេត្រដែលមានពណ៌ស ចេញអំពីក្រចកដែលផុតចាកស្បែក និងសាច់ អស់ទីប្រមាណ ៨០ ហត្ថ ព្រះរស្មីមានពណ៌ហង្សបាទ ផ្សាយចេញអំពីទីដែលមានពណ៌ក្រហម ពណ៌លឿងលាយគ្នា អស់ទីប្រមាណ ៨០ ហត្ថ ។ រស្មីពណ៌ផ្កែកផ្សាយទៅឆ្ងាយ មានប្រយោជន៍ជាងគេទាំងអស់ ។ ព្រះពុទ្ធរស្មីមានពណ៌ ៦ ធ្វើទីប្រមាណ ៨០ ហត្ថ ដោយជុំវិញយ៉ាងនេះ ឲ្យរុងរឿងផ្សាយឆ្ងៀលឆ្ងាត់ ផ្សាយទៅកាន់ទិសតូច-ធំ ដូចអណ្តាតប្រទីបធំ ផ្សាយចេញអំពីគប់ភ្លើង ដែលមានជង្ងឹវិចិត្រដោយមាស ទៅកាន់អាកាស ដូចផ្កែកបន្ទោរចេញអំពីស្រទាប់ពពក ក្នុងទីបទាំង ៤ ជាហេតុឲ្យចំណែកនៃទិសទាំងពួងរុងរឿង ដូចរាយដោយផ្កាចម្ប៉ាមាស ដូចយកទឹកមាសចាក់ចេញអំពីក្អមមាស ដូចក្រាលដោយបន្ទះមាស ដែលផ្សាយចេញទៅ ហាក់ដូចដេរដាសដោយលម្អិតនៃផ្កាចារ និងផ្កាកណិការ និងផ្កាឈូសផ្ងន ដែលផ្សាយទៀងដោយខ្យល់កំបុតត្បូង ដូចជ្រលក់ដោយលម្អិតល័ខ ។ ពិតហើយ ព្រះរូបរបស់ព្រះសាស្តា រុងរឿងដោយអនុព្យញ្ជនៈ ៨០ និងរស្មីមួយព្យាមដោយជុំវិញ ប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ដែលជ្រុសចាកគ្រឿង

សៅហ្មង មានប្រជ្រុយអាចម៍រុយជាដើម រុងរឿងដូចអាកាស ដែលភ្លឺដោយពួកផ្កាយ ដូចគុម្ពឈូកដែលរីក ដូចដើមបារិច្ឆត្តកៈ កម្ពស់ ១០០ យោជន៍ រីកស្គុសស្គាយ ដូចគ្របសង្កត់នូវសិរីរបស់ព្រះចន្ទ ៣២ ដួង របស់ព្រះអាទិត្យ ៣២ ដួង របស់ស្តេចចក្រពត្តិ ៣២ របស់ទេវរាជ ៣២ របស់មហាព្រហ្ម ៣២ ដែលតម្រៀបគ្នាជាលំដាប់ ដែលប្រដាប់ដោយភាពជាបុគ្គលមានបារមី ៣០ ដែល ទ្រង់បំពេញមកដោយប្រពៃ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ កើតឡើងដោយការបំពេញទាន ដោយការរក្សាសីល ដោយការបំពេញកល្យាណធម៌អស់ ៤ អសង្ខ្យេយ្យ និងមួយសែនកប្ប ប្រជុំចុះក្នុង ១ អត្តភាព កាលមិនបានឱកាសដែលនឹងឲ្យផល ហាក់ដូចជាដល់នូវការចង្អៀត ដូចលើកយកបរស់ក្នុងទូក ១០០០ ដាក់លើទូក ១ ដូចលើកបរស់ក្នុងរទេះ ១០០០ ដាក់ លើរទេះ ១ និងដូចស្ទឹងគង្គា ២៥ ខ្សែ ហូរមកជួបគ្នាតែ ១ ដូច្នោះ ។

គប់ភ្លើងច្រើនពាន់ផុសឡើងចំពោះព្រះកន្ត្រៃរបស់ព្រះសាស្តា ដែលកំពុងភ្លឺដោយពុទ្ធរស្មី ទាំងខាងក្រោយ ខាងឆ្វេង ខាងស្តាំក៏ដូចគ្នា ។ ផ្កាម្ទិះ ផ្កាចម្ប៉ា ផ្កាម្ទិះរួត ឧប្បលក្រហម ឧប្បលខៀវ ផ្កាពិកុល ផ្កាសិន្ទុវារជាដើម និងលម្អិតគ្រឿងក្រអូប មានពណ៌ខៀវ និងពណ៌លឿងជាដើម តម្រៀបគ្នាដូចគ្រាប់ភ្លៀង ដែលប្រាសចាកពពកទាំង ៤ ទិស សំឡេងរងំនៃតន្ត្រីមានអង្គ ៥ និងសំឡេងរងំ ទាក់ទងដោយពុទ្ធគុណ ធម្មគុណ និងសង្ឃគុណ លាន់ឮគ្រប់ទិស ភ្នែករបស់របស់ទេវតា គ្រុឌ នាគ យក្ខ គន្ធព្វ និងមនុស្ស ហាក់

ដូចបានផឹកទឹកអម្រឹត ។ ក្នុងទីនេះ គួរនឹងពោលសរសើរការយោងទៅដោយ ពាន់បទ ។ តែក្នុងទីនេះ មានមុខបាឋៈដូចតទៅនេះ

ព្រះលោកនាយក នាំលោកទៅដោយវិសេស សម្បូរដោយ សីរសពិង្គកាយយ៉ាងនេះ ជាអ្នកធ្វើផែនដីឲ្យញាប់ញ័រ ជា អ្នកមិនបៀតបៀនពួកសត្វ ទ្រង់យាងទៅ ។ ព្រះនរាសភៈ ទ្រង់លើកព្រះបាទស្តាំឡើងមុន ជាអ្នកដល់ព្រមដោយសិរី ទ្រង់ឧត្តមជាងសត្វជើង ២ យាងទៅល្អ ផ្ទៃព្រះបាទខាង ក្រោមរបស់ព្រះពុទ្ធដ៏ប្រសើរ ដែលទ្រង់យាងទៅ ទន់ ពាល់ ត្រូវផែនដីដ៏ស្មើ មិនប្រឡាក់ដោយធូលី ។ សូម្បីផែនដីដែល មិនមានចិត្ត កាលព្រះលោកនាយកយាងទៅ ទីដែលទំនាប រមែងប៉ោងឡើង ទីដែលប៉ោងឡើងក៏ស្មើ ។ កាលព្រះលោក-នាយកយាងទៅ មាគ៌ាទាំងអស់ប្រាសចាកថ្ម ដុំក្រួស អំបែង ដង្គត់ និងបន្លា ។ មិនលើកព្រះបាទក្នុងទីធ្លាយពេក មិនជាក់ ព្រះបាទក្នុងទីជិតពេក ព្រះជានុ និង-កព្រះបាទទាំង ២ មិន សង្កៀតគ្នា យាងទៅ ។ ព្រះមុនី មានព្រះដំណើរដល់ព្រម មានព្រះហឫទ័យតាំងមាំ កាលយាងទៅ ក៏មិនប្រញាប់ពេក និងមិនយឺតពេក ។ ទ្រង់យាងទៅ មិនបានទតមើលខាងលើ ខាងក្រោម ខាងទទឹង ទិសតូច-ធំ ក៏ដូចគ្នា ទ្រង់ទតត្រឹម មួយជួរនឹម ។ ព្រះជិនស្រីអង្គនោះ ទ្រង់មានពុទ្ធលីលា ដូច

ស្តេចដំរី ល្វាស់ល្វន់ក្នុងការយាងទៅ ទ្រង់ជាអគ្គបុគ្គលក្នុងលោក ទ្រង់យាងទៅល្អ ធ្វើលោក ព្រមទាំងទេវលោក ឲ្យត្រេកអរ ។ ទ្រង់រុងរឿងដូចស្តេចឧសភ: ដូចកេសរសីហ: មានការដើរដ៏រុងរឿង ទ្រង់ញ្ចាំងពួកសត្វជាច្រើនឲ្យត្រេកអរ យាងដល់ស្រុកដ៏ប្រសើរ ។ នេះឈ្មោះថា ជាពេលសរសើរ ។ កម្មាំងរបស់ធម្មកថិកប៉ុណ្ណោះ ជាប្រមាណក្នុងការសរសើរព្រះរូប និងសរសើរព្រះគុណរបស់ព្រះសាស្តា ក្នុងកាលទាំងឡាយយ៉ាងនេះ ។ ដោយចុរណីយបទដែលចងជាគាថាគួរនឹងពោលតាមដែលអាច មិនគួរនឹងពោលថា ពោលបានលំបាក ឬពោលឧសរបៀប ។ ពិតហើយ សូម្បីព្រះពុទ្ធទាំងឡាយ ក៏មិនអាចពោលគុណរបស់ព្រះពុទ្ធដែលមានគុណប្រមាណមិនបាន ដោយឥតសេសសល់ ព្រោះកាលសរសើរព្រះគុណអស់ ១ កប្ប ក៏មិនអាចឲ្យព្រះគុណអស់បាន នឹងពោលថ្វី ដល់ពួកសត្វក្រៅអំពីនេះ ។

ព្រះមានព្រះភាគ ប្រដាប់ដោយព្រះសិរីវិលាសនេះ យាងចូលទៅកាន់បាដលិគ្រាម ដែលពួកជនមានចិត្តជ្រះថ្លា បូជាដោយសក្ការ: មានផ្កា គ្រឿងក្រអូប ធូមគន្ធ និងលម្អិតសម្រាប់អប់ជាដើម យាងចូលទៅកាន់អាវសថាគារ ។ ដោយហេតុនោះ ទើបលោកពោលថា គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ឃ្ពុំចីវរ កាន់បាត្រ និងចីវរ មួយអន្ទើដោយភិក្ខុសង្ឆ ចៀសទៅ

កាន់អាវសថាគារ ដូច្នេះ ។

បទថា **ចាតេ បក្កាលេត្វា** *សេចក្តីថា បើកក់ គឺធូលីមិនប្រឡាក់ព្រះបាទព្រះមានព្រះភាគ ក៏ពិត តែទ្រង់ជ្រាបថ្នាសេចក្តីចម្រើនក្រៃលែងនៃត្រកូលរបស់ឧបាសក និងឧបាសិកាទាំងនោះ ទើបទ្រង់លាងព្រះបាទដើម្បីឲ្យជនដទៃកាន់យកជាទិដ្ឋានុគតិ ។ ម្យ៉ាងទៀត ឈ្មោះថា ព្រះសរីរៈដែលមានចិត្តគ្រប់គ្រង ក៏ត្រូវធ្វើឲ្យត្រជាក់ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើនូវការស្រង់ និងលាងព្រះបាទជាដើម ដើម្បីជាប្រយោជន៍នេះឯង ។*

បទថា **ភគវន្តញ្ហេវ បុរក្ខត្វា** *បានដល់ ធ្វើព្រះមានព្រះភាគខាងមុខ សេចក្តីនោះ ព្រះមានព្រះភាគ ទ្រង់ប្រថាប់គង់ក្នុងកណ្តាលនៃភិក្ខុទាំងឡាយ និងនៃឧបាសក ឧបាសិកាទាំងឡាយ ទ្រង់ស្រង់ដោយទឹកក្រអូបហើយ ធ្វើឲ្យទឹកស្អុតដោយសំពត់ហើយ ធ្វើឲ្យស្អុតដោយជាតិហិង្គុ រមែងរុងរឿងក្រៃពេកដូចរូបបដិមាដែលធ្វើដោយមាស ប្រតិស្ឋានលើតាំង ដែលដណ្តប់សំពត់កម្ពលក្រហម ។*

ក្នុងសេចក្តីនេះ ជាបទប្រព័ន្ធ ដែលបុរាណបណ្ឌិតចងដូច្នេះ

> *ព្រះលោកនាថ ជាអគ្គបុគ្គលនៃសត្វលោក ទ្រង់ដូចស្តេចដំរីយាងយាស យាងទៅកាន់មណ្ឌប មានពន្លឺរុងរឿង គង់ប្រថាប់លើបវរពុទ្ធាសនៈ ទ្រង់ដូចនាយសារថីទូន្មាន នរជនជាទេវតាក្រៃលែងជាងទេវតា ជាអ្នកមានបុញ្ញលក្ខណៈរាប់រយ គង់ប្រថាប់លើបវរពុទ្ធាសនៈនោះ រុងរឿងក្នុងកណ្តាល*

ពុទ្ធាសនៈ ដូចជុំមាស រុងរឿងក្នុងសំពត់កម្ពលពណ៌លឿង ដូច្នោះ ។ ទ្រង់ប្រាសចាកមន្ទិល រមែងរុងរឿង ដូចជុំមាស ជម្ពូនុទ ដែលគេដាក់លើសំពត់កម្ពលលឿង ដូចកែវមណីដ៏ រុងរឿង ដូច្នោះ ។ ទ្រង់បរិសុទ្ធ ល្អល្អះជាងវត្ថុទាំងពួង ដូច ដើមមហាសាលព្រឹក្ស មានផ្ការីកស្គុសស្គាយ ដែលប្រដាប់ ដោយស្គេចឈើ ដូចគ្នានឹងប្រាសាទមាស ដូចផ្ការឈូកឈ្មោះ កោកនុទ ដូចដើមឈើដែលលម្អដោយប្រទីបកំពុងឆេះ ដូច ភ្លើងលើកំពូលភ្នំ ដូចបារិច្ឆត្តកៈរបស់ទេវតា ដូច្នោះ ។

[១៧០] បទថា **ចាជលិគ្គាមិកេ ឧចាសកេ អាមន្តេសិ** សេចក្តីថា ព្រោះឧបាសក ឧបាសិកាទាំងនោះជាច្រើនតាំងនៅក្នុងសីល ដូច្នោះ ដើម្បី ប្រកាសទោសនៃសីលវិបត្តិ ជាលំដាប់ដំបូងមុនហើយ ខាងក្រោយ ទើប សម្តែងអានិសង្សនៃសីលសម្បត្តិ ទើបត្រាស់ហៅមក ដើម្បីសម្តែងធម៌ ដោយន័យជាដើមថា **បញ្ចិមេ គហបតយោ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុស្សីលោ** បានដល់ ជាអ្នកមិនមានសីល ។ បទថា **សីលវិប្បន្នោ** បានដល់ ដែលមានសីលវិបត្តិ គឺដែលទម្លាយសំវរៈ។ ក្នុងបទទាំងនេះ ដោយបទថា **ទុស្សីលោ** ត្រាស់ដល់បុគ្គលដែលមិនមាន សីល ។ បុគ្គលដែលមិនមានសីលនោះ មាន ២ យ៉ាង គឺព្រោះមិនសមាទាន ១ ឬទម្លាយសីលដែលសមាទានហើយ ១ ។ ក្នុង ២ យ៉ាងនោះ ប្រការទី ១ មិនមានទោស ដូចប្រការទី ២ ដែលមានទោសច្រើនជាង ។ ដើម្បីនឹងសម្តែង

ការមិនមានសីល ដែលមានទោស តាមដែលបំណងជាហេតុ ដោយទេសនាជាបុគ្គលាធិដ្ឋាន ទើបត្រាស់ពាក្យថា **សីលវិប្បន្នោ** *ដូច្នេះ ។ ដោយហេតុនោះ ទើបទ្រង់សម្តែងអត្ថនៃបទថា* **ទុស្សីលោ** *ដូច្នេះ ។ បទថា* **សមាធាធិការណំ** *បានដល់ មានការប្រមាណជាហេតុ ។*

សូត្រនេះមកហើយ ដោយអំណាចគ្រហស្ថទាំងឡាយ តែបព្វជិតក៏ប្រើបានដូចគ្នា ។ ពិតហើយ គ្រហស្ថចិញ្ចឹមជីវិត ដោយអាស្រ័យសិប្បៈណាជាកសិកម្មក្តី ពាណិជ្ជកម្មក្តី គោរក្ខកម្មក្តី ជាអ្នកប្រមាទដោយបាណាតិបាតជាដើម មិនអាចនឹងញុំាងសេចក្តីព្យាយាមក្នុងសិប្បៈនោះ ឲ្យសម្រេចបានតាមកាលដែលសមគួរ កាលបើដូច្នេះ ការងារបស់បុគ្គលនោះ ក៏នឹងវិនាសទៅ តែកាលបុគ្គលធ្វើបាណាតិបាតជាដើម ក្នុងកាលដែលបុគ្គលនោះអាយាតរមែងដល់នូវការវិនាសចាកភោគៈធំ ដោយអំណាចអាជ្ញា ។ បព្វជិតដែលទ្រុស្តសីល រមែងដល់នូវការវិនាសចាកសីល ចាកព្រះពុទ្ធវចនៈ ចាកឈាន ចាកអរិយធម៌ ៧ ប្រការ ព្រោះសេចក្តីប្រមាទជាហេតុ ។ បទថា **ចាបភោគិកត្តិសទ្ទោ** *សេចក្តីថា កិត្តិសព្ទដ៏លាមករបស់គ្រហស្ថ រមែងផ្សាយខ្ទរខ្ទាយទៅកណ្តាលបរិស័ទ ៤ ថា គ្រហស្ថឈ្មោះនោះ កើតក្នុងត្រកូលឈ្មោះនោះ ជាអ្នកទ្រុស្តសីល ជាអ្នកមានធម៌ដ៏លាមក ជាអ្នកលះលោកនេះ និងលោកខាងមុខ រមែងមិនឲ្យទាន ដោយវត្តុត្រឹមតែសលាកភត្ត ។ កិត្តិសព្ទដ៏លាមករបស់បព្វជិត រមែងផ្សាយខ្ទរខ្ទាយទៅយ៉ាងនេះថា បព្វជិតឈ្មោះនោះ បួសក្នុងសាសនារបស់ព្រះសាស្តា មិនអាចរក្សាសីល មិនអាចរៀនពុទ្ធវចនៈ*

ជាបុគ្គលប្រកបដោយអគារវ: ៦ ចិញ្ចឹមជីវិតដោយអនេសនាកម្ម មានវេជ្ជ-
កម្មជាដើម ។ បទថា **អវិសារធោ** សេចក្តីថា លំដាប់ដំបូង គ្រហស្ថដែល
មានភ័យ ចៀសវាងមិនបាន ចូលទៅក្នុងទីប្រជុំជន ដោយគិតថា បុគ្គលណា
នឹងដឹងកម្មអាក្រក់របស់អញ នឹងនិន្ទា នឹងសង្កត់សង្កិន នឹងចង្អុលបង្ហាញដល់
រាជត្រកូល ជាអ្នកខ្ចាសអៀន ឌ៉ន-ក អង្គុយឌ៉នមុខ ជាអ្នកមិនហ៊ានពោល ។
ឯបព្វជិតដែលមានភ័យ ចៀសវាងមិនបាន ចូលទៅក្នុងកាលភិក្ខុជាច្រើនប្រជុំ
គ្នា ដោយគិតថា បព្វជិតមួយរូប នឹងដឹងកម្មអាក្រក់របស់អញដោយពិត កាល
បើដូច្នេះ ភិក្ខុទាំងឡាយនឹងវៀរឧបោសថកម្មក្តី បវារណាកម្មក្តីរបស់អញ នឹង
ទាញអញ ឲ្យចេញចាកភាពជាសមណ: រមែងជាបុគ្គលមិនក្លាហាន អាចនឹង
ពោលបាន ។ តែបុគ្គលខ្លះដល់នូវភាពជាបុគ្គលទ្រុស្តសីល ក៏រមែងប្រព្រឹត្ត
ដូចអ្នកមានសីល ។ បុគ្គលទ្រុស្តសីលនោះ ក៏រមែងជាអ្នកអៀនខ្ចាស ដោយ
អធ្យាស្រ័យដូចគ្នា ។

បទថា **សម្មុឡ្ហោ កាលំ ករោតិ** សេចក្តីថា ពិតហើយ កាលបុគ្គល
ទ្រុស្តសីលដេកលើគ្រែសម្រាប់ស្លាប់ ឋាន:ដែលខ្ជូនសមាទានកម្ម គឺភាពជា
បុគ្គលទ្រុស្តសីលរមែងមកប្រាកដ បើកភ្នែកឃើញលោកនេះ បិទភ្នែកឃើញ
លោកខាងមុខ អបាយ ៤ រមែងប្រាកដដល់បុគ្គលនោះ តាមសមគួរដល់កម្ម
ជាបុគ្គលដូចត្រូវចាក់ដោយលំពែង ១០០ និងដូចត្រូវរលាកដោយអណ្តាត
ភ្លើង បុគ្គលនោះ រមែងកន្ទក់កន្ទេញថា សូមចុះ សូមបង្អង់ចុះ ដូច្នេះ រហូត
ដល់ស្លាប់ ។ ដោយហេតុនោះ ទើបលោកពោលថា វង្វេងក្នុងកាលធ្វើកាល-

កិរិយា ដូច្នេះជាដើម ។ បទថា **កាយស្ស ភេទា** *បានដល់ ព្រោះលះបង់ខុបាទិន្នកក្ខន្ធ ។*

បទថា **បរម្មរណា** *បានដល់ សំដៅយកខន្ធដែលគប្បីកើតក្នុងភពដែលជាលំដាប់នៃខុបាទិន្នកក្ខន្ធនោះ ។ ម្យ៉ាងទៀត បទថា* **កាយស្ស ភេទា** *បានដល់ ព្រោះជីវិតិន្ទ្រិយដាច់ទៅ ។ បទថា* **បរម្មរណា** *បានដល់ ខាងមុខអំពីចុតិ ។ បទថា* **អថាយំ** *ជាដើម ជាវេវចនៈនៃនរកទាំងអស់ ។ ពិតហើយ នរកឈ្មោះថា* **អថាយ** *ព្រោះច្រាសចាកសេចក្តីចម្រើន ពោល គឺបុណ្យដែលជាហេតុនៃសួគ៌ និងព្រះនិព្វាន និងព្រោះមិនមានសេចក្តីចម្រើន ឬការមកនៃសេចក្តីសុខ ។ ឈ្មោះថា* **ទុគ្គតិ** *ព្រោះជាភូមិជាទីទៅ គឺទីពំនាក់អាស្រ័យនៃទុក្ខ ។ ម្យ៉ាងទៀត ឈ្មោះថា* **ទុគ្គតិ** *ព្រោះជាភូមិជាទីទៅ ដែលកើតដោយកម្មអាក្រក់ ព្រោះច្រើនទៅដោយទោសៈ ឈ្មោះថា* **វិនិបាត** *ព្រោះជាទីច្រាសចាកអំណាចធ្លាក់ទៅរបស់បុគ្គលដែលធ្វើកម្មអាក្រក់ ។ ម្យ៉ាងទៀត ឈ្មោះថា* **វិនិបាត** *ព្រោះជាទីវិនាសធ្លាក់ទៅរបស់បុគ្គលដែលមានអវយវៈតូច-ធំបែកទៅ ឈ្មោះថា* **និរយ** *ព្រោះដែលមិនមានសេចក្តីចម្រើន ដែលហៅថា សេចក្តីត្រេកអរ ។*

ម្យ៉ាងទៀត ដោយសព្ទថា **អបាយ** *ទ្រង់សម្តែងដល់កំណើតសត្វតិរច្ឆាន ។ ពិតហើយ កំណើតសត្វតិរច្ឆាន ឈ្មោះថា* **អបាយ** *ព្រោះច្រាសចាកភូមិជាទីទៅល្អ ចាត់ជាទុគ្គតិ ព្រោះជាទីកើតរបស់ស្តេចនាគជាដើមដែលមានសក្តិធំ ។ ដោយសព្ទថា* **ទុគ្គតិ** *លោកសម្តែងដល់វិសัยនៃប្រេត ។*

ពិតហើយ បិត្តិវិសយនោះ ឈ្មោះថា **អចាយ** *ព្រោះច្រាសចាកសុគតិ និង ឈ្មោះថា* **ទុគ្គតិ** *ព្រោះជាភូមិជាទីទៅនៃទុក្ខ តែមិនចាត់ជាវិនិបាត ព្រោះមិនបានធ្លាក់ទៅដោយឥតអំណាចនៃពួកអសុរ ពិតហើយ សូម្បីវិមាន ក៏រមែងកើតដល់ពួកប្រេតដែលមានឫទ្ធិច្រើន ដោយសព្ទថា* **វិនិបាត** *ទ្រង់សម្តែងដល់អសុរកាយ ។ អសុរកាយនោះ ពោលដោយអត្ថតាមដែលពោលហើយ លោកហៅថា* **អចាយ** *និង* **ទុគ្គតិ** *ហៅថា* **វិនិបាត** *ព្រោះធ្លាក់ទៅដោយឥតអំណាច ចាកគំនរសម្បត្តិទាំងអស់ ។ ដោយសព្ទថា* **និរយ** *ទ្រង់សម្តែងចំពោះនរកដែលមានប្រការច្រើន មានអវីចីជាដើម ។ បទថា* **ឧបបជ្ជតិ** *ប្រែថា រមែងកើតឡើង ។*

គប្បីជ្រាបអានិសង្សកថា ដោយបរិយាយផ្ទុយគ្នា ដូចពោលហើយ ។ ចំណែកការបែកគ្នាមានដូចតទៅនេះ បទថា **សីលវា** *បានដល់ ដែលមានសីល ដោយការសមាទាន ។ បទថា* **សីលសម្បន្នោ** *បានដល់ ដែលសម្បូរដោយសីល ព្រោះញុំាងសីលឲ្យសម្រេច ដោយធ្វើឲ្យបរិសុទ្ធបរិបូណ៌ ។ បទថា* **ភោគក្ខន្ធំ** *បានដល់ គំនរនៃភោគៈ ។ ដោយ* **សុគតិ** *សព្ទ ក្នុងបទថា* **សុគតឺ សគ្គំ លោកំ** *នេះ លោកសង្គ្រោះយកគតិនៃមនុស្សចូលផង ដោយសព្ទថា* **សគ្គ** *លោកសំដៅយកគតិនៃទេវតាចូលផង ។ ក្នុងគតិទាំងនោះ ឈ្មោះថា* **សុគតិ** *ព្រោះមានគតិល្អ ឈ្មោះថា* **សគ្គ** *ព្រោះមានអារម្មណ៍ល្អ មានរូបជាដើម ។ សគ្គៈទាំងអស់នោះ ឈ្មោះថា* **លោក** *ព្រោះអត្ថថា បែកធ្លាយ ។*

[๑๗๑] បទថា **ចាដលិគាមិយេ ឧចាសកេ ពហុទេវ រត្តឹ ធម្មិយា កថាយ** សេចក្តីថា ពោលដោយធម្មកថា និងដោយកថាជាគ្រឿងអនុមោទនា សម្រាប់ទីស្នាក់អាស្រ័យដែលផុតចាកបាលីជនៃ ។

ក្នុងគ្រានោះ ព្រោះហេតុដែលព្រះបាទអជាតសត្រូវ កាលទ្រង់សាងនគរបាដលីបុត្រ ក្នុងទីនោះ ទើបទ្រង់នាំយកកុដុម្ភិកៈដែលសម្បូរដោយសីល និងអាចារ ក្នុងគាមនិគម ជនបទ និងរាជធានីជនៃៗ ហើយប្រទានទ្រព្យធញ្ញាហារត្រង់ស្រុក ត្រង់ស្រែជាដើម និងការគ្រប់គ្រងហើយ ឲ្យនៅអាស្រ័យជួច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងអានិសង្សនៃសីលមុនដល់ឧបាសក ឧបាសិកាអ្នកបាដលិគ្រាម ដែលធ្ងន់ក្នុងសីលដោយពិសេស ព្រោះជាអ្នកឃើញអានិសង្ស និងព្រោះសីលជាទីតាំងនៃគុណទាំងពួង បន្តអំពីនោះ កាលនឹងសម្តែងបកិណ្ណកកថា ដែលនាំមកនូវប្រយោជន៍ និងសេចក្តីសុខដល់ឧបាសក និងឧបាសិកា អ្នកបាដលិគ្រាម ដូចញុំាងអាកាសគង្គាឲ្យឈមចុះ ដូចទាញមកនូវក្រមុំផែនដី ដូចចាប់កំពូលព្រឹងធំឲ្យញាប់ញ័រ និងដូចយកគ្រឿងយន្ត ច្របាច់សម្បកឃ្នុំប្រមាណមួយយោជន៍ ឲ្យសម្រេចជាទឹកឃ្នុំដែលល្អ ទើបទ្រង់សម្តែងធម្មកថាជាច្រើន ដែលវិចិត្រដោយនយផ្សេងៗ យ៉ាងនេះថា ម្នាលគហបតីទាំងឡាយ ធម្មតាអាវាសទាននេះ ជាបុណ្យច្រើនតថាគត និងភិក្ខុសង្ឃ បានប្រើប្រាស់អាវាសរបស់អ្នក កាលតថាគត និងភិក្ខុសង្ឃប្រើប្រាស់ហើយ ក៏ឈ្មោះថា ធម្មវតនៈបានប្រើដូចគ្នា កាលវតនៈ ๓ បានប្រើហើយយ៉ាងនេះ រមែងមានវិបាក មិនមានប្រមាណ ម្យ៉ាងទៀត

កាលថ្វាយអាវាសទាន ក៏ឈ្មោះថា ថ្វាយទានទាំងពួងនោះឯង បុគ្គលឯណា មិនអាចកំណត់អានិសង្សរបស់បណ្ណសាលា ដែលសាងលើផែនដី ឬរបស់សាខាមណ្ឌប ដែលសាងឧទ្ទិសសង្ឃ ក៏ដោយអានុភាពនៃអាវាសទាន សូម្បីសត្វដែលកើតក្នុងកព ក៏ឈ្មោះថា នៅក្នុងគភ៌ដែលត្រូវបៀតបៀនក៏មិនមែនផ្ទៃរបស់មាតានៃសត្វដែលកើតក្នុងគភ៌នោះ នឹងមិនចង្អៀតឡើយ ដូចបន្ទប់ប្រមាណ ១២ ហត្ថ ដូច្នេះហើយ ទើបត្រាស់កថាពោលដោយអានិសង្សនៃអាវាសទាន ជាងកន្លះយោមក្នុងរាត្រីថា

> (វិហារ គឺទីអាវាស ឬសេនាសន:ជាទីនៅនៃសង្ឃទាំង-ឡាយ) រមែងការពាររងាផង ក្តៅផង ម្រឹគសាហាវទាំង-ឡាយផង ពស់តូច ពស់ធំទាំងឡាយផង មូសទាំងឡាយផង ត្រជាក់ទាំងឡាយផង គ្រាប់ភ្លៀងទាំងឡាយផង ខ្យល់និងកម្តៅថ្ងៃដ៏ក្លាខ្លាំងដែលកើតឡើងហើយ រមែងបាត់ទៅវិញ ព្រោះវិហារនោះៗ ។ វិហារទាន គឺការឲ្យលំនៅ (ដែលបុគ្គលបានឲ្យហើយ) ដល់សង្ឃសម្រាប់ជ្រកកោនផង សម្រាប់នៅជាសុខផង ដើម្បីដុតបាបធម៌ផង ដើម្បីចម្រើនវិបស្សនាផង ព្រះពុទ្ធជាម្ចាស់ទាំងឡាយ តែងត្រាស់សរសើរថា ជាអគ្គទាន (ទានដ៏ប្រសើរ) ។ ព្រោះហេតុនោះឯង បុរស (ស្ត្រី) ជាបណ្ឌិត កាលបើបានឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ហើយគប្បីកសាងវិហារ គឺអាវាស ឬ

សេនាសនៈទាំងឡាយ ដ៏ជាទីគួរវេកវាយ ហើយគប្បីនិមន្ត លោក ដែលជាពហូសូត គឺលោកអ្នកចេះដឹងច្រើនទាំង-ឡាយ ឲ្យនៅក្នុងទីនោះ ។ គប្បីមានចិត្តជ្រះថ្លាចំពោះលោកទាំងឡាយ ដែលមានកាយ និងចិត្តត្រង់ ហើយឲ្យម្ហូបចំណីផង ទឹកផង សំពត់ និងសេនាសនៈទាំងឡាយផង ដល់លោកទាំងនោះចុះ ។ លោកទាំងនោះ រមែងសម្តែងធម៌ ជាគ្រឿងបន្ទោបង់សេចក្តីទុក្ខគ្រប់ប្រការដល់អ្នកនោះ លុះអ្នកនោះបានដឹងធម៌ណា ក្នុងព្រះពុទ្ធសាសនានេះហើយ ក៏ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ដូច្នេះឯង ។

សរុបសេចក្តីថា នេះជាអានិសង្សនៃអាវាសទាន ដោយប្រការដូច្នេះ ។ តែក្នុងអានិសង្សអាវាសទាននេះ លោកលើកគាថានេះឯងឡើងកាន់សង្គាយនា ឯបកិណ្ណកធម្មទេសនា មិនបានលើកឡើងកាន់សង្គាយនាឡើយ ។

បទថា **សន្តសេ្សត្វា** *ជាដើម មានអត្ថដូចពោលហើយនោះឯង ។ បទថា* **អភិក្កន្តា** *បានដល់ កន្លងទៅ ២ យាម ។ បទថា* **យស្សទានិ កាលំ មញ្ញថ** *បានដល់ ចូរអ្នកសម្គាល់កាលដែលអ្នកទៅចុះ អធិប្បាយថា នេះជាកាលទៅរបស់អ្នក ចូរអ្នកទៅចុះ ។*

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគបញ្ជូនភិក្ខុទាំងនោះទៅ ។ ឆ្លើយថា ដើម្បីអនុគ្រោះ អធិប្បាយថា ព្រះមានព្រះភាគ ទ្រង់បញ្ជូនទៅដោយសេចក្តីអនុគ្រោះ ២ យ៉ាង គឺកាលភិក្ខុទាំងនោះ អង្គុយក្នុងទីនោះ ឲ្យយាម

៣ នៃរាត្រីកន្លងទៅ អាពាធគប្បីកើតឡើង ក្នុងរាងកាយរបស់ពួកលោក សូម្បីកិក្ខុសង្ឃ ក៏គួរបានឱកាសក្នុងការសិង និងការអង្គុយដែលប្រាសចាកទីវាល ។

បទថា **សុញ្ញាគារំ** បានដល់ ឈ្មោះថា សុញ្ញាគារដោយចំពោះរមែងមិនមានក្នុងទីនោះ ។ បានឮថា គហបតីទាំងនោះបានយកសំពត់វាំងននព័ទ្ធក្នុងចំណែកម្ខាងរបស់អាវសថាគារនោះឯង ហើយឲ្យចាត់ចែងគ្រែដ៏សមគួរ លាតនូវកម្រាលដ៏សមគួរក្នុងទីនោះ ចងពិតាន ដែលប្រដាប់ដោយផ្កាយមាសផ្កាយប្រាក់ គ្រឿងក្រអូប និងផ្កាកម្រងជាដើម លើកប្រទីបប្រេងខាងលើ ដោយគិតថា ធ្វើម្តេចហ្ន៎ ព្រះសាស្តាគប្បីក្រោកចាកធម្មាសនៈ សម្រាកបន្តិចគប្បីផ្ទុំក្នុងទីនេះ កាលបើដូច្នេះ ព្រះមានព្រះភាគទ្រង់នឹងប្រើអាវសថាគារនេះរបស់ពួកយើង ដោយឥរិយាបថ ៤ និងគប្បីប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍និងសេចក្តីសុខអស់កាលយូរ ។ សូម្បីព្រះសាស្តាទ្រង់សំដៅសេចក្តីនោះឯង ទើបទ្រង់ឲ្យរៀបចំក្រាលសំពត់សង្ឃាដីក្នុងទីនោះ រួចទើបសម្រេចសីហ-សេយ្យាសនៈ ដូចលោកពោលថា ទ្រង់ចូលទៅកាន់សុញ្ញាគារ ។ ក្នុងសុញ្ញាគារនោះ ទ្រង់យាងទៅចាប់តាំងអំពីទីលាងព្រះបាទ រហូតដល់ធម្មាសនៈ ការដែលទ្រង់យាងទៅក្នុងទីមានប្រមាណប៉ុណ្ណេះសម្រេចហើយ ទ្រង់ដល់ធម្មាសនៈហើយ ប្រថាប់ឈរបន្តិច នេះជាឥរិយាបថឈរ ក្នុងទីនោះ ទ្រង់ប្រថាប់គង់លើធម្មាសនៈអស់ ២ យាម ឥរិយាបថអង្គុយ ក្នុងទីមានប្រមាណប៉ុណ្ណេះសម្រេចហើយ ទ្រង់បញ្ជូនឧបាសក ឧបាសិកាទាំងឡាយទៅ ហើយ

យាងចុះអំពីធម្មាសនៈ ទ្រង់សម្រេចសីហាសេយ្យនៈ ក្នុងទីដូចពោលហើយ ។ ទីនោះ បានជាទីដែលព្រះមានព្រះភាគទ្រង់ប្រើប្រាស់ហើយ ដោយឥរិយាបថ ៤ ដោយប្រការដូច្នេះ ។

[១៧២] *បទថា* **សុនីធវស្សការា** *បានដល់ ព្រាហ្មណ៍ ២ នាក់ គឺសុនីធព្រាហ្មណ៍ និងវស្សការព្រាហ្មណ៍ ។ បទថា* **មគធមហាមត្តា** *បានដល់ មហាមាត្យនៃព្រះបាទមគធៈ ឬអមាត្យក្នុងដែនមគធៈ ។ ឈ្មោះថា មហាមាត្យ ព្រោះប្រកបដោយហេតុត្រឹមតែជាឥស្សរៈយ៉ាងធំ ។ បទថា* **ចាជលិគ្គាមេ ឧគរំ មាបេន្តិ** *បានដល់ ឲ្យសាងព្រះនគរក្នុងភូមិ ប្រទេស គឺបាជលិគ្រាម ។ បទថា* **វជ្ជីនំ បដិពាហាយ** *បានដល់ ដើម្បីការពារផ្លូវចម្រើនរបស់ពួកស្តេចលិច្ឆវី ។*

បទថា **សហាស្សេវ** *បានដល់ បែងចេញជា ១ ពួក ១ ពាន់ៗ ។ បទថា* **វត្ថូនិ** *បានដល់ ទីសាងផ្ទះ ។ បទថា* **ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ** *សេចក្តីថា ចិត្តនៃបុគ្គលដែលដឹងផ្ទៃដី រមែងបង្អោនទៅ ដើម្បីសាងព្រះរាជនិវេសន៍ និងទីនៅអាស្រ័យរបស់រាជអមាត្យ ។*

បានឮមកថា ជនទាំងនោះ ដឹងផ្ទៃដីប្រមាណ ៣០ ហត្ថខាងក្រោមផែនដី ដោយអានុភាពនៃសិប្បៈរបស់ខ្លួនថា ក្នុងទីនេះ នាគគ្រប់គ្រង ក្នុងទីនេះ យក្ខគ្រប់គ្រង ក្នុងទីនេះ ភូតគ្រប់គ្រង ក្នុងទីនេះ មានដុំថ្ម និងដង្គត់ឈើ ។ ក្នុងកាលនោះ ពួកជនទាំងនោះ ពោលដល់សិប្បៈហើយ ដូចប្រឹក្សាជាមួយពួកទេវតា ទើបសាងទ្បើង ។ ម្យ៉ាងទៀត ពួកទេវតាអាស្រ័យក្នុងរាងកាយនៃ

ជនទាំងនោះ ហើយបង្អោនចិត្តទៅ ដើម្បីសាងនិវេសន៍ក្នុងទីនោះៗ ។ ទេវតាទាំងនោះ ក៏បាត់ទៅក្នុងខណៈដែលពួកជនទាំងនោះ ចោះបង្គោលត្រង់ជ្រុងទាំង ៤ រួចចាប់ចងផែនដី ។ ពួកទេវតាដែលមានសទ្ធារបស់ត្រកូលដែលមានសទ្ធា ក៏រមែងធ្វើយ៉ាងនោះ ។ ទេវតាដែលមិនមានសទ្ធារបស់ត្រកូលដែលមិនមានសទ្ធា ក៏រមែងធ្វើយ៉ាងនោះ ព្រោះហេតុអ្វី ព្រោះទេវតាដែលមានសទ្ធា តែងគិតយ៉ាងនេះថា ពួកមនុស្ស រមែងសាងនិវេសន៍ក្នុងទីនេះ និងនិមន្តឲ្យភិក្ខុសង្ឃអង្គុយមុនហើយ ទើបនិមន្តឲ្យពោលមង្គល កាលបើដូច្នេះ ពួកយើងនឹងបានឃើញអ្នកមានសីល ស្តាប់ធម្មកថា ស្តាប់ការឆ្លើយប្រស្នា និងបានស្តាប់អនុមោទនា ។ ម្យ៉ាងទៀត ពួកមនុស្សឲ្យទានហើយ នឹងឧទ្ទិសចំណែកបុណ្យដល់ពួកយើង ។ ឯទេវតាដែលមិនមានសទ្ធា រមែងមានគំនិតយ៉ាងនេះថា អញនឹងបានឃើញកិច្ចបដិបត្តិរបស់ភិក្ខុទាំងនោះ នឹងបានស្តាប់កថាតាមសមគួរដល់សេចក្តីត្រូវការរបស់ខ្លួន ពួកមនុស្សក៏ធ្វើយ៉ាងនោះដូចគ្នា ។

បទថា **តាវតឹសេហិ** សេចក្តីថា ព្រោះអាស្រ័យមនុស្សដែលជាបណ្ឌិតម្នាក់ក្នុងត្រកូលមួយ និងភិក្ខុដែលជាពហូសូតមួយរូប ក្នុងវិហារមួយ សំឡេងរមែងលាន់ឮទៅថា ពួកមនុស្សក្នុងត្រកូលនោះ ជាបណ្ឌិត ពួកភិក្ខុក្នុងវិហារនោះជាពហូសូត យ៉ាងណា ព្រោះអាស្រ័យសក្កទេវរាជ និងវិស្សកម្មទេវបុត្រ ទើបសំឡេងផ្សាយទៅថា ពួកទេវតាជាន់តាវត្តិង្សជាបណ្ឌិត ដូច្នោះដូចគ្នា ។ ដោយហេតុនោះ ទើបលោកពោលថា **តាវតឹសេហិ** ដូច្នេះជាដើម ។ ដោយ

ពាក្យថា **សេយ្យថាបិ** *ជាដើម ទ្រង់សម្តែងថា សុនីធព្រាហ្មណ៍ និងវស្សការព្រាហ្មណ៍ នាំគ្នាសាងព្រះនគរ ដូចប្រឹក្សាជាមួយពួកទេវតាជាន់តាវត្តិង្ស ។*

បទថា **យាវតា អានន្ទ អរិយំ អាយតនំ** *សេចក្តីថា ឈ្មោះថា ទីដែលជាទីប្រជុំនៃពួកមនុស្សដែលជាអរិយៈ មានប្រមាណប៉ុនណា មាន ។ បទថា* **យាវតា វណិប្បថោ** *បានដល់ ឈ្មោះថា ទីដែលទិញ និងលក់ដោយគំនរទំនិញ ដែលពួកឈ្មួញនាំមក មានប្រមាណប៉ុនណា មាន ឬទីដែលជាទីរស់នៅរបស់ពួកឈ្មួញ មានប្រមាណប៉ុនណា មាន ។ បទថា* **ឥទំ អគ្គនគរំ** *បានដល់ នគរនេះ នឹងជានគរដ៏កំពូល ប្រសើរ ជាប្រធាននៃពួកមនុស្សដែលជាអរិយៈ និងពួកឈ្មួញទាំងនោះ ។ បទថា* **ឫជភេឧនំ** *បានដល់ ជាទីដែលស្រាយ និងខ្ចប់របស់របរ អធិប្បាយថា ជាទីដែលដោះកញ្ចប់ទ្រព្យទាំងឡាយ អធិប្បាយថា ក្នុងទីនេះឯង ពួកជនទាំងនោះ នឹងបានទ្រព្យដែលមិនទាន់បានក្នុងជម្ពូទ្វីបទាំងមូល សូម្បីនឹងទៅលក់ក្នុងទីដទៃ ក៏នឹងទៅលក់ក្នុងទីនោះឯង ព្រោះដូច្នោះ ពួកគេនឹងបែងចែករបស់របរនៅក្នុងទីនោះឯង ។ ស្តានទីប្រមាណ ៥ សែនកន្លែង បានជ្រាកដឡើង ដើម្បីសេចក្តីចម្រើនក្នុងទីនោះរាល់ថ្ងៃយ៉ាងនេះ គឺត្រង់ទ្វារទាំង ៤ មាន ៤ សែនកន្លែង ត្រង់សភា ១ សែនកន្លែង សភាវៈទាំងនោះ លោកសម្តែងថា ជាសេចក្តីចម្រើន ។*

វា *សព្ទ ក្នុងបទថា* **អគ្គិនោ វា** *ជាដើម ជាសមុច្ចយត្ថ អធិប្បាយថា នឹងវិនាសទៅដោយភ្លើង ដោយទឹក និងដោយការបែកមិត្តសម្ពន្ធ ។ ឯក្រុងជាដលិគ្រាមនោះ ចំណែកមួយ នឹងវិនាសទៅដោយភ្លើង សូម្បីពួកមនុស្សក៏*

មិនអាចលត់ភ្លើងបាន ។ ចំណែកមួយ ស្ដឹងគង្គានទីងកួចទៅ ។ ចំណែកមួយ នទីងវិនាសទៅដោយការបែកបាក់គ្នានិងគ្នានៃពួកមនុស្ស ដែលពោលដល់រឿង ដែលមនុស្សនេះមិនពោលដល់មនុស្សនោះ នទីងពោលដល់រឿងមនុស្សនោះ មិនបានពោលដល់រឿងមនុស្សនេះ បែកគ្នាទៅដោយបិសុណាវាចា គឺវាចាញុះញង់ ។

ព្រះមានព្រះភាគ កាលត្រាស់យ៉ាងនេះហើយ ទើបយាងទៅកាន់ច្រាំងស្ដឹងគង្គា ជម្រះព្រះភក្ត្រស្រេចហើយ ប្រថាប់គង់រង់ចាំពេលភិក្ខាចារ ។ ឯសុនីធព្រាហ្មណ៍ និងវស្សការព្រាហ្មណ៍ នាំគ្នាគិតថា ព្រះរាជារបស់ពួកយើងជាឧបដ្ឋាករបស់ព្រះសមណាគោតម ទ្រង់ត្រាស់សួរពួកយើងដែលចូលទៅគាល់ថា បានឮថា ព្រះសាស្ដាយាងចូលទៅកាន់ជាដលិគ្រាម ពួកអ្នកចូលទៅគាល់ទ្រង់ដែរឬ ឬថា មិនចូលទៅគាល់ទេ បើពួកយើងឆ្លើយថា បានចូលទៅគាល់ហើយ នទីងត្រាស់សួរថា ពួកលោកនិមន្ត ឬមិនបាននិមន្ត កាលបើពួកយើងឆ្លើយថា មិនបាននិមន្ត ដូច្នេះ ក៏នទីងលើកទោសរបស់ពួកយើង សូម្បីពួកយើងសាងព្រះនគរនេះក្នុងទីដែលមិនធ្លាប់សាងក៏ពិត ទោះជាដូច្នោះ ពួកសត្វកាឡកណ្ណីក៏នទីងផ្ទាស់ទីកន្លែងទៅ ក្នុងទីដែលព្រះសមណាគោតមយាងទៅដល់ហើយ ពួកយើងនឹងឲ្យព្រះសមណាគោតមនោះ ត្រាស់ភាពជាមង្គលដល់ព្រះនគរ ដូច្នេះ ទើបនាំគ្នាចូលទៅគាល់ព្រះសាស្ដា ទូលនិមន្ត ។ ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ សុនីធវស្សការា** *ដូច្នេះជាដើម ។*

[๑๗๓] *បទថា* **បុព្ពណ្ហសមយំ** *ប្រែថា ក្នុងពេលព្រឹក ។ បទថា*

និវាសេត្វា បានដល់ ទ្រង់គ្រងសំពត់ដោយទំនងយាងចូលស្រុក ហើយចងវត្ថពន្ធចង្កេះ ។ បទថា **បត្តចីវរមាទាយ** បានដល់ ទ្រង់ដណ្តប់ចីវរព្រះហស្តកាន់បាត្រ ។

បទថា **សីលវន្តេត្ត** បានដល់ និមន្តអ្នកមានសីលឲ្យបរិភោគក្នុងប្រទេសនោះ គឺក្នុងលំនៅរបស់ខ្លួន ។ បទថា **សញ្ញតេ** បានដល់ សង្រួមដោយកាយ វាចា និងចិត្ត ។ បទថា **តាសំ ទក្ខិណមាទិសេ** សេចក្តីថា គប្បីខទ្ទិសបច្ចុយ ៤ ដែលថ្វាយដល់សង្ឆ គឺគប្បីឲ្យចំណែកបុណ្យដល់ទេវតាដែលនៅអាស្រ័យក្នុងផ្ទះនោះៗ ។ បទថា **ឃូឌិតា ឃូឌយន្តិ** សេចក្តីថា ធ្វើការរក្សាឲ្យជាការចាត់ចែងដោយល្អ គឺធ្វើការរក្សាដោយល្អ ដោយគិតថា មនុស្សទាំងនេះនឹងបានជាញាតិរបស់ពួកយើងយ៉ាងនោះ ក៏គង់ឲ្យចំណែកបុណ្យដល់ពួកយើង ។ បទថា **មានិតា មានយន្តិ** សេចក្តីថា ទេវតាដែលគេរាប់អាន ដោយការធ្វើពលីកម្មតាមកាលដ៏សមគួរ រមែងរាប់អាន គឺរមែងកម្ចាត់អន្តរាយដែលកើតឡើង ដោយគិតថា មនុស្សទាំងនេះ សូម្បីមិនជាញាតិនៃពួកយើង តែក៏គង់ធ្វើពលីកម្មដល់ពួកយើង អស់កាល ៤-៥ ថ្ងៃ និង ៦ ថ្ងៃ ។ បទថា **តតោ នំ** សេចក្តីថា បន្ទាប់អំពីនោះ រមែងអនុគ្រោះបុរសដែលមានជាតិជាបណ្ឌិតនោះ ។ បទថា **ឧរសំ** បានដល់ ឲ្យធំធាត់ត្រង់ទ្រូង ដូចមាតាអនុគ្រោះបុត្រ ដែលកើតអំពីទ្រូង អធិប្បាយថា រមែងអនុគ្រោះ ដោយព្យាយាមដើម្បីកម្ចាត់អន្តរាយដែលកើតឡើងនោះឯង ។ បទថា **ភទ្រានិ បស្សតិ** បានដល់ រមែងឃើញថា ល្អ ។

[១៧៤] *បទថា* **អនុមោទិត្វា** *សេចក្តីថា ទ្រង់សម្តែងធម្មកថា ដល់មហាមាត្យឈ្មោះសុនីធៈ និងវស្សការៈ ដោយអនុមោទនាចំណែកបុណ្យដែលពួកគេនាំគ្នាខ្វល់ខ្វាយក្នុងកាលនោះ ។ ឯមហាមាត្យ ឈ្មោះសុនីធៈ និងវស្សការៈ បានស្តាប់ព្រះតម្រាស់របស់ព្រះមានព្រះភាគថា គួរឧទ្ទិសទក្ខិណាដល់ទេវតាដែលនៅអាស្រ័យក្នុងទីនោះៗ ទើបបានឲ្យចំណែកបុណ្យដល់ទេវតាទាំងនោះ ។ បទថា* **តំ គោតមទ្វារំ ឥម អហោសិ** *សេចក្តីថា ទ្វាររបស់ព្រះនគរនោះ បានឈ្មោះថា គោតមទ្វារ ព្រោះជាហេតុយាងចេញរបស់ព្រះសាស្តា ម្យ៉ាងទៀត មិនបានឈ្មោះថា* **គោតមតិត្ត** *ព្រោះមិនបានចុះកាន់កំពង់ដើម្បីឆ្លងស្ទឹងគង្គា ។*

បទថា **ឫភា** *ប្រែថា ពេញ ។ បទថា* **សមតិត្តិកា** *បានដល់ ពេញគឺពេញដោយទឹកស្មើច្រាំង ។ បទថា* **កាកបេយ្យា** *បានដល់ មានទឹកដែលល្មមក្អែកទំត្រង់ច្រាំងអាចផឹកបាន ។ ដោយបទទាំង ២ លោកសម្តែងចំពោះទឹកដែលពេញក្នុងច្រាំងទាំង ២ ។ បទថា* **ឧឡុម្បំ** *បានដល់ កម្រងដែលគេយកឈើខ្ចាស់ ហើយបោះស្មៅតទុកដើម្បីឆ្លងច្រាំង ។ បទថា* **កុល្លំ** *បានដល់ ក្បូនដែលគេយកវល្លិចងឫស្សី និងបបុសធ្វើ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងដល់នូវការដែលមហាជន មិនអាចនឹងឆ្លងសូម្បីទឹកក្នុងស្ទឹងគង្គាប៉ុណ្ណោះ តែទ្រង់ និងភិក្ខុសង្ឃឆ្លងអន្លង់ គឺសង្សារដ៏ជ្រៅផង ធំទូលាយពន់ពេកផងបានហើយ ទើបទ្រង់បន្លឺឧទាននេះ ដែលសម្តែងដល់សេចក្តីនោះ ។*

បណ្តាបទទាំងនោះ បទថា **អណ្ណវំ** *នេះ ជាឈ្មោះរបស់ទឹកដែលជ្រៅ និងទទឹងប្រមាណមួយយោជន៍ ដោយកំណត់យ៉ាងទាប ។ បទថា* **សរំ** *លោកបំណងដល់ទឹកក្នុងទីនេះ ព្រោះហូរទៅ ។ លោកអធិប្បាយថា ពួកជនដែលឆ្លងអន្លង់ទឹក គឺសង្សារ និងស្ទឹង គឺតណ្ហា ជ្រៅផង ធំផង ធ្វើស្ពាន គឺអរិយមគ្គ មិនពាល់ត្រូវ គឺមិនប៉ះពាល់កក់ គឺរណ្តៅដែលពេញដោយទឹក ឯជននេះ បំណងនឹងឆ្លង មានប្រមាណតិចនេះ ទើបចងក្បួន គឺព្យាយាមក្រៃលែង ដើម្បីចងក្បួន ។ បទថា* **តិណ្ណា មេធាវិនោ ជនា** *សេចក្តីថា ព្រះពុទ្ធ និងពុទ្ធសាវក ឈ្មោះថា ជាអ្នកមានមេធា ព្រោះប្រកបដោយមេធាពោល គឺអរិយមគ្គញ្ញាណ ទោះបីវៀរបង់នូវក្បួន ក៏ឆ្លងបាន គឺតាំងនៅត្រង់ត្រើយនាយនោះឯង ។*

អដ្ឋកថា ចាជលិគាមិយសូត្រទី ៦ ចប់

សុត្តន្តបិដក

ទ្វិធាបថសូត្រ

[๑๗๔] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់យាងទៅកាន់ផ្លូវឆ្ងាយ ក្នុងដែនកោសល មានព្រះនាគសមាលៈដ៏មានអាយុ ជាបច្ឆាសមណៈ ។ នាគសមាលៈដ៏មានអាយុ បានឃើញផ្លូវបែកជា ២ ត្រង់ចន្លោះផ្លូវ លុះបានឃើញហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា*

បពិត្រព្រះមានព្រះភាគដ៏ចម្រើន នេះផ្លូវ យើងទៅតាមផ្លូវនេះ ។ កាលព្រះនាគសមាល:ដ៏មានអាយុ ក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះនាគសមាល:ដ៏មានអាយុថា ម្នាលនាគសមាល: នេះផ្លូវ យើងទៅតាមផ្លូវនេះវិញ ។ ព្រះនាគសមាល:ដ៏មានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគអស់វារៈ ២ ដងថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន នេះផ្លូវ យើងទៅតាមផ្លូវនេះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះនាគសមាល:ដ៏មានអាយុ អស់វារៈ ២ ដងថា ម្នាលនាគសមាល: នេះផ្លូវ យើងទៅតាមផ្លូវនេះវិញ ។ ព្រះនាគសមាល:ដ៏មានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគអស់វារៈ ៣ ដងថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន នេះផ្លូវ យើងទៅតាមផ្លូវនេះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះនាគសមាល: ដ៏មានអាយុ អស់វារៈ ៣ ដងថា ម្នាលនាគសមាល: នេះផ្លូវ យើងទៅតាមផ្លូវនេះវិញ ។ គ្រានោះ ព្រះនាគសមាល:ដ៏មានអាយុ ដាក់ចោលបាត្រ និងចីវរ របស់ព្រះមានព្រះភាគលើផែនដី ក្នុងផ្លូវនោះឯង ហើយចេញទៅ ដោយពាក្យថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន នេះបាត្រ និងចីវរ ។ លំដាប់នោះ កាលព្រះនាគសមាល:ដ៏មានអាយុ ដើរទៅតាមផ្លូវនោះ ពួកចោរត្រង់ចន្លោះផ្លូវចេញមក ទះទាត់ដោយដៃខ្លះ ជើងខ្លះ ហើយបំបែកបាត្រ ហែកទាំងសង្ឃាដិចោល ។ លំដាប់នោះ ព្រះនាគសមាល:ដ៏មានអាយុ កាលបើបាត្របែក រហែកសង្ឃាដិហើយ ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះនាគសមាល:

ដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គដើរទៅតាមផ្លូវនោះ ពួកចោរត្រង់ចន្លោះផ្លូវស្រាប់តែចេញមក ទះទាត់ដោយដៃខ្លះ ជើងខ្លះ បំបែកទាំងបាត្រ ហែកទាំងសង្ឃាដិចោលអស់ ។ លុះព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> *បុគ្គលអ្នកដល់នូវវេទ គឺមគ្គផល ជាអ្នកចេះដឹង កាលត្រាច់ទៅជាមួយ (នឹងជនពាល) ច្រឡូកច្រឡំដោយជនដទៃ រមែងលះបង់បាបកម្មបាន ដូចសត្វក្រៀលផឹកនូវទឹកដោះស្រស់លះបង់ទឹកស្ងួត ។ សូត្រទី ៧ ។*

អដ្ឋកថា

ទ្វិធាបថសូត្រ

ទ្វិធាបថសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ

[១៧៥] *បទថា* **អទ្ធានមគ្គប្បដិបន្នោ** *បានដល់ ជាអ្នកដើរផ្លូវវែង គឺផ្លូវឆ្ងាយ ។ បទថា* **នាគសមាលេន** *បានដល់ ព្រះថេរៈមានឈ្មោះយ៉ាងនោះ ។ បទថា* **បច្ឆាសមណេន** *បានដល់ ក្នុងកាលនោះ ព្រះថេរៈនេះបានជាឧបដ្ឋាកព្រះមានព្រះភាគ ដោយហេតុនោះ ទើបព្រះមានព្រះភាគយាងដោយមានព្រះនាគសមាលៈជាបច្ឆាសមណៈ ។ ពិតហើយ ក្នុងបឋមពោធិកាល*

ព្រះមានព្រះភាគ មិនមានឧបដ្ឋាកជាប្រចាំអស់កាល ២០ ឆ្នាំ ។ ក្រោយអំពីនោះ រហូតដល់បរិនិព្វាន ព្រះអានន្ទបានឧបដ្ឋាក ដូចស្រមោលអនុលតាមប្រាណ អស់ ២៥ ឆ្នាំ តែកាលនេះ មិនមែនឧបដ្ឋាកជាប្រចាំ ។ ដោយហេតុនោះ ទើបលោកពោលថា **អាយស្មតា នាគសមាលេន បច្ចា-សមណេន** *ដូច្នេះជាដើម ។*

បទថា **ទ្វិធាបថំ** *បានដល់ ផ្លូវបែកជា ២ ។ អាចារ្យពួកខ្លះពោលថា* **ទ្វេធាបថំ** *ដូច្នេះក៏មាន ។*

ព្រះនាគសមាល: ព្រោះខ្លួនស្និទ្ធស្នាលនឹងផ្លូវនោះមកអំពីមុន និងព្រោះសំដៅដល់ផ្លូវនោះ ជាផ្លូវត្រង់ ទើបក្រាបទូលថា បពិត្រព្រះមានព្រះភាគ នេះផ្លូវ ។ ក្នុងកាលនោះ ព្រះមានព្រះភាគទ្រង់ជ្រាបថា ផ្លូវនោះមានអន្តរាយ ទើបមានបំណងយាងទៅផ្លូវដទៃអំពីផ្លូវនោះ ទើបត្រាស់ថា ម្នាលនាគសមាល: នេះផ្លូវ ។ កាលទ្រង់ត្រាស់ថា ផ្លូវនេះមានអន្តរាយ ទើបមិនជឿ ហើយពោលថា បពិត្រព្រះអង្គដ៏ចម្រើន ផ្លូវនោះ មិនមានអន្តរាយឡើយ ការដែលព្រះនាគសមាល:មិនជឿ ហើយទូលយ៉ាងនោះ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរ ព្រោះហេតុនោះ ទើបទ្រង់មិនត្រាស់ថា មានអន្តរាយ ។ ព្រះនាគសមាល:ក្រាបទូលអស់ ៣ ដងថា នេះផ្លូវ សូមទ្រង់ទៅផ្លូវនេះចុះ ។ ក្នុងលើកទី ៤ ទើបគិតថា ព្រះសាស្តាមិនប្រាថ្នាយាងទៅផ្លូវនេះ ហើយផ្លូវនេះឯងជាផ្លូវត្រង់ ណ្ហើយចុះ អញនឹងឲ្យជាត្រ និងចីវរដល់ព្រះមានព្រះភាគ ដើរទៅផ្លូវនេះ កាលមិនអាចប្រគល់

ជាត្រ និងចីវរ ក្នុងព្រះហស្តរបស់ព្រះសាស្តា ទើបដាក់ត្រង់ផែនដី ដែលកម្ម របស់ខ្លួនជាផ្លូវនៃទុក្ខជ្រាកដឡើងជាស់តឿន មិនបានអើពើក្នុងព្រះតម្រាស់ របស់ព្រះសាស្តា ទើបចៀសចេញទៅ ។ ដោយហេតុនោះ ទើបលោកពោលថា គ្រានោះឯង ព្រះនាគសមាលៈដ៏អាយុ ដាក់ចោលជាត្រ និងចីវរ របស់ព្រះមានព្រះភាគ លើផែនដី ក្នុងផ្លូវនោះឯង ហើយចេញទៅ ។

បណ្តាបទទាំងនោះ បទថា **ភគវតោ បត្តចីវរំ** *បានដល់ នូវជាត្រ និងចីវរបស់ព្រះមានព្រះភាគ ដែលនៅក្នុងដៃរបស់ខ្លួន ។ បទថា* **តត្ថេវ** *សេចក្តីថា ដាក់ត្រង់ផែនដី គឺលើផែនដី តាមផ្លូវនោះឯង ហើយចៀសចេញទៅ ។ អធិប្បាយថា បពិត្រព្រះមានព្រះភាគ នេះជាត្រ និងចីវររបស់ទ្រង់ បើទ្រង់ជ្រាថ្នា និមន្តយកចុះ បើទ្រង់បំណងយាងទៅចំពោះផ្លូវដែលទ្រង់ជ្រាថ្នា ។ ឯព្រះមានព្រះភាគ ទ្រង់កាន់យកជាត្រ និងចីវររបស់ទ្រង់ ដោយព្រះអង្គឯង យាងទៅកាន់ផ្លូវ តាមដែលទ្រង់បំណង ។*

បទថា **អន្តរាមគ្គេ ចោរា ឯកូមិគ្គា** *សេចក្តីថា បានឮថា ក្នុងកាលនោះ បុរស ៥០០ នាក់ ជាអ្នកលេង មានជាតដៃប្រឡាក់ឈាម ជាអ្នកធ្វើខុសចំពោះព្រះរាជា ចូលទៅកាន់ព្រៃ ចិញ្ចឹមជីវិតដោយចោរកម្ម គិតថា ពួកយើងនឹងស្កាត់ផ្លូវចម្រើនរបស់ព្រះរាជា ដោយភាពជាសត្រូវនឹងគ្នា ដូច្នេះហើយ ទើបចុះជំរំក្នុងព្រៃក្បែរផ្លូវ ។ បុរសទាំងនោះ ឃើញព្រះថេរៈកំពុងដើរទៅ ទើបគិតថា សមណៈនេះ មកផ្លូវនេះ ប្រើប្រាស់ផ្លូវដែលមិនសមគួរប្រើ មិនដឹងថាជារបស់អញ ណ្ហើយចុះ អញនឹងធ្វើឲ្យលោកដឹង ដូច្នេះហើយ ទើង*

ក្រោធ សុះចេញអំពីគុម្ពោតព្រៃ ទាត់ធាក់ព្រះថេរ: ឲ្យដួលចុះ ត្រង់ផែនដីដោយរហ័ស ហើយវាយបាត្រដីរបស់លោក ហែកចីវរឲ្យជាកំណាត់តូច-ធំដោយយល់ឃើញថា បព្វជិត ទើបដោះលែងដោយប្រាប់ថា ពួកខ្ញុំមិនសម្ងាប់លោក តាំងអំពីនេះទៅ ចូរលោកដឹងថា ផ្ទូវនេះមានអន្តរាយ ។ ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ អាយស្មតោ ។បេ។ វិច្ចាលេសុំ** ដូច្នេះជាដើម ។

ព្រះមានព្រះភាគ ទ្រង់ជ្រាបថា ព្រះនាគសមាល:នេះ ទៅផ្ទូវនោះ ត្រូវចោរបៀតបៀន ស្វែងរកតថាគត នឹងមកក្នុងឥឡូវនេះឯង ដូច្នេះហើយ យាងទៅបន្តិច គេចចេញអំពីផ្ទូវ គង់ប្រថាប់ត្រង់ដើមឈើមួយ ។ ឯព្រះនាគ-សមាល:វិលត្រឡប់មកកាន់យកផ្ទូវដែលព្រះសាស្តាយាងទៅនោះឯង កំពុងដើរទៅ ជួបព្រះសាស្តាត្រង់គល់ឈើនោះ ទើបចូលទៅគាល់ ថ្វាយបង្គំហើយ ក្រាបទូលរឿងនោះដល់ព្រះសាស្តា ។ ព្រោះហេតុនោះ ទើបលោកពោលថា **អថ ខោ អាយស្មា ឆាគសមាលោ ។បេ។ សផ្ឡាដិញ្ជ វិច្ចាលេសុំ** ជាដើម ។

បទថា **ឯតមត្តំ វិធិត្វា** សេចក្តីថា ទ្រង់ជ្រាបថា ព្រះនាគសមាល:មិនអើពើចំពោះពាក្យរបស់ព្រះអង្គ ហើយដើរទៅកាន់ផ្ទូវដែលមិនផុតភ័យ ទ្រង់ជ្រាបថា ទ្រង់យាងទៅកាន់ផ្ទូវដែលផុតភ័យនេះហើយ ទើបទ្រង់បន្ទឹឧទាននេះសម្តែងសេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **សធ្ទឹ ចរំ** ប្រែថា ត្រាច់ទៅរួមគ្នា ។ បទថា

ឯកគោ វសំ នេះ ជាវេវចនៈនៃបទថា **សទ្ធឹ ចរំ** នោះឯង អធិប្បាយថា នៅរួមគ្នា ។ បទថា **មិស្សេ អញ្ញជនេន វេទគូ** សេចក្តីថា ឈ្មោះថា ដល់នូវវេទ ព្រោះដល់ គឺសម្រេចដោយអរិយមគ្គញ្ញាណ គឺសច្ចៈ ៤ ពោល គឺវេទ ព្រោះអត្ថថា ដែលបុគ្គលគប្បីដឹង ឬព្រោះដល់នូវត្រើយនៃវេទ គឺញេយ្យធម៌ទាំងមូល ។ ឈ្មោះថា បុគ្គលមិនដឹង ព្រោះមិនដឹងវត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍របស់ខ្លួន អធិប្បាយថា បុគ្គលមិនដឹង គឺល្ងង់ខ្លៅ ។ ជាអ្នកច្រឡូកច្រឡំដោយបុគ្គលមិនដឹងនោះ គឺច្របូកច្របល់ដោយត្រឹមតែការត្រាច់ទៅរួមគ្នា ។ បទថា **វិទិត្វា បដិហាតិ ចាបកំ** សេចក្តីថា បុគ្គលដឹង គឺជ្រាបដោយការៈដែលដល់នូវវេទនោះ រមែងលះបង់នូវវត្ថុដែលអាក្រក់ គឺវត្ថុដែលមិនចម្រើន បានដល់ វត្ថុដែលនាំទុក្ខមកឲ្យខ្លួន គឺលះបុគ្គលអាក្រក់ គឺបុគ្គលមិនល្អ ប្រៀបដូចអ្វី ប្រៀបដូចសត្វក្រៀល ផឹកតែទឹកដោះ វៀរទឹក អធិប្បាយថា សត្វក្រៀល កាលបើគេនាំទឹកដោះដែលលាយដោយទឹកចូលទៅ ឈ្មោះថា ផឹកតែទឹកដោះ វៀរទឹក ផឹកតែទឹកដោះប៉ុណ្ណោះ រមែងលះ គឺវៀរនូវទឹក ពោល គឺទឹកដែលហូរទៅកាន់រណ្តៅយ៉ាងណា បានឮថា បណ្ឌិតក៏ដូច្នោះ សូម្បីនៅរួមជាមួយបុគ្គលដែលមានបញ្ញាថោកថយ ក្នុងឥរិយាបថ មានការឈរ និងអង្គុយជាដើម ក៏លះបុគ្គលដែលមានបញ្ញាថោកថយនោះ ដោយអើពើ គឺក្នុងកាលខ្លះ ក៏មិនព្រមនៅច្រឡូកច្រឡំជាមួយនឹងបុគ្គលនោះ ។

អដ្ឋកថា ទ្វិធាបថសូត្រទី ៧ ចប់

សុត្តន្តបិដក

វិសាខាសូត្រ

[១៧៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់លើប្រាសាទ របស់មិគារមាតា ក្នុងបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង ចៅស្រីជាទីស្រឡាញ់ពេញចិត្ត របស់នាងវិសាខាមិគារមាតា ធ្វើមរណកាព ។ គ្រានោះ វិសាខាមិគារមាតា មានសំពត់សើម សក់សើម ចូលទៅគាល់ព្រះមានព្រះភាគទាំងថ្ងៃត្រង់ លុះចូលទៅដល់ ក្រាបថ្វាយបង្គំ ព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលវិសាខា ចុះនាងមកពីណា មានសំពត់សើម សក់សើម ចូលមកក្នុងទីនេះ ទាំងថ្ងៃត្រង់ ។ បពិត្រព្រះអង្គដ៏ចម្រើន ចៅស្រីជាទីស្រឡាញ់ពេញចិត្ត របស់ខ្ញុំព្រះអង្គ ធ្វើមរណកាព ព្រោះហេតុនោះ បានជាខ្ញុំព្រះអង្គ មានសំពត់សើម សក់សើម ចូលមកក្នុងទីនេះ ទាំងថ្ងៃត្រង់ ។ ម្នាលវិសាខា មនុស្សក្នុងក្រុងសាវត្ថី មានចំនួនប៉ុន្មាន នាងចង់បានកូន និងចៅចំនួនប៉ុណ្ណោះឬ ។ បពិត្រព្រះមានព្រះភាគដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថីមានចំនួនប៉ុន្មាន ខ្ញុំព្រះអង្គចង់បានកូន និងចៅចំនួនប៉ុណ្ណោះ ។ ម្នាលវិសាខា ចុះមនុស្សទាំងឡាយ ក្នុងក្រុងសាវត្ថីជាច្រើន តែងធ្វើមរណកាពរាល់ៗ ថ្ងៃប៉ុន្មាននាក់ ។ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណកាពរាល់ៗ ថ្ងៃ ១០ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណកាពរាល់ៗ ថ្ងៃ ៩ នាក់ខ្លះ

បពិត្រព្រះអង្គដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណភាពរាល់ៗ ថ្ងៃ ៨ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណភាពរាល់ៗ ថ្ងៃ ៧ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណភាពរាល់ៗ ថ្ងៃ ៦ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណភាពរាល់ៗ ថ្ងៃ ៥ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណភាពរាល់ៗ ថ្ងៃ ៤ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណភាពរាល់ៗ ថ្ងៃ ៣ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណភាពរាល់ៗ ថ្ងៃ ២ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណភាពរាល់ៗ ថ្ងៃ តែម្នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សក្នុងក្រុងសាវត្ថី ចេះតែធ្វើមរណភាពមិនដែលស្ងាត់ទេ ។ ម្នាលវិសាខា នាងសម្គាល់ហេតុនោះដូចម្តេច ចុះនាងជាអ្នកមានសំពត់សើម សក់សើម ក្នុងកាលម្តងៗ ទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះ មិនមែនដូច្នោះទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ លុមត្រឹមតែកូននឹងចៅច្រើនប៉ុណ្ណោះ ។ ម្នាលវិសាខា បុគ្គលណា មានវត្ថុជាទីស្រឡាញ់ ១០០ បុគ្គលនោះ មានសេចក្តីទុក្ខ ១០០ បុគ្គលណា មានវត្ថុជាទីស្រឡាញ់ ៩០ បុគ្គលនោះ មានសេចក្តីទុក្ខ ៩០ បុគ្គលណា មានវត្ថុជាទីស្រឡាញ់ ៨០ បុគ្គលនោះ មានសេចក្តីទុក្ខ ៨០ បុគ្គលណា មានវត្ថុជាទីស្រឡាញ់ ៧០ បុគ្គលនោះ មានសេចក្តីទុក្ខ ៧០ បុគ្គលណា មានវត្ថុជាទីស្រឡាញ់ ៦០ បុគ្គលនោះ មានសេចក្តីទុក្ខ ៦០ បុគ្គលណា មានវត្ថុ

ជាទីស្រឡាញ់ ៥០ បុគ្គលនោះ មានសេចក្តីទុក្ខ ៥០ បុគ្គលណា មានវត្ថុ
ជាទីស្រឡាញ់ ៤០ បុគ្គលនោះ មានសេចក្តីទុក្ខ ៤០ បុគ្គលណា មានវត្ថុ
ជាទីស្រឡាញ់ ៣០ បុគ្គលនោះ មានសេចក្តីទុក្ខ ៣០ បុគ្គលណា មានវត្ថុ
ជាទីស្រឡាញ់ ២០ បុគ្គលនោះ មានសេចក្តីទុក្ខ ២០ បុគ្គលណា មានវត្ថុ
ជាទីស្រឡាញ់ ១០ បុគ្គលនោះ មានសេចក្តីទុក្ខ ១០ បុគ្គលណា មានវត្ថុ
ជាទីស្រឡាញ់ ៩ បុគ្គលនោះ មានសេចក្តីទុក្ខ ៩ បុគ្គលណា មានវត្ថុជាទី
ស្រឡាញ់ ៨ បុគ្គលនោះ មានសេចក្តីទុក្ខ ៨ បុគ្គលណា មានវត្ថុជាទី
ស្រឡាញ់ ៧ បុគ្គលនោះ មានសេចក្តីទុក្ខ ៧ បុគ្គលណា មានវត្ថុជាទី
ស្រឡាញ់ ៦ បុគ្គលនោះ មានសេចក្តីទុក្ខ ៦ បុគ្គលណា មានវត្ថុជាទី
ស្រឡាញ់ ៥ បុគ្គលនោះ មានសេចក្តីទុក្ខ ៥ បុគ្គលណា មានវត្ថុជាទី
ស្រឡាញ់ ៤ បុគ្គលនោះ មានសេចក្តីទុក្ខ ៤ បុគ្គលណា មានវត្ថុជាទី
ស្រឡាញ់ ៣ បុគ្គលនោះ មានសេចក្តីទុក្ខ ៣ បុគ្គលណា មានវត្ថុជាទី
ស្រឡាញ់ ២ បុគ្គលនោះ មានសេចក្តីទុក្ខ ២ បុគ្គលណា មានវត្ថុជាទី
ស្រឡាញ់ ១ បុគ្គលនោះ មានសេចក្តីទុក្ខ ១ បុគ្គលណា មិនមានវត្ថុ
ជាទីស្រឡាញ់ បុគ្គលនោះ ក៏មិនមានសេចក្តីទុក្ខសោះដែរ ទើបតថាគត
ពោលថា បុគ្គលទាំងនោះ ជាអ្នកមិនមានសោក ជាបុគ្គលប្រាសចាកធូលី
គឺកិលេស ជាអ្នកមិនមានសេចក្តីចង្អៀតចង្អល់ ។ លុះព្រះមានព្រះភាគ ទ្រង់
ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

សេចក្តីសោកក្តី សេចក្តីខ្សឹកខ្សួលក្តី ណាមួយ ឬ សេចក្តីទុក្ខជាច្រើនយ៉ាង ក្នុងលោក ធម៌ទាំងនុ៎ះ រមែងកើតឡើង ព្រោះអាស្រ័យសត្វ និងសង្ខារជាទីស្រឡាញ់ កាលបើមិនមានសត្វ និងសង្ខារ ជាទីស្រឡាញ់ ធម៌ទាំងនុ៎ះ ក៏រមែងមិនមាន ។ ព្រោះហេតុនោះឯង បុគ្គលណា មិនមានសត្វ និងសង្ខារជាទីស្រឡាញ់ក្នុងលោក ណាមួយទេ បុគ្គលនោះ ទើបមានសេចក្តីសុខ ប្រាសចាកសេចក្តីសោក ព្រោះថា បុគ្គលប្រាថ្នាសេចក្តីមិនសោក និងការប្រាសចាកធូលី គឺកិលេស មិនគប្បីធ្វើសត្វ និងសង្ខារឲ្យជាទីស្រឡាញ់ ក្នុងលោកណាមួយឡើយ ។ សូត្រទី៨ ។

អដ្ឋកថា

វិសាខាសូត្រ

វិសាខាសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះថា

[១៧៦] *បទថា* **វិសាខាយ មិគារមាតុយា ឯតទហោសិ** *បានដល់ ក្មេងស្រីដែលជាធីតារបស់កូនប្រុសនៃមហាឧបាសិកា ឈ្មោះវិសាខាស្លាប់ ។*

បានឮថា កុមារីនោះសម្បូរដោយវត្ត ជ្រះថ្លាក្រៃលែងក្នុងព្រះសាសនា ជាអ្នកមិនប្រមាទ បានធ្វើការខ្វល់ខ្វាយដែលខ្លួនគប្បីធ្វើដល់កិកូ និងកិកូនី ទាំងឡាយ ចូលទៅកាន់ស្រុកមហាឧបាសិកា ក្នុងកាលមុនអាហារ និងក្រោយអាហារ បដិបត្តិតាមចិត្តរបស់ជីដូន ។ ដោយហេតុនោះ មហាឧបាសិកា-វិសាខា កាលចេញអំពីផ្ទះទៅខាងក្រៅ បានប្រគល់នាទីទាំងអស់ ដល់កុមារីនោះឯង រួចទើបទៅ កុមារីក៏មានរូបគួរសរសើរ គួរជ្រះថ្លា ដូច្នោះ ទើបនាងជាទីស្រឡាញ់ ជាទីពេញចិត្តដោយពិសេសរបស់មហាឧបាសិកាវិសាខានោះ ។ នាងត្រូវរោគគ្របសង្កត់ ទើបស្លាប់ ។ ដោយហេតុនោះ ទើបលោកពោលថា សម័យនោះឯង ចៅស្រីជាទីស្រឡាញ់ពេញចិត្តរបស់នាងវិសាខាមិគារមាតា ធ្វើមរណកាព ។

លំដាប់នោះ មហាឧបាសិកា កាលមិនអាចអត់សង្កត់សេចក្តីសោក ព្រោះការស្លាប់របស់ចៅស្រីបាន ទើបទោមនស្ស ឲ្យយកសពទៅកប់ ហើយចូលទៅគាល់ព្រះសាស្តា ដោយគិតថា ក្នុងកាលដែលអញទៅគាល់ព្រះសាស្តា

គប្បីបាននូវការត្រេកអរ ។ ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ វិសាខាមិគារមាតា** *ជូរច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **ឯតទវោចុំ** *ប្រែថា ក្នុងវេលាថ្ងៃ អធិប្បាយថា ក្នុងពេលថ្ងៃត្រង់ ។*

ព្រះមានព្រះភាគ កាលទ្រង់ជ្រាបថា នាងវិសាខាត្រេកអរក្រៃលែងក្នុងវដ្តៈ ដើម្បីទ្រង់ធ្វើសេចក្តីសោករបស់នាងឲ្យធូរស្បើយ ដោយឧបាយ ទើបត្រាស់ពាក្យជាដើមថា ម្នាលវិសាខា មនុស្សក្នុងក្រុងសាវត្ថី មានចំនួនប៉ុន្មាន នាងចង់បានកូន និងចៅចំនួនប៉ុណ្ណោះឬ ។

បណ្តាបទទាំងនោះ បទថា **យាវតិកា** *ប្រែថា មានប្រមាណប៉ុនណា ។ បានឮថា ក្នុងកាលនោះ មនុស្ស ៧ កោដិ អាស្រ័យនៅក្នុងក្រុងសាវត្ថី ទើបព្រះមានព្រះភាគត្រាស់សួរថា ម្នាលនាងវិសាខា មនុស្សក្នុងក្រុងសាវត្ថីដែលស្លាប់ទៅរាល់ថ្ងៃ មួយថ្ងៃប៉ុន្មាន ។ ទើបនាងទូលថា មួយថ្ងៃ ១០ នាក់ខ្លះ ជូរច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **តីណិ** *កែជា* **តយោ** *ប្រែថា ៣ នាក់ ម្យ៉ាងទៀត ពាលីក៏យ៉ាងនេះឯង ។ បទថា* **អវិរត្តា** *ប្រែថា មិនទេ ។*

សម័យនោះ ព្រះមានព្រះភាគ កាលប្រកាសបំណងរបស់ទ្រង់ ទើបត្រាស់ថា នាងជាអ្នកមិនមានសំពត់សើម មិនមានសក់សើមក្នុងកាលខ្លះឬ ។ ទ្រង់សម្តែងថា កាលបើជូរច្នោះ កាលនាងវិសាខាត្រូវសេចក្តីសោកគ្របសង្កត់សព្វកាល ទើបនាងមានសក់សើម មានសំពត់សើម ដោយការចុះទឹក ដោយ

ប៉ះនឹងវត្ថុដែលមិនជាមង្គលរបស់កូនជាដើម ដែលស្ទាប់ទៅមិនមែនឬ ។

ឧបាសិកាបានស្តាប់ដូច្នោះហើយ ទើបកើតសេចក្តីសង្វេគ បដិសេធថា មិនមែនដូច្នោះទ្បើយ ព្រះអង្គ ។ ដូច្នេះហើយ ទើបក្រាបទូលថា ចិត្តនៃខ្ញុនត្រឡប់ចាកការក្តៅក្រហាយ ក្នុងវត្ថុជាទីស្រឡាញ់ដល់ព្រះសាស្តា ទើបក្រាបទូលថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថី មានចំនួនប៉ុន្មាន ខ្ញុំព្រះអង្គចង់បានកូន និងចៅចំនួនប៉ុណ្ណោះ ។ លំដាប់នោះ ព្រះសាស្តាកាលទ្រង់សម្តែងធម៌ដល់នាងថា ឈ្មោះថា ទុក្ខនេះ មានវត្ថុជាទីស្រឡាញ់ជាហេតុ របស់ជាទីស្រឡាញ់មានប្រមាណប៉ុនណា ទុក្ខក៏មានប្រមាណប៉ុណ្ណោះ ព្រោះដូច្នោះ បុគ្គលអ្នកស្រឡាញ់សុខ ខ្ពើមទុក្ខ គប្បីឲ្យចិត្តកើតសង្វេគអំពីវត្ថុជាទីស្រឡាញ់ ដោយប្រការទាំងពួង ទើបត្រាស់ពាក្យជាដើមថា ម្នាលវិសាខា បុគ្គលណា មានវត្ថុជាទីស្រឡាញ់ ១០០ បុគ្គលនោះ មានសេចក្តីទុក្ខ ១០០ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សតំ បិយានិ** បានដល់ របស់ទីស្រឡាញ់ ១០០ ។ អាចារ្យពួកខ្ញះពោលថា **សតំ បិយំ** ដូច្នេះក៏មាន ។ ក្នុងពាក្យទាំងនេះ រាប់តាំងអំពី ១ ដល់ ១០ ឈ្មោះថា មានការរាប់ជាប្រធាន ដូច្នោះ ទើបបាលីមកដោយន័យជាដើមថា បុគ្គលណាមានវត្ថុជាទីស្រឡាញ់ ១០ បុគ្គលនោះមានទុក្ខ ១០ តែអាចារ្យពួកខ្ញះពោលដោយន័យជាដើមថា បុគ្គលមានរបស់ជាទីស្រឡាញ់ ១០ បុគ្គលនោះក៏កើតទុក្ខ ១០ ពាក្យនោះ មិនល្អ ។ ព្រោះហេតុដែលរាប់តាំងអំពី ២០ រហូតដល់ ១០០ ឈ្មោះថា មាន

ការរាប់ជាប្រធានដូចគ្នា ។ ដូច្នោះ ព្រោះកាន់យកចំពោះវត្ថុជាទីស្រឡាញ់ ដែលមានការរាប់ជាប្រធាន ក្នុងសេចក្តីនោះ ទើបបាលីមកជាដើមថា **យេសំ ខោ វិសាខេ សតំ បិយានិ សតំ តេសំ ទុក្ខានិ** *ដូច្នេះ ។ បាលីរបស់អាចារ្យទាំងពួងថា ជនទាំងឡាយណា មានវត្ថុជាទីស្រឡាញ់ ១ ជនទាំងនោះក៏មានទុក្ខ ១ ដូច្នេះ តែបាលីថា* **ទុក្ខស្ស** *ដូច្នេះ មិនមាន ។ ក្នុងចំណែកនេះ ទេសនារបស់ព្រះមានព្រះភាគ មានរសតែមួយ ព្រោះដូច្នោះ គប្បីជ្រាបបាលីដែលមានន័យតាមដែលពោលហើយនោះឯង ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងនូវអត្ថនេះថា ទុក្ខតាមផ្លូវចិត្ត និងកាយ មានសោក និងបរិទេវៈជាដើម មានវត្ថុជាទីស្រឡាញ់ជាហេតុ ប្រាកដក្នុងកាល មានវត្ថុជាទីស្រឡាញ់ រមែងមិនប្រាកដក្នុងកាលមិនមានវត្ថុជាទីស្រឡាញ់ ទើបទ្រង់បន្ទឹឧទាននេះ ដែលសម្តែងសេចក្តីនោះ ។*

ពាក្យនៃឧទាននោះ មានអធិប្បាយដូចតទៅនេះ ធម៌ពួកណាមួយ មានលក្ខណៈធ្វើចិត្តនៃបុគ្គលពាល ត្រូវសេចក្តីវិនាសញ្ជាតិ រោគៈ រោគ សីល និងទិដ្ឋិពាល់ត្រូវហើយ ឆេះនៅខាងក្នុង ក្តៅក្រហាយក្តី សេចក្តីសោកប្រកេទណាមួយ តិចតួច និងកណ្តាលជាដើមក្តី ការរៀបរាប់ មានលក្ខណៈរវើរវាយដោយវាចា ដែលសម្តែងដល់សេចក្តីសោក ដែលឲ្យតាំងឡើងនៃជនដែលត្រូវសេចក្តីសោកទាំងនោះឯង ពាល់ត្រូវហើយ ឲ្យតាំងឡើងឡើងក្តី ទុក្ខមានការបៀតបៀនកាយរបស់បុគ្គល ដែលមានកាយត្រូវផោដ្ឋព្វារម្មណ៍ មិន

ជាទីប្រាថ្នាប៉ះខ្ទប់ហើយក្តី ទោមនស្ស និងឧបាយាសជាដើម ដែលកាន់យក ដោយ ៥ សព្ទ ដែលជាវិកប្បត្ថ: ដែលមិនបានអធិប្បាយនោះ ដែលមាន រូបជាអនេក គឺមានបែបផ្សេងៗ គ្នា ដោយការផ្សេងគ្នានៃវិស័យក្តី តែង ប្រាកដ គឺរមែងកើតឡើងក្នុងសត្វលោកនេះ ។ សត្វទាំងអស់នោះ រមែង អាស្រ័យ គឺពឹងផ្អែកសត្វ និងសង្ខារ ដែលជាទីស្រឡាញ់ គឺមានជាតិជាទី ស្រឡាញ់ បានដល់ ធ្វើឲ្យជាបច្ចយកើតឡើង គឺកើតឡើង ។ កាលវត្ថុជាទី ស្រឡាញ់តាមដែលពោលហើយនោះ គឺកាលសត្វ និងសង្ខារជាទីស្រឡាញ់ មិនមាន បានដល់ លះធនូរាគ:ដែលធ្វើនូវភាពជាទីស្រឡាញ់ សេចក្តីសោក ជាដើមនោះ រមែងមិនកើតឡើងក្នុងកាលខ្លះ ។ សមដូចពាក្យលោកពោលថា សេចក្តីសោក កើតអំពីសេចក្តីស្រឡាញ់ ។បេ។ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកអំពីណា ។ ដូចព្រះតម្រាស់ក្នុងសុត្តនិបាតថា

> ការឈ្លោះ ការទាស់ទែងគ្នា ការខ្សឹកខ្សួល ការសោក ស្តាយ និងសេចក្តីកំណាញ់ ការប្រកាន់ ការមើលងាយ និងការញុះញង់ កើតមកអំពីរបស់ជាទីស្រឡាញ់ ឯ កិលេសធម៌ មានការឈ្លោះ និងការជជែកគ្នា (ជាដើម) ប្រកបក្នុងសេចក្តីកំណាញ់ កាលបើសេចក្តីទាស់ទែងគ្នា កើតឡើងហើយ ពាក្យញុះញង់ក៏កើតឡើងដែរ ដូច្នេះ ជាដើម ។

ឥឡូវនេះ លោកពោលដោយលិង្គវិបល្លាសថា **បរិធេវិតា ៥ ធុក្ខា ៥**

ម្យ៉ាងទៀត កាលគួរនឹងពោលថា **បរិនេវិតានិ វា ទុក្ខានិ វា** *ដូច្នេះ គប្បីជ្រាបថា លោកធ្វើការលុបវិភត្តិចោល ។ បទថា* **តស្មា ហិ តេ សុខិនោ វីតសោកា** *សេចក្តីថា ព្រោះសេចក្តីសោកជាដើមដែលកើតអំពីសត្វ និងសង្ខារជាទីស្រឡាញ់ រមែងមិនមានដល់ជនទាំងឡាយណា ដូច្នោះ ជនទាំងនោះឯង ឈ្មោះថា មានសេចក្តីសុខ ប្រាសចាកសេចក្តីសោក ។ បុគ្គលទាំងនោះ គឺអ្នកណា គឺជនដែលមិនមានសត្វ និងសង្ខារជាទីស្រឡាញ់ក្នុងលោកណាមួយ អធិប្បាយថា ជនពួកណា គឺព្រះអរិយៈ រមែងមិនមានសត្វ និងសង្ខារដែលជាទីស្រឡាញ់ គឺការៈជាទីស្រឡាញ់ ជាបុត្រក្តី ជាបងប្អូនប្រុសក្តី បងប្អូនស្រីក្តី ជាភរិយាក្តី មិនមានក្នុងលោកណាឡើយ គឺក្នុងសត្វលោក និងក្នុងសង្ខារលោក ព្រោះប្រាសចាករាគៈ ដោយប្រការទាំងពួង គឺសត្វ និងសង្ខារជាទីស្រឡាញ់ បានដល់ សេចក្តីស្រឡាញ់ មិនមានក្នុងសង្ខារលោកថា នេះជារបស់អញ អញបាន អញនឹងបាននូវសេចក្តីសុខឈ្មោះនេះ ដោយវត្ថុនេះ ។ បទថា* **តស្មា អសោកំ វិរជំ បត្តយានោ បិយំ ន កយិរាថ កុហិញ្ចិ លោកេ** *សេចក្តីថា ព្រោះហេតុដែលសត្វប្រាសចាកសេចក្តីសោក ឈ្មោះថា មានសេចក្តីសុខ ព្រោះប្រាសចាកសេចក្តីសោកនោះឯង ទើបឈ្មោះថា មិនមានសេចក្តីស្រឡាញ់ក្នុងអារម្មណ៍ណាមួយ ព្រោះដូច្នោះ បុគ្គលកាលប្រាថ្នាការមិនសោក គឺការៈមិនមានសេចក្តីសោក ព្រោះមិនមានសេចក្តីសោក ដូចពោលហើយខាងដើម ឈ្មោះថា ប្រាសចាកធូលី គឺការៈដែលមិនមានធូលី ព្រោះប្រាសចាកធូលី គឺរាគៈ បានដល់ ភាពជាអរហត្ត គឺព្រះ*

និព្វាន ដែលបានឈ្មោះថា **អសោក** និងឈ្មោះថា **វិរជ** ព្រោះមិនមានសេចក្តីសោក និងព្រោះហេតុនៃការមិនមានធូលី គឺរាគៈជាដើម ទើបកើតឆន្ទៈដោយអំណាចការពេញចិត្តក្នុងកុសល គឺការប្រាថ្នាដើម្បីធ្វើ មិនគប្បីធ្វើ គឺមិនគប្បីឲ្យសត្វ និងសង្ខារជាទីស្រឡាញ់ គឺសេចក្តីស្រឡាញ់ឲ្យកើតក្នុងធម៌ មានរូបជាដើម ដោយហោចក្នុងធម៌ គឺសមថៈ និងវិបស្សនា ក្នុងលោកណាមួយ ។ សមដូចព្រះតម្រាស់ដែលមានក្នុងមជ្ឈិមនិកាយ មូលបណ្ណាសកៈថា ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ដឹងច្បាស់នូវធម៌ មានឧបមាដូចក្បួនដែលតថាគតសម្តែងហើយ គប្បីលះបង់ធម៌ទាំងឡាយចេញ នឹងចាំបាច់ពោលទៅថ្ងៃដល់អកុសលធម៌ ៗ

អដ្ឋកថាវិសាខាសូត្រទី ៨ ចប់

សុត្តន្តបិដក

បឋមឧព្វសូត្រ

[១៧៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តវេឡុវនកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះទព្វមល្លបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះទព្វមល្លបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគ

ថា បពិត្រព្រះសុគត ឥឡូវនេះ ជាកាលគួរបរិនិព្វាន របស់ខ្ញុំព្រះអង្គ ។ ម្នាលទព្វៈ អ្នកសម្គាល់កាលគួរនឹងបរិនិព្វាន ក្នុងកាលឥឡូវនេះចុះ ។ គ្រានោះ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហោះទៅឯអាកាស អង្គុយពែនភ្នែនក្នុងអាកាសដ៏ស្រឡះ ចូលកាន់តេជោធាតុ ចេញហើយ ទើបបរិនិព្វាន ។ គ្រាកាលព្រះទព្វមល្លបុត្តដ៏មានអាយុ ហោះទៅឯអាកាស អង្គុយពែនភ្នែនក្នុងអាកាសដ៏ស្រឡះ ចូលកាន់តេជោធាតុ ចេញហើយ បរិនិព្វាន សរីរៈ បណ្តាលភ្លើងឆាបឆេះ ទាំងផេះក៏មិនប្រាកដ កម្ទេចធាតុក៏មិនប្រាកដ ដូចសប្បិ ឬប្រេង កាលបើភ្លើងឆាបឆេះ ទាំងផេះក៏មិនប្រាកដកម្ទេចក៏មិនប្រាកដ យ៉ាងណា កាលព្រះទព្វមល្លបុត្តដ៏មានអាយុ ហោះទៅឯអាកាស អង្គុយពែនភ្នែន ក្នុងអាកាសដ៏ស្រឡះ ចូលកាន់តេជោធាតុ ចេញហើយ បរិនិព្វាន សរីរៈ ក៏បណ្តាលភ្លើងឆាបឆេះ ទាំងផេះក៏មិនប្រាកដ កម្ទេចធាតុក៏មិនប្រាកដ យ៉ាងនោះដែរ ។ លំដាប់នោះ ព្រះមានព្រះភាគ ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> *រាងកាយ (របស់ទព្វមល្លបុត្ត) បែកធ្លាយហើយ សញ្ញាក៏រលត់ វេទនាទាំងអស់ ក៏ត្រជាក់ សង្ខារធម៌ទាំងឡាយ ក៏ស្ងប់រម្ងាប់ វិញ្ញាណ ក៏ដល់នូវសេចក្តីវិនាស ។ សូត្រទី ៩ ។*

អដ្ឋកថា

បឋមឧព្ភសូត្រ

បឋមទព្ភសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ

[១៧៧] *បទថា* **អាយស្មា** *បានដល់ ពាក្យដែលជាទីស្រឡាញ់ ។ បទថា* **តញ្ញោ** *បានដល់ ជាឈ្មោះរបស់ព្រះថេរៈនោះ ។ បទថា* **មល្លបុត្តោ** *បានដល់ ឱរសរបស់ស្តេចមល្លៈ ។*

*ពិតហើយ ព្រះថេរៈអង្គនោះបានបំពេញអភិនីហារទៀបបាទមូលរបស់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ បានសាងសន្សំបុណ្យអស់សែនកប្ប កើតហើយក្នុងព្រះគភ៌របស់ព្រះរាជទេវីនៃស្តេចមល្លៈ ក្នុងកាលនៃព្រះដ៏មានព្រះភាគរបស់យើង ក្នុងកាលខ្លួនមានយុ ៧ ឆ្នាំអំពីកំណើត ទើបចូលទៅរកមាតាបិតា សូមអនុញ្ញាតបព្វជ្ជា ព្រោះដោយអំណាចខ្លួនបានសាងបុញ្ញាធិការ ។ ឯមាតាបិតាទាំង ២ នោះ បានអនុញ្ញាតថា នែកូន អ្នកបួសហើយ ចូរសិក្សាក្នុងអាចារៈ បើកូនមិនត្រេកអរក្នុងការសិក្សាអាចារៈនោះ កូនត្រូវត្រឡប់មកទីនេះវិញ ។ ទើបចូលទៅគាល់ព្រះសាស្តា ទូលសូមបព្វជ្ជា ។ ឯព្រះសាស្តាទ្រង់ប្រមើលមើលនូវការសម្បូរនូវឧបនិស្សយរបស់លោកហើយ ទើបទ្រង់អនុញ្ញាតឲ្យបព្វជ្ជា ។ ក្នុងកាលលោកបព្វជ្ជា ភព ៣ ប្រាកដដល់លោក ដូចភ្លើងឆេះ តាមឱកាសដែលព្រះសាស្តាទ្រង់ប្រទានហើយ ។ ទើបលោកផ្តើមតាំងវិបស្សនា សម្រេចអរហត្ត ក្នុងខណៈចុងកាំបិតកោរដល់សីសៈនោះឯង ។ លោកសម្រេចធម៌ណាមួយ ដែលសាវ័កគប្បីសម្រេចទាំងអស់ មានវិជ្ជា ៣

បដិសម្ភិទា ៤ អភិញ្ញា ៦ លោកុត្តរធម៌ ៩ ទើបលោកបានសង្គ្រោះចូលក្នុង បណ្តាមហាសាវក ៨០ រូប ។ សមដូចពាក្យព្រះថេរៈនោះពោលវិនយបិដក មហាវិភង្គថា អញកើតឡើងបាន ៧ ឆ្នាំ បានសម្រេចអរហត្តផល គុណជាត ឯណានីមួយដែលសាវកត្រូវដល់ គុណជាតទាំងអស់ (នោះ) ក៏អញបាន ដល់ដោយលំដាប់ហើយ ដូច្នេះជាដើម ។

បទថា **យេន ភគវា តេនុបសង្កមិ** *សេចក្តីថា បានឮថា ថ្ងៃមួយ ព្រះ ថេរៈអង្គនោះត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ត្រឡប់អំពីបិណ្ឌបាត ខាងក្រោយ សម្តែងវត្តដល់ព្រះមានព្រះភាគ ហើយចូលទៅកាន់ទីសម្រាកពេលថ្ងៃ កាន់ យកទឹកអំពីក្អម លាងជើងទាំង ២ ធ្វើឲ្យខ្លួនត្រជាក់ ក្រាលកំណាត់ស្បែក ហើយអង្គុយកំណត់កាលចូលសមាបត្តិ ។ សម័យនោះ ព្រះថេរៈចេញអំពី សមាបត្តិតាមកាលកំណត់ ហើយប្រមើលមើលអាយុសង្ខារបស់ខ្លួន អាយុ សង្ខារទាំងនោះរបស់លោកអស់ហើយ នៅសល់ត្រឹមតិចតួច លោកគិតថា ការដែលអញមិនលាព្រះសាស្តា សព្រហ្មចារីទាំងឡាយក៏មិនជ្រាប នឹងអង្គុយ បរិនិព្វានក្នុងទីនេះឯង មិនសមគួរដល់អញឡើយ បើដូច្នោះ អញគប្បីចូល ទៅគាល់ព្រះសាស្តា ឲ្យទ្រង់អនុញ្ញាតបរិនិព្វានជាមុនសិន ហើយសម្តែងវត្ត ដល់ព្រះសាស្តា កាលប្រកាសឥទ្ធានុភាពរបស់ខ្លួន ដើម្បីឲ្យដឹងថា ព្រះ សាសនា ជាហេតុនាំសត្វឲ្យចេញចាកទុក្ខ ទើបអង្គុយក្នុងអាកាស ចូល តេជោធាតុ ហើយបរិនិព្វាន កាលបើដូច្នោះ ជនដែលមិនមានសទ្ធា មិន ជ្រះថ្លាក្នុងអញ ក៏នឹងកើតសេចក្តីជ្រះថ្លា សេចក្តីនោះ គប្បីប្រព្រឹត្តទៅដើម្បី*

ជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនទាំងនោះ អស់កាលយូរ ។ ព្រះ ថេរៈអង្គនោះ កាលគិតយ៉ាងនេះហើយ ទើបចូលទៅគាល់ព្រះមានព្រះភាគ បានធ្វើសេចក្តីទាំងអស់នោះ ដោយប្រការនោះឯង ដោយហេតុនោះ ទើប លោកពោលថា គ្រានោះឯង ព្រះទព្វមល្ជបុត្រដ៏មានអាយុ ចូលទៅគាល់ ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយ អង្គុយក្នុងទីសមគួរ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **បរិនិព្វានកាលោ មេ** សេចក្តីថា ព្រះទព្វ-មល្ជបុត្រពោលថា បពិត្រព្រះមានព្រះភាគ កាលជាទីបរិនិព្វានដោយអនុបា-ទិសេសនិព្វានធាតុបានប្រាកដដល់ខ្ញុំព្រះអង្គហើយ ខ្ញុំព្រះអង្គនឹងក្រាបទូល ការបរិនិព្វាននោះ ហើយបរិនិព្វាន ។ តែអាចារ្យពួកខ្ជះពោលថា ព្រះថេរៈ មិនទាន់ចាស់ មិនទាន់ឈឺ លោកទូលលាព្រះសាស្តាដើម្បីបរិនិព្វាន ក្នុង សេចក្តីនោះ មានហេតុដូច្នេះ គឺកាលមេត្តេយ្យភិក្ខុ និងភុម្មជកភិក្ខុ កាលមុន បាននាំគ្នាចោទអញ ដោយអាបត្តិបារាជិកមិនមានមូល កាលអធិករណ៍នោះ ស្ងប់ហើយ ក៏នៅតែជេរនោះឯង ឯបុថុជ្ជនពួកដទៃ ជឿភិក្ខុទាំងនោះ ទើបធ្វើ ការមិនគោរព និងមើលងាយអញ និងព្រោះនាំភារៈ គឺទុក្ខនេះ ដែលឥត ប្រយោជន៍ទៅ នឹងមានប្រយោជន៍អ្វី ព្រោះដូច្នោះ អញនឹងបរិនិព្វានក្នុងកាល ឥឡូវនេះ ព្រះថេរៈធ្វើការសម្រេចចិត្តដូចពោលមកនេះ ទើបទូលលាព្រះ សាស្តា ។ សេចក្តីនោះ មិនជាហេតុ ។ ពិតហើយ ព្រះខីណាស្រពទាំង-ឡាយ បើអាយុសង្ខារមិនទាន់អស់ រមែងមិនគិតព្យាយាមដើម្បីបរិនិព្វាន តែ

ព្រោះខ្លាចអ្នកជនៃប្រទូស្តជាដើម នឹងមិនតាំងនៅបានយូរ ព្រោះអ្នកជនៃសរសៅរជាដើម ។ ដោយពិតនោះ ព្រះខីណាស្រពទាំងនោះរង់ចាំអាយុសង្ខារបស់ខ្លួន មួយអន្ទើដោយកិច្ចរបស់ខ្លួននោះឯង ដូចលោកពោលទុកក្នុងខុទ្ទកនិកាយ ថេរគាថាថា

អាត្មាមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរ
នឹងការរស់នៅ អាត្មារង់ចាំតែកាលនឹងបរិនិព្វាន
ដូចជាអ្នកស៊ីឈ្នួល ទន្ទឹងតែអស់ថ្ងៃ ជូច្នោះ ។

ចំណែកព្រះមានព្រះភាគ ទ្រង់ប្រមើលមើលអាយុសង្ខារបស់លោកជីឯងថា អស់ទៅហើយ ទើបត្រាស់ថា ម្នាលទព្វៈ ចូរអ្នកសម្គាល់កាលគួរចុះ ។ បទថា **វេហាសំ អព្ភុគ្គន្ត្វា** *បានដល់ ហោះឡើងទៅកាន់អាកាស អធិប្បាយថា ទៅក្នុងវេហាស៍ ។ ពិតហើយ បទថា* **វេហាសំ អព្ភុគ្គន្ត្វា** *នេះ ជាទុតិយាវិភត្តិ ព្រោះប្រកបដោយ* **អភិ** *សព្ទ ។ តែគប្បីជ្រាបអត្តដោយអំណាចសត្តមីវិភត្តិ ។ ដើម្បីចៀសវាងពាក្យសួរថា ហោះទៅក្នុងអាកាសធ្វើអ្វី ទើបពោលពាក្យជាដើមថា អង្គុយពត់ភ្លៃនក្នុងអាកាស គឺកណ្តាលវេហាស៍ ជូច្នេះ បណ្តាបទទាំងនោះ បទថា* **តេជោធាតុំ សមាបជ្ជិត្វា** *សេចក្តីថា ចូលចតុត្ថជ្ឈានសមាបត្តិ ដែលមានតេជោកសិណជាអារម្មណ៍ ។*

ពិតហើយ ក្នុងកាលនោះ ព្រះថេរៈថ្វាយបង្គំព្រះសាស្តាហើយ ធ្វើប្រទក្សិណ ៣ ជុំ ឈរក្នុងទីបំផុតនាចំណែកម្ខាង ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនៅក្នុងទីនោះៗ ជាមួយព្រះអង្គ បំពេញមកអស់សែន

កប្ប បំណាងយកប្រយោជន៍នេះប៉ុណ្ណោះ ទើបបានបំពេញប្រយោជន៍នេះដល់ទីបំផុតហើយ ក្នុងថ្ងៃនេះ នេះជាការឃើញចុងក្រោយ ។ ក្នុងបណ្តាភិក្ខុបុថុជ្ជន បុគ្គលជាព្រះសោតាបន្ន និងព្រះសកទាគាមី ពួកខ្លះ មានសេចក្តីកុណាយ៉ាងធំ ពួកខ្លះ ទ្រហោយំ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបវារចិត្តរបស់លោកហើយ ត្រាស់ថា ម្នាលទព្វៈ បើដូច្នោះ ចូរអ្នកសម្តែងឥទ្ធិ-ប្បាដិហារ្យដល់តថាគត និងដល់ភិក្ខុសង្ឃ ។ ក្នុងខណៈនោះឯង ភិក្ខុសង្ឃទាំងអស់ប្រជុំគ្នា ។ លំដាប់នោះ ព្រះទព្វៈសម្តែងបាដិហារ្យទាំងអស់ ដែលទូទៅដល់សាវក ដែលមកដោយន័យជាដើមថា សូម្បីបុគ្គលម្នាក់ ក៏ក្លាយជាច្រើននាក់បាន ដូច្នេះ ថ្វាយបង្គំព្រះមានព្រះភាគ ហោះទៅក្នុងអាកាសនោះឯង និម្មិតផែនដីក្នុងអាកាស អង្គុយពត់ភ្នែនក្នុងអាកាសនោះ ធ្វើបរិកម្មដោយតេជោកសិណសមាបត្តិ ចូលសមាបត្តិ ចេញហើយ ពិចារណាពងកាយ ចូលសមាបត្តិទៀត អធិដ្ឋានតេជោធាតុ ញុំាងកាយឲ្យឆេះ ហើយបរិនិព្វាន ។ មួយអន្ទើដោយការអធិដ្ឋាន ទើបរាងកាយទាំងអស់ត្រូវភ្លើងឆេះ ។ ក្នុងខណៈនោះឯង ភ្លើងនោះ ហាក់ដូចភ្លើងប្រល័យកប្ប ឆេះសង្ខារត្រឹមតែអណុមួយក្តី ត្រឹមតែកំញ្ចរក្តី គ្មានសេសសល់ក្នុងសង្ខារទាំងនោះឡើយ ដោយកម្លាំងនៃអធិដ្ឋាន ហើយបរិនិព្វាន ។ ដោយហេតុនោះ ទើបលោកពោលថា គ្រានោះឯង ព្រះទព្វមល្លបុត្រ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **វុដ្ឋហិត្វា បរិនិព្វាយិ** សេចក្តីថា ចេញចាកចិត្ត ដែលសម្រេចដោយឫទ្ធិ ហើយបរិនិព្វានដោយភវង្គចិត្ត ។ បទថា

ឈាយមានស្ស បានដល់ ដែលភ្លើងកំពុងឆេះ ។ បទថា **ឧយ្ហមានស្ស** នេះ ជាវេវចនៈនៃបទថា **ឈាយមានស្ស** នោះឯង ។ ម្យ៉ាងទៀត បទថា **ឈាយមានស្ស** លោកពោលសំដៅយកខណៈដែលភ្លើងឆេះឡើង ។ បទថា **ឧយ្ហមានស្ស** លោកពោលសំដៅយកខណៈដែលជ្រុសចាករងើក ។ បទថា **ឆារិកា** បានដល់ ផេះ ។ បទថា **មសិ** បានដល់ ធ្យូង ។ បទថា **ន បញ្ញាយិត្ថ** បានដល់ មិនឃើញ អធិប្បាយថា វត្ថុទាំងអស់អន្តរធានទៅក្នុងខណៈនោះឯង ដោយកម្លាំងនៃអធិដ្ឋាន ។

សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈសម្តែងបាដិហារ្យដែលជាឧត្តរិមនុស្សធម៌ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហាមការធ្វើឥទ្ធិប្បាដិហារទុកមិនមែនឬ ។ ឆ្លើយថា សេចក្តីនេះ មិនទាក់ទង ព្រោះទ្រង់ហាមការធ្វើបាដិហារ្យចំពោះមុខគ្រហស្ថទាំងឡាយ ហើយសេចក្តីនោះទ្រង់ហាម ដោយអំណាចការសម្តែងឫទ្ធិផ្សេងៗ មិនត្រាស់ឃាត់ដោយអធិដ្ឋាន ព្រះថេរៈអង្គនោះ ដែលព្រះធម្មសាមីត្រាស់ហើយ ទើបសម្តែងបាដិហារ្យ ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងដល់ព្រះទព្វមល្លបុត្របរិនិព្វាន ដោយអនុបាទិសេសនិព្វាននេះ ទើបទ្រង់បន្ទឹខទាននេះ ដែលសម្តែងសេចក្តីនោះ ។*

បណ្តាបទទាំងនោះ បទថា **អភេទិ កាយោ** *សេចក្តីថា រូបកាយដែលមានសន្តតិ ៤ មានមហាភូតរូប ៤ និងឧបាទាយរូបទាំងអស់បែកទៅ វិនាសទៅ អន្តរធានទៅ ដោយមិនមានសេសសល់ គឺដល់នូវការមិនកើតឡើងជា*

ធម្មតា ។ បទថា **និរោធិ សញ្ញោ** បានដល់ សញ្ញាទាំងអស់ មានរូបសញ្ញា ជាដើម ព្រោះមានរូបាយតនៈជាអារម្មណ៍ និងរលត់ទៅហើយ ដោយការរលត់ដោយឥតសេសសល់ មិនមានបដិសន្ធិ ។ បទថា **វេទនា សីតិភវីសុ សព្វា** បានដល់ វេទនាទាំងអស់ គឺវិបាកវេទនា និងកិរិយាវេទនា បានជាធម្មជាតត្រជាក់ ព្រោះមិនមានសេចក្តីក្រវល់ក្រវាយនៃវេទនា មានប្រមាណប៉ុនអណុមួយ ព្រោះរលត់ឥតសេសសល់ មិនមានបដិសន្ធិ ។ តែកុសល-វេទនា និងអកុសលវេទនាដល់នូវការរលត់មិនមានសេសសល់ក្នុងខណៈនៃអរហត្តផលនោះឯង ។ អាចារ្យពួកខ្លះពោលថា **សីតិរហីសុ** រៀបចាកការត្រជាក់ដូច្នេះក៏មាន អធិប្បាយថា បានជាធម្មជាតស្ងប់ រលត់ទៅ ។ បទថា **រូបសមីសុ សង្ខារា** សេចក្តីថា ធម៌ គឺសង្ខារក្ខន្ធ មានផស្សៈទាំងអស់ ជាដើម ដោយវិបាក និងកិរិយា ស្ងប់ហើយដោយវិសេសនោះឯង ព្រោះរលត់ដោយឥតសេសសល់ ដោយការរលត់មិនមានសេសសល់ មិនមានបដិសន្ធិនោះឯង ។ បទថា **វិញ្ញាណំ អត្ថមាគមា** សេចក្តីថា សូម្បីវិញ្ញាណទាំងអស់ មានវិបាក និងកិរិយា ដល់នូវការតាំងនៅមិនបាន គឺការវិនាស បានដល់ដាច់សូន្យ ព្រោះរលត់ដោយឥតសេសសល់ ដោយមិនមានបដិសន្ធិនោះឯង ។

ដូច្នោះ ព្រះមានព្រះភាគទ្រង់បន្ទឺខុទាន ដែលបន្ទឺចេញដោយកម្លាំងនៃបីតិ ព្រោះអាស្រ័យខន្ធ ៥ របស់ព្រះទព្វមល្លបុត្ររលត់ឥតសេសសល់ ដោយមិនមានបដិសន្ធិ ដូចភ្លើងដែលអស់កំញ្ចឹម ដូច្នោះ ព្រោះរលត់ខុទាន

គឺកិលេស និងអភិសង្ខារក្នុងកាលមុន ដោយឥតសេសសល់ ฯ

អដ្ឋកថា បឋមធម្មសូត្រនី ៩ ចប់

សុត្តន្តបិដក

ខុតិយធម្មសូត្រ

[๑๗๘] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ฯ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ฯ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំង-ឡាយ ฯ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ฯ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលទព្វមល្លបុត្ត ហោះទៅឯអាកាស អង្គុយពែនភ្នែន ក្នុងអាកាសដ៏ស្រឡះ ចូលកាន់តេជោធាតុ ចេញហើយ បរិនិព្វាន សរីរៈ បណ្តាលភ្លើងឆាបឆេះ ទាំងផេះក៏មិនប្រាកដ កមេ្មចធាតុក៏មិនប្រាកដ ដូចសប្បិ ឬប្រេង កាលបើភ្លើងឆាបឆេះ ទាំងផេះក៏មិនប្រាកដ កមេ្មចក៏មិនប្រាកដ យ៉ាងណា ម្នាលភិក្ខុទាំង-ឡាយ កាលទព្វមល្លបុត្ត ហោះទៅឯអាកាស អង្គុយពែនភ្នែន ក្នុងអាកាសដ៏ស្រឡះ ចូលកាន់តេជោធាតុ ចេញហើយ បរិនិព្វាន សរីរៈ ក៏បណ្តាលភ្លើងឆាបឆេះ ទាំងផេះក៏មិនប្រាកដ កមេ្មចធាតុក៏មិនប្រាកដយ៉ាងនោះឯង ฯ លំដាប់នោះ ព្រះមានព្រះភាគ ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺ*

ឧទាននេះ ក្នុងវេលានោះថា

បុគ្គល រមែងមិនដឹងគតិ របស់ភ្លើងកំពុងឆេះ និងដុំដែកដែលគេដំហើយ ដែលរលត់ទៅដោយលំដាប់ យ៉ាងណាមិញ គតិរបស់ពួកលោកអ្នករួចស្រឡះចាកកិលេស ដោយប្រពៃ អ្នកឆ្លងចាកចំណង និងឱឃៈ គឺកាម ដល់នូវសេចក្តីសុខ មិនញាប់ញ័រ រមែងមិនអាចដឹងបាន ក៏យ៉ាងនោះដែរ ។ សូត្រទី ១០ ។

បាដលិគ្គាមិយវគ្គទី ៨ ចប់

ឧទ្ទាននៃវគ្គនោះគឺ

ពោលអំពីព្រះនិព្វាន ៤ លើក អំពីចុន្ទកម្មារបុត្ត ១ អំពីពួកឧបាសកឧបាសិកា អ្នកបាដលិគ្រាម ១ អំពីផ្លូវបែកជាពីរ ១ អំពីនាងវិសាខា ១ ព្រមទាំងព្រះថេរៈទព្វមល្លបុត្តពីរលើកក្នុងជា ១០ ។ ពោធិវគ្គដ៏ប្រសើរ ជាវគ្គទី ១ មុចលិន្ទវគ្គជាវគ្គទី ២ នន្ទកវគ្គដ៏ប្រសើរ ជាវគ្គទី ៣ មេឃិយវគ្គដ៏ប្រសើរ ជាវគ្គទី ៤ សោណត្ថេរ-វគ្គដ៏ប្រសើរ ជាវគ្គទី ៥ ជច្ចន្ធវគ្គដ៏ប្រសើរ ជាវគ្គទី ៦ ចូឡវគ្គដ៏ប្រសើរ ជាវគ្គទី ៧ បាដលិគ្គាមិយវគ្គដ៏ប្រសើរ ជាវគ្គទី ៨ ។ វគ្គទាំង ៨ នេះ មានសូត្រដ៏ប្រសើរ ៨០ មិនខ្វះ ដែលលោកចែកទុកហើយ ដោយប្រពៃមែនពិត ព្រះសូត្រណាដែលព្រះសម្ពុទ្ធប្រាសចាកមន្ទិល មានចក្ខុទ្រង់សម្តែងហើយ បណ្ឌិតទាំងឡាយ អ្នកមាន

សទ្ធា បាននោលព្រះសូត្រនោះ ថាជាឧទាន ។

ឧទាន ចប់

អដ្ឋកថា

ទុតិយឧព្ភសុត្រ

ទុតិយទព្ភសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ

[๑๗๘] *បទថា* **តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ** *សេចក្តីថា ព្រះមានព្រះភាគ កាលប្រថាប់នៅតាមពេញព្រះហឫទ័យក្នុងក្រុងរាជគ្រឹះ កាលទ្រង់ទៅក្នុងជនបទ យាងដល់ក្រុងសាវត្ថីដោយលំដាប់នោះ ប្រថាប់នៅក្នុងវត្តជេតពន ដើម្បីសម្តែងការដែលព្រះទព្ធមល្លបុត្រចូលបរិនិព្វាន ដែលមិនទាន់ប្រចក្ស ឲ្យប្រចក្សដល់ពួកភិក្ខុ និងដើម្បីឲ្យបុថុជ្ជនធ្វើយចាកសេចក្តីគោរពក្នុងព្រះថេរៈ ដោយការពោលទោសរឿងមិនពិត ដែលពួកមេត្តិយភិក្ខុ និងភុម្មជកធ្វើ ឲ្យកើតការរាប់អានច្រើនក្នុងព្រះថេរៈ ទើបត្រាស់ហៅ ។*

បណ្តាបទទាំងនោះ បទថា **តត្រ** *នេះ ត្រឹមតែជានិបាត ប្រើក្នុងអត្ថាឲ្យឃើញច្បាស់តាមពាក្យ ។ សព្ទថា* **ខោ** *ប្រើក្នុងអត្ថា អវធារណៈ ប្រែថាឃាត់នូវសេចក្តីដទៃ ។ បណ្តាបទទាំងនោះ បទថា* **តត្រ** *នេះ ត្រូវបញ្ចាំងអត្ថដែលពោលដល់បទទាំងនេះថា* **ភគវា ភិក្ខូ អាមន្តេសិ** *ព្រះមានព្រះភាគត្រាស់ហៅចំពោះភិក្ខុ ។ ទ្រង់សម្តែងសេចក្តីនេះថា ដោយបទថា* **ខោ** *នេះ*

ទ្រង់ត្រាស់ហៅដូចគ្នា ក្នុងការត្រាស់ហៅ ភិក្ខុមិនមានអន្តរាយណាមួយឡើយ ម្យ៉ាងទៀត បទថា **តត្រ** បានដល់ ក្នុងអាវាសនោះ ។ សព្ទថា **ខោ** ជានិបាតប្រើក្នុងអត្ថថា វចនាលង្ការ គឺអលង្ការរបស់ពាក្យធ្វើឲ្យពីរោះ ។ បទថា **អាមន្តេសិ** ប្រែថា បានត្រាស់ហៅហើយ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ហៅចំពោះភិក្ខុទាំង-ឡាយ ឆ្លើយថា ព្រោះជាបុគ្គលចម្រើន ជាបុគ្គលប្រសើរ ជាបុគ្គលជិត ជាអ្នកមានចិត្តតាំងមាំដោយល្អសព្វកាល ព្រោះជាបុគ្គលទទួលនូវធម្មទេសនាដោយពិសេស ។

បទថា **ភិក្ខវោ** ជាការសម្តែងអាការ គឺការហៅភិក្ខុទាំងនោះ ។ បទថា **ភទន្តេ** ជាបទដែលពួកភិក្ខុត្រូវត្រាស់ហៅ ហើយឆ្លើយតបដល់ព្រះសាស្តាដោយគោរព ។ ព្រះមានព្រះភាគ កាលត្រាស់ហៅ ទើបត្រាស់ហៅភិក្ខុទាំងនោះ ក្នុងបណ្តាពាក្យទាំងនោះ ដោយពាក្យថា **ភិក្ខវោ** ។ ភិក្ខុទាំងនោះ កាលទូលក៏ទូលតបថា **ភទន្តេ** ។ ម្យ៉ាងទៀត ដោយពាក្យថា **ភិក្ខវោ** នេះ ដែលជាព្រះតម្រាស់អាស្រ័យព្រះហឫទ័យដ៏ត្រជាក់ បណ្តាលឲ្យកើតព្រះករុណាជាប្រធាន ព្រះអង្គទ្រង់ឲ្យភិក្ខុទាំងនោះត្រឡប់ចាកមនសិការកម្ម និងពិចារណាធម៌ជាដើមហើយ ឲ្យបែរមុខមករកព្រះអង្គ ។ ដោយពាក្យថា **ភទន្តេ** នេះជាពាក្យសម្តែងដល់ការអើពើ ការរាប់អានច្រើន និងការគោរពក្នុងព្រះសាស្តា ទើបភិក្ខុទាំងនោះ ប្រកាសដល់ភាពដែលខ្លួនជាអ្នកស្តាប់ដោយល្អ និងភាពដែលខ្លួនមានសេចក្តីគោរព ក្នុងការទទួលព្រះឱវាទ ។ បទថា **ភគវតោ**

បច្ចុស្សាសុំ *សេចក្តីថា ភិក្ខុទាំងនោះឆ្លើយតប គឺឲ្យកើតសេចក្តីត្រេកអរដើម្បីស្តាប់ព្រះតម្រាស់របស់ព្រះមានព្រះភាគ ។ បទថា* **ឯតទវោច** *សេចក្តីថា ព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រទាំងអស់នេះ គឺដែលកំពុងពោលក្នុងឥទ្ធរនេះ ។ មានពាក្យជាដើមថា* **ឧញ្ញស្ស ភិក្ខវេ មល្លបុត្តស្ស** *ជួចេះ មានអត្ថដូចពោលក្នុងសូត្រជាប់គ្នានោះឯង ។ សូម្បីក្នុងបទថា* **ឯតមត្ថំ** *ជាដើម មិនមានពាក្យដែលមិនធ្លាប់ពោល គប្បីជ្រាបដោយនយដែលពោលហើយក្នុងសូត្រជាប់គ្នាដូចគ្នា ។*

ក្នុងគាថាទាំងឡាយ មានវិគ្គហៈដូចតទៅនេះ បទថា **អយោឃនហតស្ស** *សេចក្តីថា វត្ថុឈ្មោះថា* **អយោឃន** *ព្រោះជាគ្រឿងវាយដែក បានដល់ ញញួរដែក និងដំបងដែករបស់ពួកជាង ។ នៃភ្លើងដែលត្រូវញញួរដែកនោះវាយ គឺទង្គិច ។ តែអាចារ្យពួកខ្លះអធិប្បាយថា បទថា* **អយោឃនហតស្ស** *បានដល់ វាយដុំដែក ។* **ឯវ** *សព្ទ ក្នុងពាក្យថា* **អយោឃនហតស្ស** *នោះ បានដល់ ភ្លើងដែលឆេះ ។ បទថា* **ជលតោ ជាតវេទសោ** *នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថថា អនាទរ ។ បទថា* **អនុបុព្ពូបសន្តស្ស** *សេចក្តីថា កាលភ្លើងស្ងប់ គឺអស់ បានដល់ រលត់ដោយឥតសេសសល់តាមលំដាប់ ។ បទថា* **យថា ន ញ្ញាយតេ គតិ** *សេចក្តីថា ដូចគតិរបស់ភ្លើងនោះ ជីងមិនបាន លោកអធិប្បាយពាក្យនេះថា កាលភ្លើងត្រូវញញួរដែកធំ និងញញួរដែកតូចជាដើម ប៉ះខូប គឺខូត ឬឆេះជាប់ត្រង់កាជនៈ សំរឹទ្ធជាដើម ម្យ៉ាងទៀត កាលសំឡេងដែលកើតឡើង ក៏យ៉ាងនោះ ស្ងប់*

គឺចូលទៅស្ងប់ដោយល្អ ដោយលំដាប់ គតិរបស់ក្លើង ឬសំឡេង រមែងមិន ប្រាកដក្នុងទីណាមួយឡើយ ក្នុងទិសទាំង ១០ ព្រោះរលត់ឥតសេសសល់ ដោយមិនមានបដិសន្ធិ ដោយការរម្ងត់បច្ចុយ ។ បទថា **ឯវំ សម្មា វិមុត្តានំ** សេចក្តីថា គតិរបស់ព្រះខីណាស្រពទាំងឡាយ ដែលរួចផុតដោយប្រពៃ ព្រោះរួចផុតចាកឧបាទាន ៤ និងអាសវៈ ៤ ដោយប្រពៃ គឺដោយហេតុ ដោយញាយធម៌ បានដល់ ដោយអរិយមគ្គដែលមានតទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិ ជាប្រធានលំដាប់នោះឯងឈ្មោះថា ជាអ្នកឆ្ងងឱឃៈដែលជាគ្រឿងចង គឺកាម ព្រោះឆ្ងងកាមោឃៈ ពោល គឺគ្រឿងចង គឺកាម និងឱឃៈដ៏សេស មានភវោឃៈជាដើម ឈ្មោះថា ជាអ្នកដល់ គឺសម្រេចសេចក្តីសុខ ដែលចូលទៅស្ងប់សង្ខារទាំងពួង ពោល គឺអនុបាទិសេសនិព្វាន ដែលឈ្មោះថា មិនញាប់ញ័រ ព្រោះស្ងប់រម្ងាប់កិលេស ដែលជាហេតុអនុះអនៃុងដោយល្អបាន និងព្រោះមិនញាប់ញ័រដោយឲ្យល់ គឺអភិសង្ខារ បានដល់ កិលេសរមែងមិនមាន គឺរមែងមិនបានដើម្បីនឹងបញ្ញត្ត ដោយមិនមានប្រការដែលគប្បីបញ្ញត្ត ថា នេះ ឈ្មោះថា គតិ ក្នុងបណ្តាគតិ មានទេវតា និងមនុស្សជាដើម អធិប្បាយថា ព្រះទព្វមល្ងបុត្រនោះ ទៅកាន់ភាវៈដែលមិនមានបញ្ញត្តនោះ ដូចក្លើងតាមដែលពោលហើយ ដូច្នោះ ។

អដ្ឋកថាឧតិយឧព្វស្ងត្រទី ១០ ចប់

ចាដលិគ្គាមិយវគ្គទី ៨ ចប់

និគមគាថា

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ទ្រង់ជាអ្នកបួចផុតដោយល្អ ចាកការប្រកាន់មាំក្នុងភព ដែលទេវតា និងទានវៈរាប់អានហើយ ជាអ្នកកាត់នូវតំណៃតណ្ហាជាច់ហើយ ជាអ្នកសម្តែងបីតិ និងសង្វេគ ជាអ្នកត្រេកអរក្នុងការប្រទានព្រះសទ្ធម្ម ជាលោកនាយកដោយពិសេស ទ្រង់បន្ទឺឧទានណា ក្នុងទីនោះៗ ព្រោះជាហេតុអស់ឧបាទាន ដែលព្រះធម្មសង្គាហកាចារ្យប្រមូលចងក្រងទាំងអស់ចូលគ្នាហើយ លើកឡើងកាន់សង្គាយនា ចងក្រង ដោយឈ្មោះឈ្មោះថា ឧទានណា ដើម្បីប្រកាសអត្ថនៃឧទាននោះ ដែលអាស្រ័យបុរាណអដ្ឋកថា ដែលខ្ញុំធម្មបាលាចារ្យពណ៌នាអត្ថដោយល្អ វណ្ណនាអត្ថនោះ ដោយឈ្មោះ ឈ្មោះថា បរមត្ថទីបនី ដែលជាគ្រឿងប្រកាសអត្ថដ៏ក្រៃលែង ក្នុងព្រះសូត្រនោះតាមសមគួរ មានវិនិច្ឆ័យមិនស្រពិចស្រពិល ចប់បរិបូណ៌ដោយបាលីភាណវារប្រមាណ ៣៤ ភាណវារ ដូច្នោះ ដោយអានុភាពនៃបុណ្យដែលខ្ញុំបានរចនាបរមត្ថទីបនីនោះ បានទទួលហើយ សូមសាសនារបស់ព្រះលោកនាថភ្លឺរុងរឿង ដោយបដិបទា មានសីលជាដើមដ៏បរិសុទ្ធ ចូរសព្វសត្វជាអ្នកមានចំណែកនៃវិមុត្តិរស សូមសាសនារបស់ព្រះសម្មាសម្ពុទ្ធស្ថិតនៅអស់កាលយូរ ចូរពួកសត្វមានសេចក្តីគោរពក្នុងព្រះពុទ្ធសាសនាជានិច្ច ចូរភ្លៀងធ្លាក់លើផែនដីដោយប្រពៃតាមរដូវកាល ចូរបុគ្គលដែលត្រេកអរក្នុងព្រះសទ្ធម្ម គ្រប់គ្រងលោកដោយធម៌ហោង ៗ

អដ្ឋកថាឧទាន ដែលព្រះធម្មបាលាចារ្យ

នៅក្នុងពរទតិត្ថវិហារបានរចនា ចប់បរិបូណ៌ហោង ៗ

ខ្ញុំព្រះករុណា សូមជល់ទូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក



តេជធរោ ឈាវ ប៉ាធាន កាលបួសឆ្នាំ ២០០៤

បណ្ឌិតគួរតម្កល់ខ្លួនទុក ក្នុងគុណដ៏សមគួរជាមុនសិន ហើយ
សឹមប្រៀនប្រដៅអ្នកដទៃជាខាងក្រោយ (ធ្វើយ៉ាងនេះ) ទើប
មិនលំបាកឡើយ (ឥដកតាគ ៥២ ឃ្លាម ២២)។